**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញាអន្តរជាតិ

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Jan-2018, 11:13
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់ អមដោយឧបសម្ព័ន្ធសម្ងាត់ ១៤

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស: **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង**

---

**<u>ដាក់ដោយ៖</u>**

**សហព្រះរាជអាជ្ញាអន្តរជាតិ៖**
Nicholas KOUMJIAN

**<u>ចម្លងជូន៖</u>**

**សហព្រះរាជអាជ្ញាជាតិ៖**
ជា លាង

**<u>ផ្ញើជូន៖</u>**

**សហចៅក្រមស៊ើបអង្កេត៖**
ចៅក្រម យូ ប៊ុនឡេង
ចៅក្រម Michael BOHLANDER

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៣ ទាំងអស់**

**សហមេធាវីការពារក្តីជនត្រូវចោទ មាស មុត**
អាង ឧត្តម
Michael KARNAVAS

# មាតិកា


**I. សេចក្តីផ្តើម** .......... 13

**II. ប្រវត្តិនីតិវិធី** .......... 14

ការផ្លាស់ប្តូរចៅក្រមស៊ើបអង្កេតក្នុងអំឡុងពេលស៊ើបសួរ .......... 16

សេចក្តីជូនដំណឹងឆ្នាំ ២០១១ ដែលថា កិច្ចស៊ើបសួរតាមផ្លូវតុលាការបានបិទបញ្ចប់ .......... 17

ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត .......... 19

តំណាងផ្នែកច្បាប់របស់ មាស មុត និងការចូលមើលសំណុំរឿង .......... 22

ការចោទប្រកាន់ មាស មុត .......... 24

ការចូលរួមក្នុងកិច្ចស៊ើបសួរ .......... 29

ការអំពាវនាវឱ្យដាក់សារណា .......... 39

ការកាត់បន្ថយបទចោទប្រកាន់ .......... 41

ការបិទបញ្ចប់កិច្ចស៊ើបសួរ .......... 43

ដំណើរការផ្លូវច្បាប់សំខាន់ៗ .......... 45

ភ័ស្តុតាងក្នុងសំណុំរឿង ០០៣ .......... 47

**III. តួនាទី និងទំនួលខុសត្រូវរបស់ មាស មុត** .......... 47

*១. ប្រវត្តិរូប និងតួនាទីរបស់ មាស មុត មុនឆ្នាំ ១៩៧៥* .......... *47*

*២. តួនាទីរបស់ មាស មុត ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ* .......... *56*

សមាជិកនៃបក្សកុម្មុយនីស្តកម្ពុជា .......... 56

សមាជិកគណៈកម្មាធិការមជ្ឈិម .......... 57

អនុលេខាសេនាធិការ .......... 63

លេខាធិការកងពល ១៦៤ .......... 82

លេខាតំបន់ឯករាជ្យកំពង់សោម .......... 102

ការគ្រប់គ្រងដោយប្រសិទ្ធភាព .......... 114

*៣. ការរួមចំណែករបស់ មាស មុត ក្នុងឧក្រិដ្ឋកម្ម* .......... *137*

ការចូលរួមក្នុងការធ្វើទុក្ខបុកម្នេញ និងការសម្លាប់ខ្មាំង .......... 137

ទិដ្ឋភាពទូទៅ .......... 137

កងទ័ពប្រជាជនបដិវត្តន៍កម្ពុជា .......... 145

ក) កងពល និងវរសេនាធំឯករាជ្យរបស់ ក.ប.ប.ក .......... 145

ខ) កងពល ១៦៤ .......... 150

គ) កងពល១១៧ និង តំបន់៥០៥ .......... 177

ជនជាតិវៀតណាម .......... 186

ជនជាតិថៃ និងជនជាតិលោកខាងលិច .......... 203

មន្ទីរសន្តិសុខកងពលធំ១៦៤ ........................................ 208

ក) មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ ........................................ 210

ខ) មន្ទីរសន្តិសុខទឹកសាប ........................................ 218

មន្ទីរសន្តិសុខ ស-២១ ........................................ 221

ក) អគ្គសេនាធិការ ក.ប.ក កងពលធំមជ្ឈិមបក្ស និងវរសេនាធំ ........................................ 227

ខ) តំបន់កំពង់សោម និងតំបន់ ៥០៥ ........................................ 229

ការចូលរួមក្នុងការដាក់ជាទាសករនៅតាមការដ្ឋាន ........................................ 231

ទិដ្ឋភាពទូទៅ ........................................ 231

ក) ការអនុវត្តរបស់ មាស មុត នូវគោលនយោបាយនៃការដាក់ជាទាសករ ........................................ 231

ខ) ការដឹងឮរបស់ មាស មុត អំពីស្ថានភាពនៃការដាក់ជាទាសករ ........................................ 240

ការដ្ឋានរាម ........................................ 244

ការដ្ឋានស្ទឹងហាវ ........................................ 249

ការចូលរួមក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទ ........................................ 253

**IV. រចនាសម្ព័ន្ធអំណាចកងពលធំលេខ ១៦៤ (អតីតកងពលធំលេខ ៣) ........................................ 271**

កងពលធំលេខ៣ (ឆ្នាំ ១៩៧៣/១៩៧៤- ខែ កក្កដា ឆ្នាំ ១៩៧៥) ........................................ 271

កងពលធំលេខ ១៦៤ (ខែ កក្កដា ឆ្នាំ ១៩៧៥ - ខែ មករា ឆ្នាំ ១៩៧៩) ........................................ 289

គណៈកម្មាធិការកងពលធំលេខ ១៦៤ ........................................ 327

សមាសភាព និងតួនាទីរបស់កងវរៈសេនាធំលេខ ១៦១ លេខ ១៦២ លេខ ១៦៣ និងរបស់កងទ័ពជើងទឹក (កងវរៈសេនាធំលេខ ១៤០) ........................................ 340

ក) កងវរៈសេនាធំលេខ ១៦១ (អតីតកងវរៈសេនាធំលេខ ២០) ........................................ 340

ខ) កងវរៈសេនាធំលេខ ១៦២ (អតីតកងវរៈសេនាធំលេខ ២១) ........................................ 348

គ) កងវរៈសេនាធំលេខ ១៦៣ (អតីតកងវរៈសេនាធំលេខ ២២) ........................................ 359

ឃ) កងវរៈសេនាធំកងទ័ពជើងទឹកឯករាជ្យលេខ ១៤០ ........................................ 373

កងវរៈសេនាតូចឯករាជ្យ ........................................ 395

ក) កងវរៈសេនាតូចលេខ ១៦៥ (កងកម្លាំងពិសេស អតីតកងវរៈសេនាតូចលេខ ៤៥០) ........................................ 395

ខ) កងវរៈសេនាតូចលេខ ១៦៦ លេខ ១៦៧ លេខ ១៦៨ លេខ ១៦៩ និង លេខ ១៧០ ........................................ 401

**V. ការប្រាស្រ័យទាក់ទង ........................................ 406**

*១. សេចក្តីផ្តើម ........................................ 406*

*២.ការប្រាស្រ័យទាក់ទងផ្ទៃក្នុងរបស់កងពលធំលេខ ១៦៤ ........................................ 406*

វិទ្យុទាក់ទង ........................................ 418

ទូរលេខ ........................................ 424

ទូរស័ព្ទ ........................................ 427

នីរសារ ............................................................ 429

កិច្ចប្រជុំ............................................................ 432

ឧបករណ៍វ៉ាដា ............................................................ 441

*៣. ទំនាក់ទំនងរវាងកងពល ១៦៤ និងមជ្ឈិម............................................................ 444*

*៤. ទំនាក់ទំនងរវាងកងពល ១៦៤ និងកងពលផ្សេងទៀត ............................................................ 455*

ទំនាក់ទំនងរវាងកងពល ១៦៤ និងកងពលលេខ ១ ............................................................ 455

ទំនាក់ទំនងរវាងកងពល ១៦៤ និងកងពល ១១៧............................................................ 459

**VI. ជម្លោះប្រដាប់អាវុធអន្តរជាតិ............................................................ 459**

**VII. គោលនយោបាយរបស់ ប.ក.ក ពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំងនឹង មាស មុត............................................................ 491**

ការកម្ទេចខ្មាំង និងការប្រឆាំងនឹងថ្នាក់ដឹកនាំ បក.ក. ............................................................ 491

គោលនយោបាយកសិកម្ម សេដ្ឋកិច្ច និងសង្គមកិច្ច ............................................................ 509

ការបង្កើតសហករណ៍ និងការដ្ឋានការងារ ............................................................ 509

ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ............................................................ 541

**VIII. ឧក្រិដ្ឋកម្ម និងទីតាំងឧក្រិដ្ឋកម្ម ............................................................ 543**

**ក. ការបោសសម្អាតក្នុងកងពល ១៦៤............................................................ 543**

*១. គោលនយោបាយបោសសម្អាតខ្មាំងផ្ទៃក្នុងរបស់ ប.ក.ក/កងទ័ពបដិវត្តកម្ពុជា និងគោលបំណងរបស់ មាស មុត ក្នុងការបោសសម្អាតនៅក្នុងជួរកងពល ១៦៤ ............................................................ 543*

*២. ការសម្រិតសម្រាំងទាហានក្នុងកងពល ១៦៤ តាមរយៈប្រវត្តិរូបរបស់ពួកគេ............................................................ 559*

*៣. ប្រភេទនៃសមាសភាពអាក្រក់ និងជាប់និន្នាការនៅក្នុងកងពល ១៦៤ ដែលត្រូវបានបោសសម្អាត............................................................ 570*

ក) ទាហានកងពលលេខ ៣ ដែលត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅវៀតណាមនៅឆ្នាំ ១៩៧៥............................................................ 570

ខ) ទាហានរត់ចោលជួរ/អ្នកចុះចូលជាមួយខ្មាំង (ក្នុងរបបទាំងមូល)............................................................ 575

គ) ទាហានដែល “ជាប់ពាក់ព័ន្ធ” ជាមួយនឹងរបបសាធារណរដ្ឋខ្មែរចាស់............................................................ 577

គ) អ្នកដែលគេសន្មតថាជា “ជនក្បត់” នៅក្នុងកងពល ១៦៤ និងបណ្តាញរបស់ពួកគេ............................................................ 581

បណ្តាញតំបន់ ៣៧ (កងវរសេនាតូច ៣៨៦ ចាស់) ក្រោមការគ្រប់គ្រងរបស់ ជ័យ ហាន ហៅ ឆាន សមាជិកគណៈកងពល ១៦៤............................................................ 592

បណ្តាញភូមិភាគបូព៌ា (តំបន់ ២២) ក្រោមការគ្រប់គ្រងរបស់ ហ៊ឹង ឌឿន ហៅ ឌឹម មេបញ្ជាការរងកងពល ១៦៤ ............................................................ 614

ក) ទំនាក់ទំនងផ្សេងទៀតជាមួយបរទេស ............................................................ 636

ខ) កំហុសធ្ងន់ និងស្រាល............................................................ 644

*៤. ការបញ្ចូលទាហានមួយចំនួនដែលត្រូវបានបោសសម្អាត ទៅក្នុងកងពល ១៦៤ វិញ ដើម្បីតែវាយវៀតណាមប៉ុណ្ណោះ ............................................................ 653*

**ខ. ការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកដែលត្រូវបានកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យចាប់ខ្លួននៅក្នុងដែនទឹក និងនៅលើកោះ ដែលអះអាងកាន់កាប់ដោយកម្ពុជាប្រជាធិបតេយ្យ ..................... 654**

*១. ទិដ្ឋភាពទូទៅ ..................... 655*

*២. បញ្ហា និងទំនាក់ទំនងរបស់កងពល ១៦៤ ពាក់ព័ន្ធនឹងការចាប់ទូក/ពលរដ្ឋបរទេសនៅសមុទ្រ ..................... 664*

*៣. តួនាទីរបស់កងពលលេខ ១ ក្នុងការចាប់ខ្លួន ..................... 683*

*៤. បញ្ហារបស់ មាស មុត ពាក់ព័ន្ធនឹងពលរដ្ឋវៀតណាម ..................... 687*

បញ្ហារបស់ មាស មុត ពាក់ព័ន្ធនឹងពលរដ្ឋថៃ ..................... 700

បញ្ហារបស់ មាស មុត ពាក់ព័ន្ធនឹងពលរដ្ឋមិនមែនកម្ពុជាផ្សេងទៀត ..................... 707

ការចាប់ខ្លួន និងការបញ្ជូន ..................... 713

*៥. ឧក្រិដ្ឋកម្ម ..................... 725*

មនុស្សឃាត ការសម្លាប់ដោយចេតនា និងការសម្លាប់ផ្តាច់ពូជ ..................... 725

ក) ការសម្លាប់នៅលើសមុទ្រ ..................... 725

ខ) ការសម្លាប់នៅលើកោះ ..................... 727

គ) ការសម្លាប់នៅកំពង់សោម ..................... 745

ឃ) ការសម្លាប់នៅមន្ទីរ ស-២១ ..................... 755

*៦. កម្រិតញឹកញាប់នៃការចាប់ និងសម្លាប់ ..................... 766*

**គ. មន្ទីរសន្តិសុខកងពល ១៦៤ ..................... 773**

*១. បណ្តាញមន្ទីរសន្តិសុខ ..................... 773*

ក) នៅក្នុងកំពង់សោម ..................... 773

ខ) បណ្តាញសន្តិសុខទូលំទូលាយជាងនេះរបស់កម្ពុជាប្រជាធិបតេយ្យ ..................... 774

*២. ការចាប់ និងឃុំខ្លួន នៅមន្ទីរសន្តិសុខកងពល ១៦៤ ..................... 780*

ការអនុវត្តការចាប់ខ្លួន ..................... 780

កង្វះដំណើរការក្តីតាមផ្លូវច្បាប់ ..................... 792

*៣. មន្ទីរសន្តិសុខវត្តឥន្ទញាណ ..................... 798*

ទីតាំង ការពណ៌នាអំពីទីតាំង និងប្រតិបត្តិការ ..................... 798

រយៈពេលនៃដំណើរការ ..................... 801

រចនាសម្ព័ន្ធអំណាច ..................... 804

ឧក្រិដ្ឋកម្ម ..................... 810

ការដាក់មន្ទីរឃុំឃាំង ..................... 810

ក) កម្មាភិបាលនិងយុទ្ធជនរំសាយ របស់កងពល ១៦៤ ..................... 812

ខ) ជនស៊ីវិល ..................... 816

គ) ជនបរទេស ..................... 816

ឃ) ស្ត្រី និងកុមារ ........ 820

ការប្រព្រឹត្តិដោយអមនុស្សធម៌........ 822

ការធ្វើទារុណកម្ម ........ 831

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការបាត់ខ្លួនដោយបង្ខំ ........ 832

*៤. មន្ទីរសន្តិសុខទឹកសាប ........ 841*

ទីតាំង ការពណ៌នាអំពីទីតាំង និងប្រតិបត្តិការ ........ 841

រយៈពេលនៃដំណើរការ ........ 851

រចនាសម្ព័ន្ធអំណាច និងការទំនាក់ទំនង ........ 856

ឧក្រិដ្ឋកម្ម........ 867

ការដាក់ក្នុងមន្ទីរឃុំឃាំង និងការឃុំខ្លួនដោយខុសច្បាប់ ........ 867

ក) កម្មាភិបាលកងពលធំលេខ ១៦៤ និងទាហានរំសាយ ........ 868

ខ) ជនស៊ីវិលនៅក្នុងតំបន់កំពង់សោម........ 875

គ) ជនបរទេសដែលត្រូវបានចាប់ខ្លួននៅសមុទ្រ........ 880

ឃ) កុមារ ........ 882

ប្រព្រឹត្តកម្មអមនុស្សធម៌ និងការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬការឈឺចាប់ធ្ងន់ធ្ងរ........ 885

ការធ្វើទារុណកម្ម ........ 891

ការធ្វើមនុស្សឃាត ការសម្លាប់ដោយចេតនា ការសម្លាប់រង្គាល និងការបាត់ខ្លួនដោយបង្ខំ ........ 893

ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ - វត្តឥន្ទញាណ និងទឹកសាប ........ 904

ក) កម្មាភិបាលកងពលធំលេខ ១៦៤ និងទាហានរំសាយ ........ 905

ខ) ប្រជាជនថ្មី (១៧ មេសា) និងអ្នកដែលមានទំនាក់ទំនងជាមួយរបប លន់ នល់........ 905

គ) ជនបរទេស ........ 906

ឃ) ខ្មែរក្រោម ........ 906

**ឃ) មន្ទីរសន្តិសុខ ស-២១........ 907**

*១. សេចក្តីផ្តើម ........ 907*

*២. ទីតាំង និងប្រតិបត្តិការ........ 908*

*៣. រចនាសម្ព័ន្ធអំណាច និងទំនាក់ទំនង........ 912*

នៅក្នុងមន្ទីរសន្តិសុខ ........ 912

ទំនាក់ទំនងជាមួយសេនាធិការ ........ 915

*៤. ការទទួលខុសត្រូវរបស់ មាស មុត ចំពោះអ្នកទោសដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១........ 921*

*៥. ឧក្រិដ្ឋកម្ម ........ 955*

ការដាក់ពន្ធនាគារ និងការឃុំឃាំងដោយខុសច្បាប់ ........ 955

ក) ការដកហូតសេរីភាពបុគ្គលដែលបានបញ្ជូនទៅមន្ទីរ ស-២១ ........ 955

ខ) កង្វះដំណើរការនីតិវិធីផ្លូវច្បាប់ត្រឹមត្រូវ ..... 961

គ) ការចងក្រងឯកសារស្ដីពីការចូលរបស់អ្នកទោស ..... 965

អំពើអមនុស្សធម៌ផ្សេងទៀត ដែលបង្កដោយចេតនាឲ្យមានការរងទុក្ខ និងរបួសធ្ងន់ធ្ងរ ..... 967

ការសួរចម្លើយ និងការប្រើប្រាស់ទារុណកម្ម..... 985

ក) ការប្រើទារុណកម្មជាប្រព័ន្ធក្នុងអំឡុងពេលសួរចម្លើយនៅមន្ទីរស-២១ ..... 985

ខ) វិធីសាស្ត្រ និងទម្រង់ទារុណកម្មដែលបានប្រើនៅមន្ទីរស-២១ ..... 991

គ) របួសដែលបង្កឡើងលើអ្នកទោសក្នុងអំឡុងពេលសួរចម្លើយ ..... 1000

ឃ) ការប្រើប្រាស់ទារុណកម្មដើម្បីទទួលបានចម្លើយសារភាព ..... 1004

ង) ការសួរចម្លើយ និងការធ្វើទារុណកម្មអ្នកទោសដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១ ដោយ មាស មុត 1007

ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការសម្លាប់ដោយចេតនា..... 1012

ក) ការសម្លាប់រង្គាលជាលក្ខណៈប្រព័ន្ធនូវអ្នកទោសដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១..... 1012

ខ) ការសម្លាប់នៅក្នុងបរិវេណមន្ទីរស-២១ និងនៅតាខ្មៅ ..... 1016

គ) ការសម្លាប់នៅជើងឯក..... 1021

**ង. ការដ្ឋានស្ទឹងហាវ..... 1027**

*១. ការពិពណ៌នាពីទីកន្លែង..... 1027*

*២. វចនាសម្ព័ន្ធអំណាច..... 1047*

*៣. ឧក្រិដ្ឋកម្ម..... 1061*

ការធ្វើឲ្យទៅជាទាសករ ..... 1061

ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ..... 1081

ការធ្វើមនុស្សឃាត និងការបាត់ខ្លួនដោយបង្ខំ..... 1091

ការឃុំខ្លួនដោយខុសច្បាប់ និងការធ្វើទារុណកម្ម..... 1096

អំពើអមនុស្សធម៌ផ្សេងទៀត ..... 1108

ក) ការធ្វើបាបដោយអមនុស្សធម៌ ..... 1108

**ច. ការដ្ឋាននៅតំបន់រាម ..... 1113**

*១. ការពណ៌នាអំពីការដ្ឋាន..... 1113*

*២. វចនាសម្ព័ន្ធអំណាច..... 1134*

*៣. ឧក្រិដ្ឋកម្ម..... 1151*

ការធ្វើឲ្យក្លាយជាទាសករ..... 1151

ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ..... 1175

ក) កម្មាភិបាលរំសាយ ..... 1178

ខ) ប្រជាជន ១៧ មេសា..... 1191

គ) ខ្មែរក្រោម ..... 1192

មនុស្សឃាត ការសម្លាប់ផ្ដាច់ពូជ និងការបាត់ខ្លួនដោយបង្ខំ ..... 1193
ក) ទីតាំងសម្លាប់មនុស្សចម្ការទុរេនទី ១ ..... 1209
ខ) ទីតាំងសម្លាប់មនុស្សចម្ការទុរេនទី ២ ..... 1211
គ) ទីតាំងសម្លាប់មនុស្ស សេអ៊ី ..... 1216
អំពើអមនុស្សធម៌ផ្សេងៗទៀត (ការប្រព្រឹត្តិអមនុស្សធម៌) ..... 1220
**ធ.បទឧក្រិដ្ឋប្រល័យពូជសាសន៍ប្រឆាំងជនជាតិវៀតណាម ..... 1232**
*១. សេចក្ដីផ្ដើម ..... 1232*
*២. ជនជាតិវៀតណាម ជាក្រុមជាតិពន្ធុដាច់ដោយឡែកមួយ ..... 1233*
គោលនយោបាយទូទៅប្រឆាំងនឹងជនជាតិវៀតណាម ..... 1233
បណ្ដេញចេញ និងកម្ទេច៖ គោលនយោបាយបក្សកុម្មុយនីស្ដកម្ពុជាកម្ទេចជនជាតិវៀតណាម ..... 1235
មិនមែនគោលដៅយោធា៖ ការបំផ្លាញជនជាតិវៀតណាម ..... 1244
ភ័ស្ដុតាងបញ្ជាក់ពីកំហឹងរបស់ បក ចំពោះជនជាតិវៀតណាម ជាក្រុមជនជាតិភាគតិច.ក. ..... 1246
ការអនុវត្តគោលនយោបាយប្រល័យពូជសាសន៍មកលើជនជាតិវៀតណាម ..... 1258
ការនិរទេសជនជាតិវៀតណាម ..... 1258
ការសម្លាប់ជនជាតិវៀតណាម ..... 1263
ក) ការកំណត់អត្តសញ្ញាណជនជាតិវៀតណាម ..... 1265
ខ) ជីកឫស៖ ការដាក់គោលដៅរបស់ ប.ក.ក លើគ្រួសារខាងម្ដាយជាជនជាតិវៀតណាម ..... 1269
ការសម្លាប់នៅទូទាំងកម្ពុជាប្រជាធិបតេយ្យ ..... 1271
ការអនុវត្តរបស់ មាស មុត លើគោលនយោបាយប្រល័យពូជសាសន៍ ..... 1274
ក) បទបញ្ជាសម្លាប់ជនជាតិវៀតណាមនៅកងពល ១៦៤ ..... 1274
ខ) ការអះអាងរបស់ មាស វឿន ចំពោះបញ្ជាឲ្យសម្លាប់វៀតណាមទាំងអស់ ..... 1281
គ) ការសម្លាប់ប្រជាជនវៀតណាមដោយបុគ្គលិកកងពល ១៦៤ - ជនរងគ្រោះដែលចាប់បាននៅសមុទ្រ 1284
ឃ) ការសម្លាប់ប្រជាជនវៀតណាមមកពីក្រចេះ នៅ ស-២១ ពេល មាស មុត គ្រប់គ្រងតំបន់ ៥០៥ ..... 1292
**ជ. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ ..... 1293**
*១. សេចក្ដីផ្ដើម ..... 1293*
**២. ការបង្កើតគោលនយោបាយជាតិស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ..... 1293**
ទស្សនាទាននៃគ្រួសារបដិវត្តន៍ ..... 1297
តម្រូវការកំណើនប្រជាជន ..... 1302
*៣. ការអនុវត្តគោលនយោបាយថ្នាក់ជាតិស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ..... 1310*
ការរៀបចំ ..... 1310
ការបង្ខំឲ្យរៀបការ ..... 1312
ពិធីរៀបអាពាហ៍ពិពាហ៍ ..... 1325

ការរំលោភសេពសន្ថវៈនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ (ការរួមដំណេកដោយបង្ខំ) ..... 1329

ការបំបែកមិនឱ្យរស់នៅជាមួយគ្នា ..... 1333

*៤. ការអនុវត្តគោលនយោបាយនៅតំបន់កំពង់សោម ..... 1334*

ការផ្សព្វផ្សាយគោលនយោបាយរបស់ បក ស្តីពីការរៀបអាពាហ៍ពិពា.ក.ហ៍ នៅកងពល ១៦៤ និងតំបន់កំពង់សោម ..... 1337

ការរៀបចំ និងការជូនដំណឹង ..... 1341

ក) ការរៀបចំ ..... 1341

ខ) ពិធីអាពាហ៍ពិពាហ៍ ..... 1349

គ) គ្មានការព្រមព្រៀង ..... 1353

ឃ) ការរួមដំណេកដោយបង្ខំ (ការរំលោភសេពសន្ថវៈ) ..... 1359

ង) របួសប៉ះទង្គិចផ្លូវកាយ និងផ្លូវចិត្តដែលជនរងគ្រោះទទួលរងនៅតំបន់កំពង់សោម ..... 1362

*៥. សេចក្តីសន្និដ្ឋាន ..... 1363*

**ឈ. ការបោសសម្អាតកងពល ១១៧ និងតំបន់ ៥០៥ ..... 1364**

*១. សេចក្តីផ្តើម ..... 1364*

*២. រចនាសម្ព័ន្ធអំណាច ..... 1367*

តំបន់ ៥០៥ (ខេត្តក្រចេះ) ..... 1367

កងពល ១១៧ ..... 1382

*៣. ការបោសសម្អាត ការជំនួស និងការត្រួតពិនិត្យ ..... 1392*

*៤. ការបន្តបោសសម្អាត ..... 1418*

*៥. ឧក្រិដ្ឋកម្ម ..... 1422*

ការដាក់ក្នុងមន្ទីរឃុំឃាំង ..... 1422

មនុស្សឃាត ការសម្លាប់រង្គាលផ្តាច់ពូជ និងការបាត់ខ្លួនដោយបង្ខំ ..... 1424

ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ..... 1426

**IX. អង្គច្បាប់ ..... 1428**

**ក. ឧក្រិដ្ឋកម្ម ..... 1428**

*១. អំពើប្រល័យពូជសាសន៍ ..... 1428*

ក្រុមដែលត្រូវការពារ ..... 1429

ធាតុផ្សំសត្យានុម័ត ..... 1435

ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម ..... 1436

ធាតុផ្សំអត្តនោម័តិ ..... 1437

ក) ចេតនាបំផ្លិចបំផ្លាញក្រុម "បែបនេះ" ..... 1437

ខ) ទាំងស្រុង ឬមួយផ្នែក ..... 1444

គ) ការបង្ហាញឲ្យឃើញចេតនា ........ 1445
ឃ) ទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបាន ........ 1448
*២. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ........ 1450*
លក្ខខណ្ឌតម្រូវទូទៅ ........ 1450
ការវាយប្រហារ ........ 1451
លក្ខណៈរាលដាល ឬលក្ខណៈជាប្រព័ន្ធ ........ 1452
សំដៅលើប្រជាជនស៊ីវិល ........ 1452
ការរឹតត្បិតត្បិតនៃយុត្តាធិការ ........ 1457
ទំនាក់ទំនងរវាងអំពើរបស់ចារី និងការវាយប្រហារ ........ 1458
បទល្មើសជាក់លាក់ ........ 1459
ការធ្វើមនុស្សឃាត ........ 1459
ការសម្លាប់រង្គាល ........ 1462
ការដាក់ជាទាសករ ........ 1467
ការចាប់ដាក់ពន្ធនាគារ ........ 1470
ទារុណកម្ម ........ 1472
ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា ........ 1478
ក) អំពើសកម្ម ឬអំពើអកម្មដែលបដិសេធ ឬរំលោភសិទ្ធិជាសារវន្ត ........ 1478
ក) អំពើសកម្ម ឬអំពើអកម្មដែលបដិសេធ ឬរំលោភសិទ្ធិជាសារវន្ត ........ 1480
គ) ធាតុផ្សំអត្តនោម័តិ ........ 1482
អំពើអមនុស្សធម៌ដទៃទៀត ........ 1483
ក) ការប្រព្រឹត្តិបែបអមនុស្សធម៌ ........ 1487
ខ) ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិដោយសារលក្ខខណ្ឌនៃការឃុំឃាំង ........ 1489
គ) អាពាហ៍ពិពាហ៍ដោយបង្ខំ ........ 1491
ឃ) ការរំលោភផ្លូវភេទ ........ 1493
ង) ការបាត់ខ្លួនដោយបង្ខំ ........ 1496
ច) ពលកម្មដោយបង្ខំ ........ 1497
*៣. ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ........ 1500*
លក្ខខណ្ឌតម្រូវទូទៅ ........ 1501
ជម្លោះប្រដាប់អាវុធអន្តរជាតិ ........ 1501
បុគ្គលដែលទទួលបានការការពារ ........ 1502
ការដឹងពីកាលៈទេសៈអង្គហេតុ ........ 1504
បទល្មើសជាក់លាក់ ........ 1504

ការសម្លាប់ដោយចេតនា ........ 1504
ការធ្វើទារុណកម្ម ឬការប្រព្រឹត្តដោយអមនុស្សធម៌ ........ 1505
ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ........ 1506
ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ និងទៀងទាត់ ........ 1507
ការឃុំឃាំងប្រជាជនស៊ីវិលដោយខុសច្បាប់ ........ 1508
**ខ. ទម្រង់នៃការទទួលខុសត្រូវ ........ 1509**
*១. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល ........ 1510*
ការប្រព្រឹត្ត ........ 1510
ក) អំពើពិរុទ្ធ ........ 1511
ខ) ចេតនាប្រព្រឹត្តបទល្មើស ........ 1520
ផែនការ ........ 1521
ការញុះញង់ ........ 1523
ការបញ្ជា ........ 1525
ការជួយនិងជំរុញ ........ 1528
*២) ការទទួលខុសត្រូវរបស់ថ្នាក់លើ ........ 1531*
ទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោម ........ 1533
ការដឹង ឬមានមូលហេតុត្រូវដឹង ........ 1535
ការខកខានក្នុងការទប់ស្កាត់ ឬដាក់ទណ្ឌកម្ម ........ 1536
**គ. បទដ្ឋានភ័ស្តុតាងដែលតម្រូវឲ្យមានចំពោះឧប្បត្តិហេតុ ........ 1538**
**ឃ. យុត្តាធិការបុគ្គល ........ 1541**
*១. អ្នកទទួលខុសត្រូវខ្ពស់បំផុត ........ 1542*
*២. មេដឹកនាំជាន់ខ្ពស់ ........ 1545*
**X. ឧក្រិដ្ឋកម្មជាតិ និងឧក្រិដ្ឋកម្មដែលមិនត្រូវបានចោទប្រកាន់ ........ 1546**
ឧក្រិដ្ឋកម្មនៅក្រោមក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦ ........ 1546
ឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ ដែលមិនត្រូវបានចោទប្រកាន់ពីមុន ........ 1548
**XI. យុត្តាធិការលើរឿងក្តី ........ 1551**
**កឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ . ........ 1551**
ការវាយប្រហារលើជនស៊ីវិល ........ 1551
លក្ខណៈរាលដាល ឬជាប្រព័ន្ធ ........ 1552
មូលហេតុរើសអើង ........ 1553
ការដឹងឮរបស់ មាស មុត អំពីការវាយប្រហារ ........ 1554
**ខការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ . ........ 1555**

ជម្លោះប្រដាប់អាវុធអន្តរជាតិ ..... 1555
ជនដែលត្រូវការពារ ..... 1557
ការយល់ដឹងអំពីជម្លោះប្រដាប់អាវុធ ..... 1557

**XII. យុត្តាធិការបុគ្គល ..... 1558**

*១. មេដឹកនាំជាន់ខ្ពស់ ..... 1559*

*២. អ្នកទទួលខុសត្រូវខ្ពស់បំផុត ..... 1561*

**XIII. ទំនួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល ..... 1570**

**ក. ទិដ្ឋភាពទូទៅ ..... 1570**

**ក. ទម្រង់នៃការទទួលខុសត្រូវ ..... 1571**

*១. ការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម ..... 1571*

ការចូលរួមចំណែកក្នុងការធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្មាំង ..... 1574
នៅតំបន់ ១៦៤ ..... 1575
នៅក្នុងកងពល ១១៧ និងតំបន់ ៥០៥ ..... 1577
ជនជាតិវៀតណាម ..... 1578
ជនជាតិថៃ និងពួកបស្ចិមប្រទេស ..... 1579
ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខវត្តឥន្ទញាណ ..... 1580
ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខទឹកសាប ..... 1580
ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខ ស-២១ ..... 1581
នៅគ្រប់ទីកន្លែងទាំងអស់ ..... 1582
ការរួមចំណែកក្នុងការដាក់ឲ្យធ្វើជាទាសករនៅការដ្ឋាន ..... 1582
ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៅការដ្ឋានតំបន់រាម ..... 1583
ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលកើតមាននៅការដ្ឋានស្ទឹងហាវ ..... 1584
នៅគ្រប់ទីកន្លែងទាំងអស់ ..... 1585
ការចូលរួមចំណែកចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ ..... 1585

*២. ធ្វើផែនការ ញុះញង់ បញ្ជា និងជួយនិងជំរុញ ..... 1588*

*៣. ការទទួលខុសត្រូវរបស់ថ្នាក់លើ ..... 1590*

**XIV. បទចោទប្រកាន់ ..... 1591**

## I. សេចក្ដីផ្ដើម

1. **មាស មុត** គឺជាមេដឹកនាំយោធា និងនយោបាយដ៏មានឥទ្ធិពលម្នាក់ក្នុងរបបកម្ពុជាប្រជាធិតេយ្យ។ គាត់គឺជាសមាជិកនៃគណៈកម្មាធិការកណ្ដាលនៃគណបក្សកាន់អំណាច លេខាធិការនៃតំបន់ស្វយ័តកំពង់សោម អ្នកដឹកនាំក្នុងតំបន់ស្វយ័ត៥០៥ មេញ្ញាការក្នុងកងពលបំផុតក្នុងកងទ័ពកម្ពុជាប្រជាធិបតេយ្យ ប្រធានកងទ័ពជើងទឹកកម្ពុជាប្រជាប្រជាធិបតេយ្យ និងជាសមាជិកនៃសេនាធិការនៃកងកម្លាំងប្រដាប់អាវុធ ដែលចុងក្រោយក្លាយជាបុគ្គលម្នាក់ក្នុងចំណោមអនុប្រធានតែពីររូបប៉ុណ្ណោះនៃស្ថាប័នដ៏មានឥទ្ធពលមួយនេះ។

2. ដីកាសន្និដ្ឋានស្ថាពរនេះរៀបរាប់លម្អិតអំពីភ័ស្តុតាង ដែលទទួលបានតាមរយៈកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ បង្ហាញថាតើ **មាស មុត** បានប្រើប្រាស់សិទ្ធិអំណាចដូចម្ដេច ដើម្បីអនុវត្តយុទ្ធនាការឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ **មាស មុត** ប្រជាជនយ៉ាងច្រើនលើសលប់ត្រូវបានប្រែក្លាយឱ្យទៅជាទាសករនៅតាមការដ្ឋាននានា ត្រូវបានចាប់ខ្លួន និងដាក់គុកដោយគ្មានដំណើរការជំនុំជម្រះតាមផ្លូវច្បាប់ ត្រូវទទួលរងការធ្វើទារុណកម្ម សម្លាប់ និង/ឬ ត្រូវបានបង្ខំឱ្យរៀបរាបការ និងបង្ខំឱ្យរួមភេទ បន្ទាប់ពីរៀបការរួច។

3. ដីកាសន្និដ្ឋានស្ថាពរនេះពន្យល់ថាតើភ័ស្តុតាងបង្ហាញថា **មាស មុត** ទទួលខុសត្រូវព្រហ្មទណ្ឌដូចម្ដេច ចំពោះការសម្លាប់ ការដាក់ឱ្យទៅជាទាសករ ការដាក់ពន្ធនាគារតាមទំនើងចិត្ត ការធ្វើទារុណកម្ម ការប្រព្រឹត្តិអមនុស្សធម៌ ការបាត់ខ្លួន អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈដែលបានធ្វើឡើងដោយបង្ខំ តាមរយៈការបញ្ជារបស់គាត់ក្នុងតំបន់ដែលគាត់គ្រប់គ្រង និងធ្វើឡើងដោយមានការដឹងឮ និងក្រោមការបញ្ជារបស់គាត់។

4. សេចក្ដីសន្និដ្ឋានស្ថាពរនេះលើកទឡ្ហីករណ៍ថា ដោយសារតែតួនាទីដ៏មានឥទ្ធិពលរបស់គាត់ ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត និងមុខងារផ្ទាល់ និងដ៏សំខាន់របស់គាត់នៅក្នុងឧក្រិដ្ឋកម្មទាំងនេះ **មាស មុត** ច្បាស់ណាស់ជាមេដឹកនាំជាន់ខ្ពស់ និងជាមនុស្សម្នាក់ក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយអាស្រ័យហេតុនេះ **មាស មុត** ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។

5. ស.ព.អ ស្នើទៅសហចៅក្រមស៊ើបអង្កេតឱ្យធ្វើការចោទប្រកាន់ **មាស មុត** និងបញ្ជូនគាត់ទៅជំនុំជម្រះពីបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត ដែលបានរកឃើញនៅក្នុងកិច្ចស៊ើបសួរ ដែលភស្តុតាងនៃពិរុទ្ធភាពរបស់គាត់នេះមានវិសាលភាពធំធេង ដោយប្រើប្រាស់បទចោទព្រហ្មទណ្ឌមួយចំនួនដែលបញ្ជាក់យ៉ាងច្បាស់លាស់បំផុតពីទង្វើរបស់គាត់ និងទុក្ខវេទនារបស់ជនរងគ្រោះ។ ស.ព.អ ស្នើឱ្យធ្វើការចោទប្រកាន់ **មាស មុត** ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិលើចំណុចការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការដាក់ពន្ធនាគារ ការធ្វើឱ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងទៀត ដែលបញ្ចូលទាំងអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ និងការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយ ព្រមទាំងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញានៃទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩។

## II. ប្រវត្តិនីតិវិធី

6. នៅថ្ងៃ ១០ ខែ កក្កដា ឆ្នាំ ២០១៦ សហព្រះអាជអាជ្ញាបានចាប់ផ្ដើមកិច្ចស៊ើបកិច្ចស៊ើបសួរបឋមលើឧក្រិដ្ឋកម្មនានា នៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដោយអនុលោមតាមវិធាន ៥០ នៃវិធានផ្ទៃក្នុង [1]។ សហព្រះរាជអាជ្ញាបានស្ដាប់ចម្លើយសាក្សី ចុះទៅស៊ើបសួរនៅតាមមូលដ្ឋាន និងប្រមូលភស្តុតាង ឯកសារដើម្បីកំណត់ថាតើមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនានា ឬទេ ហើយកំណត់អត្តសញ្ញាណជនសង្ស័យ និងសាក្សីដែលមានសក្ដានុពល។

7. នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ដោយសារតែបានរកឃើញថា មានហេតុផលដែលជឿថា ឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានប្រព្រឹត្តដោយជនសង្ស័យចំនួនពីររូប ដែលមានទំនាក់ទំនងជាមួយនឹងកងទ័ពបដិវត្តន៍កម្ពុជានោះ ទើប ស.ព.អ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ ដោយស្នើសុំឱ្យធ្វើការស៊ើបសួរតាមផ្លូវតុលាការ ពាក់ព័ន្ធនឹង ស៊ូ ម៉េត និង **មាស មុត** អំពីឧក្រិដ្ឋកម្មនានា ដែលស្ថិតនៅក្រោយយុត្តាធិការរបស់ អ.វ.ត.ក[2]។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរនេះបានសង្ខេបអង្គហេតុ បទចោទដែលត្រូវបានចោទប្រកាន់ និងពីមាត្រាពាក់ព័ន្ធនៃច្បាប់ដែលកំណត់ និងដាក់ទណ្ឌកម្មលើឧក្រិដ្ឋកម្មដែលបានចោទប្រកាន់។ ទោះ

---

1 ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២ របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងកងទ័ពបដិវត្តកម្ពុជា ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២") កថាខណ្ឌ ៧។

2 ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២។

ជាយ៉ាងនេះក្ដី សហព្រះអាជ្ញាជាតិយល់ឃើញថា ដោយសារតែ អ.វ.ត.ក មានដែនកំណត់លើយុត្តាធិការបុគ្គលប្រាំរូប ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីមួយ ជនសង្ស័យផ្សេងៗទៀតមិនគួរត្រូវស៊ើបអង្កេតនោះទេ[3]។

8. ដោយសារតែមានករណីខ្វែងយោបល់គ្នារវាង ស.ព.អ និង ស.ព.ជ ទាក់ទងថាតើគួរដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរទៅឱ្យ ស.ច.ស ឬយ៉ាងណានោះ នីតិវិធីដោះស្រាយករណីខ្វែងយោបល់គ្នាត្រូវបានផ្ដួចផ្ដើមឡើង[4]។ ករណីខ្វែងយោបល់គ្នានេះត្រូវបានបញ្ជូនទៅ អ.ប.ជ ប៉ុន្តែដោយសារតែ អ.ប.ជ មិនអាចរកសំឡេងច្រើនលើសលប់ចាំបាច់សម្រាប់ធ្វើសេចក្ដីសម្រេចនោះ សកម្មភាពនៃសហព្រះរាជអាជ្ញាតែម្នាក់ត្រូវបានអនុញ្ញាតឱ្យបន្តអនុវត្ត អនុលោមតាមវិធានផ្ទៃក្នុង[5]។

9. នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ស.ព.អ ស្ដីទីបានបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ និងសំណុំរឿងនេះទៅ ស.ច.ស ដើម្បីបើកកិច្ចស៊ើបសួរតាមផ្លូវតុលាការ[6]។ សំណុំរឿងនេះមានទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ហើយមានឯកសារជាង ៥០០ ឯកសារ ដែលក្នុងនោះមានចម្លើយសាក្សី របាយការណ៍ពីកម្ពុជាប្រជាធិបតេយ្យ និងសារទូរលេខ។ បន្ទាប់មក ស.ច.ស បានបើកសំណុំរឿង ០០៣ និងចាប់ផ្ដើមកិច្ចស៊ើបសួរ។

---

3 សំណុំរឿង ០០២ ឯកសារ D3 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧។ កំណត់សម្គាល់៖ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី១ បានដាក់នៅសំណុំរឿង០០២ និងស្នើសុំឱ្យស៊ើបសួរលើឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តដោយ នួន ជា, អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ និង កាំង ហ្គេចអ៊ាវ ហៅ ឌុច។

4 អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩) ធ្វើវិសោធនកម្មនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ ("វិធាន") វិធាន ៧១។

5 ឯកសារ D1/1.3 សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ កថាខណ្ឌ ៤៥។ វិធាន ៧១(៤)(គ)។ សូមមើលផងដែរច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២៧ ខែ តុលា ឆ្នាំ ២០០៤ (នស/រកម/១០០៤/០០៦) ("ច្បាប់ អវតក") មាត្រា ២០ថ្មី។

6 ឯកសារ D1/1 សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្ដីទីអំពីការដាក់ឯកសារដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩។

10. បន្ទាប់មក ស.ព.អ បានបញ្ជាក់បំភ្លឺ និង/ឬ ពង្រីកវិសាលភាពនៃកិច្ចស៊ើបសួរចំនួនពីរដង។ ដំបូង គាត់បានបញ្ជាក់បំភ្លឺថា ស.ច.ស មិនបានប្តឹងពីមន្ទីរសន្តិសុខកងពលទាំងអស់របស់កងទ័ពបដិវត្តន៍កម្ពុជា ឬទីតាំងឧក្រិដ្ឋកម្មផ្សេងៗទៀត ហើយខ្លួនក៏គ្មានចេតនាប្តឹងឲ្យសហចៅក្រមស៊ើបអង្កេតបើកការស៊ើបសួរទៅលើមន្ទីរសន្តិសុខបឹងកន្សែង[7]។ លើកទីពីរ ស.ព.អ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដោយធ្វើការបញ្ជាក់បំភ្លឺពីវិសាលភាពនៃកិច្ចស៊ើបសួរ ទាក់ទងនឹងការបោសសម្អាតក្នុងតំបន់ ៥០៥ (ក្រចេះ) និងពលកម្មដោយបង្ខំ និងការសម្លាប់មនុស្សក្នុងឃុំរាម (ស្រុកព្រៃនប់) និងបានប្តឹង ស.ច.ស ឲ្យស៊ើបអង្កេតលើអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមភេទដោយបង្ខំបន្ទាប់អាពាហ៍ពិពាហ៍ទាំងនេះ (រំលោភសេពសន្ថវៈ) ស្ថិតក្រោមអំពើអមនុស្សធម៌ផ្សេងៗទៀត[8]។

## ការផ្លាស់ប្តូរចៅក្រមស៊ើបអង្កេតក្នុងអំឡុងពេលស៊ើបសួរ

11. កិច្ចស៊ើបសួរលើសំណុំរឿង ០០៣ បានចាប់ផ្តើម នៅអាណត្តិរបស់សហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Marcel Lemonde[9]។ នៅថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១០ ចៅក្រម Lemonde ត្រូវបានជំនួសដោយចៅក្រម Siegfried Blunk ដែលក្រោយមកបានលាឈប់ពីតំណែងនៅថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១១[10]។ ចៅក្រម Laurent Kasper-Ansermet បានស្បថចូលកាន់តំណែងជាចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង នៅចំពោះមុខកិច្ចប្រជុំពេញអង្គរបស់ អ.វ.ត.ក នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១[11] ហើយបានបង្ហាញគម្រោងលាឈប់ពីតំណែងរបស់គាត់នៅខែ មីនា ឆ្នាំ ២០១២ ដោយការលាឈប់ពីតំណែងរបស់គាត់ដែលនឹងចូលជាធរមានពី

---

7 ឯកសារ D1/2/1 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំការបញ្ជាក់បំភ្លឺ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១១ កថាខណ្ឌ ២, ៣។

8 ឯកសារ D120 ដីកាសន្និដ្ឋានបញ្ជូនរឿងរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង០០៣ ថ្ងៃទី៣១ ខែ តុលា ឆ្នាំ ២០១៤។

9 ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២។

10 សេចក្តីប្រកាសសារព័ត៌មាន អវតក៖ Dr. Siegfried Blunk ត្រូវបានចាត់តាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី ចុះថ្ងៃទី១ ខែ ធ្នូ ឆ្នាំ២០១០។ សេចក្តីប្រកាសសារព័ត៌មាន អវតក៖ សេចក្តីប្រកាសសារព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១១។

11 សេចក្តីប្រកាសសារព័ត៌មាន អវតក៖ សេចក្តីថ្លែងការណ៍ជាសាធារណៈរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ថ្ងៃទី៩ ខែ កុម្ភៈ ឆ្នាំ ២០១២។

ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១២[12]។ នៅថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១២ ចៅក្រម Mark Harmon បានស្បថចូលបំពេញការងារជា ស.ច.ស.អ[13]។ នៅខែ កក្កដា ឆ្នាំ២០១៥ ចៅក្រម Harmon បានប្រកាសពីការលាឈប់ពីតំណែងរបស់គាត់ ហើយក្រោយមកគាត់ត្រូវបានជំនួសដោយ ស.ច.ស.អ បច្ចុប្បន្នឈ្មោះ Michael Bohlander[14]។

## សេចក្តីជូនដំណឹងឆ្នាំ ២០១១ ដែលថា កិច្ចស៊ើបសួរតាមផ្លូវតុលាការបានបិទបញ្ចប់

12. នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ស.ច.ស បានជូនដំណឹងទៅសហព្រះរាជអាជ្ញាថា ខ្លួនបានពិចារណាបិទបញ្ចប់កិច្ចស៊ើបសួរតាមផ្លូវតុលាការក្នុងសំណុំរឿង ០០៣ (“សេចក្តីជូនដំណឹង ខែ មេសា ឆ្នាំ ២០១១”)[15]។ បន្ទាប់មក ស.ព.អ បានចេញសេចក្តីថ្លែងការណ៍សាធារណៈមួយ ដោយប្រកាស *ក្នុងចំណោមបញ្ហាផ្សេងទៀត* ថា គាត់យល់ឃើញថា ឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ មិនត្រូវបានស៊ើបអង្កេតឲ្យបានពេញលេញនៅឡើយ ហើយគាត់មានបំណងស្នើសុំឲ្យមានកិច្ចស៊ើបសួរបន្ថែមទៀត[16]។ បន្ទាប់មក ស.ព.អ បាន

---

[12] សេចក្តីប្រកាសសារព័ត៌មាន អវតក៖ សេចក្តីប្រកាសព័ត៌មានជាសារធារណៈពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២។

[13] សេចក្តីប្រកាសសារព័ត៌មាន អវតក៖ Mark Harmon ស្បថចូលកាន់តំណែងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១២។

[14] សេចក្តីប្រកាសសារព័ត៌មាន អវតក៖ ចៅក្រម Mark Harmon ប្រកាសលាឈប់ពីមុខតំណែង ចុះថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០១៥។ សេចក្តីប្រកាសសារព័ត៌មាន អវតក៖ ការតែងតាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៥។

[15] ឯកសារ D13 សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១។

[16] សេចក្តីប្រកាសសារព័ត៌មាន អវតក៖ សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣ ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១១។ កំណត់សម្គាល់៖សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវបានបង្គាប់ឲ្យដកសេចក្តីថ្លែងការណ៍ របស់គាត់ តាមរយៈដីកាសម្រេចស្តីអំពីសេចក្តីប្រកាសសារព័ត៌មានជាសារធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង០០៣ ឯកសារ D14 ថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០១១។ សហព្រះរាជអាជ្ញាអន្តរជាតិ បានប្តឹងឧទ្ធរណ៍ជំទាស់នឹងដីការបស់សហចៅក្រមស៊ើបអង្កេត(សូមមើល D14/1/1 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំង “ដីកាសម្រេចស្តីអំពីសេចក្តីប្រកាសសារព័ត៌មានជាសារធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង០០៣” ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១១) ប៉ុន្តែ ដីកានេះត្រូវបានតម្កល់ទុកពីព្រោះថាអង្គបុរេជំនុំជម្រះមិនអាចរកបានសម្លេងភាគច្រើនលើបញ្ហានេះ (សូមមើល D14/1/3 សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចរបស់សហ

ដាក់សំណើរបស់ខ្លួន ហើយ ស.ច.ស បានច្រានចោលសំណើទាំងនោះចំនួនពីរដង ដោយលើកទីមួយ ដោយសារតែមូលហេតុនីតិវិធី និងលើកទីពីរ (បន្ទាប់ពី ស.ព.អ បានកែតម្រូវវិការៈនីតិវិធី និងបានដាក់សំណើឡើងវិញ) ដោយសារតែកង្វះយុត្តាធិការបុគ្គល[17]។ ស.ព.អ បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចទាំងពីរ[18]។ នៅថ្ងៃទី ២ និងទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ អ.ប.ជ បាន

---

ចៅក្រមស៊ើបអង្កេតលើសេចក្តីប្រកាសសារព័ត៌មានជាសាធារណៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណុំរឿង០០៣ ថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១១)។ បន្ទាប់មក សហព្រះរាជអាជ្ញាអន្តរជាតិបានដកសេចក្តីថ្លែងការណ៍របស់គាត់វិញដែលមាននៅក្នុងសេចក្តីប្រកាសសារព័ត៌មាន អវតក សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើការដកសេចក្តីថ្លែងការណ៍នៅក្នុងសំណុំរឿង០០៣ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១១។

17 ឯកសារ D17 សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១ របស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងសំណុំរឿង០០៣ សុំឱ្យទទួលយកឯកសារបន្ថែម និងសេចក្តីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ ថ្ងៃទី ១៨ ខែ ឧសភាឆ្នាំ ២០១១។ ឯកសារ D18 សំណើលើកទី២ របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងលោក ស៊ូ មេត ព្រមទាំងពាក់ព័ន្ធនឹងទីតាំងប្រព្រឹត្តបទល្មើស ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១។ ឯកសារ D19 សំណើបំពេញកិច្ចស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹង មាស មុត និងទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១។ សំណើទាំងបីនេះត្រូវបានបដិសេធ ដោយផ្អែកលើមូលហេតុខ្វះនីតិវិធី តាមរយៈឯកសារ D20/3 ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីសំណើសុំពន្យាពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង០០៣ ("ដីកាសម្រេចបដិសេធរបស់ កសចស")។ សំណើទាំងបីនេះត្រូវបានដាក់ជាថ្មីឡើងវិញដោយ សហព្រះរាជអាជ្ញាអន្តរជាតិ បន្ទាប់ពីបានដោះស្រាយលើបញ្ហានីតិវិធី៖ ឯកសារ D22 សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១ របស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងសំណុំរឿង០០៣ សុំឱ្យទទួលយកឯកសារបន្ថែម និងសេចក្តីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០១១, ឯកសារ D23 សំណើលើកទី២ របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងលោក ស៊ូ មេត ព្រមទាំងពាក់ព័ន្ធនឹងទីតាំងប្រព្រឹត្តបទល្មើស ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ ២០១១ និង ឯកសារ D24 សំណើបំពេញកិច្ចស៊ើបសួរលើកទី៣របស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹង មាស មុត និងទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ ២០១១។ សំណើទាំងបីនេះក៏ត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេត ផងដែរ លើកនេះ ដោយផ្អែកលើយុត្តាធិការលើបុគ្គល៖ សូមមើលឯកសារ D26 ដីកាសម្រេចស្តីពីការដាក់ឯកសារជាថ្មីនូវសំណើសុំបំពេញកិច្ចស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងសំណុំរឿង០០៣។

18 ឯកសារ D20/4/1 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់នឹង"សេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣" ថ្ងៃទី៧ ខែ កក្កដា ឆ្នាំ២០១១ ជាពិសេស កថាខណ្ឌ៧៥។ ឯកសារ D26/1/1 បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់នឹង"សេចក្តីសម្រេចលើការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបីរបស់របស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង០០៣" ថ្ងៃទី ២៦ ខែសីហា ឆ្នាំ២០១១។

ប្រកាសថា ខ្លួនរកមិនបានសំឡេងយ៉ាងហោចណាស់ពីចៅក្រមបួនរូប ដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍ទាំងនេះបានទេ[19]។

13. នៅមុនពេលពិនិត្យលើសេចក្តីពិចារណារបស់ អ.ប.ជ នោះ ស.ច.ស.អ Blunk បានលាឈប់ពីតំណែង[20]។ នៅថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១១ ស.ច.ស.អ បម្រុង Kasper-Ansermet បានពិចារណាឡើងវិញលើភាពអាចទទួលយកបាននៃសំណើសុំកិច្ចស៊ើបសួរទាំងបីរបស់ ស.ព.អ ហើយបញ្ជាក់ថា កិច្ចស៊ើបសួរតាមផ្លូវតុលាការហាក់បីដូចជា "មានលក្ខណៈខ្វះចន្លោះ និងប៉ះពាល់ដល់ផលប្រយោជន៍របស់គ្រប់ភាគីទាំងអស់" [ហើយ] ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិជនសង្ស័យ ជនរងគ្រោះ និងអយ្យការ"[21]។ គាត់បានប្រកាសថា សំណើរបស់ ស.ព.អ ស្នើសុំបំពេញកិច្ចស៊ើបសួរ អាចទទួលយកបាន ហើយបង្គាប់ឱ្យបើកកិច្ចស៊ើបសួរតាមផ្លូវតុលាការឡើងវិញ[22]។

## ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត

14. ស.ច.ស មានចំណុចខ្វែងយោបល់គ្នាមួយចំនួន ក្នុងអំឡុងពេលស៊ើបអង្កេតក្នុងសំណុំរឿង ០០៣។ ទីមួយ ពួកគេមិនឯកភាពគ្នាលើដីកាចាត់ឱ្យស៊ើបសួរជំនួស ដែលនៅក្នុងដីកានោះ ស.ច.ស.អ បានបង្ហាញខ្លឹមសារនៃបេសកកម្មកិច្ចស៊ើបសួរ និងបានប្រគល់ដីកាចាត់ឱ្យស៊ើបសួរជំនួសនោះទៅឱ្យអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស[23]។ ទីពីរ ពួកគេបានខ្វែងគំនិតគ្នាលើសំណើសុំការបញ្ជាក់បំភ្លឺរបស់

---

19 ឯកសារ D20/4/4 សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់នឹង"សេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង០០៣" ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១១។ ឯកសារ D26/1/3 សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជំទាស់នឹង"សេចក្តីសម្រេចលើការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី" ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១។

20 សេចក្តីប្រកាសសារព័ត៌មាន អវតក៖ សេចក្តីប្រកាសសារព័ត៌មានពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០១១។

21 ឯកសារ D28 ដីកាសម្រេចស្តីពីការបើកការស៊ើបអង្កេតបឋមឡើងវិញ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ២០១១ កថាខណ្ឌ ៨។

22 ឯកសារ D28 ដីកាសម្រេចស្តីពីការបើកការស៊ើបអង្កេតបឋមឡើងវិញ ទំព័រ ១៣៖ (ផ្នែកសេចក្តីសម្រេច)។

23 ឯកសារ D2 ដីកាចាត់ឱ្យស៊ើបសួរជំនួស ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១០។ សូមមើលផងដែរ ឯកសារ D20/3 ដីកាបដិសេធរបស់ កសចស កថាខណ្ឌ ៦ (ii) យោងលើកំណត់ហេតុករណីខ្វែងយោបល់គ្នាពាក់ព័ន្ធនឹងដីកាចាត់ឱ្យស៊ើបសួរជំនួស។

ស.ច.ស.អ ដែលបានស្នើសុំឱ្យ ស.ព.អ បញ្ជាក់បំភ្លឺអំពីវិសាលភាពនៃកិច្ចស៊ើបសួរ ទាក់ទងនឹង មន្ទីរសន្តិសុខកងពលនៃកងទ័ពបដិវត្តន៍កម្ពុជា និងបឹងកន្សែង[24]។

15. ការខ្វែងយោបល់គ្នាទីបីរវាង ស.ច.ស ត្រូវបានចុះបញ្ជីនៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ដែលនៅពេលនេះពាក់ព័ន្ធនឹងស្ថានភាពនៃកិច្ចស៊ើបសួរ និងសុពលភាពនៃឯកសារមួយចំនួនដែលបានដាក់ក្នុងសំណុំរឿង បន្ទាប់ពីការលាឈប់ពីការងាររបស់ចៅក្រម Blunk[25]។ នៅក្នុងថ្ងៃនោះផងដែរ សហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង បានចេញដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ឱ្យសហព្រះរាជអាជ្ញាដែលយោងលើសេចក្តីជូនដំណឹង ខែ មេសា ឆ្នាំ ២០១១ អំពីការបិទបញ្ចប់កិច្ចស៊ើបសួរតាមផ្លូវតុលាការ ហើយបានបញ្ជាក់ថា តាមការយល់ឃើញរបស់គាត់ សំណុំរឿងនេះមានតែឯកសារដែលបានដាក់នៅក្នុងសំណុំរឿង នៅពេលការលាឈប់ពីតំណែងរបស់ចៅក្រម Blunk ប៉ុណ្ណោះ[26]។ ម្យ៉ាងទៀត ស.ច.ស.អ Harmon បានបញ្ជាក់ថា គាត់បានវាយតម្លៃពីស្ថានភាពនៃកិច្ចស៊ើបសួរ ហើយបានសន្និដ្ឋានថា កិច្ចស៊ើបសួរបន្ថែមទៀតគឺជាការចាំបាច់[27]។ បន្ទាប់មកចៅក្រម Harmon បានដាក់ប្រតិចារឹកចូលទៅក្នុងសំណុំរឿង និងបានអនុសញ្ញាតឱ្យមានកិច្ចស៊ើបសួរបន្ថែម[28]។ នៅថ្ងៃបន្ទាប់ ស.ព.អ បានបញ្ជូនសំណុំរឿងត្រឡប់ទៅ ស.ច.ស ដោយបញ្ជាក់ថា

---

[24] ឯកសារ D1/2 សំណើសុំការបញ្ជាក់បំភ្លឺនៅក្នុងសំណុំរឿង០០៣ ថ្ងៃទី៨ ខែ កុម្ភៈ ឆ្នាំ ២០១១។ សូមមើលផងដែរ ឯកសារ D20/3 ដីកាបដិសេធរបស់ កសចស កថាខណ្ឌ ៦(iii) យោងលើកំណត់ហេតុករណីខ្វែងយោបល់គ្នាពាក់ព័ន្ធនឹងដីកាចាត់ឱ្យស៊ើបសួរជំនួស។

[25] ឯកសារ D53/2 សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់ប្រតិចារឹកសំណុំរឿង០០២ ចូលទៅក្នុងសំណុំរឿង ថ្ងៃ៧ ខែកុម្ភៈ ឆ្នាំ២០១៣ ("សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់ប្រតិចារឹកសំណុំរឿង") កថាខណ្ឌ១០។

[26] ឯកសារ D52 ដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ ២០១៣។ សេចក្តីប្រកាសសារព័ត៌មាន អវតក៖ សេចក្តីថ្លែងការណ៍ពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងសំណើក្នុងសំណុំរឿង០០៣ ពីសហព្រះរាជអាជ្ញាអន្តរជាតិ ថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ២០១១។

[27] ឯកសារ D53/2 សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់ប្រតិចារិតសំណុំរឿង កថាខណ្ឌ ៩, ១២។ សេចក្តីប្រកាសសារព័ត៌មាន អវតក៖ សេចក្តីថ្លែងការណ៍ពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងសំណើក្នុងសំណុំរឿង០០៣ ពីសហព្រះរាជអាជ្ញាអន្តរជាតិ ថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ២០១១។

[28] ឯកសារ D53/2 សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដាក់ប្រតិចារិតសំណុំរឿង កថាខណ្ឌ១៧។ ឯកសារ D54 ដីកាចាត់ឱ្យស៊ើបសួរជំនួស ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ២០១៣។ ឯកសារ D55 ដីកាចាត់ឱ្យស៊ើបសួរជំនួស ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ២០១៣។

កិច្ចស៊ើបសួរមិនបានបំពេញបង្គ្រប់យ៉ាងជាក់ស្តែង សកម្មភាពរបស់ចៅក្រម Harmon ដែលបានលើកឡើងក្នុងសេចក្តីជូនដំណឹង ខែ មេសា ឆ្នាំ ២០១១ ដោយគ្មានអនុភាពផ្លូវច្បាប់ កិច្ចស៊ើបសួរហាក់បីដូចជាត្រូវបានអនុវត្តឡើងវិញដោយ ស.ច.ស និងថាដូច្នេះ ស.ព.អ មិនអាចដំណើរការដោយស្របច្បាប់ដើម្បីទទួលយកមកគ្រប់គ្រងលើសំណុំរឿងនេះ ឬចេញដីកាសន្និដ្ឋានស្ថាពរណាមួយឡើយ[29]។

16. ក្រោយមកក្នុងខែនោះ ស.ច.ស បានចេញសេចក្តីថ្លែងការសាធារណៈមួយអំពីស្ថានភាពនៃសំណុំរឿងនេះ ដោយធ្វើការកត់សម្គាល់ពីទស្សនៈខុសគ្នារបស់ពួកគេ[30]។ ដោយប្រឈមជាថ្មីម្តងទៀតចំពោះភាពខុសគ្នានៃការយល់ឃើញ និងជាការឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតជាតិដែលថា គាត់នឹង "ពិចារណាផងដែរលើដីកាសន្និដ្ឋានផ្សេងៗទៀតរបស់សហព្រះរាជអាជ្ញាដែលធ្វើឡើងក្នុងរយៈពេលបីខែ ដោយចាប់ផ្តើមពីថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៣" សហព្រះរាជអាជ្ញាបានស្នើសុំការបញ្ជាក់បំភ្លឺទាក់ទងនឹងស្ថានភាពនៃសំណុំរឿង និងថាតើត្រូវបន្តរៀបចំដីកាសន្និដ្ឋានស្ថាពរ ឬយ៉ាងណា[31]។ គ្មានការបញ្ជាក់បំភ្លឺត្រូវបានចេញ ហើយកិច្ចស៊ើបសួរបានបន្តអនុវត្ត។

17. នៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០១៤ ភាគីទាំងអស់បានទទួលការជូនដំណឹងអំពីសេចក្តីសម្រេចមួយដែលបានយោងជាលើកដំបូងទៅការខ្វែងគំនិតគ្នាទីបួនរវាង ស.ច.ស ដែលបានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣[32]។ ពីរថ្ងៃក្រោយមក សហមេធាវីការពារក្តី **មាស មុត** បានបញ្ជូនលិខិតមួយច្បាប់ទៅកាន់ ស.ច.ស ស្នើសុំព័ត៌មានទូទៅអំពីលក្ខណៈនៃការខ្វែងគំនិតគ្នានៅថ្ងៃទី ៧ និងថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ហើយថាតើការខ្វែងគំនិតគ្នាដូច្នេះនៅពេលបច្ចុប្បន្នត្រូវបានដាក់នៅ

---

[29] ឯកសារ D52/1 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ២០១៣ កថាខណ្ឌ៣-៧។

[30] សេចក្តីប្រកាសសារព័ត៌មាន អវតក៖ សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិពាក់ព័ន្ធនឹងសំណើក្នុងសំណុំរឿង០០៣ ថ្ងៃទី២៨ ខែ កុម្ភៈ ឆ្នាំ២០១៣។

[31] ឯកសារ D63 សំណើរបស់សហព្រះរាជអាជ្ញាសុំការបំភ្លឺអំពីស្ថានភាពបច្ចុប្បន្នភាពនៃសំណុំរឿង ថ្ងៃទី១១ ខែមេសា ឆ្នាំ ២០១៣ កថាខណ្ឌ ៤, ១០។

[32] ឯកសារ D82/3 ការជូនដំណឹងទាក់ទងនឹងសំណើរបស់ជនសង្ស័យសុំចូលពិនិត្យសំណុំរឿង និងចូលរួមការស៊ើបសួរ (D82) និងសុំឯកសារទាំងមូលនៃដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ និងសម្អាងគាំទ្រ (D82/2) ថ្ងៃទី១០ ខែ កក្កដា ឆ្នាំ២០១៤ ទំព័រ ២។

ចំពោះមុខ អ.ប.ជ ឬនៅ[33]។ ចៅក្រម Harmon បានឆ្លើយតបថា ករណីខ្វែងយោបល់គ្នាទាំងនេះគឺជាឯកសារ*របស់ភាគីមួយគត់* ហើយគាត់មិនស្ថិតនៅក្នុងតួនាទីមួយដែលត្រូវបង្ហាញពីខ្លឹមសារ ឬជាលក្ខណៈទូទៅនៃករណីខ្វែងយោបល់គ្នាទាំងនេះឡើយ ប៉ុន្តែគាត់បានបញ្ជាក់បំភ្លឺថា ករណីខ្វែងយោបល់គ្នាទាំងនេះមិនបានលើកយកមកដាក់នៅចំពោះមុខ អ.ប.ជ ដើម្បីដោះស្រាយទេ[34]។

18. ករណីខ្វែងយោលប់គ្នាទីប្រាំរវាង ស.ច.ស ត្រូវបានចុះបញ្ជី នៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤ ដែលហាក់បីដូចជាទាក់ទងនឹងការចេញដីកាកោះ **មាស មុត** ឲ្យចូលបង្ហាញខ្លួនលើកដំបូង នៅចំពោះមុខ អ.វ.ត.ក ដើម្បីធ្វើការចោទប្រកាន់[35]។ ជាចុងក្រោយ ករណីខ្វែងយោបល់គ្នាទីប្រាំមួយត្រូវបានចុះបញ្ជីនៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧[36] ប៉ុន្តែភាគីពុំបានទទួលព័ត៌មានទាក់ទងនឹងលក្ខណៈនៃករណីខ្វែងយោយល់គ្នានេះទេ។

## តំណាងផ្នែកច្បាប់របស់ មាស មុត និងការចូលមើលសំណុំរឿង

19. អង្គភាពគាំពារការការពារក្ដីបានស្នើសុំសិទ្ធិពិនិត្យមើលសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ នៅក្នុងលិខិតផ្ញើជូន ក.ស.ច.ស នៅថ្ងៃទី ២៩ ខែ កក្កដា និងថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០[37]។ ស.ច.ស

---

33 ឯកសារ D82/3/1 សំណើសុំព័ត៌មានទាក់ទងនឹងការខ្វែងគំនិតគ្នាកត់ត្រានៅ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៣ និងនៅថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១៣ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤។

34 ឯកសារ D82/3/2 ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅនឹងសំណើសុំព័ត៌មានទាក់ទងនឹងកំណត់ហេតុនៃករណីខ្វែងយោបល់គ្នាចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៣ និងនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៤។

35 ឯកសារ A66 ដីកាកោះឲ្យបង្ហាញខ្លួនលើកដំបូង ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ទំព័រ១។ ឯកសារ D82/5 ការជូនដំណឹង អំពីសំណើរបស់ជនសង្ស័យសុំចូលពិនិត្យមើលសំណុំរឿង ចូលរួមការស៊ើបអង្កេត និងសុំលុបចោលចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០១៤ កថាខណ្ឌ១០។

36 សូមមើលឧទាហរណ៍ ឯកសារ D236 សេចក្ដីសម្រេចលើសំណើរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសុំពន្យារពេលកំណត់ ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០១៧ កថាខណ្ឌ១។ ឯកសារ D256/3 សេចក្ដីសម្រេចលើកាលបរិច្ឆេទកំណត់សម្រាប់ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា និងចម្លើយតបរបស់ក្រុមមេធាវីការពារក្ដី ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៧ កថាខណ្ឌ១។

37 ឯកសារ A1 លិខិតរបស់អង្គភាពគាំពារការពារក្ដីស្ដីពីសិទ្ធិការពារក្ដីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១០។ ឯកសារ A1/1 លិខិតរំលឹករបស់អង្គភាពគាំពារការពារក្ដីស្ដីពីសិទ្ធិការពារក្ដីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០១០។

បានឆ្លើយតបថា សិទ្ធិពិនិត្យមើលសំណុំរឿងមិនអាចផ្តល់ជូនបានទេ ពីព្រោះសិទ្ធិការពារក្តីអាចអនុវត្តបានពេញលេញ តែនៅពេលដែលជនម្នាក់ត្រូវបានចោទប្រកាន់ និងបានក្លាយជាភាគីនៃកិច្ចដំណើរការនីតិវិធី[38]។ នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១១ អង្គភាពគាំពារការការពារក្តី បានជូនដំណឹងដល់ ស.ច.ស ថា គង់ សំអុន ត្រូវបានចាត់តាំងជាបណ្តោះអាសន្នឱ្យការពារផលប្រយោជន៍ជនសង្ស័យដែលមិនបង្ហាញអត្តសញ្ញាណក្នុងសំណុំរឿង ០០៣ និង ០០៤[39]។ បីថ្ងៃបន្ទាប់ពីសេចក្តីជូនដំណឹង គង់ សំអុន បានស្នើសុំសិទ្ធិពិនិត្យសំណុំរឿង[40]។ ស.ច.ស បានច្រានចោលសំណើនេះ ដោយបានសម្រេចថា ជនសង្ស័យមិនទាន់មានសិទ្ធិទទួលបានមេធាវីការពារក្តី ឬសិទ្ធិពិនិត្យសំណុំរឿងនៅឡើយ[41]។

20. នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ស.ច.ស បម្រុង បានជូនដំណឹងដល់ ស៊ូ ម៉េត និង **មាស មុត** ថា ពួកគេកំពុងត្រូវបានស៊ើបអង្កេតចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តក្នុងយុត្តាធិការរបស់ អ.វ.ត.ក ហើយក្នុងនាមជាជនសង្ស័យ ពួកគាត់មានសិទ្ធិ *ក្នុងចំណោមសិទ្ធិនានា* មានតំណាងផ្លូវច្បាប់តាមការជ្រើសរើសរបស់ខ្លួន[42]។

21. នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ សេចក្តីប្រកាសព័ត៌មានបានផ្តល់ព័ត៌មានដល់សាធារណជនថា អង្គភាពគាំពារការការពារក្តីបានចាត់តាំង អាង ឧត្តម្ភ និង Michael G. Karnavas (“សហមេធាវី”) ជាមេធាវីការពារក្តីឱ្យជនសង្ស័យម្នាក់ក្នុងសំណុំរឿង ០០៣[43]។ បួនថ្ងៃក្រោយមក ប្រធានអង្គភាព

---

38 ឯកសារ A1/2 ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតទាក់ទងនឹងសិទ្ធិការពារក្តី នៅក្នុងសំណុំរឿង ០០៣ និង ០០៤ ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១០។

39 ឯកសារ A2 ការជូនដំណឹងពីការចាត់តាំងមេធាវីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១១ [មេធាវីត្រូវបានចាត់តាំងនៅថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ២០១០]។

40 ឯកសារ D3 សំណើសុំចូលពិនិត្យមើលសំណុំរឿង០០៣ និង ០០៤ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១។

41 ឯកសារ D3/1 ដីកាសម្រេចលើសំណើសុំចូលពិនិត្យមើលសំណុំរឿង០០៣ និង ០០៤ ថ្ងៃទី៥ ខែមេសា ឆ្នាំ ២០១១។ សូមមើលផងដែរឯកសារ D3/2/1 ដីកាសម្រេចស្តីពីសំណើពិនិត្យឡើងវិញនូវដីកាសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពិនិត្យមើលសំណុំរឿង០០៣ និង ០០៤ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០១១។

42 ឯកសារ D30 ការជូនដំណឹងអំពីសិទ្ធិរបស់ជនងស្ស័យ [វិធាន២១.១ឃ] ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០១២ ទាក់ទងនឹង [មាស មុត]។ ឯកសារ D31 ការជូនដំណឹងអំពីសិទ្ធិរបស់ជនងស្ស័យ [វិធាន២១.១ឃ] ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០១២ ទាក់ងនឹង [ស៊ូ មេត] ។

43 សេចក្តីប្រកាសសារព័ត៌មាន អវតក៖ លោក អាង ឧត្តម និង លោក Michael G. Karnavas ត្រូវបានចាត់តាំងជាមេធាវីការពារក្តីឱ្យជនសង្ស័យម្នាក់នៅក្នុងសំណុំរឿង ០០៣ ថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ ២០១២។

គាំពារការការពារក្តីបានជូនដំណឹងដល់ ស.ច.ស ថា កាលពី ៦ ខែមុន **មាស មុត** បានជ្រើសរើសសហមេធាវីជាតំណាងផ្នែកច្បាប់របស់ខ្លួន ហើយមិនទទួលខុសត្រូវចំពោះទំនាស់ផលប្រយោជន៍ណាមួយដែលអាចកើតមានពីការតំណាងនេះ ខណៈដែលពួកគាត់បានតំណាងឱ្យ អៀង សារី ក្នុងសំណុំរឿង ០០២[44]។

22. នៅថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១២ ស.ព.អ បានស្នើទៅ ស.ច.ស ឱ្យច្រានចោលការចាត់តាំងសហមេធាវី ពីព្រោះការការពារទាំង អៀង សារី និង **មាស មុត** នាំឱ្យមានទំនាស់ផលប្រយោជន៍[45]។ នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៤ អ.ប.ជ បានទទួលស្គាល់ អាង ឧត្តម និង Michael Karna ជាសហមេធាវីរបស់ **មាស មុត**[46]។

## ការចោទប្រកាន់ មាស មុត

23. នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ ស៊ូម៉េត បានស្លាប់ ហើយជាលទ្ធផល ស.ច.ស បានច្រានចោលការចោទប្រកាន់ព្រហ្មទណ្ឌទាំងអស់ប្រឆាំងនឹងគាត់ នៅចំពោះមុខ អ.វ.ត.ក[47] ដោយនៅសល់តែ **មាស មុត** ម្នាក់ប៉ុណ្ណោះគឺជាជនសង្ស័យក្នុងសំណុំរឿង ០០៣។

24. នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ស.ច.ស.អ Harmon បានកោះហៅ **មាស មុត** ឱ្យបង្ហាញខ្លួនលើកដំបូង នៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៤ នៅ អ.វ.ត.ក[48]។ **មាស មុត** បានជូនដំណឹងដល់ ស.ច.ស

---

44 ឯកសារ D56 លិខិតរបស់អង្គភាពគាំពារការការពារក្តីផ្ញើជូនសហចៅក្រមស៊ើបអង្កេតស្តីពីការចាត់តាំងសហមេធាវីឱ្យធ្វើជាតំណាងឱ្យលោក មាស មុត ដែលជាសង្ស័យម្នាក់នៅក្នុងសំណុំរឿង០០៣ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២។

45 ឯកសារ D56/1 សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំឱ្យបដិសេធចោលការចាត់តាំងសហមេធាវីការពារក្តីដោយមូលហេតុទំនាស់ផលប្រយោជន៍ដែលមិនអាចផ្សះផ្សារបាន ថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ ២០១២។

46 ឯកសារ D56/19/36 សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ច្រានចោលការចាត់តាំង អាង ឧត្តម និង Michael G. Karnavas ជាសហមេធាវីការពារក្តី ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៤។ សូមមើលផងដែរឯកសារ D56/19/38 សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបដិសេធការចាត់តាំងលោក អាង ឧត្តម និងMichael G. Karnavas មិនឱ្យធ្វើជាសហមេធាវីការពាររបស់គាត់ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០១៤ [ផ្តល់មូលហេតុរបស់ង្គជំនុំជម្រះ]។

47 ឯកសារ D86/3 ការលើកលែងការចោទប្រកាន់ប្រឆាំងនឹង ស៊ុំ មេត ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥។

48 ឯកសារ A66 ដីកាកោះហៅលោក មាស មុត ឱ្យបង្ហាញខ្លួនលើកដំបូង ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៤ [មានជាកំណត់ហេតុ ថា ដីកាកោះនេះបានប្រគល់ឱ្យ មាស មុត នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤]។

.អ នៅក្នុងលិខិតមួយ ដែលបានចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ ថា គាត់មិនទទួលស្គាល់សុពលភាពនៃដីកាកោះ ដែលបានចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់នោះឡើយ[49]។ នៅថ្ងៃបន្ទាប់ អ.ប.ជ បានចេញសេចក្តីសម្រេច ដែលទទួលស្គាល់សុពលភាពនៃដីកាកោះ ដែលចេញដោយសហចៅក្រមតែម្នាក់[50] ប៉ុន្តែ **មាស មុត** ខកខានមិនបានបង្ហាញខ្លួននៅសវនាការ ហើយចៅក្រម Harmon បានចេញដីកាបង្គាប់ឲ្យនាំខ្លួនគាត់[51]។

25. សហចៅក្រមរបស់ **មាស មុត** បានដាក់ពាក្យសុំរបស់ខ្លួន សុំឲ្យ ស.ច.ស ប្តឹង អ.ប.ជ ឲ្យទទួលពិនិត្យ និងចាត់ការលើសំណើសុំមោឃភាពដីកាកោះឲ្យបង្ហាញខ្លួនលើកដំបូង[52] ដែលត្រូវបានច្រានចោលដោយ ស.ច.ស.អ ដោយសារកង្វះមូលដ្ឋានគាំទ្រ[53]។ សហមេធាវីបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ ស.ច.ស.អ[54] ប៉ុន្តែ អ.ប.ជ មានការមិនឯកភាពលើចំណុចថាតើ **មាស មុត**

---

[49] ឯកសារ A67/1.1 សេចក្តីជូនដំណឹងស្តីពីការមិនទទួលស្គាល់ដីកាកោះ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ [បដិសេធមិនទទួលស្គាល់សុពលភាពដីកាកោះដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ តែមិនមានហត្ថលេខារបស់សហចៅក្រមស៊ើបអង្កេតជាតិ ហើយស្នើសុំឲ្យសហមេធាវីរបស់គាត់បានចូលពិនិត្យមើលសំណុំរឿង]។

[50] ឯកសារ D117/1/1/2 សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះ ដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេត តែម្នាក់ ថ្ងៃទី៣ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ១៦ [ច្រានចោលបណ្តឹងឧទ្ធរណ៍របស់ មាស មុត និងរំលឹកថា សហចៅក្រមស៊ើបអង្កេតម្នាក់ អាចចេញដីកាកោះក្នុងគោលបំណងដាក់ជនសង្ស័យឲ្យស្ថិតក្រោមការពិនិត្យប្រសិនបើនិតីវិធីនៃការខ្វែងយោបល់ដែលមានចែងនៅក្នុងវិធានផ្ទៃក្នុងត្រូវបានអនុវត្ត]។

[51] ឯកសារ C1 ដីកាបង្គាប់ឲ្យនាំខ្លួន មាស មុត ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤។

[52] ឯកសារ A77 ពាក្យសុំរបស់ មាស មុត សុំប្តឹងអង្គបុរេជំនុំជម្រះឲ្យពិនិត្យ និងចាត់ការលើសំណើសុំមោឃភាពដីកាកោះឲ្យបង្ហាញខ្លួនលើកដំបូង ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៤។

[53] ឯកសារ A77/1 សេចក្តីសម្រេចលើពាក្យសុំរបស់ មាស មុត សុំប្តឹងអង្គបុរេជំនុំជម្រះឲ្យពិនិត្យ និងចាត់ការលើសំណើសុំមោឃភាពដីកាកោះឲ្យបង្ហាញខ្លួនលើកដំបូង ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ១៤-១៦, ២២ [មាស មុត ត្រូវបានជូនដំណឹងថា ប្រសិនត្រូវដាក់ឲ្យស្ថិតក្រោមការពិនិត្យនៅចុងបញ្ចប់នៃការបង្ហាញខ្លួនលើកដំបូង គាត់អាចប្រើសិទ្ធិទាំងអស់ដែលជនត្រូវចោទមានសិទ្ធិទទួលបាន តែគាត់បានរំលោភបំពានដោយចេតនា និងដោយបានដឹងឮ មិនគោរពតាមដីកាដែលជាប់កាតព្វកិច្ចផ្លូវច្បាប់ ហើយបច្ចុប្បន្ននេះមិនមែនជាភាគីនៅក្នុងសំណុំរឿងទេ (គ្រាន់តែជាជនសង្ស័យតែប៉ុណ្ណោះ) ដោយសារគាត់រាំងស្ទះដល់កិច្ចដំណើរការនិតីវិធីដែលអាចផ្តល់ឲ្យគាត់នូវសិទ្ធិទាំងអស់]។

[54] ឯកសារ A77/1/1/1 បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការបដិសេធរបស់សហចៅក្រមស៊ើបអង្កេត HARMON នូវពាក្យសុំរបស់ មាស មុត សុំប្តឹងអង្គបុរេជំនុំជម្រះឲ្យពិនិត្យ និងចាត់ការលើសំណើសុំមោឃភាពដីកាកោះឲ្យបង្ហាញខ្លួនលើកដំបូង ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៥។

មានមូលដ្ឋានដើម្បីប្ដឹងឧទ្ធរណ៍ដែរ ឬទេ ពីព្រោះថា គាត់នៅតែជាជនសង្ស័យ និងមិនមែនជាជនត្រូវចោទ ហើយពុំមានសេចក្ដីសម្រេចណាមួយត្រូវបានធ្វើឡើងឡើយ[55]។ នៅក្នុងលិខិតមួយ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៥ ចៅក្រម Harmon បានបញ្ជាក់ថា គាត់នឹងដាក់ជនសង្ស័យ *ឲ្យស្ថិត*ក្រោមការពិនិត្យ *ដោយកំបាំងមុខ* ប្រសិនបើគាត់ខកខានមិនបានបង្ហាញខ្លួន នៅមុនថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឬប្រសិនបើដីកាបង្គាប់ឲ្យនាំខ្លួនមិនត្រូវបានអនុវត្តមកត្រឹមពេលនោះទេ[56]។

26. គ្មានព្រឹត្តិការណ៍ណាមួយបានកើតឡើងឡើយ ហើយនៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ ចៅក្រម Harmon បានដាក់ **មាស មុត** ឲ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ* ពីបទរំលោភបំពានមាត្រា ៥០០ មាត្រា ៥០១ និងមាត្រា ៥០៦ នៃក្រុមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ (ការធ្វើទារុណកម្ម និងអំពើមនុស្សឃាត) ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រង់ចំណុចការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ពន្ធនាគារ ការធ្វើទុក្ខបុកម្នេញ និងអំពើអនុស្សធម៌ផ្សេងៗទៀត[57]។ បន្ទាប់ពីចេញដីកាសម្រេចនេះ ស្ថានភាពរបស់ **មាស មុត** ត្រូវបានផ្លាស់ប្ដូរពី "ជនសង្ស័យ" ទៅជា "ជនត្រូវចោទ" ហើយគាត់មានសិទ្ធិពិនិត្យសំណុំរឿង និងចូលរួមពេញលេញក្នុងកិច្ចស៊ើបអង្កេតតាមផ្លូវតុលាការ[58]។ សហមេធាវីបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចដាក់ **មាស មុត** ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*[59] និងបានជំទាស់ទៅនឹងយុត្តាធិការរបស់តុលាការលើបទចោទនានាប្រឆាំងនឹងគាត់[60]។

---

55 ឯកសារ A77/1/1/2 ការពិចារណារបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការបដិសេធរបស់សហចៅក្រមស៊ើបអង្កេត HARMON នូវពាក្យសុំរបស់ មាស មុត សុំប្ដឹងអង្គបុរេជំនុំជម្រះឲ្យពិនិត្យ និងចាត់ការលើសំណើសុំមោឃភាពដីកាកោះឲ្យបង្ហាញខ្លួនលើកដំបូង ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥ កថាខណ្ឌ២៤-២៥ ផ្នែកសេចក្ដីសម្រេច។

56 ឯកសារ D127 លិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិជូនឯកឧត្តម ឯម សំអាន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងប្រធានគណៈកម្មាធិការសន្តិសុខសម្រាប់ អវតក ថ្ងៃទី៣០ ខែ មករា ឆ្នាំ ២០១៥។

57 ឯកសារ D128 ដីកាសម្រេចដាក់ មាស មុត ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យដោយកំបាំងមុខ ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ D128.1 ឧបសម្ព័ន្ធ៖ ការជូនដំណឹងអំពីបទចោទប្រកាន់ប្រឆាំង មាស មុត ថ្ងៃទី៣ ខែ មីនា ឆ្នាំ ២០១៥។

58 ឯកសារ D128 ដីកាសម្រេចដាក់ មាស មុត ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យដោយកំបាំងមុខ កថាខណ្ឌ ៦៨, ៧២, ៧៦ ។

59 ឯកសារ D128/1/3 បណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យដោយកំបាំងមុខ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៥ [លើកឡើង

27. មួយសប្តាហ៍ក្រោយមក សហមេធាវីបានស្នើសុំ ស.ច.ស.អ ឱ្យទុកជាមោឃៈនូវដីកាបង្គាប់ឱ្យនាំខ្លួន[61] ប៉ុន្តែ ស.ច.ស.អ បានធ្វើមោឃភាពដីកាបង្គាប់ឱ្យនាំខ្លួននេះ ដោយដាក់ជំនួសដីកាបង្គាប់ឱ្យនាំខ្លួនចាស់នូវដីកាបង្គាប់ឱ្យនាំខ្លួនថ្មី ដែលបានបង្គាប់ឱ្យនគរបាលយុត្តិធម៌នាំខ្លួន **មាស មុត** មកបង្ហាញខ្លួននៅចំពោះមុខ ស.ច.ស.អ សម្រាប់សវនាការដេញដោលទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន[62]។ បន្ទាប់មក សហមេធាវីបានដាក់សំណើទៅ អ.ប.ជ សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនថ្មី ដោយរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ ស.ច.ស.អ ដាក់ **មាស មុត** ឱ្យស្ថិតក្រោមការពិនិត្យ*ដោយកំបាំងមុខ*[63]។ អ.ប.ជ ខកខានក្នុងការរកបានសំឡេងគាំទ្រភាគច្រើន ដូច្នេះដីកាបង្គាប់ឱ្យនាំខ្លួម **មាស មុត** មិនត្រូវបានអនុវត្តឡើយ[64]។

---

ថា សហចៅក្រមស៊ើបអង្កេត HARMON ធ្វើហួសអំណាចក្របខណ្ឌច្បាប់របស់ អវតក ដែល ស.ច.ស ត្រូវដឹកនាំការស៊ើបសួររួមគ្នា ហើយការបំពេញកិច្ចដោយឯកតោភាគីបានរំលោភបំពានសិទ្ធិរបស់ មាស មុត ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌]។ សូមមើលផងដែរ ឯកសារ D128/1/9 សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រមការត្រួតពិនិត្យដោយកំបាំងមុខ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ [មិនអាចរកបានសម្លេងគាំទ្របាន]។

60 ឯកសារ D128.1/1/3 បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត HARMON អំពីការចោទប្រកាន់ប្រឆាំងនឹង មាស មុត ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០១៥ [ជំទាស់នឹងយុត្តាធិការរបស់ អវតក លើការបំពារបំពានយ៉ាងធ្ងន់ធ្ងរ ឧក្រិដ្ឋកម្មជាតិ សហឧក្រិដ្ឋកម្មរួម និងការទទួលខុសត្រូវថ្នាក់លើ]។

61 ឯកសារ D130 សំណើរបស់ មាស មុត សុំឱ្យទុកជាមោឃភាពនូវដីកាបង្គាប់ឱ្យនាំខ្លួនដែលបានចេញនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០១៥។

62 ឯកសារ C2 ដីកាបង្គាប់ឱ្យនាំខ្លួន មាស មុត ថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៥។ សូមមើលផងដែរ ឯកសារ D130/3 ចម្លើយតបរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅនឹងសំណើរបស់ មាស មុត សុំឱ្យទុកជាមោឃភាពនូវដីកាបង្គាប់ឱ្យនាំខ្លួនដែលបានចេញនៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៤ ថ្ងៃទី៤ ខែ មិថុនា ឆ្នាំ ២០១៥ កថាខណ្ឌ ៤។ ឯកសារ C2.1 លិខិតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិផ្ញើជូននគរបាលយុត្តិធម៌៖ ដីកាបង្គាប់ឱ្យនាំខ្លួនថ្មីដើម្បីឱ្យអនុវត្តភ្លាមៗ ថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៥។

63 ឯកសារ C2/1 សំណើបន្ទាន់របស់មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនដែលចេញនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត HARMON ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រមការត្រួតពិនិត្យដោយកំបាំងមុខ ថ្ងៃទី ៥ ខែមិថុនា ឆ្នាំ២០១៥។ សូមមើលផងដែរឯកសារ C2/2 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនដែលចេញនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត HARMON ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឱ្យស្ថិតនៅក្រមការត្រួតពិនិត្យដោយកំបាំងមុខ ថ្ងៃទី

28. នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៥ **មាស មុត** បានបង្ហាញខ្លួននៅចំពោះមុខ ស.ច.ស.អ Bohlander និងទទួលបានការណែនាំអំពីសិទ្ធិរបស់គាត់[65]។ បន្ទាប់មក ចៅក្រម Bohlander បានចោទ **មាស មុត** ពីបទអំពើប្រល័យពូជសាសន៍ ការរំលោភបំពានមាត្រា ៥០១ និងមាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ការបំពារបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រង់ចំណុច ការសម្លាប់រង្គាល ការសម្លាប់មនុស្ស ការដាក់ពន្ធនាគារ ការធ្វើទារុណកម្ម ការធ្វើឲ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងជាតិសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការប្រព្រឹត្តិដោយអមនុស្សធម៌ ការវាយប្រហារប្រឆាំងនឹងភាពថ្លៃថ្នូរជាមនុស្ស ដោយសារលក្ខខណ្ឌនៃការឃុំខ្លួន ការបាត់ខ្លួនដោយបង្ខំ ពលកម្មដោយបង្ខំ អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ)[66]។ ចៅក្រម Bohlander បានប្រកាសថា ការចោទប្រកាន់ដែលគាត់បានលើកឡើងនៅថ្ងៃនោះ គឺជាការចោទប្រកាន់ជាក់ស្តែងប្រឆាំងនឹង **មាស មុត** ហើយបទចោទដែលបានធ្វើឡើងកន្លងមក *ដោយកំបាំងមុខ* ត្រូវបានចាត់ទុកជាមោឃៈ[67]។ គាត់ក៏បានប្រាប់ **មាស មុត** ផងដែរថា មុននឹងបញ្ចប់កិច្ចស៊ើបសួរ គាត់អាចសម្រេចចោទប្រកាន់ **មាស មុត** ចំពោះឧក្រិដ្ឋកម្មបន្ថែមផ្សេងៗទៀត ដោយផ្អែកលើបទចោទនានា នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីពីរ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

---

២២ ខែមិថុនា ឆ្នាំ ២០១៥។ ឯកសារ C2/3 ការឆ្លើយតបរបស់ មាស មុតទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួនដែលបានចេញនៅថ្ងៃទី៤ ខែ មិថុនា ឆ្នាំ ២០១៥ ដោយសហចៅក្រមស៊ើបអង្កេត HARMON ដើម្បីរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត HARMON ដែលសម្រេចដាក់ មាស មុត ឲ្យស្ថិតនៅក្រមការត្រួតពិនិត្យដោយកំបាំងមុខ ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០១៥។

64 ឯកសារ C2/4 សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះលើសំណើបន្ទាន់របស់ មាស មុត សុំផ្អាកការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន ថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០១៥ កថាខណ្ឌ ១១-១២ ផ្នែកសេចក្តីសម្រេច។

65 ឯកសារ D174 កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥។

66 ឯកសារ D174 កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង។

67 ឯកសារ D174 កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ទំព័រ ១៦។ សូមមើលផងដែរ ឯកសារ D128.1/1/11 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេត HARMON អំពីការចោទប្រកាន់ប្រឆាំងនឹង មាស មុត ថ្ងៃទី៣ ខែ កុម្ភៈ ឆ្នាំ ២០១៦។

បន្ថែម ឬដីកាសន្និដ្ឋានផ្សេងៗទៀត នាពេលអនាគតពី ក.ស.ព[68]។ ដីកាបង្គាប់ឲ្យនាំខ្លួនដែលបាន ចេញនៅថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៥ ក៏ត្រូវបានចាត់ទុកជាមោឃៈផងដែរ[69]។

29. នៅថ្ងៃ ៦ ខែ មករា ឆ្នាំ ២០១៦ សហមេធាវីបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងបទចោទ ដែលបានធ្វើឡើង ដោយចៅក្រម Bohlander[70] ប៉ុន្តែ អ.ប.ជ បានខកខានរកសំឡេងភាគច្រើនទាក់ទងនឹងភាពអាច ទទួលយកបាន[71] ហើយបទចោទត្រូវតម្កល់។

## ការចូលរួមក្នុងកិច្ចស៊ើបសួរ

30. សហមេធាវីរបស់ **មាស មុត** បានចូលរួមយ៉ាងសកម្មក្នុងកិច្ចស៊ើបសួរតាមផ្លូវតុលាការក្នុងសំណុំ រឿង ០០៣។ ឧទាហរណ៍ ពួកគេបានដាក់សំណើចំនួន ២០ សុំឲ្យ ស.ច.ស បំពេញកិច្ចស៊ើបសួរ ជាក់លាក់[72] សំណើចំនួន ៣ សុំលទ្ធផលការងាររបស់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស[73] សំណើ

---

68 ឯកសារ D174 កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ទំព័រ ១៦-១៧។

69 ឯកសារ D174 កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង ទំព័រ ១៦។

70 ឯកសារ D174/1/1 បណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អន្តរជាតិ ដែលដាក់ មាស មុត ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីអំពើបំពារបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និង ឧក្រិដ្ឋកម្មថ្នាក់ជាតិ និង ការអនុវត្តសហឧក្រិដ្ឋកម្មរួម និងទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ថ្ងៃទី ៦ ខែ មករា ឆ្នាំ២០១៦។.

71 ឯកសារ D174/1/4 សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អន្តរជាតិ ដែលដាក់ មាស មុត ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីអំពើបំពារបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ និងឧក្រិដ្ឋកម្មថ្នាក់ជាតិ និងការអនុវត្តសហឧក្រិដ្ឋកម្មរួម និងទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ ថ្ងៃទី២៧ ខែ មេសា ឆ្នាំ ២០១៦ កថាខណ្ឌ ២៤។

72 (1)៖ ឯកសារ D87/2/1.6 សំណើរបស់ មាស មុត សុំឲ្យផ្ដល់លិខិតឆ្លើយឆ្លងពីប្រធានផ្នែកច្បាប់របស់ ក.ស.ច.ស ផ្ញើជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ និងឯកសារពាក់ព័ន្ធទាំងអស់ ព្រមទាំងសុំឲ្យដាក់ឯកសារនេះចូលក្នុងសំណុំរឿង ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៣ [ស្នើសុំឲ្យផ្ដល់សំណៅមួយច្បាប់នៃលិខិតដែលមានព័ត៌មានថាបានបញ្ជូនមកពីប្រធានផ្នែកច្បាប់របស់ ក.ស.ច.ស ផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិទាក់ទងនឹងការបិទកិច្ចស៊ើបសួរសំណុំរឿង០០៣ និងឯកសារពាក់ព័ន្ធទាំងអស់ ហើយស្នើសុំដាក់ឯកសារនេះចូលក្នុងសំណុំរឿង ដើម្បីកំណត់ថាតើសុចរិតភាពនៃការស៊ើបសួរត្រូវបានប៉ះពាល់ដែរឬអត់ និងដើម្បីកំណត់ថាតើមានការជ្រៀតជ្រែកមិនត្រឹមត្រូវចូលក្នុងកិច្ចការតុលាការបានកើតឡើងដែរឬអត់]- សំណើនេះមានសេចក្ដីសម្រេច D87/2/1.6/1 ដីកាសម្រេចលើសំណើរបស់ មាស មុត សុំឲ្យផ្ដល់លិខិតឆ្លើយឆ្លងពីប្រធានផ្នែកច្បាប់របស់ ក.ស.ច.ស ផ្ញើជូនលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ និងឯកសារពាក់ព័ន្ធទាំងអស់ ថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ [បដិសេធសំណើនេះ ពីព្រោះវាពាក់ព័ន្ធនឹង

ភាពមិនលម្អៀង និងឯករាជ្យរបស់ ស.ច.ស មិនមែនពាក់ព័ន្ធនឹងភាពមិនលម្អៀង និងឯករាជ្យរបស់បុគ្គលិក ស.ច.ស ឡើយ។ លិខិតនោះ និងឯកសារពាក់ព័ន្ធដទៃទៀតមិនពាក់ព័ន្ធនឹងការស្វែងរកការពិតនៅក្នុងសំណុំរឿង០០៣]ទេ។ (2): ឯកសារ D87/2/1.8 សំណើរបស់ មាស មុត សុំឱ្យ កសចស ដាក់ប្រតិចារិតទាំងមូលនៃកំណត់ហេតុស្ដាប់ចម្លើយទាំងអស់នៅក្នុងសំណុំរឿង ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៣ [ស្នើសុំឱ្យផ្ដល់ប្រតិចារឹកទាំងមូលនៃកំណត់ហេតុស្ដាប់ចម្លើយជូនមេធាវីការពារក្ដី ហើយដាក់ចូលក្នុងសំណុំរឿង ពីព្រោះថា សេចក្ដីសង្ខេបនៃកំណត់ហេតុស្ដាប់ចម្លើយមិនអាចទុកចិត្តបាន និងត្រូវប្រើពេលវេលាច្រើនក្នុងការស្ដាប់ខ្សែអាត់ថតសម្លេង]-សំណើនេះមានសេចក្ដីសម្រេច D87/2/1.8/1 ដីកាសម្រេចលើសំណើរបស់ មាស មុត សុំឱ្យ កសចស ដាក់ប្រតិចារិតទាំងមូលនៃកំណត់ហេតុស្ដាប់ចម្លើយទាំងអស់នៅក្នុងសំណុំរឿង ថ្ងៃទី២៦ ខែមករា ឆ្នាំ ២០១៦ [បដិសេធសំណើនេះពីព្រោះ អាចកើតមានភាពខុសគ្នាមួយចំនួនរវាងខ្សែអាត់សំឡេង ជាមួយនឹងសេចក្ដីសង្ខេបនៃកំណត់ហេតុស្ដាប់ចម្លើយ តែភាពខុសគ្នាមិនបានបង្ហាញថា ភ័ស្តុតាងត្រូវបានបំភាន់ទេ ហើយក៏មិនតម្រូវឱ្យធ្វើប្រតិចារិត និងបកប្រែទាំងស្រុងចំពោះខ្សែរអាត់សំឡេងទាំងអស់នៃការស្ដាប់ចម្លើយនៅក្នុងសំណុំរឿងទេ]។ (3): ឯកសារ D87/2/1.14 សំណើរបស់ មាស មុត សុំឱ្យ កសចស សម្ភាសសាក្សីសាជាថ្មី ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៣ [ស្នើសុំឱ្យ កសចស ពិនិត្យសាក្សីទាំងអស់នៅក្នុងសំណុំរឿងសម្រេចថាតើសាក្សីណាខ្លះអាចត្រូវស្ដាប់ឡើងវិញដែរឬអត់ដោយសារមានកំហុសនៅក្នុងការស្ដាប់ចម្លើយដើម ធ្វើការស្ដាប់ចម្លើយបែបនេះឡើយវិញ ហើយដាក់ដាក់លទ្ធផលនៃការវិភាគនេះចូលសំណុំរឿង] -សំណើនេះមានសេចក្ដីសម្រេច D87/2/1.14/1 ដីកាសម្រេចលើសំណើរបស់ មាស មុត ស្នើសុំឱ្យ កសចស ស្ដាប់ចម្លើយសាក្សីឡើងវិញ ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥ [បដិសេធសំណើដោយសារមិនបានបំពេញតាមលក្ខខណ្ឌនៃភាពច្បាស់លាស់ និងលក្ខខណ្ឌនៃភាពពាក់ព័ន្ធជាបឋម តែណែនាំមេធាវីការពារក្ដី ឱ្យពិនិត្យសំណុំរឿង(ដែលនៅពេលនេះមេធាវីអាចចូលពិនិត្យមើលបាន) ហើយប្រសិនបើយល់ឃើញថាចាំបាច់ត្រូវស្ដាប់ចម្លើយសាក្សីណាម្នាក់ឡើងវិញនោះ មេធាវីការពារក្ដី ត្រូវដាក់សំណើដែលបំពេញតាមលក្ខខណ្ឌទាំងនេះ]។ (4): ឯកសារ D159 សំណើរបស់ មាស មុត សុំឱ្យអ្នកស៊ើបអង្កេត ក.ស.ច.ស ស្ដាប់ចម្លើយសាក្សីមួយចំនួនឡើងវិញ ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១៦ [ស្នើសុំឱ្យ ក.ស.ច.ស ស្ដាប់ចម្លើយសាក្សី ចំនួន ១០៤ នាក់ឡើងវិញ ថតយកសំឡេងនៃការស្ដាប់ចម្លើយ និងធ្វើកំណត់ហេតុនៃការស្ដាប់ចម្លើយទាំងនេះ ឬក៏ពិនិត្យមើលកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីដែលពាក់ព័ន្ធ ដើម្បីសម្រេចថាតើចាំបាច់ត្រូវស្ដាប់ចម្លើយឡើងវិញដែរឬអត់] -សំណើនេះមានសេចក្ដីសម្រេច D159/1 ដីកាសម្រេចលើសំណើរបស់ មាស មុត ស្នើសុំឱ្យអ្នកស៊ើបអង្កេត ក.ស.ច.ស ស្ដាប់ចម្លើយសាក្សីមួយចំនួនឡើងវិញ ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១៥ [បដិសេធសំណើ ដោយបញ្ជាក់ថា ការអនុញ្ញាតតាមសំណើសុំឱ្យថតការស្ដាប់ចម្លើយទាំងនោះនាពេលអនាគត មិនបានធ្វើឱ្យការអនុវត្តពីមុនដែលមិនបានថតការស្ដាប់ចម្លើយនោះ ខុសច្បាប់ ឬគ្មានសុពលភាពទេ ហើយប្រកាសថា មិនចាំបាច់ ពិនិត្យឡើងវិញចំពោះកំណត់ហេតុស្ដាប់ចម្លើយទាំងនោះឡើយ]។ (5): ឯកសារ D160 សំណើរបស់ មាស មុត សុំឱ្យសហចៅក្រមស៊ើបអង្កេតបង្គាប់ឱ្យបុគ្គលិកស៊ើបអង្កេតរបស់ខ្លួនយកខ្សែអាត់សំឡេង/រូបភាពនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងដាក់ខ្សែអាត់ទាំងនោះនៅក្នុងសំណុំរឿង ថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០១៥ និង ឯកសារ D160/1 សំណើរបស់ មាស មុត សុំជំនួសឧបសម្ព័ន្ធ ខ នៃសំណើរបស់ មាស មុត សុំឱ្យសហចៅក្រមស៊ើបអង្កេតបង្គាប់ឱ្យបុគ្គលិកស៊ើបអង្កេតរបស់ខ្លួនយកខ្សែអាត់សំឡេង/រូបភាពនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងដាក់ខ្សែអាត់ទាំងនោះ (D160) នៅក្នុងសំណុំរឿង ដោយឧបសម្ព័ន្ធ ខ កែប្រែ ដែលភ្ជាប់នឹងសំណើនេះ ថ្ងៃទី ២០

ខែ តុលា ឆ្នាំ ២០១៥-សំណើនេះមានសេចក្ដីសម្រេច D160/2 ដីកាសម្រេចលើសំណើរបស់ មាស មុត សុំឱ្យសហចៅក្រមស៊ើបអង្កេតបង្គាប់ឱ្យបុគ្គលិករបស់ខ្លួនយកខ្សែអាត់សំឡេង/រូបភាពនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងដាក់ខ្សែអាត់ទាំងនោះនៅក្នុងសំណុំរឿង ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០១៥ [អនុញ្ញាតតាមសំណើរបស់មេធាវីការពារក្ដី សុំដាក់ដាក់ខ្សែអាត់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាចូលក្នុងសំណុំរឿង ដោយផ្ដល់អាទិភាពលើកិច្ចសម្ភាសន៍ដែលបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ខ កែប្រែ]។ (6): ឯកសារ D162 សំណើរបស់ មាស មុត សុំឱ្យស្ដាប់ឡើងវិញនៅក្នុងឯកសារ D114/128 និងឯកសារ D114/129 ដោយថតយកសំឡេង និងសុំដាក់ខ្សែអាត់សំឡេងនៃការស្ដាប់ចម្លើយសាក្សី D114/130 នៅក្នុងសំណុំរឿង ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១៥ [ស្នើសុំឱ្យស្ដាប់ចម្លើយឡើងវិញចំនួនពីរ ថតការស្ដាប់ចម្លើយទាំងនោះ ហើយដាក់ខ្សែអាត់សំឡេងនៃការស្ដាប់ចម្លើយទាំងនោះចូលក្នុងសំណុំរឿង ពីព្រោះថា ការស្ដាប់ចម្លើយទាំងនោះមិនបានអនុវត្តតាមនិតិវិធីថ្មីដែលកំណត់ឡើងដោយសហចៅក្រមស៊ើបអង្កេតក្នុងការថតការស្ដាប់ចម្លើយ ហើយក៏ស្នើផងដែរថាខ្សែអាត់សំឡេងនៃការស្ដាប់ចម្លើយមួយទៀតគួរដាក់បន្ថែមចូលក្នុងសំណុំរឿង] -សំណើនេះមានសេចក្ដីសម្រេច D162/1 ដីកាសម្រេចលើសំណើរបស់ មាស មុត សុំស្ដាប់ចម្លើយសាក្សីទាក់ឡើងវិញដោយយកសំឡេង ហើយដាក់ខ្សែអាត់សំឡេងនៃឯកសារ D114/130 ចូលក្នុងសំណុំរឿង ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៦ [សំណើត្រូវបានបដិសេធមួយផ្នែក ដោយសារអ្នកស៊ើបអង្កេតកំពុងតែចុះបេសកម្មនៅពេលចេញសេចក្ដីណែនាំ ហើយអ្នកស៊ើបអង្កេតគ្មានលទ្ធភាពប្រើប្រាស់ឧបករណ៍ថតសំឡេង ហើយបដិសេធផ្នែកផ្សេងទៀតទាំងអស់នៃសំណើ ថាអស់សុពលភាព ដោយសារខ្សែអាត់សំឡេងបានដាក់ក្នុងសំណុំរឿងបន្ទាប់ពីសំណើនេះដាក់មក]។ (7): ឯកសារ D170 សំណើរបស់ មាស មុត សុំឱ្យយក និងដាក់ក្នុងសំណុំរឿងនូវសម្ភារៈឯកសាររបស់អង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការបង្កើត អវតក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ [ស្នើសុំសហចៅក្រមស៊ើបអង្កេត ទទួលឱ្យបាន ហើយដាក់ចូលក្នុងសំណុំរឿងនូវឯកសារបណ្ណសាររបស់អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការចរចាបង្កើត អវតក និងការធ្វើសេចក្ដីព្រាងច្បាប់ស្ដីពីការបង្កើត អវតក] -សំណើនេះមានសេចក្ដីសម្រេច D181/1 សេចក្ដីជូនដំណឹងអំពីការព្យាយាមមិនបានសម្រេចទទួលយកបានឯកសារបណ្ណសារសម្ងាត់បំផុតរបស់អង្គការសហប្រជាជាតិ ថ្ងៃទី៣ ខែឧសភា ឆ្នាំ ២០១៦ [ជូនដំណឹងថា ការព្យាយាមមិនបានសម្រេចមិនអាចបានឯកសារបណ្ណសារសម្ងាត់បំផុតរបស់អង្គការសហប្រជាជាតិទេ ពីព្រោះឯកសារទាំងនោះត្រូវបានចាត់ទុកថាជាឯកសាររសើបដែលមិនអាចបង្ហាញជូនបាន និងឯកសារ D181/2 សេចក្ដីជូនដំណឹងអំពីការដាក់បញ្ចូលទៅក្នុងសំណុំរឿងនូវឯកសារដែលទាក់ទងនឹងការបង្កើត អវតក ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៦ [ដាក់ចូលក្នុងសំណុំរឿងនូវឯកសារចំនួន ៣៤ ឯកសារ ដែលយោងលើគោលបំណងវិសាលភាពយុត្តាធិការរបស់ អវតក]។ (8): ឯកសារ D177 សំណើរបស់ មាស មុត សុំឱ្យសហចៅក្រមស៊ើបអង្កេតចុះពិនិត្យដល់ទីតាំង ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១៥ [ស្នើសុំចុះពិនិត្យដល់ទីតាំងឧក្រិដ្ឋកម្មទាំងអស់ដែលបានចោទ ដោយមានវត្តមានរបស់ភាគី និងសាក្សីដែលពាក់ព័ន្ធ]- -សំណើនេះមានសេចក្ដីសម្រេច ឯកសារ D177/1 ដីកាសម្រេចលើសំណើរបស់ មាស មុត សុំឱ្យសហចៅក្រមស៊ើបអង្កេតចុះពិនិត្យដល់ទីតាំង ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ [បដិសេធសំណើដោយសារសំណើខ្វះភាពច្បាស់លាស់ និងយល់ខុសថាគោលបំណងនៃការចុះពិនិត្យដល់ទីតាំងគឺជាមធ្យោបាយស៊ើបអង្កេត]។ (9): ឯកសារ D192 ស្នើសុំឱ្យបង្គាប់អ្នកស៊ើបអង្កេតនៃ កសចស ផ្ដល់លេខឯកសារទាំងអស់ដែលត្រូវបានបង្ហាញទៅសាក្សី និង ដើមបណ្ដឹងរដ្ឋប្បវេណី និងភ្ជាប់ទៅនឹងកំណត់ហេតុនៃការស្ដាប់ចម្លើយនូវឯកសារណាដែលមិនទាន់មាននៅក្នុងសំណុំរឿង ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦-

សំណើនេះមានសេចក្តីសម្រេច D192/1 ដីកាសម្រេចលើសំណើរបស់ក្រុមមេធាវីការពារក្តី មាស មុត ពាក់ព័ន្ធនឹងឯកសារដែលបានបង្ហាញដល់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៦ [អនុញ្ញាតតាមសំណើមួយផ្នែក ដោយបានបញ្ជាក់ពីកំណត់ហេតុស្តាប់ចម្លើយចំនួនបួនដូចដែលមេធាវីការពារក្តីបានបញ្ជាក់ តែបដិសេធសំណើសុំពិនិត្យសំណុំរឿងទាំងមូលឡើងវិញចំពោះករណីមិនមានការលើកយោងឯកសារ]។ (10): ឯកសារ D191/16 ស្នើសុំឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត យកការបកប្រែជាភាសាអង់គ្លេសនៃសេចក្តីសម្រេចចំនួនបី ជាភាសាអាល្លឺម៉ង់ពីតុលាការកំពូលនៃតំបន់គ្រប់គ្រងដោយអង់គ្លេស និងសេចក្តីសម្រេចមួយជាភាសាហូឡង់ពីតុលាការកំពូលពិសេស ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦ [ស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតទទួលឲ្យបាននូវការបកប្រែត្រឹមត្រូវជាភាសាអង់គ្លេសនៃសេចក្តីសម្រេចរឿងក្តីចំនួនបួនដែលបានចេញនៅឆ្នាំ ១៩៤៨ និងឆ្នាំ១៩៤៩ ដើម្បីឲ្យមេធាវីការពារក្តីអាចឆ្លើយតបទៅនឹងសារណារបស់អ្នកដែលមិនមែនជាភាគី] -សំណើនេះមានសេចក្តីសម្រេច D191/16/1 ដីកាសម្រេចលើសំណើទទួលបានការបកប្រែជាភាសាអង់គ្លេសនៃសេចក្តីសម្រេចចំនួនបីជាភាសាអាល្លឺម៉ង់ និងសេចក្តីសម្រេចមួយជាភាសាហូឡង់ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ [បដិសេធសំណើ និងណែនាំមេធាវីការពារក្តីគួរតែប្រើប្រាស់ថវិកាដែលខ្លួនអាចចំណាយ ដើម្បីទទួលបានការបកប្រែឯកសារដែលបានបង្ហាញនៅក្នុងសំណើ]។ (11): ឯកសារ D206 សំណើរបស់ មាស មុត សុំឲ្យផ្តល់នូវឈ្មោះ និងរហស្សនាមនៃសាក្សីរឿងក្តី ០០២ ទាំងអស់ដែលត្រូវបានស្តាប់ចម្លើយដោយ កសចស ក្នុងរឿងក្តី០០៣ ថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០១៦ [ស្នើសុំសហច្រៅមស៊ើបអង្កេតឲ្យផ្តល់នូវបញ្ជីឈ្មោះ និងរហស្សនាមរបស់សាក្សីទាំងអស់ដែលបានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២ ហើយផ្តល់ភស្តុតាងនៅក្នុងសំណុំរឿង០០៣ផងដែរ] -សំណើនេះមានសេចក្តីសម្រេច D206/1 ដីកាសម្រេចលើសំណើសុំឈ្មោះ និងរហស្សនាមរបស់សាក្សីនៃសំណុំរឿង ០០២ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៦ [អនុញ្ញាតតាមសំណើ]។ (12): ឯកសារ D215 សំណើរបស់ មាស មុត សុំឲ្យផ្តល់នូវនូវបញ្ជីឈ្មោះ និងរហស្សនាមដែលមានបច្ចុប្បន្នភាពនៃសាក្សីរឿងក្តី ០០២ ទាំងអស់ដែលត្រូវបានស្តាប់ចម្លើយដោយ កសចស ក្នុងរឿងក្តី០០៣ ថ្ងៃទី ០០៣ ខែ វិច្ឆិកា ឆ្នាំ២០១៦-សំណើនេះមានសេចក្តីសម្រេច D215/1 ដីកាសម្រេចលើសំណើរបស់ មាស មុត សុំបច្ចុប្បន្នភាពបញ្ជីឈ្មោះ និងរហស្សនាមរបស់សាក្សីសំណុំរឿង០០២ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ [អនុញ្ញាតតាមសំណើ]។ (13): ឯកសារ D216 សំណើរបស់ មាស មុត សុំឲ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងដែលបាត់ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ [ស្នើសុំដាក់របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងដែលបានបាត់នៅក្នុងសំណុំរឿង ជាពិសេសកន្លែងមូលដ្ឋានកងទ័ពជើងទឹកនៅរាម និងតំបន់ជុំវិញ ចំការធូរេន ឆ្នេរអូរឈើទាល និងរោងកុននៅព្រះសីហនុឬក៏ ស្នើឲ្យសហចៅក្រមស៊ើបអង្កេតពន្យល់អំពីមូលហេតុដែលរបាយការណ៍នេះមិនអាចបានដាក់ក្នុងសំណុំរឿង ហើយស្នើសុំដាក់ចូលសំណុំរឿងនូវកំណត់សម្គាល់ណាមួយរបស់សមាជិកក្រុមស៊ើបអង្កេត]- សំណើនេះមានសេចក្តីសម្រេច D216/1 ដីកាសម្រេចលើសំណើរបស់ មាស មុត ពាក់ព័ន្ធនឹងរបាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងដែលបាត់ ថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១៦ [ជូនដំណឹងថា កិច្ចដែលបានស្នើសុំត្រូវបានបំពេញរួចហើយ]។ (14): ឯកសារ D227 សំណើរបស់ មាស មុត សុំឲ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងឯកសារ D114/174, D114/184 និងការស្តាប់ចម្លើយសាក្សីដែលពាក់ព័ន្ធ និងការប្រើប្រាស់ជាសក្ខានុភូតនៃភស្តុតាងដែលទទួលបានតាមរយៈទារុណកម្ម ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៧ [ស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេត ស៊ើបសួរកាលៈទេសៈដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបានចាប់អារម្មណ៍សាក្សីបួននាក់ ជាពិសេស ថាតើបានស្គាល់ពួកគាត់ដោយសារពួកគាត់មានឈ្មោះនៅក្នុង

ប្រវត្តិរូបនៅមន្ទីរ ស ២១ ដែលធ្វើឡើងដោយកម្មាភិបាលមកពីក្រចេះដែលគេអះអាងថាត្រូវបានបោសសម្អាត ដូច្នេះជាភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម]-សំណើនេះមានសេចក្តីសម្រេច ឯកសារ D251 សេចក្តីសម្រេចរួមលើសំណើរបស់ មាស មុត សុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងការប្រើប្រាស់ជាសក្តានុភូតនៃភស្តុតាងដែលទទួលបានតាមរយៈទារុណកម្ម ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០១៧ [សម្រេចថា ការហាមដាច់ខាតមិនឱ្យប្រើប្រាស់ជាភស្តុតាងនូវចម្លើយដែលទទួលបានតាមរយៈការធ្វើទារុណកម្ម គឺមិនអាចឱ្យសហចៅក្រមស៊ើបអង្កេតប្រើប្រាស់ខ្លឹមសារនៃចម្លើយសារភាពពីមន្ទីរស២១ ជាតម្រុយស៊ើបអង្កេតនោះទេ។ កំណត់ហេតុស្តាប់ចម្លើយចំនួនបីក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយសាក្សីនោះមិនមានបញ្ហាទេ តែកំណត់ហេតុស្តាប់ចម្លើយមួយមិនមែនជា"ព័ត៌មានសត្យានុម័ត"ទេ ហើយអាចស្ថិតក្នុងការសន្មតជាមុនថាមានការធ្វើទារុណកម្ម និងមិនអាចជឿទុកចិត្តបាន] (15): ឯកសារ D229 សំណើរបស់ មាស មុត សុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងទំនាក់ទំនងជាមួយសាក្សីដោយមិនមានកំណត់ត្រា និងសំណើសុំឱ្យពិនិត្យកែប្រែកំណត់ហេតុ ស្តាប់ចម្លើយសាក្សី ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៧ [ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតស៊ើបសួរហេតុការណ៍មួយដែលអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតអាចធ្វើឱ្យមានឥទ្ធិពលលើសក្ខីកម្មសាក្សី និងស្នើសុំឱ្យពិនិត្យកែប្រែកំណត់ហេតុស្តាប់ចម្លើយសាក្សីនោះ ដើម្បីឆ្លុះបញ្ចាំងពីសក្ខីកម្មសាក្សីនោះឱ្យបានកាន់តែល្អ]-សំណើនេះមានសេចក្តីសម្រេច D251 ដីកាសម្រេចរួមលើសំណើរបស់ មាស មុត សុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងការប្រើប្រាស់ជាសក្តានុពលនៃភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១៧ [ឆ្លើយសំណួរជាក់លាក់របស់មេធាវីការពារក្តី ហើយបដិសេធសំណើឱ្យពិនិត្យកែប្រែកំណត់ហេតុស្តាប់ចម្លើយសាក្សីនោះ ពីព្រោះ មាស មុត មិនបានទទួលរងផលប៉ះពាល់ជាក់ស្តែងណាមួយដោយសារភាពខុសគ្នានោះឡើយ]។ (16): ឯកសារ D232 សំណើរបស់ មាស មុត សុំឱ្យផ្តល់លេខឯកសារមួយចំនួនដែលអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានបង្ហាញដល់សាក្សី ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ [ស្នើសុំលេខឯកសារដែលបានលើកយោងនៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន ១៣ ]-សំណើនេះមានសេចក្តីសម្រេច D232/1 ដីកាសម្រេចរួមលើសំណើរបស់ មាស មុត សុំផ្តល់លេខនៃឯកសារមួយចំនួនដែលអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានបង្ហាញដល់សាក្សី ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៧ [អនុញ្ញាតតាមសំណើ និងដាក់ឯកសារដែលបានលើកយោងចូលក្នុងសំណុំរឿង]។ (17): ឯកសារ D237 សំណើរបស់ មាស មុត សុំឱ្យកែតម្រូវ និងដាក់បន្ថែមក្នុងឯកសារសំណុំរឿងមួយចំនួន ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៧ [ស្នើសុំសហចៅក្រមស៊ើបអង្កេតដាក់បន្ថែម និងកែតម្រូវឯកសារសំណុំរឿងមួយចំនួន]-សំណើនេះមានសេចក្តីសម្រេច D237/1 ដីកាសម្រេចរួមលើសំណើរបស់ មាស មុត សុំដាក់បន្ថែម និងកែតម្រូវឯកសារសំណុំរឿងមួយចំនួន ថ្ងៃទី១៧ ខែ មេសា ឆ្នាំ២០១៧ [ដាក់បន្ថែមចូលក្នុងសំណុំរឿងនូវកំណត់ហេតុនៃការស្តាប់ចម្លើយចំនួនពីរនៅក្នុងសំណុំរឿង ០០៤ ដោះស្រាយភាពខុសគ្នាដែលបានបង្ហាញនៅក្នុងសំណៅបកប្រែនៃឯកសារ D1.3.30.2 បដិសេធសំណើសុំកែតម្រូវការលើកយោងមិនត្រឹមត្រូវនៅក្នុងឯកសារ D114/189 និងកែសម្រួលភាពមិនត្រឹមត្រូវនៅក្នុងសំណៅបកប្រែនៃឯកសារ D114/216]។ (18): ឯកសារD247 សំណើរបស់ មាស មុត សុំឱ្យធ្វើបច្ចុប្បន្នភាពសំណុំរឿងទាក់ទងនឹងសំណៅកែប្រែនៃអត្ថបទប្រតិចារឹករឿងក្តី ០០២ ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៧ [ស្នើសុំសហចៅក្រមស៊ើបអង្កេតធ្វើបច្ចុប្បន្នភាពអត្ថបទប្រតិចារឹករឿងក្តី ០០២ ដែលមាននៅក្នុងសំណុំរឿង០០៣ នៅពេលណាដែលសំណៅកែប្រែបានដាក់ចូលក្នុងសំណុំរឿង០០២]- សំណើនេះមានសេចក្តីសម្រេច D255 អនុស្សរណៈផ្ញើជូនភាគី កម្មវត្ថុ៖ ការកែប្រែចអត្ថបទប្រតិចារឹកក្នុងរឿងក្តី០០២ ថ្ងៃទី១៨ ខែ ក

កក្កដា ឆ្នាំ ២០១៧ [ដាក់ប្រតិចារឹកថ្មីដែលបានកែប្រែ ជំនួសប្រតិចារឹកសំណុំរឿង ០០២ ទាំងអស់ដែលមាននៅក្នុងសំណុំរឿង០០៣]។ (19): ឯកសារ D254 សំណើរបស់ មាស មុត សុំដាក់ខ្សែអាត់សំឡេងដែលពាក់ព័ន្ធនឹងកំណត់ហេតុនៃការស្ដាប់ចម្លើយ D114/301, D114/302, D114/303, និង D114/304 ទៅក្នុងសំណុំរឿង ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៧ [ស្នើសុំសហចៅក្រមស៊ើបអង្កេតដាក់ចូលក្នុងសំណុំរឿងនូវខ្សែអាត់សំឡេងនៃកំណត់ហេតុស្ដាប់ចម្លើយដែលបានបង្ហាញ ឬក៏ពន្យល់អំពីមូលហេតុដែលពុំមានការថតយកសំឡេង]-សំណើនេះមានសេចក្ដីសម្រេច D254/1 ដីកាសម្រេចលើសំណើរបស់ មាស មុត សុំដាក់ខ្សែអាត់សំឡេងដែលពាក់ព័ន្ធនឹងកំណត់ហេតុនៃការស្ដាប់ចម្លើយចំនួនបួន ចូលក្នុងសំណុំរឿង ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០៩១៧ [ជូនដំណឹងមេធាវីការពារក្ដីថា ខ្សែអាត់សំឡេងនៃការស្ដាប់ចម្លើយមាននៅក្នុងសំណុំរឿងហើយ]។ (20): ឯកសារ D260 សំណើរបស់ មាស មុត សុំដាក់ដីកាដំណោះស្រាយរឿងក្ដី ០០៤/០១ ដែលមិនមានការកោសលុប ទៅក្នុងសំណុំរឿង ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៧-សំណើនេះមានសេចក្ដីសម្រេច D260/1 ដីកាសម្រេចដាក់ដាក់ដីកាដំណោះស្រាយរឿងក្ដី ០០៤/០១ (សំអាងហេតុ) ទៅក្នុងសំណុំរឿង០០៣ ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៧។

73 (1): ឯកសារ D87/2/1.9 សំណើរបស់ មាស មុត សុំលទ្ធផលការងាររបស់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ដែកពាក់ព័ន្ធនឹងទម្លាប់អនុវត្តន៍កិច្ចស៊ើបសួរមិនត្រឹមត្រូវក្នុងសំណុំរឿង០០២ ថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១៣ [ស្នើសុំលទ្ធផលការងាររបស់អ្នកស៊ើបអង្កេត ក.ស.ច.ស ចំនួន ប្រាំនាក់ ដើម្បីសម្រេចថាតើចាំបាច់ដាក់ពាក្យសុំមោឃភាព ដែរឬអត់]-សំណើនេះមានសេចក្ដីសម្រេច D87/2/1.9/1 ដីកាសម្រេចលើសំណើរបស់ មាស មុត សុំលទ្ធផលការងាររបស់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស នៅក្នុងសំណុំរឿង ០០២ ថ្ងៃទី១៥ ខែតុលា ឆ្នាំ ២០១៥ [បដិសេធសំណើពីព្រោះថា ភាពខុសគ្នានៅក្នុងសំណុំរឿង០០២ មិនគាំទ្រសេចក្ដីសន្និដ្ឋានដែលថា ភាពខុសគ្នាបែបនេះមិនអាចចៀសរួចបានទេនៅក្នុងសំណុំរឿង០០៣ ហើយសិទ្ធិពិគ្រោះយោបល់ជាមួយសំណុំរឿង មិនឈានដល់សិទ្ធិទទួលបានលទ្ធផលការងារផ្ទៃក្នុងរបស់ ក.ស.ច.ស ដែលមានលក្ខណៈសម្ងាត់បំផុតឡើយ]។ (2): ឯកសារ D87/2/1.4 សេចក្ដីជូនដំណឹងរបស់ មាស មុត ពីការជំទាស់ទៅនឹងការចូលរួមពាក់ព័ន្ធបន្ថែមទៀតរបស់លោក Stephen Heder នៅក្នុងសំណុំរឿង ០០៣ និងសំណើសុំលទ្ធផលការងាររបស់ Stephen Heder ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១៣ [ជំទាស់ទៅនឹងការចូលរួមពាក់ព័ន្ធបន្ថែមទៀតរបស់លោក Stephen Heder នៅក្នុងសំណុំរឿង ០០៣ ដោយចោទថា Stephen Heder ក្នុងនាមជាអតីតបុគ្គលិកនៅការិយាល័យសហព្រះរាជអាជ្ញា គឺមានភាពលម្អៀង ហើយការចូលរួមពាក់ព័ន្ធបន្ថែមទៀតរបស់គាត់នឹងប៉ះពាល់ដល់កិច្ចស៊ើបសួរ ហើយក៏ស្នើសុំលទ្ធផលការងាររបស់គាត់ ដើម្បីសម្រេចថាតើអាចចាំបាច់ត្រូវដាក់ពាក្យសុំមោឃភាពណាមួយ]- សំណើនេះមានសេចក្ដីសម្រេ D164 ដីកាសម្រេចរួមលើការជំទាស់ទៅនឹងការចូលរួមពាក់ព័ន្ធបន្ថែមទៀតរបស់លោក Stephen Heder និងលោក David Boyle ក្នុងសំណុំរឿង ០០៣ និងសំណើសុំលទ្ធផលការងាររបស់ពួកគាត់ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៥ [បដិសេធសំណើ ពីព្រោះ ស.ច.ស គឺជាអ្នកមានសិទ្ធិអំណាច និងការទទួលខុសត្រូវផ្ដាច់មុខលើការបំពេញកិច្ចស៊ើបសួរ និងសម្រេចលើអ្វីដែលជាទម្ងន់ភ័ស្ដុតាង និងមតិយោបល់]។ (3): ឯកសារ D87/2/1.5 សេចក្ដីជូនដំណឹងរបស់ មាស មុត ស្ដីពីការបដិសេធមិនឲ្យលោក DAVID BOYLE ជាប់ពាក់ព័ន្ធនៅក្នុងសំណុំរឿង ០០៣ បន្តទៅទៀត និងសំណើសុំឲ្យបង្ហាញលទ្ធផលការងារកន្លងមករបស់ DAVID BOYLE ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០១៣ [ចោទថាលោក BOYLE អតីតអ្នកប្រឹក្សាផ្នែកច្បាប់នៅ ក.ស.ច.ស មានភាពលម្អៀង ហើយការចូលរួមពាក់ព័ន្ធណាមួយរបស់គាត់នឹងប៉ះពាល់ដល់ការស៊ើបអង្កេតរបស់ កស

ចំនួន ៤ សុំបញ្ជាក់បំភ្លឺ ឬផ្លាស់ប្តូរបច្ចេកទេសស៊ើបសួរ ដែលកំពុងប្រើប្រាស់ដោយអ្នកស៊ើបអង្កេត[74] ពាក្យសុំប្តឹងចំនួន ១៣ ទៅ អ.ប.ជ ស្នើសុំធ្វើមោឃភាពផ្នែកខ្លះនៃកិច្ចស៊ើបសួរ[75] និងសំណើជាច្រើនទៀតសុំកែតម្រូវ ឬបញ្ជាក់បំភ្លឺឯកសារ ដែលបានដាក់រួចហើយក្នុងសំណុំរឿង[76]។

---

ចស និងស្នើសុំឱ្យបង្ហាញលទ្ធផលការងាររបស់គាត់ដើម្បីកំណត់អំពីថាតើអាចចាំបាច់ត្រូវដាក់ពាក្យសុំធ្វើមោឃភាពណាមួយ] និង ឯកសារ D87/2/1.5.1 សេចក្តីជូនដំណឹងជាថ្មីរបស់ មាស មុត ស្តីពីការជំទាស់ទៅនឹងការចូលរួមពាក់ព័ន្ធបន្ថែមទៀតរបស់លោក David Boyle ក្នុងសំណុំរឿង ០០៣ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៥-សំណើទាំងនេះមានសេចក្តីសម្រេច D164 ដីកាសម្រេចរួមលើការជំទាស់ទៅនឹងការចូលរួមពាក់ព័ន្ធបន្ថែមទៀតរបស់លោក Stephen Heder និងលោក David Boyle ក្នុងសំណុំរឿង ០០៣ និងសំណើសុំលទ្ធផលការងាររបស់ពួកគាត់ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៥ [បដិសេធសំណើ ពីព្រោះ ស.ច.ស គឺជាអ្នកមានសិទ្ធិអំណាច និងការទទួលខុសត្រូវផ្តាច់មុខលើការបំពេញកិច្ចស៊ើបសួរ និងសម្រេចលើអ្វីដែលជាទម្ងន់ភស្តុតាង និងមតិយោបល់ មិនមែនបុគ្គលិករបស់ ស.ច.ស ទេ]។

74 (1): ឯកសារ D87/2/1.3 សំណើរបស់ មាស មុត ស្នើសុំព័ត៌មានស្តីពីវិធីសាស្ត្រ និងមធ្យោបាយក្នុងការស៊ើបអង្កេតរបស់ ការិយាល័យសហចៅក្រមស៊ើបអង្កេត ថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១៣ [ស្នើសុំព័ត៌មានផ្សេងៗ រួមមានព័ត៌មានអំពីការរៀបចំ ផែនការ និងវិធីសាស្ត្ររួមរបស់ ស.ច.ស ក្នុងការអនុវត្តការស៊ើបសួរតាមផ្លូវតុលាការ គុណវុឌ្ឍិ និងបទពិសោធន៍របស់អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ព័ត៌មានថាតើ ក.ស.ច.ស មាន បទដ្ឋានការងារដែរឬអត់នៅ]-សំណើនេះមានសេចក្តីសម្រេចដោយ D87/2/1.3/1 ដីកាសម្រេចលើសំណើរបស់ មាស មុត សុំព័ត៌មានទាក់ទងនឹងយុទ្ធសាស្ត្រ និងវិធីសាស្ត្រស៊ើបអង្កេតរបស់ ក.ស.ច.ស ថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៥ [សម្រេចថា សំណើមិនអាចទទួលយកទេ]។ (2): ឯកសារ D136 សំណើរបស់ មាស មុត សុំឱ្យសហចៅក្រមស៊ើបអង្កេតបង្គាប់ឱ្យអ្នកស៊ើបអង្កេតនៅ ក.ស.ច.ស ថតយកសំឡេង ឬរូបភាពនូវរាល់ការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១៥ [ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបង្គាប់ឱ្យអ្នកស៊ើបអង្កេតនៅ ក.ស.ច.ស ថតយកសំឡេង ឬ រូបភាពនូវរាល់ការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ មិនថាកំណត់ហេតុនៃការស្តាប់ចម្លើយបានធ្វើ ឬក៏អត់នោះទេ]-សំណើនេះមានសេចក្តីសម្រេច D136/1 ដីកាសម្រេចលើសំណើរបស់ មាស មុត សុំថតយកសំឡេង ឬរូបភាពនូវរាល់ការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ [បដិសេធសំណើមួយផ្នែកថាលែងមានសុពលភាព ដោយហេតុថា សេចក្តីណែនាំបានចេញរួចហើយ ដែលតម្រូវឱ្យអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ថតយកសំឡេងការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ (សូមមើល ឯកសារ D154) ហើយបដិសេធសំណើត្រង់ចំណុចដែលស្នើថតសំឡេង ឬរូបភាពនៅដំណាក់កាលសម្រិតសម្រាំង]។ (3): ឯកសារ D194 សំណើរបស់ មាស មុត សុំឱ្យសហចៅក្រមស៊ើបអង្កេតពិនិត្យមើលបច្ចេកទេសស៊ើបអង្កេតដែលប្រើប្រាស់ដោយអ្នកស៊ើបអង្កេតមួយចំនួននៃ ក.ស.ច.ស និងអនុវត្តបែបបទត្រឹមត្រូវ ដើម្បីធានាបានថា ភស្តុតាងដែលផ្តល់ដោយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានធ្វើខូចដោយសារបច្ចេកទេសមិនត្រឹមត្រូវ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៦ [ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតពិនិត្យមើលបច្ចេកទេសស៊ើបអង្កេត"ដែលមានបញ្ហា" និងស្នើសុំឱ្យដាក់ប្រវត្តិការងាររបស់អ្នកស៊ើបអង្កេតទាំងអស់របស់ ក.ស.ច.ស ចូលក្នុងសំណុំរឿង]-សំណើនេះមានសេចក្តីសម្រេច D219 ដីកាសម្រេចរួមលើសំណើរបស់ មាស មុត ទាក់ទងនឹងសំណើសួរសាក្សី ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៦

[ច្រានចោលការអះអាងរបស់មេធាវីការពារក្តីដែលថា អ្នកស៊ើបអង្កេត ក.ស.ច.ស ប្រើប្រាស់បច្ចេកទេសមិនត្រឹមត្រូវក្នុងការសាកសួរសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ហើយបដិសេធសំណើសុំដាក់ប្រវត្តិការងាររបស់អ្នកស៊ើបអង្កេតទាំងអស់ ចូលក្នុងសំណុំរឿង]។ (4): ឯកសារ D197 សំណើរបស់ មាស មុត ទាក់ទងនឹងការប្រើប្រាស់សំណួរនាំមុខនៅក្នុងការស្តាប់ចម្លើយ និងតម្លៃភស្តុតាងដែលទទួលបានតាមរយៈសំណួរបែបនេះ ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ២០១៦ [ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកាបង្គាប់ឱ្យបញ្ឈប់ទម្លាប់ប្រើប្រាស់សំណួរនាំមុខនៅក្នុងស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី បណ្តុះបណ្តាលអ្នកស៊ើបអង្កេតរបស់ខ្លួនឱ្យចៀសវាងសួរសំណួរណាមួយដែលអាចធ្វើឱ្យខូចចម្លើយរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ហើយឱ្យតម្លៃ តិចតួច ឬក៏មិនឱ្យតម្លៃសោះដល់ភស្តុតាងដែលទទួលបានតាមរយៈសំណួរនាំមុខ]-សំណើនេះមានសេចក្តីសម្រេច D219 ដីកាសម្រេចរួមលើសំណើរបស់ មាស មុត ទាក់ទងនឹងសំណើសួរសាក្សី ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៦ [បដិសេធសំណើ ដោយសារគ្មានការហាមឃាត់មិនឱ្យប្រើប្រាស់សំណួរនាំមុខ ហើយមានពេលដែលចាំបាច់ត្រូវសួរសំណួរនាំមុខ]។

75 (1): ឯកសារ D103/1.6 ពាក្យសុំរបស់ មាស មុត ស្នើសុំឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើឃុំមោឃភាពកិច្ចស៊ើបសួរទាំងអស់ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មចំនួនពីរដែលរងការចោទប្រកាន់ ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១៤ [ពាក់ព័ន្ធនឹងចំការធ្វូរេននៅឃុំរាម និងការដ្ឋានបិតត្រាងនៅឃុំបិតត្រាង]- ពាក្យសុំនេះមានសេចក្តីសម្រេច D134 ដីកាសម្រេចលើពាក្យសុំរបស់ មាស មុត ស្នើសុំឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៥ [បដិសេធពាក្យសុំ]។ (2): ឯកសារ D103/1.7 ពាក្យសុំរបស់ មាស មុត ស្នើសុំឱ្យអង្គបុរេជំនុំជម្រះ ទទួលពិនិត្យ និងចាត់ការលើសំណើឃុំមោឃភាពកិច្ចស៊ើបសួរទាំងអស់ដែលពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញខាងសាសនា ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៤-ពាក្យសុំនេះមានសេចក្តី D134 ដីកាសម្រេចលើពាក្យសុំរបស់ មាស មុត ស្នើសុំឱ្យអង្គបុរេជំនុំជម្រះទទួលពិនិត្យ និងចាត់ការលើសំណើចំនួនពីរសុំមោឃភាពកិច្ចស៊ើបសួរ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៥ [បដិសេធពាក្យសុំ]។ (3): ឯកសារ D137 ពាក្យសុំរបស់ មាស មុត ឱ្យប្តឹងអង្គបុរេជំនុំជម្រះអំពីសំណើឃុំមោឃភាពកិច្ចស៊ើបសួរ និងការចោទប្រកាន់ទាំងអស់ទាក់ទងនឹងការបោសសម្អាតដែលរងការចោទប្រកាន់នៅក្នុងខេត្តក្រចេះ (តំបន់៥០៥) នៅចុងឆ្នាំ១៩៧៨ ថ្ងៃទី២១ ខែ ឧសភា ឆ្នាំ ២០១៥-ពាក្យសុំនេះមានសេចក្តីសម្រេច D165 ដីកាសម្រេចលើពាក្យសុំចំនួន ៩ របស់ មាស មុតឱ្យប្តឹងអង្គបុរេជំនុំជម្រះអំពីសំណើឃុំមោឃភាពកិច្ចស៊ើបសួរ អនុលោមតាមវិធានផ្ទៃក្នុង ៧៦(២) ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ២០១៥ ("ដីកាសម្រេចលើសំណើចំនួន៩") [អនុញ្ញាតតាមពាក្យសុំ]។ (4): ឯកសារ D138 ពាក្យសុំរបស់ មាស មុត ឱ្យប្តឹងអង្គបុរេជំនុំជម្រះអំពីសំណើឃុំមោឃភាពកិច្ចស៊ើបសួរទាំងអស់ទាក់ទងនឹងទឹកសាប ថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១៥-ពាក្យសុំនេះមានសេចក្តីសម្រេច D165 ដីកាសម្រេចលើសំណើចំនួន៩ [បដិសេធពាក្យសុំ]។ (5): ឯកសារ D139 ពាក្យសុំរបស់ មាស មុត ឱ្យប្តឹងអង្គបុរេជំនុំជម្រះអំពីសំណើឃុំមោឃភាពកិច្ចស៊ើបសួរដែលទាក់ទងនឹងការដ្ឋានពលកម្មដោយបង្ខំ និងមន្ទីរកែប្រែកងកេង ដែលរងការចោទប្រកាន់ ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៥-ពាក្យសុំនេះមានសេចក្តីសម្រេច D165 ដីកាសម្រេចលើសំណើចំនួន៩ [បដិសេធពាក្យសុំ]។ (6): ឯកសារ D140 ពាក្យសុំរបស់ មាស មុត ឱ្យប្តឹងអង្គបុរេជំនុំជម្រះអំពីសំណើសុំមោឃភាពកិច្ចស៊ើបសួរទាំងអស់ដែលបានធ្វើឡើងទាក់ទងនឹងការស្តាប់ចម្លើយសាក្សី ឯកសារ D2/3, D2/4, D2/11, D2/15, D2/16, D32/2, D32/4, D32/13, D32/14 និង D32/15 ថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៥ -ពាក្យសុំនេះមានសេចក្តីសម្រេច D165 D165 ដីកាសម្រេចលើសំណើចំនួន៩ [បដិសេធពាក្យ

សុំ]។ (7): ឯកសារ D141 ពាក្យសុំរបស់ មាស មុត ឲ្យប្ដឹងអង្គបុរេជំនុំជម្រះអំពីសំណើសុំមោឃភាពកិច្ចស៊ើបសួរទាំងអស់ដែលទាក់ទងនឹងរាម ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៥-ពាក្យសុំនេះមានសេចក្ដីសម្រេច D165 ដីកាសម្រេចលើសំណើចំនួន៩ [បដិសេធពាក្យសុំ]។ (8): ឯកសារ D144 ពាក្យសុំរបស់ មាស មុត ឲ្យប្ដឹងអង្គបុរេជំនុំជម្រះអំពីសំណើឃុំមោឃភាពកិច្ចស៊ើបសួរទាំងអស់ ដែលបានធ្វើឡើងទាក់ទងនឹងសាក្សី ហែម លាប ថ្ងៃទី ២២ កក្កដា ឆ្នាំ ២០១៥-ពាក្យសុំនេះមានសេចក្ដីសម្រេច D165 ដីកាសម្រេចលើសំណើចំនួន៩ [បដិសេធពាក្យសុំ]។ (9): ឯកសារ D146 ពាក្យសុំរបស់ មាស មុត ឲ្យប្ដឹងអង្គបុរេជំនុំជម្រះអំពីសំណើសុំមោឃភាពបទចោទប្រកាន់ពីអំពើរំលោភបំពានធ្ងន់ធ្ងរ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥-ពាក្យសុំនេះមានសេចក្ដីសម្រេច D165 ដីកាសម្រេចលើសំណើចំនួន៩ [បដិសេធពាក្យសុំ]។ (10): ឯកសារ D151 ពាក្យសុំរបស់ មាស មុត ឲ្យប្ដឹងអង្គបុរេជំនុំជម្រះអំពីសំណើឃុំមោឃភាពកិច្ចស៊ើបសួរទាំងអស់ ដែលធ្វើឡើងទាក់ទងនឹងអាពាហ៍ពិពាហ៍ដែលបង្ខំ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៥-ពាក្យសុំនេះមានសេចក្ដីសម្រេច D165 ដីកាសម្រេចលើសំណើចំនួន៩ [បដិសេធពាក្យសុំ]។ (11): ឯកសារ D153 ពាក្យសុំរបស់ មាស មុត ឲ្យប្ដឹងអង្គបុរេជំនុំជម្រះអំពីសំណើសុំមោឃភាពឯកសារ D54/81 និងឯកសារភ្ជាប់នឹងឯកសារនេះ ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ២០១៥-ពាក្យសុំនេះមានសេចក្ដីសម្រេច D165 ដីកាសម្រេចលើសំណើចំនួន៩ [ពាក្យសុំលែងមានសុពលភាព]។ (12): ឯកសារ D253 ពាក្យសុំរបស់ មាស មុត ឲ្យប្ដឹងអង្គបុរេជំនុំជម្រះអំពីសំណើសុំមោឃភាពឯកសារ D114/164, D114/167, D114/170,និង D114/171 ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៧-ពាក្យសុំនេះមានសេចក្ដីសម្រេច D253/1 ដីកាសម្រេចលើពាក្យសុំរបស់ មាស មុត ឲ្យប្ដឹងអង្គបុរេជំនុំជម្រះអំពីសំណើសុំមោឃភាពឯកសារ D114/164, D114/167, D114/170,និង D114/171 ថ្ងៃទី៤ ខែ កក្កដា ឆ្នាំ ២០១៧ [អនុញ្ញាតតាមពាក្យសុំ]។ (13): ឯកសារ D257 ពាក្យសុំរបស់ មាស មុត ឲ្យប្ដឹងអង្គបុរេជំនុំជម្រះអំពីពាក្យសុំមោឃភាពផ្នែកនានានៃកំណត់ហេតុនៃការស្ដាប់ចម្លើយដែលកើតចេញពីភស្ដុតាងបានមកពីទារុណកម្ម ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០១៧-ពាក្យសុំនេះមានសេចក្ដីសម្រេច D257/1 ដីកាសម្រេចលើពាក្យសុំរបស់ មាស មុត ឲ្យប្ដឹងអង្គបុរេជំនុំជម្រះអំពីសំណើសុំមោឃភាពផ្នែកនានានៃកំណត់ហេតុនៃការស្ដាប់ចម្លើយដែលកើតចេញពីភស្ដុតាងបានមកពីទារុណកម្ម ថ្ងៃទី ១ ខែសីហា ឆ្នាំ ២០១៧ [អនុញ្ញាតតាមពាក្យសុំ]។

76 សូមមើល ឧទាហរណ៍ឯកសារ D163 សំណើសុំការបញ្ជាក់ទាក់ទងនឹងកាលៈទេសៈនៃការស្ដាប់ចម្លើយសាក្សីដែលសង្ខេប នៅក្នុងកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីឯកសារ D54/96 ថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០១៥។ ឯកសារ D176 សំណើសុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឯកសារចំនួននៅក្នុងសំណុំរឿង ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ២០១៥។ ឯកសារ D185 សំណើសុំការបញ្ជាក់ទាក់ទងនឹងឯកសារ D59/2/10a និងឯកសារ D114/51.1 ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១៦។ ឯកសារ D88/1 សំណើទាក់ទងនឹងឯកសារ D88 ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១៦។ ឯកសារ D186 សំណើទាក់ទងនឹងរបាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែងដែលមិនមាននៅក្នុងសំណុំរឿង ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦។ ឯកសារ D187 សំណើទាក់ទងនឹងកំហុសឆ្គងនៅក្នុងឯកសារមួយចំនួនក្នុងសំណុំរឿង ថ្ងៃទី១៧ ខែ មីនា ឆ្នាំ២០១៦។ ឯកសារ D188 សំណើទាក់ទងនឹងឯកសារជាន់គ្នា និង/ឬឯកសារខុសនៅក្នុងសំណុំរឿង ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦។ ឯកសារ D220 សំណើរបស់ មាស មុត សុំកែតម្រូវភាពមិនស្របគ្នានៅក្នុងឯកសារសំណុំរឿង ថ្ងៃទី៥ ខែ ធ្នូ ឆ្នាំ ២០១៦។ ឯកសារ D228 សំណើរបស់ មាស មុត សុំកែតម្រូវឯកសារសំណុំរឿងមួយចំនួន ថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៧។ ឯកសារ D240 សំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឯកសារ D114/298.3 ថ្ងៃទី ៧ ខែ

31. ភាគីផ្សេងៗទៀតក្នុងសំណុំរឿង ០០៣ ក៏បានចូលរួមផងដែរក្នុងកិច្ចស៊ើបសួរតាមផ្លូវតុលាការ។ សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានដាក់សំណើមួយសុំឱ្យមានកិច្ចស៊ើបសួរ[77] ខណៈដែលសហព្រះរាជអាជ្ញាបានដាក់សំណើចំនួនប្រាំមួយ[78]។

---

មីនា ឆ្នាំ ២០១៧។ ឯកសារ D241 សំណើរបស់ មាស មុត សុំកែតម្រូវកំហុសជាក់ស្ដែងនៅក្នុងឯកសារសំណុំរឿងមួយចំនួន និងសុំឱ្យសហចៅក្រមស៊ើបអង្កេតពិចារណាលើកំហុសផ្សេងទៀតនៅពេលវាយតម្លៃភ័ស្ដុតាង ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧។ ឯកសារ D242 សំណើរបស់ មាស មុត សុំកែតម្រូវកំហុសនៅក្នុងឯកសារសំណុំរឿងមួយចំនួន ថ្ងៃទី២៨ ខែ មីនា ឆ្នាំ២០១៧។ ឯកសារ D245 សំណើរបស់ មាស មុត សុំកែតម្រូវកំហុសនៅក្នុងឯកសារសំណុំរឿងមួយចំនួន ថ្ងៃទី២១ មេសា ឆ្នាំ២០១៧។

77 ឯកសារ D235 សំណើរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីសុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់ឯកសារចូលក្នុងសំណុំរឿង ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៧ កថាខណ្ឌ ៣, ១១, ១២។

78 ឯកសារ D22 សំណើសុំបំពេញកិច្ចស៊ើបសួរលើកទីមួយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងសំណុំរឿង ០០៣ សុំឱ្យទទួលយកឯកសារបន្ថែម និងសេចក្ដីសង្កេតលើស្ថានភាពនៃការស៊ើបសួរ ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១១។ ឯកសារ D23 សំណើលើកទី២ របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងលោក ស៊ូ មេត ព្រមទាំងពាក់ព័ន្ធនឹងទីតាំងប្រព្រឹត្តបទល្មើស ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១។ ឯកសារ D24 សំណើលើកទី៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងលោក មាស មុត និងទីតាំងប្រព្រឹត្តបទល្មើស ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១។ ឯកសារ D208 សំណើសុំឱ្យបំពេញកិច្ចស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងបញ្ជីឈ្មោះរួមអ្នកទោស ស-២១ របស់សហចៅក្រមស៊ើបអង្កេត អមដោយឧបសម្ព័ន្ធសម្ងាត់ ក និង ខ ថ្ងៃទី ៨ ខែសីហា ឆ្នាំ២០១៦ [ស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេត ដាក់ឯកសារ ស-២១ ចូលទៅក្នុងសំណុំរឿង ពិចារណាបន្ថែមឈ្មោះដែលជាអ្នកទោសនៅ ស-២១ កែប្រែបញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស] ហើយដាក់បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស ដែលបានកែប្រែ ចូលក្នុងសំណុំរឿង។ ឯកសារ D233 សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរក្នុងសំណុំរឿង០០៣ ថ្ងៃទី៩ ខែ កុម្ភៈ ឆ្នាំ២០១៧ [ស្នើអ្នកស៊ើបអង្កេតចុះទៅពិនិត្យកោះតាងដល់ទីកន្លែងជាមួយសាក្សី ឯក នី ស្ដាប់ចម្លើយសាក្សីមួយចំនួនដែលពាក់ព័ន្ធឯកងកេង បិទត្រាង ស-២១ ទឹកសាប និងអាពាហ៍ពិពាហ៍ដោយបង្ខំ ស្ដាប់ចម្លើយកម្មាភិបាលកងពល១៦៤ ដែល មាស មុត បានបង្ហាញអត្តសញ្ញាណ ហើយទទួលឱ្យបាននូវសំណៅមួយច្បាប់នៃភាពយន្តឯកសារចំណង(បងទី ១) "Brother Number One" និងប្រតិចារឹកឯកសារនេះ ហើយស្នើសុំដាក់ឯកសារទាំងនេះចូលក្នុងសំណុំរឿង]។ ឯកសារ D234 សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់សម្ភារៈក្នុងសំណុំរឿង០០៣ ថ្ងៃទី៩ ខែ កុម្ភៈ ឆ្នាំ២០១៧ [ស្នើសុំសហចៅក្រមស៊ើបអង្កេតដាក់ឯកសារ ផែនទី និងវីដេអូមួយចំនួននៃសំណុំរឿង០០២ ព្រមទាំងឯកសារ ដែលមូលដ្ឋាននៃបញ្ជីឈ្មោះស-២១ របស់ ក.ស.ច.ស]។

## ការអំពាវនាវឱ្យដាក់សារណា

32. នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ ស.ច.ស.អ Bohlander បានស្នើទៅភាគីនានាក្នុងសំណុំរឿង ០០៣ និង ០០៤ និងបុគ្គល ឬអង្គការណាដែលមានលក្ខណសម្បត្តិឱ្យដាក់សារណាពាក់ព័ន្ធនឹងបញ្ហាច្បាប់ ថាតើ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលចូលជាធរមាននៅចម្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះ ការវាយប្រហាររបស់រដ្ឋ ឬអង្គការទៅលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន អាច ឬក៏មិនអាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិល បើយោងតាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[79]។ នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១៦

ស.ព.អ[80] អោ អាន[81] យឹម ទិត្យ[82] និង **មាស មុត**[83] សុទ្ធតែបានដាក់សារណាឆ្លើយតបទៅនឹងការអំពាវនាវឱ្យដាក់សារណា ក៏ដូចជា*អ្នកមិនមែនជាភាគីនៃរឿងក្តី*ចំនួន ១១ នាក់ផ្សេងទៀតផងដែរ[84]។ យឹម ទិត្យ[85] និង **មាស មុត**[86] បានដាក់ចម្លើយតបទៅនឹងសារណា របស់*អ្នកមិនមែនជាភាគីនៃរឿងក្តី*។

---

79 ឯកសារ D191 សេចក្តីអំពាវនាវសុំឱ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង០០៣ និង ០០៤ និងអ្នកដែលមិនមែនជាភាគី ថ្ងៃទី១៩ ខែ មេសា ឆ្នាំ២០១៦។

80 ឯកសារ D191/1 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីអំពាវនាវសុំឱ្យដាក់សារណាពីសហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៦។

81 សំណុំរឿង ០០៤/២ ឯកសារ D306/3 សារណារបស់ អោ អាន ស្តីពីបញ្ហាថាតើការវាយប្រហារដោយរដ្ឋ ឬអង្គការមួយទៅលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់ខ្លួន អាចត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ ឬយ៉ាងណា តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ២០១៦។

82 សំណុំរឿង ០០៤ ឯកសារ D306/1 សារណារបស់ យឹម ទិត្យ ស្តីពីការបកស្រាយវាក្យស័ព្ទ “ប្រជាជនស៊ីវិល” តាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦។

83 ឯកសារ D191/2 សារណារបស់ មាស មុត ស្តីពីសំណួរថា តើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥-១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬអង្គការទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនអាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិល តាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬយ៉ាងណា ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦។

84 ឯកសារ D191/3 សារណាមិនមែនជាភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤-សាស្ត្រាចារ្យ Ben Saul។ ឯកសារ D191/4 សារណារបស់ អ្នកមិនមែនជាភាគីនៃរឿងក្តីក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤– Catherine Drummond, Philippa Webb, និង Dapo Akande។ ឯកសារ D191/5 សារណាមិនមែនជាភាគីនៅក្នុងសំណុំរឿង ០០៣ និង០០៤ ស្តីពីនីត្យានុកូលភាពនៃការដាក់គោលដៅលើយោធាខ្លួនឯង។ ឯកសារ D191/6 សារណារបស់អ្នកមិន

33. នៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ ស.ច.ស.អ បានសម្រេចថា "តាមច្បាប់ច្បាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលនៅជាធរមានចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬអង្គការមួយប្រឆាំងនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់ខ្លួន អាចចាត់ទុកថាជាការវាយប្រហារសំដៅទៅលើប្រជាជនស៊ីវិល ស្របតាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក" នៅពេលដែលកងកម្លាំងប្រដាប់អាវុធ ដែលទទួលរងការវាយប្រហារនោះមិនបានចងសម្ព័ន្ធភាពជាមួយ ឬក៏មិនបានផ្ដល់ការគាំទ្រពាក់ព័ន្ធផ្នែកយោធាដល់ភាគីប្រឆាំងក្នុងជម្លោះប្រដាប់អាវុធនោះ[87]។ **មាស មុត** បានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចរបស់ ស.ច.ស.អ[88]។ ខណៈពេល

---

មែនជាភាគី នៃរឿងក្ដីសាស្ត្រាចារ្យ Robinson, deGuzman, Jalloh និង Cryer ស្ដីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (សំណុំរឿង ០០៣ និង ០០៤); ឯកសារ D191/7 សារណាដែលមិនមែនជាភាគីរបស់ Ido Rosenzweig ក្នុងសំណុំរឿង ០០៣ និង ០០៤។ ឯកសារ D191/8 សារណាមិនមែនជាភាគីនៅក្នុងសំណុំរឿង ០០៣ និង០០៤ របស់បណ្ឌិត Joanna Nicholson។ ឯកសារ D191/9 សារណាមិនមែនជាភាគីនៅក្នុងសំណុំរឿង ០០៣ និង០០៤ របស់សាស្ត្រាចារ្យ Nicholas Tsagourias។ ឯកសារ D191/10 សារណាមិនមែនជាភាគីនៅក្នុងសំណុំរឿង ០០៣ និង០០៤ របស់ Oliver Windridge។ ឯកសារ D191/11 សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដីដែលដាក់ដោយបណ្ឌិត Williams និង Grey ក្នុងការឆ្លើយតបទៅនឹងការអំពាវនាវឱ្យដាក់សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្ដីក្នុងសំណុំរឿង ០០៣ និង០០៤ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦។ ឯកសារ D191/12 សារណា មិនមែនជាភាគី ដាក់ដោយមជ្ឈមណ្ឌលច្បាប់អន្តរជាតិ និងច្បាប់ប្រៀបធៀបមហាវិទ្យាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យ Baltimore ស្ដីពីនីត្យានុកូលភាពនៃការដាក់គោលដៅវាយប្រហារយោធាខ្លួនឯង។ ឯកសារ D191/13 ចម្លើយតបរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សនៃសាកលវិទ្យាល័យ Queen's University Belfast ទៅនឹង"ការអំពាវនាវឱ្យដាក់សាណាពីភាគីនៃសំណុំរឿង ០០៣ និង០០៤ និងការអំពាវនាវឱ្យដាក់សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្ដី" របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៃ អ.វ.ត.ក។

85 សំណុំរឿង ០០៤ ឯកសារ D306/16 ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងសារណាដែលបានដាក់ជូនដោយ អ្នកមិនមែនជាភាគីអនុលោមតាមឯកសារ D306 ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៦។

86 ឯកសារ D191/17 ចម្លើយរួមរបស់ មាស មុត តបនឹងសារណារបស់ អ្នកដែលមិនមែនជាភាគី លើបញ្ហាដែលថា តើតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥-១៩៧៩ ការវាយប្រហារដោយរដ្ឋ ឬអង្គការទៅលើកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន អាចជាការវាយប្រហារដែលសំដៅលើប្រជាជនស៊ីវិល តាមគោលបំណងនៃមាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ឬយ៉ាងណា ចុះថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៦។

87 ឯកសារ D191/18 ការជូនដំណឹងស្ដីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់របប ឬរដ្ឋនោះ ចុះថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ២០១៧ កថាខណ្ឌ ៦៩, ៥៦-៥៧។

ដែលអង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆ័ន្ទថា បណ្តឹងឧទ្ធរណ៍នោះមិនអាចទទួលយកបាន ពីព្រោះសេចក្តីជូនដំណឹងអំពីការដាក់បណ្តឹងឧទ្ធរណ៍នោះត្រូវបានដាក់ នៅក្រោយថ្ងៃផុតកំណត់ ដែលបានបញ្ជាក់ អង្គជំនុំជម្រះបានក៏កត់សម្គាល់ឃើញថា បណ្តឹងឧទ្ធរណ៍ដែលបានដាក់ទាន់ពេលវេលាក្នុងសំណុំរឿងផ្សេងទៀតក៏ត្រូវបានសម្រេចថា មិនអាចទទួលយកបានផងដែរ ព្រោះបណ្តឹងឧទ្ធរណ៍ទាំងនោះមិនមែនជាសេចក្តីសម្រេចដែលអាចតវ៉ាបាន តាមន័យនៃវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង សំណូមពរដែលបានលើកឡើង មានលក្ខណៈជាសេចក្តីប្រកាស ហើយផលប៉ះពាល់នៃសេចក្តីសម្រេចណាមួយគ្រាន់តែមានភាពលក្ខណៈស្មាន១តែប៉ុណ្ណោះ[89]។

## ការកាត់បន្ថយបទចោទប្រកាន់

34. នៅថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៦ ស.ច.ស.អ Bohlander បានជូនដំណឹងដល់ភាគីទាំងអស់អំពីគោលបំណងរបស់គាត់ មិនបន្តកិច្ចស៊ើបសួរលើអង្គហេតុចំនួនប្រាំពីរ ដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ និងបានអញ្ជើញភាគីទាំងនោះផ្តល់មតិយោបល់លើបញ្ហានេះ[90]។ អង្គហេតុទាំងប្រាំពីរនោះរួមមាន៖ ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងមន្ទីរ

---

[88] ឯកសារ D191/18/1/4 បណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ការជូនដំណឹងរបស់ចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីការបកស្រាយលើ "ការវាយប្រហារលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋ ឬរបបនោះ ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៧។ សូមមើលផងដែរ ឯកសារ D191/18/1/5 ចម្លើយតបរបស់ព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស្តីពីប្រជាជនស៊ីវិល ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២៩១៧។ ឯកសារ D191/18/1/7 ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយរបស់ព្រះរាជអាជ្ញាអន្តរជាតិតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតអំពីប្រជាជនស៊ីវិល ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៧។

[89] ឯកសារ D191/18/1/8 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់លោក មាស មុត ជំទាស់ការជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីការបកស្រាយលើ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋ ឬរបបនោះ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១៧ [អ.ប.ជ យល់ឃើញថា នៅក្នុងករណីនេះ ពុំឃើញមានមូលហេតុល្អណាមួយដែលផ្តល់យុត្តិកម្មឱ្យដាក់ការជូនដំណឹងពីបណ្តឹងឧទ្ធរណ៍ដែលហួសកាលបរិច្ឆេទកំណត់នោះទេ ហេតុនេះ អ.ប.ជ យល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ]។

[90] ឯកសារ D184 សំណើសុំមតិយោបល់ទាក់ទងនឹងការចោទប្រកាន់អំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២៩១៦។ ("សំណើសុំមតិយោបល់")។

សន្តិសុខ ស-២២ (អង្គហេតុទី ១) ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង (អង្គហេតុទី ២) ការចោទប្រកាន់ទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅប្រទេសវៀតណាម ក្រៅពីកោះនានាដែលកម្ពុជាប្រជាធិបតេយ្យអះអាងថាជារបស់ខ្លួន និងតំបន់ព្រំដែនភាគខាងកើត (អង្គហេតុទី ៣) ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងគុកលេខ ៨១០ (អង្គហេតុទី ៤) ការចោទប្រកាន់នានាទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខផ្សេងទៀតដែលមិនបានកំណត់អត្តសញ្ញាណគ្រប់គ្រងដោយកងទ័ពបដិវត្តន៍កម្ពុជា (អង្គហេតុទី ៥) ការចោទប្រកាន់ទាំងអស់ទាក់ទងនឹងទីតាំងសម្លាប់មនុស្សស្ទឹងតូច (អង្គហេតុទី ៦) និងការចោទប្រកាន់ទាំងអស់ទាក់ទងនឹងការចូលរួមរបស់ ក.ប.ក ក្នុង "ការបោសសម្អាត" ភូមិភាគកណ្តាល ភូមិភាគឧត្តរថ្មី និងភូមិភាគបូព៌ា ដោយមិនរាប់បញ្ចូលការចោទប្រកាន់អំពី "ការបោសសម្អាត" សមាជិកនៃកង/អង្គភាពរបស់ ក.ប.ក ដែលមានទីតាំងនៅតំបន់ទាំងនោះ (អង្គហេតុទី ៧)[91]។

35. សហមេធាវីបានឆ្លើយតបភ្លាមៗ ដោយផ្អែកលើការយល់ដឹងរបស់ខ្លួនលើវិធាន ៦៦ស្ទួន និង ៦៧ នៃវិធានផ្ទៃក្នុង[92]។ នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៦ ស.ព.អ បានឆ្លើយតប ដោយគាំទ្រគោលបំណងរបស់ ស.ច.ស.អ ដែលមិនចង់ស៊ើបសួរបន្ថែមទៀត លើអង្គហេតុទី១ ដល់ទី៧ នោះ ប៉ុន្តែបានស្នើថា វាជាការលឿនពេកក្នុងការកំណត់លើការអនុវត្តចុងក្រោយនៃវិធាន ៦៦ស្ទួន ឬ ៦៧ នៃវិធានផ្ទៃក្នុង ក្នុងដំណាក់កាលនេះនៃកិច្ចស៊ើបសួរនេះ[93]។ ស.ព.អ ក៏បានសន្និដ្ឋានផងដែរថា គាត់នឹងមិនជំទាស់ទៅនឹង ស.ច.ស.អ ដែលចង់បញ្ឈប់កិច្ចស៊ើបសួរលើ "ការបោសសម្អាត" កងពល ៥០២ និង ៣១០ ("អង្គហេតុទី ៨") នោះផងដែរ[94]។ នៅថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ស.ច.ស.អ បានជូនដំណឹងដល់ភាគីទាំងអស់ថា គាត់នឹងមិនបន្តស៊ើបសួរបន្ថែមលើអង្គហេតុទី១ ដល់ទី៧ ទេ ប៉ុន្តែនឹងបន្តស៊ើបសួរលើអង្គហេតុទី ៨ ហើយថា សេចក្តីសម្រេចបដិសេធនដែល

---

91 ឯកសារ D184 សំណើសុំមតិយោបល់។

92 ឯកសារ D184/1 សំណើសុំមតិយោបល់ទាក់ទងនឹងអង្គហេតុដែលត្រូវបានចោទប្រកាន់ ដែលនឹងមិនត្រូវបានស៊ើបសួរបន្ថែមទៀត (ឯកសារ D184) ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦។

93 ឯកសារ D184/2 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសុំយោបល់ទាក់ទងនឹងអង្គហេតុចោទប្រកាន់ដែលមិនត្រូវស៊ើបអង្កេតបន្ថែម ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៦ ("ចម្លើយតបរបស់ ស.ព.អ ទៅនឹងសំណើសុំមតិយោបល់")។

94 ឯកសារ D184/2 ចម្លើយតបរបស់ ស.ព.អ ទៅនឹងសំណើសុំមតិយោបល់ កថាខណ្ឌ ២២។

អនុលោមតាមវិធាន ៦៦ស្ទួន ឬ ៦៧ នៃវិធានផ្ទៃក្នុងនេះ នឹងត្រូវធ្វើឡើង នៅពេលបញ្ចប់កិច្ចស៊ើបសួរ[95]។

36. ស.ច.ស.អ បានជូនដំណឹងបន្ថែមទៀតដល់ភាគីទាំងអស់ នៅថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ អំពីចេតនារបស់គាត់ដែលចង់ដកអង្គហេតុទី១ ទី២ ទី៦ និងទី៧ ចេញពីកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៦៦ស្ទួន នៃវិធានផ្ទៃក្នុង នៅពេលបញ្ចប់កិច្ចស៊ើបសួរ ដោយបញ្ចេញមតិថា អង្គហេតុដែលនៅសល់នឹងតំណាងឱ្យលក្ខណៈ និងវិសាលភាពនៃឧក្រិដ្ឋកម្ម ព្រមទាំងប្រភេទក្រុមជនរងគ្រោះ ដូចដែលបានកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីពីរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[96]។ ស.ព.អ មិនបានជំទាស់នោះទេ[97]។ នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ ចៅក្រម Bohlander បានជូនដំណឹងដល់ភាគីទាំងអស់ថា កិច្ចស៊ើបសួរតាមផ្លូវតុលាការបានបិទបញ្ចប់ហើយ និងហេតុនេះ វាជាការសមស្របក្នុងការដកអង្គហេតុទី១ ទី២ ទី៦ និងទី៧ ចេញពីកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុង[98]។

## ការបិទបញ្ចប់កិច្ចស៊ើបសួរ

37. នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៧ ស.ច.ស.អ Bohlander បានជូនដំណឹងដល់ភាគីទាំងអស់ថា គាត់បានពិចារណាលើការបិទបញ្ចប់កិច្ចស៊ើបសួរតាមផ្លូវតុលាការក្នុងសំណុំរឿង ០០៣ ហើយផ្តល់ពេលដល់ភាគីទាំងអស់ចំនួន ៣០ ថ្ងៃដើម្បីដាក់ពាក្យសុំបំពេញកិច្ចស៊ើបសួរបន្ថែម[99]។ ភាគីទាំងនោះបានដាក់ពាក្យសុំបំពេញកិច្ចស៊ើបសួរមួយចំនួន ក្នុងនោះរួមទាំងសំណើសុំចុះទៅពិនិត្យ

---

[95] ឯកសារ D184/3 សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៦ កថាខណ្ឌ ២១-២២។

[96] ឯកសារ D184/4 សេចក្តីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦ ស្ទួន (២) ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥, ៦។

[97] ឯកសារ D184/4/1 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអនុលោមតាមវិធាន ៦៦ ស្ទួន (២) ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ២។

[98] ឯកសារ D226 ដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរយោងតាមវិធានផ្ទៃក្នុង ៦៦ ស្ទួន ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧។

[99] D225ឯកសារ D225 សេចក្តីជូនដំណឹងអំពីការបិទការស៊ើបសួរប្រឆាំង មាស មុត ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ កថាខណ្ឌ ៦-៧។

ទីតាំង និងស្តាប់ចម្លើយសាក្សីបន្ថែមផង[100]។ បន្ទាប់ពីបានឆ្លើយតបទៅនឹងសំណើទាំងនេះហើយ នៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១៧ ចៅក្រម Bohlander បានចេញសេចក្តីជូនដំណឹងជាលើកទីពីរ និងចុងក្រោយរបស់គាត់អំពីការបិទបញ្ចប់កិច្ចស៊ើបសួរលើ **មាស មុត** និងជូនដំណឹងដល់ភាគីទាំងអស់ថា គ្មានសំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែមទៀតណាអាចដាក់បានឡើយ[101]។

38. ចៅក្រម Bohlander បានចេញដីកាបញ្ជូនសំណុំរឿងទៅពិនិត្យជាភាសាអង់គ្លេស នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៧ ដោយស្នើឲ្យសហព្រះរាជអាជ្ញាដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ក្នុងរយៈពេលបីខែ[102]។ នៅថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៧ ស.ព.អ បានស្នើសុំព័ត៌មានអំពីកាលបរិច្ឆេទរំពឹងទុកនៃការជូនដំណឹងអំពីដីកាបញ្ជូនសំណុំរឿងទៅពិនិត្យជាភាសាខ្មែរ ដោយអនុលោមតាមវិធាន

៦៦(៥) នៃវិធានផ្ទៃក្នុង និងក៏បានស្នើសុំកាលវិភាគដែលបានកែប្រែសម្រាប់ការដាក់ដីកាសន្និដ្ឋានស្ថាពររបស់គាត់ផងដែរ[103]។ នៅថ្ងៃបន្ទាប់ សហមេធាវីបានស្នើសុំឲ្យមានភាពបត់បែនដូចគ្នានេះចំពោះខ្លួន ប្រសិនបើភាពបត់បែននោះត្រូវបានអនុញ្ញាតឲ្យ ស.ព.អ[104]។ ឯកសារជាភាសាខ្មែរនៃ

---

[100] ឯកសារ D227 សំណើរបស់ មាស មុត សុំឲ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងឯកសារ D114/174, D114/184 និងការស្តាប់ចម្លើយសាក្សីដែលពាក់ព័ន្ធ និងការប្រើប្រាស់ជាសក្តានុភូតនៃភ័ស្តុតាងដែលទទួលបានតាមរយៈទារុណកម្ម ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៧។ ឯកសារ D229 សំណើរបស់ មាស មុត សុំឲ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងការទំនាក់ទំនងជាមួយសាក្សីដោយមិនមានកំណត់ត្រា និងសំណើសុំឲ្យពិនិត្យកែប្រែកំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧។ ឯកសារ D233 សំណើរបស់ព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧។ ឯកសារ D234 សំណើសរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរដើម្បីដាក់សម្ភារៈទៅក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧។

[101] ឯកសារ D252 សេចក្តីជូនដំណឹងលើកទី២ ស្តីពីការបិទកិច្ចស៊ើបសួរលើ មាស មុត ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ កថាខណ្ឌ ១៨-១៩។

[102] ឯកសារ D256 ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យយោងតាមវិធានផ្ទៃក្នុង ៦៦ (៤) ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ ("ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ") កថាខណ្ឌ ១៤។

[103] ឯកសារ D256/1 សំណើរបស់ព្រះរាជអាជ្ញាអន្តរជាតិ សុំព័ត៌មានអំពីកាលបរិច្ឆេទរំពឹងទុកនៃការជូនដំណឹងអំពីសំណៅជាភាសាខ្មែរនៃដីការបញ្ជូនរឿងទៅពិនិត្យ និងសំណើសុំកែប្រែកាលវិភាគសម្រាប់ដាក់ដីកាសន្និដ្ឋានស្ថាពរ ចុះថ្ងៃទី ០៨ ខែសីហា ឆ្នាំ២០១៧។

[104] ឯកសារ D256/2 ចម្លើយរបស់ មាស មុត តបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំព័ត៌មានអំពីកាលបរិច្ឆេទរំពឹងទុកនៃការជូនដំណឹងអំពីសំណៅជាភាសាខ្មែរនៃដីកាបញ្ជូនរឿងទៅពិនិត្យ និងសំណើសុំកែប្រែកាលវិភាគសម្រាប់ដាក់ដីកាសន្និដ្ឋានស្ថាពរ ចុះថ្ងៃទី ០៩ ខែសីហា ឆ្នាំ២០១៧។

ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យត្រូវបានជូនដំណឹងនៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១៧។ នៅថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១៧ ស.ច.ស.អ បានបង្គាប់ ស.ព.អ ឱ្យដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួនជាភាសាអង់គ្លេស ក្នុងរយៈពេលបីខែ បន្ទាប់ពីកាលបរិច្ឆេទដែលដីកាបញ្ជូនសំណុំរឿងទៅពិនិត្យត្រូវបានជូនដំណឹង ទាំងភាសាអង់គ្លេស និងភាសាខ្មែរ[105]។ សហមេធាវីត្រូវបានបង្គាប់ឱ្យដាក់ចម្លើយតបរបស់ខ្លួនជាភាសាអង់គ្លេសក្នុងរយៈពេល ៦០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដែលការបកប្រែពេញលេញនៃដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ ត្រូវបានជូនដំណឹង[106]។

## ដំណើរការផ្លូវច្បាប់សំខាន់ៗ

39. នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ សហមេធាវីបានដាក់ញត្តិមួយស្នើសុំឱ្យ ស.ច.ស ច្រានចោលការអនុវត្តអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងទម្រង់ "អំពើឃោរឃៅអមនុស្សធម៌ផ្សេងទៀត"[107] ដែលបច្ចុប្បន្ននៅមិនទាន់សម្រេច នៅចំពោះមុខ ស.ច.ស នៅឡើយ។ ភាគីទាំងអស់មិនយល់ស្របលើចំណុចដែលថា តើញត្តិនេះធ្វើឡើងមុនអាយុកាលឬទេ និងគប្បីត្រូវដោះស្រាយនៅពេលចេញដីកាដំណោះស្រាយឬយ៉ាងណា ថាតើឧក្រិដ្ឋកម្មនេះរំលោភលើគោលការណ៍នីត្យានុកូលភាពដែរឬទេ និងថាតើអង្គហេតុសំខាន់ៗ ពីសម័យកម្ពុជាប្រជាធិបតេយ្យឆ្លើយតបនឹងលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរ ឬទេ[108]។

---

[105] ឯកសារ D256/3 សេចក្តីសម្រេចទៅលើកាលវិភាគនៃសេចក្តីសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា និងចម្លើយតបរបស់ផ្នែកការពារក្តី ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៧ កថាខណ្ឌ ៨។

[106] ឯកសារ D256/5 សេចក្តីសម្រេចលើសំណើសុំរបស់ មាស មុត ឱ្យពិចារណាឡើងវិញទៅលើកាលវិភាគនៃចម្លើយតបរបស់ផ្នែកការពារក្តី ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៧។

[107] ឯកសារ D214 ញត្តិរបស់ មាស មុត ជំទាស់ការអនុវត្តអាពាហ៍ពិពាហ៍ដោយបង្ខំជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ("ញត្តិស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ")។

[108] សូមមើលឯកសារ D214 ញត្តិស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ឯកសារ D214/1 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងញត្តិរបស់ មាស មុត ជំទាស់ការអនុវត្តអាពាហ៍ពិពាហ៍ដោយបង្ខំជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៦។ ឯកសារ D214/1/1 ការឆ្លើយតបរបស់ មាស មុត ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិតបនឹងញត្តិរបស់ មាស មុត ជំទាស់ការអនុវត្តអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងនាមជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ជាអំពើអនុស្សធម៌ផ្សេងទៀត ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០១៦។

40. សហមេធាវីបានដាក់សំណើសុំធ្វើមោឃភាពចំនួនពីរ ដែលនៅតែមិនទាន់បានសម្រេចនៅឡើយនៅចំពោះមុខ អ.ប.ជ នៅត្រឹមកាលបរិច្ឆេទនៃការដាក់ដីកាសន្និដ្ឋាននេះ។ សំណើទីមួយស្នើឲ្យ អ.ប.ជ ធ្វើមោឃភាពកំណត់ហេតុស្តាប់ចម្លើយចំនួន ៤ ដោយហេតុផលថា ប្រវត្តិរូបពីមន្ទីរស-២១ ត្រូវបានប្រើប្រាស់ជាតម្រុយសម្រាប់ស៊ើបអង្កេត ដើម្បីកំណត់ពីទីតាំងសាក្សីដែលត្រូវបានស្តាប់ចម្លើយនៅពេលនោះ ដោយលើកជាទឡ្ហីករណ៍ថា ចម្លើយដែលទទួលបាននោះ គឺជាភ័ស្តុតាងដែលទទួលបានពីការធ្វើទារុណកម្ម[109]។ ស.ព.អ អះអាងថា ការអនុញ្ញាតឲ្យប្រើប្រាស់ប្រវត្តិរូបពីមន្ទីរ ស-២១ ធ្វើជាតម្រុយស៊ើបអង្កេតមិនបានបំពានគោលនយោបាយណាមួយ ដែលស្ថិតនៅក្រោមវិធានបដិសេធភ័ស្តុតាង ដែលអាចអនុវត្តបានចំពោះភ័ស្តុតាងដែលប្រឡាក់ប្រឡូសដោយការធ្វើទារុណកម្មខ្លួនឯងផ្ទាល់នោះទេ និងជាការពិតនឹងជំរុញឲ្យមានការបង្ការ និងការផ្តន្ទាទោសលើការធ្វើទារុណកម្មផង[110]។ ដូចគ្នានេះដែរ សំណើទីពីរដែលមិនទាន់សម្រេច ស្នើឲ្យ អ.ប.ជ ច្រានចោលនូវអ្វីដែលសហមេធាវីចាត់ទុកថាជាផ្នែកកំណត់ហេតុស្តាប់ចម្លើយចំនួន ២២ ដែលបានមកពីការធ្វើទារុណកម្ម ដែលបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយនេះ[111]។ នៅក្នុងដីកាបញ្ជូនរឿងទៅពិនិត្យ ចៅក្រម Bohlander បានបញ្ជាក់ថា តាមការយល់ឃើញរបស់គាត់ សំណើទីមួយមិនចាំបាច់ត្រូវដោះស្រាយ មុនពេលសហព្រះរាជអាជ្ញាដាក់ដីកាសន្និដ្ឋានស្ថាពររបស់ពួកគេនោះទេ ហើយគាត់ក៏បានកត់សម្គាល់ផងដែរថា អ.ប.ជ អាចចាត់ទុកសំណើនេះថាមិនអាចទទួល

---

109 ឯកសារ D253/1/3 ពាក្យសុំរបស់ មាស មុត សុំឲ្យមោឃភាពឯកសារ D114/164, D114/167, D114/170, និង D114/171, 17 Jul 2017។

110 ឯកសារ D253/1/4 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ មាស មុត សុំធ្វើមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួនបួន ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧។

111 ឯកសារ D257/1/3 ពាក្យសុំរបស់ មាស មុត សុំឲ្យធ្វើមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយដែលទទួលបានពីភស្តុតាងបានមកពីទារុណកម្ម ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៧។ ឯកសារ D257/1/3.2 ឧបសម្ព័ន្ធ៖ សម្រង់នៃកំណត់ហេតុនៃការស្តាប់ចម្លើយដែលទទួលបានពាក់ព័ន្ធនឹងចម្លើយសារភាពពីមន្ទីរ ស-២១។ សូមមើលផងដែរ ឯកសារ D257/1/4 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងពាក្យសុំមោឃភាពកំណត់ហេតុនៃកាស្តាប់ចម្លើយសាក្សី ដែលត្រូវបានចោទប្រកាន់ថាបានមកពីការធ្វើទារុណកម្ម ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៧។ ឯកសារ D257/1/7 ការឆ្លើយតបរបស់ មាស មុត ចំពោះចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិ តបទៅនឹងពាក្យសុំធ្វើការមោឃភាពកំណត់ហេតុនៃការស្តាប់ចម្លើយ ដែលត្រូវបានអះអាងថាបានមកពីភ័ស្តុតាងបានពីទារុណកម្ម ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧។

យកបាន ដោយសារតែសំណើនេះត្រូវបានដាក់ក្រោយពេលវេលាកំណត់[112]។ សំណើទីពីរដែលមិនទាន់សម្រេច ត្រូវបានដាក់លើសពីពីរសប្តាហ៍ បន្ទាប់ពីការចេញដីកាបញ្ជូនរឿងទៅពិនិត្យ។

## ភ័ស្តុតាងក្នុងសំណុំរឿង ០០៣

41. នៅពេលបិទបញ្ចប់កិច្ចស៊ើបសួរ សំណុំរឿង ០០៣ មានឯកសារប្រមាណ ៧.០០០ ឯកសារ[113] ដែលរួមមានកំណត់ហេតុស្តាប់ចម្លើយជាង ៩០០ កំណត់ហេតុ ព្រមទាំងឯកសារស្តីពីសម័យកម្ពុជាប្រជាធិបតេយ្យ បញ្ជីឈ្មោះអ្នកទោសមន្ទីរស-២១ ពាក្យស្នើសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី បទសម្ភាសន៍ និងការចងក្រងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប្រតិចារឹកសវនាការពីសំណុំរឿង ០០១ សំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ រូបថត ផែនទី របាយការណ៍ពីប្រព័ន្ធផ្សព្វផ្សាយ ព្រមទាំងសៀវភៅ និងអត្ថបទស្រាវជ្រាវផ្សេងៗទៀត។ ភ័ស្តុតាងនេះបង្ហាញយ៉ាងជាក់ច្បាស់ពីវិសាលភាពដែល **មាស មុត** បានចូលរួមនៅក្នុង និងទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលកំពុងតែត្រូវបានចោទប្រកាន់។

## III. តួនាទី និងទំនួលខុសត្រូវរបស់ មាស មុត

### ១. ប្រវត្តិរូប និងតួនាទីរបស់ មាស មុត មុនឆ្នាំ ១៩៧៥

42. **មាស មុត** គឺជាសមាជិកជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា ជាមេបញ្ជាការយោធាដ៏មានបទពិសោធន៍ និងជាមេដឹកនាំដ៏ល្បីល្បាញម្នាក់ក្នុងជួរយោធាខ្មែរក្រហម នៅពេលបក្សកុម្មុយនីស្តកម្ពុជាបានឡើងកាន់អំណាចនៅកម្ពុជា នៅខែ មេសា ឆ្នាំ ១៩៧៥។

43. **មាស មុត** ដែលគេស្គាល់ផងដែរថាជា "ខែ មុត" បានកើតនៅភូមិពោធិ៍ ឃុំស្រែក្នុង ស្រុកឈូក ខេត្តកំពត នៅឆ្នាំ ១៩៣៨[114]។ គាត់បានចូលរួមជាមួយចលនាខ្មែរក្រហមនៅខែ ឧសភា ឆ្នាំ

---

112 ឯកសារ D256 ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ កថាខណ្ឌ ១១-១២។

113 ឯកសាររាប់រយដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Blunk ផ្ទេរពីសំណុំរឿង ០០២ គឺមិនពាក់ព័ន្ធផ្ទាល់ជាមួយនឹងបទចោទសំណុំរឿង ០០៣ ទេ។ លើសពីនេះទៅទៀត ឯកសារជាច្រើនផ្សេងទៀតក៏ក្លាយជាឯកសារមិនពាក់ព័ន្ធដែរ បន្ទាប់ពី ស៊ូ មេត ស្លាប់ នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣។

114 ឯកសារ D22.2.181 ចម្លើយ មាស មុត ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម( Meas Muth US POW/MIA Statement) ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០១ KH 00741996 ["មាស មុត កើតនៅក្នុងភូមិពោធិ៍ ឃុំស្រែក្នុង ស្រុកឈូក ខេត្តកំពត ប្រទេសកម្ពុជា ក្នុងឆ្នាំ ១៩៣៨ [...] លោកក៏មានឈ្មោះក្រៅ ខែ មុត និង តា មុត ផងដែរ"]

១៩៧០[115] និងនៅជាមួយចលនានេះរហូតដល់ឆ្នាំ ១៩៩៩ នៅពេលដែលគាត់បានចុះចូលជាមួយរដ្ឋាភិបាលកម្ពុជា[116]។ ទោះជាមានការរៀបរាប់ខ្លួនឯងថាជា "សមាជិកសាមញ្ញម្នាក់របស់បក្សប៉ុណ្ណោះ" ក្តី[117] ក៏ភ័ស្តុតាងបង្ហាញថា **មាស មុត** បានឡើងឋានានុក្រមខ្មែរក្រហមយ៉ាងឆាប់រហ័សរហូតដល់ទីបំផុតបានកាន់តំណែងជាន់ខ្ពស់ ដោយសារតែគាត់ជាសមាជិកម្នាក់ក្នុងចំណោមសមាជិកដែលគួរឲ្យជឿទុកចិត្តបំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា។

44. បន្ទាប់ពីបានចូលរួមជាមួយចលនាខ្មែរក្រហមនៅឆ្នាំ ១៩៧០ **មាស មុត** ត្រូវបានចាត់ឲ្យធ្វើជាពេទ្យទាហាន។ គាត់ត្រូវបានដាក់ឲ្យបំពេញការងារដំបូងនៅក្នុងភូមិពោធិ៍ និងបន្ទាប់មកនៅស្រុកអង្គរជ័យ (ស្រុក ១០២) ស្ថិតក្នុងតំបន់ ១៣[118]។ នៅចុងឆ្នាំ ១៩៧០ ឬដើមឆ្នាំ ១៩៧១ **មាស មុត** បាន

---

។ ឯកសារ D114/29.1.4 Ben Kienan របប ប៉ុល ពត KH 00637489 ["កូនប្រសារប្រុសរបស់តាម៉ុក ឈ្មោះខែ មុត"]។ ឯកសារ D88.1.17 សៀវភៅនិពន្ធដោយ Dave Kattenberg ចំណងជើង Foxy Lady, EN 00916251 ["ភូមិកំណើតរបស់ មាស មុត នៅភូមិពោធិ៍ ខេត្តកំពត"]។ ឯកសារ D1.3.13.1 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ Boch Koy EN 00217558 ["សាក្សីបានបញ្ជាក់ថា មាស មុត មកពីស្រុកជុំគិរី ខេត្តកំពត"]។ ឯកសារ D54/1.1 Southeast Asia Globe គោលជំហាចុងក្រោយ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ EN 00915789 ["មាស មុត កើតនៅខេត្តកំពត ប៉ែកខាងត្បូងប្រទេសកម្ពុជា"]។ ឯកសារ D1.3.32.28 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយមាស ចាន់ណា KH 00020375 ["សៈ តា មុត គាត់អ្នកស្រុកហ្នឹងម៉ង? ឆៈ ចា។ សៈភូមិពោធិ៍ ហ្នឹងម៉ង? ឆៈ ចា"]។

115 ឯកសារ D22.2.181 ចម្លើយ មាស មុត ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០១ KH 00741996 ["មាស មុត បានចូលរួមក្នុងចលនាខ្មែរកុម្មុយនីស្ត នៅខែឧសភា ឆ្នាំ១៩៧០។"]។

116 ឯកសារ D54/1.1 Southeast Asia Globe គោលជំហាចុងក្រោយ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ EN 00915789 ["ចាប់តាំងពីមាស មុត បែកខ្លួនចូលរដ្ឋាភិបាលនៅឆ្នាំ១៩៩៩ គាត់បានកែប្រែខ្លួនឯងថាជាព្រឹទ្ធាចារ្យព្រះពុទ្ធសាសនាដោយចំណាយថ្លៃការកសាងវត្តមួយនៅក្នុងភូមិ ហើយនិយាយទៅកាន់អ្នកភូមិដោយសំដីគួរសម"]។

117 ឯកសារ D1.3.7.8 កាសែត ខេមបូឌា ដេលី ចំណងជើង រឿងកន្លងផុត បំភ្លេចចោលចុះ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៨ EN 00165821 ["កាលនោះ ខ្ញុំគ្រាន់តែសមាជិកធម្មតាម្នាក់របស់បក្សតែប៉ុណ្ណោះ"]។

118 ឯកសារ D22.2.181 ចម្លើយ មាស មុត ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាមចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០១ KH 00741996 ["មាស មុត បានចូលរួមក្នុងចលនាខ្មែរកុម្មុយនីស្ត នៅខែឧសភា ឆ្នាំ១៩៧០"] [...] កាលពីដំបូង គេចាត់តាំងលោកឲ្យធ្វើពេទ្យនៅក្នុងភូមិរបស់លោក បន្ទាប់មកទៅកាន់តំបន់ ១៣"]។ ឯកសារ D22.2.182 ចម្លើយ មាស មុត ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០២ KH 00741989 ["ពីដំបូង ឧត្តមសេនីយ៍ត្រី មាស មុត ត្រូវបានចាត់តាំងឲ្យធ្វើជាគ្រូពេទ្យនៅក្នុងស្រុកអង្គរជ័យ ស្រុក ១០២ តំបន់១៣ ក្នុងឆ្នាំ១៩៧០"]។

ក្លាយជាមេបញ្ជាការរងយោធាស្រុកអង្គរជ័យ ដែលនៅទីនោះ គាត់បានគ្រប់គ្រងកងទ័ពយ៉ាងហោចណាស់ ២០០ នាក់[119]។ មិនយូរប៉ុន្មានក្រោយមក គាត់ត្រូវបានតែងតាំងជាគណៈកម្មាធិការតំបន់ ១៣ ក្នុងភូមិភាគនិរតី[120] ដែលនៅទីនោះ គាត់ទទួលបន្ទុកខាងយោធារហូតយ៉ាងហោច

---

119 ឯកសារ D22.2.182 ចម្លើយ មាស មុត ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០២ KH 00741989 ["នៅចុងឆ្នាំ១៩៧០ ឬដើមឆ្នាំ១៩៧១ លោកបានក្លាយជាមេបញ្ជាការរងយោធាស្រុកអង្គរជ័យ។ នៅពេលនោះ មានកងទ័ពប្រហែល ២០០ នាក់ នៅក្នុងយោធាស្រុក"]។

120 ឯកសារ D22.2.181 ចម្លើយ មាស មុត ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០១ KH 00741996 ["នៅចុងឆ្នាំ ១៩៧០ លោកត្រូវបានចាត់តាំងឲ្យធ្វើជាយោធានៅក្នុងស្រុកអង្គរជ័យ ក្នុងខេត្តកំពត ហើយក្រោយមកទៅកាន់ទីបញ្ជាការដ្ឋានតំបន់ ១៣ ក្នុងខេត្តតាកែវ ភាគខាងត្បូង។ លោក មាស មុត បានបម្រើការងារនៅក្នុងទីបញ្ជាការដ្ឋានតំបន់ ១៣ រហូតទាល់តែអង្គការបានចាត់តាំងរូបលោកឲ្យទទួលបន្ទុកការងារថ្មីនៅទីបញ្ជាការដ្ឋានភូមិភាគនិរតីក្នុងឆ្នាំ ១៩៧៣"]។ ឯកសារ D114/297.1.22 ម៉ឹង វេត ប្រតិចារឹក ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១៦ ម៉ 09.59.38-10.03.14 ["ពី ៧៣ មកដល់ ៧៥ អាហ្នឹង បងមុត គាត់លេខា បងសោម អនុ។ ដល់ពេល មុត ឡើងទៅនៅកងពលទី៣ ទៅបាន បងសោម ឡើងអនុវិញ អាហ្នឹងខ្ញុំនិយាយពីអំឡុង៧៥វិញ។ ស៖ នៅមួយពេលនោះគឺ មុត - តាមុត គាត់បានចាកចេញពីតំបន់ ហើយទៅមានតួនាទីថ្មីផ្សេងមួយទៀត។ តើអីចឹងមែនទេ? ឆ៖ ក្រោយពីមើលពី៧៣មក ខ្ញុំដឹងមកគាត់តំបន់មែន តែមុន៧៥ ប្រហែលជាខ្ទង់ ៧៤អីនេះ គាត់ឡើងទៅកាន់កងពលថ្មី គាត់ទៅខាង គាត់នៅខាងកងពលទី៣។ ដូច្នេះគាត់ផុតពីតំបន់បាន បងសោម ឡើងលេខាវិញ។ ស៖ តើមន្ទីររបស់លោកមានទីតាំងនៅកន្លែងណាឲ្យពិតប្រាកដទៅនៅក្នុងស្រុកអង្គរជ័យនោះនៅពេលដែលលោកធ្វើជានីរសារចន្លោះពីឆ្នាំ១៩៧៣ ទៅដល់ខែកញ្ញា ១៩៧៥ នោះ? ឆ៖ ចូល៧៣ មកដល់ ៧៥ វាមានផ្លាស់កន្លែង ខ្ញុំនៅពីភ្នំស្រមោច ដំរីរមៀលនេះមក ខ្ញុំមកផ្លាស់នៅក្បាលថ្នល់អង្គគ្រៀវមួយរយៈ ពី៧៥ ហើយអាហ្នឹងមកនៅដល់ហ្នឹង គឺនៅក្បាលថ្នល់ខាងអង្គគ្រៀវហ្នឹងនៅជិតផ្លូវជាតិហ្នឹង ហើយនិងស្រុកអង្គរជ័យដដែល"]។ ឯកសារ D54/62 ម៉ឹង វេត កំណត់ហេតុស្តាប់ចម្លើយ ឆ.១៥ ["ស៖ តើពេលណាដែលលោកបានឃើញ មាស មុត នៅគណៈតំបន់ ១៣ ហើយគាត់នៅគណៈតំបន់ ១៣ ហ្នឹង ពីពេលណាដល់ពេលណា? ឆ.១៥៖ នៅពេលដែលខ្ញុំចូលចលនាបដិវត្តន៍ឆ្នាំ១៩៧៣ ខ្ញុំបានឃើញគាត់នៅគណៈតំបន់រួចហើយ"]។ ឯកសារ D54/60.2 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ម៉ឹង វេត KH 00975714-15 ["ស៖ តា មុត ហ្នឹងគាត់ធ្វើជា? ឆ៖ គណៈតំបន់១៣។ ស៖ គណៈតំបន់មាន តា មុត? ឆ៖ មាន តា មុត មាន តា សោម"]។ ឯកសារ D4.1.783 ពេជ្រ ជឹម កំណត់ហេតុស្តាប់ចម្លើយ KH 00373458 ["តា សោម (ហៅ ថន) ជាលេខាតំបន់១៣ [...] អនុលេខាតំបន់១៣ឈ្មោះ ផែន ទទួលបន្ទុកសេដ្ឋកិច្ច [...] សមាជិកតំបន់ឈ្មោះ មាស មុត ទទួលបន្ទុកយោធា"]។ ឯកសារ D4.1.784 ពេជ្រ ជឹម កំណត់ហេតុស្តាប់ចម្លើយ KH 00373387 ["សមាសភាពគណៈតំបន់១ ៣ រួមមាន តា សោម ជាលេខា និង ផែន ជាអនុលេខា និង តាមុត សមាជិក"]។ ឯកសារ D114/29.1.4 ប៉ែន យឿនិន របប ប៉ុល ពត KH 00637489 ["កូនប្រសាប្រុសរបស់ តាម៉ុក ឈ្មោះ ខែ មុត បានចាប់ផ្តើមការងារអាជីពរបស់ខ្លួនជាលេខាបក្ស ស្រុកត្រាំកក់ ហើយក៏បានក្លាយជាអនុលេខាបក្សតំបន់ ១៣"]។

ណាស់ដល់ឆ្នាំ ១៩៧៣[121]។ នៅដំណាក់កាលនោះ **មាស មុត** ត្រូវបានបញ្ចូលជាសមាជិកពេញសិទ្ធិនៃបក្សកុម្មុនីស្តកម្ពុជារួចទៅហើយ[122]។

121 ឯកសារ D22.2.181 ចម្លើយ មាស មុត ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០១ KH 00741996 ["នៅចុងឆ្នាំ១៩៧០ លោកត្រូវបានចាត់តាំងឱ្យធ្វើជាយោធានៅក្នុងស្រុកអង្គរជ័យ ក្នុងខេត្តកំពត ហើយក្រោយមកទៅកាន់ទីបញ្ជាការដ្ឋានតំបន់ ១៣ ក្នុងខេត្តតាកែវ ភាគខាងត្បូង។ លោក មាស មុត បានបម្រើការងារនៅក្នុងទីបញ្ជាការដ្ឋានតំបន់១៣ រហូតទាល់តែអង្គការបានចាត់តាំងរូបលោកឱ្យទទួលបន្ទុកការងារថ្មីនៅទីបញ្ជាការដ្ឋានភូមិភាគនិរតីក្នុងឆ្នាំ១៩៧៣"]។ ឯកសារ D114/297.1.22 ម៉ឹង វេត ប្រតិចារឹត ចុះថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១៦ ម៉ 09.59.38-10.03.14 ["ពី ៧៣ មកដល់ ៧៥ អាហ្នឹង បងមុត គាត់លេខា បងសោម អនុ។ ដល់ពេលមុត ឡើងទៅនៅកងពលទី៣ ទៅបាន បងសោម ឡើងអនុវិញ អាហ្នឹងខ្ញុំនិយាយពីអំឡុង៧៥វិញ។ ស៖ នៅមួយពេលនោះគឺ មុត - តាមុត គាត់បានចាកចេញពីតំបន់ ហើយទៅមានតួនាទីថ្មីផ្សេងមួយទៀត។ តើអីចឹងមែនទេ? ឆ៖ ក្រោយពីមើលពី៧៣មក ខ្ញុំដឹងមកគាត់តំបន់មែន តែមុន៧៥ ប្រហែលជាខ្ទង់ ៧៤អីនេះ គាត់ឡើងទៅកាន់កងពលថ្មី គាត់ទៅខាង គាត់នៅខាងកងពលទី៣។ ដូច្នេះគាត់ផុតពីតំបន់បាន បងសោម ឡើងលេខាវិញ។ ស៖ តើមន្ទីររបស់លោកមានទីតាំងនៅកន្លែងណាឱ្យពិតប្រាកដទៅនៅក្នុងស្រុកអង្គរជ័យនោះនៅពេលដែលលោកធ្វើជានីរសារចន្លោះពីឆ្នាំ១៩៧៣ ទៅដល់ខែកញ្ញា ១៩៧៥ នោះ? ឆ៖ ចូល៧៣ មកដល់ ៧៥ វាមានផ្លាស់កន្លែង ខ្ញុំនៅពីភ្នំស្រមោច ដំរី រមៀលនេះមក ខ្ញុំមកផ្លាស់នៅក្បាលថ្នល់អង្គគ្រៀវមួយរយៈ ពី៧៥ ហើយអាហ្នឹងមកនៅដល់ហ្នឹង គឺនៅក្បាលថ្នល់ខាងអង្គគ្រៀវហ្នឹង នៅជិតផ្លូវជាតិហ្នឹង ហើយនិងស្រុកអង្គរជ័យដដែល"]។ ឯកសារ D54/62 ម៉ឹង វេត កំណត់ហេតុនៃការស្តាប់ចម្លើយ ឆ.១៥-២១ ["ស១៥៖ តើពេលណាដែលលោកបានឃើញ មាស មុត នៅគណៈតំបន់១៣ ហើយគាត់នៅគណៈតំបន់ហ្នឹង ពីពេលណាដល់ពេលណា? ឆ.១៥៖ នៅពេលដែលខ្ញុំចូលចលនាបដិវត្តន៍ឆ្នាំ១៩៧៣ ខ្ញុំបានឃើញគាត់នៅគណៈតំបន់រួចហើយ។ ប្រហែលឆ្នាំ១៩៧៤ មាស មុត បានទៅកាន់កងទ័ព នៅពេលភូមិភាគនិរតីរៀបចំកងពលលេខ៣។ បន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ គាត់បានទៅកំពង់សោម។ ស៖ តើ មាស មុត ជាមេបញ្ជាការកងពលលេខ៣ដំបូងគេនៅពេលបង្កើតឬ? ឆ.១៦៖ បាទ។ ស៖ នៅពេលដែលលោកឃើញ មាស មុត ដំបូងនៅគណៈតំបន់១៣ តើលោកដឹងថា តួនាទី និងមុខងាររបស់គាត់ជាអ្វី? ឆ.១៧៖ គាត់នៅក្នុងគណៈតំបន់ហ្នឹង ហើយទទួលខុសត្រូវខាងយោធា។ [...] ឆ.១៨៖ មានយោធារាប់ពាន់នាក់ស្ថិតនៅក្រោមបញ្ជារបស់ មាស មុត ក្នុងតំបន់១៣។ នៅពេលនោះមិនទាន់មានជាវរៈសេនាធំ ឬក៏កងពលនៅឡើយទេ គ្រាន់តែមានវរៈសេនាតូចតែប៉ុណ្ណោះ។ ស៖ តើលោកមានចាំលេខកងវរៈសេនាតូចនៅក្នុងតំបន់ ១៣ ដែលស្ថិតនៅក្រោមបញ្ជារបស់ មាស មុត ដែរឬទេ? ឆ.១៩៖ ខ្ញុំចាំកងវរៈសេនាតូច ត១១០ ស្ថិតនៅក្រោមឈ្មោះ ជួង និងប៉ាវ ដែលត្រូវបាន មាស មុត យកទៅកំពង់សោមជាមួយគាត់។ កង២៧ ជាកងនាវាចាស់ ដែលត្រូវបានបង្កើតតាំងពីមុនឆ្នាំ១៩៧៣។ ក្រៅពីនេះខ្ញុំមិនចាំទេ។ ស៖ តើទីតាំងកង ២៧ ស្ថិតនៅកន្លែងណា ហើយប្រតិបត្តិការនៅកន្លែងណាមុនឆ្នាំ១៩៧៣? ឆ.២០៖ កងវរៈសេនាតូច២៧ ស្ថិតនៅក្រោមបញ្ជា មាស មុត គេហៅថាកងជើងទឹក តាំងពីមុខពេលខ្ញុំចូលចលនាបដិវត្តន៍ក្នុងឆ្នាំ១៧៣ម្លេះ។ កងនេះប្រតិបត្តិការនៅតំបន់ខាងត្បូងខេត្តតាកែវ គេពុំមានទូកឬកាណូតអ្វីទេ។ ជាទូទៅគេធ្វើការប្រតិបត្តិការនៅលើដីគោក។ តំបន់ក្នុងស្រុកកោះអណ្តែត ខេត្តតាកែវ គឺលិចទឹកស្មើរតែទាំងស្រុកនៅរដូវវស្សារ។ នៅពេលនោះយោធា ក្នុងកងជើងទឹកនេះប្រើដើមចេក ឫស្សីសម្រាប់ហែល

45. នៅឆ្នាំ ១៩៧៣ ឬដើមឆ្នាំ ១៩៧៤ **មាស មុត** ត្រូវបានតែងតាំងជាមេបញ្ជាការកងពល ៣ ដែលទើបនឹងបង្កើតថ្មីក្នុងភូមិភាគនិរតី[123]។ គាត់ "ទទួលខុសត្រូវលើការផ្គត់ផ្គង់ស្បៀងអាហារ គ្រាប់

---

ដើម្បីធ្វើប្រតិបត្តិការក្នុងតំបន់នោះ។ សៈ លោកបាននិយាយថា កង២៧ ថាជាកងជើងទឹក។ តើកងជើងទឹកហ្នឹងប្រជាជនហៅថាអីចឹង ឬក៏ឈ្មោះផ្លូវការរបស់ថ្នាក់លើហៅថាជាកងជើងទឹក តាំងពីមុនឆ្នាំ១៩៧៣មក? ឆ.២១៖ ជាទូទៅប្រជាជនតែងតែហៅពួកគេថាជាកងជើងទឹក ពីព្រោះគេតែងតែឃើញកងហ្នឹងប្រតិបត្តិការនៅលើទឹក"]។ ឯកសារ D4.1.783 ពេជ្រ ជឹម កំណត់ហេតុនៃការស្តាប់ចម្លើយ KH 0037348 ["សមាជិកតំបន់ឈ្មោះ មាស មុត ទទួលបន្ទុកយោធា"]។ ឯកសារ D4.1.784 ពេជ្រ ជឹម កំណត់ហេតុស្តាប់ចម្លើយ KH 00373387 ["សមាសភាពគណៈតំបន់១៣ រួមមាន តា សោម ជាលេខា និង ផែន ជាអនុលេខា និង តាមុត សមាជិក"]។ ឯកសារ D54/99.1 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឡាយ ប៊ុនហាក់ KH 00990753 ["សៈ តំបន់១៣ កាលហ្នឹងតំបន់តាកែវ តំបន់១៣ ពីណាគ្រប់គ្រង"]? ឆៈ ឈ្មោះលោកមេបញ្ជាការលោក សោម អីសោមទេ ខ្ញុំអត់ស្គាល់ទេ។ សៈ តាសោម ហី? ឆៈ ឈ្មោះតាសោមហ្នឹង បន្ទាប់មកបាន មាស មុត។ សៈ បាទ! តាមុត គាត់ធ្វើខាងអី? ឆៈ តាមុត គាត់ខាងអី មេមុតកាលហ្នឹងគាត់ធ្វើខាង ខាងកិច្ចការងាររដ្ឋបាល។ សៈ ខាងរដ្ឋបាលតំបន់១៣ហ្នឹង? ឆៈ បាទ! តាសោមគាត់ខាងយោធា"]។ ឯកសារ D54/60.2 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ម៉ឹង វេត KH 00975714-15 ["សៈ តា មុត ហ្នឹងគាត់ធ្វើជា? ឆៈ គណៈតំបន់១៣។ សៈ គណៈតំបន់មាន តា មុត? ឆៈ មាន តាមុត មាន តា សោម"]។ ឯកសារ D59/1/1.8a កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ព្រំ សារ៉ាត់ KH 00926348 ["សៈ ចុះកាលជំនាន់នឹង តាមុត គាត់នៅណា? ឆៈ តាមុត មាសមុតនេះគាត់នៅតំបន់ ១៣ ហៅថាតំបន់តាកែវ។ សៈ ប៉ុនស្រុកកំណើតគាត់នៅខាងនឹងដែរតើ? ឆៈ គាត់នៅស្រែក្នុង។ សៈ ប៉ុន្តែគាត់ពេលតស៊ូ គាត់មកនៅខាងតំបន់១៣ វិញ ខាងតាកែវវិញ? ឆៈ បាទ"]។

122 ឯកសារ D54/110 លុន សេង កំណត់ហេតុស្តាប់ចម្លើយ ឆ.២៧ ["មាស មុត ជាសមាជិកពេញសិទ្ធិរបស់បក្ស។ ចំពោះខ្ញុំៗក្លាយជាសមាជិកពេញសិទ្ធិរបស់បក្សតាំងពីឆ្នាំ១៩៧៣ ម្លេះ។ មាស មុត ជាសមាជិកពេញសិទ្ធិរបស់បក្សមុនខ្ញុំទៅទៀត ពីព្រោះគាត់ចូលបដិវត្តន៍តាំងពីយូរណាស់មកហើយ តាំងពីឆ្នាំ១៩៦០"]។

123 ឯកសារ D22.2.181 ចម្លើយ មាស មុត ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០១ KH 00741996 ["ក្នុងឆ្នាំ១៩៧៤ លោកត្រូវបានតែងតាំងឱ្យធ្វើជាមន្ត្រីនយោបាយទទួលបន្ទុកកងពលធំលេខ ៣"]។ ឯកសារ D22.2.182 182 ចម្លើយ មាស មុត ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២ KH 00741991 ["នៅខែមីនា ឆ្នាំ១៩៧៤ គេបានផ្ទេរឧត្តមសេនីយ៍ត្រី មុត ទៅកាន់តំបន់ភូមិភាគនីរតីក្នុងនាមជាមេបញ្ជាការកងពលធំលេខ ៣"]។ ឯកសារ D114/297.1. 22 ម៉ឹង វេត ប្រតិចារឹក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ ម៉ 09.59.38-10.03.14 ["មុន៧៥ ប្រហែលជាខ្ទង់៧៤អីនេះ គាត់ឡើងទៅកាន់កងពលថ្មី គាត់ទៅខាង គាត់នៅខាងកងពលទី៣"] បញ្ជាក់ពី ឯកសារ D54/62 ម៉ឹង វេត កំណត់ហេតុស្តាប់ចម្លើយ ឆ.១៥ ["ប្រហែលឆ្នាំ១៩៧៤ មាស មុត បានទៅកាន់កងទ័ព នៅពេលភូមិភាគនិរតីរៀបចំកងពលលេខ៣"]។ ឯកសារ D54/98 ប៉ាង វ៉េត កំណត់ហេតុស្តាប់ចម្លើយ ឆ.៣៨ ["មាស មុត ត្រូវបានតែងតាំងជាមេបញ្ជាការពលលេខ ៣ នៅក្នុងឆ្នាំ១៩៧៣ នៅពេលដែលកងពលនេះត្រូវបានបង្កើតឡើង"]។ ឯកសារ D54/99.1 កិច្ចសម្ភាសន៍

រំសេវ និងអាវុធ"[124]។ គាត់ក៏មានតួនាទីជាគ្រូបង្វឹកយោធានៅភ្នំដំរីរមៀល ស្ថិតនៅតាមព្រំដែននៃខេត្តកំពង់ស្ពឺ កំពត និងតាកែវទៀតផង[125]។

46. នៅថ្ងៃ ឬនៅប្រហែលថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៧៥ **មាស មុត** បានរៀបចំកិច្ចប្រជុំមួយនៅភូមិរោងដំរី ស្រុកត្រពាំងឈូក ខេត្តកណ្ដាល ដែលក្នុងអំឡុងពេលប្រជុំនោះ គាត់បានដឹកនាំទាហាននៅក្រោមអំណាចរបស់គាត់ឲ្យត្រៀមវាយប្រហារទីក្រុងភ្នំពេញ។ គាត់បានប្រគល់អាវុធថ្មីៗទៅឲ្យទាហាន និងបានប្រាប់ពួកគេថា ការវាយប្រហារនោះនឹងកើតមានក្នុងរយៈពេលបីថ្ងៃ[126]។ ពីរបីថ្ងៃក្រោយមក កងពល ៣ ក្រោមការដឹកនាំរបស់ **មាស មុត** បានចូលរួមការវាយលុកចុងក្រោយលើទី

---

មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ KH 00990755 ["ស៖ អញ្ចឹងអង្គភាពថ្មីហ្នឹង គេទើបបង្កើតថ្មីទេ កងពលលេខបីហ្នឹង [នៅពេលណាគេដកលោកមកកងពលទី៣ហ្នឹង ក្នុងឆ្នាំ១៩៧៤]? ឆ៖ បាទ! បង្កើតថ្មី។ ស៖ ពីណាគេទទួល? ឆ៖ ដឹកនាំដោយលោកអើ មាស មុត"]។ ឯកសារ D114/29.1.4 ប៉ែន យៀនិន របបប៉ុល ពត KH 00637489-90 ["ក្នុងឆ្នាំ១៩៧៣ មុត បានឡើងជាលេខាធិការកងពលធំទី៣ភូមិភាគនិរតី"]។ ឯកសារ D1.3.7.9 ទស្សនាវដ្ដី ស្វែងរកការពិត ខ្ញុំចង់បានតែយុត្តិធម៌ ចេញខែ សីហា ឆ្នាំ២០០០ EN 00204275 ["នៅឆ្នាំ១៩៧៣ មាស មុត ជាលេខាតំបន់កងពល៣ ដែលទើបតែតាំងតាំង"]។

124 ឯកសារ D54/41 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ សាវ៉ាន់ ឆ.៨-៩ ["ខ្ញុំដឹងថា មេបញ្ជាការកងពលមានតែម្នាក់ទេគឺ មាស មុត។ មាស មុត គឺជាមេបញ្ជាការកងពលលេខ ៣ បញ្ជាផ្ទាល់ទៅកងវរៈសេនាធំ និងវរៈសេនាតូចទាំងអស់។ ស៖ នៅពេលដែលលោកនិយាយថា មាស មុត ជាមេបញ្ជាការរបស់កងពលទូទៅហ្នឹង តើលោកអាចរៀបរាប់ថាតើ មាស មុត ទទួលខុសត្រូវអ្វីខ្លះ? ឆ.៩៖ មាស មុត ទទួលខុសត្រូវរួមក្នុងកងពលទាំងអស់ រួមមានស្បៀងអាហារ គ្រាប់រំសេវ និងសព្វាវុធ"]។

125 ឯកសារ D114/82 កំណត់ហេតុស្តាប់ចម្លើយ កែវ សាន ឆ.៧ ["ខ្ញុំស្គាល់ឈ្មោះគាត់ចាប់តាំងពីឆ្នាំ១៩៧៣មក។ មាស មុត ជាអ្នកបង្រៀនផ្នែកយោធានៅភ្នំដំរីរមៀលដែលជាភ្នំជាប់ព្រំប្រទល់ខេត្តចំនួនបី គឺខេត្តកំពង់ស្ពឺ ខេត្តកំពត និងខេត្តតាកែវ"]។

126 ឯកសារ D54/46 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.៣១, ៣៣ ["នៅពេលដែលគាត់មកប្រជុំ ហើយប្រកាសថា កងវរៈសេនាតូច ៤៥០ ជាកងពិសេសចំណុះកងពលលេខ៣ ដោយមិនចំណុះឲ្យកងវរៈសេនាធំណាមួយទេ។ គាត់ប្រកាសថា ពីខែកុម្ភៈ ឆ្នាំ១៩៧៥ ទៅ គឺត្រូវរៀបចំដើម្បីវាយរំដោះភ្នំពេញ។ ដូច្នេះការប្រយុទ្ធគឺធ្វើតាមកងថ្មើរជើង និងត្រូវមានជំនួយពីកងវរៈសេនាតូចពិសេស៤៥០។ ពីព្រោះកងវរៈសេនាតូចពិសេស៤៥០នេះ មានប្រាំពីរកងអនុសេនាធំ [...] ស៖ តើលោកនៅចាំថា មាស មុត មាននិយាយអ្វីទៀតទេ នៅក្នុងអង្គប្រជុំនោះ? ឆ.៣៣៖ ការប្រជុំនោះធ្វើចំនួន ៣ថ្ងៃ ពីថ្ងៃទី១១ ដល់ថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៥។ ការប្រជុំនោះធ្វើនៅភូមិរោងដំរី ឃុំត្រពាំងឈូក ក្នុងខេត្តកណ្ដាល។ មាស មុត បានប្រាប់ថា ត្រូវរំដោះទីក្រុងភ្នំពេញក្នុងរយៈពេល៧ថ្ងៃ ដោយផ្លាស់ប្ដូរអាវុធចាស់ បំពាក់អាវុធថ្មី"]។

ក្រុងភ្នំពេញ[127]។ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ **មាស មុត** បានបញ្ជាសមរភូមិភាគខាងជើងនៃផ្លូវជាតិលេខ ៤ និងបានរៀបចំកិច្ចប្រជុំជាមួយប្រធានកងវរសេនាធំ និងកងវរសេនាតូច ដើម្បីកំណត់គោលដៅប្រយុទ្ធ[128]។ បន្ទាប់ពីពួកខ្មែរក្រហមឡើងកាន់កាប់ទីក្រុងភ្នំពេញរួចមក **មាស មុត** ត្រូវបានផ្ទេរទៅកំពង់សោម រួមជាមួយនឹងកងពល ៣[129]។

---

127 ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.៦-៧ ["ស៖ ពេលដែលវៃចូលភ្នំពេញ តើអ្នកណាជាអ្នកបញ្ជាកងពលលេខ៣ ឲ្យវៃ? ឆ.៦៖ តា មុត ដែលជាមេបញ្ជាការកងពលលេខ៣។ ស៖ ពេលវៃចូលភ្នំពេញ តើទីបញ្ជាការរបស់កងពលលេខ៣ ស្ថិតនៅកន្លែងណា? ឆ.៧៖ ទីបញ្ជាការកងពលលេខ៣របស់ មាស មុត ស្ថិតនៅភ្នំថ្នាតពង អំឡុងពេលវៃចូលភ្នំពេញ"]។ ឯកសារ D114/29.1.4 ប៉ែន យៀនិន របបប៉ុល ពត KH 00637407-8 ["កម្លាំងផ្សេងៗទៀត ដែលចូលប្រឡូកក្នុងការវាយប្រយុទ្ធនេះដែរ មានកងពលធំលេខ៣ នៃភូមិភាគនិរតីដែលដឹកនាំដោយមេបញ្ជាការឈ្មោះ មុត ជាកូនប្រសាប្រុសរបស់លេខាធិការភូមិភាគនេះឈ្មោះ ម៉ុក និងកងពលធំលេខ១ នៃភូមិភាគនិរតីដែលដឹកនាំដោយ ប៉ែត សឿង ដែលសម្រុកចូលព្រលានយន្តហោះពោធិ៍ចិនតុងពីទិសបស្ចិម តាមផ្លូវជាតិលេខ៤។ ចំពោះកងកម្លាំងរបស់ភូមិភាគខាងជើងវិញ បានចលនាកម្លាំងចុះតាមបឹងទន្លេសាបតាមផ្លូវជាតិលេខ៥។ ពួកគេត្រូវបានប្រមែប្រមូលយ៉ាងប្រញាប់ យកមកឈរជើងនៅក្នុងទីតាំងរៀបចំជើងព្រួលដោយមានកងអង្គភាពយ៉ាងច្រើន បានធ្វើដំណើរថ្មើរជើងលើចម្ងាយផ្លូវជាងរយគីឡូម៉ែត្រ ដើម្បីចាប់ផ្តើមធ្វើការវាយប្រហាផ្តាច់ព្រ័ត្រនៅថ្ងៃ១៤ ខែមសារ។ នៅខណៈនោះ ពួកគេបានរុលទៅមុខយ៉ាងលឿន រហូតទាល់តែដាច់ខ្សែរយៈទាក់ទងជាមួយទីបញ្ជាការរបស់ខ្លួនអស់រយៈពេល២៤ម៉ោង"]។

128 ឯកសារ D54/46 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.៣៥ ["នៅថ្ងៃទី១ យើងវៃបន្ទាយវត្តដើមពោធិ៍ ស្ថិតនៅខាងជើងផ្លូវជាតិលេខ៤ ខាងលិចផ្លូវរថភ្លើង ហើយយើងបានកាន់កាប់ទីតាំងបន្ទាយនោះ។ នៅពេលនោះកងកម្លាំងទាហានលន់ នល់ បានដកថយមកំបូល។ នៅថ្ងៃទី២ មានបញ្ជាពី មាស មុត ឲ្យអនុសេនាធំចំនួន២ (អនុសេនាធំទី២ និងទី៣) ធ្វើការវៃវ៉ាសំរោង។ ហើយនៅពេលនោះយោធាពីភូមិភាគពិសេសមកជួយវៃពីទីសខាងជើង។ យើងបានកាន់កាប់វ៉ាសំរោងនោះ តែយើងមិនបោះទីតាំងនៅទីនោះទេ ហើយមកបោះទីតាំងស្នាក់នៅវត្តជិពូវ័ន្ត។ នៅថ្ងៃទី៣ មានបញ្ជាពីកងពលដាក់ទិសដៅឲ្យវៃសម្រុកទៅមុខទៅចោមចៅ។ ដូច្នេះយើងបានវាយរំដោះចោមចៅ និងពោធិ៍ចិនតុង នៅថ្ងៃនោះគឺថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥"]។ ឯកសារ D54/30 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.៨-១០ ["កងវរៈសេនាតូច ៥៥០ ត្រូវបានបង្កើតឡើងប្រហែលពីរខែមុនបែកភ្នំពេញ ក្នុងខែមេសា ឆ្នាំ១៩៧៥។ វរៈសេនាតូចនេះ ត្រូវបានគេហៅថាវរៈសេនាតូចពិសេស ហើយយោធាក្នុងកងនេះគឺដកយកមកពីកងផ្សេងយកមកបញ្ចូលគ្នា។ កងវរៈសេនាតូចពិសេសនេះ ដែលឋិតក្រោមមេបញ្ជាសមរភូមិតំបន់ខាងជើងផ្លូវជាតិលេខ ៤ គឺមាសមុត។ ស៖ ក្នុងពេលវាយចូលភ្នំពេញ មាស មុត ជាមេបញ្ជាការសមរភូមិខាងជើងផ្លូវជាតិលេខ ៤ ក្នុងពេលនោះ តើកងពលណាឋិតនៅក្រោមបញ្ជាការរបស់គាត់? ឆ.៩៖ កងពលលេខ ៣ នៅក្រោមបញ្ជាការរបស់ មាស មុត នៅពេលនោះ។ ស៖ ក្នុងនាមជាមេបញ្ជាការសមរភូមិ តើមុខងាររបស់គាត់ធ្វើអ្វីខ្លះ? ឆ.១០៖ ក្នុងនាមជាមេបញ្ជាការសមរភូមិ គាត់ប្រជុំជាមួយប្រធានប្រធានវរៈធំ/វរៈសេនាតូច ដើម្បីចាត់តាំងមុខព្រួញប្រយុទ្ធ។ ហើយគាត់នៅខ្សែត្រៀមខាងក្រោយជាមួយកាំភ្លើងត្បាល់

47. ភាពជោគជ័យយ៉ាងឆាប់រហ័សរបស់ **មាស មុត** តាមរយៈឋានៈយោធា និងនៅក្នុងថ្នាក់ដឹកនាំបក្ស ត្រូវបានផ្សារភ្ជាប់ទៅនឹងទំនាក់ទំនងយ៉ាងជិតស្និទ្ធរបស់គាត់ជា មួយនឹងលេខាធិការភូមិភាគនិរតី និងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ឈិត ឈឿន ហៅ តា ម៉ុក។ **មាស មុត** បានជួប តា ម៉ុក នៅពេលដែលគាត់រៀននៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត និងស្នាក់នៅវត្តមួយដែលគ្រប់គ្រងដោយ

---

១០៥ មីលីម៉ែត្រ"]។ ឯកសារ D114/25 កំណត់ហេតុស្ដាប់ចម្លើយ អ៊ូ ដាវ ឆ.៩ ["ពេលហ្នឹងខ្ញុំចាំថា កាលពីថ្ងៃទី១៧ មេសា ១៩៧៥ ពេលដែលខ្ញុំចូលមកដល់ព្រលានយន្តហោះពោធិ៍ចិនតុងដំបូង ក៏ខ្ញុំបានឃើញ មាស មុត ក្រោយមក ឃើញ ស៊ូ ម៉េត ហើយនិង តាម៉ុក ក៏បានចូលមកក្នុងព្រលានយន្តហោះដែរ។ កាលពីជំនាន់សង្គ្រាម មាស មុត គាត់ជា បញ្ជាការទី២ ក្នុងសមរភូមិខាងត្បូងផ្លូវជាតិលេខ៤ ជាមេកងពលលេខ២ និងលេខ៣។ កាលពីពេលហ្នឹង ស៊ូ ម៉េត ជា មេបញ្ជាការនៅក្នុងសមរភូមិខាងជើងផ្លូវជាតិលេខ៤"]។

129 ឯកសារ D22.2.182 182 ចម្លើយ មាស មុត ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម ចុះថ្ងៃទី ៣០ ខែឧសភា ឆ្នាំ២០០២ KH 00741991 ["នៅពេលទីក្រុងភ្នំពេញ ត្រូវបានរំដោះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងពលធំលេខ ៣ បានទទួលបញ្ជាឲ្យដកថយទៅកាន់ខេត្តកំពង់សោម"]។ ឯកសារ D54/62 កំណត់ហេតុស្ដាប់ ចម្លើយ ម៉ឹង វេត ឆ.១៥ ["បន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ គាត់បានទៅកំពង់សោម"]។ ឯកសារ D114/286 កំណត់ហេតុស្ដាប់ចម្លើយ ប៊ាង រ៉េត ឆ.៣៥-៣៦ ["សៈ យើងនិយាយគ្នាពីពេលវេលាម្ដង កាលពីសម្ភាសន៍មុនលោក បានប្រាប់ថា នៅភ្នំពេញបានតែមួយថ្ងៃទេ បន្ទាប់ពីភ្នំពេញដួលរលំ ហើយបន្ទាប់មកលោកធ្វើដំណើរទៅកំពង់សោម ដោយប្រើពេល៤ថ្ងៃ។ ហើយគេសួរថាតើលោកមានចាំទេ ប្រហែលប៉ុន្មានថ្ងៃបានតាមុត គាត់ទៅដល់កំពង់សោម? ឆ. ៣៥៖ ខ្ញុំទៅមុន ហើយតាម៉ុក គេមកទទួលតាំងពីដោះកញ្ចោ តាម៉ុក គាត់បើកឡានអាស្សីបមកទទួលយើងទៅកំពង់ សោម។ តាមុត មិនដឹងទៅតាំងពីពេលណា ទាល់តែក្រោយមកបានឃើញ តាមុតទៅប្រជុំ សៈ ពេលដែលលោក ឃើញតាមុត ដំបូងនៅកំពង់សោម ប្រហែលជាពេលណាប៉ុន្មានអាទិត្យ? ឆ.៣៦៖ ប្រហែលជា២ ទៅ៣អាទិត្យ ក្រោយពេលការមកដល់របស់ខ្ញុំ គាត់ទៅប្រជុំប្រកាសរៀបរយ"]។ ឯកសារ D54/100 កំណត់ហេតុស្ដាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.៨៨-៨៩ ["កងពលលេខ៣ បានប្ដូរមកជាកងពលលេខ១៦៤ នៅពេលផ្លាស់មកកំពង់សោម មេ បញ្ជាការមុនគឺឈ្មោះ តារិន នៅពេលត្រូវបានផ្លាស់មកកំពង់សោមគឺតាមុត ជាអ្នកគ្រប់គ្រងវិញ។ សៈ តើការផ្លាស់ប្ដូរ មេបញ្ជានៅពេលណា? ឆ.៨៩៖ កងពលលេខ៣ កំពុងប្រយុទ្ធនៅភ្នំពេញគឺមានមេបញ្ជាការ តារិន ពេលប្ដូរមកកំពង់ សោម ក៏ដូរមកតាមុត វិញនៅឆ្នាំ១៩៧៥ ពេលរំដោះភ្នំពេញ"]។ ឯកសារ D114/186 កំណត់ហេតុស្ដាប់ចម្លើយ សាត ចក់ ឆ.១៦ ["ជំនាន់នោះ គឺរំដោះហើយ១៩៧៥ ពេលនោះគឺគេធ្វើការរើសកងទ័ពជើងទឹក នៅក្នុងកងពលលេខ ៣ គឺ មកនៅកំពង់សោមទាំងអស់ ហើយកងពលនេះគឺ មាស មុត ជាអ្នកដឹកនាំទាំងអស់ ទើបគេបានរើសយកកងពលលេខ ៣ មកកាន់កាប់នៅជើងទឹកទាំងអស់។ ក្រោយមក គេប្រមូលកងពល៣មកដាក់កំពង់សោម ហើយទើបគេរៀបចំអង្គ ភាពហ្នឹងថ្មីហើយដាក់ឈ្មោះថាកងពលលេខ១៦៤"]។ ឯកសារ D4.1.784 ពេជ្រ ជឹម កំណត់ហេតុស្ដាប់ចម្លើយ KH 00373387 ["២-៣ ខែក្រោយថ្ងៃរំដោះ១៧ មេសា ១៩៧៥ មាស មុត និងប្រពន្ធរបស់គាត់ឈ្មោះ ខុម ត្រូវបានផ្លាស់ ទៅកាន់កាប់កំពង់ផែកំពង់សោម នៅក្នុងអង្គភាពជើងទឹក"]។

តា ម៉ុក និងបក្សកុម្មុយនីស្តកម្ពុជា[130]។ ក្រោយមក គាត់ត្រូវបានជ្រើសរើសឲ្យចូលរួមជាមួយចលនាខ្មែរក្រហម និងបានរៀបការជាមួយកូនស្រីរបស់ តា ម៉ុក យាយ ខុម មុនឆ្នាំ ១៩៧៣[131]។ តា ម៉ុក ត្រូវគេស្គាល់ថាជាអ្នកគាំទ្រសាច់ញាតិរបស់គាត់ ដោយតែងតាំងពួកគេឲ្យកាន់តំណែងដ៏មានអំណាច ជាពិសេសនៅក្នុងភូមិភាគនិរតី[132] ហើយ **មាស មុត** ក៏មិនមែនជាករណីលើកលែង

130 ឯកសារ D114/159 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ឆ.៩ ["មាស មុត ក៏ជាប់សាច់ឈាមបងម៉ុក ដែរ ហើយជាសង្ឃរៀននៅពុទ្ធវិទ្យាល័យព្រះសុរាម្រិត គង់នៅកុដិដែលបងម៉ុក គាត់សង់នៅវត្តមហាមន្ត្រី។ កុដិនេះគ្រប់គ្រងដោយសាខាបក្សកុម្មុយនីស្តកម្ពុជា គ្រប់គ្រងដោយបងម៉ុក អាកុដិហ្នឹង។ គេជ្រើសរើសមនុស្សអីចឹង"]។

131 ឯកសារ D22.2.181 ចម្លើយ មាស មុត ពាក់ព័ន្ធនឹងល្បើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០១, KH 00741996 ["លោក មាស មុត បានចូលរួមក្នុងចលនាខ្មែរកុម្មុយនិស្តនៅខែឧសភា ឆ្នាំ១៩៧០"]។ ឯកសារ D54/70 កំណត់ហេតុស្តាប់ចម្លើយសាក្សី មុត ម៉ៅ, ឆ.១៥ ["សៈ តើយាយខុម រៀបការជាមួយ មាស មុត ហើយឬនៅ កាលឆ្នាំ១៩៧៣? ឆៈ ចាស គាត់រៀបការជាមួយគាត់ហើយពេលដែលខ្ញុំទៅនៅជាមួយគាត់ក្នុងឆ្នាំ១៩៧៣ ហើយ។ ខ្ញុំមិនដឹងថាគាត់រៀបការនៅពេលណាទេ តែនៅពេលដែលខ្ញុំទៅនៅជាមួយគាត់ដំបូង គាត់មានកូនរួចហើយ។"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយសាក្សី កង ស៊ុំ ឆ.៣៨ ["សៈ ចុះ តាមុត និង តាម៉ុក មានទំនាក់ទំនងអ្វីនឹងគ្នា? ឆៈ តាមុត និងតាម៉ុក ជាកូនប្រសារ និងឪក្មេក"]។ ឯកសារ D114/82 កំណត់ហេតុស្តាប់ចម្លើយសាក្សី កែវ សាន ឆ.៨ ["សៈ តើលោកដឹងថាប្រពន្ធទី១របស់ មាស មុត ជាកូនស្រីរបស់ តា ម៉ុក ដែរឬទេ? ឆៈ បាទ ខ្ញុំដឹងពីរឿងនេះ តែខ្ញុំអត់ស្គាល់ឈ្មោះប្រពន្ធរបស់គាត់ទេ"]។ ឯកសារ D59/2/4.16a កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ សេង សឿន KH 00059330 ["មាស មុត ហើយកូនប្រសារតាម៉ុកនោះ"]។ ឯកសារ D1.3.32.28 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ មាស ចាន់ណា KH 00020374 ["តាមុត ហ្នឹង អើខ្សែរយៈគាត់ តា ម៉ុក តាម៉ុកអីអស់ហ្នឹង។ សៈ តាមុត ត្រូវជាម៉េច? ឆៈ ត្រូវជាកូនប្រសារគាត់"]។

132 ឯកសារ D114/159 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅឌុច ឆ.៩ ["ប៉ុល ពត តាមរយៈ សុន សេន និង តាម៉ុក។ តាមគោលការណ៍ដែលមានចែងក្នុងលក្ខន្តិកៈបក្ស គេត្រូវជ្រើសរើសតាមគោលការណ៍១០ខ នៃការកសាងកម្មាភិបាលបក្ស។ តែក្នុងការអនុវត្ត គេជ្រើសរើសមនុស្សតាមខ្សែគ្រួសារ។ ជាក់ស្តែង សំ ប៊ិត កូនក្មួយបងម៉ុក។ គាត់របររកស៊ីពីមុនជាស្តេចល្ខោន។ មាស មុត ក៏ជាប់សាច់ឈាមបងម៉ុកដែរ [...] គេជ្រើសរើសមនុស្សអញ្ចឹង។ [...] គេរើសតាមខ្សែចាត់តាំង"]។ ឯកសារ D114/29.1.4 Ben Kiernan របបប៉ុលពត KH 00637605-06 ["មកត្រឹមឆ្នាំ ១៩៧៥ រដ្ឋបាលភូមិភាគត្រូវបានត្រួតត្រាដោយម៉ុក ដែលជាសមាជិកគណៈអចិន្ត្រៃយ៍បក្ស និងបងប្អូនថ្លៃ កូនស្រីកូនប្រុស និងកូនប្រសាររបស់គាត់សរុបទាំងអស់ ១៣ នាក់ទៀត។ ពេលដែលឥទ្ធិពល និងអំណាចរបស់ម៉ុកកាន់តែខ្លាំងក្លាឡើង បងប្អូនញាតិសណ្តានរបស់គាត់បានឡើងមុខតំណែងជាបន្តបន្ទាប់។ ក្នុងឆ្នាំ ១៩៧៦ កូនស្រីរបស់គាត់ឈ្មោះ ខុម ត្រូវបានដំឡើងពីមុខនាទីលេខាបក្សស្រុកត្រាំកក់ ឲ្យទៅជាអនុលេខាតំបន់ ១៣ មុនពេលដែល ខុម បានស្លាប់ដោយសារជម្ងឺ ក្នុងរយៈពេលមួយឆ្នាំក្រោយពីនោះមក។ ប្អូនថ្លៃប្រុសរបស់ម៉ុក ឈ្មោះសាន ដែលជាអតីតគ្រូបង្រៀនបានឡើងមុខនាទីជាលេខាស្រុកត្រាំកក់នាឆ្នាំ ១៩៧៧ ១៩៧៨។ ខែ មុត ដែលជាប្តីរបស់ ខុម បានក្លាយជាលេខាក្រុងកំពង់សោម និងជាបញ្ជាការកងនាវាកម្ពុជាប្រជាធិបតេយ្យ។ កូនប្រសារប្រុសទីពីរឈ្មោះបូរ៉ាន់ អាចដើរតាមជំហាន

នោះទេ ពោលគឺ តា ម៉ុក ជាអ្នកទទួលខុសត្រូវលើការតែងតាំង **មាស មុត** ជាសមាជិកនៃគណៈកម្មាធិការតំបន់ ១៣ និងជាមេបញ្ជាការកងពល ៣[133]។

## ២. តួនាទីរបស់ មាស មុត ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

### សមាជិកនៃបក្សកុម្មុយនីស្តកម្ពុជា

48. នៅត្រឹមយ៉ាងហោចណាស់ឆ្នាំ ១៩៧៣ **មាស មុត** បានក្លាយជាសមាជិកពេញសិទ្ធិនៃអ្វីដែលគេស្គាល់ថាបក្សកុម្មុយនីស្តកម្ពុជារួចទៅហើយ[134]។ ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា គាត់ត្រូវបានតម្រូវឲ្យចូលរួមចំណែកក្នុងការរៀបចំ និងបង្កើត "ជំហរនយោបាយមនោគមវិជ្ជា និងអង្គការចាត់តាំងរបស់បក្ស" និងក្នុងការអនុវត្តឲ្យកាន់តែល្អប្រសើរ និងកាន់តែ

---

របស់ម៉ុក ជាលេខាភូមិភាគក្នុងចុងឆ្នាំ ១៩៧៨។ ប្អូនថ្លៃប្រុសទីពីរឈ្មោះ ទិត គឺជាគណៈស្រុក ១០៩។ ក្នុងឆ្នាំ ១៩៧៧ កូនប្រសារប្រុសទីបីឈ្មោះសឿន ត្រូវបានតំឡើងពីបញ្ជាការកងពលធំ ទៅជាលេខាស្រុក ១០៧ ហើយកូនប្រសារប្រុសទីបួនឈ្មោះរ៉េន ដែលជាបញ្ជាការកងពលតូច បានដំឡើងទៅជាបញ្ជាការកងពលធំ។ នៅក្នុងឆ្នាំដដែលនោះ កូនប្រុសរបស់ម៉ុកម្នាក់ឈ្មោះចុង ត្រូវបានដំឡើងពីលេខាស្រុក ៥៥ ទៅជាលេខាតំបន់ ៣៣។"]។

133 ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.៥ ["តាម៉ុកបង្កើតកងពលលេខ ៣ ហើយចាត់តាំងឲ្យ មាស មុត ធ្វើជាប្រធាន។"] ។ ឯកសារ D114/29.1 Ben Kiernan របប ប៉ុល ពត, KH 00637605 ["មកត្រឹមឆ្នាំ ១៩៧៥ រដ្ឋបាលភូមិភាគត្រូវបានត្រួតត្រាដោយម៉ុក ដែលជាសមាជិកគណៈអចិន្ត្រៃយ៍បក្ស និងបងប្អូនថ្លៃ កូនស្រីកូនប្រុស និងកូនប្រសាររបស់គាត់សរុបទាំងអស់ ១៣ នាក់ទៀត។ ពេលដែលឥទ្ធិពល និងអំណាចរបស់ម៉ុកកាន់តែខ្លាំងក្លាឡើង បងប្អូនញាតិសណ្តានរបស់គាត់បានឡើងមុខតំណែងជាបន្តបន្ទាប់។ [...] ខែ មុត ដែលជាប្តីរបស់ ខុម បានក្លាយជាលេខាក្រុង កំពង់សោម និងជាបញ្ជាការកងនាវាកម្ពុជាប្រជាធិបតេយ្យ។ "]។ ឯកសារ D1.3.32.28 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ មាស ចាន់ណា KH 00020374-75 ["ស៖ ចុះមីងនិយាយម៉េចឈ្មោះតាមុតៗ ហ្នឹងត្រូវជាម៉េច? ឆ៖ តាមុត ហ្នឹង អើខ្សែរយៈគាត់ តា ម៉ុក តាម៉ុកអីអស់ហ្នឹង។ ស៖ មាស មុត ហ្នឹងជំនាន់ ... ឆ៖ អើ ខ្សែរយៈគាត់នៅស្រុកនេះ"]។ ឯកសារ D114/159 កំណត់ហេតុស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច, ឆ.៩៖ ["ប៉ុល ពត តាមរយៈ សុន សុន និង តាម៉ុក។ តាមគោលការណ៍ដែលមានចែងក្នុងលក្ខន្តិកៈបក្ស គេត្រូវជ្រើសរើសតាមគោលការណ៍១០ខ នៃការកសាងកម្មាភិបាល បក្ស។ តែក្នុងការអនុវត្ត គេជ្រើសរើសមនុស្សតាមខ្សែគ្រួសារ។ ជាក់ស្តែង សំ ប៊ិត កូនក្មួយបងម៉ុក។ គាត់ របររកស៊ីពីមុនជាស្តេចឈ្លោន។ មាស មុត ក៏ជាប់សាច់ឈាមបងម៉ុកដែរ [...] គេជ្រើសរើសមនុស្សអញ្ចឹង។ [...] គេរើសតាមខ្សែចាត់តាំង"]។

134 ឯកសារ D54/110 កំណត់ហេតុស្តាប់ចម្លើយសាក្សី លុន សេង ឆ.២៧៖ ["មាស មុត ជាសមាជិកពេញសិទ្ធិរបស់បក្ស។ ចំពោះខ្ញុំៗក្លាយជាសមាជិកពេញសិទ្ធិរបស់បក្សតាំងពីឆ្នាំ១៩៧៣ ម្លេះ។ មាស មុត ជាសមាជិកពេញសិទ្ធិរបស់បក្សមុនខ្ញុំទៅទៀត។"]។

មានប្រសិទ្ធភាព នូវ "នយោបាយបក្ស មនោគមវិជ្ជា និងអង្គការចាត់តាំង" ដើម្បីសម្រេចគោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជា[135]។

## សមាជិកគណៈកម្មាធិការមជ្ឈិម

49. **មាស មុត** គឺជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដូចដែលបានបញ្ជាក់ដោយ ខៀវ សំផន ដែលជាប្រមុខរដ្ឋកម្ពុជាប្រជាធិបតេយ្យ និងជាសមាជិកសមមិត្តនៃគណៈកម្មាធិការមជ្ឈិម៖ "គណៈកម្មាធិការមជ្ឈិម មានសមាជិកជាង ៣០ នាក់ [...]។ ក្នុងចំណោមពួកគេ មានម្នាក់ គឺជា **មាស មុត**"[136]។ ដូច្នេះហើយ **មាស មុត** គឺជាសមាជិកម្នាក់ក្នុងចំណោមសមាជិកគណៈ

[135] ឯកសារ D1.3.22.1 លក្ខន្តិកៈបក្សកុម្មុយនីសកម្ពុជា ខែមករា ឆ្នាំ ១៩៧៦ KH 00053016-18 [មាត្រា២៖ អំពីភារកិច្ចរបស់បក្សជន៖ បក្សជនគ្រប់រូបសុទ្ធតែមានភារកិច្ចដូចតទៅ៖ ១. ភារកិច្ចក្នុងមហាជនគឺ៖ ក. ឃោសនាអប់រំមហាជនអំពីនយោបាយ សតិអារម្មណ៍ចាត់តាំងរបស់បក្ស ហើយប្រឡូកជាប់ជិតស្និទ្ធនឹងមហាជន កម្មករ កសិករ ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តត្រូវទទួលខុសត្រូវខ្ពស់ចំពោះមហាជន បម្រើមហាជនអស់ពីចិត្តពីថ្លើម និងគ្មានលក្ខខណ្ឌ រាបសារនឹងមហាជន និងខិតខំរៀនសូត្រពីមហា ជន។ ខ. បំផុសបំផុលចលនាមហាជន ពិសេសមហាជនកម្មករ កសិករ ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តឲ្យក្តៅគគុក និងជាប់ជានិច្ច ក្នុងកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ តាមទិសនៃបដិវត្តសង្គមនិយម និងការកសាងសង្គមនិយម។ ២. ភារកិច្ចផ្ទៃក្នុងគឺ៖ ក. មានជីវភាព ក្នុងអង្គការសាខាបក្សមួយ ទៀងទាត់មួយខែម្តង។ បក្សជនគ្រប់រូប ទោះជាមាននាទីខ្ពស់យ៉ាងណា រហូតដល់ខ្ពស់បំផុតក៏ដោយ ក៏ត្រូវស្ថិតក្នុងសាខាបក្សមួយ ហើយត្រូវមានជីវភាពសាខាទៀងទាត់។ ខ. គោរពអង្គការវិន័យរបស់បក្ស ដោយគ្មានលក្ខខណ្ឌ និងដោយភ្ញាក់រលឹកខ្ពស់។ គ. ខិតខំកសាង គោលជំហរនយោបាយ សតិអារម្មណ៍ ចាត់តាំងរបស់បក្ស ឲ្យកាន់តែជ្រួតជ្រាប កាន់តែរឹងមាំ ដើម្បីអនុវត្តនយោបាយ សតិអារម្មណ៍ និងចាត់តាំងរបស់បក្សឲ្យកាន់តែល្អ និងកាន់តែមានប្រសិទ្ធិភាពឡើងជានិច្ច។ ឃ. ខិតខំថែរក្សា ពង្រឹង ពង្រីកសាមគ្គីភាព ឯកភាពផ្ទៃក្នុងបក្សឲ្យបានល្អជាប់ជានិច្ចដាច់ខាត។ ង. ខិតខំរក្សាការសម្ងាត់របស់បក្សដាច់ខាត ដោយមានគោលជំហរប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ជានិច្ច។ ច. ខិតខំអនុវត្តរបបទិតៀន និងស្វ័យទិតៀន របបត្រួតពិនិត្យ ជីវទស្សនៈបដិវត្តន៍ឲ្យបានត្រឹមត្រូវ ហ្មត់ចត់ និងសកម្មដើម្បីកសាងខ្លួន និងផ្ទៃក្នុងបក្សឲ្យបានជាគំរូល្អ សកម្មប្រយុទ្ធជាប់ជានិច្ច និងកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យតាមទិសបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមរបស់បក្ស។ ឆ. ត្រូវមានគោលជំហរស្នេហាជាតិនិយមអធន និងអន្តរជាតិនិយមអធន ត្រឹមត្រូវ និងរឹងប៉ឹង។ ជ. ខិតខំរៀនសូត្រ វប្បធម៌ បច្ចេកទេស វិទ្យាសាស្ត្រ ដើម្បីបង្កើនសមត្ថភាព បម្រើការងារ ការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យតាមទិសបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមឲ្យកាន់តែល្អ និងកាន់តែមានប្រសិទ្ធិភាព"]។

[136] ឯកសារ D1.3.33.15 កំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ KH 00156619-20 ["គណៈកម្មាធិការមជ្ឈិមមានសមាជិកប្រមាណជា ៣០ នាក់ ប៉ុន្តែខ្ញុំមិនចាំឈ្មោះអស់នោះទេ។ ខ្ញុំចាំដូចជា មាស មុត

កម្មាធិការមជ្ឈិមមួយចំនួនតូច ដែលជាផ្នែកនៃ "អង្គភាពប្រតិបត្តិការខ្ពស់បំផុត នៅទូទាំងប្រទេស" បន្ទាប់ពីសមាជបក្ស[137] និងជាការពិត វាជាអង្គភាពខ្ពស់បំផុតលំដាប់ទីពីរនៅក្នុងរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា[138]។

50. សមាជិកនៃគណៈកម្មាធិការមជ្ឈិម រួមមានសមាជិកពេញសិទ្ធិ សមាជិកបម្រុង និងតាមព្រឹត្តិន័យ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ព្រមទាំងលេខាធិការភូមិភាគ និងតំបន់ រដ្ឋមន្ត្រី និងមេបញ្ជាការកងពល ដូចជា **មាស មុត** ផងដែរ[139]។ អនុលោមតាមលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា

---

(កូនប្រសាររបស់តាម៉ុក ដែលជាលេខានៃកងពលមួយដែលឈរជើងនៅកំពត ហើយក្រោយឆ្នាំ១៩៧៥ ត្រូវបានប្ដូរទៅជាកងទ័ពជើងទឹក) និង សឿ វ៉ាស៊ី ហៅឌឿន (ជាប្រធានមន្ទីរ ៨៧០) ឬផងដែរ កុយ ធួន កែ ពក។ ខ្ញុំខ្លួនឯង ក៏ជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម ជាដំបូង ជាសមាជិកត្រៀមនៅឆ្នាំ ១៩៧១ និងក្លាយជាសមាជិកពេញសិទ្ធិនៅឆ្នាំ ១៩៧៦។ សមាជិកត្រៀមគឺជាអ្វីដែលអ្នកខ្លះបានហៅថាជាសមាជិកបេក្ខជន ប៉ុន្តែតាមដែលខ្ញុំដឹង មិនមានពាក្យសមាជិកបម្រុងនោះទេ។"] សូមមើលផងដែរ ឯកសារ D114/277.8 កាំង ហ្កេកអ៊ាវ ហៅឌុច ប្រតិចារិកចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង 10.57.59-11.00.47 KH 01323392 ["ដូច្នេះ វាពីលើវរសេនាធំ វាមានកងពល កងពលដែលចូលមជ្ឈិមនៅខាងសេនាធិការមានតែពីររូបទេ គឺបងមុត ហើយនិងមិត្តម៉េត"] ។ ឯកសារ D4.1.405 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅឌុច KH 00244235 ["មាស មុត និង សំ ប៊ិត ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការមជ្ឈិមនៅឆ្នាំ ១៩៧៥"]។

137 ឯកសារ D1.3.22.1 លក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា ខែមករា ឆ្នាំ១៩៧៦ KH 00053025 [មាត្រា ៧៖ "ក្នុងរយៈពេលពីមហាសន្និបាតមួយ ទៅមួយទៀត មានអង្គភាពប្រតិបត្តិការខ្ពស់ជាងគេបំផុត សម្រាប់ទូទាំងប្រទេស គឺគណៈកម្មាធិការ មជ្ឈិម"]។

138 ឯកសារ D1.3.33.15 កំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ KH 00156619 ["ជាគោលការណ៍ អង្គការដែលសំខាន់ជាងគេគឺ គណៈកម្មាធិការមជ្ឈិម។ ប៉ុន្តែជាក់ស្តែង គឺគណៈកម្មាធិការអចិន្ត្រៃយ៍"]។

139 ឯកសារ D1.3.33.15 កំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ KH 00156619-20 ["គណៈកម្មាធិការមជ្ឈិមមានសមាជិកប្រមាណជា ៣០ នាក់ ប៉ុន្តែ ខ្ញុំមិនចាំឈ្មោះអស់នោះទេ។ ខ្ញុំចាំដូចជា មាស មុត (កូនប្រសាររបស់តាម៉ុក ដែលជាលេខានៃកងពលមួយដែលឈជើងនៅកំពត ហើយក្រោយឆ្នាំ១៩៧៥ ត្រូវបានប្ដូរទៅជាកងទ័ពជើងទឹក) និង សឿ វ៉ាស៊ី ហៅឌឿន (ជាប្រធានមន្ទីរ ៨៧០) ឬផងដែរ កុយ ធួន កែ ពក។ ខ្ញុំខ្លួនឯង ក៏ជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម ជាដំបូង ជាសមាជិកត្រៀមនៅឆ្នាំ ១៩៧១ និងក្លាយជាសមាជិកពេញសិទ្ធិនៅឆ្នាំ ១៩៧៦។ សមាជិកត្រៀមគឺជាអ្វីដែលអ្នកខ្លះបានហៅថាជាសមាជិកបេក្ខជន ប៉ុន្តែតាមដែលខ្ញុំដឹង មិនមានពាក្យសមាជិកបម្រុងនោះទេ។"]។ ឯកសារ D1.3.30.29 Masato Matsushita និង Stephen Heder កិច្ចសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ KH 00324765 ["កម្មាភិបាលបក្សកុម្មុយនិស្តកម្ពុជាដែលបានចូលរួមក្នុងសមាជបក្សលើកទី៥ ក្នុងឆ្នាំ ១៩៧៨ បានបញ្ជាក់ថា គណៈមជ្ឈិម ភាគច្រើនជាលេខាតំបន់ លេខាភូមិភាគ អនុលេខាភូមិភាគ និងសមាជិកភូមិភាគ"]។ ឯកសារ D4.1.4 Timothy Carney រចនាសម្ព័ន្ធអំណាច- The

ភារកិច្ច និងទំនួលទទួលខុសត្រូវរបស់សមាជិកគណៈកម្មាធិការមជ្ឈិម គឺស្ថិតក្នុងចំណោមភារកិច្ច និងទំនួលខុសត្រូវសំខាន់ៗបំផុតនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងរួមមាន៖ (១) អនុវត្តមាគ៌ានយោបាយបក្ស (២) ណែនាំគណៈកម្មាធិការភូមិភាគ និងតំបន់ទាំងអស់ឲ្យអនុវត្តសកម្មភាពនានាស្របតាមមាគ៌ានយោបាយ និង (៣) គ្រប់គ្រង និងចាត់តាំងកម្មាភិបាល និងសមាជិកបក្ស ដោយ "ឲ្យច្បាស់ និងឲ្យជាប់ជានិច្ចនូវលើប្រវត្តិរូប ជំហរនយោបាយ និងអង្គការចាត់តាំង"[140]។

51. ប្រធានមន្ទីរស-២១ ឌុច[141] និងទាហានកងពល ១៦៤ លុន សេង[142] បានបញ្ជាក់ថា **មាស មុត** បានធ្វើការយ៉ាងជិតស្និទ្ធជាមួយសមាជិកគណៈកម្មាធិការមជ្ឈិមផ្សេងៗទៀត នៅទូទាំងរបបកម្ពុ

---

Organization of Power, KH 00332367-69, 78-88។ ឯកសារ D1.3.17.6 Stephen Heder និង Brian Tittemore បុគ្គលប្រាំពីររូបដែលត្រូវយកទៅជំនុំជម្រះទោស, KH 00951116។ សូមមើលផងដែរ ឯកសារ D4.1.403 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅឌុច KH 00242892 ["ខ្ញុំអាចចង្អុលបង្ហាញថា រដ្ឋមន្ត្រីទាំង ៣ ដែលខ្ញុំទើបតែបាននិយាយ វន វេត, កុយ ធួន និង សៀ វ៉ាស៊ី គឺសុទ្ធតែជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម ប៉ុន្តែ កៅ រិត មិនមែនទេ។"]។ ឯកសារ D4.1.405 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅឌុច KH 00244235 ["មាស មុត និង សំ ប៊ិត ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការមជ្ឈិមនៅឆ្នាំ ១៩៧៥។"]។ ឯកសារ D4.1.1115 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅឌុច KH 00146664 ["ម៉ែន សាន ហៅ យ៉ា ជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការកណ្តាល"]។

140 ឯកសារ D1.3.22.1 លក្ខន្តិកៈបក្សកុម្មុយនីសកម្ពុជា ខែមករា ឆ្នាំ ១៩៧៦ KH 0053033-34 [មាត្រា ២៣៖ "ភារកិច្ចរបស់ គណៈកម្មាធិការមជ្ឈិម៖ ភារកិច្ចរបស់ គណៈកម្មាធិការមជ្ឈិមគឺ៖ ១. អនុវត្តមាគ៌ានយោបាយរបស់បក្ស និងលក្ខន្តិកៈរបស់បក្សនៅក្នុងបក្សទាំងមូល។ ២. ណែនាំអង្គការភូមិភាគតំបន់ ក្រុងទាំងអស់ និងអង្គការបក្សនៅក្នុងបក្សទទួលខុសត្រូវផ្នែកផ្សេងៗទូទាំងប្រទេស ធ្វើសកម្មភាពតាមមាគ៌ានយោបាយ គោលជំហរសតិអារម្មណ៍ និងមាគ៌ាចាត់តាំង តាមភារកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ និងតាមទិសបដិវត្តសង្គមនិយម និងការកសាងសង្គមនិយមរបស់បក្ស។ ៣. គ្រប់គ្រងនិងចាត់ចែងកម្មាភិបាល និងបក្ខជនក្នុងបក្សទាំងមូល ព្រមទាំងអង្គការស្នូលទាំងអស់ដោយក្តាប់ប្រវត្តិរូប ជំហរនយោបាយ សតិអារម្មណ៍ និងចាត់តាំងឲ្យច្បាស់ និងឲ្យជាប់ជានិច្ច ហើយអប់រំបំពាក់បំប៉នគេខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំងជាប់ជានិច្ច។ ៤. តាងនាមបក្សក្នុងការទាក់ទងបណ្តាបក្សម៉ាក្ស-លេនីនជាបងប្អូន"]។

141 ឯកសារ D114/277.8 កាំង ហ្គេកអ៊ាវ ហៅឌុច ប្រតិចារិកចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 10.57.59-11.00.47 KH 01323392 ["ដូច្នេះ វាពីលើវរសេនាធំ វាមានកងពល កងពលដែលចូលមជ្ឈិមនៅខាងសេនាធិការមានតែពីររូបទេ គឺបងមុត ហើយនិងមិត្តម៉េត"] ។ ឯកសារ D55/8.1.4 កាំង ហ្គេកអ៊ាវ ហៅឌុច ប្រតិចារិកចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.22.16-10.26.50 ["អ្នកដែលស្ថិតនៅក្នុងជំនួយការមជ្ឈិមនេះ បុគ្គលទីមួយគឺ ឈឹម សំអោក ហៅប៉ង់ ហើយក្នុងនោះក៏មាន ស៊ូ ម៉េត ហើយនិង មាស មុត។"], 10.19.09-10.22.16 ["គណៈកម្មាធិការមជ្ឈិមមានបួនថ្នាក់។ ថ្នាក់ក្រោមជាងគេបំផុតគេហៅថាជំនួយការមជ្ឈិម។ ពួកនេះមានសិទ្ធិទៅរៀនសូត្រជាមួយនឹង

គេ។ តែដល់មហាសន្និបាតមជ្ឈិមមិនមានសិទ្ធិមានមតិទេ។"], 10.30.53-10.34.54["ដោយឡែក ឈឹម សំអោក ហៅ ប៉ង់ គេទៅជាសមាជិកមជ្ឈិមហើយ។ ស៊ូ ម៉េត ក៏ទៅជាសមាជិកមជ្ឈិមដែរ"]។ ឯកសារ D1.3.33.10 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅឌុច KH 00195568-69 ["ថ្ងៃមួយ មុនការរៀបការខ្ញុំបន្តិច នៅចុងឆ្នាំ១៩៧៥ ណាត បាននិយាយប្រាប់ខ្ញុំថា សុន សេន សប្បាយចិត្តដោយសារគាត់ទើបត្រូវបានតម្លើងថ្នាក់ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលគាត់មិនធ្លាប់ជាសមាជិកពីមុនមកនោះទេ[...] គាត់ក៏បានរៀបរាប់ប្រាប់ខ្ញុំ អំពីការរៀបចំរចនាសម្ព័ន្ធផ្នែកយោធា ដែលសមាជិក៤រូប ត្រូវបានតែងតាំងនៅក្នុងគណៈកម្មាធិការជំនួយការ ដែលមានការទទួលខុសត្រូវផ្នែកនយោបាយ (មាស មុត ស៊ូ ម៉េត សំ ប៊ិត និងពេទ្យសឿង)។ នៅពេលដែលគាត់ពន្យល់ខ្ញុំពីចំណុចទាំងនេះ ណាតបាននិយាយថាគាត់ខកចិត្តដោយសារគាត់មិនត្រូវបានគេតម្លើងឋានៈ។ ខ្ញុំមិនសូវជឿណាត ទេ។ ដូច្នេះហើយខ្ញុំបានសួរចម្លើយ កុយ ធួន ពីបញ្ហានេះ នៅពេលដែលគាត់ជាប់ឃុំនៅ ស ២១ ហើយគាត់បានបញ្ជាក់អះអាងពីចំណុចនេះ។ ប៉ង់ក៏បានបញ្ជាក់អះអាងពីព័ត៌មាននេះដែរនៅថ្ងៃមួយដែលគាត់បានមក ស២១"]។ ឯកសារ D114/158 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅឌុច ឆ.៣២ ["ជំនួយការមជ្ឈិមនេះ មានសិទ្ធិ ទី១ ទៅរៀនជាមួយគណៈមជ្ឈិមគេធំៗ។ តែគ្មានសិទ្ធិបញ្ចេញមតិ ពេលសន្និបាត ជំនួយការមជ្ឈិមគ្មានសិទ្ធិបញ្ចេញមតិ។ ហើយទី២ គ្មានសិទ្ធិបោះឆ្នោត។ អានេះនិយាយពីជំនួយការមជ្ឈិម"]។ ឯកសារ D114/159 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅឌុច ឆ.៣-៥, ៩ ["មាស មុត, ស៊ូ ម៉េត, សំ ប៊ិត, សឿង មកពីយោធា ជាលេខាកងពល។ ស៖ តើលោកដឹងថា ហេតុអ្វីបានជាឈ្មោះទាំងអស់ដែលលោករៀបរាប់ខាងលើត្រូវបានជ្រើសរើសឱ្យចូលក្នុងគណៈកម្មាធិការនេះដែរឬទេ? ឆ.4៖ ខ្ញុំបាននិយាយពីរឿងចូលមជ្ឈិម ណាត និយាយថាប្អូននាក់ហ្នឹងចូលមជ្ឈិម។ ហើយដល់ក្រោយមក មេខ្ញុំ សុន សេន គាត់ថាពួកនេះមិនមែនជាសមាជិកមជ្ឈិមត្រៀមអីទេ ពួកគេគ្រាន់តែជាសមាជិកមជ្ឈិមជ្រើសរើសឱ្យបម្រើការងារពួកគេមានសិទ្ធិតែចូលរៀនជាមួយចាស់ៗ។ ចាស់ៗ សំដៅគណៈមជ្ឈិមចាប់ពី ប៉ុល ពត ចុះក្រោម សមាជិកត្រៀម [...] ឆ. 5: ទាំងប្អូននាក់នោះ ទាំងបងប៊ិត, បងមុត, បងសឿង, ហើយនិងមិត្តមេត (ស៊ូ ម៉េត)។ ទាំងអស់នេះសុទ្ធតែជាលេខាកងពល។ ហើយអ្នកដែលបានជ្រើសរើសគឺមជ្ឈិមបក្ស ពិសេស ប៉ុល ពត គឺជ្រើសរើសតាមរយៈ តាម៉ុក និង សុន សេន [...] ឆ.9៖ ប៉ុល ពត តាមរយៈ សុន សេន និងតាម៉ុក ។ តាមគោលការណ៍ដែលមានចែងក្នុងលក្ខខន្តិកៈបក្ស គេត្រូវជ្រើសរើសតាមគោលការណ៍១០ខ នៃការកសាងកម្មាភិបាលបក្ស។ តែក្នុងការអនុវត្ត គេជ្រើសរើសមនុស្សតាមខ្សែរគ្រួសារ។ ជាក់ស្តែង សំ ប៊ិត កូនក្មួយបងម៉ុក។ គាត់ របររកស៊ីពីមុនជាស្តេចឈ្លោន។ មាស មុត ក៏ជាប់សាច់ឈាមបងម៉ុកដែរ [...] គេជ្រើសរើសមនុស្សអញ្ចឹង។ [...] គេរើសតាមខ្សែចាត់តាំង"]។ ឯកសារ D12 ណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅឌុច KH 00680802 ["ខ្ញុំនៅតែរក្សាការពិតទាំងអស់ដែលខ្ញុំបានបញ្ជាក់ដដែល គឺ មាស មុត និង ស៊ូ ម៉េត គឺពិតជាជំនួយការមជ្ឈិម។ ពីដំបូង ណាត (ឈ្មោះដើម អ៊ិន លន ជាប្រធាន ស ២១ មុនខ្ញុំ) តូចចិត្តនឹងបុគ្គលបួននាក់បានចូលជាជំនួយការមជ្ឈិម ប៉ុន្តែមិនមានគាត់។ ទីមួយគឺ សំ ប៊ិត ទី២ មាស មុត ទី៣ បង ពេទ្យ សឿន និងទី៤ ស៊ូ ម៉េត។ ទាំងអស់នេះគឺណាត ជាអ្នកនិយាយប្រាប់ខ្ញុំ។ ដូចគ្នាដែរ មេរបស់ខ្ញុំ សុន សេន ក៏បាននិយាយពីរឿងនេះប្រាប់ខ្ញុំដែរ។ ខ្ញុំក៏ធ្លាប់និយាយប្រាប់ចៅក្រមស៊ើបសួរដែរថា មានសមាជិកជំនួយការមជ្ឈិមផ្សេងទៀត ដូចជា ចេង អន និង ឈឹម សំអោក ហៅប៉ង់ ដែលជាសមាជិកជំនួយការទីមួយ។ ចំណុចនេះ កុយ ធួន ក៏ធ្លាប់បានប្រាប់ខ្ញុំដែរ, KH 00680802 ["ក្រុមជំនួយការនេះអាចចូលរួមរៀនសូត្រជាមួយគេ និងធ្វើការកត់ត្រា ប៉ុន្តែប្រសិនបើមានការពិភាក្សា ពួកគេមិនមានសិទ្ធិចូលរួមពិភាក្សា និងបោះឆ្នោតសម្រេច"]។ ឯកសារ D4.1.405

ជាប្រជាធិបតេយ្យ។ ប្រតិបត្តិករទូរស័ព្ទរបស់ **មាស មុត** បានរាយការណ៍ថា គាត់បានទទួលការហៅទូរស័ព្ទ "ម្តងក្នុងមួយថ្ងៃ និងពេលខ្លះរៀងរាល់ពីរថ្ងៃម្តង" ពីមន្ទីរ ក-១[143] ដែលនៅពេលផ្សេងៗគ្នា គឺជាកន្លែងធ្វើការ និងលំនៅដ្ឋានរបស់សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍[144] រួមទាំង ប៉ុ

---

កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅឌុច KH 00244235 ["[ណាត] គាត់បង្ហាញពីការច្រណែននៅពេលដែល មាស មុត និង សំ ប៊ិត ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការមជ្ឈិមនៅឆ្នាំ ១៩៧៥"]។ ឯកសារ D1.3.33.13 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅឌុច KH 00154927 ["ក្នុងចំណោមសមាជិកនៃគណៈកម្មាធិការជំនួយការ មាន៖ ឈឹម សំអោក ហៅប៉ង់ សំ ប៊ិត(ជាអនុរបស់តាម៉ុក) មាស មុត (មេបញ្ជាការជើងទឹក) ស៊ូ សាមេត (មេបញ្ជាការកងទ័ពអាកាស) ពេទ្យសឿង (ជាប្រធានតំបន់ស្វយ័តសៀមរាបអង្គរ) វឿន អែម ហៅសារុន (ប្រធាននៃតំបន់ ៣១ បស្ចិម)។

142 ឯកសារ D54/110 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.20-23 ["ស៖ មានសាក្សីមួយចំនួនបានផ្តល់ព័ត៌មានឲ្យយើងដឹងថា មាស មុត អាចជាសមាជិកម្នាក់នៅក្នុងគណៈកម្មាធិការជំនួយរបស់គណៈមជ្ឈិម។ តើលោកដឹងអំពីគណៈកម្មាធិការនេះដែរឬទេ? ឆ.20 ៖ បាទ ខ្ញុំធ្លាប់ឮអំពីគណៈកម្មាធិការជំនួសនេះ ហើយ មាស មុត នៅក្នុងគណៈកម្មាធិការជំនួសនេះដែរ។ គណៈកម្មាធិការជំនួសនេះ គឺសម្រាប់ជួយដល់គណៈមជ្ឈិម។ ស៖ តើលោកដឹងរឿងនេះដោយរបៀបណា? ឆ.21៖ បន្ទាប់ពីគេរៀបចំរចនាសម្ព័ន្ធពីខាងក្រោមឡើងទៅខាងលើរួចហើយ គេប្រកាសប្រាប់ពួកយើងនៅក្នុងអង្គប្រជុំអំពីរចនាសម្ព័ន្ធនេះ។ ស៖ តើលោកអាចប្រាប់យើងបន្ថែមទៀតឬទេថា គណៈកម្មាធិការជំនួយជួយរឿងអ្វីខ្លះទៅខាងគណៈមជ្ឈិម? ឆ.22៖ តាមដែលខ្ញុំដឹង គណៈកម្មាធិការជំនួយមានមុខងារសម្រាប់ផ្សព្វផ្សាយគោលនយោបាយ និងព័ត៌មានផ្សេងៗដែលគេទទួលពីមជ្ឈិមទៅឲ្យថ្នាក់ក្រោម។ ស៖ តើទៅដល់ថ្នាក់ក្រោមណាខ្លះដែលលោកនិយាយថាថ្នាក់ក្រោមនោះ? តើទៅផ្នែកខាងយោធា ហើយនិងស៊ីវិលដែរឬយ៉ាងណា? ឆ.23៖ គណៈកម្មាធិការជំនួយផ្សព្វផ្សាយគោលនយោបាយទៅដល់យោធា ហើយនិងប្រជាជនស៊ីវិលផងដែរ។ ដូចគ្នានឹងចៅហ្វាយខេត្ត ដែលផ្តល់ព័ត៌មានទៅនាយកដ្ឋានឲ្យផ្សព្វផ្សាយព័ត៌មាននោះទៅប្រជាជន"]។

143 ឯកសារ D54/73 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.៣-៥ [សាក្សីគឺជាបុគ្គលិកខាងទូរសព្ទរបស់ មាស មុត៖ "ស៖សូមលោកស្រីរកនឹកមើល ថាតើអ្នកដែលទូរសព្ទមកពីមជ្ឈិមមករកមេបញ្ជាការកងពល ១៦៤ មាស មុត ហ្នឹង តើគាត់ឈ្មោះអ្វី? ឆ.3៖ ទេ ខ្ញុំមិនចាំឈ្មោះទេ ខ្ញុំគ្រាន់តែចាំលេខអ្នកទូរសព្ទ គឺលេខ ក-១។ ស៖ តើ ក-១ ហ្នឹងទូរសព្ទមកញឹកញាប់ប៉ុនណា? ឆ.4៖ ពេលខ្លះ១ថ្ងៃម្តង ពេលខ្លះ២ថ្ងៃម្តង។ កាលហ្នឹង មានទូរសព្ទទៅមករវាងមេបញ្ជាការកងពល ១៦៤ មាស មុត និងមជ្ឈិម ប៉ុន្តែខ្ញុំមិនចាំច្បាស់ពីរបៀបហៅហ្នឹងយ៉ាងម៉េចទេ ដូច្នេះខ្ញុំមិនអាចប្រាប់លោកបានទេ។ ស៖ ជាទូទៅ នៅពេលដែល ក-១ ទូរសព្ទចូលមក តើលោកស្រីភ្ជាប់ខ្សែទូរសព្ទចូលត្រង់ទៅផ្ទះ មាស មុត តែម្តង ឬក៏លោកស្រីភ្ជាប់ខ្សែទូរសព្ទទៅកន្លែងណាផ្សេងទៀត? ឆ.5៖ ខ្ញុំភ្ជាប់ខ្សែរទូរសព្ទទៅផ្ទះ តា មុត តែម្តង។"]។

144 ឯកសារ D4.1.1074 កំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ KH 00156676-77 ["ស៖ តើ ក១ និងក៣ សម្តៅលើអ្វីខ្លះ? ឆ៖ វាគឺជាទីកន្លែងរស់នៅ និងធ្វើការងាររបស់គណៈកម្មាធិការអចិន្ត្រៃយ៍។ ក១ ស្ថិតនៅទល់មុខទន្លេ បាសាក់ (អាគារមួយដែលនៅខាងត្បូងជិតសាលមហាស្រពជាតិ) ហើយ ក៣ ស្ថិតនៅក្រោយព្រះបរមរាជវាំង [...] ចំពោះខ្ញុំ ខ្ញុំរស់នៅ ក៣ បន្ទាប់ពីបានស្នាក់នៅ ក១ បាន១ ឬ២ខែ បន្ទាប់ពីបានប្តូរមកពីប្រាសាទប្រាក់។

ល ពត នួន ជា និង ខៀវ សំផន ផង។ **មាស មុត** បានជូនដំណឹងជាប់ជានិច្ចដល់មេដឹកនាំបក្ស កុម្មុយនីស្តកម្ពុជា ដូចជា ប៉ុល ពត នួន ជា និង វ៉ន វ៉េត អំពីស្ថានភាពនៅក្នុងតំបន់ដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់គាត់[145] បានទាក់ទងជាញឹកញាប់ជាមួយសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និង មេបញ្ជាការសេនាធិការ សុន សេន[146] និងបានអមដំណើរអនុនាយករដ្ឋមន្ត្រី អៀង សារី ទៅចូល

---

[...] ចំណែកឯ ប៉ុល ពត វិញ [...] គាត់ទៅស្នាក់នៅ ក១ ផងដែរ។ កិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ភាគច្រើន ត្រូវបានធ្វើនៅក១ ពេលខ្លះនៅក៣ នៅផ្ទះរបស់ ប៉ុល ពត ឬនៅផ្ទះបាយ។”]។

145 ឯកសារ D1.3.8.3 កំណត់ហេតុនៃអង្គប្រជុំ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៧៦ [រៀបរាប់អំពីកិច្ចប្រជុំដែលចូលរួមដោយ ប៉ុល ពត, វន វ៉េត, សុន សេន, មាស មុត, សមមិត្ត ង៉ែត, សមមិត្តខឹម និងសមមិត្តទូច ជាអ្នកធ្វើកំណត់ហេតុ]។ ឯកសារ D4.1.699 សារទូរលេខ ១១ របស់ ខឹម ផ្ញើជូនបងមុត (មាស មុត) ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៦, KH 00092628 [សារទូរលេខរបស់អនុ មាស មុត រៀបរាប់អំពីស្ថានភាពសន្តិសុខនៅកំពង់សោម ចម្លងជូន នួន ជា, សុន សេន, មន្ទីរ៨៧០ ឯកសារ។] ។ ឯកសារ D4.1.635 របាយការណ៍របស់មុត (មាស មុត) ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨ [របាយការណ៍ស្តីពីការចាប់ខ្លួន និងសម្លាប់ជនជាតិវៀតណាម ១០២ នាក់ រវាងពីថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៨ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៨។ ចម្លងជូន នួន ជា ប៉ុល ពត បងវ៉ាន់ និង ឯកសារ]។ ឯកសារ D1.3.12.2 របាយការណ៍របស់មុត (មាស មុត) ផ្ញើជូនបង ៨៩ (សុន សេន) ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំមិនដឹង [របាយការណ៍រៀបរាប់អំពីការវាយប្រហារ និងការចាប់ទូកនេសាទថៃ។ ចម្លងជូនបង ៨៧ (វន វ៉េត) បង និង ឯកសារ]។

146 ឯកសារ D4.1.1020 សារទូរលេខរបស់ មុត (មាស មុត) ផ្ញើជូនបង ៨៩ (សុន សេន) ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៦។ ឯកសារ D1.3.12.3 របាយការណ៍របស់មុត (មាស មុត) ផ្ញើជូនបង ៨៩ (សុន សេន) ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦។ ឯកសារ D1.3.14.1 សារទូរលេខរបស់ មុត (មាស មុត) ផ្ញើជូនបង ៨៩ (សុន សេន) ថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៦។ ឯកសារ D1.3.34.10 សារទូរលេខ ៤៤ របស់ មុត (មាស មុត) ផ្ញើជូនបង ៨៩ (សុន សេន) ថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៧៦។ ឯកសារ D1.3.4.1 របាយការណ៍របស់មុត (មាស មុត) ផ្ញើជូនបង ៨៩ (សុន សេន) ថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៦។ ឯកសារ D1.3.2.2 សារទូរលេខ ១០ របស់ បង ៨៩ (សុន សេន) ផ្ញើជូនមិត្ត មុត (មាស មុត) និងកងពលធំលេខ ១៦៤ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ឯកសារ D1.3.12.18 សារទូរលេខ ០៩ របស់ មុត (មាស មុត) ផ្ញើជូនបង ៨៩ (សុន សេន) ថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧។ ឯកសារ D1.3.34.64 ទូរសព្ទសម្ងាត់ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ របស់ មាស មុត ផ្ញើជូនបង ៨៩ (សុន សេន)។ ឯកសារ D4.1.637 របាយការណ៍របស់មុត (មាស មុត) ផ្ញើជូនបង ៨៩ (សុន សេន) ថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៧៨។ ឯកសារ D1.3.12.2 របាយការណ៍របស់មុត (មាស មុត) ផ្ញើជូនបង ៨៩ (សុន សេន) ថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំមិនច្បាស់។

រួមកិច្ចប្រជុំនានាជាមួយនឹងអាជ្ញាធរបរទេស[147]។ **មាស មុត** ខ្លួនឯងបានទទួលស្គាល់ថា គាត់បានជួបជាមួយ សុន សេន "ដើម្បីអនុវត្តការងាររបស់គណៈកម្មាធិការមជ្ឈិម"[148]។

**អនុលេខាសេនាធិការ**

52. នៅឆ្នាំ ១៩៧៨ **មាស មុត** ត្រូវបានតែងតាំងជាអនុលេខានៃគណៈកម្មាធិការសេនាធិការនៃកងទ័ពបដិវត្តន៍កម្ពុជា ដែលជាទីបញ្ជាការយោធាមជ្ឈិម[149]។ សេនាធិការទទួលខុសត្រូវរក្សាសន្តិសុខផ្ទៃក្នុង[150] ត្រួតពិនិត្យលើគ្រោះគំរាមកំហែងផ្ទៃក្នុង និងពីខាងក្រៅ[151] និងសម្របសម្រួលលើការអនុវត្ត

---

147 ឯកសារ D4.1.1031 សេចក្តីថ្លែងការណ៍របស់ អៀង សារី ថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៧៦ KH 00003684 [អង្គប្រជុំរវាង ឧបនាយករដ្ឋមន្ត្រី អៀង សារី ជាមួយសមមិត្ត ផាន ហៀន អនុរដ្ឋមន្ត្រីក្រសួងការបរទេស សាធារណរដ្ឋវៀតណាមប្រជាមានិត៖ "មិត្ត អៀង សារី បានទទួលសមមិត្ត ផាន ហៀន នៅថ្ងៃ១៩ ឧសភា ១៩៧៦។ សុន្ទនាការបានចាប់ផ្តើមនៅម៉ោង ៨.០០។ បានចូលរួមក្នុងពេលនោះ ខាងភាគីកម្ពុជា មានមិត្ត មុត មិត្ត តូច មិត្ត ផន មិត្ត គង់។ ខាងភាគីវៀតណាមមាន សមមិត្ត ង៉ៀង ស៊ីង សមមិត្ត ង៉ៀង ធឿង សមមិត្ត ផាំ ទ្រុងហ៊ីវ និងសមមិត្ត គីវ មិញ"]។ ឯកសារ D22.1.10 FBIS គណៈប្រតិភូចិនធ្វើទស្សនកិច្ចនៅតំបន់កំពង់សោម ថ្ងៃទី១២ ខែធ្នូ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៧៧ KH 01194843-44 ["កាលពីព្រឹកថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៧ សមមិត្ត Chen Yung-kuei សមាជិកការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តចិន និងជាឧបនាយករដ្ឋមន្ត្រីនៃក្រុមប្រឹក្សារដ្ឋ និងសមមិត្តចិនដទៃទៀត បានធ្វើទស្សនកិច្ចនៅក្រុងកំពង់សោម។ ពួកគាត់ត្រូវបានរួមដំណើរដោយសមមិត្ត ប៉ុល ពត លេខាបក្សកុម្មុយនីស្តកម្ពុជា និងជានាយករដ្ឋមន្ត្រី និងសមមិត្ត អៀង សារី និង ជួន ជឿន។ នៅទីនោះ សមមិត្ត Chen Yung-kuei និងសមមិត្តដទៃទៀត ត្រូវបានទទួលស្វាគមន៍ដោយសមមិត្ត មុត លេខាបក្សកុម្មុយនិស្តកម្ពុជា ក្រុងកំពង់សោម និងជាប្រធានគណៈកម្មាធិការបម្រើប្រជាជនក្រុងកំពង់សោម"]។

148 ឯកសារ D1.3.7.8 កាសែត ខេមបូឌា ដេលី ចំណងជើង រឿងកន្លងផុត បំភ្លេចចោលចុះ ថ្ងៃទី០១ ខែមីនា ឆ្នាំ២០០៨ EN 00165821 ["មាស មុត ទទួលស្គាល់ថា គាត់បានជួបជាមួយ សុន សេន ពីរបីដង ដើម្បីបំពេញការងារគណៈមជ្ឈិម"]។

149 ឯកសារ D1.3.27.19 កំណត់ហេតុកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ថ្ងៃទី ០៩ ខែតុលា ឆ្នាំ១៩៧៥ KH 0019112-0019114 [អង្គប្រជុំគណៈអចិន្ត្រៃយ៍ ពិភាក្សាអំពីក្របខណ្ឌការងារសេនាធិការ និងការប្រគល់ការទទួលខុសត្រូវផ្នែកសេនាធិការ និងសន្តិសុខឲ្យ សុន សេន]។ ឯកសារ D1.3.19.2 របាយការណ៍របស់មិត្ត ខៀវ (សុន សេន) ផ្ញើជូនគណៈកងពល និងគណៈវរសេនាធំ ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩៧៧ [សុន សេន ចេញសេចក្តីណែនាំពីសេនាធិការទៅកងពល និងវរសេនាធំយោធា]។

150 ឯកសារ D1.3.8.9 កំណត់ហេតុនៃកិច្ចប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៧៦ [កំណត់ហេតុកិច្ចប្រជុំសេនាធិការ លើកឡើងអំពីស្ថានភាពខ្មាំងក្នុងប្រទេស និងការចេញបញ្ជាផ្សេងៗ]។ ឯកសារ D1.3.12.16 កំណត់ហេតុនៃកិច្ចប្រជុំរបស់កងទ័ពបដិវត្តន៍កម្ពុជាចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៦ [ឯកសារសេនាធិការ

គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា នៅក្នុងអង្គភាពនៃកងទ័ពបដិវត្តន៍កម្ពុជា ដែលស្ថិតក្រោមបញ្ជាការរបស់ខ្លួន[152]។ សេនាធិការ ជាអ្នកគ្រប់គ្រងលើស្ថាប័នទាំងបីនៃកងទ័ពបដិវត្តន៍កម្ពុជា

---

សង្ខេបអំពីសកម្មភាពខ្មាំងនៅក្នុងប្រទេស និងនៅតាមព្រំដែន]។ ឯកសារ D1.3.8.6 កំណត់ហេតុនៃកិច្ចប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៧៦ [លើកឡើងអំពីចំណុច"ខ្វះខាត"ផ្នែកការពារប្រទេស និងបញ្ជាក់ថា កម្មាភិបាលដែលមាននិន្នាការនយោបាយមិនល្អ គួរត្រូវផ្ទេរទៅការពារសន្តិសុខផ្ទៃក្នុង]។ ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខា និងវរៈសេនាធំឯករាជ្យ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៦, KH 00052402, 00052405-08, 00052412-16 [សុន សេន ពិភាក្សាអំពីគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យពាក់ព័ន្ធនឹងស្ថានភាពខ្មាំងខាងក្រៅ ខាងក្នុង ការបោសសម្អាតផ្ទៃក្នុង និងការសួរចម្លើយ ដើម្បីបោសសម្អាតសមាសភាពមិនល្អ ដែលជាប់ចោទថាជាគិញសេអ៊ីអា ឬកាហ្សេបេ]។ ឯកសារ D1.3.19.1 សេចក្តីសម្រេចរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦, KH 00003136 [សិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រៅជួរ"]។

151 ឯកសារ D1.3.12.16 របាយការណ៍របស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៦ [សង្ខេបអំពីការចាប់ខ្លួន និងសកម្មភាពខ្មាំងដែលជាប់សង្ស័យ]។ ឯកសារ D1.3.12.11 របាយការណ៍របស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៦ [រៀបរាប់អំពីបទពិសោធន៍ដើរល្បាតនៅភ្នំពេញ ដែលកម្មករខ្លះបានប្រើខ្សែភ្លើងឆក់ត្រី មានរោងចក្រជាច្រើន ប្រើប្រាស់កាំភ្លើង និងអ្នកបើកឡានបើកលឿនគួរឲ្យព្រួយបារម្ភណ៍]។ ឯកសារ D1.3.12.13 កំណត់ហេតុកិច្ចប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៧៦ [សេចក្តីរាយការណ៍អំពីការបាញ់ជនសង្ស័យជាខ្មាំងដែលគេគិតថាមានគ្រាប់បែក]។ ឯកសារ D1.3.8.9 កំណត់ហេតុកិច្ចប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៦ [កំណត់ហេតុកិច្ចប្រជុំសង្ខេបអំពីស្ថានភាពខ្មាំងនៅក្នុងប្រទេស]។

152 ឯកសារ D1.3.19.1 សេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ KH 00003136 [អនុញ្ញាតឲ្យសេនាធិការ "កំទេស"នៅក្នុងជួរ"កងទ័ពមជ្ឈិម"]។ សូមមើលផងដែរ អង្គប្រជុំជាទៀងទាត់រវាងសមាជិកសេនាធិការ ជាមួយមេបញ្ជាការកងពល និងកងវរសេនាធំឯករាជ្យ ដែលក្នុងអង្គប្រជុំទាំងនោះ សុន សេន និងតំណាងសេនាធិការផ្សេងទៀត សង្ខេបអំពីស្ថានភាពខ្មាំងនៅក្នុងប្រទេស ចេញបញ្ជា និងបំពាក់បំប៉នអ្នកចូលរួមអំពីគោលនយោរបស់បក្ស៖ ឯកសារ D1.3.27.8 កំណត់ហេតុកិច្ចប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៧៦, ឯកសារ D1.3.8.2 កំណត់ហេតុកិច្ចប្រជុំរបស់កងទ័ពបដិវត្តន៍កម្ពុជាថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៧៦, ឯកសារ D1.3.27.11 កំណត់ហេតុកិច្ចប្រជុំរបស់កងទ័ពបដិវត្តន៍កម្ពុជាថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៦, ឯកសារ D1.3.27.13 កំណត់ហេតុកិច្ចប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧៦, ឯកសារ D1.3.27.14 កំណត់ហេតុកិច្ចប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៧៦, ឯកសារ D1.3.8.4 កំណត់ហេតុកិច្ចប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៧៦, ឯកសារ D1.3.27.17 កំណត់ហេតុកិច្ចប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦, ឯកសារ D1.3.27.18 កំណត់ហេតុកិច្ចប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦, ឯកសារ D1.3.8.6 កំណត់ហេតុកិច្ចប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៧៦, ឯកសារ

ពោលគឺ កងទ័ពថ្មើរជើង កងទ័ពអាកាស និងកងទ័ពជើងទឹក[153] និងទទួលបន្ទុកអនុវត្តតាមបញ្ជារបស់គណៈកម្មាធិការមជ្ឈិម[154] ជាពិសេសទាក់ទងនឹងការសម្លាប់ខ្មាំងស៊ីរូងផ្ទៃក្នុង[155]។

D1.3.27.20 កំណត់ហេតុកិច្ចប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៦ KH 00052402-16, ឯកសារ D1.3.8.7 កំណត់ហេតុកិច្ចប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៦, ឯកសារ D1.3.27.21 កំណត់ហេតុកិច្ចប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៦, ឯកសារ D1.3.27.23 កំណត់ហេតុកិច្ចប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៦, ឯកសារ D1.3.27.24 កំណត់ហេតុកិច្ចប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៦, ឯកសារ D1.3.27.25 កំណត់ហេតុកិច្ចប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៦, ឯកសារ D1.3.27.26 កំណត់ហេតុកិច្ចប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៧៧។

153 ឯកសារ D1.3.27.1 កំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ០៩ តុលា ១៩៧៥ KH 00019112-14 [កិច្ចប្រជុំគណៈអចិន្ត្រៃយ៍ពិភាក្សាអំពីក្របខណ្ឌសេនាធិការ និងចាត់តាំងសេនាធិការនូវភារកិច្ចរៀបចំកម្លាំងកងទ័ពជើងគោកថ្មី កងទ័ពជើងទឹក និងកងទ័ពអាកាស]។ ឯកសារ D1.3.8.1 កំណត់ហេតុនៃការប្រជុំ ថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៧៦ [នៅក្នុងកិច្ចប្រជុំនោះ សោម (សុន សេន) បានណែនាំអំពីការជ្រើសរើសកម្លាំងសម្រាប់កងទ័ពអាកាស]។ ឯកសារ D1.3.8.3 កំណត់ហេតុនៃអង្គប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៧៦ [កិច្ចប្រជុំពាក់ព័ន្ធនឹងការដាក់ពង្រាយកម្លាំងកងទ័ពជើងទឹក និងស្ថានភាពខ្មាំងនៅក្នុងតំបន់ដែលគ្រប់គ្រងដោយកងទ័ពជើងទឹក]។ ឯកសារ D1.3.8.5 កំណត់ហេតុការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៦ [ពិភាក្សាអំពីបញ្ហាហ្វឹកហ្វឺនធ្វើឡើងដោយអ្នកជំនាញចិន ស្តីពីការប្រើប្រាស់ ជួសជុល និងថែទាំកាំភ្លើងធំ]។ ឯកសារ D1.3.8.9 កំណត់ហេតុការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៦ [ពិភាក្សាអំពីបញ្ហាសន្តិសុខផ្សេងៗ ដែលរាយការណ៍ដោយកងពលនានានៃកងទ័ពកម្ពុជាប្រជាធិបតេយ្យ រួមទាំងការរៀបរាប់អំពីមនុស្សដែលជាប់ខ្លួននៅក្នុងភ្នំពេញ និងនៅក្បែរភ្នំពេញ។ រៀបរាប់អំពីវិធានការដែលត្រូវអនុវត្ត និងវិន័យយាមកាមនៅពេលដើរល្បាត និងចំណុចត្រួតពិនិត្យ]។ ឯកសារ D54/62 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត, ឆ.23 ["នៅក្នុងកងទ័ពគឺមានគឺជើងគោក ជើងទឹក និងជើងអាកាស។ កងទ័ពទាំងបីនេះស្ថិតនៅក្រោមបញ្ជារបស់អគ្គសេនាធិការ"]។

154 ឯកសារ D1.3.22.1 លក្ខន្តិកៈបក្សកុម្មុយនីសកម្ពុជា ខែមករា ឆ្នាំ១៩៧៦ KH 00053035 [មាត្រា២៨: "កងទ័ពបដិវត្ត កម្ពុជាមានការចាត់តាំងតាមប្រជាធិបតេយ្យ ប្រមូលផ្តុំ។ គណៈកម្មាធិការមជ្ឈិមបក្សកំណត់ការអនុវត្តប្រជាធិបតេយ្យប្រមូលផ្តុំនេះតាមសភាពការណ៍ជាក់ស្តែង"]។ ឯកសារ D1.3.27.1 កំណត់ហេតុការប្រជុំអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ KH 00019110 [កំណត់ហេតុការប្រជុំបង្ហាញពីកំណត់សម្គាល់របស់គណៈអចិន្ត្រៃយ៍៖ "ការពារប្រទេសចាត់ចែងតាមមជ្ឈិម"]។ ឯកសារ D1.3.27.7 កំណត់ហេតុការប្រជុំអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៥ [សុន សេន រាយការណ៍អំពីបញ្ហាការពារប្រទេសជូនគណៈអចិន្ត្រៃយ៍]។ ឯកសារ D1.3.19.1 សេចក្តីសម្រេចរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ KH 00003136 [អនុញ្ញាតឱ្យសេនាធិការ "កំទេស"នៅក្នុងជួរ"កងទ័ពមជ្ឈិម"]។ ឯកសារ D1.3.24.2 ទង់បដិវត្ត ខែតុលា ឆ្នាំ១៩៧៦ KH 00062942 ["គឺមានតែបក្ស ដឹកនាំកងទ័ព គ្មានអង្គការណាផ្សេង

53. សុន សេន ជាលេខាសេនាធិការនៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ[156]។ ម៉ែន សាន ហៅ យ៉ា និង សៀត ឆែ បានចូលបង្គ្រប់គណៈកម្មាធិការសេនាធិការ ដោយ ម៉ែន សាន មានតួនាទីជាអនុលេខា និង សៀត ឆែ ជាសមាជិក[157]។ **មាស មុត** ដែលជាមេបញ្ជាការកងទ័ពជើងទឹក និងមេបញ្ជាការយោធាជាន់ខ្ពស់ផ្សេងទៀត ដូចជា ស៊ូ ម៉េត, ណាត និង ពេជ្រ ឆន ហៅ សោម ក៏ជាសមាជិកនៃសេនាធិការនោះដែរ[158]។ នៅក្នុង ឬនៅប្រហែលឆ្នាំ ១៩៧៧ សៀត ឆែ ត្រូវបានចាប់

---

ទៀត ឬបុគ្គលផ្សេងទៀតដឹកនាំទេ"]។ ឯកសារ D12 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច KH 00680803 [សេនាធិការ ទទួលអនុវត្តតាមបញ្ជារបស់ ប៉ុល ពត ហើយ សុន សេន ជាអ្នកអនុវត្តបញ្ជាទាំងនោះ]។

155 ឯកសារ D1.3.19.1 សេចក្តីសម្រេចរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ KH 00003136 KH 00003136 [អនុញ្ញាតឲ្យសេនាធិការ "កំទេស"នៅក្នុងជួរ"កងទ័ពមជ្ឈិម"]។

156 ឯកសារ D1.3.27.1 កំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ KH 00019108, 00019112-15 [អង្គប្រជុំគណៈអចិន្ត្រៃយ៍ ពិភាក្សាអំពីក្របខណ្ឌការងារសេនាធិការ និងការប្រគល់ការទទួលខុសត្រូវផ្នែកសេនាធិការ និងសន្តិសុខឲ្យ សុន សេន]។ ឯកសារ D1.3.19.2 របាយការណ៍ពីខៀវ (សុន សេន) ផ្ញើជូនគណៈកងពលធំ និងកងវរសេនាធំ ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩៧៧ [រៀបរាប់អំពីសេចក្តីណែនាំពីអគ្គសេនាធិការ ដល់កងពលធំ និងកងវរសេនាធំ។ សេចក្តីណែនាំទាំងនេះចេញពី សុន សេន ក្នុងនាមជាលេខាអគ្គសេនាធិការ]។ ឯកសារ D12 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅឌុច KH 00680803-04 ["នៅក្នុងសមាជិកអចិន្ត្រៃយ៍នៃអគ្គសេនាធិការ មានមនុស្សបីនាក់សំខាន់ជំបូងគេ គឺ ទី១ សុន សេន ហៅបង៨៩ ជាលេខា [...] ភាពជាសមាជិកអគ្គសេនាធិការនេះ គឺត្រូវបានតែងតាំងសម្រាប់មួយរបបពេញតែម្តង។"]។ ឯកសារ D114/158 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅឌុច ឆ. 24 [" ក្រោយឆ្នាំ១៩៧៥ ពេលរៀបចំកងទ័ពមជ្ឈិម ខ្ញុំនិយាយពីគណៈកម្មាធិការសេនាធិការ។ គណៈកម្មាធិការសេនាធិការលេខាគឺ សុន សេន"]។ ឯកសារ D54/62 កំណត់ហេតុស្តាប់ចម្លើយ ម៉ុង វេត ឆ.23 ["សុន សេន ជាមេបញ្ជាការអគ្គសេនាធិការទទួលខុសត្រូវរួម និងកងថ្មើរជើង"]។ ឯកសារា D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.60 ["សៈ តើនរណាជាមេរបស់ មាស មុត? ឆៈ ខ្ញុំគ្រាន់តែដឹងថា នៅពីលើ មាស មុត គឺអគ្គសេនាធិការដែលមាន សុន សេន ជាប្រធាន។"]។

157 ឯកសារ D114/158 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅឌុច ឆ. 24 [" ក្រោយឆ្នាំ១៩៧៥ ពេលរៀបចំកងទ័ពមជ្ឈិម ខ្ញុំនិយាយពីគណៈកម្មាធិការសេនាធិការ។ គណៈកម្មាធិការសេនាធិការលេខាគឺ សុន សេន។ បន្ទាប់មក ម៉ែន សាន ហៅយ៉ា ជាអនុរបស់ សុន សេន។ បន្ទាប់មក សៀត ឆែ ហៅទុំ សមាជិក។"]។ ឯកសារ D12 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅឌុច KH 00680803 ["នៅក្នុងសមាជិកអចិន្ត្រៃយ៍នៃអគ្គសេនាធិការ មានមនុស្សបីនាក់សំខាន់ជំបូងគេ គឺ ទី១ សុន សេន ហៅបង៨៩ ជាលេខា ទីពីរ គឺ ម៉ែន សាន ហៅយ៉ា ដែលជាអនុប្រធាន និងផងដែរ ជាសមាជិកមជ្ឈិមពេញសិទ្ធិ និងទី៣ គឺ សៀត ឆែ ហៅទុំ ហៅបង៨១ ដែលជាសមាជិក និងផងដែរ ជាសមាជិកមជ្ឈិមត្រៀម"]។

158 ឯកសារ D54/110 កំណត់ហេតុស្តាប់ចម្លើយ ឡុង សេង ឆ.9-10 ["បាទ ហើយវាមិនមែនមានតែសម្រាប់កងពល ១៦៤មួយទេ កងពលណាក៏ដោយ ដែលជារបស់មជ្ឈិម បេបញ្ជាការកងពលទាំងនោះ គឺជាសមាជិកគណៈបញ្ជាការ

ខ្លួន ហើយ ម៉ែន សាន ត្រូវបានផ្ទេរទៅភូមិភាគពាយ័ព្យ[159]។ ពួកគេមិនត្រូវបានជំនួសភ្លាមៗនោះទេ ហើយ សុន សេន នៅតែជាសមាជិកតែម្នាក់គត់នៃគណៈកម្មាធិការសេនាធិការដដែលរហូតដល់

---

របស់សេនាធិការ។ ពេលណាដែលកងពលក្លាយទៅជាកងពលរបស់មជ្ឈិម មេបញ្ជាការរបស់កងពលនោះ ក្លាយជាសមាជិកគណៈកម្មាធិការសេនាធិការ។ សៈ តើលោកដឹងថា ចាប់ពីពេលណាដល់ពេលណាដែល មាស មុត ក្លាយជាសមាជិកគណៈកម្មាធិការសេនាធិការ? ឆ.១០៖ តាមខ្ញុំដឹង មាស មុត ក្លាយជាសមាជិកគណៈកម្មាធិការសេនាធិការចាប់តាំងពីរំដោះភ្នំពេញ ខែមេសា ឆ្នាំ១៩៧៥ម្លេះ ហើយគាត់បម្រើនៅក្នុងកិច្ចការហ្នឹងរហូតដល់របបខ្មែរក្រហមដួលរលំ។"]។ ឯកសារ D114/158 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅឌុច, ឆ.24 ["ក្រោយឆ្នាំ ១៩៧៥ ពេលរៀបចំកងទ័ពមជ្ឈិម ខ្ញុំនិយាយពីគណៈកម្មាធិការសេនាធិការ។ គណៈកម្មាធិការសេនាធិការលេខាគឺ សុន សេន។ បន្ទាប់មក ម៉ែន សាន ហៅយ៉ា ជាអនុរបស់ សុន សេន។ បន្ទាប់មក សៀត ឆែ ហៅទុំ ជាសមាជិក។ នេះអចិន្ត្រៃយ៍សេនាធិការរបស់គេ។ ហើយសមាជិកគណៈកម្មាធិការសេនាធិការរបស់គេមានតទៅទៀត ទីមួយគឺបងមុត ទទួលខុសត្រូវខាងកងទ័ពជើងទឹក ខាងសមុទ្រ។ មិត្ត ម៉េត ទទួលខុសត្រូវខាងអាកាស។ ឯចំណែកគណៈកម្មាធិការសេនាធិការផ្សេងទៀត នៅត្រឹមតែជំនួយការសេនាធិការទេ"]។ ឯកសារ D114/159 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅឌុច ឆ.23 ["សមាជិកសេនាធិការត្រៀមមាន មាស មុត និង ស៊ូ ម៉េត ព្រមទាំងជំនួយការសេនាធិការមួយចំនួន"]។ ឯកសារ D12 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅឌុច KH 00680803 ["នៅក្នុងសមាជិកអចិន្ត្រៃយ៍នៃអគ្គសេនាធិការ មានមនុស្សបីនាក់សំខាន់ដំបូងគេ គឺទី១ សុន សេន ហៅបង៨៩ ជាលេខា ទី២ គឺ ម៉ែន សាន ហៅយ៉ា ដែលជាអនុប្រធាន និងផងដែរ ជាសមាជិកមជ្ឈិមពេញសិទ្ធិ និងទី៣ គឺ សៀត ឆែ ហៅទុំ ហៅបង៨១ ដែលជាសមាជិក និងផងដែរ ជាសមាជិកមជ្ឈិមត្រៀម។ បន្ទាប់មកទៀតទើបមានសមាជិកគឺ មាស មុត ទទួលបន្ទុកកងទ័ពជើងទឹក ស៊ូ ម៉េត ទទួលបន្ទុកជើងអាកាស ប៉ុន្តែចំពោះជើងគោក មិនមានអ្នកទទួលបន្ទុកទេ [...] មាស មុត និង ស៊ូ ម៉េត ជាសមាជិកអគ្គសេនាធិការទទួលបន្ទុកកងទ័ពជើងទឹក និងអាកាស។"], 00680803 ["មានជំនួយការផងដែរ ដែលសុទ្ធតែជាលេខានៃកងពលទាំងអស់ ដូចជា ស៊ុន ទី ទទួលបន្ទុកភស្តុភារ ពេជ ឆន ហៅសោម ទទួលបន្ទុករដ្ឋបាល និងណាត ទទួលបន្ទុករត់ការងារបញ្ជូនមនុស្សមក ស ២១ ជាដើម។ និងមានបុគ្គលខ្លះទៀត ត្រូវបានតែងតាំងជាជំនួយការដែរ ដូចជា ចាន់ ចក្រី និង ជ័យ ហាន ហៅឆាន ប៉ុន្តែ ត្រូវបានយកមកធ្វើទុកសម្រាប់តាមដានតែប៉ុណ្ណោះ"]។ ឯកសារD114/160កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅឌុច ឆ.8 ["ទី១ ខ្ញុំសូមនិយាយអំពី មាស មុត ហើយនិង ស៊ូ ម៉េត។ ថ្វីត្បិតតែឡើងជាសមាជិកត្រៀមនៃអគ្គសេនាធិការក៏ដោយ ក៏ប៉ុន្តែគាត់មិនទៅបោះទីតាំងនៅហ្នឹងទេ [នៅភ្នំពេញ ជិតបុរីកីឡា]"។ ឯកសារ D1.3.27.5 កំណត់ហេតុប្រជុំរបស់គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ថ្ងៃទី១៩ ដល់២១ ខែមេសា ឆ្នាំ១៩៧៦ KH 00019145 ["3. ការចាត់តាំងសេនាធិការ និងកងទ័ពជើងអាកាស៖ [...] សមមិត្តសាន និងសមមិត្តណាត គ្រាន់តែជាកម្មាភិបាលសេនាធិការចល័ត ជួយក្នុងសេនាធិការ ខាងប្រតិបត្តិការប្រយុទ្ធ អត់ក្តាប់កម្លាំងផ្ទាល់ទេ"]។

159 ឯកសារ D114/159 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅឌុច ឆ.23-24 ["ពេលគេចាប់ សៀត ឆែ ហៅទុំ បញ្ជូនមកស-២១។ មុនរឿង សៀត ឆែ ទៀតមាន ម៉ែន សាន ហៅយ៉ា ត្រូវ ប៉ុល ពត ដកចេញពីអនុលេខាសេនាធិការ បញ្ជូនទៅធ្វើលេខានៅភូមិភាគឦសាន្ត [...] ឥឡូវសូមយើងទាំងអស់គ្នាពិភាក្សាគ្នាយឺតៗត្រង់ចំណុចនេះ។ ហេតុ

ឆ្នាំ ១៩៧៨ នៅពេលដែល **មាស មុត** ត្រូវបានតែងតាំងឲ្យកាន់តំណែងជាអនុប្រធានម្នាក់របស់ សុន សេន[160]។ គាត់បានកាន់តំណែងនេះរួមជាមួយនឹង ស៊ូ ម៉េត រហូតដល់របបកម្ពុជាប្រជាធិបតេយ្យ

---

ការណ៍ដែលលោកបានរៀបរាប់ខាងលើកើតឡើងក្នុងឆ្នាំ ១៩៧៧។ សៀត ឆែ ត្រូវបានចាប់ខ្លួនក្នុងខែ កក្កដា ឆ្នាំ ១៩៧៧ ហើយ សុន សេន បានចេញទៅសមរភូមិនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៧៧។ តើត្រឹមត្រូវដែរឬទេ? ឆ.24 ទី១ រឿងចាប់ខ្លួន សៀត ឆែ ខ្ញុំមិនចាំទេ។ ឯ ចំណែក សុន សេន ទៅសមរភូមិនៅថ្ងៃ១៥ ដូចខែសីហា មិនមែនថ្ងៃទី១៧ ទេ។"]។

160 ឯកសារ D114/159 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅឌុច ឆ.23 ["តាមពិតអចិន្ត្រៃយ៍សេនាធិការ វារលាយពេលគេចាប់ សៀត ឆែ ហៅទុំ បញ្ជូនមក ស-២១។ មុនរឿង សៀត ឆែ ទៀតមាន ម៉ែន សាន ហៅយ៉ា ត្រូវ ប៉ុល ពត ដកចេញពីអនុលេខាសេនាធិការ បញ្ជូនទៅធ្វើលេខានៅភូមិភាគពាយ័ព្យ។ ដូច្នេះ សេនាធិការគ្មានអចិន្ត្រៃយ៍ទេ មានតែ សុន សេន ម្នាក់គត់ ដែលជាលេខាគណៈកម្មាធិការសេនាធិការ"]។ ឯកសារ D54/62 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត, ឆ.22-23, 27 ["តាមដែលខ្ញុំដឹង មាស មុត ជាអគ្គសេនាធិការរបស់កងទ័ព មានន័យថា អនុរបស់ សុន សេន។ នៅពេលយួនវ៉ៃបុកមកលើយើងនៅតាមព្រំដែន មាស មុត ត្រូវតែទៅត្រួតពិនិត្យស្ថានការណ៍នៅសមរភូមិមុខ។ ឆ៖ លោកជាអនុប្រធានមន្ទីរកងពល ១១៧ ទទួលខុសត្រូវផ្នែកភ័ស្តុភារ ហេតុអ្វីបានជាលោកដឹងថា មាស មុត ជាអគ្គសេនាធិការរង? ឆ.23៖ ដំបូងខ្ញុំសូមប្រាប់លោក អំពីរចនាសម្ព័ន្ធកងទ័ពកម្ពុជាប្រជាធិបតេយ្យ នៅក្នុងកងទ័ពគឺមាន គឺជើងគោក ជើងទឹក និងជើងអាកាស។ កងទ័ពទាំងបីនេះស្ថិតនៅក្រោមបញ្ជារបស់អគ្គសេនាធិការ។ សុន សេន ជាមេបញ្ជាការអគ្គសេនាធិការទទួលខុសត្រូវរួម និងកងថ្មើរជើង។ មាស មុត ជាអនុរបស់ សុន សេន ទទួលខុសត្រូវខាងជើងទឹក។ ស៊ូ ម៉េត ជាសមាជិកទទួលខុសត្រូវខាងជើងអាកាស។ រាល់ទំនាក់ទំនងតាមវិទ្យុទាក់ទងនិងសារទូរលេខគឺត្រូវតែឆ្លងកាត់អគ្គសេនាធិការ។ [...] ស៖ តើនៅពេលណាដែលកងវរៈសេនាធំជើងទឹករបស់ ភាព ទៅដល់ខេត្តក្រចេះ? ឆ៖ ប្រហែលចុងខែវិច្ឆិកា ឆ្នាំ១៩៧៨"]។ ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.93, 95-96 ["នៅពេលនោះមានមនុស្សថ្មីមកជំនួសការងាររបស់គាត់។ អ្នកមកជំនួសការងារ មាស មុត គឺឈ្មោះ ទឹម សេង ដែលពីមុនគាត់ជាអ្នកគ្រប់គ្រងកងនាវាប្រឆាំង។ នៅពេល ទឹម សេង មកជំនួស មាស មុត គាត់គ្រប់គ្រងអង្គភាពយោធាទាំងអស់នៅកំពង់សោម។ [...] ស៖ លោកដឹងថា តើនរណាជាអ្នកឲ្យ ទឹម សេង មកជំនួស មាស មុត? ឆ.95៖ បើតាមខ្ញុំយល់ គឺបញ្ជាពីខាងលើមក [...] ឆ. 96៖ មាស មុត គាត់ទៅខាងអគ្គសេនាធិការ ដូច្នេះការងារទាំងអស់ គាត់បញ្ជាពីខាងលើមកតាមរយៈ ទឹម សេង"]។ ឯកសារ D114/169 កំណត់ហេតុស្តាប់ចម្លើយ សេង សឿន ឆ.5 ["ហើយទៅដល់ក្រចេះហ្នឹង អ្នកប្រកាសចាត់តាំងហ្នឹងគឺ មុត ហ្នឹង មាស មុត គេជំនួសមុខឲ្យ ប៉ុល ពត និង នួន ជា ហ្នឹង ពេលហ្នឹង មុត គាត់ទៅ។ គាត់មានតែប្រកាសចាត់តាំងហ្នឹង បង មុត រួចពីនុងទៅ ខ្ញុំទៅ យួនវាយចូលមក រួចរត់ឡើងភ្នំដងរែកទៅ។"] ឆ. 25 ["ស៖ តើ មាស មុត មានតួនាទីអ្វីនៅពេលនោះ? ឆ៖ ជម្រាបបង ពេលនុងគាត់កាន់កងទឹក កងទ័ពជើងទឹកផង មកកាន់គេហៅអនុក្រសួងការពារជាតិ ជំនួស សុន សេន ប៉ុន្តែ មេត គេប្រធាន មុត អនុ ហើយចុះមករៀបចំតំបន់ក្រចេះ"]។ ឯកសារ D54/54 កំណត់ហេតុស្តាប់ចម្លើយ មាស រឿន ឆ.5 ["ខ្ញុំបានសង្កេតឃើញថា ការងាររបស់គាត់គឺផ្ទុះបញ្ច្រាំងទៅនឹងតួនាទីមួយដែលគាត់ជាសមាជិកម្នាក់របស់គណៈកម្មាធិការសេនាធិការ សោយសារខ្ញុំធ្លាប់បានឃើញគាត់មានសិទ្ធិណែនាំទៅកងផ្សេងៗទៀត ដូចជាកងពលលេខ ១ របស់ខ្ញុំជា

ដើម នៅក្នុងការប្រតិបត្តិការនៅក្នុងដែនសមុទ្រ។ មាស មុត បានរាយការណ៍ទៅអគ្គសេនាធិការ សុន សេន ដោយផ្ទាល់"], ឆ.26 ["ក្នុងឆ្នាំ ១៩៧៨ យើងត្រូវបានគេណែនាំឲ្យបន្ថយជម្លោះនៅខាងលិច ពីព្រោះនៅព្រំដែនខាងកើតមានជម្លោះកាន់តែខ្លាំងឡើងៗ។ អគ្គសេនាធិការបានប្រជុំណែនាំតាមរយៈ តា មុត និង តា សឿង"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចក់, ឆ.126-27, 129-30 ["ខ្ញុំដឹងថា មាស មុត ឆ្នាំ១៩៧៨ ដឹងថាគាត់មកភ្នំពេញ ប៉ុន្តែមិនដឹងថាគាត់ទៅណាៗ មិនដឹងទេ។ ឆ៖ តើលោកដឹងថា មាស មុត មកភ្នំពេញដោយរបៀបណា? ឆ. 127: បានថាដឹង តែពេលមានការងារអី មេបញ្ជាការតាមជាន់ថ្នាក់ គេផ្សាយប្រាប់យើងហើយ […] ឆ.129: […] គេថា មាស មុត ទៅនៅភ្នំពេញហើយ គេប្រាប់ទៀតថា មាស មុត មកធ្វើជារងសេនាធិការនៅភ្នំពេញ។ បើគេផ្សព្វផ្សាយអញ្ចឹង នេះខ្ញុំនិយាយតាមតែការដឹងទេ។ ស៖ អញ្ចឹង លោកចង់និយាយថា មេបញ្ជាររបស់លោក ប្រាប់លោកថា មាស មុត ទៅនៅភ្នំពេញ ហើយគាត់ទៅធ្វើជារងសេនាធិការ តើមែនទេ? ឆ. 130៖ បាទ"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.9-10 ["មាស មុត គឺជាមេបញ្ជាការកងពលលេខ ៣ ហើយគាត់គឺជាអនុរបស់ សុន សេន ដែលនៅសេនាធិការរបស់កងទ័ពជាតិ […] ឆ.10: ក្នុងពេលនោះ ក្នុងមួយត្រីមាសម្តង គេតែងតែរៀបចំសន្និបាតដ៏ធំមួយសម្រាប់យោធា។ នៅពេលនោះ គេតែងឧទ្ទេសនាមប្រាប់ ដែលគេថា មាស មុត គឺជាអនុរបស់ សុន សេន"]។ ឯកសារ D59/1/1.8a កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រំ សារ៉ាត់ KH 00926403 ["ស៖ តាមុត អញ្ចឹងគាត់អគ្គមេបញ្ជាការរង? ឆ៖ បាទ មេបញ្ជាការរង។ ស៖ ចាប់ពី៧៥ មកដែរ? ឆ៖ ហេ! ទើបនឹងឡើងទេ ទើបនឹងទៅក្នុងចន្លោះ ៧៨ ទេ ពី៧៥ ដល់៧៧ ៧០ អី គាត់នៅក្របខណ្ឌ តួនាទីរបស់គាត់ជាជើងទឹក គ្រប់គង ១៦៤។ ស៖ ៧៨ បានគាត់ឡើង? ឆ៖ ចុង ៧៨]។ ឯកសារ D54/99.1 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ KH 00990786-87 ["ស៖ តាមុត គាត់អើគ្រប់គ្រងនៅខាងកំពង់សោម នៅកំពង់សោមហ្នឹងរហូតដល់បែក៧៩ ឬក៏? ឆ៖ បាទ! រហូតមក ចុង៧៨ គាត់គេដកមកគាត់ ក្រោយមកគាត់ឡើង នាយអគ្គសេនាធិការរង"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង រ៉េត KH 00926561-62 ["ស៖ កាលគាត់ [មាស មុត] ទៅហ្នឹងជាអគ្គមេបញ្ជាការតែម្តង ឬយ៉ាងម៉េច? ឆ៖ ក្នុងគណៈកម្មការយោធា។ ស៖ ចឹង សុន សេន គាត់នៅដដែរ? ឆ៖ បាទ! សុន សេននៅដដែល តាមពិត សុន សេន គាត់ជាប្រធានចឹងណាស់ […] បន្ទាប់មកអនុប្រធានដូចជា មាស មុត ចឹងទៅ។ ស៖ ហើយពីណាទៀត? ឆ៖ សមាជិក ស៊ូ សាម៉េចចឹងទៅ ព្រោះសុន សេន ខាងជើងគោកចឹង[…] ហើយខាងជើងទឹក មាស មុត […] ហើយជើងអាកាសត្រូវស៊ូ សាម៉េត ហើយ[…] ព្រោះកងទ័ពត្រូវមានអទិភាពបី ទី១ ខាងជើងគោក ទី២ ជើងទឹក និងទី៣ ជើងអាកាសចុងក្រោយគេ។"]។ ឯកសារ D54/60.2 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ឹង វេត KH 00975728 ["ស៖ ដល់ពេលបែកឆ្នាំ៧៥ កងពលទី៣ របស់តាម៉ុក គាត់ចូលទៅខាង? ឆ៖ ទៅខាងអគ្គសេនាធិការវិញហើយហ្នឹងមជ្ឈិមគ្រប់គ្រង កងមជ្ឈិមហើយ […] [មាស មុត] ជើងទឹកផង ហើយគាត់រួមជាមួយតា ខៀវ នេះ ជាមួយតា សុន សេន រួមទូទាំងប្រទេស គាត់ជាអគ្គសេនាធិការរង ដល់ចឹង គាត់គ្រប់គ្រងទិសទាំងអស់"]។

បានដួលរលំ[161]។ ភស្តុតាងបង្ហាញថា ឥទ្ធិពលរបស់ **មាស មុត** នៅក្នុងសេនាធិការ បានកើនឡើងនៅទូទាំងរបបនេះ ដោយបានឈានដល់ចំណុចកំពូលនៅចុងឆ្នាំ ១៩៧៨ នៅពេលដែលគាត់ត្រូវបានប្រគល់ភារកិច្ចឱ្យគ្រប់គ្រងលើស្ថាប័នយោធាទាំងបី និងត្រូវបានចាត់ឱ្យទៅធ្វើការបោសសម្អាតនៅក្នុងកងពលធំមជ្ឈិម និងនៅក្នុងតំបន់ស្វយ័តនានាជំនួសឱ្យមជ្ឈិមបក្ស។

54. ក្នុងនាមជាមេបញ្ជាការកងទ័ពជើងទឹក និងជាសមាជិកនៃសេនាធិការ **មាស មុត** បានរាយការណ៍ទៅកាន់ និងទទួលបញ្ជាដោយផ្ទាល់ពី សុន សេន[162] និងបានចូលរួមក្នុងការប្រជុំប្រចាំខែនៅទី

---

[161] ឯកសារ D114/297.1.27 សេង សឿន ប្រតិចារិកសវនាការថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ម៉ 13.54.58-14.01.14 ["ពូ សុន សេន នោះ ក្រសួងការពារជាតិហ្នឹងក៏លែងទៅណាណីដែរ ស្រាប់តែពីរនាក់ហ្នឹង គាត់ទៅកាន់តំណែងក្រសួងការពារជាតិហ្នឹងទៅ។ ស្រាប់ដល់បង មុត ទៅចាត់តាំងខ្ញុំហ្នឹង ពេលការរាយការណ៍មក រាយការណ៍ឱ្យបងម៉េត។ ខ្ញុំអង្គុយស្តាប់គាត់រាយការណ៍តាម មិនមែនទូរស័ព្ទទេ កាលនោះគេនេះទេ ដល់អញ្ចឹង ខ្ញុំអង្គុយស្តាប់ក្បែរគាត់ហ្នឹងទៅ។ បានជាខ្ញុំដឹងនោះ។ សះខ្ញុំសូមសួរលោកពីចំណុចមួយ ថាតើលោកដឹងថាតើ មាស មុត កាន់មុខតំណែងនៅក្រោម សុន សេន ដែលជាតំណែងជាអនុរដ្ឋមន្ត្រីការពារប្រទេសក្រោម សុន សេន ដែរឬទេ? [...] ឆះ ខ្ញុំមិនដឹងថាប្រធាន ឬអនុប្រធានទេ"]។ ឯកសារ កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត D54/63 ឆ.31 ["ពីព្រោះនៅក្នុងចុងឆ្នាំ ១៩៧៨ សុន សេន ត្រូវបានគេបញ្ជូនទៅនៅសួង ដោយមិនប្រគល់ការងារអ្វីច្បាស់លាស់ឱ្យគាត់ទេ។ ក្នុងពេលនោះរាល់សំណើសុំទាំងឡាយដែលស្នើទៅអគ្គសេនាធិការ គឺមានការឆ្លើយតបមកវិញដោយ តា ម៉េត និង តា មុត។ ខ្ញុំដឹងរឿងនេះតាមរយៈសារទូរលេខ"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.12 ["តាមរយៈរចនាសម្ព័ន្ធនេះ យើងដឹងថា សេនាធិការក៏មានរចនាសម្ព័ន្ធប្រហាក់ប្រហែលនេះ ដែរ។ ក្នុងនោះ សុន សេន គឺជាប្រធានសេនាធិការ ហើយ មាស មុត ដែលជាបញ្ជាការកងទ័ពជើងទឹក គឺជាអនុម្នាក់របស់ សុន សេន និង ស៊ូ ម៉េត ដែលជាមេបញ្ជាការកងទ័ពជើងអាកាស គឺជាអនុម្នាក់ទៀតរបស់សេនាធិការ"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង រ៉េត KH 00926561-62 ["សះ កាលគាត់ [មាស មុត] ទៅហ្នឹងជាអគ្គមេបញ្ជាការតែម្តង ឬយ៉ាងម៉េច? ឆះ ក្នុងគណៈកម្មការយោធា។ សះ ចឹង សុន សេន គាត់នៅដែរ? ឆះ បាទ! សុន សេននៅដែល តាមពិត សុន សេន គាត់ជាប្រធានចឹងណាស់ [...] បន្ទាប់មកអនុប្រធានដូចជា មាស មុត ចឹងទៅ។ សះ ហើយពីណាទៀត? ឆះ សមាជិក ស៊ូ សាម៉េចចឹងទៅ ព្រោះសុន សេន ខាងជើងគោកចឹង[...] ហើយខាងជើងទឹក មាស មុត [...] ហើយជើងអាកាសត្រូវ ស៊ូ សាម៉េត ហើយ[...] ព្រោះកងទ័ពត្រូវមានអទិភាពបី ទី១ ខាងជើងគោក ទី២ ជើងទឹក និងទី៣ ជើងអាកាសចុងក្រោយគេ"]។

[162] ឯកសារ D4.1.1020 របាយការណ៍របស់ មុត (មាស មុត) ផ្ញើជូនបង ៨៩ (សុន សេន) ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ១៩៧៦។ ឯកសារ D1.3.12.3 របាយការណ៍របស់ មុត (មាស មុត) ផ្ញើជូនបង ៨៩ (សុន សេន) ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦។ ឯកសារ D1.3.14.1 សារទូរលេខរបស់ មុត (មាស មុត) ផ្ញើជូនបង ៨៩ (សុន សេន) ថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៦។ ឯកសារ D1.3.34.10 សារទូរលេខ ៤៤ របស់ មុត (មាស មុត) ផ្ញើជូនបង ៨៩ (សុន សេន) ថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៧៦។ ឯកសារ D1.3.8.4 កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ

បញ្ជាការកណ្ដាលនៃសេនាធិការ នៅទីក្រុងភ្នំពេញ[163]។ ផ្ទុយពីការអះអាងរបស់ **មាស មុត** ដែលថា "នៅក្នុងការប្រជុំដែលខ្ញុំបានចូលរួមជាមួយ សុន សេន យើងបានពិភាក្សាគ្នាថាតើមានស្រូវអង្ករគ្រប់គ្រាន់ ឬក៏អត់។ [...] ខ្ញុំមិនបានចូលរួមក្នុងការប្រជុំសម្ងាត់ ដែលមេដឹកនាំបានស៊ើប

១៩៧៦ [រៀបរាប់អំពីស្ថានភាពខ្លាំងផ្ទៃក្នុងនៅកងពល ១៦៤។ សុន សេន បានបញ្ជាឱ្យចាប់ខ្លួន និងសួរចម្លើយ វង់ស្រួល ដែលធ្លាប់ព្យាយាមរត់]។ ឯកសារ D1.3.4.1 របាយការណ៍របស់ មុត (មាស មុត) ផ្ញើជូនបង ៨៩ (សុន សេន) ថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៦ [ដោយមានចំណារសរសេរដៃរបស់បង ខៀវ (សុន សេន)]។ ឯកសារ D1.3.2.2 សារទូរលេខ ១០ របស់ បង ៨៩ (សុន សេន) ផ្ញើទៅ មុត (មាស មុត) ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ឯកសារ D1.3.4.2 របាយការណ៍របស់ ខៀវ (សុន សេន) ផ្ញើជូន ឌីម ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦ [លិខិតរបស់ សុន សេន ផ្ញើជូនសមមិត្ត ឌីម អនុលេខាកងពល ១៦៤។ ជាដំបូង លិខិតនោះកត់សម្គាល់ ថា មានឃើញយន្តហោះខ្មាំងហោះលើឆ្នេរកោះ។ លិខិតនោះក៏កត់សម្គាល់ថែមទៀតថា យន្តហោះនោះចង់ហោះចូលមកតាមកោះកុង ហើយផ្ដល់ជាព័ត៌មានថា "ពេលសមមិត្តត្រឡប់ទៅវិញ នឹងជំរាបច្បាស់"]។ ឯកសារ D1.3.12.18 សារទូរលេខ ០៩ របស់ មុត (មាស មុត) ផ្ញើជូនបង ៨៩ (សុន សេន) ថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧ [ដោយមានចំណារសរសេរដៃរបស់បង ខៀវ (សុន សេន)]។ ឯកសារ D1.3.19.2 របាយការណ៍របស់ ខៀវ (សុន សេន) ផ្ញើជូនគណៈកងពលធំ និងកងវរសេនាធំ ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ១៩៧៧ [រៀបរាប់អំពីសេចក្ដីណែនាំរបស់អគ្គសេនាធិការ ទៅកាន់កងពលធំ និងកងវរសេនាធំ។ សេចក្ដីណែនាំនោះចេញដោយ សុន សេន ក្នុងនាមជានាយអគ្គសេនាធិការ]។ ឯកសារ D1.3.34.64 កិច្ចសន្ទនាតាមទូរសព្ទសម្ងាត់រវាង មាស មុត និងបង ៨៩ (សុន សេន) ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨។ ឯកសារ D4.1.637 របាយការណ៍របស់ មុត (មាស មុត) ផ្ញើជូនបង ៨៩ (សុន សេន) ថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៧៨។ ឯកសារ D1.3.12.2 របាយការណ៍របស់ មុត (មាស មុត) ផ្ញើជូនបង ៨៩ (សុន សេន) ថ្ងៃទី០៦ ខែកុម្ភៈ (ពុំដឹងឆ្នាំ)។ សូមពិនិត្យមើលផងដែរ ឯកសារ D54/52 កំណត់ហេតុស្ដាប់ចម្លើយ មាស វឿន, ឆ.12-13 ["សៈ ហេតុអ្វីបានជា មាស មុត រាយការណ៍អំពីព្រឹត្តិការណ៍នោះទៅបង ៨៩? ឆៈ ពីព្រោះ មាស មុត ទទួលខុសត្រូវការពារដែនសមុទ្រ និងព្រំដែនទឹករបស់ប្រទេសកម្ពុជា ហើយបង ៨៩ គឺជាអ្នកដែលនៅអគ្គសេនាធិការ។ សៈ តើបង ៨៩ នៅអគ្គសេនាធិការហ្នឹង ជាអ្នកណា? ឆ. 13ៈ ខ្ញុំមិនច្បាស់ ប៉ុន្តែវាអាចជា សុន សេន។ យោងតាមការយល់របស់ខ្ញុំអំពីរចនាសម្ព័ន្ធបញ្ជាការ មាស មុត គឺជាកម្លាំងរបស់មជ្ឈិម ដូច្នេះគាត់ត្រូវតែរាយការណ៍ទៅឱ្យថ្នាក់លើរបស់គាត់ គឺ សុន សេន ដែលជាសេនាធិការ"]។ ឯកសារ D54/54 កំណត់ហេតុស្ដាប់ចម្លើយ មាស វឿន ឆ.5 ["មាស មុត បានរាយការណ៍ទៅអគ្គសេនាធិការ សុន សេន ដោយផ្ទាល់"]។ ឯកសារ D54/87 កំណត់ហេតុស្ដាប់ចម្លើយ ព្រំ សារ៉ាត ឆ.75 ["ខ្ញុំបានឮអំពីរឿងនេះពីមេបញ្ជាការកងវរសេនាធំរបស់ខ្ញុំថា លោក សុន សេន បានបញ្ជាឱ្យ មាស មុតដឹកនាំទ័ពទៅបង្ក្រាបពួកបះបោរនៅភូមិភាគបូព៌ា ដែលដឹកនាំដោយ សោ ភឹម"]។

163 ឯកសារ D54/37 កំណត់ហេតុស្ដាប់ចម្លើយ ស៊ឹម នី ឆ.30-31 ["សៈ តើលោកធ្លាប់ឮថា មាស មុត ធ្វើការអគ្គសេនាធិការដែរឬទេ? ឆ. 30ៈ បាទខ្ញុំឮ។ គាត់ត្រូវប្រជុំមួយខែម្ដងជាមួយសេនាធិការនៅភ្នំពេញ។ សៈ ហេតុម៉េច បានជាលោកដឹងអំពីរឿងនេះ? ឆ. 31ៈ ខ្ញុំដឹងដោយសារប្រធានរបស់ខ្ញុំជាគ្រិន ក៏បានទៅចូលរួមប្រជុំនោះដែរ"]។

អង្កេតលើករណីខ្មាំងនោះទេ”[164] ឯកសារបក្សកុម្មុយនីស្តកម្ពុជាបង្ហាញថា គោលនយោបាយប្រឆាំងខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា និងការអនុវត្តគោលនយោបាយនោះ ជាញឹកញាប់គឺជាប្រធានបទសំខាន់ៗនៃការប្រជុំបែបនោះ[165]។

55. ការធ្វើដំណើរទៅកាន់ទីក្រុងភ្នំពេញរបស់ **មាស មុត** ដើម្បីចូលរួមកិច្ចប្រជុំសេនាធិការកាន់តែញឹកញាប់ឡើងៗនៅក្នុងឆ្នាំក្រោយៗនៃរបបនេះ។ សំណុំឯកសារស្តីពីកងទ័ពបដិវត្តន៍កម្ពុជាដែលនៅមាន បង្ហាញថា **មាស មុត** បានចូលរួមកិច្ចប្រជុំជាន់ខ្ពស់យ៉ាងហោចណាស់ចំនួនប្រាំមួយដង ចាប់ពីថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ១៩៧៦ ដល់ថ្ងៃទី ១ ខែ មីនា ឆ្នាំ ១៩៧៧[166]។ បុគ្គលិកយោធានៃកងទ័ពបដិវត្តន៍កម្ពុជាបញ្ជាក់ថា មាស មុត បានធ្វើដំណើរជាញឹកញាប់ពីកំពង់សោមទៅភ្នំពេញដើម្បីជួបជាមួយ សុន សេន និងមេដឹកនាំកងពលផ្សេងៗទៀត[167]។

---

164 ឯកសារ D22.2.180 សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ បទសម្ភាសន៍ជាមួយ មាស មុត ថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ EN 00161880 [“សៈ ផ្អែកលើរបាយការណ៍ លោកបានចូលរួមប្រជុំសេនាធិការជាច្រើនជាមួយ[អតីតរដ្ឋមន្ត្រីការពារជាតិខ្មែរក្រហម] សុន សេន ដែលកាលនោះ គាត់បានបង្ហាញពីគោលនយោបាយចំពោះសត្រូវរបស់របបខ្មែរក្រហម។ ឆៈ ពេលដែលខ្ញុំចូលរួមកិច្ចប្រជុំទាំងនោះ គឺគ្រាន់តែពិភាក្សាអំពីការបង្កបង្កើនផលតែប៉ុណ្ណោះ [...] ដូចដែលខ្ញុំបានប្រាប់លោករួចមកហើយ នៅក្នុងអង្គប្រជុំដែលខ្ញុំបានចូលរួមជាមួយ សុន សេន គឺយើងបានពិភាក្សាអំពីបញ្ហាថាតើមានអង្ករគ្រប់គ្រាន់ដែរឬអត់។ ខ្ញុំគ្រាន់តែជាប្រធានកងពលម្នាក់ប៉ុណ្ណោះ ហើយខ្ញុំពុំបានចូលរួមកិច្ចប្រជុំសម្ងាត់ដែលថ្នាក់ដឹកនាំធ្វើការស្រាវជ្រាវលើករណីខ្មាំងសត្រូវអ្វីនោះទេ”]។

165 សូមមើលផ្នែក III.៣. ការចូលរួមរបស់ មាស មុត នៅក្នុងឧក្រិដ្ឋកម្ម - ការចូលរួមធ្វើទុក្ខបុកម្នេញ និងសម្លាប់សត្រូវ។

166 ឯកសារ D1.3.8.2, ឯកសារ D4.1.632 កំណត់ហេតុកិច្ចប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៧៦ KH 00162484។ ឯកសារ D1.3.8.3 កំណត់ហេតុកិច្ចប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៧៦។ ឯកសារ D1.3.27.18 កំណត់ហេតុកិច្ចប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦ KH 00052389-90។ ឯកសារ D1.3.27.20 កំណត់ហេតុកិច្ចប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៦ KH 00052411។ ឯកសារ D1.3.27.22 កំណត់ហេតុកិច្ចប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៧៦ KH 00088929។ ឯកសារ D1.3.27.26 កំណត់ហេតុកិច្ចប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៧៧ KH 00052305។

167 ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន ឆ.3 [“មាស មុត មិនស្នាក់នៅជាប្រចាំនៅកំពង់សោមទេ គាត់ធ្វើដំណើរទៅមកៗ ពីភ្នំពេញទៅកំពង់សោម។ គាត់ទៅភ្នំពេញ គាត់ទៅជួយ សុន សេន នៅសេនាធិការ”]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ ឆ.126-27 [“ខ្ញុំដឹងថា មាស មុត ឆ្នាំ១៩៧៨ ដឹងថាគាត់មកភ្នំពេញ ប៉ុន្តែមិនដឹងថាគាត់ទៅណាៗ មិនដឹងទេ។ សៈ តើលោកដឹងថា មាស មុត មកភ្នំពេញដោយរបៀបណា? ឆ.

56. ការប្ដេជ្ញារបស់ **មាស មុត** ចំពោះ និងការអនុវត្តយ៉ាងមានប្រសិទ្ធភាពនូវគោលនយោបាយបក្សកុម្មុយនីស្ដកម្ពុជា បាននាំដល់ការដំឡើងមុខតំណែងរបស់គាត់ជាអនុលេខាសេនាធិការ[168]។ នៅចុង

---

១២៧៖ បានថាដឹង តែពេលមានការងារអី មេបញ្ជាការតាមជាន់ថ្នាក់ គេផ្សាយប្រាប់យើងហើយ"]។ ឯកសារ D54/37 កំណត់ហេតុស្ដាប់ចម្លើយ ស៊ឹម នី ឆ.30-31 ["ស៖ តើលោកធ្លាប់ឮថា មាស មុត ធ្វើការអគ្គសេនាធិការដែរឬទេ? ស.30៖ បាទ ខ្ញុំឮ។ គាត់ត្រូវប្រជុំមួយខែម្ដងជាមួយសេនាធិការនៅភ្នំពេញ។ ស៖ ហេតុម៉េច បានជាលោកដឹងអំពីរឿងនេះ? ឆ. 31៖ ខ្ញុំដឹងដោយសារប្រធានរបស់ខ្ញុំជាគ្រិន ក៏បានទៅចូលរួមប្រជុំនោះដែរ"]។ ឯកសារ D59/1/1.8a កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រំ សារ៉ាត KH 00926401 ["ស៖ អញ្ចឹងគាត់នៅកំពង់សោមជាប់រហូតម៉ង? ឆ៖ តាមុត គាត់ដាច់ក្រោយ ពេលក្នុង ចុះ៧៨ គាត់ដកមកភ្នំពេញ"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង វ៉េត KH 00926542-43 ["ស៖ ហើយមានពីណាទៀត? ឆ៖ បើនិយាយទៅមាន ទឹម សេង តែស្លាប់បាត់ដែរ មុនដំបូងគាត់គ្រប់គ្រងជើងទឹក ដល់ក្រោយមក គាត់មកគ្រប់គ្រងកងពល ១៦៤ ហើយ មាស មុត គាត់ឡើងមកធ្វើជាមេបញ្ជាការនៅភ្នំពេញ"], KH 00926561 ["ស៖ ចឹង តា មុត គាត់ផ្លាស់មកភ្នំពេញនៅឆ្នាំណា? ឆ៖ នៅឆ្នាំ ៧៧ តាមមើល។ ស៖ចឹង គាត់មកនៅភ្នំពេញបានយូរដែរ? ឆ៖ បានយូរដែរ។ ស៖ បានប៉ុន្មាន បានបែក? ឆ៖បានមួយឆ្នាំជាងដែលហ្នឹង គាត់មកនៅភ្នំពេញហ្នឹង បានគាត់រត់ចេញពីភ្នំពេញឆ្នាំ៧៩ ហ្នឹងបានគាត់ដាក់បទបញ្ជាឱ្យដកពីកំពង់សោម"]។

168 ឯកសារ D54/100 កំណត់ហេតុស្ដាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.93 ["នៅពេលនោះ [ចុងឆ្នាំ ១៩៧៨] មានមនុស្សថ្មីមកជំនួសការងាររបស់គាត់។ អ្នកមកជំនួសការងារ មាស មុត គឺឈ្មោះ ទឹម សេង ដែលពីមុនគាត់ជាអ្នកគ្រប់គ្រងកងនាវាប្រឆាំង។ នៅពេល ទឹម សេង មកជំនួស មាស មុត គាត់គ្រប់គ្រងអង្គភាពយោធាទាំងអស់នៅកំពង់សោម"] ឆ. 95-96 ["ស៖ លោកដឹងថា តើនរណាជាអ្នកឱ្យ ទឹម សេង មកជំនួស មាស មុត? ឆ.95៖ បើតាមខ្ញុំយល់ គឺបញ្ជាពីខាងលើមក [...] ឆ. 96៖ មាស មុត គាត់ទៅខាងអគ្គសេនាធិការ ដូច្នេះការងារទាំងអស់ គាត់បញ្ជាពីខាងលើមកតាមរយៈ ទឹម សេង"]។ ឯកសារ D54/62 កំណត់ហេតុស្ដាប់ចម្លើយ ម៉ុង វេត ឆ.22-23, 27 ["តាមដែលខ្ញុំដឹង មាស មុត ជាអគ្គសេនាធិការរងរបស់កងទ័ព មានន័យថា អនុរបស់ សុន សេន [...] មាស មុត ជាអនុរបស់ សុន សេន ទទួលខុសត្រូវខាងជើងទឹក។ ស៊ូ ម៉េត ជាសមាជិកទទួលខុសត្រូវខាងជើងអាកាស។ រាល់ទំនាក់ទំនងតាមវិទ្យុទាក់ទង និងសារទូរលេខគឺត្រូវតែឆ្លងកាត់អគ្គសេនាធិការ។ [...] ស៖ តើនៅពេលណាដែលកងវរៈសេនាធំជើងទឹករបស់ ភាព ទៅដល់ខេត្តក្រចេះ? ឆ៖ ប្រហែលចុងខែវិច្ឆិកា ឆ្នាំ១៩៧៨"]។ ឯកសារ D114/169 កំណត់ហេតុស្ដាប់ចម្លើយ សេង សឿន ឆ.25 ["ស៖ តើ មាស មុត មានតួនាទីអ្វីនៅពេលនោះ? ឆ៖ជម្រាបបង ពេលនុង គាត់កាន់កងទឹក កងទ័ពជើងទឹកផង មកកាន់គេហៅអនុក្រសួងការពារជាតិ ជំនួស សុន សេន ប៉ុន្តែ មេត គេប្រធាន មុត អនុ ហើយចុះមករៀបចំតំបន់ក្រចេះ"]។ ឯកសារ D54/54 កំណត់ហេតុស្ដាប់ចម្លើយ មាស វឿន ឆ.26 ["ក្នុងឆ្នាំ ១៩៧៨ យើងត្រូវបានគេណែនាំឱ្យបន្ថយជម្លោះនៅខាងលិច ពីព្រោះនៅព្រំដែនខាងកើត មានជម្លោះកាន់តែខ្លាំងឡើងៗ។ អគ្គសេនាធិការបានប្រជុំណែនាំតាមរយៈ តា មុត និង តា សឿង"]។ ឯកសារ D114/186 កំណត់ហេតុស្ដាប់ចម្លើយ សាត ចាក់ ឆ.126-27, 129 ["ខ្ញុំដឹងថា មាស មុត ឆ្នាំ១៩៧៨ ដឹងថាគាត់មកភ្នំពេញ ប៉ុន្តែមិនដឹងថាគាត់ទៅណាៗ មិនដឹងទេ។ ឆ៖ តើលោកដឹងថា មាស មុត មកភ្នំពេញដោយរបៀបណា? ឆ.127: បានថាដឹង តែពេលមានការងារអី មេបញ្ជាការតាម

ឆ្នាំ ១៩៧៨ គាត់ត្រូវបានចាត់ឱ្យទៅធ្វើការនៅទីបញ្ជាការកណ្តាលយោធានៅទីក្រុងភ្នំពេញ ខណៈពេលដែលគាត់នៅតែបន្តគ្រប់គ្រងកងពល ១៦៤ និងតំបន់កំពង់សោមដដែល[169]។ នៅដំណាក់

---

ជាន់ថ្នាក់ គេផ្សាយប្រាប់យើងហើយ [...] ឆ.129: [...] គេថា មាស មុត ទៅនៅភ្នំពេញហើយ គេប្រាប់ទៀតថា មាស មុត មកធ្វើជារងសេនាធិការនៅភ្នំពេញ"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.9-10 ["មាស មុត គឺជាមេបញ្ជាការកងពលលេខ ៣ ហើយគាត់គឺជាអនុរបស់ សុន សេន ដែលនៅសេនាធិការរបស់កងទ័ពជាតិ [...] ឆ.10: ក្នុងពេលនោះ ក្នុងមួយត្រីមាសម្តង គេតែងតែរៀបចំសន្និបាតដ៏ធំមួយសម្រាប់យោធា។ នៅពេលនោះ គេតែងឧទ្ទេសនាមប្រាប់ ដែលគេថា មាស មុត គឺជាអនុរបស់ សុន សេន"]។ ឯកសារ D59/1/1.8a កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រំ សារ៉ាត KH 00926403 ["ស៖ តាមុត អញ្ចឹងគាត់អគ្គមេបញ្ជាការរង? ឆ៖ បាទ! មេបញ្ជាការរង។ ស៖ ចាប់ពី ៧៥ មកដែរ? ឆ៖ ហេ! ទើបនឹងឡើងទេ ទើបនឹងទៅក្នុងចន្លោះ ៧៨ ទេ ពី៧៥ ដល់៧៧ ៧០ អី គាត់នៅក្របខ័ណ្ឌ តួនាទីរបស់គាត់ជាជើងទឹក គ្រប់គ្រង១៦៤។ ស៖ ៧៨ បានគាត់ឡើង? ឆ៖ ចុង ៧៨]។ ឯកសារ D54/99.1 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ KH 00990786-87 ["ស៖ តាមុត គាត់អើគ្រប់គ្រងនៅខាងកំពង់សោម នៅកំពង់សោមហ្នឹងរហូតដល់បែក៧៩ ឬក៏? ឆ៖ បាទ! រហូតមក ចុង៧៨ គាត់គេដកមកគាត់ ក្រោយមកគាត់ឡើង នាយអគ្គសេនាធិការរង"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង រ៉េត KH 00926561-62 ["ស៖ កាលគាត់ [មាស មុត] ទៅហ្នឹងជាអគ្គមេបញ្ជាការតែម្តង ឬយ៉ាងម៉េច? ឆ៖ ក្នុងគណៈកម្មការយោធា។ ស៖ ចឹង សុន សេន គាត់នៅដដែរ? ឆ៖ បាទ! សុន សេននៅដដែល តាមពិត សុន សេន គាត់ជាប្រធានចឹងណាស់ [...] បន្ទាប់មកអនុប្រធានដូចជា មាស មុត ចឹងទៅ។ ស៖ ហើយពីណាទៀត? ឆ៖ សមាជិក ស៊ូ សាម៉េចចឹងទៅ ព្រោះសុន សេន ខាងជើងគោកចឹង[...] ហើយខាងជើងទឹក មាស មុត [...] ហើយជើងអាកាសត្រូវ ស៊ូ សាម៉េត ហើយ[...] ព្រោះកងទ័ពត្រូវមានអទិភាពបី ទី១ ខាងជើងគោក ទី២ ជើងទឹក និងទី៣ ជើងអាកាសចុងក្រោយគេ"]។ ឯកសារ D54/60.2 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ឺង វេត KH 00975728 ["ស៖ ដល់ពេលបែកឆ្នាំ៧៥ កងពលទី៣ របស់តាម៉ុក គាត់ចូលទៅខាង? ឆ៖ ទៅខាងអគ្គសេនាធិការវិញហើយហ្នឹង មជ្ឈិមគ្រប់គ្រង កងមជ្ឈិមហើយ [...] [មាស មុត] ជើងទឹកផង ហើយគាត់រួមជាមួយតា ខៀវ នេះ ជាមួយតា សុន សេន រួមទូទាំងប្រទេស គាត់ជាអគ្គសេនាធិការរង ដល់ចឹង គាត់គ្រប់គ្រងទិសទាំងអស់"]។

169 មាស មុត ខ្លួនឯងបានទទួលស្គាល់ថា គាត់បន្តគ្រប់គ្រងកងពល ១៦៤ បន្ទាប់ពីគាត់ចេញពីកំពង់សោម។ ក៏ប៉ុន្តែ ចំណុចនេះមានភាពមិនស៊ីសង្វាក់ទៅនឹងភ័ស្តុតាងដទៃទៀតដែលមាននៅក្នុងសំណុំរឿង។ គាត់បានបញ្ជាក់ថា ហេតុការណ៍នេះកើតឡើងនៅខែ កុម្ភៈ ឆ្នាំ ១៩៧៨៖ ឯកសារ D54/16/1R ខ្សែអាត់សំឡេងនៃកិច្ចសម្ភាសន៍របស់ David Kattenburg ជាមួយ មាស មុត ខែ មេសា ឆ្នាំ ២០០៩ នាទី 34:37-35:28 [បកប្រែពីភាសាអង់គ្លេស] "ខ្ញុំមិនបាននៅកំពង់សោមទេ។ នៅខែ កុម្ភៈ ឆ្នាំ ១៩៧៨ ខ្ញុំបានចាកចេញពីកំពង់សោមហើយ។ ស. តើលោកទៅណា? ឆ. ខ្ញុំត្រូវគេចាត់តាំងឱ្យទៅធ្វើការនៅខេត្តក្រចេះជិតព្រំដែនឡាវ។ ស. ដូច្នេះ លោកបានចាកចេញពីកងពល ១៦៤ ទាំងស្រុងនៅខែ កុម្ភៈ ឆ្នាំ ១៩៧៨? ឆ៖ អត់ទេ ខ្ញុំនៅតែមានតួនាទី ប៉ុន្តែ ខ្ញុំត្រូវគេចាត់តាំងការងារមួយទៀតនៅក្រចេះ"]។ សូមមើលផងដែរ ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.93, 95-96 ["នៅពេលនោះមានមនុស្សថ្មី

មកជំនួសការងាររបស់គាត់។ អ្នកមកជំនួសការងារ មាស មុត គឺឈ្មោះ ទឹម សេង ដែលពីមុនគាត់ជាអ្នកគ្រប់គ្រងកងនាវាប្រឆាំង។ នៅពេល ទឹម សេង មកជំនួស មាស មុត គាត់គ្រប់គ្រងអង្គភាពយោធាទាំងអស់នៅកំពង់សោម។ [...] ស៖ លោកដឹងថា តើនរណាជាអ្នកឲ្យ ទឹម សេង មកជំនួស មាស មុត? ឆ.95៖ បើតាមខ្ញុំយល់ គឺបញ្ជាពីខាងលើមក [...] ឆ. 96៖ មាស មុត គាត់ទៅខាងអគ្គសេនាធិការ ដូច្នេះការងារទាំងអស់ គាត់បញ្ជាពីខាងលើមកតាមរយៈ ទឹម សេង ហើយ ទឹម សេង ដើរមើលការងារនិងបញ្ជាការងារបន្ត [...] ស៖ លោកអម្បាញ់មិញថា មាស មុត នៅអគ្គសេនាធិការ តើលោកដឹងដោយរបៀបម៉េច? ឆ.100៖ ក្រោយពេលដែលយួនវៃចូលមកខ្លាំង ខ្ញុំបានឃើញតា មាស មុត ត្រលប់មកវិញ ប្រហែលជាង ១០ ថ្ងៃមុនវៀតណាមទម្លាក់គ្រាប់បែកនៅក្រុងកំពង់សោម គឺចុងឆ្នាំ ១៩៧៨។ ខ្ញុំសន្និដ្ឋានថាគាត់ប្រហែលទៅអគ្គសេនាធិការ"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ ឆ.126-27, 129 ["ខ្ញុំដឹងថា មាស មុត ឆ្នាំ១៩៧៨ ដឹងថាគាត់មកភ្នំពេញ ប៉ុន្តែមិនដឹងថាគាត់ទៅណាៗ មិនដឹងទេ។ ឆ៖ តើលោកដឹងថា មាស មុត មកភ្នំពេញដោយរបៀបណា? ឆ.127: បានថាដឹង តែពេលមានការងារអី មេបញ្ជាការតាមជាន់ថ្នាក់ គេផ្សាយប្រាប់យើងហើយ [...] ឆ.129: ធម្មតាមេបញ្ជាការតាមថ្នាក់ៗអញ្ជើញ ថាមួយខែគេត្រូវមករៀនជាមួយកងពលម្តង ដល់ពេលហ្នឹងហើយ ពេលគេចុះទៅវិញ គេថា មាស មុត ទៅនៅភ្នំពេញហើយ គេប្រាប់ទៀតថា មាស មុត មកធ្វើជារងសេនាធិការនៅភ្នំពេញ"]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត ឆ.171-172 ["ស៖ លោកបានបញ្ជាក់នៅខាងដើមថា មាស មុត បានទៅស្រុកមេមត់នៅចុងឆ្នាំ ១៩៧៨ តាមការណែនាំរបស់លោក សុន សេន។ តើ មាស មុត នៅតែមានអំណាចដឹកនាំដឹកនាំគ្រប់គ្រងអ្វីៗនៅខេត្តកំពង់សោមដដែលទេ នៅពេលដែលគាត់ទៅស្រុកមេមត់នោះ? ឆ.171៖ ការងាររបស់គាត់នៅពេលនោះ គឺគាត់នៅមានឥទ្ធិពល និងសិទ្ធិគ្រប់គ្រងចាត់ចែង គឺមិនទាន់ដាច់ចេញពីកំពង់សោមទេ។ ស៖ តើលោកដឹងដោយរបៀបណា? ឆ.172៖ ដឹងតាមប្រព័ន្ធទាក់ទងតាមតេអូ"]។ ឯកសារ D54/99.1 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ KH 00990786-87 [ ស៖ តាមុត គាត់អើគ្រប់គ្រងនៅខាងកំពង់សោម នៅកំពង់សោមហ្នឹងរហូតដល់បែក៧៩ ឬក៏? ឆ៖ បាទ! រហូតមក ចុង៧៨ គាត់គេដកមកគាត់ ក្រោយមកគាត់ឡើង នាយអគ្គសេនាធិការរង ដល់ពេល ៧៩ គាត់ត្រលប់ទៅរកអង្គភាពយើងវិញ។ ស៖ បាទ ប៉ុនពេលដែលគាត់ឡើងមកអគ្គសេនាធិការរង មកនៅភ្នំពេញ ប៉ុន្តែគាត់នៅតែបញ្ជា នៅតែក្តោបក្តាប់មក? ឆ៖ មានអើ មានអនុកងពលមួយនៅទួលសែត ទទួលជំនួស។ ស៖ ពីណាគេ? ឆ៖ ឯកឧត្តម ទឹម សេង។ ស៖ ទឹម សេង ហី? ឆ៖ បាទ! ស៖ គាត់ទទួលការពីណា? ឆ៖ ការងារពីតាមុត ផ្នែកយោធាណា។ ស៖ បាទ! ប៉ុន្តែផ្សេងៗ នៃការងារអីនៅតែទាក់ទងមក តាមុត ដដែល? ឆ៖ បាទ! អ្នកទទួលបញ្ជាពីលើមករាយការណ៍"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង វ៉េត KH 00926542-43 ["ស៖ ហើយមានពីណាទៀត? ឆ៖ បើនិយាយទៅមាន ទឹម សេង តែស្លាប់បាត់ដែរ មុនដំបូងគាត់គ្រប់គ្រងជើងទឹក ដល់ក្រោយមក គាត់មកគ្រប់គ្រងកងពល ១៦៤ ហើយ មាស មុត គាត់ឡើងមកធ្វើជាមេបញ្ជាការនៅភ្នំពេញ"], KH 00926561 ["ស៖ ចឹង តា មុត គាត់ផ្លាស់មកភ្នំពេញនៅឆ្នាំណា? ឆ៖ នៅឆ្នាំ ៧៧ តាមមើល។ ស៖ចឹង គាត់មកនៅភ្នំពេញបានយូរដែរ? ឆ៖ បានយូរដែរ។ ស៖ បានប៉ុន្មាន បានបែក? ឆ៖បានមួយឆ្នាំជាងដែលហ្នឹង គាត់មកនៅភ្នំពេញហ្នឹង បានគាត់រត់ចេញពីភ្នំពេញឆ្នាំ៧៩ ហ្នឹងបានគាត់ដាក់បទបញ្ជាឲ្យដកពីកំពង់សោម"]។ ស៖ ចឹងគាត់នៅភ្នំពេញ គាត់នៅតែបញ្ជា? ឆ៖ គាត់នៅឥទ្ធិពល។ ស៖ ចឹងគាត់នៅទទួលខាងកងពល ១៦៤ ដដែលឬយ៉ាងម៉េច? ឆ៖ ក្នុងគណៈកម្មការយោធា"]។

កាលនោះ គណៈកម្មាធិការសេនាធិការត្រូវបានបង្កើតឡើងដោយ សុន សេន, **មាស មុត**និង ស៊ូ ម៉េត[170]។

57. បន្ទាប់ពីគាត់បានឡើងតំណែង ភារកិច្ចរបស់ **មាស មុត** នៅក្នុងសេនាធិការបានផ្លាស់ប្ដូរយ៉ាងខ្លាំង។ ក្នុងនាមជាសមាជិកម្នាក់របស់សេនាធិការ ការទទួលខុសត្រូវរបស់គាត់គឺត្រូវផ្ដល់ការទ្រទ្រង់ភ័ស្ដុភារក្នុងការកេណ្ឌកម្លាំង បង្កើតយុទ្ធសាស្ត្រប្រយុទ្ធ និងចាត់ចែងការផ្គត់ផ្គង់ចំណីអាហារ និងគ្រាប់រំសេវ[171]។ ទោះជាយ៉ាងណា ជាផ្នែកមួយនៃភារកិច្ចរបស់ សុន សេន, **មាស មុត** បានក្លាយ

---

170 ឯកសារ D114/297.1.27 សេង សឿន ប្រតិចារិកសវនាការ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ម៉ោង 13.54.58-14.01.14 ["ពូ សុន សេន នោះ ក្រសួងការពារជាតិហ្នឹងក៏លែងទៅណាណើដែរ ស្រាប់តែពីរនាក់ហ្នឹង គាត់ទៅកាន់តំណែងក្រសួងការពារជាតិហ្នឹងទៅ។ ស្រាប់ដល់បង មុត ទៅចាត់តាំងខ្ញុំហ្នឹង ពេលការវាយការណ៍មក រាយការណ៍ឲ្យបងម៉េត។ ខ្ញុំអង្គុយស្ដាប់គាត់រាយការណ៍តាម មិនមែនទូរស័ព្ទទេ កាលនោះគេនេះទេ ដល់អញ្ចឹង ខ្ញុំអង្គុយស្ដាប់ក្បែរគាត់ហ្នឹងទៅ។ បានជាខ្ញុំដឹងនោះ។ សៈខ្ញុំសូមសួរលោកពីចំណុចមួយ ថាតើលោកដឹងថាតើ មាស មុត កាន់មុខតំណែងនៅក្រោម សុន សេន ដែលជាតំណែងជាអនុរដ្ឋមន្ត្រីការពារប្រទេសក្រោម សុន សេន ដែរឬទេ? [...] ឆ៖ ខ្ញុំមិនដឹងថាប្រធាន ឬអនុប្រធានទេ"]។ ឯកសារ D54/62 កំណត់ហេតុស្ដាប់ចម្លើយម៉ឹង វេត ឆ.23៖ ["សុន សេន ជាមេបញ្ជាការអគ្គសេនាធិការ [...] មាស មុត ជាអនុរបស់ សុន សេន ទទួលខុសត្រូវខាងជើងទឹក។ ស៊ូ ម៉េត ជាសមាជិកទទួលខុសត្រូវខាងជើងអាកាស"]។ ឯកសារ D54/63 កំណត់ហេតុស្ដាប់ចម្លើយម៉ឹង វេត ឆ.31 ["ពីព្រោះនៅក្នុងចុងឆ្នាំ ១៩៧៨ សុន សេន ត្រូវបានគេបញ្ជូនទៅនៅស្ទួង ដោយមិនប្រគល់ការងារអ្វីច្បាស់លាស់ឲ្យគាត់ទេ។ ក្នុងពេលនោះរាល់សំណើសុំទាំងឡាយដែលស្នើទៅអគ្គសេនាធិការ គឺមានការឆ្លើយតបមកវិញដោយ តា ម៉េត និងតាមុត។ ខ្ញុំដឹងរឿងនេះតាមរយៈសារទូរលេខ"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀងរ៉េត KH 00926561-62 ["ស៖ កាលគាត់ [មាស មុត] ទៅហ្នឹងជាអគ្គមេបញ្ជាការតែម្ដង ឬយ៉ាងម៉េច? ឆ៖ ក្នុងគណៈកម្មការយោធា។ ស៖ ចឹង សុន សេន គាត់នៅដដែរ? ឆ៖ បាទ! សុន សេននៅដដែល តាមពិត សុន សេន គាត់ជាប្រធានចឹងណាស់ [...] បន្ទាប់មកអនុប្រធានដូចជា មាស មុត ចឹងទៅ។ ស៖ ហើយពីណាទៀត? ឆ៖ សមាជិក ស៊ូ សាម៉េចចឹងទៅ ព្រោះសុន សេន ខាងជើងគោកចឹង[...] ហើយខាងជើងទឹក មាស មុត [...] ហើយជើងអាកាសត្រូវ ស៊ូ សាម៉េត ហើយ[...] ព្រោះកងទ័ពត្រូវមានអទិភាពបី ទី១ ខាងជើងគោក ទី២ ជើងទឹក និងទី៣ ជើងអាកាសចុងក្រោយគេ"]។ ឯកសារ D114/65 កំណត់ហេតុស្ដាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.12 ["តាមរយៈរចនាសម្ព័ន្ធនេះ យើងដឹងថា សេនាធិការក៏មានរចនាសម្ព័ន្ធប្រហាក់ប្រហែលនេះ ដែរ។ ក្នុងនោះ សុន សេន គឺជាប្រធានសេនាធិការ ហើយ មាស មុត ដែលជាបញ្ជាការកងទ័ពជើងទឹក គឺជាអនុម្នាក់របស់ សុន សេន និង ស៊ូ ម៉េត ដែលជាមេបញ្ជាការកងទ័ពជើងអាកាស គឺជាអនុម្នាក់ទៀតរបស់សេនាធិការ"]។

171 ឯកសារ D54/29 កំណត់ហេតុស្ដាប់ចម្លើយសាក្សី លៀត ឡុន ឆ.៣ ["សេង ប្រាប់ខ្ញុំថា មាស មុត គឺជាជំនួយការរបស់សេនាធិការ។ សេង ដឹងរឿងនេះ ពីព្រោះពេលតា មុតមិននៅកំពង់សោម គឺសេង ទទួលខុសត្រូវចំនួស។"], ឆ.១០ ["សូមលោករៀបរាប់អំពីពាក្យដែលថា ជំនួយការសេនាធិការ? ឆ.១០៖ តាមការយល់ដឹងរបស់ខ្ញុំ មុខងាររបស់

ជាអ្នកចូលរួមក្នុងការត្រួតពិនិត្យមើលបញ្ហាព្រំដែន[172] មានសិទ្ធិអំណាចក្នុងការសម្រេច ជំនួសឱ្យសេនាធិការ[173] និងទទួលបន្ទុកលើការប្រតិបត្តិតាមបញ្ជាពីមជ្ឈិមបក្ស[174]។

---

ជំនួយការសេនាធិការ គឺជួយខាងចាត់ចែងកម្លាំង បង្កើតយុទ្ធសាស្ត្រអ៊ី ជួយភស្តុភារ ការផ្គត់ផ្គង់ស្បៀង និងគ្រាប់រំសេវ។ ទាំងអស់នេះគឺជាការងារចម្បងរបស់កងទ័ព"]។

172 ឯកសារ D54/62 កំណត់ហេតុស្តាប់ចម្លើយសាក្សីម៉ឹង វេត ឆ.២២, ២៥ ["មាស មុត ជាអគ្គសេនាធិការរងរបស់កងទ័ព មានន័យថា អនុរបស់ សុន សេន។ នៅពេលយួនវៃបុកមកលើយើងនៅតាមព្រំដែន មាស មុត ត្រូវតែនៅត្រួតពិនិត្យស្ថានការណ៍នៅសមរភូមិមុ [...] ឆ.២៥៖ តាមខ្ញុំដឹង ក្នុងនាមគាត់ជាអគ្គសេនាធិការរង ដូច្នេះគាត់ត្រូវតែទៅពិនិត្យស្ថានការណ៍នៅកន្លែងដែលមានជម្លោះនៅតាមព្រំដែន"]។ ឯកសារ D54/54 កំណត់ហេតុស្តាប់ចម្លើយ មាស រឿន ឆ.២៦ ["នៅក្នុងពេលនោះ ក្នុងឆ្នាំ១៩៧៨ យើងត្រូវបានគេណែនាំឱ្យបន្ថយជម្លោះនៅខាងលិច ពីព្រោះនៅព្រំដែនខាងកើតមានជម្លោះកាន់តែខ្លាំងឡើងៗ។ អគ្គសេនាធិកាបានប្រជុំណែនាំតាមរយៈ តាមុត និងតាសឿង"] ។ ឯកសារ D54/63 កំណត់ហេតុស្តាប់ចម្លើយម៉ឹង វេត ឆ.១៩ ["ស៖ តាមលោកដឹង តើពេលណាដល់ពេលណា ដែល មាស មុត ពាក់ព័ន្ធជាមួយការទទួលខុសត្រូវនៅព្រំដែនខាងកើត? ឆ.១៩៖ តាមការដឹងរបស់ខ្ញុំ មាស មុត ចាប់ផ្តើមពាក់ព័ន្ធទទួលខុសត្រូវបញ្ហានៅតាមព្រំដែនខាងកើតនៅក្នុឆ្នាំ១៩៧៨ ពេលដែលយួនវៃបុកខ្លាំង"]។ ឯកសារ D54/60.2 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ឹង វេត KH 00975728 ["ស៖ តា មុត គាត់កាន់សមរភូមិទិសនៅខាងណាទៅកាលពេលវាយ? ឆ៖ គាត់កាន់ខាងកំពង់សោម ... ឆ្នាំ៧៨ នេះ បានគាត់ទៅក្រចេះបានតបន្តិចហ្នឹង ទៅក្រោយចាប់អ៊ំវន វេតហើយទេ។ ស៖ គាត់ទៅទទួលទិសខាងក្រចេះវិញ? ឆ៖ បាទ! ហ្នឹងច្រកព្រំដែន"]។

173 ឯកសារ D114/297.1.24 ម៉ឹង វេត ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦ ម៉. 09.41.57-09.45.02 ["ស៖ កាលពីម្សិលមិញ នៅពេលដែលលោកឆ្លើយទៅសំណួររបស់ចៅក្រម ឡាវែន៍ លោកបានឆ្លើយថា អ្នកទាំងអបីនាក់ដែលលោករាយការណ៍ទៅនោះ ដឹងថាមាន ជួនមាស មុត ជួនស៊ូ ម៉េត ជួន សុន សេន។ តើលោកនិយាយអីចឹងមែនទេ? ឆ៖ បាទ បញ្ហាហ្នឹងខ្ញុំនិយាយអីចឹងមែន បាទ ត្រឹមត្រូវ។ ស៖តើអ្នកទាំងបីនាក់ហ្នឹង គឺមានតែបីនាក់ហ្នឹងទេដែលលោករាយការណ៍ទៅផ្ទាល់ ឬក៏យ៉ាងម៉េច? ឆ៖ បាទ បី ទាំងបី អ៊ុំៗទាំងបីនាក់ ពូ អ៊ុំទាំងបីហ្នឹង គឺចង់ថាអីចេះ ចង់ថាគាត់--ខាងខ្ញុំរាយការណ៍ទៅ គឺរាយការណ៍ទៅអគ្គសេនាធិការ អាហ្នឹងជាប្រចាំ។ តែខាងគាត់ហ្នឹង គាត់ខាងណាទទួលក៏បានដែរ ដូចឧទាហរណ៍ខាងខ្ញុំទៅឧទាហរណ៍ថា សារឥឡូវសូមឱ្យជំនួយយន្តហោះថាទៅជួយអីចឹង គឺគាត់ជួយក៏ជួយ បើគាត់មិនជួយអាហ្នឹងឡើងដល់គាត់ សារដល់គាត់ហើយ ព្រោះក្នុងមួយថ្ងៃរាយការណ៍ព្រឹកល្ងាចជាប្រចាំ ដំណឹងអីផ្សេងៗរាយការណ៍ឱ្យគាត់ដឹង ដល់សភាពកាណ៍ហ្នឹងម៉េចៗអាហ្នឹងអ្នកសារទូរលេខគេដឹងតែគេបញ្ជូនទៅ ព្រោះមេគាត់នៅមុខអីចឹង គាត់ឱ្យយើងជំនួសម គាត់គ្រាន់តែចារមកថា "រាយការណ៍ទៅគាត់" ត្រូវគ្រាប់ត្រូវចេញគ្រាប់ប៉ុន្មាន ត្រូវកាំភ្លើងខ្វះស្អីៗ។ ដល់អីចឹងទៅជាប្រចាំ គឺត្រូវរាយការណ៍ប្រចាំថ្ងៃ អាហ្នឹងច្បាប់យោធាគឺត្រូវអីចឹង។ ដល់អីចឹងរាយការណ៍ទៅគាត់ ក្នុងអគ្គសេនាធិការហ្នឹង គាត់ខាងណាទទួលមុនក៏បាន អាហ្នឹងវាក្នុងមន្ទីរគាត់ៗមានរបស់គាត់ វិទ្យុទាក់ទងគាត់រាប់រយឯណោះ ខាងណាទទួលក៏បាន។ គាត់អត់នៅ តែក្នុងហ្នឹង ក្នុងមន្ទីរគាត់ទទួលចេញ បញ្ជូនឱ្យ"]។ ឯកសារ D54/63 កំណត់ហេតុស្តាប់ចម្លើយសាក្សីម៉ឹង វេត ឆ.១១-១៣ ["ក្នុងឯកសារប្រតិចារឹកនៃកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ភាសាអង់គ្លេស ត្រង់ទំព័រ២១ លោកបាននិយាយថា មាស មុត បញ្ជាឱ្យយន្ត

58. **មាស មុត** ត្រូវបានបញ្ជូនទៅកាន់ស្រុកមេមត់ ខេត្តកំពង់ចាម ដើម្បីដឹកនាំកងពល ១៦៤ និងកងទ័ពមជ្ឈិម ក្នុងអំឡុងពេលបង្ក្រាបការបះបោរដែលបានសន្មតថាបានធ្វើឡើងនៅភូមិភាគបូព៌ា[175]។

---

ហោះ៤គ្រឿងទៅទម្លាក់គ្រាប់បែកលើកងវៀតណាម។ ហេតុអ្វីបានជា មាស មុត អ្នកបញ្ជាឲ្យទៅទម្លាក់ តែបែចាមិនមែនជា ស៊ូ ម៉េត វិញ? ឆ.១១៖ ស៊ូ ម៉េត ក៏នៅសេនាធិការ ហើយក៏មានសិទ្ធិបញ្ជាដែរ ហេតុអ្វីបានជា មាស មុត ត្រូវបានទាក់ទងនឹងព្រឹត្តិកាណ៍នៅខែតុលា ឆ្នាំ១៩៧៨ នៅខេត្តក្រចេះ បញ្ជាឲ្យយន្តហោះមកទម្លាក់គ្រាប់បែកលើកងទ័ពវៀតណាម? ស៖ ស៊ូ ម៉េត ក៏នៅសេនាធិការ ហើយក៏មានសិទ្ធិបញ្ជាដែរ ហេតុអ្វីបានជា មាស មុត ត្រូវបានទាក់ទងនឹងព្រឹត្តការណ៍នៅខែតុលា ឆ្នាំ១៩៧៨ នៅខេត្តក្រចេះ បញ្ជាឲ្យយន្តហោះមកទម្លាក់គ្រាប់បែកលើកងទ័ពវៀតណាម? ឆ. ១២៖ ដោយសារយើងនៅខាងកងពលបានផ្ញើសារទូរលេខទៅកងពល ៥០២ ដើម្បីសុំជំនួយ ពួកគេមិនអើពើនឹងសំណើរបស់យើង។ ដូច្នេះ យើងក៏បានស្នើសុំទៅ មាស មុត តែម្តង ហើយគាត់បានប្រាប់ រុំ ឲ្យចាំបន្តិចហើយនៅពេលរសៀល គាត់បានបញ្ជូនយន្តហោះមកជួយយើង។ ស៖ ហេតុអ្វីបានជាលោកដឹងអំពីព្រឹត្តិការណ៍ទាំងនេះតាមដំណាក់ៗ? ឆ.១៣៖ ក្នុងនាមជានីរសារ ខ្ញុំធ្វើការនៅក្នុងមន្ទីរជាមួយនឹងអ្នកសារទូរលេខ ហើយនិងមេបញ្ជាការ ដូច្នេះខ្ញុំអាចដឹងអំពីអ្វីៗដែលកើតឡើងនៅក្នុងមន្ទីរហ្នឹង"]។

174 ឯកសារ D114/169 កំណត់ហេតុស្តាប់ចម្លើយសាក្សី សេង សឿន ឆ.៥, ២៣ ["ទៅដល់ក្រចេះហ្នឹង អ្នកប្រកាសចាត់តាំងហ្នឹង គឺ មុត ហ្នឹង មាស មុត គេជំនួសមុខឲ្យ ប៉ុល ពត និង នួន ជា ហ្នឹងពេលហ្នឹង មុត គាត់ទៅ។ គាត់មានតែប្រកាសចាត់តាំងហ្នឹង បង មុត រួចពីនុំងទៅ ខ្ញុំទៅ យួន វាយចូលមករួចរត់ឡើងភ្នំដងរែកទៅ [...] ស៖ ការតែងតាំងដែលធ្វើឡើងសម្រាប់លោក លោកគិតថា វាជាតួនាទីសំខាន់ និងជាន់ខ្ពស់នៅខេត្តក្រចេះមែនទេ? ឆ.២៣៖ ទាប ឬខ្ពស់ទេ បងមុត គេជំនួសឲ្យរដ្ឋាភិបាល សម័យនោះគេហៅរដ្ឋាភិបាល ប៉ុល ពត អ្នកដឹកនាំ គេមិនមកផ្ទាល់ គេឲ្យ បងមុតមករៀបចំទាំងយោធា និងស៊ីវិល នៅតំបន់ក្រចេះ យោធាតំបន់ និងកងពល អាហ្នឹងលើដែបងមុត"]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ឆ.៧០-៧១, ៧៣-៧៥ ["តើលោកដឹងទេ អ្នកណាជាមេផ្ទាល់របស់ មុត? ឆ.៧០៖ សុន សេន គឺជាមេផ្ទាល់របស់ មាស មុត។ ស៖ តើលោកដឹងអំពីតួនាទី និងមុខងាររបស់ សុន សេន ដែរឬទេ? ឆ.៧១៖ សុន សេន ទទួលបន្ទុកខាងកិច្ចការការពារប្រទេស។ [...] ឆ.៧៣៖ តាមខ្ញុំដឹង នៅចុងឆ្នាំ ១៩៧៨ មាស មុត បានទៅស្រុកមេមត់ ខេត្តកំពង់ចាម ទៅក្នុងនាមជំនួស សុន សេន គឺធ្វើជាស្តីទី សុន សេន។ [...] ឆ.៧៤៖ ខ្ញុំដឹងព័ត៌មាននេះ តាមរយៈ បង សារឿន ដែលជាប្រធានកងវរៈសេនាធំប្រាប់ខ្ញុំ។ គាត់ប្រាប់ថា មាស មុត ទៅស្រុកមេមត់តាមការបញ្ជារបស់ សុន សេន។ [...] ឆ.៧៥៖ [...] ខ្ញុំបានឮហេតុការណ៍បង្ក្រាបមួយនេះពី សុន សេន កាលដែលខ្ញុំទៅរៀនវគ្គអប់រំរបស់អគ្គសេនាធិការនៅភ្នំពេញ។ សុន សេន បានបញ្ជាក់ថា សោ ភឹមត្រូវបានបង្ក្រាបហើយ"]។ ឯកសារ D59/2/4.16a កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយសេង សឿន KH 00059330 ["កាលហ្នឹង មាស មុត គាត់មករៀបចំជំនួសឲ្យប៉ុល ពត អ្នាស់។ [...] បង មុត គាត់មរៀបទាំងទ័ពទាំងរដ្ឋបាលឲ្យឯងធ្វើនេះ អានោះ ធ្វើនោះ ចាត់តាំងអញ្ចឹងណ៎ា [...] [គាត់] មករៀបចំខ្ញុំហ្នឹង ពេលដែលខ្ញុំមកនៅថ្ងៃ៥ ខែ ១២ ឆ្នាំ៧៨"]។

175 ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ឆ.៧០-៧១, ៧៣-៧៧, ៨៤ ["តើលោកដឹងទេ អ្នកណាជាមេផ្ទាល់របស់ មុត? ឆ.៧០៖ សុន សេន គឺជាមេផ្ទាល់របស់ មាស មុត។ ស៖ តើលោកដឹងអំពីតួនាទី និងមុខងា

គាត់ក៏បានធ្វើដំណើរផងដែរទៅខេត្តក្រចេះ ដែលគេស្គាល់ថាជាតំបន់ស្វយ័តលេខ ៥០៥ នៅចុងឆ្នាំ ១៩៧៨ ដើម្បីធ្វើការបោសសម្អាតបុគ្គលិកយោធានៃកងពលធំមជ្ឈិម ១១៧ និងកម្មាភិបាលស៊ីវិលជាន់ខ្ពស់តំបន់ ៥០៥។ នៅក្នុងខេត្តក្រចេះ **មាស មុត** បានបញ្ជាឱ្យមានការចាប់ខ្លួនកម្មាភិបាល បានរៀបចំការដឹកជញ្ជូនអ្នកដែលត្រូវបានចាប់ខ្លួនទាំងនោះទៅកាន់ភ្នំពេញដោយខ្លួនឯងផ្ទាល់ និងបានរៀបចំរចនាសម្ព័ន្ធបញ្ជាការក្នុងកងពល ១១ និងតំបន់ ៥០៥ ឡើងវិញ[176]។ លើសពីនេះទៀត

---

របស់ សុន សេន ដែរឬទេ? ឆ.៧១៖ សុន សេន ទទួលបន្ទុកខាងកិច្ចការការពារប្រទេស។ [...] ឆ.៧៣៖ តាមខ្ញុំដឹងនៅចុងឆ្នាំ១៩៧៨ មាស មុត បានទៅស្រុកមេមត់ ខេត្តកំពង់ចាម ទៅក្នុងនាមជំនួស សុន សេន គឺធ្វើជាស្ដីទី សុន សេន។ [...] ឆ.៧៤៖ ខ្ញុំដឹងព័ត៌មាននេះ តាមរយៈ បង សារឿន ដែលជាប្រធានកងវរៈសេនាធំប្រាប់ខ្ញុំ។ គាត់ប្រាប់ថា មាស មុត ទៅស្រុកមេមត់តាមការបញ្ជារបស់ សុន សេន។ [...] ឆ.៧៥៖ [...] ខ្ញុំបានឮអំពីរឿងនេះពីមេបញ្ជាការកងវរៈសេនាធំរបស់ខ្ញុំថា លោក សុន សេន បានបញ្ជាឱ្យ មាស មុត ដឹកនាំទ័ពទៅបង្ក្រាបពួកបះបោរនៅភូមិភាគបូព៌ា ដែលដឹកនាំដោយ សោ ភឹម។ ដូចដែលលោកបានជ្រាបខាងលើ សត្រូវ និងខ្មាំងទី១របស់កម្ពុជាប្រជាធិបតេយ្យគឺវៀតណាម និងទី២គឺខ្មាំងផ្ទៃក្នុង។ ខ្ញុំបានឮហេតុការណ៍បង្ក្រាបមួយនេះពី សុន សេន កាលដែលខ្ញុំទៅរៀនវគ្គអប់រំរបស់អគ្គសេនាធិការនៅភ្នំពេញ។ សុន សេន បានបញ្ជាក់ថា សោ ភឹមត្រូវបានបង្ក្រាបហើយ។ ស៖ តើ សុន សេន បាននិយាយប្រាប់លោកថា មាស មុត ទៅស្រុកមេមត់ធ្វើអ្វីដែរឬទេ? ឆ.៧៦៖ នៅចុងឆ្នាំ១៩៧៨ មាស មុត បានទស្រុកមេមត់ដើម្បីធ្វើជាបញ្ជាការ នៅពេលដែលមានហេតុការណ៍ផ្ទៃក្នុងនៅភូមិភាគបូព៌ា។ ស៖ ចុះពេលនោះ សុន សេន គាត់ទៅណា? ឆ.៧៧៖ សុន សេន គាត់នៅភ្នំពេញ។ [...] ស៖ តើលោកដឹងអំពីកងទ័ពដែល មាស មុត នាំទៅជាមួយគាត់ទៅស្រុកមេមត់នោះដែរឬទេ? ឆ.៨៤៖ ខ្ញុំមិនដឹងទេ ខ្ញុំគ្រាន់តែដឹងថា មាស មុត ទៅជាមួយយោធាខ្លះមកពីកំពង់សោមយោធាខ្លះទៀតមកពីសេនាធិការ តែខ្ញុំមិនដឹងអំពីលេខកង លេខអង្គភាព និងមេបញ្ជាការទាំងនោះទេ"]។ ឯកសារ D59/1/1.8a កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយព្រុំ សារ៉ាត់ KH 00926401-2 ["ស៖ អញ្ចឹងគាត់នៅកំពង់សោមជាប់រហូតម៉ង? ឆ៖ តា មុត គាត់ដាច់ក្រោយពេលក្នុងចុះ៧៨ គាត់ដកមកភ្នំពេញ។ ស៖ ចុះគាត់ដកមកភ្នំពេញនឹង ពីណាគេអ្នកគ្រប់គ្រងវិញទៅ? ឆ៖ គ្រប់គ្រងបង សេង បងសារឿន គាត់គ្រប់គ្រងនាវា ហើយគ្រប់គ្រងក្របខ័ណ្ឌដែនកោះនឹង នឹងគាត់គ្រប់គ្រង។ [...]ស៖ ចុះតាមុតគាត់ទៅ (ភ្នំពេញ) ចន្លោះតាងពីខែប៉ុន្មាន? ឆ៖ ក្នុងអាចមុនគ្នា ២ ៣ខែ អត់មានពេលវេលាឆ្ងាយទេ ពេលវេលាខ្លី ទទួលនឹងសភាពការណ៍ប្រឹបមក។ ស៖ ថាទៅមុនបែក២ ៣ខែនឹង? ឆ៖ បាទ! ២ ៣ខែ កាត់តាមមេមត់ កាត់អីអញ្ចឹង។ ស៖ តាមុត គាត់ទៅដល់មេមត់ដែរ? ឆ៖ គាត់ជំនួសឱ្យតា សុន សេន"]។

176 សូមមើល ផ្នែក VIII.I. ការបោសសម្អាតកងពល ១១៧ និងតំបន់ ៥០៥។ សូមមើលផងដែរ ឯកសារ D114/297.1.27 សេង សឿន ប្រតិចារឹក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ម៉. 13.48.25-13.51.55 ["កាលគេបញ្ជូនខ្ញុំ មើល៍ មួយ ពីរ បី បួនទាំងខ្ញុំគឺ បង ផុន (សៅ ផុន ហ្នឹង) អនុស្រុកទេជិនាន់នោះ។ តំបន់ក្រចេះហ្នឹង គេតែងតាំងបងមុត ហ្នឹងឱ្យធ្វើជាអនុលេខាតំបន់ ហើយយកម្នាក់ទៀតឈ្មោះ ភាព មកធ្វើលេខាតំបន់។ ភាព ហ្នឹងគេនៅកងពលជើងទឹកជាមួយបង មុត។ ហើយពួកខ្ញុំទាំងអស់ ហើយការចាត់តាំង តែងតាំងគេអ្នក ទាំងខ្ញុំហ្នឹងធ្វើមន្ទីរស្រុក --ប្រធានតំបន់។ ម្នាក់ហ្នឹងដែលជាបញ្ជាការស្រុកក្រចេះ ម្នាក់ទៀតនៅក្រសួងកសិកម្ម។ ក្នុងការប្រកាសចាត់តាំងហ្នឹង

គឺមាន តាមុត (មាស មុត) ហ្នឹងគាត់អ្នកទៅរៀបចំ ខេត្តក្រចេះហ្នឹង ព្រោះគេ ពេលនោះគេដកចាប់ខ្លួនអស់ហើយគណៈតំបន់អីៗ គណៈស្រុកមួយចំនួន ពេលខ្ញុំដែលឡើងស្រុកហ្នឹងៗ គឺបងមុត គាត់ជាអ្នករៀបចំចាត់តាំងជួសមុខ ប៉ុលពត កាលហ្នឹង។ ឯកសារ D114/297.1.23 ម៉ឹង វេត ប្រតិចារឹក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ ម៉. 09.35.25-09.39.51 ["ស៖ អរគុណ។ ក្រោយពីពួកគាត់ទាំងអស់ហ្នឹងត្រូវបានគេបញ្ជូនពីក្រចេះមកភ្នំពេញនោះ ទោះបីថាជិះយន្តហោះជាមួយគ្នា ឬក៏យន្តហោះផ្សេងគ្នាក៏ដោយ <ក្រោយពីរឿងនោះបានកើតឡើង> តើលោកធ្លាប់មានចូលរួមប្រជុំជាមួយ មាស មុត ទេ? ឆ៖ បាទ បញ្ហានុ៎ង ខ្ញុំបានបកស្រាយនៅសេចក្តីសម្អាសមុនហើយ។ ខ្ញុំបានប្រជុំជាមួយគាត់តែ១ថ្ងៃហ្នឹង [...] ស៖ តើមាស មុត គាត់ចំណាយពេលប្រហែលប៉ុន្មានដែរ ក្នុងការថ្លែងនៅក្នុងកិច្ចប្រជុំនោះ? ឆ៖ បញ្ហាហ្នឹង គាត់នៅប្រហែលជាមិនដល់មួយម៉ោងទេ ប៉ុន្តែខ្ញុំគិតថាមួយម៉ោងទៅចុះ ព្រោះនៅហៅប្រជុំជួរកងមន្ទីរហ្នឹង ហៅទាំងពួកនិយាយរួមនៅក្នុងមន្ទីរហ្នឹងទាំងអស់ គាត់ហៅប្រជុំហ្នឹងដើម្បីប្រកាសថា ឥឡូវគាត់ត្រូវដូរមេកងពល។ ហ្នឹងគាត់ហៅតែពួកក្រុមនីរសារ ពួកតែកុងឡាន ពួកហ្គារ៉ាសឡាន ពួកអីៗសម្រាប់នេះហ្នឹង ពេទ្យអីហ្នឹងមួយចំនួនហ្នឹង គាត់ហៅមកប្រជុំទាំងអស់។ និយាយរួមអ្នកនៅក្នុងមន្ទីរហ្នឹង។ ដល់អីចឹងគាត់ហៅប្រមូលគ្នាមក ថាឥឡូវមេត្រូវដូរហើយ មេអ្នែងក្បត់ហើយ មេអ្នែងក្បត់អស់ហើយ ឥឡូវត្រូវដូរមក ឥឡូវ ញ៉ាន់ ឡើងមេបញ្ជាការប្រធានកងពលនេះ។ អ្ហ៎! ឥឡូវរៀប។ ដល់អីចឹងទៅ ដឹងតែប៉ុណ្ណឹងទៅ ឮតែមេក្បត់ហើយ ខ្ញុំប្រមូលទ័ពទៅមុខទៅ។ ហើយកម្លាំងដែលនៅពួកតែកុងឡានអីមួយចំនួន ត្រូវដឹកសម្ភារៈចេញពីហ្នឹងទៅស្ទឹងត្រែង ក៏ត្រូវទៅឆ្លងស្ទឹងត្រែងទៅ។ អីចឹងមានប៉ុណ្ណឹង។ នៅរយៈពេលថាមិនដល់មួយម៉ោងចុះ ប៉ុន្តែគិតមួយម៉ោងទៅ។ គាត់ប្រជុំប្រកាសហើយ ក៏គាត់ប្រញិបប្រញាប់ចេញដំណើរមកទៀត"]។ ឯកសារ D114/297.1.24 ម៉ឹង វេត ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦ ម៉. 09.52.25-09.55.21 ["ខ្ញុំចង់បញ្ជាក់ថា ធី និង គង់ នេះជាអ្នកសារទូរលេខផ្ទាល់របស់ ពូ មុត (អ៊ុំមុត) ណា តែអ៊ុំមុត គាត់អត់បាននាំមកជិះឡានជាមួយទេ គឺនៅឯគោលាប់ នៅអីសំបូរនោះ នៅឯជើងនោះ ហើយខ្ញុំនៅជិតក្រចេះនេះ។ តែដោយខ្សែកសំបុត្រហ្នឹងគឺ ពូធី ហើយនិង គង់ គេមកពីព្រលានយន្តហោះ មកពីកន្លែង៥០២នេះ ព្រលានយន្តហោះខាងកើតក្រចេះនេះ បានកាន់សំបុត្រហ្នឹងមក បានខាងខ្ញុំនេះអាចយោគយល់ថាអីចេះ ថាចង់ថាសំបុត្រហ្នឹងអាចផ្ញើសារតាមរយៈ៥០២នេះតាមសារទូរលេខ៥០២ បញ្ជូនមកខាងខ្ញុំនេះ ចង់និយាយថាដែល ពូរុំ គាត់សន្និដ្ឋានខ្លួនគាត់មនុស្សនឹងគាត់ទៅ គឺគាត់ចង់និយាយអីចឹងណា អាហ្នឹងបញ្ហាសំបុត្រមួយច្បាប់ហ្នឹង។ អាហ្នឹងខ្ញុំចង់និយាយអីចេះ គ្រាន់តែ ម-៨៧០ តែសំបុត្រហ្នឹងនិយាយខ្លីគ្រាន់តែ "សូមអញ្ជើញ វុំ និងគណៈកម្មាធិការប៉ុន្មានរូបដែលរាយឈ្មោះមកហើយ គ្រាន់តែដាក់ថា ម-៨៧០ទៀត" អត់មានដាក់អីទេ"]។ ឯកសារ D54/62 កំណត់ហេតុស្តាប់ចម្លើយសាក្សីម៉ឹង វេត ឆ.២៤, ២៩-៣០, ៣២-៣៣, ៣៨-៣៩ [រៀបរាប់ពីសមាសភាពក្រុមកម្មាភិបាលដែលបានចាប់បញ្ជូនទៅភ្នំពេញតាមយន្តហោះដើម្បីចូលរួមការប្រជុំ គឺថា លិខិតដែលហៅពួកគេមកភ្នំពេញ គឺទទួលបានពីនីរសាររបស់ មាស មុត ហើយ ជាចុងក្រោយពួកគេត្រូវសម្លាប់នៅមន្ទីរសន្តិសុខ ស-២១]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយសាក្សីប៉ាក សុខ ឆ.៨-៩ ["មាស មុត ត្រូវបានបញ្ជូនទៅក្រចេះ ពីព្រោះពេលនោះមានការចាប់កម្មាភិបាល គឺមានសន្ទុះខ្លាំង [...] ឆ.៩៖ គាត់ទៅទីនោះនៅចុងឆ្នាំ១៩៧៨"]។ ឯកសារ D114/169 កំណត់ហេតុស្តាប់ចម្លើយសាក្សី សេង សឿន ឆ.៥, ២៣,៣០ ["ទៅដល់ក្រចេះហ្នឹង អ្នកប្រកាសចាត់តាំងហ្នឹង គឺ មុត ហ្នឹង មាស មុត គេជំនួសមុខឲ្យ ប៉ុល ពត និង នួន ជា ហ្នឹងពេលហ្នឹង មុត គាត់ទៅ។ គាត់មានតែប្រកាសចាត់តាំងហ្នឹង បងមុត រួចពីនុ៎ងទៅខ្ញុំទៅឃ្លួនវាយចូលមក រួចវត់ឡើងភ្នំដងរែកទៅ [...] ឆ.២៣៖ [...] គេឲ្យ បង មុត មករៀបចំទាំងយោធា និងស៊ីវិល នៅតំបន់ក្រចេះ យោធា

ក្នុងនាមជាអនុលេខាសេនាធិការ **មាស មុត** ក៏មានទំនាក់ទំនងសម្ងាត់ជាមួយកងពលធំមជ្ឈិមនានាផងដែរ[177]។

តំបន់ និងកងពល អាហ្នឹងលើដៃបងមុត។ [...] សៈ ម៉េចបានលោកដឹងថា គេចាប់ប្អូនជីដូនមួយ ចាប់ក្មួយ? ឆ.៣០៖ ខ្ញុំមកដល់ អឿង គេប្រាប់។ ពីរបីថ្ងៃក្រោយមក មុតប្រាប់ថា គាត់សម្លាប់ អឿង។ មុត ជាអ្នកបញ្ជូនអ្នកដែលចាប់ខ្លួននោះតាមយន្តហោះមកភ្នំពេញ។ [...] គឺត្រង់ហ្នឹង គឺបងមុត ជាអ្នកបញ្ជូនឡើងយន្តហោះ បន្ថែមប៉ណ្ណឹងឲ្យយល់។ អ្នកមុនហ្នឹង មុតជាអ្នកចាត់ចែង"]។ ឯកសារ D114/170 កំណត់ហេតុស្តាប់ចម្លើយសាក្សីព្រំ ម៉ុន ឆ.២០, ៣៥-៣៦ ["ស៖ តើគាត់ (ប្តីរបស់លោកស្រី) ជាប្រធានកងពល១១៧? ឆ.២០៖ ចាស គាត់ប្រធានកងពល១១៧។ [...] ឆ.៣៥៖ [...] គាត់ (នីរសាររបស់គាត់ឈ្មោះ ស្លូង) ប្រាប់ខ្ញុំថា គេយកគាត់ទៅរៀន [...] ប្រហែលជាពីរបីថ្ងៃក្រោយមក បានគាត់មកប្រាប់ខ្ញុំថា គេចាប់ប្តីខ្ញុំយកទៅហើយ។ គាត់មិនយកគាត់ទៅរៀនទេ។ [...] ឆ.៣៦៖ [...] លឹម ថា ប្តីរបស់ខ្ញុំគេចាប់យកទៅ។ តាមុត ជាអ្នកបញ្ជាឲ្យចាប់"]។ ឯកសារ D54/60.2 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយម៉ឹង វេត KH 00975728 ["គាត់កាន់ខាងកំពង់សោម....ឆ្នាំ៧៨នេះ បានគាត់ទៅក្រចេះបានតែបន្តិចហ្នឹង ទៅក្រោយចាប់អ៊ុំ វន វេត ហើយទេ"]។ ឯកសារ D59/2/4.16a កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសេង សឿន KH 00059330 ["កាលហ្នឹងមាស មុត គាត់មក (ក្រចេះ) រៀបចំជំនួសឲ្យ ប៉ុល ពត អ្នកស្រស់។ [...] បងមុតគាត់មករៀបទាំងទ័ពទាំងរដ្ឋបាលឲ្យឯងធ្វើនេះ អានោះធ្វើនោះ ចាត់តាំងអញ្ចឹងណា [...] [គាត់] មករៀបចំខ្ញុំហ្នឹងពេលដែលខ្ញុំមកនៅថ្ងៃ ៥ ខែ ១២ ឆ្នាំ៧៨"]។

177 ឯកសារ D114/297.1.24 ម៉ឹង វេត ប្រតិចារឹក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៦ ម៉. 09.41.57-09.45.02 ["[មាស មុត, ស៊ូ ម៉េត, សុន សេន] -- អ៊ុំៗទាំងបីនាក់ ពូ អ៊ុំទាំងបីហ្នឹង គឺចង់ថាអីចេះ ចង់ថាគាត់ -- ខាងខ្ញុំរាយការណ៍ទៅ គឺរាយការណ៍ទៅអគ្គសេនាធិការ អាហ្នឹងជាប្រចាំថ្ងៃ។ តែខាងគាត់ហ្នឹង គាត់ខាងណាទទួលក៏បានដែរ ដូចឧទាហរណ៍ខាងខ្ញុំទៅ ឧទាហរណ៍ថា សារឥឡូវសូមឲ្យជំនួយយន្តហោះថាទៅជួយអីចឹង គឺគាត់ជួយក៏ជួយ បើគាត់មិនជួយអាហ្នឹងឡើងដល់គាត់ សារដល់គាត់ហើយ ព្រោះក្នុងមួយថ្ងៃរាយការណ៍ព្រឹកល្ងាចជាប្រចាំ ដំណឹងអីផ្សេងៗរាយការណ៍ឲ្យគាត់ដឹង ដល់សភាពការណ៍ហ្នឹងម៉េចៗ អាហ្នឹងអ្នកសារទូរលេខគេដឹងតែគេបញ្ជូនទៅ ព្រោះមេគាត់នៅមុខអីចឹងគាត់ឲ្យយើងជំនួសមក គាត់គ្រាន់តែចារមកថា "រាយការណ៍ទៅគាត់" ត្រូវគ្រាប់ ត្រូវចេញគ្រាប់ប៉ុន្មាន ត្រូវកាំភ្លើងខ្វះស្អីៗ។ ដល់អីចឹងទៅជាប្រចាំ គឺត្រូវរាយការណ៍ប្រចាំថ្ងៃ អហ្នឹងច្បាប់យោធាគឺត្រូវអីចឹង។ ដល់អីចឹងរាយការណ៍ទៅគាត់ ក្នុងអគ្គសេនាធិការហ្នឹង គាត់ខាងណាទទួលមុនក៏បាន អាហ្នឹងវាក្នុងមន្ទីរគាត់ៗមានរបស់គាត់វិទ្យុទាក់ទងគាត់រាប់រយឯណោះ ខាងណាទទួលក៏បាន។ គាត់អត់នៅតែក្នុងហ្នឹង ក្នុងមន្ទីរគាត់ទទួលចេញ បញ្ជូនឲ្យ"]។ ឯកសារ D54/63 កំណត់ហេតុស្តាប់ចម្លើយសាក្សីម៉ឹង វេត ឆ.១១-១៩ ["មាស មុត នៅសេនាធិការ ដូច្នេះគាត់មានសិទ្ធិអំណាចបញ្ជាទៅកងទ័ពទាំងបីប្រភេទ។ [...] ឆ.១២៖ [...] ដោយសារយើងនៅខាងកងពលបានផ្ញើសារទូរលេខទៅកងពល៥០២ ដើម្បីសុំជំនួយ ពួកគេមិនអើពើនឹងសំណើរបស់យើង។ ដូច្នេះយើងក៏បានស្នើសុំទៅ មាស មុត តែម្តង ហើយគាត់បានប្រាប់ វ៉ុ ឲ្យចាំបន្តិច ហើយនៅពេលរសៀល គាត់បានបញ្ជូនយន្តហោះមកជួយយើង។ សៈ ហេតុអ្វីបានជាលោកដឹងអំពីព្រឹត្តការណ៍ទាំងនេះតាមដំណាក់? ឆ.១៣៖ ក្នុងនាមជានីរសារ ខ្ញុំធ្វើការនៅក្នុងមន្ទីរជាមួយនឹងអ្នកសារទូរលេខ ហើយនិងមេបញ្ជាការ ដូច្នេះខ្ញុំអាចដឹងអំពីអ្វីៗដែលកើតឡើងនៅមន្ទីរហ្នឹង។ សៈ នៅពេលដែលលោក

## លេខាធិការកងពល ១៦៤

59. ក្នុងនាមជាលេខាធិការកងពល ១៦៤ **មាស មុត** បានដឹកនាំកងពលយោធាធំជាងគេបំផុតនៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា ដែលទទួលខុសត្រូវលើសន្តិសុខផ្ទៃក្នុង និងខាងក្រៅដែនទឹកកម្ពុជា កោះ និងតំបន់ស្វយ័តកំពង់សោម។

60. នៅក្រោយការប្រកាសអំពីការបង្កើតកងទ័ពបដិវត្តន៍កម្ពុជានៅខែ កក្កដា ឆ្នាំ ១៩៧៥[178] កងពល ៣ របស់ **មាស មុត** ត្រូវបានរៀបចំរចនាសម្ព័ន្ធឡើងវិញ[179] និងបានក្លាយជាកងពលមជ្ឈិម

---

និយាយថា មាស មុត បញ្ជាឱ្យ រ៉ុ រងចាំ តើគាត់ប្រាប់តាមសារទូរលេខ ឬតាមវិទ្យុទាក់ទង? ឆ.១៤៖ គាត់បានឆ្លើយតបមកវិញ តាមសារទូរលេខ។ សៈ ពេលផ្ញើរបាយការណ៍ពីកងពល១១៧ ទៅឱ្យ មាស មុត តើគេធ្វើជាប្រចាំថ្ងៃ ឬក៏ឡើងរាល់ពេលដែលមានព្រឹត្តការណ៍កើតឡើង? ឆ.១៥៖ មុនពេលមានការវ៉ៃគ្នា របាយការណ៍នេះគឺផ្ញើទៅជាប្រចាំថ្ងៃរាល់ៗថ្ងៃ ប៉ុន្តែក្រោយពីមានព្រឹត្តិការណ៍វ៉ៃគឺរបាយការណ៍ត្រូវបានផ្ញើរាល់ពេលដែលមានហេតុការណ៍កើតឡើង។ កងពល១១៧នេះ ស្ថិតនៅក្រោមបញ្ជាសេនាធិការផ្ទាល់ មិនឆ្លងកាត់តាមភូមិភាគទេ។ សៈ តើរបាយការណ៍គេធ្វើហ្នឹង តើគេដាក់ជូនទៅ មាស មុត ឬក៏ដាក់ជូនទៅសេនាធិការ ឬក៏គេដាក់ជូនទៅទាំងពីរ? ឆ.១៦៖ គឺដាក់ថា ជូនទៅអគ្គសេនាធិការ គឺមិនមែនដាក់ទៅបុគ្គលណាជាក់លាក់ទេ ប៉ុន្តែយើងដឹងថា អ្នកទទួលសារទូរលេខ គឺជាអ្នកដែលធ្វើការឱ្យអ្នកណាម្នាក់ហើយ។ ឧទាហរណ៍ ធី និងគង់ ជាអ្នកកាន់សារទូរលេខឱ្យ មាស មុត។ សៈ ហេតុអ្វីបានជាលោកដឹង មាស មុតជាអ្នកផ្ញើសារទូរលេខឱ្យ រ៉ុ ឱ្យរងចាំការបញ្ជូនយន្តហោះនៅពេលនោះ? ឆ.១៧៖ ខ្ញុំមិនដឹងលេខសារទូរលេខទេ ប៉ុន្តែខ្ញុំដឹងអំពីរឿងនេះតាមរយៈការឃើញសារទូរលេខ។ សៈ តើលោកនៅចាំលេខកូដរបស់ មាស មុត នៅក្នុងសារទូរលេខដែរទេ? ឆ.១៨៖ អត់ទេ តែខ្ញុំគ្រាន់តែដឹងថា គេហៅគាត់ថា ១៦៤។ សៈ តាមលោកដឹង តើពីពេលណាដល់ពេលណា ដែល មាស មុត ពាក់ព័ន្ធជាមួយការទទួលខុសត្រូវនៅព្រំដែនខាងកើត? ឆ.១៩៖ តាមការដឹងរបស់ខ្ញុំ មាស មុត ចាប់ផ្តើមពាក់ព័ន្ធទទួលខុសត្រូវបញ្ជានៅតាមព្រំដែនខាងកើតនៅក្នុងឆ្នាំ១៩៧៨ ពេលដែលយួនវ៉ៃបុកខ្លាំង"]។ ឯកសារ D54/60.2 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយម៉ឹង វេត KH 00975743 ["បានតា មុត ហ្នឹង ឱ្យយន្តហោះជួយទំលាក់ អាស្តាបកាត់ទៅឆេះ អាស្តាបកាត់ហ្នឹងមួយទៀតធ្លាក់ ទៅប្អូនគ្រឿងហ្នឹង អាប្រដេញ ហៅពីថ្ងៃបុកមុនដំបូង ថ្ងៃ១១ ខែតុលានោះ អាប្រដេញគេចុះនៅលាវមួយបាត់ហើយហ្នឹង មកភ្នំពេញវិញតែមួយហ្នឹង"]។

178 ឯកសារ D4.1.861 ទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៥ KH 00063324["["កាលពីថ្ងៃ ២២ កក្កដា ១៩៧៥ ក្នុងឱកាសពិធីចាត់តាំង កងទ័ពបដិវត្ត របស់មជ្ឈបក្សកុម្មុយនីសកម្ពុជា សមមិត្តប្រធាននៃគណៈកម្មាធិការ យោធាជាន់ខ្ពស់របស់បក្ស បានធ្វើសន្និសីទនយោបាយមួយដ៏សំខាន់ ជូនតំណាងគ្រប់អង្គភាព នៃកងទ័ពបដិវត្ត ប្រមាណបីពាន់នាក់របស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ សន្និសីទសំខាន់នេះ មានខ្លឹមសារទាំងស្រុងដូចតទៅ៖[...] ៤. ភារកិច្ចថ្មីនៃកងទ័ពបដិវត្តយើង"]។។ ឯកសារ D98/3.1.20 ឆោម សែ ប្រតិចារឹក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ម៉. 11.38.14, 11.50.00-11.52.27 [អង្គសន្និបាត នៅក្នុងស្តាតអូឡាំពិក ទាក់ទងទៅនឹង "ការបង្កើតខួបរបស់កងទ័ពគ្រប់ប្រភេទ" និងមជ្ឈិមដឹកនាំទូទាំងប្រទេសចូលរួម],14.01.48-14.07.06, 14.11.21 [បញ្ជាក់ថា សន្និបាតកងទ័ពបដិវត្តកម្ពុជា ថ្ងៃ

ទី ២២ ខែកក្កដា ឆ្នាំ ១៩៧៥ ដែលបានរៀបរាប់នៅក្នុងទង់បដិវត្តន៍ ខែសីហា ឆ្នាំ ១៩៧៥ គឺត្រូវតាមសន្និបាតដែលគាត់បានចូលរួម បើទោះបីជាគាត់ដំបូងគិតថា វាធ្វើឡើងនៅខែ កញ្ញា ឆ្នាំ១៩៧៥ ក៏ដោយ។ ឯកសារ D4.1.801 កំណត់ហេតុស្តាប់ចម្លើយសាក្សីឆោម សែ ឆ.៣ ["កងពល៨០១ នេះ ត្រូវបានបង្កើតឡើងនៅភ្នំពេញ នៅក្នុងមហាសន្និបាតនៅស្តាតអូរឡាំពិក ប្រហែលជាខែកញ្ញា។ យោធាភូមិពិសេសមានបីកងពល គឺកងពល៧០៣ កងពល៦០៥ និងកងពល៨០១"]។ ឯកសារ D4.1.805 កំណត់ហេតុស្តាប់ចម្លើយសាក្សីឆោម សែ ឆ.៣-៤ ["ស៖ នៅក្នុងបទសម្ភាសថ្ងៃទីសាមសិបមួយ ខែតុលា ឆ្នាំពីរពាន់ប្រាំបួន លោកមានប្រសាសន៍ថា កងពល៨០១ ត្រូវបានបង្កើតឡើងក្នុងមហាសន្និបាតបក្ស ក្នុងខែកញ្ញា ឆ្នាំ១៩៧៥។ [...] ឆ.៣៖ មហាសន្និបាតនៅខែកញ្ញា ឆ្នាំ១៩៧៥។ មានកងទ័ពគ្រប់កងពលចាប់ពីមេកងពលរហូតដល់ថ្នាក់អនុសេនាធំចូលរួមប្រជុំ។ ក្នុងនោះខ្ញុំក៏ចូលរួមប្រជុំដែរ ក្នុងឋានៈជាអនុប្រធានអនុសេនាធំកងពល៨០១។ [...] គោលបំណងនៃមហាសន្និបាតគឺនិយាយអំពីជីវប្រវត្តិរបស់កងទ័ព កិច្ចដំណើការរបស់កងទ័ពជាថ្មី និងកម្មវិធីប្រកាសសមាសភាពដឹកនាំមជ្ឈិមបក្សជូនដល់កម្មាភិបាល [...] ក្នុងពេលនោះគេប្រកាសបង្កើតភូមិភាគពិសេស ដែលមានកងពល៣បញ្ចូលគ្នា គឺកងពល៨០១ កងពល៧០៣ និងកងពល៦០៥។ ទ័ពស្រួច (កងទ័ពមជ្ឈិម) ទាំងអស់គឺមាន១២កងពល គឺជាកងទ័ពសម្រាប់ចល័តទូទាំងប្រទេស។ [...] ក្រោយពីប្រជុំមហាសន្និបាតរួចគេសម្រេចបញ្ជូនកងពល ៨០១ ទៅរតនគិរី។ [...] ឆ.៤៖ សុន សេន ជារដ្ឋមន្ត្រីក្រសួងការពារជាតិជាអ្នករៀបចំមហាសន្និបាត បានឡើងថ្លែងការណ៍យ៉ាងយូរ ហើយចុងក្រោយ ប៉ុល ពត ជាអ្នកឡើងថ្លែងការណ៍"]។ ឯកសារ D4.1.454 កំណត់ហេតុស្តាប់ចម្លើយសាក្សីកុយ ម៉ុន (កងពល១៧០) KH 00195436 ["នៅពាក់កណ្តាលឆ្នាំ១៩៧៥ ប៉ុល ពត បានហៅមេៗកងទ័ពមកពីគ្រប់អង្គភាព ទាំងទ័ពមជ្ឈិម និងទ័ពភូមិភាគ ឲ្យចូលរួមសន្និបាទនៅស្តាតអូឡាំពិក [...] បានលើកផែនការកងទ័ពមជ្ឈិម និងភូមិភាគឲ្យបង្កបង្កើនផល និងធ្វើស្រែ"]។ ឯកសារ D4.1.827 កំណត់ហេតុស្តាប់ចម្លើយសាក្សីហ៊ឹម ហ៊ន KH 00422488 [រៀបរាប់អំពីការប្រជុំមួយនៅចុងឆ្នាំ១៩៧៥ នៅស្តាតអូឡាំពិក ដែលនិយាយពី "ការប្រគល់កងទ័ពឲ្យមជ្ឈិមបក្ស" ដែល ប៉ុល ពត, នួន ជា, អៀង សារី និងខៀវ សំផន មានវត្តមាននៅការប្រជុំនោះ ហើយក្នុងអំឡុងពេលនោះគាត់បានឮ នួន ជា និយាយអំពីការប្រគល់កងទ័ពឲ្យមជ្ឈិមបក្ស ដែលមាន ប៉ុល ពត ជាអ្នកគ្រប់គ្រង"]។ ឯកសារ D4.1.794 កំណត់ហេតុស្តាប់ចម្លើយអ៊ុង រ៉ែន KH 00398517 ["កាលពីប្រកាសកងពល ៨០១ គឺមានថ្នាក់ដឹកនាំជាន់ខ្ពស់ទាំងអស់ចូលរួម គឺមាន ប៉ុល ពត នួន ជា អៀង សារី សុន សេន ជាអ្នកប្រកាសតែងតាំងនៅស្តាតអូរឡាំពិក ក្រោយពីរំដោះភ្នំពេញបានប្រហែលដប់ប្រាំថ្ងៃ"]។ អ៊ុង រ៉ែន បានបញ្ជាក់ពីពេលវេលានេះក្នុងសវនាការ៖ ឯកសារ D98/3.1.20 អ៊ុង រ៉ែន ប្រតិចារឹក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ម៉. 09.09.05-09.13.29 [អះអាងថា ការប្រជុំនៅអូរឡាំពិកបានប្រព្រឹត្តនៅពេលមួយបន្ទាប់គាត់ ចាកចេញពីមន្ទីពេទ្យ ក្នុងខែឧសភា ឆ្នាំ១៩៧៥]។ ឯកសារ D1.3.17.4 សៀវភៅរបស់ ហ៊ុយ វណ្ណៈ កងពលខ្មែរក្រហមលេខ ៧០៣ KH 00192938 [រៀបរាប់ថា នៅថ្ងៃទី ២២ ខែកក្កដា ឆ្នាំ១៩៧៥ កងពលលេខ១២ ក្លាយទៅជាកងពលលេខ ៧០៣]។ ឯកសារ D1.3.17.1 អេលីស្សាបែត បេ៊ែកខ័រ នៅពេលដែលសង្គ្រាមរលត់ទៅ KH ERN 00237731។

179 ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយសាក្សីព្រុំ សារ៉ាត់ (ប៊ុន សារ៉ាត់) ឆ.៦, ១០៣ ["ព្រោះពេលហ្នឹង ពីឆ្នាំ ៧៤ ដល់៧៥ ចាប់ពីថ្ងៃទី១៧ មេសា ហ្នឹង កងពលលេខ៣ អស់ហើយ ដូរឈ្មោះទៅជាកងពល១៦៤ [..] ប្រវត្តិរបស់អតីតកងពលលេខ៣ អត់មាន១៤០ទេ ក្រៅពីហ្នឹង មានដូចគ្នាទាំងអស់។ សំណួរអំមិញ ខ្ញុំបញ្ជាក់ឡើងវិញ កុំឲ្យលោកច្រឡំថា កងពលលេខ៣ រាប់ចាប់ពី៧៤ ដល់ ៧៥ ត្រឹមខែ៧ ចាប់ផ្តើមប្តូរឈ្មោះទៅជាកងពល១៦៤"]។ ឯកសារ

ដែលរាយការណ៍ដោយផ្ទាល់ទៅកាន់សេនាធិការ[180]។ កងពល ៣ ត្រូវបានរួមបញ្ចូលគ្នាជាមួយកងកម្លាំងផ្សេងៗទៀត[181] និងបានប្តូរឈ្មោះទៅជាកងពល ១៦៤[182] និងត្រូវបានគេស្គាល់ផងដែរថាជា

---

D54/47 កំណត់ហេតុស្តាប់ចម្លើយសុន អែម ឆ.១៨-១៩ ["នៅខែសីហា ឆ្នាំ១៩៧៥ កងពលថ្មី១៦៤ ត្រូវបានបង្កើតឡើង [...] ឆ.១៩៖ មឿន ម៉ុន [...] ដែលជាមេបញ្ជាការអនុសេនាធំ និង ហេង ហុក ដែលជាមេបញ្ជាការកងអនុសេនាធំ ដែលស្ថិតនៅក្នុងកងវរៈសេនាតូច៤៨០។ ពួកគេបានប្រាប់ខ្ញុំថា កងពលធំលេខ៣ បានប្តូរទៅជាកងពលធំលេខ ១៦៤ ហើយក៏មានការបង្កើតនូវកងពលតូចមួយទៀតដែរ គឺកងពលតូចលេខ ១៤០ ដែលជាកងជើងទឹក"]។ ឯកសារ D2/8 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ..៤៣ ["ខ្ញុំមិនបានចាំច្បាស់ថាប្តូរនៅពេលណាទេ ប៉ុន្តែពេលមកដល់កំពង់សោមគេប្រាប់ថាកងពលលេខ៣ ដូរទៅហៅថា កងពល១៦៤ ហើយវរៈសេនាធំលេខ២០ ដូរទៅ១៦១ វរៈសេនាធំលេខ២១ ដូរទៅ១៦២ និងវរៈសេនាធំលេខ២២ ដូរទៅលេខ១៦៣"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ ឆ.១៦ ["ជំនាន់នោះ គឺរំដោះហើយ១៩៧៥ ពេលនោះគឺគេធ្វើការរើសកងទ័ពជើងទឹក នៅក្នុងកងពលលេខ៣ គឺមកនៅកំពង់សោមទាំងអស់ ហើយកងពលនេះគឺមាស មុត ជាអ្នកដឹកនាំទាំងអស់ ទើបគេបានរើសយកកងពលលេខ៣ មកកាន់កាប់នៅជើងទឹកទាំងអស់។ ក្រោយមក គេប្រមូលកងពល៣មកដាក់កំពង់សោម ហើយទើបគេរៀបចំអង្គភាពហ្នឹងថ្មី ហើយដាក់ឈ្មោះថាកងពលលេខ១៦៤"]។ ឯកសារ D54/50 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.៤ ["នៅពេលដែលខ្ញុំសួរថាកងពលណាជាកងពល១៦៤ យោធាបានប្រាប់ខ្ញុំថា កងពល១៦៤ ជាកងពលរបស់តា មុត។ ពេលនោះខ្ញុំគិតថាកងពល១៦៤នេះ ប្រហែលជាចេញពីកងពលលេខ៣ ហើយ ព្រោះនៅក្រោមបញ្ជារបស់ មាស មុត ដូចគ្នា"]។ ឯកសារ D54/35.1 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយប្រាក់ សុខា KH 00964248 ["ស៖ ចឹងមកដល់កំពង់សោមមានកងពលមានអីហើយ? ឆ៖ នៅកំពង់សោមមានកងពល១៦៤ហ្នឹង កាលវៃចូលភ្នំពេញហ្នឹងក៏មានកងពលដែល តែកាលហ្នឹងកងពលលេខ៣ ជំនាន់ហ្នឹង។ ស៖ បាទ។ ឆ៖ ដល់មកដល់កំពង់សោមផ្លាស់កងពលហើយ មកជាកងពល១៦៤"]។

180 ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.៩ ["កងពលលេខ៣ គឺស្ថិតនៅក្រោមភូមិភាគនិរតី ពេលដែលកងពលនេះ ដូរទៅជាកងពល១៦៤ គឺវាស្ថិតនៅក្រោមសេនាធិការកងទ័ពជាតិ"]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.៦ ["ក្រោយឆ្នាំ១៩៧៥ កងពលលេខ៣ ត្រូវបានប្តូរទៅជាកងពលលេខ១៦៤ ជាកងទ័ពជើងទឹក។ នៅពេលនោះកងពល១៦៤ មិនមែនជាកងពលរបស់ភូមិភាគនិរតីទៀតទេ"]។ ឯកសារ D4.1.859 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅឌុច KH 00403879 ["អង្គភាពរបស់មាស មុត ស្ថិតនៅក្រោមការដឹកនាំរបស់ សុន សេន ដែលជានាយសេនាធិការ"]។ ឯកសារ D54/50 កំណត់ហេតុស្តាប់ចម្លើយមាស វឿន ឆ.៦ ["តាមអ្វីដែលយើងដឹង កងពល១៦៤ ជាកងមកមជ្ឈិម ហើយមានអំណោចលើកងពលផ្សេងទៀត"]។ ឯកសារ D54/52 កំណត់ហេតុស្តាប់ចម្លើយមាស វឿន ឆ.៤, ៦, ១២-១៣ ["តា មុត កាន់កងទ័ពជើងទឹកនៅថ្នាក់មជ្ឈិម [...] ឆ.៦៖ មាស មុត ជាថ្នាក់មជ្ឈិម ហើយគាត់មានកប៉ាល់ និងមធ្យោបាយផ្សេងៗទៀត ដើម្បីការពារដែនដីប្រទេសកម្ពុជា [...] ស៖ ហេតុអ្វីជា មាស មុត រាយការណ៍អំពីការណ៍នោះទៅ បង ៨៩? ឆ.១២ ពីព្រោះ មាស មុត ទទួលខុសត្រូវការពារដែនសមុទ្រ និងព្រំដែនទឹករបស់ប្រទេសកម្ពុជា ហើយបង៨៩ គឺជាអ្នកដែលនៅអគ្គសេនាធិការ [...] ឆ.១៣៖ [...] មាស មុត គឺជាកម្លាំងរបស់មជ្ឈិម ដូច្នេះគាត់ត្រូវតែរាយការណ៍ទៅឲ្យថ្នាក់លើរបស់គាត់ គឺ សុន សេន

ដែលជាសេនាធិការ"]។ ឯកសារ D54/54 កំណត់ហេតុស្តាប់ចម្លើយមាស វឿន ឆ.៤ ["មាស មុត ជាមេបញ្ជាការកងពលលេខ ១៦៤ ដែលជាកងពលនៅក្រោមសេនាធិការ ហើយនិងជារបស់មជ្ឈិម។ កងពលលេខ ១៦៤ មានឋានៈខុសពីកងពលលេខ១ របស់ខ្ញុំ។ សម្រាប់ខ្ញុំ ខ្ញុំគ្រាន់តែជាសមាជិករបស់គណៈកងពលលេខ១ របស់ភូមិភាគបស្ចិមប៉ុណ្ណោះ។ កងពលរបស់ខ្ញុំនេះ ស្ថិតនៅថ្នាក់ភូមិភាគដែលមានឋានៈនៅក្រោមកងពលរបស់ មាស មុត ដែលនៅថ្នាក់មជ្ឈិម"]; ឯកសារ D114/286 កំណត់ហេតុស្តាប់ចម្លើយប៊ិាង វ៉េត ឆ.៣០ ["កងពលក៏មជ្ឈិមគ្រប់គ្រងដែរ តែខាងនេសាទ ដូចមិនច្បាស់។ ១៦៤ គ្រប់គ្រងដោយអគ្គបញ្ជាការកងទ័ព។ ខាងទ័ពគេទៅខាងអគ្គបញ្ជាការទ័ពទៅ បើខាងរដ្ឋបាលខាងខេត្តខាងអី គេទៅខាងរដ្ឋបាលគេទៅ។ គេហ្នឹង បើខ្ញុំដឹងខាងអគ្គបញ្ជាការគឺ សុន សេន។ ហើយគេធ្វើការការតែខាងផ្នែកកងទ័ពទេ"]។ ឯកសារ D54/24 កំណត់ហេតុស្តាប់ចម្លើយប៉ាក សុខ ឆ.១៦ ["នៅក្នុងបញ្ជីនេះ គឺជារបាយការណ៍អំពីកងទាំងឡាយដែលនៅក្រោមបញ្ជាការរបស់កងពលលេខ១៦៤ ដែលតា មុត ជាអ្នករៀបចំដាក់ទៅជាកងទ័ពរបស់មជ្ឈិម"]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន ឆ.៣១-៣២ ["មាស មុត គ្រប់គ្រងកងពល១៦៤ដែរ ហើយកងពលនេះត្រូវបានគេចាត់ទុកថាជាកងពលធំរបស់មជ្ឈិម ស៖ តើកងពលធំថ្នាក់មជ្ឈិមមានន័យថាម៉េច? ឆ.៣២៖ កងពលនេះស្ថិតក្រោមការគ្រប់គ្រងគណៈមជ្ឈិម"]។ ឯកសារ D54/60.2 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ម៉ឹង វេត KH 00975728 ["ស៖ ដល់ពេលបែកឆ្នាំ៧៥ កងពលទី៣ របស់ តា មុត គាត់ចូលទៅខាង? ឆ៖ ទៅខាងអគ្គសេនាធិការវិញហើយហ្នឹង មជ្ឈិមគ្រប់គ្រង កងមជ្ឈិមហើយ អត់មានពាក់ព័ន្ធជាមួយខាងភូមិភាគទេ"]។

181 ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង អ៊ុន ឆ.២០ ["នៅពេលនោះ ឌឹម និងយោធា៧០០នាក់មកពីភូមិភាគបូព៌ាបានមកដល់ គេបានរៀបចំពួកយោធាបូព៌ាបញ្ចូលនឹងយោធាកងពលលេខ៣ឲ្យទៅជាកងពល១៦៤"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយព្រំ សារ៉ាត់ (ប៊ុន សារ៉ាត់) ឆ.១៥៨ ["ក្រោយមកទៀត បានមានជ្រើសរើសកម្លាំងខាងបូព៌ា៧០០នាក់បន្ថែម ជាការរៀបចំកម្លាំងពីអគ្គសេនាធិការបញ្ជូនទៅ។ ច្របាច់កម្លាំងទាំងពីរនេះចូលគ្នា កម្លាំងមកពីបូព៌ាមាន៧០០នាក់"]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.៨ ["មិនមែនយោធាទាំងអស់នៅក្នុងកងវរៈសេនាធំ៥២ ត្រូវបញ្ជូនបានទៅកំពង់សោមនោះទេ។ តាមខ្ញុំដឹងយោធាត្រូវបានជ្រើសរើសមកពីកងវរៈខុសៗគ្នា ដើម្បីបញ្ជូនទៅកំពង់សោម លើកលែងតែកងអនុសេនាធំ ឬក៏កងវរៈសេនាតូចកងពិសេសដែលត្រូវបានគេបញ្ជូនទៅទាំងអស់គ្នា។ សរុបទៅមានយោធាកងវរៈសេនាធំប្រហែល៧០០នាក់ត្រូវបានបញ្ជូនទៅកំពង់សោម"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយយឹម ស្រឿង ឆ.៥១-៥២ ["ពេលនៅជាកងវរៈសេនាធំលេខ ៦១ អត់មានទាហានថ្មីទេ ប៉ុន្តែនៅពេលដែលបង្កើតវរៈសេនាធំលេខ១៤០ ទើបមានទាហានពីបូព៌ាមកចូលក្នុងកងទ័ពជើងទឹកនេះដែរ [...] ឆ.៥២៖ កាលពីនៅវរៈសេនាធំ១៤០ គេបញ្ជូនទាហានពីភូមិភាគបូព៌ាមានចំនួនប្រហែលជា៥០០ទៅ៦០០នាក់ ដើម្បីចូលជាមួយកងនាវាចរនេះដែរ"]។ ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន (ណាំ ឡុន) ឆ.១៩ ["ឌឹម មកកំពង់សោមជាមួយនឹងយោធាប្រហែលជាពីរកងវរៈសេនាតូច។ គាត់មកពីភូមិភាគបូព៌ា នៅពេលដែលគេរៀបចំកងពល១៦៤។ គាត់មកប្រហែលជា១ខែ បន្ទាប់ពីរដ្ឋប្រហារលន់នល់ពីជួលភ្នំពេញ"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយឌុល សុង ឆ.២៨ ["ខ្ញុំគិតថាប្រហែលពាក់កណ្តាលឬចុងឆ្នាំ១៩៧៥ នៅពេលដែលពួកបូព៌ាមកដល់កំពង់សោមចូលជាមួយកងពល១៦៤ ខ្ញុំនៅចាំពេលដែលមកដល់ស្ទឹងហាវ"]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយណុប ហាល KH 00926642 ["ស៖ ខ្ញុំចង់បញ្ជាក់ពួតិចទៀត កន្លែងកងពល១៦៤

កងទ័ពជើងទឹកនៃកងទ័ពបដិវត្តន៍កម្ពុជា ដោយសារតែកងនេះត្រូវចាត់តាំងឲ្យការពារដែនទឹកនៃកម្ពុជាប្រជាធិបតេយ្យ[183]។

---

នឹង ពេលដែលដូរឈ្មោះពីកងពលទី៣ទៅ១៦៤ ដូចថាមានបញ្ចូលក្រុមណាផ្សេងមក? ឆ៖ អូ! នោះយកពីបូព៌ាមក"]។ ឯកសារ D54/96 កំណត់ហេតុស្តាប់ចម្លើយតេង សារឹម ហៅជឹម ជ្រឿន ឆ.២០-២១ ["គឺមួយកងវរៈសេនាធំ១៥២ ក្រោមបញ្ជាការរបស់ ខឹម ត្រូវបានបញ្ជូនទៅកំពង់សោមទាំងអស់ គឺមានចំនួនប្រហែលជិត១០០០នាក់ [...] ឆ.២១៖ សមាជិករបស់កងវរៈសេនាធំ១៥២ ពុំមែនមកពីតំបន់២២ តែមួយទេ គឺមកពីភូមិភាគបូព៌ាទាំងមូលតែម្តង"]។ ឯកសារ D54/44 កំណត់ហេតុស្តាប់ចម្លើយ លុន សេង កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆ.៥ ["បាទ មានយោធា ១៥០០នាក់មកពីភូមិភាគបូព៌ា មកនៅក្នុងកងរបស់ខ្ញុំ [...] ពួកគេមកពីរដំណាក់កាល លើកទី១ មានយោធា៧០០នាក់ និងលើកទី២ មានយោធា៨០០នាក់។ ខ្ញុំចាំមិនច្បាស់ថានៅក្នុងឆ្នាំណា ប៉ុន្តែចន្លោះពីឆ្នាំ១៩៧៥-១៩៧៧ ដោយសារគេមកដល់មុនពេលខ្ញុំចាកចេញពីកងពល១៦៤ នៅឆ្នាំ១៩៧៧ ទៅភ្នំពេញ"]។

182 ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ឆ.១៦ ["ជំនាន់នោះ គឺរំដោះហើយ១៩៧៥ ពេលនោះគឺគេធ្វើការរើសកងទ័ពជើងទឹក នៅក្នុងកងពលលេខ៣គឺមក នៅកំពង់សោមទាំងអស់ ហើយកងពលនេះគឺមាស មុត ជាអ្នកដឹកនាំទាំងអស់ ទើបគេបានរើសយកកងពលលេខ៣ មកកាន់កាប់នៅជើងទឹកទាំងអស់។ ក្រោយមក គេប្រមូលកងពល៣មកដាក់កំណង់សោម ហើយទើបគេរៀបចំអង្គភាពហ្នឹងថ្មីហើយដាក់ឈ្មោះថាកងពលលេខ ១៦៤"]។ ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.១៨-១៩ ["នៅខែសីហា ឆ្នាំ១៩៧៥ កងពលថ្មី១៦៤ ត្រូវបានបង្កើតឡើង [...] ឆ.១៩៖ [...] មឿន ម៉ុន ដែលជាមេបញ្ជាការអនុសេនាធំ និងឈ្មោះ ហេង ហុក ដែលជាមេបញ្ជាការកងអនុសេនាធំ ដែលស្ថិតនៅក្នុងកងវរៈសេនាតូច៤៨០។ ពួកគេបានប្រាប់ខ្ញុំថា កងពលធំលេខ៣បានប្តូរទៅជាកងពលធំលេខ១៦៤ ហើយក៏មានការបង្កើតនូវកងពលតូចមួយទៀតដែរ គឺកងពលតូចលេខ១៤០ ដែលជាកងជើងទឹក"]។ ឯកសារ D54/50 កំណត់ហេតុស្តាប់ចម្លើយ មាស រឿន ឆ.៤ ["នៅពេលដែលខ្ញុំសួរថាកងពលណាជាកងពល១៦៤ យោធាបានប្រាប់ខ្ញុំថា កងពល១៦៤ ជាកងពលរបស់ តា មុត"]។ ឯកសារ D54/35.1 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយប្រាក់ សុខា KH 00964248 ["សៈ ចឹងមកដល់កំពង់សោមមានកងពលមានអីហើយ? ឆ៖ នៅកំពង់សោមមានកងពល១៦៤ ហ្នឹង កាលវៃចូលភ្នំពេញហ្នឹងក៏មានកងពលដែល តែកាលហ្នឹងបងពលលេខ៣ ជំនាន់ហ្នឹង។ សៈ បាទ។ ឆ៖ ដល់មកដល់កំពង់សោមផ្លាស់កងពលហើយមកជាកងពល១៦៤"]។ ឯកសារ D4.1.759 ចម្លើយរបស់ គង់ ចាយ ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម KH 00658142 ["លោក ចាយ បានបញ្ជាក់ពីការរៀបចំកងពលធំលេខ៣ មុន និងបន្ទាប់ពីបែកភ្នំពេញ។ កងពលលេខ៣ ត្រូវបានផ្ទេរទៅជាកងទ័ពជើងទឹកកម្ពុជា ហើយបានប្តូរឈ្មោះទៅជាកងពលធំលេខ១៦៤"]។

183 ឯកសារ D54/51 កំណត់ហេតុស្តាប់ចម្លើយមាស រឿន ឆ.៧ ["ខ្ញុំមិនបានចាំលម្អិតអំពីអ្វីដែល ប៉ុល ពត បាននិយាយនោះទេ ប៉ុន្តែខ្ញុំចាំចំណុចសំខាន់ៗ ដែលគាត់បាននិយាយអំពីមុខងារ និងការទទួលខុសត្រូវរបស់កងទ័ពជើងទឹក គឺការការពារព្រំដែនសមុទ្រ និងកោះផ្សេងៗ ហើយនិងធ្វើការកសាងប្រទេសឡើងវិញ"]។ ឯកសារ D54/52 កំណត់ហេតុស្តាប់ចម្លើយមាស រឿន ឆ.១២ ["មាស មុត ទទួលខុសត្រូវការពារដែនសមុទ្រ និងព្រំដែនទឹករបស់ប្រទេសកម្ពុជា"]។

61. **មាស មុត** ដែលធ្លាប់ជាមេបញ្ជាការកងពល ៣ ចាប់តាំងពីការកកើតកងពលនេះនៅឆ្នាំ ១៩៧៣[184] នៅតែជាអ្នកគ្រប់គ្រងដដែល បន្ទាប់ពីកងពលនេះត្រូវបានរៀបចំរចនាសម្ព័ន្ធឡើងវិញទៅជាកងពល ១៦៤[185] និងនៅតែជាមេបញ្ជាការដដែលរហូតដល់ខែ មករា ឆ្នាំ ១៩៧៩[186]។ បន្ទាប់ពីបក្ស

---

ឯកសារ D1.3.33.7 កំណត់ហេតុសួរចម្លើយ កាំង ហ្កេក អ៊ាវ ហៅ ឌុច KH 00896775 ["មាស មុត ទទួលភារកិច្ចជាបញ្ជាការកងជើងទឹក"]។

184 ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហៀង រ៉េត ឆ.៣៨ ["មាស មុត ត្រូវបានតែងតាំងជាមេបញ្ជាការកងពលលេខ ៣ នៅក្នុងឆ្នាំ១៩៧៣ នៅពេលដែលកងពលនេះត្រូវបានបង្កើតឡើង"]; ឯកសារ D114/181 កំណត់ហេតុស្តាប់ចម្លើយ សែម កុល ឆ.៦-៨ ["សៈ តើកាលនោះ លោកស្គាល់ឈ្មោះ មាស មុត ដែរទេ? ឆ.៦៖ ស្គាល់។ សៈ តើលោកស្គាល់គាត់ហ្នឹង ដោយសារគាត់មានមុខនាទីអ្វីដែរ? ឆ.៧៖ គាត់ជាកងពលតូចលេខ៣។ កងពលហ្នឹងវាគ្រប់គ្រងបីវរៈសេនាធំ។ កាលហ្នឹងក្នុងឆ្នាំ១៩៧៣។ សៈ តើគាត់គឺជាមេបញ្ជាការគ្រប់គ្រងវរៈសេនាធំលោកដែរទេ? ឆ.៨៖ គាត់ទទួលទាំងអស់។ នៅក្នុងកងពលហ្នឹង គាត់គ្រប់គ្រងទាំងអស់ ម៉ាតាកែវហ្នឹង"]។ ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.៥ ["កងពលលេខ៣ជាកងពលរបស់ភូមិភាគនិរតី ដែលបង្កើតឡើងដោយ តា ម៉ុក ក្នុងឆ្នាំ១៩៧៣។ [...] តា ម៉ុក បង្កើតកងពលលេខ៣ ហើយចាត់តាំងឲ្យ មាស មុត ធ្វើជាប្រធាន"]។

185 ឯកសារ D114/82 កំណត់ហេតុស្តាប់ចម្លើយកែវ សាន ឆ.៥ ["គេបង្កើតកងទ័ពជើងទឹកនៅក្នុងឆ្នាំ១៩៧៥។ កាលនោះ គេហៅថាជាកងពលធំទី៣ ដែលមានមេបញ្ជាការ ឈ្មោះ មាស មុត"]។ ឯកសារ D54/51 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.១ ["ពេលនោះ គេប្រកាសថា មាស មុត គឺជាមេបញ្ជាការកងទ័ពជើងទឹក [ក្នុងឆ្នាំ១៩៧៥"]។

186 ឯកសារ D1.3.12.1 សេចក្តីរាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ពី ទាញ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៧៦ KH 00160081 [ដាក់ថា មាស មុត ជាមេបញ្ជាការកងពលធំ១៦៤]។ ឯកសារ D1.3.30.2 របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យពី មុត (មាស មុត) ជូនបង៨៩ (សុន សេន) ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦ KH 00021446 [សេចក្តីរាយការណ៍ប្រចាំខែរបស់ មាស មុត ពាក់ព័ន្ធនឹងកងពល ១៦៤ ផ្ញើជូន បង៨៩]។ ឯកសារ D1.3.30.25 ទូរសព្ទសម្ងាត់ ពី មុត ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨ KH 00017026។ ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.២៦ ["សៈ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តើ មាស មុត កាន់កងពលលេខ៣/១៦៤ ពេញមួយឆ្នាំ គឺឆ្នាំ១៩៧៥ មែនដែរទេ តាមលោកដឹង? ឆ.២៦៖ កាន់នៅហ្នឹង"]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយព្រំ សារ៉ាត ឆ.៤៤-៤៥ ["សៈ តើមេបញ្ជាការកងពល១៦៤ឈ្មោះអ្វី? ឆ.៤៤៖ ឈ្មោះ មាស មុត។ សៈ តាមដែលលោកដឹង តើ មាស មុត ជាមេបញ្ជាការកងពល១៦៤ ចាប់ពីពេលណាដល់ពេលណា? ឆ.៤៥៖ មាស មុត ធ្វើជាមេបញ្ជាការកងពល១៦៤ ពីខែមិថុនា ឆ្នាំ១៩៧៥ រហូតដល់ចុងឆ្នាំ១៩៧៨"]។ ឯកសារ D114/82 កំណត់ហេតុស្តាប់ចម្លើយកែវ សាន ឆ.៥ ["គេបង្កើតកងទ័ពជើងទឹកនៅក្នុងឆ្នាំ១៩៧៥។ កាលនោះ គេហៅថាជាកងពលធំទី៣ ដែលមានមេបញ្ជាការឈ្មោះ មាស មុត"]។ ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយស៊ឹម នី ឆ.២៧-២៩ ["នៅពេលដែលខ្ញុំទៅដល់ភូមិភាគបូព៌ា គេដាក់ខ្ញុំចូលក្នុងកង១៦៤។ សៈតើលោកដឹងថា នៅពេលនោះ មាស មុត នៅឯណាដែរឬទេ? ឆ.២៨៖ ពេលនោះ មាស មុត នៅកំពង់សោម។ ខ្ញុំឃើញមានតែ តារ៉ែន នៅទីនោះ។ សៈ តើលោកដឹងថា មាស មុត នៅកំពង់សោមតាមរបៀបណា នៅពេលនោះ? ឆ.២៩៖ ដោយសារមេបញ្ជាការរបស់ខ្ញុំទាក់ទងសារទូរលេខជាមួយ

កុម្មុយនីស្តកម្ពុជាបានគ្រប់គ្រងទីក្រុងភ្នំពេញភ្លាម **មាស មុត** បានផ្លាស់ទៅក្រុងកំពង់សោម[187] ដែលបម្រើជាមូលដ្ឋានយោធាសម្រាប់កងពល ៣/១៦៤[188] និងត្រូវបានកាន់កាប់ជាចម្បងដោយពួកទាហាន[189] បន្ទាប់ពីការជម្លៀសប្រជាជនស៊ីវិលក្នុងក្រុងនេះទៅកាន់ភូមិក្បែរៗនោះ[190]។

---

មាស មុត ដូច្នេះខ្ញុំដឹងអំពីរឿងនេះ។ រឿងនេះ វាកើតឡើងនៅខែធ្នូ ឆ្នាំ១៩៧៨"]។ ឯកសារ D54/31 កំណត់ហេតុស្តាប់ចម្លើយស៊ឹម នី ឆ.៧ ["សៈ តើផ្ទះរបស់ មាស មុត និងបញ្ជាការនៅជិតផ្សារលើ ចាប់ពីពេលណាដល់ពេលណា? ឆ.៧៖ ផ្ទះរបស់ មាសម មុត និងមន្ទីរធ្វើការរបស់គាត់នៅត្រង់កន្លែងនោះគឺចាប់ពីឆ្នាំ១៩៧៥ រហូតដល់ចុងឆ្នាំ១៩៧៨ ពេលដែលខ្ញុំត្រូវបានបញ្ជូនទៅព្រំដែនវៀតណាម"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយសាត ចក់ ឆ.១៦ ["ជំនាន់នោះ គឺរំដោះហើយ១៩៧៥ ពេលនោះគឺគេធ្វើការរើសកងទ័ពជើងទឹក នៅក្នុងកងពលលេខ៣ គឺមកនៅកំពង់សោមទាំងអស់ ហើយកងពលនេះគឺ មាស មុត ជាអ្នកដឹកនាំទាំងអស់ ទើបគេបានរើសយកកងពលលេខ៣មកកាន់កាប់នៅជើងទឹកទាំងអស់។ ក្រោយមក គេប្រមូលកងពល៣មកដាក់កំពង់សោម ហើយទើបគេរៀបចំអង្គភាពហ្នឹងថ្មី ហើយដាក់ឈ្មោះថាកងពលលេខ១៦៤"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយប៉ាក សុខ ឆ.១ ["មាស មុត ជាប្រធានកងពល១៦៤ ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩"]។ ឯកសារ D114/181 កំណត់ហេតុស្តាប់ចម្លើយសែម កុល ឆ.១១ ["សៈ តើលោកស្ថិតនៅក្នុងអង្គភាពក្រោមបញ្ជាការ មាស មុត បានយូរប៉ុន្មានដែរ? ឆ.១១៖ បានយូររហូតដល់៧៩។ ព្រោះគាត់ក្តោបក្តាប់អាហ្នឹង ក្តោបក្តាប់កងទ័ពជើងទឹកនៅសមុទ្រ រហូតដល់ឆ្នាំ៧៩ ទៀត"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយសេង ស៊ុន ឆ.១៥, ១៨, ៦៦ ["សៈ តើលោកដឹងថា អនុសេនាធំ២ ហ្នឹងស្ថិតនៅក្នុងកងវរៈសេនាធំ និងតូចណាដែរ? ឆ.១៥៖ កងពល១៦៤ហ្នឹង មាន មាស មុត ជាស្នងការធំ [...] សៈ អ្នកណាប្រាប់លោកថា មាស មុត ជាអគ្គបញ្ជាការ? ឆ.១៨៖ ប៊ុន ធឿន ជាអ្នកប្រាប់ខ្ញុំ [...] សៈ តើលោកស្គាល់ មាស មុត ដោយរបៀបណា? ឆ.៦៦៖ គេប្រកាសថា គាត់ជាប្រធានកងពល១៦៤ តាំងពីរៀបកងពលឯណោះ។ ខ្ញុំឃើញគាត់នៅក្នុងកិច្ចប្រជុំដើម្បីបញ្ចូលកងទាំង៣នោះ"]។

187 ឯកសារ D54/62 កំណត់ហេតុស្តាប់ចម្លើយម៉ឹង វេត ឆ.១៥ ["បន្ទាប់ពីខែមេសា ឆ្នាំ១៩៧៥ គាត់ (មាស មុត) បានទៅកំពង់សោម"]។ ឯកសារ D114/286 កំណត់ហេតុស្តាប់ចម្លើយហ៊ាង រ៉េត ឆ.៣៥-៣៦ ["សៈ យើងនិយាយគ្នាពីពេលវេលាម្តង កាលពីសម្ភាសន៍មុនលោកបានប្រាប់ថា នៅភ្នំពេញបានតែមួយថ្ងៃទេ បន្ទាប់ពីភ្នំពេញដួលរលំ ហើយបន្ទាប់មកលោកធ្វើដំណើរទៅកំពង់សោម ដោយប្រើពេល៤ថ្ងៃ។ ហើយគេសួរថាតើលោកមានចាំទេ ប្រហែលប៉ុន្មានថ្ងៃបានតាមុត គាត់ទៅដល់កំពង់សោម? ឆ.៣៥៖ ខ្ញុំទៅមុន ហើយតាម៉ុក គេមកទទួលតាំងពីដោះកញ្ចោ តាម៉ុក គាត់បើកឡានអាហ្សីបមកទទួលយើងទៅកំពង់សោម។ តាមុតមិនដឹងទៅតាំងពីពេលណា ទាល់តែក្រោយមកបានឃើញតាមុត ទៅប្រជុំ។ សៈ ពេលដែលលោកឃើញតាមុត ដំបូងនៅកំពង់សោម ប្រហែលជាពេលណាប៉ុន្មានអាទិត្យ? ឆ.៣៦៖ ប្រហែលជា២ ទៅ៣អាទិត្យ ក្រោយពេលការមកដល់របស់ខ្ញុំ គាត់ទៅប្រជុំប្រកាសរៀបរយ"]។ ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយឡាយ ប៊ុនហាក់ ឆ.៨៨-៨៩ ["កងពលលេខ៣ បានប្តូរមកជាកងពលលេខ១៦៤ នៅពេលផ្លាស់មកកំពង់សោម មេបញ្ជាការមុនគឺឈ្មោះ តារិន នៅពេលត្រូវបានផ្លាស់មកកំពង់សោមគឺតាមុត ជាអ្នកគ្រប់គ្រងវិញ។ សៈ តើការផ្លាស់ប្តូរមេបញ្ជានៅពេលណា? ឆ.៨៩៖ កងពលលេខ៣ កំពុងប្រយុទ្ធនៅភ្នំពេញគឺមានមេបញ្ជាការ តារិន ពេលប្តូរមកកំពង់សោម ក៏ដូរមក តាមុត វិញនៅឆ្នាំ១៩៧៥ ពេលរំដោះភ្នំពេញ"]។ ឯកសារ

62. **មាស មុត** ត្រូវបានណែនាំជាផ្លូវការថាជាមេបញ្ជាការកងទ័ពជើងទឹក នៅក្នុងអំឡុងសន្និបាតមួយ ដែលប្រារព្ធធ្វើឡើងនៅពហុកីឡាដ្ឋានអូឡាំពិក ក្នុងទីក្រុងភ្នំពេញ ដោយមានវត្តមានរបស់ ប៉ុល ពត, នួន ជា, អៀង សារី, សុន សេន និង ខៀវ សំផន[191]។ នៅក្នុងពិធីនោះ ប៉ុល ពត បាន

---

D114/186 កំណត់ហេតុស្តាប់ចម្លើយសាត ចក់ ឆ.១៦ ["ជំនាន់នោះ គឺរំដោះហើយ១៩៧៥ ពេលនោះគឺគេរើសកងទ័ពជើងទឹក នៅក្នុងកងពលលេខ៣គឺមកនៅកំពង់សោមទាំងអស់ ហើយកងពលនេះគឺមាស មុត ជាអ្នកដឹកនាំទាំងអស់ ទើបគេបានរើសយកកងពលលេខ៣ មកកាន់កាប់នៅជើងទឹកទាំងអស់។ ក្រោយមក គេប្រមូលកងពល៣មកដាក់កំពង់សោម ហើយទើបគេរៀបចំអង្គភាពហ្នឹងថ្មីហើយដាក់ឈ្មោះថាកងពលលេខ១៦៤"]។ ឯកសារ D22.2.182 182 ចម្លើយ មាស មុត ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម KH 00741991 ["នៅពេលទីក្រុងភ្នំពេញ ត្រូវបានរំដោះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងពលធំលេខ ៣ បានទទួលបញ្ជាឲ្យដកថយទៅកាន់ខេត្តកំពង់សោម"]។

188 ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយអ៊ឹង ឆុន ឆ.១០ ["កងពលលេខ៣ របស់តាមុត គេបោះទីតាំងនៅក្រុងកំពង់សោម"]។ ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយឡាយ ប៊ុនហាក់ ឆ.៨៨-៨៩ ["កងពលលេខ៣ បានប្តូរមកជាកងពលលេខ១៦៤ នៅពេលផ្លាស់មកកំពង់សោម មេបញ្ជាការមុនគឺឈ្មោះ តារិន នៅពេលត្រូវបានផ្លាស់មកកំពង់សោមគឺតាមុត ជាអ្នកគ្រប់គ្រងវិញ។ សៈ តើការផ្លាស់ប្តូរមេបញ្ជានៅពេលណា? ឆ.៨៩៖ កងពលលេខ៣ កំពុងប្រយុទ្ធនៅភ្នំពេញគឺមានមេបញ្ជាការ តារិន ពេលប្តូរមកកំពង់សោម ក៏ដូរមក តាមុត វិញនៅឆ្នាំ១៩៧៥ ពេលរំដោះភ្នំពេញ"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយសាត ចក់ ឆ.១៦ ["ជំនាន់នោះ គឺរំដោះហើយ១៩៧៥ ពេលនោះគឺគេរើសកងទ័ពជើងទឹក នៅក្នុងកងពលលេខ៣គឺមកនៅកំពង់សោមទាំងអស់ ហើយកងពលនេះគឺមាស មុត ជាអ្នកដឹកនាំទាំងអស់ ទើបគេបានរើសយកកងពលលេខ៣ មកកាន់កាប់នៅជើងទឹកទាំងអស់។ ក្រោយមក គេប្រមូលកងពល៣មកដាក់កំពង់សោម ហើយទើបគេរៀបចំអង្គភាពហ្នឹងថ្មីហើយដាក់ឈ្មោះថាកងពលលេខ១៦៤"]។ ឯកសារ D59/1/1.29 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ង៉ែត ចាន់ថូ KH 00733609 ["[មាស មុត] ហ្នឹងហើយផ្លាស់ពីកងពលហ្នឹងទៅ១៦៤ ហ្នឹងនៅកំពង់សោម"]។

189 ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយសុក វណ្ណា ឆ.១៤ ["តាមពិតទៅ ពុំមានប្រជាជនធម្មតារស់នៅកំពង់សោម ឬនៅតាមកោះទេ គឺសុទ្ធតែយោធាទាំងអស់។ ប្រជាជនធម្មតារស់នៅតាមភូមិផ្សេងៗ ដូចជាស្នាច់ដែង ថ្មធំ ពូធឿង ដីឥដ្ឋជាដើម"]។ ឯកសារ D54/99.1 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយឡាយ ប៊ុនហាក់ KH 00990786 ["ប្រជាជន ដូចអត់មាន មានតាគ្រួសារយោធា (កំពង់សោម)"។

190 ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយអ៊ឹង ឆុន ឆ.១០-១១ ["កងពលលេខ៣ របស់តាមុត គេបោះទីតាំងនៅក្រុងកំពង់សោម តែខ្ញុំមិនដឹងថាឋិតនៅកន្លែងណាពិតប្រាកដទេ។ សៈ តើកងពលលេខ៣ បោះទីតាំងនៅកំពង់សោមហើយឬនៅ ពេលដែលប្រជាជនជម្លៀសចេញពីក្រុងកំពង់សោម? ឆ.១១៖ ពេលដែលយោធាកងពលលេខ៣ ចូលដល់កំពង់សោម គេបញ្ជាឲ្យប្រជាជនជម្លៀសចេញពីក្នុងក្រុង"]។

191 ឯកសារ D54/50 កំណត់ហេតុស្តាប់ចម្លើយមាស រឿន ឆ.២៥ ["ខ្ញុំបានជួប មាស មុត ម្តងនៅក្នុងឆ្នាំ១៩៧៥ នៅពេលដែលគេធ្វើសន្និបាតកងទ័ពនៅស្តាតអូឡាំពិក។ ពេលនោះ គឺគេរៀបចំបង្កើតកងទ័ពជើងគោក កងទ័ពជើង

ប្រគល់ស័ក្តិយោធាតំណាងស្ថាប័ននីមួយៗនៃកងកម្លាំងប្រដាប់អាវុធ ទៅដល់មេបញ្ជាកាតាមអង្គភាព។ **មាស មុត** បានទទួលនិមិត្តសញ្ញាកងទ័ពជើងទឹក ហើយ ប៉ុល ពត បានសង្កត់ធ្ងន់ថា ទំនួលខុសត្រូវរបស់កងទ័ពជើងទឹកគឺត្រូវ "ការពារដែនទឹក និងកោះ និងត្រូវកសាងប្រទេសនេះឡើងវិញ"[192]។ ដែនទឹកដែលកងពល ១៦៤ តម្រូវឱ្យគ្រប់គ្រង លាតសន្ធឹងលើឆ្នេរសមុទ្រប្រវែង

---

អាកាស និងកងទ័ពជើងទឹក"]។ ឯកសារ D54/51 កំណត់ហេតុស្តាប់ចម្លើយមាស រឿន ឆ.១ ["យើងនិយាយគ្នាពីម្សិលមិញ មុននឹងយើងបញ្ចប់នៅពេលថ្ងៃរសៀលអំពីសន្និបាតដែលធ្វើឡើងនៅស្តាតអូរឡាំពិក។ ពេលនោះលោកបាននិយាយថា លោកបានឃើញ មាស មុត នៅក្នុងសន្និបាតនោះដែរ។ តើលោកអាចពន្យល់ប្រាប់យើងបានទេអំពីមុខតំណែង និងមុខងារនៅក្នុងសន្និបាតនោះ ថាគាត់មានមុខងារជាអ្វី? ឆ.១៖ ដូចដែលខ្ញុំបាននិយាយកាលពីម្សិលមិញថា ពិធីបុណ្យអបអរនោះ គឺជាពិធីអបអរកំណើតកងទ័ពដែលធ្វើឡើងដើម្បីបង្កើតកងទ័ពជើងគោក កងទ័ពជើងអាកាស និងកងទ័ពជើងទឹក ហើយនិងអបអរខួបជ័យជម្នះថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥។ ពេលនោះ គេប្រកាសថា មាស មុត គឺជាមេបញ្ជាការកងទ័ពជើងទឹក]។

192 ឯកសារ D54/51 កំណត់ហេតុស្តាប់ចម្លើយមាស រឿន ឆ.១-៥, ៧ ["នៅក្នុងសន្និបាតនោះ គេបានប្រគល់រូបសញ្ញារបស់កងទ័ពនីមួយៗទៅឱ្យមេបញ្ជាការរៀងៗខ្លួន។ ពេលនោះ គេប្រកាសថា មាស មុត គឺជាមេបញ្ជាការកងទ័ពជើងទឹក ដែលជាអ្នកទទួលនូវស្លាកសញ្ញារបស់កងទ័ពជើងទឹកនោះ [...] ស៖ តើលោកនៅចាំទេថា នៅពេលនោះ តើអ្នកណាជាអ្នកប្រកាសឈ្មោះអ្នកដែលទទួលខុសត្រូវខាងកងទ័ពជើងគោក កងទ័ពជើងទឹក និងកងទ័ពជើងអាកាស របស់កម្ពុជាប្រជាធិបតេយ្យ? ឆ.២៖ ប៉ុល ពត ជាអ្នកប្រកាស។ ស៖ តើលោកនៅចាំទេថា តើអ្នកណាជាមេបញ្ជាការទទួលខុសត្រូវខាងកងទ័ពជើងគោក កងទ័ពជើងអាកាស និងកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ? ឆ.៣៖ កងទ័ពនីមួយៗមានគណៈបញ្ជាការចំនួនបីនាក់។ កងទ័ពជើងអាកាសមាន ស៊ូ ម៉េត ជាមេបញ្ជាការ ហើយអនុរបស់គាត់ឈ្មោះ ល្វៃ [...] គណៈបញ្ជាការកងទ័ពជើងគោក ឈ្មោះ រ៉ែន (ស្លាប់) ជាមេបញ្ជាការ ហើយអនុរបស់គាត់ឈ្មោះ ចក្រី [...] មាស មុត ជាមេបញ្ជាការ ហើយគាត់ជាកូនប្រសាររបស់ តាម៉ុក។ [...] ឆ.៤៖ ប៉ុល ពត ជាអ្នកប្រគល់ស្លាកសញ្ញាកងទ័ព។ ការប្រកាសនៅពេលនោះក៏បាននិយាយអំពី សុន សេន ដែរ ដោយប្រកាសថា សុន សេន គឺជាអគ្គសេនាធិការ ហើយកងទ័ពទាំងអស់ស្ថិតនៅក្រោមបង្គាប់អគ្គសេនាធិការ។ [...] ស៖ តើស្លាកសញ្ញាកងទ័ពដែលគេប្រគល់ឱ្យគណៈបញ្ជាការនីមួយៗនោះធ្វើអំពីអ្វី? ឆ.៥៖ វាដូចជារូបចម្លាក់ដែលគេដាក់នៅក្នុងប្រអប់កញ្ចក់ តែខ្ញុំមិនដឹងថារូបចម្លាក់នោះធ្វើអំពីអ្វីទេ។ [...] ស៖ តើ ប៉ុល ពត មានបានធ្វើសេចក្តីប្រកាសក្នុងការបង្កើតកងទ័ពជើងទឹក ហើយនិងអំពីតួនាទី និងភារកិច្ចរបស់កងទ័ពជើងទឹកដែរឬទេ? ឆ.៧៖ ខ្ញុំមិនបានចាំលម្អិតអំពីអ្វីដែល ប៉ុល ពត បាននិយាយនោះទេ ប៉ុន្តែខ្ញុំចាំចំណុចសំខាន់ៗ ដែលគាត់បាននិយាយអំពីមុខងារ និងការទទួលខុសត្រូវរបស់កងទ័ពជើងទឹក គឺការការពារព្រំដែនសមុទ្រ និងកោះផ្សេងៗ ហើយនិងធ្វើការកសាងប្រទេសឡើងវិញ"]។

ជាង ៤០០ គីឡូម៉ែត្រ និងរួមបញ្ចូលកោះប្រមាណ ២០០ កោះផង ដូចជា កោះរ៉ុង កោះថ្មី កោះព្រីង កោះតាង និងកោះពូឡូវៃ[193]។

---

[193] ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយជេត ប៊ុណ្ណា ឆ.១១ ["ក្នុងពេលសន្និបាតនោះ គេក៏និយាយអំពីការការពារដែនសមុទ្រ និងព្រំដែនសមុទ្រ ដែលមានប្រវែងជាង៤០០គីឡូម៉ែត្រ ហើយនិងការការពារកោះរបស់កម្ពុជា ដែលមានជិត២០០កោះ"]។ សូមមើលផងដែរ ការប្រាស្រ័យទាក់ទងរបស់ មាស មុត ពាក់ព័ន្ធនឹងតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់៖ D1.3.30.2 របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ផ្ញើពី មុត (មាស មុត) ជម្រាបបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ១៩៧៦ KH 00021446 [សេចក្តីរាយការណ៍ប្រចាំខែរបស់កងពល ១៦៤ អំពីសភាពការណ៍កងទ័ពនៅតាមកោះរបស់កម្ពុជា ដូចជាកោះត្រល់ កោះសេះ កោះថ្មី កោះសំពោច កោះរ៉ុង កោះរាម កោះរុងក្រៅ]។ ឯកសារ D1.3.12.3 របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ផ្ញើពី មុត (មាស មុត) ជម្រាប បង ៨៩ (សុន សេន) ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ KH 00021461 [សេចក្តីរាយការណ៍ពី មាស មុត ជូនបង៨៩ (សុន សេន) រៀបរាប់ពីស្ថានភាពនៅប៉ែកនិរតី នៃកោះសេះ នៅខាងលិច និងខាងជើង វាលវិញ]។ ឯកសារ D1.3.8.3 កំណត់ហេតុនៃអង្គប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៧៦ KH 00021496 [មាស មុត បង្ហាញពីការដាក់ពង្រាយកម្លាំងទ័ពនៅក្រុងកំពង់សោម រាម កងកេង និងតាមកោះ មួយចំនួន ដូចជា កោះវៃ កោះតាំង កោះព្រីង កោះរ៉ុង និងកោះសេះ]។ ឯកសារ D1.3.34.10 ទូរលេខ ៤៤ ផ្ញើពី មុត (មាស មុត) ជម្រាបបង៨៩ (សុន សេន) ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៧៦ KH 00000860 [សេចក្តីរាយការណ៍របស់ មាស មុត អំពីសភាពការណ៍នៅកោះតាង កោះយំ កោះស្តេច និងកោះសោម]។ ឯកសារ D1.3.34.14 ទូរលេខ១៥ ពីសមមិត្ត ឌឹម ជូនបង មុត (មាស មុត) ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ១៩៧៦ KH 00000866 [មាស មុត ទទួលទូរលេខពី ឌឹម ដែលរៀបរាប់ពីបញ្ហាផ្សេងៗ ដូចជា សភាពការណ៍យោធា/សន្តិសុខនៅកោះកុង កោះឫស្សី និងកោះសេះ]។ ឯកសារ D1.3.14.2 សារតាមទូរសព្ទសម្ងាត់ ៤៣ ផ្ញើពី មឿន ជូនបង មុត (មាស មុត) ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៧៧ KH 00161788-89 [មាស មុត ទទួលទូរលេខដែលរៀបរាប់ពីសភាពការណ៍ខ្មាំង នៅឆ្នេរអូរទាល និងកោះរ៉ុងសន្លឹម]។ ឯកសារ D4.1.637 សេចក្តីរាយការណ៍ ផ្ញើពី មុត (មាស មុត) ជូន បង ៨៩ (សុន សេន) ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៧៨ KH 00143515 [របាយការណ៍ពី មាស មុត ជូន សុន សេន អំពីសភាពការណ៍នៅកោះត្រល់]។ សូមមើលផងដែរ D54/51 កំណត់ហេតុស្តាប់ចម្លើយមាស រឿន ឆ.១៧ ["កងទ័ពជើងទឹក ត្រួតត្រាដីគោក ចាប់ពីវាលរេញរហូតដល់កំពង់សោម។ ចំណែកឯនៅលើផ្ទៃសមុទ្រវិញ គឺចាប់ពីកោះរ៉ុង កោះថ្មី កោះព្រីង កោះតាង រហូតដល់កោះពូលូវៃ និងកោះដទៃទៀតដែលខ្ញុំមិនស្គាល់ឈ្មោះ"]។ ឯកសារ D54/104 កំណត់ហេតុនៃការស្តាប់ចម្លើយឯក នី ឆ.១៦ ["តំបន់គ្រប់គ្រងរបស់កងពល១៦៤ មានព្រំដែនខាងកើតនៅចំទឹកសាប ខាងជើងនៅស្ទឹងហាវ ខាងលិចគឺសមុទ្រ ហើយនិងកោះមួយចំនួន លើកលែងតែកោះម្នាស់ ដែលស្ថិតនៅក្នុងតំបន់១១"]។ ឯកសារ D114/209 កំណត់ហេតុស្តាប់ចម្លើយម៉ុង សេង ឆ.១៧-១៨ ["ពូរបស់ខ្ញុំ (ជាមេបញ្ជាការកងវរៈសេនាធំកាំភ្លើងធំ បោះទីតាំងនៅទឹកសាប) ត្រូវរាយការណ៍ទៅឲ្យឈ្មោះ មាស មុត។ ខ្ញុំមិនដឹងច្បាស់ថា មាស មុត មានតួនាទីអ្វីច្បាស់លាស់ទេ នៅកំពង់សោម។ ស៖ ហេតុអ្វីបានលោកដឹងថា គាត់រាយការណ៍ឲ្យ មាស មុត? ឆ.១៨៖ ពីព្រោះនៅកំពង់សោម មានតែ មាស មុត ទេ ដែលជាអ្នកគ្រប់គ្រង"]។ ឯកសារ D114/116 កំណត់ហេតុនៃការស្តាប់ចម្លើយស្វាយ សំអាន ឆ.៥-៦ ["ស៖ អំឡុង

63. កងពល ១៦៤ ទទួលខុសត្រូវល្បាតឆ្នេរសមុទ្រ និងកោះនានារបស់កម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាផ្តល់ការគាំទ្រផ្នែកឃោធាដល់កងពលផ្សេងៗទៀត និងធ្វើប្រតិបត្តិការការដ្ឋាន និងមន្ទីរសន្តិសុខនានាក្នុងតំបន់ដែលខ្លួនគ្រប់គ្រង[194]។

---

ពេលលោកឃាមឃ្លាំងនៅទឹកសាប តើលោកមានឃើញបញ្ជាការកងពលធំ១៦៤ ចុះមកទឹកសាបដែរឬទេ? ឆ.៥៖ បាទ ខ្ញុំឃើញគេចុះមកម្តងម្កាល។ ស៖ តើលោកឃើញអ្នកណាចុះមកម្តងម្កាលនោះ? ឆ.៦៖ មាស មុត មេបញ្ជាការកងពល១៦៤"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយអ៊ុយ ញ៉ិក ឆ.៥២ ["ខ្ញុំធ្លាប់ឃើញ តា មុត ជិះឡានមកមើលតាមកន្លែងធ្វើការនៅស្ទឹងហាវ តែគាត់មិនដែលឈប់ និងចេញពីឡានទេ"]។ ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយមាស អ៊ឹម ឆ.៣៩ ["ដើមឆ្នាំ៧៧ បានជួប (មាស មុត) ដូចខ្ញុំកំណត់អីចឹង នៅស្ទឹងហាវ គាត់មកមួយអាទិត្យម្តង"]។ ឯកសារ D54/92 កំណត់ហេតុស្តាប់ចម្លើយសំអុន យ៉ែម ឆ.៤៩ ["ស៖នៅព្រឹកមិញនេះ លោកនិយាយអំពីតា មុត តើលោកដឹងអ្វីខ្លះអំពីតាមុត? ឆ.៤៩៖ ខ្ញុំធ្លាប់ឃើញគាត់ម្តងនៅលើកោះរ៉ុងសន្លឹម នៅពេលដែលគាត់ជូនគណៈប្រតិភូចិនទៅទស្សនកិច្ចនៅលើកោះ"]។

194 ឯកសារ D1.3.12.18 ទូរលេខ ០៩ ផ្ញើពី មុត (មាស មុត) ជូនបង៨៩ (សុន សេន) ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧ KH 00162487 [រៀបរាប់ពីបេសកកម្មដែលបញ្ជាឲ្យឃាមល្បាតម្តុំកោះកុង]។ ឯកសារ D1.3.34.39 ទូរលេខ ០៤ ផ្ញើពី រឿន ជូន បង មុត (មាស មុត) ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ១៩៧៧ KH 00161791 [រៀបរាប់ពីការឃាមល្បាតនៅម្តុំកោះកុង]។ ឯកសារ D54/52 កំណត់ហេតុស្តាប់ចម្លើយមាស រឿន ឆ.៦-៧ ["មាស មុត ជាថ្នាក់មជ្ឈិម ហើយគាត់មានកប៉ាល់ និងមធ្យោបាយផ្សេងៗទៀត ដើម្បីការពារដែនដីប្រទេសកម្ពុជា។ ក្នុងនាមគាត់ជាកងទ័ពមជ្ឈិម គាត់អាចធ្វើប្រតិបត្តិការនៅកន្លែងផ្សេងៗទៀតនៅក្នុងប្រទេសបាន។ ស៖ តើលោកមានន័យថាម៉េច មធ្យោបាយផ្សេងៗហ្នឹង? ឆ.៧៖ កងទ័ពជើងទឹករបស់គាត់គឺកប៉ាល់ចម្បាំង គ្រាប់រំសេវ រ៉ាដា អាវុធប្រឆាំង កាំភ្លើងបាញ់យន្តហោះ គ្រឿងប្រដាប់មុជទឹក កប៉ាល់ដឹកជញ្ជូនសម្ភារៈ និងកប៉ាល់ប្រដេញ...។ល។"] ឯកសារ D54/51 កំណត់ហេតុស្តាប់ចម្លើយមាស រឿន ឆ.១៧-១៨ ["កងពលលេខ១ គឺជាកងទ័ពជើងគោករបស់ភូមិភាគបស្ចិម។ តួនាទីរបស់កងពលលេខ១ គឺការពារទឹកដីតាមព្រំដែននៅក្នុងភូមិភាគបស្ចិម ទាំងព្រំដែនទឹក និងព្រំដែនគោក។ ប្រសិនបើមានជម្លោះនៅលើសមុទ្រជាមួយប្រទេសដទៃ កងពលលេខ១ធ្វើការទាក់ទងជើងទឹកដើម្បីអន្តរាគមន៍ទប់ទល់ជាមួយបញ្ហាទាំងនោះ ពីព្រោះកងទ័ពជើងទឹកមាននាវាចម្បាំង ឯកពលលេខ១ មិនមាននាវាចម្បាំង គឺមានតែទូកតូចៗសម្រាប់ល្បាត និងដឹកជញ្ជូនប៉ុណ្ណោះ [...] កងពលលេខ១ មានកាណូតខ្លួនឯងដើម្បីល្បាតតាមបណ្តោយខ្សែបន្ទាត់ព្រំដែន។ ប្រសិនបើមានបញ្ហាធ្ងន់ធ្ងរនៅលើសមុទ្រ កងពលលេខ១ ហៅកងទ័ពជើងទឹកមកជួយធ្វើអន្តរាគមន៍"]។ ឯកសារ D54/17 កំណត់ហេតុស្តាប់ចម្លើយសយ ប៊ិន ឆ.១៤ ["ស៖ លោកបានចង្អុលបង្ហាញពីទីតាំងឡូតដ្ឋដែលនៅជិតព្រលានយន្តហោះកងកេងតាមបណ្តោយផ្លូវទៅរាម តើលោកបានដឹងពីអ្វីខ្លះពីទីកន្លែងនេះ? ឆ.១៤៖ វាជាកន្លែងការដ្ឋានពលកម្មធម្មតារបស់កងពល១៦៤"]។ ឯកសារ D114/58 កំណត់ហេតុស្តាប់ចម្លើយសំ សោម ឆ.១៤ ["ខ្ញុំមិនច្បាស់ថាអង្គភាពកម្រិតណានោះទេ ប៉ុន្តែខ្ញុំគិតថាទំនប់នេះ ស្ថិតក្រោមការគ្រប់គ្រងរបស់កងពល១៦៤។ ខ្ញុំនិយាយដូច្នេះ ដោយសារតែតំបន់ទំនប់នេះស្ថិតក្រោមការគ្រប់គ្រងរបស់កងពល១៦៤"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយប៉ាក សុខ ឆ.៤០ ["ខ្ញុំដឹងកន្លែងមួយ ដែលជាមន្ទីរឃុំឃាំងរបស់កងពល១៦៤ ដែលស្ថិតនៅទឹកសាប"]។ ឯកសារ D114/209 កំណត់ហេតុ

64. កងពលរបស់ **មាស មុត** ត្រូវបានកត់ត្រាថាមានទាហានចំនួន ៨.៦១១ នាក់ នៅខែ តុលា ឆ្នាំ ១៩៧៦ និងបុគ្គលិក ៨.៥៦៨ នាក់ នៅខែ មេសា ឆ្នាំ ១៩៧៧ ដែលធំជាងកងពល ៣១០ ដែលជាកងពលធំមធ្យមធំជាងគេទីពីរ ដែលមានទាហានចំនួនតែ ៦.០៩៦ នាក់ នៅខែ មេសា ឆ្នាំ ១៩៧៧[195]។ ទំហំដ៏ធំនៃកងពលរបស់គាត់ត្រូវបានបញ្ជាក់អះអាងដោយ **មាស មុត** ខ្លួនឯង

---

ស្តាប់ចម្លើយម៉ឺង សេង ឆ.១៧-១៨ ["ពូរបស់ខ្ញុំ (ជាមេបញ្ជាការកងវរៈសេនាធំកាំភ្លើងធំ បោះទីតាំងនៅទឹកសាប) ត្រូវរាយការណ៍ទៅឲ្យឈ្មោះ មាស មុត។ ខ្ញុំមិនដឹងច្បាស់ថា មាស មុត មានតួនាទីអ្វីច្បាស់លាស់ទេ នៅកំពង់សោម។ សះ ហេតុអ្វីបានលោកដឹងថា គាត់រាយការណ៍ឲ្យ មាស មុត? ឆ.១៨៖ ពីព្រោះនៅកំពង់សោម មានតែ មាស មុត ទេ ដែលជាអ្នកគ្រប់គ្រង"]។ ឯកសារ D114/116 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីស្វាយ សំអាន ឆ.៥-៦ ["សះ អំឡុងពេលលោកឃាមឃ្លាំងទឹកសាប តើលោកមានឃើញបញ្ជាការកងពល១៦៤ ចុះមកទឹកសាបដែរឬទេ? ឆ.៥៖ បាទ ខ្ញុំឃើញគេចុះមកម្តងម្កាល។ សះ តើលោកឃើញអ្នកណាចុះមកម្តងម្កាលនោះ? ឆ.៦៖ មាស មុត មេបញ្ជាការកងពល១៦៤"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយអ៊ុយ ញ៉ិក ឆ.៥២ ["ខ្ញុំធ្លាប់ឃើញ តា មុត ជិះឡានមកមើលតាមកន្លែងធ្វើការនៅស្ទឹងហាវ"]។ ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយមាស អ៊ឹម ឆ.៣៩ ["ដើមឆ្នាំ ៧៧ បានជួប (មាស មុត) ដូចខ្ញុំកំណត់អីចឹង នៅស្ទឹងហាវ គាត់មកមួយអាទិត្យម្តង"]។ ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយសុក វណ្ណា ឆ.១៤ ["[មាស មុត] ក៏មានសិទ្ធិអំណាចបញ្ជាទៅតាមមេសហករណ៍ និងមេឃុំដែរ"]។ ឯកសារ D59/2/2.16a កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយស៊ឹម នី KH 00735601-02 ["សះ អ្នកសួរចម្លើយអីហ្នឹង បញ្ចូលបញ្ចេញអីគឺ តាមុត (វត្តឥន្ទយាន)? ឆះ ហ្នឹងហើយ មាស មុត ទេជាអ្នកបញ្ជូនបញ្ចេញ។ [...] សះ ឃើញ តាមុត គាត់អាសារចេញចូលនៅហ្នឹងដែរ? ឆះ បាទ!"]។

195 ឯកសារ D1.3.30.9 របាយការណ៍កម្ពុជាប្រជាធិបតេយ្យពីអគ្គសេនាធិការ ក.ប.ក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៧៧ KH 00052319 [បញ្ជាក់ថា កងពល១៦៤ មានកម្លាំងសរុបចំនួន ៨ ៥៦៨ នាក់ រួមមានកម្មករ ១៦៩ នាក់។ កងពល ៣១០ គឺជាកងពលដែលធំជាងគេទី២ ដែលមានកងទ័ពចំនួន៦០៩៦នាក់]។ ឯកសារ D1.3.5.3 បញ្ជីក្តាប់កំលាំងប្រចាំថ្ងៃរបស់កងពល១៦៤ រៀបចំដោយ មាស មុត ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៧៦ KH 00160145-47 [រៀបរាប់ពីរចនាសម្ព័ន្ធ និងទំហំកងពល១៦៤។ ចំនួនកម្លាំងសរុបនៃកងពល១៦៤ មាន ៨៦១១នាក់ គិតត្រឹមថ្ងៃទី២៧ ខែតុលា ឆ្នាំ ១៩៧៦]។ សូមមើលផងដែរ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយជេត ប៊ុណ្ណា ឆ.១២ ["យើងធ្លាប់បានមើលកុនចិន ឃើញរូប សុន សេន ហើយនិងសកម្មភាពខ្លះរបស់យោធាខ្មែរក្រហម ដែលមានចំនួន ២៥ កងពល។ យើងក៏បានដឹងដែរថា កងជើងទឹកដែលនៅក្រោម មាស មុត គឺជាកងពលមួយដែលធំជាងគេបង្អស់ ក្នុងចំណោមកងពលទាំង ២៥របស់ខ្មែរក្រហម"]។ ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ការិយាល័យសហព្រះរាជអាជ្ញាជាមួយ សៀង EN 00217564 ["នៅខែមេសា ឆ្នាំ១៩៧៥ ក្រោយពីបែកភ្នំពេញ គាត់បានចូលកងពល ១៦៤ ហើយបម្រើនៅកងវរសេនាធំលេខ ៦២។ កងវរសេនាធំនេះ មានកម្មាភិបាលចំនួនប្រហែល ៦០០ នាក់ បូករួមទាំងជំនួយការ។ នៅកងពល ១៦៤ ទាំងមូល មានកម្លាំងលើសពី ១០០០០នាក់"]។

ដែលបានលើកឡើងថា គាត់មានបុគ្គលិកចំនួន ១០.០០០ ទៅ ១២.០០០នាក់ ក្រោមបញ្ជាការរបស់គាត់[196]។

65. កងពល ១៦៤ កើតឡើងពីកងវរសេនាធំចំនួន ៤ និងកងវរសេនាតូចឯករាជ្យចំនួន ៦ ដែលកងទាំងអស់នេះបានរាយការណ៍ដោយផ្ទាល់ទៅកាន់ **មាស មុត**។ កងវរសេនាធំនៃកងពល ១៦៤ គឺមានលេខ ១៦១ លេខ ១៦២ លេខ ១៦៣ និងលេខ១៤០ ដែលកងចុងក្រោយនេះកាន់កាប់នាវានៃកងទ័ពជើងទឹកទាំងអស់របស់កម្ពុជាប្រជាធិបតេយ្យ។ កងវរសេនាធំនីមួយៗមានកងវរសេនាតូចយ៉ាងតិចបី។ កងវរសេនាតូចនីមួយៗមានកងអនុសេនាធំបី ឬច្រើនជាងនេះ។ ហើយកងអនុសេនាធំនីមួយៗមានកងអនុសេនាតូចយ៉ាងហោចណាស់បី។ កងវរសេនាតូចឯករាជ្យទាំងប្រាំមួយនោះ គឺមានលេខ ១៦៥ (គេស្គាល់ផងដែរថាជា ៤៥០) លេខ ១៦៦ លេខ ១៦៧ លេខ ១៦៨ លេខ ១៦៩ និងលេខ ១៧០។ រួមបញ្ចូលគ្នា កងវរសេនាធំ និងកងវរសេនាតូចទាំងនេះទទួលខុសត្រូវការពារដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ ឈរជើងប្រចាំការនៅលើកោះរបស់កម្ពុជាប្រជាធិបតេយ្យ និងការពារក្រុងកំពង់សោម និងតំបន់ជុំវិញនោះ។ ជាពិសេស កងវរសេនាតូច ១៦៥ (៤៥០) ទទួលបន្ទុកលើក្រុងកំពង់សោម រួមទាំងមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ។ កងវរសេនាធំ ១៦៣ ទទួលបន្ទុកលើតំបន់រាម និងមន្ទីរសន្តិសុខទឹកសាប និងកងវរសេនាធំ ១៦២ គ្រប់គ្រងលើកន្លែងសម្លាប់មនុស្សចម្ការទុរេនទី ១ ដែលមានទីតាំងស្ថិតនៅជិតឆ្នេររាម និងការដ្ឋាននានាដែលនៅជុំវិញស្ទឹងហាវ[197]។

---

196 ឯកសារ D22.2.180 កាសែត ភ្នំពេញប៉ុស្តិ៍ បទសម្ភាសន៍ជាមួយ មាស មុត ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ EN 00161880 ["សៈ តើមានមនុស្សប៉ុន្មាននាក់នៅក្នុងកងពលរបស់លោក? ឆៈ ប្រហែលជាង ១០០០០នាក់"]។ ឯកសារ D22.2.181 ចម្លើយ មាស មុត ពាក់ព័ន្ធនឹងល្បើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ ២០០១ KH 00742002-03 ["នៅចុងឆ្នាំ ១៩៧៥ កងពលធំលេខ ៣ ត្រូវបានរៀបចំរចនាសម្ព័ន្ធទៅជាកងពលធំលេខ ១៦៤ [...]នៅពេលបញ្ចប់ការរៀបចំរចនាសម្ព័ន្ធឡើងវិញនេះ កងពលធំលេខ ១៦៤ មានទាហានចំនួនប្រហែល ១២.០០០នាក់]។

197 សូមមើល IV. កងពល ១៦៤ (អតីតកងពល ៣) រចនាសម្ព័ន្ធសិទ្ធិអំណាច, VIII.ច. ការដ្ឋានតំបន់រាម, VIII.ង. ការដ្ឋានស្ទឹងហាវ និង VIII.គ.មន្ទីរសន្តិសុខកងពលធំ១៦៤។

66. **មាស មុត** បានរស់នៅ និងធ្វើការនៅទីបញ្ជាការកណ្តាលនៃកងពល ១៦៤ ចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៥ រហូតដល់យ៉ាងហោចណាស់ចុងឆ្នាំ ១៩៧៨[198]។ ទីបញ្ជាការកណ្តាលដំបូងស្ថិតនៅក្នុងបរិវេណផ្សារលើ ក្នុងក្រុងកំពង់សោម និងក្រោយមកស្ថិតនៅទីតាំងមួយផ្សេងទៀតនាភាគអាគ្នេយ៍នៃទីផ្សារនេះ និងភាគពាយ័ព្យនៃសណ្ឋាគារសុខា[199]។ ទីធ្លានៃទីបញ្ជាការកណ្តាលនោះរួមមានទាំងផ្ទះរបស់ **មាស មុត** មន្ទីរទូរលេខ មន្ទីរផ្សព្វផ្សាយ កន្លែងស្នាក់នៅរបស់នីរសារ និងរោងបាយ[200]។

67. **មាស មុត** បានគ្រប់គ្រងលើរាល់ការសម្រេចទាំងអស់ដែលទាក់ទងនឹងតំបន់ប្រតិបត្តិការរបស់កងពល ១៦៤[201]។ គាត់បានត្រួតពិនិត្យដោយផ្ទាល់លើកោះ ការដ្ឋាន និងមន្ទីរសន្តិសុខដែលស្ថិតក្រោម

---

[198] សូមមើល កថាខណ្ឌ ៥៦, ២១៦។ សូមមើលផងដែរ D54/31 កំណត់ហេតុស្តាប់ចម្លើយស៊ឹម នី ឆ.៧ ["សៈ តើផ្ទះរបស់ មាស មុត និងបញ្ជាការនៅជិតផ្សារលើ ចាប់ពីពេលណាដល់ពេលណា? ឆ.៧៖ ផ្ទះរបស់ មាស មុត និងមន្ទីរធ្វើការរបស់គាត់នៅត្រង់កន្លែងនោះគឺចាប់ពីឆ្នាំ១៩៧៥ រហូតដល់ចុងឆ្នាំ១៩៧៨"]។ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយប៉ាក សុខ ឆ.៣ ["ផ្ទះរបស់ មាស មុត គឺនៅនឹងកន្លែងមន្ទីរធ្វើការរបស់គាត់តែម្តង"]។ ឯកសារ D114/181 កំណត់ហេតុស្តាប់ចម្លើយសែម កុល ឆ.៤៣ ["នៅកំពង់សោម ឃើញពីរបីដងដែរ។ នៅ៧៦ ៧៧ គាត់ជិះឡានមើលកូនចៅគាត់ ជិះអាហ្សិប។ ដើរមើលអង្គភាពគាត់។ ពេលផ្សេងទៀត គឺគាត់នៅតែកន្លែងគាត់ហ្នឹង"]។

[199] សូមមើល កថាខណ្ឌ ២១៦។

[200] ឯកសារ D54/71 កំណត់ហេតុស្តាប់ចម្លើយមុត ម៉ៅ ឆ.១៨, ២០, ២៨ ["តើលោកស្រីអាចពិពណ៌នាអំពីទីកន្លែងដែលលោកស្រីស្នាក់នៅជាមួយ មាស មុត បន្ទាប់ពីលោកស្រីចាកចេញពីផ្ទះភ្ញៀវសុខាមក? ឆ.១៨៖ កន្លែងនោះ ហៅថាមន្ទីរក្នុងរបស់កងពល១៦៤។ ប្រសិនបើលោកធ្វើដំណើរពីផ្សារលើទៅកាន់រង្វង់មូលតោពីរ ហើយមកដល់ចំណុចផ្លូវកោង មានផ្លូវមួយកាត់ទទឹងធំ លោកអាចបត់ស្តាំប្រហែល៥០០ម៉ែត្រ លោកនឹងទៅដល់កន្លែងទីតាំងមន្ទីរក្នុងរបស់កងពល [...] សៈ តើមន្ទីរក្នុងរបស់កងពល១៦៤ ហ្នឹងមានមុខងារធ្វើអ្វីខ្លះ? ឆ.២០៖ វាគឺជាផ្ទះដែល មាស មុត ស្នាក់នៅ។ [...] ឆ.២៨៖ មានអគារផ្សេងៗគ្នានៅក្នុងបរិវេណនៃមន្ទីរក្នុង។ នៅកន្លែងនោះមានរោងបាយរួម ផ្ទះរបស់ មាស មុត កន្លែងស្នាក់នៅរបស់នីរសារ និងអ្នកផ្សេងៗទៀតស្នាក់នៅ កន្លែងសារទូរលេខ កន្លែងមួយហៅថា មន្ទីរផ្សាយ ដែលស្ថិតនៅជិតរង្វង់មូលតោពីរ"]។

[201] ឯកសារ D54/24 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.20 ["សៈ តើលោកមានន័យថាម៉េច ដែលនិយាយថា មាស មុត ជាមេបញ្ជាការធំជាងគេបង្អស់របស់កងពល? តើគាត់ទទួលខុសត្រូវការងារហ្វឹកហ្វឺនពួកយោធា ហើយនិងការងារភស្តុភារ ជាដើមឬ? ឆ.20៖ មាស មុត ទទួលខុសត្រូវគ្រប់យ៉ាងដូចជា ខាងផ្នែកយោធា ភស្តុភារ នេសាទ ដួសជុលកប៉ាល់ សកម្មភាពកំពង់ផែ ហើយនិងការងារជាច្រើនទៀត។ គាត់ទទួលខុសត្រូវខាងផ្នែកប្រតិបត្តិការក្នុងការប្រយុទ្ធ ឧទាហរណ៍គាត់ឱ្យបញ្ជាទៅតា បូ ដែលជាមេបញ្ជាការវរសេនាធំលេខ១៤០ សម្រាប់ធ្វើប្រតិបត្តិការក្នុងពេលប្រយុទ្ធ។ គាត់ទទួលខុសត្រូវខាងសកម្មភាពនៅកំពង់ផែលើការចេញចូលរបស់កប៉ាល់បរទេសផងដែរ។ ឧទាហរណ៍ផ្សេងទៀត ក្នុងពេលរត់ភៀសខ្លួនពីវៀតណាមនៅឆ្នាំ១៩៧៩ ពេលចុងក្រោយនៃរបបនោះ មាស មុត បានបញ្ជាឱ្យខ្ញុំទៅរៀម ធ្វើការកម្ទេចគ្រាប់រំសេវ រួមទាំងគ្រាប់មីន កម្ទេចនាវាទាំងអស់។ នៅពេលនោះ ពួកអ្នកធ្វើការនៅកន្លែងនោះ

សិទ្ធិអំណាចរបស់គាត់[202]។ លើសពីនេះទៀត ជាញឹកញាប់ **មាស មុត** បានផ្ដល់ការណែនាំដល់ និងទទួលរបាយការណ៍ពីមន្ត្រីក្រោមឱវាទរបស់គាត់អំពីស្ថានភាពនៅលើកោះ និងលើដីគោក[203]។

---

ប្រុងសម្លាប់ខ្ញុំចោល ដោយចោទខ្ញុំថាជាគីញ កាហ្សេបេ របស់យួន។ ប៉ុន្តែខ្ញុំបានប្រាប់គេថា ខ្ញុំបានធ្វើតាមបញ្ជារបស់ តា មុត ទេ ទើបខ្ញុំបានរួចខ្លួន"]។ ឯកសារ D54/10 កំណត់ហេតុស្ដាប់ចម្លើយ ម៉ើ រ៉េត ឆ.12 ["ស៖ តើលោកដឹងឬទេ នៅក្នុងឆ្នាំ១៩៧៥ ក្នុងនាមជាមេបញ្ជាការកងពល តើមុខងារ និងការងាររបស់ មាស មុត មានអ្វីខ្លះ? ឆ.12៖ ក្នុងនាមជាមេបញ្ជាការកងពល គាត់ទទួលខុសត្រូវរួមលើកងពល។ គាត់ធ្វើដំណើរចុះឡើង ដើម្បីពិនិត្យឱ្យដឹងថា កងនីមួយៗរបស់កងពលយ៉ាងម៉េចខ្លះ។ គាត់ជាអ្នកបង្រៀនអបរំនយោបាយ និងជាអ្នកបញ្ជាកងទ័ពក្នុងសមរភូមិ ហើយជាអ្នកចលនាទ័ពពីកន្លែងមួយទៅកន្លែងផ្សេងៗ"]។ ឯកសារ D54/24.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ KH 00955508 ["ស៖ ចឹងចាប់បានបញ្ជាពីកងពលទៅឬមួយធ្វើដោយខ្លួនឯង? ឆ៖បញ្ជាពីកងពលទៅ។ ស៖ បញ្ជាចេញពីនរណាទៅ? ឆ៖ បញ្ជាចេញពីតា មុត។ ស៖ បញ្ជាឱ្យសម្លាប់តែម្ដង? ឆ៖ បាទ"]។ ឯកសារ D59/2/2.16a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH 00735601-02 ["ស៖ ប៉ុន្តែអ្នកសួរចម្លើយអីហ្នឹងបញ្ជូនបញ្ចេញ [ពីវត្តឥន្ទញាណ] អីគឺ តាមុត? ឆ៖ ហ្នឹងហើយ មាស មុត ទេជាអ្នកបញ្ជូនបញ្ចេញ។ [...] ស៖ ឃើញ តាមុត គាត់អាសារចេញចូលនៅហ្នឹងដែរ? ឆ៖ បាទ!"]។

202 សូមមើល III.3. ការចូលរួមចំណែករបស់ មាស មុត នៅក្នុងឧក្រិដ្ឋកម្មនានា - ការចូលរួមក្នុងការធ្វើទុក្ខបុកម្នេញ និងការសម្លាប់ខ្មាំង។ III.3. ការចូលរួមចំណែករបស់ មាស មុត នៅក្នុងឧក្រិដ្ឋកម្មនានា - ការចូលរួមក្នុងការដាក់ឱ្យទៅជាទាសករ នៅការដ្ឋានការងារនានា។

203 ឯកសារ D4.1.699 សារទូរលេខ ១១ ពី ឌឹម ជូន បង មុត (មាស មុត) ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH 00092628 [សារទូរលេខរៀបរាប់ពីស្ថានភាពនៅកំពង់សោម]។ ឯកសារ D1.3.34.12 ទូរលេខ ១២ ពីមិត្ត ឌឹម ជូន បង មុត (មាស មុត) ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH 00021528 [រៀបរាប់ពីការផ្ទុះអាវុធរវាងកោះកុង និងកោះមូល]។ ឯកសារ D1.3.34.13 សារទូរលេខ ១៦ ពី ឌឹម ជូន បង មុត (មាស មុត) ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៧៦ KH 00000865 [សារទូរលេខរៀបរាប់ពីការល្បាតនៅកោះសេះ និងកោះកុង]។ ឯកសារ D1.3.34.14 សារទូរលេខ ១៥ ពីមិត្ត ឌឹម ជូន បង មុត (មាស មុត) ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៧៦ KH 00000866 [សារទូរលេខរៀបរាប់បន្ថែមពីបញ្ហាផ្សេងៗ មានពីស្ថានភាពយោធា/សន្តិសុខ នៅកោះកុង កោះឫស្សី និងកោះសេះ]។ ឯកសារ D1.3.34.15 សារទូរលេខ ១៧ ពី ឌឹម ជូន បង មុត (មាស មុត) ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ១៩៧៦ KH 00000867 [សារទូរលេខរៀបរាប់ពីស្ថានភាពយោធា/សន្តិសុខ និងភស្តុភារ]។ ឯកសារ D1.3.14.2 ឯកសារ D4.1.636 សារទូរលេខ ៤៣ ពី មឿន ជូន បង មុត (មាស មុត) ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៧៧ KH 00161788 [សារទូរលេខរៀបរាប់ពីស្ថានភាពខ្មាំងនៅអូរ ឈើទាល និងកោះរង់សន្លឹម]។ ឯកសារ D1.3.34.28 សារទូរលេខ ១៤១ ពី ស៊ឹម ជូន បង (កងពល) ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៧៧ KH 00161729 [មាស មុត និង សុន សេន ត្រូវបានគេចម្លងជូននូវរបាយការណ៍សារទូរលេខមួយដែលសរសេរដោយកងពលនយោបាយនៃកងពល១៦៤។ របាយការណ៍នោះបានរៀបរាប់ការចាប់ទូកថៃចំនួន ២ ដែលបានចូលដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ។ អ្នកនៅក្នុងទូកលោតចុះទៅក្នុងទឹកដើម្បីរត់គេច ហើយអ្នកដែលគេចាប់ខ្លួនបានទាំងអស់ត្រូវបានគេសម្លាប់ចោល]។ ឯកសារ D1.3.34.39 សារ

ទូរលេខ ៤ ពី រឿន ជូន បង មុត (មាស មុត) ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ KH 00161791 [មាស មុត បានទទួលសារទូរលេខមួយពី រឿន ស្តីអំពីការល្បាតនៃកោះនានាជុំវិញកោះកុង ការហ្វឹកហ្វឺន និងការឃាត់នាវាឡើងវិញនៅសមុទ្រ និងការផលិតស្រូវ]។ សូមមើលផងដែរនូវ ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.48 ["បន្ទាប់ពីយើងបានមកដល់កោះតាងដោយមានយោធា៥០នាក់ [...] យើងបានដើរល្បាតលើកោះ ហើយយើងបានបង្កើតប៉ុស្តិ៍យោធាដើម្បីទំនាក់ទំនងជាមួយនឹងដីគោក។ យើងបានធ្វើការប្រាស្រ័យទាក់ទងអំពីស្ថានភាពតាមវិទ្យុទាក់ទងមកកងពល មាស មុត ជាប្រចាំថ្ងៃ"]។ ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.21-22 ឆ.26 ឆ.32 ["សៈ ហេតុអ្វីលោកដឹង នៅពេលដែលលោកនៅកោះតាង ថា មាស មុត មានវត្តមាន ឬអវត្តមាន? ឆ.21៖ ខ្ញុំដឹងថា មាស មុត មានវត្តមាន នៅពេលខ្ញុំរាយការណ៍ទៅអ្នកកាន់វិទ្យុទាក់ទង ដើម្បីរាយការណ៍ទៅ មាស មុត។ សៈ នៅពេលដែលលោកនៅកោះតាង តើលោករាយការណ៍ទៅ មាស មុត ញឹកញាប់ដែរឬទេ? ឆ.22៖ នៅពេលដែលខ្ញុំនៅកោះតាង វិទ្យុទាក់ទងទៅដីគោក គឺទាក់ទងគ្នាជាប្រចាំពីព្រឹកដល់យប់។ [...] ឆ.26៖ ខ្ញុំបាននិយាយផ្ទាល់តាមវិទ្យុជាមួយ មាស មុត ម្តង ក្រោយពេលវៃគ្នាធំជាមួយទាហានអាមេរិកាំង បន្ទាប់ពីវិទ្យុរបស់ខ្ញុំខូច ខ្ញុំបានទាក់ទង មាស មុត ដោយផ្ទាល់តាមវិទ្យុជាមួយគាត់នៅលើកាណូត PCS នៅពេលកប៉ាល់នោះទៅដល់ [នៅកោះតាង [...] ឆ.32៖ ខ្ញុំបានទៅជួប មាស មុត នៅមន្ទីររបស់គាត់ ហើយគាត់បានសួរខ្ញុំឱ្យពន្យល់អំពីស្ថានការណ៍នៅកោះតាង"]។ ឯកសារ D54/49 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.48 ["នៅពេលខ្ញុំចូលរួមជាមួយកងពល ខ្ញុំរាយការណ៍ដោយផ្ទាល់ទៅ មាស មុត ពីព្រោះគ្មានវរៈសេនាធំនៅរវាងកងវរៈសេនាតូច៤៥០ របស់ខ្ញុំ និង មាស មុត ទេ។ ខ្ញុំបានរាយការណ៍ទៅ មាស មុត អំពីលទ្ធផលនៃបញ្ជាដែលគាត់ដាក់មកឱ្យខ្ញុំអនុវត្ត។ អំឡុងពេលនោះ មិនមានប្រព័ន្ធរាយការណ៍ជាផ្លូវការនោះទេ។ ការរាយការណ៍គឺធ្វើឡើងតាមសភាពជាក់ស្តែង ជាទូទៅតាមវិទ្យុទាក់ទង ឬតាមនីរសារ"]។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ឆ.22 ["[មេបញ្ជាការកងវរៈសេនាធំ និងមេបញ្ជាការកងវរៈសេនាតូច] ត្រូវរាយការណ៍ទៅ មាស មុត ដែលជាមេបញ្ជាការកងពល"]។ ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.19 ["សៈ ហេតុអ្វីបានជា មាស មុត ដែលជាស្នងការនយោបាយ ត្រូវតែដឹងអំពីព្រឹត្តិការណ៍ទាំងអស់នេះ? ឆ. 19៖ ព្រឹត្តិការណ៍អ្វីដែលកើតឡើងត្រូវតែរាយការណ៍ទៅឱ្យកងវរសេនាតូច ហើយកងវរសេនាតូចរាយការណ៍ទៅមេបញ្ជាការកងវរសេនាធំ ហើយកងវរសេនាធំរាយការណ៍ទៅឱ្យមេបញ្ជាការកងពល។ បន្ទាប់មកមេបញ្ជាការកងពលធ្វើសេចក្តីសម្រេច ហើយដាក់បញ្ជាបញ្ជូនចុះមកវិញតាមជាន់ថ្នាក់ទាំងនេះមកវិញ"]។ ឯកសារ D54/31 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.5 ["សៈ ក្នុងពេលលោកនៅកំពង់សោមនាពេលនោះ តើបញ្ជាការដ្ឋានរបស់កងពលទី៣ និងផ្ទះរបស់ មាស មុត ស្ថិតនៅកន្លែងណា? ឆ.5៖ នៅពេលនោះ មាស មុត រស់នៅទីកន្លែងមួយជិតផ្សារលើ ហើយទីបញ្ជាការដ្ឋានកងពល៣នៅទីនោះដែរ។ ផ្ទះរបស់ មាស មុត នៅចម្ងាយ ១៥០ម៉ែត្រខាងកើតពីផ្សារលើ។ នៅពេលនោះទីបញ្ជាការដ្ឋានកងពល និងផ្ទះរបស់មេបញ្ជាការកងពលគឺនៅជាមួយគ្នា។ រៀងរាល់ខែ ពួកមេបញ្ជាការវរៈសេនាធំនីមួយៗមកប្រជុំនៅទីនោះរៀងរាល់ថ្ងៃទី ១០, ថ្ងៃទី២០, និងថ្ងៃទី៣០"]។

គាត់ទទួលខុសត្រូវបន្ថែមទៀតលើការត្រួតពិនិត្យលើអង្គភាពយោធានីមួយៗ នៅក្នុងកងពល និងសម្របសម្រួលលើចលនាយោធា[204]។

68. **មាស មុត** ក៏ទទួលបន្ទុកផ្តល់ការបណ្តុះបណ្តាលនយោបាយដល់បុគ្គលិកនៃកងពល ១៦៤ ផងដែរ[205]។ ក្នុងអំឡុងពេលនៃវគ្គសិក្សា ដែលជាទូទៅត្រូវបានធ្វើឡើងនៅរោងភាពយន្តកំពង់សោម[206] **មាស មុត** បានបង្រៀនអំពីកិច្ចការនយោបាយ និងមនោគមវិជ្ជា ដោយបានណែនាំអ្នកចូលរួមឱ្យ

[204] ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ឆ.12 ["សៈ តើលោកដឹងឬទេនៅក្នុងឆ្នាំ ១៩៧៥ ក្នុងនាមជាមេបញ្ជាការកងពល តើមុខងារ និងការងាររបស់ មាស មុត មានអ្វីខ្លះ? ឆ.12៖ ក្នុងនាមជាមេបញ្ជាការកងពល គាត់ទទួលខុសត្រូវរួមលើកងពល។ គាត់ធ្វើដំណើរចុះឡើង ដើម្បីពិនិត្យឱ្យដឹងថា កងនីមួយៗរបស់កងពលយ៉ាងម៉េចខ្លះ។ គាត់ជាអ្នកបង្រៀនអប់រំនយោបាយ និងជាអ្នកបញ្ជាកងទ័ពក្នុងសមរភូមិ ហើយជាអ្នកចលនាទ័ពពីកន្លែងមួយទៅកន្លែងផ្សេងៗ"]។

[205] ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.34 ["សៈ តើអ្នកណាជាអ្នកទទួលខុសត្រូវរួមក្នុងផ្នែកអប់រំនយោបាយនៅក្នុងកងពល១៦៤ ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩? ឆ.34៖ គឺ មាស មុត ដែលជាអ្នកស្នងការនយោបាយរបស់កងពល"]។ ឯកសារ D114/132 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ រ៉ាន់ ឆ.63 ["ការរៀនសូត្រហ្នឹងគឺធ្វើឡើងពេលដែលយើងជួបជុំគ្នា គឺរៀបចំដោយ មាស មុត ហើយអ្នកបង្រៀនមាន មាស មុត"]។ ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង ឆុន ឆ.15 ["ថ្ងៃមួយ [...] ខ្ញុំត្រូវបានហៅឱ្យទៅហ្វឹកហ្វឺនដោយតាមុតនៅកំពង់សោម។ ការបង្រៀននោះបានធ្វើនៅអតីតៈរោងកុងកំពង់សោម ដែលបង្រៀនដោយតាមុត"]។

[206] ឯកសារ D54/17 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.6 ឆ.8 ["សៈ តើការប្រជុំនៅអតីតៈកោះរុងនោះជាការប្រជុំថ្នាក់អ្វីដែរ? ឆ.6៖ នៅឆ្នាំ១៩៧៥ គេប្រជុំរៀនសូត្រនយោបាយនៅកន្លែងនេះ សម្រាប់ការប្រជុំនយោបាយ ប្រធាន/អនុប្រធានវរៈសេនាតូច ប្រធាន/អនុប្រធានកងអនុសេនាធំ រហូតដល់ថ្នាក់ប្រធានក្រុម ដែលគេហៅថាកម្មាភិបាល។ [...] សៈ តើលោកដឹងពីវគ្គរៀនសូត្រនយោបាយទាំងនោះដោយរបៀបណា? ឆ.8៖ ដោយសារខ្ញុំក៏បានចូលរួមវគ្គរៀនសូត្រទាំងនោះដែរ ហើយខ្ញុំបានចូលរៀនវគ្គរៀនសូត្រនោះមួយដងក្នុងមួយឆ្នាំ"]។ ឯកសារ D114/132 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ រ៉ាន់ ឆ.63-65 ["សៈ មុនពេលសម្រាក លោកបាននិយាយអំពីការចូលវគ្គរៀនសូត្រ តើវាធ្វើឡើងពេលណា? ហើយនរណាជាអ្នករៀបចំ? ឆ.63៖ ការរៀនសូត្រហ្នឹងគឺធ្វើឡើងពេលដែលយើងជួបជុំគ្នា គឺរៀបចំដោយ មាស មុត ហើយអ្នកបង្រៀនមាន មាស មុត និង អនុរបស់គាត់ម្នាក់ទៀត តែខ្ញុំភ្លេចឈ្មោះគាត់ហើយ។ សៈ កាលពីពេលនោះ លោករៀននៅឯណាដែរ? ឆ.64៖ រៀននៅរោងកុនផ្សារលើ។ សៈ រោងកុនផ្សារលើនៅឯណា? ឆ.65៖ នៅក្នុងកំពង់សោម"]។ ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង ឆុន ឆ.15 ["ថ្ងៃមួយ [...] ខ្ញុំត្រូវបានហៅឱ្យទៅហ្វឹកហ្វឺនដោយតាមុតនៅកំពង់សោម។ ការបង្រៀននោះបានធ្វើនៅអតីតៈរោងកុងកំពង់សោម ដែលបង្រៀនដោយតាមុត"]។

"ឃ្លាំមើលសកម្មភាពខ្មាំងស៊ីរូងផ្ទៃក្នុង"[207]។ ជាផ្នែកមួយនៃការបោសសម្អាតកាន់តែទូលំទូលាយរបស់កងទ័ពបដិវត្តន៍កម្ពុជា[208] គាត់ត្រួតពិនិត្យមើលប្រវត្តិរូបរបស់ទាហានជើងទឹក និងផ្តល់សិទ្ធិ

[207] ឯកសារ D54/17 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.8-12 ["ស៖ តើលោកដឹងពីវគ្គរៀនសូត្រនយោបាយទាំងនោះដោយរបៀបណា? ឆ.8៖ ដោយសារខ្ញុំក៏បានចូលរួមវគ្គរៀនសូត្រទាំងនោះដែរ ហើយខ្ញុំបានចូលរៀនវគ្គរៀនសូត្រនោះមួយដងក្នុងមួយឆ្នាំ។ ស៖ ក្នុងវគ្គរៀនសូត្រទាំងនោះ តើលោកធ្លាប់បានឃើញលោក មាស មុត ដែរឬទេ? ឆ.9៖ បាទ, ខ្ញុំបានឃើញគាត់នៅពេលបិទវគ្គរៀនសូត្រម្តងៗ។ ស៖ តើក្នុងកម្មវិធីបិទវគ្គរៀនសូត្រនោះ តើលោកមាសមុតបំពេញមុខងារជាអ្វី? ឆ.10៖ ក្នុងការអនុវត្តន៍ មេបញ្ជាការទទួលបន្ទុកនយោបាយគឺ មាស មុត ត្រូវបង្រៀនអំពីកិច្ចការនយោបាយ សតិអារម្មណ៍ ចាត់តាំង។ មេបញ្ជាការទទួលបន្ទុកយោធាគឺ ឌឹម ដែលត្រូវបង្រៀនពីបច្ចេកទេសយោធាប្រយុទ្ធ មេបញ្ជាការខាងភស្តុភារគឺ ឆាន គាត់ទទួលបន្ទុកអាវុធយោធភ័ណ្ឌ ការហូបចុកប្រើប្រាស់ផ្គត់ផ្គង់ និងសុខភាព។ ពេលបិទវគ្គ មាស មុត មកធ្វើជាគណៈអធិបតី ដើម្បីបូកសរុបពីលទ្ធផលនៃវគ្គរៀនសូត្ររបស់សិក្ខាកាម ការពិនិត្យជីវទស្សន៍ និងការផ្តល់ការណែនាំបន្ថែមជាចុងក្រោយនៃវគ្គនីមួយៗ។ ស៖ តើលោក មាស មុត បាននិយាយអំពីជនក្បត់នៅក្នុងវគ្គនីមួយដែរឬទេ? ឆ.11៖ បាទ, គាត់បាននិយាយថា យើងត្រូវពិនិត្យមើលសកម្មភាពខ្មាំងនៅក្នុងជួររបស់យើង។ ស៖ តើពាក្យថា ឲ្យពិនិត្យមើលសកម្មភាពខ្មាំងក្នុងជួរមានន័យដូចម្តេច? ឆ.12៖ មានន័យថាជាការណែនាំរបស់ មាស មុត ឲ្យសិក្ខាកាមពិនិត្យមើល និងរាយការណ៍ទៅថ្នាក់លើអំពីសកម្មភាពទាំងនោះ ប្រសិនបើមាន"]។ ឯកសារ D114/132 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ វ៉ាន់ ឆ.63 ឆ.66-69 ["ស៖ មុនពេលសម្រាក លោកបាននិយាយអំពីការចូលវគ្គរៀនសូត្រ តើវាធ្វើឡើងពេលណា? ហើយនរណាជាអ្នករៀបចំ? ឆ.63៖ ការរៀនសូត្រហ្នឹងគឺធ្វើឡើងពេលដែលយើងជួបជុំគ្នា គឺរៀបចំដោយ មាស មុត ហើយអ្នកបង្រៀនមាន មាស មុត និង អនុរបស់គាត់ម្នាក់ទៀត តែខ្ញុំភ្លេចឈ្មោះគាត់ហើយ។ [...] ស៖ តើគេបង្រៀនលោកអំពីអ្វីខ្លះ? ឆ.66៖ រៀនដូចជាច្បាប់វិន័យកងទ័ព។ ស៖ ពេលនោះ តើមានគេនិយាយអ្វីទាក់ទងពីខ្មាំងដែរឬទេ? ឆ.67៖ គេនិយាយអំពីរឿងបរទេស មានដូចជាវៀតណាមអីជាដើម។ ស៖ តើនរណាជាអ្នកនិយាយពីរឿងជនបរទេស? ឆ.68៖ ពេលណា មាស មុត ឡើងបង្រៀន គឺគាត់និយាយពីរឿងនេះ ហើយបើមាននរណាផ្សេងទៀតឡើងបង្រៀនគឺគេក៏និយាយពីរឿងនេះដែរ។ ស៖ សូមលោករកនឹកពាក្យពេចន៍ដែល មាស មុត និយាយនៅពេលនោះអំពីវៀតណាម ឬជនបរទេសដទៃទៀតបានទេ? ឆ.69៖ គាត់និយាយពីកងទ័ពវៀតណាមដែលចង់ដណ្តើមទឹកដីកម្ពុជា គឺគាត់និយាយថា ឲ្យកងទ័ពការពារ ជាពិសេស កន្លែងណាដែលមានជាប់ព្រំប្រទល់នឹងព្រំដែនវៀតណាម"]។

[208] ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំ លេខា និងអនុលេខា និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH 00052407-11 [មាស មុត បានមានវត្តមាននៅក្នុងការប្រជុំក្នុងពេលដែល សុន សេន បានបញ្ជាទៅមេដឹកនាំកងទ័ពបដិវត្តន៍កម្ពុជាឲ្យប្រកាន់ខ្ជាប់នូវការ "ក្តាប់អង្គភាពយើងឱយជាប់ កុំឲ្យខ្មាំងស៊ីរូងផ្ទៃក្នុងបាន ធ្វើម៉េចឲ្យកងទ័ពយើងស្អាត"។ ក្នុងអំឡុងពេលប្រជុំ មាស មុត បានធ្វើការបញ្ចេញមតិ "យល់ព្រម ឯកភាពជាមួយបក្សទាំងស្រុង" ហើយបាននិយាយថាពួកគេគួរតែ "ធ្វើម៉េច កុំឲ្យស្ថានការណ៍ [ខ្មាំង] ជ្រួលច្របល់ [...] ហើយកុំឲ្យវាពង្រឹងពង្រីកខ្លួនបានឲ្យសោះ"]។ សូមមើលផងដែរនូវ III.3. ការចូលរួមចំណែករបស់ មាស មុត នៅក្នុងឧក្រិដ្ឋកម្ម

ឲ្យចាប់ខ្លួនជនក្បត់ដែលត្រូវបានចោទប្រកាន់ពីកងពល ១៦៤[209]។ **មាស មុត** បានបញ្ជាក់អំពីតួនាទីឈានមុខគេរបស់គាត់នៅក្នុងការចែកចាយមនោគមវិជ្ជា និងគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដល់សមាជិកនៃកងពលទាំងអស់ ដោយលើកឡើងថា គាត់ "ជាអ្នកទទួលបន្ទុកខាងនយោបាយ"[210]។

69. កងពល ១៦៤ គឺ "ស្ថិតនៅក្រោមការដឹកនាំផ្ទាល់មុខរបស់បក្សកុម្មុយនីស្តកម្ពុជា"[211]។ ដូច្នេះ **មាស មុត** តម្រូវឲ្យមានទំនាក់ទំនងរាយការណ៍ដោយផ្ទាល់ជាមួយមេដឹកនាំជាន់ខ្ពស់ដទៃទៀត

---

នានា - ការចូលរួមក្នុងការធ្វើទុក្ខបុកម្នេញ និងការសម្លាប់ខ្មាំង - កងទ័ពបដិវត្តន៍កម្ពុជា [រៀបរាប់ពី ការយល់ព្រមរបស់ មាស មុត ក្នុងការចូលរួមក្នុងគម្រោងឧក្រិដ្ឋកម្មរួមមួយដើម្បីបោសម្អាតកងទ័ពបដិវត្តន៍កម្ពុជា]។

209 ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.15-16 ["សៈ តើនរណាជាមេបញ្ជាការកងពល ៣/១៦៤? ឆ.15៖ មេបញ្ជាការគឺ មាស មុត។ [...] សៈ តើបញ្ជាការកងពល មានសិទ្ធអំណាចសម្រេចធ្វើអ្វីខ្លះ? ឆ.16៖ តាមការយល់ដឹងរបស់ខ្ញុំ ក្នុងនាមជាមេបញ្ជាការកងពលទ័ពជើងទឹក មាស មុត គាត់ទទួលខុសត្រូវក្នុងរឿងព្រំដែនទឹក ធ្វើការសម្រិតសម្រាំងប្រវត្តិរូបរបស់យោធាជើងទឹក សម្រេចចាប់ចង និងសម្លាប់អ្នកណាដែលធ្វើខុស"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.6-8 ["សៈ តើនរណាគេជាអ្នករៀបចំប្រជុំអំពីការចាប់ចងនេះ? ឆ.6៖ ព័ត៌មានអំពីការចាប់ចងនេះ បញ្ជូនចុះមកពីកងពលមកកងអនុសេនាតូច។ សៈ តើលោកដឹងឬទេថា តើ មាស មុត ជាអ្នកចេញប្រកាសព័ត៌មាននេះ? ឆ.7៖ បាទ ដោយសារគាត់ជាមេបញ្ជាការកងពល ដូច្នេះគឺមានតែគាត់ហើយជាអ្នកបញ្ជូនសេចក្តីប្រកាសនេះមកថ្នាក់ក្រោម។ សៈ ម៉េចបានជាលោកដឹងរឿងនេះ? ឆ.8៖ គ្មាននរណាទៀតក្រៅពីគាត់ដែលអាចចេញប្រកាសនេះ ពីព្រោះគាត់ជាមេបញ្ជាការកងពល។ ការប្រកាសអំពីការចាប់ចងនេះ គឺសម្រាប់តែការចាប់ចងពួកប្រធានកងដែលក្បត់តែប៉ុណ្ណោះ មិនមែនសម្រាប់ការចាប់ចងទូទៅទេ"]។

210 ឯកសារ D54/16/1R កំណត់ហេតុជាខ្មែរអាត់សម្លេងនៃបទសម្ភាសន៍ មាស មុត ដោយ David Kattenburg ខែ មេសា ឆ្នាំ ២០០៩ ត្រង់នាទី 20:07-23:03 ["រចនាសម្ព័ន្ធនៃការបញ្ជាគឺយ៉ាងដូច្នេះ មានមេដឹកនាំពីរនាក់ មានមេបញ្ជាការពីរក្នុងកងពលមួយ។ មេបញ្ជាការម្នាក់គឺក្តាប់ខាងនយោបាយ ហើយម្នាក់ទៀតក្តាប់ខាងយោធា ការវាយសម្រុក និងការប្រយុទ្ធ អីជាដើម។ ដូច្នេះ មេបញ្ជាការដែលក្តាប់ខាងកងទ័ពគឺគិតតែពីរឿងប្រយុទ្ធ យុទ្ធសាស្ត្រ ខ្មាំង ការបាញ់ប្រហារ ការទាមទារ។ ក៏ប៉ុន្តែ ខាងនយោបាយ គឺពួកគេគឺគិតតែពីរឿងនយោបាយ អប់រំទាហាន ពង្រឹងសីលធម៌។ ហើយមានម្នាក់ទៀតកាន់ខាងភស្តុភារ អ៊ីចឹង មានបីនាក់។ ប៉ុន្តែអ្នកទី៣ហ្នឹង គឺគេហៅថាសមាជិក មិនមែនជាមេបញ្ជាការទេ។ ដូច្នេះ លោកអាចនិយាយបានថាក្នុងមួយកងពលមានមេបញ្ជាការបីនាក់។ សៈ ខាងនយោបាយម្នាក់ ខាងភស្តុភារម្នាក់ និងខាងយោធាម្នាក់? ឆៈ បាទ។ សៈ អ៊ីចឹង មុត ខាងអ្វី? ឆៈ ខ្ញុំក្តាប់ខាងនយោបាយ។ លោកដឹងស្រាប់ហើយ មុនពេលលោកសម្រេចធ្វើការអ្វីមួយ មុនការងារអ្វីមួយ ទាល់តែមានមានបីនាក់ ទើបអាចធ្វើការនោះបាន មិនអាច... បង្កើតកិច្ចព្រមព្រៀងរវាងអ្នកទាំងបី"]។

211 ឯកសារ D1.3.22.1 លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦ មាត្រា១៧ KH 00053031។

របស់បក្ស[212] ហើយគាត់បានធ្វើដូច្នេះបានតាមរយៈការរាយការណ៍ទៀងទាត់ទាក់ទងនឹងប្រតិបត្តិការរបស់កងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ ទៅឲ្យមេបញ្ជាការសេនាធិការ សុន សេន និងមេដឹកនាំជាន់ខ្ពស់ដទៃទៀតនៃបក្សកុម្មុយនីស្តកម្ពុជា ជាពិសេសទាក់ទងនឹងការចាប់នាវាថៃ ឬវៀតណាមទាំងឡាយណាដែលបានចូលក្នុងដែនទឹកកម្ពុជា[213]។

---

[212] ឯកសារ D1.3.22.1 លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦ មាត្រា២៧-២៨ KH 00053035-36 ["កងទ័ពបដិវត្តកម្ពុជា ទាំង៣ប្រភេទ៖ ស្រួច តំបន់ ឈ្លប ត្រូវស្ថិតនៅក្រោមការដឹកនាំផ្តាច់មុខ ដាច់ខាត និងគ្រប់ផ្នែករបស់បក្សកុម្មុយនីសកម្ពុជា។ មាត្រា២៨៖ ក្នុងកងទ័ពបដិវត្តកម្ពុជា មានការចាត់តាំងតាមប្រជាធិបតេយ្យ - ប្រមូលផ្តុំ។ គណៈកម្មាធិការមជ្ឈិមបក្ស កំណត់ការអនុវត្ត ប្រជាធិបតេយ្យ - ប្រមូលផ្តុំនេះ តាមសភាពការណ៍ជាក់ស្តែង។ ក្នុងកងទ័ពបដិវត្តកម្ពុជា មានការចាត់តាំងអង្គការបក្ស ជាថ្នាក់ផ្សេង៣ ដូចតទៅ៖ - សាខាបក្ស ក្នុងអង្គភាពអនុសេនាធំ - គណៈកម្មាធិការបក្ស វរៈសេនាតូច - គណៈកម្មាធិការបក្ស វរៈសេនាធំ - គណៈកម្មាធិការបក្សកងពល។ ឯនៅក្រោម អង្គភាពអនុសេនាធំ ត្រូវចាត់តាំងជាអនុសាខាបក្ស នៅតាមកងអនុសេនាតូច"]។

[213] ឯកសារ D1.3.12.2 របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ពី មុត (មាស មុត) ជូនបង ៨៩ (សុន សេន) ខែ កុម្ភៈ (ឆ្នាំមិនស្គាល់) KH 00021454 [រៀបរាប់ពីស្ថានភាពក្នុងតំបន់ខាងលិចនៃកោះព្រីង កោះត្រល់ និងកោះសេះ និងកត់សម្គាល់ថាកម្លាំងកម្ពុជាប្រជាធិបតេយ្យបានបាញ់ទូកនេសាទថៃ]។ ឯកសារ D1.3.30.2 របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ពី មុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ KH 00021446 [រៀបរាប់ពីស្ថានភាពយោធានៅកោះជាក់លាក់របស់កម្ពុជា ហើយសំដៅទៅការប្រយុទ្ធយ៉ាងធ្ងន់ធ្ងរជាមួយនឹងខ្មាំង]។ ឯកសារ D1.3.12.3 របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ពី មុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ KH 00021461 [រៀបរាប់ស្ថានភាពខ្មាំងនៅទឹកសាប]។ ឯកសារ D1.3.8.3 កំណត់ហេតុនៃអង្គប្រជុំ ការងារយោធា នៅកំពង់សោម ចុះថ្ងៃទី ០៣ ខែសីហា ឆ្នាំ១៩៧៦ KH 00021496-502 [រៀបរាប់ស្ថានភាពខ្មាំង (ថៃ និងវៀតណាម) និងវត្តមាននៃកប៉ាល់នៅដែនទឹកកម្ពុជា។ ការប្រជុំនេះត្រូវបានចូលរួមដោយ ប៉ុល ពត, សុន សេន, វន វេត, មាស មុត, សមមិត្ត ឌឹម និង សមមិត្ត ង៉ែត]។ ឯកសារ D1.3.34.10 សារទូរលេខ ៤៤ ពី មុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ១៩៧៦ KH 00000860 [រៀបរាប់ពីការផ្ទុះប្រដាប់អាវុធជាមួយអ្នកនេសាទថៃនៅកោះកុង និងការចាប់ទូកនេសាទថៃមួយគ្រឿង]។ ឯកសារ D1.3.34.14 សារទូរលេខ ១៥ ពីមិត្ត ឌឹម ជូនបង មុត (មាស មុត) ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៧៦ KH 00000866 [សារទូរលេខរៀបរាប់ពីកប៉ាល់ខ្មាំងចូលដែនសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យ។ ចម្លងជូនមួយច្បាប់ទៅ នួន ជា, សុន សេន, មន្ទីរ និងឯកសារ]។ ឯកសារ D1.3.12.18 សារទូរលេខ ០៩ ពី មុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៧៧ KH 00162487 [សារទូរលេខរៀបរាប់ពីការចាប់ទូកថៃមួយគ្រឿង និងស្ថានភាពតាមព្រំដែនវៀតណាម។ សុន សេន បានបន្ថែមសំណេរដោយដៃនៅខាងក្រោមរបាយការណ៍នេះ និងបានបញ្ជាក់ថា វាបានបញ្ជូនទៅអង្គការហើយ]។ ឯកសារ D1.3.12.20 របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ពី មុត (មាស មុត) ចំណារដោយខៀវ (សុន សេន) ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៧ KH 00020912 [រៀបរាប់ពីការចាប់មនុស្សប្រាំទូកជិតកោះកុង

## លេខាតំបន់ឯករាជ្យកំពង់សោម

70. ក្នុងតួនាទី ជាលេខាតំបន់ឯករាជ្យកំពង់សោម **មាស មុត** រួមទាំងសមាជិកពីររូបទៀតនៃគណៈតំបន់ បានទទួលខុសត្រូវចំពោះរាល់អង្គការចាត់តាំងរដ្ឋបាលទាំងអស់ នៅថ្នាក់តំបន់ ស្រុក និងឃុំ។

71. តំបន់កំពង់សោម ស្ថិតក្នុងដែនដីកម្ពុជាប្រជាធិបតេយ្យជាប់ព្រំប្រទល់ភូមិភាគនិរតី និងភាគបស្ចិម មានផ្ទៃក្រឡាប្រហែល៨០០គីឡូម៉ែត្រការ៉េ[214]។ នៅចុងទិសខាងជើងតំបន់នេះ មានកំពង់ផែស្ទឹងហាវ ព្រំប្រទល់ខាងកើតមានឃុំវាលរេញ ចុងខាងត្បូងមានឃុំរាម ហើយក្រុងកំពង់សោមស្ថិតនៅចុងទិសខាងលិច[215]។ ក្នុងតំបន់នេះ ពីជើងមកត្បូងមានចម្ងាយឆ្ងាយបំផុត៣០គីឡូម៉ែត្រ ហើយ ពីកើតមកលិច មានចម្ងាយ៣៥ គីឡូម៉ែត្រ[216]។

---

សុន សេន បានធ្វើចំណារទៅកាន់អង្គការ ជាមួយនឹងសេចក្ដីសង្ខេបនៃមាតិកានេះ]។ ឯកសារ D1.3.34.23 សារទូរលេខ ២៨ ពី សឿង បានធ្វើចំណារដោយ ខៀវ (សុន សេន) ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៧ KH 00020910 [សុន សេន បានធ្វើការកត់សម្គាល់ថា "តាមស.ម មុត រ/ក ផ្ទាល់មាត់ថា ម្សិលមិញ យើងចាប់ទូកវាមួយ (១៧០ សេះ) នៅកោះកុងក្រៅត្រង់ចុងកោះខាងត្បូង។ (កន្លែងបង និងខ្ញុំចតកប៉ាល់)។ ចាប់ថៃ ៤ និងខ្មែរ១"]។ ឯកសារ D1.3.34.28 សារទូរលេខ ១៤១ ពី ស៊ីម ជូន បង (កងពល) ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៧៧ KH 00161729 [រៀបរាប់ពីការចាប់ទូកនេសាទថៃពីរ។ អ្នកនៅលើទូកមួយចំនួនបានលោតទៅក្នុងទឹកដើម្បីធ្វើការគេចខ្លួន ហើយអ្នកដទៃទៀតត្រូវបានសម្លាប់ចោល។ ចម្លងជូនបង ៨៩ (សុន សេន), មាស មុត, មន្ទីរ និងឯកសារ]។ ឯកសារ D1.3.34.64 ទូរស័ព្ទសម្ងាត់ ពី មាស មុត ជូនបង ៨៩ (សុន សេន) KH 00020982 [រៀបរាប់ពីការវាយប្រហារទៅកាន់ទូកវៀតណាមមួយគ្រឿង ដែលក្រោយមកបានលិច ការចាប់ទូកថៃមួយគ្រឿងជាមួយនឹងមនុស្ស២១នាក់ និងការចាប់ទូកវៀតណាមពីរគ្រឿង និងការចាប់ខ្លួនវៀតណាម ៧៦នាក់]។

214 ការគណនារបស់ការិយាល័យសហព្រះរាជអាជ្ញាផ្អែកលើចំណុចយោងដែលបានផ្ដល់ឲ្យដោយសាក្សីនានា: សូមមើល លេខយោងជើងទំព័រ 215 ខាងក្រោម។

215 សូមមើល ឧបសម្ព័ន្ធ C.2។ ឯកសារ D54/51 កំណត់ហេតុស្ដាប់ចម្លើយ មាស វឿន ឆ.17 ["កងទ័ពជើងទឹកត្រួតត្រាដីគោក ចាប់ពីវាលរេញរហូតដល់កំពង់សោម។ ចំណែកឯលើផ្ទៃសមុទ្រវិញ គឺចាប់ពីកោះរ៉ុង កោះថ្មី កោះព្រីង កោះតាង រហូតដល់កោះពូលូវៃ និងកោះដទៃទៀតដែលខ្ញុំមិនស្គាល់ឈ្មោះ"]។ ឯកសារ D54/104 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.16 ["តំបន់គ្រប់គ្រងរបស់កងពល១៦៤ មានព្រំដែនខាងកើតនៅចំទឹកសាប ខាងជើងនៅស្ទឹងហាវ ខាងលិចគឺសមុទ្រ ហើយនិងកោះមួយចំនួន លើកលែងតែកោះម្នាស់ដែលស្ថិតនៅក្នុងតំបន់១១"]។ ឯកសារ D54/77 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុយ ញិក ឆ.52 ["ខ្ញុំធ្លាប់ឃើញ តា មុត ជិះឡានមកមើលតាមកន្លែងធ្វើការនៅស្ទឹងហាវ"]។ ឯកសារ D114/215 កំណត់ហេតុស្ដាប់ចម្លើយ មាស អ៊ឹម ឆ.39 ["ដើមឆ្នាំ៧៧ បានជួប [មាស មុត] ដូចខ្ញុំកំណត់

72. ពេលមកដល់កំពង់សោម **មាស មុត** ត្រូវបានតែងតាំងជាលេខាតំបន់ ហើយនៅជាបញ្ជាការនៃកងពល៣/១៦៤[217]។ ដោយសារតែកំពង់សោមជាតំបន់ឯករាជ្យ[218] មាស មុត រាយការណ៍ផ្ទាល់ទៅ

---

អ៊ីចឹង នៅស្ទឹងហាវ គាត់មកមួយអាទិត្យម្តង"]។ សូមមើលផងដែរនូវ ការរាយការណ៍របស់ មាស មុត លើតំបន់ក្រោមការត្រួតត្រារបស់គាត់: D1.3.12.3 របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ពី មុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ KH 00021461 [របាយការណ៍ពី មាស មុត ជូនបង ៨៩ (សុន សេន) រៀបរាប់ពីស្ថានភាពនៅខាងនិរតីនៃកោះសេះ នៅខាងលិច និងខាងជើងនៃវាលរេញ]។ ឯកសារ D1.3.8.3 កំណត់ហេតុនៃអង្គប្រជុំ ការងារយោធា នៅកំពង់សោម ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៧៦ KH 00021496 [មាស មុត បានបង្ហាញពីការដាក់ពង្រាយកងកម្លាំងប្រដាប់អាវុធនៅក្រុងកំពង់សោម រាម កងកេង និងនៅលើកោះមួយចំនួនដូចជា កោះរ៉ៃ កោះតាំង កោះព្រីង កោះរ៉ុង និងកោះសេះ]។ ឯកសារ D1.3.34.10 សារទូរលេខ ៤៤ ពី មុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៧៦ KH 00000860 [មាស មុត រាយការណ៍ពីស្ថានភាពនៅកោះតាំង កោះធំ កោះស្តេច និងកំពង់សោម]។ ឯកសារ D1.3.14.2 សារទូរលេខ ៤៣ ពី មឿន ជូនបង មុត (មាស មុត) ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៧៧ KH 00161788-89 [មាស មុត ទទួលសារទូរលេខមួយរៀបរាប់អំពីស្ថានភាពខ្មាំងនៅអូរ ឈើទាល]។

216 ការគណនារបស់ការិយាល័យសហព្រះរាជអាជ្ញាផ្អែកលើចំណុចយោងដែលបានផ្តល់ឲ្យដោយសាក្សីនានា: សូមមើលលេខយោងជើងទំព័រ 215 ខាងលើ។

217 ឯកសារ D114/159 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ឆ.10 ["បងមុត លេខាកងពល១៦៤ ដែលជាកងពលសមុទ្រ និងជាលេខាតំបន់ពិសេសកំពង់សោម។ មានភូមិមួយចំនួននៅជុំវិញផែកំពង់សោម ហើយវាមានគណៈកម្មាធិការផែវាមួយដោយឡែកទៀត។ ទាំងភូមិ ទាំងផែនេះ វានៅក្នុងការគ្រប់គ្រងរបស់បងមុត"]។ ឯកសារ D114/29.1.4 ប៊ែន ឃៀរនិន, សៀវភៅមានចំណងជើងថា៖ របប ប៉ុល ពត KH 00637491 ["[ប្រហែលឆ្នាំ១៩៧៥ មាស] មុត បានកាន់ទីបញ្ជាការកងពលធំលេខ៣ ភូមិភាគនិរតី ហើយក៏បានក្លាយជាលេខាបក្សក្រុងកំពង់សោម និងមេបញ្ជាការកងទ័ពជើងទឹកនៃរបបកម្ពុជាប្រជាធិបតេយ្យទៀតផង"]។ ឯកសារ D4.1.1030 បទសម្ភាសន៍ជាមួយ ចាប ឡុញ (US POW/MIA) EN 00526844 ["មុត លេខាគណៈកម្មាធិការកំពង់សោម ស្នងការនយោបាយនៃកងទ័ពជើងទឹកនៃរបបកម្ពុជាប្រជាធិបតេយ្យ"]។ ឯកសារ D1.3.30.29 គណៈកម្មាធិការ Ishiyama បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ KH 00324722-23 [លេខ ១៨ ប្រភព: បុរសម្នាក់មកពីតំបន់១៣ (តាកែវ) ក្នុងប៉ែកនិរតី ដែលទំនងជាមនុស្សរបស់បក្ស: "កាលដើមឡើយ អនុលេខាចាប់ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៣ គឺ តា មុត។ បន្ទាប់មកគាត់ក៏បានក្លាយជាលេខាកងពលធំទី៣ ក្នុងភូមិភាគនិរតី។ តំបន់ប្រតិបត្តិការរបស់គាត់គឺ នៅតាមផ្លូវជាតិលេខ៤។ គាត់គឺជាលេខាកងពលធំរហូតដល់កងទ័ពវៀតណាមបានចូលមកដល់។ ក្នុងឆ្នាំ១៩៧៥ គាត់ក៏បានកាន់តួនាទីជាលេខាក្រុងកំពង់សោមផងដែរ។ គាត់ទទួលបន្ទុកក្រុងកំពង់សោមទាំងមូល។ គាត់ក៏ទទួលបន្ទុកទ័ពជើងទឹកផងដែរ"]។ សូមមើលផងដែរនូវ ឯកសារ D22.1.10 (ហ្វ៊ីប៊ីស) សេវាផ្សាយសារព័ត៌មានបរទេស គណៈប្រតិភូចិន ធ្វើទស្សនកិច្ចនៅតំបន់កំពង់សោម ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH 01194843 ["នៅទីនោះ Chen Yung-kuei និងសមមិត្តដទៃទៀត ត្រូវបានទទួលស្វាគមន៍ដោយសមមិត្ត មុត លេខាបក្សកុម្មុយនីស្តកម្ពុជាក្រុងកំពង់

គណៈកម្មាធិការអចិន្ត្រៃយ៍តាមរយៈមន្ទីរ៨៧០[219]។ សមាជិកពីររូបទៀតនៃគណៈកម្មាធិការតំបន់ ឈ្មោះ ជា គ្រិន អនុលេខារបស់ មាស មុត និង ឈ្មោះ តា ឡូញ[220]។ ជាពិសេស គ្រិន មាននាទី

---

សោម និងជាប្រធានគណៈកម្មាធិការបម្រើប្រជាជនក្រុងកំពង់សោម"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.11 ["ខ្ញុំបានឮថា គាត់ [មាស មុត] ជាលេខាបក្សកំពង់សោម"]។ ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.28-30 ឆ.33 ["ស៖ នៅក្នុងទំព័រដំបូងនៃឯកសារ [D22.1.10, KH 01194843, 01063905] មាស មុត គឺជាលេខាបក្សកុម្មុយនីស្តកម្ពុជាក្រុងកំពង់សោម ហើយនៅទំព័រទី២ មាស មុត គឺជាគណៈបក្សក្រុងកំពង់សោមបក្សកុម្មុយនីស្តកម្ពុជា។ តើលោកអាចពន្យល់ប្រាប់យើងបានដែរឬទេ? ឆ.28៖ តាមខ្ញុំយល់ ពាក្យដែលត្រឹមត្រូវ គឺ លេខាគណៈបក្សកុម្មុយនីស្តកម្ពុជាក្នុងកំពង់សោម។ ស៖ តាមការយល់ដឹងរបស់លោក តើ មាស មុត គាត់ទទួលខុសត្រូវអ្វីខ្លះ ក្នុងតួនាទីជាលេខាបក្សកុម្មុយនីស្តកម្ពុជាក្រុងកំពង់សោម? ឆ.29៖ ខ្ញុំមិនដឹងពីតួនាទីរបស់គាត់ទេ នៅពេលដែលគាត់ជាលេខាបក្សក្រុងកំពង់សោមនេះទេ។ ស៖ តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការផ្ទេរអង្គភាពរបស់លោកពីកងពលលេខ៣ ទៅនៅក្រោមការគ្រប់គ្រងរបស់ គ្រិន? ឆ.30៖ ខ្ញុំមិនដឹងទេ តែទោះយ៉ាងណា ក្រៅពី គ្រិន និង មាស មុត មិនមានអ្នកណាផ្សេងអាចធ្វើដូច្នេះបានឡើយ។ [...] ឆ.33៖ មាស មុត ទទួលខុសត្រូវខាងយោធា ហើយ គ្រិន ទទួលខុសត្រូវខាងស៊ីវិល កម្មករនៅផែ។ មាស មុត ជាតំណាងបក្សកុម្មុយនីស្តកម្ពុជានៅកំពង់សោម ចំណែកឯ គ្រិន ជាអនុលេខា"]។ ឯកសារ D114/91 កំណត់ហេតុស្តាប់ចម្លើយ សេង អុល ឆ.361 ["ខ្ញុំឮតាមុត [មាស មុត] ជាអ្នកកាន់នៅកំពង់សោម"]។

218 ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.30 ["ខ្ញុំដឹងថាតំបន់កំពង់សោមជាតំបន់ស្វយ័ត ដោយសារ ខ្ញុំចូលរួមកិច្ចប្រជុំកងវរសេនាធំ និងកិច្ចប្រជុំផ្ទៃក្នុងរបស់បក្សជន។ កម្មករចម្ការកៅស៊ូ កម្មករកំពង់ផែ ទាហាននៅកំពង់សោមទាំងអស់សុទ្ធតែដឹងថាតំបន់កំពង់សោមជាតំបន់ស្វយ័ត ដោយសារព័ត៌មាននេះត្រូវបានគេផ្សព្វផ្សាយយ៉ាងទូលំទូលាយ"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.9 ["តំបន់ទឹកដីដែលស្ថិតនៅក្រោមបញ្ជារបស់ មាស មុត លាតសន្ធឹងតាំងពីទឹកសាប កងកេង រាម កំពង់សោម ហើយនិងកោះទាំងអស់នៅក្នុងសមុទ្រ។ កន្លែងតំបន់ទាំងអស់នេះ គឺហៅថាតំបន់ស្វយ័តដែលស្ថិតនៅក្រោមអំណាចរបស់ មាស មុត"]។ ឯកសារ D54/99.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ KH 00990786 ["ស៖ បាទ! ខាងកំពង់សោមហ្នឹងពីណាគេអ្នកគ្រប់គ្រងទូទៅម៉ងជាផ្នែករដ្ឋបាល? ឆ៖ [...] តំបន់ស្វ័យត្យមានការគ្រប់គ្រងខុសគ្នាអញ្ចឹងណា"]។

219 ឯកសារ D1.3.22.1 លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦ មាត្រា៨ ["ចំពោះតំបន់ណា ឬអង្គការណា ដែលមានលក្ខណៈពិសេស ខាងនយោបាយក្តី ខាងយោធាក្តី ខាងសេដ្ឋកិច្ចក្តី ខាងវប្បធម៌-សង្គមកិច្ចក្តី អាចចាត់តាំងជាផ្នែកដោយឡែក ដោយគណៈកម្មាធិការមជ្ឈិម ទទួលភារៈដឹកនាំដោយផ្ទាល់ ឬដោយប្រយោល តាមខ្សែចាត់តាំងជាក់ស្តែង។"] មាត្រា១៥ ["គណៈកម្មាធិការតំបន់-ក្រុង ត្រូវធ្វើសន្និបាត តំណាងតំបន់-ក្រុង ជាសាមញ្ញ ៦ខែម្តង ដើម្បី៖ ១ - ពិនិត្យ តាមដាន និងវិនិច្ឆ័យ សកម្មភាពរបស់តំបន់-ក្រុង ដោយដកពិសោធន៍ រកគុណសម្បត្តិ និងគុណវិបត្តិ ឱយច្បាស់លាស់ និងជ្រៅជ្រះ។ ២ - កំណត់ការងារថ្មី តាមមាគ៌ានយោបាយរបស់បក្ស។ ត្រូវកំណត់ផែនការ ការងារក្នុងមហាជន ឱយច្បាស់ និងការងារផ្ទៃក្នុងឱយច្បាស់ ក្នុងក្របខណ្ឌតំបន់-ក្រុងរបស់ខ្លួន។ ៣ - ជ្រើសតាំងអង្គការ

ដឹកនាំថ្មី ជាគណៈកម្មាធិការតំបន់-គណៈកម្មាធិការក្រុង។ (ឈរលើលក្ខណៈសម្បត្តិ១០យ៉ាងរបស់បក្ស ហើយត្រូវគណៈកម្មាធិការភូមិភាគ និងគណៈកម្មាធិការមជ្ឈិម ពិនិត្យ វិនិច្ឆ័យ និងយល់ព្រម ទើបបានការ)"] មាត្រា ១៦ ["ភារកិច្ចរបស់គណៈកម្មាធិការតំបន់-ក្រុង៖ ភារកិច្ចរបស់គណៈកម្មាធិការតំបន់-ក្រុងគឺ៖ ១ - ចុះជាប់ស្រុក សាខា និងមូលដ្ឋានជាក់ស្តែងរបស់សាខា ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្ត ដើម្បីដឹកនាំអនុវត្តភារកិច្ច ក្នុងមហាជន និងផ្ទៃក្នុង ឱយសកម្ម ក្តៅជាប់ ជាផែនការ តាមភារកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជាប្រជាធិបតេយ្យ និងតាមទិសបដិវត្តសង្គមនិយម និងការកសាងសង្គមនិយមរបស់បក្ស។ ២ - ក្តាប់មហាជន ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្ត ក្នុងក្របខណ្ឌតំបន់-ក្រុងរបស់ខ្លួន ឱយជាប់ និងឱយណែនជានិច្ច ខាងនយោបាយ សតិអារម្មណ៍ ចាត់តាំងដោយអប់រំបំពាក់បំប៉នគេ ខាងនយោបាយ សតិអារម្មណ៍ ចាត់តាំង ឱយជាប់ជានិច្ច តាមភារកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជា ប្រជាធិបតេយ្យ និងតាមទិសបដិវត្តសង្គមនិយម និងការកសាងសង្គមនិយម របស់បក្ស។ […] ៣ - ក្តាប់អង្គការស្រុក អង្គការសាខា កម្មាភិបាលបក្ខជន និងអង្គការស្នូលទាំងអស់ ក្នុងតំបន់ ខាងប្រវត្តិរូប ខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង ហើយអប់រំបំពាក់បំប៉នគេ ខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង ជាប់ជានិច្ច តាមភារកិច្ចការពារប្រទេស និងកសាងប្រទេសកម្ពុជា ប្រជាធិបតេយ្យ និងតាមទិសបដិវត្តសង្គមនិយម និងការកសាងសង្គមនិយម របស់បក្ស។ ៤ - កាន់កាប់ទ្រព្យសម្បត្តិរបស់អង្គការតំបន់-ក្រុង អនុវត្តវិន័យក្នុងក្របខណ្ឌតំបន់-ក្រុង មានរបបរាយការណ៍ អំពីស្ថានការណ៍ និងការងាររបស់តំបន់-ក្រុង ជូនថ្នាក់លើ"] មាត្រា ១៧ ["គណៈកម្មាធិការតំបន់-ក្រុង ត្រូវប្រជុំជាសាមញ្ញ ១ខែម្តង ដើម្បីពិនិត្យ តាមដាន វិនិច្ឆ័យ ការងារចាស់ និងលើកការងារថ្មី"]។

220 ឯកសារ D22.1.10 (ហ្វ៊ីប៊ីស) សេវាផ្សាយសារព័ត៌មានបរទេស គណៈប្រតិភូចិន ធ្វើទស្សនកិច្ចនៅតំបន់កំពង់សោម ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH 01194843 ["នៅទីនោះ Chen Yung-kuei និងសមមិត្តដទៃទៀត ត្រូវបានទទួលស្វាគមន៍ដោយសមមិត្ត មុត លេខាបក្សកុម្មុយនីស្តកម្ពុជាក្រុងកំពង់សោម និងជាប្រធានគណៈកម្មាធិការបម្រើប្រជាជនក្រុងកំពង់សោម សមមិត្ត គ្រិន អនុលេខាបក្សកុម្មុយនីស្តកម្ពុជាក្រុងកំពង់សោម សមមិត្ត ឡាញ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាក្រុងកំពង់សោម កម្មាភិបាលថ្នាក់ភូមិភាគ ថ្នាក់តំបន់ និងថ្នាក់ស្រុក និងកម្មាភិបាលមកពីមន្ទីរ និងការិយាល័យនានា"]។ ឯកសារ D114/266.1.2 បញ្ជីភ្ជាប់ទៅនឹងឯកសាររុស្ស៊ី ខែ តុលា ឆ្នាំ ១៩៧៧ KH 01509098 [ចុះបញ្ជី មុត គ្រិន លុន ជាលេខ អនុលេខា និងសមាជិកនៃបក្សកុម្មុយនីស្តកម្ពុជានៅកំពង់សោម]។ ឯកសារ D54/31 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.10-12 ["មាស មុត ជា គ្រិន តាឡាញ គឺជាគណៈកម្មាការមជ្ឈិមនៅកំពង់សោម។ មាស មុត ទទួលខុសត្រូវខាងយោធា ហើយ ជា គ្រិន ទទួលខុសត្រូវខាងកំពង់ផែ និងរោងចក្រប្រេងកាត ឯ ឡាញ ទទួលខុសត្រូវខាងនេសាទ។ ស៖ សូមលោករៀបរាប់អំពីឋានានុក្រមគណៈកម្មការ មាស មុត ជា គ្រិន និង ឡាញ? ឆ.11៖ មាស មុត គឺជាប្រធានធំជាងគេ បន្ទាប់មក ជា គ្រិន និង ឡាញ។ ស៖ តើការបែងចែកការទទួលខុសត្រូវយ៉ាងម៉េចខ្លះ? ឆ.12៖ គេត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវមុខងារផ្សេងៗគ្នា ប៉ុន្តែឋិតនៅក្រោមការគ្រប់គ្រងរបស់ មាស មុត។ មាស មុត គឺទទួលខុសត្រូវរួមទាំងអស់ ហើយរួមទាំងផ្ទៃសមុទ្រផង"]។ ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.29-30 ឆ.33 ["ស៖ តាមការយល់ដឹងរបស់លោក តើ មាស មុត គាត់ទទួលខុសត្រូវអ្វីខ្លះ ក្នុងតួនាទីជាលេខាបក្សកុម្មុយនីស្តកម្ពុជាក្រុងកំពង់សោម? ឆ.29៖ ខ្ញុំមិនដឹងពីតួនាទីរបស់គាត់ទេ នៅពេលដែលគាត់ជាលេខាបក្សក្រុងកំពង់សោមនេះទេ។ ស៖ តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការផ្ទេរអង្គភាពរបស់លោកពីកងពលលេខ៣ ទៅនៅក្រោមការគ្រប់គ្រងរបស់ គ្រិន? ឆ.30៖ ខ្ញុំមិនដឹងទេ តែទោះយ៉ាងណា ក្រៅ

គ្រប់គ្រងខាងផែកំពង់សោម ហើយ ឡូញ គ្រប់គ្រងខាងភស្តុភារ[221]។ យោងតាមឋានៈជាសមាជិក នៃគណៈកម្មាធិការតំបន់ បក្សកុម្មុយនីស្តកម្ពុជាដាក់កាតព្វកិច្ចឲ្យ **មាស មុត**, ជា គ្រិន និង តា ឡូញ ត្រូវតែដឹកនាំជាសមូហភាព ដោយស្របទៅតាមការទទួលខុសត្រូវរបស់បុគ្គលរៀ

ពី គ្រិន និង មាស មុត មិនមានអ្នកណាផ្សេងអាចធ្វើដូច្នេះបានឡើយ។ [...] ឆ.33៖ មាស មុត ទទួលខុសត្រូវខាងយោធា ហើយ គ្រិន ទទួលខុសត្រូវខាងស៊ីវិល កម្មករនៅផែ។ មាស មុត ជាតំណាងបក្សកុម្មុយនីស្តកម្ពុជានៅកំពង់សោម ចំណែកឯ គ្រិន ជាអនុលេខា"]។ ឯកសារ D54/30.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH 00964128 ["តាឡូញ ប្រធាននេសាទ អារឿងកាលពីគណៈដឹកនាំដែលក្រោយពីចាប់លោក ខឹម ទៅនោះ គឺអ្នកដឹកនាំគ្រប់គ្រងក្នុងបរិវេណក្នុងកំពង់សោមទាំងមូលហ្នឹង គឺមាន៣រូប មាន មាស មុត មាន តាឡូញ ហើយនិង ជា គ្រិន"]។ ឯកសារ D59/2/2.16a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH 00735596 ["អារឿងកាលពីគណៈដឹកនាំដែលក្រោយពីចាប់លោក ខឹម ទៅនោះគឺអ្នកដឹកនាំគ្រប់គ្រងក្នុងបរិវេណក្នុងកំពង់សោមទាំងមូលហ្នឹង គឺមាន៣រូប មាន មាស មុត មាន តាឡូញ ហើយនិង ជា គ្រិន"] KH 00735605 ["ចុះបើគាត់ [មាស មុត] ផ្តាច់មុខអស់ហើយ ដោយឡែកតែក្នុងជើងគណៈកម្មាហ្នឹងបានវានៅជាប់គណៈកម្មា ឧទាហរណ៍ថាមាន មាស មុត មាន ជា គ្រិន និងមាន តាឡូញ មាន៣នាក់ហ្នឹង ហើយ៣នាក់ហ្នឹងជាជើងគណៈកម្មាសម្រាប់មួយកំពង់សោមហ្នឹង ប៉ុន្តែគ្រាន់តែផ្នែកគ្រប់គ្រង ផ្នែកដឹកនាំអង្គភាពដាច់ៗពីគ្នា ជា គ្រិន ហ្នឹងគាត់ខាងជីវកសហាគ្រាសទៅ ឯខាង មាស មុត ខាងយោធា ហើយ តាឡូញ នោះគាត់ខាងនេសាទផ្គត់ផ្គង់សម្រាប់អង្គភាពរដ្ឋទៅ អាហ្នឹងវាមានផ្នែកខុសគ្នាអញ្ចឹងទៅ តែបើមានផែនការណ៍អីគឺក្នុងជើងគណៈកម្មារបស់គាត់ត្រូវតែមានការពិគ្រោះគ្នា"]។

221 ឯកសារ D54/31 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.10 ["មាស មុត ជា គ្រិន តាឡូញ គឺជាគណៈកម្មាការមជ្ឈិមនៅកំពង់សោម។ មាស មុត ទទួលខុសត្រូវខាងយោធា ហើយ ជា គ្រិន ទទួលខុសត្រូវខាងកំពង់ផែ និងរោងចក្រប្រេងកាត ឯ ឡូញ ទទួលខុសត្រូវខាងនេសាទ"]។ ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.33 ["មាស មុត ទទួលខុសត្រូវខាងយោធា ហើយ គ្រិន ទទួលខុសត្រូវខាងស៊ីវិល កម្មករនៅផែ"]។ ឯកសារ D54/30.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH 00964128 ["តាឡូញ ប្រធាននេសាទ"]។ ឯកសារ D59/2/2.16a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH 00735596 ["អារឿងកាលពីគណៈដឹកនាំដែលក្រោយពីចាប់លោក ខឹម ទៅនោះគឺអ្នកដឹកនាំគ្រប់គ្រងក្នុងបរិវេណក្នុងកំពង់សោមទាំងមូលហ្នឹង គឺមាន៣រូប មាន មាស មុត មាន តាឡូញ ហើយនិង ជា គ្រិន"] KH 00735605 ["ចុះបើគាត់ផ្តាច់មុខអស់ហើយ ដោយឡែកតែក្នុងជើងគណៈកម្មាហ្នឹងបានវានៅជាប់គណៈកម្មា ឧទាហរណ៍ថាមាន មាស មុត មាន ជា គ្រិន និងមាន តាឡូញ មាន៣នាក់ហ្នឹង ហើយ៣នាក់ហ្នឹងជាជើងគណៈកម្មាសម្រាប់មួយកំពង់សោមហ្នឹង ប៉ុន្តែគ្រាន់តែផ្នែកគ្រប់គ្រង ផ្នែកដឹកនាំអង្គភាពដាច់ៗពីគ្នា ជា គ្រិន ហ្នឹងគាត់ខាងជីវកសហាគ្រាសទៅ ឯខាង មាស មុត ខាងយោធា ហើយ តាឡូញ នោះគាត់ខាងនេសាទផ្គត់ផ្គង់សម្រាប់អង្គភាពរដ្ឋទៅ អាហ្នឹងវាមានផ្នែកខុសគ្នាអញ្ចឹងទៅ តែបើមានផែនការណ៍អីគឺក្នុងជើងគណៈកម្មារបស់គាត់ត្រូវតែមានការពិគ្រោះគ្នា"]។

ង១ខ្លួន[222]។ ដូចនេះ ពួកគេ មានកាតព្វកិច្ចត្រូវចូលរួមប្រជុំនានា ហើយបញ្ចេញយោបល់របស់ខ្លួនលើបញ្ហាផ្សេងៗទាក់ទងនឹងតំបន់[223]។

73. តួនាទីជាលេខាតំបន់ និងអំណាចរបស់ មាស មុត ក្នុងការគ្រប់គ្រងរដ្ឋបាលបានប្រកាសដោយមជ្ឈិមបក្ស ក្នុងការប្រកាសសាធារណៈ នៅថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៧៧ ដែលបានផ្សាយថា

---

222 ឯកសារ D234/2.1.27 ទស្សនាវដ្តីទង់បដិវត្ត ចេញខែ កញ្ញា-តុលា ឆ្នាំ ១៩៧២ KH 00442297 ["ន័យសំខាន់នៃប្រជាធិបតេយ្យប្រមូលផ្តុំ គឺសមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវដោយឡែក"] KH 00442308 ["ត្រូវវិភាគគ្រប់បញ្ហាជាសមូហភាព ដើម្បីឃើញគ្រប់ជ្រុងជ្រោយគ្រប់ទិដ្ឋភាព ស្រួល និងលំបាក"] KH 00442323 ["ផែនការ ត្រូវលើកឡើងដោយសមូហភាព និងតាមប្រជាធិបតេយ្យប្រមូលផ្តុំ"]។ ឯកសារ D4.1.887 ទស្សនាវដ្តីទង់បដិវត្ត ចេញខែ វិច្ឆិកា ឆ្នាំ ១៩៧៦ KH 00064991-92 ["ទី១៖ សំរេចតែម្នាក់ឯង គឺឈរលើគោលការណ៍ ដែលបានសំរេចជាសមូហភាព។ ទី២៖ សំរេចដោយពិគ្រោះពិភាក្សា ក្នុងក្របខ័ណ្ឌ អង្គការចាត់តាំងនៃគណៈកម្មាធិការ ឬបើធំជាងនេះទៅទៀត យើងសំរេចក្នុងសន្និបាតអង្គការចាត់តាំងពេញអង្គ ក្នុងគណៈកម្មាធិការពេញអង្គ ឬក៏ស្មើមតិខាងលើ។ នេះគឺជានិស្ស័យសមូហភាពដឹកនាំ ដោយឡែកទទួលខុសត្រូវ"]។ ឯកសារ D234/2.1.19 សារាចរររបស់បក្សកុម្មុយនីស្តកម្ពុជា៖ តើសតិអារម្មណ៍អង្គការ និងវិន័យរបស់បក្សយ៉ាងណា? ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ KH 00442058 ["ប្រមូលផ្តុំខាងមតិ៖ សន្និបាត អនុមតិ សេចក្តីសំរេច។ ទាំងអស់គ្នា ត្រូវគោរព ត្រូវប្រតិបត្តិតាមជាដាច់ខាត ទោះជាខ្លួនមានមតិតវ៉ា ឬប្រឆាំងនឹងភាគច្រើនក៏ដោយ។ នេះជាសមូហភាពព្រោះសេចក្តីសំរេច អនុលោមលក្ខការភាគតិច គោរពភាគច្រើន"]។ ឯកសារ D98/3.1.160 នួន ជា ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ នៅម៉ោង 10.57.18-11.01.42 ["គ្រប់ៗការសម្រេចផ្សេងរបស់បក្សត្រូវធ្វើឡើងដោយសមូហភាព បានន័យថា ការសម្រេចអ្វីៗទាំងអស់របស់បក្សត្រូវរួមគ្នាសម្រេច មិនមែនបុគ្គលសម្រេចទេ [...] គ្រប់ការចាត់តាំងរបស់បក្សត្រូវអនុវត្តតាមគោលការណ៍នេះទាំងអស់"] នៅម៉ោង 10.58.59 ["សូមជម្រាបលោកប្រធាន! ប្រជាធិបតេយ្យប្រមូលផ្តុំនេះ ក៏វាផ្នែកមួយនៃសមូហភាពដឹកនាំដែរ។ ឯសមូហភាពដឹកនាំ ក៏វាជាផ្នែកមួយនៃប្រជាធិបតេយ្យប្រមូលផ្តុំដែរ"]។

223 ឯកសារ D98/3.1.160 នួន ជា ប្រតិចារឹក ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ នៅម៉ោង 11.02.32-11.04.47 [""សមូហភាព" បានន័យថា ប្រជុំរួមគ្នាទាំងអស់ មានមតិជាប្រជាធិបតេយ្យប្រមូលផ្តុំ ប្រជុំអីក៏អ៊ីចឹងដែរ។ មិនមែនត្រឹមតែប្រជុំមជ្ឈិម ប្រជុំអចិន្ត្រៃយ៍ទេ"]។ សូមមើលផងដែរនូវ ឯកសារ D59/2/2.16a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH 00735596 ["អារឿងកាលពីគណៈដឹកនាំដែលក្រោយពីចាប់លោក ឌឹម ទៅនោះគឺអ្នកដឹកនាំគ្រប់គ្រងក្នុងបរិវេណក្នុងកំពង់សោមទាំងមូលហ្នឹង គឺមាន៣រូប មាន មាស មុត មាន តាឡូញ ហើយនិង ជា គ្រិន"] KH 00735605 ["ចុះបើគាត់ផ្តាច់មុខអស់ហើយ ដោយឡែកតែក្នុងជើងគណៈកម្មាហ្នឹងបានវានៅជាប់គណៈកម្មាឧទាហរណ៍ថាមាន មាស មុត មាន ជា គ្រិន និងមាន តាឡូញ មាន៣នាក់ហ្នឹង ហើយ៣នាក់ហ្នឹងជាជើងគណៈកម្មាសម្រាប់មួយកំពង់សោមហ្នឹង ប៉ុន្តែគ្រាន់តែផ្នែកគ្រប់គ្រង ផ្នែកដឹកនាំអង្គភាពដាច់ៗពីគ្នា ជា គ្រិន ហ្នឹងគាត់ខាងសហគ្រាសទៅ ឯខាង មាស មុត ខាងយោធា ហើយ តាឡូញ នោះគាត់ខាងនេសាទផ្គត់ផ្គង់សម្រាប់អង្គភាពរដ្ឋទៅ អាហ្នឹងវាមានផ្នែកខុសគ្នាអញ្ចឹងទៅ តែបើមានផែនការណ៍អីគឺក្នុងជើងគណៈកម្មារបស់គាត់ត្រូវតែមានការពិគ្រោះគ្នា"]។

មាស មុត គឺជា "លេខាគណៈកម្មាធិការបក្សក្រុងកំពង់សោមនៃបក្សកុម្មុយនីស្តកម្ពុជា និងប្រធានគណៈកម្មាធិការបម្រើប្រជាជនក្រុងកំពង់សោម"។ ការប្រកាសផ្សាយនេះក៏បានលើកឡើងឈ្មោះសមាជិកពីរនាក់ទៀត គឺ គ្រិន និង ឡូញ ថា "សមមិត្ត (គ្រិន) អនុប្រធានគណៈកម្មាធិការបម្រើប្រជាជន ក្រុងកំពង់សោម"[224]។

74. ការប្រកាសនេះ ផ្សាយថា មាស មុត, គ្រិន, និង ឡូញ កំពុងធ្វើបដិសណ្ឋារកិច្ចគណៈប្រតិភូចិន ដែលមាន ប៉ុល ពត និង អៀង សារី អមដំណើរមកក្រុងកំពង់សោម នៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៧៧។ ក្នុងកិច្ចតែមួយទាំងអស់គ្នា សមាជិកគណៈកម្មាធិការបានជូនភ្ញៀវទស្សនៈកិច្ចបណ្តាកោះនានា ក្នុងដែនទឹកនៃកម្ពុជាប្រជាធិបតេយ្យ ហើយបានរៀបចំ "ពិធីជប់លាងយ៉ាងអធិកអធម" ដែលក្នុងនោះ មាស មុត បានស្វាគមន៍ចំពោះ "ភាតរភាពបដិវត្តមហាអស្ចារ្យ និងសាមគ្គីភាពយោធាមហាអស្ចារ្យរវាងបក្សប្រជាជន និងប្រទេសទាំងពីរ"[225]។

---

224 ឯកសារ D22.1.10 (ហ្វ៊ីប៊ីស) សេវាផ្សាយសារព័ត៌មានបរទេស គណៈប្រតិភូចិន ធ្វើទស្សនកិច្ចនៅតំបន់កំពង់សោម ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH 01194843 ["កាលពីព្រឹកថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៧ សមមិត្ត Chen Yung-kuei សមាជិកការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន និងជាឧបនាយករដ្ឋមន្ត្រីនៃក្រុមប្រឹក្សារដ្ឋ និងសមមិត្តចិនដទៃទៀត បានធ្វើទស្សនកិច្ចនៅក្រុងកំពង់សោម។ ពួកគាត់ ត្រូវបានរួមដំណើរដោយសមមិត្ត ប៉ុល ពត លេខាបក្សកុម្មុយនីស្តកម្ពុជា និងជានាយករដ្ឋមន្ត្រី និងសមមិត្ត អៀង សារី និង ជួន ជឿន។ នៅទីនោះ Chen Yung-kuei និងសមមិត្តដទៃទៀត ត្រូវបានទទួលស្វាគមន៍ដោយសមមិត្ត មុត លេខាបក្សកុម្មុយនីស្តកម្ពុជាក្រុងកំពង់សោម និងជាប្រធានគណៈកម្មាធិការបម្រើប្រជាជនក្រុងកំពង់សោម សមមិត្ត គ្រិន អនុលេខាបក្សកុម្មុយនីស្តកម្ពុជាក្រុងកំពង់សោម សមមិត្ត ឡូញ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាក្រុងកំពង់សោម"]។

225 ឯកសារ D22.1.10 (ហ្វ៊ីប៊ីស) សេវាផ្សាយសារព័ត៌មានបរទេស គណៈប្រតិភូចិន ធ្វើទស្សនកិច្ចនៅតំបន់កំពង់សោម ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH 01194843-44 ["កាលពីព្រឹកថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៧៧ សមមិត្ត Chen Yung-kuei សមាជិកការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន និងជាឧបនាយករដ្ឋមន្ត្រីនៃក្រុមប្រឹក្សារដ្ឋ និងសមមិត្តចិនដទៃទៀត បានធ្វើទស្សនកិច្ចនៅក្រុងកំពង់សោម។ ពួកគាត់ត្រូវបានរួមដំណើរដោយសមមិត្ត ប៉ុល ពត លេខាបក្សកុម្មុយនីស្តកម្ពុជា និងជានាយករដ្ឋមន្ត្រី និងសមមិត្ត អៀង សារី និង ជួន ជឿន។ នៅទីនោះ Chen Yung-kuei និងសមមិត្តដទៃទៀត ត្រូវបានទទួលស្វាគមន៍ដោយសមមិត្ត មុត លេខាបក្សកុម្មុយនីស្តកម្ពុជាក្រុងកំពង់សោម និងជាប្រធានគណៈកម្មាធិការបម្រើប្រជាជនក្រុងកំពង់សោម សមមិត្ត គ្រិន អនុលេខាបក្សកុម្មុយនីស្តកម្ពុជាក្រុងកំពង់សោម សមមិត្ត ឡូញ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាក្រុងកំពង់សោម កម្មាភិបាលថ្នាក់ភូមិភាគ ថ្នាក់តំបន់ និងថ្នាក់ស្រុក និងកម្មាភិបាលមកពីមន្ទីរ និងការិយាល័យនានា។ [...] នៅពេលរសៀល ថ្ងៃដដែលនោះ សមមិត្ត Chen Yung-kuei និងសមមិត្តចិនដទៃទៀត រួមដំណើរដោយលេខាគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា សមមិត្ត អៀង សារី, ជួន ជឿន, មុត, គ្រិន និង ឡូញ បានធ្វើដំណើរតាមនាវា ទៅទ

75. ឌុច បានផ្តល់សក្ខីកម្មចំពោះមុខសហចៅក្រមស៊ើបអង្កេត ថា មាស មុត គឺជា "លេខាតំបន់ពិសេសកំពង់សោម"[226] ហើយជា "ប្រធានគណៈកម្មាធិការក្រុងកំពង់សោម"[227] ព្រមទាំងថា "ភូមិទាំងឡាយ [ជុំវិញកំពង់សោម] និងកំពង់ផែ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ បង មុត"[228]។ ប៉ាក សុក ក៏បានបញ្ជាក់ដែរថា មាស មុត "គ្រប់គ្រងទូទៅនៅកំពង់សោមទាំងមូល ទាំងកងទ័ព ទាំងកម្មករ និងទាំងកំពង់ផែ"[229]។ អំណាចរបស់ មាស មុត លើតំបន់កំពង់សោមទាំងមូលបានបង្ហាញបន្ថែម តាមរយៈការតែងតាំងមេបញ្ជាការឋានៈខ្ពស់ៗនៃកងពល ១៦៤ ឡុង សារឿន ជាប្រធាន និង សុក ភាព ជាអនុប្រធាននៃកំពង់ផែកំពង់សោម បន្ទាប់ពី គ្រិន បានទទួលការចាត់តាំងទៅហុងកុង នៅក្នុង ឬប្រហែលខែ កុម្ភៈ ឆ្នាំ ១៩៧៨[230]។

---

ស្សនាកោះមួយចំនួននៅក្នុងដែនទឹកកម្ពុជា។ សមមិត្តចិនរបស់យើង ក៏បានទស្សនាកន្លែងសាងសង់នាវានៅកំពង់សោម។ [...] នៅល្ងាចថ្ងៃទី១២ ខែធ្នូ គណៈកម្មាធិការបក្សកុម្មុយនីស្តកម្ពុជាក្រុងកំពង់សោម និងគណៈកម្មាធិការបម្រើប្រជាជនក្រុងកំពង់សោម បានរៀបចំពិធីលៀងសាយភោជន៍ដ៏អធិកអធមមួយ ដែលជាការផ្តល់កិត្តិយលជូនសមមិត្ត Chen Yung-kuei និងសមមិត្តចិនដទៃទៀត។ ពិធីលៀងសាយភោជន៍បានប្រព្រឹត្តទៅក្នុងបរិយាកាសកក់ក្តៅ និងស្និទ្ធស្នាល។ ក្នុងអំឡុងលៀងសាយភោជន៍ សមមិត្ត Chen Yung-kuei បានលើកកែវស្រាប្រសិទ្ធពរដល់មិត្តភាពបដិវត្តន៍ និងសមាគ្គីភាពយោធាដ៏ឧត្តុង្គឧត្តមរវាងបក្សទាំងពីរ និងប្រជាជន និងប្រទេសទាំងពីរ"]។

226 ឯកសារ D114/159 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ឆ.10 ["បងមុត លេខាកងពល១៦៤ ដែលជាកងពលសមុទ្រ និងជាលេខាតំបន់ពិសេសកំពង់សោម"]។

227 ឯកសារ D1.3.33.7 កំណត់ហេតុសួរចម្លើយតុលាការយោធា កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00089675 ["មាស មុត ទទួលភារកិច្ចជាបញ្ជាការកងជើងទឹកប្រចាំការនៅក្រុងកំពង់សោម និងជាប្រធានគណកម្មាធិការក្រុងកំពង់សោម"]។

228 ឯកសារ D114/159 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ឆ.10 ["បងមុត លេខាកងពល១៦៤ ដែលជាកងពលសមុទ្រ និងជាលេខាតំបន់ពិសេសកំពង់សោម។ មានភូមិមួយចំនួននៅជុំវិញផែកំពង់សោម ហើយវាមានគណៈកម្មាធិការផែវាមួយដោយឡែកទៀត។ ទាំងភូមិ ទាំងផែនេះ វានៅក្នុងការគ្រប់គ្រងរបស់បងមុត"]។

229 ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.11 ឆ.15 ["ស៖ តើលោកដឹងថា មាស មុត គាត់អាចជាសមាជិករបស់គណកម្មាធិការជំនួយកងទ័ពកម្ពុជាប្រជាធិបតេយ្យ? ឆ.11៖ ខ្ញុំមិនច្បាស់ទេ ខ្ញុំបានឮថា គាត់ជាលេខាបក្សកំពង់សោម។ [...] ឆ.15៖ ខ្ញុំមិនដឹងច្បាស់អំពីមុខងារ និងតំណែងរបស់គាត់នៅក្នុងបក្សនោះទេ ប៉ុន្តែខ្ញុំដឹងថាគាត់ទទួលខុសត្រូវរួមទាំងអស់នៅកំពង់សោម រួមមានខាងយោធា ខាងកម្មករ ខាងកំពង់ផែ"]។

230 ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.34 ឆ.37 ["តាមពិត គ្រិន បានចាកចេញពីផែកំពង់សោម ទៅរៀននៅភ្នំពេញរយៈពេល១អាទិត្យ ហើយត្រឡប់មកកំពង់សោមវិញនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៧៨។ នៅពេលគាត់ត្រឡប់មកវិញ គាត់រៀបចំការប្រជុំ ហើយប្រាប់កម្មករទាំងអស់នៅផែថា គាត់ទៅធ្វើឯកអគ្គរដ្ឋទូតនៅហុងកុង។ បន្ទាប់ គ្រិន ចាកចេញទៅ អ្នកដែលមកជំនួសគាត់នៅផែនោះមិនមែនជាមនុស្សមកពីផែទេ ប៉ុន្តែមកពីកងពល១៦៤។ [...] ស៖ តើអ្នកមកជំនួស គ្រិន ដែលមកពីកងពល១៦៤ ជាអ្នកណា? ឆ.37៖ នៅថ្ងៃប្រជុំ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ

76. ក្នុងនាទីជាលេខា នៃកងពល ១៦៤ និងតំបន់ឯករាជ្យកំពង់សោម មាស មុត គ្រប់គ្រងភារកិច្ច យោធា និងស៊ីវិលនៅតំបន់កំពង់សោម[231]។ អាស្រ័យហេតុនេះ អំណាចរបស់គាត់មិនកំណត់ត្រឹមក

---

១៩៧៨ គ្រិន បានណែនាំឈ្មោះ ភាព និងឈ្មោះ សួង។ ពួកគេទាំងពីរមកពីកងពលលេខ១៦៤។ ភាព មានតួនាទីជាប្រធានស្តីទីនៅផែ ហើយ សួង ជាអនុប្រធាន។ ក្រោយមកប្រហែលខែមិថុនា ឬខែកក្កដា ឆ្នាំ១៩៧៨ សារឿន មកពីកងពល១៦៤ ដែរនោះ មកធ្វើជាប្រធានកំពង់ផែ។ ភាព ក្លាយជាអនុប្រធាន ហើយ សួង ក្លាយជាសមាជិកវិញ។ ក៏ប៉ុន្តែ សារឿន មិននៅផែជាអចិន្ត្រៃយ៍ទេ ដូច្នេះនៅពេលគាត់អវត្តមាន ភាព និង សួង ជាអ្នកទទួលខុសត្រូវជំនួស។ ពួកគេមិនដែលជ្រើសរើសមនុស្សមកពីកំពង់ផែមកកាន់តួនាទីសំខាន់ ឬតួនាទីខ្ពស់នោះទេ។ ពួកគេតែងតែយកមនុស្សមកពីកងពល១៦៤"]។ ឯកសារ D114/195 កំណត់ហេតុស្តាប់ចម្លើយ នាក់ ខឿន ឆ.17 ឆ.19 ["សៈ តើលោកដឹងទេថាអ្នកណាឡើងមកជំនួស គ្រិន ដែរទេ នៅឆ្នាំ១៩៧៨? ឆ.17៖ ខ្ញុំនៅហ្នឹង ខ្ញុំដឹងមុនរត់។ មុននឹងវៀតណាមចូល ខ្ញុំបានរត់ចេញពីកំពង់ផែ ចុងឆ្នាំ១៩៧៨ វាដូចជាឈ្មោះប្រហែលជាតាសារឿន រាងខ្មៅបន្តិច។ គាត់នៅកន្លែងហ្នឹង មិនបានមួយឆ្នាំទេ គឺប្រហែលជា៥ ឬ៦ខែមុនពេលដាច់របប។ គេផ្លាស់ពីតាគ្រិន មកតាសារឿន [...] សៈ តើតាសារឿន មកពីជួរយោធាមែនទេ? ឆ.19៖ ខ្ញុំឮថាគាត់ផ្លាស់ពីយោធាមក"]។ ឯកសារ D54/73 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.6 ឆ.9 ["សៈ តើអ្នកណាជាអនុរបស់ មាស មុត? ឆ.6៖ ខ្ញុំមិនដឹងថាអ្នកណាជាមេបញ្ជាការ អ្នកណាជាអនុទេ ប៉ុន្តែនៅក្នុងគណៈរបស់គាត់មានគ្នាបីនាក់ គឺមាន តាមុត, តា សារឿន និងតា ញ៉ាន់ [...] ឆ.9៖ តា សារឿន ក្រោយមកត្រូវបានបញ្ជូនទៅធ្វើការនៅផែកំពង់សោម"]។ ឯកសារ D59/1/1.12 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល KH 00926645 ["[វរសេនាធំ១៤០] ដំបូងបំផុតហ្នឹងមានឈ្មោះតាសារឿន។ បាទ! សារឿនហ្នឹងប្រធាន ហើយសំ ហ្នឹងមកពីខាងតាដឹមហ្នឹង បញ្ជាការ អនុប្រធាន ហើយបានតាសេង ដល់នេះគេដក តាសំ ហ្នឹងគេចាប់ទៅ បាទ! គេចាប់ទៅជំនាន់តាដឹម ហ្នឹង តាសារឿន គេដកមកគ្រប់គ្រងផែ"]។ ឯកសារ D54/81 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ិច ឆ.14 ["មេបញ្ជាការកងពលលេខ៣ឈ្មោះ អ៊ំ មុត [...] អនុកងពលឈ្មោះ ឌឹម មកពីភូមិភាគបូព៌ា។ សមាជិកកងពលមកពីខេត្តកោះកុងឈ្មោះបង ឆាន។ ក្រោយមក យ៉ាន មកកាន់កងពល១៦៤ជាមួយ អ៊ំ មុត ដែរ។ គាត់ជាអតីតមេបញ្ជាការវរៈសេនាធំ៦៣។ ក្រោយមក ខ្ញុំមិនដឹងថាគាត់ទៅណាទេ។ ក្រោយមក សារឿន មកជំនួស យ៉ាន។ សារឿន មកពីកងវរៈសេនាធំ១៤០ ប្រហែលជាមកជំនួស តា យ៉ាន"]។

231 ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.9 ឆ.10 ["មាស មុត គឺជាមេបញ្ជាការកងពលលេខ៣ ហើយគាត់គឺអនុរបស់ សុន សេន ដែលនៅសេនាធិការរបស់កងទ័ពជាតិ។ តំបន់ទឹកដីដែលស្ថិតនៅក្រោមបញ្ជារបស់មាស មុត លាតសន្ធឹងតាំងពីទឹកសាប កងកេង រាម កំពង់សោម ហើយនិងកោះទាំងអស់នៅក្នុងសមុទ្រ។ កន្លែងតំបន់ទាំងអស់នេះ គឺហៅថាតំបន់ស្វយ័តដែលស្ថិតនៅក្រោមអំណាចរបស់ មាស មុត។ គាត់មានអំណាចចាប់ចង និងសម្លាប់ទាំងយោធា និងទាំងប្រជាជនស៊ីវិលដែលនៅក្នុងតំបន់របស់គាត់ ឧទាហរណ៍ បើគាត់សង្កេតឃើញថា គោ ឬសត្វពាហនៈ ស្គម ហើយមិនត្រូវបានថែទាំផិតដល់ល្អ គាត់នឹងចេញបញ្ជាឲ្យចាប់អ្នកដែលថែទាំគោទាំងនោះ [...] ឆ. 10៖ [...] នៅក្រោមបញ្ជា និងការគ្រប់គ្រងរបស់គាត់ ក៏មានសហករណ៍របស់ប្រជាជនស៊ីវិលមួយចំនួនដែរ។ សហករណ៍ទាំងនោះរួមមាន៖ សហករណ៍ថ្មធំ អូរឬ្ស ឡឥដ្ឋ ស្នាច់ដែង ពុតធឿង និងបបុស"]។ ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា ឆ.14-15 ["គាត់ក៏មានសិទ្ធិអំណាចបញ្ជាទៅតាមសហករណ៍ និងមេឃុំដែរ

ម្ចាភិបាលកងពល ១៦៤ និងក្រុងកំពង់សោមនោះទេ ប៉ុន្តែថែមទាំងពង្រីកលើតំបន់កំពង់សោមទាំងមូល ហើយរួមមានទាំងសហករណ៍ស៊ីវិល ដូចជា ថ្មធំ, អូរម្លូ, ឡូ ឥដ្ឋ, ស្ទាច់ ដែង, ពុ ធឿង, និងបបោស ព្រមទាំងប្រជាជនដែលរស់នៅក្នុងទីតាំងទាំងនោះ[232]។

---

[…] ពុំមានប្រជាជនធម្មតារស់នៅកំពង់សោម ឬនៅតាមកោះទេ គឺសុទ្ធតែយោធាទាំងអស់។ ប្រជាជនធម្មតារស់នៅតាមភូមិផ្សេងៗ ដូចជាស្ទាច់ដែង ថ្មធំ ពុតធឿង ដីឥដ្ឋ ជាដើម។ ស៖ តើលោកដឹងមកពីអ្នកណា ដែលថា មាស មុត មានសិទ្ធិអំណាចបញ្ជាលើប្រធានសហករណ៍ និងមេឃុំនោះ? ឆ.15៖ ខ្ញុំឮគេនិយាយតៗគ្នា ថាគាត់មានសិទ្ធិបញ្ជាប្រជាជនធម្មតា។ ខ្ញុំដឹងច្បាស់ថាគាត់មានសិទ្ធិបញ្ជាអង្គភាពយោធា"]។ ឯកសារ D114/25 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដាវ ឆ.8 ["មាស មុត ជាមេបញ្ជាការទទួលខុសត្រូវក្នុងតំបន់កំពង់សោមទាំងមូល និងកងទ័ពជើងទឹកទាំងមូល។ ខ្ញុំដឹងតាមរយៈមេបញ្ជាការវរសេនាតូចរបស់ខ្ញុំឈ្មោះបង ប៊ុន ថេង។ ហើយខ្ញុំក៏ដឹងតាមរយៈយោធានៅក្នុងកងជើងទឹកជាមួយគ្នា"]។ ឯកសារ D114/96 កំណត់ហេតុស្តាប់ចម្លើយ ចេង ឡូង ឆ.11 ["ប្រជាជន [នៅភូមិបបុស] ទាំងនោះបាននិយាយថា មាស មុត គ្រប់គ្រងពួកយើងទាំងអស់គ្នា។ នេះមានន័យថា មាស មុត នៅកំពង់សោម ប៉ុន្តែគាត់គ្រប់គ្រង និងកាន់កាប់តំបន់នេះផងដែរ"]។ ឯកសារ D1.3.13.11 បទសម្ភាសន៍របស់ការិយាល័យសហព្រះរាជអាជ្ញាជាមួយ សៀង EN 00217564 ["មាស មុត មានអំណាចគ្រប់គ្រងក្នុងតំបន់កំពង់សោមទាំងមូល"]។ ឯកសារ D59/2/3.17a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ យ៉ែម សំអុន KH 00958354 ["កន្លែងនោះគាត់ [មាស មុត] គ្រប់គ្រងវា ពិនមានឈ្មោះខាងសុខាភិបាលវាផ្សេង គេមានពេទ្យមានអី អើពិនពេទ្យ ពេទ្យកងពលដែរ អញ្ចឹងប្រហែលជាគាត់គ្រប់គ្រងទាំងអស់ហ្នឹង ព្រោះកាលហ្នឹងមិនទាន់មានកងណាចូលប្រឡូកប៉ូកប៉ាកអីទេ សុទ្ធតែចំណុះកងពលទាំងអស់ទាំងកងដឹកជញ្ជូន ទាំងកងសុខាភិបាល ទាំងកងទ័ពទាំងអស់ […] ស៖ ចឹងមានន័យថាម៉ាកំពង់សោមហ្នឹងស្ថិតក្រោមការគ្រប់គ្រងរបស់ មាស មុត ទាំងអស់? ឆ៖ បាទៗ។ ស៖ ទាំងកងជើងទឹក និងកងសុខាភិបាលស្អីៗ? ឆ៖ បាទៗ! កងដឹកជញ្ជូនអី នារីនារ៉េញអីទាំងអស់"]។ ឯកសារ D54/60.2 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ឺន វ៉េត KH 00975728 ["តា មុត កាលហ្នឹងគាត់នៅកំពង់សោមហ្នុងមែន តែគ្រាន់កិច្ចការជើងគោក គាត់មានសិទ្ធិ គាត់ជំនួស តា ខៀវ បាន កិច្ចការអីបញ្ជូនទាំងអស់ឡើងអី តា មុត គាត់មានសិទ្ធិបញ្ជាបាន។ ស៖ តា មុត គាត់កាន់សមរភូមិទិសខាងណាទៅ? កាលពេលវាយ? ឆ៖ គាត់កាន់ខាងកំពង់សោម"]។

232 ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.9-10 ["តំបន់ទឹកដីដែលស្ថិតនៅក្រោមបញ្ជារបស់ មាស មុត លាតសន្ធឹងតាំងពីទឹកសាប កងកេង រាម កំពង់សោម ហើយនិងកោះទាំងអស់នៅក្នុងសមុទ្រ។ កន្លែងតំបន់ទាំងអស់នេះ គឺហៅថាតំបន់ស្វយ័តដែលស្ថិតនៅក្រោមអំណាចរបស់ មាស មុត។ គាត់មានអំណាចចាប់ចង និងសម្លាប់ទាំងយោធា និងទាំងប្រជាជនស៊ីវិលដែលនៅក្នុងតំបន់របស់គាត់ ឧទាហរណ៍ បើគាត់សង្កេតឃើញថា គោ ឬសត្វពាហនៈ ស្គម ហើយមិនត្រូវបានថែទាំដិតដល់ល្អ គាត់នឹងចេញបញ្ជាឲ្យចាប់អ្នកដែលថែទាំគោទាំងនោះ […] ឆ.10៖ […] នៅក្រោមបញ្ជា និងការគ្រប់គ្រងរបស់គាត់ ក៏មានសហករណ៍របស់ប្រជាជនស៊ីវិលមួយចំនួនដែរ។ សហករណ៍ទាំងនោះរួមមាន៖ សហករណ៍ថ្មធំ អូរម្លូ ឡូត្ត ស្ទាច់ដែង ពុតធឿង និងបបុស"]។ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.30 ["ពីព្រោះតំបន់នោះ [ភូមិស្ទាច់ដែង ភូមិគគីរ និងចំណោតរាម] ស្ថិតក្រោមការគ្រប់គ្រងរបស់ មាស មុត គឺចាប់ពីវាលវិញមក"]។ ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា ឆ.14-15 ["គាត់

77. មាស មុត ធ្វើរបាយការណ៍ និងទទួលរបាយការណ៍អំពីប្រជាជន និងការបង្កបង្កើនផលស្បៀងនៅក្នុងតំបន់[233] ហើយអនុវត្តទិសដៅបក្សកុម្មុយនីស្តកម្ពុជា ដូចជា របបអាហារសម្រាប់ភ្ញៀវបរទេសស្នាក់នៅក្នុងតំបន់[234]។ នៅថ្ងៃទី១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ មាស មុត បានរាយការណ៍អំពីតំបន់កំពង់សោម ថា មានប្រជាជន ១៧០០០នាក់ ក្នុងនោះមានទាំងយោធា និងស៊ីវិលដែលធ្វើការដាំដុះផលដំណាំ នៅក្នុងតំបន់ដែលគាត់គ្រប់គ្រង[235]។

---

[មាស មុត] ក៏មានសិទ្ធិអំណាចបញ្ជាទៅតាមសហករណ៍ និងមេឃុំដែរ។ តាមពិតទៅ ពុំមានប្រជាជនធម្មតារស់នៅកំពង់សោម ឬនៅតាមកោះទេ គឺសុទ្ធតែយោធាទាំងអស់។ ប្រជាជនធម្មតារស់នៅតាមភូមិផ្សេងៗ ដូចជាស្នាច់ដែង ថ្មធំ ពូធឿង ជីតដ្ឋ ជាដើម។ សៈ តើលោកដឹងមកពីអ្នកណា ដែលថា មាស មុត មានសិទ្ធិអំណាចបញ្ជាលើប្រធានសហករណ៍ និងមេឃុំនោះ? ឆ.15៖ ខ្ញុំឮគេនិយាយតៗគ្នា ថាគាត់មានសិទ្ធិបញ្ជាប្រជាជនធម្មតា"]។ ឯកសារ D114/96 កំណត់ហេតុស្តាប់ចម្លើយ ចេង ឡុង ឆ.11 ["ប្រជាជន [នៅភូមិបបុស] ទាំងនោះបាននិយាយថា មាស មុត គ្រប់គ្រងពួកយើងទាំងអស់គ្នា។ នេះមានន័យថា មាស មុត នៅកំពង់សោម ប៉ុន្តែគាត់គ្រប់គ្រង និងកាន់កាប់តំបន់នេះផងដែរ"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.16 ["មាស មុត មានសិទ្ធិអំណាចចាប់ចងប្រជាជនស៊ីវិល យោធា ហើយនិងគ្រួសារយោធាដែលស្ថិតនៅក្រោមការត្រួតត្រារបស់កងពល១៦៤។ តំបន់គ្រប់គ្រងរបស់កងពល ១៦៤ មានព្រំដែនខាងកើតនៅចំទឹកសាប ខាងជើងនៅស្ទឹងហាវ ខាងលិចគឺសមុទ្រ ហើយនិងកោះមួយចំនួន"]។

233 ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភាររបស់កងពល និងវរៈសេនាធំ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH 00052390-91 [មាស មុត ផ្តល់របាយការណ៍មួយស្តីពីសភាពការណ៍ខ្មាំង សភាពការណ៍បង្កបង្កើនផល សភាពការណ៍សុខភាព សភាពការណ៍ស្បៀង និងសភាពការណ៍បក្សនៅក្នុងតំបន់ក្រោមការត្រួតត្រារបស់គាត់]។ ឯកសារ D1.3.34.10 សារទូរលេខ ៤៤ ពី មុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៧៦ KH 00000860 [សារទូរលេខរៀបរាប់ក្នុងចំណោមបញ្ហាផ្សេងទៀតពីការធ្លាក់ភ្លៀងនៅកំពង់សោម នៅខែសីហា ឆ្នាំ ១៩៧៦ និងប្រាប់ថា "[ប្រជាជន] បាចទឹកដាក់ស្រែវិញម្តងហើយ"]។ ឯកសារ D4.1.699 សារទូរលេខ ១១ ពីមិត្ត ឌឹម ជូន បង មុត (មាស មុត) ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ [សារទូរលេខរៀបរាប់ពីបញ្ហាកសិកម្មនានានៅក្នុងតំបន់កងកេង។ ចម្លងជូន នួន ជា សុន សេន មន្ទីរ (៨៧០) និងឯកសារ]។

234 ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.12 ["សៈ តើហេតុអ្វីបានជា មាស មុត គាត់ជាអ្នកចុះហត្ថលេខាសម្រេចនៅលើរបបអាហារសម្រាប់ភ្ញៀវចិនទាំងនេះ? ឆ.12៖ សម្រាប់របបអាហារ គឺចេញពីគណៈមជ្ឈិមរបស់បក្ស ហើយ មាស មុត នៅកំពង់សោម គឺអ្នកអនុវត្តតាមគោលការណ៍នោះ ខ្ញុំបានដឹងពីរឿងនេះ ពីព្រោះខ្ញុំឋិតក្នុងសម្ព័ន្ធយុវកក ហើយនៅក្នុងពេលគេធ្វើសន្និបាតរបស់យុវកក គេក៏បានប្រកាសប្រាប់អំពីរបបអាហារនេះដែរ"]។

235 ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភាររបស់កងពល និងវរៈសេនាធំ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH 00052391 ["សមមិត្ត មុត [...] មកទល់ថ្ងៃ ២០.៨ បានស្ទូងហើយអស់ ទាំងស្រូវស្រាល ទាំងស្រូវធ្ងន់។ ស្រូវស្រាល ដល់ថ្ងៃ ៣០.៨ ច្រូតបាន ៣០ហិកតា ផលបាន ៥០ថាំង ១ហិកតា ស្រូវកណ្តាល ធ្វើបានជិត ៣០០ហិកតា ប្រហែលថ្ងៃ ១០.១០ ដឹកចេញអស់។ ស្រូវធ្ងន់ ស្ទូងហើយ ទាំងកងទ័ព និងប្រជាជន ទំហំគឺ ១.៦០០ហិកតា។

78. នៅចុងឆ្នាំ ១៩៧៨ មាស មុត បានទទួលការចាត់តាំងទៅធ្វើការនៅទីបញ្ជាការយោធានៅភ្នំពេញ។ ប៉ុន្តែ គាត់នៅតែបន្តគ្រប់គ្រងតំបន់កំពង់សោម រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយចេញបញ្ជាតាមរយៈ ទឹម សេង ប្រធានវរៈសេនាធំ ១៤០ ដែលបានទទួលការតែងតាំងជាបញ្ជាការលើដែនដីនានាដែលស្ថិតក្រោមការគ្រប់គ្រងរបស់កងពល ១៦៤ ក្រោយពេល មាស មុត បានប្ដូរមកភ្នំពេញ[236]។

---

កំលាំងមនុស្ស ទាំងប្រជាជន ទាំងកងទ័ព ១៧.០០០នាក់។ ផលស្រូវ គិត ២ តោនស្មើ ក្នុងដី ២.០០០ហិកតា ត្រូវខ្វះ ៦១.០០០ថាំង"]។

236 មាស មុត បានបញ្ជាក់ដោយខ្លួនឯងថាគាត់បានគ្រប់គ្រងលើការត្រួតត្រាកងពល១៦៤ ក្រោយពេលគាត់បានចាកចេញពីកំពង់សោម។ ទោះយ៉ាងណា វាមិនត្រូវគ្នានឹងភស្តុតាងទៃទៀតទាំងអស់ដែលនៅក្នុងសំណុំរឿងនោះទេ គាត់បានថ្លែងថា ហេតុការណ៍នេះកើតឡើងនៅខែ កុម្ភៈ ឆ្នាំ ១៩៧៨៖ ឯកសារ D54/16/1R កំណត់ហេតុជាខ្សែអាត់សម្លេងនៃបទសម្ភាសន៍ មាស មុត ដោយ David Kattenburg ខែ មេសា ឆ្នាំ ២០០៩ ត្រង់នាទី 34:37-35:28 ["ខ្ញុំមិនបាននៅកំពង់សោមទេ។ នៅខែ កុម្ភៈ ឆ្នាំ ១៩៧៨ ខ្ញុំបានចាកចេញពីកំពង់សោមហើយ។ ស៖ តើគាត់បានទៅណា? ឆ៖ ខ្ញុំត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅខេត្តក្រចេះជិតព្រំដែនឡាវ។ ស៖ អ៊ីចឹង គាត់បានចាកចេញពីកងពល១៦៤ រួចស្រេចហើយនៅខែ កុម្ភៈ ឆ្នាំ ១៩៧៨ មែនទេ? ឆ៖ ទេ ខ្ញុំនៅមានតួនាទីនៅឡើយ ក៏ប៉ុន្តែខ្ញុំត្រូវបានចាត់តាំងសម្រាប់បេសកកម្មមួយទៀតនៅក្រចេះ"]។ សូមមើលផងដែរនូវ ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.93 ឆ.95-96 ឆ.100 ["នៅពេលនោះ [ចុងឆ្នាំ ១៩៧៨] មានមនុស្សថ្មីមកជំនួសការងាររបស់គាត់ [មាស មុត]។ អ្នកមកជំនួសការងារ មាស មុត គឺឈ្មោះ ទឹម សេង ដែលពីមុនគាត់ជាអ្នកគ្រប់គ្រងកងនាវាប្រឆាំង។ នៅពេល ទឹម សេង មកជំនួស មាស មុត គាត់គ្រប់គ្រងអង្គភាពយោធាទាំងអស់នៅកំពង់សោម [...] ស៖ លោកដឹងថាតើនរណាជាអ្នកឲ្យ ទឹម សេង មកជំនួស មាស មុត? ឆ.95៖ បើតាមខ្ញុំយល់គឺបញ្ជាពីខាងលើមក។ [...] ឆ.96៖ មាស មុត គាត់ទៅខាងអគ្គសេនាធិការ ដូច្នេះការងារទាំងអស់គាត់បញ្ជាពីខាងលើមកតាមរយៈ ទឹម សេង ហើយ ទឹម សេង ដើរមើលការងារ និងបញ្ជាការងារបន្ត [...] ស៖ លោកអម្បាញ់មិញថា មាស មុត នៅអគ្គសេនាធិការ តើលោកដឹងដោយរបៀបម៉េច? ឆ.100៖ ក្រោយពេលដែលយួនវៃចូលមកខ្លាំង ខ្ញុំបានឃើញ តាមាស មុត ត្រឡប់មកវិញប្រហែលជាង ១០ថ្ងៃមុនវៀតណាមទម្លាក់គ្រាប់បែកនៅក្រុងកំពង់សោមគឺចុងឆ្នាំ១៩៧៨។ ខ្ញុំសន្និដ្ឋានថាគាត់ប្រហែលទៅអគ្គសេនាធិការ"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ ឆ.126-7 ឆ.129 ["ខ្ញុំដឹងថាមាស មុត ឆ្នាំ១៩៧៨ ដឹងថាគាត់មកភ្នំពេញ ប៉ុន្តែមិនដឹងថាគាត់ទៅណាៗមិនដឹងទេ។ ស៖ តើលោកដឹងថាមាស មុត មកភ្នំពេញដោយរបៀបណា? ឆ.127៖ បានថាដឹង តែពេលមានការងារអី មេបញ្ជាការតាមជាន់ថ្នាក់គេផ្សាយប្រាប់យើងហើយ។ [...] ឆ.129៖ [...] ធម្មតាមេបញ្ជាការតាមថ្នាក់ៗអ៊ីចឹង ថាមួយខែគេត្រូវមករៀនជាមួយកងពលម្តង ដល់ពេលហ្នឹង ពេលគេចុះទៅវិញគេថាមាស មុតទៅនៅភ្នំពេញហើយ គេប្រាប់ទៀតថា មាស មុត មកធ្វើជារងសេនាធិការនៅភ្នំពេញ"]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត ឆ.171-72 ["ស៖ លោកបានបញ្ជាក់នៅខាងដើមថា មាស មុត បានទៅស្រុកមេមត់នៅចុងឆ្នាំ១៩៧៨ តាមការណែនាំរបស់ សុន សេន។ តើ មាស មុត នៅតែ

## ការគ្រប់គ្រងដោយប្រសិទ្ធភាព

79. ក្នុងអំឡុងនៃកម្ពុជាប្រជាធិបតេយ្យ មាស មុត បានគ្រប់គ្រងទាំងតាមព្រឹត្តិហេតុ និងតាមច្បាប់លើកម្មាភិបាលយោធាកងពល ១៦៤ និងកម្មាភិបាលរដ្ឋបាលតំបន់កំពង់សោម។ គាត់មានអំណាចចេញបញ្ជាដល់កម្មាភិបាលក្រោមបង្គាប់ទាំងនេះ តែងតាំង និងដកតួនាទីកម្មាភិបាលយោធា និងស៊ីវិល ព្រមទាំងដាក់វិន័យ និងទណ្ឌកម្មលើកម្មាភិបាលទាំងនោះ។ ជាពិសេស អំណាចរបស់មាស មុត បានធ្វើឱ្យគាត់អាចទប់ស្កាត់ និងដាក់ទណ្ឌកម្មបានចំពោះបទឧក្រិដ្ឋដែលកម្មាភិបាលក្រោមបង្គាប់របស់គាត់ប្រព្រឹត្ត ប្រសិនបើគាត់មានចេតនាចង់ធ្វើដូច្នោះ។

80. លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ចែងថា “ថ្នាក់ក្រោមគោរពថ្នាក់លើ” ហើយថា ថ្នាក់ក្រោម “ត្រូវតែអនុវត្ត” ការណែនាំ និងបញ្ជារបស់មេបញ្ជាការ។ ជាក់ស្តែង ក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ បញ្ជារបស់មាស មុត តែងតែអនុវត្តដោយកម្មាភិបាលក្រោមដែលគោរព និងខ្លាចគាត់

---

មានអំណាចដឹកនាំគ្រប់គ្រងអ្វីៗនៅខេត្តកំពង់សោមដដែលទេនៅពេលដែលគាត់ទៅស្រុកមេមត់នោះ? ឆ.171៖ ការងាររបស់គាត់នៅពេលនោះ គឺគាត់នៅមានឥទ្ធិពល និងសិទ្ធិគ្រប់គ្រងចាត់ចែង គឺមិនទាន់ដាច់ចេញពីកំពង់សោមទេ។ ស៖ តើលោកដឹងដោយរបៀបណា? ឆ.172៖ ដឹងតាមប្រព័ន្ធទាក់ទង តាមតេឡេ”]។ ឯកសារ D54/99.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ KH 00990786-87 [“ស៖ តាមុត គាត់អើគ្រប់គ្រងនៅខាងកំពង់សោម នៅកំពង់សោមហ្នឹងរហូតដល់បែក៧៩ឬក៏? ឆ៖ បាទ! រហូតមក ចុង៧៨គាត់គេដកមកគាត់ ក្រោយមកគាត់ឡើងនាយអគ្គសេនាធិការរង ដល់ពេល៧៩ គាត់ត្រឡប់ទៅរកអង្គភាពយើងវិញ។ ស៖ បាទ! ប៉ុន្តែពេលដែលគាត់ឡើងមកអគ្គសេនាធិការរងមកនៅភ្នំពេញ ប៉ុន្តែគាត់នៅតែបញ្ជានៅតាក្តោបក្តាប់មក? ឆ៖ មានអើអនុកងពលមួយនៅទទួលជំនួស ខាងណោះដែរ។ ស៖ ពីណាគេ? ឆ៖ ឯកឧត្តម ទឹម សេង។ ស៖ ទឹម សេង ហី? ឆ៖ បាទ! ស៖គាត់ទទួលការពីណា? ឆ៖ ការងារពីតាមុត ផ្នែកយោធាណា។ ស៖ បាទ! ប៉ុន្តែផ្សេងៗនៃការងារអីនៅតាទាក់ទងមក តាមុត ដដែល? ឆ៖ បាទ! អ្នកទទួលបញ្ជាពីលើមករបាយការណ៍”]។ ឯកសារ D59/1/1.11a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង រ៉េត KH 00926542-43 [“ស៖ ហើយមានពីណាទៀតគ្រប់គ្រងរៈសេនាធំ [១៤០]? ឆ៖ បើនិយាយទៅមាន ទឹម សេង [...] មុនដំបូងគាត់គ្រប់គ្រងជើងទឹក ដល់ក្រោយមកគាត់មកគ្រប់គ្រងកងពល១៦៤ហើយ មាស មុតឡើងមកធ្វើជាមេបញ្ជាការនៅភ្នំពេញ”] KH 00926561 [“ស៖ ចឹងតា មុត គាត់ផ្លាស់មកភ្នំពេញនៅឆ្នាំណា? ឆ៖ នៅឆ្នាំ៧៧តាមមើល។ ស៖ ចឹងគាត់មកនៅភ្នំពេញបានយូរដែរ? ឆ៖ បានយូរដែរ។ ស៖ បានប៉ុន្មានបានបែក? ឆ៖ បានមួយឆ្នាំជាងដែរហ្នឹង គាត់មកនៅភ្នំពេញហ្នឹងបានគាត់រត់ចេញពីភ្នំពេញឆ្នាំ៧៩ ហ្នឹងបានគាត់ដាក់បទបញ្ជាឱ្យដកពីកំពង់សោម។ ស៖ ចឹងគាត់នៅភ្នំពេញ គាត់នៅតែបញ្ជា? ឆ៖ គាត់នៅឥទ្ធិពល។ ស៖ ចឹងគាត់ទទួលខាងកងពល១៦៤ដដែលឬយ៉ាងម៉េច? ឆ៖ បាទ! តែគាត់ទទួលខាងជើងទឹក”]។

ដោយសារធម្មជាតិ និងចរិតម៉ឺងម៉ាត់របស់គាត់[237]។ ក្នុងភាពជាអ្នកដឹកនាំ មាស មុត មានគេហៅថា ជា "ជនផ្តាច់ការ" ដែលតាមដានតឹងរ៉ឹងចំពោះវិន័យ និងឥរិយាបថរបស់អ្នកក្រោមបង្គាប់របស់គាត់[238]។

237 ឯកសារ D54/92 កំណត់ហេតុស្តាប់ចម្លើយ យ៉ែម សំអុន ឆ.65-73 ["សៈ ហេតុអ្វីបានជាលោកដឹងថា មាស មុត គឺជាមនុស្សម្នាក់ដែលមានឥទ្ធិពលនៅក្នុងកងពល? ឆ.65៖ នៅពេលដែលឮឈ្មោះគាត់ ឬឈ្មោះកងពលរបស់គាត់ គឺគេខ្លាច។ សៈ លោកនិយាយថា "មាស មុត មានឋានៈខ្ពស់ ហើយគេខ្លាចគាត់" តើពាក្យ "គេ" សំដៅលើអ្នកណា? ឆ.68 ៖ ទាំងខ្ញុំ និងយោធាផ្សេងទៀតមានការខ្លាចចំពោះមាស មុត។ ខ្ញុំមិនដែលឮរឿងរ៉ាវអ្វីដែលទាក់ទងនឹង មាស មុត ទេ។ សៈ លោកអាចពន្យល់បានទេថា តើហេតុអ្វីបានជាលោក និងយោធាផ្សេងទៀតខ្លាច មាស មុត? ឆ.69៖ មាស មុត គឺជាមនុស្សថាម៉ាត់ណា ម៉ាត់ហ្នឹង ហ្មត់ចត់។ ដូច្នេះហើយបានជាគេខ្លាចគាត់គ្រប់គ្នា ខ្លាចហ្នឹងមិនមែនមានន័យថាខ្លាចគាត់ធ្វើបាប ឬសម្លាប់ទេ គឺខ្លាចគាត់តាមឋានានុក្រមយោធា។ [...] ឆ.72៖ នៅពេលនោះ ខ្ញុំមិនសូវហ៊ាននិយាយស្តី និងស្និទ្ធស្នាលជាមួយគាត់ទេ ព្រោះគាត់ធ្លាប់ធ្វើជាមេរបស់ខ្ញុំ [...] សៈ នៅក្នុងអត្ថបទកាសែតភ្នំពេញប៉ុស្តិ៍លោកបាននិយាយថា "ខ្ញុំជឿថា មាស មុត មានចំណែកដ៏ធំក្នុងការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តិនៅក្នុងរបបខ្មែរក្រហម" ហេតុអ្វីបានជាលោកនិយាយដូច្នេះ? ឆ.73៖ បានជាពេលនោះខ្ញុំនិយាយដូច្នេះ ពីព្រោះតុលាការនេះគឺមានគោលដៅយកតែថ្នាក់ដឹកនាំខ្ពស់មកកាត់ទោស។ ហើយ មាស មុត គឺជាមេកងពលដែលជាមេដឹកនាំជាន់ខ្ពស់មួយរូបផងដែរ"]។

238 ឯកសារ D54/37 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.6 ឆ.26 ["ពេលដែលគាត់ឃើញពួកយោធាសង់ផ្ទះនោះមិនធ្វើតាមការណែនាំរបស់គាត់ឲ្យបានត្រឹមត្រូវ នៅលើផ្នែកមួយនៃដំបូលផ្ទះទៅតាមរាងដែលគាត់ចង់បាន គាត់ក៏ហៅមេជាងនោះឲ្យចុះមកដី ពេលមេជាងនោះចុះមកដល់ជិតគាត់ហើយមេជាងបានសួរគាត់ថា តើមានការអ្វីជាមួយការសាងសង់នេះ ពេលនោះគាត់មិនឆ្លើយ គាត់បានកញ្ឆក់ពូថៅពីមេជាងនោះហើយវាយចំថ្ពាស់មេជាងនោះ ធ្វើឲ្យឈាមហូរស្រោចពេញមុខ នៅពេលកូនជាងបានឃើញដូច្នោះ គេចង់យកមេជាងនោះទៅពេទ្យ តែពេលនោះតាមុតនិយាយថា អ្នកណាហ៊ានយកទៅពេទ្យនឹងទទួលរឿងដូចមេជាងនេះ [...] ឆ.26៖ ការដឹកនាំរបស់គាត់ក្នុងរបៀបផ្តាច់ការ ឧទាហរណ៍៖ ពេលមិត្តភក្ត្ររបស់ខ្ញុំដែលនៅក្នុងកងជាមួយគ្នាពីដើម មកលេងជាមួយខ្ញុំ ហើយខ្ញុំបានឲ្យបារី និងម្ហូបអាហារ ប្រសិនបើជាគាត់ដឹង គាត់នឹងដកពួកនោះឲ្យទៅធ្វើការនៅកន្លែងផ្សេង ដូចជានៅរាមជាដើម"]។ ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា ឆ.23 ["តាមុត កាចណាស់។ គាត់អាចវ៉ៃ និងបាញ់ អ្នកណាម្នាក់យ៉ាងងាយ"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.20-21 ["ខ្ញុំមិនដែលឃើញមនុស្សណាដែលមានលក្ខណៈឫកពារដូច តាមុត ទេ។ គាត់តឹងរ៉ឹងណាស់។ គាត់តែងហៅបញ្ជាការវរៈសេនាធំ និងវរៈសេនាតូចឲ្យទៅកន្លែងគាត់ ហើយទទួលបញ្ជាពីគាត់។ ពួកមេបញ្ជាការវរៈទាំងនោះ យល់ច្បាស់ណាស់ថា អ្វីដែលគេនឹងត្រូវធ្វើទៅតាមបញ្ជារបស់ តាមុត។ បើគេធ្វើតាមបញ្ជាគាត់ពុំមានជោគជ័យ គេនឹងមានបញ្ហាមិនខាន។ សៈ តើលោកដឹង ពីរបៀបនេះ តាមរបៀបណា? ឆ.21៖ យើងដឹងអំពីលក្ខណៈរបស់គាត់ ដោយសារកងរបស់យើង ធ្លាប់នៅជិតក្បែរកន្លែងគាត់។ គាត់មានផ្ទះមួយ នៅជិតផ្សារលើ ហើយមួយទៀតនៅជិតវត្តឥន្ទញ្ញាណ"]។

81. មាស មុត គ្រប់គ្រងគ្រប់ផ្នែកនៃកងពលការចេញបញ្ជាពាក់ព័ន្ធនឹងប្រតិបត្តិការយោធា[239], ការល្បាតនិងចាប់ទូក[240], ការផ្លាស់ទីតាំង[241] ការរំសាយ និងផ្លាស់ប្ដូរកងទ័ព[242], ការបង្កបង្កើនផល

---

239 សូមមើល ឧទាហរណ៍ ឯកសារ D114/79 កំណត់ហេតុស្ដាប់ចម្លើយ កង ស៊ុំ ឆ.145-147 ["ស៖ កិច្ចការលោកសំខាន់ជាងគេនៅលើកោះនោះជាអ្វីដែរ? ឆ.145៖ គេឲ្យការពារកោះ។ ស៖ តើលោកការពារកោះពីអ្នកណា? ឆ.146៖ របប ប៉ុល ពត គេឲ្យយើងទៅការពារ យើងត្រូវតែទៅ។ ប៉ុល ពត បញ្ជាទៅតាមុត ហើយ តាមុត ឲ្យទាហានទៅ។ ស៖ ហេតុអ្វីបានជាលោកដឹងពីការបញ្ជានេះ? ឆ.147៖ ខ្ញុំឮពីមេៗខាងលើខ្ញុំគេថា"]។ ឯកសារ D54/43 កំណត់ហេតុស្ដាប់ចម្លើយ លុន សេង ឆ.6-9 ["ស៖ ពេលដែលវ៉ៃចូលភ្នំពេញ តើអ្នកណាជាអ្នកបញ្ជាកងពលលេខ៣ឲ្យវ៉ៃ? ឆ.6៖ តា មុត ដែលជាមេបញ្ជាការកងពលលេខ៣។ ស៖ ពេលវ៉ៃចូលភ្នំពេញ តើទីបញ្ជាការរបស់កងពលលេខ៣ ស្ថិតនៅកន្លែងណា? ឆ.7៖ ទីបញ្ជាការកងពលលេខ៣របស់ មាស មុត ស្ថិតនៅភ្នំត្នោតពង អំឡុងពេលវ៉ៃចូលភ្នំពេញ។ ស៖ តើនៅក្នុងកងពលលេខ៣ អ្នកណាខ្លះជាអ្នករាយការណ៍ទៅ មាស មុត ក្នុងពេលនោះ? ឆ.8៖ កងវរសេនាធំនីមួយៗ គឺមានស្នងការនយោបាយរបស់គេ ហើយស្នងការនយោបាយទាំងនោះរាយការណ៍ទៅ មាស មុត ដែលជាស្នងការនយោបាយរបស់កងពល ហើយ មាស មុត រាយការណ៍បន្តទៅឲ្យប្រធានភូមិភាគគឺ តា ម៉ុក។ តា ម៉ុក រាយការណ៍បន្តទៅមជ្ឈិម។ ស៖ ក្រៅពីសកម្មភាពសមរភូមិ តើមានកិច្ចការអ្វីខ្លះ ដែលស្នងការនយោបាយរបស់វរសេនាធំនីមួយៗត្រូវរាយការណ៍ទៅកងពល? ឆ.9៖ រាយការណ៍ផ្ដោតសំខាន់ទៅលើសកម្មភាពសមរភូមិ ប៉ុន្តែផងដែររាយការណ៍អំពីជីវភាពប្រចាំថ្ងៃរបស់យោធា សីលធម៌ វៀងវិន័យ បញ្ហាសង្គមកិច្ច ដូចជាជួយប្រជាជនដកស្ទូង ច្រូត កាត់ និងជួយព្យាបាលជំងឺប្រជាជន នៅពេលពួកគេឈឺ។ ក្រៅពីសកម្មភាពប្រយុទ្ធនៅលើសមរភូមិ ស្នងការនយោបាយទទួលខុសត្រូវខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង"]។ ឯកសារ D54/24 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.20 ["ស៖ តើលោកមានន័យថាម៉េច ដែលនិយាយថា មាស មុត ជាមេបញ្ជាការធំជាងគេបង្អស់របស់កងពល? តើគាត់ទទួលខុសត្រូវការងារហ្វឹកហ្វឺនពួកយោធា ហើយនិងការងារភស្តុភារ ជាដើមឬ? ឆ.20៖ មាស មុត ទទួលខុសត្រូវគ្រប់យ៉ាងដូចជា ខាងផ្នែកយោធា ភស្តុភារ នេសាទ ជួសជុលកប៉ាល់ សកម្មភាពកំពង់ផែ ហើយនិងការងារជាច្រើនទៀត។ គាត់ទទួលខុសត្រូវខាងផ្នែកប្រតិបត្តិការក្នុងការប្រយុទ្ធ ឧទាហរណ៍គាត់ឲ្យបញ្ជាទៅតា ឬ ដែលជាមេបញ្ជាការវរសេនាធំលេខ១៤០ សម្រាប់ធ្វើប្រតិបត្តិការក្នុងពេលប្រយុទ្ធ។ គាត់ទទួលខុសត្រូវខាងសកម្មភាពនៅកំពង់ផែលើការចេញចូលរបស់កប៉ាល់បរទេសផងដែរ។ ឧទាហរណ៍ផ្សេងទៀត ក្នុងពេលរត់គៀសខ្លួនពីវៀតណាមនៅឆ្នាំ១៩៧៩ ពេលចុងក្រោយនៃរបបនោះ មាស មុត បានបញ្ជាឲ្យខ្ញុំទៅរៀម ធ្វើការកម្ទេចគ្រាប់រំសេវ រួមទាំងគ្រាប់មីនកម្ទេចនាវាទាំងអស់។ នៅពេលនោះ ពួកអ្នកធ្វើការនៅកន្លែងនោះ ប្រុងសម្លាប់ខ្ញុំចោល ដោយចោទខ្ញុំថាជាគិញ កាហ្សេបេ របស់យួន។ ប៉ុន្តែខ្ញុំបានប្រាប់គេថា ខ្ញុំបានធ្វើតាមបញ្ជារបស់តា មុត ទេ ទើបខ្ញុំបានរួចខ្លួន"]។ ឯកសារ D114/194 កំណត់ហេតុស្ដាប់ចម្លើយ ស៊ន សុត ឆ.5 ឆ.39-43 ឆ.54-55 ឆ.69-70 ["និយាយរួមទៅគឺមកពីតាមុតហ្នឹងតែម្ដងដែលជាអ្នកបញ្ជា [...] ស៖ តើលោកដែលធ្លាប់ឮ ទីកន្លែងមួយឈ្មោះទឹកសាបដែរឬទេ? ឆ.39៖ ចឹមិនដែល។ អាហ្នឹងជាកន្លែងសម្រាប់ដាក់អ្នកទោស ដាក់ពួកខ្ញុំ អ្នកធ្វើស្រែជាមួយខ្ញុំពេលដែលធ្វើខុស គេយកដាក់នៅហ្នឹង [...] ស៖ តើលោកដឹងដោយរបៀបណា? ឆ.40៖ ចឹក៏មិនដឹង ពេលធ្វើខុសគេប្រាប់ថាអ៊ីចឹង។ គេប្រជុំប្រាប់ថា "មិត្តឯងប្រយ័ត្នណា តែមិត្តឯងធ្វើខុសគេបញ្ជូនទៅទឹកសាបហើយ"។ ស៖ តើលោកចាំថាអ្នកណានិយាយបែបហ្នឹងដែរ? ឆ

.41៖ អាហ្នឹងគ្នាយើងចេះតែដឹង ចេះតែឮបន្តិចៗអ៊ីចឹងទៅ ហើយអ្នកនិយាយគឺជាមេក្រុមៗនៅក្នុងសហករណ៍ ពួកគេនិយាយប្រាប់យើងត្រង់ៗអ៊ីចឹង ប៉ុន្តែខ្ញុំមិនដែលបានឃើញដោយផ្ទាល់ទេ។ ស៖ តើមេក្រុមទាំងនោះស្ថិតនៅក្រោមបញ្ជារបស់អ្នកណាដែរ? ឆ.42៖ នៅក្រោមបញ្ជារបស់តាមុតដែរ។ ស៖ ក្នុងឋានៈជាមេក្រុមគឺស្ថិតនៅឆ្ងាយណាស់ពីតាមុត តើហេតុអ្វីបានជាលោកនិយាយបែបនេះ? ឆ.43៖ គឺមាននីរសារមកពីកំពង់សោមមកដល់សហករណ៍ [...] ស៖ តើហេតុអ្វីបានជាលោកដឹងថាកម្លាំងដែលចាប់ទូកនោះស្ថិតនៅក្រោមបញ្ជាតាមុត? ឆ.54៖ បើគាត់ជាអ្នកបញ្ជា គាត់ជាមនុស្សតែម្នាក់ដែលចេញបញ្ជា។ ស៖ សូមលោកពន្យល់បន្ថែម តើហេតុអ្វីបានជាលោកដឹង? ឆ.55៖ មុនចាប់អីមួយគឺគេប្រើ C25 តេអូ ដើម្បីទាក់ទងទៅមេ ដើម្បីសួរមេថាតើចាប់ឬអត់ តែមេថាឲ្យចាប់គឺចាប់ហើយ [...] ស៖ ក្នុងសំណួរចម្លើយទី១៧ លោកបាននិយាយថាយោធាតំបន់៣៧ទាំងអស់ត្រូវបានចាប់ខ្លួនដោយមនុស្សរបស់តាមុត តើលោកចង់សំដៅទៅលើអ្នកណា? ឆ.69៖ យើងអត់ដឹង អ្នកណាចាប់។ យើងម៉េចដឹង។ ការពិតវាបញ្ហាដូច ឧទាហរណ៍ដូចថាផ្ទះមួយមានអ្នកគ្រប់គ្រងនៅទីនោះ ហើយអ្នកបញ្ជានៅកន្លែងផ្សេងគឺគេមិនមកចាប់ដោយខ្លួនឯងទេ តែគេបញ្ជាអ្នកគ្រប់គ្រងផ្ទះនោះឲ្យមកចាប់ខ្លួន។ មានមេវានៅហ្នឹង ឧទាហរណ៍ថាបើគេចង់ធ្វើបាបខ្ញុំ វាមាននីរសារមួយដែលនីរសារវាមានម៉ូតូមួយគ្រឿង [...] ស៖ ដើម្បីបញ្ជាក់ឲ្យច្បាស់ ពេលលោកនិយាយពីមុនថា គឺពួកមនុស្សរបស់តាមុតដែលគេបញ្ជូនមករំសាយពួកលោក និងវរសេនាធំរបស់លោក។ តើហេតុអ្វីបានជាលោកដឹងថាពួកអ្នកទាំងនោះថាពួកគេធ្វើតាមបញ្ជារបស់តាមុត? ឆ.70៖ បើមិនធ្វើតាមយ៉ាងម៉េច មិនកុន បើមិនធ្វើតាមស្លាប់បាត់ គេសម្លាប់ដែរហ្នឹង។ បើវាមិនធ្វើស្លាប់មុនយើងទៅទៀត [...] ហើយ១៩៧៨ រើជាមួយវៀតណាម។ រើនៅស្នាច់ដែង ហើយនិងទឹកសាបការរើ គឺរើរយៈពេលខ្លីទេ គឺប្រហែលជាម៉ោង៤ ពួកខ្ញុំដកទៅស្រែអំបិលអស់"]។

240 សូមមើល ឧទាហរណ៍ ឯកសារ D114/24 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដាវ ឆ.87-91 ឆ.138-141 ["បាទ គឺយើងបានជិះចូលទៅជិត ហើយហក់ឡើងលើទូកនេសាទត្រីថៃ ហើយបានភ្ជង់កាំភ្លើងទៅលើពួកដែលនៅលើទូក។ ក្នុងករណីបើពួកគេតដៃ ពួកយើងនឹងបាញ់សម្លាប់ពួកគេ។ ស៖ តើមានរឿងអ្វីកើតឡើងទៀត? ឆ.88៖ ក្រោយពីការចាប់ យើងឲ្យពួកគេបើកទូកនេសាទរបស់ពួកគេចូលមកក្នុងដែនសមុទ្រខ្មែរ នៅផែកំពង់សោម កន្លែងរបស់ មាស មុត។ ស៖ ក្នុងវគ្គបណ្តុះបណ្តាល តើលោកធ្លាប់ទទួលបញ្ជាឲ្យចាប់ទូកបរទេសដែលចូលមកក្នុងដែនទឹកខ្មែរដែរឬទេ? ឆ.89៖ បាទ នៅក្នុងវគ្គបណ្តុះបណ្តាល គេបានប្រាប់ថា បើសិនមានទូកបរទេសចូលមកក្នុងដែនសមុទ្រខ្មែរ គឺត្រូវតែចាប់។ ស៖ តើនរណាគេជាអ្នកបញ្ជាឲ្យចាប់ទូកនេះ? ឆ.90៖ គឺថ្នាក់លើ។ ស៖ ហេតុដូចម្តេចបានជាលោកដឹងរឿងនេះ? ឆ.91៖ ខ្ញុំដឹងពីការបញ្ជាពីថ្នាក់លើ គឺនៅពេលកងវរៈសេនាតូច ហៅកងអនុសេនាធំ និងកងអនុសេនាតូច ទៅប្រជុំ គឺគេប្រាប់ថាការបញ្ជានោះ គឺមកពីបក្ស មានន័យថាថ្នាក់លើ។ បក្ស គឺសំដៅទៅ មាស មុត។ [...] ឆ.138៖ ខ្ញុំទទួលបញ្ជាឲ្យចាប់ទូកនេសាទ ដោយប្រុងប្រយ័ត្ន។ ស៖ តើនរណាជាអ្នកបញ្ជាមក? ឆ.139៖ មេបញ្ជាការកងវរៈសេនាតូច។ ស៖ តើមេបញ្ជាការកងវរៈសេនាតូចទទួលបញ្ជាមកពីណាដែរ? ឆ.140៖ ការបញ្ជានោះគឺមកពីថ្នាក់លើ។ នៅពេលនោះ គឺមានតែ មាស មុត ទេ។ មាស មុត ទទួលបញ្ជាពីថ្នាក់លើមកទៀត។ ពេលខ្លះ មាស មុត សម្រេចចិត្តដោយខ្លួនឯង។ ថ្នាក់ក្រោមៗ មាស មុត មិនហ៊ានសម្រេចចិត្តដោយខ្លួនឯងនោះទេ។ នៅពេលខ្ញុំឃើញសភាពការណ៍អ្វីប្លែក ខ្ញុំរាយការណ៍ទៅថ្នាក់លើរបស់ខ្ញុំ ហើយថ្នាក់លើខ្ញុំក៏រាយការណ៍ទៅថ្នាក់លើបន្តទៀត។ ស៖ ហេតុអ្វីបានជាលោកដឹងថា ការបញ្ជានោះមកពីថ្នាក់លើ គឺពីមាស មុត? ឆ.141៖ ពីព្រោះ មាស មុត ទទួលខុសត្រូវរួមខាងក្នុងកងទ័ពជើងទឹក"]។ ឯកសារ D54/34 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង អុន ឆ.1-2 ["ស៖ លោកបាននិយាយថា ការងារនៅកន្លែងកោះកុងនោះ

គឺចាំតែទទួលបញ្ជាទៅចាប់ទូកនេសាទខុសច្បាប់ សូមលោកពន្យល់ប្រាប់យើងថាអ្នកណាជាអ្នកចេញបញ្ជាឱ្យចេញចាប់នោះ? ឆ.1៖ គឺតាមុត គាត់ជាអ្នកចេញបញ្ជាតាមសារទូរលេខទៅមេបញ្ជាការកប៉ាល់។ ខ្ញុំគ្រាន់តែជាយោធាធម្មតាទេ មានមេបញ្ជាការកប៉ាល់នៅពីលើខ្ញុំ ថាតើតាមុតទទួលបញ្ជាពីអ្នកណាផ្សេងទៀត គឺខ្ញុំមិនបានដឹងទេ។ សៈ ហេតុដូចម្តេចបានលោកដឹងថា តាមុតជាអ្នកបញ្ជា? ឆ.2៖ នៅកន្លែងតាមុត គាត់មានម៉ាស៊ីនសារទូរលេខ ហើយគេមានម៉ាស៊ីនសារទូរលេខម្ខាងទៀតនៅជិតផែកប៉ាល់កោះកុងដែលឋិតនៅអតីតៈដំណាក់ស្តេច។ នៅពេលដែលអ្នកកាន់សារទូរលេខនៅហ្នឹងផែទទួលបញ្ជាពីកន្លែងតាមុត អ្នកកាន់សារទូរលេខនោះផ្តល់បញ្ជាទៅឱ្យមេបញ្ជាការកប៉ាល់"]។ ឯកសារ D114/12 កំណត់ហេតុស្តាប់ចម្លើយ នាក់ យឿន ឆ.17-23 ["នៅពេលដែលទូកយើងចូលទៅជួយនាវា PCF កប៉ាល់យើងពុំបានចូលរួមចាប់ផ្ទាល់នោះទេ គឺគ្រាន់តែបានទៅជួយនាវា PCF ដោយបើកបរទៅស្កាត់មុខទូកនោះកុំឱ្យរត់ ឬឱ្យឈប់បាញ់មកលើនាវា PCF ប៉ុណ្ណោះ។ តាក់ទិចជាទូទៅរបស់យើងគឺ ធ្វើសកម្មភាពជាមួយនាវា PCF និងបើស្កាត់កុំឱ្យទូកនោះរត់រួច។ នៅពេលយើងមកដល់ ភាគច្រើនទូកយួនទាំងនោះបានមើលឃើញកាំភ្លើងធំរបស់ពួកយើង ហើយក៏ឈប់លែងហ៊ានបាញ់ត ហើយក្រោយមកនាវា PCF ក៏ចាប់ទូកនោះតែម្តងទៅ។ សៈ តើនាវារបស់លោកធ្លាប់បាញ់ ឬបើកបុកពន្លិចទូកណាមួយទេ? ឆ.18៖ ខ្ញុំចាំថា ពួកយើងមិនដែលធ្វើរឿងបែបនេះទេ គឺគ្រាន់តែបើស្កាត់កុំឱ្យពួកគេរត់ប៉ុណ្ណោះ។ សៈ តើការសុំឱ្យមកជួយ គេធ្វើដូចម្តេច? ឆ.19៖ ការសុំជំនួយអន្តរាគមពីនាវា PCF គឺដំបូងគឺស្នើទៅកងពល១៦៤ បន្ទាប់មកកងពលបញ្ជាចុះមកកងវរៈសេនាធំ១៤០ និបន្តមកទៀតកងវរៈសេនាធំបញ្ជាចុះទៅកងវរៈសេនាតូចរបស់ ហាន។ ហាន ជាអ្នកបញ្ជាឱ្យទូកយើងចេញទៅ។ ជួនកាលគេហៅទៅជួយអន្តរាគមទាំងកណ្តាលយប់។ សៈ តើលោកដឹងពីរបៀបរបបនៃការទំនាក់ទំនងគ្នានេះពីអ្នកណា? ឆ.20៖ នេះគឺជារបៀបរបបការងារទូទៅដែលគេអនុវត្តនៅពេលនោះ។ បទបញ្ជាចេញមកពីកងពលធ្លាក់រហូតដល់កងវរៈសេនាតូច ហាន។ ទូច ក៏បាននិយាយអំពីរឿងនេះដែរ។ សៈ លោកនិយាយថា បញ្ជាចេញមកពីកងពល ហើយធ្លាក់មកដល់វរៈសេនាតូច។ តើលោកដឹងថា អ្នកណានៅថ្នាក់កងពល ជាអ្នកចេញបញ្ជា? ឆ.21៖ តាមុត ជាអ្នកចេញបញ្ជា។ សៈ ហេតុអ្វីបានជាលោកដឹងថា បញ្ជានោះចេញពី តាមុត មិនមែនជាអនុរបស់គាត់ ឬក៏ទីបញ្ជាការរបស់គាត់? ឆ.22៖ ខ្ញុំសូមជូនឧទាហរណ៍លោកមួយថា ការសម្រេចចិត្តទាំងអស់គឺចេញពីមេធំ គឺក្នុងករណីដែលតាមុត អវត្តមានប៉ុណ្ណោះ ដែលអនុរបស់គាត់អាចចេញបញ្ជាបាន។ នៅថ្នាក់វរៈសេនាតូច ហាន ជាអ្នកចេញបញ្ជា។ អ្នកផ្សេងទៀតអាចនិយាយ ឬទំនាក់ទំនង ឬសរសេរបញ្ជានោះ ប៉ុន្តែការសម្រេចចិត្ត គឺជាការងាររបស់ប្រធាន។ ប្រសិនបើអនុប្រធាន សមាជិក និងប្រធានអវត្តមាន គឺទាំងអស់គ្នាពិភាក្សាទៅលើវិធានការដែលត្រូវអនុវត្ត ប៉ុន្តែការសម្រេចចិត្តគឺធ្វើឡើងដោយប្រធាន។ សៈ ក្នុងករណីដែលលោកបានរៀបរាប់ហ្នឹង តើវាដូចគ្នាទៅនឹងអ្វីដែលអនុវត្តនៅកម្រិតតាមុត ដែរឬទេ? ឆ.23៖ គឺដូចគ្នាដែរ"]។

241 សូមមើល ឧទាហរណ៍ ឯកសារ D54/28 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ឆ.14 ["នៅពេលដែលភ្នំពេញដួលរលំ កងរបស់ខ្ញុំត្រូវបានគេបញ្ជូនទៅរាម។ នៅពេលនោះ កងរបស់ខ្ញុំគឺត្រូវបានបញ្ចូលជាមួយកងពលលេខ៣ ដែល មាស មុត ជាមេបញ្ជាការ។ ពួកយើងនៅរាមតែ១ថ្ងៃ ហើយក៏ត្រូវបញ្ជូនទៅកោះសេះ ដោយនៅទីនោះប្រហែល១ខែ"] ។

242 សូមមើល ឧទាហរណ៍ ឯកសារ D54/45 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.15-16 ["សៈ អ្នកណាដែលជាអ្នកសម្រេចបញ្ជូនយោធាទាំងនោះទៅកងផលិតធំនោះ? ឆ.15៖ ខ្ញុំមិនច្បាស់ថាអ្នកណាពិតប្រាកដទេ ប៉ុន្តែខ្ញុំយល់ថា ជាសេចក្តីសម្រេចរបស់ប្រធានកងពល មាស មុត ក្នុងការបញ្ជូនយោធាទាំងនោះទៅកងផលិតធំ។ សៈ ក្រៅពីប្រធានកង

ពល មាស មុត តើមានអ្នកណានៅក្នុងកងពលមានសិទ្ធិ ឬក៏សម្រេចបញ្ជូនពួកយោធាចេញពីកងពលទៅកងផលិតធំដែរឬទេ? ឆ.16៖ អត់មានទេ"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.92-99 ["តាមពិត កងពលត្រូវបានរំសាយ គឺមានទាហានរាប់ពាន់នាក់។ ពួកគេត្រូវបានចាត់តាំងឱ្យធ្វើការងារក្នុងកងផលិតខុសៗគ្នា និងបញ្ជូនទៅតាមមុខព្រួញការងារខុសៗគ្នា។ សៈ មុននឹងគេរំសាយ តើនរណាជាអ្នកប្រាប់អំពីការរំសាយនេះ? ឆ.93៖ បញ្ជាច្បាស់ជាចេញមកពី តាមុត ហើយពួកគេជាមនុស្សរបស់តាមុត ដែលប្រមូលផ្តុំឱ្យពួកយើងប្រជុំ ហើយប្រាប់ពួកយើងថា នឹងត្រូវបញ្ជូនទៅតាមការដ្ឋានខុសៗគ្នា។ ពួកគេរួមបញ្ចូលមនុស្សមកពីអង្គភាពផ្សេងៗគ្នាឱ្យធ្វើការនៅក្នុងកងផលិត។ សៈ តើលោកបានចូលរួមប្រជុំដោយផ្ទាល់ ឬក៏ឮពីអ្នកដទៃ? ឆ.94៖ គេរៀបចំប្រជុំនៅតាមកងតូច និងតាមកងធំនីមួយៗ ហើយគេតម្រូវឱ្យសមាជិកទាំងអស់នៅក្នុងកងនោះចូលរួមប្រជុំ។ បើខ្ញុំបដិសេធ ខ្ញុំច្បាស់ជាស្លាប់ហើយ។ សៈ តើគេរៀបចំការប្រជុំតូចៗច្រើនដង ឬក៏មានតែការប្រជុំធំមួយ? ឆ.95៖ មានការប្រជុំធំមួយ ដែលគ្រប់គ្នាត្រូវតែចូលរួម ហើយក្នុងការប្រជុំនោះ គេចាត់ឱ្យអង្គភាពនេះ ឬក៏អង្គភាពនោះទៅធ្វើការនៅតាមការដ្ឋាននេះ ការដ្ឋាននោះ។ បន្ទាប់មកទៀត មានការប្រជុំតូចៗនៅតាមការដ្ឋាននោះផ្ទាល់តែម្តង ដើម្បីទទួលការណែនាំអំពីការងារ។ សៈ តើនរណាជាអ្នកដឹកនាំក្នុងការប្រជុំធំ? ឆ.96៖ តាមខ្ញុំដឹង មានការប្រជុំមួយ ដែលមានតែមេកងវរៈសេនាតូច និងវរៈសេនាធំប៉ុណ្ណោះចូលរួម ដោយដឹកនាំដោយ តាម៉ុក និង តាមុត។ ក្រោយមកទៀត ទើបមេវរៈសេនាតូច និងវរៈសេនាធំទៅប្រជុំផ្សព្វផ្សាយបន្តទៅសមាជិករបស់ខ្លួន។ សៈ ក្នុងពេលប្រជុំជាមួយនឹងសមាជិករបស់ខ្លួន តើមេកងពលបាននិយាយអំពីការប្រជុំរបស់ពួកគេជាមួយនឹង តាម៉ុក និង តាមុត ដែរឬទេ? ឆ.97៖ ពួកគេមិនបានបញ្ជាក់ថា បានប្រជុំជាមួយ តាម៉ុក និង តាមុត ទេ។ គេគ្រាន់តែនិយាយថា ពួកគេបានទទួលបញ្ជាពីថ្នាក់លើ។ សៈ តើលោកដឹងអំពីការប្រជុំដែលដឹកនាំដោយ តាម៉ុក និង តាមុត ពីអ្នកណាដែរ? ឆ.98៖ នេះចេញមកពីការយល់ឃើញ និងវិភាគរបស់ខ្ញុំផ្ទាល់។ នៅពេលដែលគេនិយាយថា ប្រជុំជាមួយថ្នាក់លើ គឺសំដៅទៅ តាម៉ុក និង តាមុត ហើយ។ នេះគឺជារបៀបរបបដែលគេធ្វើការ។ សៈ តើលោកដឹងអ្វីខ្លះពី តាម៉ុក និង តាមុត ថាជាថ្នាក់លើ? ឆ.99៖ គេដឹងជាទូទៅថា តាម៉ុក និង តាមុត ជាគណៈភូមិភាគ ដែលមានសិទ្ធិអំណាចបញ្ជាលើកងពល"]។ ឯកសារ D114/24 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដាវ ឆ.40-42 ["សៈ តើ មាស មុត និង សៀ ម៉េត មានវត្តមាននៅពេលដែលគេបើឡានចេញទៅ ឬក៏ពេលដែលគេយកមនុស្សដាក់លើឡានដែរឬទេ? ឆ.40៖ សៀ ម៉េត និង មាស មុត បាននៅទីនោះម៉ោង៩ព្រឹក បន្ទាប់មកតាម៉ុក បានមកដល់ក្រោយ។ សៀ ម៉េត និង មាស មុត គឺជាអ្នកបញ្ជាផ្ទាល់នៅទីនោះ។ សៈ តើ សៀ ម៉េត និង មាស មុត ជាអ្នកបញ្ជា និងចាត់ចែងឱ្យប្រមូលមនុស្សដឹកតាមឡានចេញទៅមែនទេ? ឆ.41៖ បាទ ត្រឹមត្រូវហើយ។ ប៉ុល ពត គឺធំជាងគេ ហើយបន្ទាប់មកមាន នួន ជា, សុន សេន។ តាម៉ុក សៀ ម៉េត និង មាស មុត ជាអ្នកបញ្ជាផ្ទាល់នៅកន្លែងនោះ។ សៈ ក្នុងពេលដែលលោកធ្វើការនៅព្រលានយន្តហោះ គេបានជូនដំណឹងលោកថា នឹងបញ្ជូនលោកទៅកំពង់សោម។ សូមលោករៀបរាប់អំពីរឿងនេះបានដែរឬទេ? ឆ.42៖ ក្រោយថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៥ គេបញ្ជូនកងវរៈសេនាតូចលេខ ១៨០ ទៅកំពង់សោម។ សៀ ម៉េត, មាស មុត និងតាម៉ុក គឺជាអ្នកបញ្ជាបញ្ជូនទៅ។ នៅពេលដល់ក្រុងកំពង់សោម គេបានដកកងទ័ពមួយចំនួន រួមទាំងខ្ញុំ បញ្ជូនទៅធ្វើជាកងទ័ពជើងទឹក ដែលស្ថិតនៅក្រោមបញ្ជារបស់ មាស មុត។ នៅពេលនោះមានជម្លោះជាមួយប្រទេសថៃ និងវៀតណាម ពាក់ព័ន្ធនឹងរឿងដែនសមុទ្រ។ ក្រោយមក នៅដើមឆ្នាំ១៩៧៦ អង្គការបានចាប់មេបញ្ជាការវរៈសេនាតូច ចំនួន៣នាក់ ហើយនិងអ្នកជិតស្និតរបស់ពួកគេចំនួន៦នាក់ រួមទាំងខ្ញុំផងដែរ"]។

កសិកម្ម[243], ការចាប់ខ្លួន[244], និងការសម្លាប់[245]។ មាស មុត មានអំណាចខ្ពស់ជាងគេក្នុងកងពល ១៦៤[246] ក្នុងការធ្វើសេចក្ដីសម្រេច ហើយតាមដានយ៉ាងហ្មត់ចត់ដើម្បីកំណត់ច្បាស់ថា កម្មាភិបាល ក្រោមបង្គាប់ពិតជាអនុវត្តតាមបញ្ជារបស់គាត់[247]។

---

243 សូមមើល ឧទាហរណ៍ ឯកសារ D114/215 កំណត់ហេតុស្ដាប់ចម្លើយ មាស អ៊ឹម ឆ.66-67 ឆ.70 ឆ.75-76 ["ស៖ ពាក់ព័ន្ធនឹងការងារនៅការដ្ឋាន តើឈ្មោះ មៀញ នេះ ធ្លាប់ទទួលការណែនាំមកពីណាវិញដែរ? ឆ.66៖ ពីមុនមក គាត់ទទួលបញ្ជាផ្ទាល់ពី មាស មុត ហ្នឹង។ ស៖ ពាក់ព័ន្ធនឹងការងារការដ្ឋាន តើលោកអាចពន្យល់បានទេថា លោក មាស មុត អាចណែនាំដល់ឈ្មោះ មៀញ យ៉ាងដូចម្ដេច? ឆ.67៖ យើងក្ដាប់អត់បាន យើងអត់ដឹងពីការណែនាំពី មាស មុត ទៅ មៀញ ផ្នែកនយោបាយយើងអត់ដឹងទេ។ យើងទទួលបានការណែនាំពីលោក មៀញ តាមរយៈ មាស មុត តែខាងបច្ចេកទេស [...] ស៖ តើការងារបច្ចេកទេសអ្វីខ្លះ ពាក់ព័ន្ធនឹងការងារលោក ដែលបងប្រុសលោកផ្ដល់មកខាងលោក តាមរយៈលោក មៀញ នោះ? ឆ.70៖ ការងារបច្ចេកទេសទី២ ធ្វើផ្លូវ។ ផ្លូវធ្វើពីរោងចក្រប្រេងកាតមកដល់ស្ទឹងហាវ។ ទី២ ធ្វើអាផ្លូវចុះឡើងក្នុងការដ្ឋានស្ទឹងហាវហ្នឹង ហើយនិងឈូសពីជើងភ្នំនៅមាត់សមុទ្រស្ទឹងហាវហ្នឹងឲ្យទៅជារាបស្មើរ [...] ស៖ តើបងប្រុសលោកប្រាស្រ័យទាក់ទងគ្នាជាមួយឈ្មោះ មៀញ ដោយមធ្យោបាយអ្វីដែរ? ឆ.75៖ ដោយមធ្យោបាយតេអូ ហើយនិងទូរលេខ។ ស៖ ហេតុអ្វីបានលោកដឹង? ឆ.76៖ បើនៅផ្ទះ មៀញ ហ្នឹង ខ្ញុំនៅជិតហ្នឹងដែរ ហើយឃើញប្រដាប់ប្រដាហ្នឹង"]។ ឯកសារ D114/175 កំណត់ហេតុស្ដាប់ចម្លើយ នាក់ ស៊ីថា ឆ.48 ឆ.52 ["គេថា មាស មុត និយាយថា "ឲ្យយើងហ្នឹងធ្វើការទៅ បើធ្វើការមិនទាន់ទេ ផ្លូវបត់ហ្នឹង កង់ប្រវត្តិសាស្ត្រកិនហើយ" [...] ឆ. 52៖ [មាស មុត] មេគេ គាត់បញ្ជាគេឲ្យធ្វើការ"]។ ឯកសារ D114/6 កំណត់ហេតុស្ដាប់ចម្លើយ យិន តេង ឆ.31-34 ["តាមខ្ញុំដឹង មេភូមិទៅប្រជុំជាមួយតាមុត នៅកន្លែងគាត់រៀងរាល់ព្រឹក មុនពេលគាត់មកប្រជុំជាមួយយើងនៅតាមភូមិ នៅម៉ោង១១ព្រឹក។ ស៖ តើលោកស្រីដឹងថា មេភូមិទៅប្រជុំជាមួយតាមុត ដោយសារអ្វី? ឆ.32៖ ពីព្រោះគេប្រាប់នៅពេលប្រជុំរាល់ថ្ងៃថា អង្គការឲ្យធ្វើនេះធ្វើនោះ។ ស៖ តើមេភូមិបាននិយាយថា គាត់បានចូលរួមប្រជុំជាមួយតាមុត ដែរឬទេ? ឆ.33៖ ចាស គេបានប្រកាសប្រាប់ពួកខ្ញុំថា គាត់បានប្រជុំជាមួយតាមុត និងប្រាប់អំពីផែនការថ្មីៗរបស់អង្គការ។ ស៖ តើមេភូមិ គាត់ប្រាប់ថាគាត់បានប្រជុំជាមួយតាមុត ញឹកញាប់ដែរឬទេ? ឆ.34៖ ខ្ញុំមិនដឹងថាគេនិយាយការពិត ឬកុហកនោះទេ ដែលថាគាត់បានប្រជុំជាមួយតាមុត ១ខែម្ដង"]។

244 សូមមើល ឧទាហរណ៍ ឯកសារ D114/24 កំណត់ហេតុស្ដាប់ចម្លើយ អ៊ូ ដាវ ឆ.26 ឆ.42 ["ស៖ តើលោកធ្លាប់ឃើញ មាស មុត កាលពីមុនដែរឬទេ? ឆ.26៖ ខ្ញុំបានឃើញគាត់កាលពីមុន គឺប្រហែលឆ្នាំ១៩៧៥, ១៩៧៦ នៅមុនពេលខ្ញុំ និងកងទ័ពជាមួយខ្ញុំផ្សេងទៀតត្រូវបានចាប់ខ្លួន។ ក្រោយថ្ងៃ២៥ មេសា ឆ្នាំ១៩៧៥ គេបញ្ជូនកងវរៈសេនាតូចរបស់ខ្ញុំទៅកំពង់សោម [...] ស៖ ក្នុងពេលដែលលោកធ្វើការនៅព្រលានយន្តហោះ គេបានជូនដំណឹងលោកថា នឹងបញ្ជូនលោកទៅកំពង់សោម។ សូមលោករៀបរាប់អំពីរឿងនេះបានដែរឬទេ? ឆ.42៖ ក្រោយថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧៥ គេបញ្ជូនកងវរៈសេនាតូចលេខ១៨០ ទៅកំពង់សោម។ សៀ ម៉េត, មាស មុត និងតាម៉ុក គឺជាអ្នកបញ្ជាបញ្ជូនទៅ។ នៅពេលដល់ក្រុងកំពង់សោម គេបានដកកងទ័ពមួយចំនួន រួមទាំងខ្ញុំ បញ្ជូនទៅធ្វើជាកងទ័ពជើងទឹក ដែលស្ថិតនៅក្រោមបញ្ជារបស់ មាស មុត។ នៅពេលនោះមានជម្លោះជាមួយប្រទេសថៃ និងវៀតណាម ពាក់ព័ន្ធនឹងរឿងដែនសមុទ្រ។ ក្រោយមក នៅដើមឆ្នាំ១៩៧៦ អង្គការបានចាប់មេបញ្ជាការវរៈសេនាតូច ចំនួន៣នាក់ ហើយនិងអ្នកជិតស្និទ្ធរបស់ពួក

គេចំនួន៦នាក់ រួមទាំងខ្ញុំផងដែរ"]។ ឯកសារ D114/85 កំណត់ហេតុស្ដាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.18-20 [ អំពីការចាប់ខ្លួនរបស់ គង់ គៀន ហៅ អ៊ឹង វ៉េត៖ "ខ្ញុំក៏ស្គាល់គាត់ដែរ ព្រោះគាត់ធ្លាប់បង្រៀនពួកខ្ញុំ និងធ្លាប់និយាយជាមួយពួកខ្ញុំ។ គ្រប់គ្នាគឺបានដឹងពីការចាប់ខ្លួនរបស់គាត់ ព្រោះគាត់ជាមនុស្សលេចធ្លោម្នាក់ដែរ។ កាលនោះ គាត់រស់នៅព្រលានយន្តហោះកងកេងតែម្ដង [...] ឆ.19៖ ប្រហែល១ខែក្រោយពីការចាប់ខ្លួន ខឹម និង ឆាន គឺគេចាប់ខ្លួនអ្នកដែលនៅក្រោមៗពួកគាត់ ហើយការចាប់ខ្លួនទាំងនេះក៏មិនត្រូវបានប្រកាសជាសាធារណៈដែរ។ ស៖ តើការប្រកាសនោះគឺធ្វើឡើងដោយ មាស មុត មែនទេ? ឆ.20៖ ត្រឹមត្រូវហើយ គឺការប្រកាសធ្វើឡើងដោយ មាស មុត"]។ ឯកសារ D54/7 កំណត់ហេតុស្ដាប់ចម្លើយ ឌុល សុង ឆ.16 ["តាមការយល់ដឹងរបស់ខ្ញុំ ក្នុងនាមជាមេបញ្ជាការកងពលទ័ពជើងទឹក មាស មុត គាត់ទទួលខុសត្រូវក្នុងរឿងព្រំដែនទឹក ធ្វើការសម្រិតសម្រាំងប្រវត្តិរូបរបស់យោធាជើងទឹក សម្រេចចាប់ចង និងសម្លាប់អ្នកណាដែលធ្វើខុស"]។ ឯកសារ D54/8 កំណត់ហេតុស្ដាប់ចម្លើយ ឌុល សុង ឆ.2-3 ["ស៖ មុនពេលយើងផ្អាកការសម្ភាសន៍ពីម្សិលមិញ លោកបាននិយាយប្រាប់យើងថា ការទទួលខុសត្រូវរបស់មេបញ្ជាការកងពលដូចជា មាស មុត គឺធ្វើការសម្រិតសម្រាំងចាប់ចងសម្លាប់អ្នកដែលធ្វើខុស។ សូមលោកពន្យល់ប្រាប់យើងអំពីអ្នកដែលធ្វើខុសសំដៅទៅលើអ្នកណា? ឆ.2៖ អ្នកធ្វើខុស គឺសំដៅទៅលើ យោធាក្នុងកងពលដែលបានប្រព្រឹត្តខុស។ ស៖ កំហុសប្រភេទណាខ្លះនៅក្នុងកងពល ១៦៤ ដែលអាចឈានទៅរកការចាប់ចងនិងសម្លាប់? ឆ.3៖ ខ្ញុំមិនដឹងច្បាស់ទេ ថាតើកំហុសប្រភេទណា ដែលអាចឈានទៅដល់ការចាប់ចងនិងសម្លាប់នោះ។ ខ្ញុំមានឧទាហរណ៍ខ្លះ សម្រាប់ការចាប់ចង។ បើយោធាណាដែលមានបងប្អូននៅឯមូលដ្ឋាន "នៅស្រុកភូមិ" ត្រូវបានគេចាប់ដោយចោទថាក្បត់ យោធានោះក៏ត្រូវគេចាប់ខ្លួនពីក្នុងកងដែរ។ ដូចជាឧទាហរណ៍ ប្រធានកងវរៈសេនាធំត្តី បើគាត់ត្រូវគេចាប់ខ្លួន គ្រួសារប្រពន្ធគាត់ក៏ត្រូវគេចាប់ខ្លួនដែរ។ ប៉ុន្តែខ្ញុំមិនដឹងថា គេយកពួកគាត់ទៅធ្វើអ្វីទេក្រោយពីការចាប់ខ្លួន។ នៅក្នុងពេលនោះ ជាទូទៅ បន្ទាប់ពីគេចាប់ខ្លួននរណាម្នាក់ហើយ អ្នកនោះបាត់ខ្លួនរហូត។ បើយោធាណាត្រូវបានគេដកចេញពីកង យោធានោះអាចត្រូវគេបញ្ជូនទៅធ្វើការនៅកន្លែងផ្សេង។ បើយោធាណាត្រូវគេចាប់ខ្លួន យោធានោះត្រូវបាត់ខ្លួនរហូត។ ដូចដែលខ្ញុំបានជំរាបបើសិនជាមេបញ្ជាការវរៈសេនាធំណាត្រូវបានគេចាប់ខ្លួនដោយចោទថាក្បត់ ថាជា KGB ឬ CIA ប្រពន្ធកូនគាត់ នីរសារ និងអ្នកជិតដិតក៏ត្រូវចាប់ខ្លួនដែរ។ ជាពិសេស ពួកអ្នកដែលត្រូវបានចោទថា ជាប់ទាក់ទងនឹងខ្សែយួន"]។ សូមមើល ឧទាហរណ៍ ឯកសារ D54/44 កំណត់ហេតុស្ដាប់ចម្លើយ លុន សេង ឆ.19 ["ស៖ ហេតុអ្វីបានជាលោកដឹងថាមានយោធា ១៥០០នាក់មកពីភូមិភាគបូព៌ា គេយកទៅដាក់នៅកងផលិតធំ? ឆ.19៖ ប្រធានកងពល មាស មុត បានបើកការប្រជុំ ហើយប្រកាសថា ពួកយោធាទាំងអស់ដែលមកពីភូមិភាគបូព៌ា គឺជាយោធាដែលមានសមាសភាពមិនល្អ ដូច្នេះពួកគេត្រូវតែដកចេញឲ្យដាច់ពីកងពល។ ខ្ញុំមិនអាចនិយាយឲ្យច្បាស់បានទេ ប៉ុន្តែខ្ញុំជឿថា វាមានការប្រកួតប្រជែងគ្នានៅក្នុងថ្នាក់ដឹកនាំរបស់កងពល ដែលបណ្ដាលឲ្យយោធាទាំងនេះមិនអាចដាក់បញ្ចូលគ្នាបាន"]។ ឯកសារ D59/2/2.16a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH 00735601-02 ["ស៖ ប៉ុន្តែអ្នកសួរចម្លើយអីហ្នឹងបញ្ជូនបញ្ចេញ [ពីវត្តឥន្ទញាណ] អីគឺ តាមុត? ឆ៖ ហ្នឹងហើយ មាស មុត ទេជាអ្នកបញ្ជូនបញ្ចេញ។ [...] ស៖ ឃើញ តាមុត គាត់អាសារចេញចូលនៅហ្នឹងដែរ? ឆ៖ បាទ!"]។

245 សូមមើល ឧទាហរណ៍ ឯកសារ D4.1.786 កំណត់ហេតុស្ដាប់ចម្លើយ ពេជ្រ ជឹម KH 00373477-78 ["ខ្ញុំសូមលើកយកឧទាហរណ៍ជាក់ស្ដែងមួយដែល តាម៉ុក បានមកណែនាំផ្ទាល់នៅនឹងមន្ទីរស្រុករបស់ខ្ញុំ ដែលនៅពេលនោះមាន តាមុត មកជួបខ្ញុំនៅមន្ទីរស្រុកដែរ។ តាម៉ុក បានស្ដីបន្ទោសឲ្យតាមុត ពីរឿងបញ្ហាគេឲ្យទៅសម្លាប់មិត្ត កង ជា ជាអ្នក

យាមគ្រាប់ឲ្យលោក សឿង ហៅ កឹត ជាមេទ័ពកងពល ថាលោកចៅហ្វាយខេត្តម៉េចចេះតែសម្លាប់កម្លាំងអញ បើឯងមិនស្គាល់ច្បាស់ម៉េចក៏មិនសួរមិត្ត ជីម។ ហើយតាម៉ុក បានប្រាប់ថា ថ្ងៃក្រោយកុំឲ្យធ្វើអ៊ីចឹងទៀត។ រឿងហេតុមានដូច្នេះ ថ្ងៃមួយ មុត បានទទួលសេចក្តីរាយការណ៍ពី ញ៉ែវ ថាឈ្មោះ កង ជា មានគ្រាប់កាំភ្លើងលាក់នៅក្នុងត្រង់សេ។ តាមុតបានទទួលសេចក្តីរាយការណ៍ហើយ ពេលល្ងាចនោះជិតយប់ហើយ គាត់បានមកមន្ទីរស្រុកជួបខ្ញុំ ហើយបញ្ជាឲ្យខ្ញុំទៅហៅ កង ជា មកជួបគាត់។ ពេលនោះ ខ្ញុំនិងកងឈ្លបម្នាក់ក៏បានទៅហៅ កង ជា ប៉ុន្តែខ្ញុំបាននិយាយជាមួយ តាមុត ថា កង ជា មិនអីទេ តែតាមុតនៅតែឲ្យទៅហៅ ខ្ញុំក៏ទៅហៅ កង ជា ដោយប្រាប់ថា តាមុត ឲ្យហៅ។ ពេលនោះឈ្លបជាអ្នកនាំ កង ជា មកជួបតាមុត ខ្ញុំមិនបានជួបតាមុតទេ។ ពេលពាក់កណ្តាលយប់ខ្ញុំឮសូរ ស្នូរគ្រាប់កាំភ្លើងអាកានៅក្នុងព្រៃ។ លុះព្រលឹមឡើងខ្ញុំហៅកងឈ្លបនោះមកសួរថាម៉េចហើយ មិត្តជា។ ឈ្លបនោះឆ្លើយថា មិត្តជា បង្ហើយស្រេចហើយ។ រឿងនេះកើតឡើងប្រហែលនៅក្នុងឆ្នាំ១៩៧៤។ ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៥ តាម៉ុក ក៏ធ្លាប់មានការណែនាំនៅក្នុងអង្គប្រជុំផងដែរ កុំឲ្យមានការសម្លាប់ផ្តេសផ្តាស"]។ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.30-31 ["សៈ ហេតុអ្វីបានជាលោកនិយាយថា យោធាមកពីកងពល១៦៤ ជាអ្នកសម្លាប់ប្រជាជន១៧ មេសាទាំងនោះ? ឆ.30៖ ពីព្រោះតំបន់នោះ ស្ថិតក្រោមការគ្រប់គ្រងរបស់ មាស មុត គឺចាប់ពីវាលរិញមក។ សៈ តើលោកធ្លាប់ទៅដល់កន្លែងសម្លាប់ ហើយនិងកន្លែងកប់សាកសពនោះដែរឬទេ? ឆ.31៖ ទេ ខ្ញុំមិនដែលចូលទៅកន្លែងនោះទេ ប៉ុន្តែយោធាដែលជាអ្នកឃ្លាលទានៅទីនោះជាអ្នកចង្អុលប្រាប់ខ្ញុំពីកន្លែងសម្លាប់នោះ"]។ ឯកសារ D54/56 របាយការណ៍នៃសកម្មភាពស៊ើបអង្កេត មាស វឿន KH 01001517 ["មាស វឿន ថ្លែងថាមានការអះអាងថា ឡញ រួចពីការចាប់ខ្លួន/ការប៉ុនប៉ងធ្វើឃាតផ្តួចផ្តើម/បញ្ជាដោយ មាស មុត ក្នុងចុងឆ្នាំ ១៩៧៨/ដើមឆ្នាំ ១៩៧៩"]។ ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ន សុត ឆ.5 ឆ.70 ["សៈ តើអ្វីដែលបានអានជូនលោកស្តាប់មុននេះត្រឹមត្រូវឬទេ? តើមានកំហុសឈ្មោះ ឬអក្ខរាវិរុទ្ធដែលលោកចង់កែតម្រូវដែរឬទេ? ឆ.5៖ គឺមានកំហុសច្រើន។ កងទ័ពតំបន់ពិសេស កងវរសេនាតូច៣៨៦ ត្រូវបានបញ្ចូលទៅក្នុងកងពលធំទី៣ក្រោយរំដោះឆ្នាំ១៩៧៥។ ដល់ចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ បានចាប់មេបញ្ជាការទាំងអស់ចោទថាតំបន់ហ្នឹងក្បត់។ ក្រោយចាប់អស់ ក៏រំលាយពួកខ្ញុំ ហើយបញ្ជូនយកទៅធ្វើស្រែ។ បើសិនជាបងប្អូនមិនធ្វើតាម គឺត្រូវគេសម្លាប់ចោល។ និយាយរួមទៅគឺមកពីតាមុត ហ្នឹងតែម្តងដែលជាអ្នកបញ្ជា។ រួចពីហ្នឹងចូលទៅឆ្នាំ១៩៧៩ ដល់ពេលអ្នកសង្គ្រោះជាតិចូលមក ក៏បានចាប់ពួកខ្ញុំយកទៅវៃវិញ គេបំពាក់អាវុធឲ្យយើងវិញដើម្បីប្រយុទ្ធជាមួយរណសិរ្សសង្គ្រោះជាតិ។ យើងអត់ចេះអីទេ តែគេបានរុញយើងឲ្យទៅបើករថក្រោះ ហើយយើងក៏ត្រូវតែបើក បើមិនអ៊ីចឹងទេគេនឹងសម្លាប់យើង [...] សៈ ដើម្បីបញ្ជាក់ឲ្យច្បាស់ ពេលលោកនិយាយពីមុនថា គឺពួកមនុស្សរបស់តាមុតដែលគេបញ្ជូនមករំសាយពួកលោក និងវរសេនាធំរបស់លោក។ តើហេតុអ្វីបានជាលោកដឹងថាពួកអ្នកទាំងនោះថាពួកគេធ្វើតាមបញ្ជារបស់តាមុត? ឆ.70៖ បើមិនធ្វើតាមយ៉ាងម៉េច មិនកុន បើមិនធ្វើតាមស្លាប់បាត់ គេសម្លាប់ដែរហ្នឹង។ បើវាមិនធ្វើស្លាប់មុនយើងទៅទៀត"]។

246 ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា ឆ.11-15 ឆ.23 ["សៈ តើកាលនោះ តាមុត មានមុខនាទី ឬតួនាទីអ្វីដែរ នៅក្នុងកងទ័ពភូមិភាគនិរតី? ឆ.11៖ គាត់ជាប្រធានកងពលលេខ៣ ហើយក្រោយពីគាត់ទៅកំពង់សោម គាត់នៅតែជាប្រធានកងពលដដែល។ សៈ តើតាមុត មានសិទ្ធិអំណាចអ្វីខ្លះ ក្នុងនាមជាមេកងពលលេខ៣ ប្រចាំការនៅកំពង់សោម? ឆ.12៖ គាត់មានសិទ្ធិអំណាចបញ្ជាទៅកងវរៈសេនាធំ និងកងវរៈសេនាតូចទាំងអស់ក្រោមកងពលលេខ៣ ក្នុងនោះរួមទាំងនាវាផ្សេងៗផង ដើម្បីឲ្យទៅការពារត្រង់នេះត្រង់នោះ ហើយទៅចាប់ទូក ឬកប៉ាល់ដែលបាន

ចូលមកក្នុងដែនសមុទ្រខ្មែរ។ សៈ តើនៅក្នុងកងពលលេខ៣មានអ្នកណាខ្ពស់ជាង មាស មុត ទៀតទេ? ឆ.13៖ ទេ មិនមានទេ។ មាស មុត គឺជាប្រធានគេទាំងអស់។ សៈ លោកនិយាយថា តាមុត មានសិទ្ធិអំណាចបញ្ជាអង្គភាពយោធា។ យើងគាត់មានសិទ្ធិអំណាចយ៉ាងម៉េចដែរចំពោះប្រជាជនទូទៅនៅកំពង់សោម? ឆ.14៖ គាត់ក៏មានសិទ្ធិអំណាចបញ្ជាទៅតាមសហករណ៍ និងមេឃុំដែរ។ តាមពិតទៅ ពុំមានប្រជាជនធម្មតារស់នៅកំពង់សោម ឬនៅតាមកោះទេ គឺសុទ្ធតែយោធាទាំងអស់ [...] សៈ តើលោកដឹងមកពីអ្នកណា ដែលថា មាស មុត មានសិទ្ធិអំណាចបញ្ជាលើប្រធានសហករណ៍ និងមេឃុំនោះ? ឆ.15៖ ខ្ញុំឮគេនិយាយតៗគ្នា ថាគាត់មានសិទ្ធិបញ្ជាប្រជាជនធម្មតា។ ខ្ញុំដឹងច្បាស់ថាគាត់មានសិទ្ធិបញ្ជាអង្គភាពយោធា [...] សៈ តើមានស្ថាប័ន ឬអង្គភាពណានៅកំពង់សោម ដែលមានសិទ្ធិអំណាចលើកងពលលេខ៣ដែរឬទេ? ឆ.23៖ ទេ មិនមានទេ។ តាមុត ដែលជាប្រធានកងពល គឺជាអ្នកមានសិទ្ធិអំណាចធំជាងគេ។ តាមុត កាចណាស់។ គាត់អាចវ៉ៃ និងបាញ់ អ្នកណាម្នាក់យ៉ាងងាយ"]។ ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ិន សុត ឆ.5 ឆ.39-43 ឆ.54-55 ឆ.69-70 ឆ.77 ["និយាយរួមទៅគឺមកពីតាមុត ហ្នឹងតែម្តងដែលជាអ្នកបញ្ជា [...] សៈ តើលោកដែលធ្លាប់ឮ ទីកន្លែងមួយឈ្មោះទឹកសាបដែរឬទេ? ឆ.39៖ ចឹមិនដែល។ អាហ្នឹងជាកន្លែងសម្រាប់ដាក់អ្នកទោស ដាក់ពួកខ្ញុំ អ្នកធ្វើស្រែជាមួយខ្ញុំពេលដែលធ្វើខុស គេយកដាក់នៅហ្នឹង [...] សៈ តើលោកដឹងដោយរបៀបណា? ឆ.40៖ ចឹក៏មិនដឹង ពេលធ្វើខុសគេប្រាប់ថាអ៊ីចឹង។ គេប្រជុំប្រាប់ថា "មិត្តឯងប្រយ័ត្នណា តែមិត្តឯងធ្វើខុសគេបញ្ជូនទៅទឹកសាបហើយ"។ សៈ តើលោកចាំថាអ្នកណានិយាយបែបហ្នឹងដែរ? ឆ.41៖ អាហ្នឹងគ្នាយើងចេះតែដឹង ចេះតែឮបន្តិចៗអ៊ីចឹងទៅ ហើយអ្នកនិយាយគឺជាមេក្រុមៗនៅក្នុងសហករណ៍ ពួកគេនិយាយប្រាប់យើងត្រង់ៗអ៊ីចឹង ប៉ុន្តែខ្ញុំមិនដែលបានឃើញដោយផ្ទាល់ទេ។ សៈ តើមេក្រុមទាំងនោះស្ថិតនៅក្រោមបញ្ជារបស់អ្នកណាដែរ? ឆ.42៖ នៅក្រោមបញ្ជារបស់តាមុត ដែរ។ សៈ ក្នុងឋានៈជាមេក្រុមគឺស្ថិតនៅឆ្ងាយណាស់ពីតាមុត តើហេតុអ្វីបានជាលោកនិយាយបែបនេះ? ឆ.43៖ គឺមាននីរសារមកពីកំពង់សោមមកដល់សហករណ៍ [...] សៈ តើហេតុអ្វីបានជាលោកដឹងថាកម្លាំងដែលចាប់ទូកនោះស្ថិតនៅក្រោមបញ្ជាតាមុត? ឆ.54៖ បើគាត់ជាអ្នកបញ្ជា គាត់ជាមនុស្សតែម្នាក់ដែលចេញបញ្ជា។ សៈ សូមលោកពន្យល់បន្ថែម តើហេតុអ្វីបានជាលោកដឹង? ឆ.55៖ មុនចាប់អីមួយ គឺគេប្រើ C25 តេអូដើម្បីទាក់ទងទៅមេ ដើម្បីសួរមេថាតើចាប់ឬអត់ តែមេថាឲ្យចាប់គឺចាប់ហើយ [...] សៈ ក្នុងសំណួរចម្លើយទី១៧ លោកបាននិយាយថាយោធាតំបន់៣៧ទាំងអស់ត្រូវបានចាប់ខ្លួនដោយមនុស្សរបស់តាមុត តើលោកចង់សំដៅទៅលើអ្នកណា? ឆ.69៖ យើងអត់ដឹង អ្នកណាចាប់។ យើងម៉េចដឹង។ ការពិតវាបញ្ជាដូច ឧទាហរណ៍ដូចថាផ្ទះមួយមានអ្នកគ្រប់គ្រងនៅទីនោះ ហើយអ្នកបញ្ជានៅកន្លែងផ្សេងគឺគេមិនមកចាប់ដោយខ្លួនឯងទេ តែគេបញ្ជាអ្នកគ្រប់គ្រងផ្ទះនោះឲ្យមកចាប់ខ្លួន។ មានមេវានៅហ្នឹង ឧទាហរណ៍ថាបើគេចង់ធ្វើបាបខ្ញុំ វាមាននីរសារមួយដែលនីរសារវាមានម៉ូតូមួយគ្រឿង [...] សៈ ដើម្បីបញ្ជាក់ឲ្យច្បាស់ ពេលលោកនិយាយពីមុនថា គឺពួកមនុស្សរបស់តាមុតដែលគេបញ្ជូនមករំសាយពួកលោក និងវរសេនាធំរបស់លោក។ តើហេតុអ្វីបានជាលោកដឹងថាពួកអ្នកទាំងនោះថាពួកគេធ្វើតាមបញ្ជារបស់តាមុត? ឆ.70៖ បើមិនធ្វើតាមយ៉ាងម៉េច មិនកុន បើមិនធ្វើតាមស្លាប់បាត់ គេសម្លាប់ដែរហ្នឹង។ បើវាមិនធ្វើស្លាប់មុនយើងទៅទៀត [...] ហើយ១៩៧៩ វ៉ៃជាមួយវៀតណាម។ វ៉ៃនៅស្មាច់ដែង ហើយនិងទឹកសាប ការវ៉ៃ គឺវ៉ៃរយៈពេលខ្លីទេ គឺប្រហែលជាម៉ោង៤ ពួកខ្ញុំដកទៅស្រែអំបិលអស់ [...] សៈ តើកាលនោះតាមុតបញ្ជាទ័ពដែរឬទេ? ឆ.77៖ បាទ គឺបញ្ជា ជាមួយតាសេង។ តាមុត គឺជាអ្នកបញ្ជាផ្ទាល់"]។ ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.39 ឆ.46-47 ["ខ្ញុំមិនបានធ្វើការងារអ្វីពាក់ព័ន្ធនឹងឯកសារផ្ទាល់ខ្លួនទាំងនេះឡើយ។ ឯកសាររបស់យោធា

82. មាស មុត ក៏មានអំណាចផងដែរក្នុងការតែងតាំង ដំឡើងឋានន្តរសក្តិ និងដកកម្មាភិបាលយោធា និងស៊ីវិលនៅក្នុងកងពល ១៦៤ និងនៅក្នុងតំបន់កំពង់សោម។ នៅក្នុងអំឡុងនៃកម្ពុជាប្រជាធិបតេយ្យ មេបញ្ជាការវរៈសេនាធំ និងវរៈសេនាតូចជាច្រើនបានឡើងឋានន្តរសក្តិខ្ពស់ៗ កាន់មុខនាទីផ្សេងៗនៅក្នុងកងពល ដែលជានិច្ចជាកាល ស្ថិតក្រោមការបញ្ជារបស់ មាស មុត[248]។ កម្មាភិបាល

---

ម្នាក់ៗ ត្រូវបានពិនិត្យឡើងវិញដោយគណកម្មាការពិសេសរបស់កងពលធំ ដែលគេហៅថា "គណកម្មាការត្រួតពិនិត្យ"។ ខ្ញុំមិនដឹងថាតើមានមនុស្សប៉ុន្មាននាក់ធ្វើការក្នុងគណកម្មាការត្រួតពិនិត្យនេះទេ ប៉ុន្តែខ្ញុំដឹងថាពួកគេបានបញ្ជូនទាហានដែលគេទុកចិត្តទៅភូមិកំណើតរបស់យោធាដើម្បីពិនិត្យប្រវត្តិរូបរបស់ពួកគេ។ គណកម្មាការនេះ បានឲ្យកងវរៈសេនាធំ ធ្វើការជ្រើសរើសយោធាដែលទុកចិត្តមួយចំនួនឲ្យចុះទៅពិនិត្យប្រវត្តិរូបនៅតាមភូមិកំណើតរបស់យោធា [...] សៈ តើធ្វើម្តេចបានលោកដឹងថា មាស មុត ជាអ្នកបង្កើតគណកម្មាការនេះ? ឆ.46៖ គាត់ជាអ្នកទទួលខុសត្រូវកងពលធំ១៦៤ ដូច្នេះអ្វីគឺសុទ្ធតែចេញពីគាត់ទាំងអស់ គឺពុំមានអ្នកណាខ្ពស់ជាង មាស មុត ទៀតឡើយ។ ដូច្នេះគណកម្មាការនេះ គឺត្រូវបានបង្កើតឡើងដោយ មាស មុត។ ខ្ញុំគិតថា មាស មុត បានបញ្ជាឲ្យបង្កើតគណកម្មាការនេះពីថ្នាក់លើ។ សៈ ហេតុអ្វីបានជាលោកគិតថា ការបញ្ជាឲ្យបង្កើតគណកម្មាការត្រួតពិនិត្យនេះមានប្រភពពីថ្នាក់លើ? ឆ.47៖ ដោយសារតែគេនិយាយថាផែនការមានប្រភពចេញពីថ្នាក់លើមក"]។

247 ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.20-21 ["ខ្ញុំមិនដែលឃើញមនុស្សណា ដែលមានលក្ខណៈឫកពារដូច តាមុត ទេ។ គាត់តឹងរ៉ឹងណាស់។ គាត់តែហៅបញ្ជាការវរៈសេនាធំ និងវរៈសេនាតូចឲ្យទៅកន្លែងគាត់ ហើយទទួលបញ្ជាពីគាត់។ ពួកមេបញ្ជាការវរៈទាំងនោះ យល់ច្បាស់ណាស់ថា អ្វីដែលគេនឹងត្រូវធ្វើទៅតាមបញ្ជារបស់តាមុត។ បើគេធ្វើតាមបញ្ជាគាត់ពុំមានជោគជ័យ គេនឹងមានបញ្ហាមិនខាន។ សៈ តើលោកដឹង ពីរបៀបនេះ តាមរបៀបណា? ឆ.21៖ យើងដឹងអំពីលក្ខណៈរបស់គាត់ ដោយសារកងរបស់យើង ធ្លាប់នៅជិតក្បែរកន្លែងគាត់។ គាត់មានផ្ទះមួយ នៅជិតផ្សារលើ ហើយមួយទៀតនៅជិតវត្តឱន្តញាន"]។

248 ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង សុំ ឆ.36 ឆ.229 ឆ.267 ឆ.269 ["តាមុត ជាប្រធាន, តា ឌឹម ជាអនុ ហើយតា ឆាង ជាសមាជិកកងពល [...] ឆ.229៖ [...] តាញ៉ាន់ គឺជាអនុកងពល ១៦៤ ជាអ្នកក្តាប់ខាងភស្តុភារ [...] សៈ អ្នកណាជាបញ្ជាការរងកងពល? ឆ.267៖ តាឌឹម និងតា ឆាន។ ខ្ញុំចាំតែប៉ុណ្ណឹងទេ នោះគឺអ្វីដែលខ្ញុំដឹងផ្ទាល់ ខ្ញុំមិនដឹងពីអ្វីដែលកើតឡើងនៅតំបន់បូព៌ាឡើយ។ ខ្ញុំគ្រាន់តែឮប៉ុណ្ណោះ [...] ឆ.269៖ តាឆានជាអនុបញ្ជាការកងពល"]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន ឆ.25 ឆ.111 ["សៈ តើមានអ្នកណាផ្សេងទៀត ជាសមាជិកកងពល? ឆ.25៖ ញ៉ាន់ (ស្លាប់)។ គាត់ជាមនុស្សមកពីកងពលទី៣ [...] ឆ.111៖ ឈ្មោះ ឡុន (ស្លាប់) និងឈ្មោះ ញ៉ាន់ (កាន់ភស្តុភារកងពលលេខ៣)"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ ក៏ម ម៉េន ឆ.31 ឆ.126 ឆ.207 ["ក្រោយពីដាក់ទ័ពវាយតាមកោះ គេរៀបចំកងពលសាជាថ្មី ទៅជាកងពលលេខ១៦៤ ដោយមាន មាស មុត ជាមេបញ្ជាការ ឌឹម ជាអនុប្រធាន (មកពីខេត្តព្រៃវែង) និង ឆាន ជាសមាជិក [...] ឆ.126 ៖ [...] ដូចជា បងញ៉ាន់ ជាដើម ម្នាក់ទៀតខ្ញុំភ្លេចឈ្មោះហើយ មកធ្វើជាអនុរបស់ មាស មុត [...] សៈ កាលពីម្សិលមិញលោកបានប្រាប់យើងថា ក្រោយពី តាឌឹម និង ឆាន បញ្ជូនចេញមក គឺ ញ៉ាន់ ទៅជំនួស។ តើពេលដែលបញ្ជូនកម្មាភិបាលទៅបូព៌ានោះ តើ តាញ៉ាន់ ទៅជាមួយទេ? ឆ.207៖ ទេ"]។ ឯកសារ D2/16 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច

ឆ.12 ["នៅពេលនោះ មាស មុត មានមុខងារជាប្រធានកងពល ហើយ តាញ៉ាន ជាសមាជិកកងពល [១៦៤]"]។ សូមកត់សម្គាល់ថា សាក្សីម្នាក់ក៏អះអាងថា តា អ៊ឹម គឺជាអនុមេបញ្ជាការកងពល១៦៤ទទួលបន្ទុកភស្តុភារដែរ៖ ឯកសារ D54/20 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.14 ["គេឲ្យទៅធ្វើពលកម្មនៅព្រលានយន្តហោះកងកេងរយៈមួយខែ។ វាជាការងារដ៏លំបាក ខ្ញុំទៅធ្វើស្រែនៅកងចល័តស្ថិតនៅក្រោមតា អ៊ឹម។ តាអ៊ឹមជាកម្មាភិបាលជាន់ខ្ពស់បន្ទាប់ពី មាស មុត។ អ៊ឹម ជាអ្នកមើលការងារនៅការដ្ឋានកងកេង ហើយគាត់ជាអនុមេបញ្ជាការកងពល១៦៤ទទួលបន្ទុកភស្តុភារ។ តាមដែលខ្ញុំដឹង អ៊ឹម ប្រហែលជាសាច់ញាតិរបស់ មាស មុត តែខ្ញុំមិនដឹងថា គាត់ជាបងប្អូនបង្កើត ឬជាជីដូនមួយទេ"]។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ឆ.9 ["បន្ទាប់ពីកងទ័ពជើងទឹកត្រូវបានបង្កើតឡើង ឈ្មោះ សេង ក្លាយជាអនុមេបញ្ជាការវរៈសេនាធំ ១៤០។ ក្រោយមកទៀត គាត់បានក្លាយជាអនុមេបញ្ជាការកងពល១៦៤"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.28 ["ក្រោយពេល ទឹម សេង ត្រូវបានឡើងជាប្រធានកងពល១៦៤ ជំនួស មាស មុត នៅឆ្នាំ១៩៧៩ នៅពេលដែលការប្រយុទ្ធគ្នាខ្លាំងជាមួយវៀតណាម តាហន ត្រូវបានឡើងជាមេបញ្ជាការកងវរសេនាធំ ១៤០"]។ ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ឆ.3 ["សេង ប្រាប់ខ្ញុំថា មាស មុត គឺជាជំនួយការរបស់សេនាធិការ។ សេង ដឹងរឿងនេះ ពីព្រោះពេលតាមុត មិននៅកំពង់សោម គឺ សេង ទទួលខុសត្រូវជំនួស"]។ ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល់ ឆ.26 ["តាមុត គឺជាមេកងពល ហើយគាត់ និងតាសេង ជាអ្នកកាន់កងពល។ តាមុត ជាឋានានុក្រមថ្នាក់លើ និងកាន់កងពលយូរមកហើយ។ នៅពេល តាសេង ចូលមក គាត់ធ្វើការក្រោមតាមុត។ ដូច្នេះ តាមុត មានឋានៈខ្ពស់ជាង តាសេង"]។ ឯកសារ D54/73 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.16 ["អំឡុងពេលដែល មាស មុត អវត្តមាន គឺមាន តាសេង និង តាញ៉ាន់ ប៉ុន្តែខ្ញុំមិនដឹងថាអ្នកណាជាអ្នកទទួលខុសត្រូវកងពលជំនួសទេ"]។ ឯកសារ D59/1/1.11a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាង រ៉េត KH 00926542-43 ["បើនិយាយទៅមាន ទឹម សេង តែស្លាប់បាត់ដែរ មុនដំបូងគាត់គ្រប់គ្រងជើងទឹក ដល់ក្រោយមកគាត់មកគ្រប់គ្រងកងពល១៦៤ហើយ មាស មុត គាត់ឡើងមកធ្វើជាមេបញ្ជាការនៅភ្នំពេញ"]។ ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.30 ["ក្រោយពីការរៀបចំឡើងវិញរបស់កងពល១៦៤នេះ លោក មាស មុត ជាប្រធាន លោក ឌឹម ជាអនុប្រធានដែលមកពីបូព៌ា និងលោក ឆាន ជាសមាជិក"]។ ឯកសារ D54/81 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ិច ឆ.14 ["អនុកងពលឈ្មោះ ឌឹម មកពីភូមិភាគបូព៌ា។ សមាជិកកងពលមកពីខេត្តកោះកុងឈ្មោះបង ឆាន។ ក្រោយមក យ៉ាន មកកាន់កងពល១៦៤ជាមួយ អ៊ំ មុត ដែរ"]។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ឆ.7 ["ក្រោយពីកងពលលេខ ៣ ប្តូរទៅជាកងពល១៦៤ មានមនុស្សម្នាក់ឈ្មោះ តាឆាន ដែលមកពីកោះកុងនៃតំបន់ ៣៧ ជាមួយនឹងយោធាប្រហែលពីរកងវរៈសេនាតូចចូលជាមួយកងពល១៦៤។ តាឆាន មកធ្វើជាអនុម្នាក់របស់កងពល"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.12 ["វានៅមានអនុរបស់គាត់ [មាស មុត] ពីរនាក់ទៀត ឈ្មោះ ឆាន និង ឌឹម"]។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.168 ["តាឆាន នៅកម្រិតកងពលលេខ ៣ គាត់ប្រធានកងពលនៅក្រោមតាមុត"]។ ឯកសារ D114/241 កំណត់ហេតុស្តាប់ចម្លើយ ឆេង ជាង ឆ.87 ["ឆាន អនុ"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.15 ["កងពល១៦៤ហ្នឹង មាន មាស មុត ជាស្នងការធំ ហើយមាន នង ឆាន ជាបញ្ជាការកងពល ១៦៤។ បន្ទាប់មកគឺ ឌឹម ដែលជាបញ្ជាការរង។ បន្ទាប់មកគឺ ង៉ែត ជាសមាជិកកងពល"]។ ឯកសារ D4.1.746 បទសម្ភាសន៍ជាមួយ សំ សុក (US POW/MIA) KH 00742596 ["ម

ទាំងនេះ បានឡើងមកកាន់មុខនាទីជំនួសបណ្ដាកម្មាភិបាលក្នុងបញ្ជីយ៉ាងវែង ដែល មាស មុត "ដក" តាមរយៈការបញ្ជាឲ្យរំសាយ ចាប់ខ្លួន និងសម្លាប់ជនដែលបានចោទថាក្បត់[249]។

ន្ត្រីនយោបាយរបស់កងពលធំលេខ៣ គឺលោក មាស មុត មន្ត្រីប្រតិបត្តិការកងពលធំលេខ៣ គឺ ខំ (ស្លាប់) ហើយមេបញ្ជាការរងនៃកងពលធំលេខ៣ គឺ ឆាន"]។ ឯកសារ D4.1.747 បទសម្ភាសន៍ជាមួយ ឯក នី (US POW/MIA) KH 00640517 ["មន្ត្រីនយោបាយកងពលធំទី៣។ លោក (ណុង) ចាន់ គឺជាមន្ត្រីនយោបាយកងពលធំទី៣"]។

249 ឯកសារ D1.3.28.45 បញ្ជីឈ្មោះអ្នកទោសស-២១ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៧៧ [ចុះបញ្ជីឈ្មោះ ម៉ម ជឹម ហៅ យ៉ាន ជាសមាជិកកងពល១៦៤]។ ឯកសារ D114/145.1.17 បញ្ជីឈ្មោះមនុស្សនៅកងពល ១៦៤ ដែលជាប់ក្នុងចម្លើយខ្មាំង ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៧៧ KH 01177862 [ចុះបញ្ជីឈ្មោះ យ៉ាន ជាសមាជិកកងពល១៦៤]។ ឯកសារ D1.3.28.2 បញ្ជីឈ្មោះអ្នកទោសស-២១ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៧៧ KH 00086997 [ចុះបញ្ជីឈ្មោះ មុំ យ៉ាន ជាសមាជិកកងពល១៦៤ ដែលបានបញ្ជូនទៅស-២១ នៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៧]។ ឯកសារ D54/10 កំណត់ហេតុស្ដាប់ចម្លើយ ម៉ី រ៉េត ឆ.8 ["ស៖ តើលោកមានដឹងថា រឿងរ៉ាវអ្វីកើតឡើងចំពោះ ឆាន ទេក្នុងឆ្នាំ១៩៧៦? ឆ.8៖ ក្រោយមកខ្ញុំបានឮថា តាឆាន ក្បត់ ហើយត្រូវបានគេដកចេញនិងបាត់ខ្លួនរហូត"]។ ឯកសារ D114/104 កំណត់ហេតុស្ដាប់ចម្លើយ អៀម ភង់ ឆ.53 ["តាឆាន គេនាំយកទៅមុន។ តាខឹម គេនាំទៅក្រោយ"]។ ឯកសារ D114/89 កំណត់ហេតុស្ដាប់ចម្លើយ សេង ស៊ីន ឆ.60 ["កាលហ្នឹងអ្នកបញ្ជូនមកពីកោះ ខ្ញុំមិនដឹងថាមានប៉ុន្មាននាក់ទេ តែ មាស មុត ប្រជុំពីបញ្ហាមេក្បត់ គឺអនុមេបញ្ជាការកងពល១៦៤ នង ឆាន ជាអ្នកក្បត់ ហើយ មាស មុត អានចម្លើយសារភាពរបស់ នង ឆាន ហ្នឹង"]។ ឯកសារ D114/116 កំណត់ហេតុស្ដាប់ចម្លើយ ស្វាយ សំអាន ឆ.27 ឆ.31 ["មុំ យ៉ាន គឺជាមនុស្សម្នាក់ដែលស្ថិតនៅក្នុងកងពល១៦៤ នៅក្នុងឆ្នាំ១៩៧៥ […] ស៖ លោកនិយាយថា គាត់បាត់ខ្លួននៅពេលមួយនោះ។ បើតាមបញ្ជីឈ្មោះនេះ មុំ យ៉ាន ត្រូវបានចាប់ខ្លួននៅមុំខែឧសភា ឆ្នាំ១៩៧៧។ តើលោកអាចប្រាប់យើងអំពីកាលៈទេសៈនៃការបាត់ខ្លួនរបស់គាត់បានដែរឬទេ? ឆ.31៖ ខ្ញុំមិនដឹងទេ ប៉ុន្តែគាត់បាត់ខ្លួននៅមុនពេលខ្ញុំចេញទៅភូមិភាគបូព៌ា [នៅក្នុងឆ្នាំ១៩៧៧]"]។ ឯកសារ D54/104 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.5 ["យ៉ាន ជាសមាជិកគណៈកងពល១៦៤ […] ឈ្មោះ យ៉ាន នេះគឺស្ថិតនៅក្នុងចំណោមពួកក្បត់ដែលតាមុត បានលើកមករៀបជាពាក្យជូនដូចកំណាព្យ"]។ ឯកសារ D114/155 កំណត់ហេតុស្ដាប់ចម្លើយ សុខ រ៉េន ឆ.67 ["ស៖ តើនរណាគេជាមេបញ្ជាការកងពល១៦៤? ឆ.67៖ ខ្ញុំបានដឹងតាមព័ត៌មានពីអ្នកស្គាល់ អ្នករួមអាវុធតស៊ូជាមួយគ្នា។ មេកងពល១៦៤ ឈ្មោះ មាស មុត។ បន្ទាប់មក ខ្ញុំអត់ដឹងថា អ្នកណាអនុប្រធានទេ។ ស្គាល់តែ តាខឹម តាយ៉ាន និង តាឆាន។ តាឆាន ចូលរួមកងពល១៦៤"]។ ឯកសារ D54/81 កំណត់ហេតុស្ដាប់ចម្លើយ ហ៊ីង អ៊ិច ឆ.14 ["អនុកងពលឈ្មោះ ខឹម មកពីភូមិភាគបូព៌ា។ សមាជិកកងពលមកពីខេត្តកោះកុងឈ្មោះបង ឆាន។ ក្រោយមក យ៉ាន មកកាន់កងពល១៦៤ជាមួយ អ៊ំ មុត ដែរ"]។ ឯកសារ D54/48 កំណត់ហេតុស្ដាប់ចម្លើយ អែម សុន ឆ.58 ["ស៖ តើលោកដឹងថាមានសមាជិកមកពីកងពល១៦៤ ត្រូវបានគេបញ្ជូនទៅទួលស្លែង ឬស-២១ដែរឬទេ? ឆ.58៖ ខ្ញុំមិនដឹងទេ។ តែខ្ញុំឮថា ង៉ែត និង ស្រស់ ត្រូវបានចាប់ខ្លួន"]។ ឯកសារ D4.1.747 បទសម្ភាសន៍ជាមួយ ឯក នី (US POW/MIA) KH 00640517 ["មន្ត្រីនយោបាយកងពលធំទី៣។ លោក (ណុង) ចាន់ គឺជាមន្ត្រីនយោបាយកងពលធំទី៣។ លោក ត្រូវ

83. មាស មុត ក៏មានអំណាចផងដែរ ក្នុងការដាក់ទណ្ឌកម្មដល់កម្មាភិបាលក្រោមបង្គាប់របស់គាត់។ គាត់ទទួលខុសត្រូវក្នុងការកំណត់ឲ្យច្បាស់ថា កម្មាភិបាលថ្នាក់ក្រោម ពិតជាបានអនុវត្តមាគ៌ា សេចក្តីណែនាំ និងបញ្ជារបស់បក្ស[250] ដែលដាក់ចុះតាមខ្សែបណ្តោយពីកម្រិតកងពលមករហូតដល់អនុសេនាតូច[251]។ គាត់មានអំណាចដាក់ទណ្ឌកម្មជនណាដែលមិនបានអនុវត្តរាល់បញ្ជាណាមួយរបស់គាត់ ហើយយោងតាម "វិន័យបក្ស" មានកាតព្វកិច្ចតម្រូវឲ្យធ្វើបែបនេះ តាមរយៈ "ការពិនិត្យ វិភាគ និងវិនិច្ឆ័យហ្មត់ចត់" ចំពោះអំពើល្មើសនីមួយៗ[252]។

84. ក្នុងការបំពេញភារកិច្ចរបស់គាត់ មាស មុត បង្កើតប្រព័ន្ធកត់ត្រា និងពិនិត្យប្រវត្តិរូបកងទ័ព ដើម្បីរកសមាសភាពខ្មាំង និងសកម្មភាពសង្ស័យ[253]។ គាត់ដាក់ទណ្ឌកម្ម អាស្រ័យតាមទម្ងន់នៃបទ

---

បានសម្លាប់ នៅក្នុងការបោសសម្អាតបុគ្គលិកមេបញ្ជាការពីកងពលធំ ក្នុងឆ្នាំ១៩៧៦ ក្បែរវត្តឥន្ទញាណ នៅកំពង់សោម"]។

ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.8 ["ហើយ ង៉ែត ជាស្នងការវរៈសេនាធំ២០ ង៉ែត ត្រូវបានគេចាប់ក្នុងរយៈពេលបោសសម្អាតប្រហែលក្នុងឆ្នាំ១៩៧៧"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ. 4-5 ["តាមដែលខ្ញុំចាំ ឈ្មោះយ៉ាន មេបញ្ជាការវរៈសេនាធំ២២ ង៉ែត មេបញ្ជាការវរៈសេនាធំ២០ និងមេបញ្ជាការវរៈសេនាតូចរបស់ខ្ញុំឈ្មោះ វេត និងប្រពន្ធគាត់ឈ្មោះរីម ត្រូវបានចាប់ខ្លួន។ [...] ពួកទាំងនោះបាត់ខ្លួនរហូត លើកលែងតែយាយ រីម នៅរស់ [...] ឆ.5៖ គេចាប់ក្នុងឆ្នាំ ១៩៧៧ ឬដើមឆ្នាំ ១៩៧៨"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.64 ["ស៖ តើលោកអាចប្រាប់ឈ្មោះអ្នកដែលលោកស្គាល់ ហើយគេនាំយកទៅនោះបានដែរទេ? ឆ.64៖ មានឈ្មោះង៉ែត ឈ្មោះខឹម ឈ្មោះ យ៉ាន ឈ្មោះឆាន និងឈ្មោះសុខ ជាដើម"]។

[250] ឯកសារ D1.3.22.1 លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា KH 00053024 ["តាមកាលកំណត់នីមួយៗ ថ្នាក់ក្រោម ត្រូវរាយការណ៍ជូនថ្នាក់លើ អំពីសភាពការណ៍ និងអំពីកិច្ចការ ដែលខ្លួនបានធ្វើ"] KH 00053032 ["ចុះជាប់តំបន់ ស្រុក សាខា និងមូលដ្ឋានជាក់ស្តែងរបស់សាខា ក្នុងសហជីព សហករណ៍ និងកងទ័ពបដិវត្តក្នុងភូមិភាគ ដើម្បីដឹកនាំ អនុវត្តភារកិច្ច ក្នុងមហាជន និងផ្ទៃក្នុង ឱយសកម្ម ក្តៅជាប់ ជាផែនការ តាមមាគ៌ានយោបាយការពារប្រទេស និងកសាងប្រទេសកម្ពុជា ប្រជាធិបតេយ្យរបស់បក្ស និងតាមទិសបដិវត្តសង្គមនិយម និងការកសាងសង្គមនិយម របស់បក្ស។"] ។

[251] សូមមើល កថាខណ្ឌ ៨៦។

[252] ឯកសារ D1.3.22.1 លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា KH 00053019 ["ត្រូវអនុវត្តវិន័យ របស់បក្សនេះ ដោយពិនិត្យវិភាគ វិនិច្ឆ័យ ម៉ត់ចត់ ឈរលើលក្ខការណ៍សមូហភាព ដាច់ខាត ហើយក្របខណ្ឌសមូហភាពនេះ ត្រូវលៃលកឱយបានច្រើនថ្នាក់ ទៅតាមសារសំខាន់នៃបញ្ហានីមួយៗទៀតផង"]។

[253] ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.16-17 ["តាមការយល់ដឹងរបស់ខ្ញុំ ក្នុងនាមជាមេបញ្ជាការកងពលទ័ពជើងទឹក មាស មុត គាត់ទទួលខុសត្រូវក្នុងរឿងព្រំដែនទឹក ធ្វើការសម្រិតសម្រាំងប្រវត្តិរូបរបស់យោធាជើងទឹក សម្រេចចាប់ចង និងសម្លាប់អ្នកណាដែលធ្វើខុស។ ស៖ ម៉េចបានជាលោកដឹងថា មេបញ្ជាការកងពលទទួល

ល្មើស ចំពោះបុគ្គលដែលបានកំណត់ថាជា "ខ្មាំង" តាមរយៈការធ្វើស្វ័យទិតៀន ការអប់រំ ការវាយ
ការចាប់ខ្លួន និងការសម្លាប់[254]។ គាត់ចេញបញ្ជាប្រហាក់ប្រហែលគ្នានេះដែរ ចំពោះយុទ្ធជនណា

---

ខុសត្រូវលើការសម្រិតសម្រាំងប្រវត្តិរូបយោធា? ឆ.17៖ ខ្ញុំពុំបានឃើញរឿងរ៉ាវទាំងអស់នោះទេ ប៉ុន្តែនេះជាការសន្និដ្ឋានរបស់ខ្ញុំថា វាជាការទទួលខុសត្រូវរបស់មេបញ្ជាការកងពល។ ចំពោះរឿងសម្រិតសម្រាំង បើសិនជាគេរកឃើញថាមានយោធាណាមានបងប្អូនធ្វើការក្នុងរបបមុន គេនឹងដកយោធានោះចេញ យកទៅដាក់មួយកន្លែងផ្សេង គេដាក់ក្នុងកងផ្សេងឲ្យធ្វើការងារស្រែចំការ។ នៅក្នុងពេលនោះ បើនរណាធ្វើខុសហើយត្រូវគេចាប់ខ្លួន គេមិនមានតុលាការសម្រាប់កាត់ក្តីទេ។ ចំពោះការសម្រិតសម្រាំង នៅក្នុងករណីរូបខ្ញុំផ្ទាល់ គេបានបញ្ជូនអ្នកស៊ើបការទៅភូមិកំណើតរបស់ខ្ញុំ ដើម្បីផ្ទៀងផ្ទាត់ថា ត្រឹមត្រូវ ឬមានបងប្អូនធ្វើការក្នុងរបបមុនៗយ៉ាងដែរឬអត់"]។ ឯកសារ D54/44 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.26-28 ["អំឡុងពេលអប់រំ គឺគេធ្វើការស្រាវជ្រាវអំពីប្រវត្តិរបស់យោធាម្នាក់ៗដោយតាមដានរហូតទៅដល់ស្រុកកំណើតរបស់។ ស៖ តើអ្នកណាជាអ្នកប្រកាសនៅក្នុងពេលអប់រំ? ឆ.27៖ ប្រធានកងពល មាស មុត។ ស៖ តើពាក្យនិយាយថា "តាមដានរហូតដល់ស្រុកកំណើតហ្នឹង" តើជាពាក្យរបស់លោក ឬមួយក៏ជាពាក្យប្រធានកងពល មាស មុត ជាអ្នកថា? ឆ.28៖ ប្រធានកងពល មាស មុត ជាអ្នកណែនាំមេបញ្ជាការវរសេនាធំឲ្យធ្វើការតាមដានប្រវត្តិយោធារបស់ខ្លួនទៅដល់ស្រុកកំណើត ដើម្បីឲ្យដឹងថាមនុស្សនោះមានប្រវត្តិស្អាតស្អំ ឬក៏អត់"]។ ឯកសារ D114/181 កំណត់ហេតុស្តាប់ចម្លើយ សែម កុល ឆ.40 ["ស៖ តើគេឲ្យលោកធ្វើប្រវត្តិរូបតែម្តងហ្នឹងទេឬ? ឆ.40៖ បាទ តែម្តង។ ពេលធ្វើគ្រូបង្រៀន បានធ្វើញឹក ពីរដងក្នុងមួយឆ្នាំ។ កាលជំនាន់នោះ យើងត្រូវលាក់ដូចថា អ្នករៀនខ្ពស់ យើងដាក់រៀនថ្នាក់ទី៧ ទីអីហ្នឹង។ យើងកសិករថ្នាក់កណ្តាល យើងដាក់ថ្នាក់ក្រោមអីចឹង"]។

254 ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.2-3 [យាយប្រាប់យើងថា ការទទួលខុសត្រូវរបស់មេបញ្ជាការកងពលដូចជា មាស មុត គឺធ្វើការសម្រិតសម្រាំងចាប់ចងសម្លាប់អ្នកដែលធ្វើខុស។ សូមលោកពន្យល់ប្រាប់យើងអំពីអ្នកដែលធ្វើខុសសំដៅទៅលើអ្នកណា? ឆ. 2៖ អ្នកធ្វើខុស គឺសំដៅទៅលើ យោធាក្នុងកងពលដែលបានប្រព្រឹត្តខុស។ ស៖ កំហុសប្រភេទណាខ្លះនៅក្នុងកងពល ១៦៤ ដែលអាចឈានទៅរកការចាប់ចងនិងសម្លាប់? ឆ.3៖ ខ្ញុំមិនដឹងច្បាស់ទេ ថាតើកំហុសប្រភេទណា ដែលអាចឈានទៅដល់ការចាប់ចងនិងសម្លាប់នោះ។ ខ្ញុំមានឧទាហរណ៍ខ្លះ សម្រាប់ការចាប់ចង។ បើយោធាណាដែលមានបងប្អូននៅឯមូលដ្ឋាន "នៅស្រុកភូមិ" ត្រូវបានគេចាប់ដោយចោទថាក្បត់ យោធា នោះក៏ត្រូវគេចាប់ខ្លួនពីក្នុងកងដែរ។ ដូចជាឧទាហរណ៍ ប្រធានកងវរៈសេនាធំក្តី បើគាត់ត្រូវគេចាប់ខ្លួន គ្រួសារប្រពន្ធគាត់ក៏ត្រូវគេចាប់ខ្លួនដែរ។ ប៉ុន្តែខ្ញុំមិនដឹងថា គេយកពួកគាត់ទៅអ្វីទេក្រោយពីការចាប់ខ្លួន។ នៅក្នុងពេលនោះ ជាទូទៅ បន្ទាប់ពីគេចាប់ខ្លួននរណាម្នាក់ហើយ អ្នកនោះបាត់ខ្លួនរហូត។ បើយោធាណាត្រូវបានគេដកចេញពីកងយោធានោះអាចត្រូវគេបញ្ជូនទៅធ្វើការនៅកន្លែងផ្សេង។ បើយោធាណាត្រូវគេចាប់ខ្លួន យោធានោះត្រូវបាត់ខ្លួនរហូត។ ដូចដែលខ្ញុំបានជំរាប បើសិនជាមេបញ្ជាការវរៈសេនាធំណាត្រូវបានគេចាប់ខ្លួនដោយចោទថាក្បត់ ថាជា KGB ឬ CIA ប្រពន្ធកូនគាត់នីរសារនិងអ្នកជិតដិតក៏ត្រូវចាប់ខ្លួនដែរ។ ជាពិសេស ពួកអ្នកដែលត្រូវបានចោទថា ជាប់ទាក់ទងនឹងខ្មែរយួន"]។ ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ន សុត ឆ.5 ["ស៖ តើអ្វីដែលបានអានជូនលោកស្តាប់មុននេះត្រឹមត្រូវឬទេ? តើមានកំហុសឈ្មោះ ឬអក្ខរាវិរុទ្ធដែលលោកចង់កែតម្រូវដែរឬទេ? ឆ.5៖ គឺមានកំហុស

ដែលមិនគោរពបញ្ជា ឬគ្រាន់តែមានកំហុស[255]។ អតីតយុទ្ធជនម្នាក់នៃវរសេនាតូច៣៨៦ បញ្ជាក់ថា បើយុទ្ធជន "មិនធ្វើតាម [មាស មុត] យ៉ាងម៉ឺច មិនកុន បើមិនធ្វើតាមស្លាប់បាត់ គេសម្លាប់ដែរហ្នឹង។ បើវាមិនធ្វើស្លាប់មុនយើងទៀត"[256]។

---

ច្រើន។ កងទ័ពតំបន់ពិសេស កងវរសេនាតូច៣៨៦ ត្រូវបានបញ្ចូលទៅក្នុងកងពលធំទី៣ក្រោយរំដោះឆ្នាំ១៩៧៥។ ដល់ចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ បានចាប់មេបញ្ជាការទាំងអស់ចោទថាតំបន់ហ្នឹងក្បត់។ ក្រោយចាប់អស់ ក៏រំលាយពួកខ្ញុំ ហើយបញ្ជូនយកទៅធ្វើស្រែ។ បើសិនជាបងប្អូនមិនធ្វើតាម គឺត្រូវគេសម្លាប់ចោល។ និយាយរួមទៅគឺមកពីតាមុត ហ្នឹងតែម្តងដែលជាអ្នកបញ្ជា។ រួចពីហ្នឹងចូលទៅឆ្នាំ១៩៧៩ ដល់ពេលអ្នកសង្គ្រោះជាតិចូលមក ក៏បានចាប់ពួកខ្ញុំយកទៅវៃវិញ គេបំពាក់អាវុធឲ្យយើងវិញដើម្បីប្រយុទ្ធជាមួយរណសិរ្សសង្គ្រោះជាតិ។ យើងអត់ចេះអីទេ តែគេបានរុញយើងឲ្យទៅបើរថក្រោះ ហើយយើងក៏ត្រូវតែបើក បើមិនអ៊ីចឹងទេគេនឹងសម្លាប់យើង"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.90-94 ["ស៖ ហេតុអ្វីបានជាគេរំសាយអង្គភាពរបស់លោក? ឆ.90៖ គេចោទយើងជាខ្សែខ្មាំង ដោយសារមេកងវរៈរបស់ពួកយើងត្រូវបានគេចាប់យកទៅបាញ់សម្លាប់អស់ហើយ។ ស៖ តើលោកមានដឹងថា ហេតុអ្វីបានជាគេបាញ់សម្លាប់មេកងវរៈទាំងអស់នោះ? ឆ.91៖ ខ្ញុំឆ្ងល់រហូតដល់សព្វថ្ងៃ ហេតុអ្វីបានជាពួកគេសម្លាប់ ឲ្យតែមេៗវរៈគេហៅមករៀនសូត្រនៅរោងកុន នៅកំពង់សោម គឺដឹងតែបាត់ខ្លួនតែម្តង ហើយមិនដែលឃើញវិលត្រឡប់មកវិញទេ។ ដោយសារតែអវត្តមានយូររបស់មេកងវរៈទាំងនោះ យើងក៏បានខ្សឹបខ្សៀវគ្នាសួរអំពីរឿងនេះ មានអ្នកខ្លះនិយាយថា គេមិនទាន់បិទវគ្គ ក៏ប៉ុន្តែកន្លងពេលយូររាប់ខែមកហើយ ក៏មិនដែលឃើញពួកគេត្រឡប់មកវិញនោះទេ។ ក្រោយពេលមេកងវរៈរបស់យើងបានបាត់ខ្លួន របបអាហារក៏កាន់តែតិច ហើយម្នាក់ៗគេឲ្យរែកដី៣ម៉ែត្រគូប ក្នុង១ថ្ងៃ ដើម្បីដាក់ខ្នងទំនប់។ ស៖ តើគេរំសាយអង្គភាពទាំងមូល ទៅជាអង្គភាពផលិតមែនទេ? ឆ.92៖ តាមពិត កងពលត្រូវបានរំសាយ គឺមានទាហានរាប់ពាន់នាក់។ ពួកគេត្រូវបានចាត់តាំងឲ្យធ្វើការងារក្នុងកងផលិតខុសៗគ្នា និងបញ្ជូនទៅតាមមុខព្រួញការងារខុសៗគ្នា។ ស៖ មុននឹងគេរំសាយ តើនរណាជាអ្នកប្រាប់អំពីការរំសាយនេះ? ឆ.93៖ បញ្ជាច្បាស់ជាចេញមកពី តាមុត ហើយពួកគេជាមនុស្សរបស់តាមុត ដែលប្រមូលផ្តុំឲ្យពួកយើងប្រជុំ ហើយប្រាប់ពួកយើងថា នឹងត្រូវបញ្ជូនទៅតាមការដ្ឋានខុសៗគ្នា។ ពួកគេរួមបញ្ចូលមនុស្សមកពីអង្គភាពផ្សេងៗគ្នាឲ្យធ្វើការនៅក្នុងកងផលិត។ ស៖ តើលោកបានចូលរួមប្រជុំដោយផ្ទាល់ ឬក៏ឮពីអ្នកដទៃ? ឆ.94៖ គេរៀបចំប្រជុំនៅតាមកងតូច និងតាមកងធំនីមួយៗ ហើយគេតម្រូវឲ្យសមាជិកទាំងអស់នៅក្នុងកងនោះចូលរួមប្រជុំ។ បើខ្ញុំបដិសេធ ខ្ញុំច្បាស់ជាស្លាប់ហើយ"]។

255 ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ន សុត ឆ.5 ["ស៖ តើអ្វីដែលបានអានជូនលោកស្តាប់មុននេះត្រឹមត្រូវឬទេ? តើមានកំហុសឈ្មោះ ឬអក្ខរាវិរុទ្ធដែលលោកចង់កែតម្រូវដែរឬទេ? ឆ.5៖ គឺមានកំហុសច្រើន។ កងទ័ពតំបន់ពិសេស កងវរសេនាតូច៣៨៦ ត្រូវបានបញ្ចូលទៅក្នុងកងពលធំទី៣ក្រោយរំដោះឆ្នាំ១៩៧៥។ ដល់ចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ បានចាប់មេបញ្ជាការទាំងអស់ចោទថាតំបន់ហ្នឹងក្បត់។ ក្រោយចាប់អស់ ក៏រំលាយពួកខ្ញុំ ហើយបញ្ជូនយកទៅធ្វើស្រែ។ បើសិនជាបងប្អូនមិនធ្វើតាម គឺត្រូវគេសម្លាប់ចោល។ និយាយរួមទៅគឺមកពីតាមុត ហ្នឹងតែម្តងដែលជាអ្នកបញ្ជា។ រួចពីហ្នឹងចូលទៅឆ្នាំ១៩៧៩ ដល់ពេលអ្នកសង្គ្រោះជាតិចូលមក ក៏បានចាប់ពួកខ្ញុំយកទៅវៃវិញ គេបំពាក់អាវុធឲ្យយើងវិញដើម្បីប្រយុទ្ធជាមួយរណសិរ្សសង្គ្រោះជាតិ។ យើងអត់ចេះអីទេ តែគេបានរុញយើងឲ្យទៅ

85. អំណាចរបស់ មាស មុត នៅតំបន់កំពង់សោមមានច្បាស់ ដោយមិនមានការសង្ស័យ ហើយគេខ្លាចគាត់។ កម្មាភិបាលក្រោមបង្គាប់របស់គាត់ចៀសវាង "ធ្វើអ្វីឲ្យខុស ពីព្រោះអ្នកទាំងអស់នោះភ័យខ្លាច"[257] ពីព្រោះ គេដឹងថា បើយុទ្ធជនណាម្នាក់ "ធ្វើខុស ឬមិនត្រឹមត្រូវ [មាស មុត] មិននិយាយប្រាប់ថាបែបនេះ បែបនោះទេ គឺគាត់នៅស្ងៀម ហើយគាត់វៃអ្នកនោះដល់សន្លប់ក៏មាន"[258]។

---

បើរថក្រោះ ហើយយើងក៏ត្រូវតែបើក បើមិនអ៊ីចឹងទេគេនឹងសម្លាប់យើង"]។ ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា ឆ.23-25 ["សៈ តើមានស្ថាប័ន ឬអង្គភាពណានៅកំពង់សោម ដែលមានសិទ្ធិអំណាចលើកងពលលេខ៣ដែរឬទេ? ឆ.23៖ ទេ មិនមានទេ។ តាមុត ដែលជាប្រធានកងពល គឺជាអ្នកមានសិទ្ធិអំណាចធំជាងគេ។ តាមុតកាចណាស់។ គាត់អាចវៃ និងបាញ់ អ្នកណាម្នាក់យ៉ាងងាយ។ សៈ ហេតុអ្វីបានជាលោកនិយាយបែបនេះ? ឆ.24៖ ឧទាហរណ៍សម្រាប់យោធា បើអ្នកណាម្នាក់ធ្វើខុស ឬមិនត្រឹមត្រូវ គាត់មិននិយាយប្រាប់ថាបែបនេះបែបនោះទេ គឺគាត់នៅស្ងៀម ហើយគាត់វៃអ្នកនោះដល់សន្លប់ក៏មាន។ សៈ តើលោកធ្លាប់ឃើញហេតុការណ៍នេះដែរឬទេ? ឆ.25៖ បាទ ខ្ញុំធ្លាប់ឃើញហេតុការណ៍ម្តងដោយផ្ទាល់ភ្នែក នៅក្រោយពេលជ័យជម្នះលើទីក្រុងភ្នំពេញ។ កាលនោះ គេឲ្យកងខ្ញុំទៅធ្វើផ្លូវរទេះពីវាលរេញទៅកំពត។ យោធាម្នាក់បានយកដុំថ្មគប់លេងចូលក្នុងព្រៃកំប៉ូត តាមុត ឃើញ គាត់ក៏ដើរមកហើយវៃយោធាម្នាក់នោះរហូតដល់សន្លប់។ ក្រោយមកទៀត ខ្ញុំក៏នៅតែឮគេនិយាយថា គាត់នៅតែកាចដដែល"]។

256 ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ិន សុត ឆ.70 ["សៈ ដើម្បីបញ្ជាក់ឲ្យច្បាស់ ពេលលោកនិយាយពីមុនថា គឺពួកមនុស្សរបស់តាមុតដែលគេបញ្ជូនមករំសាយពួកលោក និងវរសេនាធំរបស់លោក។ តើហេតុអ្វីបានជាលោកដឹងថាពួកអ្នកទាំងនោះថាពួកគេធ្វើតាមបញ្ជារបស់តាមុត? ឆ.70៖ បើមិនធ្វើតាមយ៉ាងម៉េច មិនកុន បើមិនធ្វើតាមស្តាប់បាត់ គេសម្លាប់ដែរហ្នឹង។ បើវាមិនធ្វើស្លាប់មុនយើងទៅទៀត"]។

257 ឯកសារ D54/41 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ សាវ៉ាន់ ឆ.8-10 ["ខ្ញុំដឹងថា មេបញ្ជាការកងពលមានតែម្នាក់ទេគឺ មាស មុត។ មាស មុត គឺជាមេបញ្ជាការកងពលលេខ៣ បញ្ជាផ្ទាល់ទៅកងវរសេនាធំ និងកងវរសេនាតូចទាំងអស់។ សៈ នៅពេលដែលលោកនិយាយថា មាស មុត ជាមេបញ្ជាការរបស់កងពលទូទៅហ្នឹង តើលោកអាចរៀបរាប់ថាតើ មាស មុត ទទួលខុសត្រូវអ្វីខ្លះ? ឆ.9៖ មាស មុត ទទួលខុសត្រូវរួមក្នុងកងពលទាំងអស់ រួមមានស្បៀងអាហារ គ្រាប់រំសេវ និងសព្វាវុធ។ សៈ ក្នុងនាម មាស មុត ជាមេបញ្ជាការកងពលលេខ៣ តើគាត់មានអំណាចលើកងទ័ពយ៉ាងម៉េចខ្លះ ដូចជាការដាក់វិន័យ និងការដាក់ទណ្ឌកម្ម? ឆ.10៖ នៅពេលនោះ នៅលើសមរភូមិគឺជាស្ថានភាពស្លាប់ និងរស់។ គ្មាននរណាម្នាក់ហ៊ានធ្វើខុសទេ។ មនុស្សគ្រប់គ្នាគោរពវិន័យខ្លាំងណាស់ ដូច្នេះ គ្មាននរណាម្នាក់ធ្វើអ្វីឲ្យខុសទេ ពីព្រោះអ្នកទាំងអស់នោះភ័យខ្លាច។ នៅពេលនោះ គេធ្វើការប្រជុំស្វ័យទិតៀន ដូច្នេះ មនុស្សត្រូវតែធ្វើទៅតាមការបញ្ជា និងការចាត់តាំង"]។

258 ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា ឆ.23-25 ["សៈ តើមានស្ថាប័ន ឬអង្គភាពណានៅកំពង់សោម ដែលមានសិទ្ធិអំណាចលើកងពលលេខ៣ដែរឬទេ? ឆ.23៖ ទេ មិនមានទេ។ តាមុត ដែលជាប្រធានកងពល គឺជាអ្នកមានសិទ្ធិអំណាចធំជាងគេ។ តាមុត កាចណាស់។ គាត់អាចវៃ និងបាញ់ អ្នកណាម្នាក់យ៉ាងងាយ។ សៈ ហេតុអ្វីបានជាលោកនិយាយបែបនេះ? ឆ.24៖ ឧទាហរណ៍សម្រាប់យោធា បើអ្នកណាម្នាក់ធ្វើខុស ឬមិនត្រឹមត្រូវ គាត់មិននិយាយប្រាប់ថាបែបនេះបែបនោះទេ គឺគាត់នៅស្ងៀម ហើយគាត់វៃអ្នកនោះដល់សន្លប់ក៏មាន។ សៈ តើលោកធ្លាប់

វិធានការណ៍ដាក់វិន័យតឹងរ៉ឹងរបស់ មាស មុត បានដឹងល្បីក្នុងទូទាំងជួរកម្មាភិបាលនានា។ សូម្បីតែ តា ម៉ុក លេខាភូមិភាគនិរតី ទិតៀនគាត់អំពីការបញ្ជាសម្លាប់កម្មាភិបាលម្នាក់ ដោយបានសួរ មាស មុត ថា៖ "ម៉េចចេះតែសម្លាប់កម្លាំងអញ់?"[259]។

86. មាស មុត ចេញបញ្ជា និងការណែនាំថ្នាក់ក្រោម (ពីកងពល ដល់ វរសេនាំ, ពីវរសេនាធំដល់ វរសេនាតូច, ពីវរសេនាតូចដល់អនុសេនាធំ, ហើយរួចមក ពីអនុសេនាធំដល់យុទ្ធជន)[260]។

---

ឃើញហេតុការណ៍នេះដែរឬទេ? ឆ.25៖ បាទ ខ្ញុំធ្លាប់ឃើញហេតុការណ៍ម្តងដោយផ្ទាល់ភ្នែក នៅក្រោយពេលជ័យជម្នះលើទីក្រុងភ្នំពេញ។ កាលនោះ គេឱ្យកងខ្ញុំទៅធ្វើផ្លូវរទេះពីវាលរេញទៅកំពត។ យោធាម្នាក់បានយកដុំថ្មគប់លេងចូលក្នុងព្រៃកំប៉ូត តាមុត ឃើញ គាត់ក៏ដើរមក ហើយវ៉ៃយោធាម្នាក់នោះរហូតដល់សន្លប់។ ក្រោយមកទៀត ខ្ញុំក៏នៅតែឮគេនិយាយថា គាត់នៅតែកាចដដែល"]។

259 ឯកសារ D4.1.786 កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម KH 00373477-78 [ " ខ្ញុំសូមលើកយកឧទាហរណ៍ជាក់ស្តែងមួយដែល តាម៉ុក បានមកណែនាំផ្ទាល់នៅនឹងមន្ទីរស្រុករបស់ខ្ញុំ ដែលនៅពេលនោះមាន តាមុត មកជួបខ្ញុំនៅមន្ទីរស្រុកដែរ។ តាម៉ុក បានស្តីបន្ទោសឲ្យតាមុត ពីរឿងបញ្ជាគេឲ្យទៅសម្លាប់មិត្ត កង ជា ជាអ្នកយាមគ្រាប់ឲ្យលោក សឿង ហៅ កឹត ជាមេទ័ពកងពល ថាលោកចៅហ្វាយខេត្តម៉េចចេះតែសម្លាប់កម្លាំងអញ បើឯងមិនស្គាល់ច្បាស់ម៉េចក៏មិនសួរមិត្ត ជឹម។ ហើយតាម៉ុក បានប្រាប់ថា ថ្ងៃក្រោយកុំឲ្យធ្វើអីចឹងទៀត។ រឿងហេតុមានដូច្នេះ ថ្ងៃមួយ មុត បានទទួលសេចក្តីរាយការណ៍ពី ញៀវ ថាឈ្មោះ កង ជា មានគ្រាប់កាំភ្លើងលាក់នៅក្នុងត្រង់សេ។ តាមុតបានទទួលសេចក្តីរាយការណ៍ហើយ ពេលល្ងាចនោះជិតយប់ហើយ គាត់បានមកមន្ទីរស្រុកជួបខ្ញុំ ហើយបញ្ជាឲ្យខ្ញុំទៅហៅ កង ជា មកជួបគាត់។ ពេលនោះ ខ្ញុំនិងកងឈ្លបម្នាក់ក៏បានទៅហៅ កង ជា ប៉ុន្តែខ្ញុំបាននិយាយជាមួយ តាមុត ថា កង ជា មិនអីទេ តែតាមុតនៅតែឲ្យទៅហៅ ខ្ញុំក៏ទៅហៅ កង ជា ដោយប្រាប់ថា តាមុត ឲ្យហៅ។ ពេលនោះ ឈ្លបជាអ្នកនាំ កង ជា មកជួបតាមុត ខ្ញុំមិនបានជួបតាមុតទេ។ ពេលពាក់កណ្តាលយប់ខ្ញុំឮសូរ ស្នូរគ្រាប់កាំភ្លើងអាកានៅក្នុងព្រៃ។ លុះព្រលឹមឡើងខ្ញុំហៅកងឈ្លបនោះមកសួរថាម៉េចហើយ មិត្តជា។ ឈ្លបនោះឆ្លើយថា មិត្តជា បង្ហើយស្រេចហើយ។ រឿងនេះកើតឡើងប្រហែលនៅក្នុងឆ្នាំ១៩៧៤។ ក្រោះថ្ងៃរំដោះឆ្នាំ១៩៧៥ តាម៉ុក ក៏ធ្លាប់មានការណែនាំនៅក្នុងអង្គប្រជុំផងដែរ កុំឲ្យមានការសម្លាប់ ផ្តេសផ្តាស"]។

260 ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត ឆ.54 ["ជាធម្មតាប្រព័ន្ធបញ្ជាគឺពីកងពលទៅកងវរៈសេនាធំ ពីកងវរៈសេនាធំទៅកងវរៈសេនាតូច ពីកងវរៈសេនាតូចទៅកងអនុសេនាធំ ហើយពីកងអនុសេនាធំទៅយោធាផ្ទាល់"]។ ឯកសារ D114/24 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដាវ ឆ.68 ឆ.140 ["វិទ្យុទាក់ទងបើករហូត ហើយគេបញ្ជាពីថ្នាក់វរៈសេនាធំ ចុះមកក្រោមបន្តបន្ទាប់គ្នា [...] ឆ.140៖ ការបញ្ជានោះគឺមកពីថ្នាក់លើ។ នៅពេលនោះ គឺមានតែ មាស មុត ទេ។ មាស មុត ទទួលបញ្ជាពីថ្នាក់លើមកទៀត។ ពេលខ្លះ មាស មុត សម្រេចចិត្តដោយខ្លួនឯង។ ថ្នាក់ក្រោមៗ មាស មុត មិនហ៊ានសម្រេចចិត្តដោយខ្លួនឯងនោះទេ"]។ ឯកសារ D54/82 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច (អ្នកបកសារទូរលេខ, វរៈសេនាធំ៦២, កងពល១៦៤) ឆ.9 ["ស៖ នៅកម្រិតកងវរៈសេនាធំ៦៣ នៃកងពល១៦៤ តើលោកទទួលការណែនាំពីថ្នាក់លើឯទៀតក្រៅពីកងពល១៦៤ ដែរឬទេ? ឆ.9៖ ទេ ខ្ញុំមិនដែលបានទទួលអ្វីពីអង្គភាពផ្សេង

ស្រដៀងគ្នានេះ របាយការណ៍នានាធ្វើឡើងទៅថ្នាក់លើ -អនុសេនាតូចរាយការណ៍ទៅមេបញ្ជាការអនុសេនាធំ, អនុសេនាធំរាយការណ៍ទៅវរសេនាតូច, វរសេនាតូចរាយការណ៍ទៅវរសេនាធំផ្ទាល់ដែលបន្ទាប់មក បូកសរុប និងបញ្ជូនរបាយការណ៍ប្រចាំថ្ងៃទៅកម្មាភិបាលកងពលដែលកាន់ខាងប្រតិបត្តិការវិទ្យុ ដែលជអ្នកបញ្ជូនរបាយការណ៍ ទៅ មាស មុត[261]។ កម្មាភិបាលកងពល ១៦៤

---

ទៀតទេ។ រាល់អ្វីៗទាំងអស់ដែលខ្ញុំបានទទួល គឺសុទ្ធសឹងតែទទួលបានមកពីកងពល១៦៤"]។ ឯកសារ D59/1/1.12 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល KH 00926630 ["យើងៗឃើញយើងរាយវរសេនាធំៗគេរាយឱ្យកងពល ដល់កងពលគេប្រាប់ទៅវរសេនាធំវិញថាត្រូវចាត់ការណ៍ម៉េច វរសេនាធំគេប្រាប់ទៅវរសេនាតូចអញ្ចឹងទៅ បានគេប្រើ បាទ! ក្រុមពួកខ្ញុំអញ្ចឹងទៅ"]។ ឯកសារ D2/10 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.6 ["បើនិយាយពីសភាពការណ៍នៃពេលចេញប្រយុទ្ធ គឺខ្ញុំមិនបានទទួលបញ្ជាផ្ទាល់ចេញពីកងពលទេ ការចេញបញ្ជាគឺធ្វើឡើងចេញពីប្រធានកងនាវាប្រដេញផ្ទាល់របស់ខ្ញុំ"]។ ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ. 19 ["ព្រឹត្តិការណ៍អ្វីដែលកើតឡើងត្រូវតែរាយការណ៍ទៅឱ្យកងវរសេនាតូច ហើយកងវរសេនាតូចរាយការណ៍ទៅមេបញ្ជាការកងវរសេនាធំ ហើយកងវរសេនាធំរាយការណ៍ទៅឱ្យមេបញ្ជាការកងពល។ បន្ទាប់មកមេបញ្ជាការកងពលធ្វើសេចក្តីសម្រេច ហើយដាក់បញ្ជាបញ្ជូនចុះមកវិញតាមជាន់ថ្នាក់ទាំងនេះមកវិញ"]។ ឯកសារ D114/12 កំណត់ហេតុស្តាប់ចម្លើយ នាក់ យឿន ឆ.22 ["ការសម្រេចចិត្តទាំងអស់គឺចេញពីមេធំ គឺក្នុងករណីដែលតាមុត អវត្តមានប៉ុណ្ណោះ ដែលអនុរបស់គាត់អាចចេញបញ្ជាបាន។ នៅថ្នាក់វរៈសេនាតូច ហាន ជាអ្នកចេញបញ្ជា។ អ្នកផ្សេងទៀតអាចនិយាយ ឬទំនាក់ទំនង ឬសរសេរបញ្ជានោះ ប៉ុន្តែការសម្រេចចិត្ត គឺជាការងាររបស់ប្រធាន។ ប្រសិនបើអនុប្រធាន សមាជិ និងប្រធានអវត្តមាន គឺទាំងអស់គ្នាពិភាក្សាទៅលើវិធានការដែលត្រូវអនុវត្ត ប៉ុន្តែការសម្រេចចិត្តគឺធ្វើឡើងដោយប្រធាន។"]។ ឯកសារ D114/287 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ.34 ឆ.37 ["ខ្ញុំមិនបានចូលរួមប្រជុំជាមួយ មាស មុត ផ្ទាល់ទេ តែមានប្រធានវរសេនាតូចទៅចូលរួមប្រជុំជាមួយ មាស មុត ផ្ទាល់ ហើយយកមកប្រជុំផ្សាយបន្តក្នុងអង្គភាពខ្ញុំ។ [...] ឆ.3៖ គឺថាតំណាងអង្គភាពយកព្រឹត្តការណ៍មកផ្សាយមិនឱ្យខុសពីផែនការដើមដែលទទួលមកពីកងពលទេ"]។ ឯកសារ D54/33.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ី អុន KH 00964211 ["មិនទៀងទេ ជួនកាលគាត់មានបណ្តាញគេធំៗ គេមកធ្វើការជាមួយគាត់ ហើយយើងតូចតាចហ្នឹងគេគ្រាន់តែបន្តប្រាប់យើងធ្វើអញ្ចេះធ្វើអញ្ចោះ"]។

[261] ឯកសារ D114/19.1 របាយការណ៍ពី ម៉ាក ឈឿន ទៅ មាស មុត ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៧៦ KH 01034014; ឯកសារ D54/82 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ិច (អ្នកបកសារទូរលេខ, វរៈសេនាធំ៦២, កងពល ១៦៤) ឆ.20 ["រួចហើយយើងបូកសរុបចំណុចនីមួយៗ ហើយយើងសរសេរបញ្ចូលចំណុចសំខាន់ៗ ដោយចំណុចដែលសំខាន់ជាងគេ យើងដាក់នៅក្នុងចំណុចទី១ និងចំណុចសំខាន់បន្ទាប់យើងដាក់នៅក្នុងចំណុចទី២ និងចំណុចទី៣ជាហូរហែ ហើយយើងសរសេរបញ្ចូលគ្រប់ចំណុចទាំងអស់តែក្នុងមួយច្បាប់ទេ"]។ ឯកសារ D114/19 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន (អតីតមេបញ្ជាការកងវរៈសេនាធំ៥៥០ កងពល១៦៤) ឆ.26 ឆ.28 ឆ.34 ["ខ្ញុំនិយាយទៅកាន់អ្នកកាន់វិទ្យុនៅកងពល ហើយអ្នកនោះបានបញ្ជូនសេចក្តីរាយការណ៍របស់ខ្ញុំទៅកាន់មេបញ្ជាការកងពលដែលមានតាមុត និងតាឌីម [...] ឆ.28៖ បាទ ខ្ញុំប្រើវិទ្យុទាក់ទង C-២៥ ហើយនិងម៉ាស៊ីនសារទូរលេខ។ នៅពេលដែលខ្ញុំប្រើ

ត្រូវធ្វើរបាយការណ៍យ៉ាងល្អិតល្អន់,[262] ឱ្យ មាស មុត បានដឹងសព្វគ្រប់អំពីសភាពការណ៍ តាមសមុទ្រនិងលើកោះ ការដ្ឋាន និងមន្ទីរសន្តិសុខ ដែលកងទ័ពរបស់គាត់ប្រតិបត្តិការ រួមមានរាយការណ៍ផងដែរអំពីបទឧក្រិដ្ឋដែលកងទ័ពទាំងនោះបានប្រព្រឹត្តនៅទីនោះ។

87. មាស មុត អនុវត្តការត្រួតពិនិត្យប្រហែលគ្នានេះដែរ ទៅលើកងពល១១៧ និង តំបន់ ៥០៥ នៅចុងនៃអំឡុងពេលរបស់កម្ពុជាប្រជាធិបតេយ្យ។ តាមរយៈមុខនាទីជាអនុប្រធានមួយរូបក្នុងចំណោមអនុប្រធាននានារបស់ សុន សេន ក្នុងអគ្គសេនាធិការ មាស មុត ទទួលបានអំណាចបញ្ជាដល់

---

របាយការណ៍តាមសារទូរលេខ គឺខ្ញុំផ្ញើត្រង់ទៅកាន់វរៈសេនាធំ ហើយវរៈសេនាធំបានបញ្ជូនរបាយការណ៍នោះបន្តទៅកងពលឬយ៉ាងណាគឺសម្រេចលើគេ [...] ឆ.34៖ ក្នុងនាមជាមេបញ្ជាការទទួលខុសត្រូវរួម មាស មុត គាត់ត្រូវតែចង់ដឹងថាមានរឿងអ្វីខ្លះដែលកើតមានឡើងក្នុងកងពល។ ជាទូទៅខ្ញុំត្រូវរាយការណ៍ទៅឱ្យវរៈសេនាធំ ហើយវរៈសេនាធំបញ្ជូនបន្តទៅគាត់"]។ ឯកសារ D114/24 កំណត់ហេតុស្ដាប់ចម្លើយ អ៊ូ ដាវ ឆ.104 [មេបញ្ជាការកងអនុសេនាតូចនៅក្នុងកងវរៈសេនាតូច៤៥០៖ "បាទ ខ្ញុំបានរាយការណ៍ទៅមេបញ្ជាការកងអនុសេនាធំ។ ហើយកងអនុសេនាធំ រាយការណ៍ទៅកងវរៈសេនាតូច ហើយកងវរៈសេនាតូច រាយការណ៍ទៅថ្នាក់លើ"]។ ឯកសារ D54/100 កំណត់ហេតុស្ដាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.142 ["ពេលចេញទៅបេសកកម្ម កងពលបញ្ជាមកកងវរសេនាធំឱ្យរៀបចំនាវា ដើម្បីចេញប្រតិបត្តិការណ៍តែពេលនាវាទៅដល់កណ្ដាលសមុទ្រហើយជួបប្រទះហេតុការណ៍ប្រយុទ្ធ គេទាក់ទងមកកងវរសេនាធំ ហើយកងវរសេនាធំទាក់ទងមកកងពល"]។ ឯកសារ D59/1/1.12 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល KH 00926630 ["យើងៗឃើញយើងរាយវរសេនាធំៗគេរាយឱ្យកងពល"]។ ឯកសារ D54/25 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.19 ["ព្រឹត្តិការណ៍អ្វីដែលកើតឡើងត្រូវតែរាយការណ៍ទៅឱ្យកងវរសេនាតូច ហើយកងវរសេនាតូចរាយការណ៍ទៅមេបញ្ជាការកងវរសេនាធំ ហើយកងវរសេនាធំរាយការណ៍ទៅឱ្យមេបញ្ជាការកងពល។ បន្ទាប់មកមេបញ្ជាការកងពលធ្វើសេចក្ដីសម្រេច ហើយដាក់បញ្ជាបញ្ជូនចុះមកវិញតាមជាន់ថ្នាក់ទាំងនេះមកវិញ"]។ ឯកសារ D59/1/4.25 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡុង លី KH 00930812 [មេកងចល័តស្រី៖ "ស៖ អីចឹងមានការអីមកតាម អ៊ំញ៉ាន់ ហ្នឹងបាន អ៊ំញ៉ាន់ ទៅអ៊ំមុត? ឆ៖ ទៅ អ៊ំមុតទៀតទៅ"]។

262 ឯកសារ D54/25 កំណត់ហេតុស្ដាប់ចម្លើយ ណុប ហាល់ ឆ.19 ["ខ្ញុំមិនដឹងទេ។ ដូចខ្ញុំបានប្រាប់លោកហើយថា បទបញ្ជាក្នុងការចាប់ទូក និងបញ្ជូនទូកទៅណាៗនោះ គឺចេញមកពីថ្នាក់លើ។ បទបញ្ជា គឺច្បាស់ណាស់ថា យើងត្រូវរាយការណ៍រាល់អ្វីដែលយើងបានសង្កេតឃើញនៅលើដែនសមុទ្រខ្មែរ ហើយបទបញ្ជាថា ត្រូវធ្វើអ្វីនោះ គឺចេញមកពីថ្នាក់លើ"]។ សូមមើលឧទាហរណ៍ ឯកសារ D1.3.34.14 សារទូរលេខ ១៥ ពី ឌឹម ជូន មាស មុត ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៧៦ KH 00000866 [ឌឹម រាយការណ៍អំពីកប៉ាល់ចូលក្នុងដែនទឹក ពីស្រូវ និងស្នើសុំប្រេងម៉ាស៊ីនសម្រាប់ទូក]។ ឯកសារ D1.3.14.2 សារទូរលេខ ៤៣ ពី មឿន ជូន មាស មុត ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៧៧ [មឿន រៀបរាប់អំពីសភាពការណ៍ខ្មាំងនៅអូរ ឈើទាល និងកោះរង់សន្លឹម ទិតៀនមាយាទកម្មកអ្នកដឹកជញ្ជូនម្នាក់នៅអូរ ឈើទាល ហើយសំណូមពរឱ្យមានការសម្រេចពី មាស មុត លើថាតើ នាវា០២ គួរយកទៅធ្វើនៅរៀមឬអត់]។

កម្មាភិបាលយោធាកងពល១១៧ ដោយរក្សាបាននូវការទាក់ទងផ្ទាល់ជាមួយមេបញ្ជាការកងពល[263]។ គាត់អនុវត្តអំណាចក្នុងការដាក់ទណ្ឌកម្ម ដក និងតែងតាំងសមាជិកកងពល និងតំបន់ ដូចដែលបានស្តែងតាមរយៈទស្សនកិច្ចរបស់គាត់នៅខេត្តក្រចេះ នាខែ វិច្ឆិកា ឆ្នាំ ១៩៧៨ ខណៈដែលគាត់ចាត់ចែងដោយផ្ទាល់នូវការបោសសម្អាតបណ្តាកម្មាភិបាលឋានៈខ្ពស់ៗ[264] ហើយដាក់

---

263 ឯកសារ D114/297.1.23 ម៉ឹង វ៉េត ប្រតិចារឹក ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 13.45.51-13.50.21 ["គាត់ទទួលខាងច្រកជួរមុខ ដូចទៅក្រចេះអ៊ីចឹង សារត្រូវបញ្ជូនឲ្យគាត់ មិនអាចបញ្ជូនទៅៗខាង "ម" អីប្រធានបានទេ។ ដល់អ៊ីចឹងទៅ ខ្ញុំត្រូវទំនាក់ទំនងមកគាត់។ ដល់អ៊ីចឹងទៅ រឿងគាត់ គាត់ទំនាក់ទំនងគ្នាបានហើយ។ សម្ភារៈអី បើដឹក បើក៏មិនឆ្លងគាត់ទាំងអស់ ក៏ដឹកចេញមិនបាន។ ដូចគ្រាប់ ត្រូវគ្រាប់ប៉ុន្មានកប៉ាល់ ត្រូវអាវុធប៉ុន្មានពាន់ដើម"]។ ឯកសារ D54/62 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វ៉េត ឆ.22 ឆ.25 ["នៅពេលយួនវ៉ៃបុកមកលើយើងនៅតាមព្រំដែន មាស មុត ត្រូវតែទៅត្រួតពិនិត្យស្ថានការណ៍នៅសមរភូមិមុខ [...] ឆ.25៖ តាមខ្ញុំដឹង ក្នុងនាមគាត់ជាអគ្គសេនាធិការរង ដូច្នេះគាត់ត្រូវតែទៅពិនិត្យស្ថានការណ៍នៅកន្លែងដែលមានជម្លោះនៅតាមព្រំដែន"]។ ឯកសារ D54/63 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វ៉េត ឆ.11-17 ឆ.19 ["ពីព្រោះ មាស មុត នៅសេនាធិការ ដូច្នេះគាត់មានសិទ្ធិអំណាចបញ្ជាទៅកងទ័ពទាំងបីប្រភេទ។ ឆ.12៖ [នៅខែ តុលា ឆ្នាំ ១៩៧៨] យើងក៏បានស្នើសុំទៅ មាស មុត តែម្តង ហើយគាត់បានប្រាប់ រ៉ុ ឲ្យចាំបន្តិច ហើយនៅពេលរសៀល គាត់បានបញ្ជូនយន្តហោះមកជួយយើង [...] ឆ.13៖ ក្នុងនាមជានីរសារ ខ្ញុំធ្វើការនៅក្នុងមន្ទីរជាមួយនឹងអ្នកសារទូរលេខ ហើយនិងមេបញ្ជាការ ដូច្នេះខ្ញុំអាចដឹងអំពីអ្វីៗដែលកើតឡើងនៅក្នុងមន្ទីរហ្នឹង។ ស៖ នៅពេលដែលលោកនិយាយថា មាស មុត បញ្ជាឲ្យ រ៉ុ រង់ចាំ តើគាត់ប្រាប់តាមសារទូរលេខ ឬតាមវិទ្យុទាក់ទង? ឆ.14៖ គាត់បានឆ្លើយតបមកវិញ តាមសារទូរលេខ។ ស៖ ពេលផ្ញើរបាយការណ៍ពីកងពល១១៧ ទៅឲ្យ មាស មុត តើគេធ្វើជាប្រចាំថ្ងៃ ឬក៏ធ្វើឡើងរាល់ពេលដែលមានព្រឹត្តិការណ៍កើតឡើង? ឆ.15៖ មុនពេលមានការវ៉ៃគ្នា របាយការណ៍នេះគឺផ្ញើទៅជាប្រចាំថ្ងៃរាល់ៗថ្ងៃ ប៉ុន្តែក្រោយពីមានព្រឹត្តិការណ៍វ៉ៃគឺរបាយការណ៍ត្រូវបានផ្ញើរាល់ពេលដែលមានហេតុការណ៍កើតឡើង [...] ឆ.16៖ គឺដាក់ថា ជូនទៅអគ្គសេនាធិការ គឺមិនមែនដាក់ទៅបុគ្គលណាជាក់លាក់ទេ ប៉ុន្តែយើងដឹងថា អ្នកទទួលសារទូរលេខ គឺជាអ្នកដែលធ្វើការឲ្យអ្នកណាម្នាក់ហើយ។ ឧទាហរណ៍ ធី និង គង់ ជាអ្នកកាន់សារទូរលេខឲ្យ មាស មុត។ ស៖ ហេតុអ្វីបានជាលោកដឹងថា មាស មុត ជាអ្នកផ្ញើសារទូរលេខឲ្យ រ៉ុ ឲ្យរង់ចាំការបញ្ជូនយន្តហោះនៅពេលនោះ? ឆ.17៖ ខ្ញុំមិនដឹងលេខសារទូរលេខទេ ប៉ុន្តែខ្ញុំដឹងអំពីរឿងនេះតាមរយៈការឃើញសារទូរលេខ [...] ឆ.19៖ តាមការដឹងរបស់ខ្ញុំ មាស មុត ចាប់ផ្តើមពាក់ព័ន្ធទទួលខុសត្រូវបញ្ជានៅតាមព្រំដែនខាងកើតនៅក្នុងឆ្នាំ ១៩៧៨ ពេលដែលយួនវ៉ៃបុកខ្លាំង"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន សារ៉ាត់ (ព្រំ សារ៉ាត) ឆ.224 ["ពេល មាស មុត គាត់ធ្វើដំណើរទៅក្រចេះ គោលបំណងសំខាន់ គឺសង្គ្រាមតាមព្រំដែនរវាងវៀតណាម កម្ពុជា ចាប់ផ្តើមមានការប្រយុទ្ធក្នុងសភាពការតានតឹង"]។

264 មាស មុត បានទទួលស្គាល់ខ្លួនឯងថាគាត់បានទៅក្រចេះ។ ទោះយ៉ាងណា វាមិនត្រូវគ្នានឹងភស្តុតាងទៃទៀតទាំងអស់ដែលនៅក្នុងសំណុំរឿងនោះទេ គាត់បានថ្លែងថា ហេតុការណ៍នេះកើតឡើងនៅខែ កុម្ភៈ ឆ្នាំ ១៩៧៨៖ ឯកសារ D54/16/1R កំណត់ហេតុជាខ្សែអាត់សម្លេងនៃបទសម្ភាសន៍ មាស មុត ដោយ David Kattenburg ខែ មេសា ឆ្នាំ ២០០៩ ត្រង់នាទី 34:37-35:28 ["ខ្ញុំមិនបាននៅកំពង់សោមទេ។ នៅខែ កុម្ភៈ ឆ្នាំ ១៩៧៨ ខ្ញុំបានចាកចេញពីកំពង់

ជំនួសដោយយោធាកងពល ១៦៤[265]។ ចាប់ពីពេលនោះមក មាស មុត បន្តកាន់ជាបញ្ជាការ និង គ្រប់គ្រង ទាំងតំបន់៥០៥ ទាំងកងពល១១៧[266] ដោយចេញបញ្ជា[267] និងបន្តមានវត្តមានផ្ទាល់នៅក្រចេះ[268] រហូតពេលកងទ័ពវៀតណាមមកដល់ នាប៉ុន្មានថ្ងៃចុងក្រោយនៃឆ្នាំ ១៩៧៨។

---

សោមហើយ។ សះ តើគាត់បានទៅណា? ឆ៖ ខ្ញុំត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅខេត្តក្រចេះជិតព្រំដែនឡាវ។ សះ អ៊ីចឹង គាត់បានចាកចេញពីកងពល១៦៤ រួចស្រេចហើយនៅខែ កុម្ភៈ ឆ្នាំ ១៩៧៨ មែនទេ? ឆ៖ ទេ ខ្ញុំនៅមានតួនាទីនៅឡើយ ក៏ប៉ុន្តែខ្ញុំត្រូវបានចាត់តាំងសម្រាប់បេសកកម្មមួយទៀតនៅក្រចេះ"]។ សូមមើល ឯកសារ D114/297.1.22 ម៉ឹង វ៉េត ប្រតិចារឹក ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 15.38.26-15.41.36 ["ការផ្លាស់ប្តូរមុខតំណែងវាត្រូវអ្នកថ្មីទៅដូរ អ្នកចាស់ត្រូវដកជិះយន្តមកភ្នំពេញមកក៏ត្រូវបាត់ខ្លួនរហូតទល់វត់ កៀកនឹងវត់ យួនបុកខ្លាំងនេះហើយ សភាពការណ៍តឹងតែងមែនទែន ដែលយួនយកស្នួលបានទាំងមូលហើយអាហ្នឹងៗខ្ញុំ អាហ្នឹងដែលបញ្ជាដែលខ្ញុំទៅទីនុង់ផ្ទាល់ខ្ញុំដឹង។ ពីព្រោះ តាមុត គាត់ទៅ"] នៅម៉ោង 15.43.55-15.46.20 និងឯកសារ D114/297.1.24 ម៉ឹង វ៉េត ប្រតិចារឹក ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.52.20-09.54.38 [បានផ្តល់សក្ខីកម្មថាបានឃើញសំបុត្រដាក់ថា "ម-៨៧០" បញ្ជូនដោយនីរសាររបស់ មាស មុត គឺ ធី និង គង់ ទៅមេបញ្ជាការកងពល១១៧ ឈ្មោះ រុំ ដើម្បីកោះហៅបុគ្គល ១១រូបពីកងពល១១៧ និងតំបន់៥០៥ ទៅភ្នំពេញ ហើយបានបញ្ជាក់ពីការធ្វើដំណើររបស់ពួកគេដោយយន្តហោះ] បញ្ជាក់ពីលើ ឯកសារ D54/62 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វ៉េត ឆ.24 ឆ.29 ["មាននីរសារម្នាក់មកពីវាលយន្តហោះយកសំបុត្រមកឲ្យ រុំ ដែលជាមេបញ្ជាការកងពល១១៧ ដើម្បីឲ្យចូលរួមការប្រជុំនៅភ្នំពេញ [...] ខ្ញុំបានឃើញសំបុត្រនោះផ្ញើមកពី មន្ទីរ ម-៨៧០ [...] សំបុត្រនោះមានឈ្មោះ១១នាក់ត្រូវហៅឲ្យទៅប្រជុំ [...] ឆ.29៖ [...] មនុស្សដែលនាំសំបុត្ររបស់មន្ទីរ ម-៨៧០ យកមកឲ្យ រុំ គឺ ធី និង គង់។ ធី និង គង់ ជាអ្នកកាន់សារទូរលេខ នៅក្នុងកងនីរសាររបស់ មាស មុត"]។ ឯកសារ D54/60.2 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ឺន វ៉េត KH 00975728 ["ឆ្នាំ៧៨នេះ បានគាត់ [មាស មុត] ទៅក្រចេះបានតែបន្តិចហ្នឹង ទៅក្រោយ ចាប់អ៊ំ វន វ៉េត ហើយទេ"]។ ឯកសារ D114/52 កំណត់ហេតុស្តាប់ចម្លើយ ឈាង ជួ ឆ.42 ["សះ តើ មាស មុត ទៅដល់តំបន់ក្រចេះនៅពេលណា? ឆ.42៖ តាមព្រឹត្តិការណ៍ដែល តាញ៉ាន់ ទៅកាន់បញ្ជាការកងពល១១៧ គឺប្រហែល១ខែមុនពេលវៀតណាមចូលគឺនៅប្រហែលជាចុងខែវិច្ឆិកា ឬដើមខែធ្នូ ឆ្នាំ១៩៧៨។ ដូច្នេះ ខ្ញុំគិតថា មាស មុត ទៅដល់ទីនោះនៅអំឡុងពេលនោះឯង"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.8-9 ["មាស មុត ត្រូវបានគេបញ្ជូនទៅក្រចេះ ពីព្រោះពេលនោះមានការចាប់កម្មាភិបាលគឺមានសន្ទុះខ្លាំង [...] ឆ.9៖ គាត់ទៅទីនោះនៅចុងឆ្នាំ១៩៧៨ ក្នុងរយៈពេលខ្លី គឺប្រហែលជាពីរអាទិត្យ ឬកន្លះខែប៉ុណ្ណោះ"]។ ឯកសារ D114/169 កំណត់ហេតុស្តាប់ចម្លើយ សេង សឿន ឆ.30 ["មុត ជាអ្នកបញ្ជូនអ្នកដែលចាប់ខ្លួននោះតាមយន្តហោះមកភ្នំពេញ [...] គឺបងមុត ជាអ្នកបញ្ជូនឡើងយន្តហោះ បន្ថែមប៉ុណ្ណឹងឲ្យយល់។ អ្នកមុនហ្នឹង មុតជាអ្នកចាត់ចែង"]។ ឯកសារ D114/170 កំណត់ហេតុស្តាប់ចម្លើយ ព្រំ ម៉ុន ឆ.36 ឆ.38 [ប្រពន្ធរបស់លេខាកងពល១១៧ យុន រ៉ុម៖ "លឹម ថាប្តីរបស់ខ្ញុំគេចាប់យកទៅ។ តាមុតជាអ្នកបញ្ជាឲ្យចាប់ [...] ឆ.38៖ មានប្តីខ្ញុំ តាមឿន និងតាលាង [ត្រូវបានគេចាប់ទាំងអស់]"]។

[265] ឯកសារ D114/297.1.27 សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 13.46.29-13.50.40 ["ភាព មកធ្វើជាលេខាតំបន់។ ភាព ហ្នឹងគេនៅកងពលជើងទឹកជាមួយ បងមុត"] នៅម៉ោង 13.51.58-13.57.20

[“ទៅៗដល់ហ្នឹងទៅជួបអីហ្នឹង ហៅប្រជុំ [...] ប្រជុំហ្នឹង បងមាស មុត ហ្នឹងប្រកាសឲ្យ មិត្តភាព លេខាតំបន់”]។ ឯកសារ D4.1.810 កំណត់ហេតុស្តាប់ចម្លើយ សេង សឿន ឆ.32 [“សុខ ភាព គឺជាប្រធានគណៈកម្មាធិការតំបន់ ៥០៥ ចំណែកខ្ញុំ គឺជាប្រធានមន្ទីរតំបន់”]។ ឯកសារ D59/2/4.16a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សេង សឿន KH 00059329 [“សុខ ភាព សៅ ផុន មកលេខាអនុលេខា”]។ ឯកសារ D54/62 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វ៉េត ឆ.24 ឆ.26-27 [“ខ្ញុំបានដឹងតាមរយៈកងវរៈសេនាធំមួយកងរបស់កងទ័ពជើងទឹកក្រោមបញ្ជារបស់ភាព ទៅជួយកងពលលេខ១១៧របស់ខ្ញុំ។ នៅពេលនោះក៏មានការបោសសម្អាតដែលត្រូវបានធ្វើឡើងផងដែរ។ ពេលដែលភាព គាត់មកជាមួយកងវរៈសេនាធំរបស់គាត់ គាត់បានឡើងធ្វើជាលេខាតំបន់៥០៥ ពីព្រោះពេលហ្នឹង គេចាប់ មឿន ហើយ [...] ឆ.26៖ [...] កងវរៈសេនាធំរបស់ ភាព គឺជាកងកម្លាំងពិសេសរបស់ មាស មុត [...] ឆ.27៖ [កងវរៈសេនាធំជើងទឹករបស់ ភាព] ប្រហែល [បានមកដល់ខេត្តក្រចេះ] ចុងខែវិច្ឆិកា ឆ្នាំ១៩៧៨”]។ ឯកសារ D114/297.1.23 ម៉ឹង វ៉េត ប្រតិចារឹក ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.35.51-09.41.29 [រៀបរាប់ពីការប្រជុំនៅក្រចេះ ដែលនៅទីនោះ មាស មុត បានប្រកាសថា មេដឹកនាំចាស់ “ក្បត់ហើយ” ហើយថា “ត្រូវដូរមេកងពល”។ មាស មុត បានប្រាប់នៅក្នុងការប្រជុំថា ញ៉ាន់ នឹងមកជំនួសមេបញ្ជាការកងពលចាស់]។ ឯកសារ D54/63 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វ៉េត ឆ.1-3 [ធ្វើការបញ្ជាក់នោះនៅក្នុងកិច្ចប្រជុំ មាស មុត “ប្រកាសការផ្លាស់ប្តូរថ្នាក់ដឹកនាំកងពល” គាត់ថា “ញ៉ាន់ មកទទួលដឹកនាំជំនួស រុំ នៅក្នុងកងពល១១៧”]។ ឯកសារ D114/52 កំណត់ហេតុស្តាប់ចម្លើយ ឈាង ជួ ឆ.35 ឆ.40-41 [“តាញ៉ាន់ មកកាន់កងពល១១៧ [...] ឆ.40៖ មាស មុត បានមករៀបចំកងពល១១៧ ហើយចាត់តាំង តាញ៉ាន់ ជាបញ្ជាការកងពល ១១៧នេះ [...] ឆ.41៖ ខ្ញុំដឹងតាមរយៈអ្នកដែលមកកាន់កាប់ថ្មីហ្នឹង គឺតាញ៉ាន់។ តាញ៉ាន់ និយាយថា “បង មាស មុត ចុះមកក្រចេះ ដើម្បីរៀបចំកងពល១១៧ ឡើងវិញ””]។ ឯកសារ D54/110 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.5-6 [“ញ៉ាន់ គឺជាមនុស្សម្នាក់ដែលបានទៅក្រចេះជាមួយ មាស មុត [...] ឆ.6៖ [...] មាស មុត ត្រូវតែនាំទៅជាមួយគាត់ដូចជា ញ៉ាន់ បញ្ជាការកងពិសេស និងបញ្ជាការផ្សេងៗទៀតដែលគាត់ជឿទុកចិត្ត។ ខ្ញុំបានដឹងអំពីរឿងពួកអ្នកទាំងអស់នេះទៅក្រចេះ ពីព្រោះនៅពេលប្រជុំ មេបញ្ជាការរបស់ខ្ញុំបានធ្វើការប្រកាសប្រាប់ពួកយើង អំពីឈ្មោះថ្នាក់ដឹកនាំណាទៅកន្លែងណាខ្លះ”]។ ឯកសារ D114/157.1.3 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ចិន ផាត KH 01197651 [“កាលនោះឃើញគេបញ្ជូន អ៊ំ ញ៉ាន់ [មកជំនួស រុំ និង លាង] [...] គាត់ទៅនឹង គាត់ជំនួសខាងកងពល”]។ ឯកសារ D114/203 កំណត់ហេតុស្តាប់ចម្លើយ ម៉ិញ នឿម ឆ.44 [“ញ៉ាន់ ស្គាល់។ គាត់ក៏ជាប្រធានកងពលដែរ [១១៧]”]។ ឯកសារ D114/102 កំណត់ហេតុស្តាប់ចម្លើយ អែម រិន ឆ.25 [ធ្វើការកំណត់អត្តសញ្ញាណជាវិជ្ជមាននូវ ឯកសារ D114/18.1 រូបថតមួយសន្លឹករបស់ គឹម ញ៉ាន់ ហៅ ញ៉ាន់ ដែលបាននៅក្រចេះក្នុងឆ្នាំ ១៩៧៨]។ សូមមើលផងដែរនូវ ឯកសារ D114/191 កំណត់ហេតុស្តាប់ចម្លើយ សៅ សូ ឆ.46 [ធ្វើការបញ្ជាក់ថាបានឃើញ ញ៉ាន់ នៅក្រចេះ ក្នុងខែ ធ្នូ ឆ្នាំ ១៩៧៨]។ ឯកសារ D114/18 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន (ម៉ា ឈឿន) ឆ.16-17 [អតីតអ្នកក្រោមបង្គាប់របស់ ញ៉ាន់ នៅកំពង់សោម បានបញ្ជាក់ថាគាត់បានឈប់រាយការណ៍ទៅឲ្យគាត់ “រយៈពេលខ្លីមុនពេលវៀតណាមចូលមកដល់” “ដោយសារពេលនោះ តាញ៉ាន់ ត្រូវបានបញ្ជូនចេញទៅបាត់ [...] ទៅវ៉ៃជាមួយវៀតណាមនៅតាមព្រំដែន”]។

266 ឯកសារ D54/60.2 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ឹន វ៉េត KH 00975745 [“ស៖ មានតែ មាស មុត មួយទេ។ ឆ៖ បាទ”]។ ឯកសារ D114/169 កំណត់ហេតុស្តាប់ចម្លើយ សេង សឿន ឆ.23 [“បងមុត គេ

## ៣. ការរួមចំណែករបស់ មាស មុត ក្នុងឧក្រិដ្ឋកម្ម

## ការចូលរួមក្នុងការធ្វើទុក្ខបុកម្នេញ និងការសម្លាប់ខ្មាំង

### ទិដ្ឋភាពទូទៅ

88. នៅក្នុងពេញអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ មាស មុត បានរួមចំណែកក្នុងគោលនយោបាយធ្វើទុក្ខបុកម្នេញ និងសម្លាប់បុគ្គលទាំងឡាយដែលរបបនេះបានសង្ស័យថា មិនស្មោះត្រង់ខាងនយោបាយ និងបានចោទថាជា "ខ្មាំង"។ នៅក្នុងដែនដីដែលគាត់គ្រប់គ្រង និងតាមរយៈការប្រើកម្លាំងក្រោមអំណាចរបស់គាត់ មាស មុត ចេញបញ្ជា ញុះញង់ សម្រួល និងលើកទឹកចិត្តចំពោះការចាប់ខ្លួន ការចាប់ដាក់មន្ទីរឃុំឃាំង ការប្រព្រឹត្តិដោយអមនុស្សធម៌ ការធ្វើទារុណកម្ម ការបាត់

---

ជំនួសរដ្ឋាភិបាល សម័យនោះគេហៅរដ្ឋាភិបាល [...] គេឱ្យបងមុត មករៀបចំទាំងយោធា និងស៊ីវិល នៅតំបន់ក្រចេះ យោធាតំបន់ និងកងពល អាហ្នឹងលើដៃបងមុត"]។

[267] ឯកសារ D114/297.1.27 សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 10.58.45-11.00.50 ["ចំអាពេលយួនមកគេឱ្យ មុត ទៀត បញ្ជាខ្ញុំឱ្យដើរប្រមូលទ័ព មាស មុត ហ្នឹង ពេលហ្នឹងដើរទៅណាខ្ញុំទេ"] នៅម៉ោង 13.37.25-14.03.52 ["បង មុត ឱ្យប្រមូលទ័ពដែលបាក់ចេញពីព្រំដែនយួនមកហ្នឹង"]។ បានបញ្ជាក់នៅក្នុង ឯកសារ D114/297.1.28 សេង សឿន ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 09.04.50-09.06.50 ["ខ្ញុំមកដល់ខេត្តក្រចេះ [...] ខ្ញុំមកដល់ហ្នឹងមានភារកិច្ចតែមួយ មាស មុត គាត់ប្រើឱ្យប្រមូលទ័ពដែលកំពុងបាក់ពីយួនទៅព្រំដែនស្នួលនោះ"]។ ឯកសារ D54/62 កំណត់ហេតុស្តាប់ចម្លើយ ម៉ឺង វ៉េត ឆ.26 ឆ.30 ["កងវរៈសេនាធំរបស់ ភាព គឺជាកងកម្លាំងពិសេសរបស់ មាស មុត។ [...] ឆ.30៖ [...] "ដូច្នេះ ពួកអាធំៗទៅវ៉ៃយួន ចំណែកពួកអាតូចៗក្មេងៗដឹកសម្ភារៈទៅស្ទឹងត្រែង""]។ ឯកសារ D54/63 កំណត់ហេតុស្តាប់ចម្លើយ ម៉ឺង វ៉េត ឆ.10-11 ["ថ្ងៃបន្ទាប់មក ខ្ញុំបានឃើញ ញ៉ាន់ ទទួលបានសារទូរលេខ ថា មាស មុត ត្រឡប់ទៅដល់ភ្នំពេញវិញហើយ [...] ឆ.11៖ ពីព្រោះ មាស មុត នៅសេនាធិការ ដូច្នេះ គាត់មានសិទ្ធិអំណាចបញ្ជាទៅកងទ័ពទាំងបីប្រភព"]។ សូមមើលផងដែរនូវ ឯកសារ D54/60.2 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ឺន វ៉េត KH 00975745 ["គាត់ប្រាប់ថា អែងអាធំៗទៅវ៉ៃយួន នេះមេកងពលឯងនេះ មាន ញ៉ាន់ មានអីនេះ"]។

[268] ឯកសារ D114/297.1.27 សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 13.55.39-13.58.19 ម៉ោង13.59.45-14.00.52 [ផ្តល់សក្ខីកម្មថាពួ មុត នៅក្នុងមន្ទីរតំបន់៥០៥ រាយការណ៍ទៅ ស៊ូ ម៉េត]។ ឯកសារ D114/169 កំណត់ហេតុស្តាប់ចម្លើយ សេង សឿន ឆ.24 ["បងផុន បងភាព ហើយនិងបងមុតនុំង នៅកន្លែងហ្នឹង។ មានអង្គរក្សរៀងខ្លួន ប៉ុននៅជុំទាំងអស់គ្នា"]។ ឯកសារ D54/63 កំណត់ហេតុស្តាប់ចម្លើយ ម៉ឺង វ៉េត ឆ.23 ["បើសិនជា មាស មុត ទៅក្រចេះ តើគាត់ស្នាក់នៅកន្លែងណា? ឆ.23៖ ខ្ញុំមិនដឹងទេ ប៉ុន្តែធម្មតា គាត់ស្នាក់នៅភូមិគោលាប់ ដែលជាកន្លែងយោធាកងវរៈសេនាធំ របស់កងពល១៦៤ បោះទីតាំង"]។

ខ្លួន និងការសម្លាប់បុគ្គលទាំងឡាយនៃបណ្តាក្រុម ដែលបក្សកុម្មុយនីស្តកម្ពុជាបានចោទថាជាខ្មាំង។ មាស មុត បានចូលរួមក្នុងឧក្រិដ្ឋកម្មទាំងនេះ ជាមួយនឹងសមាជិកជាន់ខ្ពស់ផ្សេងៗទៀតនៃ ប.ក.ក មេបញ្ជាការយោធាជាន់ខ្ពស់នៃកងទ័ពបដិវត្តន៍កម្ពុជា និងជាមួយមេបញ្ជាការយោធា និងស៊ីវិលក្រោមបង្គាប់ នៅតាមមូលដ្ឋានក្នុងពល១៦៤ និងតំបន់កំពង់សោម។

89. ជាពិសេស មាស មុត បានចូលរួមក្នុងឧក្រិដ្ឋកម្មទាំងនេះ តាមដែនទឹកនៃកម្ពុជាប្រជាធិបតេយ្យ និង តាមកោះ លើដីគោកតំបន់កំពង់សោម ហើយនៅចុងឆ្នាំ ១៩៧៨ នៅតំបន់៥០៥ ព្រមទាំងទីតាំងទាំងឡាយ ដែលគាត់ជាអ្នកកាន់អំណាចដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ។ ទីតាំងទាំងនេះរួមមានទាំងមន្ទីរសន្តិសុខកងពល ១៦៤ នៅវត្តឥន្ទញ្ញាណ និងទឹកសាប ទីតាំងសម្លាប់មនុស្ស ទូទាំងតំបន់កំពង់សោម និងការដ្ឋាននៅស្ទឹងហាវ និងរាម។ មាស មុត ក៏បានបញ្ជូនជនសង្ស័យថាក្បត់ មកមន្ទីរសន្តិសុខ ស-២១ នៅភ្នំពេញ។

90. ដូចបានលើកឡើងត្រង់ផ្នែក *ការបោសសម្អាតខ្មាំង និងជនណាប្រឆាំងនឹងការដឹកនាំ ប.ក.ក* មាគ៌ាបក្សចំពោះ "ខ្មាំង" នៅក្នុងរយៈពេញទូទាំងរបបកម្ពុជាប្រជាធិបតេយ្យមានលក្ខណៈជ្រុល និងឃោរឃៅ។ មាស មុត បានដឹងច្បាស់នូវគោលនយោបាយនេះ តាមរយៈព័ត៌មានដែលគាត់ទទួលក្នុងឋានៈជាមេដឹកនាំជាន់ខ្ពស់នៃ ប.ក.ក និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា ដូចជា លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ការបោះផ្សាយប្រចាំខែ នៃទស្សនាវដ្តី *ទង់បដិវត្តន៍* និង *យុវជន យុវនារីបដិវត្តន៍*[269] ព្រមទាំងសារាចរណ៍ និងសេចក្តីណែនាំកម្រិតខ្ពស់ផ្សេងៗទៀត[270] ដែលបានពិភាក្សា

---

[269] ឯកសារ D98/3.1.316 យុន គីម ប្រតិចារឹក ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ នៅម៉ោង 10.10.11-10.12.03 ["ពេលរៀនគ្រប់វគ្គហ្នឹង ខ្ញុំសន្និដ្ឋានថា ជាខ្លឹមសារដែលដកស្រង់មួយចំណែកធំពីទង់បដិវត្ត ពីព្រោះអត្ថន័យហ្នឹងគឺ ព្រោះទង់បដិវត្តជាឯកសារសម្រាប់ណែនាំផ្លូវក្នុងការអនុវត្តរាល់ការងារ"]។ ឯកសារ D98/3.1.129 គឹម វុន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១២ នៅម៉ោង 11.39.34 -11.41.20 ["បើនិយាយទៅ ទង់បដិវត្ត […] គឺពីថ្នាក់ដឹកនាំលើ ទៅដឹកនាំថ្នាក់តាមលំដាប់"]។ ឯកសារ D98/3.1.21 ឆោម សែ ប្រតិចារឹក ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៣ នៅម៉ោង 11.54.34-11.57.10 ["រឿងទង់បដិវត្តនេះ វាការសិក្សារៀនសូត្រវាតែងតែមានហើយ។ ការបណ្តុះបណ្តាលនៃស្នូលដឹកនាំនៅក្នុងអង្គភាពដល់ក្របខ័ណ្ឌបញ្ជាការគ្រប់ថ្នាក់ សុទ្ធតែមានការបណ្តុះបណ្តាលបន្តបន្ទាប់ជារៀងរហូតមក។ បាទ បានមានសិទ្ធកែទម្រង់ការដឹកនាំនេះ"]។ ឯកសារ D4.1.845 កំណត់ហេតុស្តាប់ចម្លើយ ឡាញ់ ដុស ឆ.57-59 ["សៈ នៅពេលដែលលោកចូលរួមការរៀនសូត្រជាមួយ សុន សេន តើពេលនោះខ្លឹមសារនៃការបង្រៀននោះគាត់និយាយអំពីអ្វី? តើគាត់មានប្រើទស្សនាវដ្តីបដិវត្តន៍ ឬទស្សនាវដ្តីយុវជនបដិវត្តន៍ បង្រៀនដែរឬទេ? ឆ.57៖ ការប្រជុំរៀនសូត្រគឺរៀនធម្មតា ឯកសារទស្សនាវដ្តីទង់បដិវត្តន៍គេចែកឲ្យអានទូទៅ ចំពោះបក្ខជន និងយុវកក។ សៈ តើលោក

ដោយចំហ នូវវិសាលភាព និងចំណុចពិស្តារនៃគោលនយោបាយ ប.ក.ក រួមទាំងទម្រង់ដែលនយោបាយទាំងនោះត្រូវអនុវត្តតាមផង[271]។ មាស មុត ថែមទាំងបានទទួលនូវខ្លឹមសារនៃគោល

---

មានដែលទទួលទស្សនាវដ្ដីទង់បដិវត្តន៍ ហើយបានអានដែរឬទេ? ឆ.58៖ ពេលនោះ គេចែកជាទូទៅ ឲ្យតែយុវកក បក្ខជនគេចែកឲ្យអានទាំងអស់។ សៈ តើគេចែកជារឿយៗឬ? ឆ.59៖ គេចែកជាប្រចាំខែ"]។ ឯកសារ D4.1.856 កំណត់ហេតុស្ដាប់ចម្លើយ ណាំ ចៃ KH 00357498 ["សៈ តើប្រជាជនទាំងអស់ត្រូវតែអនុវត្តតាមទស្សនាវដ្ដី និងទង់បដិវត្តន៍មែនទេ? ឆៈ បាទ ប្រជាជនទាំងអស់ត្រូវតែអនុវត្ត និងប្រតិបត្តិតាមទស្សនាវដ្ដី និងទង់បដិវត្តន៍"]។

270 ឯកសារ D98/1.2.34 សៅ សារុន ប្រតិចារឹក ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១២ នៅម៉ោង 09.48.02-09.52.48 ម៉ោង 09.57.19-10.05.54 ម៉ោង 10.22.31-10.31.22 បញ្ជាក់លើ ឯកសារ D4.1.444 កំណត់ហេតុស្ដាប់ចម្លើយ សៅ សារុន KH 00251437, 41; ឯកសារ D4.1.793 កំណត់ហេតុស្ដាប់ចម្លើយ សៅ សារុន KH 00398480-83 [សាក្សីបានផ្ដល់សក្ខីកម្មថា "តំណាងគ្រប់កងពល" បានចូលរួមមហាសន្និបាត នៅខែកញ្ញា ឆ្នាំ ១៩៧៨ នៅភ្នំពេញក្នុងពេលនោះដែរ គោលការណ៍គណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា ឯកសារ (D4.1.583) ចុះខែ មិថុនា ឆ្នាំ ១៩៧៨ ត្រូវបានអានឲ្យស្ដាប់ និង "ត្រូវបានចែក"]។

271 សូមមើល ឧទាហរណ៍ ឯកសារ D4.1.862 ទស្សនាវដ្ដីទង់បដិវត្ត ចេញខែ មេសា ឆ្នាំ ១៩៧៧ KH 00062986 ["ឯចំពោះខ្មាំងជាភ្នាក់ងារ ßស អ អà ßក ស បà និង ភ្នាក់ងារ ßយà ជាឆ្កែបំរើខ្មាំងយ៉ាងថោកទាប ដែលលួចបង្កប់ [...] ត្រូវកម្ទេច [...] ឲ្យវាកាន់តែខ្ទេចខ្ទីតទៅទៀត ងើបក្បាលមិនរួច។ ធ្វើយ៉ាងនេះ យើងរឹតតែបង្កើនលក្ខណៈសម្បត្តិឲ្យយើងទៅវាយខ្មាំង ឆ្នាំ១៩៧៨ និងឆ្នាំតៗទៅទៀត កាន់តែខ្លាំង និងកាន់តែបានជ័យជំនះធំៗថែមទៀត"] KH 00062991-92 ["ត្រូវបំពាក់បំប៉ន និងបំផុសមហាជន [...] ធ្វើឲ្យខ្មាំងទៅជាកណ្ដុរក្នុងរង្វង់ហ៊ុំព័ទ្ធ វាយកំទេចរបស់ប្រជាជន ដ៏កុះករ [...] ត្រូវសំរិតសំរាំងជំរុះ និងបោសសំអាតសមាសភាពមិនល្អ និងសមាសភាពខ្មាំងហើយពង្រឹង និងពង្រីកសមាសភាពល្អតទៅទៀត ដែលចេញមកពីចលនា ជាបន្តបន្ទាប់"] KH 00062993 ["បញ្ហាមួយ ដែលត្រូវយកចិត្តទុកដាក់សំខាន់ណាស់ដែរគឺវែកមុខពួក ßស អ អà និងភ្នាក់ងាររបស់វា ពួក ßក ស បà និងភ្នាក់ងាររបស់វា ពួក ßយà លេបទឹកដី និងឆ្កែបំរើរបស់វាឲ្យច្បាស់ និងជាបន្តបន្ទាប់...ឲ្យស្អាតជាស្ថាពរ"]។ ឯកសារ D4.1.653 ទស្សនាវដ្ដីទង់បដិវត្ត ចេញខែ មិថុនា ឆ្នាំ ១៩៧៧ KH 00062803 ["បំផុសអប់រំមហាជន [...] ឲ្យគេឃើញច្បាស់ថា ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងធ្វើសកម្មភាពយ៉ាងម៉េចឲ្យគេជ្រួតជ្រាប ដើម្បីគេទៅជាកម្លាំងរកខ្មាំង និងវាយខ្មាំងតទៅទៀត"] KH 00062809 ["ដោយរបបឯកជនទាំងអស់គ្មានបានរើរួចទេ [...] បោសសំអាតខ្មាំងតទៅទៀត។ វាយខ្មាំងបោសសំអាតខ្មាំងជាភ្នាក់ងារអន្តរជាតិ ខ្មាំងជាខ្មាំងបង្កប់ ខ្មាំងជាខ្មាំងវណ្ណៈ មិនឲ្យវាត្រដេវត្រដរ ធ្វើសកម្មភាព សូម្បីតែបន្តិចបានឡើយ"]។ ឯកសារ D10.1.59 ទស្សនាវដ្ដីទង់បដិវត្ត ចេញខែ សីហា ឆ្នាំ ១៩៧៧ KH 00062970 ["វណ្ណៈមិនល្អកាន់អំណាចក្នុងសហករណ៍ វាមានធាតុពិតអ្វី? គឺប្រឆាំងបដិវត្ត"]។ ឯកសារ D4.1.864 ទស្សនាវដ្ដីទង់បដិវត្ត ចេញខែ កញ្ញា ឆ្នាំ ១៩៧៧ KH 00063141 ["នៅតែបំផុសឱយវណ្ណៈកសិករគេឃើញទំនាស់។ បំផុសឱយគេឃើញទំនាស់ហើយមានកំហឹងវណ្ណៈដើម្បីតស៊ូ បញ្ហានេះជាបញ្ហាគន្លឹះ ជាបញ្ហាមូលដ្ឋាន ដែលកំណត់នៃជ័យជំនះ"] KH 00063170-71 ["សមាសភាពប្រឆាំងបដិវត្ត ក្បត់បដិវត្ត និងបំផ្លិចបំផ្លាញបដិវត្តទាំងនេះ យើងមិនកំណត់ថាជាប្រជាជនទេ យើងកំណត់ថាជាខ្មាំងសត្រូវ របស់កម្ពុជាប្រជាធិបតេយ្យ របស់បដិវត្តកម្ពុជា របស់ប្រជាជនកម្ពុជា"]។ ឯក

យោបាយបក្សកុម្មុយនីស្តកម្ពុជា ទាក់ទងនឹងខ្មាំង តាមរយៈបណ្តាអង្គប្រជុំកម្រិតខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា[272]។

---

សារ D4.1.865 ទស្សនាវដ្តីទង់បដិវត្ត ចេញខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៧ KH 00064758 ["នៅក្នុងមជ្ឈិម នៅក្នុងសេនាធិការ នៅក្នុងភូមិភាគ នៅក្នុងមូលដ្ឋាន សុទ្ធតែមានខ្មាំងបង្កប់នៅក្នុងជួរយើង។ បើយើងមិនមានវិធានការទាន់ពេលវេលាគឺគ្រោះថ្នាក់"]។ ឯកសារ D4.1.866 ទស្សនាវដ្តីទង់បដិវត្ត ចេញខែ កុម្ភៈ ឆ្នាំ ១៩៧៨ KH 00064443 ["ខ្មាំងសត្រូវគ្រប់ប្រភេទ នៅបន្តធ្វើសកម្មភាពចង់យាយីយើង ដើម្បីយកប្រទេសយើងធ្វើជាអាណាបវាទៀត តាមរូបភាពផ្សេងៗ៖ ជាណ្តួនពាន-ចារកម្ម-សង្កត់-គំរាមកំហែង-វិទ្ធង្សនា-ខែស៊ីរូងផ្ទៃក្នុង ប៉ងប្រាថ្នារំលំអំណាចបដិវត្តយើង"]។ ឯកសារ D4.1.45 ទស្សនាវដ្តីទង់បដិវត្ត ចេញខែ កុម្ភៈ ឆ្នាំ ១៩៧៨ KH 00063491 ["ភារកិច្ចរបស់យើងបច្ចុប្បន្ន និងតទៅអនាគតទៀត គឺត្រូវលើកកំពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តឱយខ្ពស់ជាប់ជានិច្ច ដើម្បីការពារឯករាជជាតិ [...] ដែលខ្មាំងសត្រូវគ្រប់ប្រភេទ វារកតែឱកាសវាយបំបាក់ និងជាន់ឈ្លីឱយលិចលង់វិនាសសាបសូន្យជាបន្តបន្ទាប់"]។ ឯកសារ D1.3.24.5 ទស្សនាវដ្តីទង់បដិវត្ត ចេញខែ ឧសភា-មិថុនា ឆ្នាំ ១៩៧៨ KH 00064556 ["យើងបានឃើញ [...] សភាពពិសពុល នៃខ្មាំងខាងក្នុងនេះថែមទៀត [...] យើងត្រូវពង្រឹងគោលជំហរតស៊ូវណ្ណៈ [...] ដើម្បីកំចាត់ខ្មាំង ទាំងក្នុង ទាំងក្រៅ ពិសេសខ្មាំងខាងក្នុងនេះជាបន្តបន្ទាប់"] KH 00064578 ["ដូច្នេះ ភារកិច្ចរបស់យើង គឺវាយកំទេច ជាដាច់ខាត [...] ឯខ្មាំងវិញត្រូវខ្ទេចខ្ទី ខ្ចាត់ខ្ចាយ និងរលំរលាយ"] KH 00064579 ["ត្រូវឃើញមុខមាត់ខ្មាំងឱយច្បាស់ [...] បោសសំអាតខ្មាំងទាំងនេះ បោសហើយ បោសទៀត បោសហើយ បោសទៀត គ្មានឈប់ឈរ ដើម្បីឱយកំឡាំងបក្សរបស់យើងស្អាត កំឡាំងដឹកនាំរបស់យើងគ្រប់ថ្នាក់ គ្រប់ផ្នែក និងគ្រប់ពេលវេលាស្អាត"]។ ឯកសារ D4.1.869 ទស្សនាវដ្តីទង់បដិវត្ត ចេញខែ កក្កដា ឆ្នាំ ១៩៧៨ KH 00064488 ["៦ខែ ដើមឆ្នាំ ១៩៧៨នេះ បក្សយើងបានបំផុសចលនាទូទាំងប្រទេស [...] បោសសំអាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង [...] ដែលអាចធ្វើបាននៅតាមកន្លែងនីមួយៗ [...] តែខ្មាំងបង្កប់ជាភ្នាក់ងារផ្ទៃបំរើយួន វាជាសត្រូវស្លាប់រស់ដែលមានពិសពុលបំផុតមានគ្រោះថ្នាក់បំផុតជាងគេ"] KH 00064494 ["ដើម្បីបោសសំអាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងឱយបានស្អាត [...] សំរិតសំរាំងនៅក្នុងជួរបក្ស ជួរមហាជន និងកងទ័ព"] KH 00064490 ["អាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងត្រូវបែកមុខ។ យើងរក្សាការពារកំឡាំងបដិវត្តបាន ពង្រឹងកំឡាំងបដិវត្ត បានសំរិតសំរាំងសមាសភាពអាក្រក់ចេញ ហើយបន្តដឹកនាំមហាជនតស៊ូយកជ័យជំនះតទៅទៀត"] KH 00064502 ["ជាពិសេសថែមទៀត ក្នុងមហាចលនាមហាជនវាយកំទេចខ្មាំងយួន [...] បំបាត់ពូជសាសន៍ [...] នាំមកនូវជ័យជំនះជាយុទ្ធសាស្ត្រជូនជាតិ ប្រជាជន បក្ស និងបដិវត្ត"]។ ឯកសារ D4.1.870 ទស្សនាវដ្តីទង់បដិវត្ត ចេញខែ សីហា ឆ្នាំ ១៩៧៨ ["បក្ខជនណា...ស្អាតស្អំ...មានអនាគតល្អ [...] ផ្ទុយទៅវិញ បើបក្ខជនណា [...] មិនស្អាតស្អំ ខុសពីការរស់នៅតាមបែបបទបដិវត្ត [...] ជំពាក់ជំពិនជាមួយខ្មាំង [...] មុខជាវិវត្តបញ្ច្រាស់ចរន្តបដិវត្ត ជាមិនខាន"]។

272 ឯកសារ D54/16/1R កំណត់ហេតុជាខ្សែអាត់សម្លេងនៃបទសម្ភាសន៍ មាស មុត ដោយ David Kattenburg ឆ្នាំ ២០០៩ ត្រង់នាទី 03:45-05:45 [មាស មុត បានបញ្ជាក់ថាគាត់បានចូលរួមកិច្ចប្រជុំធំដែលបានចូលរួមដោយ ប៉ុល ពត នួន ជា អៀង សារី សុន សេន និង ខៀវ សំផន]។ ឯកសារ D1.3.8.3 កំណត់ហេតុនៃអង្គប្រជុំ ការងារយោធានៅកំពង់សោម ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំលេខា និងភស្តុ

91. មាស មុត មានការទាក់ទងជិតស្និទ្ធជាមួយសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងទូទាំងរបបនោះទាំងមូល ដែលធ្វើឱ្យគាត់មានឱកាសជួបអ្នកធ្វើគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។ គាត់រាយការណ៍ផ្ទាល់ទៅ សុន សេន លើបញ្ជាកងពល ១៦៤,[273] ហើយជារឿយៗដាក់បញ្ជូនសារឱ្យ

---

ភារ របស់កងពល និងវរៈសេនាធំ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខា និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH 00052411។ ឯកសារ D1.3.27.22 កំណត់ហេតុនៃការប្រជុំគណៈកងពលពេញអង្គ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.26 កំណត់ហេតុនៃការប្រជុំលេខា អនុលេខា កងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧។ សូមមើលផងដែរនូវ ឯកសារ D54/37 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.30-31 [“សៈ តើលោកធ្លាប់ឮថា មាស មុត ធ្វើការអគ្គសេនាធិការដែរឬទេ? ឆ.30៖ បាទ ខ្ញុំឮ។ គាត់ត្រូវប្រជុំមួយខែម្តងជាមួយសេនាធិការនៅភ្នំពេញ។ សៈ ហេតុម៉េចបានជាលោកបានដឹងអំពីរឿងនេះ? ឆ.31៖ ខ្ញុំដឹងដោយសារ ប្រធានរបស់ខ្ញុំជាគ្រិន ក៏បានទៅចូលរួមប្រជុំនោះដែរ”]។ ឯកសារ D4.1.408 កំណត់ហេតុស្តាប់ចម្លើយ ឈូក រីន ហៅ សុខ KH 00194467-68 [“មេបញ្ជាការយោធាជាន់ខ្ពស់ រួមទាំងរូបខ្ញុំ បានទទួលបញ្ជាតាមទូរលេខ ឱ្យធ្វើដំណើរទៅភូមិភាគបូព៌ា ហើយយើងក៏បានទទួលបញ្ជាផ្ទាល់មាត់ដែរក្នុងការប្រជុំពិសេសមួយនៅទីក្រុងភ្នំពេញ ដោយមានមេបញ្ជាការចូលរួម។ អង្គប្រជុំនេះបានធ្វើឡើងប្រហែលជានៅពេលតំណាលគ្នានៃការធ្វើមហាសន្និបាទប្រចាំឆ្នាំរបស់បក្ស។ មានការប្រជុំផ្សេងគ្នាសម្រាប់មេបញ្ជាការយោធា និងស៊ីវិល។ ខ្ញុំបានចូលរួមការប្រជុំសម្រាប់មេបញ្ជាការយោធា ដោយមានមេបញ្ជាការកងពលធំ និង កងវរៈសេនាធំ ប្រហែល ៤០ ទៅ ៥០នាក់ មានវត្តមាននៅទីនោះ។ ប៉ុល ពត បាននិយាយមកកាន់ពួកយើង បន្ទាប់មក តាម៉ុក ទៅលើចំណុចនៃការចាំបាច់ដើម្បី “ធ្វើការបោសសំអាតនៅក្នុងបក្ស”។ នួន ជា បាននិយាយពី “ការសំអាតក្នុងជួរបក្ស”។ សេចក្តីសម្រេចធ្វើការបោសសំអាតភូមិភាគបូព៌ា បានធ្វើឡើងរួមគ្នា ដោយគណៈអចិន្ត្រៃយ៍ សុន សេន ធ្វើតាមបញ្ជារបស់ ប៉ុល ពត ហើយ នួន ជា និង តាម៉ុក មានវត្តមានទាំងអស់គ្នានៅក្នុងអង្គប្រជុំ។ ក្នុងចំណោមមេបញ្ជាការយោធាដែលមានវត្តមានទាំងអស់ រួមមាន មាស-មុត អៀង-ផាន សុខ-ឈាន (អនុអៀង ផាន) ធីឌី និង ធី ពូសេ។ ការប្រជុំដើម្បីផ្តល់ការណែនាំពីការបោសសំអាតនេះ ធ្វើឡើងនៅកន្លែងផ្សេងគ្នាពីមហាសន្និបាតបក្សដែលធ្វើឡើងនៅពហុកីឡដ្ឋានអូឡាំពិក។ ការប្រជុំផ្តល់ការណែនាំនោះ ធ្វើឡើងនៅទីបញ្ជាការយោធា នៅជិតបឹងត្របែក។ សេចក្តីសម្រេចនោះអាចរកឃើញនៅក្នុងទស្សនាវដ្តីទង់ ប.ក.ក លេខ ៧ ហើយត្រូវបានពិភាក្សានៅក្នុងមហាសន្និបាតប្រចាំឆ្នាំ ក្នុងចុងឆ្នាំ១៩៧៧។ អ្នកដែលមានសិទ្ធិចូលរួមក្នុងសន្និបាតស្តីពីទង់ ប.ក.ក លេខ៧ គឺត្រូវតែជាបក្សជន”]។

273 សូមមើល ឧទាហរណ៍ ឯកសារ D4.1.1020 សារទូរលេខ ពី មុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៧៦។ ឯកសារ D1.3.12.3 របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ពី មុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦។ ឯកសារ D1.3.14.1 សារទូរលេខ ពី មុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.34.10 សារទូរលេខ ៤៤ ពី មុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.4.1 របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ពី មុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៧៦។ ឯកសារ

ទៅដល់ប៉ុល ពត, នួន ជា និងអៀង សារី ជាពិសេស ពេលដែលគាត់រាយការណ៍អំពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ស្តីអំពីខ្មាំងនៅក្នុងមូលដ្ឋានដែលគាត់គ្រប់គ្រង[274]។ តាមពិត ក្នុងឋានៈជាលេខាតំបន់ឯករាជ្យ មាស មុត យោងតាមលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ត្រូវអនុវត្តតាម

---

D1.3.2.2 សារទូរលេខ ១០ ពី ៨៩ (សុន សេន) ជូនសមមិត្ត មុត (មាស មុត) និង កងពល ១៦៤ ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.12.18 សារទូរលេខ ០៩ ពី មុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៧៧។ ឯកសារ D1.3.34.64 ទូរស័ព្ទ សំងាត់ ពី មាស មុត ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨។ ឯកសារ D4.1.637 របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ពី មុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៧៨។ ឯកសារ D1.3.12.2 របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ពី មុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៦ ខែ កុម្ភៈ (ឆ្នាំមិនដឹង)។ សូមមើលផងដែរនូវ ឯកសារ D114/29.1.6 កំណត់ហេតុស្តាប់ចម្លើយ សៅ សារុន KH 00345912 ["យោធាតំបន់មានសិទ្ធិរាយការណ៍មកតែគណៈតំបន់ ចំណែកឯកងពលមជ្ឈិមត្រូវរាយការណ៍ទៅមជ្ឈិមផ្ទាល់"]។ ឯកសារ D54/54 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.5 ["មាស មុត បាយរាយការណ៍ទៅអគ្គសេនាធិការ សុន សេន ដោយផ្ទាល់"]។ ឯកសារ D54/110 កំណត់ហេតុស្តាប់ចម្លើយ លុន សេង (មេកងអនុសេនាធំលេខ ៨ កងវរៈសេនាតូច ៤២០ កងវរៈសេនាធំ ២១) ឆ.9 ["បាទ ហើយវាមិនមែនមានតែសម្រាប់កងពល១៦៤មួយទេ កងពលណាក៏ដោយដែលជារបស់មជ្ឈិម មេបញ្ជាការកងពលទាំងនោះ គឺជាសមាជិកគណៈបញ្ជាការរបស់សេនាធិការ។ ពេលណាដែលកងពលក្លាយទៅជាកងពលរបស់មជ្ឈិម មេបញ្ជាការរបស់កងពលនោះក្លាយជាសមាជិកគណៈកម្មាធិការសេនាធិការ"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.9 ["មាស មុត គឺជាមេបញ្ជាការកងពលលេខ៣ ហើយគាត់គឺអនុរបស់ សុន សេន ដែលនៅសេនាធិការរបស់កងទ័ពជាតិ"]។ ឯកសារ D1.3.13.13 បទសម្ភាសន៍របស់ការិយាល័យសហព្រះរាជអាជ្ញាជាមួយ ទូច សឿលី EN 00217575 ["ទីបញ្ជាការកងទ័ពជើងទឹកបានធ្វើការទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងទីបញ្ជាការសេនាធិការនៅភ្នំពេញ និងជាមួយនឹងភូមិភាគនិរតីនៅក្រោម តាម៉ុក"]។

274 ឯកសារ D4.1.699 សារទូរលេខ ១១ ពី ឌឹម ជូនបង មុត (មាស មុត) ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ [សារទូរលេខពីអនុរបស់ មាស មុត រៀបរាប់ក្នុងចំណោមបញ្ហាផ្សេងៗពីសភាពការណ៍ខ្មាំងនៅកំពង់សោម។ ចម្លងជូន នួន ជា សុន សេន មន្ទីរ ៨៧០ និង ឯកសារ]។ ឯកសារ D1.3.34.60 សារទូរលេខ ០០ ពី មុត (មាស មុត) ជូន ម-៨៧០ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ [រៀបរាប់ពីការប្តេជ្ញារបស់ មាស មុត ក្នុងការ "បោសសំអាត គ្មានស្នាក់ស្ទើរសមាសភាពបង្កប់របស់ខ្មាំង ជាយួននិងខ្មាំងដទៃទៀត" និងប្រយុទ្ធជាមួយនឹងពួកយួនលេបទឹកដី។ សារទូរលេខនេះត្រូវបានចម្លងជូនអ៊ុំ (ប៉ុល ពត) អ៊ុំ នួន (នួន ជា) បងវ៉ាន់ (អៀង សារី) បង វន បងខៀវ (សុន សេន) មន្ទីរ និងឯកសារ]។ ឯកសារ D1.3.30.25 ទូរស័ព្ទ សំងាត់ ពី មុត ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៨ [រាយការណ៍ពីការចាប់ និងសម្លាប់នៃជនជាតិវៀតណាម១២០នាក់នៅក្នុងអំឡុងថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៧៨ ដល់ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៨។ ចម្លងជូន នួន ជា ប៉ុល ពត បងវ៉ាន់ (អៀង សារី) និងឯកសារ]។ ឯកសារ D1.3.12.2 របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ពី មុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៦ ខែ កុម្ភៈ (ឆ្នាំមិនដឹង) [របាយការណ៍រៀបរាប់ពីការវាយប្រហារ និងការចាប់ទូកនេសាទថៃ។ ចម្លងជូន បង ៨៧ (វន វេត) បង និងឯកសារ]។

"របបរាយការណ៍ ជូនគណៈកម្មាធិការមជ្ឈិម"[275] មួយ ដែលគាត់បានអនុវត្តតាមរយៈការទាក់ទងប្រចាំថ្ងៃតាមទូរស័ព្ទជាមួយមន្ទីរ ក-១[276]។

92. ការដឹងឮរបស់ មាស មុត ចំពោះគោលនយោបាយអំពីខ្មាំង មានទទ្ទីករណ៍បន្ថែមផ្អែកលើការចូលរួមរបស់គាត់ក្នុងប្រជុំអគ្គសេនាធិការ ដែលក្នុងនោះ ក្រុមបុគ្គលទាំងឡាយ ត្រូវបានកំណត់ថា "សមាសភាពមិនល្អ" ជាមុខសញ្ញាសម្រាប់បោសសម្អាត។ ក្រុមទាំងនេះ រួមមាន: (១) ជនណាដែលប្រឆាំងបក្ស ដោយបានប្រព្រឹត្តកំហុសដូចជា លួច ធ្វើវិទ្ធង្សនា ដាក់ជាតិពុល ញុះញង់ឲ្យកងទ័ពផឹកជាតិស្រវឹង ឬបេះផ្លែឈើហូប,[277] (៣) ជនណាដែល "ខ្ជិល", "ធ្វើពុត" ឈឺ ឬ សំដែងការមិនពេញចិត្តជាមួយរបបនោះ,[278] (៤) ជនដែលមានកូនជាទាហាន មេឃុំ ឬប៉ូលិស ដែលត្រូវបាន

---

[275] ឯកសារ D1.3.22.1 លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦ មាត្រា១៩ KH 00053032 ["កាន់កាប់ទ្រព្យសម្បត្តិ របស់អង្គការភូមិភាគ អនុវត្តវិន័យ ក្នុងក្របខណ្ឌភូមិភាគ មានរបបរាយការណ៍ អំពីស្ថានការណ៍ និងការងាររបស់ភូមិភាគ ជូនគណៈកម្មាធិការមជ្ឈិម"]។

[276] ឯកសារ D54/73 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.3-5 [សាក្សីបានធ្វើជាអ្នកឆ្លើយឆ្លងទូរស័ព្ទសម្រាប់ មាស មុត ៖ "សៈ សូមលោកស្រីរកនឹកមើល ថាតើអ្នកដែលទទួលទូរស័ព្ទមកពីមជ្ឈិមមករកមេបញ្ជាការកងពល១៦៤ មាស មុត ហ្នឹង តើគាត់ឈ្មោះអ្វី? ឆ.3៖ ទេ ខ្ញុំមិនចាំឈ្មោះទេ ខ្ញុំគ្រាន់តែចាំលេខអ្នកទូរស័ព្ទ គឺលេខ ក-១។ សៈ តើ ក-១ ហ្នឹងទូរស័ព្ទមកញឹកញាប់ប៉ុនណា? ឆ.4៖ ពេលខ្លះ១ថ្ងៃម្តង ពេលខ្លះ២ថ្ងៃម្តង។ កាលហ្នឹងមានទូរស័ព្ទទៅមករវាងមេបញ្ជាការកងពល១៦៤ មាស មុត និង មជ្ឈិម ប៉ុន្តែខ្ញុំមិនចាំច្បាស់ពីរបៀបហៅហ្នឹងយ៉ាងម៉េចទេ ដូច្នេះខ្ញុំមិនអាចប្រាប់លោកបានទេ។ សៈ ជាទូទៅនៅពេលដែល ក-១ ទូរស័ព្ទចូលមក តើលោកស្រីភ្ជាប់ខ្សែទូរស័ព្ទចូលត្រង់ទៅផ្ទះ មាស មុត តែម្តង ឬក៏លោកស្រីភ្ជាប់ខ្សែទូរស័ព្ទទៅកន្លែងណាផ្សេងទៀត? ឆ.5៖ ខ្ញុំភ្ជាប់ខ្សែទូរស័ព្ទទៅផ្ទះ តា មុត តែម្តង"]។

[277] ឯកសារ D1.3.27.26 កំណត់ហេតុនៃការប្រជុំលេខា អនុលេខា កងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧ KH 00052305 ["សមមិត្ត ភាព [និយាយពីខ្មាំង]៖ [...] ផ្ទៃក្នុងអង្គភាព មានកម្មាភិបាលអនុសេនាតូចម្នាក់ ឈ្មោះ ហេង នាំយុទ្ធជនផឹកស្រា។ កម្មាភិបាលអនុសេនាធំម្នាក់ ឈ្មោះ ចំរើន ទំនាស់នឹងការហាមឃាត់ មិនឱយបេះផ្លែឈើស៊ីសេរី"]។ ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំ លេខា និងអនុលេខា និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH 00052410 ["សមមិត្ត អឿន៖ [...] សរុបពួកមិនល្អ បាន ៣៦ នាក់។ មានសកម្មភាពបំពុល ដាក់អង់ខ្រីនឱយបងប្អូនផឹក ពុលអស់មួយអនុសេនាតូច"]។

[278] ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំ លេខា និងអនុលេខា និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH 00052410 [សមមិត្ត ភាព៖ [...] "អង្គភាព មានពួកចាញ់ច្រាប ជឿឧបាយកលខ្មាំង ខ្ជិលធ្វើការងារ ពុតត្បុត ទោមនស្សនឹងរបប"]។

សម្លាប់ពីមុនមក,[279] (៥) ជនដែល "និយមឋានៈនិងបុណ្យសក្តិ" [280] (៦) កងទ័ពរត់ចោលជួរ, [281] (៧) បុគ្គលឬគ្រួសារមកពីប្រទេសវៀតណាម[282] និងជនណាពាក់ព័ន្ធជាមួយខ្មាំងខាងក្រៅ រួមទាំងវៀតណាមផង[283]។

[279] ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំ លេខា និងអនុលេខា និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH 00052403 [សមមិត្ត សួង៖ "កម្មាភិបាល ដែលម៉ែឪត្រូវយើងបោសសំអាតចេញអាកប្បកិរិយា អាជ្ញាដាក់មហាជន"]។ ឯកសារ D1.3.27.26 កំណត់ហេតុនៃការប្រជុំលេខា អនុលេខា កងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧ KH 00052305 [សមមិត្ត ឈិន៖ […] "ខ្មាំងក្នុងអង្គភាព នៅមាន ត្រូវយើងតាមដាន និងក្តាប់បានមួយចំនួន។ - ក្រោយរៀនសូត្រ បានសំរិតសំរាំងពួកចេញពីវៀតណាម កូនរបស់ទាហាន មេឃុំ ឬប៉ូលិស ឱយបង្កបង្កើនផលមួយជុំ"]។

[280] ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំ លេខា និងអនុលេខា និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH 00052409 ["សមមិត្ត ពីន […] មូលហេតុក្បត់ មកពីពួក ទំនាស់មុខមាត់ បុណ្យសក្តិ […] មាននៅសេសសល់ខ្លះ ពួកចចេចចចូច ពួកលួចឆក់ ពួកទំនាស់មុខមាត់បុណ្យសក្តិ បានប្រមូលផ្តុំ ចំនួន ៨០ នាក់"] KH 00052412 [សុន សេន៖ "ពិសោធនេះ នាំឱយចាប់អារម្មណ៍កាន់តែខ្ពស់ទៀត ចំពោះសមាសភាពមានប្រវត្តិមិនល្អ មានសតិអារម្មណ៍ មុខមាត់ បុណ្យសក្តិ ខ្ពស់"]។

[281] ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំ លេខា និងអនុលេខា និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH 00052403-04 [ករណីរត់នានាបានត្រូវពិភាក្សាដោយ សួង, សាន]។ ឯកសារ D1.3.27.22 កំណត់ហេតុនៃការប្រជុំគណៈកងពលពេញអង្គ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ KH 00088926 [កងពល ១៧០ - សមមិត្ត សុក […] ង. សភាពការណ៍ខ្មាំង៖ "ក្នុងអង្គភាព មានរត់ដែរ។ រត់ជាច្រើនសារហើយ"] ។

[282] ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំ លេខា និងអនុលេខា និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH 00052410 [សមមិត្ត អឿន៖ "បាតុភាព មានពួកលាក់ប្រវត្តិរូប រហូតកម្មាភិបាលអនុសេនាធំ ពីដើមជាខ្មែរស ធ្លាប់នៅជាមួយវៀតណាម"]។

[283] ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំ លេខា និងអនុលេខា និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH 00052405-06 [សុន សេន ពន្យល់ ពីរបៀបថា ចក្រី ជា "ខ្សែខ្មែរសេរី" និងមេរបស់គាត់ ឈូក លេខាតំបន់ ២៤ ត្រូវបានចាប់ខ្លួនដោយសារទាក់ទងវៀតណាម "រៀបចំវាយក្បាលម៉ាស៊ីនដឹកនាំបក្សយើង។ វាវាយពីក្នុង វៀតណាមវាយពីក្រៅ […] ឈូក ឆ្លើយមកដល់ឈ្មោះ យ៉ា។ យើងចាប់ យ៉ា […] ខ្មាំងខាងកើត៖ វៀតណាម និងសូវៀតនៅពីក្រោយ ផែនការសំខាន់វាយពីក្នុង តាមរយៈកំលាំងក្បត់របស់ យ៉ា _កែវ មាស_ ឈូក_ ចក្រី"] KH 00052413 ["ខ្មាំងវានឹងធ្វើសកម្មភាពតាមសមុទ្រនិងព្រំដែនតិចតួច តទៅទៀត។ ឯខ្មាំងកំប៉ិកកំប៉ុកខាងក្នុង ក៏ត្រូវយកចិត្តទុកដាក់ កុំឱយវាធ្វើសកម្មភាពបាន ដើម្បីការពារបក្ស ការពារផលបដិវត្ត"] KH 00052413 ["ក្នុងឋានៈជាកងទ័ពត្រូវស្គាល់កម្មវត្ថុ ដែលត្រូវវាយ គឺចក្រពត្តិអាមេរិក ពួកសេរីរើ វៀតណាម និងដៃជើងក្បត់របស់វា"]។

93. ដូចបានសរសេរពិស្តារបន្ថែមខាងក្រោមនេះ មាស មុត សហការជាមួយមេបញ្ជាការយោធាផ្សេងៗទៀតក្នុងការអនុវត្តគោលនយោបាយនេះ ក្នុងក្របខណ្ឌកងពលមជ្ឈិមរបស់កងទ័ពបដិវត្តន៍កម្ពុជា។ បន្ទាប់មក គាត់អនុវត្តគោលនយោបាយនេះនៅក្នុងកងពល និងតំបន់របស់គាត់ ដោយបញ្ជាកម្មាភិបាលក្រោមបង្គាប់របស់គាត់ ស្វែងរក និងកម្ទេច "សមាសភាពមិនល្អ" ក្នុងកងពល ១៦៤ តំបន់កំពង់សោម និងក្នុងដែនទឹកនៃកម្ពុជាប្រជាធិបតេយ្យ។ ការស្វែងរកគ្មានឈប់ឈរចំពោះខ្មាំងទាំងនេះ បណ្ដាលឲ្យបុគ្គលរាប់ពាន់នាក់ក្នុងក្រុមមុខសញ្ញាត្រូវបានចាប់ដាក់មន្ទីរឃុំឃាំង បង្ខំឲ្យធ្វើពលកម្ម ធ្វើទារុណកម្ម និង/ឬ សម្លាប់នៅមន្ទីរសន្តិសុខកងពល ១៦៤ ទីតាំងសម្លាប់មនុស្ស និងការដ្ឋាន ដែលស្ថិតនៅទូទាំងកំពង់សោម នៅសមុទ្រ និងនៅមន្ទីរសន្តិសុខ ស-២១។

## <u>កងទ័ពប្រជាជនបដិវត្តន៍កម្ពុជា</u>

### *ក) កងពល និងវរសេនាធំឯករាជ្យរបស់ ក.ប.ប.ក*

94. មាស មុត សហការជាមួយមេបញ្ជាការនៃអគ្គសេនាធិការ កងពលមជ្ឈិមនិងវរសេនាធំឯករាជ្យក្នុងការអនុវត្តផែនការឧក្រិដ្ឋសំដៅបោសសម្អាតកងទ័ពបដិវត្តន៍កម្ពុជា ដោយបានចាប់ខ្លួន ដាក់មន្ទីរសន្តិសុខ ធ្វើទារុណកម្ម និងសម្លាប់សមាជិកនៃកងពលមជ្ឈិម និងវរសេនាធំឯករាជ ដែលបានចោទថាក្បត់ ឬជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយគ្មានគោរពនីតិវិធី។ ជាពិសេស មាស មុត ចូលរួមក្នុងឧក្រិដ្ឋកម្មទាំងនេះ នៅទីតាំងដែលគាត់ទទួលខុសត្រូវ និងដោយបញ្ជូនបុគ្គលត្រូវបានចាប់ ទៅដាក់មន្ទីរសន្តិសុខស-២១ នៅភ្នំពេញ។

95. ក្នុងឋានៈជាលេខាកងពល ១៦៤ មាស មុត ជាសមាជិកអគ្គសេនាធិការ ទទ្ទឹមគ្នាដូចមេបញ្ជាការផ្សេងទៀតនៃកងពលមជ្ឈិម និងវរសេនាធំឯករាជ្យដែរ។[284] គាត់មកភ្នំពេញជាប្រចាំរាល់ខែ ជួបជាមួយអគ្គសេនាធិការសុនសេន និកម្មាភិបាលជាន់ខ្ពស់ផ្សេងទៀតនៃកងទ័ពបដិវត្តន៍កម្ពុជា[285]។ ពេលប្រជុំសុន សេន ណែនាំមេបញ្ជាការយោធាទាំងនោះ អំពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ក្នុងការសម្លាប់បុគ្គលក្នុងកងទ័ពបដិវត្តន៍កម្ពុជា ដែលបានកំណត់ថា ខ្មាំងបដិវត្តន៍ និង "អប់រំ" ឬ

---

[284] សូមមើល III. 2. តួនាទីរបស់ មាស មុត ក្នុងកម្ពុជាប្រជាធិបតេយ្យ - អនុលេខានៃអគ្គសេនាធិការ កថាខណ្ឌ ៥៣

[285] ឯកសារ D54/37 កំណត់ហេតុស្ដាប់ចម្លើយ ស៊ឹម នី ឆ.30-31 ["សៈ តើលោកធ្លាប់ឮថា មាស មុត ធ្វើការអគ្គសេនាធិការដែរឬទេ? ឆ.30៖ បាទ ខ្ញុំឮ។ គាត់ត្រូវប្រជុំមួយខែម្ដងជាមួយសេនាធិការនៅភ្នំពេញ។ សៈ ហេតុម៉េចបានជាលោកបានដឹងអំពីរឿងនេះ? ឆ.31៖ ខ្ញុំដឹងដោយសារ ប្រធានរបស់ខ្ញុំជាគ្រិន ក៏បានទៅចូលរួមប្រជុំនោះដែរ"] ។

"កសាង" "សមាសភាពមិនល្អ"។ ជាការឆ្លើយតប មេបញ្ជាការកងពលទាំងនោះបញ្ចេញមតិឯកភាព និងការប្ដេជ្ញាគោរពគោលនយោបាយបក្សកុម្មុយនីស្ដកម្ពុជានេះ ព្រមទាំងរាយការណ៍សភាពការណ៍ទៅអង្គភាពរបស់ខ្លួនស្ដីអំពីការចាប់ខ្លួនខ្មាំងផ្ទៃក្នុង[286]។

96. កម្មាភិបាល ដែលបានចូលរួមក្នុងអង្គប្រជុំទាំងនេះជាមួយ មាស មុត ដែលធ្វើផែនការ និងពិភាក្សាពីឧក្រិដ្ឋកម្ម រួមមាន៖ ស៊ូ មេត ហៅ ស៊ូ សាមេត (កងពល៥០២), ពីន (កងពល៧០៣), ស្បូវ ហ៊ីម ហៅ អឿន (កងពល៣១០), សុក (កងពល១៧០), ជា ណុន ហៅ សួង (កងពល៤៥០), តាល់ (កងពល) ២៩០, ភាព (កងពល៤៨៨), ណៃ (កងពល៣៧៧), ម៉ែន ម៉េង ហៅ ឈិន (កងពល ៩២០), រឿន (កងពល៨០១), ស៊ីម (វរសេនាធំ ១៥២), វិន (វរសេនាធំ ៧៥), និង នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ (ស-២១)។[287] លេខា និងអនុលេខានៃកងពល និងវរសេនាធំឯករាជ្យផ្សេងៗ

---

[286] ឯកសារ D1.3.27.10 កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពល លេខា និងអនុលេខាវរៈសេនាធំ ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.12 កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.13 កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.16 កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពល និង វរៈសេនាធំឯករាជ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភារ របស់កងពល និងវរៈសេនាធំ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.19 កំណត់ហេតុ ពីការប្រជុំការងារបង្កើនផល ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំ លេខា និងអនុលេខា និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.8.7 កំណត់ហេតុនៃការប្រជុំលេខា អនុលេខាកងពល និងវរៈសេនាធំ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.21 កំណត់ហេតុនៃការប្រជុំលេខា អនុលេខាកងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.22 កំណត់ហេតុនៃការប្រជុំគណៈកងពលពេញអង្គ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.23 កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភារកងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.26 កំណត់ហេតុនៃការប្រជុំលេខា អនុលេខា កងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧។

[287] ឯកសារ D1.3.8.2 កំណត់ហេតុនៃការប្រជុំគ្រប់គណៈកងពលទូលាយ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភារ របស់កងពល និងវរៈសេនាធំ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំ លេខា និងអនុលេខា និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.22 កំណត់ហេតុនៃការប្រជុំគណៈកងពលពេញអង្គ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.26 កំណត់ហេតុនៃការប្រជុំលេខា អនុលេខា កងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧។

ទៀត ដែលមានវត្តមានជាច្រើនលើកក្នុងចំណោមអង្គប្រជុំទាំងអស់នោះ រួមមាន អនុលេខាកងពល ១៦៤ ឌីម, កម្មាភិបាលអគ្គសេនាធិការ ណាត, ឆេន, ស៊ឹម, យ៉ាន, តាត, មុម, រិន, សាវ, និង អឿន។[288]

97. ឯកសារដែលនៅសេសសល់របស់បក្សកុម្មុយនីស្តកម្ពុជា បង្ហាញថា សភាពការណ៍ខ្មាំងផ្ទៃក្នុងបានពិភាក្សាយ៉ាងទៀងទាត់ និងយ៉ាងច្រើន នៅពេលប្រជុំអគ្គសេនាធិការទាំងនោះ។ តាមពិត ក្នុងចំណោមកំណត់ហេតុទាំង១៦ ដែលមានក្នុងសំណុំរឿង មានតែកំណត់ហេតុ៣ ប៉ុណ្ណោះ មិនបាននិយាយច្បាស់ពីការបោសសម្អាតសមាជិកកងទ័ពបដិវត្តន៍កម្ពុជា[289]។ កម្មាភិបាលទាំងអស់ដែលចូល

---

[288] ឯកសារ D1.3.8.2 កំណត់ហេតុនៃការប្រជុំគ្រប់គណៈកងពលទូលាយ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភារ របស់កងពល និងវរៈសេនាធំ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំ លេខា និងអនុលេខា និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.22 កំណត់ហេតុនៃការប្រជុំគណៈកងពលពេញអង្គ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.26 កំណត់ហេតុនៃការប្រជុំលេខា អនុលេខា កងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧។

[289] ខ្មាំងផ្ទៃក្នុងមិនត្រូវបានពិភាក្សាក្នុងការប្រជុំដូចតទៅ៖ ឯកសារ D1.3.8.2 កំណត់ហេតុនៃការប្រជុំគ្រប់គណៈកងពលទូលាយ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦។ ឯកសារ D234/2.1.18 កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភារកងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.11 កំណត់ហេតុនៃការប្រជុំគណៈប្រចាំការកងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៦។ ខ្មាំងផ្ទៃក្នុងត្រូវបានពិភាក្សាក្នុងការប្រជុំដូចតទៅ៖ ឯកសារ D1.3.27.8 កំណត់ហេតុនៃការប្រជុំលេខា និងសេដ្ឋកិច្ចកងពល ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.10 កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពល លេខា និងអនុលេខាវរៈសេនាធំ ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.12 កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.13 កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.16 កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភារ របស់កងពល និងវរៈសេនាធំ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.19 កំណត់ហេតុ ពីការប្រជុំការងារបង្កើនផល ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំ លេខា និងអនុលេខា និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.8.7 កំណត់ហេតុនៃការប្រជុំលេខា អនុលេខាកងពល និងវរៈសេនាធំ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.21 កំណត់ហេតុនៃការប្រជុំលេខា អនុលេខាកងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.22 កំណត់ហេតុនៃការប្រជុំគណៈកងពលពេញអង្គ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.23 កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភារកងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ១៥ ខែ ធ្នូ

រួមប្រជុំទៀងទាត់ បានយល់គោលនយោបាយបោសសម្អាតនេះ ហើយប្រកាន់នូវ "ស្មារតីប្រុងប្រយ័ត្នបដិវត្ត" ក្នុងជួរកងពលរបស់ខ្លួន ដោយរាយការណ៍ការវិវឌ្ឍជារឿយៗនៅក្នុងអង្គប្រជុំទាំងនោះ។

98. មាស មុត រាយការណ៍អំពីការស្វែងរកខ្មាំងផ្ទៃក្នុង ក្នុងកងពល ១៦៤ ដូចដែលមេបញ្ជាការផ្សេងទៀតបានស្វែងរកក្នុងអង្គភាពរបស់គេដែរ។ ឧទាហរណ៍ នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៥ មាស មុត បានពិភាក្សាសភាពការណ៍ខ្មាំង ក្នុងតំបន់កំពង់សោម និងបណ្ដាកោះនានា និងរាយការណ៍អំពីយុទ្ធជននៅកងកេងបានប្រព្រឹត្តអំពើលួច[290]។ លើសពីនេះទៀត នៅថ្ងៃទី ១ ខែ មីនា ឆ្នាំ ១៩៧៧ គាត់បានប្រាប់ដល់មេបញ្ជាការកងពលផ្សេងទៀតថា "អង្គភាពឃ្លាំង សម្រិតសម្រាំងមួយអនុសេនាតូច តែពុំទាន់អស់ និងធានានៅឡើយ"[291]។ នៅក្នុងប្រជុំនេះ សុន សេន បញ្ចូលទ្រឹស្ដីដល់អ្នកចូលរួមអំពីសញ្ញាណនៃ "ការប្រុងប្រយ័ត្នបដិវត្តន៍" ដោយលើកឡើងថា សញ្ញាណនោះ "មានន័យថា វាយសំរុកខ្មាំងស៊ីរូងឲ្យជាប់ ឲ្យដាច់ខាត" ហើយបានរំឭកអ្នកចូលរួមថា "ចាំបាច់ត្រូវបន្តបោសសម្អាតថែមទៀតជាដាច់ខាត"[292]។ រាល់តំណាងនីមួយៗរបស់ កងពល១១ និងវរសេនាធំដែលមានវត្តមានក្នុងអង្គប្រជុំនេះ បានរាយការណ៍អំពីការបោសសម្អាតក្នុងអង្គភាពរបស់ខ្លួន[293]។

---

ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.26 កំណត់ហេតុនៃការប្រជុំលេខា អនុលេខា កងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧។

290 ឯកសារ D4.1.655 កំណត់ហេតុនៃការប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ EN 00143159 [សមមិត្ត មុត៖ ១. សភាពការណ៍ខ្មាំង៖ "នៅកងកេង មានចោរកម្មដែរ ដែលច្រើនតែបានប្រព្រឹត្តដោយយោធា"]។

291 ឯកសារ D1.3.27.26 កំណត់ហេតុនៃការប្រជុំលេខា អនុលេខា កងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧ KH 00052305 [សមមិត្ត ម៉ូត៖ "កម្មាភិបាល និងយុទ្ធជនការពារឃ្លាំងមួយចំនួន ធ្លាប់នៅជាមួយពួកក្បត់យូរ ជាកងការពារវា។ អង្គភាពឃ្លាំង បានសំរិតសំរាំងមួយអនុសេនាតូច តែនៅពុំទាន់អស់ និងធានានៅឡើយ"]។ សុន សេន បានធ្វើការឆ្លើយតបទៅ មាស មុត៖ KH 00052311 ["៤. បញ្ហាឃ្លាំង ត្រូវប្រុងប្រយ័ត្ន ពួកពាក់ព័ន្ធសមាសភាពក្បត់ ត្រូវដកចេញ។ សំរិតសំរាំងផ្ទៃក្នុងឱយស្អាត"]។

292 ឯកសារ D1.3.27.26 កំណត់ហេតុនៃការប្រជុំលេខា អនុលេខា កងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧ KH 00052309។

293 ឯកសារ D1.3.27.26 កំណត់ហេតុនៃការប្រជុំលេខា អនុលេខា កងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧។

99. ការពិភាក្សាជាចំហដោយមេបញ្ជាការយោធានៅក្នុងអង្គប្រជុំអគ្គសេនាធិការ អំពីការអនុវត្តគោលនយោបាយខ្មាំងនៅទូទាំងប្រទេស បង្ហាញថា មេបញ្ជាការទាំងនោះមានគោលដៅរួមបោសសម្អាត "សមាសភាពមិនល្អដាច់ខាត" នៅក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជា។[294] ឧទាហរណ៍មួយបញ្ជាក់ច្បាស់ជាងគេអំពីការព្រមព្រៀងគ្នានេះ អាចមើលឃើញក្នុងកំណត់ហេតុប្រជុំកងពលនាថ្ងៃទី ៩ ខែ តុលា ឆ្នាំ១៩៧៦។ នៅក្នុងអង្គប្រជុំនេះ សុន សេន រាយការណ៍ពិស្តារពីការចាប់ខ្លួនមេដឹកនាំមួយចំនួននៃបក្សកុម្មុយនីស្តកម្ពុជា ដោយលើកឡើងថា បក្សបានចាប់ខ្លួនជនក្បត់ ក្នុងនោះមានទាំង ឈូក និង ចាន់ ចក្រី (លេខាកងពល ១៧០ តំបន់២៤ ភូមិភាគបូព៌ា) ម៉ែន សាន ហៅ យ៉ា (លេខាភូមិភាគឥសាន) និង កែវ មាស[295] ហើយបានលើកទឹកចិត្តអ្នកដែលមានវត្តមានទាំងអស់គ្នាឲ្យបន្តចាប់ "ជនក្បត់" ធានា ថា កងទ័ព "ស្អាត" ហើយថា "កុំឲ្យខ្មាំងស៊ីរូងផ្ទៃក្នុងបាន"[296]។

100. អ្នកចូលរួមប្រជុំគ្រប់រូបបានយល់ស្របជាមួយ "មតិរបស់អង្គការស្តីពីសភាពការណ៍ខ្មាំងខាងក្នុង និងខាងក្រៅ" ដោយលើកឡើងថា ឥឡូវពួកគេបាន "ដឹងពេញលេញនិងច្បាស់លាស់" នូវកម្រិតនៃ "អំពើក្បត់" ក្នុងបក្ស និង "រីករាយចំពោះវិធានការណ៍របស់បក្សដែលបានរកឃើញ ចាប់បាន [ជនក្បត់]" ហើយថា "ចាំបាច់ត្រូវហ៊ានដាច់ខាតក្នុងការបោសសម្អាត"[297]។ មាស មុត បញ្ជាក់ការព្រមព្រៀងរបស់គាត់ ដោយប្តេជ្ញាគោរពសេចក្តីណែនាំរបស់បក្សចំពោះការបោសសម្អាតកងទ័ពបដិវត្តន៍កម្ពុជា តាមរយៈការលើកឡើងថា៖

---

[294] ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំ លេខា និងអនុលេខា និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH 00052408 ["ត្រូវដាច់ខាតសំរិតសំរាំងសមាសភាពមិនល្អ តែកុំឆ្វេង កុំស្តាំ"]។

[295] ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំ លេខា និងអនុលេខា និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH 00052405-08។ សូមមើល ចម្លើយសារភាព ស-២១៖ ឯកសារ D4.1.22 ឯកសារ D4.1.651 ចម្លើយសារភាព ស-២១ របស់ ចាន់ ចក្រី ហៅ នៅ មាន ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦ EN 00183019-85 (សម្រង់) [ត្រូវបានចាប់ខ្លួននៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៧៦]។ ឯកសារ D4.1.943 ចម្លើយសារភាព ស-២១ របស់ សួស នៅ ហៅ ឈូក ហៅ ម៉ែន ហៅ VIII, EN [ត្រូវបានចាប់ខ្លួននៅថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៧៦]។ ឯកសារ D10.1.120 ចម្លើយសារភាព ស-២១ របស់ ម៉ែន សាន ហៅ នៃ សារ៉ាន ហៅ អាចារ្យ សៀង ហៅ យ៉ា EN 00769572-78 [ត្រូវបានចាប់ខ្លួននៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៧៦]។

[296] ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំ លេខា និងអនុលេខា និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH 00052407។

[297] ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំ លេខា និងអនុលេខា និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH 00052408 KH 00052409-11។

សុំចាប់អារម្មណ៍សកម្មភាពពួកក្បត់ក្នុងបក្ស ជាជ័យជម្នះមួយធំរបស់បក្សយើង។ [...] សមាសភាពមិនល្អឬខ្លាំង នៅពួនបន្ត បង្កប់ក្នុងជួរទៀត។ បញ្ហាក្តាប់សតិអារម្មណ៍ ជាប្រចាំថ្ងៃរបស់អង្គការស្នូល ជាកត្តាសំខាន់បំផុត។ ត្រូវចាត់វិធានការ ម្ចាស់ការជាមុន សុំយល់ស្របជាមួយបក្សទាំងស្រុង។ ធ្វើម៉េចកុំឱ្យស្ថានការណ៍ជ្រុលហួស កុំឱ្យវាពង្រីងពង្រីកខ្លួន បានឱ្យសោះ[298]។

101. ផលវិបាកធ្ងន់ធ្ងរពីការព្រមព្រៀងរវាង មាស មុត និងមេបញ្ជាការជាន់ខ្ពស់ កងទ័ពបដិវត្តន៍កម្ពុជា ក្នុងឧក្រិដ្ឋកម្មនេះ បានបញ្ជាក់ច្បាស់តាមរយៈអង្គហេតុថា មេបញ្ជាការទាំងនេះ បានបញ្ជូនកម្មាភិបាល កងទ័ពបដិវត្តន៍កម្ពុជា យ៉ាងហោចណាស់ ៤៩០០នាក់ មក មន្ទីរស-២១[299]។ នៅទីនោះ ជនរងគ្រោះត្រូវឃុំឃាំង ដាក់ក្នុងលក្ខខណ្ឌអមនុស្សធម៌ ធ្វើទារុណកម្ម និងសម្លាប់ ក្នុងរយៈពេលជាងបីឆ្នាំកន្លះ[300]។

102. តាមរយៈការបោសសម្អាតកងពល ១៦៤របស់គាត់ផ្ទាល់ កងពល១១៧ និងមេដឹកនាំតំបន់៥០៥ ដោយចាប់ ដាក់មន្ទីរឃុំឃាំង បង្ខំឱ្យធ្វើពលកម្មជាទាសករ ទារុណកម្ម បាត់ខ្លួន និងសម្លាប់បុគ្គលទាំងនេះ មាស មុត បានរួមចំណែកជាដុំកំភួន ក្នុងការព្រមព្រៀងបោសសម្អាតខ្មាំងក្នុងកងទ័ពបដិវត្តន៍កម្ពុជា ទូទាំងកងពលមជ្ឈិម និងវរសេនាធំឯករាជ្យរបស់កម្ពុជាប្រជាធិបតេយ្យ។ ជាពិសេស មាស មុត បានចូលរួមការបោសសម្អាតទាំងនេះ តាមរយៈឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខ វត្តឥន្ទញាណ ទឹកសាប និង ស-២១ នៅការដ្ឋាននិងទីតាំងសម្លាប់មនុស្សនៅស្ទឹងហាវ នៅរាម និងនៅក្រចេះ។

*ខ) កងពល ១៦៤*

103. ការបោសសម្អាតរបស់ មាស មុត មកលើកងពលរបស់គាត់ផ្ទាល់ ពាក់ព័ន្ធនឹងការអនុវត្តប្រព័ន្ធមួយ ដែលកំណត់ថា ជនដែលសង្ស័យថាក្បត់ ត្រូវកំណត់អត្តសញ្ញាណ ចាប់ខ្លួន ដាក់មន្ទីរឃុំឃាំង បង្ខំ ឱ្យធ្វើការជាទាសករ ហើយជារឿយៗ បាត់ខ្លួនឬត្រូវបានសម្លាប់។ មាស មុត អនុវត្តការ

---

298 ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំ លេខា និងអនុលេខា និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH 00052411។

299 សូមមើល កថាខណ្ឌ ១៧២។

300 សូមមើល VIII.ឃ. មន្ទីរសន្តិសុខ ស-២១

បោសសម្អាតនេះជាប្រចាំ ក្នុងទូទាំងអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ។ ដើម្បីកំណត់អត្តសញ្ញាណបានថា ជនណាគួរចាប់ខ្លួន មាស មុត បានតម្រូវឱ្យយុទ្ធជនកងពល ១៦៤ សរសេរប្រវត្តិរូបរៀងៗខ្លួន ហើយបង្កើតគណៈកម្មាធិការពិនិត្យ ដើម្បីពិនិត្យប្រវត្តិរូប និងស៊ើបអង្កេតសុពលភាពប្រវត្តិរូបទាំងនោះ[301]។

104. ដំណើរការស្រង់ប្រវត្តិរូបនេះ គឺយោងតាមគោលនយោបាយបក្ស និងផ្តល់លទ្ធភាពឱ្យ មាស មុត អាចកំណត់អត្តសញ្ញាណអ្នកដែលមាននិន្នាការមូលធន[302] និងអ្នកប្រព្រឹត្តកំហុស យកមកដាក់មន្ទីរឃុំឃាំង ឬសម្លាប់[303]។ ជាផ្នែកមួយនៃដំណើរការនេះ ឧទាហរណ៍ មាស មុត បានស្នើឱ្យមាន

---

301 សូមមើល ជំពូក ៨.ក. ការបោសសម្អាតនៅក្នុងកងពលធំ១៦៤។

302 ឯកសារ D114/181 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែម កុល ឆ.៤០-៤១ ["ស: តើគេឱ្យលោកធ្វើប្រវត្តិរូបតែម្តងហ្នឹងទេឬ? ឆ៤០: បាទ តែម្តង។ ពេលធ្វើគ្រូបង្រៀន បានធ្វើញឹក ពីរដងក្នុងមួយឆ្នាំ។ កាលជំនាន់នោះ យើងត្រូវលាក់ដូចថា អ្នករៀនខ្ពស់ យើងដាក់រៀនថ្នាក់ទី៧ ទីអីហ្នឹង។ យើងកសិករថ្នាក់កណ្តាល យើងដាក់ថ្នាក់ក្រោមអ៊ីចឹង។ ព្រោះជំនាន់ហ្នឹង ធ្វើបដិវត្តន៍គេកម្ចាត់របបមូលធន អនុធនអីហ្នឹង កាលហ្នឹង គេបំបាត់របបសក្តិភូមិ នាយទុន។ កាលណាមិនលាក់ ព្រោះគេចង់បំបាត់ស្រទាប់លើ។ បដិវត្តន៍ ទិសដៅ គេបំបាត់របបសក្តិភូមិ បំបាត់នាយទុន។ ស: បំបាត់ហ្នឹង មានន័យម៉េចដែរ? ឆ៤១: បំបាត់ហ្នឹង កម្ចាត់ពួកហ្នឹង ឱ្យមានថ្នាក់ស្មើៗគ្នា។ កុំឱ្យមានអ្នកមាន អ្នកក្រ។ ខ្ញុំមិនដឹងដែរ បើនិយាយពីអ្នក ឧទាហរណ៍ថា អ្នកមាននិន្នាការ អ្នកមានគួរសម ខ្ញុំមិនដែលបានជួបប្រទះ ឪពុកម្តាយខ្ញុំគេជម្លៀសចេញពីផ្ទះដែរ កាលជំនាន់នោះ ប៉ុន្តែមិនដឹងខាងណាអ្នកធ្វើ។ ខ្ញុំនៅកំសី ជម្លៀសទៅនៅខ្វាវតាសិត"]។

303 ឯកសារ D54/7 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ឆ.១៦-១៧ ["តាមការយល់ដឹងរបស់ខ្ញុំ ក្នុងនាមជាមេបញ្ជាការកងពលទ័ពជើងទឹក មាស មុត គាត់ទទួលខុសត្រូវក្នុងរឿងព្រំដែនទឹក ធ្វើការសម្រិតសម្រាំងប្រវត្តិរូបរបស់យោធាជើងទឹក សម្រេចចាប់ចងនិងសម្លាប់អ្នកណាដែលធ្វើខុស។ ស: ម៉េចបានជាលោកដឹងថា មេបញ្ជាការកងពលទទួលខុសត្រូវលើការសម្រិតសម្រាំងប្រវត្តិរូបយោធា? ឆ ១៧: ខ្ញុំពុំបានឃើញរឿងរ៉ាវទាំងអស់នោះទេ ប៉ុន្តែនេះជាការសន្និដ្ឋានរបស់ខ្ញុំថា វាជាការទទួលខុសត្រូវរបស់មេបញ្ជាការកងពល។ ចំពោះរឿងសម្រិតសម្រាំង បើសិនជាគេរកឃើញថា មានយោធាណាមានបងប្អូនធ្វើការក្នុងរបបមុន គេនឹងដកយោធានោះចេញ យកទៅដាក់មួយកន្លែងផ្សេង គេដាក់ក្នុងកងផ្សេងឱ្យធ្វើការងារស្រែចំការ។ នៅក្នុងពេលនោះ បើនរណាធ្វើខុសហើយ ត្រូវគេចាប់ខ្លួន គេមិនមានតុលាការសម្រាប់កាត់ក្តីទេ។ ចំពោះការសម្រិតសម្រាំងនៅក្នុងករណីរូបខ្ញុំផ្ទាល់ គេបានបញ្ជូនអ្នកស៊ើបការទៅភូមិកំណើតរបស់ខ្ញុំ ដើម្បីផ្ទៀងផ្ទាត់ថា ត្រឹមត្រូវ ឬមានបងប្អូនធ្វើការក្នុងរបបមុនៗយ៉ាងដែរឬអត់"]។ ឯកសារ D54/8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ឆ.២-៣ ["ស: [...] លោកបាននិយាយប្រាប់យើងថា ការទទួលខុសត្រូវរបស់មេបញ្ជាការកងពលដូចជា មាស មុត គឺធ្វើការសម្រិតសម្រាំងចាប់ចងសម្លាប់អ្នកដែលធ្វើខុស។ សូមលោកពន្យល់ប្រាប់យើងអំពីអ្នកដែលធ្វើខុសសំដៅទៅលើអ្នកណា? ឆ២: អ្នកធ្វើខុស គឺសំដៅទៅលើយោធាក្នុងកងពលដែលបានប្រព្រឹត្តខុស។ [...] កំហុសប្រភេទណាខ្លះនៅក្នុងកងពល ១៦៤ ដែលអាចឈានទៅរកការចាប់ចង និងសម្លាប់? ឆ៣: ខ្ញុំដឹងមិនច្បាស់ទេ ថាតើកំហុសប្រភេទណា ដែលអាចឈានទៅដល់ការចាប់ចង និងសម្លាប់នោះ។ ខ្ញុំមាន

ការស៊ើបអង្កេតប្រវត្តិរបស់យុទ្ធជនភូមិភាគបូព៌ាដើម្បីរកខ្សែខ្មាំង[304]។ បើ ដំណើរការពិនិត្យនេះ បង្ហាញ ថា ប្រវត្តិរូបមួយមានខ្សែខ្មាំង ឬមិនមានការពិត បុគ្គលដែលជាម្ចាស់ប្រវត្តិរូបនោះ នឹងត្រូវដាក់ខណ្ឌកម្ម ដោយបញ្ជូនទៅការដ្ឋានធ្វើពលកម្ម (កសាង) ឬទៅមន្ទីរសន្តិសុខធ្វើពលកម្មដោយបង្ខំ និង\ឬ សម្លាប់[305]។

105. ក្នុងការជួយស្វែងរកខ្មាំង មាស មុត បើកវគ្គរៀនសូត្រ ក្នុងនោះគាត់ណែនាំឲ្យកម្មាភិបាលកងពល ១៦៤ ទាំងអស់សកម្មស្វែងរក "សកម្មភាពខ្មាំងក្នុងជួររបស់យើង" ហើយរាយការណ៍ទៅមេបញ្ជាការរបស់ខ្លួន នូវរាល់បណ្តាសម្មភាពណាគួរឲ្យសង្ស័យ[306]។ មាស មុត ពិភាក្សា

---

ឧទាហរណ៍ខ្លះសម្រាប់ការចាប់ចង។ បើយោធាណាដែលមានបងប្អូននៅឯមូលដ្ឋាន "នៅស្រុកភូមិ" ត្រូវបានគេចាប់ដោយចោទថាក្បត់ យោធានោះក៏ត្រូវគេចាប់ខ្លួនពីក្នុងកងដែរ។ ដូចជាឧទាហរណ៍ ប្រធានកងវរៈសេនាធំក្តី បើគាត់ត្រូវគេចាប់ខ្លួន គ្រួសារប្រពន្ធគាត់ក៏ត្រូវគេចាប់ខ្លួនដែរ។ ប៉ុន្តែមិនដឹងថា គេយកពួកគាត់ទៅអ្វីទេក្រោយពីការចាប់ខ្លួន។ នៅក្នុងពេលនោះ ជាទូទៅ បន្ទាប់ពីគេចាប់ខ្លួននរណាម្នាក់ហើយ អ្នកនោះបាត់ខ្លួនរហូត។ បើយោធាណាត្រូវបានគេដកចេញពីកងយោធានោះអាចត្រូវគេបញ្ជូនទៅធ្វើការកន្លែងផ្សេង។ បើយោធាណាត្រូវគេចាប់ខ្លួន យោធានោះត្រូវបាត់ខ្លួនរហូត។ ដូចដែលខ្ញុំបានជំរាប បើសិនជាមេបញ្ជាការវរៈសេនាធំណាត្រូវបានចាប់ខ្លួនដោយចោទថាក្បត់ ថាជា KGB ឬ CIA ប្រពន្ធកូនគាត់និរសារ និងអ្នកជិតដិតក៏ត្រូវចាប់ខ្លួនដែរ។ ជាពិសេសពួកអ្នកដែលត្រូវបានចោទថាជាប់ទាក់ទងនឹងខ្សែយួន"]។

304 ឯកសារ D54/44 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ឆ.២៦-២៨ ["សៈ តើការប្រកាសអំពីយោធាភូមិភាគបូព៌ាហ្នឹង ធ្វើនៅក្នុងការប្រជុំជាអចិន្ត្រៃយ៍ ឬក៏ធ្វើនៅក្នុងការប្រជុំពិសេសណាមួយ? ឆ២៦: ការប្រកាសនោះត្រូវធ្វើនៅក្នុងកិច្ចប្រជុំពិសេសមួយដែលថ្នាក់ដឹកនាំផ្នែកវរសេនាតូច និងវរសេនាធំត្រូវបានគេជ្រើសរើសឲ្យមកចូលរួម។ ការប្រកាសអំពីយោធាភូមិភាគបូព៌ានោះ គឺមិនបានធ្វើជាសាធារណៈនោះទេ។ ខ្ញុំនៅចាំថា ការប្រកាសអំពីយោធាភូមិភាគបូព៌ានោះ គឺមិនត្រូវបានចាត់ទុកថាជាខ្មាំងនោះទេ។ គេថា យោធាទាំងនេះ ត្រូវតែបញ្ជូនទៅធ្វើការអប់រំ ដើម្បីឲ្យដឹងថា តើគេអាចទទួលការអប់រំបាន ឬមិនបាន។ បើសិនជាអ្នកណាទទួលការអប់រំបានល្អ អ្នកនោះនឹងត្រូវបញ្ជូនឲ្យទៅកងដើមគេវិញ។ សម្រាប់អ្នកដែលមិនអាចអប់រំបាន គេទុកសម្រាប់អប់រំបន្ត។ អំឡុងពេលអប់រំ គឺគេធ្វើការស្រាវជ្រាវអំពីប្រវត្តិរបស់យោធាម្នាក់ៗ ដោយតាមដានរហូតទៅដល់ស្រុកកំណើតរបស់គេ។ សួរ: តើអ្នកណាជាអ្នកប្រកាសនៅក្នុងពេលអប់រំ? ឆ២៧: ប្រធានកងពល មាស មុត។ សៈ តើពាក្យនិយាយថា "តាមដានរហូតដល់ស្រុកកំណើតហ្នឹង" តើជាពាក្យរបស់លោក ឬមួយក៏ជាពាក្យប្រធានកងពល មាស មុត ជាអ្នកថា? ឆ២៨: ប្រធានកងពល មាស មុត ជាអ្នកណែនាំមេបញ្ជាការវរសេនាធំឲ្យធ្វើការតាមដានប្រវត្តិយោធារបស់ខ្លួនទៅដល់ស្រុកកំណើត ដើម្បីឲ្យដឹងថាមនុស្សនោះមានប្រវត្តិស្អាតស្អំ ឬក៏អត់"]។

305 សូមមើល ជំពូក ៨.ក. ការបោសសម្អាតនៅក្នុងកងពលធំ១៦៤។

306 ឯកសារ D54/17 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ន ឆ.១១-១២ ["សៈ តើលោក មាស មុត បាននិយាយអំពីជនក្បត់នៅក្នុងវគ្គនីមួយៗដែរឬទេ? ឆ១១: បាទ គាត់បាននិយាយថា យើងត្រូវពិនិត្យមើលសកម្មភាពខ្មាំង

គោលនយោបាយបោសសម្អាត និងកម្មោចខ្មាំងផ្ទៃក្នុង នៅពេលប្រជុំ[307] ហើយលើកទឹកចិត្តឱ្យកម្មាភិបាលកងពល ១៦៤ តាមដានដោយសម្ងាត់ រកជនណាដែលសង្ស័យថាក្បត់[308]។

106. ជាទូទៅ កម្មាភិបាលជាន់ខ្ពស់ ត្រូវបានបញ្ជូនមកស-២១ ឱ្យទទួលការសួរចម្លើយ ទារុណកម្ម និងសម្លាប់ ខណៈដែលកម្មាភិបាលក្រោមបង្គាប់របស់គេត្រូវបោសសម្អាតនៅតំបន់កំពង់សោម[309]។

---

នៅក្នុងជួររបស់យើង។ សៈតើពាក្យថា ឱ្យពិនិត្យមើលសកម្មភាពខ្មាំងក្នុងជួរ មានន័យដូចម្តេច? ឆ១២: មានន័យថាជាការណែនាំរបស់មាស មុត ឱ្យសិក្ខាកាមពិនិត្យមើល និងរាយការណ៍ទៅថ្នាក់លើអំពីសកម្មភាពទាំងនោះ ប្រសិនបើមាន"]។

307 ឯកសារ D114/284 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៥-៧ ["សៈ ចង់ឱ្យលោកពន្យល់ ដែលគេនិយាយបោសសម្អាត ឬកម្មោច គេចង់និយាយថាម៉េច ជាភាសាសាមញ្ញរបស់យើង? ឆ៥: អ្នកដែលមានការពាក់ព័ន្ធជាខ្មែរ កងទ័ព គេនិយាយបោសសម្អាតក្នុងកងទ័ព ដែលខ្សែរយៈជាយួន ប៉ុន្តែមិនថាខ្សែណាៗទេ។ បោសសម្អាតផ្ទៃក្នុងគឺក្នុងកងទ័ព។ សៈ ពាក្យសម្តីដែលលោកបានមើល ពាក្យសម្តីដែលគេនិយាយនៅក្នុងទូរលេខហ្នឹង ដូចពាក្យសម្តីដែលគេបង្រៀនយើង កាលប្រជុំទេ? ឆ៦: ដូច ដូចទាមងស្រុងតែម្តង។ សៈ យូរហើយក៏ដោយ ប៉ុន្តែយើងចង់ដឹង លោកនៅចាំទេ លោកធ្លាប់ប្រជុំពេលដែលតាមុត បើកអង្គប្រជុំនិយាយពីពួកក្បត់។ តើកាលពីពេលហ្នឹងតាមុត មានលើកនិយាយភាសាពាក្យពេជន៍ដូចគេនិយាយក្នុងឯកសារនេះទេ? ឆ៧: ដូចៗទាំងស្រុងតែម្តង"]។

308 ឯកសារ D114/58 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ឆ.២៣, ឆ.២៥-២៧ ["សៈ នៅពេលដែលលោកនិយាយថា មាស មុត ចូលរួមម្តងម្កាល តើលោកមានន័យថាម៉េច? ឆ២៣: នៅពេលដែលខ្ញុំចូលរួមវគ្គសិក្សានោះ មាស មុត គឺជាអ្នកបើក និងបិទវគ្គសិក្សានោះ ហើយក៏ជាអ្នកឡើងនិយាយក្នុងវគ្គសិក្សានោះដែរ។ សម្រាប់វគ្គសិក្សាផ្សេងទៀតដែលខ្ញុំមិនបានចូលរួម ខ្ញុំមិនដឹងនោះទេ [...] ឆ២៥: មានប្រហែលពី៥០ ទៅ៦០នាក់ មកពីអង្គភាពផ្សេងៗដែលចំណុះឱ្យកងពល១៦៤ ទាំងស៊ីវិល ទាំងយោធា។ សៈ នៅក្នុងវគ្គសិក្សានោះ តើមាស មុត ឬវាគ្មិនដទៃទៀតបាននិយាយអំពីស្ថានភាពខ្មាំង ទាំងខ្មាំងផ្ទៃក្នុង ទាំងខ្មាំងខាងក្រៅដែរឬទេ? ឆ២៦: បាទ ប៉ុន្តែខ្ញុំមិនចាំទេ ហើយខ្ញុំក៏មិនយល់រឿងទាំងអស់នេះដែរ។ ពួកគេនិយាយអំពី កា.ហ្សេ.បេ (KGB) វៀតណាម និងភ្នាក់ងារជាដើម"]។

309 ឯកសារ D98/1.2.1 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹកថ្ងៃទី ១៨ ខែឧសភា ឆ្នាំ២០០៩ 10.29.13-10.33.00 ["ពីដំបូងស-២១ មានសមត្ថកិច្ចត្រឹមតែចំពោះអ្នកទោសដែលសំខាន់ ឬអ្នកទោសដែលរស់នៅភ្នំពេញ និងសមាជិកនៃគណៈកម្មការមជ្ឈិមប៉ុណ្ណោះ ដូច្នេះ ពីដំបូងយុវជនថ្នាក់ទាបមិនត្រូវបានបញ្ជូនមក ស-២១ នោះទេ លើកលែងតែនៅពេលណាដែលពួកគេត្រូវចាប់ខ្លួននៅភ្នំពេញ ប៉ុណ្ណោះ។ យល់ព្រម"]។ ឯកសារ D1.3.33.9 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច KH 00178048 ["ពីដំបូង ស-២១ មានសមត្ថកិច្ចត្រឹមតែចំពោះអ្នកទោសដែលសំខាន់ ឬអ្នកទោសដែលរស់នៅភ្នំពេញ និងសមាជិកនៃគណៈកម្មាធិការមជ្ឈិមប៉ុណ្ណោះ។ ដូច្នេះពីដំបូង យុវជនថ្នាក់ទាប មិនត្រូវបានបញ្ជូនមក ស-២១នោះទេលើកលែងតែនៅពេលណាដែលពួកគេត្រូវបានចាប់ខ្លួននៅភ្នំពេញតែ

អ្នកដែលបានបោសសម្អាតនៅកំពង់សោម ត្រូវបញ្ជូនទៅមន្ទីរសន្តិសុខ និងការដ្ឋានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ មាស មុត តាមរយៈអង្គភាពក្រោមរបស់គាត់[310]។ ក្នុងឋានៈជាមេបញ្ជាការកងពល ១៦៤ មាស មុត ត្រូវកំណត់រកជនក្បត់ឲ្យបានបន្ថែមទៀតចេញមកពីខ្លឹមសារចម្លើយសារភាពស-២១ ដែលស្រង់ពីកម្មាភិបាលបោសសម្អាតមុនៗ ហើយពិចារណាចាប់ជនណាដែលមានចម្លើយឆ្លើយដាក់[311]។ ការចាប់មនុស្សបន្ថែម ត្រូវឆ្លងការអនុញ្ញាតពី មាស មុត ដោយមានការប្រឹក្សាជាមួយ សុន សេន[312]។

---

ប៉ុណ្ណោះ។ ប៉ុន្តែពេលក្រោយមក នៅពេលដែលការបង្ក្រាប មានចំនួនកើនឡើងខ្លាំង ស-២១ ក៏ទទួលមនុស្សមកពីជនបទផងដែរ"]។

310 សូមមើល ជំពូក៨.គ កងពលធំលេខ១៦៤-មន្ទីរសន្តិសុខ; ជំពូក ៨.ច ការដ្ឋាននៅរាម; ជំពូក ៨.ង ការដ្ឋាននៅស្ទឹងហាវ។

311 ឯកសារ D98/1.2.6 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹកថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០០៩ 09.32.55 ["ចម្លើយដែលចេញពីស-២១ [...] គឺទៅដៃមេខ្ញុំ។ មេខ្ញុំឲ្យទៅ ស៊ូ ម៉េត ហើយ ស៊ូ ម៉េត...ជ្រើសមនុស្សមួយចំនួនដែលនៅក្នុងកងពល៥០២"]។ 09.55.10-10.16.21, 10.31.21។ ឯកសារ D4.1.400 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ហៅឌុច ERN KH 00239838 [" មុនការចាប់ខ្លួននរណាម្នាក់ គេត្រូវតែពិភាក្សាជាមួយប្រធានអង្គភាពរបស់អ្នកនោះ។ នៅពេលណាដែលបានទទួលចម្លើយសារភាពរួចហើយ ចម្លើយសារភាពត្រូវបានផ្ញើដោយសុន សេន (បន្ទាប់មក នួន ជា) ទៅឲ្យប្រធានអង្គភាព"]។ ឯកសារ D12 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ហៅឌុច ERN KH 00680805 ["សុន សេន មុនពេលសម្រេច គាត់តែងតែសុំយោបល់និងការជួយសម្រេចពីប្រធានកងពលផ្ទាល់នោះ"]។ ឯកសារ D4.1.860 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ហៅឌុច ERN KH 00403906 ["ក្នុងការអនុវត្តជាក់ស្តែង ពេលដែលមនុស្សម្នាក់ត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព ថ្នាក់លើជូនដំណឹងទៅអ្នកទទួលខុសត្រូវអង្គភាពនីមួយៗ"]។ ឯកសារ D4.1.404 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ហៅឌុច ERN KH 00242921 ["ចម្លើយសារភាពត្រូវបានផ្ញើទៅប្រធានអង្គភាពដោយមានគោលបំណង២៖ ទី១ ប្រាប់ដំណឹងដល់គាត់អំពីសកម្មភាពរបស់ខ្មាំងនៅក្នុងអង្គភាពនោះ និងទី២ អនុញ្ញាតឲ្យគាត់គិតពីការចាប់ខ្លួនមនុស្សដែលគេបានឆ្លើយដាក់"]។

312 ឯកសារ D98/1.2.6 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹកថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០០៩ 09.32.55 ["ចម្លើយដែលចេញពីស-២១ [...] គឺទៅដៃមេខ្ញុំ។ មេខ្ញុំឲ្យទៅ ស៊ូ ម៉េត ហើយ ស៊ូ ម៉េត...ជ្រើសមនុស្សមួយចំនួនដែលនៅក្នុងកងពល៥០២"]។ 09.55.10-10.16.21, 10.31.21។ ឯកសារ D4.1.400 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ហៅឌុច ERN KH 00239838 [" មុនការចាប់ខ្លួននរណាម្នាក់ គេត្រូវតែពិភាក្សាជាមួយប្រធានអង្គភាពរបស់អ្នកនោះ។ នៅពេលណាដែលបានទទួលចម្លើយសារភាពរួចហើយ ចម្លើយសារភាពត្រូវបានផ្ញើដោយសុន សេន (បន្ទាប់មក នួន ជា) ទៅឲ្យប្រធានអង្គភាព"]។ ឯកសារ D12 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ហៅឌុច ERN KH 00680805 ["សុន សេន មុនពេលសម្រេច គាត់តែងតែសុំយោបល់និងការជួយសម្រេចពីប្រធាន

107. មាស មុត គ្រប់គ្រងយុទ្ធជនកងពល ១៦៤ តាមរយៈការធ្វើឲ្យមានការភ័យខ្លាច។ គាត់រៀបចំប្រជុំ ដែលក្នុងឱកាសនោះ គាត់ប្រកាស ការចាប់ខ្លួន និងចម្លើយសារភាពរបស់ "ជនក្បត់"[313] ជាការរំឭកជាប្រចាំចំពោះវាសនារបស់អ្នកដែលបានចោទថា មានខ្សែខ្មាំង។ មាស មុត ពិភាក្សាចំណុចពិស្តារនៃចម្លើយសារភាព[314] និង ហៅអ្នកដែលបានចាប់រួច ថាជា "ជនក្បត់" វាយឈ្មោះជន

---

កងពលផ្ទាល់នោះ"]។ ឯកសារ D4.1.860 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ហៅឌុច ERN KH 00403906 ["ក្នុងការអនុវត្តជាក់ស្តែង ពេលដែលមនុស្សម្នាក់ត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព ថ្នាក់លើជូនដំណឹងទៅអ្នកទទួលខុសត្រូវអង្គភាពនីមួយៗ"]។ ឯកសារ D4.1.404 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ហៅឌុច ERN KH 00242921 ["ចម្លើយសារភាពត្រូវបានផ្ញើទៅប្រធានអង្គភាពដោយមានគោលបំណង២៖ ទី១ ប្រាប់ដំណឹងដល់គាត់អំពីសកម្មភាពរបស់ខ្មាំងនៅក្នុងអង្គភាពនោះ និងទី២ អនុញ្ញាតឲ្យគាត់គិតពីការចាប់ខ្លួនមនុស្សដែលគេបានឆ្លើយដាក់"]។

313 ឯកសារ D54/8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ឆ.៥-៩ ["សៈ តើគេចាប់មេបញ្ជាការទាំងអស់នោះនៅក្នុងឆ្នាំណា? ឆ៥: គេចាប់ក្នុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨។ ខ្ញុំមិនបានឃើញការចាប់នោះដោយផ្ទាល់ភ្នែកនោះទេ ប៉ុន្តែគេប្រជុំតាមកងប្រាប់អំពីការចាប់ចងនេះ។ សៈ តើនរណាគេជាអ្នករៀបចំប្រជុំអំពីការចាប់ចងនេះ? ឆ៦: ព័ត៌មានអំពីការចាប់ចងនេះ បញ្ជូនចុះមកពីកងពលមកកងអនុសេនាតូច។ សៈ តើលោកដឹងឬទេថា តើមាស មុត ជាអ្នកចេញប្រកាសព័ត៌មាននេះ? ឆ៧: បាទ, ដោយសារគាត់ជាមេបញ្ជាការកងពល ដូច្នេះគឺមានតែគាត់ហើយជាអ្នកបញ្ជូនសេចក្តីប្រកាសនេះមកថ្នាក់ក្រោម។ សៈ ម៉េចបានជាលោកដឹងរឿងនេះ? ឆ៨: គ្មាននរណាទៀតក្រៅពីគាត់ដែលអាចចេញការប្រកាសនេះ ពីព្រោះគាត់ជាមេបញ្ជាការកងពល។ ការប្រកាសអំពីការចាប់ចងនេះ គឺសម្រាប់តែការចាប់ចងពួកប្រធានកងដែលក្បត់តែប៉ុណ្ណោះ មិនមែនសម្រាប់ការចាប់ចងទូទៅទេ។ សៈ តើលោកមានធ្លាប់បានចូលរួមផ្ទាល់ស្តាប់ការប្រកាសរបស់មាស មុត អំពីការចាប់ចងដែរឬទេ? ឆ៩: ទេ, ខ្ញុំមិនធ្លាប់ចូលរួមទេ តែខ្ញុំបានទទួលព័តមានពីប្រធានកងតូចរបស់ខ្ញុំ"]។

314 ឯកសារ D54/104 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.១០ ["ខ្ញុំមិនបានដឹងទេ។ ពេលនោះ ខ្ញុំធ្លាប់ឃើញឡានឃ្លុបបាំងជិតដែលមានអ្នកទោសនៅខាងក្នុង បើកឆ្ពោះទៅទិសខាងកើតក្នុងទិសដៅទៅភ្នំពេញនៅម៉ោងប្រហែលពារសៀលរៀងរាល់ថ្ងៃ។ ថ្ងៃមួយ មុនពេលកងរបស់ខ្ញុំត្រូវបានដកអាវុធ និងក្រោយពេល ខឹម បាត់ខ្លួន ខ្ញុំបានឮសូរពីយោធាក្នុងកងជាមួយគ្នា និយាយថាខឹម និងឆាន ត្រូវបានបញ្ជូនទៅកាន់ម៉ាស៊ីនបូមទឹកនៅបឹងជើងឯក។ នៅពេលនោះ យើងជឿថា រឿងហ្នឹងជារឿងពិត។ ប៉ុន្តែក្រោយមកនៅពេលដែល តាមុត ប្រកាសនៅក្នុងប្រជុំ អំពីចម្លើយសារភាពរបស់ពួកក្បត់ និងខ្សែរយៈសេអ៊ីអា និងកាហ្សេបេ ហើយបន្ទាប់ពីការបាត់ខ្លួនពួកនោះ ទើបយើងដឹងថា ពួកគេទាំងនោះត្រូវបានចាប់ខ្លួនហើយ។ រហូតដល់ក្រោយឆ្នាំ១៩៧៩ ទើបយើងដឹងថា ស-២១ និងបឹងជើងឯក គឺជាគុក និងកន្លែងសម្លាប់មនុស្ស"]។

ទាំងនោះក្នុងទំនុកដែលមានសំឡេងរណ្តំជួនគ្នា[315] ធានាថា កម្មាភិបាលក្រោមបង្គាប់របស់គាត់នឹងមិនភ្លេចនូវផលវិបាកនៃអំពើក្បត់។

[315] ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.១-២ ["បន្ទាប់មក មាស មុត បានមកធ្វើមីទ្ទីងជាមួយពួកយើងនៅភូមិគគីរ នៅជិតព្រលានយន្តហោះកងកេង ដោយមានអតីតយោធាចូលរួមប្រហែលរាប់ពាន់នាក់ដោយមានកងវរៈសេនាតូច៣៨៦ និងកងផ្សេងៗទៀត។ នៅក្នុងអង្គប្រជុំ មាស មុត អានចម្លើយសារភាពរបស់ពួកក្បត់ គាត់បានរៀបរាប់ឈ្មោះកម្មាភិបាលក្បត់ចាប់ពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់មូលដ្ឋាន។ ខ្ញុំនៅចាំថា គាត់ហៅឈ្មោះអាយ៉ា, អាធុច, អាញ៉ឹក, អាយ៉ាន, អាឆាន, និងអាឌឹម។ ខ្ញុំនៅចាំ មាស មុត ហៅពួកគេថា "អា" ពីព្រោះ "អា" ជាពាក្យបន្តុះបង្អាប់សម្រាប់និយាយទៅកាន់ពួកក្បត់។ -តាយ៉ា ហើយនឹង តាធុច គឺជាកម្មាភិបាលថ្នាក់ភូមិភាគ តែខ្ញុំមិនដឹងថាគាត់នៅភូមិណាច្បាស់លាស់ទេ។ តាញ៉ឹកគឺជាលេខាតំបន់៣៧ ឆាន ជាបញ្ជាការទ័ពនៃកងពល១៦៤ យ៉ានជាបញ្ជាការរបស់កងវរៈសេនាធំនៃតំបន់៣៧ ឌឹមគឺមកពីភូមិភាគបូព៌ា ហើយគាត់ជាអនុរបស់មាស មុត នៅក្នុងកងពល ១៦៤ មាស មុត ទី១, ឆានទី២, និងឌឹមទី៣។ ស: ហេតុដូចម្តេចបានជាលោកនៅចាំឈ្មោះអ្នកទាំងអស់នេះច្បាស់ម្លេះព្រោះវាយូរឆ្នាំមកហើយ? ឆ២: ដោយសារឈ្មោះទាំងនេះត្រូវបានប្រកាសដោយ មាស មុត នៅក្នុងអង្គប្រជុំ ហើយដោយសារខ្ញុំស្គាល់អ្នកទាំងនេះច្បាស់ ដូច្នេះទោះបីជាវាកើតឡើងច្រើនឆ្នាំក៏ដោយ ក៏ខ្ញុំនៅតែចាំឈ្មោះពួកគាត់ច្បាស់ដែរ។ ខ្ញុំនៅចាំឈ្មោះអ្នកទាំងនេះ ពីព្រោះថាពេលនិយាយឈ្មោះទាំងនេះ គឺមានពាក្យជួនគ្នាដូចជាកំណាព្យអ៊ីចឹង។ ដូច្នេះវាជាការងាយស្រួលសម្រាប់ខ្ញុំក្នុងការចងចាំឈ្មោះទាំងនេះ។ ឯកសារ D54/104 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៣-៥ ["តាមដែលខ្ញុំចាំ វ៉េត គឺជាប្រធានវរៈសេនាតូច៦៣១ តែនៅពេលនោះខ្ញុំនៅកងវរៈសេនាតូច៦២៣។ វ៉េត នៅកងទ័ពជើងគោក មានទីតាំងនៅព្រលានយន្តហោះកងកេង ហើយគាត់ត្រូវបានចាប់ខ្លួន។ ខ្ញុំមិនដឹងថាវ៉េត នៅរស់ឬស្លាប់ទេ ប៉ុន្តែខ្ញុំជឿថាគាត់ស្លាប់ហើយ ពីព្រោះនៅពេលដែលតាមុត ប្រជុំប្រាប់អំពីចម្លើយសារភាពហើយតាមុត បានប្រកាសថា វ៉េត ក្បត់ហើយ។ ស: តើលោកប្រាប់យើងបានឬទេអំពីអ្វីដែលលោកស្គាល់ និងដឹងនៅលើឈ្មោះ ម៉ែន ង៉ែត ក្នុងលេខរៀង១៦១បានដែរឬទេ? ឆ៤: ម៉ែន ង៉ែត គឺជាសមាជិកគណៈកងពល១៦៤ គាត់ត្រូវបានចាប់ខ្លួន។ ខ្ញុំមិនដឹងថាគាត់នៅរស់ឬស្លាប់ទេ។ ក្នុងឆ្នាំ ១៩៩០-១៩៩១ ខ្ញុំបានជួបកូនប្រុសរបស់ ម៉ែន ង៉ែត ឈ្មោះម៉ាំង (វ៉ាំង) នៅពេលដែលយោធាខ្មែរក្រហមចុះចូលជាមួយរដ្ឋាភិបាល។ ម៉ាំង គឺជាយោធាខ្មែរក្រហមម្នាក់ដែលនៅពេលនោះ។ ម៉ាំង នៅពេលនោះប្រាប់ខ្ញុំថា គាត់ទៅរស់នៅជាមួយបងស្រីរបស់គាត់នៅកំពង់សោម តែខ្ញុំមិនស្គាល់ឈ្មោះបងស្រីរបស់ ម៉ាំងទេ។ ខ្ញុំបានដាច់ការទាក់ទងជាមួយ ម៉ាំង តាំងពីសម័យអ៊ុនតាក់ នៅឆ្នាំ១៩៩៣។ ស: តើលោកប្រាប់យើងបានឬទេអំពីអ្វីដែលលោកស្គាល់ និងដឹងនៅលើឈ្មោះ មុំ ជឹម ហៅ យ៉ាន ក្នុងលេខរៀង១៦៩ បានដែរឬទេ? ឆ៥: យ៉ាន ជាសមាជិកគណៈកងពល១៦៤។ យ៉ាន ពីដើមមកពីភូមិភាគនិរតី ទទួលខុសត្រូវបីកងវរៈសេនាតូចគឺ ១៧០,១៨០,១៣២។ កងវរៈសេនាតូចទាំងបីនេះ គឺស្ថិតក្នុងកងវរៈសេនាធំមួយ តែខ្ញុំមិនស្គាល់ឈ្មោះកងវរៈសេនាធំនេះទេ។ តាស្រស់ គឺជាស្នងការរបស់វរៈសេនាធំនោះ ហើយ យ៉ាន គឺជាបញ្ជាការ។ ឈ្មោះយ៉ាន នេះគឺស្ថិតនៅក្នុងចំណោមពួកក្បត់ដែល តាមុត បានលើកមករៀបជាពាក្យជួនដូចកំណាព្យថា "ញ៉ឹក,ឆាន,យ៉ាន,ឌឹម ជាពួកក្បត់"។ ឌឹមគឺជាអ្នកមកពីភូមិភាគបូព៌ា"]។

108. ជាពិសេស មាស មុត ប្រកាស បោសសម្អាតកម្មាភិបាលជាន់ខ្ពស់នៃកងពល ១៦៤ ដូចជា អនុលេខាកងពល ១៦៤ ឌឹម និងសមាជិកគណៈកម្មាធិការ ឆាន[316]។ ក្រោយពេលបោសសម្អាត ឆាន នៅខែ តុលា ឆ្នាំ ១៩៧៦ មាស មុត បញ្ជាឲ្យចាប់មេបញ្ជាការអតីតវរសេនាតូច ៣៨៦

316 ឯកសារ D114/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេត ប៊ុណ្ណា ឆ.១៨-២១, ២៣, ៣២-៣៤ ["ស: យើងចង់បង្ហាញឲ្យលោកមើលឯកសារពីមន្ទីរស២១ ដែលមានឈ្មោះ គង់ គៀន ហៅ អ៊ឹង វ៉េត ឯកសារ D1.3.18.4 ភាសាខ្មែរ ERN KH 00017305 លេខាកងវរៈសេនាតូច១៦៣ កងវរៈសេនាធំ៦៣ កងពល១៦៤? ឆ១៨: ខ្ញុំក៏ស្គាល់គាត់ដែរ ព្រោះគាត់ធ្លាប់បង្រៀនពួកខ្ញុំ និងធ្លាប់និយាយជាមួយពួកខ្ញុំ។ គ្រប់គ្នាគឺបានដឹងពីការចាប់ខ្លួនរបស់គាត់ ព្រោះគាត់ជាមនុស្សលេចធ្លោម្នាក់។ កាលនោះ គាត់រស់នៅព្រលានយន្តហោះកងកេងតែម្តង។ ស: តើការចាប់ខ្លួនរបស់គាត់ប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរ? ឆ១៩: យើងមិនដឹងថា គេចាប់ខ្លួនគាត់របៀបណាទេ។ គ្រាន់តែដឹងថា ប្រហែល១ខែក្រោយពីការចាប់ខ្លួនរបស់ ឌឹម និងឆាន គឺគេចាប់ខ្លួនអ្នកដែលនៅក្រោមៗពួកគាត់ ហើយការចាប់ខ្លួនទាំងនេះក៏មិនត្រូវបានប្រកាសជាសាធារណៈដែរ។ ស: តើការប្រកាសនោះគឺធ្វើឡើងដោយ មាស មុត មែនទេ? ឆ២០: ត្រឹមត្រូវហើយ គឺការប្រកាសធ្វើឡើងដោយ មាស មុត។ ស: តើលោកអាចរៀបរាប់អំពីការប្រកាសនេះបន្ថែមបានដែរឬទេ? ឆ២១: ខ្ញុំចាំបានថា នៅព្រឹកថ្ងៃមួយ ដែលធ្វើការប្រកាសនេះ គឺធ្វើឡើងនៅថ្ងៃបុណ្យរំឭកថ្ងៃជ័យជម្នះ១៧មេសា សម្រាប់កងពល១៦៤។ ការប្រកាសនោះធ្វើឡើងនៅឆ្នេរអូរឈើទាលនៅប៉ែកខាងចុង ដែលជាទីបញ្ជាការកងទ័ពជើងទឹក។ ស: សូមលោករៀបរាប់បន្ថែមទៀត? [...] ឆ២៣: មាស មុត បាននិយាយតែម្នាក់ឯងទេ នៅក្នុងថ្ងៃនោះ ដោយមានការចូលរួមរបស់យោធាប្រហែល១០០០នាក់មកពីកងទ័ពជើងទឹកកងពល១៦៤ និងមន្ទីរពាក់ព័ន្ធនឹងកងពល១៦៤ ដូចជា អង្គភាពពេទ្យ អង្គភាពដឹកជញ្ជូន អង្គភាពភស្តុភារ។ ខ្ញុំក៏បានសង្កេតឃើញថា តាសេង និងតាសំ អង្គុយនៅសងខាង មាស មុតដែរ។ ក្នុងចំណោមរឿងផ្សេងទៀត មាស មុត ក៏បានប្រកាសថា ឆាន និងឌឹម ត្រូវបានចាប់ខ្លួនដោយសារពួកគេក្បត់។ តាមខ្ញុំដឹង ឆានគឺត្រូវបានចាប់ខ្លួនមុនគេចាប់ខ្លួន ឌឹម។ ហើយមានតែការចាប់ខ្លួនរបស់ឆាន និង ឌឹម ទេ ដែលគេបានប្រកាសជាសាធារណៈ។ ចំពោះការចាប់ខ្លួនកងទ័ពក្រោមបង្គាប់របស់ឆាន និងឌឹម ពុំប្រកាសជាសាធារណៈទេ។ យើងបានដឹងអំពីការចាប់ខ្លួនកូនចៅក្រោមៗគាត់ ដោយការនិយាយតៗគ្នាប៉ុណ្ណោះ។ ជួនកាលយើងថែមទាំងធ្វើពើមិនដឹងអំពីហេតុការណ៍ទាំងនោះផង ដោយសារវាជារឿងសម្ងាត់។ [...] ស: លោកទើបតែបាននិយាយអំពីការចោទប្រកាសចំពោះយុទ្ធមិត្តរបស់លោក តើលោកចាំថាមានការប្រកាសក្នុងកម្មវិធីរំឭកជ័យជម្នះនោះដែរឬទេ? ការចោទប្រកាន់ទាំងនោះធ្វើឡើងដោយតុលាការណាមួយក្នុងអំឡុងរបបខ្មែរក្រហមទេ? ឆ៣២: ពួកគេមិនបាននិយាយអំពីប្រព័ន្ធតុលាការ ពីចៅក្រម ឬការចោទប្រកាន់ជាផ្លូវការពីប្រព័ន្ធតុលាការណាមួយដល់ពួកគាត់ទេ។ គេគ្រាន់តែនិយាយាថា ចំពោះជនក្បត់ អង្គការត្រូវតែកម្ទេចចោល។ ស: តើអ្នកណាជាអ្នកនិយាយបែបនេះ? ឆ៣៣: មាស មុត។ ស: ដោយសារតែមានរយៈពេលយូរអង្វែងមកហើយ តើលោកអាចព្យាយាមរំឭកអំពីការចោទប្រកាន់នានា ដែលគេបានលើកឡើងនៅកនុងការចោទប្រកាន់នោះដែរឬទេ? ឆ៣៤: មាស មុត បាននិយាយយ៉ាងច្បាស់ៗថា ឌឹម ហើយនិង ឆាន គឺមានផែនការទម្លាក់រូបគាត់ចេញ ហើយកាន់កាប់កងពលធំ ដើម្បីបង្កើតរដ្ឋាភិបាលមួយខុសពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ"]។

ទាំងមូល[317]។ បន្ទាប់មក បើកអង្គប្រជុំនៅចុងឆ្នាំ ១៩៧៦ ឬ ដើមឆ្នាំ ១៩៧៨ នៅភូមិ គគី ជិតអាកាសយានដ្ឋាន កង កេង ដែលក្នុងនោះ គាត់អានចម្លើយសារភាពអ្នកដែលបានចាប់ខ្លួន ទៅចំពោះយុទ្ធជនរាប់ពាន់នាក់ រួមទាំងយុទ្ធជនអតីតវរសេនាតូច ៣៨៦ ផង[318]។

---

317 ឯកសារ D114/31 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.៩១, ១២៧-១២៨ [និយាយអំពី យាន រ៉េម និង ស្នួរ ជាមេបញ្ជាការដែលជាអ្នកដែលត្រូវបានគេនាំយកទៅហើយត្រូវបានគេសំលាប់នៅក្រោមលេសថាពួកគេត្រូវបានគេយកទៅសិក្សា]។ ឯកសារ D54/101 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៩ [" គឺជារ៉េម ដែលជាស្នងការនយោបាយកងវរៈសេនាតូច៣៨៦ ដែលត្រូវបានបាញ់សម្លាប់នៅមុខវត្តឥន្ទញ្ញាណ"]។ ឯកសារ D114/40 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.៧៤ [" យាន ជាមេបញ្ជាការកងវរៈសេនាតូចលេខ៣៨៦"]។ ឯកសារ D114/244 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន ឈឿន ឆ.១២-១៣,១៦ ["មុននឹងបែកភ្នំពេញ ខ្ញុំនៅនឹងអង្គភាពតំបន់៣៧ ជាពេទ្យ អង្គភាពវរសេនាតូច៣៨៦។ សៈ តើមេវរៈរបស់លោកឈ្មោះអ្វីដែរកាលនោះ? [...] ឆ១៣: មេបញ្ជាការវរៈ៣៨៦ ឈ្មោះលោកយាន។ ឆ១៦: អនុប្រធានលោក រ៉េម"]។ ឯកសារ D54/12 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រេស មាន ឆ.១៦ ["គឺយើនហ្នឹងដែលធ្លាប់ធ្វើជាអនុមេបញ្ជាការវរៈសេនាតូច ៣៨៦ ពេលដែលរ៉េម ធ្វើជាមេបញ្ជាការ"]។ ឯកសារ D114/194 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ឆ.១៥,១៧-១៨ ["សៈ តើលោកស្គាល់មនុស្សម្នាក់ឈ្មោះរ៉េមដែលជាស្នងការនយោបាយនៃវរសេនាតូច៣៨៦ដែរឬទេ? ឆ១៥: បាទ បងរ៉េម មួយទៀត ហើយនិងស្នួន ឆាន [...] ពួកគេជាអ្នកក្តាប់រួមវរសេនាតូច៣៨៦ និងយោធាតំបន់ ហើយមាន ៣កងអនុសេនាធំ [...] ឆ១៧: គេថាពួកខ្ញុំហ្នឹងក្បត់ គេថាយោធា១តំបន់ ៣៧ក្បត់ គឺពួកតាមុតហ្នឹងជាអ្នកចាប់តែម្តង។ សៈ តើលោកនៅចាំហេតុការណ៍នៃការចាប់ខ្លួនរ៉េម ដែរឬទេ? ឆ១៨: ចាំតើ។ មិនមែនចាប់តែគាត់ទេ គឺចាប់តាំងពីថ្នាក់ធំមេបញ្ជាការ រហូតដល់មេក្រុម"]។ ឯកសារ D54/77 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញ៉ិក ឆ.៣ ["ខ្ញុំភ្លេចឈ្មោះមេបញ្ជាការកងវរៈសេនាតូចហើយ តែខ្ញុំនៅចាំឈ្មោះមេបញ្ជាការឈ្មោះ យាន នៅពេលដែលជម្លៀសប្រជាជនចេញពីក្រុងកំពង់សោមនៅពេលនោះ"]។ ឯកសារ D114/155 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រ៉េន ឆ.៦២ ["ខ្ញុំបានបាត់ឈ្មោះមួយចំនួនទៀតដែលខ្ញុំស្គាល់ដូចជាបងរ៉េម គាត់ជាមេបញ្ជាការវរសេនាធំជើងទឹក ដែលធ្លាប់អ្នកតស៊ូនៅជាមួយតំបន់៣៧ [...] បងយើននេះ ត្រូវគេចាប់ខ្លួន បាត់ខ្លួន ដែលមានឈ្មោះឯក នី ជាអ្នកដឹង [...] យាន និងទ្រា បាត់ខ្លួនអស់។ យើនថ្នាក់វរសេនាតូច ខ្ញុំអត់ដឹងថា អ្នកទាំងនោះត្រូវបានគេចាប់ខ្លួនយកទៅលុតដំនៅស្ទឹងហាវនោះទេ គ្រាន់តែដឹងថា គេចាប់ទៅបាត់ ហើយក៏មិនដឹងថាយកទៅសម្លាប់ឬយ៉ាងណាទេ។ ពួកគេបាត់ខ្លួនរហូត"]។ ឯកសារ D114/105 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុច ទុយ ឆ.១៨ ["តាយឺនមេកងវរសេនាតូច និងតាយានអនុកងវរសេនាតូច និងតាយានអនុកងវរសេនាតូច ស្លាប់ហើយដោយហៅឲ្យទៅរៀនសូត្រនៅខេត្តកំពង់សោម"]។ ឯកសារ D114/146 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញ៉ិក ឆ.៤៩ ["មានបងប្រុសរបស់ខ្ញុំម្នាក់ដែលជាអនុបញ្ជាការវរៈ ឈ្មោះយាន ត្រូវបានគេមកបញ្ជូនឲ្យទៅជួយច្រូតស្រូវគ្រួសារយោធា នៅជិតកងកេង ហើយក៏បាត់ខ្លួនចាប់ពីពេលនោះមក"]។

318 ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.១ ["នៅចុងឆ្នាំ១៩៧៦ ដើមឆ្នាំ១៩៧៧ [...] បន្ទាប់ពីគេដកអាវុធពីពួកយើងអស់ ពួកគេមិនអនុញ្ញាតិឲ្យយើងទុកកាំបិតទេ យើងគឺអនុញ្ញាតិឲ្យកាន់តែចប។ បន្ទាប់

109. បន្តិចក្រោយមក នៅ ឬ ប្រហែលនៅខែ មេសាឆ្នាំ១៩៧៧ នៅក្នុងឱកាស"ប្រារព្ធថ្ងៃជ័យជំនះ" នៅអង្គប្រជុំមួយនៅខាងចុងផ្ទេអូឈើទាល មាស មុត បានប្រកាសជាថ្មីម្តងទៀត នូវការចាប់ខ្លួន ឌឹម និង ឆាន ទៅចំពោះយុទ្ធជនកងពល ១៦៤ ចំនួន១០០០នាក់[319] ដោយចោទថា ឌឹម និងជនផ្សេងៗទៀត មាន"ផែនការបះបោរ"[320]។

---

មក មាស មុត បានមកធ្វើមីទ្ទីងជាមួយពួកយើងនៅ ភូមិគគីរ នៅជិតព្រលានយន្តហោះកងកេង ដោយមានអតីតយោធាចូលរួមប្រហែលរាប់ពាន់នាក់ ដោយមានកងវរៈភូសេនាតូច៣៨៦ និងកងផ្សេងៗទៀត។ នៅក្នុងអង្គប្រជុំ មាស មុត អានចម្លើយសារភាពរបស់ពួកក្បត់ គាត់បានរៀបរាប់ឈ្មោះកម្មាភិបាលក្បត់ចាប់ពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់មូលដ្ឋាន។ ខ្ញុំនៅចាំថា គាត់ហៅឈ្មោះ អាយ៉ា, អាធុច, អាញឹក, អាឆាន និងអាឌឹម"]។ ឯកសារ D54/104 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៣,៥,៩-១០ ["វេតនៅកងទ័ពជើងគោក មានទីតាំងនៅ ព្រលានយន្តហោះកងកេង ហើយគាត់ត្រូវបានចាប់ខ្លួន។ ខ្ញុំមិនដឹងថា វេត នៅរស់ឬស្លាប់ទេ ប៉ុន្តែខ្ញុំជឿថាគាត់ស្លាប់ហើយ ពីព្រោះនៅ ពេលដែលតាមុត ប្រជុំប្រាប់អំពីចម្លើយសារភាព ហើយតាមុត បានប្រកាសថា វេតក្បត់ហើយ។ [...] ឆ៥: យ៉ានជាសមាជិកកងពល១៦៤ ។ យ៉ាន ពីដើមមកពីភូមិភាគនិរតី ទទួលខុសត្រូវបីកងវរៈសេនាតូចគឺ ១៧០,១៨០,១៣២។ កងវរៈសេនាតូចទាំងបីនេះ គឺស្ថិតក្នុងកងវរៈសេនាធំមួយ តែខ្ញុំមិនស្គាល់ឈ្មោះកងវរៈសេនាធំនេះទេ។ តាស្រស់គឺជាស្នងការរបស់វរៈសេនាធំនោះ ហើយយ៉ានគឺជាបញ្ជាការ។ ឈ្មោះយ៉ាន នេះគឺស្ថិតនៅក្នុងចំណោមពួកក្បត់ដែលតាមុត បានលើកមករៀបជាពាក្យជួនដូចកំណាព្យថា "ញឹក, ឆាន, យ៉ាន, ឌឹម ជាពួកក្បត់"។ [...] ឆ៩: ខ្ញុំគិតថា ឌឹម នៅក្នុងឯកសារនេះគឺជា ឌឹម ដែលខ្ញុំបានប្រាប់លោកខាងដើម ដែលរាប់នៅក្នុងពាក្យជួនថា អាញឹក, អាឆាន, អាយ៉ាន, អាឌឹម។ [...] ឆ១០: ខ្ញុំបានឮសូរពីយោធាក្នុងកងជាមួយគ្នា និយាយថាឌឹម និងឆាន ត្រូវបានបញ្ជូនទៅកាន់ម៉ាស៊ីនបូមទឹកនៅបឹងជើងឯក។ នៅពេលនោះយើងជឿថា រឿងហ្នឹងជារឿងពិត។ ប៉ុន្តែក្រោយមកនៅពេលដែល តាមុត ប្រកាសនៅក្នុងអង្គប្រជុំ អំពីចម្លើយសារភាពរបស់ពួកក្បត់ និងខ្សែរយៈសេអ៊ីអា និងកាហ្សេបេ ហើយបន្ទាប់ពីការបាត់ខ្លួនពួកនោះ ទើបយើងដឹងថាពួកគេទាំងនោះត្រូវបានចាប់ខ្លួនហើយ។ D114/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ិន ឆ.៥៦,៥៨-៦០,៦៣ ["យើងត្រូវគេបញ្ជូនមកឈប់នៅព្រលានយន្តហោះកងកេង ហើយគេប្រជុំនៅពេលព្រឹកហ្នឹង។ ហើយមាស មុត ជាប្រធានអង្គជំនុំ។ [...] ឆ៥៨: [ក្នុងពេលប្រជុំ] មានអ្នកយាម មានទាហានយាម។ [...] ស: តើទាហានដែលយាមនោះមានអាវុធទេ? ឆ៥៩: មាន [...] ឆ៦០: ការប្រជុំពីបញ្ហាមេក្បត់គឺអនុមេបញ្ជាការកងពល ១៦៤ នង ឆាន ជាអ្នកក្បត់ ហើយមាស មុត អានចម្លើយសារភាពរបស់នង ឆាយហ្នឹង។ [...] ឆ៦៣: ចាំបានត្រង់គាត់និយាយពីចម្លើយសារភាពរបស់ពួកក្បត់ និយាយពី នង ឆាន និងមេៗរបស់ខ្ញុំទាំងពីរនាក់ហ្នឹង។ មាស មុតគ្រាន់តែនិយាយថាពួកគាត់ក្បត់"]។

319 ឯកសារ D114/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.១០,២១,២៣-២៤,២៦ ["នៅប្រហែលចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ ដែល មាស មុត បានប្រកាសថាឈ្មោះ ជ័យ ឆាន ដែលជាកូនរបស់ ជ័យ/នង សួន [...] ជារដ្ឋមន្ត្រីសេដ្ឋកិច្ចបានធ្វើជាជនក្បត់ឱ្យវៀតណាម។ ការចាប់ខ្លួនឈ្មោះឌឹម ក៏ត្រូវបានប្រកាសក្នុងពេលតែមួយនោះដែរ និងជាមួយបទចោទដូចគ្នា [...] ឆ២១: ការប្រកាសធ្វើឡើងនៅថ្ងៃបុណ្យរំឭកថ្ងៃជ័យជម្នះ១៧មេសា សម្រាប់កង

110. បន្ទាប់មក ក្នុងពេលប្រជុំពិសេសមួយ នៅស្ទឹងហាវ នាពាក់កណ្ដាលឆ្នាំ ១៩៧៧ មាស មុត ប្រកាស ថា អតីតមេដឹកនាំ តំបន់៣៧ ជា "ជនក្បត់"[321]។ មាស មុត រៀបចំអង្គប្រជុំពិសេសនានា ពិភាក្សាពីយុទ្ធជនកងពល ១៦៤ ដែលមកពីភូមិភាគបូព៌ា ដោយលើកឡើងថា "យុទ្ធជនទាំងអស់ ដែលមកពីភូមិភាគបូព៌ា គឺជាយុទ្ធជនដែលមានសមាសភាពមិនល្អ ដូច្នេះ ពួកគេត្រូវតែដកចេញឱ្យ

---

ពល១៦៤។ ការប្រកាសនោះធ្វើឡើងនៅឆ្នេរអូរឈើទាលនៅប៉ែកខាងចុង ដែលជាទីបញ្ជាការកងទ័ពជើងទឹក [...] ឆ២៣: មាស មុត បាននិយាយតែម្នាក់ឯងទេ នៅក្នុងថ្ងៃនោះ ដោយមានការចូលរបស់យោធាប្រហែល១០០០នាក់ មកពីកងទ័ពជើងទឹកកងពល១៦៤ និងមន្ទីរពាក់ព័ន្ធនឹងកងពល១៦៤ ដូចជាអង្គភាពពេទ្យ អង្គភាពដឹកជញ្ជូន អង្គភាពភស្តុភារ [...] ក្នុងចំណោមរឿងផ្សេងៗទៀត មាស មុតក៏បានប្រកាសថា ឆាន និងឌីម ត្រូវបានចាប់ខ្លួនដោយសារពួកគេក្បត់។ តាមខ្ញុំដឹង ឆាន គឺត្រូវបានចាប់ខ្លួនមុនគេចាប់ខ្លួន ឌីម។ ហើយមានតែការចាប់ខ្លួន ឆាន និងឌីមទេ ដែលគេបានប្រកាសជាសាធារណៈ។ ចំពោះការចាប់ខ្លួនកងទ័ពក្រោមបង្គាប់របស់ឆាន និងឌីម ពុំប្រកាសជាសាធារណៈទេ។ [...] ឆ២៤: ពិធីនោះគេធ្វើចំថ្ងៃ ១៧ មេសា ហ្នឹងតែម្ដង គឺធ្វើតែមួយព្រឹកទេ [...] ឆ២៦: មានតែការចាប់ខ្លួនរបស់ឆាន និងឌីមទេដែលត្រូវបានប្រកាស ហើយខ្ញុំក៏មិនដឹងថា ពួកគេត្រូវបានចាប់ខ្លួនមុនការប្រកាសនោះយូរប៉ុនណាដែរ"]។

320 ឯកសារ D114/85 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.៣៤ ["មាស មុតបាននិយាយយ៉ាងច្បាស់ៗ ឌីម ហើយនឹងឆាន គឺមានផែនការទម្លាក់រូចគាត់ចេញ ហើយកាន់កាប់កងពលធំ ដើម្បីបង្កើតរដ្ឋាភិបាលមួយខុសពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ"]។ ឯកសារ D114/104 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អៀម ភង់ ឆ.៥០ ["តាឆាន និងតាឌីមជាអនុបញ្ជាការ។ តាឆាន និងឌីម ត្រូវបានគេសម្លាប់ដោយចោទថា ក្បត់ ហើយតាមពិតគេមានផែនការក្បត់មែន"]។ ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍សៀងរបស់ការិយាល័យសហព្រះរាជអាជ្ញា EN 00217564 ["ឌីមបានបាត់ខ្លួនក្នុងឆ្នាំ១៩៧៧ នៅពេលដែលមានទំនាស់ផ្ទៃក្នុង"]។

321 ឯកសារ D54/12 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រេស មាន ឆ.៣០ ["ស: នៅក្នុងអង្គប្រជុំនោះ [នៅស្ទឹងហាវក្នុងពាក់កណ្ដាលឆ្នាំ១៩៧៧] តើតាមុតមានបាននិយាយឈ្មោះអ្នកណាខ្លះថាជាពួកក្បត់ឬទេ នៅក្នុងអង្គប្រជុំនោះ? ឆ៣០: បាទ, គាត់បានប្រកាសថា តាញ៉ឹកជាលេខាតំបន់៣៧, តាប៊ុននៅក្នុងគណៈតំបន់៣៧ និងឆាននៅក្នុងគណៈតំបន់៣៧ដែរ (ជនក្បត់)"]។ ឯកសារ D54/13 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រេស មាន ឆ.២, ៤-៥ ["តាមុតបាននិយាយថា ញ៉ឹក, ប៊ុន, ឆាយ ដែលជាគណៈតំបន់៣៧ ជាអ្នកប្រឆាំងបដិវត្ត។ គាត់បាននិយាយឈ្មោះជាច្រើន តែខ្ញុំចាំមិនអស់ [...] ឆ៤: វាមិនមែនជាការប្រជុំជាប្រចាំទេ។ នៅឆ្នាំ១៩៧៧ ស្ថានការណ៍នៅពេលនោះមានការច្របូកច្របល់បក្សកុម្មុយនីស្ដកម្ពុជាគាំទ្រដោយចិន ហើយបក្សពលករគាំទ្រដោយវៀតណាមមានពួក CIA អាមេរិកាំង និង KGB នៅក្នុងជាមួយប្រជាជនដែរ ដូច្នេះគេត្រូវសម្រិតសម្រាំងពួកសមាសភាពទាំងនោះចេញ។ ស: តើនេះជាគំនិតរបស់លោកផ្ទាល់ឬក៏គេប្រាប់លោក? ឆ៥: តាមុតបានប្រកាសនៅក្នុងអង្គប្រជុំ។ រឿងនេះត្រូវបានប៉ះពាល់ដល់ខ្ញុំដែរពីព្រោះខ្ញុំជាមនុស្សនៅតំបន់៣៧"]។ សូមមើលផងដែរ ឯកសារ D114/95 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យឹម ស្រៀង ឆ.៦៤ ["មានឈ្មោះ ង៉ែត ឌីម យ៉ាន ឆាន សុខ និង សុ អូន។ ពួកគេត្រូវចោទថាជាគិនវៀតណាម ឬ សេអ៊ីអា"]។

ដាច់ពីកងពល"[322]។ បន្ថែមលើការប្រកាសទាំងនោះ មាស មុត ក៏បានលើកឡើងជាទូទៅ ថា មាន ខ្មាំង បង្កប់ក្នុងជួរ ហើយថា ពួកវាស្ថិតក្រោមការតាមដានជាប្រចាំ[323]។

322 ឯកសារ D54/44 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ឆ.១៩, ២២-២៤, ២៦-២៨ ["ស: ហេតុអ្វីបានជាលោកដឹងថា មានយោធា១៥០០នាក់មកពីភូមិភាគបូព៌ា គេយកទៅដាក់នៅកងផលិតធំ? ឆ១៩: ប្រធានកងពល មាស មុត បានបើកការប្រជុំ ហើយប្រកាសថា ពួកយោធាទាំងអស់ដែលមកពីភូមិភាគបូព៌ា គឺជាយោធាដែលមានសមាសភាពមិនល្អ ដូច្នេះពួកគេត្រូវតែដកចេញឲ្យដាច់ពីកងពល។ ខ្ញុំមិនអាចនិយាយឲ្យបានច្បាស់បានទេ ប៉ុន្តែខ្ញុំជឿថា វាមានការប្រកួតប្រជែងគ្នានៅក្នុងថ្នាក់ដឹកនាំរបស់កងពល ដែលបណ្តាលឲ្យយោធាទាំងនេះមិនអាចដាក់បញ្ចូលគ្នាបាន។ [...] ឆ២២: ខ្ញុំបានចូលរួមការប្រជុំដែរ បានខ្ញុំដឹង [...] ឆ ២៣: នៅទីបញ្ជាការកងពល នៅកំពង់សោម [...] ឆ២៤: ទីបញ្ជាការកងពលមានទីតាំងស្ថិតនៅជិតផ្សារលើ ជាកន្លែងដែលតា មុត គាត់រស់នៅ។ ការប្រជុំគឺធ្វើនៅអតីតរោងកុនមួយ ក្បែរទីបញ្ជាការកងពលនោះ។ ការប្រជុំកងពលពេលខ្លះធ្វើនៅអតីតរោងកុន និងពេលខ្លះទៀតនៅឆ្នេរអូរឈើទាល [...] ស: តើការប្រកាសអំពីយោធាភូមិភាគបូព៌ាហ្នឹង ធ្វើនៅក្នុងការប្រជុំជាអចិន្ត្រៃយ៍ ឬក៏ធ្វើនៅក្នុងការប្រជុំពិសេសណាមួយ? ឆ២៦: ការប្រកាសនោះត្រូវធ្វើនៅក្នុងកិច្ចប្រជុំពិសេសមួយដែលថ្នាក់ដឹកនាំផ្នែកវរសេនាតូច និងវរសេនាធំត្រូវបានគេជ្រើសរើសឲ្យមកចូលរួម។ ការប្រកាសអំពីយោធាភូមិភាគបូព៌ានោះ គឺមិនត្រូវបានចាត់ទុកថាជាខ្មាំងនោះទេ។ គេថា យោធាទាំងនេះ ត្រូវតែបញ្ជូនទៅធ្វើការអប់រំ ដើម្បីឲ្យដឹងថា តើគេអាចទទួលការអប់រំបាន ឬមិនបាន។ បើសិនជាអ្នកណាទទួលការអប់រំបានល្អ អ្នកនោះនឹងត្រូវបញ្ជូនឲ្យទៅកងដើមគេវិញ។ សម្រាប់អ្នកដែលមិនអាចអប់រំបាន គេទុកសម្រាប់អប់រំបន្ត។ អំឡុងពេលអប់រំ គឺគេធ្វើការស្រាវជ្រាវអំពីប្រវត្តិរបស់យោធាម្នាក់ៗ ដោយតាមដានរហូតដល់ស្រុកកំណើតរបស់គេ។ ស: តើអ្នកណាជាអ្នកប្រកាសនៅក្នុងពេលអប់រំ? ឆ២៧: ប្រធានកងពល មាស មុត។ ស: តើពាក្យនិយាយថា "តាមដានរហូតដល់ស្រុកកំណើតហ្នឹង" ជាពាក្យរបស់លោក ឬមួយក៏ជាពាក្យប្រធានកងពល មាស មុត ជាអ្នកថា? ឆ.២៨: ប្រធានកងពលមាស មុត ជាអ្នកណែនាំមេបញ្ជាការវរសេនាធំឲ្យធ្វើការតាមដានប្រវត្តិយោធារបស់ខ្លួនទៅដល់ស្រុកកំណើត ដើម្បីឲ្យដឹងថាមនុស្សនោះមានប្រវត្តិស្អាតស្អំ ឬក៏អត់"]។ ឯកសារ D114/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.១៨-២០ ["ខ្ញុំក៏ស្គាល់គាត់ដែរ ព្រោះគាត់ធ្លាប់បង្រៀនពួកខ្ញុំ និងធ្លាប់និយាយជាមួយពួកខ្ញុំ។ គ្រប់គ្នាគឺបានដឹងពីការចាប់ខ្លួនរបស់គាត់ ព្រោះគាត់ជាមនុស្សលេចធ្លោម្នាក់ដែរ។ កាលនោះ គាត់រស់នៅព្រលានយន្តហោះកងកេងតែម្តង [...] ឆ.១៩: គាត់ត្រូវបានចាប់ខ្លួនប្រហែលមួយខែក្រោយពីការចាប់ខ្លួនរបស់ ឌឹម និងឆាន គឺគេចាប់ខ្លួនអ្នកដែលនៅក្រោមៗពួកគាត់ ហើយការចាប់ខ្លួនទាំងនេះក៏មិនត្រូវបានប្រកាសជាសាធារណៈដែរ"]។

323 ឯកសារ D54/105 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៧-៨ ["ខ្លឹមសារដែលខ្ញុំអាននេះគឺពិត។ ឯកសារនេះ គឺជាឯកសារអប់រំនយោបាយដែលគេប្រើសម្រាប់អប់រំពួកយើងនៅក្នុងជួរកងទ័ព។ គេនិយាយអំពីរឿងល្អៗ ដូចជាថាលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ប្រុងប្រយ័ត្នអនាម័យចំពោះប្រជាជន។ ប៉ុន្តែការពិអ្វីដែលគេនិយាយគឺគ្រោះថ្នាក់ ឧទាហរណ៍ដូចជា មាស មុត និយាយនៅក្នុងឯកសារនេះថា យើងត្រូវតែធ្វើការតាមដានខ្មាំងលាក់ខ្លួននៅក្នុងជួរឲ្យជាប់។ សម្តីនេះធ្វើឲ្យខ្ញុំនឹកឃើញពេលដែលគាត់និយាយនៅក្នុងអង្គប្រជុំជាមួយពួកយើង គឺធ្វើឲ្យយើងខ្លាចជិតងាប់។ សម្រាប់ពេលបច្ចុប្បន្ន នៅពេលដែលមនុស្សណាធ្វើខុស គេគ្រាន់តែយកទៅឃុំនៅព្រៃស ប៉ុន្តែនៅសម័យ

111. ដើម្បីបោសសម្អាតកងពល ១៦៤ មាស មុត ធ្វើការជិតស្និទ្ធជាមួយថ្នាក់លើផ្ទាល់របស់គាត់ គឺ សុន សេន និងជាមួយមេបញ្ជាការក្រោមបង្គាប់របស់គាត់ផ្ទាល់ គឺ ឌឹម (រហូតពេលចាប់ ឌឹម ក្នុងឆ្នាំ ១៩៧៧)។ ឧទាហរណ៍ នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៧៦ មាស មុត បានទូរលេខទៅ សុន សេន ថា "អ្នកមានរឿងដែលឃុំឃាំង" ត្រូវយុទ្ធជនពីរនាក់នៃកងពល ១៦៤ ដោះលែង[324]។ ពីរសប្តាហ៍ក្រោយមក ក្នុងពេលប្រជុំ កងទ័ពបដិវត្តន៍កម្ពុជា មាស មុត ឬ តំណាងរបស់គាត់ បានចាត់ទុកយុទ្ធជនកងពល ១៦៤ ពីរនាក់នេះ ថាជា "យុទ្ធជនក្បត់" ដោយសារបានដោះលែងយុទ្ធជនកងពល ១៦៤[325]។

112. នៅខែ កញ្ញា ឆ្នាំ ១៩៧៦ កម្មាភិបាលក្រោមបង្គាប់ផ្ទាល់មាស មុត គឺ អនុលេខាកងពល ១៦៤ ឌឹម រាយការណ៍ប្រាប់ មាស មុត ថា គាត់បានអនុវត្តតាមបញ្ជារបស់មុតរួចហើយ ក្នុងការចាប់បុគ្គលទាំងឡាយដែលបានសង្ស័យថា ខ្មាំង ឬក្បត់។ នៅចុងខែនោះ ឌឹម បានទូរលេខទៅ មាស មុត ថា "យើងបានចាត់វិធានការណ៍ចំពោះខ្មាំងមួយដែលបងបានសម្រេច [...] វាបានរត់ចូលព្រៃប្រាំនាក់ [ហើយ] ឥឡូវយើងតាមចាប់បានទាំងអស់"[326]។

113. មាស មុត ដោយមានការឃុបឃិតជាមួយ សុន សេន បានបន្តចាប់មនុស្ស ដូចមានបញ្ជាក់តាមរយៈសារចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ ដែល សុន សេន ណែនាំទៅកងពល ១៦៤ ឲ្យមាស មុត រក្សាការសម្ងាត់ចំពោះការចាប់មនុស្សនាពេលថ្មីៗនោះ[327]។ នៅពេញឆ្នាំ ១៩៧៦ យុទ្ធជនជាច្រើន

---

ខ្មែរក្រហម ប្រសិនបើអ្នកធ្វើខុស ហើយគេចាប់ខ្លួន គឺមានន័យថាស្លាប់។ សៈ នៅពេលដែលលោកធ្វើការប្រៀបធៀបព័ត៌មាន ពាក្យពេចន៍ សូរសៀង ហើយនឹងភាសានៅសុន្ទរកថារបស់ មាស មុត ក្នុងខែតុលា ឆ្នាំ១៩៧៦ ទៅនឹងសុន្ទរកថារបស់គាត់ក្នុងដើមឆ្នាំ១៩៧៧ ទៅលើពួកយោធាកងវរៈសេនាតូច៨៦ (៣៨៦) ក្នុងរយៈពេលធ្វើការ ដកអាវុធនោះ តើលោកមានយោបល់យ៉ាងណាដែរ? ឆ.៨: ខ្ញុំយល់ថា ន័យរបស់វាគឺដូចគ្នាទាំងស្រុង មានន័យថា ពួកយើងជាយោធា ឬប្រជាជនត្រូវបានគេតាមដានជាប់ជានិច្ច។ សុន្ទរកថារបស់មាស មុត នៅក្នុងឯកសារនេះគឺកើតឡើងមុនពេលការដកអាវុធពីកងរបស់ខ្ញុំនៅឆ្នាំ១៩៧៧"]។

324 ឯកសារ D1.3.34.10 ទូរសាររបស់ មាស មុតទៅកាន់បង ៨៩ (សុន សេន) ចុះថ្ងៃទី ១៣ ខែសីហា ឆ្នាំ១៩៧៦។

325 ឯកសារ D1.3.12.7 របាយការណ៍យោធាកម្ពុជាប្រជាធិបតេយ្យ សរុបសភាពការណ៍ ពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ១៩៧៦ ដល់ ៣១ ខែសីហា ឆ្នាំ១៩៧៦ ERN KH 00021503

326 ឯកសារ D1.3.34.11 ទូរលេខ១១ របស់ ឌឹម ទៅកាន់ មាស មុត ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៧៦ (សេចក្តីបញ្ជាក់បានបន្ថែម)។

327 ឯកសារ D1.3.2.2 ទូរលេខរបស់ បង ៨៩ (សុន សេន) ទៅកាន់ មាស មុត ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៧៦។

នៃកងពល ១៦៤ ត្រូវបានបញ្ជូនមកស-២១[328] រួមមានទាំងសមាជិកកងពល ១៦៤[329] ឈ្មោះ ជ័យ ហាន ហៅ ឆាន[330]។ ក្រោយការចាប់ខ្លួនរបស់គាត់ មានបន្តបោសសម្អាតថ្នាក់ដឹកនាំទាំងមូល

328 សូមមើលឧបសម្ព័ន្ធ Annex D.1 ។ សូមមើលផងដែរ ជំពូក ៨.ឃ មន្ទីរសន្តិសុខ ស-២១ កថាខណ្ឌ ៥៤១-៥៤២

329 សូមមើល ជំពូក៤ កងពលធំលេខ១៦៤ (អតីតកងពលធំទី៣) រចនាសម្ព័ន្ធអាជ្ញាធរ។

330 ឯកសារ D114/230.1.1 ក.ស.ច.ស. បញ្ជីឈ្មោះអ្នកទោសនៅ ស-២១ លេខ ១៤១៥៦ [ជ័យ ហាន ចូលមកស-២១ ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៦]។ សូមមើលផងដែរ ឯកសារ D54/104 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.១០ ["ខ្ញុំបានឃើញឡានឃ្លុបបាំងជិតដែលមានអ្នកទោសនៅខាងក្នុង បើកឆ្ពោះទៅទិសខាងកើតក្នុងទិសដៅទៅភ្នំពេញនៅម៉ោងប្រហែលពារសៀលរៀងរាល់ថ្ងៃ។ ថ្ងៃមួយ មុនពេលកងរបស់ខ្ញុំត្រូវបានដកអាវុធ និងក្រោយពេលខឹមបាត់ខ្លួន ខ្ញុំបានឮសូរពីយោធាក្នុងកងជាមួយគ្នានិយាយថា ខឹម និងឆាន ត្រូវបានបញ្ជូនទៅកាន់ម៉ាស៊ីនបូមទឹកនៅបឹងជើងឯក។ នៅពេលនោះ យើងជឿថា រឿងហ្នឹងជារឿងពិត។ ប៉ុន្តែក្រោយមកនៅពេលដែល តា មុត ប្រកាសនៅក្នុងអង្គប្រជុំ អំពីចម្លើយសារភាពរបស់ពួកក្បត់ និងខ្សែរយៈសេអ៊ីអា និងកាហ្សេបេ ហើយបន្ទាប់ពីការបាត់ខ្លួនពួកនោះ ទើបយើងដឹងថា ពួកគេទាំងនោះត្រូវបានចាប់ខ្លួនហើយ។ រហូតដល់ក្រោយឆ្នាំ១៩៧៩ ទើបយើងដឹងថា ស-២១ និងបឹងជើងឯក គឺជាគុក និងកន្លែងសម្លាប់មនុស្ស"]។ ឯកសារ D114/282 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.១១ ["បង ឆាន បន្ទាប់ពីតាមុត។ តាមុត ចាប់យកទៅសម្លាប់នៅបឹងជើងឯកនេះ នៅភ្នំពេញ"]។ ឯកសារ D114/226 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម ហាវ ឆ.៨២-៨៤ ["[ឆាន] ស្លាប់នៅឆ្នាំ១៩៧៧ [...] ឆ.៨៣: គាត់ស្លាប់ដោយប៉ុល ពត យកទៅរៀនសូត្រយកទៅសម្លាប់។ គេថាទៅរៀនសូត្រៗ ទៅបាត់បណ្តោយ។ ស: តើអ្នកណាមកហៅគាត់ទៅរៀនសូត្រ? ឆ.៨៤: ពួកភូមិភាគ [...] ឆ.៨៥: នៅជំនាន់នោះ គេថាទៅរៀនសូត្រៗ គឺយកទៅសម្លាប់ចោល"]។ ឯកសារ D114/113 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម ម៉េន ឆ.១២៦, ២៥៨ ["នៅឆ្នាំ ១៩៧៧ [...] បងខឹម និងបងឆាន ដែលខឹម ទៅសេនាការនៅភ្នំពេញ ហើយឆាន ត្រឡប់ទៅភ្នំពេញ។ ឆាន គឺមកពីតំបន់៣៧ ក្រោយមក គេផ្លាស់គាត់ទៅសេនាធិការនៅភ្នំពេញ [...] ឆ.២៥៨: ក្រែងលោគេឃោសនាកុហកខ្ញុំថា គាត់ត្រូវបានគេឱ្យមកភ្នំពេញធ្វើសេនាធិការនោះ ខ្ញុំមិនដឹងទេ"]។ ឯកសារ D114/130 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ផង់ ឆ.២៨ ["ចាប់ពីបុណ្យហ្នឹង តាឆាន គាត់ឡើងមកគោក គាត់ចម្រាញ់បានច្រើន តែកងខ្ញុំអត់មានកាំភ្លើងទេ។ គាត់ប្រមូលបានតែមួយកង៥០ ទេ រួចគាត់មិនមានកងកម្លាំងគ្រប់គាត់ក៏ត្រៀមកប៉ាល់នៅកោះរ៉ុង តែពេលគាត់ទៅតាមទឹក ហើយគេចាប់គាត់កមកដាក់គុកទួលស្លែង"]។ សូមមើលផងដែរ ឯកសារ D54/10 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ុី រ៉េត ឆ.៧-៨ ["តាឆានមកធ្វើជាអនុម្នាក់របស់កងពល។ ស: តើលោកមានដឹងថា រឿងរ៉ាវអ្វីកើតឡើងចំពោះឆាន ទេក្នុងឆ្នាំ១៩៧៦? ឆ៨: ក្រោយមកខ្ញុំបានឮថា តា ឆាន ក្បត់ ហើយត្រូវបានគេដកចេញ និងបាត់ខ្លួនរហូត "]។ ឯកសារ D69.2.20 របស់ BBC SWB ស្តីពីទំនាក់ទំនងនៃបណ្តាប្រទេសចុងបូព៌ា ថ្ងៃទី ១៤ ខែតុលា ឆ្នាំ១៩៧៨ KH S 00810138 [ហ៊ុនសែននិយាយអំពីការបោសសំអាតផ្ទៃក្នុងនិងលុបបំបាត់សមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា: "បន្ទាប់ពីពួកគេ គឺឆាន ដែលជាមេបញ្ជាការកងពល ១៦៤ ឈរជើងនៅកំពង់សោម និងខឹមជា ស្នងការនយោបាយនៃកងពលធំនេះ"]។

នៃអតីតវរសេនាតូច ៣៨៦[331] ព្រមទាំងកម្មាភិបាលផ្សេងៗទៀត ដែលនៅក្រោមបញ្ជា ឆាន ក្នុងកងពល ១៦៤ ក្នុងនោះមានមេបញ្ជាការអនុសេនាធំ និងអនុសេនាតូចផង[332]។

---

331 ឯកសារ D114/194 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ឆ.១៥, ១៧-១៨ ["សៈ តើលោកស្គាល់មនុស្សម្នាក់ឈ្មោះរ៉ែម ដែលជាស្នងការនយោបាយនៃវរសេនាតូច៣៨៦ដែរឬទេ? ឆ.១៥: បាទ បងរ៉ែម មួយទៀត និង ស្ងួន ឆាន [...] ពួកគាត់ជាអ្នកក្តាប់រួមវរសេនាតូច៣៨៦ និងយោធាតំបន់ ហើយមានពាកងអនុសេនាធំ [...] ឆ.១៧: គេថាពួកខ្ញុំហ្នឹងក្បត់ គេថាយោធា១តំបន់៣៧ក្បត់ គឺពួកតាមុតហ្នឹងជាអ្នកចាប់តែម្តង។ សៈ តើលោកនៅចាំហេតុការណ៍នៃការចាប់ខ្លួនរ៉ែម ដែរឬទេ? ឆ.១៨: ចាំតើ។ មិនមែនចាប់តែគាត់ទេ គឺចាប់តាំងពីថ្នាក់ធំមេបញ្ជាការ រហូតដល់មេក្រុម គឺនៅរស់តែកូនទាហានទេ"]។ ឯកសារ D54/101 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៩ ["រ៉ែមដែលជាស្នងការនយោបាយកងវរសេនាតូច៣៨៦ ដែលត្រូវបានបាញ់សម្លាប់នៅមុខវត្តឥន្ទញ្ញាណ"]។ ឯកសារ D114/244 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ីន យ៉ើ ឆ.១២-១៣,១៦ ["មុនបែកភ្នំពេញហ្នឹង ខ្ញុំនៅអង្គភាពតំបន់៣៧ ជាពេទ្យ អង្គភាពវរសេនាតូច៣៨៦។ សៈ តើមេវរៈរបស់លោកឈ្មោះអ្វីដែរ កាលនោះ? ឆ.១៣: មេបញ្ជាការវរៈ៣៨៦ ឈ្មោះលោកយាន [...] ឆ.១៦: អនុប្រធានគឺលោក រ៉ែម"]។ ឯកសារ D114/40 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.៧៤ ["យានគឺជាមេបញ្ជាការកងវរៈសេនាតូចលេខ៣៨៦"]។ ឯកសារ D54/12 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រេស មាន ឆ.១៦ ["គឺយឺនហ្នឹង ដែលធ្លាប់ធ្វើជាអនុមេបញ្ជាការវរៈសេនាតូច៣៨៦ ពេលដែលរ៉ែម ធ្វើជាមេបញ្ជាការ"]។ ឯកសារ D54/77 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញ៉ិក ឆ.៣ ["ខ្ញុំភ្លេចឈ្មោះមេបញ្ជាការកងវរៈសេនាតូចហើយ តែខ្ញុំនៅចាំឈ្មោះអនុមេបញ្ជាការឈ្មោះ យាន នៅពេលដែលជម្លៀសប្រជាជនចេញពីក្រុងកំពង់សោមនៅពេលនោះ"]។ ឯកសារ D114/31 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.៩១,១២៧-១២៨ ["និយាយអំពីយាន រ៉េម និងសួរដែលជាមេកងវរៈទាំងអស់នោះ ត្រូវគេចាប់យកទៅបាញ់សម្លាប់ក្រោមរូបភាពថាយកទៅរៀនសូត្រ"]។ ឯកសារ D114/155 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រ៉េន ឆ.៦២ ["ខ្ញុំបានបាត់ឈ្មោះមួយចំនួនទៀតដែលខ្ញុំស្គាល់ ដូចជាបងរ៉ែម គាត់ជាមេបញ្ជាការវរសេនាធំជើងទឹក ដែលធ្លាប់អ្នកតស៊ូនៅជាមួយតំបន់៣៧ [...] បងយឺន ត្រូវគេចាប់ខ្លួន បាត់ខ្លួន ពេលដែលចាប់ខ្លួនមានឈ្មោះ ឯក នីជាអ្នកដឹង [...] យាន និងទ្រាបាត់ខ្លួនអស់។ យឺនថ្នាក់វរសេនាតូច អ្នកទាំងនោះ ត្រូវបានគេចាប់ខ្លួនយកទៅលុតដំនៅស្ទឹងហាវនោះទេ គ្រាន់តែដឹងថា គេចាប់ទៅបាត់ ហើយក៏មិនដឹងថាយកទៅសម្លាប់ឬយ៉ាងណាទេ។ ពួកគេបាត់ខ្លួនរហូត"]។ ឯកសារ D114/105 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុច ទុយ ឆ.១៨ ["តាយឺនគឺជាមេកងវរសេនាតូច និងតាយានជាអនុកងវរសេនាតូច ស្លាប់ហើយដោយគេហៅឲ្យទៅរៀនសូត្រ នៅខេត្តកំពង់សោម"]។ ឯកសារ D54/25 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ឆ.២១ ["តាយឺន ហៅយឿន ដែលជាមេបញ្ជាការកងវរសេនាតូចរបស់ខ្ញុំ គឺវរសេនាតូចលេខ៦២២"]។ ឯកសារ D114/116 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញ៉ិក ឆ.៤៩ ["បងប្រុសរបស់ខ្ញុំជាអនុកងវរសេនាតូច ដែលត្រូវបានឲ្យទៅជួយក្រុមគ្រួសារទាហានច្រូតស្រូវក្បែរកងកេង ហើយគាត់បានបាត់ខ្លួនចាប់ពីពេលនោះ"]។

332 ឯកសារ D114/105 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុច ទុយ ឆ.១៨ ["ខ្ញុំស្ថិតក្នុងកងវរសេនាតូចលេខ ៨៦ តាយឺនមេកងវរសេនាតូច និងតាយានអនុកងវរសេនាតូច ស្លាប់ហើយដោយគេហៅឲ្យទៅរៀនសូត្រនៅកំពង់សោម"]

។ ឯកសារ D114/194 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ន សុត ឆ.៥, ១៧-១៩ ["កងទ័ពតំបន់ពិសេស កងវរសេនាតូច៣៨៦ ត្រូវបានបញ្ចូលទៅក្នុងកងពលធំទី៣ក្រោយរំដោះឆ្នាំ១៩៧៥។ ដល់ចុង១៩៧៧ ឬដើម១៩៧៧ បានចាប់មេបញ្ជាការទាំងអស់ចោទថាតំបន់ហ្នឹងក្បត់។ ក្រោយចាប់អស់ ក៏រំលាយពួកខ្ញុំ ហើយបញ្ជូនយកទៅធ្វើស្រែ។ បើសិនជាបងប្អូនមិនតាមទេ គឺត្រូវគេសម្លាប់ចោល។ និយាយរួមទៅគឺមកពីតាមុត ហ្នឹងតែម្តងដែលជាអ្នកបញ្ជា [...] ឆ.១៧: គេថាពួកខ្ញុំហ្នឹងក្បត់ គេថាយោធា១តំបន់៣៧ក្បត់ គឺពួកតាមុតហ្នឹងជាអ្នកចាប់តែម្តង [...] ឆ.១៨: គឺចាប់ទាំងអស់ ចាប់តាំងពីថ្នាក់ធំមេបញ្ជាការរហូតដល់មេក្រុម គឺនៅរស់តែកូនទាហានទេ [...] ឆ.១៨: វាចាប់ផ្តើមចោទថាក្បត់តាំងពីចុងឆ្នាំ១៩៧៦ "]។ ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.១៤ ["កងពិសេសគឺជាដូចជាកងអង្គរក្សអ៊ិចឹង។ វាគឺជាកងដែលមេគេជឿទុកចិត្ត ហើយគេប្រើយោធាក្នុងកងនេះសម្រាប់ចាប់ចងអ្នកក្បត់ ហើយនិងការងារសំខាន់ៗដទៃទៀត។ នៅពេលដែលគេចង់ចាប់កងវរសេនាតូច និងកងវរសេនាធំ គេប្រើយោធាកងពិសេសទៅហៅពួកគេថា បងកងពលឱ្យមកប្រជុំ"]។ ឯកសារ D54/103 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៧-៨, ២១-២២ ["តាមុតបានមកប្រជុំជាមួយនឹងពួកយើងក្រោយពេលដែលដកកាំភ្លើង នៅពេលដែលគាត់បានប្រកាសនៅក្នុងអង្គប្រជុំថា ឆាន ជាពួកក្បត់ ហើយសម្រាប់អតីត៨៦ (៣៨៦) គឺមិនគួរទុកចិត្តបានទៀតទេ។ បន្ទាប់ពីគេចាប់ ឆាន រួចហើយ ថ្នាក់ដឹកនាំដែលជាស្នងការនយោបាយ និងមេបញ្ជាការថ្នាក់កងវរសេនាតូច កងអនុសេនាធំ កងអនុសេនាតូចគឺត្រូវបានគេចាប់ខ្លួនផងដែរ [...] ឆ.៨: អ្នកដែលចូលរួមប្រជុំទាំងអស់ប្រហែល៥០០នាក់ ដែលរួមទាំងអតីតយោធា៨៦ (៣៨៦) ប្រហែលជា១០០នាក់ ដែលគេដកកាំភ្លើងរួច។ នៅពេលនោះតាមុតបាននិយាយនៅក្នុងអង្គប្រជុំនោះថា ទាំងអស់គ្នាត្រូវតែតាមដានពួកអតីតយោធាកង៨៦នេះ។ គាត់បាននិយាយថា ពួកអតីតយោធាកង៨៦ សុទ្ធតែនៅក្នុងខ្សែកាហ្សេបេ និងសេអ៊ីអា។ គាត់ថាខ្សែកាហ្សេបេ និងសេអ៊ីអា នេះមិនទាន់បានកម្ទេចទាំងស្រុងនៅឡើយទេ។ ក្នុងចំណោមយោធាជាង៥០០នាក់ ដែលចូលរួមប្រជុំនេះ ក្រៅពីអតីតយោធាកង៣៨៦ គឺសុទ្ធតែពួកយោធារបស់ពួកគេ ដើម្បីមកតាមដានពួកអតីតយោធាកង៣៨៦ [...] ស.២១: តាមដែលលោកស្មាន តើអតីតយោធា៣៨៦ ត្រូវបានបាត់ខ្លួនរហូតនៅក្នុងរយៈពេលឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ មានចំនួនប៉ុន្មាននាក់? ហើយតើមានប្រហែលជាប៉ុន្មាននាក់នៅរស់រហូតដល់ឆ្នាំ១៩៧៩ ពេលវៀតណាមចូល? ឆ.២១: ពេលនោះក្នុងកងវរៈ៣៨៦ ទាំងមូល មានយោធានៅសល់តែជាង២០០នាក់ទេ។ យោធាទាំងនោះជាងពាក់កណ្តាលនៃកងវរៈដែលមានចំនួនជាង ១០០នាក់ ត្រូវបានចាប់ខ្លួន ហើយបាត់ខ្លួនរហូត [...] ស: តើមានពួកយោធាដែលមានសមាសភាពមិនល្អ ហើយនិងអតីតយោធា៣៨៦ ខ្លះត្រូវបានអប់រំកែប្រែបានហើយ ត្រូវបញ្ជូនទៅអង្គភាពដើមវិញដែរឬទេ មុនឆ្នាំ១៩៧៩? ឆ.២២: តាមខ្ញុំដឹង គឺគ្មានទេ"]។ ឯកសារ D54/76 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញ៉ិក ឆ.១៦ ["ស: ហេតុអ្វីបានជាគេដូរមេបញ្ជាការនៅក្នុងកងអនុសេនាធំរបស់លោក [...] ? ឆ.១៦: នៅពេលនោះ គេបានចោទពួកអតីតយោធារបស់កងតំបន់៣៧ និងពួកភូមិភាគបូព៌ា ថាជាសមាសភាពមាននិន្នាការមិនល្អ។ សូម្បីតែអ្នកដែលបញ្ជូនទៅហ្វឹកហ្វឺននៅស្រុកចិន ក៏ត្រូវហៅត្រឡប់មកវិញដែរ"]។ ឯកសារ D114/31 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.១៦, ១៩,៩១, ១២៧-១២៨ ["ឆានជាមេបញ្ជាការ [...]ក្រោយមកឆានត្រូវបានគេយកទៅសម្លាប់ចោល [...] ឆ.១៩: ប្រសិនបើខ្ញុំមានឋានៈ និងតួនាទី ដូចជាប្រធានកងធំ គឺគេច្បាស់ជាយកទៅសម្លាប់អស់ហើយ ព្រោះឋានៈចាប់ពីមេកងធំឡើងទៅ ត្រូវបានគេយកទៅសម្លាប់ទាំងអស់ ក្រោមហេតុផលហៅយកទៅរៀនសូត្រ [...] ឆ.៩១: ខ្ញុំធ្លាប់រហូតដល់សព្វថ្ងៃ ហេតុអ្វីបានពួកគេសម្លាប់ ឲ្យតែមេៗវរៈគេហៅមករៀនសូត្រនៅរោងកុន នៅកំពង់សោម គឺដឹងតែ

114. នៅឆ្នាំ ១៩៧៧ ការបោសសម្អាតរបស់ មាស មុត មកលើកងពល ១៦៤ និងតំបន់កំពង់សោម កាន់តែកើនឡើង។ យុទ្ធជនវរសេនាតូច ៣៨៦ ដែលផុតពីការចាប់ខ្លួន និងសម្លាប់ចុងឆ្នាំ ១៩៧៦ ត្រូវរំសាយ ហើយផ្លាស់ទៅកាន់អង្គភាពបង្កបង្កើនផលដែលប្រតិបត្តិកា រនៅក្រោមកងពល ១៦៤ ដោយសារមានជាប់ខ្សែឆាន[333]។ នៅថ្ងៃទី១ ខែ មីនា ឆ្នាំ ១៩៧៧ មាស មុត រាយការណ៍ទៅ សុន សេន និងមេបញ្ជាការផ្សេងៗទៀតអំពីការបោសសម្អាតនៅក្នុងកងពលរបស់គាត់ ដោយប្រាប់ថា ការចាប់ខ្លួនទាំងនោះនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ ក្នុងការទប់ទល់នឹងការគំរាម

---

បាត់ខ្លួនតែម្តង ហើយមិនដែលឃើញវិលត្រឡប់មកវិញទេ [...] កន្លងទៅរាប់ខែ ក៏មិនដែលឃើញពួកគេត្រឡប់មកវិញនោះទេ [...] ស: លោកនិយាយថា មេវរៈបានបាត់ខ្លួន។ តើលោកអាចផ្តល់ឈ្មោះអ្នកទាំងនោះបានដែរឬទេ? ឆ.១២៧: ឈ្មោះយាន, វ៉ែម និងសួរ [...] ឆ.១២៨: ឆានក៏បាត់ខ្លួនដែរ។ និយាយទៅ មេៗគឺបាត់ខ្លួនទាំងអស់ គឺលើកលែងតែកូនទាហានធម្មតាទេ”]។ ឯកសារ D114/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេត ប៊ុណ្ណា ឆ.២៣ [“មានតែ ឆាន និងឌឹមត្រូវបានគេប្រកាសថាក្បត់ជាសាធារណៈ។ ចំពោះការចាប់ខ្លួនកងទ័ពក្រោមបង្គាប់របស់ឆាន និងឌឹម ពុំប្រកាសជាសាធារណៈទេ។ យើងបានដឹងអំពីការចាប់ខ្លួនកូនចៅក្រោមៗគាត់ ដោយការនិយាយតៗគ្នាប៉ុណ្ណោះ”]។ ឯកសារ D54/12 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រេស មាន ឆ.៣០ [“ស: តើតាមុតបាននិយាយឈ្មោះអ្នកណាខ្លះថា ជាពួកក្បត់ឬទេនៅក្នុងអង្គប្រជុំនោះ? ឆ.៣០: បាទ, គាត់បានប្រកាសថា តាញ៉ឹកជាលេខតំបន់៣៧, តាប៊ុននៅក្នុងគណៈតំបន់ ៣៧ និងឆាននៅក្នុងគណៈតំបន់៣៧ដែរ តែខ្ញុំមិនដឹងពីតួនាទីអ្នកទាំងពីរនេះឲ្យច្បាស់ទេ ហើយឌឹមជាអនុរបស់តាមុតនៃកងពល១៦៤”]។ ឯកសារ D114/33 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម អាង ឆ.៣២ [“ក្រោយពីគេចោទថា មេៗនៅតំបន់៣៧ ក្បត់អ្នកដែលទៅពីមជ្ឈិមក៏ឡើងជំនួស ហើយអតីតសមាជិកតំបន់៣៧ ត្រូវបានគេរំសាយចោល ហើយឲ្យទៅធ្វើការដូចប្រជាជនធម្មតាវិញ”]។ ឯកសារ D114/226 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម ហាវ ឆ៩១-៩៣ [“ស: អ្នកដទៃទៀត ដែលគេយកទៅហ្នឹង អ្នកណាខ្លះ? ឆ.៩១: បងសួ, បងហិន, បងសេត, បងហ៊ាន, បងផល ហ្នឹងសុទ្ធតែជាប្រធានវរៈ ដែលគេយកទៅរៀនសូត្រ សុទ្ធតែមេធំៗ មេវរៈ មេកងវរយ ហ្នឹងទ័ពណា។ សុទ្ធតែប្រធានវរៈ អនុវរៈ និងលេខា។ ស: តើអ្នកណាដែលគេយកទៅរៀនសូត្រមុនគេ? ឆ.៩២: គឺអ៊ំឆាន [...] ឆ៩៣: នៅដើមឆ្នាំ១៩៧៧។ នៅដើមឆ្នាំ ខ្ទង់ខែថ្ងៃទី២ ទី៣ហ្នឹងចាប់បណ្តើរៗ។ ហ្នឹងទ័ពភូមិភាគមកចាប់ ខ្ញុំមិនដឹងភូមិភាគណាដែរ”]។ ឯកសារ D114/135 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ផន ឆ.៣-៥ [អតីតវរសេនាធំលេខ៦៣ នៅក្នុងអង្គភាពលេខ៤២០ ប្រចាំការនៅកោះតាង បានពន្យល់ថាមេៗរបស់គេត្រូវបានគេបញ្ជូនទៅរៀនសូត្រ ហើយបាត់ខ្លួនរហូត]។

333 ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.១ [“រឿងនេះកើតឡើងនៅចុងឆ្នាំ១៩៧៦ ជិតចូលឆ្នាំ១៩៧៧ [...] ពួកគេបានដកយោធាកង៣៨៦ ទាំងអស់យកទៅដាក់នៅកងផលិត។ បន្ទាប់ពីគេដកអាវុធពីពួកយើងអស់ ពួកគេមិនអនុញ្ញាតឲ្យយើងទុកកាំបិតទេ [...] មាស មុត បានមកធ្វើមីទ្ទីងជាមួយពួកយើងនៅភូមិគគីរ នៅជិតព្រលានយន្តហោះកងកេង ដោយមានអតីតយោធាចូលរួមប្រហែលរាប់ពាន់នាក់ ដោយមានកងវរៈសេនាតូច៣៨៦ និងកងផ្សេងៗទៀត។ គាត់បានអានចម្លើយសារភាពរបស់ពួកក្បត់ គាត់បានរៀបរាប់ឈ្មោះកម្មាភិបាលក្បត់ចាប់ពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់មូលដ្ឋាន។ ខ្ញុំនៅចាំថា គាត់ហៅឈ្មោះ អាយ៉ា, អាធុច, អាញ៉ឹក, អាយ៉ាន, អាឆាន និងអាឌឹម”]។

កំហែងរបស់ខ្មាំង[334]។ ដូចនេះ ប្រាំពីរសប្តាហ៍ក្រោយ ចាប់ពីថ្ងៃទី២១ ខែ មេសា មាស មុត បាន បោសសម្អាតកម្មាភិបាលជាន់ខ្ពស់កងពល ១៦៤ ក្នុងទ្រង់ទ្រាយធំ។ ការបោសសម្អាតនោះ មាន អនុលេខាកងពល ១៦៤ ឈ្មោះ ហ៊ីង ឌឿន ហៅ ឌីម[335] និង សមាជិក ឈ្មោះ ម៉ុម ជិម ហៅ យ៉ាន[336] និង ម៉ែន ង៉ែត[337]។

115. នៅក្នុងអង្គប្រជុំនៅអាកាសយានដ្ឋានកង កេង ដែលក្នុងនោះ មាស មុត បានអានចម្លើយសារភាពរបស់កម្មាភិបាលកងពល ១៦៤ ដែលបានបោសសម្អាត[338] គាត់បានលើកឡើងផងដែរថា "សម្រាប់ពួកអតីតយោធានៃ[អង្គភាព]៨៦ (៣៨៦) គឺមិនគួរទុកចិត្តបានទៀតឡើយ" ហើយបន្តិចក្រោយមក ជាងពាក់កណ្តាលនៃយុទ្ធជនវរសេនាតូច៣៨៦ ដែលពេលនោះបានដកអាវុធហើយនោះ ត្រូវបានចាប់ និងបាត់ខ្លួន[339]។

---

334 ឯកសារ D1.3.27.26 កំណត់ហេតុនៃការប្រជុំលេខា-អនុលេខា កងពល និងវរៈសេនាធំឯករាជ្យ ចុះថ្ងៃទី ១ ខែ មីនា ឆ្នាំ១៩៧៧ ERN KH 00052305 ["អង្គភាពឃ្លាំងបានសំរិតសំរាំងមួយអនុសេនាតូច តែនៅពុំទាន់អស់ និងធានានៅឡើយ"]។

335 ឯកសារ D114/230.1.1 ក.ស.ច.ស បញ្ជីឈ្មោះអ្នកទោសនៅស-២១ [កំណត់អត្តសញ្ញាណ លេខ ១៦២៤ ជា ហ៊ីង ឌឿន បានមកដល់ស-២១ នៅថ្ងៃទី ២១ ខែមេសា ឆ្នាំ១៩៧៧]។ ឯកសារ D9.3 ក.ស.ច.ស បញ្ជីឈ្មោះអ្នកទោសនៅស-២១ មកពីកងពលធំ១៦៤ [កំណត់អត្តសញ្ញាណ លេខ ១១ ជា ហ៊ីង ឌឿន ហៅឌីម ត្រូវបានសម្លាប់នៅថ្ងៃទី ៨ ខែធ្នូ ឆ្នាំ១៩៧៧]។ ឯកសារ D1.3.28.40 បញ្ជីឈ្មោះអ្នកទោស បញ្ជីឈ្មោះអ្នកទោសដែលត្រូវបានកម្ទេច និងថតរូប នៅថ្ងៃទី ៨ ខែធ្នូ ឆ្នាំ១៩៧៧ ERN EN 00873281, ERN KH 00009146 [កំណត់អត្តសញ្ញាណ លេខ២ ជា ហ៊ីង ឌឿន]។

336 ឯកសារ D114/230.1.1 ក.ស.ច.ស បញ្ជីឈ្មោះអ្នកទោសនៅស-២១ [កំណត់អត្តសញ្ញាណ លេខ៤៧៩៧ ជា មុំ ជីម ដែលបានមកដល់ស-២១ ថ្ងៃទី ២៨ ខែមេសា ឆ្នាំ១៩៧៧ និងកម្ទេចនៅថ្ងៃទី ១៣ ខែមីនា ឆ្នាំ១៩៧៨]។ ឯកសារ D9.3 ក.ស.ច.ស បញ្ជីឈ្មោះអ្នកទោសនៅស-២១ មកពីកងពលធំ១៦៤ [កំណត់អត្តសញ្ញាណ លេខ ២៤ (និងលេខ២៧ ស្ទួន) ជា មុំ វាន]។

337 ឯកសារ D114/230.1.1 ក.ស.ច.ស បញ្ជីឈ្មោះអ្នកទោសនៅស-២១ [កំណត់អត្តសញ្ញាណ លេខ៥៣៤២ ជា ម៉ែន ង៉ែត ដែលមកដល់ស-២១ ថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៧៧]។ ឯកសារ D9.3 ក.ស.ច.ស បញ្ជីឈ្មោះអ្នកទោសនៅស-២១ មកពីកងពលធំ១៦៤ [កំណត់អត្តសញ្ញាណ លេខ ២៦ ជា ម៉ែន ង៉ែត]។

338 សូមមើល កថាខណ្ឌទី ១០៨។

339 ឯកសារ D54/103 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៧-១០, ២១ ["កងយោធារបស់ខ្ញុំត្រូវបានគេដកកាំភ្លើយនៅដើមខែវស្សា ក្នុងឆ្នាំ១៩៧៧។ នៅពេលនោះ តាមុតបានមកប្រជុំជាមួយនឹងពួកយើង ក្រោយពេលដែលដកកាំភ្លើង នៅពេលដែលគាត់បានប្រកាសនៅក្នុងអង្គប្រជុំថា ឆាន ជាពួកក្បត់ ហើយសម្រាប់ពួកអតីត ៨៦ (៣៨៦) គឺ

116. មាស មុត ជាស្វ័យប្រវត្តិ ចាត់ទុកយុទ្ធជនក្រោមបង្គាប់ទាំងឡាយ ថា "បានពាក់ព័ន្ធ" ឬ ជា"ខ្សែ" របស់មេបញ្ជាការយុទ្ធជនទាំងនោះ[340] ហើយដោយសារអនុលេខារបស់គាត់ ឌឹម បានឆ្លើយដាក់

---

មិនគួរទុកចិត្តបានទៀតទេ។ បន្ទាប់ពីគេចាប់ឆាន រួចហើយ ថ្នាក់ដឹកនាំដែលជាស្នងការនយោបាយ និងមេបញ្ជាការថ្នាក់កងវរៈសេនាតូច កងអនុសេនាធំ កងអនុសេនាតូចគឺត្រូវបានគេចាប់ខ្លួនផងដែរ។ ខ្ញុំមិនដឹងពេលវេលាច្បាស់ថាគេចាប់ពួកនារីទាំងនោះនៅពេលណាទេ រហូតដល់ខ្ញុំឃើញពួកគេនៅកន្លែងទឹកសាប។ សៈ នៅពេលដែលមាស មុត បាននិយាយថា កង៨៦(៣៨៦) ថាជាពួកដែលមិនគួរឱ្យទុកចិត្ត តើមាស មុតបាននិយាយថា ត្រូវចាត់ការពួកនេះយ៉ាងម៉េចទេ នៅពេលអនាគតខាងមុខ? ឆ.៨: នៅពេលនោះ អ្នកដែលចូលរួមប្រជុំទាំងអស់មានប្រហែល៥០០នាក់ ដែលរួមទាំងអតីតយោធាកង៨៦ (៣៨៦) ប្រហែលជាង១០០នាក់ ដែលគេដកកាំភ្លើងរួច។ នៅពេលនោះតាមុតបាននិយាយនៅក្នុងអង្គប្រជុំនោះថា ទាំងអស់គ្នាត្រូវតែតាមដានពួកអតីតយោធា៨៦នេះ។ គាត់បាននិយាយថា ពួកអតីតយោធាកង៨៦សុទ្ធតែកាហ្សេប្រេ និងសេអ៊ីអា។ គាត់ថាខ្សែកាហ្សេប្រេ និងសេអ៊ីអា នេះមិនទាន់បានកម្ទេចបានទាំងស្រុងនៅឡើយទេ។ ពួកនេះគឺនៅលាក់ខ្លួនក្នុងជួរយើង ដូច្នេះយើងត្រូវតែតាមដានពួកនេះឱ្យជាប់។ ក្នុងចំណោមយោធាជាង៥០០នាក់ដែលចូលរួមប្រជុំនេះ ក្រៅពីអតីតយោធាកង៣៨៦គឺសុទ្ធតែពួកយោធារបស់ពួកគេ ដើម្បីមកតាមដានពួកអតីតយោធា៣៨៦។ សៈ តើលោកនៅចាំបានដែរឬទេ នៅពេលនោះបរិយាកាសក្នុងពេលប្រជុំនោះយ៉ាងម៉េច នៅពេលដែល មាស មុត ធ្វើការប្រកាសយ៉ាងដូច្នេះ? តើអារម្មណ៍របស់ពួកអតីតយោធាកង៨៦ (៣៨៦) ហើយនឹងយោធាដទៃទៀតយ៉ាងម៉េចដែរ? ឆ.៩: សម្រាប់អតីតយោធា៣៨៦ គឺយើងមានការភ័យតក់ស្លុតយ៉ាងខ្លាំងបន្ទាប់ពីសេចក្តីប្រកាសនេះ ពួកយើងដេកមិនលក់ទេ ពេលយប់ យើងរស់នៅដោយការភ័យខ្លាចជាប់ជានិច្ច។ សម្រាប់ពួកយោធាផ្សេងៗវិញ គេបានផ្លាស់ប្តូរឫកពាររបស់ពួកគេទាំងស្រុងចំពោះពួកយើង ទោះបីពួកយើងធ្លាប់ស្គាល់គ្នាពីមុនក៏ដោយ ពួកគេឈប់និយាយរកយើង ហើយឈប់និយាយរកយើង ហើយឈប់មើលមុខយើងចំទៀតដែរ។ ពេលខ្លះគេចំអកដាក់យើង ថាយើងជាខ្សែក្បត់។ ពេលខ្លះខ្ញុំឃើញគេសរសេរនៅលើជញ្ជាំងដោយធ្យូងថា "អតីតយោធា៣៨៦ គឺជាពួកខ្សែក្បត់"។ សៈ នៅក្នុងពេលដែលមាស មុតធ្វើការប្រកាសក្នុងអង្គប្រជុំនោះ តើអតីតស្នងការ និងមេបញ្ជាការវរៈសេនាតូច អនុសេនាធំ និងអនុសេនាតូច កង៨៦(៣៨៦) ត្រូវបានគេចាប់ខ្លួនអស់ហើយឬនៅ ឬក៏គេចាប់ខ្លួនពួកនោះមុនឬក្រោយពេលប្រជុំ? ឆ.១០: ថ្នាក់ដឹកនាំប្រហែល៧០ភាគរយត្រូវបានចាប់ខ្លួនមុនប្រជុំ ហើយអ្នកនៅសល់ត្រូវបានចូលរួមប្រជុំ ហើយក្រោយមកក៏ត្រូវបានគេចាប់ខ្លួនផងដែរ [...] ឆ.២១: ពេលនោះ ក្នុងកងវរៈ៣៨៦ទាំងមូល មានយោធានៅសល់តែជាង២០០នាក់ទេ។ យោធាទាំងនោះជាងពាក់កណ្តាលនៃកងវរៈដែលមានចំនួនជាង១០០នាក់ត្រូវបានចាប់ខ្លួន ហើយបាត់ខ្លួនរហូត"]។

340 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ 14.24.11-14.26.40 ["តាឌឹម [...] ក្រោយមក គាត់ត្រូវបានចាប់ខ្លួន បាទ បាត់ទៅ។ ពេលដែលចាប់ខ្លួនទៅ កងទ័ព កងយោធាទាំងអស់ជាកងយុទ្ធភូមិភាគបូព៌ា ឃើញថាឃើញចាប់ខ្លួនជាបន្តបន្ទាប់រហូតដល់អស់រលីងនៅកំពង់សោម។ កងភូមិភាគបូព៌ាអត់មាននៅសល់ទេ ក្រោយមកចាប់ទាំងអស់ ចាប់បាត់អស់។ ខ្ញុំក៏អត់ដែលឃើញអីទាំងអស់ មិនដឹងចាប់យកទៅណា ទៅណីទេ អត់ឃើញទេ [...]។ ក្រោយពីតាឌឹម គេចាប់ខ្លួនបាត់ហើយ ក្រោយមក ចាប់យោធាៗដែលកងពលរបស់គាត់ ជាវរៈមួយវរសេនាធំនោះ។ ដោយសារដែលគេចាប់តាឌឹម បាត់ទៅ គឺតាឌឹម នោះគឺគាត់មានចម្លើយយ៉ាងម៉េចទេ ឬដឹង

យុទ្ធជន និងកម្មាភិបាលកងពល ១៦៤ ជាច្រើននាក់ខណៈត្រូវសួរចម្លើយនៅស-២១នោះ[341] មាស មុត ក៏ចេញបញ្ជាបោសសម្អាតយោធា និងកម្មាភិបាលភូមិភាគបូព៌ាក្នុងកងពល ១៦៤[342]។

---

ចម្លើយយ៉ាងម៉េចអីយ៉ាងម៉េចទេ ហើយសាច់ទ័ពរបស់គាត់ដែលរស់នៅក្នុងកំពង់សោមនោះ សុទ្ធតែជាប់និន្នាការនយោបាយចម្លើយពីតាខឹមទាំងអស់។ ក្រោយមកបានចាប់ដកចេញទាំងអស់ ប៉ុនមិនដឹងដកចេញទៅកន្លែងណាទេ។ មិនមែនបញ្ជូនទៅភូមិភាគបូព៌ាវិញទេ គឺមិនដឹងយកទៅត្រង់ណាទេ បាត់ទាំងអស់ បាត់អត់ដែលឃើញទេមួយវរសេនាធំហ្នឹង]។14.26.40 [ចម្លើយពីខាងលើមកវាជាប់កងទ័ពទាំងអស់ យោធាទាំងអស់ហ្នឹង ឃើញថាជាប់និន្នាការនយោបាយរបស់តាខឹមទាំងអស់។ អ៊ីចឹង គេយកមេទៅហើយ គេសង្ស័យថាទ័ពទាំងអស់ដែលវរសេនាធំដែលគាត់មកពីភូមិភាគបូព៌ានោះ គេលែងទុកចិត្តហើយ គេដកចេញ មិនដឹងដកចេញទៅណាទេ អត់ដែលដឹង]។ សូមមើលផងដែរ ឯកសារ D98/3.1.89 កាំង ហ្កេកអ៊ាវ ហៅឌុច ប្រតិចារឹក ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ 16.18.55 ["ខ្ញុំគិតថាម៉េចខ្សែខ្លាំង ម៉េចអីៗ អាហ្នឹងគិតមែន]។ ឯកសារ D54/8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ឆ.៣ ["សៈ កំហុសប្រភេទណាខ្លះ នៅក្នុងកងពល១៦៤ ដែលអាចឈានទៅរកការចាប់ចងនិងសម្លាប់? ឆ.៣: ខ្ញុំដឹងមិនច្បាស់ទេថាតើកំហុសប្រភេទណា ដែលអាចឈានទៅដល់ការចាប់ចងនិងសម្លាប់នោះ។ ខ្ញុំមានឧទាហរណ៍ខ្លះ សម្រាប់ការចាប់ចង។ បើយោធាណាដែលមានបងប្អូននៅឯមូលដ្ឋាន នៅស្រុកភូមិ ត្រូវបានគេចាប់ដោយចោទថាក្បត់ យោធានោះក៏ត្រូវបានគេចាប់ខ្លួនពីក្នុងកងដែរ។ ដូចជាឧទាហរណ៍ ប្រធានកងវរៈសេនាធំក្តី បើគាត់ត្រូវបានគេចាប់ខ្លួន គ្រួសារប្រពន្ធគាត់ក៏ត្រូវចាប់ខ្លួនដែរ"]។

341 ឯកសារ D234/2.1.55 ចម្លើយសារភាពរបស់ ហង់ ឌឿន ឬ ហ៊ីង ឌឿន ហៅ ខឹម នៅ ស-២១ ERN EN 00224085។ ឯកសារ D1.3.18.1 ចម្លើយសារភាពរបស់ ហង់ ឌឿន ឬ ហ៊ីង ឌឿន ហៅ ខឹម នៅ ស-២១។ ឯកសារ D1.3.18.2 ចម្លើយសារភាពរបស់ ហង់ ឌឿន ឬ ហ៊ីង ឌឿន ហៅ ខឹម នៅ ស-២១ ERN EN 00759713-17, ERN KH 00177026-30។

342 ឯកសារ D54/8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ឆ.១២ ["ខឹមត្រូវបានបញ្ជូនមកពីភូមិភាគបូព៌ាមកធ្វើជាអនុកងពលរបស់មាស មុត។ នៅពេលនោះ គេចាប់ពួកមកពីបូព៌ាដែលនៅតាមកងនានាដែលនៅក្នុងកងពល"]។ ឯកសារ D2/16 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ឆ.២០ ["តើពួកកម្លាំងដែលបញ្ជូនមកពីបូព៌ាទាំងអស់ដែលចូលមកកងជើងទឹកត្រូវបានគេចាប់ និងដកចេញទាំងអស់ឬយ៉ាងម៉េច? ឆ.២០: មុនដំបូង ពួកគេបានហៅមេៗយកចេញទៅបាត់ បន្ទាប់មកគេដកយកអ្នកថ្នាក់ក្រោមៗទាំងអស់"]។ ឯកសារ D54/26 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ឆ.១០,៣៣,៣៥-៣៦ ["មេបញ្ជាការរបស់យើង គឺខឹម ត្រូវបានគេចាប់ពីបទក្បត់។ ក្រោយគេចាប់ខឹម គេបន្តចាប់អ្នកថ្នាក់ក្រោម។ នៅកងកេង គេឲ្យយើងធ្វើស្រែ [...] ដំបូង គេមកហៅយើង ដោយយកលេសថាអង្គការហៅយើងទៅរៀនសូត្រ។ ពេលយើងមកដល់ គេប្រើយើងធ្វើស្រែ។ មនុស្សមួយចំនួនក៏បានបាត់ខ្លួន នៅពេលនោះ... គេបាត់ខ្លួនរហូត... ពួកយើងគ្មាននរណាម្នាក់ហ៊ានសួរ ឬឆ្ងល់ឡើយ។ នៅពេលនោះ មានតែកូនចៅថ្នាក់ក្រោមប៉ុណ្ណោះដែលនៅរស់រានមានជីវិត មេដឹកនាំបានបាត់ខ្លួនរហូត [...] ឆ.៣៣: ខឹមមកពីភូមិភាគបូព៌ាជាមួយយោធាមួយកងពល មកចូលរួមជាមួយនឹងកងពល១៦៤។ បន្ទាប់ពីការចាប់ ខឹមទៅ យោធាភូមិភាគបូព៌ាទាំងនោះត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ដែរ។ នៅពេលនោះ យោធាភូមិភាគបូព៌ាម្នាក់ [...] ឈ្មោះ ជៀន ស្រាប់តែបាត់

មុខតែម្តង។ ខ្ញុំគិតថាយោធារបស់ភូមិភាគបូព៌ាដែលត្រូវបានចាប់ខ្លួនទាំងនោះ ប្រហែលជាត្រូវបានគេសម្លាប់ចោលនៅកន្លែងសម្លាប់នោះដែរហើយ [រាម សំដៅលើចំណោទរាម] ប៉ុន្តែ ខ្ញុំមិនច្បាស់ទេ។ ប្រហែល១ខែក្រោយមក មេបញ្ជាការវរសេនាតូចរបស់ខ្ញុំ បានបើកវគ្គបង្រៀនអប់រំរៀនសូត្រនយោបាយ ដែលនៅក្នុងនោះ គាត់បានប្រកាសថា ឌឹម កុយ ធួន ហៅធុច ហើយនឹងថ្នាក់ដឹកនាំមួយចំនួនទៀត គឺសុទ្ធតែជា កាហ្សេបេ និងសេអ៊ីអារបស់យួន ហើយសុទ្ធតែជាពួកក្បត់[...]។ ឆ.៣៥ : ខ្ញុំដឹងអំពីការបោសសម្អាតយោធាភូមិភាគបូព៌ាម្តង [...]។ គេបានប្រកាសថាមួយវរសេនាតូចមានយោធា៥០នាក់ ក៏មិនមានបញ្ហាអ្វីដែរ ដរាបយោធាទាំងនោះជាយោធាល្អ។ យោងទៅតាមការចងចាំរបស់ខ្ញុំ ការបោសសម្អាតយោធាភូមិភាគបូព៌ាចាប់ផ្តើមក្នុងឆ្នាំ១៩៧៦ មុនពេលគេបញ្ជូនខ្ញុំទៅវរសេនាធំ១៤០ មុនឆ្នាំ១៩៧៧។ នៅក្នុងពេលនោះ គេចាប់មេដឹកនាំមុន រួចហើយទើបគេចាប់យោធាតាមក្រោយ។ ឆ.៣៦ : ខ្ញុំបានឮនៅក្នុងរយៈពេលអប់រំនយោបាយថា ការចាប់ចងគឺធ្វើឡើងតាមចម្លើយសារភាពរបស់មេដឹកនាំដែលត្រូវបានគេចាប់យកទៅមុន។ ឯកសារ D54/13 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រេស មាន ឆ.១៥ ["នៅពេលនោះ គេចំរាញ់យកចេញតែពួកថ្នាក់ដឹកនាំដែលមកពីភូមិភាគបូព៌ាតែប៉ុណ្ណោះ។ ចំណែកពួកយោធាធម្មតា គេគ្រាន់តែដកកាំភ្លើងហើយបញ្ជូនទៅវាយថ្ម។ ឯកសារ D54/36 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ឆ.១២ ["អតីតទាហានភូមិភាគបូព៌ាត្រូវបានចល័តនៅក្នុងក្រុមជាមួយយើង។ ពួកគេត្រូវបានគេចោទថាក្បត់"]។ ឯកសារ D54/33 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ឆុង ឆ.២០ ["យើងបានស្នាក់នៅកំពង់សោមចំនួនមួយអាទិត្យ មុនពេលពួកយើងបញ្ជូនទៅទីរួមខេត្តកោះកុង ដើម្បីទៅជំនួសពួកភូមិភាគបូព៌ានៅលើកប៉ាល់ ប៉េសេអេស (PCF) ដែលត្រូវបានគេដកចេញ"]។ ឯកសារ D114/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.១២ ["អំពីរចនាសម្ព័ន្ធបញ្ជាការរបស់កងវរសេនាធំ១៤០ ដូចតទៅនេះ "តាសេងគឺជាមេបញ្ជាការ ហើយតាសំដែលមកពីភូមិភាគបូព៌ា គឺជាអនុ ប៉ុន្តែតាសំត្រូវបានកម្ទេចនៅពេលនោះ"]។ ឯកសារ D114/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.៣០ ["សៈ យើងចង់បង្ហាញឱ្យលោកមើលឯកសារមកពីមន្ទីរទួលស្លែង ស-២១ មួយទៀត D1.3.5.9 ជាភាសាខ្មែរ ERN KH 00161779។ ឈ្មោះឯកសារ កម្លាំងពួកក្បត់នៅអង្គភាព១៦៤ និង១៥២ តើលោកយល់យ៉ាងណាដែរចំពោះឯកសារនេះ? ឆ.៣០: ខ្ញុំស្គាល់មនុស្សនៅលេខរៀងទី១ គឺឈ្មោះ កេត សំ និងឈ្មោះនៅលេខរៀងទី១២ ឈ្មោះឌឹម (គុណ ឌឹម) ដែលអ្នកទាំងពីរនេះជាបុគ្គលដែលគេស្គាល់ច្រើន"]។ ឯកសារ D114/219 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សន ជួន ឆ.១៦,២៣ ["(ទាហាននៅភូមិភាគបូព៌ា ១៦៤នៅរស់): "បន្ទាប់ពីកងទ័ពពីបូព៌ាបញ្ចូលតែមួយ និងរួមរស់ជាមួយគ្នាបានរយៈពេល៣ខែ ក៏លែងទុកចិត្តគ្នាវិញ។ ក្រោយមកទៀតគេចាប់សង្ស័យថា ភូមិភាគបូព៌ាថាខ្មាំងទាំងអស់ [...] នៅដើមឆ្នាំ ១៩៧៧ យើងមកកាប់ព្រៃគុប ជិតស្ទឹងហាវ។ ហ្នឹងមានគ្នាច្រើនណាស់ រាប់រយនាក់ [...] ប្រហែលពីរ បីខែក្រោយមក វាក៏ដកពួកខ្ញុំហ្នឹងថាឡើងទៅរៀនតែខ្ញុំមិនទាន់ទៅទេ ទៅតែពួកខ្ញុំនៅក្នុងកងហ្នឹង។ ដល់ដកទៅរៀន បាត់រហូត អត់ឃើញមកវិញទេ [...] នៅពេលដែលគេដកទៅរៀន បាត់រហូត អត់ឃើញមកវិញទេ [...] ដល់ពេលរៀបចំទៅចំនួនគ្នាបួនប្រាំនាក់ដើម្បីទៅរៀន [...] នៅពេលទៅដល់សាលាមួយ ផ្លូវទៅស្ទឹងហាវនេះ ពួកវាឡើងលើផ្ទះធំមួយកន្លែងហ្នឹង ហើយពួកខ្ញុំចូលខាងក្រោមផ្ទះពួកវាលោតចុះមកក្រោមព័ទ្ធជុំវិញពួកខ្ញុំ ហើយភ្ជង់ចាប់ពួកខ្ញុំ ចាប់ខ្ញុំបានវ៉ៃដំទាត់ធាក់ ហើយចងស្លាបសេក ដល់នាំខ្ញុំចូលទៅគុក [...] ព្រឹកឡើងវាបញ្ចេញម្នាក់ម្តងៗ វ៉ៃសួរចម្លើយ បន្ទាប់មកពេលព្រឹកវាដាក់ច្រវាក់ឱ្យធ្វើការ ដាក់ច្រវ៉ាក់ឱ្យធ្វើការ ដាក់ច្រវ៉ាក់កជើងមកចង្កេះ ឱ្យលោតៗ ចេញមកដាំដំណាំ បន្ទាប់ពីមួយអាទិត្យ ឬ១០ថ្ងៃ ក៏ចាប់ផ្តើមសាថ្មី វ៉ៃសួរចម្លើយម្តងទៀត [...] ឆ.២៣ [...] ពួកគេបាន

117. នៅពេញឆ្នាំ ១៩៧៧ សុន សេន ស្នើមាសមុត ឲ្យពិនិត្យចម្លើយសារភាព ដែលស្ថនៅស-២១ ថា តើ យុទ្ធជនកងពល ១៦៤ ដែលមានឈ្មោះឆ្លើយដាក់នោះ ជាជនក្បត់ ឬយ៉ាងណា។ ចម្លើយសារភាពពីររបស់អ្នកទោសស-២១ មានចំណារសុន សេន ដែលបង្ហាញថា សំណើជាក់លាក់នានាបានស្នើឲ្យ មាស មុត ស៊ើបអង្កេតបន្ថែម។ ក្រោយថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ១៩៧៨ សុន សេន លើកឡើងថា គាត់"នឹងហៅសមមិត្តមកពិនិត្យបញ្ហានេះជាមួយគ្នា"[343] ហើយនៅថ្ងៃទី ១០ ខែ

---

សង្ស័យពួកខ្ញុំទាំងអស់ថាពួកបូព៌ាហ្នឹងសុទ្ធតែខ្មាំង"]។ ឯកសារ D54/40 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ែន វី ឆ.២៣-២៤ ["អង្គការថ្នាក់លើនិយាយថា អ្នកតំបន់២២គឺជាពួកក្បត់។ នៅពេលនោះ គេបានចាក់ខ្សែអាត់សំឡេងពីការសារភាពរបស់ឌឹម និងស៊ីម ឲ្យយោធាស្ដាប់ ដើម្បីឲ្យយោធាជឿថា អ្នកទាំងពីរនេះពិតជាក្បត់មែន។ ខ្ញុំស្គាល់សំឡេងគាត់ទាំងពីរនាក់ច្បាស់។ ស: តើអ្នកណាជាអ្នកយកខ្សែអាត់សំឡេងអ្នកទាំងពីរចាក់ឲ្យយោធាស្ដាប់ ហើយចាក់ខ្សែអាត់នោះនៅកន្លែងណា? ឆ.២៤: គឺមេបញ្ជាការបន្ទាប់ពីឌឹម ជាអ្នកចាក់ខ្សែអាត់សារភាពរបស់អ្នកទាំងពីរឲ្យយោធាស្ដាប់។ ខ្សែអាត់បានចាក់ឲ្យយោធាស្ដាប់នៅព្រៃកលៀប"]។ ឯកសារ D59/2/3.14a កិច្ចសម្ភាសន៍ជាមួយ ប៉ាក សុខ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា KH 00958291 ["បន្ទាប់ពីឌឹមបានចាប់ខ្លួន រីឯកូនចៅនៅក្នុងកងពលរបស់គាត់ត្រូវបានជម្លៀសចេញបាត់។ ស: តើពួកគេជម្លៀសយកទៅទីណា? ឆ: ពួកគេជម្លៀសដើម្បីយកទៅសម្លាប់។ ពួកគេសម្លាប់នៅចំណោតរាម។ បន្ទាប់ពីពួកគេសម្លាប់រួច ពួកយកម៉ាស៊ីនត្រាក់ទ័រមកឈូសទៀត"]។ ឯកសារ D54/33.1 កិច្ចសម្ភាសន៍ជាមួយ អ៊ី ឆុង របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ERN EN 01073811, ERN KH 00964200 ["ទាហានចំនួន៧០០នាក់មកពីភាគបូព៌ាត្រូវបានរួមបញ្ចូលជាមួយទ័ពជើងទឹក ហើយក្រោយមក ខ្លះបានរត់គេច ខ្លះទៀតត្រូវបានចាប់ខ្លួន និងខ្លះទៀតត្រូវដកចេញ [...] នៅចុងក្រោយ ក្រុមដែលមកពីភាគបូព៌ាហ្នឹងដកចេញទាំងអស់ [...] តាឌឹមក៏ត្រូវបានដកចេញដែរ [...] ទាំងថ្នាក់លើរហូតដល់ថ្នាក់ក្រោមត្រូវបានដកចេញនៅពេលដែលមានជម្លោះធ្ងន់ធ្ងរពេក"]។

343 ឯកសារ D234/2.1.55 មន្ទីរស-២១ ចម្លើយសារភាពរបស់ ហង់ ឌឿន ហៅឌឹម ERN KH 00162140 ["ចំណារពន្យល់របស់សុន សេន ថ្ងៃទី ០៨ ខែឧសភា ឆ្នាំ ១៩៧៧ ស្ដីពីចម្លើយសារភាពរបស់លេខាអនុកងពល១៦៤: "ទោះបីជាមនុស្សមួយចំនួនគឺជាមនុស្សដែលត្រឹមត្រូវក៏ដោយក៏មួយចំនួនផ្សេងទៀតដែលខ្ញុំស្គាល់គឺមិនមែនទេ។ ខ្ញុំនឹងអញ្ជើញមេបញ្ជាការ មុតដើម្បីពិនិត្យជាមួយគ្នា"]។ ឯកសារ D4.1.766 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ថ្ងៃទី ២១ ខែតុលា ឆ្នាំ២០០៩ ERN KH 00398195 [ការវិភាគលើចំណារពន្យល់របស់សុន សេន ស្ដីពីចម្លើយសារភាពរបស់ ហង់ ឌឿន]។ ឯកសារ D234/2.1.55 មន្ទីរស-២១ ចម្លើយសារភាពរបស់ ហង់ ឌឿន ហៅឌឹម (ថតចម្លងពណ៌) ERN EN 00224085, ERN FR 00235668 [ចំណារពន្យល់របស់សុន សេន ស្ដីពីចម្លើយសារភាពរបស់លេខាអនុកងពល១៦៤: "សូមបងប្រុសមេត្តាជ្រាបថា ចំពោះផែនការគឺវាត្រូវបានធ្វើតាមយ៉ាងរលូន។ ទោះបីជាមនុស្សមួយចំនួនគឺជាមនុស្សដែលត្រឹមត្រូវក៏ដោយក៏មួយចំនួនផ្សេងទៀតដែលខ្ញុំស្គាល់គឺមិនមែនទេ។ ខ្ញុំនឹងអញ្ជើញមេបញ្ជាការ មុតដើម្បីពិនិត្យជាមួយគ្នា។ មនុស្សម្នាក់នេះនឹងជាប់ពាក់ព័ន្ធនឹងអ្នកដទៃ [...] ថ្ងៃទី ០៨ ខែឧសភា ឆ្នាំ ១៩៧៧។ ឯកសារបកប្រែជាភាសាអង់គ្លេសអាចរកឃើញដូចខាងក្រោម៖

កញ្ញា ឆ្នាំ ១៩៧៧ គាត់ ចាត់ឱ្យកម្មាភិបាល "ទាក់ទងសមមិត្តមុត ដើម្បីគាត់អាចចាត់វិធានការណ៍"[344]។ នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៧៧ មាស មុត បញ្ជាក់ថែមទៀតពីភារកិច្ចរបស់គាត់ ក្នុងការសម្លាប់ខ្មាំង នៅក្នុងទូរលេខមួយទៅមន្ទីរ៨៧០។ គាត់លើកឡើងថា កងទ័ពជើងទឹកមានភារកិច្ចបោសសម្អាត "គ្មានស្ទាក់ស្ទើរ" នូវបណ្តាខ្មាំងទាំងអស់របស់កងពល រួមទាំងខ្មាំងផ្ទៃក្នុងផង[345]។

118. មកត្រឹមឆ្នាំ ១៩៧៨ ការបោសសម្អាតកងពល ១៦៤ បានដំណើរការពេញលេញ ដោយកម្មាភិបាលក្រោមបង្គាប់ មាស មុត មានភារកិច្ចពិនិត្យប្រវត្តិរូប ស្វែងរក និងបោសសម្អាតខ្មាំងផ្ទៃក្នុង។ សាក្សី បញ្ជាក់ថា នៅពេញឆ្នាំនោះ យុទ្ធជនត្រូវធ្វើប្រវត្តិរូប[346] អង្គភាពត្រូវរំសាយ[347] បញ្ជាចាប់

---

ឯកសារ D54/97.1 មន្ទីរស-២១ ចម្លើយសារភាពរបស់ ហង់ ឌឿន ហៅ ឌីម ERN EN 01072501 [" សូមបងប្រុសមេត្តាជ្រាបថា ចំពោះផែនការគឺវាត្រូវបានធ្វើតាមយ៉ាងរលូន។ ដូចចំពោះមនុស្សខ្លះគឺវាត្រឹមត្រូវហើយ ប៉ុន្តែចំពោះមនុស្សខ្លះដែលខ្ញុំស្គាល់ គឺវាហាក់បីដូចមិនសមហេតុផល ខ្ញុំនឹងអញ្ជើញមេបញ្ជាការមុតដើម្បីមកស៊ើប...អាចពិនិត្យលើការតបតរបស់ជនប្រឆាំង"]។ កាំង ហ្គិចអ៊ាវ ហៅឌុច បានផ្ទៀងផ្ទាត់ភាពត្រឹមត្រូវសម្រាប់ចំណារពន្យល់នេះលើការសរសេរដោយដៃរបស់សុន សេនៈ ឯកសារ D4.1.766 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ERN KH 00398195 ["ឯកសារដំបូង (ERN 00174375) គឺត្រូវបានចារដោយ សុន សេន ផ្ញើទៅប៉ុលពត។ ខ្ញុំមិនមែនជាម្ចាស់ចំណារនេះទេ (ខ្ញុំមិនប្រើពាក្យថា 'សមមិត្ត មុត' ដោយគិតពីឋានៈ និងអាយុរបស់គាត់ដែលធំនិងច្រើនជាងខ្ញុំ)។ ឯកសារទីពីរ (ERN 00174384) ត្រូវបានចារដោយ សុន សេន លើកលែងតែអក្សរសដែលមានគូសជុំវិញដែលខ្ញុំជាអ្នកសរសេរ ដែលមានន័យថា 'សំងាត់'"]។

344 ឯកសារ D234/2.1.54 មន្ទីរស-២១ ចម្លើយសារភាពរបស់ គុណ ឌឹម ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ១៩៧៧ , ERN EN 00822359, ERN KH 00175293 [កំណត់សម្គាល់របស់សុន សេនៈ "កងពល១៦៤ របស់សមមិត្ត មុត ត្រូវបានលើកឡើង [...] ទាក់ទង សមមិត្ត មុត ដើម្បីឱ្យគាត់ធ្វើការចាត់វិធានការ។ យើងបានធ្វើការកំចាត់អ្នកដែលនៅខាងសមមិត្ត មុត រួចរាល់ហើយ"]។ សូមមើលផងដែរ ភស្តុតាងគាត់បានទទួល និងពិភាក្សាអំពីមាតិកានៃការសារភាពរបស់បក្សពួកឌឹមនៅកងពល១៦៤ (ដែលមកពីផ្នែកទី២២)ៈ ឯកសារ D234/2.1.54 មន្ទីរស-២១ ចម្លើយសារភាពរបស់ គុណ ឌឹម ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ១៩៧៧ , KH 00175293 [កំណត់សម្គាល់របស់សុន សេនៈ "កងពល១៦៤ របស់សមមិត្ត មុត ត្រូវបានលើកឡើង [...] ទាក់ទង សមមិត្ត មុត ដើម្បីឱ្យគាត់ធ្វើការចាត់វិធានការ។ យើងបានធ្វើការកំចាត់អ្នកដែលនៅខាងសមមិត្ត មុត រួចរាល់ហើយ"]។

345 ឯកសារ D1.3.34.60 ទូរលេខ០០ ពីមុត (មាស មុត) ទៅការិយាល័យ ៨៧០ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៧៧ ERN KH 00001325។

346 ឯកសារ D114/83 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ នាង ឆ.៣៤-៣៥ ["អ៊ំរបស់ខ្ញុំម្នាក់ធ្លាប់ធ្វើជាទាហាន លន់ នល់ [...] សំណាងល្អ គេពុំបានដឹងថាខ្ញុំជាប់សាច់ញាតិនឹងគាត់ទេ។ ខ្ញុំកាន់តែបារម្ភខ្លាំងនៅចន្លោះឆ្នាំ ១៩៧៧-១៩៧៨ ដោយសារគេបានឱ្យខ្ញុំធ្វើប្រវត្តិរូប ហើយយកទៅស្រាវជ្រាវដល់ភូមិកំណើតតែម្តង។ ក្នុងគ្រាមួយ ខ្ញុំបានជួប

មនុស្ស[348] ហើយបន្តធ្វើទុក្ខបុកម្នេញយុទ្ធជនភូមិភាគបូព៌ា ដល់បានសម្លាប់យុទ្ធជនទាំងនោះស្ទើរទាំងអស់[349] ខណៈដែល "ការបោសសម្អាតគឺត្រូវបានធ្វើឡើងយ៉ាងខ្លាំង"[350]។ នៅក្នុងដំណើរការ

---

អ្នកភូមិជាមួយគ្នាម្នាក់ឈ្មោះ នន នៅជិតផ្សារលើកំពង់សោម។ កាលនោះគាត់ហាក់ដូចជាអ្នកគ្រប់គ្រង ឬកាន់កាប់នៅគុកទឹកសាប។ ដោយសារគាត់មានសាច់ញាតិធ្លាប់ធ្វើការនៅក្នុងសម័យលន់ នល់ ដែរ គាត់ក៏មានការបារម្ភដូចខ្ញុំដែរ។ គាត់ប្រាប់ខ្ញុំថា ប្រសិនបើគេមកចាប់គាត់ គឺគាត់មិនឱ្យចាប់ទេ គាត់សុខចិត្តរត់ ហើយឱ្យគេបាញ់ចុះ [...] ខ្ញុំបានដឹងថា មុនវៀតណាមចូលប្រហែល១ខែ គេបានមករកចាប់គាត់មែន តែគាត់បានរត់ ហើយគេក៏បានបាញ់គាត់ស្លាប់តែម្តងទៅ [...] ឆ.៣៥: ក្នុងជំនាន់នេះ ប្រសិនបើអ្នកជាប់ពាក់ព័ន្ធទៅនឹងរបបមុន អ្នកនោះនឹងទទួលការចាប់អារម្មណ៍ខ្លាំង។ របបខ្មែរក្រហម គឺគេចម្រាញ់យកតែអ្នកល្អៗទេ អ្នកផ្សេងត្រូវតែទៅហើយ។ ប្រសិនបើអ្នកពាក់ព័ន្ធជាប់ទៅនឹងរបបមុន ធ្វើការងារធម្មតាដូចគេដូចឯង ដោយមិនត្អូញត្អែរ ឬក៏ប្រឆាំងអ្វីនោះ គឺអ្នកនោះមិនមានបញ្ហាអ្វីទេ។ ប៉ុន្តែប្រសិនបើអ្នកនោះ ត្អូញត្អែរ ឬប្រឆាំងរបបកាលនោះ នឹងចាត់ទុកអ្នកនោះថាប្រឆាំងនឹងរបបខ្លួនហើយ។ សៈ ចំពោះអ្នកដែលលោកស្រី រៀបរាប់ខាងលើ តើនឹងមានផលវិបាកអ្វីខ្លះដល់ពួកគេ? ឆ.៣៦: គឺត្រូវចាប់ខ្លួនសួរចម្លើយ និងទទួលការអប់រំ"]។

347 ឯកសារ D114/83 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ ប៊ុនហាក់ ឆ១០១-១០២ [សាក្សីត្រូវបានគេបញ្ឈរជើងពីបញ្ហាការវរសេនាធំ១៤០នៅចុងខែមិថុនា ឆ្នាំ១៩៧៨ ដោយបង្ខំនិងគំរាម ឱ្យធ្វើការ ពីព្រោះប្អូនថ្លៃរបស់គាត់ត្រូវបានចាប់ខ្លួននៅមន្ទីរពេទ្យកងពល១៦៤ ហើយត្រូវបានគេស្រាវជ្រាវរកញាតិសណ្តាន]។ ឯកសារ D114/121 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន ផ ឆ.៤២ ["ខ្ញុំបានគេបញ្ជូនឱ្យទៅវាយថ្មនៅស្ទឹងហាវនៅខែមករា ឬកុម្ភៈ ឆ្នាំ១៩៧៨។ ខ្ញុំចង់និយាយថាកងរបស់ខ្ញុំទាំងអស់គ្នាដែលត្រូវរំសាយ និងឱ្យធ្វើការនៅកងកេង ត្រូវបានគេបញ្ជូនទៅនៅពេលនោះ"]។

348 ឯកសារ D54/111 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ភីន ឆ.១៧-១៩, ២៣-២៤ ["សៈ សូមលោករៀបរាប់ដោយសង្ខេបអំពីព្រឹត្តិការណ៍នៃការចាប់ខ្លួនរបស់លោកនៅពេលនោះ ឧទាហរណ៍ថាតើគេចាប់លោកនៅពេលណា? តើការចាប់ខ្លួនលោកនោះធ្វើឡើងដោយរបៀបណា? មូលហេតុអ្វីបានជាលោកត្រូវចាប់ខ្លួន? តើអ្នកណាជាអ្នកបញ្ជាឱ្យចាប់ខ្លួនលោក? តើគេយកលោកទៅកន្លែងណា? ហើយគេធ្វើយ៉ាងម៉េចខ្លះចំពោះលោក? តើអ្នកណាខ្លះត្រូវបានចាប់ខ្លួនជាមួយលោកនៅពេលនោះ? ឆ.១៧: ខ្ញុំត្រូវបានគេចាប់ខ្លួនអាចនៅចុងឆ្នាំ១៩៧៧ ឬក៏ដើមឆ្នាំ១៩៧៨។ ខ្ញុំមិនចាំកាលបរិច្ឆេទពិតប្រាកដទេ។ នៅពេលនោះ អ្នកបើកឡានម្នាក់បើកឡានមកមុខផ្ទះរបស់ខ្ញុំ ពីកន្លែងតាមុត។ គាត់បានហៅខ្ញុំចេញពីផ្ទះហើយបង្ហាញលិខិតមួយមកខ្ញុំថា "ខ្ញុំត្រូវបានចាត់តាំងឱ្យទៅធ្វើការនៅកន្លែងថ្មី"។ អ្នកបើកឡាននោះមកជាមួយឡានតូចទ្វារបួនពណ៌ស។ ខ្ញុំនឹងប្រពន្ធរបស់ខ្ញុំបានរៀបចំឥវ៉ាន់ ហើយឡើងជិះឡាន ដែលមានយុវជន៣នាក់ និងនារីម្នាក់នៅក្នុងឡាននោះជាស្រេច។ យើងបានចេញដំណើរទៅ ហើយអ្នកបើកឡានប្រាប់ខ្ញុំថាទៅភ្នំពេញ។ ពេលមកដល់ភ្នំពេញដំបូង យើងមកដល់កន្លែង ក-៧ នៅមាត់ទន្លេ នៅជិតវាំង។ នៅពេលដែលខ្ញុំសួរអ្នកធ្វើការនៅទីនោះ ថាខ្ញុំត្រូវធ្វើអ្វីទៀត? គេបានប្រាប់ខ្ញុំថា គេនៅចាំសេចក្តីសម្រេចពីមន្ទីរ៨៧០សិន។ ខ្ញុំមិនបានដឹងថារូបខ្ញុំនេះកំពុងតែត្រូវបានគេចាប់ខ្លួននោះទេ រហូតមកដល់វត្តជ័យឧត្តម ពេលដែលគេដករបស់របរ និងថ្នាំពេទ្យរបស់ខ្ញុំចេញ ហើយសួរចម្លើយខ្ញុំ ទើបខ្ញុំដឹងថា ខ្ញុំកំពុងតែត្រូវបានគេចាប់ខ្លួន។ បន្ទាប់មកគេបំបែកខ្ញុំចេញពីប្រពន្ធរបស់ខ្ញុំ។ មួយរយៈខ្លីក្រោយមក

មានក្មេងស្រីម្នាក់មកហៅខ្ញុំឱ្យទៅជួបយោធាទាំង២នាក់នោះ ដែលនៅរងចាំខ្ញុំ។ នៅពេលខ្ញុំបានជួបយោធាពីរនាក់នោះ យោធានោះបាននិយាយមកសុំទោសចំពោះខ្ញុំ ដោយនិយាយថាមកនាំខ្ញុំទៅមន្ទីរក-៧វិញ។ នៅពេលដែលយើងទៅដល់មន្ទីរក-៧ ខ្ញុំបានជួបអ៊ំ ខៀវ សំផន គាត់បាននិយាយសុំទោសខ្ញុំថា រឿងរ៉ាវទាំងអស់កើតឡើងដោយសារការច្រឡំឈ្មោះ និងអត្តសញ្ញាណ។ នៅពេលនោះ ខ្ញុំបានប្រាប់អ៊ំ ខៀវ សំផន ថាប្រសិនបើខ្ញុំមានកំហុស ហេតុអ្វីមិនសម្លាប់ខ្ញុំនៅកំពង់សោមទៅ ចាំបាច់ដឹកឱ្យខាតសាំងមកទីនេះដើម្បីអ្វី? អ៊ំ ខៀវ សំផននៅតែសុំទោសខ្ញុំដដែល។ បន្ទាប់មកទើបគេបានដឹកយើងត្រឡប់ទៅកំពង់សោមវិញ។ តាមខ្ញុំដឹង សំបុត្រឱ្យចាប់ខ្លួនខ្ញុំនោះគឺចេញពីតាមុតដែលជាមេបញ្ជាការកងពល១៦៤។ សៈ ម៉េចបានជាលោកដឹងថា ការចាប់ចងនេះចេញពីតាមុត ដែលជាមេបញ្ជាការកងពល? ឆ.១៨: ពីព្រោះអ្នកបើកឡានហ្នឹងគឺមកកន្លែងតាមុត។ ខ្ញុំមិនបានចាប់អារម្មណ៍ថាអ្នកណាជាអ្នកចុះហត្ថលេខានៅលើសំបុត្រនោះទេ។ សៈ ហេតុអ្វីបានជាលោកដឹងថា ខៀវ សំផន ពេលដែលលោកជួបនៅមន្ទីរក-៧? ឆ.១៩: អ្នកធ្វើការនៅមន្ទីរក-៧ បានប្រាប់ខ្ញុំ [...] សៈ តើលោកបានជួបជាមួយ មាស មុត ហើយនិយាយជាមួយគាត់អំពីព្រឹត្តិការណ៍នោះដែរឬទេ? ឆ២៣: បាទ ខ្ញុំបាននិយាយជាមួយគាត់ នៅពេលដែលខ្ញុំជួបគាត់នៅដើមឆ្នាំ១៩៨០នៅព្រំដែន។ សៈ តើ តាមុតមាននិយាយថាម៉េចចំពោះលោកនោះពេលនោះ? ឆ.២៤: តាមុត បាននិយាយលេងសើចជាមួយខ្ញុំថា គាត់ចេញសំបុត្រនោះ ចាត់តាំងឱ្យខ្ញុំទៅធ្វើការនៅកន្លែងថ្មី ហេតុអ្វីពួកនោះធ្វើអ៊ីចឹងទៅលើឯង"]។

349 ក្នុងចំណោមទាហានដឹកម្រដែលនៅរស់គឺ សាន ជួន (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯកសារ D114/219 និង D114/220) និងសាក្សីជាទាហាន ប៉ាក សុខ បានចាំថា ឈានគឺបានបានបញ្ចប់ការធ្វើការដោយបង្ខំនៅក្នុងការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង និងបានគ្រប់គ្រងដើម្បីរស់រានក្នុងស្ថានភាពដ៏លំបាក រួមទាំងការសម្លាប់អតីតទាហាននៅតំបន់បូព៌ានៅទីនោះ: សូមមើល ឯកសារ D234/2.1.92 ប៉ាក សុខ ប្រតិចារិកថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០១៦ 10.36.49-10.39.53។ សូមមើលផងដែរ ឯកសារ D54/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តេង សារីម ឆ.១៩ [បានពន្យល់ដោយផ្ទាល់ថាគាត់មិនស្គាល់នរណាម្នាក់ពីអតីតកងវរសេនាតូចទី១៥២ ដែលបានរួចជីវិតហើយត្រឡប់មកពីកំពង់សោមទេ ប៉ុន្តែបានឮពីអតីតអភិបាលស្រុកអូរាំងឳអំពីមនុស្សពីរនាក់ឈ្មោះសារឿននិងយ៉ាតបានរួចរស់ជីវិត]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារិកថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ 14.23.54-14.26.40 ["តាឌឹម [...] បានចាប់ខ្លួន បាត់ទៅ។ ពេលដែលចាប់ខ្លួនទៅ កងទ័ព កងយោធាទាំងអស់ជាកងយុទ្ធភូមិភាគបូព៌ានោះ ឃើញថា ឃើញចាប់ខ្លួនជាបន្តបន្ទាប់រហូតដល់អស់រលីងនៅកំពង់សោម កងភូមិភាគបូព៌ាអត់មាននៅសល់ទេ ក្រោមមកចាប់ទាំងអស់ ចាប់បាត់អស់។ ខ្ញុំក៏អត់ដែលឃើញអីទាំងអស់ មិនដឹងចាប់យកទៅណា ទៅណីទេ អត់ឃើញទេ [...] ក្រោយពីតាឌឹម គេចាប់ខ្លួនបាត់ហើយ ក្រោយមកចាប់យោធាៗដែលកងពលរបស់គាត់ជាវរៈ មួយវរសេនាធំនោះ។ ដោយសារដែលគេចាប់តាឌឹមបាត់ទៅ គឺតាឌឹមនោះគឺគាត់មានចម្លើយយ៉ាងម៉េចទេ ឬដឹងចម្លើយយ៉ាងម៉េចអីយ៉ាងម៉េចទេ ហើយសាច់ទ័ពរបស់គាត់ដែលរស់នៅក្នុងកំពង់សោមនោះសុទ្ធតែជាប់និន្នាការនយោបាយចម្លើយពីរបស់តាឌឹមទាំងអស់ ក្រោយមកបានគេចាប់ដកចេញទាំងអស់ ប៉ុនមិនដឹងដកចេញទៅកន្លែងណាទេ [...] ខ្ញុំមិនឃើញពួកគេទៀតទេ]។ 14.26.40 [ទាហាននៅក្រោមបង្គាប់របស់តាឌឹមសុទ្ធតែជាប់និន្នាការនយោបាយរបស់គាត់ទាំងអស់។ គេបានចាប់មេយកទៅហើយ គេសង្ស័យថាទ័ពទាំងអស់ដែលវរសេនាធំដែលគាត់មកពីភូមិភាគបូព៌ានោះជា... គេលែងទុកចិត្តហើយ គេដកចេញ មិនដឹងដកចេញទៅកន្លែងណាទេ អត់ដែលដឹង មិនដឹងចាប់ទៅណា"]។ ឯកសារ D59/2/3.14a បទសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ KH 00958291 [" បន្ទាប់ពីឌឹមបានចាប់

ខ្លួន និងកូនចៅរបស់គាត់ទាំងអស់នៅក្នុងកងពលត្រូវបានគេយកទៅ។ សៈ តើគេយកពួកគេទៅណា? ឆៈ ពួកគេត្រូវគេយកទៅសម្លាប់នៅចំណោតរៀម។ បន្ទាប់ពីសម្លាប់ ពួកគេបានយកអាត្រាក់មកឈូស"]។ ការបកប្រែផ្សេងទៀតនៅក្នុងការសម្ភាសន៍ដូចគ្នា (ជាមួយកំណែតម្រូវដោយ ប៉ាក សុខ) អាចយកបានតាមៈ ឯកសារ D54/24.1 បទសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ KH 00955511-12 ["បន្ទាប់ពីឌីមបានចាប់ខ្លួន និងកូនចៅរបស់គាត់ទាំងអស់នៅក្នុងកងពលត្រូវបានគេយកទៅ។ សៈ តើគេយកពួកគេទៅណា? ឆៈ ពួកគេត្រូវគេយកទៅសម្លាប់នៅចំណោតរៀម។ បន្ទាប់ពីសម្លាប់ ពួកគេបានយកត្រាក់ទ័រមកឈូសសាកសព"]។ ឯកសារ D54/26 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ឆ១០, ៣៣, ៣៥ ["មេបញ្ជាការឌីមរបស់យើងត្រូវបានចាប់ខ្លួនបន្ទាប់ពីត្រូវចោទថាក្បត់ជាតិ ក្រោយមកកូនចៅរបស់គាត់ទាំងអស់នៅក្នុងកងពលត្រូវបានគេចាប់។ នៅកងកេង ពួកគេបានឱ្យយើងធ្វើស្រែដោយប្រើកន្ទុយ [...] ដំបូងពួកគេមកហៅយើងដោយប្រើលេសដែលអង្គការបានហៅយើងអោយទៅអប់រំ [...] មនុស្សមួយចំនួនក៏បានបាត់ខ្លួននៅពេលនោះដែរ ពួកគេបានបាត់ខ្លួនហើយមិនដែលត្រឡប់មកវិញ ហើយគ្មាននរណាម្នាក់ហ៊ានសួរឬឆ្ងល់អំពីអ្វីនោះទេ។ នៅពេលនោះមានតែអ្នកក្រោមបង្គាប់ថ្នាក់ក្រោមប៉ុណ្ណោះដែលនៅរស់គឺមេដឹកនាំទាំងអស់បានបាត់ខ្លួនហើយមិនដែលត្រឡប់មកវិញ [...] ឆ៣៣ៈ បន្ទាប់ពីការចាប់ ឌីមទៅ យោធាភូមិភាគបូព៌ាទាំងនោះត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ដែរ [...] ខ្ញុំគិតថាយោធានៅភូមិភាគបូព៌ាដែលត្រូវចាប់ខ្លួនអាចត្រូវបានគេយកទៅសម្លាប់នៅ [ចំណោតរាម] ប៉ុន្តែខ្ញុំមិនប្រាកដទេ [...] ឆ៣៥ៈ ខ្ញុំបានដឹងអំពីការបោសសម្អាតយោធាភូមិភាគបូព៌ា [...] គេបានប្រកាសថាមួយកងវរសេនាតូចមានយោធា៥០នាក់ក៏មិនមានបញ្ហាអ្វីដែរ ដរាបយោធាទាំងនោះជាយោធាល្អ។ យោងទៅតាមការចងចាំរបស់ខ្ញុំ ការបោសសម្អាតយោធាភូមិភាគបូព៌ាចាប់ផ្តើមក្នុងឆ្នាំ១៩៧៦ មុនពេលគេបញ្ជូនខ្ញុំទៅកងវរសេនាធំ១៤០ មុនឆ្នាំ១៧៧ [...] ក្នុងពេលនោះ គេចាប់មេដឹកនាំមុន រួចហើយទើបគេចាប់យោធាតាមក្រោយ"]។ ឯកសារ D114/219 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សន ជួន ឆ១៦, ២៣, ៣៨ [ទាហានដែលនៅរស់រាននៅកងពល១៦៤ ភូមិភាគបូព៌ា " ក្រោយមកទៀត គឺគេចាប់សង្ស័យថា ភូមិភាគបូព៌ាថាខ្មាំងទាំងអស់ [...] នៅឆ្នាំ១៩៧៧ យកយើងមកកាប់ព្រៃគុប ជីតស្ទឹងហាវ។ ហ្នឹងមានគ្នាច្រើនណាស់ រាប់រយនាក់ [...] ពីរ ឬបីខែក្រោយមកពួកគេដកក្រុមរបស់ខ្ញុំចេញ ហើយយកពួកយើងទៅអប់រំ [...] ពួកខ្ញុំចូលខាងក្រោមផ្ទះ ពួកវាលោតចុះមកក្រោមព័ទ្ធជុំវិញពួកខ្ញុំ ហើយភ្ជង់ ចាប់ពួកខ្ញុំ [...] ពួកគេបានយកអ្នកទោសចេញមកក្រៅដើម្បីសួរចម្លើយម្តងម្នាក់ នៅពេលព្រឹកបានឱ្យពួកគេធ្វើការទាមងជាប់ច្រវ៉ាក់ [...] ឆ២៣ៈ ពួកគេសង្ស័យពួកយើងទាំងអស់នៅភូមិភាគបូព៌ាថាជាជនក្បត់ [...] ឆ៣៨ៈ [...] សេង និង [...] ឈើ។ ពួកគេបានអៀសខ្លួនប៉ុន្តែត្រូវបានចាប់ខ្លួននិងត្រូវបានគេដាក់នៅក្នុងគុកហើយបន្ទាប់មកត្រូវគេវាយរហូតដល់ស្លាប់"]។ ឯកសារ D114/209 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង សេង ឆ.៤៦ និងឆ.៥២ ["ខ្ញុំគ្រាន់តែដឹងថាអង្គការហៅទៅប្រជុំ ឬក៏ទៅរៀនសូត្រ គឺទៅបាត់រហូត [...]។ ឆ.៥២ៈ ខ្លបខ្លាចដោយឃើញបាត់ សម័យនោះតឹងរ៉ឹង។ ទាំងអស់នេះហើយដែលធ្វើឱ្យខ្ញុំខ្លបខ្លាច"]។ ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដេត ប៊ុណ្ណា ឆ.១៩ ["វរៈសេនាតូចលេខ២១ ស្ថិតនៅបឹបុសខាងកើត។ កងនេះស្ថិតក្រោមបញ្ជាការរបស់តាខេង។ នៅក្នុងកងនេះ មានមនុស្សជាង២០០នាក់ ដែលសុទ្ធតែជាអតីតយោធាមកពីភូមិភាគបូព៌ា។ នៅពេលដែលមានអ្នកណាម្នាក់ នៅក្នុងកងសមាសភាពមិនល្អទាំងនេះធ្វើខុស គេនឹងត្រូវបញ្ជូនទៅឃុំខ្លួននៅទឹកសាប។ ពេលគេនៅក្នុងមន្ទីរឃុំឃាំងទឹកសាប ពួកអ្នកទោសទាំងនេះត្រូវបានគេដាក់ឱ្យធ្វើការនៅត្រើយខាងកើតស្ទឹង។ ចំណែកពួកខ្ញុំ ដែលនៅក្នុងកងទាំងបីនេះ ត្រូវបានគេដាក់ឱ្យធ្វើការនៅត្រើយខាងលិចស្ទឹង។ ឯកសារ

នេះ មាស មុត បានបញ្ជាចាប់ និងសម្លាប់សមាជិកគណៈកម្មាធិការក្រុងកំពង់សោម ឈ្មោះ ឡូញ ដែលបាននៅរស់រួចផុតពីការប៉ុនប៉ងសម្លាប់នោះ[351]។

119. ជាលទ្ធផលនៃការបោសសម្អាតមនុស្សមកពីកងពល ១៦៤ នៅមន្ទីរសន្តិសុខ និងការដ្ឋានក្រោមការ គ្រប់គ្រងរបស់ មាស មុត នោះ យុទ្ធជនកងពល១៦៤ រាប់ពាន់នាក់ បានជាប់មន្ទីរឃុំឃាំង និងបង្ខំធ្វើការជាទាសករ រាប់រយនាក់បានសម្លាប់ ឬបាត់ខ្លួនតែម្តង ក្រោយពេលចាប់[352]។ ក្នុងចំណោម យុទ្ធជនដែលបានចាប់ខ្លួន មាស មុត បានបញ្ជូនចំនួន ៦៧ នាក់ ទៅ ស-២១ មន្ទីរសន្តិ

---

D2/16 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ឆ.២១ ["សៈ លោកធ្លាប់បានប្រាប់ពីរថ្ងៃមុនថា មិនមែនកម្លាំងបូព៌ាទាំងអស់ត្រូវបាត់ខ្លួនទាំងអស់គ្នាទេ ប៉ុន្តែ មានកម្លាំងខ្លះត្រូវបានដកយកទៅធ្វើស្រែ តើពិតមែនឬទេ? ឆ.២១ ["បាទ ពិតមែនហើយ ខ្ញុំដឹងថាកម្លាំងមួយចំនួនត្រូវបានដកយកទៅធ្វើស្រែនៅមុំព្រលានយន្តហោះកងកេង។ ឯកសារ D54/33.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ អ៊ី ឆុន (អ៊ឹង ឆុង) ERN EN 01073811, ERN KH 00964200 ["ក្រោយមក រត់ទៅវិញរួចខ្លះ ហើយគេចាប់មកវិញយកទៅលុតដំអីណា [...] នៅចុងបញ្ចប់ ពួកមកពីភូមិភាគបូព៌ាហ្នឹង ដកចេញទាំងអស់ អត់មានឱ្យនៅទេ]។ ERN EN 01073818, ERN KH 00964206 ["សៈ តាឌឹម និងកូនចៅគាត់ ៧០០នាក់ជាងហ្នឹង នៅឆ្នាំណាដែលខ្ចាតខ្ចាយ គេដកទៅវិញហើយគេយកទៅលុតដំហ្នឹង? មកនៅបានយូរទេ? [...] ឆៈ មកបានយូរដែរហ្នឹង ហើយអ្នកខ្លះរត់ គេចាប់មកវិញ ខ្ញុំមិនច្បាស់តេ តែភាគច្រើនគេវៃចោលហើយ។ សៈ វៃចោល? ឆៈ បាទ! ]

350 ឯកសារ D54/8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ឆ.១២-១៣ , ១៥, ១៨ ["នៅពេលនោះ គេចាប់ពួកមកពីបូព៌ាដែលនៅតាមកងនានាដែលនៅក្នុងកងពល [...] ឆ.១៣: គេយកឌឹម និងពួកបូព៌ាងទៃទៀតទៅ [...] សៈ តើលោកនៅចាំទេ ថាឆ្នាំណាដែលគេចាប់ពួកបូព៌ានៅក្នុងកងពល ១៦៤? ឆ.១៥: [...] វាប្រហែលជានៅឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨។ ការចាប់ពួកបូព៌ាធ្វើឡើងក្នុងពេលជាមួយគ្នានឹងការកើតមានទំនាស់រវាងពួកបូព៌ា និងកងទ័ពវៀតណាមនៅតាមព្រំដែន [...] សៈ នៅក្នុងកងវរសេនាធំ១៤០របស់លោក តើមានពួកបូព៌ាប៉ុន្មាននាក់ត្រូវបានដកចេញ និងប៉ុន្មាននាក់ត្រូវបានចាប់ខ្លួន? ឆ.១៨: ខ្ញុំមិនដឹងពីចំនួនទាំងអស់ទេ។ ការបោសសំអាត គឺត្រូវបានធ្វើឡើងយ៉ាងខ្លាំង។ មិនមែនតែមេបញ្ជាការមកពីបូព៌ាទេដែលត្រូវបានចាប់ខ្លួន សូម្បីតែយោធាដទៃក្នុងកងពលក៏ត្រូវបានគេដកឬចាប់ខ្លួន"]។

351 ឯកសារ D54/56 របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត មាស វឿន EN 01001515 ["មាស វឿន បាននិយាយថា រួចពីការចាប់ខ្លួន/ការប៉ុនប៉ងធ្វើឃាតផ្តួចផ្តើម/បញ្ជាដោយ មាស មុត ក្នុងចុងឆ្នាំ១៩៧៨ ដើមឆ្នាំ១៩៧៩"]។

352 សូមមើលជំពូក ៨.ក ការសំរិតសំរាំងនៅក្នុងកងពល ១៦៤។ ជំពូក ៨.គ មន្ទីរសន្តិសុខរបស់កងពលធំ ១៦៤ ។ ជំពូក ៨.ង ការដ្ឋានស្ទឹងហាវ។ ជំពូក ៨.ច ការដ្ឋានធ្វើការនៅរាម។

សុខ ដែលយុទ្ធជនទាំងនោះ ត្រូវឃុំឃាំង ដាក់ក្នុងលក្ខខណ្ឌរស់នៅអមនុស្សធម៌ ធ្វើទារុណកម្ម និង សម្លាប់[353]។

*គ) កងពល១១៧ និង តំបន់៥០៥*

120. មាស មុត បានរួមចំណែកថែមទៀត ក្នុងការធ្វើទុក្ខបុកម្នេញកងទ័ពបដិវត្តន៍កម្ពុជា និងកម្មាភិបាលផ្សេងៗទៀត តាមរយៈការចាត់ចែងដោយផ្ទាល់ការបោសសម្អាតយុទ្ធជន និងកម្មាភិបាល កងពល ១១៧ និងតំបន់ ៥០៥ នៅចុងឆ្នាំ១៩៧៨។ ជាពិសេស ការចូលរួមរបស់គាត់ រួមមាន ការស្វែងរកចាប់ខ្លួន និងឃុំឃាំងកម្មាភិបាលយោធា និងស៊ីវិល ក្នុងតំបន់៥០៥ ហើយបន្ទាប់មក សម្លាប់កម្មាភិបាលទាំងនោះ នៅស-២១ បន្ទាប់ពីបានបញ្ជូនមកដល់ភ្នំពេញ។

121. មាស មុត មានអំណាចលើកងពល១១៧ ក្រោយពេលបានឡើងជាអនុរបស់ សុន សេន នៅក្នុងអគ្គសេនាធិការ ក្នុងឆ្នាំ១៩៧៨[354]។ មកត្រឹមខែតុលាឆ្នាំនោះ បញ្ជាផ្ទាល់ និងគ្រប់គ្រងកម្លាំងកងពល ១១៧ ទទួលរបាយការណ៍ និងបញ្ជាទ័ពដែលកំពុងប្រយុទ្ធតាមព្រំដែនវៀតណាម[355]។

---

353 សូមមើលឧបសម្ព័ន្ធ ឃ.១ ។ សូមមើលផងដែរ ជំពូក ៨.ឃ មន្ទីរសន្តិសុខ ស-២១ -៥ ឧក្រិដ្ឋកម្ម-សកម្មភាពអមនុស្សធម៌ផ្សេងទៀត។

354 សូមមើលជំពូក ៣.២ តួនាទីរបស់មាស មុត ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ- អគ្គលេខាធិការរងនៃអគ្គសេនាធិការបុគ្គលិក។ ឯកសារ ជំពូក ៣.២ តួនាទីរបស់មាស មុតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ -ការគ្រប់គ្រងដ៏មានប្រសិទ្ធភាព៖ សូមមើលផងដែរ ឯកសារ D114/297.1.23 ម៉ឹង វៀត ប្រតិចារឹក ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១៦ 13.48.51-13.50.21 ["ខ្ញុំនៅក្នុងកងពល១១៧ និងពូមាស មុតជាអគ្គសេនាធិការរង។ កន្លងទៅកម្ពុជាប្រជាធិបតេយ្យមាន សុន សេនជាអគ្គសេនាធិការ មាស មុតជាអគ្គសេនាធិការរង និងស៊ូ ម៉េត ជាជើងអាកាស អគ្គសេនាធិការរង"]។ សូមមើលបន្ថែម ឯកសារ D54/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.២២-២៣ ["តាមដែលខ្ញុំដឹង មាស មុតជាអគ្គសេនាធិការរងរបស់កងទ័ព មានន័យថា អនុរបស់ សុន សេន [...] ឆ.២៣: សុន សេនជាមេបញ្ជាការអគ្គសេនធិការទទួលខុសត្រូវរួម និងកងថ្មើរជើង [...] រាល់ទំនាក់ទំនងតាមវិទ្យុទាក់ទងនឹងសារទូរលេខគឺត្រូវតែឆ្លងកាត់អគ្គសេនាធិការ"]។ ឯកសារ D114/297.1.27 សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៦ 13.54.58-13.57.43, 13.59.45-14.00.52 ["ពីមុន ស៊ូ ម៉េត ជាអគ្គសេនាធិការកងពល១ ហើយមាស មុតមកពីកងពល៣។ សុន សេន ជារដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវបានផ្ទេរទៅកាន់កន្លែងមួយផ្សេងទៀត។ ពួកគេទាំងពីរនាក់គឺទទួលខុសត្រូវលើការងាររបស់ក្រសួងការពារជាតិ ហើយមាស មុត បានមកកាន់កាប់កន្លែងរបស់ពួកយើង"]។ ឯកសារ D114/169 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.២៥ ["នៅពេលនោះ មាស មុតគាត់កាន់កងទឹក កងទ័ពជើងទឹកផង មកកាន់គេហៅអនុក្រសួងការពារជាតិ ជំនួស សុន សេន ប៉ុន្តែមេត គេប្រធាន មុត អនុ ហើយចុះមករៀបចំ

តំបន់ក្រចេះ"]។ ឯកសារ D59/1/1.8a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រំ សារ៉ាត់ ERN KH 00926341 [ នៅខែកញ្ញា ១៩៧៨ មាសមុតបានទៅភ្នំពេញ។ មាសមុតគឺជាមេបញ្ជាការរងរងនៃអគ្គសេនាធិការដែលបានតំឡើងឋានៈនេះនៅចុងឆ្នាំ ១៩៧៨]។ ឯកសារ D54/28.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ លាត ឡាន (ណាំ ឡន) ERN KH 00926341 [ តាមុតជាកូនចៅរបស់សុន សេន នៅអគ្គសេនាធិការ និងនៅភ្នំពេញ]។

355 ឯកសារ D114/297.1.23 ម៉ឹង វេត ប្រតិចារឹក ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១៦ 13.46.24-13.48.51 ["សេចក្តីសម្រេចអ្វីៗ ហើយបញ្ហាយោធាគឺនៅលើមុត។ ខាងខ្ញុំបញ្ជូនតែទៅដូចថា ឥឡូវបើអ៊ំ ដូចអ៊ំមុតគាត់ទទួលខាងច្រកជួរមុខ ដូចទៅក្រចេះ សារត្រូវបញ្ជូនទៅឱ្យគាត់ មិនអាចបញ្ជូនទៅខាង ម អ៊ំប្រធានបានទេ។ គាត់ត្រូវទំនាក់ទំនងគ្នាសម្ភារៈអី បើដឹក បើមិនឆ្លងគាត់ក៏ដឹកចេញមិនបាន។ ដូចគ្រាប់ ត្រូវគ្រាប់ប៉ុន្មានកប៉ាល់ត្រូវអាវុធប៉ុន្មានពាន់ដើម"]។ ឯកសារ D54/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.២២,២៥ ["នៅពេលយួនវាយបុកមកលើយើងតាមព្រំដែន មាស មុត ត្រូវតែទៅ ត្រួតពិនិត្យស្ថានការណ៍នៅសមរភូមិមុខ [...] ឆ.២៥: តាមខ្ញុំដឹង ក្នុងនាមគាត់ជាអគ្គសេនាធិការរង ដូច្នេះគាត់ត្រូវតែទៅពិនិត្យស្ថានការណ៍នៅកន្លែងដែលមានជម្លោះនៅតាមព្រំដែន"]។ ឯកសារ D54/63 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.១១-១៧,១៩ ["មាស មុតនៅសេនាធិការ ដូច្នេះគាត់មានសិទ្ធិអំណាចបញ្ជាទៅកងទាំងបីប្រភេទ [...] ឆ.១២: នៅឆ្នាំ១៩៧៨ យើងបានសុំជំនួយពីមាស មុត ហើយគាត់បានប្រាប់រុំឱ្យចាំបន្តិច ហើយនៅពេលរសៀល គាត់បានបញ្ជូនយន្តហោះមកជួយយើង [...] ឆ.១៣: ក្នុងនាមជានីរសារ ខ្ញុំធ្វើការនៅក្នុងមន្ទីរជាមួយនឹងអ្នកសារទូរលេខ ហើយនិងមេបញ្ជាការ ដូច្នេះខ្ញុំអាចដឹងអំពីអ្វីៗដែលកើតឡើងនៅក្នុងមន្ទីរហ្នឹង សៈ នៅពេលដែលលោកនិយាយថា មាស មុតបញ្ជាឱ្យរុំរងចាំ តើគាត់ប្រាប់តាមសារទូរលេខ ឬតាមវិទ្យុទាក់ទង? ឆ.១៤: គាត់បានឆ្លើយតបមកវិញតាមសារទូរលេខ សៈ ពេលផ្ញើរបាយការណ៍ពីកងពល១១៧ ទៅឱ្យ មាស មុត តើគេធ្វើជាប្រចាំថ្ងៃ ឬក៏ធ្វើឡើងរាល់ពេលដែលមានព្រឹត្តិការណ៍កើតឡើង? ឆ.១៥: មុនពេលមានការវាយគ្នា របាយការណ៍នេះគឺធ្វើជាប្រចាំរាល់ៗថ្ងៃ ប៉ុន្តែក្រោយពីមានព្រឹត្តិការណ៍វាយគឺរបាយការណ៍ត្រូវបានធ្វើរាល់ពេលដែលមានហេតុការណ៍កើតឡើង។ កងពល១១៧នេះ ស្ថិតនៅក្រោមបញ្ជាសេនាធិការផ្ទាល់ មិនឆ្លងកាត់តាមភូមិភាគទេ [...] ឆ.១៦: គឺដាក់ថា ជូនទៅអគ្គសេនាធិការ គឺមិនមែនដាក់ទៅបុគ្គលណាជាក់លាក់ទេ ប៉ុន្តែយើងដឹងថា អ្នកទទួលសារទូរលេខគឺជាអ្នកដែលធ្វើការឱ្យអ្នកណាម្នាក់ហើយ។ ឧទាហរណ៍ ធី និងគង់ ជាអ្នកកាន់សារទូរលេខឱ្យមាស មុត សៈ ហេតុអ្វីបានជាលោកដឹង មាស មុត ជាអ្នកផ្ញើសារទូរលេខឱ្យ រុំ ឱ្យរងចាំការបញ្ជូនយន្តហោះនៅពេលនោះ? ឆ.១៧: ខ្ញុំមិនដឹងលេខសារទូរលេខទេ ប៉ុន្តែខ្ញុំដឹងអំពីរឿងនេះតាមរយៈការឃើញសារទូរលេខ [...] ឆ.១៩: តាមការដឹងរបស់ខ្ញុំ មាស មុត ចាប់ផ្តើមពាក់ព័ន្ធទទួលខុសត្រូវបញ្ហានោះតាមព្រំដែនខាងកើតនៅក្នុងឆ្នាំ១៩៧៨ ពេលដែលយួនវាយបុកខ្លាំង"]។ ឯកសារ D114/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ុន សារ៉ាត់ ឬ ព្រំ សារ៉ាត់ ឆ.២២៤ ["ពេល មាស មុត គាត់ធ្វើដំណើរទៅក្រចេះ គោលបំណងសំខាន់ គឺសង្គ្រាមតាមព្រំដែនរវាងវៀតណាម កម្ពុជា ចាប់ផ្តើមមានការប្រយុទ្ធក្នុងសភាពការតានតឹង"]។

122. ដើម្បីបោសសម្អាតកងពល១១៧ និង តំបន់៥០៥ មាស មុត ផ្លាស់ទៅក្រចេះ[356] ដោយយកកម្លាំងយោធារបស់គាត់ទៅគ្រប់គ្រងទាំងកងពល និងតំបន់នោះតំណាងឲ្យមជ្ឈិមបក្ស[357]។ ពេលទៅដល់

---

356 មាសមុតបានសារភាពថាគាត់ប៉ុនប៉ងទៅខេត្តក្រចេះ។ ទោះបីជាយ៉ាងណាក៏ដោយមិនមានភស្តុតាងផ្សេងទៀតនៅក្នុងឯកសារសំណុំរឿងនោះទេ គាត់បាននិយាយថានេះបានកើតឡើងនៅក្នុងខែកុម្ភៈឆ្នាំ ១៩៧៨: ឯកសារ D54/16/1R ខ្សែអាត់នៃកិច្ចសម្ភាសន៍របស់មាស មុតជាមួយ ដេវីដ ខេតថេនបឺហ្គ ឆ្នាំ២០០៩ 34:37-35:28 ["ខ្ញុំមិនមែននៅកំពង់សោមទេ នៅខែកុម្ភៈ ឆ្នាំ១៩៧៨ ខ្ញុំបានចាកចេញពីកំពង់សោមហើយ ស: តើអ្នកទៅណា? ឆ: ខ្ញុំត្រូវបានចាត់តាំងឲ្យទៅក្រចេះ ក្បែរព្រំដែនឡាវ ស: ដូច្នេះតើគាត់បានចាកចេញពីកងពល១៦៤ នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៨? ឆ: អត់ទេ ខ្ញុំនៅតែមានតួនាទីដដែល គ្រាន់តែខ្ញុំត្រូវចាត់តាំងបំពេញបេសកកម្មផ្សេងទៀតនៅខេត្តក្រចេះ"]។ សូមមើល ឯកសារ D114/297.1.22 ម៉ឹង វេត ប្រតិចារឹកថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១៦ 15.38.26-15.41.36 ["ការផ្លាស់ប្តូរមុខតំណែងវាត្រូវអ្នកថ្មីទៅដូរ អ្នកចាស់ត្រូវដកជិះយន្តមកភ្នំពេញមកក៏ត្រូវបាត់ខ្លួនរហូតទល់រត់ គៀកនឹងរត់ យួនបុកខ្លាំងនេះហើយ សភាពការណ៍តឹងតែង ដែលយួនយកស្ទួលបានទាំងមូលហើយ។ មាស មុតក៏បានទៅទីនោះដែរ"]។ ឯកសារ D54/60.2 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ឹង វេត ERN KH 00975710 ["វាមិនមែនរហូតដល់ឆ្នាំ ១៩៧៨ ថា [មាសមុត] បានទៅខេត្តក្រចេះបន្ទាប់ពីលោកវ៉ុនវេតត្រូវបានចាប់ខ្លួន"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ ឆ.៤២ ["តើ មាស មុតទៅដល់តំបន់ក្រចេះនៅពេលណា? ឆ.៤២: តាមព្រឹត្តិការណ៍ដែល តាញ៉ាន់ទៅកាន់បញ្ជាការកងពល១១៧ គឺប្រហែល១ខែមុនពេលវៀតណាមចូលគឺនៅប្រហែលចុងខែវិច្ឆិកា ឬដើមខែធ្នូ ឆ្នាំ១៩៧៨។ ដូច្នេះខ្ញុំគិតថា មាស មុត ទៅដល់ទីនោះនៅអំឡុងពេលនោះឯង"]។ ឯកសារ D54/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ឆ.៨-៩ ["មាស មុតត្រូវបានគេបញ្ជូនទៅក្រចេះ ពីព្រោះពេលនោះមានការចាប់កម្មាភិបាលគឺមានសន្ទុះខ្លាំង [...] ឆ.៩: គាត់នៅទីនោះចុងឆ្នាំ១៩៧៨ ក្នុងរយពេលខ្លី គឺប្រហែលជាពីរអាទិត្យឬកន្លះខែប៉ុណ្ណោះ"]។

357 ឯកសារ D114/297.1.22 ម៉ឹង វេត ប្រតិចារឹកថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១៦ 15.43.55-15.46.20 និង ឯកសារ D114/297.1.24 ម៉ឹង វេត ប្រតិចារឹកថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១៦ 09.52.20-09.54.38 [បានថ្លែងថាបានឃើញលិខិតមួយដែលមានសញ្ញាសម្គាល់ថា "ម-៨៧០" ដែលត្រូវបានបញ្ជូនដោយអ្នកនាំពាក្យរបស់លោកមាសមុតគឺលោកធីនិងឃាងទៅកាន់លេខ ១១៧ មេបញ្ជាការរ៉ុំ ហៅថា១១ ពីកងពលលេខ ១១៧ និងផ្នែក ៥០៥ ទៅកាន់រាជធានីភ្នំពេញនិងបញ្ជាក់លម្អិតអំពីការធ្វើដំណើរតាមអាកាសរបស់ពួកគេ] បញ្ជាក់បន្ថែម ឯកសារ D54/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.២៤,២៩ ["ខ្ញុំនៅចាំថា ថ្ងៃមួយមាននីរសារម្នាក់មកពិវាលយន្តហោះយកសំបុត្រមកឲ្យរ៉ុំ ដែលជាមេបញ្ជាការកងពល១១៧ ដើម្បីចូលរួមការប្រជុំនៅភ្នំពេញ។ សំបុត្រនោះ បាននិយាយថាមានយន្តហោះនឹងមកនៅម៉ោងប្រាំបួនព្រឹកដើម្បីយកពួកគេ[...] ខ្ញុំបានឃើញសំបុត្រនោះផ្ញើមកពីមន្ទីរ ម-៨៧០ [...] សំបុត្រនោះមានឈ្មោះ រ៉ុំ និង១១នាក់ត្រូវហៅឲ្យទៅប្រជុំ"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ ឆ.៣០-៣២ ["អំឡុងពេលនោះ ការបោសសម្អាតបានចាប់ផ្តើម គេដកមិត្តរួមអាវុធខ្ញុំដូចជា រ៉ុំ និងលាង [...] ពួកគេបានហៅឲ្យទៅប្រជុំនៅក្រចេះ ហើយក៏បាត់ខ្លួនរហូត [...] ឆ.៣១: គេគឺថ្នាក់មជ្ឈិម [...] ឆ.៣២: មុនពេលរ៉ុំ និងលាងទៅប្រជុំនៅក្រចេះ គេប្រជុំជាមួយយើង ដោយប្រាប់ថាពួកគេត្រូវបានហៅប្រជុំនៅក្រចេះ ដោយមជ្ឈិម។

មាស មុត កំណត់ច្បាស់ថា កម្មាភិបាលចំនួន១០ នាក់ បានបញ្ជូនទៅស-២១[358]។ គាត់មានវត្តមាន ផ្ទាល់ពេល ដែលកម្មាភិបាលមួយចំនួនឡើងយន្តហោះមកភ្នំពេញ[359]។ មាស មុត បន្ទាប់មក ធ្វើជា

---

ពេលនោះគេមិនហៅមជ្ឈិមទេគឺហៅថា "៨៧" […] ឆ.៤០: ថ្នាក់លើកងពលហ្នឹងគឺថ្នាក់មជ្ឈិមទេ ប៉ុន្តែនៅពេលនោះ មាស មុត បានមករៀបចំកងពល១១៧ ហើយចាត់តាំង តាញ៉ាន់ជាបញ្ជាការកងពល១១៧នេះ"]។ ឯកសារ D114/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត់ ឆ.២៣០ ["តើអ្នកណាជាអ្នកបញ្ជូន មាសមុតទៅក្រចេះ? ឆ.២៣០: គឺអគ្គបញ្ជាការបើតាមខ្ញុំដឹង"]។ ឯកសារ D114/101 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯម សារិន ឆ.២៥-៤០ [ដោយបានបញ្ជាក់ថាលោកបានសម្របសម្រួលជាមួយការិយាល័យ៨៧ ដើម្បីរៀបចំឱ្យលោកយ៉េង និងភួនមកកាន់ទីក្រុងភ្នំពេញ]។

358 សូមមើលឧបសម្ព័ន្ធ D.2 និង D.4 និងកថាខណ្ឌ ៥៥០, ៨៦១ នៃការដាក់ស្នើនេះ។ សូមមើលផងដែរ ឯកសារ D114/297.1.22 ម៉ឹង វេត ប្រតិចារឹកថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១៦ 15.43.55-15.46.20 និង D114/297.1.24 ម៉ឹង វេត ប្រតិចារឹកថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០១៦ 09.52.20-09.54.38 [បានថ្លែងថាបានឃើញលិខិតមួយដែលមានសញ្ញាសម្គាល់ថា "ម-៨៧០" ដែលត្រូវបានបញ្ជូនដោយអ្នកនាំពាក្យរបស់លោកមាសមុតគឺលោកធីនិងឃាងទៅកាន់លេខ ១១៧ មេបញ្ជាការរុំ ហៅថា១១ ពីកងពលលេខ ១១៧ និងផ្នែក ៥០៥ ទៅកាន់រាជធានីភ្នំពេញនិងបញ្ជាក់លម្អិតអំពីការធ្វើដំណើរតាមអាកាសរបស់ពួកគេ] បញ្ជាក់បន្ថែម ឯកសារ D114/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.២៤,២៩ និង ឯកសារ D114/169 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.៣០ ["មុតគឺជាអ្នកដែលបានបញ្ជូនអ្នកចាប់ខ្លួនទាំងនោះទៅភ្នំពេញដោយយន្តហោះ […] ខ្ញុំចង់បន្ថែមសម្រាប់ការយល់ដឹងរបស់អ្នកថា មុតបានបញ្ជូនពួកគេដោយយន្តហោះ។ មុតបានរៀបចំវា"]។ ឯកសារ D114/170 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ ម៉ុន ឆ.៣៦,៣៨ [" លឹម [កងវរសេនាធំ] ប្រាប់ខ្ញុំថាតាមុតបានបញ្ជាឱ្យចាប់ខ្លួនប្តីរបស់ខ្ញុំ [ឃុន វុំ] […] ឆ.៣៨: ប្តីរបស់ខ្ញុំ តាមឿន តាលាងត្រូវបានចាប់ខ្លួនទាំងអស់"]។

359 ឯកសារ D114/297.1.27 សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៦ 14.03.52-14.10.10 [លោកសេងសឿនបានធ្វើជាសាក្សីឱ្យលោកហុនយ៉េងលេខាធិការស្រុកស្នួល និងលោកឈុំឈុន ហៅភួន "កំពុងជិះយន្តហោះទៅភ្នំពេញ" ។ ទោះជាយ៉ាងណាក៏ដោយ សេងសឿននិងភួន ដែលជាយុវជនរបស់គាត់មិនបាននិយាយជាមួយគ្នាទេ ដោយសារមាសមុតនៅជុំវិញនោះ]។ ឯកសារ D114/169 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ .៣០,៤០,៤២,៤៧,៤៩ ["មុតគឺជាអ្នកដែលបានបញ្ជូនអ្នកចាប់ខ្លួនទាំងនោះទៅភ្នំពេញដោយយន្តហោះ […] ខ្ញុំចង់បន្ថែមសម្រាប់ការយល់ដឹងរបស់អ្នកថា មុតបានបញ្ជូនពួកគេដោយយន្តហោះ។ មុតបានរៀបចំវា ឆ.៤០: អាចិន ខ្ញុំស្គាល់ច្បាស់។ អាយ៉េង ខ្ញុំស្គាល់ពេលហៅឡើងយន្តហោះ […] ឆ.៤២: មុនឡើងយន្តហោះ បានជួបគ្នា រៀបនឹងនិយាយគ្នា វាក៏ចង់និយាយជាមួយខ្ញុំដែរ តែ មុតមើលមុខថ្លៃ យើងក៏អត់បាននិយាយគ្នាទៅ […] ឆ.៤៧: ពេលនោះមុតហៅទៅជួបគាត់ ត្រូវប្រមូលទ័ព ចំជើងយន្តហោះហ្នឹងមក ពីរនាក់ហ្នឹងគេចាប់យកមកហើយ […] ឆ.៤៩: មាសមុតមកប្រចាំការរៀបចំ ហើយបានហៅគេហៅអ្នកណាៗត្រូវនាំខ្លួនឱ្យឡើងយន្តហោះ"]។ ឯកសារ D4.1.810 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.៣៥-៣៦ ["យ៉េង គឺបានដឹកតាមយន្តហោះ ប្រហែលជាទៅកាន់ទីក្រុងភ្នំពេញ ដើម្បីសម្លាប់។ ខ្ញុំដឹងព័ត៌មាននេះដោយសារ មាស មុត និយាយថាមនុស្សទាំងនោះត្រូវបានគេយក

អធិបតីអង្គប្រជុំជាមួយកម្មាភិបាលដែលនៅសេសសល់ ហើយប្រកាសថា គាត់បានសម្រេចដកមេដឹកនាំរបស់កម្មាភិបាលទាំងនេះ ពីព្រោះ មេដឹកនាំនោះ “ជាជនក្បត់”[360] ជាអ្នកដែល “មិនដាច់ខាតក្នុងការប្រយុទ្ធជាមួយទ័ពវៀតណាម”[361]។

123. ក្រោយការបោសសម្អាត ដើម្បីបង្ហាញនូវការគ្រប់គ្រងរបស់គាត់លើកងពល១១៧ និងតំបន់៥០៥[362] មាស មុត បានដកកម្មាភិបាលដែលបានបោសសម្អាត ហើយដាក់ជំនួសដោយយុទ្ធជនដែលទុកចិត្ត[363]។ គាត់ក៏បានដាក់ពង្រាយយុទ្ធជនកងពល ១៦៤ យ៉ាងច្រើនគួរកត់សម្គាល់

---

ទៅកម្ពេច ឆ.៣៦ […] ចិនត្រូវបានគេបញ្ជូនទៅក្រុងភ្នំពេញដើម្បីសម្លាប់ដែរ។ ខ្ញុំបានឃើញភាន់ និងយេង នៅពេលពួកគាត់ឡើងយន្តហោះ”]។

360 ឯកសារ D114/297.1.24 ម៉ឹង វេត ប្រតិចារឹកថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១៦ 09.35.51-09.41.29 [ពិពណ៌នាអំពីកិច្ចប្រជុំមួយនៅក្នុងខេត្តក្រចេះដែលលោកមាសមុតបានប្រកាសថាមេដឹកនាំ "ត្រូវបានចាត់ទុកថាជាជនក្បត់" ហើយថា "មេបញ្ជាការកងពលធំត្រូវបានជំនួសដោយពួកថ្មី “ មាសមុតបានលើកឡើងថាក្រុមរបស់ខ្ញុំមិនប្រឹងប្រែងវ៉ៃខ្លាំងឲ្យអស់លទ្ធភាពទាល់តែសោះដើម្បីប្រឆាំងនឹងយួន ទើអនុញ្ញាតឱ្យយួនចូលមក”។ ឯកសារ D54/63 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.២ [“ពេលមាស មុតដើរចូលរួមប្រជុំ គាត់បាននិយាយថានៅខាងក្រៅជាមួយនីរសារ និងយោធាផ្សេងទៀតថា “ មេៗរបស់ឯងក្បត់អស់ហើយ””]។ ឯកសារ D54/60.2 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ឹង វេត ERN KH EN 00992993-94, 00993000-01 [“ពិពណ៌នាអំពីការប្រជុំដែលមាស មុត "បានប្រកាសជនក្បត់" ហើយបានប្រគល់កម្មាភិបាលទៅ វ៉ៃប្រហារ “យួន” ”]។

361 ឯកសារ D54/63 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.២ [“មាស មុតខឹងយ៉ាងខ្លាំង ហើយបាននិយាយថា ពួកយើងមិនដាច់ខាតវ៉ៃនឹងយួនទេ ដោយសារតែព្រឹត្តិការណ៍ទាំងនេះ បានជាតាមុតគាត់ឈប់ជឿលើថ្នាក់ដឹកនាំកងពល ហើយដកអ្នក១១នាក់នោះចេញ”]។

362 ឯកសារ D114/51 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ ឆ.១ [“ស: ពេលនេះ នៅក្រោមការស្បថរួចហើយ តើលោកចាត់ថា សេចក្តីសង្ខេបដែលយើងរៀបរាប់នេះ គឺពិតជាត្រឹមត្រូវតាមការសន្ទនារបស់យើងកាលពីម្សិលមិញដែរឬទេ? ឆ.១: បាទគឺត្រឹមត្រូវហើយ”]។

363 ឯកសារ D114/297.1.23 ម៉ឹង វេត ប្រតិចារឹកថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១៦ 09.38.19-09.39.48 [“ [មាស មុត] គាត់ហៅប្រជុំក្នុងជួរមន្ទីរទាំងអស់ ដើម្បីប្រកាសថា ឥឡូវគាត់ត្រូវដូរមេកងពល។ គាត់ហៅតែពួកក្រុមនីរសារ ពួកតែកុងឡាន ពួកហ្គារាសឡាន ពួកអីៗសម្រាប់ហ្នឹង ពេទ្យ គាត់ហៅមកប្រជុំទាំងអស់។ គាត់ប្រាប់ថា ឥឡូវត្រូវដូរមេក្បត់ហើយ មេអ្អែងក្បត់អស់ហើយ ឥឡូវត្រូវដូរមកញ៉ាន់ ឡើងមេបញ្ជាការប្រធានកងពលនេះ”]។ ឯកសារ D54/63 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.១ [“ខ្ញុំចាំថាខ្ញុំបានចូលរួមប្រជុំជាមួយមាស មុត ម្តង នៅពេលដែលគាត់មកបើកការប្រជុំ និងប្រកាសការផ្លាស់ប្តូរថ្នាក់ដឹកនាំកងពល”]។ ឯកសារ D114/297.1.27 សេង សឿន ប្រតិចារឹកថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៦ 13.51.58-13.57.20 [ផ្តល់សក្ខីកម្មថាការតែងតាំងថ្មីចំនួនប្រាំរូបមកពីភូមិភាគនិរតីត្រូវបានគេហៅឱ្យទៅជួបជាមួយលោកមាសមុតនៅពេលមកដល់]។ ឯកសារ D114/169 កំណត់ហេតុនៃ

ឲ្យគ្រប់គ្រង កម្លាំងផ្សេងៗទៀត នៅក្រចេះ[364]។ ពេញខែធ្នូ ឆ្នាំ ១៩៧៨ មាស មុត និងកម្លាំងក្រោមបង្គាប់របស់គាត់ បន្តបោសសម្អាតគោលដៅកម្មាភិបាលថ្នាក់ក្រោម និងជនស៊ីវិល[365]។ ជា

ការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.១៩ ["សៈ តើលោកជួប បងមុតហ្នឹង គាត់មកទទួលនៅយន្តហោះ ឬក៏លោកចុះពីយន្តហោះទៅជួបនៅ ឯផ្ទះ? ឆ.១៩: មកដល់មន្ទីរតំបន់ក្រចេះហើយហ្នឹង យប់បានមកទទួល ប៉ុន្តែនៅសមរភូមិ"]។ ឯកសារ D114/297.1.27 សេង សឿន ប្រតិចារឹកថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៦ 13.46.29-13.58.19 [ដោយលើកឡើងថាមាសមុត "បានមករៀបចំមុខតំណែងរបស់ខ្លួននៅក្រចេះ" ។ នៅពេលដែលសាក្សីបានមកដល់ខេត្តក្រចេះជាមួយនឹងកម្មការិនីជំនួសផ្សេងទៀតពួកគេបានប្រគល់ជីវប្រវត្តិរបស់ពួកគេទៅឱ្យលោកមាសមុតដែលជាប្រធាននៃការផ្សព្វផ្សាយ "ក្នុងនាមប៉ុលពត" ។ លោកមុតមុតបានសម្រេចចិត្តដាក់លោកសេងសឿនទទួលបន្ទុកការិយាល័យកណ្តាល ៥០៥]។ ឯកសារ D4.1.810 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.២៧,៣១ ["លិខិតនោះបញ្ជាក់ថា មាស មុតគឺជាអ្នកទទួលខុសត្រូវចាត់ចែងការងារឲ្យមនុស្សខាងលើ" [...] ឆ.៣១: គេបញ្ជូនគាត់មកក្រចេះមុន ដើម្បីរៀបចំតែងតាំងការងារថ្មីឲ្យពួកយើង"]។ ឯកសារ D114/169 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.២០ ["កាលជួបដំបូងប្រគល់លិខិតដែលឲ្យមកហ្នឹងជួបនៅកន្លែងមន្ទីរតំបន់របស់ក្រចេះហ្នឹង ទាំងអស់គ្នាមកហ្នឹងរួចបានគាត់ប្រកាសចាត់តាំង"]។ ឯកសារ D59/2/4.16a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សេង សឿន ERN KH 00059307 ["មាស មុតបានមកតែងតាំងខ្ញុំនៅពេលខ្ញុំមកដល់នៅថ្ងៃទី ៥ ខែធ្នូឆ្នាំ ១៩៧៨"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជូ ឆ.៤០-៥៤ ["សៈ តើអ្នកណាជាអ្នកចោទមកលើកងពល១១៧ ថាដូច្នេះ? ឆ.៤០: ថ្នាក់លើកងពលហ្នឹងទៀតគឺថ្នាក់មជ្ឈិម ពីព្រោះកងពលនេះស្ថិតនៅក្រោមបញ្ជារបស់មជ្ឈិមផ្ទាល់។ ខ្ញុំមិនដឹងថាអ្នកណាពិតប្រាកដនៅថ្នាក់មជ្ឈិមទេ ប៉ុន្តែនៅពេលនោះ មាស មុត បានមករៀបចំកងពល១១៧ ហើយចាត់តាំង តាញ៉ាន់ជាបញ្ជាការកងពល១១៧នេះ។ ដូច្នេះខ្ញុំគិតថា មាស មុតគឺតំណាងមកពីមជ្ឈិម។ សៈ តើម៉េចបានជាលោកដឹងថា មាស មុត ចាត់តាំងឲ្យតាញ៉ាន់ធ្វើជាបញ្ជាការកងពល១១៧? ឆ.៤១: ខ្ញុំដឹងតាមរយៈអ្នកដែលមកកាន់កាប់ថ្មី គឺតាញ៉ាន់។ តាញ៉ាន់និយាយថា "បងមាស មុតចុះមកក្រចេះដើម្បីរៀបចំកងពល១១៧ឡើងវិញ" សៈ តើ មាស មុត ទៅដល់តំបន់ក្រចេះនៅពេលណា? ឆ.៤២: តាមព្រឹត្តិការណ៍ដែលតាញ៉ាន់ ទៅកាន់បញ្ជាការកងពល១១៧ គឺប្រហែល១ខែមុនពេលវៀតណាមចូលគឺនៅជាចុងខែវិច្ឆិកា ឬដើមខែធ្នូ ឆ្នាំ ១៩៧៨។ ដូច្នេះខ្ញុំគិតថា មាស មុត ទៅដល់ទីនោះនៅអំឡុងពេលនោះឯង [...] សៈ តើតាញ៉ាន់ ប្រកាសអំពីមុខងារ និងឋានៈរបស់មាស មុត ថាជាអ្វីនៅ ពេលដែលតាញ៉ាន់ មកប្រកាសថា តា មុត មកនៅក្រចេះ ដើម្បីរៀបចំកងពល និងថ្នាក់ដឹកនាំឡើងវិញ? ឆ.៥៤: ពេលនោះ តាញ៉ាន់ ប្រជុំផ្សព្វផ្សាយប្រាប់កម្មាភិបាលថ្នាក់ក្រោមថា តាមុត មកពីភ្នំពេញ មករៀបចំកងពលថ្មី និងរៀបចំថ្នាក់ដឹកនាំថ្មី។ ចំណែករ៉ុំ និងលាង គេផ្លាស់ចេញពីកងពលហ្នឹងហើយ។ ដូច្នេះខ្ញុំកំណត់ថា តាមុត ទៅរៀបចំកងពលថ្មីនេះ គឺតាមុតតំណាងឲ្យមជ្ឈិមហើយ"]។

364 ឯកសារ D54/110 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ឆ.៦-៧ ["មាស មុតបានយកមនុស្សទៅជាមួយគាត់ដូចជា ញ៉ាន់ បញ្ជាការកងពិសេស និងបញ្ជាការផ្សេងៗទៀត ដែលគាត់ជឿទុកចិត្ត។ ខ្ញុំបានដឹងអំពីរឿងពួកអ្នកទាំងអស់នេះទៅក្រចេះ ពីព្រោះនៅពេលប្រជុំ មេបញ្ជាការរបស់ខ្ញុំបានធ្វើការប្រកាសប្រាប់ពួកយើងអំពីឈ្មោះថ្នាក់ដឹកនាំណាទៅកន្លែងណាខ្លះ។ សៈ តើលោកដឹងថា មានយោធាចំនួនប៉ុន្មាននាក់ទៅក្រចេះជាមួយ មាស មុត? ឆ.៧:

យោធាភាគច្រើននៃកងជើងគោករបស់កងកម្លាំងកងទ័ពជើងទឹកត្រូវបានបញ្ជូនទៅក្រចេះទៅវៃជាមួយតាមុត លើកលែងតែអ្នកកាន់នាវា"]។ ឯកសារ D114/297.1.22 ម៉ឹង វេត ប្រតិចារឹកថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១៦ 15.38.37-15.41.36 ["មាស មុតមកពីកំពង់សោមរួមជាមួយទាហានវរសេនាធំ ទម្លាក់នៅភាពនេះ បានយកគាត់ ខ្ញុំបានដឹងថាទ័ពរបស់គាត់នៅឃុំគោលាប់ [...] ម្តុំភ្នំសំបុក"]។ ឯកសារ D54/63 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.២១, ២៣-២៤ ["ស: តើកាលពីពេលនោះពួកមជ្ឈិមបានយកយោធាប៉ុន្មានកងដាក់ពង្រាយនៅក្រចេះ? ឆ.២១: ដំបូងគឺមានកងពល១១៧ ហើយក្រោយមកកងវរៈសេនាធំមួយទៀតមកពីកងពល១៦៤ ត្រូវបានដាក់ពង្រាយនៅទីនោះ [...] ស: តើគាត់ស្នាក់នៅកន្លែងណាពេលដែលគាត់ទៅក្រចេះ? ឆ.២៣: ខ្ញុំមិនដឹងទេ ប៉ុន្តែធម្មតា គាត់ស្នាក់នៅភូមិគោលាប់ ដែលជាកន្លែងយោធាកងវរៈសេនាធំ របស់កងពល១៦៤បោះទីតាំងនៅ [...] ឆ.២៤: កងវរៈសេនាធំកងពល១៦៤ នៅទីនោះរហូតដល់កងទ័ពយួនវៃបុកខ្លាំង នៅក្នុងខែធ្នូ ឆ្នាំ១៩៧៨"]។ ឯកសារ D54/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.២៦ ["កងវរៈសេនាធំរបស់ភាគគឺជាកងកម្លាំងពិសេសរបស់ មាស មុត"]។ ឯកសារ D114/191 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សូ ឆ.៤៤ ["ខ្ញុំដឹងថាកងពលមកពីកំពង់សោម នៅជាមួយតាមុត [...] ប៉ុន្តែខ្ញុំអត់បានជួប អត់បានឃើញ ពួកគេមកជួយកងពល១១៧ ដែលវាយអត់ឈ្នះ"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជូ ឆ.៥៦ ["ខ្ញុំគ្រាន់តែដឹងថាកងទ័ពបានទៅជាមួយតាញ៉ាន់នៅក្រចេះ"]។ ឯកសារ D54/98 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាង រ៉េត ឆ.៣៦ ["កងពល១៦៤ ត្រូវបញ្ជូនកម្លាំងមួយចំនួនទៅជួយកម្លាំងដែលឈរជើងនៅតាមព្រំដែន។ នៅពេលនោះមាស មុត បានដឹកនាំកម្លាំងយោធាជាងពាក់កណ្តាលពីកងវរសេនាធំ៦១, ៦២ និង៦៣ ទៅវៃជាមួយវៀតណាមនៅឯព្រំដែន"]។ ឯកសារ D114/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត់ ឆ.២២៦ [បញ្ជាក់ថាមាស មុត បានយកកងពល១៦៤របស់គាត់ទៅក្រចេះ]។ ឯកសារ D54/50 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ឆ.៥-៦, ៩ [មេបញ្ជាការកងពលធំទី 1 បានបញ្ជាក់ថាកងពលធំលេខ ១៦៤ ដែលបញ្ជាដោយផ្ទាល់របស់តាមុតត្រូវបានដាក់ពង្រាយនៅតាមបណ្តោយព្រំដែនវៀតណាមជា "ខ្សែការពារខាងក្រោយ" ហើយរៀបរាប់អំពីឧប្បត្តិហេតុដែលកើតឡើងរវាងកងពលធំលេខ ១ និងកងពលធំ ១៦៤ "នៅក្នុងខែវិច្ឆិកាឬធ្នូ ១៩៧៨]។ សូមមើលផងដែរ ឯកសារ D54/63 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.២ [រំលឹកឡើងវិញថាទូចអ្នកនាំសាររបស់លោកញ៉ានវ៉ាយដែលជាអ្នកបកប្រែលេខទូរស័ព្ទ និងខាដែលជាអ្នកសរសេរអក្សរទូរលេខស្ថិតក្នុងចំណោមបុគ្គលិក ១៦៤ នាក់ដែលបានបញ្ជូនទៅខេត្តក្រចេះ]។ ទាហានក៏ត្រូវបានព្រាងចេញពីកន្លែងផ្សេងហើយដាក់ក្រោមបញ្ជារបស់លោកញ៉ាន់: ឯកសារ D114/149 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច ឈុំ ឆ.១-៧១ [បានរៀបរាប់ថាត្រូវបានបញ្ជូនដោយស៊ូម៉េតទៅក្រចេះដើម្បីប្រយុទ្ធនឹងពួកយួន។ លោកម៉េតបានប្រាប់គាត់ថា: "ដើម្បីសហការជាមួយអង្គភាពលេខ ១៦៤ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យដោយផ្ទាល់របស់ញ៉ាន់" ។ នៅទីនោះគាត់បានរាយការណ៍ទៅញ៉ាន់។ ទោះបីជាគាត់មិនបានចងចាំយ៉ាងច្បាស់ពីកាលបរិច្ឆេទនៃការផ្ទេររបស់គាត់ក៏ដោយវាទំនងជាគាត់បានផ្លាស់ទីនៅទីនោះនៅក្នុងខែវិច្ឆិកាឆ្នាំ ១៩៧៨]។

[365] សូមមើលថាខណ្ឌ ៥៥០, ៨៦៧-៨៦៨។ សូមមើលផងដែរ ឯកសារ D114/75 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុផល ឆ.១៥៣-១៦៥ [បានធ្វើសាក្សីពីការដក និងការចាប់ខ្លួនមេបញ្ជាការកងវរសេនាតូចនៅខេត្តក្រចេះនៅខែធ្នូ ឆ្នាំ១៩៧៨ ដោយ "ទាហានមកពីភូមិភាគនិរតី"។ កម្មាភិបាលជាន់ទាបទាំងនេះត្រូវបាន 'ចោទប្រកាន់ពីបទ

ពិសេស មាស មុត ចេញបញ្ជាផ្ទាល់ឲ្យសម្លាប់សមាជិកគណៈកម្មាធិការតំបន់៥០៥ ទទួលខាងភារកិច្ចយោធា[366]ឈ្មោះ ម៉ៅ អឿង[367]។

---

ក្បត់ដោយសារតែមេបញ្ជាការទាំងអស់របស់ពួកគេត្រូវបានចាប់ខ្លួន"។ សាក្សីឈ្មោះភីន សុភី និងឌីវ៉ាន់ បានឃើញពួកគេត្រូវ "បោះចូលក្នុងរថយន្តដូចជាជ្រូក"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជូ ឆ.៣៩ ["បន្ទាប់មកទៀត បញ្ជាការកងវរៈសេនាធំ និងមេបញ្ជាការវរៈសេនាតូចខ្លះ ត្រូវបានហៅទៅទៀត ហើយបាត់ខ្លួនរហូត។ ពេលនោះ បញ្ជាការវរៈសេនាតូច វរៈសេនាធំខ្លះ បានរត់ចោលកង ព្រោះខ្លាចគេចាប់យកទៅសម្លាប់ដែរ"]។ ឯកសារ D98/3.1.316 យុន គីម ប្រតិចារឹក ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០១២ 15.52.09-15.59.01 ERN KH 00818208 [ សាក្សីបានបង្ហាញឯកសារ D1.3.28.146 បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរស-២១ ដែលមានឈ្មោះ២២នាក់ពីផ្នែក៥០៥ ដែលបានមកដល់ ស-២១ នៅថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ១៩៧៨។ គាត់បានបញ្ជាក់ពីការចំណាំឈ្មោះ "សម្បត្តិពីឃុំសំបុក" "ស: តើអ្នកអាចរំលឹកការចងចាំនៅចុងឆ្នាំ ១៩៧៨ ថាប្រធានឃុំនិងសហករណ៍មួយចំនួននៅក្នុងខេត្តក្រចេះត្រូវបានគេចាប់ខ្លួនដែរឬទេ? តើអ្នកចាំទេ? ឆ: ខ្ញុំបានឮអំពីការចាប់ខ្លួនគណៈកម្មាធិផ្នែកនេះ។ បន្ទាប់មកមានមនុស្សជាច្រើនត្រូវបានចាប់ខ្លួននៅភូមិថ្មគ្រែ ឃុំសំបុក និងនៅឃុំដទៃទៀតផងដែរ"]។ ឯកសារ D114/193 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សារុន ឆ.៦៤ [បានឮពីអ្នកផ្សេងថា "ញ៉ាន់ដែលមកពីកងនាវាចរហើយបានមកដល់ខេត្តក្រចេះដើម្បីធ្វើការចាប់ខ្លួន"] បញ្ជាក់ពីឯកសារ D4.1.444 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សារុន ERN KH 00251435 [" លោកញ៉ាន់ អតីតប្រធានកងម៉ារីននៅកំពង់សោមបានធ្វើដំណើរទៅខេត្តក្រចេះ ហើយខ្ញុំបានឮពីមនុស្សផ្សេងទៀតថាអង្គការមានក្រុមរបស់គាត់មកចាប់ខ្លួនជនស៊ីវិលនិងយោធា"]។

366 ឯកសារ D54/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.១២ ["មេបញ្ជាការវរៈសេនាធំតំបន់ម្នាក់ឈ្មោះអឿង មេបញ្ជាការយោធាស្រុកស្នួលឈ្មោះក្រេន បានចូលរួម [ពិធីចូលរៀនរបស់ម៉ឹង វេត] "]។ ឯកសារ D59/2/4.16a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សេង សឿន ERN KH 00059307 ["ខ្ញុំបានមកដល់នៅពេលដែលមឿននិងខុនត្រូវបានចាប់ខ្លួនហើយអឿងនៅតែនៅទីនោះ។ គាត់គឺដូចជាអនុប្រធានយោធាហើយបានក្លាយជាប្រធានយោធានៅក្នុងវិស័យនេះបន្ទាប់ពីអ្នកទាំងពីរ [មឿននិងខុន] ត្រូវបានគេចាប់ខ្លួន [...] អឿងទទួលបន្ទុកកងទ័ព"]។

367 ឯកសារ D114/297.1.27 សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៦ 14.17.50-14.19.31 [ ផ្តល់សក្ខីកម្មថា "មាសមុតខ្លួនឯងដែលបានបញ្ជាឱ្យអ្នកនាំសាររបស់គាត់សម្លាប់លោកម៉ៅ អឿង" ដែលជាអតីតមិត្តភ័ក្ត្រនៃសាក្សីមកពីភូមិកំណើតរបស់គាត់។ មាសមុត បានប្រាប់សាក្សីដោយផ្ទាល់ថា "គាត់បានដោះស្រាយរឿងនេះរួចហើយ"]។ ឯកសារ D114/169 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.២៧-៣០ [ដោយបញ្ជាក់ថាពីរឬបីថ្ងៃបន្ទាប់ពីគាត់បានមកដល់ខេត្តក្រចេះ លោកមាសមុតបានបញ្ជាឱ្យប្រតិបត្តិរឿងអឿងភ្លាមៗ។ មុតបានហៅសាក្សីនេះទៅការិយាល័យរបស់គាត់ប្រាប់គាត់ថា " ខ្ញុំបានបញ្ជារួចហើយដើម្បីដោះស្រាយរឿងរបស់អឿង"។ សាក្សីបានពន្យល់ថា "មុតមិនបានធ្វើវាដោយខ្លួនឯងទេ: អង្គរក្សរបស់គាត់បានបាញ់សម្លាប់គាត់"]។

124. មាស មុត ក៏ទទួលខុសត្រូវផងដែរ ចំពោះការដែលទ័ពរបស់គាត់បានបាញ់ និងសម្លាប់កម្លាំងយុទ្ធជនណាដែលដកថយ យោងតាមគោលនយោបាយមជ្ឈិមបក្ស[368]។ យុទ្ធជនទាំងនោះ"ត្រូវបានចោទថា មិនស្នេហាជាតិ មិនដាច់ខាត និងមិនមានការប្ដេជ្ញាខ្ពស់" ដោយសារបានដកថយពីការប្រយុទ្ធនៅព្រំដែនវៀតណាម[369]។ លើសពីនេះទៀត មាស មុត ក៏បានតំណាងឱ្យមជ្ឈិមបក្សផង

[368] ឯកសារ D4.1.849 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃុំ គីម ឆ.៥ [បានរៀបរាប់ពីកិច្ចប្រជុំជាមួយ នួនជានៅក្នុងឆ្នាំ ១៩៧៧ដែលគាត់បានប្រកាសថាការលុកលុយរបស់វៀតណាមចូលទៅក្នុងប្រទេសកម្ពុជាគឺ "បណ្ដាលមកពីសត្រូវដែលលុកលុយពីក្នុងជួរកងទ័ព និងរដ្ឋបាលរបស់ខ្មែរក្រហមដែលបានសហការជាមួយពួកយួន" ដោយបន្ថែមថាអ្នកដែលនៅក្នុងជួរកងទ័ព ត្រូវតែព្យាយាម" ល្អបំផុតដើម្បីការពារទឹកដី [កម្ពុជាប្រជាធិបតេយ្យ] ហើយថាប្រសិនបើពួកគេ "បាត់បង់ដីមួយអ៊ីញ" ពួកគេជា "ជនក្បត់"]។ ឯកសារ D4.1.791 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ ជាតិ ERN KH 00389513 ['នៅពេលនោះពួកគេបានចេញបទបញ្ជាដ៏តឹងរឹងមួយដែលយើងមិនត្រូវបរាជ័យក្នុងការប្រយុទ្ធឬប្រសិនបើយើងត្រូវចាញ់យើងត្រូវតែមានហេតុផលច្បាស់លាស់។ និយាយជាទូទៅយើងមិនត្រូវបានអនុញ្ញាតឱ្យដកខ្លួនចេញទេ។ ប្រសិនបើយើងដកខ្លួនយើងត្រូវតែមានហេតុផល"]។ ឯកសារ D32/4 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុផល ឆ.៥៧ ["នៅពេលណាដែលយោធា និងកម្មាភិបាលភូមិភាគបូព៌ាដកថយពីសមរភូមិ យោធាកណ្ដាលនៅចាំទីនោះ ចាប់ពួកនោះនិងសម្លាប់នៅទីនោះតែម្ដង"]។

[369] ឯកសារ D54/50 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ឆ.៤, ៥, ៨ [មេបញ្ជាការកងពលធំទី ១ បានទទួលដំណឹងពីកងពលធំលេខ ១ ដែលបានដកខ្លួនចេញពីការប្រយុទ្ធគ្នានៅព្រំដែនវៀតណាមដែលពួកគេត្រូវបានគេដេញតាមនិងវាយប្រហារដោយកងកម្លាំងយោធា [...] កងពល១៦៤ ក្រោមការដឹកនាំរបស់មាស មុត។ គាត់បានពន្យល់ថា " កងពលលេខ១មិនអាចទប់ទល់ជាមួយទ័ពយួនបាន កងពលលេខ១៦៤បានរើកងពលលេខ១ ដោយចោទថាយើងមិនស្នេហាជាតិ មិនដាច់ខាត និងមិនមានការប្ដេជ្ញាខ្ពស់ [...] ឆ.៥: នៅពេលដែលយួនវាយខ្លាំងមកលើខ្សែត្រៀមរបស់កងពលលេខ១ យោធារបស់កងពលលេខ១មួយចំនួនបានដកថយ ពេលដែលកងពលលេខ១៦៤បានឃើញយោធាកងពលលេខ១ដកថយ គេក៏បានបាញ់ និងផ្ដោងគ្រាប់ដាក់យោធាដែលកំពុងដកថយទាំងនោះ [...] បើយោធានៅខ្សែត្រៀមខាងមុខដកថយនោះ កងមជ្ឈិមនេះនឹងចាប់ ឬក៏បាញ់ពួកនោះហើយ ពីព្រោះគេមិនចង់ឱ្យយើងដកថយពីសមរភូមិមុខទេ [...] ឆ.៨:តាមដែលខ្ញុំដឹង មានយោធារបួសប្រហែលបីបួននាក់ និងស្លាប់បួនប្រាំនាក់ ប៉ុន្តែមួយចំនួនទៀតបានលង់ទឹកស្លាប់នៅពេលពួកគេបានហែលទឹកឆ្លងទន្លេ ពេលដែលពួកយោធាកងពលលេខ១៦៤ដេញបាញ់ពីក្រោយ"]។ ឯកសារ D54/50 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ឆ.៦ ["ស: ហេតុដូចម្ដេចបានជាលោកដឹងថាមុខងាររបស់កងពល១៦៤ គឺជាអ្នកទទួលខុសត្រូវក្នុងការការពារមិនឱ្យយោធាកងពលដទៃទៀតដកថយ? ឆ.៦: តាមដែលអ្វីយើងដឹង កងពល១៦៤ ជាកងពលមកពីមជ្ឈិម ហើយមានអំណាចលើកងពលផ្សេងៗទៀត។ កងពលលេខ១៦៤នេះស្ថិតនៅក្រោមបញ្ជាផ្ទាល់របស់តាមុត។ កងពលនេះទទួលខុសត្រូវខាងផ្នែកសមរភូមិ និងមុខព្រួញឱ្យកងពលដទៃទៀតឱ្យទៅឈរជើង។ ដោយសារកងពលនេះជារបស់មជ្ឈិម គេមានសិទ្ធិចាប់ និងបាញ់សម្លាប់យោធាកងពលណាដែលដកថយពីសមរភូមិមុខ"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ ERN KH 00955508 ["ស: តើវាជាបញ្ជាពីកងពលដើម្បីចាប់ខ្លួននិងសំលាប់ពួកគេឬតើអ្នកធ្វើដោយខ្លួនឯងទេ?

ដែរ ខណៈដែលគាត់ផ្លាស់ទៅមេមុត ក្នុងពេលដំណាលគ្នានេះ មកដឹកនាំកម្លាំងកងពល ១៦៤ និងមជ្ឈិម បង្ក្រាបពួកបះបោរនៅភូមិភាគបូព៌ា[370]។ ភស្តុតាងបន្ថែមទៀតដែលគាំទ្រថា មាស មុត ចូលរួមក្នុងការបោសសម្អាតយុទ្ធជនកងទ័ពបដិវត្តន៍កម្ពុជា ក្នុងកងពលផ្សេងៗក្រៅពីកងពល ១៦៤ គឺ គាត់បានទទួលស្គាល់ថា បានទៅក្រចេះ "បំពេញបេសកកម្មមួយទៀត" ក្នុងឆ្នាំ ១៩៧៨[371]។

## ជនជាតិវៀតណាម

125. ក្នុងការអនុវត្តគោលនយោបាយប.ក.ក មាស មុត បានគាំទ្រ និងចូលរួមយ៉ាងសកម្ម ក្នុងការចាប់មនុស្ស ដាក់មន្ទីរឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់អ្នកមានសញ្ជាតិវៀតណាម ជាតិពន្ធុវៀតណាម ឬអ្នកណាផ្សេងដែលសង្ស័យថាជាវៀតណាម។ អំពើនេះបានប្រព្រឹត្តនៅដែនទឹកកម្ពុជា លើកោះ នៅតំបន់កំពង់សោម និងនៅមន្ទីរស-២១ នៅភ្នំពេញ។

126. ក្នុងឋានៈជាមេបញ្ជាការជើងទឹក មាស មុត តាមរយៈកងពល ១៦៤ និងជាពិសេស កងពល១៤០ ប្រើវ៉ាដាដើម្បីពិនិត្យដែនសមុទ្រកម្ពុជា ហើយបញ្ជូនកប៉ាល់ទៅចាប់ទូកដែលកំណត់ថាបានចូលមក

---

ឆ: វាជាការបញ្ជាពីកងពល។ ស: តើអ្នកណាបានបញ្ជានោះ? ឆ: អ្នកបញ្ជាមកពីតាមុត។ ស: តើវាជាការបញ្ជាឱ្យសម្លាប់ដែរឬទេ? ឆ: បាទ"]។

370 ឯកសារ D54/87 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត់ ឆ.៧៥-៧៦, ៨៤ ["ខ្ញុំបានឮអំពីរឿងនេះពីមេបញ្ជាការកងវរៈសេនាធំរបស់ខ្ញុំថា លោក សុន សេន បានបញ្ជាឱ្យមាស មុត ដឹកនាំទ័ពទៅបង្ក្រាបពួកបះបោរនៅភូមិភាគបូព៌ាដែលដឹកនាំដោយ សោ ភឹម។ ដូចដែលលោកជ្រាបខាងលើ សត្រូវ និងខ្មាំងទី១របស់កម្ពុជាប្រជាធិបតេយ្យគឺវៀតណាម និងទី២គឺខ្មាំងផ្ទៃក្នុង។ ខ្ញុំបានឮហេតុការណ៍បង្ក្រាបមួយនេះពី សុន សេន កាលដែលខ្ញុំទៅរៀនវគ្គអប់រំរបស់អគ្គសេនាធិការនៅភ្នំពេញ។ សុន សេន បានបញ្ជាក់ថា សោ ភឹមត្រូវបានបង្ក្រាបហើយ។ ស: តើសុន សេន បាននិយាយប្រាប់លោកថា មាស មុតទៅស្រុកមេមត់ធ្វើអ្វីដែរឬទេ? ឆ.៧៦: នៅចុងឆ្នាំ១៩៧៨ មាស មុតបានទៅស្រុកមេមត់ ដើម្បីធ្វើការបញ្ជាការនៅពេលដែលមានហេតុការណ៍ផ្ទៃក្នុងនៅភូមិភាគបូព៌ា [...] ស: តើលោកដឹងអំពីកងទ័ពដែល មាស មុតនាំទៅជាមួយគាត់ទៅស្រុកមេមត់ដែរឬទេ? ឆ.៨៤: ខ្ញុំមិនដឹងទេ ខ្ញុំគ្រាន់តែដឹងថា មាស មុតទៅជាមួយយោធាខ្លះមកពីកំពង់សោម យោធាខ្លះទៀតមកពីសេនាធិការ តែខ្ញុំមិនដឹងអំពីកង លេខអង្គភាព និងមេបញ្ជាការទាំងនោះទេ"]។

371 ឯកសារ D54/16/1R បទសម្ភាសន៍មាស មុត ជាមួយដេវីដ ខេចែនបឺហ្គ ឆ្នាំ២០០៩ 33:32-35:26 ["ខ្ញុំនៅខែកុម្ភៈឆ្នាំ ១៩៧៩ ខ្ញុំបានចាកចេញពីកំពង់សោមរួចហើយ។ ស: តើគាត់ទៅណា? ឆ: ខ្ញុំត្រូវបានគេចាត់តាំងឱ្យធ្វើការនៅខេត្តក្រចេះជិតព្រំដែនឡាវ។ ស: ដូច្នេះគាត់បានចាកចេញពីកងពល១៦៤ ទាំងស្រុងនៅខែកុម្ភៈឆ្នាំ ១៩៧៨? ឆ: ទេខ្ញុំនៅតែមានតំណែងរបស់ខ្ញុំ ប៉ុន្តែខ្ញុំត្រូវបានចាត់តាំងឱ្យបំពេញបេសកកម្មមួយផ្សេងទៀត"]។

ក្នុងដែនសមុទ្រកម្ពុជា។ មាស មុត ចេញបញ្ជាឲ្យកម្មាភិបាលក្រោមបង្គាប់របស់គាត់ចាប់ ហើយបញ្ជូន ឬសម្លាប់ជនបរទេសដែលធ្វើដំណើរតាមទូកទាំងនោះ។ គាត់លើកទឹកចិត្ត និងបញ្ជាសម្លាប់វៀតណាមដែលចាប់បាន នៅមន្ទីរសន្តិសុខ ឬទីតាំងសម្លាប់មនុស្ស នៅតំបន់កំពង់សោម ឬនៅស-២១ ដែលគាត់បានបញ្ជូនវៀតណាមទៅសម្លាប់យ៉ាងហោចណាស់១៩៤នាក់[372]។

127. ជាពិសេស ការចាប់ខ្លួន និងសម្លាប់វៀតណាម នៅតំបន់កំពង់សោម នៅស-២១ នៅលើកោះ និងនៅសមុទ្រ បានប្រព្រឹត្តទៅ ដោយអនុលោមតាមគោលនយោបាយជាតិរបស់ប.ក.ក ស្តីពីការកំណត់គោលដៅ និងសម្លាប់បុគ្គលទាំងឡាយណាដែលជាវៀតណាម នៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ មាស មុត បានដឹងពីគោលនយោបាយនេះ តាមរយៈសេចក្តីថ្លែងការណ៍របស់មេដឹកនាំជាន់ខ្ពស់របស់ប.ក.ក និងឯកសារគោលនយោបាយប.ក.កសំខាន់ៗ ដូចជា ទស្សនាវដ្តី *ទង់បដិវត្តន៍* ដែលក្នុងនោះ ប្រជាជនវៀតណាម ត្រូវបានប្រមាថជាសត្វធាតុ ហើយរៀបរាប់ដោយលក្ខណៈស្អប់ខ្ពើម។

128. ឧទាហរណ៍ នៅខែមេសាឆ្នាំ១៩៧៧ មជ្ឈិមបក្សបានហៅវៀតណាមថា ជា"ខ្មែបម្រើខ្មាំង" ដែល "ត្រូវខ្ចាត់ខ្ចាយរប៉ាត់រប៉ាយជាមូលដ្ឋាន ប្រៀបដូចកណ្តុរត្រូវបំបែកសំបុកធ្លាក់ទឹក ហើយកំពុងត្រូវប្រជាជនដេញសំពង វិនាសអន្តរធាន"[373]។ ក្នុងឯកសារបោះផ្សាយនេះ បក្សបានណែនាំកម្មាភិបាលថា៖ "យើងត្រូវបន្តវាយវាតទៅទៀត ជាន់វាថែមទៀត [...] ក្នុងឋានៈយើងមានប្រៀបដាច់ខាត វាយសំរុកជាប់ជានិច្ចក្នុងមួយឆ្នាំ១៩៧៧ នេះ ឲ្យវាកាន់តែខ្ទេចខ្ទីតទៅទៀត ងើបក្បាលមិនរួច"[374]។

---

372 សូមមើល ជំពូក ៨.ខ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សដែលចាប់បានដោយកងទ័ពជើងទឹកនៅដែនទឹក និងលើកោះដែលទាមទារដោយកម្ពុជាប្រជាធិបតេយ្យ។ ឯកសារ ជំពូក ៨.គ.៤ មន្ទីរសន្តិសុខទឹកសាប។ ឯកសារ ជំពូក ៨.ច កន្លែងធ្វើការនៅរាម-៣. ឧក្រិដ្ឋកម្ម-ឃាតកម្ម , ការសម្លាប់រង្គាល និងការអនុវត្តនៃការបាត់ខ្លួន។ ឧបសម្ព័ន្ធ D.5.

373 ឯកសារ D4.1.862 ទង់បដិវត្ត ខែមេសា ឆ្នាំ១៩៧៧ ERN KH 00062984 ["ចំពោះសត្រូវដែលជាភ្នាក់ងាររបស់[យួន] សត្រូវជាខ្មែថោកដែលកំពុងរត់ [...] កម្លាំងដែលនៅសល់ត្រូវបានគេបែកខ្ញែកជាមូលដ្ឋានដូចជាកណ្តុរត្រូវបានវាយនិងធ្លាក់ពីសំបុករបស់ពួកគេចូលក្នុងទឹកហើយ ដេញតាមនិងវាយប្រហារដោយមនុស្សហើយបំផ្លាញ"]។

374 ឯកសារ D4.1.862 ទង់បដិវត្ត ខែមេសា ឆ្នាំ១៩៧៧ ERN KH 00062984 ["យើងត្រូវបន្តវាយធ្វើបាបពួកគេនិងជាន់ពន្លិចពួកគេពីតួនាទីរបស់យើងដែលមានអត្ថប្រយោជន៍ទាំងស្រុង និងត្រូវតែបន្តការប្រឆាំងនឹងពួកគេក្នុងឆ្នាំ ១៩៧៧ ដើម្បីវាយលុកពួកគេកាន់តែខ្លាំងឡើង ដូច្នេះពួកគេមិនអាចងើបក្បាលរបស់ពួកគេបានឡើយ"]។

129. ការបញ្ចេញសំដីស្អប់ខ្ពើមវៀតណាមបន្តកាន់តែខ្លាំងឡើង ក្រោយពេលរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យផ្តាច់ទំនាក់ទំនងការទូតជាមួយប្រទេសវៀតណាម នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧។ ទស្សនាវដ្តី *ទង់បដិវត្តន៍* [375] និងការផ្សាយវិទ្យុ[376] ចាប់ពីឆ្នាំ ១៩៧៨ មានលើកឡើងពីសារទាំង

---

[375] ឯកសារ D4.1.868 ទង់បដិវត្ត ខែមេសា ឆ្នាំ១៩៧៨ ERN KH 00064706 ["បទបង្ហាញរបស់សមមិត្តលេខា [បក្សកុម្មុយនីស្តយ៍កម្ពុជា] ក្នុងឱកាសខួបឆ្នាំទី ៣ នៃជ័យជំនះដ៏ធំថ្ងៃទី ១៧ ខែមេសា"]។ សូមមើលផងដែរ ឯកសារ D1.3.24.5 ទង់បដិវត្ត ខែឧសភា-មិថុនា ឆ្នាំ១៩៧៨ ERN KH 000664551 ["ការសង្ខេបរឿងរ៉ាវរបស់ភាគីម្ខាងទៀតគឺផ្ទុយពីយើងគឺ សេអ៊ីអា, យួន និង កាហ្សេបេ ហើយក្នុងចំនោមទាំងនេះយួនគឺគ្មានគ្រោះថ្នាក់និងស្រួចស្រាវបំផុត។ ការបន្តពីការវិភាគនៃភាពផ្ទុយគ្នានៃជីវិតនិងទំនាស់ស្រួចស្រាវនេះតើវិធានការវាយប្រហាររបស់យើងគឺជាអ្វី? ១. ការវាយប្រហារដ៏ស្រួចស្រាវបំផុតរបស់យើងគឺនៅលើការឈ្លានពានទឹកដីរបស់យួន។ ២. នៅពេលដូចគ្នានេះដែរយើងវាយប្រហារ សេអ៊ីអា និង កាហ្សេបេ។ យើងវាយប្រហារក្នុងពេលដំណាលគ្នាប៉ុន្តែយើងយកចិត្តទុកដាក់បំផុតដើម្បីវាយប្រហារយួនដោយព្រោះតែវាជាជាតិពុលនិងស្រួចស្រាវបំផុត"]។ ឯកសារ D4.1.869 ទង់បដិវត្ត ខែកក្កដា ឆ្នាំ ១៩៧៨ ERN KH 00064485 ["កាតព្វកិច្ចជាតិរបស់យើងទាំងអស់គ្នាដើម្បីតស៊ូប្រយុទ្ធដើម្បីលុបបំបាត់សត្រូវរបស់យើងដែលឈ្លានពាន វាតទី និងលុកលុយលេបត្របាក់ពីសំណាក់យួន។ ដូចជាពួកកម្ពុជាជំនាន់បច្ចុប្បន្នដែរ គ្មានខ្មែរកម្ពុជាជំនាន់ក្រោយៗណាមួយនឹងដាក់អាវុធចុះហើយបញ្ឈប់ការប្រយុទ្ធប្រឆាំងនឹងសត្រូវឈ្លានពាននិងបំផ្លិចបំផ្លាញនិងលេបត្របាក់ទឹកដីពីសត្រូវនៃពូជសាសន៍កម្ពុជាដោយប្រល័យពូជសាសន៍យួន"]។

[376] ឯកសារ D4.1.617 របាយការណ៍ការពារជាតិកាលពីឆ្នាំមុនត្រូវបានពិនិត្យឡើងវិញ ថ្ងៃទី ១០ ខែឧសភា ឆ្នាំ១៩៧៨ ERN KH 00340547 ["បក្សបានណែនាំថា យើងត្រូវតែព្យាយាមបំផ្លាញខ្មាំងឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន និងដើម្បីរក្សាកងកម្លាំងយើងឲ្យបានអតិបរមា [...] នេះជាពាក្យស្លោករបស់យើង គិតតាមចំនួន យើងម្នាក់ត្រូវសម្លាប់វៀតណាម៣០នាក់"]។ ERN KH 00340551 ["យើងត្រូវបោសសំអាតកងកម្លាំងប្រដាប់អាវុធរបស់យើង គណបក្សរបស់យើងនិងប្រជាជន ដើម្បីបន្តប្រយុទ្ធប្រឆាំងនឹងសត្រូវក្នុងការការពារទឹកដីកម្ពុជានិងជាតិសាសន៍កម្ពុជា ប្រសិនបើយើងមិនធ្វើដូច្នេះពូជសាសន៍របស់យើងនឹងរលាយបាត់"]។ សូមមើលផងដែរ ឯកសារ D69.1.21 សន្ទរកថារបស់ខៀវ សំផន ថ្ងៃទី ១៥ ខែមេសា ឆ្នាំ១៩៧៨ ERN KH 00704519 ["យើងខ្ញុំមានមោទនភាពចំពោះកងទ័ពបដិវត្តន៍យើង យើងខ្ញុំសូមសំដែងនូវការដឹងគោរព និងកោតស្ញប់ស្ញែងជាខ្លាំងចំពោះពួកគេ ដោយហេតុថាពួកគេគឺជាសសរទ្រូងដ៏រឹងមាំសម្រាប់ការពារឯករាជ្យភាព អធិបតេយ្យភាព បូរណភាពដែនដី កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ជាតិ ព្រមទាំងជាតិសាសន៍កម្ពុជា"]។

ឡាយ ដូចជា សុន្ទរកថារបស់ប៉ុលពតថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៨[377] ដែលក្នុងនោះ គាត់បាន អំពាវនាវឲ្យរាល់ខ្មែរម្នាក់សម្លាប់វៀតណាមឲ្យបាន៣០នាក់[378]។

130. ចេតនា របស់ មាស មុត ក្នុងការអនុវត្តគោលនយោបាយជាតិនេះ បានបញ្ជាក់ច្បាស់ក្នុងទូរលេខ ដែលគាត់បានបញ្ជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍ តាមរយៈមន្ទីរ៨៧០ ដែលក្នុងនោះ គាត់សរសេរ ថា៖

> យើងបានទទួលមតិណែនាំ និងសេចក្តីថ្លែងការណ៍របស់បក្ស ស្តីពីការឈ្លានពានរបស់យួន មកលេបទឹកដីមាតុភូមិកម្ពុជារបស់យើង។ យើងខ្ញុំដែលមានភារកិច្ចការពារមុខសញ្ញាសមុទ្រ សូម៖ ១. ឯកភាពទាំងស្រុងជាមួយបក្ស [...] ហើយការពាររដ្ឋអំណាច កម្មករ កសិករ សមូហភាព និងការពារមាតុភូមិកម្ពុជា សង្គមនិយមដាច់ខាត។ ដោយបោសសម្អាត គ្មានស្មាក់ស្មើរសមាសភាពបង្កប់របស់ខ្មាំងជាយួន និងខ្មាំងដទៃទៀត[379]។

---

377 ឯកសារ D114/277.9 កាំង ហ្គិចអ៊ាវ ហៅ ឌុច ប្រតិចារឹក ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៦ 13.51.23-13.59.16 [បញ្ជាក់ថាគាត់បានស្តាប់ការធ្វើបទបង្ហាញនៅក្នុងឯកសារទង់បដិវត្តន៍ D4.1.868 នៅថ្ងៃទី ១៧ ខែមេសាឆ្នាំ ១៩៧៨ ជាការប្រមូលផ្តុំដែលគាត់បានចូលរួម]។

378 ឯកសារ D4.1.869 ទង់បដិវត្ត ខែមេសា ឆ្នាំ១៩៧៨ ERN KH 00064485 ["គណបក្សបានធ្វើការប្តេជ្ញាចិត្តដើម្បីវាយប្រហារនិងកម្ទេចកងកម្លាំងជីវិតរបស់សត្រូវធំ ១ និងការពារកងកម្លាំងរបស់យើងឱ្យបានច្រើនបំផុត [...] នេះគឺជាពាក្យស្លោករបស់យើង។ សម្លឹងមើលតួលេខនេះ យើងម្នាក់ត្រូវតែប្រយុទ្ធនឹងយួន៣០នាក់។ ប្រសិនបើយើងអាចអនុវត្តពាក្យស្លោកនេះយើងឈ្នះ [...] ដូច្នេះនៅពេលយើងមាន ២,000,000 ហើយយើងមានច្រើនជាងយើងត្រូវការដើម្បីប្រយុទ្ធជាមួយពួកគេដោយសារតែពួកគេមានត្រឹមតែ ៥0.000.000 ប៉ុណ្ណោះ។ យើងមិនចាំបាច់ប្រើ ៨,000,000 ទេ។ យើងអាចប្រើកំលាំងបានត្រឹមតែ ២,000,000 ដើម្បីប្រយុទ្ធនិងវាយបំបែកយួន ហើយនៅតែសល់ ៦,000,000 ទៀត"]។ សូមមើលផងដែរ ឯកសារ D1.3.25.33, FBIS សេចក្តីថ្លែងការណ៍របស់ខៀវ សំផន នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៧៧ ERN KH 00229014 ["បានលើកឡើងម្តងទៀតទៅលើ "នៅពេលសត្រូវ១00នាក់ត្រូវបានសម្លាប់ឬរងរបួស យើងត្រូវស្លាប់ឬរងរបួសតែ៣ ឬ៥នាក់ប៉ុណ្ណោះ" ដែលអាចជាប្រភពដើមនៃការនិយាយ 30: 1 នៅក្នុងសុន្ទរកថារបស់ប៉ុល ពត]។

379 ឯកសារ D1.3.34.60 ទូរសារ 00 ពីមាស មុត ទៅកាន់ការិយាល័យ ៨៧0 ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៧៧ EN 00184995។

131. មាស មុត បានហ្វឹកហ្វឺនដល់យោធាថ្នាក់ក្រោមនូវមនោគមវិទ្យា ប.ក.ក ស្តីអំពីខ្មាំងខាងក្រៅ[380] ប្រាប់យោធាគាត់ថា "កុំឲ្យចាញ់ល្បិចកលវៀតណាម"[381]។ នៅក្នុងពេលប្រជុំ និងវគ្គរៀនសូត្រ

[380] ឯកសារ D54/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ឆ.៣១-៣៤ ["តាមគំនិតរបស់លោក ថាតើវាខុស ឬត្រូវ ចំពោះការសម្លាប់អ្នកដែលចាប់បាន? ឆ.៣១: ខ្ញុំគិតថា វាខុសទាំងស្រុង ពីព្រោះប្រជាជនទាំងអស់នោះមិនដឹងអ្វីទាំងអស់ ពួកគេគឺគ្រាន់តែរត់គេចពីសង្គ្រាម ដើម្បីរស់រានមានជីវិតតែប៉ុណ្ណោះ។ ប៉ុន្តែនៅពេលនោះ ខ្មែរក្រហមគិតថា ពួកយួន ជាសត្រូវស្នូរពូជ [...] ឆ.៣២: ថៃមិនមានទំនាស់ច្រើនជាមួយខ្មែរទេនៅក្នុងប្រវត្តិសាស្ត្រ ប៉ុន្តែយួនមានទំនាស់ជាមួយខ្មែរច្រើន ទើបយួនត្រូវបានចាត់ទុកថាជា សត្រូវស្នូពូជ និងសត្រូវទី១។ សៈ ហេតុអ្វីបានជាលោកដឹងអំពីរឿងអស់ទាំងនេះ? ឆ.៣៣: ពីព្រោះមេបញ្ជាការកងវរសេនាតូច និងវរសេនាធំទៅរៀនសូត្រជាមួយនឹងកងពល ហើយពេលគេត្រឡប់មកវិញ គឺគេបានបង្រៀនយើងអំពីរឿងនេះនៅក្នុងវគ្គអប់រំរៀនសូត្រ។ សៈ តើអ្នកណាជាអ្នកទទួលខុសត្រូវរួមក្នុងផ្នែកអប់រំនយោបាយនៅក្នុងកងពល១៦៤ ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩? ឆ.៣៤: គឺ មាស មុត ដែលជាស្នងការនយោបាយរបស់កងពល"]។ ឯកសារ D114/284 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ .៣-៧ ["សៈ ចង់និយាយបញ្ជាក់លោកថា យើងយល់ក្នុងរឿងនេះ ប៉ុន្តែយើងដឹងថាដូចលោកជាយោធាម្នាក់បម្រើការងារហ្នឹង គេមានអង្គការលើ គេមានគោលនយោបាយរបស់គេដាក់មកថា ត្រូវសម្លាប់ឬកម្ទេចយួន។ តើគេសំដៅថាដោយសារឲ្យតែថាជាតិសាសន៍យួន ឬសញ្ជាតិយួនខាងត្បូង ឬខាងជើង ក្មេង ចាស់ ឬទេ? ឆ.៣: យើងត្រូវតែគោរពវិន័យ គោរពបទបញ្ជា។ យើងមិនសំដៅតែលើយួនខាងត្បូង ខាងជើង ក្មេង ចាស់គឺអត់ទេ ឲ្យតែយួន។ សៈ សារទូរលេខដែលតាមុតផ្ញើទៅអង្គការលើ ឯកសារ D 1.3 .34.60 ជាភាសាអង់គ្លេស 00184995 និងជាភាសាខ្មែរ 00001325។ សារទូលេខគឺពាក់ព័ន្ធនឹងប្រធានបទពួកយួនហ្នឹង។ តើរបៀបដែលគេបញ្ចូលមនោគមន៍វិជ្ជារបស់យើងហ្នឹង គេធ្វើដូចម្តេចដល់ទាហានថ្នាក់ក្រោមៗហ្នឹង? ឆ.៤: វាត្រូវដូចខ្ញុំនិយាយមែន វាត្រូវៗ។ ដាច់ខាតអ៊ីចឹង មិនខុសពីក្នុងហ្នឹងទេ។ បោសសម្អាតផ្ទៃក្នុងផង និងកម្ចាត់ផងគឺដាច់ខាត។ សៈ ចង់ឲ្យលោកពន្យល់ ដែលគេនិយាយបោសសម្អាត ឬកម្ទេច គេចង់និយាយថាម៉េច ជាភាសាសាមញ្ញរបស់យើង? ឆ.៥: អ្នកដែលមានការពាក់ព័ន្ធជាខ្មែរ កងទ័ពគេនិយាយបោសសម្អាតក្នុងកងទ័ព ដែលខ្សែរយៈជាយួន ប៉ុន្តែមិនថាខ្សែណាៗទេ។ បោសសម្អាតផ្ទៃក្នុងគឺក្នុងកងទ័ព។ សៈ ពាក្យសម្តីដែលលោកបានមើល ពាក្យសម្តីដែលគេនិយាយនៅក្នុងទូរលេខហ្នឹង ដូចពាក្យសម្តីដែលគេបង្រៀនយើងកាលប្រជុំទេ? ឆ.៦: ដូច ដូចទាំងស្រុងតែម្តង។ សៈ យូរហើយក៏ដោយ ប៉ុន្តែយើងចង់ដឹង លោកនៅចាំទេ លោកធ្លាប់ប្រជុំ ពេលដែលតាមុត បើកអង្គប្រជុំនិយាយពីពួកក្បត់។ តើកាលពីពេលហ្នឹងតាមុត មានលើកនិយាយភាសាពាក្យពេជន៍ដូចគេនិយាយក្នុងឯកសារនេះទេ? ឆ.៧: ដូចៗ ទាំងស្រុងតែម្តង"]។ ឯកសារ D114/95 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រឿង ឆ.២០២-២០៨ ["សៈ តើលោកធ្លាប់ជួបជាមួយមាស មុត ឬក៏ដែលឮពាក្យគាត់និយាយដែរឬទេ? ឆ.២០២: ខ្ញុំធ្លាប់ឃើញគាត់ នៅពេលដែលគាត់ចូលរួមប្រជុំ ប៉ុន្តែខ្ញុំមិនដែលនិយាយជាមួយគាត់ទេ។ សៈ តើគាត់ប្រជុំនៅពេលណា? ឆ.២០៣: ការប្រជុំអប់រំកងទ័ព ដែលគេធ្វើ១ឆ្នាំម្តង។ សៈ តើលោកបាននិយាយថាមួយឆ្នាំគេប្រជុំម្តង តើលោកបានចូលរួមប្រជុំតាំងពីឆ្នាំ៧៥ ដល់ឆ្នាំ៧៩ឬ? ឆ.២០៤: បាទ។ សៈ តើនៅក្នុងកិច្ចប្រជុំនោះ មាស មុត និយាយអំពីអ្វីដែរ? ឆ.២០៥: គាត់បាននិយាយអប់រំកងទ័ព ស្តីពិការកសាងប្រទេស ការការពារប្រទេស និងពង្រឹងពីវិន័យកងទ័ពឲ្យបានម៉ឺងម៉ាត់ ទាំងកងទ័ពជើងទឹកនិង ជើងគោក។ សៈ តើមាស មុត មាននិយាយ

អំពីថាតើសត្រូវប្រភេទណាដែលយើងត្រូវប្រយុទ្ធជាមួយដែរឬទេ? ឆ.២០៦: គាត់មិនបាននិយាយអ៊ីចឹងទេ គាត់និយាយថា អ្នកណាក៏ដោយដែលប្រឆាំងគឺជាសត្រូវ។ សៈ តើពេលដែលគាត់និយាយពាក្យហ្នឹង គាត់សំដៅទៅលើជនជាតិបរទេស ឬក៏ជនជាតិខ្មែរ? ឆ.២០៧: គាត់និយាយទៅកាន់កងទ័ពខ្មែរ កុំឲ្យចាញ់បោកគេ ហើយកុំឲ្យក្បត់ក្នុងជួរយើង។ សៈ តើមាស មុត មាននិយាយទាក់ទងថា ឲ្យប្រយ័ត្នយ៉ាងម៉េចដែរ ចំពោះជនដែលបោកប្រាស់ជនជាតិខ្មែរ? ឆ.២០៨: គេចង់និយាយថា កុំឲ្យចាញ់ឧបាយកលវៀតណាម"]។ ឯកសារ D114/58 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ឆ.២៥-២៦ ["សៈ តើមានមនុស្សប៉ុន្មាននាក់ចូលរួមក្នុងវគ្គសិក្សានោះ? ឆ.២៥: មានប្រហែលពី៥០ទៅ៦០នាក់ មកពីអង្គភាពផ្សេងៗដែលចំណុះឲ្យកងពល១៦៤ ទាំងស៊ីវិល ទាំងយោធា។ សៈ នៅក្នុងវគ្គសិក្សានោះ តើមាស មុត ឬវាគ្មិនដទៃទៀតបាននិយាយអំពីស្ថានភាពខ្មាំង ទាំងខ្មាំងផ្ទៃក្នុង ទាំងខ្មាំងខាងក្រៅដែរឬទេ? ឆ.២៦: បាទ ប៉ុន្តែខ្ញុំមិនចាំទេ ហើយខ្ញុំក៏មិនយល់រឿងទាំងអស់នេះដែរ។ ពួកគេនិយាយអំពីកាហ្សេបេវៀតណាម និងភ្នាក់ងារជាដើម"]។ ឯកសារ D114/19 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ឆ.១៨, ២០ ["សៈ តើមានការណែនាំអ្វីខ្លះនៅក្នុងការប្រជុំនេះ ពាក់ព័ន្ធនឹងការការពារទឹកដីពីការចូលរួមនៃកប៉ាល់នេសាទនិងកប៉ាលបរទេស? ឆ.១៨: ការណែនាំគឺថា បើយើងឃើញកប៉ាល់នេសាទណាឆ្លងចូលក្នុងដែនទឹករបស់យើង ជិតៗព្រំដែនយើងមិនធ្វើអ្វីទេ ប៉ុន្តែកាណូតទាំងនោះចូលមកជ្រៅ ហើយយូរក្នុងដែនទឹកយើង យើងនឹងវាយប្រហារ(?)វៃភ្លាម។ រឿងនេះភាគច្រើនគឺកើតឡើងនៅកន្លែងរបស់ខ្ញុំ។ កន្លែងរបស់ខ្ញុំគឺនៅជិតព្រំដែនវៀតណាម ដូច្នេះពួកនេសាទដែលចូលមកនោះ គឺភាគច្រើនកាណូតវៀតណាម។ ពួកកាណូតនេសាទទាំងនោះ ភាគច្រើនគឺមានកាំភ្លើង និងសញ្ញាវុធ [...] សៈ តើអ្នកណាជាអ្នកផ្តល់ការណែនាំឲ្យវៃទូទាំងនោះ? ឆ.២០: បើតាមុត គាត់ជាអធិបតីនៅក្នុងពេលប្រជុំ គាត់ជាអ្នកចេញសេចក្តីណែនាំនេះ។ បើតាឌឹមជាអធិបតី គឺគាត់ជាអ្នកប្រាប់ការណែនាំនេះ"]។ ឯកសារ D54/12 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រេស មាន ឆ.២៧-៣២ ["សៈ តើលោកធ្លាប់បានឃើញតាមុតច្រើនដងដឬទេនៅស្ទឹងហាវ? ឆ.២៧: ខ្ញុំបានឃើញគាត់តែម្តងគត់ក្នុងពេលប្រជុំនោះ។ សៈ តើលោកមានចាំឬទេ ថាតាមុតមានបានថ្លែងទៅកាន់អង្គប្រជុំអំពីការងារនៅហ្នឹងការដ្ឋានវាយថ្ម ឬក៏ផែថ្ម ឬការដ្ឋានផ្សេងៗទៀតនៅស្ទឹងហាវ? ឆ.២៨: ខ្ញុំមិនអាចចាំថា គាត់និយាយអំពីការដ្ឋាននោះទេ។ តែខ្ញុំនៅចាំបានច្បាស់ថា គាត់បាននិយាយអំពីអ្នកដែលក្បត់បក្ស ហើយចំពោះអ្នកដែលត្រូវចោទថាក្បត់នោះត្រូវប្រមូលយកកទៅទុកមួយកន្លែង [...] ឆ.២៩: មាស មុត បាននិយាយថា អ្នកដែលធ្លាប់នៅក្នុងបក្សពលករដែលជាបក្សរបស់វៀតណាម គឺត្រូវចាត់ទុកថាជាពួកក្បត់។ សៈ តើតាមុត មានបាននិយាយឈ្មោះអ្នកណាខ្លះ ថាជាពួកក្បត់ឬទេនៅក្នុងអង្គប្រជុំនោះ? ឆ.៣០: បាទ គាត់បានប្រកាសថា តាញ៉ឹកជាលេខតំបន់៣៧ តាប៉ុននៅក្នុងគណៈតំបន់៣៧ និងឆាននៅក្នុងគណៈតំបន់៣៧ដែរ តែខ្ញុំមិនដឹងពីតួនាទីអ្នកទាំងពីនេះច្បាស់ទេ ហើយឌឹមជាអនុរបស់តាមុតនៃកងពល១៦៤ [...] សៈ តើតាមុតមានបានប្រាប់ថា គេយកពួកអ្នកទាំងនោះទៅណាដែរឬទេ? ឆ.៣១: ប្រសិនបើគេរកឃើញអ្នកក្បត់ ពួកគេត្រូវបានយកទៅបាត់ហើយ មុនពេលគេប្រកាស។ សៈ តើតាមុតមានបានពន្យល់ក្នុងអង្គប្រជុំថា តើមានរឿងអ្វីកើតឡើងចំពោះអ្នកដែលលោករៀបរាប់នេះដែរឬទេ? ឆ.៣២: គាត់បាននិយាយថាជាពួកក្បត់"]។ ឯកសារ D54/13 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រេស មាន ឆ.៤-៥, ១១-១២ ["សៈ ហេតុអ្វីបានជាតាមុតបើកកិច្ចប្រជុំឡើងនៅពេលនោះ? តើវាជាព្រឹត្តិការណ៍ពិសេសឬ? ឆ.៤: វាមិនមែនជាការប្រជុំជាប្រចាំទេ។ នៅឆ្នាំ១៩៧៧ស្ថានការណ៍នៅពេលនោះមានការច្របូកច្របល់ បក្សកុម្មុយនីស្តកម្ពុជាគាំទ្រដោយចិន ហើយបក្សពលករគាំទ្រដោយវៀតណាមមានពួកសេអ៊ីអា អាមេរិកាំង និងកាហ្សេបេ នៅក្នុងជាមួយប្រជាជនដែរ ដូច្នេះហាគេត្រូវសម្រិតសម្រាំងពួក

នយោបាយ គាត់ប្រើពាក្យញុះញង់សំដៅបង្កការស្អប់ខ្ពើមចំពោះវៀតណាម។ គាត់ហៅ វៀតណាម ថា "សត្រូវស្នូលពូជ" និង "សត្រូវលេខមួយ" ពន្យល់យុទ្ធជនគាត់ថា "ថៃមិនមានទំនាស់ច្រើនជាមួយខ្មែរទេក្នុងប្រវត្តិសាស្ត្រ ប៉ុន្តែយួនមានទំនាស់ជាមួយខ្មែរច្រើន ទើបយួនត្រូវបានចាត់ទុកជាសត្រូវស្នូលពូជ និងសត្រូវលេខ១"[382]។

សមាសភាពទាំងនោះចេញ។ សៈ តើនេះជាគំនិតរបស់លោកផ្ទាល់ឬក៏គេប្រាប់លោក? ឆ.៩: តាមុតបានប្រកាសនៅក្នុងអង្គប្រជុំ [...] សៈ តើមានតែតាមុតម្នាក់ដែលនិយាយក្នុងអង្គប្រជុំ ឬក៏មានកម្មាភិបាលផ្សេងទៀតនិយាយដែរ? ឆ.១១: មានតែតាមុតម្នាក់គត់។ សៈ តើមានថ្នាក់ដឹកនាំកងពល១៦៤ផ្សេងទៀតមកជាមួយគាត់ដែរឬទេ? ឆ.១២: គឺមានតែគាត់ម្នាក់ និងកងការពាររបស់គាត់តែប៉ុណ្ណោះ"]។

381 ឯកសារ D114/95 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រៀង ឆ.២០២-២០៨ ["សៈ តើលោកធ្លាប់ជួបជាមួយមាស មុត ឬក៏ដែលឮពាក្យគាត់និយាយដែរឬទេ? ឆ.២០២: ខ្ញុំធ្លាប់ឃើញគាត់ នៅពេលដែលគាត់ចូលរួមប្រជុំ ប៉ុន្តែខ្ញុំមិនដែលនិយាយជាមួយគាត់ទេ។ សៈ តើគាត់ប្រជុំនៅពេលណា? ឆ.២០៣: ការប្រជុំអប់រំកងទ័ព ដែលគេធ្វើ១ឆ្នាំម្តង។ សៈ តើលោកបាននិយាយថា មួយឆ្នាំគេប្រជុំម្តង តើលោកបានចូលរួមប្រជុំតាំងពីឆ្នាំ៧៥ ដល់ឆ្នាំ៧៩ឬ? ឆ.២០៤: បាទ។ សៈ តើនៅក្នុងកិច្ចប្រជុំនោះ មាស មុត និយាយអំពីអ្វីដែរ? ឆ.២០៥: គាត់បាននិយាយអប់រំកងទ័ព ស្តីពីការកសាងប្រទេស ការការពារប្រទេស និងពង្រឹងពីវិន័យកងទ័ពឲ្យបានម៉ឺងម៉ាត់ ទាំងកងទ័ពជើងទឹកនិង ជើងគោក។ សៈ តើមាស មុត មាននិយាយអំពីថាតើសត្រូវប្រភេទណាដែលយើងត្រូវប្រយុទ្ធជាមួយដែរឬទេ? ឆ.២០៦: គាត់មិនបាននិយាយអ៊ីចឹងទេ គាត់និយាយថា អ្នកណាក៏ដោយដែលប្រឆាំងគឺជាសត្រូវ។ សៈ តើពេលដែលគាត់និយាយពាក្យហ្នឹង គាត់សំដៅទៅលើជនជាតិបរទេស ឬក៏ជនជាតិខ្មែរ? ឆ.២០៧: គាត់និយាយទៅកាន់កងទ័ពខ្មែរ កុំឲ្យចាញ់បោកគេ ហើយកុំឲ្យក្បត់ក្នុងជួរយើង។ សៈ តើមាស មុត មាននិយាយទាក់ទងថា ឲ្យប្រយ័ត្នយ៉ាងម៉េចដែរ ចំពោះជនដែលបោកប្រាស់ជនជាតិខ្មែរ? ឆ.២០៨: គេចង់និយាយថា កុំឲ្យចាញ់ឧបាយកលវៀតណាម"]។

382 ឯកសារ D54/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ឆ.៣១-៣៤ ["តាមគំនិតរបស់លោក ថាតើវាខុសឬត្រូវ ចំពោះការសម្លាប់អ្នកដែលចាប់បាន? ឆ.៣១: ខ្ញុំគិតថា វាខុសទាំងស្រុង ពីព្រោះប្រជាជនទាំងអស់នោះមិនដឹងអ្វីទាំងអស់ ពួកគេគឺគ្រាន់តែរត់គេចពីសង្គ្រាម ដើម្បីរស់រានមានជីវិតតែប៉ុណ្ណោះ។ ប៉ុន្តែនៅពេលនោះ ខ្មែរក្រហមគិតថា ពួកយួន ជាសត្រូវស្នូរពូជ [...] ឆ.៣២: ថៃមិនមានទំនាស់ច្រើនជាមួយខ្មែរទេនៅក្នុងប្រវត្តិសាស្ត្រ ប៉ុន្តែយួនមានទំនាស់ជាមួយខ្មែរច្រើន ទើបយួនត្រូវបានចាត់ទុកថាជា សត្រូវស្នូលពូជ និងសត្រូវទី១។ សៈ ហេតុអ្វីបានជាលោកដឹងអំពីរឿងអស់ទាំងនេះ? ឆ.៣៣: ពីព្រោះមេបញ្ជាការកងវរសេនាតូច និងវរសេនាធំទៅរៀនសូត្រជាមួយនឹងកងពល ហើយពេលគេត្រឡប់មកវិញ គឺគេបានបង្រៀនយើងអំពីរឿងនេះនៅក្នុងវគ្គអប់រំរៀនសូត្រ។ សៈ តើអ្នកណាជាអ្នកទទួលខុសត្រូវរួមក្នុងផ្នែកអប់រំនយោបាយនៅក្នុងកងពល១៦៤ ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩? ឆ.៣៤: គឺ មាស មុត ដែលជាស្នងការនយោបាយរបស់កងពល"]។

132. មាស មុត បញ្ជាឱ្យយុទ្ធជនរបស់គាត់រាយការណ៍គាត់ រាល់ពេលពួកគេចាប់បានជនជាតិវៀតណាម នៅសមុទ្រ[383] ហើយចេញបញ្ជាទៅថ្នាក់ក្រោមទាំងអស់ឱ្យធ្វើតាមការណែនាំស្តីពីវិធានការណ៍ ដែលពួកគេគួរអនុត្តន៍ជាមួយជនដែលចាប់បាន[384]។ កងទ័ពជើងទឹកម្នាក់ ឈ្មោះ ឯក នី នៅចាំបាន បញ្ជាពី មាស មុត ឱ្យសម្លាប់វៀតណាមដែលចាប់បាន៖

---

383 ឯកសារ D54/87 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារ៉ាត់ ឆ.១៣៨-១៣៩ ["សៈ តើគេរាយការណ៍ដោយរបៀបណាទៅអ្នកណា អំពីការចាប់បានវៀតណាមទាំងទាហាន និងស៊ីវិល? ឆ.១៣៨: នៅពេលដែលចាប់បាន គេរាយការណ៍តាមវិទ្យុទាក់ទងពីកោះនានាមកកាន់កងពល។ សៈ តើគេរាយការណ៍ពីការចាប់បានវៀតណាមទាំងនោះទៅមាស មុតឬក៏ទៅអ្នកណា? ឆ.១៣៩: មានករណីពីរអំពីការរាយការណ៍នៅពេលដែល មាស មុត នៅកន្លែងគឺគេរាយការណ៍ទៅគាត់ផ្ទាល់។ តែពេលគាត់មិននៅ ឬអវត្តមាន គេរាយការណ៍ទៅអ្នកណាម្នាក់ដែលជំនួសគាត់នោះ"]។

384 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១៥ 10.04.24-10.07.37 ["បាទ រឿងនេះរាយការណ៍ជាបន្តបន្ទាប់ អត់មានអត់រាយការណ៍ទេ។ បើចាប់យួនប្រាប់ថាយួន បើចាប់ថៃ នេសាទថៃ អាហ្នឹងប្រាប់ថានេសាទថៃ។ បាទ រាយការណ៍ច្បាស់ៗទៅជូនវរសេនាតូច វរសេនាតូចរាយការណ៍ទៅវរសេនាធំ វរសេនាធំរាយការណ៍ទៅកងពលជាបន្ទាន់"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១៥ 11.03.07-11.06.59 បញ្ជាក់ពីឯកសារ D54/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ឆ.២៧-២៨ ["វាជាបញ្ជាទូទៅរបស់កងពល ទៅគ្រប់កងទាំងអស់ [...] ឆ.២៨: [...] ត្រូវតែរាយការណ៍ឱ្យច្បាស់លាស់នូវអ្វីដែលយើងចាប់បាន។ ឧទាហរណ៍ថាតើគេជាជនជាតិវៀតណាមភៀសខ្លួន ជាអ្នកនេសាទថៃ ឬជាទាហាន យើងត្រូវរាយការណ៍ទៅថ្នាក់លើឱ្យបានច្បាស់លាស់ជាមុន"]។ សូមមើលផងដែរ ឯកសារ D114/12 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ យឿន ឆ.១៦, ១៩-២៣ ["សៈ តើមានហេតុការណ៍អ្វីកើតឡើង នៅពេលដែលនាវាលោកចេញទៅគាំទ្រនាវា ប៉េសេអេហ្វ ទាំងពីរឬបីលើកនោះ? ឆ.១៦: ហេតុការណ៍ទី១ គឺកើតឡើងនៅពេលដែលនាវា ប៉េសេអេហ្វ ចេញទៅចាប់ទូកនេសាទវៀតណាមណាមួយ ហើយទូកនោះក៏បានបាញ់តគ្នាជាមួយនឹងនាវា ប៉េសេអេហ្វ។ នាវា ប៉េសេអេហ្វ ក៏បានសុំឱ្យការអន្តរាគម ដើម្បីមកជួយ។ ហើយសម្រាប់ហេតុការណ៍ទី២ និងលើកទី៣ គឺសុទ្ធតែទូកវៀតណាមដែរ។ ក្នុងករណីដែលយើងបានចូលទៅអន្តរាគម ទូកយើងបានបើកទៅកាត់មុខទូកវៀតណាមទាំងនោះកុំឱ្យរត់រួច ហើយនាវា ប៉េសេអេហ្វក៏ចាប់ផ្តើមធ្វើការចាប់ទូកនោះទៅ [...] សៈ តើការសុំឱ្យមកជួយ គេធ្វើដូចម្តេចដែរ? ឆ.១៩: ការសុំជំនួយអន្តរាគមពីនាវា ប៉េសេអេហ្វ គឺដំបូងគឺស្នើទៅកងពល១៦៤ បន្ទាប់មកកងពលបញ្ជាចុះមកកងវរសេនាធំ ១៤០ និងបន្តមកទៀតកងវរសេនាធំបញ្ជាចុះទៅកងវរសេនាតូចរបស់ហាន។ ហាន ជាអ្នកបញ្ជាឱ្យទូកយើងចេញទៅ។ ជួនកាលគេហៅទៅជួយអន្តរាគមទាំងកណ្តាលយប់។ សៈ តើលោកដឹងពីរបៀបរបបនៃការទំនាក់ទំនងគ្នានេះពីអ្នកណា? ឆ.២០: នេះជារបៀបរបបការងារទូទៅដែលគេអនុវត្តនៅពេលនោះ។ បទបញ្ជាចេញមកពីកងពលធ្លាក់រហូតដល់កងវរសេនាតូច ហាន។ ទូច ក៏បាននិយាយអំពីរឿងនេះដែរ។ សៈ លោកនិយាយថា បញ្ជាចេញមកពីកងពល ហើយមកដល់កងវរសេនាតូច។ តើលោកដឹងថា អ្នកណានៅថ្នាក់កងពលជាអ្នកចេញបញ្ជា? ឆ.២១: តាមុតជាអ្នកចេញបញ្ជា។ សៈ ហេតុអ្វីបានជាលោកដឹងថា បញ្ជានោះចេញពីតាមុត មិនមែនជាអនុរបស់គាត់ ឬក៏ទីបញ្ជាការរបស់

គាត់? ឆ.២២: ខ្ញុំសូមជូនឧទាហរណ៍លោកមួយថា ការសម្រេចចិត្តទាំងអស់គឺចេញពីមេធំ គឺក្នុងករណីដែលតាមុត អវត្តមានប៉ុណ្ណោះ ដែលអនុរបស់គាត់អាចចេញបញ្ជាបាន។ នៅថ្នាក់វរសេនាតូច ហាន ជាអ្នកចេញបញ្ជា។ អ្នកផ្សេងទៀតអាចនិយាយ ឬទំនាក់ទំនង ឬសរសេរបញ្ជានោះ ប៉ុន្តែការសម្រេចចិត្តគឺជាការងាររបស់ប្រធាន។ ប្រសិនអនុប្រធាន សមាជិក និងប្រធានអវត្តមាន គឺទាំងអស់គ្នាពិភាក្សាទៅលើវិធានការដែលត្រូវអនុវត្ត ប៉ុន្តែការសម្រេចចិត្តគឺធ្វើឡើងដោយប្រធាន។ សៈ ក្នុងករណីដែលលោករៀបរាប់ហ្នឹង តើវាដូចគ្នាទៅនឹងអ្វីដែលអនុវត្តនៅកម្រិតតាមុត ដែរឬទេ? ឆ.២៣: គឺដូចគ្នាដែរ"]។ សូមមើលបន្ថែម ឯកសារ D54/116 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ យឿន ឆ.៣៦-៤២ ["សៈ នៅក្នុងកិច្ចសម្ភាសរបស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ទំព័រទី១៧ លោកនិយាយថា មនុស្សដែលគេចាប់បានត្រូវបានគេយកទៅសម្លាប់ ឬបាញ់ចោលនៅកោះរ៉ុង។ សូមលោកពន្យល់បន្ថែមអំពីករណីនេះ? ឆ.៣៦: កាលនោះ ខ្ញុំបានឃើញទូកដែលគេចាប់បានត្រូវបានសណ្តោងទៅកោះរ៉ុង ហើយទូកនោះជាទូករបស់យួន។ គេទុកនៅកោះរ៉ុងនោះមួយយប់។ ថ្ងៃបន្ទាប់ប្រហែលម៉ោង២ថ ឬម៉ោងបីរសៀល ទើបគេសណ្តោងទៅទំនប់រលកនៅកំពង់សោម។ ខ្ញុំបានសួរ ទូច ដែលជានីរសារផ្ទាល់របស់ហ៊ាន ថាតើមានរឿងអ្វីកើតឡើងចំពោះមនុស្សដែលចាប់បាននៅលើទូកនោះ? ទូច ប្រាប់ខ្ញុំថា ពួកគេត្រូវបានបាញ់សម្លាប់នៅលើកោះនោះអស់ហើយ។ ពេលនោះ ហ៊ាន ក៏បានគំរាមពួកយើងមិនឱ្យនិយាយពីរឿងនេះទៀតដែរ។ សៈ នៅក្នុងកិច្ចសម្ភាសរបស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ទំព័រទី១៧ លោកនិយាយថា នៅពេលដែលចាប់បាន "គេ" តេអូមកកងពល ហើយកងពលប្រាប់ទៅវិញថា "ឯងធ្វើម៉េចធ្វើទៅកុំទុក"។ តើ "គេ" នេះ លោកសំដៅទៅលើអ្នកណា? ឆ.៣៧: កាលនោះ ហ៊ាន ទៅរស់នៅលើកោះរ៉ុងរួចហើយ។ "គេ" សំដៅទៅលើហ៊ាន។ អ្នកដែលត្រូវបានគេសម្លាប់នៅកោះរ៉ុង គឺជនជាតិវៀតណាម។ សៈ តើឃ្លាដែលថា "ឯងធ្វើម៉េចធ្វើទៅកុំទុក" តើមានន័យថាម៉េច? ឆ.៣៨: តាមខ្ញុំយល់ មានន័យថា បាញ់ពួកគេចោលនៅនឹងកន្លែងនៅកោះរ៉ុងនោះតែម្តង គឺមិនទុកឱ្យរស់ ឬក៏នាំយកមកទៅកំពង់សោមទេ។ សៈ តើលោកដឹងពីការទំនាក់ទំនងនេះដោយរបៀបណា? ឆ.៣៩: ខ្ញុំបានសួរទូច ហើយគាត់បានប្រាប់ខ្ញុំអំពីរឿងនេះ។ ទូចជានីរសារផ្ទាល់របស់ ហ៊ាន។ ទូច ជាមនុស្សស្មោះត្រង់ គាត់មិនរាយការណ៍ពីរឿងខ្ញុំសួរនេះទៅឱ្យហ៊ានទេ។ ហ៊ាន តែងតែឱ្យទូចកាន់វិទ្យុទាក់ទងរបស់ខ្លួន។ សៈ តើទូចប្រាប់លោកថាអ្នកណាជាអ្នកចេញបញ្ជាមកពីកងពលហ្នឹង? ឆ.៤០: បញ្ជានោះគឺចេញមកពីតាមុត ដែលជាមេបញ្ជាការកងពល។ សៈ តើទូចនៅរស់ឬស្លាប់? ឆ.៤១: គាត់ត្រូវវៀតណាមបាញ់ស្លាប់ហើយ។ សៈ តើលោកនៅចាំទីកន្លែង ណិងកាលៈទេសៈ ដែលទូចប្រាប់លោកនូវរឿងទាំងនេះទេ? ឆ.៤២: គឺនៅលើកោះរ៉ុង ចុងឆ្នាំ១៩៧៦ ដែលកាលនោះខ្ញុំធ្វើការនៅលើកប៉ាល់។ ទូចប្រាប់ខ្ញុំអំពីបទបញ្ជានេះ ប្រហែល១អាទិត្យក្រោយពីគេសណ្តោងទូកវៀតណាមទៅកំពង់សោម។ កាលនោះ ខ្ញុំទៅលាងកប៉ាល់របស់ខ្ញុំ ហើយទូចក៏ប្រាប់ខ្ញុំអំពីរឿងនេះ ដែលកាលនោះមានតែគ្នាពីរនាក់ទេ គឺក្នុងពេលសម្រាកហូបបាយថ្ងៃត្រង់ ដែលជាពេលស្ងប់ស្ងាត់។ អ្នកដែលគេហូបបាយហើយ គេសម្រាកថ្ងៃត្រង់ ដែលជាពេលស្ងាត់ល្អសម្រាប់ខ្ញុំសាកសួរសំណេះសំណាលជាមួយទូច"]។

ពីដំបូងឡើង ពេលយើងចាប់ពួកវៀតណាម និងថៃបាន យើងបញ្ជូនឲ្យតាមុត នៅកំពង់សោម ប៉ុន្តែក្រោមមក តា មុត បានបញ្ជាមកយយើងកុំឲ្យខាតសាំង ដើម្បីដឹកពួកគេមកកំពង់សោមធ្វើអី ឲ្យយកធ្វើជាជីដាក់គល់ដូងនៅលើកោះទាំងអស់ទៅ[385]។

133. ការអនុវត្តគោលនយោបាយនេះ តម្រូវឲ្យកម្មាភិបាលកងពល ១៦៤ មានភារកិច្ចស្វែងរកជនសង្ស័យ វៀតណាម ឬសង្ស័យថា ពាក់ព័ន្ធនឹងវៀតណាម ហើយជាសរុប មានភារកិច្ច បញ្ជាសម្លាប់ មិនត្រឹមតែទាហានប៉ុណ្ណោះទេ តែថែមទាំង ជនភៀសខ្លួន ដែលចាប់បានក្នុងដែនសមុទ្រ

385 សូមមើលបន្ថែម ឯកសារ D54/102 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី ឆ.៤១, ៤៣-៤៤ ["ខ្ញុំសូមបន្ថែមរឿងខ្លះជូនលោក ពួកថៃ និងវៀតណាមដែលចាប់បានគឺស្លៀកសម្លៀកបំពាក់ស៊ីវិលពណ៌ចម្រុះ។ មានមាសជាច្រើនដែលយកបានពីពួកវៀតណាម ហើយយកទុកនៅមន្ទីររបស់កងវរៈសេនាធំ។ ពីដំបូងឡើង ពេលយើងចាប់ពួកវៀតណាម និងថៃបានយើងបញ្ជូនទៅឲ្យតាមុត នៅកំពង់សោម ប៉ុន្តែក្រោយមក តាមុត បានបញ្ជាមកយើងកុំឲ្យខាតសាំង ដើម្បីដឹកពួកគេមកកំពង់សោមធ្វើអី ឲ្យយកធ្វើជាជីដាក់គល់ដូងនៅលើកោះទាំងអស់ទៅ។ សាកសពម្នាក់ត្រូវកាត់ជាពីរកំណាត់ ហើយមួយកំណាត់ៗកប់នៅក្រោមដើមដូងមួយដើមៗ [...] សៈ នៅពេលដែលលោកនិយាយថា ពេលចាប់ពួកវៀតណាម និងថៃ គឺបញ្ជូនទៅឲ្យតាមុត នៅកំពង់សោម សូមលោកពន្យល់ថាតើលោកនិយាយនេះមានន័យថាម៉េច? ឆ.៤៣: អ្នកណាក៏ដោយ ដែលចាប់បានដោយកងជើងទឹកត្រូវតែបញ្ជូនទៅឲ្យតាមុត នៅកំពង់សោម ហើយយើងឮថា ពួកគេនឹងត្រូវបង្ហើយនៅចម្ការធូរ៉េនទាំងអស់។ នៅពេលនោះកន្លែងដែលសម្លាប់របស់កងពល១៦៤ គឺមានតែនៅចម្ការធូរ៉េនទេ។ សៈ ម៉េចបានជាលោកដឹងថា តាមុត ប្រាប់មិនឲ្យបញ្ជូនអ្នកដែលចាប់ទាំងនោះទៅកំពង់សោមទៀត? ឆ.៤៤: ពួកមេកងៗប្រាប់ថា យើងមិនបាច់បញ្ជូនអ្នកទាំងនោះទៅកំពង់សោមទៀតទេ ពីព្រោះបងប្រធានកងពលបានប្រាប់យើងឲ្យបញ្ចប់ពួកនោះនៅនឹងកន្លែងតែម្តង"]។

កម្ពុជាប្រជាធិបតេយ្យ ពេលដែលជនទាំងនោះជិះទូកទៅជ្រកកោននៅប្រទេសផ្សេងៗ[386] អ្នកនេសាទ[387] និងខ្មែរក្រោមដែលបានចោទថាខ្សែវៀតណាម[388]។

134. ការទទួលខុសត្រូវរបស់ មាស មុត ក្នុងការឃាត់ ចាប់ខ្លួន និងសម្លាប់ក្រុមទាំងនោះបានបង្ហាញតាមរយៈរបាយការណ៍កងពលរបស់គាត់ ស្តីពីបញ្ហាទាំងនោះ ទៅ សុន សេន និងមេដឹកនាំផ្សេងៗទៀត[389] ហើយតាមរយៈអង្គហេតុថា កម្មាភិបាលថ្នាក់ក្រោមរបស់ មាស មុត ត្រូវ "តែវាយ

---

386 សូមមើលបន្ថែម ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.២៩ ["ក្នុងអំឡុងពេលនោះ នៅពេលដែលគេចាប់បានជនភៀសខ្លួនជនជាតិវៀតណាម ដែលធ្វើដំណើរតាមទូកភៀសខ្លួនទៅប្រទេសទី៣ គេយកពួកវៀតណាមទាំងនោះទៅសម្លាប់ដាក់នៅចម្ការធូរ៉េនផងដែរ។ គេហៅអ្នកភៀសខ្លួនវៀតណាមទាំងនោះថាជាកូនជ្រូក។ គេថាគេយកអ្នកទាំងនោះទៅធ្វើជីដាក់ដើមធូរ៉េន"]។ ឯកសារ D54/24.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ ERN KH 00955508 ["ស: តើពួកគេភាគច្រើនជាទាហានយួនមែនទេ? ឆ: ពួកគេភាគច្រើនជាជនភៀសខ្លួនដែលរត់គេចខ្លួនទៅកាន់ប្រទេសទីបី។ ភាគច្រើននៃអ្នកទាំងនោះបានគេចពីសង្គ្រាមហើយធ្វើដំណើរឆ្លងកាត់តំបន់របស់យើង។ នៅពេលយើងចាប់ខ្លួនពួកគេយើងបានបាញ់សម្លាប់ពួកគេ"]។

387 ឯកសារ D114/283 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៤ ["ស: តើពេលនោះ ចំពោះតែវៀតណាមដែលយើងចាប់បានមក ភាគច្រើនជាពួកកូនជ្រូក ដែលជាជនភៀសខ្លួនតាមទូក ហើយមានពួកនេសាទខ្លះទេ ហើយនិងមានពួកទាហានវៀតណាមខ្លះទេ? ឆ.៤: អត់ទេ ច្រើនតែពួកកូនជ្រូក ហើយនឹងពួកនេសាទវៀតណាម"]។

388 សូមមើលកថាខណ្ឌ ៤៩៨។ សូមមើលផងដែរ ឯកសារ D54/36 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ឆ.១០ ["ស: ហេតុអ្វីបានជាខ្មែរកម្ពុជាក្រោមត្រូវបានគេបញ្ជូនទៅកងចល័ត? ឆ.១០: ខ្មែរក្រហមបានចោទខ្មែរកម្ពុជាក្រោមថាមានទំនាក់ទំនងជាមួយយួន ពីព្រោះពួកគេរស់នៅវៀតណាម"]។

389 ឯកសារ D1.3.34.64 ទំនាក់ទំនងទូរស័ព្ទសំងាត់ពីមាស មុត ទៅបង៨៩ (សុន សេន) ថ្ងៃទី ២០ ខែមីនា ឆ្នាំ១០៧៨ [រាយការណ៍ពីការចាប់ខ្លួននិងចាប់ខ្លួន "ប្រជាជនវៀតណាម៧៦នាក់ ទាំងក្មេងទាំងចាស់ ប្រុសនិងស្រី" លើទូកពីរនៅកោះតាង និងចាប់បានជនជាតិថៃ ២១នាក់នៅលើទូកនៅកោះវៃ]។ ឯកសារ D54/73.1 របាយការណ៍តាមទូរស័ព្ទសំងាត់ពីមាស មុត ថ្ងៃទី ០១ ខែមេសា ឆ្នាំ១៩៧៨ ១០ ERN KH 00979298 ["មានជនជាតិវៀតណាមសរុប ១២០ នាក់ ដែលត្រូវបានចាប់ខ្លួននិងបាញ់សម្លាប់ពីថ្ងៃទី ២៧ ខែមីនា ដល់ថ្ងៃទី ៣០ ខែមីនា ឆ្នាំ១៩៧៨ "]។ ឯកសារ D1.3.12.20 របាយការណ៍តាមទូរស័ព្ទសំងាត់ពីមាស មុត ថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៧៧ និង ឯកសារ D1.3.34.23 ចំណាររបស់សុន សេន ទៅកាន់អង្គការ ថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៧៧ [របាយការណ៍ពីមុតចាប់ទូកនេសាទថៃនិងចាប់ខ្លួនជនជាតិថៃ ៤ នាក់និងខ្មែរ ១ នាក់ ដែលត្រូវបានគេសួរចម្លើយ]។ ឯកសារ D1.3.8.4 កំណត់ហេតុប្រជុំរវាង សុន សេន និងកងពល១៦៤ ថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ១៩៧៦ ERN KH 00162489 [រាយការណ៍ពីការចាប់ខ្លួនមនុស្សលើទូកនេសាទថៃពីរនាក់និងការចាប់ខ្លួនអនុសេនីយម្នាក់ពីអតីតរបបមុន], ERN KH 00162490 [សេចក្តីបង្គាប់របស់សុន សេនដើម្បីប្រមូលផ្តុំ "កងកម្លាំងទាហាន" និងឱ្យ "បញ្ជូនទូកដែលបានមកដល់កោះរ៉ុងសន្លឹមដើម្បីអង្គការដើម្បីសួរចម្លើយ]។ ឯកសារ D1.3.27.18 កំណត់ហេតុប្រជុំរបស់លេខាធិការកងពល ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ១៩៧៦ ERN KH

ការណ៍ឲ្យច្បាស់លាស់នូវអ្វីដែលយើងចាប់បាន។ ឧទាហរណ៍ថាតើគេជនជាតិវៀតណាមភៀស ខ្លួន ជាអ្នកនេសាទថៃ ឬជាទាហាន យើងត្រូវតែរាយការណ៍ទៅថ្នាក់លើឲ្យបានច្បាស់លាស់ជាមុន”[390]។

135. ការចូលរួមរបស់ មាស មុត ក្នុងការធ្វើទុក្ខបុកម្នេញ និងអំពើប្រល័យពូជសាសន៍វៀតណាម បានមើលឃើញតាមរយៈការចូលរួមជាប្រចាំរបស់គាត់ ក្នុងការចាប់ខ្លួន និងសម្លាប់បុគ្គលទាំងនោះ ក្នុងទូទាំងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ភ័ស្តុតាងខាងក្រោមផ្តល់ឧទាហរណ៍ថែមទៀត ស្តីពីការប្តេជ្ញាចិត្តរបស់មាស មុត ក្នុងការអនុវត្តគោលនយោបាយជាតិទាំងនេះ នៅតំបន់ដែលគាត់ គ្រប់គ្រង។

136. កងពល ១៦៤ កំណត់គោលដៅបោសសម្អាតវៀតណាម ចាប់តាំងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ហើយបានវិវត្តន៍ឆ្លងកាត់ច្រើនឆ្នាំតាមការប្រែប្រួលគោលនយោបាយ និងការណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជា។ នៅខែមេសា ឬឧសភា ឆ្នាំ ១៩៧៥ មេបញ្ជាការម្នាក់នៃកងទ័ពបដិវត្តន៍កម្ពុជា ដែលបាន “សុំការណែនាំស្តីពីការចាត់ចែង” ជនភៀសខ្លួនវៀតណាមជាង១០ នាក់ដែល

---

00052390 [របាយការណ៍ពីមុតចាប់ទូកនេសាទថៃ]។ ឯកសារ D1.3.34.28 របាយការណ៍តាមទូរស័ព្ទសំងាត់ពីកងពល១៦៤ ទៅកាន់ មាស មុត ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ១៩៧៧ [របាយការណ៍នៃការចាប់ខ្លួនទូកថៃពីរនាក់ និងការសម្លាប់មនុស្សនៅលើយន្តហោះ]។ ឯកសារ D1.3.12.3 របាយការណ៍ពីមាស មុត ទៅបង៨៩ ថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ១០៧៦ [រាយការណ៍ពីការចាប់ខ្លួនក្រុមមនុស្សឃាតមួយក្រុមដែលបានចោទប្រកាន់ពីតំបន់វាលរិញ ហើយដែលម្នាក់ត្រូវបានគេសួរចម្លើយ]។ ឯកសារ D1.3.34.11 ទូរលេខ ១១ ពីឌឹម ទៅកាន់ មុត ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៧៦ [រាយការណ៍ពីការចាប់ខ្លួនខ្មាំងសត្រូវ ៥ នាក់ដែលព្យាយាមរត់គេចចេញពីឃុំរាម និងបបុស តាមការសម្រេចរបស់មាស មុត។ ចម្លងជូនសុន សេន និងនួន ជា]។ ឯកសារ D1.3.34.12 ទូរលេខ ១២ ពីឌឹម ទៅកាន់ មុត ថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ១៩៧៦ [រាយការណ៍ពីការចាប់ខ្លួនក្មេងប្រុសអាយុ ១៦ ឆ្នាំដែលសារភាពថាជាចារកម្មឲ្យពួក “ចោរព្រៃ”។ ចម្លងជូនសុន សេន និងនួន ជា]។ ឯកសារ D1.3.34.13 ទូរលេខ ១៦ ពីឌឹម ទៅកាន់ មុត ថ្ងៃទី ៦ ខែតុលា ឆ្នាំ១៩៧៦ [ពិពណ៌នាអំពីការប្រើកុមារនិងក្រុមវាយឆ្មក់ដើម្បី “ស្វែងរកចោរព្រៃ”និង “ជនក្បត់ដែលបង្កប់នៅក្នុងភូមិ”។ ចម្លងជូនសុន សេន និងនួន ជា]។

390 ឯកសារ D54/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆ.២៨ [“ត្រូវតែរាយការណ៍ឲ្យច្បាស់នូវអ្វីដែលយើងចាប់បាន។ ឧទាហរណ៍ថាតើគេជាជនជាតិវៀតណាមភៀសខ្លួន ជាអ្នកនេសាទថៃ ឬជាទាហាន យើងត្រូវតែរាយការណ៍ទៅថ្នាក់លើឲ្យបានច្បាស់លាស់ជាមុន”]។

ចាប់បាន[391] បានទទួលបញ្ជាពី "មេបញ្ជាការថ្នាក់លើនៅក្នុងកំពង់សោម" ឲ្យសម្លាប់ចោលជនភៀសខ្លួនទាំងនោះ។ មេបញ្ជាការរូបនោះ និងអនុរបស់គាត់ អនុវត្តតាមបញ្ជានេះ[392]។ ដោយសារ មាស មុត គឺជាអ្នកកាន់អំណាចកំពូលយោធា និងស៊ីវិលនៅកំពង់សោម តាំងពីខែមេសា ឆ្នាំ ១៩៧៥[393] គាត់ ប្រាកដជាបានដឹងពីព្រឹត្តការណ៍នោះ ហើយទំនងបំផុតនោះ គាត់គឺជាអ្នកបញ្ជាការសម្លាប់នោះ។

137. ស្របតាមគោលនយោបាយបក្ស មាស មុត ហៅវៀតណាម ថា ជា"ខ្មាំង" ក្នុងរបាយការណ៍ទៅថ្នាក់លើ ដូចដែលឃើញក្នុងកំណត់ហេតុ ប្រជុំ ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ១៩៧៦ នៅកំពង់សោម ដែល ប៉ុល ពត, វ៉ន វេត និង សុន សេន បានចូលរួមដែរ[394]។ បន្ទាប់មកក្នុងឆ្នាំដដែល នៅថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៧៦ ក្នុងការប្រជុំលេខា អនុលេខាកងពល និងវរសេនាធំឯករាជ្យ សុន សេន បានផ្សព្វផ្សាយទស្សនៈនោះ ដល់បណ្តាមេបញ្ជាការកងពល ដោយសង្កត់ធ្ងន់ថា "ពីមុនយើងថា វា [វៀតណាម] ជាមិត្តមានទំនាស់ ឥឡូវវាជាសត្រូវយើងពិតប្រាកដហើយ"[395]។ នៅអង្គប្រជុំនោះ មាស មុត និងអនុរបស់គាត់ឈ្មោះ ឌឹម បានឯកភាពជាមួយនឹងនយោបាយសម្លាប់វៀតណាម និងខ្មាំង

---

[391] ឯកសារ D4.1.754 ក្រសួងការពារជាតិអាមេរិក ក្នុងតំបន់៣៧ និង ក្នុងអង្គភាពកងពលលេខ ៣/១៦៤ នៅកោះតាង បន្ទាប់ពីឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០៥ ERN KH 00791380 ["បន្ទាប់ពីពួកគេបានចាប់នាវា ៤០៨ មេបញ្ជាការបានទាក់ទងកំពង់សោមសម្រាប់ការណែនាំរៀបចំជនភៀសខ្លួន ដែលមេបញ្ជាការជាន់ខ្ពស់នៅកំពង់សោមបានបញ្ជាឲ្យមេបញ្ជាការសម្លាប់ជនភៀសខ្លួន។ មេបញ្ជាការនិងអនុប្រធានរបស់គាត់បានធ្វើតាមបញ្ជាភ្លាម"]។

[392] ឯកសារ D4.1.754 ក្រសួងការពារជាតិអាមេរិក ក្នុងតំបន់៣៧ និង ក្នុងអង្គភាពកងពលលេខ ៣/១៦៤ នៅកោះតាង បន្ទាប់ពីឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០៥ ERN KH 00791380 ["បន្ទាប់ពីពួកគេបានចាប់នាវា ៤០៨ មេបញ្ជាការបានទាក់ទងកំពង់សោមសម្រាប់ការណែនាំរៀបចំជនភៀសខ្លួន ដែលមេបញ្ជាការជាន់ខ្ពស់នៅកំពង់សោមបានបញ្ជាឲ្យមេបញ្ជាការសម្លាប់ជនភៀសខ្លួន។ មេបញ្ជាការនិងអនុប្រធានរបស់គាត់បានធ្វើតាមបញ្ជាភ្លាម"]។

[393] សូមមើលជំពូក ៣.២ តួនាទីក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់មាស មុត លេខាធិការនៃផ្នែកស្វ័យយ័តនៅកំពង់សោម។

[394] ឯកសារ D1.3.8.3 កំណត់ហេតុនៃការប្រជុំកងទ័ពក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ១៩៧៦ ERN KH 00021496 ["សភាពការណ៍ខ្មាំង: [...] ខ. ខាងវៀតណាម: ឥឡូវមិនឃើញមានធ្វើសកម្មភាពអីទេ។ យើងដាក់ពោងមួយចម្ងាយ ២គ.ម ពីកោះសេះ ដើម្បីទុកចំណាំបាញ់ វាមកលួចយកទៅបាត់"]។

[395] ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំកងទ័ពក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែតុលា ឆ្នាំ១៩៧៦ ERN KH 00052408។

ក្រៅជួរផ្សេងៗទៀត[396]។ នៅឆ្នាំ ១៩៧៦ កម្លាំងរបស់ មាស មុត បានបញ្ជូនអ្នកទោសវៀតណាម៣០ នាក់ មក ស-២១[397]។

138. ចាប់តាំងពេលនោះមក កម្មាភិបាលក្រោមបង្គាប់មាស មុត បើកវគ្គរៀនសូត្រ នៅគ្រប់វរសេនាតូចទាំងអស់របស់កងពល ១៦៤[398] ដែលនៅក្នុងនោះ កម្មាភិបាល "ត្រូវបានណែនាំឲ្យសម្លាប់ [វៀតណាម]" ពេលចាប់បាន[399]។ សមាជិកវរសេនាធំ និងវរសេនាតូចចូលរួមវគ្គរៀនសូត្រនៅកម្រិតកងពល ហើយបន្ទាប់មក បញ្ជូនបន្តនូវការណែនាំទាំងនេះ ទៅដល់គ្រប់អង្គភាពទាំងអស់នៃកងពល[400]។

---

396 ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំយោធាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែតុលា ឆ្នាំ១៩៧៦ ERN KH 00052408 [" តាមការសង្កេតនិងពិនិត្យមើលកងកម្លាំងរបស់ខ្ញុំ ពី ៩០ ទៅ ៩៥ភាគរយនៃអ្នកទាំងនោះគឺជាអ្នកដែលអាចទុកចិត្តបានគឺអ្នកដែលស្មោះត្រង់ចំពោះបក្ស។ ប៉ុន្តែប្រសិនបើចង់បានជំនឿថាកងទ័ពនេះស្អាតហើយដូចជាមិនទាន់ស្អាតហើយវាជាការចាំបាច់ដើម្បីតាមដានសំរិតសំរាំងតទៅទៀត"]។

397 សូមមើលឧបសម្ព័ន្ធ D.5. និងកថាខណ្ឌ ៥៤៥-៥៤៦

398 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១៥ 13.31.54-13.34.17 [" ជាការពិត ខ្ញុំជាយុទ្ធជននៅកងពល១៦៤ ក្រោយពីបានឆ្នាំ១៩៧៦ គឺបើកវគ្គសាលាសិក្សា ដើម្បីប្រកាស បាទ ប្រកាសពេញសិទ្ធិសត្រូវស្ងួរពូជគឺវា យួន និងកម្ពុជា [...] វគ្គសិក្សានៅតាមអង្គភាពជាវរសេនាតូច។ បន្ទាប់ពីទទួលការរៀនសូត្រ វគ្គសិក្សានៅតាមសាលាតូចៗនៅតាមជួរយោធាខាងមុខនៅលើកោះ នៅក្នុងកងពល"]។

399 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១៥ 13.36.35-13.38.32 [" យើងត្រូវបានបង្ហាត់ឲ្យស្គាល់សត្រូវស្ងួរពូជ ដើម្បីសម្លាប់មិនរើសមុខ មិនលើកលែងសូម្បីកូនង៉ែត។ ដូច្នេះវាជាទំនួលខុសត្រូវរបស់គ្រប់កងពលនីមួយៗដែលទទួលផែនការនេះ"]។ សូមមើលផងដែរ ឯកសារ D54/24.1 កិច្ចសម្ភាសន៍ជាមួយ ប៉ាក សុខ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ERN KH 00955507 [" ស: តើលោកបាននិយាយថាបើចាប់បានយួននោះ? ឆ: បើពួកយួនចាប់បានគេយកមកសម្លាប់ចោល។ ស:សម្លាប់នៅឯណា? ឆ: ជួនកាលគេសម្លាប់នៅលើកោះហ្នឹងទៅ។ ស: ភាគច្រើនពួកកងទ័ពយួនឬមួយយ៉ាងម៉េច? ឆ: ច្រើនតែប្រជាជនដែលរត់ភៀសខ្លួនទៅប្រទេសទីបី ភាគច្រើនពួកហ្នឹងរត់គេចពីសង្គ្រាម ដែលរត់ឆ្លងមកយើងចាប់បានបាញ់សម្លាប់ចោលទៅ។ ឆ: វាគឺធ្វើតាមបញ្ជារបស់កងពល [...] ហើយបញ្ជានេះចេញពីតាមុត"]។

400 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ២០១៥ 13.43.50.-13.485.57 [" នៅវរសេនាតូចនិងកងវរសេនាធំដែលបានទៅរៀនសូត្រនៅថ្នាក់កងពល ពួកគេបានត្រឡប់មកវិញនិងបានផ្តល់ការបង្រៀនដល់ទាហានជើងទឹកទាំងអស់នៅក្នុងកងវរសេនាតូចនៃកងពលធំនេះ"]។

139. នៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៧៧ មាស មុត បានបញ្ជូនទូរលេខទៅសុនសេន ពិគ្រោះយោបល់អំពីវត្តមានរបស់ទូកនេសាទវៀតណាម ដែលចាប់មិនបាន[401]។ នៅពេលជំណាលគ្នានោះដែរ ប្រជាជនខ្មែរក្រោមបានបញ្ជូនមកទឹកសាប ដែលនៅទីនោះពួកគេ ទំនងជាត្រូវបានសម្លាប់[402]។ បន្ទាប់មកក្នុងឆ្នាំដដែល នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ បន្ទាប់ពីការកាត់ផ្តាច់ទំនាក់ទំនងកម្ពុជា

---

401 ឯកសារ D1.3.12.18 ទូរលេខ ០៩ ពី មាស មុត ទៅបង៨៩ (សុន សេន) ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ១៩៧៦ EN 00233992-93។

402 ឯកសារ D114/69 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុយ សម្បត្តិ ឆ.១, ៩ ["ថ្ងៃមួយ ពេលខ្ញុំកំពុងស្ទូងស្រូវនៅភាគខាងលិច មិនឆ្ងាយប៉ុន្មានពីផ្ទះបច្ចុប្បន្នរបស់ខ្ញុំនេះ ពោលគឺប្រមាណជា៣០០ម៉ែត្រ ពីទីនេះ ខ្ញុំបានឃើញរថយន្តចំនួនប្រាំមួយគ្រឿង ធ្វើដំណើរទៅភ្នំដែលស្ថិតនៅភាគខាងលិចនៃអូរទឹកសាប។ ខ្ញុំឃើញឡាននេះពីចម្ងាយ ដោយសារតែខ្ញុំអាចមើលឃើញច្បាស់ ខ្ញុំអាចឮសំឡេងឡាន និងមានដីហុយទ្រលោមនៅលើផ្លូវដី ដែលខ្ញុំអាចមើលឃើញយ៉ាងច្បាស់។ ខ្ញុំមិនបានឃើញការសម្លាប់នោះដោយផ្ទាល់ទេ ប៉ុន្តែខ្ញុំដឹងច្បាស់ថា មនុស្សទាំងនោះ ពិតជាត្រូវបានគេយកទៅសម្លាប់។ ប៉ុន្តែខ្ញុំដឹងថា រថយន្តដដែលនេះ បានត្រឡប់មកវិញនៅពេលរសៀល។ រថយន្តទាំងនេះ បានត្រឡប់មកសហករណ៍ស្នាច់ដែងវិញ។ សហករណ៍ស្នាច់ដែងនេះ មានទីតាំងស្ថិតនៅខាងក្រោយវត្ត។ ខ្មែរក្រហមដែលមកតាមឡានទាំងនេះ យកខោអាវមកចែកប្រជាជននៅក្នុងសហករណ៍។ ខ្មែរក្រហមបានប្រាប់ប្រជាជនថា បងប្អូនអាចយកសម្លៀកបំពាក់នេះទៅប្រើប្រាស់បានដោយសារតែទូកដែលដឹកអ្នកកម្ពុជាក្រោមទាំងនេះបានលិចនៅកណ្តាលសមុទ្រ ហើយអ្នកទាំងនោះ បានលង់ទឹកស្លាប់អស់ហើយ។ យើងដឹងថា នេះមិនមែនជាការពិតឡើយ ហើយអ្នកកម្ពុជាក្រោមទាំងនោះ ត្រូវបានគេសម្លាប់អស់ហើយ។ គ្រប់គ្នាដឹងអំពីរឿងនេះ ប៉ុន្តែគ្មានអ្នកណាហ៊ាននិយាយឡើយ។ ខ្ញុំក៏បានដឹងពីរឿងនេះដែរ។ យើងមិនហ៊ានបដិសេធមិនទទួលយកខោអាវទាំងនេះឡើយ [...] ឆ.៩: វាស្ថិតនៅក្នុងខែមេសា ឬឧសភា ឆ្នាំ ១៩៧៧។ ខ្ញុំចាំថា វាស្ថិតនៅរដូវប្រាំងនៅឡើយ"]។ ឯកសារ D114/141 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៅទឹកសាប ERN KH 01517362 ["ដំណាក់កាលទី១: សាក្សីបានសង្កេតឃើញថាមនុស្សត្រូវបានគេដាក់នៅលើឡានដឹកទំនិញចំនួនប្រាំមួយនៅមុខផ្ទះរបស់គាត់នៅសង្កាត់ស្នាច់ដែងក្រោមព័ត៌មានដែលបានប្រាប់ថាឡានដឹកទំនិញទាំងនេះនឹងនាំយកអ្នកភូមិជនជាតិដើមវៀតណាមនៅកម្ពុជាក្រោមមកវៀតណាម។ ដំណាក់កាលទី ២: សាក្សីបន្ទាប់មកបានសង្កេតឃើញពីទីតាំងរបស់គាត់នៅកសិដ្ឋានស្រូវជិតទឹកសាបដែលឡានដឹកទំនិញចំនួនប្រាំមួយបានផ្ទុកអ្នកដំណើរឆ្លងកាត់ស្ពានទឹកសាបហើយនឹងចាកចេញពីផ្លូវហាយវេ ៤ និងបានបើកត្រឡប់ទៅតំបន់ទឹកសាប។ សាក្សីមិនបានឃើញឡានបានងាកមកទេតែឮសម្លេងរំខានរបស់ម៉ាស៊ីនហើយឃើញធូលីដីរបស់ឡានដែលធ្វើឱ្យគាត់សន្និដ្ឋានថាឡានទាំងនោះបានទៅតំបន់ទឹកសាប។ ដំណាក់កាលទី ៣: នៅថ្ងៃដដែលសាក្សីនៅក្បែរនោះបានសង្កេតឃើញថាឥវ៉ាន់និងសម្លៀកបំពាក់របស់អ្នកភូមិដែលគាត់បានឃើញនៅពេលព្រឹកត្រូវបានចែកចាយទៅឱ្យឃុំសង្កាត់នៅសង្កាត់ស្នាច់ដែង។ សាក្សីបានដឹងថានៅដំណាក់កាលនោះថាខ្មែរក្រហមបាននិយាយថាមនុស្សទាំងនោះនៅលើឡានទាំងអស់បានស្លាប់ដោយសារតែពួកគេលង់ទឹកនៅតាមសមុទ្រពេលធ្វើដំណើរទៅប្រទេសវៀតណាម [...] ខ្ញុំបានឃើញហេតុការណ៍នៅចុងឆ្នាំ ១៩៧៧ និងដើមឆ្នាំ ១៩៧៨ ដែលក្នុងនោះពួកគេបានយកប្រជាជនខ្មែរក្រហមនិងមនុស្សផ្សេងទៀតទៅសម្លាប់"]។

ប្រជាធិបតេយ្យ-វៀតណាម មាស មុត សរសេរក្នុងទូរលេខទៅ មន្ទីរ៨៧០ ថា គាត់ប្តេជ្ញា "[បោសសម្អាត]ឲ្យស្អាត" ខ្មាំង"យួន"[403]។

140. យោងតាមភារកិច្ចរបស់ មាស មុត ដែលត្រូវគោរពគោលនយោបាយប.ក.ក ស្តីពី ការធ្វើទុក្ខបុកម្នេញ និងសម្លាប់វៀតណាម គាត់ ត្រូវរាយការណ៍លទ្ធផលដែលសម្រេចបានជាទីពេញចិត្តដល់មជ្ឈិមបក្ស។ ឧទាហរណ៍ នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ រាយការណ៍ ថាបានពន្លិចទូកវៀតណាមមួយ។ គាត់ថែមទាំងរាយការណ៍ប្រាប់សុន សេន ថា ចាប់បានវៀតណាម៧៦ នាក់ --"មានក្មេងចាស់ ប្រុសស្រី"--នៅកោះតាង។ របាយការណ៍នោះលើកឡើងថា ក្នុងចំណោមវៀតណាមទាំងនោះមានពីរនាក់ធ្លាក់ចូលទឹក បន្ទាប់ពីបានចងរួចរាល់ហើយ អ្នកផ្សេងទៀតត្រូវ "បាននាំយកមកដល់ដីគោក"[404] ពីរបីថ្ងៃក្រោយមក នៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៧៨ បានធ្វើរបាយការណ៍មួយមានចម្លងជូនប៉ុល ពត និងមេដឹកនាំផ្សេងៗទៀត រៀបរាប់ពិស្តារអំពីការចាប់ និងសម្លាប់ "យួន" ១២០នាក់ ក្នុងរយៈពេលបីថ្ងៃ ចុងខែ មីនា ឆ្នាំ ១៩៧៨។[405]

141. បន្ទាប់មកក្នុងឆ្នាំដដែល[406] ជនជាតិវៀតណាមបីនាក់ ស្ត្រីចំណាស់ម្នាក់ និងក្មេងជំទង់ពីរនាក់[407] ត្រូវបាននាំមកដល់ទីបញ្ជាការមាស មុត នៅកំពង់សោម។ សាក្សី មុត ម៉ៅ ចាំបានថា "ក្មេងទាំង

---

[403] ឯកសារ D1.3.34.60 ទូរលេខ ០០ ពី មាស មុត ទៅការិយាល័យ ៨៧០ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៧៧។

[404] ឯកសារ D1.3.34.64 របាយការណ៍ទំនាក់ទំនងតាមទូរស័ព្ទសម្ងាត់រវាងមាស មុត និងបង៨៩ (សុន សេន) ថ្ងៃទី ២០ ខែមីនា ឆ្នាំ១៩៧៨ ERN KH 00020982 ["នៅកោះតាង នាថ្ងៃទី ២០ ខែមីនា ឆ្នាំ ១៩៧៨ នៅវេលាម៉ោង ២.៣០ នាទី កាណូត ៨០០សេសរបស់យើងបានចាប់កាណូតវៀតណាមចំនួន ២ គ្រឿងជាមួយប្រជាជនវៀតណាម ៧៦ នាក់ ទាំងក្មេងនិងចាស់ប្រុសនិងស្រី។ នៅពេលដែលយើងចងពួកគេរួចហើយ កាណូតចាប់ផ្តើមឃ្លោង បណ្តាលឲ្យលិច។ ជាលទ្ធផលមនុស្សពីរនាក់បានធ្លាក់ចូលក្នុងទឹកហើយរកពុំឃើញ។ សល់ប៉ុន្មានត្រូវបាននាំយកទៅដីគោក"]។

[405] ឯកសារ D54/11.1 របាយការណ៍ទំនាក់ទំនងតាមទូរស័ព្ទសម្ងាត់រវាងមាស មុត និងមជ្ឈមណ្ឌល ថ្ងៃទី ០១ ខែមេសា ឆ្នាំ១៩៧៨ ERN KH 00936715 ["ចំនួនទាហានវៀតណាមសរុបដែលត្រូវបានចាប់ខ្លួននិងបាញ់សម្លាប់នៅចន្លោះថ្ងៃទី ២៧ ខែមីនា ឆ្នាំ ១៩៧៨ និងថ្ងៃទី ៣០ ខែមីនា ឆ្នាំ ១៩៧៨ ចំនួន១០២ "។ ចម្លងជូន ប៉ុល ពត នួន ជា និងអៀង សារី"]។ ឯកសារ D1.3.30.25 របាយការណ៍ទំនាក់ទំនងតាមទូរស័ព្ទសម្ងាត់ពី មុត ថ្ងៃទី ០១ ខែមេសា ឆ្នាំ១៩៧៨ ERN KH 00017026 ["សរុបមកចំនួនយួនដែលត្រូវបានចាប់ខ្លួននិងបាញ់សម្លាប់ពីថ្ងៃទី ២៧ ខែមីនា ឆ្នាំ ១៩៧៨ ដល់ថ្ងៃទី ៣០ ខែមីនា ឆ្នាំ ១៩៧៨ មាន ១២០ ក្បាល"]។

[406] ឯកសារ D54/71 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ឆ.៦០ ["រឿងនេះកើតឡើងនៅចុងឆ្នាំ១៩៧៨ គឺប្រហែល២-៣ខែ មុនវៀតណាមចូល"]។

នោះយំផង ស្រែកផង"[408]។ ពួកនោះ "គេចាប់បានជាមួយទូករបស់ពួកគេមកពីសមុទ្រ"[409] ហើយបានសម្លាប់ចម្ងាយត្រឹមតែពីរបីម៉ែត្រ ពីផ្ទះរបស់ មាស មុត[410]។ ជនជាតិវៀតណាមយ៉ាងហោចណាស់១៥០ នាក់ ត្រូវកងពលរបស់មាស មុត ចាប់ និងបញ្ជូនមក ស-២១ នៅឆ្នាំ ១៩៧៨ ដើម្បីធ្វើទារុណកម្ម និងសម្លាប់ ក្នុងនោះ មាន"អ្នកយកការណ៍សម្ងាត់" ទាហាន អ្នកនេសាទ ជនស៊ីវិល និងកុមារ[411]។

142. សុន្ទរកថាផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សររបស់មាស មុត អំពើរបស់គាត់ផ្ទាល់ និងរបស់កម្មាភិបាលក្រោមបង្គាប់របស់គាត់ ចំពោះវៀតណាម ដែលកងពល ១៦៤ ចាប់បាន បង្ហាញច្បាស់ថា គាត់មិនត្រឹមតែមានចេតនាសម្លាប់បុគ្គលទាំងនេះនោះទេ ប៉ុន្តែគាត់ថែមទាំងមានចេតនាកម្ទេច

---

407 ឯកសារ D54/71 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ឆ.៥៦,៥៩ ["ខ្ញុំឃើញយោធាបណ្តើរពួកនោះម្តងមួយៗ។ មនុស្សចាស់ស្រីម្នាក់ និងក្មេងជំទង់២នាក់ អាយុប្រហែល១០ឆ្នាំជាង។ ស្ត្រីចាស់នោះត្រូវបានសម្លាប់នៅចម្ងាយប្រហែល៣០ម៉ែត្រពីផ្ទះរបស់ខ្ញុំ ហើយនឹងក្មេងៗជំទង់២នាក់ទៀត ត្រូវបានសម្លាប់នៅចម្ងាយប្រហែល១០០ម៉ែត្រពីផ្ទះរបស់ខ្ញុំ [...] សៈ តើស្ត្រីវៀតណាមចាស់នោះមានអាយុប៉ុន្មាន? ឆ.៥៩: គាត់មានអាយុជិត៧០ឆ្នាំ"]។

408 ឯកសារ D54/71 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ឆ.៣៩ ["នៅយប់មួយ ខ្ញុំបានឃើញគេយកស្រីយួនចាស់ម្នាក់ ហើយនឹងក្មេងៗពីរបីនាក់ យកមកសម្លាប់នៅក្នុងបរិវេណមន្ទីរក្នុង។ ពួកក្មេងទាំងនោះស្រែកយំ"]។

409 ឯកសារ D54/71 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ឆ.៦១ ["សៈ តើលោកស្រីដឹងថា ពួកយួនទាំងនោះគេយកមកពីណា? ឆ.៦១: ទេ ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំបានឮតាមពួកនីរសារនិយាយគ្នានៅទីនោះ ពួកវៀតណាមទាំងនោះគឺគេចាប់បានជាមួយទូករបស់ពួកគេមកពីសមុទ្រ"]។

410 ឯកសារ D54/71 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត ម៉ៅ ឆ.៥៣,៥៦, ៦៣-៦៥ ["សៈ តើផ្ទះដែលលោកស្រីស្នាក់នៅ ស្ថិតនៅចម្ងាយណាពីផ្ទះមាស មុត ស្នាក់នៅ? ឆ.៥៣: វាស្ថិតនៅឆ្ងាយពីគ្នាប្រហែល ៥០-៦០ម៉ែត្រ។ ដំបូងផ្ទះរបស់គាត់ បន្ទាប់មកផ្ទះបាយ បន្ទាប់មកទៀតបានផ្ទះរបស់ខ្ញុំស្នាក់នៅ [...] ខ្ញុំឃើញយោធាបណ្តើរពួកនោះម្តងមួយៗ។ មនុស្សចាស់ស្រីម្នាក់ និងក្មេងជំទង់២នាក់ អាយុប្រហែល១០ឆ្នាំជាង។ ស្ត្រីចាស់នោះត្រូវបានសម្លាប់នៅចម្ងាយប្រហែល៣០ម៉ែត្រពីផ្ទះរបស់ខ្ញុំ ហើយនឹងក្មេងៗជំទង់២នាក់ទៀត ត្រូវបានសម្លាប់នៅចម្ងាយប្រហែល១០០ម៉ែត្រពីផ្ទះរបស់ខ្ញុំ [...] សៈ តើកន្លែងនោះ គេប្រើជាកន្លែងសម្លាប់មនុស្សផ្សេងទៀតដែរឬទេ? ឆ.៦៣: ទេ តាមខ្ញុំដឹងគេមិនសម្លាប់មនុស្សផ្សេងទៀតនៅទីនោះទេ។ សៈ លោកស្រីបាននិយាយថា គេសម្លាប់ស្ត្រីវៀតណាមចាស់ម្នាក់នៅចម្ងាយប្រហែល៣០ម៉ែត្រពីផ្ទះដែលលោកស្រីស្នាក់នៅ តើក្រោយមកលោកស្រីធ្លាប់ទៅកន្លែងរណ្តៅនោះដែរឬទេ? ឆ.៦៤: ដោយសារកន្លែងនោះ វានៅចម្ងាយ៣០ម៉ែត្រពីក្រោយផ្ទះរបស់ខ្ញុំ ខ្ញុំចាំថា ខ្ញុំបានទៅដល់ទីនោះ ហើយបានឃើញរណ្តៅពីរ បី។ សៈ តើលោកស្រីបានឃើញរណ្តៅនោះ ជារណ្តៅកប់សាកសពរួម ឬក៏រណ្តៅកប់សាកសពមួយៗ? ឆ.៦៥: រណ្តៅនីមួយៗគឺជារណ្តៅតូចៗសម្រាប់កប់សាកសពម្នាក់ៗ។ ខ្ញុំបានឃើញចំនួនពីរ បីរណ្តៅទេ ដែលស្ថិតនៅជិតដើមខ្នុរ និងដើមស្វាយ"]។

411 សូមមើលឧបសម្ព័ន្ធ D.5. រួមទាំងកថាខណ្ឌ ៥៤៨។

ជាតិពន្ធុវៀតណាមនៅកម្ពុជាទៀតផង។ បញ្ជា និងអំពើរបស់មាស មុត បានរួមចំណែកយ៉ាងច្រើន ក្នុងការប្រល័យពូជសាសន៍វៀតណាម នៅដែនទឹកកម្ពុជាប្រជាធិបតេយ្យ នៅកោះ និងនៅកំពង់សោម ជាផ្នែកមួយនៃយុទ្ធការទូទាំងប្រទេសសម្លាប់ក្រុមជនជាតិវៀតណាម។ ជាងមួយភាគបីនៃវៀតណាម ដែលមានក្នុងបញ្ជីចូលស-២១ គឺយកមកពីតំបន់ ដែលស្ថិតក្រោមអំណាច និង គ្រប់គ្រង របស់ មាស មុត[412]។

<u>ជនជាតិថៃ និងជនជាតិលោកខាងលិច</u>

143. ស្រដៀងនេះ អនុលោមតាមគោលនយោបាយ ប.ក.ក **មាស មុត** បានចូលរួមយ៉ាងសកម្មក្នុងការធ្វើទុក្ខបុកម្នេញ និងការសម្លាប់ជនបរទេសដទៃទៀតដែលត្រូវបានចាត់ទុកជាខ្មាំងខាងក្រៅ ពិសេសប្រជាជនថៃ និងប្រជាជនលោកខាងលិច ដែលត្រូវបានចាប់ខ្លួនក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ ឬនៅតាមបណ្តាកោះរបស់ខ្លួន។

144. **មាស មុត** បានចេញបញ្ជាឲ្យចាប់ទូកបរទេសទាំងអស់ដែលបានចូលមកក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ[413] និងបានរាយការណ៍ជាទៀងទាត់ទៅមជ្ឈិមបក្សអំពីសកម្មភាពរបស់កងពលរបស់គាត់ ទាក់ទងការល្បាតតំបន់នេះ។ ជាឧទាហរណ៍ នៅឯអង្គប្រជុំកងពលជាន់ខ្ពស់មួយដែលបានធ្វើនៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ **មាស មុត** បានប្រាប់អ្នកចូលរួមអំពីការទន្ទ្រានចូលដែនទឹកកម្ពុជា

412 ចំនួនសរុបនៃបុគ្គលដែលត្រូវបានកំណត់ជាជនជាតិវៀតណាមនៅក្នុង ក.ស.ច.ស មន្ទីរស-២១ បញ្ជីឈ្មោះអ្នកទោស ៥១៧ (D114/230.1.1)។ ក្នុងចំណោមអ្នកទាំងនោះ មាន១៨៨នាក់ ត្រូវបានយកទៅមន្ទីរស-២១ ដោយកងពល ១៦៤។ សូមមើល ឧបសម្ព័ន្ធ Annex D.5 [ឈ្មោះប្រាំមួយដែលមិនត្រូវបានបញ្ចូលនៅក្នុងបញ្ជីឈ្មោះអ្នកទោសមន្ទីរស-២១ របស់ ក.ស.ច.ស ត្រូវបានបន្ថែមទៅក្នុងឧបសម្ព័ន្ធ D.5]។

413 ឯកសារ D114/24 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ ដាវ ឆ.៨៧-៩១ ["យើងបានជិះចូលទៅជិត ហើយហក់ឡើងលើទូកនេសាទត្រី ហើយបានភ្ជង់កាំភ្លើងទៅលើពួកដែលនៅលើទូក។ ក្នុងករណីបើពួកគេតដៃ ពួកយើងនឹងបាញ់សម្លាប់ពួកគេ។ សៈ តើមានរឿងអ្វីកើតឡើងទៀត? ឆ.៨៨: ក្រោយពីការចាប់ យើងឲ្យពួកគេបើកទូកនេសាទរបស់ពួកគេចូលមកក្នុងដែនសមុទ្រខ្មែរ នៅផែកំពង់សោម កន្លែងរបស់ មាស មុត។ សៈ ក្នុងវគ្គបណ្តុះបណ្តាល តើលោកធ្លាប់ទទួលបញ្ជាឲ្យចាប់ទូកបរទេសដែលចូលក្នុងដែនទឹកខ្មែរដែរឬទេ? ឆ.៨៩: បាទ នៅក្នុងវគ្គបណ្តុះបណ្តាល គេបានប្រាប់ថា បើសិនមានទូកបរទេសចូលមកក្នុងដែនសមុទ្រខ្មែរគឺត្រូវតែចាប់។ សៈ តើនរណាគេជាអ្នកបញ្ជាឲ្យចាប់ទូកនេះ? ឆ.៩០: គឺថ្នាក់លើ។ សៈ ហេតុដូចម្តេចបានជាលោកដឹងរឿងនេះ? ឆ.៩១: ខ្ញុំដឹងពីការបញ្ជាពីថ្នាក់លើ គឺនៅពេលកងវរៈសេនាតូច ហៅកងអនុសេនាធំ និងកងអនុសេនាតូចទៅប្រជុំ គឺគេប្រាប់ថាការបញ្ជានោះ គឺមកពីបក្ស មានន័យថាថ្នាក់លើ។ បក្សសំដៅទៅ មាស មុត"]។

ប្រជាធិបតេយ្យពីសំណាក់ទូកនេសាទថៃ និងការចាប់ទូកមួយក្នុងចំណោមទូកទាំងនោះប៉ុន្មានថ្ងៃមុននោះ[414]។

145. **មាស មុត** ក៏បានប្រាប់ សុន សេន អំពីការចាប់ខ្លួនជនជាតិថៃពីសំណាក់កងទ័ពជើងទឹកផងដែរ។ ជាក់ស្តែងនៅខែ សីហា ឆ្នាំ ១៩៧៧ គាត់បានរាយការណ៍អំពីការសួរចម្លើយអ្នកនេសាទថៃចំនួន ៥ នាក់ ដែលតាមរយៈនេះបានបង្ហាញអំពីការសង្ស័យទៅលើប្រជាជនថៃ ដែលធ្វើឡើងដោយ **មាស មុត** និងឋានានុក្រម ប.ក.ក[415]។ ការសង្ស័យនេះត្រូវបានបង្ហាញបន្ថែមដោយចំណាររបស់ សុន សេន នៅលើរបាយការណ៍នេះ ដែលគាត់គូសបញ្ជាក់ថាចំណុចចូលមកក្នុងកម្ពុជាប្រជាធិបតេយ្យ ត្រូវតែកំណត់ឲ្យបានច្បាស់ដើម្បីទប់ស្កាត់ការចូលមកនៅពេលក្រោយទៀត[416]។ ទោះជាដូច្នេះក្តី នៅថ្ងៃទី ១ ខែ មីនា ឆ្នាំ ១៩៧៨ **មាស មុត** បានប្រាប់ ប៉ុល ពត និង នួន ជា អំពីការដោះលែងប្រជាជនថៃទាំងនោះ។ ការដោះលែងនោះហាក់ដូចជាត្រូវបានរៀបចំដោយសមាជិកគណៈកម្មាធិការក្រុងកំពង់សោម ឈ្មោះ ឡុញ ក្រោមការត្រួតពិនិត្យរបស់ **មាស មុត** និងដោយមានការឯកភាពពីមេដឹកនាំបក្ស[417]។

---

414 ឯកសារ D114/27.1.5 កំណត់ហេតុប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាម ១៩៧៦ ERN KH 00052389-01 ["ជនជាតិថៃកាន់តែច្រើនឡើងបានមករកត្រីនៅក្នុងដែនសមុទ្ររបស់យើង។ ពួកគេបានមកជាជួរៗដោយមានទូកនេសាទពី ១០០ ទៅ ១៥០។ ពួកគេភាគច្រើនបានមកនៅតំបន់ជុំវិញកោះកុងនិងកោះត្រាង។ នៅថ្ងៃទី ១១ ខែកញ្ញាយើងបានចាប់ទូកនេសាទមួយគ្រឿងជាមួយម៉ាស៊ីន ៥០ សេស"]។

415 ឯកសារ D1.3.12.20 របាយការណ៍ពីមាស មុត ទៅកាន់ខៀវ (សុន សេន) ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧ ERN KH 00020912 ["កាលពីម្សិលមិញនៅថ្ងៃទី ១១ ខែសីហា ឆ្នាំ១៩៧៧ នៅពេលយើងបើកយាមល្បាតយើងបានចាប់ទូកម៉ាស៊ីនពីរ ៣៥០សេស និង១៧៥សេស ។ ក្រោយមកបានដឹកមនុស្សប្រាំនាក់ដោយគ្មានឧបករណ៍នេសាទ។ ពួកគេត្រូវបានចាប់ខ្លួនចម្ងាយ ២ គីឡូម៉ែត្រពីកោះកុង។ ក្រោយមកយើងបានសាកសួរពួកគេ"]។

416 ឯកសារ D1.3.12.20 របាយការណ៍ពីមាស មុត ទៅកាន់ខៀវ (សុន សេន) ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧ ERN KH 00020912 ["[ចំណារដោយអក្សរដៃនៅខាងឆ្វេង] ជូនអង្គការ: (១) យើងខ្ញុំឲ្យសួររកខ្សែខាងក្នុង (២) រកផ្លូវចេញចូល (៣) សភាពការពួកអាក្សត់នៅតាមព្រំដែន"]។

417 ឯកសារ D54/11.1 របាយការណ៍ទំនាក់ទំនងតាមទូរស័ព្ទសម្ងាត់រវាងមាស មុត និងមជ្ឈមណ្ឌល ថ្ងៃទី ០១ ខែមេសា ឆ្នាំ១៩៧៨ ERN KH 00936715 ["ចំនួនសរុបនៃទាហានវៀតណាមដែលត្រូវបានចាប់ខ្លួននិងបាញ់សម្លាប់នៅចន្លោះថ្ងៃទី ២៧ ខែមីនាឆ្នាំ ១៩៧៨ និងថ្ងៃទី៣០ ខែមីនា ឆ្នាំ ១៩៧៨ ចំនួន ១០២ ។ ក្នុងអំឡុងពេលនេះយើងក៏រឹបអូសទូកម៉ូតូប្រាំគ្រឿងរវាងម៉ាស៊ីន ១០ និង ៣៧ ហ្វា និងកាំភ្លើងជាច្រើនរួមទាំង M៧៩ និងសម្ភារៈយោធាផ្សេងទៀត។ យើងបានបរាជ័យក្នុងការដោះលែងពួកអ្នកទោសថៃតាមការគ្រោងទុកដោយសារតែឈ្មោះរបស់ពួកគេមួយចំនួនមិនត្រូវគ្នា

146. ប៉ុន្តែ មិនមែនប្រជាជនថៃដែលត្រូវបានចាប់ខ្លួនទាំងអស់សុទ្ធតែទទួលបានការប្រព្រឹត្តិដូចៗគ្នានៅក្រោយពេលចាប់ខ្លួនឡើយ។ **មាស មុត** បានចេញបញ្ជាដោយផ្ទាល់ឱ្យសម្លាប់ប្រជាជនថៃ នៅឯទីតាំងពិឃាតមួយកន្លែងរបស់កងពលធំ ១៦៤ ឈ្មោះចម្ការទុរេន I[418]។ គាត់ក៏បានទទួលរបាយការណ៍លម្អិតនានាដែលថា មនុស្សក្រោមបង្គាប់របស់គាត់បានកំពុងសម្លាប់ប្រជានេសាទថៃ។ ជាឧទាហរណ៍ អនុលេខារបស់ **មាស មុត** បានរាយការណ៍ទៅ **មាស មុត** និង សុន សេន ថា "ចំពោះទូកថៃពីរដែលបានចូលមកក្បែរដែនទឹករបស់យើង ក្បែរកោះរបស់យើង ខ្ញុំបានបើកកប៉ាល់របស់

---

ជាមួយនឹងបញ្ជីឈ្មោះភ្នាក់ងាររបស់យើង។ មិនមែនឈ្មោះទាំងមូលទេប៉ុន្តែមានតែឈ្មោះចុងបញ្ចប់ត្រូវបានសរសេរមិនត្រឹមត្រូវ។ យើងមិនអាចទាក់ទងគ្នាដើម្បីទទួលបានដំបូន្មាននោះទេពីព្រោះវិទ្យុមិនដំណើរការ។ ដោយផ្អែកលើព័ត៌មាននៅក្នុងទូរលេខពីសមមិត្តឡង់ និងដោយសារការបញ្ជូនសារយឺតយ៉ាវ ការប្រគល់កងទ័ពថៃត្រូវបានពន្យារពេលរហូតដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ ១៩៧៨ នៅម៉ោង ៨:០០ យប់។ ភ្នាក់ងារទាំងនោះគឺជាចៅហ្វាយស្រុកខ្លងយ៉ៃ និងជាសមាជិកនៃក្រុមទទួល។ ភ្នាក់ងារថៃបានប្រគល់ដល់សមមិត្តរបស់យើងនូវបារីចំនួនបីសុង និងប្រេងកូឡា១ដប "។ ចម្លងជូន ប៉ុល ពត នួន ជា និងអៀង សារី"]។

418 ឯកសារ D54/102 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី ឆ.២៩, ៤១-៤៤ ["កន្លែងនៅខាងលិចចម្ការដូងជាប់នឹងជើងភ្នំ គឺជាចម្ការធូរេន ដែលជាកន្លែងតាមុត យកជនជាតិថៃទៅសម្លាប់ ហើយកប់សាកសពនៅក្រោមដើមធូរេនសម្រាប់ធ្វើជី។ ប្រសិនបើជនជាតិថៃចង់ស្វែងរកឆ្អឹងបងប្អូនពួកគេ ពួកគេអាចទៅរកនៅចម្ការធូរេននោះចុះ។ ពេលគេចាប់បានទូកនេសាទថៃ ១៤០០សេស ចំនួនពីរគ្រឿង និង១៨០០សេស ១គ្រឿង គេយកអ្នកនេសាទថៃទាំងអស់ទៅសម្លាប់នៅទីនោះ។ នាវានោះលឿនណាស់ដូចយន្តហោះអ៊ីចឹង។ អំឡុងពេលនោះ នៅពេលដែលគេចាប់បានជនភៀសខ្លួនជនជាតិវៀតណាម ដែលធ្វើដំណើរតាមទូកភៀសខ្លួនទៅប្រទេសទី៣ គេយកពួកវៀតណាមទាំងនោះទៅសម្លាប់នៅចម្ការធូរេនផងដែរ។ គេហៅអ្នកទាំងនោះទៅធ្វើជីដាក់ដើមធូរេន [...] ឆ.៤១: ពីដំបូងឡើង ពេលយើងចាប់បានជនជាតិវៀតណាម និងថៃបាន យើងបញ្ជូនទៅឱ្យតាមុត នៅកំពង់សោម ប៉ុន្តែក្រោយមកតាមុត បានបញ្ជាមកយើងកុំឱ្យខាតសាំង ដើម្បីដឹកពួកគេមកកំពង់សោមធ្វើអី ឲ្យយកធ្វើជាជីដាក់គល់ដូងនៅលើកោះទាំងអស់ទៅ។ សាកសពម្នាក់ត្រូវកាត់ជាពីរកំណាត់ ហើយមួយកំណាត់ៗកប់នៅក្រោមដើមដូងមួយដើមៗ។ សៈ តើលោកបានឃើញការកាត់សាកសពជាពីរកំណាត់ដោយផ្ទាល់ភ្នែករបស់លោកដែរឬទេ? ឆ.៤២: ទេ ខ្ញុំមិនបានឃើញពេលដែលគេកំពុងកាត់សាកសពនោះទេ ប៉ុន្តែគ្រប់ៗគ្នាដឹងអំពីរឿងនេះ ដោយសារក្លិន ហើយនិងស្នាមហើមនៅខាងក្រោមរណ្ដៅដូងតូចៗនោះ។ សៈ នៅពេលដែលលោកនិយាយថា ពេលចាប់ពួកវៀតណាម និងថៃ គឺបញ្ជូនទៅឱ្យតាមុត នៅកំពង់សោម សូមលោកពន្យល់ថាតើលោកនិយាយនេះមានន័យថាម៉េច? ឆ.៤៣: អ្នកណាក៏ដោយ ដែលចាប់បានដោយកងជើងទឹកត្រូវតែបញ្ជូនទៅឱ្យតាមុត នៅកំពង់សោម ហើយយើងឮថា ពួកគេនឹងត្រូវបង្ហើយនៅចម្ការធូរេនទាំងអស់។ នៅពេលនោះកន្លែងដែលសម្លាប់របស់កងពល១៦៤ គឺមានតែនៅចម្ការធូរេនទេ។ សៈ ម៉េចបានជាលោកដឹងថា តាមុត ប្រាប់មិនឱ្យបញ្ជូនអ្នកដែលចាប់ទាំងនោះទៅកំពង់សោមទៀត? ឆ.៤៤: ពួកមេកងៗប្រាប់ថា យើងមិនបាច់បញ្ជូនអ្នកទាំងនោះទៅកំពង់សោមទៀតទេ ពីព្រោះបងប្រធានកងពលបានប្រាប់យើងឱ្យបញ្ចប់ពួកនោះនៅនឹងកន្លែងតែម្ដង"]។

យើង និងអាចចាប់បានទាំងពីរ មួយគឺ ៣០០សេស ហើយមួយទៀតគឺ ៤០០សេស។ ចំពោះទូកដែលយើងចាប់បាននៅខាងត្បូងកោះកុង មានផ្ទុកត្រីខ្លះ និងប្រេងខ្លះ។ មនុស្សភាគច្រើននៅលើទូកបានលោតចូលក្នុងទឹកដើម្បីគេចខ្លួន។ *កម្មាភិបាលយើងបានកម្ទេចអ្នកដែលនៅសេសសល់*"[419]។

147. ប្រជាជនថៃជាច្រើនរយនាក់បានបាត់ខ្លួន ឬត្រូវបានសម្លាប់ក្នុងតំបន់ដែល **មាស មុត** ទទួលខុសត្រូវក្នុងអំឡុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ[420] ដោយរួមបញ្ចូលប្រជាជនថៃចំនួន ៥៨ នាក់ដែលត្រូវបានបញ្ជូនពីកំពង់សោមទៅមន្ទីរសន្តិសុខ ស-២១ ដើម្បីសម្លាប់[421]។

148. **មាស មុត** ក៏ទទួលខុសត្រូវចំពោះការចាប់ខ្លួន និងការសម្លាប់ជនជាតិលោកខាងលិចយ៉ាងហោចណាស់ចំនួន ១០ នាក់ផងដែរ ដែលត្រូវបានចាប់ខ្លួនក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យពីសំណាក់មនុស្សក្រោមបង្គាប់របស់គាត់។ **មាស មុត** បានពន្យល់ថា កងពលធំ ១៦៤ នឹងមិនទុកជនជាតិលោកខាងលិច "ឱ្យយូរដូចអ្នកដែលមកពីប្រទេសជិតខាងឡើយ" ពីព្រោះ "ប៉ុល ពត ខៀវ សំផន អៀង សារី បានទទួលការអប់រំនៅលោកខាងលិចក្នុងប្រទេសបារាំង [...]។ នោះជាមូលហេតុដែលពួកគាត់ចាត់ការពួកលោកខាងលិចលឿនដូច្នេះ គឺចាត់ការពួកលោកខាងលិចលឿនជាងមនុស្សដទៃ ពីព្រោះពួកគាត់ខ្លាច ប៉ុល ពត ខៀវ សំផន ខ្លាច"[422]។

149. ជនបរទេសចំនួន ៨ នាក់ក្នុងចំណោមជនបរទេសដែលមិនមែនជាអាស៊ី ដែលត្រូវបានចាប់ខ្លួននៅសមុទ្រ ត្រូវបានបញ្ជូនទៅ ស-២១ ដែលនៅទីនោះពួកគាត់ត្រូវបានឃុំឃាំង ទទួលទារុណកម្ម និងត្រូវបានសម្លាប់ បន្ទាប់ពីបានផ្តល់ "ចម្លើយសារភាព"[423]។ មនុស្សបួននាក់មកពីសហរដ្ឋអាមេរិក

---

[419] ឯកសារ D118/207.2 របាយការណ៍ពីឌឹម ទៅកាន់បង៨៩ (សុន សេន) និងបងមុត (មាស មុត) ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ១៩៧៧ ["ចំពោះទូកថៃដែលចូលក្នុងសមុទ្រយើងយ៉ាងជ្រៅ ហើយជិតកោះរបស់យើង ខ្ញុំបានចេញកប៉ាល់ធ្វើការចាប់បានទូក២គ្រឿង១គ្រឿងធុន៣០០សេស និង១គ្រឿងទៀត ៤០០សេស។ ចំពោះទូកដែលចាប់បាននៅខាងត្បូងកោះកុង នៅលើទូកមានកូឡាំង២គ្រឿង និងត្រីមួយចំនួន និងប្រេង ចំពោះមនុស្សគ្មានបានទេ ពីព្រោះវាលោតធ្លាក់ទឹកនៅសល់មួយចំនួន បងប្អូនកំទេចចោលអស់" (សេចក្តីបញ្ជាក់បានបន្ថែម)]។

[420] សូមមើល ជំពូក ៨.ខ.៤ បទបញ្ជារបស់លោកមាសមុតទាក់ទងនឹងជនជាតិថៃ។ ជំពូក ៨.ខ. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សដែលចាប់បានដោយកងទ័ពជើងទឹកនៅដែនទឹកនិងលើដែនកោះកម្ពុជាប្រជាធិបតេយ្យដែលអះអាងដោយកម្ពុជាប្រជាធិបតេយ្យ។ ជំពូក ៨.ច ទីតាំងការងារនៅរាម។

[421] សូមមើល ឧបសម្ព័ន្ធ D.6. និង ផ្នែក VIII.D. មន្ទីរសន្តិសុខ ស-២១ ។ III. តួនាទី និងទំនួលខុសត្រូវរបស់មាស មុត។

[422] ឯកសារ D54/16/1R សម្លេងសម្ភាសន៍របស់មាស មុត ជាមួយ ដេវីដ ខេថេនបឺហ្គ ឆ្នាំ២០០៩ 43:52-46:09។

[423] សូមមើល ឧបសម្ព័ន្ធ D.7។

ពីរនាក់មកពីអូស្ត្រាលី និងម្នាក់មកពីញូហ្សេឡែន និងម្នាក់ទៀតមកពីចក្រភពអង់គ្លេស[424]។ មនុស្សពីរនាក់ផ្សេងទៀតដែលត្រូវបានចាប់ខ្លួន ដោយមនុស្សក្រោមបង្គាប់របស់ **មាស មុត** គឺទាហានអាមេរិកដែលត្រូវបាននាំខ្លួនទៅកំពង់សោមតាមបញ្ជារបស់ **មាស មុត**។ ពួកគាត់មិនដែលត្រូវបានឃើញនៅមានជីវិតម្តងទៀតឡើយ[425]។

---

424 ឯកសារ D98/3.1.93 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹក ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០៩ 10.05.29-10.18.09 [ជនបរទេសលោកខាងលិចដែលត្រូវបានបញ្ជូនទៅស -២១ ត្រូវបាន "ចាប់ខ្លួនដោយមន្ត្រីកងនាវាចរនៃកងពល ១៦៤ ហើយពួកគេត្រូវបានបញ្ជូនតាមកំពង់សោម"]។ ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០១៦ 09.46.04-09.48.23 ["មានអ្នកទោសវៀតណាម អាមេរិច និងអូស្ត្រាលីដែលខ្ញុំធ្លាប់ឃើញ"]។ ឯកសារ D1.3.33.3 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ERN KH 00146477 [ជនជាតិស្បែកខ្មៅដែលត្រូវបានឃុំខ្លួននិងសម្លាប់នៅមន្ទីរ ស-២១ "បានចូលក្នុងដែនទឹករបស់ប្រទេសកម្ពុជាហើយអង្គភាពកងនាវាចរបានចាប់ខ្លួនហើយបញ្ជូនពួកគេ"]។ ឯកសារ D1.3.33.4 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ERN KH 00197967 [ស: តើរដ្ឋមន្ត្រីក្រសួងការបរទេសបានដឹងអំពីការចាប់ខ្លួនជនជាតិបរទេស ៤នាក់ ដែលសាកសពរបស់ពួកគេត្រូវបានដុតទេ? ខ្ញុំមិនគិតដូច្នោះទេសុន សេន បានបញ្ជូនពួកគេពីរនាក់ហើយ នួនជាបានបញ្ជូនពីរនាក់ទៀត"]។ ឯកសារ D4.1.742 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម អេន ERN KH 00162833 [អតីតទាហានស-២១ បានថតរូប "មនុស្សដែលមានសញ្ជាតិផ្សេងទៀតដែលបាននាំយកមកពីសមុទ្រ" ដែលមាន "ធំ មានច្រមុះស្រួច" និងពុកចង្ការ]។ ឯកសារ D114/302 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ ផៃ ឆ.៧៣-៨៥ [ពិពណ៌នាអំពីអ្នកទោសជនជាតិអាមេរិកពីរនាក់ដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១ នៅឆ្នាំ 1978 ដែលត្រូវបានសួរដេញដោលដោយឌុចហើយត្រូវបានគេនាំយកទៅសម្លាប់បន្ទាប់ពីសួរចម្លើយពួកគេនិងកំណត់អត្តសញ្ញាណរូបថតអ្នកទោស]។ ឯកសារ D114/301 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុន ផល ឆ.៦២-៦៩។ ឯកសារ D114/132 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ៅ វ៉ាន់ ឆ.១៩៦-១៩៩ [ពិពណ៌នាអំពីទូកដែលចាប់បានដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ]។ ឯកសារ D2/15 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ឆ.១-៨ [ពិពណ៌នាពីជនបរទេសបាននាំយកពីអូរឈើទាលដោយកងពលលេខ១៦៤]។ ឯកសារ D37 កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី រ៉ូប៊ើត ហាមីល (Robert Hamill) ERN KH 00945759 [ការទទួលយកពីលោកមាសមុតថាជនបរទេសដែលត្រូវបានចាប់ខ្លួននៅសមុទ្រ "ត្រូវបានបញ្ជូនទៅស -២១"]។ ឯកសារ D88.1.17 និពន្ធដោយលោក ដេវីដ ខេថេប៊ឺហ្គ (David Kattenburg) ស្តីពី នារីដូចចចក: សេចក្តីពិត ការចងចាំ និងការស្លាប់របស់អ្នកជិះទូកខាងលិចនៅកម្ពុជាប្រជាធិបតេយ្យ (Foxy Lady: Truth, Memory & the Death of Western Yachtsmen in Democratic Kampuchea។ EN 00916182 [សង្ខេបការសម្ភាស Stony Beach ជាមួយអតីតកងពល ១៦៤ ដែលបានចាប់យកទូកបរទេស]។

425 សូមមើលកថាខណ្ឌ ៤៥៧-៤៥៩។ ឯកសារ D54/48 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ឆ.១៧-១៩ ["ស: តើបញ្ជាដែលចេញពីមាស មុតនោះមានអ្វីខ្លះ? ឆ.១៧: បញ្ជាមានដូចជា គាត់ បើកកាណូត បេអឺ ដោយដឹក

<u>មន្ទីរសន្តិសុខកងពលធំ១៦៤</u>

150. **មាស មុត** បានបង្កើតមន្ទីរសន្តិសុខនានានៅក្នុងតំបន់កំពង់សោម ជាផ្នែកមួយនៃបណ្ដាញមន្ទីរសន្តិសុខនៃកម្ពុជាប្រជាធិបតេយ្យ ដែលបានរួមបញ្ចូលមន្ទីរសន្តិសុខ ស-២១ នៅភ្នំពេញ។ ការអនុវត្ត "ការប្រុងប្រយ័ត្នបដិវត្តន៍" ចំពោះគ្រប់ទម្រង់នៃសកម្មភាពខ្មាំង[426] នៅតាមបណ្ដាតំបន់ក្រោមការ

---

យោធាវរសេនាតូច៤១០ ទៅកោះតាង ដើម្បីប្ដូរក្រុមរបស់ខ្ញុំ។ បន្ទាប់មកគាត់ត្រូវដឹកទាហានអាមេរិកាំងពីរនាក់ និងកងវរសេនាតូចរបស់ខ្ញុំមកដីគោកវិញ។ ស: តើបញ្ជាហ្នឹងជាបញ្ជាចេញមកពីមេបញ្ជាការកងពល មាស មុត ឬ? ឆ.១៨: អ្នកកាន់វិទ្យុហៅ មាស មុតថាអ៊ំ។ គេបានបញ្ជាក់ប្រាប់ថា បញ្ជានេះចេញមកពីអ៊ំ? ស: នៅពេលដែលមេបញ្ជាការកងពល មាស មុត អវត្តមាន តើមានអ្នកណាផ្សេងអាចប្រើលេខវិទ្យុទាក់ទងលេខ៦៣ ឬអ៊ំដែរឬទេ? ឆ.១៩: ក្នុងករណីដែលអវត្តមាន មាស មុត គឺ ទឹម សេង ឬក៏សេង ង៉ែត ជាអ្នកទទួលខុសត្រូវជំនួស ក៏ប៉ុន្តែពួកគេមានលេខសម្រាប់ទាក់ទងតាមវិទ្យុរៀងៗខ្លួន។ ចំណែក មាស មុត មានលេខវិទ្យុលេខ៦៣"]។

426 ឯកសារ D4.1.94 កំណត់ហេតុប្រជុំការងារមូលដ្ឋានរបស់បក្សកុំមុយនីស្តយ៍កម្ពុជា ថ្ងៃទី ៨ ខែមីនា ឆ្នាំ១៩៧៦ ERN KH 00017116 ["ប៉ុល ពត: ការប្រុងប្រយ័ត្នរបស់យើងត្រូវតែខ្ពស់ជាងនេះ"]។ ឯកសារ D4.1.195 សេចក្តីថ្លែងការរបស់នួន ជានៃបក្សកុំមុយនីស្តយ៍កម្ពុជាជូនបក្សកុំមុយនីស្តយ៍ដាណឺម៉ាក ខែកក្កដា ឆ្នាំ១៩៧៨ ERN KH 00224457 ["ក្រុមការងារត្រូវបានណែនាំដោយប្រុងប្រយ័ត្នការធ្វើបដិវត្តន៍ផងដែរ និងត្រូវយកចិត្តទុកដាក់ដើម្បីការពារប្រឆាំងនឹងសត្រូវ"]។ ឯកសារ D4.1.986 សន្ទរកថារបស់ខៀវ សំផន ថ្ងៃទី ១៥ ខែមេសា ឆ្នាំ១៩៧៧ ERN KH 00292805 ["យើងត្រូវតែបោសសម្អាតសត្រូវក្នុងសមត្ថភាពរបស់យើងម្ចាស់លើស្ថានការណ៍ ... អ្វីៗត្រូវធ្វើបានយ៉ាងល្អប្រណិត និងគ្រប់ជ្រុងជ្រោយ ... យើងត្រូវតែប្ដេជ្ញាដោយខ្លួនឯងបន្ថែមទៀត ត្រូវប្រុងប្រយ័ត្នជាប់ជានិច្ច រក្សាស្មារតីបដិវត្តឥតងាករេ បន្តវាយប្រយុទ្ធនិងទប់ស្កាត់សត្រូវគ្រប់ប្រភេទ គ្រប់ពេលវេលា"]។ ឯកសារ D4.1.177 របាយការណ៍ធ្វើការជាមួយគណៈកម្មាធិការគ្រប់អង្គភាព ថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ១៩៧៧ ERN KH 00086710 [អៀង សារី: "យើងត្រូវលើកកម្ពស់ប្រុងប្រយ័ត្នបដិវត្តឲ្យកាន់តែខ្ពស់"]។ ឯកសារ D114/27.1.8 កំណត់ហេតុប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ, កំណត់ហេតុនៃកិច្ចប្រជុំរបស់លេខាធិការនិងភស្តុភារ [ប្រធាន] នៃកងពលនិងវរៈសេនាធំ ថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ១៩៧៦ ERN KH 00195352 [សុន សេន: "យើងត្រូវតែបង្ហាញពីទស្សនៈនៃការប្រុងប្រយ័ត្នពីបដិវត្តន៍ដើម្បីវាយប្រហារការខបាយកលរបស់សត្រូវ"]។ ឯកសារ D1.3.27.20 កំណត់ហេតុប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៩ ខែតុលា ឆ្នាំ១៩៧៦ ERN KH 00052407 [សុន សេន: "ប្រតិបត្តិការជាក់ស្ដែងនៃការប្រុងប្រយ័ត្នបដិវត្តន៍ មានន័យថាការកាន់កាប់ក្រុមអង្គភាពរបស់យើងដើម្បីធានាថា
សត្រូវមិនអាចទទួលបានពីខាងក្រៅ និងធ្វើអ្វីដែលចាំបាច់ដើម្បីធានាថាកងទ័ពរបស់យើងស្អាតស្អំ"]។ ERN KH 00052411 [លោកស៊ូម៉េត លេខាធិការដ្ឋាន កងពល៥០២ បានមានប្រសាសន៍ថា: "បទពិសោធន៏នេះបង្ហាញថាបក្សរបស់យើងមានការក្ដាប់បានជំហរនៃការប្រុងប្រយ័ត្នជាប់" [...] [កងពល១៦៤ លេខាធិការដ្ឋាន មាស មុត] "មេរៀននេះបានពង្រឹងគោលជំហរប្រុងប្រយ័ត្នបដិវត្តមួយកំរិតថែមទៀត"]។

គ្រប់គ្រងរបស់គាត់ បានទទួលលំហូរជាប់ជាប្រចាំនៃ "ខ្មាំង" ដែលត្រូវចាត់ការតាមរយៈមន្ទីរសន្តិសុខទាំងនោះ។

151. ការបង្កើតរបស់ **មាស មុត** នូវមន្ទីរសន្តិសុខឥន្ទញ្ញាណ និងមន្ទីរសន្តិសុខទឹកសាប គឺស៊ីសង្វាក់ជាមួយគោលនយោបាយ ប.ក.ក ក្នុងការវែកមុខ និងកម្ចាត់ខ្មាំង ដោយរួមបញ្ចូលមនុស្សដែលគេចាត់ទុកជា "ជនក្បត់" និង "គិញ"[427] ដោយគ្មានដំណើរការតាមច្បាប់នៅឯមន្ទីរសន្តិសុខនានាដែល ប.ក.ក បានបង្កើតនៅទូទាំងប្រទេសតាំងពីឆ្នាំ ១៩៧១[428]។ វិធីសាស្ត្រនៃទារុណកម្ម និងការសួរចម្លើយដែលប្រើប្រាស់ដោយមនុស្សក្រោមបង្គាប់របស់ **មាស មុត** នៅតាមមន្ទីរសន្តិសុខទាំងនោះ[429] ត្រូវបានបង្កើតឡើងមុនឆ្នាំ ១៩៧៥ អនុលោមតាមការណែនាំរបស់មេដឹកនាំបក្ស[430]។ មន្ទីរ

---

427 ឯកសារ D234/2.1.14 ថេត សម្បត្តិ នៅពីក្រោយវាលពិឃាត EN 00757526។

428 ឯកសារ D4.1.1112 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ERN KH 00185465 ["ខ្ញុំគឺជាប្រធាន M-១៣ ចាប់ពីថ្ងៃទី ២០ ខែកក្កដាឆ្នាំ ១៩៧១ រហូតដល់ថ្ងៃទី ១ ខែមករាឆ្នាំ ១៩៧៥"]។ ឯកសារ D1.3.33.3 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ERN KH 00146477 ["បានបញ្ជាក់ពីការធ្វើទារុណកម្មមុននឹង ស-២១ ក្លាយជា "ការិយាល័យ ១៣" មុនថ្ងៃទី ២០ ខែកក្កដាឆ្នាំ ១៩៧១"]។ ឯកសារ D98/3.1.214 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផាន ឈិន ERN KH 00483937 [សាក្សីបញ្ជាក់ថាការិយាល័យក្រាំតាចាន់ដែលត្រូវបានប្រើដើម្បីសួរចម្លើយអ្នកទោសត្រូវបានបើកនៅក្នុងឆ្នាំ ១៩៧២]។ ឯកសារ D4.1.785 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផាន ឈិន ERN KH 00373463 [សាក្សីបញ្ជាក់ថាការិយាល័យក្រាំតាចាន់បានបើកនៅក្នុងឆ្នាំ១៩៧២]។

429 សូមមើល VIII.C. មន្ទីរសន្តិសុខកងពល១៦៤។

430 ឯកសារ D98/3.1.79 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹក ថ្ងៃទី ៧ ខែមេសា ឆ្នាំ២០០៩ 14.03.10-14.06.09។ ឯកសារ D98/1.2.15 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹក ថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១២ 15.40.48 ["លោកវន វ៉េតបានណែនាំខ្ញុំអំពីវិធីធ្វើទារុណកម្ម"]។ 15.52.49-15.55.05 [ការងាររបស់នគរបាលនេះត្រូវបានអនុម័តដោយវប្បធម៌របស់គណបក្ស ... គំរូនេះត្រូវបានទុកចោលពីឥស្សរៈ ហើយវាត្រូវបានអនុវត្តនៅស -២១]។ ឯកសារ D4.1.1115 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ERN KH 00146657។ ឯកសារ D1.3.33.3 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ERN KH 00146477 ["វន វ៉េតគឺជាអ្នកបង្រៀនខ្ញុំ"]។ ឯកសារ D4.1.346 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ម ណៃ ERN KH 00162877 [" សៈ តើនរណានៅកំរិតខ្ពស់? ឆៈ នៅអមលាំង លោកវន វ៉េត ជាមេបញ្ជាការតំបន់"]។

ទាំងនេះត្រូវបានបង្កើតឡើងដើម្បីអនុញ្ញាតឲ្យ ប.ក.ក សម្លាប់ "ខ្មាំង" ជាសម្ងាត់ដើម្បីបញ្ចៀសប្រតិកម្មអវិជ្ជមានប្រឆាំងបក្ស[431]។

152. ទោះបី **មាស មុត** អះអាងថា "គ្មានមន្ទីរឃុំឃាំងនៅកំពង់សោម" និងថាក្នុងតំបន់នេះមានតែកន្លែង "ទុក[មនុស្សដែលត្រូវបានចាប់ខ្លួន] យ៉ាងហោចណាស់ចំនួនមួយសប្តាហ៍ដោយរង់ចាំមន្ត្រីនានាពីភ្នំពេញមកយកពួកគាត់ទៅ" ក៏ដោយ[432] ក៏ភស្តុតាងបង្ហាញផ្ទុយពីនេះ។ **មាស មុត** បានអនុវត្តតាមសារាចរណ៍របស់ ប.ក.ក ទាក់ទងភាពចាំបាច់នៃមន្ទីរសន្តិសុខ តាមរយៈការបង្កើតគុកយ៉ាងហោចណាស់ចំនួនពីរនៅតំបន់កំពង់សោម៖ វត្តអង្គតាញ្ញាណ និងទឹកសាប។ ទីតាំងទាំងនោះក៏ត្រូវបានស្គាល់ថាជាមន្ទីរកែប្រែកងពលធំ១៦៤[433] និងត្រូវបានប្រើប្រាស់ដើម្បី "លត់ដំ" ចាប់ខ្លួន ឃុំឃាំង សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់មនុស្សទាំងឡាយ ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តកំហុស ឬជាប់សង្ស័យថាជាប់ខ្សែរយៈខ្មាំង។

*ក) មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ*

153. នៅមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណក្នុងក្រុងកំពង់សោម **មាស មុត** បានគ្រប់គ្រងកងវរសេនាតូច ១៦៥ (៤៥០) ដោយផ្ទាល់ ដែលទទួលខុសត្រូវលើប្រតិបត្តិការមន្ទីរសន្តិសុខនេះ[434]។ មេបញ្ជាការ កងវរ

---

431 ឯកសារ D234/2.1.28 ទង់បដិវត្ត ខែកក្កដា ឆ្នាំ១៩៧៣ ERN KH 00442019 ["ប្រសិនបើពួកចារបុរសត្រូវបានឃាត់ខ្លួននៅក្នុងការប្រជុំនៅមុខមនុស្សនោះមនុស្សខ្លះប្រហែលជាភ័យខ្លាចយើង [...] គោលជំហរដើម្បីបំបែកអ្នកស៊ើបការណ៍គឺត្រឹមត្រូវប៉ុន្តែវាត្រូវបានអនុវត្តមិនត្រឹមត្រូវ"]។

432 ឯកសារ D54/16/1R សម្ភាសន៍របស់មាស មុត ជាមួយ ដេវីដ ខេថេនបឺហ្គ ឆ្នាំ២០០៩ 42:46-43:50

433 ឯកសារ D54/98 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាង រ៉េត ឆ.១៣៧ ["ស: នៅក្នុងកិច្ចសម្ភាសរបស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ជាភាសាអង់គ្លេស ទំព័រ ៥៦ និងទំព័រ៥៧ លោកនិយាយថា "មានមន្ទីរអប់រំកែប្រែរបស់កងពល" តើលោកអាចបញ្ជាក់បានទេ មន្ទីរអប់រំកែប្រែនោះមានទីតាំងនៅកន្លែងណា? ឆ.១៣៧: មន្ទីរអប់រំកែប្រែនោះគឺស្ថិតនៅទឹកសាប"]។

434 ឯកសារ D54/7 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ឆ.១៣ ["ស: ប៉ុន្តែក្នុងចំណុចនេះ ហេតុអ្វីបានជាលោកដឹងថា កងវរៈពិសេសនេះឋិតនៅក្រោមបញ្ជាការផ្ទាល់របស់មេបញ្ជាការកងពល? ឆ.១៣: ម៉េចបានថា ខ្ញុំមិនអាចដឹងកើត ខ្ញុំដឹងច្បាស់ថា កងវរៈពិសេសនេះឋិតនៅក្រោមបញ្ជាការផ្ទាល់របស់កងពល។ កងវរៈពិសេសនេះមិនឋិតនៅក្រោមបញ្ជាការរបស់វរៈសេនាធំណាមួយទេ។ ឋានៈរបស់មឿន ដែលជាមេបញ្ជាការរបស់វរៈសេនាតូចពិសេសនេះ គឺមានឋានៈដូចមេបញ្ជាការកងវរៈសេនាធំដទៃទៀតក្នុងកងពលដែរ"]។ សូមមើលផងដែរ ឯកសារ D54/98 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាង រ៉េត ឆ.១២, ៩២ ["យោធាខ្លះត្រូវបានបញ្ជូនទៅការពារនៅតំបន់ផ្សេង

សេនាតូច ១៦៥ (៤៥០) ឈ្មោះ ស សាមឿន ហៅ តា មឿន[435] និងទាហានឈ្មោះ ណាន[436] ជាប្រធានមន្ទីរសន្តិសុខ។ កងវរសេនាតូចនេះត្រូវបានស្គាល់ថា "អង្គភាពពិសេសនៃកងពលធំ

---

គ្នានៅកំពង់សោម ខ្លះបញ្ជូនទៅការពារនៅតាមឆ្នេរ [...] និងវត្តឥណ្ឌញ្ញាណ។ ស: តើលោកដឹងថានរណាជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខនៅក្នុងវត្តនោះដែរឬទេ? [...] ឆ.៩២: ខ្ញុំដឹងថា មន្ទីរសន្តិសុខនោះគ្រប់គ្រងដោយនីរសាវរសេនាតូច ៤៥០"]។ ឯកសារ D2/15 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ឆ.២៣-២៤, ៣០ ["កង៤៥០ ត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវខាងផ្នែកសន្តិសុខវិញ [...] ឆ.២៤: មិនមែនតែកន្លែងវត្តឥណ្ឌញ្ញាណហ្នឹងទេ គឺជាកងសន្តិសុខរបស់កងពល១៦៤ នៅក្រុងកំពង់សោមទាំងមូល [...] ស: នៅពេលដែលលោកទៅវត្តឥណ្ឌញ្ញាណក្នុងពេលនោះ តើអ្នកយាមនៅទីនោះ ជាយោធារបស់កងវរ:៤៥០ ឬយ៉ាងណា? ឆ.៣០: បាទពិតមែន"]។ សូមមើលបន្ថែម ឯកសារ D114/187 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ឆ.៥៧-៥៨, ១០៦-១០៨ ["ស: ពេលលោកត្រូវសម្ភាសឆ្នាំ២០១០ នៅចម្លើយទី២៣ D2/15 លោកនិយាយថា ពេលឈប់វ៉ៃគ្នាហើយ កងវរ:សេនាតូច ៤៥០ ត្រូវបានគេឲ្យទៅទទួលខុសត្រូវខាងសន្តិសុខ។ តើលោកអាចប្រាប់បានទេ វាមានន័យថាម៉េច? ឆ.៥៧: បាទ វាប្រហាក់ប្រហែលដែលខ្ញុំបានប្រាប់ដែរគឺថា មួយចំនួននៅកោះប៉ូឡូវ៉ៃ ហើយមួយចំនួនទៀតទៅកងទ័ពជើងទឹក ហើយខ្លះទៀតត្រូវទៅធ្វើជាកងសន្តិសុខ។ ស: តើកិច្ចការសន្តិសុខអ្វីខ្លះដែលកង៤៥០ ត្រូវដោះស្រាយ? ឆ.៥៨: [...] ខ្ញុំដឹងថា ប្រហែលជាចុង៧៦ ឬដើម៧៧ ពួកគេទទួលខុសត្រូវខាងសន្តិសុខ និងសណ្តាប់ធ្នាប់ តែតួនាទី និងការទទួលខុសត្រូវយើងមិនដឹងទេ [...] ស: តើទាហាននៅក្នុងកងពល ១៦៤ ខ្លាចវរ: ៤៥០ ឬទេ នៅពេលដែលពួកគេបានទទួលខុសត្រូវខាងផ្នែកសន្តិសុខ និងកន្លែងផ្សេងទៀត ដូចជាវត្តឥន្ទញ្ញាណដែរឬទេ? ឆ.១០៦: ក្នុងឆ្នាំ១៩៧៧ បើកាលណាមានឃើញអង្គភាពហ្នឹងទៅកន្លែងណាគឺមានការព្រួយបារម្ភថានឹងមានបញ្ហាកើតឡើងនៅកន្លែងហ្នឹង។ ប៉ុន្តែឲ្យខ្លាចគឺអត់ខ្លាចទេ។ ស: តើកងវរសេនាតូច ៤៥០ តែងតែត្រូវបានគេបញ្ជូនទៅកន្លែងដែលមានបញ្ហាមែនដែរឬទេ? ឆ.១០៧: យើងគ្រាន់តែដឹងថា ក្នុងឆ្នាំ១៩៧៧ ហ្នឹង អង្គភាព៤៥០ហ្នឹងគឺជាកង ជាក្រុមសន្តិសុខ។ ដូច្នេះបើកាលណាឃើញគេទៅកន្លែងណា ច្បាស់ជាមានបញ្ហានៅកន្លែងហ្នឹងហើយ។ ស: តើលោកចាំទេថា តើមានកងសន្តិសុខផ្សេងទៀតដែរឬទេ? ឬក៏មានតែកងវរសេនាតូច ៤៥០នេះ? ឆ.១០៨: ខ្ញុំដូចមិនឮមានអង្គភាពផ្សេងណាទៀតទេ ព្រោះមានតែក្រុមអង្គភាព ៤៥០ហ្នឹង"]។

435 ឯកសារ D2/15 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ឆ.១២-១៤, ១៨ ["ស: នៅយប់ថ្ងៃ ១៧ មេសា អង្គភាព៤២០ របស់ខ្ញុំនោះ បានថយមកសម្រាកនៅអង្គស្នួល។ ពេលនោះដោយមេបញ្ជាការរបស់ខ្ញុំ ស សាមឿន បានត្រូវរបួស ខ្ញុំមិនបាននៅក្នុងកងនោះទៀតទេ ខ្ញុំវិលមកកងចាស់របស់ខ្ញុំវិញគឺវរ: ៤៥០។ លុះព្រឹកឡើងថ្ងៃ១៨ ខែមេសា កងវរ:៤២០ និងកងពិសេសត្រូវបានបញ្ជូនមកក្រុងកំពង់សោម។ កងវរ:៤២០ ពេលនោះគេទៅស្នាក់នៅរាម និងកងពិសេសនៅកំពង់សោម។ ក្រោយពីបញ្ជាការរបស់ខ្ញុំ ស សាមឿន ជារបួស គាត់បានមកកាន់អង្គភាពកងពិសេសរបស់គាត់នៅកំពង់សោម នៅពេលនោះគាត់ក៏យកខ្ញុំពីរាមមកនៅជាមួយគាត់នៅកំពង់សោមវិញ[...]។ ស: តើបន្ទប់តាមឿន ដែលជាមេបញ្ជាការនៅកន្លែងណា? ហើយបន្ទប់លោកស្នាក់នៅកន្លែងណា? ឆ.១៨: បន្ទប់ប៉ែកខាងលិចគេបង្អស់មានពេទ្យ និងគេអូស្នាក់នៅ។ បន្ទប់បន្ទាប់មកជាបន្ទប់មេបញ្ជាការ។ ហើយបន្ទាប់មកទៀត បន្ទប់ទីបីជាបន្ទប់របស់ខ្ញុំជានិរសាស្នាក់នៅ"]។ សូមមើលផងដែរ ឯកសារ D114/187 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ឆ

១៦៤"[437] "អង្គរក្ស" របស់ **មាស មុត** ឬ "អង្គភាពដែលស្គាំរបស់គាត់"[438] និងទទួលបន្ទុក "ការពារមេដឹកនាំកងពលធំ" និងចាប់ខ្លួនមនុស្សដែល "បានប្រព្រឹត្តកំហុស"[439]។

---

.៧, ១១, ៣៦ ["ស: នៅក្នុងកិច្ចសម្ភាសលោកលើកមុន លោកនិយាយថា មេបញ្ជាការរបស់លោកឈ្មោះ សាមឿន។ តើសាមឿន ជាមេបញ្ជាការនៅក្នុងអង្គភាពពិសេស ដែលស្ថិតនៅក្រោមកងពលធំលេខ១៦៤មែនទេ? ឆ.៧: បាទ ខ្ញុំនៅជាមួយ ស សាមឿន ដែលជាមេបញ្ជាការនៅក្នុងកងពល ៤៥០ ចំណុះឱ្យកងពលធំ១៦៤ពិតមែន ព្រោះពេលដែលយើងចេញពីភ្នំពេញទៅ ចេញពីអង្គស្នួលទៅ១កំពង់សោម យើងបានទទួលព័ត៌មានថា ប្តូរឈ្មោះកងពលហ្នឹងថា លែងចំណុះកងពលនិរតីទៀតហើយ [...] ស សាមឿន ជាមេបញ្ជាការនៅក្នុងកងវរសេនាតូច៤៥០ អ៊ីចឹងនៅក្នុងនោះមានកងអនុសេនាធំ ៤ ដែលចំណុះឱ្យកង៤៥០ [...] ឆ.៣៦: ខ្ញុំនៅជាមួយ ស សាមឿន ជាមេបញ្ជា"]។ ឯកសារ D54/46 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ឆ.២៧ ["ប្រហែលជាក្នុងខែមីនា ១៩៧៥ គេបានផ្លាស់ខ្ញុំពីកងវរសេនាតូច៤១៥ ដោយបង្កើតជាកងពិសេស កងវរសេនាតូច៤៥០ របស់កងពល៣ ដែលមានប្រធានកងវរសេនាតូច៤៥០ ឈ្មោះ មឿន"]។ ឯកសារ D54/10 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ី រ៉េត ឆ.២២, ២៧ ["ឈ្មោះ មឿន ពីដើមជាអតីតមេបញ្ជាការកងពិសេសរបស់ មាស មុត ហើយនៅក្នុងនោះគាត់ជាមេបញ្ជាការវរៈសេនាតូច ១៤១ នៃវរៈសេនាតូច ១៤០ [...] ស: យោលទៅតាមការយល់ដឹងរបស់លោក តើមឿន ធ្លាប់ធ្វើជាមេបញ្ជាការវរៈសេនាតូច៤៥០ នៃកងពលលេខ៣ដែរឬទេ? ឆ.២៧: បាទ, គាត់ធ្លាប់"]។ ឯកសារ D54/7 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ឆ.៨, ១៣ ["មឿនជាស្នងការវរៈសេនាតូចពិសេស [...] ឆ.១៣: មឿនជាមេបញ្ជាការរបស់វរៈសេនាតូចពិសេសនេះ គឺមានឋានៈដូចមេបញ្ជាការកងវរៈសេនាធំដទៃទៀតក្នុងកងពលដែរ"]។

436 ឯកសារ D2/15 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ឆ.២៧ និងឆ.៣៣ ["ស: នៅឆ្នាំ១៩៧៧ លោកបានចូលវត្តឥន្ទញ្ញាណរយៈពេលខ្លី និងបានឃើញអ្នកទោសនៅទីនោះ។ តើលោកអាចរៀបរាប់លំអិតអ្វីដែលលោកបានឃើញនៅទីនោះ? ឆ.២៧ : បាទ។ ឆ.៣៣ : តាមអ្វីដែលខ្ញុំដឹង តានន គឺជាអ្នកទទួលខុសត្រូវកងសន្តិសុខនៅពេលនោះ"]។ សូមមើលផងដែរ ឯកសារ D114/187 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ឆ.៤៣-៤៤, ឆ.៥៩ និង ឆ.៦១ ["ស: នៅក្នុងការសម្ភាសន៍លើកមុន លោកបាននិយាយថាតាននគឺជាអ្នកទទួលខុសត្រូវនៅមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណនោះ។ តើត្រឹមត្រូវទេ? តើតានន ជាទាហាននៅអង្គភាព៤៥០ដែរទេ? ឆ.៤៣: តានន ជាមនុស្សនៅអង្គភាព៤៥០ ជាមួយគ្នាពីដើម។ គាត់ជាបញ្ជាការអនុសេនាធំ ចំណុះឲ្យ៤៥០ចាស់។ តែដល់យើងទៅកងទ័ពជើងទឹក គាត់អត់បានទៅកងទ័ពជើងទឹកទេ។ ស: តើ ស សាមឿនជាមេរបស់តាននទេ? ឆ.៤៤ : បាទ. [...] ឆ.៥៩ : យើងចាំឈ្មោះតែបងនន ដែលជាអ្នកទទួលខុសត្រូវ។ ហើយបងនន មិនអាចនៅរហូតដែរ ប្រហែលជាចុងឆ្នាំ១៩៧៨ ក៏បាត់ខ្លួនទៀត ដោយឮសូរថាជាប់ពាក់ព័ន្ធការរំលោភអ្នកទោសហ្នឹង។ ប៉ុន្តែរឿងហ្នឹង ខ្ញុំដឹងអត់ច្បាស់ទេ។ តែខ្ញុំឮថាដែលពាក់ព័ន្ធការរំលោភអ្នកទោស និងដោះលែងអ្នកទោស។ ហើយដែលថាអ្នកទោសហ្នឹងការពិតអត់មានទោសអីទេ ដល់លែងទៅ ក៏អត់មានទៅណា។ អ្នកទោសហ្នឹងរស់នៅជិតអង្គភាពគេហ្នឹង ពួកគេអត់ទៅណាទេ [...] ឆ.៦១: ខ្ញុំដឹងថាមានអង្គភាព៤៥០ ដែលនៅសល់ ដែលដឹកនាំដោយតានន កាន់នៅសន្តិសុខនោះ"]។

437 ឯកសារ D2/15 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច សឿលី ឆ.២០-២១ ["គឺជាកងវរៈសេនាតូច៤៥០ ឬកងពិសេសរបស់កងពលធំ១៦៤។ ស: លោកធ្លាប់បានប្រាប់ពីថ្ងៃមុនថា កងវរៈសេនាតូច៤៥០ មិននៅក្រោមកងវរៈ

សេនាធំណាមួយទេ ប៉ុន្តែវាជាកងពិសេសរបស់កងពល១៦៤។ តើពិតមែនដែរឬទេ? ឆ.២១: បាទ ពិតមែន"]។ ឯកសារ D114/187 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទូច សឿលី ឆ.៧, ឆ.៩ និង ឆ.៤៧-៤៩ ["ខ្ញុំនៅជាមួយ ស សាមឿន ដែលជាមេបញ្ជាការនៅក្នុងកងពល៤៥០ ចំណុះឱ្យកងពលធំ១៦៤ ពិតមែន [...] សៈ ចឹង មានន័យថាកងវរៈសេនាតូច៤៥០ លែងស្ថិតក្រោមកងវរៈសេនាធំ គឺស្ថិតក្រោមចំណុះកងពលធំ១៦៤ មែនទេ? ឆ.៩ : កងអង្គភាព៤៥០ គឺជាអង្គភាពពេញរបស់អង្គភាពវរៈសេនាតូច ដែលរៀបចំនៅថ្ងៃទី ១១-១២ ខែមេសាហ្នឹង។ វាជាកងពិសេសកងពល៣ [...] ឆ.៤៧ : កង៤៥០ គឺជាកងពិសេសកងពល។ សៈ តើកងវរៈសេនាតូច៤៥០ ជួនកាលគេហៅថាជាកងការពារដែរទេ? ឆ.៤៨ : មិនមែនទេ គឺជាកងប្រយុទ្ធ កងទ័ពពិសេសប្រយុទ្ធ។ គេអ្នកពិសេសជាងគេ សម្រាប់ប្រយុទ្ធតែម្ដង។ សៈ អីចឹង មានន័យថាពួកគេមានការហ្វឹកហ្វឺនល្អបំផុត ឧបករណ៍ល្អបំផុតមែនទេ? ឆ.៤៩ : បាទ"]។ ឯកសារ D54/98 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហ៊ាង រ៉េត ឆ.១១ ["សៈ តើមុខងាររបស់កងវរៈសេនាតូច៤៥០គឺជាអ្វី? ឆ.១១ : កងវរៈសេនាតូច៤៥០ ហៅថាកងពិសេស"]។ ឯកសារ D54/7 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឌុល សុង ឆ.១០ និង ឆ.១៣ ១១ ["កងវរៈសេនាតូចពិសេសនេះមិនស្ថិតនៅក្រោមបញ្ជាការរបស់កងវរៈសេនាធំណាមួយទេ។ វាស្ថិតនៅក្រោមមេបញ្ជាការកងពលធំ (លេខ៣/១៦៤) [...] ឆ.១៣: [...] ខ្ញុំដឹងច្បាស់ថាកងវរៈពិសេសនេះឋិតនៅក្រោមបញ្ជាការផ្ទាល់របស់កងពល។ កងវរៈពិសេសនេះមិនឋិតក្រោមបញ្ជាការរបស់វរៈសេនាធំណាមួយទេ"]។ សូមផលផងដែរ ឯកសារ D54/46 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អែម សុន ឆ.២៧ និងឆ.៣១ ["ប្រហែលជាខែមីនា ឆ្នាំ១៩៧៥ គេបានផ្លាស់ខ្ញុំ [...] ទៅកងពិសេសវរៈសេនាតូច៤៥០ របស់កងពល៣ ដែលមានប្រធានកងវរៈសេនាតូច៤៥០ ឈ្មោះ មឿន [...] ឆ.៣១: [...] នៅក្នុងដែលគាត់ (មាស មុត) មកប្រជុំហើយប្រកាសថាកងវរៈសេនាតូច៤៥០ ជាកងពិសេស ចំណុះឱ្យកងពលលេខ៣ ដោយមិនចំណុះឱ្យកងវរៈសេនាធំណាមួយទេ។ គាត់បានប្រកាសថាពីខែកុម្ភៈ ឆ្នាំ១៩៧៥ទៅ គឺត្រូវរៀបចំ ដើម្បីវាយរំដោះភ្នំពេញ"]។ ឯកសារ D2/16 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទូច សឿលី ឆ.១៩ ["អ្នកដែលមកចាប់គឺកងសន្តិសុខ៤៥០។ ខ្ញុំមិនដឹងថាការចាប់ចងនោះកើតឡើងដោយរបៀបម៉េចទេ ខ្ញុំគ្រាន់តែដឹងថាមានការចាប់ចងជាបន្តបន្ទាប់"]។

438 ឯកសារ D54/101 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី ឆ.១០ ["យោធាទាំងនោះគឺមកពីកងពិសេសរបស់តាមុត។ ពួកនោះគឺដូចជាអង្គរក្សរបស់តាមុត ឬក៏ហៅថាកងដៃស្ដាំរបស់គាត់"]។ ឯកសារ D54/102 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី ឆ.១៤ និងឆ.២០ ["កងពិសេសគឺដូចជាកងអង្គរក្សចឹង។ វាគឺជាកងដែលមេគេជឿទុកចិត្ត [...] សៈ សាក្សីដទៃទៀតបាននិយាយប្រាប់យើងថាមាស មុត មានកងការពារផង និងមានកងនីរសារផង យើងមិនយល់ថាតើអាហ្នឹងជាកងតែមួយ ឬយ៉ាងម៉េច? ឆ.២០ :វាជាកងតែមួយ"]។ ឯកសារ D54/103 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី ឆ.១៥ ["នៅក្នុងកងពិសេស គឺមានទាំងកងការពាររបស់មាស មុត ដែលតាមការពារគាត់គ្រប់ទីកន្លែង"]។ សូមមើលផងដែរ ឯកសារ D54/7 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឌុល សុង ឆ.១១ ["មុខងាររបស់កងពិសេស គឺការពារថ្នាក់ដឹកនាំកងពល និងចាប់ចងអ្នកដែលមានទោស [...] ដូច្នេះកងពិសេសសម្រាប់ការពារថ្នាក់ដឹកនាំកងពល និងចាប់ចងអ្នកធ្វើខុស។

439 ឯកសារ D54/10 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ី រ៉េត ឆ.២៨ ["សៈ តើមាស មុត គាត់ប្រើវរៈសេនាតូច៤៥០ យ៉ាងដូចម្ដេច? ឆ.២៨ : ក្នុងរយៈពេលសង្គ្រាម គាត់តែងបញ្ជូនកងពិសេសនេះទៅសមរភូមិដែលតឹងតែងខ្លាំង"]។ ឯកសារ D54/87 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រំ សារ៉ាត ឆ.៩៤ ["ពួកគេ (កងវរៈសេនាតូច៤៥០)

154. ទីស្នាក់ការ និងលំនៅដ្ឋានរបស់ **មាស មុត** ស្ថិតនៅចម្ងាយប្រមាណ ២.៤ គីឡូម៉ែត្រពីវត្តឥន្ទញ្ញាណ ដែលស្ថិតនៅកណ្ដាលក្រុងកំពង់សោម។ មន្ទីរសន្តិសុខបានធ្វើប្រតិបត្តិការពីឆ្នាំ ១៩៧៥ ដល់ចុងបញ្ចប់នៃរបបខ្មែរក្រហម និងមានកុដិព្រះសង្ឃចំនួនពីរ និងរោងបាយមួយ ដែលសម្រាប់ឃុំឃាំងអ្នកទោស។ អ្នកទោសភាគច្រើនជាទាហានកងពលធំ ១៦៤ ប៉ុន្តែស្ត្រីនិងកុមារខ្លះក៏ត្រូវបានឃុំឃាំងនៅទីនោះផងដែរ។ អ្នកជាប់ឃុំឃាំងបានរស់នៅក្រោមស្ថានភាពអមនុស្សធម៌ក្រៃលែង។ ពួកគាត់ស្គមស្គាំង រងទារុណកម្ម និងជាប់ខ្នោះជើង នៅពេលថ្ងៃនិងយប់។ មនុស្សជាច្រើនរយនាក់ត្រូវបានដាក់ពន្ធនាគារ ត្រូវបានបង្ខំឲ្យធ្វើការងារ និងបន្ទាប់មកត្រូវបានសម្លាប់នៅវត្តឥន្ទញ្ញាណ[440]។

155. **មាស មុត** បានរក្សាការគ្រប់គ្រងដាច់ខាតលើមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ[441]។ មេគុកឈ្មោះ មឿន បានរាយការណ៍ដោយផ្ទាល់ទៅ **មាស មុត** និងបានទទួលបញ្ជាពី **មាស មុត**[442]។ ពួកគាត់បានធ្វើ

---

ជាកងការងារ"]។ ឯកសារ D54/7 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឌុល សុង ឆ.១១ ["កងវរៈសេនាតូចពិសេសនេះ (នៃកងពលធំលេខ៣/១៦៤)គឺចិតនៅជាមួយបញ្ជាការ ឬស្នងការកងពល។ មុខងាររបស់កងពិសេស គឺការពារថ្នាក់ដឹកនាំកងពល និងចាប់ចងអ្នកដែលមានទោស។ នៅពេលនោះ ប្រទេសជាតិបានសន្តិភាពហើយ កងពិសេសនេះមិនត្រូវការទៅច្បាំងនៅកន្លែងណាទេ ដូច្នេះកងពិសេសសម្រាប់ការពារថ្នាក់ដឹកនាំកងពល និងចាប់ចងអ្នកធ្វើខុស។

440 សូមមើល ជំពូក ៨.ក.៣ មន្ទីរសន្តិសុខវត្តឥន្ទញ្ញាន

441 ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ស៊ឹម នី ERN EN 01070563, ERN FR 00976267, ERN KH 00964137 ["បាទ មានតែមាស មុតជាអ្នកចាត់ចែង និងសម្រេចចិត្តនៅទីនោះ (វត្តឥន្ទញ្ញាណ)"]។ ឯកសារ D114/66 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.១៤ ["សៈ តើលោកធ្លាប់ដែលបានឮកន្លែងមួយ ហៅថាវត្តឥន្ទញ្ញាន ហៅវត្តក្រោម ដែរឬទេ? ឆ.១៤: បាទ វាជាគុករបស់កងពល១៦៤ របស់តាមុត។ ក្រោយមក គេរើវាទៅទឹកសាប។ ឯកសារ D54/102 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី ឆ.៦ ["វត្តឥន្ទញ្ញានគឺជាមន្ទីរសន្តិសុខនិងឃុំឃាង របស់កងពល១៦៤ ក្រោមការដឹកនាំរបស់តាមុត"]។ ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ ក.ស.ព ERN EN 00217562 ["ការឃុំឃាំងស្ថិតក្រោមកងពលទី១ ដឹកនាំដោយ មាស មុត ដែលជាអ្នកគ្រប់គ្រងទីក្រុងនោះ"]។

442 ឯកសារ D54/98 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ាង រ៉េត ឆ.៩៣-៩៤ ["សៈ តើនរណាជាមេបញ្ជាការរបស់វរៈសេនាតូច៤៥០? ឆ.៩៣ : ស មឿន គឺជាមេបញ្ជាការវរៈសេនាតូច៤៥០។ សៈ តើស មឿន ស្ថិតនៅក្រោមបញ្ជារបស់នរណាដែរ? ឆ.៩៤ : ស មឿន ត្រូវរាយការណ៍ផ្ទាល់ទៅកងពល១៦៤ គឺ មាស មុត "]។ សូមផងផងដែរ ឯកសារ D114/187 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទូច សឿលី ឆ.៤៧ ["សៈ តើនៅពេល ស សាមឿន

ការងារស្និតរមួតជាមួយគ្នា ដូចដែលបានបង្ហាញដោយការចូលរួមរបស់ មឿន ក្នុងអង្គប្រជុំថ្នាក់ខ្ពស់របស់កងពលធំ ១៦៤ បើទោះបីជាគាត់ជាមេបញ្ជាការកងវរសេនាតូចក៏ដោយ[443]។ បុគ្គលិកនៃ កងវរសេនាតូច១៦៥ (៤៥០) ដទៃទៀតក៏ស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ **មាស មុត** ផងដែរ ដូចដែលបានពន្យល់ដោយសាក្សី ឯម ស៊ុន៖ "នៅពេលខ្ញុំចូលកងពលនេះ ខ្ញុំបានរាយការណ៍ដោយផ្ទាល់ទៅ មាស មុត ពីព្រោះគ្មានកងវរសេនាធំ រវាងកងវរសេនាតូច៤៥៩ របស់ខ្ញុំ និង មាស មុត។ ខ្ញុំបានរាយការណ៍ទៅ មាស មុត អំពីលទ្ធផលនៃបញ្ហារបស់ មាស មុត"[444]។

156. **មាស មុត** បានចូលរួមដោយផ្ទាល់ក្នុងការប្រតិបត្តិការរបស់មន្ទីរសន្តិសុខនេះ-ការសួរចម្លើយដោយផ្ទាល់ ការកត់ត្រាចម្លើយ ការបញ្ជូនអ្នកជាប់ឃុំឃាំង "ចេញ" និងការកាន់កាប់សិទ្ធិធ្វើសេចក្តី

---

ទទួលខុសត្រូវនៅអង្គភាព៤៥០ តើគាត់ទទួលបញ្ជាពីមាស មុតផ្ទាល់ដែរឬទេ? ឆ.៤៧ : កង៤៥០ ជាកងពិសេសកងពល ដូច្នេះ អាចទទួលបញ្ជាផ្ទាល់ហើយ"]។

443 ឯកសារ D114/286 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាង រ៉េត ឆ.៣៥-៣៨ [ទាហានមកពីវរៈសេនាតូច ៤៥០ បានរៀបរាប់អំពីកិច្ចប្រជុំមួយ នៅក្នុងកំពង់សោម នៅឆ្នាំ១៩៧៥ ដែលពេលនោះ មាស មុតបានប្រកាសអំពីសមាសភាពចូលរួម ក្នុងនោះមានសមាជិកកងវរៈសេនាតូច៤៥០]។ ឯកសារ D54/7 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ឆ.១៣ ["សៈ ប៉ុន្តែក្នុងចំណុចនេះ ហេតុអ្វីបានជាលោកដឹងថា កងវរៈពិសេសនេះឋិតនៅក្រោមបញ្ជាការផ្ទាល់របស់មេបញ្ជាការកងពល? ឆ.១៣: ម៉េចបានថាខ្ញុំមិនអាចដឹងកើត? ខ្ញុំដឹងច្បាស់ថាកងវរៈពិសេសនេះ ឋិតនៅក្រោមបញ្ជាការផ្ទាល់របស់កងពល។ កងវរៈពិសេសនេះមិនឋិតក្រោមបញ្ជាការរបស់វរៈសេនាធំណាមួយទេ។ ឋានៈរបស់មឿន ដែលជាមេបញ្ជាការវរៈសេនាតូចពិសេសនេះ គឺមានឋានៈដូចមេបញ្ជាការកងវរៈសេនាធំដទៃទៀតក្នុងកងពលដែរ។ ពេលដែលមានប្រជុំ មេបញ្ជាការវរៈសេនាធំទាំងអស់ត្រូវបានហៅទៅចូលរួមប្រជុំ ហើយមឿនក៏ត្រូវបានហៅទៅចូលរួមប្រជុំជាមួយដែរ"]។ ឯកសារ D54/38.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ លន់ សេង ERN KH 00967318-19 ["សៈ ចុះក្រោយមក មានប្រជុំជាមួយគណៈភូមិភាគ កងពល ជាមួយ តា មុត អីពីព្រឹត្តិការណ៍នឹង? ពូមានគេហៅទៅប្រជុំអត់? ឆៈ ខ្ញុំក្រោយមក ខ្ញុំអត់បានទៅប្រជុំទេ។ មឿន នឹងគេទៅ។ ហ្នឹងហើយ មេកង គេទៅ ព្រោះរបាយការណ៍អីៗ នៅក្នុងសមរភូមិ យើងរាយការណ៍ឲ្យគេអស់ហើយ [...] គាត់ទៅប្រជុំទទួលការងារអីពីកន្លែងបញ្ជាការកងពលធំ"]។

444 ឯកសារ D54/49 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ឆ.៤៨ ["នៅពេលខ្ញុំចូលរួមជាមួយកងពល ខ្ញុំរាយការណ៍ដោយផ្ទាល់ទៅមាស មុត ពីព្រោះគ្មានវរសេនាធំនៅ រវាងកងវរៈសេនាតូច៤៥០របស់ខ្ញុំ និងមាស មុតទេ។ ខ្ញុំបានរាយការណ៍ទៅមាស មុត អំពីលទ្ធផលនៃបញ្ហាដែលគាត់ដាក់មកឲ្យខ្ញុំអនុវត្ត។ អំឡុងពេលនោះ មិនមានប្រព័ន្ធរាយការណ៍ជាផ្លូវការនោះទេ។ ការរាយការណ៍ធ្វើឡើងតាមសភាពជាក់ស្តែង ជាទូទៅ តាមប្រព័ន្ធវិទ្យុទាក់ទង ឬតាមនីរសារ។

សម្រេច[445]។ គាត់បានឃើញដោយផ្ទាល់ភ្នែកនូវស្ថានភាពដ៏យ៉ាប់យ៉ឺននៅវត្តឥន្ទញ្ញាណ ក្នុងអំឡុងពេលទស្សនកិច្ចរបស់គាត់ជាប្រចាំមកកាន់មន្ទីរសន្តិសុខនេះ[446]។ **មាស មុត** បានទៅទីនោះ "ដើម្បីជួបមនុស្សដែលមានសិទ្ធិអំណាច និងដើម្បីពិនិត្យសភាពការណ៍" នៅគុកនេះ[447]។ វត្តមានរបស់គាត់នៅមន្ទីរសន្តិសុខនេះមានភាពញឹកញាប់រហូតដល់ **មាស មុត** អាចរក្សាទំនាក់ទំនងស្អិត

---

445 ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ស៊ឹម នី ERN KH 00964133 ["មុតហ្នឹងឲ្យតាឡូញ អ្នកគ្រប់គ្រង ឯចំពោះសួរចម្លើយកំណត់ហេតុអី តាឡូញ អត់ទេ។ សៈ ពីណាគេវិញអញ្ចឹង? ឆៈ មាស មុតដដែលហ្នឹង តាឡូញគាត់គ្រាន់តែមានការផ្គត់ផ្គង់ប៉ុណ្ណឹងឯង។ សៈ គាត់ផ្គត់ផ្គង់ជាស្បៀង? ឆៈ បាទ។ សៈ ប៉ុន្តែអ្នកសួរចម្លើយអីហ្នឹងបញ្ជូនបញ្ចេញអី គឺតាមុត? ឆៈ ហ្នឹងហើយ មាស មុត ទេជាអ្នកបញ្ជូនបញ្ចេញ។ សៈ កាលហ្នឹងពូដឹងអញ្ចឹង? "] ERN KH 00964137 ["បាទ មានតែមាស មុតជាអ្នកចាត់ចែង និងសម្រេចចិត្តនៅទីនោះ (វត្តឥន្ទញ្ញាណ)"]។

446 ឯកសារ D54/88 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ឆ.១២-១៦ ឆ.១៧-១៨ ["ខ្ញុំកំពុងធ្វើការនៅក្នុងចម្ការសណ្តែករបស់ខ្ញុំ។ មិនមានអ្វីបាំងមិនឲ្យខ្ញុំឃើញទេ។ ខ្ញុំធ្លាប់ឃើញ មាស មុត ពីរដង។ មាស មុតធ្វើដំណើរដោយឡានហ្ស៊ីប A2 សំដៅទៅទិសវត្តឥន្ទញ្ញាណ។ គាត់ធ្វើដំណើរតាមផ្លូវដែលយើងធ្វើដំណើរព្រឹកមិញនេះ រយៈពេលដែលយើងធ្វើការកំណត់អត្តសញ្ញាណទីកន្លែង។ មាស មុតបានយកម្ហូបអាហារដាក់ក្នុងឡានហ្ស៊ីបរបស់គាត់យកទៅឲ្យអ្នកយាមនៅវត្តឥន្ទញ្ញាណ។ ឡានហ្ស៊ីបរបស់គាត់មកឈប់នៅកន្លែងផ្ទះអ្នកយាម ដើម្បីប្រគល់ម្ហូបអាហារទាំងនោះឲ្យអ្នកយាម។ សៈ តើមាស មុតមកវត្តឥន្ទញ្ញាណញឹកញ៉ាប់ប៉ុនណា? ឆ.១៣ :យោងតាមការដឹងរបស់ខ្ញុំ គាត់មកវត្តឥន្ទញ្ញាណ១ខែម្តង ដើម្បីនាំយកម្ហូបអាហារទៅឲ្យអ្នកយាម។ គាត់មក១ខែម្តង បន្ទាប់ពីគាត់ត្រឡប់មកពីការប្រជុំនៅស្ទឹងហាវ […] ឆ.១៤ : ខ្ញុំគិតថាខ្ញុំសម្គាល់ឃើញមាស មុត យកម្ហូបអាហារទៅផ្តល់ឲ្យអ្នកយាមនៅវត្តឥន្ទញ្ញាណ១ខែម្តង។ "]។សៈ តើលោកបានឃើញ មាស មុត យកម្ហូបអាហារទៅឲ្យអ្នកយាមនៅវត្តឥន្ទញ្ញាណ ពីកន្លែងដែលលោកធ្វើការយ៉ាងម៉េចកើត បើកន្លែងរបស់លោកនៅឆ្ងាយពីវត្តយ៉ាងនេះ? ឆ.១៥ : ខ្ញុំដឹងតាមរយៈអ្នកយាមនៅវត្តឥន្ទញ្ញាណពីរនាក់ ថាមាស មុត នាំយកម្ហូបអាហារមកឲ្យពួកគេ។ សៈ តើម្ហូបអាហារទាំងនោះគឺសម្រាប់អ្នកយាម ឬក៏សម្រាប់អ្នកទោស? ឆ.១៦ : ទេ ខ្ញុំមិនដឹងទេ។ សៈ តើអ្នកយាមទាំងពីរនាក់នេះនៅរស់ដល់សព្វថ្ងៃដែរឬទេ? ហើយមានឈ្មោះអ្វីខ្លះ? ឆ.១៧ : ម្នាក់ឈ្មោះ សារិ និងម្នាក់ទៀត ឈ្មោះកុយ។ ខ្ញុំមិនស្គាល់នាមត្រកូលរបស់ពួកគេទេ។ ខ្ញុំបែកពួកនេះតាំងពីឆ្នាំ១៩៧៧។ សៈ តើលោកដឹងថាមាស មុត ចូលទៅក្នុងវត្តឥន្ទញ្ញាណធ្វើអ្វីខ្លះ? ឆ.១៨ : ខ្ញុំឃើញមាស មុត ជិះឡានទៅវត្តឥន្ទញ្ញាណចំនួន២ដង។ ប៉ុន្តែ ខ្ញុំពុំអាចដឹងថាគាត់ទៅធ្វើអ្វីនៅក្នុងវត្តឥន្ទញ្ញាណទេ"]។

447 ឯកសារ D54/32 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ឆ.៣៨ ["បើតាមខ្ញុំគិត តាមុតមកជួបអ្នកទទួលខុសត្រូវ ហើយមកមើលស្ថានការណ៍នៅវត្តឥន្ទញ្ញាណយ៉ាងណា ចំណែកតាឡូញក៏ដូច្នោះដែរ"]។

រមួតជាមួយឆ្នាំគុក ដែលផ្តល់អាហារទៅពួកគាត់មួយខែម្តង នៅពេលគាត់បានឈប់នៅក្បែរគុកនោះ នៅពេលត្រឡប់ពីប្រជុំនៅស្ទឹងហាវ[448]។

157. **មាស មុត** បានដឹងច្បាស់អំពីការសម្លាប់នៅវត្តឥន្ទញ្ញាណ និងបានប្រកាសអំពីការសម្លាប់ទាំងនោះទៅកាន់មនុស្សក្រោមបង្គាប់របស់គាត់ក្នុងអំឡុងពេលប្រជុំ។ ជាឧទាហរណ៍ **មាស មុត** បានប្រាប់អំពីរឿងរបស់អតីតមេបញ្ជាការកងវរសេនាតូច ៣៨៦ ឈ្មោះ រឹម ដែលត្រូវបានសម្លាប់នៅមុខមន្ទីរសន្តិសុខនេះ "តា មុត កាលពីពេលនោះថែមទាំងបានប្រើប្រាស់រឿងនោះជាមួយចម្លើយសារភាពរបស់ [កម្មាភិបាល] ខ្លះក្នុងចំណោមកម្មាភិបាលដែលត្រូវបានចាប់ខ្លួន ដើម្បីបង្រៀនយើងក្នុងអង្គប្រជុំ។ គាត់អានចម្លើយសារភាព និងរឿងនោះប្រាប់យើង និងបានប្រកាសថា អ្នកដែលបានឆ្លើយសារភាព ស្ថិតក្នុងជួរក្បត់"[449]។

---

448 ឯកសារ D54/88 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ឆ.១២-១៦ ឆ.១៧-១៨ ["ខ្ញុំកំពុងធ្វើការនៅក្នុងចម្ការសណ្តែករបស់ខ្ញុំ។ មិនមានអ្វីបាំងមិនឲ្យខ្ញុំឃើញទេ។ ខ្ញុំធ្លាប់ឃើញ មាស មុត ពីរដង។ មាស មុតធ្វើដំណើរដោយឡានហ្ស៊ីប A2 សំដៅទៅទិសវត្តឥន្ទញ្ញាណ។ គាត់ធ្វើដំណើរតាមផ្លូវដែលយើងធ្វើដំណើរព្រឹកមិញនេះ រយៈពេលដែលយើងធ្វើការកំណត់អត្តសញ្ញាណទីកន្លែង។ មាស មុតបានយកម្ហូបអាហារដាក់ក្នុងឡានហ្ស៊ីបរបស់គាត់យកទៅឲ្យអ្នកយាមនៅវត្តឥន្ទញ្ញាណ។ ឡានហ្ស៊ីបរបស់គាត់មកឈប់នៅកន្លែងផ្ទះអ្នកយាម ដើម្បីប្រគល់ម្ហូបអាហារទាំងនោះឲ្យអ្នកយាម។ ស: តើមាស មុតមកវត្តឥន្ទញ្ញាណញឹកញ៉ាប់ប៉ុនណា? ឆ.១៣ :យោងតាមការដឹងរបស់ខ្ញុំ គាត់មកវត្តឥន្ទញ្ញាណ១ខែម្តង ដើម្បីនាំយកម្ហូបអាហារទៅឲ្យអ្នកយាម។ គាត់មក១ខែម្តង បន្ទាប់ពីគាត់ត្រឡប់មកពីការប្រជុំនៅស្ទឹងហាវ [...] ឆ.១៤ : ខ្ញុំគិតថាខ្ញុំសម្គាល់ឃើញមាស មុត យកម្ហូបអាហារទៅផ្តល់ឲ្យអ្នកយាមនៅវត្តឥន្ទញ្ញាណ ១ខែម្តង។ "]។ស: តើលោកបានឃើញ មាស មុត យកម្ហូបអាហារទៅឲ្យអ្នកយាមនៅវត្តឥន្ទញ្ញាណ ពីកន្លែងដែលលោកធ្វើការយ៉ាងម៉េចកើត បើកន្លែងរបស់លោកនៅឆ្ងាយពីវត្តយ៉ាងនេះ? ឆ.១៥ : ខ្ញុំដឹងតាមរយៈអ្នកយាមនៅវត្តឥន្ទញ្ញាណពីរនាក់ ថាមាស មុត នាំយកម្ហូបអាហារមកឲ្យពួកគេ។ ស: តើម្ហូបអាហារទាំងនោះគឺសម្រាប់អ្នកយាម ឬក៏សម្រាប់អ្នកទោស? ឆ.១៦ : ទេ ខ្ញុំមិនដឹងទេ។ ស: តើអ្នកយាមទាំងពីរនាក់នេះនៅរស់ដល់សព្វថ្ងៃដែរឬទេ? ហើយមានឈ្មោះអ្វីខ្លះ? ឆ.១៧ : ម្នាក់ឈ្មោះ សារិ និងម្នាក់ទៀត ឈ្មោះកុយ។ ខ្ញុំមិនស្គាល់នាមត្រកូលរបស់ពួកគេទេ។ ខ្ញុំបែកពួកនេះតាំងពីឆ្នាំ១៩៧៧។ ស: តើលោកដឹងថាមាស មុត ចូលទៅក្នុងវត្តឥន្ទញ្ញាណធ្វើអ្វីខ្លះ? ឆ.១៨ : ខ្ញុំឃើញមាស មុត ជិះឡានទៅវត្តឥន្ទញ្ញាណចំនួន២ដង។ ប៉ុន្តែ ខ្ញុំពុំអាចដឹងថាគាត់ទៅធ្វើអ្វីនៅក្នុងវត្តឥន្ទញ្ញាណទេ"]។

449 ឯកសារ D54/103 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.១១ ["នៅពេលនោះ ព័ត៌មានអំពីចាប់ខ្លួនថ្នាក់ដឹកនាំរបស់កង៣៨៦ ដូចជារ៉ែម ដែលជាស្នងការ ដែលត្រូវបានគេបាញ់ចំក្បាល សម្លាប់នៅខាងមុខវត្តឥន្ទញ្ញាណ "]។ ឯកសារ D54/101 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.១១ ["តាមុត បានលើកយករឿងនេះមកបង្រៀនពួកយើងនៅពេលនោះ ដោយមានចម្លើយសារភាពរបស់ពួកនោះមកអានប្រាប់យើងស្តាប់ផង ហើយគាត់បានប្រកាសថាពួកនេះជាខ្សែរយៈពួកក្បត់"]។

ខ) មន្ទីរសន្តិសុខទឹកសាប

158. មន្ទីរសន្តិសុខទឹកសាប ដែលស្ថិតនៅក្នុងតំបន់កំពង់សោម ស្ថិតក្រោមការគ្រប់គ្រងរបស់វរសេនាធំ ១៦៣ ដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ **មាស មុត**[450]។ ទីស្នាក់ការវរសេនាធំនេះស្ថិតនៅក្បែរមន្ទីរសន្តិសុខ[451] ហើយ ញ៉ែន ជាប្រធានគុក រហូតដល់យ៉ាងហោចណាស់ឆ្នាំ ១៩៧៧[452]។

---

450 ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.១៩ ["នៅពេលខ្ញុំមកដល់ទឹកសាបដំបូងនៅឆ្នាំ១៩៧៧ តាចនជាអ្នកទទួលខុសត្រូវកន្លែងនោះ។ តាចនគឺជាមេបញ្ជាការវរៈសេនាធំ៦៣ ហើយតាញ៉ានជាអនុរបស់គាត់"]។ ឯកសារ D114/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹង ណុច ឆ.១៣៧-១៣៨,១៤៦,២៤៩ ["សៈ នៅទឹកសាប មានជាអគារ ឬរោងទេ? ឆ.១៣៧: មានអគាររបស់កងវរៈសេនាធំ។ សៈ កងវរៈសេនាធំមួយណា? កងវរៈសេនាធំលេខ៦៣ [...] សៈ តើទឹកសាបគឺជាអ្វី? ជាសហករណ៍ ជាមន្ទីរសន្តិសុខ ឬក៏ជាបញ្ជាការដ្ឋានរបស់កងវរៈសេនាធំ? ឆ.១៤៦: ជាកន្លែងសន្តិសុខ [...] សៈ លោកមានដឹងថាបញ្ជាការដ្ឋានកងវរៈសេនាធំ៦៣ នៅទីណាទេ? ឆ.២៤៩: នៅទឹកសាប"]។ ឯកសារ D54/41 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ សារ៉ាន់ ឆ.២១ ["មន្ទីរបញ្ជាការរបស់កងវរសេនាធលេខ៦៣ នៅទឹកសាប"]។ ឯកសារ D114/77 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សាម៉េត ឆ.២០ ["សៈ ក្នុងចំណោមវរៈសេនាធំចំណុះក្រោមកងពលធំ១៦៤ តើកងវរៈសេនាធំមួយណាដែលគ្រប់គ្រងទឹកសាប? ឆៈ វរៈសេនាធំ៦៣"]។ ឯកសារ D114/115 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សាម៉ាន ឆ.៨ ["ទឹកសាបស្ថិតនៅក្រោមវរៈសេនាធំ៦៣ កងពលធំ១៦៤"]។ សូមមើលផងដែរ បញ្ជារបស់សុន សេន ទៅកាន់កងពលធំ១៦៤ ទាក់ទងនឹងទឹកសាប បង្ហាថាទីតាំងនោះស្ថិតក្រោមកងពលធំ១៦៤។ ឯកសារ D114/27.1.5 កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភាររបស់កងពល និងវរៈសេនាធំ ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ១៩៧៦ ERN KH 000523400 ["កងពល១៦៤ត្រូវទប់ទឹកជើងភ្នំ ទប់ព្រែកទឹកសាប ឲ្យបានដាច់ខាត"]។

451 ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹង ណុច ឆ.137-ឆ.138, 146, 249 ["សៈ នៅទឹកសាប មានជាអគារ ឬរោងទេ? ឆ.137៖ មានអគាររបស់កងវរៈសេនាធំ។ សៈ កងវរៈសេនាធំមួយណា? ឆ.138៖ កងវរៈសេនាធំ ៦៣ [...] សៈ ទឹកសាបជាអី? ជាសហករណ៍ ជាមន្ទីរសន្តិសុខ ឬក៏ជាបញ្ជាការដ្ឋានរបស់កងវរៈសេនាធំ? ឆ.146៖ ជាមន្ទីរសន្តិសុខ [...] សៈ លោកមានដឹងថាបញ្ជាការដ្ឋានកងវរៈសេនាធំ ៦៣ នៅទីណាទេ? ឆ.249៖ នៅទឹកសាប"]។ ឯកសារ D54/41 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ សារ៉ាន់ ឆ.21 [ទីបញ្ជាការដ្ឋានរបស់កងវរៈសេនាធំ ៦៣ មានមូលដ្ឋាននៅទឹកសាប]។

452 ឯកសារ D114/115 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.5 ["សៈ តើលោកអាចប្រាប់យើងបានទេ ថាតើអ្នកណាជាប្រធានគុក? ឆៈ ញ៉ែន តែខ្ញុំមិនស្គាល់ត្រកូលរបស់គាត់ទេ ញ៉ែន ជាបងថ្លៃរបស់ខ្ញុំ តែគាត់ស្លាប់ហើយ។ ញ៉ែន ជាប្តីបងស្រីរបស់ខ្ញុំ"]។ ឯកសារ D114/116 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.47 ["នៅពេលដែលលោកចេញពីទឹកសាបនៅឆ្នាំ១៩៧៧ តើ ញ៉ែន នៅតែកាន់គុកទឹកសាបទៀតដែរឬទេ? ឆៈ បាទ គាត់នៅកាន់គុកទឹកសាប"]។

159. ទីស្នាក់ការ និងលំនៅស្ថានរបស់ **មាស មុត** ស្ថិតនៅប្រមាណ ១៧ គីឡូម៉ែតពីគុកនេះ។ **មាស មុត** តាមរយៈមនុស្សក្រោមបង្គាប់របស់គាត់ បញ្ជូនទាហានកងពលធំ ១៦៤ និងប្រជាជនស៊ីវិល ដោយរួមបញ្ចូលខ្មែរក្រហម ទៅកាន់មន្ទីរសន្តិសុខនេះដើម្បីឃុំឃាំង និងលត់ដំ ដែលរមែងបានបណ្តាលឱ្យមានការសម្លាប់ក្រៅប្រព័ន្ធតុលាការ។ អ្នកជាប់ឃុំឃាំងស្ថិតក្រោមការងារពលកម្មដោយបង្ខំ បានទទួលអាហារមិនគ្រប់គ្រាន់ និងជាប់ខ្នោះជើងស្ទើរតែគ្រប់ពេល។ បន្ថែមពីនេះ វិធីសាស្ត្រសួរចម្លើយដ៏ឃោរឃៅ និងការធ្វើទារុណកម្មត្រូវបានប្រើប្រាស់ជាញឹកញាប់។ ទោះបីគ្មានចំនួនជាក់លាក់ក៏ដោយ ក៏មានការព្យាករថា អ្នកទោសរាប់ពាន់នាក់ត្រូវបានឃុំឃាំង និង/ឬ ត្រូវបានសម្លាប់នៅទឹកសាប[453]។

160. **មាស មុត** បានដឹងទាំងស្រុងអំពីការចាប់ដាក់ពន្ធនាគារ លក្ខខណ្ឌអមនុស្សធម៌ ទារុណកម្ម ការបាត់ខ្លួន និងការសម្លាប់នៅទឹកសាប។ គាត់បានរាយការណ៍ទៅ សុន សេន អំពីការស្វែងរក ការចាប់ខ្លួន និងការសួរចម្លើយមនុស្សដែលសង្ស័យថាជាខ្មាំងក្នុងបរិវេណមន្ទីរសន្តិសុខទឹកសាប។ ឧទាហរណ៍ នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ **មាស មុត** បានផ្ញើទូរលេខទៅ សុន សេន ដោយបានគូសបញ្ជាក់ថា "យោងតាមចម្លើយរបស់ម្នាក់ដែលយើងចាប់បាន នៅប៉ែកខាងកើតទឹកសាប មនុស្សប្រាំពីរនាក់ដែលយើងចាប់បាននៅស្ទឹងហាវគឺស្ថិតក្នុងក្រុមរបស់វា"[454]។

161. **មាស មុត** ក៏ដឹងដែរថា ចម្លើយសារភាពបានមកពីអ្នកទោសនៅមន្ទីរសន្តិសុខនេះ។ នៅថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៧៦ ជាឧទាហរណ៍ **មាស មុត** បានមានវត្តមាននៅអង្គប្រជុំសេនាធិការ នៅពេលអនុប្រធានរបស់គាត់ឈ្មោះ ឌឹម បានរាយការណ៍អំពីចម្លើយសារភាពរបស់ក្មេងជំទង់ម្នាក់ដែលត្រូវបានចាប់ខ្លួនដោយកងពលធំ ១៦៤៖ "យើងចាប់បានក្មេងស្រីម្នាក់អាយុ ១៣ ឆ្នាំ ក្នុងបរិវេណ

---

453 សូមមើល VIII.គ.4. មន្ទីរសន្តិសុខទឹកសាប។

454 ឯកសារ D1.3.12.3 ទូរលេខពី មាស មុត ជូន បង៨៩ (សុន សេន) ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ KH ERN 00021461 ["សភាពការណ៍ខ្មាំង ពួក ៧ នាក់ ដែលចាប់នៅសង្ហារតាមចំលើយអាមួយ ដែលចាប់នៅខាងកើតទឹកសាប វាថាជាក្រុមរបស់វា។ ដូច្នេះ អានេះជាក្រុមចោរព្រៃ ដែលពួននៅម្តុំខាងលិច និងខាងជើងវាលវិញ ធ្វើការងារមហាជននៅមូលដ្ឋាននៅវាលវិញ"]។

ទឹកសាប។ វាបានឆ្លើយសារភាពថា វាស្ថិតក្នុងចំណោមក្រុមមួយដែលមានគ្នាបីនាក់ ដែលប្រហែលកំពុងស្នាក់នៅអូរផុសនៅពេលនេះ"[455]។

162. **មាស មុត** បានឃើញដោយផ្ទាល់ភ្នែកនូវលក្ខខណ្ឌអមនុស្សធម៌ដែលអ្នកទោសបានទទួលរងនៅទឹកសាប ក្នុងអំឡុងពេលគាត់ចុះពិនិត្យជាទៀងទាត់នៅគុកនេះ ដែលមានចំនួនមួយលើកក្នុងរយៈពេលបួន ឬប្រាំខែ[456]។ សាក្សី ស្វាយ សំអាន បានពិពណ៌នាអំពីទស្សនកិច្ចរបស់ **មាស មុត** ទៅកាន់ទីតាំងនេះដោយបានគូសបញ្ជាក់ថាគាត់ "បានឃើញ [មាស មុត] ក្នុងរថយន្ត បន្ទាប់មក មាស មុត បានចុះទៅផែ នៅជាយដែទឹកសាប"[457]។

163. ការដឹងឮ និងសិទ្ធិអំណាចរបស់ **មាស មុត** លើប្រតិបត្តិការនៃមន្ទីរសន្តិសុខទឹកសាប ត្រូវបានបង្ហាញបន្ថែមតាមរយៈតួនាទីរបស់គាត់ក្នុងការបញ្ជូនអ្នកទោសពីសំណាក់កងពលរបស់គាត់ ពីមន្ទីរសន្តិសុខទឹកសាបទៅកាន់មន្ទីរស-២១[458]។ ដូចដែលបានពន្យល់ដោយប្រធានមន្ទីរ ស-២១ ឈ្មោះ ឌុច "មុនពេលចាប់នរណាម្នាក់ ចាំបាច់ត្រូវពិគ្រោះជាមួយប្រធានអង្គភាពរបស់អ្នកនោះ

---

455 ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH ERN 00052404 [សមមិត្ត ឌឹម (វត្តមានរបស់ មាស មុត) "ចាប់បាននារីម្នាក់ អាយុ ១៣ឆ្នាំ ម្តុំទឹកសាប សារភាពថាមានគ្នា ៣នាក់ ប្រហែលវានៅអូរផុស"]។

456 ឯកសារ D114/116 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.11 ["មាស មុត ចុះមកទឹកសាបប្រហែលជា ៤-៥ ខែម្តង។ ក្មេងៗជាអ្នកមកប្រាប់ខ្ញុំថា គាត់ជាអ្នកចុះមក"]។

457 ឯកសារ D114/116 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.5-8 ["បាទ ខ្ញុំឃើញគេចុះមក [ទឹកសាប] ម្តងម្កាល [...] ឆ.6៖ មាស មុត មេបញ្ជាការកងពល ១៦៤ [...] ឆ.7៖ ខ្ញុំឃើញគាត់ជិះឡានមក ខ្ញុំឃើញគាត់នៅក្នុងឡាន ហើយចុះទៅផែ ដែលនៅមាត់ស្ទឹងទឹកសាប [...] ឆ.8៖ ឡានហ្ស៊ីពចិន"]។

458 សូមមើល VIII.ឃ. មន្ទីរសន្តិសុខ ស២១-- ៤. ការទទួលខុសត្រូវរបស់ មាស មុត ចំពោះអ្នកទោសបញ្ជូនទៅ ស ២១។ សូមមើលផងដែរ ឯកសារ D54/20 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.10-12 [អ្នកទោសទឹកសាប គឺ "ឋិតក្រោមបញ្ជាការកងពល ១៦៤ របស់ មាស មុត [...] អ្នកទោសខ្លះគេបញ្ជូនទៅទឹកសាប "បណ្តោះអាសន្ននៅទីនោះ មុននឹងគេបញ្ជូនទៅភ្នំពេញ"]។

សិន"[459]។ មេបញ្ជាការកងពលធំ ១៦៤ **មាស មុត** ដែលទទួលបន្ទុកមន្ទីរសន្តិសុខទឹកសាប នឹងត្រូវបានពិគ្រោះទាក់ទងការបញ្ជូនអ្នកដែលត្រូវបានចាប់ខ្លួនទាំងនោះទៅកាន់មន្ទីរ ស-២១។

<u>មន្ទីរសន្តិសុខ ស-២១</u>

164. **មាស មុត** ក៏បានអនុញ្ញាតឲ្យបញ្ជូនមនុស្សដែលចាត់ទុកជាខ្មាំង ទៅមន្ទីរ ស-២១ ដែលតាមចេតនារបស់គាត់ ពួកគាត់ត្រូវបានឃុំឃាំង ទទួលទារុណកម្ម និងត្រូវបានសម្លាប់។ ក្នុងឋានៈជាលេខាកងពលធំ ១៦៤ និងជាប្រធានគណៈកម្មាធិការកំពង់សោម **មាស មុត** មានការទទួលខុសត្រូវព្រមគ្នាជាមួយមេដឹកនាំមជ្ឈិមបក្សនៅភ្នំពេញ ដើម្បីកំណត់ថា នរណាខ្លះពីកងពលធំ ១៦៤ និងកំពង់សោម នឹងត្រូវបានចាប់ខ្លួន និងបញ្ជូនទៅ ស-២១។

165. ស-២១ ជាគុកសំខាន់បំផុតក្នុងប្រព័ន្ធសន្តិសុខជាតិរបស់កម្ពុជាប្រជាធិបតេយ្យ។ ស-២១ បានទទួលយកអ្នកទោសពីគ្រប់ឋានានុក្រមទាំងអស់ ដោយរួមបញ្ចូលកម្មាភិបាលដឹកនាំក្នុងជួរ ប.ក.ក ក្រសួងនានានៃកម្ពុជាប្រជាធិបតេយ្យ និងស្ថាប័នរដ្ឋបាលនានា ក.ប.ក និងភូមិភាគ តំបន់ និងស្រុក។ ការធ្វើបាបដែលអ្នកទោសបានទទួលរងនៅ ស-២១ បានរួមបញ្ចូលលក្ខខណ្ឌដ៏យ៉ាប់យ៉ឺននៃការឃុំឃាំង អាហារមិនគ្រប់គ្រាន់ និងការថែទាំវេជ្ជសាស្ត្រមិនគ្រប់គ្រាន់ និងការបំពានរាងកាយ។ អ្នកទោសដែលចូលមន្ទីរ ស-២១ ត្រូវបានសួរចម្លើយជាប្រព័ន្ធ ក្រោមទារុណកម្មអំពីប្រវត្តិរូបរបស់ពួកគាត់ "គូកន" និង "សកម្មភាព" ដែលនាំទៅដល់ការចាប់ខ្លួន។ អ្នកទោសចំនួនជាង ១៥.០០០ នាក់បានចូលមន្ទីរ ស-២១ ក្នុងអំឡុងពេលជិតបួនឆ្នាំនៃអត្ថិភាពរបស់ខ្លួន ដោយត្រូវបានសម្លាប់ស្ទើរតែទាំងអស់ លើកលែងតែអ្នកទោសមួយក្តាប់តូចប៉ុណ្ណោះ[460]។

166. **មាស មុត** បានដឹងទាំងស្រុងអំពីអត្ថិភាព និងគោលបំណងនៃ ស-២១ នៅពេលដែលគាត់ប្រាស្រ័យទាក់ទងជាមួយ សុន សេន ឬ នួន ជា អំពីថាត្រូវបញ្ជូននរណាទៅទីនោះ[461]។ បន្ថែមពីលើនេះ គាត់

---

[459] ឯកសារ D4.1.400 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេចអ៊ាវ ហៅឌុច KH ERN 00239838 ["មុនការចាប់ខ្លួននរណាម្នាក់ គេត្រូវតែពិភាក្សាជាមួយអង្គភាពរបស់អ្នកនោះ។ នៅពេលណាដែលបានទទួលចម្លើយសារភាពរួចហើយ ចម្លើយសារភាពត្រូវបានផ្ញើដោយ សុន សេន (បន្ទាប់មក ជួន ជា) ទៅឲ្យប្រធានអង្គភាព"]។

[460] សូមមើល VIII.ឃ. មន្ទីរសន្តិសុខ ស-២១។ សូមមើលផងដែរ ឯកសារ D114/230.1.1 បញ្ជីអ្នកទោស ស-២១ របស់ ក.ស.ច.ស។

[461] សូមមើល កថាខណ្ឌ ១៦៨។

បានចូលរួមប្រជុំដែលក្នុងអំឡុងពេលប្រជុំនោះ តំណាង ស-២១ ដូចជា សមាជិកគណៈកម្មាធិការ ស-២១ ឈ្មោះ នុន ហ៊ុយ ហៅ ហ៊ុយ ស្រែ[462] និងបុព្វការីរបស់ ឌុច ឈ្មោះ ណាត[463] បានជូនដំណឹងអំពីសកម្មភាពទាក់ទង ស-២១[464]។

167. នៅអង្គប្រជុំទាំងនេះ មេបញ្ជាការកងពលធំដទៃទៀតក៏ប្រកាសផងដែរ អំពីការបញ្ជូនអ្នកទោសពីកងពលរបស់ពួកគាត់ទៅ ស-២១។ ឧទាហរណ៍ នៅថ្ងៃទី ១ ខែ មីនា ឆ្នាំ ១៩៧៧ លេខាកងពល ៥០២ ស៊ូ ម៉េត បាននិយាយដោយមានវត្តមានរបស់ **មាស មុត** ថា "សមាសភាពមិនល្អចំនួនជាងហាសិបនាក់ត្រូវបានបញ្ជូនទៅ ស-២១"[465]។ **មាស មុត** និងមេបញ្ជាការកងពលដទៃបានសម្តែងការឯកភាពជាញឹកញាប់ជាមួយការបោសសម្អាតរបស់ ប.ក.ក នៅអង្គប្រជុំសេនាធិការ[466] ដែលជាការឯកភាពបោសសម្អាត "ខ្មាំង" ក្នុងជួររបស់ពួកគាត់តាម រយៈការបញ្ជូនពួកគាត់ទៅ ស-២១ ដើម្បីទទួលទារុណកម្ម និងសម្លាប់។

168. **មាស មុត** បានចូលរួមចំណែកក្នុងផែនការនេះ តាមរយៈការបញ្ជូនអ្នកទោសទៅ ស-២១ ពីកំពង់សោម និងតំបន់ ៥០៥ ដោយពិគ្រោះជាមួយ សុន សេន ឬ នួន ជា។ ឌុច ប្រធានមន្ទីរសន្តិសុខ ស-២១ បានពន្យល់ថា លេខាកងពលនៃ ក.ប.ក ទទួលខុសត្រូវចំពោះការសម្រេចថា ត្រូវចាប់បញ្ជូននរណាពីកងពលរបស់ពួកគាត់ និងពីតំបន់ក្រោមការគ្រប់គ្រងរបស់ពួកគាត់ ទៅមន្ទីរ ស-២១

---

462 ឯកសារ D234/2.1.115 ហ៊ីម ហ៊ុយ ប្រតិចារឹក ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៦ 15.42.46-15.45.53 ["បងហ៊ុយគឺជាសមាជិករបស់ ស-២១"]។

463 ឯកសារ D1.3.33.3 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេចអ៊ាវ KH ERN 00146479 [មុនខែ មីនា ឆ្នាំ ១៩៧៦ ណាត គឺជា "ប្រធានធំសម្រេចរាល់កិច្ចការទាំងអស់"]។ ឯកសារ D4.1.346 កំណត់ហេតុស្តាប់ចម្លើយ ម៉ម ណៃ KH ERN 00162883។ ឯកសារ D4.1.387 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន ហេង KH ERN 00163688-89។

464 ឯកសារ D1.3.27.10 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៧៦ KH ERN 00052355។ ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00052393។ ឯកសារ D1.3.27.19 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00088912 [សេចក្តីរាយការណ៍របស់តំណាង ស-២១]។

465 ឯកសារ D1.3.27.26 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧ KH ERN 00052304-05។

466 សូមមើល កថាខណ្ឌ ១០០។

ដោយសហការជាមួយមេដឹកនាំមជ្ឈិមបក្ស[467]។ ដំណើរការពិគ្រោះនេះមានភាពជាក់ស្តែងមួយផ្នែក ក្នុងចំណារនានាដែលសរសេរដោយ សុន សេន នៅលើចម្លើយសារភាពនៅ ស-២១ ដែលក្នុងនោះ គាត់ស្នើសុំយោបល់របស់ **មាស មុត** ទាក់ទងមនុស្សដែលត្រូវបានចោទប្រកាន់[468]។

---

467 ឯកសារ D114/277.5 កាំង ហ្គេចអ៊ាវ ហៅ ឌុច ប្រតិចារឹក ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦ 14.34.50-14.38.00 ["ភូមិភាគក៏ដោយច្រើនតែខាងលើប្រគល់រុញទៅហើយ ខ្មាំងឆ្លើយដាក់ប៉ុន្មានដែលខាងលើគិតថា អាណាមានលទ្ធភាពធំជាងគេចាប់ហើយ"]។ ឯកសារ D98/1.2.6 កាំង ហ្គេចអ៊ាវ ហៅ ឌុច ប្រតិចារឹក ថ្ងៃទី 20៧ ខែ ឧសភា ឆ្នាំ ២០០៩ 09.32.55 ["ចម្លើយដែលចេញពីស-២១ [...] គឺទៅដៃមេខ្ញុំ។ មេខ្ញុំឲ្យទៅ ស៊ូ ម៉េត ហើយ ស៊ូ ម៉េត ជ្រើសមនុស្សមួយចំនួនដែលនៅក្នុងកងពល ៥០២"], 09.55.10-10.16.21 ["សេចក្តីសារភាព ដែលខ្ញុំជូនទៅ សុន សេន, សុន សេន មើលពិចារណា [...] ឯចុះចំណែក ស៊ូ ម៉េត ធ្វើការជាមួយ សុន សេន"], 10.33.21 ["សេចក្តីសារភាពដែលយើងខ្ញុំបាន យើងខ្ញុំជូនអីចារ ជាពិសេសច្រើនតែចារហើយជូនផ្ទាល់ទៅមេគឺ សុន សេន។ ហើយ សុន សេន ហៅប្រធានអង្គភាពគេ ជាពិសេសបើកងពល ៥០២ គឺហៅ ស៊ូ ម៉េត មកផ្ទាល់តែម្តង ដើម្បីសម្រេចជាមួយគ្នា នេះជាវិធីដែលធ្លាប់ធ្វើការ [...] ដូច្នេះ សម្រេច គឺគេសម្រេចក្នុងក្របខ័ណ្ឌលេខាអគ្គសេនាធិការ និងលេខាកងពល ជាហូរហែគឺសម្រេចអ៊ីចឹង គ្មានតួនាទីរបស់ ស-២១ ទៅសម្រេចនឹងគេទេ"]។ ឯកសារ D4.1.404 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេចអ៊ាវ ហៅ ឌុច KH ERN 00242921 ["ចម្លើយសារភាពត្រូវបានផ្ញើទៅប្រធានអង្គភាព ដោយមានគោលបំណង ២៖ ទី១ ប្រាប់អំពីសកម្មភាពរបស់ខ្មាំងនៅក្នុងអង្គភាពនោះ និងទី ២ អនុញ្ញាតឲ្យគាត់គិតពីការចាប់ខ្លួនមនុស្សដែលគេបានឆ្លើយដាក់"]។ ឯកសារ D4.1.860 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេចអ៊ាវ ហៅ ឌុច KH ERN 00403906 ["នៅក្នុងការអនុវត្តជាក់ស្តែង ពេលដែលមនុស្សម្នាក់ត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព ថ្នាក់លើជូនដំណឹងទៅអ្នកទទួលខុសត្រូវអង្គភាពនីមួយៗ"]។ ឯកសារ D4.1.400 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេចអ៊ាវ ហៅ ឌុច KH ERN 00239838 ["មុនការចាប់ខ្លួននរណាម្នាក់ គេត្រូវតែពិភាក្សាជាមួយអង្គភាពរបស់អ្នកនោះ។ នៅពេលណាដែលបានទទួលចម្លើយសារភាពរួចហើយ ចម្លើយសារភាពត្រូវបានផ្ញើដោយ សុន សេន (បន្ទាប់មក នួន ជា) ទៅឲ្យប្រធានអង្គភាព"]។ ឯកសារ D4.1.1156 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេចអ៊ាវ ហៅ ឌុច KH ERN 00205153 ["នៅពេលដែលថ្នាក់លើ (សុន សេន និង បន្ទាប់មក នួន ជា) កំណត់សម្គាល់ឃើញឈ្មោះមនុស្សដែលត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព គេកោះហៅប្រធានអង្គភាពរបស់អ្នកនោះ (ក្នុងករណីយើង គឺ អៀង ធីរិទ្ធ) ដើម្បីសម្រេច ឬទី ២ មានបញ្ហាកើតឡើងក្នុងអង្គភាព ប្រធានអង្គភាព ធ្វើរបាយការណ៍ទៅថ្នាក់លើដែលជាអ្នកសម្រេចពីការចាប់ខ្លួន ហើយបញ្ជូនសេចក្តីសម្រេចនោះទៅប្រធាននៃអង្គភាព"]។ ឯកសារ D12 កំណត់ហេតុស្តាប់ចម្លើយជាមួយ កាំង ហ្គេចអ៊ាវ ហៅ ឌុច KH ERN 00680805 ["សុន សេន មុនពេលសម្រេច គាត់តែងតែសុំយោបល់ និងការជួយសម្រេចពីប្រធានកងពលផ្ទាល់នោះ"]។ សូមមើលផងដែរ ឯកសារ D98/1.2.33 សៅ សារុន ប្រតិចារឹក ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២ 11.09.11-11.12.30 [បញ្ជាក់ថា ក្នុងនាមជាលេខាតំបន់ ១០៥ គាត់ទទួលទូរលេខពី ប៉ុល ពត ដែលជូនដំណឹងគាត់ថា ចម្លើយសារភាពពីកម្មាភិបាលតំបន់ ១០៥ ម្នាក់បានបង្ហាញថា"សមមិត្ត សុត"ជាជនក្បត់]។ ឯកសារ D4.1.578 ទូរលេខ ៥៤ ពីសារុន ជូនបងជាទីគោរព ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៧៨ [ទូរលេខពីលេខាតំបន់ ១០៥ ពិភាក្សាអំពីការចាប់ខ្លួន សុត ដែល"គេឆ្លើយដាក់នៅក្នុងចម្លើយសារភាពរបស់ជនក្បត់ អាឈួន""]។ ឯកសារ

169. ទាក់ទងចម្លើយសារភាពនៅ ស-២១ ឌុច បានពន្យល់ថា "នៅពេលចម្លើយសារភាពត្រូវបានប្រមូល វាត្រូវបានបញ្ជូនទៅប្រធានអង្គភាពដោយ សុន សេន (បន្ទាប់មក នួន ជា)"[469]។ **មាស**

---

D98/3.1.20 ឆោម សែ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ 15.28.00-15.38.48 [សក្ខីកម្មរបស់ប្រធានកងពលធំ ៨០១ បញ្ជាក់ថា បន្ទាប់ពី សារឿន ដែលជាលេខាកងពលធំ បានទទួលចម្លើយសារភាពពីភ្នំពេញ គឺមាន "ឈ្មោះរបស់មនុស្សដែលមានគេឆ្លើយដាក់" សេចក្តីសម្រេចនោះ គឺធ្វើឡើង"ថាតើបុគ្គលគួរតែចាប់ខ្លួន គឺក៏ដាក់ទណ្ឌកម្មខាងវិន័យចំពោះបុគ្គលទាំងនោះ"] ដែលបញ្ជាក់ពីឯកសារ D4.1.805 កំណត់ហេតុស្តាប់ចម្លើយ ឆោម សែ ឆ.6 ["ចម្លើយសារភាពទាំងនោះ [...] គេយកទៅជួបមេកងពលតា សូរ សារឿន រួចហើយគេបញ្ជូនទៅអង្គភាពសាមុីរបស់អ្នកទោសនោះ ដើម្បីធ្វើការចាប់អ្នកទោសនោះមកមន្ទីរសន្តិសុខអូរកន្សែង"]។ ឯកសារ D98/3.1.221 វ៉ែចាម តុន ហៅ ភី ភួន ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ 11.36.45-11.44.44 [សក្ខីកម្មរបស់ប្រធានសន្តិសុខក្រសួងកិច្ចការបរទេស បញ្ជាក់ថា អៀង សារី បានទទួលចម្លើយសារភាពមានចំណារពីមន្ទីរ ៨៧០ ដែលឆ្លើយថាជា "កា.ហ្សេ.បេ ឬ សេ.អុី.អា"] ដែលនេះ បញ្ជាក់ពី ឯកសារ D4.1.241 កំណត់ហេតុស្តាប់ចម្លើយ វ៉ែចាម តុន ហៅ ភី ភួន KH ERN 00228845 ["ឈ្មោះដែលគេឆ្លើយដាក់នោះ ត្រូវបានបញ្ជូនមកអ៊ំ អៀង សារី ដើម្បីឱ្យគាត់បញ្ជាក់ប្រាប់ថា ជននោះជាអ្នកណា"]។ ឯកសារ D98/3.1.198 សួង ស៊ីគឿន ប្រតិចារឹក ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ 09.26.23-09.29.27 [បញ្ជាក់ថា អៀង សារី បានអានចម្លើយសារភាព]។ ឯកសារ D98/3.1.244 សួង ស៊ីគឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១២ 11.34.17-11.36.35 [បញ្ជាក់ថា គាត់ត្រូវគេហៅទៅមន្ទីររបស់ អៀង សារី ហើយគេប្រាប់គាត់ថា គាត់ត្រូវគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព]។ ឯកសារ D4.1.835 កំណត់ហេតុស្តាប់ចម្លើយ សាឡុត បាន KH ERN 00357530-07 [បញ្ជាក់ថា ចម្លើយសារភាពពី ស-២១ បានបញ្ជូនទៅក្រសួងការបរទេស]។ ឯកសារ D4.1.443 កំណត់ហេតុស្តាប់ចម្លើយហាំ អនស៊ី KH ERN 00242413 [ប្រធានយោធាតំបន់ ១០៥ បានទទួលពីមជ្ឈិមបក្សនូវចម្លើយសារភាព ស-២១ របស់យោធាកងពលធំ ៩២០ អំពី"មនុស្សដែលគេឆ្លើយដាក់ ដែលពួកគេទើបតែដឹង"]។

468 ឯកសារ D234/2.1.55 ចម្លើយសារភាព ស-២១ របស់ ហង់ ឡឿន ហៅ ខឹម EN ERN 00224085, KH ERN 00162140 [ចំណាររបស់ សុន សេន ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ១៩៧៧ លើចម្លើយសារភាពរបស់អនុលេខាកងពលធំ ១៦៤៖ "ដោយមនុស្សមួយចំនួនគឺល្អ ហើយមនុស្សមួយចំនួនដែលខ្ញុំស្គាល់គឺមិនល្អ ខ្ញុំសូមឱ្យសមមិត្តមុត ត្រួតពិនិត្យទាំងអស់គ្នាលើបញ្ហានេះ"]។ ឯកសារ D234/2.1.54 ចម្លើយសារភាព ស-២១ របស់ គុណ ខឹម ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩៧៧ EN ERN 00822359, KH ERN 00175293 [ចំណាររបស់ សុន សេន៖ "កងពល ១៦៤ របស់ ស/ម មុត [...] អ/ក ស/ម មុត ដើម្បីមានវិធានការ។ ខាង ស/ម មុត យើងដកអស់ជាមូលដ្ឋានហើយ"]។ ឯកសារ D4.1.766 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេចអ៊ាវ ហៅ ឌុច KH ERN 00398202 [បញ្ជាក់ថាជាចំណាររបស់ សុន សេន នៅលើចម្លើយសារភាពរបស់ ហង់ ឡឿន]។

469 ឯកសារ D4.1.400 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេចអ៊ាវ ហៅ ឌុច KH ERN 00239838 ["មុនការចាប់ខ្លួននរណាម្នាក់ គេត្រូវតែពិភាក្សាជាមួយអង្គភាពរបស់អ្នកនោះ។ នៅពេលណាដែលបានទទួលចម្លើយសារភាពរួចហើយ ចម្លើយសារភាពត្រូវបានផ្ញើដោយ សុន សេន (បន្ទាប់មក ជួន ជា) ទៅឱ្យប្រធានអង្គភាព"]។

**មុត** បានទទួលចម្លើយសារភាពទាំងនោះ និងបានប្រើប្រាស់ចម្លើយទាំងនោះដើម្បីលើកទឹកចិត្តការស្វែងរក ខ្មាំងក្នុងជួរ ក.ប.ក និងដើម្បីព្រមានទ័ពរបស់គាត់អំពីផលវិបាកនៃការក្បត់។ **មាស មុត** បានអានសម្រង់នៃចម្លើយសារភាពនៅ ស-២១ របស់អនុប្រធានរបស់គាត់ឈ្មោះ ឌឹម និងសមាជិកគណៈ កម្មាធិការឈ្មោះ ឆាន ទៅកាន់ទាហានកងពលធំ ១៦៤ ចំនួនរាប់ពាន់នាក់[470]

---

470 ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.11, 13, 15-16 ["សៈ តើមានតែ តាមុត ម្នាក់ដែលនិយាយនៅក្នុងអង្គប្រជុំ ឬក៏មានកម្មាភិបាលផ្សេងទៀតនិយាយដែរ? ឆ.11៖ មានតែ តាមុត ម្នាក់គត់ [...] ឆ.13៖ ខ្ញុំដឹងថា ឌឹម ជាអនុរបស់គាត់ ប៉ុន្តែក្នុងពេលប្រជុំគាត់បានប្រកាសថា ឌឹម បានក្លាយទៅជាជនក្បត់រួចទៅហើយ [...] សៈ តើមានអ្នកចូលរួមប្រជុំដែលមកពីបូព៌ាជាមួយ ឌឹម ដែលបានចូលរួមដែរឬទេ? ឆ.15៖ បាទ គឺមានខ្លះបានចូលរួម។ តែខ្ញុំមិនដឹងថាមានចំនួនប៉ុន្មានពិតប្រាកដទេ។ នៅពេលនោះ គេចំរាញ់យកចេញតែពួកថ្នាក់ដឹកនាំដែលមកពីភូមិភាគបូព៌ាតែប៉ុណ្ណោះ។ ចំណែកពួកយោធាធម្មតា គេគ្រាន់តែដកកាំភ្លើង ហើយបញ្ជូនទៅវាយថ្ម [...] សៈ ចំពោះ ឌឹម តើលោកដឹងថា គាត់បាត់ខ្លួនមុនការប្រជុំ ឬក៏លោកដឹងថាគាត់បាត់ខ្លួនក្នុងពេលគេប្រកាសក្នុងអង្គប្រជុំ? ឆ.16៖ ខ្ញុំទើបតែដឹងពីការបាត់ខ្លួនរបស់គាត់ នៅពេលដែលគេប្រកាសក្នុងអង្គប្រជុំនេះ ពីព្រោះគាត់នៅកំពង់សោម ឯខ្ញុំនៅស្ទឹងហាវ"]។ ឯកសារ D114/85 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.10, 21, 23-24, 26 ["ក្នុងចុងឆ្នាំ ១៩៧៦ ឬដើមឆ្នាំ១៩៧៧ ដែល មាស មុត បានប្រកាសថា ឈ្មោះ ជ័យ ឆាន [...] ជនក្បត់ឲ្យវៀតណាម។ ការចាប់ខ្លួនឈ្មោះ ឌឹម ក៏ត្រូវបានប្រកាសក្នុងពេលតែមួយនោះដែរ [...] ឆ.21៖ ការប្រកាសនេះ គឺធ្វើឡើងនៅថ្ងៃបុណ្យរំពុកថ្ងៃជ័យជម្នះ ១៧ មេសា សម្រាប់កងពល ១៦៤។ ការប្រកាសនោះធ្វើឡើងនៅឆ្នេរអូរឈើទាល នៅប៉ែកខាងចុង ដែលជាទីបញ្ជាការកងទ័ពជើងទឹក [...] ឆ.23៖ មាស មុត បាននិយាយតែម្នាក់ឯងទេ នៅក្នុងថ្ងៃនោះ ដោយសារការចូលរួមយោធាប្រហែល ១000,នាក់ [...] ក្នុងចំណោមរឿងផ្សេងទៀត មាស មុត ក៏បានប្រកាសថា ឆាន និង ឌឹម ត្រូវបានចាប់ខ្លួនដោយសារពួកគេក្បត់។ តាមខ្ញុំដឹង ឆាន ត្រូវបានចាប់ខ្លួនមុនគេចាប់ខ្លួន ឌឹម។ ហើយមានតែការចាប់ខ្លួនរបស់ ឆាន និង ឌឹម ទេ ដែលគេប្រកាសជាសាធារណៈ [...] ឆ.24៖ គឺគេធ្វើចំថ្ងៃ ១៧ មេសា ហ្នឹងតែម្តង គឺធ្វើតែមួយព្រឹកទេ [...] ឆ.26៖ មានតែការចាប់ខ្លួនរបស់ ឆាន និង ឌឹម ទេ ដែលត្រូវបានប្រកាស ហើយខ្ញុំមិនដឹងថា ពួកគេត្រូវបានចាប់ខ្លួន មុនការប្រកាសនោះយូរប៉ុនណាដែរ"]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.1 ["ចុងឆ្នាំ ១៩៧៦ ចូលទៅដើមឆ្នាំ ១៩៧៧ [...] មាស មុត បានមកធ្វើមីទ្ទីងជាមួយអ្នកភូមិនៅគគីរ នៅជិតព្រលានយន្តហោះកងកេង ដោយមានអតីតយោធាចូលរួមប្រហែលរាប់ពាន់នាក់ [...] នៅក្នុងកិច្ចប្រជុំ មាស មុត អានចម្លើយសារភាពពួកក្បត់ គាត់បានរៀបរាប់ឈ្មោះកម្មាភិបាលក្បត់ចាប់ពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់មូលដ្ឋាន។ ខ្ញុំនៅចាំថា គាត់ហៅឈ្មោះ អាយ៉ា, អាធុច , អាញ៉ឹក, អាយ៉ាន, អាឆាន, និង អាឌឹម"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.5, 9-10 ["ឈ្មោះ យ៉ាន នេះគឺស្ថិតនៅក្នុងចំណោមពួកក្បត់ដែល តាមុត បានលើកមករៀបជាពាក្យជួនដូចកំណាព្យថា "ញ៉ឹក, ឆាន, យ៉ាន, ឌឹម ជាពួកក្បត់" [...] ឆ.9៖ ខ្ញុំគិតថា ឌឹម នៅក្នុងឯកសារនេះ គឺជា ឌឹម ដែលខ្ញុំបានប្រាប់លោកខាងដើម ដែលរៀបរាប់នៅក្នុងពាក្យជួនថា អាញ៉ឹក, អាឆាន, អាយ៉ាន, អាឌឹម [...] ឆ.10៖ ខ្ញុំបានឮសូរពីយោធាក្នុងកងជាមួយគ្នា និយាយថា ឌឹម និង ឆាន ត្រូវបានបញ្ជូនទៅកាត់ម៉ាស៊ីនបូមទឹកនៅបឹងជើងឯក។ នៅពេលនោះយើងជឿថា រឿងហ្នឹងជារឿងពិត។ ប៉ុន្តែក្រោយមកនៅពេលដែល មុត ប្រកាសនៅក្នុងអង្គប្រជុំ អំពីចម្លើយ

សារភាពរបស់ជនក្បត់ និងខ្មែរយៈសេអ៊ីអា និងកាហ្សេបេ ហើយបន្ទាប់មកពីការបាត់ខ្លួនពួកនោះ ទើបយើងដឹងថា ពួកគេទាំងនោះត្រូវបានចាប់ខ្លួនហើយ”]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.7-8 [“ស៖ តើលោកដឹងឬទេថា តើ មាស មុត ជាអ្នកចេញប្រកាសព័ត៌មាននេះ? ឆ.7៖ បាទ, ដោយសារគាត់ជាមេបញ្ជាការកងពល ដូច្នេះគឺមានតែគាត់ហើយជាអ្នកបញ្ជូនសេចក្តីប្រកាសនេះមកថ្នាក់ក្រោម។ ស៖ ម៉េចបានជាលោកដឹងរឿងនេះ? ឆ.8៖ គ្មាននរណាទៀតក្រៅពីគាត់ដែលអាចចេញការប្រកាសនេះ ពីព្រោះគាត់ជាមេបញ្ជាការកងពល។ ការប្រកាសអំពីការចាប់ចងនេះ គឺសម្រាប់តែការចាប់ចងពួកប្រធានកងដែលក្បត់តែប៉ុណ្ណោះ មិនមែនសម្រាប់ការចាប់ចងទូទៅទេ”]។ ឯកសារ D54/40 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន រី ឆ.23-24 [“អង្គការថ្នាក់លើនិយាយថា អ្នកតំបន់ ២២ គឺជាពួកក្បត់។ ពេលនោះ គេបានចាក់ខ្សែអាត់សំឡេងពីការសារភាពរបស់ ឌឹម និង ស៊ីម ឱ្យយោធាស្តាប់ ដើម្បីឱ្យយោធាជឿថាអ្នកទាំងពីរនេះពិតជាក្បត់មែន។ ខ្ញុំស្គាល់សំឡេងគាត់ទាំងពីរនាក់ច្បាស់។ ស៖ តើអ្នកណាជាអ្នកយកខ្សែអាត់សំឡេងអ្នកទាំងពីរចាក់ឱ្យយោធាស្តាប់ ហើយចាក់ខ្សែអាត់នោះនៅកន្លែងណា? ឆ.24៖ គឺមេបញ្ជាការបន្ទាប់ពី ឌឹម ជាអ្នកចាក់ខ្សែអាត់សារភាពរបបស់អ្នកទាំងពីរឱ្យយោធាស្តាប់។ ខ្សែអាត់បានចាក់ឱ្យយោធាស្តាប់នៅព្រែកលៀប”]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.1 [“បន្ទាប់ពីពួកយើងត្រូវបានគេដកអាវុធ [...] មាស មុត បានមកធ្វើមីទ្ទីងជាមួយពួកអ្នកភូមិគគីរ នៅជិតព្រលានយន្តហោះកងកេង ដោយមានអតីតាកយោធាចូលរួមប្រហែលរាប់ពាន់នាក់ ដោយមានកងវរសេនាតូច ៣៨៦ និងកងផ្សេងៗទៀត។ [...] នៅក្នុងកិច្ចប្រជុំ មាស មុត អានចម្លើយសារភាពពួកក្បត់ គាត់បានរៀបរាប់ឈ្មោះកម្មាភិបាលក្បត់ចាប់ពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់មូលដ្ឋាន។ ខ្ញុំនៅចាំថាគាត់ហៅឈ្មោះ អាយ៉ា, អាធុច , អាញ៉ឹក, អាយ៉ាន, អាឆាន, និង អាឌឹម។ ខ្ញុំនៅចាំ មាស មុត ហៅពួកគេថា “អា” ជាពាក្យបន្ទុះបង្អាប់សម្រាប់និយាយទៅកាន់ពួកក្បត់”]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.56-60, 63 [“គេបញ្ជូនយើង [“កងវរសេនាតូច ៣៨៦ និងទាហានភូមិភាគបូព៌ា ដែលត្រូវបានដកហូតអាវុធ]មកហ្នឹងឈប់នៅព្រលានយន្តហោះកងកេង ហើយគេប្រជុំនៅពេលព្រឹកហ្នឹង។ ហើយ មាស មុត ជាប្រធានអង្គជំនុំ [...] ឆ.58៖ [ក្នុងអំឡុងពេលប្រជុំ] មានអ្នកយាម មានទាហានយាម [...] ស៖ តើទាហានដែលយាមនោះ មានអាវុធទេ? ឆ.59៖ មាន។ [...] ឆ.60៖ ប្រជុំពីបញ្ហាមេក្បត់ គឺអនុមេបញ្ជាការកងពល ១៦៤ នង ឆាន ជាអ្នកក្បត់ ហើយ មាស មុត អានចម្លើយសារភាពរបស់ នង ឆាន ហ្នឹង។ [...] ឆ.63៖ ខ្ញុំចាំបាន ត្រង់គាត់និយាយពីចម្លើយសារភាពរបស់ពួកក្បត់ និយាយពី នង ឆាន និងមេៗរបស់ខ្ញុំទាំងពីរហ្នឹង [...] មាស មុត គ្រាន់តែនិយាយថា ពួកគាត់ក្បត់”]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.10 [“ខ្ញុំបានឮសួរពីយោធាក្នុងកងជាមួយគ្នា និយាយថា ឌឹម និង ឆាន ត្រូវបានបញ្ជូនទៅកាន់ម៉ាស៊ីនបូមទឹកនៅបឹងជើងឯក។ នៅពេលនោះយើងជឿថា រឿងហ្នឹងជារឿងពិត។ ប៉ុន្តែក្រោយមកនៅពេលដែល មុត ប្រកាសនៅក្នុងអង្គប្រជុំ អំពីចម្លើយសារភាពរបស់ជនក្បត់ និងខ្មែរយៈសេអ៊ីអា និងកាហ្សេបេ ហើយបន្ទាប់មកពីការបាត់ខ្លួនពួកនោះ ទើបយើងដឹងថា ពួកគេទាំងនោះត្រូវបានចាប់ខ្លួនហើយ”]។ ឯកសារ D54/101 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.11 [“តាមុត បានយករឿងនោះ [...] ដោយមានទាំងចម្លើយសារភាពរបស់ពួក[កម្មាភិបាល]នោះមកអានប្រាប់យើងស្តាប់ ហើយគាត់បានប្រកាសថា ពួកនេះជាខ្មែរយៈពួកក្បត់”]។

ដោយបានអះអាងថា ខឹម និងមនុស្សផងទៃ "បានមានផែនការដកគាត់ចេញពីមុខតំណែង និងគ្រប់គ្រងកងពលធំនេះដើម្បីបង្កើតរដ្ឋាភិបាលមួយទៀត ដែលប្រឆាំងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ"[471]។

170. ការភ័យស្លន់ស្លោររបស់ **មាស មុត** អំពីចេតនារបស់មនុស្សក្រោមបង្គាប់ខ្លះក្នុងចំណោមមនុស្សក្រោមបង្គាប់របស់គាត់ ពន្យល់អំពីការប្រើប្រាស់ដោយចេតនានូវចម្លើយសារភាពទាំងនេះដើម្បីលើកទឹកចិត្ត "ការប្រុងប្រយ័ត្នបដិវត្តន៍" ក្នុងកងពលធំរបស់គាត់។ តាមរយៈការទទួល និងការប្រើប្រាស់ចម្លើយសារភាពទាំងនេះ គាត់ចង់ឲ្យមានការចាប់ខ្លួននិងបញ្ជូនទៅ ស-២១ នូវ "ជនក្បត់" ដោយមិនអើពើទាល់តែសោះអំពីទុក្ខវេទនាដែលពួកគាត់នឹងទទួលរង ពីព្រោះគាត់បានដឹងថាអ្នកទោសទាំងនេះនឹងត្រូវបានតម្រូវឲ្យផ្តល់ "ចម្លើយសារភាព" ក្រោមទារុណកម្មនៅមន្ទីរសន្តិសុខនេះ។ **មាស មុត** បានចាប់ផ្តើមការស្វែងរកដែលមិនចេះចប់នូវ "ខ្មាំង" ដែលនៅទីបំផុតនឹងបញ្ចប់ នៅ ស-២១ ឬមន្ទីរសន្តិសុខផងទៃទៀត ដែលនៅទីនោះពួកគាត់នឹងទទួលរងទារុណកម្ម និងត្រូវបានសម្លាប់។

*ក) អគ្គសេនាធិការ ក.ប.ក កងពលធំមជ្ឈិមបក្ស និងវរសេនាធំ*

171. ក្នុងតួនាទីជាសមាជិកដ៏សំខាន់នៃសហឧក្រិដ្ឋកម្មរួមដើម្បីបោសសម្អាត ក.ប.ក តាមរយៈការចាប់ខ្លួន និងការឃុំឃាំង ការធ្វើទារុណកម្ម និងការសម្លាប់ក្រៅប្រព័ន្ធតុលាការ **មាស មុត** ទទួលខុសត្រូវជាលក្ខណៈបុគ្គលចំពោះការចាប់ដាក់ពន្ធនាគារ ការធ្វើបាប និងការសម្លាប់បុគ្គលិក ក.ប.ក យ៉ាងហោចណាស់ចំនួន ៤៨០០ នាក់ ដែលត្រូវបានបញ្ជូនទៅ ស-២១។ គាត់រួមចំណែកក្នុងគោលបំណងរួមជាមួយអគ្គសេនាធិការ និងមេបញ្ជាការកងពលធំមជ្ឈិមបក្ស និងមេបញ្ជាការវរសេនាធំឯករាជ្យ ដើម្បីចាប់ខ្លួនខ្មាំងផ្ទៃក្នុងរបស់ ក.ប.ក ធ្វើទុកបុកម្នេញពួកគាត់ និងសម្លាប់ពួកគាត់នៅ ស-២១។

---

471 ឯកសារ D114/85 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.34 ["មាស មុត បាននិយាយយ៉ាងច្បាស់ៗថា ខឹម ហើយនិង ឆាន គឺមានផែនការទម្លាក់រូបគាត់ចេញ ហើយកាន់កាប់កងពលធំ ដើម្បីបង្កើតរដ្ឋាភិបាលមួយខុសពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ"]។ សូមមើលផងដែរ ឯកសារD1.3.13.11 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សៀង EN ERN 00217564 ["ខឹម បាត់ខ្លួននៅឆ្នាំ ១៩៧៧ នៅពេលដែលមានទំនាស់ផ្ទៃក្នុង"]។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយអៀម ភង់ ឆ.50["តាឆាន និង ខឹម ត្រូវបានសម្លាប់ ដោយចោទថា ក្បត់ ហើយតាមពិតគេមានផែនការក្បត់មែន"]។

172. **មាស មុត** បានរួមចំណែកយ៉ាងសំខាន់ដល់សហឧក្រិដ្ឋកម្មរួមនេះ តាមរយៈការលើកឡើងអំពីការគាំទ្រគោលនយោបាយនេះតាមបណ្ដាអង្គប្រជុំអគ្គសេនាធិការ តាមរយៈការធ្វើទុក្ខបុកម្នេញ និងការសម្លាប់មនុស្សក្រោមបង្គាប់របស់គាត់ក្នុងកងពលធំ ១៦៤ នៃ ក.ប.ក នៅកំពង់សោម និងមេដឹកនាំកងពល ១១៧ នៅក្រចេះ ព្រមទាំងការបញ្ជូនបុគ្គលខ្លះក្នុងចំណោមបុគ្គលទាំងនេះទៅសម្លាប់នៅ ស-២១។ នៅទីនោះ គាត់បានដឹង និងមានចេតនាចង់ឲ្យអ្នកទោសដែលគាត់បានបញ្ជូននឹងត្រូវបានប្រើប្រាស់ដើម្បីនាំយកជនក្បត់បន្ថែមដែលត្រូវបានចោទប្រកាន់ រងទារុណកម្ម និងការសម្លាប់ បន្ថែមពីលើការរងទារុណកម្ម និងការសម្លាប់ដោយខ្លួនឯង។ ជាលទ្ធផលនៃការអនុវត្តកិច្ចព្រមព្រៀងនេះ មនុស្សយ៉ាងហោចណាស់ចំនួន ៤៩០០ នាក់ដែលមកពីអគ្គសេនាធិការ ក.ប.ក កងពលធំមជ្ឈិមបក្ស និងវរសេនាធំមជ្ឈិមបក្ស ដោយរួមបញ្ចូលកងពលធំ ១៦៤ និង ១១៧ ត្រូវបានបញ្ជូនទៅ ស-២១[472]។ ចំនួនពីអង្គភាពនីមួយត្រូវបានសង្ខេបដូចខាងក្រោម៖

(១) អគ្គសេនាធិការ- ៤៥៣ នាក់

(២) ស-២១- ៣៤នាក់

(៣) កងពលធំ ១៧០-៤០៣ នាក់

(៤) កងពលធំ ២៩០-៤៤១ នាក់

(៥) កងពលធំ ៣១០-១១១៧ នាក់

(៦) កងពលធំ ៤៥០-៥០៩ នាក់

---

472 ឯកសារ D114/230.1.1 បញ្ជីអ្នកទោស ស-២១ របស់ ក.ស.ច.ស បង្ហាញថាអ្នកទោសមួយចំនួនខាងក្រោមនេះ "ចាប់ខ្លួនពី" កងពល កងវរសេនាធំ និងមន្ទីរផ្សេងទៀតដែលមានកងទ័ពបដិវត្តន៍កម្ពុជា ហើយមេដឹកនាំរបស់ពួកគេបានចូលរួមជាមួយ មាស មុត នៅក្នុងកិច្ចប្រជុំលេខាកងពល៖ កងពល ១៦៤ – អ្នកទោស ស-២១ ចំនួន ៦៧ នាក់, កងពល ១១៧ – អ្នកទោស ៥ នាក់, កងពល ១៧០ – អ្នកទោស ស-២១ ចំនួន ៤០៣ នាក់, កងពល ២៩០ – អ្នកទោស ៤៤១ នាក់, កងពល ៣១០ – អ្នកទោស ១ ១១៧ នាក់, កងពល ៤៥០ – អ្នកទោស ៥០៩នាក់, កងពល ៥០២ – អ្នកទោស ៣៥៧ នាក់, កងពល ៧០៣ – អ្នកទោស ៦៧៦ នាក់, កងពល ៨០១ – អ្នកទោស ៣៥ នាក់, កងពល ៩២០ – អ្នកទោស ៣៩៥នាក់, កងវរសេនាធំ ១៥២ – អ្នកទោស ២៩១ នាក់, កងវរសេនាធំ ៣៧៧ – អ្នកទោស ៥៣ នាក់, កងវរសេនាធំ ៤៨៨ – អ្នកទោស ៧៧នាក់, អគ្គសេនាធិការ– អ្នកទោស ៤៥៣ នាក, ស-២១៖ អ្នកទោស ៣៤ នាក់។

(៧) កងពលធំ ៥០២-៣៥៧នាក់

(៨) កងពលធំ ៧០៣-៦៧៦ នាក់

(៩) កងពលធំ ១៦៤-៦៧នាក់ (**ឧបសម្ព័ន្ធ** D.1)

(១០) កងពលធំ ១១៧- ៦ នាក់ (**ឧបសម្ព័ន្ធ** D.2)

(១១) កងពលធំ ៨០១- ៣៥នាក់

(១២) កងពលធំ ៩២០-៣៩៥ នាក់

(១៣) កងពលធំ ១៥២- ២៩១ នាក់

(១៤) កងវរសេនាធំ ៣៧៧-៥៣នាក់

(១៥) កងវរសេនាធំ ៤៨៨-៧៧នាក់

*ខ) តំបន់កំពង់សោម និងតំបន់ ៥០៥*

173. **មាស មុត** ក៏ទទួលខុសត្រូវផងដែរចំពោះការបញ្ជាឲ្យចាប់ខ្លួន ឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់មនុស្សចំនួន ៦៣៣ ដូចខាងក្រោម ដែលមនុស្សក្រោមបង្គាប់របស់គាត់ បានចាប់ខ្លួននៅតំបន់កំពង់សោម និងតំបន់ក្រចេះ ព្រមទាំងក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ និងនៅតាមបណ្តាកោះរបស់ខ្លួន និងបានបញ្ជូនទៅ ស-២១។

(១) កងពលធំ ១ & ២- ២ នាក់ (**ឧបសម្ព័ន្ធ** D.3)

(២) តំបន់ ៥០៥-២៦ នាក់ (**ឧបសម្ព័ន្ធ** D.4)

(៣) ប្រជាជនវៀតណាម-១៩៤ នាក់ (**ឧបសម្ព័ន្ធ** D.5)

(៤) ប្រជាជនថៃ-៥៨ នាក់ (**ឧបសម្ព័ន្ធ** D.6)

(៥) ប្រជាជនលោកខាងលិច-៨នាក់ (**ឧបសម្ព័ន្ធ** D.7)

(៦) អតីត លន់ នល់-២១ នាក់ (**ឧបសម្ព័ន្ធ D.8**)

(៧) តំបន់កំពង់សោម-ប្រជាជនស៊ីវិល ៧៣ នាក់ (**ឧបសម្ព័ន្ធ D.9**)

(៨) ផែកំពង់សោម-កម្មករចំនួន ២៥១ នាក់ (**ឧបសម្ព័ន្ធ D.10**)

174. តាមរយៈចម្លើយជាលាយលក្ខណ៍អក្សរ និងដោយផ្ទាល់មាត់របស់ **មាស មុត** ដែលបង្ហាញអំពីចេតនារបស់គាត់ក្នុងការធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្មាំងផ្ទៃក្នុង ជនបរទេស ដោយរួមបញ្ចូលប្រជាជនវៀតណាម ថៃ និងជនជាតិលោកខាងលិច និងបុគ្គលដទៃដែលត្រូវបានចាត់ទុកថាមានលក្ខណៈជាខ្មាំង ការគ្រប់គ្រងប្រកបដោយសុវត្ថិភាពរបស់គាត់លើមនុស្សក្រោមបង្គាប់ក្នុងកងពលធំ ១៦៤ និង ១១៧ និងក្នុងតំបន់ ៥០៥ ព្រមទាំងសមត្ថកិច្ចរដ្ឋបាលក្នុងតំបន់កំពង់សោម និងការមកដល់ជាបន្តនៃខ្មាំងដែលត្រូវបានសង្ស័យពីកំពង់សោម ទៅ ស-២១ នៅពេញមួយរយៈកាលកម្ពុជាប្រជាធិបតេយ្យ **មាស មុត** ច្បាស់ជាបានបញ្ជា និងបានអនុញ្ញាតឲ្យមានការផ្ទេរមនុស្សទាំងនេះទៅ ស-២១។

175. **មាស មុត** ជាបុគ្គលដែលមានសិទ្ធិអំណាចខ្ពស់បំផុត ដោយទទួលខុសត្រូវដោយផ្ទាល់ចំពោះការចាប់ខ្លួន ការឃុំឃាំង ការផ្ដន្ទាទោស និងការសម្លាប់មនុស្សក្រៅប្រព័ន្ធតុលាការ ដែលត្រូវបានចាត់ទុកជាខ្មាំងផ្ទៃក្នុង ឬខ្មាំងខាងក្រៅក្នុងកងពលធំ ១៦៤ ក្នុងតំបន់កំពង់សោម ក្នុងដែនទឹក និងនៅលើកោះនានាដែលគាត់គ្រប់គ្រង និងក្នុងកងពលធំ ១ និងតំបន់ ៥០៥ ខណៈពេលដែលគាត់បានស្ថិតនៅទីនោះ។

176. ពីចម្លើយ របាយការណ៍ និងការប្រាស្រ័យទាក់ទងទាំងអស់ដែល **មាស មុត** បានធ្វើទៅកាន់ថ្នាក់ក្រោម និងថ្នាក់លើរបស់គាត់ និងដែលត្រូវបានធ្វើមកគាត់ និងពីសកម្មភាពរបស់គាត់ពេញមួយរយៈកាលកម្ពុជាប្រជាធិបតេយ្យ មានភាពជាក់ស្ដែងដែលថា **មាស មុត** បានអនុវត្តដោយចេតនា និងដោយសេចក្ដីសាទរនូវគោលនយោបាយ ប.ក.ក នៃការធ្វើទុក្ខបុកម្នេញ និងការសម្លាប់ "ខ្មាំង" ដោយគ្មានដំណើរការច្បាប់ និងបានមានចេតនាឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ។ ទោះបីជាមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើកម្លាំងក្រោមបញ្ជារបស់គាត់ក៏ដោយ ក៏ **មាស មុត** បានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះតាមរយៈសហឧក្រិដ្ឋកម្មរួម ព្រមទាំងបានរៀបចំផែនការ ញុះញង់ បញ្ជា និងជួយជំរុញដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ។

## ការចូលរួមក្នុងការដាក់ជាទាសករនៅតាមការដ្ឋាន

<u>ទិដ្ឋភាពទូទៅ</u>

177. **មាស មុត** ជាមនុស្សដែលមានសិទ្ធិអំណាចខ្ពស់បំផុត និងបានបង្កើតគោលនយោបាយទាំងអស់នៅតាមការដ្ឋានដែលស្ថិតក្នុងតំបន់កំពង់សោម ដែលប្រជាជនស៊ីវិល និងទាហានដែលគាត់មិនចូលចិត្ត ត្រូវបានបង្ខំឱ្យធ្វើការងារពលកម្មក្រោមលក្ខខណ្ឌ ដែលបានបំពេញធាតុផ្សំទាំងអស់នៃឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃការដាក់ជាទាសករ។ កម្លាំងក្រោមការគ្រប់គ្រង និងសិទ្ធិអំណាចរបស់ **មាស មុត** និងដោយអនុវត្តតាមបញ្ជារបស់គាត់ បានអនុវត្តសិទ្ធិអំណាចជាម្ចាស់លើប្រជាជនស៊ីវិល និងបានរំសាយកងកម្លាំងយោធា ដែលត្រូវបានបង្ខំឱ្យធ្វើការងារពលកម្មដោយគ្មានការទូទាត់សង និងក្រោមលក្ខខណ្ឌអមនុស្សធម៌ នៅតាមការដ្ឋានទាំងនេះ។ កម្លាំងរបស់ **មាស មុត** បានដកហូតពលករនូវសិទ្ធិជាសារវ័ន្តទាំងអស់ និងបានចាត់ទុកពួកគាត់ជារបស់ដែលប្រើហើយអាចបោះចោលបាន។

### *ក) ការអនុវត្តរបស់ មាស មុត នូវគោលនយោបាយនៃការដាក់ជាទាសករ*

178. នៅចន្លោះខែ មិថុនា ដល់ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ **មាស មុត** បានចូលរួមប្រជុំ ក.ប.ក ថ្នាក់ខ្ពស់យ៉ាងហោចណាស់ចំនួន ៥ លើក ដែលក្នុងនោះគោលនយោបាយ និងគោលដៅផលិតកម្ម ត្រូវបានពិភាក្សា[473]។ នៅតាមអង្គប្រជុំទាំងនេះ សុន សេន បានប្រកាសអំពីផែនការ ប.ក.ក ទាក់ទងការ

---

[473] ឯកសារ D1.3.8.2 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ១៩៧៦ KH ERN 00162480។ ឯកសារ D1.3.8.3 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ១៩៧៦ KH ERN 00021497-500។ ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00052396-400។ ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH ERN 00052412-15។ ឯកសារ D1.3.27.22 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ KH ERN 00088932-35។ សូមមើលផងដែរ ឯកសារ D22.2.180 កិច្ចសម្ភាសន៍របស់កាសែតភ្នំពេញប៉ុស្តិ៍ជាមួយ មាស មុត, មាស មុត៖ "យើងស្ថិតនៅក្នុងទ្រុងដូចសព្វថ្ងៃ" ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១ EN ERN 00161880 ["ស៖ តាមរបាយការណ៍ លោកបានចូលរួមកិច្ចប្រជុំអគ្គសេនាធិការជាច្រើន ជាមួយ [អតីតរដ្ឋមន្ត្រីការពារជាតិរបស់ខ្មែរក្រហម] សុន សេន ដែលគាត់បានបង្ហាញពីគោលនយោបាយចំពោះខ្មាំងរបស់របបនោះ។ ឆ៖ ពេលខ្ញុំចូលរួមកិច្ចប្រជុំទាំងនោះ វាគ្រាន់តែជាការពិភាក្សាអំពីការផលិតស្រូវតែប៉ុណ្ណោះ [...] ដូចខ្ញុំបានប្រាប់លោកអ៊ីចឹង នៅក្នុងកិច្ចប្រជុំដែលខ្ញុំចូល

កសាងជាតិ និងបានណែនាំមេបញ្ញាការឃោធាអំពី "ចលនាមហាលោតផ្លោះ"[474]។ គាត់បានណែនាំអំពីផលិតកម្មស្រូវ ការលើកទំនប់ ព្រមទាំងរបបអាហារ[475] ដោយបានពន្យល់ថា "ភារកិច្ចរបស់ពួកគាត់គឺបង្កើនផលិតកម្មឱ្យបានបីតោនក្នុងមួយហិកតា និងពង្រីកប្រព័ន្ធប្រឡាយឱ្យបានសាមសិបភាគរយ"[476]។ **មាស មុត** ពុំបានស្ទាក់ស្ទើរក្នុងការអនុវត្តគោលដៅផលិតកម្ម ប.ក.ក ដែលមិនប្រាកដនិយម បើទោះជាគាត់ដឹងថា ផែនការទាំងនោះអាចត្រូវបានសម្រេចតាមរយៈការដាក់ប្រជាជនជាទាសករក្រោមការគ្រប់គ្រងរបស់គាត់។

179. **មាស មុត** បានអនុវត្តគោលនយោបាយផលិតកម្មដោយប្រើប្រាស់សិទ្ធិអំណាចរបស់គាត់ ជាលេខាកងពលធំ ១៦៤ និងតំបន់ស្វយ័តកំពង់សោម។ គាត់បានគាំទ្រជាសាធារណៈ "ផែនការថ្មី*របស់អង្គ*

រួមជាមួយ សុន សេន យើងពិភាក្សាថា តើវាមានស្រូវគ្រប់គ្រាន់ ឬអត់"]។ ឯកសារ D54/37 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.30-31 ["ស៖ តើលោកធ្លាប់ឮថា មាស មុត ធ្វើការអគ្គសេនាធិការដែរឬទេ? ឆ.30៖ បាទ ខ្ញុំឮ។ គាត់ត្រូវប្រជុំមួយខែម្តងជាមួយសេនាធិការនៅភ្នំពេញ។ ស៖ ហេតុម៉េចបានជាលោកដឹងអំពីរឿងនេះ ឆ.31៖ ខ្ញុំដឹងដោយសារប្រធានរបស់ខ្ញុំ គ្រិន ក៏បានទៅចូលរួមប្រជុំនោះដែរ"]។

474 ឯកសារ D1.3.8.2 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ១៩៧៦ KH ERN 00162481 [សុន សេន៖ "ខ - កសាងប្រទេស៖ ភារកិច្ចយើង បង្កើតផលឱ្យបាន ៣ តោន ១ ហិកតា លើកប្រព័ន្ធភ្លឺឱ្យបាន ៣០ ភាគរយ។ ចលនាមហាលោតផ្លោះ ខ្លាំងនៅជនបទហើយ ចលនាធ្វើព្រែកជីក ចលនាធ្វើប្រឡាយ ចលនាលើកប្រព័ន្ធភ្លឺ ខ្លាំងក្លាណាស់"]។ សូមមើលផងដែរ ឯកសារ D1.3.8.3 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ១៩៧៦ KH ERN 00021497-500។ ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00052396-400។ ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំ របស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH ERN 00052412-15។ ឯកសារ D1.3.27.22 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ KH ERN 00088932-35។

475 ឯកសារ D1.3.8.2 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ១៩៧៦ KH ERN 00162481។ ឯកសារ D1.3.8.3 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ១៩៧៦ KH ERN 00021497-500។ ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00052396-400។ ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH ERN 00052412-15។ ឯកសារ D1.3.27.22 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ KH ERN 00088932-35។

476 ឯកសារ D1.3.8.2 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ១៩៧៦ KH ERN 00162481។

*ការ* ទាក់ទងផលិតកម្មនៅទូទាំងកំពង់សោម[477] បានចេញបញ្ជាទៅបុគ្គលិកកងពលធំ ១៦៤ ទាក់ទងការចាត់ចែងការងារ[478] បានជួបជាមួយប្រធានសហករណ៍ជាទៀងទាត់[479] បានសម្រប

[477] ឯកសារ D114/6 កំណត់ហេតុស្ដាប់ចម្លើយ យិន តេង ឆ.31-34 ["តាមខ្ញុំដឹង មេភូមិទៅប្រជុំជាមួយ តាមុត នៅកន្លែងគាត់រៀងរាល់ថ្ងៃ មុនពេលគាត់មកប្រជុំជាមួយយើងនៅតាមភូមិនៅម៉ោង ១១ ព្រឹក។ ស៖ តើលោកស្រីដឹងថា មេភូមិទៅប្រជុំជាមួយ តាមុត ដោយសារអ្វី? ឆ.32៖ ពីព្រោះគេប្រាប់នៅពេលប្រជុំរាល់ថ្ងៃថា អង្គការឱ្យធ្វើនេះធ្វើនោះ។ ស៖ តើមេភូមិបាននិយាយថា គាត់បានចូលរួមប្រជុំជាមួយ តាមុត ដែរឬទេ? ឆ.33៖ ចាស គេបានប្រកាសប្រាប់ពួកខ្ញុំថា គាត់បានប្រជុំជាមួយ តាមុត និងប្រាប់អំពីផែនការថ្មីៗរបស់អង្គការ។ ស៖ តើមេភូមិគាត់ប្រាប់ថា គាត់បានប្រជុំជាមួយ តាមុត ញឹកញាប់ដែរឬទេ? ឆ.34៖ ខ្ញុំមិនដឹងថា គេនិយាយយការពិត ឬកុហកនោះទេ ដែលថា គាត់បានប្រជុំជាមួយ តាមុត ១ ខែម្ដង"]។ ឯកសារ D59/1/4.25 កិច្ចសម្ភាសន៍ជាមួយ ឡុង លី KH ERN 00930812 ["ធ្វើការតែជាមួយគ្នា កន្លែងធ្វើការគាត់ [មុត] នៅឆ្ងាយពីយើងអ៊ីចឹងទៅ យើងនៅសហករណ៍នេះ ដល់ពេលគាត់មានការអី គាត់ឱ្យនីរសារគាត់យកសំបុត្រមកឱ្យ ថ្ងៃនេះយើងប្រជុំ ឬថ្ងៃនេះ យើងអី ទៅតាមណាត់"]។

[478] ឯកសារ D114/215 កំណត់ហេតុស្ដាប់ចម្លើយ មាស អ៊ឹម ឆ.66-67, 70, 75-76 ["ស៖ ពាក់ព័ន្ធនឹងការងារនៅការដ្ឋាន តើឈ្មោះ មៀញ នេះ ធ្លាប់ទទួលការណែនាំពីណាមកវិញដែរ? ឆ.66៖ ពីមុនមក គាត់ទទួលបញ្ជាផ្ទាល់ពី មាស មុត ហ្នឹង។ ស៖ ពាក់ព័ន្ធនឹងការងារការដ្ឋាន តើលោកអាចពន្យល់បានទេថា លោក មាស មុត អាចណែនាំដល់ឈ្មោះ មៀញ យ៉ាងដូចម្ដេចខ្លះ? ឆ.67៖ យើងក្ដាប់អត់បានទេ យើងអត់ដឹងពីការណែនាំពី មាស មុត ទៅ មៀញ ផ្នែកនយោបាយយើងអត់ដឹងទេ។ យើងទទួលបានការណែនាំពីលោក មៀញ តាមរយៈ មាស មុត តែខាងបច្ចេកទេស។ [...] ស៖ តើការងារបច្ចេកទេសអ្វីខ្លះ ពាក់ព័ន្ធនឹងការងារលោក ដែលបងប្រុសលោកផ្ដល់មកខាងលោក តាមរយៈលោក មៀញ នោះ? ឆ.70៖ ការងារបច្ចេកទេសទី ១ ធ្វើផ្លូវ។ ផ្លូវធ្វើពីរោងចក្រប្រេងកាតមកដល់ស្ទឹងហាវ។ ទី ២ សាងសង់ផ្លូវចុះឡើងក្នុងការដ្ឋានស្ទឹងហាវហ្នឹង ហើយនិងឈូសពីជើងភ្នំនៅមាត់សមុទ្រស្ទឹងហាវហ្នឹងឱ្យទៅជារាបស្មើ។ [...] ស៖ តើបងប្រុសលោកប្រាស្រ័យទាក់ទងគ្នាជាមួយឈ្មោះ មៀញ ដោយរយៈមធ្យោបាយអ្វីដែរ? ឆ.75៖ ដោយមធ្យោបាយតេអូ ហើយនិងទូរលេខ ស៖ ហេតុអីបានលោកដឹង? ឆ.76៖ បើនៅផ្ទះ មៀញ ហ្នឹង ខ្ញុំនៅជិតហ្នឹងដែរ ហើយឃើញប្រដាប់ប្រដាហ្នឹង"]។ ឯកសារ D114/175 កំណត់ហេតុស្ដាប់ចម្លើយ នាក់ ស៊ីថា ឆ.20, 48, 51-53, 56-57 ["ស៖ តើលោកស្រីអាចរៀបរាប់បន្ថែមបានទេ ពីពាក្យដែលលោកស្រីប្រើ "ជាការដ្ឋានក្ដៅគគុក" តើស្ថានភាពការងារយ៉ាងម៉េចដែរ? ឆ.20៖ កន្លែងហ្នឹងជាកន្លែងគេធ្វើការ គាប់ដី ធ្វើស្រែ ស្ទូង ច្រូត អត់មានពេលឈប់។ [...] ស៖ តើលោកស្រីបានឮអ្វីខ្លះដែរអំពី មាស មុត នៅក្នុងសម័យខ្មែរក្រហម? ឆ.48៖ គេថា មាស មុត និយាយថា "ឱ្យយើងហ្នឹងធ្វើការងារទៅ បើធ្វើការមិនទាន់ទេ ផ្លូវបត់ហ្នឹង កង់ប្រវត្តិសាស្រ្តកិនហើយ" (ដើមបណ្ដឹងរដ្ឋប្បវេណីបង្ហាញអំពីផ្លូវបត់ គឺដូចនឹងកន្លែងកែងដែបត់)។ កង់ប្រវត្តិសាស្ត្រម៉េចទេ នាំគ្នាភ័យណាស់។ ស៖ ក្នុងសំណួរចម្លើយទី ១៥ យើងបានសួរលោកស្រីអំពីអ្នកទទួលខុសត្រូវនៅព្រៃនប់ និងកន្លែងផ្សេងៗទៀត ដែលលោកស្រីធ្លាប់ធ្វើការ ហើយលោកស្រីបញ្ជាក់ថា លោកស្រីមិនស្គាល់ពួកគេទេ។ តើលោកស្រីគិតថា ទីតាំងនេះមានជាប់ពាក់ព័ន្ធនឹង មាស មុត ដែរឬទេ ក្រោយពីយើងចាប់ផ្ដើមនិយាយពីឈ្មោះ មាស មុត នេះ? ឆ.51៖ មាស មុត គេមេបញ្ជាការតំបន់។ ស៖ ប្រាប់យើងបន្ថែម អ្វីដែលលោកស្រីដឹង? ឆ.52៖ គាត់មេគេ គាត់បញ្ជាគេឱ្យធ្វើការ។ ស៖ តើលោកស្រីកំពុងតែប្រាប់យើង

សម្រួលជាមួយប្រធានភូមិទាក់ទងផែនការសម្រាប់តំបន់[480]។ មនុស្សក្រោមបង្គាប់របស់ **មាស មុត** ជាញឹកញាប់បាននិយាយអំពីឈ្មោះរបស់គាត់ នៅឯអង្គប្រជុំនានាដែលផែនការអំពីការងារ

---

ថា មាស មុត អាចទទួលខុសត្រូវតំបន់ ឬក៏ទីតាំងនានា ដែលលោកស្រីធ្លាប់ធ្វើការមែនទេ? ឆ.53៖ ចាស។ [...] ស៖ លោកស្រីថា មិនដែលបានជួបមុខ មាស មុត ទេ ហើយពាក្យ "កង់ប្រវត្តិសាស្ត្រ" ហេតុអ្វីបានលោកស្រីដឹងថាជាពាក្យរបស់ មាស មុត? ឆ.56៖ ចុះបើកងចល័តជាមួយគ្នានិយាយតៗមកអ៊ីចឹងមក។ ពាក្យហ្នឹងគេប្រជុំតាមមូលដ្ឋាន ហើយគេនិយាយពេលប្រជុំជាមួយចាស់ៗ ដូចម៉ែឪខ្ញុំហ្នឹង ដោយគេថា កង់ប្រវត្តិសាស្ត្រ កុំខ្ជិលច្រអូស ខិតខំធ្វើការ ហើយខ្ញុំសួរវិញថា កង់ប្រវត្តិសាស្ត្រហ្នឹងម៉េចម៉ែ។ ស៖ ហេតុអ្វីបានលោកស្រីជឿជាក់ថា ពាក្យនេះចេញមកពីមាត់របស់ មាស មុត? ឆ.57៖ មាស មុត បើកអង្គសន្និបាត គេនិយាយ។ កាលនោះ ១ ខែ គេបើកម្តង។ ខ្ញុំមិនបានចូលរួមប្រជុំទេ ព្រោះខ្ញុំនៅកងចល័ត"]។

479 ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.31-34 ["តាមខ្ញុំដឹង មេភូមិទៅប្រជុំជាមួយ តាមុត នៅកន្លែងគាត់រៀងរាល់ថ្ងៃ មុនពេលគាត់មកប្រជុំជាមួយយើងនៅតាមភូមិនៅម៉ោង ១១ ព្រឹក។ ស៖ តើលោកស្រីដឹងថា មេភូមិទៅប្រជុំជាមួយ តាមុត ដោយសារអ្វី? ឆ.32៖ ពីព្រោះគេប្រាប់នៅពេលប្រជុំរាល់ថ្ងៃថា អង្គការឱ្យធ្វើនេះធ្វើនោះ។ ស៖ តើមេភូមិបាននិយាយថា គាត់បានចូលរួមប្រជុំជាមួយ តាមុត ដែរឬទេ? ឆ.33៖ ចាស គេបានប្រកាសប្រាប់ពួកខ្ញុំថា គាត់បានប្រជុំជាមួយ តាមុត និងប្រាប់អំពីផែនការថ្មីៗរបស់អង្គការ។ ស៖ តើមេភូមិគាត់ប្រាប់ថា គាត់បានប្រជុំជាមួយ តាមុត ញឹកញាប់ដែរឬទេ? ឆ.34៖ ខ្ញុំមិនដឹងថា គេនិយាយការពិត ឬកុហកនោះទេ ដែលថា គាត់បានប្រជុំជាមួយ តាមុត ១ ខែម្តង"]។ ឯកសារ D59/1/4.25 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡុង លី KH ERN 00930812 ["ធ្វើការតែជាមួយគ្នា កន្លែងធ្វើការគាត់ [មុត] នៅឆ្ងាយពីយើងអ៊ីចឹងទៅ យើងនៅសហករណ៍នេះ ដល់ពេលគាត់មានការអី គាត់ឱ្យនីរសារគាត់យកសំបុត្រមកឱ្យ ថ្ងៃនេះយើងប្រជុំ ឬថ្ងៃនេះ យើងអីទៅតាមណាត់"]។ សូមមើលផងដែរ ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ន សុត ឆ.40-43 ["ចឹក៏មិនដឹង ពេលធ្វើខុសគេប្រាប់ថាអ៊ីចឹង។ គេប្រជុំប្រាប់ថា "មិត្តឯងប្រយ័ត្នណា តែមិត្តឯងតែធ្វើខុស គេបញ្ជូនទៅទឹកសាបហើយ"។ ស៖ តើលោកចាំថា អ្នកណានិយាយបែបហ្នឹងដែរទេ? ឆ.41៖ អាហ្នឹងគ្នាយើងចេះតែដឹង ចេះតែឮបន្តិចៗអ៊ីចឹងទៅហើយអ្នកនិយាយគឺជាមេក្រុមៗនៅក្នុងសហករណ៍ ។ ពួកគេនិយាយប្រាប់យើងត្រង់ៗអ៊ីចឹង ប៉ុន្តែខ្ញុំមិនដែលបានឃើញដោយផ្ទាល់ទេ។ ស៖ តើមេក្រុមនោះស្ថិតនៅក្រោមបញ្ជារបស់អ្នកណាដែរ? ឆ.42៖ នៅក្រោមបញ្ជារបស់ តាមុត ដែរ។ ស៖ ក្នុងឋានៈជាមេក្រុម គឺស្ថិតនៅឆ្ងាយណាស់ពី តាមុត តើហេតុអ្វីបានជាលោកនិយាយបែបនេះ? ឆ.43៖ គឺមាននីរសារមកពីកំពង់សោមមកដល់សហករណ៍"]។

480 ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.30-ឆ.35 [ពិភាក្សាអំពីកិច្ចប្រជុំនៅភូមិថ្មធំ ៖ "ស៖ តើអ្នកណាជាអ្នកដឹកនាំការប្រជុំនោះ? ឆ.30៖ ប្រធានភូមិ។ ស៖ តើមេភូមិដឹកនាំប្រជុំរៀងរាល់ថ្ងៃឬ? ឆ.31៖ ចាស រៀលរាល់ថ្ងៃ។ តាមខ្ញុំដឹង មេភូមិទៅប្រជុំជាមួយ តាមុត នៅកន្លែងគាត់រៀងរាល់ថ្ងៃ មុនពេលគាតមកប្រជុំជាមួយយើងនៅតាមភូមិនៅម៉ោង ១១ ព្រឹក។ ស៖ តើលោកស្រីដឹងថា មេភូមិទៅប្រជុំជាមួយ តាមុត ដោយសារអ្វី? ឆ.32៖ ពីព្រោះគេប្រាប់នៅពេលប្រជុំរាល់ថ្ងៃថា អង្គការឱ្យធ្វើនេះធ្វើនោះ។ ស៖ តើមេភូមិបាននិយាយថា គាត់បានចូលរួមប្រជុំជាមួយ តាមុត ដែរឬទេ? ឆ.33៖ ចាស គេបានប្រកាសប្រាប់ពួកខ្ញុំថា គាត់បានប្រជុំជាមួយ តាមុត និងប្រាប់អំពី

ពលកម្មដោយបង្ខំត្រូវបានពិភាក្សា[481]។ ក្នុងអង្គប្រជុំទាំងនោះ ប្រធានភូមិបានប្រាប់អ្នកចូលរួមថា "បញ្ជារបស់ **មាស មុត** ត្រូវតែធ្វើតាម អនុវត្ត និងគោរព។ បើមិនដូច្នោះ នឹងអាចមានបញ្ហា"[482]។

180. **មាស មុត** បានធ្វើដំណើរទៅបណ្តាកោះនានាដើម្បី "ធ្វើឱ្យប្រាកដថាសេចក្តីសម្រេចរបស់បក្ស ត្រូវបានអនុវត្តដោយជោគជ័យ"[483] "បានធ្វើដំណើរឡើងចុះដើម្បីឃ្លាំមើលអង្គភាពយោធានីមួយៗ ក្នុងកងពលធំនេះ"[484] និងបានគ្រប់គ្រងការដើរហើររបស់មនុស្សទាំងឡាយ ដែលស្ថិតក្រោមសិទ្ធិ

---

ផែនការថ្មីៗរបស់អង្គការ។ សៈ តើមេភូមិគាត់ប្រាប់ថា គាត់បានប្រជុំជាមួយ តាមុត ញឹកញាប់ដែរឬទេ? ឆ.34៖ ខ្ញុំមិនដឹងថា គេនិយាយយកការពិត ឬកុហកនោះទេ ដែលថា គាត់បានប្រជុំជាមួយ តាមុត ១ ខែម្តង។ សៈ តើមេភូមិដែលបង្គាប់ ឬក៏ដាក់បញ្ជាចេញពី តាមុត ដែរឬទេ? ឆ.35៖ ទេ ពួកគេមិនបាននិយាយឈ្មោះ តាមុត ទេ មេភូមិខ្លួនឯងជាអ្នកប្រាប់ថា ប្រជាជនត្រូវលើកដី ១ ម៉ែត្រគូប ក្នុងម្នាក់ឱ្យហើយក្នុង១ ថ្ងៃ"]។

481 ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.153, 164 ["គេប្រជុំនិយាយអំពីផែនការ គេឱ្យយើងលើកប្រឡាយ ដាំដំណាំ ពង្រឹងជំហរ។ ក្នុងរយៈពេល ២ ឬ ៣ អាទិត្យ គេលើកឈ្មោះ តាមុត មកនិយាយម្តង [...] សៈ តើគេបាននិយាយអំពីឈ្មោះ តាមុត ដែរឬទេ នៅក្នុងការប្រជុំទាំងនោះ? ឆ.164៖ ការប្រជុំក្នុងចំណោមប្រជុំជនធម្មតា គឺមិនមានលើកពីឈ្មោះ តាមុត ទេ។ តែបើការប្រជុំក្នុងចំណោមកម្មាភិបាល គេលើកពីឈ្មោះ តាមុត។ ខ្ញុំដឹងរឿងនេះពីព្រោះខ្ញុំធ្វើការនៅចម្ងាយប្រហែលកន្លះគីឡូម៉ែត្រពីកន្លែងប្រជុំ"]។

482 ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.153-154 ["សៈ លោកស្រីបាននិយាយថា បានចូលរួមប្រជុំរាល់ថ្ងៃហ្នឹង។ តើគេនិយាយអំពីឈ្មោះ តាមុត ញឹកញាប់ដែរឬទេ នៅក្នុងពេលប្រជុំទាំងនោះ? ឆ.153៖ ប្រជុំនិយាយអំពីផែនការ គេឱ្យយើងលើកប្រឡាយ ដាំដំណាំ ពង្រឹងជំហរ។ ក្នុងរយៈពេល ២ ឬ ៣ អាទិត្យ គេលើកឈ្មោះ តាមុត មកនិយាយម្តង។ សៈ តើគេនិយាយអ្វីខ្លះពីឈ្មោះ តាមុត នេះ? ឆ.154៖ គេនិយាយថា បញ្ជា តាមុត ត្រូវតែធ្វើតាម ត្រូវតែអនុវត្តតាម ត្រូវតែគោរព បើមិនដូច្នោះទេ អាចនឹងមានបញ្ហាកើតឡើង"]។

483 ឯកសារ D1.3.30.2 ទូរលេខពី មុត (មាស មុត) ជូន បង ៨៩ (សុន សេន) ថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៧៦ KH ERN 00021446 [មាស មុត៖ "ខ្ញុំនៅកោះរុង និងរុងក្រៅ ដើម្បីតាមដាន និងណែនាំអនុវត្តសេចក្តីសំរេចចិត្តនេះរបស់បក្សឱ្យមានប្រសិទ្ធភាព។ គ្រាប់ និងអង្ករនៅតាមកោះទាំងអស់ អាចធានាបាន ៦ ខែ តែដោយឡែកអង្ករវាផ្លូវបន្តិច ព្រោះអង្ករចាស់ដែរ"]។ សូមមើលផងដែរ ឯកសារ D114/19 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.33-34 ["សៈ តើ មាស មុត ធ្លាប់ទៅមើលដល់កោះរបស់លោក ដើម្បីបញ្ជាក់ថា ការអនុវត្តផែនការបានត្រឹមត្រូវដែរឬទេ? ឆ.33៖ មាស មុតធ្លាប់ទៅដល់កោះខ្ញុំម្តង មុនពេលព្រឹត្តិការណ៍នេះ។ សៈ តើ មាស មុត នឹងធ្វើការពិនិត្យ ដើម្បីឱ្យដឹងច្បាស់ថាការណែនាំរបស់គាត់ និងរបស់បក្សត្រូវបានអនុវត្តត្រឹមត្រូវដែរឬទេ ឬយ៉ាងណា? ឆ.34៖ ក្នុងនាមជាមេបញ្ជាការទទួលខុសត្រូវរួម មាស មុត គាត់ត្រូវតែចង់ដឹងថា មានរឿងអ្វីខ្លះដែលកើតមានឡើងក្នុងកងពល។ ជាទូទៅ ខ្ញុំត្រូវរាយការណ៍ទៅឱ្យវរសេនាធំ ហើយវរសេនាធំបញ្ជូនបន្តទៅគាត់"]។

484 ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ឆ.12 ["សៈ តើលោកដឹងឬទេ នៅក្នុងឆ្នាំ ១៩៧៥ ក្នុងនាមជាមេបញ្ជាការកងពល តើមុខងារ និងការងាររបស់ មាស មុត មានអ្វីខ្លះ? ឆ.12៖ ក្នុងនាមជាមេបញ្ជាការកង ពល គាត់

អំណាចរបស់គាត់[485]។ លើសពីនេះ **មាស មុត** បានបញ្ជាទ័ពដែលត្រូវបានរំសាយឲ្យធ្វើការងារក្នុងកងផលិតកម្ម[486] និងបានប្រគល់សិទ្ធិអំណាចឲ្យប្អូនប្រុសរបស់គាត់ឈ្មោះ មាស អ៊ុម ដើម្បី

---

ទទួលខុសត្រូវរួមលើកងពល។ គាត់ធ្វើដំណើរចុះឡើង ដើម្បីពិនិត្យឲ្យដឹងថា កងពលនីមួយៗរបស់កងពលយ៉ាងម៉េចខ្លះ"]។

485 ឯកសារ D54/38.1 កំណត់ហេតុស្តាប់ចម្លើយ លុង សេង KH ERN 00967324 ["ស៖ ប៉ុនពេលដែលគេហៅទៅធ្វើប្រវត្តិរូបឆ្នាំប៉ុន្មាន? ឆ៖ ឆ្នាំ ១៩៧៦ៗហ្នឹងចេះ ខ្ញុំនេះគេប្រុកឲ្យមកលេងផ្ទះម្តង ឆ្នាំ ៧៦ ហ្នឹងខាងកងពលធំ មាស មុត ហ្នឹង គេសរសេរលិខិតអនុញ្ញាតិឲ្យខ្ញុំប៉ុនៗហ្នឹងឯង មួយក្រដាសរ៉ាមយើង គេបោះត្រា បោះអីហើយស្រេចហើយ។ ដល់ចឹងគេណែនាំចឹងថា ឲ្យខ្ញុំទៅមិនមែនឲ្យមកលេងផ្ទះ ទៅមើលមិត្តណាមួយនៅម្តុំនឹងទៀត គេណែនាំចឹង។ ប៉ុនដល់ចែដន្យអី អាអ្នកទៅលេងផ្ទះហ្នឹង ទៅដល់ឃើញគេធ្វើបាបឪពុកម្តាយ អ្នកមូលដ្ឋានធ្វើបាបឪពុកម្តាយរបស់ខ្លួនខ្លាំងពេក ក៏ទៅនាំអង្គភាពទៅវ៉ៃទីតាំង ទីចាត់ការគេហ្នឹងខ្ទេចខ្ទីមានរឿង។ ចុះវាខឹងនោះ ទៅកងទ័ពមកដល់គេធ្វើឪពុកម្តាយរលេមរហាម ដាក់ទោសដាក់ពៃរ៍អីក៏នាំគ្នាជាង ៤០ នាក់មកដល់វ៉ៃគេរត់របាត់របាយងាប់ខ្លះអីខ្លះ។ គេរករឿង គេមិនរាយការណ៍ព័ត៌មានគេជូនតាមអង្គភាពនោះ។ នោះគាត់ដឹង គាត់ហៅខ្ញុំមកនិយាយ ខ្ញុំថាឲ្យសេងឯងទៅហើយ នេះសំបុត្រ អនុញ្ញាតិឲ្យទៅហើយ ព្រោះខានទៅលេងផ្ទះយូរហើយ នឹកឪពុកម្តាយ បងប្អូនខ្ញុំអនុញ្ញាតិឲ្យទៅ ប៉ុនក្នុងហ្នឹងជាប់ភារកិច្ចឲ្យទៅដែរ សេង ឯងទៅមើលអ្នកនេះអ្នកនោះឲ្យខ្ញុំផង តាមដានប្រវត្តិយ៉ាងម៉េចៗ។ ទី ១ គេចង់ដឹងប្រវត្តិបើយើងល្អ គេជួយតំឡើងឋានៈនាទីយើង ទី ២ បើសិនណាមិនល្អ គេក៏ដឹង មិនដឹង"]។

486 ឯកសារ D54/44 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.19, 22 ["ស៖ ហេតុអ្វីបានជាលោកដឹងថា មានយោធា ១ ៥០០ នាក់មកពីភូមិភាគបូព៌ា គេយកទៅដាក់នៅកងផលិតធំ? ឆ.19៖ ប្រធានកងពល មាស មុត បានបើកការប្រជុំ ហើយប្រកាសថា ពួកយោធាទាំងអស់ដែលមកពីភូមិភាគបូព៌ា គឺជាយោធាដែលមានសមាសភាពមិនល្អ ដូច្នេះពួកគេត្រូវតែដកចេញឲ្យដាច់ពីកងពល [...] ស៖ កាលដែលកងពលបើកវគ្គប្រជុំរៀនសូត្រ ហើយប្រកាសប្រាប់ថា ពួកយោធាភូមិភាគបូព៌ា ជាសមាសភាពមិនល្អ តើលោកនៅទីនោះដែរឬទេ? ឆ.22៖ ខ្ញុំបានចូលរួមការប្រជុំដែរ បានខ្ញុំដឹង"]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.1 ["នៅពេលនោះ គេបានដកយោធាកង ៣៨៦ ទាំងអស់យកទៅដាក់នៅកងផលិត។ បន្ទាប់ពីគេដកអាវុធពីពួកយើងអស់ ពួកគេមិនអនុញ្ញាតឲ្យយើងទុកកាំបិតទេ យើងគឺអនុញ្ញាតឲ្យកាន់តែចប។ បន្ទាប់មក មាស មុត បានមកធ្វើមីទ្ទីងជាមួយពួកយើងនៅភូមិគគីរ នៅជិតប្រឡានយន្តហោះកងកេង ដោយមានអតីតយោធាចូលរួមប្រហែលរាប់ពាន់នាក់ ដោយមានកងវរសេនាតូច ៣៨៦ និងកងផ្សេងៗទៀត។ នៅក្នុងអង្គប្រជុំ មាស មុត អានចម្លើយសារភាពរបស់ពួកក្បត់ គាត់បានរៀបរាប់ឈ្មោះកម្មាភិបាលក្បត់ចាប់ពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់មូលដ្ឋាន"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.56, 60-61 ["ស៖ លោកនិយាយថា ពេលដែលលោកទៅដល់ដីគោក គេប្រជុំម្តងទៀត។ តើការប្រជុំនោះ នៅទីណា ហើយពេលណា? ឆ.56៖ គេបញ្ជូនមកហ្នឹង ឈប់នៅព្រលានយន្តហោះកងកេង ហើយគេប្រជុំនៅពេលព្រឹកហ្នឹង។ ហើយ មាស មុត ជាប្រធានអង្គជំនុំ [...] ឆ.60៖ [...]ប្រជុំពីបញ្ហាមេក្បត់ គឺអនុមេបញ្ញាការកងពល ១៦៤ នង ឆាន ជាអ្នកក្បត់ ហើយ មាស មុត អានចម្លើយសារភាពរបស់ នង ឆាន ហ្នឹង។ [...] ឆ.61៖ គាត់អត់និយាយអ្វីទៀតទេ គាត់បញ្ជូនពួកខ្ញុំទៅកងផលិតពេលប្រជុំចប់"]។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ

គ្រប់គ្រងការដ្ឋាន និងសហករណ៍នានាក្នុងតំបន់នេះ[487]។ អនុប្រធានរបស់ **មាស មុត** ឈ្មោះ ឌឹម និងសមាជិកដទៃទៀតនៃកងពលធំ ១៦៤ បានរាយការណ៍អំពីការដ្ឋានទាំងនោះដោយផ្ទាល់ទៅ

---

២០១៣ ឆ.6 ["ស៖ [...] លោកត្រូវបានគេសម្រាំងចេញ ដោយសារលោកមានប្រវត្តិរូបមិនល្អ។ ដូច្នេះហើយ បានគេបញ្ជូនលោកឱ្យទៅកន្លែងវាយថ្ម តើមែនឬទេ? ឆ.6៖ បាទ, វាបានកើតមានមកលើខ្ញុំអញ្ចឹងមែន"]។ សូមមើលផងដែរ ឯកសារ D54/15 របាយការណ៍សកម្មភាពស៊ើបអង្កេត KH ERN 00984853 ["[ប្រេស មាន] កំណត់អត្តសញ្ញាណមូលដ្ឋានកងទ័ពដែលនៅជិតការដ្ឋានវាយថ្មស្ទឹងហាវ ជាកន្លែងដែលគាត់បានសង្កេតពីការប្រជុំដែលរៀបចំដោយ មាស មុត នៅពាក់កណ្តាលឆ្នាំ ១៩៧៧ ដែលគាត់និយាយអំពីពួកក្បត់"]។

487 ឯកសារ D114/58 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.14, 16 ["មាស អ៊ីម មិនត្រឹមតែជាអ្នកទទួលខុសត្រូវនៅទំនប់ [ទំនប់អូរឈើទាល] នេះទេ គាត់ជាអ្នកមើលនៅការដ្ឋាននៅកងកេង (ការដ្ឋានស្រែ និងការដ្ឋានទំនប់ពូធឿន) ផងដែរ ហើយគាត់ជាអ្នកទទួលខុសត្រូវផ្នែកភស្តុភារនៅតំបន់នោះ។ [...] ឆ.16៖ មាស អ៊ីម ជាអ្នកទទួលខុសត្រូវគ្រប់ការដ្ឋានទាំងអស់ រួមទាំងការដ្ឋាននៅកងកេងផង"]។ ឯកសារ D54/20 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ. 14 ["ខ្ញុំទៅធ្វើស្រែនៅកងចល័តបិតក្រោម តាអ៊ឹម។ តាអ៊ឹម ជាកម្មាភិបាលជាន់ខ្ពស់បន្ទាប់ពី មាស មុត។ អ៊ឹម ជាអ្នកមើលការងារនៅការដ្ឋានកងកេង ហើយគាត់ជាអនុមេបញ្ជាការកងពល ១៦៤ ទទួលបន្ទុកភស្តុភារ"]។

**មាស មុត**[488] ដែលបានជូនដំណឹងមជ្ឈិមបក្សអំពីការវិវត្តន៍របស់កងពលធំរបស់គាត់ តាមរយៈការប្រជុំ[489] ការប្រាស្រ័យទាក់ទងការងារជាលាយលក្ខណ៍អក្សរ[490] និងរបាយការណ៍ប្រចាំខែ[491]។

---

488 ឯកសារ D4.1.699 ទូរលេខពី ខឹម ជូន បងមុត (មាស មុត) ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00092628 ["សភាពស្រូវនៅគ្រប់កន្លែង មានការរីកចំរើន តែនៅកងកេងមានទឹកជ្រូវ ១២ ហិកតា ប៉ុន្តែបងប្អូន [យុទ្ធជន] កំពុងប្រយុទ្ធសង្គ្រោះ ហើយចំពោះដីចំការកាប់ហើយតាមផែនការកំណត់ភ្ជួរហើយមួយសារ ប៉ុន្តែត្រូវភ្ជួររាស់ទៀត"]។ ឯកសារ D1.3.34.14 ទូរលេខពី ខឹម ជូន មុត (មាស មុត) ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៧៦ KH ERN 00000866 ["ស្រែរបស់យើង ជាទូទៅ គ្មានទាន់ប្រែប្រួលអ្វីធំដុំទេ ភ្លៀងធ្លាក់ ២ ដង ពីរនេះ"]។ ឯកសារ D1.3.14.2 ទូរលេខពី មឿន ជូន បងមុត (មាស មុត) ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៧៧ KH ERN 00161788-89។ ឯកសារ D1.3.34.39 ទូរលេខពី រឿន ជូន បងមុត (មាស មុត) ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ KH ERN 00161791 ["សភាពការណ៍ស្រូវស្រែឥឡូវនេះ យើងកំពុងតែច្រូតស្រូវប្រែតទៅទៀត ព្រោះស្រូវមានការទំបន្តជាប់ ខាងជើងថ្នល់ ក៏ដូចខាងត្បូងថ្នល់ ផ្នែកបញ្ហាវាំងស្ងួត យើងកំពុងតែមានវិធានការ និងបាចស្រែណាដែលមានសភាពស្ងួត ឯក្រៅពីនេះចំពោះទឹក មិនមានបញ្ហាអីចោទធ្ងន់ប៉ុន្មានទេ"]។ សូមមើលផងដែរ ឯកសារ D114/214 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.30, 32-33 ["ស៖ តើលោកចង់សំដៅទៅលើការដ្ឋានណាមួយដែរ [នៅស្ទឹងហាវ]? ឆ.30៖ ឈ្មោះ មៀញ [...] ស៖ តើឈ្មោះ មៀញ ត្រូវរាយការណ៍ជូនដល់ថ្នាក់លើកគាត់ឈ្មោះអីដែរ? ឆ.32៖ ឈ្មោះ មៀញ រាយការណ៍ទៅ មាស មុត ហ្នឹង ស៖ តើគាត់រាយការណ៍ទៅ មាស មុត ដោយផ្ទាល់តែម្តង? ឆ.33៖ បាទ ផ្ទាល់"]។ ឯកសារ D59/1/4.25 កិច្ចសម្ភាសន៍ជាមួយ ឡុង លី KH ERN 00930812 ["ស៖ អ៊ីចឹងមានការអីមកតាម អ៊ំញាន់ ហ្នឹងបាន អ៊ំញាន់ ទៅ អ៊ំមុត? ឆ៖ បាទ ទៅ អ៊ំមុត ទៅទៀត"]។

489 ឯកសារ D1.3.8.2 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ១៩៧៦ KH ERN 00162481។ ឯកសារ D1.3.8.3 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ១៩៧៦ KH ERN 00021497-500។ ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00052396-400។ ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH ERN 00052412-15។ ឯកសារ D1.3.27.22 កំណត់ហេតុកិច្ចប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ KH ERN 00088932-35។

490 ឯកសារ D1.3.30.2 របាយការណ៍ពី មុត (មាស មុត) ជូន បង ៨៩ (សុន សេន) ថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៧៦ KH ERN 00021446 [មុត រាយការណ៍អំពីចំនួន និងគុណភាពអង្ករនៅកោះរុង]។ ឯកសារ D4.1.1020 ទូរលេខពី មុត (មាស មុត) ជូន បង ៨៩ (សុន សេន) ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ KH ERN 00021459។ ឯកសារ D1.3.34.10 ទូរលេខពី មុត (មាស មុត) ជូន បង ៨៩ (សុន សេន) ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៧៦ KH ERN 00000860 ["ក្នុងខែ ៨ នេះ នៅកំពុងសោម មានភ្លៀងតែម្តងគត់ រហូតមកដល់ថ្ងៃនេះ។ ឥឡូវ [ប្រជាជន] បាចទឹកដាក់ស្រែវិញម្តងហើយ[ដោយដៃ]"]។ ឯកសារ D1.3.12.7 របាយការណ៍ពី កាន និង មុត (មាស មុត) ជូនបងជាទីគោរព ថ្ងៃទី ១៥ ខែកក្កដា-ថ្ងៃទី៣១ ខែ សីហា ឆ្នាំ ១៩៧៦ KH ERN 00021503 ។ ឯកសារ D1.3.4.1 សំបុត្រពី

181. កងពលធំ ១៦៤ របស់ **មាស មុត** បានសម្រេចគោលដៅផលិតកម្មស្រូវរបស់ខ្លួនមិនដែលខកខាន[492] និងត្រូវបាន **សុន សេន** ចាត់ទុកជាកងពលធំគំរូសម្រាប់ផលិតកម្មរបស់ខ្លួន[493]។ ប៉ុន្តែដើម្បីសម្រេចបានកូតាដែលបានកំណត់ **មាស មុត** បានអនុវត្តវិធានការដ៏គំហុកតាមរយៈការដាក់ជាទាសករ នូវប្រជាជនក្នុងតំបន់កំពង់សោម។ គាត់បានបង្ខំឱ្យប្រជាជនស៊ីវិល និងទាហានដែលត្រូវបានចាត់ទុកជា "សមាសភាពមិនល្អ" ឱ្យធ្វើការងារលំបាកក្នុងលក្ខខណ្ឌអមនុស្សធម៌នៅតាមការដ្ឋានក្នុងតំបន់រាម ព្រមទាំងនៅតាមបណ្ដាការដ្ឋាននៅស្ទឹងហាវ[494]។ តម្លៃដែលត្រូវចំណាយដោយអ្នកទាំងឡាយដែលធ្វើការងារនៅតាមសហករណ៍ និងការដ្ឋាននានាដើម្បីសម្រេចគោលដៅផលិតកម្មដែលគ្មានលក្ខណៈប្រាកដនិយមរបស់បក្ស មានកម្រិតខ្ពស់ក្រៃលែង។ **មាស មុត** បានដឹងអំពីទុក្ខវេទនាដែលបានបង្កឡើងទៅលើកម្មករទាំងនោះ ប៉ុន្តែពុំបានចាត់វិធានការទប់ស្កាត់ឧក្រិដ្ឋកម្មទាំងនេះ ឬផ្ដន្ទាទោសចារីទាំងនោះឡើយ។

---

មុត (មាស មុត) ជូន បង៨៩ (សុន សេន) ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៧៦ KH ERN 00160064 [សមមិត្ត មុត រៀបរាប់អំពីការដេកពេទ្យរបស់ប្រពន្ធអាចារ្យ កង]។

491 ឯកសារ D1.3.30.2 ទូរលេខពី មុត (មាស មុត) ជូន បង ៨៩ (សុន សេន) ថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៧៦ KH ERN 00021446 ["ខ្ញុំនៅកោះរុង និងរុងក្រៅ ដើម្បីតាមដាន និងណែនាំអនុវត្តសេចក្ដីសំរេចចិត្តនេះរបស់បក្ស ឲ្យមានប្រសិទ្ធភាព។ គ្រាប់ និងអង្ករនៅតាមកោះទាំងអស់ អាចធានាបាន ៦ ខែ តែដោយឡែកអង្ករវាផ្លូវបន្ដិច ព្រោះអង្ករចាស់ដែរ [...] ខ្ញុំផ្ញើជូនបង ៨៩ របាយការណ៍ប្រចាំខែរបស់អង្គភាព ១៦៤ តាមរទេះភ្លើង"]។

492 ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00052401 [ស្ថិតិអំពីការធ្វើស្រែ]។

493 ឯកសារ D1.3.19.2 របាយការណ៍ពី ខៀវ (សុន សេន) ជូនគណៈកងពល និងវរសេនាធំ ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ១៩៧៧ [សុន សេន នៅក្នុងតំណែងរបស់គាត់ជាប្រធានអគ្គសេនាធិការ៖ "សុំកងពលរៀបចំធ្វើឡទឹកត្រីរបស់ខ្លួន។ [...]សុំទៅមើលខាងកងពល ១៦៤ ដើម្បីរៀនសូត្រ"]។

494 សូមមើលឧទាហរណ៍ VIII.ង. ការដ្ឋានស្ទឹងហាវ- ៣. ឧក្រិដ្ឋកម្ម- ការធ្វើឲ្យទៅជាទាសករ, VIII.ង.៣. ឧក្រិដ្ឋកម្ម- អំពើអមនុស្សធម៌ផ្សេងទៀត, VIII.ច. ការដ្ឋានតំបន់រាម - ៣. ឧក្រិដ្ឋកម្ម- ការធ្វើឲ្យទៅជាទាសករ, VIII.ច.៣. ឧក្រិដ្ឋកម្ម- អំពើអមនុស្សធម៌ផ្សេងទៀត(ការប្រព្រឹត្តិអំពើអមនុស្សធម៌)។

*ខ) ការដឹងឮរបស់ មាស មុត អំពីស្ថានភាពនៃការដាក់ជាទាសករ*

182. **មាស មុត** ក្រោយពេលមានការណែនាំរបស់ សុន សេន ឲ្យ "ចុះទៅស្រែ [...] ដើម្បីមើល និងស្ដាប់របាយការណ៍ដើម្បីអាចសង្ខេបអំពីបទពិសោធន៍ឲ្យបានច្បាស់លាស់"[495] បានត្រួតពិនិត្យការដ្ឋាន និងសហករណ៍ដោយផ្ទាល់[496]។ ក្នុងអំឡុងពេលទស្សនកិច្ចទៅកាន់ទីតាំងទាំងនោះ គាត់បានមានឱកាសដើម្បីមើលឃើញស្ថានភាពរស់នៅដ៏លំបាក និងស្ថានភាពការងារដ៏លំបាកដោយផ្ទាល់ភ្នែក ដែលត្រូវបានដាក់ទៅលើប្រជាជន[497]។ ជាងនេះទៀត ក្នុងរបាយការណ៍នានាទៅកាន់មជ្ឈិមបក្ស គាត់បានធ្វើសេចក្ដីអត្ថាធិប្បាយស្ដីអំពីភាពមិនគ្រប់គ្រាន់នៃចំណីអាហារ[498] និងការផ្គត់ផ្គង់

495 ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00052400 ["[យើង] ត្រូវចុះឲ្យដល់ស្រែ ដល់ស្រូវ ដល់ម៉ាស៊ីបូមទឹក។ ចុះឲ្យឃើញផង ស្ដាប់សេចក្ដីរាយការណ៍ផង ទើបសរុបពិសោធបានច្បាស់"]។

496 សូមមើល កថាខណ្ឌ ១៩១-១៩២, ១៩៧។

497 សូមមើល VIII.ង. ការដ្ឋានស្ទឹងហាវ- ៣. ឧក្រិដ្ឋកម្ម- ការធ្វើឲ្យទៅជាទាសករ, VIII.ង.៣. ឧក្រិដ្ឋកម្ម- អំពើអមនុស្សធម៌ផ្សេងទៀត, VIII.ច. ការដ្ឋានតំបន់រាម- ៣. ឧក្រិដ្ឋកម្ម- ការធ្វើឲ្យទៅជាទាសករ, VIII.ច.៣. ឧក្រិដ្ឋកម្ម- អំពើអមនុស្សធម៌ផ្សេងទៀត(ការប្រព្រឹត្តិអំពើអមនុស្សធម៌)។

498 ឯកសារ D1.3.8.2 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ១៩៧៦ KH ERN 00162484 [មាស មុត៖ "អង្គការឲ្យអង្ករ ១ ៥០០ បាវ ប្រជាជនអាចហូបស្រូវផ្សំនឹងដំឡូងដល់ខែ ៨"]។ ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00052388-91 [មាស មុត៖ "សភាពការណ៍ស្បៀង - គិតទៅដល់ថ្ងៃទី ១៥ ខែ ១១ ត្រូវអស់ តែផលស្រូវថ្មីដល់ហើយ។ ស្បៀងតាមកោះ ត្រូវអស់ខែ ខែ០១ ៧៧។ ដំណាំរួមផ្សំនៅដីគោក ប្រើតរល្អយ។ ដំឡូងមានលើដី ទំហំ ៣០ ហិកតា"]។ ឯកសារ D1.3.27.22 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ KH ERN 00088929 [មាស មុត៖ "ស្បៀងសំរាប់ដីគោក គ្រប់ដល់ដំណាច់ឆ្នាំ ក្នុងរបប ២ កំប៉ុង។ ស្បៀងតាមកោះ គ្រប់ដល់ថ្ងៃ ១៥-៤-៧៧ [...] គិតជាផល ២ តោនស្មើ បាន ៣.២៦០ តោន - ត្រូវហូប ៣.៧៤៥ តោក្នុង ១ ឆ្នាំ គិត ៣១២ គ.ក្រ សំរាប់ ១២.០០០ នាក់ ទាំងកងទ័ព ទាំងប្រជាជន។ - ទុកពូជ ២២៥ តោន សំរាប់ដី ១.៥០០ ហិកតា។ - រួមទាំងហូប រួមទុកពូជផង ត្រូវខ្វះ ៣១០ តោន"]។ ឯកសារ D1.3.30.2 ទូរលេខពី មុត (មាស មុត) ជូនបង ៨៩ (សុន សេន) ថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៧៦ KH ERN 00021446 ["គ្រាប់ និងអង្ករនៅតាមកោះទាំងអស់អាចធានាបាន ៦ ខែ តែដោយឡែកអង្ករវាផ្លូវបន្តិច ព្រោះអង្ករចាស់ដែរ"]។

វេជ្ជសាស្ត្រ[499] និងស្ដីពីស្ថានភាពការងារដ៏យ៉ាប់យ៉ឺន ដែលអ្នកធ្វើការងារពលកម្មដោយបង្ខំបានជួបប្រទះនៅតាមការដ្ឋានទាំងនោះ[500]។

183. ឧទាហរណ៍ក្នុងសារទូរលេខមួយផ្ញើទៅ សុន សេន និងចម្លងជូនមេដឹកនាំផ្សេងទៀត **មាស មុត** បានរាយការណ៍ថា "អ្នកជំងឺដែលបានមកស្នាក់នៅមន្ទីរពេទ្យនៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ មានចំនួន ១៣០០ នាក់ ដោយមិនរាប់បញ្ចូលចំនួនមនុស្សដែលកើតជំងឺផ្ដាសាយ និងស្នាក់នៅតាមក្រុមការងាររបស់ពួកគាត់ឡើយ។ កម្មាភិបាលចំនួនជាង ៣០ នាក់បានស្លាប់ពីថ្ងៃទី ២០ ខែ មករា ដល់ថ្ងៃទី ២០ ខែ កុម្ភៈ"[501]។ បន្ទាប់មកជាថ្មីម្ដងទៀតនៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ គាត់បានរាយការណ៍ថា ទ័ពនិងប្រជាជនចំនួន ១៧០០០ នាក់បានកំពុងដាំដុះស្រូវ ប៉ុន្តែនឹងមានការខ្វះខាតស្រូវចំនួន៦១០០០ ល្អី និងដោយគូសបញ្ជាក់ទៀតថា មនុស្សជាច្រើនកើតជំងឺផ្ដាសាយ ពីព្រោះពួកគាត់ "គ្មានអាវភ្លៀងប្រើប្រាស់"[502]។

184. ហេតុដូច្នេះ **មាស មុត** បានដឹងថា មនុស្សនៅតាមការដ្ឋានទាំងនេះ ដែលគាត់ជាអ្នកទទួលខុសត្រូវ បានជួបប្រទះលក្ខខណ្ឌការងារដ៏លំបាក ខ្វះចំណីអាហារគ្រប់គ្រាន់ និងបានរងគ្រោះពីភាពអត់ឃ្លាន និងជំងឺតម្កាត់។ ការប៉ុនប៉ងរបស់ **មាស មុត** ក្នុងការគេចចេញពីការទទួលខុសត្រូវតាមរយៈ

---

499 ឯកសារ D4.1.1020 ទូរលេខពី មុត (មាស មុត) ជូន បង ៨៩ (សុន សេន) ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ KH ERN 00021459 ["[យើង] បានទទួលថ្នាំមួយចំនួន ដែលបងបញ្ជូនមកហើយ ថ្នាំនេះភាគច្រើន កាល់ស្យូម ឯថ្នាំគ្រុន និងសេរ៉ូម ពុំទាន់ឃើញ ប្រហែលជាជើងក្រោយ"]។

500 ឯកសារ D1.3.34.10 ទូរលេខពី មុត (មាស មុត) ជូន បង ៨៩ (សុន សេន) ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៧៦ KH ERN 00000860 ["ក្នុងខែ ៨ នេះ នៅកំពង់សោម មានភ្លៀងតែម្តងគត់ រហូតមកដល់ថ្ងៃនេះ។ ឥឡូវ [ប្រជាជន] បាចទឹកដាក់ស្រែវិញម្តងហើយ [ដោយដៃ]"]។ ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00052391 [មាស មុត៖ "សភាពការណ៍សុខភាព - ខែ ៩ បងប្អូនមានគ្រុនច្រើន តែពុំទាន់មានប៉ះពាល់អាយុជីវិតទេ មូលហេតុភ្លៀងច្រើន បងប្អូនមិនសូវមានសំពត់ភ្លៀង"]។

501 ឯកសារ D4.1.1020 ទូរលេខពី មុត (មាស មុត) ជូន បង ៨៩ (សុន សេន) ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ KH ERN 00021459 ["ចំនួនអ្នកជំងឺ ដែលមកនៅមន្ទីរពេទ្យ ថ្ងៃទី២០-២-៧៦ មាន ១ ៣០០ នាក់។ ឯគ្រុនដេកនៅតាមកង មិនបានគិតក្នុងនេះទេ។ សមមិត្តពលីកម្ម ពីថ្ងៃទី ២០-១ ដល់ថ្ងៃទី ២០-២ មានជាង ៣០ នាក់"]។

502 ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00052391។

ការបដិសេធថាគ្មានការងារពលកម្មដោយបង្ខំក្នុងកងពលធំរបស់គាត់[503] បានត្រឹមតែបង្ហាញអំពីការដឹងឮរបស់គាត់អំពីឧក្រិដ្ឋកម្មទាំងឡាយដែលកម្មករទទួលរង និងការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់គាត់។ ភស្តុតាងនេះបង្ហាញថា ការងារពលកម្មដោយបង្ខំគ្រាន់តែជាផ្នែកមួយនៃលក្ខខណ្ឌអមនុស្សធម៌ ដែលទទួលរងដោយទាហាន និងជនស៊ីវិល នៅកំពង់សោមក្នុងអំឡុងរបបនេះ[504]។ ក្នុងឋានៈជាមេបញ្ជាការកងពលធំ ១៦៤ និងជាលេខាកំពង់សោម **មាស មុត** បានមានសិទ្ធិគ្រប់គ្រងទាំងស្រុងលើតំបន់កំពង់សោមទាំងមូល ដោយរួមបញ្ចូលការដ្ឋាន និងសហករណ៍នានាដែលស្ថិតនៅក្នុងតំបន់នោះ[505] និងទទួលខុសត្រូវព្រហ្មទណ្ឌចំពោះមហាទុក្ខវេទនា ដែលបានបង្កឡើងទៅលើប្រជាជន ពីសំណាក់មនុស្សក្រោមបង្គាប់ទាំងឡាយ ដែលអនុវត្តក្រោមសិទ្ធិអំណាចរបស់គាត់។

185. នៅពេលត្រូវបានសួរអំពីមនុស្សក្នុងកងពលធំរបស់គាត់ **មាស មុត** បានពន្យល់ថា "គ្រប់គ្រងមនុស្សមិនដូចគ្រប់គ្រងសត្វពាហនៈឡើយ។ ចំពោះសត្វពាហនៈ អ្នកអាចឱ្យស្មៅពួកវាស៊ី។ ប៉ុន្តែមនុស្ស ពួកគេត្រូវការអាហារ ហើយពួកគេក៏មានអារម្មណ៍ផងដែរ"[506]។ ប៉ុន្តែ ជនរងគ្រោះនៃការដាក់ជាទាសករដែលគាត់បានអនុវត្តនៅកំពង់សោម ត្រូវបានចាត់ទុកដូចសត្វពាហនៈ។ ពួកគាត់ត្រូវបានដកហូតសេរីភាពដើរហើរ[507] បានទទួលអាហារតិចតួច[508] និងត្រូវបានរំពឹងឱ្យសម្រេចកូតាការងារដ៏ធ្ងន់ធ្ងរ[509] និងធ្វើការងារជាច្រើនម៉ោងដោយគ្មានសម្រាក[510]។

---

503 ឯកសារ D114/307.6 កិច្ចសម្ភាសន៍របស់ VOA ជាមួយ មាស មុត ជនសង្ស័យរបស់តុលាការយល់ឃើញថា តួនាទីរបស់តុលាការ "មានកម្រិត" ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០១១ KH ERN 01380588 ["តាមពីទៅ ទីមួយ គឺមិនមានជនស៊ីវិលទេនៅកន្លែងខ្ញុំ។ ទីពីរ មានតែកងទ័ព និងក្រុមគ្រួសាររបស់ពួកគេប៉ុណ្ណោះ។ ហេតុដូច្នេះមិនមានពលកម្មដោយបង្ខំឡើយនៅក្នុងកងរបស់ខ្ញុំ"]។

504 សូមមើល VIII.ង. ការដ្ឋានការងារស្ទឹងហាវ, VIII.ច. ការដ្ឋានតំបន់រាម។

505 សូមមើល III.២. តួនាទីរបស់មាស មុតនៅកម្ពុជាប្រជាធិបតេយ្យ- ការគ្រប់គ្រងដោយប្រសិទ្ធភាព។

506 ឯកសារ D22.2.180 កិច្ចសម្ភាសន៍របស់កាសែតភ្នំពេញប៉ុស្តិ៍ជាមួយ មាស មុត, មាស មុត៖ "យើងស្ថិតនៅក្នុងទ្រុងដូចសព្វថ្ងៃ" ចុះថ្ងៃទី ២០ ខែកក្កដា-ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១ EN ERN 00161880 ["កាសែត៖ តើមានមនុស្សប៉ុន្មាននាក់នៅក្នុងកងពលរបស់លោក? មុត៖ ប្រហែលច្រើនជាង ១០ ០០០ នាក់។ ការគ្រប់គ្រងមនុស្ស គឺមិនដូចគ្រប់គ្រងសត្វទេ។ បើសត្វ អាចឱ្យស្មៅវាស៊ី តែមនុស្ស ត្រូវការទាំងអាហារ ហើយមានអារម្មណ៍ផងដែរ"]។

507 សូមមើលឧទាហរណ៍ ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.19 ["ប្រជាជន មិនត្រូវបានអនុញ្ញាតឱ្យដើរទៅណាមណារហេតរហូតទេ"]។ ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.82 ["ស៖ តើលោកអាចចេញពីកន្លែងវិវត្ត ឬកន្លែងដែលលោកស្នាក់នៅទេ? ឆ.82៖ ទាល់តែគេចាត់តាំងទើបចេញបាន"]។

ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ ស្វន ផ ឆ.33, 47-48 ["សៈ តើគេអនុញ្ញាតឱ្យលោកចាកចេញពីកន្លែងស្នាក់នៅ និងកន្លែងការងារដែរឬទេ? ឆ.33៖ អត់ទេ ពេលធ្វើការ គឺយើងពុំអាចចេញពីកន្លែងធ្វើការបានទេ បើមិនដូច្នេះទេ គឺគេចាប់ហើយ។ [...] សៈ តើលោកចង់ធ្វើការងារនោះដែរឬទេ? តើលោកមានជម្រើសធ្វើអ្វីផ្សេងដែរឬទេ? ឆ.47៖ ខ្ញុំអត់ចង់ទេ តែខ្ញុំត្រូវតែធ្វើការងារនោះ ដើម្បីជាថ្នូរនឹងជីវិតរបស់ខ្ញុំ។ បើតាមខ្ញុំយល់ ប្រសិនជាគេចាប់បាននរណាម្នាក់ព្យាយាមរត់ចេញពីកន្លែងនោះ អ្នកនោះច្បាស់ជាគេសម្លាប់ចោលហើយ។ [...] ឆ.48៖ បាទ ខ្ញុំតែងតែរស់នៅ ដោយការភ័យខ្លាចថាថ្ងៃណាមួយនឹងអស់ជីវិត"]។ ឯកសារ D54/123 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.2 ["គេមិនឱ្យយើងដើរទៅណាមកណាទេ នៅពេលយប់ លុះត្រាណាតែគេចាត់តាំងឱ្យយើងធ្វើអ្វីមួយដូចជាលើកទំនប់ និងលើកភ្លឺស្រែជាដើម""]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.122 ["ពួកយើងស្ថិតនៅក្រោមការឃ្លាំមើលគ្រប់ពេលវេលា ដើម្បីឱ្យដឹងថា យើងធ្វើសកម្មភាពប្រឆាំងនឹងរបបនោះ ឬក៏រៀបចំផែនការរត់គេច"]។ ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.33 ["សៈ ហេតុអ្វីបានជាលោកមិនរកវិធីរត់គេចពីទីនោះ នៅពេលដែលស្ថានភាពការងារនៅទីនោះមានការលំបាកខ្លាំង? ឆ.33៖ មិនមានផ្លូវរត់ចេញទេ ពីព្រោះយើងហូបបាយរួម ដូច្នេះបើយើងរត់គេចទៅកន្លែងផ្សេង យើងនឹងមិនមានអាហារហូបចុកទេ ហើយយើងនឹងត្រូវចាប់ខ្លួន ហើយនឹងត្រូវសម្លាប់ដោយយោធា ដែលល្បាតនៅតំបន់នោះ"]។

508 សូមមើលឧទាហរណ៍ ឯកសារ D54/20 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.14 ["ចំណែករបបអាហារមិនគ្រប់គ្រាន់ទេ ពេលព្រឹកម៉ោង ៧ ព្រឹក គេឱ្យបបរ និងពេលថ្ងៃត្រង់ និងល្ងាច គេឱ្យហូបបាយ តែការហូបចុកនោះ មិនគ្រប់គ្រាន់ទេ"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.82-83 ["ចំណីអាហារ បើនិយាយឱ្យខ្លី គឺមិនដែលស្គាល់ថ្ងៃឆ្អែត។ [...] ឆ.83៖ ពីរពេលក្នុងមួយថ្ងៃ"]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ុន យ៉ឺ ឆ.25 ["ជីវិតរបស់ខ្ញុំកាលពីខ្ញុំនៅកងកេង ជីវភាពហ្នឹងវាមុនដាបណាស់ កម្លាំងពលាំងក៏មិនសូវមាន។ ព្រោះជីវភាពហ្នឹង វាចែករបបស្ងួតស្ដែងពេក។ ក្នុងហូបបាយម៉ាឆ្នាំងហ្នឹង វាមានកំណត់ ១០ នាក់ ប៉ុន្មានកំប៉ុងអ៊ីចឹងទៅ"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.12 ["ម្ហូបអាហារមិនគ្រប់គ្រាន់ទេ"]។ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.25 ["គ្រួសារខ្ញុំមាន ៤ នាក់ គេឱ្យអង្ករមួយកំប៉ុងក្នុង ១ ថ្ងៃ ដូច្នេះខ្ញុំហូមមិនគ្រប់គ្រាន់ទេ"]។

509 សូមមើលឧទាហរណ៍ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.12 ["ពេលយើងលើកទំនប់នៅភូមិបបុស ម្នាក់ត្រូវឱ្យរែកដី ៣ ម៉ែត្រគូបឱ្យអស់ក្នុងមួយថ្ងៃ ហើយការជកប្រឡាយក៏គេតម្រូវម្នាក់ៗឱ្យរែកអស់ ៣ ម៉ែត្រគូបដែរ"]។ ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.42 ["មនុស្សម្នាក់ៗត្រូវបានវាស់ដីឱ្យរែក ពី ២ ទៅ ៣ ម៉ែត្រគូក្នុងមួយថ្ងៃ"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.112 ["យើងត្រូវច្បាស់លាស់នឹងការងារខ្លាំង ដើម្បីអាចធ្វើការងារដែលគេដាក់ឱ្យ ៣ ម៉ែត្រគូប ក្នុងមួយថ្ងៃ"]។ ឯកសារ D54/33.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ី អុន KH ERN 00964204 ["វ៉ៃថ្មហ្នឹង មិនថាទ័ព មិនថាអីជំនាន់ហ្នឹង លុតដំទាំងអស់ ហើយទ័ពហ្នឹងក៏យ៉ាប់ដែរ។ សៈ វ៉ៃថ្ម? ឆៈ បាទ! គេសុទ្ធតែកំណត់ ថ្មមុនដំបូង វ៉ៃ ២ នាក់ អញ្ចឹងតែ ៤ ម៉ែត្រគីបទេ បើយើងវ៉ៃបានចេះតែដំឡើងរហូតដល់ ៦ នាក់ ១២ ម៉ែត្រគីប គេកំណត់ហ្នឹង បើយើងនេះវេទនាណាស់ ហើយមានម៉ាស៊ីនខ្លួងម៉ាស៊ីនអីមកពីណា សុទ្ធតែមនុស្សបុកហ្នឹង ដែកប្រហាវែងហ្នឹងបុក ហើយអ្នកបុកគេកំណត់មួយថ្ងៃរន្ធមួយម៉ែត្រ"]។

## <u>ការដ្ឋានរាម</u>

186. ជាពិសេស **មាស មុត** បានឯកភាព និងបានចូលរួមយ៉ាងសកម្មក្នុងការដាក់ជាទាសករ ការបាត់ខ្លួន និងការសម្លាប់ក្រុមដែលត្រូវបានដាក់ជាគោលដៅតាមរយៈការបង្កើត និងប្រតិបត្តិការនៃការដ្ឋាននានាក្នុងតំបន់រាម។ **មាស មុត** បានចូលរួមក្នុងឧក្រិដ្ឋកម្មទាំងនេះដោយផ្ទាល់ និងតាមរយៈមនុស្សក្រោមបង្គាប់របស់គាត់ក្នុងអង្គភាពកងពលធំ ១៦៤ ដែលទទួលខុសត្រូវចំពោះការគ្រប់គ្រងពលករនៅតាមការដ្ឋានទាំងនោះ[511]។

---

[510] សូមមើលឧទាហរណ៍ ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.22 ["សៈ លោកនិយាយថា ១០ នាក់ក្នុងចំណោមមនុស្សទាំង ៣០០ នាក់ ត្រូវបានគេចាត់តាំងឱ្យយាមទីតាំងលើកទំនប់រៀងរាល់យប់។ តើគេឱ្យអ្នកទាំងនេះឈប់សម្រាក់ដែរឬទេ នៅថ្ងៃបន្ទាប់ ឬក៏ពួកគេត្រូវបានតម្រូវឱ្យបំពេញការងារ ៣ ម៉ែត្រគូបដដែលក្នុង ១ ថ្ងៃ? ឆ.22៖ ព្រឹកបន្ទាប់ អ្នកទាំង ១០ នាក់នោះ គេតម្រូវឱ្យធ្វើការជាធម្មតា ពុំឱ្យឈប់សម្រាកទេ"]។ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.47 ["នៅពេលគេចាត់តាំងឱ្យយើងជីកប្រឡាយ មានអ្នកយាម ៤ នាក់តាមចាំឃ្លាំមើលយើង បួន នាក់ ក្នុងនោះ មានខ្ញុំដែរ។ ដូច្នេះអ្នកយាមម្នាក់ ឃ្លាំងមើលអ្នកធ្វើការម្នាក់។ បើធ្វើមិនហើយតាមផែនការ យើងត្រូវតែធ្វើការងារនោះឱ្យទាល់តែហើយ ជួនកាលដល់ម៉ោង ៩ ឬ ១០ យប់ទើបចប់ផែនការ"]។ ឯកសារ D114/96 កំណត់ហេតុស្តាប់ចម្លើយ ចឹង ឡុង ឆ.69 ["ខ្ញុំអាចនិយាយបានថា ប្រជាជនដែលធ្វើការនៅកន្លែងលើកទំនប់ ពិជាធ្វើការលំបាកណាស់ ព្រោះប្រជាជនធ្វើការទាំងយប់ទាំងថ្ងៃ"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.112, 117 ["គេតម្រូវឱ្យយើងធ្វើឱ្យហើយក្នុង១ថ្ងៃដាច់ខាត បើធ្វើមិនចប់តាមផែនការគេកំណត់ គឺមិនឱ្យឈប់សម្រាកហូបបាយទេ។ [...] ឆ.117៖ គេឱ្យប្រជាជនធ្វើការរហូតដល់ដើរលែងរួច"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.46 ["ពួកខ្ញុំធ្វើការពេញមួយអាទិត្យ និងមួយខែ ពុំមានពេលសម្រាកទេ លើកលែងតែមានការប្រជុំ ទើបបានឈប់សម្រាកខ្លះ"]។ ឯកសារ D54/20 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.14 ["គេចាត់តាំងឱ្យខ្ញុំកាប់ផ្កាក់ដីស្រែដោយប្រើចបឱ្យបានពីរកុង (២០ ម៉ែត្រការ៉េ) មួយថ្ងៃ ហើយការងាររាល់ថ្ងៃ ចាប់ផ្តើមពីម៉ោង ៧ ដល់ម៉ោង ១១ ហើយសម្រាកមួយម៉ោង និងបន្តពីម៉ោង ១ ដល់ម៉ោង ៥ ល្ងាច"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.80 ["យើងធ្វើពីម៉ោង ៣ ភ្លឺ ដលម៉ោង ១១ ហើយថ្ងៃធ្វើម៉ោង ១ ដល់ម៉ោង ៦ ល្ងាច។ ពេលខ្លះ ធ្វើលើសម៉ោង ៦ ល្ងាចទៀត ដល់ម៉ោង ៩ យប់អី ក៏មាន"]។

[511] ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ.121, 127 ["តាញ៉ាន់ គឺជាមេបញ្ជាការវរសេនាធំ ៦៣ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពល ១៦៤ ដែលមាន មាស មុត ជាមេបញ្ជាការ។ សៈ យើងទៅលើកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយថា "តាញ៉ាន់ គឺជាមេបញ្ជាការវរសេនាធំ ៦៣ ឈរជើងនៅកងកេង"។ តើរឿងនេះត្រឹមត្រូវដែរឬទេ? ឆ.127៖ បាទ ត្រឹមត្រូវហើយ"]។ ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.30 ["សៈ តើលោកស្គាល់មនុស្សម្នាក់ឈ្មោះ មុំ យ៉ាន ដែរឬទេ? ឆ.30៖ បាទ ខ្ញុំស្គាល់។ គាត់គឺជាមេបញ្ជាការកងវរសេនាធំលេខ ៦៣។ មូលដ្ឋានរបស់គាត់នៅក្នុងព្រលានយន្តហោះកងកេង ជិតផ្លូវ

187. ការដ្ឋានរាម និងទីតាំងសម្លាប់មនុស្សស្ថិតនៅខាងជើង និងខាងត្បូងផ្លូវជាតិលេខ៤ ចម្ងាយប្រមាណ ១៥ គីឡូម៉ែតពីទីស្នាក់ការរបស់ **មាស មុត** ក្នុងក្រុងកំពង់សោម។ តំបន់នេះបានរួមបញ្ចូលទំនប់ ប្រឡាយ ផែថ្ម ឡឥដ្ឋ ស្រែ និងទីតាំងសម្លាប់មនុស្ស។ នៅតាមការដ្ឋានទាំងនោះ អ្នកធ្វើការងារពលកម្មចំនួនរាប់ពាន់នាក់ស្ថិតក្រោមលក្ខខណ្ឌអមនុស្សធម៌ ដែលត្រូវបានបង្ខំឲ្យធ្វើការជាច្រើនម៉ោងដោយគ្មានសម្រាក ត្រូវបានបង្ខំឲ្យបំពេញកូតាដែលមិនសមហេតុផល និងត្រូវបានផ្ដល់ឲ្យអាហារមិនគ្រប់គ្រាន់[512]។

188. **មាស មុត** បានរក្សាការគ្រប់គ្រងទាំងស្រុងលើតំបន់រាម និងបានជាប់ពាក់ព័ន្ធក្នុងប្រតិបត្តិការនៃការដ្ឋាន និងសហករណ៍ទាំងឡាយដែលស្ថិតក្នុងតំបន់នេះ។ គាត់បានចេញបញ្ជាទាក់ទងនឹងទីតាំងទាំងនោះ ដូចដែលបានបង្ហាញក្នុងសារទូរលេខចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ ដែលអនុប្រធានរបស់ **មាស មុត** ឈ្មោះ ឌឹម បានប្រាប់គាត់ថា "នៅរាម និងឃុំបបោសពីរ យើងបានចាត់*វិធានការដូចដែលបងបានសម្រេច*។ ខ្មាំងប្រាំនាក់បានរត់ចូលក្នុងព្រៃ។ ប៉ុន្តែឥឡូវយើងចាប់ពួកវាបានទាំងអស់"[513]។ ឌឹម ក៏បានប្រាប់ **មាស មុត** អំពីការស្លាប់របស់ទាហានវរសេនាធំ ១៦២ ម្នាក់នៅពេល "កំពុងធ្វើស្រែក្នុងបរិវេណចម្ការដូង"[514] និងការវិវត្តន៍នៅតំបន់កងកេង៖ "ស្រូវនៅគ្រប់កន្លែងទាំងអស់កំពុងមានការវិវត្តន៍។ ប៉ុន្តែនៅកងកេង មានដីចំនួនដប់ពីរហិកតាដែលមានទឹកជ្រៅ។ ប៉ុន្តែបង

---

បំបែករវាងផ្លូវចូលទៅព្រលានយន្តហោះ និងផ្លូវជាតិត្រង់ស្ទាច់ម៉ែង។ គាត់គឺជាមេបញ្ជាការកងវរសេនាធំលេខ ៦៣ មុនពេលដែល ជន ចូលមកកាន់ជំនួស។ ខ្ញុំមិនដឹងពីអ្វីដែលបានកើតឡើងចំពោះគាត់ឡើយ"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហ៊ាង រ៉េត KH ERN 00926575 ["កាលហ្នឹង តាញាន់ៗ គាត់នៅកាន់វរសេនាធំ ៦៣ នៅកងកេង"]។

512 សូមមើល ផ្នែក VIII.ច. ការដ្ឋានតំបន់រាម។

513 ឯកសារ D4.1.699 ទូរលេខ ១១ ពី ឌឹម ជូន បងមុត (មាស មុត) ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ (គូសបញ្ជាក់បន្ថែម) KH ERN 00092628 ["សភាពដីគោកនៅឃុំរាម និងបបុស ពីយើងមានវិធានការចំពោះខ្មាំងមួយដែលបងសំរេច វាមានរត់ចូលព្រៃ ៥ នាក់ ឥឡូវយើងបានចាប់បានអស់ហើយ"]។

514 ឯកសារ D4.1.699 ទូរលេខ ១១ ពី ឌឹម ជូន បងមុត (មាស មុត) ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00092628 ["សភាពការណ៍យើង យុទ្ធជននៅកង ៦២ ធ្វើស្រែ ទៅធ្វើស្រែម្តុំចំការដូង ពលីម្នាក់ ដោយលង់ទឹក ប៉ុន្តែមូលហេតុពិនិត្យមិនទាន់ច្បាស់"]។

ប្អូន [យុទ្ធជន] យើងកំពុងជួយសង្គ្រោះស្រូវ [ពីទឹកជំនន់]។ ចំពោះដី យើងបានភ្ជួររួចហើយតាមផែនការ។ ហើយយើងបានស្ទូងបានម្តងរួចហើយ។ ប៉ុន្តែយើងត្រូវរាស់ម្តងទៀត”[515]។

189. ឯកសារភ័ស្តុតាងដែលបានកត់ត្រាអំពីការប្រជុំរបស់ **មាស មុត** នៅថ្នាក់កងពលធំ បង្ហាញថាគាត់បានដឹងទាំងស្រុងអំពីគ្រប់ផ្នែកនៃធនធាន ផលិតភាព និងសកម្មភាពខ្មាំងដោយរួមបញ្ចូលការចាប់ខ្លួនជនសង្ស័យក្នុងកងពលធំ ១៦៤ នៅតាមការដ្ឋានទាំងនោះ។ ជាឧទាហរណ៍ **មាស មុត** បានរាយការណ៍អំពីការរៀបចំកម្លាំងការពារនៅកំពង់សោមទៅប៉ុល ពត សុន សេន និងមេដឹកនាំ ប.ក.ក ដទៃទៀត។ គាត់បាននិយាយថា មានកាំភ្លើងធំចំនួនប្រាំមួយដែលបានដាក់នៅរាម និងកងកេងដែលមានបីទំហំ គឺ ១០៥មីល្លីម៉ែត ៣៧មីល្លីម៉ែត និង ១២.៨មីល្លីម៉ែត[516]។ នៅថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ ក្នុងអំឡុងការប្រជុំកងពលធំ ១៦៤ មានការជូនដំណឹងទៅ សុន សេន ថា “ប្រជាជនមូលដ្ឋាននៅកងកេង បានបង្ហាញអំពីលំនាំប្លែកៗនៃសកម្មភាពដោយរួមបញ្ចូល៖ ជាឧទាហរណ៍ ពួកគាត់បានកាត់សាច់ក្របី។ ពួកគាត់បានដាក់ដុំថ្មខ្លះៗក្នុងឡឥដ្ឋ។ ចោរបានកើនឡើងយ៉ាងខ្លាំង។ ក្នុងចំណោមប្រជាជនមូលដ្ឋានទាំងនោះ មានទាហានមិនល្អ។ អនុសេនីយ៍ពីរនាក់ត្រូវបានកំណត់អត្តសញ្ញាណ និងត្រូវបានចាប់ខ្លួន”[517]។

---

515 ឯកសារ D4.1.699 ទូរលេខ ១១ ពី ឌឹម ជូន បងមុត (មាស មុត) ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00092628 [“សភាពស្រូវនៅគ្រប់កន្លែង មានការរីកចំរើន តែនៅកងកេងមានទឹកជ្រូវ ១២ ហិកតា ប៉ុន្តែបងប្អូន [យុទ្ធជន] កំពុងប្រយុទ្ធសង្គ្រោះ ហើយចំពោះដីចមការកាប់ហើយតាមផែនការកំណត់ភ្ជួរហើយមួយសារ ប៉ុន្តែត្រូវភ្ជួររាស់ទៀត”]។

516 ឯកសារ D1.3.8.3 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ១៩៧៦ KH ERN 00021496 [“I. របាយការណ៍អំពីសភាពការយោធា៖ សមមិត្តមុត៖ ១. ការរៀបចំកម្លាំងការពារ៖ ក. កម្លាំងអាវុធនៅជុំវិញកំពង់សោម លើដីគោក ៖ កំពង់សោម មានកាំភ្លើងធំ ១០៥ ម.ម ៤ ដើម - កាំភ្លើង ៤០ ម.ម ១ ដើម - កាំភ្លើង ៣៧ ម.ម ៦ ដើម - ១២.៧ ម.ម ២ ដើម។ នៅរាម និងកងកេង មានកាំភ្លើងធំ ១០៨ ម.ម - ៣៧ ម.ម និង ១២.៨ ម.ម ទាំងអស់ ៦ ដើម”]។

517 ឯកសារ D54/8.1 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00936685 [“ខាងគោក ចូលខែ ៩ មក ប្រជាជនមូលដ្ឋានកងកេង មានសកម្មភាពប្លែកផ្សេង។ ឧទហរណ៍៖ កាប់យកសាច់ក្របីមួយដុំ យកដុំថ្មដាក់ឡានឡឥដ្ឋ និងសកម្មភាពលួចកើតច្រើន។ នៅក្នុងប្រជាជននេះ ភាគច្រើនល្អ តែទាហានមានចលនាមិនល្អ។ កន្លងមក រកឃើញទាហានសក្តិ ២ ២ នាក់ បានចាប់ហើយ”]។ សូមមើលផងដែរ ឯកសារ D1.3.8.4 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00162489 [“ខាងគោក ចូលខែ ៩ មក ប្រជាជនមូលដ្ឋានកងកេង មានសកម្មភាពប្លែកផ្សេង។ ឧទហរណ៍៖ កាប់យក

190. ដប់ថ្ងៃក្រោយគឺនៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ **មាស មុត** ខណៈពេលដែលគាត់រាយការណ៍អំពីសភាពការណ៍ខ្មាំង បាននិយាយថា "នៅកងកេង ក៏មានការលួចដែលត្រូវបានធ្វើឡើងដោយទាហាន"[518]។ ជាងនេះទៀត នៅថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៧៦ អនុប្រធានរបស់ **មាស មុត** បានប្រាប់គាត់អំពីសភាពការណ៍ខ្មាំងនៅកងកេង ដែលនោះគឺថាកងពលធំ១៦៤ បាន "ចាប់ខ្លួនចោរជាបន្តបន្ទាប់នៅម្តុំកងកេង។ ពួកគាត់ស្ថិតក្នុងចំណោមមនុស្សដែលបានរត់ចូលក្នុងព្រៃនាពេលថ្មីៗ"[519]។

191. កំណត់ត្រា ប.ក.ក ដែលនៅសេសសល់បន្តិចបន្តួច បង្ហាញអំពីភាពញឹកញាប់នៃការប្រជុំយោធាទាំងនេះ និងកម្រិតនៃភាពលម្អិតដែលត្រូវបានពិភាក្សា ដែលបង្ហាញថា **មាស មុត** បានដឹងឮអំពីលក្ខខណ្ឌ និងឧក្រិដ្ឋកម្មនានាដែលត្រូវបានប្រព្រឹត្ត នៅតាមការដ្ឋាននានានៅជុំវិញតំបន់រាម។ ការដឹងឮរបស់គាត់អំពីលក្ខខណ្ឌនានាដែលពលកម្មត្រូវបានបង្ខំឲ្យធ្វើការងារពលកម្ម និងការបាត់ខ្លួន និងការសម្លាប់មនុស្សទាំងឡាយ ដែលត្រូវបានរដ្ឋអំណាចចាត់ទុកថាគ្មានប្រយោជន៍ ឬជាជនសង្ស័យនយោបាយ អាចត្រូវបានបង្ហាញបន្ថែមពីចម្លើយរបស់សាក្សីដែលបញ្ជាក់អះអាងថា **មាស មុត** បានធ្វើការត្រួតពិនិត្យតំបន់កងកេង (ពិសេសនៅឡឥដ្ឋ) ហើយគាត់បានចេញចូលផ្ទះមួយជាទៀងទាត់ នៅសហករណ៍មួយដែលស្ថិតក្បែរអាកាសយានដ្ឋានដើម្បីទទួលទានអាហារ និងធ្វើដំណើរកាត់តាមផ្លូវជាតិនេះពីកន្លែងដែលគាត់បានពិនិត្យការដ្ឋានទាំងនោះ[520]។

---

សាច់ក្របីមួយដុំ យកដុំថ្មដាក់ឡាន់ឡឥដ្ឋ និងសកម្មភាពលួចកើតច្រើន។ នៅក្នុងប្រជាជននេះ ភាគច្រើនល្អ តែទាហានមានចលនាមិនល្អ។ កន្លងមក រកឃើញទាហានសក្តិ ២ ២ នាក់ បានចាប់ហើយ។"]។

518 ឯកសារ D4.1.655 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ EN ERN 00143159 ["សមមិត្ត មុត៖ ១. សភាពការណ៍ខ្មាំង៖ [...] នៅកងកេង វាមានចោរ ដែលសំខាន់ប្រព្រឹត្តឡើងដោយពួកទាហាន"]។

519 ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH ERN 00052404 ["ជុំវិញកងកេង រាម យើងចាប់បានចោរព្រៃជាបន្តបន្ទាប់ តែជាពួកទើបចូលព្រៃថ្មី"]។

520 ឯកសារ D54/17 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.15-16 ["ស៖ តើលោកដឹងដោយរបៀបណាថា ការដ្ឋាននេះឋិតនៅក្រោមការគ្រប់គ្រងរបស់កងពល ១៦៤? ឆ.15៖ ពីព្រោះមិនមានប្រធានវរសេនាធំណាមកពិនិត្យការងារនៅទីនេះទេ ប៉ុន្តែមេបញ្ជាការកងពល ១៦៤ មាស មុត ក៏បានមកពិនិត្យការងារនៅទីនោះដែរ។ ស៖ លោកនិយាយថាលោកបានទៅទីនោះបានតែម្តងទេ តើ មាស មុត មកមើលកន្លែងនេះដែរឬទេ? ឆ.16៖ ខ្ញុំបានសួរមិត្តភ័ក្រ ដែលធ្វើការនៅទីនោះ តើ មាស មុត មកមើលកន្លែងនេះដែរឬទេ? គេបានប្រាប់ខ្ញុំថា គាត់បានមកមើលនៅទីនេះដែរ"]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.50-54 ["ស៖ តើលោកធ្លាប់ជួប ឬឃើញ តាមុត ហ្នឹងទេ? ឆ.50 ៖ ខ្ញុំមិនដែលជួបទេ។ ខ្ញុំឃើញគាត់ពីក្រោយ ជិះកង់ ដោយមាននីរសាររបស់គាត់។ ហើយគេប្រាប់ខ្ញុំថា នោះជា តាមុ

192. សាក្សីនានាក៏បានបញ្ជាក់អះអាងថា **មាស មុត** បានចុះទៅសហករណ៍ដែលស្ថិតក្នុងតំបន់រាម ដើម្បីពិនិត្យថាតើត្រូវការធនធានបន្ថែមដែរ ឬទេ បានប្រាស្រ័យទាក់ទងជាមួយប្រធានសហករណ៍ តាមរយៈលិខិតលាយលក្ខណ៍អក្សរ[521]។ នៅពេលសំណើសុំការផ្គត់ផ្គង់ត្រូវបានធ្វើ គាត់បានណែនាំ ដោយផ្ទាល់ទៅប្រធានសហករណ៍ឱ្យប្រមូលរបស់របរដែលត្រូវបានស្នើសុំ[522]។ **មាស មុត** ក៏បាន ប្រជុំមួយខែម្តងដើម្បីពិភាក្សា "ផែនការថ្មីរបស់ *អង្គការ*" ជាមួយប្រធានភូមិ ដែលបន្ទាប់មកនឹង ទទួលខុសត្រូវក្នុងការបញ្ជូនបញ្ជារបស់គាត់ទៅកាន់មនុស្ស ក្រោមបង្គាប់របស់ពួកគាត់នៅតាមអង្គ ប្រជុំថ្នាក់ភូមិ[523]។ គាត់ក៏បានថែរក្សាទំនាក់ទំនងជាញឹកញាប់ជាមួយអ្នកគ្រប់គ្រងការដ្ឋាន ដោយ

---

ត។ សៈ ពេលដែលលោកឃើញគាត់ហ្នឹង ឃើញនៅកន្លែងណា? ឆ.51៖ ខ្ញុំមិនដឹងថាសឃើញនៅពេលណាទេ តែនៅឆ្នាំ ៧៧ នៅព្រលានយន្តហោះ កងកេង។ សៈ តើលោកចាំថានៅខែណា នៅឆ្នាំ១៩៧៧? ឆ.52៖ នៅរដូវប្រាំង រដូវច្រូតស្រូវ បោកស្រូវ។ សៈ ហ្នឹងនៅដើមឆ្នាំ ឬនៅចុងឆ្នាំ? ឆ.53៖ ពេលហ្នឹងអាចនៅចន្លោះចុងឆ្នាំក៏ថាបាន។ សៈ តើលោកចាំថានៅដើមឆ្នាំ ឬចុងឆ្នាំ ៧៧? ឆ.54៖ នៅដើមឆ្នាំ ៧៧"]។ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ.224 ["ឮតែគេថា តាមុត ហ្នឹងមកមើលការដ្ឋាន។ ជួនកាល ខ្ញុំឮគេនិយាយថា គាត់កំពុងឈរនៅលើផ្លូវជាតិ"]។ ឯកសារ D114/68 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.5 [សាក្សីចិញ្ចឹមទានៅជិតព្រលានយន្តហោះកងកេង រហូតដល់ខែមករា ឆ្នាំ ១៩៧៨ ៖ "ខ្ញុំស្គាល់ មាស មុត ច្បាស់។ នៅក្នុងរបបខ្មែរក្រហម ផ្ទះរបស់ខ្ញុំស្ថិតនៅជិតវាលយន្តហោះកងកេង។ គ្រួសាររបស់ខ្ញុំត្រូវបានគេចាត់តាំងឱ្យចិញ្ចឹមទា។ ពេលនោះហើយ ដែលជាឱកាសខ្ញុំបានស្គាល់ មាស មុត។ មាស មុត គឺជាមេបញ្ជាការកងពលទទួលខុសត្រូវក្នុងតំបន់នេះ។ មាស មុត មកហូបបាយនៅផ្ទះខ្ញុំជាញឹកញាប់ ហើយយកពងទាទៅហូបនៅកន្លែងគាត់"]។ ឯកសារផ្ទុយ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.20 [មាស មុត មិនដែលឃើញមកកន្លែងទាំងនេះទេ"], ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.18 ["មិនមានថ្នាក់ដឹកនាំមកមើលពួកយើងទេ"]។

521 ឯកសារ D59/1/4.25 កិច្ចសម្ភាសន៍ជាមួយ ឡុង លី KH ERN 00930812 ["សៈ អ៊ីចឹងនិយាយទៅ មាស មុត នៅក្នុងជាកងពលអ៊ីចឹង តែគាត់មើលការខុសត្រូវដល់សហករណ៍ដែរ? ឆៈ ចាំ គាត់ចុះមកមើលម្តងៗ ខ្វះខាតអី ខ្វះខាតអីក៏យើងប្រាប់ទៅ ហើយយើងប្រធានហ្នឹង យើងមើលទៅ ខ្វះខាតអីយើងធ្វើជាក្រដាសស្នើទៅ ហើយឱ្យយកមក"]។

522 ឯកសារ D59/1/4.25 កិច្ចសម្ភាសន៍ជាមួយ ឡុង លី KH ERN 00930812 ["សៈ អ៊ីចឹងនិយាយទៅ មាស មុត នៅក្នុងជាកងពលអ៊ីចឹង តែគាត់មើលការខុសត្រូវដល់សហករណ៍ដែរ? ឆៈ ចាំ គាត់ចុះមកមើលម្តងៗ ខ្វះខាតអី ខ្វះខាតអីក៏យើងប្រាប់ទៅ ហើយយើងប្រធានហ្នឹង យើងមើលទៅ ខ្វះខាតអីយើងធ្វើជាក្រដាសស្នើទៅ ហើយឱ្យយកមក"]។

523 ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.31-34 ["តាមខ្ញុំដឹង មេភូមិទៅប្រជុំជាមួយ តាមុត នៅកន្លែងគាត់រៀងរាល់ថ្ងៃ មុនពេលគាត់មកប្រជុំជាមួយយើងនៅតាមភូមិនៅម៉ោង ១១ ព្រឹក។ សៈ តើលោកស្រីដឹងថាមេភូមិទៅប្រជុំជាមួយ តាមុត ដោយសារអ្វី? ឆ.32៖ ពីព្រោះគេប្រាប់នៅពេលប្រជុំរាល់ថ្ងៃថា អង្គការឱ្យធ្វើនេះធ្វើនោះ។ សៈ តើមេភូមិបាននិយាយថា គាត់បានចូលរួមប្រជុំជាមួយ តាមុត ដែរឬទេ? ឆ.33៖ ចាស គេបានប្រកាសប្រាប់ពួកខ្ញុំថា គាត់បានប្រជុំជាមួយ តាមុត និងប្រាប់អំពីផែនការថ្មីៗរបស់អង្គការ។ សៈ តើមេភូមិគាត់ប្រាប់ថា គាត់

បានណែនាំឲ្យប្រធានសហករណ៍នៅចំណោត រាម ចូលរួមប្រជុំនៅក្រុងកំពង់សោម តាមរយៈសំណើជាលាយលក្ខណ៍អក្សរ ដែលប្រគល់ដោយនីរសាររបស់គាត់[524]។

<u>ការដ្ឋានស្ទឹងហាវ</u>

193. ការដ្ឋានទាំងប៉ុន្មាននៅស្ទឹងហាវ ស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់មនុស្សក្រោមបង្គាប់របស់ **មាស មុត** ដែលបានជូនដំណឹងគាត់អំពីការកសាងកំពង់ផែ និងផ្លូវនៅទីតាំងនោះ។ កម្មាភិបាលចំនួនរាប់រយនាក់ និងប្រហែលរាប់ពាន់នាក់នៃកងពលធំ១៦៤ ត្រូវបានបង្ខំឲ្យធ្វើការងារលំបាកជាច្រើនម៉ោង ក្រោមលក្ខខណ្ឌដ៏យ៉ាប់យ៉ឺន។ ពលករត្រូវបានចាប់ខ្លួន រងទារុណកម្ម បាត់ខ្លួន និងសម្លាប់ជាញឹកញាប់ដោយសារឋានៈជាខ្មាំងរបស់ពួកគាត់ដែលត្រូវបានគេសន្មត[525]។

194. ដើម្បីគ្រប់គ្រងការដ្ឋានទាំងនេះ **មាស មុត** បានតែងតាំងកម្មាភិបាលនានាក្រោមការគ្រប់គ្រងរបស់គាត់ដូចជាបង មាស អ៊ឹម[526] លេខាវរសេនាធំ១៦២ អៀក ម៉ាញ[527] និងមុនពេលពួកគាត់ត្រូវបាន

---

បានប្រជុំជាមួយ តាមុត ញឹកញាប់ដែរឬទេ? ឆ.34៖ ខ្ញុំមិនដឹងថា គេនិយាយយការពិត ឬកុហកនោះទេ ដែលថា គាត់បានប្រជុំជាមួយ តាមុត ១ ខែម្តង"]។

524 ឯកសារ D59/1/4.25 កិច្ចសម្ភាសន៍ជាមួយ ឡុង លី KH ERN 00930812 ["ធ្វើការតែជាមួយគ្នា កន្លែងធ្វើការគាត់ [មុត] នៅឆ្ងាយពីយើងអីចឹងទៅ យើងនៅសហករណ៍នេះ ដល់ពេលគាត់មានការអី គាត់ឲ្យនីរសារគាត់យកសំបុត្រមកឲ្យ ថ្ងៃនេះយើងប្រជុំ ឬថ្ងៃនេះ យើងអី ទៅតាមណាត់"]។

525 សូមមើល VIII.ង. ការដ្ឋានស្ទឹងហាវ។

526 ឯកសារ D54/49 កំណត់ហេតុស្តាប់ចម្លើយ អែម សុខ ឆ.34-35 ["អ៊ឹម ជាគណៈកម្មាធិការកសាងផែនៅស្ទឹងហាវ។ អ៊ឹម ជាប្អូនប្រុសរបស់ មាស មុត ដែលមានឪពុកផ្សេងគ្នា។ សៈ តើ អ៊ឹម មានតួនាទី និងមុខងារជាអ្វី? ឆ.35៖ ខ្ញុំឮថា ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ គាត់ជាប្រធានសហករណ៍។ បន្ទាប់ពីរំដោះឆ្នាំ ១៩៧៥ មាស មុត បានយកគាត់ទៅជាមួយ ហើយតែងតាំងគាត់ជាគណៈស្ទឹងហាវ"]។ ឯកសារ D54/78.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល KH ERN 00926615 ["តាអ៊ឹម ហ្នឹង ប្អូន មាស មុត"]។

527 ឯកសារ D114/214 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.30, 32-33 ["សៈ សៈ តើលោកចង់សំដៅទៅលើការដ្ឋានណាមួយដែរ? ឆ.30៖ ឈ្មោះ មៀញ [...] សៈ តើឈ្មោះ មៀញ ត្រូវរាយការណ៍ជូនដល់ថ្នាក់លើកគាត់ឈ្មោះអីដែរ? ឆ.32៖ ឈ្មោះ មៀញ រាយការណ៍ទៅ មាស មុត ហ្នឹង សៈ តើគាត់រាយការណ៍ទៅ មាស មុត ដោយផ្ទាល់តែម្តង? ឆ.33៖ បាទ ផ្ទាល់"]។ ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.4-6, 66, 77 ["ឈ្មោះ មៀញ នេះ តួនាទីរបស់គាត់ជា មេបញ្ជាការវរសេនាធំ [...] សៈ យើងទៅតាមឯកសាររបស់យើង គឺមានតែឈ្មោះ មៀញ ម្នាក់ទេ ក្នុងកងបល ១៦៤ ដែលមានឈ្មោះ ពេញ អៀកមៀញ ហើយគាត់គឺជាមេកងវរសេនាធំ ៦២ ក្រោមកងពល ១៦៤។ តើយើងកំពុងនិយាយអំពីឈ្មោះមនុស្សតែមួយមែនទេ? ឆ.6៖ មនុស្សតែមួយទេ។ [...] សៈ សៈ ពាក់ព័ន្ធ

ឃោសសម្អាត ទៅអនុប្រធានរបស់គាត់ឈ្មោះ ឌឹម និង ឆាន[528]។ ឯកសារ ប.ក.ក ដែលនៅសេស សល់ទាក់ទងនឹងស្ទឹងហាវ បង្ហាញអំពីការដឹងឮជាក់លាក់របស់ **មាស មុត** និងការចូលរួមដ៏សកម្ម ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ។

195. នៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ **មាស មុត** បានប្រាប់ សុន សេន ថា នៅស្ទឹងហាវ កងពលធំ របស់គាត់បាន "បញ្ឈប់ទូកកម្លាំងប្រាំពីរសេះដែលបានដឹកមនុស្ស អង្ករបីបាវ និងកាំភ្លើងអាកាពីរ ដើម។ យើងមិនប្រាកដថា តើមនុស្សទាំងនោះជាទាហាន ឬ [អ្នកធ្វើដំណើរ] ឬយ៉ាងណាឡើយ។ យើងកំពុងស៊ើបអង្កេតបញ្ហានេះ។ របាយការណ៍បន្ថែមនឹងត្រូវបានបញ្ជូននៅពេលក្រោយ នៅពេល ព័ត៌មានត្រូវបានបញ្ជាក់"[529]។ ក្រោយមកនៅឆ្នាំនោះ នៅថ្ងៃទី ៩ ខែ កញ្ញា នៅក្នុងអង្គប្រជុំកម្មាភិបា លកងពលធំ ១៦៤ សុន សេន បានទទួលព័ត៌មានអំពីមនុស្សមួយក្រុម ដែលមានគ្នាសែសិបនាក់ ដែលបានពិភាក្សាអំពីផែនការរត់គេចខ្លួនពីស្ទឹងហាវ ដោយសារស្ថានភាពនៅទីនោះ។ គណៈកម្មាធិ

---

នឹងការងារនៅការដ្ឋាន តើឈ្មោះ មៀញ នេះ ធ្លាប់ទទួលការណែនាំពីណាមកពីវិញដែរ? ឆ.66៖ ពីមុនមក គាត់ទទួល បញ្ជាផ្ទាល់ពី មាស មុត ហ្នឹង។ [...] ស៖ តើ មៀញ ស្នាក់នៅ និងធ្វើការនៅត្រង់ចំណុចណាដែរ? ឆ.77៖ ស្ទឹងហាវ"] ។

528 ឯកសារ D1.3.13.8 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ផេន សារិន EN ERN 00217562 ["អនុ របស់ មុត គឺ ឌឹម ហើយនិង នង ឆាន។ នៅឆ្នាំ ១៩៧៦ ឆាន គឺជាអ្នកគ្រប់គ្រងនៅតំបន់ស្ទឹងហាវហ្នឹង"]។ ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.22-24 ["ខ្ញុំជួប តាឆាន គាត់ទៅប្រជុំទៅណែនាំ គាត់ថា បើកន្លែង គាត់មានបញ្ហាផ្ទុះអាវុធ គាត់សួរថា តើគាត់សួរថា ពួកយើងជួយគាត់ ឬអត់. ស៖ តើគាត់បង្ហាត់អ្វីដល់លោក? ឆ.23៖ គាត់បង្រៀន គាត់ពន្យល់ ធ្វើការងារវ៉ៃថ្ម វ៉ៃអី។ ដល់ពេលគាត់សួរវិញ គាត់សួរអ៊ីចឹង។ ស៖ តើនេះនៅស្ទឹងហាវឬ? ឆ. 24៖ បាទ"]។ ឯកសារ D1.3.13.11 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សៀង (Sieng) EN ERN 00217564 ["អនុទី ១ របស់ មុត គឺ ឌឹម មកពីភូមិភាគបូព៌ា"]។ ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ីម ឆ.63 ["ខ្ញុំដឹងតែត្រឹមលោក ឌឹម យកខ្ញុំទៅធ្វើការនៅនុំងទេ ក្រៅពីហ្នឹងងទៀត ខ្ញុំមិនដឹងទេ"]។ សូមមើល ផងដែរ ឯកសារ D4.1.699 ទូរលេខ ១១ ពី ឌឹម ជូន បងមុត (មាស មុត) ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00092628 ["ពីរនាក់ (យុទ្ធជន) រត់អង្គភាពពីសង្ការ យុទ្ធជននេះ នឹងដូរពីកង ៦៣"]។

529 ឯកសារ D4.1.1020 ទូរលេខពី មុត (មាស មុត) ជូន បង ៨៩ (សុន សេន) ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ KH ERN 00021459 ["សភាពការណ៍មួយថ្ងៃកន្លងមក ពុំមានអ្វីគួរឲ្យចាប់អារម្មណ៍ធំដុំទេ នៅចំណុចនានា លើកលែងតែ នៅសង្ការ យើងចាប់ទូកមួយ ៧ សេះ មានមនុស្ស ៧ នាក់ ដឹកអង្ករ ៣ បាវ អាវុធអាកា ២ ដើម។ ពុំច្បាស់ជាទ័ព ឬចំ រពរចទេ។ កំពុងឲ្យពិនិត្យឲ្យច្បាស់ ព័ត៌មានច្បាស់ ជូនក្រោយ"]។

ការកងពលធំ ១៦៤ បាន "បែងចែកមនុស្សមិនល្អ និងបានដកពួកគាត់ចេញ ដើម្បីកុំឲ្យពួកគាត់នៅលាយឡំជាមួយមនុស្សល្អ"[530]។

196. សុន សេន បានណែនាំឲ្យកងពលធំស្វែរចម្លើយអ្នកដឹកនាំក្រុមភ្លាមៗ ដោយបាននិយាយថាវា "ហាក់ដូចជាមិនចំណេញក្នុងការបំបែកអ្នកដែលបានរត់គេចខ្លួនទៅអង្គភាពដទៃ។ ល្អិតណាមានខ្លាំងក្នុងចំណោមពួកគាត់ ពួកគាត់នៅតែអាចអនុវត្តសកម្មភាពរបស់ពួកគាត់។ ប្រវត្តិរូបរបស់ពួកគាត់ត្រូវក្តាប់ឲ្យច្បាស់ និងថាពួកគាត់ត្រូវដាក់ក្នុងក្រុមធ្វើស្រែ"[531]។ ជាងនេះទៀត នៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ អនុប្រធានកងពលធំ ១៦៤ ឈ្មោះ ឌឹម បានប្រាប់ **មាស មុត** ថា "យុទ្ធជន ២ នាក់ទៀត បានរត់ចោលអង្គភាពនៅស្ទឹងហាវ ពួកគាត់នឹងត្រូវបានបញ្ជូនពីអង្គភាព ៦៣"[532]។

197. **មាស មុត** ក៏បានធ្វើដំណើរជាទៀងទាត់ទៅស្ទឹងហាវ ដើម្បីទៅពិនិត្យ ឬប្រជុំពីពាក់កណ្តាលឆ្នាំ ១៩៧៦[533] រហូតដល់យ៉ាងហោចណាស់ឆ្នាំ ១៩៧៧[534] និងអាចដល់ឆ្នាំ ១៩៧៨[535]។ គាត់បានស្ថិត

---

530 ឯកសារ D54/8.1 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00936685។

531 ឯកសារ D54/8.1 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00936686 ។

532 ឯកសារ D4.1.699 ទូរលេខ ១១ ពី ឌឹម ជូន បងមុត (មាស មុត) ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00092628។

533 ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ីម ឆ.64 ["សៈ តើលោក មាស មុត ចាប់ផ្តើមទៅធ្វើទស្សនកិច្ចនៅការដ្ឋាននោះ នៅពាក់កណ្តាលឆ្នាំ ១៩៧៦ ដែរទេ? ឆ.64៖ មែន"]។

534 ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ីម ឆ.12, 39, 43 ["សៈ តើ មាស មុត បានទៅធ្វើទស្សនកិច្ចនៅទីតាំងសំណង់ស្ទឹងហាវញឹកញាប់ប៉ុនណាដែរ? ឆ.12៖ ធម្មតា មាស មុត មួយអាទិត្យមកជួបភ្ញៀវចិននៅការដ្ឋានស្ទឹងហាវម្តង។ [...] ឆ.39៖ ដើមឆ្នាំ ៧៧ បានជួប ដូចខ្ញុំកំណត់អ៊ីចឹង នៅស្ទឹងហាវ គាត់មកមួយអាទិត្យម្តង [...] ឆ. 43៖ ខ្ញុំបានជួបមួយអាទិត្យម្តង ពេលគាត់មកជួយបជាមួយភ្ញៀវចិន"]។

535 ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.16, 25 ["គេបញ្ជូនឲ្យខ្ញុំទៅធ្វើការនៅទីនោះ នៅថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ១៩៧៨។ [...] សៈ តើលោកដែលឃើញ មាស មុត មេបញ្ជាការកងពល ១៦៤ ទៅស្ទឹងហាវដែរឬទេ? ឆ.25៖ ទេ ខ្ញុំមិនដែលឃើញគាត់ទេ ប៉ុន្តែធ្លាប់ឮថា គាត់ធ្លាប់ទៅពិនិត្យការងារនៅទីនោះ មុនពេលដែលខ្ញុំទៅធ្វើការនៅទីនោះ"]។

នៅទីនោះមួយសប្តាហ៍ម្តង[536]។ ក្នុងទស្សនកិច្ចខ្លះក្នុងចំណោមទស្សនកិច្ចទាំងនោះ **មាស មុត** បានជួបអ្នកបច្ចេកទេស និងភ្ញៀវចិន ដោយបានស្នាក់នៅមួយយប់នៅទីតាំងនោះមួយរយៈផងដែរ[537]។

---

536 ឯកសារD114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.12, 39, 43 ["សំ៖ តើ មាស មុត បានទៅធ្វើទស្សនកិច្ចនៅទីតាំងសំណង់ស្ទឹងហាវញឹកញាប់ប៉ុនណាដែរ? ឆ.12៖ ធម្មតា មាស មុត មួយអាទិត្យមកជួបភ្ញៀវចិននៅការដ្ឋានស្ទឹងហាវម្តង។ [...] ឆ.39៖ ដើមឆ្នាំ ៧៧ បានជួប ដូចខ្ញុំកំណត់អ៊ីចឹង នៅស្ទឹងហាវ គាត់មកមួយអាទិត្យម្តង។ [...] ឆ.43៖ [...] ខ្ញុំបានជួបមួយអាទិត្យម្តង ពេលគាត់មកជួបជាមួយភ្ញៀវចិន"]។ ឯកសារ D114/146 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ញិក ឆ.52-53 ["នៅពេលនោះ យើងវាយថ្ម យកទៅធ្វើជាផែទាហាន។ ហើយពេលនោះ តាមុត ជិះឡានហ្ស៊ីបអាដឺ ទៅមើលកន្លែងធ្វើការជាញឹកញាប់។ សំ៖ ពេលដែលលោកនិយាយថា តាមុត តើលោកចង់មានន័យថា មាស មុត ឬយ៉ាងណា? ឆ.53៖ បាទ តាមុត គឺ មាស មុត"]។ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.26 ["សំ៖ តើលោកធ្លាប់បានឃើញ មាស មុត មកទស្សនកិច្ចនៅផែស្ទឹងហាវ ឬការដ្ឋានស្ទឹងហាវ ដែលកាលនោះលោកនៅមេវរសេនាតូច ៦១២ ដែរឬទេ? ឆ.26៖ បាទ ខ្ញុំបានឃើញគាត់ នៅពេលគេទៅសម្ពាធបើកការដ្ឋាន ឬពេលពួកចិនមកធ្វើទស្សនកិច្ចម្តងៗ ក៏ខ្ញុំឃើញដែរ"]។ ឯកសារ D1.3.13.8 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ផេន សារិន EN ERN 00217560 ["មាស មុត បានមកទស្សនកិច្ច [ស្ទឹងហាវ] ជាញឹកញាប់ ហើយគាត់ស្នាក់នៅស្ទឹងហាវហ្នឹង គាត់ស្នាក់នៅជាមួយកន្លែងដែលពួកអ្នកបច្ចេកទេសចិននៅ ដែលអគារហ្នឹង គឺនៅខាងជើងនៃមន្ទីរស្រុកបច្ចុប្បន្នហ្នឹង។"]។ សូមមើលផងដែរ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ញិក ឆ.55 ["សំ៖ តើ មាស មុត មកស្ទឹងហាវញឹកញាប់ប៉ុនណា? ឆ.55៖ គាត់មកប្រហែល ២ អាទិត្យម្តង"]។

537 ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.12, 39, 43 ["សំ៖ តើ មាស មុត បានទៅធ្វើទស្សនកិច្ចនៅទីតាំងសំណង់ស្ទឹងហាវញឹកញាប់ប៉ុនណាដែរ? ឆ.12៖ ធម្មតា មាស មុត មួយអាទិត្យមកជួបភ្ញៀវចិននៅការដ្ឋានស្ទឹងហាវម្តង។ [...] ឆ.39៖ ដើមឆ្នាំ ៧៧ បានជួប ដូចខ្ញុំកំណត់អ៊ីចឹង នៅស្ទឹងហាវ គាត់មកមួយអាទិត្យម្តង [...] ឆ. 43៖ ខ្ញុំបានជួបមួយអាទិត្យម្តង ពេលគាត់មកជួបជាមួយភ្ញៀវចិន"]។ ឯកសារ D114/146 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ញិក ឆ.52-53 ["នៅពេលនោះ យើងវាយថ្ម យកទៅធ្វើជាផែទាហាន។ ហើយពេលនោះ តាមុត ជិះឡានហ្ស៊ីបអាដឺ ទៅមើលកន្លែងធ្វើការជាញឹកញាប់។ សំ៖ ពេលដែលលោកនិយាយថា តាមុត តើលោកចង់មានន័យថា មាស មុត ឬយ៉ាងណា? ឆ.53៖ បាទ តាមុត គឺ មាស មុត"]។ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.26 ["សំ៖ តើលោកធ្លាប់បានឃើញ មាស មុត មកទស្សនកិច្ចនៅផែស្ទឹងហាវ ឬការដ្ឋានស្ទឹងហាវ ដែលកាលនោះលោកនៅមេវរសេនាតូច ៦១២ ដែរឬទេ? ឆ.26៖ បាទ ខ្ញុំបានឃើញគាត់ នៅពេលគេទៅសម្ពាធបើកការដ្ឋាន ឬពេលពួកចិនមកធ្វើទស្សនកិច្ចម្តងៗ ក៏ខ្ញុំឃើញដែរ"]។ ឯកសារ D1.3.13.8 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ផេន សារិន EN ERN 00217560 ["មាស មុត បានមកទស្សនកិច្ច [ស្ទឹងហៅ] ជាញឹកញាប់ ហើយគាត់ស្នាក់នៅស្ទឹងហាវហ្នឹង គាត់ស្នាក់នៅជាមួយកន្លែងដែលពួកអ្នកបច្ចេកទេសចិននៅ ដែលអគារហ្នឹង គឺនៅខាងជើងនៃមន្ទីរស្រុកបច្ចុប្បន្នហ្នឹង។"]។ សូមមើលផងដែរ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ញិក ឆ.55 ["សំ៖ តើ មាស មុត មកស្ទឹងហាវញឹកញាប់ប៉ុនណា? ឆ.55៖ គាត់មកប្រហែល ២ អាទិត្យម្តង"]។

## ការចូលរួមក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទ

198. **មាស មុត** បានអនុវត្តគោលនយោបាយ ប.ក.ក ដើម្បីបង្កើនចំនួនប្រជាជនតាមរយៈការបង្ខំឱ្យមនុស្សរៀបការ និងបន្ទាប់មកផ្សំដំណេកនៅកំពង់សោម។ គោលនយោបាយនេះត្រូវបានបញ្ជាក់

លម្អិតក្នុងទស្សនាវដ្តី *ទង់បដិវត្តន៍* និង *យុវជនបដិវត្តន៍*[538] និងផ្សព្វផ្សាយក្នុងសុន្ទរកថារបស់ នួន ជា, ខៀវ សំផន, អៀង សារី និង ប៉ុល ពត[539]។

538 ឯកសារ D4.1.872 ទង់បដិវត្ត ខែ តុលា-ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ KH ERN 00063246 ["ជាក់ស្តែង គឺប្រែក្លាយប្រទេសយើង ពីកសិកម្មអន់ថយទៅជាកសិកម្មសម័យឲ្យឆាប់រហ័សពី ១០ ឆ្នាំ ទៅ ១៥ ឆ្នាំខាងមុខ។ ពីកសិកម្មទៅឧស្សាហកម្មពី ១៥ ឆ្នាំ ទៅ ២០ ឆ្នាំ [...] [ការកសាងប្រទេសឲ្យឆាប់រហ័ស] គឺដើម្បីប្រជាជនយើងមានចំនួនកើនឆាប់រហ័ស"]។ ឯកសារ D4.1.874 យុវជនបដិវត្ត ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ KH ERN 00063614-15។ ឯកសារ D114/36.1.59 ការចេញផ្សាយរបស់បក្សកុម្មុយនីសត្តកម្ពុជា លោកទស្សនៈ បដិវត្ត និងមិនបដិវត្តចំពោះបញ្ហាកសាងគ្រួសារ, បោះពុម្ពសារជាថ្មីពីថ្ងៃទី ថ្ងៃទី ០២ ខែ កុម្ភៈ ១៩៧៤ នៅថ្ងៃទី ០២ ខែ មិថុនា ១៩៧៥ និងបោះពុម្ភផ្សាយម្តងទៀតនៅថ្ងៃទី ០២ ខែ កញ្ញា ១៩៧៥ (១០០០ច្បាប់)។ ឯកសារ D4.1.893 យុវជនបដិវត្ត ខែ តុលា ឆ្នាំ ១៩៧៨ KH ERN 00376494 ["ចំពោះបញ្ហាគ្រួសារបច្ចុប្បន្ននេះ គ្មានអ្វីជាឧបសគ្គទេ ឲ្យតែឈរលើគោលការណ៍របស់បក្សទាំងពីរយ៉ាងគឺ៖ ទី ១. សាមីខ្លួនទាំងសងខាង យប់ព្រម។ ទី ២. សមូហភាព យល់ព្រម ក៏ជាការស្របទៅហើយ។"]។ ឯកសារ D4.1.886 ទង់បដិវត្ត ខែ កញ្ញា-ខែ តុលា ឆ្នាំ ១៩៧៦ KH ERN 00063104 ["កម្មសិទ្ធិឯកជន មិនដែលឲ្យបច្ច័យល្អទេ [...] កម្មសិទ្ធិឯកជនវាប៉ះពាល់ដល់ផលប្រយោជន៍បដិវត្ត [...]អ្នកណាគិតគូរផលប្រយោជន៍គ្រួសារច្រើន តែងតែប្រាសចាកបដិវត្ត។ បះបង់បដិវត្ត រស់នៅដោយឡែក រកសុភមង្គលក្នុងគ្រួសារវិញ មិនរកសុភមង្គលក្នុងបក្សទេ [...] ទំនាស់ជាមួយបក្ស"]។ ឯកសារ D4.1.888 ទង់បដិវត្ត ខែធ្នូ ឆ្នាំ ១៩៧៦-ខែ មករា ឆ្នាំ ១៩៧៧ KH ERN 00063054 [នួន ជា៖ "សារៈសំខាន់នៃបដិវត្តសង្គមនិយម នឹងការកសាងសង្គមនិយម មានទិសដៅ កសាងប្រទេសឲ្យបានល្អ ការពារប្រទេសបានល្អ និងដោះស្រាយជីវភាពប្រជាជនបានឆាប់រហ័ស។ យើងត្រូវការប្រជាជនពី ១៥ ទៅ ២០ លាន់ ទើបគ្រប់គ្រាន់ នឹងដីយើង។ ដើម្បីឲ្យប្រជាជនកើនបានឆាប់ ទាន់តែជីវភាពឡើង សុខភាពបានល្អ [...] ដូច្នេះ មានតែបង្កបង្កើនផលឲ្យបានរហ័ស"]។ ឯកសារ D4.1.864 ទង់បដិវត្ត ខែ កញ្ញា ឆ្នាំ ១៩៧៧ KH ERN 00063184 ["យើងខំពុះពារបែបប៉ន[...] ហើយប្រជាជនកម្ពុជាបានកើនឡើងជាលំដាប់ យ៉ាងឆាប់រហ័សដើម្បីការពារ និងកសាងកម្ពុជាយើង ឲ្យរីកលូតលាស់ ចំរុងចំរើនឈោតឆ្ពោះ"]។ ឯកសារ D4.1.871 ទង់បដិវត្ត ខែ កញ្ញា ឆ្នាំ ១៩៧៨ KH ERN 00064617-18 [ប៉ុល ពត៖ "នយោបាយបង្កើនប្រជាជនរបស់យើង ក៏កំពុងទទួលបានលទ្ធផលល្អ [...] ពីពាក់កណ្តាលឆ្នាំ ១៩៧៧ ដល់ពាក់កណ្តាល ១៩៧៨ ចំនួនទារកដែលកើតថ្មី មានចំនួន ៣៩២ ០០០ នាក់ក្នុងចំនួនមនុស្ស ៧ ៨០០ ០០០ នាក់ [...] បច្ចុប្បន្ននេះ ចំនួនមនុស្សដែលស្លាប់ទៅវិញ មានមិនដល់ ១៣ ភាគពាន់ទេ ដោយបច្ចុប្បន្ននេះ ចំនួនទារក និងកុមារស្លាប់មានការថយច្រើន។ ដូច្នេះ ចំនួនប្រជាជនយើងមានការកើនលឿនជាងកាលជំនាន់មុនរដ្ឋប្រហារ។ ប៉ុន្តែ លឿននេះនៅមិនទាន់គ្រប់គ្រាន់ទេ បើប្រៀបធៀប និងសំណូមពររបស់បក្សដែលសំដៅឲ្យបង្កើនប្រជាជនឲ្យបានពី ១៥ ទៅ ២០ លាននាក់ ក្នុងរយៈពេល ១០ ទៅ ១៥ ឆ្នាំ"]។

539 ឯកសារ D54/74.1.6 ឯកសារ D114/29.1.5 FBIS សុន្ទរកថារបស់ ប៉ុល ពត នៅអង្គប្រជុំខួបប្រចាំឆ្នាំរបស់បក្សកុម្មុយនីស្តកម្ពុជា ថ្ងៃទី ៤ ខែ តុលា ឆ្នាំ ១៩៧៧ EN ERN 00168651 ["យើងចង់ឲ្យចំនួនប្រជាជនរបស់យើងកើនដល់ ១៥ ទៅ ២០ លាន នាក់នៅក្នុងរយៈពេល ១០ ឆ្នាំខាងមុខ ឬក៏ច្រើនជាងនេះទៀត [...] យើងត្រូវតែខំប្រឹងទ្វេដង [...] ដូច្នេះប្រជាជនកម្ពុជារបស់យើងជាទូទៅអាចមានចំនួនច្រើនយ៉ាងឆាប់រហ័ស ដើម្បីការពារ និងកសាងកម្ពុជា

យើង ឲ្យរីកលូតលាស់ ចំរុងចំរើនលោតផ្លោះ ។ យើងគ្មានហេតុផលកាត់បន្ថយ [...] ចំនួនប្រជាជនយើងនោះទេ [...] ដោយសារថា ចំនួនប្រជាជនយើងបច្ចុប្បន្ន - ជិត ៨ លាននាក់ - នៅតែតិចណាស់មិនអាចទប់ទល់នឹងសក្តានុពលរបស់ប្រទេសយើងបានទេ ដែលទាមទារឱ្យប្រជាជនកម្ពុជាឲ្យមានចំនួនច្រើនជាង ២០ លាននាក់។ ដូច្នេះ គោលបំណងរបស់យើង គឺបង្កើនចំនួនប្រជាជនឲ្យបានលឿន តាមដែលយើងអាចធ្វើបាន"]។ ឯកសារ D64.1.44 FBIS ការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការផ្តល់ជំនួយខាងថ្នាំពេទ្យទូទៅទាំងប្រទេស ថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨ EN ERN 00170124 ["ខណៈពេលដែលព្យាយាមទប់ស្កាត់ជំងឺ ត្រូវអារម្មណ៍ លើបញ្ហាអនាម័យ និងអាហារូបត្ថម្ភ។ ទាំងអស់នេះគឺដើម្បីបង្កើនសុខភាពរបស់ប្រជាជនយើង និងបង្កើនចំនួនប្រជាជនរបស់យើង ឲ្យបាន ១៥ ទៅ ២០ លាននាក់នៅក្នុងរយៈពេល ១០ ទៅ ១៥ ឆ្នាំ ខាងមុខ"]។ ឯកសារ D114/36.1.8 FBIS អត្ថបទតាមវិទ្យុអំពីសេចក្តីថ្លែងការណ៍របស់លោកអៀង សារី នៅអង្គការសហប្រជាជាតិនៅថ្ងៃទី ១១ ខែតុលា ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ១៩៧៧ EN ERN 00168718 ["យើងបន្តព្យាយាមពង្រឹងជីវភាពរស់នៅ និងសុខភាពរបស់ប្រជាជនយើង ពីព្រោះថាយើងចង់ឲ្យប្រជាជនយើងកើនឡើង ទៅ ១៥-២០ លាន់នាក់នៅក្នុងរយៈពេល ១០ ខាងមុខ"]។ ឯកសារ D64.1.45 FBIS សេចក្តីសន្និដ្ឋានចំពោះសុន្ទរកថារបស់ ប៉ុល ពត នៅក្នុងកិច្ចប្រជុំនៅភ្នំពេញ នៅថ្ងៃទី ២៧ ខែកញ្ញា ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៧៨ EN ERN 00170168 ["គោលនយោបាយបង្កើនប្រជាជនយើង កំពុងទទួលបានលទ្ធផលល្អជាជំហានដំបូងហើយ។ ពីពាក់កណ្តាលឆ្នាំ ១៩៧៧ ដល់ពាក់កណ្តាលឆ្នាំ ១៩៧៨ ចំនួនទារកដែលកើតថ្មីមានចំនួន ៣៩២ ០០០ នាក់ ក្នុងចំនួនប្រជាជន ៧ ៨០០ ០០០ នាក់។ ដូច្នេះ ចំនួនប្រជាជនយើងមានការកើនល្បឿនជាងកាលជំនាន់មុនរដ្ឋប្រហារ។ ប៉ុន្តែ ល្បឿននេះនៅតែមិនគ្រប់គ្រាន់ទេ បើគិតពីគោលដៅបង្កើនចំនួនប្រជាជនរបស់យើងឲ្យដល់ ១៥ ទៅ ២០ លានក្នុងរយៈពេលពី ១០ ឆ្នាំ ទៅ ១៥ ឆ្នាំខាងមុខនេះ។ ដូច្នេះ យើងត្រូវយកចិត្តទុកដាក់លើកស្ទួយ និងថែបំប៉នជីវភាពប្រជាជន និងថែបំប៉នសុខភាពប្រជាជនយើងឲ្យកាន់ល្អថែមទៀត [...] ដើម្បីបង្កើនចំនួនប្រជាជនរបស់យើងឲ្យកាន់តែបានឆាប់រហ័ស"]។ សូមមើលផងដែរ ឯកសារ D4.1.189 សេចក្តីថ្លែងការណ៍របស់ អៀង សារី ជូនមហាសន្និបាតអង្គការសហប្រជាជាតិ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៧៧ KH ERN 00291028 កថាខណ្ឌ ៦០ និង ៦៣ ["60. [...] យើងត្រូវការប្រជាជនចំនួន ១៥ ទៅ ២០ លាន់នាក់ ក្នុងរយៈពេល ១០ ឆ្នាំខាងមុខ [...] 63. ប្រជាជនយើង នៅខ្វះច្រើនណាស់ធៀបនឹងសមត្ថភាពរបស់ប្រទេសយើង ដែលត្រូវការប្រជាជនជាង ២០ លាន់នាក់"]។ ឯកសារ D234/2.1.33 សុន្ទរកថារបស់ ខៀវ សំផន ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៨ KH ERN 00249991 [ខៀវ សំផន បង្ហាញពីសេចក្តីសម្រេចស្រាយនានាដែលបក្សបានអនុម័ត រួមមាន "(៦) [...] សម្រេចតាមគោលដៅឲ្យមានប្រជាជនចំនួន ១៥ ទៅ ២០ លាន នាក់ ក្នុងរយៈពេលពី ១០ ទៅ ១៥ ឆ្នាំខាងមុខ " និង "(៧) [...] បង្កើនបរិមាណប្រជាជនសម្រាប់រយៈពេលមួយឆ្នា បីឆ្នាំ ប្រាំឆ្នាំ និង ១៥ ឆ្នាំ"]។ ឯកសារ D4.1.1013 សុន្ទរកថារបស់ ប៉ុល ពត ទៅកាន់គណៈប្រតិភូរបស់សមាគមប៊ែលហ្សិក-កម្ពុជា ថ្ងៃទី ៥ ខែ សីហា ឆ្នាំ ១៩៧៨ KH ERN 00106284 ["បក្សកុម្មុយនីស្តកម្ពុជាប្រជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ មានផែនការបង្កើនចំនួនប្រជាជន ពី ១៥ ទៅ ២០ លាន ក្នុងរយៈពេលពី ១០ ទៅ ១៥ ឆ្នាំ"]។ ឯកសារ D234/2.1.22 សេចក្តីថ្លែងការណ៍របស់កម្ពុជាប្រជាធិបតេយ្យទៅកាន់អង្គការសហប្រជាជាតិ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៧៨ KH ERN 00701215-16 ["ធានាថា ប្រជាជនកម្ពុជាកើនឡើងយ៉ាងឆាប់រហ័ស ដើម្បីការពារ និងអភិវឌ្ឍប្រទេស និងសម្រេចបានភាពរុងរឿងមហាលោតផ្លោះ មហាអស្ចារ្យ [...]

199. ទស្សនៈដែលថាបក្សបានកំណត់លើគ្រប់ផ្នែកនៃការរៀបចំអាពាហ៍ពិពាហ៍ ត្រូវបានពិភាក្សាដោយចំហក្នុងឯកសារបោះពុម្ពផ្សាយទាំងនោះ។ ឧទាហរណ៍ ឯកសារបោះពុម្ពផ្សាយរបស់ ប.ក.ក ចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ១៩៧៥ បានគូសបញ្ជាក់ថា៖

> នៅពេលរៀបការ ចាំបាច់ធ្វើសំណើដោយស្មោះត្រង់ទៅអង្គការ ទៅសហករណ៍ ដើម្បីឱ្យពួកគាត់ជួយ [...]។ ត្រូវតែអង្គការវិន័យដាច់ខាត។ ក្នុងបញ្ហាកសាងគ្រួសារ ទោះជាលទ្ធផលនៃការវាយតម្លៃ និងការសម្រេចរបស់អង្គការ និងសហករណ៍ យ៉ាងដូចម្ដេចក៏ដោយ ពួកគាត់ត្រូវតែគោរពដាច់ខាត[540]។

200. ចេតនាពីក្រោយគោលនយោបាយនេះគឺដូចគ្នាទៅនឹងអ្វី ដែលត្រូវបានឃោសនាជាសាធារណៈដោយមេដឹកនាំកំពូលរបស់ ប.ក.ក ដូចជា ប៉ុល ពត ដែលបានប្រកាសថា "គោលនយោបាយបង្កើនចំនួនប្រជាជនរបស់ ប.ក.ក" "ពុំទាន់គ្រប់គ្រាន់ឡើយ បើប្រៀបធៀបជាមួយគោលបំណង

---

ចំនួនប្រជាជន ៨ លាននាក់សព្វថ្ងៃនេះ គឺមានកម្រិតទាប ជាងសក្ដានុពលប្រទេស ដែលត្រូវការចំនួនប្រជាជនជាង ២០ លាននាក់ឯណោះ"]។

540 ឯកសារ D114/36.1.59 ការចេញផ្សាយរបស់បក្សកុម្មុយនីស្ដកម្ពុជា លោកទស្សនៈ បដិវត្ត និងមិនបដិវត្តចំពោះបញ្ហាកសាងគ្រួសារ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៧៥ EN ERN 00417943, FN ERN 00593929, KH ERN 00407100 ["ដូច្នេះ ការកសាងគ្រួសារបដិវត្តយើង គឺមិនមែនគ្រាន់តែដើម្បីផលប្រយោជន៍កូន គួរបានសុខ បានសប្បាយ មានកូនមានចៅសំរាប់បន្តពូជវង្សខ្លួនប៉ុណ្ណោះទេ។ តែសំខាន់គឺដើម្បីធ្វើបដិវត្ត សំរាប់ភារកិច្ច ដ៏ឧត្តុង្គឧត្តមរំដោះប្រទេសជាតិ"]EN ERN 00417943, FN ERN 00593930, KH ERN 00407100-01 ["1. (...) បើមានការអីត្រូវលើកស្នើដល់អង្គការ ដល់សមូហភាព ដោយស្មោះត្រង់ ឲ្យជួយដោះស្រាយ។ 2. ត្រូវគោរពអង្គការ វិន័យដាច់ខាត។ ក្នុងបញ្ហាកសាងគ្រួសារនេះ បើអង្គការសមូហភាព ពិនិត្យឃើញយ៉ាងណា សំរេចយ៉ាងណា ត្រូវគោរពតាមដាច់ខាត"]។ សូមមើលផងដែរ ឯកសារ D4.1.874 យុវជនបដិវត្ត ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ EN ERN 00522460, FN ERN 00525856-57, KH ERN 00063614-15 ["នៅក្នុងជួរបដិវត្តយើង យុទ្ធជន-យុទ្ធនារី និងកម្មាភិបាលយើងទាំងអស់ សុទ្ធតែបានលះបង់កម្មសិទ្ធិផ្ទាល់ខ្លួន ជាផ្ទះសំបែង ស្រែចំការ ច្បារដំណាំ ជាគ្រួសារម៉ែឪ បងប្អូនកូនចៅ និងឯងជាទ្រព្យសម្បត្តិផ្សេងៗទៀតទាំងអស់ ដើម្បីបម្រើបក្ស បដិវត្ត និងប្រជាជន"]។ ឯកសារ D114/36.1.60 ទូរលេខ ៦១ ពីកាន ជូនបងជាទីគោរពស្នេហា ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ១៩៧៨ EN ERN 00434864, FN ERN 00623009 KH ERN 00020965-66 ["ចម្លើយរបស់ កាន ៖ [...] សមាជិកកងចល័តអាចរៀបចំគ្រួសារឲ្យតែស្នើត្រឹមត្រូវ គណៈបញ្ជាការកងចល័ត ឬកងសហករណ៍សម្រេចរៀបចំគ្រួសារឱ្យគេបាន"]។ ឯកសារ D54/74.1.20 Philip Short, ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់ EN ERN 00396533-34, FN ERN 00639883 ["គ្រួសារនៅតែបន្តមាន ប៉ុន្តែ [...] គោលបំណងចម្បងរបស់បក្ស គឺ"ធ្វើជាម៉ែឪកុមារដើម្បីបម្រើបក្ស"។ ទំនាក់ទំនងរវាងសមាជិកគ្រួសារម្នាក់ៗធ្វើឱ្យខ្សោយៗទៅនៅក្នុងសហគមន៍ជារួម [...] 'ការជ្រើសរើសគូស្រករដោយសេរី" ត្រូវថ្កោលទោសដាច់ខាត"]។

របស់បក្ស” ដែល “បង្កើនប្រជាជនឲ្យបានចំនួន ១៥ ដល់ ២០ លាននាក់ក្នុងរយៈពេលដប់ ទៅដប់ប្រាំឆ្នាំ”[541]។

201. **មាស មុត** បានផ្សព្វផ្សាយអំពីគោលនយោបាយនេះ ក្នុងតំបន់ក្រោមការទទួលខុសត្រូវរបស់គាត់ និងបានណែនាំកម្មាភិបាលឲ្យរៀបចំអាពាហ៍ពិពាហ៍សម្រាប់ទាហានកងពលធំ ១៦៤។ ឧទាហរណ៍ ក្នុងឆ្នាំ ១៩៧៨ ក្នុងអំឡុងវគ្គរៀនសូត្រមួយ ដែលធ្វើនៅឆ្នេរអូរឈើទាលនៅកំពង់សោម **មាស មុត** បានបង្ហាញ “ផែនការអាពាហ៍ពិពាហ៍ប្រចាំឆ្នាំស្ដីពីចំនួនគូស្រករដែលត្រូវរៀបការ”[542]។ ក្នុងអង្គប្រជុំនោះ **មាស មុត** និងសមាជិកកងពលធំ ១៦៤ ឈ្មោះ តា ញ៉ន “បានពិនិត្យសំណើទាំងអស់ដែលត្រូវបានធ្វើ និងបានសម្រេចអំពីចំនួនគូស្រករដែលត្រូវរៀបការ”[543]។

202. **មាស មុត** បានណែនាំកម្មាភិបាលឲ្យ “ពិនិត្យសំណើអាពាពិពាហ៍ទាំងអស់ និងរៀបការពួកគាត់” និងបានពន្យល់ជាសាធារណៈថា នេះជាការចាំបាច់ដើម្បីសម្រេចគោលដៅបក្ស ក្នុងការបង្កើនចំនួន

---

541 ឯកសារ D4.1.871 ទង់បដិវត្ត ខែ កញ្ញា ឆ្នាំ ១៩៧៨ KH ERN 00064617-18 [ប៉ុល ពត៖ “នយោបាយបង្កើនប្រជាជនរបស់យើង ក៏កំពុងទទួលបានលទ្ធផលល្អ [...] ចំនួនប្រជាជនយើងមានការកើនលឿន ជាងកាលជំនាន់មុនរដ្ឋប្រហារ។ ប៉ុន្តែល្បឿននេះនៅមិនទាន់គ្រប់គ្រាន់ទេ បើប្រៀបធៀប និងសំណូមពររបស់បក្ស ដែលសំដៅឲ្យបង្កើនប្រជាជនឲ្យបានពី ១៥ ទៅ ២០ លាននាក់ ក្នុងរយៈពេល ១០ ទៅ ១៥ ឆ្នាំ”]។ សូមមើលផងដែរ ឯកសារ D4.1.1056 កំណត់ហេតុស្ដាប់ចម្លើយ ជួន ធី ឆ.4 [“[នៅសន្និបាលមួយ ប៉ុល ពត] បានបន្ថែមថា “យើងត្រូវបង្កើនចំនួនប្រជាជនក្នុងរយៈពេល ១០ ទៅ ២០ ឆ្នាំឲ្យបានពី ២០ ទៅ ៣០ លាននាក់ ដើម្បីការពារប្រទេស”។ ក្នុងន័យនេះ ប៉ុល ពត បានបញ្ជាក់ថា គាត់តម្រូវឲ្យមានការរៀបចំឲ្យមានអាពាហ៍ពិពាហ៍ ដើម្បីបង្កើនចំនួនប្រជាជន ដោយឲ្យថ្នាក់ក្រោមបង្គាប់ជាអ្នករៀបចំអាពាហ៍ពិពាហ៍របស់ប្រជាជន”]។

542 ឯកសារ D114/103 កំណត់ហេតុស្ដាប់ចម្លើយ លៀត ឡូន ឆ.96, 204, 207-209 [“ស៖ តើលោកជួយ [មាស មុត] នៅក្នុងឆ្នាំណា? ឆ.96៖ ពេលខ្ញុំត្រឡប់មកពីចិនវិញ នៅឆ្នាំ ១៩៧៨ [...] ស៖ ហេតុអ្វីបានជាលោកដឹងពីគោលនយោបាយហ្នឹង? ឆ.204៖ គោលនយោបាយនេះត្រូវបានបង្ហាញក្នុងវគ្គរៀនសូត្រ ដែលមាន តាមុត និង តាញ៉ាន់ ធ្វើជាអធិបតី។ ពួកគេបានដាក់ចេញនូវផែនការប្រចាំឆ្នាំអំពីចំនួនគូដែលគួររៀបការ។ [...] ស៖ តើវគ្គរៀនសូត្រហ្នឹង គេរៀបចំនៅកន្លែងណា? ឆ.207៖ នៅអូរឈើទាល ស៖ តើនៅក្នុងឆ្នាំណា? ឆ.209៖ ប្រហែល ១ ខែក្រោយ ពេលខ្ញុំត្រឡប់មកពីចិនវិញ”]។

543 ឯកសារ D114/103 កំណត់ហេតុស្ដាប់ចម្លើយ លៀត ឡូន ឆ.204 [“ស៖ ហេតុអ្វីបានជាលោកដឹងពីគោលនយោបាយហ្នឹង? ឆ.204៖ គោលនយោបាយនេះត្រូវបានបង្ហាញក្នុងវគ្គរៀនសូត្រ ដែលមាន តាមុត និង តាញ៉ាន់ ធ្វើជាអធិបតី។ ពួកគេបានដាក់ចេញនូវផែនការប្រចាំឆ្នាំអំពីចំនួនគូដែលគួររៀបការ។ ពួកគេបានពិនិត្យមើលសំណើសុំរៀបការកន្លងមកទាំងអស់ ហើយកំណត់គូដែលត្រូវរៀបការ”]។

ប្រជាជនឱ្យបាន ២០ លាននាក់[544]។ ការណែនាំនេះត្រូវបានអនុវត្តដោយកម្មាភិបាលជាន់ខ្ពស់នៃកងពលធំ ១៦៤ ដែលបានអនុវត្តផែនការអាពាហ៍ពិពាហ៍ប្រចាំឆ្នាំក្នុងអង្គភាពរបស់ពួកគាត់[545]។

---

544 ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ឆ.206 ["សៈ ពេលលោកទៅចូលរួមវគ្គរៀនសូត្រ តើ តាមុត និយាយអ្វីពីគោលនយោបាយរៀបការ? ឆ.206៖ តាមុត និយាយថា យើងគួរពិនិត្យលើសំណើទាំងអស់ដែលស្នើសុំរៀបការ ហើយរៀបការឱ្យអ្នកទាំងនោះឱ្យអស់។ ធ្វើតាមរបៀបនេះ យើងអាចសម្រេចគោលដៅរបស់យើងចំនួនពីរ ទី ១ ពង្រីកចំនួនប្រជាជនដល់ជាង ២០ លាន និងទី ២ ដោះស្រាយការមិនសប្បាយចិត្តរបស់អ្នកដែលស្នើសុំរៀបការយូរមកហើយ ប៉ុន្តែមិនទាន់បានរៀបការ"]។ សូមមើលផងដែរ ឯកសារ D4.1.871 ទង់បដិវត្ត ខែ កញ្ញា ឆ្នាំ ១៩៧៨ KH ERN 00064617-18 [ប៉ុល ពត៖ "នយោបាយបង្កើនប្រជាជនរបស់យើងក៏កំពុងទទួលបានលទ្ធផលល្អ [...] ពីពាក់កណ្តាលឆ្នាំ ១៩៧៧ ដល់ពាក់កណ្តាល ១៩៧៨ ចំនួនទារកដែលកើតថ្មី មានចំនួន ៣៩២ ០០០ នាក់ក្នុងចំនួនមនុស្ស ៧ ៨០០ ០០០ នាក់ [...] បច្ចុប្បន្ននេះ ចំនួនមនុស្សដែលស្លាប់ទៅវិញ មានមិនដល់ ១៣ ភាគពាន់ទេ ដោយបច្ចុប្បន្ននេះ ចំនួនទារក និងកុមារស្លាប់មានការថយច្រើន។ ដូច្នេះ ចំនួនប្រជាជនយើងមានការកើនលឿន ជាងកាលជំនាន់មុនរដ្ឋប្រហារ។ ប៉ុន្តែ ល្បឿននេះនៅមិនទាន់គ្រប់គ្រាន់ទេ បើប្រៀបធៀប និងសំណូមពររបស់បក្ស ដែលសំដៅឱ្យបង្កើនប្រជាជនឱ្យបានពី ១៥ ទៅ ២០ លាននាក់ ក្នុងរយៈពេល ១០ ទៅ ១៥ ឆ្នាំ"]។

545 ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ឆ.211-212 ["សៈ តើលោកដឹងថា មានកំណត់ផែនការថា រៀបការប៉ុន្មានគូនៅក្នុងអង្គភាពរបស់លោកទេ? ឆ.211៖ បាទ ខ្ញុំមានផែនការ ហើយផែកការខ្ញុំ គឺត្រូវរៀបការឱ្យសមាជិកទាំងអស់របស់កងខ្ញុំ។ ខ្ញុំរៀបការឱ្យពួកគេបានច្រើនគូដែរ។ ខ្ញុំរៀបការឱ្យម្តងបានតែពីរគូទេ។ ខ្ញុំមិនបានរៀបចំពិធីឱ្យដល់ទៅបួនគូឡើយ។ សៈ បន្ទាប់ពីរៀបការឱ្យគេហើយ តើលោករាយការណ៍ទៅថ្នាក់លើថា រៀបការប៉ុន្មានគូៗទេ? ឆ.212៖ តាមពិតខ្ញុំបានស្នើសុំច្បាប់អនុញ្ញាតរៀបការឱ្យគេតាំងពីមុនពិធីទៅទៀត"]។ សូមមើលផងដែរ ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.22-25, 30, 32, 34 ["សៈ តើនៅក្នុងកងពលធំលេខ ១៦៤ មានគោលនយោបាយរៀបការយ៉ាងម៉េចដែរ? ឆ.22៖ គូស្រករមិនបានស្គាល់គ្នាឡើយមុនពេលពួកគេរៀបការ រឿងនេះកើតឡើងចំពោះខ្ញុំ និងអ្នកដទៃផងដែរ។ នៅក្នុងករណីរបស់ខ្ញុំ គេប្រាប់ខ្ញុំមុនមួយថ្ងៃ ហើយថ្ងៃបន្ទាប់ ខ្ញុំត្រូវរៀបការតែម្តង ដោយយើងមិនស្គាល់គ្នាឡើយ ហើយយើងក៏មិនបានណាត់ជួបគ្នាដូចបច្ចុប្បន្ននេះដែរ គឺយើងរៀបការជាមួយគ្នាតែម្តង សៈ តើលោកនៅបន្តនៅជាមួយប្រពន្ធរបស់លោកដែរឬទេ? ឆ.23៖ បាទ។ សៈ ហេតុអ្វីបានជាដូច្នេះ? ឆ.24៖ ខ្ញុំមិនដឹងទេ។ ប៉ុន្តែប្រសិនបើអ្នកបដិសេធការស្នើរបស់ពួកគេ យើងខ្លាចថា យើងមានបញ្ហា។ សៈ តើពួកគេជាអ្នកណា? តើអ្នកណាជាអ្នកលើកសំណើនេះ? ឆ.25៖ ជាអ្នកមកពីកងវរសេនាធំ។ នីរសារម្នាក់មកពីកងវរសេនាធំម្នាក់មកប្រាប់ខ្ញុំថា ខ្ញុំនឹងត្រូវរៀបការ។ [...] សៈ តើពិធីរៀបការនេះធ្វើឡើងនៅកន្លែងណា? ឆ.30៖ នៅកំពង់សោម។ ពិធីរៀបការនោះធ្វើឡើងនៅជិតរូបតោបច្ចុប្បន្ននេះ មានតែ ៣ គូប៉ុណ្ណោះ ដែលគេរៀបការឱ្យនៅពេលនោះ។ ទីកន្លែងគឺជាកន្លែងភស្តុភារ។ [...] សៈ តើលោកធ្លាប់ប្រាប់គេថា លោកមិនចង់រៀការដែរឬទេ? ឆ.32៖ ខ្ញុំមិនបានតតាំងជាមួយពួកគេឡើយ ដោយសារខ្ញុំកត់សម្គាល់ឃើញថា អ្នកដែលមិនចុះសម្រុងគ្នាក្រោយពេលរៀបការរួច លែងទទួលបានការទុកចិត្តពីថ្នាក់លើរបស់ពួកគេទៀត ពួកគេនិយាយថា យើងមិនបានគោរពទៅតាមការរៀបចំរបស់អង្គការ។ [...] សៈ តើគោលនយោបាយស្តីពីការរៀបការនេះអនុវត្តលើមនុស្សទាំងអស់នៅក្នុងកងពលឬ? ឆ.34៖ គោល

ប្រធានផ្នែកប្រឆាំងនាវាមុជទឹក ឈ្មោះ លៀត ឡូន[546] បានបញ្ជាក់អះអាងថា "ផែនការរបស់គាត់ គឺរៀបការសមាជិកទាំងអស់នៃអង្គភាពរបស់ខ្ញុំ" និងថា គាត់បានរៀបការពួកគាត់ជាច្រើនតាមបញ្ជារបស់ **មាស មុត**[547]។

203. អាពាហ៍ពិពាហ៍ទាំងអស់ដែលបានធ្វើនៅកំពង់សោមក្នុងអំឡុងរបបនោះ ត្រូវតែមានការអនុញ្ញាតពីសំណាក់មេដឹកនាំកងពលធំ ១៦៤[548]។ **មាស មុត** ក្នុងឋានៈជាមេបញ្ជាការកងពលធំ បានមានសិទ្ធិ

---

នយោបាយនេះ គឺអនុវត្តជាទូទៅ"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.29-31 ["នៅពេលនោះ គឺមានច្បាប់នៅក្នុងកងពលលេខ ១៦៤ ដែលកំណត់ថា អ្នកដែលមានអាយុតិចជាង ២៥ ឆ្នាំ មិនអាចរៀបការបានទេ [...] ស៖ តើអ្នកណាជាអ្នកបង្កើតច្បាប់កំណត់អាយុរៀបការនៅអាយុ ២៥ ឆ្នាំ? ឆ.30៖ ប្រធានកង ជាអ្នកផ្សព្វផ្សាយអំពីច្បាប់នេះ នៅក្នុងពេលប្រជុំ។ ស៖ តើប្រជាជនអាចរៀបការបានលុះត្រាណាតែគេសុំច្បាប់រៀបការ ឬយ៉ាងណា? ឆ.31៖ បាទ ប្រជាជនអាចរៀបការបាន បើសិនជាគេស្នើសុំរៀបការ។ ខ្ញុំពុំធ្លាប់ដែលឃើញគូណាដែលគេបង្ខំឱ្យរៀបការទេ"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គីម ម៉េន ឆ.230-231, 234 ["ស៖ កាលសម័យនោះ កងពលធំអ្នកឱ្យរៀបចំការឬ? ឆ.230៖ បាទ។ ស៖ តើដូច្នេះខាងកងពលជាអ្នករើសគូស្រករឱ្យកងទ័ពមែនទេ? ឆ.231៖ បាទ ប៉ុន្តែគេក៏សួរយោបល់យើងដែរ។ [...] ស៖ [...] ពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ តើការរៀបចំរៀបការទាំងអស់ គឺកងពលជាអ្នករៀបចំឱ្យ ឬយ៉ាងម៉េច? ឆ.234៖ បើរៀបការ ការនៅកន្លែងកងពល។ ខាងកងពលរៀបការឱ្យ ព្រោះជាថ្នាក់ដឹកនាំកម្មាភិបាល ដូចជាវរសេនាតូច វរសេនាធំ។ បើយើងត្រឹមតែកងពលធម្មតា គឺគណៈកម្មការទៅតាមអង្គភាពគេរៀបការ"]។

546 ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ឆ.64-67 ["ស៖ តើលោកទៅបង្រៀននៅកន្លែងណា? ឆ. 64៖ នៅសមុទ្រតែម្តង ហើយខ្ញុំបង្រៀនបង្ហូកទេសបើកបរនាវាជាក់ស្តែង ស៖ តើលោកបង្រៀននៅជិតមូលដ្ឋានទ័ពតែម្តង? ឆ.65៖ បាទ។ ស៖ នៅមូលដ្ឋានទ័ពមួយណា? ឆ.66៖ នៅរាម។ ស៖ តើគេឱ្យមុខតំណែងលោកជាអ្វី? ឆ.67៖ ប្រធានផ្នែកប្រឆាំងនាវាមុជទឹក"]។

547 ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ឆ.211 ["ស៖ តើលោកដឹងថា មានកំណត់ផែនការថារៀបការប៉ុន្មានគូនៅក្នុងអង្គភាបរបស់លោកទេ? ឆ.211៖ បាទ ខ្ញុំមានផែនការ ហើយផែកការខ្ញុំ គឺត្រូវរៀបការឱ្យសមាជិកទាំងអស់របស់កងខ្ញុំ។ ខ្ញុំរៀបការឱ្យពួកគេបានច្រើនគូដែរ។"]។

548 ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ឆ.211-212 ["ស៖ តើលោកដឹងថា មានកំណត់ផែនការថា រៀបការប៉ុន្មានគូនៅក្នុងអង្គភាបរបស់លោកទេ? ឆ.211៖ បាទ ខ្ញុំមានផែនការ ហើយផែកការខ្ញុំ គឺត្រូវរៀបការឱ្យសមាជិកទាំងអស់របស់កងខ្ញុំ។ ខ្ញុំរៀបការឱ្យពួកគេបានច្រើនគូដែរ។ ខ្ញុំរៀបការឱ្យម្តងបានតែពីរគូទេ។ ខ្ញុំមិនបានរៀបចំពិធីឱ្យដល់ទៅបួនគូឡើយ ដោយសារគេខ្ញុំធ្លាប់ឮគេច្រឡំដៃគូគ្នា ហើយវាត្រូវការពេលវេលាយូរ បើរៀបការម្តងបួនគូ។ ស៖ បន្ទាប់ពីរៀបការឱ្យគេហើយ តើលោករាយការណ៍ទៅថ្នាក់លើថា រៀបការប៉ុន្មានគូៗទេ? ឆ.212៖ តាមពិតខ្ញុំបានស្នើសុំច្បាប់អនុញ្ញាតរៀបការឱ្យគេតាំងពីមុនពិធីទៅទៀត"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.31 [ទាហានកងវរសេនាតូច ២០ រៀបរាប់អំពីគោលនយោបាយរបស់កងពល ១៦៤៖ "ស៖ តើប្រជា

អំណាចមិនត្រឹមតែលើការសម្រេចអំពីអាពាហ៍ពិពាហ៍ទេ គឺថែមទាំងសម្រេចថា តើអ្នកដែលប្រកែកមិនរៀបការ នឹងត្រូវផ្តន្ទាទោស ឬយ៉ាងណា។ ដូចដែលទាហានឈ្មោះ លន់ សេន បានប្រាប់៖

> មានការរៀបចំមួយចំនួនតូចសម្រាប់ខ្ញុំ ខណៈពេលខ្ញុំស្ថិតនៅកំពង់សោម ប៉ុន្តែខ្ញុំប្រកែក ពីព្រោះខ្ញុំមិនបានស្រឡាញ់នារីណាម្នាក់ក្នុងចំណោមនារីទាំងនោះឡើយ។ កាលណោះ អ្នកខ្លះដែលបានប្រកែកការរៀបចំនេះត្រូវបានផ្តន្ទាទោស ប៉ុន្តែខ្លះក៏មិនត្រូវបានផ្តន្ទាទោស។ [...] មាស មុត បានយល់អំពីខ្ញុំ ពីព្រោះយើងធ្លាប់បានបម្រើការងារជាមួយគ្នា និងធ្លាប់សប្បាយជាមួយគ្នា។ នោះជាមូលហេតុដែលខ្ញុំអាចរួចខ្លួន[549]។

204. ទោះបីជាសាក្សីខ្លះប្រកែកថា ការរៀបការនៅតំបន់កំពង់សោមមិនមែនជាការរៀបការដោយបង្ខំក៏ដោយ ក៏ចម្លើយរបស់ពួកគាត់រមែងបង្ហាញអំពីការគ្រប់គ្រងទាំងស្រុងរបស់ថ្នាក់កំពូលនៃកងពលធំនេះ ទៅលើការផ្គូផ្គង និងកង្វះការឯកភាពដោយសេរីពីយ៉ាងហោចណាស់ភាគីមួយក្នុងចំណោមភាគីទាំងឡាយដែលពាក់ព័ន្ធការរៀបចំទាំងនោះ[550]។ អាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានដាក់ទៅ

---

ជនអាចរៀបការបានលុះត្រាណាតែគេសុំច្បាប់រៀបការ ឬយ៉ាងណា? ឆ.31៖ បាទ ប្រជាជនអាចរៀបការបាន បើសិនជាគេស្នើសុំរៀបការ។ ខ្ញុំពុំធ្លាប់ដែលឃើញគូណាដែលគេបង្ខំឱ្យរៀបការទេ"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ កឹម ម៉េន ឆ.234 ["ស៖ [...] ពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ តើការរៀបចំរៀបការទាំងអស់ គឺកងពលជាអ្នករៀបចំឱ្យ ឬយ៉ាងម៉េច? ឆ.234៖ បើរៀបការ ការនៅកន្លែងកងពល។ ខាងកងពលរៀបការឱ្យ ព្រោះជាថ្នាក់ដឹកនាំម្ចាភិបាល ដូចជាវរសេនាតូច វរសេនាធំ។ បើយើងត្រឹមតែកងពលធម្មតា គឺគណៈកម្មការទៅតាមអង្គភាពគេរៀបការ"]។

549 ឯកសារ D54/38.1 កំណត់ហេតុស្តាប់ចម្លើយ លុន សេង EN ERN 01072395-6 ["ស៖ កាលហ្នឹង អង្គការគេមិនរៀបចំឱ្យ? ឆ៖ គេរៀបចំឱ្យដែរ ប៉ុនយើងអត់ស្រឡាញ់ [សត្រីដែលជ្រើសរើស] យើងអត់យកដែរ,។ ស៖ចឹងរៀបចំប៉ុន្មានដងដែរអត់យក? ឆ៖ ខ្ញុំនៅកំពង់សោម ២-៣ ដង ប៉ុនអត់យក អត់ស្រឡាញ់ អត់យក។ ស៖ មកពីមិនស្រឡាញ់ ឬក៏ថាមកពីបារម្ភ? ឆ៖ មិស្រឡាញ់តែម្តង គេរើសឱ្យយើងអត់ពេញចិត្ត អត់យកចេះតែប្រកែកជាមួយគេហើយ កាលនោះអ្នកប្រកែកខ្លះមានទោស។ អ្នកប្រកែកខ្លះអត់ទេ។ ស៖ ហេតុអីបានជាពូហ៊ានប្រកែកច្រើនដងម៉េច? ឆ៖ ខ្ញុំប្រកែកបើថាអត់ពេញចិត្ត។ ហើយម្យ៉ាងអ្នកគ្រង មឿន អីនៅពីលតើខ្ញុំសុទ្ធតែអ្នកស្គាល់គ្នា ដូចមិត្តភ័ក្តិផង ចឹងចេះតែអត់អោនផង បង្កាប់គ្នាលេងចឹងផង ចេះអត់អោនដែរ។ ហើយ មាស មុត ហ្នឹង ក៏ចឹងដែរ ជាអង្គភាពចាស់ពីមុនមក គេធ្លាប់ស្គាល់ចិត្តស្គាល់ថ្លើមយើង ហើយចឹងយើងលេងខ្លះ មែនខ្លះ ក៏អត់ដករហូត ប្រកែករួចខ្លួនរហូតខ្ញុំហ្នឹង។"]។

550 ឯកសារ D114/91 កំណត់ហេតុស្តាប់ចម្លើយ សេង អុល ឆ.173 ["ស៖ នៅក្នុងកងលោកស្រី តើមាននារីណាត្រូវបញ្ជូនទៅរៀបការនៅកន្លែងផ្សេង ដូចជាជាមួយកងទ័ពជើងគោក កងទ័ពជើងទឹកដែរឬទេ? ឆ.173៖ ចាស មាន នៅក្នុងឆ្នាំ ៧៦ ៧៧ ខាងលើគេឱ្យខ្ញុំជ្រើសរើសនារី ៤ ឬ ៥ នាក់ទៅរៀបការជាមួយកងទ័ពនៅកំពង់សោម។ នៅពេលនោះខ្ញុំធ្វើស្រែប្រាំង ហើយខ្ញុំបានជ្រើសរើសនារី ៤ ទៅ ៥ នាក់។ តាមពិតពួកគេស្ម័គ្រចិត្តទៅ"] ប៉ុន្តែ សូមមើល ឯកសារ D114/36.1.64 កំណត់ហេតុស្តាប់ចម្លើយ សេង អុល ឆ.20 ["ក្នុងឆ្នាំ ១៩៧៧ ឬ ១៩៧៨ ធ្លាប់មានទ័ពមកស្នើ

លើកម្មាភិបាលជាន់ខ្ពស់ទៀតផង ដូចជា លៀត ឡូន ដែលត្រូវបានបង្ខំឲ្យរៀបការជាមួយសាច់

---

នារីពីកងរបស់ខ្ញុំទៅរៀបការនៅកំពង់សោម។ ពេលនោះមានលិខិតស្នើសុំពិកងទ័ព មកឃុំរបស់ខ្ញុំ ហើយគណៈឃុំក៏បានប្រាប់ខ្ញុំឲ្យជ្រើសរើសនារីយកទៅកំពង់សោម ដោយគេប្រាប់ថា កងទ័ពស្នើ។ នៅពេលនោះ ខ្ញុំ និងនារីដែលត្រូវជ្រើសរើសឲ្យទៅនោះ មិនដឹងថា គេយកទៅរៀបការជាមួយកងទ័ពពិការទេ"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.29, 31-32 ["សៈ ឥឡូវយើងប្តូរប្រធានបទ ទៅនិយាយអំពីការរៀបការដែលគេធ្វើនៅក្នុងកងពល ១៦៤ កាលពីពេលនោះ។ អ្នកដែលនៅក្នុងកងពល ១៦៤ ចង់រៀបការ និងអ្នកដែលត្រូវតែរៀបការថា តើរបៀបស្នើរៀបការ ត្រូវធ្វើយ៉ាងដូចម្តេច? ឆ.29៖ ខ្ញុំឃើញពិធីរៀបការតែមួយទេ ដែលនៅក្នុងពិធីនោះ គឺមានកូនកំលោះកូនក្រមុំចំនួន ១០ គូ នៅក្នុងពិធីរៀបការនោះ ក៏មាន តាសេង តាមឿន ហើយនិងអ្នកដឹកនាំដទៃទៀត។ ក្នុងចំណោម ១០ គូនេះ តាមការពិនិត្យរបស់ខ្ញុំ គូទាំងអស់អត់មានបញ្ហាអ្វីទេ ដោយសារពួកគេមានអាយុស្របាលៗគ្នា។ មានតែមួយគូប៉ុណ្ណោះ ដែលខ្ញុំស្គាល់ឃើញប្លែកពីគេ គូនោះ គឺគូ តាសេង ដោយសារគាត់មានអាយុចាស់ជាងកូនក្រមុំយ៉ាងច្រើន។ តាមការសង្ស័យរបស់ខ្ញុំ ៗគិតថា កូនក្រមុំនៅក្មេងអ៊ីចឹង អាចមិនពេញចិត្តរៀបការជាមួយកូនកំលោះចំណាស់ តាសេង នោះទេ។ [...] ក្រោយមក ខ្ញុំធ្លាប់ឮគេនិយាយអំពីការរៀបការដោយបង្ខំ ប៉ុន្តែតាមបទពិសោធន៍របស់ខ្ញុំនោះ ខ្ញុំពុំដែលឃើញអ្នកដែលគេបង្ខំឲ្យរៀបការទេ។ [...] សៈ តើប្រជាជនធាចរៀបការបាន លុះត្រាណាតែគេសុំច្បាប់រៀបការ ឬយ៉ាងណា? ឆ.31៖ បាទ ប្រជាជនអាចរៀបការបាន បើសិនជាគេស្នើសុំរៀបការ។ ខ្ញុំពុំធ្លាប់ដែលឃើញគូណាដែលគេបង្ខំឲ្យរៀបការទេ។ សៈ នៅក្នុងករណីរបស់ តាសេង ក្រៅពីអាយុ តើលោកមានគិតថា កូនក្រមុំ អាចនឹងត្រូវគេបង្ខំឲ្យរៀបការនឹងគាត់ដែរឬទេ? ឆ.32៖ នៅក្នុងពេលនោះ តាមខ្ញុំយល់ គាត់មិនមានអារម្មណ៍បង្ខំឲ្យរៀបការ [ជាមួយ តាសេង] ទេ ពីព្រោះ បងពៅ គឺជាមនុស្សដែលស្មោះត្រង់ជាមួយនឹងរបបអង្គការ។ អាយុរបស់បងពៅ និង តាសេង ខុសគ្នាឆ្ងាយណាស់។ បងពៅ មានអាយុ ១៨ ឬ ១៩ ឆ្នាំ ដែលប្រហាក់ប្រហែលនឹងខ្ញុំ។ ចំណែកតាសេង គាត់មានអាយុជាង សែសិបឆ្នាំទៅហើយ។" (សង្កត់ន័យបន្ថែម)]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ.241 ["សៈ មានអ្នកដែលយើងធ្លាប់សម្ភាសកន្លងមក បាននិយាយថា នៅកំពង់សោមមានការបង្ខំឲ្យរៀបការជាច្រើន បើប្រកែក គឺមានបញ្ហាហើយ។ តើលោកមានដឹងរឿងនេះទេ? ឆ.241៖ ខ្ញុំមិនដឹងទេ តែបើពួកខ្ញុំ គឺមិនមានរឿងបែបនេះទេ។ ហើយមានតែអាណិតវិញផងបើបានប្រពន្ធមិនស្អូវស្អាត។"] ប៉ុន្តែសូមមើល ឆ.230-231, 236-237 [សៈ កាលសម័យនោះ កងពលធំអ្នករៀបចំការឬ? ឆ.230៖ បាទ។ សៈ តើធម្មតាពេលគេរៀបការ តែងតែមានច្រើនគូរៀបការដំណាលគ្នាមែនទេ? ឆ.231៖ ចំពោះខ្ញុំ មានតែបីគូប៉ុណ្ណោះ ខ្ញុំមិនដឹងករណីអ្នកផ្សេងទៀតទេ ប៉ុន្តែអ្នកផ្សេងដូចជាយុទ្ធជនជាដើម ខ្ញុំឮថា ពេលគេរៀបការ អាចមានដប់គូ។ [...] ឆ.236៖ មិនមានបញ្ហាទេ [ប្រសិនជាយើងបដិសេធការរៀបការ]។ បើយើងពេញចិត្ត យើងយក បើយើងមិនពេញចិត្ត យើងថា យើងអត់ទាន់ចង់បានប្រពន្ធទេ។ បើយើងនិយាយថា យើងអត់យក ខ្លាចនារីខ្មាស។ សៈ តើលោកមានដឹងថា ហេតុអ្វីបានជាកងពលចង់ឲ្យមនុស្សរៀបការឬទេ? ឆ.237៖ មនុស្សភាគច្រើន ដល់អាយុត្រូវតែយក។ ពួកយើងសុទ្ធតែចាស់ ដូចខ្លះអាយុ ២៤ ២៥ទៅ ៣០ ឆ្នាំហើយ។ សម្រាប់ទាហាន គេនឹងយកនារីមកឲ្យយុទ្ធជនមើល ហើយខ្ញុំសួរយុទ្ធជនថា មិត្តពេញចិត្តនារីនេះទេ។ បើពេញចិត្ត យើងកំណត់ឈ្មោះអ្នកទាំងពីរ បើអត់ពេញចិត្ត ក៏អត់ទៅ។ ខាងនារីក៏មានអ្នកតំណាងរបស់គេមកជាមួយដើម្បីសួរចិត្តផងដែរ។ ពួកខ្ញុំគ្រាន់តែរៀបចំឲ្យបាន ឃើញគ្នាប៉ុណ្ណោះ"]។

ញាតិរបស់អនុប្រធានរបស់ **មាស មុត** ឈ្មោះ ទឹម សេង[551]។ អាពាហ៍ពិពាហ៍នោះបានធ្វើនៅកន្លែងរបស់ **មាស មុត**[552] និងត្រូវបានធ្វើឡើងដោយសមាជិកកងពលធំ ១៦៤ ទទួលបន្ទុកពស្តុភារ ឈ្មោះ តា ញ៉ាន[553]។

---

551 វុន ប៊ុនណា អះអាងថា ការរៀបការរបស់គាត់ជាមួយ លៀត ឡូន គឺរៀបចំឡើងដោយបងជីដូនមួយរបស់គាត់ឈ្មោះ (ធឹម) សេង និង ញ៉ាន់ ខណៈពេលដែល លៀត ឡូន នៅចាំតែឈ្មោះ ញ៉ាន់ តែប៉ុណ្ណោះជាអ្នករៀបចំការរៀបការនេះ៖ ឯកសារ D114/304 កំណត់ហេតុស្តាប់ចម្លើយ វុន ប៊ុនណា ឆ.68-70, 86, 96, 98, 100, 107, 109, 112-113 ["ដោយសារបងជីដូមួយ នៅហ្នឹង ហើយគាត់ផ្លាស់ខ្ញុំទៅ។ [...] ឆ.69៖ ឈ្មោះ សេង (ប្រុស) [...] ឆ.70៖ គាត់ជាកងពល [១៦៤] [...] ឆ.86៖ ការរៀបការហ្នឹងដោយមានការចាត់តាំង ដូចបងឲ្យយកទៅអ៊ីចឹង សម្រេចយកតាមគាត់ទៅ។ បងហ្នឹង គឺបងជីដូនមួយខ្ញុំ ឈ្មោះ សេង ដែលរៀបចំការរៀបការឲ្យខ្ញុំ [...] ឆ.96៖ អត់ទាន់ចង់រៀបការទេ ព្រោះនៅក្មេងដែរ តែបងគាត់រៀបចំហើយ ខ្ញុំអត់និយាយអីទេ [...] ឆ.98៖ [...] ខ្ញុំដឹងតែបងជីមួយខ្ញុំដែលជាអ្នករៀបចំ [...] ឆ.100៖ [...] នៅផ្ទះបាយ នៅកំពង់សោម នៅមន្ទីរ [បងជីដូនមួយ] [...] ឆ.107៖តាញ៉ាន់ គាត់បានចូលរួមដែរ តែខ្ញុំមិនដឹងពីឋានៈរបស់គាត់ទេ [...] ស៖ នៅក្នុងថ្ងៃរៀបការ តើអ្នកណាជាអធិបតី ដែលប្រកាសឲ្យលោកស្រីចាប់ដៃគ្នា ហើយចាប់អារម្មណ៍? ឆ.109៖ វាយូរហើយ មិនដឹងថាបងជីដូនមួយខ្ញុំ ឬអ្នកណាផ្សេងទេ [...] ឆ .112៖ ខ្ញុំ និង លាត ឡូន ទៅស្នាក់នៅផ្ទះជិតនោះ ដែលជាផ្ទះបងជីដូនមួយខ្ញុំ"]។ ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ឆ.3, 6, 8 ["អ្នកនិយាយវិទ្យុទាក់ទងបានមកហៅខ្ញុំ ដោយប្រាប់ខ្ញុំថា មាស មុត ចង់ជួបខ្ញុំនៅផ្ទះ [...] ពេលនោះ ខ្ញុំមិនដឹងថាគេកំពង់រៀបចំកម្មវិធីអ្វីទេ ភ្លាមៗនោះ តាញ៉ាន់ បានប្រកាសអំពីកម្មវិធីរៀបមង្គលការ [...] ក្រោយមក ខាងកូនក្រមុំឡើងចាប់អារម្មណ៍ ថាគាត់យលព្រម តែខ្ញុំពុំព្រមឡើងចាប់អារម្មណ៍ទេ [...] នៅពេលលនោះ ឪពុកម្តាយកូនក្រមុំ ហើយនិងកម្មាភិបាលធំៗបានប្រកាសថា យើងទាំងពីរនាក់ក្លាយជាប្តីប្រពន្ធហើយ [...] ឆ .6៖ ខ្ញុំមិនមានជម្រើសទេ។ ខ្ញុំត្រូវតែទទួលយកអាបាហ៍ពិពាហ៍នោះ បើមិនដូច្នេះទេ គេនឹងដកខ្ញុំចេញពីការងារ ហើយបញ្ជូនទៅទីកន្លែងផ្សេងដែលយើងពុំដឹង។ [...] ឆ.8៖ ខ្ញុំគិតថា តាមុត ជាអ្នកផ្តួចផ្តើមអាពាហ៍ពិពាហ៍របស់ខ្ញុំនៅពេលនោះ។ ខ្ញុំមិនដឹងហេតុផលទេ តែខ្ញុំគិតថា គាត់ចង់ឲ្យខ្ញុំក្លាយជាសាច់ញាតិរបស់គាត់ ព្រោះខាងស្រីក៏ជាសាច់ញាតិរបស់គាត់ដែរ"]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ឆ.162, 171-172, 174, 176 ["ស៖ តើអ្នកណាជាអ្នករៀបចំរៀបការឲ្យលោក? ឆ.162៖ ញ៉ាន់ [...] ស៖ តើពេលនោះ លោកប្រកែកថា មិនព្រមរៀបការដែរឬទេ? ឆ.171៖ បាទ ខ្ញុំប្រកែក ខ្ញុំនិយាយថា ខ្ញុំខឹង ព្រោះគេមិនបានប្រាប់ខ្ញុំជាមុន ហើយខ្ញុំប្រកែកមិនព្រមឡើងប្តេជ្ញាទេ។ ស៖ ចុះប្រពន្ធលោកយ៉ាងម៉េចដែរ ពេលនោះ? ឆ.172៖ គាត់បានប្រកែកដែរ ប៉ុន្តែ តាញ៉ាន់ បានសួរថា តើតាមបក្ស ឬក៏តាមអ្នកណា។ [...] ឆ.174៖ អ្នកដែលរៀបចំគឺ ញ៉ាន់។ខ្ញុំគិតថា ប្រធានកងពល ក៏បានដឹងពីរឿងនេះដែរ [...] ឆ.176៖ មានតែ តាញ៉ាន់ ប៉ុណ្ណោះដែលមានឋានៈធំជាងគេ"]។

552 ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ឆ.177 ["ស៖ តើលោករៀបការនៅកន្លែងណា? ឆ.177៖ នៅផ្ទះរបស់ តាមុត នៅកំពង់សោម"]។

553 ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ឆ.174 ["អ្នកដែលរៀបចំគឺ ញ៉ាន់។ ខ្ញុំគិតថា ប្រធានកងពល ក៏បានដឹងពីរឿងនេះដែរ [...] ឆ.176៖ មានតែ តាញ៉ាន់ ប៉ុណ្ណោះដែលមានឋានៈធំជាងគេ"]។ ឯកសារ

205. ការអនុវត្តគោលនយោបាយ ប.ក.ក របស់ **មាស មុត** ស្តីពីអាពាហ៍ពិពាហ៍ និងការកសាងគ្រួសារ បានញុាំងទៅដល់អាពាហ៍ពិពាហ៍ដោយបង្ខំ និងអាពាហ៍ពិពាហ៍ជាទ្រង់ទ្រាយធំ ដែលត្រូវបានធ្វើនៅតំបន់កំពង់សោម នៅពេញមួយរយៈកាលនៃរបបនោះ[554]។ គូស្រករចំនួនច្រើនរហូតដល់ ៥០

---

D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ឆ.3 ["ពេលខ្ញុំទៅដល់ផ្ទះរបស់គាត់ [មាស មុត] នៅជិតផ្សារកំពង់សោម ខ្ញុំបានឃើញកម្មាភិបាលធំៗប្រមូលផ្តុំគ្នានៅផ្ទះនោះ។ ពេលនោះ ខ្ញុំមិនដឹងថា គេកំពុងរៀបចំពិធីអ្វីទេ។ ភ្លាមៗនោះ តាញ៉ាន់ បានហៅកូនក្រមុំឱ្យចេញ ហើយ តាញ៉ាន់ បានប្រកាសអំពីកម្មវិធីរៀបមង្គលការ"]។ សូមមើលផងដែរ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ឆ.111 [ប្រធានផ្នែកប្រឆាំងនាវានៅកងពល ១៤០៖ "ស៖ តើលោកស្គាល់ឈ្មោះបញ្ជាការពិសេសៗ ដែល មាស មុត បញ្ជូនទៅច្បាំងដែរឬទេ? ឆ.111៖ ឈ្មោះ ឡូន (ស្លាប់) និងឈ្មោះ ញ៉ាន់ (កាន់ភស្តុភារកងពលលេខ ៣)"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ.207 [មេបញ្ជាការកងវរសេនាតូច ៦២៣៖ "ស៖ កាលពីម្សិលមិញ លោកប្រាប់យើងថា ក្រោយពី តាឌឹម និង ឆាន បញ្ជូនចេញមក គឺ ញ៉ាន់ ទៅជំនួស។ តើពេលដែលបញ្ជូនកម្មាភិបាលទៅបូព៌ានៅ តើ តាញ៉ាន់ ទៅជាមួយទេ? ឆ.207៖ ទេ"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.265 [វរសេនាតូច ៣១ កងវរសេនាធំ ៣១០៖ "ស៖ តើ តាញ៉ាន គាត់មានតួនាទីធ្វើអ្វី? ឆ.265៖ គាត់កាន់ខាងភស្តុភាររបស់កងពលធំ ១៦៤"]។ ឯកសារ D59/1/1.7a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ា ឈឿន, KH ERN 00926305-06 [មេបញ្ជាការកងវរសេនាតូច ៥៥០ ៖ "ស៖ ពីណាគេទទួលខាងវរៈសេនាធំ ៦៣? ឆ៖ តាញ៉ាន់"]។

554 ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ឆ.256-257, 262-263, 265-266, 273, 275-276 ["ស៖ ពេលដែលលោកស្រីមកដល់កំពង់សោមបានប៉ុន្មានថ្ងៃ ទើបគេឱ្យរៀបការ? ឆ.256៖ ប្រហែលមួយខែ ស៖ អ៊ីចឹងបានន័យថា ខែតុលា ឆ្នាំ ៧៧ ដែលលោកស្រីរៀបការ? ឆ.257៖ ចាស។ [...] ស៖ តើមានអ្វីកើតឡើង ពេលដែលគេមករកលោកស្រីឱ្យរៀបការ? ឆ.262៖ គេប្រាប់ថា គេមកឱ្យលោកស្រីរៀបការហើយ។ តែខ្ញុំមិនព្រម តែគាត់ប្រាប់ថា បើមិនការទេ គេនឹងដាក់គុកហើយ ដូច្នេះហើយ ទើបខ្ញុំព្រម។ ស៖ ចុះអ្នកផ្សេងទៀត ដែលគាត់មិនព្រមការវិញ? ឆ. 263៖ បើគេមិនព្រមការ គឺគេសុខចិត្តស្លាប់ ហើយគេក៏នៅទីនោះទៅ។ [...] ស៖ ពេលដែលលោកស្រីព្រមការនោះ តើមានអ្វីកើតឡើង? ឆ.265៖ ពេលព្រមការហើយ គេយកខ្ញុំទៅកន្លែងរៀបការនៅស្ទឹងហាវ នៅកំពង់សោម ជិតហាងផលិតទឹកត្រី [...] ស៖ តើលោកស្រីស្គាល់ ប្តីលោកស្រីពីមុនមកទេ? ឆ.266៖ មិនស្គាល់ទេ [...] ស៖ ពេលថ្ងៃប្តេជ្ញានោះ តើគេរៀបចំនៅទីណា? ឆ.273៖ នៅស្ទឹងហាវ វាជាទីទួលខ្ពស់ [...] ស៖ មានអ្នកណាចូលរួមខ្លះ? ឆ.275៖ មានពួកស្រីៗទាំងខ្ញុំ ៧ នាក់ ហើយប្រុសៗ នៅទីនោះរួចហើយ ព្រោះវាជាកន្លែងរបស់គេ ស៖ តើមានមនុស្សប្រុសៗជាអ្នករៀបការប៉ុន្មាននាក់? ឆ.276៖ មាន ៧ នាក់"]។ ឯកសារ D114 / 32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន ឆ. 2-6, 10 ["ចង់គូសបញ្ជាក់ប្រាប់ថា គឺកងវរសេនាតូច ១៦០ ក្រោមកងពលធំលេខ ៣ ទេ។ ស៖ តើលោកស្រីអាចប្រាប់បានទេថា កាលនោះនៅខែណា នៅចុងឆ្នាំ ១៩៧៥ ដែរឬទេ? ឆ.3៖ សុំទោស ខ្ញុំពុំចាំខែពិតប្រាកដទេ។ តែខ្ញុំចាំថា គឺនៅចុងឆ្នាំ ១៩៧៥ និងដើមឆ្នាំ ១៩៧៦។ ស៖ តើមានអ្នកដទៃរៀបការដែរឬទេ ក្នុងជំនាន់នោះ? ឆ.4៖ កាលនោះ គឺមានសរុប ៧១ គូ ទាំងគូខ្ញុំផង ស៖ ហេតុអ្វីបានជាលោកស្រីនៅចាំទូរលេខនេះ ប្រាកដយ៉ាងនេះ? ឆ.5៖ គេរៀបការពួកខ្ញុំនៅក្នុងរោងកុនកំពង់សោម។ គឺមានមនុស្សពេញរោងកុននោះតែម្តង ហើយគេក៏បានប្រកាសថា មានសរុប ៧១

គូ។ សៈ តើលោកស្រីដឹងថា គេរៀបចំឱ្យមានគូស្រករនៅពេលណាដែរ? ឆ.6៖ ខ្ញុំមិនដែលបានដឹងពីការរៀបចំឱ្យខ្ញុំមានគូស្រករនោះពីមុនមកសោះ [...] ឆ.10៖ ក្រោយពីបានទៅដល់រោងកុន ខ្ញុំមានការភ្ញាក់ផ្អើល ដោយសារមានមនុស្សច្រើន ហើយខ្ញុំក៏បានសួរគេ ហើយគេប្រាប់ថា គេកំពុងតែរៀបចំពិធីការខ្ញុំចង់រត់ពីទីនោះដែរ ប៉ុន្តែមិនអាចរត់រួចពីព្រោះទាហាននៅសងខាង"]។ ឯកសារ D114/78 កំណត់ហេតុស្ដាប់ចម្លើយ ស្វាយ សាម៉េត ឆ.22-25, 30, 32, 34 ["សៈ តើនៅក្នុងកងពលធំលេខ ១៦៤ មានគោលនយោបាយរៀបការយ៉ាងម៉េចដេរ? ឆ.22៖ គូស្រករមិនបានស្គាល់គ្នាឡើយមុនពេលដែលពយកគរៀបការ រឿងនេះកើតឡើងចំពោះខ្ញុំ និងអ្នកដទៃផងដែរ។ នៅក្នុងករណីរបស់ខ្ញុំ គេប្រាប់ខ្ញុំមុនមួយថ្ងៃ ហើយថ្ងៃបន្ទាប់ ខ្ញុំត្រូវរៀបការតែម្ដង ដោយយើងមិនស្គាល់គ្នាឡើយ ហើយយើងក៏មិនបានណាត់ជួបគ្នា ដូចបច្ចុប្បន្ននេះដេរ គឺយើងរៀបការជាមួយគ្នាតែម្ដង សៈ តើលោកនៅបន្តនៅជាមួយប្រពន្ធរបស់លោកដែរឬទេ? ឆ.23៖ បាទ។ សៈ ហេតុអ្វីបានជាដូច្នេះ? ឆ.24៖ ខ្ញុំមិនដឹងទេ។ ប៉ុន្តែប្រសិនបើអ្នកបដិសេធការស្នើរបស់ពួកគេ យើងខ្លាចថា យើងមានបញ្ហា។ សៈ តើពួកគេជាអ្នកណា? តើអ្នកណាជាអ្នកលើកសំណើនេះ? ឆ.25៖ ជាអ្នកមកពីកងវរសេនាធំ។ នីរសារម្នាក់មកពីកងវរសេនាធំម្នាក់មកប្រាប់ខ្ញុំថា ខ្ញុំនឹងត្រូវរៀបការ។ [...] សៈ តើពិធីរៀបការនេះធ្វើឡើងនៅកន្លែងណា? ឆ.30៖ នៅកំពង់សោម។ ពិធីរៀបការនោះ ធ្វើឡើងនៅជិតរូបតោបច្ចុប្បន្ននេះ មានតែពគូប៉ុណ្ណោះ ដែលគេរៀបការឱ្យនៅពេលនោះ។ ទីកន្លែងគឺជាកន្លែងភស្តុភារ។ [...] សៈ តើលោកធ្លាប់ប្រាប់គេថា លោកមិនចង់រៀការដែរឬទេ? ឆ.32៖ ខ្ញុំមិនបានតតាំងជាមួយពួកគេឡើយ ដោយសារខ្ញុំកត់សម្គាល់ឃើញថា អ្នកដែលមិនចុះសម្រុងគ្នាក្រោយពេលរៀបការរួច លែងទទួលបានការទុកចិត្តពីថ្នាក់លើរបស់ពួកគេទៀត ពួកគេនិយាយថា យើងមិនបានគោរពទៅតាមការរៀបចំរបស់អង្គការ។ [...] សៈ តើគោលនយោបាយស្ដីពីការរៀបការនេះអនុវត្តលើមនុស្សទាំងអស់នៅក្នុងកងពលឬ? ឆ.34៖ គោលនយោបាយនេះគឺអនុវត្តជាទូទៅ"]។ ឯកសារ D114/83 កំណត់ហេតុស្ដាប់ចម្លើយ សុខ នាង ឆ.45 ["សៈ តើមានការរៀបការដែរឬទេ នៅក្នុកងពលធំ ១៦៤? ឆ.45៖ ខ្ញុំបានដឹងពីការរៀបការនេះច្រើនណាស់ ព្រោះគេរៀបការឱ្យញឹកញាប់ដែរ។ ជាទូទៅ ប្រសិនបើនារីមិនហ៊ានប្រកែក ហើយមិនសូវចេះនិយាយនោះ គឺពួកគេយល់ព្រមទៅតាមការផ្សំផ្គុំនោះ។ ជួនកាល គេរៀបការម្ដងពីរគូ បីគូ ឬប្រាំគូ"]។ ឯកសារ D59/1/1.7a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ា ឈឿន KH ERN 00926325-26, KH ERN 00926329-30 ["សៈ ពូរៀបគ្រួសារតាំងពីអង្គាលទៅ? ឈឿន៖ ៧៦។ សៈ ៧៦! គ្រួសារពូកាលហ្នឹង គាត់ធ្វើការខាងណាដែរ? ឈឿន៖ នៅខាងនារីកងទ័ពដែរ [...] សៈ អញ្ចឹងវរៈសេនាតូចរបស់នារីហ្នឹងគាត់ អឺគេនៅកំពង់សោម? វ៉ាត់៖ ចាស៎! [...] សៈ ... កាលពូរៀបការជាមួយមីងដំបូង រៀបការប៉ុន្មានគូទៅ? ឈឿន៖ ច្រើនគូដែរ នៅកំពង់សោម វ៉ាត៖ ៣០ នាក់។ សៈ ៣០ នាក់។ កាលហ្នឹងសុទ្ធតែយើងជាអី ហៅថាយ៉ាងម៉េចទៅពេលដែលយើងរៀបការ? ឈឿន៖ រៀបការ គេហៅប្រមូលគ្នាមក។ សៈ ដូចថាយើងរៀបការជាមួយកម្មាភិបាល ឬក៏មានយុទ្ធជនរៀបការលាយជាមួយគ្នាដែរ? ឈឿន៖ លាយគ្នា វ៉ាត៖ លាយគ្នា កម្មាភិបាលខ្លះ [...] សៈ កាលហ្នឹងមានពីណាគេណែនាំមានមតិណែនាំឱ្យការ? វ៉ាត៖ តាម៉ុត។ [...] សៈ ហើយកាលហ្នឹងម៉េចបានពូស្គាល់មីងបានរៀបការ ពូស្រឡាញ់គ្នាមុន ឬក៏យ៉ាងម៉េច ដូចថា អឺបានស្នើបានរៀបការ? ឈឿន៖ អត់ទេ ខ្ញុំស្គាល់គ្នា ដូចថាកងដឹងជញ្ជូនអញ្ចឹង ហើយកងទ័ពស្គាល់គ្នា ដល់អញ្ចឹងទៅ ឃើញទៅ ខ្ញុំស្នើគេ សួរគេទៅ សួរគេថា គេស្រឡាញ់យើង ដល់ស្រឡាញ់ ក៏ស្រឡាញ់ទៅដល់អត់ ក៏អត់ ដល់អ្នកខ្លះត្រូវគេចាត់តាំងដែរ ចាត់តាំងដូចថាគ្នាមិនពេញចិត្តមានបញ្ហាខ្លះអញ្ចឹងដែរកាលជំនាន់ហ្នឹងបាក់បែកគ្នា ក៏មានដែរ"]។ ឯកសារ D114/53 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុក សុក ឆ.180, 184-85, 333-334 ["ស

៖ តើលោកស្រីការនៅឆ្នាំណា? ឆ.180៖ ១៩៧៨។ [...] ស៖ លោកស្រីថា លោកស្រីចេញពីកងកុមារលើកទីពីរ ១៩៧៧ ហើយលោកស្រីរៀបការ ១៩៧៨ តើលោកស្រីធ្វើអ្វីនៅក្នុងឆ្នាំ ១៩៧៨? ឆ.184៖ នៅកងមីង១ នៅភូមិស្នាច់ ដែង ជិតព្រលានយន្តហោះកងកេង។ ស៖ តើសហករណ៍នោះឈ្មោះអីដែរ? ឆ.185៖ សហករណ៍ភូមិស្នាច់ដែង [...] ស៖ តើអ្នកផ្សេងក្នុងសហករណ៍រៀបការដូចលោកស្រីដែរឬទេ? ឆ.333៖ រៀបដូចគ្នា ស៖ [...] តើគេត្រូវបង្ខំឱ្យរៀប ការដូចលោកស្រីទេ? ឆ.334៖ ពួកគេមិនមែនទើបតែរៀបការនៅពេលនោះទេ។ ពួកគេបានរៀបការមុនហ្នឹងរួចហើ យ។ ពួកគេជាប្រពន្ធទាហាន ហើយបានយកមកនៅទីនោះ"]។ ឯកសារ D11/387/1 អ្នកដាក់ពាក្យសុំតាំងខ្លួនជា បណ្តឹងរដ្ឋប្បវេណី សំ វុទ្ធី EN ERN 00991851 ["នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៨ អ្នកដាក់ពាក្យសុំត្រូវគេបញ្ជូនទៅ លើកទំនប់ពុធត្រៀន។ នៅពេលដែលគាត់ដល់ភូមិស្នាច់ដែង សមមិត្ត លន និងប្រធានឃុំ [...] បានបង្ខំឱ្យគាត់រៀប ការជាមួយ សមមិត្ត ភាព ជាមួយនឹង ២០ គូផ្សេងទៀត ប៉ុន្តែការរៀបការនោះត្រូវគេរំសាយចោលវិញ ព្រោះ សមភាព ភាព ឈើ ហើយទាំងពួកប្រុស១ និងស្រី១ ដើបប្រឆាំងតវ៉ា ហើយរត់ទៅវៀតណាម"]។ ឯកសារ D114/91 កំណត់ហេតុស្តាប់ចម្លើយ សេង អុល ឆ.173 ["ស៖ នៅក្នុងកងលោកស្រី តើមាននារីណាត្រូវបញ្ជូនទៅរៀបការនៅ កន្លែងផ្សេង ដូចជាជាមួយកងទ័ពជើងគោក កងទ័ពជើងទឹកដែរឬទេ? ឆ.173៖ ចាស មាន នៅក្នុងឆ្នាំ ៧៦ ៧៧ ខាង លើគេឱ្យខ្ញុំជ្រើសរើសនារី ៤ ឬ ៥ នាក់ទៅរៀបការជាមួយកងទ័ពនៅកំពង់សោម។ នៅពេលនោះខ្ញុំធ្វើស្រែប្រាំង ហើយខ្ញុំបានជ្រើសរើសនារី ៤ ទៅ ៥ នាក់។ តាមពិតពួកគេស្ម័គ្រចិត្តទៅ។ ខ្ញុំបាននាំពួកគេមក ហើយមានឡានដឹកគេ ទៅកំពង់សោម។ តាមពិត ខ្ញុំមិនច្បាស់ទេ ប្រហែលជា ១០ នាក់ ក៏មិនដឹង"]។ ឯកសារ D114/36.1.64 កំណត់ហេតុ ស្តាប់ចម្លើយ សេង អុល ឆ.20 ["ស៖ នៅក្នុងកងនារីរបស់អ្នកស្រី តើធ្លាប់មានកងទ័ពមកស្នើសុំនារីយកទៅរៀបការ ជាមួយកងទ័ពពិការដែរឬទេ? ឆ.20៖ ក្នុងឆ្នាំ ១៩៧៧ ឬ ១៩៧៨ ធ្លាប់មានទ័ពមកស្នើនារីពីកងរបស់ខ្ញុំទៅរៀបការនៅ កំពង់សោម។ ពេលនោះមានលិខិតស្នើសុំពីកងទ័ព មកឃុំរបស់ខ្ញុំ ហើយគណៈឃុំក៏បានប្រាប់ខ្ញុំឱ្យជ្រើសរើសនារីយក ទៅកំពង់សោម ដោយគេប្រាប់ថា កងទ័ពស្នើ។ នៅពេលនោះ ខ្ញុំ និងនារីដែលត្រូវជ្រើសរើសឱ្យទៅនោះ មិនដឹងថា គេ យកទៅរៀបការជាមួយកងទ័ពពិការទេ [...] នៅក្នុងកងរបស់ខ្ញុំ ខ្ញុំបានជ្រើសរើសនារីប្រហែលជា ៣ ទៅ ៥ នាក់"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿន ឆ.245, 248, 250, 252-254 ["ស៖ តើលោកដែលឃើញ មានទាហាននៅក្នុងកងពល ១៦៤ ត្រូវបានគេរៀបការឱ្យនៅក្នុងសម័យនោះដែរឬទេ? ឆ.245៖ បាទ ខ្ញុំបានឃើញ។ [...] ស៖ តើការរៀបការនោះ រៀបចំដោយគណៈកម្មាធិការនោះឬ? ឆ.248៖ បាទ។ កម្មាធិការនោះ គឺជាប្រធាន ដោយមានឈ្មោះ ហាន និង ឆាវ ជាដើម។ [...] ស៖ តើរៀបការម្តង១ មានប៉ុន្មានគូដែរ? ឆ.250៖ មាន ៣ គូ ៥ គូ ៧ គូ ហើយខ្លះ ២ គូ និងខ្លះ ១ គូ ក៏មាន [...] ស៖ តើគូប្តីប្រពន្ធនោះ គេជ្រើសរើសគ្នាទៅវិញទៅមក ឬក៏មានអ្នកណា គេជ្រើសរើសឱ្យ? ឆ.252៖ គូខ្លះ គេចាត់តាំងឱ្យរៀបការ ហើយគូខ្លះស្ម័គ្រចិត្តរៀបការដោយខ្លួនឯង។ ស៖ តើអ្នក ណាជាអ្នកចាត់តាំងឱ្យរៀបការនោះ? ឆ.253៖ អ្នកចាត់តាំងឱ្យរៀបការ គឺមេ១ មានដូចជា មាស មុត និង ហាន ជាដើ ម។ [...] ស៖ ហេតុអ្វីបានជាលោកថា មាស មុត ជាអ្នកចាត់តាំងឱ្យរៀបការ? ឆ.254៖ ព្រោះគាត់ជាមេ"]។ ឯក សារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ឆ.60-62, 174-178 ["ស៖ ពេលណាដែលលោកត្រឡប់មក វិញ ឆ.60៖ ឆ្នាំ ១៩៧៨។ ស៖ តើលោកចាំខែទេ? ឆ.61៖ អត់ទេ ខ្ញុំភ្លេចអស់ហើយ។ ស៖ តើនៅចុងឆ្នាំ ឬដើមឆ្នាំ? ឆ. 62៖ នៅចុងឆ្នាំ ១៩៧៨។ [...] ឆ.174៖ ខ្ញុំមិនដឹងទេ តែអ្នកដែលរៀបចំគឺ ញ៉ាន់។ ខ្ញុំគិតថា ប្រធានកងពលក៏បានដឹងពី រឿងនេះដែរ។ ស៖ តើមានអ្នកណាខ្លះបានចូលរួម? ឆ.175៖ មានកម្មាភិបាលច្រើនណាស់មកពីជើងទឹក និងជើងគោក

ទៅ ៧០ គូ រៀបការក្នុងពេលដំណាលគ្នា[555] ដែលជួនកាលត្រូវបានរៀបចំដោយ **មាស មុត**[556] និង ក្រោមអធិបតីរបស់មេដឹកនាំទ័ពជើងទឹកកំពូលៗ ដូចជាសមាជិកគណៈកម្មាធិការកងពលធំ ១៦៤

---

[...] សៈ តើមានមនុស្សសំខាន់ណាមកចូលរួមក្នុងពិធីរៀបការលោកដែរឬទេ? ឆ.176៖ មានតែ តាញ៉ាន់ ប៉ុណ្ណោះ ដែលមានឋានៈធំជាងគេ។ សៈ តើលោករៀបការនៅកន្លែងណា? ឆ.177៖ នៅផ្ទះរបស់ តាមុត នៅកំពង់សោម សៈ តើ តាមុត មានចូលរួមរៀបការរបស់លោកដែរឬទេ? ឆ.178៖ តាមុត រវល់វៃយួន និងជួយបញ្ជាកងទ័ពនៅភ្នំពេញ"]។ ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ឆ.3-4, 7 ["អ្នកនិយាយវិទ្យុទាក់ទងបានមកហៅខ្ញុំ ដោយប្រាប់ខ្ញុំថា មាស មុត ចង់ជួបខ្ញុំនៅផ្ទះ។ នៅពេលដែលខ្ញុំឡើងមកដល់ផែ មានម៉ូតូចាំទទួលខ្ញុំនៅទីនោះជាស្រេច។ នៅពេលដែលខ្ញុំទៅដល់ផ្ទះរបស់គាត់នៅជិតផ្សារកំពង់សោម ខ្ញុំឃើញកម្មាភិបាលធំៗ ប្រមូលផ្តុំគ្នានៅនឹងផ្ទះនោះ។ ពេលនោះ ខ្ញុំមិនដឹងថាគេកំពុងរៀបចំកម្មវិធីអ្វីទេ ភ្លាមៗនោះ តាញ៉ាន់ បានប្រកាសអំពីកម្មវិធីរៀបមង្គលការ [...] ខ្ញុំមិនព្រមឡើងចាប់អារម្មណ៍ទេ ពីព្រោះខ្ញុំ មិនពេញចិត្តនូវហេតុការណ៍ដែលខ្ញុំមិនដឹងខ្លួន។ បន្ទាប់មក ញ៉ាន់ សួរខ្ញុំថា "មិត្តនៅខាងណា?" ខ្ញុំឆ្លើយថា "ខ្ញុំមិនដែលក្បត់បក្សទេ ប៉ុន្តែបក្សក្បត់ខ្ញុំ"។ ពេលនោះ ឪពុកម្តាយកូនក្រមុំ ហើយនិងកម្មាភិបាលធំៗ បានប្រកាសថា យើងទាំងពីរនាក់ក្លាយជាប្តីប្រពន្ធហើយ [...] ឆ.4៖ ខ្ញុំបានរៀបការនៅក្នុងឆ្នាំ ១៩៧៨។ ខ្ញុំមិនអាចបញ្ជាក់ពីពេលវេលាពិតប្រាកដទេ គឺនៅពេលដែលវៀតណាមចូលមកដល់កំពង់សោមប្រហែល ២ ខែ បន្ទាប់ពីការរៀបការរបស់ខ្ញុំ។ [...] សៈ តើលោកដឹងថា មានការរៀបអាពាហ៍ពិពាហ៍បែបនេះកើតឡើងនៅក្នុងកងពល ១៦៤ នៅក្នុងករណីដទៃផ្សេងទៀតដែរឬទេ? ឆ.7៖ បាទ មានករណីផ្សេងទៀតកើតឡើង តែខ្ញុំមិនចាំឈ្មោះអ្នកដែលបានរៀបការនោះទេ។ ខ្ញុំបានឮថា ពេលខ្លះគេរៀបការចាប់ពីពីរគូ ទៅប្រាំគូ។ ខ្ញុំបានឮថា គូស្រករថ្មីនេះ បានច្រឡំគូគ្នា"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.29 ["សៈ ឥឡូវយើងប្តូរប្រធានបទ ទៅនិយាយអំពីការរៀបការដែលគេធ្វើនៅក្នុងកងពល ១៦៤ កាលពីពេលនោះ។ អ្នកដែលនៅក្នុងកងពល ១៦៤ ចង់រៀបការ និងអ្នកដែលត្រូវតែរៀបការថា តើរបៀបស្នើរៀបការ ត្រូវធ្វើយ៉ាងដូចម្តេច? ឆ.29៖ ខ្ញុំឃើញពិធីរៀបការតែមួយទេ ដែលនៅក្នុងពិធីនោះ គឺមានកូនកំលោះកូនក្រមុំចំនួន ១០ គូ នៅក្នុងពិធីរៀបការនោះ ក៏មាន តាសេង តាមឿន ហើយនិងអ្នកដឹកនាំដទៃទៀត"]។

555 ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន ឆ.2-6, 10 ["សៈ តើលោកស្រីនៅចាំថា លោកស្រីបានគូសបញ្ជាក់ប្រាប់ថា លោកស្រីត្រូវបានគេបង្ខំឲ្យរៀបការជាមួយយោធាក្នុងកងពលធំ ១៦៤។ តើត្រឹមត្រូវឬទេ? ឆ.2៖ ទេ ខ្ញុំចង់គូសបញ្ជាក់ប្រាប់ថា គឺកងវរសេនាតូច ១៦០ ក្រោមកងពលធំលេខ ៣ ទេ។ សៈ តើលោកស្រីអាចប្រាប់បានទេថា កាលនោះនៅខែណា នៅចុងឆ្នាំ ១៩៧៥ ដែរឬទេ? ឆ.3៖ សុំទោស ខ្ញុំពុំចាំខែពិតប្រាកដទេ។ តែខ្ញុំចាំថា គឺនៅចុងឆ្នាំ ១៩៧៥ និងដើមឆ្នាំ ១៩៧៦។ សៈ តើមានអ្នកដទៃរៀបការដែរឬទេ ក្នុងជំនាន់នោះ? ឆ.4៖ កាលនោះ គឺមានសរុប ៧១ គូ ទាំងគូខ្ញុំផង សៈ ហេតុអ្វីបានជាលោកស្រីនៅចាំទូរលេខនេះ ប្រាកដយ៉ាងនេះ? ឆ.5៖ គេរៀបការពួកខ្ញុំនៅក្នុងរោងកុនកំពង់សោម។ គឺមានមនុស្សពេញរោងកុននោះតែម្តង ហើយគេក៏បានប្រកាសថា មានសរុប ៧១ គូ។ សៈ តើលោកស្រីដឹងថា គេរៀបចំឲ្យមានគូស្រករនៅពេលណាដែរ? ឆ.6៖ ខ្ញុំមិនដែលបានដឹងពីការរៀបចំឲ្យខ្ញុំមានគូស្រករនោះពីមុនមកសោះ [...] ឆ.10៖ ក្រោយពីបានទៅដល់រោងកុន ខ្ញុំមានការភ្ញាក់ផ្អើល ដោយសារមានមនុស្សច្រើន ហើយខ្ញុំក៏បានសួរគេ ហើយគេប្រាប់ថា គេកំពុងតែរៀបចំពិធីការខ្ញុំចង់រត់ពីទីនោះដែរ ប៉ុន្តែមិនអាចរត់រួច ពីព្រោះ

ទាហាននៅសងខាង"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ.232 ["សៈ តើតាមធម្មតាពេលគេរៀបការ តែងតែមានច្រើនគូររៀបដំណាលគ្នាមែនទេ? ឆ.232៖ ចំពោះខ្ញុំ មានតែបីគូប៉ុណ្ណោះ ខ្ញុំមិនដឹងករណីអ្នកផ្សេងទៀតទេ ប៉ុន្តែអ្នកផ្សេងដូចជាយុទ្ធជនជាដើមខ្ញុំឮថា ពេលគេរៀបការ អាចមានដប់គូ"]។ ឯកសារ D230/1.1.631D អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សំ ប៊ុនឡេង EN ERN 00477162 [កងវរសេនាតូចមួយ ឈ្មោះតាជួប បានស្នើឱ្យអ្នកដាក់ពាក្យសុំនេះជ្រើសរើសប្រពន្ធ។ ក្រោយមក អ្នកដាក់ពាក្យសុំនេះ ក៏បានប្រាប់ទៅកងវរសេនាតូចនោះវិញថា គាត់មានគូដណ្តឹងហើយ។ ពេលនោះ មាន ៥០ គូ រៀបការនៅពេលដំណាលគ្នា នៅព្រលានយន្តហោះកងកេង នៅកំពង់សោម។ ពួកគេគឺជាទាហានកងពលធំលេខ ៣]។ ឯកសារ D59/1/1.7a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ា ឈឿន KH ERN 00926325 ["សៈ ពូរៀបគ្រួសារតាំងពីអង្កាលទៅ? ឈឿន៖ ៧៦។ សៈ ៧៦! គ្រួសារពូកាលហ្នឹង គាត់ធ្វើការខាងណាដែរ? ឈឿន៖ នៅខាងនារីកងទ័ពដែរ [...] សៈ អញ្ចឹងវរៈសេនាតូចរបស់នារីហ្នឹងគាត់ អឺគេនៅកំបង់សោម? វ៉ាត់៖ ចាស៎! [...] សៈ ... កាលពូរៀបការជាមួយមីងដំបូង រៀបការប៉ុន្មានគូទៅ? ឈឿន៖ ច្រើនគូដែរ នៅកំពង់សោម វ៉ាត៖ ៣០ នាក់។"]។

556 ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ឆ.3, 8 ["អ្នកនិយាយវិទ្យុទាក់ទងបានមកហៅខ្ញុំ ដោយប្រាប់ខ្ញុំថា មាស មុត ចង់ជួបខ្ញុំនៅផ្ទះ។ នៅពេលដែលខ្ញុំឡើងមកដល់ផែ មានម៉ូតូចាំទទួលខ្ញុំនៅទីនោះជាស្រេច។ នៅពេលដែលខ្ញុំទៅដល់ផ្ទះរបស់គាត់នៅជិតផ្សារកំពង់សោម ខ្ញុំឃើញកម្មាភិបាលធំៗ ប្រមូលផ្តុំគ្នានៅនឹងផ្ទះនោះ។ ពេលនោះខ្ញុំមិនដឹងថាគេកំពុងរៀបចំកម្មវិធីអ្វីទេ ភ្លាមៗនោះ តាញ៉ាន់ បានប្រកាសអំពីកម្មវិធីរៀបមង្គលការ [...] ក្រោយមកខាងកូនក្រមុំឡើងចាប់អារម្មណ៍ ថាគាត់យលព្រម តែខ្ញុំពុំព្រមឡើងចាប់អារម្មណ៍ទេ [...] ឆ.8៖ ខ្ញុំគិតថា តាមុត ជាអ្នកផ្តួងផ្តើមអាពាហ៍ពិពាហ៍របស់ខ្ញុំនៅពេលនោះ។ ខ្ញុំមិនដឹងហេតុផលទេ តែខ្ញុំគិតថា គាត់ចង់ឱ្យខ្ញុំក្លាយជាសាច់ញាតិរបស់គាត់ ព្រោះខាងស្រីក៏ជាសាច់ញាតិរបស់គាត់ដែ"]។ ឯកសារ D59/1/1.7a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ា ឈឿន KH ERN 00926326 [មេបញ្ជាការកងវរៈសេនាតូច ៥៦០ ៖ "សៈ ពូរៀបគ្រួសារតាំងពីអង្កាលទៅ? ឈឿន៖ ៧៦។ សៈ ៧៦! គ្រួសារពូកាលហ្នឹង គាត់ធ្វើការខាងណាដែរ? ឈឿន៖ នៅខាងនារីកងទ័ពដែរ [...] សៈ អញ្ចឹងវរៈសេនាតូចរបស់នារីហ្នឹងគាត់ អឺគេនៅកំបង់សោម? វ៉ាត់៖ ចាស៎! [...] សៈ ... កាលពូរៀបការជាមួយមីងដំបូង រៀបការប៉ុន្មានគូទៅ? ឈឿន៖ ច្រើនគូដែរ នៅកំពង់សោម វ៉ាត៖ ៣០ នាក់។ សៈ ៣០ នាក់។ កាលហ្នឹងសុទ្ធតែយើងជាអី ហៅថាយ៉ាងម៉េចទៅពេលដែលយើងរៀបការ? ឈឿន៖ រៀបការ គេហៅប្រមូលគ្នាមក។ សៈ ដូចថាយើងរៀបការជាមួយកម្មាភិបាល ឬក៏មានយុទ្ធជនរៀបការលាយជាមួយគ្នាដែរ? ឈឿន៖ លាយគ្នា វ៉ាត៖ លាយគ្នា កម្មាភិបាលខ្លះ [...] សៈ កាលហ្នឹងមានពីណាគេណែនាំ មានមតិណែនាំឱ្យការ? វ៉ាត៖ តាម៉ុត។"]។ សូមមើលផងដែរ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿន ឆ.253 ["អ្នកចាត់តាំងឱ្យរៀបការ គឺមេៗ មានដូចជា មាស មុត និង ហន ជាដើម"]។ ឯកសារ D114/91 កំណត់ហេតុស្តាប់ចម្លើយ សេង អុល ឆ.247-248 ["សៈ ពេលដែលលោកស្រីបញ្ជូននារីទៅខេត្តមួយទៀត តើត្រូវមានការអនុញ្ញាតពីថ្នាក់ស្រុកសិនមែនទេ? ឆ.247 ៖ ជាធម្មតា ការបញ្ជាចេញពីថ្នាក់ស្រុកមកឃុំ ហើយខ្ញុំទទួលបញ្ជាពីឃុំ។ សៈ មានន័យថា ប្រសិនបើមានសំណើឱ្យស៊ី ជាអ្នកធ្វើ មានន័យថា ថ្នាក់ស្រុកពិតជាបានយល់ព្រមរួចអស់ហើយមែនទេ? ឆ.248៖ ប្រហែលជាដូច្នេះហើយ ព្រោះពួកគេស្ថិតនៅក្នុងរចនាសម្ព័ន្ធតែមួយ"]។

ឈ្មោះ តា ញ៉ន[557]។ ពិធីអាពាហ៍ពិពាហ៍ជាច្រើនក្នុងចំណោមពិធីអាពាហ៍ពិពាហ៍ទាំងឡាយ ត្រូវបានធ្វើនៅក្រុងកំពង់សោម[558] ក្បែរផ្ទះនិងមន្ទីររបស់ **មាស មុត**[559]។ សិទ្ធិរៀបអាពាហ៍ពិពាហ៍ ឬ

---

557 ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ឆ.3 ["អ្នកនិយាយវិទ្យុទាក់ទងបានមកហៅខ្ញុំ ដោយប្រាប់ខ្ញុំថា មាស មុត ចង់ជួបខ្ញុំនៅផ្ទះ។ នៅពេលដែលខ្ញុំឡើងមកដល់ផែ មានម៉ូតូចាំទទួលខ្ញុំនៅទីនោះជាស្រេច។ នៅពេលដែលខ្ញុំទៅដល់ផ្ទះរបស់គាត់នៅជិតផ្សារកំពង់សោម ខ្ញុំឃើញកម្មាភិបាលធំៗ ប្រមូលផ្តុំគ្នានៅនឹងផ្ទះនោះ។ ពេលនោះខ្ញុំមិនដឹងថាគេកំពុងរៀបចំកម្មវិធីអ្វីទេ ភ្លាមៗនោះ តាញ៉ាន់ បានប្រកាសអំពីកម្មវិធីរៀបមង្គលការ"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ កឹម ម៉េន ឆ.225-226, 228-229 ["ស៖ តើលោករៀបការសម័យខ្មែរក្រហមមែនទេ? ឆ.225៖ បាទ គឺចុងឆ្នាំ ១៩៧៧ ឬដើម ១៩៧៨។ ស៖ តើធ្វើម៉េច ទើបលោកបានជួយប្រពន្ធ? ឆ.226៖ គាត់ធ្វើពេទ្យខាងកំពង់សោម ហើយថ្នាក់លើរៀបចំការឲ្យ។ ខ្ញុំមិនដែលស្គាល់គាត់ទេ។ តាញ៉ាន់ ដែលមកជំនួស តានាន គឺជាអ្នករៀបចំរៀបការឲ្យ [...] ស៖ លោកនិយាយថា ញ៉ាន់ អ្នករៀបការឲ្យលោក។ តើកាលនោះ គាត់នៅកងពលធំ ឬ? ឆ.228៖ បាទ គឺកងពលធំ ១៦៤។ ស៖ តើខាងកងពលធំហ្នឹង បានរៀបចំការឲ្យច្រើនគូទេ នៅខាងកំពង់សោមហ្នឹង? ឆ.229៖ កាលគេរៀប មានបីគូ [...] ខាងស្រីបីនាក់ ឲ្យអង្គុយទល់មុខខាងប្រុស ហើយ ញ៉ាន់ អង្គុយនៅក្បាលតុ"]។ ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.22, ឆ.29-30 ["ស៖ ឥឡូវនេះ យើងប្តូរប្រធានបទវិញ។ តើនៅក្នុងកងពលធំលេខ ១៦៤ មានគោលនយោបាយរៀបការយ៉ាងម៉េចដែរ? ឆ.22៖ គូស្រករមិនបានស្គាល់គ្នាមុនឡើយ មុនពេលដែលពួកគេរៀបការ រឿងនេះកើតឡើងចំពោះខ្ញុំ និងអ្នកដទៃផងដែរ។ [...] ស៖ តើអ្នកណាជាអ្នកធ្វើអធិបតីនៅក្នុងពិធីរៀបការនោះ? ឆ.29៖ គឺឈ្មោះ ញ៉ាន់ គាត់ធ្វើជាអធិបតី នៅក្នុងពិធីរៀបការរបស់ខ្ញុំជាមួយនឹងមនុស្ស២នាក់ទៀត ដែលមានឈ្មោះ អាន។ ស៖ តើពិធីរៀបការនោះធ្វើឡើងនៅកន្លែងណា? ឆ.30៖ នៅកំពង់សោម"]។ សូមមើលផងដែរ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.29 ["ស៖ ឥឡូវយើងប្តូរប្រធានបទ ទៅនិយាយអំពីការរៀបការដែលគេធ្វើនៅក្នុងកងពល ១៦៤ កាលពីពេលនោះ។ អ្នកដែលនៅក្នុងកងពល ១៦៤ ចង់រៀបការ និងអ្នកដែលត្រូវតែរៀបការថា តើរបៀបស្នើរៀបការ ត្រូវធ្វើយ៉ាងដូចម្តេច? ឆ.29៖ ខ្ញុំឃើញពិធីរៀបការតែមួយទេ ដែលនៅក្នុងពិធីនោះ គឺមានកូនកំលោះកូនក្រមុំចំនួន ១០ គូ នៅក្នុងពិធីរៀបការនោះ ក៏មាន តាសេង តាមឿន ហើយនិងអ្នកដឹកនាំដទៃទៀត"]។

558 ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.30 ["ស៖ តើពិធីរៀបការនេះធ្វើឡើងនៅកន្លែងណា? ឆ.30៖ នៅកំពង់សោម។ ពិធីរៀបការនោះធ្វើឡើងនៅជិតរូបគោបច្ចុប្បន្ននេះ មានតែ ៣ គូប៉ុណ្ណោះ ដែលគេរៀបការឲ្យនៅពេលនោះ។ ទីកន្លែងគឺជាកន្លែងភស្តុភារ។"]។ ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សាវ៉ាន ឆ.5 ["គេរៀបការពួកខ្ញុំនៅក្នុងរោងកុនកំពង់សោម។ គឺមានមនុស្សពេញរោងកុននោះតែម្តង ហើយគេក៏បានប្រកាសថាមានសរុប ៧១ គូ។ ស៖ តើលោកស្រីដឹងថា គេរៀបចំឲ្យមានគូស្រករនៅពេលណាដែរ? ឆ.6៖ ខ្ញុំមិនដែលបានដឹងពីការរៀបចំឲ្យខ្ញុំមានគូស្រករនោះពីមុនមកសោះ [...] ឆ.10៖ ក្រោយពីបានទៅដល់រោងកុន ខ្ញុំមានការភ្ញាក់ផ្អើលដោយសារមានមនុស្សច្រើន ហើយខ្ញុំក៏បានសួរគេ ហើយគេប្រាប់ថា គេកំពុងតែរៀបចំពិធីការខ្ញុំចង់រត់ពីទីនោះដែរ ប៉ុន្តែមិនអាចរត់រួច ពីព្រោះទាហាននៅសងខាង"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ កឹម ម៉េន ឆ.234 ["ស៖ តាមលោកដឹង ពី ១៩៧៥ ដល់ ១៩៧៩ តើការរៀបចំរៀបការទាំងអស់ គឺកងពល [១៦៤] ជាអ្នករៀបចំឲ្យ ឬ

មិនរៀបអាពាហ៍ពិពាហ៍ជាមួយដៃគូតាមការជ្រើសរើសរបស់សាម៉ីខ្លួន ត្រូវបានដកហូតពីមនុស្សទាំងអស់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ **មាស មុត**[560] ដែលបានបណ្តាលឱ្យមនុស្សរាប់រយនាក់បានរងការបង្ខិតបង្ខំឱ្យរៀបការនៅតំបន់កំពង់សោម[561]។

---

យ៉ាងម៉េច? ឆ.234៖ បើរៀបការនៅកន្លែងកងពល។ ខាងកងពលរៀបការឱ្យ ព្រោះជាថ្នាក់ដឹកនាំកម្មាភិបាល ដូចជាវរសេនាតូច វរសេនាធំ។ បើយើងត្រឹមតែកងពលធម្មតា គឺមានគណៈកម្មាការ ទៅតាមអង្គភាពគេរៀបការ"]។

559 ឯកសារ D54/71 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.18-20, 28 ["សៈ តើលោកស្រីអាចពិពណ៌នាអំពីទីកន្លែងដែលលោកស្រីស្នាក់នៅជាមួយ បន្ទាប់ពីលោកស្រីចាកចេញពីផ្ទះស្ទៀវសុខាមក? ឆ.18៖ កន្លែងនោះ ហៅថា មន្ទីរក្នុងរបស់កងពល ១៦៤។ ប្រសិនបើលោកធ្វើដំណើរពីផ្សារលើទៅកាន់រង្វង់មូលតោពីរ លោកមកដល់ចំណុចផ្លូវកោងមានផ្លូវមួយកាត់ទទឹងផ្លូវធំ លោកអាចបតស្តាំងប្រហែល ៥០០ ម៉ែត្រ លោកនឹងទៅដល់កន្លែងទីតាំងមន្ទីរក្នុងរបស់កងពល [...] សៈ តើមន្ទីរក្នុងរបស់កងពល ១៦៤ ហ្នឹងមានមុខងារធ្វើអ្វីខ្លះ? ឆ.20៖ វាគឺជាផ្ទះដែល មាស មុត ស្នាក់នៅ។ [...] ឆ.28៖ មានអគារផ្សេងៗគ្នានៅក្នុងបរិវេណនៃមន្ទីរក្នុង។ នកន្លែងនោះមានរោងបាយរួម ផ្ទះរបស់ មាស មុត កន្លែងស្នាក់នៅរបស់និរសារ និងអ្នកផ្សេងៗទៀតស្នាក់នៅ កន្លែងសារទូរលេខ កន្លែងមួយហៅថា មន្ទីរផ្សាយដែលស្ថិតនៅជិតរង្វង់មូលតោពីរ"]។ ឯកសារ D54/17 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.4-5 ["ទីតាំងប្ញជាការ/កន្លែងរស់នៅរបស់ មាស មុត មេបញ្ជាការកងពលធំ ១៦៤ នៅជិតផ្លូវសំនាក់តោ ដែលជាកន្លែងដែលកាត់តែងតែជួបជាមួយមេបញ្ជាការ ដែលគាត់ធ្លាប់ចេញបញ្ជាតាមរយៈនីរសារ សៈ តើទីតាំងរូបសំនាកតោនៅក្នុងព្រះសីហនុបិតនៅជិតទីបញ្ជាការរបស់ មាស មុត ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដែរឬទេ? ឆ.4៖ បាទ ទីតាំងរូបសំនាកតោ គឺនៅដដែល ប៉ុន្តែរូបតោមិនមែនជារូបសំនាក់ចាស់ទេ។ សៈ ហេតុអ្វីបានជាលោកដឹងថា ទីតាំងរបស់ មាស មុត ឋិតនៅជិតត្រពាំងទឹក ឆ.5៖ ថ្ងៃមួយ ខ្ញុំបានទៅទីនោះជាមួយមិត្តភក្រ័ម្នាក់ ដែលជានីរសាររបស់កងពល។ ខ្ញុំបានទៅទីនោះប្រហែលជាចុងឆ្នាំ ១៩៧៥ ជាមួយនីរសារនោះ។ ខ្ញុំមិនបានទៅជិតផ្ទះរបស់លោក មាស មុត ទេ ខ្ញុំគ្រាន់តែបានមើលឃើញពីចម្ងាយប្រហែលពី ៤០ ទៅ ៥០ ម៉ែត្រ។ ផ្ទះនោះនៅជិតត្រពាំងទឹកមួយ ដែលត្រពាំងទឹកនោះ នៅមានរហូតដល់ឥឡូវនេះ។ ហើយផ្ទះនោះ គឺជាផ្ទះធ្វើពីឈើរាងវែង។ តាមដែលខ្ញុំដឹង លោក មាស មុត រស់នៅ និងធ្វើការនៅក្នុងផ្ទះនោះ ពីព្រោះខ្ញុំមិនដឹងថា មានកន្លែងណាទៀត ដែលគាត់ធ្វើការក្រៅពីកន្លែងនេះទេ"]។ ឯកសារ D54/26 កំណត់ហេតុ ស្តាប់ចម្លើយប៉ាក សុខ ឆ.3 ["សៈ តើផ្ទះដែល មាស មុត ស្នាក់នៅ និងមន្ទីររបស់ មាស មុត ធ្វើការមានចម្ងាយប៉ុន្មានពីគ្នា? ឆ.3៖ មន្ទីរបញ្ជាការរបស់ មាស មុត ហើយនិងផ្ទះស្នាក់នៅរបស់គាត់មានចម្ងាយប្រហែល ២ គីឡូម៉ែត្រពីវត្តឥណ្ឌញាណ។ ផ្ទះរបស់ មាស មុត គឺនៅនឹងកន្លែងមន្ទីរធ្វើការរបស់គាត់តែម្តង"]។

560 ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.34 ["សៈ តើគោលនយោបាយស្តីពីការរៀបការនេះអនុវត្តលើមនុស្សទាំងអស់នៅក្នុងពលកលឬ? ឆ.34៖ គោលនយោបាយនេះ គឺអនុវត្តជាទូទៅ"]។

561 ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន ឆ.2-5 ["ទេ ខ្ញុំចង់គូសបញ្ជាក់ប្រាប់ថា គឺកងវរសេនាតូច ១៦០ ក្រោមកងពលធំលេខ ៣ ទេ។ សៈ តើលោកស្រីអាចប្រាប់បានទេថា កាលនោះនៅខែណា នៅចុងឆ្នាំ ១៩៧៥ ដែរឬទេ? ឆ.3៖ សុំទោស ខ្ញុំពុំចាំខែពិតប្រាកដទេ។ តែខ្ញុំចាំថា គឺនៅចុងឆ្នាំ ១៩៧៥ និងដើមឆ្នាំ ១៩៧៦។ សៈ តើមានអ្នកដទៃរៀបការដែរឬទេ ក្នុងជំនាន់នោះ? ឆ.4៖ កាលនោះ គឺមានសរុប ៧១ គូ ទាំងគូខ្ញុំផង សៈ ហេតុអ្វីបានជាលោក

206. **មាស មុត** បានខកខានពុំចាត់វិធានការណាមួយទប់ស្កាត់មនុស្សក្រោមបង្គាប់របស់គាត់ មិនឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងទម្រង់ជាអាពាហ៍ពិពាហ៍ដោយបង្ខំ ឬការរំលោភផ្លូវភេទឡើយ។ ប៉ុន្តែ ការជាប់ពាក់ព័ន្ធផ្ទាល់របស់គាត់តាមរយៈការបញ្ជា ការអនុញ្ញាត និងការរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំទាំងនេះ និងការផ្សំដំណេកដោយបង្ខំ (ការរំលោភផ្លូវភេទ) នៅកំពង់សោម បានញុះញង់

---

ស្រីនៅចាំទូរលេខនេះ ប្រាកដយ៉ាងនេះ? ឆ.5៖ គេរៀបការពួកខ្ញុំនៅក្នុងរោងកុនកំពង់សោម។ គឺមានមនុស្សពេញរោងកុននោះតែម្តង ហើយគេក៏បានប្រកាសថា មានសរុប ៧១ គូ។"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ កឹម ម៉េន ឆ.232 ["ស៖ តើតាមធម្មតាពេលគេរៀបការ តែងតែមានច្រើនគូរៀបដំណាលគ្នាមែនទេ? ឆ.232៖ ចំពោះខ្ញុំមានតែបីគូប៉ុណ្ណោះ ខ្ញុំមិនដឹងករណីអ្នកផ្សេងទៀតទេ ប៉ុន្តែអ្នកផ្សេងដូចជាយុទ្ធជនជាដើមខ្ញុំឮថា ពេលគេរៀបការអាចមានដប់គូ"]។ ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណារ សុខន ឆ.256-257, 262-263, 265-266, 273, 275-276 ["ស៖ ស៖ ពេលដែលលោកស្រីមកដល់កំពង់សោមបានប៉ុន្មានថ្ងៃ ទើបគេឱ្យរៀបការ? ឆ.256៖ ប្រហែលមួយខែ ស៖ អ៊ីចឹងបានន័យថា ខែតុលា ឆ្នាំ ៧៧ ដែលលោកស្រីរៀបការ? ឆ.257៖ ចាស។ [...] ស៖ តើមានអ្វីកើតឡើង ពេលដែលគេមករកលោកស្រីឱ្យរៀបការ? ឆ.262៖ គេប្រាប់ថា គេមកឱ្យលោកស្រីរៀបការហើយ។ តែខ្ញុំមិនព្រម តែគាត់ប្រាប់ថា បើមិនការទេ គេនឹងដាក់គុកហើយ ដូច្នេះហើយ ទើបខ្ញុំព្រម។ ស៖ ចុះអ្នកផ្សេងទៀតដែលគាត់មិនព្រមការវិញ? ឆ.263៖ បើគេមិនព្រមការ គឺគេសុខចិត្តស្លាប់ ហើយគេក៏នៅទីនោះទៅ។ [...] ស៖ ពេលដែលលោកស្រីព្រមការនោះ តើមានអ្វីកើតឡើង? ឆ.265៖ ពេលព្រមការហើយ គេយកខ្ញុំទៅកន្លែងរៀបការនៅស្ទឹងហាវ នៅកំពង់សោម ជិតហាងផលិតទឹកត្រី [...] ស៖ តើលោកស្រីស្គាល់ ប្តីលោកស្រីពីមុនមកទេ? ឆ.266៖ មិនស្គាល់ទេ [...] ស៖ ពេលថ្ងៃប្តេជ្ញានោះ តើគេរៀបចំនៅទីណា? ឆ.273៖ នៅស្ទឹងហាវ វាជាទីទួលខ្ពស់ [...] ស៖ មានអ្នកណាចូលរួមខ្លះ? ឆ.275៖ មានពួកស្រីៗទាំងខ្ញុំ ៧ នាក់ ហើយប្រុសៗ នៅទីនោះរួចហើយ ព្រោះវាជាកន្លែងរបស់គេ ស៖ តើមានមនុស្សប្រុសៗជាអ្នករៀបការប៉ុន្មាននាក់? ឆ.276៖ មាន ៧ នាក់"]។ ឯកសារ D230/1.1.631D អ្នកដាក់ពាក្យសុំតាំងខ្លួនជាបណ្តឹងរដ្ឋប្បវេណី សំ ប៊ុនឡេង EN ERN 00477162 [កងវរសេនាតូច ឈ្មោះ តាជួប បានស្នើឱ្យអ្នកដាក់ពាក្យសុំនេះ ជ្រើសរើសប្រពន្ធ។ ក្រោយមក អ្នកដាក់ពាក្យសុំនេះ ក៏បានប្រាប់ទៅកងវរសេនាតូចនោះវិញថា គាត់មានគូដណ្តឹងហើយ។ ពេលនោះ មាន ៥០ គូ រៀបការនៅពេលដំណាលគ្នានៅព្រលានយន្តហោះកងកេង នៅកំពង់សោម។ ពួកគេគឺជាទាហានកងពលធំលេខ ៣]។ ឯកសារ D59/1/1.7a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ា ឈឿន, KH ERN 00926325 ["ស៖ ពូរៀបគ្រួសារតាំងពីអង្គាលទៅ? ឈឿន៖ ៧៦។ ស៖ ៧៦! គ្រួសារពូកាលហ្នឹង គាត់ធ្វើការខាងណាដែរ? ឈឿន៖ នៅខាងនារីកងទ័ពដែរ [...] ស៖ អញ្ចឹងវរៈសេនាតូចរបស់នារីហ្នឹងគាត់ អឹគេនៅកំពង់សោម? វ៉ាត់៖ ចាស់! [...] ស៖ ... កាលពូរៀបការជាមួយមីងដំបូង រៀបការប៉ុន្មានគូទៅ? ឈឿន៖ ច្រើនគូដែរ នៅកំពង់សោម វ៉ាត៖ ៣០ នាក់។ ស៖ ៣០ នាក់។ កាលហ្នឹងសុទ្ធតែយើងជាអី ហៅថាយ៉ាងម៉េចទៅពេលដែលយើងរៀបការ? ឈឿន៖ រៀបការ គេហៅប្រមូលគ្នាមក។ ស៖ ដូចថាយើងរៀបការជាមួយកម្មាភិបាល ឬក៏មានយុទ្ធជនរៀបការលាយជាមួយគ្នាដែរ? ឈឿន៖ លាយគ្នា វ៉ាត៖ លាយគ្នា កម្មាភិបាលខ្លះ [...] ស៖ កាលហ្នឹងមានពីណាគេណែនាំ មានមតិណែនាំឱ្យការ? វ៉ាត៖ តាម៉ុត។"]។

មនុស្សក្រោមបង្គាប់របស់គាត់ឱ្យជំរុញគោលនយោបាយឧក្រិដ្ឋកម្ម នៃការបង្ខំមនុស្សឱ្យរៀបការ និងរួមភេទដោយគ្មានការឯកភាពដោយសេរី។

## IV. រចនាសម្ព័ន្ធអំណាចកងពលធំលេខ ១៦៤ (អតីតកងពលធំលេខ ៣)

207. **មាស មុត** បានបញ្ជាកងពលធំរបស់មជ្ឈិមលេខ ១៦៤ ដែលឈរជើងនៅកំពង់សោមពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ បន្ទាប់ពីបានដឹកនាំកងពលធំលេខ ៣ នៅភូមិភាគនិរតី។

<u>កងពលធំលេខ៣ (ឆ្នាំ ១៩៧៣/១៩៧៤- ខែ កក្កដា ឆ្នាំ ១៩៧៥)</u>

208. កងពលធំលេខ ៣ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៧៣ ឬនៅដើមឆ្នាំ ១៩៧៤[562] ជាផ្នែកមួយនៃកងទ័ពភូមិភាគនិរតី[563]។ កងពលនេះមានកងទ័ពរាប់ពាន់នាក់[564]។ តា ម៉ុក ដែលជាលេខាភូមិភាគ

---

562 ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.38 [មាស មុត ត្រូវបានតែងតាំងជាមេបញ្ជាការកងពលលេខ ៣ នៅពេលដែលកងពលនេះបង្កើតឡើង"]។ ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុង សេង ឆ.5 ["កងពលលេខ ៣ ជាកងពលរបស់ភូមិភាគនិរតី ដែលបង្កើតឡើងដោយ តាម៉ុក ក្នុងឆ្នាំ ១៩៧៣"]។ ឯកសារ D114/29.1.4 ប៉ែន យៀនិន របបខ្មែរក្រហម KH ERN 00637488 ["នៅក្នុងឆ្នាំ ១៩៧៣ មុត បានឡើងទៅជាលេខាកងពលធំលេខ ៣ របស់ភូមិភាគនិរតី"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចាក់ ឆ.1 ["ខ្ញុំនៅជាមួយគាត់តាំងពីនៅកងពលទី ៣ តាំងពីឆ្នាំ ១៩៧៣ មក ។ ឯកសារ D114/181 កំណត់ហេតុស្តាប់ចម្លើយ សែម កុល ឆ.7 [មាស មុត "ជាកងពលតូចលេខ ៣។ កងពលហ្នឹង វាគ្រប់គ្រង ៣ វរសេនាធំ។ កាលហ្នឹង នៅក្នុងឆ្នាំ ១៩៧៣"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ.15 ["សៈ តើគេដាក់លោកចូលក្នុងកងពលលេខ ៣ នៅឆ្នាំណា? ឆ.15៖ ដើមឆ្នាំ ១៩៧៤ វាអាចចន្លោះពីឆ្នាំ ១៩៧៣ ទៅឆ្នាំ ១៩៧៤ គឺខ្ញុំមិនច្បាស់ទេ"]។ ឯកសារ D22.2.181 ចម្លើយ មាស មុត ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០១ EN ERN 00249693, KH ERN 00741996 ["នៅក្នុងឆ្នាំ ១៩៧៤ លោកត្រូវបានតែងតាំងឱ្យធ្វើជាមន្ត្រីនយោបាយទទួលបន្ទុកកងពលធំលេខ ៣ ទើបតែបង្កើតថ្មីរបស់កងទ័ពខ្មែរកុម្មុយនីស្ត"]។ ឯកសារ D234./2.1.91 ព្រឹត្តិបត្រ ប្រតិចារឹក ថ្ងៃទី ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ 15.18.30-15.22.54 ["វាកើតឡើងនៅក្នុងឆ្នាំ ១៩៧៤។ កងពលធំលេខ ៣ បានចូលជាផ្លូវការនៅក្នុងភូមិភាគនិរតី"]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.6 ["ក្នុងឆ្នាំ ១៩៧៣-១៩៧៤ វរសេនាតូច ១០៤ ត្រូវបាន តាម៉ុក យកចូលទៅក្នុងកងពលលេខ ៣ របស់ភូមិភាគនិរតី"]។ ឯកសារ D54/20 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ សំ កេត ឆ.1 ["គេឱ្យខ្ញុំទៅនៅកងពលទី ៣ ក្នុងឆ្នាំ ១៩៧៣"]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល EN ERN 00968373-74, KH ERN 00926602 ["សៈ ថ្ងៃ១ ខែ១ ឆ្នាំ៧៤ ហ្នឹង គេរៀបកងទ័ពភាគជាកងទពទី ៣? ឆៈ កងពលទី ៣។ សៈ កងពលទី ៣ ហ្នឹង គេបង្កើតថ្ងៃហ្នឹងហ្មង? ឆៈ បាទ! បង្កើតថ្ងៃហ្នឹង"]។ ឯកសារ D114/132 ម៉ៅ វ៉ាន់ ឆ.17 ["ក្នុងឆ្នាំ ១៩៧៤ ពេលគេរៀបចំកងពល ខ្ញុំដឹងតែថា យើងនៅក្រោមកងពលលេខ ៣ ដែលមានមេបញ្ជាការ

និរតី និងជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍របស់ ប.ក.ក ដ៏មានអំណាចម្នាក់[565] បានតែងតាំងកូនប្រសារដែលគាត់ទុកចិត្តឈ្មោះ **មាស មុត** ជាមេបញ្ជាការកងពលធំលេខ ៣ និង (ជាមន្ត្រី

---

ឈ្មោះ មាស មុត"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន សារ៉ាត់ ឆ.1, 24 ["តើលោកគេបញ្ជូនទៅកងពលលេខ ៣ លើកដំបូងនៅពេលណា? ឆ.1៖ ខ្ញុំចូលទៅក្នុងកងពលទី ៣ ខ្ញុំចាំតែខែ ខែមេសា ឆ្នាំ ១៩៧៤ [...] ឆ. 24៖ កងពលធំ ៣ [...] គឺបង្កើតឡើងនៅក្នុងឆ្នាំ ១៩៧៤"]។ ឯកសារ D2/8 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ. 21, 28 ["រហូតដល់ឆ្នាំ ១៩៧៤ ទើបគេបញ្ជូនខ្ញុំឱ្យទៅធ្វើកងទ័ពរបស់ភូមិភាគ [...] ប្រហែលជាពាក់កណ្តាលឆ្នាំ ១៩៧៤ [...] ឆ.28៖ ខ្ញុំត្រូវបានគេបញ្ចូលក្នុងកងពលលេខ ៣។ ដូច្នេះកងពលនេះមានតាំងពីមុនខ្ញុំចូលមកម្ល៉េះ"]។ ឯកសារ D54/46 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.27-28។ ឯកសារ D54/99 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.17។ ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ឆ.9។ ឯកសារ D54/99.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ EN ERN 01115964-65, KH ERN 00990754-55។ ឯកសារ D4.1.759 ចម្លើយ ខែម ងួន ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម EN ERN 00387265, KH ERN 00658135។

563 ឯកសារ D54/35 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.10 ["កងវរៈសេនាតូច ៤៣០ ឋិតក្នុងកងពលទី ៣ ដែលមាន តាមុត ជាមេបញ្ជាការកងពល ហើយ តាម៉ុក ជាប្រធានភូមិភាគនិរតី"]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.6 ["ក្នុងឆ្នាំ ១៩៧៣-១៩៧៤ វរសេនាតូច ១០៤ ត្រូវបាន តាម៉ុក យកចូលទៅក្នុងកងពលលេខ ៣ ភូមិភាគនិរតី"]។ ឯកសារ D59/1/1.7a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ា ឈឿន EN ERN 00969926, KH ERN 00926304 ["ស៖ កងពលទី ៣ ហ្នឹង ជាកងពលរបស់តំបន់ដែរ ឬក៏របស់យ៉ាងម៉េច? ឆ៖ របស់ភូមភាគ ភូមិភាគ តាម៉ុក ហើយអាហ្នឹង"]។ ឯកសារ D54/92.1 យ៉ែម សំអុន កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយEN ERN 01063506, KH ERN 00958347។

564 ឯកសារ D54/42.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហេង វៀច EN ERN 00983438, KH ERN 00967564, FN ERN 00996810 [អំពីកងពលធំលេខ ៣ ក្នុងឆ្នាំ ១៩៧៤៖ "ទ័ពច្រើនណាស់ កងសុទ្ធតែ ៤ ពាន់ ទៅ ៥ពាន់ [...] បើថាទៅសមរភូមិ ទៅសមរភូមិ ១ អាទិត្យ ឬ ១០ នាក់ត្រូវចាយវាយស្លាប់ទ័ពអស់ ១-២ រយ ចាក់សំបុត្រទៅភូមិ-ឃុំ បញ្ជូនមកទៀតភ្លាម [...] អត់មានខ្វះទេ"]។

565 ឯកសារ D54/35 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.10 ["កងវរៈសេនាតូច ៤៣០ ឋិតក្នុងកងពលទី ៣ ដែលមាន តាមុត ជាមេបញ្ជាការកងពល ហើយ តាម៉ុក ជាប្រធានភូមិភាគនិរតី"]។ ឯកសារ D98/1.1.6 កំណត់ហេតុស្តាប់ចម្លើយ នុច នៅ ឆ.30។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.6។ ឯកសារ D59/1/1.7a កិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជារបស់ ម៉ា ឈឿន EN ERN 00969926, KH ERN 00926304។ ឯកសារ D98/3.1.176 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ មាស វឿន KH ERN 00733338-39។ ឯកសារ D54/51 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.4, 24។ ឯកសារ D1.3.33.15 កំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន KH ERN 00156619 ["គណៈកម្មាធិការអចិន្ត្រៃយ៍ មានសមាជិក ៧ រូប៖ ប៉ុល ពត, នួន ជា, វន វេត, សោ ភឹម, តាម៉ុក, សុន សេន និង អៀង សារី"]។ ឯកសារ D4.1.964 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

នយោបាយ)[566]។ ម៉ែន ង៉ែត ហៅ ង៉ែត និងឡុង សារឿន (សារិន)[567] ហៅ រឿន ឬ រិន គឺជាអនុ របស់ **មាស មុត**[568]។ ទោះជាយ៉ាងនេះក្តី ភ្លាមៗបន្ទាប់ពីមកដល់កំពង់សោម សារឿន និង ង៉ែត

ជាមួយ អៀង សារី KH ERN 00062454 ["ឆ. គណៈអចិន្ត្រៃយ៍ហ្នឹងទាំងអស់មាន៖ ប៉ុល ពត, នួន ជា, សោ ភឹម, ខ្ញុំ, សុន សេន, តាម៉ុក [...] វន វេត"]។ ឯកសារ D1.3.33.3 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេចអ៊ាវ ហៅ ឌុច KH ERN 00146482 ["ទាក់ទងបុគ្គលសំខាន់ៗទាំង ៧ ក្នុងបក្ស៖ [...] ទី ៤ អ៊ុង ជឿន ហៅម៉ុក ទទួលភារៈនិរតី"]។ ឯកសារ D1.3.33.10 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេចអ៊ាវ ហៅ ឌុច KH ERN 00195568 [និយាយអំពី ប៉ុល ពត, នួន ជា, សោ ភឹម, តាម៉ុក, អៀង សារី, សុន សេន វន វេត ដែល ជាសមាជិកអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា]។

566 ឯកសារ D22.2.181 ចម្លើយ មាស មុត ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០១ EN ERN 00249693, KH ERN 00741996 ["នៅក្នុងឆ្នាំ ១៩៧៤ លោកត្រូវបានតែងតាំងឲ្យធ្វើជាមន្ត្រីនយោបាយទទួលបន្ទុកកងពលធំលេខ ៣ ទើបបង្កើតឡើងថ្មីរបស់កងទ័ពខ្មែរកុម្មុនីស្ត។ ទីបញ្ជាការដ្ឋានភូមិភាគនិរតី បានបង្កើតកងពលធំលេខ ៣ ចេញពីសមាសភាពនៃតំបន់ ៣៧ និងកងវរសេនាតូចឯករាជ្យនៃភូមិភាគនិរតី"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន សារ៉ាត់ ឆ.212 ["មាស មុត ជាកូនប្រសាររបស់ តាម៉ុក [...] (ប្រពន្ធមុនរបស់ មាស មុត ជាកូនរបស់ តាម៉ុក)"]។ ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុង សេង ឆ.5 ["ហើយត្រូវបានបញ្ជូនមកធ្វើជាយោធាតំបន់ ហើយបន្ទាប់មកបញ្ជូនមកធ្វើជាយោធាភូមិភាគ ដែលមានកងពលលេខ ៣។ តាម៉ុក បង្កើតកងពលលេខ ៣ ហើយចាត់តាំងឲ្យ មាស មុត ធ្វើជាប្រធាន។ បន្ទាប់មក តាម៉ុក ជ្រើសរើស និងចម្រាញ់យោធា មុនពេលបញ្ជូលពួកនោះមកដាក់ក្នុងកងពល"]។ ឯកសារ D54/46 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.26 ["ស៖ តើនរណាគេជាមេបញ្ជាការកងពលធំលេខ ៣ [...] ឆ.26៖ គឺ មាស មុត"]។ ឯកសារ D59/1/1.29 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ង៉ែត ចាន់ធូ (ពេទ្យទាហាន) EN ERN 00968434, KH ERN 00733609 ["គឺ មាស មុត ដែលជាកូនប្រសាររបស់ តាម៉ុក"]។ ឯកសារ D114/158 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេចអ៊ាវ ហៅ ឌុច ឆ.22 ["បងមុត គឺជាកូនប្រសាររបស់ បងម៉ុក"]។ ឯកសារ D4.1.911 កំណត់ហេតុស្តាប់ចម្លើយអៀប ឌុច KH ERN 00163490 ["សមមិត្តនារី ខុម ជាកូន តាម៉ុក ។ ក្រោយមកជាប្រពន្ធ តាមុត (មាស មុត)"]។ ឯកសារ D114/216 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ុម ឆ.22 ["[ប្រពន្ធទី ១ របស់ មាស មុត] បានស្លាប់នៅក្នុងឆ្នាំ ១៩៧៥ ឬ ឆ្នាំ១៩៧៦។ [គាត់] ស្លាប់ដោយសារជំងឺរិកលចរិត"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.6។ ឯកសារ D54/81 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ិច ឆ.14 ។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.50។ ឯកសារ D54/62 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ឆ.16។ ឯកសារ D54/99.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ EN ERN 01115965, KH ERN 00990754-55។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាង វ៉េត EN ERN 00974079, KH ERN 00926525។ ឯកសារ D54/112.1 ឯកសារ D59/1/1.10a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ផ្លុងង ឈា EN ERN 00968344-45, KH ERN 00926490

។ ឯកសារ D4.1.759 ចម្លើយរបស់ ម៉ៅ វ៉ាន់ ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម EN ERN 00387267, KH ERN 00658139។

567 ឈ្មោះ ឡុង រឿន (លេខាកងវរសេនាធំ) ក៏មានឈ្មោះនៅក្នុងរបាយការណ៍ពីររបស់អគ្គសេនាធិការ៖ ឯកសារ D1.3.30.6 របាយការណ៍អគ្គសេនាធិការ វគ្គរៀនសូត្រទូទៅលើកទី ២- វគ្គរៀនសូត្រ- តារាងស្ថិតិសិក្ខាកាម ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ EN ERN 00195333, KH ERN 00008467, FN ERN 00623211 [លេខ ២១០ ឡុង រឿន លេខាកងវរសេនាធំនៃកងពលលេខ ១៦៤]។ ឯកសារ D1.3.8.8 របាការណ៍អគ្គសេនាធិការរបស់កម្ពុជាប្រជាធិបតេយ្យ - វគ្គសិក្សារៀនសូត្រលើកទី ២ របស់អគ្គសេនាធិការ EN ERN 00535795, KH ERN 0006512, FN ERN 00504103 [ដាក់ថា ឡុង រឿន ជាប្រធានក្រុមទី ២ នៃកងពល ១៦៤ សម្រាប់ "ស្វ័យទិតៀនបដិវត្ត"]។

568 ឯកសារ D54/99.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ EN ERN 01115965, KH ERN 00990755 ["ស៖ តើនរណាខ្លះ គឺជាគណៈកងពលធំ? ឆ៖ គឺ សារិន ហៅ រិន"]។ ឯកសារ D54/82 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.17 ["កាលពីម្សិលមិញ ខ្ញុំបាននិយាយអំពីឈ្មោះ សារឿន រួចទៅហើយ។ ខ្ញុំសង្ស័យថា ឈ្មោះ រឿន និងឈ្មោះ សារឿន ជាមនុស្សតែមួយ។ ក្នុងចំណោមកម្មាភិបាលគេឮឈ្មោះគាត់ច្រើន ហើយខ្ញុំក៏មិនស្គាល់គាត់ឈ្មោះដែរ"]។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ហៅ សារ៉េត ឆ.11 [នៅក្នុងឆ្នាំ ១៩៧៥៖ "ខ្ញុំគ្រាន់តែដឹងថា ង៉ែត ហើយនិង រិន គឺជាអនុរបស់ តាម៉ុក"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿន ឆ.66 ["ពួកគេគឺសុទ្ធតែនៅក្រោម មាស មុត។ ឧទាហរណ៍ ង៉ែត គឺជាអនុរបស់ មាស មុត"]។ ឯកសារ D2/8 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.27 ["ឈ្មោះ មាស មុត ជាលេខាកងពល និងឈ្មោះ រិន ជាអនុ"]។ ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.32 ["ស៖ តើលោកមានចាំបានទេ មុនពេល ឌឹម ក្លាយទៅជាប្រធាន តើនរណាជាអនុប្រធាន? ឆ.32៖ មុនពលេដែលកងត្រូវបានប្តូរលេខ អនុប្រធានមុន ឌឹម គឺឈ្មោះ រិន"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ.16 ["ស៖តើលោកមានដឹងថា នរណាជាមេបញ្ជាការរបស់កងពលធំ គឺជានរណាទេ? ឆ.16៖ [...] គឺ បងរិន"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន សារ៉ាត់ ឆ.34 [មកដល់ខែ សីហា ឆ្នាំ ១៩៧៥ "មេបញ្ជាការកងពលលេខ ៣ លោក មាស មុត។ មេបញ្ជាការរង រិន"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាង រ៉េត EN ERN 00974079, KH ERN 00926526 ["ស៖ តើនរណាគេខ្លះទទួលបន្ទុកគ្រប់គ្រងកងពលធំ ក្រៅពី តាមុត? ឆ៖ មាន តាមុត ហើយនិង តារិន [...] តែដល់ក្រោយមកទៀតនៅឆ្នាំ ៧៥ កងពលធំទី ៣ បានក្លាយទៅជាកងពលជើងទឹក]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយប៉ាក សុខ (ប៉ាក សុខ ធ្វើការកែតម្រូវនៅក្នុងអំឡុងពេលកិច្ចសម្ភាសន៍ជាមួយ ក.ស.ច.ស) EN ERN 00978566, KH ERN 00955493 ["[ចំណារពន្យល់បន្ថែម] តាសារឿន អនុម្នាក់របស់ តាម៉ុក។ គាត់មិនមែនជាប្រធានធំជាងគេរបស់កងពលទេ។ តាម៉ុក គឺជាប្រធានធំជាងគេ ទទួលខុសត្រូវរួមនេះកងពលលេខ ៣ នៅក្នុងពលេនោះ"]។ មាស មុត លើកឡើងថា សារឿន នៅក្នុងគណៈកងពលធំលេខ ៣ ទោះបីជាការរៀបរាប់អំពីតួនាទីផ្សេងៗរបស់គាត់នៅក្នុងនោះ(រួមទាំងតួនាទីរបស់គាត់ផ្ទាល់)គឺមានលក្ខណៈបន្តិចដែរ៖ ឯកសារ D22.2.181 ចម្លើយ មាស មុត ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម EN ERN 00249695, KH ERN 00741997 ["គណៈបញ្ជាការកងពលធំលេខ ៣ រួមមាន៖ ផាន ជាមេបញ្ជាការកងពល គាត់ជាមេបញ្ជាការទទួលបន្ទុកក្នុងអំឡុងពេលមានឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស ប៉ុន្តែទីបញ្ជា

ត្រូវបានដកតំណែងជាអនុមេបញ្ជាការកងពលធំលេខ ៣ ហើយត្រូវបានជំនួសដោយ ហឹង ឌឿន ហៅ ឌឹម (ឌិម) និង ជ័យ ហាន ហៅ ឆាន់ (នង ឆាន់)។ សារឿន បានក្លាយជាមេបញ្ជាការកងវរៈសេនាធំលេខ ១៤០[569] ខណៈដែល ង៉ែត នៅតែជាសមាជិកគណៈកម្មាធិការកងពលធំ និងជាមេដឹកនាំកងវរៈសេនាធំលេខ ២០/១៦១[570]។

---

ការដ្ឋាននេះស្ថិតនៅកំពង់សោម និងរាម។ សារឿន (Saroeun) មេបញ្ជាការរង។ មាស មុត ជាមន្ត្រីនយោបាយ។ ញ៉ាន់ (Nhan) ជាសមាជិកនៃគណៈភស្តុភារ។ លន (Lon) ជាប្រធានផ្នែកភស្តុភារ" (គូសបញ្ជាក់បន្ថែម)]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចាក់ ឆ.10-11 ["ស៖ នៅក្នុងឆ្នាំ ១៩៧៤ ពេលដែលលោកចូលកងពលលេខ ៣ តើលោកនៅក្រោមវរសេនាធំលេខប៉ុន្មាន? ឆ.10៖ គឺនៅក្រោមវរសេនាធំលេខ ១៥។ ស៖ ពេលហ្នឹង ប្រធានវរសេនាធំលេខ ១៥ ឈ្មោះអី? ឆ.11៖ ឈ្មោះ សារឿប (ប្រុស)"]។ ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុង សេង ឆ.2 ["មាស មុត គឺជាស្នងការនយោបាយរបស់កងពលលេខ ៣។ នៅក្នុងកងពលលេខ ៣មាន ៣ វរសេនាធំ ហើយមានមេបញ្ជាការទទួលខុសត្រូវរៀងៗខ្លួន។ ខ្ញុំនៅចាំតែប្រធានវរសេនាធំរបស់ខ្ញុំគឺ បងសារឿន"]។

569 សូមមើលឧទាហរណ៍ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ឆ.10, 22 ["ស៖ តើលោកស្គាល់មនុស្សម្នាក់ឈ្មោះ សារឿន ដែរឬទេ នៅក្នុងកងពលលេខ ៣/១៦៤? ឆ.10៖ បាទ ខ្ញុំស្គាល់ឈ្មោះ សារឿន ពេលដែលកងវរៈសេនាធំ ១៤០ បង្កើតជាលើកដំបូង សារឿន គឺជាមេបញ្ជាការរបស់វរសេនាធំនោះ [...] ឆ.22៖ (និយាយសំដៅលើឯកសារ D1.3.14.2EN ERN 00233944-45, KH ERN 00161788-89) ["ឯកសារទី ២ [...] មនុស្សម្នាក់ឈ្មោះរឿន ដែលនិយាយនៅក្នុងទូរសារនេះ គឺ សារឿន- មេបញ្ជាការកងវរសេនាធំ ១៤០ ដែលខ្ញុំទើបនិយាយរួចហើយ"], ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន ឆ.36 ["ស៖ អ្នកណាជាមេបញ្ជាការកងទ័ពជើងទឹក? ឆ. 36៖ សារឿន"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.28 ["សារឿន ជាមេបញ្ជាការកងវរសេនាធំ ១៤០។ ក្រោយមក សារឿន ត្រូវបានជំនួសដោយ ទឹម សេង"]។ ឯកសារ D114/132 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ រ៉ាន់ ឆ.176។ ឯកសារ D114/48 កំណត់ហេតុស្តាប់ចម្លើយ សុខ ង៉ុក ឆ.20។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាលEN ERN 00968421, KH ERN 00926645 ["ដំបូងបំផុតហ្នឹងមានឈ្មោះ តាសារឿន [...] តាសារឿន ហ្នឹង ប្រធាន"]។ ឯកសារ D4.1.758 ចម្លើយរបស់ជនមិនស្គាល់អត្តសញ្ញាណ ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម EN ERN 00387312, KH ERN 01506014។

570 ឯកសារ D2/8 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.45 ["ឈ្មោះ ង៉ែត ធ្វើជាស្នងការកងវរសេនាធំលេខ ២០ ឬ ៦១ [...] ស្នងការគេមិនដូរទេ គឺនៅដដែលតាំងពីមុនពេលភ្នំពេញបែក និងក្រោយភ្នំពេញបែក"]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.8 ["ង៉ែត គឺជាប្រធានកងផ្នែកនយោបាយរបស់កងវរសេនាធំ ២០"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.4 ["ង៉ែត ជាមេបញ្ជាការកងវរសេនាធំ ២០"]។ ឯកសារ D59/1/1.9a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ EN ERN 00963712, KH ERN 00926446 ["ស៖ ធំលេខ ២០ ដែលរបស់ឈ្មោះ ង៉ែត ហ្នឹងហី? ឆ៖ បាទ"]។ យើងទៅតាមឯកសារពី ស-២១

209. នៅក្នុងកងពលធំលេខ ៣ អង្គភាពយោធានីមួយៗទទួលបញ្ជា និងរាយការណ៍យ៉ាងទៀងទាត់ជូនថ្នាក់លើផ្ទាល់របស់ខ្លួន ៖ ក្រុម (ទាហានប្រហែលបីនាក់) ទទួលបញ្ជា និងរាយការណ៍ជូនកង (ទាហានប្រហែល ១២ នាក់) កងអនុសេនាតូច (ច្រើនជាង ៣០ នាក់) រាយការណ៍ជូនកងអនុសេនាធំ (១០០-១៥០ នាក់) កងអនុសេនាធំរាយការណ៍ជូនកងវរៈសេនាតូច (ទាហានជាង ៣០០ នាក់) កងវរៈសេនាតូចរាយការណ៍ជូនកងវរៈសេនាធំ (ទាហានប្រហែល ១.០០០ នាក់ ឬច្រើនជាងនេះ) ហើយកងវរៈសេនាធំ និងកងវរៈសេនាតូចឯករាជ្យរាយការណ៍ជូនកងពលធំ ដែលបញ្ជាដោយ **មាស មុត**[571]។ ប្រធានបទនៃរបាយការណ៍របស់កងវរៈសេនាធំ គឺជាព័ត៌មាននៅសមរភូមិ

---

និងសាក្សីមួយចំនួន ង៉ែត គឺមានតំណែងសមាជិកតែមួយគត់នៅក្នុងគណៈកងពលធំ ៣/១៦៤ មុននឹងគេដកគាត់ពីតំណែងជាអតីតមេបញ្ជាការរងរបស់គាត់នេះ៖ ឯកសារ D114/230.1.1 បញ្ជីអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង 5342 [សមាជិកកងពល ១៦៤ ចូល ស-២១ នៅខែ មិថុនា ឆ្នាំ ១៩៧៧]។ ឯកសារ D9.3 បញ្ជីអ្នកទោស ស-២១ របស់ ក.ស.ច.ស មកពីកងពល ១៦៤ លេខរៀង 26។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.15 ["កងពល ១៦៤ ហ្នឹង មាន មាស មុត ជាស្នងការធំ ហើយមាន នង ឆាន ជាបញ្ជាការកងពល ១៦៤។ បន្ទាបមកគឺ ឌឹម ដែលជាបញ្ជាការរង។ បន្ទាប់មកគឺ ង៉ែត ជាសមាជិកកងពល"]។ ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.12 ["ថ្នាក់កងពលមាន ឆាន, អ៊ំង៉ែត, បងយ៉ាន, បងឌឹម"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.4 ["ម៉ែន ង៉ែត គឺជាសមាជិកគណៈកងពល ១៦៤ គាត់ត្រូវបានចាប់ខ្លួន"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀន ឆ.64, 66 ["ស៖ តើលោកអាចប្រាប់ឈ្មោះអ្នកដែលលោកស្គាល់ ហើយគេនាំយកទៅនោះបានដែរឬទេ? ឆ.64៖ មានឈ្មោះ ង៉ែត, ឈ្មោះ ឌឹម, ឈ្មោះ យ៉ាន, ឈ្មោះ ឆាន និងឈ្មោះ សុខ ជាដើម ដែលគេចោទថាជាគិញរៀតណាម ឬក៏សេអ៊ីអា [...] ឆ.66៖ សុទ្ធជាអ្នកដែលនៅក្រោម មាស មុត ដូចជា ង៉ែត ជាអនុប្រធានរបស់ មាស មុត។ ឌឹម នៅក្រោម មាស មុត នៅថ្នាក់កងពល។ ឆាន នៅថ្នាក់កងពល។ យ៉ាន ប្រធានវរសេនាធំ។ សុខ ជាប្រធានពេទ្យនៅកងពល"]។

571 ឯកសារ D114/263 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី ឆ.49 ["កទ័ពពេលនោះ គឺរៀបចំពេញសណ្តាប់ធ្នាប់ ជាអនុសេនាធំ អនុសេនាតូច មិនឱ្យខ្វះទេ។ បើគិតជាអង្គភាពពេញលេញ វរសេនាតូចមាន ៣០០ អនុសេនាធំ ១០០ នាក់ អនុសេនាតូច ៣០ នាក់"]។ ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុង សេង ឆ.10 ["ក្នុងមួយពួកមាន ៣ នាក់ រាយការណ៍ឡើងទៅក្រុម ១២ នាក់។ ប្រធានក្រុមរាយការណ៍ទៅកងអនុសេនាតូច។ របៀបចាត់តាំងចាប់ផ្តើមចេញពីពួក ដែលមានគ្នា ៣ នាក់។ ថ្នាក់ដឹកនាំក្រុមមានគណៈ ៣ នាក់ [...] ចាប់ពីថ្នាក់ក្រុមឡើងទៅថ្នាក់កងពល គណៈដឹកនាំទាំងបីនាក់នេះ គឺរាយការណ៍ទៅគណៈកងថ្នាក់លើបន្ទាប់ៗ [...] ដូច្នេះ ពួករាយការណ៍ឡើងក្រុម ហើយក្រុមរាយការណ៍ទៅកងអនុវរសេនាតូច ហើយអនុវរសេនាតូចរាយការណ្ឌទៅកងអនុវរសេនាធំ។ កងអនុសេនាធំ រាយការណ៍ទៅ កងវរសេនាតូច។ កងវរសេនាតូចរាយការណ៍ទៅកងវរសេនាធំ ហើយវរសេនាធំរាយការណ៍ទៅកងពល [...] របាយការណ៍ត្រូវធ្វើជាប្រចាំ ៣ ថ្ងៃម្តង លើកលែងតែក្នុងករណីដែលជាប់ដៃប្រយុទ្ធនៅសមរភូមិ ដែលយើងត្រូវតែរាយការណ៍ភ្លាមៗ"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន សារ៉ាត់ ឆ.106 [សំដៅលើកងពលលេខ

ការប្រព្រឹត្តិ និងវិន័យរបស់កម្មាភិបាល និងទាហាន និងបញ្ហាកសិកម្ម និងសុខភាព[572]។ របាយការណ៍ត្រូវបានចាត់ទុកថាជាកាតព្វកិច្ចដ៏សំខាន់បំផុត "ដាច់ខាត"[573]។ របាយការណ៍ត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ជាលាយលក្ខណ៍អក្សរ ឬតាមវិទ្យុ[574]។ មុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ **មាស មុត** ខ្លួនគាត់ផ្ទាល់បានរាយការណ៍ទៅ តា ម៉ុក លេខាភូមិភាគដែលបន្ទាប់មក តា ម៉ុក បានរាយការណ៍ទៅមជ្ឈិមបក្ស[575]។ បន្ទាប់ពីការកាន់កាប់ទីក្រុងភ្នំពេញ **មាស មុត** ក្នុងនាមជាមេបញ្ជាការកងទ័ពជើងទឹក និងជាលេខាតំបន់ឯករាជ្យកំពង់សោម បានរាយការណ៍ដោយផ្ទាល់ទៅអគ្គសេនាធិការចំពោះបញ្ហាយោធា និងទៅកាន់មជ្ឈិមបក្សចំពោះបញ្ហារដ្ឋបាលថ្នាក់តំបន់[576]។

---

៣/១៦៤ ៖ "នៅក្នុងកងទ័ព ធម្មតាពីលើ គឺកងពលធំទៅវរសេនាធំ។ វរសេនាធំចុះទៅវរសេនាតូច។ អនុសេនាធំទៅអនុសេនាតូច។ អនុសេនាតូចទៅក្រុម។ ក្រុមទៅពួក។ ពួកនៅក្នុងក្របខ័ណ្ឌរបស់យុទ្ធជន"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.4។

572 ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុង សេង ឆ.9 ["របាយការណ៍ផ្តោតសំខាន់ទៅលើសកម្មភាពសមរភូមិ ប៉ុន្តែផងដែរ រាយការណ៍អំពីជីវភាពប្រចាំថ្ងៃរបស់យោធា សីលធម៌ រឿងវិន័យ បញ្ហាសង្គមកិច្ច ដូចជាជួយប្រជាជនដកស្ទូង ច្រូត កាត់ និងជួយព្យាបាលជំងឺប្រជាជន នៅពេលពួកគេឈឺ។ ក្រៅពីសកម្មភាពប្រយុទ្ធនៅលើសមរភូមិ ស្នងការនយោបាយទទួលខុសត្រូវខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង។"]។

573 ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុង សេង ឆ.10 ["គេចាត់ថា របាយការណ៍គឺជាភារកិច្ចសំខាន់ណាស់ដែលយើងត្រូវតែធ្វើរបាយការណ៍ដាច់ខាត ជាពិសេសអំពីស្ថានភាពខ្មាំង"]។

574 ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុង សេង ឆ.10 ["មធ្យោបាយសម្រាប់រាយការណ៍មានបីប្រភេទ គឺយើងត្រូវតែរាយការណ៍ដោយផ្ទាល់មាត់ ឬតាមរយៈសំបុត្រ ឬតាមវិទ្យុទាក់ទង ធ្វើយ៉ាងណាដើម្បីឱ្យរបាយការណ៍នោះទៅដល់គោលដៅ"]។

575 ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុង សេង ឆ.8 ["កងវរសេនាធំនីមួយៗ គឺមានស្នងការនយោបាយរបស់គេ ហើយស្នងការនយោបាយទាំងនោះ រាយការណ៍ទៅ មាស មុត ដែលជាស្នងការនយោបាយរបស់កងពល ហើយ មាស មុត រាយការណ៍បន្តទៅឱ្យប្រធានភូមិភាគ គឺ តាម៉ុក។ តាម៉ុក រាយការណ៍បន្តទៅមជ្ឈិម"]។

576 ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.23, 28-30, 38 ["គាត់ [ឡូញ] ជាមេដឹកនាំម្នាក់នៅតំបន់ស្វយ័ត [...] ស៖ នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយថា កំពង់សោម ជាតំបន់ស្វយ័ត តើតំបន់ស្វយ័តនោះកើតឡើងពេលណា? ដោយរបៀបណា? ឆ.28៖ បើតាមខ្ញុំដឹង គឺខាងរដ្ឋាភិបាលកណ្តាលជាអ្នកបញ្ជាត្រង់មកតំបន់ស្វយ័ត ហើយគ្មានអ្នកណាបញ្ជាមកនោះទេ។ ស៖ តើនរណាគេជាអ្នកបញ្ជាផ្ទាល់មកតំបន់ស្វយ័ត ឆ.29៖ ខ្ញុំមិនដឹងអ្នកណាជាអ្នកបញ្ជានោះទេ គឺដឹងត្រឹមតែមជ្ឈិម ហើយខ្ញុំដឹងនៅពេលប្រជុំ ដោយគេនិយាយថា កំពង់សោមជាតំបន់ស្វយ័តតែប៉ុណ្ណោះ ស៖ តើកិច្ចប្រជុំហ្នឹង ធ្វើនៅក្នុងកងវរសេនាធំរបស់លោកឬ? ឆ.30៖ ខ្ញុំដឹងថា តំបន់កំពង់សោម ជាតំបន់ស្វយ័ត ដោយសារសខ្ញុំចូលរួមកិច្ចប្រជុំនៅក្នុងវរសេនាធំ និងកិច្ចប្រជុំផ្ទៃក្នុងរបស់បេក្ខជន។ កម្មករចម្ការកៅស៊ូ កម្មករកំពង់ផែ ទាហាននៅកំពង់សោមទាំងអស់សុទ្ធតែដឹងថា តំបន់

210. មុនការវាយប្រហារចុងក្រោយលើទីក្រុងភ្នំពេញ ដែលបានចាប់ផ្តើមនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៧៥ កងទ័ពកងពលធំលេខ ៣ បានប្រយុទ្ធនៅតំបន់កំពត លង្វែក និងទីតាំងផ្សេងៗទៀតនៅតាមបណ្តោយផ្លូវជាតិលេខ ៤[577]។ នៅដើមឆ្នាំ ១៩៧៥ **មាស មុត** បានចេញបញ្ជាដល់កងទ័ពកងពលធំលេខ ៣ របស់គាត់ នៅពេលប្រយុទ្ធឆ្ពោះទៅកាន់ទីក្រុងភ្នំពេញពីទីបញ្ជាការរបស់គាត់នៅភ្នំត្នោតពង[578]។ ទោះបីកងពលធំលេខ ៣ បានចូលរួមយ៉ាងមានប្រសិទ្ធភាពក្នុងការកាន់កាប់ទីក្រុង

---

កំពង់សោមជាតំបន់ស្វយ័ត ដោយសារព័ត៌មានហ្នឹង ត្រូវបានគេផ្សព្វផ្សាយយ៉ាងទូលំទូលាយ [...] សៈ តើនរណាជាអ្នកបង្ហាត់បង្រៀននៅក្នុងវគ្គរៀនសូត្រនយោបាយ? ឆ.38៖ គឺលេខាកងពលតា មាស មុត"]។ ឯកសារ D114/286 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.30 ["កងពល ១៦៤ គ្រប់គ្រងដោយអគ្គបញ្ជាការកងទ័ព។ ខាងទ័ពគេទៅខាងអគ្គបញ្ជាការទ័ពទៅ បើខាងរដ្ឋបាល ខាងខេត្តខាងអី គេនៅខាងរដ្ឋបាលរបស់គេ។ គេហ្នឹង បើខ្ញុំដឹង ខាងអង្គបញ្ជាការគេគឺ សុន សេន"]។ សូមមើលផងដែរ កថាខណ្ឌ ២២០។

577 ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ឆ.9 ["សៈ មុនពេលបែកភ្នំពេញ គឺថា កងវរសេនាធំលេខ ២២ មានកន្លែងប្រតិបត្តិការនៅបែកចាន, ទួលលាប, ចោមចៅ និងដោះកញ្ជន [...] ? ឆ.9៖ បាទ"]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាលEN ERN 00968376, KH ERN 00926604-05 ["ដល់អាក្នុង ៧៤ [...] វាទៅវ៉ៃច្រើនកន្លែងណាស់ ក្នុងឆ្នាំ ៧៤ ហ្នឹង ចេញពី [តំបន់ខាងត្បូង] ភ្នំពេញ មក ទៅវ៉ៃនៅកំពតI [...] ខែមេសា ឆ្នាំដែលហ្នឹង វាវ៉ៃនៅកំពត [...] ហើយបានចេញពីហ្នឹងមក បានប៉ុន្មានខែ ខ្ញុំមិនចាំទេ ទៅវ៉ៃនៅលង្វែក"]។ ឯកសារ D59/1/1.9a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៉ុនហាក់ EN ERN 00963713, KH ERN 00926446-47 ["សៈ មកវ៉ៃនៅភ្នំពេញហើយ? ឆៈ វ៉ៃដោះក្រជ"]។

578 ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុង សេង ឆ.6-7 ["សៈពេលដែលវ៉ៃចូលភ្នំពេញ តើអ្នកណាជាអ្នកបញ្ជាកងពលលេខ ៣ ឲ្យវ៉ៃ? ឆ.6៖ តាមុត ដែលជាមេបញ្ជាការកងពលលេខ ៣។ សៈ ពេលវ៉ៃចូលភ្នំពេញ តើទីបញ្ជាការរបស់កងពលលេខ ៣ ស្ថិតនៅកន្លែងណា? ឆ.7៖ ទីបញ្ជាការកងពលលេខ ៣ របស់ មាស មុត ស្ថិតនៅភ្នំត្នោតពង អំឡុងពេលវ៉ៃចូលភ្នំពេញ"]។ ឯកសារ D59/1/1.9a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៉ុនហាក់ EN ERN 00963713, KH ERN 00926447 ["ដើម្បីរៀបកងកម្លាំង ត្រៀមថែមកម្លាំងដែលខូចខាត បន្ថែមកម្លាំងទៀត ពីរខែ ក្រោយមកខែ ១១ គេបញ្ជូនពួកខ្ញុំមកភូមិភាគភ្នំពេញ ដើម្បីត្បាពោង ដើម្បីត្រៀមវ៉ៃភ្នំពេញ ណា ៧៥ណា ថ្ងៃ១ ខែ១ ៧៥ វ៉ៃភ្នំពេញ"]។ សូមមើលផងដែរ ស្តីពីទីតាំងអតីតបញ្ជាការដ្ឋានកងពលធំលេខ ៣៖ ឯកសារ D2/8 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.35, 37 ["កាលនោះមូលដ្ឋានកងពលលេខ ៣ ប្រហែលជានៅខាងត្បូងផ្លូវជាតិលេខ ៤ គឺនៅខាងត្បូងប្រពាំងក្រឡឹង ក្នុងខែកំពង់ស្ពឺ [...] ស្នងការដែលជាលេខារបសបក្ស និងអ្នកក្តាប់រួមដឹកនាំផ្នែករៀនសូត្រ។ ស្នងការមានទីតាំងនៅខាងជើងផ្លូវជាតិលេខ ៤ នៅម្តុំត្រាពាំងគង ដែលជាកន្លែងមានសុវត្ថិភាព [...] ឆ.37៖ នៅពេលនោះ កងពលមិននៅជួយកន្លែងទេ។ គេផ្លាស់ប្តូរបញ្ជាការដ្ឋានពីមួយកន្លែងទៅមួយកន្លែង គឺការពារការទម្លាក់គ្រាប់បែកដោយយន្តហោះ"]។ ឯកសារ D4.1.758 ចម្លើយរបស់ជនមិនស្គាល់អត្តសញ្ញាណ ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម EN ERN 00387311, KH ERN 01506012 ["នៅពេលនោះ កងពលធំបានតាំងមូលដ្ឋានទ័ពនៅភូមិអាងសង្កែ (CNA) ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ប្រទេសកម្ពុជា"]។

ភ្នំពេញនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ តាមតំបន់ថ្នល់ទទឹង និងស្ទឹងមានជ័យក៏ដោយ[579] ក៏កងពលនេះមិនដែលបានឈរជើងនៅខាងក្នុងក្រុងនោះដែរ ហើយបន្តស្ថិតនៅក្នុងតំបន់ចោមចៅក្បែរអាកាសយានដ្ឋានយោធាពោធិ៍ចិនតុង[580]។

211. ក្នុងរយៈពេលប៉ុន្មានម៉ោងបន្ទាប់ពីការកាន់កាប់ទីក្រុងភ្នំពេញ កងពលធំលេខ ៣ ត្រូវបានផ្ទេរទៅបំពេញភារកិច្ចក្នុងការឈរជើងនៅតំបន់កំពង់សោម និងចាកចេញពីទីក្រុងភ្នំពេញតាមផ្លូវជាតិលេខ ៤ ដោយប្រើប្រាស់មធ្យោបាយដឹកជញ្ជូនផ្សេងៗគ្នា[581]។ នៅកំពង់សោម អង្គភាពកងពលធំ

---

579 ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល EN ERN 00968376, KH ERN 00926604 ["ចូលទៅភ្នំពេញ តាមទៅអី! ទៅដំបូងម៉ាជួរយើងថ្នល់ទទឹងអីហ្នឹង"]។

580 ឯកសារ D22.2.181 ចម្លើយ មាស មុត ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០១ EN ERN 00249693-94, KH ERN 00741996-97 ["នៅពេលទីក្រុងភ្នំពេញបានធ្លាក់ចូលក្នុងកណ្ដាប់ដៃរបស់កងកម្លាំងកុម្មុយនីស្តនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មាស មុត និងកងពលធំលេខ ៣ ស្ថិតនៅលើសមរភូមិមុខផ្លូវជាលេខ ៤ នៅត្រពាំងឆ្នោត [...] ទួលលាប [...] និងនៅភ្នំឱរ៉ាល់ [...] កងពលធំលេខ ៣ នេះ មិនបានចូលទៅក្នុងទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ទេ"]។ ឯកសារ D4.1.759 ចម្លើយ ខែម ងួន និង ម៉ៅ រ៉ាន់ ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម EN ERN 00387265, KH ERN 00658135 ["ទោះជាយ៉ាងណាក្តី កងពលធំលេខ ៣ មិនត្រូវបានអនុញ្ញាតឲ្យចូលក្រុងភ្នំពេញទេ ដោយនៅឈរជើងនៅម្តុំចោមចៅជិតព្រលានយន្តហោះពោធិ៍ចិនតុង នៅក្រៅក្រុងភ្នំពេញ"] EN ERN 00387267, KH ERN 00658138 ["កងពលលេខ ៣ នៃកងកម្លាំងកុម្មុយនីស្តខ្មែរ បានចូលរួមក្នុងការកាន់កាប់ក្រុងភ្នំពេញ ប៉ុន្តែមិនត្រូវបានអនុញ្ញាតឲ្យចូលក្នុងទីក្រុងទេ"]។ ឯកសារ D59/1/1.7a កិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ា ឈឿន EN ERN 00969927, KH ERN 00926304 [សៈ"ចន្លោះ ១ ខែហ្នឹង ពូមានវៃចូលភ្នំពេញដែរអត់? ឆៈ វ៉ៃ វ៉ៃដែរតា វ៉ៃអាខាងលិចពោធិចិនតុង"]។ ឯកសារ D59/1/1.14 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហ៊ីង អ៊ុច EN ERN 00970735, KH ERN 00926675 ["ខ្ញុំនៅពោធិចិនតុង កាលរំដោះភ្នំពេញ"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហ៊ាង រ៉េត EN ERN 00974080, KH ERN 00926526-27។ ឯកសារ D4.1.751 ចម្លើយរបស់ជនមិនស្គាល់អត្តសញ្ញាណ ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម EN ERN 00387257, KH ERN 01519651។

581 ឯកសារ D2/8 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.37 ["ក្រោយពេលបែកភ្នំពេញ កងពលត្រូវបានបញ្ជូនទៅកំពង់សោម"]។ ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿនលី ហៅក្រៅ សឿ ទូច ឆ.12 ["ព្រឹកឡើងថ្ងៃទី ១៨ ខែ មេសា [...] កងវរៈ ៤២០ ពេលនោះគេទៅស្នាក់នៅរាម និងកងពិសេសនៅកំពង់សោម"]។ ឯកសារ D22.2.181 ចម្លើយ មាស មុត ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០១ EN ERN 00249694, KH ERN 00741997 ["នៅម៉ោង ៤ ល្ងាច ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៧ កងពលធំលេខ ៣ បានទទួលបញ្ជាឲ្យទៅកាន់កំពង់សោម"]។ ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.18 ["គាត់ទៅ

លេខ ៣ មួយចំនួន ត្រូវបានដាក់ឲ្យឈរជើងនៅមូលដ្ឋានកងទ័ពជើងទឹករាម[582] អាកាសយានដ្ឋាន កង កេង[583] និងអូរឈើទាល[584]។ កងពលធំលេខ ៣ បានប្តូរទីបញ្ជាការរបស់ខ្លួនទៅកាន់ក្រុងកំពង់សោម[585]។

---

កំពង់សោមក្រោយថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥"]។ ឯកសារ D4.1.746 ចម្លើយរបស សំ សុខ ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម EN ERN 00387463, KH ERN 00742598 [នៅថ្ងៃទី ១៨ ខែសីហា មួយថ្ងៃមុនភ្នំពេញធ្លាក់ក្នុងដៃរបស់បក្សកុម្មុយនីស្ត កងពលធំលេខ ៣ ត្រូវបានគេបញ្ជាទៅរាម [...] និងកំពង់សោម"]។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ហៅ សារ៉េត ឆ.2។ ឯកសារ D4.1.748 ចម្លើយរបស់ ញ៉ុង ត្រេង ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម EN ERN 00387383, KH ERN 01506151។ ឯកសារ D59/1/1.7a កិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ា ឈឿន EN ERN 00969927, KH ERN 00926305។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហ៊ាង រ៉េតEN ERN 00974080, KH ERN 00926525។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN ERN 00978566, KH ERN 00955492។ ឯកសារ D4.1.751 ចម្លើយរបស់ជនមិនស្គាល់អត្តសញ្ញាណ ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម EN ERN 00387258, KH ERN 01519652 ។

582 ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿនលី ហៅក្រៅ សឿ ទូច ឆ.12 ["ព្រឹកឡើងថ្ងៃទី ១៨ ខែមេសា [...] កងវរៈ ៤២០ ពេលនោះគេទៅស្នាក់នៅរាម និងកងពិសេសនៅកំពង់សោម"]។ ឯកសារ D4.1.759 ចម្លើយ ខែម ងួន ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម EN ERN 00387265, KH ERN 00658135 ["នៅថ្ងៃទី ១៨ ខែមេសា ឆ្នាំ១៩៧៥ កងពលធំលេខ ៣ ត្រូវបានបញ្ជូនទៅកំពង់សោម (ក្រុងព្រះសីហនុ) ដោយទៅដល់ទីនោះនៅថ្ងៃទី ២១ ខែមេសា ឆ្នាំ ១៩៧៥។ មុនដំបូង ឧត្តមសេនីយ៍ត្រី ងួន ឈរជើងនៅម្តុំផ្សារធំថ្មីនៅកំពង់សោម ហើយត្រូវបានផ្ទេរទៅមូលដ្ឋានកងទ័ពជើងទឹករាម ប្រហែលពីរខែក្រោយមក"]។

583 ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.1 ["ខ្ញុំទៅដល់កំពង់សោមដំបូង អង្គភាពអនុសេនាធំរបស់ខ្ញុំមានការចែកកម្លាំងធ្វើការជាមួយកសិករផង និងការពារព្រលានយន្តហោះកងកេងផង"]។ ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ឆ.13 ["សៈ កងវរសេនាតូច ៥៥០ ស្នាក់នៅព្រលានយន្តហោះកងកេង ប្រហែល ១៥ មុនគេបញ្ជូនទៅកោះតាងមែនឬទេ ឆ.13៖ បាទ ត្រឹមត្រូវ"]។ ឯកសារ D59/2/3.17a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ យ៉ែម សំអុន KH ERN 00958350 ["សៈ កងពលទី ៣ ទាំងអស់ដែលត្រូវទៅកន្លែងកងកេង? ឆៈ បាទ! ទៅដល់កន្លែងហ្នឹងតាមូលគ្នា បានដឹងថា កងពលទី ៣ ទាំងអស់"]។

584 ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿន ឆ.35 ["យើងនៅកំពង់ផែកំពង់សោមបានពីរបីថ្ងៃ រួចហើយទៅនៅអូរឈើទាល"]។ ឯកសារ D59/1/1.9a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ EN ERN 00963714-15, KH ERN 00926447-48 ["អង្គភាពខ្ញុំទាំងមូលហ្នឹង កងពលលេខ ៣ គេដកមកកំពង់សោម [...] មកថ្ងៃ ១៧ វិញ ខ្ញុំទៅដល់ថ្ងៃទី ២៣ បានដល់ [...] យើងឈរជើងនៅឆ្នេរអូរឈើទាល"]។

212. នៅកំពង់សោម ទាហានកងពលធំលេខ ៣ ត្រូវបានចូលរួមភ្លាមៗដោយកងកម្លាំងតំបន់ ៣៧ ជាពិសេស កងវរៈសេនាតូចលេខ ៣៨៦[586]។ កងកម្លាំងទាំងនេះចំណុះឱ្យកងពលធំលេខ ៣ និងត្រូវបានដាក់ក្រោមអំណាចរបស់ **មាស មុត** ទោះបីជាពួកគេមិនត្រូវបានបញ្ចូលជាផ្លូវការទៅក្នុងកងពលនេះរហូតដល់ចុងខែ កក្កដា ឆ្នាំ ១៩៧៥ ក៏ដោយ[587]។ **មាស មុត** ខ្លួនគាត់ផ្ទាល់បានប្រកាសថា

---

585 ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង នុន ឆ.10 ["កងពលធំលេខ ៣ របស់តាមុត គេបោះទីតាំងនៅក្នុងកំពង់សោម"]។ ឯកសារ D54/93 យ៉ែម សំអុន កំណត់ហេតុស្តាប់ចម្លើយ ឆ.66 ["ស៖ តើលោកដឹងថា មន្ទីរកងពលលេខ ៣ ស្ថិតនៅកន្លែងណាដែរ? ឆ.66៖ វាស្ថិតនៅប្រហែលក្បែររោងកុនចាស់មួយ នៅកំពង់សោម តាមបណ្តោយផ្លូវមកពីសមុទ្រ"]។ ឯកសារ D4.1.746 ចម្លើយរបស សំ សុខ ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម EN ERN 00387463, KH ERN 00742598 ["ទីបញ្ជាការកងពលធំលេខ ៣ គឺនៅក្រុងកំពង់សោម"]។ ប៉ុន្តែ យោងតាម មាស មុត កងពលធំលេខ ៣ មានទីបញ្ជាការដ្ឋានដំបូងនៅរាម៖ ឯកសារ D22.2.181 ចម្លើយ មាស មុត ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០១ EN ERN 00249694, KH ERN 00741997 ["នៅពេលមានឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស ទីបញ្ជាការដ្ឋាននៃកងពលធំលេខ ៣ មានទីតាំងស្ថិតនៅរាម"]។

586 ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.6-7, 9 ["១៨ មេសា កងពលលេខ ៣ ចូលដល់កំពង់សោម។ ថ្ងៃទី ១៧ កំពង់សោម មិនទាន់រំដោះទេ កងពលលេខ ៣ ជួយកងទ័ពតំបន់វៃរំដោះកំពង់សោម ស៖ ពេលដែលលោកថា កងទ័ពតំបន់ហ្នឹង ចង់និយាយថា តំបន់ ៣៧ ហ្នឹងឬ? ឆ.7៖ បាទ [...] ឆ.9៖ មុនដំបូងកងពលលេខ ៣ អត់ដឹងភូមិសាស្ត្រកំពង់សោមទេ។ ក្រោយមក ទើបវរៈ ៣៨៦ អ្នកនាំដាក់កន្លែងណា របៀបទៅណា ព្រោះយើងម្ចាស់ផែនទី"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េង ឆ.179-180 ["ស៖ ពេលដែលលោកនៅកោះតាំង តើលោកមានចំថា មានកងទ័ពប៉ុន្មាននាក់ ដែលមកពីតំបន់ ៣៧ ទេ? ឆ.179៖ មកជាមួយ បងឆាន គឺមួយវរសេនាធំ ដែលមានបីវរសេនាតូច [...] ឆ.180៖ ឱ្យតែមកជាមួយ បងឆាន គឺសុទ្ធតែមកពីតំបន់ ៣៧"]។ ឯកសារ D114/286 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.12 ["យើងបានយកកងវរសេនាតូចរបស់កងតំបន់ ៣៧ មកដាក់ក្នុងកងជើងទឹក ១៦៤ រួចហើយយើងធ្វើការគ្រប់គ្រងកប៉ាល់ចេញពីពួកគេ"]។ ឯកសារ D114/260 កំណត់ហេតុស្តាប់ចម្លើយ ស៊ិន សុត ឆ.6-9។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.39។

587 ឯកសារ D4.1.754 ចម្លើយរបស់កម្មាភិបាលកម្ពុជាប្រជាធិបតេយ្យដែលមិនស្គាល់អត្តសញ្ញាណ ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម EN ERN 00387427, KH ERN 00791381 [ទាហានកងវរសេនាតូចលេខ ៣៨៦ និយាយអំពីពេលវេលាបន្ទាប់ពីថ្ងៃទី ១៧ មេសា ឆ្នាំ ១៩៧៥៖ "មតិយោបល់ពីប្រភព- នៅពេលនោះ កងអនុសេនាធំលេខ ៤០៨ មិនទាន់ក្លាយទៅជាផ្នែកមួយចំណុះឱ្យកងពលធំលេខ ៣ នៅឡើយទេ"], EN ERN 00387429, KH ERN 00791383 [ចម្លើយខាងក្រោមនេះបង្ហាញថា មេបញ្ជាការកងពលធំលេខ ៣ មានអំណាចគ្រប់គ្រងកងវរសេនាតូចលេខ ៣៨៦ និងកងអនុសេនាធំរបស់កងវរសេនាតូចនេះ រួមមានកងអនុសេនាធំ ៤០៨ មុនខែកក្កដា ឆ្នាំ១៩៧៥៖ "ក្រោយពីប្រភពនេះបានបោះទីតាំងនៅលើកោះពូឡូវៃថ្មី នៅក្នុងខែមេសា-ឧសភា ឆ្នាំ ១៩៧៥ អង្គភាពរបស់គាត់បានចាប់នាវាមួយគ្រឿងដែលបានដឹកជនភៀសខ្លួនវៀតណាមជាង ១០ នាក់ រួមទាំងស្ត្រី និងកុមារ។

នៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ កងពលធំលេខ ៣ មានកងវរៈសេនាធំជាសេនាធិការ ដែលមានកង

---

[...] បន្ទាប់មកពួកគេចាប់បាននាវានោះមក មេបញ្ជាការកងអនុសេនាធំលេខ ៤០៨ បានទាក់ទងក្រុងកំពង់សោម ដើម្បីសុំការណែនាំស្តីពីការចាត់ចែងជនភៀសខ្លួនទាំងនោះ។ មេបញ្ជាការថ្នាក់លើនៅក្នុងក្រុមកំពង់សោមបានបញ្ជាឱ្យ មេបញ្ជាការកងអនុសេនាធំនេះសម្លាប់ជនភៀសខ្លួនទាំងនោះចោល។ មេបញ្ជាការ និងអនុបញ្ជាការកងអនុសេនាធំបាន អនុវត្តតាមបញ្ជានេះ។"]។ ឯកសារ D4.1.749 ចម្លើយរបស់ សេង ស៊ិន ហៅ គុណ និង ខៀវ នុក ពាក់ព័ន្ធនឹងឈ្លើយ សឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម EN ERN 00387442 ["នៅពេលលោក ខេង ស៊ិន និងលោក ខៀវ នុក មក ដល់កោះតាង កងវរសេនាតូចលេខ ៣៨៦ ដែលធ្លាប់ស្ថិតនៅក្រោមបញ្ជាការតំបន់ ៣៧ បានឋិតនៅក្រោមបញ្ជាការ អតីតកងពលធំលេខ ៣ ហៅកងពលធំលេខ ១៦៤ វិញ។ លោក សេង ស៊ីន និងលោក ខៀវ នុក គឺជាសមាជិកអនុ សេនាតូចលេខ ២ នៃកងអនុសេនាធំលេខ ៤៣ កងវរសេនាតូចលេខ ៣៨៦ កងវរសេនាធំលេខ ៦២ កងពលធំលេខ ១៦៤"]។ ឯកសារ D114/261 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី ឆ.2 ["អង្គភាពរបស់ភូមិភាគនិរតីហៅកងពលលេខ ៣ នៅពេល ៧៥ បែកភ្នំពេញ គេបញ្ជូនមកនៅកំពង់សោម។ រួច បានបញ្ចូនកងទ័ពតំបន់ ៣៧ និងកងទ័ពភូមិភាគនិរតី ហៅកងពលលេខ ៣ បញ្ចូលគ្នាបង្កើតជាកងពល ១៦៤"]។ ឯកសារ D114/264 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី ឆ.36 ["ស៖ ប្រសិនបើកងកម្លាំងនេះជាការបូកបញ្ចូលគ្នារវាងកងពល ១៦៤/កងពល ៣ និងអង្គភាពយោធាតំបន់ ៣៧ តើប្រតិបត្តិការនេះ ធ្វើឡើងក្រោមការបញ្ជាជាទូទៅរបស់អ្នកណាដែរ? ឆ.36៖ ក្រោមការបញ្ជាទូទៅរបស់ មាស មុត ទាំងអស់"]។ ឯកសារ D54/109 កំណត់ហេតុស្តាប់ចម្លើយ សៅ សំ ឆ.3 ["បន្ទាប់ពីថ្ងៃរំដោះ ១៧ មេសា ឆ្នាំ ១៩៧៥ យោធារបស់តំបន់ ៣៧ ត្រូវបានរំលាយយកមកបញ្ចូលក្នុងកងពល ១៦៤ ដែរ"]។ ឯកសារ D4.1.757 ចម្លើយរបស់ជនមិនស្គាល់អត្តសញ្ញាណពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម EN ERN 00387365, KH ERN 01507817 [" រយៈពេលប្រហែល ១៥ ថ្ងៃ បន្ទាប់ពីការវាយប្រហាររបស់អាមេរិកមកលើ កោះតាង កងអនុសេនាធំលេខ ១៩ ត្រូវបានបញ្ជូនឱ្យត្រឡប់ទៅកោះតាងវិញ។ នៅពេលនោះ កងអនុសេនាធំទាំងបី មកពីកងវរសេនាតូចលេខ ៣៨៦ ស្ថិតនៅលើកោះតាង។ ទោះជាយ៉ាងនេះក្តី កងអនុសេនាធំទាំងនោះ មិនស្ថិតនៅ ក្រោមការគ្រប់គ្រងរបស់កងវរសេនាតូចលេខ ៣៨៦ តទៅទៀតឡើយ ប៉ុន្តែត្រូវបានចាត់ឱ្យទៅកងវរសេនាធំលេខ ២២ កងពលធំលេខ ៣ (លេខ ១៦៤)"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.8 ["ពេលបែក ហើយនោះ គេប្រមូលយកកងវរៈ ៣៨៦ និងកងមកពីបូព៌ាហ្វឹង យកទៅបញ្ចូលគ្នាជាមួយកងពលទី ៣ ដែលរៀបជា កងមជ្ឈិមលេខ ១៦៤"]។ ឯកសារ D4.1.752 ចម្លើយរបស់ជនមិនស្គាល់អត្តសញ្ញាណពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិ ក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម EN ERN 00387361, KH ERN 01519660 ["កងវរសេនាតូចផ្សេងទៀតតែមួយគត់ ដែលជាប់ទាក់ទងនឹងកងពលទី ៣ និងកោះតាង គឺកងវរសេនាតូចទី ៣៨៦ នៃតំបន់ ៣៧"]។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.30-31, 39 ["កាលនោះ មិនទាន់ចូលកងពលទេ គេហៅថា កងតំបន់ ៣៧។ ស៖ តើកាលនោះ មុន ឬក៏ក្រោយ ប៉ុល ពត ឈ្នះភ្នំពេញហើយ? ឆ.31៖ មុន [...] ឆ.39៖ ពេលនៅកោះតាងនោះ ខ្ញុំឮ គេនិយាយថា គេបញ្ជូនពួកខ្ញុំទៅក្នុងកងពលទី ៣"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.7 ។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.19។ ឯកសារ D54/76 កំណត់ហេតុស្តាប់ចម្លើយ អ៊ុ ច ញិក ឆ.8-9។ ឯកសារ D114/155 កំណត់ហេតុស្តាប់ចម្លើយសុខ រ៉េន ឆ.64។

កម្លាំងមកពីតំបន់ ៣៧[588]។ ដោយសារកងពលធំលេខ ៣ ខ្វះខាតកងទ័ពដែលធ្លាប់បំពេញការងារនៅលើកោះ និងអាចបញ្ជានាវាបាន ទើបកងទ័ពកងវរៈសេនាតូចលេខ ៣៨៦ ដែលបានឈរជើងនៅមូលដ្ឋានកងទ័ពជើងទឹករាមមុននោះ បានជួយប្រតិបត្តិការបញ្ជាទូក និងការពារកោះនៅឆ្ងាយពីឆ្នេរ រួមទាំងកោះតាង និងកោះពូលូវ៉ៃផងដែរ[589]។

213. នៅមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ កងពលធំលេខ ៣ មានកងវរៈសេនាធំចំនួនបី។ សាក្សីស្ទើរតែទាំងអស់គ្នា បាននិយាយថា កងវរៈសេនាធំទាំងនោះ មានកងវរៈសេនាធំលេខ ២០ លេខ

[588] ឯកសារ D22.2.181 ចម្លើយ មាស មុត ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០១ EN ERN 00249693, KH ERN 00741996-97 ["ទីបញ្ជាការដ្ឋានភូមិភាគនិរតីបានបង្កើតកងពលធំលេខ ៣ ចេញពីសមាសភាពនៃតំបន់ ៣៧ និងកងវរសេនាតូចឯករាជ្យនៃភូមិភាគនិរតី"]EN ERN 00249694, KH ERN 00741997 ["នៅពេលមានឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស ទីបញ្ជាការដ្ឋាននៃកងពលធំលេខ ៣ មានទីតាំងស្ថិតនៅរាម។ កងពលធំនេះ មានកងវរសេនាធំលេខ ៣៧ ១៤ និង ១៦ ដែលស្ថិតនៅក្រោមបង្គាប់។ មូលហេតុដែលគេដាក់ឈ្មោះថាជាកងវរសេនាធំលេខ ៣៧ ពីព្រោះកងវរសេនាធំនេះ ត្រូវបានបង្កើតចេញពីកងកម្លាំងមកពីតំបន់ ៣៧"]។

[589] ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.6-7, 9, 14, 21 ["ថ្ងៃទី ១៧ កំពង់សោម មិនទាន់រំដោះទេ កងពលលេខ ៣ ជួយកងទ័ពតំបន់វ៉ៃរំដោះកំពង់សោម។ សៈ ពេលដែលលោកថា កងទ័ពតំបន់ហ្នឹង ចង់និយាយថាតំបន់ ៣៧ ហ្នឹងឬ? ឆ.7៖ បាទ។ [...] ឆ.9៖ មុនដំបូងកងពលលេខ ៣ អត់ដឹងភូមិសាស្ត្រកំពង់សោមទេ ក្រោយមកទើបវរៈ ៣៨៦ អ្នកនាំដាក់កន្លែងណា របៀបទៅណា ព្រោះយើងម្ចាស់ផែនទី ម្ចាស់កាន់កាប់ទឹកដី [...] ឆ.14៖ នៅកោះសេះ វរៈ ៣៨៦ មានពីរអនុសេនាតូច ហើយកងពលលេខ ៣ មានពីរអនុសេនាតូច គេយល់គ្នា [...] ឆ.21៖ កងតំបន់ [៣៧] និងកងពលទី ៣ បញ្ជូនទៅកោះពូលូវ៉ៃ កោះពូលូវ៉ៃថ្មី កោះពូលូវ៉ៃចាស់ កោះរ៉ុងសន្លឹម និងកោះរ៉ុងធំ ហើយនិងកោះម្នាស់ និងកោះតាង។ រួចកម្លាំងនៅសល់ប៉ុន្មាននៅដីគោក និងនៅលើកប៉ាល់ទាំងអស់"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.23 ["ពួកខ្ញុំ កងវរៈសេនាតូច ដែលស្គាល់ភូមិសាស្ត្រនៅទីនោះច្បាស់ គេឱ្យប្រចាំការនៅលលើកោះរ៉ុងហ្វា និងកោះរ៉ុងសន្លឹម"]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.4 ["ថ្ងៃទី ១៨ មេសា ឆ្នាំ ១៩៧៥ កងវរសេនាតូច ៣៨៦ ត្រូវបានបញ្ជូនទៅរាម។ ពីរ ឬបីថ្ងៃក្រោយមក កងខ្ញុំត្រូវបានបញ្ជូនទៅការពារកោះឫស្សី"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ញ៉ិក ឆ.6 ["ប្រហែលជា ២ សប្តាហ៍ក្រោយរំដោះហើយ កងវរសេនាតូច ៣៨៦ ទាំងមូល ត្រូវបានពង្រាយនៅតាមកោះរុង កោះពូល្វៃ កោះតាង និងកោះព្រីង"]។ ឯកសារ D54/101.1 ចម្លើយរបស់ ឯក នី ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម EN ERN 00992727 KH ERN 01509142 ["កងងវរសេនាតូចទី ៣៨៦ ដើម្បីផ្តល់បុគ្គលិកដល់កោះសំខាន់ៗចេញពីឆ្នេរសមុទ្រកំពង់សោម"]។ ឯកសារ D4.1.754 ចម្លើយរបស់កម្មាភិបាលកម្ពុជាប្រជាធិបតេយ្យដែលមិនស្គាល់អត្តសញ្ញាណ ពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/អ្នកបាត់ខ្លួននៅក្នុងសង្គ្រាម EN ERN 00387427, KH ERN 00791381។

២១ និងលេខ ២២[590] បើទោះជាសាក្សីមួយចំនួនទៀត រួមទាំង **មាស មុត** ផងដែរនោះ បានកំណត់អត្តសញ្ញាណកងវរៈសេនាធំទាំងនេះថាជាកងវរៈសេនាធំ លេខ ១៣ លេខ ១៤ លេខ ១៥ ឬ លេខ ១៦ [591] ឬថែមទាំងលេខ ៣១ លេខ ៣២ ឬលេខ ៣៣[592]។ ភ័ស្តុតាងបង្ហាញថា កងវរៈសេនាធំ

---

590 សូមមើលឧទាហរណ៍ ឯកសារ D2/8 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.34 [“ការពិតគឺមានបីវរសេនាធំលេខ ២០ ២១ និង២២”]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.8 [“កងពលលេខ ៣ មានវរសេនាធំលេខ ២០ ២១ និង ២២ កងវរសេនាតូចពិសេស និង កងកាំភ្លើងធំ”]។ ឯកសារ D4.1.751 របាយការណ៍ទាក់ទងទៅនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387258 និង KH ERN 01519652 [“កងពលនេះមានវរសេនាធំចំនួន ៣ ចាប់ពីលេខ ២០ ដល់ ២២ និងកងវរសេនាតូចវិស្វកម្មទី ៤៥០”]។ ឯកសារ D4.1.750 របាយការណ៍ទាក់ទងទៅនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387278 និង KH ERN 01496677 [“នៅពេលទីក្រុងភ្នំពេញដួលរលំ កងពលលេខ ៣ របស់ចលនាកុម្មុយនីស្តខ្មែរមាន ៣ កងវរសេនាធំគឺ កងវរសេនាធំលេខ ២០ លេខ ២១ លេខ ២២ និងលេខ ២៣”]។ ឯកសារ D4.1.759 ចម្លើយរបស់ ម៉ៅ រ៉ាន់ ទាក់ទងទៅនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387267 និង KH ERN 00658138-39 [“កងពលធំលេខ៣ ស្ថិតក្រោមការគ្រប់គ្រងរបស់ មាស មុត ហើយ យឹម សេង ជាអនុ។ កងពលធំនេះមានកងវរសេនាធំបីជាចំណុះ រួមមានកងវរសេនាធំលេខ ២០ លេខ ២១ និងលេខ២២”]។ សូមមើលផងដែរ ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.33 [“កងវរសេនាធំលេខ២០ ២១ ២២ និង១៤០ និងកងវរសេនាតូចឯករាជ្យលេខ៤៥០ ប៉ុន្តែមិនស្គាល់មេបញ្ជាការរបស់ពួកគេទាំងនោះទេ [...]”]។

591 ក្នុងករណីណាក៏ដោយ គឺសំដៅលើកងវរសេនាធំបី ដូចគ្នា ៖ ឯកសារ D22.2.181 ចម្លើយរបស់ មាស មុត ទាក់ទងទៅនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០១ EN ERN 00249694, KH ERN 00741997 [“នៅពេលមានឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស ទីបញ្ជាការដ្ឋាននៃកងពលធំលេខ ៣ មានទីតាំងស្ថិតនៅរាម។ កងពលធំនេះ មានកងវរសេនាធំលេខ ៣៧, ១៤, ១៥ និង ១៦ ដែលស្ថិតនៅក្រោមបង្គាប់។ មូលហេតុដែលគេដាក់ឈ្មោះថាជាកងវរសេនាធំលេខ ៣៧ ពីព្រោះកងវរសេនាធំនេះ ត្រូវបង្កើតចេញពីកងកម្លាំងមកពីតំបន់ ៣៧។”]។ ហៀង រ៉េត ដំបូងជឿថា កងវរសេនាធំទាំងនោះមានលេខ ១១, ១២ និង ១៣ មុនពេលគាត់នឹកឃើញវិញថាមានលេខ ២០, ២១ និង២២។៖ ឯកសារ D114/286 កំណត់ហេតុស្តាប់ចម្លើយ ហៀង រ៉េត ឆ.9-10 និង 21 [“ឆ: នៅក្នុងសម្ភាសរបស់លោកលើកមុន លោកបានបង្ហាញប្រាប់អំពីវរសេនាធំ ១៣ និង១៤ ក្នុងនោះគឺឯកសា D59/1/1.11a នៅទំព័រលេខ២០។ ហើយនៅក្នុងឯកសារហ្នឹងដដែលទំព័រ២៦ លោកបាននិយាយអំពីកងម៉ារីន ដែលលោកថាកងម៉ារីនហ្នឹង គឺមានកង ២១ និងវរសេនាធំ ១៣ ហើយលោកបាននិយាយថាក្រោយមក បានក្លាយទៅជាវរៈសេនាធំ២១ [...] ឆ.9៖ បើនិយាយប្រវត្តិដើមដំបូងគឺកងពលលេខ៣ នៅភូមិភាគនិរតី។ វរសេនាធំក្នុងនោះមាន វរសេនាធំ ១១ ១២ ១៣ តែដល់ក្រោយមក ឆ្នាំ៧៥ យើងវ៉ៃបានភ្នំពេញហើយ [...] ពេលទៅដល់នោះ គឺថា កងពលគេប្រជុំ ប្រកាសពីកងពលលេខ៣ មកជាកងពល១៦៤ [...] វរសេនាធំ ១១ ទៅជាវរសេនាធំ ១៦១។ វរសេនាធំ ១២ ទៅ វរសេនាធំ១៦២។ ហើយវរសេនាធំ១៣ ទៅជាវរសេនាធំ ១៦៣ [...] ឆ.21៖ ខ្ញុំទើបនឹកឃើញថាមានកងវរសេនាធំលេខ ២០, ២១ និង ២២ ហ្នឹងមែន។ វរសេនាធំលេខ២០ ក្លាយជាវរសេនាធំ ១៦១។ ២១ ទៅជាវរសេនាធំ១៦២, ២២ ទៅ១៦៣ ហើយក៏

លេខ ២០ មានយ៉ាងហោចណាស់កងវរៈសេនាតូចចំនួនបួន គឺកងវរៈសេនាតូចលេខ ៣១០ លេខ ៣២០ លេខ ៣៣០ និងលេខ ៣៧០[593]។ កងវរៈសេនាធំលេខ ២១ មានអំណាចលើកងវរៈសេនា

---

មានវរសេនាធំលេខ១១, ១២ និង១៣ ដែរ។ តែលេខនេះ គឺដូចគ្នានឹងវរសេនាធំលេខ២០, ២១ ២២ ទេ [163]។ តែខ្ញុំមិនដឹងច្បាស់ថាគេប្រើខ្ទង់ ១០ មុន ឬខ្ទង់២០មុន"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត់ (ប៊ុន សារ៉ាត់) ឆ.2-3 និង 18 និង 20 ["ខ្ញុំនៅក្នុងកងវរសេនាតូច៥៤០ ក្នុងវរសេនាធំលេខ១៥ នៅក្នុងកងពលលេខ៣។ [...] A3៖ មេបញ្ជាការវរសេនាធំឈ្មោះ យ៉ាន (ស្លាប់) និង ស្រស់ហ្នឹងក៏ស្លាប់ដែរ [...] ឆ.18៖ មានតែវរសេនាធំ ១៣ ១៥ និង១៦ [...] ឆ.20៖ យើងនិយាយក្នុងក្របខណ្ឌក្នុងកងពលលេខ៣។ ខ្ញុំសូមបញ្ជាក់បោះទីតាំង ១៦ ដែលយ៉ាននៅព្រលានយន្តហោះកងកេង។ ១៥ ទៅកោះ បញ្ជូនទៅកោះ។ ១៣ ក៏ទៅកោះដែរ"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ ឆ.10 ["ស៖ នៅឆ្នាំ១៩៧៤ ពេលដែលលោកចូលកងពលលេខ៣ តើលោកនៅក្រោមវរសេនាធំលេខប៉ុន្មាន? ឆ.10៖ គឺនៅក្រោមវរសេនាធំលេខ១៥។ ស៖ ពេលហ្នឹង ប្រធានវរសេនាធំលេខ១៥ ឈ្មោះអី? ឆ11៖ ឈ្មោះ សារឿន (ប្រុស)"]។

592 ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា ឆ.4-5 ["តាយ៉ាន គឺជាប្រធានកងពលវរសេនាធំ៣៣។ តាមខ្ញុំដឹង នៅក្រោមកងពលវរសេនាធំលេខ៣ មានបីកងវរសេនាធំ គឺលេខ ៣១, ៣២ និង ៣៣ [...] ស៖ សាក្សីផ្សេងទៀត ដែលយើងបានសម្ភាសកន្លងមក បានប្រាប់ថា លេខសម្គាល់ចាស់របស់កងវរសេនាធំទាំងបីក្រោមកងពលលេខ៣ គឺកងវរសេនាធំលេខ២០ ២១ និង ២២ មុនកងពលលេខ៣ប្តូរមកជាកងពល១៦៤ ហើយក្រោយមក លេខសម្គាល់កងវរសេនាធំទាំងនោះមានលេខសម្គាល់ ៦១ ៦២ និង ៦៣។ ឆ.5៖ ខ្ញុំច្បាស់ ហើយចាំថា កងវរសេនាធំទាំងនោះមានលេខសម្គាល់ ៣១ ៣២ និង៣៣។ ឈ្មោះសារី ជាមេបញ្ជាការកងវរសេនាធំលេខ ៣១ ផ្នែកជើងគោក ហើយឈរជើងនៅកងកេង។ យ៉ាន ជាមេបញ្ជាការកងវរសេនាធំលេខ៣៣ ដែលមានទីបញ្ជាការនៅទឹកសាប។ ខ្ញុំមិនស្គាល់ឈ្មោះមេបញ្ជាការកងវរសេនាធំលេខ៣២ ទេ។ គ្រាន់តែដឹងថាទីបញ្ជាការនៅឡឺរួមខេត្តកំពង់សោម"]។

593 ឯកសារ D54/99 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.17 ["វរសេនាតូចលេខ ៣៧០ នៅក្រោមវរសេនាធំលេខ២០"]។ ឯកសារ D4.1.751 របាយការណ៍ទាក់ទងទៅនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387258 និង KH ERN 01519652 ["កងវរសេនាធំទី ២០ មានវរសេនាតូចជាចំណុះទី ៣២០, ៣៣០ និងទី ៣៧០"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.31 ["មានកងវរសេនាតូច ៣។ ដែលមានលេខ ៣៣០, ៣២០ និង ៣១០។"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ ឆ.110 116-117 ["៣១០ គឺអង្គភាពខ្ញុំហើយ។ ប៉ុន្តែពេលហ្នឹងខ្ញុំនៅកោះតាម [...] ឆ116៖ មិនមែនកងពលទេ។ ជាកងវរសេនាតូច៣១០ [...] ឆ117៖ កងវរសេនាតូចវាមាន កង៣១០ ៣២០ ជាដើម"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ. 2, 9 និង 11 [និយាយអំពីសមាជិកវរសេនាតូចលេខ ៣១០ ដោយសារអង្គការចាត់ទុកយើងថាជាពួកសមាសភាពមិនល្អ"]។ ឯកសារ D114/264 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី ឆ.40 [កងវរសេនាធំលេខ៣១០]។ ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ4 [រៀបរាប់អំពីរបៀបដែលសមាជិកកងពលវរសេនាតូច ៣១០ ត្រូវកងទ័ពវៀតណាម ចាប់ខ្លួន ប៉ុន្តែក្រោយមកត្រូវដោះលែងឲ្យត្រឡប់មកកម្ពុជាវិញ]។ ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុន សេនង ឆ.15 [កងវរសេនាតូចលេខ ៣១០]។ ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ

តូចលេខ ៤១០ (ដែលកាលពីមុនគេស្គាល់ថាជាកងវរៈសេនាតូចលេខ ១០៣ នៅក្នុងតំបន់ ៣៣) [594] កងវរៈសេនាតូចលេខ ៤២០ (ដែលកាលពីមុនគេស្គាល់ថាជាកងវរៈសេនាតូចលេខ ១០២ នៅក្នុងតំបន់ ៣៣)[595] កងវរៈសេនាតូចលេខ ៤៣០ លេខ ៤៨០ និងទំនងជាលេខ ៤១៥ ផងដែរ[596]។

---

សាម៉េត ឆ.16 [“ខ្ញុំគិតថា […] ជុំ [មកពី] វរសេនាតូច៣៣០”]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.12, 15 និង 220 [“ខ្ញុំនៅក្នុងវរសេនាធំលេខ៣០ វរសេនាតូច៣៧០ និងកងពលធំលេខ៣ […] ឆ.15៖ វរសេនាតូចលេខ៣៧០ មានឈ្មោះ សុន ជាប្រជាប្រធាន។ […] ឆ220៖ កងវរសេនាតូច៣៧០ និវរសេនធំ៦១ គឺនៅដដែល។”]។ ឯកសារ D2/8 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.54 [“ខ្ញុំធ្លាប់ឮវរសេនាតូច៣៨០ និង ៣៧០”]។ ឯកសារ D114/260 កំណត់ហេតុស្តាប់ចម្លើយ ស៊ិន សុត ឆ.33 [“តាជី គេចាប់គាត់ទៅវៀតណាម ពេលវៀតណាមវៃចូលកោះប៉ូលូវៃ គាត់នៅកងពល១៦៤ ដែរ។ គាត់ទំនងជានៅវរសេនាតូច ៣៧០”]។

594 ឯកសារ D114/132 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ រ៉ាន់ ឆ.28 [“មុនឆ្នាំ៧៥ គេហៅថាវរសេនាតូចលេខ ១០៣ […] បន្ទាប់ពីឆ្នាំ១៩៧៥ អង្គភាពវរសេនាតូច ១០៣ ដូរមកជាវរសេនាតូចលេខ៤១០ ក្នុងវរសេនាធំលេខ២១ ក្នុងកងពលលេខ៣”]។ ឯកសារ D4.1.762 ចម្លើយរបស់ កាំ ម៉ែន ទាក់ទងទៅនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387329 និង KH ERN 00742580 [“កងវរសេនាតូច ៤១០ ត្រូវបានបង្កើតឡើងពីអតីតកងវរសេនាតូចលេខ ១០៣ (ហៅ ១០៣) មកពីតំបន់ ៣៣ របស់ពួកកុម្មុយនីស្តខ្មែរ”]។

595 ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.11 [“ខែមករា ១៩៧៥ […] ពេលនោះអង្គភាពកង១០២ លែងនៅក្រោមកងតំបន់៣៣ ទៀតហើយ។ ត្រូវបញ្ចូលទៅជាកងពលរបស់ភូមិភាគនិរតីដែលជាកងពលលេខ៣។ រួចកងវរសេនាតូច១០២ វាក្លាយទៅជាកងវរសេនាតូច៤២០”]។

596 ឯកសារ D114/263 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី (កងវរសេនាតូចលេខ ៤២០ និងកងវរសេនាធំលេខ ២១), ឆ.48 [“ស៖ តើលោកគិតថា កងវរសេនាតូច ៤៣០ ដែលឈរជើងនៅកោះក្រចកសេះ អាចស្ថិតក្រោមចំណុះ ឬ ក៏ចំណុះឱ្យវរសេនាធំដូចគ្នា និងវរសេនាធំលោកដែរទេ? ឆ48៖ តាមការដឹងខ្លះរបស់ខ្ញុំប្រហែលជាចំណុះលេខ វរសេនាធំ ២១ ដូចគ្នា ព្រោះវាមាន ៤១០, ៤២០, ៤៣០ ព្រោះវាមិនដែលបញ្ជាក់ប្រាប់យើងជាអង្គភាពនេះទេ យើងយល់ខ្លួនឯង ព្រោះយើងជាយុទ្ធជន”]។ ឯកសារ D114/132 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ រ៉ាន់ ឆ.27-28 [“ខ្ញុំស្ថិតនៅក្នុងវរសេនាតូចលេខ ៤១០ វរសេនាធំលេខ២១ ស្ថិតនៅក្នុងកងពលលេខ ៣។ […] ឆ28៖ បន្ទាប់ពីឆ្នាំ ១៩៧៥ អង្គភាពវរសេនាតូច ១០៣ ដូរមកជាវរសេនាតូចលេខ៤១០ ក្នុងវរសេនាធំលេខ ២១ ក្នុងកងពលលេខ៣”]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.36 [“បន្ទាប់មក វៀតណាមក៏វាយយើងកាន់កាប់កោះពូលូវៃ និង កោះក្រចកសេះ ឡើងវិញ។ កងដែលទៅវាយនៅទីនោះ គឺមានវរសេនាតូច៤១០ និង ៤២០ របស់កងពលលេខ៣។ វរសនាតូចទាំងពីរនេះ មានមេបញ្ជាការឈ្មោះ ទន និង វឿន។ ទនជាមេបញ្ជាការវរ៤២០ ហើយ វឿន ជាមេបញ្ជាការវរ៤១០”]។ ឯកសារ D54/46 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.27 [“ក្រោយមក គេបានផ្លាស់ខ្ញុំពីវរសេនាតូច៤១៥។ ប្រធានវរសេនាតូច៤១៥ ឈ្មោះគង់ ខ្ញុំជាអនុប្រធាន ង៉ែត ង៉េន ជាសមាជិក។ វរសេនាតូច៤១៥ ស្ថិតនៅក្រោមកងវរសេនាធំ២១ ក្នុងកងពលលេខ៣”]។ ឯកសារ D54/49 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.3 [“បូល មកពីវរសេនាតូច៤១៥”]។ ឯកសារ D114/76 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.15 [“ខ្ញុំគិតថាវាកើតឡើងនៅឆ្នាំ

កងវរៈសេនាធំលេខ ២២ មានយ៉ាងហោចណាស់កងវរៈសេនាតូចចំនួនបួន គឺកងវរៈសេនាតូចលេខ ៥២០ លេខ ៥៣០ លេខ ៥៤០ និងលេខ ៥៥០ (ពេលខ្លះហៅថា ៥៦០) និងប្រហែលជាកងវរៈសេនាតូចលេខ ៥៨០ ផងដែរ[597]។ **មាស មុត** បានលើកឡើងថា នៅចន្លោះថ្ងៃទី ១៧ ខែ

---

១៩៧៦ [...] ទន និងមឿន គឺជាបញ្ជាការកងវរសេនាតូចលេខ៤២០ [...] ប៉ុន្តែមឿន ត្រូវបានគេដកចេញនៅក្រោយពេលក្រោយទៀត"]។ ឯកសារ D54/35 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.10 ["ខ្ញុំឋិតនៅកងវរសេនាតូច៤៣០។ ហើយខ្ញុំជានីរសាររបស់មេបញ្ជាការកងវរសេនាតូច។ មេបញ្ជាការកងវរសេនាតូចឈ្មោះបង បូ។ កងវរសេនាតូច៤៣០ឋិតក្នុងកងពលទី៣ ដែលមានតាមុតជាមេបញ្ជាការកងពល ហើយតាម៉ុកជាប្រធានភូមិភាគនិរតី"]។ ឯកសារ D4.1.751 របាយការណ៍ទាក់ទងទៅនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387258 និង KH ERN 01519652 ["កងពលនេះមានកងវរសេនាធំចំនួន ៣ ចាប់ពីលេខ ២០ ដល់២២ និងកងវរសេនាតូចវិស្វកម្មទី ៤៥០ [...] កងវរសេនាធំទី ២១ មានកងវរសេនាតូចជាចំណុះទី ៤១០ ទី ៣៣០ និងទី ៤៨០។"]។ ចម្លើយរបស់ កាំ ម៉ែន ទាក់ទងទៅនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387329 និង KH ERN 00742580 ["កងវរសេនាធំមានកងវរសេនាតូចចំនួនបួន ៤១០ ៤២០ ៤៨០ និង ៤៩០ និងមានទីតាំងនៅរាម"]។ ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.17 [កងវរសេនាធំលេខ ៤១០]។ ឯកសារ D114/287 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង រ៉េត ឆ.43 ["ស៖ សូមលោកប្រាប់យើងថាតើកងអនុសេនាធំ និងវរសេនាតូចមួយណារបស់កងវរសេនាធំ២១ ឬ១៦២ដែលគេបញ្ជូនឲ្យបោះទីតាំងនៅកោះក្រចកសេះ? ឆ43៖ ពេលនោះមានជម្រើសច្រើន កងចម្រុះ តែជាស្នូលមានកងវរសេនាតូច៤១០ តែដល់ក្រោយមកមិនដឹង ដាក់លេខប៉ុន្មាន តែពេលនោះជាកងវរសេនាតូច៤១០ ហើយក៏មានកង៤៥០ មួយផ្នែកទៅដែរ"]។ ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.3 [មេបញ្ជាការរបស់កងអនុសេនាធំលេខ៨ នៃកងវរសេនាតូច៤២០]។ ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.11 ["អង្គភាពកង១០២ លែងនៅក្រោមកងតំបន់៣៣ ទៀតហើយ។ ត្រូវបញ្ចូលទៅជាកងពលរបស់ភូមិភាគនិរតីដែលជាកងពលលេខ៣។ រួចកងវរសេនាតូច១០២ វាក្លាយទៅជាកងវរៈសេនាតូច៤២០"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ ក៏ម ម៉េន ឆ.61 ["ស៖ តើវរសេនាតូច៤៨០ ជាលេខវរសេនាតូចថ្មីឬចាស់? ឆ.61៖ គឺខ្ញុំភ្លេចហើយ តែសំខាន់ចេញពីកងតំបន់លេខ១៣។ តាមខ្ញុំស្មាន ៤៨០ ប្រហែលជាលេខចាស់"]។ ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.16 ["ខ្ញុំគិត ប៉ុន្តែមិនប្រាកដឡើយថាញូន អាចមកពីវរសេនាតូច៤៨០"]។

597 ឯកសារ D2/8 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.34 និង 51 ["ការពិតគឺមានបីវរសេនាធំអញ្ចឹងមែន គឺមានវរសេនាធំ២០, ២១ និង ២២។ [...] ឆ.51៖ ឥឡូវខ្ញុំនឹកឃើញហើយកងវរសេនាតូចដែលនៅក្រោមកងវរសេនាធំ ២២។ ៖ កាលពីមុនបែកភ្នំពេញមានឈ្មោះដូចតទៅគឺ កងវរសេនតូច៥២០ ៥៣០, ៥៤០ និង ៥៥០"]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.7 ["ខ្ញុំមិនច្បាស់អំពីខ្ទង់លេខទីមួយថាជាលេខ ១ ឬលេខ ៥ ទេ តែថាខ្ញុំចាំច្បាស់ថា គឺពីរលេខខាងចុង គឺលេខ ២០, ៣០, ៤០, ៥០ ក្នុងវរៈសេនាធំ ២២"]។ ឯកសារ D114/48 កំណត់ហេតុស្តាប់ចម្លើយ សុខ ង៉ុន ឆ.6 ["ស៖ តើលោកចូលធ្វើយោធានៅកន្លែងណា? ឆ.6៖ តាមដែលខ្ញុំនឹកឃើញមិនសូវច្បាស់ប្រហែលជាវរសេនាតូច៥២០"]។ ឯកសារ D114/18 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.29 និង 32-33 ["វរ

សេនាតូច៥៤០ ដែលមានមេបញ្ជាការឈ្មោះ សារី ហើយទីបញ្ជាការរបស់គាត់នោះគឺនៅខាងក្រៅបរិវេណវាលយន្ត ហោះកងកេង។ [...] ឆ32៖ យោងតាមការចង់ចាំរបស់ខ្ញុំ គឺមានវរសេនាតូច៥២០ នៅក្រោមហាន វរសេនាតូច៥៣០ នៅក្រោមវ៉េត វរសេនាតូច៥៤០ នៅក្រោមសារី ហើយវរសេនាតូច៥៦០ គឺនៅក្រោមខ្ញុំ គឺមិនមានវរសេនាតូច ៥៥០ នោះទេ [...] ឆ33៖ វរសេនាតូចនេះ [520] ត្រូវបានបញ្ជូនទៅកងជើងទឹក"]។ ឯកសារ D59/1/1.11a បទសម្ភាសន៍ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ហៀង វ៉េត EN ERN 00974078 និង KH ERN 00926525 ["ស៖ តើក ងវរយរបស់ពូ នៅក្នុងកងវរសេនាតូចទៅ? ឆ៖ នៅវរសេនាតូច ៥៣០ [...] ស៖ កងអនុសេនាធំលេខ ប៉ុន្មាន? ឆ៖ វរ សេនាធំលេខ ១៦"]។ ឯកសារ D4.1.762 ចម្លើយរបស់ កាំ ម៉ែន ទាក់ទងទៅនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួន ក្នុងសង្គ្រាម EN ERN 00387329 និង KH ERN 00742581 ["គាត់ចាំបានថា កងវរសេនាតូចដែលត្រូវបានបង្កើត ក្រោមឱវាទកងវរសេនាធំលេខ ៦៣ ប្រើលេខសម្គាល់ខ្ទង់ ៥០០ ហើយគាត់សន្និដ្ឋានថា កងវរសេនាតូចដែលត្រូវបាន បង្កើតក្រោមឱវាទកងវរសេនាធំលេខ ៦១ ប្រើលេខសម្គាល់ខ្ទង់ ៣០០"]។ ឯកសារ D54/33 កំណត់ហេតុស្តាប់ ចម្លើយ អ៊ុង ឆុន ឆ.9 ["កងអនុសេនាធំទាំង៣នេះ ឋិតនៅក្រោមវរសេនាតូច៥៤០ ដែលមានមេបញ្ជាការឈ្មោះ សារី [...] វរសេនាតូច ៥៣០ ៥៤០ និង ៥៥០ ឋិតនៅក្នុងវរសេនាធំក្រោមបញ្ជាការរបស់តាម យ៉ាន"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត់ (ប៊ុន សារ៉ាត់) ឆ.2 ["ខ្ញុំនៅក្នុងកងវរសេនាតូច ៥៤០ ក្នុងវរសេនាធំ លេខ ១៥ នៅក្នុងកងពលលេខ៣"]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.64 និង 246 [កងវរសេនាធំលេខ៤៤០] និង ឆ.17, 22 និង 248 ["ស៖ កងកុមាររបស់លោកហ្នឹងស្ថិតនៅកងវរសេនាតូចណាដែរ? ឆ17៖ កងវរសេនាតូច ៥៨០ [...] ឆ22៖ ពួកគេមានអាយុ ១២ ប្រហែល ១៣ ទៅ ២០ ឆ្នាំ [...] ស៖ តើកងវរសេនា តូច ៥៨០ គ្រប់គ្រងតំបន់ណាខ្លះ? ឆ248៖ ចំការដូង"]។ ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ឆ.9 និង 11 ["ស៖ [...]នៅក្នុងឆ្នាំ ១៩៧៤ គ-៤ ត្រូវបានច្របាច់បញ្ចូលគ្នាទៅនឹងកងពលដែលទើបបង្កើតថ្មី ហៅថា កង ពលលេខ៣។ [...] នៅពេលនោះ គ-៤ ត្រូវបានប្តូរឈ្មោះទៅជាកងវរសេនាតូចលេខ ៥៥០ ដែលស្ថិតនៅក្រោមកងវរ សេនាធំលេខ២២។ តើកថាខណ្ឌដែលបានអាននេះ ត្រឹមត្រូវដែរឬទេ? ឆ9៖ បាទ, ត្រឹមត្រូវហើយ [...] ឆ11៖ តាម ដែលលោកចាំ តើមានអ្នកណាខ្លះ នៅក្នុងកងវរសេនាតូចលេខ៥៥០ ក្រោយមកចូលទៅក្នុងកងទ័ពជើងទឹក"]។ ឯក សារ D2/9 កំណត់ហេតុស្តាប់ចម្លើយ ស៊ុយ ប៊ន ឆ.37 ["ស៖ តើកាលនោះ មនុស្សច្រើនឬទេ ដែលចេញពីវររ គ៤ ឬវ រ:៥៥០ ចូលមកខាងទ័ពជើងទឹក? ឆ37៖ មិនមានមនុស្សច្រើនប៉ុន្មានទេ។ ដែលតាមដែលខ្ញុំចាំគឺមានប្រហែលជាជាង ១០នាក់ប៉ុណ្ណោះដែលចេញពីវររគ៤ ឬ៥៥០"]។ ឯកសារ D54/30 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.8 និង 11 ["កងវរសេនាតូច ៥៥០ ត្រូវបានបង្កើតឡើងប្រហែល ២ ខែមុនបែកភ្នំពេញ ក្នុងខែមេសា ឆ្នាំ១៩៧៥។ វរសេនាតូច នេះ ត្រូវបានគេហៅថាវរសេនាតូចពិសេស ហើយយោធាក្នុងកងនេះគឺដកយកមកពីកងផ្សេងយកមកបញ្ចូលគ្នា។ [...] ឆ11៖ [មុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥] ខ្ញុំនៅក្នុងក្រុមស៊ើបការណ៍លើទីកន្លែងកងទ័ពម្ខាងទៀត ដែលនៅ តាមមុខព្រួញទាំងពីរនោះ"]។

មេសា ឆ្នាំ ១៩៧៥ និងការបង្កើតកងពលធំមជ្ឈិមលេខ ១៦៤ កងពលធំលេខ ៣ មានកងវរៈសេនាធំលេខ ៤ ដែលមានអតីតកងទ័ពតំបន់ ៣៧[598]។ លើសពីនេះទៀត មានកងវរៈសេនាតូចឯករាជ្យមួយចំនួន ដូចជា កងវរៈសេនាតូចលេខ ៤៥០ (កងកម្លាំងពិសេស) ដែលត្រូវបានដាក់ដោយផ្ទាល់ក្រោមការដឹកនាំរបស់ **មាស មុត**[599]។

<u>កងពលធំលេខ ១៦៤ (ខែ កក្កដា ឆ្នាំ ១៩៧៥ - ខែ មករា ឆ្នាំ ១៩៧៩)</u>

214. នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៧៥ នៅឯកិច្ចប្រជុំធំមួយនៅពហុកីឡដ្ឋានជាតិអូឡាំពិកក្នុងទីក្រុងភ្នំពេញ ប៉ុល ពត បានប្រកាសពីការបង្កើតកងទ័ពបដិវត្តន៍កម្ពុជានៅក្នុងការថ្លែងសុន្ទរកថាមួយនៅចំពោះមុខទាហាន ៣.០០០ នាក់[600]។ ជាផ្នែកមួយនៃការរៀបចំឡើងវិញនេះ កងពលធំយោធភូមិ

---

598 ឯកសារ D22.2.181 ចម្លើយរបស់ មាស មុត ទាក់ទងទៅនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០១ EN ERN 00249694 និង KH ERN 00741997 ["នៅពេលមានឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស ទីបញ្ជាការដ្ឋាននៃកងពលធំលេខ ៣ មានទីតាំងស្ថិតនៅរាម។ កងពលធំនេះ មានកងវរសេនាធំលេខ ៣៧, ១៤, ១៥ និង ១៦ ដែលស្ថិតនៅក្រោមបង្គាប់។ មូលហេតុដែលគេដាក់ឈ្មោះថាជាកងវរសេនាធំលេខ៣៧ ពីព្រោះកងវរសេនាធំនេះ ត្រូវបង្កើតចេញពីកងកម្លាំងមកពីតំបន់ ៣៧។"]។

599 ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ មើ រ៉េត ហៅ សារ៉េត ឆ.27 ["បាទ, គាត់ធ្លាប់។ វរសេនាតូច ៤៥០ គឺកងពិសេសរបស់តាមុត"]។ ឯកសារ D54/46 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.38 ["សម្រាប់ទ័ពថ្មើរជើងគឺបញ្ជាចេញពីកងពលលេខ៣ មកវរសេនាធំ ពីវរសេនាធំមកវរសេនាតូច ហើយពីវរសេនាតូចមកវរសេនាធំ។ តែសម្រាប់កងពិសេសរបស់ខ្ញុំ វរសេនាតូច៤៥០ គឺទទួលបញ្ជាផ្ទាល់ពី មាស មុត ដែលជាមេបញ្ជាការកងពលលេខ៣តែម្តង"]។ ឯកសារ D114/15 កំណត់ហេតុស្តាប់ចម្លើយ សុខ វណ្ណា ឆ.18 ["សៈ តើលោកធ្លាប់ឮអំពីកងវរសេនាតូចពិសេស៤៥០ នៃកងពលលេខ៣ ដែរឬទេ? ឆ18៖ បាទ, ខ្ញុំឮអំពីកងនេះ គឺនៅក្រោមមាស មុត"]។ ឯកសារ D4.1.762 ចម្លើយរបស់ កាំ ម៉ែន ទាក់ទងទៅនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387328 និង KH ERN 00742578 ["កងពលធំលេខ ១៦៤ ត្រូវបានរៀបចំជាកងទ័ពថ្មើរជើង ក្រោមឱវាទចំនួនបីកងវរសេនាធំ គឺ កងវរសេនាធំលេខ ៦១, ៦១ និង ៦៣ រួមទាំងកងវរសេនាតូចប្រតិបត្តិការពិសេសលេខ ៤៥០"]។ ឯកសារ D59/1/1.11a បទសម្ភាសន៍ជាមួយ ហៀង រ៉េត EN ERN 00974081 និង KH ERN 00926527 ["កងពិសេសបើនិយាយទៅជាកងឯករាជ្យរបស់កងពល[...] ស្មើនិងកងវរសេនាធំដែរ"]។ ឯកសារ D234/2.1.92 ព្រុំ សារ៉ាត ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ 14.38.20-14.42.45 ["អង្គភាពពិសេស ៤៥០ នេះ គឺជាកងពិសេសរបស់កងពលប្រចាំជុំវិញកងពល១៦៤ [...] អង្គភាពពិសេសនេះ ត្រូវបានគេហៅថា កងវរសេនាពិសេសប្រចាំកងពលទី ៣"]។

600 ឯកសារ D4.1.861 ទង់បដិវត្ត ខែ សីហា ឆ្នាំ ១៩៧៥ EN ERN 00401488 KH ERN 00063323-24 និង FN ERN 00538963 ["កាលពីថ្ងៃ ២២ កក្កដា ១៩៧៥ ក្នុងឱកាសពិធីចាត់តាំង កងទ័ពបដិវត្ត របស់មជ្ឈបក្សកុម្មុយនីស

កម្ពុជា សមមិត្តប្រធាននៃគណៈកម្មាធិការ យោធាជាន់ខ្ពស់ របស់បក្ស បានធ្វើសន្និសីទនយោបាយមួយដ៏សំខាន់ ជូនតំណាងគ្រប់អង្គភាព នៃកងទ័ពបដិវត្ត ប្រមាណបីពាន់នាក់ របស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ សន្និសីទសំខាន់នេះមានខ្លឹមសារទាំងស្រុងដូចតទៅ៖[...] ៤. ភារកិច្ចថ្មីនៃកងទ័ពបដិវត្តយើង"]។ D98/3.1.20 ឆោម សែ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ 11.38.49, 11.40.51, 11.50.33-11.52.30 [អង្គសន្និបាត នៅក្នុងស្តាតអូឡាំពិក ទាក់ទងទៅនឹង "ការបង្កើតខួបរបស់កងទ័ពគ្រប់ប្រភេទ" និងមជ្ឈិមដឹកនាំទូទាំងប្រទេសចូលរួម] និង 14.01.48-14.06.23 [បញ្ជាក់ថា សន្និបាតកងទ័ពបដិវត្តកម្ពុជា ថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ១៩៧៥ ដែលបានរៀបរាប់នៅក្នុងទង់បដិវត្តន៍ ខែសីហា ឆ្នាំ ១៩៧៥ គឺត្រូវតាមសន្និបាតដែលគាត់បានចូលរួម បើទោះបីជាគាត់ដំបូងគិតថា វាធ្វើឡើងនៅខែ កញ្ញា ឆ្នាំ ១៩៧៥ ក៏ដោយ។ ឯកសារ D4.1.801 កំណត់ហេតុស្តាប់ចម្លើយ ឆោម សែ ឆ.3 ["កងពល៨០១ ត្រូវបានបង្កើតឡើងនៅភ្នំពេញ នៅក្នុងមហាសន្និបាតនៅស្តាតអូឡាំពិក ប្រហែលជាខែកញ្ញា។ យោធភូមិពិសេសមានបីកងពល គឺកងពល ៧០៣ កងពល ៦០៥ និងកងពល៨០១"]។ ឯកសារ D4.1.805 កំណត់ហេតុស្តាប់ចម្លើយ ឆោម សែ ឆ3-4 ["ស៖ នៅក្នុងបទសម្ភាសថ្ងៃទីសាមសិបមួយ ខែតុលា ឆ្នាំពីរពាន់ប្រាំបួន លោកមានប្រសាសន៍ថា កងពល៨០១ ត្រូវបានបង្កើតឡើងក្នុងមហាសន្និបាតបក្ស ក្នុងខែកញ្ញា ឆ្នាំ១៩៧៥។ [...] ឆ3៖ មហាសន្និបាតនៅខែកញ្ញា ឆ្នាំ១៩៧៥។ មានកងទ័ពគ្រប់កងពល ចាប់ពីមេកងពលរហូតដល់ថ្នាក់អនុសេនាធំចូលរួមប្រជុំ ក្នុងនោះខ្ញុំក៏ចូលរួមប្រជុំដែរ ក្នុងឋានៈជាអនុប្រធានអនុសេនាធំកងពល៨០១ [...] គោលបំណងនៃមហាសន្និបាតគឺនិយាយអំពីជីវប្រវត្តិរបស់កងទ័ព កិច្ចដំណើរការរបស់កងទ័ពជាថ្មី និងកម្មវិធីប្រកាសសមាសភាពដឹកនាំ មជ្ឈិមបក្សជូនដល់កម្មាភិបាល [...] ក្នុងពេលនោះ គេប្រកាសបង្កើតភូមិភាគពិសេស ដែលមានកងពល៣បញ្ចូលគ្នា គឺកងពល៨០១ កងពល៧០៣ និងកងពល ៦០៥។ ទ័ពស្រួច (កងទ័ពមជ្ឈិម) ទាំងអស់គឺមាន ១២ កងពល គឺជាកងទ័ពសម្រាប់ចល័តទូទាំងប្រទេស [...] ក្រោយពីប្រជុំមហាសន្និបាតរួច គេសម្រេចបញ្ជូនកងពល ៨០១ ទៅរតនគីរី [...] ឆ4៖ សុន សេន ជារដ្ឋមន្ត្រីក្រសួងការពារជាតិ ជាអ្នករៀបចំមហាសន្និបាត។ បានឡើងថ្លែងការណ៍យ៉ាងយូរ ហើយចុងក្រោយគឺ ប៉ុល ពត ជាអ្នកថ្លែងការណ៍"]។ ឯកសារ D4.1.454 កំណត់ហេតុស្តាប់ចម្លើយ កុយ ម៉ុន (កងពលលេខ១៧០) EN ERN 00272715, KH ERN 00195436 ["នៅពាក់កណ្តាលឆ្នាំ១៩៧៥ ប៉ុល ពត បានហៅមេៗកងទ័ពមកពីគ្រប់អង្គភាព ទាំងទ័ពមជ្ឈិម និងទ័ពភូមិភាគ ឲ្យចូលរួមសន្និបាតនៅស្តាតអូឡាំពិក។ ខ្លឹមសារប្រជុំ [...] ហើយបានលើកឡើងផែនការកងទ័ពមជ្ឈិម និងភូមិភាគឲ្យបង្កបង្កើនផល និងធ្វើស្រែ"]។ ឯកសារ D4.1.827 កំណត់ហេតុស្តាប់ចម្លើយ ហ៊ឹម ហ៊ន EN ERN 00425235-36, KH ERN 00422488 [រៀបរាប់អំពីអង្គប្រជុំនៅស្តាតអូឡាំពិក ចុងឆ្នាំ ១៩៧៥ "ការប្រគល់កងទ័ពឲ្យមជ្ឈិមបក្ស" ហើយបានឃើញ ប៉ុល ពត នួន ជា, អៀង សារី និង ខៀវ សំផន អង្គុយនៅលើវេទិកា។ នួន ជា បាននិយាយអំពីការប្រគល់កងទ័ពឲ្យមជ្ឈិមបក្ស ដែលមាន ប៉ុល ពត ជាអ្នកគ្រប់គ្រង"]។ ឯកសារ D4.1.794 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង រ៉េន EN ERN 00408399, KH ERN 00398517 ["កាលពីប្រកាសកងពល៨០១ គឺមានថ្នាក់ដឹកនាំជាន់ខ្ពស់ទាំងអស់ចូលរួម គឺមាន ប៉ុល ពត, នួន ជា, អៀង សារី សុន សេន ជាអ្នកប្រកាសតែងតាំងនៅស្តាតអូឡាំពិក ក្រោយពីរំដោះភ្នំពេញបានប្រហែលដប់ប្រាំថ្ងៃ"]៖ អ៊ុង រ៉េន បញ្ជាក់ពី រយៈពេលនៅក្នុងសវនាការ៖ D98/3.1.20 អ៊ុង រ៉េន ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ 09.09.08-09.12.30 EN ERN 00879822-24 [អះអាងថា អង្គប្រជុំនៅពហុកីឡដ្ឋានអូឡាំពិកបានរៀបចំឡើងបន្ទាប់ពីគាត់ចាកចេញពីមន្ទីរពេទ្យនៅខែឧសភាឆ្នាំ ១៩៧៥]។ ឯកសារ D1.3.17.4 ហ៊ុយ វណ្ណៈ កងពលខ្មែរក្រហមលេខ ៧០៣ KH ERN 00081292 [រៀបរាប់ថា

ភាគមួយចំនួន ត្រូវបានរៀបចំឡើងវិញជាកងពលមជ្ឈិមថ្មីចំនួនប្រាំបួន[601] ដែលបានរាយការណ៍ដោយផ្ទាល់ទៅអគ្គសេនាធិការ និងមេដឹកនាំរបស់ខ្លួនគឺ សុន សេន ដែលបានក្លាយជារដ្ឋមន្ត្រី

---

នៅថ្ងៃទី ២២ ខែកក្កដា ឆ្នាំ១៩៧៥ កងពលលេខ១២ ក្លាយទៅជាកងពលលេខ ៧០៣]។ ឯកសារ D1.3.17.1 អេលីស្សាបែត បេ៊កខ័រ នៅពេលដែលសង្គ្រាមរលត់ទៅ KH ERN 00237731។

601 ក្រៅពីកងពលធំលេខ ១៦៤ (កងពលជើងទឹក) នៅកំពង់សោម ទាហានបដិវត្តន៍កម្ពុជាមជ្ឈិមផ្សេងទៀតរួមមាន កងពលលេខ១៧០ ២៩០ ៣១០ ៤៥០ ៥០២ ៧០៣ ៨០១ និង៩២០។ កងពលធំលេខ១៧០ គឺមកពីភូមិភាគបូព៌ា ហើយឈរជើងនៅក្រៅភ្នំពេញ ក្រោមការដឹកនាំដំបូងបំផុតរបស់ ចាន់ ចក្រី ហៅ នូវ មាន រហូតដល់គាត់ត្រូវបានគេចាប់ខ្លួន៖ ឯកសារ D4.1.845 កំណត់ហេតុស្តាប់ចម្លើយ ឡាញ់ ដុស ឆ.24។ ឯកសារ D4.1.454 កំណត់ហេតុស្តាប់ចម្លើយ កុយ ម៉ុន EN ERN 00272715, KH ERN 00195436។ ឯកសារ D4.1.22 ចម្លើយសារភាពនៅមន្ទីរស-២១ របស់ ចាន់ ចក្រី ហៅ នូវ មាន។ កងពលធំលេខ២៩០ ក៏បានមកពីភូមិភាគបូព៌ា (តំបន់២៤) ដោយមានសមមិត្ត តាល់ ជាប្រធាន៖ ឯកសារ D4.1.908 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៧៦ [ការប្រជុំពិពណ៌នាអំពី សុន សេន, ឌុច ហើយនិងគណៈកងពលធំលេខ១៧០ និង ២៩០]។ កងពលធំលេខ ៣១០ (ភូមិភាគពាយ័ព្យ) គឺបានឈរជើងនៅទីក្រុងភ្នំពេញ ជ្រោយចង្វារ ដោយមាន ស្បូវ ហ៊ឹម ហៅ អឿន ជាប្រធានដំបូង រហូតដល់គាត់ត្រូវបានគេចាប់ខ្លួន ហើយនិងសម្លាប់៖ ឯកសារ D114/230.1.1 បញ្ជីអ្នកទោស ស-២១ EN ERN 01222656។ ឯកសារ D4.1.827 កំណត់ហេតុស្តាប់ចម្លើយ ហ៊ឹម ហ៊ន EN ERN 00425235-36, KH ERN 00422488។ ឯកសារ D4.1.845 កំណត់ហេតុស្តាប់ចម្លើយ ឡាញ់ ដុស ឆ.24។ ឯកសារ D1.3.27.21 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ឯកសារ D4.1.556 កំណត់ហេតុស្តាប់ចម្លើយ គង់ គីម, EN ERN 00278682, 84, KH ERN 00270164, 66-67។ កងពលធំលេខ៤៥០ (ភូមិភាគពាយ័ព្យ) ដំបូងត្រូវបានគ្រប់គ្រងដោយ ជា នន ហៅ ស្អួង៖ ឯកសារ D1.3.9.1 របាយការណ៍ពីសមមិត្ត រ៉ែន ទៅអង្គការ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៧៦ EN ERN 00233930, KH ERN 00087054។ ឯកសារD4.1.841 កំណត់ហេតុស្តាប់ចម្លើយ សុខ ឆាយ EN ERN 00404296, KH ERN 00398508។ កងពលធំលេខ៥០២ (កងទ័ពអាកាសរបស់កម្ពុជាប្រជាធិបតេយ្យ) គឺមានទីតាំងនៅព្រលានយន្តហោះពោចិនតុង ហើយទទួលខុសត្រូវក្នុងការកសាងព្រលានយន្តហោះកំពង់ឆ្នាំងជាមួយនឹង សូ ម៉េត ហៅ សូ សាមិត ដែលជាប្រធាន៖ ឯកសារ D4.1.845 កំណត់ហេតុស្តាប់ចម្លើយ ឡាញ់ ដុស ឆ.24។ ឯកសារ D4.1.854 កំណត់ហេតុស្តាប់ចម្លើយ សេង ម៉ុន, EN ERN 00359932, KH ERN 00357536។ ឯកសារ D4.1.242 កំណត់ហេតុស្តាប់ចម្លើយ ផាន់ ពេជ្រ EN ERN 00231406, KH ERN 00228841។ ឯកសារ D4.1.553 កំណត់ហេតុស្តាប់ចម្លើយ ស្រេង ធី EN ERN 00282224, KH ERN 00270178។ ឯកសារ D1.3.32.27 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡេង គីម ហៅ គង់ គីម EN ERN 00184123។ ឯកសារ D1.3.12.9 របាយការណ៍ពីសមមិត្ត មេត ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៧៦។ ឯកសារ D4.1.837 កំណត់ហេតុស្តាប់ចម្លើយ ហែន សុផល EN ERN 00374046, KH ERN 00373259។ កងពលធំលេខ ៧០៣ (អតីតកងពលធំលេខ១២ របស់ភូមិភាគបូព៌ា) មានមូលដ្ឋាននៅទីក្រុងភ្នំពេញខាងត្បូងចំការមន ដែលស្ថិតក្រោមការដឹកនាំរបស់សមមិត្ត ពីន៖ ឯកសារ D1.3.8.7 កំណត់ហេតុនៃការប្រជុំរបស់

ក្រសួងការពារជាតិជាផ្លូវការភ្លាមៗបន្ទាប់នោះ[602]។ ហេតុដូច្នេះ អតីតកងពលធំលេខ ៣ ពីភូមិភាគនិរតី បានក្លាយជាកងពលធំមជ្ឈិមលេខ ១៦៤ ជាផ្លូវការ នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៧៥

---

កងទ័ពកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៦។ ឯកសារ D6.1.1158 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ឯកសារ D98/3.1.20 ប្រតិចារឹក ឆោម សែ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ ម៉ោង 11.05.40-11.08.39។ ឯកសារ D4.1.845 កំណត់ហេតុស្តាប់ចម្លើយ ឡុញ ដុស ឆ. 24។ ឯកសារ D1.3.17.4 កងពលខ្មែរក្រហមលេខ៧០៣ ហ៊ុយ វណ្ណៈ EN ERN 00081292។ កងពលធំលេខ ៨០១ (មានមូលដ្ឋានក្នុងខេត្តរតនគិរី ក្នុងភូមិភាគឦសាន) បង្កើតឡើងដោយរួមបញ្ចូលគ្នារវាងកងពលតូចលេខ១១ និងកងពលតូចលេខ១៤ ដែលត្រូវបាននាំដោយ សូរ សារឿន ហៅ តាអុល៖ ឯកសារ D4.1.634 របាយការណ៍ជូនបង ៨៧ (សុន សេន) ពី រឿន ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៧៦។ ឯកសារ D98/3.1.306 ប្រតិចារឹក អ៊ុង អ៊ែន ថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០១៣ ម៉ោង 10.56.46-10.58.51, 11.55.59-11.58.02, 13.38.210-13.41.23។ ឯកសារ D98/3.1.20 ប្រតិចារឹក ឆោម សែ ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៣ ម៉ោង 11.05.40-11.08.39, 11.11.05, 11.50.00-11.52.27។ ឯកសារ D4.1.845 កំណត់ហេតុស្តាប់ចម្លើយ ឡុញ ដុស ឆ.24។ ឯកសារ D4.1.803 កំណត់ហេតុស្តាប់ចម្លើយ ជិន គឹមថុង ហៅ ឆាង EN ERN 00403579-80, KH ERN 00401323-24។ ឯកសារ D4.1.789 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង អ៊ែន EN ERN 00381032, 35។ ឯកសារ D4.1.804 កំណត់ហេតុស្តាប់ចម្លើយ ជិន គឹមថុង ហៅ ឆាង EN ERN 00404077-78, KH ERN 00401333-34។ កងពលធំលេខ ៩២០ (មានមូលដ្ឋានក្នុងខេត្តមណ្ឌលគិរី ជាតំបន់ស្វយ័តលេខ ១០៥) ស្ថិតក្រោមលេខាកងពល ញ៉ែម សាន ដែលជាអ្នកមកជំនួស ម៉ែន ម៉េង ហៅ ឈិន គឺបន្ទាប់ពីការចាប់ខ្លួន ម៉ែន ម៉េង ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៧៖ ឯកសារ D1.3.27.14, ឯកសារ D4.1.81 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៧៦។ ឯកសារ D1.3.34.3 ទូរលេខពី ឈិន ជូនបង ៨៩ ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ១៩៧៦។ ឯកសារ D4.1.234 របាយការណ៍ពី ឈិន ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ១៩៧៦។ ឯកសារ D234/2.1.49 ទូរលេខ ១១ ពី សាន ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៩៧៧ EN ERN 00531038, KH ERN 00052312។ ឯកសារ D4.1.845 កំណត់ហេតុស្តាប់ចម្លើយ ឡុញ ដុស ឆ .24។ ឯកសារ D4.1.444 កំណត់ហេតុស្តាប់ចម្លើយ សៅ សារុន EN ERN 00278695, 97, KH ERN 00251438-40។ ឯកសារ D4.1.443 កំណត់ហេតុស្តាប់ចម្លើយ ហាំ អនស៊ី EN ERN 00250750, KH ERN 00242413។ ឯកសារ D114/35.2 Sara Colm និង ស៊ឹម សុរិយា ការបោសសម្អាតរបស់ខ្មែរក្រហមនៅខ្ពង់រាបខេត្តមណ្ឌលគីរី EN ERN 00397617, 704។ សូមមើលផងដែរ ឯកសារ D4.1.801 កំណត់ហេតុស្តាប់ចម្លើយ ឆោម សែ EN ERN 00406211, KH ERN 00401299 ["កងពល៨០១នេះត្រូវបានបង្កើតឡើងនៅភ្នំពេញ នៅក្នុងមហាសន្និបាទនៅស្តាតអូឡាំពិក ប្រហែលជាខែកញ្ញា។ យោធាភូមិពិសេសមានបីកងពល គឺកងពល៧០៣, កងពល៦០៥, និងកងពល៨០១"]។

602 សេចក្តីសម្រេចមួយរបស់គណៈអចិន្ត្រៃយ៍ កាលពីថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៧៥ បានផ្តល់នូវការគ្រប់គ្រងទៅលើកងទ័ពឲ្យ ប៉ុល ពត ហើយ សុន សេន ក៏បានក្លាយទៅជាប្រធានអគ្គសេនាធិការជាផ្លូវការ ហើយនិងជារដ្ឋមន្ត្រីក្រសួងការពារជាតិ៖ ឯកសារ D1.3.27.1 ការប្រជុំអចិន្ត្រៃយ៍ នៅថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៧៥ EN ERN 00183393, KH

[603] ដូចដែលមាស មុត បានប្រកាសនៅចំពោះមុខកងទ័ពកងពលធំលេខ ៣ និងកងវរៈសេនាតូចលេខ ៣៨៦ នៅលើកោះតាងក្នុងរយៈពេលដ៏ខ្លីក្រោយមក[604]។ ទោះជាយ៉ាងនេះក្តី មាស មុត បាន

---

ERN 00019108។ ឯកសារ D98/1.2.25 ប្រតិចារឹក កាំង ហ្កេកអ៊ាវ ហៅ ឌុច ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១២ ម៉ោង 15.17.32-15.19.37 ["តាមពិតគាត់ដើរតួជានាយអគ្គសេនាធិការកងទ័ពបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យ [...] សុន សេន សមាជិកមជ្ឈិមត្រៀម ប្រធានគណៈកម្មាធិការសេនាធិការ [...] ដោយ សុន សេន គាត់កាន់កាប់ខាងសន្តិសុខ"]។ ឯកសារ D1.3.19.1 សេចក្តីសម្រេចរបស់គណៈមជ្ឈិម ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ EN ERN 00182814, KH ERN 00003141 ["សមមិត្ត ខៀវ : ឧបនាយក ទទួលខាងការពារប្រទេស"]។

603 ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត់ (ប៊ុន សារ៉ាត់) ឆ.6, 103 ["ព្រោះពេលហ្នឹង ពីឆ្នាំ៧៤ ដល់៧៥ ចាប់ពីថ្ងៃទី១៧ មេសាហ្នឹង កងពលលេខ ៣អស់ហើយ ដូរឈ្មោះទៅជាកងពលលេខ១៦៤ [...] ឆ.103៖ ប្រវត្តិរបស់អតីតកងពលលេខ៣ អត់មាន១៤០ទេ ក្រៅពីហ្នឹង មានដូចគ្នាទាំងអស់។ សំណួរអំមិញ ខ្ញុំបញ្ជាក់ឡើងវិញ កុំឱ្យលោកច្រឡំថា កងពលលេខ៣ រាប់ចាប់ពី៧៤ ដល់៧៥ ត្រឹមខែ៧ ចាប់ផ្តើមប្តូរឈ្មោះទៅជាកងពលលេខ១៦៤" (សង្កត់ន័យបន្ថែម)]។ ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.18-19 ["នៅខែសីហា ឆ្នាំ១៩៧៥ កងពលថ្មី១៦៤ ត្រូវបានបង្កើតឡើង [...] ឆ.19៖ គឺមានឈ្មោះ មឿន ម៉ុន [...] មេបញ្ជាការអនុសេនាធំ និងឈ្មោះ ហោង ហុក ដែលជាមេបញ្ជាការកងអនុសេនាធំ ដែលស្ថិតនៅក្នុងកងវរសេនាតូច៤៨០។ ពួកគេបានប្រាប់ខ្ញុំថា កងពលធំលេខ៣បានប្តូរទៅជាកងពលធំលេខ១៦៤ ហើយក៏មានការបង្កើតនូវកងពលតូចមួយទៀតដែរ គឺកងពលតូចលេខ១៤០ ដែលជាកងជើងទឹក"]។ ឯកសារ D2/8 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.43 ["ខ្ញុំមិនបានចាំច្បាស់ថាប្តូរនៅពេលណាទេ ប៉ុន្តែពេលមកដល់កំពង់សោមគេប្រាប់គេថាកងពលលេខ៣ ដូរទៅហៅថា កងពល១៦៤ ហើយវរៈសេនាធំលេខ២០ ដូរទៅ១៦១ វរៈសេនាធំលេខ២១ ដូរទៅ១៦២ និងវរៈសេនាធំលេខ២២ ដូរទៅលេខ១៦៣"]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.6 ["ក្រោយឆ្នាំ ១៩៧៥ កងពលលេខ ៣ ត្រូវបានប្តូរទៅកងពលលេខ១៦៤ ជាកងពលជើងទឹក។ នៅពេលនោះកងពល ១៦៤ មិនមែនជាកងពលរបស់ភូមិភាគនិរតីទៀតទេ"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.9 ["កងពលលេខ៣ គឺស្ថិតនៅក្រោមភូមិភាគនិរតី ពេលដែលកងពលនេះ ដូរទៅជាកងពលលេខ១៦៤ គឺវាស្ថិតនៅក្រោមសេនាធិការកងទ័ពជាតិ"]។ ឯកសារ D4.1.759 បទសម្ភាសន៍ជាមួយ គង់ ចាយ ទាក់ទងជាមួយនឹងល្បើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387269, KH ERN 00658142 ["លោក ចាយ បានបញ្ជាក់ពីការរៀបចំកងពលធំលេខ៣ មុន និងបន្ទាប់ពីបែកភ្នំពេញ។ កងពលធំលេខ៣ ត្រូវបានផ្ទេរទៅជាកងទ័ពជើងទឹកកម្ពុជា ហើយបានប្តូរឈ្មោះទៅជាកងពលធំលេខ១៦៤"]។ ឯកសារ D4.1.759 បទសម្ភាសន៍ជាមួយ ខែម ងួន ទាក់ទងជាមួយនឹងល្បើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387265, KH ERN 00658135។ ឯកសារ D4.1.845 កំណត់ហេតុស្តាប់ចម្លើយ ឡាញ ឌុស ឆ. 24។

604 ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.171, 173, 177 ["ស៖ លោកថា មាស មុត ទៅមើលកោះតាងដើម្បីប្រកាសពីការបង្កើតកង ១៦៤ ក្នុងកិច្ចប្រជុំមួយ។ សូមលោកជួយបញ្ជាក់ពីបញ្ហានេះ។ ឆ.171៖ ដល់បញ្ជូនគ្នាទៅ គេយកកង៣៨៦ និងកងមកពីបូព៌ា ទៅបញ្ចូលជាមួយកងទី៣នៅកោះតាង។ រួចមក ទើបគេរៀបចំជា

រំឭកឡើងវិញដោយមិនត្រឹមត្រូវថា វាមិនមែនរហូតដល់ចុងឆ្នាំ ១៩៧៥ ទេ ដែលកងពលធំលេខ ១៦៤ ត្រូវបានបង្កើតឡើងនោះ[605]។

215. ក្រៅពីអតីតទាហានកងពលធំលេខ ៣ ទាំងអស់[606] និងកងទ័ពដែលនៅសេសសល់ពីតំបន់ ៣៧ (ជាពិសេស កងវរៈសេនាតូចលេខ ៣៨៦)[607]កងពលធំលេខ ១៦៤ ចាប់តាំងពីការបង្កើតកងពលធំ

---

កងវរៈតូចៗ បន្តទៅទៀតទៅ។ [...] សៈ អ្នកណាជាអ្នកនិយាយនៅក្នុងកិច្ចប្រជុំនោះ? ឆ.173៖ មានតែ មាស មុត ទេ។ [...] ឆ.177៖ គេធ្វើឡើងនៅកណ្ដាលកោះតាង នៅកណ្ដាលវាល"]។ សូមមើលផងដែរ ឯកសារ D114/286 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាង រ៉េត (ប៉ាង រ៉េត) ឆ.9 ["ពេលទៅដល់នោះ គឺថាខាងកងពលគេប្រជុំ ប្រកាសពីកងពលលេខ៣ មកជាកងពល១៦៤ គេថាកងពល ជាកងពលរបស់មជ្ឈិម របស់អគ្គបញ្ជាការ មិននៅក្រោមភូមិភាគដូចមុនទេ ព្រោះតំបន់កំពង់សោមជាតំបន់ស្វយ័ត ហើយហៅថាជាកងទ័ពជើងទឹក"]។ ឯកសារ D114/104 កំណត់ហេតុស្ដាប់ចម្លើយ អៀម ភង់ ឆ.30-31, 39 ["សៈ តើកងពលលេខប៉ុន្មាន? ឆ.30៖ កាលនោះ មិនទាន់ចូលកងពលទេ គេហៅថា កងតំបន់៣៧។ សៈ តើកាលនោះ មុន ឬក៏ក្រោយប៉ុល ពត ឈ្នះភ្នំពេញហើយ? ឆ.31៖ មុន។ [...] ឆ.39៖ ពេលនៅកោះតាងនោះ ខ្ញុំឮគេនិយាយថា គេបញ្ចូលពួកខ្ញុំទៅក្នុងកងពលទី៣"]។

605 ឯកសារ D22.2.181 បទសម្ភាសន៍ជាមួយ មាស មុត ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០១ EN ERN 00249698-99, KH ERN 00742002-03 ["នៅចុងឆ្នាំ ១៩៧៥ កងពលធំលេខ ៣ ត្រូវបានរៀបចំរចនាសម្ព័ន្ធទៅជាកងពលធំលេខ ១៦៤ និងត្រូវបានដាក់ឱ្យស្ថិតនៅក្រោមចំណុះកងនាវីកម្ពុជាប្រជាធិបតេយ្យ។ កងពលធំលេខ ១៦៤ នេះ ក៏ត្រូវបានរួមបញ្ចូលកងទ័ពបន្ថែមទៀតពីតំបន់ ២២ ២៤ និងកងទ័ពផ្សេងទៀតនៃតំបន់ ៣៧ ផងដែរ"]។ ឯកសារ D1.3.30.2 របាយការណ៍ពី មាស មុត ជូនបង ៨២ ចុះថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៧៦ [ទូរលេខដំបូងរបស់ មាស មុត ដែលនៅសល់ ចុះនៅថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៧៦ ហើយក៏បានប្រើជារបាយការណ៍ប្រចាំខែរបស់អង្គភាព ១៦៤ ដែលបានបញ្ជាក់យ៉ាងច្បាស់ថា កងពលធំលេខ ១៦៤ ត្រូវបានបង្កើតមុន]។ សូមមើលផងដែរ ឯកសារ D4.1.754 បទសម្ភាសន៍ជាមួយ កម្មាភិបាលកម្ពុជាប្រជាធិបតេយ្យដែលមិនស្គាល់អត្តសញ្ញាណ ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387428, KH ERN 00791382 ["នៅក្នុងខែធ្នូ ឆ្នាំ ១៩៧៥ កងអនុសេនាធំលេខ ៤០៨ ត្រូវបានផ្លាស់ប្ដូរទីតាំងពីកោះពូឡូវ៉ៃថ្មីទៅកាន់កោះតាង។ កងអនុសេនាធំលេខ ៤០៩ បានបោះទីតាំងនៅជិតប៉មផ្ដល់សញ្ញាឱ្យនាវានៅលើកោះរូងសន្លឹម ហើយកងអនុសេនាធំលេខ ៤២០ បានទទួលភារកិច្ចការពាររោងចក្រជួសជុលអាវុធនៅមូលដ្ឋានកងទ័ពជើងទឹករាម។ បន្ទាប់ពីការផ្លាស់ប្ដូរទីតាំងមួយរយៈខ្លីរួចមក (NFI) កងវរសេនាតូចលេខ ៤៨៦ ត្រូវបានរំលាយចោល ហើយកងទ័ពរបស់កងវរសេនាតូចនេះ ត្រូវបានដាក់បញ្ជូនទៅក្នុងកងពលធំលេខ ៣ ដែលត្រូវបានដាក់ឈ្មោះជាថ្មីថាកងពលធំលេខ ១៦៤។ ឯកសារ D4.1.747 បទសម្ភាសន៍ជាមួយ ឯក នី ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387289, KH ERN 00640516 ["ក្នុងឆ្នាំ១៩៧៦ កងវរៈសេនាតូចទី៣៨៦ ត្រូវបានរំលាយចូលទៅក្នុងកងពលធំទី៣។ នៅពេលនោះផងដែរ កងពលធំនេះត្រូវបានប្ដូរឈ្មោះទៅជាកងពលធំទី១៦៤"]។

នេះមក មានកងទ័ពភូមិភាគបូព៌ាយ៉ាងហោចណាស់ ៧០០នាក់[608] (និងរហូតដល់ ១.០០០-១.៥០០ នាក់)[609] មកពីតំបន់ ២២ និង ២៤ (ជាពិសេស មកពីកងវរៈសេនាធំលេខ ១៥២) ដែលបានទៅ

---

606 ឯកសារ D2/8 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.43 ["ពេលមកដល់កំពង់សោមគេប្រាប់គេថាកងពលលេខ៣ ដូរទៅហៅថា កងពល១៦៤ ហើយវរៈសេនាធំលេខ២០ ដូរទៅ១៦១ វរៈសេនាធំលេខ២១ ដូរទៅ១៦២ និងវរៈសេនាធំលេខ២២ ដូរទៅលេខ១៦៣"]។ ឯកសារ D4.1.750 បទសម្ភាសន៍ជាមួយ ជនមិនស្គាល់អត្តសញ្ញាណ ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387279, KH ERN 01496679 ["ប្រភពរាយការណ៍ បានផ្តល់ព័ត៌មានលម្អិតអំពីការរៀបចំអង្គភាពចំណុះឲ្យកងពលលេខ ៣ ឡើងវិញ ក្រោយពីព្រឹត្តិការណ៍កប៉ាល់ម៉ាយ៉ាហ្គេសរួចមក។ កងពលលេខ ៣ ត្រូវបានចាត់តាំងទៅជាកងពលលេខ ១៦៤"]។ ឯកសារ D59/1/1.29 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ង៉ែត ចាន់ថូ EN ERN 00968434, KH ERN 00733609 ["ខ្ញុំនៅកងពលទី៣ ក្រោយមកគេដាក់១៦៤"]។ ឯកសារ D4.1.759 បទសម្ភាសន៍ជាមួយ គង់ ចាយ ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387269, KH ERN 00658142 ["កងពលធំលេខ ៣ ត្រូវបានផ្ទេរទៅជាកងទ័ពជើងទឹកកម្ពុជា ហើយបានប្តូរឈ្មោះទៅជាកងពលធំលេខ១៦៤"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង រ៉េត EN ERN 00974097, KH ERN 00926541 ["សៈ បាទ! កាលហ្នឹងកងពលទី៣ដូរឈ្មោះមកកងពល? ឆៈ កងពល១៦៤"]។

607 សូមមើលឯកសារខាងលើ កថាខណ្ឌ ២១២ ជើងទំព័រ ៥៨៦, ៥៨៧ ពាក់ព័ន្ធជាមួយនឹងការបញ្ចូលកងវរៈសេនាតូច ៣៨៦ (តំបន់ ៣៧) ទៅក្នុងកងពលធំលេខ៣ មុននឹងត្រូវបានបញ្ចូលជាផ្លូវការនៅក្នុងខែកក្កដា ឆ្នាំ១៩៧៥។

608 ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆុន ឆ.20 ["នៅពេលនោះ ឌឹម និងយោធា៧០០នាក់មកពីភូមិភាគបូព៌ាបានមកដល់ គេបានរៀបចំពួកយោធាបូព៌ាបញ្ចូលនឹងយោធាកងពលលេខ៣ឲ្យទៅជាកងពល ១៦៤"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត់ (ប៊ុន សារ៉ាត់) ឆ.158 ["ក្រោយមកទៀត បានមានជ្រើសរើសកម្លាំងខាងបូព៌ា៧០០នាក់បន្ថែម ជាការរៀបចំកម្លាំងពីអគ្គសេនាធិការបញ្ជូនទៅ។ ច្របាច់កម្លាំងទាំងពីរនេះចូលគ្នា កម្លាំងមកពីបូព៌ាមាន៧០០នាក់"]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.8 ["មិនមែនយោធាទាំងអស់នៅក្នុងកងវរៈសេនាធំ៥២ ត្រូវបញ្ជូនបានទៅកំពង់សោមនោះទេ។ តាមខ្ញុំដឹងយោធាត្រូវបានជ្រើសរើសមកពីកងវរៈសេនាខុសៗគ្នា ដើម្បីបញ្ជូនទៅកំពង់សោម លើកលែងតែកងអនុសេនាធំ ឬក៏កងវរៈសេនាតូចកងពិសេសដែលត្រូវបានគេបញ្ជូនទៅទាំងអស់គ្នា។ សរុបទៅមានយោធាកងវរៈសេនាធំប្រហែល៧០០នាក់ត្រូវបានបញ្ជូនទៅកំពង់សោម"]។ យោងទៅតាម យឹម ស្រឿង កងវរៈសេនាធំលេខ ៥០០ ឬ ៦០០ បានចូលជាមួយនឹងកងវរៈសេនាធំលេខ ១៤០ តែមួយៈ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.51-52 ["ពេលនៅជាកងវរសេនាធំលេខ៦១ អត់មានទាហានថ្មីទេ ប៉ុន្តែនៅពេលដែលបង្កើតវរសេនាធំលេខ១៤០ ទើបមានទាហានពីបូព៌ាមកចូលក្នុងកងទ័ពជើងទឹកនេះដែរ។ [...] ឆ.52 កាលពីនៅវរសេនាធំ១៤០ គេបញ្ជូនទាហានពីភូមិភាគបូព៌ាមានចំនួនប្រហែលជា ៥០០ ទៅ៦០០នាក់ ដើម្បីចូលជាមួយកងនាវាចរនេះដែរ"]។ ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន (ណាំ ឡុន) ឆ.19 ["ឌឹម មកកំពង់សោមជាមួយនឹងយោធាប្រហែលជាពីរកងវរសេនាតូច។ គាត់មកពីភូមិភាគបូព៌ា នៅពេលដែលគេរៀបចំកងពល១៦៤។ គាត់មកប្រហែលជា១ខែ បន្ទាប់ពីដួលភ្នំពេញ"]។ ឯកសារ D54/8

តាមមេបញ្ជាការកងវរៈសេនាធំឈ្មោះ ឌឹម នៅកំពង់សោម។ ឌឹម បានក្លាយជាមេបញ្ជាការរងទីមួយនៃកងពលធំលេខ ១៦៤[610] ខណៈដែល **មាស មុត** បានរក្សាតួនាទីរបស់គាត់ជាមន្ត្រីនយោ

---

កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.28 ["គេបញ្ជូនទៅស្ទឹងហាវ ខ្ញុំគិតថាប្រហែលពាក់កណ្តាលឬចុងឆ្នាំ ១៩៧៥ នៅពេលដែលពួកបូព៌ាមកដល់កំពង់សោមចូលជាមួយកងពល១៦៤"]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968417, KH ERN 00926642 ["ស៖ ហើយខ្ញុំចង់បញ្ជាក់ពូតិចទៀត កន្លែងកងពល១៦៤នឹង ពេលដែលដូរឈ្មោះពីកងពលទី៣ ទៅ១៦៤ ដូចថាមានបញ្ចូលក្រុមណាផ្សេងមក? ឆ៖ អូ! នោះយកពីបូព៌ាមក"]។

609 ឯកសារ D54/96 កំណត់ហេតុស្តាប់ចម្លើយ តេង សារឹម ហៅ ជឹម ជ្រឿន (អតីតយោធាកងវរសេនាធំលេខ ១៥២ តំបន់២២) ឆ.20-21 ["គឺមួយកងវរៈសេនាធំ១៥២ ក្រោមបញ្ជាការរបស់ ឌឹម ត្រូវបានបញ្ជូនទៅកំពង់សោមទាំងអស់ គឺមានចំនួនប្រហែលជិត១០០០នាក់។ [...] ឆ.21៖ សមាជិករបស់កងវរៈសេនាធំ១៥២ ពុំមែនមកពីតំបន់២២ តែមួយទេ គឺមកពីភូមិភាគបូព៌ាទាំងមូលតែម្តង"]។ ឡុន សេង ប្រធានអនុសេនាធំក្នុងកងវរសេនាធំលេខ២១/៦១ បានប៉ាន់ប្រមាណថា មានទាហានភូមិភាគបូព៌ាសរុបទាំងអស់ មិនតិចជាង ១.៥០០នាក់ទេ ដែលបានចូលរួមក្នុងកងពលធំលេខ ១៦៤ ជាពីរដំណាក់កាល៖ ឯកសារ D54/44 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.5 ["បាទ មានខ្លះត្រូវបានបញ្ជូនទៅក្នុងកររបស់ខ្ញុំ មានយោធា១៥០០នាក់មកពីភូមិភាគបូព៌ាមកនៅក្នុងកងរបស់ខ្ញុំ។ [...] ពួកគេមកពីរដំណាក់កាល លើកទី១ មានយោធា៧០០នាក់ និងលើកទី២ មានយោធា៨០០នាក់។ ខ្ញុំមិនចាំច្បាស់ថានៅក្នុងឆ្នាំណា ប៉ុន្តែចន្លោះពីឆ្នាំ ១៩៧៥-១៩៧៧ ដោយសារគេមកដល់មុនខ្ញុំចាកចេញពីកងពល១៦៤ នៅឆ្នាំ១៩៧៧ ទៅភ្នំពេញ"]។

610 ឯកសារ D22.2.181 បទសម្ភាសន៍ជាមួយ មាស មុត ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០១ EN ERN 00249698-99, KH ERN 00742002-03 ["កងពលធំលេខ ១៦៤ នេះ [...] ក៏ត្រូវបានរួមបញ្ចូលកងទ័ពបន្ថែមទៀតពីតំបន់ ២២ ២៤ និងកងទ័ពផ្សេងទៀតនៃតំបន់ ៣៧ ផងដែរ" (សង្កត់ន័យបន្ថែម)]។ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស លេខរៀង ១៦២៤ [បញ្ជីឈ្មោះ ហង់ ឌឿន ហៅ ឌឹម កំណត់អត្តសញ្ញាណជាអនុលេខាកងពលលេខ ១៦៤]។ ឯកសារ D1.3.28.40 បញ្ជីឈ្មោះអ្នកទោសដែលកំទេច ហើយថត នៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ១៩៧៧ EN ERN 00873280-81, KH ERN 00009146 [លេខរៀង ២ នៅក្នុងបញ្ជី]។ ឯកសារ D234/2.1.55 សម្រង់ចម្លើយសារភាពរបស់ ហង់ ឌឿន ហៅ ឌឹម នៅមន្ទីរស-២១ EN ERN 00224085។ ឯកសារ D1.3.18.1 សម្រង់ចម្លើយសារភាពរបស់ ហង់ ឌឿន ហៅ ឌឹម នៅមន្ទីរស-២១។ ឯកសារ D1.3.18.2 សម្រង់ចម្លើយសារភាពរបស់ ហង់ ឌឿន ហៅ ឌឹម នៅមន្ទីរស-២១។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.33 ["ស៖ កងពល ១៦៤ ហើយ តា មុត ជាអ្នកគ្រប់គ្រង។ តើអ្នកណាជាអនុ? ឆ.33៖ តា ឌឹមជាអនុ"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.12 ["ឌឹម គឺជាអនុទី១របស់ មាស មុត ហើយគាត់ជាអ្នកមកពីភូមិភាគបូព៌ា"]។ ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ ស៊ាង EN ERN 00217564 ["អនុប្រធានទី១ របស់ មុត ឈ្មោះ ឌឹម ជាមនុស្សមកពីភូមិភាគបូព៌ា។ ឌឹម បានបាត់ខ្លួនក្នុងឆ្នាំ ១៩៧៧ ពេលដែលមានជម្លោះផ្ទៃក្នុង"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ កឹម ម៉េន ឆ.31 ["មាស មុត ជាមេបញ្ជាការ ឌឹម ជាអនុប្រធាន (មកពីខេត្តព្រៃវែង) និង ឆាន ជាសមាជិក"]

បាយ និងជាមេបញ្ជាការក្តាប់រួមរបស់កងពលនេះ[611] ទោះបីជាគាត់ម្នាក់ឯងបានបដិសេធតួនាទីនេះក៏ដោយ[612]។

។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.15 ["កងពល១៦៤ហ្នឹង មាន មាស មុត ជាស្នងការធំ ហើយមាន នង ឆាន ជាបញ្ជាការកងពល ១៦៤។ បន្ទាប់មក គឺ ឌឹម ដែលជាបញ្ជាការរង។ បន្ទាប់មកគឺ ង៉ែត ជាសមាជិកកងពល"]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.4, 5, 8, 12 ["ឌឹម ជាអ្នកមកពីតំបន់២២ គាត់ទទួលខុសត្រូវមុខព្រួញខាងកើតភ្នំពេញ ជាមួយកងវរៈសេនាធំ៥២ (១៥២) [...] ឆ.5៖ ឌឹម ទៅកំពង់សោមមុនខ្ញុំនិង សំ ទៅទៀត។ នៅកំពង់សោម ឌឹម ជាអនុមេបញ្ជាការកងពល១៦៤។ [...] ឆ.8៖ មិនមែនយោធាទាំងអស់នៅក្នុងកងវរៈសេនាធំ៥២ ត្រូវបញ្ជូនបានទៅកំពង់សោមនោះទេ។ [...] ឆ.12៖ នៅពេលដែល ឌឹម ត្រូវបានបញ្ជូនទៅកំពង់សោមមួយរយៈ គាត់បានត្រឡប់មកប្រមូលកម្លាំងយោធាកងវរៈសេនាធំរបស់គាត់ទៅកំពង់សោមជាមួយគាត់ដែរ។ [...] យោធាដែលមានសមត្ថភាពត្រូវបានជ្រើសរើសឲ្យទៅធ្វើការជាមួយ ឌឹម នៅកំពង់សោម ដើម្បីបញ្ចូលនៅក្នុងកងពល១៦៤"]។ ឯកសារ D54/95 កំណត់ហេតុស្តាប់ចម្លើយ ឃុន ថន (បងប្រុសរបស់ ឃុន ឌឿម ឬ ឃុន ឌឹម កងវរសេនាតូចលេខ ១៤១ កងវរសេនាធំលេខ ១៤០ កងពលលេខ១៦៤) ឆ.20 ["ពួកគាត់ត្រឡប់មកភូមិឃុំនានាក្នុងតំបន់២២ ដើម្បីស្រាវជ្រាវប្រវត្តិកូនទាហានរបស់ពួកគាត់ ដែលគេបញ្ជូនពីតំបន់២២ ទៅកំពង់សោមជាមួយគាត់នោះ"]។ ឯកសារ D54/44 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.5 ["ឌឹម ក្លាយជាអនុរបស់ មាស មុត ទទួលខុសត្រូវខាងបញ្ជាការយោធានៅក្នុងកងពល១៦៤"]។ ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន (ណាំ ឡុន) ឆ.19 ["ប៉ុន្តែនៅពេលដែលគេរៀបចំកងពល១៦៤ នោះ គាត់ក្លាយជាមេបញ្ជាការផ្នែកយោធា និងជាអនុរបស់ មាស មុត"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.66 ["សុទ្ធជាអ្នកដែលនៅក្រោម មាស មុត ដូចជា ង៉ែត ជាអនុរបស់ មាស មុត។ ឌឹម នៅក្រោម មាស មុត នៅថ្នាក់កងពល។ ឆាន នៅថ្នាក់កងពល។ យ៉ានប្រធានវរសេនាធំ។ សុខ ជាប្រធានពេទ្យនៅកងពល"]។ ឯកសារ D54/81 កំណត់ហេតុស្តាប់ចម្លើយ ហ៊ឹង អ៊ិច ឆ.14 ["អនុកងពលឈ្មោះ ឌឹម មកពីភូមិភាគបូព៌ា។ សមាជិកកងពលមកពីខេត្តកោះកុងឈ្មោះបង ឆាន។ ក្រោយមក យ៉ានមកកាន់កងពល១៦៤ជាមួយ អ៊ំ មុត ដែរ"]។ ឯកសារ D2/16 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.10។ ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង ឆុន ឆ.20។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.50។ ឯកសារ D54/51 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន (ស្វាយ វឿន) ឆ.12។

611 សូមមើល ឧទាហរណ៍ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.15, 66 ["កងពល១៦៤ហ្នឹង មាន មាស មុត ជាស្នងការធំ [...] ឆ.66៖ គេប្រកាសថា គាត់ជាប្រធានកងពល ១៦៤ តាំងពីរៀបករពលឯណោះ។ ខ្ញុំឃើញគាត់នៅក្នុងកិច្ចប្រជុំដើម្បីបញ្ចូលកងទាំង៣នោះ។ ឯកសារ D54/109 កំណត់ហេតុស្តាប់ចម្លើយ សៅ សំ ឆ. 26 ["មាស មុត ទទួលខុសត្រូវកងពលស្វយ័តលេខ១៦៤នៅកំពង់សោម"]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន (ណាំ ឡុន) ឆ.44 ["មាស មុត ជាមេ ហើយ មាស មុត គ្រប់គ្រងទាំងផ្នែកជើងទឹក និងជើងគោកនៅក្នុងភូមិភាគ"]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.14 ["ពួកគេទាំងពីរធ្វើការជាមួយគ្នា តែ មាស មុត ជាមេបញ្ជាការកងពល ហើយ ឌឹម ជាអនុរបស់ មាស មុត"]។ ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន ឆ.129 ["តាម៉ុត [...] ខ្ញុំឮថាគាត់កាន់កងពលនៅកំពង់សោម។ គាត់ជាកូនប្រសាររបស់តា ម៉ុ

216. ទីបញ្ជាការកងពលធំលេខ ១៦៤ ត្រូវបានគេហៅថា "ម-១៦៤"[613] ជា"មន្ទីរផ្ទៃក្នុង ឬមន្ទីរក្នុង"[614] ឬគ្រាន់តែជា "មន្ទីរកងពលធំ" ឬ"មន្ទីរ តា មុត"[615]។ មន្ទីរនេះស្ថិតនៅក្នុងក្រុងកំពង់សោម[616] ប៉ុន្តែ

---

ក"]។ ឯកសារ D59/2/2.16a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី (ស៊ឹម នី) EN ERN 01332593, KH ERN 00735592 ["ស៖៖ តាមុត គ្រប់គ្រងទាំងអស់? ឆ៖ បាទ! ទាំងលើគោក ទាំងក្នុងទឹក"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.16 ["មាស មុត មានសិទ្ធអំណាចចាប់ចងប្រជាជនស៊ីវិលយោធា ហើយនិងគ្រួសារយោធាដែលស្ថិតនៅក្រោមការត្រួតត្រារបស់កងពល១៦៤"]។ ឯកសារ D98/1.2.22 កាំងហ្គេកអ៊ាវ ហៅ ឌុច ប្រតិចារឹក ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ ម៉ោង 14.19.38 ["ប្រធានកងពលជើងទឹកឈ្មោះមុត គឺ មាស មុត នៅក្នុងមជ្ឈិមបក្ស"]។ ឯកសារ D114/297.1.20 ប្រតិចារឹក ប្រាក់ សុខ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 09.42.30-09.46.54, 11.20.27-11.23.29។ ឯកសារ D114/116 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.6។ ឯកសារ D54/50 កំណត់ហេតុស្តាប់ចម្លើយ មាស ធឿន (ស្វាយ ធឿន) ឆ.22។ ឯកសារ D2/8 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.27, 36។ ឯកសារ D2/16 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.12។ ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល់ ឆ.26។ ឯកសារ D114/128 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង រិន ឆ.17, 19។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.47។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN ERN 00978566, KH ERN 009554492។ ឯកសារ D59/1/4.21 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ុក សុខ EN ERN 01070618, KH ERN 00930598។

612 ឯកសារ D22.2.181 បទសម្ភាសន៍ជាមួយ មាស មុត ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០១ EN ERN 00249694, KH ERN 00741997-98 ["គណៈបញ្ជាការនៃកងពលធំលេខ ៣ រួមមាន៖ ឆាន (Chhan) ជាមេបញ្ជាការកងពលធំ។ គាត់ជាមេបញ្ជាការទទួលបន្ទុកក្នុងអំឡុងពេលមានឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស ប៉ុន្តែទីបញ្ជាការដ្ឋាននេះ ស្ថិតនៅកំពង់សោម និងរាម។ សារឿន (Saroeun) ជាមេបញ្ជាការរង។ មាសមុត ជាមន្ត្រីនយោបាយ។ ញ៉ាន (Nhan) ជាសមាជិកនៃគណៈកម្មាការទទួលបន្ទុកភស្តុភារ។ ឡុន (Lon) ជាប្រធានផ្នែកភស្តុភារ"]។ EN ERN 00249698-99, KH ERN 00742002-03 ["កងពលធំលេខ ៣ ត្រូវបានរៀបចំរចនាសម្ព័ន្ធទៅជាកងពលធំលេខ ១៦៤ [...] សមាសភាពនៃគណៈបញ្ជាការកងពលធំនេះ ស្ថិតនៅដដែល"]។

613 ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់កងពលធំលេខ ១៦៤ ធ្វើដោយ មាស មុត នៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ EN ERN 00575529, FR ERN 00507699, KH ERN 00160069។ ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ ដោយ មាស មុត នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦ EN ERN 00233989, KH ERN 00160145 ["ម-១៦៤" ភាសាខ្មែរ "ម-១៦៤" បកប្រែជាភាសាអង់គ្លេស]។ ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.22, 27-29 [ទាក់ទងនឹងតារាងស្ថិតិក្នុង ឯកសារ D1.3.5.3៖ "អក្សរ "ម" គឺជាមន្ទីររបស់១៦៤។ [...] ឆ.27៖ តាមខ្ញុំយល់ឃើញរបស់ខ្ញុំ ម-១៦៤ គឺជាមន្ទីរ១៦៤។ [...] ឆ.28-29៖ ម-១៦៤ នេះជាមន្ទីររបស់ស្នងការ [...] មានទីតាំងស្ថិតនៅកំពង់សោម"]។ ឯកសារ D114/102 កំណត់ហេតុស្តាប់ចម្លើយ អែម សារិន ឆ.14 ["ពេលខ្ញុំ

ទីតាំងពិតប្រាកដរបស់មន្ទីរនេះបានផ្លាស់ប្តូរ ក្នុងអំឡុងពេលមួយពីមុំផ្សារលើក្នុងក្រុងកំពង់សោម[617] ទៅនៅតំបន់រាងឆ្ងាយបន្តិចនៅភាគអាគ្នេយ៍នៃផ្សារនេះ និងភាគពាយ័ព្យនៃសណ្ឋាគារសុខា[618] ក្នុង

ជួប ខេង ខ្ញុំសួរគាត់ ថាតើគាត់ជាអ្នកមូលដ្ឋាននេះឬ គាត់ថា មិនមែនទេ គឺគាត់មកពីមន្ទីរ១៦៤ នៅកំពង់សោម"]។ ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.24 ["តាមខ្ញុំយល់ ម-១៦៤ ជាមន្ទីររបស់កងពល រួមមានផ្នែកផ្សេង ដែលមានផ្នែកបញ្ជី ធ្វើឯកសារនីរសារ និងផ្នែកទំនាក់ទំនង"]។

614 ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ (ឡាយ ប៊ុនហាក់) ឆ.62 ["ទីបញ្ជាការកងពលនៅក្នុងក្រុងកំពង់សោម គេហៅថា "មន្ទីរក្នុង" តែខ្ញុំមិនដឹងនៅទីណាច្បាស់ទេ"]។ ឯកសារ D54/71 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.18 [មេបញ្ជាការរបស់មន្ទីរទូរសារក្នុងនៃកងពលលេខ១៦៤៖ "ស៖ តើលោកស្រីអាចពិពណ៌នាអំពីទីកន្លែងដែលលោកស្រីស្នាក់នៅជាមួយ មាស មុត [...] ឆ.18៖ កន្លែងនោះ ហៅថា មន្ទីរក្នុងរបស់កងពល១៦៤"]។

615 ឯកសារ D22.2.4 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៦ EN ERN 00950654, KH ERN 00160116 [និយាយពី "មន្ទីរកងពលធំ"]។ ឯកសារ D22.2.5 របាយការណ៍ស្ថិតិរបស់អង្គភាពកងពលធំ ១៦៤ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៦ EN ERN 00950656 ["មន្ទីរកងពលធំ"]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត ឆ.36 ["នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គឺគេហៅបញ្ជាការដ្ឋានថាជាមន្ទីរ"]។ ឯកសារ D114/286 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត (ហ៊ាង រ៉េត) ឆ.17 ["មន្ទីរ១៦៤ មន្ទីររបស់កងពល [...] បុគ្គលិកគ្រប់គ្រងប្រព័ន្ធទំនាក់ទំនង បញ្ជាទៅតាមកោះ បញ្ជាប្រចាំថ្ងៃទៅរ៉ាដា ទទួលបន្ទុកទំនាក់ទំនងរបាយការណ៍ បញ្ជូនបញ្ជាទៅតាមកោះ ទៅមកភ្នំបូកគោ។ [...] ការិយាល័យទី១ គ្រប់គ្រងឯកសាររបស់កងពល"]។ ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.7 ["មន្ទីរនោះគេហៅថាមន្ទីរ តាមុត"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង សុំ ឆ.331 ["ជួបនៅកំពង់សោម នៅមន្ទីរ០៤ ដែលជាមន្ទីររបស់កងពល១៦៤"]។

616 សូមមើល ឧទាហរណ៍ ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ (ឡាយ ប៊ុនហាក់) ឆ.62 ["ទីបញ្ជាការកងពលនៅក្នុងក្រុងកំពង់សោម"]។ ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.29 ["មន្ទីររបស់ស្នងការមានទីតាំងស្ថិតនៅកំពង់សោម"]។ ឯកសារ D54/44 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.23។

617 ឯកសារ D54/31 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.5-7 ["នៅពេលនោះ មាស មុតរស់ទីកន្លែងមួយជិតផ្សារលើ ហើយទីបញ្ជាការដ្ឋានកងពលពក៏នៅទីនោះដែរ។ ផ្ទះរបស់ មាស មុត នៅចម្ងាយ ១៥០ម៉ែត្រខាងកើតពីផ្សារលើ។ នៅពេលនោះទីបញ្ជាការដ្ឋានកងពលនិងផ្ទះរបស់មេបញ្ជាការកងពលគឺនៅជាមួយគ្នា។ រៀងរាល់ខែ ពួកគេបញ្ជាការវរៈសេនាធំនីមួយៗមកប្រជុំនៅទីនោះរៀងរាល់ថ្ងៃទី១០, ថ្ងៃទី២០ និង ថ្ងៃទី៣០ [...] ឆ.6៖ យើងដាំបន្លែនៅលើដីមួយកន្លែងខាងលិចផ្សារលិចផ្សារលើ កន្លែងដាំបន្លែនេះនៅមិនឆ្ងាយប៉ុន្មានពីកន្លែងផ្ទះ មាស មុត ដែលនៅខាងកើតផ្សារលើនោះទេ។ [...] ឆ.7៖ មាស មុត ស្នាក់នៅក្នុងផ្ទះនោះ ពីព្រោះកាលពីពេលនោះ ផ្ទះនោះគឺជាផ្ទះថ្មមួយហើយធំនៅកន្លែងនោះ សម្រាប់ឲ្យគាត់ស្នាក់នៅនិងធ្វើការ"]។ ឯកសារ D54/46 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.8, 25 ["ខ្ញុំគ្រាន់តែដឹងថាមន្ទីរទីមួយមានទីតាំងស្ថិតនៅជិត ផ្សារលើ។ មន្ទីរនោះជាផ្ទះឥដ្ឋដែល មាស មុត ស្នាក់នៅមន្ទីរនោះ

ផងដែរ [...] ឆ.25៖ កងពលលេ១៦៤ត្រូវបានបង្កើតឡើងហើយតំបន់ប្រត្តិការណ៍របស់កងពលនេះ ចាប់ពីផ្សារលើ រហូតរាម"]។ ឯកសារ D54/48.3 ផែនទីកំពង់សោម ដែលបានគូសសម្គាល់ដោយ អែម សុន KH ERN 00969463 [រៀបរាប់ថា បញ្ជាការដ្ឋានកងពលធំគឺនៅជិតផ្សារលើ ដូចដែលបានយោងក្នុង ឯកសារ D54/48 ឆ.46]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក់ សុខ EN ERN 00978575, KH ERN 00955506 ["ស៖ ចុះកាលជំនាន់នឹងកន្លែងទីបញ្ជាការកាលនឹងនៅខាងវៀម? ឆ៖ នៅកំពង់សោម។ [...] តាម៉ុតនៅខាងជិតផ្សារធំ [នៅកំពង់សោម]"]។ ឯកសារ D54/93 កំណត់ហេតុស្តាប់ចម្លើយ យ៉ែម សំអុន ឆ.66 ["តើលោកដឹងថាមន្ទីរកងពលលេខ៣ស្ថិតនៅកន្លែងណាដែរ? វាស្ថិតនៅប្រហែលក្បែររោងកុនចាស់មួយ នៅកំពង់សោម តាមបណ្តោយផ្លូវមកពីសមុទ្រ"]។ ឯកសារ D54/45 កំណត់ហេតុស្តាប់ចម្លើយ លុន សេង (លុន សេង) ឆ.27 ["ទីបញ្ជាការរបស់កងពល១៦៤ នៅជិតផ្សារលើ"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង រ៉េត EN ERN 00974093, KH ERN 00926538 ["ទីតាំងកងពលនៅលើទួលខ្ពស់ នៅលើផ្សារនៅខាងលិចមន្ទីរពេទ្យ"]។

618 ឯកសារ D54/72.2 ផែនទីទេសចរណ៍ក្រុងព្រះសីហនុ ដោយបានគូសសម្គាល់ដោយ មុត ម៉ៅ [កន្លែងដែលគាត់បានគូសរង្វង់ ពីលើ គឺជាទីតាំងរបស់មន្ទីរក្នុង វាស្ថិតនៅខាងត្បូងផ្សារលើ និងខាងជើងឆៀងខាងកើតនៃសណ្ឋាគារសុខា] ។ ឯកសារ D54/72 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ខាងក្រោម ឆ.26 យោបល់របស់អ្នកស៊ើបអង្កេត ["សាក្សីបាននិយាយថា មានផ្លូវចូលចំនួន៤ ទៅកាន់មន្ទីរក្នុងនៃកងពល១៦៤ ដោយយោងទៅតាមការចងចាំរបស់គាត់។ បើធ្វើដំណើរចេញពីផ្សារលើមុនពេលមកដល់ផ្លូវកាច់ជ្រុងជិតមន្ទីរពេទ្យ មានផ្លូវចូលពីរ។ បើចេញពីមន្ទីរពេទ្យទៅរង្វង់មូលតោពីរ គឺមានផ្លូវចូលពីរទៀត គឺមួយផ្លូវធំ និងមួយទៀតគឺផ្លូវតូច ដែលនៅមិនឆ្ងាយពីរង្វង់មូលតោពីរ"]។ មុត ម៉ៅ បានពន្យល់ថា ភ្ញៀវចិន ក៏ដូចជាប្រពន្ធរបស់ មាស មុត ពួកគេស្នាក់នៅកន្លែងទីតាំងសណ្ឋាគារសុខា រហូតដល់ពេលដែលប្រពន្ធរបស់ មាស មុត ស្លាប់ក្នុងឆ្នាំ១៩៧៦ ប៉ុន្តែ មាស មុត មិនស្នាក់នៅទីនោះទេ៖ ឯកសារ D54/71 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.2-3, 7, 10-11, 18, 20 ["ពេលដែល មាស មុត យកយាយ ខុម មកកំពង់សោម មាស មុត យកយាយ ខុម ទៅស្នាក់នៅសណ្ឋាគារ សុខា។ [...] ឆ.3៖ សណ្ឋាគារសុខា ជារបស់កងពល១៦៤។ [...] ស៖ តើអ្នកណាជាអ្នកទទួលខុសត្រូវនៅកន្លែងសណ្ឋាគារសុខានាពេលនោះ? [...] ឆ.10៖ ខ្ញុំបានស្នាក់នៅ និងធ្វើការនៅកន្លែងផ្ទះទទួលភ្ញៀវសុខាប្រហែលកន្លះឆ្នាំ រហូតដល់យាយ ខុម ស្លាប់ ទើប តា មុត បានយកខ្ញុំពីផ្ទះភ្ញៀវទៅនៅជាមួយគាត់វិញ។ [...] ឆ.11៖ ក្រោយមក ក្នុងរយៈពេលខ្លីមុនពេលដែលខ្ញុំចេញពីកន្លែងនោះ កន្លែងនោះគេឈប់ធ្វើជាកន្លែងផ្ទះភ្ញៀវសម្រាប់ពួកចិនស្នាក់នៅទៀតហើយ។ គេបានប្តូរកន្លែងនោះទៅប្រើប្រាស់សម្រាប់ប្រារព្ធពិធីជប់លៀងផ្សេងៗតែប៉ុណ្ណោះ។ [...] ស៖ តើលោកស្រីអាចពិពណ៌នាអំពីទីកន្លែងដែលលោកស្រីស្នាក់នៅនៅជាមួយ មាស មុត បន្ទាប់ពីលោកស្រីចាកចេញពីផ្ទះភ្ញៀវសុខាមក? ឆ.18៖ កន្លែងនោះ ហៅថា មន្ទីរក្នុងរបស់កងពល១៦៤។ ប្រសិនបើលោកធ្វើដំណើរពីផ្សារលើទៅកាន់រង្វង់មូលតោពីរ ហើយមកដល់ចំណុចផ្លូវកោង មានផ្លូវមួយកាត់ទទឹងផ្លូវធំ លោកអាចបត់ស្តាំប្រហែល៥០០ម៉ែត្រ លោកនឹងទៅដល់កន្លែងទីតាំងមន្ទីរក្នុងរបស់កងពល។ [...] ស៖ តើមន្ទីរក្នុងរបស់កងពល១៦៤ ហ្នឹងមានមុខងារធ្វើអ្វីខ្លះ? ឆ.20៖ វាគឺជាផ្ទះដែល មាស មុត ស្នាក់នៅ"]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត ឆ.36, 46, 66 ["[បញ្ជាការដ្ឋានរបស់កងពល១៦៤] ស្ថិតនៅខាងត្បូងផ្សារកំពង់សោម" [...] ឆ.46៖ មន្ទីររបស់ មាស មុត ស្ថិតនៅខាងត្បូងផ្សារកំពង់សោម [...] ស៖ ដោយសារលោកជួប មាស

បរិវេណដែល **មាស មុត** រស់នៅ[619]។ យោងតាមឯកសារនៅក្នុងរបបនោះ កម្មាភិបាល និងយុទ្ធជនប្រមាណពី ៨៥ ទៅ ៣១៩ នាក់បានធ្វើការនៅក្នុង ម-១៦៤ នៅចុងឆ្នាំ ១៩៧៦[620] ក្រោមការ

---

មុត ១ឆ្នាំតែពីរដង ហេតុអ្វីលោកដឹងថា មន្ទីរ មាស មុត មានទីតាំងនៅខាងត្បូងផ្សារកំពង់សោម? ឆ.66៖ ខ្ញុំដឹងតាមរយៈ ហន និង សារឿនង"]។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ឆ.19 ["ស៖ តើលោកដឹងឬទេថា បញ្ជាការដ្ឋានរបស់កងពល ៣/១៦៤ ឋិតនៅកន្លែងណា? ឆ.៖ ខ្ញុំនៅចាំ បើយើងធ្វើដំណើរពីអូរឈើទាលមកដល់រូបសំណាក់តោពីរ។ មានផ្លូវមួយបត់ទៅខាងជើង ទើបទៅដល់កន្លែងបញ្ជាការដ្ឋានកងពល នៅតាមបណ្តោយផ្លូវនោះក៏មាន ពេទ្យកងពលនៅវាយម្តុំនោះដែរ"]។ ឯកសារ D54/17 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.4-5 [សាក្សីបានពន្យល់ថា នៅចុងឆ្នាំ ១៩៧៥ គាត់បានអមដំណើរជាមួយកងពលនីរសារម្នាក់ទៅផ្ទះរបស់ លោក មាស មុត នៅជិតត្រពាំងទឹកមួយក្បែរទីតាំងរូបសំណាកតោ]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.9 ["នៅចុងឆ្នាំ១៩៧៨ កន្លែងធ្វើការរបស់ខ្ញុំគឺនៅជិតនឹងមន្ទីររបស់គាត់នៅនឹងក្រុងកំពង់សោម។ កន្លែងធ្វើការរបស់ខ្ញុំគឺនៅត្រង់កន្លែងសណ្ឋាគារសុខាបច្ចុប្បន្ននេះ។ កាលសម័យនោះ ក៏គេហៅថាផ្ទះភ្ញៀវសុខាដែរ។ ខ្ញុំអាចមើលឃើញកន្លែងមន្ទីរបញ្ជាការរបស់ មាស មុត ពីកន្លែងធ្វើការរបស់ខ្ញុំ"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.125 ["ស៖ តើលោកដឹងឈ្មោះ សណ្ឋាគារ ៧ជាន់នោះទេ? ឆ.125៖ គេហៅអូតែល ដំណាក់ស្តេច ហើយគេក៏ហៅថាអូតែល សុខា ដែរ"]។

619 ឯកសារ D54/71 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.20, 28 ["ស៖ តើមន្ទីរក្នុងរបស់កងពល១៦៤ ហ្នឹងមានមុខងារធ្វើអ្វីខ្លះ? ឆ.20៖ វាគឺជាផ្ទះដែល មាស មុត ស្នាក់នៅ។ [...] ឆ.20៖ មានអគារផ្សេងៗគ្នានៅក្នុងបរិវេណនៃមន្ទីរក្នុង។ នៅកន្លែងនោះមានរោងបាយរួម ផ្ទះរបស់ មាស មុត កន្លែងស្នាក់នៅរបស់នីរសារ និងអ្នកផ្សេងៗទៀតស្នាក់នៅកន្លែងសារទូរលេខ កន្លែងមួយហៅថា មន្ទីរផ្សាយ ដែលស្ថិតនៅជិតរង្វង់មូលតោពីរ តែខ្ញុំមិនដឹងថាគេផ្សាយអំពីអ្វីទេ"]។ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.3 ["មន្ទីរបញ្ជាការរបស់ មាស មុត ហើយនិងផ្ទះស្នាក់នៅរបស់គាត់មានចម្ងាយប្រហែល២គីឡូម៉ែត្រពីវត្តឥន្ទញ្ញាណ។ ផ្ទះរបស់ មាស មុត គឺនៅនឹងកន្លែងមន្ទីរធ្វើការរបស់គាត់តែម្តង"]។ ឯកសារ D114/139 កំណត់ហេតុស្តាប់ចម្លើយ ងួន ឡាយ ហៅ អ៊ី ឆ.60 ["ខ្ញុំធ្លាប់ទៅផ្ទះគាត់ដែរ នៅអូរទី ៥ គេហៅផ្ទះខៀវ។ ដឹកឌីឡឹកឲ្យគាត់"]។

620 ឯកសារ D22.2.4 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៦ EN ERN 00950654-55, KH ERN 00160116-18 [បញ្ជាក់ថា ក្នុងយោធាសរុបចំនួន៣១៩ ដែលធ្វើការនៅមន្ទីរកងពលធំ រួមមាន នីរសារចំនួន៥០នាក់ និងកុមារ១៦៩នាក់ ៛ ទោះបីជា បន្ថែមទៅលើចំនួនតួលេខនីមួយក៏ដោយ ចំនួនសរុបមានត្រឹម៣១៩នាក់ប៉ុណ្ណោះ]។ ឯកសារ D22.2.5 របាយការណ៍ស្ថិតិរបស់អង្គភាពកងពលធំលេខ ១៦៤ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៦ EN ERN 00950656-57, KH ERN 00160121-23 [ពេលដែលសរុបទៅ មានមនុស្សចំនួន៨៥នាក់ នៅមន្ទីរកងពលធំ ប៉ុន្តែតាមរយៈទិន្ន័យ/បញ្ជាក់លម្អិត ហាក់បីដូចជាមានបាត់ និងមានភាពខុសគ្នាដ៏សម្បើមពីមុនខែដែលមិនអាចពន្យល់បាន]។ ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ ដោយ មាស មុត នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦ EN ERN 00233989, KH ERN 00160145-47 [លើកឡើងថា មនុស្ស១០៣នាក់ បានធ្វើការនៅម-១៦៤ ក្នុងអំឡុងខែតុលា ឆ្នាំ១៩៧៦ ប៉ុន្តែម្នាក់ក្នុងចំណោមពួកគេ "បាត់ខ្លួនពីអង្គភាព" ពីព្រោះ

គ្រប់គ្រងរបស់ កេង និង អៀង[621] បន្ថែមទៅនឹងទាហាននៃអង្គភាពពិសេស (កងវរៈសេនាតូចលេខ ១៦៥ អតីតកងវរៈសេនាតូចលេខ ៤៥០) ដែលត្រូវបានដាក់ឱ្យឈរជើងនៅក្បែរនោះ[622]។

---

គាត់/នាង ត្រូវបាន "ដក"]។ ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ ដោយ មាស មុត នៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ EN ERN 00575529-31, FR ERN 00507699-701, KH ERN 00160069-71 [របាយការណ៍របស់ មាស មុត លើកឡើងអំពីចំនួនមនុស្សសរុប ១០២នាក់ ដែលធ្វើការនៅម-១៦៤]។ ឯកសារ D114/286 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត (ប៉ាង រ៉េត) ឆ.17 ["មន្ទីរ១៦៤ មន្ទីររបស់កងពល ហើយ១០៣នាក់ [នៅការិយាល័យ] នេះជាបុគ្គលិកគ្រប់គ្រងប្រព័ន្ធទំនាក់ទំនង បញ្ជាទៅតាមកោះ បញ្ជាប្រចាំថ្ងៃទៅវ៉ាដា ទទួលបន្ទុកទំនាក់ទំនង របាយការណ៍ បញ្ជូនបញ្ជាទៅតាមកោះ ទៅមកភ្នំបូកគោ។ វាដូចជាគេហៅថា ក១ ឬ ការិយាល័យទី១ គ្រប់គ្រងឯកសាររបស់កងពល"]។ ឯកសារ D54/71 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.8, 36 ["ពួកគេ [តាមុត, តាសារឿន, និង តាញ៉ាន់) ទាំងអស់គ្នាសុទ្ធតែស្នាក់នៅក្នុងបរិវេណមន្ទីរ ប៉ុន្តែនៅផ្ទះផ្សេងៗគ្នា។ ពួកគេហូបបាយជុំគ្នានៅផ្ទះបាយ តែពេលខ្លះនីរសាររបស់ពួកគេយកបាយម្ហូបទៅឱ្យនៅផ្ទះរបស់ពួកគេ [...] ស៖ តើមានមនុស្សប៉ុន្មាននាក់ ដែលធ្វើការនៅក្នុងមន្ទីរក្នុង? ឆ.៖ មានមនុស្សប្រហែល៣០ ទៅ ៤០នាក់ធ្វើការនៅទីនោះ"]។ ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.24 ["តាមខ្ញុំយល់ ម-១៦៤ ជាមន្ទីររបស់កងពល រួមមានផ្នែកផ្សេង ដែលមានផ្នែកបញ្ជី ធ្វើឯកសារនីរសារ និងផ្នែកទំនាក់ទំនង"]។ ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.8 ["មន្ទីរនោះ ជាផ្ទះថ្ម ហើយ មាស មុត ស្នាក់នៅក្នុងមន្ទីរនោះដែរ។ តាមការប៉ាន់ស្មានរបស់ខ្ញុំ ប្រហែលមានបុគ្គលិក ១០០នាក់ធ្វើការនៅផ្នែកផ្សេងៗក្នុងមន្ទីរនោះ"]។

621 កេង ជាប្រធានមន្ទីរ ១៦៤ ខណៈដែល អៀង ជាអ្នកបើកបរ/អង្គរក្ស/នីរសាររបស់ មាស មុត។ ឯកសារ D54/71 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.29, 31 ["ស៖ តើអ្នកណាជាអ្នកទទួលខុសត្រូវនៅមន្ទីរក្នុងហ្នឹង? ឆ.29៖ គាត់ឈ្មោះ កេង។ [...] ឆ.31៖ អៀង ជានីរសាររបស់ មាស មុត"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.9 ["ខ្ញុំស្គាល់កងការពារនិងនីរសាររបស់គាត់ទាំងអស់។ ប្រធានមន្ទីររបស់ មាស មុត ឈ្មោះ តា កេង"]។ ឯកសារ D114/102 កំណត់ហេតុស្តាប់ចម្លើយ អែម សារិន ឆ.14 ["ពេលខ្ញុំជួប ខេង ខ្ញុំសួរគាត់ ថាតើគាត់ជាអ្នកមូលដ្ឋាននេះឬ គាត់ថា មិនមែនទេ គឺគាត់មកពីមន្ទីរ១៦៤ នៅកំពង់សោម"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សាវ៉ាត់ (ប៉ុន សាវ៉ាត់) ស.42 ["ស៖ ដោយសារលោកធ្លាប់បានធ្វើការជាមួយ មាស មុត តាំងពីឆ្នាំ៧៣ ៧៤ មក តើលោកមានដឹងថាតែកុងឡានរបស់គាត់ឈ្មោះអីដែរទេ? ឆ.៤២ ["តែកុងឡានរបស់គាត់ ពាក្យយើងពីមុនហៅថា នីរសាររបស់គាត់ ឈ្មោះ អៀង"]។ ផ្ទុយគ្នាដោយផ្នែក ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.7 ["អៀង គឺជាប្រធានមន្ទីរ ហើយមន្ទីរនោះគេហៅថាមន្ទីរ តាមុត"]។

622 ឯកសារ D54/72 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.5, 7-8, 16 ["ស៖ លោកស្រីបាននិយាយកាលពីម្សិលមិញថា "ខ្ញុំគិតថាមានតែកងនីរសារ ឬកងពិសេស ដែលជាអ្នកយកមនុស្សទៅសម្លាប់ គឺពួកគេអាចជាកងពិសេស ឬក៏កងនីរសារ"។ ហេតុអ្វីបានជាលោកស្រីនិយាយដូច្នេះ? ឆ.5៖ ការងារប្រភេទអ៊ីចឹងៗ គឺជាការងាររបស់កងពិសេស ពីព្រោះមានតែកងពិសេសទេ ដែលត្រូវបានគេចាត់តាំងឱ្យធ្វើការងារបែបនេះផ្ទាល់ [...] ឆ.7៖ កងពិសេសគឺដូចជាកងការពាររបស់ មាស មុតអ៊ីចឹងដែរ។ ក្រុមនីរសារគឺជាក្រុមដែលធ្វើការនៅជិតនិងជាប់ជាមួយ តា មុត គ្រប់ពេលវេ

រោងកុនដែលនៅជិតផ្សារលើត្រូវបានប្រើសម្រាប់កិច្ចប្រជុំនយោបាយរបស់កងពលធំលេខ ១៦៤ វគ្គអប់រំរៀនសូត្រ និងពិធីរៀបអាពាហ៍ពិពាហ៍[623] ខណៈដែលកិច្ចប្រជុំ និងវគ្គបណ្តុះបណ្តាលផ្សេងទៀត ត្រូវបានធ្វើឡើងនៅអូរឈើទាល[624]។

---

លា។ ប៉ុន្តែកងពិសេស គឺសម្រាប់យាមកាម ហើយនិងយាមប៉ុស្តិ៍ឆែកឆេរនៅជុំវិញមន្ទីរ និងផ្ទះរបស់គាត់ [...] ឆ.8៖ គឺជាកងវរៈសេនាតូច [...] ឆ.16៖ តា នន គឺនៅក្នុងកងពិសេសសម្រាប់ការពារកងពល។ មានប៉ុស្តិ៍យាម ហើយនិងផ្ទះមួយដែលស្ថិតនៅច្រកចូលទៅផ្ទះរបស់ តា មុត ដែលជាកន្លែងដែល នន និងយោធារបស់គាត់ស្នាក់នៅ។ ខ្ញុំមិនដែលទៅដល់កន្លែងនោះទេ ដូច្នេះខ្ញុំមិនដឹងថា មានយោធាប៉ុន្មាននាក់ទេ នៅទីនោះ"]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត ឆ.93-95 ["កងវរៈសេនាតូច៤៥០ ឈរជើងនៅជុំវិញកងពល [...] ឆ.94៖ ពួកគេជាកងការពារ [...] ឆ.95៖ ការងារចម្បងគឺការពារទីបញ្ជាការរបស់កងពល"]។ ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.23 ["ក្រោយមកដោយពុំមានការប្រយុទ្ធនៅលើសមរភូមិទៀតទេ កង៤៥០នោះ ត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវខាងផ្នែកសន្តិសុខវិញ"]។ ឯកសារ D54/101 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.10 ["កងពិសេសរបស់ តា មុត។ ពួកនោះគឺដូចជាកងអង្គរក្សរបស់ តា មុត ឬក៏ហៅថាកងដៃស្តាំរបស់គាត់"]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.11 ["ស៖ តើកងវរៈសេនាតូចពិសេសនេះត្រូវបានចាត់តាំងឱ្យធ្វើអ្វីក្រោយឆ្នាំ ១៩៧៥ ពេលកងពល ៣/១៦៤ មកនៅកំពង់សោម? ឆ.11៖ កងវរៈសេនាតូចពិសេសនេះ គឺថិតនៅជាមួយបញ្ជាការឬស្នងការកងពល។ មុខងាររបស់កងពិសេសគឺការពារថ្នាក់ដឹកនាំកងពលនិងចាប់ចងអ្នកដែលមានទោស។ នៅពេលនោះប្រទេសជាតិបានសន្តិភាពហើយ កងពិសេសនេះមិនត្រូវការទៅច្បាំងនៅកន្លែងណាទេ ដូច្នេះកងពិសេសសម្រាប់ការពារថ្នាក់ដឹកនាំកងពលនិងចាប់ចងអ្នកធ្វើខុស"]។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ហៅ សារ៉េត ឆ.27 ["វរៈសេនាតូច ៤៥០ គឺកងពិសេសរបស់តាមុត"]។

623 ឯកសារ D54/44 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.24 ["ការប្រជុំ គឺធ្វើនៅអតីតរោងកុនមួយ ក្បែរទីបញ្ជាការកងពលនោះ។ ការប្រជុំកងពលពេលខ្លះ ធ្វើនៅអតីតរោងកុន និងពេលខ្លះទៀតនៅឆ្នេរអូរឈើទាល។ ខ្ញុំបានចូលរួមការប្រជុំអប់រំនៅអតីតរោងកុនចំនួនពីរដង ដែលម្តងៗមានរយៈពេលពីរសប្តាហ៍"]។ ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន ឆ.5 ["គេរៀបការពួកខ្ញុំនៅក្នុងរោងកុនកំពង់សោម។ គឺមានមនុស្សពេញរោងកុននោះតែម្តង ហើយគេក៏បានប្រកាសថា មានសរុប៧១គូ"]។ ឯកសារ D114/132 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ វ៉ាន់ ឆ.63-64, 66 ["ការរៀនសូត្រហ្នឹងគឺធ្វើឡើងពេលដែលយើងជួបជុំគ្នា គឺរៀបចំដោយ មាស មុត ហើយអ្នកបង្រៀនមាន មាស មុត និង អនុរបស់គាត់ម្នាក់ទៀត [...] ឆ.64៖ រៀននៅរោងកុនផ្សារលើ [...] ឆ.66៖ រៀនដូចជា ច្បាប់វិន័យកងទ័ព"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ.102-104 ["ស៖ តើការរៀនសូត្រប្រចាំឆ្នាំនេះ គេធ្វើនៅឯណា? ឆ.102៖ គេធ្វើនៅកងពល១៦៤។ [...] ស៖ តើកន្លែងនោះ វាជាទីបញ្ជាការកណ្តាលរបស់កងពល១៦៤ឬ? ឆ.103៖ បាទ ត្រឹមត្រូវហើយ គឺនៅកំពង់សោម។ ស៖ តើលោកមានដឹងថា ទីបញ្ជាការកណ្តាល គឺនៅទីតាំងត្រង់ណាទេ? ឆ.104៖ គឺកន្លែងរោងកុនចាស់ពីដើមមក"]។ ឆ.99-108 [បានពន្យល់ថា វគ្គសិក្សាប្រចាំឆ្នាំរបស់កងពលធំលេខ១៦៤ បានធ្វើឡើងនៅរោងកុន ក្រោមអធិបតីភាពរបស់ មាស មុត ដែលជាអ្នកដឹកនាំការបណ្តុះបណ្តាល ហើយកម្មាភិបាលទាំងអស់បានចូលរួម ប៉ុន្តែពុំមានទាហានធម្មតាចូលរួមនោះទេ។ វគ្គសិក្សាទាំងនោះគឺធ្វើឡើងចន្លោះ

217. បន្ទាប់ពីការដាក់បញ្ចូលកងកម្លាំងតំបន់ ៣៧ និងកងកម្លាំងភូមិភាគបូព៌ា កងវរៈសេនាធំលេខ ២០ លេខ ២១ និងលេខ ២២ នៃកងពលធំលេខ ៣ (ដែលហៅផងដែរថា លេខ ១៣ លេខ ១៤ និង

ពី ១០ ទៅ ១៥ថ្ងៃ]។ ឯកសារ D54/83 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ិច ឆ.25 ["ខ្ញុំដឹងថារោងកុននៅកំពង់សោម គឺជាកន្លែងប្រជុំសម្រាប់កងពលលេខ១៦៤។ គេប្រើសម្រាប់ប្រជុំ និងសម្រាប់រៀនសូត្រ [...] ខ្ញុំនៅការពារខាងក្រៅ [...] ខ្ញុំសម្គាល់ឃើញកម្មាភិបាលថ្នាក់មធ្យមមកចូលរួមប្រជុំ"]។ ឯកសារ D114/48 កំណត់ហេតុស្តាប់ចម្លើយ សុខ ង៉ុន ឆ.14 ["នៅក្នុងក្រុងកំពង់សោម ខ្ញុំត្រូវបានគេដាក់ឱ្យរៀនសូត្រនយោបាយនៅក្នុងកន្លែងផ្សារ"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.120, 124-125 ["ពេលនោះគឺមានសន្និបាតដែលមេៗនៅក្នុងកងពល ១៦៤បានចូលរួមប្រជុំ [...] ឆ.124៖ កិច្ចប្រជុំធ្វើឡើងក្នុងឆ្នាំ១៩៧៥ [...] ឆ.125៖ កិច្ចប្រជុំនោះធ្វើឡើងនៅក្នុងរោងកុននៅកំពង់សោម"]។ ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង ឆុន ឆ.15-16 ["ខ្ញុំត្រូវបានហៅឱ្យទៅហ្វឹកហ្វឺនដោយតាមុតនៅកំពង់សោម។ ការបង្រៀននោះបានធ្វើនៅអតីតៈរោងកុនកំពង់សោម ដែលបង្រៀនដោយតាមុត។ [...] ឆ.16៖ ខ្ញុំបានរៀនសូត្របានកន្លះខែ ជាមួយមាសមុត។ ក្នុងរយៈពេលនៃការហាត់រៀននោះ គេបានឱ្យយើងធ្វើជីវទស្សផងដែរ"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.91 ["ឱ្យតែមេៗវរៈគេហៅមករៀនសូត្រនៅរោងកុន នៅកំពង់សោម គឺដឹងតែបាត់ខ្លួនតែម្តង ហើយមិនដែលឃើញវិលត្រឡប់មកវិញទេ"]។ ឯកសារ D54/17 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.6 ["ស៖ តើការប្រជុំនៅអតីតៈរោងកុនកោះរុងនោះ [នៅក្នុងក្រុងកំពង់សោម] ជាការប្រជុំថ្នាក់អ្វីដែរ? ឆ.៖ នៅឆ្នាំ១៩៧៥ គេប្រជុំរៀនសូត្រនយោបាយនៅកន្លែងនេះ សម្រាប់ការប្រជុំនយោបាយ ប្រធាន/អនុប្រធានវរៈសេនាតូច ប្រធាន/អនុប្រធានកងអនុសេនាធំ រហូតដល់ថ្នាក់ប្រធានក្រុម ដែលគេហៅថាជាកម្មាភិបាល។ ចំពោះការប្រជុំថ្នាក់ប្រធាន ថ្នាក់វរៈសេនាធំ គេអាចធ្វើឡើងនៅទីបញ្ជាការរបស់មាសមុត"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.214, 216 ["តើអ្នកណាជាអ្នកបង្រៀនរឿងនយោបាយហ្នឹង? ឆ.214៖ ការបង្រៀននោះ គឺមាស មុត តែម្តង ហើយក្រោម មាស មុត មានឈ្មោះ ហន។ [...] ស៖ នៅពេលដែលគេបង្រៀនវគ្គហ្វឹកហ្វឺននយោបាយនោះ តើគេបង្រៀននៅកន្លែងណាដែរ? ឆ.216 ភាគច្រើននៅអូរឈើទាល នៅផ្សារកំពង់សោម រោងកុនកំពង់សោម"]។

624 ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.216 ["ស៖ នៅពេលដែលគេបង្រៀនវគ្គហ្វឹកហ្វឺននយោបាយនោះ តើគេបង្រៀននៅកន្លែងណាដែរ? ឆ.216 ភាគច្រើននៅអូរឈើទាល នៅផ្សារកំពង់សោម រោងកុនកំពង់សោម"]។ ឯកសារ D114/48 កំណត់ហេតុស្តាប់ចម្លើយ សុខ ង៉ុន ឆ.14 ["ពេលដែលខ្ញុំទៅដល់កំពង់សោមដំបូង គេដាក់ខ្ញុំឱ្យទៅហ្វឹកហ្វឺនកងទ័ពជើងទឹកនៅក្រុងកំពង់សោម។ ពេលខ្លះយើងត្រូវបានគេបញ្ជូនទៅហាត់រៀននៅនឹងឆ្នេរអូរឈើទាល"]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត ឆ.39-40 ["ខ្ញុំមិនដែលទៅទីបញ្ជាការដ្ឋានកងពល១៦៤ទេ តែខ្ញុំធ្លាប់ចូលរួមប្រជុំដែលរៀបចំដោយកងពល១៦៤នៅឆ្នេរអូរឈើទាល [...] ស៖ តើវគ្គបណ្តុះបណ្តាលនោះធ្វើជាញឹកញាប់ដែរឬទេ? ឆ.40៖ ធ្វើជារៀងរាល់ឆ្នាំ"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.16 ["នៅពេលនោះ គេផ្តើមរៀបចំកងទ័ពជើងទឹក ពេលនោះគេបញ្ជូនពួកខ្ញុំឱ្យទៅធ្វើការហ្វឹកហ្វឺននៅអូរឈើទាល"]។ ឯកសារ D114/286 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត (ប៉ាង រ៉េត) ឆ.31 ["មានតែសំណង់មួយនៅអូរឈើទាល គេប្រើសម្រាប់អប់រំនយោបាយ"]។

លេខ ១៥ ឬ លេខ ១៦)[625] ត្រូវបានរៀបចំឡើងវិញជាកងវរៈសេនាធំលេខ ១៦១ លេខ ១៦២ និងលេខ ១៦៣[626] ដែលត្រូវបានហៅជាទូទៅថា កងវរៈសេនាធំលេខ ៦១ លេខ ៦២ និងលេខ ៦៣[627] ។ កងវរៈសេនាធំទាំងនោះទទួលខុសត្រូវក្នុងការការពារកោះនៅឆ្ងាយពីឆ្នេរ (កោះពូលូវៃ, កោះ

---

625 សូមមើលខាងលើ កថាខណ្ឌ ២១៣, ជើងទំព័រ ៥៨១។

626 សូមមើល ឧទាហរណ៍ ឯកសារ D2/8 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.43 ["ពេលមកដល់កំពង់សោមគេប្រាប់គេថាកងពលលេខ៣ ដូរទៅហៅថា កងពល១៦៤ ហើយវរៈសេនាធំលេខ២០ ដូរទៅ១៦១ វរៈសេនាធំលេខ២១ ដូរទៅ១៦២ និងវរៈសេនាធំលេខ២២ ដូរទៅលេខ១៦៣"]។ ឯកសារ D22.2.181 បទសម្ភាសន៍ជាមួយ មាស មុត ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០១ EN ERN 00249698, KH ERN 00742001-02 ["នៅចុងឆ្នាំ ១៩៧៥ កងពលធំលេខ ៣ ត្រូវបានរៀបចំរចនាសម្ព័ន្ធទៅជាកងពលធំលេខ ១៦៤"]។ EN ERN 00249699, KH ERN 00742002 ["កងវរៈសេនាធំត្រូវបានរៀបចំសាជាថ្មី។ កងវរៈសេនាធំលេខ ១៤ បានក្លាយទៅជាកងវរៈសេនាធំលេខ ៦១ ហើយកងវរៈសេធំលេខ ១៥ បានក្លាយជាកងវរៈសេនាធំលេខ ៦២ ចំណែកឯកងវរៈសេនាធំលេខ ១៦ បានក្លាយជាកងវរៈសេនាធំលេខ ៦៣"]។ ឯកសារ D4.1.750 បទសម្ភាសន៍ជាមួយ ជនមិនស្គាល់អត្តសញ្ញាណ ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387279, KH ERN 01496679 ["កងវរសេនាធំលេខ ២០ បានក្លាយជាកងវរសេនាធំលេខ ៦១។ កងវរសេនាធំលេខ ២១ បានក្លាយជាកងវរសេនាធំលេខ ៦២"]។ ឯកសារ D114/286 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត (ប៉ាង រ៉េត) ឆ.21 ["ខ្ញុំទើបតែនឹកឃើញថាមានកងវរសេនាធំលេខ២០ ២១ និង២២ ហ្នឹងមែន។ វរសេនាធំលេខ២០ ក្លាយជាវរសេនាធំ១៦១, ២១ ទៅជាវរសេនាធំ១៦២, ២២ ទៅ [១៦៣]"]។

627 ឯកសារ D22.2.4 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៦។ ឯកសារ D22.2.5 របាយការណ៍ស្ថិតិរបស់អង្គភាពកងពលធំលេខ ១៦៤ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ ដោយ មាស មុត នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦។ ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ ដោយ មាស មុត នៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦។ ឯកសារ D2/8 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.43 ["គេប្រាប់គេថាកងពលលេខ៣ ដូរទៅហៅថា កងពល ១៦៤ ហើយវរៈសេនាធំលេខ២០ ដូរទៅ១៦១ វរៈសេនាធំលេខ២១ ដូរទៅ១៦២ និងវរៈសេនាធំលេខ២២ ដូរទៅលេខ ១៦៣។ ប៉ុន្តែពេលនោះគេអត់ហៅ១០០ខាងដើមទេ គេហៅតែ៦១, ៦២, ៦៣"]។ ឯកសារ D54/111 កំណត់ហេតុស្តាប់ចម្លើយ សំ ភីន ឆ.6 ["នៅក្នុងកងពល១៦៤ មានកវរៈសេនាធំលេខ៦១, ៦២, ៦៣"]។ ឯកសារ D114/287 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត (ប៉ាង រ៉េត) ឆ.38 ["កង៤៥០ជាវរសេនាតូចឯករាជ្យ។ ហើយការទាក់ទងរបស់វាគឺត្រូវទាក់ទងនឹងកងពលផ្ទាល់ ប្រជុំជាមួយកងវរសេនាធំ៦១ ៦២ ៦៣ ពេលទៅប្រជុំមានឋានៈស្មើគ្នាដែរ"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.28 ["នៅពេលកងពលលេខ៣ ប្តូរទៅជាកងពល១៦៤ នៅកំពង់សោម [...] កងពល១៦៤ រួមមានកងវរសេនាធំ៦១, ៦២, ៦៣ និង១៤០។ កងវរសេនាធំ៦១, ៦២ និង៦៣ មានភារកិច្ចការពារតាមឆ្នេរសមុទ្រ និងកោះ។ កងវរសេនាធំ១៤០ គ្រប់គ្រងនាវាទាំងអស់"]។ ឯកសារ D114/283 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.43។

តាង, កោះព្រីង, កោះរុង, កោះរុងសន្លឹម, កោះសេះ, កោះថ្មី និងកោះតូចៗមួយចំនួនផ្សេងទៀត) ក៏ដូចជាតំបន់ដីគោក (កងកេង, រាម, ទឹកសាប, ស្ទឹងហាវ, ក្រុងកំពង់សោម និងស្ពានីយ៍រ៉ាដាចម្ងាយឆ្ងាយនៅលើភ្នំបូកគោនៅជិតកំពត)[628]។ នៅខែ សីហា ឆ្នាំ ១៩៧៥ បន្ទាប់ពីកងពលធំលេខ ៣ បានក្លាយជាកងពលធំមជ្ឈិមលេខ ១៦៤ អង្គភាពកងទ័ពជើងទឹកឯករាជ្យមួយ ដែលហៅថាកងវរៈសេនាធំលេខ ១៤០ ក៏ត្រូវបានបង្កើតជាផ្លូវការផងដែរ និងមានកងទ័ពជើងទឹក*ពិសេស* (Navy *sensustricto)* [629]។ ក្នុងនាមជាមេបញ្ជាការកងពល **មាស មុត** បានធ្វើជាអធិបតីនៃកិច្ចប្រជុំយ៉ាងទៀងទាត់រវាងមេបញ្ជាការកងវរៈសេនាធំចំនួនបួន និងបណ្ដាកងវរៈសេនាតូចឯករាជ្យនានា[630]។

---

628 ឯកសារ D22.2.181 បទសម្ភាសន៍ជាមួយ មាស មុត ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០១ EN ERN 00249699, KH ERN 00742002 ["កងពលធំនេះ រក្សាទាហានឲ្យឈរជើងនៅតំបន់កំពង់សោម និងរាម និងកោះពូឡូវៃ [...] កោះព្រីង [...] កោះតាង [...] កោះរ៉ូងសន្លឹម និងកោះសេះ"]។ ឯកសារ D132.1.85 របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យពី មាស មុត ជូន សុន សេន (បង ៨៩) ចុះថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៧៦ [ពិភាក្សាអំពីការដាក់ពង្រាយយោធាកងពលធំលេខ ១៦៤ នៅលើកោះសេះ កោះថ្មី កោះសំពោច កោះរាម និងវត្តមានរបស់ មាស មុត នៅកោះរុង និងកោះរុងក្រៅ ក្នុងពេលដែលធ្វើរបាយការណ៍នេះ]។ ឯកសារ D114/282 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.14, 21 ["នៅកោះសេះ វរៈ៣៨៦ មានពីរអនុសេនាតូច ហើយកងពលលេខ៣ មានពីរអនុសេនាតូច គេលាយគ្នា [...] ឆ.21៖ កងតំបន់ [៣៧] និងកងទី៣ បញ្ជូនទៅកោះពូលូវៃ កោះពូលូវៃថ្មី កោះពូលូវៃចាស់ កោះរុងសន្លឹម និងកោះរុងធំ ហើយនិងកោះម្នាស់ និងកោះតាង។ រួចកម្លាំងនៅសល់ប៉ុន្មានទៅដីគោក និងនៅលើកប៉ាល់ទាំងអស់"]។ ឯកសារ D54/98 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាង រ៉េត ឆ.28 ["កងវរសេនាធំ៦១, ៦២ និង៦៣ មានភារកិច្ចការពារតាមឆ្នេរសមុទ្រ និងកោះ"]។ ឯកសារ D114/286 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាង រ៉េត (ប៉ាង រ៉េត) ឆ.16 [កងភ្នំបូកគោនេះ "កងហ្នឹងគ្រប់គ្រងប្រព័ន្ធរ៉ាដាសមុទ្រ"]។

629 ឯកសារ D54/47 កំណត់ហេតុស្ដាប់ចម្លើយ អែម សុន ឆ.18-19 ["នៅខែសីហា ឆ្នាំ១៩៧៥ កងពលថ្មី១៦៤ ត្រូវបានបង្កើតឡើង [...] ឆ.19៖ គឺមានឈ្មោះ មឿន ម៉ុន [...] មេបញ្ជាការអនុសេនាធំ និងឈ្មោះ ហេង ហុក ដែលជាមេបញ្ជាការកងអនុសេនាធំ ដែលស្ថិតនៅក្នុងកងវរសេនាតូច៤៨០។ ពួកគេបានប្រាប់ខ្ញុំថា កងពលធំលេខ៣បានប្ដូរទៅជាកងពលធំលេខ១៦៤ ហើយក៏មានការបង្កើតនូវកងពលតូចមួយទៀតដែរ គឺកងពលតូចលេខ១៤០ ដែលជាកងជើងទឹក"]។ ឯកសារ D4.1.758 បទសម្ភាសន៍ជាមួយ ជនមិនស្គាល់អត្តសញ្ញាណ ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387312, KH ERN 01506014 ["កងវរៈសេនាធំលេខ១៤០ នៃកងទ័ពជើងទឹក៖ នៅអំឡុងខែ សីហា ឆ្នាំ ១៩៧៥ កងពលធំលេខ១៦៤ (កងពលធំលេខ៣) បានបង្កើតកងវរៈសេនាធំលេខ១៤០ នៃកងទ័ពជើងទឹក។ កងវរៈសេនាធំនេះមាន ២ ផ្នែក៖ អង្គភាពកងទ័ពជើងទឹក និងអង្គភាពកងទ័ពថ្មើរជើងនៃកងទ័ពជើងទឹក"]។ ឯកសារ D114/95 កំណត់ហេតុស្ដាប់ចម្លើយ យឹម ស្រឿង ឆ.38 ["នៅឆ្នាំ១៩៧៦ គេបានបង្កើតវរសេនាធំ១៤០ គឺជាអង្គភាពជើងទឹក។ ចំណែកវរសេនាធំលេខ៦១ ៦២ ៦៣ គេទៅនៅតាមកោះ"]។ ឯកសារ D114/65 កំណត់ហេតុស្ដាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.16 ["នៅចុងបញ្ចប់ ការរៀនសូត្រ ប្រហែលជាខែមករា ឬកុម្ភៈ ឆ្នាំ១៩៧៦

218. កងវរៈសេនាធំនីមួយៗក្នុងកងពលធំលេខ ១៦៤ មានកងវរៈសេនាតូចយ៉ាងហោចណាស់បី (ជាទូទៅ កងវរៈសេនាតូចនីមួយៗ មានសមាជិកជាង ៣០០ នាក់) កងវរៈសេនាតូចនីមួយៗមានកង

---

មាស មុត បានប្រកាសការរៀបចំកងជើងទឹក ហៅថា វរៈសេនាធំ១៤០"]។ ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.16 ["ប៉ុន្តែនៅពេលនោះមានការរៀបចំកងទ័ពជើងទឹក។ គឺគេរើសចេញពីកងវរៈសេនាធំ៦១ ៦២ ៦៣ របស់កងពល១៦៤ រៀបចំទៅជាកង១៤០ ដោយមានបញ្ចូលកងវរៈសេនាធំដែលបញ្ជូនមកពីបូព៌ា ដែលហៅថាកង ១៤០"]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968419, KH ERN 00926644 ["ដល់រំដោះហើយបានយូរតិចនឹង បានគេបង្កើតវរសេនាធំនែក! ខាងនាវានឹងដាក់ ១៤០"]។ ឯកសារ D54/38.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ លន់ សេង EN ERN 01072382, KH ERN 00967309 ["កងពលគាត់ទទួលកងពលរួម ប៉ុនកងពលនឹងគេមានអង្គភាពនាវាចម្បាំង គេហៅថាវរសេនាធំលេខ១៤០"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.36 ["គាត់ប្រាប់ខ្ញុំថា គាត់នៅក្នុងកងជើងទឹកលេខ ១៤០"]។ ឯកសារ D4.1.762 បទសម្ភាសន៍ជាមួយ កាំ ម៉ែន (កាំ ម៉ែន) ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387328, KH 00742578 ["កងពលធំនេះ ក៏មានវរៈសេនាធំជើងទឹកលេខ ១៤០ ក្រោមឱវាទមួយផងដែរ"]។

630 ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.14-15 ["សម្រាប់សំណួរដែលថា អ្នកណាជាអ្នកដឹកនាំប្រជុំជាប្រចាំនៃមេបញ្ជាការវរៈសេនាធំនិងកងវរៈពិសេស គឺជាមេបញ្ជាការរបស់កងពលលេខ ៣/១៦៤។ [...] ឆ.15៖ មេបញ្ជាការគឺ មាស មុត"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.20 ["ខ្ញុំមិនដែលឃើញមនុស្សណា ដែលមានលក្ខណៈឬកពារដូច តាមុត ទេ។ គាត់តឹងរ៉ឹងណាស់។ គាត់តែងហៅបញ្ជាការវរៈសេនាធំ និងវរៈសេនាតូច ឲ្យទៅកន្លែងគាត់ ហើយទទួលបញ្ជាពីគាត់។ ពួកមេបញ្ជាការវរៈសេនាទាំងនោះ យល់ច្បាស់ណាស់ថា អ្វីដែលគេនឹងត្រូវធ្វើទៅតាមបញ្ជាការរបស់ តាមុត។ បើគេធ្វើតាមបញ្ជាគាត់ពុំមានជោគជ័យ គេនឹងមានបញ្ហាមិនខាន"]។ ឯកសារ D54/44 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.26, A28 [អំពីសេចក្តីប្រកាសដែលធ្វើឡើងដោយ មាស មុត អះអាងថា ទាហានភូមិភាគបូព៌ា ជាទាហានដែលមានសមាសភាពមិនល្អ]៖ "ការប្រកាសនោះត្រូវធ្វើឡើងនៅក្នុងកិច្ចប្រជុំពិសេសមួយដែលថ្នាក់ដឹកនាំផ្នែកវរសេនាតូច និងវរសេនាធំត្រូវបានគេជ្រើសរើសឲ្យមកចូលរួម។ [...] ឆ.28 ៖ ប្រធានកងពល មាស មុត ជាអ្នកណែនាំមេបញ្ជាការវរសេនាធំឲ្យធ្វើការតាមដានប្រវត្តិយោធារបស់ខ្លួនទៅដល់ស្រុកកំណើត"]។ ឯកសារ D114/19 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.16-17 ["ពេលខ្លះ តាឌឹម ជាអធិបតីក្នុងអង្គប្រជុំ ហើយពេលខ្លះតាមុតជាអធិបតីក្នុងអង្គប្រជុំ [...] ឆ.17៖ ពេលខ្លះការប្រជុំរួមមេបញ្ជាការវរៈសេនាតូច វរៈសេនាធំទាំងអស់ និងកងជើងទឹក ជើងគោករបស់កងពល១៦៤ តែពេលខ្លះខាងកងជើងទឹក និងកងជើងគោកប្រជុំផ្សេងពីគ្នា"]។ ឯកសារ D54/31 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.5 ["នៅពេលនោះទីបញ្ជាការដ្ឋានកងពលនិងផ្ទះរបស់មេបញ្ជាការកងពលគឺនៅជាមួយគ្នា។ រៀងរាល់ខែ ពួកគេបញ្ជាការវរៈសេនាធំនីមួយៗមកប្រជុំនៅទីនោះរៀងរាល់ថ្ងៃទី១០, ថ្ងៃទី២០ និង ថ្ងៃទី៣០"]។

អនុសេនាធំចំនួនបី ឬបួន (កងអនុសេនាធំនីមួយៗមានសមាជិកជាង ១០០ នាក់)[631] ហើយកងអនុសេនាធំនីមួយៗមានកងអនុសេនាតូចបី ឬបួន (កងអនុសេនាតូចនីមួយៗមានសមាជិកជាង ៣០ នាក់ និងរហូតដល់ ៥០ នាក់)[632] និងទាហានវិស្វករម្នាក់[633]។ កងអនុសេនាតូចនីមួយៗត្រូវបាន

---

631 ឧទាហរណ៍ កងវរៈសេនាតូចពីរ នៅក្នុងកងវរៈសេនាធំលេខ ៦២ មានបួនកងពល៖ ឯកសារ D4.1.759 បទសម្ភាសន៍ជាមួយ គង់ ចាយ ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387269, KH ERN 00658142 ["ក្រោយពេលមានការរៀបចំរចនាសម្ព័ន្ធជាថ្មី កងអនុសេនាធំនៃ កងវរៈសេនាតូចនេះ ត្រូវបានប្តូរឈ្មោះជា កងអនុសេនាធំលេខ៧ លេខ៨ លេខ៩ និងលេខ១០វិញ"]។ ឯកសារ D4.1.762 បទសម្ភាសន៍ជាមួយ កាំ ម៉ែន (កាំ ម៉ែន) ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម KH ERN 00742580 ["កងអនុសេនាធំលេខ៧ ៨ ៩ គឺជាកងអនុសេនាធំថ្មើរជើង ហើយកងអនុសេនាធំលេខ ១០ គឺជាកងអនុសេនាធំមានសមាសភាពពីបណ្ដាអង្គភាពផ្សេងៗ ដោយមានកងប្រតិបត្តិការពិសេស កាំភ្លើងធំ ផ្នែកទំនាក់ទំនង និងកងអនុសេនាតូចដឹកជញ្ជូន"]។ ឯកសារ D114/127 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គីម ហៅ រ៉េត ឆ.13 ["នៅក្រោមវរសេនាធំ៦២ មានវរសេនាតូច៦២១។ ក្រោមវរសេនាតូចនេះមានអនុសេនាធំចំនួនបួនគឺ អនុសេនាធំ១៥, ១៦, ១៧ និង១៨"]។ ឯកសារ D220/1.2.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ូ គីម ហៅ រ៉េត EN ERN 01375020, KH 01102508 ["វាមាន៤កងធំ"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ.21 ["កោះវែរ៍នេះ ជាកោះតូចទេ យើងដាក់ទ័ពតែមួយក្រុមទេ គឺមាន១២នាក់។ កោះព្រីង មានអនុសេនាធំដែលមានមនុស្សប្រហែល១២០នាក់"]។

632 ឧទាហរណ៍ ឯកសារ D4.1.759 បទសម្ភាសន៍ជាមួយ ម៉ៅ រ៉ាន់ ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម KH ERN 00658139 [នៅក្នុងកងវរៈសេនាតូច ៤១០/៦២១ "កងអនុសេនាធំលេខ៨ ត្រូវបានបង្កើតទៅជាកងអនុសេនាតូចលេខ២១ លេខ២២ និងលេខ២៣។ [...] កងអនុសេនាធំលេខ៩ មានកងអនុសេនាតូចចំនួនបីជាចំណុះគឺ កងអនុសេនាតូចលេខ២៤ លេខ២៥ និងលេខ២៦។ [...] កងអនុសេនាធំលេខ១០ មានកងអនុសេនាតូចចំនួនបីជាចំណុះគឺ កងអនុសេនាតូចលេខ២៤ លេខ២៩ និងលេខ៣០"]។ ឯកសារ D4.1.762 បទសម្ភាសន៍ជាមួយ កាំ ម៉ែន (កាំ ម៉ែន) ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387329, KH ERN 00742580 ["កងអនុសេនាធំនីមួយៗ មានកងអនុសេនាតូចចំនួនបួន ហើយកងអនុសេនាធំនីមួយៗមានបួនក្រុម"]។

633 ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.133 ["តាមធម្មតាផែនការ គឺមកពីកងវរយ រួចចេញមកកងហា ទើបកងហាប្រាប់ទៅតាមមេក្រុមមួយៗតទៅទៀត"]។ ឯកសារ D114/132 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ រ៉ាន់ ឆ.38 [មួយក្រុមដែលមានទាហាន១៥នាក់]។ ឯកសារ D114/57 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ កេត ឆ.4 ["ខ្ញុំធ្វើជាប្រធានក្រុម ដែលមានសមាជិកជាយោធា១២នាក់"]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.28-29 ["បីកងអនុសេនាធំ។ ក្នុងមួយកងអនុសេនាធំ មានបីអនុសេនាតូច។ [...] ឆ.29៖ ក្នុងមួយអនុសេនាតូចមានបីក្រុមតូចៗទៀត [១២នាក់]"]។ ឯកសារ D4.1.746 បទសម្ភាសន៍ជាមួយ សំ សុក ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387462, KH ERN 00742596 ["កងវរៈសេនាធំនីមួយៗមាន ៣ កងអនុសេនាតូច ហើយកងវរៈសេនាតូចនីមួយៗមាន ៣ កងអនុសេនាធំ"]។ ឯកសារ D54/87

បែងចែកទៅជាបីក្រុម ដែលក្រុមនីមួយៗមានចំនួនពី ១០ ដល់ ១២ នាក់[634]។ កងវរៈសេនាធំលេខ ៦៣ មានកងវរៈសេនាតូច លេខ ៦១១ លេខ ៦១២ និង ៦១៣ ជាចំណុះ[635]។ កងវរៈសេនាតូច លេខ ៦២១ លេខ ៦២២ លេខ ៦២៣ និងប្រហែលជាលេខ ៦២៤ ស្ថិតក្រោមកងវរៈសេនាធំលេខ ៦២[636]។ កងវរៈសេនាធំលេខ ៦៣ មានកងវរៈសេនាតូចលេខ ៦៣១ លេខ ៦៣២ និងលេខ

---

កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត ឆ.32 ["សៈ លោកបាននិយាយថា កងពល១៦៤ មានសមាជិកកងទ័ពចន្លោះពី ៧០០០នាក់ទៅ៩០០០នាក់ តើលោកផ្អែកលើមូលដ្ឋានអ្វី បានជាលោកប៉ាន់ស្មានបែបនេះ? ឆ.32៖ តាមការសន្និដ្ឋានរបស់ខ្ញុំគឺផ្អែកលើចំនួនកងទ័ពក្នុងកងវរៈសេនាធំ ដែលកងវរៈសេនាធំនីមួយៗមាន៤វរៈសេនាតូច"]។

634 ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.39, 41-42 ["មួយក្រុមមាន ១០ ទៅ ១២នាក់ ហើយមួយកងហា មានបីក្រុម ហើយមួយកងរយ មានបីកងហា [...] ឆ.41៖ បីកងរយ បានមួយវរសេនាតូច [...] ឆ.42៖ មួយកងរយឬ? បីកងរយ បានមួយវរសេនាតូច។ ហើយបីវរសេនាតូច បានមួយកងវរសេនាធំ"]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.29 ["ក្នុងមួយអនុសេនាតូចមានបីក្រុមតូចៗទៀត"]។ ឯកសារ D4.1.746 បទសម្ភាសន៍ជាមួយ សំ សុក ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387462 ["កងអនុសេនាតូច ត្រូវបានបែងចែកជា ៣ ក្រុម ដែលក្រុមនីមួយៗមានសមាជិក ១២នាក់"]។

635 ឯកសារ D114/230.1.1 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស លេខរៀង ១៣១៥៥ [សេក ផេង អនុលេខាកងវរៈសេនាតូច ៦១៣] លេខរៀង ៨៦១៨ [សឹង គ្រិន ហៅ ងួន ជាមេបញ្ជាការកងអនុសេនាធំ ក្នុងកងវរសេនាតូចលេខ ៦១១]។ ឯកសារD4.1.1070 សម្រង់ចម្លើយសារភាពរបស់ សឹង គ្រិន ហៅ ងួន។ ឯកសារ D1.3.10.1 បញ្ជីឈ្មោះមនុស្សដែលត្រូវបានបញ្ចូលក្នុងចម្លើយសារភាពរបស់ខ្មាំង EN ERN 001408058-60, KH ERN 000161751-53 [បញ្ជីកងវរសេនាតូច ១៦១ កងវរសេនាធំ ១៦១ កពល ១៦៤]។ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.16-17, 23 ["គេក៏បានដកខ្ញុំពីកងវរសេនាតូចកាំភ្លើងធំ ឲ្យទៅស្ទឹងហាវ [...] ឆ.17៖ កងវរសេនាតូចលេខ ៦១២ [...] ឆ.23៖ នៅវរសេនាតូច៦១២ តួនាទីរួមមាន ខួងថ្ម បំបែកថ្ម និងលើកថ្មមកបាំងនៅការដ្ឋាន និងធ្វើការងារផ្សេងទៀត"]។ ឯកសារ D54/83 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.38 ["មានបួនកងវរៈសេនាតូចនៅក្នុងកងវរៈសេនាធំ៦១។ មានតែបីវរៈសេនាតូចដែលផ្ទេរទៅបោះទីតាំងនៅស្ទឹងហាវ។ ខ្ញុំមិនដឹងអំពីកងវរៈសេនាតូចផ្សេងទៀតទេ តែសម្រាប់កងវរៈសេនាតូចរបស់ខ្ញុំគឺទៅរៀនបច្ចេកទេស។ កងវរៈសេនាតូចរបស់ខ្ញុំលេខ៤១២ ឬ៣១២ ព្រោះខ្ញុំចាំមិនសូវច្បាស់ទេ" (សង្កត់ន័យបន្ថែម)]។

636 ឯកសារ D114/283 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.43 ["នៅវរៈ៦២ មានវរៈសេនាតូចតូច ៦២១, ៦២២, និង ៦២៣"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.3 ["នៅពេលនោះខ្ញុំនៅកងវរៈសេនាតូច៦២៣"]។ ឯកសារ D114/57 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ កេត ឆ.3 ["ខ្ញុំស្ថិតនៅក្នុងកងវរៈសេនាធំលេខ២១ កងវរៈសេនាតូច៦២៣។ ក្រោយមកកងវរៈសេនាធំលេខ២១ ប្តូរឈ្មោះទៅជាកងវរៈសេនាធំលេខ៦២ វិញ"]។ ឯកសារ D54/20 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ សំ កេត ឆ.2 ["ខ្ញុំឋិតនៅក្នុងកងវរៈសេនាធំ២១ កងវរៈសេនាតូច ៦២៣"]។ ឯកសារ D4.1.746 បទសម្ភាសន៍ជាមួយ សំ សុក ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387462, KH ERN 00742597 ["កងវរៈសេនាធំលេខ ៦២ [...] ត្រូវបានបែងចែកទៅជា

៦៣៣[637]។ កងវរៈសេនាធំលេខ ១៤០ (កងទ័ពជើងទឹក) មានកងវរៈសេនាតូចចំនួនបួន គឺលេខ ១៤១ លេខ ១៤២ លេខ ១៤៣ និងលេខ ១៤៤[638]។ លើសពីនេះទៀត មានកងវរៈសេនាតូចឯក

---

៣ កងវរៈសេនាតូច រួមមាន កងវរៈសេនាតូចលេខ ២១ ២២ និងលេខ ២៣"]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968386, KH ERN 00926614 ["ស៖ កោះ ៦២១ ៦២២ ៦២៣ តែ៣ទេ ក្នុងវរសេនាធំ? ឆ៖ ៦៤២មួយទៀត ឈ្មោះជុំ"]។ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស លេខរៀង ៤១៥៩ [ណុប នន លេខាកងវរសេនាតូចលេខ៦២១]។ ឯកសារ D114/126 កំណត់ហេតុស្ដាប់ចម្លើយ អ៊ូ គីម ឆ.7 ["ខ្ញុំធ្វើការនៅក្នុងកងអនុសេនាធំលេខ១៥ ដែលមានមេបញ្ជាការឈ្មោះ ហាន នៃកងវរសេនាតូច៦២១ កងវរសេនាធំ៦២"]។ ឯកសារ D54/78 កំណត់ហេតុស្ដាប់ចម្លើយ ណុប ហាល់ ឆ.8, 9, 14 ["ខ្ញុំទៅនៅកងវរៈសេនាតូច ៦២៤ ក្រោមកងវរៈសេនាធំ៦២ [...] កាលនោះ ខ្ញុំវាមិនច្បាស់មិនដឹងថា កងវរៈសេនាតូច៦២១ ឬ៦២៣ ដែលគេបញ្ជូនទៅចាប់នោះ [...] ស៖ តើការយល់របស់ខ្ញុំត្រឹមត្រូវដែរឬទេថា នៅពេលលោកនិយាយអំពីកងវរៈសេនាតូច៦២១, ៦២២, ៦២៤ គឺលោកសំដៅទៅលើកងវរៈសេនាធំ៦២ នៃកងពល១៦៤មែនឬទេ? ឆ.9៖ បាទ ត្រឹមត្រូវ [...] ឆ.14៖ ខ្ញុំនៅក្នុងកងវរៈសេនាតូច៦២២ នៃវរៈសេនាធំ៦២។ វរៈសេនាតូចខ្ញុំមានទូក២គ្រឿង, កងវរៈសេនាតូច៦២១ មានទូក២គ្រឿង, កងវរៈសេនាតូច ៦២៣ មានទូក១គ្រឿង"]។ ឯកសារ D114/113 កំណត់ហេតុស្ដាប់ចម្លើយ កឹម ម៉េន ឆ.44 [ដែលបានបង្ហាញថាកងវរសេនាតូចលេខ ៦២២ និង ៦២៣ មានដើមកំណើតមកពីតំបន់៣៣]។

637 ឯកសារ D114/283 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.52 ["៦៣ មានវរសេនាតូចចាប់ផ្ដើមពី ៣១, ៣២, ៣៣ (៦៣១, ៦៣២, ៦៣៣)។ ចំណែកវរសេនាធំ ៦២ មាន ៦២១, ៦២២, ៦២៣"]។ ឯកសារ D54/104 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.3 ["វ៉េត គឺជាប្រធានវរៈសេនាតូច៦៣១"]។ ឯកសារ D54/41 កំណត់ហេតុស្ដាប់ចម្លើយ អ៊ូ សាវ៉ាន់ (អ៊ូ សាវ៉ាន់) ឆ.16, 20 ["ខ្ញុំស្ថិតនៅក្នុងកងអនុសេនាធំលេខ៣ វរសេនាតូចលេខ៦៣១ វរសេនាធំលេខ៦៣។ [...] ឆ.20៖ ខ្ញុំមិនច្បាស់ថាកងវរសេនាតូចលេខ៦៣២ ឬ៦៣៣ ទេ ដែលមកជំនួសវរសេនាតូចរបស់ខ្ញុំនៅកងកេង"]។ ឯកសារ D1.3.1.2 ចម្លើយសារភាពនៅមន្ទីរស-២១ របស់ គង់ គៀន ហៅ អ៊ឹង វ៉េត ចុះថ្ងៃទី ៧ ខែ ឧសភា [លេខាវរៈសេនាតូច៦៣១]។ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស លេខរៀង ២៣៦៨ [គង់ គៀន ហៅ អ៊ុង ឬ អ៊ឹង វិត កងវរសេនាតូចលេខ ៦៣១]។

638 ឯកសារ D114/65 កំណត់ហេតុស្ដាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.16 ["នៅក្នុងវរៈសេនាធំ១៤០នោះ គេបានរៀបចំជាបួនវរៈសេនាតូច គឺវរៈសេនាតូច១៤១, ១៤២, ១៤៣ និង១៤៤"]។ ឯកសារ D114/286 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាង វ៉េត (ប៉ាង វ៉េត) ឆ.10 ["គេរើសយកតាមវរសេនាធំ ប៉ុន្មានរយៗនាក់ ទៅជាកងវរសេនាធំ១៤០ទៅគ្រប់គ្រងកប៉ាល់ វាមាន៤វរសេនាតូច។ មាន៤វរសេនាតូច ១៤១, ១៤២, ១៤៣, ១៤៤"]។ ឯកសារ D114/66 កំណត់ហេតុស្ដាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.2 ["មឿន គឺជាមេបញ្ជាការវរៈសេនាតូច១៤១ ដែលស្ថិតនៅក្នុងកងជើងទឹកវរៈសេនាធំ១៤០"]។ ឯកសារ D54/87 កំណត់ហេតុស្ដាប់ចម្លើយ ព្រុំ សាវ៉ាត ឆ.29, 32 ["ខ្ញុំស្ថិតនៅក្នុងកងវរៈសេនាធំ១៤០ ដែលមាន ៤វរៈសេនាតូច គឺកងវរៈសេនាតូច ៤១, ៤២, ៤៣ និង ៤៤។ [...] ឆ.32៖ តាមការសន្និដ្ឋានរបស់ខ្ញុំគឺផ្អែកលើចំនួនកងទ័ពក្នុងកងវរៈសេនាធំ ដែលកងវរៈសេនាធំទីមួយៗមាន៤វរៈសេនាតូច។ ដូចជាកងវរៈសេនាធំ១៤០របស់ខ្ញុំ មានកង

វាជ្យចំនួនប្រាំមួយ ដែលត្រូវបានដាក់ឲ្យស្ថិតក្រោមអំណាចផ្ទាល់របស់ **មាស មុត** និងគណៈកម្មាធិការកងពលធំលេខ ១៦៤ របស់គាត់ ៖ កងវរៈសេនាតូចលេខ ១៦៥ (អតីតកងវរៈសេនាតូចពិសេសលេខ ៤៥០) លេខ ១៦៦ លេខ ១៦៧ លេខ ១៦៨ លេខ ១៦៩ និងលេខ ១៧០[639]។ ស្រដៀងគ្នានឹងកងពលធំលេខ ៣ ដែរ (*សូមមើលផ្នែកខាងលើ* កថាខណ្ឌ ២០៩) ការបញ្ជា និងរបាយការណ៍ត្រូវបានទំនាក់ទំនងតាមរយៈ និងទៅគណៈកម្មាធិការកងពលធំលេខ ១៦៤ តាមរយៈខ្សែចង្វាក់នៃការបញ្ជា[640]។

---

ទ័ពចំនួន១៤០០នាក់"]។ ឯកសារ D114/85 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.28-29 ["[គុណ ខឹម] មកពីកងវរៈសេនាតូច១៤១ កងវរៈសេនាធំ១៤០។ គាត់មកពីតំបន់២២ ភូមិភាគបូព៌ាជាមួយ តាខឹម ដែរ។ [...] ឆ.29៖ [...] គាត់ស្ថិតនៅក្នុងកងវរៈសេនាតូច១៤១ ហើយខ្ញុំស្ថិតនៅក្នុងកងវរៈសេនាតូច១៤២ ក្រោមបញ្ជារបស់ឈ្មោះ សាង"]។ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស លេខរៀង ៣២២៣ [គុណ ខឹម អនុលេខាកងវរសេនាតូច ១៤១]។ លេខរៀង ៣៩៩៤ [គង់ ស៊ាន ហៅ សាន លេខាកងវរៈសេនាតូច លេខ១៤២] ឯកសារ D54/45 កំណត់ហេតុស្តាប់ចម្លើយ លុន សេង (លុន សេង) ឆ.24 ["កងវរសេនាធំ និងកងវរសេនាតូច ដែលនៅក្នុងកងវរសេនាធំចាប់ផ្តើមលេខពីរខាងដើមដូចគ្នា ឧទាហរណ៍ នៅក្នុងកងវរសេនាធំលេខ១៤០ មានវរសេនាតូចលេខ ១៤១, ១៤២, ១៤៣"]។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ហៅ ឆ.21 ["នៅជិតផែនោះ គឺជាទីបញ្ជាការដ្ឋានរបស់វរៈសេនាធំ ១៤០ ហើយនៅតាមបណ្តោយផ្លូវជិតឆ្នេរនោះក៏មានទីតាំងរបស់កវរៈសេនាតូច១៤១, ១៤២ដែរ។ ខ្ញុំមិនចាំច្បាស់ទីតាំងរបស់វរៈសេនាតូច១៤៣និង ១៤៤ទេ"]។

639 ឯកសារ D114/286 កំណត់ហេតុស្តាប់ចម្លើយ ប៊ាង រ៉េត (ប៊ាង រ៉េត) ឆ.13 ["១៦៥ សំដៅកងរបស់ខ្ញុំ គេហៅកងពិសេសរបស់កងពល។ ១៦៦ គឺជាកងកាំភ្លើងធំ។ ១៦៧ កងទ័ពនារី តែមួយវរសេនាតូចទេ និងជាកងឯករាជ្យ។ [...] ១៦៥ ដល់១៧០ គឺសុទ្ធតែកងរាជវាជ្យ។ ១៦៨ជាកងគ្រប់គ្រងឡាន សម្រាប់ដឹកជញ្ជូនឡាន។ ១៦៩ ជាអង្គភាពពេទ្យ។ ១៧០ ជាអង្គភាពជាង គ្រឿង សម្រាប់ធ្វើស្អី។ ១៦៨ និង១៦៩ ខ្ញុំអាចច្រឡំគ្នាថាមិនដឹងអាណា ជាអាណាមួយទេ ព្រោះវាយូរហើយ"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.19 ["ខ្ញុំដឹងថា កងវរៈសេនាធំ៦១, ៦២, ៦៣ គឺស្ថិតនៅក្រោមកងពលធំ១៦៤។ ១៦៥ ខ្ញុំគិតថាជាកងវរៈសេនាតូចពិសេស តែខ្ញុំមិនច្បាស់ទេ។ ១៦៦ គឺជាកងវរៈសេនាតូចទទួលបន្ទុកកាំភ្លើងធំ។ ១៦៧ គឺជាកងវរៈសេនាតូចរបស់ខ្ញុំ។ ១៦៨ គឺទំនងជាកងវរៈសេនាតូច ទទួលបន្ទុកផ្នែកដឹកជញ្ជូន។ ១៦៩ គឺជាកងវរៈសេនាតូចទទួលបន្ទុកផ្នែកពេទ្យ និង កងវរៈសេនាធំ១៤០ ទទួលបន្ទុកផ្នែកនាវា។ ខ្ញុំមិនចាំ ១៧០ ជាកងវរៈសេនាតូចទទួលបន្ទុកផ្នែកអ្វីនោះទេ"]។ ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ ដោយ មាស មុត នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦។

640 សូមមើល ឧទាហរណ៍ ឯកសារ D114/297.1.20 ប្រតិចារឹក ប្រាក់ សុខ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 11.03.07-11.05.06 ["បញ្ជាមកវរសេនាធំ កងពលបញ្ជាមកវរសេនាធំ។ វរសេនាធំបញ្ជាទៅវរសេនាតូច វរសេនាតូចបានបញ្ជាអ្នកយោធា អ្នកដែលធ្វើសកម្មភាព"]។ ឯកសារ D114/25 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដាវ ឆ.10 ["ពេលដែលយើងចាប់ទូកនេសាទថៃ ឧទាហរណ៍៖ ក្នុងនាមខ្ញុំជាបញ្ជាកងនៅក្នុងកងអនុសេនាតូច ខ្ញុំទទួលបញ្ជាពីមេ

219. យោងតាម **មាស មុត** ខ្លួនគាត់ផ្ទាល់ ចំនួនទាហានកងពលធំលេខ ១៦៤ មានចំនួនសរុបពី ១០.០០០ដល់ ១២.០០០ នាក់នៅចុងឆ្នាំ ១៩៧៥[641]។ ស្ថិតិកងកម្លាំងឈរជើងប្រចាំខែ ដែលមេបញ្ជាការ **មាស មុត** ផ្តល់ជូន សុន សេន បង្ហាញថា ចំនួនទាហានកងពលធំលេខ ១៦៤ មាន ៨.៧២៨ នាក់ក្នុងខែ ឧសភា ឆ្នាំ ១៩៧៦[642] ចំនួន ៨.៧១៦ នាក់ក្នុងខែ កក្កដា ឆ្នាំ ១៩៧៦[643] ចំនួន

---

បញ្ជាការអនុសេនាធំដែលទទួលបញ្ជាពីមេបញ្ជាការវរៈសេនាតូច ដែលទទួលបញ្ជាពីមេបញ្ជាការវរសេនាធំ ដែលទទួលបញ្ជាពីមេបញ្ជាការកងពល"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.25 ["បើយើងឃើញទូក ឬក៏កប៉ាល់នៅលើដែនទឹករបស់យើង យើងនឹងរាយការណ៍តាមវិទ្យុទាក់ទងទៅវរៈសេនាតូច ហើយបញ្ជាការដ្ឋានរបស់វរៈសេនាតូចរាយការណ៍ទៅឱ្យវរៈសេនាធំ។ វរៈសេនាធំរាយការណ៍បន្តទៅកងពល។ រួចហើយទើបកងពលបញ្ជាការតាមខ្សែរយៈត្រឡប់ចុះមកវិញ ថាតើយើងគួរធ្វើយ៉ាងម៉េចជាមួយទូក កប៉ាល់ ហើយនិងមនុស្សដែលយើងចាប់បាន។ ពេលនោះ កងវរសេនាតូចនឹងបញ្ជាមកយើង ថាតើយើងគួរសម្លាប់អ្នកដែលយើងចាប់នោះនៅសមុទ្រតែម្តង ឬយកឡើងមកកោះ"]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត ឆ.54, 60។

641 ឯកសារ D22.2.181 បទសម្ភាសន៍ជាមួយ មាស មុត ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០១ EN ERN 00249699, KH ERN 00742002-03 ["នៅចុងឆ្នាំ ១៩៧៥ កងពលធំលេខ ៣ ត្រូវបានរៀបចំរចនាសម្ព័ន្ធទៅជាកងពលធំលេខ ១៦៤ [...] នៅពេលបញ្ចប់ការរៀបចំរចនាសម្ព័ន្ធឡើងវិញនេះ កងពលធំលេខ ១៦៤ មានទាហានចំនួនប្រហែល ១២.០០០នាក់" (សង្កត់ន័យបន្ថែម)]។ ឯកសារ D22.2.180 ភ្នំពេញប៉ុស្តិ៍ មាស មុត៖ "ពួកយើងនៅក្នុងទ្រុងដូចថ្ងៃនេះអ៊ីចឹង" ២០ កក្កដា- ០២ សីហា ២០០១ EN 00161880 ["តើមានមនុស្សប៉ុន្មាននាក់នៅក្នុងកងពលរបស់លោក? មុត៖ ប្រហែលជាលើសពី ១០.០០០ នាក់"]។ សាក្សី ជេត ប៊ុណ្ណា បានិយាយអំពីទាហាន ១៨.០០០នាក់ ប៉ុន្តែគាត់ទំនងជារាប់បញ្ចូលទាំងប្រជាជនស៊ីវិលនៅក្នុងចំនួននេះផងដែរ៖ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.10 ["ខ្ញុំគិតថា មុខតំណែង មាស មុត ជាអនុរបស់សេនាធិការ គឺវាផ្ទុះបញ្ចាំងទៅនឹងការងារ ហើយនិងការទទួលខុសត្រូវរបស់គាត់ ដោយពេលនោះ គាត់មានយោធា១៨ពាន់នាក់ នៅក្រោមបញ្ជារបស់គាត់។ យោធាទាំងនោះ រួមមាន កងដែលនៅតាមកប៉ាល់ កងប្រយុទ្ធថ្មើរជើង កងដឹកជញ្ជូន ហើយនិងកងផ្សេងៗទៀត។ នៅក្រោមបញ្ជានិងការគ្រប់គ្រងរបស់គាត់ ក៏មានសភាពការណ៍របស់ប្រជាជនស៊ីវិលមួយចំនួនដែរ។ សហករណ៍ទាំងនោះរួមមាន: សហករណ៍ថ្មធំ អូរឬទ្ធ ឡូឥដ្ឋ ស្មាច់ដែង ពុតធឿង និងបបុស"]។ សូមមើលផងដែរ ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ ស៊ាង EN ERN 00217564 ["កងពលធំលេខ១៦៤ ទាំងមូលមានច្រើនជាង ១០.០០០នាក់"]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត ឆ.23, 32 [ចំនួនទាហានកងពលធំលេខ១៦៤ សរុបប្រមាណជា ៧.០០០នាក់ ទៅ ៩.០០០នាក់ រាប់បញ្ចូលទាំងកងវរៈសេនាធំលេខ១៤០ ចំនួន១.៤០០នាក់]។

642 ឯកសារ D22.2.2 របាយការណ៍ស្ថិតរបស់អង្គភាពកងពលលេខ ១៦៤ ចុះខែ ឧសភា ឆ្នាំ ១៩៧៦ EN ERN 00950653, KH ERN 00160102។

643 ឯកសារ D22.2.4 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល ១៦៤ នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៦ EN ERN 00950655, KH ERN 00160118។

៨.៨៨៧ នាក់ក្នុងខែ សីហា ឆ្នាំ ១៩៧៦[644] ចំនួន ៨.៦១១ នាក់ក្នុងខែតុលា ឆ្នាំ ១៩៧៦[645] ចំនួន ៨.៦៨៥ នាក់ក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៦[646] និងចំនួន ៨.៥៦៨ នាក់ ក្នុងខែ មីនា ឆ្នាំ ១៩៧៧[647]។ កងវរៈសេនាធំនីមួយៗនៃកងវរៈសេនាធំលេខ ៦១ លេខ ៦២ និងលេខ ៦៣ មានកងទ័ព ១.៤៥០ នាក់ ឬច្រើនជាងនេះ ខណៈដែលកងវរៈសេនាធំលេខ ១៤០ មានទាហានជាង ១.១៥០ នាក់[648]។

---

644 ឯកសារ D22.2.5 របាយការណ៍ស្ថិតិរបស់អង្គភាពកងពលធំលេខ ១៦៤ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៦ EN ERN 00950657, KH ERN 00160123 [ចុះក្នុងបញ្ជីមានទាហាន ៨.២៥៤នាក់ ដោយមិនរាប់បញ្ចូលទាហានចំនួន ៦៣៣នាក់ ដែលក្នុងនោះរួមមាន ទាហានពិការ និងក្មេងៗនៅចំការដូង ចំនួន៤០០នាក់ យុទ្ធជននិងកម្មាភិបាលនៅនៅឡឥដ្ឋ ចំនួន១៧៦នាក់ និងទាហានពិការ៥៧ផ្សេងទៀត]។

645 ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ ដោយ មាស មុត នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦ EN ERN 00233989។

646 ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ ដោយ មាស មុត នៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ EN ERN 00575531, KH ERN 00160071។ ឯកសារនេះត្រូវបានធ្វើការបញ្ជាក់ដោយ អែម សុន៖ ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.25 ["តាមការយល់របស់ខ្ញុំបញ្ជីនេះ [ឯកសារ D22.2.6] រៀបចំសម្រាប់ មាស មុត ហើយ មាស មុត សរសេរឈ្មោះរបស់គាត់។ ខ្ញុំស្គាល់អក្សរដៃរបស់ មាស មុត"]។

647 ឯកសារ D1.3.30.9 របាយការណ៍ស្ថិតិរបង់អង្គភាពកងពលលេខ ១៦៤ ចុះខែ មីនា ឆ្នាំ ១៩៧៧ EN ERN 00183956។ សូមមើលផងដែរ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត ឆ.23 ["ខ្ញុំអាចផ្តល់ជូនការប៉ាន់ស្មានបាន គឺមានចន្លោះពី៧០០០នាក់ ទៅ៩០០០នាក់ ចំនួននេះគឺរាប់បញ្ចូលទាំងកងនារីផងដែរ"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត (ប៉ាង រ៉េត) ឆ.29 ["នៅក្នុងកងពល១៦៤ គឺជាកងពលធំ មានយោធាប្រហែលជា៧០០០ ទៅ៨០០០នាក់"]។

648 ទោះបីជាមានចំនួនលេខនៅក្នុងតារាងផ្សេងៗទាំងនោះមានកំហុសក៏ដោយ ក៏លទ្ធផលមិនបានឆ្លុះបញ្ចាំងលើចំនួនបន្ថែមដែរ (សូមមើល ឧទាហរណ៍ ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ ដោយ មាស មុត នៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ EN ERN 00575528, KH ERN 00160068 ["មូលហេតុលើសមកពីកងរាយមិនអស់"]។ នេះជារបាយការណ៍សរុបពី មាស មុត ឬ គណៈកងពលធំរបស់គាត់៖ ឯកសារ D22.2.4 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៦ EN ERN 00950655, KH 00160118 [កងវរសេនាធំលេខ៦១: ១.៤៩៦នាក់, កងវរសេនាធំលេខ៦២: ១.៧៨៤នាក់, កងវរសេនាធំលេខ៦៣: ១.៥៩៩នាក់, កងវរសេនាធំលេខ១៤០: ១.៩១១នាក់]។ ឯកសារ D22.2.5 របាយការណ៍ស្ថិតិរបស់អង្គភាពកងពលធំលេខ ១៦៤ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៦ EN ERN 00950657, KH ERN 00160123 [កងវរសេនាធំលេខ៦១: ១.៤៨៧, កងវរសេនាធំលេខ៦២: ១.៧៦៤, កងវរសេនាធំលេខ៦៣: ១.៥៩៩, កងវរសេនាធំលេខ១៤០: ១.១៩២ (ដោយមិនរាប់បញ្ចូលទាហានពិការ និងក្មេងៗនៅចំការដូង ចំនួន៤០០នាក់ យុទ្ធជន និងកម្មាភិបាលនៅឡឥដ្ឋ ចំនួន១៧៦នាក់ និងទាហានពិការ៥៧នាក់ផ្សេងទៀត)]។ ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ ដោយ មាស មុត នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦ [កងវរៈសេនាធំលេខ៦១: ១.៤៦០នាក់, កងវរៈសេនាធំលេខ៦២: ១.៧២៧

ចំពោះកងវរៈសេនាតូចឯករាជ្យនានា ចំនួនកងទ័ពមានភាពខុសគ្នាដោយមានចាប់ពី ២៤១ រហូតដល់ ៨៤១ នាក់ ដោយយោងតាមកងវរៈសេនាតូចដែលពាក់ព័ន្ធ និងអំឡុងពេល[649]។ របាយការណ៍ប្រចាំខែ មីនា ឆ្នាំ ១៩៧៧ បង្ហាញថា កងទ័ពកងពលធំលេខ ១៦៤ មានចំនួនច្រើនជាងកងពលធំមជ្ឈិមរបស់ ក.ប.ក ផ្សេងទៀត ដោយមានចំនួនកងទ័ពពី ៣.៥២៨ ដល់ ៦.០៩៦ នាក់[650]។ ភាព

នាក់, កងវរៈសេនាធំលេខ៦៣: ១.៥៦៥នាក់, កងវរៈសេនាធំលេខ៦៤: ១.១៥៤នាក់]។ ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ ដោយ មាស មុត នៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ EN ERN 00575531, KH ERN 00160071 [កងវរៈសេនាធំលេខ៦១: ១.៤៤៩នាក់, កងវរៈសេនាធំលេខ៦២: ១.៧០៣នាក់, កងវរៈសេនាធំលេខ៦៣: ១.៥៦៦នាក់, កងវរៈសេនាធំលេខ១៤០: ១.១៩៧នាក់]។

649 ឯកសារ D22.2.4 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៦ EN ERN 00950655, KH ERN 00160118 [កងវរសេនាតូចលេខ១៦៥: ២៦៥នាក់, កងវរសេនាតូចលេខ១៦៦: ២៤៣នាក់, កងវរសេនាតូចនារី១៦៧: ៣៩១នាក់, កងវរសេនាតូចលេខ១៦៩: ៣៨០នាក់, កងវរសេនាតូចលេខ១៧០: ៣២០នាក់]។ ឯកសារ D22.2.5 របាយការណ៍ស្ថិតិរបស់អង្គភាពកងពលធំលេខ ១៦៤ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៦ EN ERN 00950657, KH 00160123 [កងវរសេនាតូចលេខ១៦៥: ២៥៤, កងវរសេនាតូចលេខ១៦៦: ២៤១, កងវរសេនាតូចលេខ១៦៦: ២៤១, កងវរសេនាតូចនារីលេខ១៦៧: ៣៩១, កងវរសេនាតូចលេខ១៦៨: ៧២៩, កងវរសេនាតូចលេខ១៦៩: ៣៧៩, កងវរសេនាតូចលេខ១៧០: ២២៥ (ដោយមិនរាប់បញ្ចូលទាហានពិការ និងក្មេងៗនៅចំការដូងចំនួន៤០០នាក់ យុទ្ធជន និងកម្មាភិបាលនៅឡឥដ្ឋ ចំនួន១៧៦នាក់ និងទាហានពិការ៥៧នាក់ផ្សេងទៀត)]។ ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ ដោយ មាស មុត នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦ [កងវរៈសេនាតូចលេខ១៦៥: ២៦៥នាក់, កងវរៈសេនាតូចលេខ១៦៦: ២៤១នាក់, កងវរៈសេនាតូចនារីលេខ១៦៧: ៤៣៤នាក់, កងវរៈសេនាតូចលេខ១៦៨: ៨១៣នាក់, កងវរៈសេនាតូចលេខ១៦៩: ៣០៥នាក់, កងវរៈសេនាតូចលេខ១៧០: ៣២០នាក់]។ ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ ដោយ មាស មុត នៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ EN ERN 00575531, KH ERN 00160071 [កងវរសេនាតូចលេខ១៦៥៖ ២៦៥នាក់, កងវរសេនាតូចលេខ១៦៦៖ ២៤១នាក់, កងវរសេនាតូចនារីលេខ១៦៧៖ ៤២៩នាក់, កងវរសេនាតូចលេខ១៦៨៖ ៨៤១នាក់, កងវរសេនាតូចលេខ១៦៩៖ ៣២០នាក់, កងវរសេនាតូចលេខ១៧០៖ ៣៤៧នាក់]។ បន្ថែមពីលើនេះ កងបូកគោ និងកង៤៧ បូកបញ្ចូលគ្នាមានយោធាជិត១៥០នាក់។ បន្ថែមពីនេះ អង្គភាពបូកគោ និងអង្គភាព៤៧ រួមបញ្ចូលទាហានជិត១៥០នាក់។

650 ឯកសារ D1.3.30.9 របាយការណ៍របស់កងទ័ពបដិវត្តកម្ពុជា ចុះថ្ងៃទី ៧ ខែ មេសា ឆ្នាំ ១៩៧៧ EN ERN 00183956 [កងពលលេខ៧០៣ (៥.៣៦៩កងទ័ព), កងពលលេខ៣១០ (៦.០៩៦កងទ័ព), កងពលលេខ៤៥០ (៥.២៥៩កងទ័ព), កងពលលេខ១៧០ (៥.៩៤៣កងទ័ព), កងពលលេខ៦៩០ (៤.៩០៦កងទ័ព), កងពលលេខ៣៥០២ (៥.៥៤៣កងទ័ព), កងពលលេខ៨០១ (៥.២៨៤កងទ័ព), កងពលលេខ៩[២]០ (៣.៥២៨កងទ័ព)]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.12 ["យើងក៏បានដឹងដែរថា កងជើងទឹកដែលស្ថិតនៅក្រោម មាស មុត គឺជាកងពលមួយដែលធំជាងគេបង្អស់ ក្នុងចំណោមកងពលទាំង២៥របស់ខ្មែរក្រហម"]។

ខុសគ្នានៃតួលេខដែលផ្តល់ដោយ **មាស មុត** ក្នុងបទសម្ភាសន៍ក្នុងឆ្នាំ ២០០១ និងតួលេខដែលគាត់បានរាយការណ៍ទៅ សុន សេន ក្នុងឆ្នាំ ១៩៧៦-១៩៧៧ អាចជាផ្នែកមួយនៃការបោសសម្អាតកងទ័ពកងពលធំលេខ ១៦៤ ដែលបានចាប់ផ្តើមនៅក្នុងឆ្នាំ ១៩៧៥ នៅពេលទាហាន ៤០០-៧០០ នាក់ ដែលកងទ័ពវៀតណាមបានចាប់ខ្លួន ត្រូវបានដោះលែងពីកោះត្រល់ (ភូកុក)[651]។ ទាហានរាប់ពាន់នាក់ ត្រូវបានដកចេញពីអង្គភាពរបស់ពួកគេ នៅក្នុងកងពលធំលេខ ១៦៤ ចន្លោះពីខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ចុងឆ្នាំ ១៩៧៨ និងត្រូវបានដកហូតអាវុធ មុនពេលបង្ខំឱ្យធ្វើការនៅតាមការដ្ឋានផ្សេងៗ និងត្រូវបានឃុំខ្លួន និង/ឬសម្លាប់[652]។ អ្នកផ្សេងទៀតត្រូវបានផ្ទេរឱ្យទៅពង្រឹងកងកម្លាំងកងពលធំលេខ ១៦៤[653] ដែលអាចពន្យល់បានខ្លះៗផងដែរពីការប៉ាន់ស្មានរបស់ **មាស មុត** អំពីចំនួនកងទ័ពសរុបខ្ពស់ជាងនេះ។

---

651 សូមមើល កថាខណ្ឌ ៣៤២ ដែលបានបញ្ជាក់ថា មានទាហានពី៣០០ទៅ៧២០នាក់ ត្រូវបានបោសសម្អាតមុនពេលពួកគេត្រូវបានដោះលែងដោយវៀតណាម។

652 សូមមើល VII.ក.៣ ប្រភេទជាប់សមាសភាព និងសមាសភាពមិនល្អ ក្នុងកងពលធំលេខ១៦៤ ដែលត្រូវបានបោសសម្អាត។ សូមមើលផងដែរ ចំនួនមនុស្សដែល "បាត់ខ្លួន" ពីតាមកងវរសេនាធំ កងវរសនាតូច និងកងផ្សេងៗទៀតក្នុងកងពលធំលេខ១៦៤ ដែលមាននៅក្នុងតារាងស្ថិតិចំនួនបួនដែលនៅសេសសល់ (នៅក្នុងអំឡុងពេលមួយ ដែលការបោសសម្អាតមិនមែនជាការសំខាន់បំផុត)៖ ឯកសារ D22.2.4 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៦ EN ERN 00950655, KH ERN 00160118 [មានទាហាន១៩៨នាក់ "បានបាត់ខ្លួនពីតាមកងនានា" តែក្នុងខែ កក្កដា ឆ្នាំ ១៩៧៦ប៉ុណ្ណោះ ក្នុងនោះរួមមាន៦នាក់ "ស្លាប់" ៦នាក់ "រត់គេចខ្លួន" និង១៨៦នាក់ "ត្រូវបានដកចេញ" (មានន័យតែមួយទៅនឹងពាក្យ "ផ្លាស់ប្តូរ" ឬ "បោសសម្អាត") ភាគច្រើនពីកងវរសេនាធំលេខ ១៤០ (សង្កត់ន័យបន្ថែម)]។ ឯកសារ D22.2.5 របាយការណ៍ស្ថិតិរបស់អង្គភាពកងពលធំលេខ ១៦៤ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៦ EN ERN 00950657, KH ERN 00160123 [មនុស្ស៣៨នាក់ ត្រូវបានបញ្ចូលតែក្នុងកងវរសេនាធំលេខ៦៣ប៉ុណ្ណោះ។ ស្ថិតិផ្សេងទៀត អាចមានការបាត់ ហើយចំនួនសរុបក៏អាចមានការបាត់ផងដែរ]។ ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ ដោយ មាស មុត នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦ [អង្គភាពកងពលលេខ១៦៤ ទាហាន៣៧នាក់ "បាត់មុខពីអង្គភាព" រួមទាំង ៥នាក់ "ពលី" ៣នាក់ "រត់" និង ២៩នាក់ "ដក" (សង្កត់ន័យបន្ថែម)]។ ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ ដោយ មាស មុត នៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ EN ERN 00575531, KH 00160071 [ទាហាន ៨៧នាក់ គឺត្រូវ "បាត់មុខពីអង្គភាព" រួមទាំង២នាក់ដែលរបាយការណ៍ ពលីកម្ម និង ៨៥នាក់ "ដក" (សង្កត់ន័យបន្ថែម)]។

653 ឯកសារ D22.2.4 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ នៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៦ EN ERN 00950655, KH ERN 00160118 [មានទាហាន១៩៨នាក់ "បានបាត់ខ្លួនពីតាមកងនានា" តែក្នុងខែ កក្កដា ឆ្នាំ ១៩៧៦ ប៉ុណ្ណោះ ក្នុងនោះរួមមាន៦នាក់ "ស្លាប់" ៦នាក់ "រត់គេចខ្លួន" និង១៨៦នាក់ "ត្រូវបានដកចេញ" (មានន័យតែមួយទៅ

220. កងពលធំលេខ ១៦៤ បានកាន់កាប់បេសកកម្មដែលបានចាត់តាំងឲ្យកងពលធំលេខ ៣ ដូច្នេះកងពលនេះទទួលខុសត្រូវចំពោះកងទ័ពជើងទឹករបស់ ក.ប.ធ ដែលកំពុងឃាមល្បាតដែនទឹក (ជាពិសេស កងវរៈសេនាធំលេខ ១៤០ ដែលត្រូវបានដាក់ពង្រាយនៅកំពង់សោម និងនៅជិតកោះកុង) នៃប្រជុំកោះសមុទ្រកម្ពុជាដែលមានចំនួនប្រហែល ២០០ កោះ[654]។ ឆ្នេរសមុទ្រកម្ពុជាទាំងមូល និងតំបន់ដីគោកនៅជុំវិញកំពង់សោម ដែលលាតសន្ធឹងពីតំបន់ទឹកសាបនៅភាគឦសានរហូតដល់កំពង់ផែស្ទឹងហាវ នៅភាគពាយ័ព្យ និងរួមបញ្ចូល ក្នុងចំណោមតំបន់ផ្សេងៗទៀត មានដូចជា រាម,

---

នឹងពាក្យ "ផ្លាស់ប្តូរ" ឬ "បោសសម្អាត") ភាគច្រើនពីកងវរសេនាធំលេខ១៤០ (សង្កត់ន័យបន្ថែម)]។ ឯកសារ D22.2.5 របាយការណ៍ស្ថិតិរបស់អង្គភាពកងពលធំលេខ ១៦៤ ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៦ EN ERN 00950657, KH ERN 00160123 [មានទាហាន២០នាក់ត្រូវបានបន្ថែម (៣នាក់ ទៅកងវរសេនាតូចលេខ ១៦៧, ៧នាក់ទៅកងវរសេនាតូចលេខ ១៦៩ និង១០នាក់ ទៅមន្ទីរកងពលធំ។ ចំនួនសរុបបញ្ជាក់ខុស ដាក់ថា "១០នាក់"]។ ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ ដោយ មាស មុត នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦ [ថែមទាហាន ៥៩នាក់]។ ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់អង្គភាពកងពល១៦៤ ដោយ មាស មុត នៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ EN ERN 00575531, KH ERN 00160071 [ទាហាន៩៦ត្រូវបានដាក់បន្ថែម, ជាក់ស្តែងមាន៧៤នាក់ទេ ដោយមានការគណនាខុសពីមុនមក]។

654 ឯកសារ D98/1.2.22 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹក ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ ម៉ោង 14.17.58-14.19.38 ["កងពល១៦៤ នេះ វាការពារដែនសមុទ្រកម្ពុជា គឺបូរណភាពដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ"]។ ម៉ោង 14.21.14-14.24.21 ["ជាពិសេសកងពល១៦៤ គេៗមានភារកិច្ចការពារបូរណភាពដែនសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យរបស់គេ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណោះ។"]។ ឯកសារ D114/297.1.21 ប្រតិចារឹក ប៉ាក សុខ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 13.33.48–13.36.39 ["កងទ័ពជាភារកិច្ចអ្នកការពារនៅទឹកដីព្រំដែនកោះ នៅសមុទ្រ"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.11 ["នៅពេលខ្លះ មេបញ្ជាការកងវរៈសេនាធំ ជាអ្នកប្រកាសនៅក្នុងរយៈពេលសន្និបាត។ ក្នុងពេលសន្និបាតនោះ គេក៏និយាយអំពីការការពារដែនសមុទ្រ និងព្រំដែនសមុទ្រដែលមានប្រវែងជាង៤០០គីឡូម៉ែត្រ ហើយនិងការការពារកោះរបស់កម្ពុជាដែលមានជិត២០០កោះ"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង សុំ ឆ.114 ["ស៖ តើកងទ័ពជើងទឹកនៅឯណា? ឆ.114៖ នៅផ្សារកំពង់សោម រាម ព្រលានយន្តហោះកងកេង នៅលើមួយជួរកោះទាំងអស់ កោះជាង២០០កោះ"]។ ឯកសារ D114/105 កំណត់ហេតុស្តាប់ចម្លើយ កុយ ទុយ ឆ.30 [បានរៀបរាប់អំពីកោះជាច្រើន រួមមានកោះមួយចំនួនដូចជា កោះតាង, កោះរ៉ុង, កោះរ៉ុងក្នុង, កោះម្នាស់, កោះយ៉, កោះសាលី, កោះថ្មី និងកោះព្រីង]។ ឯកសារD114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.34 ["ស៖ តើមានគេប្រាប់លោក ថាហេតុអ្វីបានគេបញ្ជូនកងពលធំទៅកំពង់សោមដែរទេ? ឆ.34៖ គេប្រាប់យើងថា ដើម្បីការពារទឹក ការពារដី និងការពារកោះ។ ទឹក គឺសំដៅសមុទ្រ"]។

កងកេង, បិត ត្រាង និងក្រុងកំពង់សោមដោយផ្ទាល់[655]។ យោងតាមឯកសារឆ្នាំ ១៩៧៦ ដែលរៀបចំដោយ **មាស មុត** បន្ថែមទៅកងទ័ពកងពលធំលេខ ១៦៤ អំណាចរបស់ **មាស មុត** បាន

[655] ឯកសារ D114/49 កំណត់ហេតុស្តាប់ចម្លើយ ព្រំ ង៉ុន ឆ.15 ["កងពល១៦៤ ជាអ្នកទទួលខុសត្រូវតំបន់សមុទ្រ"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.9 ["តំបន់ទឹកដីដែលស្ថិតនៅក្រោមបញ្ជារបស់ មាស មុត លាតសន្ធឹងតាំងពីទឹកសាប កងកេង រាម កំពង់សោម ហើយនិងកោះទាំងអស់នៅក្នុងសមុទ្រ។ កន្លែងតំបន់ទាំងអស់នេះ គឺហៅថាតំបន់ស្វយ័តដែលស្ថិតនៅក្រោមអំណាចរបស់ មាស មុត"]។ ឯកសារ D114/84 កំណត់ហេតុស្តាប់ចម្លើយ ឯក សុផល ឆ.7, 11, 19 ["ស៖ "ចំពោះកំពង់សោម កោះថ្មី កោះសេះ គឺស្ថិតនៅក្រោមកងពលធំ១៦៤ [...] តើការសង្ខេបនេះត្រឹមត្រូវដែរឬទេ? ឆ.7៖ បាទ ត្រឹមត្រូវហើយ [...] ឆ.11៖ ស្ថិតនៅក្រោមបញ្ជាការរបស់កងពល១៦៤ហើយ។ ពួកគេបញ្ជូនយោធាទៅកាន់កាប់កោះ [...] ឆ.19៖ កងពល១៦៤គឺទទួលបន្ទុកនាវា និងកប៉ាល់ចម្បាំងទាំងអស់"]។ ឯកសារ D114/112 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.19 ["កងទ័ពជើងទឹកខ្មែរក្រហមមានបីកងវរសេនាធំគឺ ៦១, ៦២ និង៦៣។ អង្គភាពនៅក្រោមកងវរសេនាធំទាំងនេះ ត្រូវបានពង្រាយឱ្យឈរជើងនៅតាមគ្រប់កោះទាំងអស់នៅ នៅក្នុងដែនសមុទ្រខ្មែរ"]។ ឯកសារ D54/52 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ហៅ ស្វាយ វឿន ឆ.12 ["មាស មុត ទទួលខុសត្រូវការពារដែនសមុទ្រ និងព្រំដែនទឹករបស់ប្រទេសកម្ពុជា ហើយបង៨៩ គឺជាអ្នកដែលនៅអគ្គសេនាធិការ"]។ ឯកសារ D54/51 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ហៅ ស្វាយ វឿន ឆ.17 ["កងទ័ពជើងទឹកត្រួតត្រាដីគោក ចាប់ពីវាលរេញរហូតដល់កំពង់សោម"]។ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ.100-101, 110, 250, 252 ["ស៖ ពេលហ្នឹង តើកងកុមារនៅកន្លែងណាដែរ? [...] ឆ.100៖ នៅភូមិពូធឿង [...] ឆ.101៖ បើទៅពីកងកេងឆ្ងាយប្រហែល ៣ទៅ ៤គីឡូម៉ែត្រ [...] ស៖ កងលោកស្រី ជាផ្នែកមួយនៃកងកុមារធំ ឬជាផ្នែកមួយនៃសហករណ៍? ឆ.110៖ ចាស សហករណ៍នោះ ឈ្មោះ សហករណ៍ពូធឿង [...] ស៖ ចុះកងពលធំលេខ ៣ ជាអ្នកគ្រប់គ្រងគ្រប់ការដ្ឋានការងារទាំងអស់នៅជិតសហករណ៍របស់លោកស្រីមែនទេ? ឆ.250៖ ចាស។ ទាហានទាំងអស់ជាសមាជិករបស់កងពលធំនេះ [...] ស៖ លោកស្រីមានដឹងថា កងពលធំលេខ៣ ក្រោយមកផ្លាស់ទៅជាកងពល ១៦៤ ទេ? ឆ.252៖ ចាស ដឹង ជាកងពលដដែល"]។ ឯកសារ D54/17 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.14-15 ["ស៖ លោកបានចង្អុលបង្ហាញពីទីតាំងឡឥដ្ឋដែលនៅជិតព្រលានយន្តហោះកងកេងតាមបណ្តោយផ្លូវទៅរាម តើលោកបានដឹងពីអ្វីខ្លះពីទីកន្លែងនេះ? ឆ.14៖ វាជាកន្លែងការដ្ឋានពលកម្មធម្មតារបស់កងពល ១៦៤ [...] ឆ.15៖ [...] មេបញ្ជាការកងពល១៦៤ មាស មុត ក៏បានពិនិត្យការងារនៅទីនោះដែរ"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង សុំ ឆ.83 ["មានតែ ១៦៤ មួយទេដែលនៅខេត្តកំពង់សោម"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.17, 19-20, 23 ["យើងធ្វើការនៅក្នុងតំបន់ជុំវិញព្រលានកងកេង ហើយនឹងតំបន់ជិតទឹកសាប [...] ឆ.19៖ ប្រធានកងវរៈសេនាតូច២០របស់ខ្ញុំឈ្មោះ បង ថន ឯកងវរៈសេនាតូច២១ ខ្ញុំមិនស្គាល់ទេ។ កងវរៈសេនាតូចទាំងពីរនេះឋិតក្រោមការគ្រប់គ្រងរបស់កងពល ១៦៤ [...] ឆ.20៖ មេបញ្ជាការបានប្រកាសក្នុងពេលប្រជុំថា កងរបស់យើងឋិតនៅក្រោមការត្រួតត្រារបស់កងពល [...] ឆ.23៖ [...] នេះជាគំរោងការរបស់អង្គការ ឱ្យបញ្ជូនទៅស្ទឹងហាវ"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.72, 166 ["ស៖ តើកងផលិតហ្នឹងនៅឯណាដែរ? ឆ.72៖ នៅប្រហែលបីគីឡូពីកន្លែងប្រជុំ ដែលនៅព្រលានយន្តហោះកងកេង,

ពង្រីកដល់ជនស៊ីវិលពី ៨.០០០ ទៅ ៩.០០០ នាក់[656] ដែលធ្វើការនៅតាមភូមិ និងសហករណ៍នៅតំបន់កំពង់សោម[657]។ ផ្ទុយទៅនឹងអ្វីដែល **មាស មុត** បាននិយាយនៅក្នុងបទសម្ភាសន៍មួយ[658]

---

នៅភូមិប្រហុក។ [...] សៈ កងផលិតហ្នឹង ជាផ្នែកមួយនៃកង ១៦៤ ហ្នឹងឬ? ឆ.166៖ បាទ”]។ ឯកសារ D114/15 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា (សុក វណ្ណៈ) ឆ.28 [“តាមខ្ញុំយល់ កប៉ាល់ទាំងអស់ ហើយនិងយោធាដែលឈរជើងនៅតាមកោះ គឺស្ថិតនៅក្រោមបញ្ជារបស់ មាស មុត ទាំងអស់”]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.16 [“ក្នុងនាមជាមេបញ្ជាការកងពលទ័ពជើងទឹក មាស មុត, គាត់ទទួលខុសត្រូវក្នុងរឿងព្រំដែនទឹក”]។ ឯកសារ D54/42.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហេង វៀច EN ERN 00983447, KH ERN 00967571។

656 ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពបដិវត្តន៍កម្ពុជា (បុគ្គលិកទូទៅ) ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00052391 [“សមមិត្ត មុត [...] សភាពការណ៍បង្កបង្កើនផល [...] ស្រូវ ស្ទូង ហើយទាំងកងទ័ព និងប្រជាជន ទំហំគឺ ១.៦០០ហិចតា។ កំលាំងមនុស្ស ទាំងប្រជាជន ទាំងកងទ័ព ១៧.០០០នាក់”]។ ក្នុងអំឡុងពេលដូចគ្នានៃឆមាសទី២ ឆ្នាំ១៩៧៦ មាស មុត បានរាយការណ៍ទៅ សុន សេន ថាចំនួនយោធាក្នុងកងពលធំលេខ ១៦៤ ក្នុងខែកក្កដា ឆ្នាំ១៩៧៦ មានចំនួន ៨.៧៦១នាក់, ក្នុងខែសីហា មានចំនួន ៨.៨៨៧នាក់, ក្នុងខែតុលា មានចំនួន ៨.៦១១ នាក់ និងក្នុងខែវិច្ឆិកា មានចំនួន ៨.៦៨៥ (សូមមើលខាងលើ កថាខណ្ឌ ២១៩, ជើងទំព័រ ៦៤៣-៦៤៦)។ ដូច្នេះវាអាចត្រូវបានកាត់បន្ថយ ដែលចំនួនប្រជាជនស៊ីវិលស្ថិតក្រោមការគ្រប់គ្រងរបស់ មាស មុត ក្នុងរវាងខែកញ្ញា ឆ្នាំ១៩៧៦ មានចំនួនលើសពី ៨.០០០នាក់(ពីខែសីហា ទៅខែតុលា ឆ្នាំ១៩៧៦ មានចំនួនពី៨.១១៣ ទៅ៨.៣៨៩នាក់)។ ឯកសារ D1.3.8.4 កំណត់ហេតុនៃការប្រជុំរបស់កងទ័ពបដិវត្តន៍កម្ពុជា (កងពលធំលេខ ១៦៤ និង សុន សេន) ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ EN ERN 00657355 [កម្មាភិបាលម្នាក់ អាចជា មាស មុត ឬអនុប្រធានគាត់ រាយការណ៍ពីសកម្មភាពរបស់កងពលធំលេខ ១៦៤ ដោយបានស្នើសុំខោអាវ៥.០០០កំប្លេសម្រាប់ប្រជាជន និង៧.០០០កំប្លេសម្រាប់យោធា (សូមមើល IV-ផ្សេងៗ) នេះវាផ្តល់នូវការចង្អុលបង្ហាញថា មានប្រជាជនស៊ីវិលលើសពី ៥.០០០នាក់]។ សាក្សី ជេត ប៊ុណ្ណា បានបញ្ជាក់ថា មាន “កងទ័ព” ១៨.០០០នាក់ ក្នុងកងពលធំលេខ ១៦៤ (ទំនងជារួមបញ្ចូលទាំងជនស៊ីវិល និងយោធា) ដែលចំនួននេះវាប្រហែលគ្នានឹងចំនួនមនុស្ស ១៧.០០០នាក់ ដែល មាស មុត បានរាយការណ៍ទៅ សុន សេន។ ។ ចំនួនមនុស្ស១៨.០០០នាក់ ដែលស្ថិតនៅក្រោមការគ្រប់គ្រងនេះ អាចនឹងបែងចែកស្មើរតែប្រហែលគ្នា រវាងយោធា (តិចជាង៩.០០០នាក់បន្តិច ដោយយោងទៅតាមស្ថិតិផ្លូវការនៅចុងឆ្នាំ ១៩៧៦) និងប្រជាជនស៊ីវិល (ច្រើនជាង៩.០០០នាក់បន្តិច)៖ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.10 [“ខ្ញុំគិតថា មុខតំណែង មាស មុត ជាអនុរបស់សេនាធិការ គឺវាឆ្លុះបញ្ចាំងទៅនឹងការងារ ហើយនិងការទទួលខុសត្រូវរបស់គាត់ ដោយពេលនោះ គាត់មានយោធា១៨ពាន់នាក់ នៅក្រោមបញ្ជារបស់គាត់។ យោធាទាំងនោះ រួមមាន កងដែលនៅតាមកប៉ាល់ កងប្រយុទ្ធថ្មើរជើង កងដឹកជញ្ជូន ហើយនិងកងផ្សេងៗទៀត។ នៅក្រោមបញ្ជានិងការគ្រប់គ្រងរបស់គាត់ ក៏មានសភាពការណ៍របស់ប្រជាជនស៊ីវិលមួយចំនួនដែរ។ សហករណ៍ទាំងនោះរួមមាន: សហករណ៍ថ្មធំ អូរម្លូ ឡូឥដ្ឋ ស្នាច់ដែង ពុតធឿង និងបបុស”]។

ប្រជាជនទាំងនោះមិនត្រឹមតែជាសមាជិកគ្រួសាររបស់ទាហានកងពលធំលេខ ១៦៤ ប៉ុណ្ណោះទេ ប៉ុន្តែក៏មានកសិករមកពីតំបន់នោះផងដែរ "ប្រជាជនថ្មី" មកពីក្រុងកំពង់សោម ឬទីក្រុងភ្នំពេញ ព្រមទាំងទាហានដែលត្រូវបានដកហូតអាវុធ/បោសសម្អាតផងដែរ[659]។ នៅក្នុងកិច្ចការរដ្ឋបាល

---

657 សូមមើល ឧទាហរណ៍ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.9-10 ["តំបន់ទឹកដីដែលស្ថិតនៅក្រោមបញ្ជារបស់ មាស មុត លាតសន្ធឹងតាំងពីទឹកសាប កងកេង រាម កំពង់សោម ហើយនិងកោះទាំងអស់នៅក្នុងសមុទ្រ។ កន្លែងតំបន់ទាំងអស់នេះ គឺហៅថាតំបន់ស្វយ័តដែលស្ថិតនៅក្រោមអំណាចរបស់ មាស មុត។ [...] ឆ.10៖ នៅក្រោមបញ្ជានិងការគ្រប់គ្រងរបស់គាត់ [មាស មុត] ក៏មានសភាពការណ៍របស់ប្រជាជនស៊ីវិលមួយចំនួនដែរ។ សហករណ៍ទាំងនោះរួមមាន: សហករណ៍ថ្មធំ អូរម្លូ ឡឥដ្ឋ ស្នាច់ដែង ពុតធឿង និងបបុស"]។ ឯកសារ D54/89 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.6, 9 [និយាយពីសហករណ៍បបុស និងសហករណ៍ពូធឿង]។ ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.2 ["នៅកន្លែងនេះមានសហករណ៍បបុស និងសហករណ៍ពូធឿង ហើយមនុស្សនៅក្នុងសហករណ៍ទាំងពីរនេះមានចំនួនរាប់ពាន់នាក់ រួមទាំងគ្រួសារយោធា យោធាផង"]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.14។ ឯកសារ D114/33 កំណត់ហេតុស្តាប់ចម្លើយ ហែម អាង ឆ.16-17។

658 ឯកសារ D114/307.6 កិច្ចសម្ភាសន៍វីអូអេ ជាមួយ មាស មុត ជនសង្ស័យរបស់តុលាការយល់ឃើញថា តួនាទីរបស់តុលាការ មានកម្រិត" ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១១ EN ERN 00746176, KH ERN 01380588, FR ERN 01529701 ["តាមពិតទៅទីមួយគឺមិនមានជនស៊ីវិលនៅកន្លែងខ្ញុំ។ ទីពីរមានតែកងទ័ពនិងក្រុមគ្រួសាររបស់ពួកគេប៉ុណ្ណោះ។ ហេតុដូច្នេះមិនមានពលកម្មដោយបង្ខំឡើយនៅក្នុងកងរបស់ខ្ញុំ"]។

659 ឯកសារ D114/94 កំណត់ហេតុស្តាប់ចម្លើយ សំ វុទ្ធី ឆ.19, 38, 44, 57 [អ្នកដែលបានជម្លៀសចេញពីភ្នំពេញបានពន្យល់ថា គាត់ និង "ប្រជាជនថ្មី" ៣០នាក់ផ្សេងទៀត ត្រូវបានបញ្ចូលក្នុងបញ្ជីឈ្មោះដែលត្រូវបញ្ជូនទៅធ្វើការក្នុងកងចល័តនៅកំពង់សោម ក្នុងឆ្នាំ១៩៧៧។ គាត់ធ្វើការក្នុងសហករណ៍ពូធឿង នៅបិតត្រាង]។ ឯកសារ D114/38 កំណត់ហេតុស្តាប់ចម្លើយ ជុំ រឹម (ជា រឹម) ឆ.7, 20-21, 27 [បានពន្យល់ថា អង្គភាពនារីទាំងអស់ត្រូវបានបញ្ជូនពីស្រែអំបិលកំពតទៅកំពង់សោម នៅក្នុងឆ្នាំ ១៩៧៧ ដើម្បីធ្វើការនៅចម្ការកៅស៊ូក្បែរនឹងស្ទឹងហាវ]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.29 [ពន្យល់ថា "មានយោធាចំនួនតិចតួចប៉ុណ្ណោះ" ដែលបានរៀបការក្នុងកងពលធំលេខ១៦៤ ហើយវាមានច្បាប់ដែលប្រើប្រាស់រហូតដល់ឆ្នាំ១៩៧៨ ដែលបញ្ជាក់ថា ក្នុងចំណោមយោធាក្នុងកងពលធំលេខ ១៦៤ "អ្នកដែលមានអាយុតិចជាង២៥ឆ្នាំ មិនអាចរៀបការបានទេ"។ សម្រាប់អ្នកដែលរៀបការហើយ "យោធាទាំងនោះ ត្រូវបានអនុញ្ញាតឲ្យយកប្រពន្ធមកពីស្រុក" ប៉ុន្តែប្រពន្ធយោធាទាំងនោះ ត្រូវបញ្ជូនឲ្យទៅរស់នៅក្នុងសហករណ៍ជាមួយនឹងប្រជាជនធម្មតា"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.89-90, 92, 100 ["ក្រោយមក គេបានរំសាយកងទ័ព ហើយប្រែក្លាយអង្គភាពយើង [កងវរៈសេនាតូចលេខ ៣៨៧ មកពីតំបន់៣៧] ទៅជាកងផលិត ដោយឲ្យធ្វើស្រែ លើកទំនប់ និងជីកប្រឡាយ។ សៈ ហេតុអ្វីបានជាគេរំសាយអង្គភាពរបស់លោក? ឆ.90៖ គេចោទយើងជាខ្សែខ្មាំង ដោយសារមេកងវរៈរបស់ពួកយើងត្រូវបានគេចាប់យកទៅបាញ់សម្លាប់អស់ហើយ។ [...] ឆ.92៖ តាមពិត កងពលត្រូវបានរំសាយ គឺមានទាហានរាប់ពាន់នាក់។ ពួកគេត្រូវបានចាត់តាំងឲ្យធ្វើ

តំបន់កំពង់សោម គឺជាតំបន់ឯករាជ្យមួយក្រោមការដឹកនាំរបស់ **មាស មុត** ហើយត្រូវបានដាក់ដោយផ្ទាល់នៅក្រោមមជ្ឈិមបក្ស[660]។ នៅក្នុងវិស័យយោធា តំបន់នេះត្រូវបានគ្រប់គ្រងដោយកងពលធំលេខ ១៦៤ និងត្រូវបានគេពិពណ៌នាថាជាភូមិភាគយោធាស្វយ័តលេខ ៧[661]។

---

ការងារក្នុងកងផលិតខុសៗគ្នា និងបញ្ជូនទៅតាមមុខព្រួញការងារខុសៗគ្នា [...] ឆ.93៖ បញ្ជាច្បាស់ជាចេញមកពី តាមុត ហើយពួកគេជាមនុស្សរបស់តាមុត ដែលប្រមូលផ្តុំឱ្យពួកយើងប្រជុំ ហើយប្រាប់ពួកយើងថា នឹងត្រូវបញ្ជូនទៅតាមការដ្ឋានខុសៗគ្នា [...] សៈ តើក្នុងខែឆ្នាំណា ដែលគេចោទពួកលោកថាជាខ្សែខ្មាំង? ឆ.100៖ គឺចុងឆ្នាំ១៩៧៧ ហើយកងពលចាស់ទាំងមូលត្រូវបានរំសាយទាំងស្រុង"] [សង្កត់ន័យបន្ថែម]។ ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ហៅ ខេន ឆ.56-62, 235-331 [រវាងខែ កញ្ញា ឆ្នាំ ១៩៧៧ នាវីៗមូលដ្ឋានក្នុងឃុំព្រៀងញ៉ៀង ស្រុកត្រាំកក់ ភូមិភាគនិរតី ត្រូវបានបញ្ជូនឱ្យទៅធ្វើនៅចម្ការដូង ហើយត្រូវបានបង្ខំឱ្យរៀបការនៅកំពង់សោម]។ ឯកសារ D114/47 កំណត់ហេតុស្តាប់ចម្លើយ វី តើ ឆ.15-19 [គ្រួសារចាមបានប្តូរទីលំនៅពីកោះសេះទៅកំពង់សោម ជាទីកន្លែងដែលគេបំបែក និងធ្វើការនៅទីតាំងផ្សេង]។

660 ឯកសារ D114/277.4 ប្រតិចារឹក កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង 11.11.52-11.15.32 ["ខ្ញុំសូមលើកអំពីតំបន់ឯករាជ្យមួយ គឺតំបន់ឯករាជ្យកំពង់សោម។ តំបន់ឯករាជ្យកំពង់សោមនេះឆ្លងរាយការណ៍មិនមែនឆ្លងមកលេខាភូមិភាគនិរតីទេ ត្រូវរាយការណ៍មក៨៧០ [...] ទោះបីអាតំបន់កំពង់សោមនេះ វាស្ថិតនៅក្នុងទឹកដីភូមិភាគនិរតីក៏ដោយ ក៏ប៉ុន្តែរឿងអីៗអា១៦៤នេះ វារាយការណ៍មកដល់អចិន្ត្រៃយ៍ វារាយការណ៍មកដល់ការិយាល័យនយោបាយមជ្ឈិមបក្ស"]។ ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ (ឡាយ ប៊ុនហាក់) ឆ.23, 28-30, 38 ["[ឡូញ] ជាមេដឹកនាំម្នាក់នៅតំបន់ស្វយ័ត [...] សៈ នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយថាកំពង់សោមជាតំបន់ស្វយ័ត តើតំបន់ស្វយ័តនោះកើតឡើងពេលណា? ដោយរបៀបណា? ឆ.28៖ បើតាមខ្ញុំដឹង គឺខាងរដ្ឋាភិបាលកណ្តាលជាអ្នកបញ្ជាត្រង់មកតំបន់ស្វយ័ត ហើយគ្មានអ្នកណាបញ្ជាមកនោះទេ។ សៈ តើនរណាគេជាអ្នកបញ្ជាផ្ទាល់មកតំបន់ស្វយ័ត? ឆ.29៖ ខ្ញុំមិនដឹងអ្នកណាជាអ្នកបញ្ជានោះទេ គឺដឹងត្រឹមតែមជ្ឈិម ហើយខ្ញុំដឹងនៅពេលប្រជុំដោយគេនិយាយថាកំពង់សោមជាតំបន់ស្វយ័តប៉ុណ្ណោះ។ សៈ តើកិច្ចប្រជុំហ្នឹងធ្វើនៅក្នុងកងវរសេនាធំរបស់លោកឬ? ឆ.30៖ ខ្ញុំដឹងថាតំបន់កំពង់សោមជាតំបន់ស្វយ័តដោយសារ ខ្ញុំចូលរួមកិច្ចប្រជុំក្នុងកងវរសេនាធំ និងកិច្ចប្រជុំផ្ទៃក្នុងរបស់បក្ខជន។ កម្មករចម្ការកៅស៊ូ កម្មករកំពង់ផែ ទាហាននៅកំពង់សោមទាំងអស់សុទ្ធតែដឹងថាតំបន់កំពង់សោមជាតំបន់ស្វយ័ត ដោយសារព័ត៌មានហ្នឹងត្រូវបានគេផ្សព្វផ្សាយយ៉ាងទូលំទូលាយ។ [...] សៈ តើនរណាជាអ្នកបង្ហាត់បង្រៀននៅក្នុងវគ្គរៀនសូត្រនយោបាយ? ឆ. 38៖ គឺលេខាកងពលតា មាស មុត"]។ ឯកសារ D114/159 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ឆ. 10 ["បងមុត លេខាកង១៦៤ ដែលជាកងពលសមុទ្រ និងជាលេខាតំបន់ពិសេសកំពង់សោម។ មានភូមិមួយចំនួននៅជុំវិញផែកំពង់សោម ហើយវាមានគណៈកម្មាការផែវាមួយដោយឡែកទៀត។ ទាំងភូមិ ទាំងផែនេះ វានៅក្នុងការគ្រប់គ្រងរបស់បងមុត"] [សង្កត់ន័យបន្ថែម]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.9-10 ["តំបន់ទឹកដីដែលស្ថិតនៅក្រោមបញ្ជារបស់ មាស មុត លាតសន្ធឹងតាំងពីទឹកសាប កងកេង រាម កំពង់សោម ហើយនិងកោះទាំងអស់នៅក្នុងសមុទ្រ។ កន្លែងតំបន់ទាំងអស់នេះ គឺហៅថាតំបន់ស្វយ័តដែលស្ថិតនៅក្រោមអំណាចរបស់

221. កងពលធំលេខ ១៦៤ ទទួលខុសត្រូវក្នុងការការពារ និងសន្តិសុខកំពង់ផែកំពង់សោម[662]។ កម្មករកំពង់ផែ និងរោងចក្រកែច្នៃប្រេងកាត ត្រូវបានដាក់តាមឋានានុក្រមក្រោមឈ្មោះ ធុច រិន ហៅ គ្រិន

---

មាស មុត។ [...] ឆ.10៖ នៅក្រោមបញ្ជានិងការគ្រប់គ្រងរបស់គាត់ [មាស មុត] ក៏មានសភាពការណ៍របស់ប្រជាជនស៊ីវិលមួយចំនួនដែរ។ សហករណ៍ទាំងនោះរួមមាន: សហករណ៍ថ្មធំ អូរម្ទូ ឡាឥដ្ឋ ស្នាច់ដែង ពុតធៀង និងបបុស"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.199-200 ["នៅពេលនោះ មាស មុត គ្រប់គ្រងទាំងអស់ លើតំបន់ស្វយ័តកំពង់សោមទាំងអស់ លើកលែងតែ កំពង់ផែកំពង់សោមមួយចេញ ព្រោះជារបស់រដ្ឋ ហើយនៅក្រោមការគ្រប់គ្រងរបស់មនុស្សម្នាក់ប្រហែលជាឈ្មោះ គ្រិន។ សៈអ៊ីចឹងបានន័យថា កំពង់សោមជាតំបន់ស្វយ័តដែលគ្រប់គ្រងដោយ មាស មុត មែនទេ? ឆ.200៖ បាទ"]។ ឯកសារ D22.1.10 (ហ្វ៊ីប៊ីស) សុន្ទរកថារបស់ វន វ៉េត ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៧៧ EN ERN 00168355 ["សមមិត្តឧបនាយករដ្ឋមន្ត្រី នឹង យឹងគួយ និងសមមិត្តចិនដទៃទៀត បានចំណាយកម្លាំងជាច្រើនក្នុងដំណើរទស្សនកិច្ចទៅកាន់តំបន់ជាច្រើននៃកម្ពុជាប្រជាធិបតេយ្យ រួមមាន តំបន់ភាគបូព៌ា, ភាគកណ្តាល, ភាគឧត្តរ, ភាគពាយ័ព្យ, ភាគបស្ចិម និងភាគនិរតី និងតំបន់កំពង់សោម"(សង្កត់ន័យបន្ថែម)]។ ឯកសារ D64.1.37 (ហ្វ៊ីប៊ីស) ទីភ្នាក់ងារសារព័ត៌មានចិន (NCNA) អ្នកឆ្លើយឆ្លងព័ត៌មានបន្តទស្សនកិច្ចនៅកម្ពុជា ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៧៨ EN 00169127 [នៅថ្ងៃទី ១២ ខែ ធ្នូ ក្រុមអ្នកឆ្លើយឆ្លងព័ត៌មានរបស់ទីភ្នាក់ងារសារព័ត៌មានស៊ីនហួរ ដែលដឹកនាំដោយសមមិត្ត លី ណាន ដែលជានាយករងផ្នែកព័ត៌មានអន្តរជាតិរបស់ទីភ្នាក់ងារសារព័ត៌មានស៊ីនហួរ បានចាប់ផ្តើមដំណើរទស្សនកិច្ចទៅកាន់តំបន់ភាគនិរតី, តំបន់កំពង់សោម និងទីក្រុងភ្នំពេញ [...] នៅថ្ងៃទី ១៤ ខែ ធ្នូ តំណាងទីភ្នាក់ងារសារព័ត៌មានស៊ីនស្ហួរ បានទៅទស្សនកិច្ចតំបន់កំពង់សោម រួមមាន តំបន់កំពង់ផែថ្មី និងកំពង់ផែចាស់ និងតំបន់មួយចំនួនទៀត"]។ ឯកសារ D59/1/1.9a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ KH ERN 00926477 ["សៈ អញ្ចឹងកាលជំនាន់ហ្នឹងពួកអ៊ំៗ គាត់ខស្សាហ៍ចុះទៅកំពង់សោមដែរណោះ? ឆ៖ បាទ ព្រោះតំបន់ស្វយ័ត្សខ្ញុំទៅបន្តិច [...] គ្រាន់តែផ្នែកយោធាឯកឧត្តម មាស មុត ហ្នឹងឯង ហើយផ្នែកការងាររដ្ឋបាលកំពង់ផែហ្នឹងមិនដឹងជាខាងណាទៀត តំបន់ស្វ័យត្សមានការគ្រប់គ្រងខុសគ្នាអញ្ចឹងណា"]។

661 ឯកសារ D114/297.1.20 ប្រតិចារឹក ប្រាក់ សុខ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 09.46.54-09.53.19 ["កងពលនុ៎ង [...] នៅក្នុងយុទ្ធភូមិភាគនៅក្រុងកំពង់សោមតែម្តង [...] ប៉ុន្តែកងទ័ពហ្នឹង ភូមិភាគហ្នឹង យុទ្ធភូមិភាគហ្នឹង គឺជាកងទ័ពមជ្ឈិមតែម្តង។ កងពល១៦៤ហ្នឹង"]។ ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.21 ["ខ្ញុំបានឮគេនិយាយថា កងពល១៦៤ ជាផ្នែកមួយរបស់យុទ្ធភូមិភាគ៧ ដែលជាភូមិភាគស្វយ័ត។ តាមដែលខ្ញុំយល់យុទ្ធភូមិភាគ៧ គឺគ្របដណ្តប់តំបន់កំពង់សោម"]។ ឯកសារ D114/286 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត (ប៉ាង រ៉េត) ឆ.9 ["ខាងកងពលគេប្រជុំ ប្រកាសពីកងពលលេខ៣ មកជាកងពល១៦៤ គេថាកងពល ជាកងពលរបស់មជ្ឈិម របស់អគ្គបញ្ជាការ មិននៅក្រោមភូមិភាគដូចមុនទេ ព្រោះតំបន់កំពង់សោមជាតំបន់ស្វយ័ត ហើយហៅថាជាកងទ័ពជើងទឹក"]។

662 សាក្សី អែម សុន កម្មាភិបាលក្នុងកងវរសេនាតូចលេខ ៤៥០ កងពលធំលេខ ៣ (កងពិសេស) ត្រូវបានដកចេញទៅនៅកំពង់ផែ ក្នុងខែ មេសា ឆ្នាំ ១៩៧៥ ហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ គ្រិន៖ ឯកសារ D54/46 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.25 ["ដំបូងឡើងវាស្ថិតនៅក្នុងកងពលលេខ៣ ហើយកងពល៣បានបញ្ជូនវរសេនាតូចខ្ញុំទៅ

មកពីក្រសួងពាណិជ្ជកម្ម[663] ចាប់ពីពេលគាត់មកដល់កំពង់សោមក្នុងខែ មេសា ឆ្នាំ ១៩៧៥[664] រហូតដល់ចុងខែ កុម្ភៈឆ្នាំ ១៩៧៨ នៅពេលគាត់ត្រូវបានចាត់តាំងឡើងវិញជាឯកអគ្គរដ្ឋទូតរបស់ ក.ប.ធ

---

យាមការពារនៅផែកំពង់សោម ដើម្បីទៅយាមកម្មករនៅទីនោះ។ ក្រោយមក អ្នកគ្រប់គ្រងនៅផែកំពង់សោមបានស្នើសុំកងពលលេខ៣ ឱ្យកងវរសេនាតូចរបស់ខ្ញុំមកប្រចាំការណ៍ជាអចិន្ត្រៃយ៍នៅផែកំពង់សោម"]។ ឯកសារ D54/31 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.3 [ក្នុងអំឡុងថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ១៩៧៥៖ "ពេលមកដល់កំពង់សោម កងវរៈសេនាតូច ៥៥០របស់ពួកខ្ញុំ ត្រូវបានគេឱ្យមកឈរជើងនៅផែកំពង់សោម។ ពេលនៅហ្នឹងផែនោះនៅបានរយៈពេល ៣ថ្ងៃ មានកប៉ាល់ចិនផ្ទុកទំនិញមួយគ្រឿងចំណុះ៣០០០តោនបានដឹកអង្ករចូលមក។ ក្រោយមក កងវរៈសេនាតូច ៥៥០ ត្រូវបានចាត់តាំងដូចខាងក្រោមនេះមួយកងអនុសេនាធំនៅការពារកំពង់ផែ មួយកងអនុសេនាធំទៀតត្រូវបានបញ្ជូនទៅកោះតាង និងកោះពូលូវៃ និងមួយអនុសេនាធំទៀតត្រូវបានបញ្ជូនទៅកោះរ៉ុងក្នុងនិងកោះរ៉ុងក្រៅ។ ចំណែកកងអនុសេនាធំរបស់ខ្ញុំនៅការពារកំពង់ផែ"]។ ឯកសារ D114/286 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត (ហ៊ាង រ៉េត) ឆ.9, 20, 23-27 [ក្នុងឆ្នាំ១៩៧៥ កម្មាភិបាលមកពីកងវរៈសេនាតូច ៤៥០៖ "ហើយពេលយើងទៅដល់ទីក្រុង យើងចាត់តាំងឱ្យបោះទីតាំងសំខាន់ៗដូចជាឃ្លាំងប្រាក់ និងកំពង់ផែកំពង់សោម [...] ឆ.20៖ [...] ខាងកំពង់ផែហ្នឹង គេបានយកកម្មករធ្វើការនៅទីនោះឱ្យស្នាក់នៅ ដូច្នេះខ្ញុំក៏ប្រគល់តំបន់ហ្នឹងឱ្យគេ។ [...] ឆ.23៖ [...] នៅនឹងផែហ្នឹងក៏មានកងរបស់វរសេនាតូច៤៥០ទៅនៅកន្លែងហ្នឹងដែរ [...] វាមានកងអនុសេនាធំផ្សេងៗគ្នា។ [...] ឆ.24៖ មិនមែនទេ គឺបញ្ជាមកពីថ្នាក់លើឱ្យខ្ញុំប្រគល់កន្លែងទាំងនោះ [កំពង់ផែ] ទៅឱ្យអង្គភាពរបស់ផែគ្រប់គ្រង។ [...] ឆ.25៖ ពេលនោះ គេរៀបចំផែឡើងវិញ ដោយឱ្យផែជាអ្នកកាន់កាប់ ពេលនោះ គេចាត់តាំងចៅហ្វាយកំពង់ផែ ដែលដាច់ដោយឡែកពីកងពល [...] ឆ.26៖ ចៅហ្វាយកំពង់ផែ មិនអាច មាស មុត ចាត់តាំងបានទេ។ ទៅកាន់កាប់ដំបូង មកពីរៀបចំគ្រប់គ្រងមិនទាន់បាន ដូច្នេះគេចេះតែឱ្យយោធាឈរជើងនៅ និងការពារ ហើយក្រោយមកគេចាប់ផ្តើមរៀបចំផែ ហើយចាត់តាំងអ្នកដឹកនាំ។ ស៖ ពេលណាបានរៀបរយចាត់តាំង ហើយប៉ុន្មានខែ? ឆ.27៖ មិនយូរទេ កប៉ាល់ចិនគេដឹកអីវ៉ាន់ចូល គេរៀបចំហ្នឹង មិនបានពីរខែទេ"]។ ផ្ទុយពី ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ.34 ["នៅកំពង់សោម សម្រាប់កម្លាំងយោធា គឺមានតែកងពល១៦៤ប៉ុណ្ណោះ។ ប៉ុន្តែនៅកំពង់ផែរដ្ឋអំណាចកំពង់ផែ មានកងកម្លាំងសន្តិសុខឯករាជ្យផ្ទាល់ខ្លួន"]។

663 ឯកសារ D4.1.931 កំណត់ហេតុស្តាប់ចម្លើយ សគីម ល្មុត ឆ.10-11 ["គណៈកម្មការកំពង់ផែ ខ្ញុំស្គាល់ឈ្មោះ គ្រិន [...] ឆ.11៖ ពេលដែលខ្ញុំទៅកំពង់សោមជាមួយផ្នែកពាណិជ្ជ គេបានឱ្យខ្ញុំបកប្រែភាសាបារាំង-ខ្មែរ ពេលនោះខ្ញុំក៏ឮអំពីឈ្មោះ គ្រិន ទេ"]។ ឯកសារ D98/3.1.249 ប្រតិចារឹក សគីម ល្មុត ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ ម៉ោង 13.46.33-13.48.33 ["ថាតែធ្វើការទៅវាមានពាណិជ្ជ ហើយនិងកំពង់ផែវាត្រូវទាក់ទងគ្នា ព្រោះនាំទំនិញចេញចូល"]។ ឯកសារ D114/195 កំណត់ហេតុស្តាប់ចម្លើយ នាក់ ខឿន ឆ.5 ["មាស មុត គឺជាមេទ័ពទេ។ ខ្ញុំនៅកំពង់ផែ គឺមិនស្ថិតនៅក្រោមការដឹកនាំរបស់ មាស មុត ទេ។ មួយ ខាងកំពង់ផែ ហើយមួយខាងកងទ័ព។ អ្នកដឹកនាំកំពង់ផែ គឺជាតា គ្រិន ទេ ប៉ុន្តែខ្ញុំឮមេដឹកនាំទ័ពថាមានឈ្មោះ តាមុត មែន"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ.199 ["នៅពេលនោះ មាស មុត គ្រប់គ្រងទាំងអស់ លើតំបន់ស្វយ័តកំពង់សោមទាំងអស់ លើកលែងតែកំពង់ផែកំពង់សោមមួយចេញ ព្រោះជារបស់រដ្ឋ ហើយនៅក្រោមការគ្រប់គ្រងរបស់មនុស្សម្នាក់ប្រហែលជាឈ្មោះ គ្រិ

ប្រចាំនៅទីក្រុងហុងកុង (និងក្រោយមកទៀតជាប្រធានក្រុមហ៊ុន រ៉ុន ហ្វុងផងដែរ)[665]។ ភស្តុតាងបង្ហាញថា **មាស មុត** និងអ្នកក្រោមបង្គាប់របស់គាត់ដែលមានឋានៈខ្ពស់ពីកងពលធំលេខ ១៦៤

---

ន"]។ ឯកសារ D114/159 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ឆ.12 ["ឌុច រិន មានតួនាទីតែខាងផែទេ គ្មានតួនាទីទៅខាងកងពល និងប្រជាជនទេ"]។ ឯកសារ D114/217 កំណត់ហេតុស្តាប់ចម្លើយ នាក់ ខឿន ឆ.32 ["គ្រិន គ្រប់គ្រងតែ កងលើកដាក់អីវ៉ាន់, កងសំណង់, កងនាវាចរណ៍ និងពេទ្យនៅក្នុងកំពង់ផែ"]។ ឯកសារ D114/218 កំណត់ហេតុស្តាប់ចម្លើយ សាំ គំនិត ហៅ ហ៊ុត ឆ.18 ["ឱក គ្រិន ឋានៈគាត់ជាប្រធានគ្រប់គ្រងកំពង់ផែ, បន្ទាប់មក អនុប្រធានគាត់ឈ្មោះ ផូ សោម"]។ ឯកសារ D54/31 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.10-11 ["ស៖ តើរោងចក្រប្រេងកាត ឋិតនៅក្រោមការគ្រប់គ្រងរបស់ថ្នាក់ណា? ឆ.10៖ គឺវាឋិតនៅក្រោមការគ្រប់គ្រងរបស់មជ្ឈិម។ មាស មុត ជាគ្រិន តាឡូញ គឺជាគណៈកម្មការមជ្ឈិមនៅកំពង់សោម។ មាស មុត ទទួលខុសត្រូវខាងយោធា ហើយជា គ្រិនទទួលខុសត្រូវខាងកំពង់ផែនិងរោងចក្រប្រេងកាត ឯ ឡូញទទួលខុសត្រូវនេសាទ [...] ឆ.11៖ មាស មុត គឺជាប្រធានធំជាងគេ បន្ទាប់មក ជា គ្រិន និង ឡូញ"]។ ឯកសារ D54/46 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.25 ["ដំបូងឡើងវាស្ថិតនៅក្នុងកងពលលេខ៣ ហើយកងពល៣បានបញ្ជូនវរសេនាតូចខ្ញុំទៅយាមការពារនៅផែកំពង់សោម ដើម្បីទៅយាមកម្មករនៅទីនោះ។ ក្រោយមក អ្នកគ្រប់គ្រងនៅផែកំពង់សោមបានស្នើសុំកងពលលេខ៣ ឱ្យកងវរសេនាតូចរបស់ខ្ញុំមកប្រចាំការណ៍ជាអចិន្ត្រៃយ៍នៅផែកំពង់សោម"]។ ឯកសារ D125/143 កំណត់ហេតុស្តាប់ចម្លើយ អ៊ួង ធា KH ERN 00236044 ["គឺឈ្មោះ តាគ្រិន គាត់ជាអ្នកទទួលខុសត្រូវពាណិជ្ជកម្មកំពង់ផែកំពង់សោម"]។ ឯកសារ D114/241 កំណត់ហេតុស្តាប់ចម្លើយ ឆេង ជាង ឆ.40។

664 ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.9, 15, 17-18 [បន្ទាប់ពីថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥៖ "ខ្ញុំមិនបានឃើញ មាស មុត មកដល់កំពង់សោមនៅថ្ងៃណាទេ តែពេលដែលខ្ញុំមកដល់ផែកំពង់សោមបាន ប្រហែល ២-៣ថ្ងៃ បានខ្ញុំឃើញមនុស្សម្នាក់ទៀតឈ្មោះ ឱម គ្រិន ហៅ ធុច រិន មកដល់ផែកំពង់សោម។ [...] ស៖ នៅពេលដែលលោកនៅកំពង់សោម១អាទិត្យ តើលោកបានរាយការណ៍ទៅកងពលលេខ៣ ប៉ុន្មានដងដែរ? ឆ.15៖ នៅពេលនោះខ្ញុំមិនបានរាយការណ៍ទៅ មាស មុត ទេ តែខ្ញុំរាយការណ៍ទៅ ឱម គ្រិន ដែលជាអ្នកគ្រប់គ្រងផែកំពង់សោម។ [...] ឆ.17៖ នៅពេលដែលខ្ញុំត្រឡប់មកពីកោះតាង ខ្ញុំទៅធ្វើការនៅក្រោមការគ្រប់គ្រងរបស់ គ្រិន ដដែល។ [...] ឆ.18៖ នៅខែសីហា ឆ្នាំ១៩៧៥ កងពលថ្មី១៦៤ ត្រូវបានបង្កើតឡើង ហើយកងអនុសេនាធំលេខ២ របស់ខ្ញុំត្រូវបានបញ្ជូនទៅកំពង់ផែ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ គ្រិន"]។

665 ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.34, 37 ["តាមពិត គ្រិន បានចាកចេញពីផែកំពង់សោម ទៅរៀននៅភ្នំពេញរយៈពេល១អាទិត្យ ហើយត្រឡប់មកកំពង់សោមវិញនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៧៨។ នៅពេលគាត់ត្រឡប់មកវិញ គាត់រៀបចំការប្រជុំ ហើយប្រាប់កម្មករទាំងអស់នៅផែថា គាត់ទៅធ្វើឯកអគ្គរដ្ឋទូតនៅហុងកុង។ បន្ទាប់ គ្រិន ចាកចេញទៅអ្នកដែលមកជំនួសគាត់នៅផែនោះមិនមែនជាមនុស្សមកពីផែទេ ប៉ុន្តែមកពីកងពល១៦៤។ [...] ឆ.37៖ នៅថ្ងៃប្រជុំ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៧៨ គ្រិនបានណែនាំឈ្មោះ ភាព និង ឈ្មោះ សួង។ ពួកគេទាំងពីរមកពីកងពលលេខ១៦៤។" (សង្កត់ន័យបន្ថែម)]។ ឯកសារ D1.3.30.29 បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជា នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៨០ KH ERN 00324759 ["ធុច រិន គាត់ក៏ភ័យដែរ

ឈ្មោះ (ឡុង) សារឿន, សុក ភាព និង ស្ងួង បានគ្រប់គ្រងយ៉ាងពេញលេញនូវកំពង់ផែកំពង់សោម និងកម្មកររបស់កំពង់ផែនេះ ចាប់ពីយ៉ាងហោចណាស់នៅចុងខែ កុម្ភៈ ឆ្នាំ ១៩៧៨ រហូតដល់ការមកដល់របស់វៀតណាមនៅដើមខែ មករា ឆ្នាំ ១៩៧៩[666]។ លើសពីនេះទៀត ពាក់ព័ន្ធនឹងការគ្រប់

ពេលគេផ្លាស់គាត់ពីតួនាទីប្រធានកំពង់ផែកំពង់សោម ទៅហុងកុង"]។ ឯកសារ D54/47.2 ទូរលេខពីគណៈកម្មាធិការពាណិជ្ជកម្ម ជូន ធុច រិន (គ្រិន) និង ផល វ៉ាំ ហៅ ណាត នៅហុងកុង ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៨ EN ERN 00701958-59, KH ERN 00076290-91, FR ERN 00665451 [ពិភាក្សាអំពីការផ្ទេរឈ្មោះ និងភាគទុនរបស់ក្រុមហ៊ុនកម្ពុជាឈ្មោះ រ៉េន ហ្វុង នៅទីក្រុងហុងកុង ពីឈ្មោះ អ៊ឹង សុខ ទៅឲ្យឈ្មោះ ធុច រិន ហៅ គ្រិន និងពីឈ្មោះ ផល វ៉ាំ ហៅ ណាត ទៅអ្នកផ្សេង]។ ឯកសារ D98/3.1.249 ប្រតិចារឹក សតិម ល្អុត ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ ម៉ោង 15.39.50-15.48.25 [បញ្ជាក់ថាអ្នកណាជា សុខ និងព្រឹត្តិការណ៍ផ្ទេរភាគទុនទៅឲ្យ គ្រិន ដែលជាអតីតគណៈកំពង់ផែសមុទ្រ៖ "រ៉េន ហ្វុង វាឈ្មោះក្រុមហ៊ុន ហើយនិងភាគទុន វាមានៗ ណាត វាមាន សុខ ហើយត្រូវផ្ទេរពីមួយទៅមួយ គឺថាផ្ទេរទៅមួយ មួយទៀតអស់សិទ្ធិហើយ ឧបមាថាផ្ទេរពី ណាត ទៅ គ្រិន, គ្រិន ជាម្ចាស់ភាគហ៊ុនថ្មី ណាត ហ្នឹងអស់ហើយ"]។ ម៉ោង 15.53.11-15.56.58 [បានរៀបរាប់ក្នុងសំបុត្រផ្សេងមួយទៀតដែលចេញដោយគណៈកម្មាធិការពាណិជ្ជកម្ម ទៅឲ្យឈ្មោះ គ្រិន និង ណាត ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៧៨ ដោយបានហៅ ណាត និង សុខ ឲ្យត្រឡប់មកកម្ពុជាវិញ និងផ្ទេរភាគទុនរបស់ពួកគេឲ្យទៅ គ្រិន]។ សូមមើលផងដែរ ភស្តុតាងនៃការជាប់ពន្ធនាគាររបស់ សុខ និង ប្រពន្ធរបស់គាត់ ណាត នៅមន្ទីរស-២១៖ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស EN ERN 01222853 លេខរៀង ១២៧៩៥, ១៤៨៤៩ [លេខរៀង ១២.៧៩៥ អ៊ឹង សុខ ប្រធានពាណិជ្ជកម្មប្រចាំទីក្រុងហុងកុង ពាណិជ្ជកម្មរដ្ឋ, ថ្ងៃខែចូល ស-២១៖ ២៩ ធ្នូ ១៩៧៨។ លេខរៀង ១៤.៨៤៩ ផល វ៉ាំ ហៅ ណាត សមាជិកគណៈកម្មាធិការពាណិជ្ជកម្មប្រចាំទីក្រុងហុងកុង ពាណិជ្ជកម្មរដ្ឋ, ថ្ងៃខែចូល ស-២១៖ ៣០ ធ្នូ ១៩៧៨]។

666 ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.34, 37 ["គ្រិន [...] គាត់ទៅធ្វើឯកអគ្គរដ្ឋទូតនៅហុងកុង។ បន្ទាប់ គ្រិន ចាកចេញទៅអ្នកដែលមកជំនួសគាត់នៅផែនោះមិនមែនជាមនុស្សមកពីផែទេ ប៉ុន្តែមកពីកងពល១៦៤។ [...] ស៖ តើអ្នកមកមកជំនួស គ្រិន ដែលមកពីកងពល១៦៤ ជាអ្នកណា? ឆ.37៖ នៅថ្ងៃប្រជុំ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ ១៩៧៨ គ្រិនបានណែនាំឈ្មោះ ភាព និង ឈ្មោះ ស្ងួង។ ពួកគេទាំងពីរមកពីកងពលលេខ១៦៤។ ភាព មានតួនាទីជាប្រធានស្តីទីនៅផែ ហើយស្ងួង ជាអនុប្រធាន។ ក្រោយមកប្រហែលខែមិថុនា ឬ ខែកក្កដា ឆ្នាំ១៩៧៨ សារឿន មកពីកងពល១៦៤ ដែរនោះ មកធ្វើជាប្រធានកំពង់ផែ។ ភាព ក្លាយជាអនុប្រធាន ហើយ ស្ងួង ក្លាយជាសមាជិកវិញ។ ក៏ប៉ុន្តែ សារឿន មិននៅផែជាអចិន្ត្រៃយ៍ទេ ដូច្នេះនៅពេលគាត់អវត្តមាន ភាព និង ស្ងួង ជាអ្នកទទួលខុសត្រូវជំនួស។ ពួកគេមិនដែលជ្រើសរើសមនុស្សមកពីកំពង់ផែមកកាន់តួនាទីសំខាន់ ឬតួនាទីខ្ពស់នោះទេ។ ពួកតែងតែយកមនុស្សមកពីកងពល១៦៤" (សង្កត់ន័យបន្ថែម)]។ ឯកសារ D114/195 កំណត់ហេតុស្តាប់ចម្លើយ នាក់ ខឿន ឆ.17, 19 ["ស៖ តើលោកដឹងថាអ្នកណាឡើងមកជំនួសគ្រិនដែរទេ នៅឆ្នាំ១៩៧៨? ឆ.17៖ ខ្ញុំនៅហ្នឹង ខ្ញុំដឹងមុនរត់។ មុននឹងវៀតណាមចូល ខ្ញុំបានរត់ចេញពីកំពង់ផែ ចុងឆ្នាំ១៩៧៨ វាដូចជាឈ្មោះប្រហែលជាតាសារឿន រាងខ្មៅបន្តិច។ គាត់នៅកន្លែងហ្នឹង មិនបានមួយឆ្នាំទេ គឺប្រហែលជា៥ ឬ៦ខែមុនពេលដាច់របប។ គេផ្លាស់ពីគ្រិន មកតាសារឿន ហ្នឹង [...] ស៖ តើតាសារឿ

គ្រងលើតំបន់កំពង់សោមនេះផ្ទាល់តែម្តង **មាស មុត** គឺជាលេខានៃ"គណៈកម្មាធិការ ប.ក.ក ប្រចាំក្រុងកំពង់សោម" ហេតុដូច្នេះហើយ គាត់មានឋានៈខ្ពស់ជាងគ្រិន (អនុលេខា) និង ឡាញ (សមាជិក មកពីជលផលរដ្ឋ)[667]។

ន មកពីជួរយោធាមែនទេ? ឆ.19៖ ខ្ញុំឮថាគាត់ផ្លាស់ពីយោធាមក"]។ ឯកសារ D54/73 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.6, 9 ["ស៖ [...] [នៅក្នុងកងពលធំលេខ១៦៤] តើអ្នកណាជាអនុរបស់ មាស មុត? ឆ.6៖ ខ្ញុំមិនដឹងថាអ្នកណាជាមេបញ្ជាការ អ្នកណាជាអនុទេ ប៉ុន្តែនៅក្នុងគណៈរបស់គាត់មានគ្នាបីនាក់ គឺមាន តា មុត, តា សារឿន, និងតា ញ៉ាន់ [...] ឆ.9៖ តា សារឿន ក្រោយមត្រូវបានបញ្ជូនទៅធ្វើការនៅផែកំពង់សោម"]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968421, KH ERN 00926645 ["បាទ! ម៉ារៀបដំបូងនឹង ដំបូងបំផុតនឹង [ខាងវរសេនាធំ១៤០] មានឈ្មោះតាសារឿន។ [...] សារឿងនឹងប្រធាន [...] តាសារឿន គេដកមកគ្រប់គ្រងផែ"]។ ឯកសារ D54/82 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ិច ឆ.17 ["កាលពីម្សិលមិញ ខ្ញុំបាននិយាយអំពីឈ្មោះ សារឿន រួចទៅហើយ។ ខ្ញុំសង្ស័យថាឈ្មោះ រឿន និងឈ្មោះ សារឿន ជាមនុស្សតែមួយ"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៊ាង រ៉េត (ប៊ាង រ៉េត) ឆ.28 ["នៅពេលកងពលលេខ៣ ប្តូរទៅជាកងពល ១៦៤ នៅកំពង់សោម មាន មាស មុត ជាមេបញ្ជាការ។ ហើយមេបញ្ជាការរងត្រូវបានផ្លាស់ប្តូរជាបន្តបន្ទាប់ ដែលរួមមាន តារិន, តាឆាន និងតាខឹម [...] តាញ៉ាន់ ជាមេបញ្ជាការកងវរសេនាធំ៦៣។ សារឿន ជាមេបញ្ជាការកងវរសេនាធំ១៤០។ ក្រោយមកសារឿន ត្រូវបានជំនួសដោយ ទឹម សេង"]។ ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.26 ["ស៖ តើអ្នកណាបញ្ជូនលោកពីកំពង់សោមទៅភូមិភាគបូព៌ា? ឆ.26៖ គឺ តា សារឿន (ស្លាប់)។ គាត់ជាអ្នកជំនួស តាគ្រិន បន្ទាប់ពី គ្រិន បាត់ខ្លួន"]។

667 ឯកសារ D22.1.10 (ហ្វ៊ីប៊ីស) គណៈប្រតិភូចិន ធ្វើទស្សនកិច្ចនៅតំបន់កំពង់សោម ថ្ងៃទី១២ ខែធ្នូ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 01194843 ["សមមិត្ត Chen Yung kuei និងសមមិត្តដទៃទៀត ត្រូវបានទទួលស្វាគមន៍ដោយសមមិត្តមុត លេខាបក្សកុម្មុនីស្តកម្ពុជាក្រុងកំពង់សោម និងជាប្រធានគណៈកម្មាធិការបម្រើប្រជាជនកំពង់សោម, សមមិត្ត គ្រិន អនុលេខាបក្សកុម្មុយនីស្តក្រុងកំពង់សោម, សមមិត្ត ឡាញ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជាកំពង់សោម"]។ Chen Yung-kuei ធ្វើទស្សនកិច្ចទៅតំបន់នីរតី KH ERN 01063905។ ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.32-33 ["តាមការយល់របស់ខ្ញុំ មាស មុត មានតួនាទីធំជាង គ្រិន ពីព្រោះគាត់មកពីគណៈយោធា។ [...] ឆ.33៖ ប៉ុន្តែពេលនោះ មាស មុត ទទួលខុសត្រូវខាងយោធា ហើយ គ្រិន ទទួលខុសត្រូវខាងស៊ីវិល កម្មករនៅផែ។ មាស មុត ជាតំណាងបក្សកុម្មុយនីស្តកម្ពុជានៅកំពង់សោម ចំណែកឯ គ្រិន ជាអនុលេខា"]។ ឯកសារ D54/31 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.10-12 ["មាស មុត ជាគ្រិន តាឡាញ គឺជាគណៈកម្មការមជ្ឈឹមនៅកំពង់សោម។ មាស មុត ទទួលខុសត្រូវខាងយោធា ហើយជា គ្រិនទទួលខុសត្រូវខាងកំពង់ផែ និងរោងចក្រប្រេងកាត ឯ ឡាញទទួលខុសត្រូវនេសាទ [...] ឆ.11៖ មាស មុត គឺជាប្រធានធំជាងគេ បន្ទាប់មក ជា គ្រិន និង ឡាញ [...] ឆ.12៖ គេត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវមុខងារផ្សេងៗគ្នា ប៉ុន្តែឋិតនៅក្រោមការគ្រប់គ្រងរបស់ មាស មុត។ មាស មុត គឺទទួលខុសត្រូវរួមទាំងអស់ ហើយរួមទាំងផ្ទៃសមុទ្រផង។ ឯកសារ D4.1.1030 បទសម្ភាសន៍ជាមួយ ឆាប ឡុន ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ

222. ក្នុងនាមជាមេបញ្ជាការរបស់កងពលធំមជ្ឈិម និងដូច្នេះជាសមាជិកនៃគណៈកម្មាធិការអគ្គសេនាធិការ (និងក្រោយមកជាអនុប្រធាន)[668] **មាស មុត** មានអំណាចទាក់ទងនឹងដែនដីទឹកកម្ពុជាលើកងពលធំ កងទ័ពភូមិភាគទាំងអស់ ដែលត្រូវបានដាក់ពង្រាយនៅលើដីគោកនៅតាមឆ្នេរសមុទ្រ ជាពិសេស កងពលធំលេខ ១ នៅភូមិភាគបស្ចិម[669]។

---

២០០១ EN ERN 00526844 ["គ្រិន (ធុច រិន, អ៊ុក គ្រុន) អនុលេខាគណៈកម្មាធិការកំពង់សោម]។ សូមមើលផង ដែរ ឯកសារ D114/218 កំណត់ហេតុស្តាប់ចម្លើយ សាំ គំនិត ហៅ ហ៊ុត ឆ.20 ["ខាងកំពង់សោម ស្ថិតក្រោមយោធា កាន់កាប់។ កំពង់ផែកំពង់សោម និងក្រុងកំពង់សោម ស្ថិតក្រោមការគ្រប់គ្រងផ្សេងគ្នា"]។

668 ឯកសារ D54/110 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.9 ["ហើយវាមិនមែនមានតែសម្រាប់កងពល១៦៤មួយទេ កងពលណាក៏ដោយដែលជារបស់មជ្ឈិមមេបញ្ជាការកងពលទាំងនោះ គឺជាសមាជិកគណៈបញ្ជាការរបស់សេនាធិកា រ។ ពេលណាដែលកងពលក្លាយទៅជាកងពលរបស់មជ្ឈិម មេបញ្ជាការរបស់កងពលនោះក្លាយជាសមាជិកគណៈក ម្មាធិការសេនាធិការ"]។ ឯកសារ D32/10 កំណត់ហេតុស្តាប់ចម្លើយ ខៀវ សារ៉ន ឆ.15 ["សៈ តើនរណាខ្លះជា សមាជិកសេនាធិការ? ឆ.15៖ មេបញ្ជាការកងពលទាំងអស់ រួមទាំងមេបញ្ជាការវរៈសេនាតូចនិងវរៈសេនាធំស្វយ័ត្ត ដូចជា ម៉ៅជាដើមជាសមាជិករបស់សេនាធិការ"]។ ឯកសារ D12 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុ ច EN ERN 00680797-98, KH ERN 00680803-04 ["បន្ទាប់ពីមនុស្សទាំងនេះ [សុន សេន ឬ បង៨៩ ម៉ែន សាន ហៅ យ៉ា និង សៀត ឆែ ហៅ ទុំ ឬបង៨១] មានសមាជិក គឺមាស មុត Meas Muth ទទួលបន្ទុកកងទ័ពជើងទឹក ស៊ូ ម៉េត Sou Met ទទួលបន្ទុកជើងអាកាស [...] មាស មុត Meas Muth និង ស៊ូ ម៉េត Sou Met ជាសមាជិកអគ្គសេនា ធិការទទួលបន្ទុកកងទ័ពជើងទឹក និងអាកាស [...] ភាពជាសមាជិកអគ្គសេនាធិការនេះ គឺ ត្រូវបានតែងតាំងសម្រាប់ មួយរបបពេញតែម្តង"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.9 ["មាស មុត គឺជាមេ បញ្ជាការកងពលលេខ៣ ហើយគាត់គឺជាអនុរបស់ សុន សេន ដែលនៅសេនាធិការរបស់កងទ័ពជាតិ"]។ ឯកសារ D54/60.2 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ឹង វ៉េត EN ERN 01212291, KH ERN 00975728 ["សៈ អ៊ីចឹង តា មុត គាត់ឡើងទៅជាអគ្គសេនាធិការគាត់គ្រប់គ្រងកងពលជើងទឹកវិញ? ឆ៖ ជើងទឹកផង ហើយគាត់រួមជាមួយតា ខៀវ នេះ ជាមួយតា សុន សេន រួមទូទាំងប្រទេស គាត់ជាអគ្គសេនាធិការរង ដល់អ៊ីចឹងគាត់ គ្រប់គ្រងទិសទាំងអស់"]។

669 ឯកសារ D54/54 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន (ស្វាយ វឿន) ឆ.4-5 ["សម្រាប់ខ្ញុំ ខ្ញុំគ្រាន់តែជាសមាជិក របស់គណៈកងពលលេខ១ របស់ភូមិភាគបស្ចិមប៉ុណ្ណោះ។ កងពលរបស់ខ្ញុំនេះស្ថិតនៅថ្នាក់ភូមិភាគដែលមានឋានៈនៅ ក្រោមកងពលរបស់ មាស មុត ដែលនៅថ្នាក់មជ្ឈិម [...] ឆ.5៖ ក្រៅពីមុខងារជាមេបញ្ជាការកងទ័ពជើងទឹក មាស មុត ជាសមាជិកពេញសិទ្ធិរបស់បក្ស [...] ខ្ញុំបានសង្កេតឃើញថាការងាររបស់គាត់គឺផ្តោះបញ្ចាំងទៅនឹងតួនាទីមួយ ដែលគាត់ជាសមាជិកម្នាក់របស់គណៈកម្មាធិការសេនាធិការ ដោយសារខ្ញុំធ្លាប់បានឃើញគាត់មានសិទ្ធិណែនាំទៅកងជ ទៃៗទៀត ដូចជាកងពលលេខ១របស់ខ្ញុំជាដើម"]។ ឯកសារ D54/52 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន (ស្វាយ វឿន) ឆ.9-10 ["តាសឿង ទទួលខុសត្រូវកងពលលេខ១។ សៈ នៅក្នុងចំណុចដែល មាស មុត គាត់ទទួលមតិពីអង្គ

## គណៈកម្មាធិការកងពលធំលេខ ១៦៤

223. សមាសភាពនៃកងពលធំលេខ ១៦៤ បានប្រែប្រួលតាមពេលវេលា ដោយសារការបោសសម្អាតជាបន្តបន្ទាប់ដែលត្រូវបានធ្វើឡើងដោយ **មាស មុត** និងអគ្គសេនាធិការ/មជ្ឈិមបក្ស នៅក្នុងកងពលធំ[670]។ នៅខែ កក្កដា ឆ្នាំ ១៩៧៥ នៅពេលកងពលធំលេខ ១៦៤ ត្រូវបានបង្កើតឡើង គណៈកម្មាធិការនេះ មានសមាសភាព ដូចជា **មាស មុត** ជាមេបញ្ជាការ ឌឹម ជាមេបញ្ជាការរងទីមួយ[671]

---

ការ ហើយយកមកពិភាក្សាជាមួយនឹង តា សឿន និង តារ៉ន តើនេះបញ្ជាក់ឱ្យឃើញថា មាស មុត គាត់មានអំណាចសម្រាប់មើលពីលើការងារនៅក្នុងភូមិភាគហ្នឹងឬយ៉ាងម៉េច? ឆ.10៖ ពីព្រោះ មាស មុត តំណាងមកពីមជ្ឈិម គឺគាត់ត្រូវតែមើលការងារពីលើអ្នកទាំងនោះ"]។ ឯកសារ D54/34 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆុន ឆ.12 ["នៅពេលកងពលទី១ បានរាយការណ៍ទៅឱ្យមន្ទីរសារទូរលេខរបស់កងនាវានៅកោះកុងតាមរយៈវិទ្យុទាក់ទង។ អ្នកកាន់សារទូរលេខ រាយការណ៍បន្តទៅឱ្យតាមុត ហើយតាមុតជាអ្នកចេញបញ្ជា។ ចំពោះសំណួរដែលថា កងពលទី១ត្រូវរាយការណ៍ទៅឱ្យមន្ទីរសារទូរលេខរបស់កងពល១៦៤ ពីព្រោះកងពលទី១ មិនមាននាវាប្រយុទ្ធសម្រាប់ប្រឈមនឹងព្រឹត្តិការណ៍នោះទេ"]។ ឯកសារ D114/84 កំណត់ហេតុស្តាប់ចម្លើយ ឯក សុផល ឆ.15 ["ស៖ ប្រសិនបើការបញ្ជូនទ័ពទៅកោះត្រល់ ដើម្បីវ៉ៃជាមួយវៀតណាមស្ថិតក្រោមបញ្ជារបស់កងពល១៦៤ ចុះហេតុអ្វីបានជាមានការចូលរួមពីកងពលធំទី១? ឆ.15៖ កម្លាំងកងពលធំទី១ ត្រូវបានបញ្ជូនទៅ ដើម្បីជាកម្លាំងជំនួយ សម្រាប់គាំទ្រកងពល១៦៤។ កងពល១៦៤ ជាអ្នកស្នើសុំកម្លាំងពីតាមកងពលផ្សេងៗទៀត ហើយជាទម្លាប់កងពលផ្សេងៗទៀតនោះត្រូវតែបញ្ជូនកម្លាំងទៅជួយ"]។ សូមមើលផងដែរ អំពីសង្គ្រាមជាមួយវៀតណាម នៅឆ្នាំ១៩៧៨៖ ឯកសារ D54/50 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន (ស្វាយ វឿន) ឆ.6 ["ដោយសារកងពលនេះជាកងពលរបស់មជ្ឈិម គេមានសិទ្ធិចាប់ និងបាញ់សម្លាប់ យោធាកងពលណាដែលដកថយពីសមរភូមិមុខ។ របៀបនៃការបញ្ជូនយោធារបស់កងពលលេខ១ ទៅព្រំដែនខាងកើតមានដូចតទៅ គឺ តា សឿង ដែលជាមេបញ្ជាការកងពលលេខ១ បានបញ្ជូនកងខ្លះដែលស្ថិតនៅក្រោមកងពលរបស់គាត់ ទៅបញ្ចូលក្នុងកងពលលេខ១៦៤ ហើយកងពល១៦៤ ជាអ្នករៀបចំចាត់ចែងពង្រាយកម្លាំងទាំងនោះទៅតាមមុខព្រួញរបស់គេ"]។

670 សូមមើល VIII ក.៣ ប្រភេទនៃសមាសភាពមិនល្អ និងមានការជាប់ពាក់ព័ន្ធក្នុងកងពលធំលេខ ១៦៤ ដែលគេយកទៅបោសសម្អាត ពិសេសផ្នែក ឃ គេស្គាល់ថាជា "ជនក្បត់" នៅក្នុងកងពលធំលេខ ១៦៤ និងខ្សែរយៈរបស់ពួកគេ។

671 ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.12 ["ឌឹម គឺជាអនុទី១របស់ មាស មុត ហើយគាត់ជាអ្នកមកពីភូមិភាគបូព៌ា"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.12 ["ឌឹម ត្រូវបានបញ្ជូនមកពីភូមិភាគបូព៌ាមកធ្វើជាអនុកងពលរបស់ មាស មុត"]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.5, 14 ["ឌឹម ទៅកំពង់សោមមុនខ្ញុំនិង សំ ទៅទៀត។ នៅកំពង់សោម ឌឹម ជាអនុមេបញ្ជាការកងពល១៦៤។ សំ នៅកងវរសេនាធំ [...] ឆ.14៖មាស មុត ជាមេបញ្ជាការកងពល ហើយ ឌឹម ជាអនុរបស់ មាស មុត"]។ ឯកសារ D2/16 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី (សឿ ទូច) ឆ.10 ["ឌឹម គឺជាអនុកងពល"]។ ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.21 ["[ឌឹម] ជាអ្នកមកពីភូមិភាគបូព៌ា [...] ឌឹម គឺជាអនុរបស់ មាស មុត"]។ ឯក

ឆាន់ ជាមេបញ្ជាការរង[672] ម៉ែន ង៉ែត (ជាមេបញ្ជាការកងវរៈសេនាធំលេខ ៦១ ផងដែរ)[673] និង មុំ ជីមហៅ យ៉ាន (ក៏ជាមេបញ្ជាការកងវរៈសេនាតូចលេខ ៦៣ ផងដែរ)[674] ជាសមាជិក។ លើក

---

សារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត ឆ.53 ["មេបញ្ជាការរងឈ្មោះ ឌឹម។ គណៈកងពល១៦៤មានមេបញ្ជាការ មាស មុត, ឌឹម ជាអនុ, ហើយ ឆាន និង ញ៉ាន់ ជាសមាជិក"]។ ឯកសារ D54/95 កំណត់ហេតុស្តាប់ចម្លើយ ឃុន ថន (ឈុន ថន) ឆ.12 ["ឌឹម ជាយោធាខ្មែរក្រហម ហើយគាត់មានតួនាទីធំជាងបងប្រុសរបស់ខ្ញុំ [ឃុន ឌឹម]។ ឌឹម នៅកងខុសពីបងប្រុសរបស់ខ្ញុំ [នៅតំបន់២២]"។ ឯកសារ D54/44 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.5 ["ឌឹម ក្លាយជាអនុរបស់ មាស មុត ទទួលខុសត្រូវខាងបញ្ជាការយោធានៅក្នុងកងពល១៦៤"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.15 ["កងពល១៦៤ហ្នឹង មាន មាស មុត ជាស្នងការធំ ហើយមាននង ឆាន ជាបញ្ជាការកងពល ១៦៤។ បន្ទាប់មក គឺ ឌឹម ដែលជាបញ្ជាការរង។ បន្ទាប់មកគឺ ង៉ែត ជាសមាជិកកងពល"]។ ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន (ណាំ ឡូន) ឆ.19 ["ប៉ុន្តែនៅពេលដែលគេរៀបចំកងពល១៦៤ នោះ [ឌឹម] ក្លាយជាមេបញ្ជាការផ្នែកយោធា និងជាអនុរបស់ មាស មុត។ ក្រោយពីខ្ញុំត្រឡប់មកពីស្រុកចិនវិញ ហើយបានសួរយោធាដែលធ្វើការជាមួយគ្នាអំពី ឌឹម ពួកគេបានប្រាប់ខ្ញុំថា ឌឹម ត្រូវបានបញ្ជូនទៅធ្វើការនៅកន្លែងផ្សេងបាត់ទៅហើយ"]។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.50 ["តាឆាន ជាអនុបញ្ជាការ និងតាឌឹម ជាអនុបញ្ជាការ"]។ ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ ស៊ាង EN ERN 00217564 ["អនុប្រធានទី១ របស់ មុត ឈ្មោះ ឌឹម ជាមនុស្សមកពីភូមិភាគបូព៌ា។ ឌឹម បានបាត់ខ្លួនក្នុងឆ្នាំ ១៩៧៧ ពេលដែលមានជម្លោះផ្ទៃក្នុង"]។ ឯកសារ D54/92 កំណត់ហេតុស្តាប់ចម្លើយ យ៉ែម សំអុន ឆ.16។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ.66។ ឯកសារ D54/81 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ិច ឆ. 14។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ កឹម ម៉ែន ឆ.31។

672 ប្រភពជាច្រើនបានបញ្ជាក់ថាគាត់ជាអនុមេបញ្ជាការ។ អ្នកខ្លះផ្សេងទៀតជាសមាជិកគណៈកម្មាធិការកងពលធំលេខ ១៦៤ (និងជាគណៈកម្មាធិការកងពលធំលេខ៣ ក្នុងអំឡុងពេលដែលមានការបញ្ចូលគ្នារវាងកងពលធំលេខ៣ ជាមួយនឹងកងកម្លាំងពីតំបន់៣៧ របស់ ឆាន រួមទាំងវរសេនាតូចលេខ ៣៨៦)៖ ឯកសារ D114/277.2 ប្រតិចារឹក កាំង ហ្កេកអ៊ាវ ហៅ ឌុច ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង 11.07.31-11.10.23 ["ជ័យ ហាន ហៅ ឆាន់។ វាជាអនុលេខាកងពល១៦៤ជាមួយ បងមុត"]។ ឯកសារ D114/159 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ឆ. 33 ["មនុស្សដែលសំខាន់ជាងគេ ដែលចាប់ពីកំពង់សោម ឈ្មោះ សៅ ឆាន ហៅ ហាន ដែលជាកូន នងសួន។ សូមកែឈ្មោះគឺ ជ័យ ហាន ហៅ ឆាន"]។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ើ រ៉េត ហៅ សារ៉េត ឆ.7 ["ក្រោយពីកងពលលេខ ៣ប្តូរទៅជាកងពល១៦៤ មានមនុស្សម្នាក់ឈ្មោះ តា ឆាន ដែលមកពីកោះកុងនៃតំបន់ ៣៧ ជាមួយនឹងយោធាប្រហែលពីរកងវរៈសេនាតូចចូលជាមួយកងពល១៦៤។ តា ឆានមកធ្វើជាអនុម្នាក់របស់កងពល"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.12 ["វានៅមានអនុរបស់គាត់ពីរនាក់ទៀត ឈ្មោះ ឆាន និង ឌឹម។ ឌឹម គឺជាអនុទី១របស់ មាស មុត"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង សុំ ឆ.267, 269 ["ស ៖ អ្នកណាជាបញ្ជាការរងកងពល? ឆ.267៖ តាឌឹម និងតា ឆាន។ [...] ឆ.269៖ តាឆានជាអនុបញ្ជាការកងពល"]។ ឯកសារ D234/2.1.92 ប្រតិចារឹក ព្រុំ សារ៉ាត ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 15.03.11-15.06.23 [បាន

ចង្អុលបង្ហាញថា សមាជិកគណៈកងពលធំ គឺ មាស មិត, ឌឹម, ឆាន និង ញ៉ាន់]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត ឆ.86 ["មាស មុត ទទួលបន្ទុកកិច្ចការនយោបាយ។ ឌឹម មេបញ្ជាការរងកងពលទទួលបន្ទុកកិច្ចការយោធា។ ឆាន ទទួលបន្ទុកខាងមេបញ្ជាការរង និង ញ៉ាន់ ទទួលបន្ទុកខាងភស្តុភារ"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ.28 ["នៅពេលកងពលលេខ៣ ប្តូរទៅជាកងពល១៦៤ នៅកំពង់សោម មាន មាស មុត ជាមេបញ្ជាការ។ ហើយមេបញ្ជាការរងត្រូវបានផ្លាស់ប្តូរជាបន្តបន្ទាប់ ដែលរួមមាន តារិន, តាឆាន និងតាឌឹម"]។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.50 ["តាឆាន ជាអនុបញ្ជាការ និងតាឌឹម ជាអនុបញ្ជាការ"]។ ឯកសារ D114/241 កំណត់ហេតុស្តាប់ចម្លើយ ឆេង ជាង ឆ.87 ["ឆាន អនុ"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.15 ["កងពល១៦៤ហ្នឹង មាន មាស មុត ជាស្នងការធំ ហើយមាន នង ឆាន ជាបញ្ជាការកងពល ១៦៤។ បន្ទាប់មក គឺ ឌឹម ដែលជាបញ្ជាការរង។ បន្ទាប់មកគឺ ង៉ែត ជាសមាជិកកងពល"]។ ឯកសារD4.1.746 បទសម្ភាសន៍ជាមួយ សំ សុក ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387462, KH ERN 00742596 ["មន្ត្រីនយោបាយរបស់កងពលធំលេខ ៣ គឺលោក មាស មុត (MEAS Mut) មន្ត្រីប្រតិបត្តិការកងពលធំលេខ ៣ គឺ ឌុំ (Dum) (ស្លាប់) ហើយមេបញ្ជាការរងនៃកងពលធំលេខ ៣ គឺ ឆាន (Chhan)"]។ ឯកសារ D4.1.747 បទសម្ភាសន៍ជាមួយ ឯក នី ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387291, KH ERN 00640517 ["លោក (ណុង) ចាន់ គឺជាមន្ត្រីនយោបាយកងពលធំទី៣"]។ ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.30 ["ក្រោយពីការរៀបចំឡើងវិញរបស់កងពល១៦៤នេះ លោក មុត ជាប្រធាន, លោក ឌឹម ជាអនុប្រធាន ដែលមកពីបូព៌ា និងលោក ឆាន ជាសមាជិក"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ កឹម ម៉េន ឆ.31 ["ក្រោយពីដាក់ទ័ពវាយតាមកោះ គេរៀបចំកងពលសាជាថ្មីទៅជាកងពលលេខ១៦៤ ដោយមាន មាស មុត ជាមេបញ្ជាការ ឌឹម ជាអនុប្រធាន (មកពីខេត្តព្រៃវែង) និង ឆាន ជាសមាជិក"]។ ឯកសារ D54/81 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.14 ["មេបញ្ជាការកងពលលេខ៣ឈ្មោះ អ៊ំ មុត។ [...] អនុកងពលឈ្មោះ ឌឹម មកពីភូមិភាគបូព៌ា។ សមាជិកកងពលមកពីខេត្តកោះកុងឈ្មោះបង ឆាន។ ក្រោយមក យ៉ាន មកកាន់កងពល១៦៤ជាមួយ អ៊ំ មុត ដែរ"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.36, 269 ["តាមុត ជាប្រធាន, តា ឌឹម ជាអនុ ហើយតា ឆាង ជាសមាជិកកងពល។ [...] ឆ.269៖ តាឆានជាអនុបញ្ជាការកងពល"]។ ឯកសារ D114/261 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី ឆ.34។ ឯកសារ D54/17 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.6-7, 10។

673 យោងទៅតាមឯកសារមន្ទីរ ស-២១ ហើយនិងសាក្សីមួយចំនួន ពាក់ព័ន្ធជាមួយនឹងមេបញ្ជាការកងវរសេនាធំ ម៉ែន ង៉ែត បានស្ថិតក្នុងមុខតំណែងជាសមាជិកគណៈកម្មាធិការកងពលធំលេខ១៦៤ គឺបន្ទាប់ពីត្រូវបានគេដកចេញពីមុខតំណែងមុន ដែលជាអនុមេបញ្ជាការកងពលធំលេខ ៣៖ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស [កំណត់អត្តសញ្ញាណ ឈ្មោះ មែន ង៉ែត លេខរៀង ៥៣៤២ ដែលជាសមាជិកមួយនៅកងពលលេខ១៦៤ បានបញ្ជូនទៅមន្ទីរស-២១ នៅខែមិថុនា ឆ្នាំ១៩៧៧]។ ឯកសារ D9.3 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស ពីកងពលធំលេខ១៦៤ លេខរៀង ២៦។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.15 ["កងពល១៦៤ហ្នឹង មាន មាស មុត ជាស្នងការធំ ហើយមាន នង ឆាន ជាបញ្ជាការកងពល ១៦៤។ បន្ទាប់មក គឺ ឌឹម ដែលជាបញ្ជាការរង។ បន្ទាប់មកគឺ ង៉ែត ជាសមាជិកកងពល"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់

លែងតែ

**មាស មុត** កម្មាភិបាលដែលមានឋានន្តរសក្តិខ្ពស់ទាំងនេះ ត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរ ស-២១ នៅចន្លោះចុងឆ្នាំ ១៩៧៦ និងពាក់កណ្ដាលឆ្នាំ ១៩៧៧ ហើយបន្ទាប់មកត្រូវបានសម្លាប់ បន្ទាប់ពីការសារភាពរបស់ពួកគេត្រូវបានចាត់ទុកថាបានចប់សព្វគ្រប់ ៖ ឆាន់ គឺជាអ្នកទីមួយដែលបានចូលទៅ

ចម្លើយ ឯក នី ឆ.4 ["ម៉ែន ង៉ែត គឺជាសមាជិកគណៈកងពល១៦៤"]។ ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី (Ni) ឆ.12 ["ថ្នាក់កងពលមាន ឆាន, អ៊ំង៉ែត, បងយ៉ាន, បងឌឹម"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ.64, 66 ["ស៖ តើលោកអាចប្រាប់ឈ្មោះអ្នកដែលលោកស្គាល់ ហើយគេនាំយកទៅនោះបានដែរទេ? ឆ.64៖ មានឈ្មោះ ង៉ែត, ឈ្មោះ ឌឹម, ឈ្មោះ យ៉ាន, ឈ្មោះ ឆាន និងឈ្មោះ សុខ ជាដើម ដែលគេចោទថាជាគិញវៀតណាម ឬក៏សេអ៊ីអា។ [...] ឆ.66៖ ដូចជា ង៉ែត ជាអនុរបស់ មាស មុត។ ឌឹម នៅក្រោម មាស មុត នៅថ្នាក់កងពល។ ឆាន នៅថ្នាក់កងពល។ យ៉ាន ប្រធានវរសេនាធំ។ សុខ ជាប្រធានពេទ្យនៅកងពល"]។ ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.58 ["ស៖ តើលោកដឹងថាមានសមាជិកមកពីកងពល១៦៤ ត្រូវបានគេបញ្ជូនទៅទួលស្លែង ឬស-២១ដែរឬទេ? ឆ.58៖ ខ្ញុំមិនដឹងទេ។ តែខ្ញុំឮថា ង៉ែត និងស្រស់ ត្រូវបានចាប់ខ្លួន"]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.8 ["ហើយង៉ែតជាស្នងការវរៈសេនាធំ២០ ង៉ែតត្រូវបានគេចាប់ក្នុងរយៈពេលបោសសំអាតប្រហែលក្នុងឆ្នាំ១៩៧៧"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.4 ["តាមដែលខ្ញុំចាំឈ្មោះ យ៉ាន មេបញ្ជាការវរៈសេនាធំ ២២, ង៉ែត មេបញ្ជាការវរៈសេនាធំ ២០ និងមេបញ្ជាការវរៈសេនាតូចរបស់ខ្ញុំឈ្មោះ វេត"]។

674 ឯកសារ D1.3.28.45 បញ្ជីអ្នកទោសនៅមន្ទីរស-២១ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៧៧ EN ERN 01321440 [កំណត់អត្តសញ្ញាណលេខរៀង ៣ ឈ្មោះ ម៉ម ជឹម ហៅ យាន ជាសមាជិកកងពលធំ១៦៤]។ ឯកសារ D1.3.28.2 បញ្ជីអ្នកទោសនៅមន្ទីរស-២១ ចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ១៩៧៧ EN ERN 01321750, KH ERN 00086996 [កំណត់អត្តសញ្ញាណ លេខរៀង ១ ឈ្មោះ មុំ យាន ជាសមាជិកកងពលធំលេខ១៥៤ មានអាយុ ៣០ឆ្នាំ ដែលត្រូវបានបញ្ជូនទៅស-២១នៅខែឧសភា ឆ្នាំ១៩៧៧]។ ឯកសារ D114/116 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.27 ["មុំ យ៉ាន គឺជាមនុស្សម្នាក់ដែលស្ថិតនៅក្នុងកងពល១៦៤ នៅក្នុងឆ្នាំ១៩៧៥"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី (នី) ឆ.5 ["យ៉ាន ជាសមាជិកគណៈកងពល១៦៤"]។ ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.12 ["ថ្នាក់កងពលមាន ឆាន, អ៊ំង៉ែត, បងយ៉ាន, បងឌឹម"]។ ឯកសារ D114/155 កំណត់ហេតុស្តាប់ចម្លើយ សុខ រ៉េន ឆ.67 ["ស៖ តើនរណាគេជាមេបញ្ជាការកងពល១៦៤? ឆ.67៖ [...] មេកងពល១៦៤ ឈ្មោះ មាស មុត។ [...] ស្គាល់តែ តាឌឹម តាយ៉ាន និង តាឆាន។ តាឆាន ចូលរួមកងពល១៦៤"]។ ឯកសារ D54/81 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.14 ["អនុកងពលឈ្មោះ ឌឹម មកពីភូមិភាគបូព៌ា។ សមាជិកកងពលមកពីខេត្តកោះកុងឈ្មោះបង ឆាន។ ក្រោយមក យ៉ាន មកកាន់កងពល១៦៤ជាមួយ អ៊ំ មុត ដែរ"]។ ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន ឆ.26 ["តាមខ្ញុំដឹង យ៉ានហ្នឹងគឺគាត់នៅកាន់គណៈកងពលធំលេខ៣"]។

ក្នុងមន្ទីរ ស-២១ ដោយសារទោសក្បត់ជាតិ ប្រហែលនៅក្នុងខែ តុលា ឆ្នាំ ១៩៧៦[675] ហើយបន្ទាប់មក គឺ ឌឹម នៅថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៧[676] យ៉ាន នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៧[677] និង ង៉ែត នៅដើមខែ មិថុនា ឆ្នាំ ១៩៧៧[678]។

---

675 សូមមើល ឧទាហរណ៍ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស លេខរៀង ១៩១៥៦ [ជ័យ ហាន ហៅ ឆាន, បានសរសេរខុសថា គាត់ចូល ស-២១ ក្នុងខែ វិច្ឆិកា ឆ្នាំ ១៩៧៦]។ ឯកសារ D114/145.1.1 ចម្លើយសារភាពរបស់ ជ័យ ហាន ហៅ ឆាន ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ EN ERN 01191572, KH ERN 01176817 [មានចំណារមួយចំនួនសរសេរដោយអ្នកសួរចម្លើយ ប៊ុន ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៧៦ ដែលវាបណ្តាលឲ្យគាត់ត្រូវគេចាប់ខ្លួនមុនពេលឪពុករបស់គាត់ និងមុនខែ វិច្ឆិកា ឆ្នាំ ១៩៦៧ ដូចដែលបានបញ្ជាក់ក្នុងឯកសារ D114/230.1.1] EN ERN 01191539, KH ERN 01176685 [ការសួរចម្លើយលើកទី៣ ធ្វើឡើងនៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៧៦]។ សូមមើលផងដែរឯកសារយោងផ្សេងទៀតក្នុងសំណុំរឿង ០០៣ ពាក់ព័ន្ធនឹងចម្លើយសារភាពនៅ ស-២១ របស់ ជ័យ ហាន ហៅ ឆាន៖ ឯកសារ D22.2.42, ឯកសារ D22.2.26, ឯកសារ D22.2.30, ឯកសារ D22.2.46, ឯកសារ D22.2.39, ឯកសារ D22.2.37, ឯកសារ D22.2.28, ឯកសារ D22.2.33, ឯកសារ D22.2.23, ឯកសារ D22.2.31, ឯកសារ D22.2.32, ឯកសារ D22.2.45, ឯកសារ D22.2.41, ឯកសារ D22.2.35, ឯកសារ D22.2.43, ឯកសារ D22.2.47, ឯកសារ D22.2.38, ឯកសារ D22.2.36, ឯកសារ D22.2.44, ឯកសារ D22.2.29, ឯកសារ D22.2.25, ឯកសារ D22.2.40, ឯកសារ D22.2.34, ឯកសារ D22.2.24, ឯកសារ D22.2.27; ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.11 ["បងឆាន បន្ទាប់ពីតាមុត។ តាមុត ចាប់យកទៅសម្លាប់នៅបឹងជើងឯកនេះ នៅភ្នំពេញ"]។ ឯកសារ D114/226 កំណត់ហេតុស្តាប់ចម្លើយ គីម ហាវ ឆ.82-85 ["[ឆាន] ស្លាប់ឆ្នាំ៧៧ [...] ឆ.83៖ ស្លាប់ដោយ ប៉ុល ពត យកទៅរៀនសូត្រយកទៅសម្លាប់។ គេថាទៅរៀនសូត្រៗ ទៅបាត់បណ្តោយ។ ស៖ តើអ្នកណាមកហៅគាត់ទៅរៀនសូត្រ? ឆ.84៖ ពួកភូមិភាគ [...] ឆ.85៖ អត់ដឹងទេ ទ័ពខ្ញុំដឹងថា គេឲ្យចៅហ្វាយខេត្តទៅរៀនសូត្របាត់ហើយ យើងអត់ដឹងទេ។ គេថាអង្គការហៅទៅរៀនសូត្របាត់ហើយ។ កាលជំនាន់នោះ គេថាទៅរៀនសូត្រៗ គឺយកទៅសម្លាប់ចោល"]។ ឯកសារ D114/159 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ឆ.33 ["មនុស្សដែលសំខាន់ជាងគេ ដែលចាប់ពីកំពង់សោម ឈ្មោះ សៅ ឆាន ហៅ ហាន ដែលជាកូន នងសួន។ សូមកែឈ្មោះគឺ ជ័យ ហាន ហៅ ឆាន"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.60 ["កាលហ្នឹងអ្នកបញ្ជូនមកពីកោះ ខ្ញុំមិនដឹងថាមានប៉ុន្មាននាក់ទេ តែ មាស មុត ប្រជុំពីបញ្ហា មេក្បត់គឺអនុមេបញ្ជាការកងពល ១៦៤ នង ឆាន ជាអ្នកក្បត់ ហើយ មាស មុត អានចម្លើយសារភាពរបស់ នង ឆាន ហ្នឹង"]។ ឯកសារ D4.1.747 បទសម្ភាសន៍ជាមួយ ឯក នី ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387291, KH ERN 00640517 ["លោក (ណុង) ចាន់ គឺជាមន្ត្រីនយោបាយកងពលធំទី៣។ លោក ត្រូវបានសម្លាប់ នៅក្នុងការបោសសម្អាតបុគ្គលិកមេបញ្ជាការពីកងពលធំ ក្នុងឆ្នាំ១៩៧៦"]។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.53 ["តាឆាន គេនាំយកទៅមុន។ តាឌឹម គេនាំទៅក្រោយ"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ កឹម ម៉េន ឆ.126, 258។ ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.28។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ើ រ៉េត ហៅ សារ៉េត ឆ.7-8។ ឯកសារ D69.2.20 ប៊ីប៊ីស៊ី

អេស.ឌេប៊ើលយូ.ប៊ី BBC SWB ទំនាក់ទំនងនៃបណ្តាប្រទេសចុងបូព៌ា ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៧៨ EN ERN S 00013194, KH ERN S 00810138, FR ERN S 00793509. សូមមើលផងដែរ កថាខណ្ឌ ៣៥០ [កន្លែងដែលបានពន្យល់ថា ដំបូង ឆាន ត្រូវបានផ្លាស់ចេញពីកងពលធំលេខ ១៦៤ ទៅអគ្គសេនាធិការ បន្ទាប់មកចាប់ខ្លួននៅទីនោះ វាគឺជាយុទ្ធសាស្ត្រដែលប្រើដើម្បីបញ្ចៀសការរឹងទទឹងពីគាត់]។

676 ឯកសារ D114/230.1.1 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស លេខរៀង ១៦២៤ [ចូលស-២១ នៅថ្ងៃទី ២១ ខែមេសា ឆ្នាំ១៩៧៧]។ ឯកសារ D9.3 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស ពីកងពលធំលេខ១៦៤ លេខរៀង ១១ [សម្លាប់នៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ១៩៧៧]។ ឯកសារ D1.3.28.40 បញ្ជីឈ្មោះអ្នកទោសកំទេច នៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៩៧៧ EN ERN 00873621, KH ERN 00009252 [លេខរៀង ១៧២៖ ហង់ ឌឿន ហៅ ឌឹម កំណត់អត្តសញ្ញាណជាអនុលេខាកងពលលេខ ១៦៤]។ ឯកសារ D1.3.28.40 បញ្ជីឈ្មោះអ្នកទោសដែលកំទេច ហើយថត នៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ១៩៧៧ EN ERN 00873280-81, KH ERN 00009146 [លេខរៀង ២៖ ហឹង ឌឿន ហៅ ឌឹម កំណត់អត្តសញ្ញាណជាអនុលេខាកងពលលេខ ១៦៤]។ ឯកសារ D1.3.28.40 បញ្ជីឈ្មោះអ្នកទោសកំទេច នៅមន្ទីរស-២១ EN ERN 00873281។ ឯកសារ D1.3.28.27 បញ្ជីអ្នកទោសនៅមន្ទីរស-២១ EN ERN 01215100, KH ERN 00088754 [កំណត់អត្តសញ្ញាណ លេខរៀង ២ ឈ្មោះ អ៊ឹង ឌឿ ហៅ ឌឹម មេបញ្ជាការរងនៃកងពលធំលេខ ១៦៤]។ ឯកសារ D1.3.28.49 បញ្ជីឈ្មោះអ្នកទោសសួរចម្លើយ EN ERN 00937118, KH ERN 00082795-96 [ចាប់ខ្លួននៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៧ បញ្ចប់ការស៊ើបសួរនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧៧]។ ឯកសារ D234/2.1.55 សម្រង់ចម្លើយសារភាពរបស់ ហង់ ឌឿន ហៅ ឌឹម នៅមន្ទីរស-២១ EN ERN 00224085។ ឯកសារ D1.3.18.1 សម្រង់ចម្លើយសារភាពរបស់ ហង់ ឌឿន ហៅ ឌឹម នៅមន្ទីរស-២១។ ឯកសារ D1.3.18.2 សម្រង់ចម្លើយសារភាពរបស់ ហង់ ឌឿន (ហឹង ឌឿន) នៅមន្ទីរស-២១។ ឯកសារ D114/85 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.11 ["ស៖ [...] ឯកសារនេះមានលេខស្គាល់ D1.3.18.1 ភាសាខ្មែរ ERN 00162140] ឆ.11៖ ត្រូវហើយ [...] គឺឈ្មោះ ឌឹម ដែលខ្ញុំបាននិយាយនោះឯង។ ពេលខ្ញុំមើលឯកសារនេះ ត្រង់កាលបរិច្ឆេទ ខ្ញុំអាចនិយាយថា វាគឺត្រឹមត្រូវណាស់ ដោយសារគេយកអ្នកទាំងនោះទៅ នៅដើមឆ្នាំ១៩៧៧"]។ ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ ស៊ាង EN ERN 00217564 [អនុប្រធានទី១ របស់ មុត ឈ្មោះ ឌឹម ជាមនុស្សមកពីភូមិភាគបូព៌ា។ ឌឹម បានបាត់ខ្លួនក្នុងឆ្នាំ ១៩៧៧ ពេលដែលមានជម្លោះផ្ទៃក្នុង"]។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.50, 53-54។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.10។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.13 ["មិនមាននរណាម្នាក់អាចដឹងបានថា អ្នកមកពីខាងណាចាប់អ្នកណានោះទេ។ ខ្ញុំគ្រាន់តែដឹងថា គេចោទ ឌឹម ក្បត់។ គេមកយក ឌឹមនិងពួកបូព៌ាដទៃទៀតទៅ យើងមិនបានដឹងថា [អ្នកដែលគេចាប់នោះ] ត្រូវបាននាំយកទៅទីណាទេ"]។ សូមមើលផងដែរ កថាខណ្ឌ ៣៥៨ [ចំពោះការដែលថា ឌឹម ត្រូវបានដកចេញពីមុខតំណែងរបស់គាត់, ត្រូវបានចាប់ខ្លួន និងឃុំខ្លួន ពេលខ្លះគឺកើតឡើងមុនពេលការបញ្ជូនគាត់ទៅស-២១]។

677 ឯកសារ D114/230.1.1 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស លេខរៀង ៤៧៩៧ [ត្រូវបញ្ជូនខ្លួននៅថ្ងៃទី ២៨ ខែមេសា ឆ្នាំ១៩៧៧ ត្រូវបានសម្លាប់នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៨]។ ឯកសារ D9.3 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស ពីកងពលធំលេខ១៦៤ លេខរៀង ២៤ (និងលេខរៀង ២៧ - ស្ទួន)។ ឯកសារ D1.3.28.2

បញ្ជីអ្នកទោសនៅមន្ទីរស-២១ ចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ១៩៧៧ EN ERN 01321750, KH ERN 00086996 [កំណត់អត្តសញ្ញាណ លេខរៀង ១ ឈ្មោះ មុំ យាន ជាសមាជិកកងពលធំលេខ១៥៤ មានអាយុ ៣០ឆ្នាំ ដែលត្រូវបានបញ្ជូនទៅស-២១នៅខែឧសភា ឆ្នាំ១៩៧៧]។ ឯកសារ D1.3.28.45 បញ្ជីអ្នកទោសនៅមន្ទីរស-២១ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៧៧ EN ERN 01321440 [កំណត់អត្តសញ្ញាណលេខរៀង ៣ ឈ្មោះ ម៉ម ជីម ហៅ យាន ជាសមាជិកកងពលធំ១៦៤]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.5 ["យ៉ាន ជាសមាជិកគណៈកងពល១៦៤។ [...] ឈ្មោះ យ៉ាន នេះគឺស្ថិតនៅក្នុងចំណោមពួកក្បត់ដែលតា មុត បានលើកមករៀបជាពាក្យជូនដូចកំណាព្យ"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.4-5 ["យ៉ាន មេបញ្ជាការវរៈសេនាធំ២២, ង៉ែត មេបញ្ជាការវរៈសេនាធំ ២០ និងមេបញ្ជាការវរៈសេនាតូចរបស់ខ្ញុំឈ្មោះ វេត។ [...] ឆ.5៖ គេចាប់ក្នុងឆ្នាំ ១៩៧៧ឬដើមឆ្នាំ ១៩៧៨។ ខ្ញុំមិនបានឃើញការចាប់នោះដោយផ្ទាល់ភ្នែកទេ ប៉ុន្តែគេប្រជុំតាមកងប្រាប់អំពីការចាប់ចងនេះ"]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.1 ["នៅក្នុងអង្គប្រជុំ មាស មុត អានចម្លើយសារភាពរបស់ពួកក្បត់ គាត់បានរៀបរាប់ឈ្មោះកម្មាភិបាលក្បត់ចាប់ពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់មូលដ្ឋាន។ ខ្ញុំនៅចាំថា គាត់ហៅឈ្មោះ អាយ៉ា, អាធុច, អាញ៉ឹក, អាយ៉ាន, អានាន និងអាឌឹម។ ខ្ញុំនៅចាំ មាស មុត ហៅពួកគេថា "អា" ពីព្រោះ "អា" ជាពាក្យបន្តុះបង្អាប់សម្រាប់និយាយទៅកាន់ពួកក្បត់"]។ ឯកសារ D114/116 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.26-33 [បានពន្យល់ថា មុំ យាន ជាមេបញ្ជាការកងពលធំ៦៣ ត្រូវបានបាត់ខ្លួននៅឆ្នាំ១៩៧៧]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.35 ["វរសេនាធំ៦៣ មានមេបញ្ជាការឈ្មោះ បងយ៉ាន កាន់នៅកោះសេះ កោះតាគាវ កោះថ្មី ម្តុំរាម មកចម្ការដូង កងកេង"]។ ឯកសារ D54/81 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.14 ["ក្រោយមក យ៉ាន មកកាន់កងពល១៦៤ជាមួយ អ៊ំ មុត ដែរ។ គាត់ជាអតីតមេបញ្ជាការវរៈសេនាធំ៦៣"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.64, 67, 226 ["មានឈ្មោះ ង៉ែត, ឈ្មោះ ឌឹម, ឈ្មោះ យ៉ាន, ឈ្មោះ ឆាន និងឈ្មោះ សុខ ជាដើម ដែលគេចោទថា ជាគិញវៀតណាម ឬក៏សេអ៊ីអា។ [...] ឆ.67៖ បានជាខ្ញុំដឹង ពីព្រោះគេបានហៅអ្នកទាំងនោះយកទៅ ហើយបន្ទាប់ពីពីរបីថ្ងៃក្រោយមក ប្រធានអង្គភាពវរសេនាធំ១៤០ ឈ្មោះ ហាន បានប្រជុំប្រាប់ថា ទាំងនោះ ជាខ្មាំងស៊ីរូងផ្ទៃក្នុង។ [...] ឆ.226៖ រឿងហ្នឹង គឺមេបញ្ជាការខ្ញុំឈ្មោះ ហាន បានប្រាប់ខ្ញុំថា អ្នកប៉ុន្មាននាក់ខាងលើនេះ សុទ្ធតែជាអ្នកក្បត់ក្នុងជួរកងទ័ព"]។

678 ឯកសារ D114/230.1.1 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស លេខរៀង ៥៣៤២ [កំណត់អត្តសញ្ញាណសមាជិកកងពលលេខ១៦៤ ដែលត្រូវបញ្ជូនទៅ ស-២១ នៅដើមខែមិថុនា ឆ្នាំ១៩៧៧]។ ឯកសារ D9.3 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស ពីកងពលធំលេខ១៦៤ លេខរៀង ២៦។ ឯកសារ D1.3.5.5 បញ្ជីឈ្មោះកម្មាភិបាលបីរូបមកពីកងពលធំ១៦៤ នៅមន្ទីរស-២១ KH ERN 00159970 [ពីរនាក់ត្រូវបានសម្គាល់ថាចាប់ខ្លួនរួចហើយ គ្មានការបកប្រែជាភាសាអង់គ្លេស]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.4 ["ម៉ែន ង៉ែត គឺជាសមាជិកគណៈកងពល១៦៤ គាត់ត្រូវបានចាប់ខ្លួន"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.64, 67 ["ស៖ តើលោកអាចប្រាប់ឈ្មោះអ្នកដែលលោកស្គាល់ ហើយគេនាំយកទៅនោះបានដែរទេ? ឆ.64៖ មានឈ្មោះ ង៉ែត, ឈ្មោះ ឌឹម, ឈ្មោះ យ៉ាន, ឈ្មោះ ឆាន និងឈ្មោះ សុខ ជាដើម ដែលគេចោទថា ជាគិញវៀតណាម ឬក៏សេអ៊ីអា។ ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.58 ["ស៖ តើលោកដឹងថាមានសមាជិកមកពីកងពល១៦៤ ត្រូវបានគេបញ្ជូនទៅទួលស្លែង ឬស-២១ដែរឬទេ? [...] ឆ.58៖ [...] តែខ្ញុំឮថា ង៉ែត និងស្រស់ ត្រូវ

224. ក្នុងអំឡុងពេលបន្ទាប់ពីការបោសសម្អាតទាំងនេះ យ៉ាងហោចណាស់កម្មាភិបាលដែលមានឋានន្តរសក្តិខ្ពស់បីនាក់ផ្សេងទៀត គឺជាផ្នែកមួយនៃគណៈកម្មាធិការកងពលធំលេខ ១៦៤៖

(ក) ឡុង សារឿន ហៅ រឿន/រិន (អតីតមេបញ្ជាការរងកងពលធំលេខ ៣[679] កងវរៈសេនាធំលេខ ១៤០)[680] មេបញ្ជាការរងកងពលធំលេខ ១៦៤ ពីពាក់កណ្តាលឆ្នាំ ១៩៧៧ រហូតដល់គាត់ត្រូវបានចាត់តាំងឲ្យទៅធ្វើជាប្រធានផែកំពង់សោមនៅក្នុងខែ មិថុនា ឬ កក្កដា ឆ្នាំ ១៩៧៨[681]។

---

បានចាប់ខ្លួន"]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.8 ["ហើយង៉ែតជាស្នងការវរៈសេនាធំ២០ង៉ែតត្រូវបានគេចាប់ក្នុងរយៈពេលបោសសំអាតប្រហែលក្នុងឆ្នាំ១៩៧៧"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.4-5 ["យ៉ាន មេបញ្ជាការវរៈសេនាធំ២២, ង៉ែត មេបញ្ជាការវរៈសេនាធំ ២០ និងមេបញ្ជាការវរៈសេនាតូចរបស់ខ្ញុំឈ្មោះ វេត។ [...] ឆ.5៖ គេចាប់ក្នុងឆ្នាំ ១៩៧៧ឬ ដើមឆ្នាំ ១៩៧៨។ ខ្ញុំមិនបានឃើញការចាប់នោះដោយផ្ទាល់ភ្នែកទេ ប៉ុន្តែគេប្រជុំតាមកងប្រាប់អំពីការចាប់ចងនេះ"]។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ីរ៉េត ហៅ សារ៉េត ឆ.5 ["អនុមេបញ្ជាការកងពលនោះឈ្មោះ ង៉ែត [...] ក្រោយមកគាត់បាត់មុខពីកងពល"]។

679 សូមមើល កថាខណ្ឌ ២០៨។

680 សូមមើល កថាខណ្ឌ ២៤៥។

681 ទាក់ទងនឹងមុខតំណែងរបស់គាត់ជាអនុមេបញ្ជាការកងពលធំលេខ ១៦៤៖ ឯកសារ D54/73 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.6, 9 ["[នៅក្នុងគណៈកងពលធំលេខ១៦៤] មានគ្នាបីនាក់ គឺមាន តា មុត, តា សារឿន, និងតា ញ៉ាន់ [...] ឆ.9៖ តា សារឿន ក្រោយមត្រូវបានបញ្ជូនទៅធ្វើការនៅផែកំពង់សោម"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត (Hieng Reth) ឆ.28 ["នៅពេលកងពលលេខ៣ ប្តូរទៅជាកងពល១៦៤ នៅកំពង់សោម មាន មាស មុត ជាមេបញ្ជាការ។ ហើយមេបញ្ជាការរងត្រូវបានផ្លាស់ប្តូរជាបន្តបន្ទាប់ ដែលរួមមាន តារិន, តានាន និងតាឌឹម [...] តាញ៉ាន់ ជាមេបញ្ជាការកងវរសេនាធំ៦៣។ សារឿន ជាមេបញ្ជាការកងវរសេនាធំ១៤០។ ក្រោយមកសារឿន ត្រូវបានជំនួសដោយ ទឹម សេង"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.1 ["តា សារឿន (ស្លាប់) អនុម្នាក់របស់ មាស មុត ដែរ ទទួលខុសត្រូវផ្នែកយោធា"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.224-225 ["វរសេនាធំ១៤០ មានឈ្មោះ សារឿន (ស្លាប់) ជាប្រធាននយោបាយ បន្ទាប់ពីសារឿនឈ្មោះ សេង (ស្លាប់) ជាអនុរបស់ សារឿន ហើយឈ្មោះ សំ ជាសមាជិករបស់ សេង។ [...] ឆ.225៖ នៅពេលដែលសារឿន ត្រូវបានដំឡើងឋានៈទៅថ្នាក់កងពល ឈ្មោះ សេង បានឡើងជំនួស សារឿន ហើយ សំ ឡើងជំនួស សេង រួចហាន ឡើងជំនួស សំ"]។ ឯកសារ D54/81 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.14 [នៅគណៈកងពល " សារឿន មកជំនួស យ៉ាន។ សារឿន មកពីកងវរៈសេនាធំ១៤០ ប្រហែលជាមកជំនួស តា យ៉ាន"]។ ឯកសារ D54/82 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.17 ["ខ្ញុំសង្ស័យថាឈ្មោះ រឿន និងឈ្មោះ សារឿន ជាមនុស្សតែមួយ"]។ ទាក់ទងនឹងការងាររបស់គាត់ជាប្រធាននៅផែកំពង់សោម សូមមើល ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ

(ខ) គឹម ញ៉ាន ហៅ ញ៉ាន (ក៏ជាមេបញ្ជាការកងវរៈសេនាធំលេខ ៦៣ ផងដែរ) សមាជិកគណៈកម្មាធិការកងពលធំលេខ ១៦៤ ឬជាមេបញ្ជាការរងទទួលបន្ទុកភ័ស្តុភារ/សេដ្ឋកិច្ចពីពាក់កណ្តាលឆ្នាំ ១៩៧៧ ឬដើមឆ្នាំ ១៩៧៨ រហូតដល់ខែ វិច្ឆិកា ឬខែ ធ្នូ ឆ្នាំ ១៩៧៨[682]

---

អែម សុន ឆ.34, 37 [“តាមពិត គ្រិន បានចាកចេញពីផែកំពង់សោម ទៅរៀននៅភ្នំពេញរយៈពេល១អាទិត្យ ហើយត្រឡប់មកកំពង់សោមវិញនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៧៨។ នៅពេលគាត់ត្រឡប់មកវិញ គាត់រៀបចំការប្រជុំ ហើយប្រាប់កម្មករទាំងអស់នៅផែថា គាត់ទៅធ្វើឯកអគ្គរដ្ឋទូតនៅហុងកុង។ បន្ទាប់ គ្រិន ចាកចេញទៅអ្នកដែលមកជំនួសគាត់នៅផែនោះមិនមែនជាមនុស្សមកពីផែទេ ប៉ុន្តែមកពីកងពល១៦៤។ [...] ស៖ តើអ្នកមកជំនួស គ្រិន ដែលមកពីកងពល១៦៤ ជាអ្នកណា? ឆ.37៖ នៅថ្ងៃប្រជុំ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៧៨ គ្រិនបានណែនាំឈ្មោះ ភាព និង ឈ្មោះ សួង។ ពួកគេទាំងពីរមកពីកងពលលេខ១៦៤។ ភាព មានតួនាទីជាប្រធានស្តីទីនៅផែ ហើយសួង ជាអនុប្រធាន។ ក្រោយមកប្រហែលខែមិថុនា ឬ ខែកក្កដា ឆ្នាំ១៩៧៨ សារឿន មកពីកងពល១៦៤ ដែរនោះ មកធ្វើជាប្រធានកំពង់ផែ។ ភាព ក្លាយជាអនុប្រធាន ហើយ សួង ក្លាយជាសមាជិកវិញ។ ក៏ប៉ុន្តែ សារឿន មិននៅផែជាអចិន្ត្រៃយ៍ទេ ដូច្នេះនៅពេលគាត់អវត្តមាន ភាព និង សួង ជាអ្នកទទួលខុសត្រូវជំនួស។ ពួកគេមិនដែលជ្រើសរើសមនុស្សមកពីកំពង់ផែមកកាន់តួនាទីសំខាន់ ឬតួនាទីខ្ពស់នោះទេ។ ពួកតែងតែយកមនុស្សមកពីកងពល១៦៤”]។ ឯកសារ D114/195 កំណត់ហេតុស្តាប់ចម្លើយ នាក់ ខឿន ឆ.17, 19 [“ស៖ តើលោកដឹងថាអ្នកណាឡើងមកជំនួសគ្រិនដែរទេ នៅឆ្នាំ១៩៧៨? ឆ.17៖ [...] ចុងឆ្នាំ១៩៧៨ វាដូចជាឈ្មោះប្រហែលជាតាសារឿន [...] គាត់នៅកន្លែងហ្នឹង មិនបានមួយឆ្នាំទេ គឺប្រហែលជា៥ ឬ៦ខែមុនពេលដាច់របប។ គេផ្លាស់ពីគ្រិន មកតាសារឿន ហ្នឹង [...] ឆ.19៖ ខ្ញុំឮថាគាត់ផ្លាស់ពីយោធាមក”]។ ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.26 [“ស៖ តើអ្នកណាបញ្ជូនលោកពីកំពង់សោមទៅភូមិភាគបូព៌ា? ឆ.26៖ គឺ តា សារឿន (ស្លាប់)។ គាត់ជាអ្នកជំនួស តាក្រិន បន្ទាប់ពី ក្រិន បាត់ខ្លួន”]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968421, KH ERN 00926645 [“តាសារឿន គេដកមកគ្រប់គ្រងផែ”]។

682 ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ.126 [“នៅឆ្នាំ១៩៧៧ [...] ហើយចំណោកនៅកងពល១៦៤វិញ មានមនុស្សមកជំនួសអ្នកទាំងនោះ [ឌឹម និង ឆាន] ដូចជា បងញ៉ាន់ ជាដើម ម្នាក់ទៀតខ្ញុំភ្លេចឈ្មោះហើយ មកធ្វើជាអនុរបស់ មាស មុត”]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.229 [នៅការដ្ឋានអូរម្លូ៖ “តាញ៉ាន់ គឺជាអ្នកចេញបញ្ជាឲ្យយើងវៃថ្មឲ្យបាន ៧ម៉ែត្រគូបនេះ។ តាញ៉ាន់ គឺជាអនុកងពល ១៦៤ ជាអ្នកក្តាប់ខាងភស្តុភារ”]។ ឯកសារ D54/73 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.6, 8-9, 16 [នៅក្នុងគណៈកងពលធំលេខ១៦៤៖ “មានគ្នាបីនាក់ គឺមាន តា មុត, តា សារឿន, និងតា ញ៉ាន់ [...] ស៖ “ហេតុអ្វីបានជាលោកស្រីដឹងថា តា សារឿន និង តាញ៉ាន់ ស្ថិតនៅក្នុងគណៈជាមួយ មាស មុត? ឆ.8៖ ពួកគាត់ទាំងអស់គ្នាស្នាក់នៅបរិវេណមន្ទីរក្នុង ប៉ុន្តែនៅផ្ទះផ្សេងៗគ្នា។ ពួកគាត់ហូបបាយនៅផ្ទះបាយរួម ហើយពេលខ្លះនីរសាររបស់ពួកគាត់មកលើកម្ហូបអាហារយកទៅឲ្យគាត់ហូបនៅផ្ទះរបស់ពួកគាត់រៀងៗខ្លួន [...] ឆ.9៖ តា សារឿន ក្រោយមត្រូវបានបញ្ជូនទៅធ្វើការនៅផែកំពង់សោម [...] ឆ.16៖ បន្ទាប់ពី តា សារឿន ត្រូវបានបញ្ជូនទៅធ្វើការនៅកំពង់ផែ តា សេង បានមកដល់។ អំឡុងពេលដែលមាស មុត អវត្តមាន គឺមាន តា សេង និត តា ញ៉ាន់”]។ ឯកសារ D234/2.1.92 ប្រតិចារឹក ព្រុំ សារ៉ាត ថ្ងៃទី ២៦ ខែ មករា

ខណៈពេលដែលគាត់ត្រូវបាន **មាស មុត** បញ្ជូនទៅខេត្តក្រចេះទៅជំនួសមេបញ្ជាការកងពលធំលេខ ១១៧ ដែលត្រូវបានបោសសម្អាត[683]។

---

ឆ្នាំ ២០១៦ ម៉ោង 15.03.11-15.06.23 [បានចង្អុលបង្ហាញថា សមាជិកគណៈកងពលធំ គឺ មាស មិត, ខឹម, ឆាន និង ញ៉ាន់]។ ឯកសារ D234/2.1.93 ព្រុំ សារ៉ាត ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 09.19.46-09.22.33។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត ឆ.86។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ ឆ. 176-178 ["នរណាជាអ្នកក្តាប់ ឬបញ្ជានៅកន្លែងធ្វើការនោះ? តើលោកចាំថាគាត់ឈ្មោះអី អង្គភាពណា? [...] ឆ.177៖ ក្តាប់រួមជាទូទៅការដ្ឋានគឺឈ្មោះ ញ៉ាន់ យ៉ាងម៉េចទេនេះ។ ស៖ តើលោកចាំទេថា ញ៉ាន់ហ្នឹងមកពីអង្គភាពណា? ឆ.178 ៖ ញ៉ាន់ គឺវងកងពល១៦៤"]។ ឯកសារ D22.2.181 បទសម្ភាសន៍ជាមួយ មាស មុត ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម ចុះថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០១ EN ERN 00249694, KH ERN 00741997 ["គណៈបញ្ជាការនៃកងពលធំលេខ ៣ រួមមាន៖ [...] ញ៉ាន់ (Nhan) ជាសមាជិកនៃគណៈកម្មាការទទួលបន្ទុកភស្តុភារ។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន (ណាំ ឡាន) ឆ.25, 111 ["ស៖ តើមានអ្នកណាផ្សេងទៀត ជាសមាជិកកងពល? ឆ.25៖ ញ៉ាន់ (ស្លាប់)។ គាត់ជាមនុស្សមកពីកងពលទី៣។ [...] ឆ.111៖ ឈ្មោះ ឡូន (ស្លាប់) និងឈ្មោះ ញ៉ាន់ (កាន់ភស្តុភារកងពលលេខ៣)"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ .1 ["តា ញ៉ាន់ ត្រកូលរបស់គាត់ ញ៉ែត គឺជាអនុម្នាក់របស់ មាស មុត ទទួលខុសត្រូវខាងផ្នែកសេដ្ឋកិច្ច បន្ទាប់ពី ខឹម បាត់ខ្លួនទៅ។ តា ញ៉ាន់ ស្លាប់។ ហង្ស ឌឿន ហៅ ខឹម (ស្លាប់) ក៏ជាអនុម្នាក់របស់ មាស មុត ដែរ ទទួលខុសត្រូវខាងផ្នែកសេដ្ឋកិច្ច មុនតា ញ៉ាន់ [...] តា ញ៉ាន ជាសមាជិករបស់ តា មាស មុត ចាប់ពីចុងឆ្នាំ១៩៧៨ រហូតដល់ឆ្នាំ ១៩៧៩។ នៅពេលនោះ ស្ថានការណ៍ក្នុងប្រទេសវឹកវរ ហើយកងពលខ្វះអនុសម្រាប់ធ្វើការ ទើបគេដក ញ៉ាន់ ដែលជាមេបញ្ជាការវរសេនាធំលេខ៦៣ យកទៅធ្វើជាសមាជិករបស់កងពល"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.1 ["តា ញ៉ាន ជាសមាជិករបស់ តា មាស មុត ចាប់ពីចុងឆ្នាំ១៩៧៨ រហូតដល់ឆ្នាំ១៩៧៩។ នៅពេលនោះ ស្ថានការណ៍ក្នុងប្រទេសវឹកវរ ហើយកងពលខ្វះអនុសម្រាប់ធ្វើការ ទើបគេដក ញ៉ាន់ ដែលជាមេបញ្ជាការវរសេនាធំលេខ៦៣ យកទៅធ្វើជាសមាជិករបស់កងពល"]។ ឯកសារ D2/16 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.12 ["នៅពេលនោះ មាស មុត មានមុខងារជាប្រធានកងពល ហើយ តា ញ៉ាន ជាសមាជិកកងពល [១៦៤]"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.19 ["ញ៉ាន់ ហើយនិង សេង នៅចុងរបបខ្មែរក្រហម ចុងឆ្នាំ១៩៧៨ ខ្ញុំតែងតែឃើញគាត់តំណាងឲ្យកងពល រាល់ពេលប្រជុំ"]។ ឯកសារ D114/12 Neak Yoeun កំណត់ហេតុស្តាប់ចម្លើយ នាក់ យឿន ឆ.27។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.229 ["តាញ៉ាន់ គឺជាអនុកងពល ១៦៤ ជាអ្នកក្តាប់ខាងភស្តុភារ"]។ ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា ឆ.1។

683 សូមមើល លម្អិតខាងក្រោម VIII.I ការបោសសម្អាតកងពលធំលេខ ១១៧ និង តំបន់ ៥០៥។ សូមមើលផងដែរ ឯកសារ D114/52 កំណត់ហេតុស្តាប់ចម្លើយ ឈាង ជួ ឆ.35, 40-42 ["ឈ្មោះ តាញ៉ាន់ មកកាន់កងពល១១៧ [...] ឆ. 40៖ នៅពេលនោះ មាស មុត បានមករៀបចំកងពល ១១៧ ហើយចាត់តាំង តាញ៉ាន់ ជាមេបញ្ជាការកងពល១១៧នេះ [...] ឆ.41៖ ខ្ញុំដឹងតាមរយៈអ្នកដែលមកកាន់កាប់ថ្មីហ្នឹង គឺតាញ៉ាន់។ តាញ៉ាន់និយាយថា "បង មាស មុត ចុះមក

(គ) ទីម សេង ហៅ សេង មេបញ្ជាការរង និងក្រោយមកជាមេបញ្ជាការកងវរៈសេនាធំលេខ ១៤០ ដែលបានជំនួស តា សារឿន ក្នុងនាមជាមេបញ្ជាការកងពលធំលេខ ១៦៤ នៅពេល តា សារឿន ត្រូវបានតែងតាំងជាប្រធានផែកំពង់សោមជំនួស ធុច រិន ហៅ គ្រិន ក្នុងខែមិថុនា ឬខែ កក្កដា ឆ្នាំ ១៩៧៨[684]។ នៅពេលនោះគាត់ជាមេបញ្ជាការកងពលធំស្ដីទី នៅពេល

---

ក្រចេះ ដើម្បីរៀបចំកងពល១១៧ ឡើងវិញ [...] ឆ.42៖ [...] តាមព្រឹត្តិការណ៍ដែល តាញ៉ាន់ ទៅកាន់បញ្ជាការកងពល១១៧ គឺប្រហែល១ខែមុនពេលវៀតណាមចូលគឺនៅប្រហែលជាចុងខែវិច្ឆិកា ឬដើមខែធ្នូ ឆ្នាំ១៩៧៨"]។ ឯកសារ D54/110 កំណត់ហេតុស្ដាប់ចម្លើយ លុន សេង ឆ.5-6។ ឯកសារ D114/193 កំណត់ហេតុស្ដាប់ចម្លើយ សៅ សារុន ឆ.64។ ឯកសារ D4.1.444 កំណត់ហេតុស្ដាប់ចម្លើយ សៅ សារុន EN ERN 00278696។ ឯកសារ D114/192 កំណត់ហេតុស្ដាប់ចម្លើយ ចិន ផាត ឆ.41-42។ ឯកសារ D114/102 កំណត់ហេតុស្ដាប់ចម្លើយ អែម សារិន ឆ.22។ ឯកសារ D54/62 កំណត់ហេតុស្ដាប់ចម្លើយ ម៉ឹង វេត ឆ.30។ ឯកសារ D54/63 កំណត់ហេតុស្ដាប់ចម្លើយ ម៉ឹង វេត ឆ.1។ ឯកសារ D114/149 កំណត់ហេតុស្ដាប់ចម្លើយ ទូច ឈុំ ឆ.13។ ឯកសារ D54/29 កំណត់ហេតុស្ដាប់ចម្លើយ លៀត ឡុន (ណាំ ឡុន) ឆ.15។ ឯកសារ D114/18 កំណត់ហេតុស្ដាប់ចម្លើយ ម៉ាក ឈឿន ឆ.16។

684 ឯកសារ D54/79 កំណត់ហេតុស្ដាប់ចម្លើយ ណុប ហាល់ ឆ.26 ["តាមុត គឺជាមេកងពល ហើយគាត់ និង តាសេង ជាអ្នកកាន់កាប់កងពល។ តាមុត ជាឋានន្តរក្រមថ្នាក់លើ និងកាន់កងពលយូរមកហើយ។ នៅពេល តាសេង ចូលមក គាត់ធ្វើការក្រោម តាមុត។ ដូច្នេះ តាមុត មានឋានៈខ្ពស់ជាង តាសេង"]។ ឯកសារ D54/81 កំណត់ហេតុស្ដាប់ចម្លើយ ហ៊ីង អ៊ុច ឆ.14-15 ["ក្រោយមក សេង មកពីកងវរៈសេនាធំ១៤០ មកនៅចុងឆ្នាំ១៩៧៨ រហូតដល់វៀតណាមចូលក្នុងឆ្នាំ១៩៧៩។ គាត់មានសិទ្ធិអំណាចក្នុងការចេញបញ្ជា។ [...] ខ្ញុំមិនដឹងច្បាស់ថា អ៊ំ មុត នៅកន្លែងណាដែរ ពីព្រោះខ្ញុំទទួលបញ្ជាដោយផ្ទាល់ពី សេង។ [...] ឆ.15៖ ខ្ញុំកត់សម្គាល់ឃើញថា សេង ជាអ្នកចេញបញ្ជារហូតនៅពេលនោះ"]។ ឯកសារ D54/10 កំណត់ហេតុស្ដាប់ចម្លើយ ម៉ី រ៉េត ហៅ សារ៉េត ឆ.9 ["បន្ទាប់ពីកងទ័ពជើងទឹកត្រូវបានបង្កើតឡើង ឈ្មោះ សេង ក្លាយជាអនុបញ្ជាការវរៈសេនាធំ ១៤០។ ក្រោយមកទៀត គាត់បានក្លាយជាអនុមេបញ្ជាការកងពល១៦៤"]។ ឯកសារ D54/98 កំណត់ហេតុស្ដាប់ចម្លើយ ហ៊ាង រ៉េត (Hieng Reth) ឆ.28, 35 ["ក្រោយពេលទីម សេង ត្រូវបានឡើងជាប្រធានកងពល១៦៤ ជំនួស មាស មុត នៅឆ្នាំ១៩៧៩ នៅពេលដែលមានការប្រយុទ្ធគ្នាខ្លាំងជាមួយវៀតណាម តាហាន ត្រូវបានឡើងជាមេបញ្ជាការកងវរសេនាធំ១៤០ [...] ឆ.35៖ មាស មុត បាននាំកម្លាំងយោធាទៅវ៉ៃជាមួយកងទ័ពវៀតណាម នៅព្រំដែនកម្ពុជាវៀតណាម។ ហើយនៅពេលនោះ ទីម សេង បានឡើងជាមេបញ្ជាការកងពល១៦៤"]។ ឯកសារ D54/29 កំណត់ហេតុស្ដាប់ចម្លើយ លៀត ឡុន(ណាំ ឡុន) ឆ.3 ["សេង ប្រាប់ខ្ញុំថា មាស មុត គឺជាជំនួយការរបស់សេនាធិការ។ សេង ដឹងរឿងនេះ ពីព្រោះពេលតា មុត មិននៅកំពង់សោម គឺ សេង ទទួលខុសត្រូវជំនួស"]។ ឯកសារ D54/73 កំណត់ហេតុស្ដាប់ចម្លើយ មុត ម៉ៅ ឆ.16 ["បន្ទាប់ពី តាសារឿន ត្រូវបានបញ្ជូនទៅធ្វើការនៅកំពង់ផែ តា សេង បានមកដល់។ អំឡុងពេលដែលមាស មុត អវត្តមាន គឺមាន តា សេង និត តា ញ៉ាន់ ប៉ុន្តែខ្ញុំមិនដឹងថាអ្នកណាទទួលខុសត្រូវកងពលជំនួសទេ"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង រ៉េត EN ERN 00974098, KH ERN 00926542-43 ["បើនិយាយទៅមានទីម សេង [...] មុនដំបូងគាត់គ្រប់គ្រងជើងទឹក ដល់ក្រោយមកគាត់មកគ្រប់គ្រងកងពល១៦៤

**មាស មុត** ទៅទីក្រុងភ្នំពេញ ឬទៅជិតសមរភូមិមុខវៀតណាម (រួមទាំងខេត្តក្រចេះ)[685]។ ទោះជាយ៉ាងនេះក្តី **មាស មុត** បានបន្តចេញបញ្ជាដល់កងពលធំនេះ តាមរយៈសេង ក្នុងអំឡុងពេលនោះ[686]។

---

ហើយ មាស មុត គាត់ឡើងមកធ្វើជាមេបញ្ជាការនៅភ្នំពេញ"]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡួន(ណាំ ឡួន) ឆ.22, 24 ["ស៖ តើ ទឹម សេង កាន់កងទ័ពជើងទឹកពីឆ្នាំណាដល់ឆ្នាំណា? ឆ.22៖ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៨។ [...] ស៖ តើអ្នកណាជាមេបញ្ជាការកងវរៈសេនាធំរបស់លោក? ឆ.24៖ ទឹម សេង ហើយ គាត់ក៏ជាសមាជិកកងពលផងដែរ"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.1 ["ឈ្មោះ សេង គឺ អនុម្នាក់ទៀតរបស់តា មាស មុត។ ខ្ញុំមិនដឹងពីមុខងាររបស់គាត់ច្បាស់ទេ ប៉ុន្តែខ្ញុំធ្លាប់ឃើញគាត់បញ្ជាកប៉ាល់"]។ ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ីម ឆ.29, 32 ["ស៖ លោកបាននិយាយមុននេះថា មាស មុត បានទៅភ្នំពេញក្នុងឆ្នាំ១៩៧៧ ឬក៏៧៨។ តើហេតុអ្វីបានលោកនិយាយបែបនេះ? ឆ.29៖ ខ្ញុំនិយាយយ៉ាងនេះ ព្រោះខ្ញុំទទួលការណែនាំអី ពី មៀញ ហើយ មៀញ ដែលទទួលផែនការ ការងារពី ទឹម សេង [...] ស៖ តើឈ្មោះ ទឹម សេង មានតួនាទី និងភារកិច្ចធ្វើអ្វីដែរ? ឆ.32៖ [...] ទឹម សេង យើងដឹងតាមរយៈទូទៅ គាត់បានទៅរៀននៅស្រុកចិន ខាងបច្ចេកទេសយោធាជើងទឹក។ ដល់ពេលត្រឡប់មកវិញ គាត់ប្រចាំការនៅកន្លែងពល"]។

685 ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ីម ឆ.29, 66 ["ស៖ លោកបាននិយាយមុននេះថា មាស មុត បានទៅភ្នំពេញក្នុងឆ្នាំ១៩៧៧ ឬក៏៧៨។ តើហេតុអ្វីបានលោកនិយាយបែបនេះ? ឆ.29៖ ខ្ញុំនិយាយយ៉ាងនេះ ព្រោះខ្ញុំទទួលការណែនាំអី ពី មៀញ ហើយ មៀញ ដែលទទួលផែនការ ការងារពី ទឹម សេង [...] ស៖ ពាក់ព័ន្ធនឹងការងារនៅការដ្ឋាន តើឈ្មោះ មៀញ នេះ ធ្លាប់ទទួលការណែនាំពីណាមកពីវិញដែរ? ឆ.66៖ ពីមុនមក គាត់ទទួលបញ្ជាផ្ទាល់ពី មាស មុត ហ្នឹង"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.19 ["ញ៉ាន់ ហើយនិង សេង នៅចុងរបបខ្មែរក្រហម ចុងឆ្នាំ១៩៧៨ ខ្ញុំតែងតែឃើញគាត់តំណាងឲ្យកងពល រាល់ពេលប្រជុំ"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត (ហ៊ាង រ៉េត) ឆ.28, 35 ["ក្រោយពេលទឹម សេង ត្រូវបានឡើងជាប្រធានកងពល១៦៤ ជំនួស មាស មុត នៅឆ្នាំ១៩៧៩ នៅពេលដែលមានការប្រយុទ្ធគ្នាខ្លាំងជាមួយវៀតណាម [...] ឆ.35៖ មាស មុត បាននាំកម្លាំងយោធាទៅវ៉ៃជាមួយកងទ័ពវៀតណាម នៅព្រំដែនកម្ពុជាវៀតណាម។ ហើយនៅពេលនោះ ទឹម សេង បានឡើងជាមេបញ្ជាការកងពល១៦៤"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.9 ["នៅពេលដែល មាស មុត ទៅក្រចេះបាត់ តា សេង ទទួលខុសត្រូវខាងផ្នែកបញ្ជាការកងពល"]។ ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡួន (ណាំ ឡួន) ឆ.3 [នៅចុងឆ្នាំ ១៩៧៨៖ "សេង ប្រាប់ខ្ញុំថា មាស មុត គឺជាជំនួយការរបស់សេនាធិការ។ សេង ដឹងរឿងនេះ ពីព្រោះពេលតា មុត មិននៅកំពង់សោម គឺ សេង ទទួលខុសត្រូវជំនួស។ ខ្ញុំមិនដឹងថា តើ មាស មុត ធ្វើដំណើរទៅមកភ្នំពេញ កំពង់សោមញឹកញាប់ប៉ុនណាទេ"]។ ឯកសារ D54/81 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.14-15 ["ក្រោយមក សេង មកពីកងវរៈសេនាធំ១៤០ មកនៅចុងឆ្នាំ១៩៧៨ រហូតដល់វៀតណាមចូលក្នុងឆ្នាំ១៩៧៩។ គាត់មានសិទ្ធិអំណាចក្នុងការចេញបញ្ជា។ [...] ខ្ញុំមិនដឹងច្បាស់ថា អ៊ំ មុត នៅកន្លែងណាដែរ ពីព្រោះខ្ញុំទទួលបញ្ជាដោយផ្ទាល់ពី សេង។ [...] ឆ.15៖ ខ្ញុំកត់សម្គាល់ឃើញថា សេង ជាអ្នកចេញបញ្ជារហូតនៅពេលនោះ"]។ ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.19 ["ក្នុងករណីដែល

225. នៅពេលការបោសសម្អាតបានកើនឡើងនៅក្នុងកងពលធំនោះ តួនាទីនេះត្រូវបានកាន់ដោយប្អូនប្រុសរបស់ **មាស មុត** ឈ្មោះ មាស អ៊ឹម (អ៊ុម)[687] ទោះបីជាគាត់មិននៅក្នុងគណៈកម្មាធិការកងពលធំជាផ្លូវការក៏ដោយ ក៏គាត់បានក្លាយទៅជាមនុស្សសំខាន់ជាងមុន ៖ **មាស មុត** បានឲ្យគាត់ទទួលខុសត្រូវផ្នែកភ័ស្តុភារសម្រាប់កងពលធំលេខ ១៦៤ ទាំងមូល។ បន្ថែមទៅនឹងតួនាទីដែល

---

អវត្តមាន មាស មុត គឺ ទឹម សេង [...] ជាអ្នកទទួលខុសត្រូវជំនួស ក៏ប៉ុន្តែពួកគេមានលេខសម្រាប់ទាក់ទងតាមវិទ្យុរៀងៗខ្លួន។ ចំណែក មាស មុត លេខវិទ្យុ លេខ៦៣"]។ ឯកសារ D54/73 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.16 ។

686 ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ (ឡាយ ប៊ុនហាក់) ឆ.93, 96 ["អ្នកមកជំនួសការងារ មាស មុត គឺ ឈ្មោះ ទឹម សេង ដែលពីមុនគាត់ជាអ្នកគ្រប់គ្រងកងនាវាប្រវាំង។ នៅពេល ទឹម សេង មកជំនួស មាស មុត គាត់គ្រប់គ្រងអង្គភាពយោធាទាំងអស់នៅកំពង់សោម។ [...] សៈ លោកបាននិយាយក្នុងបទសម្ភាសន៍ថា ទោះបី តាមុត នៅឆ្ងាយពីកងពលក៏គាត់នៅតែបញ្ជាមកកងពលដដែល តាមរយៈ ទឹម សេង តើលោកដឹងដោយរបៀបណា? ឆ .96៖ មាស មុត គាត់ទៅខាងអគ្គសេនាធិការ ដូច្នេះការងារទាំងអស់គាត់បញ្ជាពីខាងលើមកតាមរយៈ ទឹម សេង ហើយទឹម សេង ដើរមើលការងារនិងបញ្ជាការងារបន្ត"]។ ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល់ ឆ.26 ["តាមុត គឺជាមេកងពល ហើយគាត់ និង តាសេង ជាអ្នកកាន់កាប់កងពល។ តាមុត ជាឋានន្តរក្រមថ្នាក់លើ និងកាន់កងពលយូរមកហើយ។ នៅពេល តាសេង ចូលមក គាត់ធ្វើការក្រោម តាមុត។ ដូច្នេះ តាមុត មានឋានៈខ្ពស់ជាង តាសេង"]។

687 ឯកសារ D114/216 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.21, 27 ["សៈ តើបងទី៤ របស់លោកឈ្មោះអ្វីដែរ? ឆ. 21៖ មាស មុតហ្នឹង [...] សៈ តើបងទី៥ របស់លោកឈ្មោះអ្វីដែរ? ឆ.27៖ ទី៥ មកគឺ ខ្ញុំ"]។ ឯកសារ D114/214 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.1-2។ ឯកសារ D1.3.30.6 របាយការណ៍អគ្គសេនាធិការរបស់កម្ពុជាប្រជាធិបតេយ្យ តារាងស្ថិតិសិក្ខាកាម វគ្គសេនាធិការ លើកទី២ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ EN ERN 00195331, KH ERN 00008465-66, FR ERN 00623209 [លេខរៀង ១៨៧ មាស អ៊ឹម ធ្វើឲ្យមុខតំណែងកងពល១៦៤ចុះខ្សោយ]។ កត់សម្គាល់នៅក្នុងឯកសារបកប្រែបន្ទាប់លើកឡើងអំពីមុខតំណែងរបស់គាត់នៅខែវិច្ឆិកា ឆ្នាំ១៩៧៦ ថាជាមេបញ្ជាការកងវរៈសេនាតូច (ដែលមានឋានៈស្មើនឹង ភាព ដែលនៅមាននៅបន្ទាប់ពីគាត់នៅក្នុងបញ្ជី)៖ ឯកសារ D114/77.1 របាយការណ៍អគ្គសេនាធិការរបស់កម្ពុជាប្រជាធិបតេយ្យ (ភ្ជាប់ជាមួយ ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត) EN ERN 01156172, KH ERN 01101693។ ឯកសារ D54/78.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ KH ERN 00926615 ["តាអ៊ឹម នឹងប្អូន មាស មុត"]។ ឯកសារ D54/70 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.24 ["ខ្ញុំធ្លាប់ឮឈ្មោះគាត់ [មាស អ៊ឹម] តែខ្ញុំមិនដែលឃើញមុខគាត់ទេ។ គាត់គឺជាបងប្អូនរបស់ មាស មុត"]។

គាត់កាន់នៅក្នុងគណៈកម្មាធិការស្ទឹងហាវ គាត់ទទួលខុសត្រូវក្នុងការសាងសង់ទំនប់អូរឈើទាល និងការដ្ឋានកងកេង (វាលស្រែ និងទំនប់ពូធឿង)[688]។

<u>សមាសភាព និងតួនាទីរបស់កងវរៈសេនាធំលេខ ១៦១ លេខ ១៦២ លេខ ១៦៣ និងរបស់កងទ័ពជើងទឹក (កងវរៈសេនាធំលេខ ១៤០)</u>

*ក) កងវរៈសេនាធំលេខ ១៦១ (អតីតកងវរៈសេនាធំលេខ ២០)*

226. មេដឹកនាំកងវរៈសេនាធំលេខ ១៦១ ត្រូវបានផ្លាស់ប្តូរជាបន្តបន្ទាប់ ដែលបង្កឱ្យមានការលំបាកក្នុងការកំណត់រយៈពេលពិតប្រាកដ ក្នុងអំឡុងពេលដែលមេបញ្ជាការមួយចំនួនរបស់កងវរៈសេនាធំនេះបានអនុវត្តអំណាចរបស់ពួកគេទៅលើកងទ័ព[689]។ ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ទីម

---

688 ឯកសារ D54/49 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.34-35 ["អ៊ឹម ជាគណៈកម្មាធិការកសាងផែនៅស្ទឹងហាវ។ អ៊ឹម ជាប្អូនប្រាប់របស់ មាស មុត [...] ស៖ តើ អ៊ឹម មានតួនាទី និងមុខងារអ្វី? ឆ.35៖ [...] បន្ទាប់ពីរំដោះឆ្នាំ១៩៧៥ មាស មុត បានយកគាត់ទៅជាមួយ ហើយតែងតាំងគាត់ជាគណៈស្ទឹងហាវ"]។ ឯកសារ D114/58 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.14, 16 ["តំបន់ទំនប់នេះស្ថិតក្រោមការគ្រប់គ្រងរបស់កងពល១៦៤។ ខ្ញុំដឹងផងដែរថា ឈ្មោះ មាស អ៊ឹម ជាអ្នកទទួលខុសត្រូវផ្នែកភស្តុភារ។ តាមពិតខ្ញុំមិនដឹងថាពាក្យភស្តុភារនេះ មានន័យថាម៉េចនោះទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថាឈ្មោះមាស អ៊ឹម នេះជាអ្នកមើលការខុសត្រូវទំបន់នេះ។ មាស អ៊ឹម មិនត្រឹមតែជាអ្នកទទួលខុសត្រូវនៅតំបន់ទំនប់នេះទេ គាត់ជាអ្នកមើលនៅការដ្ឋាននៅកងកេង (ការដ្ឋានស្រែ និងការដ្ឋានទំនប់ពូធឿង) ផងដែរ ហើយគាត់ជាអ្នកទទួលខុសត្រូវផ្នែកភស្តុតាងនៅតំបន់នោះ [...] ឆ.16៖ នៅឆ្នាំ១៩៧៧ [...] មាស មុត ជាអ្នកទទួលខុសត្រូវគ្រប់ការដ្ឋានទាំងអស់ រួមទាំងការដ្ឋាននៅកងកេងផង"]។ ឯកសារ D54/20 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ សំ កេត ឆ.14 ["ក្រោយមកគេឱ្យទៅធ្វើពលកម្មនៅព្រលានយន្តហោះកងកេងរយៈមួយខែ។ វាជាការងារដ៏លំបាក ខ្ញុំទៅធ្វើស្រែនៅកងចល័តបិតក្រោមតា អ៊ឹម។ តាអ៊ឹមជាកម្មាភិបាលជាន់ខ្ពស់បន្ទាប់ពីមាសមុត។ អ៊ឹមជាអ្នកមើលការងារនៅការដ្ឋានកងកេង ហើយគាត់ជាអនុមេបញ្ជាការកងពល១៦៤ទទួលបន្ទុកភស្តុភារ។ តាមដែលខ្ញុំដឹង អ៊ឹមប្រហែលជាសាច់ញាតិរបស់មាសមុត តែខ្ញុំមិនដឹងថា គាត់ជាបងប្អូនបង្កើតឬជាជីដូនមួយទេ" (សង្កត់ន័យបន្ថែម)]។ ឯកសារ D114/215 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ មាស អ៊ឹម EN 01301422 ["ក្នុងឆ្នាំ ១៩៧៦ អនុប្រធានកងពលធំលេខ ១៦៤ ឌីម បានតែងតាំង អ៊ឹម ឱ្យកាន់មុខតំណែងជាប្រធានជាងម៉ាស៊ីនកងពលធំលេខ ១៦៤។ អ៊ឹម ទទួលខុសត្រូវជួសជុលឡានកាមីញ៉ុង និងត្រាក់ទ័រ។ មានយោធា៨០០នាក់ ក្រោមការគ្រប់គ្រងរបស់ អ៊ឹម"]។ ឯកសារ D114/214 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.28 [បានអះអាងថាគាត់គ្រប់គ្រងត្រាក់ទ័រពីរបីគ្រឿងនៅការដ្ឋានស្ទឹងហាវ និងមិនមានទាហាន៨០០នាក់ទេ]។

689 សូមមើល ឧទាហរណ៍ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968420, KH ERN 00926644 ["ស៖ ដល់៦១ ពីណាគេប្រធាន? ឆ៖ ៦១នឹង កាលមុននឹងតាង៉ែត។ ស

សេង គឺជាមេបញ្ជាការកងវរៈសេនាធំលេខ ២០[690] រហូតដល់ខែ សីហា ឆ្នាំ ១៩៧៥ ជាពេលដែលគាត់បានក្លាយជាមេបញ្ជាការរងនៃកងវរៈសេនាធំលេខ ១៤០ ដែលទើបតែបង្កើតឡើងថ្មីនៅក្នុងកងពលធំលេខ ១៦៤[691]។ រហូតទាល់តែគាត់បានក្លាយជាសមាជិកគណៈកងពលធំលេខ ១៦៤ ម៉ែន ង៉ែត បានបន្តដើរតួនាទីជាអ្នកដឹកនាំនៅក្នុងកងវរៈសេនាធំលេខ ២០/១៦១ ក្នុងនាមជាមេ

---

៖ តាង៉ែត ក្រោយមក? ឆ. បាទ! ក្រោយមកដាក់តាសេង អឺ!មិនមែនសេងទេ [...] បាទ! ក្រោយមកគេដាក់៦១នឹង អឺ! តាភាព វាដក វាប្តូរចុះរហូតកាលនឹង"]។

690 ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ហៅ សារ៉េត ឆ.2, 9 ["ខ្ញុំជាកូនទាហានធម្មតាក្នុងកងពលលេខ ៣, វរៈសេនាធំលេខ ២០ មានមេបញ្ជាការឈ្មោះសេង (ស្លាប់) វរៈសេនាតូចលេខ៤៣០ មានមេបញ្ជាការឈ្មោះរ៉ឹម [...] ឆ. 9៖ មាន សេង តែមួយទេដែលខ្ញុំធ្លាប់ស្គាល់ គាត់ជាមេបញ្ជាការវរៈសេនាធំ ២០ បន្ទាប់ពីកងទ័ពជើងទឹកត្រូវបានបង្កើតឡើង ឈ្មោះ សេង ក្លាយជាអនុបញ្ជាការវរៈសេនាធំ ១៤០។ ក្រោយមកទៀត គាត់បានក្លាយជាអនុមេបញ្ជាការកងពល១៦៤"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ.15, 221 ["វរសេនាធំលេខ ២០ ឈ្មោះ សេង [...] ឆ.221៖ កាលពីមុន សេង ជាមេបញ្ជាវរសេនាធំ៦១ ហើយបានជំនួសដោយឈ្មោះ សុន វិញ"]។ ឯកសារ D54/46 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.37 ["មិនមានឈ្មោះ យឹម សេង ទេ គឺមានតែឈ្មោះ ទឹម សេង គាត់ជាមេបញ្ជាការវរសេនាធំលេខ២០ ហើយ ង៉ែត ជាមេបញ្ជាការវរសេនាធំលេខ២១។ មានម្នាក់ទៀត ញ៉ាន់ កាន់ខាងភស្តុភារ។ ស្រស់ ជាមេបញ្ជាការកងវរសេនាធំលេខ២២"]។

691 ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ.222 ["ស៖ តើសេង ទៅណា បានជាលែងធ្វើជាមេបញ្ជាការវរសេនាធំ៦១? ឆ.222៖ ពីព្រោះ សេង ត្រូវបានគេដកទៅវរសេនាធំលេខ១៤០វិញ"]។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ហៅ សារ៉េត ឆ.9 ["គាត់ [សេង] ជាមេបញ្ជាការវរៈសេនាធំ ២០ បន្ទាប់ពីកងទ័ពជើងទឹកត្រូវបានបង្កើតឡើង ឈ្មោះ សេង ក្លាយជាអនុបញ្ជាការវរៈសេនាធំ ១៤០"]។ ឯកសារ D114/132 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ រ៉ាន់ ឆ.177 ["ស៖ យើងបានទទួលព័ត៌មានថា ទឹម សេង គាត់ក៏ធ្លាប់ជាមេបញ្ជាការវរសេនាធំលេខ១៤០ ហ្នឹងដែរ។ តើលោកមានដែលធ្លាប់ឮឈ្មោះគាត់ដែរទេ? ឆ.177៖ ខ្ញុំមិនត្រឹមតែធ្លាប់ឮឈ្មោះគាត់ទេ ខ្ញុំថែមទាំងស្គាល់គាត់ទៀតផង គាត់ជាអនុរបស់ សារឿន"]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968421, KH ERN 00926645 ["ស៖ ចុះអឺ! ខាងវរសេនាធំ១៤០ មានតាសេង គាត់អ្នកដឹកនាំ? [...] ឆ៖ តា ដំបូងបំផុតនឹងតាសេងនឹងគាត់អនុគេទេ"]។ ឯកសារ D1.3.5.4 បញ្ជីឈ្មោះមនុស្សដែលជាប់ក្នុងចម្លើយខ្មាំង នៅមន្ទីរស-២១ KH ERN 00161749 [លេខរៀង១, ២, ៣៖ កំណត់អត្តសញ្ញាណ សេង ជាអនុប្រធានបញ្ជាការកងវរៈសេនាធំ១៤០ និង សារឿន ជាស្នងការ]។ កថាខណ្ឌ ២៤៤។ សូមមើលផងដែរ កថាខណ្ឌ ២៤៤។

បញ្ជាការ ឬស្នងការនយោបាយនៅក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥។ គាត់ត្រូវបានចាប់ខ្លួន ហើយត្រូវបានបញ្ជូនទៅកាន់មន្ទីរ ស-២១ ក្នុងខែ មិថុនា ឆ្នាំ ១៩៧៧[692]។

227. ក្រោយមក កម្មាភិបាលពីរនាក់ផ្សេងទៀត បានក្លាយជាមេបញ្ជាការកងវរៈសេនាធំលេខ ១៦១ គឺ ម៉ោង សុន ហៅ សុន ដែលជាអតីតមេបញ្ជាការកងវរៈសេនាតូចលេខ ៣៧០ ក្នុងកងពលធំលេខ ៣ [693] និង សុក ភាព[694]។

---

692 ឯកសារ D2/8 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.45 ["ឈ្មោះ ង៉ែត ធ្វើជាស្នងការកងវរៈសេនាធំលេខ២០ ឬ ៦១។ [...] ស្នងការគេមិនដូរទេ គឺនៅដដែល តាំងពីមុនពេលភ្នំពេញបែក និងក្រោយភ្នំពេញបែក"]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.8 ["ហើយង៉ែតជាស្នងការវរៈសេនាធំ២០ ង៉ែតត្រូវបានគេចាប់ក្នុងរយៈពេលបោសសំអាតប្រហែលក្នុងឆ្នាំ១៩៧៧។ ខ្ញុំមិនចាំថាអ្នកណាជាស្នងការវរៈសេនាធំ ២១ទេ ហើយ យ៉ាន គឺជាស្នងការវរៈសេនាធំ ២២"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.4 ["យ៉ាន មេបញ្ជាការវរៈសេនាធំ២២, ង៉ែត មេបញ្ជាការវរៈសេនាធំ ២០"]។ ឯកសារ D59/1/1.9a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ EN ERN 00963712, KH 00926446 ["ធំលេខ២០ ដែលរបស់ឈ្មោះ ង៉ែត ហ្នឹងហី? ឆ៖ បាទ"]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល EN ERN 00968420, KH ERN 00926644 ["៦១នឹង កាលមុននឹងតាង៉ែត"]។ ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ ពិន សារិន EN ERN 00217561 ["ពួកគេបានធ្វើស្រែនៅឃុំស្នាច់ដែង ក្រោមការគ្រប់គ្រងរបស់ តាង៉ែត ដែលជាមេបញ្ជាការកងវរៈសេនាធំ"]។ សូមមើលផងដែរ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស [កំណត់អត្តសញ្ញាណ ឈ្មោះ ម៉ែន ង៉ែត លេខរៀង ៥២៤២ ដែលជាសមាជិកកងពលធំលេខ ១៦៤ ត្រូវបានបញ្ជូនទៅមន្ទីរស-២១ នៅខែមិថុនា ឆ្នាំ១៩៧៧]។ ឯកសារ D9.3 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស ពីកងពលធំលេខ១៦៤ លេខរៀង ២៦ EN ERN 00679642។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.15។ ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.12។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.4។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.62, 66។ ឯកសារ D54/46 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.58។ អែម សុន បានបដិសេធតួនាទី និងមុខតំណែងមួយចំនួនក្នុងកងពលធំលេខ ១៦៤៖ ឯកសារ D54/46 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.37 ["មិនមានឈ្មោះ យឹម សេង គាត់ជាមេបញ្ជាការវរសេនាធំលេខ២០ ហើយ ង៉ែត ជាមេបញ្ជាការវរសេនាធំលេខ២១"]។

693 ឯកសារ D59/1/1.9a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ EN ERN 00963711, KH ERN 00926445 ["វរៈសេនាតូចលេខ៣៧០ មេបញ្ជាការវរៈសេនា ម៉ៅ សុន"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.15, 221 ["វរសេនាធំលេខ៣៧០ ឈ្មោះ សុន ហើយវរសេនាធំលេខ២០ ឈ្មោះ សេង ហើយកងពលធំលេខ៣ គឺលោក មាស មុត។ [...] ឆ.221៖ កាលពីមុន សេង ជាមេបញ្ជាវរសេនាធំ៦១ ហើយបានជំនួសដោយឈ្មោះ សុន វិញ"]។ ឯកសារ D59/1/1.14 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហ៊ីង អ៊ិច KH ERN 00926673 ["ស៖ ចុះឈ្មោះ សុន? ឆ៖ គាត់ប្រធានវរៈ។ ស៖ ប្រធានវរៈ

228. កិច្ចការស្នូលរបស់កងទ័ពនៃកងវរៈសេនាធំលេខ ១៦១ គឺការពារតំបន់ឆ្នេរ និងគ្រប់គ្រងកោះត្រល់ និងកោះរុង (កោះរុងធំ និងកោះរុងសន្លឹម)[695]។ ទីបញ្ជាការរបស់កងវរៈសេនាធំលេខ ១៦១ ស្ថិត

---

៣៧០នឹង? ឆ៖ បាទ!"]។ ឯកសារ D59/1/1.7a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ា ឈឿន EN ERN 00969931, KH ERN 00926308 ["ស៖ ចុះគាត់អ្នកទទួលខុសត្រូវខាង៦១? ឆ៖ ឈ្មោះតាសុន"]។ ឯកសារ D54/81.2 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហ៊ីង អ៊ុច EN ERN 01001396, KH ERN 00984339 ["វរសេនាធំ៦១បងសុននឹង ឡើងមកនឹង"]។ ឯកសារ D54/110 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ. 17 ["សុន ជាមេបញ្ជាការកងវរៈសេនាធំលេខ ៦២"]។ ម៉ៅ សុន ប្រហែលជាមេបញ្ជាការ នាវ សុខន ហៅ កេន ត្រូវបានបង្គំឱ្យរៀបការនៅស្ទឹងហាវ ក្នុងឆ្នាំ ១៩៧៧ ឬ ១៩៧៨ (ទោះបីជានាងបានគិតថា គាត់ជាមេបញ្ជាការកងវរសេនាធំលេខ ១៤០ ក៏ដោយ)៖ ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ហៅ ខេន ឆ.247-250, 267-269 [និយាយពី មុត ឬ សុន មុត]។

694 ឯកសារ D1.3.30.6 របាយការណ៍អគ្គសេនាធិការរបស់កម្ពុជាប្រជាធិបតេយ្យ តារាងស្ថិតិសិក្ខាកាម វគ្គសេនាធិការលើកទី២ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ EN ERN 00195331, KH ERN 00008465-66 [បញ្ជីឈ្មោះ ភាព ជាមេបញ្ជាការកងវរៈសេនាធំលេខ១៦៤]។ ឯកសារ D54/9 កំណត់ហេតុស្តាប់ចម្លើយ មិន ផុន ឆ.5 ["នៅស្ទឹងហាវ កងអនុសេនាធំរបស់ខ្ញុំត្រូវបានដាក់បញ្ចូលទៅក្រោមបញ្ជាការកងវរៈសេនាតូចមួយរបស់វរៈសេនាធំ ៦១ នៃកងពល ១៦៤។ កងវរៈសេនាតូចថ្មីរបស់ខ្ញុំមានទីតាំងនៅខាងក្រៅស្ទឹងហាវ [...] ខ្ញុំនៅចាំឈ្មោះមេបញ្ជាការវរៈសេនាធំ ៦១ កាលពីពេលនោះឈ្មោះ ភាព"]។ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.21 ["ខ្ញុំរាយការណ៍ឡើងទៅមេវរសេនាធំ ឈ្មោះ ភាព និង ឡន"]។ ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ ស៊ាង EN ERN 00217564 ["ប្រធានកងវរសេនាធំរបស់គាត់គឺ ភាព (សុខ ភាព)"]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968420, KH ERN 00926644 ["ស៖ ដល់៦១ ពីណាគេប្រធាន? ឆ៖ ៦១នឹង កាលមុននឹងតាង៉ែត។ ស៖ តាង៉ែត ក្រោយមក? ឆ. បាទ! ក្រោយមកដាក់តាសេង អឺ!មិនមែនសេងទេ [...] បាទ! ក្រោយមកគេដាក់៦១នឹង អឺ!តាភាព វាដក វាប្តូរចុះរហូតកាលនឹង"]។ ឯកសារ D4.1.752 បទសម្ភាសន៍ជាមួយ ជនមិនស្គាល់អត្តសញ្ញាណ ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387359, KH ERN 01519658 ["មេបញ្ជាការនៃកងវរសេនាធំទី ៦១ គឺ ((ភាព))"]។ ឯកសារ D4.1.746 បទសម្ភាសន៍ជាមួយ សំ សុក ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387462, KH ERN 00742597 ["កងវរៈសេនាធំលេខ ៦១ ប្រតិបត្តិការនៅជិតត្រពាំងខ្លុង (Trapeang Khlung) (មិនឃើញនៅលើផែនទី)។ មេបញ្ជាការកងវរៈសេនាធំគឺ ភាព (Pheap)"]។

695 ឯកសារ D114/57 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ កេត ឆ.8 ["អង្គភាពដែលស្ថិតនៅលើកោះរុងសន្លឹង គឺស្ថិតនៅក្រោមកងវរៈសេនាធំ៦១។ ក្រោមវរៈសេនាធំលេខ៦១ មានកោះដូចជាកោះកុង កោះរុងធំ និងកោះរុង"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត់ (ប៊ុន សារ៉ាត់) ឆ. 141 ["វរសេនាធំ៦១ បោះនៅកោះរុងធំ"]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968388,

នៅឆ្នេរអូរឈើទាលរហូតដល់ឆ្នាំ ១៩៧៦[696]។ នៅពេលដែលមជ្ឈិមបក្សបានសម្រេចសាងសង់កំពង់ផែយោធានៅស្ទឹងហាវ ដោយចាប់ផ្តើមក្នុងឆ្នាំ ១៩៧៦ នោះ ទីបញ្ជាការរបស់កងវរៈសេនាធំលេខ ១៦១ ត្រូវបានផ្លាស់ប្តូរទីតាំងទៅកាន់ទីនោះ ដែលបានជួយដល់ការសម្របសម្រួល និងការឃ្លាំមើលពលករជាទាហានដែលត្រូវបានបោសសម្អាតនៅកងពលធំលេខ ១៦៤[697] រាប់រយនាក់។

229. បើទោះជាកងវរៈសេនាធំលេខ ២០ មានយ៉ាងហោចណាស់កងវរៈសេនាតូចលេខ ៣១០ លេខ ៣២០ លេខ ៣៣០ និងលេខ ៣៧០ នៅចន្លោះពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ខែ សីហា

---

KH ERN 00926615 ["គេដាក់វរសេនាធំ៦១ [កោះរ៉ុង]"]។ ឯកសារ D59/1/1.7a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ា ឈឿន EN ERN 00969931, KH ERN 00926308 ["៦១ នៅខាងកោះរ៉ុង"]។

696 ឯកសារ D54/81.2 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហ៊ីង អ៊ុច EN ERN 01001394, KH ERN 00984337 ["ស៖ មកដល់ដំបូង ពូនៅម្តុំណាទៅ? ឆ៖ បាទ! ខ្ញុំនៅអូរឈើទាល [...] ខ្ញុំនៅម៉ាវរៈ វរសេនាតូចតាមភាគតិច [...] ៧៥ ជិតចូល៧៦នេះ"]។ EN ERN 01001395, KH ERN 00984338 ["ស៖ ពេលកងពល១៦៤ដល់វរៈសេនាធំប៉ុន្មាន? ឆ៖ វរសេនាធំ៦១"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ.35, 37, 40 ["យើងនៅកំពង់ផែកំពង់សោមបានពីរបីថ្ងៃ រួចហើយទៅនៅអូរឈើទាល រហូតដល់ឆ្នាំ១៩៧៦។ [...] ឆ.37៖ វរសេនាធំលេខ៦១ របស់ខ្ញុំ គឺនៅអូរឈើទាល [...] ស៖ នៅពេលលោកនៅអូរឈើទាល តើលោកធ្វើអ្វីខ្លះ? [...] ឆ.40៖ យើងការពារតាមឆ្នេរសមុទ្រ គឺយើងខ្លាចគិញចូលមកយកការណ៍"]។ ឯកសារ D54/99 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.31 ["ទៅដល់កំពង់សោម អង្គភាពខ្ញុំបានបោះទីតាំងនៅអូរឈើទាល"]។

697 ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.39 ["ស៖ តើនៅស្ទឹងហាវហ្នឹងគឺជាទីបញ្ជាការវរសេនាធំ៦១ ឬគ្រាន់តែជាមូលដ្ឋានមួយរបស់វរសេនាធំ៦១? ឆ.39៖ ទីបញ្ជាការវរសេនាធំ៦១"]។ ឯកសារ D54/83 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.36-38, 42 ["ខ្ញុំនៅស្ទឹងហាវបានប្រហែល១-២ខែ គឺនៅដើមឆ្នាំ១៩៧៧ [...] ឆ.37៖ ពីព្រោះអង្គភាពរបស់ខ្ញុំកងវរៈសេនាធំ៦១ ត្រូវបានផ្ទេរទៅស្ទឹងហាវ ហើយមានទីតាំងនៅទីនោះ [...] ឆ.38៖ មានតែបីវរៈសេនាតូចដែលផ្ទេរទៅបោះទីតាំងនៅស្ទឹងហាវ [...] កងវរៈសេនាតូចរបស់ខ្ញុំលេខ៤១២ ឬ៣១២ [...] ឆ. 42៖ ខ្ញុំចាំថាបញ្ជាការដ្ឋានកងវរៈសេនាធំ៦១មានទីតាំងនៅក្បែរចម្ការដូងក្បែរអូរត្រេះនៅស្ទឹងហាវ"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ.178, 180 ["ស៖ តើលោកទៅស្ទឹងហាវនៅឆ្នាំណាដែរ? ឆ.178៖ ខ្ញុំទៅទីនោះ នៅពាក់កណ្តាលឆ្នាំ១៩៧៧។ [...] ស៖ នៅស្ទឹងហាវ តើមានទាហានបោះទីតាំងនៅដីគោកដែរទេ? ឆ. 180៖ បាទ មាន គឺវរសេនាធំលេខ៦១"]។ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.24 ["ការប្រជុំជាមួយវរសេនាធំ គឺធ្វើឡើងមន្ទីរវរសេនាធំ នៅស្ទឹងហាវតែម្តង"]។ ឯកសារ D4.1.750 បទសម្ភាសន៍ជាមួយជនមិនស្គាល់អត្តសញ្ញាណ ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387278, KH ERN 01496677 ["កងវរសេនាធំលេខ ២០ ឈរជើងនៅស្ទឹងហាវ និងនៅរោងចក្រចម្រាញ់ប្រេងកាត"]។ សូមមើល VIII.E. ផ្នែកការដ្ឋានការងារស្ទឹងហាវ សម្រាប់ព័ត៌មានលម្អិតអំពីរចនាសម្ព័ន្ធ និងការចាត់តាំងការដ្ឋានការងារ។

ឆ្នាំ ១៩៧៥[698] ក៏ដោយ ក៏កងវរៈសេនាធំលេខ ៦១ មានតែកងវរៈសេនាតូចតែបីកងប៉ុណ្ណោះ គឺកងវរៈសេនាតូចលេខ ៦១១ លេខ ៦១២ (អតីតលេខ ៣៧០) និងលេខ ៦១៣[699]។ ការណ៍នេះអាចត្រូវបានពន្យល់ដោយកត្តាពីរយ៉ាង គឺទាហានចំនួនប្រហែល ៣០០ នាក់មកពីកងវរៈសេនាតូចលេខ ៣១០ ត្រូវបានដកហូតអាវុធ និងបោសសម្អាត បន្ទាប់ពីកងទ័ពវៀតណាមបានដោះលែងពីកោះត្រល់នៅពាក់កណ្ដាលឆ្នាំ ១៩៧៥ ខណៈកងទ័ពមួយចំនួនផ្សេងទៀតមកពីកងវរៈសេនាធំលេខ ២០

---

[698] ឯកសារ D4.1.751 បទសម្ភាសន៍ជាមួយ ជនមិនស្គាល់អត្តសញ្ញាណ ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387258, KH ERN 01519652 ["កងវរសេនាធំទី ២០ មានកងវរសេនាតូចជាចំណុះទី ៣២០ ទី ៣៣០ ទី ៣៧០"]។ ឯកសារ D114/79 កំណត់ហេតុស្ដាប់ចម្លើយ កង សុំ ឆ.31 ["មាន កងវរសេនាតូច ៣ ដែលមានលេខ ៣៣០, ៣២០, ៣១០"]។ ឯកសារ D54/99 Lកំណត់ហេតុស្ដាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.17 ["វរសេនាតូចលេខ៣៧០ នៅក្រោមវរសេនាធំលេខ២០"]។ ឯកសារ D114/186 កំណត់ហេតុស្ដាប់ចម្លើយ សាត ចក់ ឆ.116-117។ ឯកសារ D54/36 កំណត់ហេតុស្ដាប់ចម្លើយ ប្រាក់ សុខា ឆ.2, 9, 11។ ឯកសារ D114/264 កំណត់ហេតុស្ដាប់ចម្លើយ ជុំ ជី ឆ.40។ ឯកសារ D54/105 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.4។ ឯកសារ D54/43 កំណត់ហេតុស្ដាប់ចម្លើយ លុន សេង ឆ.15។ ឯកសារ D114/78 កំណត់ហេតុស្ដាប់ចម្លើយ ស្វាយ សាម៉េត ឆ.16។ ឯកសារ D114/95 កំណត់ហេតុស្ដាប់ចម្លើយ យឹម ស្រៀង ឆ.12, 15, 220។ ឯកសារ D2/8 កំណត់ហេតុស្ដាប់ចម្លើយ សយ ប៊ិន ឆ.54 ["ធ្លាប់ឮវរៈសេនាតូច៣៨០, ៣៧០"]។ ឯកសារ D114/260 កំណត់ហេតុស្ដាប់ចម្លើយ ស៊ិន សុត ឆ.33។

[699] ឯកសារ D114/230.1.1 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស ការកំណត់អត្តសញ្ញាណ លេខរៀង ១៣.១១៥ ជា សេក ហៀង ហៅ សេក ផៀង ជាអនុលេខាវរសេនាតូចលេខ ៦១៣ ត្រូវបានចាប់ខ្លួននៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៧៧ ហើយស្លាប់ដោយជំងឺនៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៨] [ការកំណត់អត្តសញ្ញាណ លេខរៀង ៤.១៦០ ជា សុក ហឿន លេខាកងអនុសេនាធំលេខ ២ កងវរសេនាតូចលេខ ៦១១ កងវរសេនាធំ ចូលស-២១ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៧៧]។ ឯកសារ D4.1.1070 សម្រង់ចម្លើយសារភាពរបស់ សឹង គ្រិន ហៅ ងួន។ ឯកសារ D114/43.7 បញ្ជីអ្នកទោសនៅមន្ទីរស-២១ (បញ្ជីឈ្មោះអ្នកទោសចូលខែ ឧសភា ឆ្នាំ ១៩៧៧) KH ERN 01065643 [កំណត់អត្តសញ្ញាណ លេខរៀង ៥៦ ឈ្មោះ អ៊ុក អឿន ជាលេខាអនុកងវរសេនាធំ ៦១១ ដែលត្រូវបានចាប់ខ្លួននៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៧៧]។ ឯកសារ D114/208 កំណត់ហេតុស្ដាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.16-17, 23 ["គេក៏បានដកខ្ញុំពីកងវរសេនាតូចកាំភ្លើងធំ ឲ្យទៅស្ទឹងហាវ [...] ឆ.17៖ កងវរសេនាតូចលេខ ៦១២ [...] ឆ.23៖ នៅវរសេនាតូច៦១២ តួនាទីរួមមាន ខួងថ្ម បំបែកថ្ម និងលើកថ្មមកបាំងនៅការដ្ឋាន និងធ្វើការងារផ្សេងទៀត"]។ ឯកសារ D54/83 កំណត់ហេតុស្ដាប់ចម្លើយ ហ៊ីង អ៊ុច ឆ.38 ["មានបួនកងវរៈសេនាតូចនៅក្នុងកងវរៈសេនាធំ៦១។ មានតែបីវរៈសេនាតូចដែលផ្ទេរទៅបោះទីតាំងនៅស្ទឹងហាវ។ ខ្ញុំមិនដឹងអំពីកងវរៈសេនាតូចផ្សេងទៀតទេ តែសម្រាប់កងវរៈសេនាតូចរបស់ខ្ញុំគឺទៅរៀនបច្ចេកទេស។ កងវរៈសេនាតូចរបស់ខ្ញុំលេខ៤១២ ឬ៣១២ ព្រោះខ្ញុំចាំមិនសូវច្បាស់ទេ"]។

បានចូលរួមជាមួយកងទ័ពជើងទឹកដែលទើបតែបង្កើតថ្មី (កងវរៈសេនាធំលេខ ១៤០)[700]។ នៅទីកន្លែងណាដែលជាធម្មតាគេហៅកងវរៈសេនាធំលេខ ១៦១ ថាជាកងវរៈសេនាធំលេខ "៦១" នោះ

[700] ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុ ឆ.121, 126, 148-153, 156-163, 229 [យោធាកងវរសេនាតូចលេខ ៣១០ រៀបរាប់អំពីរបៀបដែលយោធា៣០០នាក់មកវរសេនាតូច រួមទាំងគាត់ផង ត្រូវគេវាយប្រហារនៅលើកោះក្រចកសេះ (កោះពូលូតាំងសង់) នៅពាក់កណ្តាល ឆ្នាំ ១៩៧៥ ហើយត្រូវគេចាប់ចង និងបិទមុខ បញ្ជូនទៅកោះត្រល់ដែលជាកន្លែងពួកគេត្រូវឃុំខ្លួន និងធ្វើការអស់រយៈពេល៣ខែ ក្នុងឋានៈជាឈ្លើយសឹក]។ ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.15 ["ការវ៉ៃកោះពូលូវ៉ៃទេ។ នៅថ្ងៃមួយ តាមខ្ញុំចាំ កងទ័ពយួនបានជិះកប៉ាល់ P-111 ដែលមានកងទ័ពប្រហែល៣០០ ទៅ ៤០០នាក់ ហើយឈប់នៅកោះពូលូវ៉ៃ ហើយនៅពេលជាមួយគ្នានោះ កងទ័ពយួនមួយចំនួនទៀតបានហែលទឹកពីគ្រប់ទិសនៅជុំវិញកោះហ្នឹង ដើម្បីវ៉ៃយើងដោយមិនដឹងខ្លួន។ ពេលនោះ ទ័ពយួនក៏បានចាប់យោធារបស់កងវរសេនាតូច៣១០ទាំងអស់ ហើយបញ្ជូនទៅទុកលើកោះត្រល់។ កងទ័ពយួននៅពេលនោះបានចាប់ទាំងទូកល្បាតរបស់យើង ហើយនិងពួកយោធា និងពេទ្យមកពីកំពង់សោម ដែលមកជួយអន្តរាគមន៍ផង"]។ ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ិន សុត ឆ.73 ["[កងវរៈសេនាតូច៣១០គឺ] កងទ័ពតាមុត [...] វ៉ៃហ្នឹងនៅកោះពូលូវ៉ៃ ដែលពួកវៀតណាមនៅវ៉ៃកងទ័ពមុត ហ្នឹងណា មិនមែនកោះត្រល់ទេ ដល់ពេលវៀតណាមចាប់បាន ទើបបញ្ជូនទៅកោះត្រល់។ ហើយបញ្ជូនទៅកោះត្រល់ហើយ ទើបបញ្ជូនមកវិញតាមកែប ហើយបានបញ្ជូនមកកន្លែងខ្ញុំធ្វើស្រែទាំងអស់ ដោយសារគេខ្លាចថាពួកវៀតណាមបំពាក់នយោបាយអ្វី គេមិនឱ្យធ្វើទ័ពវិញទេ"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ ឆ.111, 113, 119-121 ["ពេលវៀតណាមមកវ៉ៃ គឺវ៉ៃនៅកោះពូលូវ៉ៃ ដោយវាថាកោះនេះជាកោះរបស់វា [...] រឿងនេះវាពិតហើយថាវៀតណាមចាប់មនុស្សពីអង្គភាពរបស់ខ្ញុំយកទៅ [កងវរៈសេនាតូច៣១០] ពេលគេបញ្ជូនមកវិញ អ្នកដែលគេបញ្ជូនមក ក៏បានមកនៅក្នុងអង្គភាពខ្ញុំវិញដែរ ប៉ុន្តែអង្គភាពគេមិនឱ្យអ្នកដែលគេចាប់យកទៅមកនៅផ្តុំគ្នាវិញទេ ឧទាហរណ៍ថាដាក់ទីនេះ ២នាក់ ទីនោះ២នាក់អីចឹង ទៅមិនអាចផ្តុំគ្នាបានទេ [...] ដល់ពេលគេពង្រាយអីចឹងហើយ អ្នកដែលគេចាប់ទៅ គឺបានដកចេញពីអង្គភាពហ្នឹងអស់ គឺឱ្យមកនៅកងផលិត ឱ្យមកធ្វើស្រែនៅម្តុំកងកេង [...] គេថាពួកគាត់ជាអ្នកដែលមានប្រវត្តិដែលទៅនៅវៀតណាម [...] ឆ.113៖ គឺយកការធ្វើស្រែជាមូលដ្ឋាន គឺថាយកមកធ្វើស្រែនៅនឹងកងកេងហ្នឹងតែម្តង។ កងកេងជាឈ្មោះព្រលានយន្តហោះ គេយកអ្នកដែលមកសមាសភាពមិនល្អ ទៅធ្វើស្រែនៅទីហ្នឹង [...] ឆ.119៖ គេចាប់ពង្រាយគឺគេមកពីវៀតណាមហើយ គេចូលសាលានយោបាយហើយ [...] គេយកមកបញ្ចូលក្នុងអង្គភាព ប៉ុន្តែនៅក្នុងវរសេនាតូចដដែលទេ តែគេមិនដាក់ឱ្យពួកគាត់នៅជាមួយគ្នាទេ ក្នុងមួយក្រុមគេដាក់១ មួយកងដាក់១ ឬ២អីចឹងទៅ [...] ឆ.120៖ ជំនាន់ហ្នឹងដូចចូលឆ្នាំ១៩៧៦ [...] ឆ.121៖ នៅបានយូរដែរ គ្រាន់តែខ្ញុំមិនបានគិតថ្ងៃ គិតខែ គ្រាន់តែពេលហ្នឹងគេស្រាវជ្រាវប្រវត្តិរូប ដោយគេឱ្យប្រវត្តិរូប ដែលប្រវត្តិរូបគឺសំខាន់ណាស់។ គេមិនដកម្តងទាំងអស់ទេ គឺគេដកមួយៗ។ អ្នកដែលសកម្មនឹងការងារ មានសីលធម៌ល្អ ក៏នៅបានយូរអីចឹងទៅ"]។ សម្រាប់ព័ត៌មានបន្ថែម សូមមើល VII.ក.៣.ក) យោធាកងពលធំលេខ៣ ត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅវៀតណាម ក្នុងឆ្នាំ១៩៧៥។ ពាក់ព័ន្ធទៅនឹងការបង្កើតកងវរសេនាធំ១៤០ ដោយប្រើកម្លាំងបង្ខំមកពីកងពលនៃកងវរសេនាធំ៣ សូមមើល ឧទាហរណ៍ ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.16 ["ប៉ុន្តែនៅពេលនោះមានការរៀបចំកងទ័ពជើងទឹក។ គឺគេរើសចេញពីកងវ

នៅទីនោះជួនកាលគេហៅកងវរៈសេនាតូចលេខ ៦១១ លេខ ៦១២ និងលេខ ៦១៣ ថាជាកងវរៈសេនាតូចលេខ "១" "២" ឬ "៣"[701]។

230. ការស៊ើបអង្កេតនៅក្នុងសំណុំរឿងនេះមិនបានបង្ហាញថា តើអ្នកណាជាមេដឹកនាំរបស់កងវរៈសេនាតូចលេខ ៦១១ នោះទេ។ ឡុង ផាន់នី បានឡើងជំនួស ម៉ៅ សុន ក្នុងនាមជាមេបញ្ជាការកងវរៈសេនាតូចលេខ ៦១២ រហូតដល់ឆ្នាំ ១៩៧៧ ឬ ១៩៧៨[702]។ កងវរៈសេនាតូចនេះបានឈរជើងនៅស្ទឹងហាវ[703]។ ឡុន គឺជាលេខាកងវរៈសេនាតូចលេខ ៦១៣[704] ហើយ សេក ហៀង ឬ សេក ភៀង គឺជាអនុលេខា[705]។ កម្មាភិបាលម្នាក់ឈ្មោះ យាង ត្រូវបានពិពណ៌នាថាជាមេបញ្ជាការដំបូងគេនៃកងវរៈសេនាតូចមួយនៃកងវរៈសេនាធំលេខ ៦១ មុនពេលគាត់ត្រូវបានផ្ទេរឲ្យធ្វើជាមេបញ្ជាការ

---

វរៈសេនាធំ៦១ ៦២ ៦៣ របស់កងពល១៦៤ រៀបចំទៅជាកង១៤០ ដោយមានបញ្ចូលកងវរៈសេនាធំដែលបញ្ជូនមកពីបូព៌ា ដែលហៅថាកង១៤០"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.220។

701 ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.32-33 ["ពេលទៅដល់កំពង់សោម [...] កងពលធំលេខ៣ បានប្តូរឈ្មោះ ទៅជាកងពលលេខ១៦៤។ [...] ស៖ តើវរសេនាធំរបស់លោកមានប្តូរលេខដែរឬទេ? ឆ.33៖ ខ្ញុំនៅវរសេនាធំលេខ៦១ នៅក្នុងកងពលធំលេខ១៦៤ វរសេនាតូចលេខ២ ហើយអនុសេនាធំលេខ២ និងអនុសេនាតូចលេខ២"]។

702 ឯកសារ D1.3.30.5 របាយការណ៍អគ្គសេនាធិការរបស់កម្ពុជាប្រជាធិបតេយ្យ តារាងស្ថិតិសិក្ខាកាម វៀនវគ្គសេនាធិការលើកទី១ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៧៦ EN ERN 00897656, KH ERN 00095537-38 [បញ្ជីឈ្មោះសមមិត្ត ឡុង ផានស៊ី ជាលេខាកងវរៈសេនាធំនៅកងពលលេខ១៦៤]។ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.16-17, 27 ["ការដកទៅស្ទឹងហាវនេះ គឺដកតែខ្ញុំម្នាក់ឯងទេ តែខ្ញុំមានអង្គរក្សរបស់ខ្ញុំម្នាក់ដែរ។ គេដកពីកាំភ្លើងធំ ហើយឲ្យមកកាន់មួយវរសេនាតូច ដែលមានស្រាប់នៅស្ទឹងហាវ [...] ឆ.17៖ កងវរសេនាតូចលេខ ៦១២ [...] ឆ.27៖ ខ្ញុំធ្វើជាមេវរសេនាតូច៦១២ រហូតដល់គេចាប់ខ្លួនខ្ញុំ នៅក្នុង ខែ១ ឬខែ២ ឆ្នាំ១៩៧៧ ឬ១៩៧៨"]។

703 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.15-17 ["គេឲ្យខ្ញុំគ្រប់គ្រងមួយកងវរសេនាតូច កសាងកំពង់ផែនៅស្ទឹងហាវ [...] ឆ.16៖ ការដកទៅស្ទឹងហាវនេះ គឺដកតែខ្ញុំម្នាក់ឯងទេ តែខ្ញុំមានអង្គរក្សរបស់ខ្ញុំម្នាក់ដែរ។ គេដកពីកាំភ្លើងធំ ហើយឲ្យមកកាន់មួយវរសេនាតូច ដែលមានស្រាប់នៅស្ទឹងហាវ [...] ឆ.17៖ កងវរសេនាតូចលេខ ៦១២"]។

704 ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.31 [ការពិពណ៌នាថា តាឡុន ជាមេកងវរៈសេនាតូចរបស់លោក បានចាត់តាំងកងវរៈសេនាតូចទៅយាមកោះរ៉ុង/កោះរ៉ុងសន្លឹម បន្ទាប់ពីការមកដល់របស់ពួកគេនៅកំពង់សោម]។

705 ឯកសារ D114/230.1.1 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស លេខរៀង ១៣១៥៥ [សេក ហៀង ឬ សេក ផៀង អនុលេខាកងវរសេនាតូចលេខ ៦១៣ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៧៧ និងស្លាប់ដោយសារជំងឺ នៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៨]។

កងវរៈសេនាធំលេខ ១៦២[706]។ វ៉ាន់នី និង ផេង គឺជាមេដឹកនាំនៃកងវរៈសេនាតូចផ្សេងទៀត (អង្គភាពកាំភ្លើងត្បាល់) នៅស្ទឹងហាវ[707]។

*ខ) កងវរៈសេនាធំលេខ ១៦២ (អតីតកងវរៈសេនាធំលេខ ២១)*

231. អៀក មៀញ (ឬ មឿន/មាញ/ម៉ាញ/មាឃ) គឺជាមេបញ្ជាការដំបូងគេនៃកងវរៈសេនាធំលេខ ២១/១៦២ នៅក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[708] ហើយ សុន គឺជាអនុរបស់គាត់[709]។ បន្ទាប់ពី

---

706 ឯកសារ D54/83 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.13, 15-18 ["ស៖ ហេតុអ្វីបានជាគេផ្ទេរលោកពីកងវរៈសេនាធំ៦១ ទៅ៦២? ឆ.13៖ ដំបូងឡើយខ្ញុំនៅកងវរៈសេនាធំលេខ៦១ ប៉ុន្តែចាប់តាំងពីមេរបស់ខ្ញុំដែលជាមេបញ្ជាការកងវរៈសេនាតូចត្រូវបានតំឡើងទៅជាមេបញ្ជាការកងវរៈសេនាធំ៦២ គាត់យកខ្ញុំទៅធ្វើការជាមួយគាត់ដែរ [...] ស៖ តើមេបញ្ជាការកងវរៈសេនាធំ៦២ឈ្មោះអ្វី? ឆ.15៖ ឈ្មោះ បងយាង [...] ស៖ តើអ្នកណាជាមេបញ្ជាការវរៈសេនាធំ ៦២ មុនពេលដែល យាង មកកាន់? ឆ.16៖ ឈ្មោះ បង សុន [...] ឆ.17៖ នៅពេលដែល បង យាង មកជំនួស សុន, បង សារី នៅតែធ្វើជាមេបញ្ជាការរងដដែល។ ស៖ តើលោកស្គាល់កម្មាភិបាលម្នាក់ឈ្មោះ មាញ ដែរឬទេ? ឆ.18៖ បាទ ខ្ញុំធ្លាប់ឮកម្មាភិបាលឈ្មោះ តា មាញ។ ខ្ញុំមិនសូវច្បាស់ប៉ុន្មានទេ ប៉ុន្តែបើតាមការសន្និដ្ឋានរបស់ខ្ញុំ គាត់អាចជាមេបញ្ជាការកងវរៈសេនាធំ ពីព្រោះកាលជំនាន់ លន់ នល់ ខ្ញុំឮគេហៅឈ្មោះនេះ ហើយខ្ញុំសង្ស័យថា គាត់កាន់តំណែងជាមេបញ្ជាការកងវរៈសេនាធំ៦២មុន តាសុន។ គេហៅគាត់ថា តាមាញ ៦២"]។

707 ឯកសារ D54/9 កំណត់ហេតុស្តាប់ចម្លើយ មិន ផុន ឆ.5 ["មេបញ្ជាការវរៈសេនាតូចរបស់ខ្ញុំឈ្មោះ វ៉ាន់នី និងអនុរបស់គាត់ឈ្មោះ ផេង។ ខ្ញុំនៅក្នុងកងកាំភ្លើងត្បាល់ ៨២មីលីម៉ែត្រ"]។

708 ឯកសារ D1.3.30.5 របាយការណ៍អគ្គសេនាធិការរបស់កម្ពុជាប្រជាធិបតេយ្យ តារាងស្ថិតិសិក្ខាកាម រៀនវគ្គសេនាធិការលើកទី១ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៧៦ EN ERN 00897655, KH ERN 00095536-37 [បញ្ជីឈ្មោះសមមិត្ត អៀក ម៉ែន ជាលេខាកងវរៈសេនាធំនៅក្នុងកងពលលេខ១៦៤]។ ឯកសារ D114/132 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ រ៉ាន់ ឆ.30 ["ស៖ តើនរណាជាមេបញ្ជាការវរសេនាធំលេខ២១? ឆ.30៖ ឈ្មោះ តាមាញ"]។ ឯកសារ D54/20 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ សំ កេត ឆ.7 ["មេបញ្ជាការវរៈសេនាធំ២១ ដំបូងឈ្មោះមាញ តែក្រោយមកទៀត ខ្ញុំមិនបានដឹងថាអ្នកណាមកជំនួសគាត់ទេ"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត់ (ប៊ុន សារ៉ាត់) ឆ.18 ["វរសេនាធំ១៥ មេង"]។ ឯកសារ D2/8 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.45 ["ឈ្មោះ មាញ ជាស្នងការកងវរៈសេនាធំលេខ២១ ឬ ៦២។ [...] ស្នងការគេមិនដូរទេ គឺនៅដដែល តាំងពីមុនពេលភ្នំពេញបែក និងក្រោយភ្នំពេញបែក"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង រ៉េត EN ERN 00974090, KH ERN 00926536 ["កាលពួកវរៈសេនាធំ១៣ណាស់ ដល់ក្រោយមក២១។ [...] ស៖ ចឹងកាលវរៈ១៣ហ្នឹងមានពីណាគេជាអ្នកគ្រប់គ្រង? ឆ៖ តា មាញ"]។ ឯកសារ D54/111 កំណត់ហេតុស្តាប់ចម្លើយ សំ ភីន ឆ.7 ["មាញ ជាមេបញ្ជាការវរៈសេនាធំលេខ៦២"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.35 ["មេវរសេនាធំ៦២ ឈ្មោះ តាមៀញ"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.15 ["វរសេនាធំលេខ ៦២ ដែលមាន មាញ ជាប្រធាន"]។ ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.6, 66

មាញ ត្រូវបានផ្ទេរចេញពីកងវរៈសេនាធំលេខ ១៦២ ក្នុងឆ្នាំ ១៩៧៦ (ហើយត្រូវបានដាក់ឃុំឃាំងនៅមន្ទីរសន្តិសុខ ទឹក សាប)[710] រួចមក សុន បានដើរតួនាទីជាមេបញ្ជាការបណ្ដោះអាសន្ននៃកងវរ

---

["ស៖ យោងទៅតាមឯកសាររបស់យើង គឺមានតែឈ្មោះ មៀញ ម្នាក់ទេក្នុងកងពល១៦៤ ដែលមានឈ្មោះពេញ អៀក មៀញ ហើយគាត់គឺជាមេកងវរសេនាធំ៦២ ក្រោយកងពល១៦៤។ តើយើងកំពុងនិយាយអំពីឈ្មោះមនុស្សតែមួយមែនទេ? ឆ៖ មនុស្សតែមួយទេ។ [...] ឆ.66៖ ពីមុនមក [មៀញ] គាត់ទទួលបញ្ជាផ្ទាល់ពី មាស មុត ហ្នឹង"]។ ឯកសារ D4.1.746 បទសម្ភាសន៍ជាមួយ សំ សុក ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387462, KH ERN 00742597 ["កងវរៈសេនាធំលេខ ៦២ ប្រតិបត្តិការនៅជិតស្រែខ្លុង។ លោក មាញ (Meanh) (ស្លាប់) ជាមេបញ្ជាការនៃកងវរៈសេនាធំលេខ ៦២ នេះ"]។ ឯកសារ D4.1.750 បទសម្ភាសន៍ជាមួយ ជនមិនស្គាល់អត្តសញ្ញាណ ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387279, KH ERN 01496679 ["តា (មាញ) (ស្លាប់) គឺជាមេបញ្ជាការកងវរសេនាធំលេខ ៦២"]។ ឯកសារ D59/1/1.7a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ា ឈឿន EN ERN 00969930, KH ERN 00926307 ["ស៖ ចុះវរៈសេនាធំ៦២? ឆ៖ ឈ្មោះ មាញ"]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968420, KH ERN 00926644 ["៦២នឹងតាមាយដកពីនឹងមក បាទ!ហើយបានដកតាមាយនឹង បានចូលតាយាង។ ស៖ តាយាងតែ២នាក់នឹងទេ? ឆ៖ បាទ! ហ្នឹងហើយ"]។

709 ឯកសារ D54/83 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.15-18 ["ស៖ តើមេបញ្ជាការកងវរៈសេនាធំ៦២ឈ្មោះអ្វី? ឆ.15៖ ឈ្មោះ បងយាង [...] ស៖ តើអ្នកណាជាមេបញ្ជាការវរៈសេនាធំ៦២ មុនពេលដែល យាង មកកាន់? ឆ.16៖ ឈ្មោះ បង សុន [...] ឆ.17៖ នៅពេលដែល បង យាង មកជំនួស សុន, បង សារី នៅតែធ្វើជាមេបញ្ជាការរងដដែល។ [...] ឆ.18៖ ខ្ញុំសង្ស័យថា គាត់ [មាញ] កាន់តំណែងជាមេបញ្ជាការកងវរៈសេនាធំ៦២មុន តាសុន។ គេហៅគាត់ថា តាមាញ ៦២"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.15 ["វរសេនាធំលេខ ៦២ ដែលមាន មាញ ជាប្រធាន ហើយអនុ គឺ សុន"]។

710 ឯកសារ D54/20 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ សំ កេត ឆ.8-9 ["គឺជាកងវរៈសេនាតូចនៃកងវរៈសេនាធំ២១ [...] មាញត្រូវបានគេបញ្ជូនទៅរៀនសូត្រក្នុងឆ្នាំ១៩៧៧ ប៉ុន្តែខ្ញុំចាំបានថា គេដាក់គុកគាត់នៅគុកទឹកសាប [...] ស៖ ហេតុអ្វីបានជាលោកដឹងថា មាញត្រូវបានគេបញ្ជូនទៅគុកទឹកសាប? ឆ.9៖ ក្នុងឆ្នាំ១៩៨១ ឬ១៩៨២ ខ្ញុំបានដឹងរឿងនេះពីឈ្មោះ ស្វាយ សំអាន ដែលជាអ្នកយាមគុកនៅទឹកសាប។ សំអានបានប្រាប់ខ្ញុំថា គេចាប់តាមាញដាក់គុកនៅទីនោះ។ ខ្ញុំបានសួរសំអានថា តើគាត់ដឹងអ្វីខ្លះពីតាមាញ? ខ្ញុំមិនបានសួរគាត់ថា គុកទឹកសាបនោះឋិតនៅកន្លែងណាទេ ហើយក៏មិនបានដឹងថាគេសម្លាប់តាមាញនៅទីណាដែរ"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ.92 ["ស៖ តើ មាញ ដូរចេញពេលណា? ឆ.92៖ នៅឆ្នាំ១៩៧៦ ហើយដាក់ឈ្មោះ យាង ចូលវិញ។ គាត់ដូរមកកំពង់សោម"]។ ឯកសារ D54/20 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ សំ កេត ឆ.7 ["មេបញ្ជាការវរៈសេនាធំ២១ដំបូងឈ្មោះមាញ តែក្រោយមកទៀត ខ្ញុំមិនបានដឹងថាអ្នកណាមកជំនួសគាត់ទេ"]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968420, KH ERN 00926644 ["៦២នឹងតាមាយដកពីនឹងមក បាទ!ហើយបានដកតាមាយនឹង បានចូលតាយាង"]។

វរៈសេនាធំលេខ ១៦២ រហូតទាល់តែ យ៉ាង (ឬ យ៉ាង) បានក្លាយជាមេបញ្ជាការ ហើយ សារឿន ជាមេបញ្ជាការរង[711]។ កំណត់ត្រារបស់មន្ទីរ ស-២១ ក៏បង្ហាញផងដែរថា កម្មាភិបាលម្នាក់ឈ្មោះ សាន់ ស៊ាប ហៅ សំ ធ្លាប់ជាអនុលេខានៃកងវរៈសេនាធំ មុនពេលត្រូវបានចាប់ខ្លួននៅខែ មេសា ឆ្នាំ ១៩៧៧[712]។

232. កងវរៈសេនាធំលេខ ១៦២ មានកងវរៈសេនាតូចលេខ ៦២១ លេខ ៦២២ លេខ ៦២៣ និងលេខ ៦២៤[713] ខណៈដែលកងវរៈសេនាធំលេខ ២១ មុន មានកងវរៈសេនាតូចលេខ ៤១០ លេខ ៤១៥

---

711 ឯកសារ D54/83 កំណត់ហេតុស្ដាប់ចម្លើយ ហ៊ីង អ៊ុច ឆ.15-18 ["សៈ តើមេបញ្ជាការកងវរៈសេនាធំ៦២ឈ្មោះអ្វី? ឆ.15៖ ឈ្មោះ បងយាង [...] សៈ តើអ្នកណាជាមេបញ្ជាការវរៈសេនាធំ៦២ មុនពេលដែល យាង មកកាន់? ឆ.16៖ ឈ្មោះ បង សុន [...] ឆ.17៖ នៅពេលដែល បង យាង មកជំនួស សុន, បង សារី នៅតែធ្វើជាមេបញ្ជាការរងដដែល។ [...] ឆ.18៖ ខ្ញុំសង្ស័យថា គាត់ [មាញ] កាន់តំណែងជាមេបញ្ជាការកងវរៈសេនាធំ៦២មុន តាសុន។ គេហៅគាត់ថា តាមាញ ៦២"]។ ឯកសារ D114/126 កំណត់ហេតុស្ដាប់ចម្លើយ អ៊ូ គឹម ហៅ រ៉េត ឆ.13 ["សៈ តើអ្នកណាជាមេបញ្ជាការនៅលើកោះតាង? ឆ.13៖ ខ្ញុំមិនច្បាស់ទេ តែខ្ញុំដឹងថាគឺឈ្មោះ តាយាង ជាមេបញ្ជាការវរសេនាធំ៦២ និងអនុគាត់ឈ្មោះ សារឿន ជាអ្នកកាន់កាប់នៅលើកោះនោះ"]។ ឯកសារ D114/113 កំណត់ហេតុស្ដាប់ចម្លើយ គឹម ម៉េន ឆ.90 ["កាលនោះ គេផ្លាស់បង មាញ ចេញទៅ គឺឈ្មោះ យាង ចូលមកជំនួស ហើយគាត់ជាអ្នកដាក់បញ្ជា"]។ ឯកសារ D54/23 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.2 ["វរៈសេនាធំលេខ៦២ មេបញ្ជាការឈ្មោះ តា យាង"]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968420, KH ERN 00926644 ["៦២នឹងតាមាយដកពីនឹងមក បាទ!ហើយបានដកតាមាយនឹង បានចូលតាយាង"]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968388-89, KH ERN 00926615-16 ["សៈ យៀងប្រធានវរសេនាធំ៦២? ឆៈ បាទ!ប្រធាន។ [...] សៈ ចុះបញ្ជាការ? [...] ឆៈ ក្រោយនឹងតាបាននឹង គាត់ឡើងអនុ ដល់ឡើងបាម៉ារយៈគេដកតាបាននឹងទៅខាងបូព៌ា អញ្ចឹងតាយៀងនៅម្នាក់ឯងទេ វរសេនាធំនៅម្នាក់ឯងទេចុងក្រោយនឹង"]។

712 ឯកសារ D1.3.28.40 បញ្ជីឈ្មោះអ្នកទោសកំទេច នៅមន្ទីរស-២១ នៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៩៧៧ EN ERN 00873167, KH 00009083 [កំណត់អត្តសញ្ញាណ លេខរៀង ១៧ ឈ្មោះ សាន់ ស៊ាប ហៅ សំ ជាអនុលេខាកងវរសេនាធំ ៦២ កងពល ១៦៤ បញ្ជូនទៅស-២១ នៅខែមេសា ឆ្នាំ១៩៧៧ (ហើយក៏ត្រូវបានសម្លាប់នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៧)]។ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស លេខរៀង ៨១៧៦។ ឯកសារ D9.3 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស ពីកងពលធំលេខ១៦៤ EN ERN 00679643 [កំណត់អត្តសញ្ញាណ ឈ្មោះ សាន ស៊ាប ហៅ សេម លេខរៀង ៤០ ដែលត្រូវបានបញ្ជូនទៅស-២១ នៅខែ មេសា ឆ្នាំ ១៩៧៧ និងត្រូវបានសម្លាប់នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៧]។

713 សូមមើល កថាខណ្ឌ ២១៨។ សូមមើលផងដែរ ឯកសារ D54/78 កំណត់ហេតុស្ដាប់ចម្លើយ ណុប ហាល់ ឆ.8-9, 14 ["ខ្ញុំទៅនៅកងវរៈសេនាតូច ៦២៤ ក្រោមកងវរៈសេនាធំ៦២ [...] កាលនោះ ខ្ញុំវាមិនច្បាស់មិនដឹងថា កងវរៈសេនា

លេខ ៤២០ លេខ ៤៣០ លេខ ៤៥០ និងលេខ ៤៨០[714]។ ភ្លាមៗក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ កងវរៈសេនាធំនេះដំបូងឡើយមានទីបញ្ជាការនៅជិតរាម ហើយទាហានរបស់កងវរៈសេនាធំនេះត្រូវបានដាក់ពង្រាយនៅលើកោះនៅជិតរាម[715] និងលើកោះនៅភាគខាងត្បូងឆ្ងាយៗ

---

តូច៦២១ ឬ៦២៣ ដែលគេបញ្ជូនទៅចាប់នោះ [...] ស៖ តើការយល់របស់ខ្ញុំត្រឹមត្រូវដែរឬទេថា នៅពេលលោកនិយាយអំពីកងវរៈសេនាតូច៦២១, ៦២២, ៦២៤ គឺលោកសំដៅទៅលើកងវរៈសេនាធំ៦២ នៃកងពល១៦៤មែនឬទេ? ឆ.9៖ បាទ ត្រឹមត្រូវ [...] ឆ.14៖ ខ្ញុំនៅក្នុងកងវរៈសេនាតូច៦២២ នៃវរៈសេនាធំ៦២។ វរៈសេនាតូចខ្ញុំមានទូក២គ្រឿង , កងវរៈសេនាតូច៦២១ មានទូក២គ្រឿង, កងវរៈសេនាតូច ៦២៣ មានទូក១គ្រឿង"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ ក៏ម ម៉េន ឆ.44 [ដែលបានបង្ហាញថាកងវរសេនាតូចលេខ ៦២២ និង ៦២៣ មានដើមកំណើតមកពីតំបន់៣៣]។ ឯកសារ D114/283 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.43 ["នៅវរៈ៦២ មានវរៈសេនាតូចតូច ៦២១, ៦២២, និង៦២៣"]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968386, KH ERN 00926614 ["ស៖ កោះ៦២១ ៦២២ ៦២៣ តែ៣ទេ ក្នុងវរសេនាធំ? ឆ៖ ៦៤២មួយទៀត ឈ្មោះជុំ"]។ ឯកសារ D4.1.746 បទសម្ភាសន៍ជាមួយ សំ សុក ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387462, KH ERN 00742597 ["កងវរៈសេនាធំលេខ ៦២ [...] ត្រូវបានបែងចែកទៅជា ៣ កងវរៈសេនាតូច រួមមាន កងវរៈសេនាតូចលេខ ២១ ២២ និងលេខ ២៣"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.3។ ឯកសារ D114/57 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ កេត ឆ.3។ ឯកសារ D54/20 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ សំ កេត ឆ.2។ ឯកសារ D114/126 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គឹម ឆ.7។ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស EN ERN 01222489 [កំណត់អត្តសញ្ញាណ លេខរៀង ៤១៥៩ ឈ្មោះ ណុប នន ជាលេខាកងវរសេនាតូចលេខ ៦២១]។

714 សម្រាប់ព័ត៌មានលម្អិត សូមមើល កថាខណ្ឌ ២១៣។

715 ឯកសារ D4.1.750 បទសម្ភាសន៍ជាមួយ ជនមិនស្គាល់អត្តសញ្ញាណ ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387279, KH ERN 01496677 ["(ឯកសារពីសមរភូមិ៖ យោងតាមព័ត៌មានសង្ខេបៗផ្សេងទៀត កងវរសេនាធំលេខ ២១ មានទីបញ្ជាការនៅជិតរាម [...] ហើយមន្ទីរពេទ្យរបស់កងវរសេនាធំនេះមានទីតាំងនៅឯចម្ការដូង"]។ ឯកសារ D4.1.762 បទសម្ភាសន៍ជាមួយ កាំ ម៉ែន (កាំ ម៉ែន) ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387329, KH ERN 00742580 ["កងវរៈសេនាធំមានកងវរៈសេនាតូចក្រោមឱវាទចំនួនបួនគឺ កងវរៈសេនាតូចលេខ ៤១០ ៤២០ ៤៨០ និងកងវរៈសេនាតូច៤៩០ ហើយមានទីបញ្ជាការដ្ឋាននៅរាម"]។ ឯកសារ D4.1.746 បទសម្ភាសន៍ជាមួយ សំ សុក ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387463, KH ERN 00742598 ["កងវរៈសេនាធំលេខ ៦១ មានមូលដ្ឋាននៅកំពង់ផែកំពង់សោម កងវរៈសេនាធំលេខ ៦២ មានមូលដ្ឋាននៅរាម ហើយកងវរៈសេនាធំលេខ ៦៣ មានមូលដ្ឋាននៅទឹកសាប"]។ ឯកសារ D114/132 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ រ៉ាន់ ឆ.54។ ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.12។

ផ្សេងទៀត រួមទាំងកោះពូលូវ៉ៃចាស់ កោះពូលូវ៉ៃថ្មី កោះតាង កោះព្រីង (និងនៅលើកោះក្រចកសេះ ដែលមានជម្លោះក្នុងរយៈពេលពីរសប្តាហ៍)[716]។ ក្រោយពីមានការចាត់តាំងឡើងវិញនូវកងវរៈសេនាធំលេខ ២១ ឱ្យទៅជាកងវរៈសេនាធំលេខ ១៦២ នៅខែ កក្កដា-សីហា ឆ្នាំ ១៩៧៥ ហើយនោះ កងវរៈសេនាធំកងទ័ពថ្មើជើងលេខ ១៦២ បានគ្រប់គ្រងកោះតាង កោះពូលូវ៉ៃ (ចាស់ និងថ្មី) កោះ

---

716 ឯកសារ D114/297.1.21 ប្រតិចារឹក ប៉ាក សុខ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 10.02.00-10.05.07 ["អង្គភាពរបស់ខ្ញុំនៅលើកោះហ្នឹង [កោះតាង] គឺវរសេនាតូចរបស់ខ្ញុំហ្នឹង មិនទាន់ផ្លាស់ប្តូរនៃកងលេខ -- លេខកងទេនៅកងវរសេនាតូចលេខ៤១០"]។ ឯកសារ D114/287 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត (ប៉ាង រ៉េត) ឆ.17, 43 ["ពេលដែលគេបញ្ជូនទ័ពដល់កំពង់សោម គេបញ្ជូនទ័ពមួយចំនួនទៅកាន់នៅកោះក្រចកសេះ និងកោះពូលូវ៉ៃ។ អាហ្នឹងមានកងវរសេនាធំ២១ ដែលហៅថា១៦២នោះ គេបញ្ជូនទៅ [...] ស៖ សូមលោកប្រាប់យើងថាតើកងអនុសេនាធំ និងវរសេនាតូចមួយណារបស់កងវរសេនាធំ២១ ឬ១៦២ ដែលគេបញ្ជូនឱ្យបោះទីតាំងនៅកោះក្រចកសេះ? ឆ.43៖ ពេលនោះ មានជម្រើសច្រើន កងចម្រុះ តែជាស្នូលមានកងវរសេនាតូច៤១០ តែដល់ក្រោយមកមិនដឹងដាក់លេខប៉ុន្មាន តែពេលនោះជាកងវរសេនាតូច៤១០ ហើយក៏មានកង៤៥០មួយផ្នែកទៅដែរ។ ៤១០ គេធ្វើជាស្នូលទៅមុនយូរហើយ"]។ ឯកសារ កំណត់ហេតុស្តាប់ចម្លើយ សៅ សំ ឆ៖9, 14 ["ខ្ញុំនៅកងវរៈសេនាតូច៤១០ វរៈសេនាធំ៦២ កងពលលេខ៣ [...] ឆ.14៖ កងរបស់ខ្ញុំ [...] ទើបផ្លាស់ទៅនៅ កោះពូលូវ៉ៃថ្មី និងចាស់"]។ ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.17 ["[មាស មុត] បញ្ជាមានដូចជា តាក់ បើកកាណូត បេអឺ ដោយដឹកយោធាវរសេនាតូច៤១០ ទៅកោះតាង ដើម្បីទៅប្តូរក្រុមរបស់ខ្ញុំ។ បន្ទាប់មកគាត់ត្រូវដឹកទាហានអាមេរិកាំងពីរនាក់ និងកងវរសេនាតូចរបស់ខ្ញុំមកដីគោលវិញ"]។ ឯកសារ D114/132 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ រ៉ាន់ ឆ.32, 38 ["គឺនៅក្នុងអនុសេនាតូចលេខ៣០ ក្នុងអនុសេនាធំលេខ១០ ក្រោមវរសេនាតូចលេខ៤១០ [...] ឆ.38៖ នៅពេលនោះ ថ្នាក់លើដកយក១ក្រុម ដែលមានគ្នា១៥នាក់ ដែលនៅក្នុងនោះមានខ្ញុំផងដែរ ដោយយកទៅឈរជើងនៅលើកោះតាំង"]។ ឯកសារ D4.1.750 បទសម្ភាសន៍ជាមួយ ជនមិនស្គាល់អត្តសញ្ញាណ ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387278, KH ERN 01496677 ["កងវរសេនាតូចដទៃទៀត ចំណុះឱ្យកងវរសេនាធំលេខ ២១ ត្រូវបានបញ្ជូនឱ្យទៅឈរជើងនៅលើកោះតាង កោះព្រីង ព្រមទាំង (ទីតាំង) កោះពូឡូវ៉ៃចាស់ និងកោះពូឡូវ៉ៃថ្មី"]។ ឯកសារ D4.1.762 បទសម្ភាសន៍ជាមួយ កាំ ម៉ែន (កាំ ម៉ែន) ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387330, KH ERN 00742581 ["ការដាក់ពង្រាយកងទ័ពបឋម។ ក្នុងអំឡុងពេលកិច្ចប្រជុំ កងវរៈសេនាតូចលេខ៤១០ ត្រូវបានបញ្ជាឱ្យរៀបចំការពារនៅលើកោះនានាឆ្ងាយពីឆ្នេរសមុទ្រវាម។ កាំ ម៉ែន ត្រូវបានគេចាត់តាំងឱ្យរៀបចំអង្គភាពតូចៗ ដែលមានទាហាន ៥០នាក់ ក្នុងមួយអង្គភាពដើម្បីដាក់ពង្រាយនិងការពារសុវត្ថិភាពកោះនីមួយៗ [...] កាំ ម៉ែន បានដាក់ពង្រាយកងទ័ពនៃអង្គភាពមួយ ដែលមានទាហាន ៥០នាក់ លើកទីមួយ យកពីកងអនុសេនាធំជាច្រើននៅក្នុងកងវរៈសេនាតូចលេខ ៤១០ នៅកោះពូឡូវ៉ៃចាស់ [...] កងទ័ពបញ្ជូនត្រូវបានបញ្ជាដោយ ស៊ឹម មន្ត្រីនយោបាយនៃកងវរៈសេនាតូចលេខ ៤១០។ កងទ័ពផ្សេងទៀតត្រូវបានបញ្ជូនទៅដាក់ពង្រាយតាមកោះព្រីង [...] និងកោះតាង។ កងវរៈសេនាតូចលេខ ៤៨០ បានដាក់ពង្រាយកងទ័ពទៅកាន់កោះពូឡូវ៉ៃថ្មី"]។

ព្រីង កោះវាល និងកោះតូចៗមួយចំនួនទៀតដែលស្ថិតនៅឆ្ងាយខាងភាគនិរតី[717]។ កងវរៈសេនាធំកងទ័ពថ្មើជើងនេះមានទីបញ្ជាការនៅលើកោះតាង[718]។

233. កងវរៈសេនាតូចលេខ ៤៨០ បានក្លាយជាកងវរៈសេនាតូចលេខ ៦២១ បន្ទាប់ពីការចាត់តាំងឡើងវិញនេះ[719]។ ណុប នន គឺជាមេបញ្ជាការកងវរៈសេនាតូចលេខ ៦២១ រហូតដល់ពេលដែលគាត់ត្រូវ

---

717 ឯកសារ D54/78 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល់ ឆ.11 ["ស៖ តើមានកោះប៉ុន្មានដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់កងវរៈសេនាធំ៦២? ឆ.11៖ មាន កោះតាង កោះព្រីង កោះវៀ កោះពូលូវ៉ៃចាស់ កោះពូលូវ៉ៃថ្មី ហើយនិងកោះតូចៗមួយចំនួនទៀត"]។ ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.6 ["វរសេធំលេខ ៦២ គឺជាកងវរសេនាធំជើងទឹកវ៉ៃលើគោករបស់កងពល១៦៤"]។ ឯកសារ D114/57 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ កេត ឆ.9 ["ខ្ញុំបានគូសតំបន់ដែលស្ថិតនៅក្រោមចំណុះកងវរៈសេនាធំ៦២ កោះទាំងនោះរួមមានកោះតាង កោះព្រីង និងកោះពូលូវ៉ៃ"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.35 ["មេវរសេនាធំ៦២ ឈ្មោះ តាមៀញ កាន់នៅកោះពូលូវ៉ៃ កោះព្រីង និងកោះតាង"]។ ឯកសារ D114/283 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ហៅ អ៊ុក ឆ.52 ["នៅកោះតាង គឺវរសេនាធំ៦២"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សាវ៉ាត់ (ប៊ុន សាវ៉ាត់) ឆ.141 ["វរសេនាធំ៦២ បោះនៅកោះតាង និងកោះពូលូវ៉ៃចាស់ និងពូលូវ៉ៃថ្មី"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ កឹម ម៉េន ឆ.59 ["ក្រោយការរៀបចំជាថ្មី វរសេនាតូច៦៦២ ទៅនៅកោះពូឡូវ៉ៃចាស់ ហើយ ៦២៣ ទៅកោះតាំង ហើយ៤៨០ ទៅកោះពូឡាវ៉ៃថ្មី (មានមេបញ្ជាការឈ្មោះ នន)"]។ ឯកសារ D54/78.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968388, KH ERN 00926615 ["ដែលការពារកោះនឹងមាន៩វរៈនឹង កោះដូចខ្ញុំថាអញ្ចឹង ៦២៤ នឹងមានកម្លាំងខ្លះមកធ្វើស្រែ តែការពារកោះប៊ូឡូវ៉ៃចាស់ ប៊ូឡូវ៉ៃថ្មី កោះតាង កោះព្រីង កោះវៀវ ក្រោយមកបង្រួញនៅប៊ុននឹង ពីមុនការពារនៅកោះរ៉ុងទៀត [...] ស៖ ចេះអានេះវរសេនាធំ៦២ហ៎? ឆ៖ បាទ! អាខាងប៉ុន្មានកោះខ្ញុំរាប់មិញនេះ ៦២ បាទ!"]។

718 ឯកសារ D54/78 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល់ ឆ.10 ["ទីបញ្ជាការវរៈសេនាធំ៦២ ឋិតនៅកោះតាង"]។ ឯកសារ D114/57 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ កេត ឆ.6 ["កោះតាងគឺជាបន្ទាយរបស់កងវរៈសេនាធំលេខ៦២"]។ ឯកសារ D54/82 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.35 ["នៅលើកោះពូលូវៃ្ល មានកងវរៈសេនាតូចមួយសហការជាមួយវរៈសេនាធំ១៤០ ដែលអង្គការនេះកប៉ាល់ PCF ចំនួនពីរគ្រឿង។ កងវរៈសេនាតូច រាយការណ៍ទៅកាន់កងវរៈសេនាធំ៦២នៅកោះតាង"]។ ឯកសារ D114/262 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី ឆ.19។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ កឹម ម៉េន ឆ.164។ ឯកសារ D114/57.1 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ កេត ឧបសម្ព័ន្ធ៖ ផែនទីនៃកោះ EN ERN 01077740 [សាក្សីបានគូសដោយផ្ទាល់ដៃរបស់គាត់នៅតំបន់នៃកងវរសេនាធំលេខ៦២ នៅលើកោះតាង]។

719 ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968378, KH ERN 00926606 ["ស៖ ១៥ដដែល ឬក៏ដូរដែរ? ឆ៖ វរសេនាធំគេដាក់៦២ បាទ!ដល់ក្រោយមកគេប្រើអា៤៨០ នឹងម៉ារយៈទេ គេដាក់ថាវាខ្ញុំចេញពីនឹង បាទ!ចេញពី៤៨០ នឹង គេដាក់កងអី!៦២១"]។

បានចាប់ខ្លួននៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៧[720]។ បន្ទាប់ពីគាត់បានបាត់ខ្លួនមក ស្វាយ សាម៉េត ហៅ ម៉េត ដែលជាអនុរបស់គាត់ បានក្លាយជាមេបញ្ជាការគិតចាប់ពីពាក់កណ្ដាលឆ្នាំ រហូតដល់ចុងឆ្នាំ ១៩៧៧[721]។ កងទ័ពរបស់កងវរៈសេនាតូចលេខ ៦២១ ដំបូងឡើយត្រូវបានដាក់ពង្រាយទៅកាន់

---

720 ឯកសារ D114/113 កំណត់ហេតុស្ដាប់ចម្លើយ គឹម ម៉េន ឆ.59 ["ក្រោយការរៀបចំជាថ្មី [...] ៤៨០ ទៅកោះពូឡូវៃថ្មី (មានមេបញ្ជាការឈ្មោះ នន)"]។ ឯកសារ D114/78 កំណត់ហេតុស្ដាប់ចម្លើយ ស្វាយ សាម៉េត ឆ.16-17 ["ជុំ និង ញូន គឺជាបញ្ជាការកងវរៈសេនាតូច។ ខ្ញុំគិត ប៉ុន្តែមិនប្រាកដឡើយថា ញូន អាចមកពីកងវរៈសេនាតូច៤៨០ ហើយ ជុំ អាចមកពីកងវរៈសេនាតូច៣៣០។ នៅពេលដែលខ្ញុំត្រូវបានគេបញ្ជូនឲ្យទៅធ្វើស្រែដំបូង ខ្ញុំធ្វើការក្រោមការគ្រប់គ្រងរបស់ ញូន ហើយ ក្រោយមក ញូន ត្រូវបានគេបញ្ជូនចេញទៅកោះមួយ ហើយ ជុំ ចូលកាន់ជំនួសវិញ។ ក្រោយមកទៀត ជុំ ត្រូវបានគេបញ្ជូនទៅកោះតាង ប៉ុន្តែនៅពេលដែល ខ្ញុំត្រូវបានគេបញ្ជូនទៅកោះតាងដែរ ខ្ញុំមិនបានឃើញ ជុំ ទៀតឡើយ។ ញូន ត្រូវបានគេបញ្ជូនទៅកោះព្រីង។ ញូន ក៏បាត់ខ្លួនរហូតដែរ [...] សៈ តើឆ្នាំណាដែលពួកអ្នកទាំងនេះបាត់ខ្លួន? ឆ.17៖ នៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧"]។ ឯកសារ D54/104 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.6 ["ណុប នន គឺជាស្នងការនៃកងវរៈសេនាតូចមួយ មានទីតាំងនៅកោះពូលូវៃ។ មានកោះពូលូវៃពីរ ហៅពូលូវៃចាស់ និងកោះពូលូវៃថ្មី តែខ្ញុំមិនចាំថា នន បោះទីតាំងនៅកោះពូលូវៃចាស់ ឬកោះពូលូវៃថ្មីទេ។ ខ្ញុំនៅចាំថា ពេលនោះមានមានកងវរៈសេនាតូចពីរ គឺកងវរៈសេនាតូច៦២១ និង៦២២។ កងវរៈសេនាតូចនីមួយៗមានទីតាំងនៅកោះពូលូវៃមួយៗ"]។ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស លេខរៀង ៤១៥៩ [កំណត់អត្តសញ្ញាណ ឈ្មោះ ណុប នន ជាលេខាកងវរសេនាតូច ៦២១ កងពលធំ១៦៤ និងត្រូវបានចាប់ខ្លួននៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៧៧]។ ឯកសារ D114/43.7 បញ្ជីអ្នកទោសនៅមន្ទីរស-២១ (បញ្ជីឈ្មោះអ្នកទោសចូលខែ ឧសភា ឆ្នាំ ១៩៧៧) KH ERN 01065643 [កំណត់អត្តសញ្ញាណ ឈ្មោះ ណុប នន ជាលេខាកងវរសេនាតូច ៦២១ កងពលធំ១៦៤ និងត្រូវបានចាប់ខ្លួននៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៧៧]។ ឯកសារ D1.3.30.5 របាយការណ៍អគ្គសេនាធិការរបស់កម្ពុជាប្រជាធិបតេយ្យ តារាងស្ថិតិសិក្ខាកាម រៀនវគ្គសេនាធិការលើកទី១ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៧៦ EN ERN 00897656, KH ERN 00095537-38 [បញ្ជីឈ្មោះ ណុប នន ជាលេខាកងវរៈសេនាធំ នៅក្នុងកងពលលេខ១៦៤]។ ឯកសារ D1.3.28.33 របាយការណ៍ពី ម៉ម ណៃ ហៅ ចាន់ នៅមន្ទីរស-២១ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៧៧ EN ERN 00795289, KH ERN 00088735 [កំណត់អត្តសញ្ញាណឈ្មោះ ណុប នន ជាលេខាកងវរៈសេនាតូច នៅកងពល ១៦៤ ដែលត្រូវបានបញ្ជូនទៅស-២១ នៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៧៧]។

721 ឯកសារ D114/76 កំណត់ហេតុស្ដាប់ចម្លើយ ស្វាយ សាម៉េត ឆ.21 ["ខ្ញុំធ្វើការងារនៅតំបន់នេះរហូតដល់ឆ្នាំ១៩៧៧ នៅពេលដែលខ្ញុំត្រូវបានគេបញ្ជូនទៅកោះពូលូវៃ។ ខ្ញុំចាំថា នៅពេលនោះគឺនៅចុងឆ្នាំ១៩៧៧។ ខ្ញុំត្រូវបានគេបញ្ជូនទៅកោះពូលូវៃ ដើម្បីជួយគ្រប់គ្រងកងវរៈសេនាតូចលេខ៤៨០"]។ ឯកសារ D220/1.2.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ុំ គីម ហៅ រ៉េត EN ERN 01375018-19, KH 01102507 ["សៈ ពីណាគេអ្នកប្រធានវរសេនាតូច? ឆៈ តាណន [...] អនុ តាម៉េត"]។ ឯកសារ D1.3.30.6 របាយការណ៍អគ្គសេនាធិការរបស់កម្ពុជាប្រជាធិបតេយ្យ តារាងស្ថិតិសិក្ខាកាម វគ្គសេនាធិការ លើកទី២ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ EN ERN 00195332, KH ERN 00008466 [បញ្ជីឈ្មោះ ស្វាយ ម៉េត ជាអនុលេខាកងវរៈសេនាធំនៅក្នុងកងពល ១៦៤]។

រាម និងកោះផ្សេងៗទៀត មុនពេលមកឈរជើងនៅលើកោះពូលូវ៉ៃថ្មី[722] ជាទីដែលកងវរៈសេនាតូចនេះបោះទីបញ្ជាការនៅទីនោះ[723]។ នៅកោះពូលូវ៉ៃថ្មី កងអនុសេនាធំចំនួនបួនកងរបស់កងវរៈសេនាតូចលេខ ៦២១ បានទទួលទូក និងក្រុមការងារលើទូកដែលត្រូវបានចាប់ខ្លួន[724]។

---

722 ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ កឹម ម៉េន ឆ.59 ["ក្រោយការរៀបចំជាថ្មី [...] ៤៨០ ទៅកោះពូឡាវ៉ៃថ្មី (មានមេបញ្ជាការឈ្មោះ នន)"]។ ឯកសារ D114/127 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គីម ហៅ វ៉េត ឆ.13 ["កោះពូលូវៃ្ល គឺស្ថិតក្រោមការគ្រប់គ្រងរបស់វរសេនាធំ៦២ នៃកងពល១៦៤។ នៅក្រោមវរសេនាធំ៦២ មានវរសេនាតូច ៦២១"]។ ឯកសារ D114/126 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គឹម ហៅ វ៉េត ឆ.9 ["ដំបូងឡើង គេបញ្ជូនខ្ញុំទៅធ្វើការនៅលើកោះតាគារ ប្រហែល១ឆ្នាំ មុននឹងគេបញ្ជូនខ្ញុំទៅកោះរុងប្រហែល១អាទិត្យ ហើយបន្ទាប់គេបញ្ជូនខ្ញុំទៅធ្វើការ និងរស់នៅលើកោះតាងប្រហែល១ឆ្នាំ និងចុងក្រោយ [...] គេបញ្ជូនខ្ញុំទៅធ្វើការ និងឈរជើងនៅលើកោះពូលូវៃ្ល"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.6 ["ពេលនោះមានមានកងវរៈសេនាតូចពីរ គឺកងវរៈសេនាតូច ៦២១ និង៦២២។ កងវរៈសេនាតូចនីមួយៗមានទីតាំងនៅកោះពូលូវៃ្លមួយៗ"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ កឹម ម៉េន ឆ.59 ["គឺខាងលើរៀបចំប្រមូលចាត់តាំងជាអង្គភាព ប្រមូលផ្តុំ។ ក្រោយការរៀបចំជាថ្មី វរសេនាតូច៦៦២ ទៅនៅកោះពូឡូវ៉ៃចាស់ ហើយ៦២៣ ទៅកោះតាំង ហើយ៤៨០ ទៅកោះពូឡាវ៉ៃថ្មី (មានមេបញ្ជាការឈ្មោះ នន)"]។ ឯកសារ D114/76 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.21 ["ខ្ញុំធ្វើការងារនៅតំបន់នេះរហូតដល់ឆ្នាំ១៩៧៧ នៅពេលដែលខ្ញុំត្រូវបានគេបញ្ជូនទៅកោះពូលូវ៉ៃ។ ខ្ញុំចាំថា នៅពេលនោះគឺនៅចុងឆ្នាំ១៩៧៧។ ខ្ញុំត្រូវបានគេបញ្ជូនទៅកោះពូលូវ៉ៃ ដើម្បីជួយគ្រប់គ្រងកងវរៈសេនាតូចលេខ៤៨០"]។ ឯកសារ D4.1.762 បទសម្ភាសន៍ជាមួយ កាំ ម៉ែន (Koem Men) ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387330, KH ERN 00742582 ["កងវរៈសេនាតូចលេខ ៤៨០ បានដាក់ពង្រាយកងទ័ពទៅកាន់កោះពូឡូវ៉ៃថ្មី"]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968378, KH ERN 00926607 ["ខ្ញុំឈប់នៅបាន៦២១ហើយ ខ្ញុំទៅនៅកង៦២១ តាមមេខ្ញុំទៅនោះកោះប៉ូឡូវ៉ៃៗចាស់ខ្ញុំនៅនោះ"]។

723 ឯកសារ D114/127 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គីម ហៅ វ៉េត ឆ.13, 51 ["កោះពូលូវៃ្ល គឺស្ថិតក្រោមការគ្រប់គ្រងរបស់វរសេនាធំ៦២ នៃកងពល១៦៤។ នៅក្រោមវរសេនាធំ៦២ មានវរសេនាតូច៦២១ [...] ស៖ តើការប្រជុំនោះ ធ្វើឡើងនៅទីណាដែរ? ឆ.51៖ នៅទីបញ្ជាការវរសេនាតូច ប្រហែល១គីឡូម៉ែត្រពីផែ [កោះពូលូវៃ្ល]"]។

724 សូមមើល VIII.ខ.ឧក្រិដ្ឋដែលប្រព្រឹត្តប្រឆាំងនឹងអ្នកដែលត្រូវបានចាប់ខ្លួនដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ ក្នុងដែនទឹក និងលើកោះដែលប្រកាសដោយកម្ពុជាប្រជាធិបតេយ្យ។ សូមមើលផងដែរ ឯកសារ D114/127 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គីម ហៅ វ៉េត ឆ.7, 13 ["ភាគច្រើនពួកគេស្ទើរតែទាំងអស់ត្រូវបានចង [...] ឆ.៖ ទូកទាំងនោះគឺពួកនាវាប៉េសេអេសជាអ្នកចាប់ [...] ក្រោយពីពួកគេចាប់បានទូក និងមនុស្សនៅលើទូក គេយកទាំងមនុស្ស និងទូកមកកោះ។ ចំពោះមនុស្សនៅលើទូក គឺគេប្រគល់ឲ្យយោធាដែលឈរជើងនៅលើកោះ។ កោះពូលូវៃ្ល គឺស្ថិតក្រោមការគ្រប់គ្រងរបស់វរសេនាធំ៦២ នៃកងពល១៦៤។ ក្រោមវរសេនាតូចនេះមានអនុសេនាធំចំនួនបួនគឺ អនុសេនាធំ១៥, ១៦, ១៧, និង១៨ ដែលអង្គភាពអ្នកទាំងនេះប្រចាំការនៅលើកោះទាំងអស់។ ខ្ញុំស្ថិតនៅក្នុងកងអនុសេនាធំ១៥។

234. យឺន ហៅ យឿន គឺជាមេបញ្ជាការដំបូងគេរបស់កងវរៈសេនាតូចលេខ ៦២២[725] រហូតទាល់តែ សំណាង បានជំនួសគាត់ប្រហែលនៅចុងឆ្នាំ ១៩៧៥[726]។ យោងតាមសាក្សី ណុប ហាល បានឲ្យដឹងថា សឿន គឺជាលេខាកងវរៈសេនាតូចលេខ ៦២២ នៅពេលមួយ[727]។ កងវរៈសេនាតូចលេខ ៦២២ មានកងអនុសេនាធំចំនួនបីកង[728] ដែលបានឈរជើងនៅលើកោះពូលូវៃចាស់[729]។ នីតិវិធីនៃ

---

ជាទូទៅ គេបង្កើតក្រុមមួយ ដោយរើសយោធា២-៣នាក់មកពីអនុសេនាធំនីមួយៗដើម្បីត្រៀមទទួលមនុស្ស និងទូកដែលគេចាប់បាន"]។

725 ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.6 ["វរសេធំលេខ៦២ ក្រោមតា យាង ប្រតិបត្តិការនៅ កោះតាង កោះពូល្វៃចាស់ និងកោះពូល្វៃថ្មី។ [...] ឆ.7៖ ខ្ញុំស្ថិតនៅក្នុងកងពលលេខ១៦៤ តាំងពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ ១៩៧៩ [...] ឆ.21៖ តា យឺន ហៅ យឿន ដែលជាមេបញ្ជាការកងវរសេនាតូចរបស់ខ្ញុំ គឺវរសេនាតូចលេខ៦២២"]។

726 ឯកសារ D1.3.30.6 របាយការណ៍អគ្គសេនាធិការរបស់កម្ពុជាប្រជាធិបតេយ្យ តារាងស្ថិតិសិក្ខាកាម វគ្គសេនាធិការលើកទី២ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ EN ERN 00195332, KH ERN 00008466 [បញ្ជីឈ្មោះ ឌិក ឆាយ "សំណាង" ជា លេខាកងវរៈសេនាធំនៅកងពល១៦៤]។ ឯកសារ D114/297.1.21 ប្រតិចារឹក ប៉ាក សុខ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 11.16.01-11.21.35 ["ឈ្មោះ តាសំណាង ជាមេបញ្ជាការរបស់ខ្ញុំ ដែលនៅក្នុងវរសេនាតូច ៦២២ នោះ [...] នៅក្នុងឆ្នាំ៧៥ដែរ ខ្ញុំបានទៅនៅលើកោះនោះ [ពូលូវៃ] រយៈរហូតដល់ឆ្នាំ៧៧។ បាទ ៧៧ បានអង្គការដកឲ្យខ្ញុំមកនៅខាងកងនាវាជើងទឹកវិញ"]។

727 ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968385-86, KH ERN 00926613 ["ស៖ ពីណាគេនឹងប្រធាន [...] ៦២២? ឆ៖ ឈ្មោះសឿន។ [...] ស្តាប់អំឡុងខែ១៣ និង ៤នឹង ខែប៉ុន្មាន៧៩នឹង"]។

728 ឯកសារ D54/101 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.9 ["នៅក្នុងកងវរៈសេនាតូច៦២២ នេះ មានបីកងអនុសេនាធំ គឺ៤១, ៤២, ៤៣។ កងវរៈសេនាតូច៦២២ គឺស្ថិតនៅក្នុងកងវរៈសេនាធំ៦២ នៃកងពលលេខ១៦៤"]។ ឯកសារ D4.1.746 បទសម្ភាសន៍ជាមួយ សំ សុក ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387462, KH ERN 00742597 ["កងវរៈសេនាតូចលេខ ២២ ត្រូវបានចែកចេញជាកងអនុសេនាធំលេខ ៤១ លេខ ៤២ និងលេខ ៤៣"]។ EN ERN 00387464, KH ERN 00742598 ["កងអនុសេនាតូចទាំងបីនៃកងអនុសេនាធំលេខ ៤១ ត្រូវបានពង្រាយទៅកាន់ឆ្នេរភាគបូព៌ានៅចុងកោះភាគឧត្តរ [...] កងនីមួយៗមានគ្នាប្រហែលពី ១២ ទៅ ១៦នាក់ [...] កងអនុសេនាធំលេខ ៤២ មានមូលដ្ឋាននៅលើកោះនៅភាគទក្សិណនៃឆ្នេរភាគបូព៌ា ហើយកងអនុសេនាធំលេខ ៤៣ មានមូលដ្ឋាននៅទីតាំងបច្ចុប្បន្នរបស់ទីបញ្ជាការដ្ឋានកងវរៈសេនាតូចជើងទឹក"]។

729 ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968385-86, KH ERN 00926613 ["ស៖ ៦២២? [...] ស៖ អឺ! នឹងកោះ២២ នៅកោះវៃចាស់? ឆ៖ បាទ!"]។ ឯកសារ D220/1.2.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ូ គីម ហៅ រ៉េត EN ERN 01375021 [កងវរសេនាតូចលេខ៦២២ ប្រហែលជានៅលើកោះពូលូវៃចាស់]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ហៅ អ៊ីក ឆ.6 ["ខ្ញុំនៅចាំថាពេលនោះមានមានកងវរៈសេនាតូចពីរ គឺកងវរៈសេនាតូច៦២១ និង៦២២។ កងវរៈសេនា

ការរឹបអូសទូកនៅលើកោះពូលូវៃចាស់ តម្រូវឲ្យកងវរៈសេនាតូចរាយការណ៍ទៅកាន់កងវរៈសេនាធំលេខ ៦២ នៅឯកោះតាង ហើយក្រោយមកកងវរៈសេនាធំរាយការណ៍ទៅកាន់កងពលធំ តាមរយៈកំពង់ផែរបស់ពួកគេ[730]។

235. ទន, គឹម ម៉ែន និង សំណាង ហៅ កូវ គឺជាមេដឹកនាំចម្បងៗរបស់កងវរៈសេនាតូចលេខ ៦២៣ (ដែលរួមបញ្ចូលទាំងអតីតកងវរៈសេនាតូចលេខ ៤២០ ផងដែរ)[731]។ បើទោះជា គឹម ម៉ែន បានថ្លែងថា សំណាង គឺជាមេបញ្ជាការ ហើយ ទន និងខ្លួនគាត់គឺជាមេបញ្ជាការរងរបស់គាត់ក៏ដោយ ក៏សាក្សីពីរនាក់ផ្សេងទៀតបានប្រកាសថា ទន គឺជាមេបញ្ជាការកងវរៈសេនាធំនេះ ហើយ គឹម ម៉ែន គឺជាអនុ[732]។ កងវរៈសេនាតូចលេខ ៦២៣ បានឈរជើងជាចម្បងនៅលើកោះព្រីង កោះវាល

---

តូចនីមួយៗមានទីតាំងនៅកោះពូលូឡៃមួយៗ។ ខ្ញុំមិនដឹងថា នន ស្លាប់ឬរស់ទេ"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉ែន ឆ.59 ["ក្រោយការរៀបចំជាថ្មី វរសេនាតូច៦៦២ ទៅនៅកោះពូឡូវៃចាស់"]។ ឯកសារ D54/27 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.6 ["ក្នុងឆ្នាំ១៩៧៦ កងវរសេនាតូចលេខ៦២២ របស់ខ្ញុំគឺមានទីតាំងនៅលើកោះពូឡៃ"]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968385-86, KH ERN 00926613 ["សៈ ៦២២? [...] សៈ អឺ!នឹងកោះ២២ នៅកោះវៃចាស់? ឆៈ បាទ!"]។ ឯកសារ D220/1.2.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ូ គីម ហៅ រ៉េត EN ERN 01375021 [កងវរសេនាតូចលេខ៦២២ ប្រហែលជានៅលើកោះពូលូឡៃចាស់]។

730 ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968399, KH ERN 00926626 ["អញ្ចឹងយើងកោះតាងវរសេនាតូច គឺរាយការណ៍ទៅវរសេនាតូចគឺរាយការណ៍ទៅវរសេនាធំ [៦២] ដល់វរសេនាធំគេរាយទៅលើតាមផែរបស់គេទៀតទៅ"]។

731 ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.36 ["វៀតណាមក៏វាយយើងកាន់កាប់កោះ ពូលូវៃ។ ក្រោយមកទៀត វៀតណាមក៏បានវាយយើង កាន់កាប់កោះ ពូលូវៃ និងកោះ ក្រចកសេះ ឡើងវិញ។ កងដែលទៅវាយនៅទីនោះ គឺមានវរៈសេនាតូច៤១០ និង៤២០ របស់កងពលលេខ៣។ វរៈសេនាតូចទាំងពីរនេះ មានមេបញ្ជាការឈ្មោះ ទន និង វឿន។ ទន ជាមេបញ្ជាការវរៈ៤២០ ហើយ វឿន ជាមេបញ្ជាការកងវរៈសេនា៤១០"]។ ឯកសារ D114/76 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.15 ["កាលពីពេលនោះ [នៅឆ្នាំ១៩៧៦] ទន និង មឿន គឺជាបញ្ជាការកងវរៈសេនាតូចលេខ៤២០។ ទន បន្តកាន់កងវរៈសេនាតូចនេះ ប៉ុន្តែមឿន ត្រូវបានគេដកចេញនៅពេលក្រោយទៀត"]។

732 ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉ែន ឆ.34, 44, 69-70 ["នៅក្នុងវរសេនាតូច២២៣ មានសំណាង (ហៅ កូវ) ជាមេបញ្ជាការ ទន ជាអនុ និង ម៉ែន (ខ្ញុំ) ក៏ជាអនុដែរ ប៉ុន្តែពេលនោះ គេហៅថាសមាជិក។ [...] សៈ តើលោកអាចបញ្ជាក់បានទេថា លេខវរសេនាតូចនោះ គឺ៦២៣ ឬ២២៥? ឆ.44ៈ ត្រឹមត្រូវហើយ វរសេនាតូចរបស់ខ្ញុំ គឺលេខ៦២៣។ បាទខ្ញុំសុំទោស [...] ឆ.69ៈ [...] ពីសង្គ្រាម គឺ មឿន កាលនោះនៅជាវរសេនាតូចនៅឡើយ។ ក្រោយពេលប្ដូរទៅជា៦២៣ គឺមានសំណាង, ទន ហើយនិងខ្ញុំ។ សៈ រវាង សំណាង, ទន និងលោក តើនរណា

និងកោះតាង[733]។ សាក្សី ណុប ហាល បានអះអាងថា កងវរៈសេនាធំលេខ ៦២ ក៏បានក្តោបក្តាប់ កងវរៈសេនាតូចមួយផ្សេងទៀតនៅលើកោះតាងផងដែរ នោះគឺកងវរៈសេនាតូចលេខ ៦២៤ ដែល ដឹកនាំដោយ ញ៉ន ហើយក្រោយមកដោយ ជុំ[734]។

---

មួយជាមេរបស់៦២៣? ឆ.70៖ គឺសំណាង ហៅ កូវ ជាមេបញ្ជាការ។ បើនិយាយពីឋានៈ គឺខ្ញុំនៅក្រោមគេបង្អស់"]។ ឯកសារ D114/283 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.46 ["វរសេនាតូច បងទន, អត់បានគ្រប់ទេ ពេលរៀបនោះ វាបានពីរ១នាក់ទេ។ អនុគឺ បងម៉េន។ វរសេនាធំអ៊ំមៀញ ហើយអនុ បងសុន"]។ ឯកសារ D114/89 កំណត់ហេតុ ស្តាប់ចម្លើយ សេង ស៊ីន ឆ.15 ["ចំណែកឯកងវរសេនាតូចលេខ ៦២៣ ដែលមាន ទន ជាប្រធាន ហើយ មេន ជាអនុ កងវរសេនាតូច"]។

733 ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ.21, 59, 63 ["ជាបញ្ជាការរងវរសេនាតូច ប្រចាំនៅកោះ តាំង កោះព្រីង កោះវែរ៍។ កោះវែរ៍នេះ ជាកោះតូចទេ យើងដាក់ទ័ពតែមួយក្រុមទេ គឺមាន១២នាក់។ កោះព្រីង មានអនុ សេនាធំដែលមានមនុស្សប្រហែល១២០នាក់។ កោះព្រីង ជាកោះភ្លោះនៅជាប់គ្នាខណ្ឌដោយសមុទ្រ។ ម្ខាងតូច ម្ខាងធំ នៅផ្នែកខាងធំ យើងដាក់ពីរអនុសេនាតូច ហើយនៅខាងតូច យើងដាក់មួយអនុសេនាតូច។ [...] ឆ.59៖ ៦២៣ ទៅ កោះតាំង [...] ឆ.63៖ [នៅឆ្នាំ ១៩៧៥ [...] ពួកខ្ញុំចល័តទៅកោះតាំង កោះព្រីង កោះវែរ៍"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.20 ["ក្រោយថ្ងៃទី១៧ មេសា ហើយហ្នឹង ទើបគេបញ្ជូនទៅ [កោះតាង]"]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968385, KH ERN 00926612 ["នៅកោះព្រីងនឹង កោះវានឹងកម្លាំងអានឹងម៉ាវរៈ។ ស៖ ៦២៣? ឆ៖ បាទ! ៦២៣"]។

734 ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN ERN 00968379, KH ERN 00926607 ["ឆ៖ មានទៅខ្ញុំទៅនៅកោះតាងនឹង នៅដំបូងគេរៀបកងថ្មីមួយគេហៅកង៦២៤។ ស៖ ៦២៤? ឆ៖ បាទ! មានលោកជុំនោះគាត់ស្លាប់ហើយ សព្វថ្ងៃគាត់ស្នងការ គាត់ស្នងការ តាញ៉ុនខ្ញុំនិយាយមិញនឹងគាត់ បញ្ជាការ"]។ EN ERN 00968386, KH ERN 00926614 ["ស៖ កោះ៦២១ ៦២២ ៦២៣ តែ៣ទេ ក្នុងវរសេនាធំ? ឆ៖ ៦២៤មួយទៀត។ [...] វាចេះ [...] ៦២៤ [...] នឹងកម្លាំងចែកជា២ មួយចំណែកនៅកោះតាងដែរ មួយចំនែកមក ធ្វើស្រែនៅម៉ុំយើងកងកេងនេះ"]។ EN ERN 00968387, KH ERN 00926614 [គាត់ [ជុំ] កាន់នៅក្នុងដើម៧៨។ ស៖ ដល់ពេលចុង៧៨? ឆ៖ ដល់អាគាត់កាន់ម៉ារយៈគាត់ឡើងអនុវរសេនាធំ ដល់អាគាត់ឡើងអនុវរសេនាធំឡើងបាន ម៉ារយៈគេដកទៅវៃបូព៌ា"]។

### *គ) កងវរៈសេនាធំលេខ ១៦៣ (អតីតកងវរៈសេនាធំលេខ ២២)*[735]

236. ភ្លាមៗក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ យ៉ាន គឺជាមេបញ្ជាការ ស្រស់ គឺជាញ្ជាការរង ហើយ ញ៉ាន់ ជាសមាជិកនៃកងវរៈសេនាធំលេខ ២២/៦៣[736]។ យ៉ាន ដែលជាសមាជិកគណៈកម្មាធិការកងពលធំលេខ ១៦៤ ផងដែរ ចាប់តាំងពីការបង្កើតកងពលធំនេះមក ត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅកាន់មន្ទីរ ស-២១ នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៧ (*សូមមើលខាងលើអំពីគ*

---

735 ផងដែរសាក្សីបានហៅថាជា "កងវរៈសេនាធំ"៖ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត់ (ប៊ុន សារ៉ាត់) ឆ.20 ["១៦ យ៉ាន នៅព្រលានយន្តហោះកងកេង"]។ អំពីការផ្លាស់ប្តូរឈ្មោះនៅក្នុងខែ កក្កដា - សីហា ឆ្នាំ ១៩៧៥ សូមមើលឧទាហរណ៍ ឯកសារ D2/8 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.39 ["ស៖ តើកងវរៈសេនាធំលេខ១៦៣ មានឈ្មោះដើមជាកងវរៈសេនាធំលេខប៉ុន្មាន? ឆ.39៖ កងវរៈសេនាធំលេខ២២"]។

736 ឯកសារ D2/8 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.40 ["ឈ្មោះ យាន គឺជាស្នងការ, ឈ្មោះ ស្រស់ គឺជាអនុ, ឈ្មោះ ញ៉ាន់ គឺជាសមាជិក"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.5 ["តាស្រស់ គឺជាស្នងការរបស់វរៈសេនាធំនោះ ហើយ យ៉ាន គឺជាបញ្ជាការ។ ឈ្មោះ យ៉ាន នេះគឺស្ថិតនៅក្នុងចំណោមពួកក្បត់ដែលតា មុត បានលើកមករៀបជាពាក្យជូនដូចកំណាព្យថា "ញ៉ឹក, ឆាន, យ៉ាន, ឌឹម ជាពួកក្បត់"]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.6 ["តា យ៉ាន ស្នងការវរៈសេនាធំ ២២"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត់ (ប៊ុន សារ៉ាត់) ឆ.3, 20 ["វរសេនាធំឈ្មោះ យ៉ាន (ស្លាប់) មេបញ្ជាការរបស់គាត់ឈ្មោះ ស្រស់ [...] ឆ.20៖ បញ្ជាក់បោះទីតាំង ១៦ យ៉ាន នៅព្រលានយន្តហោះកងកេង"]។ ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង ឆុន ឆ.9 ["វរៈសេនាតូច ៥៣០, ៥៤០ និង៥៥០ ឋិតនៅក្នុងវរៈសេនាធំក្រោមបញ្ជាការរបស់តា យ៉ាន"]។ ឯកសារ D114/116 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.30 ["ស៖ តើ មុំ យ៉ាន ស្ថិតនៅអង្គភាពណា ហើយគាត់មានមុខងារអ្វីដែរ? ឆ.30៖ គាត់គឺជាបញ្ជាការកងវរសេនាធំ៦៣ នៃកងពល១៦៤ តាំងពីដើមដំបូងមកម្លេះ។ នោះគឺជាពេលដែលកងវរសេនាធំស្ថិតនៅកងកេង"]។ ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.30 ["ស៖ តើលោកស្គាល់មនុស្សម្នាក់ឈ្មោះ មុំ យ៉ាន ដែរឬទេ? ឆ.30៖ បាទ ខ្ញុំស្គាល់ គាត់គឺជា មេបញ្ជាការកងវរៈសេនាធំលេខ៦៣។ មូលដ្ឋានរបស់គាត់នៅក្នុងព្រលានយន្តហោះកងកេង ជិតផ្លូវបំបែករវាងផ្លូវចូលទៅព្រលានយន្តហោះ និងផ្លូវជាតិត្រង់ស្នាច់ដែង។ [...] ជន ចូលមកកាន់ជំនួស"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ. 35 ["មេវរសេនាធំ៦២ ឈ្មោះ តាមៀញ កាន់នៅកោះពូលូវៃ កោះព្រីង និងកោះតាង"]។ ឯកសារ D54/81 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.14 ["យ៉ាន [...] ជាអតីតមេបញ្ជាការវរៈសេនាធំ៦៣"]។ ឯកសារ D54/46 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.37 ["ស្រស់ ជាមេបញ្ជាការកងវរសេនាធំលេខ២២"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង រ៉េត EN ERN 00974078-79, KH ERN 00926525 ["ស៖អ៊ីចឹងកងវរៈសេនាធំ១៦? ឆ៖ ឈ្មោះយ៉ាន"]។ ឯកសារ D54/112.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ផ្លុង ឈា EN ERN 00968345, KH ERN 00926490 ["ស៖ ចាំ អ៊ីប្រធានទេ? [...] ឆ៖ លោក យ៉ាន"]។ ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា ឆ.5។

*ណៈកម្មាធិការកងពលធំលេខ ១៦៤)*[737]។ ស្រស់ ត្រូវបានចាប់ខ្លួនប្រហាក់ប្រហែលគ្នានេះដែរ[738]។ ស៊ិន ជន បានជំនួសតំណែង យ៉ាន ជាមេបញ្ជាការកងវរៈសេនាធំលេខ ១៦៣ មុនពេលដែលមានការចាប់ខ្លួន យ៉ាន ដែលទំនងជាកើតមាននៅចុងឆ្នាំ ១៩៧៦[739]។ បើទោះជាបានសម្លាប់ប្រជា

---

737 ឯកសារ D114/230.1.1 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស [កំណត់អត្តសញ្ញាណ ឈ្មោះ មុំ ជឹម ហៅ មុំ យ៉ាន លេខរៀង ៤៧៩៧ ដែលត្រូវបានបញ្ជូនខ្លួននៅថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៧ និងបានសម្លាប់នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៨]។ ឯកសារ D9.3 បញ្ជីអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស ពីកងពលធំលេខ១៦៤ លេខរៀង ២៤ (និងលេខរៀង២៤ - ស្ទួន)។ ឯកសារ D1.3.28.2 បញ្ជីអ្នកទោសនៅមន្ទីរស-២១ ចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ១៩៧៧ EN ERN 01321750, KH ERN 00086996 [កំណត់អត្តសញ្ញាណ ឈ្មោះ មុំ យាន ដែលត្រូវបានបញ្ជូនទៅស-២១នៅខែឧសភា ឆ្នាំ១៩៧៧]។ ឯកសារ D1.3.28.45 បញ្ជីអ្នកទោសនៅមន្ទីរស-២១ (ឯកសារបញ្ជីអ្នកទោសនៅមន្ទីរស-២១ - អង្គភាព១៦៤) ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៧៧ [រួមមានឈ្មោះ ម៉ម ជឹម ហៅ យាន ជាសមាជិកកងពលធំ ដែលបានសារភាពថាជាខ្មែរអាត់]។ ឯកសារ D114/116 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.27 ["មុំ យ៉ាន គឺជាមនុស្សម្នាក់ដែលស្ថិតនៅក្នុងកងពល១៦៤ នៅក្នុងឆ្នាំ១៩៧៥"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.5។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.1។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.4-5។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.6។ ឯកសារ D114/155 កំណត់ហេតុស្តាប់ចម្លើយ សុខ រ៉េន ឆ.67។ ឯកសារ D54/81 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.14។ ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន ឆ.26 ["យ៉ានហ្នឹងគឺគាត់នៅកាន់គណៈកងពលធំលេខ៣"]។ ឯកសារ D114/116 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.27-28, 30។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.35។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ.64, 67, 226។ ឯកសារ D114/139 កំណត់ហេតុស្តាប់ចម្លើយ ងួន ឡាយ ហៅ អ៊ី ឆ.23។

738 ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.58 ["តែខ្ញុំឮថា ង៉ែត និង ស្រស់ ត្រូវបានចាប់ខ្លួន តែខ្ញុំមិនដឹងថាគេបញ្ជូនពយកគេទៅណាទេ"]។

739 ឯកសារ D1.3.30.5 របាយការណ៍អគ្គសេនាធិការរបស់កម្ពុជាប្រជាធិបតេយ្យ តារាងស្ថិតិសិក្ខាកាម រៀនវគ្គសេនាធិការលើកទី១ ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៧៦ EN ERN 00897655, KH ERN 00095536-37 [បញ្ជីឈ្មោះសមមិត្ត ស៊ិន ជន ជាលេខាកងវរៈសេនាធំ នៅក្នុងកងពលលេខ១៦៤]។ ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.20, 30 ["មេបញ្ជាការកងវរៈសេនាធំលេខ៦៣នេះ ឈ្មោះ ជន ហើយនិង ញ៉ាន់ដែលជាអនុ របស់ ជន [...] ឆ.30៖ គាត់ [យ៉ាន] គឺជាមេបញ្ជាការកងវរៈសេនាធំលេខ៦៣ មុនពេលដែល ជន ចូលមកកាន់ជំនួស។ ខ្ញុំមិនដឹងពីអ្វីដែលបានកើតឡើងចំពោះគាត់ឡើយ"]។ ឯកសារ D114/18 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.6 ["មេបញ្ជាការកងវរៈសេនាធំនោះឈ្មោះ យ៉ាន។ ក្រោយមក ពេលដែលយើងនៅកំពង់សោមក្នុងឆ្នាំ១៩៧៦ តាយ៉ានត្រូវបានផ្លាស់ចេញទៅកន្លែងផ្សេង ហើយតាជន បានក្លាយជាមេបញ្ជាការកងវរៈសេនាធំរបស់ខ្ញុំ នៅពេលនោះកងវរៈសេនាធំរបស់ខ្ញុំគឺលេខ ៦៣។ ដល់ឆ្នាំ១៩៧៧ តាជន បានបាត់ខ្លួនទៅ"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.12, 19 ["មាន តាញ៉ាន់ និង តាជន ដែលបញ្ជាការកងវរៈសេនាធំ៦៣ [...] ឆ.19៖ ពេលខ្ញុំមក

ជនដោយមិនបានទទួលការអនុញ្ញាតពី **មាស មុត**[740] ក្តី ក៏ គីម ញ៉ាន់ ដំបូងឡើយត្រូវបានដំឡើងតំណែងជាមេបញ្ជាការរងកងវរៈសេនាធំលេខ ១៦៣ ដែលស្ថិតនៅក្រោមអំណាចរបស់ ជន[741] ហើយក្រោយមកត្រូវបានដំឡើងជាមេបញ្ជាការ[742]បន្ទាប់ពី ជន ខ្លួនគាត់ផ្ទាល់ត្រូវបានចាប់ខ្លួននៅ

---

ដល់ទីកសាបដំបូង ក្នុងឆ្នាំ១៩៧៧ តាជន ជាអ្នកទទួលខុសត្រូវនៅទីនោះ។ តាជន គឺជាមេបញ្ជាការវរៈសេនាធំ៦៣។ ហើយ តាញ៉ាន់គឺជាអនុរបស់គាត់"]។ ឯកសារ D114/115 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.14 ["បញ្ជាការកងវរៈសេនាធំ៦៣ឈ្មោះ ជន ផ្ទះរបស់គាត់គឺនៅជិតទឹកសាប។"] ឯកសារ D114/114 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.19 ["សៈ តើអ្នកណាជាមេបញ្ជាការកងពលធំ១៦៤ និងកងវរសេនាធំ៦៣? ឆ.19៖ [...] បញ្ជាការកងវរសេនាធំឈ្មោះ ជន"]។

740 ក្នុងខែ កក្កដា ឆ្នាំ ១៩៧៥ មាស មុត គ្រាន់តែស្តីបន្ទោស គីម ញាញ់ ចំពោះការសម្លាប់មនុស្ស ប៉ុន្តែ មាស មុត មិនបានដាក់ទណ្ឌកម្មនោះទេ ជាងនេះទៅទៀត គីម ញាញ់ ត្រូវបានតែងតាំងជាមេបញ្ជាការកងវរសេនាធំ និងត្រូវបានជឿទុកចិត្តដោយ មាស មុត ឱ្យដោយទៅជំនួសតំណែងមេបញ្ជាកងពលធំលេខ ១៧៧ ក្នុងខេត្តក្រចេះ នៅចុងឆ្នាំ ១៩៧៨ ៖ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត (Hieng Reth) ឆ.28, 120-122, 124 ["ខ្ញុំចាំថាតាញ៉ាន់ជាមេបញ្ជាការកងវរសេនាធំ៦៣ [...] សៈ យោងទៅលើកិច្ចសម្ភាសរបស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាជាភាសាអង់គ្លេស ទំព័រ៧១ លោកនិយាយថា "បន្ទាប់ពីស្តាប់របាយការណ៍ហើយ បងមាស មុត បានសួរតាញ៉ាន់អំពីការសម្លាប់មនុស្ស គាត់សួរថា៖ "តើនរណាគេឱ្យឯងសម្លាប់ប្រជាជនទាំងនោះ តើនរណាគេអនុញ្ញាតឱ្យឯងស៊ើបសួរប្រជាជនតាមផ្ទះរបស់គេ? ឯងសមនឹងប្រជាជនធ្វើអ៊ីចឹងដាក់ហើយ តាមពិតទៅប្រជាជនគួរតែចាក់ទឹកក្តៅលើក្បាលឯង។ ឯងគ្មានសិទ្ធិតាមដានពួកគេទេ។ មុននឹងឯងសម្លាប់មនុស្សតើឯងមានការអនុញ្ញាតពីមេរបស់ឯងដែរឬទេ?" តើលោកបានឮមាស មុត ស្តីឱ្យតាញ៉ាន់ផ្ទាល់ដែរឬទេ? ឆ.120៖ បាទ ខ្ញុំបានឮដោយផ្ទាល់ ពីព្រោះពេលនោះគឺមានសន្និបាតដែលមេៗនៅក្នុងកងពល១៦៤បានចូលរួមប្រជុំ [...] ឆ.121៖ តាញ៉ាន់ គឺជាមេបញ្ជាការវរៈសេនាធំ៦៣ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពល១៦៤ ដែលមាន មាស មុត ជាមេបញ្ជាការ។ ដូច្នេះក្នុងន័យនេះ មានន័យថាគាត់ត្រូវមានការអនុញ្ញាតពីមាស មុត ជាមុនសិន [...] ឆ.122៖ ខ្ញុំមិនដឹងថាប្រជាជនទាំងនោះត្រូវបានតាញ៉ាន់សម្លាប់ក្នុងកាលៈទេសៈណានោះទេ។ ប៉ុន្តែខ្ញុំចាំបានថានៅក្នុងអង្គប្រជុំនោះ តាញ៉ាន់បានរាយការណ៍ប្រាប់ មាស មុត ថាគាត់បានសម្លាប់មនុស្ស [...] ឆ.124៖ [...] កិច្ចប្រជុំធ្វើឡើងក្នុងឆ្នាំ១៩៧៥"]។

741 ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.19 ["ពេលខ្ញុំមកដល់ទឹកសាបដំបូង ក្នុងឆ្នាំ១៩៧៧ តាជន ជាអ្នកទទួលខុសត្រូវនៅទីនោះ។ តាជន គឺជាមេបញ្ជាការវរៈសេនាធំ៦៣។ ហើយ តាញ៉ាន់គឺជាអនុរបស់គាត់"]។ ឯកសារ D114/18 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.11 ["នៅក្នុងឆ្នាំ១៩៧៦ គឺ តាជន បានឡើងមកជំនួសតាយ៉ាន ដែលជាមេបញ្ជាការកងវរៈសេនាធំ៦៣ ហើយ តាញ៉ាន់ គឺជាអនុរបស់តាជន"]។ ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.20 ["មេបញ្ជាការកងវរៈសេនាធំលេខ៦៣នេះ ឈ្មោះ ជន ហើយនិង ញ៉ាន់ដែលជាអនុ របស់ ជន"]។

742 ឯកសារ D114/18 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.11-12 ["ក្នុងឆ្នាំ១៩៧៧ ពេលដែលតាជន បាត់ខ្លួនទៅ តាញ៉ាន់ ដែលជាអនុរបស់គាត់បានឡើងកាន់បញ្ជាការកងវរៈសេនាធំជំនួស [...] ឆ.12៖ នៅពេលនោះ មានតែតាញ៉ាន់

ឆ្នាំ ១៩៧៧[743]។ ញ៉ាន់ បានកាន់កាប់តំណែងនេះរហូតដល់ **មាស មុត** បានបញ្ជាឱ្យគាត់ធ្វើដំណើរទៅកាន់ខេត្តក្រចេះ ដើម្បីជំនួសតំណែងជាមេបញ្ជាការកងពលធំលេខ ១១៧ ដែលមេបញ្ជាការកងពលធំនេះត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅកាន់មន្ទីរ ស-២១[744]។

---

ម្នាក់ទេ មិនមានចាត់តាំងអនុរបស់តាញ៉ាន់ នៅឡើយទេ ហើយក៏ពុំមានការប្រកាសជាផ្លូវការថាតាញ៉ាន់ ជាអ្នកជំនួសផងដែរ ប៉ុន្តែការងារប្រចាំថ្ងៃរបស់កងវរៈសេនាធំ គឺ តាញ៉ាន់ ជាអ្នកទទួលខុសត្រូវ ពីព្រោះតាញ៉ាន់ ជាអ្នកទំនាក់ទំនងទៅជាមួយកងពល"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.12, 19 ["មាន តាញ៉ាន់ និង តាជន ដែលបញ្ជាការកងវរៈសេនាធំ៦៣ ប៉ុន្តែក្រោយមក ខ្ញុំឮថា តាជន ត្រូវបានចាប់ខ្លួនបាត់ [...] ឆ.19៖ [...] ក្រោយមក ជន ត្រូវបានចាប់ខ្លួន ហើយ ញ៉ាន់ ឡើងជំនួស"]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ. 26 ["តាញ៉ាន់ គឺជាមេវរៈសេនាធំ៦៣"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.2 ["វរៈសេនាធំលេខ៦២ មេបញ្ជាការឈ្មោះ តា យាង"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត (Hieng Reth) ឆ. 28, 121 ["ខ្ញុំចាំថាតាញ៉ាន់ ជាមេបញ្ជាការកងវរសេនាធំ៦៣ [...] ឆ.121៖ តាញ៉ាន់ គឺជាមេបញ្ជាការវរៈសេនាធំ៦៣ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពល១៦៤ ដែលមាន មាស មុត ជាមេបញ្ជាការ"]។ ឯកសារ D114/17.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ា ឈឿន EN ERN 01313341, KH ERN 01033986 ["ស៖ ពីណាគេទទួលខាងវរៈសេនាធំ៦៣? ឆ៖ តាញ៉ាន់"]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន (ណាំ ឡុន) ឆ.37, 111 ["ស៖ តើអ្នកណាជាអ្នកគ្រប់គ្រងកងទ័ពជើងគោក? ឆ.37៖ ញ៉ាន់ គាត់ស្លាប់បាត់ហើយ។ [...] ឆ.111៖ ឈ្មោះ ឡុន (ស្លាប់) និងឈ្មោះ ញ៉ាន់ (កាន់ភស្តុភារកងពលលេខ៣)"]។ ឯកសារ D114/139 កំណត់ហេតុស្តាប់ចម្លើយ ងួន ឡាយ ហៅ អ៊ី ឆ.14, 17-20 ["ខ្ញុំក៏ធ្វើជាអង្គរក្សផ្ទាល់របស់ ញ៉ាន់ [...] ឆ.17៖ [...] តាញ៉ាន់ហ្នឹងគេឱ្យគាត់ទៅនៅកំពង់សោមវិញ [...] ឆ.18៖ [...] ខ្ញុំទៅតាមគាត់ ជាអង្គរក្ស [...] ឆ.19៖ [...] គេច្រូតហើយ ទៅចុង៧៥ ជិតចូលឆ្នាំ ៧៦ [...] ឆ.20៖ [...] ខ្ញុំទៅនៅកងពល ១៦៤ វរៈសេនាធំលេខ ៦៣"]។ ឯកសារ D114/202 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ សារ៉ាន់ ឆ.14, 38 ["ស៖ តើមេបញ្ជាការកងវរសេនាធំ ៦៣ នៅពេលនោះឈ្មោះអ្វីដែរ? ឆ.14៖ គេហៅថា អ៊ំញ៉ាន់ [...] ឆ.38៖ ឈ្មោះ សមមិត្ត វេត ដដែល ហើយ ញ៉ាន់ នៅវរសេនាធំនៅតែលើគោកទេ"]។ ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា ឆ.1, 7, 37 ["[តាញ៉ាន់] គាត់ឡើងពីប្រធានកងអនុសេនាធំ ទៅប្រធានកងវរៈសេនាតូច ទៅប្រធានកងវរៈសេនាធំ រហូតឡើងដល់ធ្វើជាអនុរបស់តាមុត [...] ឆ.37៖ ខ្ញុំធ្លាប់ចូលរួមប្រជុំជាច្រើនដងនៅថ្នាក់វរៈសេនាធំ ដែលដឹកនាំដោយតាញ៉ាន់។ គឺមានតែអ្នកដែលមានប្រវត្តិរូបល្អ ដេលគេហៅឱ្យទៅចូលរួមប្រជុំបន្តទៀត"]។

743 ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.19 ["ក្រោយមក ជន ត្រូវបានចាប់ខ្លួន ហើយ ញ៉ាន់ ឡើងជំនួស"]។ ឯកសារ D114/18 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.6 ["ខ្ញុំមិនចាំលេខកងវរៈសេនាធំទេ តែមេបញ្ជាការកងវរៈសេនាធំនោះឈ្មោះ យ៉ាន ។ ក្រោយមក ពេលដែលយើងនៅកំពង់សោមក្នុងឆ្នាំ១៩៧៦ តាយ៉ាន ត្រូវបានផ្លាស់ចេញទៅកន្លែងផ្សេង ហើយតាជន បានក្លាយជាមេបញ្ជាការកងវរៈសេនាធំរបស់ខ្ញុំ នៅពេលនោះកងវរៈសេនាធំរបស់ខ្ញុំគឺលេខ ៦៣។ ដល់ឆ្នាំ១៩៧៧ តាជន បានបាត់ខ្លួនទៅ"]។

237. ទីបញ្ជាការរបស់កងវរៈសេនាធំលេខ ១៦៣ ដំបូងឡើយស្ថិតនៅ កងកេង[745] ហើយក្រោយមកនៅទឹកសាបរហូតទាល់តែចប់របបនេះ[746]។ កងវរៈសេនាធំលេខ ១៦៣ បានគ្រប់គ្រងមន្ទីរសន្តិខុស

---

744 សូមមើល កថាខណ្ឌ ៨៩៥។ សូមមើលផងដែរ ឯកសារ D114/52 កំណត់ហេតុស្តាប់ចម្លើយ ឈាង ជូ ឆ.35, 40-42 [“ឈ្មោះ តាញ៉ាន់ មកកាន់កងពល១១៧ [...] ឆ.40៖ [...] នៅពេលនោះ មាស មុត បានមករៀបចំកងពល ១១៧ ហើយចាត់តាំង តាញ៉ាន់ ជាមេបញ្ជាការកងពល១១៧នេះ [...] ឆ.41៖ ខ្ញុំដឹងតាមរយៈអ្នកដែលមកកាន់កាប់ថ្មីហ្នឹង គឺតាញ៉ាន់។ តាញ៉ាន់និយាយថា “បង មាស មុត ចុះមកក្រចេះ ដើម្បីរៀបចំកងពល១១៧ ឡើងវិញ [...] ឆ.42៖ [...] តាមព្រឹត្តិការណ៍ដែល តាញ៉ាន់ ទៅកាន់បញ្ជាការកងពល១១៧ គឺប្រហែល១ខែមុនពេលវៀតណាមចូលគឺនៅប្រហែលជាចុងខែវិច្ឆិកា ឬដើមខែធ្នូ ឆ្នាំ១៩៧៨”]។ ឯកសារ D54/110 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.5-6។ ឯកសារ D114/193 កំណត់ហេតុស្តាប់ចម្លើយ សៅ សារុន ឆ.64។ ឯកសារ D4.1.444 កំណត់ហេតុស្តាប់ចម្លើយ សៅ សារុន EN ERN 00278696។ ឯកសារ D114/192 កំណត់ហេតុស្តាប់ចម្លើយ ចិន ផាត ឆ.42។ ឯកសារ D114/102 កំណត់ហេតុស្តាប់ចម្លើយ អែម សារិន ឆ.22។ ឯកសារ D54/62 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ឆ.30។ ឯកសារ D54/63 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ឆ.1។ ឯកសារ D114/149 កំណត់ហេតុស្តាប់ចម្លើយ ទូច ឈុំ ឆ.13។ ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ ឈៀត ឡួន (ណាំ ឡួន) ឆ.15។ ឯកសារ D114/18 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.16-17។

745 ឯកសារ D114/116 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.30 [“[មុំ យ៉ាន] គឺជាបញ្ជាការកងវរសេនាធំ៦៣ នៃកងពល១៦៤ តាំងពីដើមដំបូងមកម្លេះ។ នោះគឺជាពេលដែលកងវរសេនាធំស្ថិតនៅកងកេង”]។ ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.30 [“[មុំ យ៉ាន] ជាមេបញ្ជាការកងវរៈសេនាធំលេខ៦៣។ មូលដ្ឋានរបស់គាត់នៅក្នុងព្រលានយន្តហោះកងកេង ជិតផ្លូវបំបែករវាងផ្លូវចូលទៅព្រលានយន្តហោះ និងផ្លូវជាតិត្រង់ស្នាច់ដែង”]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.22-23 [“វរៈសេនាធំ ២២ របស់ខ្ញុំបោះទីតាំងនៅព្រលានយន្តហោះ កងកេង។ ហើយកន្លែងធ្វើការរបស់យើងគឺនៅជុំវិញព្រលានយន្តហោះ កងកេងនោះ។ ក្រោយមកប្រហែលដើមឆ្នាំ១៩៧៦ ខ្ញុំបានចេញពីវរៈសេនាធំ ២២ [...] ឆ.23៖ [...] ព្រលានយន្តហោះ កងកេង គឺជាមូលដ្ឋានកងវរៈសេនាធំ ២២”]។ ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.3 [“ស៖ តើកងអនុសេនាធំលេខ២២ របស់លោកមានទីបញ្ជាការនៅកន្លែងណា? ឆ.៖ ទីតាំងរបស់កងវរៈសេនាធំស្ថិតនៅភូមិថ្មធំ ជាប់ព្រលានយន្តហោះ”]។ ឯកសារ D114/139 កំណត់ហេតុស្តាប់ចម្លើយ ងួន ឡាយ ហៅ អ៊ី ឆ.20 [“ខ្ញុំទៅនៅកងពល ១៦៤ វរៈសេនាធំលេខ៦៣ ខ្ញុំទៅនៅព្រលានយន្តហោះកងកេង”]។ ឯកសារ D114/18 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.26-28 [“ទីបញ្ជាការវរៈសេនាធំលេខ៦៣ នៅក្នុងបរិវេណវាលយន្តហោះកងកេង [...] ឆ.27៖ ទីបញ្ជាការវរៈសេនាធំ៦៣ នោះ គឺនៅក្នុងវាលយន្តហោះកងកេងតែម្តង ប៉ុន្តែមានកងដែលនៅខាងក្រោមដូចជាកងភ័ស្តុភាររបស់កងវរៈសេនាធំ៦៣ មានទីតាំងនៅទឹកសាប [...] ឆ.28៖ ផ្ទះរបស់មេបញ្ជាការវរៈសេនាធំ៦៣ ដែលស្នាក់នៅ គឺស្ថិតនៅបរិវេណវាលយន្តហោះកងកេងតែម្តង។ នៅពេលនោះ វាលយន្តហោះកងកេងមិនមានដំណើរការទេ ដូច្នេះមេបញ្ជាការស្នាក់នៅនឹងអគារដែលនៅក្នុងបរិវេណវាលយន្តហោះតែម្តង”]។

ទឹកសាប[747] ដែលនៅជាប់នោះ ព្រមទាំងការដ្ឋាននានានៅក្នុងឃុំរាម (រួមទាំង កងកេង និង បិតត្រាងផងដែរ)[748]។ កងទ័ពរបស់កងវរៈសេនាធំលេខ ១៦៣ ក៏បានឈរជើងនៅលើកោះសេះ និងកោះថ្មី ដែលនៅជិតនឹងកោះត្រល់ (វៀតណាម)[749] ផងដែរ។

---

746 ឯកសារ D114/115 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.8, 10, 14, 30 ["គុកទឹកសាបស្ថិតនៅក្រោមកងវរសេនាធំលេខ៦៣ នៃកងពល១៦៤ [...] ឆ.10៖ [...] ខ្ញុំនៅកងកេង ហើយខ្ញុំទៅមកទឹកសាបរៀងរាល់ថ្ងៃ។ នៅចុងឆ្នាំ ១៩៧៥ ខ្ញុំប្តូរទៅនៅតំបន់ទឹកសាបជិតស្ពាន។ ឃ្លាំងទាំងអស់ក៏ត្រូវ ឃ្លាំងទាំងអស់ក៏ត្រូវបានផ្លាស់ទៅទឹកសាបដែរ [...] ឆ.14៖ បញ្ជាការកងវរសេនាធំ៦៣ឈ្មោះ ជន ផ្ទះរបស់គាត់គឺនៅជិតទឹកសាប [...] ស៖ តើបញ្ជាការដ្ឋានកងវរសេនាធំនៅកន្លែងណាបន្ទាប់ពីផ្លាស់ទៅទឹកសាប? ឆ.30៖ [...] បញ្ជាការដ្ឋាននោះ មានទីតាំងនៅក្នុងអគារថ្មនៅផែទឹកសាប"]។ ឯកសារ D54/41 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ សារ៉ាន់ ឆ.21, 28 ["ស៖ តើមន្ទីរបញ្ជាការរបស់កងវរសេនាធំលេខ៦៣ នៅកន្លែងណា? ឆ.21៖ នៅទឹកសាប [...] ឆ.28៖ ខ្ញុំមិនដឹងថាតើបញ្ជាការដ្ឋានកងវរសេនាធំលេខ ៦៣ ស្ថិតនៅទឹកសាបនោះរហូតដល់ពេលណាទេ"]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ. 249 ["ស៖ លោកមានដឹងថា បញ្ជាការដ្ឋានកងវរៈសេនាធំ៦៣ នៅទីណាទេ? ឆ.249៖ នៅទឹកសាប"]។ ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ឆ.38, 43 ["ដូច្នេះកងវរសេនាធំ២២ នៅទឹកសាប ខ្ញុំនៅក្នុងកងវរសេនាធំ២២ នៅស្មាច់ដែង [...] ឆ.43៖ [...] ហើយវរសេនាធំលេខ២២ មានទីតាំងនៅទឹកសាប"]។ ឯកសារ D54/111 កំណត់ហេតុស្តាប់ចម្លើយ សំ ភីន ឆ.16 ["តាមខ្ញុំដឹង ទឹកសាបស្ថិតនៅក្រោមកងវរៈសេនាធំលេខ៦៣។ ទឹកសាប នៅជិតព្រៃទប់ឯណោះ"]។ ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា ឆ.5 ["យ៉ាន ជាមេបញ្ជាការកងវរៈសេនាធំលេខ៣៣ ដែលមានទីបញ្ជាការនៅទឹកសាប"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ .19 ["ពេលខ្ញុំមកដល់ទឹកសាបដំបូង ក្នុងឆ្នាំ១៩៧៧ តាជន ជាអ្នកទទួលខុសត្រូវនៅទីនោះ។ តាជន គឺជាមេបញ្ជាការវរៈសេនាធំលេខ៦៣។ ហើយ តាញ៉ាន់ គឺជាអនុរបស់គាត់។ វរៈសេនាធំ៦៣ មានទីតាំងនៅកន្លែងផ្លូវបំបែកផ្លូវជាតិលេខ៤ ទៅរាម នៅជិតវាលយន្តហោះ"]។ ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.20 ["ស ៖ តើអង្គភាពមួយណាស្ថិតក្រោមចំណុះកងពលធំ១៦៤ ដែលគ្រប់គ្រងតំបន់ទឹកសាប? ឆ.20៖ កងវរៈសេនាធំលេខ៦៣"]។ ឯកសារ D114/202 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ សារ៉ាន់ ឆ.17 ["ស៖ ពេលអង្គភាពលោកឈរជើងនៅព្រលានយន្តហោះកងកេង តើកងវរសេនាធំ ៦៣ ស្ថិតនៅណា? ឆ.17៖ ខ្ញុំឮថា នៅទឹកសាបៗ។ តែខ្ញុំមិនច្បាស់ទេ ព្រោះគេមិនឱ្យអ្នកណាទៅទីបញ្ជាការគេទេ។ បើចូលផ្តេសផ្តាស គេចាប់"]។

747 សូមមើល កថាខណ្ឌ ៤៨៨។ សូមមើលផងដែរ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.11-12, 19 [មេបញ្ជាការកងវរសេនាធំលេខ ៦៤ ជន និងអនុបញ្ជាការ ញាន់ ជាអ្នកទទួលខុសត្រូវនៅគុកទឹកសាប]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.137-138, 146, 249 [កងវរសេនាធំលេខ៦៣ មានមន្ទីរសន្តិសុខ និងមន្ទីរបញ្ជាការ ស្ថិតនៅទឹកសាប]។ ឯកសារ D54/41 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ សារ៉ាន់ (អ៊ូ សារ៉ាន់) ឆ.21 [មន្ទីរបញ្ជាការរបស់កងវរសេនាធំលេខ៦៣ ស្ថិតនៅទឹកសាប]។

748 សូមមើល VIII.F. ការដ្ឋានតំបន់រាម។

238. ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ កងវរៈសេនាតូចលេខ ៥២០ លេខ ៥៣០ លេខ ៥៤០ លេខ ៥៥០ (៥៦០) និងអាចមានលេខ ៥៨០ ផងដែរនោះ ស្ថិតនៅក្រោមកងវរៈសេនាធំលេខ ២២[750]។ នៅ ខែ កក្កដា ឆ្នាំ ១៩៧៥ កងវរៈសេនាតូចលេខ ៥២០ ត្រូវបានផ្ទេរទៅជាផ្នែកមួយនៃ

---

749 ឯកសារ D114/57 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ កេត ឆ.9 ["ខ្ញុំបានគួសតំបន់ដែលស្ថិតនៅក្រោមចំណុះកងវរៈសេនាធំ៦៣ កោះទាំងនោះមានដូចជាកោះសេះ កោះថ្មី និងព្រែកចាក ដែលស្ថិតនៅខាងកើតរាម"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត់ (ប៊ុន សារ៉ាត់) ឆ.141 ["វរសេនាធំ៦២ -- សូមទោស សូមប្តូរបន្តិច ៦១ បោះនៅកោះរុងធំ។ វរសេនាធំ៦២ បោះនៅកោះតាង និងកោះពូលូវ៉ៃចាស់ និងពូលូវ៉ៃថ្មី។ ៦៣ វរសេនាធំ៦៣ បោះនៅកោះថ្មី និងកោះសេះ"]។ ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.6 ["វរសេនាធំលេខ៦១ ក្រោម តា ញ៉ាន់ ប្រតិបត្តិការនៅកោះសេះ កោះអន្លាយ កោះខ្យង។ គេអត់មានកប៉ាល់ចម្បាំងទេ ប៉ុន្តែគេមានកាណូតដឹកជញ្ជូនរបស់គេ"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.35 ["វរសេនាធំ៦៣ មានមេបញ្ជាការឈ្មោះ បងយ៉ាន កាន់នៅកោះសេះ កោះតាគាវ កោះថ្មី ម៉ូរាម មកចម្ការដូង កងកេង"]។

750 ឯកសារ D2/8 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.51 ["ឥឡូវខ្ញុំនឹកឃើញហើយកងវរៈសេនាតូចដែលនៅក្រោមកងវរៈសេនាធំ២២ កាលពីមុនបែកភ្នំពេញមានឈ្មោះដូចតទៅគឺ កងវរៈសេនាតូច៥២០, ៥៣០, ៥៤០, និង៥៥០"]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.7 ["ខ្ញុំមិនច្បាស់អំពីខ្ទង់លេខទីមួយថាជាលេខ ១ឬលេខ ៥ ទេ តែខ្ញុំចាំច្បាស់ថា គឺពីរលេខខាងចុង គឺលេខ២០, ៣០, ៤០, ៥០ ក្នុងវរៈសេនាធំ ២២"]។ ឯកសារ D114/48 កំណត់ហេតុស្តាប់ចម្លើយ សុខ ង៉ុន ឆ.6 ["ស៖ [...] កងរបស់លោកឈ្មោះអ្វី? ឆ.6៖ ប្រហែលជាវរៈសេនាតូច៥២០"]។ ឯកសារD4.1.762 បទសម្ភាសន៍ជាមួយ កាំ ម៉ែន (Koem Men) ទាក់ទងជាមួយនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387329, KH 00742581។ ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង អុន ឆ.9 ["វរៈសេនាតូច ៥៣០, ៥៤០ និង៥៥០ ចិតនៅក្នុងវរៈសេនាធំក្រោមបញ្ជាការរបស់តា យ៉ាន"]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.64, 246 [លើកឡើងអំពីកងវរសេនាតូច ៥៤០] ឆ.17, 22, 248 ["ស៖ កងកុមាររបស់លោកហ្នឹង ស្ថិតនៅកងវរៈសេនាតូចណាដែរ? ឆ.17៖ កងវរៈសេនាតូច ៥៨០។ [...] ឆ.22៖ ១២ ប្រហែល ១៣ ដល់ ២០ ឆ្នាំ។ [...] ស៖ តើកងវរៈសេនាតូច ៥៨០គ្រប់គ្រងតំបន់ណាខ្លះ? ឆ.248៖ ចម្ការដូង"]។ ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ឆ.9, 11។ ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.37។ ឯកសារ D54/30 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.8, 11។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង រ៉េត EN ERN 00974078, KH ERN 00926525 [វរៈសេនាតូច ៥៣០ កងវរៈសេនាធំ១៦ គឺជាចំណុះឲ្យកងពលលេខ៣]។ មានតែ ម៉ាក ឈឿន (ទេព ឈឿន) អះអាងថា តាមពិតកងវរៈសេនាតូច ៥៥០ គឺ ត្រូវបានគេហៅថា កងវរៈសេនាតូច ៥៦០ (ឬក៏ឈ្មោះត្រូវបានប្តូរពីកងវរៈសេនាតូច ៥៥០ ទៅ ៥៦០)៖ ឯកសារ D114/18 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.29, 32-33 ["វរៈសេនាតូច៥៤០ នៅក្រោមបញ្ជាការរបស់សារី [...] ឆ.32៖ [...] វរៈសេនាតូច៥២០ នៅក្រោមហន វរៈសេនាតូច៥៣០ នៅក្រោម រ៉េត វរៈសេនាតូច៥៤០ នៅក្រោមសារី ហើយវរៈសេនាតូច៥៦០ គឺនៅក្រោមខ្ញុំ គឺមិនមានវរៈសេនាតូច ៥៥០នោះទេ។ [...] ឆ.33៖ ហន គឺជាមេបញ្ជាការវរៈសេនាតូច៥២០"]។

កងវរៈសេនាធំកងទ័ពជើងទឹកថ្មី (១៤០) កងវរៈសេនាតូចលេខ ៥៣០ បានក្លាយជាកងវរៈសេនាតូចលេខ ៦៣១ កងវរៈសេនាតូចលេខ ៥៤០ បានក្លាយជាកងវរៈសេនាតូចលេខ ៦៣២ ហើយកងវរៈសេនាតូចលេខ ៥៥០ (៥៦០) នៅពេលនោះត្រូវបានហៅថាកងវរៈសេនាតូចលេខ ៦៣៣[751]។ សមាជិកភាគច្រើននៃកងវរៈសេនាតូចទាំងនេះ បានបន្តហៅកងវរៈសេនាតូចទាំងនោះដោយឈ្មោះមុនៗរបស់កងវរៈសេនាតូចទាំងនោះដដែល[752]។ កងវរៈសេនាតូចលេខ ៥៨០ ទំនងជាត្រូវបានបញ្ចូលទៅក្នុងកងវរៈសេនាតូចលេខ ៦៣២ នៅក្រោយខែ កក្កដា ឆ្នាំ ១៩៧៥ ខណៈពេលដែលចម្ការដូងជាទីដែលកងវរៈសេនាតូចនេះបានឈរជើងនោះ មានទីតាំងស្ថិតនៅតំបន់កងកេង/អូរម្លូ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់កងវរៈសេនាតូចលេខ ៥៤០/៦៣២[753]។

---

751 នេះពឹងផ្អែកលើឈ្មោះថ្នាក់ដឹកនាំកងវរសេនាតូចទាំងនោះ ដែលភាគច្រើននៅដដែល។ សូមមើលផងដែរ ឯកសារ D114/283 កំណត់ហេតុនៃការស្តាប់ចម្លើយ ឯក នី ឆ.52 ["[វរសេនាធំ] ៦៣ មានវរសេនាតូចចាប់ផ្តើមពី ៣១, ៣២, ៣៣ (៦៣១, ៦៣២, ៦៣៣"]។ ឯកសារ D54/104 កំណត់ហេតុនៃការស្តាប់ចម្លើយ ឯក នី, ឆ.3 ["វើត គឺជាប្រធានវរសេនាតូច ៦៣១"]។ ឯកសារ D54/41 កំណត់ហេតុនៃការស្តាប់ចម្លើយអ៊ូ សាវ៉ាន់ ឆ.១៦ ["ខ្ញុំស្ថិតនៅក្នុងកងអនុសេវាធំលេខ ៣ វរសេនាតូលេខ ៦៣១ វរសេនាធំលេខ ៦៣"]។

752 សូមមើលឧទាហរណ៍ ម៉ាក ឈឿន តែងតែប្រើឈ្មោះកងវរសេនាតូច៥៦០ (ឬ ៥៥០) នៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយគាត់ទាំងអស់ ទោះបីជាគាត់ជាមេបញ្ជាការនៃកងវរសេនាតូចថ្មី ៦៣៣ ក៏ដោយ: ឯកសារ D234/2.1.141 ប្រតិចារឹក ម៉ាក ឈឿន, ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦, ម៉ោង 15:25:37 – 15:28:58 ["វរសេនាតូច ៥៣០ ហ្នឹងឈ្មោះ វើត, វរសេនាតូច ៥៤០ ឈ្មោះ សារី ឯ ៥៦០ ហ្នឹង ខ្ញុំ។"]។ ឯកសារ D114/20 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.34 - 35 ["បាទ! ខ្ញុំស្គាល់ អ៊ឹង វើត។ ខ្ញុំចាំ គាត់គឺជាលេខាវរសេនាតូច ៥៣០។ ស៖ ឈ្មោះនៅក្នុងឯកសារនេះ គឺដាក់ថាវរសេនាតូចលេខ ៦៣១។ ហេតុអីបាន ជាលោកនិយាយថា វើត គាត់ជាមេបញ្ជាការវរសេនាតូច ៥៣០ ទៅវិញ? ឆ35៖ ខ្ញុំមិនច្បាស់ទេ អំពីលេខលើឯកសរនេះ ថាហេតុអ្វីបានជាលេខវរសេនាតូចនេះ ជា ៦៣១ តាមដែលខ្ញុំចាំ វើត គឺជាលេខាវរសេនាតូច ៥៣០ ទេ។ ខ្ញុំមិនច្បាស់អំពី រឿងផ្លាស់ប្តូរលេខនេះទេ កាលពីពេលនោះ។"]។ ឯកសារ D114/18 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.32 ["យោងតាមការចងចាំរបស់ខ្ញុំ គឺមានវរសេនាតូច ៥២០ នៅក្រោម ហន វរសេនាតូច ៥៣០ នៅក្រោម វើត វរសេនាតូច ៥៤០ នៅក្រោម សារី ហើយវរសេនាតូច ៥៦០ គឺនៅក្រោមខ្ញុំ គឺមិនមានវរសេនាតូច ៥៥០ នោះ។"]។

753 ឯកសារ D114/156 កំណត់ហេតុនៃការស្តាប់ចម្លើយ សឹង ណុច, ឆ.17, 22, 63 - 64, 248 ["ស៖ កងកុមាររបស់លោក ហ្នឹង ស្ថិតនៅកងវរសេនាតូចណាដែរ? ឆ.17 ៖ កងវរសេនាតូច ៥៨០។ [...]ឆ.22៖ ១២ ប្រហែល ១៣ ដល់ ២០ឆ្នាំ [...] ឆ.63 ៖ មានកងវរសេនាតូចមួយទៀត នៅជិតតំបន់នោះ [ចំការដូងនៅក្នុងចំណុចភូមិអុង មកទល់ព្រលានយន្តហោះកងកេង] [...] ឆ.64 ៖ ខ្ញុំឮគេហៅ កងវរសេនាតូច ៥៤០ [...] ស៖ តើកងវរសេនាតូច ៥៨០ គ្រប់គ្រងតំបន់ណាខ្លះ? ឆ.248៖ ចំការដូង។"]។ ឯកសារ D54/33 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ឹង ឆុន, ឆ. 8 - 9 ["ពួកកងអនុសេនាធំរបស់ខ្ញុំ បោះទីតាំងមកនៅភូមិថ្មធំ ប្រហែល៥០០ម៉ែត្រ ពីខាងត្បូងព្រលានយន្តហោះកងកេង

239. ទាហានភាគច្រើននៃកងវរៈសេនាតូចលេខ ៥២០ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ហាន ត្រូវបានរួមបញ្ចូលទៅក្នុងកងវរៈសេនាធំលេខ ១៤០ នៅពេលដែលកងវរៈសេនាធំនេះត្រូវបានបង្កើតឡើង[754]។ ហាន បានក្លាយជាមេបញ្ជាការកងវរៈសេនាធំលេខ ១៤០ នៅចុងឆ្នាំ ១៩៧៨ (*សូមមើលខាងក្រោម ផ្នែកឃ) កងវរៈសេនាធំកងទ័ពជើងទឹកឯករាជ្យលេខ ១៤០)*។

240. មេបញ្ជាការរបស់កងវរៈសេនាតូចលេខ ៦៣១ (៥៣០) គឺ គង់ គៀន ហៅ អ៊ឹង វ៉េត (ឬជាធម្មតាគេហៅត្រឹមតែ "វ៉េត") ដែលត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅមន្ទីរ ស-២១ នៅខែ មេសា ឆ្នាំ ១៩៧៧[755] ហើយ ម៉ុន គឺជាមេបញ្ជាការរងរបស់កងវរៈសេនាតូចនេះ[756]។ ដំបូងឡើយឈរជើង

---

នៅតាមផ្លូវទៅផែរាម។ [...]ឆ. 9៖ [...] កងអនុសេនាធំលេខ ២៤ បោះទីតាំងនៅភូមិឡូឥដ្ឋ ហើយកងអនុសេនាធំ ២៦ របស់ខ្ញុំ បោះទីតាំងនៅភូមិថ្មធំ ហើយកងអនុសេនាធំ ២៨ នៅភូមិអូរឬស្សី។ ចំណែកមេបញ្ជាការវរសេនាតូច បោះទីតាំងនៅភូមិអូរឬស្សីដែរ។ កងអនុសេនាធំទាំង៣នេះ ស្ថិតនៅក្រោមវរសេនាតូច ៥៤០"]។

754 ឯកសារ D114/18 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.32 - 33 ["យោងតាមការចងចាំរបស់ខ្ញុំ គឺមានវរសេនាតូច ៥២០ នៅក្រោម ហាន [...] ឆ.33៖ ហាន គឺជាមេបញ្ជាការវរសេនាតូច ៥២០។ តាមការចងចាំរបស់ខ្ញុំ វរសេនាតូចនេះ ត្រូវបានបញ្ជូនទៅកងជើងទឹក ដែល ហាន ជាមេបញ្ជាការ។ [...] តាមដែលខ្ញុំដឹង ហាន គឺនៅក្នុងកងជើងទឹក ហៅថា កងនាវាប្រយុទ្ធ។"]។ ឯកសារ D114/20 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.41 ["មានម្នាក់ទៀត ឈ្មោះ ឈឿន ដែរ នៅទីងកន្លែងនោះជាមួយ សារី។ ឈឿន នៅបញ្ជាការក្នុងវរសេនាតូចរបស់ ហាន ដែលយើងនិយាយពីខាងដើម។ កងរបស់ ហាន ត្រូវបំបែកទៅខាងជើងទឹកខ្លះ និងទៅតាមកោះខ្លះ"]។

755 ឯកសារ D1.3.28.2 បញ្ជីអ្នកទោសស-២១ នៅថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ១៩៧៧ EN 01321750, KH 00086996 [កំណត់អត្តសញ្ញាណថា គង គៀន ហៅ អ៊ឹង វ៉េត ជាលេខាវរសេនាតូច ៦៣១ ហើយបានចូលមកមន្ទីរស-២១ នៅ ខែ មេសា ឆ្នាំ ១៩៧៧]។ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសស-២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត [កំណត់អត្តសញ្ញាណនៅលេខរៀងទី ២៣៦៨ ថា គង់ គៀន ហៅ អ៊ឹង វ៉េត ជាលេខាវរសេនាតូច ៦៣១ ហើយបានចូលមកមន្ទីរស-២១នៅ ខែ មេសា ឆ្នាំ ១៩៧៧ និងកំទេចនៅថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ១៩៧៨]។ ឯកសារ D54/27.2 បញ្ជីអ្នកទោសមកពីកងពល១៦៤បានចាប់, EN 01185467 - 01185471, KH 00955558 - 00955560 [ដាក់ថា គង គៀន ហៅ អ៊ឹង វ៉េត ជាលេខាវរសេនាតូច ៦៣១ កងពល១៦៤ និង ឈ្មោះ ម៉ុន ជាអនុលេខាវរសេនាតូច ៦៣១]។ ឯកសារ D1.3.18.4 ចម្លើយសារភាពរបស់មន្ទីរស-២១ គង់ គៀន ហៅ អ៊ឹង វ៉េត, EN 00822048, KH 00017305, FR 00825431។ ឯកសារ D114/20.3 ចម្លើយសារភាពរបស់មន្ទីរស-២១ គង់ គៀន ហៅ អ៊ឹង វ៉េត, EN 01507936, KH 01034043 [វ៉េត បានរៀបរាប់ថា ជាបញ្ជាការវរសេនាតូច ៥៣០]។ ឯកសារ D234/2.1.141 ប្រតិចារឹក ម៉ាក ឈឿន, ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦, ម៉ោង 15:25:37 – 15:28:58 ["វរសេនាតូច ៥៣០ ហ្នឹងឈ្មោះ វ៉េត"]។ ឯកសារ D114/18 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.32 ["វរសេនាតូច ៥៣០ នៅក្រោម វ៉េត"]។ ឯកសារ D114/139 កំណត់ហេតុនៃការស្តាប់ចម្លើយ ងួន ឡាយ ហៅ អ៊ី, ឆ.36, ឆ.65 - 66, 74, ឆ.77 ["ដឹងតែកោះសេះ លេខ ៣១ ឈ្មោះ វ៉េត គាត់ស្លាប់បាត់ហើយ។ [...] ឆ.65៖ [វ៉េត] [...] គេចាប់គាត់ [...] ឆ.66៖ [...]

ពេលដែលគាត់ទៅ សិក្ខាសាលានៅលើគោក គេចាប់គាត់ទៅ ខ្ញុំឮគេនិយាយអីចឹង។ ពេលដែលគាត់ទៅគោកអីហ្នឹង ទូកខ្ញុំក៏ដឹកគាត់ទៅចូលរួមសិក្ខាសាលា [...] ស៖ មេៗដែលគេហៅទៅសិក្ខាសាលា ដូចជា វ៉េត តើពួកគេមានបានត្រឡប់មកវិញទេ? ឆ.74៖ [...]មានតែមួយហ្នឹង អត់ឃើញត្រឡប់ទៅវិញ។ [...] ស៖ តើលោកដឹងថា គេចាប់ខ្លួន វ៉េត នៅពេលហ្នឹងតែម្តង ឬពីរបីខែ ក្រោយមកបានដឹង? [...]ឆ. 77៖ បាទ! ឮ ពេលដែលអ្នកសិក្ខាសាលា ត្រឡប់មកវិញ។"]។ ឯកសារ D4.1.764 កំណត់ហេតុនៃការស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច, EN 00398164, KH 00398157 ["ឧទាហរណ៍មួយទៀត ចម្លើយសារភាពរបស់ គង់ គៀង ហៅ អ៊ឹង វ៉េត (លេខាវរសេនាតូច ៦៣១ វរសេនាធំ ៦៣ កងពល ១៦៤)"]។ ឯកសារ D54/104 កំណត់ហេតុនៃការស្តាប់ចម្លើយ ឯក នី, ឆ.3 ["វ៉េត គឺជាប្រធានវរសេនាតូច ៦៣១[...] វ៉េត នៅកងទ័ពជើងគោក មានទីតាំងនៅព្រលានយន្តហោះកងកេង ហើយគាត់ត្រូវបានចាប់ខ្លួន។ [...] ខ្ញុំជឿថា គាត់ស្លាប់ហើយ ពីព្រោះនៅពេលដែល តាម៉ុក ប្រជុំប្រាប់អំពីចម្លើយសារភាព ហើយ តាម៉ុក បានប្រកាសថា វ៉េត ក្បត់ ហើយ។"]។ ឯកសារ D114/202 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ូ សាវ៉ាន់, ឆ.38 ["ស៖ ពេលលោកឈរជើងនៅលើ កោះនោះ តើមេបញ្ជាការរបស់កងវរសេនាតូចឈ្មោះអីដែរ កាលនោះ? ឆ.38៖ ឈ្មោះសមមិត្ត វ៉េត ដដែល ហើយ ញ៉ាន់ នៅវរសេនាធំ នៅតែលើគោកទេ មានតែ វ៉េត ទេ ទៅនៅលើកោះ [កោះសេះ]។"]។ ឯកសារ D114/20 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.34, 36 ["បាទ! ខ្ញុំស្គាល់ អ៊ឹង វ៉េត។ ខ្ញុំចាំគាត់គឺជាលេខាវរសេនាតូច ៥៣០។ [...] ឆ.36 ៖ ខ្ញុំដឹង អំពីការបាត់ខ្លួននេះ ប៉ុន្តែខ្ញុំមិនដឹងពីថ្ងៃខែឆ្នាំទេ។ នៅពេលនោះ ខ្ញុំគិតថា គាត់ត្រូវបានផ្លាស់ទៅកន្លែងផ្សេងវិញ។"]។ ឯកសារ D54/7 កំណត់ហេតុនៃការស្តាប់ចម្លើយ ឌុល សុង, ឆ.6 ["នៅពេលនោះ វ៉េត បានឡើងជាមេបញ្ជាការវរសេនាតូច ១០៥"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង, ឆ.4 ["អ្នកដែលត្រូវចាប់ខ្លួន: [...] វ៉េត ជាមេបញ្ជាការវរសេនាតូចរបស់ខ្ញុំ"]។ ឯកសារ D114/85 កំណត់ហេតុនៃការស្តាប់ចម្លើយ ជេត ប៊ុណ្ណា, ឆ.18 [ពន្យល់ថាមនុស្សគ្រប់គ្នា ដឹងពីការចាប់ខ្លួន គង់ គៀន ហៅ អ៊ឹង វ៉េត ព្រោះគាត់ជាមនុស្សលេចធ្លោ]។ ឯកសារ D54/112.1 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្លុង ឈា, EN 00968344 - 00968345, KH 00926489 - 00926490 ["ស៖ កងពលទី៣ វរសេនាធំទី២២ វរសេនាតូច? ឆ៖ វរសេនាតូច ៣៣០។ [...] វរសេនាតូច អី! លោក វ៉េត។"]។ ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង វ៉េត, EN 00974078, KH 00926525 ["ស៖ កាលហ្នឹង វរសេនាតូច ៥៣០ ប្រធានគេឈ្មោះអីទៅ? ឆ៖ ឈ្មោះ វ៉េត។"]។

756 ឯកសារ D54/27.2 បញ្ជីអ្នកទោសមកពីកងពល១៦៤បានចាប់, EN 01185467 - 01185471, KH 00955558 - 00955560 [កំណត់អត្តសញ្ញាណថា គង គៀន ហៅ អ៊ឹង វ៉េត ជាលេខាវរសេនាតូច ៦៣១ កងពល១៦៤ និង ឈ្មោះ ម៉ុន ជាអនុលេខាវរសេនាតូច ៦៣១]។ សូមមើលផងដែរ ឯកសារ D1.3.18.4 ចម្លើយសារភាពរបស់មន្ទីរស-២១ គង់ គៀន ហៅ អ៊ឹង វ៉េត ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៧៧, KH 00017351 [កំណត់អត្តសញ្ញាណថា ម៉ុន ជា អនុលេខាវរសេនាតូច ៦៣១]។

នៅព្រលានយន្តហោះកងកេង[757] ហើយក្រោយមកបន្តិចនៅក្នុងឆ្នាំ ១៩៧៥[758] កងវរៈសេនាតូច លេខ ៦៣១ បានឈរជើងនៅកោះសេះចាប់ពីឆ្នាំ ១៩៧៦ មក[759]។ បន្ទាប់ពី អ៊ឹង វ៉េត ត្រូវបានចាប់

[757] ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង, ឆ.22 - 23។ ឯកសារ D2/9 កំណត់ហេតុនៃការស្តាប់ចម្លើយ សយ ប៊ិន ឆ.3។ ឯកសារ D54/112.1, ឯកសារ D59/1/1.10a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយ មជ្ឈមណ្ឌលឯកសារ កម្ពុជា ផ្លុង ឈា, EN 00968346, KH 00926491 - 00926492។

[758] ឯកសារ D114/18 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.34 - 36 ["ទីបញ្ជាការដ្ឋានរបស់វរសេនាតូច ៥៣០ របស់ វ៉េត នៅទឹកសាប នៅជិតកន្លែងភស្តុភាររបស់វរសេនាធំ ៦៣។ [...] ឆ.35៖ [...] បញ្ជាការដ្ឋានរបស់វរសេនាតូច ៦៣០ គឺនៅក្នុងកន្លែងមូលដ្ឋានទ័ព លន់ នល់ [...] ឆ.36 ៖ [...] យោធានៅក្នុងវរសេនាតូច ៥៣០ ត្រូវបញ្ជូនចេញទៅធ្វើ ការនៅកន្លែងផ្សេងៗ។ [...] នៅនឹងទឹកសាប មានតែកន្លែងបញ្ជាការដ្ឋានទេ [...] ខ្ញុំឮថា ក្នុងឆ្នាំ ១៩៧៧ វរសេនាតូច ៥៣០ នេះ ប្រហែលជាត្រូវរំសាយ នៅពេលនោះ វ៉េត បានបាត់ខ្លួន ហើយយោធាក្នុងកងរបស់គាត់អាចនឹងបញ្ចូលទៅក្នុងកងជើង ទឹកខ្លះ។"]។ ឯកសារ D114/19 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ .29 [គូសបង្ហាញនៅលើផែនទី (D114/19.2) ដាក់ថា "ទីកន្លែងបញ្ជាការវរសេនាតូច ៥៣០ នៃវរសេនាធំ ៦៣ នៅទឹកសាប"]។

[759] ឯកសារ D1.3.8.3 កំណត់ហេតុនៃអង្គប្រជុំ អចិន្ត្រៃយ៍នៃបក្សកុម្មុយនិសកម្ពុជា ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ១៩៧៦, EN 00234012, KH 00021496 - 00021497 ["កម្លាំងមនុស្ស: ១ វរសេនាធំ (៣ វរសេនាតូច) នៅកោះវៃ, កោះតាង និង កោះ រ៉ុង, ១ វរសេនាតូច នៅកោះសេះ និង ១ វរសេនាតូច នៅកោះមួយទៀតជិតនោះ"]។ ឯកសារ D114/139 កំណត់ហេតុនៃការស្តាប់ចម្លើយ ងួន ឡាយ ហៅ អ៊ី, ឆ.36, ឆ.65 - 66, 74, ឆ.77 ["ដឹងតែកោះសេះ លេខ ៣១ ឈ្មោះ វ៉េត"]។ ឯកសារ D54/41 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ូ សាវ៉ាន់, ឆ.19, ឆ.20, ឆ.27 ["កងវរសេនាតូចរបស់ខ្ញុំត្រូវបានបញ្ជូនទៅបោះ ទីតាំងនៅចម្ការដូងរបស់ ចេង ហេង និងវាលយន្តហោះកងកេង។ [...] ឆ.20៖ ចុងឆ្នាំ ១៩៧៥ កងវរសេនាតូចរបស់ខ្ញុំ ត្រូវ បានបញ្ជូនចេញពីចម្ការដូង និងវាលយន្តហោះកងកេង ឲ្យទៅនៅកោះសេះ [...] ឆ. 27៖ [...] នៅដើមឆ្នាំ ១៩៧៦ [...] កងវរសេនាតូចរបស់ខ្ញុំត្រូវបានបញ្ជូនទៅកោះសេះ។"]។ ឯកសារ D114/202 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ូ សាវ៉ាន់, ឆ.16, ឆ.37 - 38 ["មួយវគ្គដំបូង នៅព្រលានយន្តហោះកងកេង នៅឆ្នាំ ១៩៧៥។ ហើយក្រោយមកទៀត គេបញ្ជូនទៅកោះសេះ មួយឆ្នាំពេញ។ [...] ឆ.37៖ ដើមឆ្នាំ ៧៦ ទៅយាមកោះ [...] មួយវរសេនាតូច ៦៣១ ទាំងមូល ត្រូវបានគេបញ្ជូនទៅនោះ [...] ឆ.38៖ វ៉េត ទេ ទៅលើកោះ [កោះសេះ]"]។ ឯកសារ D114/156 កំណត់ហេតុនៃការស្តាប់ចម្លើយ សឹង ណុច, ឆ.56, 63 - 64 ["ស៖ ពេលដែលលោកនៅកងអនុសេនាតូច ៥៨០ នោះ តើកងពល ១៦៤ ហ្នឹង មកកាន់ហើយនៅ? ឆ.56៖ បាទ! [...] ឆ.63 ៖ មានកងវរសេនាតូចមួយទៀត នៅជិតតំបន់នោះ [ចំការដូង] [...] កងវរសេនាតូចនោះ ផ្លាស់ពីមួយកន្លែទៅមួយកន្លែង ក្រោយមកត្រូវបានគេបញ្ជូនទៅកោះ។ [...] ឆ.64 ៖ ខ្ញុំឮគេហៅ កងវរសេនាតូច ៥៤០"]។

ខ្លួន កងទ័ពរបស់កងវរៈសេនាតូចលេខ ៦៣១ មួយចំនួន ក្រោយមកត្រូវបានផ្ទេរទៅកាន់សមរភូមិមុខនៅភូមិភាគបូព៌ា[760]។

241. មេបញ្ជាការកងវរៈសេនាតូចលេខ ៦៣២ (៥៤០) គឺ ញ៉ែត សារី[761]។ ទីបញ្ជាការរបស់កងវរៈសេនាតូចនេះមានទីតាំងស្ថិតនៅអូរម្លូនៅជិតកងកេង[762]។

---

760 ឯកសារ D54/41 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ូ សារ៉ាន់, ឆ.28 ["នៅដើមឆ្នាំ ១៩៧៧ ខ្ញុំត្រូវបានគេបញ្ជូនពីកោះសេះឲ្យមកស្នាក់ដែង។ នៅទីនោះ ខ្ញុំ និង យោធាជាង ១០០ នាក់ទៀត ដែលមកពីកងផ្សេងៗ ហើយត្រូវបានគេបញ្ជូនទៅភូមិភាគបូព៌ា នៅក្នុងកងពលលេខ ១៨០។"]។ ឯកសារ D114/202 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ូ សារ៉ាន់, ឆ.43 ["ពេលចេញពីកំពង់សោម កោះសេះនោះទៅ គេរើសកម្លាំងខ្លះចូលទៅបូព៌ា។ គេបញ្ចូលទៅអង្គភាពថ្មីមួយទៀតហៅថា កងពល២៨០"]។

761 ឯកសារ D1.3.30.5 របាយការណ៍សេនាធិការ របស់កម្ពុជាប្រជាធិបតេយ្យ តារាងស្ថិតិសិក្ខាកាមរៀន នៅវគ្គសេនាធិការលើកទី១ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៧៦, EN 00897656, KH 00095538 [បញ្ជីលេខរៀង ១៤៥ ញ៉ែត សារី ជាលេខាវរសេនាតូច នៅកងពល ១៦៤]។ ឯកសារ D234/2.1.141 ប្រតិចារឹក ម៉ាក ឈឿន, ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦, ម៉ោង 15:25:37 – 15:28:58 ["វរសេនាតូច ៥៣០ ហ្នឹងឈ្មោះ វេត, វរសេនាតូច ៥៤០ ឈ្មោះ សារី"]។ ឯកសារ D114/18 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.29 ["វរសេនាតូច ៥៤០ នៅក្រោមបញ្ជាការរបស់ សារី ហើយទីបញ្ជាការរបស់កងគាត់ នោះ គឺនៅខាងក្រៅបរិវេណយន្តហោះកងកេង"]។ ឯកសារ D54/33 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ឹង នុន, ឆ. 9 ["កងអនុសេនាធំលេខ ២៤ បោះទីតាំងនៅភូមិឡឥដ្ឋ ហើយកងអនុសេនាធំ ២៦ របស់ខ្ញុំ បោះទីតាំងនៅភូមិថ្មធំ ហើយកងអនុសេនាធំ ២៨ នៅភូមិអូរម្លូរ"]។ ទីបញ្ជាការកងវរសេនាតូចរបស់យើងបោះទីតាំងនៅភូមិអូរម្លូរៈ កងអនុសេនាធំទាំង៣នោះ ឋិតនៅក្រោមកងវរសេនាតូច ៥៤០ ដែលមានមេបញ្ជាការឈ្មោះ សារី គាត់បានស្លាប់ហើយ។ កងវរសេនាតូច ៥៣០, ៥៤០, និង ៥៥០ ឋិតនៅក្នុងកងវរសេនាធំក្រោមបញ្ជារបស់ តាយ៉ាន ខ្ញុំមិនចាំលេខរបស់វរសេនាធំនោះទេ" (បន្ថែមការសង្កត់ធ្ងន់)]។ ឯកសារ D114/285 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រំ សារ៉ាត់ (ប៊ុន សារ៉ាត់), ឆ.3 ["ប្រធានវរសេនាតូចឈ្មោះ សារី បញ្ជាការឈ្មោះ អូច។"]។ ឯកសារ D114/20 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.41 ["មានម្នាក់ទៀតឈ្មោះ ឈឿន ដែរនៅនឹងកន្លែងនោះជាមួយ សារី។ ឈឿន នៅជាបញ្ជាការ ក្នុងវរសេនាតូចរបស់ ហន ដែលយើងនិយាយពីខាងដើម។ កងរបស់ ហន ត្រូវបានបំបែកទៅខាងជើងទឹកខ្លះ និងទៅតាមកោះខ្លះ។ ដូច្នេះ ខ្ញុំមិនដឹងថា មានរឿងអ្វីកើតឡើងចំពោះគាត់ទេ។"]។ ឯកសារ D59/1/1.7a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ម៉ា ឈឿន, EN 00969929, KH 00926306 ["សៈ ចុះ ៥៤០ ពីណាគេទទួល? ឆៈ សារី"]។

762 ឯកសារ D54/33 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ឹង នុន, ឆ. 8 - 9 ["ពួកកងអនុសេនាធំរបស់ខ្ញុំ បោះទីតាំងមកនៅភូមិថ្មធំ ប្រហែល៥០០ម៉ែត្រ ពីខាងត្បូងព្រលានយន្តហោះកងកេង នៅតាមផ្លូវទៅផែរាម។ [...]ឆ. 9 ៖ [...] កងអនុសេនាធំលេខ ២៤ បោះទីតាំងនៅភូមិឡឥដ្ឋ ហើយកងអនុសេនាធំ ២៦ របស់ខ្ញុំ បោះទីតាំងនៅភូមិថ្មធំ ហើយកងអនុសេនាធំ ២៨ នៅភូមិអូរម្លូរ។ ចំណែកមេបញ្ជាការវរសេនាតូច បោះទីតាំងនៅភូមិអូរម្លូរដែរ។ កងអនុសេនាធំទាំង៣

242. មេបញ្ជាការរបស់កងវរៈសេនាតូចលេខ ៦៣៣ (៥៥០) គឺ ទេព ឈឿន (សាក្សី ម៉ាក ឈឿន)[763] ។ បន្ទាប់ពីត្រូវបានពង្រាយកងទ័ពទៅកាន់កោះផ្សេងៗ[764] កងវរៈសេនាតូចនេះត្រូវបានចាត់តាំងឲ្យ

---

នេះ ស្ថិតនៅក្រោមវរសេនាតូច ៥៤០"]។ ឯកសារ D114/156 កំណត់ហេតុនៃការស្តាប់ចម្លើយ សឹង ណុច, ឆ.63 - 64 ["មានកងវរសេនាតូចមួយទៀត នៅជិតតំបន់នោះ [ចំការដូង នៅក្នុងចំណុចភូមិអុង មកទល់ព្រលានយន្តហោះកងកេង] [...] ឆ.64 ៖ ខ្ញុំឮគេហៅ កងវរសេនាតូច ៥៤០"]។ ឯកសារ D114/19 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.29 ["ទីកន្លែងវរសេនាតូច ៥៤០ នៃវរសេនាធំ ៦៣ ដែលស្ថិតនៅក្រោមបញ្ជាការរបស់ សារី នៅជិតកងកេង ឆ្លងផ្លូវជាតិលេខ៤។"]។ ឯកសារ D114/18 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.29 ["វរសេនាតូច ៥៤០ នៅក្រោមបញ្ជាការរបស់ សារី ហើយទីបញ្ជាការរបស់កងគាត់ នោះ គឺនៅខាងក្រៅបរិវេណយន្តហោះកងកេង។"]។ ឯកសារ D54/41 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ូ សារ៉ាន់, ឆ.20 ["ចុងឆ្នាំ ១៩៧៥ កងវរសេនាតូចរបស់ខ្ញុំ ត្រូវបានបញ្ជូនចេញពីចម្ការដូង និងវាលយន្តហោះកងកេង ឲ្យទៅនៅកោះសេះ ហើយវរសេនាតូចមួយទៀត នៅក្នុងវរសេនាធំជាមួយគ្នា មកនៅចម្ការដូង និងវាលយន្តហោះវិញ។ ខ្ញុំមិនច្បាស់ ថាកងវរសេនាតូចលេខ ៦៣២ ឬ ៦៣៣ ទេ ដែលមកជំនួសវរសេនាតូចរបស់ខ្ញុំនៅកងកេង នៅពេលនោះ។"]។

763 ឯកសារ D1.3.30.5 របាយការណ៍សេនាធិការ របស់កម្ពុជាប្រជាធិបតេយ្យ តារាងស្ថិតិសិក្ខាកាមរៀន នៅវគ្គសេនាធិការលើកទី១, ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៧៦, EN 00897656, KH 00095538 [បញ្ជីលេខរៀង ១៤៦ ទេព ឈឿន ជាលេខាវរសេនាតូច នៅកងពល ១៦៤]។ ឯកសារ D234/2.1.141 ប្រតិចារឹក ម៉ាក ឈឿន, ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦, ម៉ោង 15:25:37 – 15:28:58 ["វរសេនាតូច ៥៣០ ហ្នឹងឈ្មោះ វ៉េត, វរសេនាតូច ៥៤០ ឈ្មោះ សារី , ឯ ៥៦០ ហ្នឹង ខ្ញុំ។"]។ ឯកសារ D114/20 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.26 ["ខ្ញុំចាំថា ធ្លាប់បានទៅរៀនសូត្រទាំងនេះ។ ខ្ញុំចាំថាការរៀន សូត្រនេះ ធ្វើឡើងនៅស្តាតអូឡាំពិច ភ្នំពេញ ខ្ញុំនៅចាំថា ខ្ញុំធ្លាប់ត្រូវបញ្ចូលឲ្យទៅចូលរួមរៀនសូត្រនេះ ចំនួនពីរដង។ ប៉ុន្តែ លើកទី១ ខ្ញុំមិនបាទៅទេ ដោយសារឡានរបស់ខ្ញុំក្រឡាប់ [...] នៅលេខរៀង ទី១២៣ ឈ្មោះ ឌឹម ជាអនុកងពល ឯអ្នកដែល នៅត្រង់លេខ ១៤៦នេះ គឺជាឈ្មោះ ខ្ញុំ កាលពីជំនាន់របបខ្មែរក្រហម ខ្ញុំប្រើឈ្មោះជីតារបស់ខ្ញុំ ទេព ដាក់នាមត្រកូល។ ប៉ុន្តែ សព្វថ្ងៃនេះ ខ្ញុំប្រើឈ្មោះឪពុកខ្ញុំ (ម៉ាក) ជានាមត្រកូលវិញ"]។ ឯកសារ D114/32 កំណត់ហេតុនៃការស្តាប់ចម្លើយ មាស សារ៉ាន, ឆ.90 ["ប្តីរបស់ ញ៉ន គឺឈ្មោះ ឈឿន ដែលមានឋានៈជាមេបញ្ជាការកងវរសេនាតូច"]។ ឯកសារ D114/18 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.32 ["យោងតាមការចងចាំរបស់ខ្ញុំ គឺមានវរសេនាតូច ៥២០ នៅក្រោម ហន វរសេនាតូច ៥៣០ នៅក្រោម វ៉េត វរសេនាតូច ៥៤០ នៅក្រោម សារី ហើយវរសេនាតូច ៥៦០ គឺនៅក្រោមខ្ញុំ គឺមិនមានវរសេនាតូច ៥៥០ នោះទេ"]។ ឯកសារ D114/16 កំណត់ហេតុនៃការស្តាប់ចម្លើយ សុក វណ្ណា (សួស វណ្ណា), ឆ.7 ["ដូចខ្ញុំបានប្រាប់ហើយថា ឈឿន ដែលខ្វាក់ភ្នែកម្ខាង មានស្រុកកំណើតនៅភូមិព្រៃវែង គឺជាមេកងវរសេនាតូចរបស់ខ្ញុំតែម្តង ហើយពួកខ្ញុំឈរជើងនៅលើកោះថ្មី។ ឯកសារ D114/17.1 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ម៉ា ឈឿន, EN 01313341, KH 01033986 ["សៈ កាលហ្នឹងពូធ្វើខាង អីទទួលខាងវរសេនាតូច? ឆៈ បាទ! វរសេនាតូច។ សៈ គេហៅវរសេនាតូចអីគេ? ឆៈ វរសេនាតូចលេខ ៥៥០ [ចំណាំសរសេរដោយដៃ:វរសេនាតូច ៥៦០]"]។

ទៅឈរជើងនៅលើកោះថ្មីចាប់ពីឆ្នាំ ១៩៧៥ និងនៅលើកោះសេះចាប់ពីឆ្នាំ ១៩៧៧ (បន្ទាប់ពីមានការចាប់ខ្លួន វ៉េត ដែលជាមេបញ្ជាការកងវរៈសេនាតូចលេខ ៦៣១) រហូតទាល់តែចប់របបនេះ[765]។ **មាស មុត** បានបញ្ជាឱ្យកងវរៈសេនាតូចលេខ ៦៣៣ (៥៥០) ទៅការពារកោះទាំងនេះ និងដែនទឹកកម្ពុជាប្រឆាំងនឹងការឈ្លានពានណាមួយរបស់វៀតណាមដែលបានឈរជើងនៅលើកោះត្រល់ (វៀតណាមហៅថាកោះភូកុក) ដែលស្ថិតនៅជិតកម្ពុជា[766]។

---

764 ឯកសារ D54/31 កំណត់ហេតុនៃការស្តាប់ចម្លើយ ស៊ឹម នី, ឆ.3 [“ក្រោយមក កងវរសេនាតូច ៥៥០ ត្រូវបានចាត់តាំង ដូចខាងក្រោមនេះ មួយកងអនុសេនាធំនៅការពារកំពង់ផែ មួយកងអនុសេនាធំទៀត ត្រូវបានបញ្ជូនទៅកោះតាង និងកោះប៉ូឡូវ៉ៃ និងមួយអនុសេនាធំទៀត ត្រូវបានបញ្ជូនទៅកោះរ៉ុងក្នុង និងកោះរ៉ុងក្រៅ។”]។ ឯកសារ D2/6 កំណត់ហេតុនៃការស្តាប់ចម្លើយ ញូង ជ្រោង, ឆ.13 [“ស៖ កង ៥៥០ នៅព្រលានយន្តហោះកងកេងប្រហែល ១៥ថ្ងៃ ទើបបញ្ជូនទៅកោះតាង […] ឆ៖បាទ!ត្រឹមត្រូវ”]។ ឯកសារ D54/12 កំណត់ហេតុនៃការស្តាប់ចម្លើយ ប្រេស មាន, ឆ.6 [“ខ្ញុំមិនចាំលេខកងវរសេនាតូច របស់ខ្ញុំទេ តែខ្ញុំនៅក្នុងកងវរសេនាធំ ២២។ បន្ទាប់ពីរៀបចំកងរួចហើយ ខ្ញុំត្រូវបានបញ្ជូនទៅនៅកោះតាង។”]។ ឯកសារ D4.1.746 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក សំ សុក, EN 00387463, KH 00742598 [“លោក សុក បានធ្វើដំណើរជាមួយ កងវរសេនាតូចលេខ ២២ ឆ្ពោះទៅកាន់ រាម។ ពួកគេបានស្នាក់នៅ រាម អស់រយៈពេលប្រហែល ៥ថ្ងៃ បន្ទាប់មកកងវរសេនាតូចទាំងមូលត្រូវពង្រាយទៅកាន់កោះតាង តាមទូកចំនួន៣”]។

765 ឯកសារ D114/19 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.29 [“បញ្ជាការពីររបស់វរសេនាតូចខ្ញុំ ទី១ នៅលើកោះថ្មី និងមួយទៀត នៅលើកោះសេះ។”]។ ឯកសារ D114/18 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ .6, 24 [“កងវរសេនាធំរបស់ខ្ញុំ គឺលេខ ៦៣។ […] ឆ.24៖ ខ្ញុំនៅលើកោះថ្មីហ្នឹងតាំងពីឆ្នាំ ១៩៧៥។ […] ខ្ញុំនៅលើកោះហ្នឹង រហូតដល់ជិតបែកខ្មែរក្រហម”]។ ឯកសារ D59/1/1.7a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ម៉ា ឈឿន, EN 00969930, KH 00926307 [“ខាង ៦៣ហ្នឹង ប្រចាំលើកោះណាខ្លះទៅ? ឆ៖ ខ្ញុំដឹងតែរបស់ខ្ញុំទេ ចាំនេះអឺកោះសេះ កោះថ្មី កងរបស់ខ្ញុំ។”]។ EN 00969939, KH 00926317 [“ពូនៅកោះសេះ កោះថ្មីហ្នឹង រហូតដល់ពេលណា? ឆ៖ អឺ! នៅរហូតដល់សង្គ្រាមចុងក្រោយនេះ ៧៩ហ្នឹង”]។ ឯកសារ D54/115.1 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា នាក់ យឿន (យោធាជើងទឹក, កងពល១៦៤), EN 01088459, KH 01007858 [“ឈឿន នឹងខាង គាត់ខាងកោះអឺៗថ្មីកោះអឺ”]។

766 ឯកសារ D1.3.30.2 របាយការណ៍ពី មុត (មាស មុត) គោរពជូនបង ៨៩ (សុន សេន), ថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៧៦, EN 00231824, KH 00021446។ ឯកសារ D2/6 កំណត់ហេតុនៃការស្តាប់ចម្លើយ ញូង ជ្រោង, ឆ.22 [“គេឱ្យខ្ញុំនៅការពារកោះទប់ទល់នឹងកងទ័ពវៀតណាម និងធ្វើស្រែចម្ការនៅទីនោះ។”]។ ឯកសារ D114/104 កំណត់ហេតុនៃការស្តាប់ចម្លើយ អៀម ភង់, ឆ.65 [“គេបញ្ជាយើងថា ឱ្យទៅការពារកោះ ខ្លាចយួននៅ”]។ ឯកសារ D114/139 កំណត់ហេតុនៃការស្តាប់ចម្លើយ ងួន ឡាយ ហៅ អ៊ី, ឆ.38 [“នៅកោះសេះ កោះថ្មីហ្នឹង វាមានផែពីរ។ ការងារ មានតែអូសត្រីហ្នឹង បានច្រើនយកទៅចែកតាមកង”]។ ឯកសារ D114/109 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រំ សម្បត្តិ, ឆ.

### *ឃ) កងវរៈសេនាធំកងទ័ពជើងទឹកឯករាជ្យលេខ ១៤០*

243. អង្គភាពកងទ័ពជើងទឹករបស់កងពលធំលេខ ១៦៤ គឺកងវរៈសេនាធំលេខ ១៤០ បានប្រតិបត្តិការចាប់តាំងពីខែ កក្កដា-សីហា ឆ្នាំ ១៩៧៥ *ខ.* ចាប់តាំងពីកងពលធំមជ្ឈិមលេខ ១៦៤ ត្រូវបានបង្កើតឡើង[767]។ កងពលធំមជ្ឈិមនេះមានទាហានមកពីកងវរៈសេនាធំចំនួនបីកងរបស់កងពលធំលេខ ៣ ទាហានមួយចំនួនរបស់តំបន់ ៣៧ និងទាហានមកពីភូមិភាគបូព៌ា[768]។ បេសកម្មស្នូល

---

30 ["គេឱ្យនៅយាមកោះពីពួក វៀតណាម នៅកោះត្រល់។"]។ ឯកសារ D59/1/1.7a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយ មជ្ឈមណ្ឌលឯកសារ កម្ពុជា ម៉ា ឈឿន, EN 00969934, KH 00926311 - 00926312 ["ស៖ ដូចថា ពេលការពារហ្នឹង យើងមានបានជួបអីដែរ អត់? ឆ៖ ជួបវៃគ្នា វៃយួនដែរហ្នឹង។ ស៖ វៃជាមួយយួន? ឆ៖ បាទ! កោះត្រល់ ហើយនិងកោះសេះ មើលគ្នាឃើញហ្នឹង។ មើលគ្នាឃើញអីចឹង វាដើរយើងដើរ។ ស៖ បានន័យថាយើងវៃជាមួយយួនហ្នឹង យួននៅកោះត្រល់វៃជាមួយ? ឆ៖ វាកោះត្រល់ យើងកោះសេះ"]។

767 ឯកសារ D54/47 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ.18 - 19 ["នៅខែ សីហា ឆ្នាំ ១៩៧៥ កងពលថ្មី ១៦៤ ត្រូវបានបង្កើតឡើង [...]ឆ.19៖ [...] កងពលធំលេខ ៣ បានប្តូរទៅជាកងពលធំលេខ ១៦៤ ហើយក៏មានការបង្កើតនូវកងពលតូចមួយទៀតដែរ គឺកងពលតូចលេខ ១៤០ ដែលជាកងជើងទឹក"]។ ឯកសារ D4.1.758 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក មិនស្គាល់ឈ្មោះ, EN 00387312, KH 01506014 ["កងវរសេនាធំលេខ ១៤០ នៃកងទ័ពជើងទឹក៖ នៅអំឡុងខែ សីហា ឆ្នាំ ១៩៧៥ កងពលធំលេខ ១៦៤ (កងពលធំលេខ ៣) បានបង្កើតកងវរសេនាធំលេខ ១៤០ នៃកងទ័ពជើងទឹក"]។ ឯកសារ D59/1/1.12 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ណុប ហាល, EN 00968419, KH 00926644 ["ដល់ពេលរំដោះហើយ បានយូរតិចនឹង បានគេបង្កើតវរសេនាធំ នៃក!ខាងនាវានឹងដាក់ ១៤០"]។ ឯកសារ D2/9 កំណត់ហេតុនៃការស្តាប់ចម្លើយ សយ ប៊ិន, ឆ.16។ ឯកសារ D54/36 កំណត់ហេតុនៃការស្តាប់ចម្លើយ ប្រាក់ សុខា, ឆ.36។ ឯកសារ D4.1.762 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក កាំ ម៉ែន, EN 00387328, KH 00742578។ សាក្សីមួយចំនួនមានការភាន់ច្រឡំចំពោះការបង្កើតកងវរសេនាធំនេះនៅឆ្នាំ ១៩៧៦ និងមិនមែននៅឆ្នាំ ១៩៧៥ ទេ: ឯកសារD114/95 កំណត់ហេតុនៃការស្តាប់ចម្លើយ យឹម ស្រៀង, ឆ.38, ឆ.51 - 52 ["នៅឆ្នាំ ១៩៧៦ គេបានបង្កើតវរសេនាធំ ១៤០ គឺជាអង្គភាពជើងទឹក។ ចំណែកវរសេនាធំលេខ ៦១ ៦២ ៦៣ គេទៅនៅតាមកោះ [...]ឆ. 51៖ [...] នៅពេលដែលបង្កើតវរសេនាធំលេខ ១៤០ ទើបមានកងទ័ពពីបូព៌ាមកចូលក្នុងកងទ័ពជើងទឹកនេះដែរ។ [...] ឆ.52៖ កាលពីនៅវរសេនាធំ ១៤០ គេបញ្ជូនកងទ័ពពីភូមិភាគបូព៌ាមានចំនួនប្រហែលជា ៥០០ ទៅ ៦០០ នាក់ ដើម្បីចូលជាមួយកងនាវាចរនេះដែរ"]។ ឯកសារ D114/65 កំណត់ហេតុនៃការស្តាប់ចម្លើយ ជេត ប៊ុណ្ណា, ឆ.16 ["នៅចុងបញ្ចប់ ការរៀនសូត្រ ប្រហែលជាខែ មករា ឬ កុម្ភៈ ឆ្នាំ ១០៧៦ មាស មុត បានប្រកាសការរៀបចំកងជើងទឹក ហៅថា វរសេនាធំ១៤០"]។

768 ឯកសារ D2/16 កំណត់ហេតុនៃការស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច, ឆ.17 ["វារំជើបរំជួល ច្របូកច្របល់ខ្លាំងនៅក្នុងកងពល ១៦៤ ហើយជាពិសេសគឺកងវរសេនាធំ ១៤០ ដែលមាន៤វរសេនាតូច ក្នុងនោះមាន វរសេនាតូច

របស់កងវរៈសេនាធំលេខ ១៤០ គឺដើម្បីការពារកោះ និងព្រំដែនសមុទ្រតាមរយៈការគ្រប់គ្រងរបស់ខ្លួនលើទូក និងកប៉ាល់ចម្បាំងរបស់កងទ័ពជើងទឹកទាំងអស់[769] ដែលឈរជើងនៅទីតាំងផ្សេងៗ[770]។

លេខ ១៤១ ១៤២ ១៤៣ និង ១៤៤។ ៤ វរសេនាតូចនេះ គឺជាកម្លាំងចម្រុះគ្នានៅកំពង់សោម និងកម្លាំងដែលបញ្ជូនមកពីភ្នំពេញ"]។ ពេលខ្លះ វរសេនាធំ ១៤០ បានហៅថា អង្គភាព ១៤០: ឯកសារ D2/9 កំណត់ហេតុនៃការស្ដាប់ចម្លើយ សយ ប៊ន, ឆ.16 ["នៅពេលនោះមានការរៀបចំកងទ័ពជើងទឹក។ គឺគេរើសចេញពីកងវរសេនាធំ ៦១ ៦២ ៦៣ របស់កងពល ១៦៤ រៀបចំទៅជាកង ១៤០ ដោយមានបញ្ចូលកងវរសេនាធំដែលបញ្ជូនមកពីបូព៌ា ដែលហៅថាកង ១៤០"]។ ឯកសារ D54/100 កំណត់ហេតុនៃការស្ដាប់ចម្លើយ ឡាយ ប៊ុនហាក់, ឆ.63 ["ស៖ នៅក្នុងកងវរសេនាធំលេខ ១៤០ តើមានយោធាមកពីណាខ្លះ? តើមានមកពីភូមិភាគបូព៌ាដែរទេ? ឆ.63៖ មានកម្លាំងចម្រុះគ្នា គឺមានទាំងអ្នកភូមិភាគបូព៌ា"]។ ឯកសារ D114/285 កំណត់ហេតុនៃការស្ដាប់ចម្លើយ ព្រំ សារ៉ាត់ (ប៊ុន សារ៉ាត់), ឆ.51 ["អង្គភាព១៦៤ មានកងវរសេនាធំជើងទឹក ១៤០ ជាយុទ្ធជន កម្មាភិបាល ដែលដកចេញពីអង្គភាពវរសេនាធំទាំងបីដែលនៅក្នុងកងពលលេខ ៣។ យុទ្ធជនទាំងអស់ហ្នឹង ប្រមូលមក តាមខ្ញុំចាំ ជាង ៧00នាក់"]។ ឯកសារ D54/36 កំណត់ហេតុនៃការស្ដាប់ចម្លើយ ប្រាក់ សុខា, ឆ.36។ ឯកសារ D4.1.762 សេចក្ដីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក កាំ ម៉ែន, EN 00387328, KH 00742578។

769 ឯកសារ D54/8 កំណត់ហេតុស្ដាប់ចម្លើយ ឌុល សុង, ឆ.15 ["កងវរសេនាធំ១៤០ ត្រូវបានចាត់តាំងការពារកោះ និងព្រំដែនទឹក"]។ ឯកសារ D114/95 កំណត់ហេតុនៃការស្ដាប់ចម្លើយ យឹម ស្រៀង, ឆ.40 ["យើងការពារតាមឆ្នេរសមុទ្រ គឺយើង ខ្លាចគិញចូលមកយកការណ៍"]។ ឯកសារ D54/79 កំណត់ហេតុនៃការស្ដាប់ចម្លើយ ណុប ហាល់, ឆ.3 ["នាវាចម្បាំងទាំង អស់ គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងវរសេនាធំ ១៤០"]។ ឯកសារ D54/113 កំណត់ហេតុនៃការស្ដាប់ចម្លើយ លៀង បៀ, ឆ.19 ["នៅកងវរសេនាធំ ១៤០ ហើយមានតួនាទីប្រយុទ្ធនៅលើដែនសមុទ្រ។ កប៉ាល់នៃកងទ័ពជើងទឹកទាំងអស់ គឺស្ថិតនៅក្រោមកងវរសេនាធំ ១៤០"]។ ឯកសារ D54/98 កំណត់ហេតុនៃការស្ដាប់ចម្លើយ ប៉ាង រ៉េត (ហៀង រ៉េត), ឆ.28 ["កងវរសេនាធំ ១៤០ គ្រប់គ្រងនាវាទាំងអស់"]។ ឯកសារ D114/83 កំណត់ហេតុនៃការស្ដាប់ចម្លើយ សុខ នាង, ឆ.19 ["វរសេនាធំ ១៤០ ទទួលបន្ទុកផ្នែកនាវា"]។

770 ឯកសារ D54/98 កំណត់ហេតុនៃការស្ដាប់ចម្លើយ ប៉ាង រ៉េត (ហៀង រ៉េត), ឆ.31, ឆ.33 ["នៅក្នុងកងវរសេនាធំ ១៤០ មានកប៉ាល់ ប្រយុទ្ធចិនប្រភេទ ១៣៦ មាន ៤គ្រឿង កប៉ាល់ប្រដេញ មាន១២ គ្រឿង នាវាប្រឆាំងនាវាមុជទឹកមាន២គ្រឿង។ [...] ឆ.33៖ កប៉ាល់ទាំងនោះចតនៅកន្លែងផ្សេងគ្នា ដូចជានៅកោះរ៉ុង"]។ ឯកសារ D54/33 កំណត់ហេតុនៃការស្ដាប់ចម្លើយ អ៊ឹង អុន, ឆ. 20 ["ពេលខ្លះ កប៉ាល់របស់ខ្ញុំចតនៅ អូរឈើទាល និងជួនពេលខ្លះចតនៅរាម ពេលនោះគឺស្រេចតែបញ្ជាមកពីកងពល"]។ ឯកសារ D59/1/1.8a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រំ សារ៉ាត់, EN 00974195, KH 00926375 ["ស៖ ចុះ ១៧-៨ ១៧-៩? ឆ៖ អាហ្នឹងនៅប្រចាំកោះរ៉ុង ពេលខ្លះកោះរ៉ុង ពេលខ្លះអូរឈើទាល"]។

244. សារឿន គឺជាមេបញ្ជាការដំបូងគេរបស់កងវរៈសេនាធំលេខ ១៤០[771] ស្ថិតក្រោមអំណាចផ្ទាល់របស់ **មាស មុត**[772]។ គាត់បានស្ថិតនៅក្នុងមុខតំណែងនេះរហូតដល់គាត់បានក្លាយជាមេបញ្ជាការ

---

771 ឯកសារ D54/10 កំណត់ហេតុនៃការស្ដាប់ចម្លើយ ម៉ី រ៉េត (សារ៉េត) ឆ.10, ឆ.22 ["ឆ.ខ្ញុំស្គាល់ឈ្មោះ សារឿន ពេលដែល កងវរសេនាធំ ១៤០ បង្កើតជាលើកដំបូង សារឿន គឺជាមេបញ្ជាការរបស់វរសេនាធំនោះ។ [...] ឆ.22៖ បញ្ជាក់ការយល់ឃើញក្នុងឯកសារលេខ D1.3.14.2, EN 00233944-45, KH 00161788-89: "ក្នុងឯកសារទី២ គេនិយាយអំពីផែនការយកនាវាលេខ ០២ ទៅជួសជុល ឈ្មោះ រឿន នៅក្នុងសារទូរលេខនេះ គឺ សារឿន មេបញ្ជាការកងវរសេនាធំ ១៤០"]។ ឯកសារ D114/103 កំណត់ហេតុនៃការស្ដាប់ចម្លើយ លៀត ឡូន, ឆ.36 ["ស៖ អ្នកណាជាមេបញ្ជាការកងទ័ពជើងទឹក? ឆ.36៖ សារឿង តែគាត់បាត់ខ្លួន ហើយក្រោយមក សេង ជាអ្នកកាន់កងទ័ពជើងទឹក។"]។ ឯកសារ D54/98 កំណត់ហេតុនៃការស្ដាប់ចម្លើយ ហ៊ាង រ៉េត (ហៀង រ៉េត), ឆ.28 ["សារឿន ជាមេបញ្ជាការកងវរសេនាធំ ១៤០។ ក្រោយមក សារឿន ត្រូវបានជំនួសដោយ ទឹម សេង។"]។ ឯកសារ D59/1/1.12 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ណុប ហាល, EN 00968421, KH 00926645 ["សារឿន ហ្នឹងប្រធាន ហើយ សំ ហ្នឹង មកពីខាង តាឌឹម ហ្នឹង បញ្ជាតា អនុប្រធាន ហើយបាន តាសេង ដល់នេះគេដក តាសំ ហ្នឹងគេចាប់ទៅ បាទ!គេចាប់ទៅជំនាន់ តាឌឹម និង តាសារឿន"]។ ឯកសារ D4.1.758 សេចក្ដីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក មិនស្គាល់ឈ្មោះ, EN 00387312, KH 01506014 ["មេបញ្ជាការកងវរសេនាធំនេះ មានឈ្មោះ (សារឿន) (ស្លាប់) ដែលជាមន្ត្រីនយោបាយរបស់កងវរសេនាធំនេះផងដែរ។"]។ ឯកសារ D114/132 កំណត់ហេតុនៃការស្ដាប់ចម្លើយ ម៉ៅ វ៉ាន់, ឆ.176 - 178 ["ស៖ យើងចង់សួរលោកពីកងវរសេនាធំ ១៤០ តើនរណាជាមេបញ្ជាការកងវរសេនាធំ ១៤០ នេះ? ឆ.176៖ ឈ្មោះ សារឿន។ ស៖ យើងបានទទួលព័ត៌មានថា ទឹម សេង គាត់ក៏ធ្លាប់ជាមេបញ្ជាការវរសេនាធំលេខ ១៤០ ហ្នឹងដែរ។ តើលោកមានដែលធ្លាប់ឮឈ្មោះគាត់ដែរទេ? ឆ.177 ៖ ខ្ញុំមិនត្រឹមតែធ្លាប់ឮឈ្មោះគាត់ទេ ខ្ញុំថែមទាំងស្គាល់គាត់ទៀតផង គាត់ជាអនុរបស់ សារឿន។ [...] ឆ.178៖ [...] នៅក្នុងវរសេនាធំ ១៤០ មានតែឈ្មោះ សារឿន, សេង និង ហាន។"]។ ឯកសារ D54/43 កំណត់ហេតុនៃការស្ដាប់ចម្លើយ លុន សេង, ឆ.2 ["មាស មុត គឺជាស្នងការនយោបាយរបស់កងពលលេខ ៣។ នៅក្នុងកងពលលេខ ៣ មាន ៣វរសេនាធំ ហើយមានមេបញ្ជាការទទួលខុសត្រូវរៀងៗខ្លួន។ ខ្ញុំនៅចាំតែប្រធានវរសេនាធំខ្ញុំគឺ បសារឿន។"]។ ឯកសារ D2/9 កំណត់ហេតុនៃការស្ដាប់ចម្លើយ សយ ប៊ិន, ឆ.34 ["ស៖ កាលនោះ តើនរណាខ្លះត្រូវបានគេចាត់តាំងធ្វើជាប្រធាន អនុ និង សមាជិក នៃកង ១៤០? ឆ.34៖ ក្នុងកងនោះ ខ្ញុំមិនបានដឹងថា គេចាត់តាំងយ៉ាងម៉េចទេ។ ប៉ុន្តែ ក្នុងកងនេះខ្ញុំដឹងថា សារឿន ជាប្រធាន ក្រោយពី សារឿន បានបាត់ខ្លួន ឬផ្លាស់ប្ដូរចេញទៅ"]។ ឯកសារ D114/48 កំណត់ហេតុនៃការស្ដាប់ចម្លើយ សុខ ង៉ុន, ឆ.20 ["ស៖ តើមេបញ្ជាការកងវរសេនាធំ ១៤០ ឈ្មោះអ្វី? ឆ.20៖ ឈ្មោះ តាសារឿន [...] និង តាហ៊ិន"]។ ឯកសារ D54/17 កំណត់ហេតុនៃការស្ដាប់ចម្លើយ សយ ប៊ិន, ឆ.2។

772 ឯកសារ D54/87 កំណត់ហេតុនៃការស្ដាប់ចម្លើយ ព្រំ សារ៉ាត់, ឆ.56 ["មាស មុត ជាអ្នកបញ្ជាពីកងពលទៅកងវរសេនាធំ ឈ្មោះ សារឿន ហើយ សារឿន បញ្ជាបន្តទៅកងវរសេនាតូច ឈ្មោះ ហាន ហើយ ហាន បញ្ជាបន្តមកខ្ញុំ ដែលមេបញ្ជាការកងអនុសេនាធំ"]។

រងនៃកងពលធំនៅក្នុងឆ្នាំ ១៩៧៧ បន្ទាប់ពី ឌឹម ត្រូវបានចាប់ខ្លួន[773]។ សំ (មកពីភូមិភាគបូព៌ា) គឺជាមេបញ្ជាការរងដំបូងគេក្នុងរយៈពេលខ្លី ដោយសារគាត់ត្រូវបានចាប់ខ្លួន ហើយក្រោយមកត្រូវបានបង្ខំឲ្យសារភាពនៅមន្ទីរ ស-២១ នៅដើមខែ កក្កដា ឆ្នាំ ១៩៧៦[774] មុនពេលមានការដំឡើង

---

773 ឯកសារ D54/73 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ, ឆ.6, ឆ.9 ["សៈ តើអ្នកណាជាអនុ មាស មុត? ឆ.6៖ ខ្ញុំមិនដឹងថា អ្នកណាជាមេបញ្ជាការ អ្នកណាជាអនុទេ ប៉ុន្តែនៅក្នុងគណៈរបស់គាត់មានគ្នា៣នាក់ គឺមាន តាមុត តាសារឿន និង តាញ៉ាន់។ [...] ឆ.9៖ តាសារឿន ក្រោយមកត្រូវបានបញ្ជូនទៅធ្វើការនៅផែកំពង់សោម"]។ ឯកសារ D54/81 កំណត់ហេតុនៃការស្តាប់ចម្លើយ ហ៊ីង អ៊ុច, ឆ.14 ["ក្រោយមក យ៉ាន មកកាន់កងពល១៦៤ជាមួយ អ៊ំមុត ដែរ។ [...] សារឿនមកជំនួស យ៉ាន។ សារឿន មកពីកងវរសេនាធំ ១៤០ ប្រហែលជាមកជំនួស តាយ៉ាន។"]។ ឯកសារ D54/82 កំណត់ហេតុនៃការស្តាប់ ចម្លើយ ហ៊ីង អ៊ុច, ឆ.17 ["កាលពីម្សិលមិញ ខ្ញុំបាននិយាយអំពីឈ្មោះ សារឿន រួចទៅហើយ។ ខ្ញុំសង្ស័យថា ឈ្មោះ រឿង និង ឈ្មោះ សារឿន ជាមនុស្សតែមួយ។ ក្នុងចំណោមកម្មាភិបាល គេឮឈ្មោះគាត់ច្រើន ហើយខ្ញុំក៏ស្គាល់គាត់ច្បាស់ដែរ"]។ ឯកសារ D54/98 កំណត់ហេតុនៃការស្តាប់ចម្លើយ ហ៊ាង រ៉េត (ហៀងរ៉េត), ឆ.28 ["សារឿន ជាមេបញ្ជាការកងវរសេនាធំ ១៤០។ ក្រោយមក សារឿន ត្រូវបានជំនួសដោយ ទឹម សេង"]។ ឯកសារ D54/23 កំណត់ហេតុនៃការស្តាប់ចម្លើយ ប៉ាក សុក, ឆ.1 ["តាសារឿន (ស្លាប់ អនុម្នាក់របស់ មាស មុត ដែលទទួលខុសត្រូវផ្នែកយោធា។ មាស មុត គឺជាស្នងការនយោបាយ ទទួលខុសត្រូវរួម"]។ ឯកសារ D114/95 កំណត់ហេតុនៃការស្តាប់ចម្លើយ យឹម ស្រៀង, ឆ.224 - 225 ["វរសេនាធំ ១៤០ មានឈ្មោះ សារឿន (ស្លាប់) ជាប្រធាននយោបាយ បន្ទាប់ពី សារឿន ឈ្មោះ សេង (ស្លាប់) ជាអនុរបស់ សារឿន ហើយ សំ ជាសមាជិករបស់ សេង។ [...] ឆ. 225៖ នៅពេល សារឿន ត្រូវបានតម្លើងឋានៈទៅថ្នាក់កងពល ឈ្មោះ សេង បានឡើងជំនួស សារឿន"]។

774 ឯកសារ D114/65 កំណត់ហេតុនៃការស្តាប់ចម្លើយ ជេត ប៊ុណ្ណា, ឆ.12 ["តាសំ ដែលមកពីភូមិភាគបូព៌ា គឺជាអនុ ប៉ុន្តែ តាសំ ត្រូវបានកម្ទេចនៅពេលនោះ"]។ ឯកសារ D54/97 កំណត់ហេតុនៃការស្តាប់ចម្លើយ ខឹម យ៉ាត, ឆ.5 ["ឌឹម ទៅកំពង់សោមមុនខ្ញុំ និង សំ ទៅទៀត។ នៅកំពង់សោម ឌឹម ជាអនុមេបញ្ជាការកងពល១៦៤។ សំ នៅកងវរសេនាធំ"]។ ឯកសារ D59/1/1.12 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ណុប ហាល, EN 00968421, KH 00926645 ["សារឿន ហ្នឹងប្រធាន ហើយ សំ ហ្នឹង មកពីខាង តាឌឹម ហ្នឹង បញ្ជាតា អនុប្រធាន ហើយបាន តាសេង ដល់នេះគេដក តាសំ ហ្នឹងគេចាប់ទៅ បាទ!គេចាប់ទៅជំនាន់ តាឌឹម និង តាសារឿន"]។ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសស-២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត [កំណត់អត្តសញ្ញាណនៅលេខរៀងទី ១៤៥៦១ ថា សំ ជាវរសេនាធំ ១៤០ កងពល១៦៤]។ ឯកសារ D9.3 បញ្ជីអ្នកទោសមន្ទីរស ២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត មកពីកងពល ១៦៤ លេខរៀងទី ៣៩, EN 00679643។ ឯកសារ D1.3.1.8 ចម្លើយសារភាពពីមន្ទីរស-២១ សំ, ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៧៦។ ឯកសារ D1.3.5.4 បញ្ជីឈ្មោះមនុស្សដែលជាប់ក្នុងចម្លើយខ្មាំងពីមន្ទីរស-២១, EN 01149197, KH 00161749 [កំណត់អត្តសញ្ញាណលេខរៀងទី១ ឈ្មោះ សារឿន ជាស្នងការវរសេនាធំ ១៤០។ លេខរៀងទី២ ឈ្មោះ សំ ជាបញ្ជាការវរសេនាធំ ១៤០។ លេខរៀងទី៣ ឈ្មោះ សេង ជាអនុបញ្ជាការវរសេនាធំ ១៤០]។ សាក្សីឈ្មោះ យឹម ស្រៀង មានការយល់ច្រឡំថា សំ ជំនួសតំណែង

តំណែងរបស់ សារឿន។ សេង គឺជាមេបញ្ជាការរងទីពីរនៃកងវរៈសេនាធំលេខ ១៤០ ចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៦[775]។ បន្ទាប់ពីការចាប់ខ្លួន សំ និងការដំឡើងតំណែងរបស់ សារឿន រួចមក ទីម សេង បានក្លាយជាមេបញ្ជាការកងវរៈសេនាធំលេខ ១៤០ ជាផ្លូវការរយៈពេលប្រហែលមួយឆ្នាំ គិតចាប់ពីពាក់កណ្ដាលឆ្នាំ ១៩៧៧[776] និងចប់មុខតំណែងនេះ បន្ទាប់ពីទទួលបានការបណ្ដុះបណ្ដា

---

សេង: ឯកសារ D114/95 កំណត់ហេតុនៃការស្ដាប់ចម្លើយ យឹម ស្រឿង, ឆ.225 [“នៅពេល សារឿន ត្រូវបានតម្លើងឋានៈទៅថ្នាក់កងពល ឈ្មោះ សេង បានឡើងជំនួស សារឿន”]។

775 សេង ប្រហែលជាអ្នកជំនួសតួនាទីរបស់ សំ ជាមេបញ្ជាការរង ក្រោយពីគេចាប់ខ្លួន សំ នៅចុងឆ្នាំ ១៩៧៦ ឬប្រហែលជាមេបញ្ជាការរងទី២ ចាប់តាំងពីការបង្កើតកងវរសេនាធំ ១៤០ នៅខែ សីហា ១៩៧៥: ឯកសារ D54/10 កំណត់ហេតុនៃការស្ដាប់ចម្លើយ ម៉ើ រ៉េត (សារ៉េត), ឆ.9 [“បន្ទាប់ពីកងទ័ពជើងទឹកត្រូវបានបង្កើតឡើង ឈ្មោះ សេង ក្លាយជាអនុមេបញ្ជាការវរសេនាធំ ១៤០”]។ ឯកសារ D114/132 កំណត់ហេតុនៃការស្ដាប់ចម្លើយ ម៉ៅ រ៉ាន់, ឆ.177 - 178 [“ស៖ យើងបានទទួលព័ត៌មានថា ទីម សេង គាត់ក៏ធ្លាប់ជាមេបញ្ជាការវរសេនាធំលេខ ១៤០ ហ្នឹងដែរ។ តើលោកមានដែលធ្លាប់ឮឈ្មោះគាត់ដែរទេ? ឆ.177៖ ខ្ញុំមិនត្រឹមតែធ្លាប់ឮឈ្មោះគាត់ទេ ខ្ញុំថែមទាំងស្គាល់គាត់ទៀតផងគាត់ជាអនុរបស់ សារឿន។ […] ឆ.178៖ […] នៅក្នុងវរសេនាធំ ១៤០ មានតែឈ្មោះ សារឿន, សេង និង ហន”]។ ឯកសារ D114/95 កំណត់ហេតុនៃការស្ដាប់ចម្លើយ យឹម ស្រឿង, ឆ.222 - 224 [“ស៖ តើ សេង ទៅណា បានជាលែងធ្វើជាមេបញ្ជាការវរសេនាធំ៦១? ឆ.222៖ ពីព្រោះ សេង ត្រូវបានគេដកទៅវរសេនាធំលេខ ១៤០ វិញ។ ស៖ តើ សេង នៅវរសេនាធំ ១៤០ គាត់មានតួនាទីអ្វីដែរ? ឆ.223៖ សេង មានឋានៈធំជាង ហន ទៅទៀត។ ស៖ តើនៅក្នុងវរសេនាធំ ១៤០ មានថ្នាក់ដឹកនាំធំៗណាខ្លះដែរទេ សូមលោកជួយរៀបរាប់? ឆ.224៖ វរសេនាធំ ១៤០ មានឈ្មោះ សារឿន (ស្លាប់) ជាប្រធាននយោបាយ បន្ទាប់ពី សារឿន ឈ្មោះ សេង (ស្លាប់) ជាអនុរបស់ សារឿន ហើយ សំ ជាសមាជិករបស់ សេង។ […] ឆ. 225៖ នៅពេល សារឿន ត្រូវបានតម្លើងឋានៈទៅថ្នាក់កងពល ឈ្មោះ សេង បានឡើងជំនួស សារឿន។”]។ ឯកសារ D59/1/1.12 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ណុប ហាល, EN 00968421, KH 00926645 [“ស៖ ខាងវរសេនាធំ ១៤០ មាន តាសេង គាត់អ្នកដឹកនាំ? […] ឆ៖ ដំបូងបំផុតនឹង មានឈ្មោះ តាសេង […] គាត់អនុគេទេ។”]។ ឯកសារ D1.3.5.4 បញ្ជីឈ្មោះមនុស្សដែលជាប់ក្នុងចម្លើយខ្មាំងពីមន្ទីរស-២១, EN 01149197, KH 00161749 [កំណត់អត្តសញ្ញាណលេខរៀងទី១ ឈ្មោះ សារឿន ជាស្នងការវរសេនាធំ ១៤០។ លេខរៀងទី២ ឈ្មោះ សំ ជាបញ្ជាការវរសេនាធំ ១៤០។ លេខរៀងទី៣ ឈ្មោះ សេង ជាអនុបញ្ជាការវរសេនាធំ ១៤០]។

776 ឯកសារ D54/98 កំណត់ហេតុនៃការស្ដាប់ចម្លើយ ហ៊ាង រ៉េត (ហៀង រ៉េត), ឆ.28 [“សារឿន ជាមេបញ្ជាការកងវរសេនាធំ ១៤០។ ក្រោយមក សារឿន ត្រូវបានជំនួសដោយ ទីម សេង”]។ ឯកសារ D114/103 កំណត់ហេតុនៃការស្ដាប់ចម្លើយ លៀត ឡូន (ណាំ ឡូន), ឆ.36, ឆ.88 [“ស៖ តើអ្នកណាជាមេបញ្ជាការកងទ័ពជើងទឹក? ឆ.36៖ សារឿន តែគាត់បាត់ខ្លួន ហើយក្រោយមក សេង ជាអ្នកកាន់កងទ័ពជើងទឹក។ […] ស៖ តើបញ្ជាការកងវរសេនាធំផ្សេងទៀតឈ្មោះអ្វី? ឆ.88៖ ទីម សេង”]។ ឯកសារ D114/86 កំណត់ហេតុនៃការស្ដាប់ចម្លើយ ជេត ប៊ុណ្ណា, ឆ.26 [“កាលខ្ញុំនៅក្នុងកងទ័ពជើងទឹកនៅឡើយ តាសេង គឺជាមេបញ្ជាការវរសេនាធំ ១៤០”]។ ឯកសារ D114/66 កំណត់ហេតុនៃការ

លបច្ចេកទេសមួយរយៈនៅប្រទេសចិន[777] បន្ទាប់មកគាត់ទទួលបានការតែងតាំងឱ្យធ្វើជាមេបញ្ជាការរងកងពលធំលេខ ១៦៤ នៅក្នុងខែ មិថុនា-កក្កដា ឆ្នាំ ១៩៧៨[778]។ បន្ទាប់ពី ទីម សេង ត្រូវបានផ្ទេរទៅគណៈកងពលធំលេខ ១៦៤ ហាន ត្រូវបានដំឡើងតួនាទីទៅជាមេបញ្ជាការកងវរៈសេនាធំលេខ ១៤០[779]។ មឿន (ប្រធានកងវរៈសេនាតូចលេខ ១៤១ អតីតមេបញ្ជាការកងវរៈសេនាតូច

---

ស្តាប់ចម្លើយ ជេត ប៊ុណ្ណា, ឆ.1 ["តាសេង បានក្លាយទៅជាមេបញ្ជាការកងវរសេនាធំ ១៤០ ហើយទទួលខុសត្រូវនៅកន្លែងអូរឈើទាល"]។ ឯកសារ D54/49 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ.26 ["កប៉ាល់ កប៉ាល់ចម្បាំងទាំងនោះ ជាកប៉ាល់វរសេនាធំឯករាជ្យ ១៤០ ដែលមាន ទីម សេង ជាមេបញ្ជាការ"]។ ឯកសារ D54/99.1 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយ មជ្ឈមណ្ឌលឯកសារកម្ពុជា ឡាយ ប៊ុនហាក់, EN 01115974, KH 00990769 ["ស៖ ទីបញ្ជាការវរសេនាធំរបស់ពីណាគេ? ឆ៖ ឈ្មោះ អឺ! ទីម សេង"]។ ឯកសារ D59/1/1.12 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ណុប ហាល, EN 00968421, KH 00926645 [" តាសារឿន គេដកមកគ្រប់គ្រងផែ […] ឡើង តាសេងរហូត […] ១៤០ ក៏នៅលើគាត់"]។ ឯកសារ D59/1/1.7a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយ មជ្ឈមណ្ឌលឯកសារកម្ពុជា ម៉ា ឈឿន, EN 00969932, KH 00926309 ["ស៖ […] សេង គាត់ធ្វើអីទៅ? ឆ៖ សេង វរសេនាធំដែរហ្នឹង វរសេនាធំជើងទឹក។ វរៈជើងទឹក គេរៀបចំថ្មី ហើយអាហ្នឹងវារៀបចំជើងទឹកហើយ"]។ ឯកសារ D114/65 កំណត់ហេតុនៃការស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.12។

[777] នៅពេលមួយរវាងពីពាក់កណ្តាលឆ្នាំ ១៩៧៧ ដល់ ពាក់កណ្តាលឆ្នាំ ១៩៧៨ ទីម សេង បានចាកចេញទៅរៀនបច្ចេកទេសនៅប្រទេសចិន (ប្រហែលជាពីរ ឬបីសប្តាហ៍ ឬមួយខែ): ឯកសារ D114/103 កំណត់ហេតុនៃការស្តាប់ចម្លើយ លៀត ឡូន (ណាំ ឡូន), ឆ.20 , ឆ.22 - 23, ឆ.52 - 53 ["ទីម សេង ជាអ្នកគ្រប់គ្រងកងទ័ពជើងទឹក […] ឆ. 22៖ ទីម សេង ក៏ត្រូវបានបញ្ជូនទៅរៀននៅប្រទេសចិនដែរ។ ស៖ ពេលគេបញ្ជូន សេង ទៅរៀននៅចិន តើអ្នកណាជាអ្នកកាន់ទ័ពជំនួសគាត់? ឆ.23៖ មានរងជាច្រើននាក់ ហើយមានម្នាក់ឈ្មោះ ហាន។ […] ស៖ ពេលលោកនៅចិន តើអ្នកណាជាមេរបស់លោក? ឆ.52៖ ទីម សេង។ ស៖ កាលហ្នឹង ទីម សេង ចេញទៅរៀនដំណាលលោកដែរឬ? ឆ.53៖ បាទ! ចេញដំណាលគ្នា"]។ ឯកសារ D114/215 កំណត់ហេតុនៃការស្តាប់ចម្លើយ មាស អ៊ឹម, ឆ. 32 ["ទីម សេង យើងដឹងតាមរយៈទូទៅ គាត់បានទៅរៀននៅស្រុកចិន ខាងបច្ចេកទេសយោធាជើងទឹក។ ដល់ពេលត្រឡប់មកវិញគាត់ប្រចាំការនៅកន្លែងកងពល"]។

[778] សូមមើល កថាខណ្ឌ ២២៤ (គ)។

[779] ឯកសារ D114/95 កំណត់ហេតុនៃការស្តាប់ចម្លើយ យឹម ស្រៀង, ឆ.64, ឆ.67, ឆ.225 - 226 ["មានឈ្មោះ ង៉ែត ឈ្មោះ ឌឹម ឈ្មោះ យ៉ាន ឈ្មោះ ឆាន និង ឈ្មោះ សុខ ជាដើម ដែលគេចោទថា ជាគិញវៀតណាម ឬក៏សេអ៊ីអា។ […] ឆ.67៖ ខ្ញុំដឹងពីព្រោះគេបានហៅអ្នកទាំងនោះយកទៅ ហើយបន្ទាប់ពី ពីរបីថ្ងៃក្រោយមក ប្រធានអង្គភាពវរសេនាធំ ១៤០ ឈ្មោះ ហាន បានប្រជុំប្រាប់ថា ទាំងនោះជាខ្មាំងស៊ីរូងផ្ទៃក្នុង។ […] ឆ.225៖ ក្រោយមកនៅពេលដែល សេង និង សំ ត្រូវបានគេដកទៅកន្លែងផ្សេង ប្រហែលជាទៅកងពលហើយ ហើយ ហាន បានឡើងជាមេបញ្ជាការវរសេនាធំលេខ ១៤០។ […] ឆ.226៖ មេ បញ្ជាការខ្ញុំ ហាន បានប្រាប់ខ្ញុំថា អ្នកប៉ុន្មាននាក់ខាងលើនេះ សុទ្ធតែជាអ្នកក្បត់

ពិសេសលេខ ៤៥០) ឆាវ, ឈិន សម្បត្តិ ហៅ បូ និង អ៊ួច ធ្វើការងារនៅក្រោមបញ្ជារបស់ហាន[780]។ ទោះជាយ៉ាងណា ប៉ាក សុខ បានអះអាងថា បូ បានក្លាយជាមេបញ្ជាការឃោធាកងវរៈសេនាធំលេខ ១៤០ រហូតដល់ចុងបញ្ចប់នៃរបបនេះ[781]។

---

ក្នុងជួរកងទ័ព"]។ ឯកសារ D114/103 កំណត់ ហេតុនៃការស្តាប់ចម្លើយ លៀត ឡូន (ណាំ ឡូន), ឆ.23 ["ស៖ ពេលគេបញ្ជូន សេង ទៅរៀននៅចិន តើអ្នកណាជាអ្នកកាន់ទ័ពជំនួសគាត់? ឆ.23៖ មានរងច្រើននាក់ ហើយមានម្នាក់ឈ្មោះហាន"]។ ឯកសារ D114/132 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ៅ រ៉ាន់, ឆ.178 ["នៅក្នុងវរសេនាធំ ១៤០ មានតែឈ្មោះ សារឿន, សេង និង ហាន"]។ ឯកសារ D54/98 កំណត់ហេតុនៃការស្តាប់ចម្លើយ ហ៊ាង រ៉េត (ហៀង រ៉េត), ឆ.28 ["សារឿន ជាមេបញ្ជាការកងវរសេនាធំ ១៤០។ ក្រោយមក សារឿន ត្រូវបានជំនួសដោយ ទឹម សេង។ ក្រោយពេល ទឹម សេង ត្រូវបានឡើងជាប្រធានកងពល១៦៤ ជំនួស មាស មុត នៅឆ្នាំ ១៩៧៩ នៅពេលដែលមានការប្រយុទ្ធគ្នាខ្លាំងជាមួយ វៀតណាម តាហាន ត្រូវបានឡើងជាមេបញ្ជាការកងវរសេនាធំ ១៤០ ជំនួស ទឹម សេង"]។ ឯកសារ D114/48 កំណត់ហេតុនៃការស្តាប់ចម្លើយ សុខ ង៉ុន, ឆ.20 ["ស៖ តើមេបញ្ជាការកងវរសេនាធំ ១៤០ ឈ្មោះអ្វី? ឆ.20៖ ឈ្មោះ តាសារឿន [...] និង តាហ៊ាន"]។ ឯកសារ D54/100 កំណត់ហេតុនៃការស្តាប់ចម្លើយ ឡាយ ប៊ុនហាក់, ឆ.34 ["មេបញ្ជាការ [វរសេនាធំ ១៤០] ឈ្មោះ ហាន"]។ ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974098, KH 00926542 - 00926543 ["និយាយទៅមាន ទឹម សេង តែស្លាប់បាត់ដែរ មុនដំបូង គាត់គ្រប់គ្រងជើងទឹក ដល់ក្រោយមក គាត់មកគ្រប់ គ្រងកងពល ១៦៤ ហើយ មាស មុត គាត់ឡើងមកធ្វើជាមេបញ្ជាការនៅភ្នំពេញ ទឹម សេង ឡើងមេបញ្ជាការ ១៦៤ ហើយ ហាន និង គាត់មកកាន់កងពលជើងទឹក ១៤០"]។ សូមមើល ចំណុចផ្ទុយគ្នាខ្លះ ឯកសារ D54/113 កំណត់ហេតុនៃការស្តាប់ចម្លើយ លៀង បៀ, ឆ.28 - 29 ["ប្រធានកងវរសេនាធំ ១៤០ ឈ្មោះ ហាន [...] ឆ.29៖ [...] គាត់ធ្វើជាប្រធាន នៅពេលដែលខ្ញុំទៅដល់នៅឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៩"]។

780 ឯកសារ D114/95 កំណត់ហេតុនៃការស្តាប់ចម្លើយ យឹម ស្រៀង, ឆ.76, ឆ.223, ឆ.225 ["បន្ទាប់ពី ហាន មក មានឈ្មោះ មឿន ជាអនុរបស់ ហាន។ ឈ្មោះ ឆាវ ជាអនុរបស់ មឿន និង អួច នៅក្រោម ឆាវ។ ឈ្មោះ បូ ក៏នៅក្នុងចំណោម គណៈកម្មាធិការវរសេនាធំហ្នឹងដែរ។ [...] ឆ.223៖ សេង មានឋានៈធំជាង ហាន ទៅទៀត។ [...] ឆ.225 ៖ ហាន បានឡើងជាមេបញ្ជាការវរសេនាធំលេខ ១៤០។ ចំណែក មឿន ឆាវ អួច និង បូ គឺនៅក្រោម ហាន"]។ ឯកសារ D54/10 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ី រ៉េត (សារ៉េត), ឆ.22 ["ឯឈ្មោះ មឿន ពីដើមជាអតីតមេបញ្ជាការកងពិសេសរបស់ មាស មុត ហើយនៅក្នុងនោះគាត់ជាមេបញ្ជាការវរសេនាតូច ១៤១ នៃវរសេនាធំ ១៤០"]។ ឯកសារ D114/132 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ៅ រ៉ាន់, ឆ.178 - 179 ["នៅក្នុងវរសេនាធំ ១៤០ មានតែឈ្មោះ សារឿន, សេង និង ហាន។ [...] យើងមានព័ត៌មានថា ម្នាក់ឈ្មោះ ឈិន សម្បត្តិ ហៅ បូ គឺជាមេបញ្ជាការរបស់វរសេនាធំលេខ ១៤០ ដែរ។ តើលោកស្គាល់គាត់ទេ? ឆ.179៖ ខ្ញុំស្គាល់ បូ គាត់មិនមែនមេបញ្ជាការនៅក្នុងកងវរសេនាធំលេខ ១៤០ ទេ តែគាត់ជាមេបញ្ជាការនៅតាមទូក"]។ ឯកសារ D54/100 កំណត់ហេតុនៃការស្តាប់ចម្លើយ ឡាយ ប៊ុនហាក់, ឆ.34 ["មេបញ្ជាការ [វរសេនាធំ ១៤០] ឈ្មោះ ហាន (ស្លាប់) ហើយអនុរបស់គាត់ឈ្មោះ ឆាវ (ស្លាប់ ១៩៧៩)"]។ ឯកសារ D2/9 កំណត់ហេតុនៃការស្តាប់ចម្លើយ សយ ប៊ន, ឆ.34 ["ក្រោយពី សារឿន [...]

245. កំពង់ផែអូរឈើទាលបានក្លាយជាទីតាំងបញ្ជាការរបស់កងវរៈសេនាធំលេខ ១៤០[782]។ ការបណ្តុះបណ្តាលកងទ័ពជើងទឹក ត្រូវបានធ្វើឡើងជាប្រចាំឆ្នាំនៅឆ្នេរអូរឈើទាលសម្រាប់សមាជិករបស់

---

គណៈដឹកនាំកងមានឈ្មោះ ហាន, បូ, និង មឿន"]។ ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយ ជេត ប៊ុណ្ណា, ឆ.2 ["មឿន គឺជាមេបញ្ជាការវរសេនាតូច ១៤១ ដែលស្ថិតនៅក្នុងកងជើងទឹក វរសេនាធំ ១៤០។ មឿន នៅផែអូរឈើទាលនោះរហូត។ ក្រោយមក ក្នុងឆ្នាំ ១៩៧៧ ពេលដែលគេដកខ្ញុំចេញពីកងជើងទឹក ខ្ញុំឃើញ មឿន នៅទីនោះនៅឡើយ។ ពេលនោះ គាត់គឺជាបញ្ជាការកប៉ាល់មួយគ្រឿង ដែលខ្ញុំនៅចាំថា កប៉ាល់របស់គាត់លេខ ១០៣។"]។ ឯកសារ D54/49 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ.27 ["បូ ជាអតីតគណៈកងវរសេនាធំឯករាជ្យ ១៤០។ នៅពេលនោះ គាត់ទទួលខុសត្រូវកប៉ាល់បណ្តែត"]។ ឯកសារ D114/103 កំណត់ហេតុនៃការស្តាប់ចម្លើយ លៀត ឡូន (ណាំ ឡូន), ឆ.88 - 89 ["សៈ តើមេបញ្ជាការវរសេនាធំឈ្មោះអ្វី? ឆ.88៖ ទឹម សេង។ សៈ បញ្ជាការកងវរសេនាធំផ្សេងទៀតឈ្មោះអ្វី? ឆ.89៖ ហាន (ស្លាប់) និង បូ"]។ ឯកសារ D4.1.758 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក មិនស្គាល់ឈ្មោះ, EN 00387312, KH 01506014 ["មឿន គឺជាសមាជិកអចិន្ត្រៃយ៍របស់គណៈកម្មាធិការបញ្ជាការកងវរសេនាធំ"]។ យោងទៅលើ តួនាទីរបស់ មឿន ពីមុននៅកងពលទី៣ ដែលជាមេបញ្ជាការកងវរសេនាតូចពិសេសលេខ ៤៥០: ឯកសារ D54/7 កំណត់ហេតុនៃការស្តាប់ចម្លើយ ឌុល សុង, ឆ.8 ["មឿន ជាស្នងការកងវរសេនាតូចពិសេស "]។

781 ឯកសារ D54/23 កំណត់ហេតុនៃការស្តាប់ចម្លើយ ប៉ាក សុក, ឆ.1 - 2 ["ឈ្មោះ សេង គឺអនុម្នាក់ទៀតរបស់ តាមាស មុត។ [...] ខ្ញុំធ្លាប់ឃើញគាត់បញ្ជាកប៉ាល់។ [...] អនុរបស់ មាស មុត ម្នាក់ទៀតឈ្មោះ បូ។ បូ គឺជាមេបញ្ជាការយោធាម្នាក់នៅក្នុងកងទ័ពជើងទឹកវរសេនាធំ ១៤០។ បូ គឺជាប្រធានវរសេនាធំលេខ ១៤០ ទទួលខុសត្រូវខាងផ្នែកនាវាទាំងអស់របស់កងទ័ព ជើងទឹកលេខ ១៤០។ ខ្ញុំ គឺជានិរសាររបស់ បូ នៅក្នុងកងទ័ពជើងទឹក ចាប់ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៨។ [...] ឆ.2 [...] ឆាវ គឺជាអនុរបស់ បូ [...] អួច គឺជាសមាជិក [...] បូ, ឆាវ, និង អួច គឺជាបញ្ជាការកងទ័ពជើងទឹក"]។

782 ឯកសារ D114/285 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រំ សារ៉ាត់ ប៊ុ(ន សារ៉ាត់) ឆ.141 ["វរសេនាធំ ១៤០ បោះទីតាំងនៅ អូរឈើទាល"]។ ឯកសារ D54/113 កំណត់ហេតុនៃការស្តាប់ចម្លើយ លៀង ប៉ៀ, ឆ.18 ["សៈ ពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៩ នៅពេលដែលលោកធ្វើជាកងទ័ពនៅកងវរសេនាធំ ១៤០ តើកងរបស់លោកឈរជើងនៅកន្លែងណា? ឆ.18៖ កងវរសេនាធំ ១៤០ របស់ខ្ញុំ ឈរជើងនៅអូរឈើទាល"]។ ឯកសារ D54/17 កំណត់ហេតុនៃការស្តាប់ចម្លើយ សយ ប៊ិន, ឆ.2 ["ផ្ទះនេះ គឺជាកន្លែងធ្វើការរបស់មេបញ្ជាការវរសេនាធំ ១៤០ ឈ្មោះ សាមឿន។ ក្រោយពី សាមឿន បាត់ខ្លួន គេបានប្រើ ផ្ទះនេះជាកន្លែងរបស់ក្រុមទូរលេខរបស់វរសេនាធំ ១៤០"]។ ឯកសារ D54/98 កំណត់ហេតុនៃការស្តាប់ចម្លើយ ហ៊ាង រ៉េត (ហៀង រ៉េត), ឆ.42 ["ខ្ញុំត្រូវបានគេបញ្ជូនឲ្យទៅធ្វើការនៅទីបញ្ជាការយោធាជើងទឹករបស់វរសេនាធំ ១៤០ ដែលមានទីតាំងនៅអូរឈើទាល"]។ ឯកសារ D54/10 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ី រ៉េត (សារ៉េត), ឆ.21 ["សៈ តើកងណាដែលមានទីតាំងថិតនៅឆ្នេរអូរឈើទាល? ឆ.21៖ នៅជិតផែនោះ គឺជាទីបញ្ជាការរដ្ឋានរបស់វរសេនាធំ ១៤០ ហើយនៅតាមបណ្តោយផ្លូវជិតឆ្នេរនោះ ក៏មានទីតាំងរបស់កងវរសេនាតូច ១៤១ ១៤២ ដែរ។ ខ្ញុំមិនចាំច្បាស់ទីតាំងរបស់វរសេនាតូច ១៤៣ និង ១៤៤ ទេ ប៉ុន្តែ៤វរសេនាតូចនេះថិតនៅក្រោម

កងវរៈសេនាធំលេខ ១៤០ ដែលសមាជិកម្នាក់ៗទទួលការបណ្តុះបណ្តាលពីបីទៅប្រាំមួយខែ[783]។ ការបណ្តុះបណ្តាលបានផ្តោតលើគ្រឿងម៉ាស៊ីន អាវុធ ទូរគមនាគមន៍ ការថែទាំ ការរៀបចំផែនការ

វរសេនាធំ ១៤០"]។ ឯកសារ D54/100 កំណត់ហេតុនៃការស្តាប់ចម្លើយ ឡាយ ប៊ុនហាក់, ឆ.60 - 61។ ឯកសារ D114/132 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ៅ ភ៉ន់, ឆ.61 [សៈ មុនពេលលោកទៅដល់អូរឈើទាល តើមានគេមកប្រាប់ពួកលោកថា ទៅធ្វើអ្វីខ្លះ? ឆ.61៖ អ្នកដែលត្រូវចូលទៅអង្គភាពថ្មី គឺកងវរសេនាធំលេខ ១៤០ គឺបន្តនៅទីនោះ [នៅអូរឈើទាល]"]។ ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយ ជេត ប៊ុណ្ណា, ឆ.1, ឆ.23។ ឯកសារ D54/11.3 ផែនទីរដ្ឋបាលស្រុកមិត្តភាព - ការបង្ហាញពីទីតាំង ដោយ ម៉ី រ៉េត, EN 00936717 [សាក្សីបានចង្អុរបង្ហាញពីទីបញ្ជាការវរសេនាធំ ១៤០ និង វរសេនាតូច ១៤១ នៅក្បែរផែអូរឈើទាល]។

783 ឯកសារ D114/48 កំណត់ហេតុនៃការស្តាប់ចម្លើយ សុខ ង៉ុន, ឆ.14 ["ពេលដែលខ្ញុំទៅដល់កំពង់សោមដំបូង គេដាក់ខ្ញុំឱ្យទៅហ្វឹកហ្វឺនកងទ័ពជើងទឹកនៅក្រុងកំពង់សោម។ ពេលខ្លះ យើងត្រូវបានគេបញ្ជូនទៅហាត់រៀននៅនឹងឆ្នេរអូរឈើទាល"]។ ឯកសារ D54/87 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រុំ សារ៉ាត់, ឆ.39 - 40 ["ខ្ញុំមិនដែលទៅទីបញ្ជាការដ្ឋានកងពល ១៦៤ ទេ តែខ្ញុំធ្លាប់ចូលរួមប្រជុំដែលរៀបចំដោយកងពល ១៦៤ នៅឆ្នេរអូរឈើទាល។ សៈ តើវគ្គបណ្តុះបណ្តាលនោះ ធ្វើញឹកញាប់ ដែរទេ? ឆ.40៖ ធ្វើជារៀងរាល់ឆ្នាំ។"]។ ឯកសារ D114/65 កំណត់ហេតុនៃការស្តាប់ចម្លើយ ជេត ប៊ុណ្ណា, ឆ.16 ["នៅពេលនោះ គេផ្តើមរៀបចំកងទ័ពជើងទឹក ពេលនោះគេ បញ្ជូនពួកខ្ញុំឱ្យទៅធ្វើការហ្វឹកហ្វឺននៅអូរឈើទាល។ [...] ខ្ញុំត្រូវបានគេដាក់ឱ្យហ្វឹកហ្វឺននៅលើកប៉ាល់មួយនៅក្នុងចំណោមកប៉ាល់ទាំង៤នោះសម្រាប់រយៈពេល៦ខែ"]។ ឯកសារ D114/132 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ៅ ភ៉ន់, ឆ.75 ["យើងបោះទីតាំងនៅអូរឈើទាល ក្រោយពីបង្កើតអង្គភាពថ្មី ហើយមានបើកវគ្គរៀនខាងបច្ចេកទេសនាវា [...] អ្នកដែលរៀនចប់ហើយគេឱ្យឡើងទៅកប៉ាល់ចម្បាំងធំៗ"]។ ឯកសារ D54/10 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ី រ៉េត (សារ៉េត), ឆ.17 ["ខ្ញុំឱ្យទៅនៅឆ្នេរអូរឈើទាល ខ្ញុំនៅទីនោះហាត់រៀនមុជ និងហែលទឹក ហើយក្រោយមក ខ្ញុំត្រូវបានហ្វឹកហ្វឺនគ្រឿងម៉ាស៊ីនរបស់នាវាប្រដេញ"]។ ឯកសារ D114/103 កំណត់ហេតុនៃការស្តាប់ចម្លើយ លៀត ឡុន (ណាំ ឡុន), ឆ.207។ ឯកសារ D54/112.1 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្លុង ឈា, EN 00968349, KH 00926494 ["មួយវគ្គៗ រៀនម្តង ៤-៥-៦កប៉ាល់នោះ។ សៈ រៀនប៉ុន្មានខែ ប៉ុន្មានឆ្នាំ? ឆ៖ រៀន៣ខែទៅ៦ខែ"]។ ឯកសារ D59/1/1.7a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយ មជ្ឈមណ្ឌលឯកសារកម្ពុជា ម៉ា ឈឿន, EN 00969943, KH 00926321។ ឯកសារ D54/24.1 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ប៉ាក សុខ, EN 00978568, KH 00955496 ["សៈ ចេងគេឱ្យមករៀនសូត្រនៅ [...] អូរឈើទាល? ឆ៖ បាទ! [...] រៀនបានរយៈពេល ៣ខែៗហ្នឹង យើងអាចយកទៅប្រើប្រាស់បានហើយ"]។ ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974096, KH 00926540។ ឯកសារ D54/115.1 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា នាក់ យឿន, EN 01088456, KH 01007855។

សម្ងាត់ និងនាវាចរណ៍[784]។ កំពង់ផែត្រូវបានប្រើប្រាស់ដើម្បីចូលចត និងរៀបចំកប៉ាល់ចម្បាំង[785] និងជាទីកន្លែងមួយសម្រាប់ការបញ្ជូនមនុស្ស ដែលត្រូវបានចាប់ខ្លួននៅឯសមុទ្រ រួមទាំងជនជាតិថៃ និងវៀតណាមផងដែរ[786] មកកាន់ដីគោក។

---

784 ឯកសារ D54/99.1 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយ មជ្ឈមណ្ឌលឯកសារកម្ពុជា ឡាយ ប៊ុនហាក់, EN 01115974, KH 00990769 ["ចូលរៀនខែ ម៉ាវគ្គទី១ ៦ខែ ចាប់ពីខែ ១ ដល់ខែ ៦ ខ្ញុំរៀន ខែ១០ ៧៦ [១៩៧៦] [...] ខ្ញុំរៀនខាងឯកទេសនាំផ្លូវ"]។ ឯកសារ D54/112.1 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្លុង ឈា, EN 00968350 - 00968351, KH 00926495 - 00926497 ["រៀនពីបច្ចេកទេស ពីការប្រើប្រាស់ការថែទាំ និងការប្រយុទ្ធនៅលើសមុទ្រ។ [...] មានផ្នែករ៉ាដា ផ្នែកត្រីវិស័យ ផ្នែកទូរលេខ ផ្នែកទី និងផ្នែកម៉ាស៊ីន ផ្នែកបើកបរ"]។ ឯកសារ D59/1/1.8a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រំ សារ៉ាត់ , EN 00974180, KH 00926362 ["បង្ហាត់ហ្វឹកហ្វឺនដោយមានផ្នែកវាណា បើកបរ ម៉ាស៊ីន កាំភ្លើង អគ្គីសនី ទូរគមនាគមន៍ ខាងទូរលេខ ខាងវិទ្យុទាក់ទង ហើយខាងសញ្ញា។ [...] រ៉ាដាមួយទៀត]។ ឯកសារ D54/115.1 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា នាក់ យឿន, EN 01088456, KH 01007855 ["រៀនមានផ្នែកគេ ឥឡូវផ្នែកកប៉ាល់នឹងមានផ្នែកម៉ាស៊ីន អានឹងមានផ្នែកម៉ាស៊ីនទៅ ហ៊ីកផ្នែកបើកបរ រៀនផ្នែកបើកបរទៅ ផ្នែកទូរលេខរៀនផ្នែកទូរលេខទៅ។ ហើយខ្ញុំរៀនផ្នែកកងកាំភ្លើងទៅ"]។ ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាហៀង រ៉េត, EN 00974096, KH 00926541 ["យើងហាត់ទៅមានជំនាញសម្រាប់ការពារ [...] នៅស្រុកយើងនឹងមានហាត់សម្រាប់ការពាត និងអាបណ្ដែត"]។

785 ឯកសារ D54/100 កំណត់ហេតុនៃការស្ដាប់ចម្លើយ ឡាយ ប៊ុនហាក់, ឆ.61 ["ហើយនិង [ទី២] នៅទីតាំងអូរឈើទាល គឺសម្រាប់ នាវាប្រឆាំង និងនាវាបាញ់គ្រាប់បែកទឹក"]។ ឯកសារ D54/29 កំណត់ហេតុនៃការស្ដាប់ចម្លើយ លៀត ឡូន (ណាំ ឡូន), ឆ.3 ["បន្ទាប់មក ខ្ញុំត្រូវបានបញ្ជូនទៅនៅកប៉ាល់ប្រឆាំងនឹងនាវាមុជទឹក ដែលបោះយុថ្កានៅជិតផែឈើអូរឈើ ទាល"]។ ឯកសារ D54/33 កំណត់ហេតុនៃការស្ដាប់ចម្លើយ អ៊ឹង ឆុន, ឆ. 20 ["ពេលខ្លះកប៉ាល់របស់ខ្ញុំចតនៅ អូរឈើទាល និងជួនពេលខ្លះចតនៅរាម"]។ ឯកសារ D59/1/1.12 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ណុប ហាល, EN 00968381, KH 00926609 ["ផែអូរឈើទាល គេមិនសូវឲ្យចូលទេ ព្រោះហេតុផលគឺកន្លែងហ្នឹងគេ សម័យនឹងគឺគេផ្ទុកនាវាចម្បាំងនៅផែអូរឈើទាល"]។ ឯកសារ D59/1/1.8a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រំ សារ៉ាត់, EN 00974188, KH 00926369 ["ខ្ញុំនៅមុខអូរឈើទាល"]។ EN 00974195, KH 00926375 ["ស៖ ចុះ ១៧-៨ ១៧-៩? ឆ៖ អាហ្នឹងនៅប្រចាំកោះរ៉ុង ពេលខ្លះកោះរ៉ុង ពេលខ្លះអូរឈើទាល"]។

786 សម្រាប់ព័ត៌មានបន្ថែម សូមមើល VIII.ខ. ឧក្រិដ្ឋកម្មមកលើមនុស្សដែលចាប់ខ្លួន ដោយកងនាវាជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ នៅដែនទឹក និងនៅលើដីកោះដែលកម្ពុជាប្រជាធិបតេយ្យអះអាងថាជារបស់ខ្លួន កថាខណ្ឌ ៣៩០, ៣៩២ - ៣៩៨, និង ៤២២។ សូមមើលផងដែរ ឯកសារ D54/25 កំណត់ហេតុនៃការស្ដាប់ចម្លើយ ប៉ាក សុខ, ឆ.6, ឆ.10, ឆ.22 ["កងទ័ពទាំងនេះធ្វើការចាប់ចងមនុស្សណា ដែលឆ្លងចូលដល់ដែនទឹកកម្ពុជា ក្នុងតំបន់ប្រតិបត្តិការរបស់គេ។ នៅពេលដែលមានប្រតិបត្តការដូចដែលមានរៀបរាប់ក្នុងឯកសារខ្ញុំអាននេះ កើតឡើង គឺខ្ញុំកំពុងនៅក្នុងកងវរ

246. កងវរៈសេនាធំលេខ ១៤០ ត្រូវបានបំបែកជាទីបួនក្រុម គឺក្រុមប្រដេញ ក្រុមការពារ ក្រុមប្រឆាំងកប៉ាល់មុជទឹក និងក្រុមបោសសម្អាតមីន[787]។ ក្រុមទាំងនេះធ្វើទំនាក់ទំនងជាមួយនឹងកងវរៈសេនា

---

សេនាធំលេខ ១៤០។ ខ្ញុំទើបតែត្រឡប់មកពីកោះប៉ូឡូវ៉ៃ មកធ្វើការនៅនឹងផែឈើ នៅនឹងឆ្នេរអូរឈើទាល។ នៅពេលដែលពួកយោធាតាមកោះចាប់បានពួកមនុស្សទាំងនោះ ក៏បញ្ជូនមកដីគោក ហើយគេតែងតែយកអ្នកទាំងនោះចូលមកដាក់នៅផែអូរឈើទាល នៅកន្លែងខ្ញុំធ្វើការ។ [...] ឆ. 10៖ មនុស្សដែលចាប់បាន គឺមានចំនួនរាប់ពាន់នាក់ បើគិតជាចំនួនទាំងអស់ ដែលតាមខ្ញុំដឹង។ ក្នុង១ខែ១ គេបញ្ជូនមនុស្សមកតាមផែអូរឈើទាលពី ៤ ទៅ ៥ ដង។ ហើយក្នុងម្តង១មានមនុស្សចន្លោះពី ១០ នាក់ ទៅ ៥០ នាក់។ [...] ឆ.22៖ ខ្ញុំបានឃើញព្រឹត្តិការណ៍មួយទៀត នៅពេលដែលខ្ញុំចាប់និងដឹកជនអៀសខ្លួនវៀតណាមចំនួន ១៣នាក់ មកអូរឈើទាល"]។ ឯកសារ D59/1/1.12 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ណុប ហាល, EN 00968401, KH 00926627 ["ស៖ ដល់ពេលបញ្ជូនមកកំពង់សោម យើងបញ្ជូនមក រាម ឬក៏មកអូរឈើទាល? ឆ៖ បញ្ជូនមកច្រើនអូរឈើទាល"]។ ឯកសារ D54/115.1 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា នាក់ យឿន, EN 01088468, KH 01007867 ["មកម្តង បញ្ជូនមក មកដល់អូរឈើទាលហ្នឹង"]។

[787] ឯកសារ D54/113 កំណត់ហេតុនៃការស្តាប់ចម្លើយ លៀង បៀ ឆ.21 ["មានកប៉ាល់ប្រឆាំងនឹងនាវាមុជទឹក កប៉ាល់ការពារ កប៉ាល់បណ្តែត កប៉ាល់រាវមីន (តូច១)"]។ ឯកសារ D54/99 កំណត់ហេតុនៃការស្តាប់ចម្លើយ ឡាយ ប៊ុនហាក់, ឆ.33 ["នៅក្នុងកងអង្គភាព ១៤០ មាន ៤ ផ្នែក ១) នាវាប្រឆាំង ២) នាវាការពារ (ខ្ញុំ) ៣) នាវាបណ្តែតទឹក (០២៦) ៤) នាវាបោសមីន និងមួយទៀត នាវាដឹកប្រេង (នាវាឧបម្ភត្ថ)"]។ ឯកសារ D54/87 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រំ សារ៉ាត់ ឆ.25 ["ខ្ញុំមិនចាំអំពីចំនួនទូក កាណូតតូច១នោះទេ តែខ្ញុំចាំចំនួនកប៉ាល់ នាវាជើងទឹករបស់កងវរសេនាធំ ១៤០។ ពីពាក់កណ្តាលឆ្នាំ ១៩៧៦ រហូតដល់ឆ្នាំ ១៩៧៩ កងវរសេនាធំ ១៤០ មាននាវាធុនការពារចំនួន ១០ គ្រឿង នាវាបណ្តែត ១០ គ្រឿង កប៉ាល់ដឹកប្រេង ១ គ្រឿង កប៉ាល់បោសសម្អាតមីនចំនួន ៤ គ្រឿង។"]។ ឯកសារ D114/103 កំណត់ហេតុនៃការស្តាប់ចម្លើយ លៀត ឡុន (ណាំ ឡុន), ឆ.40 ["កាលនោះ គេបែងចែក អ្នកខ្លះមកពីផ្នែកប្រឆាំងនាវាមុជទឹក នាវាការពារ និងនាវាប្រដេញ"]។ ឯកសារ D114/12 កំណត់ហេតុនៃការស្តាប់ចម្លើយ នាក់ យឿន, ឆ.10 ["មានកងវរសេនាតូចខុសៗគ្នា ចំណុះឲ្យកងវរសេនាធំ ១៤០ ក្នុងនោះរួមមាន កងវរសេនាតូចនាវាប្រដេញ កងវរសេនាតូចនាវាផ្តាច់មីន កងវរសេនាតូចនាវាការពារ និងកងវរសេនាតូចនាវា PCF"]។ ឯកសារ D59/1/1.9a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារ កម្ពុជា ឡាយ ប៊ុនហាក់, EN 00963728, KH 00926461 ["វាកាលហ្នឹង ប្រជាជនកាលហ្នឹងមាន ៤ ផ្នែក មួយនាវាការពារ១២៥ ទី២ នាវាបណ្តែត ០២៦ ទី៣នាវាដោះមីន ទី៤នាវាប្រឆាំង ទី៥នាវាដឹកប្រេងមួយទៀត"]។ ឯកសារ D4.1.761 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក មិនស្គាល់ឈ្មោះ, EN 00387299, KH 01507823 ["ចំណុះរបស់កងវរសេនាធំរបស់ប្រភពរួមមាន អង្គភាពដែលមានទំហំស្មើកងវរសេនាតូចចំនួន ៣ កងវរសេនាតូចប្រដេញ តាមល្បឿនចំនួន ១ កងវរសេនាតូចការពារជាតិចំនួន ១ និងកងវរសេនាតូចប្រឆាំងនាវាមុជទឹកចំនួន ១"]។ ឯកសារ D114/264 កំណត់ហេតុនៃការស្តាប់ចម្លើយ ជុំ ជី, ឆ.27 ["កប៉ាល់ទាំងអស់ដែលមាន ៣ ធុន: នាវាបណ្តេញ នាវាការពារដែនសមុទ្រ ១២៥ តោន និងនាវាប្រឆាំងនាវាមុជទឹកចំណុះមនុស្ស ៧៥ នាក់"]។

តូចចំនួនបួនរបស់កងវរៈសេនាធំលេខ ១៤០ នោះគឺកងវរៈសេនាតូចលេខ ១៤១ លេខ ១៤២ លេខ ១៤៣ និងលេខ ១៤៤[788]។

247. កងវរៈសេនាតូចលេខ ១៤១ គឺជាអង្គភាពទូកប្រដេញ[789] ដែលស្ថិតក្រោយបញ្ជារបស់ សរ មឿន ហៅ មឿន[790] ដោយមានការជួយជ្រោមជ្រែងពី គុណ ខឹម ដែលជាអនុលេខា[791] រហូតទាល់តែ

---

788 ឯកសារ D114/65 កំណត់ហេតុនៃការស្តាប់ចម្លើយ ជេត ប៊ុណ្ណា, ឆ.16 ["នៅក្នុងវរសេនាធំ ១៤០ នោះ គេបានរៀបចំ៤ វរសេនាតូច គឺ វរសេនាតូច ១៤១ ១៤២ ១៤៣ និង ១៤៤"]។ ឯកសារ D2/8 កំណត់ហេតុនៃការស្តាប់ សយ ប៊ិន, ឆ.50 ["ក្រោយពេលភ្នំពេញបែក មានកងវរសេនាតូច ៤១, ៤២, ៤៣, ៤៤។ ការពិតគេមិនបានហៅលេខ ១០០ ខាងដើមទេ គឺគេហៅតែខាងចុង ៤១, ៤២, ៤៣, និង ៤៤"]។ ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974099, KH 00926543 ["ស៖ ចឹងកង ១៤០ ហ្នឹងវាមានកងវរសេនាតូចដែរ? [...] ឆ៖ មាន ១៤១, ១៤២, ១៤៣, និង ១៤៤"]។ ឯកសារ D4.1.758 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក មិនស្គាល់ឈ្មោះ, EN 00387312, KH 01506014 ["គណៈកម្មាធិការនេះ ផ្ទេរបទបញ្ជាទៅកងវរសេនាធំឲ្យគ្រប់គ្រងលើ កប៉ាល់ នានា ទៅតាមប្រភេទកប៉ាល់"]។

789 ឯកសារ D54/10 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ី រ៉េត (សារ៉េត), ឆ. 21 ["កងវរសេនាតូច ១៤១ ជាកងនាវាប្រដេញ និងកង វរសេនាតូច ១៤២ ជាកងនាវាការពារ"]។ ឯកសារ D114/12 កំណត់ហេតុនៃការស្តាប់ចម្លើយ នាក់ យឿន, ឆ.10 ["មានកងវរសេនាតូចខុសៗគ្នា ចំណុះឲ្យកងវរសេនាធំ ១៤០ ក្នុងនោះរួមមាន កងវរសេនាតូចនាវាប្រដេញ កងវរសេនាតូចនាវាផ្គត់មីន កងវរសេនាតូចនាវាការពារ និងកងវរសេនាតូចនាវា PCF"]។

790 ឯកសារ D1.3.30.5 របាយការណ៍សេនាធិការ របស់កម្ពុជាប្រជាធិបតេយ្យ តារាងស្ថិតិសិក្ខាកាមរៀន នៅវគ្គសេនាធិការលើកទី១, ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៧៦, EN 00897655, KH 00095536 [បញ្ជីលេខរៀង ១២៩ សរ មឿន ជាលេខាវរសេនាតូច នៅកងពល ១៦៤]។ ឯកសារ D114/67 កំណត់ហេតុនៃការស្តាប់ចម្លើយ សរ សារិន, ឆ.4 ["ម្នាក់ទៀត ឈ្មោះ សរ មឿន។ គាត់ គឺជាមេបញ្ជាការវរសេនាតូច ១៤១"]។ ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយ ជេត ប៊ុណ្ណា, ឆ.2 ["មឿន គឺជាមេបញ្ជាការវរសេនាតូច ១៤១ ដែលស្ថិតនៅក្នុងកងជើងទឹក វរសេនាធំ ១៤០។ មឿន នៅផែអូរឈើទាលនោះរហូត"]។ ឯកសារ D54/10 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ី រ៉េត (សារ៉េត), ឆ.22 ["ឯឈ្មោះ មឿន ពីដើមជាអតីតមេបញ្ជាការកងពិសេសរបស់ មាស មុត ហើយនៅក្នុងនោះគាត់ជាមេបញ្ជាការវរសេនាតូច ១៤១ នៃវរសេនាធំ ១៤០។"]។ ឯកសារ D54/106.2 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា សាន់ កាន់ ហៅ ប៊ុត, EN 01509181, KH 00993434 ["មាន ៤ វរសេនាតូច មាន ៤១, ៤២, ៤៣, និង៤៤។ [...] ៤១ ឈ្មោះ មឿន"]។ ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974099, KH 00926543 ["វរសេនាតូច ១៤១ ឈ្មោះ មឿន"]។ ឯកសារ D4.1.758 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក មិនស្គាល់ឈ្មោះ, EN 00387312, KH 01506014 ["មឿន បញ្ជានាវាចម្បាំង"]។ ឯកសារ D54/38.1 កំណត់ហេតុនៃការ

គុណ ឌឹម ត្រូវបានចាប់ខ្លួននៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ១៩៧៧ ហើយត្រូវបានសម្លាប់នៅឯមន្ទីរ ស-២១ នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៧[792]។ កងវរៈសេនាតូចលេខ ១៤១ មានទូកប្រដេញ/ទូកប

សម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លន់ សេង EN 01072392, KH 0096731។ សូមមើលផ្ទុយមកវិញ ឯកសារ D54/17 កំណត់ហេតុនៃការស្តាប់ចម្លើយ សយ ប៊ន, ឆ.2 ["បូ ដែលជាប្រធានកងនាវាប្រដេញ មកជំនួស សារឿន គាត់បានធ្វើការនៅផ្ទះនេះម្តងម្កាល ប៉ុន្តែភាគច្រើន គាត់ប្រចាំការណ៍នៅលើនាវា"]។

791 ឯកសារ D114/230.1.1 បញ្ជីអ្នកទោសស-២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត [កំណត់អត្តសញ្ញាណនៅលេខរៀងទី ៣២២៣ ថា គុណ ឌឹម ជាអនុលេខាវរសេនាតូច ១៤១ កងពល១៦៤ ហើយពីមុននៅតំបន់២២ ភូមិភាគបូព៌ា]។ ឯកសារ D1.3.30.6 របាយការណ៍កម្ពុជាប្រជាធិបតេយ្យពីសេនាធិការ, វគ្គសេនាធិការលើកទី២ - តារាងស្ថិតិសិក្ខាកាម, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦, EN 00195332, KH 00008466 [កំណត់អត្តសញ្ញាណថា គុណ ឌឹម ជាអនុលេខាវរសេនាតូច កងពល ១៦៤]។ ឯកសារ D1.3.28.49 បញ្ជីសួរចម្លើយអ្នកទោសស-២១, EN 00937118, KH 00082795 [កំណត់អត្តសញ្ញាណនៅលេខរៀងទី ១៧ ឈ្មោះ គុណ ឌឹម ជាបញ្ជាការវរសេនាតូច កងពល ១៦៤]។ ឯកសារ D114/85 កំណត់ហេតុនៃការស្តាប់ចម្លើយ ជេត ប៊ុណ្ណា, ឆ.28 ["គាត់ [គុណ ឌឹម] មកពីវរសេនាតូច ១៤១ កងវរសេនាធំ"]។ ឯកសារ D1.3.28.45 បញ្ជីឈ្មោះអ្នកទោសដែលមានឯកសារហើយ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៧៧ [កំណត់អត្តសញ្ញាណឈ្មោះ គុណ ឌឹម ជាមេបញ្ជាការវរសេនាតូច កងពល ១៦៤]។ ឯកសារ D2/16 កំណត់ហេតុនៃការស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច, ឆ.1 – 2, ឆ.15 ["ឈ្មោះ គុណ ឌឹម បញ្ជាការវរសេនាតូចលេខ ១៤១។ [...] សៈ តើកងនេះជាកងដែលលោកនៅឬ? ឆ.2៖ បាទ! [...] ឆ.15៖ ឈ្មោះ ឌឹម ដែលយើងស្គាល់ជាទូទៅថា ជាអនុប្រធានកងពល ១៦៤"]។

792 ឯកសារ D9.3 បញ្ជីឈ្មោះអ្នកទោសមន្ទីរស ២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត មកពីកងពល ១៦៤, [គុណ ឌឹម ត្រូវបានសម្លាប់នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៧]។ ឯកសារ D1.3.28.49 បញ្ជីសួរចម្លើយអ្នកទោសស-២១, EN 00937118, KH 00082795 [កំណត់អត្តសញ្ញាណនៅលេខរៀងទី ១៧ ឈ្មោះ គុណ ឌឹម ជាបញ្ជាការវរសេនាតូច កងពល ១៦៤ ដែលបានចាប់ខ្លួន នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៧ និងបានសួរចម្លើយចប់ នៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩៧៧]។ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសស-២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត [កំណត់អត្តសញ្ញាណនៅលេខរៀងទី ៣២២៣ ថា គុណ ឌឹម ជាអនុលេខាវរសេនាតូច ១៤១ កងពល១៦៤ ហើយពីមុននៅតំបន់២២ ភូមិភាគបូព៌ា ដែលបានចូលមកមន្ទីរស-២១ នៅថ្ងៃទី ២០ ឬ ២៥ ខែ មេសា ឆ្នាំ ១៩៧៧]។ ឯកសារ D1.3.18.3 ចម្លើយសារភាពមន្ទីរស-២១ គុណ ឌឹម, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៧៧, EN 00758228, KH 00091857 [សេចក្តីសង្ខេបចម្លើយសារភាពរបស់ គុណ ឌឹម ដោយបុគ្គលិកមន្ទីរស-២១ បញ្ជាក់ថា "អតីតបញ្ជាការវរសេនាតូច វរសេនាធំ ១៥២ → វរសេនាតូច ១៤១/១៤០/១៦៤"។ យោងលើវរសេនាធំ ១៥២ ពីមុនរបស់គាត់ ដែលដឹកនាំដោយ ហឹង ឌឿន នៅភូមិភាគបូព៌ា និងយោងលើអង្គហេតុដែលថាគាត់បានផ្ទេរទៅវរសេនាតូច ១៤១ វរសេនាធំ ១៤០ នៃកងពល ១៦៤] EN 00758239, KH 00091863 [សេចក្តីសង្ខេបដោយអ្នកសួរចម្លើយ និយាយពីកាលបរិច្ឆេទ នៃការចាប់ខ្លួនរបស់គាត់ នៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៧]។ ឯកសារ D2/16 កំណត់ហេតុនៃការស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច, ឆ.5 ["ខ្ញុំដឹងថា គាត់ [គុណ ឌឹម] ត្រូវបានចាប់ខ្លួននៅអូរឈើទាល"]។ ឯកសារ

ណ្ដែតប្រដាប់ដោយអាវុធចំនួនដប់ពីរគ្រឿង[793] ដែលត្រូវបានរៀបចំឡើងដើម្បីបាញ់ទិសដៅសត្រូវធំៗ រួមទាំងកប៉ាល់មុជទឹកផងដែរ[794]។

248. កងវរៈសេនាតូចលេខ ១៩២ ដែលត្រូវបានគេស្គាល់ថាជាអង្គភាពទូកការពារនោះ[795] ត្រូវបានបញ្ជាដោយ គង់ ស៊ាន ហៅ សាង (សាន)[796] បន្ទាប់ពី ហាន ត្រូវបានផ្ទេរទៅកាន់កងវរៈសេនាតូច

---

D114/85 កំណត់ហេតុនៃការស្ដាប់ចម្លើយ ជេត ប៊ុណ្ណា, ឆ.28 - 29 ["គាត់ [គុណ ខឹម] មកពីវរសេនាតូច ១៩១ កងវរសេនាធំ ១៩០ [...]ឆ. 29៖ ការចាប់ខ្លួនគាត់ គឺធ្វើឡើងដោយសម្ងាត់។ គុណ ខឹម គឺដូចជាអ្នកជិតខាង របងជាប់គ្នាជាមួយខ្ញុំដែរ។ [...] ពេលគាត់បាត់ខ្លួន ប្រពន្ធ និងកូនគាត់ ក៏បានបាត់ខ្លួនដែរ"]។

793 ឯកសារ D54/10 កំណត់ហេតុនៃការស្ដាប់ចម្លើយ ម៉ី រ៉េត (សារ៉េត), ឆ.22 ["កប៉ាល់លេខ ០២ គឺជានាវាប្រដេញមួយនៅក្នុងនាវាប្រដេញ។ ក្នុងនាវាប្រដេញនេះ គឺមានកប៉ាល់ប្រដេញចំនួន ១២ គ្រឿង"]។ ឯកសារ D114/67 កំណត់ហេតុនៃការស្ដាប់ចម្លើយ សរ សារិន, ឆ.20 ["ខ្ញុំស្ថិតនៅក្នុងកងនាវាបណ្ដែត។ នៅក្នុងកងនាវាបណ្ដែត មាននាវាចំនួន ១២ គ្រឿង។ នាវានីមួយៗ មានទទឹងប្រវែង៥.១ម៉ែត្រ ហើយមានបណ្ដោយ ២២.៥ ម៉ែត្រ។ នាវានីមួយៗមាននាវិកចំនួន ១៣ នាក់"]។ ឯកសារ D54/87 កំណត់ហេតុនៃការស្ដាប់ចម្លើយ ព្រំ សារ៉ាត់, ឆ.25, ឆ.27 ["ពីពាក់កណ្ដាលឆ្នាំ ១៩៧៦ រហូតដល់ឆ្នាំ ១៩៧៩ កងវរសេនាធំ ១៩០ មាននាវាផុនការពារចំនួន ១០ គ្រឿង នាវាបណ្ដែត ១០ គ្រឿង កប៉ាល់ដឹកប្រេង ១ គ្រឿង កប៉ាល់បោសសម្អាតមីនចំនួន ៤ គ្រឿង។ [...] ឆ.27៖ ខ្ញុំមិនចាំអំពីទំហំទេ តែខ្ញុំចាំថា នាវាបណ្ដែត (នាវាប្រយុទ្ធ) មានកាំភ្លើងបាញ់កម្ទេចនាវាចំនួន២ដើម នៅសងខាង ដែលមានអង្កត់ផ្ចិតគ្រាប់ទំហំ ៥៥ មីលីម៉ែត្រ"]។ ឯកសារ D114/103 កំណត់ហេតុនៃការស្ដាប់ចម្លើយ លៀត ឡុន (ណាំ ឡុន), ឆ.74 ["តែមាននាវាមុជទឹក ២ គ្រឿង នាវាការពារ ៦ គ្រឿង និងនាវាសម្រាប់វាយប្រហារប្រហែល ១០ គ្រឿង"]។ ឯកសារ D2/9 កំណត់ហេតុនៃការស្ដាប់ចម្លើយ សយ ប៊ិន, ឆ.45 ["ស៖ តើលោកមានចាំដែរឬទេ នៅក្នុងអង្គភាពប្រដេញ មាននាវាចំនួនប៉ុន្មានគ្រឿង? ឆ.45៖ [...] តាមខ្ញុំចាំ គឺមាននាវាប្រហែលជា ១២ ឬ ១៤ គ្រឿង។"]។ ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974099, KH 00926543 ["ខ្ញុំនៅ ១៩១។ ស៖ អាហ្នឹង កាន់កប៉ាលើអី? ឆ៖ កាន់កប៉ាល់ពួកអាបណ្ដែត"]។

794 ឯកសារ D54/113 កំណត់ហេតុនៃការស្ដាប់ចម្លើយ លៀង បៀ, ឆ.26 ["មានកាំភ្លើងកាំជ្រួចចំនួនពីរដើម (ដូចមីស៊ីល) នៅសងខាងកប៉ាល់ ទុកសម្រាប់បាញ់កប៉ាល់ធំៗរបស់ខ្មាំង"]។ ឯកសារ D114/261 កំណត់ហេតុនៃការស្ដាប់ចម្លើយ ជុំ ជី, ឆ.7 ["ប្រភេទមួយហៅថា ០១, ០២ គេហៅកប៉ាល់ប្រដេញ និងកប៉ាល់ផ្ដាច់មីន វាលឿន សម្រាប់ទម្លាក់មីន មុជទឹក នាវាមុជទឹក។ យើងទទួលបានចំនួន ១២ គ្រឿង"]។

795 ឯកសារ D54/10 កំណត់ហេតុនៃការស្ដាប់ចម្លើយ ម៉ី រ៉េត (សារ៉េត), ឆ.21 ["កងវរសេនាតូច ១៩១ ជាកងនាវាប្រដេញ និង កងវរសេនាតូច ១៩២ ជាកងនាវាការពារ"]។ ឯកសារ D114/12 កំណត់ហេតុនៃការស្ដាប់ចម្លើយ នាក់ យឿន, ឆ.10 ["មានកងវរសេនាតូចខុសៗគ្នា ចំណុះឱ្យកងវរសេនាធំ ១៩០ ក្នុងនោះរួមមាន កងវរសេនាតូចនាវាប្រដេញ កងវរសេនាតូចនាវាផ្ដាច់មីន កងវរសេនាតូចនាវាការពារ និងកងវរសេនាតូចនាវា PCF"]។

លេខ ១៤៤ និងផ្ទេរពីកងវរៈសេនាតូចលេខ ១៤៤ ទៅកាន់គណៈកម្មាធិការកងវរៈសេនាធំលេខ ១៤០[797]។ គង់ ស៊ាន ក៏ត្រូវបានចាប់ខ្លួនផងដែរនៅខែ មេសា ឆ្នាំ ១៩៧៧ ហើយ "បានស្លាប់ដោយសារជំងឺ" នៅឯមន្ទីរ ស-២១ ក្នុងខែ កុម្ភៈ ឆ្នាំ ១៩៧៨[798]។ ទូកការពាររបស់កងវរៈសេនាតូចលេខ ១៤២ រួមបញ្ចូលក្រុមទូកល្បាតល្បឿនលឿន (PCF) ឬហៅថាទូកល្បាត ដែលផលិតនៅសហរដ្ឋអាមេរិក និងទូកវាយប្រហារល្បឿនលឿនដែលផលិតនៅចិន[799] ដែលត្រូវបានប្រើប្រាស់

---

796 ឯកសារ D114/85 កំណត់ហេតុនៃការស្តាប់ចម្លើយ ជេត ប៊ុណ្ណា, ឆ.29 ["ខ្ញុំស្ថិតនៅក្នុងកងវរសេនាតូច ១៤២ ក្រោមបញ្ជាការរបស់ឈ្មោះ សាង"]។ ឯកសារ D114/95 កំណត់ហេតុនៃការស្តាប់ចម្លើយ យឹម ស្រៀង, ឆ.168 - 169 ["អ្នកធំនោះ ឈ្មោះ សាង ជាប្រធានវរសេនាតូចលេខ ២ តែខ្ញុំមិនច្បាស់ប្រហែលជាលេខ ២ ឬក៏លេខ ៤២។ [...] ស៖ តើ សាង ស្ថិតក្រោមវរសេនាធំលេខប៉ុន្មានដែរ? ឆ.169៖ គាត់នៅក្រោម តាហន ក្នុងវរសេនាធំលេខ ១៤០"]។ ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974099, KH 00926543 ["១៤២ ឈ្មោះ សាង"]។

797 ឯកសារ D54/10 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ី រ៉េត (សារ៉េត), ឆ.22 ["សមមិត្ត ហន នៅក្នុងរបាយការណ៍នេះ ជាមេបញ្ជាការ វរសេនាតូច ១៤២ ដែលកងនាវាការពារនៅក្នុងវរសេនាធំ ១៤០"]។ ឯកសារ D2/10 កំណត់ហេតុនៃការស្តាប់ចម្លើយ សយ ប៊ិន, ឆ.24 ["គឺ លោក ហន ជាប្រធានរបស់កងនាវាការពារ"]។ ឯកសារ D4.1.758 សេចក្តីរាយការណ៍ពីការិយាល័យល្បើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក មិនស្គាល់ឈ្មោះ, EN 00387312, KH 01506014 ["ហុន ជាអ្នកកំណត់ដាក់បទបញ្ជាលើកប៉ាល់ទាំងអស់ ដែលប្រើប្រាស់ជាកងនាវាការពារ ឬ កប៉ាល់ដែលអាចប្រើប្រាស់ សម្រាប់ការពារដែនសមុទ្រ។ មឿន បញ្ជានាវាចម្បាំង ចំណែក បូ បញ្ជាលើនាវាវាយប្រហារ រហ័ស"]។ ឯកសារ D2/9 កំណត់ហេតុនៃការស្តាប់ចម្លើយ សយ ប៊ិន, ឆ.13 ["កងវរសេនាតូរបស់ខ្ញុំពេលនោះ គឺវរសេនាតូច ១៤៤ ដែលមានប្រធានឈ្មោះ ហន"]។ ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974099, KH 00926543 ["១៤៤ ឈ្មោះ ហន ហ្នឹងដល់ក្រោយមកទៀត ហន ហ្នឹង មកកាន់ ១៤០"]។ សូមមើលផងដែរ កថាខណ្ឌ ២៣៩ យោងទៅលើតួនាទីរបស់ ហន ដែលជាអតីតប្រធានវរសេនាតូច ៥២០ (វរសេនាធំ ២២) មុនពេលគាត់បានផ្ទេរទៅវរសេនាធំ ១៤០ (សូមមើល កថាខណ្ឌ ២៤៤)។

798 ឯកសារ D114/230.1.1 បញ្ជីអ្នកទោសស-២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត [កំណត់អត្តសញ្ញាណនៅលេខរៀងទី ៣៩៩៤ ថា គង់ ស៊ាន ហៅ សាន ជាលេខាវរសេនាតូច ១៤២ ដែលបានចូលមកមន្ទីរស-២១ នៅថ្ងៃទី ២៧ ឬ ២៨ ខែ មេសា ឆ្នាំ ១៩៧៧ និងបានស្លាប់ដោយសារជម្ងឺ នៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៨]។ ឯកសារ D9.3 បញ្ជីអ្នកទោសមន្ទីរស ២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត មកពីកងពល ១៦៤, [កំណត់អត្តសញ្ញាណលេខរៀងទី ២០ គឺ គង់ សៀង ហៅ សាង លេខាវរសេនាតូច ដែលចូលមកមន្ទីរស-២១ នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៧ ហើយបានស្លាប់ដោយសារជម្ងឺនៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៨]។

799 ឯកសារ D54/87 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រំ សារ៉ាត់, ឆ.25 ["ខ្ញុំមិនចាំអំពីចំនួនទូក កាណូតតូចៗនោះទេ តែខ្ញុំចាំចំនួនកប៉ាល់ នាវាជើងទឹករបស់កងវរសេនាធំ ១៤០។ ពីពាក់កណ្តាលឆ្នាំ ១៩៧៦ រហូតដល់ឆ្នាំ ១៩៧៩ កងវរ

ដើម្បីស្ទាក់ និងវាយប្រហារសត្រូវ[800]។ ទូកទាំងនេះបានឈរជើងនៅកំពង់ផែរាម[801] និងនៅលើកោះផ្សេងៗជាជាងនៅឆ្នេរអូរឈើទាល រួមទាំងនៅកោះតាង កោះកុង និងកោះរុងសន្លឹមផងដែរ[802]។ ទូក PCF ដែលមានចំណុះ ១២ នាក់ មានភាពទំនើប លឿន និងមានបំពាក់អាវុធទំនើប

---

សេនាធំ ១៤០ មាននាវាធុនការពារចំនួន ១០ គ្រឿង នាវាបណ្តែត ១០ គ្រឿង កប៉ាល់ដឹកប្រេង ១ គ្រឿង កប៉ាល់បោសសម្អាតមីនចំនួន ៤ គ្រឿង។"]។ ឯកសារ D114/281 កំណត់ហេតុនៃការស្តាប់ចម្លើយ ជុំ ជី, ឆ.16 ["នាវាការពារ ១២៥ តោន ចំណុះ [...] នេះជានាវាជំនួយពីចិនទាំងអស់។"]។ ឯកសារ D2/10 កំណត់ហេតុនៃការស្តាប់ចម្លើយ សយ ប៊ន, ឆ.27 ["នៅក្នុងកងនាវាការពារ គឺមាននាវាប្រហែលជា ៨ ឬ ១០ គ្រឿង។"]។ ឯកសារ D114/12 កំណត់ហេតុនៃការស្តាប់ចម្លើយ នាក់ យឿន, ឆ.8 - 9 ["សៈ តើមានកប៉ាល់ប្រភេទនេះប៉ុន្មានគ្រឿង ដែលស្ថិតនៅក្រោមការគ្រប់គ្រងវរសេនាធំ ១៤០? ឆ.8៖ មានកប៉ាល់ប្រហែល ៦ គ្រឿង [...] ឆ.9៖ កប៉ាល់របស់ខ្ញុំ គេហៅថាកប៉ាល់ការពារ។"]។ ឯកសារ D114/181 កំណត់ហេតុនៃការ ស្តាប់ចម្លើយ សែម កុល, ឆ.18, ឆ.24 ["សៈ តើនាវាដែលគេចាត់តាំងឱ្យលោកធ្វើការ ជាប្រភេទនាវាអ្វីដែរ? ឆ.18៖ ជាប្រភេទនាវាធុនការពារ។ [...] ឆ.24៖ នាវាទាំងអស់មាន ១០១, ១០២, ១០៣, ១០៤, ១០៥, ១០៦, ១០៧ និង ១០៨។"]។ ឯកសារ D4.1.758 សេចក្តីរាយការណ៍ពីការិយាល័យល្ហើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក មិនស្គាល់ឈ្មោះ, EN 00387312, KH 01506014 ["នាវាការពារ រួមមាន កប៉ាល់ចាស់២គ្រឿងប្រភេទ PCF របស់អាមេរិច និង នាវាវាយប្រហាររហ័ស ៧ គ្រឿងរបស់ចិន។"]។ EN 00387313, KH 01506014 - 01506015 ["នាវាចាស់ ២ គ្រឿងប្រភេទ PCF របស់អាមេរិច បង្កើតបានជាកងនាវា១ និង បោះមូលដ្ឋាននៅ កោះកុង [...] នាវា ៧ គ្រឿងរបស់ចិន មានលេខរៀងពី ១០១ ដល់ ១០៧"]។

800 ឯកសារ D2/10 កំណត់ហេតុនៃការស្តាប់ចម្លើយ សយ ប៊ន, ឆ.28 ["ថ្វីបើគេហៅថា ជានាវាការពារក៏ដោយ ភារកិច្ចរបស់វា គឺសម្រាប់ប្រយុទ្ធ។"]។ ឯកសារ D54/113 កំណត់ ហេតុនៃការស្តាប់ចម្លើយ លៀង បៀ, ឆ.25, ឆ.63 ["តួនាទីរបស់កប៉ាល់ការពារហ្នឹង នៅពេលដែល មានខ្មាំងមករំលោភដែនសមុទ្ររបស់យើង គឺគេបញ្ជូនកប៉ាល់ការពារនេះទៅវ៉ៃ។ [...] ឆ.63៖ បើមានកប៉ាល់ ឬកាណូត ចម្បាំងចូលមកជ្រៅក្នុងដែនទឹកយើង ទើបគេបញ្ជាឱ្យកប៉ាល់ការពារចេញទៅ។"]។ ឯកសារ D59/1/1.9a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ឡាយ ប៊ុនហាក់, EN 00963730, KH 00926463 ["សៈ អាហ្នឹង គេប្រើដែរអត់ PCF ហ្នឹង? ឆៈ ប្រើដែរ យាមត្បាតពេលយប់នៅកោះកុង"] EN 00963732, KH 00926465។

801 ឯកសារ D54/97 កំណត់ហេតុនៃការស្តាប់ចម្លើយ ខឹម យ៉ាត, ឆ.24 ["ក្រោយមក គេឱ្យខ្ញុំបើកកប៉ាល់ PCF ហើយនៅរាម កប៉ាល់ PCF មានលេខ ១០១, ១០២, ១០៣, ១០៤។"]។ ឯកសារ D114/181 កំណត់ហេតុនៃការ ស្តាប់ចម្លើយ សែម កុល, ឆ.19 ["សៈ តើនាវារបស់លោកមានមូលដ្ឋាននៅទីណាដែរ? ឆ.19៖ នៅកោះរ៉ុងសន្លឹម និង រាម។"]។

802 ឯកសារ D2/10 កំណត់ហេតុនៃការស្តាប់ចម្លើយ សយ ប៊ន, ឆ.29 ["កងនាវាការពារ គឺកងនេះត្រូវបានរាយទៅប្រចាំការនៅកន្លែងផ្សេងៗតាមកោះ ហើយរងចាំបញ្ជាសម្រាប់ប្រយុទ្ធ"]។ ឯកសារ D114/181 កំណត់ហេតុនៃការស្តាប់ចម្លើយសែម កុល, ឆ.19, ឆ.24 ["សៈ តើនាវារបស់លោកមានមូលដ្ឋាននៅទីណាដែរ? ឆ.19៖ នៅកោះរ៉ុងសន្លឹម និងរាម។ [...] ឆ.24៖ នាវាទាំងអស់មាន ១០១, ១០២, ១០៣, ១០៤, ១០៥, ១០៦, ១០៧ និង ១០៨។ ខ្ញុំនៅនាវា ១០៤"]

និងបានចូលរួមក្នុងការប្រយុទ្ធ និងចាប់ទូកបរទេសជាច្រើន ដែលបានរកឃើញនៅក្នុងដែនទឹក ដែលត្រូវបានអះអាងថាជាដែនទឹករបស់កម្ពុជា[803]។ ទូកដែលផលិតនៅចិន និងមានបំពាក់អាវុធ

---

។ ឯកសារ D2/16 កំណត់ហេតុនៃការស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច, ឆ.30 [“ស៖ ពួក PCF តើជាផ្នែកមួយរបស់កងវរសេនាធំ១៤០ ឬកងជើងទឹកនៅលើដី? ឆ.30៖ ពួកគេមិនបានចតនៅឆ្នេរអូរឈើទាលទេ”]។ ឯកសារ D54/115.1 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា នាក់ យឿន, EN 01088470, KH 01007870 [“អឺ! PCF ច្រើនណាស់ ១៦ នោះ បើគ្រប់កោះ ម៉ាកោះមួយ កោះពីរ។ ហើយកោះរ៉ុង ប្រចាំការនៅកោះដែរ ប៉ុន្តែនៅកំពង់សោម”]។ ឯកសារ D4.1.758 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក មិនស្គាល់ឈ្មោះ, EN 00387313, KH 01506014 - 01506015 [“នាវាទាំងនោះបោះមូលដ្ឋាននៅទីតាំង ៣។ […] កងនាវាដែលរួមមាន នាវាលេខ១០៥ ១០៦ និង ១០២ ១០៤ និងនាវាលេខ ១០១ តាំងមូលដ្ឋាននៅកោះរ៉ុងសន្លឹម ចំណែកនាវាលេខ ១០៣ និង ១០៧ តាំងមូលដ្ឋាននៅកោះតាង។ […] នាវាចាស់២គ្រឿងប្រភេទ PCF របស់អាមេរិកបង្កើតបានជាកងនាវា១ និងបោះមូលដ្ឋាននៅកោះកុង”]។ សូមមើលផងដែរ ឯកសារ D54/34 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ឹង ឆុន, ឆ.14 [“នៅកោះកុង ក្នុងពេលនោះ គេមាននាវាចម្បាំងធុន PCF ចំនួន ២ គ្រឿង ដែលបោះទីតាំងនៅទីនោះ”]។ ឯកសារ D54/100 កំណត់ហេតុនៃការស្តាប់ចម្លើយ ឡាយ ប៊ុនហាក់, ឆ.60 - 61 [“[វរសេនាធំ ១៤០] មានពីរកន្លែង […] ឆ.61៖ […] [កន្លែងទី] មួយនៅកោះរ៉ុងសន្លឹម គ្រប់គ្រងនាវាការពារ”]។ ឯកសារ D59/1/1.9a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ឡាយ ប៊ុនហាក់, EN 00963730, KH 00926463 [“ PCF កប៉ាល់សម័យសង្គ្រាម […] ប្រើដែរ យាមត្បាតពេលយប់នៅកោះកុង”]។

803 ឯកសារ D54/51.1 សារទូរលេខលេខ ០៩ ពី មាស មុត ទៅបង ៨៩ (សុន សេន), ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៧៧, EN 01109278, KH 00970626 [“យើងខ្ញុំបានសម្រេចឱ្យបងប្អូនដែលប្រចាំការនៅទីនោះចេញ PCF យាមចុងកោះកុងពី ៦ ទៅ ១០ គីឡូម៉ែត្រ […] យើងចេញធ្វើការនោះ ក៏បានជួបហ្វូងកាណូតថៃប្រហែល ៥០ ទៅ ៦០ គ្រឿង យើងក៏សំដៅទៅរកវា ឯទៀតនាំគ្នារត់អស់ នៅសល់ធុន ៤០០ សេះមួយគ្រឿង ត្រូវយើងចាប់ខ្លួន]។ ឯកសារ D54/79 កំណត់ហេតុនៃការស្តាប់ចម្លើយ ណុប ហាល់, ឆ.8 [“ពេលនោះ គឺគេចាប់បានទូក វៀតណាមពីកោះប៉ូឡូវៃចាស់ ហើយមានមនុស្សជាង ១៦ នាក់ មានប្រុស មានស្រី និងក្មេង។ កាលនោះ ប្រហែលជានៅដើម ឆ្នាំ ១៩៧៨ ហើយពុំមានរលកច្រើនទេ។ ទូកនោះ ត្រូវបានចាប់នៅចន្លោះម៉ោង ៦ និង ៧ ព្រឹក ដោយនាវា PCF របស់វរសេនាធំ ១៤០ ដែលកាលនោះ គេកំពុងប្រចាំការនៅកោះប៉ូឡូវៃថ្មី ហើយទូកនោះ បើកមកក្បែរកោះប៉ូឡូវៃចាស់។”]។ ឯកសារ D54/73.2 របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពី ស៊ឹម ទៅ កងពល ១៦៤, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៧៧ [យោងទៅលើ “ចំពោះទូក […] ចាប់បាននៅខាងត្បូងកោះកុង។”]។ ឯកសារ D54/79 កំណត់ហេតុនៃការស្តាប់ចម្លើយ ណុប ហាល់, ឆ.3 [“នាវា PCF មានលក្ខណៈទំនើប លឿន និងបំពាក់ដោយអាវុធគ្រប់គ្រាន់។ ឯកសារ D114/95 កំណត់ហេតុនៃការស្តាប់ចម្លើយ យឹម ស្រៀង, ឆ.100, ឆ.107 [“កប៉ាល់ PCS តូច ហើយលឿនជាង ហើយស៊ីសាំងតិច ជាងកប៉ាល់ខ្ញុំ។ […] ឆ.107៖ បាទ! កប៉ាល់នោះ ធ្លាប់ចូលរួមប្រយុទ្ធជាមួយកប៉ាល់វៀតណាម នៅចុងឆ្នាំ ១៩៧៨។”]។ ឯកសារ D54/115.1 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា នាក់ យឿន, EN 01088458, KH 01007857 [“PCF របស់អាមេរិចកាំង ដែលយើងវាយបាន […] ប្រើការ អានឹងមាន ៨០

(អាចផ្ទុកមនុស្សបានពី ៣០ ទៅ ៤០ នាក់)[804] ត្រូវបានប្រើប្រាស់ដើម្បីវាយប្រហារកប៉ាល់ចម្បាំងធំៗ ដោយសារទូកប្រភេទនេះអាចផ្ទុកគ្រាប់រំសេវបានជិតមួយតោន[805]។ ទោះបីជាទូកប្រភេទ

---

[ទំហំក្បាលគ្រាប់80mm] នៅក្នុង [...] ហើយមាន១២អី [កាំភ្លើងយន្តទំហំ12.7mm] នៅលើនឹងដែរ"]។ ឯកសារ D114/281 កំណត់ហេតុនៃការស្តាប់ចម្លើយ ជុំ ជី, ឆ.36 ["បុគ្គលិក សមាជិកនៅលើ PCF គឺ ១២ នាក់។"]។ ឯកសារ D114/209 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ុង សេង, ឆ.27 ["ក្នុងមួយនាវា PCF មាន ១២ នាក់។"]។ ឯកសារ D54/34 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ុំ ឆុន, ឆ.14 - 15 ["នៅកោះកុង ក្នុងពេលនោះ គេមាននាវាចម្បាំងធុន PCF ចំនួន ២ គ្រឿង ដែលបោះទីតាំងនៅទីនោះ [...] ឆ.15៖ [...] យើងធ្លាប់ចាប់បានទូកនេសាទ ៣០០ សេះ ទៅ ៤០០ សេះ។"]។ ឯកសារ D114/15 កំណត់ហេតុនៃការស្តាប់ចម្លើយ សុក វណ្ណា (ស្លូស វណ្ណា), ឆ.23 ["ភាគច្រើនដែលចាប់នោះ គឺប្រភេទ ឬម៉ាក ៥២ ដែលចាប់ដោយកប៉ាល់ការពារ និងកប៉ាល់ PCF។"]។ ឯកសារ D4.1.758 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក មិនស្គាល់ឈ្មោះ, EN 00387313, KH 01506015 ["នាវាវាយប្រហាររហ័ស ខ្នាតតូច និងនាវាប្រភេទ PCF ត្រូវបានប្រើប្រាស់ដើម្បីឆែកឆេរនាវាបរទេសខ្នាតតូច ឬនាវាកម្ពុជាដែលប៉ុនប៉ងចាកចេញពី ដែនទឹកកម្ពុជា។"]។ ឯកសារ D59/1/1.12 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ណុប ហាល, EN 00968397 - 00968398, KH 00926623 ["ស៖ អីចឹងពេលពូទៅដល់កន្លែងកោះតាងហ្នឹង អី!ដូចថាពេលដូចទូកពួកនេសាទខាងថៃ ខាងយួនអីម៉េចដែរ ចូលមកក្នុងដែនសមុទ្រ មានអាហ្នឹងយើងមានវិធានការម៉េចខ្លះ? ឆ៖ ចាប់។ [...] អាដំបូងភ្លាមនឹង គឺមានតែ PCF ទេ ទៅចាប់។"]។ សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងការចាប់ទូកបរទេស សូមមើល VIII.ខ. ឧក្រិដ្ឋកម្មមកលើមនុស្សដែលចាប់ខ្លួនដោយកងនាវាជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ នៅដែនទឹក និងនៅលើដីកោះដែលកម្ពុជាប្រជាធិបតេយ្យអះអាងថាជារបស់ខ្លួន។

804 ឯកសារ D114/281 កំណត់ហេតុនៃការស្តាប់ចម្លើយ ជុំ ជី, ឆ.16 ["នាវាការពារ ១២៥ តោន ចំណុះសមាជិក ៣៧ នាក់។"]។ ឯកសារ D114/65 កំណត់ហេតុនៃការស្តាប់ចម្លើយ ជេត ប៊ុណ្ណា, ឆ.16 ["តាមដែលខ្ញុំនឹកឃើញ កប៉ាល់របស់ខ្ញុំ នោះមានលេខ ១០៤ ហើយវាមានចំណុះរហូតដល់ ១២៥តោន។ នាវិកដែលធ្វើការនៅលើនោះមាន ៣៦ នាក់ រួមទាំងអ្នក បើកបរកប៉ាល់ផង"]។ ឯកសារ D114/113 កំណត់ហេតុនៃការស្តាប់ចម្លើយ កឹម មេន, ឆ.145 - 146 ["ខ្ញុំឃើញកប៉ាល់ប្រភេទការពារ ដែលមានចិនជួយ ហើយពេលកប៉ាល់ទៅចតនៅកោះ ខ្ញុំឃើញមានមនុស្សប្រហែល ៣៦ ទៅ ៤០ នៅលើ កប៉ាល់។ [...] ឆ.146៖ គេបាញ់គ្នាក្នុងទឹក ប្រើគ្រាប់ ៣៧ មីលីម៉ែត្រ"]។ ឯកសារ D54/113 កំណត់ហេតុនៃការស្តាប់ចម្លើយ លៀង បៀ, ឆ.24 ["នាវាការពារមាននាវិកចំនួន៣៧នាក់ [...] ខ្ញុំនៅលើកប៉ាល់នេះ"]។ ឯកសារ D114/95 កំណត់ហេតុនៃការស្តាប់ចម្លើយ យឹម ស្រៀង, ឆ.86 - 87, ឆ.122។ ឯកសារ D54/87 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រំ សារ៉ាត់, ឆ.26។ ឯកសារ D4.1.758 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក មិនស្គាល់ឈ្មោះ, EN 00387313, KH 01506014។ ឯកសារ D114/181 កំណត់ហេតុនៃការស្តាប់ចម្លើយ សែម កុល, ឆ.24។ ឯកសារ D59/1/1.9a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ឡាយ ប៊ុនហាក់, EN 00963730, KH 00926462។ ឯកសារ D54/115.1

ណាក៏ដោយ ការបញ្ជាដោយផ្ទាល់ពីកងពលធំត្រូវការជាចាំបាច់សម្រាប់ទូកទាំងនេះ ដើម្បីបើកការវាយប្រហារសត្រូវ និងចាប់ទូកនានា[806]។

249. កងវរៈសេនាតូចលេខ ១៤៣ បានគ្រប់គ្រងកប៉ាល់ប្រឆាំងកប៉ាល់មុជទឹកចំនួនពីរគ្រឿង។ លៀត ឡួន ហៅ ណាំ ឡួន គឺជាប្រធានរបស់កងវរៈសេនាតូចនេះ ហើយ ជន គឺជាអ្នកដឹកនាំកប៉ាល់

កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា នាក់ យឿន, EN 01088457, KH 01007856 ។

805 ឯកសារ D114/281 កំណត់ហេតុនៃការស្តាប់ចម្លើយ ជុំ ជី, ឆ.37 ["ហើយទុកសម្រាប់បាញ់នាវាចម្បាំងធុនធំ ស៊ីជម្រៅទឹកជ្រៅ ចាប់ពី ៤ ម៉ែត្រចុះក្រោម។"]។ ឯកសារ D4.1.758 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក មិនស្គាល់ឈ្មោះ, EN 00387313, KH 01506015 ["នាវាខ្នាតធំ និងនាវាពិឃាដដែលផលិតនៅប្រទេសចិន ត្រូវបានប្រើប្រាស់ដើម្បីបញ្ឈប់ និងព្រមានដល់កប៉ាល់ ដឹកទំនិញខ្នាតធំ ឬក្នុងករណីដែលអាចកើតមានជម្លោះជាមួយនាវាប្រដាប់អាវុធផ្សេងទៀត"]។ ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974102 - 00974103, KH 00926546 - 00926547 ["ស៖ ចឹង បណ្តែតហ្នឹង យើងសម្រាប់ធ្វើយ៉ាងម៉េចទៅ? ឆ៖ លក្ខណៈរបស់វា វ៉ៃឆ្នក់ និងវ៉ៃកម្ទេច ព្រោះគ្រាប់របស់វាមានរំសេវនៅក្នុង គ្រាប់ជិតមួយតោន។ [...] ឬមួយកប៉ាល់មានកងទ័ពវ៉ៃវាឲ្យទ្រោមហើយ តែលក្ខណៈធ្វើឲ្យវាលិច ធ្វើអត់បានទេ ត្រូវឲ្យកប៉ាល់ហ្នឹងទៅវ៉ៃពន្លេចចោល។ [...] កប៉ាល់របស់ចិន។ ស៖ ចឹងកប៉ាល់បណ្តែត និងវាខុសពីកប៉ាល់ការពារ និងកប៉ាល់ ល្បាត? ឆ៖ ខុស"]។

806 ឯកសារ D54/79 កំណត់ហេតុនៃការស្តាប់ចម្លើយ ណុប ហាល់, ឆ.3 ["ខ្ញុំសូមពន្យល់អំពីដំណើរការចាប់ទូកដែលមានដំណាក់កាលដូចតទៅ៖ កងវរសេនាតូចរាយការណ៍ទៅកងវរសេនាធំអំពីទូកដែលចូលមកឈ្លានពាន ហើយជាទូទៅ កង វរសេនាធំ រាយការណ៍ទៅកងពលធំ ដែលមានទីតាំងនៅកំពង់សោម។ ក្រោយមក កងពលធំ ១៦៤ បញ្ជូននាវា PCF របស់កងវរសេនាធំ ១៤០ ដែលជួនកាលស្ថិតនៅកំពង់សោម និងនៅទីតាំងប្រចាំការ"]។ ឯកសារ D114/95 កំណត់ហេតុនៃការស្តាប់ចម្លើយ យឹម ស្រៀង, ឆ.86, ឆ.95, ឆ.101 ["ស៖ តើកប៉ាល់ ១០២ ជាប្រភេទកប៉ាល់អ្វី? ឆ.86៖ ជាកប៉ាល់ការពារ ដែល ផលិតនៅប្រទេសចិន។ [...] ស៖ មុនពេលសម្រាក លោកបាននិយាយថាកប៉ាល់ ១០២ គឺចេញបានទាល់តែមានបញ្ជាពីថ្នាក់ កងពល តើត្រឹមត្រូវទេ? ឆ.95៖ បាទ! [...] ឆ.101៖ លុះត្រាតែមានបញ្ជាពីថ្នាក់លើ ទើបកប៉ាល់ខ្ញុំចេញ"]។ ឯកសារ D54/34 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ឹង ឆុន, ឆ.14, ឆ.22 ["នៅកោះកុង ក្នុងពេលនោះ គេមាននាវាចម្បាំងធុន PCF ចំនួន ២ គ្រឿង ដែលបោះទីតាំងនៅទីនោះ ដែលមានមេបញ្ជាការនាវាទាំងពីរ ឈ្មោះ ស៊ឹម [...] ឆ.22៖ តាស៊ឹម មិនមានសិទ្ធិសម្រេចលើអ្វីដែលត្រូវធ្វើចំពោះទូកដែលត្រូវចាប់បាននោះ គាត់ត្រូវតែធ្វើតាមបញ្ជាពីកងពល"]។ ឯកសារ D54/113 កំណត់ ហេតុនៃការស្តាប់ចម្លើយ លៀង ប៉ៀ, ឆ. 47 - 48។ ឯកសារ D4.1.758 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក មិនស្គាល់ឈ្មោះ, EN 00387313, KH 01506014 [លម្អិតអំពីប្រព័ន្ធវិទ្យុទាក់ទង]។

ផ្សេងៗក្នុងឆ្នាំ ១៩៧៨[807]។ កន្លងមក នៀវ រ៉ែម (រ៉ែន) គឺជាលេខាកងវរៈសេនាតូចលេខ ១៤៣ (អតីតស្ថិតក្នុងកងវរៈសេនាតូចលេខ ៣៨៦)[808]។ គាត់ត្រូវបានកងអង្គរក្សរបស់កងវរៈសេនាតូចពិសេសលេខ ១៦៥ របស់ **មាស មុត** បាញ់សម្លាប់ នេះបើយោងតាមសាក្សី ឯក នី[809]។

---

807 លៀត ឡូន បានសារភាពខ្លួនឯងថា ពីរខែក្រោយពីគាត់ត្រឡប់មកវិញនៅឆ្នាំ ១៩៧៨ ពីរៀនបច្ចេកទេសរយៈពេលយូរនៅប្រទេសចិនមក គាត់ក្លាយជាប្រធានកងវរសេនាតូចនាវាមុជទឹក ប៉ុន្តែគាត់ច្រឡំលេខវរសេនាតូច (១៤៣) ជាមួយនឹងកងវរសេនាតូចលេខ ១៤២: ឯកសារ D114/103 កំណត់ហេតុនៃការស្តាប់ចម្លើយ លៀត ឡូន (ណាំ ឡូន), ឆ.67, ឆ.71, ឆ.83, ឆ.86, ឆ.102 ["សៈ តើគេឲ្យមុខតំណែងលោកជាអ្វី? ឆ.67៖ ប្រធានផ្នែកប្រឆាំងនាវាមុជទឹក [...] ឆ. 71៖ មាននាវាប្រឆាំងនឹងនាវាមុជទឹកចំនួន ២ គ្រឿង ត្រូវបាននាំមក។ [...] ឆ.83៖ នៅក្នុងអង្គភាពរបស់ខ្ញុំ ដែលជាអង្គភាពប្រឆាំងនាវាមុជទឹក គឺកងសេនាតូច ១៤២ [...] សៈ តើនៅក្នុងកងវរសេនាតូចរបស់លោក អ្នកណាជាមេបញ្ជាការ? ឆ.86៖ កាលពីមុន គឺរូបខ្ញុំ។ [...] សៈ តើអ្នកណាជាអ្នកតែងតាំងលោកឲ្យធ្វើជាមេបញ្ជាការកងវរសេនាតូច? ឆ.102៖ ទីម សេង"]។ ឯកសារ D2/10 កំណត់ហេតុនៃការស្តាប់ចម្លើយ សយ ប៊ន, ឆ.33 ["នៅក្នុងកងនាវាប្រឆាំងនឹងនាវាមុជទឹកនោះ មាននាវាចំនួនតែ ២ គ្រឿងទេ។"]។ ឯកសារ D114/15 កំណត់ហេតុនៃការស្តាប់ចម្លើយ សុក វណ្ណា (សួស វណ្ណា), ឆ.26 - 27 ["សៈ តើអ្នកណាជាមេកងកប៉ាល់ប្រឆាំងនាវាមុជទឹក? ឆ.26៖ ខ្ញុំនៅលើនាវា ០១១ ហើយមេបញ្ជាការខ្ញុំ ឈ្មោះ ជន។ ជន ទទួលបញ្ជាដោយផ្ទាល់ពី មាស មុត។ នាវាប្រឆាំងនឹងនាវាមុជទឹកទាំងពីរគ្រឿង ស្ថិតនៅក្រោមបញ្ជាផ្ទាល់របស់ មាស មុត។ [...] សៈ តើអ្នកណាជាមេបញ្ជាការនៅលើនាវាប្រឆាំងនាវាមុជទឹកលេខ ០១២? ឆ.27៖ ឈ្មោះ ឡូន ជាមេបញ្ជាការ។"]។ ឯកសារ D4.1.761 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក មិនស្គាល់ឈ្មោះ, EN 00387299, KH 01507823 ["មេបញ្ជាការកងវរសេនាតូចប្រឆាំងនឹងនាវាមុជទឹក គឺ ((ចន)) [...] មេបញ្ជាការរង គឺ ((ឡូន))"]។ ឯកសារ D54/98 កំណត់ហេតុនៃការស្តាប់ចម្លើយ ហ៊ាង រ៉េត (ហៀង រ៉េត), ឆ.31។ ឯកសារ D114/261 កំណត់ហេតុនៃការស្តាប់ចម្លើយ ជុំ ជី, ឆ.7 ។

808 ឯកសារ D1.3.30.5 របាយការណ៍សេនាធិការ របស់កម្ពុជាប្រជាធិបតេយ្យ តារាងស្ថិតិសិក្ខាកាមរៀន នៅវគ្គសេនាធិការលើកទី១ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៧៦, EN 00897656, KH 00095537 [បញ្ជីលេខរៀង ១៣១ នៀវ រ៉ែមជាលេខាវរសេនាតូច នៅកងពល ១៦៤]។ ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974099, KH 00926543 ["១៤៣ ឈ្មោះ តារ៉ែន"]។ សូមមើលផងដែរ ឯកសារ D4.1.1066 ចម្លើយសារភាពពីមន្ទីរស-២១ ប៉ែន ហាម ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៧៧, EN 00822410, KH 00174164 [កំណត់អត្តសញ្ញាណ ឈ្មោះ រ៉ែម លេខាវរសេនាតូច ១៤៣ វរសេនាធំ ១៤០]។

809 ឯកសារ D54/101 កំណត់ហេតុនៃការស្តាប់ចម្លើយ ឯក នី ឆ.10 ["នៅក្នុងពេលនោះ ថ្នាក់ដឹកនាំកងពល គេបានដកពួកអតីតយោធារបស់កងវរសេនាតូច ៣៨៦ ចេញពីកោះ និងកន្លែងផ្សេងៗ រួចបញ្ជូនយកទៅដាក់នៅក្នុងកងផលិត។ ពេលនោះ ខ្ញុំឮយោធាដែលត្រូវដកចេញ ហើយយកទៅដាក់នៅកងផលិតជាមួយខ្ញុំនិយាយថា បងរ៉ែម ដែលជាអតីតមេបញ្ជាការ កងវរសេនាតូច ៣៨៦ ត្រូវបានគេបាញ់សម្លាប់នៅមុខវត្តឥន្ទញាណ។ [...] ពួកយោធានោះហើយគឺមកពីកងពិសេសរបស់ តា មុត។ ពួកនោះគឺដូចជាកងអង្គរក្សរបស់តា មុត ឬក៏ហៅថាកងដៃស្តាំរបស់គាត់។ បន្ទាប់ពី

250. កងវរៈសេនាតូចលេខ ១៤៤ ស្ថិតក្រោមបញ្ជារបស់ ហាន រហូតដល់ពាក់កណ្ដាលឆ្នាំ ១៩៧៨ ជាពេលដែលគាត់បានក្លាយជាមេបញ្ជាការកងវរៈសេនាធំលេខ ១៤០[810]។ កងវរៈសេនាតូចនេះមានទូកបោសសម្អាតមីនចំនួនបួនគ្រឿង ដែលត្រូវបាននាំយកទៅកាន់សមុទ្រ បន្ទាប់ពីត្រូវបានប្រើប្រាស់ដើម្បីកម្ទេចមីននៅទន្លេមេគង្គរួចមក[811]។ ទូកចំនួនពីរគ្រឿងឈរជើងនៅកែប[812] ហើយទូក

---

ដាល់ពួកយោធាទាំងនោះហើយ វ៉ែម បានលោតចុះពីលើឡាន ហើយពួកយោធាបានបាញ់ចំក្បាលរបស់គាត់ ហើយគាត់ដួលស្លាប់នៅលើថ្នល់នៅមុខវត្តឥន្ទញ្ញាណនោះតែម្ដង"]។

810 ឯកសារ D2/9 កំណត់ហេតុនៃការស្ដាប់ចម្លើយ សយ ប៊ន, ឆ.13 ["កងវរសេនាតូចរបស់ខ្ញុំពេលនោះ គឺវរសេនាតូច ១៤៤ ដែលមានប្រធានឈ្មោះ ហាន"]។ ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974099, KH 00926543 ["១៤៤ ឈ្មោះ ហាន ហ្នឹងដល់ក្រោយមកទៀត ហាន ហ្នឹងមកកាន់ ១៤០"]។ សូមមើលផងដែរ ឯកសារ D1.3.5.13 បញ្ជីឈ្មោះមនុស្សដែលជាប់ក្នុងចម្លើយខ្មាំងរបស់មន្ទីរស-២១, EN 01148978, KH 00161771 [កំណត់អត្តសញ្ញាណ ឈ្មោះ ហាន ជាមេបញ្ជាការវរសេនាតូច ១៤៤]។ យោងទៅលើការតំឡើងតួនាទីរបស់ ហាន ជាមេបញ្ជាការវរសេនាធំ ១៤០ នៅពាក់កណ្ដាលឆ្នាំ ១៩៧៨ សូមមើល កថាខណ្ឌ ២៤៤ ខាងលើ។

811 ឯកសារ D54/87 កំណត់ហេតុនៃការស្ដាប់ចម្លើយ ព្រំ សារ៉ាត់, ឆ.25 ["ពីពាក់កណ្ដាលឆ្នាំ ១៩៧៦ រហូតដល់ឆ្នាំ ១៩៧៩ កងវរសេនាធំ ១៤០ [...] កប៉ាល់បោសសម្អាតមីនចំនួន ៤ គ្រឿង"]។ ឯកសារ D2/10 កំណត់ហេតុនៃការស្ដាប់ចម្លើយ សយ ប៊ន, ឆ.35 ["នាវានោះ គេហៅថានាវាបោសសម្អាតមីន។ មាននាវា ៤ គ្រឿង ប៉ុន្តែសុទ្ធតែចាស់ៗ [...] នៅពេលនោះ មិនមែនសម្រាប់តែបោសសម្អាតមីននៅក្រោមសមុទ្រនេះទេ គឺយកទៅបោសសម្អាតមីននៅទន្លេមេគង្គផងដែរ"]។ ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974104, KH 00926548 ["មាន៤គ្រឿងកាលហ្នឹង ពួកអាបណ្ដាច់មីនហ្នឹង យកមក បណ្ដាច់មីន បោសមីនតាមទន្លេមេគង្គ កាលហ្នឹង។ [...] ខ្ញុំបើកតើកាលហ្នឹង បើយកមកប្រើប្រាស់ទន្លេមេគង្គអស់ ហើយបានគេឲ្យទៅសមុទ្រវិញ"]។

812 ឯកសារ D2/10 កំណត់ហេតុនៃការស្ដាប់ចម្លើយ សយ ប៊ន, ឆ.35 ["ស៖ តើលោកមានដែលឮអំពី គេហៅថា ប៉ុស្តិ៍ឃ្លាំមើលជួរមុខនៅហ្នឹង កែប កន្លែងដែលមាននាវាបោសសម្អាតមីន ២ គ្រឿងដែរឬទេ? ឆ.35៖ នាវានោះ គេហៅថានាវាបោសសម្អាតមីន"]។ ឯកសារ D4.1.758 សេចក្ដីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក មិនស្គាល់ឈ្មោះ, EN 00387312, KH 01506014 ["លម្អិតអំពីប្រព័ន្ធវិទ្យុទាក់ទង"]។

នៅសល់ផ្សេងទៀតឈរជើងនៅកោះរុងសន្លឹម[813]។ កប៉ាល់ល្បឿនលឿនទាំងនោះត្រូវបានប្រើប្រាស់ដើម្បីការពារដែនទឹកសមុទ្រ និងជួយក្នុងការចាប់ទូកបរទេស[814]។

251. កងវរៈសេនាតូចនីមួយៗ នៃកងវរៈសេនាតូចទាំងបួនរបស់កងវរៈសេនាធំលេខ ១៤០ ត្រូវបានបណ្ដុះបណ្ដាល និងរៀបចំឱ្យទទួលខុសត្រូវលើទូកយាមល្បាតនៅឯសមុទ្រ និងនៅជុំវិញកោះរបស់កម្ពុជា[815]។ តំបន់យាមល្បាតត្រូវបានបែងចែង ហើយកងវរៈសេនាតូចទាំងនេះនឹងផ្លាស់ប្ដូរវេនគ្នាដើម្បីយាមល្បាតតំបន់រៀងៗខ្លួនរបស់កងវរៈសេនាតូចទាំងនោះ[816]។

---

813 ឯកសារ D59/1/1.8a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រុំ សារ៉ាត់ EN 00974177, KH 00926360 [“ខ្ញុំនៅក្នុងវរៈ ៤៤”]។ EN 00974188, KH 00926369 [“នៅតាមចំនុចខ្លះៗទៅនៅកោះរ៉ុងសន្លឹម ព្រោះ កន្លែងហ្នឹងវាខ្យល់ស្ងាត់រលក”]។

814 ឯកសារ D54/102 កំណត់ហេតុនៃការស្ដាប់ចម្លើយ ឯក នី, ឆ.29 [“នៅពេលនោះ គេប្រើនាវាបោសសម្អាតមីន ដែលមានល្បឿនលឿន ដើម្បីចាប់ទូកនេសាទថៃ”]។ ឯកសារ D54/109 កំណត់ហេតុនៃការស្ដាប់ចម្លើយ សៅ សំ, ឆ.11 [“នៅពេលណាដែលយើងឃើញទូកវៀតណាម ថៃ ឬក៏ទូកបរទេសណាផ្សេងទៀត ចូលមកដែនទឹកយើង យើងរាយការណ៍តាមវិទ្យុទាក់ទង ទៅឱ្យមូលដ្ឋានកងពល ១៦៤ នៅកំពង់សោម។ ខាងកងពល គេនឹងចេញកប៉ាល់របស់គេដែលជាកប៉ាល់បោសសម្អាតមីន ដែលមានល្បឿនលឿនឱ្យតាមចាប់ទូក ឬកប៉ាល់នោះ”]។ ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974105, KH 00926548 [“ស្រុកខ្មែរគេជួយមកសម្រាប់បំផ្លាញមីន ហើយយើងចេះតែប្រើទៅអាហ្នឹងលឿនណាស់ ទៅចាប់ទូកអីហ្នឹងមួយពព្រិចដល់”], EN 00974108, KH 00926551 [“យកអាកប៉ាល់បោសមីនអីហ្នឹង ពួកអាបណ្ដែតជិនាន់ចាស់[ចាប់ទូក]”]។

815 ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974099, KH 00926543 - 00926544 [“ជ្រើសតាមវរៈមួយៗមករៀនហើយបានគេរៀបចំមកតាមអង្គភាពបណ្ដែត ការពារដែន សមុទ្រ។ […] ប្រធានវរៈមកកាន់ខាងការពារទាំងអស់ មឿន ការពារ សាង ក៏ការពារ តារ៉ែន ការពារ និង ហាន ក៏ការពារដែរ”], EN 00974100, KH 00926544 [“កប៉ាល់ការពារមានតួនាទីធ្វើអីខ្លះទៅ? ឆ៖ […] ល្បាតតាមសមុទ្រអីហ្នឹង”]។ ឯកសារ D59/1/1.8a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រុំ សារ៉ាត់, EN 00974192, KH 00926373 [“ភារកិច្ចការពារអត់មានអីទេ យប់ឡើងចេញ ឧទាហរណ៍នាវាខ្ញុំចេញទៅប្រចាំការ បោះល្បាតនៅកោះឫស្សីអាហ្នឹងខ្លួនខ្ញុំ”]។

816 ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974100, KH 00926544 [“ដល់ពេលគេចែកតំបន់ល្បាត គេចែកតាមតំបន់របស់វា ហើយដាក់វេនគ្នា”]។

## <u>កងវរៈសេនាតូចឯករាជ្យ</u>

### *ក) កងវរៈសេនាតូចលេខ ១៦៥ (កងកម្លាំងពិសេស អតីតកងវរៈសេនាតូចលេខ ៤៥០)*

252. កងវរៈសេនាតូចលេខ ១៦៥ (អតីតកងវរៈសេនាតូចលេខ ៤៥០ ដែលចំណុះឲ្យកងពលធំលេខ ៣) គឺជាអង្គភាពពិសេស និងឯករាជ្យរបស់កងពលធំលេខ ១៦៤ (ហៅថា "កងកម្លាំងពិសេស" ឬអង្គភាពអន្តរាគមន៍ពិសេស) ដែលរាយការណ៍ដោយផ្ទាល់ទៅ **មាស មុត** ប៉ុន្តែមិនស្ថិតក្រោមបទបញ្ជារបស់កងវរៈសេនាធំនោះទេ[817]។

[817] ឯកសារ D54/7 កំណត់ហេតុនៃការស្តាប់ចម្លើយ ឌុល សុង, ឆ.8, ឆ.10 - 11, ឆ.13 ["កងពលលេខ៣ មានវរសេនាធំលេខ ២០, ២១, ២២, កងវរសេនាតូចពិសេស និងកងកាំភ្លើងធំ[...] ឆ.10៖ កងវរសេនាតូចពិសេសនេះ ពុំមានឋិតនៅក្រោមបញ្ជាការរបស់វរសេនាធំណាមួយទេ វាឋិតនៅក្រោមបញ្ជាការរបស់កងពល។ [...] ស៖ តើកងវរសេនាតូចពិសេសនេះត្រូវបានចាត់តាំងឲ្យធ្វើអ្វីក្រោយឆ្នាំ ១៩៧៥ ពេលកងពល៣ /១៦៤ មកនៅកំពង់សោម? ឆ.11៖ កងវរសេនាតូចពិសេស នេះ គឺឋិតនៅជាមួយបញ្ជាការ ឬស្នងការកងពល។ [...] ឆ.13៖ ខ្ញុំដឹងច្បាស់ថា កងវរៈពិសេសនេះឋិតនៅក្រោមបញ្ជាការ ផ្ទាល់របស់កងពល។ កងវរៈពិសេសនេះ មិនឋិតនៅក្រោមបញ្ជាការរបស់វរសេនាធំណាមួយទេ។ ឋានៈរបស់ មឿន ដែលជាមេបញ្ជាការរបស់វរសេនាតូចពិសេសនេះ គឺមានឋានៈដូចមេបញ្ជាការកងវរសេនាធំដទៃទៀតក្នុងកងពលដែរ។ ពេលដែលមានប្រជុំ មេបញ្ជាការវរសេនាធំទាំងអស់ត្រូវបានហៅទៅចូលរួមប្រជុំ ហើយ មឿន ក៏ត្រូវបានហៅទៅចូលរួមប្រជុំជាមួយដែរ"]។ ឯកសារ D54/98 កំណត់ហេតុនៃការស្តាប់ចម្លើយ ហ៊ាង រ៉េត (ហៀង រ៉េត), ឆ.28 ["កងវរសេនាតូច ៤៥០ បានក្លាយជា កងវរសេនាតូច ១៦៥ ដែលជាកងអន្តរាគមន៍ពិសេស។"]។ ឯកសារ D114/83 កំណត់ហេតុនៃការស្តាប់ចម្លើយ សុខ នាង, ឆ.19 ["១៦៥ ខ្ញុំគិតថា ជាកងវរសេនាតូចពិសេស"]។ ឯកសារ D54/10 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ី រ៉េត (សារ៉េត), ឆ.27 ["វរសេនាតូច ៤៥០ គឺកងពិសេសរបស់ តាមុត"]។ ឯកសារ D54/46 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ.27, ឆ.38 ["គេបានផ្លាស់ខ្ញុំពីកងវរសេនាតូច ៤១៥ ដោយបង្កើតជាកងពិសេសកងវរសេនាតូច ៤៥០ របស់កងពល៣ [...] ឆ.38៖ ខ្សែសង្វាក់បញ្ជាដូចខាងក្រោម សម្រាប់ទ័ពថ្មើរជើង គឺបញ្ជាចេញពីកងពលលេខ ៣ មកវរសេនាធំ។ ពីវរសេនាធំមកកងវរសេនាតូច។ ហើយពីវរសេនាតូចទៅអនុសេនាធំ។ តែសម្រាប់កងពិសេសរបស់ខ្ញុំ វរសេនាតូច ៤៥០ គឺទទួលបញ្ជាផ្ទាល់ពី មាស មុត ដែលជាមេបញ្ជាការកងពលលេខ ៣ តែម្តង"]។ ឯកសារ D114/15 កំណត់ហេតុនៃការស្តាប់ចម្លើយ សុក វណ្ណា (សួស វណ្ណា), ឆ.18 ["ឆ៖ តើលោកធ្លាប់ឮអំពីកងវរសេនាតូចពិសេស ៤៥០ នៃកងពលលេខ ៣ ដែរឬទេ? ឆ. 18៖ បាទ! ខ្ញុំធ្លាប់ឮអំពីកងនេះ គឺនៅក្រោម មាស មុត"]។ ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974081, KH 00926527 ["កងពិសេស បើនិយាយទៅជាកងឯករាជ្យរបស់កងពល។ [...] ស្មើនឹងកងវរសេនាធំដែរ"]។ ឯកសារD4.1.762 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក កាំ ម៉ែន, EN 00387328, KH 00742578 ["កងពលធំ ១៦៤

253. មុនពេលបង្កើតកងពលធំលេខ ១៦៤ កងវរៈសេនាតូចលេខ ៤៥០ ទទួលបន្ទុកលើកិច្ចការជាច្រើន ដូចជា ជួយដល់កងវរៈសេនាធំក្នុងសមរភូមិជួរមុខមុនអំឡុងខែ មេសា ឆ្នាំ ១៩៧៥ ការពារឃ្លាំងកំពង់ផែនៅកំពង់សោម ឬត្រូវបានដាក់ពង្រាយនៅកោះតាងកាលពីអំឡុងខែ មេសា និងសីហា ឆ្នាំ ១៩៧៥[818]។ កិច្ចការថ្មីរបស់កងវរៈសេនាតូចលេខ ១៦៥ ត្រូវបានកែសម្រួលឡើងវិញ ក្រោយ

---

ត្រូវបានរៀបចំជាកងទ័ពថ្មើរជើង ក្រោមឱវាទចំនួនបីកងវរសេនាធំគឺ កងវរសេនាធំលេខ ៦១ ៦២ និង៦៣ រួមទាំងកងវរសេនាតូចប្រតិបត្តិការពិសេសលេខ ៤៥០"]។

818 ឯកសារ D2/15 កំណត់ហេតុនៃការស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច, ឆ.23, ឆ.34 ["សៈ លោកបានប្រាប់យើងពីម្សិលមិញថា ការងាររបស់វរសេនាតូច ៤៥០ នោះ គឺផ្លាស់ប្តូរពីមួយពេលទៅមួយពេល ដែលក្រោយមក កងនេះបានក្លាយទៅជាកងទទួលខុសត្រូវនៅមន្ទីរសន្តិសុខ តើមែនឬទេ? ឆ.23៖ ក្រោយមក ដោយពុំមានការប្រយុទ្ធនៅលើសមរភូមិទៀតទេ កង ៤៥០ នោះ ត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវខាងផ្នែកសន្តិសុខវិញ [...] សៈ លោកបាននិយាយថា កង ៤៥០ គឺជាកងសន្តិសុខរបស់កងពល ១៦៤ ទទួលខុសត្រូវនៅក្រុងកំពង់សោម តើក្រៅពីវត្តឥន្ទញ្ញាណមានមន្ទីរសន្តិសុខនៅកន្លែងផ្សេងទៀតដែរឬទេ? ឆ.34៖ ពីព្រោះខ្ញុំមិនបានឃើញផ្ទាល់នឹងភ្នែក ខ្ញុំសូមមិននិយាយ។"]។ ឯកសារ D54/10 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ី រ៉េត (សារ៉េត), ឆ.28 ["សៈ តើ មាស មុត គាត់ប្រើវរសេនាតូច ៤៥០ នេះយ៉ាងម៉េច? ឆ.28៖ ក្នុងរយៈពេលសង្គ្រាម គាត់តែងបញ្ជូនកងពិសេសនេះ ទៅសមរភូមិ ដែលតឹងតែងខ្លាំង"]។ ឯកសារ D54/46 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ.32, ឆ.35 ["សៈ ហេតុអ្វីបានជាកងពិសេសនេះ ត្រូវបានបង្កើតឡើង? ឆ.32៖ គេហៅថាកងពិសេស ដោយសារកងនោះជាកងជំនួយ។ កងពិសេសនេះដូចជាកងជំនួយអីចឹង។ នៅពេលដែលកងថ្មើរជើងហ្នឹង ត្រូវការជំនួយ កងពិសេសនេះ ជាអ្នកជួយ [...] ឆ.35៖ មាស មុត ប្រកាសក្នុងអង្គប្រជុំថា កងពិសេសត្រូវបានបង្កើតឡើង ហើយតែងនៅពីក្រោយកងថ្មើរជើង"]។ ឯកសារ D114/285 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រុំ សារ៉ាត់ (ប៊ុន សារ៉ាត់), ឆ.173 ["សៈ តាមលោកដឹង តើ ៤៥០ គេទទួលខុសត្រូវ និងមានតួនាទីអ្វីដែរ? ឆ.173៖ តាមការរៀបចំ តួនាទី និង ទទួលខុសត្រូវ សម្រាប់អន្តរាគមន៍ ពេលព្រឹត្តិការណ៍យោធា នៅចំណុចមួយណា ដែលវរសេនាធំដទៃ មានជួបឧបទ្ទវហេតុ គឺកងនេះ ជួយទាន់ពេលវេលា"]។ ឯកសារ D114/287 កំណត់ហេតុនៃការស្តាប់ចម្លើយ ប៉ាង រ៉េត (ហៀង រ៉េត), ឆ.2, ឆ.43 ["អង្គភាពរបស់ខ្ញុំមួយកងវរៈហ្នឹង មានតួនាទីគ្រប់គ្រងឃ្លាំងកំពង់ផែទាំងអស់ ហើយចំណុចសំខាន់ៗ គឺក្រុមខ្ញុំការពារទាំងអស់ [...] ឆ.43៖ ៤៥០ ក្រោយមកទៅជាកងវរសេនាតូច ១៦៥ ជ្រើសរើសមួយអនុសេនាធំ ២០ ឬ ៣០ នាក់ ដោយមានមេបញ្ជាការទៅអមជាមួយ"]។ ឯកសារ D114/15 កំណត់ហេតុនៃការស្តាប់ចម្លើយ សុក វណ្ណា (សួស វណ្ណា), ឆ.9, ឆ.13 - 14 ["ខ្ញុំធ្វើការនៅក្នុងកងពិសេស ឬ ហៅថា កងស៊ើបការណ៍[...] ឆ.13៖ មានអង្គភាពពិសេសផ្ទាល់កងពលមួយក្រុមសម្រាប់ការពារ និងគាំទ្រពិសេសដល់មេកងពល។ [...] ឆ.14៖ ចំពោះកងពិសេសរបស់កងពល ពួកគេអាចចល័តបានគ្រប់ទីកន្លែងនៅក្នុងកងពលទាំងមូល និងចូលវាយប្រយុទ្ធក្នុងស្ថានភាពពិសេសៗ ឬជួយដល់កងវរសេនាធំផ្សេងៗ"]។ ឯកសារ D4.1.745 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក មិនស្គាល់ឈ្មោះ, EN 00387261, KH 01513914 ["នៅពេលកងកម្លាំងអាមេរិកបានវាយប្រហារកោះតាង ពួកកុម្មុយនិស្តខ្មែរបានពង្រឹងកងកម្លាំងនៅលើកោះ ដោយកងទ័ពបន្ថែមប្រមាណ ៣០០ នាក់ [...] ក្រុមនេះ ត្រូវបានបង្កើតឡើងចេញ

អំឡុងខែ កក្កដា-សីហា ឆ្នាំ ១៩៧៥ ឲ្យផ្តោតតែលើផ្នែកសន្តិសុខ និងការការពារប៉ុណ្ណោះ ៖ កងវរៈសេនាតូចពិសេសនេះ ត្រូវការពារ **មាស មុត** គ្រប់ពេល ការពារសន្តិសុខនៅទីបញ្ជាការកងពលធំ និងក្រុងកំពង់សោម គ្រប់គ្រង និងការពារសន្តិសុខមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ និងបើកការស៊ើបអង្កេត និងចាប់ខ្លួនកងទ័ពក្នុងកងពលធំលេខ ១៦៤ ដែលគេចាត់ទុកថាជាជនក្បត់ ឬ "សមាសធាតុមិនល្អ"[819]។

---

សមាជិកដើមនៃអង្គភាពលេខ ២ នៃកងវរសេនាតូចទី ៤៥០ សមាជិកផ្សេងៗទៀត នៃកងវរសេនាតូចទី ៤៥០ និង កងវរសេនាតូចទី ៤៨០"]។

819 ឯកសារ D234/2.1.92 ប្រតិចារឹក ព្រំ សារ៉ាត់, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦, ម៉ោង 14.39.40 - 15.03.11 ["កង ៤៥០ អាហ្នឹង ជាកង កាលនោះ ខ្ញុំនៅចាំបានថា ជាកងពិសេសរបស់កងពលប្រចាំជុំវិញកងពល ១៦៤"]។ ឯកសារ D54/7 កំណត់ហេតុនៃការស្តាប់ចម្លើយ ឌុល សុង, ឆ. 11 ["ស៖ តើកងវរសេនាតូចពិសេសនេះត្រូវបានចាត់តាំងឲ្យធ្វើអ្វីក្រោយឆ្នាំ ១៩៧៥ ពេលកងពល៣ /១៦៤ មកនៅកំពង់សោម? ឆ.11៖ កងវរសេនាតូចពិសេសនេះ គឺថិតនៅជាមួយបញ្ជាការ ឬស្នងការកងពល។ មុខងារ របស់កងពិសេស គឺការពារថ្នាក់ដឹកនាំកងពល និងចាប់ចងអ្នកដែលមានទោស។ នៅពេលនោះ ប្រទេសជាតិបានសន្តិភាព ហើយ កងពិសេសនេះ មិនត្រូវការទៅច្បាំងនៅកន្លែងណាទេ ដូច្នេះ កងពិសេសសម្រាប់ការពារថ្នាក់ដឹកនាំកងពល និងចាប់ចងអ្នកធ្វើខុស"]។ ឯកសារ D2/15 កំណត់ហេតុនៃការស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច, ឆ.14, ឆ.20, ឆ.23 - 24 ["ស៖ ពេលនោះ តើមេបញ្ជាការ [សរ សារឿន] កងពិសេសហ្នឹង គេរៀបទីតាំងនៅកន្លែងណា? ឆ.14៖ ពេលមកដល់ ដំបូង គាត់ស្នាក់នៅឃ្លាំងប្រាក់ ឬធនាគារជាតិនៅជិតផែកប៉ាល់។ ពីរ បី ថ្ងៃក្រោយមក ទើបរើទៅនៅវត្តឥន្ទញ្ញាណ។ [...] ឆ.20៖ បាទ! វាជាកងតែមួយ គឺកងវរៈ ៤៥០ ឬកងពិសេសរបស់កងពល ១៦៤។ [...] ឆ.23៖ ក្រោយមកដោយពុំមានការប្រយុទ្ធនៅលើសមរភូមិទៀតទេ កង ៤៥០ នោះ ត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវខាងផ្នែកសន្តិសុខវិញ។ ស៖ តើនៅមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ ឬយ៉ាងណា? ឆ.24៖ មិនមែនតែកន្លែងវត្តឥន្ទញ្ញាណហ្នឹងទេ គឺជាកងសន្តិសុខរបស់កងពល ១៦៤ នៅក្រុងកំពង់សោមទាំងមូល។"]។ ឯកសារ D54/98 កំណត់ហេតុនៃការស្តាប់ចម្លើយ ប៉ាង រ៉េត (ហៀង រ៉េត), ឆ.28, ឆ.98 ["កងវរសេនាតូច ៤៥០ បានក្លាយជាកងវរសេនាតូច ១៦៥ ដែលជាកងអន្តរាគមន៍ពិសេស។ [...] ឆ.98៖ ខ្ញុំដឹងថាមន្ទីរសន្តិសុខនោះ [វត្តឥន្ទញ្ញាណ] គ្រប់គ្រងដោយនីរសាវរសេនាតូច ៤៥០"]។ ឯកសារ D54/72 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ (អតីតនិរសា របស់បងស្រីជីដូនមួយ ខុម និង អ្នកទទួលទូរស័ព្ទ សម្រាប់ មាស មុត), ឆ.7 - 8, ឆ. 16 ["កងពិសេស គឺដូចជាកងការពាររបស់ មាស មុត អីចឹងដែរ។ ក្រុមនិរសា គឺជាក្រុមដែលធ្វើការនៅជិត និងជាប់ជាមួយ តា មុត គ្រប់ពេលវេលា។ ប៉ុន្តែ កងពិសេសេ គឺសម្រាប់យាមកាម ហើយនិង យាមប៉ុស្តិ៍ ឆែកឆេរនៅជុំវិញមន្ទីរ និងផ្ទះរបស់គាត់។ [...] ឆ. 8៖ គឺជាកងវរសេនាតូច [...] ឆ.16៖ តានន គឺនៅក្នុងកងពិសេសេ សម្រាប់ការពារកងពល។ មានប៉ុស្តិ៍យាម ហើយនឹងផ្ទះមួយដែលស្ថិតនៅច្រកចូលទៅផ្ទះរបស់ តាមុត ដែលជាកន្លែងដែល នន និងយោធារបស់គាត់ស្នាក់នៅ។ ខ្ញុំមិនដែលទៅដល់កន្លែងនោះទេ ដូច្នេះ ខ្ញុំមិនដឹងថា មានយោធាប៉ុន្មាននាក់ទេ នៅទីនោះ"]។ ឯកសារ D54/71 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ, ឆ.39, ឆ.42 ["ខ្ញុំមិនដឹងថា យោធាកងណាជាអ្នកយក

254. បុគ្គលិកក្នុងកងវរៈសេនាតូចលេខ ១៦៥ នេះរួមមាន នីរសារ និងកងអង្គរក្សរបស់ **មាស មុត**។ ស្ថិតិដែលផ្តល់ដោយ **មាស មុត** នៅចុងឆ្នាំ ១៩៧៦ បង្ហាញថា កងវរៈសេនាតូចនេះមានកងទ័ពពិសេស ២៦៥ នាក់[820]។

---

ពួកយួនមកសម្លាប់នៅទីនោះទេ។ ពួកគេអាចមកពីកងពិសេសរបស់កងពល ឬក៏មកពីកងនិរសាររបស់ មាស មុត។ [...]ស៖ ហេតុអ្វីបានជាលោកស្រីនិយាយថា ពួកយោធាដែលនាំយួននោះ មកសម្លាប់ជាពួកកងពិសេសេ ឬក៏ជាពួកនិរសាររបស់ មាស មុត? ឆ.42៖ គឺមានតែយោធារបស់កងពិសេសទេ ដែលមានភារកិច្ចធ្វើការងារនោះ"]។ ឯកសារ D54/87 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រុំ សារ៉ាត់, ឆ.93 - 95 ["កងវរសេនាតូច ៤៥០ ឈរជើងនៅជុំវិញកងពល។ ស៖ តើកងវរសេនាតូច ៤៥០ មានមុខងារធ្វើអ្វីខ្លះ? ឆ.94៖ ពួកគេជាកងការពារ។ [...] ឆ.95៖ ការងារចម្បង គឺការពារទីបញ្ជាការរបស់កងពល"]។ ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយ ឯក នី, ឆ.4 ["កងពិសេស គឺជាដូចកងអង្គរក្សអីចឹង។ វាគឺជាកងដែលមេគេជឿទុកចិត្ត ហើយគេប្រើយោធាក្នុងកងនេះ សម្រាប់ចាប់ចងអ្នកក្បត់ ហើយនឹងការងារសំខាន់ៗដទៃទៀត។ នៅពេលដែលគេចង់ចាប់កងវរសេនាតូច និងកងវរសេនាធំ គេប្រើយោធាកងពិសេសទៅហៅ ពួកគេថា បងកងពលឲ្យមកប្រជុំ"]។ ឯកសារ D54/101 កំណត់ហេតុនៃការស្តាប់ចម្លើយ ឯក នី, ឆ .10 ["យោធាទាំងនោះ គឺមកពីកងពិសេសរបស់ តាមុត [ដែលចាប់ តារ៉ែម]។ ពួកនោះ គឺដូចជាកងអង្គរក្សរបស់ តាមុត ឬក៏ហៅថា កងដៃស្តាំរបស់គាត់។ បន្ទាប់ពីដាល់ពួក យោធានោះហើយ រ៉ែម បានលោតចុះពីឡាន ហើយពួកយោធាបានបាញ់ចំក្បាលរបស់គាត់ ហើយគាត់ដួលស្លាប់នៅលើថ្នល់នៅមុខវត្តឥន្ទញ្ញាណនោះតែម្តង"]។ ឯកសារ D54/105 កំណត់ហេតុនៃការស្តាប់ចម្លើយ ឯក នី, ឆ.6, ឆ.18 [ពន្យល់ពីរបៀបដែលអង្គភាពពិសេសរបស់ មាស មុត បានធ្វើអន្តរាគមន៍ចាប់ខ្លួនអតីតកម្មាភិបាល ២ នាក់មកពីកងវរសេនាតូច ៣៨៦]។ ឆ.18 [រៀបរាប់អំពីព្រឹត្តិការណ៍មួយនៅស្ទឹងហាវនៅចុងឆ្នាំ ១៩៧៨ ដែលកងកម្លាំងអង្គភាពពិសេសរបស់ មាស មុត បានចាប់ខ្លួនកម្មករប្រុសៗខាងផ្លូវដែកជាច្រើននាក់យកដាក់ឡាន]។

[820] ឯកសារ D22.2.4 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៦, EN 00950655, KH 00160118 [កងវរសេនាតូច ១៦៥ មានកងទ័ពចំនួន ២៦៥ នាក់ នៅខែ កក្កដា ឆ្នាំ ១៩៧៦]។ ឯកសារ D22.2.5 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៦, EN 00950657, KH 00160123 [កងវរសេនាតូច ១៦៥ មានកងទ័ព ចំនួន ២៥៤ នាក់ (របាយការណ៍នេះលើកឡើងថា មិនរាប់បញ្ចូលយុទ្ធជនពិការមួយចំនួន)]។ អំពីវត្តមានកងទ័ពពិការ ១២ នាក់ធ្វើការជាអ្នកយាមនៅកងវរសេនាតូច ១៦៥: ឯកសារ D54/111 កំណត់ហេតុនៃការស្តាប់ចម្លើយ សំ ភីន, ឆ.9 ["ខ្ញុំជាប្រធានក្រុមយោធាពិការ ១២ នាក់ មាននាទីជាអ្នកយាម"]។ ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦, EN 00233989, KH 0016045 [វរសេនាតូច ១៦៥ មានកងទ័ពចំនួន ២៦៥ នាក់]។ ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦, EN 00575531, KH 00160071 [វរសេនាតូច ១៦៥ មានកងទ័ពចំនួន ២៦៥ នាក់]។ ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយ ឯក នី, ឆ.4, ឆ.19 ["កងពិសេស គឺជាដូចកងអង្គរក្សអីចឹង។ វាគឺជាកងដែលមេគេជឿទុកចិត្ត [...] ឆ.19៖ [...] យោធាម្នាក់ៗនៅក្នុងកងពិសេស គឺគេចម្រាញ់អំពីប្រវត្តិរូបយ៉ាងល្អិតល្អន់ណាស់ មុនពេលដែលគេបញ្ជូនទៅក្នុងកងពិសេស"]។ ឯកសារ

255. សរ មឿន ហៅ មឿន បានក្លាយជាមេបញ្ជាការទីមួយរបស់កងវរៈសេនាតូចលេខ ៤៥០ មុនអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបន្តកាន់មុខតំណែងនេះរហូតដល់មានការបង្កើតកងវរៈសេនាធំលេខ ១៤០ នៅខែ សីហា ឆ្នាំ ១៩៧៥ (បន្ទាប់មក គាត់ត្រូវបានតែងតាំងជាមេបញ្ជាការកងវរៈសេនាតូចលេខ ១៤១)[821]។ ធាន និង អែម សុន ក៏បានកាន់តួនាទីដឹកនាំ នៅអំឡុងពេលនោះផង

D54/72 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ (អតីតនិរសា របស់បងស្រីជីដូនមួយ ខុម និង អ្នកទទួលទូរសព្ទសម្រាប់ មាស មុត), ឆ.7 - 8, ឆ.16 ["កងពិសេស គឺដូចជាកងការពាររបស់ មាស មុត អីចឹងដែរ។ ក្រុមនិរសា គឺជាក្រុមដែលធ្វើការនៅជិត និងជាប់ជាមួយ តា មុត គ្រប់ពេលវេលា។ ប៉ុន្តែ កងពិសេសេ គឺសម្រាប់យាមកាម ហើយនិងយាមប៉ុស្តិ៍ ឆែកឆេរនៅជុំវិញមន្ទីរ និងផ្ទះរបស់គាត់។ [...] ឆ. 8៖ គឺជាកងវរសេនាតូច [...] ឆ.16៖ តាននន គឺនៅក្នុងកងពិសេសេ សម្រាប់ការពារកងពល។ មានប៉ុស្តិ៍យាម ហើយនឹងផ្ទះមួយដែលស្ថិតនៅច្រកចូលទៅផ្ទះរបស់ តាមុត ដែលជាកន្លែងដែល ននន និងយើធារបស់គាត់ស្នាក់នៅ។ ខ្ញុំមិនដែលទៅដល់កន្លែងនោះទេ ដូច្នេះ ខ្ញុំមិនដឹងថា មានយោធាប៉ុន្មាននាក់ទេ នៅទីនោះ"]។

821 ឯកសារ D54/7 កំណត់ហេតុនៃការស្តាប់ចម្លើយ ឌុល សុង, ឆ.8, ឆ.13 ["មឿន ជាស្នងការកងវរសេនាតូចពិសេស។ [...] ឆ.13៖ ខ្ញុំដឹងច្បាស់ថា កងវរៈពិសេសនេះឋិតនៅក្រោមបញ្ជាការ ផ្ទាល់របស់កងពល។ កងវរៈពិសេសនេះ មិនឋិតនៅក្រោមបញ្ជាការរបស់វរសេនាធំណាមួយទេ។ ឋានៈរបស់ មឿន ដែលជាមេបញ្ជាការរបស់វរសេនាតូចពិសេសនេះ គឺមានឋានៈដូចមេបញ្ជាការកងវរសេនាធំដទៃទៀតក្នុងកងពលដែរ។ ពេលដែលមានប្រជុំ មេបញ្ជាការវរសេនាធំទាំងអស់ត្រូវបានហៅទៅចូលរួមប្រជុំ ហើយ មឿន ក៏ត្រូវបានហៅទៅចូលរួមប្រជុំជាមួយដែរ"]។ ឯកសារ D114/67 កំណត់ហេតុនៃការស្តាប់ចម្លើយ សរ សារិន, ឆ.14 ["សរ មឿន គឺជាមេបញ្ជាការវរសេនាតូចលេខ ៤៥០។ ក្រោយមក សរ មឿន បានចូលទៅខាងជើងទឹក ហើយវរសេនាតូចរបស់គាត់ គឺលេខ ១៤១។"]។ ឯកសារ D114/187 កំណត់ហេតុនៃការស្តាប់ចម្លើយ ទូច សឿលី, ឆ.11 ["ស សាមឿន គាត់ជាមេបញ្ជាការនៅក្នុងកងវរសេនាតូច ៤៥០"]។ ឯកសារ D54/47 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ.10 ["នៅពេលដែលខ្ញុំទៅដល់កោះតាងនោះ ខ្ញុំនៅមិនទាន់ទទួលបាន ដំណឹងអំពីមេបញ្ជាការ មឿន នៅឡើយទេ។ មឿន ត្រូវរបួស"]។ ឯកសារ D54/10 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ី រ៉េត (សារ៉េត), ឆ.22 ["ឯឈ្មោះ មឿន ពីដើមជាអតីតមេបញ្ជាការកងពិសេសរបស់ មាស មុត ហើយនៅក្នុងនោះគាត់ជាមេបញ្ជាការវរសេនាតូច ១៤១ នៃវរសេនាធំ ១៤០។"]។ ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974081, KH 00926527 ["កាលហ្នឹង [កងពិសេស] គ្រប់គ្រងដោយ លោក មឿន និង ធាន"]។ ឯកសារ D4.1.751 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក មិនស្គាល់ឈ្មោះ, ថ្ងៃទី ២១ ខែ មិនា ឆ្នាំ ២០០៥, EN 00387258, KH 01519652 ["ប្រភព បម្រើការជាអង្គរក្សរបស់ (ស) មឿន ដែលជាមេបញ្ជាការកងវរសេនាតូចទី ៤៥០។"]។ ឯកសារ D4.1.745 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក មិនស្គាល់ឈ្មោះ, EN 00387261, KH 01513914។ ឯកសារ D54/46 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ. 27។ ឯកសារ D2/15 កំណត់ហេតុនៃការស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច, ឆ.12។

ដែរ[822]។ ថ្នាក់ដឹកនាំរបស់កងវរៈសេនាតូចលេខ ១៦៥ ក្រោយអំឡុងខែ សីហា ឆ្នាំ ១៩៧៥ រួមមាន ឈុន លន់ ហៅ សំអាត ហៅ ស៊ុន។ គាត់ជាមេបញ្ជាការរងដែលចូលមកមន្ទីរ ស-២១ នៅខែ មិថុនា ឆ្នាំ ១៩៧៦ បន្ទាប់ពី **មាស មុត** បានរាយការណ៍ពីករណីរបស់គាត់ទៅ សុន សេន និងត្រូវបានគេយកទៅសម្លាប់នៅថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៩៧៦[823]។ ម្នាក់ទៀតគឺ នន ប្រធានកងការពារក្នុងកងវរៈសេនាតូចលេខ ១៦៥ ប្រចាំការនៅច្រកចូលផ្ទះរបស់ **មាស មុត** និងទីបញ្ជាការរបស់កងពលធំ[824]។

---

[822] ឯកសារ D54/46 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ.27, ឆ.35 [“ប្រហែលខែ មិនា ឆ្នាំ ១៩៧៥ គេបានផ្លាស់ខ្ញុំពីកងវរសេនាតូច ៤១៥ ដោយបង្កើតជាកងពិសេសកងវរសេនាតូច ៤៥០ របស់កងពល៣ [...] មឿន ហើយ សារុន គួក ជាអនុប្រធាន, ខ្ញុំ និង ធាន ជាសមាជិក។ [...] ឆ.35៖ នៅពេលនោះ ខ្ញុំទទួលខុសត្រូវអនុសេនាធំទី ២។ លោក មឿន ទទួលខុសត្រូវអនុសេនាធំទី ១ និងទី ៣ ដែរ, សារុន គួក ទទួលខុសត្រូវអនុសេនាធំទី ៤ និងទី ៥, ធាន ទទួលខុសត្រូវអនុសេនាធំ ទី ៦ និង ទី ៧ ដែរ។ បន្ទាប់ មឿន មានរបួសជើង នៅពេលការប្រយុទ្ធគ្នាដំបូង ខ្ញុំទទួលខុសត្រូវអនុសេនាធំទី ១ ទី ២ និងទី ៣ ដែរ។”]។ ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974081, KH 00926527 [“កាលហ្នឹង [កងពិសេស] គ្រប់គ្រងដោយ លោក មឿន និង ធាន។”]។ ឯកសារ D4.1.759 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក ខែម ងួន, EN 00387265, KH 00658135 - 00658136 [“មេបញ្ជាការកងវរសេនាតូច ៤៥០ ឈ្មោះ វ៉ាន់នី និង មេបញ្ជាការរងឈ្មោះ ធាន។”]។ ឯកសារ D4.1.745 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក មិនស្គាល់ឈ្មោះ, EN 00387261, KH 01513914 [“មេបញ្ជាការរងនៃកងវរសេនាតូចទី ៤៥០ វ៉ាន់នី និងសមាជិកគណៈកម្មាធិការបញ្ជាការដ្ឋាន ទៀន គឺជាមេបញ្ជាការឈរជើងផ្ទាល់នៅលើកោះនេះ”]។

[823] ឯកសារ D1.3.14.1 សារទូរលេពី មាស មុត ជម្រាប បង ៨៩ (សុន សេន) ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៧៦ [រាយការណ៍ពីការស្ទាក់ចាប់បានលិខិតមួយដោយកងពល ដែលត្រូវបានបញ្ជូនទៅឱ្យ សំអាត ហៅ ស៊ុន ជាអនុលេខាកងវរសេនាតូចលេខ ១៦៥ និង កម្មាភិបាលឈ្មោះ "ប៊ុនឌី" ឬ "ស៊ុនឌី"]។ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសស-២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត [កំណត់អត្តសញ្ញាណនៅលេខរៀងទី ៤៥០ ថា ឈុន លុន ហៅ សំអាត ជានយោបាយ វរសេនាតូច ដែលបានចូលមកមន្ទីរស-២១ នៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៧៦]។ ឯកសារ D9.3 បញ្ជីអ្នកទោសមន្ទីរស ២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត មកពីកងពល ១៦៤, [កំណត់អត្តសញ្ញាណលេខរៀងទី ៦ ឈ្មោះ ឈុន លុន អនុលេខាវរសេនាតូច ១៦៥]។ ឯកសារ D1.3.3.2 បញ្ជីឈ្មោះអ្នកទោសកម្មេច របស់មន្ទីរស-២១, EN 00874318, KH 00008819 [កំណាត់អត្តសញ្ញាណនៅលេខរៀងទី ១៣២ ឈ្មោះ ឈុន លុន ជាសមាជិកវរសេនាតូច នៃកងពល ១៦៤ ដែលបានចូលមកមន្ទីរស ២១ នៅថ្ងៃទី ២៩ ដែ កក្កដា ឆ្នាំ ១៩៧៦ និង ស្លាប់ដោយសារជម្ងឺ នៅថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៩៧៦]។ ឯកសារ D54/27.2 បញ្ជីអ្នកទោសមកពីកងពល១៦៤បានចាប់, EN 01185462, KH 00955556 [កំណត់អត្តសញ្ញាណថា ឈុន លន់ ហៅ អាត ជាអនុលេខាវរសេនាតូច ១៦៥]។

[824] ឯកសារ D54/72 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ (អតីតនិរសា របស់បងស្រីជីដូនមួយ ខុម និង អ្នកទទួលទូរស័ព្ទ សម្រាប់ មាស មុត), ឆ.10, ឆ.13 - 16 [ “សៈ តើអ្នកណាជាមេបញ្ជាការកងវរសេនាតតូចពិសេស? ឆ.10៖

*ខ) កងវរៈសេនាតូចលេខ ១៦៦ លេខ ១៦៧ លេខ ១៦៨ លេខ ១៦៩ និង លេខ ១៧០*

256. ក្រៅពីកងវរៈសេនាតូចលេខ ១៦៤ កងពលធំលេខ ១៦៤ មានកងវរៈសេនាតូចឯករាជ្យលេខ ១៦៦ លេខ ១៦៧ លេខ ១៦៨ លេខ ១៦៩ និងលេខ ១៧០ ដែលស្ថិតក្រោមការបញ្ជាផ្ទាល់របស់ **មាស មុត** និងសមាជិកគណៈកម្មាធិការកងពលធំលេខ ១៦៤។ ក្នុងចំណោមនេះមានឈ្មោះ គឹម ញ៉ាន់ ហៅ ញ៉ាន់ ដែលទទួលខុសត្រូវលើផ្នែកភ័ស្តុភារនៅអំឡុងឆ្នាំ ១៩៧៧-១៩៧៨ និងរ៉ាប់រងកិច្ចការភ័ស្តុភារសម្រាប់កងពលធំនេះ រួមទាំងកិច្ចការដែលពាក់ព័ន្ធនឹងកាំភ្លើងធំ ការដឹកជញ្ជូន សុខភាព[825]។ល។

257. កងវរៈសេនាតូចឯករាជ្យលេខ ១៦៦ ដែលមានកងទ័ពជាង ២៤០ នាក់[826] ទទួលបន្ទុកលើផ្នែកកាំភ្លើងធំ[827]។

---

ឈ្មោះ នន តែគាត់ស្លាប់ហើយ។ [...] ស៖ ហេតុអ្វីបានជាលោកស្រីដឹងថា នន ជាមេបញ្ជាការកងពិសេស? ឆ.13៖ ខ្ញុំធ្លាប់ឃើញគាត់ ចេញចូលផ្ទះ តាមុត។ ស៖ តើអ្នកណានៅពីលើ នន ទៀត? ឆ. 14៖ នន ស្ថិតនៅក្រោមបញ្ជារបស់ តាមុត។ ស៖ តើទីបញ្ជាការដ្ឋានរបស់ នន ស្ថិតនៅកន្លែងណា? ឆ.15៖ វាស្ថិតនៅច្រកចូលផ្ទះរបស់ តាមុត។ [...] ឆ. 16៖ តានន គឺនៅក្នុងកងពិសេសេ សម្រាប់ការពារកងពល។ មានប៉ុស្តិ៍យាម ហើយនឹងផ្ទះមួយដែលស្ថិតនៅច្រកចូលទៅផ្ទះរបស់ តាមុត ដែលជាកន្លែងដែល នន និងយោធារបស់គាត់ស្នាក់នៅ"]។

825 ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦។ ឯកសារ D114/286 កំណត់ហេតុនៃការស្តាប់ចម្លើយ ប៉ាង រ៉េត, ឆ.13 ["១៦៦ គឺថាកងកាំភ្លើងធំ។ ១៦៧ កងទ័ពនារី តែមួយ វរសេនាតូចទេ និងជាកងឯករាជ្យ។ កងឯករាជ្យគ្រប់គ្រងដោយកងពល។ ១៦៥ ដល់ ១៧០ គឺសុទ្ធតែកងឯករាជ្យ។ ១៦៨ ជាកងគ្រប់គ្រងឡាន សម្រាប់ដឹកជញ្ជូនឡាន។ ១៦៩ ជាអង្គភាពពេទ្យ។ ១៧០ ជាអង្គភាពជាងក្រឡឹង [...] កងទាំងនេះ មិនស្ថិតនៅក្រោមវរសេនាធំណាទេ គឺនៅក្រោមបញ្ជាផ្ទាល់របស់កងពល"]។ ឯកសារ D114/83 កំណត់ហេតុនៃការស្តាប់ចម្លើយ សុខ នាង, ឆ.19 ["ខ្ញុំដឹងថា កងវរសេនាធំ ៦១ ៦២ ៦៣ គឺស្ថិតនៅក្រោមកងពលធំ ១៦៤។ ១៦៥ ខ្ញុំគិតថា ជាកងវរសេនាតូចពិសេស តែខ្ញុំមិនច្បាស់ទេ។ ១៦៦ គឺជាកងវរសេនាតូចទទួលបន្ទុកកាំភ្លើងធំ។ ១៦៧ គឺជាកងវរសេនាតូចរបស់ខ្ញុំ។ ១៦៨ គឺទំនងជាកងវរសេនាតូច ទទួលបន្ទុកផ្នែកដឹកជញ្ជូន។ ១៦៩ គឺជាកងវរសេនាតូចទទួលបន្ទុកផ្នែកពេទ្យ [...] ខ្ញុំមិនចាំថា ១៧០ ជាកងវរសេនាតូចទទួលបន្ទុក ផ្នែកអ្វីនោះទេ"]។

826 ឯកសារ D22.2.4 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៦, EN 00950655, KH 00160118 [កងវរសេនាតូច ១៦៦ មានកងទ័ពចំនួន ២៤៣ នាក់]។ ឯកសារ D22.2.5 របាយការណ៍ស្ថិតិរបស់កងពល ១៦៤, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៦, EN 00950657, KH 00160123 [កងវរសេនាតូច ១៦៦ មានកងទ័ពចំនួន ២៤១ នាក់]។ ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦, EN 00233989, KH 0016045 [វរសេនាតូច ១៦៦ មានកងទ័ពចំនួន ២៤១ នាក់]។ ឯកសារ D22.2.6

258. កងវរៈសេនាតូចឯករាជ្យលេខ ១៦៧ ជាអង្គភាពដែលមានស្ត្រីជាង ៤០០ នាក់ រួមទាំងពេទ្យទាហានជាច្រើននាក់[828] និងស្ថិតក្រោមបទបញ្ជារបស់ នាង ឬ ណាង ដែលជាលេខា[829]។ កងវរៈសេនាតូចនេះមានកងអនុសេនាធំចំនួន ៤ ដែលកងអនុសេនាធំ ២ ប្រចាំការនៅស្ទឹងហាវ និងកងអនុសេនាធំមួយប្រចាំការនៅអូរត្រេស[830]។ នៅពេលគ្មានអ្នកជំងឺត្រូវព្យាបាល ពេទ្យទាហានស្រី

---

របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦, EN 00575531, KH 00160071 [វរសេនាតូច ១៦៦ មានកងទ័ពចំនួន ២៤១ នាក់]។

827 ឯកសារ D114/83 កំណត់ហេតុនៃការស្តាប់ចម្លើយ សុខ នាង, ឆ.19 ["១៦៦ គឺជាកងវរសេនាតូចទទួលបន្ទុកកាំភ្លើងធំ"]។ ឯកសារ D114/286 កំណត់ហេតុនៃការស្តាប់ចម្លើយ ហ៊ាង រ៉េត, ឆ.13 ["១៦៦ គឺថាកងកាំភ្លើងធំ។"]។

828 ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦, EN 00233989, KH 0016045 [វរសេនាតូច ១៦៧ មានកងទ័ពចំនួន ៣៤៣ នាក់]។ ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦, EN 00575531, KH 00160071 [វរសេនាតូចនារី ១៦៧ មានកងទ័ពចំនួន ៤២៩ នាក់]។ ឯកសារ D22.2.4 របាយការណ៍ស្ថិតិរបស់កងពល ១៦៤, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៦, EN 00950655, KH 00160118 [កងវរសេនាតូចនារី ១៦៧ មានកងទ័ពចំនួន ៣៩១ នាក់]។ ឯកសារ D22.2.5 របាយការណ៍ស្ថិតិរបស់កងពល ១៦៤, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៦, EN 00950657, KH 00160123 [កងវរសេនាតូចនារី ១៦៧ មានកងទ័ពចំនួន ៣៩១ នាក់]។ ឯកសារ D2/9 កំណត់ហេតុនៃការស្តាប់ចម្លើយ សយ ប៊ិន, ឆ.25 ["ខ្ញុំដឹងថា កង ១៦៧ គឺជាកងវរសេនាតូចរបស់នារី"]។ ឯកសារ D114/83 កំណត់ហេតុនៃការស្តាប់ចម្លើយ សុខ នាង, ឆ.5, ឆ.14, ឆ.17 ["មុនទទួលជ័យជម្នះឆ្នាំ ១៩៧៥ ខ្ញុំធ្វើការនៅកងវរសេនាតូចនារីលេខ ១៦៧ របស់កងពលទី៣ ប្រចាំការណ៍នៅថ្នល់ ទទឹង [...] ឆ.14៖ ពួកយើងធ្វើការផ្ទាល់ក្រោមបញ្ជាការរបស់កងពលធំ ១៦៤។ សមាជិករបស់កងវរសេនាតូច ១៦៧ ទាំង អស់សុទ្ធតែនារី។ [...] ឆ.17៖ កងវរសេនាតូចរបស់ខ្ញុំ គឺឯករាជ្យ ពុំស្ថិតក្រោមវរសេនាធំណាមួយទេ គឺនៅក្រោមការបញ្ជា ផ្ទាល់របស់កងពល ១៦៤។"]។ ឯកសារ D114/286 កំណត់ហេតុនៃការស្តាប់ចម្លើយ ហ៊ាង រ៉េត, ឆ.13 ["១៦៧ កងទ័ពនារី តែមួយវរសេនាតូចទេ និងជាកងឯករាជ្យ"]។ ឯកសារ D54/23 កំណត់ហេតុនៃការស្តាប់ចម្លើយ ប៉ាក សុក, ឆ.3 ["កងនារី គឺកងវរសេនាតូចលេខ ៦៧ ឬ ១៦៧"]។

829 ឯកសារ D114/83 កំណត់ហេតុនៃការស្តាប់ចម្លើយ សុខ នាង, ឆ.6 ["មេបញ្ជាការកងវរសេនាតូច ១៦៧ របស់ខ្ញុំឈ្មោះ មិត្ត ណាង (ស្រី) គាត់ស្លាប់នៅឆ្នាំ ១៩៧៩"]។ ឯកសារ D59/1/1.7a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយ មជ្ឈមណ្ឌលឯកសារកម្ពុជា ម៉ា ឈឿន, EN 00969946, KH 00926325 ["ស៖កាលហ្នឹង ប្រធានវរសេនាតូចនារី គាត់ឈ្មោះអីទៅ? ឆ៖ ឈ្មោះ នាង"]។

830 ឯកសារ D114/83 កំណត់ហេតុនៃការស្តាប់ចម្លើយ សុខ នាង, ឆ.14, ឆ.24 ["កងវរសេនាតូច ១៦៧ មានកងអនុសេនាធំ ៣ គឺ កងអនុសេនាធំ ៣២ ៣៣ និង ៣៥។ កងអនុសេនាធំចំនួន២ គឺកងអនុសេនាធំ ៣២ និង ៣៣ ត្រូវបានបញ្ជូនទៅធ្វើការ នៅស្ទឹងហាវ។ ចំណែកកងអនុសេនាធំ ៣៥ ឈរជើងនៅអូរត្រេះ។ [...] ឆ.24៖ ខ្ញុំភ្លេចប្រាប់លោក

របស់កងវរៈសេនាតូចលេខ ១៦៧ ត្រូវបានចាត់តាំងឲ្យធ្វើការងារផ្សេងៗ[831]។ ដំបូង ពួកគេជួយសាងសង់ទំនប់អូរឈើទាលរហូតដល់ឆ្នាំ ១៩៧៦។ បន្ទាប់មក ពួកគេត្រូវប្រមូលផលស្រូវនៅស្មាច់ដែង[832] ហើយនៅចុងឆ្នាំ ១៩៧៧ ពួកគេត្រូវបានផ្លាស់ទៅចម្ការត្របែកដើម្បីជួយសាងសង់កំពង់ផែស្ទឹងហាវ[833]។

259. កងវរៈសេនាតូចលេខ ១៦៨ គឺជាកងវរៈសេនាតូចឯករាជ្យធំជាងគេ ដែលមានកងទ័ព ៧៣០-៨៤០ នាក់ និងទទួលបន្ទុកលើផ្នែកដឹកជញ្ជូន[834]។ គ្មានភស្តុតាងច្បាស់លាស់ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធគ្រប់គ្រងរបស់កងវរៈសេនាតូចនេះឡើយ។

---

ថា មានកងអនុសេនាធំ មួយទៀត ចំណុះឲ្យកងវរសេនាតូច ១៦៧ គឺកងអនុសេនាធំ ៣១ ដែលមានមេបញ្ជាការឈ្មោះ បងភាព (ស្រី)"]។

831 ឯកសារ D114/83 កំណត់ហេតុនៃការស្តាប់ចម្លើយ សុខ នាង, ឆ.7 - 8 ["ពួកយើងពុំបានចូលរួមវាយប្រយុទ្ធក្នុងសមរភូមិទេ ពីព្រោះយើងជាពេទ្យ។ យើងគ្រាន់តែយកអ្នករបួសពីសមរភូមិមករុំបង់របួសឲ្យពួកគេ ដោយចាក់ថ្នាំ និងនាំពួកគេទៅសមរភូមិក្រោយ។ [...] ឆ.8៖ ខ្ញុំចង់គូសបញ្ជាក់ថា ទាំងនៅស្ទឹងហាវ និងស្មាច់ដែង ខ្ញុំធ្វើជាពេទ្យដដែល។ ពេលមានអ្នកណា ឈឺ គេឲ្យពួកខ្ញុំមើលថែ និងព្យាបាល តែបើគ្មានអ្នកណាឈឺអ្វីទេ ខ្ញុំធ្វើការដូចគេដូចឯង"]។

832 ឯកសារ D114/83 កំណត់ហេតុនៃការស្តាប់ចម្លើយ សុខ នាង, ឆ.8 ["ពួកយើងមកស្នាក់នៅតាមផ្ទះនៅទីនោះ រហូតដល់ឆ្នាំ ១៩៧៦។ ពេលស្នាក់នៅអូរទី៥ កងអនុសេនាធំរបស់ខ្ញុំបានចូលរួមលើកទំនប់អូរឈើទាល។ ចាប់ពីឆ្នាំ ១៩៧៦ រហូតមក គេឲ្យពួកយើងទៅស្នាក់នៅកណ្តាលវាលស្រែនៅស្មាច់ដែង ដោយទទួលការងារច្រូតកាត់ ដកស្ទូងនៅទីនោះ អស់រយៈពេលជិត ២ឆ្នាំ"]។ ឯកសារ D114/88 របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត, EN 01110677, KH 01513897 ["[សាក្សី នួន ង៉ូវ] ប្រពន្ធឈ្មោះ សុខ នាង គឺជាកងទ័ពវរសេនាតូច ១៦៧ ជាកងវរៈនារីនៅកងពល ១៦៤ [...] គាត់ធ្វើការនៅទីតាំងប៉ុន្មាន កន្លែង (ស្មាច់ដែង បិតត្រាំង ស្ទឹងហាវ ។ល។)"]។

833 ឯកសារ D114/83 កំណត់ហេតុនៃការស្តាប់ចម្លើយ សុខ នាង, ឆ.8, ឆ.10, ឆ.20 ["នៅចុងឆ្នាំ ១៩៧៧ គេបញ្ជូនពួកយើងទៅស្ទឹងហាវ [...] នៅស្ទឹងហាវ អង្គភាពរបស់ខ្ញុំបានចូលរួមសាងសង់កំពង់ផែ។ [...] ស៖ តើលោកស្រីស្នាក់នៅទីណា និងធ្វើការនៅទីណាខ្លះនៅស្ទឹងហាវ? ឆ.10៖ ពួកយើងស្នាក់នៅកន្លែមួយឈ្មោះ ចម្ការត្របែក។ [...] ឆ.20៖ ដោយសារតែពុំមានសង្គ្រាម ក្រោយឆ្នាំ ១៩៧៥ កងអនុសេនាតូចរបស់ខ្ញុំ គឺចូលរួមធ្វើស្រែ លើកទំនប់នៅអូរឈើទាល និងសាងសង់កំពង់ផែ នៅស្ទឹងហាវប៉ុណ្ណោះ។"]។

834 ឯកសារ D22.2.4 របាយការណ៍ស្ថិតិរបស់កងពល ១៦៤, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៦, EN 00950655, KH 00160118 [កងវរសេនាតូច ១៦៨ មានកងទ័ពចំនួន ៧២៩ នាក់]។ ឯកសារ D22.2.5 របាយការណ៍ស្ថិតិរបស់កងពល ១៦៤, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៦, EN 00950657, KH 00160123 [កងវរសេនាតូច ១៦៨ មានកងទ័ពចំនួន ៧២៩ នាក់]។ ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦, EN 00233989, KH 0016045 [វរសេនាតូច ១៦៨ មានកងទ័ពចំនួន ៨១៣ នាក់]។ ឯកសារ D22.2.6

260. កងវរៈសេនាតូចលេខ ១៦៩ គឺជាផ្នែកពេទ្យទាហាន/មន្ទីរពេទ្យដែលមានសមាជិក ៣២០-៣៨០ នាក់[835]។

261. កងវរៈសេនាតូចលេខ ១៧០ គឺជាអង្គភាពជួសជុល/ក្រឡឹងដែលមានកងទ័ពជាង ៣២០ នាក់[836]។ មានអង្គភាពមួយដែលមានសមាជិក ១០០ នាក់ក្នុងកងវរៈសេនាតូចលេខ ១៧០ ដែលមានភារកិច្ច

---

របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦, EN 00575531, KH 00160071 [វរសេនាតូច ១៦៨ មានកងទ័ពចំនួន ៨៤១ នាក់]។ ឯកសារ D114/286 កំណត់ហេតុនៃការស្តាប់ចម្លើយ ប៉ាង រ៉េត, ឆ.13 [“១៦៨ ជាកងគ្រប់គ្រងឡាន”]។ ឯកសារ D114/83 កំណត់ហេតុនៃការស្តាប់ចម្លើយ សុខ នាង, ឆ.19 [“១៦៨ គឺទំណងជាកងវរសេនាតូច ទទួលបន្ទុកដឹកជញ្ជូន”]។

835 ឯកសារ D22.2.4 របាយការណ៍ស្ថិតិរបស់កងពល ១៦៤, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៦, EN 00950655, KH 00160118 [កងវរសេនាតូច ១៦៩ មានកងទ័ពចំនួន ៣៨០ នាក់]។ ឯកសារ D22.2.5 របាយការណ៍ស្ថិតិរបស់កងពល ១៦៤, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៦, EN 00950657, KH 00160123 [កងវរសេនាតូច ១៦៩ មានកងទ័ពចំនួន ៣៧៩ នាក់]។ ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦, EN 00233989, KH 0016045 [វរសេនាតូច ១៦៩ មានកងទ័ពចំនួន ៣០៥ នាក់]។ ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦, EN 00575531, KH 00160071 [វរសេនាតូច ១៦៩ មានកងទ័ពចំនួន ៣២០ នាក់]។ ឯកសារ D114/83 កំណត់ហេតុនៃការស្តាប់ចម្លើយ សុខ នាង, ឆ.19 [“ចំណែកឯកងវរសេនាតូច ១៦៩ គឺគេទទួលបន្ទុកផ្នែកពេទ្យតែម្តង”]។ ឯកសារ D114/286 កំណត់ហេតុនៃការស្តាប់ចម្លើយ ប៉ាង រ៉េត, ឆ.13 [“១៦៩ ជាអង្គភាពពេទ្យ”]។

836 ឯកសារ D22.2.4 របាយការណ៍ស្ថិតិរបស់កងពល ១៦៤, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៦, EN 00950655, KH 00160118 [កងវរសេនាតូច ១៧០ មានកងទ័ពចំនួន ៣២០ នាក់]។ ឯកសារ D22.2.5 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៦, EN 00950657, KH 00160123 [កងវរសេនាតូច ១៧០ មានកងទ័ពចំនួន ២២៥ នាក់ (មិនរាប់បញ្ចូលយុទ្ធជនពិការ និងកុមារ ព្រមទាំង យុទ្ធជនផ្សេងទៀត)]។ ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦, EN 00233989, KH 0016045 [វរសេនាតូច ១៧០ មានកងទ័ពចំនួន ៣២០ នាក់]។ ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦, EN 00575531, KH 00160071 [វរសេនាតូច ១៧០ មានកងទ័ពចំនួន ៣៤៧ នាក់]។ ឯកសារ D2/9 កំណត់ហេតុនៃការស្តាប់ចម្លើយ សយ ប៊ន, ឆ.25 [“ខ្ញុំគ្រាន់តែដឹងថា កងវរសេនាតូច ១៧០ ជាអង្គភាពជាងក្រឡឹង”]។ ឯកសារ D114/286 កំណត់ហេតុនៃការស្តាប់ចម្លើយ ប៉ាង រ៉េត, ឆ.13 [“១៧០ ជាអង្គភាពក្រឡឹង”]។ ឯកសារ D54/42.1 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហេង វៀច, EN 00983446, KH 00967571 [“កងវរសេនាតូច ១៧០ បានកងរយហ្វ៊ីង គេចាត់តាំងឲ្យធ្វើជាងតែម្តង”], EN 00983451, KH 00967575 [“ខ្ញុំមានភារកិច្ចទៅក្រឡឹង ព្រោះយើងជាជាងខាង ១៧០ កងរយខាង ១៧០ ព្រោះហ្វ៊ីងមានម៉ាស៊ីនទំនើបយកពីចិនច្រើនជាង យកប្រដាប់ប្រដាទៅក្រឡឹងនៅ ហ្វ៊ីង”]។

សម្អាត ជួសជុល និងរក្សាទុកអាវុធយុទ្ធភណ្ឌរបស់កងពលធំលេខ ១៦៤ នៅកំពង់សោម[837]។ ប៉ែន ហម បានធ្វើជាលេខាកងវរៈសេនាតូចលេខ ១៧០ រហូតដល់គាត់ត្រូវបានឃុំឃាំងនៅមន្ទីរ ស-២១ នៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៧៧ និងត្រូវបានគេយកទៅសម្លាប់នៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៨[838]។ ងួន ឡាក់ ហៅ សារ៉ាត គឺជាអនុលេខាកងវរៈសេនាតូចនេះ ប៉ុន្តែត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅមន្ទីរ ស-២១ នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៧ និងយកទៅសម្លាប់នៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៧៨[839]។

---

837 ឯកសារ D54/42.1 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហេង វៀច, EN 00983446, KH 00967571 ["ខ្ញុំនៅខាងកង១៧០ មួយកងវរយហ្នឹង គេហៅថាផ្នែកខាងជាង។ [...] កងវរសេនាតូច ១៧០ បានកងវរយហ្នឹង គេចាត់តាំងឲ្យធ្វើជាងតែម្តង។ សៈ ជាងខាងអីអ៊ំ? ឆៈ ជាងខាងក្រឡឹង ខាងលាងកាំភ្លើង សំអាតកាំភ្លើង។ [...] សៈ អាវុធក្នុងកងពល ១៦៤ នៅកំពង់សោម ខាងអ៊ំផ្នែកវរសេនាតូចជាងហ្នឹង ជាអ្នកជួសជុល ជាអ្នកថែរក្សា? បាទ!"]។

838 ឯកសារ D114/113 កំណត់ហេតុនៃការស្តាប់ចម្លើយ ក៏ម មេន, ឆ.67 ["ហម ត្រូវបានបញ្ជូនទៅរាម ដើម្បីទទួលខុសត្រូវ ផ្នែកគ្រឿងក្រឡឹង"]។ ឯកសារ D4.1.1066 ចម្លើយសារភាពពីមន្ទីរស-២១ ប៉ែន ហម, ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ១៩៧៧, EN 00822394, KH 00174141 [កំណត់អត្តសញ្ញាណ ឈ្មោះ ប៉ែន ហម លេខាវរសេនាតូច ១៧០ កងពល ១៦៤], EN 00822431, KH 00174184 [ដកស្រង់ថា កាលបរិច្ឆេទនៃការចាប់ខ្លួនរបស់គាត់គឺ ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៧៧]។ ឯកសារ D114/236.2 បញ្ជីអ្នកទោសមកពីកងពល ១៦៤ របស់មន្ទីរស-២១ ធ្វើដោយការិយាល័យសហចៅក្រមស៊ើបអង្កេត (១៩៧៥-១៩៧៨), EN 01312194 [កំណត់អត្តសញ្ញាណនៅលេខរៀងទី ៤២ ឈ្មោះ ប៉ែន ហម ដែលបានចាប់ខ្លួននៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៧ និងបានសម្លាប់នៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៨]។ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសមន្ទីរស-២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត លេខរៀងទី ៧២០៧, EN 01222613។ ឯកសារ D1.3.30.5 របាយការណ៍សេនាធិការ របស់កម្ពុជាប្រជាធិបតេយ្យ តារាងស្ថិតិសិក្ខាកាមរៀន នៅវគ្គសេនាធិការលើកទី១, ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៧៦, EN 00897656, KH 00095537 [បញ្ជីលេខរៀង ១៣៦ ប៉ែន ហម ជាលេខាវរសេនាតូច នៅកងពល ១៦៤]។

839 ឯកសារ D1.3.28.2 បញ្ជីអ្នកទោសស-២១ នៅថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ១៩៧៧ EN 01321750, KH 00086996 [កំណត់អត្តសញ្ញាណថា ងួន ឡាក់ ហៅ សារ៉ាត ជាសមាជិកវរសេនាតូច ១៧០ វរសេនាធំ រោងជាង ហើយបានចូលមកមន្ទីរស-២១នៅ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៧]។ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសមន្ទីរស-២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត [កំណត់អត្តសញ្ញាណនៅលេខរៀងទី ៧២៤៦ ឈ្មោះ ងួន ឡាក់ ហៅ សារ៉ាត់ ជាសមាជិកវរសេនាតូច ១៧០ កងពល ១៦៤ ដែលបានចូលមកមន្ទីរស-២១ នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៧ និង បានសម្លាប់នៅថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ១៩៧៨]។ ឯកសារ D114/236.2 បញ្ជីអ្នកទោសមកពីកងពល ១៦៤ របស់មន្ទីរស-២១ ធ្វើដោយការិយាល័យសហចៅក្រមស៊ើបអង្កេត (១៩៧៥-១៩៧៨), EN 01312194 [កំណត់អត្តសញ្ញាណនៅលេខរៀងទី ៤១ ឈ្មោះ ងួន ឡាក់ ដែលបានចាប់ខ្លួននៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៧ និងបានសម្លាប់នៅ

## V. ការប្រាស្រ័យទាក់ទង

### ១. សេចក្តីផ្តើម

262. ក្នុងដំណើរការ និងការជ្រោមជ្រែងដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មរបស់ខ្លួន **មាស មុត** និងអ្នកស្ថិតក្រោមបទបញ្ជារបស់គាត់ បានបញ្ជូន និងទទួលទំនាក់ទំនង និងបទបញ្ជាតាមមធ្យោបាយផ្សេងៗទៅកាន់ និងពីអ្នកដែលស្ថិតក្នុងមជ្ឈិមបក្ស និងអ្នកដែលជាមនុស្សក្រោមបង្គាប់របស់គាត់ និងមជ្ឈិមបក្ស។ ទំនាក់ទំនងត្រូវបានបញ្ជូន និងទទួលតាមវិធីផ្សេងៗ ដូចជា សារទូរលេខ ទូរស័ព្ទ នីរសារ កិច្ចប្រជុំ វិទ្យុទាក់ទងទៅមក ការផ្សព្វផ្សាយតាមរលកវិទ្យុ និងអត្ថបទបោះពុម្ពផ្សាយ។

### ២.ការប្រាស្រ័យទាក់ទងផ្ទៃក្នុងរបស់កងពលធំលេខ ១៦៤

263. ភស្តុតាងលម្អិតខាងក្រោមបង្ហាញពីអត្ថិភាពនៃប្រព័ន្ធទំនាក់ទំនងដ៏រឹងមាំក្នុងកងពលធំលេខ ១៦៤ ដែល ៖ ១) ផ្តល់ព័ត៌មានស្តីពីបញ្ហាគ្រប់បែបយ៉ាងដល់ **មាស មុត** ក្នុងតំបន់កាន់កាប់របស់គាត់ រួមទាំងឧក្រិដ្ឋកម្ម ២) ផ្តល់លទ្ធភាពឲ្យគាត់ និងអ្នកក្រោមបង្គាប់របស់គាត់ដាក់បទបញ្ជា រួមទាំងបទបញ្ជាដែលពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម និង ៣) ផ្តល់លទ្ធភាពឲ្យគាត់ និងអ្នកក្រោមបង្គាប់របស់គាត់សម្របសម្រួលជាមួយអ្នកផ្សេងទៀតក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្ម។

264. ទីបញ្ជាការរបស់កងពលធំលេខ ១៦៤ ជាទីដែល **មាស មុត** ប្រចាំការ គឺជាមជ្ឈមណ្ឌលទំនាក់ទំនងសម្រាប់តំបន់កំពង់សោម និងកងពលធំលេខ ១៦៤។ ទីបញ្ជាការនេះមាននីរសារ[840] អ្នកកាន់វិទ្យុ[841]

---

ថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ១៩៧៨]។ ឯកសារ D1.3.30.6 របាយការណ៍កម្ពុជាប្រជាធិបតេយ្យពីសេនាធិការ វគ្គសេនាធិការលើកទី២ - តារាងស្ថិតិសិក្ខាកាម, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦, EN 00195333, KH 00008467, FR 00623211 [កំណត់អត្តសញ្ញាណនៅលេខរៀងទី ២១១ ថា ងួន ឡាក់ ជាសមាជិកវរសេនាតូច កងពល ១៦៤]។

840 ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦, EN 00233989, KH 0016045។ ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦, EN 00575529, KH 00160069។ ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974094, KH 00926538 ["អ្នកកាន់តេអូស្លាប់ ហើយនិរសាក៏ស្លាប់"]។ ឯកសារ D54/26 កំណត់ងហេតុនៃការស្តាប់ចម្លើយ ប៉ាក សុខ, ឆ.3 ["មន្ទីរបញ្ជាការរបស់ មាស មុត ហើយនិងផ្ទះស្នាក់ របស់គាត់មានចម្ងាយប្រហែល ២ គីឡូម៉ែត្រ ពីវត្តឥន្ទញ្ញាណ។ ផ្ទះរបស់ មាស មុត គឺនៅកន្លែងមន្ទីរធ្វើការរបស់គាត់តែ ម្តង"]។

និងអ្នកកាន់ទូរស័ព្ទផ្ទាល់[842] ដែលសុទ្ធតែស្ថិតក្រោមការបញ្ជាដាច់មុខរបស់ **មាស មុត**។ សាក្សី អែម សុន លើកឡើងថា "ម-១៦៤ ជាមន្ទីររបស់កងពល រួមមានផ្នែកផ្សេងៗ ដែលមាន ផ្នែកបញ្ជី ធ្វើឯកសារ នីរសារ និងផ្នែកទំនាក់ទំនង"[843] ។ ក្រៅពីនេះ ទីបញ្ជាការនេះមានកន្លែងរស់នៅសម្រាប់ នីរសារ និងកន្លែងបណ្តុះបណ្តាលផ្នែកទំនាក់ទំនង ដែលកងទ័ពរបស់កងពលធំលេខ ១៦៤ ចូលរួម វគ្គបណ្តុះបណ្តាលស្តីពីការប្រាស្រ័យទាក់ទងតាមវិទ្យុ[844]។ ជារួម ផ្អែកតាមការរៀបចំរាល់ទំនាក់ទំនង ទាំងអស់ត្រូវចូលដល់ ឬឆ្លងកាត់ទីបញ្ជាការកងពលធំរបស់ **មាស មុត** ជាទីដែលអ្នកកាន់វិទ្យុ និង នីរសារផ្តល់ព័ត៌មានលម្អិតដល់ **មាស មុត** និងថ្នាក់ដឹកនាំផ្សេងទៀតរបស់កងពលធំលេខ ១៦៤។ នីរសារ និងអ្នកកាន់វិទ្យុរបស់កងពលធំលេខ ១៦៤ ដែលត្រូវបានចាត់តាំងឲ្យស្ថិតក្រោមបង្គាប់

---

841 ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦, EN 00233989, KH 0016045។ ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦, EN 00575529, KH 00160069។

842 ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦, EN 00233989, KH 0016045។ ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត ថ្ងៃទី២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦, EN 00575529, KH 00160069។

843 ឯកសារ D54/47 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ.24 ["តាមខ្ញុំយល់ ម-១៦៤ ជាមន្ទីររបស់កងពល រួម មាន ផ្នែកផ្សេង ដែលមានផ្នែកបញ្ជី ធ្វើឯកសារ និរសា និងផ្នែកទំនាក់ទំនង"]។

844 ឯកសារ D54/71 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ, ឆ.28, ឆ.35 ["មានអគារផ្សេងៗគ្នានៅក្នុងបរិវេណនៃ មន្ទីរ ក្នុង។ នៅកន្លែងនោះមានរោងបាយរួម ផ្ទះរបស់ មាស មុត កន្លែងស្នាក់នៅរបស់និរសា និងអ្នកផ្សេងៗទៀត ស្នាក់នៅ កន្លែងសារទូរលេខកន្លែងមួយហៅថា មន្ទីរផ្សាយ ដែលស្ថិតនីជិតរង្វង់មូលតោពីរ។ [...] ឆ.35៖ កន្លែង ហាត់រៀនស្ថិតនៅអគារផ្សេង នៅទីនោះគេមានហាត់រៀនផ្នែកទូរស័ព្ទ ផ្នែកទូរលេខ និងផ្នែកផ្សាយ។ មន្ទីរទូរស័ព្ទ ទាក់ទង គឺស្ថិតនៅក្នុងអគារផ្សេង ប៉ុន្តែនៅក្នុងបរិវេណជាមួយគ្នា"]។ ឯកសារ D54/72 កំណត់ហេតុនៃការស្តាប់ ចម្លើយ មុត ម៉ៅ (អតីតនិរសា របស់បងស្រីជីដូនមួយ ខុម និង អ្នកទទួលទូរស័ព្ទសម្រាប់ មាស មុត), ឆ.30 ["មន្ទីរ ទូរស័ព្ទកណ្តាល គឺប្រើដោយកងនានាក្នុងកងពល ១៦៤ និងប្រើដោយកងពល ដើម្បីទូរស័ព្ទទៅកាន់ភ្នំពេញផងដែរ"]។ ឯកសារ D54/34 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ឹង ឆុន, ឆ.2 ["នៅកន្លែង តាមុត គាត់មានម៉ាស៊ីន សារទូរលេខ"] ។ ឯកសារ D54/70.2 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា មុត ម៉ៅ, EN 01066966, KH 00979247 ["ស៖ ចុះដល់មន្ទីរកងពលមីងធ្វើអីទៅ? ឆ៖ ខ្ញុំនៅកន្លែងទូរស័ព្ទហ្នឹង។"]។ ឯកសារ D54/98 កំណត់ហេតុនៃការស្តាប់ចម្លើយ ហ៊ាង រ៉េត (ហៀង រ៉េត), ឆ.16, ឆ.21, ឆ.63 ["ខ្ញុំឈរជើងនៅប៉ុស្តិ៍វិទ្យុ ដោយការពារប្រចាំការណ៍ និងចូលរួមវគ្គបណ្តុះបណ្តាលក្នុងការប្រើប្រាស់សម្ភារៈទំនាក់ ទំនងវិទ្យុ។ [...] ឆ.21៖ ប៉ុស្តិ៍វិទ្យុមានទីតាំងនៅចម្ងាយប្រហែល ៦០០ ម៉ែត្រ ពីវត្តក្រោម [...] ឆ.63៖ នៅពេលដែលខ្ញុំ សិក្សាក្នុងវគ្គហ្វឹកហ្វឺន យោធា គឺមានការបង្រៀនពីទំនាក់ទំនងតាមរយៈទូរលេខ និងវិទ្យុទាក់ទងដោយប្រើអក្ខរាសម្ងាត់"]។

ផ្ទាល់របស់ **មាស មុត** រួមមាន សារី ហៅ ខន, ម៉ុន, កុល, យ៉ន និងង៉ុញ[845]។ សាក្សី ប៉ាង រ៉េត បានពន្យល់ថា មានបុគ្គលិក ១០៣ នាក់ក្នុងទីបញ្ជាការរបស់កងពល "ដែលគ្រប់គ្រងប្រព័ន្ធទំនាក់ទំនង បញ្ជាទៅតាមកោះ បញ្ជាប្រចាំថ្ងៃទៅប្រព័ន្ធវ៉ាដាទទួលបន្ទុកទំនាក់ទំនង របាយការណ៍ បញ្ជូនបញ្ជាបន្តទៅតាមកោះ ទៅមកភ្នំពេញ។ វាដូចជាគេហៅថា ក-១ ឬការិយាល័យទី ១ គ្រប់គ្រងឯកសារកងពល"[846]។

265. ជារួម កងពលធំលេខ ១៦៤ មានបុគ្គលិកប្រមាណ ៤០០ នាក់ដែលត្រូវចាត់ចែងលើផ្នែកទំនាក់ទំនងសម្រាប់អង្គភាពនានានៅកម្រិតទីបញ្ជាការ កងវរៈសេនាធំ និងកងវរៈសេនាតូច។ នៅខែ វិច្ឆិកា ឆ្នាំ ១៩៧៦ បុគ្គលិកទំនាក់ទំនងរបស់កងពលធំលេខ ១៦៤ មាននីរសារ ៣៣៧ នាក់ អ្នកកាន់វិទ្យុ ៦៦ នាក់ និងអ្នកកាន់ទូរស័ព្ទ ២៦ នាក់[847]។ បន្ទាប់ពី ប.ក.ក បានឡើងកាន់អំណាច កងទ័ពរបស់កងពលធំលេខ ៣ ត្រូវពឹងផ្អែកលើទាហាន លន់ នល់ ដើម្បីបង្ហាត់បង្ហាញពួកគេពីរបៀបប្រើ

---

845 ឯកសារ D54/72 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ (អតីតនិរសា របស់បងស្រីជីដូនមួយ ខុម និង អ្នកទទួលទូរសព្ទ សម្រាប់ មាស មុត), ឆ. 2 ["អ្នកការពារ ឬនិរសាឈ្មោះ ម៉ុន។ អ្នកទាំងពីរនាក់នេះ ដើរជាមួយគាត់ជាប់រហូត។ យ៉ន និង ង៉ុ គឺជាអ្នកកាន់វិទ្យុទាក់ទង"]។ ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974094, KH 00926538 - 00926539 ["ស៖ ក្រៅពី តាមុត ដូចជានិរសាររបស់គាត់ ឬអ្នកកាន់តេអូ? ឆ៖ អ្នកកាន់តេអូស្លាប់ ហើយ និរសាក៏ស្លាប់។ [...] ស៖ ចឹង កុល ហ្នឹងគាត់ចេះអង់គ្លេសដែរឬអត់? ឆ៖ គាត់ជំនាញហើយអង់គ្លេស [...] មួយទៀត សារី ស្លាប់ដែរហើយនៅម្តុំស៊ីសុផុនយើងនេះ ឈ្មោះ សារី ហៅ ខាន់"]។ សូមផងដែរ ឯកសារ D54/48 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ.15 ["មាស មុត មិនដែលនិយាយជាមួយខ្ញុំដោយផ្ទាល់ទេ តាវិទ្យុ គឺមាន តែ សារ៉ន និង ខុល ទេ ដែលបាននិយាយតាមវិទ្យុជាមួយខ្ញុំ។ ចំពោះខ្ញុំ អ្នកទាំងពីរ គឺតំណាងឲ្យ មាស មុត នៅពេលនិយាយជាមួយខ្ញុំ។ ពួកគេបានផ្តល់បញ្ជាពី មាស មុត មកឲ្យខ្ញុំ"]។

846 ឯកសារ D114/286 កំណត់ហេតុនៃការស្តាប់ចម្លើយ ប៉ាង រ៉េត, ឆ.17 ["មន្ទីរ ១៦៤ មន្ទីររបស់កងពល ហើយ ១០៣នាក់នេះជាបុគ្គលិកគ្រប់គ្រងប្រព័ន្ធទំនាក់ទំនង បញ្ជាតាមកោះ បញ្ជាប្រចាំថ្ងៃទៅវ៉ាដា ទទួលបន្ទុកទំនាក់ទំនង របាយការណ៍ បញ្ជូនបញ្ជាទៅតាមកោះ ទៅមកភ្នំពេញ។ វាដូចជាគេហៅថា ក១ ឬ ការិយាល័យទី១ គ្រប់គ្រងឯកសាររបស់កងពល"]។

847 ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦, EN 00575529, KH 00160069។

សារទូរលេខ វិទ្យុទាក់ទង និងប្រព័ន្ធផ្តល់សញ្ញា ប៉ុន្តែមិនយូរមិនឆាប់ ពួកគេបានរៀនចេះប្រើប្រព័ន្ធទាំងនេះដោយខ្លួនឯង[848]។

266. ញឹកញាប់ណាស់ដែលសំណើ បទបញ្ជា និងរបាយការណ៍ត្រូវបានបញ្ជូនទៅមកតាមរយៈខ្សែសង្វាក់នៃការបញ្ជារបស់កងពលធំលេខ ១៦៤ ដោយមានទីបញ្ជាការរបស់ **មាស មុត** ជាចំណុចកណ្តាល[849]។ "ការទំនាក់ទំនង គឺធ្វើឡើងពីអង្គភាពបញ្ជូនទៅកងវរៈសេនាតូច និងចុងក្រោយទៅកងពល ហើយបទបញ្ជាចេញពីថ្នាក់កងពលបញ្ជូនបន្តបន្ទាប់មកដល់អង្គភាពតូចៗវិញ"[850]។ ព្រុំ សារ៉ាត

---

848 ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974085, EN 00974134, KH 00926531, KH 00926574 ["ស៖ ចឹងកាលដែលយើងចូលទៅដល់កំពង់សោម ដំបូង យើងមិនចេះបើក កប៉ាល់ យើងពឹងកងទ័ពរបស់ លន់ នល់? ឆ៖ [...] ប្រើប្រាស់ជាមួយយើងទៅ។ [...] យើងមិនមែនទៅដល់ យើង គ្រប់គ្រងផែបានភ្លាមទេ យើងត្រូវមានបុគ្គលិកចាស់មកគ្រប់គ្រង។ តាំងពីគ្រប់គ្រងផែ តាមប្រព័ន្ធទាក់ទងទូរលេខ ទាក់ទង តាមសញ្ញា ហើយតាំងអារឿងគ្រប់គ្រងកប៉ាល់បុកទាញ កប៉ាល់ធំៗចូលផែនេះ អានឹងមានអារ៉ឺបូត័រអាធំៗ មកដល់កប៉ាល់ មកដល់អីចឹងហើយ គេប្រលែងហើយ យើងទៅដល់អូរ ទៅបុកគេឲ្យគៀកផែមកអីចឹង។ ហើយយើងអត់ចេះទេអានឹង ទាល់ តែមានអ្នកឯកទេសចាស់ទៅ យើងស្រាវជ្រាវអានឹងយកមកធ្វើវិញ។ ដូចប៉ុស្តិ៍វិទ្យុអីចឹង ប៉ុស្តិ៍នៅកំពង់សោម យើងយកកម្មករ ប៉ុស្តិ៍វិទ្យុ យកឲ្យមកនៅតាមប្រព័ន្ធការងារអីចឹងទៅ"]។

849 សូមមើលឧទាហរណ៍ ឯកសារ D114/24 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ូ ដាវ, ឆ.68 ["វិទ្យុទាក់ទងបើករហូត ហើយគេ បញ្ជាពីថ្នាក់វរសេនាធំចុះមកក្រោមបន្តបន្ទាប់គ្នា"]។ ឯកសារ D59/1/1.12 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ណុប ហាល, EN 00968404, KH 00926630 ["យើងៗឃើញ យើងរាយការណ៍វរសេនាធំៗគេរាយឲ្យកងពល ដល់ កងពលគេប្រាប់ទៅវរសេនាធំវិញថា ត្រូវចាត់ការណ៍ម៉េច វរសេនាធំគេប្រាប់ទៅវរសេនាតូចអីចឹងទៅ បានគេប្រើ បាទ! ក្រុមពួកខ្ញុំអីចឹងទៅ"]។ ឯកសារ D2/10 កំណត់ហេតុនៃការស្តាប់ចម្លើយ សយ ប៊ន, ឆ.6 ["បើនិយាយពីសភាពការណ៍នៃពេលចេញប្រយុទ្ធ គឺខ្ញុំមិនបានទទួលបញ្ជាផ្ទាល់ចេញពីកងពលទេ ការចេញបញ្ជា គឺធ្វើឡើងចេញពីប្រធានកងនាវាប្រដេញផ្ទាល់របស់ខ្ញុំ"]។ ឯកសារ D54/33.1 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌល ឯកសារកម្ពុជា អ៊ុំ ឆុន, EN 01073826, KH 00964211 ["មិនទៀងទេ ជួនកាលគាត់មានបណ្តាញគេធំៗ គេមកធ្វើការជាមួយគាត់ ហើយយើងតូចតាចហ្នឹង គេគ្រាន់តែបន្តប្រាប់យើងធ្វើអញ្ចេះ ធ្វើអញ្ចោះ"]។ សូមមើលផងដែរ ឯកសារ D98/1.2.4 ប្រតិចារឹក Craig Etcheson ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩ ម៉ោង 16.08.37 - 16.12.08 ["លក្ខន្តិកៈនៃបក្សកុម្មុយនិស្តកម្ពុជា ត្រូវការដាក់លាក់ថា ឋានៈនីមួយៗនៅក្នុងបក្ស ត្រូវរាយការណ៍ជាទៀងទាត់ទៅថ្នាក់លើបន្ទាប់"]។ ឯកសារ D98/3.1.115 ប្រតិចារឹក ផាន វ៉ាន ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១២, ម៉ោង 09.09.57 – 09.09.15 ["ចំណែកឯខាងរដ្ឋបាល អត់មានទេ។ រដ្ឋបាល ត្រង់មកខាងលើ"]។

850 ឯកសារ D114/13 កំណត់ហេតុនៃការស្តាប់ចម្លើយ នាក់ យឿន, ឆ.10 ["ចំពោះរបៀបរបរការងារជាទូទៅ ដូចខ្ញុំបានពន្យល់ពីមុនថា ការទំនាក់ទំនងគឺធ្វើឡើងពីអង្គភាពបញ្ជូនទៅកងវរសេនាតូច និងចុងក្រោយទៅកងពល ហើយបទ

បានពន្យល់លម្អិតថា ៖ "ជាធម្មតា ប្រព័ន្ធបញ្ជាគឺពីកងពលទៅកងវរៈសេនាធំ ពីកងវរៈសេនាធំទៅកងវរៈសេនាតូច ពីកងវរៈសេនាតូចទៅកងអនុសេនាធំ ហើយពីកងអនុសេនាធំទៅយោធាផ្ទាល់"[851]។ ប៉ាក សុខ បានរៀបរាប់ពីវដ្តនៃការបញ្ជូនទំនាក់ទំនងទៅមកតាមខ្សែសង្វាក់នៃការបញ្ជាថា "ព្រឹត្តិការណ៍អ្វីៗដែលកើតឡើង ត្រូវតែរាយការណ៍ទៅឲ្យកងវរៈសេនាតូច ហើយកងវរៈសេនាតូច រាយការណ៍ទៅមេបញ្ជាការកងវរៈសេនាធំ ហើយកងវរៈសេនាធំរាយការណ៍ទៅឲ្យមេបញ្ជាការកងពល។ បន្ទាប់មក មេបញ្ជាការកងពលធ្វើសេចក្ដីសម្រេច ហើយដាក់បញ្ជាបញ្ជូនចុះមកវិញតាមជាន់ថ្នាក់ទាំងនេះមកវិញ"[852]។

267. ជាករណីកម្រមបំផុត ដូចជា ឧប្បត្តិហេតុលើកប៉ាល់ Mayaguez ដែល **មាស មុត** មិនគិតពីឋានានុក្រម ប៉ុន្តែបានទាក់ទងផ្ទាល់ជាមួយអង្គភាពពាក់ព័ន្ធដោយផ្ទាល់[853]។ ដូចគ្នានេះដែរ ក្នុងករណីបន្ទាន់ ដូចជាកប៉ាល់ណាមួយដែលគេចាត់ទុកថាចូលក្នុងដែនសមុទ្ររបស់កម្ពុជា អង្គភាពនានាអាចរំលងឋានានុក្រមបាន ប្រសិនបើគ្មានវត្តមានថ្នាក់លើរបស់ពួកគេ និងរាយការណ៍ផ្ទាល់ទៅទីបញ្ជាការកងពល[854]។ ប៉ុន្តែកងវរៈសេនាតូច និងកងវរៈសេនាធំឯករាជ្យក្នុងកងពលធំលេខ ១៦៤ មិនដែលទទួលបទបញ្ជាណាមួយ ក្រៅពីបទបញ្ជារបស់មេដឹកកងពលធំលេខ ១៦៤ ឡើយ[855]។

---

បញ្ជាចេញពីថ្នាក់ កងពលបញ្ជូនបន្តបន្ទាប់មកដល់អង្គភាពតូចៗវិញ។ ប៉ុន្តែ នៅក្នុងពេលប្រតិបត្តិការណ៍ពិសេសនេះ មាស មុត និយាយតាម វិទ្យុទាក់ទងដោយខ្លួនឯង និងបានចេញបញ្ជាដោយផ្ទាល់ ទៅឲ្យអង្គភាពពាក់ព័ន្ធ"]។

851 ឯកសារ D54/87 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រំ សារ៉ាត់, ឆ.54 ["ជាធម្មតា ប្រព័ន្ធបញ្ជា គឺកងពលទៅកងវរសេនាធំ ពីកងវរសេនាធំទៅកងវរសេនាតូច កងវរសេនាតូចទៅកងអនុសេនាធំ ហើយពីកងអនុសេនាធំទៅយោធាផ្ទាល់"]។

852 ឯកសារ D54/25 កំណត់ហេតុនៃការស្តាប់ចម្លើយ ប៉ាក សុខ, ឆ.19។

853 ឯកសារ D114/13 កំណត់ហេតុនៃការស្តាប់ចម្លើយ នាក់ យឿន, ឆ.9 - 10 ["ពេលដែលគាត់ចេញទៅដោយផ្ទាល់ និងចូលរួមបេសកកម្មនោះ ខ្ញុំបានឮគាត់និយាយតាមវិទ្យុទាក់ទង។ [...] ឆ.10៖ នៅក្នុងពេលប្រតិបត្តិការណ៍ពិសេសនេះ មាស មុត និយាយតាម វិទ្យុទាក់ទងដោយខ្លួនឯង និងបានចេញបញ្ជាដោយផ្ទាល់ ទៅឲ្យអង្គភាពពាក់ព័ន្ធ"]។

854 ឯកសារ D114/19 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.25 ["ឧទាហរណ៍ដូចជា បើមានកប៉ាល់/កាណូតប្រយុទ្ធចូលមកក្នុងដែនទឹកយើង ហើយបើមេបញ្ជាការកងវរសេនាធំមិននៅ ខ្ញុំត្រូវរាយការណ៍ផ្ទាល់ទៅកងពលតែម្តង"]។ ឯកសារ D114/24 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ូ ដាវ, ឆ.96 ["នៅពេលខ្លះ គេឯករាជ្យ គេបញ្ជាឲ្យចាប់ភ្លាមៗ។ ពេលខ្លះទៀត គេប្រាប់ថា គេសុំការណែនាំពីថ្នាក់លើសិន"]។ ឯកសារ D54/100 កំណត់ហេតុនៃការស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.141 - 142 ["ប្រសិនបើមានបទបញ្ជាប្រយុទ្ធ គឺកងពលជាអ្នកបញ្ជូនប្រយុទ្ធផ្ទាល់ទៅ

268. រចនាសម្ព័ន្ធរាយការណ៍តាមឋានានុក្រមនេះ មានលក្ខណៈស៊ីសង្វាក់គ្នាក្នុងកងពលរបស់កងទ័ពបដិវត្តន៍កម្ពុជា និងជាទូទៅស្ថិតក្នុង ប.ក.ក[856]។ បទបញ្ជាស្ទើរតែទាំងអស់ដែលដាក់មក គឺចេញពី **មាស មុត**។ លុះត្រាតែគាត់អវត្តមាន ទើបអ្នកក្រោមបង្គាប់ណាម្នាក់អាចផ្សព្វផ្សាយបទបញ្ជាទៅថ្នាក់ដឹកនាំកំពូលៗរបស់កងពលនេះបាន៖

> ការសម្រេចចិត្តទាំងអស់គឺចេញពីមេធំ គឺក្នុងករណីដែលតាមុតអវត្តមានប៉ុណ្ណោះ ដែលអនុរបស់គាត់អាចចេញបញ្ជាបាន។ នៅថ្នាក់វរៈសេនាតូច ហន ជាអ្នកចេញបញ្ជា។ អ្នកផ្សេងទៀតអាចនិយាយ ឬទំនាក់ទំនង ឬសរសេរបញ្ជានោះ ប៉ុន្តែការសម្រេចចិត្ត គឺជាការងាររបស់ប្រធាន។ ប្រសិនបើអនុប្រធាន សមាជិក និងប្រធានអវត្តមាន គឺទាំងអស់គ្នាពិភាក្សាទៅលើវិធានការដែលត្រូវអនុវត្ត ប៉ុន្តែការសម្រេចចិត្តគឺធ្វើឡើងដោយប្រធាន[857]។

269. អ៊ួ ដាវ បានរៀបរាប់ថា ខណៈដែល **មាស មុត** ទទួលបញ្ជាមួយចំនួនពីមជ្ឈិមបក្ស គាត់ "សម្រេចចិត្តដោយខ្លួនឯង។ ថ្នាក់ក្រោមៗ **មាស មុត** មិនហ៊ានសម្រេចចិត្តដោយខ្លួនឯងនោះទេ"[858]។

---

នាវា ដោយមិនឆ្លងកាត់កងវរសេនាធំ […]ឆ. 142៖ […] ហើយកងពលចេញបញ្ជាផ្ទាល់ទៅនាវាតែម្តង ដោយមិនឆ្លងកាត់ កងវរសេនាធំទៀតទេ ដើម្បីឱ្យការងាររហ័ស។"]។

855 ឯកសារ D54/82 កំណត់ហេតុនៃការស្តាប់ ចម្លើយ ហ៊ឹង អ៊ិច, ឆ.9 ["ស៖ នៅកម្រិតកងវរសេនាធំ ៦៣ នៃកងពល ១៦៤ តើលោកទទួលការណែនាំពីថ្នាក់លើដទៃទៀតក្រៅពីកងពល ១៦៤ ដែរឬទេ? ឆ.9៖ ទេ! ខ្ញុំមិនដែលបានទទួលអ្វីពីអង្គភាពផ្សេងៗទៀតទេ។ រាល់អ្វីទាំងអស់ដែលខ្ញុំបានទទួល គឺសុទ្ធសឹងតែទទួលបានមកពីកងពល ១៦៤"]។

856 ឯកសារ D98/1.2.4 ប្រតិចារឹក Craig Etcheson, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៩ ម៉ោង 16.16.21 – 16.23.33 ["ជាទូទៅ នៅក្នុងស្ថាប័នក្បាល់ម៉ាស៊ីនរដ្ឋបាល យោធា និងនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ការប្រាស្រ័យទាក់ទងគ្នា គឺកំណត់ បំផុត តែតាមរយៈខ្សែបណ្តោយតែប៉ុណ្ណោះ។ […] មានន័យថា គឺមជ្ឈិមបក្ស គឺជាទីចំនុចកណ្តាលសម្រាប់អង្គការចាត់តាំង ទាំងមូល"]។ សូមមើលផងដែរ ឯកសារ D234/2.1.52 របាយការណ៍អ្នកជំនាញការ Craig Etcheson, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧, EN 00142834, KH 00314792 ["គណៈអចិន្ត្រៃយ៍ បានត្រួតត្រាបណ្តាញទំនាក់ទំនងទាំងអស់ក្នុងរបបកម្ពុជា ប្រជាធិបតេយ្យ និងបណ្តាញទមានក់ទំនងទាំងអស់ ដែលត្រូវបានរៀបចំតាមឋានានុក្រមពីលើចុះក្រោម យ៉ាងតឹងរ៉ឹង"]។ ឯកសារ D1.3.22.1 លក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦, EN 00184037, KH 00053024 [មាត្រា ៦]។

857 ឯកសារ D114/12 កំណត់ហេតុនៃការស្តាប់ចម្លើយ នាក់ យឿន, ឆ.22។

858 ឯកសារ D114/24 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ួ ដាវ, ឆ.140 ["ការបញ្ជានោះ គឺមកពីថ្នាក់លើ។ នៅពេលនោះ គឺមានតែ មាស មុត ទេ។ មាស មុត ទទួលបញ្ជាពីថ្នាក់លើមកទៀត។ ពេលខ្លះ មាស មុត សម្រេចចិត្តដោយខ្លួនឯង។ ថ្នាក់ក្រោមៗ មាស មុត មិនហ៊ានសម្រេចចិត្តដោយខ្លួនឯងនោះទេ"]។

270. ដើម្បីឱ្យ **មាស មុត** បន្តទទួលបានព័ត៌មានស្តីពីបញ្ហានានាក្នុងកងពលធំលេខ ១៦៤ និងក្នុងតំបន់កាន់កាប់របស់គាត់ មេបញ្ជាការកងវរៈសេនាធំ និងមេបញ្ជាការកងវរៈសេនាតូចឯករាជ្យ ត្រូវធ្វើរបាយការណ៍យ៉ាងហោចណាស់ប្រចាំថ្ងៃ ទៅទីបញ្ជាការកងពលធំ បន្ទាប់ពីទទួលបាន និងបូកសរុបរបាយការណ៍ពីអង្គភាពក្រោមការគ្រប់គ្រងរបស់ខ្លួន[859]។ ហ៊ីង អ៊ុច បានរៀបរាប់ពីភាពទៀងទាត់នៃការងារការិយាល័យដែលត្រូវមានការដាក់របាយការណ៍ទៅ **មាស មុត** បន្ទាប់ពីទទួលបានរបាយការណ៍ពីថ្នាក់ក្រោម ថា "យើងសរសេរបញ្ចូលចំណុចសំខាន់ៗ ដោយចំណុចដែលសំខាន់ជាងគេ យើងដាក់នៅក្នុងចំណុចទី ១ និងចំណុចសំខាន់បន្ទាប់ យើងដាក់នៅក្នុងចំណុចទី ២ និងចំណុចទី ៣ ជាហូរហែ ហើយយើងសរសេរបញ្ចូលគ្រប់ចំណុចទាំងអស់តែក្នុងមួយច្បាប់ទេ"[860]។ របាយការណ៍ទាំងនេះធ្វើឡើងជាទៀងទាត់ ញឹកញាប់ ច្បាស់លាស់ និងបូកសរុប និងត្រូវរៀបរាប់លម្អិត។ ណុប ហាល់ បានពន្យល់ថា "បទបញ្ជាគឺច្បាស់ណាស់ថា យើងត្រូវរាយការណ៍រាល់អ្វីដែលយើងបានសង្កេតឃើញនៅលើដែនសមុទ្រខ្មែរ ហើយបទបញ្ជាថា ត្រូវធ្វើអ្វីៗនោះ គឺចេញមកពីថ្នាក់លើ"[861]។ របាយការណ៍លម្អិតទាំងនេះត្រូវបញ្ជូនទៅ **មាស មុត** និងអនុរបស់គាត់។ ដូច្នេះ **មាស មុត** ដឹងព័ត៌មានគ្រប់បែបយ៉ាងអំពីអ្វីដែលកើតឡើងក្នុងតំបន់គ្រប់គ្រងរបស់គាត់៖ "ខ្ញុំនិយាយ

---

859 ឯកសារ D54/82 កំណត់ហេតុនៃការស្តាប់ចម្លើយ ហ៊ីង អ៊ុច, ឆ.21 ["ចម្លើយដែលត្រឹមត្រូវ គឺរបាយការណ៍ប្រចាំថ្ងៃសម្រាប់ផ្ញើទៅកងពល ១៦៤ ជានិច្ចកាល ច្រើនតែបានផ្ញើ និងផ្ញើនៅពេលល្ងាច។ វាមិនអាចផ្ញើទៅបាននោះទេ ក្នុងការផ្ញើរបាយការណ៍ទៅកងពល ១៦៤ នៅពេលព្រឹក អាស្រ័យដោយបណ្តាកោះនានាដែលស្ថិតនៅក្រោមកងវរសេនាធំត្រូវធ្វើ របាយការណ៍របស់គេដើម្បីឱ្យយើងធ្វើការត្រួតពិនិត្យ និងបូកសរុបជាមុនសិន"]។

860 ឯកសារ D54/82 កំណត់ហេតុនៃការស្តាប់ ចម្លើយ ហ៊ីង អ៊ុច, ឆ.20 ["រួចហើយ យើងបូកសរុបចំណុចនីមួយៗ ហើយយើងសរសេរបញ្ចូលចំណុចសំខាន់ៗ ដោយចំណុចដែលសំខាន់ជាងគេ យើងដាក់នៅក្នុងចំណុចទី១ និងចំណុចសំខាន់បន្ទាប់យើង ដាក់នៅក្នុងចំណុចទី២ និងចំណុចទី៣ ជាហូរហែរ ហើយយើងសរសេបញ្ចូលគ្រប់ចំណុចទាំងអស់តែក្នុងមួយច្បាប់ទេ"]។

861 ឯកសារ D54/79 កំណត់ហេតុនៃការស្តាប់ចម្លើយ ណុប ហាល់, ឆ.19 ["ខ្ញុំមិនដឹងទេ។ ដូចខ្ញុំបានប្រាប់លោកហើយថា បទបញ្ជាក្នុងការចាប់ទូក និងបញ្ជូនទូកទៅណាៗនោះ គឺចេញមកពីថ្នាក់លើ។ បទបញ្ជា គឺច្បាស់ណាស់ថា យើងត្រូវរាយការណ៍ រាល់អ្វីដែលយើងបានសង្កេតឃើញនៅលើដែនសមុទ្រខ្មែរ ហើយបទបញ្ជាថា ត្រូវធ្វើអ្វីនោះ គឺចេញមកពីថ្នាក់លើ"]។

ទៅកាន់អ្នកកាន់វិទ្យុនៅកងពល ហើយអ្នកនោះបានបញ្ជូនសេចក្តីរាយការណ៍របស់ខ្ញុំទៅកាន់មេបញ្ជាការកងពលដែលមាន តាមុត និង តាឌឹម"[862] ។

271. **មាស មុត** មិនត្រឹមតែទទួលយករបាយការណ៍ទាំងនេះនោះឡើយ។ សាក្សីម្នាក់បានពន្យល់ថា "ក្នុងនាមជាមេបញ្ជាការទទួលខុសត្រូវរួម **មាស មុត** គាត់ត្រូវតែចង់ដឹងថា មានរឿងអ្វីខ្លះដែលកើតមានឡើងក្នុងកងពល"[863]។ ផ្អែកតាមរបៀបរបបសព្វថ្ងៃ **មាស មុត** គឺជាអ្នកគ្រប់គ្រងទូទៅលើកិច្ចការតូចៗរបស់កងពលធំលេខ ១៦៤ នៅពេលពួកគេប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ខ្លួន៖

> ព្រឹត្តិការណ៍អ្វីដែលកើតឡើងត្រូវតែរាយការណ៍ទៅឲ្យកងវរៈសេនាតូច ហើយកងវរៈសេនាតូចរាយការណ៍ទៅមេបញ្ជាការកងវរៈសេនាធំ ហើយកងវរសេនាធំរាយការណ៍ទៅ

[862] ឯកសារ D114/19 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.26, ឆ.34 ["ខ្ញុំនិយាយទៅកាន់អ្នកកាន់វិទ្យុនៅកងពល ហើយអ្នកនោះបានបញ្ជូនសេចក្តីរាយការណ៍របស់ខ្ញុំទៅកាន់មេបញ្ជាការកងពលដែលមាន តាមុត និង តាឌឹម។ [...] ឆ.34៖ ក្នុងនាមជាមេបញ្ជាការទទួលខុសត្រូវរួម មាស មុត គាត់ត្រូវតែចង់ដឹងថា មានរឿងអ្វីខ្លះ ដែលកើតមានឡើងក្នុងកងពល។ ជាទូទៅ ខ្ញុំត្រូវរាយការណ៍ទៅឲ្យវរសេនាធំ ហើយវរសេនាធំបញ្ជូនបន្តទៅគាត់"]។ សូមមើលផងដែរ ឯកសារ D114/24 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ូ ដារ, ឆ.104 ["បាទ! ខ្ញុំបានរាយការណ៍ទៅមេបញ្ជាការកងអនុសេនាធំ។ ហើយ កងអនុសេនាធំ រាយការណ៍ទៅកងវរសេនាតូច ហើយកងវរសេនាតូច រាយការណ៍ទៅថ្នាក់លើ។ ឯកសារ D54/100 កំណត់ហេតុនៃការស្តាប់ចម្លើយ ឡាយ ប៊ុនហាក់, ឆ.142 ["ពេលចេញទៅបេសកកម្ម កងពលបញ្ជាមកកងវរសេនាធំឲ្យរៀបចំនាវា ដើម្បីចេញប្រតិបត្តិការណ៍ តែពេលនាវាទៅដល់កណ្តាលសមុទ្រ ហើយជួបប្រទះហេតុការណ៍ប្រយុទ្ធ គេទាក់ទងមកកងវរសេនាធំ ហើយកងវរសេនាធំទាក់ទងមកកងពល"]។ ឯកសារ D59/1/1.12 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ណុប ហាល, EN 00968404, KH 00926630 ["យើងៗឃើញ យើងរាយការណ៍វរសេនាធំៗគេរាយឲ្យកងពល"]។ ឯកសារ D59/1/4.25 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារ កម្ពុជា ឡុង លី EN 00970714, KH 00930812 ["ស៖ អីចឹងមានការអីមកតាម អ៊ំញ៉ាន់ ហ្នឹងបានអ៊ំញ៉ាន់ ទៅអ៊ំមុត? ឆ៖ ទៅ អ៊ំមុត ទៀតទៅ។"]។ ឯកសារ D54/87 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រុំ សារ៉ាត់, ឆ.60 ["ខ្ញុំរាយការណ៍តាមទូរសព្ទទៅ ហន ហើយ ហន រាយការណ៍ទៅ សារឿន បន្ទាប់មក សារឿន រាយការណ៍បន្តទៅ មាស មុត។ នេះជាការបញ្ជាតាមខ្សែបណ្តោយ។"]។ ឯកសារ D114/19.1 របាយការណ៍ពី ម៉ាក ឈឿន ទៅ មាស មុត, ថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៧៦, EN 01513939, KH 01034014។

[863] ឯកសារ D114/19 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.26, ឆ.34 ["ខ្ញុំនិយាយទៅកាន់អ្នកកាន់វិទ្យុនៅកងពល ហើយអ្នកនោះបានបញ្ជូនសេចក្តីរាយការណ៍របស់ខ្ញុំទៅកាន់មេបញ្ជាការកងពលដែលមាន តាមុត និង តាឌឹម។ [...] ឆ.34៖ ក្នុងនាមជាមេបញ្ជាការទទួលខុសត្រូវរួម មាស មុត គាត់ត្រូវតែចង់ដឹងថា មានរឿងអ្វីខ្លះ ដែលកើតមានឡើងក្នុងកងពល។ ជាទូទៅ ខ្ញុំត្រូវរាយការណ៍ទៅឲ្យវរសេនាធំ ហើយវរសេនាធំបញ្ជូនបន្តទៅគាត់។"]។

ឲ្យមេបញ្ជាការកងពល។ បន្ទាប់មក មេបញ្ជាការកងពលធ្វើសេចក្តីសម្រេច ហើយដាក់បញ្ជាបញ្ជូនចុះមកវិញតាមជាន់ថ្នាក់ទាំងនេះមកវិញ[864]។

272. បំណងរបស់ **មាស មុត** ដែលចង់ដឹងព័ត៌មានគ្រប់បែបយ៉ាង និងទូលំទូលាយស្តីពីអ្វីដែលបានកើតឡើងក្នុងតំបន់គ្រប់គ្រងរបស់គាត់ ត្រូវបានបង្ហាញក្នុងភស្តុតាងនៃប្រធានបទផ្សេងៗដែលបានរាយការណ៍ ចាប់ពីរឿងរ៉ាវសំខាន់រហូតដល់រឿងរ៉ាវធម្មតា។ របាយការណ៍ពាក់ព័ន្ធនឹងប្រធានបទផ្សេងៗ ដូចជា ស្ថានភាពកងទ័ព[865] ចំនួនកងទ័ពស្លាប់ និងរបួសក្រោយការប្រយុទ្ធ[866] ការចាប់ឃាត់ទូក និងការចាប់ខ្លួនមនុស្ស[867] បញ្ហាដែលកើតឡើងតាមអង្គភាព[868] ការបញ្ចប់ផែនការ និង

---

864 ឯកសារ D54/25 កំណត់ហេតុនៃការស្តាប់ចម្លើយ ប៉ាក សុខ, ឆ.19 ["ព្រឹត្តិការណ៍អ្វីដែលកើតឡើងត្រូវតែរាយការណ៍ទៅឲ្យកងវរសេនាតូច ហើយកងវរសេនាតូចរាយការណ៍ទៅមេបញ្ជាការកងវរសេនាធំ ហើយកងវរសេនាធំរាយការណ៍ទៅឲ្យមេ បញ្ជាការកងពល។ បន្ទាប់មក មេបញ្ជាការកងពល ធ្វើសេចក្តីសម្រេច ហើយដាក់បញ្ជាបញ្ជូនចុះមកវិញ តាមជាន់ថ្នាក់ទាំង នេះមកវិញ។"]។

865 ឯកសារ D1.3.34.39 សារទូរលេខ លេខ ៤ ពី មឿន គោរពជូន បងមុត, ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧, EN 00233656, KH 00161791 [មឿន រាយការណ៍ពីការយាមកាមនៅលើទឹកជុំវិញកោះរ៉ុង កោះវៃចាស់-ថ្មី និង កោះសេះ ហើយនិង ការហ្វឹកហ្វឺនតាមសមុទ្រ និង ទិន្នផលស្រូវ]។ ឯកសារ D114/19.1 របាយការណ៍ពី ម៉ាក ឈឿន ទៅ មាស មុត, ថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៧៦, EN 01513939, KH 01034014 [ម៉ាក ឈឿន សង្ខេបពីការប្រយុទ្ធ និង ស្ថានភាពយោធា នៅកោះត្រល់ នៅខែ មករា ឆ្នាំ ១៩៧៦]។ ឯកសារ D114/24 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ូ ដាវ, ឆ.136, ឆ.140 ["ខ្ញុំរាយការណ៍ទៅតាមខ្សែបណ្តោយរបស់ខ្ញុំទៅខាងលើ។ [...] ឆ.140៖ នៅពេលឃើញសភាពការណ៍អ្វីប្លែក ខ្ញុំរាយការណ៍ទៅថ្នាក់លើរបស់ខ្ញុំ ហើយថ្នាក់លើខ្ញុំ រាយការណ៍ទៅថ្នាក់លើបន្តទៀត។"]។ ឯកសារ D1.3.14.2, ឯកសារ D4.1.636, ឯកសារ D54/10.2 សារទូរលេខ លេខ ៤៣ មកពី មឿន គោរពជូន មាស មុត, ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៧៧ [មឿន បានពិពណ៌នាអំពីស្ថានភាពសត្រូវនៅអូរឈើទាល និងកោះរ៉ុងសន្លឹម រិះគន់អំពីទង្វើរបស់កម្មករដឹកជញ្ជូនម្នាក់នៅអូរឈើទាល ហើយស្នើសុំការសម្រេចពី មាស មុត ថាតើត្រូវយកកប៉ាល់លេខ ២ មកជួសជុលនៅ រាម ឬទេ]។

866 ឯកសារ D54/49 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ.44 ["បាទ! ខ្ញុំរាយការណ៍គ្រប់យ៉ាង។ ឧទាហរណ៍ នៅពេលសមរភូមិចប់ ខ្ញុំរាយការណ៍ទៅថ្នាក់លើអំពីអ្វីដែលបានសម្រេច ដែលខ្ញុំបានធ្វើនៅសមរភូមិនោះ អំពីលទ្ធផល និងអំពីចំនួនអ្នកស្លាប់ និងរបួស។"]។ ឯកសារ D114/24 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ូ ដាវ, ឆ.142 ["នៅពេលដែលខ្ញុំរាយការណ៍ទីមេបញ្ជាការកងវរសេនាតូចមានទូកនេសាទចូលព្រំដែនទឹកខ្មែរ មេបញ្ជាការកងវរសេនាតូច ប្រាប់ខ្ញុំថា គាត់នឹងរាយការណ៍ទៅថ្នាក់លើ"]។

867 ឯកសារ D54/82 កំណត់ហេតុនៃការស្តាប់ ចម្លើយ ហ៊ឹង អ៊ិច, ឆ.31 - 32 ["ជាធម្មតា ខ្ញុំត្រូវតែរាយការណ៍ជាប្រចាំថ្ងៃ ហើយខ្ញុំបានដាក់ការចាប់ទូកបរទេសនេះ ជាបញ្ហាអាទិភាពទី១នៅក្នុងរបាយការណ៍ ដោយសារវាទាក់ទងទៅនឹងការចាប់។ [...] ឆ.32៖ តាមខ្ញុំចាំ ជាទម្លាប់របស់អង្គភាពខ្ញុំ ការចាប់ទូកបរទេសនេះ ត្រូវបានចាត់ទុកជាការងារអាទិ

ភារកិច្ចនានា[869] បញ្ហាភស្តុភារ ដូចជា ការខ្វះខាតប្រេងឥន្ធនៈ ឬការជួសជុលកប៉ាល់[870] ការសាងសង់[871] ការបង្កបង្កើនផលស្រូវ[872] បញ្ហាសុខភាព[873] និង "ការប្រព្រឹត្តិខុស"[874]។ សូម្បីតែនៅពេល

---

ភាព ពីព្រោះទាក់ ទងនឹងការឈ្លានពានចូលដែនទឹកកម្ពុជា"]។ ឯកសារ D54/34.1 របាយការណ៍ពី ស៊ឹម គោរពជូនកងពល ១៦៤, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៧៧, EN 01098432, KH 00964231 [សេចក្តីរាយការណ៍អំពីការចាប់ទូកថៃនៅខាងត្បូងកោះកុង]។ ឯកសារ D1.3.34.12 សារទូរលេខ លេខ ១២ មកពី ឌឹម គោរពជូន មាស មុត, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៧៦, EN 00897638, KH 00021528 [ពិពណ៌នាអំពីការចាប់ខ្លួន និងចម្លើយសារភាពរបស់ក្មេងប្រុសម្នាក់អាយុ ១៦ ឆ្នាំ]។ ឯកសារ D114/24 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ូ ដាវ, ឆ.104 ["សៈ ក្រោយពីការចាប់ទូកបាន តើលោកបានជូនដំណឹងទៅថ្នាក់លើថា ត្រូវចាត់វិធានការយ៉ាងម៉េចចំពោះទូកនោះដែរឬទេ? ឆ.104៖ បាទ!"]។ ឯកសារ D54/100 កំណត់ហេតុនៃការស្តាប់ចម្លើយ ឡាយ ប៊ុនហាក់, ឆ.156 ["ពេលដែលគេចាប់បាន គេរាយការណ៍មកកងពល"]។ ឯកសារ D54/79 កំណត់ហេតុនៃការស្តាប់ចម្លើយ ណុប ហាល់, ឆ.12 ["បាទ! ខ្ញុំសង្កេតឃើញមាននាឡិកាដៃ និងមាសសន្លឹកជាង១០សន្លឹក។ នៅពេលពួកគេត្រូវបានចាប់ខ្លួន សម្ភារៈទាំងនោះ ក៏ត្រូវបានរឹបអូស និងសរសេរដាក់ក្នុងរបាយការណ៍ ដែរ។ ទាំងមនុស្ស ទាំងទូក សម្ភារៈ និងរបាយការណ៍ ត្រូវបានបញ្ជូនទៅកំពង់សោមទាំងអស់"]។ ឯកសារ D54/23 កំណត់ហេតុនៃការស្តាប់ចម្លើយ ប៉ាក សុក, ឆ.28 ["បាទ! ត្រូវតែរាយការណ៍ឲ្យច្បាស់លាស់នូវអ្វីដែលយើងចាប់បាន។ ឧទាហរណ៍ថា តើគេជាជនជាតិវៀតណាមអៀសខ្លួន ជាអ្នកនេសាទថៃ ឬជាកងទ័ព យើងត្រូវតែរាយការណ៍ទៅថ្នាក់លើឲ្យបានច្បាស់លាស់ជាមុន"]។

868 ឯកសារ D1.3.14.2 ឯកសារ D54/10.2 សារទូរលេខ លេខ ៤៣ មកពី មឿន គោរពជូនទៅ មាស មុត, ថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ ១៩៧៧ [មឿន បានពិពណ៌នាអំពីស្ថានភាពសត្រូវ នៅអូរឈើទាល និងកោះរ៉ុងសន្លឹម រិះគន់អំពីទង្វើរបស់កម្មករដឹកជញ្ជូនម្នាក់នៅអូរឈើទាល ហើយស្នើសុំការសម្រេចពី មាស មុត ថាតើត្រូវយកកប៉ាល់លេខ ២ មកជួសជុលនៅ រាម ឬទេ]។

869 ឯកសារ D114/19 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.35 ["ជាទូទៅ យើងត្រូវរាយការណ៍គ្រប់បែបបគ្រប់យ៉ាង បើយើងធ្វើមិនបានសម្រេចតាមផែនការ និងការចាត់តាំង ក៏ត្រូវតែរាយការណ៍ពីការពិត។ បើថ្នាក់លើឃើញថា យើងមិនអាចបំពេញភារៈកិច្ចទៅតាមផែនការថ្នាក់លើនឹងពិនិត្យផែនការនោះឡើងវិញ ហើយនឹងកែប្រែវិធានការបញ្ជូនត្រឡប់ មកយើងវិញ"]។ ឯកសារ D54/100 កំណត់ហេតុនៃការស្តាប់ចម្លើយ ឡាយ ប៊ុនហាក់, ឆ. 141 ["មុនពេលចេញទៅ គេប្រាប់ ហើយពេលនាវាចេញប្រតិបត្តិការណ៍ គឺគេទាក់ទងតាមវិទ្យុទាក់ទង បើមានករណីនេះ ត្រូវតែបាញ់តបតវិញ។ នៅពេលនាវាប្រតិបត្តិការណ៍ ប្រសិនបើគេជួបប្រទះហេតុការណ៍អី គេរាយការណ៍មកកងវរសេនាធំ ហើយវរសេនាធំ រាយការណ៍ទៅកងពល"]។

870 ឯកសារ D1.3.34.15 សារទូរលេខ លេខ ១៧ ពី ឌឹម គោរពជូន មាស មុត, ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ១៩៧៦, EN 00233659, KH 00000867 [ឌឹម រាយការណ៍អំពីការរត់គេចខ្លួនរបស់យុទ្ធជនម្នាក់ និងសេចក្តីណែនាំពីចិនក្នុងការថែទាំកប៉ាល់]។ ឯកសារ D54/87 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រំ សារ៉ាត់, ឆ.59, ឆ.61 ["ខ្ញុំរាយការណ៍ទៅថ្នាក់លើតាមទូរសព្ទវិញ។ ឧទាហរណ៍ ខ្ញុំជាអ្នកគ្រប់គ្រងនាវា បើនាវាខ្ញុំ មានបញ្ហាដូចជា ត្រូវជួសជុល ឬក៏ត្រូវថែមប្រេងខ្ញុំត្រូវរាយការណ៍តាមទូរសព្ទទៅថ្នាក់លើវិញ។ [...] សៈ ក្នុងករណីដែលនាវាត្រូវការស្បៀងអាហារ ឬក៏ប្រេង តើ

**មាស មុត** ស្ថិតនៅឆ្ងាយពីតំបន់កំពង់សោមក្ដី ក៏ ឌឹម ដែលជាអនុរបស់គាត់ ត្រូវផ្ញើរបាយការណ៍ទៅ **មាស មុត** ដើម្បីផ្ដល់ព័ត៌មានថ្មីៗដែរ[875]។

---

លោកអាចទាក់ទងទៅខាងភស្តុភារផ្ទាល់ ឬក៏ទៅកងណាផ្សេងបានដែរឬទេ? ឆ.61៖ ខ្ញុំត្រូវតែធ្វើតាមខ្សែរបាយការណ៍ ដូចដែលខ្ញុំបានប្រាប់ពីខាងលើ"]។ ឯកសារ D1.3.14.2, ឯកសារ D4.1.636, ឯកសារ D54/10.2 សារទូរលេខ លេខ ៤៣ មកពី មឿន គោរពជូនទៅ មាស មុត, ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៧៧ [មឿន បានពិពណ៌នាអំពីស្ថានភាពសត្រូវ នៅអូរឈើទាល និងកោះរ៉ុងសន្លឹម រិះគន់អំពីទង្វើរបស់កម្មករដឹកជញ្ជូនម្នាក់នៅអូរឈើទាល ហើយស្នើសុំការសម្រេចពី មាស មុត ថាតើត្រូវយកកប៉ាល់លេខ ២ មកជួសជុលនៅ រាម ឬទេ]។ ឯកសារ D54/82 កំណត់ហេតុនៃការស្ដាប់ ចម្លើយ ហ៊ីង អ៊ិច, ឆ.30 ["ឧទាហរណ៍ ប្រសិនបើទូករបស់យើងណាមួយខូច គេតម្រូវឱ្យយើងរាយការណ៍អំពីបញ្ហានេះ និងចាត់វិធានការ ដោយខ្លួនឯង ដោយឯករាជ្យ ដើម្បីដោះស្រាយបញ្ហានៅក្នុងតំបន់របស់យើង"]។

871 ឯកសារ D54/82 កំណត់ហេតុនៃការស្ដាប់ ចម្លើយ ហ៊ីង អ៊ិច, ឆ.20 ["របៀបនៃការរាយការណ៍ប្រចាំថ្ងៃ ដំបូងយើងប្រមូលសេចក្ដីរាយការណ៍ពីគ្រប់កោះទាំងអស់ ដែលនៅក្រោមចំណុះកងវរសេនាធំរបស់យើង។ បន្ទាប់មកយើងពិនិត្យរបាយការណ៍ ទាំងអស់នោះ ដែលរួមមានបញ្ហាសុខភាព សភាពការណ៍ផ្សេងៗ និងការងារកសាង"]។ ឯកសារ D1.3.34.13 សារទូរលេខ លេខ ១៦ ពី ឌឹម គោរពជូន មាស មុត, ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៩៧៦, EN 00233657, KH 00000865 [ឌឹម រាយការណ៍អំពី ការតំឡើងរ៉ាដា ការមើលនាវាបរទេស និងការស្វែងរកពួកចោរ]។

872 ឯកសារ D1.3.34.39 សារទូរលេខ លេខ ៤ ពី រឿន គោរពជូន បងមុត ថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧, EN 00233656, KH 00161791 [រឿន រាយការណ៍អំពីការដើរល្បាតដែនទឹកជុំវិញកោះរ៉ុង កោះវៃថាស់-ថ្មី និង កោះសេះ ការរៀនសូត្រ និងការ ផលិតស្រូវ]។

873 ឯកសារ D54/82 កំណត់ហេតុនៃការស្ដាប់ ចម្លើយ ហ៊ីង អ៊ិច, ឆ.20 ["របៀបនៃការរាយការណ៍ប្រចាំថ្ងៃ ដំបូងយើងប្រមូលសេចក្ដីរាយការណ៍ពីគ្រប់កោះទាំងអស់ ដែលនៅក្រោមចំណុះកងវរសេនាធំរបស់យើង។ បន្ទាប់មកយើងពិនិត្យរបាយការណ៍ ទាំងអស់នោះ ដែលរួមមានបញ្ហាសុខភាព សភាពការណ៍ផ្សេងៗ និងការងារកសាង"]។ ឯកសារ D59/1/4.25 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារ កម្ពុជា ឡុង លី EN 00970714, KH 00930813 ["យើងរាយការណ៍មក បើយើងឃើញពីណាខុសឆ្គង យើងរាយការណ៍ទៅ ហើយគេហៅប្រជុំកសាង បើយើងឈឺ យើងទៅប្រាប់គេប្រធានហ្នឹង ឱ្យ ប្រធានរាយការណ៍ទៅថា ម្នាក់នេះឈឺចេះ ឈឺចោះ ហើយជួយផ្ដល់ថ្នាំមកឱ្យលេប អត់មានយើងនៅសេរី យើងដើរសេរី ដូចនៅផ្ទះយើងទេ យើងនៅអង្គភាព"]។

874 ឯកសារ D59/1/4.25 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារ កម្ពុជា ឡុង លី EN 00970714, KH 00930813 ["យើងរាយការណ៍មក បើយើងឃើញពីណាខុសឆ្គង យើងរាយការណ៍ទៅ ហើយគេហៅប្រជុំកសាង"]។

875 សូមមើលឧទាហរណ៍ ឯកសារ D4.1.699 សារទូរលេខលេខ ១១ មកពី ឌឹម គោរពជូនទៅ មាស មុត, ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦, EN 00143240, KH 00092628 [រៀបរាប់អំពីស្ថានភាពនៅកំពង់សោម រួមមានការចាប់ខ្លួនមនុស្សដែលរត់ចូលព្រៃ]។ សូមមើលផងដែរ ឯកសារ D1.3.34.12 សារទូរលេខលេខ ១២ មកពី ឌឹម គោរពជូន

273. **មាស មុត** នៅតែបន្តដាក់បញ្ជា*តាមវិទ្យុ* និងទូរលេខ ទៅកងពលធំលេខ ១៦៤ បន្ទាប់ពីគាត់ត្រូវបានបញ្ជូនទៅក្រុងភ្នំពេញ និងខេត្តក្រចេះ។ ឧទាហរណ៍មួយពាក់ព័ន្ធនឹងចំណុចនេះ គឺនៅពេលដែល **មាស មុត** បញ្ជាឱ្យកម្ទេចកប៉ាល់របស់កងពលធំលេខ ១៦៤ ដើម្បីកុំឱ្យវៀតណាមអាចប្រើប្រាស់កប៉ាល់ទាំងនោះបាននៅពេលវាយលុកចូលកម្ពុជា[876]។ តាមពិត រហូតដល់ថ្ងៃចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ **មាស មុត** នៅតែដាក់បញ្ជាទៅអង្គភាពក្នុងកងពលធំលេខ ១៦៤ តាមសារទូរលេខ[877] ឬក៏គាត់ដាក់បទបញ្ជាបន្តតាមរយៈ ទឹម សេង ដែលជាប្រធានស្តីទីរបស់កងពលធំលេខ ១៦៤[878]។

---

មាស មុត, ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៧៦, EN 00897638, KH 00021528 [រៀបរាប់អំពីការចាប់ខ្លួន និងចម្លើយសារភាពរបស់ក្មេងប្រុសម្នាក់អាយុ ១៦ ឆ្នាំ]។ ឯកសារ D1.3.34.14 សារទូរលេខ លេខ ១៥ មកពី ឌឹម គោរពជូន មាស មុត, ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៩៧៦, EN 00233661, KH 00000866 [ឌឹម រាយការណ៍អំពីនាវាដែលចូលក្នុងដែនសមុទ្រ ការផ្គត់ផ្គង់អង្ករ និងសំណើសុំប្រេងទូក]។ ឯកសារ D1.3.34.13 សារទូរលេខ លេខ ១៦ ពី ឌឹម គោរពជូន មាស មុត, ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ១៩៧៦, EN 00233657, KH 00000865 [ឌឹម រាយការណ៍អំពីការតំឡើងរ៉ាដាការមើលនាវាបរទេស និងការស្វែងរកពួកចោរ]។ ឯកសារ D1.3.34.15 សារទូរលេខ លេខ ១៧ ពី ឌឹម គោរពជូន មាស មុត, ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ១៩៧៦, EN 00233659, KH 00000867 [ឌឹម រាយការណ៍អំពីការរត់គេចខ្លួនរបស់យុទ្ធជនម្នាក់ និងសេចក្តីណែនាំពីចិនក្នុងការថែទាំកប៉ាល់]។

876 ឯកសារ D114/13 កំណត់ហេតុនៃការស្តាប់ចម្លើយ នាក់ យឿន, ឆ.20-21 ["ពេលវៀតណាមចូលមកដល់កំពង់សោម មាស មុត បានចេញពីកំពង់សោមមុននោះរួចហើយ ហើយខ្ញុំក៏មិនដឹងថា គាត់ទៅទីណាដែរកាលនោះ ប៉ុន្តែខ្ញុំដឹងថា បញ្ជាឱ្យកម្ទេចនាវា/កប៉ាល់ ទាំងនោះ គឺចេញពី មាស មុត។ [...] ឆ.21៖ ខ្ញុំឮសម្លេង មាស មុត តាមវិទ្យុទាក់ទង ហើយអ្នកផ្សេងទៀតក៏ឮដែរ។"]។ ឯកសារ D59/1/1.8a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រំ សារ៉ាត់ EN 00974227, KH 00926404 - 00926405 ["ចូលមកកោះកុងមាន អីយើងត្រូវកម្ទេចសម្ភារៈនឹងចោល កម្ទេចចោលទាំងអស់។ ស៖ ហេតុអីបានយើងចាំបាច់កម្ទេច? ឆ៖ អាហ្នឹងយើងធ្វើម៉េចកុំឱ្យពួកខ្មាំងយកបានកុំឱ្យយួនយកវិញ កុំឱ្យយួនទៅប្រើ"]។

877 ឯកសារ D59/1/1.8a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រំ សារ៉ាត់, EN 00974227, KH 00926404 [វរសេនាធំ ១៤០: "ជាសារទូរលេខអី ឆ្លងឆ្លើយ"]។

878 ឯកសារ D54/100 កំណត់ហេតុនៃការស្តាប់ចម្លើយ ឡាយ ប៊ុនហាក់, ឆ.96 ["មាស មុត គាត់ទៅខាងអគ្គសេនាធិការ ដូច្នេះការងារទាំងអស់គាត់បញ្ជាពីខាងលើមកតាមរយៈ ទឹម សេង ហើយ ទឹម សេង ដើរមើលការងារ និងបញ្ជាការងារបន្ត"]។ ឯកសារ D54/98 កំណត់ហេតុនៃការស្តាប់ចម្លើយ ប៉ាង រ៉េត (ហៀង រ៉េត), ឆ.28 ["ក្រោយពេល ទឹម សេង ត្រូវបានឡើងជាប្រធាន កងពល ១៦៤ ជំនួស មាស មុត នៅឆ្នាំ ១៩៧៨ នៅពេលដែលមានការប្រយុទ្ធគ្នាខ្លាំងជាមួយវៀតណាម [...] មាស មុត ត្រូវបានឡើងទៅធ្វើការជាអគ្គបញ្ជាការរួមជាមួយ សុន សេន និង ស៊ូ សាម៉េត"]។

274. វចនាសម្ព័ន្ធរាយការណ៍ដែលបានរៀបរាប់ខាងលើ ប្រើប្រាស់មធ្យោបាយទាក់ទងយ៉ាងច្រើន ដូចជា វិទ្យុ សារទូរលេខ ទូរស័ព្ទ នីរសារ និងកិច្ចប្រជុំ និងការបញ្ជូនព័ត៌មានពីប្រព័ន្ធវ៉ាជា។

## វិទ្យុទាក់ទង

275. វិទ្យុទាក់ទងត្រូវបានប្រើប្រាស់នៅក្នុងកងពល ១៦៤[879] និងត្រូវបានបន្តប្រើប្រាស់មួយរយៈពេលខ្លី ក្រោយពេលកងពលលេខ ៣ បានមកដល់កំពង់សោម[880]។ ទីបញ្ជាការវិទ្យុទាក់ទងរបស់កងពល ១៦៤ ស្ថិតនៅទីបញ្ជាការកងពល ហើយមានអ្នកកាន់វិទ្យុទាក់ទងពីរបីនាក់[881] ក្នុងនោះ មាន កេង និង កុល[882]។ ក្នុងអំឡុងពេលនោះ អ្នកទទួលបន្ទុកអង្គភាពវិទ្យុទាក់ទងមានដូចជា កុល, សារី[883] និងផល[884]។ យ៉ាន និង ង៉ុយ ជាអ្នកកាន់វិទ្យុទាក់ទងផ្ទាល់ខ្លួនរបស់ **មាស មុត**[885]។

---

879 ឯកសារ D59/1/1.7a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយ មជ្ឈមណ្ឌលឯកសារកម្ពុជា ម៉ា ឈឿន, EN 00969944, KH 00926323 ["ស៖ កាលហ្នឹង ពេលដែលអីខាងកងពលអី មានផែនការណ៍ទទួលបញ្ជាអី ផែនការណ៍អីថ្មីៗគេច្រើន គេខាងកងពលអី គេច្រើននិយាយថាម៉េចខ្លះទៀតទៅ? ឆ៖ ជូនកាលបញ្ជាតាមតេអូ"]។ សូមមើលផងដែរ ឯកសារ D1.3.27.1 កំណត់ហេតុនៃកិច្ចប្រជុំអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា, ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៧៥, EN 00183401 – 00183402, KH 00019118 - 00019119 ["វិទ្យុទាក់ទង: មានភារកិច្ច - បម្រើការងារចំពោះមុខ - បម្រើការងារក្នុងសង្គ្រាម - ស៊ើបការណ៍ពីខ្មាំង - កម្លាំងដែលត្រូវប្រើប្រាស់ ១៥០០ នាក់"]។

880 ឯកសារ D22.2.181 សេចក្តីរាយការណ៍ពីការិយាល័យល្បើយសឹក និងយុទ្ធជនបាត់ខ្លួនសហរដ្ឋអាមេរិក មាស មុត, EN 00249694, KH 00741997 ["ក្នុងអំឡុងពេលមានឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស កងពលធំលេខ ៣ មានវិទ្យុទាក់ទងប្រភេទ C-25 ដែលមានមូលដ្ឋាននៅកោះតាង និងនៅរាម"]។ ឯកសារ D114/285 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រុំ សារ៉ាត (ប៊ុន សារ៉ាត់), ឆ.26 ["ពេលទៅដល់ទីបញ្ជាការ កងពលបោះទីតាំងវរសេនាធំ ទីតាំងវរសេនាតូចបោះទីតាំង ហើយប្រព័ន្ធទាក់ទងជាវិទ្យុទាក់ ទង គឺមានគ្រប់អង្គភាព"]។ ឯកសារ D4.1.746 សេចក្តីរាយការណ៍ពីការិយាល័យល្បើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក សំ សុក, EN 00387463, KH 00742598 ["កងពលធំលេខ ៣ ស្ថិតនៅក្នុងផ្ទះបេតុងមួយខ្នង នៅអូរកំបុត (រកមិនឃើញនៅលើផែនទីដែលមាន។ តំបន់នេះ អាចស្ថិត នៅក្នុងផ្នែកមួយនៃទីក្រុងកំពង់សោម)។ កងពលធំលេខ ៣ ក៏មានស្ថានីយ៍វិទ្យុមួយនៅកំពង់ផែកំពង់សោម និងមួយកន្លែងទៀតនៅ រាម"]។

881 ឯកសារ D114/285 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រុំ សារ៉ាត់ (ប៊ុន សារ៉ាត់), ឆ.124 ["ធម្មតា កន្លែងកងពលមានទីបញ្ជាការរបស់គេអូមួយ។ ទីបញ្ជាការនោះ ចង់និយាយថា អ្នកកាន់តេអូ។ មនុស្សពីរនាក់ បីនាក់ តាមជាក់ស្តែងតាមការងារតិចច្រើន"]។

882 ឯកសារ D1.3.5.11 បញ្ជីអ្នកទោស បញ្ជីឈ្មោះមនុស្សដែលជាប់ក្នុងចម្លើយខ្មាំង EN 01148995, KH 00161754 [កំណត់អត្តសញ្ញាណនៅលេខរៀងទី ១៦ ឈ្មោះ កេង ក្នុងបញ្ជីគឺជាអ្នក"កាន់វិទ្យុទាក់ទង កងពល"]។ ឯកសារ

276. ប្រធានអង្គភាពវិទ្យុទាក់ទង ព្រមទាំងអ្នកកាន់វិទ្យុទាក់ទង និងនីរសារផ្សេងទៀត ដើរតួជាអន្តរការី សម្រាប់ **មាស មុត** និងអង្គភាពវិទ្យុទាក់ទងផងដែរ ដោយទាំងសងខាងទទួលសារពី **មាស មុត** រួច ផ្ញើទៅអ្នកទទួល[886]។ ប្រព័ន្ធវិទ្យុទាក់ទងរបស់កងពល ១៦៤ ប្រើលេខសម្គាល់ ដើម្បីកំណត់

---

D59/1/1.9a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ឡាយ ប៊ុនហាក់, EN 00963740, KH 00926473 ["ចុះនៅខាងអ្នកកាន់តេអ្វូនៅខាងអី! បញ្ជាការកងពល? [...] ឆ៖ មនុស្ស បងកុល ហ្នឹង ឯង បន្ទាប់មក បងកុល មកគាត់ឈ្មោះនេះឯងឈ្មោះអី ឈុន លី ឬផល្លីទេ ខ្ញុំមិនសូវស្គាល់"]។

883 ឯកសារ D59/1/1.11a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហៀង រ៉េត, EN 00974094 - 00974095, KH 00926539 - 00926540 ["ស៖ ចឹងឈ្មោះ កុល ដែលគាត់ចេះអង់គ្លេសហ្នឹង គាត់ស្លាប់ឆ្នាំណា? ឆ៖ ឆ្នាំណាមិនដឹងឆ្នាំណា កាលហ្នឹងវាមានការដកទៅនេះអីហ្នឹង យើងវាមិនដឹងណាស់។ ស៖ ចឹងបាត់ខ្លួនតាំងពីសម័យ ៣ឆ្នាំហ្នឹង ឬមួយយ៉ាងម៉េច? ឆ៖ បាទ! តាំងពីជំនាន់ហ្នឹងមក។ [...] ស៖ ចឹងបន្ទាប់ពី កុល ស្លាប់ទៅ សារី ហ្នឹងគាត់មកកាន់តេអ្វូជំនួស? ឆ៖ បាទ!"]។

884 ឯកសារ D114/13 កំណត់ហេតុនៃការស្តាប់ចម្លើយ នាក់ យឿន, ឆ.5, ឆ.7 ["នៅថ្នាក់កងពល ១៦៤ គឺ ឈ្មោះ ផល គឺជាអ្នកកាន់ខាងវិទ្យុទាក់ទង។ ផល គឺជានិរសាផ្ទាល់របស់ មាស មុត កាន់ខាងវិទ្យុទាក់ទង។ [...] ឆ.7៖ [...] នៅពេលដែលមានប្រជុំធំ" ឬក៏វគ្គរៀនសូត្រអ្វីមួយ ដែល មាស មុត ចូលរួម គឺ ផល [និរសាររបស់គាត់] តែងតែអមដំណើរទៅជាមួយ ដែរ"]។ ឯកសារ D54/115.1 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា នាក់ យឿន, EN 01088463, EN 01088466, KH 01007862, KH 01007865 ["ស៖ ចុះអ្នកនៅ PCF មកយកឈ្មោះ ផល ដែលខាងនិរសាកងពលនឹង មានយកពីណាទៅទៀត ដែលត្រូវទៅជាមួយក្នុងព្រឹត្តិការណ៍ហ្នឹងដែរ? ឆ៖ ដែលយក ប៊ុនដឹងថាយក ផល [...] បើសិនណាម៉េចម៉ា អាផល នឹងតេអ្វូមកចូលកប៉ាល់ពួកខ្ញុំ។ [...] ផល នៅកន្លែង តាម៉ុត នេះទេ"]។

885 ឯកសារ D54/72 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ (អតីតនិរសា របស់បងស្រីជីដូនមួយ ខុម និង អ្នកទទួលទូរសព្ទ សម្រាប់ មាស មុត), ឆ.2 ["យ៉ន និង ជុំញ គឺជាអ្នកកាន់វិទ្យុទាក់ទង"]។

886 ឯកសារ D114/13 កំណត់ហេតុនៃការស្តាប់ចម្លើយ នាក់ យឿន, ឆ.5 ["នៅពេលដែល ផល ទទួលបានរបាយការណ៍តាម វិទ្យុទាក់ទង គាត់ត្រូវសរសេររបាយការណ៍ការណ៍ ហើយប្រគល់ជូនទៅ មាស មុត ដែលជាមេបញ្ជាការកងពល។ ក្រោយមកទៀត មាស មុត ចេញបញ្ជាឲ្យ ផល ហើយ ផល ក៏និយាយតាមវិទ្យុទាក់ទងប្រាប់ពីបញ្ជាដែលចេញពីកងពលទៅដល់ អង្គភាពពាក់ព័ន្ធ"]។ ឯកសារ D54/48 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ.14 - 16 ["ដំបូង ខ្ញុំបាននិយាយតាមវិទ្យុទៅកាន់វិទ្យុ (តេអ្វូ) ដែលមានឈ្មោះ សារ៉ន និង ឌុល។ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំចង់និយាយជាមួយ ៦៣/មាស មុត បន្ទាប់មក ៦៣/មាស មុត និយាយជាមួយខ្ញុំតាវិទ្យុ ហើយចេញបញ្ជាឲ្យខ្ញុំនាំកងទ័ពអាមេរិកាំងពីរនាក់ដែលនៅរស់។ [...] តាមការពិត មាស មុត មិនដែលនិយាយជាមួយខ្ញុំដោយផ្ទាល់ទេ តាវិទ្យុ គឺមានតែ សារ៉ន និង ឌុល ទេ ដែលបាននិយាយតាមវិទ្យុជាមួយខ្ញុំ។ ចំពោះខ្ញុំ អ្នកទាំងពីរ គឺតំណាងឲ្យ មាស មុត នៅពេលនិយាយជាមួយខ្ញុំ។ ពួកគេបានផ្តល់បញ្ជាពី មាស មុត មកឲ្យខ្ញុំ។ [...] នៅពេលដែលខ្ញុំនិយាយវិទ្យុទាក់ទងទៅអ្នកតំណាង ខ្ញុំរាយការណ៍អំពីកងទ័ពអាមេរិកាំង។ អ្នកកាន់វិទ្យុ បានធ្វើរបាយការណ៍មួយ ហើយបញ្ជូនទៅឲ្យ មាស មុត

អត្តសញ្ញាណបុគ្គលជាក់លាក់ ឧទាហរណ៍ **មាស មុត** មានលេខសម្គាល់ "៦៣" [887]។ ក្នុងករណី **មាស** មុត អវត្តមាន កម្មាភិបាលផ្សេងទៀត ដូចជា ទឹម សេង ហៅ សេង ជាអ្នកបញ្ជាជំនួសទៅកម្មាភិបាលនៅសមរភូមិ តាមរយៈលេខសម្គាល់រៀងៗខ្លួន[888]។

277. ជាធម្មតា អ្នកកាន់វិទ្យុទាក់ទងជាច្រើននាក់ចំណុះឱ្យកងវរសេនាធំទាំងអស់ និងកងវរសេនាតូចឯករាជ្យមួយចំនួន។ កងវរសេនាធំលេខ ៦២ មានអ្នកកាន់វិទ្យុទាក់ទង ១៦ នាក់ នៅខែ វិច្ឆិកា ឆ្នាំ ១៩៧៦[889]។ វិទ្យុទាក់ទងក្នុងរវាងអង្គភាពនានាត្រូវបានប្រើប្រាស់ពេញមួយថ្ងៃ ទៅតាម

ចេញបញ្ជារបស់គាត់មកឲ្យខ្ញុំ ហើយអ្នកកាន់វិទ្យុបានទាក់ទងមកខ្ញុំ ប្រាប់តាមវិទ្យុពីបញ្ជារបស់ មាស មុត មកខ្ញុំ"]។ ឯកសារ D114/13 កំណត់ហេតុនៃការស្តាប់ចម្លើយ នាក់ យឿន, ឆ.11 ["មាស មុត ចេញបញ្ជាដែរ ប៉ុន្តែ ផល ជាអ្នកនិយាយពីបញ្ជាទាំងនោះ ដោយប្រាប់តាមវិទ្យុទាក់ទងទៅអង្គភាពពាក់ព័ន្ធ នានា"]។ ឯកសារ D114/19 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.27 ["តាមុត កម្រ និយាយណែនាំមិកវិញតាមវិទ្យុទាក់ទងណាស់។ ភាគច្រើន គឺគាត់ឲ្យសេចក្តីណែនាំមកឲ្យអ្នកកាន់វិទ្យុ ឲ្យប្រាប់បន្តមកដល់យើង ឬមួយក៏គាត់ផ្ញើការណែនាំតាមរយៈទូរលេខ។ ខ្ញុំនៅចាំថា នៅជំនាន់នោះ បង ខឹម ចូលចិត្តនិយាយតាមរយៈវិទ្យុ ទាក់ទងច្រើនជាង។"]។ ឯកសារ D54/29 កំណត់ហេតុនៃការស្តាប់ចម្លើយ លៀត ឡូន (ណាំ ឡូន), ឆ.3 ["ប្រហែល ១ទៅ២ខែក្រោយមក អ្នកនិយាយវិទ្យុទាក់ទងបានហៅមកខ្ញុំ ដោយប្រាប់ខ្ញុំថា មាស មុត ចង់ជួបខ្ញុំនៅផ្ទះ។ នៅពេលដែលខ្ញុំឡើងមកដល់ផែ មានម៉ូតូចាំទទួលខ្ញុំនៅទីនោះជាស្រេច"]។

887 ឯកសារ D54/48 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ.11 - 13 ["សៈ ហេតុអ្វីបានជាលោកដឹងថា លោកនិយាយ តាមវិទ្យុទាក់ទងជាមួយ មាស មុត? ឆ.11៖ ខ្ញុំស្គាល់សម្លេងគាត់ ពីព្រោះខ្ញុំបានស្គាល់គាត់ជាយូរមកហើយ ហើយលេខវិទ្យុ ទាក់ទងរបស់គាត់ គឺ ៦៣ ហើយលេខរបស់ខ្ញុំគឺ ៤២។ [...] ឆ.12៖ សម្រាប់វិទ្យុទាក់ទង យើងប្រើតែលេខទាក់ទងតែប៉ុណ្ណោះ ឧទាហរណ៍នៅពេលដែលខ្ញុំទាក់ទងទៅ មាស មុត តាមវិទ្យុ ខ្ញុំនិយាយថា ៦៣ ពី៤២។ ឆ. 13៖ ខ្ញុំនៅចាំលេខវិទ្យុទាក់ទងខ្លះ ដូចជា មឿន គឺ ២៤ និង ធាន គឺ ៣២។"]។

888 ឯកសារ D54/48 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ.19 ["ក្នុងករណីដែលអវត្តមាន មាស មុត គឺ ទឹម សេង ឬក៏ ង៉ែត ជាអ្នកទទួលខុសត្រូវជំនួស ក៏ប៉ុន្តែពួកគេមានលេខសម្រាប់ទាក់ទងតាមវិទ្យុរៀងៗខ្លួន។ ចំណែក មាស មុត មានលេខវិទ្យុលេខ ៦៣។"]។

889 ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦, EN 00575529, KH 00160069។ ឯកសារ D22.2.181 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនសហរដ្ឋអាមេរិក មាស មុត, EN 00249694, KH 00741997 ["ក្នុងអំឡុងពេល មានឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស កងពលធំលេខ ៣ មានវិទ្យុទាក់ទងប្រភេទ C-25 ដែលមានមូលដ្ឋាននៅកោះតាង និងនៅរាម"]។ ឯកសារ D114/285 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រំ សារ៉ាត់ (ប៊ុន សារ៉ាត់), ឆ.26 ["ពេលទៅដល់ទីបញ្ជាការ កងពលបោះទីតាំងវរសេនាធំ ទីតាំងវរសេនាតូចបោះទីតាំង ហើយប្រព័ន្ធទាក់ទងជាវិទ្យុទាក់ ទង គឺមានគ្រប់អង្គភាព"]។

តម្រូវការ[890] ហើយកងវរសេនាធំ និងកងវរសេនាតូចឯករាជ្យ រាយការណ៍ជូនទីបញ្ជាការកងពល "ពីព្រឹកទល់យប់"[891]។ "យើងបានធ្វើការប្រាស្រ័យទាក់ទងអំពីស្ថានភាព តាមវិទ្យុទាក់ទងមកកងពល មាស មុត ជាប្រចាំថ្ងៃ"[892]។ ការរាយការណ៍តាមវិទ្យុទាក់ទងត្រូវចុះកំណត់ហេតុក្នុងសៀវភៅ សម្រាប់ **មាស មុត** ទុកជាឯកសារយោង [893]។

278. វិទ្យុទាក់ទងត្រូវបានចែកចាយយ៉ាងទូលំទូលាយនៅតាមតំបន់ និងកោះនៅកំពង់សោម។ នាវារបស់កងពល ១៦៤ ត្រូវបានបំពាក់វិទ្យុទាក់ទង[894] សម្រាប់រាយការណ៍ប្រចាំថ្ងៃទៅកាន់កងវរសេនាធំ ឬ

---

[890] ឯកសារ D54/79 កំណត់ហេតុនៃការស្តាប់ចម្លើយ ណុប ហាល់, ឆ.8 ["ខ្ញុំជាអ្នកបើកទូកនោះ និងប្រើវិទ្យុទាក់ទងជាមួយនឹង កងវរសេនាធំរបស់ខ្ញុំ។ ខ្ញុំរាយការណ៍អំពីដំណើររបស់ខ្ញុំដល់ណាៗ និងពេលទៅដល់គោលដៅ។ ក្នុងពេលបែបនោះ គេឱ្យ បើកវិទ្យុទាក់ទងគ្នារហូត"]។ ឯកសារ D114/11 កំណត់ហេតុនៃការស្តាប់ចម្លើយ នាក់ យឿន, ឆ.9 - 10, ឆ.12 ["ខ្ញុំបានដឹងពីការចាប់ទូកនេសាទយួនទាំងនោះ តាមរយៈវិទ្យុទាក់ទងដែលគេបានឆ្លើយឆ្លងគ្នា និងការទំនាក់ទំនងគ្នាតាមការញាក់ភ្លើងនៅលើទូករទៅវិញទៅមក នៅពេលគេចាប់បាន។ ពួកគេប្រើភ្លើងស៊ីញ៉ូដាក់គ្នា ប្រាប់អំពីទូកដែលគេចាប់បាន ក្រោយមកទៀតពួកគេទំនាក់ទំនងគ្នាតាមវិទ្យុទាក់ទង ដើម្បីប្រាប់បន្ថែមពីទូកនោះ។ [...] ឆ. 10៖ កប៉ាល់ PGP ធ្វើការទាក់ទងតាមវិទ្យុ ទាក់ទងជាមួយអ្នកកាន់ផ្នែកវិទ្យុទាក់ទងនៅលើទូកដែលខ្ញុំធ្វើការ។ [...] ឆ. 12៖ ពួកយើងរួមទាំងអស់គ្នា ការពារដែនសមុទ្រកម្ពុជា"]។ ឯកសារ D114/11 កំណត់ហេតុនៃការស្តាប់ចម្លើយ នាក់ យឿន, ឆ.11 ["តាមខ្ញុំយល់ យើងសហការគ្នា កប៉ាល់ PGP តូចៗជាងកប៉ាល់ខ្ញុំ ហើយទទួលខុសត្រូវចាប់ទូកនេសាទ និងទូករត់ពន្ធ និងឃាមកាមតាមព្រំដែនទឹក។ សម្រាប់ទូកពួកខ្ញុំ គឺទទួលខុសត្រូវបញ្ហាធំៗជាងនេះ ឧទាហរណ៍ ធ្វើសង្គ្រាមជាមួយទូកយោធាផ្សេងទៀតជាដើម"]។

[891] ឯកសារ D54/48 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ.22 - 23 ["ស៖ នៅពេលដែលលោកនៅកោះតាង តើលោករាយការណ៍ទៅ មាស មុត ញឹកញាប់ដែរឬទេ? ឆ.22៖ នៅពេលដែលខ្ញុំនៅកោះតាង វិទ្យុទាក់ទងទៅដីគោក គឺទាក់ទងគ្នាជាប្រចាំពីព្រឹកដល់យប់។ [...] ឆ.23៖ គ្មានការណែនាំជាក់លាក់ទេ អំពីការប្រើប្រាស់វិទ្យុទាក់ទង។ វិទ្យុបើកជាប្រចាំ ប្រសិនបើម៉ាស៊ីនវិទ្យុទាក់ទងក្តៅពេក គេនឹងបិទវា ហើយបើកវិទ្យុថ្មីមួយទៀត"]។ ឯកសារ D54/87 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រុំ សារ៉ាត់, ឆ.138 - 139 ["នៅពេលដែលចាប់បាន គេរាយការណ៍តាមវិទ្យុទាក់ទងពីកោះនានា មកកាន់កងពល។ [...] មានករណីពីរអំពីការរាយការណ៍ នៅពេលដែល មាស មុត នៅកន្លែង គឺគេរាយការណ៍ទៅគាត់ផ្ទាល់។ តែពេលគាត់មិននៅ ឬអវត្តមាន គេរាយការណ៍ទៅអ្នកណាម្នាក់ ដែលជំនួសគាត់ នោះ"]។

[892] ឯកសារ D54/47 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ.48។

[893] ឯកសារ D54/87 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រុំ សារ៉ាត់, ឆ.141 ["គេរាយការណ៍តាមវិទ្យុទាក់ទង ហើយអ្នកនៅកន្លែងកាន់វិទ្យុទាក់ទងនោះ ត្រូវចុះកំណត់ហេតុក្នុងសៀវភៅប្រចាំថ្ងៃ ទោះព័ត៌មានអ្វីក៏ដោយ ដើម្បីបញ្ជូនព័ត៌មានទាំងនោះទៅឱ្យ មាស មុត"]។

[894] ឯកសារ D114/24 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ូ ដាវ, ឆ.66 ["នៅលើទូកមួយ គឺមានប្រព័ន្ធវិទ្យុទាក់ទងរបស់អាមេរិក លេខC-២៥, C-២៧, ឬ C-២៨"]។ ឯកសារ D54/79 កំណត់ហេតុនៃការស្តាប់ចម្លើយ ណុប ហាល់, ឆ.21

កងពល[895] ហើយក៏មានវិទ្យុទាក់ទងនៅលើកោះផងដែរ[896]។ ទីបញ្ជាការកងវរសេនាធំ ១៤០ នៅលើដីគោក មានអ្នកកាន់វិទ្យុទាក់ទង ២ នាក់[897] ហើយក៏មានស្ថានីយវិទ្យុទាក់ទងនៅតាមតំបន់

---

["ស៖ ជាទូទៅនៅពេលលោកធ្វើការជាអ្នកបើកកាណូត និងធ្វើការនៅលើកោះ តើលោកស្តាប់ឮតាមវិទ្យុទាក់ទង អំពីការចាប់ទូកញឹកញាប់ប៉ុនណាដែរ? ឆ.21៖ ខ្ញុំបានឮរបាយការណ៍អំពីការចាប់ទូកយូរៗម្តងប៉ុណ្ណោះ ដោយសារអង់តែនតេអូ ដែលនៅជាប់នឹងកាណូតរបស់ខ្ញុំខ្លី (C-25)"]។ ឯកសារ D59/1/1.8a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រុំ សារ៉ាត់, EN 00974227, KH 00926400 ["ផ្នែកខាងនាវាប្រើតេអូចិន ផ្នែកខាងកោះ ផ្នែកខាងកងពលប្រើតេអូអាមេរិក"]។ ឯកសារ D54/48 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ.26 ["បន្ទាប់ពីវិទ្យុរបស់ខ្ញុំខូច ខ្ញុំបានទាក់ទង មាស មុត ដោយផ្ទាល់តាមវិទ្យុ ជាមួយគាត់នៅកាណូត PCF នៅពេលកប៉ាល់នោះទៅដល់ (កោះតាង)"]។

895 ឯកសារ D114/285 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រុំ សារ៉ាត់ (ប៊ុន សារ៉ាត់), ឆ.179, ឆ.182 ["ស៖ តើខាងនាវាត្រូវ រាយការណ៍ដោយផ្ទាល់ជារៀងរាល់ថ្ងៃទៅថ្នាក់លើឬទេ? ឆ.179៖ ខាងនាវាត្រូវរាយការណ៍តាមរយៈតេអូ ទៅទីបញ្ជាការ ទៅវរសេនាធំជារៀងរាល់ថ្ងៃ ផ្នែកបច្ចេកទេសសំខាន់។ [...] ឆ.182៖ បើវរសេនាធំអត់នៅ ទើបខ្ញុំបញ្ជូនព័ត៌មានហ្នឹង ទៅ កងពល"]។

896 ឯកសារ D4.1.762 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក កាំ ម៉ែន, EN 00387330 - 00387331, KH 00742582 ["ការដាក់ពង្រាយកងទ័ពនៅលើកោះតាង [...] អង្គភាពមួយដែលមានកងទ័ព ៥០ នាក់ [...] វិទ្យុទាក់ទង C-25 មួយគ្រឿង"]។ ឯកសារ D4.1.757 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនអាមេរិក កម្មាភិបាលមិនស្គាល់ឈ្មោះ, EN 00387365, KH 01507818 ["នៅពេលប្រភពមកដល់កោះនោះ ស្ថានីយ៍វិទ្យុរបស់កងវរសេនាតូច ស្ថិតនៅខាងចុងភាគខាងត្បូងនៃឆ្នេរខាងកើត។ កងវរសេនាតូចនោះ មានវិទ្យុ C-25 មួយ"]។ ឯកសារ D114/132 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ៅ រ៉ាន់, ឆ.57 ["នៅលើកោះ គឺគេមានវិទ្យុទាក់ទង"]។ ឯកសារ D54/47 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ.13 ["យើងប្រើតេអូ VHF-46 សម្រាប់ធ្វើការទាក់ទងគ្នាបានយ៉ាងច្បាស់ រវាងកោះតាង មកកំពង់សោម។ ហើយសម្រាប់ C-25 ចម្ងាយរបស់វាគឺ ២៥គីឡូម៉ែត្រ"]។ ឯកសារ D54/100 កំណត់ហេតុនៃការស្តាប់ចម្លើយ ឡាយ ប៊ុនហាក់, ឆ.156 - 157 ["ពេលដែលគេចាប់បាន គេរាយការណ៍មកកងពល ដូច្នេះ ខ្ញុំបានឮគេនិយាយតាមវិទ្យុមក។ ដោយសារវិទ្យុទាក់ទងលេខ ២៥ ប្រើប្រេកង់ដូចគ្នា។ [...] ឆ.157៖ ជាទូទៅ អ្នកឈរជើងនោះតាមកោះ ជាអ្នកចាប់ និងរាយការណ៍មក។ ឯកសារ D114/283 កំណត់ហេតុនៃការស្តាប់ចម្លើយ ឯក នី, ឆ.54 [" កន្លែងវរសេនាធំ គេដាក់តេអូកម្លាំងអាធំ មិនដាក់ C-25ទេ។ គេប្រើអាធំជាង គឺកូឡាំង ព្រោះវាអាចទាក់ទងដល់កងពលនៅដីគោក"]។ ឯកសារ D114/146 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ុយ ញ៉ឹក, ឆ.33 - 34 ["ស៖ ពេលដែលលោកនៅលើកោះ តើលោកប្រើអ្វីសម្រាប់ទាក់ទងរវាងកោះ ហើយនឹងបញ្ជាការដ្ឋានកងទ័ពជើងទឹក? ឆ.33៖ យើងប្រើតេអូ ជាប្រភេទវិទ្យុ T-25 របស់អាមេរិកាំង ដែលមានអង់តែន។ [...] ឆ.34៖ វ៉ាដ្យូនោះ ដាក់នៅកន្លែងបញ្ជាការវរៈ សម្រាប់ធ្វើការទាក់ទងជាមួយនឹងកន្លែងផ្សេង ដែលនៅឆ្ងាយពីកោះ។"]។ ឯកសារ D114/19 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.29 ["បញ្ជាការពីររបស់វរសេនាតូចខ្ញុំ ទី១ នៅលើកោះថ្មី និងមួយទៀត នៅលើកោះសេះ។ បញ្ជាការនីមួយៗ មានវិទ្យុ

ផ្សេងទៀត នៅលើដីគោក។ ឧទាហរណ៍ ស្ថានីយវិទ្យុទាក់ទងមួយមានទីតាំងនៅមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ មួយរយៈ រួមទាំងអ្នកកាន់វិទ្យុទាក់ទងជំនាញម្នាក់ និងនីរសារម្នាក់[898]។ ក្រោយមក ស្ថានីយនេះត្រូវបានរើទៅអូរឈើទាល[899]។

---

ទាក់ទង C-២៥មួយ"]។ ឯកសារ D59/1/1.8a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រុំ សារ៉ាត់, EN 00974223, KH 00926400 ["មានវិទ្យុទាក់ទង តែវលកទាក់ទងកោះ និងទីបញ្ជាការផ្សេង ហើយយើងវលកផ្សេង គេវលកផ្សេង អត់ឱ្យចូលមកទេ។ សៈ អត់មានជួបគ្នាទេនោះ? ឆៈ បាទ! វលករួមមានដល់ហៅឆ្វេងស្តាំ វលកតែអូយើងតែអូរបស់អាមេរិកខុសគ្នា"]។ ឯកសារ D59/1/1.9a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ឡាយ ប៊ុនហាក់, EN 00963723, KH 00926456 ["ខ្ញុំក្រោយមក គេឱ្យខ្ញុំកាន់តែអូផង ជំនួយការផ្សេងៗ ជំនួយទីបញ្ជាការវរៈ។ សៈ ពូកាន់តែអូអីគេអាហ្នឹង? [...] ឆៈ C-25, C-46 មានពីរ។ សៈ អីចឹង ពេលដែលគេនិយាយតែអូពីខាងកោះ ខាងអីហ្នឹង ពូឮហើយហី? ឆៈ បាទ!"]។ ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់សហព្រះរាជអាជ្ញ សៀង, EN 00217565 - 00217566 ["ជាទូទៅ គាត់ត្រូវបានដាក់ពង្រាយនៅលើកោះតូចៗនៅកោះរ៉ុងជិតព្រំដែនថៃ។ [...] នៅពេលដែល កងវរសេនាធំត្រូវផ្លាស់ទី ពួកគេត្រូវបានគេណែនាំដោយវិទ្យុទាក់ទង - អាមេរិកាំង ទាក់ទងបានពីរដង ដែលត្រូវរឹបអូសបាននៅឆ្នាំ ១៩៧៥។"]។

897 ឯកសារ D59/1/1.9a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ឡាយ ប៊ុនហាក់, EN 00963740, KH 00926472 ["សៈ ចុះខាងកន្លែងខាងវរសេនាធំ កន្លែង ១៤០ អ្នកកាន់តែអូណា? ឆៈ អ្នកកាន់តែអូគាត់មានពីរនាក់ តែស្លាប់អស់ហើយ"]។

898 ឯកសារ D2/15 កំណត់ហេតុនៃការស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច, ឆ.18 ["បន្ទប់ប៉ែកខាងលិចគេបង្គស់មានពេទ្យ និងតែអូ ស្នាក់នៅ [វត្តឥន្ទញ្ញាណ]។ បន្ទប់បន្ទាប់មកជាបន្ទប់របស់មេបញ្ជាការ។ ហើយបន្ទាប់មកទៀតបន្ទប់ទីបី ជាបន្ទប់របស់ខ្ញុំ ជានិរសាស្នាក់នៅ។ ពេលនោះមេបញ្ជាការពេទ្យ វិទ្យុទាក់ទង និងនិរសាស្នាក់នៅជាប់ៗគ្នា។ ហើយបន្ទប់ជាន់ខាងក្រោមផ្នែក កណ្តាល គឺជាបន្ទប់សម្រាប់ដាំបាយ។ រីឯ កុដិមួយទៀតនៅខាងក្រោយ និងសាលា គឺគ្មានមនុស្សរស់នៅទេ"]។ ឯកសារ D54/88 កំណត់ហេតុនៃការស្តាប់ចម្លើយ ស៊ឹម នី, ឆ.11 ["នៅពីខាងមុខចម្ការសណ្តែករបស់ខ្ញុំហ្នឹង គឺមានផ្លូវកាត់បែកជាបួន រវាងផ្លូវធំ ហើយនិងផ្លូវដែលឆ្ពោះទៅកាន់វត្តឥន្ទញ្ញាណ។ បន្ទាប់ពីបត់នៅលើផ្លូវនោះ មានកន្លែងប៉ុស្តិ៍ យាមរបស់យោធាខ្មែរក្រហមមួយ នៅខាងក្រោយប៉ុស្តិ៍យាម គឺជាស្ថានីយ៍ផ្សាយសម្លេងរបស់ក្រុងកំពង់សោម"]។ ឯកសារ D1.3.13.13 កំណត់ហេតុនៃការស៊ើបសួរបឋមរបស់សហព្រះរាជអាជ្ញា ទូច សឿលី, EN 00217575 ["សាក្សី បានប្រាប់ថា គាត់បានស្នាក់នៅវត្ត [វត្តឥន្ទញ្ញាណ] នៅឆ្នាំ ១៩៧៥ នៅពេលដែលគាត់បានមករៀនវគ្គហ្វឹកហ្វឺន តែក្រោយមក បានប្តូរទីកន្លែងផ្សេង។ គាត់បញ្ជាក់ថា គាត់បានរៀបចំដាក់វិទ្យុមួយនៅទីនោះ ដែលក្រោយមកបានផ្លាស់ប្តូរទៅអូរឈើទាល"]។ ឯកសារ D114/98 កំណត់ហេតុនៃការស្តាប់ចម្លើយ សៀង គុយ, ឆ. 44 ["ឆលោកបាននិយាយថា លោកធ្វើដំណើរពីផ្ទះ ឡូញ ទៅបឹង បន្ទាប់ពីលោកចេញពីផ្ទះរបស់ ឡូញ លោកធ្វើដំណើរឆ្លងកាត់វិទ្យុ ហើយលោកធ្វើដំណើរបន្តទៀត ចុះទៅបឹង ហើយវត្តស្ថិតនៅខាងឆ្វេងដៃ។ តើត្រឹមត្រូវដែរឬទេ? ឆ.44៖ បាទ! ត្រឹមត្រូវ។"]។ សូមមើលផងដែរ ឯកសារ D114/46 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ និងទីតាំងពាក់ព័ន្ធកំពង់សោម ផ្សារលើ, EN 01065190, KH

279. វិទ្យុទាក់ទងនៅតាមសមរភូមិត្រូវបើកជាប្រចាំ ដើម្បីត្រៀមទទួលសារ។ អង្គភាពមានវិទ្យុទាក់ទងជាច្រើនគ្រឿង ហើយបើវិទ្យុមួយក្តៅពេក គេបិទទុកឲ្យត្រជាក់សិន រួចបើកវិទ្យុមួយទៀត[900]។ មានវិទ្យុទាក់ទងប្រភេទផ្សេងគ្នា ហើយនៅលើកោះ ចម្ងាយទាក់ទង គឺ ២៥ គីឡូម៉ែត្រ[901]។

## ទូរលេខ

280. កងពល ១៦៤ ទាក់ទងគ្នា តាមទូរលេខ[902] ហើយទីបញ្ជាការកងពលផ្តល់ការបណ្តុះបណ្តាលផ្នែកទូរលេខ[903]។ ជាញឹកញាប់ **មាស មុត** បញ្ជាតាមទូរលេខ ពីទីបញ្ជាការកងពល ១៦៤[904]។

---

01307887 [“សាក្សី [...] ពន្យល់ថាស្ថានីយ៍វិទ្យុចាស់ មានទីតាំងស្ថិតនៅខាងក្រោយផ្ទះពណ៌ស្វាយ បច្ចុប្បន្ន”]។

899 ឯកសារ D1.3.13.13 កំណត់ហេតុនៃការស៊ើបសួរបឋមរបស់សហព្រះរាជអាជ្ញា ទូច សឿលី, EN 00217575 [“សាក្សី បានប្រាប់ថា គាត់បានស្នាក់នៅវត្ត [វត្តឥន្ទញ្ញាណ] នៅឆ្នាំ ១៩៧៥ នៅពេលដែលគាត់បានមករៀនវគ្គហ្វឹកហ្វឺន តែក្រោយមក បានប្តូរទីកន្លែងផ្សេង។ គាត់បញ្ជាក់ថា គាត់បានរៀបចំដាក់វិទ្យុមួយនៅទីនោះ ដែលក្រោយមកបានផ្លាស់ប្តូរទៅអូរឈើទាល”]។

900 ឯកសារ D54/48 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ.23 [“វិទ្យុបើកជាប្រចាំ ប្រសិនបើម៉ាស៊ីនវិទ្យុទាក់ទងក្តៅពេក គេនឹងបិទវា ហើយបើកវិទ្យុថ្មីមួយទៀត”]។

901 ឯកសារ D54/47 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ.12 - 13 [“សៈ តើលោកប្រើមធ្យោបាយអ្វី ដើម្បីរាយការណ៍ទៅ មាស មុត? ឆៈ ខ្ញុំប្រើតេអូ ដើម្បីរាយការណ៍ទៅគាត់។ ខ្ញុំប្រើតេអូ C-25 ឬក៏ VHF-46 ។ សៈ តើតេអូ VHF-46 ប្រើបានចម្ងាយប៉ុន្មាន? ឆៈ យើងប្រើតេអូ VHF-46 សម្រាប់ធ្វើការទាក់ទងគ្នាបានយ៉ាងច្បាស់ រវាងកោះតាង មកកំពង់សោម។ ហើយសម្រាប់ C-25 ចម្ងាយរបស់វាគឺ ២៥គីឡូម៉ែត្រ”]។

902 ឯកសារ D114/286 កំណត់ហេតុនៃការស្តាប់ចម្លើយ ប៉ាង រ៉េត, ឆ.19 [“មានតែខាងពួកវ៉ៃទូរលេខ ឯកសារ និងផ្នែកទាក់ទង [...] ផ្នែកទាក់ទងទូរលេខសម្រាប់ទទួលសារខាងក្រោម ហើយបញ្ជូនទៅខាងលើ”]។ ឯកសារ D114/95 កំណត់ហេតុនៃការស្តាប់ចម្លើយ យឹម ស្រឿង ឆ.92 [“រ៉ាដា គឺសម្រាប់ចាប់វត្ថុណាដែលអណ្តែតលើទឹក ឬក៏ចាប់អ្វីផ្សេងៗទៀត។ ចំណែកទូរលេខ គេប្រើសម្រាប់ទទួលបញ្ជា និងបញ្ជូនសារ”]។ ឯកសារ D54/82 កំណត់ហេតុនៃការស្តាប់ចម្លើយ ហ៊ឹង អ៊ិច, ឆ.29 [“បើតាមខ្ញុំដឹង នៅក្នុងអង្គភាពរបស់ខ្ញុំ នៅពេលដែលសារទូរលេខផ្ញើចេញ គឺគេប្រាកដជាបានទទួលហើយ ពីព្រោះនៅចុចបញ្ជូនសារ នឹងមានសម្លេងឆ្លងឆ្លើយគ្នា ម្យ៉ាងវិញទៀត មិនដែលមានករណីដែលគេមិនបានទទួលសារទូរលេខនោះទេ”]។

903 ឯកសារ D54/71 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ, ឆ.35 [“ទេ! កន្លែងហាត់រៀនស្ថិតនៅអគារផ្សេង នៅទីនោះគេមានហាត់រៀនផ្នែកទូរសព្ទ ផ្នែកទូរលេខ និងផ្នែកផ្សាយ”]។

904 ឯកសារ D54/72 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ ឆ.42 [“មាស មុត កម្របើទូរសព្ទណាស់ ភាគច្រើនគាត់ប្រើសារទូរលេខ”]។ សូមមើលផងដែរ ឯកសារ D114/19 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.27

281. ក្រៅពីទីបញ្ជាការកងពល ១៦៤ មានមន្ទីរទូរលេខច្រើននៅតំបន់ស្វយ័តកំពង់សោម។ ឧទាហរណ៍ មានមន្ទីរទូរលេខមួយនៅជិតអូរឈើទាល សម្រាប់ឱ្យកងវរសេនាធំ ១៤០ ទាក់ទងជាមួយនាវា ដែលទាក់ទងបន្តទៅអង្គភាពនានាឈរជើងនៅតាមកោះ[905]។ នាវាភាគច្រើនរបស់កងពល ១៦៤ មានបំពាក់ម៉ាស៊ីនទូរលេខមួយ ឬពីរគ្រឿងរបស់ចិន ដែលត្រូវបានប្រើប្រាស់សម្រាប់ទទួលបញ្ជា និងទាក់ទងជាមួយអង្គភាពផ្សេងទៀត[906]។

---

[“តាមុត កម្រ និយាយណែនាំមកវិញតាមវិទ្យុទាក់ទងណាស់។ ភាគច្រើន គឺគាត់ឱ្យសេចក្ដីណែនាំមកឱ្យអ្នកកាន់វិទ្យុ ឱ្យប្រាប់បន្តមកដល់យើង ឬមួយក៏គាត់ផ្ញើការណែនាំតាមរយៈទូរលេខ។ ខ្ញុំនៅចាំថា នៅជំនាន់នោះ បង ខឹម ចូលចិត្ត និយាយតាមរយៈវិទ្យុ ទាក់ទងច្រើនជាង”]។ ឯកសារ D54/88 កំណត់ហេតុនៃការស្ដាប់ចម្លើយ ស៊ឹម នី, ឆ.29 [“ដោយសារមេបញ្ជាការរបស់ខ្ញុំទាក់ទងសារទូរលេខជាមួយ មាស មុត ដូច្នេះ ខ្ញុំដឹងរឿងនេះ។ រឿងនេះ វាកើតឡើង នៅខែ ឈ្មួ ឆ្នាំ ១៩៧៨។”]។ ឯកសារ D54/87 កំណត់ហេតុនៃការស្ដាប់ចម្លើយ ព្រំ សារ៉ាត់, ឆ.58 [“ស៖ ទាក់ទងនឹង សេចក្ដីណែនាំ ឬក៏ការបញ្ជាដែលលោកបានបញ្ជាក់ តើចេញមកពីកងពលទៅកងវរសេនាធំ និងកងវរសេនាតូច តាមរ យៈទូរសព្ទ ទូរសារ ឬក្រដាសស្នាមអ្វីដែរឬទេ? ឆ.58៖ មានការបញ្ជាតាមសារទូរលេខ និង ទូរសព្ទ”]។ ឯកសារ D54/29កំណត់ហេតុនៃការស្ដាប់ចម្លើយ លៀត (ណាំ) ឡូន ឆ.3 [“ប្រហែល ១ទៅ២ខែក្រោយមក អ្នកនិយាយវិទ្យុ ទាក់ទងបានហៅមកខ្ញុំ ដោយប្រាប់ខ្ញុំថា មាស មុត ចង់ជួបខ្ញុំនៅផ្ទះ។ នៅពេលដែលខ្ញុំឡើងមកដល់ផែ មានម៉ូតូចាំ ទទួលខ្ញុំនៅទីនោះជាស្រេច”]។ ឯកសារ D54/87 កំណត់ហេតុនៃការស្ដាប់ចម្លើយ ព្រំ សារ៉ាត់, ឆ.58 [“មានការបញ្ជា តាមសារទូរលេខ និងទូរសព្ទ”]។ ឯកសារ D54/34 កំណត់ហេតុនៃការស្ដាប់ចម្លើយ អ៊ឹង អុន, ឆ.2 [“នៅកន្លែង តា មុត គាត់មានម៉ាស៊ីនសារទូរលេខ [...] នៅពេលដែលអ្នកកាន់សារទូរលេខនៅហ្នឹងផែ ទទួលបញ្ជាពីកន្លែង តាមុត អ្នក កាន់សារទូរលេខនោះ ផ្ដល់បញ្ជានោះទៅមេបញ្ជាការកប៉ាល់”]។

905 ឯកសារ D54/100 កំណត់ហេតុនៃការស្ដាប់ចម្លើយ ឡាយ ប៊ុនហាក់, ឆ.124, ឆ.126 - 127 [“នៅអូរឈើទាល មាន ការិយាល័យទូរលេខមួយ។ នៅលើកោះគេមានម៉ាស៊ីនទូរលេខនៅលើនាវា នៅពេលដែលគេទទួលបានសារទូរលេខ គេ បញ្ជូន សារទូរលេខនោះទៅមេបញ្ជាការនៅលើកោះ។ [...]ឆ. 126៖ [...] នៅពេលមានសារបានបញ្ជូនមក អ្នក ទទួលខុសត្រូវ ខាងបញ្ជូនសារនឹងយកសារនោះទៅឱ្យមេបញ្ជាការនៅក្នុងបន្ទប់ធំនោះ។ បើមេបញ្ជាការគាត់ចង់បញ្ជូន សារ គឺគាត់ទៅបន្ទប់ធំ នោះ ហើយអ្នកបញ្ជូនសារ យកសារនោះមកឱ្យកាន់វិទ្យុទាក់ទងបញ្ជូនសារនោះទៅ។ ស៖ តើ លោកស្គាល់ឈ្មោះអ្នកបញ្ជូនសារទៅមេបញ្ជាការនៅបន្ទប់ធំនោះដែរទេ? ឆ.127៖ ឈ្មោះ សារី។ ចំណែក ចំរើន ជា អ្នកទទួល និងបញ្ជូនសារពីវិទ្យុទាក់ ទង និងទូរសព្ទ។ ពួកគេទាំងនោះ ស្លាប់អស់ហើយ គឺនៅសល់តែខ្ញុំម្នាក់ប៉ុណ្ណោះ”] ។

906 ឯកសារ D114/95 កំណត់ហេតុនៃការស្ដាប់ចម្លើយ យឹម ស្រឿង, ឆ.125, ឆ.242 [“ស៖ លោកបាននិយាយថា ខាង ពីឡុត ជាអ្នកទទួលខុសត្រូវខាងទូរលេខ ខាងតេអូ តើលោកមានស្គាល់ឈ្មោះដែរទេ? ឆ.125៖ មានឈ្មោះ ពាក់ គាត់ ទទួលខុស ត្រូវខាងកាន់ចង្កូតកប៉ាល់។ អ្នកកាន់ខាងតេអូឈ្មោះ គឿន។ អ្នកកាន់ខាងទូរលេខឈ្មោះ រ័ត្ន។ អ្នកកាន់ខាង

282. កងវរសេនាធំ និងកងវរសេនាតូចឯករាជ្យ នៃកងពល ១៦៤ ផ្ញើទូរលេខជាប្រចាំថ្ងៃទៅទីបញ្ជាការកងពល ក្រោយពីប្រមូល និងសង្ខេបសេចក្ដីរាយការណ៍ ដែលទទួលបាននៅក្នុងតំបន់ប្រតិបត្តិការរបស់ខ្លួន[907]។ ទូរលេខ ខុសពីវិទ្យុទាក់ទង ក៏ត្រូវបានប្រើប្រាស់សម្រាប់ផ្សព្វផ្សាយព័ត៌មានដែលត្រូវបានចាត់ទុកថាមានភាពរសើបផងដែរ ពីព្រោះវាអាចត្រូវបានបំភាន់អក្ខរៈ តាមរយៈលេខកូដសម្ងាត់[908]។ ទូរលេខបន្ទាន់ត្រូវបានប្រើប្រាស់សម្រាប់ផ្សព្វផ្សាយព័ត៌មានសំខាន់ ដូចជា ដំណើររបស់កងទ័ពមករៀនសូត្រនៅក្រុងកំពង់សោម គ្រោះថ្នាក់កប៉ាល់ ការបោកគ្រាប់បែក និងការសម្លាប់មនុស្ស[909]។

---

សញ្ញាឈ្មោះ រ៉ន។ [...] ឆ.242៖ ទាំងអស់នោះជាឧបករណ៍របស់ចិនទាំងអស់ ដែលគេមាននៅគ្រប់កប៉ាល់ទាំងអស់។ កប៉ាល់ខ្លះមានមួយ គ្រឿង ហើយកប៉ាល់ខ្លះមានពីរគ្រឿង"]។

907 ឯកសារ D54/82 កំណត់ហេតុនៃការស្ដាប់ចម្លើយ ហ៊ីង អ៊ុច, ឆ.19 ["សៈ [...] សារទូរលេខលេខ ១៥, ១៦, ១៧ ត្រូវបានផ្ញើក្នុងរយៈពេលតែ២ថ្ងៃប៉ុណ្ណោះ ក្នុងឆ្នាំ ១៩៧៦ [...] តើលោកអាចប្រាប់យើងបានដែរឬទេ អំពីកាតព្វកិច្ចផ្ញើរបាយការណ៍ប្រចាំថ្ងៃពីកងវរសេនាធំទៅកងពល? ឆ.19៖ ជាធម្មតាសម្រាប់កម្រិតរបស់ខ្ញុំ ខ្ញុំត្រូវផ្ញើរបាយការណ៍ ១ ថ្ងៃ ម្ដង នៅពេលល្ងាច ដោយបូកសរុបការងារពីគ្រប់កោះទាំងអស់ ដើម្បីផ្ញើទៅកងពល"]។

908 ឯកសារ D54/82 កំណត់ហេតុនៃការស្ដាប់ចម្លើយ ហ៊ីង អ៊ុច, ឆ.1 ["សារទូរលេខនេះ វាស្រដៀងនឹងឯកសារដែលលោក បានបង្ហាញខ្ញុំកាលពីម្សិលមិញ។ ខ្ញុំសូមបញ្ជាក់ថា មូលហេតុដែលគេប្រើសារទូរលេខ ពីព្រោះវាជាការងារសម្ងាត់ខុសពីការ ប្រើប្រាស់តេអ្វូ។ វាមិនងាយចាប់បានដូចតេអ្វូ។ ឯកសារ D54/100 កំណត់ហេតុនៃការស្ដាប់ចម្លើយ ឡាយ ប៊ុនហាក់, ឆ.123 ["តើលោកឮព័ត៌មានអ្វីខ្លះ អំពីអ្នកដែលគេបញ្ជូនទៅជីគោក តាមវិទ្យុទាក់ទង? ឆ.123៖ ការងារសម្ងាត់ គេមិននិយាយតាមវិទ្យុទេ គេច្រើនតែសរសេរទូរលេខអំពីរឿងសម្ងាត់ទាំងអស់។ គេមានក្រុមទូរលេខ ខ្ញុំធ្លាប់ឃើញម៉ាស៊ីនទូរលេខដែរ គេប្រើប្រាស់អក្សរសម្ងាត់ ដូច្នេះបើខ្ញុំបានឃើញសារទូរលេខ ក៏ខ្ញុំមិនអាចអានបានដែរ"]។

909 ឯកសារ D54/82 កំណត់ហេតុនៃការស្ដាប់ ចម្លើយ ហ៊ីង អ៊ុច, ឆ.10, ឆ.25 - 26 ["តាមទម្លាប់ខ្ញុំ នេះគឺជាសារទូរលេខសំខាន់ ពីព្រោះវាទាក់ទងនឹងការសម្លាប់មនុស្ស ហើយសារទូរលេខបែបនេះ វាតែប្រាស្រ័យទាក់ទងតាមរយៈទូរលេខ ដោយសារវាមានលក្ខណៈជាការសម្ងាត់ ព្រោះទាក់ទងនឹងគ្រាប់បែក ហើយគេមិនទាក់ទងតាមតេអ្វូទេ ចំពោះការងារបែបនេះ។ [...] ឆ.25៖ [...] សារទូរលេខបន្ទាន់ មានអាទិភាពជាង ដោយសារតែវាករណីចាំបាច់ ដូចជាមានសភាពការណ៍ធ្ងន់ធ្ងរនៅក្នុងអង្គភាព គេអាចសរសេរសារបន្ទាន់ ដោយមិនកំណត់ពេលវេលាទេ។ វាជាបទបញ្ជា បើសិនជាយើងមិនគោរព បទបញ្ជាទេ យើងត្រូវទទួលខុសត្រូវខ្លួនឯង។ សារទូរលេខបន្ទាន់បែបនេះ គឺមិនមានញឹកញាប់ទេ។ [...] ឆ.26៖ សារទូរលេខបន្ទាន់មានដូចជា ការបើកទូក ហើយមានគ្រោះថ្នាក់តាមផ្លូវ មួយទៀត ដំណើររបស់កម្មាភិបាលមករៀនសូត្រនៅក្រុង កំពង់សោម ហើយនិងហេតុការណ៍ដែលប៉ះពាល់ដល់អាយុជីវិត"]។

283. ក៏មានមន្ទីរទូរលេខមួយនៅជិតកំពង់ផែកោះកុងផងដែរ សម្រាប់សម្របសម្រួល រវាងវ៉ាដាររបស់កងពលលេខ ១ និងកប៉ាល់របស់កងពល ១៦៤[910]។

## ទូរស័ព្ទ

284. កងពល ១៦៤ មានបណ្តាញទូរស័ព្ទផ្ទៃក្នុង ដែលមន្ទីរកណ្តាល ក្រោមការដឹកនាំរបស់ កេង ស្ថិតនៅក្នុងទីបញ្ជាការកងពល ១៦៤[911]។ ខ្សែទូរស័ព្ទត្រូវបានប្រើប្រាស់សម្រាប់ទំនាក់ទំនង រវាងទីបញ្ជាការកងពល និងមេបញ្ជាការកងវរសេនាធំ ឬកងវរសេនាតូច[912]។ កម្មាភិបាលនារី ១២ នាក់ធ្វើការនៅមន្ទីរទូរស័ព្ទរបស់កងពល ដែលត្រូវបានចិនបង្រៀនឱ្យចេះប្រតិបត្តិការ និងជួសជុលទូរស័ព្ទ[913]។ ខ្សែនីមួយៗមានលេខសម្គាល់សម្រាប់ភ្ជាប់ពីមនុស្សម្នាក់ទៅមនុស្សម្នាក់[914]។ **មាស**

---

910 ឯកសារ D54/34 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ឹង អុន, ឆ.2 ["នៅកន្លែង តាមុត គាត់មានម៉ាស៊ីន សារទូរលេខ ហើយគេមានម៉ាស៊ីនទូរលេខម្ខាងទៀតនៅជិតផែកប៉ាល់កោះកុង ដែលចិតនៅអតីតដំណាក់ស្តេច។ នៅពេលដែលអ្នកកាន់សារទូរលេខនៅហ្នឹងផែ ទទួលបញ្ជាពីកន្លែង តាមុត អ្នកកាន់សារទូរលេខនោះ ផ្តល់បញ្ជានោះទៅមេបញ្ជាការកប៉ាល់ អ្នកកាន់សារទូរលេខ គេធ្វើការនៅក្នុងមន្ទីររបស់គេនៅជិតផែកប៉ាល់"]។

911 ឯកសារ D54/71 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ, ឆ.35, ឆ.37 ["មន្ទីរទូរសព្ទទាក់ទង គឺស្ថិតនៅក្នុងអគារផ្សេង ប៉ុន្តែនៅក្នុងបរិវេណជាមួយគ្នា។ [...] ឆ.37៖ នៅពេលដែលយើងមានការប្រជុំរៀងរាល់ ៣ ថ្ងៃម្តង ហើយពេលខ្លះៗ ១ អាទិត្យម្តង ក្រុមនីមួយៗនៅក្នុងមន្ទីរក្នុងរាយការណ៍ទៅឲ្យកងរាយការណ៍ទៅឲ្យអ្នកណាផ្សេងទៀត ខ្ញុំមិនដឹងទេ"]។

912 ឯកសារ D54/100 កំណត់ហេតុនៃការស្តាប់ចម្លើយ ឡាយ ប៊ុនហាក់, ឆ.74 ["[ទូរសព្ទ] គឺសម្រាប់ការទំនាក់ទំនងរវាងមេបញ្ជាការកងពល និងមេបញ្ជាការវរសេនាធំតែប៉ុណ្ណោះ"]។ ឯកសារ D54/87 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រំ សារ៉ាត់, ឆ.58 ["សៈ ទាក់ទងនឹងសេចក្តីណែនាំ ឬក៏ការបញ្ជាដែលលោកបានបញ្ជាក់ តើចេញមកពីកងពលទៅកងវរសេនាធំ និងកងវរសេនាតូច តាមរយៈទូរសព្ទ ទូរសារ ឬក្រដាសស្នាមអ្វីដែរឬទេ? ឆ.58៖ មានការបញ្ជាតាមសារទូរលេខ និង ទូរសព្ទ"]។

913 ឯកសារ D54/71 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ, ឆ.34 - 35 ["មាននារី ១២ នាក់ ធ្វើការនៅខាងផ្នែកទូរសព្ទនោះ។ [...] ឆ.35៖ កន្លែងហាត់រៀនស្ថិតនៅអគារផ្សេង នៅទីនោះគេមានហាត់រៀនផ្នែកទូរសព្ទ ផ្នែកទូរលេខ និងផ្នែកផ្សាយ"]។ ឯកសារ D54/72 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ ឆ.28 ["ខ្ញុំត្រូវបង្រៀនដោយពួកចិនមែន [...] ដំបូង គេបង្រៀនអំពីទ្រឹស្តី បន្ទាប់មកគេបង្រៀនរបៀបជួសជុលទូរសព្ទ។ ឧទាហរណ៍ ប្រសិនបើវាខូចតិចតួច ដោយរន្ទះបាញ់ ដោយអី យើងអាចជួសជុលបាន"]។ ឯកសារ D54/70.2 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា មុត ម៉ៅ, EN 01066966, KH 00979247 ["សៈ ចុះដល់មន្ទីរកងពលមីងធ្វើអីទៅ? ឆ៖ ខ្ញុំនៅកន្លែងទូរស័ព្ទហ្នឹង។ សៈ នៅកន្លែងទូរសព្ទកាលនឹង មីងបានហាត់រៀនខាងទូរស័ព្ទនឹងដែរ? ឆ៖ ខ្ញុំបានហាត់រៀនបានកន្លះឆ្នាំដែរ។ សៈ កាលនឹងពីណាគេអ្នកបង្រៀនមីង? ឆ៖ ចិន បង្រៀន។ សៈ ចិនបង្រៀន មីងចិនគេ

មុត មានលេខខ្សែផ្ទាល់ខ្លួន ហើយការហៅទូរស័ព្ទពីមេបញ្ជាការកងវរសេនាតូចអាចត្រូវបានភ្ជាប់ទៅគាត់ដោយផ្ទាល់[915]។ ប៉ុន្តែ ជាញឹកញាត់ គាត់ប្រើនីរសាររបស់គាត់ឱ្យមកមន្ទីរទូស័ព្ទកណ្តាលដើម្បីហៅទូរស័ព្ទ[916]។

285. កម្មាភិបាលនៅសមរភូមិប្រើប្រាស់ទូរស័ព្ទ សម្រាប់ទាក់ទងជាមួយទីបញ្ជាការកងពល និងថ្នាក់លើផ្សេងទៀត និងសម្រាប់បំពេញមុខងារផ្សេងទៀត ដូចជា ស្នើសុំសម្ភារៈផ្គត់ផ្គង់[917]។ ឧទាហរណ៍ អៀក មៀញ មានទូរស័ព្ទ និងម៉ាស៊ីនទូរលេខនៅក្នុងផ្ទះរបស់គាត់ នៅស្ទឹងហាវ ដើម្បីជួយសម្រួលដល់ការទាក់ទងជាមួយ **មាស មុត**[918]។ យ៉ាងហោចណាស់ កងវរសេនាធំលេខ ៦១ និង ៦២ ព្រម

---

មកបង្រៀននៅកន្លែងកងពលនឹងម៉េង? ឆ៖ ចាស! [...] ស៖ កាលមឹងរៀនជាមួយចិន ហ្នឹង មានគ្នាប៉ុន្មាននាក់? ឆ៖ ខ្ញុំកុមារ គ្នាខ្ញុំហ្នឹងគ្នា ១២ នាក់។ ស៖ រៀន ១២ នាក់ហ្នឹង តែកុមារ? ឆ៖ ចាស!"]។ EN 01066968, KH 00979248 ["ខ្ញុំនៅចាំនឹងរហូតដល់ ៧៩"]។

914 ឯកសារD54/72 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ ឆ.42 ["ខ្សែទីមួយៗគឺមានលេខសម្គាល់សម្រាប់ខ្សែទូរសព្ទមួយៗ។ ឧទាហរណ៍ ប្រសិនបើអ្នកណាម្នាក់ហៅចូល ហើយប្រាប់ថា ឱ្យភ្ជាប់ទៅលេខ ១៨ ខ្ញុំដោតឌុយលេខ ១៨ ឱ្យអ្នកនោះ។ ខ្ញុំភ្លេចលេខខ្សែរបស់ មាស មុត ហើយ តែខ្ញុំចាំថា លេខរបស់គាត់ គឺចាប់ផ្តើមដោយលេខសូន្យ។ តាមពិត មាស មុត កម្រប្រើទូរសព្ទណាស់ ភាគច្រើន គាត់ប្រើសារទូរលេខ"]។

915 ឯកសារ D54/72 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ, ឆ.42, ឆ.45 ["ស៖ ប្រសិនមេបញ្ជាការកងវរសេនាតូចចង់និយាយទាក់ទងតាមទូរសព្ទ ទៅមេបញ្ជាការកងពល ១៦៤ មាស មុត តើគេធ្វើយ៉ាងម៉េច? ឆ.42៖ ខ្សែទីមួយៗ គឺមានលេខសម្គាល់សម្រាប់ខ្សែទូរសព្ទមួយៗ។ ឧទាហរណ៍ ប្រសិនបើអ្នកណាម្នាក់ហៅចូល ហើយប្រាប់ថា ឱ្យភ្ជាប់ទៅលេខ ១៨ ខ្ញុំដោតឌុយលេខ ១៨ ឱ្យអ្នកនោះ។ ខ្ញុំភ្លេចលេខខ្សែរបស់ មាស មុត ហើយ តែខ្ញុំចាំថា លេខរបស់គាត់ គឺចាប់ផ្តើមដោយលេខសូន្យ។ [...] ស៖ តើ មាស មុត មានខ្សែទូរសព្ទនៅផ្ទះរបស់គាត់ដែរឬទេ? ឆ.45៖ ចាស! គាត់មាន។"]។

916 ឯកសារ D54/72 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ ឆ.43 ["ពីព្រោះ មាស មុត ប្រើនិរសាររបស់គាត់ឱ្យមកមន្ទីរទូរសព្ទកណ្តាល ដើម្បីហៅទូរសព្ទ"]។

917 ឯកសារ D54/87 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រំ សារ៉ាត់, ឆ.59 ["ខ្ញុំរាយការណ៍ទៅថ្នាក់លើតាមទូរសព្ទវិញ។ ឧទាហរណ៍ ខ្ញុំជាអ្នកគ្រប់គ្រងនាវា បើនាវាខ្ញុំ មានបញ្ហាដូចជា ត្រូវជួសជុល ឬក៏ត្រូវថែមប្រេង ខ្ញុំត្រូវរាយការណ៍តាមទូរសព្ទទៅថ្នាក់លើវិញ"]។ ឯកសារ D54/72 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ ឆ.29, ឆ.31 ["ការបង្រៀននោះអស់ រយៈពេល ៦ ខែ រួមមានទ្រឹស្តី និងការអនុវត្តផ្ទាល់។ [...] ឆ.31៖ ខ្សែទូរសព្ទនេះ គឺប្រើតែក្នុងកងវរៈនានាដែលស្ថិតនៅក្រោមកងពល ១៦៤"]។

918 ឯកសារ D114/215 កំណត់ហេតុនៃការស្តាប់ចម្លើយ មាស អ៊ឹម, ឆ. 75 - 76 ["ស៖ តើបងប្រុសលោកប្រាស្រ័យទាក់ទងគ្នា ជាមួយឈ្មោះ មៀញ ដោយមធ្យោបាយអ្វីដែរ? ឆ.75៖ ដោយមធ្យោបាយតេអូ ហើយនិងទូរលេខ។ ស៖ ហេតុអីបានលោកដឹង? ឆ.76៖ បើនៅផ្ទះ មៀញ ហ្នឹង ខ្ញុំនៅជិតហ្នឹងដែរ ហើយឃើញប្រដាប់ប្រដាលហ្នឹង"]។

ទាំងកងវរសេនាតូច ១៦៩ មានអ្នកប្រតិបត្តិការទូរស័ព្ទ ហើយកងវរសេនាធំលេខ ៦២ មានអ្នកប្រតិបត្តិការទូរស័ព្ទ ១៥ នាក់ នៅខែ វិច្ឆិកា ឆ្នាំ ១៩៧៦[919]។ ប៉ុន្តែ សាក្សីម្នាក់បានឆ្លើយថា កងវរសេនាតូចទាំងអស់នៅដីគោកមានទូរស័ព្ទមួយខ្សែ[920]។ ខ្សែទូរស័ព្ទមួយភ្ជាប់ពីទីបញ្ជាការកងពលទៅស្ថានីយរ៉ាដានៅបូកគោ[921]។ មិនមានទម្លាប់នៃការរាយការណ៍តាមទូរស័ព្ទជាទៀងទាត់ទេ។ ខ្សែទូរស័ព្ទ គឺប្រើនៅពេលណាដែលមានតម្រូវការប៉ុណ្ណោះ[922]។

## នីរសារ

286. នីរសារ គឺជារបៀបនៃការទាក់ទងជារួមនៅក្នុងកងពល។ កងពល ១៦៤ មានកងនីរសារមួយ និងមាននីរសារពី ២ ទៅ ៤ នាក់ អមដំណើរ **មាស មុត** ជាប្រចាំ[923]។ "ក្រុមនីរសារ គឺជាក្រុមដែលធ្វើ

---

[919] ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត, ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦, EN 00233989, KH 0016045។ ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត, ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦, EN 00575529, KH 00160069។

[920] ឯកសារ D54/72 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ ឆ.39, ឆ.41 ["នៅក្នុងកងវរសេនាតូចនីមួយៗនៃកងពល ១៦៤ គេមានខ្សែទូរសព្ទរបស់គេមួយ ប៉ុន្តែខ្សែទូរសព្ទនេះ គឺប្រើតែសម្រាប់ទំនាក់ទំនងក្នុងកំពង់សោមទេ មិនប្រើទាក់ទងទៅនឹងតាមកោះទេ។ [...] ឆ.41៖ គឺមានតែមេៗបញ្ជាការកងវរសេនាតូចតែប៉ុណ្ណោះ ដែលមានសិទ្ធិប្រើ"]។

[921] ឯកសារ D54/72 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ ឆ.33 ["ខ្ញុំមិនចាំថា មានខ្សែទូរស័ព្ទទាក់ទងពីកំពង់សោមទៅកំពតទេ តែមានខ្សែទូរស័ព្ទទាក់ទងរវាងកំពង់សោម ទៅបូកគោ"]។

[922] ឯកសារ D54/72 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ ឆ.43 - 44 ["មាស មុត ប្រើនិរសាររបស់គាត់ឱ្យមកមន្ទីរទូរសព្ទកណ្តាល ដើម្បីហៅទូរស័ព្ទ។ [...] ឆ.44៖ មិនមានទម្លាប់នៃការរាយការណ៍តាមទូរសព្ទជាទៀតទាត់ទេ។ ខ្សែទូរសព្ទ គឺប្រើនៅពេលណាដែលមានតម្រូវការប៉ុណ្ណោះ"]។

[923] ឯកសារ D54/72 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ ឆ.1 - 2, ឆ.7 ["ស៖ [...] តើកងនិរសាររបស់ មាស មុត មានចំនួនប៉ុន្មាននាក់? ឆ. 1៖ ខ្ញុំឃើញមាននិរសាចំនួនតែ ២ ទៅ ៤ នាក់ទេ ដែលនៅជាមួយគាត់ជាប់។ បើគាត់ទៅកន្លែងជិតៗ គាត់យកអ្នកបើកឡានម្នាក់ អ្នកការពារម្នាក់ទៅតាម។ បើគាត់ទៅកន្លែងឆ្ងាយៗ គាត់មានអ្នកបើកឡានម្នាក់ អ្នកកាន់វិទ្យុទាក់ទងម្នាក់ ហើយនិងពីរនាក់ទៀត ជាអ្នកការពារ និងជានិរសា។ ស៖ តើលោកស្រីអាចប្រាប់យើងអំពីឈ្មោះពួកនិរសា និងអ្នកបើកឡានរបស់ មាស មុត បានដែរឬទេ? ឆ.2៖ អ្នកបើកឡានឈ្មោះ គង់។ អ្នកការពារ ឬនិរសា ឈ្មោះ ម៉ុន។ អ្នកទាំងពីរនាក់នេះដើរជាមួយគាត់ជាប់រហូត។ [...] ឆ.7៖ [...] ក្រុមនិរសា គឺជាក្រុមដែលធ្វើការនៅជិត និងជាប់ជាមួយតាមុត គ្រប់ពេលវេលា"]។ ឯកសារ D114/103 កំណត់ហេតុនៃការស្តាប់ចម្លើយ លៀត ឡុន (ណាំ ឡុន) ឆ.134 - 135 ["ស៖ តើគាត់មកភ្នំពេញ គាត់ជិះអ្វី? ឆ.134៖ គាត់ជិះឡានហ្ស៊ីព។ ស៖ តើអ្នកណាមកជាមួយគាត់? ឆ.135៖ គាត់មកជាមួយនិរសាម្នាក់ ដែលជាក្មេងតូច ហើយនិរសានេះ ក៏ជាអ្នកបើកឡានឱ្យគាត់ផងដែរ"]។ សូមមើលផងដែរ ឯកសារ D54/87 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រំ សារ៉ាត់, ឆ.57 ["ស៖ តាមដែល

ការនៅជិត និងជាប់ជាមួយ តាមុត គ្រប់ពេលវេលា"[924]។ ពេល **មាស មុត** ទៅណាមកណា គាត់តែងតែយកនីរសារម្នាក់ទៅជាមួយជានិច្ច[925]។ "នៅពេលដែលមានប្រជុំធំៗ ឬក៏វគ្គរៀនសូត្រអ្វីមួយ ដែល មាស មុត ចូលរួម [នីរសាររបស់គាត់] តែងតែអមដំណើរទៅជាមួយដែរ"[926]។ ផល, អៀង, គង់ និង ម៉ុន ក៏ធ្លាប់ធ្វើជានីរសារផ្ទាល់ឲ្យ **មាស មុត** ផងដែរ នៅពេលខ្លះ[927]។ ពេល ផល ធ្វើ

---

លោកចាំ តើ មាស មុត ឬក៏អនុរបស់គាត់ មានជំនួយការ ឬក៏និរសា ឬក៏អ្នកបើកបរនៅរស់ដល់សព្វថ្ងៃដែរឬទេ? ឆ. 57៖ [...] ខ្ញុំមិនដែលបានជួបពួកអ្នកជំនួយការ ឬនិរសា ឬអ្នកបើកបរទាំងនោះទេ ក្រោយពីរបបនោះបានបញ្ចប់ទៅ"]។

924 ឯកសារ D54/72 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ ឆ.7 ["ក្រុមនិរសា គឺជាក្រុមដែលធ្វើការនៅជិត និងជាប់ជាមួយ តាមុត គ្រប់ពេលវេលា"]។

925 ឯកសារ D54/72 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ ឆ.1 - 2, ឆ.7 ["ស៖ [...] តើកងនិរសាររបស់ មាស មុត មានចំនួនប៉ុន្មាននាក់? ឆ. 1៖ ខ្ញុំឃើញមាននិរសាចំនួនតែ ២ ទៅ ៤ នាក់ទេ ដែលនៅជាមួយគាត់ជាប់។ បើគាត់ទៅកន្លែងជិតៗ គាត់យកអ្នកបើកឡានម្នាក់ អ្នកការពារម្នាក់ទៅតាម។ បើគាត់ទៅកន្លែងឆ្ងាយៗ គាត់មានអ្នកបើកឡានម្នាក់ អ្នកកាន់វិទ្យុទាក់ទងម្នាក់ ហើយនិង ពីរនាក់ទៀត ជាអ្នកការពារ និង ជានិរសា។ ស៖ តើលោកស្រីអាចប្រាប់យើងអំពីឈ្មោះពួកនិរសា និងអ្នកបើកឡានរបស់ មាស មុត បានដែរឬទេ? ឆ.2៖ អ្នកបើកឡានឈ្មោះ គង់។ អ្នកការពារ ឬនិរសា ឈ្មោះ ម៉ុន។ អ្នកទាំងពីរនាក់នេះដើរជាមួយគាត់ជាប់រហូត។ [...] ឆ.7៖ [...] ក្រុមនិរសា គឺជាក្រុមដែលធ្វើការនៅជិត និងជាប់ជាមួយ តាមុត គ្រប់ពេលវេលា"]។

926 ឯកសារ D114/13 កំណត់ហេតុនៃការស្តាប់ចម្លើយ នាក់ យឿន, ឆ.7 ["នៅពេលដែលមានប្រជុំធំ ឬក៏វគ្គរៀនសូត្រអ្វីមួយ ដែល មាស មុត ចូលរួម គឺ ផល [និរសាររបស់គាត់] តែងតែអមដំណើរទៅជាមួយដែរ"]។

927 ឯកសារ D114/13 កំណត់ហេតុនៃការស្តាប់ចម្លើយ នាក់ យឿន, ឆ.5, ឆ.7 ["នៅថ្នាក់កងពល ១៦៤ គឺ ឈ្មោះ ផល គឺជាអ្នកកាន់ខាងវិទ្យុទាក់ទង។ ផល គឺជានិរសាផ្ទាល់របស់ មាស មុត កាន់ខាងវិទ្យុទាក់ទង។ [...] ឆ.7៖ [...] នៅពេលដែលមានប្រជុំធំ ឬក៏វគ្គរៀនសូត្រអ្វីមួយ ដែល មាស មុត ចូលរួម គឺ ផល [និរសាររបស់គាត់] តែងតែអមដំណើរទៅជាមួយដែរ"]។ ឯកសារ D54/72 កំណត់ហេតុនៃការស្តាប់ចម្លើយ មុត ម៉ៅ ឆ.2 ["ស៖ តើលោកស្រីអាចប្រាប់យើងអំពីឈ្មោះពួកនិរសា និងអ្នកបើកឡានរបស់ មាស មុត បានដែរឬទេ? ឆ.2៖ អ្នកបើកឡាន ឈ្មោះ គង់។ អ្នកការពារ ឬនិរសាឈ្មោះ ម៉ុន។ អ្នកទាំងពីរនាក់នេះ ដើរជាមួយគាត់ជាប់រហូត។"]។ ឯកសារ D114/103 កំណត់ហេតុនៃការស្តាប់ចម្លើយ លៀត ឡុន (ណាំ ឡុន), ឆ.134-136 ["ស៖ តើគាត់មកភ្នំពេញ គាត់ជិះអ្វី? ឆ.134៖ គាត់ជិះឡានហ្ស៊ីព។ ស៖ តើអ្នកណាមកជាមួយគាត់? ឆ.135៖ គាត់មកជាមួយនិរសាម្នាក់ ដែលជាក្មេងតូច ហើយនិរសានេះ ក៏ជាអ្នកបើកឡានឲ្យគាត់ផងដែរ។ [...] ស៖ តើនិរសានោះ ឈ្មោះអ្វី? ឆ.136៖ ឈ្មោះ គង់"]។ ឯកសារ D114/15 កំណត់ហេតុនៃការស្តាប់ចម្លើយ សុក វណ្ណា (សួស វណ្ណា), ឆ.16 ["ខ្ញុំស្គាល់តែឈ្មោះ អៀង ដែលជានិរសាផ្ទាល់របស់ មាស មុត"]។ ឯកសារ D54/115.1 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា នាក់ យឿន, EN 01088463, KH 01007862 ["ស៖ ចុះអ្នកនៅ PCF មកយកឈ្មោះ ផល ដែលខាងនិរសាកងពលនឹង មានយកពី ណាទៅទៀត ដែលត្រូវទៅជាមួយក្នុងព្រឹត្តិការណ៍ហ្នឹងដែរ? ឆ៖ ដែលយក ប៉ុនដឹងថាយក ផល"]។ EN

ជានីរសារឲ្យ **មាស មុត** គាត់ក៏ទទួលបន្ទុកផ្នែកវិទ្យុទាក់ទងផងដែរ នៅទីបញ្ជាការកងពល[928]។ ផល ជាអន្តរការី សម្រាប់ **មាស មុត** និងអង្គភាពវិទ្យុទាក់ទង សម្រាប់ទំនាក់ទំនងចេញចូលមន្ទីរសមរភូមិនៃកងពល ១៦៤ និងចេញបញ្ជាតាមវិទ្យុទាក់ទងទៅកាន់មន្ទីរសមរភូមិ[929]។

287. កងវរសេនាធំ និងកងវរសេនាតូចឯករាជ្យ នៃកងពល ១៦៤ ក៏មាននីរសារផងដែរ[930]។ បញ្ជីក្លាំងកម្លាំង ពីខែ វិច្ឆិកា ឆ្នាំ ១៩៧៦ បង្ហាញអំពីចំនួនប្រែប្រួលនៃនីរសារ នៅក្នុងកងវរសេនាធំ និងកងវរ

---

01088466, KH 01007865 ["បើសិនណាម៉េចម៉ា អាផល នឹងគេអូមកចូលកប៉ាល់ពួកខ្ញុំ។ [...] ផល នៅកន្លែង តាម៉ុត នេះទេ"]។

928 ឯកសារ D114/13 កំណត់ហេតុនៃការស្តាប់ចម្លើយ នាក់ យឿន, ឆ.5 - 6 ["នៅថ្នាក់កងពល ១៦៤ គឺ ឈ្មោះ ផល គឺជាអ្នកកាន់ខាងវិទ្យុទាក់ទង។ ផល គឺជានិរសាផ្ទាល់របស់ មាស មុត កាន់ខាងវិទ្យុទាក់ទង។ [...] ឆ.6៖ [...] យើងដឹងថា ផល គឺជានិរសាជិតកាន់វិទ្យុទាក់ទងឲ្យ មាស មុត"]។

929 ឯកសារ D114/13 កំណត់ហេតុនៃការស្តាប់ចម្លើយ នាក់ យឿន, ឆ.5 ["នៅពេលដែល ផល ទទួលបានរបាយការណ៍តាម វិទ្យុទាក់ទង គាត់ត្រូវសរសេររបាយការណ៍ ហើយប្រគល់ជូនទៅ មាស មុត ដែលជាមេបញ្ជាការកងពល។ ក្រោយមកទៀត មាស មុត ចេញបញ្ជាឲ្យ ផល ហើយ ផល ក៏និយាយតាមវិទ្យុទាក់ទងប្រាប់ពីបញ្ជាដែលចេញពីកងពលទៅដល់អង្គភាពពាក់ព័ន្ធ"]។

930 ឯកសារ D22.2.181 សេចក្តីរាយការណ៍ពីការិយាល័យឈ្លើយសឹក និងយុទ្ធជនបាត់ខ្លួនសហរដ្ឋអាមេរិក មាស មុត, EN 00249694 – 00249695, KH 00741997 - 00741998 ["លោក មាស មុត មិនបានដឹងអំពីការចាត់តាំងអង្គភាពដែលស្ថិតក្រោមកម្រិតកងវរសេនាធំនោះទេ។ អង្គភាពនីមួយៗនៅក្នុងកងពលធំ មានមន្ទីរនិរសាតូចមួយ ដែលមានគ្នាប្រហែលជា ១០ នាក់។ [...] – ((រិន)) – ជាប្រធានមន្ទីរនិរសានៃកងពលធំ"]។ ឯកសារ D54/49 កំណត់ហេតុនៃការស្តាប់ចម្លើយ អែម សុន, ឆ.48 ["នៅពេលខ្ញុំចូលរួមជាមួយកងពល ខ្ញុំរាយការណ៍ដោយផ្ទាល់ទៅ មាស មុត ពីព្រោះគ្មានវរសេនាធំនៅរវាងកងវរសេនាតូច ៤៥០ របស់ខ្ញុំ និង មាស មុត ទេ។ ខ្ញុំបានរាយការណ៍ទៅ មាស មុត អំពីលទ្ធផលនៃបញ្ជាដែលគាត់ដាក់មកឲ្យខ្ញុំអនុវត្ត។ អំឡុងពេលនោះ មិនមានប្រព័ន្ធរាយការណ៍ជាផ្លូវការនោះទេ។ ការរាយការណ៍ គឺធ្វើឡើងតាមសភាពជាក់ស្តែង ជាទូទៅតាមប្រព័ន្ធវិទ្យុទាក់ទង ឬតាមនិរសា"]។ ឯកសារ D2/15 កំណត់ហេតុនៃការស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច, ឆ.25-26 ["ខ្ញុំត្រូវទៅនៅអូរឈើទាល ចេញពីកងវរៈ ៤៥០ ទៅចូលក្នុងកងដែលរៀបចំថ្មី ដើម្បីត្រៀមចូលទៅក្នុងកងនាវាចរ។ ក្នុងពេលនោះ ខ្ញុំស្នាក់នៅពេលខ្លះខាងលិច ពេលខ្លះខាងកើតអូរឈើទាល។ រហូតដល់ ឆ្នាំ ១៩៧៦ ប្រហែលខែ ១ ខែ ២ ខែ ៣ ឬ ខែ ៤ ទើបមានកប៉ាល់ចម្បាំងនាំយកមកដល់។ [...] សៈ កាលដែលលោកទៅនៅលើទួលនោះ តើគេឲ្យលោកធ្វើអ្វីខ្លះ? ឆ.26៖ អត់មានធ្វើអ្វីទេ ការងារខ្ញុំគឺនៅតែជានិរសាដដែល។ មេបញ្ជាការ ពេទ្យ វិទ្យុ និង និរសាទៅនៅនឹងផ្ទះមួយនៅលើទួលនោះជាមួយគ្នា"]។ ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់សហព្រះរាជអាជ្ញ សៀង EN 00217566 ["នៅពេលដែលកងវរសេនាធំត្រូវផ្លាស់ទី ពួកគេត្រូវបានគេណែនាំដោយវិទ្យុទាក់ទង - អាមេរិកាំង ទាក់ទងបានពីរដងដែលត្រូវរឹបអូសបាននៅឆ្នាំ ១៩៧៥។ សារមួយចំនួនត្រូវបានបញ្ជូនតាមរយៈវិទ្យុទាក់ទងផ្សេងៗ ដោយអង្គភាពបញ្ជូន

សេនាតូចឯករាជ្យ នៃកងពល ១៦៤ លើកលែងតែកងវរសេនាតូច ១៦៩ ដែលមានក្រុមនីរសារច្រើនបំផុត គឺ ៦៥ នាក់ ចំណុះឱ្យកងវរសេនាធំលេខ ៦៣[931]។ ក៏មាននីរសារចំណុះឱ្យស្ថានីយរ៉ាដានៅបូកគោផងដែរ[932]។ នីរសារត្រូវគេប្រើឱ្យនាំសារដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរ ហើយសារដែលបញ្ជូនដោយនីរសារច្រើនតែមានសារៈសំខាន់ខ្លាំង[933]។

## កិច្ចប្រជុំ

288. កងពលលេខ ៣ ឬកងពល ១៦៤ ចាប់ផ្ដើមប្រជុំជាទៀងទាត់ ស្ទើរតែភ្លាមៗតែម្ដង ក្រោយពីទៅដល់តំបន់កំពង់សោម ហើយព័ត៌មាន និងបញ្ហា ត្រូវបានបញ្ជូនទៅកម្មាភិបាលថ្នាក់ក្រោម[934]។ ជាញឹកញាប់ **មាស មុត** ជាអ្នកដឹកនាំកិច្ចប្រជុំទាំងនេះ[935]។ "ពេលខ្លះ បញ្ហាត្រូវបានបញ្ជូនតាមវិទ្យុទាក់ទង។ ក្នុងករណីផ្សេងទៀត ពួកយើងត្រូវគេហៅទៅចូលរួមប្រជុំ ឬរៀនសូត្រ ហើយនៅពេលនោះ គេនិយាយអំពីបញ្ហា"[936]។ កិច្ចប្រជុំពេញអង្គរបស់កងពល ១៦៤ "ត្រូវបានចូលរួមដោយមេ

---

សារ។ [...] អង្គភាពនីមួយៗមានចំនួននិរសាទៅជាមួយជាទូទៅ ៣ ឬ ៤ នាក់ ដែលជាអង្គរក្សការពារប្រធានអង្គភាព"]។ ឯកសារ D59/1/1.12 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ណុប ហា, EN 00968380- 00968381, KH 00926609 ["ស៖ បើនៅកោះតាងជា? ឆ៖ និរសា [...] បាទ! និរសា របស់ តាញ៉ន ហ្នឹង។"], EN 00968385, KH 00926630 ["ស៖ ដូចថាកាលគណៈវរៈមួយអីចឹង? ឆ៖ មួយនិរសាជូនកាលខ្លះ២នាក់ ជូនកាលម្នាក់ វាមិន សូវទៀងបាទ!"]។

931 ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦, EN 00575529, KH 00160069។

932 ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦, EN 00233989, KH 0016045។ ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់កងពល ១៦៤ ដោយ មាស មុត ថ្ងៃទី២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ EN 00575529, KH 00160069។

933 ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់សហព្រះរាជអាជ្ញា សៀង, EN 00217566 ["សារអាចជាផ្ទាល់មាត់ ឬ អក្សរ។ [...] សារសំខាន់ តែងតែផ្ញើទៅជាមួយនិរសា"]។

934 ឯកសារ D114/24 កំណត់ហេតុនៃការស្ដាប់ចម្លើយ អ៊ូ ដារ, ឆ.47 ["ស៖ នៅពេលលោកទៅដល់កំពង់សោម តើគេមានប្រជុំ ប្រាប់លោកឱ្យធ្វើអ្វីដែរឬទេ? ឆ.47៖ បាទ! គេមានប្រជុំប្រាប់ អំពីការការពារដែនសមុទ្រ"]។

935 ឯកសារ D54/34 កំណត់ហេតុនៃការស្ដាប់ចម្លើយ អ៊ឹង ឆុន, ឆ.40 ["ខ្ញុំចង់បញ្ជាក់ឱ្យច្បាស់ត្រង់កន្លែងនេះថា ខ្ញុំគ្រាន់តែជាយោធាធម្មតាម្នាក់ ដែលចូលរួមប្រជុំជាមួយយោធាផ្សេងៗទៀត នៅក្នុងអង្គប្រជុំដែលមាន តាមុត ជាគណៈអធិបតី"]។

936 ឯកសារ D59/1/1.7a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ម៉ា ឈឿន, EN 00969944, KH 00926323 ["ជូនកាលបញ្ហាតាមតេអូ អីចឹងទៅណា បើក្នុងករណីខ្លះ គេហៅមកប្រជុំ ហៅមករៀន

បញ្ជាការកងវរសេនាតូច មេបញ្ជាការកងវរសេនាធំ និងមេបញ្ជាការកងទ័ពជើងទឹក ជើងគោក របស់កងពល ១៦៤"[937] ដែលគេធ្វើឡើងមួយខែម្តង ឬពីរខែម្តង នៅកំពង់សោម ដែលនិយាយអំពីការកសាងប្រទេស និងការការពារព្រំដែនសមុទ្រ...[938]។ ជាធម្មតា កិច្ចប្រជុំទាំងនេះត្រូវបានដឹកនាំដោយ **មាស មុត** ឬ ឌឹម ជាអនុរបស់គាត់[939]។

---

សូត្រអីចឹងទៅ លើកផែនការអញ្ចេក លើកផែនការអញ្ចុះទៅ។ ហើយជុំវិញហ្នឹង សំខាន់គឺការពារកោះហ្នឹងហ្នុង ទឹកដីសមុទ្រ"]។

937 ឯកសារ D114/19 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.17 ["សម្រាប់ខ្ញុំ គឺការប្រជុំក្នុងកម្រិតវរសេនាតូច ហើយការប្រជុំនោះ គឺមានប្រភេទផ្សេងៗគ្នា។ ពេលខ្លះការប្រជុំរួមមេបញ្ជាការវរសេនាតូច វរសេនាធំទាំងអស់ និងកងជើង ទឹក ជើងគោករបស់កងពល១៦៤"]។

938 ឯកសារ D54/79 កំណត់ហេតុនៃការស្តាប់ចម្លើយ ណុប ហាល់ ឆ.23 ["គេហៅឲ្យប្រជុំយូរៗម្តងប៉ុណ្ណោះ គឺទាំងនៅថ្នាក់ វរសេនាតូច និងថ្នាក់អនុសេនាតូច។ គេប្រជុំមួយខែម្តង ឬពីរខែម្តង។ ក្នុងនាមជាអ្នកបើកកាណូត គេប្រជុំណែនាំឲ្យថែទាំ កាណូត។ ខ្ញុំមិនចាំថា គេបានណែនាំឲ្យប្រព្រឹត្តខុសគ្នា ចំពោះជនជាតិវៀតណាម និងជនជាតិថៃនោះទេ។ គេតែងតែប្រាប់ក្នុង ពេលប្រជុំថា ឲ្យរាយការណ៍រាល់អ្វីៗដែលយើងសង្កេតឃើញចូលក្នុងទឹកដីកម្ពុជា"]។ ឯកសារ D114/19 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.12-14, ឆ.16-18 ["ខ្ញុំទៅប្រជុំ ជួនកាល១ខែម្តង ជួនកាល២ខែម្តង។ មិនមានការរៀបចំប្រជុំជាអចិន្ត្រៃយ៍នោះទេ គឺយើងទៅតែពេលណា ដែលមានការប្រជុំពិសេសប៉ុណ្ណោះ។ […] ឆ.13៖ […] នៅក្នុងអង្គប្រជុំនោះ គឺគេនិយាយអំពីបញ្ហាផ្សេងៗជាច្រើន សម្រាប់ខ្ញុំ ដែលជាយោធា គឺខ្ញុំចាប់អារម្មណ៍តែទៅលើរឿងរ៉ាវដែលទាក់ទងនឹងយោធា ដូចជាការពារជាតិ ការពារប្រទេស ការកសាងប្រទេស ការយាមកាមដែនទឹក ដើម្បីឃ្លាំមើលទូកនេសាទ ឬទូកដទៃៗណាដែលចូលមកដែនទឹករបស់យើង ហើយនឹងការហាត់រៀនខាងផ្នែកហែលទឹក។ […] ឆ.14៖ ខ្ញុំទៅចូលរួមនោះ នៅកំពង់សោម […] ឆ.16៖ […] ពេលខ្លះ តាឌឹម ជាអធិបតីក្នុងអង្គប្រជុំ ហើយពេលខ្លះ តាមុត ជាអធិបតីក្នុងអង្គប្រជុំ […] ឆ.17៖ សម្រាប់ខ្ញុំ គឺការប្រជុំក្នុងកម្រិតវរសេនាតូច ហើយការប្រជុំនោះ គឺមានប្រភេទផ្សេងៗគ្នា។ ពេលខ្លះការប្រជុំរួមមេបញ្ជាការវរសេនាតូច វរសេនាធំទាំងអស់ និងកងជើង ទឹក ជើងគោករបស់កងពល១៦៤ […] ឆ.18៖ ការណែនាំគឺថា បើយើងឃើញកប៉ាល់នេសាទណាឆ្លងចូលផុតមកក្នុងដែនទឹករបស់យើង ជិតៗព្រំដែន យើងមិនធ្វើអ្វីទេ ប៉ុន្តែកាណូតទាំងនោះចូលមកជ្រៅ ហើយយូរក្នុងដែនទឹកយើង យើងនឹងវៃភ្លាម។ រឿងនេះ ភាគច្រើនគឺកើតឡើងនៅកន្លែងរបស់ខ្ញុំ"]។ ឯកសារ D54/88 កំណត់ហេតុនៃការស្តាប់ចម្លើយ ស៊ឹម នី ឆ.14 ["វាខុសគ្នា វាគឺជាការប្រជុំប្រចាំខែនៅផ្សារលើជាមួយមេបញ្ជាការទាំងអស់ មកពីតាមបណ្តាលកោះនានា។ ការប្រជុំប្រចាំខែនៅស្ទឹងហាវ គឺការប្រជុំអំពីការសាងសង់ផែយោធា"]។ ឯកសារ D114/65 កំណត់ហេតុនៃការស្តាប់ចម្លើយ ជេត ប៊ុណ្ណា, ឆ.10 - 11 ["នៅពេលនោះ គេតែងឧទ្ទេសនាមប្រាប់ ដែលគេថា មាស មុត គឺអនុរបស់ សុន សេន។ […]ឆ. 11៖ នៅពេលខ្លះ មេបញ្ជាការកងវរសេនាធំ ជាអ្នកប្រកាសនៅក្នុងរយៈពេល សន្និបាត។ ក្នុងពេលសន្និបាតនោះ គេក៏និយាយអំពីការការពារដែនសមុទ្រ និងព្រំដែនសមុទ្រ ដែលមានប្រវែងជាង ៤០០ គីឡូម៉ែត្រ ហើយនិងការការពារកោះរបស់កម្ពុជា ដែលមានជិត ២០០ កោះ។ រួច

289. **មាស មុត** ក៏បានរៀបចំ និងដឹកនាំកិច្ចប្រជុំតូចៗ សម្រាប់មេបញ្ជាការកងវរសេនាធំ នៅទីបញ្ជាការរបស់គាត់ ដើម្បី "ធ្វើផែនការការងារ" បីខែម្តង[940] ចំណែកឯមេបញ្ជាការកងវរសេនាតូចក៏ចូលរួមប្រជុំជាទៀងទាត់ជាមួយមេបញ្ជាការកងវរសេនាធំផងដែរ[941]។ កិច្ចប្រជុំក៏ត្រូវបានរៀបចំផងដែរ

---

ហើយ គេនិយាយអំពីកិច្ចការការពារប្រទេស ពីការឈ្លានពាន ប្រទេសពីប្រទេសជិតខាង ហើយនិយាយអំពីគម្រោងយកកោះត្រល់ និងកម្ពុជាក្រោមមកវិញ នៅក្នុងការអនុវត្តន៍ គេបានហៅមេបញ្ជាការវរសេនាតូចឱ្យទៅរៀននៅភ្នំពេញ"]។ D114/132 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ៅ រ៉ាន់, ឆ.172 ["ស៖ តើលោកធ្លាប់បានចូលរួមកិច្ចប្រជុំលេខាធិការផ្នែកភស្តុភាររបស់ប្រធានកងពល និងវរសេនាធំ ថ្ងៃទី ១៩ ខែ ៩ ឆ្នាំ ១៩៧៦ ដែរទេ? ឆ.172៖ ប្រជុំនោះគឺជាការប្រជុំធំដុំ"]។

939 ឯកសារ D114/19 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.12, ឆ.16 - 17 ["ខ្ញុំទៅប្រជុំ ជួនកាល១ខែម្តង ជួនកាល២ខែម្តង។ មិនមានការរៀបចំប្រជុំជាអចិន្ត្រៃយ៍នោះទេ គឺយើងទៅតែពេលណា ដែលមានការប្រជុំពិសេសប៉ុណ្ណោះ។ [...] ឆ.16៖ [...] ពេលខ្លះ តាឌឹម ជាអធិបតីក្នុងអង្គប្រជុំ ហើយពេលខ្លះ តាមុត ជាអធិបតីក្នុងអង្គប្រជុំ [...] ឆ.17៖ សម្រាប់ខ្ញុំ គឺការប្រជុំក្នុងកម្រិតវរសេនាតូច ហើយការប្រជុំនោះ គឺមានប្រភេទផ្សេងៗគ្នា។ ពេលខ្លះការប្រជុំរួមមេបញ្ជាការវរសេនាតូច វរសេនាធំទាំងអស់ និងកងជើង ទឹក ជើងគោករបស់កងពល១៦៤"]។

940 ឯកសារ D54/10 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ី រ៉េត (សារ៉េត), ឆ.13 ["ខ្ញុំធ្លាប់បានឃើញគាត់រៀបចំប្រជុំជាមួយមេបញ្ជាការវរសេនាធំទាំងអស់របស់គាត់។ តាមដែលខ្ញុំដឹង គាត់ហៅមេបញ្ជាការទាំងនោះប្រជុំ នៅពេលដែលមានផែនការសម្រាប់ធ្វើ"]។ ឯកសារ D54/17 កំណត់ហេតុនៃការស្តាប់ចម្លើយ សយ ប៊ន, ឆ.6 ["ចំពោះការប្រជុំថ្នាក់ប្រធាន ថ្នាក់ វរសេនាធំ គេអាចធ្វើឡើងនៅទីបញ្ជាការរបស់ មាស មុត"]។ ឯកសារ D54/31 កំណត់ហេតុនៃការស្តាប់ចម្លើយ ស៊ឹម នី, ឆ.5 ["នៅពេលនោះទីបញ្ជាការដ្ឋានកងពល និងផ្ទះរបស់បញ្ជាការកងពល គឺនៅជាមួយគ្នា។ រៀងរាល់ខែ ពួកមេបញ្ជាការវរសេនាធំនីមួយៗមកប្រជុំនៅទីនោះ រៀងរាល់ថ្ងៃទី ១០ ថ្ងៃទី ២០ និងថ្ងៃទី ៣០"]។ ឯកសារ D54/84 របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ស៊ឹម នី, EN 00985278, KH 01001424 ["សាក្សីពិពណ៌នាអំពីទីតាំងនៃបញ្ជាការដ្ឋានរបស់ មាស មុត (ម.ម)។ កិច្ចប្រជុំជាទៀងទាត់ត្រូវបានធ្វើឡើងនៅថ្ងៃទី ១០, ទី ២០, និងទី ៣០ រៀងរាល់ខែ រវាង មម និងមេបញ្ជាការនានាចំណុះឱ្យកងពលធំ នៅទីបញ្ជាការដ្ឋាន"]។

941 ឯកសារ D114/297.1.39 ប្រតិចារឹក អៀង ផាន ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦, ម៉ោង 11.25.00 - 11.26.45 ["ខ្ញុំសូមជម្រាបថា រវាងមេបញ្ជាការកងពលធំ និង មេបញ្ជាការកងពលតូច គឺថា ៣ ថ្ងៃ ជួបគ្នាម្តង។ មិនៗឱ្យយូរទេ ពីព្រោះទាក់ទងនឹងអី ទាក់ទងនឹងប្រយុទ្ធ ទាក់ទងនឹងការរៀបចំកម្លាំង ទាក់ទងនឹងភស្តុភារហិរញ្ញវត្ថុ គ្រាប់រំសេវ អីចឹងត្រូវការជួបគ្នា បាទ! ជួបគ្នា"]។ ឯកសារ D114/208 កំណត់ហេតុនៃការស្តាប់ចម្លើយ ឡុង ផាន់ស៊ី, ឆ.22, ឆ.25 ["ខ្ញុំរាយការណ៍នៅពេលខ្ញុំទៅប្រជុំមួយខែម្តង។ ក្នុងពេលនៅ ៦១២ ហ្នឹង ការងាររបស់ខ្ញុំគឺ សំដៅតែលើការងារសំណង់ ដូច្នេះ ខ្ញុំត្រូវរាយការណ៍តែក្នុង ពេលប្រជុំប៉ុណ្ណោះ។ [...] ឆ.25៖ ខ្ញុំប្រជុំតែម្នាក់ឯង រាល់ពេល ១ ថ្ងៃ ឬ ៣ ថ្ងៃម្តង ខ្ញុំប្រជុំជាមួយមេអនុសេនាធំរបស់ខ្ញុំ មុនពេលទៅប្រជុំជាមួយមេវរសេនាធំ"]។ សូមមើលផងដែរ ឯកសារ D54/106 កំណត់ហេតុនៃការស្តាប់ចម្លើយ សាន់ កាន, ឆ.20 - 21 ["ស៖ នៅពេលលោករៀនវគ្គបច្ចេកទេស តើគេមានបង្រៀនវគ្គនយោបាយទេ? ឆ.20៖ មិនមានទេ ប៉ុន្តែមានការប្រជុំ ៣ ថ្ងៃម្តង ដោយគេប្រជុំប្រាប់អំពីការខិតខំរៀន

សម្រាប់មេបញ្ជាការកងវរសេនាតូច កងអនុសេនាធំ និងកងអនុសេនាតូច នៅតាមទីតាំងផ្សេងៗ ហើយ **មាស មុត** បានចូលរួមក្នុងកិច្ចប្រជុំថ្នាក់ក្រោមនេះជាញឹកញាប់[942]។

290. ពិតណាស់ កិច្ចប្រជុំជាច្រើនប្រភេទត្រូវបានរៀបចំឡើង។ ក្រៅពីកិច្ចប្រជុំដែលបានរៀបរាប់រួចមក ហើយ មានវគ្គរៀនសូត្រនយោបាយ ដែលជាញឹកញាប់ ឧទ្ទេសនាមដោយ **មាស មុត** និង ឌឹម[943]

---

សូត្រ មិនឲ្យខ្ចិលច្រអូស។ សៈ ពេលប្រជុំ ៣ ថ្ងៃម្តង តើនរណាជាអ្នកហៅប្រជុំ? ឆ.21៖ មេក្រុម ជាអ្នកហៅមកប្រជុំ"]។ ឯកសារ D98/3.1.28 ប្រតិចារឹក ឈូក រិន, ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣, ម៉ោង 10.13.10 - 10.14.51 ["បើថានិយាយរៀបរាប់ពីការប្រជុំ ការស្ទីហ្នឹង គឺគេឲ្យប្រជុំជាពួក ជាក្រុម ថា ៣ ថ្ងៃម្តងៗហ្នឹង គ្មានពេលស្រាកស្រាន្តទេវាអីចឹង។ រឿងហ្នឹង ដែលថាភ័យខ្លាច ធ្វើអ្វីមួយវាត្រូវតែខ្លាចខុស ខ្លាចមិនត្រូវទេ ការពិត"]។

942 ឯកសារ D114/24 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ូ ដាវ, ឆ.91 ["ខ្ញុំដឹងពីការបញ្ជាពីថ្នាក់លើ គឺនៅពេលកងវរសេនាតូច ហៅកងអនុសេនាធំ និងកងអនុសេនាតូច ទៅប្រជុំ គឺគេប្រាប់ថា ការបញ្ជានោះ គឺមកពីបក្ស មានន័យថា ថ្នាក់លើ។ បក្សគឺសំដៅទៅ មាស មុត"]។ ឯកសារ D114/127 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ូ គឹម, ឆ.49, ឆ.51 ["សៈ ក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានិយាយថា ធ្លាប់ឃើញ មាសមុតមកលើកោះ។ តើលោកអាចពន្យល់បន្ថែមបានដែរឬទេ? ឆ.49៖ បាទ! ខ្ញុំពុំចាំថាប៉ុន្មានដងទេ តែច្រើនដងដែរ ដែលខ្ញុំបានឃើញគាត់ចូលរួមប្រជុំនៅលើកោះ។ ការប្រជុំនោះ គឺមានតែវរសេនាតូច អនុសេនាធំ និងអនុសេនាតូចប៉ុណ្ណោះចូលរួម។ យោធាធម្មតាដូចខ្ញុំ គេពុំឲ្យចូលរួមទេ។ [...] សៈ តើការប្រជុំនោះ ធ្វើឡើងនៅទីណាដែរ? ឆ.51៖ នៅទីបញ្ជាការវរសេនាតូច"]។

943 សូមមើលឧទាហរណ៍ ឯកសារ D114/95 កំណត់ហេតុនៃការស្តាប់ចម្លើយ យឹម ស្រឿង, ឆ.216 ["សៈ នៅពេលដែលគេបង្រៀនវគ្គហ្វឹកហ្វឺននយោបាយនោះ តើគេបង្រៀននៅកន្លែងណាដែរ? ឆ.216៖ ភាគច្រើននៅអូរឈើទាល នៅផ្សារកំពង់សោម រោងកុនកំពង់សោម"]។ ឯកសារ D114/132 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ៅ រ៉ាន់, ឆ.63 - 64, ឆ.66, ឆ.69, ឆ.72 ["ការរៀនសូត្រហ្នឹង គឺធ្វើឡើងពេលដែលយើងជួបជុំគ្នា គឺរៀបចំដោយ មាស មុត ហើយអ្នកបង្រៀនមាន មាស មុត និងអនុរបស់គាត់ម្នាក់ទៀត [...] ឆ.64៖ រៀននៅរោងកុនផ្សារលើ។ [...] ឆ.66៖ រៀនដូចជាច្បាប់វិន័យកងទ័ព [...] ឆ.69៖ គាត់និយាយពីកងទ័ពវៀតណាម ដែលចង់ដណ្តើមទឹកដីកម្ពុជា គឺគាត់និយាយថា ឲ្យកងទ័ពការពារជាពិសេស កន្លែងណាដែល មានជាប់ព្រំប្រទល់នឹងព្រំដែនវៀតណាម។ [...] ឆ.72៖ ពេលប្រជុំរៀនសូត្រមានមនុស្សចូលរួមទាំងអស់ប្រមាណ ៥០០ ទៅ ៦០០ នាក់"]។ ឯកសារ D114/48 កំណត់ហេតុនៃការស្តាប់ចម្លើយ សុខ ង៉ុន, ឆ.14 ["ពេលដែលខ្ញុំទៅដល់កំពង់សោមដំបូង គេដាក់ខ្ញុំឲ្យទៅហ្វឹកហ្វឺនកងទ័ពជើងទឹកនៅក្រុងកំពង់សោម។ ពេលខ្លះ យើងត្រូវបានគេបញ្ជូនទៅហាត់រៀននៅនឹងឆ្នេរអូរឈើទាល"]។ ឯកសារ D114/103 កំណត់ហេតុនៃការស្តាប់ចម្លើយ លៀត ឡុន (ណាំ ឡុន), ឆ.128 – 30 ["សៈ តើអ្នកណាជាអ្នករៀបចំវគ្គរៀនសូត្រហ្នឹង? ឆ.128៖ មាស មុត។ សៈ នៅក្នុងវគ្គរៀនសូត្រហ្នឹង មាស មុត និយាយអ្វីខ្លះ? ឆ.129៖ គាត់និយាយច្រើនរឿង។ គាត់ពិនិត្យលើផែនការប្រចាំខែ និងប្រចាំឆ្នាំ។ សៈ តើលោកអាចប្រាប់បន្ថែមអំពីអ្វីដែលគាត់បាននិយាយនៅក្នុងកិច្ចប្រជុំបានទេ? ឆ.130៖ ខ្ញុំមិនចាំច្រើនទេ តែខ្ញុំចាំថា គាត់និយាយពីស្ថានភាពនៅក្នុងអង្គភាពមួយចំនួន"]។ ឯកសារ D54/33 កំណត់ហេតុនៃការ

ស្តាប់ចម្លើយ អ៊ឹង ឆុន, ឆ. 16 - 18 ["ខ្ញុំបានរៀនសូត្របានកន្លះខែ ជាមួយ មាស មុត។ ក្នុងរយៈពេលនៃការហាត់រៀននោះ គេបានឱ្យយើងធ្វើជីវទស្សន៍ផងដែរ។ [...] ឆ.17៖ មានរឿងជាច្រើនណាស់ដែលគេបង្រៀន វាគឺជាការអប់រំនយោបាយ [...] ស៖ តើហេតុអ្វីបានជា មាស មុត ជាអ្នកបង្រៀនទៅវិញ? ឆ.18៖ ពីព្រោះគាត់ជាមេបញ្ជាការកងពលលេខ៣"]។ ឯកសារ D54/100 កំណត់ហេតុនៃការស្តាប់ចម្លើយ ឡាយ ប៊ុនហាក់, ឆ.31 ["គេបើកវគ្គរៀននយោបាយម្តងក្នុងមួយឆ្នាំ គឺនៅចុងខែ ១២។ គេជ្រើសរើសបក្ខជន សម្ព័ន្ធយុវកក មកចូលរួមវគ្គរៀនសូត្រនយោបាយនេះ។ ដោយវគ្គរៀនសូត្រនីមួយៗ មានរយៈពេលមួយអាទិត្យ ឬ ១៥ ថ្ងៃ។ នៅក្នុងវគ្គរៀនសូត្រនោះ គេបង្រៀនអំពីការកសាងកម្លាំង កសាងខ្លួន មនោគមន៍វិជ្ជារបស់បក្សកុម្មុយនិស្តកម្ពុជា។ ក្នុងវគ្គនីមួយៗមានមនុស្សប្រហែលជា ៣០០ នាក់ មកចូលរៀន [...] បន្ទាប់មក គេហ្វឹកហ្វឺនរបៀបរបបយោធា គឺរបៀបគោរពអ្នកធំ នៅពេលល្ងាច។ ឯកសារ D54/17 កំណត់ ហេតុនៃការស្តាប់ចម្លើយ សយ ប៊ិន, ឆ.6, ឆ.8, ឆ.10 ["នៅឆ្នាំ ១៩៧៥ គេប្រជុំរៀនសូត្រនយោបាយនៅកន្លែងនេះ សម្រាប់ការប្រជុំនយោបាយ ប្រធាន/អនុប្រធានវរសេនាតូច ប្រធាន/អនុប្រធានកងអនុសេនាធំ រហូតដល់ថ្នាក់ប្រធានក្រុម ដែលគេហៅថា ជាកម្មាភិបាល។ [...] ឆ.8៖ ដោយសារខ្ញុំក៏បានចូលរួមវគ្គរៀនសូត្រទាំងនោះដែរ ហើយខ្ញុំបានចូលរៀន វគ្គរៀនសូត្រនោះមួយដងក្នុងមួយឆ្នាំ។ [...] ឆ.10៖ មេបញ្ជាការទទួលបន្ទុកនយោបាយ គឺ មាស មុត ត្រូវបង្រៀនអំពីកិច្ចការនយោបាយ សតិអារម្មណ៍ចាត់តាំង។ មេបញ្ជាការទទួលបន្ទុកយោធា គឺ ឌីម ដែលត្រូវបង្រៀនពីបច្ចេកទេសយោធាប្រយុទ្ធ មេបញ្ជាការខាងភស្តុភារ គឺ ឆាន គាត់ទទួលបន្ទុកអាវុធយុទ្ធភ័ណ្ឌ ការហូបចុកប្រើប្រាស់ ផ្គត់ផ្គង់ និងសុខភាព។ ពេលបិទវគ្គ មាស មុត មកធ្វើជាគណៈអធិបតី ដើម្បីបូកសរុបពីលទ្ធផលនៃវគ្គរៀនសូត្ររបស់សិក្ខាកាម ការពិនិត្យជីវទស្សន៍ និងការផ្តល់ការណែនាំបន្ថែមជាចុងក្រោយនៃវគ្គនីមួយៗ"]។ ឯកសារ D114/139 កំណត់ហេតុនៃការស្តាប់ចម្លើយ ងួន ឡាយ ហៅ អ៊ី, ឆ.54 ["គេធ្វើច្រើនកន្លែង ធ្វើរបៀបជាសិក្ខាសាលា។ ភាគច្រើន គេធ្វើនៅចុងខែ ១២ មុនពេលគេបញ្ជូនកងទ័ពទៅច្បាំងទៀត"]។ ឯកសារ D114/58 កំណត់ហេតុនៃការស្តាប់ចម្លើយ សំ សោម, ឆ.26 ["នៅក្នុងវគ្គសិក្សានោះ តើ មាស មុត ឬវាគ្មិនដទៃទៀតបាននិយាយអំពីស្ថានភាពខ្មាំង ទាំងខ្មាំងផ្ទក្នុង ទាំងខ្មាំងខាងក្រៅដែរឬទេ? ឆ.26៖ បាទ! [...] ពួកគេនិយាយអំពី កា.ហ្វេ.ប៊េ វៀតណាម និងភ្នាក់ងារជាដើម"]។ ឯកសារ D54/45 កំណត់ហេតុនៃការស្តាប់ចម្លើយ លុន សេង, ឆ.1 - 3 ["មេបញ្ជាការមកពីកងវរសេនាធំទាំងអស់ក្នុងកងពល ១៦៤ បានចូលរួមនៅក្នុងកិច្ចប្រជុំ [...] ស៖ តើមានតែប្រធានកងពលតែម្នាក់ឯងទេ ដែលជាអ្នកគ្រប់គ្រងផ្សព្វផ្សាយ នៅក្នុងអង្គប្រជុំអប់រំនោះ? ឆ.2៖ បាទ! មានតែប្រធានកងពល មាស មុត ដែលជាអ្នកនិយាយផ្សព្វផ្សាយ [...] ឆ.3៖ សម្រាប់ការប្រជុំសម្រាប់ថ្នាក់ដឹកនាំដូច្នេះ វាមានរយៈពេល ៣ ថ្ងៃ។ ថ្ងៃនីមួយៗ ចាប់ផ្តើមពីម៉ោងប្រាំពីរកន្លះព្រឹក ដល់ម៉ោងដប់មួយកន្លះ និងពេលថ្ងៃចាប់ពីម៉ោងដប់បីកន្លះ ដល់ម៉ោងប្រាំមួយកន្លះ។ ការប្រជុំសម្រាប់កម្មាភិបាលដឹកនាំបែបនេះ គឺស្ងិតស្ងាញតឹងតែងណាស់"]។ ឯកសារ D54/44 កំណត់ហេតុនៃការស្តាប់ចម្លើយ លុន សេង, ឆ.2 ["អំឡុងពេលសង្គ្រាម គេមានការប្រជុំ ឬបើករៀនសូត្រ ដើម្បីអប់រំយោធាអំពីភាពក្លាហានដែលយោធាម្នាក់ៗ [...] អំឡុងពេលសន្តិភាព គេធ្វើកិច្ចប្រជុំ ណែនាំមនុស្សឱ្យចេះធ្វើសតិអារម្មណ៍ឱ្យល្អ ហើយផ្តោតលើការងារបង្កបង្កើនផល"]។ ឯកសារ D1.3.13.13 កំណត់ហេតុនៃការស៊ើបសួរបឋមរបស់សហព្រះរាជអាជ្ញា ទូច សឿលី, EN 00217574 ["សាក្សីបានថ្លែងថា មាស មុត បានហៅការហ្វឹកហាត់មួយដងក្នុងមួយឆ្នាំ នៅចុងបញ្ចប់ដែលត្រូវបានប្រារព្ធធ្វើនៅក្នុងអតីតរោងកុន។ ប្រធានបទនៃកិច្ចប្រជុំ រួមមានការពង្រឹង និងពង្រីកបដិវត្តន៍ រួមជាមួយបញ្ហានយោបាយទាក់ទងវៀតណាម និងថៃ រួមជាមួយវគ្គការរិះគន់ដោយខ្លួនឯង"]។ ឯក

ព្រមទាំងកិច្ចប្រជុំបក្ខជន និងសម្ព័ន្ធយុវជន ដែលពិភាក្សាអំពីប្រធានបទ ដូចជា ជម្លោះជាមួយវៀតណាម[944] ក៏ដូចជាវគ្គរៀនសូត្រកងនាវានៃកងវរសេនាធំ ១៤០[945] និងប្រជុំ "ជីវភាព"[946]។ ក៏

---

សារ D54/33.1 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា អ៊ី នុន, EN 01073809, KH 00964199 ["តាមុត ជាអ្នកបង្រៀន រៀននៅរោងកុនកំពង់សោមម៉ង"]។

944 ឯកសារ D54/100 កំណត់ហេតុនៃការស្ដាប់ចម្លើយ ឡាយ ប៊ុនហាក់, ឆ.45 - 46, ឆ.48 ["គេមានរៀបចំការប្រជុំមាន ២ផ្នែក ១) ប្រជុំផ្ទៃក្នុងបក្សដែលមានចូលរួមដោយបក្ខជន និងយុវកក គឺ ១ខែម្ដង និង ២) មានការប្រជុំការងារធម្មតា១ខែម្ដង។ [...] ឆ.46៖ កិច្ចប្រជុំមួយទៀត ជាការប្រជុំសាមញ្ញ ប្រជុំធំហ គឺប្រជុំពីការងារទូទៅ។ ហើយប្រធានអង្គភាពនីមួយៗ ត្រូវដាក់ខ្លួនឱ្យសមាជិកទិតៀន និងធ្វើជាគំរូសម្រាប់សមាជិកដទៃទៀត នៅក្នុងក្រុម។ ឆ.48៖ [...] គឺសភាពការណ៍ក្នុងប្រទេស និងក្រៅប្រទេស។ ការងារប្រទេស ក្រៅប្រទេស គឺទំនាស់ជាមួយពួកវៀតណាមជាដើម"]។

945 ឯកសារ D54/98 កំណត់ហេតុនៃការស្ដាប់ចម្លើយ ប៉ាង រ៉េត (ហៀង រ៉េត), ឆ.41 - 42 ["ស៖ នៅអំឡុងពេលដែលលោករស់នៅ និងធ្វើការនៅកំពង់សោម រហូតដល់ពេលដែល មាស មុត ត្រូវបានបញ្ជូនទៅព្រំដែនកម្ពុជា វៀតណាម តើលោកបានជួបគាត់ ញឹកញាប់ដែរឬទេ? [...] ឆ.42៖ ខ្ញុំបានជួប មាស មុត ១អាទិត្យ១ដង នៅក្នុងវគ្គហ្វឹកហ្វឺនយោធាជើងទឹក ដោយ មាស មុត ចុះមកប្រជុំដកពិសោធន៍ការងារជាមួយយោធាជើងទឹក នៅក្នុងវគ្គបណ្ដុះបណ្ដាលជាមួយអ្នកជំនាញចិន"]។ ឯកសារ D54/87 កំណត់ហេតុនៃការស្ដាប់ចម្លើយ ព្រុំ សារ៉ាត់, ឆ.39 - 40 ["ខ្ញុំមិនដែលទៅទីបញ្ជាការដ្ឋានកងពល១៦៤ទេ តែខ្ញុំធ្លាប់ចូលរួមប្រជុំ ដែលរៀបចំដោយកងពល១៦៤ នៅឆ្នេរអូរឈើទាល។ [...] ស៖ តើវគ្គបណ្ដុះបណ្ដាលនោះធ្វើជាញឹកញាប់ដែរឬទេ? ឆ.40៖ ធ្វើជារៀងរាល់ឆ្នាំ"]។ ឯកសារ D114/65 កំណត់ហេតុនៃការស្ដាប់ចម្លើយ ជេត ប៊ុណ្ណា, ឆ.16 ["នៅពេលនោះ គេផ្ដើមរៀបចំកងទ័ពជើងទឹក ពេលនោះគេបញ្ជូនពួកខ្ញុំឱ្យទៅធ្វើការហ្វឹកហ្វឺននៅអូរឈើទាល"]។ ឯកសារ D114/287 កំណត់ហេតុនៃការស្ដាប់ចម្លើយ ប៉ាង រ៉េត (ហៀង រ៉េត), ឆ.36 - 37 ["ខ្ញុំប្រជុំជាមួយគាត់ [មាស មុត] សឹងតែមួយអាទិត្យម្ដង ព្រោះរាល់សប្ដាហ៍ គាត់ហៅអ្នកហ្វឹកហ្វឺនទៅប្រជុំជាមួយគាត់ ដើម្បីបង្ហាញពីការដកពិសោធន៍ ពង្រឹង ការងារ។ [...] ឆ.37៖ ជាការផ្សព្វផ្សាយវិធានការហើយៗ ចាត់ការកម្លាំងបន្ថែមសម្រាប់អន្តរាគមន៍។ គឺថាតំណាងអង្គភាព យកព្រឹត្តិការណ៍មកផ្សាយមិនឱ្យខុសពីផែនការដែលទទួលមកពីកងពលទេ"]។ ឯកសារ D54/112.1ឯកសារ D59/1/1.10a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ផ្លុង ឈា, EN 00968350 – 00968351, KH 00926496 - 00926497 ["ផ្នែកហ្នឹងវាមាន អឺ!យើងដឹងថា ឧទាហរណ៍ផ្នែកកាំភ្លើង យើងដឹងតែផ្នែកកាំភ្លើង [...] មានផ្នែករ៉ាដា ផ្នែកត្រីវិស័យ ផ្នែកទូរលេខ ផ្នែកទី និងផ្នែកម៉ាស៊ីន ផ្នែកបើកបរ"]។ ឯកសារ D59/1/1.8a កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រុំ សារ៉ាត់ EN 00974180, KH 00926362 ["បង្ហាត់ហ្វឹកហ្វឺនដោយមានផ្នែកវាណា បើកបរ ម៉ាស៊ីន កាំភ្លើង អគ្គីសនី ទូរគមនាគមន៍ ខាងទូរលេខ ខាងវិទ្យុទាក់ទង ហើយខាងសញ្ញា"]។ ឯកសារ D54/115.1 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា នាក់ យឿន, EN 01088456, KH 01007855 ["រៀនមានផ្នែកគេ ឥឡូវផ្នែកកប៉ាល់នឹងមានផ្នែកម៉ាស៊ីន អានឹងមានផ្នែកម៉ាស៊ីនទៅ ហ៊ីកផ្នែកបើកបររៀនផ្នែកបើកបរទៅ ផ្នែកទូរលេខរៀនផ្នែកទូរលេខទៅ។ ហើយខ្ញុំរៀនផ្នែកកងកាំភ្លើងទៅ"]។ ឯកសារ D54/100

មាន "កិច្ចប្រជុំពិសេស" ផងដែរ ដើម្បីពិភាក្សាអំពីប្រធានបទ ដូចជា ការបោសសម្អាតសមាជិកភូមិភាគបូព៌ា ជាដើម[947]។

កំណត់ហេតុនៃការស្តាប់ចម្លើយ ឡាយ ប៊ុនហាក់, ឆ.45 - 48 ["គេមានរៀបចំការប្រជុំមាន ២ ផ្នែក ១) ប្រជុំផ្ទៃក្នុងបក្សដែលមានចូលរួមដោយបក្ខជន និងយុវកក គឺ ១ខែម្តង និង ២) មានការប្រជុំការងារធម្មតា១ខែម្តង។ [...] ឆ.46៖ កិច្ចប្រជុំមួយទៀត ជាការប្រជុំសាមញ្ញ ប្រជុំចំហ គឺប្រជុំពីការងារទូទៅ។ ហើយប្រធានអង្គភាពនីមួយៗ ត្រូវដាក់ខ្លួនឲ្យសមាជិកទិតៀន និងធ្វើជាគំរូសម្រាប់សមាជិកដទៃទៀត នៅក្នុងក្រុម។ [...] ឆ.48៖ គេនិយាយអំពីតែអង្គភាព ឬក្រុមការងារនីមួយៗប៉ុណ្ណោះ ឯការងារផ្សេងៗ គេមិនលើកមក និយាយនោះទេ។ រឿងសម្ងាត់ដែលគេលើកមកនិយាយ គឺសភាពការណ៍ក្នុងប្រទេស និងក្រៅប្រទេស។ ការងារប្រទេសក្រៅប្រទេស គឺទំនាស់ជាមួយពួកវៀតណាមជាដើម ចំណែកការងារសម្ងាត់ធំ គេមិនឲ្យយើងដឹងនោះទេ គឺយើងដឹងត្រឹមតែការងារស្រាលៗ ដែលយើងអនុវត្តរាល់ថ្ងៃតែប៉ុណ្ណោះ"]។ ឯកសារ D114/19 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ាក ឈឿន, ឆ.17 ["ពេលខ្លះការប្រជុំរួមមេបញ្ជាការវរសេនាតូច វរសេនាធំទាំងអស់ និងកងជើង ទឹក ជើងគោករបស់កងពល១៦៤ តែពេលខ្លះខាងកងជើងទឹកនិងកងជើងគោកប្រជុំផ្សេងពីគ្នា"]។ ឯកសារ D114/132 កំណត់ហេតុនៃការស្តាប់ចម្លើយ ម៉ៅ រ៉ាន់, ឆ.117, ឆ.188, ឆ.190 - 191 ["ខ្ញុំធ្លាប់ចូលរួម គឺមានតាមក្រុម តាមពួករបស់យើង។ ការប្រជុំបែបនេះ ទាំងមេក៏ចូលរួម យុទ្ធជនក៏ចូលរួមធ្វើដែរ។ [...] ឆ.សារឿន ហៅតែមេៗ ទៅចូលរួមប្រជុំ។ ចំណែកប្រជុំជាមួយយុទ្ធជន ច្រើនតែ សេង និង ហាន។ [...] ឆ.190៖ វាអត់ទៀងទាត់ទេ ជួនកាល១ខែ ២ខែ ជួនកាល៥ខែម្តង [...] ឆ.191៖ មិនមានអ្វីក្រៅអំពីការការពារទូក ធ្វើម៉េចកុំឲ្យវាបាក់ខូចប៉ុណ្ណោះ"]។ ឯកសារ D54/44 កំណត់ហេតុនៃការស្តាប់ចម្លើយ លុន សេង, ឆ.2 ["មានការអប់រំពិសេសផងដែរ ដែលគេហៅថា ការទិតៀន និងស្វ័យទិតៀន។ កាទិតៀន និងស្វ័យទិតៀននេះ ធ្វើឡើងនៅក្នុងពេលប្រជុំជីវភាព ៣ ថ្ងៃម្តង។ ប៉ុន្តែនៅក្នុងវគ្គរៀនសូត្រ គេនឹងប្រើវិធីសាស្ត្រមួយហៅថា ធ្វើជីវទស្សន៍នៅក្នុងពេលនោះ គេយកអ្នកដែលធ្វើខុសម្នាក់ចេញមក ដើម្បីឲ្យអ្នកនៅក្នុងអង្គប្រជុំធ្វើការសួរ និងតិទៀនជាសាធារណៈ"]។

946 ឯកសារ D59/1/4.27 កំណត់ហេតុនៃការសម្ភាសន៍សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ហេង វៀច, EN 00983674, KH 00930880 ["ដឹងគេប្រជុំជីវភាពផ្ទាល់ ឥឡូវយើងបង្កបង្កើន មាន់ ទា ចេះចិញ្ចឹមបានផលល្អ មិនបានផលល្អ គេផ្សាយចេះវិញ ហើយធ្វើស្រូវ ដក វាចេះល្អ ប៉ុណ្ណោះនាក់ត្រូវនង្គ័លប៉ុន្មាន ត្រូវភ្ជួរអី [...] គេផ្សាយតែអីចឹងខាងសាលានយោបាយបានគេនិយាយចោះ"]។

947 ឯកសារ D54/44 កំណត់ហេតុនៃការស្តាប់ចម្លើយ លុន សេង, ឆ.26 - 27 ["ការប្រកាសនោះ ត្រូវធ្វើនៅក្នុងកិច្ចប្រជុំពិសេសមួយ ដែលថ្នាក់ដឹកនាំផ្នែកវរសេនាតូច និងវរសេនាធំត្រូវបានគេជ្រើសរើសឲ្យមកចូលរួម។ ការប្រកាសអំពោះយោធាភូមិភាគបូព៌ានោះ គឺមិនបានធ្វើជាសាធារណៈនោះទេ។ ខ្ញុំនៅចាំថា ការប្រកាសអំពីយោធាភូមិភាគបូព៌ានោះ គឺមិនត្រូវបានចាត់ទុកថាជាខ្មាំងនោះទេ។ គេថា យោធាទាំងនេះ ត្រូវតែបញ្ជូនទៅធ្វើការអប់រំ ដើម្បីឲ្យដឹងថា តើគេអាចទទួលការអប់រំបាន ឬមិនបាន។ បើសិនជាអ្នកណាទទួលការអប់រំបានល្អ អ្នកនោះនឹងត្រូវបញ្ជូនឲ្យទៅ [...] សៈ តើអ្នកណាជាអ្នកប្រកាសនៅពេលអប់រំ? ឆ.27៖ ប្រធានកងពល មាស មុត"]។

291. ដោយហេតុថា កម្មាភិបាលកងពល ១៦៤ មិនអាចចូលរួមប្រជុំបានទាំងអស់គ្នា ក្នុងពេលតែមួយជាធម្មតា សមាជិកជាន់ខ្ពស់នៃអង្គភាពនីមួយៗ ដែលចូលរួមប្រជុំជាមួយ **មាស មុត** និង/ឬអ្នកផ្សេងទៀត បានផ្សព្វផ្សាយបន្តដល់អ្នកក្រោមបង្គាប់នូវព័ត៌មានដែលពួកគេទទួលបាន ពេលត្រឡប់ទៅអង្គភាពវិញ។ ប៉ាង រ៉េត បានពន្យល់ថា គាត់ "មិនបានចូលរួមប្រជុំជាមួយ មាស មុត ផ្ទាល់ទេ តែមានប្រធានវរសេនាតូចទៅចូលរួមប្រជុំជាមួយ មាស មុត ផ្ទាល់ ហើយយកមកប្រជុំបន្តក្នុងអង្គភាពរបស់ [គាត់]"[948]។ ដូច្នេះ ព័ត៌មានត្រូវបានផ្សព្វផ្សាយបន្តតាមតួនាទី៖ "តំណាងអង្គភាពយកព្រឹត្តិការណ៍មកផ្សាយមិនឲ្យខុសពីផែនការដើម ដែលទទួលមកពីកងពលទេ"[949]។ ដូចគ្នានេះដែរ ជាធម្មតា មេដឹកនាំអង្គភាពប្រមូលព័ត៌មានពីអ្នកនៅក្រោមបង្គាប់ មុននឹងទៅចូលរួមប្រជុំ[950]។

292. កិច្ចប្រជុំមិនត្រឹមតែត្រូវបានរៀបចំនៅតាមកន្លែងនានាក្នុងក្រុងកំពង់សោម និងលើកោះប៉ុណ្ណោះទេ ថែមទាំងត្រូវបានរៀបចំនៅតាមទីតាំងផ្សេងទៀតក្នុងតំបន់កំពង់សោម រួមទាំងស្ទឹងហាវ[951] និងរាមផងដែរ[952]។ ពេលខ្លះ មេដឹកនាំកងវរសេនាតូច និងកងវរសេនាធំ ត្រូវគេហៅទៅចូលរួមប្រជុំ

---

948 ឯកសារ D114/287 កំណត់ហេតុនៃការស្តាប់ចម្លើយ ប៉ាង រ៉េត (ហៀង រ៉េត), ឆ.34 ["ខ្ញុំមិនបានចូលរួមប្រជុំជាមួយ មាស មុត ផ្ទាល់ទេ តែមានប្រធានវរសេនាតូច ទៅចូលរួមប្រជុំ ជាមួយ មាស មុត ផ្ទាល់ ហើយយកមកប្រជុំផ្សាយបន្តក្នុងអង្គភាព ខ្ញុំ"]។

949 ឯកសារ D114/287 កំណត់ហេតុនៃការស្តាប់ចម្លើយ ប៉ាង រ៉េត (ហៀង រ៉េត), ឆ.37 ["ជាការផ្សព្វផ្សាយវិធានការហើយៗ ចាត់ការកម្លាំងបន្ថែមសម្រាប់អន្តរាគមន៍។ គឺថាតំណាងអង្គភាព យកព្រឹត្តិការណ៍មកផ្សាយមិនឲ្យខុសពីផែនការដែលទទួលមកពីកងពលទេ"]។

950 ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់សហព្រះរាជអាជ្ញ សៀង, EN 00217565 ["ប្រធានកងពល ឬ កងវរសេនាធំ បានហៅប្រធានអង្គភាព ប្រជុំ ហើយនិងមានការពិភាក្សាមុននឹងអនុញ្ញាតឲ្យនរណាម្នាក់ចូលរួមកិច្ចប្រជុំ"]។

951 ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.១ ["ស៖ ម្សិលមិញយើងបាននិយាយអំពីសេចក្តីប្រកាសដែលធ្វើឡើងដោយ មាស មុត ក្នុងកម្មវិធីរំឭកជ័យជម្នះធ្វើឡើងនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៧។ [...] ឆ.១៖ មាស មុត ក៏បានថ្លែងដែរថា នៅថ្ងៃខាងមុខនឹងធ្វើការស្រាវជ្រាវរកអ្នកដែលពាក់ព័ន្ធនឹងជនក្បត់ទាំងនេះ។"]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.២៥, ឆ.២៨ ["ស៖ លោកបាននិយាយថា តាមុត បានបើកប្រជុំនៅពាក់កណ្តាលឆ្នាំ ១៩៧៧ តើកិច្ចប្រជុំធ្វើនៅកន្លែងណា? ឆ.២៥៖ បាទ ការប្រជុំនេះ គឺធ្វើនៅអង្គភាពយោធានៅស្ទឹងហាវ [...] ឆ.២៨៖ គាត់បាននិយាយអំពីអ្នកដែលក្បត់បក្ស ហើយចំពោះអ្នកដែលត្រូវចោទថាក្បត់នោះត្រូវប្រមូលយកទៅទុកមួយកន្លែង។"]។

952 ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.១ ["នៅពេលនោះ គេបានដកយោធាកង ៣៨៦ ទាំងអស់យកទៅដាក់នៅកងផលិត។ បន្ទាប់ពីគេដកអាវុធពីពួកយើងអស់ ពួកគេមិនអនុញ្ញាតឲ្យយើងទុកកាំបិតទេ យើងគឺអនុញ្ញាត

ឬវគ្គរៀនសូត្រ ហើយត្រូវគេចាប់ខ្លួននៅពេលនោះតែម្តង[953]។ ក្នុងពេលប្រជុំ ពេលខ្លះ **មាស មុត** និងអ្នកផ្សេងទៀត អាចប្រកាសចាប់ខ្លួនជនក្បត់[954]។

---

ឲ្យកាន់តែចប។ បន្ទាប់មក មាស មុត បានមកធ្វើមីទ្ទីងជាមួយពួកយើងនៅភូមិគគីរ នៅជិតព្រលានយន្តហោះកងកេង ដោយមានអតីតយោធាចូលរួមប្រហែលរាប់ពាន់នាក់ ដោយមានកងវរសេនាតូច ៣៨៦ និងកងផ្សេងទៀត។ នៅក្នុងអង្គប្រជុំ មាស មុត អានចម្លើយសារភាពរបស់ពួកគាត់ គាត់បានរៀបរាប់ឈ្មោះកម្មាភិបាលក្បត់ចាប់ពីថ្នាក់មជ្ឈិម រហូតដល់ថ្នាក់មូលដ្ឋាន"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.៥៦, ឆ.៦០-៦១, ឆ.៦៣ ["សៈ លោកនិយាយថា ពេលដែលលោកទៅដល់ដីគោក គេប្រជុំម្តងទៀត។ តើការប្រជុំនោះ នៅទីណា ហើយពេលណា? ឆៈ គេបញ្ជូនមកហ្នឹង ឈប់នៅព្រលានយន្តហោះ កងកេង ហើយគេប្រជុំនៅពេលព្រឹកហ្នឹង។ ហើយ មាស មុត ជាប្រធានអង្គប្រជុំ។ [...] ឆ. ៦០៖ ប្រជុំពីបញ្ហា មេក្បត់ គឺអនុប្រធានមេបញ្ជាការកងពល ១៦៤ នង ឆាន ជាអ្នកក្បត់ ហើយ មាស មុត អានចម្លើយសារភាពរបស់ នង ឆាន ហ្នឹង។ [...] ឆ.៦១៖ គាត់អត់និយាយអ្វីទៀតទេ គាត់បញ្ជូនពួកខ្ញុំទៅកងផលិតពេលប្រជុំចប់។ [...] ឆ.៦៣៖ ចាំបានត្រង់គាត់និយាយពីចម្លើយសារភាពរបស់ពួកក្បត់ និយាយពី នង ឆាន និងមេៗរបស់ខ្ញុំទាំងពីរនាក់ហ្នឹង។ មេខ្ញុំគាត់មិនបានសារភាពទេ។ មាស មុត គ្រាន់តែនិយាយថា ពួគគាត់ក្បត់"]។

953 ឯកសារ D114/208 ឡុង ផាន់ស៊ី ឆ.៣១ ["វរសេនាធំហៅមកប្រជុំដើម្បីត្រៀមចាប់ តែត្រង់បញ្ហាមកពីណាខ្ញុំមិនបានដឹងទេ។ អ្នកដែលមកចាប់ខ្ញុំគឺ វរសេនាធំ ឈ្មោះ មឿន និង ឡូន។ អ្នកទាំងពីរនៅកន្លែងប្រជុំហ្នឹង កាលនោះ ម៉ោងប្រហែលប្រាំបីទៅ ប្រាំបួនយប់ទើបប្រជុំ ហើយចាប់ខ្ញុំតែម្តង។"]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ. ១៤ ["នៅពេលដែលគេចង់ចាប់កងវរសេនាតូច និងកងវរសេនាធំ គេប្រើយោធាកងពិសេសទៅហៅពួកគេថា បងកងពលឲ្យមកប្រជុំ"]។ ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ សៀង EN ERN 00217565 ["ប្រធានកងពល ឬកងវរសេនាធំបានហៅប្រធានកងប្រជុំ ហើយនឹងមានការពិភាក្សាមុន ចំពោះអ្នកដែលបានចូលរួមការប្រជុំនោះ។ គាត់បានឮថា ប្រជាជនដែលមកពីកងមួយចំនួន ត្រូវហៅទៅប្រជុំ ហើយពួកគេមិនដែលបានត្រឡប់មកវិញទេ ទោះបីមិនបានកើតឡើងនៅក្នុងកងរបស់ខ្លួនក្តី"]។ សូមមើលផងដែរ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.១៣ ["អ្នកដែលត្រូវចាប់ខ្លួននៅពេលនោះ មិនត្រូវបានប្រាប់ដំណឹងជាមុនទេ។ អ្នកដែលហៅទៅនោះ គឺគេហៅទៅរៀនសូត្រ ហើយបាត់ខ្លួនតែម្តង។ លិខិតដែលអញ្ជើញឲ្យទៅរៀនសូត្រ គឺផ្ញើមកពីកងពល។ បន្ទាប់ពីការបាត់ខ្លួនថ្នាក់ដឹកនាំ គេបានប្រកាសប្រាប់នៅក្នុងចំណោម យោធាឲ្យធ្វើការប្រយ័ត្នប្រយ៉ែង"]។

954 ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.៥, ឆ.៧, ឆ.១៤ ["គេចាប់ក្នុងឆ្នាំ ១៩៧៧ ឬដើមឆ្នាំ ១៩៧៨។ ខ្ញុំមិនបានឃើញការចាប់នោះ ដោយផ្ទាល់ភ្នែកទេ ប៉ុន្តែ គេប្រជុំតាមកងប្រាប់អំពីការចាប់ចងនេះ។ [...] ស ៖ តើលោកដឹងឬទេថា តើ មាស មុត ជាអ្នកចេញប្រកាសព័ត៌មាននេះ? ឆ.៧៖ បាទ [...] ឆ.១៤៖ យើងដឹងតាមរយៈការប្រជុំតាមកង បន្ទាប់ពីការចាប់ចង។ គេធ្វើការប្រកាសនៅក្នុងអង្គប្រជុំថា ពួកទាំងនោះ ត្រូវបានចាប់។ ខ្ញុំចង់ជម្រាបថា មិនមែនមានតែខ្ញុំម្នាក់ទេ ដែលបានដឹងអំពីការចាប់ចងនេះ"]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.១ ["ព្រឹត្តិការណ៍ដែលកើតមាននៅនឹងមុខវត្តឥន្ទញាណគឺកើតឡើងនៅចុងឆ្នាំ ១៩៧៦។ រឿងនេះ វា

## ឧបករណ៍រ៉ាដា

293. កងពល ១៦៤ ដំឡើងឧបករណ៍រ៉ាដា នៅលើភ្នំបូកគោ និងកោះតាង ហើយសម្របសម្រួលជាមួយស្ថានីយរ៉ាដារបស់កងពលលេខ ១ នៅខេត្តកោះកុង[955]។ ឧបករណ៍រ៉ាដានៅទីតាំងទាំងនេះត្រូវបាន

---

កើតឡើងជិតចូលឆ្នាំ ១៩៧៧ ហើយ [...] បន្ទាប់មក មាស មុត បានមកធ្វើមីទ្ទីងជាមួយពួកយើងនៅភូមិគគីរ នៅជិតព្រលានយន្តហោះកងកេង ដោយមានអតីតយោធាចូលរួមប្រហែលរាប់ពាន់នាក់ ដោយមានកងវរៈសេនាតូច ៣៨៦ និងកងផ្សេងៗទៀត។ នៅក្នុងអង្គប្រជុំ មាស មុត អាចចម្លើយសារភាពរបស់ពួកគាត់ គាត់បានរៀបរាប់ឈ្មោះកម្មាភិបាលក្បត់ចាប់ពីថ្នាក់មជ្ឈិម រហូតដល់ថ្នាក់មូលដ្ឋាន។ ខ្ញុំនៅចាំថា គាត់ហៅឈ្មោះ អាយ៉ា, អាធុច, អាញ៉ឹក, អាយ៉ា ឌឹម និង ឆាន"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.៦០ ["ខ្ញុំមិនដឹងថា មានប៉ុន្មាននាក់ទេ តែ មាស មុត ប្រជុំពីបញ្ហាមេក្បត់ គឺអនុមេបញ្ជាការកងពល ១៦៤ នង ឆាន ជាអ្នកក្បត់ ហើយ មាស មុត អានចម្លើយសារភាពរបស់ នង ឆាន ហ្នឹង"]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.៥ ["ពួកយើងពុំមានព្រួយបារម្ភទេ មុនការប្រកាសអំពីការចាប់ខ្លួន ឌឹម និង ឆាន ដោយសារតែពួកយើងជាយោធាដែលមានសិទ្ធិពេញលេញ។ ពួកយើងមានកាំភ្លើងប្រើ ពួកយើងអាចទៅណាមកណាបាន។ ប៉ុន្តែ ក្រោយពីការប្រកាសអំពីការចាប់ខ្លួន ឌឹម និង ឆាន និងការចាប់ខ្លួនមេវរសេនាតូច និងវរសេនាធំ (ដូចជា តាហម និងតាវ៉េត មកទៀត ពួកខ្ញុំជាច្រើននាក់កាន់តែភិតភ័យខ្លាំង)"]។

955 ឯកសារ D1.3.8.4 កំណត់ហេតុនៃការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00162488 ["បញ្ហារៀបចំរ៉ាដានៅបូកគោ៖ [...] មួយដាក់នៅវត្តលើភ្នំ និងមួយទៀតដាក់នៅសណ្ឋាគារ កាស៊ីណូ [...] គំរោងរ៉ាដានៅកោះកុង៖ គេឱ្យធ្វើផ្លូវសិន។ ត្រូវរៀបចំដាក់កោះតាងមុនបន្ទាប់ពីបូកគោ"]។ ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.២៤ ["អង្គភាពបូកគោ ជាអង្គភាពស្ថានីយ៍រ៉ាដា"]។ ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.៤១ ["ឆ៖ នៅពេលនោះ តើកងពល ១៦៤ មានរ៉ាដាចំនួនប៉ុន្មានគ្រឿង? ឆ.៤១៖ តាមខ្ញុំដឹងថាមានប្រើតែនៅភ្នំបូកគោ ដែលប្រើរាល់ថ្ងៃ ប៉ុន្តែក្រោយមក ខ្ញុំបានឮថាមានតម្លើងនៅកោះតាង និងកោះកុង"]។ ឯកសារ D54/113 កំណត់ហេតុស្តាប់ចម្លើយ លៀង បៀ ឆ.៤៥ ["ស៖ តើរ៉ាដានោះមានទីតាំងនៅកន្លែងណា? ឆ.៤៥៖ គេដាក់នៅភ្នំបូកគោ។"]។ ឯកសារ D59/1/1.14 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហ៊ីង អ៊ុច KH ERN 00926684 ["កន្លែងកោះតាង នៅពីលើកន្លែងខ្ញុំនៅហ្នឹងមានរ៉ាដាៗហ្នឹងនៅខាងគេផ្សេងទៀត កន្លែងខ្ញុំនៅខាងក្រោមអីចឹង ដូចចំណុចលើភ្នំហ្នឹង មានរ៉ាដាម៉ាគ្រឿង។"]។ ឯកសារ D4.1.758 សេចក្តីថ្លែងការណ៍អំពីឈ្លើយសឹកអាមេរិក និងជនដែលបាត់ខ្លួនក្នុងសង្គ្រាម KH ERN 01506014 ["កងវរសេនាធំនេះមានរ៉ាដា ២៖ រ៉ាដាមួយស្ថិតនៅលើភ្នំបូកគោ [...] និងរ៉ាដាមួយទៀតស្ថិតនៅលើភ្នំ ៤៤០ [...] នៅលើកោះតាង"]។ ឯកសារ D59/1/1.9a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ KH ERN 00926463 ["រ៉ាដានៅបូកគោ]។ ស៖ រ៉ាដានៅបូកគោ? ឆ៖ រ៉ាដាធំនៅបូកគោ។ [...] ក្រោយមក មានតម្លើងមួយទៀតនៅកោះតាងដែរ អាហ្នឹងធុនបន្ទាប់។ [...] ហើយបន្តមកទៀត គេត្រៀមតម្លើងនៅកោះកុង បើយើងអីចឹង"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង វ៉េត KH ERN 00926549 ["ស៖ បូកគោធំជាងគេ? ឆ៖ ធំជាងគេ មានទាងរ៉ាដាជើងទឹក និងរ៉ាដាជើងអាកាសទៀត"]។ ឯកសារ D22.1.2

ប្រតិបត្តិការដោយអង្គភាពជំនាញ[956]។ រ៉ាដាមួយនៅលើភ្នំបូកគោស្ថិតនៅក្រោមការគ្រប់គ្រងរបស់ អ៊ុក ណាង[957]។

294. ឧបករណ៍រ៉ាដាទាំងអស់ត្រូវបានដំឡើង សម្រាប់កំណត់អត្តសញ្ញាណនាវាបរទេសដែលបើកនៅក្នុង ឬជុំវិញដែនទឹកកម្ពុជា និងយន្តហោះដែលហោះហើរនៅពីលើ ឬជុំវិញលំហអាកាសកម្ពុជា[958]។

---

Henri Locard បណ្ដាញគុករបស់កម្ពុជាប្រជាធិបតេយ្យនៅក្នុងភូមិភាគបស្ចិម KH ERN 00744426 ["កប៉ាល់ចិនបាននាំចូលឡានធំៗ ត្រាក់ទ័រ សម្រាប់ធ្វើស្រែចម្ការ គ្រឿងសព្វាវុធ (រថក្រោះ រ៉ាដា កាំភ្លើងធំប្រភេទ ដេ.សេ.អា នាវាបំពាក់ដោយគ្រាប់បែកសម្រាប់បាញ់នាវាមុជទឹក)"]។ ឯកសារ D114/286 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាង រ៉េត ឆ. ១៦ ["ស៖ មានកងមួយដែលគេដាក់ថា កងភ្នំបូកគោ តើលោកអាចប្រាប់បានទេថា ជាកងអ្វី? ឆ៖ កងហ្នឹងគ្រប់គ្រងប្រព័ន្ធរ៉ាដាសមុទ្រ"]។ ឯកសារ D54/34 កំណត់ហេតុស្ដាប់ចម្លើយ អ៊ឹង ឆុន ឆ.៦-៧ ["ប្រព័ន្ធរ៉ាដា ត្រូវបានគេដាក់នៅលើកោះកុង ពីព្រោះគេអាចមើលឃើញលំហសមុទ្ទ។ [....៧៖ ស្ថានីយ៍រ៉ាដា និងកែវយិត គឺស្ថិតក្រោមកងពលទី១"]។

956 ឯកសារ D54/47 កំណត់ហេតុស្ដាប់ចម្លើយ អែម សុន ឆ.២៤ ["អង្គភាពបូកគោ ជាអង្គភាពស្ថានីយ៍រ៉ាដា"]។ ឯកសារ D59/1/1.14 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហ៊ីង អ៊ុច KH ERN 00926684 ["កន្លែងកោះតាង នៅពីលើកន្លែងខ្ញុំនៅហ្នឹងមានរ៉ាដាៗហ្នឹងនៅខាងគេផ្សេងទៀត កន្លែងខ្ញុំនៅខាងក្រោមអ៊ីចឹង ដូចចំណុចលើភ្នំហ្នឹង មានរ៉ាដាម៉ាគ្រឿង។"]។ ឯកសារ D54/10.2 របាយការណ៍ពី មឿន ជូនបង មុត (មាស មុត) ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ១៩៧៧ KH ERN 00936706 ["ខាងរ៉ាដា ងាយស្រួលទាក់ទងជាមួយចិន ខាងនេសាទ ឲ្យជួយធ្វើការ"]។

957 ឯកសារ D54/99.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ KH ERN 00990772 ["ស៖ ចុះរ៉ាដានៅបូកគោពីណាគេ អ្នកកាន់? ឆ៖ ឈ្មោះ លោក អ៊ុក ណម កាន់កាប់។"]។ ឯកសារ D59/1/1.14 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហ៊ីង អ៊ុច KH ERN 00926684 ["ខាងបូកគោ ខាងៗពូអ៊ុក ហ្នឹងហ៎? ឆ. បាទ អាច"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង រ៉េត KH ERN 00926549 ["ស៖ អ៊ុក ណាង? ឆ៖ បាទ ហ្នឹងហើយ មេរ៉ាដាបូកគោនោះ"]។ សូមមើលផងដែរ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល KH ERN 00926617 ["ដែលខ្ញុំឃើញរស់នៅ២នាក់ដែរខាងរ៉ាដាហ្នឹង។ មាន អ៊ុក ណាង ១ហ្នឹងគេខាងរ៉ាដា បូកគោ ប៉ុនសព្វថ្ងៃគេសក្ដិ៥ វរសេនីយ៍ឯក ហើយមួយទៀត ឈ្មោះ ផុន នៅអូរតាទាកនោះ ហ្នឹងគេរ៉ាដាបូកគោដែរ"]។

958 ឯកសារ D114/95 កំណត់ហេតុស្ដាប់ចម្លើយ យ៉ឹម ស្រឿង ឆ.៩២ ["រ៉ាដា គឺសម្រាប់ចាប់វត្ថុណាដែលអណ្តែតលើទឹក ឬក៏ចាប់អ្វីផ្សេងទៀត"]។ សូមមើលផងដែរ ឯកសារ D1.3.27.1 កំណត់ហេតុការប្រជុំគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ KH ERN 00019117 ["រ៉ាដាសម្រាប់៖ - តាមដានសភាពការណ៍ - រាយការណ៍"]។ ឯកសារ D1.3.34.13 ទូរលេខ ១៦ ពី ឌឹម ជូនបងមុត (មាស មុត) ចុះថ្ងៃទី ០៦ ខែតុលា ឆ្នាំ ១៩៧៦ [ចម្លងជូនបង នួន, បងខៀវ, បងមុត, មន្ទីរ៖ "បញ្ហារ៉ាដា យើងដំឡើងរួចមួយគ្រឿងហើយ ការបើកសាកល្បងមើលឃើញកប៉ាល់រត់តាមផ្លូវអន្តរជាតិ ក្រៅកោះប៉ូឡូវ៉ៃ។ ចំពោះកប៉ាល់ខាងកោះសេះ តាមកប៉ាល់ឈើ។ [...] នៅឯកោះកុង គឺជាកប៉ាល់យោធាពិតប្រាកដ"]។ ឯកសារ D126.1.1 របាយការណ៍ពីរ៉ាដាបូកគោ ជូនបង ៨៩ (បងសុន

នៅពេលនាវាបរទេសណាមួយត្រូវបានរកឃើញ ឧបករណ៍រ៉ាដាអាចទាក់ទងជាមួយអង្គភាពរបស់កងពល ១៦៤ ដើម្បីស្កាត់ចាប់នាវានោះ[959]។ *(សូមមើលផ្នែកទី ៨.ខ. ឧក្រិដ្ឋកម្មប្រព្រឹត្តប្រឆាំងនឹង*

---

សេន) ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៧៧។ ឯកសារ D1.3.34.21 របាយការណ៍ជូនបង ៨៩ (បងសុន សេន) ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៧៧។ ឯកសារ D54/63.1 ទូរលេខ ០៩ ពីមុត (មាស មុត) ជូនបង ៨៩ (បងសុន សេន) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៧៧ KH ERN 00975801 ["ពួកវានេះរកស្មើយប់មិនបើកភ្លើង យើងមើលឃើញតែតាមរ៉ាដា។"]។ ឯកសារ D54/51.1 ទូរលេខ ០៩ ពី មុត (មាស មុត) ជូនបង ៨៩ (បងសុន សេន) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៧៧ KH ERN 00970626 ["ពួកវានេះរកស្មើយប់មិនបើកភ្លើង យើងមើលឃើញតែតាមរ៉ាដា។"]។ ឯកសារ D1.3.12.18 ទូរលេខ ០៩ ពីមុត (មាស មុត) ជូនបង ៨៩ (បងសុន សេន) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៧៧ KH ERN 00162487 ["ពួកវានេះរកស្មើយប់មិនបើកភ្លើង យើងមើលឃើញតែតាមរ៉ាដា។"]។ ឯកសារ D1.3.27.1 កំណត់ហេតុការប្រជុំគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ KH ERN 00019125 ["ខាងរ៉ាដា សួរគាត់ថារួមផ្សំ ជើងទឹក និងជើងអាកាសបានទេ? អង្គការស្នើឲ្យរួមផ្សំ។ យើងខ្ញុំខ្វះមនុស្សខ្វះបច្ចេកទេស"]។

959 ឯកសារ D54/113 កំណត់ហេតុស្តាប់ចម្លើយ លៀង ប៉ៀ ឆ.៤៤-៤៧ ["ឆ៖ អម្បាញ់មិញលោកនិយាយថា នៅពេលដែលមានកប៉ាល់ខ្មាំងចូលមកដែនសមុទ្រខ្មែរ គេបញ្ជូនកប៉ាល់ការពារចេញទៅ។ តើកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យដឹងថា កប៉ាល់ខ្មាំងនោះ ចូលមកក្នុងដែនទឹករបស់យើងតាមរបៀបណា? ឆ.៤៤៖ គឺដឹងតាមរយៈរ៉ាដា។ ស៖ តើរ៉ាដានោះ មានទីតាំងនៅកន្លែងណា? ឆ.៤៥៖ គេដាក់នៅភ្នំបូកគោ។ ស៖ តើគេបញ្ជូនព័ត៌មានមកកប៉ាល់លោកតាមរយៈអ្វី? ឆ.៤៦៖ គេផ្តល់ព័ត៌មានមកមេបញ្ជាការនៅកប៉ាល់នៅកំពង់សោម។ ស៖ តើកប៉ាល់របស់លោកទទួលព័ត៌មានមកពីថ្នាក់លើហ្នឹងតាមរយៈអ្នកណា ពីកងវរៈសេនាធំ ឬពីរ៉ាដាដោយផ្ទាល់? ឆ.៤៧៖ ទទួលពីកងវរៈសេនាធំ"]។ ឯកសារ D114/19 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.២១ ["នៅក្នុងផ្នែកការពាររបស់កងពល ក៏មានរ៉ាដាដែលដាក់នៅលើភ្នំបូកគោផងដែរ។ ពេលខ្លះ រ៉ាដា នោះបានចាប់បានកាណូតដែលចូលមកក្នុងដែនទឹកយើងមុន រ៉ាដានោះ គឺជារ៉ាដារបស់កងពល ១៦៤។ នៅក្នុងសភាពការណ៍ជាក់ស្តែង ពេលដែលរ៉ាដាលើភ្នំបូកគោចាប់បានទូកនេសាទ ទោះតូចក្តីធំក្តីដែលបានចូលមកក្នុងដែនទឹកយើង គេបានប្រាប់មកខ្ញុំនៅលើកោះដោយផ្ទាល់ អំពីការចូលមកនៃទូកទាំងនេះ"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង រ៉េត KH ERN 00926549 ["ស៖ អ៊ីចឹង រ៉ាដា នៅបូកគោ ហ្នឹង ពេលឃើញមានកាណូតកប៉ាល់អីហ្នឹង គេធ្វើយ៉ាងណាទៅ? ឆ៖ គេរាយការណ៍មកខាងកពល ហើយកងពលមានបញ្ជាទៅឲ្យកប៉ាល់ណាទៅស៊ើបអង្កេតមើលទៅតាមដានមើលទៅ។ ស៖ អ៊ីចឹងកប៉ាល់ដែលច្រើនតែស៊ើបអង្កេតតាមដានហ្នឹងជាកប៉ាល់មួយណាទៅ? ឆ៖ កាលហ្នឹង ច្រើនមានតែកប៉ាល់របស់យួន និងកប៉ាល់របស់ថៃដែលជាកប៉ាល់អូសត្រី"]។ សូមមើលផងដែរ ឯកសារ D54/72 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.៣៣-៣៤ ["ខ្ញុំមិនចាំថាមានខ្សែទូរសព្ទទាក់ទងពីកំពង់សោមទៅកំពតទេ តែមានខ្សែទូរសព្ទទាក់ទងរវាងកំពង់សោម ទៅបូកគោ។ ស៖ ហេតុអ្វីបានជាមានខ្សែទូរសព្ទទាក់ទងរវាងកំពង់សោម និងបូកគោ? ឆ៖ មានរ៉ាដានៅលើភ្នំបូកគោ។ ពេលខ្លះកងវរៈចង់ទូរសព្ទទាក់ទងគ្នានៅលើភ្នំបូកគោ ខ្ញុំក៏ភ្ជាប់ខ្សែទូរសព្ទនោះទៅឲ្យគេ"]។ ឯកសារ D54/34 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង អុន ឆ.១២ ["នៅពេលកងពលទី១ បានរាយការណ៍ទៅឲ្យមន្ទីរសារទូរលេខ របស់កង

*អ្នកដែលកងនាវាកម្ពុជាប្រជាធិបតេយ្យចាប់បាន នៅក្នុងដែនទឹក និងលើកោះ ដែលកម្ពុជាប្រជាធិបតេយ្យអះអាងថាជាកម្មសិទ្ធិរបស់ខ្លួន)*។

## ៣. ទំនាក់ទំនងរវាងកងពល ១៦៤ និងមជ្ឈិម

295. កងពល ១៦៤ គឺជាកងពលមួយស្ថិតនៅក្រោមការគ្រប់គ្រងរបស់មជ្ឈិម[960]។ សេនាធិការជាអ្នកបញ្ជារួមទៅលើកងពលមជ្ឈិម និងចាត់ចែងកិច្ចការយោធា រួមបញ្ចូលទាំងការផ្គត់ផ្គង់ ភស្តុភារ អាវុធ បុគ្គលិក ទំនាក់ទំនង និងព័ត៌មាន[961]។ ក្នុងឋានៈជាមេបញ្ជាការកងពល ១៦៤ **មាស មុត**

---

នាវានៅក្នុងកោះកុងតាមរយៈវិទ្យុទាក់ទង។ អ្នកកាន់សារទូរលេខ រាយការណ៍បន្តទៅឱ្យ តាមុត ហើយ តាមុត ជាអ្នកចេញបញ្ជា។ ចំពោះសំណួរដែលថា កងពលទី១ ត្រូវរាយការណ៍ទៅឱ្យមន្ទីរសារទូរលេខរបស់កងពល ១៦៤ ពីព្រោះកងពលទី១ មិនមាននាវាប្រយុទ្ធសម្រាប់ប្រឈមនឹងព្រឹត្តិការណ៍នោះទេ"]។

960 ឯកសារ D114/29.1.6 កំណត់ហេតុស្តាប់ចម្លើយ សៅ សារុន KH ERN 00345912 ["យោធាតំបន់មានសិទ្ធិរាយការណ៍មកតែគណៈតំបន់ ចំណែកឯកងពលមជ្ឈិមត្រូវរាយការណ៍ទៅមជ្ឈិមផ្ទាល់។ [...] កងពល គឺតំណាងឱ្យយោធា និងជាយោធាមជ្ឈិម"]។ ឯកសារ D4.1.855 កំណត់ហេតុស្តាប់ចម្លើយ ឡុញ ដុស KH ERN 00357492 ["ទ័ពមជ្ឈិមគ្រប់កងពល ត្រូវរាយការណ៍មកសេនាធិការទាំងអស់។ ខាងវិទ្យុទាក់ទងនៅសេនាធិការរបស់ ខ្ញុំគឺទាក់ទងជាមួយគ្រប់កងពល មិនទាក់ទងត្រង់នឹងទ័ពតំបន់ ទ័ពស្រុកទេ"]។ ឯកសារ D114/29.1.6 កំណត់ហេតុស្តាប់ចម្លើយ សៅ សារុន KH ERN 00345912 ["យោធាតំបន់មានសិទ្ធិរាយការណ៍មកតែគណៈតំបន់ ចំណែកឯកងពលមជ្ឈិមត្រូវរាយការណ៍ទៅមជ្ឈិមផ្ទាល់។ [...] កងពលគឺតំណាងឱ្យយោធា និងជាយោធាមជ្ឈិម"]។ ឯកសារ D4.1.855 កំណត់ហេតុស្តាប់ចម្លើយ ឡុញ ដុស KH ERN 00357492 ["ទ័ពមជ្ឈិមគ្រប់កងពល ត្រូវរាយការណ៍មកសេនាធិការទាំងអស់។ ខាងវិទ្យុទាក់ទងនៅសេនាធិការរបស់ ខ្ញុំគឺទាក់ទងជាមួយគ្រប់កងពល មិនទាក់ទងត្រង់នឹងទ័ពតំបន់ ទ័ពស្រុកទេ"]។

961 ឯកសារ D98/3.1.178 មាស វឿន ប្រតិចារឹកថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ ម៉ោង 09.28.32-09.30.05 ["តាមខ្ញុំយល់ដឹងថា អគ្គសេនាធិការបញ្ជាលើគ្រប់កងពលទាំងអស់នៅក្នុងសមរភូមិ"]។ ឯកសារ D4.1.855 កំណត់ហេតុស្តាប់ចម្លើយ ឡុញ ដុស KH ERN 00357492 ["ទ័ពមជ្ឈិមគ្រប់កងពល ត្រូវរាយការណ៍មកសេនាធិការទាំងអស់"]។ ឯកសារ D4.1.520 កំណត់ហេតុស្តាប់ចម្លើយ កែ ពេជ្រវណ្ណៈ KH ERN 00340566 ["ចំណែកខ្ញុំវិញ ជាអ្នកបើកឡាន ដឹកស្បៀង ពីភ្នំពេញ ទៅស្វាយរៀង សម្រាប់ផ្គត់ផ្គង់មន្ទីរសេនាធិការ ដែលមានទីតាំងនៅស្វាយរៀង។ ជាទូទៅ ២ថ្ងៃ ខ្ញុំបានដឹកស្បៀងទៅម្តង។ ពេលនោះ សុន សេន ប្រចាំការនៅស្វាយរៀង។ ក្រៅពីដឹកស្បៀង ខ្ញុំបានជួយលើកទូរសព្ទ ហើយខ្ញុំបានដឹងព័ត៌មានមួយចំនួនទាក់ទងនឹងរឿងការពារជាតិ"]។ ឯកសារ D1.3.9.4 របាយការណ៍ដោយគណៈកម្មការផ្គត់ផ្គង់សេនាធិការ ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ១៩៧៧។

រាយការណ៍ដោយផ្ទាល់ទៅកាន់សេនាធិការ[962]។ មេផ្ទាល់គាត់ គឺ សុន សេន ជានាយសេនាធិការ និងជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ[963]។

296. កងពល និងមជ្ឈិម ទាក់ទងគ្នាជាប្រចាំ ជារៀងរាល់ថ្ងៃ ជាច្រើនដង[964]។ សេនាធិការប្រើប្រាស់វិទ្យុទាក់ទងជាមួយកងពល[965]។ ទូរស័ព្ទ ឬទូរលេខ ត្រូវគេប្រើប្រាស់ ពេលរក្សាការសម្ងាត់[966]។ ឧទាហរណ៍ ទូរលេខត្រូវគេផ្ញើ ដើម្បីកោះហៅមេបញ្ជាការឲ្យចូលរួមប្រជុំសម្ងាត់[967]។

---

[962] ឯកសារ D54/54 កំណត់ហេតុស្តាប់ចម្លើយ មាស រឿន ឆ.៥ ["មាស មុត បានរាយការណ៍ទៅអគ្គសេនាធិការ សុន សេន ដោយផ្ទាល់"]។ ឯកសារ D54/110 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.៩ ["ស៖ អ្វីដែលលោកទើបតែនិយាយអម្បាញ់មិញនេះ មានន័យថា មាស មុត គាត់មានតួនាទីនៅនឹងសេនាធិការដែរមែនឬទេ? ឆ.៩៖ បាទ ហើយវាមិនមែនមានតែសម្រាប់កងពល ១៦៤ មួយទេ កងពលណាក៏ដោយដែលជារបស់មជ្ឈិម មេបញ្ជាការកងពលទាំងនោះគឺជាសមាជិកគណៈបញ្ជាការរបស់សេនាធិការ។ ពេលណាដែលកងពលក្លាយទៅជាកងពលរបស់មជ្ឈិម មេបញ្ជាការរបស់កងពលនោះ ក្លាយជាសមាជិកគណៈកម្មាធិការសេនាធិការ"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.៩ ["មាស មុត គឺជាមេបញ្ជាការកងពលលេខ ៣ ហើយគាត់គឺជាអនុរបស់ សុន សេន ដែលនៅសេនាធិការរបស់កងទ័ពជាតិ"]។ ឯកសារ D12 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច KH ERN 00680803 ["នៅក្នុងសមាជិកអចិន្ត្រៃយ៍នៃអគ្គសេនាធិការ មានមនុស្សបីនាក់សំខាន់ ដំបូងគេគឺ ទី១ សុន សេន ហៅបង ៨៩ ជាលេខា ទី២ គឺ ម៉ែន សាន ហៅ យ៉ា ដែលជាអនុប្រធាន និងជាសមាជិកមជ្ឈិមពេញសិទ្ធិផងដែរ និងទី៣ គឺ សៀត ឆែ ហៅ ទុំ ហៅបង ៨១ ដែលជាសមាជិក និងជាសមាជិកមជ្ឈិមត្រៀមផងដែរ។ បន្ទាប់មកទៀតទើបមានសមាជិក គឺ មាស មុត ទទួលបន្ទុកកងទ័ពជើងទឹក ស៊ូ ម៉េត ទទួលបន្ទុកជើងអាកាស"]។ ឯកសារ D22.2.180 ចម្លើយមាស មុត មាស មុត៖ 'យើងស្ថិតនៅក្នុងទ្រុងដូចសព្វថ្ងៃ',ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១ EN ERN 00161880 ["ស៖ យោងរបាយការណ៍ លោកបានចូលរួមប្រជុំសេនាធិការជាច្រើន ជាមួយ(អតីតខ្មែរក្រហមដែលជារដ្ឋមន្ត្រីក្រសួងការពារជាតិ) សុន សេន ដែលគាត់បានលាតត្រដាងពីគោលការណ៍ចំពោះខ្មាំងនៃរបបនោះ។ ឆ៖ ពេលខ្ញុំមកការប្រជុំទាំងនោះ គឺពិភាក្សាតែរឿងធ្វើស្រែមួយមុខគត់"]។ ឯកសារ D1.3.13.13 កំណត់ហេតុនៃការសម្ភាសន៍ ក.ស.ព ជាមួយ ទូច សឿលី EN ERN 00217575 ["ទីស្នាក់ការកងទ័ពជើងទឹកបានទាក់ទងផ្ទាល់ជាមួយអគ្គសេនាធិការនៅភ្នំពេញ និងជាមួយភូមិភាគនិរតី ក្រោមតាម៉ុក"]។

[963] ឯកសារ D54/54 កំណត់ហេតុស្តាប់ចម្លើយ មាស រឿន ឆ.៥ ["មាស មុត បានរាយការណ៍ទៅអគ្គសេនាធិការ សុន សេន ដោយផ្ទាល់"]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន ឆ.១៤៥, ឆ.១៤៨, ឆ.១៥០, ឆ.១៥៤ ["ខ្ញុំគិតថា សេនាធិការនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ សុន សេន។ [...] ឆ.១៤៨៖ សេនាធិការមានច្រើនផ្នែកច្រើនក្រសួង ដូចជាផ្នែកវែទទួលខុសត្រូវខាងវែ ហើយក្រសួងសេដ្ឋកិច្ចទទួលភារកិច្ចខាងផ្គត់ផ្គង់អ្នកនៅជួរមុខ។ សេនាធិការធ្វើការងារជំនួសឲ្យមេៗ។ [...] ឆ.១៥០៖ គាត់ (សុន សេន) ជាអ្នកបញ្ជាទ័ពទាំងអស់។ [...] ឆ.១៥៤៖ សុន សេន ជាប្រធានរបស់ មាស មុត ហើយ សុន សេន ជាសមាជិកគណៈមជ្ឈិម"]។

964 ឯកសារ D4.1.845 កំណត់ហេតុស្តាប់ចម្លើយ ឡុញ ដុស ឆ.២២-២៣ ["សារទូរលេខទាំងអស់ដែលធ្វើការទំនាក់ទំនងគឺជាលេខសម្ងាត់ ហើយការទំនាក់ទំនងនោះមានពីរទៅបីដងក្នុងមួយថ្ងៃយ៉ាងតិច។ [...] លើកលែងតែករណីពិសេស ដែលយើងអាចបន្ថែមពេលវេលាមួយទៀត។ [...] ឆ.២៣៖ វាគឺជាការដែលយើងត្រូវតែធ្វើជាប្រចាំរាល់ថ្ងៃ ពីពីរទៅបីដងរាល់ថ្ងៃ"]។

965 ឯកសារ D4.1.855 កំណត់ហេតុស្តាប់ចម្លើយ ឡុញ ដុស KH ERN 00357492 ["ខាងវិទ្យុទាក់ទងនៅសេនាធិការរបស់ ខ្ញុំគឺទាក់ទងជាមួយគ្រប់កងពល មិនទាក់ទងត្រង់នឹងទ័ពតំបន់ ទ័ពស្រុកទេ"]។ សូមមើលផងដែរ ឯកសារ D98/3.1.177 មាស វឿន ប្រតិចារឹកថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១២ ម៉ោង ០៩.០៨.៣៨-០៩.០៩.៣៤ ["បណ្តាញទំនាក់ទំនងដែលប្រើប្រាស់ជាញឹកញាប់គឺ តាមរយៈវិទ្យុទាក់ទង និងតាមទូរលេខ។ ដើម្បីសម្រេចគោលបំណងនេះ សេនាធិការ ក៏ដូចជាកងពលនីមួយៗ មានអង្គភាពវិទ្យុទាក់ទង និងអង្គភាពទូរលេខ"]។

966 ឯកសារ D4.1.855 កំណត់ហេតុស្តាប់ចម្លើយ ឡុញ ដុស KH ERN 00357494 ["សារទូរលេខ ខ្ញុំក៏ធ្លាប់បកដែរ បញ្ជូនចេញ-ចូលទៅគ្រប់កងពល។ អ្នកបកប្រែសារទូរលេខនៅសេនាធិការមានខ្ញុំ និងឡុង"]។ ឯកសារ D4.1.1056 កំណត់ហេតុស្តាប់ចម្លើយ ជួន ធី ឆ.១៩ ["ខ្ញុំធ្លាប់ទទួលទូរលេខពាក់ព័ន្ធនឹងផែនការ និងសកម្មភាពទ័ពត្រឹមតែថ្នាក់កងពលទេ [...] ហើយមិនមានចម្លងជូនថ្នាក់ដឹកនាំណាមួយទេ ក្រៅតែពីយកមកឲ្យខ្ញុំផ្ទាល់។ ទូរលេខគឺនិយាយតែពីសកម្មភាពខ្មាំង"]។ ឯកសារ D4.1.848 កំណត់ហេតុស្តាប់ចម្លើយ ឈូក រិន ឆ.៧ ["តេឡេក្រាមនៅពេលនោះ គឺគេមិនវាយអក្សរទេ គេវាយលេខកូដសម្ងាត់ បន្ទាប់មកគេយកទៅបកប្រែ ទៅជាអក្សរជាក្រោយ ដើម្បីអាចមើលដឹងខ្លឹមសារបាន។ តេឡេក្រាម គឺជាការបញ្ជូនព័ត៌មានតាមសារពីសភាពការណ៍ផ្សេងៗ ដែលមនុស្សណាម្នាក់ទទួលបន្ទុកឲ្យទៅថ្នាក់លើ ប៉ុន្តែ តេឡេក្រាមយោធា គឺវាជាលេខកូដ។ ជាទូទៅ កងទ័ពខ្មែរក្រហមថ្នាក់មេបញ្ជាការកងពលធំ ទើបមានសិទ្ធិបញ្ជូនតេឡេក្រាមដែលតេឡេក្រាមនោះត្រូវបញ្ជូនទៅមជ្ឈិម"]។ ឯកសារ D4.1.846 កំណត់ហេតុស្តាប់ចម្លើយ អៀង ផាន ឆ.១១ ["វិធីទំនាក់ទំនងផ្នែកយោធា គឺតាមរយៈទូរលេខ វាយចេញតាមម៉ាស៊ីនហៅថា ១៥វ៉ាត់ ដែលវាយចេញជាលេខកូដសម្ងាត់ ហើយយកទៅបកប្រែចេញជាតួអក្សរ។ ម៉ាស៊ីននេះ អាចប្រើជាវិទ្យុទាក់ទងបានដែរ"]។ សូមមើលផងដែរ ឯកសារ D98/3.1.177 មាស វឿន ប្រតិចារឹកថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១២ ម៉ោង 09.08.38-09.09.34 ["បណ្តាញទំនាក់ទំនងដែលប្រើប្រាស់ជាញឹកញាប់គឺ តាមរយៈវិទ្យុទាក់ទង និងតាមទូរលេខ។ ដើម្បីសម្រេចគោលបំណងនេះ សេនាធិការ ក៏ដូចជាកងពលនីមួយៗ មានអង្គភាពវិទ្យុទាក់ទង និងអង្គភាពទូរលេខ"]។

967 ឯកសារ D4.1.855 កំណត់ហេតុស្តាប់ចម្លើយ ឡុញ ដុស KH ERN 00357492 ["ពេលសេនាធិការត្រូវហៅកងពលមកប្រជុំ គេត្រូវប្រើសារទូរលេខដើម្បីហៅមកប្រជុំនៅសេនាធិការ"]។ ឯកសារ D4.1.408 កំណត់ហេតុស្តាប់ចម្លើយ ឈូក រិន KH ERN 00194467 ["មេបញ្ជាការយោធាជាន់ខ្ពស់ រួមទាំងរូបខ្ញុំ បានទទួលបញ្ជាតាមទូរលេខ ឲ្យធ្វើដំណើរទៅភូមិភាគបូព៌ា ហើយយើងក៏បានទទួលបញ្ជាផ្ទាល់មាត់ដែរ នៅក្នុងការប្រជុំពិសេសមួយនៅទីក្រុងភ្នំពេញដោយមានមេបញ្ជាការចូលរួម"]។

297. **មាស មុត** បានចូលរួមក្នុងកិច្ចប្រជុំប្រចាំខែរបស់សេនាធិការ នៅទីក្រុងភ្នំពេញ ដើម្បីពិភាក្សាអំពីបញ្ហាយោធា[968]។ ឧទាហរណ៍ នៅថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៧៦ **មាស មុត** បានរាយការណ៍អំពីការពង្រាយកម្លាំងរបស់កងពល ១៦៤ នៅកំពង់សោម និងបានទទួលសេចក្ដីណែនាំឱ្យ "ពង្រឹង និងពង្រីកកម្លាំងមនុស្ស និងអាវុធ" នៅក្នុងកិច្ចប្រជុំមួយ ដែលចូលរួមដោយ សុន សេន, វន វ៉េត, សមមិត្ត ខឹម និងសមមិត្ត ង៉ែត[969]។ **មាស មុត** បានទទួលស្គាល់ថា គាត់បានចូលរួមប្រជុំជាមួយ

---

[968] ឯកសារ D54/37 កំណត់ហេតុស្ដាប់ចម្លើយ ស៊ឹម នី ឆ.៣០ ["សៈ តើលោកធ្លាប់ឮថា មាស មុត ធ្វើការអគ្គសេនាធិការមែនឬទេ? ឆ.៣០៖ បាទ ខ្ញុំឮ។ គាត់ត្រូវប្រជុំមួយខែម្ដងជាមួយសេនាធិការនៅភ្នំពេញ"]។ ឯកសារ D54/29 កំណត់ហេតុស្ដាប់ចម្លើយ លៀត ឡូន ឆ.៣ ["មាស មុត មិនស្នាក់នៅជាប្រចាំនៅកំពង់សោមទេ គាត់ធ្វើដំណើរទៅមកៗពីភ្នំពេញ ទៅកំពង់សោម។ គាត់ទៅភ្នំពេញ គាត់ទៅជួប សុន សេន នៅ [...] សេនាធិការ"]។ ឯកសារ D54/110 កំណត់ហេតុស្ដាប់ចម្លើយ លុន សេង ឆ.៨ ["ក្នុងនាមជាមេបញ្ជាការកងពល ជននោះ គឺជាសមាជិកម្នាក់នៅក្នុងគណៈកម្មាធិការរបស់សេនាធិការនៃកងទ័ព។ នៅពេលណាដែលសេនាធិការកងទ័ពត្រូវការរៀបចំគម្រោងការងារអ្វីមួយ សេនាធិការតែងតែ ពិភាក្សាយកយោបល់ពីមេបញ្ជាការកងពល"]។ សូមមើលផងដែរ ឯកសារ D1.3.27.22 កំណត់ហេតុអង្គប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំគណៈកងពលពេញអង្គ ចុះថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ [មុត បានកត់សម្គាល់ថា ជាអ្នកចូលរួម]។ ឯកសារ D1.3.27.20 កំណត់ហេតុអង្គប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខា និងវរសេនាធំឯករាជ្យ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH ERN 00052402-00052416 [មាស មុត បានកត់សម្គាល់ថាជាអ្នកចូលរួម]។ ឯកសារ D1.3.8.2 កំណត់ហេតុអង្គប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំគ្រប់គណៈកងពលទូលាយ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦ [មាស មុត បានកត់សម្គាល់ថា ជាអ្នកចូលរួម]។ ឯកសារ D1.3.8.3 កំណត់ហេតុអង្គប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃអង្គប្រជុំការងារយោធា នៅកំពង់សោម ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៧៦ [មាស មុត បានកត់សម្គាល់ថា ជាអ្នកចូលរួម]។ ឯកសារ D1.3.27.18 កំណត់ហេតុអង្គប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភាបស់កងពល និងវរសេនាធំ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ [មាស មុត បានកត់សម្គាល់ថា ជាអ្នកចូលរួម]។ ឯកសារ D114/27.1.5 កំណត់ហេតុអង្គប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ ហេតុនៃការប្រជុំលេខា និងភស្តុភាររបស់កងពល និងវរសេនាធំ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ [មាស មុត បានកត់សម្គាល់ថា ជាអ្នកចូលរួម]។ ឯកសារ D234/2.1.18 កំណត់ហេតុអង្គប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៧៦ [មាស មុត បានកត់សម្គាល់ថា ជាអ្នកចូលរួម]។ ឯកសារ D54/54 កំណត់ហេតុស្ដាប់ចម្លើយ មាស វឿន ឆ. ៤ ["មាស មុត ជាមេបញ្ជាការកងពលលេខ ១៦៤ ដែលជាកងពលនៅក្រោមសេនាធិការ ហើយនិងជារបស់មជ្ឈិម"]។ ឯកសារ D4.1.845 កំណត់ហេតុស្ដាប់ចម្លើយ ឡុញ ដុស ឆ .១៤ ["នៅពេលដែលមានការប្រជុំជាមួយកងពល ទើបគាត់មកប្រជុំនៅកន្លែងសេនាធិការ។ ឧទាហរណ៍ប្រជុំមួយអាទិត្យម្ដង ឬមួយខែម្ដង"]។

[969] ឯកសារ D1.3.8.3 កំណត់ហេតុអង្គប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃអង្គប្រជុំការងារយោធា នៅកំពង់សោម ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៧៦។

សុន សេន ប៉ុន្តែ អះអាងថា ពួកគេពិភាក្សាគ្នាតែអំពីការបង្កបង្កើនផលស្រូវប៉ុណ្ណោះ[970]។ **មាស មុត** ក៏បានជួបជាមួយមេដឹកនាំ ប.ក.ក នៅកំពង់សោមផងដែរ[971]។

298. កិច្ចប្រជុំយោធាបើកទូលាយត្រូវបានរៀបចំនៅស្តាតអូឡាំពិក ក្នុងទីក្រុងភ្នំពេញ និងចូលរួមដោយឥស្សរជនជាន់ខ្ពស់របស់ ប.ក.ក និងមេបញ្ជាការយោធា រួមបញ្ចូលទាំងមេបញ្ជាការកងពល[972]។ នៅពាក់កណ្តាលឆ្នាំ ១៩៧៧ **មាស មុត** បានចូលរួមក្នុងកិច្ចប្រជុំបើកទូលាយមួយ នៅភ្នំពេញ ជាមួយ ប៉ុល ពត, តាម៉ុក, នួន ជា, សុន សេន, សុខ ឈាន, អៀង ផាន, ឌី និង ធី ដើម្បីពិភាក្សា

---

970 ឯកសារ D22.2.180 ចម្លើយ មាស មុត មាស មុត៖ 'យើងស្ថិតនៅក្នុងទ្រុងដូចសព្វថ្ងៃ' ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១ EN ERN 00161880 ["សៈ [...] លោកបានចូលរួមការប្រជុំសេនាធិការជាមួយ [...] សុន សេន ដែលលាត ត្រដាងពីគោលការណ៍ចំពោះខ្មាំងនៃរបបនោះ? ឆៈ ពេលខ្ញុំមកការប្រជុំទាំងនោះ គឺពិភាក្សាតែរឿងធ្វើស្រែមួយមុខគត់។ [...] ក្នុងការប្រជុំដែលខ្ញុំបានចូលរួមជាមួយ សុន សេន យើងបានពិភាក្សាថាតើមានស្រូវអង្ករគ្រប់ ឬអត់។ ខ្ញុំគ្រាន់តែជាប្រធានកងពល ហើយខ្ញុំមិនបានចូលរួមការប្រជុំសម្ងាត់ណាទេ ដែលមេដឹកនាំត្រូវបានស៊ើបអង្កេតករណីខ្មាំងទាំងនោះ"]។

971 ឯកសារ D1.3.8.3 កំណត់ហេតុអង្គប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃអង្គប្រជុំការងារយោធា នៅកំពង់សោម ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៧៦ KH ERN 00021496 [ពាក់ព័ន្ធការងារយោធានៅកំពង់សោម មាស មុត, ខៀវ សំផន, ង៉ែត និង ខឹម បានកត់សម្គាល់ថាជាអ្នកចូលរួម]។ ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន ឆ.៣ ["បន្ទាប់មក យើងបានធ្វើដំណើរទៅកំពង់សោមតាមឡាន ជាកន្លែងដែលយើងជួប តាមុត នៅកន្លែងរោងជួបជុំគ្នានៅជិតផ្សារ"]។ ឯកសារ D1.3.8.4 កំណត់ហេតុនៃការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ (កម្មាភិបាលកងពល ១៦៤) ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ [របាយការណ៍ស្តីពីស្ថានីយ៍សាងសង់កំដា]។

972 ឯកសារ D4.1.1151 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យឿន ហៅ អ៊ី KH ERN 00172081 ["ខ្ញុំធ្លាប់ចូលរួមក្នុងពិធីខួបកំណើតបក្ស ឆ្នាំ១៩៦០ ដែលធ្វើនៅស្តាតអូឡាំពិក ក្រោយថ្ងៃរំដោះ នៅឆ្នាំ ១៩៧៥ [...] អ្នកដែលថ្លែងក្នុងពិធីនោះគឺលោក ខៀវ សំផន"]។ ឯកសារ D4.1.805 កំណត់ហេតុស្តាប់ចម្លើយ ឆោម សែ ឆ.៣ ["មហាសន្និបាតនៅខែកញ្ញា ឆ្នាំ ១៩៧៥។ មានកងទ័ពគ្រប់កងពល ចាប់ពីមេកងពលរហូតដល់ថ្នាក់អនុសេនាធំចូលរួមប្រជុំ។ [...] អ្នកចូលរួមមហាសន្និបាតនោះមាន ប៉ុល ពត, នួន ជា, ជា ជឿន ហៅតាម៉ុក, សុន សេន, ខៀវ សំផន, វ៉ន វេត, អៀង សារី, អៀង ធីរិទ្ធ, ហ៊ូ នឹម, ជួន ជឿន។ [...] សមាជិកបក្សចូលរួមមាន ២១ នាក់"]។ ឯកសារ D4.1.240 កំណត់ហេតុស្តាប់ចម្លើយ អឿន តាន KH ERN 00231802-00231903 ["សៈ លោកបានប្រាប់យើងថា មានកិច្ចប្រជុំដែលធ្វើនៅស្តាតអូឡាំពិក តើគេប្រជុំរឿងអ្វី? ឆៈ ខ្ញុំមិនដឹងថា គេប្រជុំនិយាយអំពីអ្វីទេ តែដឹងថាជាការប្រជុំយោធា។ យោធាដែលចូលរួមប្រជុំមានវរៈសេនាធំ វរសេនាតូច និងកងពលជាដើម។ [...] សៈ តើការប្រជុំនៅស្តាតអូឡាំពិកនោះញឹកញាប់ទេ? ឆៈ មិនញឹកញាប់ទេ ពេលខ្លះ ពីរដងក្នុងមួយឆ្នាំ [...] ខ្ញុំចាំថា សុន សេន ក៏ចូលរួមក្នុងការប្រជុំនោះដែរ [...] សៈ ក្រៅពីការប្រជុំទៀងទាត់ តើមានការប្រជុំនៅកន្លែងណាទៀតទេ? ឆៈ មានតែនៅអូឡាំពិក ក្នុងរវាងបីបួនខែម្តង ដែលជាការប្រជុំយោធាដឹកនាំដោយ ប៉ុល ពត"]។

អំពីការបោសសម្អាតកម្មាភិបាលបូព៌ា[973]។ មាស វឿន បានផ្តល់សក្ខីកម្មថា កម្មាភិបាលកងពល ត្រូវគេកោះហៅទៅឲ្យចូលរួមកិច្ចប្រជុំ ដែលពិភាក្សាអំពីការសម្រិតសម្រាំង និងការបោសសម្អាត ខ្មាំង[974]។

299. ក្រៅពីកិច្ចប្រជុំ[975] **មាស មុត** បានទាក់ទងជាទៀងទាត់ជាមួយមជ្ឈិមតាមទូរលេខ[976] ទូរស័ព្ទ[977] លិខិត[978] និងនីរសារ[979]។ របាយការណ៍ប្រចាំខែផ្ញើជូន និងចេញពី **មាស មុត** ត្រូវបានដឹកតាម

---

973 ឯកសារ D4.1.409 កំណត់ហេតុស្តាប់ចម្លើយ ឈូក រិន ហៅ សុក KH ERN 00210211-00210212 ["មុនពេលបេសកកម្មបោសសម្អាតកម្មាភិបាលភូមិភាគបូព៌ាចាប់ផ្តើម ខ្ញុំ និងមេបញ្ជាការយោធាដទៃទៀត បានកោះហៅឲ្យទៅចូលរួមប្រជុំនៅផ្ទះ តាម៉ុក នៅឯខេត្តតាកែវ នាពាក់កណ្តាលឆ្នាំ ១៩៧៧ [...] មួយថ្ងៃមកទៀត ពួកយើងបានចេញដំណើរទៅកាន់ខេត្តស្វាយរៀង ដោយបានមកសម្រាកនៅអ្នកលឿងចំនួនពីរទៅបីអាទិត្យ។ មានការប្រជុំជាច្រើនដោយថ្នាក់កងពល ដើម្បីរៀបចំគម្រោងផែនការនេះ បន្ទាប់មក រ៉េន ដែលជាកូនប្រសារតាម៉ុក បានហៅខ្ញុំតាមទូរលេខឲ្យទៅភ្នំពេញដើម្បីចូលរួមការប្រជុំពិសេស មួយជាមួយមេដឹកនាំធំៗពាក់ព័ន្ធរឿងគម្រោងធ្វើការបោសសម្អាតកម្មាភិបាលភូមិភាគបូព៌ា។ មានអ្នកចូលរួមប្រហែល ៦០០ ទៅ ៧០០ នាក់ ដែលក្នុងនោះ មាន មាស មុត, សុខ ឈាន, អៀង ផាន, ឌី និង ធី ហើយក៏មានវត្តមាន ប៉ុល ពត, តាម៉ុក, នួន ជា និង សុន សេន ផងដែរ។ ពេលនោះ នួន ជា បាននិយាយថា យើងត្រូវតែ "បោសសម្អាតខ្មាំងផ្ទៃក្នុង" និង "វាយពួកយួនឈ្លានពាន"]។

974 ឯកសារ D54/54 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.១៤ ["ខ្ញុំដឹងថា ពេលនោះជាឧទាហរណ៍ខាងមជ្ឈិមបានហៅថ្នាក់ភូមិភាគ ហើយនិងកងពលទៅប្រជុំដើម្បីផ្សព្វផ្សាយអំពីគោលនយោបាយបោសសម្អាត និងសម្រិតសម្រាំង"]។

975 ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡួន ឆ.១៤២-១៤៣ ["សៈ តើលោកដឹងថា ហេតុអ្វីបានជា មាស មុត ទៅភ្នំពេញញឹកញាប់អ៊ីចឹង? ឆ.១៤២៖ ខ្ញុំគិតថា គាត់ទៅភ្នំពេញដើម្បីរាយការណ៍។ សៈ តើគាត់រាយការណ៍ទៅអ្នកណា? ឆ.១៤៣៖ គាត់រាយការណ៍ទៅមជ្ឈិម"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ. ៧៥ ["ខ្ញុំបានមកចូលរួមប្រជុំសន្និបាតនៅភ្នំពេញធ្វើការបូកសរុបការងារ [...] ខ្ញុំឮ មាស មុត រាយការណ៍ពីទូកវៀតណាមដែលបានចូលក្នុងដែនសមុទ្រកម្ពុជា"]។

976 សូមមើល ឧទាហរណ៍ ឯកសារ D4.1.1020 របាយការណ៍ ពី មុត (មាស មុត) ជំរាបបង ៨៩ (សុន សេន) ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ [រាយការណ៍ពីចំនួនអ្នកជំងឺនៅក្នុងមន្ទីរពេទ្យ, ការចាប់ទូកមួយដឹកអង្ករ និងតម្រូវការអ្នកបកប្រែ សម្រាប់ការបណ្តុះបណ្តាល]។ ឯកសារ D1.3.34.10 ទូរលេខ ៤៤ ពី មុត (មាស មុត) ជំរាបបង ៨៩ (សុន សេន) ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៧៦ [ពាក់ព័ន្ធស្ថានការណ៍យោធានៅកោះកុង និងកោះតាង]។ ឯកសារ D1.3.30.2 របាយការណ៍ពីមុត (មាស មុត) ជំរាបជូន បង ៨៩ (សុន សេន) ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៧៦ [រៀបរាប់ពីការវាយប្រយុទ្ធនៅកោះសេះ និងកោះត្រល់ ហើយការផ្គត់ផ្គង់ស្រូវអង្ករនៅកោះរុង]។ ឯកសារ D1.3.12.3 របាយការណ៍ពីមុត (មាស មុត) ជំរាបមកបង ៨៩ (សុន សេន) ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ [ពាក់ព័ន្ធនឹងការចាប់ និងស្ថានភាពខ្មាំង]។ ឯកសារ D1.3.14.1 ទូរលេខ ពីមុត (មាស មុត) ជំរាបមកបង ៨៩ (សុន

សេន) ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៧៦ [មាស មុត ផ្ញើបន្តសំបុត្រមួយដែលបញ្ជាក់ថា សំអាត អនុលេខាកងវរៈសេនាតូច ១៦៥ ហើយសួរទៅ សុន សេន "ចំពោះបញ្ហានេះ សុំយោបល់អង្គការសំរេចយ៉ាងណា ព្រោះតាមមើលច្បាស់គួរសមដែរ"]។ ឯកសារ D54/51.1 (D1.3.12.18) ទូរលេខ ០៩ ពីមុត (មាស មុត) ជំរាបមកបង ៨៩ (សុន សេន) ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៧៧ [របាយការណ៍ស្តីពីការចាប់នាវាថៃចេញពីកោះកុង និងកប៉ាល់នេសាទវៀតណាមដែលចូលមកក្បែរកោះសេះ]។ ឯកសារ D1.3.2.2 ទូរលេខ ១០ ពី សុន សេន ជំរាបមក មាស មុត ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ [សេចក្តីណែនាំលម្អិត ដែលរាប់បញ្ចូលទាំងភាពចាំបាច់ដាច់ខាតក្នុងការកំទេចសត្រូវចូលដែនទឹកកម្ពុជាប្រជាធិបតេយ្យ តម្រូវការដើម្បីរក្សានូវការចាប់ខ្លួនថ្មីនេះៗពី "ខាងលិច" ដោយសម្ងាត់ និងត្រូវពង្រឹងទំនាក់ទំនង]។ សូមមើលផងដែរ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង វ៉េត ឆ.៦២ ["សៈ នៅពេលមានបញ្ហាទៅ មាស មុត តើគេធ្វើឡើងយ៉ាងដូចម្តេច? ឆ.៦២៖ តាមខ្ញុំដឹង ការបញ្ជាគឺធ្វើឡើងតាមរយៈទូរលេខ"]។ ឯកសារ D4.1.855 កំណត់ហេតុស្តាប់ចម្លើយ ឡាញ់ ឌុស KH ERN 00357492 ["ពេលសេនាធិការត្រូវហៅកងពលមកប្រជុំគេត្រូវប្រើសារទូរលេខដើម្បីហៅមកប្រជុំនៅសេនាធិការ។ ជាទូទៅគឺហៅមេបញ្ជាការកងពលមកប្រជុំនៅសេនាធិការ"]។ ឯកសារ D114/19.1 របាយការណ៍ពី មាស មុត ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៧៦ [ទាក់ទងការវាយប្រយុទ្ធនៅកោះត្រល់]។ ឯកសារ D1.3.12.2 របាយការណ៍ពី មាស មុត ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំមិនដឹង (១៩៧៦, ១៩៧៧ ឬ ១៩៧៨) [ទាក់ទងនឹងការចាប់ទូកនេសាទថៃ]។ ឯកសារ D1.3.14.2 ទូរលេខ ៨៣ ពី មឿន ជូនបងមុត (មាស មុត) ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៧៧ [ចម្លងជូន សុន សេន ៖ របាយការណ៍ស្តីពីការរកឃើញខ្មាំងខាងក្នុង នៅក្នុងចំណោមរឿងរ៉ាវផ្សេងៗ"]។ ឯកសារ D1.3.34.60 ទូរលេខ ០០ ពី មុត ជូន ម-៨៧០ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ [ទាក់ទងនឹងការការពារដែនសមុទ្រ ចម្លងជូនបង (ប៉ុល ពត) បងនួន បងវ៉ាន់ (អៀង សារី) បងវ៉ន (វ៉ន វ៉េត) បងខៀវ (សុន សេន)]។

977 ឯកសារ D54/23.3 សារទូរស័ព្ទសម្ងាត់ ពីមុត (មាស មុត) ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៧៨ [របាយការណ៍ស្តីពីចំនួនសរុបនៃជនជាតិវៀតណាមដែលបានចាប់ខ្លួន និងការខកខានក្នុងការដោះលែងអ្នកទោសថៃ]។ ឯកសារ D1.3.34.64 ការទំនាក់ទំនងទូរស័ព្ទសម្ងាត់ ពីមាស មុត ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ [រៀបរាប់ឧប្បត្តិហេតុនៃការចាប់ការណូត និងការសម្លាប់នៅតាមសមុទ្រ]។ ឯកសារ D54/73.1 ការទំនាក់ទំនងទូរស័ព្ទសម្ងាត់ ពីមាស មុត ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៨ [រៀបរាប់ការចាប់ជនជាតិវៀតណាម និងការដោះលែងអ្នកទោសថៃ និងស្នើសម្ភារៈយោធា]។ ឯកសារ D1.3.30.25 សារទូរស័ព្ទសម្ងាត់ ពីមុត (មាស មុត) ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៨ [សេចក្តីលម្អិតពីចំនួនជនជាតិវៀតណាមដែលចាប់បាន និងសម្លាប់ចោល]។ ឯកសារ D4.1.637 សារទូរស័ព្ទសម្ងាត់ ពីមុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៧៨ [ទាក់ទងនឹងការប្រយុទ្ធនៅកោះត្រល់ និងទាហានដែលរបួស]។ ឯកសារ D54/73 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.៤ ["សៈ តើ ក-១ ហ្នឹងទូរសព្ទមកញឹកញាប់ប៉ុនណា? ឆ.៤៖ ពេលខ្លះ ១ ថ្ងៃម្តង ពេលខ្លះ ២ ថ្ងៃម្តង។ កាលហ្នឹងមានទូរសព្ទទៅមករវាងមេបញ្ជាការកងពល ១៦៤ មាស មុត និងមជ្ឈិម"]។ ឯកសារ D1.3.30.26 ការទំនាក់ទំនងទូរសព្ទសម្ងាត់ពីកងវរសេនាធំ ៦៣ ជូនអ៊ំ (នួន ជា) ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៨។ ឯកសារ D1.3.12.20 (D4.1.639) ទំនាក់ទំនងទូរសព្ទសម្ងាត់ ពីកងពល ១៦៤ ជូនមុត (មាស មុត) ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៧ [ដោយមានចំណារសរសេរដៃរបស់ ខៀវ សំផន]។ សូមមើលផងដែរ ឯកសារ D98/1.2.47 នង សុផង់ ប្រតិ

រថភ្លើងម្ដងម្កាល[980]។ ទូរលេខ លិខិត និងរបាយការណ៍ស្ដីពីការហៅទូរស័ព្ទ ដែល **មាស មុត** ផ្ញើជូន សុន សេន (បង ៨៩) ត្រូវបានចម្លងជូន នួន ជា (បង នួន អ៊ំ ឬអ៊ំ នួន), វន វ៉េត (បង ៨៧), បងណាត, បងសោម, ស៊ាត ឆែ (បង ៨១) និងបង តាត[981]។

---

ចារឹកថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១២ ម៉ោង 11.40.03-11.42.22 ["ហ្នឹងគឺមានច្រើនតែម្ដង ទាំងជើងទឹក ជើងគោក ជើងអាកាសអី គឺលោកមានមធ្យោបាយគ្រប់បែប គ្រប់យ៉ាង ទាំងអ្នកវាយ ទាំងអ្នកបក រហូតដល់ទូរសព្ទមានខ្សែ អត់ខ្សែអី គឺមានគ្រប់បែបគ្រប់យ៉ាង"]។

978 ឯកសារ D1.3.4.1 របាយការណ៍ពីមុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៧៦ KH ERN 00160064 [សំបុត្រពាក់ព័ន្ធទាហានម្នាក់ ស្ថានភាពសុខភាពរបស់អាចារ្យកង]។ ឯកសារ D4.1.1010 សំបុត្រពី កាន និង មុត (មាស មុត) ជូនបង (សុន សេន) ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៧៨ [លិខិតពន្យល់សំណើរបស់អ្នកកាសែត Elizabeth Becker]។

979 ឯកសារ D22.2.181 ចម្លើយ មាស មុត អំពីឈ្លើយសឹកអាមេរិក និងជនដែលបាត់ខ្លួនក្នុងសង្គ្រាម KH ERN 00741997 ["រាល់ទំនាក់ទំនងទាំងអស់រវាងរាម/កំពង់សោម និងក្រុងភ្នំពេញក្នុងអំឡុងពេលមានឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស ត្រូវបានធ្វើឡើងតាមរយៈនីរសារ"]។

980 ឯកសារ D114/19.1 របាយការណ៍ពី មាស មុត ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៧៦ ["ខ្ញុំផ្ញើជូនបង ៨៩ សេចក្ដីរាយការណ៍ប្រចាំខែរបស់អង្គភាព ១៦៤ តាមរទេះភ្លើង"]។ ឯកសារ D1.3.30.2 របាយការណ៍ពីមុត (មាស មុត) ជំរាបជូន បង ៨៩ (សុន សេន) ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៧៦ ["របាយការណ៍ប្រចាំខែរបស់អង្គភាព ១៦៤ ត្រូវផ្ញើជូនបង ៨៩ តាមរទេះភ្លើង"]។

981 ឯកសារ D4.1.1020 របាយការណ៍ ពី មុត (មាស មុត) ជំរាបបង ៨៩ (សុន សេន) ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ [រាយការណ៍ពីចំនួនអ្នកជំងឺនៅក្នុងមន្ទីរពេទ្យ ការចាប់ទូកមួយដឹកអង្ករ និងតម្រូវការអ្នកបកប្រែសម្រាប់ការបណ្ដុះបណ្ដាល]។ ឯកសារ D1.3.34.10 ទូរលេខ ៤៤ ពី មុត (មាស មុត) ជំរាបបង ៨៩ (សុន សេន) ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៧៦ [ពិព័ណ៌នាស្ថានការណ៍យោធានៅកោះកុង និងកោះតាង ហើយនិងជនក្បត់ពីរនាក់]។ ឯកសារ D1.3.14.1 ទូរលេខ ពីមុត (មាស មុត) ជំរាបមកបង ៨៩ (សុន សេន) ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៧៦ [មាស មុត ផ្ញើបន្តសំបុត្រមួយដែលបញ្ជាក់ថា សំអាតអនុលេខាកងវរៈសេនាតូច ១៦៥ ហើយសួរទៅ សុន សេន ដើម្បីសុំយោបល់អង្គការ។]។ ឯកសារ D1.3.4.1 របាយការណ៍ពីមុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៧៦ [របាយការណ៍ស្ដីពីទាហានម្នាក់ ស្ថានភាពសុខភាពរបស់អាចារ្យកង]។ ឯកសារ D4.1.637 សារទូរស័ព្ទសម្ងាត់ ពីមុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៧៨ [ទាក់ទងនឹងការប្រយុទ្ធនៅកោះត្រល់ និងទាហានដែលរបួស]។ ឯកសារ D54/23.3 សារទូរស័ព្ទសម្ងាត់ ពីមុត (មាស មុត) ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៧៨ [របាយការណ៍ស្ដីពីចំនួនសរុបនៃជនជាតិវៀតណាមដែលបានចាប់ខ្លួន និងការខកខានក្នុងការដោះលែងអ្នកទោសថៃ]។ ឯកសារ D54/73.1 ការទំនាក់ទំនងទូរស័ព្ទសម្ងាត់ ពីមាស មុត ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៨ [រៀបរាប់ការចាប់ជនជាតិវៀតណាម និងការដោះលែងអ្នកទោសថៃ និង

300. **មាស មុត** បានរាយការណ៍ជូនមជ្ឈិមអំពីប្រធានបទផ្សេងៗ ដូចជា៖ ការចូលរួមរបស់យោធា[982] សកម្មភាព និងនាវាខ្មាំង[983] ការរកឃើញខ្មាំងផ្ទៃក្នុង និងសកម្មភាពវិទ្ធង្សនានៅក្នុងអង្គភាព[984] ការដាំស្រូវ[985] សុខភាពរបស់ទាហាន[986] និងការរីកចម្រើននៃគម្រោងសាងសង់[987]។

---

ស្នើសម្ភារៈយោធា]។ ឯកសារ D1.3.34.28 របាយការណ៍ពីស៊ឹម ជូនកងពល ១៦៤ ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៧៧ [ចម្លងជូន បង ៨៩ (សុន សេន)៖ ទាក់ទងនឹងការចាប់ទូកថៃ]។

982 ឯកសារ D1.3.34.10 ទូរលេខ ៤៤ ពី មុត (មាស មុត) ជំរាបបង ៨៩ (សុន សេន) ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៧៦ [ព័ត៌មានស្ថានការណ៍យោធានៅកោះកុង និងកោះតាង ហើយនិងជនក្បត់ពីរនាក់]។ ឯកសារ D4.1.572 របាយការណ៍ពី វឿន (អ៊ុង វ៉េន) ជូនអំ ៨៩ (សុន សេន) ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៧៧ [សេចក្តីលម្អិតពីស្ថានការណ៍ជាមួយខ្មាំងនៅព្រំដែន]។ ឯកសារ D114/19.1 របាយការណ៍ពី មាស មុត ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៧៦ [ការពិភាក្សាការប៉ះទង្គិចគ្នាដោយអាវុធ នៅលើ និងនៅជុំវិញកោះត្រល់ និងការដាក់ពង្រាយយោធាកងពល ១៦៤ នៅលើកោះសេះ កោះថ្មី កោះសំពោច កោះរាម និងវត្តមានរបស់ មាស មុត នៅកោះរុង និងកោះរុងក្រៅ នៅពេលរាយការណ៍]។ ឯកសារ D1.3.12.2 របាយការណ៍ពី មាស មុត ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំមិនដឹង (១៩៧៦, ១៩៧៧ ឬ ១៩៧៨) [ការពិភាក្សាពីកងកម្លាំងកោះព្រីងបាញ់ទូកនេសាទថៃមួយ ចាប់ទូកនេសាទថៃ និងការហោះហើរនៃឧទ្ធម្ភាគចក្រវៀតណាមលើកោះត្រល់/ភូកុក]។

983 ឯកសារ D1.3.34.10 ទូរលេខ ៤៤ ពី មុត (មាស មុត) ជំរាបបង ៨៩ (សុន សេន) ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៧៦ [ព័ត៌មានពីស្ថានការណ៍យោធានៅកោះកុង និងកោះតាង ហើយនិងជនក្បត់ពីរនាក់]។ ឯកសារ D4.1.572 របាយការណ៍ពីវឿន (អ៊ុង វ៉េន) ជូនអំ ៨៩ (សុន សេន) ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ១៩៧៧ [សេចក្តីលម្អិតពីស្ថានការណ៍ជាមួយខ្មាំងនៅព្រំដែន]។ ឯកសារ D114/19.1 របាយការណ៍ពី មាស មុត ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៧៦ [ការពិភាក្សាការប៉ះទង្គិចគ្នាដោយអាវុធ នៅលើ និងនៅជុំវិញកោះត្រល់ និងការដាក់ពង្រាយយោធាកងពល ១៦៤ នៅលើកោះសេះ កោះថ្មី កោះសំពោច កោះរាម និងវត្តមានរបស់ មាស មុត នៅកោះរុង និងកោះរុងក្រៅ នៅពេលរាយការណ៍]។ ឯកសារ D1.3.12.2 របាយការណ៍ពី មាស មុត ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំមិនដឹង (១៩៧៦, ១៩៧៧ ឬ ១៩៧៨) [ការពិភាក្សាពីកងកម្លាំងកោះព្រីងបាញ់ទូកនេសាទថៃមួយ ការចាប់ទូកនេសាទថៃ និងការហោះនៃឧទ្ធម្ភាគចក្រវៀតណាមលើកោះត្រល់/ភូកុក]។

984 ឯកសារ D1.3.14.1 ទូរលេខ ពីមុត (មាស មុត) ជំរាបមកបង ៨៩ (សុន សេន) ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៧៦ [មាស មុត ផ្ញើបន្តសំបុត្រមួយដែលបញ្ជាក់ថា សំអាត អនុលេខាកងវរសេនាតូច ១៦៥ ហើយសួរទៅ សុន សេន "ចំពោះបញ្ហានេះ សុំយោបល់អង្គការសំរេចយ៉ាងណា ព្រោះតាមមើលច្បាស់គួរសមដែរ"]។ ឯកសារ D234/2.1.45 របាយការណ៍ពី សុក ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៧៧ [គណៈកម្មាធិការនៃកងពល ១៧០ រាយការណ៍ស្តីពី ក្នុងចំណោមរឿងផ្សេងៗ ខ្មាំងខាងក្នុង ១១ នាក់]។ ឯកសារ D234/2.1.46 របាយការណ៍ពី អឿន ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ១៩៧៦ [សេចក្តីលម្អិតពីការចាប់ និងចម្លើយសារភាពខ្មាំងខាងក្នុង]។ ឯកសារ D234/2.1.48 របាយការណ៍ពីវ៉ែន (អ៊ុង វ៉ែន) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ១៩៧៧ [មន្ទីរសេនាធិការរាយការណ៍ពី ក្នុងចំណោមរឿងផ្សេងៗ ការដឹកនាំការបោសសម្អាត ការងារ"ការពារជាតិ"

នៃកងពល ១៧០ និងបញ្ហានៃកម្មាភិបាលមួយចំនួនដែលខ្ជិល ហើយត្រូវអប់រំសិន]។ ឯកសារ D10.1.98 របាយការណ៍ពី រ៉ែន (អ៊ុង រ៉ែន) ជូនពូ ៨៩ (សុន សេន) ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ [គណៈកម្មាធិការនៃកងពល ៨០១ រាយការណ៍ស្តីពីរឿងរ៉ាវផ្សេងៗក្នុងចំណោម "សត្រូវ" ពីខាងក្រៅបានចង្អុលបង្ហាញអង្គភាពខាងក្នុងមួយចំនួន] ។ ឯកសារ D4.1.643 របាយការណ៍ពីគណៈកងពល ៣១០ ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ [ទាក់ទងនឹងរឿងរ៉ាវផ្សេងៗក្នុងចំណោម សកម្មភាពផ្សេងៗនៅក្នុងកងពល ៣១០]។ សូមមើលផងដែរ ឯកសារ D1.3.14.2 ទូរលេខ ៨៣ ពី មឿន ជូនបងមុត (មាស មុត) ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៧៧ [ចម្លងជូន សុន សេន៖ របាយការណ៍ស្តីពីការរកឃើញ "ខ្មាំង"ខាងក្នុង នៅក្នុងចំណោមរឿងរ៉ាវផ្សេងៗ]។

985 ឯកសារ D1.3.30.2 របាយការណ៍ពីមុត (មាស មុត) ជំរាបជូន បង ៨៩ (សុន សេន) ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៧៦ [រៀបរាប់ពីការវាយប្រយុទ្ធនៅកោះសេះ និងកោះត្រល់ ហើយការផ្គត់ផ្គង់ស្រូវអង្ករនៅកោះរុង]។ ឯកសារ D234/2.1.45 របាយការណ៍ពី សុក ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៧៧ [គណៈកម្មាធិការនៃកងពល ១៧០ រាយការណ៍ស្តីពីការធ្វើស្រែ និងស្នើអង្គការដោះស្រាយបញ្ហាទឹក]។ ឯកសារ D234/2.1.48 របាយការណ៍ពីរ៉ែន (អ៊ុង រ៉ែន) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ១៩៧៧ [សេនាធិការមន្ទីររាយការណ៍រឿងរ៉ាវផ្សេងៗក្នុងចំណោម ផលិតកម្មកសិកម្ម]។ ឯកសារ D10.1.98 របាយការណ៍ពី រ៉ែន (អ៊ុង រ៉ែន) ជូនពូ ៨៩ (សុន សេន) ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ [គណៈកម្មាធិការនៃកងពល ៨០១ រាយការណ៍ស្តីពីរឿងរ៉ាវផ្សេងៗក្នុងចំណោម ផលិតកម្មកសិកម្ម]។

986 ឯកសារ D1.3.4.1 1 របាយការណ៍ពីមុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៧៦ [របាយការណ៍ស្តីពីទាហានម្នាក់ ស្ថានភាពសុខភាពរបស់អាចារ្យកង]។ ឯកសារ ឯកសារ D1.3.4.1 1 របាយការណ៍ពីមុត (មាស មុត) ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៧៦ [របាយការណ៍ស្តីពីទាហានម្នាក់ ស្ថានភាពសុខភាពរបស់អាចារ្យកង]។ ឯកសារ D4.1.1020 របាយការណ៍ ពី មុត (មាស មុត) ជំរាបបង ៨៩ (សុន សេន) ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ [រាយការណ៍បញ្ហាសុខភាព]។ ឯកសារ D10.1.97 ទូរលេខ ពី ធឿន ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៦ [ពាក់ព័ន្ធសុខភាពយុទ្ធជននៅកងពល ៨០១]។ របាយការណ៍ ពី មុត (មាស មុត) ជំរាបបង ៨៩ (សុន សេន) ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ [រាយការណ៍បញ្ហាសុខភាព]។ ឯកសារ D10.1.97 ទូរលេខ ពី ធឿន ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៦ [ពាក់ព័ន្ធសុខភាពយុទ្ធជននៅកងពល ៨០១]។

987 ឯកសារ D4.1.643 របាយការណ៍ពីគណៈកងពល ៣១០ ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ [ទាក់ទងនឹងរឿងរ៉ាវផ្សេងៗក្នុងចំណោម ការសាងសង់ទំនប់ក្នុងអង្គភាព ៣១០]។ ឯកសារ D4.1.1014 របាយការណ៍ពី អឿន ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៧៦ [ពាក់ព័ន្ធនឹងការសាងសង់ប្រឡាយ និងការងារដទៃទៀតដែលរួមមានការកាប់ឆ្ការព្រៃ និងជីដាំដុះ។]។ ឯកសារ D1.3.34.10 ទូរលេខពី មុត (មាស មុត) ជំរាបបង ៨៩ (សុន សេន) ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៧៦ [រៀបរាប់ក្នុងចំណោមរឿងជាច្រើនទៀត ការតម្លើងកាំភ្លើងធំនៅលើកោះ]។ សូមមើលផងដែរ ឯកសារ D1.3.14.2 ទូរលេខ ៨៣ ពី មឿន ជូនបង មុត (មាស មុត) ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៧៧ [ចម្លងជូន សុន សេន៖ របាយការណ៍ស្តីពី រឿងរ៉ាវផ្សេងៗ ក្នុងចំណោមការជួសជុល]។

301. សេនាធិការចេញបញ្ជាឱ្យ **មាស មុត** ជាលាយលក្ខណ៍អក្សរ ឬចំពោះមុខ[988] រួមបញ្ចូលទាំងសេចក្តីណែនាំស្តីពីតម្រូវការក្នុងការ "កម្ទេចឱ្យបាន" នូវខ្មាំងដែលចូលដែនទឹក ឬដែនគោករបស់កម្ពុជាប្រជាធិបតេយ្យ[989]។ សុន សេន បញ្ជូនសំណៅចម្លងនៃរបាយការណ៍ ដែលទទួលបានពីកងពលនៃកងទ័ពបដិវត្តន៍កម្ពុជា ទៅមន្ទីរ ក-១ តាមរយៈអង្គភាពវិទ្យុទាក់ទង[990]។

302. របាយការណ៍ និងទូរលេខ បង្ហាញថា កងទ័ពបដិវត្តន៍កម្ពុជាអនុវត្តសេចក្តីណែនាំរបស់អង្គការ (ថ្នាក់ដឹកនាំមជ្ឈិម) ឬស្នើសុំការបំភ្លឺពីមេដឹកនាំនយោបាយ ឬយោធាមជ្ឈិម[991]។ ឧទាហរណ៍

---

988 ឯកសារ D54/82 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.៦ ["មន្ទីរ ៨៧០ ជាអ្នកផ្ញើសារណែនាំដោយផ្ទាល់ទៅកងពល ១៦៤ ដោយឡែកខ្ញុំទទួលបានសារណែនាំបន្តពីកងពល ១៦៤"]។ សូមមើលជាទូទៅ ឯកសារ D98/3.1.307 អ៊ុង អ៊ែន ប្រតិចារឹកថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣ ម៉ោង ០៩.២៣.៣០-០៩.២៦.១១ ["ឧបមា ឥឡូវផែនការពីខាងលើទៅរៀបចំកម្លាំងយ៉ាងម៉េចៗ ហើយអង្គភាពគេត្រៀមយ៉ាងម៉េចៗអីគាត់ទៅប្រជុំអីចឹងបានខ្ញុំដឹង។ ដូច្នេះ បើឱ្យខ្ញុំដឹងថាឥឡូវដោះស្រាយយ៉ាងម៉េចអីយ៉ាងម៉េច គឺឯកភាពត្រឹមគាត់ ឬក៏ខាងលើបញ្ជា"]។

989 ឯកសារ D1.3.2.2 ទូរលេខ ១០ ពី សុន សេន ជំរាបមក មាស មុត ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ [សេចក្តីណែនាំលម្អិត ដែលរាប់បញ្ចូលទាំងភាពចាំបាច់ដាច់ខាតក្នុងការកំទេចសត្រូវចូលដែនទឹកកម្ពុជាប្រជាធិបតេយ្យ តម្រូវការដើម្បីរក្សានូវការចាប់ខ្លួនថ្មីនេះៗពី "ខាងលិច" ដោយសម្ងាត់ និងត្រូវពង្រឹងទំនាក់ទំនង]។

990 ឯកសារ D4.1.845 កំណត់ហេតុស្តាប់ចម្លើយ ឡុញ ឌុស ឆ.៣៥ [ពន្យល់ថា របាយការណ៍មួយពីកងពល ១៦៤ ជូនបងសុន សេន ត្រូវបានផ្ញើជូនអង្គការព្រោះ "រាល់បញ្ហាដែលកើតមានត្រូវតែរាយការណ៍ទៅឱ្យអង្គការ"]។ ឯកសារ D4.1.240 កំណត់ហេតុស្តាប់ចម្លើយ អឿន តាន KH ERN 00231807 ["ខ្ញុំធ្លាប់ឃើញមានសំបុត្រផ្ញើមកពី សុន សេន ដែរ។ សំបុត្រដែលផ្ញើមកពីភូមិភាគពីតំបន់ ត្រូវចូល ក-៧ សិន បន្ទាប់មកទើបយកមកដល់ ក-១ ហើយក្រុមខ្ញុំយកទៅឱ្យប៉ុល ពត"]។ សូមមើលផងដែរ ឯកសារ D4.1.611 កំណត់ហេតុស្តាប់ចម្លើយ នង សុផង់ KH ERN 00328034 ["គឺលោក សុន សេន មានទូរលេខទាក់ទងផ្ទាល់មកខាងកន្លែង យស់។ ទូរលេខរបស់គាត់ ជាលេខកូដរួចហើយ យស់ យកទៅ ក-១។ បន្ទាប់មកក្រុម ប៉ុន បកប្រែទៅជាអក្សរ។ ទិសដែលសំខាន់ៗឬអ្វីដែលសំខាន់ៗ គឺក្រុមខាងក្នុងជាអ្នកបកប្រែ។"]។ ឯកសារ D98/1.2.36 អឿន តាន(TCW-788) ប្រិតិចារឹកថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ ម៉ោង ១៥.៤៩.៣០-១៥.៥១.២១ ["សំបុត្រមកពី សុន សេន [...] ខ្ញុំយកមកឱ្យប៉ុល ពត"]។

991 ឯកសារ D1.3.14.1 ទូរលេខ ពីមុត (មាស មុត) ជំរាបមកបង ៨៩ (សុន សេន) ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៧៦ [មាស មុត ផ្ញើបន្តសំបុត្រមួយដែលបញ្ជាក់ថា សំអាតអនុលេខាកងវរសេនាតូច ១៦៥ ហើយសួរទៅ សុន សេន "ចំពោះបញ្ហានេះ សុំយោបល់អង្គការសំរេចយ៉ាងណា ព្រោះតាមមើលច្បាស់គួរសមដែរ"]។ ឯកសារ D1.3.12.20 (D4.1.639) ) ទំនាក់ទំនងទូរស័ព្ទសម្ងាត់ពីកងពល ១៦៤ ជូន មុត (មាស មុត) ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៧ [របាយការណ៍នៃការចាប់ទូកមួយនៅកោះកុង ដែលត្រូវបានបញ្ជូនទៅអង្គការដោយ សុន សេន]។ ឯកសារ D234/2.1.44 របាយការណ៍ពីអឿន ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៧៦ ["ឥឡូវនេះ គឺឱ្យបងប្អូនលបចាំមើលឱ្យច្បាស់ ហើយឱ្យយកខ្សែអាត់លួចថតយកចតសំឡេងជាក់ស្តែងជូនអង្គការ [...] អង្គរមាន

មាស មុត បានរាយការណ៍ជូន សុន សេន អំពីឧប្បត្តិហេតុនៃការបាញ់ និងចាប់កប៉ាល់វៀតណាម និងស្នើសុំយោបល់អំពីវិធានការដែលត្រូវអនុវត្ត[992]។

## ៤. ទំនាក់ទំនងរវាងកងពល ១៦៤ និងកងពលផ្សេងទៀត

### ទំនាក់ទំនងរវាងកងពល ១៦៤ និងកងពលលេខ ១

303. កងពល ១៦៤ និងកងពលលេខ ១ គ្រប់គ្រងលើតំបន់ជាប់គ្នា និងសហប្រតិបត្តិការគ្នា ដើម្បីកុំឲ្យជ្រៀតជ្រែកចូលក្នុងទំនួលខុសត្រូវរៀងៗខ្លួន[993]។ កងពលលេខ ១ គ្រប់គ្រងលើសមុទ្រមួយផ្នែកចន្លោះពីកម្ពុជា ទៅថៃ ឯកងពល ១៦៤ គ្រប់គ្រងលើផ្នែកផ្សេងទៀត[994]។

---

តែតម្រូវឲ្យស្នើតាមរយៈអង្គការ [...] ខ្ញុំសូមស្នើយោបល់អង្គការ"]។ ឯកសារ D10.1.98 របាយការណ៍ពី រ៉ែន (អ៊ុង រ៉ែន) ជូនពូ ៨៩ (សុន សេន) ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ ["អ្នកសង្ស័យថាខ្មាំង ត្រូវចាប់ដាច់ខាត។ [...] នេះជាសេចក្តីរាយការណ៍របស់គណៈកម្មាធិការ ៨០១ ចំពោះសកម្មភាពខ្មាំង និងវិធានការដូចខាងលើ ស្នើអ៊ុំមានមតិ និងជួយយោបល់។ យើងខ្ញុំរង់ចាំមតិណែនាំរបស់បក្ស"]។ ឯកសារ D4.1.1015 របាយការណ៍ពីឿន គោរពជូនអ៊ុំ ៨៩ (សុន សេន) ជាទីគោរព ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៧ ["តាមមតិអង្គការណែនាំ ស្នើដាក់ សមមិត្ត ម៉ៅ ជំនួសវិញ។ សុំអ៊ុំមានមតិចំពោះសមមិត្ត ម៉ៅ [...] សុំអ៊ុំជួយសម្រេច [...] សុំអ៊ុំមានមតិសម្រេចយ៉ាងណាអំពីសមមិត្តរូបនេះ [...] សុំអ៊ុំជួយមតិ និងវិនិច្ឆ័យ"]។ ឯកសារ D234/2.1.50 របាយការណ៍ពី រ៉ែន ជូនមន្ទីរសេនាធិកា ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ១៩៧៧ ["នេះក៏ស្នើអង្គការជួយដោះស្រាយ"]។ ឯកសារ D1.3.34.23 ទូរលេខ ២៨ ពីសឿង ជូនអង្គការ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៧ [របាយការណ៍ស្តីពីយន្តហោះខ្មាំងប្រតិកម្ម និងស្នើសុំព័ត៌មានពីអង្គការ]។

992 ឯកសារ D1.3.34.64 ការទំនាក់ទំនងទូរស័ព្ទសម្ងាត់ពី មាស មុត ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ [មាស មុត រាយការណ៍ជូន សុន សេន អំពីការចាប់ទូកថៃ និងទូកវៀតណាម]។ ឯកសារ D54/11 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ហៅ ម៉ី សារ៉េត ឆ.២០ ["ស៖ ហេតុអ្វីរបាយការណ៍នេះ ត្រូវរាយការណ៍ទៅឲ្យសុន សេន? ឆ.២០៖ តាមុត ត្រូវរាយការណ៍អំពីព្រឹត្តិការណ៍ទាំងនេះ ដូចជាការបាញ់ និងចាប់ទូកវៀតណាមទៅឲ្យថ្នាក់លើដើម្បីឲ្យថ្នាក់លើមានវិធានាការត្រឹមត្រូវ"]។ ឯកសារ D54/52 កំណត់ហេតុស្តាប់ចម្លើយ មាស ឿន ឆ.១៣ ["យោងតាមការយល់របស់ខ្ញុំអំពីរចនាសម្ព័ន្ធបញ្ជាការ មាស មុត គឺជាកម្លាំងរបស់មជ្ឈិម ដូច្នេះគាត់ត្រូវតែរាយការណ៍ទៅឲ្យថ្នាក់លើរបស់គាត់ គឺ សុន សេន ដែលជាសេនាធិការ"]។

993 ឯកសារ D98/3.1.178 មាស ឿន ប្រតិចារឹកថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ 10.15.02-10.17.39 ["ទាក់ទងសហការជាមួយកងពលលេខ ៣ ហ្នឹងមានវរសេនាធំ ខ្ញុំមិនចាំឈ្មោះ ក៏ប៉ុន្តែ ព្រំប្រទល់ដើម្បីសហការគ្នា ដើម្បីស្គាល់គ្នាតាមអង្គភាពនីមួយៗដើម្បីយល់កិច្ចការគ្នា កុំឲ្យមានប៉ះពាល់អ្វីណាមួយក្នុងអង្គភាពបាទ"]។ ឯកសារ D98/3.1.179 មាស ឿន ប្រតិចារឹកថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ ម៉ោង 11.16.18-11.19.00 ["កងពលខ្ញុំ ខ្ញុំពីត្រឹមកោះកុង។ ដូចខ្ញុំនិយាយអីចឹង ត្រឹមពីកោះស្តេច កោះកុង ទៅជើងទៅ អាហ្នឹងខាងកងៗពលខ្ញុំ។ ឯកមកខាងត្បូងវិញ គេហៅថា កង

304. កងពលលេខ ១ ឈរជើងនៅជុំវិញតំបន់កោះតាង[995] ហើយប្រើប្រាស់កែវឆ្លុះ និងរ៉ាដា ដើម្បីស្វែងរកទូកនេសាទខុសច្បាប់[996]។ កងពលលេខ ១ និងកងពល ១៦៤ ចែករំលែកព័ត៌មានគ្នា ដើម្បីជួយសម្រួលដល់ការចាប់ទូកថៃ និងវៀតណាម[997]។ ពេលកងពលលេខ ១ កំណត់បានមុខសញ្ញាមួយ គេទាក់ទងកងពល ១៦៤[998]។ កងពលលេខ១ ជាកងទ័ពជើងគោក មានតែទូកតូចៗសម្រាប់ល្បាត និងដឹកជញ្ជូនប៉ុណ្ណោះ គឺពុំមាននាវាចម្បាំង ដើម្បីទប់ទល់ជម្លោះនៅលើសមុទ្រនោះទេ[999]។ ដូច្នេះ

---

ពលលេខ ៣ ហ្នឹងហើយ ប៉ុន្តែ គេកងពេល ប្រធានកងពលហ្នឹង គេមិនដែលមកទាក់ទងខ្ញុំនឹងផង។ ទាក់ទងត្រឹមតែវរសេនាធំ ឬក៏វរសេនាតូច។ បើវរសេនាតូច គេមកញើកញាប់ ប៉ុន្តែ វរសេនាធំ គេមិនដែលមកញើកញាប់ទេ"]។

994 ឯកសារ D54/51 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ. ១៨ ["ដោយសារភូមិភាគបស្ចិមមានព្រំដែនជាប់ជាមួយថៃ និងដែនសមុទ្រអន្តរជាតិ ដូច្នេះ ផ្នែកខ្លះនៃព្រំដែនរវាងសមុទ្រកម្ពុជា និងដែនសមុទ្រអន្តរជាតិ ហើយនិងសមុទ្រកម្ពុជា និងសមុទ្រថៃ គឺស្ថិតនៅក្រោមការត្រួតត្រារបស់កងពលលេខ ១។ ផ្នែកផ្សេងៗទៀតនៃព្រំដែន ស្ថិតនៅក្រោមការត្រួតត្រារបស់កងទ័ពជើងទឹក"]។

995 ឯកសារ D54/34 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង ឆុន ឆ.៥-៦ ["នៅពេលនោះ មានកងពលថ្មើរជើងទី ១ ដែលបានដាក់ពង្រាយតាមកន្លែងផ្សេងៗនៅកោះកុង [...] ឆ.៦៖ កងកប៉ាល់របស់ខ្ញុំគឺមិនមែនឋិតនៅតែមួយកន្លែងក្នុងក្រុងកោះកុងទេ យើងចល័តពីមួយកន្លែងទៅមួយកន្លែង ដើម្បីការពារវ៉ៃដោយយន្តហោះថៃ ពេលខ្លះ យើងទៅចតនៅ ពយឡាំដាំ និងពេលខ្លះ ទៅចតនៅពយអារយាយសែន។ កោះទាំងពីរនេះ មិនឋិតនៅកោះកុងទេ"]។ ឯកសារ D54/54 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.១៧ ["កងពល ១ មានទីបញ្ជាការកងពលនៅបន្ទាយលង្វែក ដោយសារទឹកដីកោះកុងស្ថិតនៅក្នុងភូមិភាគបស្ចិម [...] មួយវរសេនាធំ ដែលមានបីវរសេនាតូចក្រោមការបញ្ជារបស់ខ្ញុំ យកទៅប្រតិបត្តិការនៅប៉ែកកោះកុង ហើយមួយផ្នែកទៀត ស្ថិតនៅទីបញ្ជាការកងពលនៅបន្ទាយលង្វែក"]។

996 ឯកសារ D54/34 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង ឆុន ឆ.៥, ៧ ["នៅកងពលទី ១ គេមានកែវយិត និងរ៉ាដារបស់គេសម្រាប់ចាប់ទិសទូកនេសាទខុសច្បាប់។ [...] ឆ.៧៖ ស្ថានីយ៍រ៉ាដា និងកែវយិត គឺស្ថិតនៅក្រោមកងពលទី ១"]។

997 ឯកសារ D54/53 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.៤ ["បាទ ការចែករំលែកព័ត៌មានគ្នា គឺសំខាន់ណាស់សម្រាប់ប្រតិបត្តការរបស់យើងក្នុងការចាប់ទូកនេសាទថៃ និងវៀតណាម"]។

998 ឯកសារ D54/34 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង ឆុន ឆ.១២ ["នៅពេលកងពលទី ១ បានរាយការណ៍ទៅឲ្យមន្ទីរសារទូរលេខរបស់កងនាវានៅក្នុងកោះកុងតាមរយៈវិទ្យុទាក់ទង។ អ្នកកាន់សារទូរលេខ រាយការណ៍បន្តទៅឲ្យ តាមុត ហើយ តាមុត ជាអ្នកចេញបញ្ជា"]។ ឯកសារ D54/52 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.៣៥ ["បាទ ខ្ញុំត្រូវតែផ្តល់ព័ត៌មានឲ្យកងរបស់ ស៊ឹម នៅពេលដែលខ្ញុំបានឃើញកប៉ាល់ពីចម្ងាយ ដូចជា ៧០ គីឡូម៉ែត្រទឹក ឬក៏ច្រើនជាងនេះ។ ប្រសិនបើខ្ញុំមិនផ្តល់ព័ត៌មាននេះទៅឲ្យកងនេះ ខ្ញុំនឹងត្រូវបានគេស្តីបន្ទោស បើសិនជាមានរឿងអ្វីកើតឡើង។ បន្ទាប់ពីខ្ញុំបានផ្តល់ព័ត៌មានទៅពួកគេ កងនោះ នឹងរាយការណ៍ទៅថ្នាក់លើរបស់គេគឺកងពលលេខ ៣ ដើម្បីទទួលបញ្ជាចានិងការណែនាំ ថាត្រូវធ្វើយ៉ាងម៉េច"]។

999 ឯកសារ D54/51 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.១៧ ["ប្រសិនបើមានជម្លោះនៅលើសមុទ្រជាមួយប្រទេសដទៃ កងពលលេខ ១ ធ្វើការទាក់ទងកងទ័ពជើងទឹកដើម្បីអន្តរាគមន៍ទប់ទល់ជាមួយបញ្ហាទាំងនោះ ពីព្រោះកងទ័ពជើង

កម្លាំងយោធាក្រោមបញ្ជារបស់ **មាស មុត** បើកកប៉ាល់ទាំងនោះ ដោយសហប្រតិបត្តិការជាមួយកងពលលេខ ១[1000]។

305. **មាស មុត** ផ្ញើបញ្ជាទៅអ្នកកាន់ទូរលេខ នៅកោះកុង រួចអ្នកកាន់ទូរលេខផ្ញើបញ្ជាត្រឡប់ទៅមេបញ្ជាការនាវា ដោយបញ្ជាក់អំពីសេចក្ដីណែនាំអំពីរបៀបចាត់ការជាមួយកប៉ាល់មុខសញ្ញា[1001]។ ប្រសិនបើឧប្បត្តិហេតុកើតឡើង ក្នុងអំឡុងពេលប្រតិបត្តិការរួមគ្នា តាសឿង ត្រូវពិភាក្សាជាមួយ **មាស មុត** មុននឹងចេញបញ្ជាទៅកងពលលេខ ១[1002]។ បន្ទាប់ពីកងពលលេខ ១ ចាប់បានទូកមួយ អ្នកទោសត្រូវបញ្ជូនទៅកងពល ១៦៤ នៅកំពង់សោម[1003]។

---

ទឹកមាននាវាចម្បាំង ឯកងពលលេខ ១ មិនមាននាវាចម្បាំង គឺមានតែទូកតូចៗសម្រាប់ល្បាត និងដឹកជញ្ជូនប៉ុណ្ណោះ"]។ ឯកសារ D54/34 កំណត់ហេតុស្ដាប់ចម្លើយ អ៊ឹង ឆុន ឆ.១២ ["ចំពោះសំណួរដែលថា កងពលទី ១ ត្រូវរាយការណ៍ទៅឱ្យមន្ទីរសារទូរលេខរបស់កងពល ១៦៤ ពីព្រោះ កងពលទី ១ មិនមាននាវាប្រយុទ្ធសម្រាប់ប្រឈមនឹងព្រឹត្តិការណ៍នោះទេ"]។

1000 ឯកសារ D54/50 កំណត់ហេតុស្ដាប់ចម្លើយ មាស វឿន ឆ.១៩ ["នៅពេលនោះ យោធារបស់ មាស មុត បើកកប៉ាល់មកធ្វើការសហការជាមួយកងរបស់ខ្ញុំនៅកោះកុង។ យោធារបស់ខ្ញុំពេលនោះ ដាក់ពង្រាយនៅតាមកោះនានានៅខេត្តកោះកុង។ ដូច្នេះ នៅពេលដែលកងយោធារបស់កងពល មាស មុត បើកប៉ាល់មកកោះកុង ពួកយើងតែងតែសហការគ្នាធ្វើការនៅក្នុងតំបន់នោះ"]។

1001 ឯកសារ D54/34 កំណត់ហេតុស្ដាប់ចម្លើយ អ៊ឹង ឆុន ឆ.២, ៥ ["នៅពេលដែលអ្នកកាន់សារទូរលេខនៅហ្វ៊ីង ផែ ទទួលបញ្ជាពីកន្លែង តាមុត អ្នកកាន់សារទូរលេខនោះផ្ដល់បញ្ជានោះទៅឱ្យមេបញ្ជាការកប៉ាល់ [...] ឆ.៥៖ នៅពេលគេចាប់បានទិសដៅមួយ គេបានបញ្ជូនព័ត៌មានមកកងកប៉ាល់ បន្ទាប់មកខាងកងកប៉ាល់រាយការណ៍ទៅ តាមុត តាមសារទូរលេខ ហើយតាមុត នឹងចេញបញ្ជាត្រឡប់មកមេបញ្ជាការកប៉ាល់វិញថា ត្រូវធ្វើយ៉ាងម៉េចជាមួយទូកនេសាទទាំងនោះ"]។

1002 ឯកសារ D54/52 កំណត់ហេតុស្ដាប់ចម្លើយ មាស វឿន ឆ.៣ ["យើងមិនអាចមានអំណាចដើម្បីបញ្ជាលើកងទ័ពជើងទឹកទេ។ ប្រសិនបើមានរឿងអ្វីកើតឡើងក្នុងអំឡុងពេលប្រតិបត្តិការរួមគ្នានោះ តាសឿង ដែលជាមេបញ្ជាការកងពលលេខ ១ ហើយនិង តាមុត ពិភាក្សាជាមួយគ្នា មុននឹងចេញបញ្ជាឱ្យយើងធ្វើការងាររបស់យើងរៀងៗខ្លួន។ ពួកខ្ញុំចាំតែទទួលបញ្ជាពីមេបញ្ជាការរបស់ខ្លួនតែប៉ុណ្ណោះ មាន តាសឿង និងតាមុត"]។

1003 ឯកសារ D54/53 កំណត់ហេតុស្ដាប់ចម្លើយ មាស វឿន ឆ.១៧-១៨ ["យើងបានបញ្ជូនអ្នកនេសាទទាំងនោះ ទៅឱ្យកងទ័ពជើងទឹកនៅផែកំពង់សោម [...] ឆ.១៨៖ យើងបានប្រាប់ តាសឿង ហើយតាសឿង បានជូនដំណឹងទៅឱ្យកងទ័ពជើងទឹកជាមុន មុននឹងពេលដែលយើងបញ្ជូនអ្នកទាំងនោះទៅ"]។

306. **មាស មុត** ក៏ទាក់ទងផងដែរជាមួយ សឿង តាមវិទ្យុទាក់ទង ពាក់ព័ន្ធនឹងកប៉ាល់ និងកម្លាំងយោធា នៅកោះកុង[1004]។ **មាស មុត** ជួប សឿង ម្តងម្កាល ដើម្បីចេញសេចក្តីណែនាំដល់កងពលលេខ ១[1005]។ កងពល ១៦៤ មានឋានៈខុសពីកងពលលេខ ១ ដោយសារតែកងពល ១៦៤ ស្ថិតនៅក្រោមមជ្ឈិម ចំណែកឯកងពលលេខ ១ ស្ថិតនៅក្រោមភូមិភាគបស្ចិម[1006]។ យោងតាមចម្លើយ

---

[1004] ឯកសារ D54/50 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.២០-២១ ["ដំបូង មាស មុត បានទំនាក់ទំនងជាមួយ តាសឿង តាមវិទ្យុទាក់ទង ហើយបន្ទាប់មក តាសឿង បានប្រាប់ខ្ញុំអំពីកប៉ាល់ និងយោធារបស់ មាស មុត នឹងមកដល់កោះកុង ដើម្បីសហការគ្នាធ្វើការ។ [...] ឆ.២១៖ ខ្ញុំចាំថាមានតែម្តងហ្នឹងទេ ការទំនាក់ទំនងរវាងអ្នកទាំងពីរនោះ គឺនៅក្នុងឆ្នាំ ១៩៧៨"]។ សូមមើលផងដែរ ឯកសារ D54/53 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.១, ៩ ["តាសឿង បានណែនាំ ឲ្យចែករំលែកព័ត៌មានជាមួយ ស៊ីម នៃកងជើងទឹករបស់កងពលលេខ ៣។ [...] ឆ.៩៖ ខ្ញុំនៅចាំព្រឹត្តិការណ៍អំពីការចាប់ទូកចំនួនពីរគ្រឿង គឺចាប់បាននៅកោះកុងក្រៅ។ មុនពេល ស៊ីម ចេញទៅចាប់ទូកពីរគ្រឿងនោះ គាត់បានប្រាប់ខ្ញុំតាមវិទ្យុទាក់ទងថា គាត់ចេញទៅប្រតិបត្តិការចាប់ទូកនេសាទពីរគ្រឿងនោះ នៅក្នុងដែនទឹករបស់យើងក្នុងចម្ងាយប្រហែល ៥០ គីឡូម៉ែត្រទឹក ពីកោះកុងក្រៅទៅ។ ខ្ញុំបានឆ្លើយប្រាប់គាត់ថា ខ្ញុំយល់ព្រមជាមួយគាត់ ហើយខ្ញុំបានបើកវិទ្យុទាក់ទង ដោយបង្វិលប្រេកង់ឲ្យត្រូវជាមួយវិទ្យុទាក់ទងរបស់គាត់ ដើម្បីឲ្យយើងបានទាក់ទងគ្នាជាប់គ្នារហូត។ ពេលនោះ ខ្ញុំបានផ្តល់ដំណឹងទៅឲ្យកងរបស់ខ្ញុំនៅតាមកោះនានា អំពីប្រតិបត្តិការនេះ។ ខ្ញុំបានប្រាប់ទៅកង ដេកា ៧៦ និង ២០ មម និង ៨០ មម នៅលើកោះកុង ដើម្បីឲ្យគេដឹងអំពីកិច្ចប្រតិបត្តិការនេះ ដើម្បីចៀសវាងការបាញ់គ្នាច្រឡំ"]។

[1005] ឯកសារ D54/54 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.៥, ១៦ ["ពេលខ្លះគាត់ ជួបជាមួយ តាសឿង ដើម្បី [...] ណែនាំអំពីការប្រតិបត្តិការនៅក្នុងដែនសមុទ្រកម្ពុជា។ កងទ័ពជើងទឹករបស់គាត់មានសិទ្ធិធ្វើប្រតិបត្តិការទូទាំងផ្ទៃសមុទ្រប្រទេសកម្ពុជា ហើយគាត់ប្រហែលជាអាចមានសិទ្ធិអំណាចលើកងផ្សេងទៀត ដែលប្រតិបត្តិការនៅតាមទន្លេមេគង្គផងដែរ។ [...] ឆ.១៦៖ ខ្ញុំមិនដឹងថាតើពួកគេមានការប្រជុំជាទៀតទាត់ ឬញឹកញាប់នោះទេ ប៉ុន្តែ ខ្ញុំសង្កេតឃើញថា ពួកគេប្រជុំនៅពេលដែលមានបញ្ហានៅក្នុងដែនសមុទ្រ ដូចជាកប៉ាល់ថៃចូលមកក្នុងដែនសមុទ្រកម្ពុជា ការនេសាទរបស់អ្នកនេសាទថៃជាដើម"]។ សូមមើលផងដែរ ឯកសារ D54/52 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.៣២ ["ការប្រជុំនេះ ធ្វើឡើងរៀងរាល់ថ្ងៃ ឬរៀងរាល់ ៣ ថ្ងៃម្តង នៅលើកោះកុងក្រៅ។ កប៉ាល់របស់កងពលលេខ ៣ បោះយុទ្ធថ្កានៅជិតកោះកុងក្រៅតាំងពីដើមឆ្នាំ ១៩៧៨។ នៅពេលនោះ កងរបស់ខ្ញុំគឺបោះទីតាំងនៅលើផ្ទៃកោះកុងក្រៅទាំងមូល ហើយកប៉ាល់របស់កងពលលេខ ៣ បោះយុទ្ធថ្កានៅក្បែរៗនោះ"]។ ឯកសារ D98/3.1.179 មាស វឿន ប្រតិចារឹកថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ ម៉ោង 11.42.17-11.44.40 ["ឯកងពលគេ គេអត់ដែលមកជួបយើងទេ តែគេប្រាប់តាមរយៈវរសេនាធំ ឬក៏វរសេនាតូច ដែលមកចែកព្រំដែនគ្នាហ្នឹង កុំឲ្យការមានការច្រឡំគ្នា ឬក៏មានការបាញ់គ្នាអី ក្នុងពេលទំនាក់ទំនងគ្នាឲ្យហើយអីចឹង"]។

[1006] ឯកសារ D54/54 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.៤ ["មាស មុត ជាមេបញ្ជាការកងពលលេខ ១៦៤ ដែលជាកងពលនៅក្រោមសេនាធិការ ហើយនិងជារបស់មជ្ឈិម។ កងពលលេខ ១៦៤ មានឋានៈខុសពីកងពលលេខ ១

របស់ មាស វឿន, **មាស មុត** មានសិទ្ធិអំណាចក្នុងការណែនាំអំពីប្រតិបត្តិការដល់អង្គភាពយោធា ដូចជា កងពលលេខ ១ ជាដើម[1007]។

**ទំនាក់ទំនងរវាងកងពល ១៦៤ និងកងពល ១១៧**

307. **មាស មុត** បានរៀបចំកិច្ចប្រជុំមួយនៅខេត្តក្រចេះ ហើយបានប្រកាសអំពីជនក្បត់នៅក្នុងកងពល ១១៧ និងតម្រូវឱ្យផ្លាស់ប្តូរថ្នាក់ដឹកនាំកងពល[1008]។ គាត់ចាប់ផ្តើមទទួលខុសត្រូវចំពោះព្រំដែនខាងកើតរបស់កម្ពុជា ពេលកងកម្លាំងវៀតណាមចាប់ផ្តើមចូលលុកលុយ នៅឆ្នាំ ១៩៧៨[1009]។

## VI. ជម្លោះប្រដាប់អាវុធអន្តរជាតិ

308. ជម្លោះប្រដាប់អាវុធបានកើតឡើងរវាងកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម (ស.ស.វ) ចាប់ពីខែ ឧសភា ឆ្នាំ ១៩៧៥ រហូតដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ជាថ្ងៃផុតយុត្តាធិការពេលវេលារបស់តុលាការនេះ។ ភ្លាមៗក្រោយពីខ្មែរក្រហមទទួលបានជ័យជម្នះលើកងកម្លាំង លន់ នល់ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ កម្ពុជាប្រជាធិបតេយ្យបានដាក់ពង្រាយយោធា ដើម្បីការពារព្រំដែនគោក និងព្រំដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ-ស.ស.វ[1010]។ ការប៉ះទង្គិចគ្នាដោយអាវុធ

---

របស់ខ្ញុំ។ សម្រាប់ខ្ញុំ ខ្ញុំគ្រាន់តែជាសមាជិករបស់គណៈកងពលលេខ ១ របស់ភូមិភាគបស្ចិមប៉ុណ្ណោះ។ កងពលរបស់ខ្ញុំស្ថិតនៅថ្នាក់ភូមិភាគដែលមានឋានៈនៅក្រោមកងពលរបស់ មាស មុត ដែលនៅថ្នាក់មជ្ឈិម"]។

1007 ឯកសារ D54/54 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.៥ ["ខ្ញុំបានសង្កេតថា ការងាររបស់គាត់គឺផ្តោះបញ្ចាំងទៅនឹងតួនាទីដែលគាត់ជាសមាជិកម្នាក់របស់គណៈកម្មាធិការសេនាធិការ ដោយសារខ្ញុំធ្លាប់បានឃើញគាត់មានសិទ្ធិណែនាំទៅកងផ្សេងៗទៀត ដូចជាកងពលលេខ ១ របស់ខ្ញុំជាដើមនៅក្នុងការប្រតិបត្តិការនៅក្នុងដែនសមុទ្រ"]។

1008 ឯកសារ D54/63 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ឆ.១-២ ["តាមការចងចាំរបស់ខ្ញុំ ខ្ញុំចាំថា ខ្ញុំបានចូលរួមប្រជុំជាមួយ មាស មុត ម្តង នៅពេលដែលគាត់មកបើកការប្រជុំ និងប្រកាសការផ្លាស់ប្តូរថ្នាក់ដឹកនាំកងពល។ ពេលនោះគាត់ថា ញ៉ាន់ មកទទួលដឹកនាំជំនួស រុំ នៅក្នុងកងពល ១១៧។ ខ្ញុំចាំអំពីការចូលរួមក្នុងអង្គប្រជុំនោះ ប៉ុន្តែ ខ្ញុំមិនចាំថ្ងៃខែទេ។ [...] ឆ.២៖ មុនពេល មាស មុត ដើរមកចូលរួមប្រជុំ គាត់បាននិយាយថា នៅខាងក្រៅជាមួយនីរសារ និងយោធាផ្សេងៗទៀតថា "មេៗរបស់ឯងក្បត់អស់ហើយ"]។

1009 ឯកសារ D54/63 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ឆ.១៩ ["តាមការដឹងរបស់ខ្ញុំ មាស មុត ចាប់ផ្តើមពាក់ព័ន្ធទទួលខុសត្រូវបញ្ហានៅតាមព្រំដែនខាងកើតក្នុងឆ្នាំ ១៩៧៨ ពេលដែលយួនវាយបុកខ្លាំង"]។

1010 ឯកសារ D54/96 កំណត់ហេតុស្តាប់ចម្លើយ តេង សារីម ឆ.២ ["ក្រោយពីទទួលបានជ័យជម្នះលើរបប លន់ នល់ ក្នុងឆ្នាំ ១៩៧៥ ខ្ញុំត្រូវបានបញ្ជូនទៅការពារនៅតាមព្រំដែនវៀតណាម"] ឆ.៤ ["ខ្ញុំនៅការពារនៅព្រំដែនវៀតណាមរហូតដល់ឆ្នាំ ១៩៧៧"]។ ឯកសារ D114/246 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល ញ៉ន ឆ.៨ ["ស៖ ក្រោយការរំដោះទី

បានចាប់ផ្តើមក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ ពេលកម្លាំងកម្ពុជាប្រជាធិបតេយ្យវាយយកកោះរបស់វៀតណាម គឺភូគុក (ជាភាសាខ្មែរ "កោះត្រល់") និងថូជូ (ជាភាសាខ្មែរ "កោះក្រចកសេះ")

---

ក្រុងភ្នំពេញ ក្នុងខែមេសា ឆ្នាំ ១៩៧៥ តើគេមានចាត់តាំងឲ្យលោកទៅទីណាដែរឬទេ? ឆ.៨៖ ដូចថាយើងរំដោះក្រុងតាកែវ ហើយគេដកកម្លាំងចេញពីទីក្រុងតាកែវ ហើយគេបញ្ជូនទៅព្រំដែនជិតវៀតណាម"]។ ឯកសារ D114/287 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ.១៧ ["ពេលដែលគេបញ្ជូនទ័ពដល់កំពង់សោម គេបញ្ជូនទ័ពមួយចំនួនទៅកាន់នៅកោះក្រចកសេះ និងកោះពូលូវ៉ៃ។ [...] នៅពេលនោះ វៀតណាមនៅមិនទាន់បែកនៅឡើយទេ [...] យើងត្រូវទៅកាន់កាប់ ព្រោះប្រវត្តិសាស្ត្រថាកោះទាំងនោះជារបស់ខ្មែរ"]។ ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.២១-២២ ["កងតំបន់ និងកងពលទី៣ បញ្ជូនទៅកោះពូលូវ៉ៃថ្មី កោះពូលូវ៉ៃចាស់ កោះរុងសន្លឹម និងកោះរុងធំ ហើយនិងកោះម្នាស់ និងកោះតាង [...]។ ឆ. ២២៖ ការចាប់ផ្តើមគឺពីថ្ងៃ ១៨ (ខែមេសា ឆ្នាំ ១៩៧៥)"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.២៤-២៥ ["តាមខ្ញុំចាំ ក្រោយទទួលបានជ័យជម្នះទាំងស្រុងនៅទីក្រុងភ្នំពេញ និងខេត្តកំពង់សោម គេដឹកយើងតាមកប៉ាល់ឲ្យទៅយាមនៅលើកោះតែម្តង។ ស៖ តើអីចឹងភ្លាមៗក្រោយការទទួលជ័យជម្នះមែនទេ? ឆ.២៥៖ បាទ ត្រឹមត្រូវហើយ"]។ ឯកសារ D54/28 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡួន ឆ.១៤ ["នៅពេលដែលភ្នំពេញដួលរលំ កងរបស់ខ្ញុំត្រូវបានគេបញ្ជូនទៅរាម។ នៅពេលនោះ កងរបស់ខ្ញុំគឺត្រូវបានបញ្ចូលជាមួយកងពលលេខ ៣ ដែល មាស មុត ជាមេបញ្ជាការ។ ពួកយើងនៅរាម តែ ១ ថ្ងៃ ហើយក៏ត្រូវបញ្ជូនទៅកោះសេះ ដោយនៅទីនោះប្រហែល ១ ខែ"]។ ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.៨ ["ខ្ញុំមកដល់កំពង់សោម នៅប្រហែលម៉ោង ៦ ល្ងាច នៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥។ ខ្ញុំស្នាក់នៅផែកំពង់សោម បានប្រហែល ១ អាទិត្យ បន្ទាប់មកគេបញ្ជូនខ្ញុំទៅកោះតាង"] ឆ.៤៧-៤៨ ["ស៖ តើលោកចាំទេ នៅថ្ងៃខែឆ្នាំណា ដែលគេបញ្ជូនលោកទៅកោះតាង? ឆ.៤៧៖ ប្រហែលនៅថ្ងៃទី ២៦ ឬ ២៧ ខែ មេសា ឆ្នាំ ១៩៧៥។ ឆ.៤៨៖ [...] ប្រហែល ១ អាទិត្យក្រោយពីយើងទៅដល់កោះតាង តាក់ បានបើកកប៉ាល់ បេអឺ ដោយដឹកកាំភ្លើងធន់ធំមកឲ្យយើង ដូចជា ដេកា ៨២ ពីរដើម ដេកា ៧៥ ពីរដើម ដេកា ១០៦ ពីរដើម និង១២,៧ មីលីម៉ែត្រ ពីរដើម"]។ ឯកសារ D54/20 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ. ៣ ["ខ្ញុំត្រូវបានគេចាត់តាំងឲ្យទៅនៅកោះសេះ បន្ទាប់មកបានទៅនៅកោះតាងក្នុងខែមិថុនា ឆ្នាំ ១៩៧៥"]។ ឯកសារ D54/38.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ លន់ សេង KH ERN 00967310 ["ក្រោយពេលដែលយើងចប់សង្គ្រាមនៅលើគោក ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ហ្នឹងមក គេក៏បញ្ជូនយើងទៅបញ្ជូនកងទ័ព [...] គេយកទៅដាក់នៅតាមកោះ"]។ ឯកសារ D59/1/1.7a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ា ឈឿន KH ERN 00926305 ["ស៖ អីចឹងពេលបែកភ្នំពេញឆ្នាំ ៧៥ ថ្ងៃ ១៧ មេសា ឆ្នាំ ៧៥ ហ្នឹង ខាងពូគេរុញមកខាងកំពង់សោម? ឆ៖ បាទ។ [...] ខ្ញុំកម្លាំងរៀបចំថ្មីហ្នឹង គ្រាន់ត្រៀមណារៀបចំទៅកោះ"] KH ERN 00926311 ["ស៖ អីចឹងតាំងពីបែកឆ្នាំ ៧៥ គេបញ្ជូនមកដល់កន្លែងកងកេង ២-៣ ថ្ងៃ គេបញ្ជូនទៅកោះ? ឆ៖ បាទ"]។ ឯកសារ D32/12.1 Pham Van Tra ជីវិតយោធាម្នាក់៖ ការចងចាំ EN ERN 00432793 ["ភ្នំពេញត្រូវបានរំដោះថ្ងៃ ១៧ មេសា។ ដោយឆ្លៀតឱកាសក្នុងអំឡុងពេលដែលយើងនៅវៀតណាមកំពុងតែយកចិត្តទុកដាក់ដោះស្រាយបញ្ហានៅក្នុងទីក្រុងភ្លាមៗក្រោយរំដោះ ប៉ុល ពត បានបញ្ជូនកងទ័ព [...] ដើម្បីរឹបអូស និងកាន់កាប់កោះរបស់យើង"]។

ដោយបានចាប់ និងសម្លាប់ប្រជាជននៅលើកោះ[1011]។ វៀតណាមបានវាយដណ្តើមយកកោះវិញពីរសប្តាហ៍ក្រោយមក ដោយបានសម្លាប់ទាហានខ្មែរក្រហមអស់ជាច្រើននាក់ និងចាប់ជាឈ្លើយ

[1011] ឯកសារ D234/2.1.1 សន្និសីទកាសែតក្រសួងការបរទេសសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៧៨ KH ERN 00305306 ["នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៧៥ កងទ័ពកម្ពុជាបានឡើងលើកោះ Phu Quoc និងនៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៥ ពួកគេបានធ្វើការវាយប្រហារពីដីគោក និងពី Hon Troc (កោះវៃ) នៅលើកោះ Tho Chu របស់វៀតណាម"]។ ឯកសារ D234/2.1.13 សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 00656202 ["ចាប់ទាំងពីដើមខែ ឧសភា ឆ្នាំ ១៩៧៥ មក កម្ពុជាបានដាក់ពង្រាយកងទ័ពរបស់ខ្លួន នៅក្នុងការវាយប្រហារទៅលើកោះភូកុក និងកោះថូជូ ដោយបានបណ្តេញជនស៊ីវិលជាង ៥០០ នាក់ចេញពីទីនោះ"]។ ឯកសារ D1.3.12.21 របាយការណ៍ក្រសួងការបរទេសសាធារណរដ្ឋសង្គមនិយមវៀតណាម ខែ មករា ឆ្នាំ ១៩៧៨ លោកនាយករដ្ឋមន្ត្រី ផាម វ៉ាន់ដុង ឆ្លើយតបទៅនឹងបទសម្ភាសន៍ធ្វើឡើងដោយទីភ្នាក់ងារសារព័ត៌មានវៀតណាម KH ERN 00283132 ["នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៧៥ កងកម្លាំងប្រដាប់អាវុធកម្ពុជាបានវាយប្រហារ កោះហ្វូកុក"] វៀតណាមៈ ព្រំដែនវៀតណាម និងកម្ពុជា និងគោលនយោបាយរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ចំពោះការដោះស្រាយបញ្ហានេះ KH ERN 00283136 ["ការរំលោភបំពានមកលើទឹកដីវៀតណាម ដែលភាគីកម្ពុជាបានប្រព្រឹត្តនៅដើមខែ ឧសភា ឆ្នាំ ១៩៧៥ នៅពេលដែលភាគីកម្ពុជាបានចេញបញ្ជា ឱ្យកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនចូលចតលើកោះហ្វូកុក ហើយបើកការវាយប្រហារទីលើកោះថូជូ"]។ ឯកសារ D69.1.30 បណ្ណាល័យនៃរបាយការណ៍សមាជ ជម្លោះវៀតណាម-កម្ពុជា ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៧៨ EN ERN 00187387 ["ខែ មេសា និងឧសភា ឆ្នាំ ១៩៧៥៖ [...] ប្រជាជនកម្ពុជា (និយាយភាសាវៀតណាម) ប៉ុនប៉ងរឹបអូសកោះភូកុក និងកោះថូជូ ហើយនិងចាប់ពង្រត់មនុស្ស ៥០០ នាក់ នៅក្នុងដំណើរការនេះ"]។ ឯកសារ D54/6.1.12 ណាយ៉ាន់ ចាន់ដា ប្រតិចារឹកថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៩ ម៉ោង ១៣.៤៤.០០-១៣.៤៨.៤៨ ["ពួកគេបានប្រើប្រាស់ទូក ហើយនិងកងកម្លាំងប្រដាប់អាវុធ ក្នុងការទៅវាយឆ្មក់យកកោះហ្វូកុក និងកោះថូជូ"]។ ឯកសារ D69.1.36 រោងពុម្ពភាសាបរទេស ជម្លោះកម្ពុជា-វៀតណាម (កំណត់ត្រាប្រវត្តិសាស្ត្រ) EN ERN 00187338 ["នៅថ្ងៃទី ០៤ ខែ ឧសភា [កងកម្លាំងប្រដាប់អាវុធកម្ពុជា] បានមកដល់កោះភូកុក និងនៅថ្ងៃទី ១០ ខែ ឧសភា បានកាន់កាប់កោះថូជូ ការសម្លាប់រង្គាល់ប្រជាជនជាច្រើន និងយកអ្នកស្រុកចេញ ៥១៥ នាក់"]។ ឯកសារ D234/2.1.11 Tuoi Tre News ការចុះចតដ៏គួរឱ្យរន្ធត់របស់ខ្មែរក្រហម ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤ KH ERN 01218829 ["របបខ្មែរក្រហម [...] បានបញ្ជូនកងទ័ពទៅចុះចតនៅលើកោះ Tho Chu នៅភាគនិរតីប្រទេសវៀតណាម និងបានចាប់ពង្រត់អ្នកដែលរស់នៅលើកោះទាំងអស់ចំនួន ៥១៣ ក្នុងខែ ឧសភា ឆ្នាំ ១៩៧៥"] KH ERN 01218832 ["ហើយប្រជាជនទាំង ៥១៣ នាក់ដែលជិះនៅលើទូកនេសាទចំនួនពីររបស់ខ្មែរក្រហម ក្រោយមកត្រូវបានអះអាងថាត្រូវបានសម្លាប់ទាំងអស់នៅលើកោះតាង"]។ ឯកសារ D1.3.17.5 ណាយ៉ាន់ ចាន់ដា សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម KH ERN 00191318 ["ខ្មែរក្រហមបានវាយលុកតាមផ្លូវសមុទ្រចូលត្រួតត្រាលើកោះនោះយ៉ាងរហ័ស។ កងទ័ពទាំងនេះបានឡើងទៅលើកោះនៅថ្ងៃ ០៤ ខែ ឧសភា ឆ្នាំ ១៩៧៥។ ៦ ថ្ងៃក្រោយមក ខ្មែរក្រហមបានវាយយកកោះពូលូប៉ង់ហ្សង់ វៀតណាមហៅថា ថូជូ ខ្មែរហៅថាកោះក្រចកសេះថែមទៀត។ ក្រោមការគំរាម

សឹកប្រហែល ៣០០ នាក់[1012]។ ជាការសងសឹកបន្ថែមទៀត វៀតណាមបានវាយយកកោះពូលូវៃ ក្នុងខែ មិថុនា ឆ្នាំ ១៩៧៥[1013] ហើយប្រគល់ឱ្យវិញ ពីរបីខែក្រោយមក[1014]។ ការប៉ះទង្គិចគ្នារវាង

---

កំហែងនៃអាវុធ ប្រជាជនវៀតណាម ៥០០ នាក់បានត្រូវបណ្តេញចេញពីទីនោះ"]។ ឯកសារ D54/74.1.15 ខៀវ សំផន ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ KH ERN 00103847 ជើងទំព័រ ៥១ ["នៅថ្ងៃ១០ ខែ ឧសភា ឆ្នាំ ១៩៧៥ អង្គភាពមួយនៃកងជើងទឹកដ៏ក្មេងខ្ចីរបស់ខ្មែរ បានទៅរឹបអូសយកកោះពូលូប៉ង់ហ្សង់ (ខ្មែរហៅថា ក្រចកសេះ)"]។ ឯកសារ D114/276.1.1 Tran Dai Quang, Tho Chau – កោះដែលចាប់ពង្រត់ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៦ KH ERN 01517418 ["ខែ មេសា ឆ្នាំ ១៩៧៥ […] កងទ័ពខ្មែរក្រហមបានចូលកាន់កាប់កោះថូជូ (ខេត្តKien Giang) […] ប្រជាជនរស់នៅលើកោះជាង ៥០០នាក់ ត្រូវបានចាប់ពង្រត់ ហើយត្រូវបានយកចេញពីកោះ"], KH ERN 01517422 ["នៅយប់ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៧៥ […] ពួកគេបានយកមនុស្សចេញទៅបាត់"]។ ឯកសារ D114/266.1.4 Nhan Dan អ្នកបង្កឱ្យមានការសម្លាប់រង្គាលប្រជាជនកម្ពុជា និងសង្គ្រាមប្រឆាំងវៀតណាម ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៨ KH ERN 01506908 ["ក្នុងរយៈពេលត្រឹមតែ ១៣ ថ្ងៃ ក្រោយការដណ្តើមបានអំណាច ថ្នាក់ដឹកនាំថ្មីបានក្បត់សាមគ្គីភាពយោធាដែលកើត […]ដោយបញ្ជាឱ្យកងទ័ពរបស់ខ្លួនវាយប្រហារលើកោះ Tho Chu និងកោះ Phu Quoc របស់វៀតណាម និងបានចាប់ផ្តើមបង្កសង្គ្រាមដ៏សាហាវមកលើប្រជាជនវៀតណាមរយៈពេលជាង ៣ ឆ្នាំមកហើយ"]។ ឯកសារ D32/12.1 Pham Van Tra ជីវិតយោធាម្នាក់៖ ការចងចាំ EN ERN 00432793 ["នៅថ្ងៃទ ០៣ ខែ ឧសភា ការប្រតិកម្មរបស់ ប៉ុល ពត នៅប្រទេសកម្ពុជាបានបញ្ជូនទ័ពដែលបានវាយប្រហារ និងកាន់កាប់ភាគខាងជើងនៃកោះភូកុក កាន់កាប់កោះហុន អ៊ុង (កោះតា) និងហុន បា (កោះ) (ដែលគេស្គាល់ជាកោះពូលូវៃ) និងកោះ ថូជូ និងសម្លាប់មនុស្សច្រើនជាង ៥០០ នាក់ ដែលជាអ្នករស់នៅយូរអង្វែងនៃកោះទាំងនេះ"]។

1012 ឯកសារ D234/2.1.1 សន្និសីទកាសែតក្រសួងការបរទេសសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៧៨ KH ERN 00305307 ["នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៧៥ កងកម្លាំងប្រដាប់អាវុធមូលដ្ឋានរបស់វៀតណាមត្រូវបានបង្ខំឱ្យប្រើប្រាស់សិទ្ធិការពារខ្លួនស្របច្បាប់របស់ពួកគេ ដើម្បីបណ្តេញអ្នកឈ្លានពានចេញពីកោះ Tho Chu"]។ ឯកសារ D114/287 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.១៧ ["ពេលវៀតណាមខាងជើងរំដោះវៀតណាមខាងត្បូង គេបញ្ជូនទ័ពទៅវៃដណ្តើមកោះក្រចកសេះ និងកោះពូលូវៃពីយើង […] ពួកគេ […]វៃ ចូលកោះក្រចកសេះ និងចាប់ពួកយើងជាឈ្លើយសឹកយកទៅកោះត្រល់"]។ ឯកសារ D114/84 កំណត់ហេតុស្តាប់ចម្លើយ ឯក សុផល ឆ.៨ ["កម្លាំងដែលបញ្ជូនទៅកោះត្រល់ត្រូវបានកងទ័ពវៀតណាមឡោមព័ទ្ធ និងចាប់ខ្លួន ហើយក្លាយជាឈ្លើយសឹក"]។ ឯកសារ D114/264 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី ឆ.២៩ ["នៅលើកោះត្រល់ ដែលយើងបានក្លាយទៅជាឈ្លើយសឹកទាំងអស់គ្នា"]។ ឯកសារ D114/283 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.១២ ["[វៀតណាម] បានទៅយកកោះយើង កោះក្រចកសេះ និងកោះពូលូវៃ។ វាកម្ទេចយើងអស់ ២ កងវរៈ"]។ ឯកសារ D1.3.17.5 ណាយ៉ាន់ ចាន់ដា សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម KH ERN 00191318 ["ពីរសប្តាហ៍ក្រោយការកាន់កាប់របស់ខ្មែរក្រហម វៀតណាមបានបើកការវាយបកមួយសងទៅវិញ ដោយបានសម្លាប់ខ្មែរក្រហមអស់ជាច្រើននាក់ និងចាប់បាន ៣០០ នាក់ជាឈ្លើយសឹក"]។ ឯកសារ D114/276.1.3 Tran Dai Quang Tho Chau – កោះដែលចាប់ពង្រត់៖ ការដោះដូរដែលបរាជ័យ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៦ KH ERN 01517425 ["ក្រោយពីការប្រយុទ្ធគ្នាអស់រយៈពេល

៣ ថ្ងៃ នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៧៥ កងទ័ពប្រជាជនវៀតណាមបានជួយសង្គ្រោះកោះថូជូ បានសម្លាប់មនុស្ស ជិត ២០០ នាក់ និងបានចាប់ខ្លួនខ្មែរក្រហមជាង ៣០០ នាក់។ ទោះជាយ៉ាងនេះក្តី ភារកិច្ចក្នុងការជួយសង្គ្រោះប្រជាជនរស់នៅលើកោះថូជូ ជាង ៥០០ នាក់ មិនបានជោគជ័យនោះទេ"]។ ឯកសារ D69.1.36 រោងពុម្ពភាសាបរទេស ជម្លោះកម្ពុជា-វៀតណាម (កំណត់ត្រាប្រវត្តិសាស្ត្រ) EN ERN 00187338 ["កងកម្លាំងប្រដាប់អាវុធក្នុងតំបន់វៀតណាម បានបើកឱ្យអ្នកឈ្លានពានចេញពីកោះថូជូ"]។ ឯកសារ D32/12.1 Pham Van Tra ជីវិតយោធាម្នាក់៖ ការចងចាំ EN ERN 00432794 ["ចាប់ខ្មាំងដោយភ្ញាក់ផ្អើល កងកម្លាំងរបស់យើងបានបំផ្លាញកងកម្លាំង ប៉ុល ពត មួយកងវរៈសេនាតូច និងចាប់អ្នកទោស ៣០០ នាក់"]។

1013 ឯកសារ D54/74.1.15 ខៀវ សំផន ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ KH ERN 00103847 ជើងទំព័រ ៥១ ["រឿងនេះ នាំឱ្យវៀតណាមប្រតិកម្មតបតវិញយ៉ាងឆាប់រហ័ស។ [...] គេថែមទាំងយកកោះពូលូវ៉ៃថែមទៀត"]។ ឯកសារ D4.1.988 ចម្លើយ អៀង ធីរិទ្ធ ចុះថ្ងៃទី ១៧-១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៧៩ KH ERN 00658249 ["នៅខែ ឧសភា ឆ្នាំ ១៩៧៥ ពួកគេបានកាន់កាប់កោះពូលូវ៉ៃ"]។ ឯកសារ D98/3.1.180 មាស វឿន ប្រតិចារឹកថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១២ ម៉ោង ០៩.១៦.៥១-០៩.១៩.៤៣ ["កងទ័ពវៀតណាមបានចូលវ៉ៃយកកោះ (ពូលូ)វ៉ៃ។ កោះវ៉ៃដែលក្រោមការគ្រប់គ្រងលោក មុត ហ្គឹង"]។ ឯកសារ D54/6.1.12 ណាយ៉ាន់ ចាន់ដា ប្រតិចារឹកថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៩ 09.32.50-09.37.24 ["វៀតណាម [...]ហើយពួកគេក៏បានធ្វើការត្រួតត្រាទៅលើកោះនោះដែរ អស់រយៈពេលប៉ុន្មានខែ"]។ ឯកសារ D234/2.1.93 ព្រុំ សារ៉ាត់ ប្រតិចារឹកថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ១១.០៩.០០-១១.១៣.៤៣ ["កងទ័ពវៀតណាមបានចាប់យកកងទ័ពកម្ពុជាប្រជាធិបតេយ្យចំនួន ៧២០ នាក់ ទៅដាក់មន្ទីរឃុំឃាំងជាឈ្លើយសឹកនៅកោះត្រល់ [...] ការចាប់នេះ គឺចាប់នៅលើអធិបតេយ្យកោះចាស់ ហៅកោះពូលូវ៉ៃចាស់ និងកោះពូលូវ៉ៃថ្មី ជាដែនទឹករបស់កម្ពុជា"]។ ឯកសារ D114/264 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី ឆ.១៣ ["យើងមិនទាន់បានឈរជើងបានប៉ុន្មានថ្ងៃផង ដូចជានៅកោះពូលូវ៉ៃ គេចង់បានកោះយើង។ [...] វៀតណាមឈ្លានពានកោះយើង ហើយបាញ់សម្លាប់ប្រយុទ្ធគ្នា [...] គេចាប់កងទ័ពកម្ពុជាប្រជាធិបតេយ្យយកទៅដាក់គុកទៀត"]។ ឯកសារ D114/261 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី ឆ.៤ ["ប្រយុទ្ធគ្នារយៈពេល មើលទៅបែប ១ សប្តាហ៍ ទៅធ្វើសង្គ្រាមក្នុងរយៈ ៧ ថ្ងៃជាមួយវៀតណាម ដោយការអត់ស្បៀង និងគ្រាប់ និងត្រូវស្លាប់ របួសច្រើន ក៏ត្រូវកំណត់ថា ត្រូវចាញ់សង្គ្រាមជាមួយនឹងវៀតណាម នៅលើកោះពូលូវ៉ៃ។ ពេលនោះ គេចាប់កងទ័ព [...] ចាប់ដាក់ជាឈ្លើយសឹក [....] ក្រោយមក គេបញ្ជូនឈ្លើយសឹកនោះ [...]មកជាប់គុកនៅកោះត្រល់"] ឆ.៥ ["ទើបខែ ៦ អីកងទ័ពវៀតណាមចូលមកវាយកោះពូលូវ៉ៃហ្នឹង"]។ ឯកសារ D114/287 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ.១៧ ["ពេលវៀតណាខាងជើងរំដោះវៀតណាមខាងត្បូង គេបញ្ជូនទ័ពទៅវ៉ៃដណ្តើមកោះក្រចកសេះ និងកោះពូលូវ៉ៃពីយើង"] ឆ.២៩ ["ស៖ ពេលដែលលោកនិយាយពីរឿងវៀតណាមវ៉ៃ ហើយបញ្ជូនអន្តរាគមន៍នៅលើកោះ តើកោះណាមួយ? ឆ.២៩៖ អន្តរាគមន៍គឺ កោះពូលូវ៉ៃ។"] ឆ.៤១ ["ក្រោយមក វៀតណាមវ៉ៃសង្គ្រប់យកទាំងអស់ ហើយចាប់ទាំងកម្លាំងចចាស់ និងថ្មីធ្វើជាឈ្លើយយកទៅកោះត្រល់"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ ឆ.១១១ ["ពេលវៀតណាមមកវ៉ៃ គឺវ៉ៃនៅកោះពូលូវ៉ៃ [...] មិនត្រូវមានខ្មែរមកនៅទេ។ រឿងនេះ វាពិតហើយថា វៀតណាមចាប់មនុស្សពីអង្គភាពរបស់ខ្ញុំយកទៅ"] ។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ. ១១ ["កម្លាំងជាង ២០០ នាក់ត្រូវបានបញ្ជូនឱ្យទៅការពារកោះប៉ូឡូវ៉ៃ ព្រោះនៅពេលនោះវៀតណាមបានចូលមកកាន់កាប់កោះ"]។ ឯកសារ D54/78.1, ឯកសារ

D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល KH ERN 00926622 ["កោះបីដែលគេយក [...] កោះក្រចកសេះ [...] កោះប៉ូឡូវ៉ៃចាស់ និងកោះប៉ូឡូវ៉ៃថ្មី [...] ក្រោយម៉ាយ៉េហ្គេសហ្នឹងមិនជាយូរណាស់ទេ"]។ ឯកសារ D114/27.1.1 កាសែត New York Times វៀតណាមដណ្តើមកាន់កាប់កោះមួយពីកម្ពុជា ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៧៥ ["កោះមួយស្ថិតនៅចម្ងាយពីឆ្នេរសមុទ្រកម្ពុជា ត្រូវបានកងទ័ពវៀតណាមដណ្តើមកាន់កាប់ក្នុងសប្តាហ៍នេះ [...] ការវាយប្រយុទ្ធនោះ គឺដើម្បីដណ្តើមកាន់កាប់កោះពូលូវ៉ៃ ដែលជាកោះថ្មតូចមួយនៅឈូងសមុទ្រសៀម ចម្ងាយប្រហែល ៦០ម៉ាយល៍ពីឆ្នេរសមុទ្រកម្ពុជា"]។ ឯកសារ D1.3.25.3 កាសែត ដឺថាមស៍នៃទីក្រុងឡុងដុង វៀតណាម និងកម្ពុជាស្ថិតនៅក្នុងការប៉ះទង្គិចគ្នាយ៉ាងសាហាវ ចុះផ្សាយថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៧៥ ["កោះវ៉ៃបានទទួលរងការលុកលុយពីសំណាក់កងទ័ពវៀតណាម បន្ទាប់ពីប្រយុទ្ធគ្នាអស់រយៈពេល ៦ ថ្ងៃមក"]។ ឯកសារ D114/276.1.3 Tran Dai Quang, Tho Chau - កោះដែលចាប់ពង្រត់៖ ការដោះដូរដែលបរាជ័យ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១៦ KH ERN 01517426 ["នៅថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ១៩៧៥ កងទ័ពវៀតណាមបានបើកការបាញ់ប្រហារទៅលើខ្មែរក្រហមនៅលើកោះ Hon Ong និង Hon Ba។ [...] ក្នុងអំឡុងពេល ១០ថ្ងៃនៃការប្រយុទ្ធគ្នា កងទ័ពវៀតណាមបានកម្ទេចកងវរសេនាតូចខ្មែរចំនួនពីរ និងចាប់បានឈ្លើយសឹក ៣២០ នាក់"]។ ឯកសារ D1.3.17.1 Elizabeth Becker ពេលសង្គ្រាមរលត់ទៅ៖ កម្ពុជា និងបដិវត្តន៍ខ្មែរក្រហម KH ERN 00232264 ["ពេលនោះ វៀតណាមកាន់កាប់កោះពូលូវ៉ៃម្តងទៀត"]។ ឯកសារ D1.3.25.4 កាសែត Herald Tribune កម្ពុជា និងវៀតណាមនិយាយអះអាងដណ្តើមដែនកោះ ចុះផ្សាយថ្ងៃទី ១៤-១៥ ខែ មករា ឆ្នាំ ១៩៧៥ ["រាយការណ៍ចុងក្រោយពីហេតុការណ៍ប្រយុទ្ធគ្នាដ៏ស្រួចស្រាវបានកើតឡើង កាលពីថ្ងៃទអង្គារនៅកោះពូលូវ៉ៃ ដែលជាកោះតូចមួយដែលមានចម្ងាយ ៦០ ម៉ៃល៍ ពីច្រាំងសមុទ្រ។ [...] តាមការអះអាងមួយ [...] ជនជាតិវៀតណាមខាងជើង ២០០ នាក់ បានឡើងគោកនៅលើកោះនោះដែរ"]។

1014 ឯកសារ D54/6.1.12 ណាយ៉ាន់ ចាន់ដា ប្រតិចារឹកថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៩ ម៉ោង ០៩.៣២.៥០-០៩.៣៧.២៤ ["វៀតណាម [...] ហើយពួកគេក៏បានធ្វើការត្រួតត្រាទៅលើកោះនោះដែរ អស់រយៈពេលប៉ុន្មានខែ មុននឹងបានប្រគល់កោះនោះមកឱ្យខ្មែរក្រហមវិញ"] ម៉ោង ១៣.៥៥.២២-១៣.៥៩.៣៥ ["[វៀតណាម]បានកាន់កាប់កោះពូលូវ៉ៃ ដែលតាមពិត គឺជាកោះរបស់ខ្មែរទេ ប៉ុន្តែ ពេលក្រោយមក គេបានប្រគល់កោះនោះមកឱ្យខ្មែរវិញ"]។ ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.៤ ["កងទ័ពវៀតណាមបានប្រយុទ្ធ ហើយនិងកាន់កាប់កោះពូលូវ៉ៃទាំងពីរបានបីខែ។]។ ឯកសារ D114/264 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី ឆ.៤៧ ["សហគមន៍អន្តរជាតិបានឱ្យវៀតណាមប្រគល់កោះពូលូវ៉ៃចាស់ និងថ្មី ឱ្យកម្ពុជាជាបន្ទាន់។"]។ ឯកសារ D54/78.1, D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល KH ERN 00926622 ["យើងទៅនៅកាន់កោះទាំង ៣ ហ្នឹង ប៉ុនដល់យួនប្រគល់ឱ្យមកវិញ ឱ្យតែ ២ ទេ។ [...] កោះក្រចកសេះ អត់ទេ។ [...] ឱ្យតែប៉ូឡូវ៉ៃចាស់ ប៉ូឡូវ៉ៃថ្មីហ្នឹងទេ"]។

ប្រទេសទាំងពីរនៅតែបន្តរហូតដល់ដើមឆ្នាំ ១៩៧៦ ពាក់ព័ន្ធនឹងកោះ និងដែនទឹកជុំវិញឈូងសមុទ្រថៃ[1015]។

309. នៅលើដីគោក កម្ពុជាប្រជាធិបតេយ្យបានទន្ទ្រានចូលទឹកដីវៀតណាម ចាប់ពីហាទៀង រហូតដល់តាយនិញក្នុងខែ ឧសភា ឆ្នាំ ១៩៧៥[1016]។ ក្នុងខែ ឧសភា និងខែ មិថុនា ជម្លោះបានផ្ទុះឡើងនៅ

---

[1015] សូមមើលឧទាហរណ៍ ឯកសារ D4.1.237 កំណត់ហេតុការប្រជុំអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ KH ERN 00019134 (កោះថ្មី ក្រោយពាក់កណ្ដាលឆ្នាំ ១៩៧៥)។ ឯកសារ D1.3.30.2 របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពីមុត (មាស មុត) ជំរាបជូន បង ៨៩ (សុន សេន) ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៧៦ (កោះត្រល់ ខែ មករា ឆ្នាំ ១៩៧៦)។ ឯកសារ D234/2.1.141 ម៉ា ឈឿន ប្រតិចារឹកថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ ម៉ោង ១៤.៥៣.៣២-១៤.៥៥.១៥ ["វរសេនាតូចរបស់ខ្ញុំឈរជើងនៅកោះសេះ និងកោះថ្មី"] ម៉ោង ១៤.៥៧.៤០-១៥.០០.៤៩ ["អាច ៧៨, ៧៩ ហ្នឹងហើយ"], ម៉ោង ១៥.០៤.៥០-១៥.០៧.០១ ["ការប្រយុទ្ធនៅសមុទ្រ។ [...] ភាគច្រើន គឺវៀតណាមវ៉ៃមុន យើងត្រូវតែតបតវិញដែរ"] (ខែ ឧសភា ឆ្នាំ ១៩៧៥-១៩៧៨)។ ឯកសារ D234/2.1.92 ព្រុំ សារ៉ាត់ ប្រតិចារឹកថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ១០.៤២.០១-១០.៤៦.១១ (កោះត្រល់ រហូតដល់ចុងឆ្នាំ ១៩៧៥)។ ឯកសារ D114/19 កំណត់ហេតុស្ដាប់ចម្លើយ ម៉ាក ឈឿន ឆ. ២៣ ["យើងត្រូវបានណែនាំថា យើងត្រូវតែបាញ់បើយើងជួប។ [ទូកវៀតណាមនៅកោះថ្មី]"] ឆ. ២៤ ["នៅពេលនោះ ពេលដែលមានទំនាស់ វៀតណាមហើយនិងខ្មែរ ក៏មានការវ៉ៃគ្នានៅហ្នឹងកោះក្រចកសេះ និងកោះប៉ូឡូវ៉ៃដែរ"] (១៩៧៥-១៩៧៦)។ ឯកសារ D54/93 កំណត់ហេតុស្ដាប់ចម្លើយ យ៉ែម សំអុន ឆ.២ ["ស៖ លោកអាចរៀបរាប់ តើកងពលលេខ ៣ ធ្វើអ្វីដែរពីឆ្នាំ ១៩៧៥ ទៅ ១៩៧៦? ឆ.២៖ [...] យោធាផ្សេងទៀតនៃកងពលលេខ ៣ គេឲ្យប្រចាំការនៅលើកោះ និងការពារព្រំដែនទឹក។"]។ ឯកសារ D59/1/1.7a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ា ឈឿន KH ERN 00926310-11 (កោះសេះ កោះត្រល់ ឆ្នាំ ១៩៧៥ កោះថ្មី ឆ្នាំ ១៩៧៦)។ ឯកសារ D54/78.1, ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល KH ERN 00926615 ["ការពារប៉ូឡូវ៉ៃចាស់ ប៉ូឡូវ៉ៃថ្មី កោះតាង កោះព្រីង កោះវៀរ ក្រោយមកបង្រួញនៅប៉ុនហ្នឹង ពីមុនការពារនៅកោះរុងទៀត"] (1975-1976)។ ឯកសារ D1.3.17.5 ណាយ៉ាន់ ចាន់ដា សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម KH ERN 00191310 ["ការដួលរលំនៃទីក្រុងព្រៃនគរ និងក្រុងភ្នំពេញបានត្រូវបន្តដោយការប្រយុទ្ធស៊ីសាច់ហុតឈាមរវាង ក្រុមអ្នកឈ្នះ ដើម្បីដណ្ដើមការត្រួតត្រាប្រជុំកោះនានានៅឈូងសមុទ្រថៃទៀត"]។

[1016] ឯកសារ D69.1.36 រោងពុម្ពភាសាបរទេស ជម្លោះកម្ពុជា-វៀតណាម (កំណត់ត្រាប្រវត្តិសាស្ត្រ) EN ERN 00187338 ["នៅមុន ថ្ងៃទី ០១ ខែឧសភា ឆ្នាំ ១៩៧៥ កងកម្លាំងប្រដាប់អាវុធកម្ពុជាបានបំពានទឹកដីវៀតណាមជាច្រើនកន្លែងតាមព្រំដែនពី ហាទៀង ដល់តាយនីញ"]។ ឯកសារ D1.3.12.21 របាយការណ៍ក្រសួងការបរទេសសាធារណរដ្ឋសង្គមនិយមវៀតណាម ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00283132 ["នៅថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៧៥ កងកម្លាំងប្រដាប់អាវុធកម្ពុជា បានឈ្លានពានចូលមកលើទឹកដីវៀតណាម នៅតាមកន្លែងផ្សេងៗ ចាប់តាំងពីហាទៀង រហូតដល់ តាយនីញ"]។ ឯកសារ D1.3.17.8 Steven Ratner និង Jason Abrams ការទទួលខុសត្រូវ

តាមព្រំដែន ជាពិសេសនៅតំបន់ចំពុះទា ខេត្តស្វាយរៀង[1017]។ ក្នុងខែ វិច្ឆិកា កម្ពុជាប្រជាធិបតេយ្យ បានចាប់ផ្តើមចល័តកម្លាំងទៅវាយវៀតណាម[1018] ហើយក្នុងខែ ធ្នូ ពួកគេបានវាយចូលវៀតណាម ១០ គីឡូម៉ែត្រ ក្នុងខេត្តយ៉ាឡៃ ខេត្តកុនទុំ និងខេត្តដាឡាក់[1019]។

---

ចំពោះអំពើឃោរឃៅសិទ្ធិមនុស្សនៅក្នុងច្បាប់អន្តរជាតិ KH ERN 00429400 ["តាំងពីខែ ឧសភា ឆ្នាំ ១៩៧៥ ម្ល៉េះ នៅពេលដែលខ្មែរក្រហមប៉ុនប៉ងដណ្តើមកាន់កាប់ [...] ខេត្តខ្លះតាមព្រំដែន"]។

1017 ឯកសារ D4.1.866 ទង់បដិវត្ត ចេញផ្សាយខែ កុម្ភៈ ឆ្នាំ ១៩៧៨ KH ERN 00064437 (រតនគិរី ស្វាយរៀង និងកំពត ខែ ឧសភា ឆ្នាំ ១៩៧៥ តទៅ)។ ឯកសារ D1.3.25.4 កាសែត Los Angeles Times កម្ពុជា និងវៀតណាមនិយាយអះអាងដណ្តើមដែនកោះ ចុះផ្សាយថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៧៥ ["កងកម្លាំងកម្ពុជា និងវៀតណាមបានបាញ់ផ្លោងដាក់គ្នា នៅក្នុងប៉ះទង្គិចគ្នារប៉េះរប៉ោះរវាងខែមុន [...] ការប៉ះទង្គិចខ្លះបានកើតឡើងនៅលើដីគោក ជាពិសេសនៅតំបន់ព្រំដែនចំពុះសេកដែលមានពេលមួយនោះផ្តល់ទីជម្រកលាក់ខ្លួនឲ្យកងទ័ពវៀតកុង ក្នុងអំឡុងពេលសង្គ្រាម។ [...] ការប៉ះទង្គិចគ្នាមិនមានប្រព័ន្ធគំរូអ្វីទេ ភាគច្រើនទាក់ទងនឹងការបាញ់គ្នាដោយអាវុធធុនតូចរវាងក្រុមទាហាន នៃអង្គភាពតូចៗ"]។ ឯកសារ D1.3.25.5 កាសែត New York Times កងទ័ពវៀតណាមត្រូវបានរាយការណ៍ថា កំពុងប៉ះទង្គិចជាមួយកងទ័ពកម្ពុជា ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៧៥ ["ការប្រយុទ្ធមួយចំនួនបានកើតឡើងនៅជិតសមរភូមិចំពុះទា នៃវៀតណាមខាងត្បូង"]។ ឯកសារ D1.3.25.7 ការពិតស្តីពីព័ត៌មានសង្ខេបឯកសារពិភពលោក ការប៉ះទង្គិចជាមួយប្រទេសវៀតណាម និងថៃ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៧៥ ["មន្ត្រីរដ្ឋាភិបាលសហរដ្ឋអាមេរិក បានរាយការណ៍កាលពីថ្ងៃទី ២១ ខែ មិថុនា ថាកងទ័ពរបស់វៀតណាមខាងជើង និងវៀតណាមខាងត្បូងបានវាយតបតកងទ័ពកម្ពុជា ជាច្រើនកន្លែងនៅតាមតំបន់ព្រំដែន ដោយរាប់បញ្ចូលព្រំប្រទល់ចំពុះសេក នៅវៀតណាមខាងត្បូងដែរ"]។

1018 ឯកសារ D4.1.237 កំណត់ហេតុការប្រជុំអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ KH ERN 00019134 ["កម្លាំងទៅមណ្ឌលគិរី ត្រូវយកទៅប្រញាប់"]។ ឯកសារ D4.1.1000 ទូរលេខពីអង្គការជំរាបសមមិត្ត យ៉ា ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ [ពិភាក្សាពីផែនការចល័តកងកម្លាំង ៣០០-៤០០ នាក់ដើម្បីវាយប្រហារខ្មាំង និងកងកម្លាំងដទៃទៀតសម្រាប់ការស្ទាក់វាយប្រហារ និងវិធីសាស្ត្រ និងអាវុធអ្វីដែលត្រូវប្រើ]។

1019 ឯកសារ D1.3.12.21 របាយការណ៍ក្រសួងការបរទេស សាធារណរដ្ឋសង្គមនិយមវៀតណាម ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00283124 ["នៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៥ កងកម្លាំងប្រដាប់អាវុធកម្ពុជាបានវាយប្រហារកាន់កាប់ទឹកដីវៀតណាមម្តងទៀត នៅក្នុងខេត្តយ៉ាឡៃ កុនទុំ និងខេត្តដាឡាក់"] KH ERN 00283144 ["កងកម្លាំងប្រដាប់អាវុធកម្ពុជាបានជ្រៀតចូលជាញឹកញាប់ទៅក្នុងទឹកដីវៀតណាមចាប់ពី [...] ហើយជួនកាលរហូតដល់ទៅ ១០ គីឡូម៉ែត្រ (ដូចនៅក្នុងការវាយប្រហារកាលពីខែ ធ្នូ ឆ្នាំ ១៩៧៥ ទៅលើតំបន់ទន្លេសាថាយ ខេត្តយ៉ាឡៃ-កុនទុំ)"]។ ឯកសារ D234/2.1.13 សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 00656202 ["នៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៥ កងទ័ពកម្ពុជាបានវាយប្រហារ និងកាន់កាប់ទឹកដីវៀតណាមនៅក្នុងខេត្តហ្គីយ៉ាឡា (Gia Lai) កុនទុម (Kontum) និងដាឡាក់ (Darlac)"]។

310. ការលុកលុយ និងការវាយចូលព្រំដែនគោក និងព្រំដែនទឹក បានបន្តពេញមួយឆ្នាំ ១៩៧៦[1020] ដោយមានការប៉ះទង្គិចគ្នានៅខេត្តមណ្ឌលគិរី[1021] ខេត្តស្វាយរៀង[1022] និងខេត្តតាកែវ[1023]។ ចាប់ពីដើម

---

1020 ឯកសារ D1.3.29.2 SWB ប៉ុល ពត និងជម្លោះជាមួយវៀតណាម ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៨ KH 00224838 ["រវាងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៦ រៀងរាល់ខែ យើងបានទទួលរងគ្រោះថ្នាក់ស្លាប់ និងរបួសជាង ៣០ នាក់ ជាមធ្យម ដោយសារការទម្លាក់គ្រប់បែក និងការវាយប្រហាររបស់វៀតណាមជារៀងរាល់ថ្ងៃ"]។ ឯកសារ D4.1.1029 សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 00442396 ["នៅឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៦ វៀតណាមបានធ្វើការឈ្លានពានជាប់"]។ ឯកសារ D234/2.1.7 សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 00591048 ["ក្នុងឆ្នាំ ១៩៧៥ និង១៩៧៦ ប្រទេសវៀតណាមបានអនុវត្តអំពើឈ្លានពានដោយឥតឈប់ឈរ"]។ ឯកសារ D4.1.338 ទូរលេខ ៣៤ ពី ឈាន ជំរាបបងជាទីគោរព ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៧៧ KH ERN 00001282 [សំបុត្រថ្ងៃទី ០២ ខែ មេសា ពីពួកវៀតណាមអះអាងថា "ចាប់ពីខែ ១២ ឆ្នាំ ១៩៧៥ ផ្នែកកម្ពុជាបានបង្កហេតុជាច្រើននឹងបន្តបន្ទាប់ [...] វាយសំរុកប៉ុស្តិ៍លេខ ៨ របស់វៀតណាមជាដើម"]។ ឯកសារ D1.3.34.1 ទូរលេខ ពី០៥ ជូនអ៊ុំ ៨៩ (សុន សេន) ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៧៦ ["យប់ថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៧៦ ពួកយួនវាលបវាយអ្នកយាមល្បាតយើង ខាងមុខក្រោយយើងវាមកបាយដល់ជំរុំយើង [...] នៅម៉ោង ១១ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៧៦ នេះ ពួកយួនវាបញ្ជូនកម្លាំងវាមកវាយយើងទៀត"] (អូររ៉ាំយ ភូមិភាគព្លិសាន)។ ឯកសារ D1.3.34.2 ទូរលេខ ៧៨ ពីប៊ុត ជំរាបបង ម-៨៧០ និងបង វី ជាទីគោរព ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៧៦ KH ERN 00000709 [មិនព្រមព្រៀងជាមួយគណៈប្រតិភូវៀតណាមដែលទាក់ទងភូមិសោប, អូររ៉ាំយ និងផ្លូវ ១៩]។ ឯកសារ D1.3.34.3 ទូរលេខពី ឈិន ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ["[វៀតណាម] ចូលដីយើង ១ គ.ម [...] ខាងផ្នែកកងទ័ពយើងត្រូវបានឲ្យវាដកចេញពីកន្លែងនេះទាំងអស់ តែវាមិនទាន់ដកទេ [...] [យើង] បានចុះពិនិត្យព្រំប្រទល់ជុំវិញកន្លែង។ នៅក្នុងការពិនិត្យ ចូលទៅជ្រៅព្រំប្រទល់តែម្តង"]។ ឯកសារ D1.3.34.4 ទូរលេខពី យ៉ា សូមជំរាបបងជាទីគោរព ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ (អូររ៉ាំយ ភូមិមុយចាស)។ ឯកសារ D1.3.34.5 ទូរលេខពី ឈិន ជំរាបជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ["ចាប់ពីថ្ងៃទី ១៥ ដល់ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ពួក ៧ បានចូលមកដីយើងចំងាយ ២ គ.ម ត្រង់អូរអាង ដោយមានគ្នា ៦០ នាក់ ... យើងបានកម្ទេចអស់ដោយគ្រាប់បែកដៃ។"] (អូរអាង)។ ឯកសារ D1.3.34.6 ទូរលេខ ២៥ ពី យ៉ា សូមជំរាបបងជាទីគោរព ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ១៩៧៦ KH ERN 00021466 [ក្នុងការប្រជុំជាមួយប្រតិភូវៀតណាម៖ "[ពួកគេ] លើកសភាពការណ៍ភូមិកមុយ អូររ៉ាំយ ថាមានការប៉ះទង្គិច បង្ហូរឈាមទាំងសងខាង។ គេថាត្រង់ចំណុចនោះ ជាទឹកដីរបស់គេ។ល។ [...] [ពួកគេ] លើកសភាពការណ៍ ១០៥ [ភូមិភាគ ១០៥] ដែលមានការវាយគ្នាពីថ្ងៃទី ២៥ ដល់ថ្ងៃទី ២៩ ខែ ២ នេះម្តងទៀត។ គេថា ខាងកម្ពុជា បានចូលជ្រៅទៅខាងដីក្រុម ៧ ចម្ងាយពី ៤-៥ គ.ម យើងចូលខាងត្បូងដាកហ៊ុត"] (ភូមិភាគព្លិសាន អូររ៉ាំយ ដាកហ៊ុត ប្រទេសវៀតណាម)។ ឯកសារ D4.1.234 ទូរលេខពី ឈិន ជំរាបបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៧៦ KH ERN 00052345 (ថ្ងៃទី ២៨ ខែ កុម្ភៈ កម្ពុជាប្រជាធិបតេយ្យវាយប្រហារចូលដែនដីវៀតណាម អូរហ៊ុច)។ ឯកសារ D1.3.27.2 កំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ចុះថ្ងៃទី ២២ ខែ

កុម្ភៈ ឆ្នាំ ១៩៧៦ KH ERN 00000713 (រតនគិរី ស្វាយរៀង ក្អមសំណ)។ ឯកសារ D4.1.330 ទូរលេខពី ឈិន ជូន បង សាយ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ (អូរហុច-ខេត្តមណ្ឌលគិរី)។ ឯកសារ D1.3.30.3 DK របាយការណ៍ពី មន្ទីរស-២១ ជូនអង្គការ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦ KH ERN 00052906 (ថ្ងៃទី ១៨ និង ២០ ខែ មីនា បាញ់ នៅព្រំដែន ជិតក្អមសំណ, អំពិលទឹក និងវាលស្បូវ)។ ឯកសារ D1.3.34.8 ទូរលេខ ២១ ពី ឆុន ជូនបងប៉ុល (ប៉ុល ពត) ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៧៦ (តំបន់ ២៤ ភូមិភាគបូព៌ា)។ ឯកសារ D4.1.66 កំណត់ហេតុប្រជុំគណៈអ ចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៧៦ KH ERN 00000737 (រតនគិរី, តាកែវ, ក្រចេះ)។ ឯកសារ D4.1.333 របាយការណ៍បក្សកុម្មុយនីស្តកម្ពុជាពី ឈិន ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៧៦ [រាយការណ៍ថា កងម្លាំងវៀតណាមប្រដាប់ដោយអាវុធគ្រប់ធុន ត្រូវបានពង្រាយនៅតាមអូរដាក់ដាំ "ហើយវា ប្រាប់យើងថា នៅរយៈ ៤ ថ្ងៃទៀត វាមកបោះទីតាំងនៅលើដីយើងចម្ងាយ ៥ គ.ម]"] (អូរដដាក់ដាំ)។ ឯកសារ D1.3.27.3 កំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៧៦ KH ERN 00000757 (ក្បាលចាម-ភូមិភាគបូព៌ា, ដែនទឹក)។ ឯកសារ D1.3.27.6 កំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍នៃបក្ស កុម្មុយនីស្តកម្ពុជា ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៧៦ KH ERN 00000810 (ការប៉ះទង្គិចគ្នាចំនួន ៨ដងនៅ មណ្ឌលគិរីតាំងពីខែ មីនា) KH ERN 00000813 (រតនគិរី)។ ឯកសារ D1.3.29.4 សេចក្តីថ្លែងការណ៍រដ្ឋាភិបាលកម្ពុ ជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៨ KH ERN 00223154 ["ហេតុអីក៏យួនតែងតែបង្កនូវឧក្រិដ្ឋ កម្មនានា ក្នុងគោលដៅផ្តួលរំលំរបបគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ? [...]រហូតដល់ខែមេសា និងកញ្ញា ឆ្នាំ ១៩៧៦ ខ្លួនបានចាប់ផ្តើមប៉ុនប៉ងជាថ្មីម្តងទៀត។"]។ ឯកសារ D1.3.12.7 របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃ ទី ៣១ ខែ សីហា ឆ្នាំ ១៩៧៦ KH ERN 00021507 [តំបន់ ២១៖ "១២ កក្កដា ១៩៧៦ [...] នៅតាមព្រំដែនត្រមូង ពួកវាបានបាញ់និងផ្លោងគ្រាប់ខ្លះមកក្នុងដីយើងដែរ"។ តំបន់ ២៣៖ "១៤ កក្កដា ១៩៧៦: នៅតាមព្រំដែនម៉ុំវាល ក្រជាស និងក្រចាសវា ពួសូរផ្តេព្រួស និងរទេះបរចេញទល់ភ្លឺ។ [...] សុទ្ធតែកងទ័ពវា នៅក្នុងភូមិ មានអាវុធគ្រប់ធុន និងគ្រប់ដៃ។"] (ភូមិភាគបូព៌ា)។ ឯកសារ D1.3.27.14 កំណត់ហេតុប្រជុំយោធាកម្ពុជាប្រជាធិបតយ្យេ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00083159 (ការប៉ះទង្គិចតិចតួចនៅភូមិភាគបូព៌ា និងភូមិភាគនិរតី)។ ឯកសារ D1.3.27.24 កំណត់ហេតុប្រជុំយោធាកម្ពុជាប្រជាធិបតយ្យេ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៧៦ KH ERN 00052333 (អូររាំង, ដាក់ដង, ពេជចិន្តា-ខេត្តមណ្ឌលគិរី)។ ឯកសារ D234/2.1.6 លិខិតឯកអគ្គកុស៊ុលសាធារណរដ្ឋបារាំង ចុះថ្ងៃ ទី ២០ ខែ តុលា ឆ្នាំ ១៩៧៧ KH ERN 00492877 ["ទោះបីទំនងជាមានឧប្បត្តិហេតុតូចតាចមួយចំនួនបានកើតឡើង ជាច្រើនលើកច្រើនសារ និងយ៉ាងពិតប្រាកដនៅឆ្នាំ ១៩៧៦ នៅតាមព្រំដែនក៏ដោយ ក៏ប៉ុន្តែ ព័ត៌មានទាក់ទងនឹងរឿងរ៉ាវ ទាំងនេះ ទើបតែត្រូវបានគេដឹងឮស្ទើរតែទូទៅ ដោយសារតែការប៉ះទង្គិចគ្នាដ៏ខ្លាំងក្លាចំនួនពីរក្នុងឆ្នាំនេះតែប៉ុណ្ណោះ"]។ ឯកសារ D54/28 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ឆ. ១៧, ឆ.១៩ ["ស៖ [...] តើលោកចេញទៅប្រទេសចិន នៅឆ្នាំណា? ឆ.១៧៖ គឺខែមករា ឆ្នាំ ១៩៧៦"] ឆ.១៩ ["អគ្គរដ្ឋទូតកម្ពុជាបានប្រាប់យើងថា ឲ្យយើងខំប្រឹងរៀនសូត្រ ព្រោះមានការវ៉ៃគ្នាជាមួយយួនទៀតហើយ នៅព្រំដែនប្រទេសកម្ពុជា"]។ ឯកសារ D32/7 កំណត់ហេតុស្តាប់ចម្លើយ អេង អាន ហៅ អុ ឆ.៤១ ["ស៖ តើលោកមានចាំឬទេ នៅក្នុងឆ្នាំណា ដែលកងរបស់លោកវ៉ៃចូលលើកទី ១ ក្នុងទឹកដី វៀតណាម? ឆ.៤១៖ ប្រហែលជានៅក្នុងឆ្នាំ ១៩៧៦"] ឆ.៤៤ ["យើងបានប្រើកាំភ្លើងត្បាល់ ៦០មម និង ៨០មម ផ្លោងចេញពីភូមិតាអាំដាក់ ទៅភូមិក្រសាំង និងធ្នោត"] ឆ.៤៦ ["មានទាំងទាហាន និងប្រជាជននៅក្នុងភូមិទាំងនោះ"]

ខែ កុម្ភៈ មក កងទ័ពវៀតណាមត្រូវបានដាក់ពង្រាយនៅតាមព្រំដែនខាងកើត ជាពិសេស ក្នុងខេត្តរតនគិរី ខេត្តស្វាយរៀង និងខេត្តកណ្ដាល ដោយចូលក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យ ចម្ងាយបីគីឡូម៉ែត្រ បណ្ដាលឲ្យការប៉ះទង្គិចគ្នាដោយអាវុធ[1024]។ នៅខ្សែបន្ទាត់ព្រំដែនសមុទ្រ វៀតណាម

---

ឆ.៥០ ["មិនដល់ ១០ថ្ងៃ ក្រោយមកងរបស់ខ្ញុំបានចូលវៃម្ដងទៀត ហើយទទួលបានជ័យជំនះ នៅពេលនោះ ពួកយើងទាំងបួនកង ក៏បានចូលវៃរួមគ្នា ហើយកាន់កាប់បានភូមិទាំងពីរ។"] (កំពង់ចាម)។ ឯកសារ D114/223 កំណត់ហេតុស្ដាប់ចម្លើយ ប៊ុន ពិន ឆ.៥៧-៥៨ ["មានការវៃតាមព្រំដែនរហូតតាំងពីចុងឆ្នាំ១៩៧៦ ដល់ ១៩៧៩ [...] ឆ.៥៨៖ ការវៃគឺមានចូលតាមកន្លែងខ្លះជ្រុលចូលក្នុងទឹកដីវៀតណាម"]។ ឯកសារ D98/3.1.155 កិច្ចសម្ភាសន៍របស់ SOAS/HRW ជាមួយ ឡឹក សាវ KH ERN 00786160 ["ការប៉ះទង្គិចគ្នាលើកដំបូងជាមួយកងទ័ពវៀតណាមគឺនៅចុងឆ្នាំ ១៩៧៦ [...] នៅបុសតាគុក ដែលស្ថិតនៅខាងលិចបេង និងខាងកើតស្នំ [...] វៀតណាមបានវាយប្រហារទ្រង់ទ្រាយតូចមួយនៅតំបន់ទឹកជ្រៅ [...] ក្រោយមកនៅដើមឆ្នាំ ១៩៧៧ [...]ភូមិភាគក៏បានបញ្ជាឲ្យពួកយើងទៅស៊ើបការណ៍ និងធ្វើការវាយបកវិញ។"] (កំពង់ចាម)។

1021 ឯកសារ D114/297.1.38 សៅ ម៉ុង ហៅ សៅ ចាំពី ប្រតិចារឹកថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង ០៩.៥៥.៤៤-១០.០៣.៣១ (ស្រុកអូររាំង ដាក់ដាំ)។

1022 ឯកសារ D234/2.1.122 ឈុន សាម៉ន ប្រតិចារឹកថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ០៩.៣៩.៤៥-០៩.៤៣.៤៦ ["ចុះតាមខ្សែក្រវាត់ព្រំដែន ដូចជាមានសភាពការណ៍តឹងតែងជាមួយវៀតណាម [...] ឆ្នាំ ១៩៧៦ កំពុងតែពេញនិយមនៅខាងខ្ញុំហ្នឹង កងទ័ពវៀតណាម និងកងទ័ពខ្មែរក្រហមយើងហ្នឹង វៃអត់ដែលបានឈប់ឈរផង [...] វៃទប់ទល់ខ្លាំងណាស់ក្នុងពេលនុំង ក្នុងដើមឆ្នាំ ៧៦ ហ្នឹង ព្រោះវៀតណាម ហើយនិងកងទ័ពកម្ពុជាយើង កងទ័ពខ្មែរក្រហមហ្នឹងនៅខេត្តស្វាយរៀង តំបន់ ២៣ ហ្នឹងមានការបាញ់គ្នា រុញច្រានគ្នាទៅវិញទៅមក។ [...] អ្នកស្លាប់ក៏ស្លាប់ច្រើន វៀតណាមស្លាប់ក៏ច្រើន។ [...]នៅស្រុករមាសហែក ខេត្តស្វាយរៀង។ ប្រយុទ្ធនៅភូមិដូង នៅទួលប្រាសាទ បាត្រាស់ កោះខ្សាស់។ ហ្នឹងវៃខ្លាំង"] ម៉ោង ១៣.៣៩.៤៥-១៣.៤២.០២ ["នៅក្នុងឆ្នាំ ១៩៧៦ [...] ប្រយុទ្ធនៅលើទឹកដីខ្មែរយើងពេញទីតែម្ដង។ ពួកកងទ័ពវៀតណាម ហើយនិងខ្មែរយើងបានបង្កើតសង្គ្រាមតាមព្រំដែនទៅ វៃច្រានគ្នាទៅត្រូវកងទ័ពវៀតណាមវៃកងទ័ពបដិវត្តន៍ចេះតែបាក់ថយចូលមកខេត្តស្វាយរៀងទៅ"]។

1023 ឯកសារ D114/297.1.23 មឹង វេត ប្រតិចារឹកថ្ងៃទី ២៧ ខែ កក្កដា ២០១៦ ម៉ោង ១១.២២.១៩-១១.២៤.២៥ ["រកាំរកូសតាំងពីឆ្នាំ៧៦ ខ្ញុំនៅគីរីវង់នោះ រកាំរកូសគ្នាពី ៧៦ មករហូតបាន ៧៧ ហ្នឹង ចាប់ផ្ដើមខ្លាំងដល់ខ្ញុំ"] (ស្រុកគីរីវង់ ខេត្តតាកែវ)។

1024 ឯកសារ D1.3.27.2 កំណត់ហេតុប្រជុំគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ["សមមិត្តខៀវ រាយការណ៍ថា ចាប់តាំងពីដើមខែ ២ មក វៀតណាមធ្វើសកម្មភាពយ៉ាងខ្លាំង នៅតាមព្រំដែនយើងខាងកើត ពិសេសនៅរតនៈគិរី ស្វាយរៀង និងក្អមសំណ។ វាចូលមកបោះ នៅក្នុងដីយើងចម្ងាយពី ២០០ ម៉ែត្រ ឬ ៣ គ.ម ពីព្រំដែន"]។ ឯកសារ D1.3.30.3 របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពីមន្ទីរស-២១ ជូនអង្គការជាទីគោរព ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦ KH ERN 00052906 ["ប្រជាជនវៀតណាម [...] ចូលដីយើងចម្ងាយ១០៥ម ពីប្រទល់ក្អមសំណ។ បងប្អូនយើងបាញ់វា [...]វេលាព្រឹក ថ្ងៃ ១៨ ខែ ០៣ ឆ្នាំ ១៩៧៦ យើងធ្វើការនៅមាត់ស្ទឹង។ ពេលយើងដក

បានបើកការបាញ់ប្រហារ ពេលកងកម្លាំងកម្ពុជាប្រជាធិបតេយ្យទៅជិត ហើយកងកម្លាំងកម្ពុជាប្រជាធិបតេយ្យទទួលបញ្ជាឲ្យចាប់ទូកដែលចូលក្នុងទឹកដីខ្លួន[1025]។ ការប៉ះទង្គិចគ្នានៅកោះត្រល់នៅតែបន្តកើតមាន[1026]។

311. ការវាយប្រយុទ្ធគ្នានៅតែបន្តកើតមានពេញមួយឆ្នាំ ១៩៧៧ តាមព្រំដែន និងតំបន់ឆ្នេរ[1027] ដោយមានការចាប់កងកម្លាំងវៀតណាម ជារៀងរាល់ខែ នៅកោះតាង និងកោះពូលូវៃ[1028]។ នៅខែ មករា

---

ថយបន្តិច វៀតកុង ចូលមកបាញ់ អឹម-៧៩ ៨គ្រាប់"] (ភូមិភាគនិរតី-តំបន់ ២៥, ក្អមសំណ, ព្រំប្រទល់ជ្រុំ, អំពិលទឹក, វាលស្បូវ)។ ឯកសារ D1.3.34.9 ទូរលេខពីមន្ទីរស-២១ ជូនអង្គការជាទីគោរព ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៦ ["ម៉ោង ៩ ព្រឹកថ្ងៃទី ២០ ខែ ០៣ ឆ្នាំ ១៩៧៦ មានវៀតកុង ១ កងអនុសេនាតូច ចូលចម្ងាយពីព្រំប្រទល់ ១៥០ ម៉ែត្រ។ វាយគ្នាអស់រយៈ ១ ម៉ោង ទើបវាដកថយ។"] (ភូមិភាគនិរតី-តំបន់ ២៥ ក្អមសំណ)។

1025 ឯកសារ D1.3.27.18 កំណត់ហេតុអង្គប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00052390 [សមមិត្តមុត (មាស មុត)៖ "វៀតណាម-ព្រំដែនទឹក យើងចូលក្បែរខ្សែបន្ទាត់តឹក វាចេះតែបាញ់។"]។ ឯកសារ D114/27.1.5 កំណត់ហេតុនៃការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00052390 [សមមិត្តមុត( មាស មុត)៖ "ខាងវៀតណាម ព្រំដែនទឹក យើងចូលក្បែរខ្សែបន្ទាត់ទឹក វាចេះតែបាញ់។ ឥឡូវ យើងចាំ បើវាចូលខ្សែនោះ បាញ់វាដែរ"]។ ឯកសារ D54/78.1, D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល KH ERN 00926607 ["ស៖ កាលពូចេញទៅនៅកោះតាងឆ្នាំណាដែរ មើលទៅ? ឆ៖ ទៅនៅដូចចុង ១៩៧៦។ KH ERN 00926623 ["ស៖ អ៊ីចឹង ពេលពូទៅដល់កោះតាងហ្នឹងដូចថា ពេលដូចទូកពួកនេសាទខាងថៃ ខាងយួនអីម៉េចដែរ ចូលមកក្នុងដែនសមុទ្រ មានអាហ្នឹងយើងមានវិធានការម៉េចខ្លះ? ឆ៖ ចាប់"]។

1026 ឯកសារ D1.3.27.18 កំណត់ហេតុអង្គប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00052397 [បង ៨៩ (សុន សេន)៖ "មានសកម្មភាពខ្លះដែរ [...] នៅកោះត្រល់ ទាក់ទងខ្នាំងខាងកើត"]។

1027 ឯកសារ D69.1.21 សុន្ទរកថារបស់ខៀវ សំផន ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៨ KH ERN S 00704517 ["ប្រទេសវៀតណាមបានផ្សងព្រេងធ្វើសង្គ្រាមឈ្លានពាន ក្នុងទ្រង់ទ្រាយធំយ៉ាងសាហាវព្រៃផ្សៃ មកលើកម្ពុជាប្រជាធិបតេយ្យ។ ជាមួយគ្នានេះ ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៧ ដល់ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៨ ជាពិសេស ចាប់តាំងពីខែ កញ្ញា ឆ្នាំ ១៩៧៧ ការវាយប្រយុទ្ធគ្នាបានប្រព្រឹត្តទៅឥតឈប់ឈរ"]។ ឯកសារ D234/2.1.7 សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 00591051 ["ក្នុងអំឡុងពេលវៀតណាមចូលឈ្លានពានក្នុងទឹកដីកម្ពុជាក្នុងឆ្នាំ ១៩៧៧"]។ ឯកសារ D234/2.1.4 ក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង ដីកាអមរួមលេខ ២១០ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៧៧ KH ERN 00810726 ["ការផ្សាយម្តងទៀតរំឭកអំពីកិច្ចខិតខំប្រឹងប្រែងរបស់កងទ័ពបដិវត្តន៍ ដើម្បី "ការពារព្រំដែនគោក" (ក្នុងខេត្តកំពត) និងព្រំដែនសមុទ្រ បង្ហាញយ៉ាងច្បាស់ជាលើកដំបូងអំពីឧប្បត្តិហេតុជាមួយវៀតណាម"]។ ឯកសារ D234/2.1.6 លិខិតអគ្គកុងស៊ុលសាធារណរដ្ឋបារាំង ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៧៧ KH ERN 00492878 ["ថ្នាក់ដឹកនាំវៀតណាមលែងលាក់ទៀត

ឆ្នាំ១៩៧៧ កងកម្លាំងថ្មើរជើងរបស់កម្ពុជាប្រជាធិបតេយ្យវាយចូលខេត្តតាយនិញរបស់វៀតណាម ហើយវៀតណាមវាយបកវិញ[1029]។ នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៧៧ កងទ័ពកម្ពុជាប្រជាធិបតេយ្យ បានឆ្លងចូលព្រំដែន និងបានសម្លាប់ជនស៊ីវិលអស់រាប់រយនាក់ ក្នុងស្រុកទិញបៀន និងភូមិមួយ

---

ហើយ អំពីឧប្បត្តិហេតុនៃការប្រឈមមុខរបស់ខ្លួនជាមួយខ្មែរ ជួននៅត្រង់ចំណុចនេះ ជួននៅត្រង់ចំណុចនោះ តាមបណ្តោយព្រំដែន និងខ្ពស់រាបខ្ពស់ៗ រហូតទៅដល់សមុទ្រ"]។ ឯកសារ D32/14 កំណត់ហេតុស្តាប់ចម្លើយ ឡុង សាត ឆ.២ ["ក្នុងឆ្នាំ ១៩៧៧ យុទ្ធនាការយោធាត្រូវបានចាប់ផ្តើមវ៉ៃវៀតណាមនៅគ្រប់មុខព្រួញ ដើម្បីព្រមានវៀតណាមថាកម្ពុជាមិនមែនខ្សោយដូចដែលគេបានគិតនោះទេ"]។ ឯកសារ D114/223 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ពិន ឆ.៥៧-៥៨ ["មានការវ៉ៃតាមព្រំដែនរហូតតាំងពីចុងឆ្នាំ ១៩៧៦ ដល់ ១៩៧៨ [...] ឆ.៥៨៖ ការវ៉ៃគឺមានចូលតាមកន្លែងខ្លះជ្រុលចូលក្នុងទឹកដីវៀតណាម"]។ ឯកសារ D114/209 កំណត់ហេតុស្តាប់ចម្លើយ មឹង សេង ឆ.៥៩ ["ការវាយប្រយុទ្ធខ្លាំងរវាងខ្មែរក្រហម និងវៀតណាមចាប់តាំងពីចុងឆ្នាំ ១៩៧៧ ម្ល៉េះ"]។ ឯកសារ D59/1/1.29 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ង៉ែត ចាន់ថូ KH ERN 00733608 ["មុនឆ្នាំ ១៩៧៧ មានចលនាធំបានទៅវ៉ៃជាមួយយួនខាងត្បូង"]។

1028 ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត ឆ.១២៩ ដោយបញ្ជាក់ ឯកសារ D59/1/1.8a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រុំ សារ៉ាត KH ERN 00926385 ["ក្នុងរយៈពេល ២ឆ្នាំ សឹងតែរាល់ខែចូលមកកោះតាង កោះវ៉ៃ"]។

1029 ឯកសារ D32/5 កំណត់ហេតុស្តាប់ចម្លើយ កែវ វិចិត្រ ហៅ កែវ សៅ ឆ.២ ["សៈ តើកងរបស់លោក គេហៅកងលេខប៉ុន្មាន? ឆ.២៖ វរៈរបស់ខ្ញុំ គឺវរសេនាតូច លេខ ១០៣ កង គ ឬអនុសេនាធំ ៤៧"] ឆ.៧ ["ក្នុងខែ០១ ថ្ងៃទី០១ វេលាម៉ោង មួយយប់ ឆ្នាំ ១៩៧៧ កងរបស់ខ្ញុំផ្តើមវាយវៀតណាមនៅភូមិស្នាច់ក្នុងទឹកដីវៀតណាម"] ឆ.៩ ["បន្ទាប់មកទៀត វៀតណាមបញ្ជូនកងស៊ើបការជិះកង់សំដៅមកកន្លែងយើង ប៉ុន្តែ យើងបាញ់វា វាបានបកត្រឡប់ទៅវិញ។ បន្ទាប់មកទើបវាបើកការវាយ យើងជាទ្រង់ទ្រាយធំ រួមមានកងរថក្រោះ កាំភ្លើងធំ យន្តហោះ និងទាហានរបស់វៀតណាមនៅក្នុងបន្ទាយ ២៧"]។ ឯកសារ D32/11 ខៀវ សារ៉ន ឆ.៣ ["សៈ តាមលោកដឹងការវ៉ៃវៀតណាមនៅខែមករា ឆ្នាំ ១៩៧៧ តើកំណត់តែក្នុងតំបន់ក្នុងភូមិភាគបូព៌ា ឬយ៉ាងណា? ឆ.៣៖ បាទ គឺនៅតំបន់របស់ភូមិភាគបូព៌ាតាមបណ្តោយព្រំដែន"] ឆ.៥ ["កងទ័ពកម្ពុជាប្រជាធិបតេយ្យនៅកំចាយមារវាយកងទ័ពវៀតណាមនៅតាមព្រៃតាមបណ្តោយព្រំប្រទល់ក្នុងខេត្តតៃនិញ។ កងទ័ពវៀតណាមវាយបកមកវិញ គេវ៉ៃចូលមកដល់កន្លែងខាងក្រោមនេះ"] ឆ.៩ ["ការវ៉ៃគ្នាជាប់ក្នុងឆ្នាំ ១៩៧៧ រហូតដល់ខែឧសភា ឆ្នាំ ១៩៧៨ ពេលដែលខ្ញុំរត់ចូលព្រៃ។ ពេលខ្ញុំកំពុងនៅក្នុងព្រៃ ខ្ញុំនៅតែឮសូរសំឡេងកាំភ្លើងធំ និងស្នូរកាំភ្លើងវាយគ្នា"]។ ឯកសារ D32/10 កំណត់ហេតុស្តាប់ចម្លើយ ខៀវ សារ៉ាន ឆ.២៥ ["សៈតើពេលណាជាពេលដំបូង ដែលកងទ័ពភូមិភាគបូព៌ានៃកម្ពុជាប្រជាធិបតេយ្យវាយចូលក្នុងប្រទេសវៀតណាម? ឆ.២៥៖ នៅដើមឆ្នាំ ១៩៧៧"]។ ឯកសារ D98/3.1.155 កិច្ចសម្ភាសន៍របស់ SOAS/HRW ជាមួយ ឡឹក សាវ KH ERN 00786160 ["នៅដើមឆ្នាំ ១៩៧៧ [...] ភូមិភាគក៏បានបញ្ជាឲ្យពួកយើងទៅស៊ើបការណ៍ និងធ្វើការវាយបកវិញ។ ការឈ្លបយកការណ៍ត្រូវឆ្លងចូលទៅក្នុងព្រំដែន"] (ខេត្តកំពង់ចាម)។

ចំនួននៃខេត្តអានយ៉ាង វៀតណាមខាងត្បូង[1030]។ បន្ទាប់មកទៀត កម្ពុជាប្រជាធិបតេយ្យបានវាយតំបន់ព្រំដែន ដោយបានប្រើប្រាស់មីន និងកាំភ្លើងធំ គ្រាប់ផ្លោង និងកាំភ្លើងត្បាល់ នាំឱ្យមានការជម្លៀសប្រជាជនជាបណ្តោះអាសន្នចេញក្រុងពីររបស់វៀតណាម គឺចូវដុក (ខេត្តអានយ៉ាង) និងហាទៀង (ខេត្តកៀនយ៉ាង)[1031]។ ទោះបីជាភាគីទាំងសងខាងយល់ព្រមប៉ុនប៉ងចរចាសន្តិភាព ក្នុង

---

1030 ឯកសារ D1.3.12.21 របាយការណ៍ក្រសួងការបរទេស សាធារណរដ្ឋសង្គមនិយមវៀតណាម ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00283128-29 ["នៅយប់ថ្ងៃទី ៣០ ខែ មេសា និងថ្ងៃទី ០១ ខែ ឧសភា ក្នុងឆ្នាំនេះ កងកម្លាំងប្រដាប់អាវុធកម្ពុជាច្រើនអង្គភាព ដោយមានការគាំទ្រយ៉ាងខ្លាំងក្លាពីកងកាំភ្លើងធំ និងកាំភ្លើងត្បាល់ ដែលដាក់ទីតាំងនៅលើទឹកដីកម្ពុជា បានឆ្លងចូលព្រំដែន និងបើកការវាយប្រហារដំណាលគ្នានេះ ទៅលើគ្រប់ប៉ុស្តិ៍យាមទាំងអស់របស់កងកម្លាំងសន្តិសុខប្រដាប់អាវុធរបស់ប្រជាជនវៀតណាម និងទៅលើ ភូមិចំនួន ១៣ ក្នុងចំណោមភូមិចំនួន ១៤ នៅតាមបណ្តោយព្រំដែនខេត្តអានយ៉ាង"]។ ឯកសារ D234/2.1.1 សន្និសីទកាសែតក្រសួងការបរទេសសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៧៨ KH ERN 00305311-12 ["នៅខែ មេសា ឆ្នាំ ១៩៧៧ មានកំណែនកម្លាំងយោធាដ៏ធំរបស់អាជ្ញាធរកម្ពុជាដោយមានការគាំទ្រយ៉ាងខ្លាំងពីក្រុមកាំភ្លើងធំ ដែលស្ថិតនៅក្នុងប្រទេសកម្ពុជាដើម្បីវាយប្រហារយ៉ាងខ្លាំង ទៅលើស្ទើរតែគ្រប់តំបន់ព្រំដែនទាំងអស់។ ពីហាទៀត ក្នុងខេត្តកៀនយ៉ាង ដល់តាយនីញ"]។ ឯកសារ D1.3.17.5 ណាយ៉ាន់ ចាន់ដា សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម KH ERN 00191402 ["ក្នុងរាត្រីថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៧៧ ខ្មែរក្រហមបានចាប់ផ្តើមវាយឆ្មក់ជាបន្តបន្ទាប់ទៅលើភូមិ និងឃុំនានារបស់ខេត្តអានយ៉ាងក្នុងដែនដីសណ្តទន្លេមេគង្គដោយបាញ់សម្លាប់អ្នកភូមិ និងដុតផ្ទះសម្បែងអស់យ៉ាងច្រើន។ ការវាយប្រហារទៅឃុំទិញបៀនតែមួយ បានធ្វើឱ្យប្រជាជនស៊ីវិលរងគ្រោះប្រហែល ១០០ នាក់"]។ ឯកសារ D32/12.1 Pham Van Tra ជីវិតយោធាម្នាក់៖ ការចងចាំ EN ERN 00432802 ["នៅយប់ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៧៧ [...] ប៉ុល ពត បានបញ្ជូន៧ កងវរសេនាតូចនៃកងពលជើងគោកទី២ របស់គាត់ និងអង្គភាព កងកម្លាំងក្នុងតំបន់ មកពីតំបន់យោធាភូមិភាគនិរតីដើម្បីវាយប្រហារតំបន់ជាច្រើនក្នុង ខេត្តអានយ៉ាង និងខេត្តកៀនយ៉ាង Kien Giang។ ចំណុចសំខាន់នៃការវាយប្រហារខ្លាំងគឺនៅភ្នំទាំង ៧ តំបន់ Tinh Bien-An Giang។ ខ្មាំងបានសម្លាប់ប្រជាជនស៊ីវិលរាប់រយនាក់ និងដុតផ្ទះជាងមួយរយខ្នង"]។

1031 ឯកសារ D1.3.25.15 កាសែត New York Times របាយការណ៍របស់ជនភៀសខ្លួនស្តីអំពីការប៉ះទង្គិចគ្នានៅព្រំដែនកម្ពុជា វៀតណាម ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៧៧ (ខេត្តអានយ៉ាង និងកៀនយ៉ាង)។ ឯកសារ D234/2.1.6 លិខិតអគ្គកុងស៊ុលសាធារណរដ្ឋបារាំង ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៧៧ KH ERN 00492874 ["ឧប្បត្តិហេតុធ្ងន់ធ្ងរផ្សេងៗទៀត ដែលបានកើតឡើងនៅខែឧសភាកន្លងទៅនេះ ដែលជាការប៉ះទង្គិចរវាងកម្លាំងវៀតណាម និងកងទ័ពកម្ពុជា នៅតំបន់ចូវដុក (ដែលស្ថិតនៅខាងលិចកូសាំងស៊ីន) និងទំនងជាកើតមាននៅក្បែរខេត្តហាទៀន លើឈូងសមុទ្រថៃ និងនៅតាមតំបន់ខ្ពង់រាបខ្ពស់ៗផងដែរ"]។ ឯកសារ D234/2.1.4 ក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង ដីកាអមរួមលេខ ២១០ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៧៧ KH ERN 00810729 ["នៅចន្លោះថ្ងៃទី ១៤ និងថ្ងៃទី ១៦ ខែ មិថុនា ការប៉ះទង្គិចគ្នាខ្លាំងកើតឡើងនៅខេត្តចូវដុក និងជិតហាទៀង"]។ ឯកសារ D234/2.1.10 ការពិតនានាអំពីជម្លោះព្រំដែនកម្ពុជា-វៀតណាមមាននៅក្នុងឯកសារ World News Digest ថ្ងៃទី១៣ ខែ សីហា ឆ្នាំ ១៩៧៧ KH ERN

ខែ មិថុនា ក៏ដោយ[1032] ក៏ការចរចានេះត្រូវបានផ្អាក[1033]។ ការវាយប្រហារ និងការទន្ទ្រានចូលទឹកដីវៀតណាមពីសំណាក់កងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យនៅតែបន្ត[1034] ហើយវៀតណាមបានតប

00826226-27 ["ការប្រយុទ្ធទ្រង់ទ្រាយធំ បានឆាបឆេះយ៉ាងខ្លាំងនៅក្នុងខែឧសភា តាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ដោយបង្ខំឲ្យភាគីវៀតណាមត្រូវជម្លៀសប្រជាជននៅតាមបណ្តាទីប្រជុំជនចំនួនពីរនៅតាមព្រំដែននាភាគខាងត្បូងរបស់ខ្លួនជាបណ្តោះអាសន្ន។ [...] ទីរួមខេត្តចូវដុកត្រូវបានទទួលរងនូវការបាញ់ផ្លោងដោយកាំភ្លើងត្បាល់ចំនួនពីរគ្រាប់ [...] ប្រជាជនស្ថិតនៅក្នុងទីរួមខេត្តចូវដុកត្រូវភៀសខ្លួនចេញនៅថ្ងៃទី ១៧ ខែ ឧសភា បន្ទាប់ពីទីរួមខេត្តនេះ ត្រូវរងការវាយប្រហារដោយកាំភ្លើងធំ ដែលការវាយប្រហារនេះ បង្កឲ្យមានអ្នករងរបួសចំនួន ៤០ នាក់។ [...] ប្រជាជនស្ថិតនៅក្នុងទីរួមខេត្តហាទៀង ត្រូវភៀសខ្លួនចេញនៅថ្ងៃទី ១៦ ខែ ឧសភា បន្ទាប់ពីមានការវាយប្រហារដោយគ្រាប់ផ្លោង និងការសម្រុកចូលតាមផ្លូវគោកពីសំណាក់កម្ពុជា"]។ ឯកសារ D64.1.34 កាសែតបាងកកប៉ុស្តិ៍ជនភៀសខ្លួនបានលើកឡើងពីការប៉ះទង្គិចគ្នារវាងកម្ពុជា និងសាធារណរដ្ឋវៀតណាម ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៧៧ EN ERN 00168725 ["ធាតុផ្សំនៃកងពលទី២ របស់ខ្មែរក្រហមបានដាក់ឲ្យអនុវត្ត ដែលបានដាក់ពង្រាយនៅតាមព្រំដែនភាគខាងលិចនៃហាទៀង, តិញ បៀន និងចូវដុក។ វៀណាមក៏បានពង្រឹងបន្ថែមទៀតផងដែរ ក្នុងពេលតែមួយដែលបញ្ហាឲ្យមានការជម្លៀសពីមជ្ឈមណ្ឌល និងជាពិសេសនៅហាទៀង"]។ ឯកសារ D32/12.1 Pham Van Tra, ជីវិតយោធាម្នាក់៖ ការចងចាំ EN ERN 00432803 ["ឆ្នាំ ១៩៧៧ ពីខែ ឧសភា ដល់ដើមខែ មិថុនា ខ្មាំង (ខ្មែរក្រហម) បានវាយប្រហារ និងកាន់កាប់ផ្នែកមួយនៃទឹកដីរបស់យើងពីដុងថាប ដល់អានយ៉ាង រហូតដល់កៀនយ៉ាង។ [...] កងកម្លាំងខ្មាំងពីកំពតបានប្រមូលកម្លាំងយ៉ាងខ្លាំងក្លា ដែលបានវាយប្រហារខេត្តហាទៀន ហើយខ្មាំងដែលវាយប្រហារជួរឈរ បានទម្លាយស្ទើរតែទាំងអស់តាមផ្លូវទៅរោងចក្រស៊ីម៉ងត៍ហាទៀន"]។

1032 ឯកសារ D1.3.12.21 របាយការណ៍ក្រសួងការបរទេស សាធារណរដ្ឋសង្គមនិយមវៀតណាម ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00283126 ["នៅថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ១៩៧៧ គណៈមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម និងរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម បានផ្ញើលិខិតមួយច្បាប់ទៀត ឲ្យទៅគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដោយបានស្នើឡើងថា ការជួបប្រជុំគួរតែត្រូវធ្វើឡើងឲ្យបានកាន់តែឆាប់កាន់តែល្អ រវាងមេដឹកនាំជាន់ខ្ពស់មកពីភាគីទាំងសងខាង និងរដ្ឋាភិបាលទាំងពីរ ដើម្បីដោះស្រាយបញ្ហា ព្រំដែនរវាងប្រទេសទាំងពីរ"]។ ឯកសារ D4.1.1078 SWB សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលវៀតណាមបដិសេធ "ការមួលបង្កាច់" របស់កម្ពុជា ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN S 00847598-99 ["នៅដើមខែ មេសា ១៩៧៦ គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តវៀតណាម និងគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជាបានព្រមព្រៀងគ្នាថា ថ្នាក់ដឹកនាំនៃបក្សទាំងពីរនឹងជួបគ្នានៅខែមិថុនា ឆ្នាំ ១៩៧៦"]។ ឯកសារ D234/2.1.1 SWB សន្និសីទកាសែតក្រសួងការបរទេសសាធារណរដ្ឋសង្គមនិយមវៀតណាម ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៧៨ KH ERN S 00305312 ["នៅថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ១៩៧៧ គណៈមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម និងរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមបានផ្ញើលិខិតមួយច្បាប់ ជូនចំពោះគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ដែលបានសំដែងថា "មានបំណងស្មោះត្រង់ក្នុងការដោះស្រាយបញ្ហាព្រំដែនជាបន្ទាន់""]។

គ តាមរយៈការឈ្លានពានចូលកម្ពុជាប្រជាធិបតេយ្យ និងការវាយប្រហារតាមផ្លូវអាកាសម្តងម្កាល[1035]។

---

1033 ឯកសារ D234/2.1.1 សន្និសីទកាសែតក្រសួងការបរទេសសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៧៨ KH ERN 00305312 ["នៅក្នុងការឆ្លើយតបរបស់ខ្លួន ចុះថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ១៩៧៧ គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានលើកឡើងថា កិច្ចប្រជុំគឺជាការចាំបាច់ តែពួកគេបានស្នើសុំឱ្យ "រង់ចាំរហូតដល់ស្ថានភាពវិលទៅរកភាពធម្មតាវិញ និងនៅពេលដែលគ្មានការប៉ះទង្គិចគ្នាតាមព្រំដែន" មុនកិច្ចប្រជុំណាមួយត្រូវធ្វើឡើង"]។ ឯកសារ D4.1.1078 SWBសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលវៀតណាមបដិសេធ "ការមួលបង្កាច់" របស់កម្ពុជា ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN S 00847597-98។ ឯកសារ D234/2.1.13 សេចក្តីថ្លែងការរដ្ឋាភិបាលសង្គមនិយមសាធារណរដ្ឋវៀតណាម ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 00656203។ ឯកសារ D1.3.17.5 ណាយ៉ាន់ ចាន់ដា សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម KH ERN 00191408-09។

1034 ឯកសារ D1.3.12.21 របាយការណ៍ក្រសួងការបរទេស សាធារណរដ្ឋសង្គមនិយមវៀតណាម ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00283126 ["តែទោះជាយ៉ាណាក៏ដោយ វាច្បាស់ណាស់ដែលថា នៅពេលនោះ ប្រទេសកម្ពុជាបានបង្កើនការវាយប្រហារផ្នែកយោធា ការឈ្លានពានទៅលើទឹកដីរបស់វៀតណាម និងការសម្លាប់រង្គាលជនស៊ីវិល"]។ ឯកសារ D234/2.1.13 សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 00656203។ ឯកសារ D4.1.1078 SWB សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលវៀតណាមបដិសេធ "ការមួលបង្កាច់" របស់កម្ពុជា ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN S 00847597-601។ ឯកសារ D114/29.1.1 កំណត់ហេតុស្តាប់ចម្លើយ ទា ទិត KH ERN 00277278 ["នៅថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ១៩៧៧ តាងាចបានប្រកាសពង្រីកទ័ពចាប់ផ្តើមវាយជាមួយវៀតណាម។ ការប្រយុទ្ធជាមួយវៀតណាម ក៏កើតមានជាបន្តបន្ទាប់រហូតដល់ពេលបាក់ទ័ពនៅចុងឆ្នាំ ១៩៧៨"]។ ឯកសារ D64.1.34 កាសែតបាងកកប៉ុស្ត៍ជនភៀសខ្លួនបានលើកឡើងពីការប៉ះទង្គិចគ្នារវាងកម្ពុជា និងសាធារណរដ្ឋវៀតណាម ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៧៧ EN ERN 00168725 ["ការប្រយុទ្ធដ៏ធ្ងន់ធ្ងរបានកើតឡើងនៅក្នុងខែ ឧសភា និង ខែមិថុនា"]។ ឯកសារ D1.3.25.15 កាសែត New York Times របាយការណ៍របស់ជនភៀសខ្លួនស្តីអំពីការប៉ះទង្គិចគ្នានៅព្រំដែនកម្ពុជា វៀតណាម ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ១៩៧៧ ["កាលពីដើមខែ មិថុនា អ្នកភូមិជាច្រើននៅភាគពាយ័ព្យនៃហាទៀង ដែលស្ថិតនៅព្រែកជីកវិញតេ ត្រូវបានកងទ័ពពីកម្ពុជាចាប់ឃុំខ្លួន ហើយនៅបន្តការឃុំខ្លួន ទោះជាអ្នកភៀសខ្លួនបានចាកចេញអស់ក្តី"]។

1035 ឯកសារ D1.3.25.59 FBIS NCNA បានដកស្រង់ពីភ្នំពេញស្តីពីការទម្លាក់គ្រាប់បែករបស់សាធារណរដ្ឋសង្គមនិយមវៀតណាមលើប្រទេសកម្ពុជា ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៧៨ KH ERN 00225470-71 ["អាជ្ញាធរវៀតណាមបានបន្តការបញ្ជូនយន្តហោះចម្បាំងឱ្យទម្លាក់គ្រាប់ និងបាញ់រះពីលើយន្តហោះមកលើភូមិនានានៅក្នុងប្រទេសកម្ពុជា និងបានប្រព្រឹត្តនូវបទល្មើសយ៉ាងធ្ងន់ធ្ងរនានា។ [...] កាលពីថ្ងៃទី២ ទី៣ ទី៧ និងទី៨ វៀតណាមបានបញ្ជូនយន្តហោះ ៤ គ្រឿងក្នុងមួយលើកៗ ទៅទម្លាក់គ្រាប់បែកនិងបាញ់រះពីលើយន្តហោះទៅលើ ភូមិស្តែន (Sden) ភូមិសោម និងភូមិដាស្រុក Punnie Khenleap តាមផ្លូវជាតិលេខ ៧។ [...] កាលពីថ្ងៃទី ១៩ និងទី ២៤ ខែកក្កដា អាជ្ញាធរវៀតណាមបាន

312. ចាប់ពីខែ មីនា ដល់ខែ កញ្ញា ឆ្នាំ ១៩៧៧ ជម្លោះបានរីកធំនៅតាមព្រំដែន លាតសន្ធឹងពីខេត្តរតនគិរី ដល់ខេត្តកំពត ដោយមានភាពតានតឹងខ្លាំងនៅខេត្តស្វាយរៀង និងខេត្តកៀនយ៉ាង ខេត្តឡុងអាន

---

បញ្ជូនយន្តហោះម្តងប្រាំមួយគ្រឿង និងម្តងដប់គ្រឿងទៅទម្លាក់គ្រាប់បែកនៅលើផ្លូវជាតិលេខ ១០ នៅក្នុងខេត្តស្វាយរៀង"]។ ឯកសារ D4.1.1029 សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 00442398 ["នៅខែ មិថុនា ឆ្នាំ ១៩៧៧ ភាគីវៀតណាម ម្យ៉ាងនៅតែបង្ករឿងឈ្លានពាននៅតាមព្រំដែនកម្ពុជា"]។ ឯកសារ D1.3.30.21 របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពីតំបន់ ២១ ថ្ងៃទី ២០-២៤ ខែ មិថុនា ឆ្នាំ ១៩៧៧ [រៀបរាប់ពីទំនាស់នៅព្រំដែននៅត្រមូង និងព្រំដែនមេមត់ ស្រុកត្រមូង]។ ឯកសារ D69.1.23 សារព័ត៌មានពីប្រទេសកម្ពុជា សេចក្តីថ្លែងការណ៍ដោយ អៀង សារី រដ្ឋមន្ត្រីក្រសួងការបរទេស ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៧៨ EN ERN S 00011306 ["នៅដើមខែ កក្កដា ឆ្នាំ ១៩៧៧ វៀតណាមបានបង្កើនសកម្មភាពឈ្លានពានរបស់ខ្លួនលើកម្ពុជា"]។ ឯកសារ D64.1.34 កាសែតបាងកកប៉ុស្តិ៍ជនភៀសខ្លួនបានលើកឡើងពីការប៉ះទង្គិចគ្នារវាងកម្ពុជា និងសាធារណរដ្ឋវៀតណាម ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៧៧ EN ERN 00168725 ["ការផ្ទុះឡើងនៃការប្រយុទ្ធគ្នាបានក្លាយជាលទ្ធផលនៃការពិភាក្សាមួយ នៃការផ្លាស់ប្តូរចេតនារបស់វៀតណាម ដើម្បីដាក់ទោសអង្គភាពខ្មែរក្រហមសម្រាប់អ្វីដែលអ្នកអង្កេតម្នាក់បានហៅថា ជាល្បាតដែលបង្កហេតុ"] EN ERN 00168726 ["នៅខែក្រោយ វៀតណាមបានបង្កើនការឈ្លានពានរបស់ខ្លួនចូលកម្ពុជា។ ទាំងនេះ ត្រូវបានបំពេញបន្ថែមដោយការបាញ់តាមផ្លូវអាកាសម្តងម្កាល ឧទ្ធម្ភាគចក្រកាំភ្លើងធុន U-17 និងជួនការយន្តហោះចម្បាំង"]។ ឯកសារ D32/12.1 Pham Van Tra ជីវិតយោធាម្នាក់៖ ការចងចាំ EN ERN 00432804 ["នៅពាក់កណ្តាលខែ មិថុនា ឆ្នាំ ១៩៧៧ យើងបានធ្វើការវាយតបដោយអាវុធរួមបញ្ចូលគ្នាចំនួន ៦ កងពល [...] កងវរសេនាធំទី២ បានកម្ចាត់កងកម្លាំងខ្មាំងទាំងអស់នៅ ភូមិ Dam Chich និងភូមិ Vinh Dien ដោយសម្លាប់ទាហានខ្មាំងជាង ២០០ នាក់ [...] យើងបានរកឃើញតំបន់ព្រំដែនទាំងអស់នៅហាទៀង"]។ ឯកសារ D234/2.1.3 Christian Science Monitor ប្រទេសកុម្មុយនីស្តជិតខាងកំពុងមានជម្លោះ? ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៧៧ ["កម្ពុជាកំពុងវាយប្រយុទ្ធជាមួយប្រទេសកុម្មុយនីស្តវៀតណាមលើបញ្ហាទំនាស់ព្រំដែនដ៏ធ្ងន់ធ្ងរ។ [...] ការប្រយុទ្ធគ្នារវាងកម្ពុជា និងវៀតណាម ត្រូវបានបញ្ជាក់កាលពីសប្តាហ៍មុននៅគ្រាដែលរដ្ឋមន្ត្រីក្រសួងការពារជាតិ Vo Nguyen Giap បានធ្វើទស្សនកិច្ចទៅកាន់តំបន់មានជម្លោះ និងបានបញ្ជាជាសាធារណៈដល់កងកម្លាំងវៀតណាមឲ្យ "ការពារព្រំដែនសមុទ្រ ព្រំដែនជាតិ និងកោះនៅក្នុងសមុទ្រ"]។ ឯកសារ D64.1.34 កាសែតបាងកកប៉ុស្តិ៍ជនភៀសខ្លួនបានលើកឡើងពីការប៉ះទង្គិចគ្នារវាងកម្ពុជា និងសាធារណរដ្ឋវៀតណាម ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៧៧ EN ERN 00168725 ["ភាពវឹកវរ និងភាពតានតឹងនៃការប៉ះទង្គិចគ្នាបានបង្ហាញពីឧប្បត្តិហេតុថ្មីៗនៅតាមបណ្តោយព្រំប្រទល់ថៃ-កម្ពុជា ឬថៃ-ឡាវ។ អង្គភាពកងកម្លាំងទៀតទាត់របស់វៀតណាម និងកម្ពុជា ជួនកាលបង្កើតឡើងក្នុងទ្រង់ទ្រាយទំហំពី ៤.០០០ ឬ ៥.០០០ នាក់នៃភាគីទាំងសងខាង ត្រូវបានប្រយុទ្ធនៅក្នុងតំបន់ហាទៀង ចូវដុក នៃព្រំដែនប្រទេសវៀតណាម-កម្ពុជា។ [...] កងកម្លាំងខ្មែរក្រហមនៅខេត្តកំពង់ឆ្នាំ បានសម្លាប់ជនជាតិវៀតណាម ៤២០ នាក់"]។

ខេត្តតាយនិញ ខេត្តដុងថាប និងខេត្តអានយ៉ាង របស់វៀតណាម[1036]។ វៀតណាមបានបន្តវាយប្រហារតាមផ្លូវអាកាស[1037]។ ជម្លោះកាន់តែឡើងកម្តៅថែមទៀត នៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ

---

[1036] ឯកសារ D1.3.34.24 ទូរលេខ ៦២ ពីឈាន ជូនម-៨១ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៧ KH ERN 00001248 ["ថ្មីៗនេះមានដំណឹងទៀតថា [...] កងទ័ពកម្ពុជាសម្លាប់រង្គាល់ប្រជាជនវៀតណាមចំនួន ១០០០ នាក់ នៅហាទៀង ខេត្ត គៀន យ៉ាង"]។ ឯកសារ D1.3.34.26 ទូរលេខ ៦៨ ពី ឈាន ជូនម-៨១ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៧៧ (អាន យ៉ាង, អៀន យ៉ាង, ឡុង អាន និងខេត្តតាយនិញ)។ ឯកសារ D1.3.12.21 របាយការណ៍ក្រសួងការបរទេសសាធារណរដ្ឋសង្គមនិយមវៀតណាម ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00283129 និង KH ERN 00283138-44 (អាន យ៉ាង, ឡុងអាន, តៃនិញ, គៀនយ៉ាង និងដុងថាប ភូមិភាគបូព៌ា)។ ឯកសារ D1.3.30.19 របាយការណ៍កម្ពុជាប្រជាធិបតេយ្យពីភូមិភាគពាយ័ព្យ ជូនអង្គការ ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៧៧ KH ERN 00052825 (តាកែវ)។ ឯកសារ D114/297.1.39 អៀង ផាន ប្រតិចារឹកថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង ០៩.៥៤.១២-០៩.៥៩.៣៣ (ខេត្តតាកែវ)។ ឯកសារ D114/297.1.38 សៅ ម៉ុង ហៅ សៅ ចាំពី ប្រតិចារឹកថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង ១០.០០.០៣-១០.០៣.៣១ ["ការប្រយុទ្ធ [...] ឆ្នាំ ១៩៧៧ និង ៧៨ គឺរត់រហូតហ្នឹង គឺញឹករហូតអ៊ីចឹង"] (ព្រំដែន ដាក់ដាំ-ខេត្តមណ្ឌលគិរី)។ ឯកសារ D1.3.30.7 របាយការណ៍បក្សកុម្មុយនីស្តកម្ពុជា ពីរឿន ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៧៧ (ខេត្តស្ទឹងត្រែង, រតនគិរី)។ ឯកសារ D234/2.1.4 ក្រសួងការបរទេសនៃសាធារណរដ្ឋបារាំង ដីកាអមរួមលេខ ២១០ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៧៧ KH ERN 00810729 ["ការប្រយុទ្ធគ្នាក៏បានកើតឡើងផងដែរ នៅខេត្តស្វាយរៀងរបស់កម្ពុជា (តំបន់ចំពុះទា)។ ការប៉ះទង្គិចគ្នាបានបណ្តាលឲ្យស្លាប់ ៤០០ នាក់។ ទីពីរ នៅចន្លោះថ្ងៃទី ១៤ និងថ្ងៃទី ១៦ ខែ មិថុនា មានការប៉ះទង្គិចគ្នាខ្លាំងកើតឡើងនៅខេត្តចូវដុក និងជិតហាទៀង។"] (ខេត្តស្វាយរៀង ចូវដុក)។ ឯកសារ D1.3.34.19 របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពីតំបន់ ២៣ ថ្ងៃទី ១៤-១៨ ខែ មិថុនា ឆ្នាំ ១៩៧៧ (តំបន់ ២៣- ខេត្តស្វាយរៀង)។ ឯកសារ D1.3.34.22 របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពីតំបន់ ២០ ថ្ងៃទី ១៧-២៥ ខែ មិថុនា ឆ្នាំ ១៩៧៧ (ស្រុកពញាក្រែក តំបន់ ២០-ខេត្តកំពង់ចាម)។ ឯកសារ D114/297.1.22 មឹង វេត ប្រតិចារឹកថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦ 15.29.14-15.33.55 (ខេត្តក្រចេះ)។ ឯកសារ D114/297.1.23 មឹង វេត ប្រតិចារឹកថ្ងៃទី ២៧ ខែ កក្កដា ២០១៦ ម៉ោង ១១.០៧.០៦-១១.១៣.៣១, ១១.១៥.១៣-១១.២០.០៣ (រតនគីរី មណ្ឌលគីរី ក្រចេះ កំពង់ចាម កំពត តាកែវ)។ ឯកសារ D234/2.1.122 ឈុន សាម៉ន ប្រតិចារឹកថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ០៩.៤៧.៤៩-០៩.៥១.០៦ (តំបន់ ២៣-ខេត្តស្វាយរៀង)។ ឯកសារ D10.1.58 របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពីរឿន ជូនពូ ៨៩ (សុន សេន) ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ១៩៧៧ KH ERN 00231377-78 (ភូមិភាគឦសាន-ខេត្តស្ទឹងត្រែង)។ ឯកសារ D1.3.30.11 របាយការណ៍កម្ពុជាប្រជាធិបតេយ្យជូន ម-៨៧០ ខែ មេសា ឆ្នាំ ១៩៧៧ (ភូមិភាគបូព៌ា)។ ឯកសារ D1.3.34.17 ទូរលេខ ៤៣ ពីលឿ ជូនបង រឿន ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៧៧ (តំបន់ ១០៧-ខេត្តរតនគិរី)។ ឯកសារ D1.3.34.18 ទូរលេខ ៥៤ ពីឆាន ជូនម-៨៧០ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៧ (ខេត្តមណ្ឌលគីរី)។ ឯកសារ D234/2.1.2 របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពីតំបន់ ២១ ចុះថ្ងៃទី ២០-២១ ខែ ឧសភា ឆ្នាំ ១៩៧៧ (ភូមិភាគបូព៌ា)។ ឯកសារ D1.3.30.20 របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពីតំបន់ ២០ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៧៧ (ភូមិភាគបូព៌ា)។ ឯកសារ D1.3.34.20 ទូរលេខ ០៧ ពីរី ជូនបងជាទីគោរព ចុះ

ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៧៧ (តំបន់ ១០៧ - ខេត្តរតនគិរី)។ ឯកសារ D234/2.1.8 ទូរលេខ ៨៥ ពី លីន ជូនម-៨៧០ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៧៧ [នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៧៖ "មកឈប់ត្រង់វាលរាំ ខាងត្បូងវាងលិចវត្តត្នោតទៅមកម្ដុកខ្លែងនោះ [...] វាមានបាញ់កាំភ្លើងជាហ្វូរហែបន្តបន្ទាប់"] (ស្រុកពញាក្រែក តំបន់ ២០ - ខេត្តកំពង់ចាម)។ ឯកសារ D1.3.30.21 21 របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពីតំបន់ ២១ ថ្ងៃទី ២០-២៤ ខែ មិថុនា ឆ្នាំ ១៩៧៧ (តំបន់ ២១-ភូមិភាគ បូព៌ា)។ ឯកសារ D1.3.34.29 ទូរលេខ ៣៩ ពីឆុន ជូនបងប៉ុល (ប៉ុល ពត) ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៧ (Daem Thngan)។ ឯកសារ D1.3.34.30 ទូរលេខ ៤១ ពីឆុន ជូនបងប៉ុល (ប៉ុល ពត) ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៧៧ (ខេត្តស្វាយរៀង)។ ឯកសារ D234/2.1.13 សេចក្ដីថ្លែងការណ៍របស់រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 00656202-03 (ហាទៀងទៅតែនិញ, ចូរដុក ខែ មេសា ឆ្នាំ ១៩៧៧។ គៀនយ៉ាង, អាងយ៉ាង, ដុងថាប, ឡុងអាន, តៃនិញខែ មិថុនា ឆ្នាំ ១៩៧៧)។ ឯកសារ D234/2.1.15 ទូរលេខ ៩៦ ជូនមន្ទីរ ៨១ KH ERN 00002824 (តៃនិញ, គៀនយ៉ាង ខែ កញ្ញា ឆ្នាំ ១៩៧៧)។ ឯកសារ D69.1.30 បណ្ណាល័យនៃរបាយការណ៍សមាជ ជម្លោះវៀតណាម កម្ពុជា ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៧៨ EN ERN 00187388 (តៃនិញ ខែ កញ្ញា ឆ្នាំ ១៩៧៧។ គៀនយ៉ាង)។ ឯកសារ D234/2.1.7 សេចក្ដីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 00591044-45 (ភូមិភាគបូព៌ា ខែ កញ្ញា ឆ្នាំ ១៩៧៧។ ខេត្តស្វាយរៀង ខែ វិច្ឆិកា ឆ្នាំ ១៩៧៧។ ខេត្តតាកែវ ខែ ធ្នូ ឆ្នាំ ១៩៧៧។ បំពានរាល់ថ្ងៃក្នុងខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ ព្រៃវែ កណ្ដាល)។ ឯកសារ D1.3.12.21 របាយការណ៍ក្រសួងការបរទេស សាធារណរដ្ឋសង្គមនិយមវៀតណាម ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00283138-43 (គៀនយ៉ាង, អានយ៉ាង ដុងថាប, ឡុងអាន តៃនិញ)។ ឯកសារ D114/157.1.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ជិន ផាត KH ERN 01197638-39 (ខេត្តក្រចេះ ឆ្នាំ ១៩៧៧)។ ឯកសារ D114/157.1.4 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហោ ឱ KH ERN 01197698-99 (ខេត្តក្រចេះ ឆ្នាំ ១៩៧៧)។ ឯកសារ D64.1.34 កាសែតបាងកកប៉ុស្តិ៍ជនភៀសខ្លួនបានលើកឡើងពីការប៉ះទង្គិចគ្នារវាងកម្ពុជា និងសាធារណរដ្ឋវៀតណាម ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៧៧ EN ERN 00168725-26 ["សកម្មភាពរបស់វៀតណាម ហាក់ដូចជាឆ្លើយតបទៅនឹងការកើនឡើង នៃការប៉ះទង្គិចគ្នានៅតាមព្រំប្រទល់ចាប់ពីកំពង់ផែហាទៀង រហូតដល់ឆ្ងាយពីខេត្តរតនគីរីភាគឦសាននៃប្រទេសកម្ពុជា។ [...] ពីថ្ងៃទី ០២ ដល់ថ្ងៃទី ០៩ ខែ ឧសភា កងកម្លាំងអាកាសរបស់វៀតណាម បានវាយប្រហារទីតាំងបន្ទាយកាំភ្លើងធំ និងយោធភូមិយោធាប្រវែង ១៥ ម៉ែល៍នៅខាងកើតកំពង់ត្រាច និងទីប្រជុំជនផ្សេងៗទៀតនៅកម្ពុជា"] (ខេត្តរតនគីរី មណ្ឌលគីរី, អានយ៉ាង, គៀនយ៉ាង, គងឌុក)។ ឯកសារ D234/2.1.3 Christian Science Monitor, ប្រទេសកុម្មុយនីស្តជិតខាងកំពុងមានជម្លោះ? ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៧៧["តំបន់មួយដែលមានរបាយការណ៍អំពីការប្រឈមមុខដាក់គ្នា គឺក្នុងខេត្តរតនគីរីរបស់កម្ពុជា ដែលស្ថិតនៅប៉ែកឦសាន។"]។ ឯកសារ D1.3.25.14 កាសែត Washington Post ប្រទេសថៃនិយាយថា ប្រទេសកម្ពុជាវាយប្រហារលើប្រទេសវៀតណាម និងឡាវ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៧៧ (តំបន់ចំពុះសេក - ខេត្តស្វាយរៀង ខែកក្កដា ឆ្នាំ ១៩៧៧)។ ឯកសារ D1.3.25.19 កាសែត New York Times ប្រទេសកម្ពុជា និងប្រទេសវៀតណាមស្ថិតក្នុងការប៉ះទង្គិតតាមព្រំដែន ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៧។ ឯកសារ D69.1.36 រោងពុម្ពភាសាបរទេស ជម្លោះកម្ពុជា-វៀតណាម (កំណត់ត្រាប្រវត្តិសាស្ត្រ) EN ERN 00187340 (គៀនយ៉ាង, តៃនិញ)។ ឯកសារ D32/12.1 Pham Van Tra ជីវិតយោធាម្នាក់៖ ការចងចាំ EN ERN 00432804-05

១៩៧៧ ពេលកម្ពុជាប្រជាធិបតេយ្យវាយប្រហារទ្រង់ទ្រាយធំចូលវៀតណាម ដោយបានសម្លាប់ជនស៊ីវិលអស់រាប់រយនាក់នៅភូមិមួយចំនួនក្នុងខេត្តតាយនិញ[1038]។ ជាការតបត កងទ័ពវៀតណា

["សភាពការណ៍នៅដុងថាបន់តែអាក្រក់ទៅៗ។ កងកម្លាំងខ្មាំងត្រូវបានជន់លិចនៅក្នុងតំបន់ឆ្លងកាត់ព្រំដែនវិញបា (Vinh Ba)។ ពួកគេបានវាយប្រហារយ៉ាងជ្រៅទៅក្នុងទឹកដីរបស់យើង ហើយបានចាប់ និងកាន់កាប់តំបន់មួយចំនួន [...] បន្ទាប់ពីស្ថានការណ៍រាប់សិបក្នុងខេត្តគៀនយ៉ាង [...] ខ្មាំងបានប្រមូលកម្លាំងដ៏ធំមួយ ដែលបានវាយប្រហារតំបន់បាជុក"] (ដុងថាប, អានយ៉ាង, គៀនយ៉ាង ខែ មិថុនា ឆ្នាំ ១៩៧៧)។

1037 ឯកសារ D234/2.1.12 ទូរលេខ ០៥ ពីសាន ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៧៧ ["យន្តហោះវៀតណាមធុនជើងស្ពោក [...] ទម្លាក់គ្រប់បែក និងបាញ់រះនៅកន្លែងនោះ។"] (អូរលីវ - ខេត្តរតនគិរី)។ ឯកសារ D1.3.25.14 កាសែត Washington Post ប្រទេសថៃនិយាយថា ប្រទេសកម្ពុជាវាយប្រហារលើប្រទេសវៀតណាម និងឡាវ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៧៧ ["នាយករដ្ឋមន្ត្រីបាននិយាយថា 'ប្រទេសទាំងពីរបានប្រើយន្តហោះទំលាក់គ្រាប់បែកដាក់គ្នាទៅវិញទៅមក"]។ ឯកសារ D64.1.34 កាសែតបាងកកប៉ុស្ដិ៍ជនភៀសខ្លួនបានលើកឡើងពីការប៉ះទង្គិចគ្នារវាងកម្ពុជា និងសាធារណរដ្ឋវៀតណាម ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៧៧ EN ERN 00168725 ["ពីថ្ងៃទី ០២ ដល់ថ្ងៃទី ០៩ ខែ ឧសភា កងកម្លាំងអាកាសរបស់វៀតណាមបានវាយប្រហារទីតាំងបន្ទាយកាំភ្លើងធំ និងយោធភូមិយោធាប្រវែង ១៥ ម៉ែល៍នៅខាងកើតកំពង់ត្រាច និងទីប្រជុំជនផ្សេងៗទៀតនៅកម្ពុជា។ [...] វៀតណាមធ្លាប់បានចាប់ យន្តហោះធុន A-37s និង F-5s ដែលផលិតដោយអាមេរិក ជាមួយនឹង យន្តហោះ MIG-21s ដែលផលិតដោយសូវៀត។ កាំភ្លើងខ្ទម្ពាគចក្រដែលផលិតដោយអាមេរិក និងយន្តហោះធុន U-17 ត្រូវបានជួសជុលស្ពាប ក៏ត្រូវបានប្រើផងដែរ នៅក្នុងការវាយប្រហារមកលើទីតាំងផ្សេងៗរបស់កម្ពុជា។"]។

1038 ឯកសារ D1.3.12.21 របាយការណ៍ក្រសួងការបរទេស សាធារណរដ្ឋសង្គមនិយមវៀតណាម ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00283143 ["ការវាយប្រហារទាំងនេះ បានចាប់ផ្ដើមនៅយប់ថ្ងៃទី ២៤ ខែ កញ្ញា។ កងកម្លាំងប្រដាប់អាវុធកម្ពុជា ដែលមានចំនួនប្រហែលជាមួយកងពល និងមានការគាំទ្រពីកាំភ្លើងធំបានបើកការវាយប្រហារព្រមៗគ្នា មកលើភូមិមួយចំនួននៅក្នុងស្រុកតានបៀន ចៅថាញ់ និងបែកៅ។ [...] ជនស៊ីវិលប្រហែល ១០០០ នាក់ ត្រូវបានសម្លាប់ ឬរងរបួស"]។ ឯកសារ D234/2.1.6 លិខិតអគ្គកុងស៊ុលសាធារណរដ្ឋបារាំង ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៧៧ KH ERN 00492877 ["នៅហ្គូដៅហា ដែលជាមូលដ្ឋានមួយស្ថិតនៅលើផ្លូវមកភ្នំពេញ និងមានចម្ងាយពីរបីគីឡូម៉ែត្រពីព្រំប្រទល់ និងដែលត្រូវបានកាន់កាប់ពេញមួយយប់នៅចុងខែកញ្ញាដោយពួកគេ។ កងទាហានទាំងពីរបីក្រុមដែលកើតចេញ ជាអាទិ៍ ពីចំណោមយុវជនវៀតណាមខាងត្បូង ដែលឈរជើងនៅក្នុងតំបន់នេះ និងនៅខេត្តតៃនិញ ទំនងជាមិនអាចទប់ទល់នឹការវាយប្រហារបានទេ"]។ ឯកសារ D234/2.1.135 Stephen Morris ប្រតិចារឹកថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង ១៤.១១.៣៧-១៤.១៤.២៤។ ឯកសារ D98/1.2.5 ណាយ៉ាន់ ចាន់ដា ប្រតិចារឹកថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៩ ម៉ោង ១០.០៤.២៥-១០.០៩.០៩។ ឯកសារ D114/258 កំណត់ហេតុស្តាប់ចម្លើយ ឡាយ អ៊ិន ហៅ អឿន ឆ.៨៩ ["យួនវៃចូលស្រុកខ្មែរ គេរៀបចំកម្លាំងវៃយួន"] ឆ.១០៧ ["[កងម្លាំងកម្ពុជាប្រជាធិបតេយ្យ] មានកាំភ្លើង ១០៥, ១២០ ក្រៅពីនោះ ថ្មើរជើងបណ្ដោយ។ កន្លែងខ្លះមានរថក្រោះទៅវៃ" ឆ.១១១-១១៤ ["ស៖ តើជនស៊ីវិលវៀតណាម ឬក៏កូនក្មេង ត្រូវគេវៃប្រហារអីទេ? ឆ.១១១៖ ល្មើយទ័ពអី ក៏ចាប់បានបញ្ជូនមក រត់មិនរួច ចាប់បាន

មប្រហែល ពីរម៉ឺននាក់[1039] បានវាយចូលព្រំដែន ក្នុងខេត្តកំពង់ចាម ខេត្តព្រៃវែង និងចូល ២៤ គីឡូម៉ែត្រក្នុងខេត្តស្វាយរៀង ភូមិភាគបូព៌ា[1040]។ នៅខែ ធ្នូ កងកម្លាំងវៀតណាម ដោយមានការគាំ

---

បញ្ជូនមក។ ស៖ [...] លោកបានប្រាប់ថា ផ្ទះ មន្ទីរពេទ្យ និងរោងចក្រវៀតណាម អីត្រូវបានបំផ្លាញ។ ម៉េចលោកដឹង? ឆ.១១២៖ ព្រោះខ្ញុំចូលទៅវៃក្នុងស្រុកយួន។ ស៖ តើលោកឃើញគេដុតផ្ទះ ដុតមន្ទីរពេទ្យ រោងចក្រនៅវៀតណាមហ្នឹង ឃើញទេ? ឆ.១១៣៖ ឃើញ។ [...] ឆ.១១៤៖ ខេត្តតៃនិញ"]។ ឯកសារ D1.3.32.27 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឡេង គីម ហៅគង់ គីម KH ERN 00054819 ["នៅក្នុងឆ្នាំ ១៩៧៧ ប្រហែលចុងខែ ៩ ខែ ១០ ហ្នឹង យកខ្ញុំទៅវៃវៀតណាមហ្នឹងចូលទៅខេត្តតៃនិញហ្នឹង។ ខ្ញុំចូលរួមវៃកាលហ្នឹង"]។ ឯកសារ D1.3.17.5 ណាយ៉ាន់ ចាន់ដា សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម KH ERN 00191525 ["នៅព្រឹកថ្ងៃទី ២៦ ខែ កញ្ញា [...] ឧត្តមសេនីយ៍ ត្រាន់ វ៉ាន់ត្រា មេបញ្ជាការយោធភូមិភាគទី៧ [...] គាត់ពិតជាមានកំហឹងយ៉ាងខ្លាំង។ ពីរយប់មុន កងទ័បខ្មែរក្រហមបានឡោមព័ទ្ធវាយប្រហារ ខេត្តតាយនិញ ដោយសម្លាប់ជនស៊ីវិលអស់ប្រមាណមួយរយនាក់"]។ ឯកសារ D1.3.17.8 Steven Ratner and Jason Abrams ការទទួលខុសត្រូវចំពោះអំពើឃោរឃៅសិទ្ធិមនុស្សនៅក្នុងច្បាប់អន្តរជាតិ KH ERN 00429400 ["នៅក្នុងខែ កញ្ញា [ឆ្នាំ ១៩៧៧] [ខ្មែរក្រហម] គេបានវាយប្រហារភូមិខ្លះទៀតក្នុងខេត្តតាយនិញរបស់វៀតណាម ដោយបានសម្លាប់ប្រជាជនស៊ីវិលរាប់រយនាក់"]។

1039 ឯកសារ D1.3.17.8 Steven Ratner និង Jason Abrams ការទទួលខុសត្រូវចំពោះអំពើឃោរឃៅសិទ្ធិមនុស្សនៅក្នុងច្បាប់អន្តរជាតិ KH ERN 00429400។

1040 ឯកសារ D234/2.1.9 សារទូរលេខពីក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ ជូនសមាគមមិត្តភាពស៊ុយអែត-កម្ពុជា ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៧៨ KH ERN 00749404 ["នៅខែ កញ្ញា ឆ្នាំ ១៩៧៧ កងទ័ពវៀតណាមបានលុកលុយចូលតំបន់ផ្លូវជាតិលេខ ៧ ហើយបានវាយយកស្រុកមេមត់ ក្រែក ភូមិស្ទឹង និងប្រធាតុ នៅចម្ងាយ ៣០ គីឡូម៉ែត្រពីព្រំដែន។ [...] នៅខែវិច្ឆិកា ឆ្នាំ ១៩៧៧ កងទ័ពវៀតណាមបានចាប់ផ្តើមឈ្លានពានលើខេត្តស្វាយរៀង និងបានវាយយកស្រុកចក និងប្រសូត្រ ស្ថិតនៅចម្ងាយ ២០ និង ៣០ គីឡូម៉ែត្ររៀងគ្នាពីព្រំដែន"] (ខេត្តស្វាយរៀង, កំពង់ចាម - ភូមិភាគបូព៌ា)។ ឯកសារ D4.1.1029 1029 សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 00442393 (ភូមិភាគបូព៌ា ខេត្តស្វាយរៀង)។ ឯកសារ D1.3.34.34 ទូរលេខ ៥៥ ពី ឆុន ជូន ម-៨៧០ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៧៧ (ខេត្តកំពង់ចាម-ភូមិភាគបូព៌ា)។ ឯកសារ D4.1.293 ទូរលេខ ពី ឆុន ជូន ម-៨៧០ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៧ (ខេត្តកំពង់ចាម-ភូមិភាគបូព៌ា)។ ឯកសារ D1.3.34.33 ទូរលេខ ៥៦ ពី ឆុន ជូន ម-៨៧០ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៧៧ (ខេត្តស្វាយរៀង)។ ឯកសារ D1.3.34.35 ទូរលេខ ៥៧ ពី ឆុន ជូន ម-៨៧០ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៧ (តំបន់ ២៣-ខេត្តស្វាយរៀង)។ ឯកសារ D1.3.34.37 ទូរលេខ ៥៩ ជូន ម-៨៧០ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៧៧ KH ERN 00020874 (តំបន់ ២៣ - ខេត្តស្វាយរៀង)។ ឯកសារ D1.3.34.36 ទូរលេខ ៦១ ពី ឆុន ជូន ម-៨៧០ ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៧៧ (ខេត្តកំពង់ចាម - ភូមិភាគបូព៌ា)។ ឯកសារ D1.3.34.38 ទូរលេខ ៦០ ពី ឆុន ជូន ម-៨៧០ ចុះថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៧៧ KH ERN 00020875 (តំបន់ ២៣ - ខេត្តស្វាយរៀង)។ ឯកសារ D4.1.295 ទូរលេខ ៤៦ ពី ធួន ទៅ យី តាមរយៈមន្ទីរ ៨៧០ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ (ខេត្តស្វាយរៀង)។ ឯកសារ D4.1.294 ទូរលេខ ៦៨ ពី ឆុន ជូន ប៉ា ចុះថ្ងៃទី ០៦

ទ្រព្យពីកងទ័ពអាកាស រថពាសដែក និងកាំភ្លើងធំ បានវាយចូលព្រំដែន ក្នុងខេត្តកំពង់ចាម ខេត្តស្វាយរៀង ខេត្តតាកែវ និងខេត្តកំពត[1041] ដោយចូលជ្រៅរហូតដល់ ៣០ គីឡូម៉ែត្រក្នុងខេត្តស្វាយ

ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ (ត្រពាំងផ្លុង)។ ឯកសារ D1.3.34.40 ទូរលេខ ៦៩ ជូន ម-៨៧០ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ (ខេត្តស្វាយរៀង)។ ឯកសារ D4.1.219 ទូរលេខ ៧៦ ពី ឝុន ជូន ម-៨៧០ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ (ខេត្តស្វាយរៀង)។ ឯកសារ D1.3.34.41 ទូរលេខ ៨២ ពី ឝុន ជូនបងប៉ុល ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ (តំបន់ ២៣ - ខេត្តស្វាយរៀង)។ ឯកសារ D4.1.296 ទូរលេខ ៨៥ ពី ឝុន ជូនបង ប៉ុល (ប៉ុល ពត) ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ១៩៧៧ KH ERN 00020866 (ខេត្តស្វាយរៀង)។ ឯកសារ D1.3.29.1 សេចក្តីថ្លែងការណ៍រាជរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00234027-29 (ខេត្តកំពង់ចាម ខេត្តស្វាយរៀង)។ ឯកសារ D234/2.1.7 សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 00591044 (ភូមិភាគបូព៌ា -ខេត្តកំពង់ចាម និងខេត្តស្វាយរៀង)។ ឯកសារ D4.1.617 ផ្សព្វផ្សាយតាមវិទ្យុកម្ពុជាប្រជាធិបតេយ្យ របាយការណ៍ការពារជាតិកាលពីឆ្នាំមុន ត្រូវបានពិនិត្យឡើងវិញ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៨ KH ERN 00340543-44 (ខេត្តកំពង់ចាម និងខេត្តស្វាយរៀង)។ ឯកសារ D234/2.1.6 លិខិតអគ្គកុងស៊ុលសាធារណរដ្ឋបារាំង ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៧៧ KH ERN 00492874 ["ឧប្បត្តិហេតុដ៏ធ្ងន់ធ្ងរមួយចំនួនបានផ្ទុះឡើងលើចំណុចជាច្រើននៅតាមបណ្តោយព្រំដែនកម្ពុជា និងវៀតណាមនាចុងខែកញ្ញា និងក្នុងរយៈពេលពាក់កណ្តាលដំបូងនៃខែ តុលា"]។ ឯកសារ D4.1.505 កំណត់ហេតុស្តាប់ចម្លើយ KH ERN 00282959 ["នៅខែច្រូតស្រូវ (ខែដប់មួយ) ឆ្នាំ ១៩៧៧ គេឲ្យខ្ញុំទៅសមរភូមិមុខ ដើម្បីប្រយុទ្ធជាមួយកងទ័ពវៀតណាម។ [...] ក្នុងខេត្តកំពង់ចាម"]។ ឯកសារ D1.3.25.19 កាសែតNew York Times ប្រទេសកម្ពុជា និងប្រទេសវៀតណាមស្ថិតក្នុងការប៉ះទង្គិចតាមព្រំដែន ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៧(ខេត្តព្រៃវែង)។

1041 ឯកសារ D4.1.988 ចម្លើយ អៀង ធីរិទ្ធ ចុះថ្ងៃទី ១៧-១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៧៩ KH ERN 00658249 ["អាជ្ញាធរក្រុងហាណូយ នៅខែធ្នូ ឆ្នាំ ១៩៧៧ បានចាប់ផ្តើមសង្គ្រាមឈ្លានពានទ្រង់ទ្រាយធំ"]។ ឯកសារ D4.1.617 ផ្សព្វផ្សាយតាមវិទ្យុកម្ពុជាប្រជាធិបតេយ្យ របាយការណ៍ការពារជាតិកាលពីឆ្នាំមុន ត្រូវបានពិនិត្យឡើងវិញ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៨ KH ERN 00340544 ["នៅក្នុងខែវិច្ឆិកា និងខែធ្នូ កងកម្លាំងវៀតណាមបានឈ្លានពានទឹកដីរបស់យើងនៅក្នុងខេត្តស្វាយរៀង កំពង់ចាមខាងកើត តាកែវ និងកំពត"]។ ឯកសារ D1.3.29.1 សេចក្តីថ្លែងការណ៍រាជរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00234027-29 (ថ្ងៃទី ០១ ខែ មករា វាយប្រហារ ៣០ គីឡូម៉ែត្រក្នុងព្រំដែនកម្ពុជាប្រជាធិបតេយ្យ។ ខែ ធ្នូ វាយប្រហារក្នុងខេត្តតាកែវ និងកំពត។)។ ឯកសារ D234/2.1.9 សារទូរលេខ ពីក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ ជូនសមាគមមិត្តភាពស៊ុយអែត-កម្ពុជា ចុះថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៧៨ KH ERN 00749404 ["នៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៧ កងទ័ពវៀតណាមបានវាយលុកទ្រង់ទ្រាយធំទៀត ក្នុងស្រុកកោះអណ្តែត និងគិរីវង់ នៃខេត្តតាកែវ និងក្នុងស្រុកកំពង់ត្រាច នៃខេត្តកំពត។"] (ខេត្តតាកែវ ខេត្តកំពត)។ ឯកសារ D1.3.34.42 ទូរលេខ ៨៥ ពី ឝុន ជូន ម-៨៧០ ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 00020864 (តំបន់ ២៣ - ខេត្តស្វាយរៀង)។ ឯកសារ D4.1.298 ទូរលេខ ៩០ ពី ឝុន ជូនមន្ទីរ ៨៧០ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៧៧ (ស្រុកពញាក្រែក - ខេត្តកំពង់ចាម)។ ឯកសារ D1.3.34.43 ទូរលេខ ៩១ ពី ឝុន ជូន ម-៨៧០ ចុះថ្ងៃទី

១០ ខែ ធ្នូ ឆ្នាំ ១៩៧៧ (ភូមិស្វាយ - ខេត្តកំពង់ចាម - ភូមិភាគបូព៌ា)។ ឯកសារ D1.3.34.44 ទូរលេខ ៩២ ពី ឆុន ជូន ម-៨៧០ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៧៧ (ខេត្តកំពង់ចាម - ភូមិភាគបូព៌ា)។ ឯកសារ D1.3.34.45 ទូរលេខ ៩៥ ពី ឆុន ជូនម-៨៧០ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៧៧ (តំបន់ ២៤ - ខេត្តព្រៃវែង)។ ឯកសារ D1.3.34.46 ទូរលេខ ៩៦ ពី ឆុន ជូន ម-៨៧០ ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៧៧ (តំបន់ ២៣ - ស្វាយរៀង)។ ឯកសារ D4.1.328 ទូរលេខ ៩៧ ពី ឆុន ជូនបងទី១ ជាទីស្រលាញ់ ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH 00020896-97 (តំបន់ ២៣ - ខេត្តស្វាយរៀង)។ ឯកសារ D4.1.302 ទូរលេខ ២៧ ពី កួន ជូន យី ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៧៧ (ផ្លូវ ១៤)។ ឯកសារ D1.3.34.50 ទូរលេខ ៦៨ ពី កួន ជូន យី តាមរយៈ ៨៧០ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៧៧ (ផ្លូវ ១៤ អូ លឹម)។ ឯកសារ D1.3.34.49 ទូរលេខ ០៥ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៧៧ (ខេត្តកំពង់ចាម - ភូមិភាគបូព៌ា)។ ឯកសារ D1.3.34.53 ទូរលេខ ០៦ ពី ភួង ជូន ម-៨៧០ ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៧៧ (ខេត្តកំពង់ចាម - ភូមិភាគបូព៌ា)។ ឯកសារ D1.3.34.52 ទូរលេខ ០៧ ពី ភួង ជូន ម-៨៧០ ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៧៧ (ខេត្តកំពង់ចាម - ភូមិភាគបូព៌ា)។ ឯកសារ D1.3.34.55 ទូរលេខ ពី ឆុន ជូនបង ប៉ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៧៧ (ខេត្តកំពង់ចាម - ភូមិភាគបូព៌ា)។ ឯកសារ D1.3.34.58 ទូរលេខ ០៩ ពី ភួង ជូន ម-៨៧០ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៧៧ (ខេត្តកំពង់ចាម - ភូមិភាគបូព៌ា)។ ឯកសារ D1.3.34.54 ទូរលេខ ០៨ ពី ភួង ជូន ម-៨៧០ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៧៧ (ខេត្តកំពង់ចាម - ភូមិភាគបូព៌ា)។ ឯកសារ D1.3.34.56 ទូរលេខ ០១១ ពី ភួង ជូន ម-៨៧០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៧៧ (ខេត្តកំពង់ចាម - ភូមិភាគបូព៌ា)។ ឯកសារ D1.3.25.33 សេចក្ដីថ្លែងការណ៍របស់ ខៀវ សំផន ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 00229016 ["នៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៧ កងកម្លាំងប្រដាប់អាវុធវៀតណាម បានរំលោភល្លានពានទ្រង់ទ្រាយធំមួយផ្សេងទៀត នៅក្នុងស្រុកកោះអណ្ដែត និងគិរីវង់ ក្នុងខេត្តតាកែវ និងស្រុកកំពង់ត្រាចក្នុងខេត្តកំពត ដើម្បីសម្លាប់ប្រជាជនកម្ពុជាដោយចេតនា"] (ខេត្តតាកែវ ខេត្តកំពត)។ ឯកសារ D1.3.25.31 កាសែត New York Times កម្ពុជាកាត់ផ្ដាច់ចំណងទាក់ទងជាមួយវៀតណាម ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 00645211 (ចំពុះសេក - ខេត្តស្វាយរៀង)។ ឯកសារ D4.1.225 ទូរលេខ ១៥ ពី ភួង ជូនម-៨៧០ ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៧៨ (ខេត្តកំពង់ចាម - ភូមិភាគបូព៌ា)។ ឯកសារ D234/2.1.7 7 សេចក្ដីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 00591044-45 (ខេត្តតាកែវ ខេត្តកំពត ខេត្តស្វាយរៀង)។ ឯកសសារ D1.3.34.59 ទូរលេខ ១៧ ពី ភួង ជូន ម-៨៧០ ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៧៨ (ខេត្តកំពង់ចាម-ភូមិភាគបូព៌ា)។ ឯកសារ D4.1.866 ទង់បដិវត្ត ចេញផ្សាយខែ កុម្ភៈ ឆ្នាំ ១៩៧៨ KH ERN 00064438 (រតនគិរី ស្វាយរៀង និងកំពត)។ ឯកសារ D4.1.868 ទង់បដិវត្ត ចេញផ្សាយខែ មេសា ឆ្នាំ ១៩៧៨ KH ERN 00064721 (ខេត្តស្វាយរៀង ខេត្តកំពង់ចាម ខេត្តតាកែវ ខេត្តកំពត)។ ឯកសារ D1.3.24.5 ឯកសារទង់បដិវត្ត ចេញផ្សាយខែ ឧសភា-មិថុនា ឆ្នាំ ១៩៧៨ KH ERN 00064558 (ខេត្តរតនគិរី ទៅខេត្តកំពត ខែធ្នូ ឆ្នាំ ១៩៧៧)។ ឯកសារ D114/297.1.39 អៀង ផាន ប្រតិចារឹកថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង ០៩.៥៤.១២-០៩.៥៦.៤១ (តាកែវ)។ ឯកសារ D114/209 កំណត់ហេតុស្ដាប់ចម្លើយ មឹង សេង ឆ. ៥៩ ["ការវាយប្រយុទ្ធខ្លាំងរវាងខ្មែរក្រហម និងវៀតណាមចាប់តាំងពីចុងឆ្នាំ ១៩៧៧ ម្ល៉េះ"]។ ឯកសារ D98/1.1.8 កំណត់ហេតុស្ដាប់ចម្លើយ ប៉ុល ញ៉ន ឆ.៦ ["គេបញ្ជូនខ្ញុំទៅវៃជាមួយយួននៅស្រុកគីរីវង់ ខេត្តតាកែវវិញនៅក្នុងខែ ធ្នូ ឆ្នាំ ១៩៧៧"]។ ឯកសារ D1.3.25.30 កាសែត The Times of London រាយការណ៍ប្រយុទ្ធរវាងវៀតណាម និងកម្ពុជា ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៧៧ (ស្វាយរៀង)។ ឯកសារ D1.3.25.32

រៀង[1042] និងវាយឱ្យកងកម្លាំងកម្ពុជាប្រជាធិបតេយ្យទទួលបរាជ័យធ្ងន់ធ្ងរ[1043]។ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យបានផ្តាច់ទំនាក់ទំនងការទូតជាមួយវៀតណាម ជាសាធារណៈ នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧[1044]។

---

សមាគមសារព័ត៌មាន កម្ពុជាផ្តាច់ទំនាក់ទំនងដោយចោទប្រកាន់ក្រុងហាណូយអំពីការឈ្លានពាន ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 00282749 (ខេត្តស្វាយរៀង)។ ឯកសារ D114/29.1.4 Ben Kiernan របបប៉ុលពត KH ERN 00637926 ["ក្រុងហាណូយបានរៀបចំខ្លួនដើម្បីផ្តើមធ្វើការលុកលុយមួយយ៉ាងធំនៅក្នុងខែ ធ្នូ ដោយកេណ្ឌប្រមូលកងទ័ពប្រយុទ្ធពី ៣០.០០០ ទៅ ៦០.០០០ នាក់គាំទ្រដោយកងកាំភ្លើងធំ កងរថក្រោះ និងកងយន្តហោះផង"]។ ឯកសារ D32/12.1 Pham Van Tra ជីវិតយោធាម្នាក់៖ ការចងចាំ EN ERN 00432806 (តាកែវ)។

1042 ឯកសារ D4.1.866 ទង់បដិវត្ត ចេញផ្សាយខែ កុម្ភៈ ឆ្នាំ ១៩៧៨ KH ERN 00064438 ["[យួន] លុកចូលជ្រៅរាប់គីឡូម៉ែត្រ ហើយកន្លែងខ្លះរាប់សិបគីឡូម៉ែត្រក្នុងដីយើង ពិសេសនៅផ្លូវលេខ ៧ និងស្វាយរៀងខាងភូមិភាគបូព៌ា"]។ ឯកសារ D1.3.29.1 សេចក្តីថ្លែងការណ៍រាជរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00234028 ["នៅខេត្តស្វាយរៀង កងទ័ពយួនបានចូល [...] ចម្ងាយ ៣០ គីឡូម៉ែត្រពីព្រំដែន"]។ ឯកសារ D1.3.17.8 Steven Ratner និង Jason Abrams ការទទួលខុសត្រូវចំពោះអំពើឃោរឃៅសិទ្ធិមនុស្សនៅក្នុងច្បាប់អន្តរជាតិ KH ERN KH 00429400 ["នៅចុងខែ ធ្នូ បានបញ្ជូនកងទ័ពអន្តរាគមន៍បន្ថែមចំនួន ៥៨,០០០ ទៅកាន់ភូមិភាគបូព៌ារបស់កម្ពុជា ដែលទ័ពទាំងនេះបានចូលជ្រៅរហូតម្តៃប្រាំម៉ែល៍"]។ ឯកសារ D69.1.23 សារព័ត៌មានពីប្រទេសកម្ពុជា សេចក្តីថ្លែងការណ៍ដោយ អៀង សារី រដ្ឋមន្ត្រីក្រសួងការបរទេស ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៧៨ EN ERN S 00011306 ["បើជម្លោះព្រំដែនថ្មីៗនេះ គឺគ្រាន់តែជម្លោះព្រំដែនធម្មតា ហេតុអីនៅចុងឆ្នាំ១៩៧៧ កងទ័ពវៀតណាមបានចូលទឹកដីកម្ពុជាចម្ងាយ ៣០ គីឡូម៉ែត្រ"]។

1043 ឯកសារ D4.1.298 ទូរលេខ ៩០ ពី ឆុន ជូនមន្ទីរ ៨៧០ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៧៧ ["ខ្មាំងបុកយើងដាច់ [...] ខ្មាំងវ៉ៃយើងខ្លាំងពីខាងលិច ផ្លូវថ្នល់២២ ទៅកើតកាត់ក្រោយខ្នង យើងត្រៀមខាងមុខ។ យើងកំពុងប្រយុទ្ធយ៉ាងខ្លាំងក្លា តាមសន្និដ្ឋាន យើងទប់មិនជាប់ [...]។ ខ្មាំងវាវ៉ៃយើងមានរថក្រោះ ៥០ គ្រឿង។"] (ខេត្តកំពង់ចាម - ភូមិភាគបូព៌ា)។ ឯកសារ D1.3.34.48 ទូរលេខ ២ ពីឆុន ជូនបង ជាទីគោរព ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៧៧ ["អាខ្មាំងបុកយើងយ៉ាងខ្លាំង [...] ធ្វើឱ្យស្លាប់ប្រជាជន និងគោបក្របីអស់ជាច្រើន។ [...] នៅគ្រប់មុខព្រួញ ត្រូវខ្មាំងវ៉ៃបុកដាច់"] (ខេត្តកំពង់ចចាម - ភូមិភាគបូព៌ា)។ ឯកសារ D1.3.34.55 ទូរលេខ ពី ឆុន ជូនបង ប៉ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៧៧ ["សភាពការណ៍ខ្មាំងវាបុកយើងជាបន្តបន្ទាប់ តាំងពីដា រហូតមកស្ទឹង [...] តែខ្មាំងមានចំនួនច្រើន មិនធម្មតាទេ"] (ខេត្តកំពង់ចាម - ភូមិភាគបូព៌ា)។ ឯកសារ D1.3.17.5 ណាយ៉ាន់ ចាន់ដា សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម KH ERN 00191540-41 ["កងទ័ពវៀតណាមដែលគាំទ្រដោយការបាញ់កាំភ្លើងធំស្រោចដូចភ្លៀង បានទន្ទ្រានចូលកម្ពុជាដូចហ្វូងស្រមោច។ កងទ័ពខ្មែរក្រហមជាង ១០០នាក់បានត្រូវសម្លាប់ ឬរបួសក្នុងប្រតិបត្តិការបោសសម្អាតជាច្រើនកន្លែង។ [...] ការទប់ទល់ដែលឥតសណ្តាប់ធ្នាប់នៃកងទ័ពភូមិភាគរបស់ខ្មែរក្រហម មិនបានសម្រេចជោគជ័យឡើងហើយត្រូវបានកម្ទេចដោយកងរថក្រោះ និងការបាញ់សន្ធាប់យ៉ាងសម្បើមពីសំណាក់សត្រូវ។ [...]

313. នៅថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៨ វៀតណាមបានដកកម្លាំងចេញពីកម្ពុជា[1045] ប៉ុន្តែ ការប៉ះទង្គិចដោយអាវុធនៅតែបន្ត[1046]។ នៅដើមឆ្នាំ ១៩៧៨ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យបានបញ្ជូនកងទ័ព

---

បណ្ដាមេដឹកនាំក្រុងភ្នំពេញ ដែលត្រូវធ្វើឱ្យស្រឡាំងកាំងដោយការវាយលុកដ៏សម្បើមខុសប្លែកពីធម្មតារបស់វៀតណាម និងដែលត្រូវធ្វើឱ្យឡប់ស្មារតីគឺដោយការបាក់ទ័ពរត់របាត់របាយរបស់កងទ័ពភូមិភាគបូព៌ា"]។

1044 ឯកសារ D69.1.5 សេចក្តីថ្លែងការនៃរដ្ឋមន្ត្រីក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧។ ឯកសារ D69.1.7 សេចក្តីថ្លែងការណ៍ក្រសួងការបរទេស ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧។ ឯកសារ D69.1.30 បណ្ណាល័យនៃរបាយការណ៍សមាជ ជម្លោះវៀតណាម កម្ពុជា ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៧៨ EN ERN 00187388។ ឯកសារ D54/6.1.12 ណាយ៉ាន់ ចាន់ដា ប្រតិចារឹកថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៩ ម៉ោង ១១.៣១.៥២-១១.៣៤.៣២, ១១.៣៩.៥៨-១១.៤៣.១៧, ១៤.២៨.២២-១៤.៣៤.១៧។ ឯកសារ D4.1.1114 កំណត់ហេតុស្ដាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច KH ERN 00186202 ["សេចក្តីប្រកាសសង្គ្រាមជាផ្លូវការជាមួយវៀតណាម ត្រូវធ្វើនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧"]។ ឯកសារ D1.3.25.32 សមាគមន៍សារព័ត៌មាន កាសែត Los Angeles Times កម្ពុជាផ្ដាច់ទំនាក់ទំនងដោយចោទប្រកាន់ក្រុងហាណូយអំពីការឈ្លានពាន ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧។ ឯកសារ D1.3.25.31 កាសែត New York Times កម្ពុជាកាត់ផ្ដាច់ចំណងទាក់ទងជាមួយវៀតណាម ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧។ ឯកសារ D69.1.4 កាសែត Washington Post កម្ពុជាកាត់ទំនាក់ទំនងការទូតជាមួយវៀតណាម ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧។ ឯកសារ D1.3.25.34 កាសែត Los Angeles Times ការទទួលស្គាល់របស់កម្ពុជាអំពីភាពតានតឹងនៃសង្គ្រាមព្រំដែនវៀតណាម ថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៧៨។ ឯកសារ D1.3.25.35 កាសែត Los Angeles Times កំហឹងពីមុនបានមើលឃើញពីជម្លោះកម្ពុជា-វៀតណាម ថ្ងៃទី ២៧ ខែ មករា ឆ្នាំ១៩៧៨ ["ការប្រយុទ្ធគ្នាជាទ្រង់ទ្រាយធំបានកើតឡើង និងទំនាក់ទំនងការទូតពីរដោយឡែកពីគ្នានៅថ្ងៃទី ៣១ ខែ ធ្នូ"]។

1045 ឯកសារ D114/37.1.73 David Chandler ប្រតិចារឹកថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៩ ម៉ោង ១៥.០២.១០-១៥.០៦.០៤ ["ក្រោយពីវៀតណាមវាយប្រហារចូលកម្ពុជាក្នុងចុងឆ្នាំ ១៩៧៧ នោះ រហូតទាល់តែគេដកនៅខែមករា ឆ្នាំ ១៩៧៨"]។ ឯកសារ D114/29.1.4 Ben Kiernan របបប៉ុលពត KH ERN 00637927 ["នៅថ្ងៃទី ៦ ខែ មករា (១៩៧៨) កងទ័ពឈ្លានពានបានបកត្រឡប់ទៅទឹកដីរបស់វៀតណាមវិញ"]។ ឯកសារ D1.3.17.5 ណាយ៉ាន់ ចាន់ដា សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម KH ERN 00191547 ["ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៨ គឺត្រូវចារឹកជាអក្សរមាសក្នុងតារាងថ្ងៃខែឆ្នាំនៃប្រវត្តិសាស្ត្រ ទុកដូចជាថ្ងៃគួរឱ្យចងចាំ ដែលខ្មែរបានវាយកម្ចាត់កម្ចាយកងទ័ពឈ្លានពានដ៏ខ្លាំងពូកែរបស់វៀតណាម"]។ ឯកសារ D1.3.17.8 Steven Ratner និង Jason Abrams ការទទួលខុសត្រូវចំពោះអំពើឃោរឃៅសិទ្ធិមនុស្សនៅក្នុងច្បាប់អន្តរជាតិ KH ERN 00429400 ["កងទ័ពវៀតណាមបានចាប់ផ្ដើមដកថយទៅវិញក្នុងខែ មករា ឆ្នាំ ១៩៧៨"]។ ឯកសារ D32/12.1 Pham Van Tra ជីវិតយោធាម្នាក់៖ ការចងចាំ EN ERN 00432807 ["នៅដើមខែ មករា ឆ្នាំ ១៩៧៨ យើងដកកម្លាំងមកវៀតណាមវិញ"]។

1046 ឯកសារ D69.1.21 សុន្ទរកថារបស់ខៀវ សំផន ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៨ KH ERN S 00704517-18 ["ការវាយប្រយុទ្ធរវាងយើង និងប្រទេសវៀតណាមមានលក្ខណៈស្វិតស្វាញ ក្ដៅគគុក និងឥតឈប់ឈរ [...] ឆ្នាំនេះការប្រយុទ្ធមានលក្ខណៈក្ដៅគគុកជាងឆ្នាំមុន [...]ជាមួយគ្នានេះ ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៧ ដល់ថ្ងៃទី ១៧ ខែ

វាប់សែននាក់ទៅព្រំដែន[1047]។ កងទ័ពកម្ពុជាបានចូលក្នុងទឹកដីវៀតណាម និងវាយប្រហារ នៅតាមទីតាំងមួយចំនួន ដូចជា ខេត្តប៊ិញភ្វក ខេត្តអានយ៉ាង ខេត្តកៀនយ៉ាង ខេត្តតាយនិញ ខេត្តយ៉ាឡៃ ខេត្តកន្ទុំ និងខេត្តដុងថាប[1048]។ ក្នុងការវាយប្រហារចូលក្រុងហាទៀង ខេត្តកៀនយ៉ាង នៅខែ មីនា

---

មេសា ឆ្នាំ ១៩៧៨ ជាពិសេស ចាប់តាំងពីខែ កញ្ញា ឆ្នាំ ១៩៧៧ ការវាយប្រយុទ្ធគ្នាបានប្រព្រឹត្តទៅឥតឈប់ឈរ។ [...] ជ័យជម្នះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៨ និងជ័យជំនះជាបន្តបន្ទាប់នាខែ កុម្ភៈ មីនា និង មេសា ទៅលើប្រទេសវៀតណាមឈ្លានពាន"]។ ឯកសារ D1.3.25.40 SWB ប្រទេសកម្ពុជារាយការណ៍អំពីការបន្តទម្លាក់គ្រាប់បែករបស់វៀតណាម ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៧៨ KH ERN 00701663 ["ចាប់តាំងពីថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៨ [...] វៀតណាមនៅតែបន្តបាញ់ផ្លោងពីទឹកដីរបស់ពួកវា"]។ ឯកសារ D4.1.617 ផ្សព្វផ្សាយតាមវិទ្យុកម្ពុជាប្រជាធិបតេយ្យ របាយការណ៍ការពារជាតិកាលពីឆ្នាំមុន ត្រូវបានពិនិត្យឡើងវិញ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៨ KH ERN 00340545-46។ ឯកសារ D56/3.4, D54/112.3 ទូរលេខពី មុត (មាស មុត) ចម្លងជូន អ៊ុំ អ៊ុំនួន បងវ៉ាន់ និងឯកសារ ចុះថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៧៨ ["សរុបយួនដែលចាប់បាន និងបាញ់ងាប់ ចាប់ពីថ្ងៃទី ២៧-៣-១៩៧៨ មកដល់ថ្ងៃ ៣០-៣-១៩៧៨ មានចំនួន ១២០ ក្បាល"]។ ឯកសារ D234/2.1.135 Stephen Morris ប្រតិចារឹកថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៦ ម៉ោង ១៤.២៩.០៩-១៤.៣៤.៣៨, ១៤.៤៣.០២-១៥.០២.២៤ [អះអាងថា កម្ពុជាប្រជាធិបតេយ្យបានបន្តវាយប្រហារវៀតណាមនៅដើមឆ្នាំ ១៩៧៨]។ ឯកសារ D114/75 កំណត់ហេតុស្តាប់ចម្លើយ ស៊ីន ស៊ីសុផល ឆ.៩២-៩៣ ["ខ្ញុំទៅដល់សមរភូមិនៅថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៧៨ [...] ទៅដល់ភ្លាមខ្ញុំចូលវ៉ៃក្នុងសមរភូមិតែម្តង។ [...] ឆ. ៩៣៖ ខ្ញុំនៅរហូតដល់ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៧៨"]។ ឯកសារ D114/149 កំណត់ហេតុស្តាប់ចម្លើយ ទូច ឈុំ ឆ .៥២ ["តាមពិតទៅតាំងពី ៧៧ ទៅដល់ចុង ៧៨ ពេលយួនវ៉ៃចូលកម្ពុជា"]។ ឯកសារ D1.3.25.45 SWB យុទ្ធសាស្ត្រការពាររបស់កម្ពុជាប្រឆាំងវៀតណាម ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៨ KH ERN 00225460 ["អំឡុងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៧ ដល់ថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៨ ការវាយប្រយុទ្ធគ្នាកើតជាបន្តបន្ទាប់ជាទ្រង់ទ្រាយតូច មធ្យម ធំ។ កម្រិតនៃការវាយប្រយុទ្ធគ្នាពិតជាបានកើនឡើងនៅឆ្នាំនេះ"]។ ឯកសារ D1.3.25.52 កាសែត New York Times វៀតណាមបដិសេធការវាយប្រហារទើប្រទេសកម្ពុជា៖ ការប្រយុទ្ធត្រូវបានរាយការណ៍ នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៧៨។ ឯកសារ D1.3.25.68 កាសែត Washington Post ជម្លោះនៅព្រំដែនផ្តល់សញ្ញាណឱ្យឃើញអំពីការព្រួយបារម្ភខ្លាចវៀតណាមវាយលុក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៧៨។ ឯកសារ D69.1.30 បណ្ណាល័យនៃរបាយការណ៍សមាជ ជម្លោះវៀតណាម-កម្ពុជា ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៧៨ EN ERN 00187388។

1047 ឯកសារ D4.1.506 កំណត់ហេតុស្តាប់ចម្លើយ ស៊ិន សុត KH ERN 00282955 ["ខ្ញុំធ្វើការនៅ [ព្រលានយន្តហោះកំពង់ឆ្នាំង] រហូតដល់ដើមឆ្នាំ ១៩៧៨ ទើបគេដកខ្ញុំ រួមទាំងអ្នកឯទៀតជាច្រើនពាន់នាក់ យកទៅទល់ដែនវៀតណាម ដើម្បីវាយប្រយុទ្ធជាមួយវៀតណាម"]។ ឯកសារ D114/246 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល ញ៉ន ឆ.៣៣ ["ប្រហែលជាដើមឆ្នាំ ១៩៧៨ [...] គេបញ្ជូនកម្លាំងមកវ៉ៃ មកការពារព្រំដែននៅតាកែវវិញ។ ព្រោះពេលហ្នឹង វៀតណាមចូលមកទឹកដីខ្មែរយើង"]។

1048 ឯកសារ D1.3.29.2 SWB របាយការណ៍វៀតណាម ស្តីអំពីការជ្រៀតចូលរបស់កម្ពុជានៅតាមព្រំដែន ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00224845-49 (Tay Ninh, Kon Tum, Gia Lai, An Giang, Dong Thap, Long

An, Kieng Giang)។ ឯកសារ D4.1.230 ទូរលេខ ១៥ ពី ឆុន ជូន ប៉ា ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៧៨ (ឆ្លងកាត់ខេត្តស្វាយរៀង និងព្រៃវែង)។ ឯកសារ D4.1.313 ទូរលេខ ០៦ ពី រ៉ុ ជូនសេនាធិការ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ១៩៧៨ (ខេត្តកំពង់ចាម-ភូមិភាគបូព៌ា)។ ឯកសារ D1.3.34.65 ទូរលេខ ១៦ ពី ៤៧ (សុន សេន) ជូនបង ០០៩ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ (តាយនិញ)។ ឯកសារ D4.1.96 សៀវភៅកំណត់ត្រា ស-២១ របស់ ម៉ម ណៃ ហៅ ចាន់ ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ១៩៧៨ KH ERN 00077852 (ពាម, ប៊ូឌុក)។ តំបន់ ២៣-ខេត្តស្វាយរៀង)។ ឯកសារ D1.3.34.67 ទូរលេខ ៣៥ ពី រឿន ជូនអ៊ំ ៨៩ (សុន សេន) ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៧៨ (អូរណាង)។ ឯកសារ D1.3.34.68 ទូរលេខ ១៨ ពី ៤៧ (សុន សេន) ជូនបងជាទីគោរព ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៧៨ (ដុងថាប)។ ឯកសារ D1.3.30.26 របាយការណ៍បក្សកុម្មុយនីស្តកម្ពុជា ជូន អ៊ំ ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៨ (Tralaung Phos, Vinh Tr, Tay Ninh)។ ឯកសារ D1.3.25.55 FBIS របាយការណ៍ទីភ្នាក់ងារវៀតណាមអំពីការលើកឡើងអំពីការបាក់ទ័ពនៃកងទ័ពឈ្លានពាន ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ១៩៧៨ KH ERN 00224284 (តាយនិញ)។ ឯកសារ D4.1.232 ទូរលេខ ១៧ ពី ឆុន ជូនបង ប៉ ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៧៨ (កំពង់រកា កំពង់រទេះ ត្នោតរហូតដល់ជំរុំ ២៧, ព្រៃកស្ដា, ជីពាយ)។ ឯកសារ D54/6.1.12 ណាយ៉ាន់ ចាន់ដា ប្រតិចារឹកថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៩ ម៉ោង ០៩.៥១.២១ -១០.០១.៥៨) ដោយបញ្ជាក់ថា ឯកសារ D1.3.17.5 ណាយ៉ាន់ ចាន់ដា សត្រូវបងប្អូនឯង ៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម KH ERN 00191557-60 (គៀនយ៉ាង, ហាទៀង) ។ ឯកសារ D114/297.1.23 ម៉ឹង វេត ប្រតិចារឹកថ្ងៃទី ២៧ ខែ កក្កដា ២០១៦ ម៉ោង ១១.២៧.១៣-១១.២៨.៥០។ ឯកសារ D114/254 កំណត់ហេតុស្តាប់ចម្លើយ ស៊ិន សុត ឆ.៤៧ ["ស៖ ឆ្នាំណាដែលគេឲ្យទៅច្បាំងជាមួយកងទ័ពវៀតណាមហ្នឹង? ឆ.៤៧៖ ៧៨"] ឆ.៦១ ["តាយនិញក៏ចូលដែរ"]។ ឯកសារ D114/246 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល ញ៉ន ឆ.៤១ ["ស៖ តើលោកនាំចាំថាគេបញ្ជូនទៅវៃនៅព្រំដែនភូមិភាគបូព៌ា ក្នុងឆ្នាំណាដែរទេ? ឆ.៤១៖ អត់ចាំខែទេ។ ប្រហែលជានៅពាក់កណ្តាល ១៩៧៨ អីហ្នឹង"] ឆ.៥៧ ["ស៖ តើកម្លាំងលោកបានវៃតបតចូលក្នុងទឹកដីវៀតណាមឆ្ងាយប៉ុណ្ណាដែរ? ឆ.៥៧៖ ក្បែរៗព្រំដែនហ្នឹង មិនឆ្ងាយទេ។ យើងមិនដឹងថា ព្រំដែនប៉ុណ្ណាៗទេ ព្រោះតំបន់សុទ្ធតែព្រៃ"]។ ឯកសារ D69.2.1 កាសែត Los Angeles Times កម្ពុជាវាយប្រយុទ្ធជាមួយវៀតណាម ថ្ងៃទី ១៦ ខែ មករា ១៩៧៨ (អានយ៉ាង, គៀនយ៉ាង) ។ ឯកសារ D69.2.14 កាសែត Los Angeles Times ទទួលបានកងកម្លាំងកម្ពុជាពីជំរុំសាយ នៅប្រទេសវៀតណាម នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៧៨ (គៀនយ៉ាង)។ ឯកសារ D4.1.315 SWB ការលុកលុយរបស់កម្ពុជាចូលទៅវៀតណាម ថ្ងៃទី ១៤-១៦ ខែ មីនា ឆ្នាំ ១៩៧៨ EN ERN S 00009944 (គៀនយ៉ាង, សុងបែ)។ ឯកសារ D69.1.17 កាសែត Washington Post វៀតណាមអះអាងថា កម្ពុជាកំពុងវាយប្រហារតាមឆ្នេរសមុទ្រ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៧៨ (គៀនយ៉ាង)។ ឯកសារ D69.1.22 SWB ការឈ្លានពានរបស់កម្ពុជាចូលក្នុងប្រទេសវៀតណាម ក្នុងខែ មេសា ចុះថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៧៨ EN ERN S 00010393 (សុងបែ, អានយ៉ាង, តៃនិញ)។ ឯកសារ D1.3.25.49 កាសែត Los Angeles Times សង្គ្រាមតាមព្រំដែនវៀតណាម-កម្ពុជាចុះថយ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៧៨ KH ERN 00283019-20 (តៃនិញ, គៀនយ៉ាង)។ ឯកសារ D1.3.25.51 កាសែត Washington Post ប្រទេសវៀតណាមធ្វើការប្រកាសពីជោគជ័យដ៏ធំរបស់ខ្លួនក្នុងការប្រយុទ្ធនៅតាមព្រំដែនជាមួយប្រទេសកម្ពុជា ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៧៨ (អានយ៉ាង, តៃនិញ)។ ឯកសារ D1.3.25.50, D69.2.16 កាសែត New York Times កងទ័ពវៀតណាមចំនួន ៦០.០០០ នាក់ ឈ្លានពានប្រទេសកម្ពុជា ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៧៨ (អានយ៉ាង, តៃនិ

ឆ្នាំ ១៩៧៨ កម្ពុជាប្រជាធិបតេយ្យបានសម្លាប់ជនស៊ីវិលរាប់រយនាក់យ៉ាងសាហាវឃោរឃៅ[1049]។ នៅលើសមុទ្រ **មាស មុត** បានរាយការណ៍ នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ ថា កងកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យបានបាញ់ពន្លិចទូកវៀតណាមមួយគ្រឿង នៅជិតកោះខ្យង និងបានបាញ់ប្រហារទូកពីរគ្រឿងទៀត ដោយចាប់វៀតណាមបាន ៧៦ នាក់ រួចដឹកជញ្ជូនទៅដីគោក[1050]។ ក្នុងចន្លោះពេលនោះ វៀតណាមបានលុកលុយមិនឈប់ឈរចូលកម្ពុជាប្រជាធិបតេយ្យ ក្នុងខេត្តកំពង់ចាម ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តក្រចេះ និងខេត្តរតនគិរី ហើយបានទម្លាក់គ្រាប់បែកនៅតាមព្រំដែនកម្ពុជាប្រជាធិបតេយ្យ-ស.ស.វ[1051]។

---

ញ)។ ឯកសារ D1.3.25.62 កាសែត Los Angeles Times សេចក្តីរាយការណ៍អំពីការប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លានៅព្រំដែនកម្ពុជា-វៀតណាម នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ១៩៧៨ (គៀនយ៉ាង)។ ឯកសារ D32/12.1 Pham Van Tra, ជីវិតយោធាម្នាក់៖ ការចងចាំ EN ERN 00432807 ["នៅពាក់កណ្តាលខែ មករា ខ្មាំងបានបញ្ជូនកងទ័ពឆ្លងកាត់ព្រំដែន ជាការវាយប្រហារទ្រង់ទ្រាយធំទៅភូមិ Nhon Hoi និងភូមិ Khanh Binh ក្នុងស្រុកចូវដុក ខេត្តអានយ៉ាង [...] ពេលដែលពួកគេទៅ ទាហានខ្មែរក្រហមបានបាញ់សម្លាប់ប្រជាជនរបស់យើង [...] ជាមួយនឹងការសម្លាប់រង្គាលប្រជាជនជាងបីពាន់នាក់ នៅបាជុក (Ba Chuc)"]។ ឯកសារ D11/347 ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ សាំង ទូច KH ERN 00989405 ["កាលឆ្នាំ ១៩៧៧ ខ្ញុំរស់នៅវត្តថ្មី [...] ខេត្តអាងយ៉ាង។ ដល់ឆ្នាំ ១៩៧៨ ពេលនោះ ខ្មែរក្រហមបានធ្វើសង្គ្រាមជាមួយវៀតណាម រួចហើយពួកវាលុកលុយចូលភូមិរបស់នាងខ្ញុំ ហើយស្រែកគំរាមកំហែងថា បើអាណាមួយមិនទៅអញនឹងបាញ់ចោល។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកភូមិដទៃទៀត ត្រូវបញ្ជូនដោយបង្ខំទៅប្រទេសកម្ពុជា] (អានយ៉ាង)។

1049 ឯកសារ D54/6.1.12 ណាយ៉ាន់ ចាន់ដា ប្រតិចារឹកថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៩ ម៉ោង ១៩.៥១.២១-១០.០១.៥៨ ដោយបញ្ជាក់ថា ឯកសារ D1.3.17.5 ណាយ៉ាន់ ចាន់ដា សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម KH ERN 00191557-60 សូមមើលផងដែរ EN ERN 00192492។ ឯកសារ D1.3.17.8 Steven Ratner និង Jason Abrams ការទទួលខុសត្រូវចំពោះអំពើឃោរឃៅសិទ្ធិមនុស្សនៅក្នុងច្បាប់អន្តរជាតិ KH ERN 00429400 ["នៅក្នុងខែ មីនា កម្ពុជាបានចូលលុកលុយវៀតណាមម្តងទៀត ដោយបានធ្វើការកាប់សម្លាប់ប្រជាជនស៊ីវិលរាប់រយនាក់នៅក្នុងភូមិហាទៀង"]។ ឯកសារ D114/29.1.4 Ben Kiernan របប ប៉ុល ពត KH ERN 00637943 ["ថ្ងៃទី ១៤ ខែ មីនា កងទ័ពរៀបរយរបស់កម្ពុជាបានចូលលុកលុយ [...] ខេត្តហាទៀង ជាទីដែលពួកនេះបានសម្លាប់រង្គាល និងរះពោះប្រជាកសិករដើមកំណើតខ្មែរ និងវៀតណាមអស់ជាង ១០០ នាក់"]។

1050 ឯកសារ D4.1.638, D1.3.34.64 ការទំនាក់ទំនងទូរស័ព្ទសម្ងាត់ ពីមាស មុត ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨។

1051 ឯកសារ D4.1.229 ទូរលេខ ១២ ពី ឆុន ជូនបង ប៉ុល (ប៉ុល ពត) ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00020937 (ខេត្តព្រៃវែង)។ ឯកសារ D4.1.231 ទូរលេខ ១៦ ពី ឆុន ជូន ប៉ា ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00001052-53 (ខេត្តស្វាយរៀង)។ ឯកសារ D4.1.233 ទូរលេខ ៦២ ពី ឆុន ជូន ប៉ា ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ

១៩៧៨ (ជីពាយ-ក្រពើ, ដូង, កំពង់ក្តី)។ ឯកសារD1.3.34.61 ទូរលេខ ១១ ពី ៤៧ (សុន សេន) ជូនបងជាទីគោរពស្រឡាញ់ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ (ខេត្តស្វាយរៀង)។ ឯកសារ D1.3.34.65 ទូរលេខ ១៦ ពី ៤៧ (សុន សេន) ជូនបង ០០៩ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ (ព្រៃចំការ, ព្រលានយន្តហោះតាយនិញ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលយោធា)។ ឯកសារ D4.1.316 ទូរលេខ ២៨ ពី ៣ម ជូនអង្គការជាទីគោរពរាប់អាន ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧៨ (ត្រពាំងផ្លុង, ពង)។ ឯកសារ D4.1.606 ទូរលេខ ១៨ ពី ៤៧ (សុន សេន) ជូនបង វ៉ាន់ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៧៨ (តំបន់ ២៤, បន្ទាយថ្មី, Tan Chau - An Giang; Dong Thap)។ ឯកសារ D4.1.610 ទូរលេខ ០២ ពី ម៉ុក ជូនបង ប៉ុល (ប៉ុល ពត) ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៧៨ (លក)។ ឯកសារ D4.1.202 ទូរលេខ ០២ ពី ពក ជូនគណៈ ៨៧០ ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៧៨ (ព្រៃកដោ, កំពង់រកា, អូរផ្អាវ, ភូមិខ្លាយ, ភូមិគរ)។ ឯកសារ D1.3.30.27 របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពីអង្គភាព ០៥ ជូនបង ០០៩ ចុះថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៨ (ភូមិភាគបូព៌ា)។ ឯកសារ D4.1.321 ទូរលេខ ០៥ ពី ពក (កែ ពក) ជូនគណៈ៨៧០ ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៨ (ខេត្តកំពង់ចាម - ភូមិភាគបូព៌ា)។ ឯកសារ D69.1.21 សុន្ទរកថាសមមិត្ត អៀង សារី ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៨ KH ERN 01507853-54 (ខេត្តព្រៃវែង, កំពត)។ ឯកសារ D4.1.603 ទូរលេខ ៥៥ ពី សារុំ ជូនបងជាទីគោរព ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៧៨ (ទេស)។ ឯកសារ D1.3.34.72 ទូរលេខ ២០ ជូនបងជាគោរពស្រឡាញ់ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៧៨ (ខេត្តស្វាយរៀង)។ ឯកសារ D69.1.24 របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ខែឧសភា ឆ្នាំ ១៩៧៨ KH ERN 00021019 (តំបន់ ២៣ (ខេត្តស្វាយរៀង) តំបន់ ២៤ (ខេត្តព្រៃវែង))។ ឯកសារ D4.1.574, D1.3.34.74 ទូរលេខ ១០ ពី ពក (កែ ពក) ជូនគណៈ ៨៧០ ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៧៨ (ខេត្តកំពង់ចាម, ខេត្តព្រៃវែង)។ ឯកសារ D4.1.575, D4.1.608 ទូរលេខ ១១ ពី ពក (កែ ពក) ជូនបង វ៉ាន់ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៨ (ខេត្តកំពង់ចាម - ភូមិភាគបូព៌ា)។ ឯកសារ D1.3.34.75 ទូរលេខ ១១ ពីពក ជូនបងជាទីនឹករលឹក ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៨ (ខេត្តកំពង់ចាម - ភូមិភាគបូព៌ា) KH ERN 00003536។ ឯកសារ D1.3.34.76 ទូរលេខ ១៣ ពីពក ជូនគណៈ ៨៧០ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៧៨ (ខេត្តកំពង់ចាម - ភូមិភាគបូព៌ា)។ ឯកសារ D10.1.8, D54/80.1.38 កំណត់ហេតុស-២១ របស់ ទុយ និង ហឿង សុងហួរ ហៅ ប៊ុន ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៨ KH 00077461 (ភូមិភាគនិរតី)។ ឯកសារ D69.1.29 សេចក្តីថ្លែងការរដ្ឋាភិបាលកម្ពុជា ប្រជាធិបតេយ្យ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៧៨ EN ERN 00078180 (ខេត្តកំពង់ចាម, ខេត្តស្វាយរៀង)។ ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ធ.១៨ [នៅពាក់កណ្តាល ឬក្រោយឆ្នាំ ១៩៧៨៖ "ថ្ងៃមួយ ខ្មែរក្រហមបើកអង្គប្រជុំប្រាប់យើងថា ពួកវៀតណាមបានចូលកាន់កាប់ខេត្តក្រចេះ ប្រហែលជា ១ ខែហើយ"] (ក្រចេះ)។ ឯកសារ D114/204 កំណត់ហេតុស្តាប់ចម្លើយ សួស ស៊ីយ៉ាត ធ. ៣៨ ["វៀតណាមវៃចូលមកខាងក្រចេះ ហើយគេដកទៅវិញ"] (ខេត្តក្រចេះ)។ ឯកសារ D114/149 កំណត់ហេតុស្តាប់ចម្លើយ ទូច ឈុំ ធ.៥៣ ["ខ្ញុំទៅ [ខេត្តក្រចេះ] ពីចុង ៧៧ រហូត ៧៨ ហ្នឹង រហូតទាល់តែយួនបុកចូលមកកម្ពុជាហ្នឹង"] (ខេត្តក្រចេះ)។ ឯកសារ D114/157.1.2 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សៅ សូ KH ERN 01197599 ["ទៅឆ្នាំ ១៩៧៨ វៀតណាមចូលដល់ក្រចេះ"] (ខេត្តក្រចេះ)។ ឯកសារ D1.3.25.49 កាសែត Los Angeles Times សង្គ្រាមតាមព្រំដែនវៀតណាម-កម្ពុជាចុះថយ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៧៨ KH ERN 00283019-20 ["ខាងវៀតណាមបានកាន់កាប់ទឹកដីពីរកន្លែងធំគួរសមរបស់កម្ពុជា [...] តំបន់ចំពុះសេកនៅក្នុងតំបន់ដីសណ្តទន្លេមេគង្គ [...] [និង] ចូលទៅក្នុងកម្ពុជា

314. របាយការណ៍សារព័ត៌មាន ចម្លើយរបស់សាក្សី និងសក្ខីកម្មនានាបង្ហាញថា ជម្លោះរវាងប្រទេសទាំងពីរ បានឡើងកម្តៅខ្លាំង ចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៨ ជាពិសេស នៅខេត្តស្វាយរៀង[1052]។

---

ក្បែរមេមត់។ កន្លែងនេះ ក្តោបលើផ្លូវធំតាមព្រំដែនភ្ជាប់ពីភ្នំពេញទៅតំបន់ចំការកៅស៊ូនៅភាគឦសានប្រទេសកម្ពុជា [...] ការវាយប្រហារផ្លូវអាកាសត្រូវបានធ្វើឡើងដោយប្រើយន្តហោះ F-5 ចាប់បានពីអាមេរិក ដែលជាញឹកញាប់បានទម្លាក់ "គ្រាប់បែកចង្កោម" [...] ការវាយប្រហារតាមផ្លូវអាកាសទាំងអស់មកលើកងទ័ពកម្ពុជា ត្រូវបានធ្វើឡើងដោយយន្តហោះ F-5 ចាប់បានពីអាមេរិក"] (ខេត្តស្វាយរៀង, ខេត្តកំពង់ចាម)។ ឯកសារ D1.3.25.50, D69.2.16 កាសែត New York Times កងទ័ពវៀតណាមចំនួន ៦០.០០០នាក់ ឈ្លានពានប្រទេសកម្ពុជា ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៧៨ (ខេត្តស្វាយរៀង)។ ឯកសារ D1.3.25.51 កាសែត Washington Post ប្រទេសវៀតណាមធ្វើការប្រកាសពីជោគជ័យដ៏ធំរបស់ខ្លួន ក្នុងការប្រយុទ្ធនៅតាមព្រំដែនជាមួយប្រទេសកម្ពុជា ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៧៨ (ខេត្តស្វាយរៀង)។ ឯកសារ D1.3.25.52 កាសែត New York Times វៀតណាមបដិសេធការវាយប្រហារទៅប្រទេសកម្ពុជា៖ ការប្រយុទ្ធត្រូវបានរាយការណ៍ នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៧៨ ["មានទាហានវៀតណាមច្រើនជា ៦០.០០០នាក់ ដែលមានទាំងកាំភ្លើងធំ និងយន្តហោះប្រយុទ្ធ បានចាប់ផ្តើមសម្រុកចូលជ្រៅទៅក្នុងប្រទេសកម្ពុជាក្នុងអំឡុង ២ សប្តាហ៍នេះ។"] (ខេត្តកំពង់ចាម - ភូមិភាគបូព៌ា)។ ឯកសារ D1.3.25.62 កាសែត Los Angeles Times សេចក្តីរាយការណ៍អំពីការប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លានៅព្រំដែនកម្ពុជា-វៀតណាម នៅថ្ងៃទី ១ ខែ សីហា ឆ្នាំ ១៩៧៨ ["ការវាយប្រហារដ៏ខ្លាំងក្លាដោយមានការបាញ់តាមអាកាសដោយយន្តហោះកម្រិតទាប បានកើតឡើងនៅបួនចំណុចតាមព្រំដែនរវាងវៀតណាម និងកម្ពុជា។ [...] សកម្មភាពវាយប្រយុទ្ធលើអាកាស ត្រូវបានធ្វើឡើងដើម្បីជួយកម្លាំងកងទ័ពលើគោករបស់វៀតណាម ដែលបានលួចចូលក្នុងតំបន់ជុំវិញខេត្តកំពង់ចាម [...] យន្តហោះដែលប្រើប្រាស់ ត្រូវបានគេរៀបរាប់ថា ជាយន្តហោះប្រតិកម្មចម្បាំងប្រភេទ F-5 របស់អាមេរិក និងយន្តហោះប្រតិកម្មប្រភេទ A-37"] (ខេត្តរតនគិរី, កំពង់ចាម, ស្វាយរៀង)។

1052 ឯកសារ D114/297.1.39 អៀង ផាន ប្រតិចារិកថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង ១០.០៤.១១-១០.០៧.៤៩ ["ខ្ញុំចេញពីខេត្តតាកែវទៅខេត្តស្វាយរៀងនៅពាក់កណ្តាលឆ្នាំ ៧៨។"] ម៉ោង ១៣.៣៧.០២-១៣.៣៩.១៧ [នៅខេត្តស្វាយរៀង៖ "ប្រយុទ្ធជារៀងរាល់ថ្ងៃអ៊ីចឹងតែម្តង របួតវៀតណាមលើកទ័ពដោយទ្រង់ទ្រាយធំមកតែម្តង"]។ ឯកសារ D114/297.1.36 ជួន ធី ប្រតិចារិកថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង ១៤.៣២.៤៣-១៤.៣៥.១០ ["គឺទៅដល់ពីរបីថ្ងៃក្នុងខែ មិថុនាគឺចាប់ប្រយុទ្ធគ្នា"]។ ឯកសារ D4.1.553 កំណត់ហេតុស្តាប់ចម្លើយ ស្រេង ធី KH ERN 00270179 ["នៅពាក់កណ្តាល ឆ្នាំ ១៩៧៨ [...] សង្គ្រាមជាមួយវៀតណាមកាន់តែខ្លាំងឡើង"]។ ឯកសារ D114/75 កំណត់ហេតុស្តាប់ចម្លើយ ស៊ុន ស៊ីសុផល ឆ. ១៤៤ ["ពីចុងខែសីហា ឆ្នាំ ១៩៧៨ ដល់ចុងខែធ្នូ ឆ្នាំ ១៩៧៨ យើងវ៉ៃជាមួយវៀតណាមរាល់ថ្ងៃ។"] (ខេត្តក្រចេះ)។ ឯកសារ D4.1.846 កំណត់ហេតុស្តាប់ចម្លើយ អៀង ផាន ឆ.៥, ៧ ["ពេលខ្ញុំទៅដល់ស្វាយរៀង នៅពាក់កណ្តាលឆ្នាំ ១៩៧៨ [...] ឆ.៧៖ [...] នៅពេលនោះ ទាហានរបស់ខ្ញុំជាច្រើនបានស្លាប់ និងត្រូវបានចាប់ខ្លួនដោយវៀតណាម"]។ ឯកសារ D1.3.25.63 កាសែត Los Angeles Times នាយករដ្ឋវៀតណាមលើកទឹកចិត្តដល់ប្រទេសវៀតណាម ឱ្យវាយរុញច្រានប្រទេសកម្ពុជា ប្រទេសចិន ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៧៨ ["ប្រទេសវៀតណាម និងប្រទេសកម្ពុជាបានមានជម្លោះនៅតាមព្រំដែនអស់រយៈពេលបីឆ្នាំមកហើយ ហើយ

នៅខែ តុលា **មាស មុត** បានដឹកនាំកម្លាំងយោធាជាងពាក់កណ្ដាល មកពីកងវរសេនាធំលេខ ៦១, ៦២ និង ៦៣ ទៅជួយកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ ដែលកំពុងប្រយុទ្ធស្រាប់នៅព្រំដែន[1053]។ ក្នុងអំឡុងពេលនោះ វៀតណាមនៅតែបន្តវាយលុក ដោយវាយប្រហារក្នុងខេត្តក្រចេះ ទម្លាក់គ្រាប់បែកលើទីក្រុងសមុទ្រកំពង់សោម[1054] ព្រមទាំងវាយប្រហារថែមទៀតលើខេត្តតាកែវ ខេត្តកំពត និងខេត្តកំពង់ស្ពឺ[1055]។ នៅថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៧៨ វៀតណាមបានបញ្ជូនកងទ័ពចំនួន ១ សែន

---

ជម្លោះនេះបានរីកឡើងយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ"]។ ឯកសារ D1.3.25.68 កាសែត Washington Post ជម្លោះនៅព្រំដែនផ្ដល់សញ្ញាណឲ្យឃើញអំពីការព្រួយបារម្ភខ្លាចវៀតណាមវាយលុក ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៧៨ ["បញ្ហាវិវាទព្រំដែនរបស់វៀតណាមជាមួយប្រទេសកម្ពុជានិងប្រទេសចិន បានក្លាយទៅជាសញ្ញាណនៃជម្លោះដែលបានរីករាលដាលក្នុងរយៈពេលពីរសប្ដាហ៍មុន"]។ ឯកសារ D1.3.25.70 កាសែត Washington Post ការវាយប្រហាររបស់វៀតណាមត្រូវបានរាយការណ៍ថា បានចាប់ផ្ដើមនៅភាគឦសាននៃប្រទេសកម្ពុជា ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ១៩៧៨ ["កងទ័ពវៀតណាមបានចាប់ផ្ដើមវាយប្រហារយ៉ាងខ្លាំងក្លានៅថ្ងៃនេះ ដើម្បីកាត់ផ្ដាច់យកខេត្តធំៗទាំងឡាយនៅភាគឦសាននៃប្រទេសកម្ពុជា"]។

1053 ឯកសារ D54/98 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាង រ៉េត ឆ.៣៦ ["កងពល ១៦៤ ត្រូវបញ្ជូនកម្លាំងមួយចំនួនទៅជួយកម្លាំងដែលឈរជើងនៅតាមព្រំដែន។ ពេលនោះ មាស មុត បានដឹកនាំកម្លាំងយោធាជាងពាក់កណ្ដាលពីកងវរៈសេនាធំ ៦១, ៦២ និង ៦៣ ទៅវ៉ៃជាមួយវៀតណាមនៅឯព្រំដែន។ [...] គាត់ទៅនោះ គឺប្រហែលជានៅខែ តុលា ឆ្នាំ ១៩៧៨"]។

1054 ឯកសារ D54/100 កំណត់ហេតុស្ដាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.១០០, ១៣៧-១៣៨ ["វៀតណាមទម្លាក់គ្រាប់បែកនៅក្រុងកំពង់សោម គឺចុងឆ្នាំ ១៩៧៨ [...] ឆ. ១៣៧៖ ការប្រយុទ្ធនៅឯសមុទ្រ គឺគេប្រយុទ្ធនៅពេលយប់ ហើយខ្ញុំបានឮសូរស្នូរកាំភ្លើង និងឃើញភ្លើងគ្រាប់កាំភ្លើងនៅលើមេឃ [...] ឆ. ១៣៨៖ នៅចុងឆ្នាំ ១៩៧៨ និងដើមឆ្នាំ ១៩៧៩"]។ ឯកសារ D114/149 កំណត់ហេតុស្ដាប់ចម្លើយ ទូច ឈុំ ឆ.៣០ ["នៅចុង ៧៨ យួនវ៉ៃបុក"] (ខេត្តក្រចេះ)។ ឯកសារ D114/52 កំណត់ហេតុស្ដាប់ចម្លើយ ឈាង ជូ ឆ.២៨ ["កងពល ១១៧ ចាប់ដកចេញពីព្រំដែនខ្មែរវៀតណាម នៅប្រហែលខែតុលា ឆ្នាំ១៩៧៨ ដោយសារកងទ័ពវៀតណាមវ៉ៃសង្កត់យើងខ្លាំង"] (ខេត្តក្រចេះ)។

1055 ឯកសារ D32/9 កំណត់ហេតុស្ដាប់ចម្លើយ ខៀវ សាវ៉ាន់ ឆ.៣ ["នៅខែធ្នូ ឆ្នាំ ១៩៧៨ ខ្ញុំត្រូវបានគេបញ្ជូនមកនៅយុទ្ធភូមិភាគទី ៩ របស់វៀតណាម ហើយក្រោយមក បញ្ជូនវាយទ័ពខ្មែរក្រហមនៅតាកែវ កំពត និងកំពង់ស្ពឺ"]។ ឯកសារ D114/112 កំណត់ហេតុស្ដាប់ចម្លើយ អ៊ឹម សុខន ឆ.១៥ ["នៅចុងឆ្នាំ ១៩៧៨ [...] កងទ័ពវៀតណាមកំពុងចូលឈ្លានពាន។ ពួកយើងក៏បានទៅប្រយុទ្ធសាជាថ្មី ហើយកងខ្ញុំបានចាញ់សង្គ្រាមជាមួយវៀតណាម នៅភ្នំពេជ្រនិល"] (ខេត្តកំពង់ស្ពឺ)។

នាក់ ចូលជ្រៀមកកម្ពុជា[1056]។ ការតបតគ្មានប្រសិទ្ធភាព ហើយកងកម្លាំងវៀតណាមបានកាន់កាប់ទីក្រុងភ្នំពេញ នៅថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៧៩[1057]។

---

1056 ឯកសារ D1.3.33.1 ទូរលេខពី អៀង សារី ផ្ញើជូនទៅប្រធានក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៨ KH ERN 00224423-24 (ខេត្តរតនគិរី, មណ្ឌលគិរី, ក្រចេះ, កំពង់ចាម)។ ឯកសារ D4.1.988 ចម្លើយ អៀង ធីរិទ្ធ ចុះថ្ងៃទី ១៧-១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៧៩ KH ERN 00658250-51 ["នៅថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៧៨ ពួកគេបានចាប់ផ្តើមសង្គ្រាមឈ្លានពានមកលើកម្ពុជាលើកទីពីរ ក្នុងទ្រង់ទ្រាយរឹតតែធំជាងមុនឆ្ងាយទៀតផង"]។ ឯកសារ D69.1.39 សេចក្តីថ្លែងការណ៍របស់ អៀង សារី ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៩ KH ERN 00704469 ["នៅថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៧៨ ជាថ្ងៃបុណ្យណូអែល អាជ្ញាធរទីក្រុងហាណូយបានបញ្ជូនកងទ័ពចំនួន ១២០.០០០ នាក់ដោយមានជំនួយពីរថក្រោះ កាំភ្លើងធំធន់ធ្ងន់ជាច្រើនរយគ្រឿង យន្តហោះ និងនាវាចម្បាំងជាច្រើនមកឈ្លានពានប្រទេសកម្ពុជាពីគ្រប់ទិសទី"]។ ឯកសារ D1.3.25.72 កាសែត Washington Post សេចក្តីរាយការណ៍ស្តីពីការវាយប្រយុទ្ធគ្នាយ៉ាងខ្លាំងរវាងកម្ពុជា និងវៀតណាមបន្ទាប់ពីភាពស្ងប់ស្ងាត់ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ១៩៧៨ ["ការរំលោភបំពានថ្មីរបស់វៀតណាម បានចាប់ផ្តើមនៅថ្ងៃបុណ្យណូអែល ដោយមានការជួយវាយប្រហារតាមអាកាស"]។ ឯកសារ D1.3.17.7 Stephen Morris ហេតុអ្វីប្រទេសវៀតណាមឈ្លានពានប្រទេសកម្ពុជា KH ERN 00224333 ["នៅថ្ងៃទី ២៥ ខែ ធ្នូ ទីក្រុងហាណូយបានចាប់ផ្តើមធ្វើការវាយលុកក្នុងទ្រង់ទ្រាយធំ ដោយប្រើកងពលធំចំនួន ១៣ កងពលធំ ដែលមានកងទ័ពជាង ១៥០.០០០ នាក់។"]។ ឯកសារ D1.3.17.8 Steven Ratner និង Jason Abrams ការទទួលខុសត្រូវចំពោះអំពើឃោរឃៅសិទ្ធិមនុស្សនៅក្នុងច្បាប់អន្តរជាតិ KH ERN 00429400 ["វៀតណាមបានបើកការឈ្លានពានជាទ្រង់ទ្រាយធំមកលើកម្ពុជា នៅក្នុងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៧៨"]។ ឯកសារ Gina Chon និង ថេត សម្បត្តិ នៅពីក្រោយវាលពិឃាដ KH ERN 00858365 ["បន្ទាប់ពីមានការវាយប្រហារកាន់តែ ខ្លាំងឡើងរយៈពេលចំនួនជាច្រើនខែ វៀតណាមបានបញ្ជូនកងទ័ពចំនួន ១០ កងពលធំ ចូលទៅកម្ពុជានៅថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៧៨"]។

1057 សូមមើល ឧទាហរណ៍ ឯកសារ D114/149 កំណត់ហេតុស្តាប់ចម្លើយ ទូច ឈុំ ឆ.៣០ ["នៅចុងឆ្នាំ ៧៨ យួនវ៉ៃបុកហើយយើងមិនអាចទប់ទល់បាន"]។ ឯកសារ D114/75 កំណត់ហេតុស្តាប់ចម្លើយ ស៊ីន ស៊ីសុផល ឆ.២០២-២០៣ ["យើងវ៉ៃចាញ់វៀតណាម [...] ឆ.២០៣៖ វានៅចំថ្ងៃ ២៧ ខែ ធ្នូ ឆ្នាំ ១៩៧៨"] (ខេត្តក្រចេះ)។ ឯកសារ D114/112 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.១៥ ["នៅចុងឆ្នាំ ១៩៧៨ [...] កងទ័ពវៀតណាមកំពុងចូលឈ្លានពាន។ ពួកយើងក៏បានទៅប្រយុទ្ធសាជាថ្មី ហើយកងខ្ញុំបានចាញ់សង្គ្រាមជាមួយវៀតណាម នៅម្តុំពេជ្រនិល"] (ខេត្តកំពង់ស្ពឺ)។ ឯកសារ D114/157.1.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ជិន ផាត KH ERN 01197653 ["ស៖ ហើយចុះពេលដែលវៀតណាមវ៉ៃចូលមកឆ្នាំ ៧៩ ហ្នឹង យើងយ៉ាងម៉េចទៅ? [...] ឆ. កាលឆ្នាំ ៧៩ បើយើងនៅផ្នែកខាងកងទ័ព យើងដកពីព្រំដែនមក ស៊ឹងទាំងអស់"]។ ឯកសារ D1.3.17.5 ណាយ៉ាន់ ចាន់ដា សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម KH ERN 00191686-87។ ឯកសារ D1.3.17.7 Stephen Morrisហេតុអ្វីប្រទេសវៀតណាមឈ្លានពានប្រទេសកម្ពុជា ["កងកម្លាំងនោះ កាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី ៧ ខែ មករា ឆ្នាំ ១៩៧៩"]។ ឯកសារ D234/2.1.14 Gina Chon និង ថេត សម្បត្តិ នៅពីក្រោយវាលពិឃាដ KH ERN 00858365 ["វៀតណាមបាន

## VII. គោលនយោបាយរបស់ ប.ក.ក ពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំងនឹង មាស មុត

315. **មាស មុត** និងសមាជិកដទៃទៀត នៃសហឧក្រិដ្ឋកម្មរួម បានអនុវត្តគោលនយោបាយឧក្រិដ្ឋនានា សំដៅជួយរក្សាថ្នាក់ដឹកនាំបក្សឲ្យនៅកាន់អំណាច និងជំរុញរបៀបវារៈនយោបាយបក្ស។ គោលនយោបាយសំខាន់ៗចំនួនពីរត្រូវបានពិភាក្សាដូចខាងក្រោម៖ ការកំណត់មុខសញ្ញាលើអ្នកដែលត្រូវគេចាត់ទុកជាខ្មាំងនយោបាយ តាមរយៈការចាប់ខ្លួន ការឃុំឃាំង ការសម្លាប់ក្រៅផ្លូវតុលាការ និងទម្រង់ផ្សេងទៀតនៃការធ្វើទុក្ខបុកម្នេញ ព្រមទាំងការអនុវត្តអំណាចនៃភាពជាម្ចាស់ (ទាសភាព) លើមនុស្សជាច្រើន ដែលត្រូវបានរបបនេះបង្ខំឲ្យធ្វើការធ្ងន់ រៀបការ និងបង្កើតកូន។

### ការកម្ទេចខ្មាំង និងការប្រឆាំងនឹងថ្នាក់ដឹកនាំ ប.ក.ក

316. ចាប់តាំងពីសមាជបក្សលើកទី ១ ក្នុងឆ្នាំ ១៩៦០ មក ខ្មែរក្រហមសម្រេចប្រើប្រាស់ហិង្សាប្រដាប់អាវុធ ដើម្បីកម្ទេច "ខ្មាំង" ហើយបន្តអនុវត្តគោលនយោបាយនេះ កាន់តែខ្លាំងក្លាឡើងៗ មិនថាចំពោះយោធាប្រឆាំងបុគ្គល ឬក្រុមប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ឬត្រូវគេចាត់ទុកថាបង្កការគំរាមកំហែង[1058]។ អ្នកទាំងនេះរួមមានអ្នកមកពីវណ្ណៈ "គហបតី" "សក្តិភូមិ" ឬ "នាយទុន"[1059]

ចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី ៧ ខែ មករា ឆ្នាំ ១៩៧៩។ [...] ទំហំនៃកងកម្លាំងរបស់ពួកគេ ព្រមជាមួយនឹងទ័ពដែលប្រដាប់ទៅដោយអាវុធទំនើបជាងខ្មែរក្រហម បានវាយសន្ធប់លើខ្មែរក្រហម"]។ ឯកសារ D1.3.25.73 កាសែត Wall Street Journal វៀតណាមកាន់កាប់ទីក្រុង និងកំពង់ផែកម្ពុជា តែសង្គ្រាមទ័ពព្រៃឃើញនៅតែបន្ត ថ្ងៃទី ៨ ខែ មករា ឆ្នាំ ១៩៧៩ ["វៀតណាម [...] បានកាន់កាប់ទីក្រុងភ្នំពេញនៃប្រទេសកម្ពុជា ផែសមុទ្រដ៏សំខាន់នៅកំពង់សោម និងទីក្រុងតូចធំសំខាន់ៗដទៃទៀត"]។ ឯកសារ D1.3.25.74 Los Angeles Times អតីតកាលរបស់ប្រទេសកម្ពុជា៖ កាលប្បវត្តិ ថ្ងៃទី ៨ ខែ មករា ឆ្នាំ ១៩៧៩ ["ថ្ងៃទី ៧ ខែ មករា ឆ្នាំ ១៩៧៩៖ រណសិរ្សបះបោរបានប្រកាសថា កងម្លាំងរបស់ខ្លួនបានកាន់កាប់ទីក្រុងភ្នំពេញ"]។

1058 ឯកសារ D64.1.31 FBIS សមមិត្ត នួន ជា ថ្លែងក្នុងទិវាខួបកំណើតកងទ័ពបដិវត្តកម្ពុជា ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៧៧ KH ERN 00679796 [ការប្រមូលផ្តុំមហាជន នៅទីក្រុងភ្នំពេញដើម្បីប្រារព្ធខួបលើកទីប្រាំបួន នៃកងទ័ពបដិវត្តកម្ពុជា នួន ជា បាននិយាយ៖ "ក្រោយឆ្នាំ ១៩៦០ អង្គការបដិវត្តន៍យើងបានសម្រេចច្បាស់ថា យើងត្រូវតែប្រើសកម្មភាពនយោបាយ និងអំពើហិង្សាប្រដាប់អាវុធ ដើម្បីផ្តួលរំលំ និងកម្ទេចខ្មាំង"]។ ឯកសារ D4.1.888 ទង់បដិវត្តចេញផ្សាយខែ ធ្នូ ឆ្នាំ ១៩៧៦ - ខែ មករា ឆ្នាំ ១៩៧៧ KH ERN 00063023 ["មាគ៌ាជាយុទ្ធសាស្ត្ររបស់បក្ស [...] កំណត់នៅឆ្នាំ ១៩៦០ [...] ត្រូវវាយរំលំសក្តិភូមិ និងនាយទុនប្រតិកិរិយានៅកម្ពុជា"]។ ឯកសារ D4.1.886 ទង់បដិវត្តចេញផ្សាយខែ កញ្ញា-តុលា ឆ្នាំ ១៩៧៦ KH ERN 00063066 ["ពិសោធជាក់ស្តែងរបស់ចលនាបដិវត្តយើង បានបង្រៀនយើងថា ទាល់តែប្រើហិង្សានយោបាយ និងហិង្សាអាវុធទើបយើងវាយឈ្នះខ្មាំង"]។ ឯកសារ D4.1.864 ទង់បដិវត្ត ចេញផ្សាយខែ កញ្ញា ឆ្នាំ ១៩៧៧ KH ERN 00063148 ["រូបភាពតស៊ូទី ១ គឺត្រូវប្រើហិង្សាបដិវត្តដោយ

អ្នកដែលត្រូវគេចោទថាជាភ្នាក់ងារសេអ៊ីអា កាហ្សេបេ ឬភ្នាក់ងារវៀតណាម[1060] អ្នកដែលមានទំនាក់ទំនងជាមួយរបប លន់ នល់ ឬបរទេស[1061] "អ្នក ១៧ មេសា" ឬ "ប្រជាជនថ្មី"[1062] អ្នក

នយោបាយ ហើយនិងហិង្សាបដិវត្តដោយអាវុធ។ [...] ហិង្សានេះ គឺកម្លាំង ដើម្បីទប់ទល់ខ្មាំង និងវាយខ្មាំង"]។ ឯកសារ D4.1.861 ទង់បដិវត្ត ចេញផ្សាយខែ សីហា ឆ្នាំ ១៩៧៥ KH ERN 00063328 ["គឺបក្សត្រូវប្រើហិង្សាបដិវត្ត ត្រូវប្រមូលប្រជាជន ប្រើហិង្សាបដិវត្ត ប្រឆាំងពួកប្រតិកិរិយា ពួកវណ្ណៈជិះជាន់ ប្រឆាំងពួកអាណានិគម ចក្រពត្តិនិយម។ ដើម្បីការពារខ្លួន និងដើម្បីរំដោះខ្លួន ត្រូវប្រើហិង្សា ជាហិង្សានយោបាយក្តី ជាហិង្សាអាវុធក្តី"]។ ឯកសារ D69.1.42 ខៀវ សំផន ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា KH ERN 00380367 ["អំពីមាគ៌ានយោបាយថ្មីរបស់បក្សថ្មី [...] កំណត់ថា "វណ្ណៈជិះជាន់" ជាសត្រូវសំខាន់ជាងគេនៃបដិវត្តន៍កម្ពុជា ហើយជាឧបករណ៍នៃចក្រពត្តិអាមេរិក។ ដូច្នេះ ប្រជាជនកម្ពុជា ត្រូវតែកម្ទេច "របបសក្តិភូមិ" តាមមធ្យោបាយសន្តិវិធី ឬតាមវិធីផ្សេងទៀត"]។

1059 សូមមើល ឧទាហរណ៍ ឯកសារ D4.1.882 ទង់បដិវត្ត ចេញផ្សាយខែ កុម្ភៈ-មីនា ឆ្នាំ ១៩៧៦ KH ERN 00063192-93 ["ន័យទី១៖ គឺវាយរបបនាយទុន ឲ្យរលំរលាយជាស្ថាពរ កុំឲ្យវាងើបក្បាលឡើងវិញបាន។ [...] យើងឃើញថា រូបភាពវណ្ណៈនាយទុន វារលំរលាយហើយ តែខ្លឹមសារនាយទុនវានៅមាន។ បើវានៅមាននៅក្នុងជួរបដិវត្តយើង នៅក្នុងជួរប្រជាជនយើង ហើយបើយើងមិនតស៊ូកំចាត់វាដាច់ខាត វានឹងពង្រីកពង្រីកខ្លួនបាន ហើយក្នុងរយៈពេលណាមួយក្នុង ៥ ឆ្នាំក្តី ១០ ឆ្នាំក្តី ឬយូរទៅទៀតក្តី វាងើបក្បាលមកវិញ វាកើតជាសេរីវើប្រឆាំងបដិវត្ត"]។ ឯកសារ D4.1.863 ទង់បដិវត្ត ចេញផ្សាយខែ កក្កដា ឆ្នាំ ១៩៧៧ KH ERN 00062884 ["បន្តវាយកំចាត់គោលជំហារកម្មសិទ្ធិឯកជនគ្រប់ប្រភេទ គោលជំហរអនុធន នាយទុន សក្តិភូមិ ព្រមទាំងកសិករ និងសិប្បករ ឲ្យបានស្អាតដាច់ខាត"] KH ERN 00062887 ["ខ្មាំងគឺចក្រពត្តិឈ្លានពាន និងបំពេញគ្រប់ប្រភេទខ្មាំងដែលមានបំណងវាតទី និងលេបយកទឹកដីយើង ខ្មាំងដែលបង្កប់ស៊ីរូងផ្ទៃក្នុងជួរបដិវត្តយើង ខ្មាំងមានវណ្ណៈសក្តិភូមិ ម្ចាស់ដី នាយទុន និងខ្មាំងមានវណ្ណៈជិះជាន់គ្រប់ប្រភេទ ខ្មាំងជារបបឯកជន"]។ ឯកសារ D4.1.864 ទង់បដិវត្ត ចេញផ្សាយខែ កញ្ញា ឆ្នាំ ១៩៧៧ KH ERN 00063138 ["សង្គមកម្ពុជាគឺត្រូវបានបែងចែកជា ៥ វណ្ណៈច្បាស់៖ វណ្ណៈកម្មករ វណ្ណៈកសិករ វណ្ណៈអនុធន វណ្ណៈនាយទុន វណ្ណៈសក្តិភូមិ។"] KH ERN 00063145 ["ការវិភាគទំនាស់នៅក្នុងសង្គម នៅក្នុងប្រទេសជាតិកម្ពុជារួចហើយ តើត្រូវកំណត់សត្រូវនៃបដិវត្តយ៉ាងម៉េច និងកម្លាំងបដិវត្តយ៉ាងម៉េច។ សត្រូវមានពីរដែលត្រូវវាយ៖ សត្រូវទី១ គឺចក្រពត្តិនិយម ពិសេសចក្រពត្តិអាមេរិកាំង ទី២ គឺវណ្ណៈសក្តិភូមិ ម្ចាស់ដី និងគឺប្រាឌ័រប្រតិកិរិយា"]។ ឯកសារ D1.3.27.15 កំណត់ហេតុនៃការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំខាងមន្ទីរអង្គការ ៧០៣ និងស-២១ ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00008503 [បង ៨៩ (សុន សេន) ណែនាំថា៖ "ទស្សនៈប្រុងប្រយ័ត្នបដិវត្តឲ្យខ្ពស់ ដោយទំនាស់កាន់តែស្រួចណាស់ កំហឹងវណ្ណៈរបស់ខ្មាំងទាំងខាងលិច ទាំងខាងកើត ចំពោះបដិវត្តកម្ពុជា កាន់តែខ្លាំងណាស់"]។

1060 សូមមើល ឧទាហរណ៍ ឯកសារ D4.1.862 ទង់បដិវត្ត ចេញផ្សាយខែ មេសា ឆ្នាំ ១៩៧៧ KH ERN 00062993 ["បញ្ហាមួយដែលត្រូវយកចិត្តទុកដាក់សំខាន់ណាស់ដែរគឺវែកមុខ "សេ.អ៊ី.អា" និងភ្នាក់ងាររបស់វា ពួក "កា.ហ្សេ.បេ" និងភ្នាក់ងាររបស់ពួកវា "យួន" លេបទឹកដី និងឆ្កែបំរើរបស់វាឲ្យច្បាស់' [...] ក្នុងបក្សទាំងមូល កងទ័ពទាំងមូល និងប្រជាជនទាំងមូល វាយផ្តាច់ខ្មាំងខាងនយោបាយ កុំឲ្យវាមកលបចូលបាននៅក្នុងបក្សយើង កងទ័ពយើង និងប្រជាជន

យើងជារៀងរហូត"]។ ឯកសារ D4.1.896 ទង់បដិវត្តយុវជន ចេញផ្សាយខែ មេសា ឆ្នាំ ១៩៧៧ KH ERN 00376269 ["ប្តេជ្ញាបោសសម្អាតពួកភ្នាក់ងារ "សេ.អ៊ី.អា" "កា.ហ្សេ.បេ" និងពួកភ្នាក់ងារផ្តែបំរើ "យួន" លេបទឹកដីដែលបង្កប់ស៊ីរូងផ្ទៃក្នុង ឲ្យស្អាតដាច់ខាត!"]។ ឯកសារ D1.3.24.5 ទង់បដិវត្ត ចេញផ្សាយខែ ឧសភា-មិថុនា ឆ្នាំ ១៩៧៨ KH ERN 00064562 ["អ្នកណាធ្វើសកម្មភាពបំរើ សេ.អ៊ី.អា ឬបំរើយួន គឺធ្វើដោយភ្នាក់រលើកដោយល់ ត្រូវមានទោស។"] KH ERN 00064566-67 ["ក្បាលដែលត្រូវវាយ គឺសេ.អ៊ី.អា យួន និងកា.ហ្សេ.បេ។ [...] ១. វាយឲ្យស្រួចជាងគេ គឺយួនឈ្លានពានវាតទីលេបទឹកដី។ ២. ព្រមជាមួយនេះ វាយ សេ.អ៊ី.អា និងកា.ហ្សេ.បេ។ វាយព្រមជាមួយគ្នា ប៉ុន្តែ យកចិត្តទុកដាក់វាយយួនជាងគ ពីព្រោះវាស្រួចស្រាវពិសពុលជាងគេ"] KH ERN 00064578 ["ដូច្នេះ ភារកិច្ចរបស់យើង គឺវាយកំទេចពួកភ្នាក់ងារ សេ.អ៊ី.អា ភ្នាក់ងារយួន និងភ្នាក់ងារ កា.ហ្សេ.បេ នេះដាច់ខាតខ្លាំងក្លា ជាបន្តបន្ទាប់ វាយហើយ វាយទៀត ឲ្យវារលំរលាយ ហើយរលំរលាយជាបន្តបន្ទាប់"]។ ឯកសារ D4.1.583 ទិសដៅគណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា សេចក្តីណែនាំរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា អំពីគោលនយោបាយរបស់បក្ស ចំពោះអ្នកភាន់ច្រឡំចូល សេ.អ៊ី.អា ឬធ្វើភ្នាក់ងារយួន ឬចូល កា.ហ្សេ.បេ ប្រឆាំងបក្សបដិវត្តប្រជាជន និងកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៧៨ [គោលនយោបាយណែនាំដល់កម្មាភិបាលថាតើអ្នកណាគួរទទួលទណ្ឌកម្ម បើចូល សេ.អ៊ី.អា យួន ឬក៏ កា.ហ្សេ.បេ ដោយប្រើលក្ខណៈវិនិច្ឆ័យដូចជាឆ្នាំដែលពួកគេបានចូលរួម និងប្រព្រឹត្តសកម្មភាពណាមួយដែលក្បត់ ឬប្រឆាំង]។

1061 សូមមើល ឧទាហរណ៍ឯកសារ D1.3.8.4 កំណត់ហេតុនៃការប្រជុំកងពល ១៦៤ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN00162489 ["កន្លងមក រកឃើញទាហានសក្តិ ២ ពីរនាក់ បានចាប់ហើយ"] KH ERN00162490 ["សមាសភាពទាហានត្រូវប្រមូល"]។ ឯកសារ D98/3.1.130 អែម អឿន ប្រតិចារឹកថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១២ ម៉ោង ១៤.៣៥.៤៧-១៤.៣៧.៥៦ [នៅវគ្គបណ្តុះបណ្តាលនៅភ្នំពេញក្នុងឆ្នាំ ១៩៧៥៖ "ស៖ តើនៅក្នុងពេលនោះដែរ លោក នួន ជា គាត់ធ្វើបទអត្ថាធិប្បាយ ផ្តោតសំខាន់លើចំណុចអ្វីបន្តពី ប៉ុល ពត? ឆ៖ [...] គាត់វែករកមើលមុខថា បុគ្គលណាដែលឈ្មោះហៅថា ស៊ីរូងផ្ទៃក្នុងរបស់បក្ស [...] អីចឹងលោកបានមានប្រសាសន៍យ៉ាងរឹងប៉ឹងត្រង់ថា យ៉ាងណាក៏ដោយ ក្នុងនាមយើងជាអ្នកដឹកនាំត្រូវតែស្គាល់ឲ្យបានច្បាស់ថា អ្នកណាខ្លះស្គាល់ អ្នកណាខ្លះចង់មានគំនិតស៊ីរូងផ្ទៃក្នុងប្រឆាំងនឹងបក្ស។ [...] បើតាមដំណើរដែលខ្ញុំគិតឃើញក្នុងឱកាសនោះ សំដៅទៅលើអ្នកដែលទី ១ អ្នកដែលមានឋានៈតួនាទីក្នុងរបបចាស់របស់គេ បានន័យថា ក្នុងរបបសង្គមរាស្ត្រនិយម ក្នុងរបប លន់ នល់ ផង។ [...] អ្នកដែលបានទៅសិក្សាក្រៅប្រទេស"]។ ឯកសារ D4.1.509 កំណត់ហេតុស្តាប់ចម្លើយ ខឹម សំហួន ហៅ តូច KH ERN 00287536 ["នៅពេលនោះ គឺនៅខែ ឧសភា ឆ្នាំ ១៩៧៥ មានបញ្ជាពីកងពល ដែលខ្ញុំដឹងថា ត្រូវទទួលបញ្ជាពីថ្នាក់លើ គឺពី សុន សេន ដែលជាអ្នកគ្រប់គ្រង ឲ្យទៅចាប់មនុស្សដែលជាអ្នករដ្ឋការមានឋានន្តរស័ក្តិធំៗរបស់របប លន់ នល់ ហើយដែលមិនព្រមចាកចេញពីទីក្រុងភ្នំពេញ ព្រមទាំងអ្នកជំងឺ ដែលជាទាហាន លន់ នល់ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យព្រះកេតុមាលា"]។ ឯកសារ D1.3.33.4 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០០៨ KH ERN 00197971 ["ខ្ញុំមិនចាំចំនួនបញ្ញាជនដែលមកពីបរទេសដែលខ្ញុំបានទទួលនៅស-២១ នោះទេ ប៉ុន្តែខ្ញុំបានទទួលមួយចំនួន"]។ ឯកសារ D4.1.964 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អៀង សារី ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ KH ERN 00062460-61 ["ទាហានអីគេយកទៅសម្លាប់អី គេសម្រេចកំណត់ថា ពួករដ្ឋការធំៗ អីខ្ញុំអត់ចូលរួម [...] ក្នុងការសម្រេច គេសម្រេចអីហ្នឹង [...] គឺសម្រេចក្រោយអាហ្នឹង តាមខ្ញុំដឹងគឺក្រោយថ្ងៃ

១៧ មេសា ក្នុងរវាងថ្ងៃ ២០ អីហ្នឹង ហ្នឹងបើតាមខ្ញុំដឹង គឺថាគេសម្រេចគឺថា ធ្វើម៉េចកុំឱ្យពួកហ្នឹងវាងើបឡើងប្រឆាំងបដិវត្តបាន។ ពីព្រោះតាមគេនិយាយប្រាប់ខ្ញុំថា ពួកនេះមានផែនការចាញ់ មានផែនការចាញ់គឺថា ខ្មែរក្រហមចូលមកដល់ក្នុងក្រុងហើយ សម្លាប់ពួកហ្នឹងធ្វើរដ្ឋប្រហារពួកហ្នឹង យកអំណាចវិញ។ [...] គេថា ឆែកឆេរតាមផ្ទះនាយទាហានអីសុទ្ធតែមានគ្រាប់បែក មានអាដែងកាំភ្លើងអីៗទាំងអស់ គឺត្រៀមរៀបចំរដ្ឋប្រហារ”]។ ឯកសារ D1.3.32.39 កិច្ចសម្ភាស៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សែម ហឿន ហៅ គីម KH ERN 00020579-81 [“ទៅកន្លែងរៀនដែលថាកន្លែងរៀនយោបាយ ហ្នឹងគឺនៅស្ពាតអូរឡាំពិក។ មកពីគ្រប់ខេត្តចាប់ពីវរសេនាតូច វរសេនាធំ អនុកងពល [...] ស្រាវជ្រាវអ្នកដែលមានសមាសភាព ដែលគេហៅថា ជាប់និន្នាការនយោបាយណា [...] ដូចជាមានបងជាប់ធ្វើទាហាន ធ្វើរាជការពីសង្គម [...] បើគេឃើញ គេដកចេញអត់ឱ្យជាប់ទេ។ [...] អោយតែជាប់នឹងនិន្នាការនយោបាយពីដើម ដែលជាប់នឹងឥទ្ធិពលពីសង្គមចាស់ ជំនាន់សម្តេចហ្នឹង។ [...] អាហ្នឹងគេដក តែដក គឺជាប់គុកព្រៃសហើយ”] KH 00020582 [“[អៀង សារី] គាត់មកអូរឡាំពិកដូចថាគាត់ជាប្រធាននយោបាយ ប្រធានសាលានយោបាយខាងបំពាក់បំប៉ន។ [...] បងប្អូនជាប់នឹងខ្សែក្បត់ បងប្អូនជាប់នឹងនិន្នាការនយោបាយ បងប្អូនជាប់នឹងនិន្នាការសង្គមចាស់ ចឹងទោះបីជាយើងជាប់នឹងថ្នាក់ណាក៏ដោយ ក៏គេដកចេញដែរ”]។

1062 សូមមើល ឧទាហរណ៍ ឯកសារ D234/2.1.77 សេង ស្រ៊ុន ប្រតិចារឹកថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ ម៉ោង ១១.២៧.៥៣-១១.៣០.៥៦ [“ទី ១ គឺគេកម្ទេចប្រជាពលរដ្ឋ គេហៅថា ប្រជាជនថ្មី ឬក៏ប្រជាជន ១៧ មេសា និងអ្នកដែលបានបម្រើរបបសាធារណរដ្ឋខ្មែរ ព្រមទាំងអ្នកដែលជាប់និន្នាការជាមន្ត្រីរាជការពីសម័យសង្គមរាស្ត្រនិយម [...] ប្រជាជនថ្មី ឬក៏ប្រជាជន ១៧ មេសា អតីតរាជការនៃរបបសង្គមរាស្ត្រនិយម ឬរបបសាធារណរដ្ឋខ្មែរ និងសូម្បីតែអ្នកធ្វើការនៅតាមកងចល័តនានា ក៏ត្រូវបានគាបសង្កត់ ធ្វើបាបគ្រប់បែបគ្រប់យ៉ាងពីនេះហ្នឹងដែរ ហើយក៏មានការចាប់ខ្លួនហ្នឹងក៏ច្រើន។”] ម៉ោង ១៥.២៦.០៣-១៥.២៩.០៦ [“គឺពាក្យ ប៉ុល ពត គេថាបនប្រល័យពូជសាសន៍ហ្នឹង ឱ្យតែជាតិសាសន៍ណាក្រៅពីជនជាតិខ្មែរ គឺជាសត្រូវនឹងគេទាំងអស់ ជនជាតិចាម ជនជាតិវៀតណាម ហើយនិងជនជាតិចិនសុទ្ធតែជាសត្រូវគេទាំងអស់ រួមទាំងបងប្អូនប្រជាជនថ្មី គឺអ្នកដែលត្រូវបានរំដោះក្នុងឆ្នាំ”]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.១១ [“តាមខ្ញុំដឹងប្រជាជនស៊ីវិលដែលធ្វើខុស និងប្រជាជន ១៧ មេសា ត្រូវបាននាំយកទៅសម្លាប់នៅកន្លែងនោះ”]។ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.២៨ [“ខ្ញុំក៏សួរយោធាដែលឃ្វាលទានៅទីនោះ (វាលស្រែនៅតំបន់រាម) អំពីការបាត់មុខរបស់អ្នកទាំងនោះ ហេតុអ្វីមិនឃើញមកធ្វើការ។ យោធាទាំងនោះ បានប្រាប់ខ្ញុំថា ប្រជាជន ១៧ មេសា គឺត្រូវបានសម្លាប់អស់ហើយ”]។ ឯកសារ D4.1.479 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម ទុន KH ERN 00212110 [នៅខេត្តកំពង់ឆ្នាំង៖ “ក្នុងឆ្នាំ ១៩៧៥ ខ្ញុំបានឃើញគេបណ្តើរមនុស្សរាប់រយនាក់យកទៅសម្លាប់ចោលនៅភ្នំគ្រេច [...] ដោយគ្មានការសួរចម្លើយទេ។ អ្នកទាំងនោះ គឺជាប្រជាជន ១៧ មេសា និងជាទាហាន លន់ នល់ ផង [...] ខ្ញុំបានចូលរួម [...] បណ្តើរមនុស្សទាំងនេះយកទៅវៃចោលនៅភ្នំគ្រេច [...] ប៉ុន្តែ ពេលដល់ជើងភ្នំគ្រេចដែលមានចម្ងាយប្រហែល ២០០-៣០០ ម៉ែត្រ គេចាប់ផ្តើមវាយមនុស្សទាំងនោះ ម្តងមួយៗ”]។

ដែលត្រូវគេចាត់ទុកជា "សមាសភាពមិនល្អ" ឬ "ខ្មាំងស៊ីរូងផ្ទៃក្នុង" ទាំងក្នុង និងក្រៅជួរកងទ័ព[1063] និងជនបរទេស ជាពិសេស ថៃ និងវៀតណាម ឬអ្នកដែលត្រូវគេចាត់ទុកថាមានទំនាក់ទំនងជាមួយ

---

[1063] សូមមើល ឧទាហរណ៍ ឯកសារ D4.1.888 ទង់បដិវត្ត ចេញផ្សាយខែ ធ្នូ ឆ្នាំ ១៩៧៦ - ខែ មករា ឆ្នាំ ១៩៧៧ KH ERN 00063055 ["ត្រូវយកចិត្តទុកដាក់ ពង្រឹង និងពង្រីក ហើយសំរិតសំរាំងឲ្យកងទ័ពយើងស្អាត បរិសុទ្ធ តាមមាគ៌ារបស់បក្ស។ កងទ័ពខ្លាំង គឺកងទ័ពស្អាត។ ឲ្យតែស្អាត ចំនួនតិចក៏ខ្លាំង"]។ ឯកសារ D4.1.862 ទង់បដិវត្ត ចេញផ្សាយខែ មេសា ឆ្នាំ ១៩៧៧ KH ERN 00062992 ["កម្លាំងដែលមានបច្ចុប្បន្ន បក្ស អង្គការស្ទួល កងទ័ព សហជីព សហករណ៍ ... ។ល។ ត្រូវសំរិតសំរាំងចំរុះ និងបោសសម្អាតសមាសភាពមិនល្អ នឹងសមាសភាពខ្មាំង"]។ ឯកសារ D4.1.653 ទង់បដិវត្ត ចេញផ្សាយខែ មិថុនា ឆ្នាំ ១៩៧៧ KH ERN 00062803-04 ["ការប្រយុទ្ធជាមួយខ្មាំងបង្កប់ខាងក្នុងមិនទាន់អស់ទេ។ សំណល់ចាស់របស់ខ្មាំងនៅសល់ ហើយវាពង្រឹងពង្រីកតទៅទៀត។ [...] បំផុសអប់រំមហាជន [...] ក្នុងកងទ័ព ក្នុងប្រជាជនឲ្យគេឃើញច្បាស់ថា ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងវាធ្វើសកម្មភាពយ៉ាងម៉េចឲ្យគេជ្រួតជ្រាប ដើម្បីគេទៅជាកម្លាំងរកខ្មាំង នឹងវាយខ្មាំងតទៅទៀត"]។ ឯកសារ D4.1.865 ទង់បដិវត្ត ចេញផ្សាយខែតុលា-វិច្ឆិកា ឆ្នាំ ១៩៧៧ KH ERN 00064758 ["នៅក្នុងមជ្ឈិម នៅក្នុងសេនាធិការ នៅក្នុងភូមិភាគ នៅក្នុងមូលដ្ឋានសុទ្ធតែមានខ្មាំងបង្កប់នៅក្នុងជួរយើង។ បើយើងមិនមានវិធានាការទាន់ពេលវេលាគឺគ្រោះថ្នាក់"]។ ឯកសារ D1.3.24.4 ទង់បដិវត្ត ចេញផ្សាយខែ ធ្នូ ឆ្នាំ១៩៧៧-ខែ មករា ១៩៧៨ KH ERN 00064516 ["ខ្មាំងវារកកម្ទេចរដ្ឋអំណាចកម្មករ-កសិកររបស់យើង ប៉ុន្តែវាត្រូវយើងវាយឲ្យវារលំរលាយជាបន្តបន្ទាប់ ហើយឲ្យវារលំរលាយជាមូលដ្ឋាន។ [...] នេះទាំងខ្មាំងក្នុង ទាំងខ្មាំងក្រៅ ជាពិសេសខ្មាំងខាងក្នុង [...] កងទ័ពក៏ការពារបាន។ កងទ័ពរបស់បក្សអត់ខូចខាតទេ មានតែពង្រឹង មានតែសំអាតបានថែមទៀត។ យើងកំចាត់ខ្មាំងដែលស៊ីរូងកងទ័ព កំចាត់សមាសភាពអន្តរាយនៅក្នុងកងទ័ពលើកគុណភាពកងទ័ពកាន់តែបានល្អជាងមុនថែមទៀត។ [...] យើងដណ្តើមបានជ័យជំនះ ហើយជាខ្សែសង្វាក់នៅឆ្នាំ ១៩៧៧ ដោយសារយើងបានសំរិតសំរាំង និងបោសសម្អាតខ្មាំង បានជាខ្សែសង្វាក់ ដីកឫសគល់របស់វាបានជាមូលដ្ឋាន។ នៅចុង ៧៦ ដែលយើងលើកផែនការនេះ ហើយនៅដើម ៧៧ ដែលយើងកំចាត់ក្បាលម៉ាស៊ីនដឹកនាំខ្មាំងបានមួយចំនួនហើយ"]។ ឯកសារ D4.1.868 ទង់បដិវត្ត ចេញផ្សាយខែ មេសា ឆ្នាំ ១៩៧៨ KH ERN 00064725 [លេខាបក្សកុម្មុយនីស្តកម្ពុជា ប៉ុល ពត៖ "ខ្មាំងសត្រូវជិតរៀបមកឃោសនាបន្លំ បោកបញ្ឆោតយើង បំភ័យយើង ឲ្យខ្លាចខ្មាំងជារូបភាព ត្រូវកំចាត់វា កុំឲ្យមេរោគហ្នឹងវាស៊ីរូងនៅក្នុងប្រជាជន នៅក្នុងបក្ស នៅក្នុងកងទ័ពរបស់យើង។ យើងធ្វើឲ្យកងទ័ពយើងស្អាត បក្សស្អាត ប្រជាជនស្អាត ដើម្បីវាយខ្មាំងតទៅទៀត ការពារទឹកដីកម្ពុជា គឺការពារពូជសាសន៍កម្ពុជា"]។ ឯកសារ D1.3.27.13 កំណត់ហេតុការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខកងពល និងវរសេនាធំឯករាជ្យ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៧៦ KH ERN 00052382 [បង ៨៩ (សុន សេន)៖ "ត្រូវសំរិតសំរាំងសមាសភាពមិនល្អតទៅទៀត"]។ ឯកសារ D114/198 កំណត់ហេតុស្តាប់ចម្លើយ ពិន សំអួន ឆ.៣៩-៥៤ [សាក្សី, អនុបញ្ជាការអនុសេនាធំក្នុងកងពល ៣១០ បានចូលរួមវគ្គបណ្តុះបណ្តាលរយៈពេល ១ ខែ នៅស្តាតអូឡាំពិក នៅពាក់កណ្តាលឆ្នាំ ១៩៧៥ សម្រាប់គ្រប់កងពលយោធា ក្រសួង និងស្ថាប័នស៊ីវិលដែលនៅក្រោមមជ្ឈិម។ សុន សេន បាននិយាយនៅទីនោះអំពី "ចំរាញ់ និងសំរិតសំរាំង"ខ្មាំង និយាយពីជួរកងទ័ពឲ្យតែមានឪពុកម្តាយ ឬបងប្អូនជាប់និន្នាការអ្នករដ្ឋការ លន់ នល់ អី គេនឹងដកទុកមួយកន្លែងក្នុងកងពិសេសមួយ

ថៃ ឬវៀតណាម ដូចជា ខ្មែរក្រោម បុគ្គលិកយោធាបច្ចុប្បន្ន ឬអតីត ជនស៊ីវិល និងជនបរទេស ដែលធ្វើដំណើរនៅក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យ[1064]។ ប.ក.ក បានញុះញង់ឲ្យមានការស្អប់ខ្ពើម

---

សម្រាប់អ្នកជាប់ "និន្នាការ"]។ សូមមើលផងដែរ VIII.A. ការបោសសម្អាតនៅក្នុងកងពល ១៦៤។ VIII.E ការដ្ឋានទំនប់ស្ទឹងហាវ – ៣. ឧក្រិដ្ឋកម្ម – ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ ។ VIII.F. ការដ្ឋានតំបន់វាម – ៣. ឧក្រិដ្ឋកម្ម – ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ។ VIII.I. ការបោសសម្អាតកងពល ១១៧ និងតំបន់ ៥០៥។

1064 សូមមើល ឧទាហរណ៍ ឯកសារ D1.3.27.20 កំណត់ហេតុអង្គប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខា និងវរសេនាធំឯករាជ្យ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH ERN 00052413 ["ក្នុងឋានៈជាកងទ័ព ត្រូវស្គាល់កម្មវត្ថុដែលត្រូវវាយ គឺពួកចក្រពត្តិអាមេរិក ពួកសេរីវៀតណាម និងដៃជើងក្បត់របស់វា"]។ ឯកសារ D114/297.1.20 ប៉ាក សុក ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ១៣.៣១.៥៤-១៣.៣៧.៤៥ ["ខ្ញុំជាយុទ្ធជននៅកងពល ១៦៤។ ក្រោយពីឆ្នាំ ១៩៧៦ គឺបើកជាវគ្គសាលាសិក្សា ដើម្បីប្រកាសយ៉ាងច្បាស់ពីសត្រូវស្លូតបូជរបស់ខ្មែរ គឺ យួន។ [...] ពួកគេបានណែនាំឱ្យសម្លាប់ចោល សូម្បីតែកូនង៉ែតមួយក៏អត់ឱ្យមានដែរ ពីព្រោះវាជាសត្រូវស្លូតបូជរបស់យើង ដូច្នេះ យើងត្រូវតែសម្លាប់ពួកវាទាំងអស់។ ដូច្នេះ វាជាការទទួលខុសត្រូវរបស់វរសេនាតូចនីមួយៗ ដែលបានទទួលផែនការច្បាស់លាស់តែម្តង"]។ ឯកសារ D234/2.1.100 អាឡិចសាន់ឌឺ ហ៊ិនតុន ប្រតិចារឹកថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង ០៩.២១.០៩-០៩.២៥.៤៣ ["ទិន្នន័យដែលចេញពីកត្តាប្រជាសាស្ត្រនោះគឺថាក្រោយពីការបណ្តេញចេញជាដំបូងហើយក្រោយពេលចាប់ផ្តើមរបបកម្ពុជាប្រជាធិបតេយ្យភ្លាម គឺថាមានជនជាតិវៀតណាមប្រហែលជា ២០០.០០០ នាក់ត្រូវបានបណ្តេញចេញពីប្រទេសកម្ពុជា ហើយអ្នកខ្លះ ឲត្រូវបានគេប្រាប់ថា ត្រូវគេសម្លាប់ចោល"]។ ឯកសារ D11/160/4.2 ចៅ នី ប្រតិចារឹកថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ ម៉ោង ១០.២៧.១១-១០.៣១.១៣ ["ឲ្យតែខ្មែរកម្ពុជាក្រោមគឺគេសម្លាប់ចោលហើយ ហេតុអីបានជាគេគុំ ខាងកម្ពុជាប្រជាធិបតេយ្យ ខាងខ្មែរក្រហម គាត់ស្អប់ខ្មែរកម្ពុជាក្រោមម្ល៉េះ។ សូម្បីតែកូនក្មេងមិនទាន់ដឹងអីផងក៏សម្លាប់ចោលដែរ ឲ្យតែខ្មែរកម្ពុជាក្រោម"]។ ឯកសារ D11/44/3.2 ថាន់ ធីម ប្រតិចារឹកថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ ម៉ោង ០៩.៤៤.០៥-០៩.៤៨.១៧ ["អង្កាល់ដែលខ្ញុំបាទ ទៅរស់នៅស្រុកគិរីវង់ [...] ខ្មែរក្រោមហ្នឹងអាខ្លះនិយាយរដឺនៗអត់ច្បាស់ទេ ហើយវៀតណាមក៏វាៗនិយាយខ្មែរវាអត់ច្បាស់ដែរ អីចឹងគេក៏ថាជា -- គេចាត់ទុកថាពួកហ្នឹងសុទ្ធតែពួកខ្មែរក្រោមទាំងអស់ហើយ ឬមួយក៏វៀតណាមអីចឹងទៅ គេថាសម្បុរសៗ ហើយនិយាយខ្មែរមិនច្បាស់ទៀត អាហ្នឹងគេថាយួនហើយ ហើយគេយកទៅបាត់ទៅ មិនដឹងគេយកទៅណាបាទ គេយក -- មិនដឹងយកទៅសម្លាប់ ឬមួយក៏គេយកទៅបាត់រហូតអីចឹងទៅ វាអត់ឃើញនៅកន្លែងហ្នឹង"]។ ឯកសារ D114/297.1.36 ង៉ែត ចាត ប្រតិចារឹកថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង ០៩.៥៧.២៥-០៩.៥៩.១៣ ["ពួកខ្មែរក្រោមហ្នឹងប្រមូលយកទៅអស់អ៊ីចឹងទៅ"]។ ឯកសារ D1.3.33.3 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៧ KH ERN 00146488 ["ស៖ តើមានជនបរទេសតែ ៤នាក់ទេនៅ ស-២១? ឆ. បាទ [...] នួន ជា បញ្ជាឲ្យដុតឲ្យសុះ ដោយប្រើសំបកកង់ឡាន។ ខ្ញុំមិនចាំឈ្មោះទេ មានអង់គ្លេស អាមេរិកាំង និងប្រហែលអូស្ត្រាលី និងសាសន៍ដទៃទៀត ដែលខ្ញុំមិនចាំ។ ស៖ ហេតុអីបានជាគេចាប់ជនបរទេសទាំងនេះ ពួកគេមកធ្វើអី? ឆ. គេចូលដែនសមុទ្រខ្មែរ ហើយកងសមុទ្រ

ក្រុមមនុស្សទាំងនេះ ដែលជា "ជនក្បត់" ឬ "ខ្មាំង" ហើយគូសបញ្ជាក់អំពីតម្រូវការក្នុងការរក្សា "ការប្រុងប្រយ័ត្នបដិវត្តន៍" ប្រឆាំងនឹងអ្នកទាំងនេះ[1065]។

---

ចាប់បញ្ជូនមកឱ្យ នួន ជា។ [...] ជនបរទេស ខ្ញុំសំដៅពួកស្នែកស"]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ. ២៩ ["ពេលគេចាប់បានទូកនេសាទថៃ [...] ចំនួន ២ គ្រឿង គេយកអ្នកនេសាទថៃទាំងអស់ទៅសម្លាប់ទីនោះ [ចម្ការធុរេន]។ [...] អំឡុងពេលនោះ នៅពេលគេចាប់បានជនភៀសខ្លួនជនជាតិវៀតណាម ដែលធ្វើដំណើរតាមទូកភៀសខ្លួនទៅប្រទេសទីពា គេយកពួកវៀតណាមទាំងនោះ ទៅសម្លាប់ដាក់នៅចម្ការធុរេនផងដែរ"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.៦១ ["រាល់ពីរបីថ្ងៃម្តង ខ្ញុំបានឃើញអ្នកនេសាទថៃពី ១០ ទៅ ១៥ នាក់ ត្រូវបានគេសម្លាប់។ [...] ប្រសិនបើគេចាប់បាន គឺគេសម្លាប់ហើយ គឺមិនទុកឱ្យរស់ទេ"]។ សូមមើលផងដែរ ឯកសារ VIII.B. ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តប្រឆាំងនឹងអ្នកដែលត្រូវចាប់ដោយទាហានជើងទឹកកម្ពុជាប្រជាធិបតេយ្យក្នុងដែនទឹក និងនៅលើកោះ ដែលអះអាងដោយរបបកម្ពុជាប្រជាធិបតេយ្យពីការចាប់ និងសម្លាប់នៅសមុទ្រ។ VIII.G. អំពើប្រល័យពូជសាសន៍ជនជាតិវៀតណាម។

1065 ឯកសារ D1.3.27.15 កំណត់ហេតុនៃការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំខាង មន្ទីរអង្គការ ៧០៣ និងស-២១ ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00008503 [បង៨៩ (សុន សេន) ណែនាំ៖ "ទស្សនៈប្រុងប្រយ័ត្នបដិវត្តឱ្យខ្ពស់ ដោយទំនាស់កាន់តែស្រួចណាស់ កំហឹងវណ្ណៈរបស់ ខ្មាំងទាំងខាងលិច ទាំងខាងកើត ចំពោះបដិវត្តកម្ពុជា កាន់តែខ្លាំងណាស់"]។ ឯកសារ D4.1.583 ទិសដៅគណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា សេចក្តីណែនាំរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា អំពីគោលនយោបាយរបស់បក្ស ចំពោះអ្នកភាន់ច្រឡំចូល សេ.អ៊ី.អា ឬធ្វើជាភ្នាក់ងារយួន ឬចូល កា.ហ្សេ.បេ ប្រឆាំងបក្សបដិវត្ត ប្រជាជន និងកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៧៨ KH ERN00079281-82 [គណៈមជ្ឈិមបានប្រកាសគួរលុបបំបាត់ "ពួកដាច់ខាតប្រឆាំងបក្សបដិវត្ត ប្រជាជន និងកម្ពុជាប្រជាធិបតេយ្យ ប្រឆាំងជាខ្សែសង្វាក់ជាបន្តបន្ទាប់ មិនព្រមកែប្រែ មិនសុខចិត្តរស់នៅជាមួយបក្សបដិវត្ត និងប្រជាជនកម្ពុជា ហើយដាច់ខាត លូនក្បាលទៅបំរើយួនឈ្លានពានវាតទីលេបទឹកដី វាតទីនិយមសូវៀត និងបក្សពួក ចក្រពត្តិអាមេរិក និងបរិវារ"]។ ឯកសារ D1.3.22.1 លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែ មករា ឆ្នាំ ១៩៧៦ មាត្រា ៥ KH N 00053020-23 ["ត្រូវកំណត់លក្ខណៈសម្បត្តិផ្សេងៗធ្វើជាលក្ខណៈវិនិច្ឆ័យដើម្បីជ្រើសរើសកម្មាភិបាលឱ្យចូលគណៈកម្មាធិការដឹកនាំផ្សេងៗរបស់បក្ស។ [រួមមាន៖] [...] ត្រូវមានជំហរ ប្រុងប្រយ័ត្នបដិវត្ត រក្សាការសម្ងាត់ និងការពារកម្លាំងបដិវត្ត ត្រឹមត្រូវ និងរឹងប៉ឹង គ្រប់កាលៈទេសៈ និងគ្រប់អំពើប្រព្រឹត្ត ធ្វើការងារ និយាយស្តី អាកប្បកិរិយា ការរស់នៅ គ្រប់បែបយ៉ាងចំពោះមុខ និងយូរអង្វែងក្នុងបក្ស និងក្រៅបក្ស។ [...] ត្រូវមានសីលធម៌រស់នៅល្អស្អាតស្អំ ត្រឹមត្រូវ មិនពុករលួយ ពាលាអាវាសែ ហើយមិនជំពាក់ជំពិនជាមួយខ្មាំង"]។ ឯកសារ D4.1.45 យុវជន និងយុវនារីបដិវត្ត ចេញផ្សាយ ខែ មករា-កុម្ភៈ ឆ្នាំ ១៩៧៨ KH ERN 00063491 ["ភារកិច្ចរបស់យើងបច្ចុប្បន្ន និងតទៅអនាគតទៀត គឺត្រូវលើកកំពស់ស្មារតី ប្រុងប្រយ័ត្នបដិវត្តខ្ពស់ជាប់ជានិច្ច"]។ ឯកសារ D4.1.77 កំណត់ហេតុប្រជុំបក្សកុម្មុយនីស្តកម្ពុជា កំណត់ហេតុនៃអង្គប្រជុំការងារឃោសនាការ នៅថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦ KH ERN 00000845 ["យើងប្រុងប្រយ័ត្នបដិវត្តថែមទៀត ពិសេស ខ្មាំងបង្កប់ [...] ខ្មាំងជាមូលដ្ឋាន វាខ្ទេចខ្ទីហើយ តែវានៅមានគោលបំណងបំផ្លាញយើង។ ជាទស្សនៈ ជាគោលជំហរ យើងត្រូវប្រុងប្រយ័ត្នថែម"]។ ឯក

317. បណ្តាញមន្ទីរសន្តិសុខយ៉ាងទូលំទូលាយ ត្រូវបានបង្កើតឡើង ដើម្បីអនុញ្ញាតឲ្យកម្មាភិបាលទូទាំងប្រទេសអនុវត្តគោលនយោបាយកំណត់មុខសញ្ញាលើអ្នកដែលត្រូវគេចាត់ទុកថាប្រឆាំង តាមរយៈការចាប់ឃុំឃាំងតាមអំពើចិត្ត[1066]។ "ខ្មាំង" ត្រូវគេចាប់ដាក់គុក និងទទួលរងនូវលក្ខខណ្ឌអមនុស្ស

សារ D4.1.986 FBIS សុន្ទរកថារបស់ខៀវ សំផន នៅឯកិច្ចប្រជុំគំរប់ខួប ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ KH ERN 00292805 ["យើងត្រូវបោសសម្អាតសត្រូវ ក្នុងសមត្ថភាពយើងជាម្ចាស់ការលើស្ថានភាព [...] យើងត្រូវតែប្តេជ្ញាដោយខ្លួនឯងបន្ថែមទៀត ត្រូវប្រុងប្រយ័ត្នជាប់ជានិច្ច រក្សាស្មារតីបដិវត្តិឥតងាករេ បន្តវាយប្រយុទ្ធ និងទប់ស្កាត់សត្រូវគ្រប់ប្រភេទ គ្រប់ពេលវេលា"] KH ERN 00292813 ["យើងត្រូវតែលើកកំពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តគ្រប់ពេលវេលា ប្រឆាំងនឹងសត្រូវមកពីគ្រប់ទិសទី ទាំងក្នុងនិងក្រៅប្រទេស"]។ ឯកសារ D4.1.739 កំណត់ហេតុអង្គប្រជុំរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យប្រជុំគណៈរដ្ឋមន្ត្រីលើកទី ១ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៧៦ KH ERN 00072760 ["ទិសវាគឺវាយក្បាលម៉ាស៊ីនដឹកនាំតាមផ្លូវងងឹត។ ដូច្នេះ ត្រូវលើកកំពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តថែមទៀត"]។ ឯកសារ D4.1.865 ទង់បដិវត្ត ចេញផ្សាយខែតុលា-វិច្ឆិកា ឆ្នាំ ១៩៧៧ KH ERN 00064759-60 ["អ្នកអន្តរាយត្រូវសំរិតសំរាំង។ [...] ពួកអាក្បត់បង្កប់ផ្ទៃក្នុង ក៏វាពាក់ស្លាកអង្គការដែរ [...] បានជាយើងបោសសម្អាតខ្មាំងបង្កប់ស៊ីរូងបាន អាក្បាលធំៗជាង ៩៩ ភាគរយហើយ។ [...] បើវាពង្រឹងពង្រីកខ្លួនវិញបាននៅកន្លែងណាមួយបានសេចក្តីថា កន្លែងនោះខ្សោយ"]។

1066 សូមមើល ឧទាហរណ៍ ឯកសារ D4.1.629 បញ្ជីឈ្មោះអ្នកទោសកម្ពុជាប្រជាធិបតេយ្យ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៨ [បញ្ជីឈ្មោះមន្ទីរសន្តិសុខ និងទីតាំងទាំងនោះចំនួន ១៩៦ កន្លែងដែលគេបានស្គាល់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ]។ ឯកសារ D4.1.1120 កាំង ហ្កេកអ៊ាវ ហៅ ឌុច រចនាសម្ព័ន្ធនៃបណ្តាញរបស់មន្ទីរសន្តិសុខ KH ERN 00198896 [បង្ហាញ ភូមិភាគនីមួយៗ តំបន់ ស្រុក និងមន្ទីរសន្តិសុខរបស់ពួកផ្ទាល់របស់ពួកគេ ដោយបន្ថែមជាពិសេសដូចជា ស-២១ ដែលសរុបមាន ១៩៦ មន្ទីរទូទាំងប្រទេស]។ ឯកសារ D10.1.64 កាំង ហ្កេកអ៊ាវ ហៅ ឌុច ដាក់របាយការណ៍ជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ កថាខណ្ឌ ៦៩ KH ERN 00404807 ["មន្ទីរសន្តិបាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងតិចណាស់មាន ចំនួន ១៩៦ កន្លែង"] កថាខណ្ឌ ៧០-៧២, KH ERN 00404807 [រៀបរាប់ពីការគ្រប់គ្រងរបស់អង្គការចាត់តាំងរបស់មន្ទីរសន្តិសុខ និងចម្លើយសារភាពត្រូវធ្វើតាមខ្សែរយៈបញ្ជា]។ ឯកសារ D4.1.462 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ អាឡាត់ ហៅ ឆុង ឡាត់ KH ERN 00196812-13 [រៀបរាប់លម្អិតពីមន្ទីរសន្តិសុខ ៥ ដែលគាត់ស្គាល់៖ មន្ទីរសន្តិសុខព្រៃស្លឹកដែលគេស្គាល់ជាក្រាំងតាសំ មន្ទីរសន្តិសុខ ០៧ ដែលគេស្គាល់ផងដែរជាមន្ទីរសន្តិសុខត្រពាំងជង មន្ទីរសន្តិសុខនៅទួលតាប៉េវ មន្ទីរសន្តិសុខចារឹក និងមន្ទីរសន្តិសុខអាទីលឡឺរី ដែលគេស្គាល់ជាមន្ទីរបន្ទាយកាំភ្លើងធំ ក្នុងខេត្តពោធិសាត់]។ ឯកសារ D4.1.369 កំណត់ហេតុស្តាប់ចម្លើយ ចាន់ ខន KH ERN 00186762-63 [ទាក់ទងនឹងមន្ទីរ ១៣]។ ឯកសារ D4.1.1112 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ KH ERN 00185467-68 [រៀបរាប់ពី ម-១៣ និង ស-២១]។

ធម៌ ការសួរចម្លើយ ការធ្វើទារុណកម្ម និង/ការសម្លាប់[1067]។ គ្មានអ្នកណាម្នាក់ទទួលបានការកាត់សេចក្តីតាមផ្លូវច្បាប់ឡើយ ដោយហេតុថា ប.ក.ក បានលុបចោលនូវរចនាសម្ព័ន្ធតុលាការ និងច្បាប់[1068]។ ជាញឹកញាប់ ការធ្វើទារុណកម្ម និងការសួរចម្លើយ នាំឱ្យមានការសារភាពដោយបង្ខំ

---

1067 សូមមើល ឧទាហរណ៍ ឯកសារ D1.3.28.81 បញ្ជីឈ្មោះអ្នកទោសសួរចម្លើយ ស-២១ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៨ [បញ្ជីអ្នកទោស ៩៨ នាក់ ពីទូទាំងប្រទេសដែលបានសួរចម្លើយនៅ ស-២១ នៅថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៨]។ ឯកសារ D4.1.495 របាយការណ៍ពី ជឹម នៅឃុំត្រពាំងធំត្បូង ជូនបក្ស ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៧៧ KH ERN 00270984-85 [របាយការណ៍ស្តីពីការធ្វើទារុណកម្ម និងការសួរចម្លើយអ្នកទោស]។ ឯកសារ D4.1.148 របាយការណ៍ពី អាន នៅមន្ទីរសន្តិសុខក្រាំងតាចាន់ (មន្ទីរអប់រំស្រុក ១០៥) ជូនបក្ស ខែ កក្កដា-សីហា ឆ្នាំ ១៩៧៧ KH ERN 00082724 [ចំណារសរសេរដៃដោយ ប្រាក់ នៃ ត-១៣ (តំបន់ ១៣) បង្គាប់ អាន ប្រធានគុកក្រាំងតាចាន់៖ "សំរេចកំទេចចុះ។ ៧/៨/៧៧។ ត-១៣, ប្រាក់"] KH ERN 00082725 ["សំរេចកំទេចចុះ។ ៧/៨/៧៧។ ត-១៣, ប្រាក់"] KH ERN 00082727 [ការណែនាំពីលេខាស្រុកឈ្មោះ គិត ជម្រាបមកសមមិត្ត អាន់ ដែលបាននិយាយថា៖ "បញ្ហាអ្នកទោសទាំងអស់ដែលចាប់នៅក្នុងឃុំជាងទង [...] សួរចម្លើយផុតខ្សែរវាឲ្យអស់, កំទេចចុះ"]។ ឯកសារ D1.3.33.8 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៧ KH ERN 00146677 ["សន្តិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ជាសន្តិបាលខុសគេ ខុសឯងទាំងស្រុង។ មិនប្រើច្បាប់ទាល់តែសោះ ប្រើតែមាគ៌ាបក្ស និងសេចក្តីសម្រេចចិត្តតូចជារបស់បក្ស ដែលចេញតែពីមាត់ ប៉ុល ពត។ [...] ប្រើតែវិធានការឧក្រិដ្ឋ (ទារុណកម្ម យកចម្លើយ កំទេច ឲ្យតែចាប់គឺត្រូវតែកំទេច)"]។ ឯកសារ D4.1.1112 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ KH ERN 00185470 ["គោលការណ៍ជាទូទៅនៅគ្រប់មន្ទីរសន្តិសុខទាំងអស់ ក៏ដូចជានៅ ស-២១ គឺគ្រប់មនុស្សដែលត្រូវបានចាប់ខ្លួន ត្រូវតែសម្លាប់ លើកលែងតែករណីពិសេស ដែលមានភាពបណ្តោះអាសន្ន [...]។ សេចក្តីសម្រេចតែមួយគត់ដែលត្រូវធ្វើ គឺទាក់ទងតែនឹងពេលវេលានៃការសម្លាប់ប៉ុណ្ណោះ"]។

1068 ឯកសារ D98/1.2.1 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ ម៉ោង ១០.០៨.៥៨-១០.២៣.៣៨ ["ពាក្យ "កម្ទេច" គឺមិនដោះលែង [...] គឺអត់ឆ្លងកាត់តុលាការទេ ព្រោះគ្មានច្បាប់ គ្មានតុលាការ អចិន្ត្រៃយ៍មជ្ឈិមបក្សប្រមូលផ្តុំអំណាចទាំងបី"]។ ឯកសារ D4.1.1109 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០០៨ KH ERN 00177581 ["រាល់សេចក្តីសម្រេចសំខាន់ៗ ត្រូវបានធ្វើដោយបក្ស ដែលដឹកនាំប្រទេសផ្តាច់មុខ និងតាមរបៀបផ្តាច់ការ [...] ចំណុចនេះ មានន័យថា គ្រប់សេចក្តីសម្រេចរបស់លេខា ឬអនុលេខាបក្ស ត្រូវតែគោរពតាម ហើយអ្នកណាមិនគោរពតាម ត្រូវតែកំទេច [...] គោលការណ៍នេះ គឺមានវិសមត្ថភាពជាមួយនឹងអត្ថិភាពនៃតុលាការ និងការធានាផ្នែកនីតិវិធី"]។ ឯកសារ D114/263 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី ឆ.២ ["ព្រោះកាលនោះ យើងអត់មានតុលាការ ច្បាប់អីសំខាន់ទេ។ មានតែបញ្ហាទេ ដែលជាតុលាការ"]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.១៧ ["នៅក្នុងពេលនោះ បើនរណាធ្វើខុសហើយត្រូវគេចាប់ខ្លួន គេមិនមានតុលាការសម្រាប់កាត់ក្តីទេ"]។ ឯកសារ D114/48 កំណត់ហេតុស្តាប់ចម្លើយ សុខ ង៉ុន ឆ.២៧ ["គេហៅរបបនោះថាជារបបផ្តាច់ការ ព្រោះមិនមានតុលាការ ឬអ្វីទេ។ អ្នកណាជាមេ គេមានសិទ្ធិសម្រេចទៅតាមចិត្តរបស់គេ"]។ ឯក

ដែលឆ្លើយដាក់អ្នកផ្សេង បង្កើតបានជាវដ្តមួយនៃការចាប់ខ្លួន និងសម្លាប់ក្រៅផ្លូវតុលាការ[1069]។ ជារឿយៗ សមាជិកគ្រួសាររបស់ "ខ្មាំង" ក៏ត្រូវបានកម្ទេចផងដែរ ដោយសារតែពួកគេត្រូវបានចាត់

---

សារ D1.3.30.28 គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បញ្ហារំលោភសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន នៅតំបន់ណាក៏ដោយ នៃពិភពលោក ដោយសំដៅជាពិសេសចំពោះបណ្តាប្រទេស និង ទឹកដីអាណានិគម និងប្រទេសឯករាជ្យដទៃទៀត ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៧៩ KH ERN 00294964 ["នៅក្នុងជំពូក ៧ នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ មានមាត្រាខ្លីៗចំនួន ២ ស្តីពីការគ្រប់គ្រងយុត្តិធម៌ និងការតែងតាំងចៅក្រម (មាត្រា ៩) និងការផ្តល់និយមន័យអំពីទំរង់ផ្សេងៗនៃការផ្តន្ទាទោស (មាត្រា ១០)។ ក៏ប៉ុន្តែនៅក្នុងឯកសារមានការចោទប្រកាន់ថា ដំណើរការនៃការជំនុំជម្រះក្តី ឬតុលាការ គឺគ្មានទាល់តែសោះនៅក្នុងប្រទេសនេះ ហើយថា ការផ្តន្ទាទោសចំពោះបទល្មើសផ្សេងៗគឺសុទ្ធតែសំដៅទៅរកការអនុវត្តន៍ក្រៅច្បាប់ទាំងស្រុង"]។ ឯកសារ D1.3.17.9 អ៊ីសោ ឧស្មាន អ៊ិត្ធូបះ៖ យុត្តិធម៌សម្រាប់ជនជាតិចាមក្រោមរបបកម្ពុជាប្រជាធិបតេយ្យ EN ERN 00078543 ["ការចាប់ខ្លួន និងការដាក់ទណ្ឌកម្មប្រជាជន ខ្មែរក្រហមមិនបានឆ្លងកាត់ដំណើរការនៃសេចក្តីសម្រេចរបស់តុលាការ និងបានបំពានរដ្ឋធម្មនុញ្ញរបស់ខ្លួន [...] ថ្នាក់មូលដ្ឋានកម្រិតទាប ឬប្រធានមូលដ្ឋាន ត្រូវបានចាប់ខ្លួន ខណៈដែលប្រធានគុក និងអ្នកក្រោមបង្គាប់ផ្ទាល់របស់ពួកគេបានសម្រេចចិត្តទាំងអស់លើទារុណកម្មសួរចម្លើយ និងសម្លាប់អ្នកទោស។ គោលការណ៍ទាំងអស់ស្ថិតនៅលើខ្សែសង្វាក់បញ្ជា ដូចបញ្ជាដែលមកពីគណៈមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា"]។

1069 សូមមើល ឧទាហរណ៍ ឯកសារ D4.1.148 របាយការណ៍ពី អាន នៅមន្ទីរសន្តិសុខក្រាំងតាចាន់ (មន្ទីរអប់រំស្រុក ១០៥) ជូនបក្ស ខែ កក្កដា-សីហា ឆ្នាំ ១៩៧៧ KH ERN 00082727 [ការណែនាំពីលេខាស្រុកឈ្មោះ គិត ជម្រាបមកសមមិត្ត អាន់ ដែលបាននិយាយថា៖ "បញ្ហាអ្នកទោសទាំងអស់ដែលចាប់នៅក្នុងឃុំជាងទង [...] សួរចម្លើយផុតខ្សែវាឲ្យអស់, កំទេចចុះ"]។ ឯកសារ D4.1.495 របាយការណ៍ពី ជឹម នៅឃុំត្រពាំងធំត្បូង ជូនបក្ស ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៧៧ KH ERN 00270984-85 [ជូនដំណឹងបក្សថា ពួកគេបាននាំមនុស្ស ៤ នាក់ ដែលជាអ្នកជាប់ចម្លើយរបស់ ភួង នៅយប់មុន ហើយឥឡូវនេះដោយផ្អែកលើវិធីសាស្ត្រ សួរត្រជាក់ខ្លះ ក្តៅខ្លះ អ្នកចាប់ខ្លួនថ្មីម្នាក់បានពាក់ព័ន្ធមនុស្សពីរនាក់ទៀតដែលជា "បណ្តាញ"]។ ឯកសារ D4.1.1058 កំណត់ហេតុស្តាប់ចម្លើយ ឆោម សែ ឆ.៨ ["តាមខ្ញុំសម្គាល់ កម្មាភិបាលមានឋានៈចាប់ពីប្រធានអនុសេនាធំឡើងទៅ និងដែលជាកម្មាភិបាលចាស់ៗ (ក្នុងការងារ) ត្រូវបានដកដោយសារមានពាក់ព័ន្ធនឹងចម្លើយនៅសេនាធិការ"]។ ឯកសារ D4.1.805 កំណត់ហេតុស្តាប់ចម្លើយ ឆោម សែ ឆ.៦ ["ចម្លើយឆ្លើយដាក់គឺមកពីភ្នំពេញ ដែលមានន័យថា ចម្លើយសារភាពអ្នកទោសដែលគេសួរនៅភ្នំពេញ [...] ចម្លើយនោះ ជាចម្លើយសារភាពដែលមានការឆ្លើយដាក់ទៅលើកងទ័ពក្នុងកងពល ៨០១ ប្រហែល ៤ ឬ ៥ នាក់។ [...] មានចម្លើយសារភាពប្រហែលជា ៣ ទៅ ៤ ចម្លើយ។ ចម្លើយសារភាពទាំងនោះ មានឃើញចារបិកក្រហមថា ជាប្រព័ន្ធរបស់ភ្នាក់ងារត្រូវត្រួតពិនិត្យឈ្មោះនេះ ឬឈ្មោះនោះ "]។ ឯកសារ D1.3.32.17 កំណត់ហេតុស្តាប់ចម្លើយ ហ៊ឹម ហ៊ុយ KH ERN 00146647 ["បើអ្នកទោសឆ្លើយដាក់ ៧០៣ នោះ ឌុច អោយគេចាប់សួរ រួចសម្លាប់"]។ ឯកសារ D4.1.250 កំណត់ហេតុស្តាប់ចម្លើយ ហ៊ឹម ហ៊ុយ KH ERN 00164447 ["ក្នុងពេលប្រជុំមួយ ឌុច បាននិយាយប្រាប់យើងថា ពួកអ្នកត្រូវអ្នកមកពីកងពល ៧០៣ ដែលធ្វើការនៅ ស-២១ និងដែលត្រូវបានអ្នកទោសមកពី ៧០៣ ចោទដាក់ ត្រូវចាប់ខ្លួនសួរចម្លើយ និងសម្លាប់នៅក្នុងបរិវេណស-២១"]។ ឯកសារ

ទុកថាជា "ខ្មែរខ្មាំង"[1070]។ ចំពោះសិទ្ធិអំណាចក្នុងការសម្រេចថា តើអ្នកណាគួរត្រូវសម្លាប់ សេចក្តីសម្រេចរបស់គណៈមជ្ឈិម ឆ្នាំ ១៩៧៦ ផ្តល់ជូនគណៈអចិន្ត្រៃយ៍ភូមិភាគ គណៈមន្ទីរមជ្ឈិម គណៈអចិន្ត្រៃយ៍ និងសេនាធិការ នូវសិទ្ធិអំណាចក្នុងការ "កម្ទេច"[1071] ដែលសំដៅដល់ការសម្លាប់ក្រៅផ្លូវតុលាការ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[1072]។

---

D4.1.1156 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៨ KH ERN 00205154 ["លោកចៅក្រម បានសួរខ្ញុំថាតើមានការចាប់ខ្លួនប៉ុន្មានភាគរយដែលត្រូវបានធ្វើ ដោយសំអាងលើការឆ្លើយដាក់នៅក្នុងចម្លើយសារភាព។ ខ្ញុំមិនអាចឆ្លើយបានទេ ប៉ុន្តែ ខ្ញុំដឹងថា មានចំនួនច្រើន។ នេះជាករណីបែបនេះ នៅពេលដែល សុន សេន បញ្ជាឲ្យមានការចាប់ខ្លួនភ្លាមនូវមនុស្សទាំងឡាយដែលត្រូវបានឆ្លើយដាក់ដោយ កុយ ធួន។ ខ្ញុំបានជំទាស់ដោយនិយាយប្រាប់គាត់ថា វាមិនសមក្នុងការចាប់ខ្លួនពួកគេទាំងអស់នោះទេ ប៉ុន្តែ គាត់បាននិយាយគំហកមកខ្ញុំថា "នេះជាចម្លើយសារភាពរបស់អាឃួន (កុយ ធួន)"។ ដូច្នេះ ខ្ញុំមិនមានលទ្ធភាពប្រឆាំងជំទាស់នឹងការសម្រេចចាប់ខ្លួននោះទេ"]។ ឯកសារ D98/3.1.226 កំណត់ហេតុស្តាប់ចម្លើយ Laurence Picq KH ERN 00252159 ["អ្នកណាក៏ដឹងដែលថា ជនណាក៏ដោយដែលត្រូវបានគេឆ្លើយដាក់តាមរយៈចម្លើយសារភាពចំនួនបីខុសៗគ្នា នឹងត្រូវចាប់ខ្លួន។ ផ្ទុយទៅវិញ ចំពោះសហព័ន្ធ គឺតម្រូវឲ្យមានចម្លើយសារភាពឆ្លើយដាក់ខ្លួនចំនួន ៥ នាក់ ទើបអាចចាប់ខ្លួនបាន"]។

1070 ឯកសារ D1.3.27.23 កំណត់ហេតុអង្គប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំនត់ហេតុនៃការប្រជុំលេខា និងភស្តុភារកងពល និងវរសេនាធំឯករាជ្យ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៧៦ KH ERN 00095514 ["ត្រូវសំរិតសំរាំងសមាសភាពអន្តរាយឲ្យអស់ពីអង្គភាព [...] លទ្ធផលក្តាប់ប្រវត្តិរូបលើកនេះ យើងធ្វើបានល្អ តែក៏នៅមានមិត្តខ្លះ នៅលាក់លៀមប្រវត្តិនៅឡើយ។ ប្រយ័ត្នបំផុតអ្នកដែលឪពុកម្តាយត្រូវបោសសម្អាត ឬបងប្អូនត្រូវបោសសម្អាត"]។ ឯកសារ D11/54/3.1 ព្រាប សុឃឿន ប្រតិចារឹកថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង ០៩.៤៥.០០-០៩.៤៨.៥០ ["បងស្រីពីរនាក់ទៀត កាលហ្នឹងគាត់នៅសហករណ៍ហ្នឹងដែរ [...]។ ប្តីគាត់ហ្នឹង គេចោទថាតាមខ្សែបណ្តាញអី គេចាប់យកទៅពីឆ្នាំ ៧៥ ឬ ៧៦។ ដល់មក ៧៧ ហ្នឹង គេយកប្រពន្ធហ្នឹងដាក់ឡានទៅសម្លាប់ទៀត។ ក្នុងរបបហ្នឹងវាស្រាវជ្រាវរកខ្សែបណ្តាញទាល់តែសម្លាប់អស់ អស់ប្រជាពលរដ្ឋ [...]គេសម្លាប់អត់មានទុកឲ្យស្នងពូជទេ គេសម្លាប់អស់ៗ"]។ ឯកសារ D234/2.1.68 អេលីហ្សាបេត បេកឃ័រ ប្រតិចារឹកថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ ម៉ោង ១០.៥១.៤០-១០.៥៣.៣៧ ["គេចោទប្រកាន់តាមរយៈបណ្តាញ ហើយការសម្លាប់ គឺការសម្លាប់បែបរុញទម្លាក់ដាក់គ្នាទៅវិញទៅមក គឺថាមនុស្សពេញវ័យមានទំនាក់ទំនងជាមួយមនុស្សពេញវ័យ ហើយបណ្តាញនេះ គឺរួមបញ្ចូលទាំងក្រុមគ្រួសារទាំងមូល"]។

1071 ឯកសារ D1.3.19.1 សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ KH ERN 00003136 [ការផ្តល់ "សិទ្ធិសំរេចកំទេចក្នុងជួរ និងក្រៅជួរ"ដូចខាងក្រោម៖ "បើនៅក្នុងក្របខណ្ឌមូលដ្ឋាន ត្រូវអចិន្ត្រៃយ៍ភាគសំរេច ជុំវិញមន្ទីរមជ្ឈិម ត្រូវគណៈមជ្ឈិមសំរេច។ តំបន់ឯករាជ្យ ត្រូវអចិន្ត្រៃយ៍សំរេច។ កងទ័ពមជ្ឈិមត្រូវសេនាធិការសំរេច"]។ សូមមើលផងដែរ ឯកសារ D98/1.2.1 កាំង ហ្គេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ ម៉ោង ១០.០៨.៥៨-១០.២៥.១៨ [យោងសេចក្តីសម្រេចថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦៖ "តាមរយៈឯកសារ

318. គោលនយោបាយ "កម្ទេចខ្មាំង" និងចាប់ "សមាសភាពមិនល្អ" ត្រូវបានផ្សព្វផ្សាយ តាមរយៈ ឯកសារផ្ទៃក្នុងរបស់ ប.ក.ក[1073] សុន្ទរកថារបស់មេដឹកនាំ ប.ក.ក[1074] និងកិច្ចប្រជុំនៅគ្រប់ជាន់

---

នេះ បានប្រគល់សិទ្ធិ ឬក៏ថា ប្រតិភូអំណាចខាងកាប់សម្លាប់ ខាងសម្រេចកម្ទេចទាំងក្នុង និងទាំងក្រៅជូរទៅឲ្យមនុស្ស បួនក្រុម។ [...] អំណាចដែលមជ្ឈិមប្រគល់ឲ្យពួក ៤ ក្រុមហ្នឹង ដែលមានសិទ្ធិពេញបរិបូរណ៍។ [...] ពេញមួយរយៈកាលពីថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ រហូតដល់ ៧ មករា ឆ្នាំ ១៩៧៩ បក្សកុម្មុយនីស្តកម្ពុជា អនុវត្តមាគ៌ាចាត់តាំងនេះ ពេញលេញ និងតឹងរ៉ឹងបំផុត"]។

1072 សូមមើល ឧទាហរណ៍ ឯកសារ D98/1.2.15 កាំង ហ្គេកអ៊ាវ ហៅ ឌុច ប្រតិចារឹកថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ ម៉ោង ១៥.៥៥.០៣-១៥.៥៦.៥៦ ["'កម្ទេច' ហ្នឹងយកទៅវៃចោល តែប៉ុននុ៎ង។ នៅតែងដែលគ្រាន់តែតែប្តូរតែមួយម៉ាត់អីចឹង នៅតែធ្វើឲ្យគ្នាស្លាប់"]។ ឯកសារ D98/1.2.1 កាំង ហ្គេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ ម៉ោង ១០.០៣.៣៨-១០.០៨.៥៨ ["[ប្រជាជន] សម្លាប់ដោយសម្ងាត់មិនឲ្យដំណឹងដល់គ្រួសារ [...] ពាក្យ "កម្ទេច" គឺមិនដោះលែង [...] អត់ឆ្លងកាត់តុលាការទេ ព្រោះគ្មានច្បាប់ គ្មានតុលាការ អចិន្ត្រៃយ៍មជ្ឈិមបក្សប្រមូលផ្តុំអំណាចទាំងបី"]។ ឯកសារ D98/1.2.7 ក្រេក អេតឆេសាន់ ប្រតិចារឹកថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ម៉ោង ០៩.០៩.៤៨-០៩.១៧.០០ ["គឺខ្ញុំដឹងភាសាវិជ្ជាទាក់ទងទៅនឹងភាសាខ្មែរ ប៉ុន្តែ តាមការយល់របស់ខ្ញុំនោះ ពាក្យខ្មែរដែលយើងបកប្រែពីពាក្យថា "smash" នេះគឺពាក្យថា "កម្ទេច" បានន័យថា កម្ទេច គឺវាមានន័យជ្រាលជ្រៅជាងការសម្លាប់ទៅទៀត។ ជាញយៗ យើងឃើញពាក្យនេះត្រូវបានបកប្រែថា មិនត្រឹមតែពាក្យថាកម្ទេចទេ វាត្រូវបានបកប្រែថា កម្ទេចឲ្យម៉ត់ ហើយនិងធ្វើឲ្យវាទៅជាកម្ទេចតូចៗ [...] គឺពាក្យនេះមិនពាក់ព័ន្ធត្រឹមតែការសម្លាប់តែប៉ុណ្ណោះនោះទេ គឺវាទាក់ទងទៅនឹងការកម្ទេចសម្លាប់ដោយផ្នែកចិត្តសាស្ត្រផងដែរ"]។ ឯកសារ D4.1.409 កំណត់ហេតុស្តាប់ចម្លើយ ឈូក រិន ហៅ សុក KH ERN 00210214 ["ចំណែក "កំទេច" គឺបានន័យថា ចាប់ និងសម្លាប់"]។

1073 សូមមើល ឧទាហរណ៍ ឯកសារ D4.1.861ទង់បដិវត្ត ចេញផ្សាយខែ សីហា ឆ្នាំ ១៩៧៥ KH ERN 00063342 ["នឹងកម្ទេចពួកចារកម្ម កម្ទេចពួកវិទ្ធេទកម្ម ដែលវាចង់បំផ្លិចបំផ្លាញបដិវត្តយើង គឺយើងបន្តកម្ទេចសំណល់ខ្មាំងដែលចាញ់នោះ ហើយពង្រឹងជ័យជំនះរបស់យើង [...] ខ្មាំងខាងក្រៅ និងខ្មាំងខាងក្នុងនៅមានរហូត។ [...] បើយើងប្រុងប្រយ័ត្នបដិវត្តជាប់ [...]ខ្មាំងធ្វើអីយើងមិនកើតទេ"]។ ឯកសារ D4.1.653 ទង់បដិវត្ត ចេញផ្សាយខែ មិថុនា ឆ្នាំ ១៩៧៧ KH ERN 00062809 ["វាយខ្មាំងបោសសម្អាតិជាភ្នាក់ងារអន្តរជាតិ ខ្មាំងជាខ្មាំងបង្កប់ ខ្មាំងជាខ្មាំងវណ្ណៈ មិនឲ្យវាត្រដេរត្រដរធ្វើសកម្មភាពសូម្បីតែបន្តិចបានឡើយ"]។ ឯកសារ D1.3.24.5 ទង់បដិវត្ត ចេញផ្សាយខែ ឧសភា-មិថុនា ឆ្នាំ ១៩៧៨ KH ERN 00064578 ["ដូច្នេះ ភារកិច្ចរបស់យើង គឺវាយកំទេចពួកភ្នាក់ងារ សេ.អ៊ី.អា ភ្នាក់ងារយួន និងភ្នាក់ងារ កា.ហ្សេ.បេ នេះដាច់ខាត ខ្លាំងក្លា ជាបន្តបន្ទាប់ វាយហើយ វាយទៀត ឲ្យវារលំរលាយ ហើយរលំរលាយជាបន្តបន្ទាប់។ លុះត្រាតែវាយវាយ៉ាងនេះ បានកម្លាំងចាស់របស់វាត្រូវខ្ទេចខ្ទី ហើយកម្លាំងនៅសេសសល់របស់វា គឺត្រូវខ្ទេចខ្ទីទៀត កម្លាំងថ្មី របស់វាងើបមកទៀត ក៏ត្រូវខ្ទេចខ្ទីទៀត។ យើងចិតក្នុងសភាពវាយសំរុក ម្ចាស់ការហើយ ឈានទៅមុខ ជាន់ខ្មាំងដណ្តើមយកជ័យជំនះជាបន្តបន្ទាប់។ ឯខ្មាំងវិញត្រូវខ្ទេចខ្ទី ខ្ចាត់ខ្ចាយ និងរលំរលាយ"]។ ឯកសារ D4.1.869 ទង់បដិវត្ត ចេញផ្សាយខែ កក្កដា ឆ្នាំ ១៩៧៨ KH ERN 00064487 ["៦ខែ ដើមឆ្នាំ ១៩៧៨នេះ បក្សយើងបានបំផុសចលនាទូទាំងប្រទេស ទាំងក្នុងបក្ស ទាំងក្នុងមហាជនសម្ហូហភាព និងក្នុងកងទ័ពបដិវត្ត បោសសម្អាតខ្មាំង

ថ្នាក់[1075] ហើយត្រូវបានគាំទ្រ និងទទួលស្គាល់ ក្នុងទស្សនាវដ្តី "ទង់បដិវត្តន៍" និង "យុវជន-យុវនារីបដិវត្តន៍" ចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[1076]។ ទូរលេខរវាងថ្នាក់ផ្សេងៗនៃឋានានុក្រម ប.ក.ក ក៏រាយការណ៍ផងដែរអំពី "សកម្មភាពខ្មាំង" និងរៀបរាប់លម្អិតអំពីមនុស្សដែលត្រូវគេសម្លាប់[1077]។

---

បង្កប់ស៊ីរូងផ្ទៃក្នុង បានទទួលមហាជ័យជំនះ សឹងមានន័យស្មើមហាជ័យជំនះ ថ្ងៃទី១៧ មេសា ១៩៧៥"] KH ERN 00064501-02 ["ក្នុងមហាចលនាមហាជនវាយកំទេចខ្មាំងយួនឈ្លានពាន វាតទីលេបទឹកដី បំបាត់ពូជសាសន៍ និងក្នុងមហាចលនាមហាជនបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ជាភ្នាក់ងារស៊ីអ៊ីអា ភ្នាក់ងារផ្តេបំរើយួន និងភ្នាក់ងារកាសេបេ សហករណ៍ទូទាំងប្រទេសបានដើរតួយ៉ាងសំខាន់ក្នុងការធ្វើសកម្មភាពបំពេញភារកិច្ចរបស់ខ្លួន"]។

1074 សូមមើល ឧទាហរណ៍ ឯកសារ D4.1.986 FBIS សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគំរប់ខួប ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ KH ERN 000292805 ["យើងត្រូវបោសសម្អាតសត្រូវក្នុងសមត្ថភាពយើងជាម្ចាស់ការលើស្ថានភាព ដើរតាមមាគ៌ាគោលនយោបាយក្នុងស្រុក គោលនយោបាយបរទេស និងគោលនយោបាយយោធារបស់អង្គការបដិវត្តរបស់យើង។ [...] យើងត្រូវតែប្តេជ្ញាដោយខ្លួនឯងបន្ថែមទៀត ត្រូវប្រុងប្រយ័ត្នជាប់ជានិច្ច រក្សាស្មារតីបដិវត្តឥតងាករេ បន្តវាយប្រយុទ្ធ និងទប់ស្កាត់សត្រូវគ្រប់ប្រភេទ គ្រប់ពេលវេលា"]។ ឯកសារ D4.1.862 ទង់បដិវត្ត ចេញផ្សាយខែ មេសា ឆ្នាំ ១៩៧៧ KH ERN 00062986 [ដកស្រង់សម្តីដោយ "សមមិត្តតំណាងអង្គការបក្ស" នៅទិវាខួបលើកទី ២ នៃជ័យជំនះ ១៧ មេសា "ចំពោះខ្មាំងជាភ្នាក់ងារ 'សេ.អ៊ី.អា' 'កា.ហ្សេ.បេ' និងភ្នាក់ងារ 'យួន' ជាផ្តេបំរើខ្មាំងយ៉ាងថោកទាប ដែលលួចបង្កប់នៅក្នុងបក្សយើង និងជួរបដិវត្តយើង ពួកអានេះ វាកំពុងឋិតក្នុងសភាពបាត់ចម្លាស់ការ កំរិតខ្ពស់បំផុត ដោយក្បាលម៉ាស៊ីនធំ និងមធ្យមរបស់វា ត្រូវកំទេចជាមូលដ្ឋាន ហើយកម្លាំងដែលនៅសេសសល់គឺត្រូវខ្ចាត់ខ្ចាយ រប៉ាត់រប៉ាយ ជាមូលដ្ឋានដែរ ប្រៀបបីដូចកណ្តុរដែលត្រូវវាយបែកសំបុកធ្លាក់ទឹក ហើយកំពុងត្រូវប្រជាជន ដេញសំពងឱ្យវិនាសអន្តរាយ។ យើងត្រូវបន្តវាយវាតទៅទៀត ជាន់វាថែមទៀត ក្នុងឋានៈយើងមានប្រៀបដាច់ខាត វាយសំរុកវាជាប់ជានិច្ចក្នុងមួយឆ្នាំ ១៩៧៧ នេះ ឱ្យវាកាន់តែខ្ទេចខ្ទីរតទៅទៀត ងើបក្បាលមិនរួច"]។ ឯកសារ D10.1.59 ទង់បដិវត្ត ចេញផ្សាយខែ សីហា ឆ្នាំ ១៩៧៧ KH ERN 00062963-65 [បទឧទ្ទេសនាមរបស់ "តំណាងអង្គការបក្ស" (ជឿថាជា នួន ជា) នៅក្នុងឱកាសសន្និបាតកម្មាភិបាលភូមិភាគបស្ចឹម នៅថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៧៧៖ "នៅក្នុងភាគនេះក៏មានខ្មាំងបង្កប់។ ក្នុងតំបន់ក៏មានសមាសភាពខ្មាំងបង្កប់ ក្នុងស្រុកក៏មានសមាសភាពខ្មាំងបង្កប់ ។ល។ យើងដណ្តើមបានជ័យជំនះ ទូទាំងប្រទេសហើយ វាមករៀបចំកម្លាំងវា វាមកស៊ីរូង ដើម្បីដណ្តើមរដ្ឋអំណាចពីយើងវិញ រដ្ឋអំណាចភាគ រដ្ឋអំណាចតំបន់ រដ្ឋអំណាចស្រុក [...] ត្រូវរៀបចំកម្លាំងទៅរើ រើកំទេចខ្មាំង និងសមាសភាពមិនល្អ បង្កប់កាន់កាប់នៅក្នុងសហករណ៍"]។ ឯកសារ D64.1.34 FBIS លោក អៀង សារី រៀបចំពិធីជប់លៀងសម្រាប់គណៈប្រតិភូ ភូមា - សុន្ទរកថារបស់សមមិត្ត អៀង សារី ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៧៧ KH ERN 00658434 ["ក្នុងរយៈពេល ៨ ខែមុននេះ ប្រជាជន និងកងទ័ពបដិវត្តន៍កម្ពុជារបស់យើង បានខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តដើម្បីបង្កើនផលិតផល និងបានការពារឯករាជ្យជាតិ អធិបតេយ្យភាព និងបូរណភាពដែនដីរបស់យើងបានដោយជោគជ័យ [...] ដោយបានកម្ទេចចោលរាល់កលល្បិចរបស់ខ្មាំងគ្រប់រូបភាព"]។

1075 សូមមើល ឧទាហរណ៍ ឯកសារ D1.3.27.1 កំណត់ហេតុការប្រជុំគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ KH ERN 00019121-22 [ពិភាក្សាថាតើសមមិត្ត ២ នាក់ (មាន និង ផាន) គួរត្រូវចាត់ទុកជា

ខ្មាំង ឬក៏អត់ទេ "ចំពោះសមមិត្ត មាន [...] ត្រូវប្រុងប្រយ័ត្នពីការនិយាយស្តី ឲ្យឃើញវាក្បត់ដែលនាំសាម៉ីខ្លួនមិនឃើញអនាគត។ យើងវិភាគកាលៈទេសៈដែលគាត់គេចឲ្យសមរម្យ ហើយកុំផ្សាយ។ [...] ពីរឿងសមមិត្ត ផាន ត្រូវស្ទាត់មែនទែន បញ្ហារាយការណ៍អីត្រូវវិភាគព្រោះគិញវាឆ្លើយបត់បែន។ រកប្រវត្តិតាមខ្សែ យើងគ្រាន់បើជាង ជឿតាមខ្សែខ្មាំងមិនបាន។ [...] តែត្រូវមើលសកម្មភាពរបស់គេ"]។ ឯកសារ D4.1.77 កំណត់ហេតុប្រជុំបក្សកុម្មុយនីស្តកម្ពុជា កំណត់ហេតុនៃអង្គប្រជុំការងារឃោសនាការ នៅថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦ KH ERN 00000845 [ទាក់ទងស្ថានីយ៍វិទ្យុ៖ "យើងត្រូវប្រុងប្រយ័ត្នបដិវត្តថែមទៀត ពិសេសខ្មាំងបង្កប់ខ្មាចវាដាក់គ្រាប់បែកផ្ទុះ។ ដូច្នេះ ត្រូវយាមកាម ត្រូវមានរបបចេញចូល កុំឲ្យរហេតរហូត។ ខ្មាំងជាមូលដ្ឋាន វាខ្ទេចខ្ទីហើយ តែវានៅមានគោលបំណងបំផ្លាញយើង។ ជាទស្សនៈជាគោលជំហរ យើងត្រូវប្រុងប្រយ័ត្នថែម"]។ ឯកសារ D4.1.739 កំណត់ហេតុអង្គប្រជុំរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យប្រជុំគណៈរដ្ឋមន្ត្រីលើកទី ១ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៧៦ KH ERN 00072761 ["ការពាររដ្ឋអំណាចបដិវត្ត លទ្ធផលបដិវត្ត ការពារបក្ស ប្រជាជន កងទ័ព ឯករាជ អធិបតេយ្យភាព ។ល។ តាមគ្រប់រូបភាពដែលខ្មាំងធ្វើសកម្មភាព ទាំងចំហ ទាំងសម្ងាត់។ យើងត្រូវប្រុងប្រយ័ត្នបដិវត្តខ្ពស់ជានិច្ច ត្រូវម្ចាស់ការជានិច្ច"]។ ឯកសារ D1.3.27.15 កំណត់ហេតុនៃការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំខាងមន្ទីរអង្គការ ៧០៣ និងស-២១ ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00008503 [ក្នុងការឆ្លើយតបទៅនឹងការចែកចាយខិត្តប័ណ្ណដែលគ្មានការអនុញ្ញាតបានរិះគន់អង្គការ បង ៨៩ (សុន សេន) ថាតើអ្នកណាអ្នកចែកចាយ និងចាត់វិធានាការអ្វីខ្លះ៖ "បញ្ហានេះ មិនមកពីក្រៅទេ។ [...] ខ្មាំងចង់ឲ្យយើងឈប់ទុកចិត្តកង ៧០៣ និង ១៨០។ [...]ំសកម្មភាពនេះជាផែនការរួមរបស់ខ្មាំង។ ត្រូវប្រយ័ត្នខ្មាំងលួចបាញ់អង្គការ។ [...] ទស្សនៈប្រុងប្រយ័ត្នបដិវត្តឲ្យខ្ពស់ ដោយទំនាស់កាន់តែស្រួចណាស់ កំហឹងវណ្ណៈរបស់ ខ្មាំងទាំងខាងលិច ទាំងខាងកើត ចំពោះបដិវត្តកម្ពុជា កាន់តែខ្លាំងណាស់។ [...] សន្តិសុខ ស្នើតាមដានសភាពការណ៍ខ្មាំងថែម"]។ ឯកសារ D4.1.1154 កំណត់ហេតុស្តាប់ ចម្លើយ ឯក ហេន ហៅ ជា KH ERN 00172064-65 ["លោក នួន ជា ធ្លាប់ដឹកនាំការប្រជុំរៀនសូត្រនៅបូរីកីឡាដែរ នៅឆ្នាំ ១៩៧៨ ដែលមានអ្នកចូលរួមប្រហែល ៥០០ នាក់ មានបុគ្គលិកកម្មករ។ ខ្លឹមសារប្រជុំរៀនសូត្រនិយាយពី [...] ការពារទឹកដីកុំឲ្យយួនឈ្លានពាន លើកបញ្ហាពួកភ្ញូមិភាគខត្តរក្បត់ កុំឲ្យកម្មករចូលរួមក្បត់ [...] គាត់ប្រាប់ពីការបោស សម្អាតអ្នកជាប់ខ្សែ កុយ ធួន"]។ ឯកសារ D4.1.817 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ផាន KH ERN 00368609-10 ["សៈ នៅពេលប្រជុំថ្នាក់តំបន់ នៅភ្នំខ្លែង តើគេបាននិយាយអំពីបញ្ហាអ្វីខ្លះ ? ឆ៖ ការប្រជុំថ្នាក់តំបន់ ជាការប្រជុំសរុបរួមប្រចាំឆ្នាំ ដោយមានការចូលរួមពី លេខា អនុ និងសមាជិកឃុំទាំងអស់។ [...] គេបានប្រាប់ឲ្យតាមដានពួកបង្កប់ស៊ីរូងផ្ទៃក្នុង។ បើឃើញបញ្ហានេះកើតឡើង យើងត្រូវរាយការណ៍ទៅថ្នាក់លើ។ ខ្មាំងស៊ីរូងផ្ទៃក្នុងមានដូចជា ការធ្វើឲ្យបាកនង្គ័ល បាក់ចប បាក់ដងរែក អ្នកដែលធ្វើពុតជាឈឺជាដើម។ ថ្នាក់លើបានបញ្ជាក់ទៀតថា អ្នកដែលធ្វើសកម្មភាពទាំងប៉ុន្មានខាងលើនេះ គឺជាខ្មាំងស៊ីរូងផ្ទៃក្នុង ដែលជាហេតុធ្វើឲ្យរាំងស្ទះដល់ចលនាបដិវត្តរបស់យើង។ ការប្រជុំថ្នាក់តំបន់ ជាការប្រជុំសរុបរួមប្រចាំឆ្នាំ ដោយមានការចូលរួមពី លេខា អនុ និងសមាជិកឃុំទាំងអស់។ [...] គេបានប្រាប់ឲ្យតាមដានពួកបង្កប់ស៊ីរូងផ្ទៃក្នុង។ បើឃើញបញ្ហានេះ កើតឡើង យើងត្រូវរាយការណ៍ទៅថ្នាក់លើ។ ខ្មាំងស៊ីរូងផ្ទៃក្នុងមានដូចជា ការធ្វើឲ្យបាកនង្គ័ល បាក់ចប បាក់ដងរែក អ្នកដែលធ្វើពុតជាឈឺជាដើម។ ថ្នាក់លើបានបញ្ជាក់ទៀតថា អ្នកដែលធ្វើសកម្មភាពទាំងប៉ុន្មានខាងលើនេះ គឺជាខ្មាំងស៊ីរូងផ្ទៃក្នុង ដែលជាហេតុធ្វើឲ្យរាំងស្ទះដល់ចលនាបដិវត្តរបស់យើង"]។

[1076] សូមមើល ឧទាហរណ៍ ឯកសារ D4.1.872 ទង់បដិវត្ត ចេញផ្សាយខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ KH ERN 00063242 ["នយោបាយបរទេសក្តីសុទ្ធតែមានធាតុពិត ប្រយុទ្ធវាយសំរុកខ្មាំងជាចក្រពត្តិប្រយុទ្ធវាយសំរុកខ្មាំង ជាវណ្ណៈសក្តិភូមិ ម្ចាស់ដី នាយទុន។ ដូច្នេះ បើកាលណា យើងអនុវត្តបានល្អម៉ត់ចត់ត្រឹមត្រូវ ខ្មាំងជាចក្រពត្តិក្តី ជាវណ្ណៈប្រឆាំងបដិវត្តក្តីវាមិនអាចឆ្លៀតឱកាសវាយបដិវត្តយើងវិញបានទេ"]។ ឯកសារ D1.3.24.2 ទង់បដិវត្ត ចេញផ្សាយខែ កក្កដា ឆ្នាំ ១៩៧៦ KH ERN 00062910 ["យើងឈរលើបដិវត្តសង្គមនិយម។ បន្តការតស៊ូវណ្ណៈនៅក្នុងសង្គមជាតិ នៅក្នុង ជួរបដិវត្ត នៅក្នុងបក្ស នៅក្នុងសហករណ៍ ក្នុងសហជីព ក្នុងកងទ័ពបដិវត្ត ទាល់តែកម្លាំងបដិវត្តសង្គមនិយមវាកំទេច វាកំចាយកម្លាំងប្រឆាំងអស់ ទើបការពារប្រទេសបាន"]។ ឯកសារ D4.1.888 ទង់បដិវត្ត ចេញផ្សាយខែ ធ្នូ ឆ្នាំ ១៩៧៦ - ខែ មករា ឆ្នាំ ១៩៧៧ KH ERN 00063005 ["ខ្សែក្បត់ដែលយើងកំទេចបានជាបន្តបន្ទាប់ ជាខ្សែចាត់តាំងក្បត់ ជាខ្សែសង្វាក់ តាំងពីក្នុងរយៈកាលបដិវត្តប្រជាជាតិ ប្រជាធិបតេយ្យម៉្លេះ។ តែក្នុងរយៈកាលនោះ វានៅជាមួយយើងបាន។ ដល់បដិវត្តសង្គមនិយម វាត្រូវបែងចែក។ ឆ្នាំ ១៩៧៦ ជាឆ្នាំប្រយុទ្ធវណ្ណៈតឹងតែង ក្នុងបដិវត្តយើងក្នុងបក្សយើង។ មេរោគចេញច្រើន។ ខ្សែក្បត់ទាងអស់វាលេចេញ។ [...]សរុបសេចក្តីទៅ ឆ្នាំនេះ យើងធ្វើបដិវត្តសង្គមនិយមជ្រាលជ្រៅមួយកំរិតសំខាន់។ ចេញជាបច្ច័យល្អ ដល់ការកំចាត់ពួកក្បត់លួចបង្កប់នៅក្នុងបក្ស ក្នុងកងទ័ព ក្នុងប្រជាជន"]។ ឯកសារ D4.1.45 យុវជន និងយុវនារីបដិវត្ត ចេញផ្សាយ ខែ មករា-កុម្ភៈ ឆ្នាំ ១៩៧៨ KH ERN 00063486 ["រាល់សកម្មភាពឈ្លានពាន និងសកម្មភាពចារកម្ម ស៊ីរូងផ្ទៃក្នុង ប៉ុនប៉ងធ្វើរដ្ឋប្រហារ របស់ចក្រពត្តអាមេរិក និងបរិវារ មកលើកម្ពុជាប្រជាធិបតេយ្យយើង"]។ ឯកសារ D4.1.867 ទង់បដិវត្ត ចេញផ្សាយខែ មីនា ឆ្នាំ ១៩៧៨ KH ERN 00064457 ["មជ្ឈិមក៏រៀនសូត្រពីការប្រយុទ្ធឆ្នាំ ៧៧ នេះ។ បក្សយើងធ្វើម្ចាស់ការវាយខ្មាំងក្នុងមុន ឯខ្មាំងខាងក្រៅក៏យើងវាយ តែខ្មាំងខាងក្នុង យើងកំទេចអស់ជាមូលដ្ឋានស្រេចទៅហើយ ដល់ខ្មាំងខាងក្រៅវាយមក អាខ្មាំងខាងក្នុងវាងើបក្បាលមិនរួច វាគ្មានកម្លាំងទេ"]។ ឯកសារ D4.1.893 ទង់បដិវត្ត យុវជន យុវនារី ចេញផ្សាយខែ តុលា ឆ្នាំ ១៩៧៨ KH ERN 00376478 ["យើងត្រូវឃើញសភាព លំបាកខាងខ្មាំងនេះជាប់ជាប្រចាំ មិនមែនដើម្បីខ្លាចខ្មាំង ឬវាយតម្លៃខ្មាំងខ្ពស់ហួសហេតុនោះទេ តែគឺដើម្បីយើងប្រុងប្រយ័ត្នបដិវត្តខ្ពស់ជាប់ជានិច្ច ត្រៀមវាយកំទេច នូវការវាយលុកឈ្លានពានរបស់វា ឱ្យបានម្ចាស់ការជាមុនស្រេចគ្រប់ពេលវេលា"] KH ERN 00376479 ["ដូច្នេះ មិត្តយុវជន យុវនារីបដិវត្ត យើងបានរួមប្រយុទ្ធវាយកំទេចខ្មាំង នៅសមរភូមិមុខក៏ខ្លាំងក្លា រួមប្រយុទ្ធបោសសំអាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងក៏បានស្អាត"]។

[1077] សូមមើល ឧទាហរណ៍ ឯកសារ D1.3.34.60 ទូរលេខ ០០ ពីលេខាកងពល ១៦៤ មាស មុត ជូន ម-៨៧០ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 00001325 ["យើងខ្ញុំដែលមានភារកិច្ចការពារមុខសញ្ញាសមុទ្រសូម [...] ប្តេជ្ញាកសាងកម្លាំងជាឧបករណ៍ការពារបក្ស ការពាររដ្ឋអំណាច កម្មករ កសិករ សមូហភាព និងការពារមាតុភូមិកម្ពុជា សង្គមនិយមដាច់ខាត។ ដោយបោសសម្អាតគ្មានស្នាក់ស្នើរសមាសបង្កប់របស់ខ្មាំងជាយួន និងខ្មាំងដទៃទៀត"]។ ឯកសារ D54/112.3 របាយការណ៍ពីលេខាកងពល មាស មុត ១៦៤ ថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៧៨ KH ERN 00017026 ["សរុបយួនដែលចាប់បាន និងបាញ់ងាប់ ចាប់ពីថ្ងៃទី ២៧-៣-១៩៧៨ មកដល់ថ្ងៃ ៣០-៣-១៩៧៨ មានចំនួន ១២០ ក្បាល"]។ ឯកសារ D4.1.578 ទូរលេខ ៥៤ ពី សារុន គោរពជូន នួន ជា ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៧៨ KH ERN 00017027 [របាយការណ៍ទាក់ទងការរកគិញយួន]។ ឯកសារ D1.3.14.3 ទូរលេខ ៦០ ពីលេខាភូមិភាគឧត្តរ សែ ជូនគណៈ ៨៧០ ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ១៩៧៧ KH ERN 00069447-48 ["អំពីសភាពការណ៍ខ្មាំងខាងក្នុង៖

319. វិធីសំខាន់មួយដែល ប.ក.ក ប្រើដើម្បីកម្ទេច "ជនក្បត់" និង "ខ្មាំង" គឺតាមរយៈការបោសសម្អាតទ្រង់ទ្រាយធំ ដែលសម្របសម្រួលដោយមជ្ឈិម[1078]។ សុន សេន និងគណៈសេនាធិការ ដែលរួម

---

នៅតាមមូលដ្ឋាន នៅតាមមន្ទីរ ក្រសួង និងយោធាយើងបានរកឃើញខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងជាបន្តបន្ទាប់ ទាំងការតាមដានសកម្មភាពក្បត់ប្រឆាំងបដិវត្ត ទាំងតាមចម្លើយ។ ឯពួកខ្មាំងជារដ្ឋការនឹងប៉ូលិស ទាហាន ចាស់យើងរកឃើញជាបន្តបន្ទាប់។ ចំពោះខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង បើប្រៀបធៀបពីមុន ឥឡូវនេះ យើងកាន់ថមថយចុះបណ្ដើរៗហើយមាននៅសល់ដែរ ដឹងវាបន្តិចបន្តួច"]។ ឯកសារ D1.3.34.63 ទូរលេខ ៣១៣ ពីលេខាភូមិភាគឧត្តរ សែ ជូនគណៈ ៨៧០ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧៨ KH ERN 00019202 ["សភាពការណ៍ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង៖ នៅរដូវប្រាំងនេះ ខ្មាំងដែលនៅសេសសល់ វាងើបក្បាលឡើងវិញធ្វើសកម្មភាពប្រឆាំងនឹងយើង នៅតាមការដ្ឋាន ពួកខ្មាំងដែលនៅសេសសល់ទាំងនេះ វាទាក់ទងជាមួយពួកប៉ូលិស ទាហាន និងពួករដ្ឋការ ពួកទាំងនេះ វាបន្លំធ្វើប្រជាជនថ្មី ក្រោយពីវាធ្វើសកម្មភាពប្រឆាំងនឹងយើង ទើបយើងស្គាល់មុខវាច្បាស់ ទន្ទឹមនឹងនេះ យើងក៏បានបោសសម្អាតវាជាខ្សែសង្វាក់។ មកដល់ថ្ងៃនេះ សភាពការណ៍ខ្មាំងបង្កប់ត្រូវស្ងប់ស្ងាត់ ពួកទាហាន ប៉ូលិស និងរដ្ឋការមួយចំនួនត្រូវវត់បាត់ ក្រោយពីយើងបោសសម្អាតចំនួនប្រមាណជាង ២០ ក្បាល យើងក៏មានវិធានការបន្តរកចាប់ពួកនេះតទៅទៀត"]។ ឯកសារ D4.1.612 ទូរលេខ ៣២៤ ពីលេខាភូមិភាគឧត្តរ សែ ជូនគណៈ ៨៧០ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៩៧៨ KH ERN 00296229 ["សភាពការណ៍ខ្មាំងខាងក្នុង៖ [...] ជាសភាពការណ៍ធម្មតា។ យើងកំពុងបន្តបោសសម្អាតពួកអានៅសេសសល់ជាបន្តបន្ទាប់ទៀត ដែលវាប្រឆាំងបដិវត្តយើងទាំងចំហកំ្ដ ទាំងដោយសម្ងាត់ក្ដី"]។

1078 សូមមើល ឧទាហរណ៍ ឯកសារ D98/1.2.1 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ ម៉ោង ១៣.៥៣.២៣-១៤.០៥.០០ ["ចម្លើយសារភាពរបស់ កុយ ធួន [...] អចិន្ត្រៃយ៍ទាំងមូល [...] ចាប់ចងខាងឧត្តរយ៉ាងធ្ងន់ដៃ ធ្ងន់មែនទែនៗ [...] ដូច្នេះ ចាប់អ្នកណាមុន ចាប់អ្នកណាក្រោយគឺគេរៀបចំ។ បានចម្លើយគេដើម្បីចាប់អ្នកទៅទៀត។ អាហ្នឹងវាសុទ្ធតែការរៀបចំរបស់អចិន្ត្រៃយ៍ហើយ"]។ ឯកសារ D234/2.1.40 កំណត់ហេតុនៃកិច្ចពិភាក្សាដេញដោល នួន ជា ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ KH ERN 00148677 ["គណៈកម្មាធិការយោធាមានភារកិច្ចការពារជាតិ និង បោសសម្អាតផ្ទៃក្នុង"]។ ឯកសារ D4.1.828 កំណត់ហេតុស្ដាប់ចម្លើយ សួន កានិល KH ERN 00373509 [គេដាក់សុទ្ធតែកម្លាំងនិរតីមកគ្រប់គ្រងតាំងពីគណៈតំបន់រហូតដល់គណៈសហករណ៍ ប្រហែល ៩០ ភាគរយ ចូលមក គ្រប់គ្រងនៅភូមិភាគកណ្ដាល"]។ ឯកសារ D4.1.817កំណត់ហេតុស្ដាប់ចម្លើយ ប៊ុន ធៀន KH ERN 00368606 [នៅភូមិភាគនិរតី៖ "ជាទូទៅ គេចាប់បញ្ជូនថ្នាក់ដឹកនាំ កម្មាភិបាលជាន់ខ្ពស់របស់របបខ្មែរក្រហម និងកងទ័ពទាំងយុវជន និងយុវនារី ដែលគេគិតថា ជាប់និន្នាការក្បត់ យកទៅដាក់នៅទីនោះទាំងអស់។ ជាប់និន្នាការក្បត់ មានន័យថា នៅពេលដែលគេចាប់មេហើយ កូនកង ឬអ្នកនៅក្រោមបង្គាប់ទាំងអស់ត្រូវគេបញ្ជូនមកដាក់នៅទីនោះដែរ"]។ ឯកសារ D114/140 កំណត់ហេតុស្ដាប់ចម្លើយ ជា ផុន ឆ. ៦៣ [ក្នុងកងវរៈសេនាតូ ៣០៣៖ "ពេលនោះ មានទាហានខាងភូមិភាគមកប្ដូរ។ គេប្រកាសជូនដំណឹងថា មេខាងលើជាជនក្បត់ ហើយគេចាប់បញ្ជូនមេបញ្ជាការធំៗទាំងបីរូប [...] បញ្ជូនទៅគុកកោះខ្សង។ ក្រោយមកទៀត គេប្រមូលកម្លាំងឡើងដីគោកទាំងអស់ ហើយរបស់របរទាំងអស់ខាងភូមិភាគជាអ្នកគ្រប់គ្រងវិញ។ [...] ក្រោយមកមេបញ្ជាការឈ្មោះ ស៊ី ប្រកាសនៅសាលាលង្វែកថា កងកម្លាំងតំបន់ ១១ សុទ្ធតែក្បត់។ គេប្រកាសទៀតថា មេទាហានក្បត់អស់ហើយ។ គេប្រកាសថា ថ្នាក់ក្រោមៗ បើមេ

មាន **មាស មុត** និងមេបញ្ជាការកងពលមជ្ឈិមផ្សេងទៀត បានពិភាក្សា និងគាំទ្រយ៉ាងពេញទំហឹង ដល់គោលនយោបាយរបស់មជ្ឈិមក្នុងការកម្ទេចខ្មាំងផ្ទៃក្នុង[1079]។ ពួកគេអនុវត្តគោលនយោបាយ

---

ក្បត់ កូនថ្នាក់ក្រោមៗក៏ជាប់និន្នាការក្បត់ដែរ។ ក្រោយមក គេចែកជាបីក្រុមក្នុងអង្គភាពហ្នឹង"]។ ឯកសារ D55/5 កំណត់ហេតុស្តាប់ចម្លើយ នោម សែ ឆ.២០ [នៅតំបន់ ១០១ ភូមិភាគពាយ័ព្យ៖ "ឆ្នាំ ១៩៧៧ ខាងមូលដ្ឋានមាន សមាសភាពក្បត់ គឺច្របូកច្របល់ណាស់ គេក៏ចាប់ផ្តើមរៀបចំនៅខាងមូលដ្ឋានឡើងវិញ។ សមាសភាពដែលគេចោទ ថាក្បត់ គេហៅទៅភ្នំពេញ តែមិនឃើញមិនវិញទេ"]។ ឯកសារ D4.1.1154 កំណត់ហេតុស្តាប់ ចម្លើយ ឯក ហេន ហៅ ជា KH ERN 00172064 ["មុនដំបូងគេចាប់មេៗ បន្ទាប់មកចាប់អនុ និងសមាជិកណាដែលមានការពាក់ព័ន្ធ នឹងខ្សែឧត្តរ និងបូព៌ាដែលគេចោទថា ក្បត់។ [...] ក្រោយមក គេយកពួកនិរតីដែលជាខ្សែរបស់ តាម៉ុក មកគ្រប់គ្រង កម្មកររោងចក្រ"]។ ឯកសារ D114/36.1.25 ជីវប្រវត្តិ កែ ពក KH ERN 00095552 ["ក្នុងខែ ២ ឆ្នាំ ១៩៧៧ ឡាន សន្តិសុខពីភ្នំពេញមកចាប់ប្រធានក្រសួង មានប្រធានក្រសួងកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម សាធារណៈការ។ [...] ក្នុងឆ្នាំ ៧៧ ដែរ ឡានសន្តិសុខពីភ្នំពេញមកចាប់គណៈតំបន់ ៤១ ចំនួន ៥-៦ នាក់ ចាប់គណៈតំបន់ ៤២ ចំនួន ៥-៦ នាក់ ចាប់គណៈតំបន់ ៤៣ ចំនួន ៥-៦ នាក់។ ចាប់គណៈតំបន់អស់ហើយ ក៏ចាប់មេៗក្រសួងរបស់តំបន់ទៀត ព្រោះតំបន់ មួយៗសុទ្ធតែមានក្រសួងរបស់ខ្លួន។ បន្ទាប់មកទៀត ឡានសន្តិសុខភ្នំពេញមកចាប់គណៈបញ្ជាការយោធា របស់ភូមិភាគទៀត។ សរុបតំបន់ និងក្រសួងដែលត្រូវចាប់មានចំនួន ៥០-៦០ នាក់"]។

1079 សូមមើល ឧទាហរណ៍ ឯកសារ D1.3.27.10 កំណត់ហេតុការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការ ប្រជុំលេខា និងអនុលេខាកងពល លេខា និងអនុលេខាវរសេនាធំ ចុះថ្ងៃទី០២ ខែ សីហា ឆ្នាំ ១៩៧៦ KH ERN 00052360 [បង ៨៩ (សុន សេន)៖ "ក្នុងការអនុវត្តភារកិច្ចការពារប្រទេស ត្រូវគិតគូរទប់ទល់ខ្មាំង ទាំងខាងក្រៅ ទាំងខាងក្នុង។ តែពិសេស ត្រូវយកចិត្តទុកដាក់ទប់ទល់ខ្មាំងស៊ីរូងផ្ទៃក្នុងជាសំខាន់។ បានសេចក្តីថា ត្រូវយកចិត្ត ទុកដាក់សំរិតសំរាំងសមាសភាពមិនល្អ ឲ្យអស់ពីក្នុងបក្ស អង្គការស្នូល និងយុទ្ធជន យុទ្ធនារី នៃកងទ័ពបដិវត្តយើង"] ។ ឯកសារ D1.3.27.13 កំណត់ហេតុការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា និងអនុ លេខកងពលនិងវរៈសេនាធំឯករាជ្យ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៧៦ KH ERN 000552381 [បង ៨៩ (សុន សេន) ៖ "កងពលពិនិត្យតាមដានសមាសភាពមិនល្អ។ ចាត់តាំងគ្រប់គ្រងឲ្យនៅដោយឡែក"] KH ERN 00052382 [បង ៨៩ (សុន សេន)៖ "ត្រូវសំរិតសំរាំងសមាសភាពមិនល្អតទៅទៀត។ ត្រូវដាច់ខាត តែកុំឆ្វេង តើគេគាំទ្រ ឬមិនគាំទ្រ មិនគាំទ្រដោយមិនយល់ ឬមិនគាំទ្រដោយប្រឆាំងចូលដៃជាមួយខ្មាំង"]។ ឯកសារ D1.3.27.20 កំណត់ហេតុអង្គប្រជុំ យោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខា និងវរសេនាធំឯករាជ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH ERN 00052407 [ក្រោយការពន្យល់ថា ចក្រី, យ៉ា, ឈូក និង កែវ មាស ជាជនក្បត់ ហើយ ត្រូវបានកម្ទេច បង ៨៩ (សុន សេន) បាននិយាយថា៖ "បញ្ហាសំខាន់ នៅត្រង់កងទ័ពយើងស្អាត បរិសុទ្ធ [...] ន័យ អនុវត្តជាក់ស្តែងខាងប្រុងប្រយ័ត្នបដិវត្ត គឺក្តាប់អង្គភាពយើងឲ្យជាប់ កុំឲ្យខ្មាំងស៊ីរូងផ្ទៃក្នុងបាន ធ្វើម៉េចឲ្យកងទ័ពយើង ស្អាត"] KH ERN 00052408 ["ត្រូវអប់រំបងប្អូនឲ្យយល់ពីសភាពទំនាស់ ពីខ្មាំងស៊ីរូង ពីឧបាយកលខ្មាំង ឲ្យជ្រួត ជ្រាបដល់ក្រោម។ [...] ត្រូវដាច់ខាតសំរិតសំរាំងសមាសភាពមិនល្អ តែកុំឆ្វេង កុំស្តាំ។"] KH ERN 00052408 [សមមិត្ត ខឹម៖ "សុំឯកភាពតាមបទឧទ្ទេសនាមរបស់អង្គការ ពីសភាពការណ៍ខ្មាំង ទាំងពីក្នុង ទាំងពីក្រៅ [...] ពិនិត្យ

នេះ ដោយធ្វើការបោសសម្អាតទ្រង់ទ្រាយធំ ក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជា រួមបញ្ចូលទាំងកងពល ១៦៤ កងពល ១១៧ និងតំបន់ ៥០៥[1080]។ អ្នកដែលត្រូវគេសង្ស័យថាមិនស្មោះត្រង់ ឬមានប្រវត្តិរូបមិនល្អ ត្រូវគេចាត់ទុកជា "សមាសភាពមិនល្អ" និងជាទូទៅ ត្រូវបញ្ជូនទៅ "កសាង" ឬ "លត់ដំ" នៅក្នុងគុក ឬនៅតាមការដ្ឋានការងារ ចំណែកឯអ្នកដែលត្រូវគេចាត់ទុកជា "ខ្មាំង" ឬ "ជនក្បត់" ត្រូវ "កម្ទេច" នៅទីបំផុត[1081]។

កម្លាំង អាចធានាពី ៩០ ទៅ ៩៥ ភាគរយ ដែលស្មោះត្រង់ជាមួយបក្ស។ តែជំនឿជ្រះស្រឡះថា កងទ័ពនេះស្អាតហើយ ដូចនៅមិនទាន់ស្អាតទេ ត្រូវតែតាមដានសំរិតសំរាំងតទៅទៀត"] KH ERN 00052411 [សមមិត្ត ម៉េត (ស៊ូ ម៉េត)៖ "ត្រូវប៉ានសំរិតសំរាំងដាច់ខាត។"] KH ERN 00052411 ["សមមិត្ត មុត [មាស មុត]៖ សុំចាប់អារម្មណ៍ពីសកម្មភាពពួកក្បត់ក្នុងបក្ស ជាជ័យជំនះមួយធំរបស់បក្សយើង។ មេរៀននេះ បានពង្រឹងគោលជំហរប្រុងប្រយ័ត្នបដិវត្តមួយកំរិតថែមទៀត។ គោលជំហរវិភាគ ចំណារខ្មាំង ជាចក្រពត្តិអាមេរិក និងពួកលើវើនិយមរបស់បក្សដែលមានផែនការវាយបដិវត្តយើង នេះជាជំហរត្រឹមត្រូវ បានបំពាក់ឲ្យយើងខ្ញុំ។ បញ្ហាក្ដាប់អង្គការ កម្មាភិបាល យុទ្ធជននៅមិនទាន់រឹងទេ។ សមាសភាពមិនល្អ ឬខ្មាំង នៅតែពួនបន្តិ បង្កប់ក្នុងជួរបានទៀត។ បញ្ហាក្ដាប់សតិអារម្មណ៍ ជាប្រចាំថ្ងៃ របស់អង្គការស្នូល ជាកត្តាសំខាន់បំផុត។ ត្រូវរៀបចំវិធានការ ម្ចាស់ការជាមុន សុំយល់ព្រមឯកភាពជាមួយបក្សទាំងស្រុង។ ធ្វើម៉េច កុំឲ្យស្ថានការណ៍ជ្រុលហួសសភាពការណ៍ វាពង្រឹងពង្រីកខ្លួនបានឲ្យសោះ"]។ ឯកសារ D1.3.27.26 កំណត់ហេតុអង្គប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា អនុលេខា កងពល និងវរសេនាធំឯករាជ្យ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧ KH ERN 00052305 ["សមមិត្ត ម៉ុត៖ [...] កម្មាភិបាល និងយុទ្ធជនការពារឃ្លាំងមួយចំនួន ធ្លាប់នៅជាមួយពួកក្បត់យូរ ជាកងការពារវា។ អង្គភាពឃ្លាំង បានសំរិតសំរាំងមួយអនុសេនាតូច តែនៅពុំទាន់អស់ និងធានានៅឡើយ"] KH ERN 00052311 [បង ៨៩ (សុន សេន)៖ "បញ្ហាឃ្លាំង ត្រូវប្រុងប្រយ័ត្ន ពួកពាក់ព័ន្ធសមាសភាពក្បត់ ត្រូវដកចេញ។ សំរិតសំរាំងផ្ទៃក្នុងឲ្យស្អាត"]។

1080 សូមមើល VIII.A. ការបោសសម្អាតក្នុងកងពល ១៦៤។ VIII.I. ការបោសសម្អាតកងពល ១១៧ និងតំបន់ ៥០៥។

1081 សូមមើល VIII.A. ការបោសសម្អាតក្នុងកងពល ១៦៤។ VIII.E. ការដ្ឋានស្ទឹងហាវ – ៣. ឧក្រិដ្ឋកម្មផ្សេងៗ– ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ។ VIII.F. ការដ្ឋានតំបន់រាម – ៣. ឧក្រិដ្ឋកម្មផ្សេងៗ– ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ។ VIII.I. ការបោសសម្អាតកងពល ១១៧ និងតំបន់ ៥០៥។

## គោលនយោបាយកសិកម្ម សេដ្ឋកិច្ច និងសង្គមកិច្ច

### ការបង្កើតសហករណ៍ និងការដ្ឋានការងារ

320. ចាប់ពីឆ្នាំ ១៩៧២ មក ប.ក.ក បានបង្កើតសហករណ៍ និងការដ្ឋានការងារ នៅតាមតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន[1082] ហើយលុបបំបាត់រូបិយវត្ថុ និងផ្សារឯកជន[1083]។ នៅឆ្នាំ ១៩៧៣ ប.ក.ក បានអនុម័តគោលនយោបាយជម្លៀសប្រជាជនស៊ីវិលដោយបង្ខំឲ្យចេញពីទីក្រុង ដើម្បីទៅ

---

1082 ឯកសារ D54/74.1.12 ខួបឆ្នាំទី ៣ នៃការចាត់តាំងសហករណ៍កសិករ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៦ KH ERN 00442209 ["ឆ្នាំ ៧២-៧៣ បក្សលើកវិធានការរៀបចំប្រជាជនខាងនយោបាយ សតិអារម្មណ៍ វាយអនុភាពសេដ្ឋកិច្ចម្ចាស់ដី នាយទុន ផ្តាច់ឯកជនលក់ដូរ ក្តាប់ពាណិជ្ជកម្ម វាយការទាក់ទងផលិតកម្មចាស់ រៀបចំការទាក់ទង ផលិតកម្មថ្មី ចាត់តាំងសហករណ៍។ ក្នុងនេះវិធានការសំខាន់ៗបំផុត គឺចាត់តាំងសហករណ៍"]។ ឯកសារ D4.1.888 ទង់បដិវត្ត ចេញផ្សាយខែ ធ្នូ ឆ្នាំ ១៩៧៦ - ខែ មករា ឆ្នាំ ១៩៧៧ KH ERN 00063040-41 ["នេះជាមាគ៌ាយុទ្ធសាស្ត្រមួយ មានសារៈសំខាន់ណាស់។ ក្តាប់ប្រជាជន ដណ្តើមប្រជាជន។ [...] គឺប្រជាជននៅខាងណា ខាងនោះឈ្នះហើយ [...] ដូច្នេះ ក្នុងកិច្ចការពារប្រទេស បច្ចុប្បន្ន ក៏ដូចថ្ងៃក្រោយ គឺត្រូវក្តាប់ប្រជាជនឲ្យបាន។ ដូច្នេះ បានជាបក្សយកចិត្តទុកដាក់ក្តាប់សហករណ៍"]។

1083 ឯកសារ D4.1.886 ទង់បដិវត្ត ចេញផ្សាយខែ កញ្ញា-តុលា ឆ្នាំ ១៩៧៦ KH ERN 00063069-70 ["ឆ្នាំ ១៩៧២៖ បក្សពិនិត្យឃើញសភាពការណ៍ [...] ក៏សំរេចបិទផ្សារ"], KH ERN 00063075 ["យើងគ្មានប្រើលុយ។ លុយនេះជាឧបករណ៍មួយ ពិសពុលបំផុត។ វាទាញយើងឲ្យមករកឯកជនវិញ រាល់ពេលវេលា។ បើមានលុយ យើងចេះតែចង់ទិញនេះ ទិញនោះ។ ឥឡូវនេះ គ្មាននរណានឹកនាចង់ចាយលុយទេ"]។ ឯកសារ D4.1.882 ទង់បដិវត្ត ចេញផ្សាយខែ កុម្ភៈ-មីនា ឆ្នាំ ១៩៧៦ KH ERN 00063195 ["គឺយើងចាប់ផ្តើមធ្វើបដិវត្តសង្គមនិយមតាំងពីឆ្នាំ ១៩៧២ ហើយពិសេសពីឆ្នាំ ១៩៧៣ ដោយរំលាយពាណិជ្ជកម្មឯកជន ហើយរដ្ឋធ្វើពាណិជ្ជកម្មដោយខ្លួនឯង រំលាយផ្សារ"]។ ឯកសារ D64.1.27 FBIS របាយការណ៍សារព័ត៌មានកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៧៧ KH ERN 00679848 ["ប្រជាជនត្រូវបានរៀបចំជាសហករណ៍ដែលទទួលខុសត្រូវលើការបែងចែកអាហារ សម្លៀកបំពាក់ និងផ្គត់ផ្គង់ថ្នាំពេទ្យ។ មិនមានការចាយលុយទេ"]។ ឯកសារ D4.1.861 ទង់បដិវត្ត ចេញផ្សាយខែ សីហា ឆ្នាំ ១៩៧៥ KH ERN 00063316-19 [ការវាយតម្លៃស្ថានភាពឈានទៅរកការលុបចោលរូបិយប័ណ្ណ និងផ្សារផងដែរ]។ ឯកសារ D4.1.444 កំណត់ហេតុស្តាប់ចម្លើយ សៅ សារុណ KH ERN 00251437 [នៅខែ ឧសភា ១៩៧៥ ប្រជុំនៅសាលាមិត្តភាពកម្ពុជាសូវៀតណា នួន ជា និង ប៉ុលពត ជាអ្នកឧទ្ទេសនាម៖ "អ្នកទាំងពីរនេះ និយាយអំពីនយោបាយ រៀបចំសហករណ៍ ហាមមិនឲ្យចាយលុយ បិទទីផ្សារ និងវត្តអារាម"]។ ឯកសារ D1.3.17.5 ណាយ៉ាន់ ចាន់ដា សត្រូវបងប្អូនឯង៖ សង្គ្រាមបន្ទាប់ពីសង្គ្រាម KH ERN 00191385 ["នៅដើមរដូវក្តៅឆ្នាំ ១៩៧៣ កម្មសិទ្ធិដីធ្លីឯកជន និងការប្រើប្រាស់ក្រដាសប្រាក់ ត្រូវបានលុបបំបាត់ចោល ដើម្បីពង្រឹងការគ្រប់គ្រងដែនដី និងសេដ្ឋកិច្ចរបស់បក្ស"]។

ធ្វើការនៅតាមសហករណ៍ និងការដ្ឋាននៅជនបទ[1084]។ គោលនយោបាយសហករណ៍របស់បក្ស មានគោលដៅ (១) វាយប្រហារកម្លាំងសេដ្ឋកិច្ចរបស់ "ម្ចាស់ដី និងនាយទុន"[1085] (២) បំបែក ត្រួតពិនិត្យ គ្រប់គ្រង និងសម្លាប់ប្រជាជនដែលប្រឆាំងនឹង ប.ក.ក និងបដិវត្តន៍[1086] និង (៣) បង្កើនផលិតកម្មកសិកម្មឲ្យបានឆាប់រហ័ស[1087]។

1084 ឯកសារ D54/74.1.14 David Chandler បងទី១ EN ERN 00393010 ["ដើមឆ្នាំ ១៩៧៣ កងទ័ពកុម្មុយនីស្តកម្ពុជា វាយប្រហារកងរដ្ឋាភិបាលទូទាំងប្រទេស ដើម្បីពង្រីកការគ្រប់គ្រងទឹកដី និងកំណត់កម្មវិធីសង្គមរបស់ពួកគេ។ [...] វិធានការដែលត្រូវបានអនុម័តនៅទីនោះរួមបញ្ចូលទាំងការកសិដ្ឋានជាសករណ៍ ចលនាបង្ខំប្រជាជន"]។ ឯកសារ D98/1.2.39 David Chandler ប្រតិចារឹកថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ២០១២ ម៉ោង ១១.១៨.២០-១១.២៣.៤០ បញ្ជាក់ថា ឯកសារ D54/74.1.14 David Chandlerបងទី១ EN ERN 00393014 [ពេលកងទ័ពបក្សកុម្មុយនីស្តកម្ពុជាដកថយពីខេត្តកំពង់ចាម៖ "ពួកគេបានប្រមូលប្រជាជនរាប់ពាន់នាក់ទៅជាមួយគេ"]។ D4.1.888 ទង់បដិវត្ត ចេញផ្សាយខែ ធ្នូ ឆ្នាំ ១៩៧៦ - ខែ មករា ឆ្នាំ ១៩៧៧ KH ERN 00063040 [ពិពណ៌នាអំពីករណីផ្លាស់ប្រជាជនស៊ីវិលចេញពីតំបន់ទីក្រុង៖ "វាយខាងបាណាមនៅឆ្នាំ ៧៣។ យកទាំងអស់ក្នុងក្រុងបាណាម។ បញ្ចេញទាំងអាណិកជនវៀតណាម អាណិកជនចិន ទាំងទាហាន ទាំងប៉ូលិស យកទាំងអស់ ពង្រឹងប្រជាជនពីខ្មាំង។ [...] យើងរំដោះឧត្តុង្គក្នុងឆ្នាំ ១៩៧៤។ យើងដកប្រជាជនទាំងអស់។ [...] នេះជាមាគ៌ាយុទ្ធសាស្ត្រមួយ មានសារៈសំខាន់ណាស់ ក្តាប់ប្រជាជន ដណ្តើមប្រជាជន"]។

1085 សូមមើល ឧទាហរណ៍ ឯកសារ D54/74.1.12 ខួបឆ្នាំទី៣ នៃការចាត់តាំងសហករណ៍កសិករ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៦ KH ERN 00442208-10 ["បក្សលើកវិធានការរៀបចំប្រជាជនខាងនយោបាយ សតិអារម្មណ៍ វាយអនុភាពសេដ្ឋកិច្ច ម្ចាស់ដី នាយទុក"] KH ERN 00442211 ["មុនបក្សចាត់តាំងសហករណ៍ទូទាំងប្រទេស យើងអត់ធ្វើម្ចាស់លើសេដ្ឋកិច្ចតំបន់រំដោះយើងបានទេ។ វណ្ណៈសក្តិភូមិ ម្ចាស់ដី នាយទុន វាធ្វើម្ចាស់។ [...] ការចាត់តាំងសហករណ៍ជាការផ្តាច់ម្ចាស់ដី នាយទុន ខាងសេដ្ឋកិច្ច"] KH ERN 00442216 ["ដោយផ្អែកលើសហករណ៍កសិករ បក្សមិនគ្រាន់តែវាយរំលំវណ្ណៈ សក្តិភូមិ ម្ចាស់ដីទេ បក្សវាយ ទាំងវណ្ណៈ នាយទុននៅទីក្រុង និងកសិករមាន រហូតដល់របបឯកជនផ្សេងទៀត ទាំងអស់ក៏ត្រូវវាយឲ្យរលំរលាយ"] KH ERN 00442241 ["គោលជំហររបស់បក្ស ពេលកន្លងមក៏ដូចបច្ចុប្បន្ននឹងទៅអនាគត គឺដាច់ខាតវាយកំទេចកម្មសិទ្ធឯកជនគ្រប់ប្រភេទ"]។ ឯកសារD4.1.886 ទង់បដិវត្ត ចេញផ្សាយខែ កញ្ញា-តុលា ឆ្នាំ ១៩៧៦ KH ERN 00063072 ["ទាល់តែចាត់តាំងសហករណ៍ ទើបក្តាប់សេដ្ឋកិច្ចបាន។ [...] ជាក់ស្តែង សហករណ៍មានធាតុពិតជាសង្គមនិយម ជាបដិវត្តសង្គមនិយម [...] ដល់យើងធ្វើបដិវត្តសង្គមនិយម យើងពង្រឹងពង្រីករបបសហភាព កំចាត់របបកម្មសិទ្ធិឯកជន របបនាយទុនបានទាំងស្រុង"]។ ឯកសារ D4.1.861 ទង់បដិវត្ត ចេញផ្សាយខែ សីហា ឆ្នាំ ១៩៧៥ KH ERN 00063313-20។

1086 សូមមើល ឧទាហរណ៍ ឯកសារ D4.1.195 នួន ជា សេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា ជូនចំពោះបក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៨ KH ERN 00224474 ["ភ្លាមៗបន្ទាប់ពីការរំដោះ យើងបានជម្លៀសប្រជាជនចេញពីទីក្រុង។ ភ្នាក់ងារ សេ.អ៊ី.អា ភ្នាក់ងារ កា.ហ្សេ.បេ និងភ្នាក់ងារវៀតណាម បានចាក

ចេញទៅកាន់ទីជនបទ ហើយពួកវាមិនអាចអនុវត្តផែនការបានឡើយ។ [...] យើងត្រូវតែបន្តកសាង និងការពារបក្សយើង និងអ្នកដឹកនាំយើង និងត្រូវចាប់ពួកអ្នកដែលបានជ្រៀតចូលក្នុងជួរបក្សយើង"]។ ឯកសារ D4.1.37 ឯកសារទី ៦៖ អំពីការក្តាប់ និងអនុវត្តមាគ៌ានយោបាយប្រមូលកម្លាំងរណសិរ្ស ប្រជាជាតិ ប្រជាធិបតេយ្យរបស់បក្ស ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៧៥ KH ERN 00072404 ["ឯពលករថ្មី ដែលចាប់ពីស្អែកទៅ ជាសមូហភាពត្រូវខំពង្រឹងពង្រីកគេ ក្តាប់គេខាងសតិអារម្មណ៍នយោបាយ និងចាត់តាំង"]។ ឯកសារ D4.1.869 ទង់បដិវត្ត ចេញផ្សាយខែ កក្កដា ឆ្នាំ ១៩៧៨ KH ERN 00064487-95 [សូមមើល អត្ថបទដែលមានចំណងជើង៖ យកចិត្តទុកដាក់បោសសំអាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ឲ្យស្អាតដាច់ខាតថែមទៀត"]។ ឯកសារ D114/36.1.5 FBIS សាទរការបង្កើតសហករណ៍កសិករ ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ១៩៧៦ EN 00168018 ["ការផ្លាស់ប្តូរនេះបានបង្កើតសហករណ៍ឡើងនូវទូទាំងប្រទេស [...] បានអនុញ្ញាតឲ្យយើងវាយប្រហារខ្មាំងទាំងស្រុង និងរឹងមាំជាងមុន ដោយយោធាផ្នែកនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌។ និយាយដោយសង្ខេប វាអនុញ្ញាតឲ្យយើងវាយប្រហារសត្រូវម្តងហើយម្តងទៀតយ៉ាងស្វិតស្វាញ គ្រប់ទីកន្លែងលើសមរភូមិទាំងអស់ នៅទូទាំងប្រទេសទាំងនៅជួរមុខ និងជួរក្រោយ"]។ ឯកសារ D64.1.42 FBIS កសិករបានកំណត់ដើម្បីការពារ និងអភិវឌ្ឍប្រទេស ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ EN ERN 00169870 ["ការយល់ដឹងច្បាស់ពីគោលដៅរបស់សហករណ៍កសិករយើង អំពីការទទួលបានឯករាជ្យ អធិបតេយ្យភាព និងការពឹងលើខ្លួនឯង គឺវាខ្ពស់ជាង [...] ឧបសគ្គរាំងដែលបង្កើតដោយសត្រូវគ្រប់រូបភាព ជាពិសេស វៀតណាមវាតទីនិយម និងខ្មាំងវៀតណាមដែលព្យាយាមរារាំង និងរាំងរាល់កិច្ចប្រឹងប្រែងក្នុងការកសាងជាតិរបស់យើង"]។ ឯកសារ D64.1.35 FBIS ដំណោះស្រាយដែលបានសម្រេច ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៨ EN ERN 00168819-20 ["យើងតំណាងសហជីពកម្មករទាំងអស់ សហករណ៍កសិករ និងកងទ័ពបដិវត្ត ៣ ប្រភេទទៀត មកពីគ្រប់ភូមិភាគ តំបន់ និងស្រុកនៅទូទាំងប្រទេស មានបំណងចង់សំដែងការសន្យារបស់យើងយ៉ាងម៉ឹងម៉ាត់ [...] ដើម្បីលុបបំបាត់ចោលទាំងស្រុង នូវភ្នាក់ងារពួកវាតទីនិយម និងវៀតណាមដែលមានចរិតឈ្លានពាន ពីអង្គភាពរបស់យើង និងពីទឹកដីកម្ពុជាជារៀងរហូត។ [...] ដើម្បីលុបបំបាត់ទាំងស្រុងនូវភ្នាក់ងារ សេ.អ៊ី.អា ពីអង្គភាពរបស់យើង និងពីទឹកដីកម្ពុជារៀងរហូត"]។

1087 សូមមើល ឧទាហរណ៍ ឯកសារ D4.1.885 ទង់បដិវត្ត ចេញផ្សាយខែ សីហា ឆ្នាំ ១៩៧៦ KH ERN 00063277 ["យើងឈរលើកសិកម្មជាមូលដ្ឋាន ដើម្បីយកទុនខាងកសិកម្ម ទៅពង្រឹង និងពង្រីកខាងឧស្សាហកម្មទៀត។ [...] យើងអាចប្រែក្លាយកសិកម្មយើងបានឆាប់រហ័ស"]។ ឯកសារ D1.3.27.4 សេចក្តីថ្លែងការណ៍នៃតំណាងកម្មករឧស្សាហកម្ម នៃអង្គប្រជុំសន្និបាតលើកទី ១ ក្នុងកាលសម័យទី ១ របស់សភាតំណាងប្រជាជនកម្ពុជា ថ្ងៃទី ១១-១៣ ខែ មេសា ឆ្នាំ ១៩៧៦ KH ERN 00053618 [៣. ប្តេជ្ញា រួមសាមគ្គីជាមួយកម្មករទាំងអស់ ដើម្បីវាយសំរុកផលិតឧបករណ៍ ម៉ាស៊ីន និងសំភារៈផ្សេងៗ ឲ្យបានខ្លាំងក្លា នឹងខ្ជាប់ខ្ជួនដើម្បីបំរើផលិតកម្មកសិកម្មផង និងបំរើជីវភាពប្រជាជនផង"] គំរោងសេចក្តីសំរេចចិត្តរបស់ អង្គប្រជុំសន្និបាតលើកទី ១ ក្នុងកាលសម័យទី ១ របស់សភាតំណាងប្រជាជនកម្ពុជា ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៧៦ KH ERN 00053636 [៣. ត្រូវពង្រឹងនិងពង្រីកកម្លាំងមហាសាមគ្គី ប្រជាជាតិគ្រប់សមរភូមិបង្កបង្កើនផល លើគ្រប់ផ្នែងទាំងអស់ ពិសេសលើផ្នែកកសិកម្ម សំដៅផលិតស្រូវឲ្យបានច្រើនជាអតិបរមា សម្រាប់ដោះស្រាយ នឹងលើកស្ទួយជីវភាពប្រជាជនយើងឲ្យបានកាន់តែខ្ពស់ និងឆាប់រហ័សថែមទៀត ហើយព្រមជាមួយនោះ ក៏សម្រាប់ជំរុញការកសាងប្រទេសយើងឲ្យបានឆាប់រហ័ស តាមសន្ទុះមហាលោតផ្លោះ មហាអស្ចារ្យ"]។ ឯកសារ D4.1.632 កំណត់ហេតុការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦

321. ក្រោយពី ប.ក.ក គ្រប់គ្រងប្រទេស សហករណ៍ និងការដ្ឋានការងារ ត្រូវបានបង្កើតនៅទូទាំងប្រទេស[1088]។ ជនស៊ីវិល និងកម្មាភិបាលវំសាយ ត្រូវបានបង្ខំឱ្យធ្វើការនៅតាមសហករណ៍ធ្វើស្រែ

---

KH ERN 00143495 [“ពិភាក្សាជាក់ស្ដែងមួយចំនួនដែលទាក់ទងដល់ការវាយសំរុកឱ្យបាន ៣ តោនក្នុង ១ ហិកតា ជាយុទ្ធសាស្ត្រឧបត្ថម្ភខ្លួនឱ្យបាន ១០០ ភាគរយ និងឧបត្ថម្ភអង្គការ ៣០ ភាគរយ”]។ ឯកសារ D4.1.38 ឯកសារបក្សកុម្មុយនីស្តកម្ពុជា គំរោងផែនការ ៤ ឆ្នាំ កសាងសង្គមនិយម គ្រប់ផ្នែករបស់បក្ស ឆ្នាំ ១៩៧៧-១៩៨០ ចុះផ្សាយក្នុងអត្ថបទ David Chandler និងអត្ថបទ ប៉ុល ពត ផែនការអនាគត KH ERN 00075827 [“សំណូមពរ [...] ដើម្បីរកទុន ប្រមូលទុន សន្សំទុន បង្កើនទុន អំពីកសិកម្ម សំដៅពង្រឹង និងពង្រីកកសិកម្ម ឧស្សាហកម្ម និងការពារជាតិយើងឱ្យបានឆាប់រហ័ស”]។ ឯកសារ D4.1.871 ទង់បដិវត្ត ចេញផ្សាយខែ កញ្ញា ឆ្នាំ ១៩៧៨ KH ERN 00064616 [“សរុបមកវិញ យើងចង់កសាងប្រទេសយើងឱ្យបានឆាប់រហ័ស កសាងកសិកម្ម ឱ្យបានឆាប់រហ័ស”]។ ឯកសារ D4.1.579 ទូរលេខ ០៤ ពីលេខាភូមិភាគបូព៌ា កែ ពក ជូន ប៉ុល ពត ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៧៦ KH ERN 00000766 [“បងប្អូនទូទាំងភូមិភាគទាំងចាស់ ទាំងថ្មីកំពុងតែវាយសំរុកយ៉ាងសស្រាក់សស្រាំ លើកប្រព័ន្ធភ្លឺស្រែថ្មីតាមទិសដែលអង្គការ លើកឡើង”]។ ឯកសារ D1.3.27.4 សេចក្តីប្រកាសព័ត៌មាន នៃអង្គប្រជុំសន្និបាតលើកទី ១ ក្នុងកាលសម័យទី ១ របស់សភាតំណាងប្រជាជនកម្ពុជា ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៧៦ KH ERN 00053636 [“សភាបានអនុមតិជាឯកច្ឆ័ន្ទ នូវទិសនយោបាយ ក្នុងប្រទេសនិងក្រៅប្រទេស ដើម្បីអនុវត្តតាម [...] ដូចតទៅ៖ [...] ត្រូវពង្រឹង និងពង្រីកកម្លាំងមហាសាមគ្គីភាពប្រជាជាតិ និងប្រជាជនទាំងមូលថែមទៀត ដើម្បីវាយសំរុកនៅគ្រប់សមរភូមិបង្កបង្កើនផល លើគ្រប់ផ្នែកទាំងអស់ ពិសេសលើផ្នែកកសិកម្ម សំដៅផលិតស្រូវឱ្យបានច្រើនជាអតិបរមាសម្រាប់ដោះស្រាយ និងលើកស្ទួយជីវភាពប្រជាជនយើងឱ្យបានកាន់តែខ្ពស់ និងឆាប់រហ័សថែមទៀត ហើយព្រមជាមួយនោះ ក៏សម្រាប់ជុំវិញការកសាង ប្រទេសយើង ឱ្យបានឆាប់រហ័ស តាមសន្ទុះមហាលោតផ្លោះ មហាអស្ចារ្យ”]។

1088 សូមមើល ឧទាហរណ៍ ឯកសារ នៅទីក្រុងភ្នំពេញ៖ D98/3.1.250 សគីម ល្មុត ប្រតិចារឹកថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១២ ម៉ោង ១៣.៤៣.២៤-១៣.៤៤.៥៣ [“គេមកប្រាប់ថា ខ្ញុំមកនៅសហករណ៍មួយនៅជិតភ្នំពេញនេះ មុំខាងត្បូងស្ទឹងមានជ័យហ្នឹង”]។ ឯកសារ ភូមិភាគឧត្តរចាស់/ភូមិភាគកណ្តាល៖ D98/3.1.280 សួន កានិល ប្រតិចារឹកថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១២ ម៉ោង ១០.១៦.៣៨.១០.១៩.៥៣ [“ទំនប់ ១ មករា វាស្ថិតនៅក្នុងហៅថា ខាងកំពង់ថ្ម នៅចូលស្រុកបារ៉ាយណ៍។ ដូច្នេះ គឺថា អ្នកដែលគេយកមក គេយកមកគ្រប់កន្លែងដែលអ្នកដែលមានហៅថា យកមកគឺថាមនុស្សច្រើនណាស់ មិនមែនតិចទេកសាងទំនប់ហ្នឹង។ គឺថាមនុស្សគេយកមកតាម ហៅថា នៅពេលនោះគេប្រើពាក្យថា សហករណ៍ តាមសហករណ៍តែម្តង”។ ឯកសារ D4.1.828 កំណត់ហេតុស្តាប់ចម្លើយ សួន កានិល KH ERN 00373509 [“គេដាក់សុទ្ធតែកម្លាំងនិរតីមកគ្រប់គ្រងតាំងពីគណៈតំបន់រហូតដល់គណៈសហករណ៍ [...] នៅពេលនោះ កម្លាំងភូមិភាគនិរតីបានកាន់កាប់ប្រហែល ៩០ ភាគរយនៃភូមិភាគកណ្តាល”]។ ឯកសារ ភូមិភាគនិរតី៖ D98/3.1.208 ពេជ្រ ជឹម ប្រតិចារឹកថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៣ ម៉ោង ១០.៥២.៥៦-១០.៥៤.២៤ [“ស៖ នៅថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ នៅថ្ងៃរំដោះ តើលោកមានមុខតំណែងជាអ្វីនៅក្នុងស្រុក ១០៥? ឆ៖ ជា [...] សមាជិកស្រុកដដែល ដូចមុនអ៊ីចឹង ហើយទទួលប្រជាជន [...] ពីភ្នំពេញទាំងអស់មករៀបចំចូលក្នុងសហករណ៍”] ម៉ោង

១៣.៣៧.៤២-១៣.៣៩.៤៩ ["ថ្ងៃនោះ ធ្វើមីទ្បឹងនៅឃុំពពេល [...] មីទ្បឹងទទួល [...] រៀបចំឱ្យឃុំសហជីពហ្នឹង សហករណ៍ហ្នឹង"]។ ឯកសារ D98/3.1.200 អុង ធុងហៀង ប្រតិចារិកថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១២ ម៉ោង ១១.២៨.៣០-១១.៣១.០០ [អះអាងថា អៀងសារី បាននិយាយ៖ "កាលពីសប្តាហ៍មុន នៅឈូក ខេត្តកំពង ខ្ញុំចោទសំណួរទៅអ្នកដែលនៅសហករណ៍ថា [...] បានអាហារបីពេលក្នុងមួយថ្ងៃ"]។ ឯកសារ D98/3.1.250 សគីម ល្មុត ប្រតិចារិកថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១២ ម៉ោង ១៣.៤១.០៥-១៣.៤៣.២៤ ["ស៖ លោកបានជម្រាបកាលពីម្សិលមិញថា លោក ហើយក្រុមគ្រួសារលោកត្រូវបានជម្លៀសទៅនៅសហករណ៍កៀនស្វាយ។ [...] ឆ៖ ទៅហ្នឹងមួយសន្ទុះទៅប៉ុន្មានអាទិត្យអីចឹងទៅ គេបង្កើតសហករណ៍ ក៏សុំមានបងប្អូនទៅណា សុំនៅហ្នឹងចូលសហករណ៍ហ្នឹងផងទៅ"]។ ភូមិភាគបស្ចិម៖ ឯកសារ D98/1.2.17 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារិកថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ ម៉ោង ០៩.៣៣.៣៦-០៩.៣៥.៤៩ ["រៀបចំបង្កើតសហករណ៍គឺនៅមូលដ្ឋានបង្អែកឃុំពាម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ហើយនិង [...] ឃុំអមលាំង ខេត្តកំពង់ស្ពឺ"]។ ឯកសារ D98/3.1.121 ខៀវ អេន ប្រតិចារិកថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១២ ម៉ោង ០៩.៣១.៥២-០៩.៣៤.១៩ [ស្រុកកំពង់លែង៖ "ខ្ញុំជួបតែអ្នកនៅហ្នឹងខេត្តខ្ញុំ"] ម៉ោង ០៩.៣៧.៣២-០៩.៣៩.៤៥ ["ប្រជាជនដែលជម្លៀសចេញទៅនេះ គឺថាគេយកទៅដាក់ក្នុងឃុំ ហើយក្នុងឃុំហ្នឹងមានសហករណ៍"]។ ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.១១ ["សហករណ៍នោះស្ថិតនៅជុំវាម តែឥឡូវគេហៅឃុំបិតត្រាំងវិញ"]។ ឯកសារ D1.3.13.11 កំណត់ហេតុសនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ សៀង EN ERN 00217566 ["មានសហករណ៍មួយនៅវាមដែលដាក់ភរិយា និងកូនៗរបស់សមាជិកនៃកងពលធំលេខ ១៦៤ រួមជាមួយបុគ្គលិកកងទ័ព និងប្រជាជនសាមញ្ញ។ មានមនុស្សរាប់ពាន់នាក់នៅក្នុងសហករណ៍"]។ ឯកសារ D1.3.13.8 កំណត់ហេតុនៃការសម្ភាស ក.ស.ព ជាមួយ ប៉ែន សារិន EN ERN 00217561 ["មានសហករណ៍ពីរនៅវាម សំរាប់ដាក់ប្រពន្ធនិងកូនទាហាន និងកម្មករផ្សេងទៀត [...] [ប៉ែន សារិន] មិនបានដឹងពីចំនួនមនុស្សសរុបនៅក្នុងសហករណ៍នោះទេ តែនៅថ្ងៃ ១៧ មេសា មានចន្លោះ ពី ៥០-១០០ នាក់នៅទីនោះ [...] សហករណ៍ក្នុងក្រុងព្រះសីហនុ គឺក្នុងមន្ទីរគមនាគមន៍សព្វថ្ងៃ"]។ ភូមិភាគពាយ័ព្យ៖ ឯកសារ D11/160/4.1 ចៅ នី ប្រតិចារិកថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០១២ ម៉ោង ១២.០១.២៩-១២.០៥.៣៥ ["ពេលខ្ញុំទៅដល់ស្រុកមោងឫស្សី ពេលចុះពីលើរថភ្លើង នៅពេលនោះ គឺ [...] រទេះគោគេមកចាំ ដឹកយើងចុះទៅកន្លែងសហករណ៍ហ្នឹង [...] ហ្នឹងជាសហករណ៍តាហឹយ [...] នៅចកធំ នៅខាងស្រុកមោងឫស្សី ខេត្តបាត់ដំបងហ្នឹង"]។ ឯកសារ D98/3.1.138 ឡាយ បូនី ប្រតិចារិកថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ ម៉ោង ០៩.១៤.០៩-០៩.១៨.៥២ ["ស៖ នៅក្នុងសហករណ៍នៅក្នុងខេត្តពោធិសាត់ដែលអ្នកស្រីបានទៅដល់ហ្នឹង តើនៅទីនោះ សម្បូរស្បៀងដូចអ្វីដែលគេបានប្រាប់ទេ ? ឆ៖ [...] តាំងពីខ្ញុំចេញពីភ្នំពេញ [...] គឺថាឱ្យតែខែស្នូងគឺអត់រហូតដល់បែកមកវិញ គឺថាឱ្យតែខែស្នូង គឺខែអត់បាយ [...] នៅសហករណ៍កោះជុំ [...] គ្រាន់តែគេចងក្រុងជាក្រុម ជាកងឱ្យយើងនៅទៅ។ ហូបបាយនៅការដ្ឋានរួម មួយកំប៉ុងបួននាក់។ ហើយថ្ងៃឡើង ព្រឹកឡើងរុញទៅចាត់តាំងទៅ អ្នកនេះទៅធ្វើការខាងនេះ អ្នកនេះទៅធ្វើការខាងនោះ ជាធម្មតា"]។ ភូមិភាគពៀសាន៖ ឯកសារ D98/3.1.131 ភ្លាន រ៉ិត ប្រតិចារិកថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ ២០១១ ម៉ោង ១៥.៤៨.២៣-១៥.៥៣.៥៧ [ឃុំតាឡាវ ស្រុកបរកែវ៖ "គេចាត់តាំងខ្ញុំនៅឆ្នាំ ១៩៧៦ ធ្វើអនុស្រុកនោះ បានគេចាត់តាំងសហករណ៍"]។ ឯកសារ D98/3.1.222 រ៉ូចាម តុន ហៅ ភី ភួន ប្រតិចារិកថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១២ ម៉ោង ១១.៣៣.៣៣-១១.៥៣.១៩។ ឯកសារ D98/1.2.32 សៅ សារុន ប្រតិចារិកថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០១២ ម៉ោង ០៩.១៩.២៧-០៩.២៣.០០ ["ស៖ ចុះនៅក្នុងខេត្តមណ្ឌលគិរីរបស់

ចម្ការ[1089] ស្រែអំបិល[1090] ការដ្ឋានសាងសង់បណ្ដាញស្រោចស្រព ទំនប់[1091] ព្រលានយន្តហោះ[1092] ផ្លូវ និងស្ពាន[1093]។ កងចល័តត្រូវបានបង្កើតឡើង ដើម្បីធ្វើការតាមការដ្ឋានជាច្រើន និងសហករណ៍

---

លោកហ្នឹង សហករណ៍ត្រូវបានបង្កើតដំបូងគេនៅពេលណាដែរ ? ឆ៖ ក្នុងអំឡុង ៧៧"]។ ភូមិភាគបូព៌ា៖ ឯកសារ D98/1.2.29 សូត្រ ទៀង ប្រតិចារឹកថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១២ ម៉ោង ១១.២៨.៥៤-១១.៣២.១៤ ["ស៖ កាលពីម្សិលមិញលោកបានរៀបរាប់ថា លោកបានអមដំណើរ នួន ជា ទៅដូចជាខេត្ត បាត់ដំបង ខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ និងភូមិភាគបូព៌ា [...] ពេលដែលលោកធ្វើដំណើរទៅតាម អមដំណើរលោក នួន ជា ទៅតាមតំបន់នីមួយៗ តើលោកមានប្រទះឃើញទិដ្ឋភាពអ្វីនៅតាមដងផ្លូវដែរឬទេ ? ឆ៖ ប្រទះប្រជាជនសហករណ៍គេស្ទូងស្រូវស្ទូងអីហ្នឹង"] ម៉ោង ១១.៣៥.៤៧ ["ជួបតាមប្រធានសហករណ៍ កន្លែងមួយៗ"]។ ឯកសារ D98/3.1.199 អ៊ុង ឈុងហៀង ប្រតិចារឹកថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១២ ម៉ោង ១៥.៥២.៣៧-១៥.៥៦.០០ ["គេដឹកទៅព្រំប្រទល់ថៃ [...] គេឲ្យពួកយើងខ្ញុំចូលទៅចូលទៅក្នុង ដើរចូលក្នុងទៅ ឲ្យទៅរស់នៅតាមសហករណ៍។ ហើយទៅដល់សហករណ៍គេចែកពួកយើងខ្ញុំ នេះម្ដុំ នោះម្ដុំ តាមសហករណ៍ផ្សេងៗ នៅក្នុងៗជិតក្រុង ជិតរទេះភ្លើងស្លុកអាចម៍រមាស"]។ ហើយតំបន់ពិសេសនៅខេត្តក្រចេះ (៥០៥)៖ ឯកសារ D98/3.1.316 យុន គីម ប្រតិចារឹកថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០១២ ម៉ោង ០៩.២៦.០៦-០៩.២៩.៤៧ ["ឆ្នាំ ១៩៧៣ លោក នួន ជា បានទៅប្រជុំនៅក្នុងឃុំដារ កន្លែងហ្នឹង។ នៅក្នុងឃុំដារ ស្រុកក្រចេះហ្នឹង បានប្រមូលមេឃុំទាំងអស់នៅក្នុងខេត្តក្រចេះ [...] គាត់បានជម្រាបដល់អង្គប្រជុំឲ្យដំណើរការការអនុវត្តការធ្វើសហករណ៍ [...] គាត់កំណត់ថា នៅក្នុងប្រទេសយើងបច្ចុប្បន្ន ដោយសង្គ្រាមវាខ្ទេចខ្ទាំ ផលវិបាកលើឧបករណ៍ផ្សេងៗ ដូច្នេះយើងមានតែរួមគ្នា ប្រមូលផ្ដុំគ្នាធ្វើសហករណ៍ ធ្វើជាក្រុមប្រវាស់ដៃ ទើបបានបប្រជាជនយើងអាចរស់បាន"]។

1089 សូមមើល ឧទាហរណ៍ ឯកសារ D98/3.1.10 ប៊ូ ផុន ប្រតិចារឹកថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០៩ ម៉ោង ១៣.៤៤.១១-១៣.៥៤.១៣ ["គេឲ្យខ្ញុំធ្វើស្រែប្រាំង និងស្រែវស្សានៅបឹងប៉ាយ៉ាប ជិតទួកគោក"]។ ឯកសារ D98/3.1.90 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹកថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ម៉ោង ០៩.២៩.៤០-០៩.៣៣.០៥ ["ព្រះភិក្ខុសង្ឃទូទាំងប្រទេស គេជម្លៀសទៅជនបទ គេផ្សឹក គេរុញឲ្យទៅជាកសិករឡើងវិញ"]។ ឯកសារ D98/3.1.138 ឡាយ បូនី ប្រតិចារឹកថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ ម៉ោង ០៩.៣៨.៥៧-០៩.៤១.១៨ [ក្នុងខេត្តពោធិសាត់ ភូមិភាគពាយ័ព្យ៖ "នៅសហករណ៍កោះជុំ គេបែងចែកជាក្រុមអី [...] យើងទៅធ្វើការរៀងៗខ្លួនហើយ។ លែងគិតអីហើយ គិតតែខំបង្កបង្កើនផលទៅ"]។ ឯកសារ D10.1.60 កំណត់ហេតុស្ដាប់ចម្លើយ Denise Affonco KH ERN 00349116-17 ["ខ្ញុំដឹងថា ខ្ញុំបានមកដល់តំបន់ភាគពាយ័ព្យ [...] ពួកយើងបានចាប់ផ្ដើមគាស់រានដី ហើយបន្ទាប់មក ទៅធ្វើស្រែ និងកិនស្រូវ។ នៅពេលរួចដែពីការងារស្រែចម្ការ ពួកយើងត្រូវបានបញ្ជូនឲ្យទៅសាងសង់ទំនប់សម្រាប់ទប់ទឹកក្នុងស្រែ"]។ ឯកសារ D4.1.387 កំណត់ហេតុស្ដាប់ចម្លើយ ប៉ែន ហេង KH ERN 00163690 [នៅព្រៃស៖ "គេឲ្យខ្ញុំធ្វើស្រែ។ ការងារធ្វើស្រែនៅទីនោះ គឺមានការលំបាកខ្លាំងណាស់ ពេលព្រឹកចាប់ពីម៉ោងបួន រហូតដល់ម៉ោង ១១ ឬ ១២ ថ្ងៃត្រង់ទើបឲ្យហូបបាយ ពេលហូបបាយរួចអត់មានឈប់សម្រាកទេ គឺបន្តធ្វើការរហូតដល់ម៉ោង ៥ ល្ងាចទើបឈប់ ហូបបាយ ក្រោយពីហូបបាយល្ងាច គេបន្ថែមការងារឲ្យជួយដកសំណាប ឬក៏រែកដី ធ្វើស្រះរហូតដល់ម៉ោង ១១ ឬ ១២ យប់ទើបសំរាក"]។ ឯកសារ D114/242 កំណត់ហេតុស្ដាប់ចម្លើយ ប្រាក់ ប៊ុនធី ឆ.៩ , ៥០-៥១ ["ឆ្នាំ ១៩៧៥ កាលហ្នឹងខ្ញុំអាយុ ១២ ឆ្នាំ។ គេយកខ្ញុំទៅប្រមូលផ្ដុំក្មេងចម្ការដូងរាម។ [...]។ ឆ.៥០៖ គេបញ្ជូនយើងបេះដូង ហើយគេឲ្យ

យើងធ្វើស្រែជាមួយយុវជនទៀត។ សៈ តើគេឲ្យធ្វើស្រែនៅទីតាំងណាខ្លះដែរទៅ? ឆ.៥១៖ នៅក្បែរតារាងយន្តហោះកងកេង"]។ ឯកសារ D4.1.817 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធៀន KH ERN 00368603 [នៅខេត្តតាកែវ ភូមិភាគនិរតី៖ "កម្លាំងបែងចែកគ្រប់មុខសញ្ញា ដូចជាកងចំការ កងប្រឡាយ កងធ្វើស្រែ"]។ ឯកសារ D114/260 កំណត់ហេតុស្តាប់ចម្លើយ ស៊ន សុត ឆ.៤០ ["គេដកពីកោះតាង ហើយបានទីធ្វើស្រែរហូត [...] ខ្ញុំធ្វើស្រែរហូតដល់ឆ្នាំ ១៩៧៩"]។ ឯកសារ D114/33 កំណត់ហេតុស្តាប់ចម្លើយ អាង ហែម ឆ.១៧, ៤៩ ["ក្នុងឆ្នាំ ១៩៧៦ ទើបគេរំសាយចេញពីកងយោធា ហើយបែងចែកទៅធ្វើការនៅតាមសហករណ៍ ជាមួយប្រជាជនស៊ីវិលធម្មតាវិញ ដោយគេនិយាយថា មេៗរបស់ពួកឯងបានក្បត់ហើយ។ [...] ឆ.៤៩៖ [...] គេកំណត់ឲ្យធ្វើការប្រចាំថ្ងៃ គឺ ៦ នាក់កាត់ស្មៅ ឲ្យរួចមួយហិចតា"]។

1090 សូមមើល ឧទាហរណ៍ ឯកសារ D114/163 កំណត់ហេតុស្តាប់ចម្លើយ ជា ថា ឆ.១៩-២០ [នៅកងកុមារនៅស្រែអំបិលក្នុងខេត្តកំពត៖ "នៅ ៧៥ តែចុងឆ្នាំហើយ។ គេឲ្យរែកអំបិល កាយអំបិល ជីកប្រឡាយ ឡើងស៊ីដៃស៊ីជើងហើយ។ កើតដំបៅ រឡេសរលួយអស់ហើយ។ [...] ឆ.២០៖ [...] មានមនុស្សរាប់ពាន់នាក់។"]។ ឯកសារ D114/162 ជាម ញ៉ ឆ.៤៤ ["សៈ អ្នកអាចប្រាប់បានទេថា នៅស្រែអំបិលនោះ មានអ្នកធ្វើការប៉ុន្មាននាក់? [...]។ ឆ.៤៤៖ ច្រើនប្រហែលរាប់រយនាក់។ នៅហ្នឹងច្រើនតែកងនារី មិនសូវមានកងយុវជនទេ។ អត់មានទាហានទេ មានតែកងនារី"]។ ឯកសារ D4.1.538 កំណត់ហេតុស្តាប់ចម្លើយ ជុំ លន KH ERN 00241998 [នៅកំពង់កណ្តាល៖ "មានកម្មកររាប់ពាន់នាក់សុទ្ធតែស្រីៗទាំងអស់ មានប្រុសៗតិចតួចជាអ្នកកាន់ម៉ាស៊ីនបូមទឹក ក្នុងមួយកងមានប្រុសតែម្នាក់ប៉ុណ្ណោះ។ [...] ពេលយប់គឺរែកអំបិលតាំងពីម៉ោង ៧ រហូតដល់ម៉ោង ១ យប់ត្រូវរែកឲ្យអស់ ៣ តោនក្នុងមួយក្រុម ហើយបើកម្មករណាមិនទៅធ្វើការត្រូវប្រធានកងមកតាមរកដល់កន្លែងដេក។ ការងាររែកអំបិលនេះ គឺត្រូវធ្វើឲ្យរួចតាមការកំណត់ទើបឈប់សម្រាក គឺរែកទាំងថ្ងៃទាំងយប់"]។ ឯកសារ D4.1.561 កំណត់ហេតុស្តាប់ចម្លើយ កែម ញ៉ KH ERN 00271423 ["តើកម្មករនៅស្រែអំបិលកំពង់កណ្តាលមានគ្នាចំនួនប៉ុន្មាននាក់? ឆ៖ មានច្រើនរហូតដល់រាប់ពាន់នាក់ ភាគច្រើនសុទ្ធតែស្រីៗ មានកម្មករកាន់ម៉ាស៊ីនបូមទឹកជាប្រុសៗផងដែរ។ [...] យើងធ្វើការតាមរដូវ ការធ្វើការទាំងយប់ទាំងថ្ងៃ គឺធ្វើនៅពេលដែលអំបិលដុះច្រើន ក្នុងខែមួយ ឬខែពីរ ធ្វើទាំងយប់ទាំងថ្ងៃ គ្មានពេលសម្រាកទេ"]។ ឯកសារ D4.1.549 កំណត់ហេតុស្តាប់ចម្លើយ ជីង ភឿន ហៅ អួន ភឿន KH ERN 00251667-68 [នៅស្រែអំបិលត្រើយកោះ៖ "ពេលណាមេឃចង់ភ្លៀង ហើយមានអំបិលដុះច្រើន គេឲ្យធ្វើការបីយប់បីថ្ងៃផ្ទួនគ្នា អត់មានពេលសម្រាកក៏មាន។ [...] សៈ នៅត្រើយកោះនោះ មានកម្មករប្រហែលប៉ុន្មាននាក់? ឆ៖ ខ្ញុំមិនអាចស្មានដឹងចំនួនប៉ុន្មានទេ។ តែនៅទីនោះ មានបីកងវរៈ [...] ក្នុងមួយកងវរៈ មានបីកងរយ"]។

1091 សូមមើល ឧទាហរណ៍ ឯកសារ D234/2.1.17 កសាង និងពង្រឹងគោលជំហរវិភាគគ្រប់បាតុភាព គ្រប់បញ្ហា តាមគោលជំហរនៃវណ្ណៈអធនរបស់បក្ស KH ERN 00441897 ["មើលចុះភូមិភាគមួយៗ ក្នុងការដ្ឋាន មួយៗ កសិករក្រនិងកណ្តាល រាប់ពាន់ រាប់ម៉ឺននាក់ សស្រាក់សស្រាំសប្បាយរីករាយ ធ្វើអាងដាក់ទឹកបានរាប់សិបៗ លានម៉ែត្រគ្រីគុណ ប្រឡាយរាប់សិបៗគីឡូ ទំនប់រាប់សិបៗគីឡូ ។ល។"]។ ឯកសាររ D4.1.877 ទង់បដិវត្ត ចេញផ្សាយខែមិថុនា ឆ្នាំ ១៩៧៦ KH ERN 00064081 ["សហករណ៍យើងនៅបានវាយសំរុកលើកទំនប់ ជីកប្រឡាយ ជីកស្រះ ជីកអាងច្រើនស្តុកស្តុះ ដោះស្រាយបញ្ហាទឹកបង្កបង្កើនផលបានមួយកំរិត"]។ ឯកសារ D4.1.989 កិច្ចសម្ភាស របស់ Ben Kiernan ជាមួយ ជា ស៊ីម នៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩១ KH ERN 00713925-26 ["នៅក្នុងឆ្នាំ ១៩៧៦ យើងចាប់

ផ្ដើមសាងសង់ទំនប់ និងប្រឡាយ ធារាសាស្ត្រទូទាំងប្រទេស។ នេះគឺជាយុទ្ធនាការដ៏ធំ រួមដៃគ្នា ដំណាលគ្នា និងទូទាំងប្រទេស"]។ ឯកសារ D64.1.27 FBIS, របាយការណ៍សារព័ត៌មានកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៧៧ KH ERN 00679833 ["នៅគ្រប់កន្លែងដែលយើងទៅ យើងឃើញបងប្អូននារីរាប់ពាន់នាក់ និងប្រជាជនចូលរួមដោយសាទរនៅក្នុងចលនាដ៏អស្ចារ្យ ដើម្បីកសាងបណ្ដាញទំនប់ទឹក ប្រឡាយ និងជីកព្រែកតូចធំ ទាំងឡាយ និងអាងស្តុកទឹកដ៏ធំ ដូចជាអាងស្តុកទឹក "១ មេសា" និងទំនប់ "១ មករា"]។ ឯកសារ D11/255/3.1 ហ៊ុន សុគ្គានី ប្រតិចារឹកថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ម៉ោង ០៩.២១.៣៧-០៩.២៣.៣៩ [នៅការដ្ឋានទំនប់ ១ មករា៖ "មនុស្សរាប់ពាន់ម៉ឺន បីតំបន់ចូលគ្នា គិតទៅតើវាប៉ុនណា"]។ ឯកសារ D4.1.520 កំណត់ហេតុស្ដាប់ចម្លើយ កែ ពេជ្រវណ្ណៈ KH ERN 00340563 [សាក្សី៖ កូនប្រុសរបស់ កែ ពក ថាំថា៖ "គណៈតំបន់ទាំងបី ជាអ្នករៀបចំប្រមូលកម្លាំងមកលើកទំនប់ ១ មករានោះ។ តាមផែនការ មួយតំបន់ត្រូវការមនុស្សមួយម៉ឺននាក់"]។ ឯកសារ D4.1.565 កំណត់ហេតុស្ដាប់ចម្លើយ សោម ផាន់ KH ERN 00279105 ["មានមនុស្សរាប់ម៉ឺននាក់ បានចូលរួមលើកទំនប់ត្រពាំងថ្ម។ អ្នកទាំងនេះមកពីប្រាំស្រុកគឺ ស្រុកភ្នំស្រុក ស្រុកព្រះនេត្រព្រះ ស្រុកសេរីសោភ័ណ ស្រុកស្វាយចេក និងស្រុកថ្មពួក។ ស្រុកទាំងប្រាំនេះស្ថិតក្នុងតំបន់ ៥ ភូមិភាគពាយ័ព្យ"]។ ឯកសារ D114/240 កំណត់ហេតុស្ដាប់ចម្លើយ ភិន វេញ ឆ.១១, ១៦ ["គេយកកុមារទៅធ្វើទំនប់ [...] ឆ.១៦៖ ទំនប់អូរប្រែហ្នឹងមានប្រវែង ២ គីឡូដី ហើយមានប្រជជនយើងធ្វើការច្រើនណាស់ ហើយរួមទាំងកុមារផង"]។ ឯកសារ D11/387 សំ វុទ្ធី បែបបទបទម្រង់ព័ត៌មានជនរងគ្រោះ KH ERN 00991864 ["មេកងឈ្មោះមិត្ត លន បានបង្ខិតបង្ខំពួកយុវជន និងយុវនារីទាំងអស់ធ្វើប្រឡាយមួយខ្សែ ដើម្បីយកទឹកធ្វើស្រែប្រាំងនៅខាងក្រោមទំនប់បិតត្រាំង"]។

1092 សូមមើល ឧទាហរណ៍ ឯកសារ D1.3.27.1 កំណត់ហេតុការប្រជុំគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ KH ERN 00019118 និង KH ERN 00019126 ["ឯព្រលានយន្តហោះខាងយោធា យើងមានផែនការធ្វើកន្លែងផ្សេង"]។ ឯកសារ D4.1.508 កំណត់ហេតុស្ដាប់ចម្លើយ ចាន់ ម៉ន ហៅ ជួប សុខុន KH ERN 00287526-27 ["នៅពាក់កណ្ដាលឆ្នាំ ១៩៧៦ គឺរដូវដកស្ទូង ល្វៃ បានចាត់តាំងខ្ញុំឲ្យមកមើលការដ្ឋានព្រលានយន្តហោះនៅឃុំក្រាំងលាវ ខេត្តកំពង់ឆ្នាំង [...] ខ្ញុំបានឃើញមនុស្សជាច្រើនម៉ឺននាក់មានស្រី ប្រុស សុទ្ធតែជាយោធា"]។ ឯកសារ D4.1.1147 កំណត់ហេតុស្ដាប់ចម្លើយ កែវ លឿ ហៅ កែវ សុផល KH ERN 00170620 ["ពេលនោះ អង្គភាពរបស់ខ្ញុំនៅសល់តែ ៤០០ នាក់ ពេលគេយកទៅលត់ដំនៅកំពង់ឆ្នាំ។ មានអង្គភាពផ្សេងៗដែរ ដូចជា កងពល ៤៥០ [...] ពេលប្រជុំគេថា ត្រូវលត់ដំ ព្រោះមេៗរបស់អ្នកឯងក្បត់"]។ ឯកសារ D4.1.511 កំណត់ហេតុស្ដាប់ចម្លើយ សែម ហឿន KH ERN 00287558-59 ["ភាគច្រើនគឺមកពីភូមិភាគឧត្តរ និងភូមិភាគបូព៌ា ដែលជាប់និន្នាការនយោបាយក្បត់ ត្រូវគេបញ្ជូនមកដើម្បីឲ្យកសាងខ្លួន"]។ ឯកសារ D4.1.454 កំណត់ហេតុស្ដាប់ចម្លើយ កុយ ម៉ុន KH ERN 00195438 ["ខ្ញុំត្រូវបានគេបញ្ជូនពីព្រៃសមកកំពង់ឆ្នាំនៅចុងឆ្នាំ ១៩៧៧។ អ្នកដែលត្រូវបញ្ជូនមកកំពង់ឆ្នាំនោះ សុទ្ធតែកងទ័ពភូមិភាគ ចំណុះមជ្ឈិម។ គេឲ្យមកវាយថ្មធ្វើព្រលានយន្តហោះ [...] ខ្ញុំមកធ្វើការបានប្រហែលកន្លះខែ បានជួបមិត្តភក្តិម្នាក់ឈ្មោះ ពីន ដែលជាប្រធានកងពល ៥០២ [...] ពីន បានលួចប្រាប់ខ្ញុំថា ពួកខ្ញុំជាប់និន្នាការនយោបាយ"]។ ឯកសារ D1.3.13.7 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ ពេជ្រ ដារី ហៅ រី KH ERN 00657415 ["កងពល ៥០២ ត្រូវបានប្រើប្រាស់ដើម្បីគ្រប់គ្រង "សមាសភាព" ដែលគេយកមកពីអង្គភាពផ្សេងៗ ដើម្បីឲ្យមកសាងសង់ព្រលានយន្តហោះយោធាខេត្តកំពង់ឆ្នាំ"]។ ឯកសារ D1.3.32.39 កិច្ចសម្ភាស់របស់មជ្ឈមណ្ឌលឯកសារកម្ពុ

ជាជាមួយ សែម ហឿន ហៅ គីម KH ERN 00020576 ["ចូល ៧៦ បានគេបញ្ជូនឲ្យទៅកំពង់ឆ្នាំង។ [...] ទៅឲ្យធ្វើព្រលានយន្តហោះនៅកំពង់ឆ្នាំង [...] ហើយឲ្យធ្វើហ្នឹងគ្មានពេលវេលា គ្មានម៉ោងអីសម្រាប់ឈប់ទេ ព្រោះយើងវាជាប់នឹងនិន្នាការនយោបាយក្បត់ណា"] KH ERN 00020591 ["គ្រប់ភូមិភាគ គ្រប់ខេត្តមិនដឹងជានៅខេត្តណា ខេត្តអីទេ ដូចជាខាងបូព៌ាអីចឹង វាជាប់និន្នាការដែលថាទោសអីចឹងគឺគេបញ្ជូនមកហើយ ខេត្តសៀមរាបអីចឹងមានទោសគេបញ្ជូនមក មកដាក់កន្លែងមួយជុំ នៅកន្លែងកសាងហ្នឹងហ្នង។ [...] ស៖ ហើយចំនួនអ្នកដែលធ្វើការនៅហ្នឹងមានច្រើនទេ? ឆ៖ ច្រើនណាស់អូនប្រហែលជាខ្ទង់ ៣ កងពល មើលទៅងងឹតរាប់ម៉ឺននាក់ មួយអង្គភាពនេះទៅ មួយអង្គភាពនោះទៅ មួយវរៈនេះទៅណែនៗហ្នឹង"]។ ឯកសារ D1.3.32.46 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សោម សុខន KH ERN 00053992-93 ["និយាយថា ពួកខ្ញុំហ្នឹងពួកក្បត់ អីចឹងទៅគេដកឲ្យទៅធ្វើព្រលានកំពង់ឆ្នាំង ពួកក្បត់គេយកធ្វើព្រលានកំពង់ឆ្នាំង"] KH ERN 00054015-16 ["ស៖ បើតាមពូប៉ាន់ស្មានមើលដូចថាកងទ័ពធ្វើនៅព្រលានយន្តហោះកំពង់ឆ្នាំមានប្រហែលប៉ុន្មាននាក់? ឆ៖ ខ្ញុំឮថា ២៧.០០០នាក់"]។ ឯកសារ D1.3.32.27 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡេង គីម ហៅ គង់ គីម KH ERN 00054864 ["គេយកទៅធ្វើព្រលានហ្នឹង ប្រើប្រៀបធៀបថា យើងជាប់និន្នាការព្រោះមេៗយើងក្បត់ [...] មេៗប្រហែលយកទៅដាក់គុកដាក់អីហ្នឹង។ អាកូនៗមកហ្នឹងទាំងអស់។ ចឹងដល់មកដល់ហ្នឹង គេរៀបជាក្រុមហើយទៅជាសហករណ៍"]។

1093 សូមមើល ឧទាហរណ៍ឯកសារ D2/7 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សារិន ឆ.១០ [ការដ្ឋានសង់ផ្លូវពីស្ទឹងហាវទៅកំពង់សោម៖ "ផ្លូវនេះបានសាងសង់ចប់នៅចុងឆ្នាំ ១៩៧៦។ ខ្ញុំជាមេជាង ការងារមានលក្ខណៈពិបាក ប៉ុន្តែ យើងចេះតែទ្រាំធ្វើការទៅ។ យើងត្រូវធ្វើការទាំងភ្លៀង ទាំងយប់រហូតដល់ម៉ោង ៩ ឬ ១២ យប់ ដោយមានការដាក់ភ្លើងធ្វើការរហូត។ ផ្លូវដែលយើងសាងសង់នេះមានប្រវែងតែ ១៣ គីឡូម៉ែត្រប៉ុណ្ណោះ [...] ផ្លូវនេះសាងសង់អស់រយៈពេល ៦ ខែ"]។ ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.៧០ ["ការងារបច្ចេកទេសទី ១ ធ្វើផ្លូវ។ ផ្លូវធ្វើពីរោងចក្រប្រេងកាតមកដល់ស្ទឹងហាវ។ ទី ២ ធ្វើអាផ្លូវចុះឡើងក្នុងការដ្ឋានស្ទឹងហាវហ្នឹង ហើយនិងឈូសពីជើងភ្នំនៅមាត់សមុទ្រស្ទឹងហាវហ្នឹងឲ្យទៅជារាមស្មើ"]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ. ១៣-១៤, ២២ ["នៅចុងឆ្នាំ ១៩៧៧ គេបានស្រាវជ្រាវប្រវត្តិរូបរបស់ខ្ញុំ ហើយគេបានរកឃើញថា ខ្ញុំមានប្រវត្តិរូបមិនល្អ ហើយគេដកកាំភ្លើងពីខ្ញុំ និងដកខ្ញុំពីអង្គភាពនេសាទឲ្យមកធ្វើការជាអ្នកលីសែងថ្មវិញ។ [...] ឆ. ១៤៖ គឺមានបញ្ជាពីមេបញ្ជាការឲ្យបញ្ជូនខ្ញុំជាមួយនឹងយោធាប្រហែលជា ២០ នាក់ទៀតឲ្យមកនៅស្ទឹងហាវ។ [...] ឆ. ២២៖ ក្នុងមួយថ្ងៃមនុស្សម្នាក់តម្រូវឲ្យជីករុន្ធសម្រាប់ដាក់រំសេវបំផ្ទុះថ្ម ឲ្យបានជម្រៅមួយម៉ែត្រ។ រហូតដល់ឆ្នាំ ១០៧៧-១៩៧៨ ទើបចិននាំយកម៉ាស៊ីនខួងថ្មមក។ គេបំផ្ទុះថ្មក្រោយម៉ោង ៥ ល្ងាច ហើយនៅពេលព្រឹកបន្ទាប់ គេឲ្យអ្នកធ្វើការលីថ្មទាំងដុំៗដាក់លើឡាន ដើម្បីគេយកទៅចាក់ធ្វើផែកប៉ាល់។ ៙"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.១៧, ២៣-២៤, ៤៥ ["ខ្ញុំនៅកងកាំភ្លើងធំរហូតដល់ប្រហែលចុងឆ្នាំ ១៩៧៧ បានគេរំសាយខ្ញុំពីកងកាំភ្លើងធំ ហើយបញ្ជូនខ្ញុំទៅធ្វើការនៅការដ្ឋានវាយថ្ម ដើម្បីធ្វើផែនៅស្ទឹងហាវ។ [...]។ ឆ.២៣៖ នៅពេលនោះ គេបានដកប្រហែលជា ៨០ ភាគរយនៃពួកអតីតយោធាកងវរសេនាតូច ៣៨៦ នៃតំបន់ ៣៧ ហើយបញ្ជូនឲ្យទៅធ្វើការនៅកន្លែងរែថ្ម នៅស្ទឹងហាវដោយសារពួកនោះចាត់ថាជាសមាសភាពមិនល្អ។ [...] ។ឆ.២៤៖ ពួកគេចោទមនុស្សនៅក្នុងតំបន់ ៣៧ ថាជាសមាសភាពមិនល្អ ពីព្រោះក្នុងតំបន់នេះ ត្រូវបានរៀបចំដោយវៀតណាមតាំងពីឆ្នាំ ១៩៧០ ម្ល៉េះ។ ដូច្នេះ គេចោទពួកយើងថាមានទំនាក់ទំនងខ្សែរយៈជាមួយវៀតណាម។ [...]។ ឆ.៤៥៖ ពួក ៨០ ភាគរយដែលដកពីកងវរសេនាតូច

កសិកម្ម[1094]។ សហករណ៍ និងការដ្ឋាន ត្រូវបានតម្រូវឱ្យមានរចនាសម្ព័ន្ធ និងរបៀបប្រតិបត្តិការដូចគ្នា នៅទូទាំងប្រទេស[1095] ហើយគោលនយោបាយទាក់ទិននឹងបញ្ហាពាក់ព័ន្ធនឹងសហករណ៍ និងការដ្ឋាន ត្រូវបានផ្សព្វផ្សាយ តាមរយៈសេចក្តីណែនាំ[1096] កិច្ចប្រជុំនៅគ្រប់ជាន់ថ្នាក់[1097] ឯកសារបោះពុម្ពផ្សាយ[1098] និងការផ្សាយតាមវិទ្យុ[1099]។

---

៣៨៦ គឺធ្វើការនៅកន្លែងទំនប់ផែទាំងអស់"]។ ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.១៧ ["ទើបគេបញ្ជូនខ្ញុំឱ្យទៅធ្វើការនៅស្ទឹងហាវ។ នៅទីនោះ គេឱ្យខ្ញុំបំបែកថ្មដើម្បីយកថ្មទៅធ្វើទំនប់រលក និងផែសម្រាប់ឱ្យកប៉ាល់ចម្បាំងចូលចត។ គេមិនចង់យកកប៉ាល់ចម្បាំងទៅចងនៅផែស៊ីវិលទេ"]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ. ១៩ ["កំពង់ផែនោះ គេហៅថា ទំនប់រលកនៅស្ទឹងហាវ។ ត្រឹមពេលដែលគេបញ្ជូនខ្ញុំទៅទីនោះ អ្នកធ្វើការទាំងអស់នៅស្ទឹងហាវ គឺគេតម្រូវឱ្យវៃថ្មនៅការដ្ឋានយកថ្មទាំងអស់គ្នា។ តាមផែនការរបស់គេ គេគ្រោងយកថ្មនោះធ្វើជាចំណតសម្ងាត់ ដែលគេអាចជួសជុលកប៉ាល់ និងជាកន្លែងស្តុតគ្រឿងផ្ទុះ ឬអាវុធ។"]។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.៣៩ ["ក្រោយមកគេរំសាយ គេឱ្យកាំបិតទៅកាប់ឈើធ្វើផ្ទះ ឱ្យទៅវាយថ្មចាក់ផែនៅស្ទឹងហាវជាមួយពួកចិន"]។

[1094] សូមមើល ឧទាហរណ៍ ឯកសារ D4.1.877 ទង់បដិវត្ត ចេញផ្សាយខែមិថុនា ឆ្នាំ ១៩៧៦ KH ERN 00064110 ["បងប្អូនមួយចំនួនជាកងផលិតចល័ត បានចុះជួយតាមសហករណ៍នានា ពិសេស ជួយភ្ជួររាស់និងដកស្ទូងសហករណ៍ណាដែលមានទឹកគ្រប់គ្រាន់ហើយ ឬមានសំណាបច្រើនល្មបដកល្មមស្ទូងបានហើយ"]។ ឯកសារ D4.1.653 ទង់បដិវត្ត ចេញផ្សាយខែ មិថុនា ឆ្នាំ ១៩៧៧ KH ERN 00062811 ["កងចល័តរបស់យើងចាត់ចែងទៅណាក៏បាន ធ្វើអាងទឹកក៏បាន ដាំដំឡូងក៏បាន ដាំចេកក៏បាន ។ល។"]។ ឯកសារ D10.1.59 ទង់បដិវត្ត ចេញផ្សាយខែ សីហា ឆ្នាំ ១៩៧៧ KH ERN 00062967 [រូបថត៖ "យុវជនចល័ត តំបន់កំពង់ឆ្នាំង កំពុងវាយសម្រុកជំរះស្មៅនៅក្នុងចំការដំឡូងឈើមួយខាងត្បូងភ្នំសន្ទួច"]។ ឯកសារ D4.1.894 ទង់បដិវត្ត ចេញផ្សាយខែ វិច្ឆិកា ឆ្នាំ ១៩៧៨ KH ERN 00376514 ["យុវជនយុវនារីកងចល័ត ផលិតកម្មយើង ត្រូវវាយសំរុកបង្កបង្កើនផលសព្វបែបយ៉ាង ពិសេសបង្កើនផលស្រូវឱ្យបានខ្លាំងក្លាជាប់ជានិច្ចទទួលផលបានច្រើនបំផុត សំរេចផែនការប្រចាំឆ្នាំរបស់បក្សឱ្យបានជោគជ័យទាំងស្រុង និងលើសថែមទៀត"]។

[1095] សូមមើល ឧទាហរណ៍ ឯកសារ D4.1.37 ឯកសារទី ៦៖ អំពីការក្តាប់ និងអនុវត្តមាគ៌ានយោបាយប្រមូលកម្លាំងរណសិរ្ស ប្រជាជាតិ ប្រជាធិបតេយ្យរបស់បក្ស ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៧៥ KH ERN 00072406-07។ ឯកសារ D4.1.872 ទង់បដិវត្ត ចេញផ្សាយខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៥ KH ERN 00063269។ ឯកសារ D1.3.24.2 ទង់បដិវត្ត ចេញផ្សាយខែ កក្កដា ឆ្នាំ ១៩៧៦ KH ERN 00062917-18។ ឯកសារ D4.1.865 ទង់បដិវត្ត ចេញផ្សាយខែ តុលា-វិច្ឆិកា ឆ្នាំ ១៩៧៧ KH ERN 00064822-23។

[1096] សូមមើល ឧទាហរណ៍ ឯកសារ D4.1.37 ឯកសារទី ៦៖ អំពីការក្តាប់ និងអនុវត្តមាគ៌ានយោបាយប្រមូលកម្លាំងរណសិរ្ស ប្រជាជាតិ ប្រជាធិបតេយ្យរបស់បក្ស ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៧៥ KH ERN 00072406-07 [ពិភាក្សាពីរបៀបពង្រឹង និងពង្រីកកម្លាំងកម្មករថ្មីនៅក្នុងសហករណ៍ រួមទាំងចាត់ចែងប្រជុំជីវភាព និងកម្មវិធីបណ្តុះបណ្តាលផ្សេ

ងៗ]។ ឯកសារ D4.1.904 ការកសាងជួរកម្មាភិបាល៖ សេចក្ដីណែនាំរបស់បក្ស ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៨ KH ERN S 00658260-64 [ណែនាំថា កម្លាំងថ្មីគួរនាំចូលទៅក្នុងបក្សនីមួយៗដែលត្រូវបានជ្រើសរើសពីថ្នាក់មូលដ្ឋាន ហើយបន្ទាប់មកបានកំណត់ការងារច្បាស់លាស់នៅក្នុងសហករណ៍]។ សូមមើលផងដែរ គោលការណ៍ណែនាំគោលនយោបាយ ៣តោន ក្នុងមួយហិកតា៖ D1.3.19.1 សេចក្ដីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ KH ERN 00003136។ ឯកសារ D4.1.227 ទូរលេខ ២៥៤ ពីលេខាភូមិភាគឧត្តរ សែ ជូនគណៈ ៨៧០ KH ERN 00001061-62។ ឯកសារ D4.1.612 ទូរលេខ លេខ ៣២៤ ពីលេខាភូមិភាគឧត្តរ សែ ជូនគណៈ ៨៧០ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៩៧៨ KH ERN 00296230-31។

1097 សូមមើល ឧទាហរណ៍ ឯកសារ D4.1.65 កំណត់ហេតុស្ដីពីដំណើរទស្សនកិច្ចរបស់គណៈ អចិន្ត្រៃយ៍ទៅកាន់ភូមិភាគឧត្តរ ថ្ងៃទី ២០-២៤ ខែ សីហា ឆ្នាំ ១៩៧៥ KH ERN 00008489 ["ត្រូវពង្រឹង ពង្រីក សហករណ៍ថែមទៀត"] KH ERN 00008490-91 ["វិធានការជាក់ស្ដែងមួយចំនួន៖ [...] យកចិត្តទុកដាក់ពិនិត្យសហករណ៍ថែម សមាសភាព ចាស់ ថ្មី។ ឲ្យស្រុក ឃុំដឹង ហើយអប់រំសហករណ៍ ខាងនយោបាយ សតិអារម្មណ៍ នឹងចាត់តាំង [...] ទិសដៅរបស់បក្ស គឺបង្កបង្កើនផល និងកសាងប្រទេស។ ត្រូវចែកកម្លាំងដែលមានដីទំនេរឲ្យបង្ក បង្កើនផលផង"]។ ឯកសារ D4.1.93 កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ KH ERN 00000711 ["មតិណែនាំរបស់អង្គការ៖ ១. បញ្ហាផលិតអំបិល៖ ស្នើជំរុញថែមឲ្យបានពី ៥០០.០០០ ទៅ ៦០០.០០០ តោន"]។ ឯកសារ D4.1.817 កំណត់ហេតុស្ដាប់ចម្លើយ ប៊ុន ធឿន KH ERN 00368609 ["ការប្រជុំថ្នាក់តំបន់ ជាការប្រជុំសរុបរួមប្រចាំឆ្នាំ ដោយមានការចូលរួមពី លេខា អនុ និងសមាជិកឃុំទាំងអស់។ [...] ការប្រជុំ គេនិយាយពីនយោបាយ យោធា សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ [...] គេណែនាំឲ្យធ្វើស្រូវវស្សាផង និងស្រូវប្រាំងផង។ ស៖ តើលោកធ្លាប់បានទទួលផែនការធ្វើស្រែមួយហិចតា ឲ្យបានបីតោនដែរឬទេ? ឆ៖ មាន មិនត្រឹមតែបីតោនទេ គឺគេធ្វើឲ្យបានរហូតដល់ ៥ តោនទៀត។ ពេលនោះ គេដាក់ផែនការឲ្យរៀបចំប្រព័ន្ធក្រឡាឈើត្រង់ ដោយមានភ្លឺទោល ភ្លឺភ្លោះ និងប្រឡាយសម្រាប់បង្ហូរទឹក"]។ ឯកសារ D4.1.521 កំណត់ហេតុស្ដាប់ចម្លើយ ទេព ប៉ូច KH ERN 00348840 [នៅស្រុកស្អាង៖ "ខ្ញុំបានចូលរួមប្រជុំជាមួយគណៈស្រុក។ ការប្រជុំគឺនិយាយអំពីការធ្វើស្រែក្នុងមួយហិកតាបីតោន ដើម្បីឲ្យប្រជាជនអនុវត្ត"] KH ERN 00348842 ["ស៖ តើនៅស្រុកបារាយណ៍ លោកធ្លាប់ចូលរួម ប្រជុំដែរឬទេ? ឆ៖ ខ្ញុំធ្លាប់ត្រូវបានគេហៅទៅប្រជុំម្ដង គឺប្រជុំនៅចម្ការលើ ខេត្តកំពង់ចាម។ អឿន (លេខាតំបន់) ជាអ្នកដឹកនាំការប្រជុំ។ ក្នុងការប្រជុំ ថ្នាក់លើបានដាក់ផែនការឲ្យធ្វើស្រែ"]។ ឯកសារ D4.1.508 កំណត់ហេតុស្ដាប់ចម្លើយ ចាន់ ម៉ន ហៅ ជួប សុខុន KH ERN 00287530 ["ស៖ តើមានការប្រជុំបែបណាខ្លះ ត្រូវបានធ្វើឡើងនៅការដ្ឋានព្រលានយន្តហោះក្រាំងលាវ ខេត្តកំពង់ឆ្នាំង? [...] ឆ៖ មានការប្រជុំមួយអាទិត្យម្ដង [...] ដោយនិយាយពីផែនការធ្វើការដ្ឋាន។ ហើយប្រធានអង្គភាពសម្រេចយកទៅផ្សព្វផ្សាយអនុវត្តជាមួយកូនក្រុម"]។

1098 សូមមើល ឧទាហរណ៍ ឯកសារ D4.1.882ទង់បដិវត្ត ចេញផ្សាយខែ កុម្ភៈ-មីនា ឆ្នាំ ១៩៧៦ KH ERN 00063219 ["តាមសេចក្ដីសម្រេចរបស់បក្ស នៅឆ្នាំ ១៩៧៦ នេះសហករ៍យើង ត្រូវវាយសំរុកបង្កបង្កើនផល ឲ្យបាន៣តោនក្នុងដី ១ហិកតា គិតជាមធ្យមនិងជាទូទៅ ម្យ៉ាងដើម្បីដោះស្រាយជីវភាពជូនប្រជាជន តែម្យ៉ាងទៀត គឺដើម្បីមានទុនការពារ និងកសាងប្រទេស ឲ្យបានលឿនមហាលោតផ្លោះ មហាអស្ចារ្យ"] KH ERN 00063224 ["ត្រូវក្ដាប់កម្លាំងពលកម្មក្នុងសហករណ៍នីមួយៗឲ្យជាប់ក្នុងដៃ"] KH ERN 00063225 ["បើសហករណ៍ណាមួយមានសំណាបច្រើន ស្ទួងមិន

322. ទិដ្ឋភាពឧក្រិដ្ឋនៃគោលនយោបាយសេដ្ឋកិច្ចរបស់ ប.ក.ក ស្តែងឡើងនៅក្នុងរបៀបនៃការប្រព្រឹត្តិចំពោះប្រជាជន គឺថា ប.ក.ក គ្រប់គ្រងលើគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតរបស់ពួកគេ ដកហូតសេរីភាពជាមូលដ្ឋានពីកម្មករ បង្ខំឱ្យពួកគេធ្វើការដោយគ្មានប្រាក់កម្រៃ ក្នុងលក្ខខណ្ឌគួរឱ្យអាណោចអាធ័ម និងគ្រោះថ្នាក់ និងដកចោលយ៉ាងស្រួលនូវអ្នកដែលត្រូវគេចាត់ទុកថាគ្មានប្រយោជន៍ដល់

---

អស់ ឬស្ទូងមិនទាន់ ត្រូវមើលចែកចាយទៅសហករណ៍ផ្សេងទៀតដែលខ្វះសំណាបស្ទូង កុំទុកឱ្យសល់រលួយចោល ឬទុកចោលទាល់តែសំណាបចាស់ ដុះថ្នាំងខូចអស់ ទើបហៅឱ្យគេ"]។ ឯកសារ D4.1.862 ទង់បដិវត្ត ចេញផ្សាយខែមេសា ឆ្នាំ ១៩៧៧ KH ERN 00062987 ["ទន្ទឹមនឹងនេះ អង្គភាពដទៃទៀត ក្នុងក្របខណ្ឌទូទាំងប្រទេសក្តី ភូមិភាគក្តី តំបន់ក្តី ស្រុកក្តី សហករណ៍ក្តី អង្គភាពយោធាក្តី ក្រសួង-មន្ទីរក្តី ត្រូវវាយសំរុក តាមលំនាំអង្គការជឿនលឿន ដើម្បីសំរេចផែនការឆ្នាំ ១៩៧៧ ទាំងស្រុង ហើយលើសផែនការថែមទៀត"]។ ឯកសារ D4.1.653 ទង់បដិវត្ត ចេញផ្សាយខែមិថុនា ឆ្នាំ ១៩៧៧ KH ERN 00062816 ["ដូចនេះ ត្រូតពិនិត្យមើលក្នុងក្រសួងមួយៗ មន្ទីរមួយៗ ការដ្ឋានមួយៗ សហករណ៍មួយៗ ត្រូវដកកម្លាំងណាបាន យកមកបង្កើនផល។ កុំឱ្យពង្រាយកម្លាំង"]។ ឯកសារ D4.1.867 ទង់បដិវត្ត ចេញផ្សាយខែ មីនា ឆ្នាំ ១៩៧៨ KH ERN 00064466 ["ក្នុងសហករណ៍មួយៗ ត្រូវរៀបចំជាប្រព័ន្ធចាត់តាំងគ្រប់ផ្នែកឱ្យកាន់តែល្អឡើង ជាស្រែ ជាដំណាំដាំដុះផ្សេងៗ សិប្បកម្ម សិប្បកម្មដែក សិប្បកម្មតម្បាញ មន្ទីរពេទ្យ កន្លែងធ្វើថ្នាំពេទ្យ កន្លែងចិញ្ចឹមទារក កន្លែងចិញ្ចឹមកុមារ។ យើងត្រូវរៀបចំឱ្យកាន់តែសមរម្យឡើង"]។ ឯកសារ D4.1.869 ទង់បដិវត្ត ចេញផ្សាយខែ កក្កដា ឆ្នាំ ១៩៧៨ KH ERN 00064503-04 [ការលុបបំបាត់វណ្ណៈ និងអ្នកបញ្ញើនៅក្នុងសហករណ៍ -ឥឡូវគ្រប់គ្នាជាសមាជិកពេញសិទ្ធិ និងកំណត់លក្ខណៈដើម្បីពិចារណាអំឡុងពេលជ្រើសរើសគណៈសហករណ៍]។

1099 សូមមើល ឧទាហរណ៍ ឯកសារ D64.1.25 FBIS តម្រូវការឱ្យសង្កត់ធ្ងន់លើការសន្សំសំចៃ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៧៦ EN ERN 00167833 [ការពិភាក្សាភាពចាំបាច់នៃសេដ្ឋកិច្ចក្នុងសហករណ៍មួយៗ និងការចាត់ចែងបដិវត្ត] ការផ្សាយតាមវិទ្យុសង្កត់ធ្ងន់លើសារៈសំខាន់នៃការជ្រើសរើសពូជ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៧៦ EN ERN 00167846-47។ ឯកសារ D64.1.30 FBIS មតិយោបល់របស់វិទ្យុស្តីពីលទ្ធផលឆ្នាំ ១៩៧៦ និងភារកិច្ចឆ្នាំ១៩៧៧ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ១៩៧៧ EN ERN 00168403 ["ចាប់តាំងពីដើមឆ្នាំ ១៩៧៦ និងពេញមួយឆ្នាំមក បងប្អូនយើងបានធ្វើការទាំងយប់ ទាំងថ្ងៃ ដើម្បីសាងសង់ប្រឡាយ ទំនប់ និងបណ្តាញបង្ហូរទឹកថ្មីដើម្បីដោះស្រាយបញ្ហាផ្គត់ផ្គង់ទឹកដើម្បីធ្វើស្រែ [...] ទាំងនោះ គឺជាគំរូដ៏អស្ចារ្យដែលយើងកោតសសើរ និងត្រូវតែព្យាយាមធ្វើតាម"] មតិយោបល់របស់វិទ្យុស្តីពីនយោបាយឆ្នាំ ៧៧ ភារកិច្ចកសិកម្ម ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៧៧ EN ERN 00168429 ["ភារកិច្ចនយោបាយរបស់យើងក្នុងឆ្នាំ ១៩៧៧ រួមមានការវាយសម្រុកដើម្បីការពារ និងកសាងប្រទេស និងដឹកនាំទៅរកការរីកចំរើន មហាអស្ចារ្យ មហាលោតផ្លោះ និងប្រកាន់ខ្ជាប់ទៅនឹងមូលដ្ឋានសំខាន់ គឺកសិកម្ម [...] ភារកិច្ចសំខាន់របស់យើងក្នុងឆ្នាំ ១៩៧៧ គឺបង្កើនការធ្វើស្រូវឱ្យបានច្រើនផង"]។ ឯកសារ D64.1.44 FBIS ផែនការដើម្បីអភិវឌ្ឍសហករណ៍កម្រិតខ្ពស់មុនឆ្នាំ ១៩៨០ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៧៨ EN ERN 00170069។

កម្មវិធីនយោបាយរបស់ ប.ក.ក ("ទុកក៏មិនចំណេញ ដកចេញក៏មិនខាត"[1100])។ កម្មករត្រូវគេចាត់ទុកដូចអត្ថប្រយោជន៍សេដ្ឋកិច្ច ជាជាងមនុស្ស។ ប៉ុន្មានឆ្នាំចុងក្រោយនេះ មេដឹកនាំ ប.ក.ក បានទទួលស្គាល់ថា ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនកម្ពុជាត្រូវបានបង្ខំឲ្យធ្វើការ និង "គ្មានសេរីភាព" នៅតាមសហករណ៍[1101]។ ដោយមិនខ្វល់នឹងការលះបង់ជីវិតមនុស្ស មេដឹកនាំបក្សកំណត់ផែនការផលិតកម្មខ្ពស់តាមការស្រមើស្រមៃ ដោយតម្រូវឲ្យប្រជាជនបង្កបង្កើនផលស្រូវឲ្យបានបីដងលើសទិន្នផលស្រូវមធ្យមប្រចាំឆ្នាំក្នុងទសវត្សរ៍ឆ្នាំ ១៩៦០[1102]។ ផែនការនេះត្រូវតែសម្រេចឲ្យបាន "ទោះក្នុងតម្លៃណាក៏ដោយ"[1103]។

---

1100 សូមមើល ឧទាហរណ៍ ឯកសារ D98/1.2.39 David Chandler,ប្រតិចារឹកថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ២០១២ ម៉ោង ១៣.៥៤.០២–១៣.៥៦.២០ ["សះ តើលោកអាចរកឃើញអ្វីបន្ថែមទៀតទេ ដែលឃ្លាមួយនិយាយថា "ទុកមិនចំណេញ ដកចេញមិនខាត" គេនិយាយទៅប្រជាជនថ្មី។ តើគេយកទៅអនុវត្តដែរឬទេ? បើសិនជាអនុវត្តក្នុងភាពជាក់ស្តែងនោះ វាចេញជាផលវិបាកដូចម្តេច? ឆ៖ គឺថា ឃ្លានេះធ្វើឲ្យប្រជាជនមានការភ័យខ្លាច ឲ្យគេប្រឹងធ្វើការ គេតែងតែនិយាយជាញឹកញាប់ [...]ចង់និយាយថា អ្នកឯងគ្មានតម្លៃទេ ប៉ុន្តែបើអ្នកឯងចង់នៅរស់ ធ្វើការឲ្យខ្លាំងទៅ។ ហើយយើងនឹងសម្រេចថាតើអ្នកឯងត្រូវរស់ ឬត្រូវស្លាប់ មួយថ្ងៃទៅមួយថ្ងៃ។ [...] នេះហើយជាពាក្យស្លោកទូទាំងប្រទេសដែលគេប្រើ"]។ ឯកសារ D1.3.33.12 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច KH ERN 00187662-63 ["សូវចាប់ច្រឡំ ១០ កុំឲ្យតែទុកខុសមួយ គឺជាការចោទប្រកាន់ត្រូវច្បាប់របស់ប្រជាជនខ្ញុំ ដែលរងទុក្ខខ្លោចផ្សាដោយសារការចាប់ចងដ៏ឧក្រិដ្ឋកតដាច់។ សុន សេន ហើយក៏ប្រហែលជាអ្នកដឹកនាំខ្មែរក្រហមផ្សេងទៀត ប្រើពាក្យលាក់ពុតថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ. ១១៧ ["បើអ្នកណាឈឺ ហើយទៅធ្វើការមិនរួច គឺត្រូវគេយកទៅសម្លាប់ចោលតែម្តង ដូចពាក្យស្លោកមួយថា "ទុកមិនចំណេញ ដកចេញក៏មិនខាត"]។

1101 ឯកសារ D4.1.965 អៀ ម៉េងទ្រី និង លឿង សូភ័ក្តិ កំណត់ត្រា (ខៀវ សំផន និង នួន ជា) ចុះថ្ងៃទី ០៩-១១ ខែ មិថុនា ឆ្នាំ ២០០៦ លេខ ERN 00000928, KH 00347036 ["នៅក្នុងសហករណ៍ប្រជាជនមិនមានសេរីភាពទេ តែពួកគេមានអាហារបរិភោគគ្រប់គ្រាន់"]។ ឯកសារ D4.1.37 កម្ពុជាប្រជាធិបតេយ្យ លេខ ៦៖ អំពីការក្តាប់ និងអនុវត្តមាគ៌ានយោបាយ ប្រមូលកម្លាំងរណសិរ្ស ប្រជាជាតិ ប្រជាធិបតេយ្យ របស់បក្ស ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៧៥ លេខ ERN EN 00244276, KH 00072404 ["គេទៅជាពលករ [...] អ្វីៗទាំងអស់នៅលើយើង [...] ម្យ៉ាងទៀត ស្ថិតនៅក្រោមការចាត់តាំងរបស់យើង។ សូម្បីតែសីហនុ ក៏មិនសូវសេរី"]។ ឯកសារ D69.1.42 ខៀវ សំផន៖ ការពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ លេខ ERN EN 00498302-03, KH 00380498-99 ["ពីព្រោះដោយសារតែមានការចាត់តាំងសហករណ៍តាំងពីឆ្នាំ ១៩៧១ ទៅហើយ ទើប ប.ក.ក [...] ក្តាប់មនុស្សបាន [...]។ ដូច្នេះ ត្រូវមានការបង្ខំសិនហើយ។ គឺបង្ខំឲ្យធ្វើការនឿយហត់ក្នុងសភាពខ្វះសព្វខ្វះគ្រប់"]។

1102 "ផែនការបួនឆ្នាំ" របស់បក្ស លើកទឹកចិត្តឲ្យផលិតស្រូវ ៥.៥ លានតោន នៅក្នុងឆ្នាំ ១៩៧៧, ៦.២៥ លានតោន នៅក្នុងឆ្នាំ ១៩៧៨ និង ៧ លានតោន នៅក្នុងឆ្នាំ ១៩៧៩ ប្រហែលជាបីដងនៃការផលិតស្រូវនៅក្នុងទសវត្សរ៍ ឆ្នាំ ១៩៦០។

សូមមើល ឯកសារ D4.1.38 ឯកសារបក្សកុម្មុយនិស្តកម្ពុជា ផែនការ ៤ឆ្នាំ កសាងសង្គមនិយមគ្រប់ផ្នែករបស់បក្ស ឆ្នាំ ១៩៧៧-១៩៨០ ដូចបានបោះពុម្ពផ្សាយនៅក្នុងសៀវភៅរបស់លោក ដេវីឌ ឆេនដ៍ល័រ និងអ្នកផ្សេងទៀត ចំណងជើង ផែនការ៤ឆ្នាំរបស់ប៉ុល ពត លេខ ERN EN 00104025, KH 00075831-32។ ឯកសារ D1.3.17.2 ក្រេហ្គ អេតជេសិន សៀវភៅមានចំណងជើងថា ការឡើងកាន់អំណាច និងការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ លេខ ERN EN 00393208។ ពាក់ព័ន្ធនឹងការជំរុញឱ្យផលិតតាមកូតា សូមមើល ឯកសារ D4.1.875 ទស្សនាវដ្តី យុវជន និងយុវនារី បដិវត្ត ប្រចាំខែ កុម្ភៈ ឆ្នាំ ១៩៧៦ ឯកសារ EN 00583759, KH 00063807 [“ធ្វើយ៉ាងណា បង្កើនផលស្រូវយើង មិនមែនឱ្យបានត្រឹមតែ១ហិកតា៣តោនប៉ុណ្ណោះទេ តែត្រូវឱ្យបាន៤ ៥ ៦ ៧ ៨ តោនក្នុងមួយហិកតាទៅទៀត។ ធ្វើការយ៉ាងនេះ ទើបហៅថា វាយសម្រុកដោយល្បឿនមហាលោតផ្លោះ”]។ ឯកសារ D1.3.19.1 សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ លេខ ERN EN 00182809, KH 00003136 [“សំណូមពរ [២] ដើម្បីតាមដានផែនការឱ្យជាប់ និងដោះស្រាយបញ្ហាឱ្យទាន់ពេលវេលា ក្នុងទិសដៅសម្រេច៣តោនក្នុង១ហិកតា”]។ ឯកសារ D1.3.27.10 កំណត់ហេតុនៃការប្រជុំយោធារបស់កម្ពុជាប្រជាធិតេយ្យ និងអនុលេខាកងពល លេខា និងអនុលេខាវរៈសេនាធំ ចុះថ្ងៃទី ២ ខែ សីហា ឆ្នាំ ១៩៧៦ លេខ ERN EN 00656576-77, KH 00052358-59 [អំពីយុទ្ធសាស្ត្រដើម្បីសម្រេចគោលនយោបាយ ៣ តោនក្នុងមួយហិកតា]។ ឯកសារ D1.3.27.11 កំណត់ហេតុនៃការប្រជុំយោធារបស់កម្ពុជាប្រជាធិតេយ្យ កំណត់ហេតុនៃការប្រជុំគណៈប្រចាំការ កងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៦ លេខ ERN EN 00183962, KH 00052372 [“២-ការខ្វះខាត៖ [...] ការសម្រេចភារកិច្ចស្រូវធ្ងន់ ៣ តោន ១ ហិកតាលើដីប្រភេទទីមួយ និងទីពីរ ក៏ពុំទាន់ធានាដែរ”]។ ឯកសារ D4.1.78 កំណត់ហេតុគណៈអចិន្ត្រៃយ៍ កំណត់ហេតុប្រជុំការងារ សង្គមកិច្ច សុខាភិបាល ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៧៦ លេខ ERN EN 00183369, KH 00017155 [មេដឹកនាំបក្សបានបញ្ជាក់ឡើងវិញថា បើសិនណាគេមិនអាចផលិតស្រូវបាន៣តោនក្នុង១ហិកតានោះ បក្សនឹងមិនអាចផ្គត់ផ្គង់ប្រជាជន ឬការពារប្រទេសបានទេ]។ ឯកសារ D4.1.883 ទស្សនាវដ្តីទង់បដិវត្តិ ចេញផ្សាយ ខែ មេសា ឆ្នាំ ១៩៧៦ លេខ ERN EN 00517866-68, KH 00062766 [ពិពណ៌នាអំពីការតស៊ូដើម្បីសម្រេចគោលដៅរបស់បក្សទាក់ទិននឹងប្រព័ន្ធទំនប់ភ្លឺស្រែ ដែលមានភាពយឺតយ៉ាវ ដោយសារ“នៅយឺត ពីព្រោះធ្វើធំពេក ស្អាតពេក ក្តាប់ទិសខុស” ដូច្នេះ កម្លាំងមនុស្សត្រូវរៀបចំឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ហើយថ្នាក់ដឹកនាំត្រូវបានណែនាំឱ្យ រក្សាទឹក សូម្បីតែមួយដំណក់ ក៏មិនឱ្យហូរចូលស្ទឹង។ ឯកសារនេះក៏ពិភាក្សាអំពីគោលដៅផលិតស្រូវ៣តោនក្នុង១ហិកតា ធ្វើជី និងរកគ្រាប់ពូជដែលផ្តល់ផលបានខ្ពស់បំផុតខណៈដែលដោះស្រាយបញ្ហាខ្វះចប ខ្វះពូថៅ និង“ខ្វះសព្វខ្វះគ្រប់”]។ ឯកសារ D1.3.24.1 ទស្សនាវដ្តី យុវជន និងយុវនារីបដិវត្ត ចេញផ្សាយខែ ឧសភា ឆ្នាំ ១៩៧៦ លេខ ERN EN 00357870-72, KH 00064005-09 [បរិយាយអំពីគោលដៅឆ្នាំ ១៩៧៦ របស់បក្សកុម្មុយនីស្ត ទាក់ទងនឹងការបង្កើនផលិតផលស្រូវឱ្យបាន៣តោន ក្នុង១ហិកតា ជាមធ្យម និងទូទាំងប្រទេសកម្ពុជា ព្រមទាំងភាពពាក់ព័ន្ធនឹងបក្ស]។ ឯកសារ D4.1.921 ឯកសារកម្ពុជាប្រជាធិបតេយ្យលេខ ៣៖ ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេស គ្រប់ផ្នែក ខែកញ្ញា ឆ្នាំ ១៩៧៥ លេខ ERN EN 00523569, KH 00072367 និង EN 00523574-75, KH 00072374-75 [ទទួលស្គាល់ថា ពួកគេត្រូវតែ “យើងត្រូវរៀបចំឱ្យបានឆាប់រហ័ស គឺកែប្រែពីកសិកម្មអន់ថយ ទៅកសិកម្មសម័យពី ១០ ទៅ ១៥ ឆ្នាំ [...] យើងឃើញថា រហ័សណាស់។ [...] ពីឆ្នាំ ១៩៧៧ ត្រូវធ្វើឱ្យបានផល ៣ តោន ក្នុង១ហិកតា។ នៅវៀតណាមខាងជើង គេ

323. ការជម្លៀសប្រជាជនដោយបង្ខំបានបង្កើនចំនួនមនុស្សយ៉ាងឆាប់រហ័សនៅតាមសហករណ៍ និងការដ្ឋាន[1104] ដែលនៅទីនោះ គ្រប់ទិដ្ឋភាពនៃជីវិតត្រូវគេគ្រប់គ្រង។ ប.ក.ក សម្រេចលើលំនៅ

---

ថា ៤០ ឆ្នាំទៀត ទើបគេម្ចាស់ការលើទឹកបាន ១០០ ភាគរយ។ បើប្រៀបធៀបនឹងយើង វៀតណាមដើរ ៣០ ឆ្នាំ យើងដោះតែ ១០ ឆ្នាំ។ [...] ឯរបៀបច្រូតស្រូវទៀត ក៏យឺត [...] តាមការប៉ាន់ប្រម៉ាណ យើងអាចលក់ស្រូវក្នុងឆ្នាំ ១៩៧៧-១៩៨០ បានពីរលានតោន ដល់ឆ្នាំ ១៩៨០ កាន់តែលក់បានច្រើនទៀត]។

1103 ឯកសារ D234/2.1.33 ការប្រារព្ធខួបថ្ងៃទី ១៧ មេសា នៅទីក្រុងភ្នំពេញ ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៨ លេខ ERN EN S 00010564 [ខៀវ សំផន បានប្រាប់កម្មករចំនួន ២០,០០០ នាក់ និងកងទ័ពឲ្យ "វាយសម្រុកបំពេញផែនការផលិតផលស្រូវក្នុងឆ្នាំ ១៩៧៨ ដោយទទួលបានផលស្រូវ ៣.៥ តោន ក្នុង១ហិកតា និងគោលដៅ ៧ តោនក្នុង ១ ហិកតា តាមគ្រប់លទ្ធភាព"]។ សូមមើលផងដែរ ឯកសារ D4.1.45 ទស្សនាវដ្ដី យុវជន យុវនារីបដិវត្ត ចេញផ្សាយខែមករា-កុម្ភៈ ឆ្នាំ ១៩៧៨ លេខ ERN EN 00278727, KH 00063511 ["ត្រូវតែហ៊ានលះបង់ទាំងអស់ ទោះបីជាវាត្រូវការកម្លាំងកាយប៉ុណ្ណា កម្លាំងលះបង់ខាងសតិអារម្មណ៍ប៉ុណ្ណា ក៏ដោយ ឬក៏ត្រូវធ្វើពលីកម្មដល់អាយុជីវិតក៏ដោយ]។

1104 សូមមើលឧទាហរណ៍ ឯកសារ D4.1.65 កំណត់ហេតុអំពីទស្សនកិច្ច អចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ថ្ងៃទី ២០-២៤ ខែសីហា ឆ្នាំ ១៩៧៥ លេខ ERN EN 00183001, KH 00008489 [សហករណ៍ស្រូបប្រជាជនថ្មីចេញពីទីក្រុងទាំងអស់ ពិសេស ក្រុងភ្នំពេញ ហើយនៅពាយ័ព្យ គឺបាត់ដំបង។ ប្រជាជនថ្មីរាប់សែននាក់នៅបាត់ដំបង មានសមាសភាពអាក្រក់គ្រប់យ៉ាង។ តែសហករណ៍ស្រូបយកអស់ ផ្គត់ផ្គង់ស្បៀង ព្រមទាំងចាត់ចែងកម្លាំង ធ្វើការងារទៀត"]។ ឯកសារ D69.1.42 ខៀវ សំផន ការពិចារណាអំពីប្រវត្តសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ លេខ ERN EN 00498281, KH 00380460-61 [ខៀវ សំផន ទទួលស្គាល់អំពីការពង្រីកយ៉ាងឆាប់រហ័សសហករណ៍កម្រិតខ្ពស់]។ ឯកសារ D4.1.882 ទស្សនាវដ្ដីទង់បដិវត្តិ ចេញផ្សាយនៅខែ កុម្ភៈ-មីនា ឆ្នាំ ១៩៧៦ លេខ ERN EN 00517828, KH 00063207-08 ["ក្រោយរំដោះទូទាំងប្រទេសភ្លាម ពេលដែលប្រជាជន រាប់ម៉ឺន រាប់សែននាក់ជម្លៀសចេញពីទីក្រុងនានា ទៅកាន់មូលដ្ឋានជនបទភ្លាម"] លេខ ERN EN 00517837, KH 00063220 ["ហើយម្យ៉ាងទៀត ប្រជាជនទីក្រុងនានា ជិត ៣ លាននាក់ ត្រូវផ្លាស់ប្ដូរទីកន្លែងទៅរស់នៅបង្កបង្កើនផលស្រូវឯជនបទ"]។ ឯកសារ D4.1.784 កំណត់ហេតុស្ដាប់ចម្លើយរបស់ ពេជ្រ ជឹម លេខ ERN EN 00379308, KH 00373392 ["ប្រជាជនចេញពីភ្នំពេញមានច្រើនណាស់។ គេធ្វើដំណើរតាមផ្លូវ ហើយគេចូលទៅតាមភូមិ តាមឃុំ ដែលនៅតាមដងផ្លូវ។ ដូច្នេះ យើងត្រូវតែប្រមូលពួកគេ និងរៀបចំពួកគេដាក់ទៅតាមភូមិឃុំ"]។ ឯកសារ D4.1.587 កំណត់ហេតុស្ដាប់ចម្លើយរបស់ ជួប ប្រសិទ្ធ លេខ ERN EN 00346944, KH 00348327 ["ទាក់ទងនឹងការជម្លៀសប្រជាជននៅទីក្រុង គឺត្រូវបានគេលើកហេតុផលថា សហរដ្ឋអាមេរិកអាចនឹងទម្លាក់គ្រាប់បែក ហើយថាមានការចាំបាច់ដើម្បីប្រឈមមុខទៅនឹងគ្រោះទុរភិក្ស ត្រូវតែមានមនុស្សនៅជនបទដើម្បីបង្កបង្កើនផលកសិកម្ម"]។ ឯកសារ D4.1.447 កំណត់ហេតុស្ដាប់ចម្លើយរបស់ ចក់ មល្លី លេខ ERN EN 00288203, KH 00273429-30 ["សៈ តើលោកដឹងថា ចំនួនប្រជាជនជម្លៀសពីភូមិភាគបូព៌ាមកខេត្តពោធិ៍សាត់ប៉ុន្មាន? ឆៈ គ្រាន់តែដឹងថា ជាប្រជាជនភូមិភាគបូព៌ា មានចំនួនរាប់ពាន់រាប់ម៉ឺននាក់ឯណោះ ប៉ុន្តែខ្ញុំមិនបានចំនួនពិត [...] ពេលមកដល់ត្រូវបានគេបែងចែកតាមសហករណ៍"]។

ស្ថានរបស់ប្រជាជន[1105] ហាមឃាត់ការដើរហើរ[1106] បង្ខំប្រជាជនឱ្យធ្វើការច្រើនម៉ោងដើម្បីសម្រេចឱ្យបានផែនការខ្ពស់[1107] បំបែកសមាជិកគ្រួសារ[1108] រឹតត្បិតសេរីភាពក្នុងការបញ្ចេញមតិ

---

1105 សូមមើលផងដែរ ឧទាហរណ៍ ឯកសារ D98/3.1.138 ប្រតិចារិក ឡាយ បូរី ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ ម៉ោង 09.31.41-09.33.35 ["មុននឹងខ្ញុំមកនៅផ្ទះឯកជន ដែលអង្គការចែកដីម្ដុំៗហ្នឹង"]។ ឯកសារ D11/160/4.1 ប្រតិចារិក អោ រី ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ ម៉ោង 09.19.56-09.21.12 [នៅខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ "មានគេធ្វើផ្ទះទុកឱ្យរួចជាស្រេច ផ្ទះល្វែង គេកាន់--ខណ្ឌមួយបន្ទប់ៗ"]។ ឯកសារ D4.1.816 កំណត់ហេតុស្ដាប់ចម្លើយរបស់ សៅ ប៊ាន ឆ.21 [ក្នុងខេត្តតាកែវ ភូមិភាគនិរតី៖ "ខ្ញុំឃើញមានច្រើន [ប្រជាជន១៧មេសា] ធ្វើរោងតូចៗហែរគ្នាដោយបាំងស្លឹកត្នោត ឱ្យរស់នៅម្តុំ"]។ ឯកសារ D114/33 កំណត់ហេតុស្ដាប់ចម្លើយរបស់ ហែម អាង ឆ. 217 [ក្នុងសហករណ៍៧ តំបន់ ៣៧៖ "អត់មានផ្ទះពិតប្រាកដទេ គេដាក់ឱ្យរស់នៅក្នុងផ្ទះមួយពីបីខែ ក្រោយមក គេឱ្យទៅផ្ទះផ្សេងពីរបីខែទៀត"]។ ឯកសារ D4.1.552 កំណត់ហេតុស្ដាប់ចម្លើយរបស់ កែវ ណេ [...] លេខ ERN EN 00327168, KH 00251678-79 [នៅស្រែអំបិលកំពង់ កណ្ដាល ខេត្តកំពត ភូមិភាគនិរតី៖ "ផ្ទះរស់នៅគេធ្វើរោងវែងៗ មានជញ្ជាំងស្លឹកព័ទ្ធជុំវិញ [...] ក្នុងមួយកងហា គេធ្វើរោងវែងមួយ ហើយគេឱ្យដេកតាមក្រុមទៀត ដើម្បីប្រធានក្រុមងាយស្រួលក្នុងការពិនិត្យ អ្នកណាទៅធ្វើការ ឬមិនទៅធ្វើការ]។

1106 សូមមើលឧទាហរណ៍ D4.1.965 អៀ ម៉េងទ្រី និង សូភ័ក្ត្រ លឿង កំណត់ត្រា (ខៀវ សំផន និង នួន ជា) ចុះថ្ងៃទី ០៩-១១ ខែ មិថុនា ឆ្នាំ ២០០៦ លេខ ERN 00000928, KH 00347036 ["នៅក្នុងសហករណ៍ ប្រជាជនមិនមានសេរីភាពទេ]។ ឯកសារ D11/61/3.1 ប្រតិចារឹក រី ពៅ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ម៉ោង 10.59.54-11.05.56 [ក្នុងខេត្តតាកែវ ភូមិភាគនិរតី៖ "កាលសម័យនោះ អ៊ីចឹងការយើងធ្វើកំពុងពលកម្មក្នុងការដ្ឋានហ្នឹង បើត្រូវបត់ដៃ ឬបទជើងអី គេឱ្យយើងជម្រាបមេពួក ឬមេក្រុមរបស់គេ ថាខ្ញុំទៅបត់ជើង ឬមួយបទដៃ ហើយរយៈពេលប៉ុន្មាននាទី ឬប៉ុន្មានម៉ោង។ កាលណាបើយើងទៅយូរ ហ្នឹងគេថាយើងសតិអារម្មណ៍"] ម៉ោង 11.04.00-11.05.56 ["គឺគ្មានអ្នកណាប៊ានដើរសេរី"]។ ឯកសារ D114/166 កំណត់ហេតុស្ដាប់ចម្លើយរបស់ ភិន យាង ឆ.30 ["គេមិនឱ្យដើរទៅផង តែដើរទៅគេចាប់"]។ ឯកសារ D114/33 កំណត់ហេតុស្ដាប់ចម្លើយរបស់ ហែម អាង ឆ.265, ឆ.267 [ក្នុងសហករណ៍៧ តំបន់ ៣៧៖ "ខ្ញុំមិនដើរទៅណាទេ ព្រោះខ្ញុំដឹងថា ខ្លួនឯងជាមនុស្សគ្មានសិទ្ធិ [...] ស៖ ចុះបើចង់ចេញពីសហករណ៍ក្នុងពេលយប់ តើបានទេ? ឆ. 267 ៖ អត់បានទេ។ យប់គេមិនឱ្យដើរទេ"]។ ឯកសារ D114/53 កំណត់ហេតុស្ដាប់ចម្លើយរបស់ អ៊ុក សុខ ឆ.92 [ក្នុងកំពង់សោម៖ "អត់ទេ សម័យនោះ យើងអត់ប៊ានទៅកន្លែងណាផ្សេង ក្រៅពីកន្លែងដែលគេឱ្យយើងនៅនោះឡើយ"]។

1107 សូមមើលឧទាហរណ៍ D114/162 កំណត់ហេតុនៃការស្ដាប់ចម្លើយ ញ៉ា ជាម ឆ.43 [បញ្ជាក់ថា គាត់បានប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ថា អ្នកទទួលខុសត្រូវកងពល ជាអ្នកចាត់តាំងកូតា លើសពីកូតាក្នុងផែនការ ហើយបើសិនជាមានអ្នកណាមិនអាចសម្រេចកូតានោះទេ អ្នកនោះនឹងត្រូវរងទណ្ឌកម្ម]។ ឯកសារ D10.1.65 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុក ភន លេខ ERN EN 00372930, KH 00368660 ["ថ្នាក់លើជាអ្នកដាក់ផែនការ? ស៖ តើលោកដឹកនាំប្រជាជនធ្វើបានគ្រប់ផែនការដែរឬទេ? ឆ៖ ថ្នាក់លើកំណត់ឱ្យបានបីតោនមែន តែយើងធ្វើមិនបានទេ"] ឯកសារ D114/156 កំណត់ហេតុស្ដាប់ចម្លើយ សឹង ណុច ឆ.98 ["គេប្រជុំ គេប្រាប់ថា អង្គការដាក់ទិសដៅឱ្យរើសដូង ២០០

ផ្ដែ ក្នុងមួយនាក់ បើរើសមិនបានទេ គេដាក់ឱ្យឈរហាលថ្ងៃហាលភ្លៀង ឬក៏ធ្វើការងារធ្ងន់"]។ ឯកសារ D4.1.560 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ ជី លេខ ERN EN 00282347, KH 00271398 ["ការជីកប្រឡាយ គេដាក់ផែនការក្នុងម្នាក់ត្រូវជីកបីម៉ែត្រគូប កាប់ដី ហើយរែកដោយខ្លួនឯង ហើយភាគច្រើនគេធ្វើមិនគ្រប់ផែនការនោះទេ មានប្រជាជនប្រហែលសាមសិបភាគរយប៉ុណ្ណោះដែលអាចធ្វើគ្រប់ផែនការនោះ"]។ ឯកសារ D4.1.549 កំណត់ហេតុស្តាប់ចម្លើយ ជីង ភឿន ហៅ អួន សាភឿន លេខ ERN EN 00705443, KH 00251668 ["អំពក(ស្រែ)តូច ទទឹងជប់ម៉ែត្រ បណ្ដោយម្ភៃម៉ែត្រ កើតអំបិលប្រហែលពីរទៅបីតោន។ គេឱ្យរែកអំបិលទាំងអស់ឱ្យអស់ក្នុងរយៈពេលតែមួយថ្ងៃ បើរែកមិនអស់ទេ ត្រូវធ្វើការទាំងយប់ទៀត រហូតទាល់អស់អំបិល"]។ ឯកសារ D4.1.538 កំណត់ហេតុស្តាប់ចម្លើយ ជុំ លន លេខ ERN EN 00250066, KH 00241998 ["នៅពេលយប់គឺរែកអំបិលតាំងម៉ោង៧រហូតដល់ម៉ោង១យប់ ត្រូវរែកឱ្យអស់៣តោនក្នុងមួយក្រុម ហើយបើកម្មករណាមិនទៅធ្វើការ ត្រូវប្រធានកងមកតាមរកដល់កន្លែងដេក។ ការងាររែកអំបិលនេះ គឺត្រូវធ្វើឱ្យរួច តាមការកំណត់ទើបឈប់សម្រាក គឺរែកទាំងថ្ងៃទាំងយប់"]។ ឯកសារ D4.1.549 កំណត់ហេតុស្តាប់ចម្លើយ ជីង ភឿន ហៅ អួន សាភឿន លេខ ERN EN 00705442, KH 00251667 ["ពេលណាមេឃចង់ភ្លៀង ហើយមានអំបិលដុះច្រើន គេឱ្យធ្វើការបីយប់បីថ្ងៃជួនគ្នា អត់មានពេលសម្រាកក៏មាន"]។ ឯកសារ D4.1.387 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន ហេង លេខ ERN EN 00163697, KH 00163690 ["គេឱ្យខ្ញុំធ្វើស្រែ។ ការងារធ្វើស្រែនៅទីនោះ គឺមានការលំបាកខ្លាំងណាស់ ពេលព្រឹកចាប់ពីម៉ោងបួនរហូតដល់ម៉ោង១១ ឬ១២ ថ្ងៃត្រង់ ទើបឱ្យហូបបាយ ពេលហូបបាយរួចអត់មានឈប់សម្រាកទេ គឺបន្តធ្វើការរហូតដល់ម៉ោងប្រាំ ទើបឈប់ហូបបាយ ក្រោយពីហូបបាយល្ងាច គេបន្ថែមការងារឱ្យជួយដកសំណាប ឬក៏រែកដីស្រះរហូតដល់ម៉ោង១១ ឬ១២យប់ទើបសម្រាក"]។ ឯកសារ D114/96 កំណត់ហេតុស្តាប់ចម្លើយ ចេង ឡុង ឆ.69 ["ខ្ញុំអាចនិយាយបានថា ប្រជាជនដែលធ្វើការនៅកន្លែងលើកទំនប់ ពិតជាធ្វើការលំបាកណាស់ ព្រោះប្រជាជនធ្វើការទាំងយប់ទាំងថ្ងៃ"]។ ឯកសារ D114/198 កំណត់ហេតុស្តាប់ចម្លើយ ពីន សំអួន ឆ.152 ["តែគេមិនអនុញ្ញាត លុះត្រាណាអ្នកនោះគេមិនអាចធ្វើការបាន ហើយវារនៅកន្លែងធ្វើការ ទើបគេអនុញ្ញាត"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ ផ សួន ឆ.46 ["ពួកខ្ញុំធ្វើការពេញមួយអាទិត្យ និងពេញមួយខែ ពុំមានពេលសម្រាកទេ លើកលែងតែមានការប្រជុំ ទើបបានឈប់សម្រាកខ្លះ។ ក្នុងប្រជុំនោះ គេនិយាយតែការខិតខំប្រឹងប្រែងធ្វើការ"]។

1108 សូមមើលឧទាហរណ៍ ឯកសារ D11/61/3.1 ប្រតិចារឹក រី ពៅ ចុះថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ម៉ោង 11.28.25-11.30.25 [ខេត្តតាកែវ ភូមិភាគនិរតី៖ "ពេលសម័យនោះ ប្រុសនៅដោយប្រុស ស្រីនៅដោយស្រី ហ្នឹងការរស់នៅតាមវ័យ។ អ៊ីចឹង វ័យយុវជននៅកន្លែងវ័យយុវជន វ័យកុមារនៅតាមកងកុមារ វ័យចាស់នៅតាមវ័យចាស់ វ័យកសិករនៅតាមកសិករអ៊ីចឹងបាទ។ នៅរៀងៗគ្នា មិនមែនមនុស្ស ១០០នាក់ហ្នឹងឱ្យខ្ញុំស្គាល់ គឺមិនអាចទេ ជួនវាវ័យខុសគ្នាអ៊ីចឹងមិនអាចស្គាល់បានទេ បាទ"]។ ឯកសារ D234/2.1.132 ប្រតិចារឹក មុំ វុន ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 14.26.39-14.29.12 [ខេត្តសៀមរាប ភូមិភាគឧត្តរ "នៅក្នុងរបបខ្មែរក្រហម គេបំបែកតើ ប្ដីទៅផ្សេង ប្រពន្ធទៅផ្សេង កូនទៅផ្សេង អត់មាននៅជុំគ្នាទេ។ កូននៅកងចល័តផ្សេងទៅ ម៉ែនៅខាងចល័តផ្សេង ឪពុកខាងចល័តផ្សេង។ អាតូចៗនៅជាមួយយាយៗ [...] ប្ដីទៅឯណេះ ប្រពន្ធក៏ទៅខាងណោះទៅ អត់ដឹងផែនការគេបំបែកនោះ គេបំបែករបៀបណាទេ។ ហើយបំបែកនោះមិនមែន កូនៗក៏បំបែក អត់បានវិលមកផ្ទះវិញទេ ទៅសម្រាកនៅការដ្ឋាន"]។ ឯកសារ D234/2.1.37 កាស៊ូមិ ណាកាហ្គាវ៉ា អំពើហិង្សាលើយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម៖ រឿងរ៉ាវរបស់អ្នកនៅរស់រាន

តាមរយៈទម្រង់ផ្សេងៗនៃការគ្រប់គ្រងលើផ្លូវចិត្ត[1109] ព្រមទាំងផ្តល់អាហារមិនគ្រប់គ្រាន់[1110] និងការថែទាំវេជ្ជសាស្ត្រមិនសមស្រប[1111]។ ការងារលំបាកខ្លាំងត្រូវបានធ្វើ ដោយគ្មានម៉ាស៊ីន

---

មានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) លេខ ERN EN 00421891, KH 00738344 ["សមាជិកគ្រួសារនីមួយៗត្រូវបានបំបែកចេញពីគ្នាដើម្បីជាការជួយដល់មូលហេតុបដិវត្តន៍។ ក្មេងៗត្រូវបានបំបែកចេញពីឪពុកម្តាយរបស់គេ ដើម្បីធ្វើការនៅក្នុងក្រុមចល័ត ឬ ក្នុងនាមជាទាហានកុមារ"]។ ឯកសារ D234/2.1.34 កាទ្រីណា ណាថាលី "ខ្ញុំដឹងថាព្រលឹងខ្ញុំចេញពីខ្លួន"៖ ការសិក្សាអំពីហិង្សាយេនឌ័រក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងខេត្តបាត់ដំបង និងខេត្តស្វាយរៀង លេខ ERN EN 00992134 ["ប្តី ប្រពន្ធ ឪពុកម្តាយ និងកូនៗ ជានិច្ចកាល ត្រូវបានបំបែកតាមកងការងារផ្សេងៗ ឬក៏ត្រូវបានបញ្ជូនទៅទីតាំងភូមិសាស្ត្រនានា [...] ទោះបីមានការប្រតិបត្តិផ្សេងពីគ្នាក៏ដោយ ក៏ជីវិតគ្រួសារដែលប្រជាជនខ្មែរធ្លាប់ស្គាល់ពីមុនមក ត្រូវបានផ្លាស់ប្រែយ៉ាងខ្លាំង នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ គឺនៅតាមឋានៈជាសារវន្តដែលគេកត់សម្គាល់ឃើញបំផុតក្នុងរបបហ្នឹង ហើយនៅតាមទីតាំងភូមិសាស្ត្រផ្សេងៗ"]។

1109 តាមរយៈការប្រើប្រាស់ការទិតៀន និងវគ្គស្វ័យទិតៀនដើម្បីប្តូរប្រព័ន្ធជំនឿពីមុន៖ ឯកសារ D54/74.1.12 រំឭកខួបលើកទីបី នៃការចាត់តាំងសហករណ៍កសិករ ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៦ លេខ ERN EN 00636026, KH 00442230 ["ការងារនយោបាយ-សតិអារម្មណ៍ ឃោសនា អប់រំ សន្និសីទ ជម្រៅ ត្រូវធ្វើឱ្យជាប់ [...] រៀនសូត្រជាវគ្គខ្លីៗ ១ម៉ោងឬ២ម៉ោង ឱ្យញឹកញាប់។ ឆ្លៀតពេលសម្រាកបំប៉នកម្លាំងផង រៀនសូត្រផង"]។ ឯកសារ D234/2.1.99 ប្រតិចារឹក អាឡេចសាន់ឌ័រ ហ៊ិនតុន ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 15.15.29-15.18.29 ["បក្សកុម្មុយនីស្តកម្ពុជា ហើយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ គឺគេព្យាយាមរក និងបង្កើតនូវសង្គមដែលធ្វើការសម្រេច ឬក៏ដុសខាត់សតិអារម្មណ៍របស់មនុស្ស ហើយប្រែទៅជាប្រជាជនបដិវត្តន៍បរិសុទ្ធ។ [...] លោកអាចមើលឃើញបញ្ហានេះនៅក្នុងការប៉ុនប៉ងបញ្ជូនមនុស្សចេញ [...] តាមរយៈយន្តទិតៀន ស្វ័យទិតៀន និងតាមរយៈការអប់រំកែប្រែខ្លួនឯង។ [...] ខ្ញុំសូមបញ្ជាក់ដោយសង្ខេប គំនិតអំពីវគ្គទិតៀន និងស្វ័យទិតៀនគ្នានេះ ចេញមកពីការដឹងថា សតិអារម្មណ៍បដិវត្តន៍ស្ថិតក្នុងសភាពមិនស្ថិតស្ថេរ។ មានន័យថា គេត្រូវដុសខាត់ៗសតិអារម្មណ៍របស់មនុស្សទាំងអស់នោះជាប្រចាំ ហើយត្រូវឱ្យបុគ្គលនោះចូលរួមគ្នានិយាយ និងពិនិត្យមើលចំណុចខ្សោយរបស់ខ្លួន ហើយថាតើពួកគេត្រូវបាននាំឱ្យធ្វើខុសដោយរបៀបណា។ ដូច្នេះ វាជាយន្តការប្រយុទ្ធជានិច្ច"]។ ដោយហាមប្រាម និង/ឬ ព្យាយាមកម្ទេចប្រភពនៃភាពស្មោះត្រង់ មនោសញ្ចេតនា និងអត្ថន័យនៅក្នុង ក្រុមគ្រួសារ៖ ឯកសារ D114/297.1.28 ប្រតិចារឹក ជា ឌៀប ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 15.13.39-15.16.20 [នៅពេលប្រជុំនៅទីក្រុងភ្នំពេញ ក្នុងឆ្នាំ ១៩៧៥ លោកខៀវ សំផន បានណែនាំថា "កុំអាល័យតែគិតម៉ែឪ នឹកម៉ែឪ គិតតែខំប្រឹងធ្វើការជូនបក្ស ជូនរដ្ឋទៅ រឿងម៉ែឪទុកមួយឡែក] ម៉ោង 15.16.20-15.18.25 ["កាត់ផ្តាច់ឪពុកម្តាយបងប្អូន [...] អង្គការប្រាប់ថា [...] ក្រោមការគ្រប់គ្រងរបស់អង្គការ មិនមែនទៅចាំម៉ែឪ អាល័យតែទៅរកម៉ែរកឪទៀតទេ គឺអង្គការជាម៉ែឪហើយ"]។ ឯកសារ D234/2.1.116 ប្រតិចារឹក ហ៊ឹម ហ៊ុយ ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង 09.24.06-09.25.48 [ជាសាក្សី និងជាអ្នកយាមនៅ ស-២១ បានរៀបរាប់ប្រាប់ថា "ព្រោះគេបង្រៀនសូត្រនេះ ក៏បង្រៀនតែខ្ញុំមួយដែរ គឺបង្រៀនទាំងអស់គ្នា។ ម្នាក់ៗជាកូនអង្គការ មិនមែនកូនម៉ែឪយើងទេ ម៉ែឪយើងគឺគ្រាន់តែបានបង្កើតយើងប៉ុណ្ណោះ [...] តែគុណមានតែអង្គការទេ ជាគុណ

យើង។ អ៊ីចឹង យើងត្រូវគោរព អង្គការម៉ែឪយើង អង្គការឱ្យធ្វើអី គឺយើងត្រូវធ្វើហ្នឹង"]។ ឯកសារ D1.3.17.1 អេលីហ្សាបែត បេ៊កខ័រ សៀវភៅមានចំណងជើងថា នៅពេលដែលសង្គ្រាមរលត់ទៅ៖ ប្រទេសកម្ពុជា និងបដិវត្តន៍ខ្មែរក្រហម លេខ ERN EN 00237929, KH 00232298-99 ["ពួកខ្មែរក្រហមដឹងខ្លួនថា ត្រូវធ្វើបារម្ភដោយលក្ខណៈគ្រប់បែបយ៉ាងនៃសេចក្តីស្រលាញ់ ឬការជំពាក់ចិត្ត៖ រវាងប្តី និងប្រពន្ធ ឪពុក និងកូន មិត្តភក្តិ និងសហសេវិក។ មនុស្សទាំងអស់តោងតែជម្រុះជីវិតឯកជនរបស់ខ្លួនចោល"] លេខ ERN EN 00237930-31, KH 00232300 ["តាមលក្ខណៈវិនិច្ឆ័យរបស់ជនជាតិអាស៊ី ជនជាតិខ្មែរជាមនុស្សដែលជំពាក់ចិត្តនឹងគ្រួសារខ្លាំងជាទីបំផុត។ ប្រាកដណាស់ការជំពាក់ជិតនេះ ជាធាតុផ្សំបង្កជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរចំពោះ "អង្គការ" ហើយមតិណែនាំស្ទើរតែទាំងអស់របស់ពួកកុម្មុយនីស្ត បានតម្រង់ទៅរកការរំលាយគ្រួសារចោល"]។ ឯកសារ D54/74.1.20 ហ្វីលីព ស្សូត សៀវភៅមានចំណងជើងថា ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ លេខ ERN EN 00396533 ["ក្រុមគ្រួសារនៅតែមាននៅឡើយ [...] ប៉ុន្តែ ទំនាក់ទំនងសមាជិកក្នុងគ្រួសារ ត្រូវបានកាត់ផ្តាច់នៅក្នុងសហគមន៍ដ៏ធំមួយ។ ម្តាយមិនគួរនឹងជំពាក់វាក់វិននឹងកូនៗរបស់ខ្លួនខ្លាំងពេកទេ តាម ប៉ុល ពត ប្រាប់ទៅគណៈមជ្ឈិម"]។ ឯកសារ D234/2.1.37 កាស៊ូមិ ណាកាហ្គាវ៉ា៖ អំពើហិង្សាលើយ៉េនឌ័រក្នុងអំឡុងរបបខ្មែរក្រហម៖ រឿងរ៉ាវរបស់អ្នកនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) លេខ ERN EN 00421891, KH 00738344 ["គោលនយោបាយមួយក្នុងចំណោមគោលនយោបាយរបស់ អង្គការ គឺដើម្បីបំផ្លាញរចនាសម្ព័ន្ធប្រពៃណីគ្រួសារកម្ពុជា។ ជាច្រើនទស្សវត្សរ៍ មកហើយប្រជាជនកម្ពុជាបានបង្កើតនូវចំណងទំនាក់ទំនងជិតដិតក្នុងចំណោមសមាជិកគ្រួសារ ជាមួយនឹងសមាជិកគ្រួសារសាច់ឆ្ងាយ ហើយការចិញ្ចឹមជីវិតរបស់ពួកគេ គឺឈើលើមូលដ្ឋានកសិកម្ម។ វាមាននូវភាពជឿជាក់គ្នាទៅវិញទៅមក រវាងសមាជិកគ្រួសារ ហើយសហគមន៍ ត្រូវបានបង្រួបបង្រួមគ្នាយ៉ាងរឹងមាំ។ របបខ្មែរក្រហមបានព្យាយាមបំផ្លាញរចនាសម្ព័ន្ធប្រពៃណីនោះ ដើម្បីជាការឈានទៅដល់ការសម្រេចបដិវត្តយ៉ាងឆាប់រហ័ស"]។ សាសនា៖ ឯកសារ ប្រតិចារឹក ដេវីដ ឆេនដ័ល័រ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ ម៉ោង 15.48.38-15.49.26 ["គឺថាមិនអាចអនុញ្ញាតឱ្យមានសាសនាទាំងអស់ គឺៗគេចាត់ទុកថាជាប្រតិកិរិយា [...] រដ្ឋធម្មនុញ្ញហ្នឹងគឺថា ណែនាំកំណត់ជាឃ្លាមួយ គឺថាដើម្បីឱ្យបរទេសគេយល់ថា មិនសូវអាក្រក់ គឺថាគឺ--ហើយគេគ្រាន់តែចែងថា មានសាសនាដើម្បីកុំឱ្យឃើញថា គេមិនអនុញ្ញាតឱ្យមានសាសនា"]។ ឯកសារ D234/2.1.100 ប្រតិចារឹក អាឡេចសានឌ័រ ហ៊ីនតុន ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 11.11.29-11.16.56 [ការបំផ្លាញវត្តអារ៉ាម និងពុទ្ធបដិមាកររបស់របបនោះ គឺជា "បំផ្លាញសសរស្តម្ភកណ្តាលនៅក្នុងជីវិតរបស់ប្រជាជនកម្ពុជា"]។ ឯកសារ D11/91/3 ប្រតិចារឹករបស់ ប៊ុន សារឿន ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៥ ម៉ោង 10.38.22-10.39.55 ["រឿងអារម្មណ៍ខ្ញុំ វានឹកឃើញថា វាសោកស្តាយដែរ កន្លែងធ្លាប់បូជាវាដូចថា វាគ្មានទីពឹងអីទាំងអស់។ វាសាសនាក៏វាអស់ ណាមួយទៅវាបាត់បង់គោរពបូជា ដឹងទៅធ្វើស្អីនៅកន្លែងណាកើត វាមិនដែលជួបប្រទះ វាមិនដែលឃើញ។ ទើបតែបានជំនាន់ហ្នឹងបានខ្ញុំឃើញ របៀបរបបហ្នឹង វាដូចជាអស្ចារ្យពេកហើយ"]។ ឯកសារ D11/523/3 ប្រតិចារឹករបស់ ម៉ើ ពៅ ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 09.28.12-09.32.26 ["ឪពុកខ្ញុំស្លាប់ដោយសារមូលហេតុគាត់ជាជនជាតិចាម កាន់សាសនាអ៊ីស្លាម ហើយគាត់ជឿជាក់ទៅលើសាសនា គាត់មិនធ្វើតាមអង្គការកំណត់ [...] ក្នុងរបបនោះ គ្មានសាសនាទេ"]។ ឯកសារ D234/2.1.65 ប្រតិចារឹករបស់ ជាំង ស្រីមុំ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥ ម៉ោង 10.59.25-11.01.53 ["គេថា គ្មានសាសនា [...] គេណែនាំឱ្យកុំឱ្យមានជំនឿទៅលើព្រះពុទ្ធសាសនា [...] ទាំងអស់ហ្នឹង សុទ្ធតែអបិយជំនឿមិនពិតប្រាកដ"] ម៉ោង

13.48.23-13.56.33 [ប្រជុំថ្នាក់ស្រុកនៅអង្គរកា និងអង្គរលាយ មេដឹកនាំបានបញ្ជាក់ច្បាស់ថា ប្រជាជនមិនគួរ "គោរពបូជារូបបដិមាករទៀតទៅ ដែលគ្រាន់តែជាកម្មេចថ្ម"]។ រាជាធិបតេយ្យ៖ ឯកសារ D1.3.17.2 ក្រេហ្គ អេត ជេសិន៖ ការឡើងកាន់អំណាច និងការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ លេខ ERN EN 00393335-43 [សូមមើល "សម្លាប់ស្ដេចពីរអង្គ"]។ លើកមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាទុកជាអង្គការដែលគ្មានឈ្មោះ មាននៅគ្រប់ទីកន្លែង និងមានអំណាចទាំងអស់ ដើម្បីបង្កឱ្យមានភាពភ័យខ្លាច មិនទុកចិត្ត និងចុះញ៉ម៖ ឯកសារ D234/2.1.65 ប្រតិចារឹករបស់ ជាំង ស្រីមុំ ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៥ ម៉ោង 13.51.45-13.54.50 ["ខ្ញុំអត់ស្គាល់ច្បាស់ទេចាសអត់ស្គាល់ ដឹងតែពីថ្នាក់លើ អង្គការ ដឹងតែអង្គការៗ ពេលនោះដឹងតែអង្គការៗ ប៉ុន្តែមិនដឹងអង្គការមកពីណាចេះតែថាមកពីលើៗ"]។ ឯកសារ D234/2.1.100 ប្រតិចារឹករបស់ អាឡេចសានឌ័រ ហ៊ីនតុន ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 11.24.15-11.26.40 ["អង្គការហ្នឹងវាជាពាក្យមួយដែលថា វាមិនមានលក្ខណៈច្បាស់លាស់ [...] ឧបមាថា ប្រជាជនថា ទៅជួបអង្គការ គឺថាវាជាមធ្យោបាយមួយ។ ដូច្នេះ គឺថាអង្គការ អាចបកស្រាយបានច្រើន ហើយអង្គការជួយ អង្គការក៏អាចសម្លាប់បានដែរ"]។ ឯកសារ D114/297.1.35 ប្រតិចារឹករបស់ ផេហ្គី ឡឺវាញ ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង 09.17.29-09.19.33 ["ទស្សនៈរបស់អង្គការ [...] ធ្វើឱ្យមានភាពភ័យខ្លាច និងមន្ទិលសង្ស័យ"] ម៉ោង 09.30.31-09.35.04 ["មានបុគ្គលម្នាក់ប្រាប់ខ្ញុំថា បើសិនណាដួងព្រលឹងរបស់ដូនតាដែលបានស្លាប់ទៅនោះ បានដើរត្រាចចរគ្រប់ទីកន្លែង គឺថាអង្គការក៏ត្រូវមានលទ្ធភាពធ្វើដូចដែលដួងព្រលឹងរបស់ដូនតានោះដូច្នេះដែរ] ម៉ោង 09.33.35-09.35.01 ["ដូច្នេះការយល់ឃើញនេះ ដែលកម្លាំងខ្លះៗដែលវាធ្វើឱ្យមានរឿងរ៉ាវកើតឡើង [...] វាហាក់បីដូចជាមានលក្ខណៈសមហេតុផលណាស់ បើសិនជាអ្នកមិនអាចធ្វើអារម្មណ៍ឱ្យសមហេតុផលចំពោះរឿងអ្វីមួយនោះ គឺថាតាំងពីមុនពេលមានប្រព័ន្ធនៃមូលដ្ឋានមួយ ដែលប្រជាជនយល់ឃើញថាមានវិញ្ញាណដើរត្រាចចរគ្រប់ទីកន្លែង ការគ្រប់គ្រងវិញ្ញាណ ការផ្លាស់ប្តូរវិញ្ញាណ វិញ្ញាណបោកបញ្ឆោត វិញ្ញាណដែលអាចបោកបញ្ឆោតអ្នក។ វាជារឿងមួយសមហេតុផល ដែលប្រជាជនចាប់ផ្ដើមមានបទពិសោធន៍ជាក់លាក់មួយក្នុងការភ័យខ្លាច ដែលពួកគេបានស៊ាំរួចទៅហើយ គឺនៅពេលដែលពួកគាត់មិនអាចគិតឃើញថា តើមានអ្វីដែលកំពុងកើតឡើងនេះ។ ហើយអង្គការនេះអាចមានកម្លាំងអ្វីមួយដែលយើងមើលមិនឃើញនេះ កម្លាំងមួយដែលវាកើតមានខ្លាំងឡើងៗពីពេលមួយទៅពេលមួយ"] ម៉ោង 10.10.28-10.11.54 ["គឺការភ័យខ្លាចនេះកើតឡើងចេញពីអង្គការដែលគិតថា អង្គការនោះមានវត្តមាននៅគ្រប់ទីកន្លែងទាំងអស់"] ម៉ោង 10.18.57-10.23.19 [អ្នកផ្ដល់បទសម្ភាសន៍ប្រាប់ឡឺវាញថា "អង្គការអាចដើបពីដីមកនៅគ្រប់ពេលវេលា ហើយសូម្បីតែសព្វថ្ងៃនេះ យើងមិនមានសុវត្ថិភាពនោះទេ"]។ ឯកសារ D234/2.1.81 ប្រតិចារឹករបស់ ប្រាក់ ឌឿន ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 11.17.48-11.20.40 ["តាមទិសអង្គការដែលគេចាត់ឱ្យយើងទៅកន្លែង យើងអត់សិទ្ធិអីថា សុំគេបានអីបានទេ"]។ ឯកសារ D114/297.1.21 ប្រតិចារឹករបស់ ប៉ាក សុក ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 11.17.10-11.18.54 ["ខ្ញុំព្យាយាមលត់ដំខ្លួនឯងដើម្បីឱ្យអង្គការជឿ"]។ ឯកសារ D11/523/3 ប្រតិចារឹករបស់ ម៉ី ពៅ ម៉ោង 09.15.04-09.19.22 ["រស់នៅតាមអង្គការកំណត់ [...] ធ្វើតាមអង្គការកំណត់"]។

1110 របបអាហារសម្រាប់ប្រភេទកម្មករផ្សេងៗគ្នា ត្រូវបានកំណត់នៅក្នុងឯកសារផែនការបក្ស ប៉ុន្តែ លក្ខខណ្ឌការងារដែលបក្សបានអនុវត្ត គឺប្រាកដជាធានាថា របបអាហារជាក់ស្ដែងដែលផ្ដល់ឱ្យកម្លាំងពលកម្ម កម្របានដល់កម្រិតដែលបានកំណត់។ សូមមើលឧទាហរណ៍ផងដែរ ឯកសារ D4.1.38 ឯកសារបក្សកុម្មុយនីស្តកម្ពុជា៖ ផែនការ៤ឆ្នាំ កសាង

សង្គមនិយម គ្រប់ផ្នែក របស់បក្ស ឆ្នាំ ១៩៧៧-១៩៨០ ដូចបានបោះពុម្ពផ្សាយលោក ដេវីឌ ឆេនដ៍ល័រ និងអ្នកផ្សេងទៀត ក្នុងសៀវភៅមានចំណងជើងថា ផែនការ៤ឆ្នាំរបស់ប៉ុល ពត លេខ ERN EN 00104053-54, KH 00075906-10 [ផ្នែក "របបស៊ីចុករបស់ប្រជាជន" ជាផែនការរបបអាហាររួមមាន បាយ ម្ហូប និងបង្អែកមជាប្រចាំ ហើយសរសេរថា ការធ្វើ "ម្ហូប និងបង្អែមឲ្យមានគុណភាព មានជាតិ ឱជារសខ្ពស់" គឺជាភារកិច្ចបដិវត្តន៍ដ៏ខ្ពង់ខ្ពស់មួយ]។ ឯកសារ D11/199/4 ប្រតិចារឹករបស់ អែម អឿន ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០១២ ម៉ោង 11.37.33-11.39.11 [រំឭកអំពីការរៀនសូត្រពីលោក ខៀវ សំផន "ខ្ញុំដឹងតែគោលការណ៍ដែលគាត់ឲ្យធ្វើ គឺខ្ញុំចាំថា ដំណើរគោលការណ៍របស់បក្សកុម្មុយនីស្តពេលនោះគឺថា ដើម្បីវែកមុខ វែកមាត់អ្នកសត្រូវស៊ីរូងផ្ទៃក្នុងរបស់យើង វាទាល់តែយើងបង្កើតជាការងារខ្ពស់ ធ្វើការងារឲ្យច្រើន សម្រាកឲ្យតិច ស៊ីបាយឲ្យតិច ធ្វើការងារឲ្យច្រើន។ អ៊ីចឹង នោះឯងទើបចេញមុខមាត់អ្នកលាក់ក្នុងពួដ៏ផ្ទៃក្នុងរបស់យើង"]។ ឯកសារ D98/1.2.39 ប្រតិចារឹករបស់ ដេវីដ ឆេនដ៍ល័រ ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ ម៉ោង 13.43.51-13.46.04 ["គេបានកាត់ផលស្រូវខ្លះ សម្រាប់ជាពូជ សម្រាប់ចិញ្ចឹមប្រជាជននៅក្នុងមូលដ្ឋាន ប៉ុន្តែផលដែលបានសម្រេចហ្នឹង វាមានកម្រិតបែបនេះ [...] មានភស្តុតាងមួយចំនួន គឺថាមានការផ្គត់ផ្គង់ចំណីអាហារហ្នឹងគឺចុះទាបទៅៗ ហើយកង្វះអាហារូបត្ថម្ភធ្វើឲ្យមានមនុស្សស្លាប់ច្រើននៅទូទាំងប្រទេសនោះផងដែរ។ ហើយគុណភាពមិនគ្រប់គ្រាន់ទៅតាមបីតោនក្នុងមួយហិកតា"]។ ឯកសារ D11/160/4.1 ប្រតិចារឹករបស់ ចៅ នី ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១២ អ៊ីចឹង 14.05.13-14.07.32 [នៅក្នុងសហករណ៍ចកទុំ ខេត្តបាត់ដំបង "ស្ថានភាព និងជីវភាពនៅកោះធំនុំងភាគច្រើនអត់អហារដាច់ពោះបាយស្លាប់"]។ ឯកសារ D11/78/3 ប្រតិចារឹករបស់ សឿន សុវណ្ណី ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣ ម៉ោង 11.32.50-11.36.52 ["ហើយគេយកបបរហ្នឹងមកលាយត្រកួន លាយបន្លែអីហ្នឹង យើញមិនបានទៀតហ្នឹង ឈ្លបហ្នឹងទាត់កាម៉ែល ខ្វាយកំពប់អស់ [...] ពួកវាថា បើយើងទៅកាន់ជនបទ ទៅដាច់ពោះនោះ ល្អជាជាង។ នោះជាអ្វីដែលពួកវានិយាយចំអកឲ្យយើង"]។ ឯកសារ D98/1.2.11 ប្រតិចារឹករបស់ រម៉ាម យុន ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ ម៉ោង 14.47.11-14.51.37 ["អត់គ្រប់។ អាហ្នឹងរឿងនេះ ប៉ុន្តែខ្លះគ្នាហត់គ្នាឡើយ ចង់ខឹងដែរ ខ្លះចងកដែរ អ៊ីចឹង។ វាស្មុគស្មាញពេក។ អាហ្នឹងហើយអង្គការថ្នាក់លើ គណៈភូមិភាគ គណៈតំបន់ គណៈស្រុក គណៈខេត្ត គេថា អ្វេ! មូលដ្ឋានស្រួលណាស់ ដឹកនាំស្រួលណាស់ អត់អីទេ! ស្រួលម៉េច! យើងទៅដល់ស្រុក ចុះក្រោមវាមិនស្រួលមិនម៉េច! ពេលកំពុងឡើង វាហត់ចង់ដាប់ ភ្នំនោះ"]។ ឯកសារ D98/3.1.198 ប្រតិចារឹករបស់ អុង ថុងហឿង ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១២ ម៉ោង 15.45.36-15.47.43 ["ប៉ុន្តែ គ្រាន់តែមានអង្ករមួយគ្រាប់ៗ ហើយនិងត្រកួនច្រើន ហើយគេហៅថាបាយជ្រូក ដូចបាយជ្រូកអ៊ីចឹងបាទ។ ដាក់ត្រកួនច្រើនមែនទែន ហើយអត់មានត្រី"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយរបស់ ប្រាក់ សុខា ឆ.12 ["ម្ហូបអាហារមិនគ្រប់គ្រាន់ទេ ពេលខ្លះយើងហូបបាយ ហើយពេលខ្លះទៀត យើងហូបបបរ ជាមួយសម្លរព្រលឹត ឬសម្លត្រកួន"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ. 114 ["ស៖ តើលោកទទួលរបបអាហារបានគ្រប់គ្រាន់ដែរឬទេ? ឆ.114៖ ទេ មិនគ្រប់គ្រាន់ទេ។ អ្នកធ្វើការម្នាក់ៗទទួលបាន បាយមួយកូនចានតូច ជាមួយនឹងសម្លត្រី។ ចំពោះខ្ញុំ ធ្លាប់ហូបបាយ ពីពចាន ទៅ៤ចានឯណោះ ដូច្នេះ បាយមួយកូនចានតូច គឺមិនគ្រប់គ្រាន់ទេ ហើយរបបអាហារ ទទួលបានតែពីរពេលប៉ុណ្ណោះក្នុងមួយថ្ងៃ គឺថ្ងៃត្រង់ និងល្ងាច"] ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយរបស់ សួន ឈុំ ឆ.11 ["ចុះមួយថ្ងៃ បបរតែមួយវែកប៉ុណ្ណឹង (សាក្សីធ្វើដៃប៉ុនចានចង្កឹះ)"]។ ឯកសារ D88.1.9 ដេវីដ ឆេនដ៍ល័រ៖ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា លេខ ERN EN 00817715 ["នៅដើមឆ្នាំ ១៩៧៦

ជំនួយ[1112]។ អ្នកដែលរអ៊ូរទាំ លួចអាហារ ដោយសារតែគេចែករបបអាហារឲ្យហូបមិនគ្រាន់គ្រាន់ ដើរហើរដោយគ្មានការអនុញ្ញាត លួចរបស់របរ សូម្បីតែស្លាបព្រាមួយ ឬប្រព្រឹត្ត "កំហុស" ត្រូវគេ

---

ចំណីអាហារបានខ្វះខាតទៅហើយ ដោយសារចំនួនទិន្នផលលើស ត្រូវបានគេប្រមូលផ្តល់ទៅកងទ័ព ប្រមូលចូលឃ្លាំង ឬ ដឹកចេញទៅក្រៅប្រទេស។ ស្ថានការណ៍កាន់តែដុនដាបនៅឆ្នាំ ១៩៧៧ និងឆ្នាំ ១៩៧៨ នៅពេលក្នុងផ្ទៃប្រទេស ភាគច្រើន បានទទួលរងគ្រោះទុរភិក្ស។ មានអ្នកនៅរស់រានមានជីវិតជាច្រើននាក់បានចងចាំថា ខ្លួនទទួលបានបបរហូបអស់ជាច្រើនខែ ដោយគ្មានអ្វីបន្ថែមទៀត"]។ ឯកសារ D114/29.1.4 បែន ឃៀរនិន៖ របបប៉ុល ពត លេខ ERN EN 00678618, KH 00637743 ["នៅភូមិភាគពាយ័ព្យ [ចំនួនមនុស្សស្លាប់] ប្រហែលមានរាប់ម៉ឺននាក់ គ្រាន់តែនៅក្នុងតំបន់ ៥ តែមួយប៉ុណ្ណោះ [...] ប្រហែលជាមានប្រជាជនចំនួន ៥០.០០០ នាក់ បានបាត់បង់ជីវិតនៅទូទាំងភូមភាគនោះ ក្នុងឆ្នាំ ១៩៧៦ ភាគច្រើននៃអ្នកទាំងនោះ ស្លាប់ដោយដាច់បាយ"] លេខ ERN EN 00678719, KH 00638011 [នៅក្នុងភូមិភាគនិរតី៖"មាន ២០ ទៅ ៣០ ភាគរយនៃចំនួនប្រជាជនសរុប បានស្លាប់ដោយដាច់បាយនៅក្នុងឆ្នាំ ១៩៧៧-១៩៧៨"]។

1111 សូមមើលឧទាហរណ៍ ឯកសារ D4.1.537 កំណត់ហេតុស្តាប់ចម្លើយរបស់ ឱ ហូ លេខ ERN EN 00250047, KH 00239910 [ស្រុកបារាយណ៍ ខេត្តកំពង់ធំ៖ "នៅពេលលើកទំនប់នោះ មានអ្នកឈឺច្រើន ដោយសារខ្វះចំណីអាហារ និងគ្មានអនាម័យ មានរុយច្រើន។ ជំងឺទាំងនោះមានដូចជាជំងឺគ្រុន ជំងឺរាគរូស ជំងឺអាសន្នរោគ។ល។ អ្នកជំងឺទាំងនោះភាគច្រើនបានស្លាប់។ ពេលនោះមានពេទ្យភូមិភាគ ពេទ្យតំបន់ចុះមកពិនិត្យដែរ។ ពេទ្យដែលចុះមកនោះ បានចែកថ្នាំអាចម៍ទន្សាយ និងថ្នាំដាក់ដបសម្រាប់ចាក់មានជាតិដូចស្រា ហើយថ្នាំទាំងនោះ ពុំមានគុណភាពទេ"] ឯកសារ D4.1.421 កំណត់ហេតុស្តាប់ចម្លើយរបស់ ជុច ពន្លក លេខ ERN EN 00275403, KH 00221548-49 [នៅទំនប់កំពីងពួយក្នុងខេត្តបាត់ដំបង៖"អ្នកលើកទំនប់ ហូបចុកមិនគ្រប់គ្រាន់ មានជំងឺដោយគ្មានថ្នាំពេទ្យ [...] មនុស្សស្លាប់ជារៀងរាល់ថ្ងៃ"]។ ឯកសារ D4.1.421 កំណត់ហេតុស្តាប់ចម្លើយរបស់ ប៊ុន ធឿន លេខ ERN EN 00384408, KH 00368611 [ក្នុងតំបន់ ១៣ ខេត្តតាកែវ៖ "គេឲ្យពង្រឹងពេទ្យ ដោយរកថ្នាំសង្កូវ ស្ល និងផលិតថ្នាំដោយខ្លួនឯង មិនត្រូវស៊ីពីខាងណាទេ (ឯករាជ្យម្ចាស់ការ)"]។ ឯកសារ D46 កំណត់ហេតុស្តាប់ចម្លើយរបស់ ចែ ហៀប លេខ ERN EN 00804120, KH 00804126 [នៅការដ្ឋានព្រលានយន្តហោះខេត្តកំពង់ឆ្នាំង៖ "មិនមានគ្រូពេទ្យអីទេ យើងត្រូវដោះស្រាយខ្លួនឯង ដោយគ្មានថ្នាំពេទ្យ"]។ ឯកសារ D10.1.70 កំណត់ហេតុស្តាប់ចម្លើយរបស់ គឹម សាវឿន លេខ ERN EN 00375476, KH 00368630 ["នៅមន្ទីរពេទ្យ [តំបន់៣៧] មិនមានថ្នាំពេទ្យគ្រប់គ្រាន់ទេ។ បើមានថ្នាំពេទ្យ គឺសម្រាប់តែទ័ពទេ"] លេខ ERN EN 00375478, KH 00368632 [សាក្សីត្រូវជួយកប់សាកសពចំនួនពី ២៥ ទៅ ៣០ នាក់ ក្នុងមួយថ្ងៃនៅមន្ទីរពេទ្យតំបន់៣៧នោះ៖ "សៈ តើអ្នកស្លាប់ទាំងនោះ គឺស្លាប់ដោយសារអ្វី? ឆៈ អ្នកស្លាប់ទាំងនោះ គឺបណ្តាលមកពីខ្វះម្ហូបអាហារ ធ្វើការហួសកម្លាំង ធ្លាក់ខ្លួនឈឺ ស្គមស្គេកស្គាំង ហើមជើង ហើមមុខ និងខ្វះថ្នាំពេទ្យសម្រាប់ព្យាបាល"]។ ឯកសារ D4.1.807 កំណត់ហេតុស្តាប់ចម្លើយរបស់ អៀង ឆាំ ហៅ ឈី ឆ.74-77។

1112 សូមមើលផងដែរ ឧទាហរណ៍ ឯកសារ D4.1.986 FBIS ៖ សុន្ទរកថារបស់ខៀវ សំផន នៅឯកិច្ចប្រជុំគម្រប់ខួប នៅថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ លេខ ERN EN 00419514, KH 00292807 ["ការដ្ឋានសាងសង់អាងស្តុកទឹក ប្រឡាយទឹក ឬទំនប់ទឹកនីមួយៗមានកម្មករធ្វើការប្រហែល ១០ ០០០ ១២ ០០០ និង ៣០ ០០០ នាក់ [...] តើសមិទ្ធ

ចាត់ទុកថាក្បត់បដិវត្តន៍ ហើយត្រូវគេដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ ឬរហូតដល់ថ្នាក់សម្លាប់ចោល[1113] ។

---

ផលទាំងនេះអាចសម្រេចបានដោយគ្រឿងម៉ាស៊ីនឬ? ទេ យើងគ្មានគ្រឿងម៉ាស៊ីនទេ។ យើងធ្វើការដោយពឹងផ្អែកទាំងស្រុងលើខ្លួនឯង"]។ ឯកសារ D4.1.873 ទស្សនាវដ្ដីទង់បដិវត្ត ចេញផ្សាយខែ សីហា ឆ្នាំ ១៩៧៥ លេខ ERN EN 00532694, KH 00399140 ["បើគ្មានគោក្របី បងប្អូនយកកម្លាំងផ្ទាល់ខ្លួន ទៅអូសនង្គ័ល រនាស់។ បើគ្មានអ្វីភ្ជួររាស់ធ្វើស្រែ បងប្អូនប្រើចបនឹងដៃទាំងគូរបស់ខ្លួន កាប់ឆ្ការ និងជីគាស់កកាយ វាយបំបែកដីឱ្យទាល់តែស្អាត អាចដាំស្រូវបាន"]។ ឯកសារ D4.1.50 ទស្សនាវដ្ដី យុវជន និងយុវនារីបដិវត្ត ចេញផ្សាយខែ មេសា ឆ្នាំ ១៩៧៦ លេខ ERN EN 00392436, KH 00064289 ["ក្នុងចលនាលើកប្រព័ន្ធភ្លឺថ្មី និងជីកប្រឡាយថ្មី [...] បដិវត្តយើងនៅក្រ គ្មានលទ្ធភាពដោះស្រាយម៉ាស៊ីន សំបូរបែបយ៉ាងនេះ បានឡើយ។ តែដោយបដិវត្តយើងមានទស្សនៈមហាជនរឹងប៉ឹង យើងប្រមូលគៀងគរប្រជាជន មហាជន និងចលនាមហាជនទូទាំងប្រទេស ធ្វើទាំងយប់ទាំងថ្ងៃ ដូច្នេះ យើងធ្វើបាន"]។ ឯកសារ D4.1.896 ទស្សនាវដ្ដី យុវជន និងយុវនារីបដិវត្ត ចេញផ្សាយខែ មេសា ឆ្នាំ ១៩៧៧ លេខ ERN EN 00491112, KH 00376249 ["យើងគ្មានម៉ាស៊ីន គ្មានគ្រឿងចក្រទំនើបៗ សំបូរបែបឯណាទេ តែយើងអាចកសាងប្រទេសយើង ដោយដៃទាំងគូយ៉ាងឆាប់រហ័សបែបនេះបាន"]។ ឯកសារ D98/1.2.12 ប្រតិចារឹករបស់ ប្រាក់ យុត ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១២ ម៉ោង 14.45.48-14.46.45 ["ស៖ លោកស្រីមានដឹងទេថា ការធ្វើទំនប់មួយៗហ្នឹង គេធ្វើគ្រឿងចក្រ ឬក៏ប្រើកម្លាំងមនុស្ស? ឆ៖ កាលហ្នឹងគេធ្វើទំនប់មិនគ្រឿងចក្រអី ប្រើមនុស្ស។ ប្រើមនុស្ស"]។

1113 សូមមើលផងដែរ ឧទាហរណ៍ ឯកសារ D4.1.869 ទស្សនាវដ្ដី ទង់បដិវត្ត ចេញផ្សាយខែ កក្កដា ឆ្នាំ ១៩៧៨ លេខ ERN EN 00428297, KH 00064495 ["ខ្មាំងគ្រប់ប្រភេទ វាថែមទាំងបំផ្លាញជីវភាពប្រជាជនទៀត។ វាធ្វើឱ្យប្រជាជនអត់បាយក្រហាយទឹក ធ្វើឱ្យប្រជាជនគ្មានស្លៀក គ្មានពាក់ គ្មានជំរក។ វាបំផ្លាញទឹក បំផ្លាញស្រូវពូជ បំផ្លាញសំណាប បំផ្លាញជី បំផ្លាញគោក្របី បំផ្លាញនង្គ័ល-រនាស់ បំផ្លាញចប បំផ្លាញស្ពាបព្រា ថាន ឆ្នាំង បំផ្លាញសព្វបំផ្លាញគ្រប់ ធ្វើយ៉ាងណាឱ្យតែប្រជាជនយើងអត់ឃ្លានគ្មានហូប។ ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង វាបំផ្លាញមាគ៌ាដោះស្រាយជីវភាពប្រជាជន"]។ ឯកសារ D1.3.27.3 កំណត់ហេតុគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៧៦ លេខ ERN EN 00182657, KH 00000756-57 [នួន ជា បានទាមទារឱ្យមានការប្រុងប្រយ័ត្នចំពោះអ្នកដែលរត់គេចដោយមិនបានវិលត្រឡប់ទៅកាន់សហករណ៍វិញ ដោយកត់សម្គាល់ថា៖ "នៅតាមមូលដ្ឋាន បានដោះស្រាយបញ្ហានេះរួចរាល់ហើយ"]។ ឯកសារ D4.1.206 ទូរលេខ ២៩២ ពី ញឹម ផ្ញើជូនអង្គការ ៨៧០ ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៨ លេខ ERN EN 00185215, KH 00021043 ["ក្នុងតំបន់ថ្ងៃទី ០៥ ខែ ឧសភា នេះ ខ្មាំងខាងក្រៅ ចូលមកបានខ្លះៗ វាបាននាំប្រជាជនរត់ ចំនួន ៤០ នាក់។ យើងកម្ទេចវាបានអស់ នៅសល់ពីរក្បាលកំពុងតាមរកវាទៀត។ នៅតំបន់ ៥ តំបន់ ៤ តំបន់ ៣ ក៏មានរត់ តែភាគច្រើន យើងកម្ទេចវាបន្តចេញ មិនសូវរួច។ ចូលក៏មិនរួចដែរ"]។ ឯកសារ D1.3.34.11 ទូរលេខ ១១ ពី ឌឹម ផ្ញើជូន បង មុត (មាស មុត) ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ ["សភាពដីគោកនៅឃុំរៀម និងបឹងបុស ពីយើងមានវិធានការចំពោះខ្មាំងមួយដែលបងសម្រេច វាមានរត់ចូលព្រៃ ៥ នាក់ ឥឡូវយើបានចាប់បានទាំងអស់"]។ ឯកសារ D11/44/3.1 ប្រតិចារឹករបស់ អៀម យេន ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥ ម៉ោង 09.20.02-09.24.55 ["ខ្ញុំធ្វើការវា កុមារកម្លាំងតូច ធ្វើការដូចថា ទ្រាំទ្រមិនបានផង។ ម្ល៉េះហើយ ខ្ញុំគេចវេះហ្នឹង ខ្ញុំរត់

ចេញហ្នឹង មេកងនឹងមកចាប់ខ្ញុំហ្នឹង មិនមែនថាចាប់ខ្លួនអី កុមារហ្នឹងបញ្ជូនទៅកន្លែងកងខ្ញុំវិញហ្នឹង ឲ្យទៅធ្វើការវិញ។ ហើយទៅធ្វើទារុណកម្មខ្ញុំពេលនោះ"]។ ឯកសារ D11/61/3.1 ប្រតិចារឹករបស់ រី ពៅ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ម៉ោង 11.05.56-11.08.00 ["សម័យនោះ ខ្ញុំសូមជម្រាបជូនលោកប្រធានឲ្យបានជ្រាប់ថា កាលពីសម័យនោះ គ្មានអ្នកណាម្នាក់ហ៊ានតវ៉ាទេ។ កាលណាអ្នកណាហ៊ានតវ៉ា ហ៊ានរឹងរូស គេថាយើងហ្នឹងខ្មាំងក្នុងសហករណ៍។ អ៊ីចឹង រស់អត់បានយូរទេ គឺគេមានវិធានការយកទៅដោយមិនដឹងខ្លួនបាទ"]។ ឯកសារ D234/2.1.41 ប្រតិចារឹករបស់ នួន ជា ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១១ ម៉ោង 10.32.13-10.40.46 ["ក៏ប៉ុន្តែ ក្នុងសហករណ៍នេះ ខ្ញុំសូមជម្រាបថា មានពួក ខូច មានពួកក្បត់ មានពួកសមាសភាពមិនល្អ វាបំផ្លាញសហករណ៍ [...] ចាន ស្តាបព្រាស្ទី១ទាំងអស់នេះ វាយកទៅ ចាក់ចោលនៅទន្លេសាបនោះ។ ដូច្នេះហើយ ធ្វើឲ្យប្រជាជនអត់មានចានហូបបាយ អត់មានអីហូបបាយ"] ឯកសារ D98/3.1.28 ប្រតិចារឹករបស់ ឈូក រីន ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ ម៉ោង 09.41.15-09.45.15 ["ប៉ុន្តែ ដូចខ្ញុំ ឧទាហរណ៍ខ្លី ពីម្សិលមិញ បាក់ចបមួយក៏បញ្ហា គោស្លាប់ក៏បញ្ហា ធ្វើផែនការមិនសម្រេចបីតោនមួយហិកតាក៏បញ្ហា។ បញ្ហាហ្នឹងបញ្ហាដែលថា ជួនកាលបញ្ហាកើតឡើងហ្នឹង អ្នកដែលទៅរៀនសូត្រ បានរៀនសូត្រសៀវភៅហ្នឹង បញ្ហាមុន គេ ព្រោះចាប់តែអ្នកទៅរៀនសូត្រហ្នឹង។ អ៊ីចឹង បានកើតការភ័យខ្លាច"]។ ឯកសារ D11/54/3.1 ប្រតិចារឹករបស់ ព្រាប សុឃឿន ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង 15.25.08-15.26.50 ["បើមិនចេញពីគំនិតណា បើទម្លាប់អ៊ីចឹងរហូតហើយ ឃើញថាឲ្យមានបញ្ហាខុសបន្តិចបន្តួច គឺគេចាប់ទៅតែម្តង ចាប់ទៅច្រើនណាស់"]។ ឯកសារ D98/3.1.17 កំណត់ហេតុស្តាប់ចម្លើយរបស់ ជា ថា ហៅ ចោល សិន លេខ ERN EN 00327176, KH 00251660 ["មានចាប់បាន ដូចក្នុងកងខ្ញុំ មានម្នាក់ត្រូវចាប់បាន។ គេចាប់បាន គេយកទៅបង្អត់បាយ រួចបញ្ជូនទៅដាក់នៅកន្លែង អ្នកទោសនៅភ្នំសន្ទុង ហើយគេមិនឲ្យត្រឡប់មកអង្គភាពវិញទេ"]។ ឯកសារ D4.1.484 កំណត់ហេតុស្តាប់ចម្លើយ របស់ សេង ស្រ៊ុន លេខ ERN EN 00242087, KH 00218554 ["ខ្ញុំដឹងថា គេនឹងកាប់សម្លាប់អ្នកភូមិណាដែលលួច រត់ ពីព្រោះខ្ញុំបានឃើញពួកគេ កាប់សម្លាប់អ្នកទោសម្នាក់មកពីការដ្ឋានតាកុក ដោយផ្ទាល់ភ្នែក ក្រោយពីជននោះ បាន រត់គេចខ្លួនបានប្រហែល១០០ម៉ែត្រ នៅដើមឆ្នាំ ១៩៧៦"]។ ឯកសារ D4.1.552 កំណត់ហេតុស្តាប់ចម្លើយរបស់ កែវ ណេ លេខ ERN EN 00327168, KH 00251678 ["មានអ្នកលួចរត់ ហើយគេតាមចាប់យកទៅវិញ។ ធ្លាប់មានអ្នក លួចរត់ចេញពីកំពង់កណ្តាលប្រហែល ២០ នាក់ ហើយក្នុងនោះ មានលង់ទឹកស្លាប់ ៧ នាក់ ឯអ្នកនៅរស់ទាំងប៉ុន្មាន ត្រូវបានគេតាមចាប់បាននៅនរាយ ហើយយកទៅនៅត្រើយកោះទាំងអស់ [...] មានបាត់ខ្លួនចំពោះអ្នកដែលលួចរត់ ដែលគេចាប់យកទៅអប់រំកសាងនៅ កន្លែងផ្សេង"]។ ឯកសារ D10.1.45 កំណត់ហេតុស្តាប់ចម្លើយរបស់ គាំ យោ លេខ ERN EN 00275023, KH 00206412-13 ["ឃើញគេសម្លាប់ក្មេងៗប្រហែលអាយុ ៧-៨ ឆ្នាំ [...] ក្មេងៗអ្នក ទោសទាំងនោះមកពីកងកុមារកាត់ស្លឹកទន្រ្ទានខេត្ត [...] ខ្មែរក្រហមចាប់ក្មេងទាំងនោះបាន នៅពេលដែលវាលួចរត់ ទៅលែងឪពុកម្តាយ [...] ពួកគេត្រូវខ្មែរក្រហមចាប់ចងបញ្ជូនមកកោះខ្យងវិញ ហើយវះពោះសម្លាប់នៅចំពោះមុខអ្នក ទោសផ្សេងទៀត ដើម្បីព្រមានកុំឲ្យយកតម្រាប់តាម"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.116 ["មិនងាយមានអ្នកណាអាចរត់គេចចេញពីការដ្ឋានព្រៃកចាក បានឡើយ គឺតឹងរ៉ឹងខ្លាំងណាស់។ បើសិន ជាមានរណាម្នាក់ព្យាយាមរត់គេច ហើយគេចាប់បាន គឺគេសម្លាប់ចោលភ្លាមតែម្តង"]។ ឯកសារ D114/163 កំណត់ហេតុស្តាប់ចម្លើយរបស់ ជា ថា ឆ.30 [ស្រែអំបិលនៅខេត្តកំពត៖ "សៈ បើតាមខ្ញុំយល់ បើសិនមានករណីធ្វើ មិនត្រឹមត្រូវគេចាប់ឃុំ និងបញ្ជូនទៅភ្នំសន្ទុង។ បើអ្នកទោសធ្ងន់ គេយកទៅសម្លាប់។ ត្រូវទេ? ឆ. 30 ចាស១"]។ ឯក

324. នៅក្នុងកិច្ចប្រជុំ ខែ សីហា ឆ្នាំ ១៩៧៦ ជាមួយនឹងមេបញ្ជាការកងពល និងមេបញ្ជាការកងវរសេនាធំឯករាជ្យ សុន សេន រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជានាយសេនាធិការ បានលើកផែនការរបស់ ប.ក.ក ចំពោះកងទ័ព ពាក់ព័ន្ធនឹងការបង្កបង្កើតផលស្រូវ ដែលត្រូវអនុវត្តដោយកម្លាំងទ័ព ៤ ម៉ឺននាក់[1114]។ នៅក្នុងកិច្ចប្រជុំសេនាធិការ និងកិច្ចប្រជុំយោធាជាច្រើន សុន សេន និងមេបញ្ជាការ

---

សារ D114/85 កំណត់ហេតុស្តាប់ចម្លើយរបស់ ជេត ប៊ុណ្ណា ឆ.5-6 ["ប្រសិនបើគេពុំពេញចិត្តនឹងការងាររបស់យើង គឺគេនឹងបញ្ជូនយើងទៅទឹកសាបភ្លាមតែម្តង [...] ឆ.6៖ យើងទាំងអស់គ្នាដែលស្ថិតនៅក្នុងកងសមាសភាពមិនល្អនេះ ចាំក្នុងខួរក្បាលខ្លួនឯងជារហូតមកថា បើសិនជាយើងធ្វើអ្វីមួយខុសសូម្បីតែតិចតួច គេនឹងយកទៅដាក់ទោសភ្លាម"]។ ឯកសារ D114/33 កំណត់ហេតុស្តាប់ចម្លើយរបស់ ហែម អាង ឆ.49,68 ["ពួកយើងកើតរមាស និងរោលពេញដៃជើង តែពុំហ៊ានត្អូញត្អែរទេ ព្រោះខ្លាចគេយកទៅវាយចោល [...] ស៖ តើអ្នកទាំងនេះធ្វើអ្វីខុសបានជាគេបញ្ជូនទៅកោះខ្យង? ឆ.68៖ មេសហករណ៍រាយការណ៍ថា ពួកគេធ្វើការមិនបានល្អ ហើយចុងក្រោយត្រូវបានគេចោទថា ជាខ្មាំង"]។ ឯកសារ D4.1.889 កំណត់ហេតុស្តាប់ចម្លើយរបស់ លឿង ប៊ុន្នី លេខ ERN EN 00384779, KH 00375539 [នៅសហករណ៍កសាង ក្នុងស្រុកព្រៃនុប៖"ខ្ញុំដឹងករណីមួយក្មេងប្រុសម្នាក់ឈ្មោះ នុច គាត់ឃ្លានខ្លាំងពេក គាត់បានលួចចំណីអាហារ។ ខ្មែរក្រហមបានចងគាត់ និងដាក់គាត់នៅក្នុងបាវមួយ ហើយបានបោះគាត់ចូលទៅក្នុងទឹកព្រែក ប៉ុន្តែគាត់នៅរស់ ហើយវិលមកសហករណ៍វិញ។ ខ្មែរក្រហមបានបោះគាត់ចូលក្នុងព្រែកពីរបីដងទៀត ហើយគាត់នៅតែមិនស្លាប់។ ចុងក្រោយ ខ្មែរក្រហមសម្លាប់គាត់ ដោយចាក់នឹងឈើចុងស្រួច [...] ខ្ញុំបានឃើញ"]។ ឯកសារ D4.1.844 កំណត់ហេតុស្តាប់ចម្លើយរបស់ ប្រាក់ យុត ឆ.29 [ស្រុកកំពង់សៀម ខេត្តកំពង់ចាម៖ "អ្នកអាក្រក់គឺជាអ្នកលួចបាយ និងរបស់របរគេ ឬក៏លួចម្ហូបអាហារហូបពីព្រោះគ្នាអត់ឃ្លាន [...] អ្នកអាក្រក់ យើងបញ្ជូនទៅឲ្យខាងឃុំឲ្យគេយកទៅអប់រំឡើងវិញ"]។ ឯកសារ D4.1.534 កំណត់ហេតុស្តាប់ចម្លើយរបស់ សុក ធុល លេខ ERN EN 00242361, KH 00238888 [ក្នុងខេត្តស្វាយរៀង៖ "តាមការឃើញរបស់ខ្ញុំ អ្នកដែលគេចាប់មកនោះ [មន្ទីរសន្តិសុខ] មានស្រីមានប្រុស ពួកគេភាគច្រើនត្រូវបានគេចាប់ដោយសារ លួចចំណីអាហារហូប លួចមាន់ខ្លួនឯងហូប និងខុសសីលធម៌។ គេចាប់បញ្ជូនមកមន្ទីរដាក់ខ្នោះជើង ហើយគេបានសួរចម្លើយ។ ខ្ញុំបានឮសំឡេងស្រែក នៅពេលសួរចម្លើយ ខណៈដែលខ្ញុំបានដើរឃ្វាលគោនៅជិតបរិវេណនោះ"]។ ឯកសារ D46 កំណត់ហេតុស្តាប់ចម្លើយរបស់ ថៃ ហៀប លេខ ERN EN 00804119, KH 00204125 ["នៅក្នុងប្រជុំជីវភាព ប្រធានប្រជុំបាននិយាយថា បើសិនមានអ្នកណាត្អូញត្អែរ គេនឹងបាត់ខ្លួន។ យើងទទួលការគំរាមកំហែង បើទោះបីយើងនិយាយអំពីការខ្វះខាតអាហារ"]។ ឯកសារ D4.1.848 កំណត់ហេតុស្តាប់ចម្លើយរបស់ ឈួក រីន ឆ.4 ["នួន ជា បានបង្រៀនប្រាប់អំពីអ្នកណាដែលជាខ្មាំងខ្លះ ដូចជាអ្នកដែលធ្វើឲ្យបាក់នង្គ័ល បាក់ចប បាក់ស្ពាបព្រា។ល។ សុទ្ធតែជាខ្មាំងទាំងអស់ ព្រោះពួកនោះជាអ្នកចង់បំផ្លេចបំផ្លាញបក្សកុម្មុយនីស្តកម្ពុជា។ គាត់បង្រៀនឲ្យចេះតាមដានខ្មាំងទាំងនោះ ហើយបើរកឃើញ ត្រូវធ្វើការបោសសម្អាត"]។ ឯកសារ D4.1.816 កំណត់ហេតុស្តាប់ចម្លើយរបស់ សៅ ហ៊ាន ឆ.42 ["សូម្បីតែអ្នកណាមានទំនាស់អំពីការហូបមិនឆ្អែត ធ្វើឲ្យបាក់ស្ពាបព្រា បាក់នង្គ័ល ក៏គេចាត់ទុកថាជាខ្មាំងដែរ"]។

[1114] ឯកសារ D1.3.27.12 កំណត់ហេតុកិច្ចប្រជុំរបស់យោធាកម្ពុជាប្រជាធិបតេយ្យ៖ កំណត់ហេតុនៃកិច្ចប្រជុំលេខា និងអនុលេខាកងពល និងវរៈសេនាធំឯករាជ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៦ លេខ ERN EN 00234456-57, KH

យោធារបស់គាត់ រួមទាំង **មាស មុត** បានពិភាក្សាគ្នាអំពីកិច្ចខិតខំប្រឹងប្រែងបង្កបង្កើនផល កង្វះខាត និងបញ្ហាប្រឈមផ្សេងទៀត ក្នុងការព្យាយាមសម្រេចគោលដៅមហិច្ឆតារបស់បក្ស[1115]។

---

00052376-77 ["បង៨៩ (សុន សេន) បានដាក់ចេញផែនការបក្សទាក់ទិននឹងការផលិតស្រូវសម្រាប់កងទ័ព និងទំហំដីដែលត្រូវធ្វើកសិកម្ម ដោយប្រើកម្លាំងមនុស្ស ៥០.០០០ នាក់ ហើយផែនការត្រូវបំបែកជាកូតាតាមកងពល"]។

1115 សូមមើល ឧទាហរណ៍ ឯកសារ D1.3.27.18 កំណត់ហេតុកិច្ចប្រជុំរបស់យោធាកម្ពុជាប្រជាធិបតេយ្យ៖ កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភាររបស់កងពល និងវរៈសេនាធំ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ [មេបញ្ជាការស៊ូ ម៉េត(៥០២), មាស មុត (១៦៤), សុខ (១៧០), ភាព (៤៨៨), តាល់ (២៩០), ហ៊ុយ, អឿន (៣១០), ស្គួង (៤៥០), ពីន (៧០៣), ហ៊ិន, ស៊ឹម (១៥២) ទីន និងបង៨១ (សៀត ឆែ រាយការណ៍អំពីបញ្ហាផ្សេងក្នុងចំណោមនោះមានការខិតខំប្រឹងប្រែងបង្កបង្កើនផល រួមមានធ្វើមិនគ្រប់ផែនការ ស្បៀងជិតអស់ ជំងឺប៉ះពាល់ដល់ប្រជាជន ហើយស៊ូ ម៉េត បានកត់សម្គាល់ជាពិសេសនៅកន្លែងគាត់ថា ដោយសារខ្វះអនាម័យនៅកន្លែងរស់នៅ។ បន្ទាប់មក បង ៨៩ (សុន សេន) ផ្តល់ការណែនាំអំពីវិធានការត្រូវអនុវត្តបន្តទៅមុខ]។ ឯកសារ D1.3.27.22 កំណត់ហេតុកិច្ចប្រជុំកម្ពុជាប្រជាធិបតេយ្យ៖កំណត់ហេតុនៃការប្រជុំកងពលពេញអង្គ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ [ស៊ូ ម៉េត (៥០២), ពីន (៧០៣), អឿន (៣១០), សុខ (១៧០), ស្គួង (៤៥០), តាល់ (២៩០), ណៃ (៣៧៧), មាស មុត (១៦៤), ភាព (៤៨៨), ស៊ឹម (១៥២), និង វីន (៧៥) រាយការណ៍អំពីសកម្មភាពបង្កបង្កើនផល និងប៉ាន់ប្រមាណអំពីបញ្ហាខ្វះខាត។ ការខ្វះខាតសរុបត្រូវប៉ាន់ប្រមាណថាមានចំនួនពី ៥.០០០ តោន ដល់ ៦.០០០ តោន។ ណាត នៅសេនាធិការ និយាយថា ការប៉ាន់ប្រមាណនេះមិនខុសទេ ពួកគេគ្រាន់តែមិនមានបទពិសោធក្នុងការប្រមូលផល ដែលធ្វើទិន្នផលទាបជាងផែនការ។ បន្ទាប់មក បង ៨៩ (សុន សេន) ផ្តល់ការណែនាំអំពីវិធានការដែលត្រូវអនុវត្តដើម្បីដោះស្រាយភាពខ្វះខាតនេះ។ មាស មុត រាយការណ៍ពិសេសថា ដើម្បីចិញ្ចឹមមនុស្សចំនួន ១២.០០០ នាក់ នៅតាមកងយោធា និងស៊ីវិល គឺកងរបស់គាត់នឹងត្រូវខ្វះអង្ករ ៣១០ តោន]។ ឯកសារ D1.3.27.23 កំណត់ហេតុកិច្ចប្រជុំយោធានកម្ពុជាប្រជាធិបតេយ្យ៖ កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភារកងពល និងវរៈសេនាធំឯករាជ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៧៦ [ស៊ូ ម៉េត,ពីន សុខ, សាអឿន, វឿង, ស្គួង, សយ, សឿន, ភាព, ស៊ឹម, ណៃ និង វិន ផ្តល់របាយការណ៍ស្ថានភាពអំពីសកម្មភាពនៅតាមតំបន់របស់ខ្លួន រួមមាន ការខិតខំបង្កបង្កើនផល និងការខ្វះខាត។ សុន សេន (បង ៨៩) ផ្តល់ការណែនាំនានា រួមមាន "ការងារណាមិនចាំបាច់ ត្រូវផ្អាកសិន ទោះបីជាប់រៀន ក៏ត្រូវផ្អាកសិនដែរ" អ៊ីចឹងទៅ ទើបការប្រមូលផល ធ្វើទាន់ពេល]។ ឯកសារ D1.3.8.2 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ៖ កំណត់ហេតុនៃការប្រជុំគ្រប់គណៈកងពលទូលាយ ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦ [បង ៨៩ (សុន សេន) ចាត់ចែងការងារបង្កបង្កើនផល និងស្តាប់របាយការណ៍សកម្មភាពបង្កបង្កើនផលពីតាល់ (២៩០), ពីន (៧០៣), សុខ (១៧០), អឿន (៣១០), ស៊ូ ម៉េត (៥០២), ស្គួង (៤៥០), មុត (មាស មុត) (១៦៤), ភាព (៤៨៨), ចិន និង ស៊ឹម (១៥២)]។ ឯកសារ D1.3.8.3 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ៖ កំណត់ហេតុនៃអង្គប្រជុំការងារយោធា នៅកំពង់សោម ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៧៦ លេខ ERN EN 00234012, KH 00021496 [ សមមិត្ត មុត (មាស មុត) រាយការណ៍ថា "១វរៈសេនាធំ (៣កងវរៈសេនាតូច) នៅកោះវ៉ៃ កោះតាង និងកោះរ៉ុង ១វរៈសេនាតូចនៅកោះសេះ ១វរៈសេនាតូចនៅកោះមួយទៀតជិតនោះ មានដីធ្វើស្រែជាង១០០ហិកតា មានចម្ការកៅស៊ូ និងចម្ការការហ្វេ [...] បងប្អូនធ្វើស្រែនៅតាមកោះ ដាំដើម

ដើម្បីសម្រេចតាមផែនការកំណត់ **មាស មុត** និងមេបញ្ជាការផ្សេងទៀត បានអនុវត្តយ៉ាងពេញលេញនូវវិធានការហួសហេតុ ដែលកំពុងត្រូវបានអនុវត្តនៅទូទាំងកម្ពុជាប្រជាធិបតេយ្យ ដោយធ្វើឲ្យជនស៊ីវិល និងកម្មាភិបាលក្លាយជាទាសករ នៅតំបន់ក្រោមការគ្រប់គ្រងរបស់ខ្លួន។ ឧទាហរណ៍ ជនស៊ីវិល និងទាហានរំសាយ ត្រូវគេធ្វើឲ្យក្លាយជាទាសករនៅព្រលានយន្តហោះកំពង់ឆ្នាំង ក្រោមបញ្ជារបស់ ស៊ូ ម៉េត លេខាកងពល ៥០២[1116]។ ក្នុងដែនអំណាចរបស់ **មាស មុត** កម្មករស៊ីវិល

---

ឈើស៊ីផ្លេ មានដូង មានសាម៉ៅ ធូរេន"] លេខ ERN EN 00234014-16, KH 00021499 [សមមិត្តលេខា (សុន សេន) និយាយថា៖ "យើងត្រូវពង្រឹង និងពង្រីក [កោះ] ឲ្យទៅជាព្រៃឈើស៊ីផ្លេ ជាចំការដំណាំ ជាទីតាំងយោធាផង ទីតាំងសេដ្ឋកិច្ចផង" ហើយពិភាក្សាអំពីការដាំដុះដំណាំ និងការប្រែក្លាយដី]។ ឯកសារ D1.3.27.8 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ៖ កំណត់ហេតុនៃការប្រជុំលេខា និងសេដ្ឋកិច្ចកងពល ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៧៦ លេខ ERN EN 00923159, KH 00088910។ ឯកសារ D1.3.8.7 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ៖ កំណត់ហេតុនៃការប្រជុំលេខា អនុលេខាកងពល និងវរៈសេនាធំ ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៧៦ លេខ ERN EN 00877019, KH 00095531។ ឯកសារ D1.3.27.11 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ៖ កំណត់ហេតុនៃការប្រជុំគណៈប្រចាំការកងពល និងវរៈសេនាធំកងឯករាជ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៦ [បង ៨៩ (សុន សេន) ពិភាក្សាអំពីការបង្កបង្កើនផលមិនបានគ្រប់ផែនការ ហើយនិយាយថា "ជាការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំសមាជិកបក្ស"]។ D1.3.27.24 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ៖កំណត់ហេតុនៃការប្រជុំកងពល ៩២០ សមមិត្ត សយ និង រ៉េន ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៧៦។ ឯកសារ D1.3.27.26 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ៖ កំណត់ហេតុនៃការប្រជុំលេខា អនុលេខា កងពល និងវរៈសេនាធំឯករាជ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧ [ស៊ូ ម៉េត, ឈិន, ម៉ូត, ភាព, យ៉ាន់, សុខ, ស៊ឹម, គាល់, ពីន, សៅ និងរីន រាយការណ៍អំពីស្ថានភាពនៅក្នុងកងរបស់ខ្លួន រួមមាន សកម្មភាពបង្កបង្កើនផល និងការខ្វះខាត។ បង ៨៩ (សុន សេន) ផ្តល់ការណែនាំសម្រាប់អនុវត្ត]។ ឯកសារ D1.3.27.25 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ៖ កំណត់ហេតុនៃការប្រជុំកងពល ៨០១ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៧៦ លេខ ERN EN 00874987-88, KH 00052330-31។ ឯកសារ D1.3.19.2 ជំរាបសមមិត្ត គណៈកងពល និងគណៈវរៈសេនាធំជាទីស្នេហា ពីខៀវ សំផន នៃសេនាធិការ ថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ ១៩៧៧ [ណែនាំឲ្យកងពលវាយសម្រុកប្រមូលផល "សម្រេចផែនការឲ្យបាន១០០ ភាគរយ" ហើយលើកទឹកចិត្តពួកគេឲ្យធ្វើអ្វីដែលអាចធ្វើឲ្យលើសពីផែនការ]។

1116 សូមមើល ឧទាហរណ៍ ភស្តុតាងដែលបានដកស្រង់នៅ ជើងទំព័រ 1092 ខាងលើ។ ឯកសារ D1.3.30.9 របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ៖ ស្ថិតិរួមនៃកងកម្លាំងប្រដាប់អាវុធ--ខែ មីនា ឆ្នាំ ១៩៧៧ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៧៧ [កត់សម្គាល់ថា មានកម្លាំង ១.១២៧ នាក់នៅកងពល ៣១០ និងមាន ១.៥២៦ នៅកងពល ៤៥០ នៅខេត្តកំពង់ឆ្នាំង]។ ឯកសារ D4.1.504 កំណត់ហេតុស្តាប់ចម្លើយរបស់ កែវ គីន លេខ ERN EN 00290500, KH 00282941 [នៅពេលសាក្សីមកដល់ដំបូងនៅព្រលានយន្តហោះកំពង់លាវ ខេត្តកំពង់ឆ្នាំង គេបង្ខំឲ្យគាត់រើផ្ទះសម្បែង កាប់ដើមឈើ និងគាស់គុលឈើ] លេខ ERN EN 00290501, KH 00282943 ["ចាប់ពីម៉ោងបួនកន្លះ ទៅម៉ោងប្រាំព្រឹក អ្នកនៅការដ្ឋាន ត្រូវទៅជួយស្ទូងប្រជាជននៅតាមស្រែ នៅតាមក្បែរព្រលាន ជារៀងរាល់ថ្ងៃពេលខែស្ទូងស្រូវ។

និងកម្មាភិបាលរំសាយ (មកពីកងពល ១៦៤ និងអង្គភាពផ្សេងទៀត) ដែលត្រូវគេកំណត់ថាជា

---

ការងារការដ្ឋានត្រូវចាប់ផ្តើមធ្វើ ចាប់ពីម៉ោងប្រាំពីររហូតដល់ម៉ោង១១ថ្ងៃ សម្រាកហូបបាយ និងចាប់ផ្តើមធ្វើការងារជាថ្មីចាប់ពីម៉ោង១រសៀលរហូតដល់ម៉ោង៥ល្ងាច។ ពេលយប់ចាប់ផ្តើមពីម៉ោង៧រហូតដល់ម៉ោង ១០:៣០ យប់។ ការងារមានការលំបាកយ៉ាងខ្លាំង ព្រោះជាការងារធ្ងន់ៗ ដូចជាដញ្ជូនស៊ីម៉ង់ត៍ និងធ្វើការគ្មានសម្រាក ព្រោះមានអ្នកត្រួតពិនិត្យ"]។ ឯកសារ D4.1.508 កំណត់ហេតុស្តាប់ចម្លើយរបស់ ចាន់ ម៉ន ហៅក្រៅ ជួប សុខឃុម លេខ ERN EN 00292823, KH 00287527 ["ការងារដំបូង ពួកយោធាទាំងនោះ ត្រូវកាប់ឈើ គាស់គល់ និងរើសឫសឈើតូចៗ សូម្បីតែប៉ុនចង្កឹះ [...] ការងារមានតាមផ្នែក ដូចជាផ្នែកឈូសដី ផ្នែករែថ្ម ផ្នែករើសឫសឈើ។ល។ ដែលការងារមានការលំបាកយ៉ាងខ្លាំង និងតឹងតែង"]។ ឯកសារ D4.1.513 កំណត់ហេតុស្តាប់ចម្លើយរបស់ ឃិន វ៉ាត លេខ ERN EN 00315914, KH 00304365 [នៅព្រលានយន្តហោះកំពង់ឆ្នាំង (ចុងឆ្នាំ ១៩៧៧)៖ "ខ្ញុំបានឃើញកងទ័ពទាំងនោះគាស់គល់ត្នោត កាប់ឆ្ការព្រៃ លាយស៊ីម៉ងត៍ ចាក់បេតុង ចុចបំផ្ទុះថ្មនៅលើភ្នំ ព្រមទាំងធ្វើរូងនៅភ្នំមួយ ដែលស្ថិតនៅខាងកើតព្រលានយន្តហោះ។ ខ្ញុំឮគេថា រូងទាំងនោះ គេធ្វើសម្រាប់ដាក់យន្តហោះ។ កងទ័ពដែលកំពុងធ្វើការងារនៅទីនោះមានស្រីប្រុសលាយឡំគ្នា [...] ការងារមានការលំបាកខ្លាំង ដោយសារថ្នាក់លើបញ្ជាឱ្យធ្វើការងារលឿនដើម្បីយកព្រលានយន្តហោះមកបម្រើការ"]។ ឯកសារ D4.1.1151 កំណត់ហេតុស្តាប់ចម្លើយរបស់ ប្រាក់ យុត ហៅក្រៅ អ៊ី លេខ ERN EN 00223337, KH 00172081 ["នៅចុងឆ្នាំ ១៩៧៧ គេបញ្ជូនឱ្យទៅធ្វើព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំង។ ខ្ញុំនៅ និងធ្វើការទីនោះរហូតដល់បែកឆ្នាំ ១៩៧៩។ នៅទីនោះ គេឱ្យខ្លះរៀបថ្ម ខ្លះវាយថ្ម [...] នៅទីនោះធ្វើការទាំងយប់ទាំងថ្ងៃ [...] តែ ការហូបចុកបានបានយពីពេល"]។ ឯកសារ D4.1.773 កំណាត់ហេតុស្តាប់ចម្លើយរបស់ ទេស ត្រិច លេខ ERN EN 00346979-80, KH 00342437 ["គេបញ្ជូនមកកំពង់ឆ្នាំង គឺខ្ញុំតែម្នាក់ឯង ប្រហែលនៅដើមឆ្នាំ ១៩៧៨។ គេឱ្យខ្ញុំដាប់ថ្ម ដើម្បីដាក់ឈ្នួនដុតឱ្យផ្ទុះដើម្បីបំបែកថ្ម ធ្វើរូងដាក់យន្តហោះ និងថ្មកិនក្រាលធ្វើព្រលានយន្តហោះ [...] ពេលខ្លះ គេឱ្យខ្ញុំជីកដីនៅកន្លែងព្រលានយន្តហោះ [...]បានហូបតែបបររាវៗ មួយថ្ងៃពីរដង តែហូបមិនឆ្អែតទេ។ មួយពេលមានបបរមួយចានតូច"]។ ឯកសារ D4.1.505 កំណត់ហេតុស្តាប់ចម្លើយរបស់ ស៊ុំ សុខន លេខ ERN EN 00292864-65, KH 00282959-60 ["នៅខែមេសា ឆ្នាំ ១៩៧៨ ខ្ញុំបានទៅដល់ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង [...] ចំពោះការងារវិញ ព្រឹកព្រលឹម ត្រូវក្រោកតម្រង់ជួរអប់រំទិតៀនគ្នា និងដកពិសោធន៍ការងារ។ បន្ទាប់មកទៀត នៅម៉ោងប្រាំមួយ ត្រូវទៅដល់កន្លែងការរដ្ឋាន ហើយត្រូវធ្វើការដល់ម៉ោងដប់មួយ ទើបសម្រាកហូបបបរ ដល់ម៉ោងមួយរសៀល ចូលធ្វើការវិញ និងត្រូវធ្វើការរហូតដល់ម៉ោងប្រាំល្ងាច រួចសម្រាកហូបបបរមួយម៉ោង រហូតដល់ម៉ោងប្រាំមួយ ត្រូវធ្វើការវិញរហូតដល់ម៉ោងដប់មួយយប់។ លក្ខខណ្ឌការងារបែបនេះត្រូវធ្វើការជារៀងរាល់ថ្ងៃដោយគ្មានសៅរ៍អាទិត្យ។ ខ្ញុំបានឃើញកម្មករឈឺ ដោយសារអត់ឃ្លាន ធ្វើការហួសកម្លាំង រហូតដល់ស្លាប់"]។ ឯកសារ D1.3.32.39 ចម្លើយរបស់ សែម ហឿន ហៅ គិម ផ្តល់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា លេខ ERN EN 00876511-12, KH 00020591 ["ស៖ ហើយអ្នកដែលបញ្ជូនទៅកំពង់ឆ្នាំងនិងគឺសុទ្ធតែអ្នកទោសទាំងអស់? ឆ៖ បាទ! អ្នកទោសទាំងអស់ [...] គ្រប់ភូមិភាគ គ្រប់ខេត្តមិនដឹងជានៅខេត្តណាខេត្តអីទេ ដូចជាខាងបូព៌ាអ៊ីចឹងវាជាប់នឹងនិន្នាការដែលថាទោសអ៊ីចឹងគឺគេបញ្ជូនមកហើយ ខេតតសៀម រាប អ៊ីចឹង មានទោសគេបញ្ជូនមក មកដាក់កន្លែងមួយដុំ នៅកន្លែងកសាងហ្នឹងហ្នង មិនមែនល្មមណា យកទៅអាចុចថ្ម"] ។

"សមាសភាពមិនល្អ" ត្រូវគេបង្ខំឱ្យធ្វើការធ្ងន់ ក្នុងលក្ខខណ្ឌអមនុស្សធម៌ នៅការដ្ឋានស្ទឹងហាវ និងរាម[1117]។

325. ការប្រព្រឹត្តិអមនុស្សធម៌របស់របបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានគេដឹងឮ និងរាយការណ៍ យ៉ាងទូលំទូលាយ[1118]។ មេដឹកនាំ ប.ក.ក នៅថ្នាក់ផ្សេងៗ បានទៅធ្វើទស្សនកិច្ចនៅតាមការដ្ឋាន[1119]

---

1117 សូមមើល ភស្តុតាងដែលបានដកស្រង់នៅ VIII.ង. ការដ្ឋានស្ទឹងហាវ - ៣. ឧក្រិដ្ឋកម្ម --ការធ្វើឱ្យទៅជាទាសករ, VIII.ង. ការដ្ឋានស្ទឹងហាវ ៣. ឧក្រិដ្ឋកម្ម --អំពើអមនុស្សធម៌ផ្សេងទៀត, VIII.ច. ការដ្ឋានតំបន់រៀម -- ៣. ឧក្រិដ្ឋកម្ម --ការធ្វើឱ្យទៅជាទាសករ, VIII.ច. ការដ្ឋានតំបន់រៀម -- ៣. ឧក្រិដ្ឋកម្ម--អំពើអមនុស្សធម៌ផ្សេងទៀត (ការប្រព្រឹត្តិដោយអមនុស្សធម៌) នៅក្នុងដីកាសន្និដ្ឋានស្ថាពរនេះ។

1118 ឯកសារ D1.3.16.3 រដ្ឋាភិបាលន័រវេ៖ សារណារបស់រដ្ឋាភិបាលន័រវេ តាមគណៈកម្មការស្តីពីសេចក្តីសម្រេចសិទ្ធិមនុស្ស លើកទី ៩ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៨ លេខ ERN EN 00087546, 00087561, 00087563-64, 00087566, 00087568-71។ ឯកសារ D1.3.30.28 គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បញ្ហាការរំលោភសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន នៅគ្រប់ប្រទេសទាំងអស់ ជាពិសេស ប្រទេស និងទឹកដីដែលមិនឯករាជ្យ និងស្ថិតនៅក្រោមអាណានិគមន៍ដទៃទៀត ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៧៩ លេខ ERN EN 00078652-53, 00078661, 00078663-64។ ឯកសារ D4.1.958 ក្រសួងការបរទេសសហរដ្ឋអាមេរិក៖អនុស្សរណៈសម្រាប់ប្រធានាធិបតី៖ ជីវិតក្នុងប្រទេសកម្ពុជា ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៦ លេខ ERN EN 00495458, 00495464-65។ ឯកសារ D4.1.957 ទូរលេខពីស្ថានទូតអាមេរិកប្រចាំ ទីក្រុងបាងកក ជូនទៅរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក និងស្ថានទូតនានា៖ ជនភៀសខ្លួនខ្មែរដើរចេញពីទីក្រុងភ្នំពេញ ឆ្នាំ ១៩៧៥ លេខ ERN EN 00495556-60។ ឯកសារ D14/36.1.13 កាសែតឈីកាហ្គោ៖ ប្រជាជនខ្មែររត់ភៀសខ្លួនចេញពីខ្មែរក្រហមឈ្លានពាន "អ្នកខ្លះនឹងមិនរស់រានមានជីវិតទេ" ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៧៥។ ឯកសារ D14/36.1.16 កាសែត ញូវយ៉កថែមស៍៖ បទឧក្រិដ្ឋនៅប្រទេសកម្ពុជា ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ១៩៧៥។ ឯកសារ D14/36.1.21 កាសែតវ៉ាស៊ីងតោន ប៉ុស្ត៍៖ រឿងគួរឱ្យភ័យរន្ធត់មួយនៅកម្ពុជា ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៨។ ឯកសារ D14/36.1.22 កាសែត ញូវយ៉ក៖ ជនភៀសខ្លួនពណ៌នាប្រទេសកម្ពុជាដែលហ៊ុំព័ទ្ធដោយភាពអត់ឃ្លាន ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ១៩៧៧។

1119 សូមមើលឧទាហរណ៍ ឯកសារ D4.1.65 កំណត់ហេតុអំពីទស្សនកិច្ចអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ថ្ងៃទី ២០-២៤ ខែ សីហា ឆ្នាំ ១៩៧៥។ ឯកសារ D1.3.27.5 កំណត់ហេតុអំពីទស្សនកិច្ចរបស់គណៈអចិន្ត្រៃយ៍ ថ្ងៃទី ១៩ -២១ ខែ មេសា ឆ្នាំ ១៩៧៦ លេខ ERN EN 00183421, KH 00019147-48 ["គណៈអចិន្ត្រៃយ៍នឹងទៅកាន់តាមមូលដ្ឋាននៅខែឧសភា [...] ដើម្បីទៅជំរុញស្រូវដើមឆ្នាំ ពិសេសនៅភូមភាគធំៗ ដូចជា ពាយ័ព្យ ឧត្តរ នីរតី និងសៀមរាប"។ ឯកសារ D4.1.1142 កំណត់ហេតុស្តាប់ចម្លើយរបស់ ថា សុត លេខ ERN EN 00226110, KH 00204742 ["ខ្ញុំធ្លាប់ជូនដំណើរការពារ អ៊ុំ នួន ជា ទៅតាមខេត្តដូចជា ខេត្តព្រៃវែង ស្វាយរៀង សៀមរាប កំពត បាត់ដំបង កំពង់សោម តាកែវ និងស្ទឹងត្រែង ដើម្បីជួបប្រជុំជាមួយកម្មាភិបាលនៅតាមតំបន់មេទាហាន ដើម្បីផ្សព្វផ្សាយអប់រំផ្នែកនយោបាយ

ហើយកង្វះខាតអាហារ និងជំងឺ ត្រូវបានទទួលស្គាល់ ក្នុងពេលប្រជុំ[1120] ក្នុងឯកសារបោះពុម្ពផ្សាយរបស់ ប.ក.ក[1121] ហើយត្រូវបានរាយការណ៍ជូនថ្នាក់លើ[1122]។ ឧទាហរណ៍ **មាស មុត** បាន

---

[...] ហើយគាត់ធ្លាប់ចុះទៅមើលការដ្ឋានទំនប់ប្រឡាយ គាត់ចុះញឹកញាប់ ៥ ទៅ ៦ ដងក្នុងមួយខែ។ នួន ជា ធ្លាប់ឃើញស្ថានភាពប្រជាជនលំបាកខ្វះខាតជីវភាពដែរ។ ខ្ញុំធ្លាប់ជូន អ៊ុំ ខៀវ សំផន ដែលអមដំណើរសម្តេច សីហនុចុះទៅតាមខេត្ត ដូចជា សៀម រាប បាត់ដំបង កំពត និងកំពង់សោម។ ធ្លាប់ជូនដំណើរ អ៊ុំ ប៉ុល ពត ទៅមើលការជីកប្រឡាយ និងលើកទំនប់ជួនកាល អ៊ុំ នួន ជា ទៅជាមួយអ៊ុំ ប៉ុល ពត ដែរ"]។ ឯកសារ D4.1.240 កំណត់ហេតុស្តាប់ចម្លើយរបស់ អឿន តាន លេខ ERN EN 00235131, KH 00231804 ["ខ្ញុំធ្លាប់ជូនគាត់ [ប៉ុល ពត] ទៅបាត់ដំបង តាកែវ សៀមរាប កំពង់ធំ កំពង់ឆ្នាំង កំពង់ចាម ក្រចេះ ដើម្បីជួបអ្នកដឹកនាំថ្នាក់តំបន់ ភូមិភាគ ហើយមានការប្រជុំជាមួយគ្នា"]។ ឯកសារ D4.1.1149 កំណត់ហេតុស្តាប់ចម្លើយរបស់ រស់ ស៊ុយ លេខ ERN EN 00205113, KH 00172051 ["លោក នួនជា ដែលបានមកមើលកន្លែងធ្វើការរបស់ខ្ញុំ។ ខ្ញុំដឹងថា ខៀវ សំផន មានការភ្ញាក់ផ្អើល ដោយដឹងថា សមាជិកកម្មាភិបាល មិនមានអ្វីហូបគ្រប់គ្រាន់ គឺបានហូបតែបបរ។ សៈ តើលោក នួន ជា ធ្លាប់និយាយពីរឿងម្ហូបអាហារ និងលក្ខខណ្ឌការងារ ឬទេ? ឆៈ គាត់មិនដែលបានសួរទេ។ គ្រាន់តែមកពិនិត្យមើលឃ្លាំងធម្មតា"]។ ឯកសារ D54/17 កំណត់ហេតុស្តាប់ចម្លើយរបស់ សយ ប៊ន ឆ.14-16 ["សៈ លោកបានចង្អុលបង្ហាញពីទីតាំងឡឥដ្ឋដែលនៅជិតព្រលានយន្តហោះ កងកេង តាមបណ្តោយផ្លូវទៅរាម តើលោកបានដឹងពីអ្វីខ្លះពីទីកន្លែងនោះ? ឆ.14៖ វាជាកន្លែងការដ្ឋានពលកម្មធម្មតារបស់កងពល ១៦៤ ខ្ញុំបានមកទីកន្លែងនេះម្តងនៅចុងឆ្នាំ ១៩៧៥។ ខ្ញុំមានមិត្តភ័ក្រមួយចំនួនបានធ្វើពលកម្មនៅទីនោះ [...] ឆ.15៖ [...] មេបញ្ជាការកងពល១៦៤ មាស មុត ក៏បានមកពិនិត្យការងារនៅទីនោះដែរ។ [...] ស.16៖ លោកនិយាយ លោកបាននៅទីនោះបានតែម្តងទេ ហេតុអ្វីបានជាលោកដឹងថា មាស មុត មកកន្លែងនោះ? ឆ.16៖ ខ្ញុំបានសួរមិត្តភ័ក្រដែលធ្វើការនៅទីនោះ តើមាស មុត មកមើលកន្លែងនេះដែរ ឬទេ? គេប្រាប់ខ្ញុំថាគាត់បានមកមើលនៅទីនេះដែរ"]។ ឯកសារ D4.1.850 កំណត់ហេតុស្តាប់ចម្លើយរបស់ សូត្រ ទឿង លេខ ERN EN 00414594-98, KH 00408435-40។ ឯកសារ D4.1.1133 កំណត់ហេតុស្តាប់ចម្លើយរបស់ សេង លីថេង លេខ ERN EN 00223564, KH 00204025។ ឯកសារ D4.1.1140 កំណត់ហេតុស្តាប់ចម្លើយរបស់ យឹម ឡាំង លេខ ERN EN 00204732, KH 00204727។

1120 សូមមើលឧទាហរណ៍ ឯកសារ D4.1.65 កំណត់ហេតុអំពីទស្សនកិច្ច អចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ថ្ងៃទី ២០-២៤ ខែ សីហា ឆ្នាំ ១៩៧៥ លេខ ERN EN 00182998, KH 00008485 ["កន្លែងស្រុកឆ្ងាយ នៅខ្វះខាតខ្លះដែរ។ ជំងឺថ្កាត់ក៏មានច្រើន។ ប្រជាជនថ្មីមានការខ្វះខាត ខ្វះស្បៀងផង ខ្វះថ្នាំសង្កូវផង"]។ ឯកសារ D4.1.76 កំណត់ហេតុការប្រជុំគណៈរដ្ឋមន្ត្រីលើកទីពីរ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៧៦ លេខ ERN EN 00182678-79, KH 00000790 ["របបហូប៖ [...] កន្លែងខ្វះខាតមានពីរកន្លែង តែយើងអាចដោះស្រាយបាន [...] ជំងឺមនុស្ស មាននៅឡើយ"]។ ឯកសារ D4.1.78 កំណត់ហេតុគណៈអចិន្ត្រៃយ៍៖ ប្រជុំការងារ សង្គមកិច្ច សុខាភិបាល ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៧៦ លេខ ERN EN 00183369 ["បើសិនយើងអាចធ្វើបានបីតោនក្នុងមួយហិកតា ម្ល៉េះ យើងអាចមានស្បៀងគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ប្រជាជន [...] សរុបមក បញ្ហាសុខាភិបាលត្រូវបានកាត់បន្ថយបានច្រើន បើប្រៀបធៀបនឹងឆ្នាំទៅ ប៉ុន្តែ ការខ្វះថ្នាំពេទ្យនៅតែជាបញ្ហាចម្បង"]។

1121 សូមមើលឧទាហរណ៍ ឯកសារ D4.1.888 ទស្សនាវដ្តី ទង់បដិវត្ត ចេញផ្សាយខែ ធ្នូ ឆ្នាំ ១៩៧៦-ខែ មករា ឆ្នាំ ១៩៧៧ លេខ ERN EN 00491400, KH 00063008 ["កាលឆ្នាំ ១៩៧៦ យើងខ្វះខាតស្បៀង និងថ្នាំសង្កូវ"]។ ឯកសារ D1.3.24.5 ទស្សនាវដ្តី ទង់បដិវត្ត ចេញផ្សាយ ខែ ឧសភា-មិថុនា ឆ្នាំ ១៩៧៨ លេខ ERN EN 00185337, KH 00064571-72 ["ផលឆ្នាំ ៧៧ នេះ យើងយកមកបម្រើប្រជាជនមិនបាន ១០០ ភាគរយទេ។ តាមទំហំផលត្រូវសម្រេចបាន ១០០ ភាគរយ។ តែខ្វះស្បៀងអាហារ ខ្វះថ្នាំសង្កូវ ខ្វះសំលៀកបំពាក់ [...] នេះជាគុណវិបត្តិរបស់យើងធំខាងដោះស្រាយជីវភាពប្រជាជន"], លេខ ERN EN 00185344, KH 00064581 ["បន្តយកចិត្តទុកដាក់ដោះស្រាយ និងលើកស្ទួយជីវភាពប្រជាជន ឲ្យកើនចម្រើនឡើងតទៅទៀត ទាំងស្បៀង អាហារ ទាំងសំលៀកបំពាក់ ទាំងសុខភាព ទាំងជម្រករស់នៅ ទាំងការសិក្សាអប់រំ។ កន្លែងខ្វះខាតត្រូវដោះស្រាយឲ្យបានគ្រប់គ្រាន់ដាច់ខាត។ កន្លែងគ្រប់គ្រាន់ហើយ ត្រូវឲ្យកើនចម្រើន និងធានាអះអាងដាច់ខាត"]។

1122 សូមមើលឧទាហរណ៍ ឯកសារ D4.1.579 ទូរលេខ ៩៤ ពី (កែ ពក) ជូនបង ប៉ុល ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៧៦ លេខ ERN EN 00182658-59, KH 00000766 [រាយការណ៍កថា "មានជំងឺគ្រុន និងរាគរូសច្រើន" ក្នុងចំណោមប្រជាជនក្នុងភូមិភាគ ដែលត្រូវដោះស្រាយដោយកាត់បន្ថយម៉ោងធ្វើការ]។ ឯកសារ D4.1.224 ទូរលេខ ១៤ ពីភ្លួង ផ្ញើជូន ម ៨៧០ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ [រាយការណ៍អំពីការខ្វះស្បៀងនៅតាមសហករណ៍ និងការដ្ឋានចាប់ពីឆ្លូងទៅក្រូចឆ្មា ខណៈដែល សកម្មភាពរបស់ខ្មាំងកាត់ផ្តាច់ផ្លូវ]។ ឯកសារ D4.1.1039 ទូរលេខ ពីឡៅ គោរពជូនបង ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ លេខ ERN EN 00548800-01, KH 00021111 [រាយការណ៍ថា ក្នុងស្រុក ២១ និង ស្រុក ២២ "ការបង្កបង្កើនស្រូវមិនគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់ប្រជាជនក្នុងស្រុកទាំងមូល" ជំងឺរួមមាន គ្រុនចាញ់ ឈឺពោះ នោមចេញឈាម ជំងឺខាន់លឿង។ ក្នុងស្រុក ៣៤ "ពិបាកណាស់" ស្ថានភាពខ្វះស្បៀងពិតជាធ្ងន់ធ្ងរ ហើយជំងឺមានដូចជា គ្រុនក្តៅ រាគរូស ឈឺប្រកាច់។ នៅ ស្រុក ៨២ និងស្រុក ៨៣ មនុស្ស បីនាក់ទទួលបានអង្ករមួយកំប៉ុងក្នុងមួយពេល។ ចំនួនអ្នកកើតឃ្លង់កើនជា ១.០០០ នាក់ហើយ]។ ឯកសារ D4.1.227 សារទូរលេខ ពីលេខាភូមិភាគឧត្តរ សែ ជូនគណៈ ៨៧០ ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៧៨ លេខ ERN EN 00182758, KH 00001061-62 [រាយការណ៍អំពីខ្មាំងបំផ្លាញការបង្កបង្កើនផលនៅតំបន់ ១០៣ និងការដាច់ស្បៀងនៅតំបន់ព្រះវិហារ ដែលលបណ្តាលមកពីការប្រមូលផលបានតិច]។ ឯកសារ D4.1.899 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៧៦ លេខ ERN EN 00517911-13, KH 00376666-68 [មេបញ្ជាការផ្សេងៗរាយការណ៍អំពីស្ថានភាពក្នុងកងរបស់ខ្លួន រួមមាន អឿន (កងពល ៣១០) ដែលបានរាយការណ៍ថា មានអ្នកជំងឺ ជាង៨០០ នាក់នៅក្នុងកងរបស់គាត់។ អង្គការទទួលស្គាល់ថា មានការប្រើប្រាស់ថ្នាំខុស និងមិនបានត្រឹមត្រូវ]។ ឯកសារ D1.3.30.2 របាយការណ៍ប្រចាំខែអង្គភាព ១៦៤ ពី មាស មុត ជូនបង ៨៩ (សុន សេន) ថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៧៦ [មាស មុត ពិពណ៌នាអំពីការវាយប្រយុទ្ធគ្នានៅកោះសេះ និងកោះត្រល់ ហើយរាយការណ៍ថា ស្បៀងអង្ករនៅកោះរុង អាចគ្រប់ក្នុងរយៈពេលប្រាំមួយខែ "តែអង្ករចាស់ទាំងនេះខូចហើយ ខ្មួតស៊ីហើយ" ចម្លងជូនបង ៨៧ (វ៉ន វេត)]។ ឯកសារ D1.3.27.10 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ៖កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពល លេខា និងអនុលេខាវរៈសេនាធំ ថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៧៦ លេខ ERN EN 00183959-60 [អ្នកចូលរួមប្រជុំបានរាយការណ៍ករណីដែលមនុស្សមិនសប្បាយចិត្ត អស់សង្ឃឹម អស់កម្លាំង និងធ្លាក់ខ្លួនឈឺ គ្មានពេលសម្រាក ត្អូញត្អែរអំពីការខ្វះស្បៀង រត់ចោលជួរ។ បង ៨៩ (សុន សេន) ពិភាក្សាអំពីការដំណោះស្រាយការផ្គត់ផ្គង់ស្បៀង]។

វាយការណ៍ថា នៅក្នុងតំបន់របស់គាត់ កងទ័ព និងប្រជាជន ១៧.០០០ នាក់ កំពុងដាំស្រូវ ប៉ុន្តែនៅខ្វះ ៦១.០០០ ថាំង ហើយបងប្អូនគ្រុនច្រើន ដោយសារតែមិនសូវមានអាវភ្លៀង[1123]។

326. ប៉ុន្តែ ទោះបីជារបបអាហារមិនគ្រប់គ្រាន់ នៅតាមការដ្ឋាន និងសហករណ៍ក៏ដោយ ក៏មជ្ឈិមបក្សនៅតែផ្តោតគោលដៅលើការនាំចេញអង្ករទៅប្រទេសផ្សេង[1124]។ ច្រើនឆ្នាំក្រោយមក ខៀវ សំផន

ឯកសារ D4.1.522 កំណត់ហេតុស្តាប់ចម្លើយរបស់ ស៊ូ សឿន លេខ ERN EN 00360113, KH 00348830 [ប្រពន្ធរបស់ កែ ពក "ប្រធានសហករណ៍ ប្រធានក្រុម បានតវ៉ាថា ការធ្វើស្រែបានផលច្រើន ហេតុអ្វីបានប្រជាជនហូបមិនឆ្អែត។ ខ្ញុំក៏ធ្លាប់បានប្រាប់អំពីសំណួមពរនេះ ទៅគណៈស្រុកដែរ ហើយគណៈស្រុកបានវាយការណ៍ទៅខាងលើ ប៉ុន្តែថ្នាក់លើ មិនបានឆ្លើយតបវិញទេ។ ចំណែកស្រូវវិញត្រូវបានគេដឹកចេញទៅក្រៅទៀត"]។

1123 ឯកសារ D1.3.27.18 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ៖ កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភាររបស់កងពល និងវរៈសេនាធំ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ លេខ ERN EN 00195341, KH 00052391។

1124 ឯកសារ D4.1.739 បទឧទ្ទេសនាមរបស់សមមិត្តលេខាក្នុងសម័យប្រជុំគណៈរដ្ឋមន្ត្រី លើកទី១ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៧៦ លេខ ERN EN 00143465, KH 00072757 ["យើងផ្តល់ជំនួយជាស្រូវ ៣០០០ តោន ឲ្យលាវទៀត ក្នុងលក្ខណៈដែលយើងទើបចេញពីសង្គ្រាមវិនាសកម្មផង"]។ ឯកសារ D4.1.588 អនុស្សរណៈក្រសួងការបរទេសបារាំង ៖ ការពិនិត្យឡើងវិញអំពីប្រទេសកម្ពុជា ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៦ លេខ ERN EN 00610832, KH 00522402 [របាយការណ៍អំពីការផ្តល់ជំនួយស្រូវចំនួន ៣ ០០០ តោន ឲ្យប្រទេសឡាវ នៅខែ ធ្នូ ឆ្នាំ ១៩៧៥]។ ឯកសារ D4.1.887 ទស្សនាវដ្តីទង់បដិវត្ត ចេញខែ វិច្ឆិកា ឆ្នាំ ១៩៧៦ លេខ ERN EN 00455284-85, KH 00064966 ["យើងត្រូវនាំផលស្រូវឆ្នាំ ១៩៧៦ នេះ ចេះទៅក្រៅ សែនតោន។ ការដែលយើងនាំអង្ករទៅក្រៅបាន ក្រោយពេលសង្គ្រាមដូច្នេះ ជះឥទ្ធិពលសំបើមណាស់ នៅក្នុងសកលោក"]។ ឯកសារ D4.1.903 សុន្ទរកថារបស់ នួន ជា នៅក្នុងមិទ្ទីញទិវាខួបកងទ័ព ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ១៩៧៧ លេខ ERN EN S 00004076, KH 00649947 ["ប្រជាជនយើងមានហូបគ្រប់គ្រាន់ [...] យើងបានផលិតស្រូវលើសតម្រូវការចំនួន ១៥ ០០០០ តោន ដើម្បីនាំចេញ។ ចំណុចនេះ មានន័យថា យើងសម្រេចបានតាមផែនការឆ្នាំ ១៩៧៦ ទាំងស្រុង"]។ ឯកសារ D4.1.38 ឯកសារបក្សកុម្មុយនីស្តកម្ពុជា៖ សេចក្តីពន្យល់បឋមមុនពេលអានផែនការ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៧៦ បោះពុម្ពផ្សាយដោយ ដេវីដ ឆេនដ៍ល័រ និងអ្នកផ្សេងច្រើនទៀត ក្នុងសៀវភៅមានចំណងជើងថា ផែនការ៤ឆ្នាំរបស់ ប៉ុល ពត លេខ ERN EN 00104071 ["យើងត្រូវនាំអង្ករចេញឲ្យច្រើន។ នៅក្នុងឆ្នាំ ១៩៧៧ យើងគ្រោងនឹងនាំអង្ករចេញពី ៨០០ ០០០ តោន ទៅមួយលានតោន"]។ ឯកសារ D4.1.986 FBIS ៖ សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគម្រប់ ខួប ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៧៧ លេខ ERN EN 00419513, KH 00292805 ["យើងបានប្រមូលបានច្រើនសម្រាប់ឆ្នាំ ១៩៧៧។ ឥឡូវនេះ យើងអាចចិញ្ចឹមប្រជាជនយើង តាមការបែងចែករបបអាហារបានគ្រប់គ្រាន់ពីរដ្ឋ។ យើនៅសល់សម្រាប់នាំចេញទៀត"]។ ឯកសារ D114/29.1.4 ប៉ែន យៀរនិន៖ របបប៉ុល ពត លេខ ERN EN 00678692, KH 00637933 ["នៅក្នុងឆ្នាំ ១៩៧៨ កម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ បានអះអាងថា នាំស្រូវចេញចំនួន ១០០ ០០០ តោន ទៅកាន់ប្រទេសផ្សេងៗ ដូចជា យូហ្គោស្លាវី ម៉ាដាហ្គាស្កា និងទីក្រុងហុង កុង"]។ ឯកសារ D234/2.1.33 ការ

បានទទួលស្គាល់ថា "ការបង្អត់បាយប្រជាជន ដោយថា ដើម្បីដឹកស្រូវទៅជូនរដ្ឋឲ្យគ្រប់តាមការកំណត់ បាននាំឲ្យមានការបាត់បង់ជីវិតមនុស្សអស់ច្រើនណាស់"[1125]។

## ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ

327. គោលនយោបាយបក្សសំដៅបង្កើតចំនួនប្រជាជនឲ្យបានឆាប់រហ័ស ពី ១៥ ទៅ ២០ លាននាក់ បាននាំទៅដល់ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមដំណេកដោយបង្ខំ (ការរំលោភសេពសន្ថវៈ) ក្នុងគោលបំណងជាក់លាក់ដើម្បីបង្កើតអ្នកធ្វើការ និងទាហាន នាពេលអនាគត[1126]។ ប.ក.ក មានគោលដៅបង្កើនចំនួនប្រជាជនឲ្យបានមួយជាពីរ ឬបី ក្នុងរយៈពេលខ្លី[1127] ប៉ុន្តែ អត្រាកំណើត

---

ប្រារព្ធខួបថ្ងៃទី ១៧ មេសា នៅទីក្រុងភ្នំពេញ ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៨ លេខ ERN EN S 00010560 [ខៀវ សំផន បានប្រាប់កម្មករចំនួន ២០ ០០០ ជាមួយនឹងកងយោធាថា "យើង [...] សម្រេចបានតាមផែនការបង្កបង្កើនផល ហើយ [...] ហើយបាននាំចេញស្រូវថែមទៀត កាលពីឆ្នាំទៅ។ នេះបានផ្តល់ឲ្យយើងមានសក្តានុពលថែមទៀតសម្រាប់ស្ថាបនាប្រទេសជាតិ ហើយនេះជាលទ្ធផលនៃការខិតខំប្រឹងប្រែងផ្នែកដាំដុះរបស់យើង"]។

[1125] ឯកសារ D69.1.42 ខៀវ សំផន៖ ខៀវ សំផន៖ ការពិចារណាអំពីប្រវត្តសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ លេខ ERN EN 00498287, KH 00380472។

[1126] ឯកសារ D4.1.888 ទស្សនាវដ្តី ទង់បដិវត្ត ចេញផ្សាយ ខែ ធ្នូ ឆ្នាំ ១៩៧៦-ខែមករា ឆ្នាំ ១៩៧៧ លេខ ERN EN 00491435, KH 00063054 ["ដូច្នេះ សារៈសំខាន់នៃបដិវត្តសង្គមនិយម និងការកសាងសង្គមនិយម មានទិសដៅកសាងប្រទេសបានល្អ និងដោះស្រាយជីវភាពប្រជាជនបានឆាប់រហ័ស។ យើងត្រូវការប្រជាជន ពី ១៥ ទៅ ២០ លាននាក់ទើបគ្រប់គ្រាន់នឹងដីយើង"]។

[1127] ឯកសារ D4.1.864 ទស្សនាវដ្តី ទង់បដិវត្ត ចេញផ្សាយខែ កញ្ញា ឆ្នាំ ១៩៧៧ លេខ ERN EN 00486262-63, KH 00063183-84 ["យើងត្រូវការចំនួនប្រជាជនកម្ពុជាចំនួនពី ១៥ លាន ទៅ ២០ លាននាក់ ក្នុងអំឡុងពេលជាង ១០ ឆ្នាំខាងមុខនេះ [...] ពីព្រោះសព្វថ្ងៃចំនួនប្រជាជនយើងជិត ៨ លាននាក់ នៅឆ្ងាយណាស់ ពីលទ្ធភាពរបស់ប្រទេសយើងដែលត្រូវការមានជនកម្ពុជាជាង ២០ លាននាក់។ ដូច្នេះ ទិសដៅរបស់យើងនឹងបង្កើតចំនួនប្រជាជន ឲ្យបានឆាប់រហ័ស"]។ ឯកសារ D4.1.189 សេចក្តីថ្លែងការណ៍របស់ អៀង សារី ទៅកាន់មហាសន្និបាតអង្គការសហប្រជាជាតិ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៧៧ លេខ ERN EN 00079815 កថាខណ្ឌ ៦០ និង ៦៣ លេខ ERN KH 00291027-28 ["យើងកំពុងខិតខំព្យាយាមធ្វើឲ្យប្រសើរយ៉ាងឆាប់រហ័សនូវស្ថានភាពរស់នៅ និងសុខភាពរបស់ប្រជាជនយើង ពីព្រោះយើងត្រូវការប្រជាជនចំនួន ១៥ ទៅ ២០ លាន នាក់ ក្នុងរយៈពេល១០ឆ្នាំ ខាងមុខ។ [...] យើងគ្មានហេតុផលដើម្បីកាត់បន្ថយចំនួនប្រជាជន ឬ រក្សានូវកម្រិតបច្ចុប្បន្ន ដែលយើងមានប្រជាជនចំនួន ៨ លាននាក់ តែប៉ុណ្ណោះ។ ចំនួនប្រជាជនយើង នៅខ្វះច្រើនណាស់ធៀបនឹងសមត្ថភាពរបស់ប្រទេសយើង ដែលត្រូវការប្រជាជនជាង ២០ លាននាក់។ ហេតុនេះហើយ ទិសដៅរបស់យើងគឺធ្វើឲ្យមានកើនឡើងចំនួនប្រជាជនយើងឲ្យបានឆាប់រហ័ស"]។ ឯកសារ D4.1.1013 សេចក្តីថ្លែងការណ៍របស់ ប៉ុល ពត នៅកិច្ចប្រជុំគណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ពិភាក្សាជាមួយនឹងគ

ត្រូវបានប៉ះពាល់ ដោយហេតុថា ស្ត្រីមានការលំបាកក្នុងការមានគភ៌ ដោយសារតែលទ្ធភាពមានកូនទាប បណ្តាលមកពីការពិបាកចិត្តខ្លាំង ការហូបចុកមិនគ្រប់គ្រាន់ និងការបំបែកបំបាក់គ្រួសារ[1128]។ ដោយសារតែទស្សនៈបង្កបង្កើនផលស្រូវទទួលបរាជ័យ ផែនការរបស់ ប.ក.ក ក្នុងការបង្កើនចំនួនប្រជាជនក៏ទទួលបរាជ័យយ៉ាងដំណំផងដែរ។ ទោះជាយ៉ាងនេះក្តី នេះជាឧទាហរណ៍ច្បាស់ក្រឡែតមួយទៀតនៃការធ្វើឲ្យប្រជាជនក្លាយជាទាសករដោយ ប.ក.ក។ មេដឹកនាំបក្សទាមទារភាពជាម្ចាស់លើជម្រើសរបស់មនុស្សថា តើប្រជាជនត្រូវរៀបការដែរឬទេ ហើយតើអ្នកណាត្រូវរៀបការជាមួយអ្នកណា និងភាពជាម្ចាស់លើសិទ្ធិទទួលបានបូរណភាពរាងកាយ តាមរយៈការបង្ខំប្រជាជនរាប់ពាន់នាក់ឲ្យរៀបការ និងរួមដំណេក ដោយគ្មានការព្រមព្រៀងពិតប្រាកដពីពួកគេ។ គោលនយោបាយនេះរបស់ ប.ក.ក ត្រូវបានបង្ហាញយ៉ាងលម្អិតនៅក្នុងផ្នែកស្តីពី *ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ* នៅក្នុងសេចក្តីសន្និដ្ឋាននេះ[1129]
។

ណៈប្រតិភូតសមាគមកម្ពុជា-ប៊ែលហ្សិក នៅថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៧៨ លេខ ERN EN 00574566, KH 00106284 ["បក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ មានផែនការបង្កើនចំនួនប្រជាជន ពី ១៥ ទៅ ២០ លាននាក់ ក្នុងរយៈពេលពី ១០ ទៅ ២០ ឆ្នាំ"]។

1128 ឯកសារ D69.1.42 ខៀវ សំផន៖ ការពិចារណាអំពីប្រវត្តសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ លេខ ERN EN 00498284, KH 00380467 [ប៉ុល ពត ចង់ឲ្យចំនួនប្រជាជនកើនឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖ "តែធ្វើម៉េចនឹងសម្រេចទិសដៅនេះបាន បើនារីរាំងរដូវដោយសារតែអត់ឃ្លាននោះ? ថ្នាក់ដឹកនាំឃើញបញ្ហានេះ"]។ ឯកសារ D11/54/3.1 ប្រតិចារឹករបស់ កុល ណៃម ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង 14.35.00-14.36.55 ["ធ្វើបាបប្រពន្ធខ្ញុំឲ្យខ្ញុំទាល់តែអត់មានកូនមានចៅ ហើយមិនមែនត្រឹមប្រពន្ធខ្ញុំទេ កូនគេខ្លះៗទៀត [...] ប៉ុនអាហ្នឹងរឿងរបស់គេ ឯរឿងខ្ញុំនេះអត់កូនតែម្តង កូនមកត្រូវរលូតៗ ដឹងវាបាក់កម្លាំង ឬមួយយ៉ាងម៉េចខ្ញុំអត់ដឹងដែរ"]។ ឯកសារ D11/255/3.1 ប្រតិចារឹករបស់ ហ៊ុន សុគន្ធី ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ម៉ោង 14.40.06-14.43.20 ["ស្រីៗនៅក្នុងភូមិខ្ញុំ មិនធ្លាក់រដូវទេ ដោយសារគ្មានអាហារហូបគ្រប់គ្រាន់"]។ ឯកសារ D1.3.17.1 អេលីហ្សាបែត ប៊ើកខ័រ៖ នៅពេលដែលសង្គ្រាមរលត់ទៅ ប្រទេសកម្ពុជា និងបដិវត្តន៍ខ្មែរក្រហម លេខ ERN EN 00237929, KH 00232298 ["ស្ត្រីភាគច្រើនលែងមានរដូវ មួយផ្នែកគឺបណ្តាលមកពីការបរិភោគអាហារមិនគ្រប់គ្រាន់ មួយផ្នែកទៀត គឺបណ្តាលមកពីដំណើរប៉ះទង្គិចខាងផ្លូវចិត្ត"]។

1129 សូមមើល VIII.ជ. ផ្នែកអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទ។

## VIII. ឧក្រិដ្ឋកម្ម និងទីតាំងឧក្រិដ្ឋកម្ម

### ក. ការបោសសម្អាតក្នុងកងពល ១៦៤

### ១. គោលនយោបាយបោសសម្អាតខ្មាំងផ្ទៃក្នុងរបស់ ប.ក.ក/កងទ័ពបដិវត្តកម្ពុជា និងគោលបំណងរបស់ មាស មុត ក្នុងការបោសសម្អាតនៅក្នុងជួរកងពល ១៦៤

328. **មាស មុត** បានអនុវត្តគោលនយោបាយរបស់មជ្ឈិមបក្ស ដើម្បី "អប់រំ" "កសាង" និង "កម្ទេច" ជារឿយៗ នូវសមាជិកយោធាដែលសង្ស័យថាមិនស្មោះត្រង់នឹងថ្នាក់ដឹកនាំបក្ស និងត្រូវបានកំណត់ថាជា "ខ្មាំង" ឬ "សមាសធាតុអាក្រក់"។

329. កំណត់ហេតុនៃកិច្ចប្រជុំរបស់ សុន សេន នាយសេនាធិការ ជាមួយមេបញ្ជាការ និងមេបញ្ជាការរងកងពលមជ្ឈិមបានកត់ត្រាថា **មាស មុត** និងអ្នករួមការងាររបស់គាត់ បានគាំទ្រផែនការរបស់ សុន សេន ក្នុងការបោសសម្អាតអ្នកដែលត្រូវបានសន្មតថាជាខ្មាំងដែលលាក់ខ្លួននៅក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជា រួមទាំង កងពល ១៦៤ ដែរ។ នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ សុន សេន បានប្រកាសថា បក្សបានចាប់ខ្លួនពួកក្បត់ ក្នុងនោះមាន ឈូក និង ចាន់ ចក្រី (តំបន់ ២៤ ភូមិបូព៌ា) ម៉ែន សាន ហៅ យ៉ា (លេខាភូមិភាគពាយ័ព្យសាន) និង កែវ មាស[1130] ហើយថា ចាំបាច់ត្រូវធានា "កុំឲ្យខ្មាំងស៊ីរូងផ្ទៃក្នុងបាន ធ្វើម៉េចឲ្យកងទ័ពយើងស្អាត [...] ត្រូវដាច់ខាតសម្រិតសម្រាំងសមាសភាពមិនល្អ"[1131]។ ក្រោយពីការប្រកាសរបស់ សុន សេន អ្នកនៅក្រោមបង្គាប់របស់ **មាស មុត**

---

1130 សូមមើល ចម្លើយសារភាព ស-២១៖ ឯកសារ D4.1.22, D4.1.651 ចម្លើយសារភាពស-២១ របស់ ចាន់ ចក្រី ហៅ នូវ មាន ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៧៦ លេខ ERN EN 00183019-85 (ដកស្រង់) លេខ ERN KH 00030985-2842 [ចាប់ខ្លួននៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៧៦]; ឯកសារ D4.1.943 ចម្លើយសារភាពស-២១របស់ សួន នៅ ហៅ ជូក ហៅ ម៉ែន ហៅ VIII [ចាប់ខ្លួននៅថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ១៩៧៦]; ឯកសារ D10.1.120 ចម្លើយសារភាពស-២១របស់ ម៉ែន សាន ហៅ ណៃ សារ៉ន ហៅអាចារ្យ សៀង ហៅ យ៉ា លេខ ERN KH 00009497-682, FR 00282377-90 (ដកស្រង់) [ចាប់ខ្លួននៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៧៦]; ចម្លើយសារភាពរបស់ កែវ មាស លេខាមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា មិនមាននៅក្នុងសំណុំរឿង ០០៣ ទេ [KH 00226710-28, EN 00284013, 00983407-24, FR 00294499]។

1131 ឯកសារ D1.3.27.20 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ លេខ ERN EN 00940344, KH 00052407, FR 00334976 [ក្រោយពីពន្យល់ថា ចក្រី, យ៉ា, ឈូក និង កែវ មាស ជាមនុស្សក្បត់ខាងវៀតណាម ហើយត្រូវបានកម្ទេចចោលនោះសុន សេន (បង ៨៩) បាននិយាយថា៖ "តែបញ្ហាសំខាន់នៅត្រង់

ឈ្មោះ ឌឹម ជាមេបញ្ជាការរងកងពល ១៦៤ បាននិយាយថា "ជំនឿជ្រះស្រឡះថា កងទ័ពនេះស្អាត ហើយ ដូចនៅមិនទាន់ស្អាតទេ ត្រូវតែតាមដានសម្រិតសម្រាំងតទៅទៀត"[1132]។ **មាស មុត** បានគាំទ្រយ៉ាងពេញទំហឹងចំពោះការអំពាវនាវឲ្យធ្វើការបោសសម្អាតបន្ថែមទៀតទៅលើជនក្បត់ និងខ្មាំងផ្ទៃក្នុង។ កំណត់ហេតុប្រជុំបានកត់ត្រាថា **មាស មុត** បានប្រាប់មេបញ្ជាការ៖

> សមាសភាពមិនល្អ ឬខ្មាំង នៅតែពួនបន្ទំ បង្កប់ក្នុងជួរបានទៀត។ បញ្ហាក្តាប់សតិអារម្មណ៍ ជាប្រចាំថ្ងៃរបស់អង្គការស្នូលជាកត្តាសំខាន់បំផុត។

---

កងទ័ពយើងស្អាត បរិសុទ្ធ [...] ន័យអនុវត្តជាក់ស្តែងខាងប្រុងប្រយ័ត្នបដិវត្ត គឺក្តាប់អង្គភាពយើងឲ្យជាប់ កុំឲ្យខ្មាំងស៊ីរូងផ្ទៃក្នុងបាន ធ្វើម៉េចឲ្យកងទ័ពយើងស្អាត"], លេខ ERN EN 00940345, KH 00052408, FR 00334977 ["ត្រូវអប់រំបងប្អូនឲ្យយល់ពីភាពទំនាស់ពីខ្មាំងស៊ីរូង ពីឱបាយកលខ្មាំង ឲ្យជ្រួតជ្រាបដល់ក្រោម។ ឲ្យបងប្អូនយល់ពីភាពទំនាស់ក្នុងសង្គមយើងឲ្យបានច្បាស់។ ៣. ត្រូវដាច់ខាតសំរិតសំរាំងសមាសភាពមិនល្អ តែកុំឆ្វេង កុំស្តាំ"]។ សូមមើលផងដែរ ឯកសារ D1.3.27.13 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៧៦ លេខ ERN EN 00183966, KH 000552381 [សុន សេន៖ "កងពលពិនិត្យតាមដានសមាសភាពមិនល្អ។ ចាត់តាំងគ្រប់គ្រងឲ្យនៅដោយឡែក"], លេខ ERN EN 00183968, KH 00052382 [សុន សេន៖ "ត្រូវសំរិតសំរាំងសមាសភាពមិនល្អតទៅទៀត។ ត្រូវដាច់ខាត តែកុំឆ្វេង តើគេគាំទ្រ ឬមិនគាំទ្រ មិនគាំទ្រដោយមិនយល់ ឬមិនគាំទ្រដោយប្រឆាំងចូលដៃជាមួយខ្មាំង?"]; ទាក់ទិនឹងការចោទប្រកាន់អំពើក្បត់របស់ ចាន់ ចក្រី សូមមើលផងដែរ ឯកសារ D1.3.27.17 កំណត់ហេតុនៃការប្រជុំជាមួយកងពល ១៧០ និង កងពល ២៩០ នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៧៦ [កិច្ចប្រជុំចូលរួមដោយ សុន សេន, ឌុច, លេខាងកងពល ១៧០ ឈ្មោះ សុខ និងលេខាកងពល ២៩០ ឈ្មោះ តាល់ ដែលបានមូលមតិគ្នាចាប់ខ្លួនកម្មាភិបាល ២៩ នាក់ពីកងពល ១៧០ ព្រមទាំង "ប្រពន្ធចក្រី និងក្មួយស្រី"]; ឯកសារ D98/1.2.21 ប្រតិចារឹករបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ម៉ោង 09.07.39-09.09.57 [កិច្ចប្រជុំពិភាក្សា ចូលរួមដោយ សុន សេន, លេខាកងពល ឈ្មោះ សុខ និង ឌុច៖ "ការប្រជុំហ្នឹង គេពិភាក្សាញូគ្នាអំពីមនុស្សណាខ្លះនៅក្នុងកងពល១៧០ ដែលជាខ្សែរបស់ ចាន់ ចក្រី [...] រៀបចំវិធានការដើម្បីយកមនុស្សពីកង១៧០"]។

1132 ឯកសារ D1.3.27.20 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ លេខ ERN EN 00940340, KH 00052404, FR 00334974 [ឌឹម ដំបូងបានរាយការណ៍អំពីព្រឹត្តិការណ៍សន្តិសុខពីរទាក់ទិននឹងយុទ្ធជនកងពល ១៦៤ និងការចាប់ខ្លួនមនុស្ស៤នាក់ផ្សេងទៀត], លេខ ERN EN 00940346, KH 00052408, FR 00334977 [តាមយោបល់របស់ សុន សេន គាត់បានសន្និដ្ឋានថា "សុំឯកភាពតាមឧទ្ទេសនាមរបស់អង្គការ ពីសភាពការណ៍ខ្មាំង ទាំងពីក្នុង ទាំងពីក្រៅ [...] ពិនិត្យកម្លាំងអាចធានាពី ៩០ ទៅ ៩៥ ភាគរយ ដែលស្មោះត្រង់ជាមួយនឹងបក្ស តែជំនឿជ្រះស្រឡះថា កងទ័ពនេះស្អាតហើយ ដូចនៅមិនទាន់ស្អាតទេ ត្រូវតែតាមដានសំរិតសំរាំងតទៅទៀត"]; លេខ ERN EN 00940350, KH 0005241l [នៅមុនពេល មាស មុត ឡើងនិយាយ ស៊ូ ម៉េត បានគូសបញ្ជាក់ថា "ត្រូវហ៊ានសំរិតសំរាំងដាច់ខាត"]។

ត្រូវរៀបចំវិធានការ *(មើលមិនច្បាស់)* សុំយល់ព្រមឯកភាពជាមួយបក្សទាំងស្រុង។ ធ្វើម៉េច កុំឱ្យស្ថានការណ៍ *(មើលមិនច្បាស់)* វាពង្រីងពង្រីកខ្លួន បានឱ្យសោះ[1133]។

330. ក្នុងពេលប្រជុំថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ ដដែលនេះ សុន សេន បានធ្វើការសង្កេតចុងក្រោយ និងសន្និដ្ឋានថា "សមាសភាពមិនល្អ" របស់កងពលមជ្ឈិមត្រូវ "សម្រិតសម្រាំងដាច់ខាត"។ កំណត់ហេតុប្រជុំក៏បានកត់ត្រាផងដែរថា សុន សេន បានណែនាំឱ្យមេបញ្ជាការបែងចែកសមាសភាពមិនល្អជាបីប្រភេទ ហើយប្រភេទនីមួយៗមានទម្រង់ទណ្ឌកម្មមួយ (សម្លាប់ អប់រំ និង កសាង)៖

[1133] ឯកសារ D1.3.27.20 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ លេខ ERN EN 00940350-51, KH 00052411, FR 00334980 ["សមមិត្ត មាស មុត៖ ខ្ញុំចាប់អារម្មណ៍ពីសកម្មភាពពួកក្បត់ក្នុងបក្ស ជាជ័យជំនះមួយសម្រាប់បក្សយើង។ មេរៀននេះបានពង្រឹងគោលជំហរប្រុងប្រយ័ត្នបានមួយកម្រិតថែមទៀត។ គោលជំហរវិភាគ កម្លាត់ខ្មាំងចក្រពត្តិអាមេរិក និងពួកសេរីនិយមរបស់បក្ស ដែលមានផែនការវាយបដិវត្តយើង នេះជាជំហរត្រឹមត្រូវ បានបំពាក់ឱ្យយើងខ្ញុំ។ បញ្ហាក្តាប់អង្គការ កម្មាភិបាល យុទ្ធជន នៅមិនទាន់រឹងទេ។ សមាសភាពមិនល្អ ឬខ្មាំង នៅតែពួនបន្លំ បង្កប់ក្នុងជួរបក្សទៀត។ បញ្ហាក្តាប់សតិអារម្មណ៍ ជាប្រចាំថ្ងៃ របស់អង្គការស្នូល ជាកត្តាសំខាន់បំផុត។ ត្រូវរៀបចំវិធានការ ម្ចាស់ការជាមុន សុំយល់ព្រមឯកភាពជាមួយបក្សទាំងស្រុង។ ធ្វើម៉េច កុំឱ្យស្ថានការណ៍ជ្រុលហួស កុំឱ្យវាពង្រឹងពង្រីកខ្លួនបានឱ្យសោះ"]។ សូមមើលផងដែរ ឯកសារ D1.3.27.26 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧ លេខ ERN EN 00933835, KH 00052305 ["សមមិត្ត មុត ៖ [...] កម្មាភិបាល និងយុទ្ធជនការពារឃ្លាំងមួយចំនួន ធ្លាប់នៅជាមួយពួកក្បត់យូរជាកងការពារវា។ អង្គភាពឃ្លាំង បានសំរិតសំរាំងមួយអនុសេនាតូច តែនៅពុំទាន់អស់ និងធានានៅឡើយ"]។ សុន សេន បានឆ្លើយតបទៅនឹង មាស មុត នៅត្រង់ លេខ ERN EN 00933844, KH 00052311 ["៤. បញ្ហាឃ្លាំង ត្រូវប្រុងប្រយ័ត្ន ពួកពាក់ព័ន្ធសមាសភាពក្បត់ ត្រូវដកចេញ។ សំរិតសំរាំងផ្ទៃក្នុងឱ្យស្អាត"]។ ទោះបីជា មាស មុត មិនបានចូលរួមមិទ្ទីញថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៧៦ ក្តី ក៏វាមានភាពពាក់ព័ន្ធត្រូវកត់សម្គាល់លើអ្វីដែល សុន សេន បានលើកឡើងអំពីគោលនយោបាយចំពោះខ្មាំង ព្រោះថា ទស្សនៈរបស់គាត់ ត្រូវបានផ្សព្វផ្សាយ និងឯកភាពពីសំណាក់មេបញ្ជាការកងពល និងមេបញ្ជាការវរៈសេនាធំ ហើយកំណត់ហេតុនៃអង្គប្រជុំនេះ គឺច្បាស់ណាស់ ត្រូវបានជូនដំណឹងទៅ មាស មុត៖ ឯកសារ D1.3.27.10 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៧៦ លេខ ERN EN 00656578, KH 00052360 ["១. ត្រូវក្តាប់ឱ្យជាប់នូវភារកិច្ចការពារប្រទេស ដែលជាភារកិច្ចស្នូលរបស់យើង [...] ២. ក្នុងការអនុវត្តភារកិច្ចការពារប្រទេស ត្រូវគិតគូរទប់ទល់ខ្មាំងទាំងខាងក្រៅ ទាំងខាងក្នុង។ តែពិសេស ត្រូវយកចិត្តទុកដាក់ ទប់ទល់ខ្មាំងស៊ីរូងផ្ទៃក្នុង ជាសំខាន់។ បានសេចក្តីថា ត្រូវយកចិត្តទុកដាក់សំរិតសំរាំងសមាសភាពមិនល្អ ចេញពីក្នុងបក្ស អង្គការស្នូល និងយុទ្ធជន-យុទ្ធនារី នៃកងទ័ពបដិវត្តយើង"]។

ត្រូវសម្រិតសម្រាំងសមាសភាពមិនល្អដាច់ខាត ក្នុងន័យតស៊ូវណ្ណៈដាច់ខាត។ សម្រិតសម្រាំងត្រូវឈរលើគោលការណ៍ ៣ យ៉ាង៖ - ប្រភេទទី ១៖ ប្រភេទអន្តរាយ ត្រូវសម្រិតសម្រាំងដាច់ខាត។ - ប្រភេទទី ២៖ ប្រភេទសេរីរើធម្មតា ត្រូវអប់រំជាបន្តបន្ទាប់ ក្នុងសាលាអប់រំរបស់យើង។ - ប្រភេទទី ៣៖ ប្រភេទពួកទើបតែខ្លាំងញុះញង់ ទើបតែជឿគេញុះញង់ជាជំហានដំបូង ត្រូវអប់រំកសាងគេកុំឱ្យជឿខ្លាំងទៀត[1134]។

331. នៅខែ មីនា ឆ្នាំ ១៩៧៧ ដោយសារតែការបោសសម្អាតមានល្បឿនលឿន សុន សេន បានបញ្ជាក់ពីការបែងចែកជាបីប្រភេទនេះ[1135] ប៉ុន្តែ បានសង្កត់ធ្ងន់ថា ការអប់រំនយោបាយ សតិអារម្មណ៍ "មិនគ្រប់គ្រាន់ទេ ត្រូវបន្តសម្រិតសម្រាំងដាច់ខាតតទៅទៀត" និងបានពន្យល់ថា "កម្លាំងក្បត់ក្នុងប្រទេសយើងសុទ្ធតែជាប់នឹងខ្មាំងខាងក្រៅទាំងអស់"[1136]។ ក្នុងចម្លើយទៅនឹងសំណួរវោហាររបស់គាត់ "តើមូលហេតុអីបានជាយើងកម្ចាត់ខ្មាំងបានជាបន្តបន្ទាប់?" សុន សេន បានអួតថា "មកពីយើងវាយសម្រុកខ្មាំងជាប់"[1137]។

---

[1134] ឯកសារ D1.3.27.20 កំណត់ហេតុកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ លេខ ERN EN 00940355, KH 00052414, FR 00334983។

[1135] ឯកសារ D1.3.27.26 កំណត់ហេតុកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧ លេខ ERN EN 00933844, KH 00052310, FR 00323929 ["III. បញ្ហាផ្សេងៗមួយចំនួន៖ 1. សំរិតសំរាំងកងទ័ព ចំពោះសមាសភាពខ្មាំង ត្រូវដកដាច់ខាត។ ពួកសេរីប្រមូលឱ្យបង្កើតផលមួយអង្គភាពទៅ។ ពួកជំពាក់ជំពិន ត្រូវអប់រំហើយប្រមូលមួយដុំ។" (បញ្ជាក់បន្ថែម)]

[1136] ឯកសារ D1.3.27.26 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧ លេខ ERN EN 00933841, KH 00052308-09, FR 00323927 [សុន សេន៖ "ព្រោះកម្លាំងក្បត់នៅក្នុងប្រទេសយើងសុទ្ធតែជាប់នឹងខ្មាំងខាងក្រៅទាំងអស់។ ប្រុងប្រយ័ត្នបដិវត្ត មានន័យថា វាយសម្រុកខ្មាំងស៊ីរូង ឱ្យជាប់ ឱ្យដាច់ខាត […] ព្រោះបើមានខ្មាំងស៊ីរូង វារាំងយើងជាប់ […] វិធានការរបស់យើង៖ ត្រូវបន្តអប់រំនយោបាយ សតិអារម្មណ៍ តទៅទៀត តែត្រឹមអប់រំ មិនគ្រប់គ្រាន់ទេ ត្រូវបន្តសំរិតសំរាំងដាច់ខាត តទៅទៀត។"] លេខ ERN EN 00933843, KH 00052310, FR 00323928 ["វិធានការចំពោះកងទ័ព ត្រូវសំរិតសំរាំងសមាសភាពមិនល្អដាច់ខាត […] កន្លងមក យើងកម្ចាត់បានខ្សែក្បត់សំខាន់ៗ ច្រើន តែត្រូវប្រុងប្រយ័ត្នបដិវត្ត តទៅទៀត ព្រោះពួកសេសសល់នៅមានហើយពួកក្បត់ថ្មីនឹងកើតមានបន្តទៀត"]។

[1137] ឯកសារ D1.3.27.26 កំណត់ហេតុកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧ លេខ ERN EN 00933844, KH 00052310, FR 00323928 ["តើមូលហេតុអី បានជាយើងកម្ចាត់ខ្មាំងបានជាបន្ត

332. កាំង ហ្គេកអ៊ាវ ហៅ ឌុច បានផ្ដល់សក្ខីកម្មថា ការបោសសម្អាតជាគោលនយោបាយសំខាន់មួយរបស់ ប.ក.ក ដែលឆ្លុះបញ្ចាំងពី "ភាពផ្ដាច់ការបដិវត្តន៍ កសាងប្រជាធិបតេយ្យសង្គមនិយម"[1138]។ ឥរិយាបថងប់ងល់របស់បក្សចំពោះការសម្លាប់ក្រៅផ្លូវតុលាការទៅលើទាហានរបស់ខ្លួន ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងសេចក្ដីសម្រេចរបស់គណៈមជ្ឈិម ប.ក.ក នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦។ នៅក្នុងសេចក្ដីសម្រេចដ៏អស្ចារ្យនេះ គណៈមជ្ឈិមបានប្រគល់អំណាចឲ្យសេនាធិការ "កម្ទេច" ខ្មាំងខាងក្នុង និងខាងក្រៅជួរយោធា[1139]។ **មាស មុត** និងមេបញ្ជាការកងពលមជ្ឈិមផ្សេងទៀត ព្រមទាំងសមាជិកគណៈសេនាធិការទាំងអស់[1140] ត្រូវបានជំរុញលើកទឹកចិត្តដោយ សុន សេន[1141]

---

បន្ទាប់? មកពីយើងវាយសម្រុកខ្លាំងជាប់។ ខ្មាំងបង្កប់ក្នុងជួរបដិវត្តតាំងពីមុនមហាសន្និបាតបក្ស លើកទីមួយ តែវាមិនហ៊ានដើបធ្វើសកម្មភាពខ្លាំង ខ្លាចបែកមុខ វាបង្ខំចិត្តត្រូវសម្រេចតាមយើង មកពីចលនាវាយសម្រុករបស់យើងខ្លាំង។ ពេលឈ្នះទូទាំងប្រទេសហើយ យើងវាយសម្រុកខ្លាំងជាប់ទៀត"]។

1138 ឯកសារ D114/159 កំណត់ហេតុស្ដាប់ចម្លើយរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ឆ.31 ["ការបោសសម្អាត វាជាចលនារួមរបស់មជ្ឈិមបក្សកុម្មុយនីស្ដកម្ពុជា។ ការបោសសម្អាតជាភារកិច្ចធំរបស់ ប៉ុល ពត ហៅថា ផ្ដាច់ការបដិវត្តន៍ កសាងប្រជាធិតេយ្យសង្គមនិយម។ គាត់សរសេរពាក្យនេះ នៅក្នុងកថាខណ្ឌទី១ នៃឯកសារសេចក្ដីសម្រេចចិត្តមួយចំនួនរបស់មជ្ឈិម ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ៧៦"]។

1139 ឯកសារ D1.3.19.1 សេចក្ដីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ លេខ ERN EN 00182809, KH 00003136, FR 00224363 ["១. សិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រៅជួរ។ សំណូមពរ៖ ១. ឲ្យមានក្របខណ្ឌក្នុងកិច្ចអនុវត្តផ្ដាច់ការបដិវត្ត របស់យើង។ ២. ពង្រឹងប្រជាធិបតេយ្យសង្គមនិយមរបស់យើង។ ទាំងនេះ ដើម្បីពង្រឹងរដ្ឋអំណាច របស់យើង។ បើនៅក្នុងក្របខណ្ឌមូលដ្ឋាន ត្រូវអចិន្ត្រៃយ៍ឯកភាពសម្រេច។ ជុំវិញមន្ទីរមជ្ឈិម ត្រូវគណៈមន្ទីរមជ្ឈិមសម្រេច។ តំបន់ឯករាជ ត្រូវអចិន្ត្រៃយ៍សម្រេច។ កងទ័ពមជ្ឈិម ត្រូវសេនាធិការសម្រេច"]។

1140 ឯកសារ D12 កំណត់ហេតុស្ដាប់ចម្លើយរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច លេខ ERN EN 00680797-98 ["ក្រោយ [សុន សេន ឬបង ៨៩ ម៉ែន សាន ហៅ យ៉ា និង សៀត ឆែ ហៅ ទុំ ឬបង ៨១] មនុស្សទាំងនេះ ក៏មានសមាជិកផ្សេងទៀតដែរ ដូចជា មាស មុត ទទួលបន្ទុកកងទ័ពជើងទឹក ស៊ូ ម៉េត ទទួលបន្ទុកទ័ពអាកាស [...] មាស មុត និង ស៊ូ ម៉េត ជាសមាជិករបស់សេនាធិការ ទទួលបន្ទុកផ្នែកទ័ពជើងទឹក និងទ័ពអាកាស [...] សមាជិកសេនាធិការមានរយៈពេលអស់មួយរបបហ្នឹង"]; ឯកសារ D32/10 កំណត់ហេតុស្ដាប់ចម្លើយរបស់ ខៀវ សំផន ឆ.15 ["ស៖ តើនរណាខ្លះជាសមាជិកសេនាធិការ? ឆ.15៖ មេបញ្ជាការកងពលទាំងអស់ រួមទាំងមេបញ្ជាការវរៈសេនាតូច និងវរៈសេនាធំស្ទើត្តិដូចជាម៉ៅ ជាដើម ជាសមាជិករបស់សេនាធិការ"]។ D54/110 កំណត់ហេតុស្ដាប់ចម្លើយរបស់ លុន សេង ឆ.8-10 ["ក្នុងនាមជាមេបញ្ជាការកងពល ជននោះគឺជាសនាជិកម្នាក់នៅក្នុងគណៈកម្មាធិការរបស់សេនាធិការនៃកងទ័ព។ នៅពេលដែលសេនាធិការកងទ័ពត្រូវការរៀបចំគម្រោងការងារអ្វីមួយ សេនាធិការតែងតែពិភាក្សាយោបល់ពីមេបញ្ជាការកងពល។ ស៖ អ្វីដែលលោកទើបតែនិយាយអម្បាញ់មិញនេះមានន័យថា មាស មុត គាត់មានតួនាទីនៅនឹងសេនាធិការ

ដែរមែនឬទេ? ឆ.9៖ បាទ ហើយវាមិនមែនមានតែសម្រាប់កងពល១៦៤មួយទេ កងពលណាក៏ដោយ ដែលជារបស់មជ្ឈិម មេបញ្ជាការកងពលទាំងនោះ គឺជាសមាជិកគណៈបញ្ជាការរបស់សេនាធិការ។ ពេលណាដែលកងពល ក្លាយទៅជាកងពលរបស់មជ្ឈិម មេបញ្ជាការរបស់កងពលនោះក្លាយជាសមាជិកគណៈកម្មាធិការសេនាធិការ។ ស៖ តើលោកដឹងថា ចាប់ពីពេលណាមកដល់ពេលណាដែរ មាស មុត ក្លាយជាសមាជិកគណៈកម្មាធិការសេនាធិការ? ឆ.10៖ តាមខ្ញុំដឹង បងមុត ក្លាយជាសមាជិកគណៈកម្មាធិការសេនាធិការចាប់តាំងពីរំដោះភ្នំពេញ ខែ មេសា ឆ្នាំ ១៩៧៥ ម្ល៉េះ ហើយគាត់បម្រើក្នុងកិច្ចការហ្នឹងរហូតដល់ខ្មែរក្រហមដួលរលំ។"]។

1141 ឯកសារ D1.3.27.20 កំណត់ហេតុកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០៩ ខែ តុលា ឆ្នាំ ១៩៧៦ លេខ ERN EN 00940354-55, KH 00052414, FR 00334983 ["ត្រូវសំរិតសំរាំងសមាសភាពមិនល្អ ដាច់ខាតក្នុងន័យតស៊ូវណ្ណៈ ដាច់ខាត។ សំរិតសំរាំងត្រូវឈរលើគោលការណ៍បីយ៉ាង៖ ប្រភេទី១៖ ប្រភេទអន្តរាយ៖ ត្រូវសំរិតសំរាំងដាច់ខាត"], លេខ ERN EN 00940338-40, 46-52, KH 00052403-05, 08-12, FR 00334973-74, 77-81 [ក្នុងរបាយការណ៍របស់ លេខាកងពល និងអនុលេខាកងពល មានការរៀបរាប់ជាទូទៅអំពីការបោសសម្អាតខ្មាំង។ លេខា និងអនុលេខា រៀបរាប់អំពីជោគជ័យក្នុងការបោសសម្អាតខ្មាំងកន្លងមក ហើយក៏រៀបរាប់អំពីតម្រូវការបោសសម្អាតតាមកងពលនីមួយៗ និងកងពលទាំងមូលនៅក្នុងកងទ័ពបដិវត្តកម្ពុជា។ ឧទាហរណ៍ ស៊ូ ម៉េត បាននិយាយថា "ដាច់ខាត ត្រូវប៊ោនបោសសម្អាត"]។ ឯកសារ D1.3.27.26 កំណត់ហេតុកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧ លេខ ERN EN 00933839, KH 00052306, FR 00323925 [ក្រោយពីបានស្តាប់របាយការណ៍អំពីខ្មាំងផ្ទៃក្នុងរួចមក សុន សេន បានអំពាវនាវឲ្យមេបញ្ជាការកងពល បន្តបោសសម្អាតតាមកងទ័ពបដិវត្តកម្ពុជា៖ "ព្រឹត្តិការណ៍បញ្ជាក់ថា ខ្មាំងជា សេ.អ៊ី.អា ជាយួន ជាសេរីរ វាបន្តធ្វើសកម្មភាពដើម្បីបំផ្លាញបដិវត្តយើង ខ្លាំងក្លាណាស់ ក្នុងគោលបំណងវាយរំលំបដិវត្តយើង បក្សយើង វាយរំលំកងទ័ត [...] សេ.អ៊ី.អា [...] វាស៊ីរូងផ្ទៃក្នុងយើង បក្ស និងកងទ័ត។ តែបច្ចុប្បន្ននេះ យើងបានវាយកម្ទាត់ពួកក្បត់បានជាមូលដ្ឋាន [...] ក្រោយយើងកម្ទាត់ពួកក្បត់ ខ្សែឈូក និងអាយ៉ាមក យើងរកឃើញខ្សែក្បត់មួយទៀត ត្រូវយើងកម្ទេចជាមូលដ្ឋាន"], លេខ ERN EN 00933841-44, KH 00052306, 08-11, FR 00323927-29 ["ប្រុងប្រយ័ត្នបដិវត្ត មានន័យថា វាយសម្រុកខ្មាំងស៊ីរូង ឲ្យជាប់ ឲ្យដាច់ខាត បើមិនវាយសម្រុកខ្មាំងជាប់ទេ កុំនិយាយពីការកសាងប្រទេស ព្រោះបើមានខ្មាំងស៊ីរូង វារាំងយើងជាប់។ [...] ត្រូវបន្តសំរិតសំរាំងដាច់ខាត តទៅទៀត [...] កន្លងមក យើងកម្ទាត់បានខ្សែក្បត់សំខាន់ៗច្រើន តែត្រូវប្រុងប្រយ័ត្នបដិវត្ត តទៅទៀត ព្រោះពួកសេសសល់នៅមាន ហើយពួកក្បត់ថ្មីនឹងកើតមានបន្តទៀត [...] តើមូលហេតុអី បានជាយើងកម្ទាត់ខ្មាំងបានជាបន្តបន្ទាប់? [...] សំរិតសំរាំងកងទ័ត ចំពោះសមាសភាពខ្មាំង ត្រូវដកដាច់ខាត [...] បញ្ហាឃ្លាំង ត្រូវប្រុងប្រយ័ត្ន ពួកពាក់ព័ន្ធសមាសភាពក្បត់ ត្រូវដកចេញ។ សំរិតសំរាំងផ្ទៃក្នុងឲ្យស្អាត"] ជាធម្មតា មេបញ្ជាការកងពល រាយការណ៍ផ្ទាល់មាត់ ក្នុងអំឡុងពេលនៃកិច្ចប្រជុំ អំពីសកម្មភាព និងវិធានការ អនុវត្តចំពោះខ្មាំងដែលរកឃើញ,លេខ ERN EN 00933834-36, KH 00052304-06, FR 00323922-24 [ស៊ូ ម៉េត ពន្យល់ថា៖ "សមាសភាពមួយចំនួន ដែលយើងចាប់កន្លងមក ច្បាស់ជាសមាសភាពខ្មាំងមែន។ ពួកមិនល្អ បានបញ្ជូនទៅ ស-២១ ជាង ៥០ នាក់។ លេខាអនុសេនាធំ ត្រូវដក ៥ នាក់ចេញទៀត ទើបបានធានា"។ មាស មុត បានរាយការណ៍អំពីការខិតខំប្រឹងប្រែងរបស់កងពលខ្លួន ក្នុងការបោសសម្អាតសមាសភាពមិនល្អ ដោយនិយាយថា៖ "កម្មាភិបាល និងយុទ្ធជនការពារឃ្លាំងមួយចំនួន ធ្លាប់នៅជាមួយពួកក្បត់យូរ ជាកងការពារ។ អង្គភាពឃ្លាំង បានសំរិតសំរាំង

និងតាមរយៈការបោះពុម្ពផ្សាយរបស់មជ្ឈិមបក្ស *(ទង់បដិវត្តន៍)*[1142] ឲ្យកំណត់អត្តសញ្ញាណ បោសសម្អាត និងកម្ទេច "ខ្មាំងផ្ទៃក្នុង"។ ក៏ប៉ុន្តែ ក្នុងកងពល ១៦៤ មានតែ **មាស មុត** ម្នាក់

មួយអនុសេនាតូច តែនៅពុំទាន់អស់ និងធានានៅឡើយ។ សមមិត្ត យ៉ាន់ បាននិយាយថា៖ "ប្រហែលមានមនុស្សចំនួន ៦០០ នាក់ ជាសមាសភាពមិនល្អ ត្រូវដកចេញ"], លេខ ERN EN 00933837-38, KH 00052307, FR 00323924 [សមមិត្តតាល់ បានពន្យល់ថា៖ "ត្រូវបានដកសមាសភាពមិនល្អមួយចំនួនចេញ ឲ្យប្រមូលផ្តុំតាមវរៈសេនាធំសិន"]។ ឯកសារ D1.3.27.13 កំណត់ហេតុកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៧៦ លេខ ERN EN 00183968, KH 00052382, FR 00386199 [សុន សេន លើកឡើងថា៖ "ត្រូវសំរិតសំរាំងសមាសភាពមិនល្អ" ហើយបានអំពាវនាវឲ្យមេបញ្ជាការកងពលមានចិត្តដាច់ខាត]។ ឯកសារ D1.3.27.23 កំណត់ហេតុកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៧៦ លេខ ERN EN 00233718, KH 00095514, FR 00386208 [សុន សេន បាននិយាយថា មេបញ្ជាការកងពលត្រូវតែ "ក្តាប់ឲ្យជាប់ពីបញ្ហាសំរិតសំរាំងកងទ័ពយើងឲ្យស្អាត។ មានបាតុភូតបន្តិចបន្តួច ត្រូវចាប់អារម្មណ៍ តាមដាន។ [...] កុំឲ្យមានទស្សនៈថា វាធម្មតាឲ្យសោះ។ ត្រូវតាមដាន និងពិនិត្យគ្រប់បាតុភូត [...] តែត្រូវចាប់អារម្មណ៍ខ្មាំងក្នុងដែលសេសសល់"]។ សូមមើលផងដែរ D1.3.27.10 កំណត់ហេតុកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ១៩៧៦ លេខ ERN EN 00656578, KH 00052360 ["២. ក្នុងការអនុវត្តភារកិច្ចការពារប្រទេស ត្រូវគិតគូរទប់ទល់ខ្មាំង ទាំងខាងក្រៅ ទាំងខាងក្នុង។ តែពិសេស ត្រូវយកចិត្តទុកដាក់ទប់ទល់ខ្មាំងស៊ីរូងផ្ទៃក្នុង ជាសំខាន់។ បានសេចក្តីថា ត្រូវយកចិត្តទុកដាក់ សំរិតសំរាំងសមាសភាពមិនល្អ ឲ្យអស់ពីក្នុងបក្ស អង្គការស្នូល និងយុទ្ធជន-យុទ្ធនារី នៃកងទ័ពបដិវត្តយើង"]។ ឯកសារ D1.3.27.12 កំណត់ហេតុកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៦ លេខ ERN EN 00234458-59, KH 00052378-79, FR 00386194-95 [សុន សេន៖: "នៅក្នុងជួរ មានកម្មាភិបាល និងយុទ្ធជនខ្លះមិនសប្បាយចិត្ត ឆ្អិះឆ្អៀលទំនាស់ បំផុសរត់ចោលជួរ បង្វែរមាគ៌ាខ្លះ ប្រឆាំងមាគ៌ាជាពាក្យសំដីខ្លះ។ បញ្ហានេះមានដោយសារ បដិវត្តកាន់តែជ្រៅម្យ៉ាង ហើយម្យ៉ាងទៀត តាមរយៈខ្សែចាត់តាំងរបស់ខ្មាំង ក៏មាន។ វិធានការ៖ [...] ៣. [...] សមាសភាពមិនល្អ ត្រូវសំរិតសំរាំងទៅទៀតដាច់ខាត"]; ឯកសារ D1.3.27.18 កំណត់ហេតុកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ លេខ ERN EN 00183979 KH 00052398 [សុន សេន៖ " ១. ទស្សនៈ [...] គ) ខ្សែសំខាន់ៗរបស់វា ត្រូវយើងវាយខ្ទេច តែត្រូវមានទស្សនៈថា ខ្មាំងមិនអស់ទេ វាបង្កសកម្មភាពវាយយើងទៀត។ ដូច្នេះ ត្រូវកុំសុទិដ្ឋិនិយមមិនបដិវត្តឲ្យសោះ(ទស្សនៈ) [...] ២. វិធានការខាងចាត់តាំង [...] គ) ត្រូវមានជំហរដាច់ខាត សំរិតសំរាំងសមាសភាពប្រឆាំងបដិវត្ត កុំស្ទាក់ស្ទើរ"]។

1142 តាមរយៈការចេញផ្សាយ ទស្សនាវដ្តីទង់បដិវត្ត ស្រដៀងគ្នានេះដែរ បក្សកុម្មុយនីស្តកម្ពុជា បានជំរុញឲ្យមានការបោសសម្អាតខ្មាំងផ្ទៃក្នុងពីកងទ័ពបដិវត្តកម្ពុជា។ សូមមើលផងដែរ ឯកសារ D1.3.24.2 ទស្សនាវដ្តីទង់បដិវត្ត ចេញផ្សាយនៅខែ កក្កដា ឆ្នាំ ១៩៧៦ លេខ ERN EN 00268923 KH 00062917, FR 00349977 ["ត្រូវពង្រឹង និងសំរិតសំរាំងកម្មាភិបាល និងបក្ខជន ក្នុងមហាចលនាមហាជនកម្មករ-កសិករ និងកងទ័ពបដិវត្តនេះ ដើម្បីឲ្យបក្សកាន់តែខ្លាំង"]។ ឯកសារ D4.1.888 ទស្សនាវដ្តីទង់បដិវត្ត ចេញផ្សាយ ខែ ធ្នូ ឆ្នាំ ១៩៧៦ -ខែ មករា ឆ្នាំ ១៩៧៧ លេខ ERN EN 00491435 KH 00063055, FR 00504064 ["ត្រូវយកចិត្តទុកដាក់ ពង្រឹង និងពង្រីក ហើយសំរិតសំរាំង ឲ្យកងទ័ព

ប៉ុណ្ណោះដែលមានអំណាចសម្រេចកម្មេចខ្មាំង។ គាត់មិនបានប្រគល់អំណាចនេះឱ្យទៅថ្នាក់ក្រោមណាម្នាក់ឡើយ ប៉ុន្តែ បានស្តីបន្ទោស (ដោយគ្មានការដាក់ទណ្ឌកម្ម) ញ៉ាន ដែលបានសម្លាប់ប្រជា

---

យើងស្អាត បរិសុទ្ធ តាមមាគ៌ារបស់បក្ស។ កងទ័ពខ្លាំង គឺកងទ័ពស្អាត។ ឱ្យតែស្អាតចំនួនតិចក៏ខ្លាំងដែរ"]។ ឯកសារ D4.1.862 ទស្សនាវដ្តីទង់បដិវត្ត ចេញផ្សាយ ខែ មេសា ឆ្នាំ ១៩៧៧ លេខ ERN EN 00478501, KH 00062992, FR 00499759 ["កម្លាំងទាំងនេះគឺ ក. កម្លាំងដែលមានបច្ចុប្បន្ន បក្ស អង្គការស្នូល កងទ័ព សហជីព សហករណ៍... ។ល។ ត្រូវសំរិតសំរាំង ជម្រុះ និងបោសសម្អាតសមាសភាពមិនល្អ និងសមាសភាពខ្មាំង"]។ ឯកសារ D4.1.653 ទស្សនាវដ្តីទង់បដិវត្ត ចេញផ្សាយ ខែ មិថុនា ឆ្នាំ ១៩៧៧ លេខ ERN EN 00445857-58, KH 00062803 ["ការប្រយុទ្ធជាមួយខ្មាំងបង្កប់ខាងក្នុងមិនទាន់អស់ទេ។ សំណល់ចាស់របស់ខ្មាំងបង្កប់វានៅសល់ ហើយវាពង្រឹង ពង្រីកទៅទៀត [...] បំផុសអប់រំមហាជន [...] ក្នុងកងទ័ពបដិវត្ត និងប្រជាជនឱ្យឃើញច្បាស់ថា ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងធ្វើសកម្មភាពយ៉ាងម៉េចឱ្យគេជ្រួតជ្រាប ដើម្បីជាកម្លាំងរកខ្មាំង និងវាយខ្មាំងតទៅទៀត"]។ ឯកសារ D4.1.865 ទស្សនាវដ្តីទង់បដិវត្ត ចេញផ្សាយ ខែតុលា -ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ លេខ ERN EN 00182549, KH 00064758, FR 00665400 ["មានខ្មាំងបង្កប់នៅគ្រប់ទីកន្លែង ក្នុងជួរបក្សយើង មជ្ឈិម សេនាធិការ ភូមិភាគ និងតាមមូលដ្ឋាន។ បើមិនចាត់វិធានការឱ្យទាន់ពេលវេលាទេ វានឹងគ្រោះថ្នាក់"]។ ឯកសារ D1.3.24.4 ទស្សនាវដ្តីទង់បដិវត្ត ចេញផ្សាយ ខែ ធ្នូ ឆ្នាំ ១៩៧៧ -ខែមករា ឆ្នាំ ១៩៧៨ លេខ ERN EN 00184301, KH 00064516-17, FR 00809241-42 ["ខ្មាំងវាមករកកម្មេចកម្មករ-កសិករ របស់យើង ប៉ុន្តែ វាត្រូវយើងវាយឱ្យរលំរលាយ ជាបន្តបន្ទាប់ ហើយវាយវាឱ្យរលំរលាយជាមូលដ្ឋាន។ នេះទាំងខ្មាំងខាងក្នុង និងខ្មាំងខាងក្រៅ ជាពិសេស ខ្មាំងខាងក្នុង [...] កងទ័ពក៏ការពារបាន។ កងទ័ពរបស់បក្សអត់ខូចខាតទេ មានតែពង្រឹង មានតែសម្អាតថែមទៀត។ យើងកំចាត់ខ្មាំងដែលស៊ីរូងកងទ័ព កំចាត់សមាសភាពអន្តរាយនៅក្នុងកងទ័ព លើកគុណភាពកងទ័ព កាន់តែបានល្អជាងមុនទៅទៀត [...] យើងដណ្តើមបានជ័យជំនះធំ ហើយជាខ្សែសង្វាក់នៅឆ្នាំ ១៩៧៧ ដោយសារយើងបានសំរិតសំរាំង និងបោសសម្អាតខ្មាំង ជាខ្សែសង្វាក់ ដឹកឫសគល់របស់វាធំៗ បានជាមូលដ្ឋាន។ នៅចុង ៧៦ ដែលយើងលើកផែនការនេះ ហើយនៅដើមឆ្នាំ ៧៧ ដែលយើងកម្ចាត់ក្បាលម៉ាស៊ីនដឹកនាំខ្មាំងបានមួយចំនួន"]។ ឯកសារ D4.1.867 ទស្សនាវដ្តីទង់បដិវត្ត ចេញផ្សាយ ខែ មីនា ឆ្នាំ ១៩៧៨ លេខ ERN EN 00504091, KH 00064482, FR 00491866 ["យើងត្រូវបន្តបោសសម្អាតសមាសភាពខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង"]។ ឯកសារ D4.1.868 ទស្សនាវដ្តីទង់បដិវត្ត ចេញផ្សាយ ខែ មេសា ឆ្នាំ ១៩៧៨ លេខ ERN EN 00519842, KH 00064724-25, FR 00520355-56 [ប៉ុល ពត៖ "ខ្ញុំសូមជម្រាបថា ឆ្នាំ ៧៥ កងទ័ពយើងមិនស្អាតស្អំទេ វាយឈ្នះអាមេរិកមែន ប៉ុន្តែ ស្រកេកស្រកាកច្រើនណាស់។ ដូច្នេះ សំរិតសំរាំងអស់មួយចំនួន ហាក់ដូចជាអស់កងទ័ព។ ឆ្នាំ ៧៦ យើងបានបោសសម្អាតមួយកម្រិត ក៏នៅតែស្រកេកស្រកាកទៀត។ ៧៧ សំរិតសំរាំងបានមួយចំនួនទៀត ក៏ស្រកេកស្រកាកខ្លះទៀត [...] ខ្មាំងសត្រូវជិតឆ្ងាយ មកឃោសនាបន្លំ បោកបញ្ឆោតយើង បំភ័យយើងឱ្យខ្លាចខ្មាំង។ ត្រូវកម្ចាត់វា កុំឱ្យវាស៊ីរូងផ្ទៃក្នុង នៅក្នុងប្រជាជន នៅក្នុងបក្ស នៅក្នុងកងទ័ពរបស់យើង។ យើងធ្វើឱ្យកងទ័ពយើងស្អាត បក្សស្អាត ប្រជាជនស្អាត ទើបអាចវាយខ្មាំង និងការពារទឹកដីកម្ពុជា"]។

ជនដោយគ្មានការអនុញ្ញាតពីគាត់[1143]។ ប៉ាង រ៉េត បានលើកឡើងថា ការសម្លាប់ទាហានធម្មតាជាការសម្រេចដែលត្រូវធ្វើឡើយដោយ **មាស មុត** ហើយថា គណៈកងពលរបស់គាត់តម្រូវឱ្យមានការឯកភាពពីសេនាធិការ ដើម្បីសម្លាប់មេបញ្ជាការកងវរសេនាតូចណាម្នាក់[1144]។

333. កំណត់ហេតុប្រជុំសេនាធិការលើកឡើងពីប្រភេទសមាសភាពមិនល្អជាច្រើន ដែលត្រូវតែបោសសម្អាតពីកងពលមជ្ឈិមនៃកងទ័ពបដិវត្តន៍កម្ពុជា រួមទាំង កងពល ១៦៤ ដែរ៖ ទាហានរត់ចោល

---

1143 ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយរបស់ ជេត ប៊ុណ្ណា ឆ.9 ["គាត់មានអំណាចចាប់ចង និងសម្លាប់ទាំងយោធា និងទាំងប្រជាជនស៊ីវិលដែលនៅក្នុងតំបន់របស់គាត់ ឧទាហរណ៍ បើគាត់សង្កេតឃើញថា គោ ឬសត្វពាហនៈស្គម ហើយមិនត្រូវបានថែទាំងជិតដល់ល្អ គាត់នឹងចេញបញ្ជាឱ្យចាប់អ្នកថែទាំគោទាំងនោះ"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយរបស់ រ៉េត ប៉ាង ឆ.121-122, 124-125 ["ស៖ នៅពេល មាស មុត និងតា ញ៉ាន់ ថា 'មុននឹងឯងសម្លាប់មនុស្ស ឯងត្រូវមានការអនុញ្ញាតពីមេរបស់ឯងជាមុនសិន' តើមេដែលគាត់និយាយនោះ គឺសំដៅលើអ្នកណា? ឆ.12៖ តាញ៉ាន់ គឺជាមេបញ្ជាការវរៈសេណាធំ៦៣ ដែលស្ថិតនៅក្រោមការគ្រប់គ្រងកងពល១៦៤ ដែលមាន មាស មុត ជាមេបញ្ជាការ។ ដូច្នេះ ក្នុងន័យនេះ មានន័យថា គាត់ត្រូវមានការអនុញ្ញាតពីមាស មុត ជាមុនសិន [...] ឆ. 122៖ ខ្ញុំចាំបានថា នៅក្នុងអង្គប្រជុំនោះ តាញ៉ាន់បានរាយការណ៍ប្រាប់ មាស មុត ថាគាត់បានសម្លាប់មនុស្ស [...]ឆ. 124៖ តាមការចងចាំរបស់ខ្ញុំ កិច្ចប្រជុំនោះ កើតឡើងនៅក្នុងខែកក្កដា ឆ្នាំ ១៩៧៥ [...] ឆ.125៖ កិច្ចប្រជុំនោះធ្វើឡើងនៅក្នុងរោងកុននៅកំពង់សោម"]។ ឯកសារ D59/1/1.11a ចម្លើយរបស់ ហៀង រ៉េត ផ្តល់ជូនមជ្ឈមណ្ឌលឯកសារកម្ពុជា លេខ ERN EN 00974135 ["ក្រោយស្តាប់របាយការណ៍រួចហើយ បង មាស មុត សួរតា ញ៉ាន់ អំពីការសម្លាប់មនុស្ស។ គាត់សួរថា 'អ្នកណាប្រាប់ឯងឱ្យសម្លាប់គេ? អ្នកណាប្រាប់ឱ្យឯងទៅស៊ើបគេដល់ផ្ទះ? ឯងសមនឹងទទួលដូចដែលឯងធ្វើដាក់គេ។ ថាទៅ គេគួរយកទឹកក្តៅចាក់លើក្បាលឯងទើបសម។ ឯងគ្មានសិទ្ធិអីទៅតាមដានគេទេ។ មុនពេលឯងសម្លាប់គេ តើឯងមានសុំមេសិនទេ?'"]។ សូមមើលផងដែរ ឯកសារ D54/46 កំណត់ហេតុស្តាប់ចម្លើយរបស់ សុន អែម ឆ.43 ["តែមើលពីខាងក្រៅ តា ម៉ុក មានតួនាទីធំជាង មាស មុត។ ក៏ប៉ុន្តែ មាស មុត មើលទៅមានអំណាចជាង។ ឧទាហរណ៍ ប្រសិនបើ តា ម៉ុក ចាប់នរណាម្នាក់ដាក់គុក មាស មុត អាចទៅដោះលែងគេបាន ក៏ប៉ុន្តែប្រសិនបើ មាស មុត ចាប់នរណាម្នាក់ដាក់គុកហើយ គឺ តាម៉ុក មិនហ៊ានទៅដោះលែងទេ"]។ ឯកសារ D54/47 សុន អែម ឆ.2 ["អ្វីដែលខ្ញុំនិយាយអំពីអំណាច មាស មុត ក្នុងការចាប់ និងដោះលែងមនុស្ស គឺជារឿងទូទៅដែលមនុស្សគ្រប់គ្នាដឹងនាពេលនោះ"]។

1144 ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយរបស់ ប៉ាង រ៉េត ឆ.130 ["នៅថ្នាក់នីមួយៗ សេចក្តីសម្រេចត្រូវធ្វើឡើងដោយគណៈកម្មាធិការនៅថ្នាក់នោះ។ មាស មុត ជាមេបញ្ជាការកងពលដែលជាថ្នាក់ចុងក្រោយក្នុងការសម្រេច ហើយសេចក្តីសម្រេចនេះ ត្រូវធ្វើឡើងដោយ មាស មុត អនុប្រធានរបស់គាត់ និងសមាជិកនៅក្នុងគណៈកងនេះ។ ខ្ញុំចង់បញ្ជាក់បន្ថែមថា សេចក្តីសម្រេចបែបនេះអាចធ្វើបានសម្រាប់តែយុទ្ធជនធម្មតាប៉ុណ្ណោះ។ ក្នុងករណីដែលមានសំណើឱ្យសម្លាប់មេបញ្ជាការវរសេនាតូចណាម្នាក់ គឺគណៈកងពលត្រូវស្នើទៅគណៈសេនាធិការដែលជាអ្នកមានសិទ្ធិសម្រេចចុងក្រោយ"]។

ជួរ[1145] អ្នកមកពីវៀតណាម[1146] កូនរបស់ទាហាន មេឃុំ ឬនគរបាលដែលត្រូវបានសម្លាប់កាលពីលើកមុន[1147] អ្នកដែលជាប់ពាក់ព័ន្ធជាមួយនឹងខ្មាំងខាងក្រៅ ក្នុងនោះមានវៀតណាម[1148] អ្នកមាន

---

1145 ឯកសារ D1.3.27.13 កំណត់ហេតុនៃកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៧៦ លេខ ERN EN 00183967, KH 00052381, FR 00386197-98 [កម្មាភិបាលកងពលមជ្ឈិម មាន រឿង, ម៉េត, ពីន និង រឿន បានពិភាក្សាគ្នាអំពីរឿងរត់ចោលជួរ]។ ឯកសារ D1.3.27.20 កំណត់ហេតុកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ លេខ ERN EN 00940338-39, KH 00052403-04 [ករណីរត់ចោលជួរ ពិភាក្សាដោយ សួង និង សាន]។ ឯកសារ D1.3.27.22 កំណត់ហេតុកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ លេខ ERN EN 00656381, KH 00088926, FR 00322986 ["កងពល ១៧០--សមមិត្ត សុខ [...] ង. សភាពការណ៍ខ្មាំង៖ [...] នៅក្នុងអង្គភាព មានរត់ដែរ រត់ជាច្រើនសារហើយ"]។ ឯកសារ D1.3.27.12 កំណត់ហេតុកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៦ លេខ ERN EN 00234458-59, KH 00052378-79, FR 00386194-95 [ស្វ សែន៖ "នៅជួរផ្ទៃក្នុងកងទ័ព មានកម្មាភិបាល និងយុទ្ធជនមួយចំនួន [...] ត្រូវបាន [...] ជំរុញរត់ចោលជួរ"]។

1146 ឯកសារ D1.3.27.20 កំណត់ហេតុកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦លេខ ERN EN 00940349, KH 00052410 ["សមមិត្ត អឿន [...] បាតុភាព មានពួកលាក់ប្រវត្តិរូប រហូតកម្មាភិបាលអនុសេនាធំ ពីដើមជាខ្មែរស ធ្លាប់នៅជាមួយវៀតណាម"]។

1147 ឯកសារ D1.3.27.20 កំណត់ហេតុកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ លេខ ERN EN 00940338, KH 00052403 [សមមិត្តសួង៖ "កម្មាភិបាល ដែលម៉ែឪ ត្រូវយើងបានបោសសម្អាតចេញ អាកប្បកិរិយា អាជ្ញាដាក់មហាជន"]។ ឯកសារ D1.3.27.26 កំណត់ហេតុនៃកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧ លេខ ERN EN 00933834, KH 00052305 ["សមមិត្ត ឈិន៖ [...] ខ្មាំងក្នុងអង្គភាព នៅមាន ត្រូវយើងតាមដាន និងក្ដាប់បានមួយចំនួន --- ក្រោយរៀនសូត្រ បានសំរិតសំរាំងពួកចេញពីវៀតណាម កូនរបស់ទាហាន មេឃុំ ឬប៉ូលិស ឲ្យបង្កើតផលមួយជុំ"]។ ឯកសារ D1.3.27.13 កំណត់ហេតុនៃកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៧៦ លេខ ERN EN 00183968, KH 00052382 [សុន សេន៖ "ខ្មាំងវាចង់ឆ្លៀតប្រមូលសមាសភាពមិនល្អ [...]ត្រូវគ្រួសារយើងបោសសម្អាត"]។ ឯកសារ D1.3.27.23 កំណត់ហេតុនៃកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៧៦លេខ ERN EN 00233712-18, KH 00095509-14, FR 00386203, 08 [សមមិត្ត សុខ រៀបរាប់អំពីបញ្ហាដែលកើតមានឡើងដោយសារអ្នកដែលមានបងប្អូនបង្កើត "ត្រូវអង្គការយកមិនដឹងរឿងហេតុអី " ហើយ សុន សេន ផ្ដល់មតិណែនាំអ្នកមានវត្តមាននៅក្នុងអង្គប្រជុំថា "ប្រយ័ត្នបំផុត អ្នកដែលឪពុកម្ដាយ ត្រូវបោសសម្អាត ឬបងប្អូនត្រូវបោសសម្អាត"]។

1148 ឯកសារ D1.3.27.20 កំណត់ហេតុនៃកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ លេខ ERN EN 00940342-43, KH 00052405-06 [សុន សេន ពន្យល់អំពីរបៀបដែល ចាន់ ចក្រី ជា "ខ្សែខ្មែរសេរី" និងមេឈ្មោះ ឈូក លេខាតំបន់ ២៤ ត្រូវបានចាប់ខ្លួនដោយសារទាក់ទងជាមួយននឹងពួកវៀតណាម "រៀបចំវាយក្បាលម៉ាស៊ីនដឹកនាំបក្សយើង។ វាវាយពីក្នុង វៀតណាមវាយពីក្រៅ [...] ឈូក ឆ្លើយមកដល់ឈ្មោះ យ៉ា។ យើង

"មុខមាត់ បុណ្យសក្តិ"[1149] អ្នកដែលប្រឆាំងនឹងបក្ស ដោយប្រព្រឹត្តកំហុស ដូចជា លួច ធ្វើវិទ្ធេទកម្ម បំពុល ញុះញង់ឱ្យយុទ្ធជនហូបគ្រឿងស្រវឹង ឬបេះផ្លែឈើហូបដោយសេរី[1150] អ្នកដែល "ខ្ជិលធ្វើការ" "ពុតត្បុត" ឬទោមនស្សនឹងរបប[1151] អ្នកដែលត្រូវបានដកតំណែងកាលពីលើក

---

ចាប់យ៉ា [...] ខ្មាំងខាងកើត៖ វៀតណាម និងសូវៀតនៅពីក្រោយ ផែនការសំខាន់វាយពីក្នុង តាមរយៈកម្លាំងក្បត់របស់យ៉ា កែវ មាស ឈូក ចក្រី"], លេខ ERN EN 00940353, KH 00052413 ["ខ្មាំងវានឹងធ្វើសកម្មភាពតាមសមុទ្រ និងព្រំដែនតិចតួច តទៅទៀត។ ឯខ្មាំងកំប៉ិកកំប៉ុកខាងក្នុង ក៏ត្រូវយកចិត្តទុកដាក់ កុំឱ្យវាធ្វើសកម្មភាពបាន ដើម្បីការពារបក្ស ការពារផលបដិវត្ត"], លេខ ERN EN 00940354, KH 00052413 ["ក្នុងឋានៈជាកងទ័ព ត្រូវស្គាល់កម្មវត្ថុ ដែលត្រូវវាយ គឺចក្រពត្តិអាមេរិក ពួកសើរើ វៀតណាម និងដៃជើងក្បត់របស់វា"]។

[1149] ឯកសារ D1.3.27.13 កំណត់ហេតុនៃកិច្ចប្រជុំឃោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៧៦ លេខ ERN EN 00183968, KH 00052382 [សុន សេន៖ "ខ្មាំងវាចង់ឆ្លៀតប្រមូលសមាសភាពមិនល្អ [...] មុខមាត់ បុណ្យសក្តិ"]។ ឯកសារ D1.3.27.20 កំណត់ហេតុនៃកិច្ចប្រជុំឃោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ លេខ ERN EN 00940352, KH 00052412, [សុន សេន៖ "ពិសោធនេះ នាំឱ្យចាប់អារម្មណ៍កាន់តែខ្ពស់ទៀត ចំពោះសមាសភាពមានប្រវត្តិមិនល្អ មានសតិអារម្មណ៍ មុខមាត់ បុណ្យសក្តិខ្ពស់ និងចូលបក្សតាមសមាសភាពមិនត្រឹមត្រូវ"], លេខ ERN EN 00940347-48, KH 00052409 ["សមមិត្ត ពីន [...] មូលហេតុមកពីពួកទំនាស់មុខមាត់ បុណ្យសក្តិ [...មាននៅសេសសល់ខ្លះ ពួកចចេសចចូច ពួកលួចឆក់ ពួកទំនាស់មុខមាត់បុណ្យសក្តិបានប្រមូលផ្តុំ ៨០ នាក់"]។

[1150] ឯកសារ D1.3.27.26 កំណត់ហេតុនៃកិច្ចប្រជុំឃោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧ លេខ ERN EN 00933835, KH 00052305 ["សមមិត្ត ភាព [និយាយអំពីខ្មាំង]៖ [...] ផ្ទៃក្នុងអង្គភាព មានកម្មាភិបាលអនុសេនាតូចម្នាក់ ឈ្មោះ ហេង នាំយុទ្ធជនផឹកស្រា។ កម្មាភិបាលអនុសេនាធំម្នាក់ ឈ្មោះ ចំរើន ទំនាស់នឹងការហាមឃាត់ មិនឱ្យបេះផ្លែឈើស៊ីសេរី"]។ ឯកសារ D1.3.27.13 កំណត់ហេតុនៃកិច្ចប្រជុំឃោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៧៦ លេខ ERN EN 00183969, KH 00052382 [សុន សេន៖ បញ្ហាលួច ត្រូវចាប់អារម្មណ៍ ជាសកម្មភាពប្រឆាំងយើង ខ្លះជុះអាចម៍ដាក់កន្លែង ដើរគោះទ្វារយប់ ឃោសនាទង់ស ទង់ក្រហម ឆ្កិះទំនាស់ និងបង្វែងមាគ៌ា"]។ ឯកសារ D1.3.27.20 កំណត់ហេតុនៃកិច្ចប្រជុំឃោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ លេខ ERN EN 00940349, KH 00052410 ["សមមិត្ត អឿន៖ [...] សរុប ពួកមិនល្អបាន ៣៦ នាក់។ មានសកម្មភាពបំពុល ដាក់អង់ត្រីនឱ្យបងប្អូនផឹក ពុលអស់មួយអនុសេនាតូច"]។

[1151] ឯកសារ D1.3.27.20 កំណត់ហេតុនៃកិច្ចប្រជុំឃោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ លេខ ERN EN 00940349, KH 00052410 ["សមមិត្ត ភាព៖ [...] អង្គភាពមានពួកចាញ់ច្រាប ជឿឧបាយកលខ្មាំង ខ្ជិលធ្វើការងារ ពុតត្បុត ទោមនស្សនឹងរបប"]។ ឯកសារ D1.3.27.12 កំណត់ហេតុនៃកិច្ចប្រជុំឃោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៦ លេខ ERN EN 00234458-59, KH 00052378-79, FR 00386194-95 [សុន សេន៖ "ផ្ទៃក្នុងជួរ មានកម្មាភិបាល និងយុទ្ធជនខ្លះមិនសប្បាយចិត្ត ឆ្កិះឆ្កៀលទំនាស់ បំផុសរត់ចោលជួរ បង្វែងមាគ៌ាបក្សខ្លះ ប្រឆាំងមាគ៌ាជាពាក្យសំដីខ្លះ។ បញ្ហានេះ មានដោយសារចលនាបដិវត្តយើងកាន់តែជ្រៅ

មុន[1152] និង "ពួកដែលមិនយល់ជ្រួតជ្រាបចលនាបដិវត្តន៍ ដើរមិនទាន់គេ"[1153]។ ក្នុងពេលប្រជុំថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ សុន សេន ខ្លួនឯងផ្ទាល់ បានអះអាងថា អ្នកដែលវាយបដិវត្តន៍ដោយសកម្មភាពកំប៉ិកកំប៉ុក ដូចជា "លួច និយាយបញ្ឆិតបញ្ឆៀងវាយបដិវត្តន៍" គឺចេញពីខ្សែក្បត់[1154]។

334. **មាស មុត** បានអនុវត្តគោលនយោបាយ ប.ក. នេះ យ៉ាងមុតមាំ ដើម្បីបោសសម្អាតកងទ័ពផ្ទាល់របស់គាត់[1155]។ ក្នុងសារទូរលេខមួយផ្ញើទៅ "គណៈ ម-៨៧០" ថ្នាក់ដឹកនាំមជ្ឈិមបក្ស នៅថ្ងៃចុងក្រោយនៃឆ្នាំ ១៩៧៧ **មាស មុត** បានធ្វើការប្តេជ្ញាចិត្ត៖

---

ម្យ៉ាង ហើយម្យ៉ាងទៀត តាមរយៈខ្សែចាត់តាំងរបស់ខ្មាំងក៏មាន។ ឯវិធានការរបស់យើង៖ [...] ៣. [...] មានសមាសភាពមិនល្អត្រូវសំរិតសំរាំងដាច់ខាត"]។

1152 ឯកសារ D1.3.27.13 កំណត់ហេតុនៃកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៧៦ លេខ ERN EN 00183968, KH 00052382 [សុន សេន៖ "ខ្មាំងវាចង់ឆ្លៀតប្រមូលពួកសមាសភាពមិនល្អ [...] ពួកត្រូវយើងដកពីតំណែង"]។

1153 ឯកសារ D1.3.27.13 កំណត់ហេតុនៃកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៧៦ លេខ ERN EN 00183968, KH 00052382 [សុន សេន៖ "ខ្មាំងវាចង់ឆ្លៀតប្រមូលពួកសមាសភាពមិនល្អ [...] ពួកដែលមិនយល់ជ្រួតជ្រាបចលនាបដិវត្ត"]។

1154 ឯកសារ D1.3.27.20 កំណត់ហេតុនៃកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ លេខ ERN EN 00940353, KH 00052413, FR 00334981 ["អង្គប្រជុំបានឯកភាពជាមួយបក្ស ចាត់ទុកការចាប់ពួកក្បត់នេះ [ចក្រី យ៉ា និងកែវ មាស] ជាមហាជោគជ័យលើពួកសើរើនិយម [...] មេរៀនមួយទៀត នាំឲ្យយើងយល់សកម្មភាពវាយបដិវត្តកំប៉ិកកំប៉ុក ដូចជាលួច និយាយបញ្ឆិតបញ្ឆៀងវាយបដិវត្ត សុទ្ធតែចេញពីខ្សែក្បត់នេះ"]។

1155 ឯកសារ D114/159 កំណត់ហេតុស្តាប់ចម្លើយរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ឆ.30 ["កងទ័ពដែល មាស មុត បោសសម្អាត មានតែកងពល១៦៤ របស់គាត់ហ្នឹងឯង។ តែការបោសសម្អាតនៅខាងកំពង់ផែ និងភូមិប្រជាជនជុំវិញផែ និងជុំវិញក្រុងកំពង់សោម ខ្ញុំជឿថា ពិតជាមាន។ ក៏ប៉ុន្តែ គ្មានឯកសារណាមួយធ្លាក់ដល់ដៃខ្ញុំទេ"]។ ឯកសារ D114/25 កំណត់ហេតុស្តាប់ចម្លើយរបស់ អ៊ូ ដាវ ហៅ សៀន ឆ.13-14 ["នៅពេលនោះ ក្នុងអង្គប្រជុំ អង្គការ ឬបក្ស មានគម្រោងចម្រាញ់នៅក្នុងកងទ័ព អង្គការ ឬបក្សមានគម្រោងកម្ទេចពួកមូលធននិយម ហើយពួកអតីតទាហានរបប លន់ នល់ [...] ឆ.14: [...] អ្នកឧទ្ទេសនាមក្នុងអង្គប្រជុំនោះគឺ មាស មុត"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយរបស់ ប៊ាង រ៉េត ឆ.57 ["បោសសម្អាតផ្ទៃក្នុង គឺជាការសម្រិតសម្រាំងផ្ទៃក្នុង ដែលមានន័យថា អ្នកដែលត្រូវបានរកឃើញថា ជាប់ពាក់ព័ន្ធនឹងនយោបាយបរទេស ឬបម្រើផលប្រយោជន៍បរទេស នឹងត្រូវបានបោសសម្អាតក្នុងគោលបំណងធ្វើឲ្យផ្ទៃក្នុងបក្សស្អាតស្អំ។ ពាក្យថា "បោសសម្អាត" មានន័យថា ពួកគេត្រូវបានដកចេញ ឬសម្លាប់"]។ ឯកសារ D114/284 កំណត់ហេតុស្តាប់ចម្លើយរបស់ ឯក នី ឆ.8-9៖ ["ព្រោះអាបោសសម្អាតផ្ទៃក្នុង ធ្វើឲ្យខ្ញុំដេកមិនលក់។ បោសសម្អាតផ្ទៃក្នុង ខ្សែរយៈ។ គ្រាន់តែសម្លាប់គ្នាឯង ក្នុងកងពល ១៦៤ មាន៦០០ នាក់

កសាងកម្លាំង ជាឧបករណ៍ការពារបក្ស ការពាររដ្ឋអំណាច កម្មករ កសិករ សម្ភហភាព និងការពារមាតុភូមិកម្ពុជា សង្គមនិយមដាច់ខាត ដោយបោស សម្អាត គ្មានស្នាក់ស្ទើរសមាសបង្កប់របស់ខ្មាំង ជាយួន និងខ្មាំងដទៃទៀត[1156]។

335. ការណែនាំឱ្យគោរពតាមគោលនយោបាយបោសសម្អាតខ្មាំងផ្ទៃក្នុង ត្រូវបានផ្តល់ឱ្យ ក្នុងពេលប្រជុំ កងពល ១៦៤[1157] ហើយភស្តុតាងបញ្ជាក់ថា គោលនយោបាយត្រូវបានអនុវត្តជាពិសេសយ៉ាង

---

ក្នុងបញ្ជី ហើយអ្នកអត់មានឈ្មោះ ក្នុងបញ្ជីហ្នឹងច្រើនទៀត អត់ឃើញ ដែលខ្ញុំស្គាល់ ហើយត្រូវបានសម្លាប់។ សាហាវណាស់។ ស៖ អម្បាញ់មិញ លោកនិយាយថា ដោយសារគោលនយោបាយហ្នឹង ធ្វើឱ្យមិត្តភក្តិលោក និងលោក មានាភាពភ័យខ្លាច? ឆ.9៖ បាទ"]។ សូមមើលផងដែរ ឯកសារ D64.1.29 FBIS ៖ អង្គភាពកងទ័ពការពារដែនកោះ ដែនទឹកប្រឆាំងនឹងការឈ្លានពាន ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ១៩៧៧ លេខ ERN EN 00168298 ["ក្រោយការដឹកនាំដ៏ភ្លឺស្វាងរបស់អង្គការចាត់តាំងបដិវត្តរបស់យើង កងទ័ពបដិវត្តកម្ពុជា ត្រូវបានចាត់តាំងឱ្យការពារដែនសមុទ្រ ដែនកោះ ឥឡូវនេះ យល់ច្បាស់ពីសារធាតុអាក្រក់របស់ចក្រពត្តិអាមេរិក ពួកពលបរិវាររបស់វា ខ្មាំងពង្រីកទឹកដី និងពួកអាក្បត់ទាំងអស់ ជាឆ្កែបម្រើពួកចក្រពត្តិនិយម" (បញ្ជាក់បន្ថែម)]។ ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយរបស់ ឯក នី ឆ. 6 ["ឧទាហរណ៍ នៅក្នុងឯកសារ [D1.3.27.20 កំណត់ហេតុនៃកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦] មាស មុត និយាយថា យើងត្រូវតែតាមដានខ្មាំងលាក់ខ្លួនក្នុងជួរឱ្យជាប់។ សំដីនេះធ្វើឱ្យខ្ញុំនឹកឃើញពេលគាត់និយាយនៅក្នុងអង្គប្រជុំជាមួយពួកយើង គឺធ្វើឱ្យយើងខ្លាច ជិតងាប់។ សម្រាប់ពេលបច្ចុប្បន្ន នៅពេលមានមនុស្សណាធ្វើខុស គេគ្រាន់តែយកទៅឃុំនៅព្រៃស ប៉ុន្តែនៅសម័យខ្មែរក្រហម ប្រសិនបើអ្នកធ្វើខុស ហើយគេចាប់ខ្លួន គឺមានន័យថាស្លាប់"]។

[1156] ឯកសារ D1.3.34.60 សារទូរលេខ ០០ ពី មាស មុត ផ្ញើជូន គណៈ ៨៧០ ចុះនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ លេខ ERN EN 00184995, KH 00001325។

[1157] ប្រសិនបើជាគោលនយោបាយមិនបានអនុវត្តទេ កម្មាភិបាលណាដែលទទួលខុសត្រូវអនុវត្ត នឹងត្រូវយកទៅរៀនសូត្រ ហើយបាត់ខ្លួន៖ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយរបស់ ព្រំ សារ៉ាត ឆ.115-116, 118-120 ["ស៖ តើគោលនយោបាយរបស់អង្គការ ធ្លាប់បាននិយាយអំពីការបង្ក្រាប ឬក៏ការបោសសម្អាតខ្មាំងដែរ ឬទេ? ឆ.115៖ នេះគឺជាផ្នែកនៃគោលនយោបាយដែលខ្ញុំបានប្រាប់នៅខាងលើ សត្រូវទីមួយ គឺយួន និងសត្រូវទី២គឺខ្មាំងផ្ទៃក្នុង។ ស៖ លោកបានចូលរួមនៅក្នុងអង្គប្រជុំ ដែលណែនាំឱ្យអនុវត្តគោលនយោបាយសំខាន់ៗ ដែលនៅក្នុងការណែនាំមួយគឺការបោសសម្អាតខ្មាំង និងខ្មាំងយួន។ តើមានបញ្ហាអ្វីដែរឬទេ បើកម្មាភិបាលណាមួយមិនអនុវត្តតាមការណែនាំបែបនោះ? ឆ. 116៖ បន្ទាប់ពីការប្រជុំផ្សព្វផ្សាយអំពីនយោបាយជាសាធារណៈ និងបានមើលឯកសារហ្នឹងទាំងអស់ហើយ កម្មាភិបាលគ្រប់រូប ខិតខំធ្វើទៅតាមការគិតរបស់ខ្លួនឯង ខំធ្វើការឱ្យអស់ពីសមត្ថភាព [...] ឆ.118៖ កម្មាភិបាលធ្វើឱ្យមានកំហុស កម្មាភិបាលនោះ នឹងត្រូវបញ្ជូនទៅកន្លែងផ្សេងដោយអង្គភាពរបស់គេ។ បន្ទាប់ពីបញ្ជូនទៅអង្គភាពផ្សេងនោះ អង្គភាពដើមមិនដឹងថា មានរឿងអ្វីកើតឡើងចំពោះអ្នកទាំងនោះទេ។ ឆ.119៖ មិនមានអ្នកណាម្នាក់ត្រឡប់មកវិញទេ អ្នកទាំងនោះបាត់ខ្លួនរហូត។ ស៖ តើលោកចង់មានន័យថាម៉េចពាក្យថា បាត់ខ្លួនរហូត? ឆ.120៖ នៅពេលដែលខ្ញុំ

កំរោលចំពោះកងពល ១៦៤។ ទាហានមកពីកងពលត្រូវបានបោសសម្អាត*ក្នុងទ្រង់ទ្រាយធំ*[1158]។ អ្នកដែលត្រូវបានកំណត់គោលដៅ មកពីកងពល ត្រូវបានដកហូតអាវុធ និង "កសាង" (ដាក់ឱ្យធ្វើជាទាសករ) នៅតាមការដ្ឋានការងារជាក់លាក់នានាដែលលក្ខខណ្ឌរស់នៅ និងការងារមានការលំបាកខ្លាំង ត្រូវបានឃុំឃាំងនៅ "មន្ទីរអប់រំ" (មន្ទីរសន្តិសុខ)[1159] បាត់ខ្លួន ឬត្រូវបានសម្លាប់[1160]។

---

សម្គាល់ឃើញ ថាមានអ្នកណាម្នាក់បាត់ខ្លួនពីអង្គភាព ខ្ញុំបានសួរសមាជិកនៅក្នុងក្រុម ហើយគេបានប្រាប់ខ្ញុំថា អង្គការយកពួកគេទៅកន្លែងអប់រំ ហើយខ្ញុំមិនដែលបានឃើញអ្នកនោះ ត្រឡប់មកវិញទេ។ ក្រោយមក ខ្ញុំមិនដឹងថា មានអ្វីកើតឡើងចំពោះពួកគេទេ"]។

1158 សូមមើលផងដែរ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.89-90, 92-93, 100 ["ក្រោយមក គេបានរំសាយកងទ័ព ហើយប្រែក្លាយអង្គភាព [កងវរសេនាតូច ៣៨៧ ពីតំបន់ ៣៧] យើងទៅជាកងផលិតដោយធ្វើស្រែ លើកទំនប់ និងជីកប្រឡាយ ស៖ ហេតុអ្វីបានជាគេរំសាយអង្គភាពរបស់លោក? ឆ.90៖ គេចោទយើងជាខ្មែរខ្មាំង ដោយសារមេកងវរៈរបស់ពួកយើង ត្រូវបានគេចាប់យកទៅបាញ់សម្លាប់អស់ហើយ។ [...] ឆ.92៖ តាមពិត កងពលត្រូវរំសាយ គឺមានទាហានរាប់ពាន់នាក់។ ពួកគេត្រូវបានចាត់តាំងឱ្យធ្វើការងារក្នុងកងផលិតខុសៗគ្នា និងបញ្ជូនទៅតាមមុខព្រួញការងារខុសៗគ្នា។ [...]ឆ.93៖ បញ្ជាច្បាស់ចេញពី តា មុត ហើយពួកគេជាមនុស្សរបស់ តាមុត ដែលត្រូវប្រមូលផ្តុំឱ្យពួកយើងប្រជុំ ហើយប្រាប់ពួកយើងថា នឹងត្រូវបញ្ជូនទៅតាមការដ្ឋានខុសៗគ្នា [...] ស៖ ក្នុងខែឆ្នាំណា ដែលគេចោទពួកលោកថា ជាខ្មែរខ្មាំង? ឆ.100៖ គឺចុងឆ្នាំ ១៩៧៧ ហើយកងពលចាស់ទាំងមូល ត្រូវបានរំសាយទាំងស្រុង" (បញ្ជាក់បន្ថែម)]។

1159 ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយរបស់ ឡាយ ប៊ុនហាក់ ឆ. 134-135 ["ចំពោះអ្នកដែលមានប្រវត្តិមិនល្អ គេបញ្ជូនទៅអង្គភាពដើមវិញ ទៅធ្វើស្រែ និងលើកទំនប់ជាដើម [...] អ្នកដែលមានប្រវត្តិរូបមិនល្អ គេយកទៅធ្វើស្រែដូចជានៅជិតព្រលានយន្តហោះកេងកងជាដើម"]។ ឯកសារ D114/139 ឡាយ ងួន ហៅ អ៊ី ឆ.20, 25, 29, 49[អង្គរក្សរបស់ តាញ៉ាន់ នៅកងវរសេនាធំ ៦៣ ត្រូវបានដកអាវុធ ដោយសារគាត់មិនមានប្រវត្តិល្អ។ តែដោយសារតែគាត់ធ្វើការបានល្អពីមុនមក គេមិនបានដាក់ទោសគាត់ធ្ងន់ធ្ងរទេ គេក៏គ្រាន់តែដកអាវុធពីគាត់តែប៉ុណ្ណោះ ហើយដកគាត់ចេញពីអង្គរក្ស ខុសពីអ្នកឯទៀត]។ ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយរបស់ សុក វណ្ណា ឆ.21, 33 ["អំឡុងពេលខ្ញុំធ្វើការនៅលើកោះ ខ្ញុំឃើញគេហៅអ្នកធ្វើការជាមួយខ្ញុំទៅច្រើនដង ដោយសារគេចោទថា ជាប់សមាសភាពមិនល្អ និងថាត្រូវបញ្ជូនទៅ ធ្វើការនៅកងកេង ដូចប្រជាជនធម្មតា [...] ឆ.33៖ វាអាចថា យោធាទាំងនោះ ធ្វើការមិនបានល្អ ឬមិនធ្វើតាមបញ្ជារគេ ដូច្នេះគេក៏ជាប់សមាសភាពមិនល្អទៅ។ ជួនកាល ក្រុមគ្រួសារដែលនៅស្រុកកំណើតយោធានោះ មានបញ្ហា ឬជាប់ពាក់ព័ន្ធនឹងសកម្មភាពអ្វីមួយ ដូច្នេះ យោធានោះក៏ត្រូវបានគេចោទថាជាប់សមាសភាពមិនល្អដែរ"]។ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយរបស់ ប៉ាក សុក ឆ.14 ["ប្រហែលពាក់កណ្តាលឆ្នាំ ១៩៧៦ ខ្ញុំត្រូវបានគេចាត់ទុកថា ជាសមាសភាពសង្ស័យ មិនល្អ ហើយត្រូវបានគេដកចេញពីកោះពូល្វែ ហើយយកមកដាក់ធ្វើការនៅវាលស្រែជិតកន្លែងចម្ការធូរេន ចម្ការដូង និងចម្ការក្រូចក្នុងរយៈពេលប្រហែលពីរខែ [...] នៅពេលនោះ មានយោធា ១២ នាក់ មកនៅជាមួយខ្ញុំ ដែលត្រូវចាត់ថាជាសមាសភាពសង្ស័យ។ របបអាហារគឺបាយមួយ

336. របាយការណ៍ផ្លូវការផ្សេងៗបង្ហាញថា កម្មាភិបាលយោធាក្នុងកងពល ១៦៤ ត្រូវបានបោសសម្អាតជាបន្តបន្ទាប់[1161]។ នៅក្នុងរបាយការណ៍ស្ថិតិប្រចាំខែដែលនៅសេសសល់ ដែល **មាស មុត** ឬកង

---

កូនវែកក្នុងមួយពេល។ ដើម្បីរស់ ខ្ញុំត្រូវតែរើសដូងទំ យកមកហូបបន្ថែម”]។ ឯកសារ D54/77 អ៊ុក ញិក ឆ.31 [“ស៖ បន្ទាប់ពីលោកដាក់ចូលទៅក្នុងពួកសមាសភាពមិនល្អ តើគេអនុវត្តចំពោះលោកយ៉ាងម៉េចខ្លះ? ឆ.31៖ បន្ទាប់ពីគេដកខ្ញុំចេញទៅ ស្ថានភាពរស់នៅរបស់ខ្ញុំ គឺមានការលំបាកខ្លាំងជាងពេលខ្ញុំធ្វើការជាយោធា។ ពេលខ្ញុំនៅជាយោធា ម្ហូបអាហារហូបចុកគ្រប់គ្រាន់ ហើយការងារមិនលំបាកទេ ប៉ុន្តែបន្ទាប់ពីខ្ញុំត្រូវបាន បញ្ជូនទៅកងផលិតនៅស្ទឹងហាវ គេមិនឱ្យហូបចុកគ្រប់គ្រាន់ទេ ហើយការងារក៏ធ្ងន់ជាងមុនដែរ”]។ ឯកសារ D54/35 កំណត់ហេតុស្តាប់ចម្លើយរបស់ ប្រាក់ សុខា ឆ.17 [“ខ្ញុំត្រូវបានគេបញ្ជូនទៅកងចល័តនៅដើមឆ្នាំ ១៩៧៦។ នៅក្នុងឆ្នាំ ១៩៧៧ តែខ្ញុំមិនចាំថ្ងៃទេ កងចល័តរបស់ខ្ញុំត្រូវបានដកចេញពីព្រែកថាកមកនៅតំបន់កងកេង ដែលគេឱ្យពួកយើងធ្វើការនៅភូមិប្របុស និងភូមិពូធឿង នៅខាងជើងផ្លូវជាតិលេខ ៤ ទល់មុខភូមិបិតត្រាំង។ យើងនៅទីនោះ ដាំស្រូវ និងកសាងទំនប់ នៅទីនោះរហូតដល់ចុងឆ្នាំ ១៩៧៧ នៅពេលនោះ គេបានប្រាប់យើងថា ពួកយើងនឹងត្រូវបញ្ជូនទៅ ស្ទឹងហាវ មិនទៅទឹកសាបទេ ដោយសារពួកយើងមានទោសស្រាល។ នៅដើមឆ្នាំ ១៩៧៨ ខ្ញុំត្រូវបានគេបញ្ជូនទៅស្ទឹងហាវ នៅទីនោះ ខ្ញុំត្រូវគេឱ្យជីករណ្ដៅមូល មានអង្កត់ផ្ចិត ៣០ម៉ែត្រជម្រៅ១០ម៉ែត្រ នៅលើភ្នំផ្នែកខាងក្រោមភ្នំដែលមានផ្ទះភ្ញៀវចិននៅពីខាងលើ។ ភ្ញៀវចិនមកពិនិត្យស្រះនេះ មួយអាទិត្យម្ដង ខ្ញុំក៏ត្រូវគេប្រើឱ្យបំបែកថ្មផងដែរ ខ្ញុំនៅស្ទឹងហាវរហូតដល់វៀតណាមចូលមក”]។

1160 សូមមើល ភ័ស្តុតាងបញ្ជាក់ពីមនុស្សនៅកងពល ១៦៤ ដែលជាប់ឃុំឃាំង និងត្រូវសម្លាប់ រួមមានចំនួន ៦៧ នាក់ នៅមន្ទីរ ស-២១ (VIII.ឃ.៤. ការទទួលខុសត្រូវ មាស មុត ចំពោះអ្នកទោសបញ្ជូនទៅ ស-២១), ចំនួនរាប់រយនាក់នៅវត្តឥន្ទញាន (VIII.គ.៣ មន្ទីរសន្តិសុខវត្តឥន្ទញាន--ឧក្រិដ្ឋកម្ម -ការឃុំខ្លួន --ក.) កម្មាភិបាលកងពល ១៦៤ និងយោធាជាប់កំណែន), ទឹកសាប (VIII.គ.៤. មន្ទីរសន្តិសុខទឹកសាប -- ឧក្រិដ្ឋកម្ម -- ការដាក់ក្នុងមន្ទីរឃុំឃាំង និងការឃុំឃាំងដោយខុសច្បាប់ - ក.) កម្មាភិបាលកងពល ១៦៤ និងយោធារំសាយ) និងចំនួនផ្សេងទៀតនៅតាមកន្លែងឃុំខ្លួនតូចជាងនេះ ដូចជា គុកស្ទឹងហាវ (VIII.ង. ការដ្ឋានស្ទឹងហាវ--៣.ឧក្រិដ្ឋកម្ម)។ ភ័ស្តុតាងដើម្បីបញ្ជាក់ថា យោធាដែលត្រូវបានបោសសម្អាតនៅកងពលផ្សេងទៀត ត្រូវបានគេសម្លាប់ជាទូទៅ រួមមាននៅមន្ទីរ ស-២១ ផងដែរ ហើយ មាស មុត បានដឹងយ៉ាងច្បាស់អំពីរឿងនេះ ។ សូមមើលផងដែរ ឯកសារ D1.3.27.26 កំណត់ហេតុនៃកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧ លេខ ERN EN 00933834, KH 00052304-05 [“សមមិត្ត ម៉េត [...] ច្បាស់ជាសមាសភាពខ្មាំងមែន។ ពួកមិនល្អបានបញ្ជូនទៅ ស-២១ ជាង ៥០ នាក់។ លេខាអនុសេនាធំ ត្រូវដក ៥ នាក់ចេញទៀត ទើបធានា”]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយរបស់ ប៉ាង រ៉េត ឆ.57 [“បោសសម្អាតផ្ទៃក្នុង គឺជាការសម្រិតសម្រាំងផ្ទៃក្នុង ដែលមានន័យថា អ្នកដែលត្រូវបានរកឃើញថា ជាប់ពាក់ព័ន្ធនឹងនយោបាយបរទេស ឬបម្រើផលប្រយោជន៍បរទេស នឹងត្រូវបានបោសសម្អាតក្នុងគោលបំណងធ្វើឱ្យផ្ទៃក្នុងបក្សស្អាតស្អំ។ ពាក្យថា "បោសសម្អាត" មានន័យថា ពួកគេត្រូវបានដកចេញ ឬសម្លាប់”]

1161 ឯកសារ D1.3.27.26 កំណត់ហេតុនៃកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៧៧ លេខ ERN EN 00933835, KH 00052305 [“សមមិត្ត មុត៖ [...] កម្មាភិបាល និងយុទ្ធជនការពារឃ្លាំងមួយចំនួន

ពលរបស់ **មាស មុត** បានផ្ញើមក បានបង្ហាញថា សមាជិកកងពល ១៦៤ ជាច្រើននាក់ ត្រូវបាន បោសសម្អាតរៀងរាល់ខែ។ នៅក្នុងតារាងស្ថិតិដែលមាននៅក្នុងរបាយការណ៍ទាំងនេះ ទាហាន ដែល "បាត់មុខពីអង្គភាព" ត្រូវបានកំណត់ថា "ដក"[1162]។ មនុស្សដែលត្រូវបានបោសសម្អាត ត្រូវ

---

ផ្តាច់នៅជាមួយពួកក្បត់យួន ជាកងការពារវា។ អង្គភាពឃ្លាំង បានសំរិតសំរាំងមួយអនុសេនាតូច តែនៅពុំទាន់អស់ និង ធានានៅឡើយ"]។ ឯកសារ D1.3.34.11 ទូរលេខ ១១ ពី ឌឹម (កងពល ១៦៤) ជូន មាស មុត ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ លេខ ERN EN 00233660, KH 00000863, FR 00654897 ["សភាពដីគោកនៅឃុំរៀម និងបបុស ពី យើងមានវិធានការចំពោះខ្មាំងមួយដែលបងសម្រេច វាមានរត់ចូលព្រៃ៥នាក់ ឥឡូវ យើងតាមចាប់បានទាំងអស់"], លេខ ERN EN 00143522, KH 00000863, FR 00654897 ["និងពីរនាក់ទៀត រត់ពីអង្គភាពពីសង្ហារ យុទ្ធជននេះ នឹងដូរពីកង ៦៣"]។ D1.3.12.7 របាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ៖ សរុបស្ថានការណ៍ ចាប់ពីថ្ងៃទី ១៥ ក ក្កដា ដល់ថ្ងៃ ៣១ សីហា ឆ្នាំ ១៩៧៦ លេខ ERN EN 00233963, KH 00021503 ["កងពល ១៦៤៖ [...] មានកម្ម ករបួននាក់ កាត់របងលួស ចូលឃ្លាំងគ្រាប់ យើងបានចាប់ និងបញ្ជូនទៅឲ្យនគរបាលហើយ"]។ ឯកសារ D1.3.8.4 កំណត់ហេតុនៃកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ (កម្មាភិបាលកងពល ១៦៤ និង សុន សេន) ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ លេខ ERN EN 00657355, KH 00162489 [មានអ្នករត់គេចចំនួន ៤០ នាក់ ដឹកនាំឈ្មោះ វង់ ស្រួល នៅស្រុកស្ទឹងហាវ៖ "កន្លងមក គណៈកងពលបានបំបែកពួកមិនល្អឲ្យនៅដោយឡែក ដើម្បីកុំឲ្យច្របូកច្របល់ នឹងពួកល្អ [...] [កងកេង] ប្រជាជននេះ ភាគច្រើនល្អ តែទាហានមានចលនាមិនល្អ។ កន្លងមក រកឃើញទាហានសក្តិ ២ បានចាប់ហើយ (អតីតរបបចាស់)"] សុន សេន បានឆ្លើយតបវិញ នៅត្រង់លេខ ERN EN 00657356, KH 00162490: ["៣. សភាពការណ៍ផ្ទៃក្នុង៖ ឈ្មោះ វង់ ស្រួល នោះ ចាប់សួរចម្លើយទៅ។ បញ្ហាបំបែក ពួករត់ឲ្យទៅកង ផ្សេងៗ ដូចមិនចំណេញ ព្រោះបើមានខ្មាំងវាធ្វើសកម្មភាពបានទៀត។ ត្រូវក្តាប់ប្រវត្តិរូបឲ្យច្បាស់ ហើយប្រមូលឲ្យ បង្កបង្កើនផលមួយដុំចុះ។ សមាសភាពទាហាន ត្រូវប្រមូល"]។ សូមមើលផងដែរ ឯកសារ D54/100 ឡាយ ប៊ុ នហាក់ ឆ.107-110 [រៀបរាប់អំពីដំណើរការចាប់ខ្លួន ហើយការចាប់ខ្លួនកម្មាភិបាលត្រូវសម្រេចដោយថ្នាក់កងពល ហើយអ្នកទោសធ្ងន់ ត្រូវបញ្ជូនចេញពីកោះ ទៅកាន់ដីគោក ដោយយោធាមកពីបញ្ជាការដ្ឋានកងពល]។

1162 ឯកសារ D22.2.4 របាយការណ៍ស្ថិតិគណៈកងពល ១៦៤៖ បញ្ជីក្តាប់កម្លាំងប្រចាំថ្ងៃ ១៦៤ ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៦ លេខ ERN EN 00950655, KH 00160118 [នៅផ្នែក"បាត់មុខពីអង្គភាព" មានចំនួន ១៨៦ នាក់ ត្រូវបាន លើកឡើងថា"ដក" ក្នុងនោះមាន ១៥៣ នាក់ មកពីវរសេនាធំ ១៤០, ៨ នាក់ មកពី វរសេនាធំ ៦២, និង ១១ នាក់ មក ពីវរសេនាធំ ៦៣]។ ឯកសារ D22.2.5 របាយការណ៍ស្ថិតិគណៈកងពល ១៦៤៖ បញ្ជីក្តាប់កម្លាំងប្រចាំថ្ងៃ ១៦៤ ចុះថ្ងៃ ទី ២៨ ខែ សីហា ឆ្នាំ ១៩៧៦ លេខ ERN EN 00950657, KH 00160123 [នៅផ្នែក "បាត់មុខពីអង្គភាព" ចំនួន ៣២ នាក់ មកពីកងពល ១៦៤ ត្រូវបាន"ដក", ១៣ នាក់ មកពីវរសេនាធំ៦១, ១៤ នាក់មកពីវរសេនាធំ ៦២, ៤ នាក់ មកពីវរសេនាតូច ១៦៦, និង ១ នាក់មកពីវរសេនាតូច ១៦៨]។ ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់ មាស មុត ៖បញ្ជីក្តាប់កម្លាំងប្រចាំថ្ងៃ ១៦៤ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦ លេខ ERN EN 00233989, KH 00160147 [នៅផ្នែក "បាត់មុខពីអង្គភាព" ចំនួន ៥ នាក់ត្រូវបានរាយការណ៍ថា បានស្លាប់ក្នុងចម្បាំង, ៣ នាក់រត់ចោលជួរ និង ២៩ នាក់ ត្រូវបានដក រួមមាន ៣ នាក់មកពីវរសេនាធំ ៦១, ១៣ នាក់ មកពីវរសេនាធំ ៦២, ៤ នាក់ មកពីវរសេនាធំ

បានកំណត់អត្តសញ្ញាណ តាមរយៈប្រវត្តិរូបរបស់ពួកគេ ព្រោះឈ្មោះរបស់ពួកគេត្រូវបានអ្នកទោសឆ្លើយប្រាប់ ក្រោមការធ្វើទារុណកម្ម នៅក្នុងមន្ទីរសន្តិសុខ ឬព្រោះពួកគេជាអ្នកនៅក្រោមបង្គាប់របស់កម្មាភិបាលដែលត្រូវបានចាប់ខ្លួន ឬព្រោះពួកគេបានធ្វើខុស។

## ២. ការសម្រិតសម្រាំងទាហានក្នុងកងពល ១៦៤ តាមរយៈប្រវត្តិរូបរបស់ពួកគេ

337. ក្នុងការអនុវត្តគោលនយោបាយបោសសម្អាត **មាស មុត** បានដាក់ឲ្យប្រើប្រាស់នីតិវិធីសម្រិតសម្រាំងប្រវត្តិរូបរបស់កងទ័ពដែលស្ថិតក្រោមបញ្ជាការរបស់គាត់ នៅក្នុងកងពល ១៦៤[1163]។

---

៦៣, ៥ នាក់ មកពីវរសេនាធំ ១៤០, និង ៧ នាក់ វរសេនាតូច ១៦៩]។ មានការបកប្រែភាសាអង់គ្លេសមួយច្បាប់ទៀតក្នុងឯកសារដដែល លើកឡើងថា មានយោធា ២០ នាក់ ត្រូវបាន "ដក"។ ឯកសារ D54/24.2 របាយការណ៍ស្ថិតិរបស់ មាស មុត៖បញ្ជីក្លាប់កម្លាំងប្រចាំថ្ងៃ ១៦៤ ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦ លេខ ERN EN 01145323, KH 00955521។ ឯកសារ D22.2.6 របាយការណ៍ស្ថិតិរបស់ មាស មុត៖បញ្ជីក្លាប់កម្លាំងប្រចាំថ្ងៃ ១៦៤ ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ លេខ ERN EN 00575531, KH 00160071 [នៅផ្នែក "បាត់មុខពីអង្គភាព" យោធាចំនួន ២ នាក់ត្រូវបានរាយការណ៍ថា ស្លាប់ និងយោធា ៨៥ នាក់ "ចូលនិវត្តន៍" រួមមាន ១៥ នាក់ មកពីវរសេនាធំ ៦១, ២១ នាក់មកពីវរសេនាធំ ៦២, ១០ នាក់ មកពីវរសេនាធំ ១០, ៥ នាក់ មកពីវរសេនាធំ ១៤០, ៥ នាក់មកពីវរៈសេនាតូច ១៦៧, និង ២៩ មកពីវរសេនាតូច ១៦៨]។

1163 ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយរបស់ ឌុល សុង ឆ.16-17 ["ក្នុងនាមជាមេបញ្ជាការកងពលកងទ័ពជើងទឹក មាស មុត [...] ទទួលខុសត្រូវធ្វើការសម្រិតសម្រាំងប្រវត្តិរូបរបស់យោធាជើងទឹក សម្រេចចាប់ចង និងសម្លាប់អ្នកណាដែលធ្វើខុស [...] ឆ.17៖ ការសន្និដ្ឋានរបស់ខ្ញុំថា វាជាការទទួលខុសត្រូវរបស់មេបញ្ជាការកងពល។ ចំពោះរឿងសម្រិតសម្រាំង បើសិនជាគេរកឃើញថា មានយោធាណាមានបងប្អូនធ្វើការក្នុងរបបមុន គេនឹងដកយោធានោះចេញ យកទៅដាក់មួយកន្លែងផ្សេង គេដាក់ក្នុងកងផ្សេង ឲ្យធ្វើការងារស្រែចម្ការ"]។ ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយរបស់ អែម សុន ឆ.2 ["អ្វីដែលខ្ញុំនិយាយអំពីអំណាចរបស់ មាស មុត ក្នុងការចាប់ និងដោះលែងមនុស្សគឺជារឿងទូទៅដែលមនុស្សគ្រប់គ្នាដឹងនាពេលនោះ"]។ ឯកសារ D54/24 កំណត់ហេតុស្តាប់ចម្លើយរបស់ ប៉ាក សុក ឆ.19-20 ["មាស មុត ក្លាយជាមេបញ្ជាការកងពលលេខ ១៦៤ ធំជាងគេបង្អស់ [...] មាស មុត ទទួលខុសត្រូវគ្រប់យ៉ាងដូចជា ខាងផ្នែកយោធា ភស្តុភារ នេសាទ ជួសជុលកប៉ាល់ សកម្មភាពកំពង់ផែ ហើយនិងការងារជាច្រើនទៀត"]។ ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយរបស់ប៉ាក សុក ឆ.3 ["ហេតុអ្វីបានលោកនិយាយនៅក្នុងកិច្ចសម្ភាសជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ការបញ្ជាឲ្យសម្លាប់ គឺជាទូទៅ គឺចេញមកពីតាមុត? ឆ.3៖ តាមការយល់ឃើញរបស់ខ្ញុំ នេះគឺជារៀបរបបការងារទូទៅរបស់កងពល"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយរបស់ ឯក នី ឆ.14, 16 ["ស៖ យោលទៅតាមការសង្កេតរបស់លោក តើអ្នកមានអំណាចខ្លាំងជាងគេ ក្នុងការចាប់ចង ការដកអាវុធ ការបញ្ជូនយោធាឲ្យទៅធ្វើពលកម្ម? ឆ.14៖ គឺមានតែបង មុត ទេ ពីព្រោះបងមុត គាត់មានតួនាទីពីរ មួយគាត់ជាលេខាកងពល១៦៤ ហើយនិងតួនាទីមួយទៀត នៅក្នុងជួរគណៈរដ្ឋមន្ត្រី [...] ឆ.16៖ មាស មុត មានសិទ្ធិអំណាចចាប់

ប្រវត្តិរូបត្រូវបានចងក្រង និងវិភាគដើម្បីកំណត់ "សមាសភាពអាក្រក់ ឬមិនល្អ" ក្នុងចំណោមកម្មាភិបាលយោធា និងទាហាន[1164]។ ប្រវត្តិរូបអាក្រក់ ឬមិនសុទ្ធ ជាប្រវត្តិរូបរបស់ទាហានដែលមានសាច់ញាតិ ខ្សែរយៈ ឬអ្នកស្គាល់គ្នា ធ្លាប់ធ្វើជាអ្នករដ្ឋការក្នុងរបបសាធារណរដ្ឋខ្មែរចាស់[1165]

---

ចងប្រជាជនស៊ីវិល យោធា ហើយនិងគ្រួសារយោធា ដែលស្ថិតនៅក្រោមការត្រួតត្រារបស់កងពល ១៦៤"]។ សូមមើលផងដែរ ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយរបស់ អ៊ឹង តុន ឆ.15-16 [ពន្យល់ថា ដើម្បីចូលកងទ័ពជើងទឹកបាន-កងវរសេនាធំ ១៤០-អ្នកនោះត្រូវមានវណ្ណៈដើមល្អ ហើយប្រវត្តិរូបនោះ ត្រូវបានកត់ត្រាទុក ក្នុងអំឡុងពេលរៀនសូត្រ ដោយ មាស មុត នៅរោងមហោស្រពកំពង់សោម"]។

1164 ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយរបស់ ស្រៀង យឹម ឆ. 59, 151 ["រឿងប្រវត្តិរូបនោះ គេសម្រេចតាមថ្នាក់ ហើយអ្នកដែលគេសម្រេចនោះ គឺនៅក្រោម មាស មុត។ អ្នកដែលល្អ គឺនៅតែល្អ ហើយអ្នកដែលអាក្រក់ គឺជាខ្មាំងស៊ីរូងផ្ទៃក្នុង [...] សៈនៅពេលដែលគេនាំពួកនោះទៅ តើលោកធ្លាប់បានជួបពួកគាត់ម្តងទៀតទេ? ឆ.151៖ អ្នកទាំងនោះស្លាប់អស់ហើយ ហើយមានអ្នកខ្លះក៏រស់ដែរ នៅពេលដែលចុងរបបខ្មែរក្រហម។ ខ្ញុំបានឃើញពួកគេមានស្នាមនៅកដៃ និងកជើង ដែលគេដាក់ខ្នោះ"]។ លោក លុន សេង បានផ្តល់និយមន័យអំពី"សមាសភាពមិនល្អ" ខុសគ្នាពីអ្វីដែល សុន សេន បានកំណត់ នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ (សូមមើលខាងលើ កថាខណ្ឌ ៣៣០ ជើងទំព័រ ១១៣៤)៖ ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយរបស់ លុន សេង ឆ.19 ["ខ្មាំងផ្ទៃក្នុងជាមនុស្សនៅក្នុងជួរដែលមិនយកចិត្តទុកដាក់នឹងការងារដែលដាក់ឲ្យធ្វើ។ ខ្មាំងសតិអារម្មណ៍ ផ្ទៃក្នុង គឺជាអ្នកដែលរុញរានឹងការងារ ហើយមិនដែលបញ្ចប់ការងារដែលប្រគល់ឲ្យ។ ពួកសមាសភាពមិនល្អ គឺជាពួកដែលធ្លាប់បម្រើការនៅក្នុងរបបរដ្ឋាភិបាលមុនៗ"]។

1165 ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.103 ["យើងត្រូវសរសេរក្នុងប្រវត្តិរូប ប្រសិនបើមានបងប្អូន ធ្លាប់ធ្វើការនៅក្នុងរបបលន់ នល់ និងជាពិសេស អំពីនិន្នាការនយោបាយរបស់យើង។ ប្រសិនបើគេដឹងថាយើងមានបងប្អូនធ្លាប់ធ្វើការក្នុងរបបចាស់ នោះយើងនឹងមានបញ្ហាហើយ។ បើសិនជាយើងមាន កំហុសតិចតួចថែមទៀត គេនឹងបេះយើងចេញ ដូចបេះផ្លែឪឡឹក (យកទៅសម្លាប់ផុយ)"]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយរបស់ ឌុល សុង ឆ.17 ["ចំពោះរឿងសម្រិតសម្រាំង បើសិនជាគេរកឃើញថា មានយោធាណាមានបងប្អូន ធ្វើការក្នុងរបបមុន គេនឹងដកយោធានោះចេញ យកទៅដាក់មួយកន្លែងផ្សេង គេដាក់ក្នុងកងផ្សេងឲ្យធ្វើការងារស្រែចម្ការ"]។ ឯកសារ D114/25 កំណត់ហេតុស្តាប់ចម្លើយរបស់ អ៊ូ ដាវ ហៅ សឿន ឆ.13-14 ["នៅពេលនោះ ក្នុងអង្គប្រជុំ អង្គការ ឬបក្សមានគម្រោងចម្រាញ់នៅក្នុងកងទ័ព អង្គការមានគម្រោងកម្ទេចពួកមូលធននិយម ហើយពួកអតីតទាហានលន់ នល់ [...] ឆ.14៖ [...] អ្នកដែលឧទ្ទេសនាមក្នុងអង្គប្រជុំនោះគឺ មាស មុត"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយរបស់ សុក នាង ឆ.34-35 ["នៅចន្លោះឆ្នាំ ១៩៧៧-១៩៧៨ [...] គេបានឲ្យខ្ញុំធ្វើប្រវត្តិរូប ហើយយកទៅស្រាវជ្រាវ ដល់ភូមិកំណើតខ្ញុំតែម្តង។ ក្នុងគ្រាមួយនោះ ខ្ញុំបានជួបអ្នកភូមិជាមួយគ្នាម្នាក់ឈ្មោះ នន នៅជិតផ្សារលើកំពង់សោម។ កាលនោះ គាត់ហាក់ដូចជាអ្នកគ្រប់គ្រង ឬកាន់កាប់នៅគុកទឹកសាប។ ដោយសារគាត់មានសាច់ញាតិធ្លាប់ធ្វើការនៅក្នុងសម័យ លន់ នល់ ដែរ គាត់ក៏មានការបារម្ភដូចខ្ញុំដែរ។ គាត់ប្រាប់ខ្ញុំថា ប្រសិនបើគេចាប់គាត់ គឺគាត់មិនឲ្យចាប់ទេ [...] ខ្ញុំបានដឹងថា មុនវៀតណាមចូលប្រហែល ១ ខែ គេបានមករកចាប់គាត់មែន តែគាត់បានរត់

ស្ថិតក្នុងវណ្ណៈខ្ពស់[1166] ឬមាននិន្នាការនយោបាយ (ទំនាក់ទំនងគ្រួសារ ឬទំនាក់ទំនងការងារជាមួយ "ជនក្បត់" ដែលត្រូវបានចាប់ខ្លួន និង/ឬមានទំនាក់ទំនងជាមួយខ្មាំងខាងក្រៅ)[1167]។ **មាស មុត ខ្លួន**

---

ហើយគេក៏បាញ់គាត់ស្លាប់តែម្តងទៅ [...] ឆ.35៖ ក្នុងជំនាន់នោះ ប្រសិនបើអ្នកជាប់ពាក់ព័ន្ធទៅនឹងរបបមុន អ្នកនោះនឹងទទួលការចាប់អារម្មណ៍ខ្លាំង។ របបខ្មែរក្រហម គឺគេចម្រាញ់រកតែអ្នកល្អៗទេ អ្នកផ្សេងត្រូវតែទៅហើយ។ ប្រសិនបើអ្នកជាប់ពាក់ព័ន្ធទៅនឹងរបបមុន ធ្វើការងារធម្មតាដូចគេដូចឯង ដោយមិនត្អូញត្អែរ ឬក៏ប្រឆាំងអ្វីនោះ គឺអ្នកនោះមិនមានបញ្ហាអ្វីទេ។ ប៉ុន្តែប្រសិនអ្នកនោះ ត្អូញត្អែរ ឬប្រឆាំងរបបកាលនោះនឹងចាត់ទុកអ្នកនោះ ថាប្រឆាំងនឹងរបបខ្លួនហើយ [...] សៈ ចំពោះអ្នកដែលលោកស្រីរៀបរាប់ខាងលើ តើនឹងមានផលពិបាកអ្វីខ្លះដល់ពួកគេ? ឆ.36៖ គឺត្រូវចាប់ខ្លួនសួរចម្លើយ និងទទួលការអប់រំ។"]។ ឯកសារ D54/93 កំណត់ហេតុស្តាប់ចម្លើយរបស់ យ៉ែម សំអុន ឆ. 19 ["អ្នកដែលមានប្រវត្តិរូបអាក្រក់ គឺអ្នកដែលធ្លាប់ពាក់ព័ន្ធ ឬមានបងប្អូន ជាប់ពាក់ព័ន្ធការងារក្នុងរបប លន់ នល់"]។ សូមមើលផងដែរ ចំពោះ រឿងបោសសម្អាត ពាក់ព័ន្ធនឹងរបបចាស់សម្តេច សីហនុ និងរបបសាធារណរដ្ឋខ្មែរ ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយរបស់ សុត ស៊ិន ឆ.25-26 ["គេបានដកខ្ញុំមុន[ពីកងវរសេនាតូច ៣៨៦ នៅលើកោះតាង] [...] ព្រោះខ្ញុំជាប់និន្នាការ ដោយសារតែខ្ញុំមានបងប្រុស និងពួខ្ញុំបានធ្វើការធំណាស់នៅសម័យសម្តេចតា [...] ឆ.26៖ បងប្អូនខ្ញុំច្រើនណាស់ដែលធ្វើការ មានសក្តិ៣ សក្តិ៤ ក្នុងរបបមុន។ ហើយពួខ្ញុំក៏គាត់មានខ្សែក្រវ៉ាត់ នៅយាមព្រលានយន្តហោះ កងកេង ហើយគាត់ជាទាហាន គាត់ជាកូនទាហានទេ"]។ ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយរបស់ លុន សេង ឆ.19 ["សមាសភាពមិនល្អ គឺជាពួកដែលធ្លាប់បម្រើការងារក្នុងរបបរដ្ឋាភិបាលមុនៗ ឬក៏មានបងប្អូនធ្លាប់ធ្វើការនៅក្នុងរបបមុនៗ។ ខ្ញុំផ្ទាល់ ក៏ស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ដែរនៅពេលនោះ ពីព្រោះពួខ្ញុំម្នាក់ពាក់សក្តិ៤ អតីតនៅកងទ័ពអាកាសរបប សីហនុ និងរបប លន់ នល់ ប៉ុន្តែខ្ញុំបានលាក់ប្រវត្តិរូបខ្ញុំជិត"]។

1166 ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយរបស់ ស្វាយ សាម៉េត ឆ.37-39 ["ខ្មាំងគឺជាវណ្ណៈមូលធន និងឥស្សរជន។ វណ្ណៈទាំងពីរនេះជាប់និន្នាការជាមួយនឹងរបប លន់ នល់។ ប្រសិនបើពួកគេជាប់និន្នាការ ពួកគេនឹងលែងទទួលបានការជឿទុកចិត្តទៀត។ ដូចជាក្នុងករណីរបស់ខ្ញុំជាដើម គេបញ្ជូនខ្ញុំទៅនេះ ទៅនោះ គេមិនឱ្យការងារសំខាន់ខ្ញុំធ្វើ [...] ប្រសិនបើអ្នកមកពីវណ្ណៈកសិករថ្នាក់កណ្តាល ហើយជាប់ពាក់ព័ន្ធនឹងនិន្នាការ លន់ នល់ ប្រព្រឹត្តកំហុសអ្វីមួយ ពួកគេនឹងត្រូវយកទៅកសាង។ ប្រសិនបើពួកគេមិនកែខ្លួននោះទេ ពួកគេនឹងត្រូវយកទៅសម្លាប់ចោល [...] សៈ តើគណៈកម្មាធិការត្រួតពិនិត្យរបស់កងពលធ្វើដូចម្តេច ប្រសិនបើក្នុងដំណើរការត្រួតពិនិត្យនោះ គេរកឃើញថា មនុស្សម្នាក់ស្ថិតក្នុងវណ្ណៈមូលធន ឬឥស្សរជន? ឆ.38៖ មនុស្សនេះនឹងបាត់ខ្លួន។ ឧទាហរណ៍ ប្រសិនបើមនុស្សម្នាក់មានចំណេះដឹងខ្ពស់ ហើយធ្វើជាមិនដឹងអី មិនយូរទេ គាត់ប្រាកដនឹងបាត់ខ្លួន។ [...] ឆ.39៖ ចំពោះការបែងចែកវណ្ណៈកសិករ ពួកគេបែងចែកអ្នក ដោយផ្អែកទៅតាមព័ត៌មានអំពីអាហារដែលមានសម្រាប់ហូបចុក។ ប្រសិនបើអ្នកមិនមានអាហារហូបចុកគ្រប់គ្រាន់ រហូតដល់ទៅបីខែ ពួកគេចាត់ទុកអ្នកថាជាកសិករវណ្ណៈកណ្តាលថ្នាក់ក្រោម។ ហើយសម្រាប់អ្នកដែលខ្វះអាហាររហូតដល់រយៈពេល៦ខែ គេចាត់ទុកជាវណ្ណៈក្រីក្រ"]។ ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយរបស់ ស្វាយ សាម៉េត ឆ.37 ["វណ្ណៈដែលគេប្រើនៅសម័យនោះរួមមាន វណ្ណៈមូលធន វណ្ណៈឥស្សរជន កសិករវណ្ណៈកណ្តាល កសិករ វណ្ណៈកណ្តាលថ្នាក់ក្រោម និងកសិករវណ្ណៈក្រីក្រ"]។ ឯកសារ D114/25 កំណត់ហេតុស្តាប់ចម្លើយរបស់ អ៊ូ ដាវ ហៅ សឿន ឆ.18 ["សៈ នៅក្នុងប្រវត្តិរូបនោះ តើគេសួរអ្វីខ្លះ? ឆ.18៖ គេសួរ [...] តើមានពាក់ព័ន្ធជាមួយនឹង

សមាសភាព ឬរបបអ្វីដែរទេ វណ្ណៈភាពជាកសិករ កម្មករ។ ឧទាហរណ៍ ជាកសិករថ្នាក់ទាប កណ្តាល ឬខ្ពស់ ជាដើម។"]។ សូមមើលផងដែរ ឯកសារ D114/181 កំណត់ហេតុស្តាប់ចម្លើយរបស់ សែម កុល ឆ.40-ឆ.41 ["ការជំនាន់យើងត្រូវលាក់ដូចថា អ្នករៀនខ្ពស់ថ្នាក់ទី៧ ទីអីហ្នឹង។ យើងកសិករថ្នាក់កណ្តាល យើងដាក់ថ្នាក់ក្រោមអីចឹង។ ព្រោះជំនាន់ហ្នឹង ធ្វើបដិវត្តន៍ គេកម្ចាត់របបមូលធន អនុធនអីហ្នឹង កាលហ្នឹង គេបំបាត់របបសក្តិភូមិ នាយទុន។ កាលណាមិនលាក់ ព្រោះគេចង់បំបាត់ស្រទាប់លើ។ បដិវត្តន៍ទិសដៅគេបំបាត់ របបសក្តិភូមិ បំបាត់នាយទុន។ ស៖ បំបាត់ហ្នឹងមានន័យម៉េចដែរ? ឆ.41៖ បំបាត់ហ្នឹង កម្ចាត់ពួកហ្នឹង ឲ្យមានថ្នាក់ស្មើៗគ្នា។ កុំឲ្យមានអ្នកមាន អ្នកក្រ"]។

1167 ឯកសារ D114/11 កំណត់ហេតុស្តាប់ចម្លើយរបស់ នាក់ យឿ ឆ.5 ["នៅពេលនោះ គេព្យាយាមរកអ្នកដែលជិតស្និទ្ធនឹងអតីតកម្មាភិបាល ដែលគេចោទថាក្បត់នឹងអង្គការ។ គេសួរយើងចង់ដឹងថា តើយើងធ្លាប់មានទំនាក់ទំនង ឬ ធ្វើការជាមួយនឹងកម្មាភិបាលទាំងនោះដែរ ឬអត់។ ប្រសិនបើយើងសរសេរនៅក្នុងប្រវត្តិរូបយើងថា ធ្លាប់ធ្វើការឲ្យកម្មាភិបាលទាំងនោះ យូរឬឆាប់អ្នកនោះនឹងបាត់ខ្លួនដែរហើយ"]។ ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយរបស់ សុក វណ្ណា ឆ.21, 33 ["ក្នុងអំឡុងពេលខ្ញុំធ្វើការនៅកោះ ខ្ញុំឃើញគេហៅអ្នកធ្វើការជាមួយខ្ញុំទៅច្រើនដង ដោយសារគេចោទថា ជាប់សមាសភាពមិនល្អ និងថាត្រូវបញ្ជូនទៅធ្វើការនៅកងកេង ដូចប្រជាជនធម្មតា។ [...] ឆ.33៖ វាអាចថា យោធាទាំងនោះ ធ្វើការមិនបានល្អ ឬមិនធ្វើតាមបញ្ជារគេ ដូច្នេះគេក៏ជាប់សមាសភាពមិនល្អទៅ។ ជួនកាល ក្រុមគ្រួសារដែលនៅស្រុកកំណើតយោធានោះ មានបញ្ហា ឬជាប់ពាក់ព័ន្ធនឹងសកម្មភាពអ្វីមួយ ដូច្នេះ យោធានោះក៏ត្រូវបានគេចោទថាជាប់សមាសភាពមិនល្អដែរ។ ក្នុងសម័យខ្មែរក្រហម ប្រសិនបងប្អូនមានបញ្ហា យើងក៏មិនអាចនៅសុខក្នុងជួរយោធាដែរ"]។ ឯកសារ D114/48 កំណត់ហេតុស្តាប់ចម្លើយរបស់ សុក ង៉ុន ឆ.17 ["អ្នកដែលមានប្រវត្តិរូបល្អ អ្នកដែលគ្មានបងប្អូនសាច់ញាតិដែលគេចាប់ខ្លួន ឬបម្រើនៅក្នុងរដ្ឋាភិបាលពីមុនមក ឬជាប់សាច់ញាតិជាមួយអ្នកដែលមាននិន្នាការនយោបាយផ្សេង"]។ ឯកសារ D54/103 កំណត់ហេតុស្តាប់ចម្លើយរបស់ ឯក នី ឆ.7-8 ["យោធាកងរបស់ខ្ញុំត្រូវបានគេដកកាំភ្លើង នៅដើមខែវស្សា ក្នុងឆ្នាំ ១៩៧៧។ នៅពេលនោះ តា មុត បានមកប្រជុំជាមួយនឹងពួកយើងក្រោយពេលដែលដកកាំភ្លើង នៅពេលដែលគាត់ប្រកាសនៅក្នុងអង្គប្រជុំថា ឆាន ជាពួកក្បត់ ហើយសម្រាប់ពួកអតីតា៨៦ (៣៨៦) គឺមិនគួរទុកចិត្តទៀតទេ។ បន្ទាប់ពីគេចាប់ឆាន រួចហើយ ថ្នាក់ដឹកនាំដែលជាស្នងការនយោបាយ និងមេបញ្ជាការថ្នាក់កងវរៈសេនាតូច កងអនុសេនាធំ កងអនុសេនាតូចគឺត្រូវបានគេចាប់ខ្លួនផងដែរ។ [...] ឆ.8៖នៅពេលនោះ តា មុត បាននិយាយនៅក្នុងអង្គប្រជុំថា ទាំងអស់គ្នាត្រូវតែតាមដានពួកអតីតយោធាកង៨៦នេះ។ គាត់បាននិយាយថា ពួកអតីតកង៨៦ សុទ្ធតែខ្សែកាហ្សេបេ និងសេអ៊ីអា។ គាត់ថា ខ្សែកាហ្សេបេ និងសេអ៊ីអា មិនទាន់បានកម្ទេចបានទាំងស្រុងនៅឡើយទេ។ ពួកនេះគឺនៅលាក់ខ្លួនក្នុងជួរយើង ដូច្នេះយើងត្រូវតែតាមដានពួកនេះឲ្យជាប់។"]។ ឯកសារ D54/76 កំណត់ហេតុស្តាប់ចម្លើយរបស់ អ៊ុយ ញ៉ឹក ឆ.16 ["នៅពេលនោះ គេបានចោទសួរអតីតយោធារបស់កងតំបន់៣៧ និងភូមិភាគបូព៌ា ថាមានសមាសភាពនិន្នាការមិនល្អ។ សូម្បីតែអ្នកបញ្ជូនទៅហ្វឹកហ្វឺននៅស្រុកចិនក៏ត្រូវហៅត្រឡប់មកវិញដែរ"]។ D114/25 កំណត់ហេតុស្តាប់ចម្លើយរបស់ អ៊ូ ដាវ ហៅ សឿន ឆ.24 ["ដំបូង គេឲ្យខ្ញុំធ្វើប្រវត្តិរូប បន្ទាប់មក គេសួរខ្ញុំថា តើឯងចូលសេអ៊ីអា ពីពេលណា ពេលនោះខ្ញុំ បានសម្រេចចិត្តឆ្លើយលាក់ប្រវត្តិរូបរបស់ខ្ញុំ"]។ D54/8 កំណត់ហេតុស្តាប់ចម្លើយរបស់ ឌុល សុង ឆ.3 ["បើយោធាណាដែលមានបងប្អូននៅឯមូលដ្ឋាន "នៅស្រុកភូមិ" ត្រូវបានគេចាប់ដោយចោទថាក្បត់ យោធានោះក៏ត្រូវគេចាប់ខ្លួនពីកងដែរ"]។

ប្រវត្តិរូបរបស់ពួកគេថាតើ ពួកគេមានជាប់ពាក់ព័ន្ធស្និតរមួតជាមួយ ម៉ុម ជឹម ហៅ យ៉ាន សមាជិកគណៈកងពល ១៦៤ ដែលទើបតែត្រូវបានចាប់ខ្លួនដោយសម្ងាត់ពីទោសក្បត់ ដែរ ឬអត់[1168]។ ប្រព័ន្ធសម្រិតសម្រាំងនេះក៏អាចត្រូវបានអនុវត្តនៅកងពលមជ្ឈិមនៃកងទ័ពបដិវត្តកម្ពុជាផ្សេងទៀត តាមការណែនាំរបស់ សុន សេន[1169] ផងដែរ។

1168 ឯកសារ D54/115 កំណត់ហេតុស្តាប់ចម្លើយរបស់ យឿន នាក់ ឆ.13, 15, 18-19, 22-24 [“កាលដែលខ្ញុំធ្វើការនៅជីគោក ពេលដែលខ្ញុំនៅកងកេង ខ្ញុំធ្វើការនៅក្រោមបញ្ជារបស់ យ៉ាន។ ក្រោយមក យ៉ាន បានបាត់ខ្លួន ហើយខ្ញុំសួរអំពីការបាត់ខ្លួនរបស់យ៉ាន តែគេប្រាប់ខ្ញុំថា ឲ្យឈប់សួរអំពីឈ្មោះ យ៉ាន នេះ។ ក្រោយមក គេបញ្ជូនខ្ញុំទៅរៀននៅកំពង់សោម អ្នកដែលទៅរៀនទាំងអស់ត្រូវបានឲ្យធ្វើប្រវត្តិរូប។ គេឲ្យយើងរាយការណ៍ថា យើងបានធ្វើការនៅក្រោម យ៉ាន ដែរ ឬអត់។ តែសម្រាប់ខ្ញុំ ខ្ញុំធ្វើការនៅក្រោមកងវរៈសេនាធំមួយ តែខ្ញុំមិនស្ថិតនៅក្រោមគាត់ផ្ទាល់ទេ […]ឆ.15៖ កាលនោះ គឺជាការរៀនសូត្រដែលមានរយៈពេល៥ថ្ងៃ។ នៅក្នុងវគ្គរៀនសូត្រនោះ គេឲ្យយើងធ្វើប្រវត្តិរូប។ កម្មាភិបាលកងពល ដែលបញ្ជាឲ្យយើងធ្វើប្រវត្តិរូបនោះមាន តាញ៉ាន់ និងតាមុត […]ឆ.18៖ តាមខ្ញុំសន្និដ្ឋានគឺគេមានចេតនារកចាប់ខ្លួនអ្នកដែលជាប់ពាក់ព័ន្ធនឹង យ៉ាន […]ឆ.19៖ មានពាក្យស្លោក និយាយថា ‘ដកស្មៅ គឺដកទាំងឫស’។ ការចាប់ យ៉ាន គឺធ្វើជាសម្ងាត់ ហើយមានតែអ្នកនៅក្បែរនិងស្និទ្ធនឹង យ៉ាន ទេដែលអាចដឹង […] ឆ.22៖ នៅថ្ងៃចុងក្រោយនៃវគ្គរៀនសូត្រនោះ ពេលគឺក្នុង ម៉ោងធ្វើប្រវត្តិរូប សំណួរត្រូវបានសួរ ឲ្យអ្នកចូលរួមឆ្លើយ។ សំណួរមួយក្នុងចំណោមសំណួរទាំងនោះ គឺសួររកអ្នកដែលធ្លាប់ធ្វើការជាមួយនឹង យ៉ាន […] ឆ.23៖ ម៉ោងធ្វើប្រវត្តិរូបនៅថ្ងៃបិទវគ្គគឺ មាសមុត ជាអ្នកបង្រៀន។ គាត់បានអានសំណួរទាំងអស់ជាមួយនឹងអ្នកចូលរួម។ គាត់បានពន្យល់ដល់អ្នកចូលរួមនូវសំណួរទាំងអស់ក្នុងក្រដាសប្រវត្តិរូប និងចម្លើយដែលត្រូវឆ្លើយ […] ស៖ តាមលោកដឹង តើមានអ្នកចូលរួមណាបាត់ខ្លួនទេក្រោយពីវគ្គរៀនសូត្រនេះ? ឆ.24៖ តាមការសង្កេតរបស់ខ្ញុំ មានមនុស្សបីបួននាក់ ដែលធ្វើការផ្ទាល់ជាមួយ យ៉ាន បានបាត់ខ្លួន តែខ្ញុំមិនស្គាល់ ឈ្មោះពួកគេទេ។ អ្វីដែលខ្ញុំដឹងគឺថា បន្ទាប់ពីបាត់ខ្លួន យ៉ាន មនុស្សខ្លះដែលស្និទ្ធនឹងគាត់ ត្រូវបានបញ្ជូនទៅធ្វើការ នៅអង្គភាពផ្សេងៗទៅកំពង់សោម។ ការរៀនសូត្រ និងការធ្វើប្រវត្តិរូបគឺធ្វើឡើងដើម្បីចម្រាញ់រកអ្នកនោះ”]។ ទាក់ទងនឹងការចាប់ខ្លួន មុំ ចឹម ហៅ យ៉ាន សូមមើលខាងក្រោម កថាខណ្ឌ 347 ជើងទំព័រ 1203។

1169 ឯកសារ D1.3.27.16 កំណត់ហេតុនៃកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៧៦ លេខ ERN EN 00184340, KH 00064956, FR 00323920 [វិធានការដែលណែនាំដោយ សុន សេន៖ “២. ត្រូវតាមដានប្រវត្តិរូបកងទ័ពឲ្យច្បាស់ ហ្មត់ចត់ ពិសេសពួកយើងបញ្ចូលថ្មី ទូងស្តប្រមូល ក្រោយរំដោះទូទាំងប្រទេស។ ៣. ត្រូវតាមដាន យាមកាមផែកផេរ ឲ្យហ្មតចត់”]។ ឯកសារ D1.3.27.20 កំណត់ហេតុនៃកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ លេខ ERN EN 00940349, KH 00052410, FR 00334979 [“សមមិត្ត ឌឹម [កងពល ៣១០]៖ តែក្តាប់ប្រវត្តិរូបកម្មាភិបាលមួយចំនួនមិនទាន់ច្បាស់ មិនដឹងថាស្អាត ផានា កក់ក្តៅ ឬមិនស្អាតនៅឡើយ។ បាតុភាព មានពួកលាក់ប្រវត្តិរូប”], EN 00940354-55, KH 00052414, FR 00334982-83 [មតិយោបល់ចុងក្រោយរបស់ សុន សេន៖ “ត្រូវក្តាប់អង្គភាពឲ្យជាប់ក្នុងដៃ ក្តាប់នេះ ក្តាប់អី? ក្តាប់បក្ស ក្តាប់អង្គការស្នូល ក្តាប់យុទ្ធជន-យុទ្ធនារី ក្តាប់ប្រវត្តិរូបឲ្យច្បាស់ ក្តាប់គោលជំហរ សតិអារម្មណ៍របស់គេ ឲ្យច្បាស់ […] ២. ក្នុង

338. នៅក្នុងកងពល ១៦៤ បុគ្គលិកយោធាទាំងអស់តម្រូវឱ្យធ្វើប្រវត្តិរូបជាប្រចាំ (យ៉ាងហោចណាស់ពេលប្តូរភារកិច្ចម្តងៗ)។ ពេលធ្វើបច្ចុប្បន្នភាពរួចហើយ ប្រវត្តិរូបត្រូវបានបញ្ជូនទៅលើតាមខ្សែសង្វាក់នៃការបញ្ជាទៅទីបញ្ជាការកងពល[1170]។ ទម្រង់បែបបទ និងការណែនាំអំពីរបៀបសរសេរ

---

កងទាំងអស់ត្រូវរៀបចំឡើងវិញ ត្រូវក្តាប់ប្រវត្តិរូបទាំងអស់ឡើងវិញ"]។ ឯកសារ D1.3.27.23 កំណត់ហេតុនៃកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៧៦ លេខ ERN EN 00233712, 15, 18, KH 00095509, 12, 14, FR 00386203, 06, 08 [ក្នុងការធ្វើបច្ចុប្បន្នភាពស្ថានការណ៍ខ្មាំងនៅក្នុងកងពលរបស់ខ្លួន សមមិត្ត ពីន និងសមមិត្ត ភាព បានរៀបរាប់អំពី'ការធ្វើប្រវត្តិរូប'។ សុន សេន លើកឡើងថា 'ក្តាប់ប្រវត្តិរូប'ជាការងារដែល'ត្រូវ'ធ្វើ និងជាវិធីស្វែងរកប្រវត្តិពិតរបស់កម្មាភិបាលដែលលាក់បាំងអ្វីមួយ ហើយបានទទូចឱ្យ"ប្រយ័ត្នបំផុតអ្នកដែលឪពុកម្តាយ ត្រូវបោសសម្អាត ឬបងប្អូនត្រូវបោសសម្អាត"]។ ឯកសារ D1.3.8.4 កំណត់ហេតុនៃកិច្ចប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ (កម្មាភិបាលកងពល ១៦៤ និងសុន សេន) ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ លេខ ERN EN 00657356, KH 00162490, FR 00643499 [សុន សេន ប្រាប់ មាស មុត ឱ្យដោះស្រាយសភាពការណ៍ខ្មាំង ដោយ"ក្តាប់ប្រវត្តិរូបឱ្យច្បាស់"]។ សូមមើលផងដែរ ឯកសារ D4.1.1104 កំណត់ហេតុស្តាប់ចម្លើយរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច (សេចក្តីបញ្ជាក់នៅក្នុងឯកសារលេខ ២) លេខ ERN EN 00197741, KH 00172304 ["ឱ្យតែម៉ែទៅហើយ កូនចៅនៅមិនសូវបានយូរទេ។ មាគ៌ាបក្សតម្រូវឱ្យអ្នកទទួលខុសត្រូវ គ្រប់ជាន់ថ្នាក់យកចិត្តទុកដាក់តាមដាន អ្នកដែលមានប្រវត្តិរូបមិនល្អ ដោយមេត្រូវសំរិតសំរាំងនេះ ឱ្យបានដឹងដល់"]។

[1170] ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយរបស់ សុក វណ្ណា ឆ.35-36 ["គេឱ្យយើងធ្វើប្រវិត្តិរូបរៀងរាល់ខែ [...] ឆ.36៖ បញ្ជាឱ្យធ្វើប្រវត្តិរូបចេញមកពីកងពល ហើយគេបញ្ជាបន្តរហូតមកដល់ពួក។ ក្នុងករណីខ្ញុំ គឺមេក្រុមជាអ្នកធ្វើប្រវត្តិរូប ហើយបន្តមកទៀត មេក្រុមក៏បានយកប្រវត្តិរូបខ្ញុំឱ្យទៅមេអនុសេនាតូច បន្ទាប់មកទៅអនុសេនាធំ បន្ទាប់មកទៀតទៅវរៈសេនាតូច បន្ទាប់មកទៅវរៈសេនាធំ និងចុងក្រោយឡើងដល់កងពលវិញ"]។ ឯកសារ D114/209 កំណត់ហេតុស្តាប់ចម្លើយរបស់ ម៉ឹង សេង ឆ.40 ["ប្រវត្តិរូបគេឱ្យធ្វើរហូត ឧបមាថា មុនពេលចូលកងទ័ព គេឱ្យធ្វើរប្រវត្តិរូបនៅឆ្នាំ ១៩៧៣ ម្តង ហើយពេលចូលធ្វើនៅនាវា ប៉េ.សេ.អេហ្វ ក្រោមកងពល ១៦៤ ខ្ញុំធ្វើប្រវិត្តិរូបម្តងទៀត"]។ ឯកសារ D114/11 កំណត់ហេតុស្តាប់ចម្លើយរបស់ នាក់ យឿន ឆ.5 ["ស៖ តើការណ៍ដែលគេតម្រូវឱ្យធ្វើប្រវត្តិរូបម្តងហើយម្តងទៀត ឱ្យកងពល ១៦៤ រួមចំណែកធ្វើឱ្យមានការមិនទុកចិត្តគ្នា និងការភ័យខ្លាច ដូចលោករៀបរាប់ខាងលើដែរឬទេ? ឆ.5៖ បាទ ត្រឹមត្រូវហើយ វាពិតជារួមចំណែកដល់អារម្មណ៍មិនទុកចិត្តគ្នា និងការភ័យខ្លាចរបស់ខ្ញុំ"]។ ឯកសារ D114/25 កំណត់ហេតុស្តាប់ចម្លើយរបស់ អ៊ូវ ដារ ហៅ សឿន ឆ.16-17 ["ជាទូទៅ គេបញ្ជូននីរសាររបស់កងវរសេនាតូចមកធ្វើប្រវត្តិរូប។ ហើយបន្ទាប់ពីគេបែងចែកយោធាខ្លះ ពីកងវរសេនាតូចរបស់ខ្ញុំឱ្យចូលទៅក្នុងកងទ័ពជើងទឹក គេធ្វើប្រវត្តិរូបនៅលើកប៉ាល់ [...] ឆ.17៖ នៅពេលដែលខ្ញុំនៅលើកប៉ាល់ គេបានបញ្ជូនឯកសារប្រវត្តិរូបយកទៅឱ្យបំពេញ រួចហើយបញ្ជូនត្រឡប់ទៅវិញ"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយរបស់ សាត ចក់ ឆ.73 ["ពេលយើងផ្លាសប្តូរអង្គភាព គឺគេធ្វើប្រវិត្តិរូប"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយរបស់ សួន ផ ឆ.29 ["កាលខ្ញុំធ្វើជាយោធា គេយកម្តង ហើយនៅពេលខ្ញុំធ្វើការនៅលើកោះ គេបានយកប្រវត្តិរូបខ្ញុំម្តងពេលខ្ញុំធ្វើការនៅព្រលានយន្តហោះកងកេងគេយកម្តងទៀត និងម្តងទៀតនៅស្ទឹងហាវ"]។ ឯកសារ D114/194

ចងក្រង និងពិនិត្យប្រវត្តិរូបទាំងនេះ ត្រូវបានបញ្ជូនទៅថ្នាក់ក្រោមពីទីបញ្ជាការកងពល[1171]។ ប្រវត្តិរូបនីមួយៗមានឈ្មោះរបស់កម្មាភិបាលយោធា ឈ្មោះបដិវត្តន៍ មុខតំណែងបច្ចុប្បន្ន អាសយដ្ឋាន កាលបរិច្ឆេទចូលបដិវត្តន៍ វណ្ណៈសង្គម ទំនាក់ទំនង និងនិន្នាការនយោបាយ និងសកម្មភាពកាលពីអតីតកាល បងប្អូនបង្កើត និងបងប្អូនសាច់ថ្លៃរបស់គាត់[1172]។

---

កំណត់ហេតុស្តាប់ចម្លើយរបស់ ស៊ន សុត ឆ.27 ["គេឲ្យរៀនសូត្រទាំងអស់នៅឆ្នាំ ១៩៧៥ គេឲ្យយើងធ្វើជីវទស្សន៍ យើងត្រូវសម្តែងឲ្យច្បាស់លាស់ពីប្រវត្តិរូបរបស់យើង បើយើងនិយាយមិនពិត ក៏គេដឹងដែរ"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយរបស់ យឹម ស្រៀង ឆ.55 ["ស៖ តើគេធ្វើប្រវត្តិរូបនោះ តាំងពីពេលណាដែរ? ឆ.55៖ តាមធម្មតា បើយើងប្តូរពីអង្គភាពមួយទៅអង្គភាពមួយ គេត្រូវប្រមូលប្រវត្តិរូប ដើម្បីឲ្យគេស្គាល់ថា យើងមកពីភូមិឃុំស្រុកណាជាដើម។ ប៉ុន្តែសម្រាប់ខ្ញុំ ខ្ញុំផ្តល់ប្រវត្តិរូបតែម្តងទេ"]។

1171 ឯកសារ D114/20 កំណត់ហេតុស្តាប់ចម្លើយជាមួយ ម៉ាក ឈឿន (មេបញ្ជាការកងវរសេនាធំ ៦៣) ឆ.3, 5, 9-10 ["ខ្ញុំបញ្ជូនប្រវត្តិរូបទាំងអស់ទៅឲ្យកងវរសេនាធំ [...] ឆ.5៖ កងវរសេនាធំបញ្ជូនក្រដាសទម្រង់បែបបទ ដើម្បីឲ្យយើងបំពេញ [...] ស៖ សម្រាប់ការធ្វើប្រវត្តិរូប តើលោកត្រូវបានទទួលការហ្វឹកហ្វឺន ឬណែនាំនូវរបៀបធ្វើប្រវត្តិរូបពីថ្នាក់វរសេនាធំ ឬកងពលដែរឬទេ? ឆ.9៖ នៅក្នុងកងវរសេនាតូចនីមួយ មានបុគ្គលិកធ្វើការតាមផ្នែកផ្សេងៗ ឧទាហរណ៍ មានការិយាល័យទី ១ ទី ២ និងទី ដែលទទួលខុសត្រូវការងារផ្សេងៗគ្នា ដូចជាការងាររដ្ឋបាល ស៊ើបការណ៍ ភស្តុភារ និងផ្នែកប្រវត្តិរូប ។ល។ សម្រាប់ការធ្វើប្រវត្តិរូប យើងបញ្ជូនបុគ្គលិកជំនាញទៅជួប ធ្វើការងារជាមួយបុគ្គលិកជំនាញថ្នាក់វរសេនាធំ នៅពេលនោះបែបបទ និងការណែនាំធ្វើប្រវត្តិរូបចេញមកពីកងពល ១៦៤ ចុះមកកងវរសេនាធំ ហើយចុះមកដល់វរសេនាតូច ស៖ តើលោកដឹងអំពីរបៀបធ្វើប្រវត្តិរូប ដែលចេញមកពីកងពល ១៦៤ តាមរបៀបណា? ឆ.10៖ វាគឺជាការអនុវត្តទូទៅ របៀបដែលធ្វើប្រវត្តិរូបនេះ គឺដូចគ្នានឹងរបៀបដែលធ្វើរបាយការណ៍ប្រចាំថ្ងៃអញ្ចឹងដែរ។ របៀបធ្វើប្រវត្តិរូប គឺគេបញ្ជូនការណែនាំ និងក្រដាសបែបបទឲ្យមកបំពេញ"]។

1172 ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយរបស់ ស្វាយ សាម៉េត ឆ.37 ["ខ្លឹមសារនៅក្នុងបញ្ជីឯកសារផ្ទាល់ខ្លួនទាំងនេះមានដូចជា ឈ្មោះដើម ឈ្មោះបដិវត្ត អាយុ ភូមិ ឃុំ ស្រុក ខេត្ត ដែលជាទីកន្លែងកំណើត ថ្ងៃខែឆ្នាំកំណើត កាលបរិច្ឆេទចូលរួមបដិវត្ត ចំនួនបងប្អូន និន្នាការនយោបាយ ប៉ុន្មាននាក់ធ្វើជាទាហាននៅសម័យ លន់ នល់ មុខរបររបស់បងប្អូន អ្នកណាធ្វើអីខ្លះនៅក្នុងសម័យ សីហនុ និងវណ្ណៈរបស់បុគ្គលជាយោធានោះនៅក្នុងសម័យមុន ដូចជាអ្នកមាន ឬជាអ្នកក្រជាដើម"]។ ឯកសារ D114/25 កំណត់ហេតុស្តាប់ចម្លើយរបស់ អ៊ូវ ដាវ ហៅ សឿន ឆ.18 ["ដំបូងគេសួរខ្ញុំ ឈ្មោះឪពុកម្តាយ ស្រុកកំណើត ចូលធ្វើកងទ័ពបដិវត្តន៍នៅខែណាឆ្នាំណា មុនងារអី តើមានការពាក់ព័ន្ធជាមួយសមាសភាព ឬរបបអីដែរទេ វណ្ណៈភាពជាកសិករ កម្មករ។ ឧទាហរណ៍៖ ជាកសិករថ្នាក់ណា ទាប កណ្តាល ឬខ្ពស់ ជាដើម"]។ ឯកសារ D114/105 កំណត់ហេតុស្តាប់ចម្លើយរបស់ កុច ទុយ ឆ.75។ សម្រាប់ឧទាហរណ៍អំពីប្រវត្តិរូបក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ សូមមើល ឯកសារ D54/67.1 ប្រវត្តិរូបក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់ នង នេត ឆ្នាំ ១៩៧៦។

339. ប្រវត្តិរូបត្រូវបានពិនិត្យមើលនៅទីបញ្ជាការកងពល ១៦៤ ដោយបុគ្គលិកជំនាញមកពីគណៈកម្មការត្រួតពិនិត្យដែល **មាស មុត** បានបង្កើតឡើង[1173]។ ក្រុមអ្នកអង្កេតធ្វើការពិនិត្យព័ត៌មានដែលត្រូវបានប្រមូលពីច្រើនប្រភព ហើយបេសកកម្មចុះផ្ទាល់ដល់ទីតាំងរបស់គណៈកម្មការត្រួតពិនិត្យមានគោលបំណងកំណត់ថាតើ ទាហានមួយណាមិនស្មោះត្រង់[1174]។ ប្រសិនបើមានប្រវត្តិរូបអាក្រក់ ឬ

1173 ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយរបស់ យឹម ស្រឿង ឆ.57 ["សៈ ពេលដែលគេនិយាយថា "គេបញ្ជូនទៅថ្នាក់លើ" តើលោកដឹងថា អ្នកណាជាអ្នកពិនិត្យមើលប្រវត្តិរូបទាំងនោះដែរទេ? ឆ.57៖ កាលនោះ ខ្ញុំអាចសន្និដ្ឋានថាក្នុងមន្ទីររបស់លោក មាស មុត ជាអ្នកពិនិត្យមើលប្រវត្តិរូបទាំងនោះ"]។ ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយរបស់ ស្វាយ សាម៉េត ឆ.39, 46 ["ខ្ញុំមិនបានធ្វើការងារអ្វីពាក់ព័ន្ធនឹងឯកសារផ្ទាល់ខ្លួនទាំងនោះឡើយ។ ឯកសាររបស់យោធាម្នាក់ៗ ត្រូវបានពិនិត្យឡើងវិញដោយគណៈកម្មាការពិសេសរបស់កងពលធំ ដែលគេហៅថា "គណៈកម្មាការត្រួតពិនិត្យ" […] សៈ តើធ្វើម្តេចបានលោកដឹងថា មាស មុត ជាអ្នកបង្កើតគណៈកម្មាការនេះ? ឆ.46៖ គាត់ជាអ្នកកទទួលខុសត្រូវកងពលធំ ១៦៤ ដូច្នេះអ្វីគឺសុទ្ធតែចេញពីគាត់ទាំងអស់ គឺពុំមានអ្នកណាខ្ពស់ជាង មាស មុត ទៀតឡើយ។ ដូច្នេះគណៈកម្មាការនេះ គឺត្រូវបានបង្កើតឡើងដោយ មាស មុត"]។

1174 ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយរបស់ ស្វាយ សាម៉េត ឆ.39, 42-43 ["ខ្ញុំមិនដឹងថា មានមនុស្សប៉ុន្មាននាក់ធ្វើការនៅក្នុងគណៈកម្មាការត្រួតពិនិត្យនេះទេ ប៉ុន្តែ ខ្ញុំដឹងថា ពួកគេបានបញ្ជូនទាហាន ដែលគេទុកចិត្តទៅភូមិកំណើតរបស់យោធា ដើម្បីពិនិត្យប្រវត្តិរូបរបស់ពួកគេ។ គណៈកម្មាការនេះ បានឱ្យកងវរសេនាធំ ធ្វើការជ្រើសរើសយោធា ដែលទុកចិត្តមួយចំនួន ឱ្យចុះទៅពិនិត្យប្រវត្តិរូបនៅតាមភូមិកំណើតរបស់យោធា […] ឆ.42៖ ព័ត៌មាននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ មិនដែលប្រមូលពីមួយប្រភពឡើយ។ ព័ត៌មានតែងតែត្រូវបានគេប្រមូលពីច្រើនប្រភព តាមរយៈការធ្វើបែបនេះ គេដឹងបានយ៉ាងលឿនថា អ្នកណាស្មោះត្រង់ អ្នកណាមិនស្មោះត្រង់។ វិធីសាស្ត្របែបនេះ ក៏ត្រូវបានប្រើប្រាស់សម្រាប់ពិនិត្យប្រវត្តិរូបផងដែរ […] ឆ.43៖ ខ្ញុំត្រូវបានគេប្រាប់ថា ខ្ញុំត្រូវបានគេចុះមកពិនិត្យប្រវត្តិរូបរបស់ខ្ញុំ"]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយរបស់ ខឹម យ៉ាត ឆ.20 ["នៅប្រហែល ៦ ខែក្រោយខ្ញុំទៅដល់កំពង់សោម គេបានធ្វើប្រវត្តិរូប […] មេបញ្ជាការគេតម្រូវឱ្យយើងធ្វើប្រវត្តិរូបទាំងអស់គ្នា។ តាមខ្ញុំដឹង គេថែមទាំងបញ្ជូនមនុស្សមកតាមដានស្រាវជ្រាវប្រវត្តិរូបរបស់ពួកខ្ញុំរហូតដល់តំបន់ ២២ តាមប្រវត្តិរូបដែលយើងបានសរសេរ"]។ ឯកសារ D114/209 កំណត់ហេតុស្តាប់ចម្លើយរបស់ ម៉ឹង សេង ឆ.42 ["ប្រសិនមិនបានសព្វគ្រប់ទេ ពេលគេស៊ើបដឹងប្រវត្តិរូបនៅឯផ្ទះឃើញថាមិនពិត នោះគេនឹងបញ្ជូនឱ្យទៅធ្វើស្រែវិញ ហើយដកពីកប៉ាល់ទៅហើយ"]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយរបស់ ឌុល សុង ឆ.17 ["ចំពោះការសម្រិតសម្រាំង នៅក្នុងករណីរូបខ្ញុំផ្ទាល់ គេបានបញ្ជូនអ្នកស៊ើបអង្កេតទៅភូមិកំណើតរបស់ខ្ញុំ ដើម្បីផ្ទៀងផ្ទាត់ថា ត្រឹមត្រូវ ឬមានបងប្អូនធ្វើការក្នុងរបបមុនៗដែរឬអត់"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយរបស់ គឹម ម៉េន ឆ.120 ["ដំបូង គេឱ្យយើងបំពេញព័ត៌មានដូចជាភូមិស្រុក ម៉ែឪ គ្រួសារ បងប្អូន រួចហើយគេសម្ភាសយើង ដូចជា លោកកំពុងសម្ភាសខ្ញុំដែរ។ រួចហើយ គេយកព័ត៌មាននោះទៅផ្ទៀងនៅស្រុកកំណើតរបស់យើង ក្រែងលោយើងនិយាយមិនពិត"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយរបស់ សាត ចក់ ឆ.73-74 ["នៅក្នុងប្រវត្តិរូប គឺគេស្រាវជ្រាវរកវណ្ណៈ ភាពស្មោះត្រង់ ដោយគេទៅស្រាវជ្រាវរហូតដល់ផ្ទះ ដើម្បីដឹងថា តើប្រវត្តិរូបរបស់យើង វាពិត ឬក៏អត់ […] ឆ.74៖

លាក់ព័ត៌មានក្នុងប្រវត្តិរូប ទាហាននោះនឹងត្រូវបានដកហូតអាវុធ ហើយបន្ទាប់មក បង្ខំឲ្យធ្វើការ (កសាង) ឬឃុំឃាំងនៅមន្ទីរអប់រំ ឬមន្ទីរសន្តិសុខរបស់កងពល។ នៅមន្ទីរទាំងនោះ ទាហានត្រូវបានបង្ខំឲ្យធ្វើការ និងសម្លាប់ជារឿយៗ[1175]។

---

ជិនាទ់ហ្នឹង មិនហ៊ានលាក់បាំងគេទេ បើកាលណាលាក់បាំងហើយ គេស្រាវជ្រាវដឹង គឺយើងនឹងមានទោសហើយ"]។ ឯកសារ D114/83 កំណត់ហេតុស្ដាប់ចម្លើយរបស់ សុខ នាង ឆ.34 ["អ៊ំរបស់ខ្ញុំម្នាក់ធ្លាប់ធ្វើជាទាហាន លន់ នល់ [...] ប៉ុន្តែសំណាងល្អ គេពុំបានដឹងថា ខ្ញុំជាប់សាច់ញាតិនឹងគាត់ទេ។ ខ្ញុំកាន់តែបារម្ភខ្លាំងនៅចន្លោះឆ្នាំ ១៩៧៧-១៩៧៨ ដោយសារគេបានឲ្យខ្ញុំធ្វើប្រវត្តិរូប ហើយយកទៅស្រាវជ្រាវដល់ភូមិកំណើតរបស់ខ្ញុំតែម្ដង"]។ ឯកសារ D114/48 កំណត់ហេតុស្ដាប់ចម្លើយរបស់ សុខ ង៉ុន ឆ.17 ["ខ្ញុំមិនដឹងថា អ្នកណាជាអ្នកធ្វើការសម្រិតសម្រាំងនោះទេ ខ្ញុំគ្រាន់តែដឹងថា ពេលនោះ គេបញ្ជូនមនុស្សឲ្យទៅស្រាវជ្រាវប្រវត្តិយើងនៅតាមស្រុកកំណើត ជាមួយគ្រួសាររបស់យើង"]។ ឯកសារ D114/16 កំណត់ហេតុស្ដាប់ចម្លើយរបស់ សុក វណ្ណា ឆ.34-35 ["គេឲ្យយើងធ្វើប្រវត្តិរូប ហើយគេចុះទៅតាមភូមិកំណើតរបស់យើង ដើម្បីផ្ទៀងផ្ទាត់ថាត្រឹមត្រូវដូចដែលយើងបានសរសេរនៅក្នុងប្រវត្តិរូបដែរឬអត់ [...] ឆ. 35៖ គេឲ្យយើងធ្វើប្រវត្តិរូបរាល់ខែ ហើយគេយកប្រវត្តិរូបរបស់យកមកផ្ទៀងផ្ទាត់ជាមួយស្រុកកំណើតរបស់យើង"]។ ឯកសារ D54/93 កំណត់ហេតុស្ដាប់ចម្លើយរបស់ យ៉ែម សំអុន ឆ.20-21 ["នៅពេលដែលគេជ្រើសខ្ញុំទៅធ្វើការ គឺគេបានទៅសួរប្រវត្តិរូបរបស់ខ្ញុំនៅស្រុកកំណើត [...] ឆ.21៖ ប្រពន្ធខ្ញុំប្រាប់ថា មានអ្នកមកសួរ និងតាមដានប្រវត្តិរូបរបស់ខ្ញុំ [...] គេក៏បានសួរអ្នកផ្សេងទៀតនៅក្នុងភូមិអំពីប្រវត្តិរូបរបស់ខ្ញុំផងដែរ"]។

1175 ឯកសារ D114/186 កំណត់ហេតុស្ដាប់ចម្លើយរបស់ សាត ចក់ ឆ.165 [នៅវាលស្រែកងកេង "ប្រភេទទី ២ ពាក់ព័ន្ធនឹងសមាសភាព មានប្រវត្តិមិនល្អ អនុធន ឬអ្នកមានគេយកមកដាក់ឲ្យធ្វើស្រែនៅហ្នឹង"]។ ឯកសារ D54/100 ស្ដាប់ចម្លើយរបស់ ឡាយ បុនហាក់ ឆ.101-102 [សាក្សីត្រូវបានគេដកពីដំណែងនៅក្នុងកងវរសេនាធំ ១៤០ នៅក្នុងចុងខែមិថុនា ឆ្នាំ ១៩៧៨ ហើយត្រូវបានគេបង្ខំឲ្យធ្វើការ និងមានការភិតភ័យ ដោយសារប្អូនប្រុសថ្លៃរបស់គាត់ គឺត្រូវបានចាប់ខ្លួន នៅមន្ទីរពេទ្យកងពលធំ ១៦៤ ហើយត្រូវបានគេរកឃើញថា មានជាប់ពាក់ព័ន្ធនឹងគ្នា]។ ឯកសារ D114/16 កំណត់ហេតុស្ដាប់ចម្លើយរបស់ សុក វណ្ណា ឆ.21, 34-35 ["អំឡុងពេលខ្ញុំធ្វើការនៅលើកោះ ខ្ញុំឃើញគេហៅអ្នកធ្វើការជាមួយខ្ញុំទៅច្រើនដង ដោយសារគេចោទថា ជាប់សមាសភាពមិនល្អ និងថាត្រូវបញ្ជូនទៅធ្វើការនៅកងកេង ដូចប្រជាជនធម្មតា [...] ឆ.34៖ បើសិនជាគ្រួសារ ឬបងប្អូនយើងមានជាប់ពាក់ព័ន្ធអ្វីមិនល្អចំពោះអង្គការ យើងដែលជាយោធា គឺត្រូវគេដកចេញពីមុខតំណែង និងមានបញ្ហាផងដែរ [...] ឆ.35៖ គេយកប្រវត្តិរូបរបស់យើងមកផ្ទៀងផ្ទាត់នៅតាមស្រុកកំណើតរបស់យើង។ ប្រសិនបើគេរកឃើញថា ឪពុកម្ដាយយើងមានជាប់ក្នុងសកម្មភាពអ្វីមួយដែលមិនល្អដល់អង្គការ គេនឹងទៅដកយើងចេញពីជួរយោធាហើយ"]។ ឯកសារ D114/194 កំណត់ហេតុស្ដាប់ចម្លើយរបស់ ស៊ិន សុត ឆ.27-29, 36-37, 39-40, 48, 66, 68 ["គេឲ្យរៀនសូត្រទាំងអស់នៅឆ្នាំ ១៩៧៥ គេឲ្យយើងធ្វើជីវទស្សន៍ យើងត្រូវសម្ដែងឲ្យច្បាស់លាស់ពីប្រវត្តិរូបរបស់យើង បើយើងនិយាយមិនពិត ក៏គេដឹងដែរ [...] ពេលរៀនចប់ក្នុងរយៈពេល ៣ ថ្ងៃនោះ គេចាប់ផ្ដើមហៅយើងទៅតម្រង់ជួរ មានអាវុធយកអាវុធ មានឆ្នាំងចាន យកឆ្នាំងចាន ហើយវាប្រាប់យើងថា អាវុធអាកា ដាក់តាមអាកា អឹមសី ដាក់តាមអឹមសី។ ហើយក៏វាវ៉ៃសាយយើងចេញទៅ [...] ឆ.28៖ គឺកើតឡើងនៅរាម [...] ឆ.29៖ នៅវត្តរាមចាស់ [...] សៈ យើងភ្លេចសួរលោកអំពីចំនួនយោធាត្រូវបានដកអាវុធ និង

រំសាយនៅវត្តរាមនោះ។ តើលោកនាំចាំថា មានយោធាប៉ុន្មាននាក់ដែរឬទេ? ឆ.36៖ គឺច្រើន គឺចូល១កងវរសេនាតូច [...] ឆ.37៖ គឺ៣០០នាក់ជាង [...] ឆ.39៖ [ទឹកសាប] ជាកន្លែងសម្រាប់ដាក់អ្នកទោស ដាក់ពួកខ្ញុំ អ្នកធ្វើស្រែជាមួយខ្ញុំពេលដែលធ្វើខុស គេយកដាក់នៅហ្នឹង។ ហើយអ្នកធំៗ គេមិនយកទៅដាក់នៅហ្នឹងទេ គឺគេយកទៅដាក់កន្លែងផ្សេង [...] ឆ.40៖ គេប្រជុំប្រាប់ថា "មិត្តឯងប្រយ័ត្នណា តែមិត្តឯងធ្វើខុស គេបញ្ជូនទៅទឹកសាបហើយ" [...] ឆ.48៖ចាប់ម្នាក់ដែលធ្វើការជាមួយខ្ញុំមានឈ្មោះថា ណើង គេចាប់យកទៅ។ គាត់កំពុងភ្ជួរស្រែដោយគោស្រាប់តែគាត់បានវ៉ៃគោ១ក្បាលដល់ស្លាប់ [...] ឆ.66៖ ពេលគ្នាហូបអត់ឆ្អែត ពេលគ្នាលួចដកដំឡូង គេក៏ចាប់គ្នាចងបញ្ជូនទៅទឹកសាបបាត់ទៅ។ គាត់នោះឈ្មោះដែលគេហៅតៗគ្នាថា ឡក់តក់ៗ [...] ឆ.68៖ គេមិនមែនថា យើងទ័ព ឬយោធាទេ គេចាត់ទុកយើងជាប្រជាជន គឺក្រោមប្រជាជនទៀត ព្រោះយើងជាប់និន្នាការ"]។ ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយរបស់ ស្វាយ សាម៉េត ឆ.4-5, 16-17, 37-38 ["ស៖ លោកបាននិយាយថា ពួកគេអាចដឹងយ៉ាងលឿនថា នរណាម្នាក់និយាយពិត ឬក៏ភូតភរនៅក្នុងប្រវត្តិរូបរបស់ពួកគេ។ មានអ្វីកើតឡើង ប្រសិនបើពួកគេរកឃើញថា នរណាម្នាក់និយាយភូតភរ? ឆ.4៖ អ្នកនឹងត្រូវបានគេដកចេញពីតួនាទីរបស់អ្នក ហើយអ្នកនឹងត្រូវគេយកទៅកសាង។ ប្រសសិនបើអ្នកកែខ្លួន អ្នកអាចត្រឡប់មកវិញ បើមិនដូច្នេះទេ អ្នកនឹងបាត់ខ្លួនជាមិនខាន ស៖ តើពាក្យថា បាត់ខ្លួន នេះមានន័យដូចម្តេច? ឆ.5៖ ខ្ញុំមិនដឹងថា គេយកពួកគេទៅណាឡើយ។ ពាក្យថា បាត់ខ្លួន នេះ មានន័យថា បាត់ខ្លួនជារៀងរហូតមិនត្រឡប់មកវិញឡើយ។ ប៉ុន្តែវាមិនបានកើតឡើងចំពោះមនុស្សច្រើននាក់ឡើយ។ មនុស្សមួយចំនួនត្រូវបានគេយកទៅកសាង ហើយមួយចំនួនបាត់ខ្លួនរហូត [...] ស៖ តើលោកអាចប្រាប់ខ្ញុំពីឈ្មោះអ្នកដែលលោកចាំថា បានបាត់ខ្លួនរហូតដែរទេ? ឆ.16៖ ជុំ, ញូន, ហ៊ីង, នន និង បាន [...] នេះជាមនុស្ស ៥ នាក់ ដែលត្រូវបានដកចេញ [...]តាមពិតមានមនុស្សជាច្រើននាក់ផ្សេងទៀត ដែលត្រូវបានគេដកចេញ ប៉ុន្តែខ្ញុំមិនចាំឈ្មោះពួកគេឡើយ។ ជុំ និង ញូន មានឋានៈខ្ពស់ជាងខ្ញុំ ពួកគេជាអ្នកកធ្វើការងារនៅស្រែ។ នៅពេលដែលខ្ញុំត្រូវបានបញ្ជូនទៅធ្វើការស្រែនៅទីនោះ ពួកគេត្រូវបានគេបញ្ជូនចេញទៅកន្លែងផ្សេង។ ជុំ និងញូន គឺជាបញ្ជាការកងវរសេនាតូច [...] ញូន ត្រូវបានគេបញ្ជូនចេញទៅកោះមួយ [...] ជុំ ត្រូវបានគេបញ្ជូនទៅកោះតាង ប៉ុន្តែនៅពេលដែលខ្ញុំត្រូវបានគេបញ្ជូនទៅកោះតាងដែរ ខ្ញុំមិនបានឃើញ ជុំ ទៀតឡើយ។ ញូន ត្រូវបានគេបញ្ជូនទៅកោះព្រីង។ ញូន ក៏បាត់ខ្លួនរហូតដែរ។ ពាក្យថា "បាត់ខ្លួន" នេះ មានន័យថា ខ្ញុំមិនដែលឃើញពួកគេម្តងទៀតឡើយរហូតមកដល់សព្វថ្ងៃនេះ [...] ឆ.17៖ នៅចុងឆ្នាំ ១៩៧៦ ឬដើមឆ្នាំ ១៩៧៧ [...] ឆ.37៖ ប្រសិនបើពួកគេមានជាប់និន្នាការ ពួកគេនឹងលែងទទួលការជឿទុកចិត្តទៀត [...] បើសិនបើអ្នកមកពី វណ្ណៈកសិករថ្នាក់កណ្តាល ហើយជាប់ពាក់ព័ន្ធនឹងនិន្នាការ នល់ នល់ ប្រព្រឹត្តកំហុសអ្វីមួយ ពួកគេនឹងត្រូវបានយកទៅកសាង។ ប្រសិនបើពួកគេមិនកែខ្លួននោះទេ ពួកគេនឹងត្រូវយកទៅសម្លាប់ចោល។ ស៖ តើគណៈកម្មការត្រួតពិនិត្យរបស់កងពលធ្វើដូចម្តេច ប្រសិនបើនៅក្នុងដំណើរការត្រួតពិនិត្យគេរកឃើញថា មនុស្សម្នាក់ស្ថិតនៅក្នុងវណ្ណៈមូលធន ឬ ឥស្សរជន? ឆ.38៖ មនុស្សនេះនឹងបាត់ខ្លួន។ ឧទាហរណ៍ ប្រសិនបើមនុស្សម្នាក់មានចំណេះដឹងខ្ពស់ ហើយធ្វើជាមិនដឹងអី មិនយូរទេ គាត់ប្រាកដនឹងបាត់ខ្លួន"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយរបស់ យឹម ស្រៀង ឆ.60, 63 ["ស៖ តើអ្នកដែលមានប្រវត្តិរូបអាក្រក់ តើគេធ្វើអ្វីចំពោះអ្នកទាំងនោះ? ឆ.60៖ គេនិយាយថា គេយកតែអ្នកអាក្រក់ទៅទេ បើគេយកទៅណា ក៏យើងមិនដឹងដែរ ព្រោះពេលនោះ គ្មានអ្នកណាហ៊ានសួរអ្វីទេ [...] ស៖ នៅពេលដែលគេហៅអ្នកណាម្នាក់ទៅនោះ តើលោកធ្លាប់ឃើញអ្នកនោះម្តងទៀតដែរទេ? ឆ.63៖ អត់ដែរឃើញទេ"]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយរបស់ ប្រេស មាន ឆ.13

340. ការវិភាគប្រវត្តិរូបមិនត្រឹមត្រូវតែជាឧបករណ៍ដែល **មាស មុត** បានប្រើ ដើម្បីកំណត់អត្តសញ្ញាណខ្មាំងដែល "បង្កប់នៅក្នុងជួរ" ប៉ុណ្ណោះនោះទេ គាត់ថែមទាំងបញ្ជាឲ្យកម្មាភិបាលកងពល ១៦៤ ទាំងអស់ស្វែងរកខ្មាំងទាំងនោះយ៉ាងសកម្ម និងរាយការណ៍ពីសកម្មភាពរបស់ពួកគេ[1176]។ ដោយហេតុថា ការបោសសម្អាតត្រូវបានធ្វើឡើង នៅក្នុងកងពល ១៦៤ អារម្មណ៍ភ័យខ្លាចជាទូទៅបានរីកសាយភាយនៅក្នុងជួរកងទ័ពទាំងមូល។ ម្នាក់ៗភ័យខ្លាចថាតើ ខ្លួនជាអ្នកបន្ទាប់ដែលត្រូវដកចេញ ឬសម្លាប់ចោល[1177]។ ភាពភ័យខ្លាចជាអចិន្ត្រៃយ៍ត្រូវបានបង្ហាញឲ្យឃើញយ៉ាងច្បាស់នៅក្នុងសម្តីរបស់ពេទ្យកងពល ១៦៤ ម្នាក់ឈ្មោះ វ៉េត ដែលបាននិយាយផ្តែផ្តាំមិត្តរបស់គាត់ឈ្មោះ

---

[1176] ឯកសារ D54/17 កំណត់ហេតុស្តាប់ចម្លើយរបស់ សយ ប៊ន ឆ.11-12 ["សៈ តើលោក មាស មុត បាននិយាយអំពីជនក្បត់នៅក្នុងវគ្គនីមួយៗដែរទេ? ឆ.11៖ បាទ, គាត់បាននិយាយថា យើងត្រូវពិនិត្យមើលសកម្មភាពខ្មាំងនៅក្នុងជួររបស់យើង។ សៈ តើពាក្យថា "ឲ្យពិនិត្យមើលសកម្មភាពខ្មាំងក្នុងជួរ" មានន័យដូចម្តេច? ឆ.12៖ មានន័យថា ការណែនាំរបស់ មាស មុត ឲ្យសិក្ខាកាមពិនិត្យមើល និងរាយការណ៍ទៅថ្នាក់លើអំពីសកម្មភាពទាំងនោះ ប្រសិនបើមាន"]។

[1177] ឯកសារ D114/284 កំណត់ហេតុស្តាប់ចម្លើយរបស់ ឯក នី ឆ.8-9 ["យើងឈឺចាប់ណាស់ ព្រោះអាបោសសម្អាតផ្ទៃក្នុង ធ្វើឲ្យខ្ញុំដេកមិនលក់ ព្រលឹងចុងសក់។ បោសម្អាតផ្ទៃក្នុង ខ្សែរយៈ។ គ្រាន់តែសម្លាប់គ្នាឯង ក្នុងកងពល ១៦៤ មាន ៦០០ នាក់ក្នុងបញ្ជី ហើយអ្នកអត់មានឈ្មោះក្នុងបញ្ជីហ្នឹងច្រើនទៀត អត់ឃើញ ដែលខ្ញុំស្គាល់ ហើយត្រូវបានសម្លាប់។ សាហាវណាស់។ សៈ អម្បាញ់មិញ លោកនិយាយថា ដោយសារគោលនយោបាយហ្នឹង ធ្វើឲ្យមិត្តភក្តិលោក និងលោក មាសការភ័យខ្លាចខ្លាំង? ឆ.9៖ បាទ"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយរបស់ ប៉ាង វ៉េត ឆ.52 ["សៈ ហេតុអ្វីបានជាអត់មានអ្នកណាហ៊ានសួរអំពីការបាត់ខ្លួនមនុស្ស? ឆ.52៖ នៅសម័យនោះ គឺមានការភ័យខ្លាចថា យើងមានការពាក់ព័ន្ធជាមួយមនុស្សដែលបាត់ខ្លួនទាំងនោះ"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយរបស់ អ៊ុយ ញ៉ិក ឆ.37-38 ["សេចក្តីភ័យខ្លាចរបស់ខ្ញុំ គឺមិនអាចពិពណ៌នាបានទេ។ ខ្ញុំរស់នៅក្នុងភាពតក់ស្លុត និងភ័យខ្លាចជារៀងរាល់ថ្ងៃ។ ខ្ញុំស្ទើរតែមិនជឿថា ខ្ញុំមានជីវិតរស់ដល់សព្វថ្ងៃនេះទេ [...] ឆ.38៖ យើងត្រូវបានគេប្រព្រឹត្តមកលើដូចសត្វមាន់ ទាអ៊ីចឹង។ ប្រសិនបើគេមិនចូលចិត្តយើង គេដកយើងទៅហើយបាត់តែម្តង។ សម្បីតែបងប្អូនយើងក៏មិនហ៊ានសួរនាំអំពីស្ថានភាពរបស់យើងដែរ"]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយរបស់ ជេត ប៊ុណ្ណា ឆ.5 ["ពួកយើងពុំមានព្រួយបារម្ភទេ មុនការប្រកាសអំពីការចាប់ខ្លួន ឌឹម និង ឆាន ដោយសារតែពួកយើងជាយោធាដែលមានសិទ្ធិពេញលេញ។ ពួកយើងមានកាំភ្លើងប្រើ ពួកយើងអាចទៅណាមកណាបាន។ ប៉ុន្តែក្រោយពីការប្រកាសអំពីការបាត់ខ្លួន ឌឹម និង ឆាន និងការចាប់ខ្លួនមេវសេនាតូច និងវរសេនាធំ ដូចជា តាហាម និង តាវ៉េត មកទៀត ពួកខ្ញុំជាច្រើននាក់កាន់តែភិតភ័យខ្លាំង ដោយសារថា យើងមិនដឹងថា គេមកចាប់យើងនៅពេលណានោះទេ"]។

សំ សោម នៅពេលគាត់ត្រូវបានបញ្ជូនទៅរៀនសូត្រនៅកំពង់សោម៖ "បើមិនបានជួបខ្ញុំទៀតទេ សូមមិត្តឯងប្រាប់ឪពុកម្ដាយ បងប្អូនខ្ញុំថា គេសម្លាប់ខ្ញុំចោលហើយ"[1178]។

## ៣. ប្រភេទនៃសមាសភាពអាក្រក់ និងជាប់និន្នាការនៅក្នុងកងពល ១៦៤ ដែលត្រូវបានបោសសម្អាត

341. ប្រភេទផ្សេងៗនៃ "សមាសភាពអាក្រក់" ដែលត្រូវបាន **មាស មុត** បោសសម្អាត នៅក្នុងកងពល ៣/១៦៤ ឬនៅក្នុងអង្គភាពយោធាក្រោមបញ្ជារបស់គាត់មានរៀបរាប់នៅខាងក្រោម៖

*ក) ទាហានកងពលលេខ ៣ ដែលត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅវៀតណាមនៅឆ្នាំ ១៩៧៥*

342. ទាហាន និងកម្មាភិបាលកងពលលេខ ៣ នៃកងទ័ពបដិវត្តន៍កម្ពុជា ចន្លោះពី ៣០០ ទៅ ៧២០ នាក់ (ភាគច្រើនមកពីកងវរសេនាតូច ៣១០, ៤១០ និង ៤២០) ត្រូវបានកងទ័ពវៀតណាមចាប់ខ្លួននៅកោះក្រចកសេះ[1179] កោះពូលូវៃថ្មី និងពូលូវៃចាស់ និងនៅសមុទ្រជុំវិញកោះទាំងនោះ នៅចុងខែឧសភា ឬដើមខែ មិថុនា ឆ្នាំ ១៩៧៥។ ទាហានទាំងនោះត្រូវបានវៀតណាមឃុំខ្លួនអស់រយៈពេលពីរបីខែជាឈ្លើយសឹក នៅលើកោះត្រល់ (កោះភូគុកជាភាសាវៀតណាម)[1180]។ ពេលពួកគេត្រូវ

---

[1178] ឯកសារ D54/20 កំណត់ហេតុស្ដាប់ចម្លើយរបស់ សំ សោម ឆ.12 ["ខ្ញុំបាននៅឯណោះឆ្ងាយ ប៉ុន្តែបានឮថាពីគេថា កាលណាគេចាប់មនុស្ស ឬមានអ្នកបាត់ខ្លួន គេយកអ្នកកទាំងនោះទៅដាក់នៅក្នុងគុកទឹកសាប់នោះ ដែលជាគុកថ្នាក់តំបន់ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ មាស មុត [...] នៅពេលនោះ ខ្ញុំបានដឹងថា គេដាក់អ្នកទោសខ្លះបណ្ដោះអាសន្ននៅទីនោះ មុននឹងគេបញ្ជូនទៅភ្នំពេញ។ ខ្ញុំពិបាកនិយាយណាស់ ពីព្រោះសម័យនោះអ្នកណាក៏មានសិទ្ធិចាប់ និងសម្លាប់មនុស្សពាសវាលពាសកាលដែរ។ ខ្ញុំក៏មានការភ័យខ្លាចគេចាប់យកទៅសម្លាប់ដែរ [...] ដូចជាករណីអង្គការមកពីហៅមិត្តជិតស្និទ្ធរបស់ខ្ញុំម្នាក់ជាពេទ្យឈ្មោះ រ៉េន ក្នុងអង្គភាពខ្ញុំ ហៅគាត់ទៅរៀនសូត្រនៅកំពង់សោម គាត់បាននិយាយផ្ដែផ្ដាំខ្ញុំថា "បើមិនបានជួបខ្ញុំទៀតទេ សូមមិត្តឯងប្រាប់ឪពុកម្ដាយបងប្អូនខ្ញុំថា គេសម្លាប់ខ្ញុំចោលហើយ"។ មូលហេតុដែលគាត់និយាយបែបនេះមកខ្ញុំ គឺដោយសារគាត់សង្កេតឃើញថា ជនរងគ្រោះភាគច្រើន ដែលគេបញ្ជូនទៅទីនោះ មិនដែលវិលត្រឡប់មកវិញទេ"]។

[1179] ក៏ហៅថា ពូលូបុាំងសង់ (កោះពូលូតង់សង់) ជាភាសាខ្មែរ និងតូជូ ឬក៏ថូជូ ជាភាសាវៀតណាម។ កោះនេះត្រូវកងទ័ពជើងទឹកខ្មែរវាយប្រហារជាលើកដំបូង នៅថ្ងៃទី ១០ ខែឧសភា ឆ្នាំ ១៩៧៥ និងត្រូវវៀតណាមដណ្ដើមយកវិញនៅចុងខែ ឧសភា ឆ្នាំ ១៩៧៥។ សូមមើល ឯកសារ D1.3.17.5 ណាយ៉ាន់ ចាន់ដា សត្រូវបងប្អូន KH ERN 00191318 និងកថាខណ្ឌ ៣០៨ ខាងលើ។

[1180] ឯកសារ D114/79 កំណត់ហេតុស្ដាប់ចម្លើយរបស់ កង ស៊ុំ ឆ.121, 126, 148-153, 156-163, 229 [យោធាកងវរសេនាតូច ៣១០ ពន្យល់របៀបដែល យោធាប្រហែល ៣០០ នាក់ពីកងវរសេនាតូចរបស់គាត់ រួមទាំងខ្លួនគាត់ រងការ

វាយប្រហារនៅកោះក្រចកសេះ (កោះពូលូវៃ តង់សង់) នៅពាក់កណ្ដាលឆ្នាំ ១៩៧៥ ហើយគេចងដៃ និងភ្នែក បញ្ជូនទៅកោះត្រល់ ជាកន្លែងដែលគាត់ជាប់ឃុំ និងធ្វើការអស់រយៈពេល ៣ ខែ ក្នុងនាមជាឈ្លើយសឹក]។ ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយរបស់ លុន សេង ឆ.15 ["ជាការវៃកោះពូលូវៃ។ នៅថ្ងៃមួយ តាមខ្ញុំចាំ កងទ័ពយួនបានជិះកប៉ាល់ P-111 ដែលមានកងទ័ពប្រហែល ៣០០ ទៅ ៤០០ នាក់ ហើយឈប់នៅកោះពូលូវៃ ហើយនៅពេលជាមួយគ្នានោះ កងទ័ពយួនមួយចំនួនទៀតបានហែលទឹកពីគ្រប់ទិសនៅជុំវិញកោះហ្នឹង ដើម្បីវៃយើងដោយមិនដឹងខ្លួន។ ពេលនោះ ទ័ពយួនក៏បានចាប់យោធារបស់កងវរសេនាតូច ៣១០ ទាំងអស់ ហើយបញ្ជូនទៅទុកលើកោះត្រល់។ កងទ័ពយួននៅពេលនោះ បានចាប់ទាំងទូកល្បាតរបស់យើង ហើយនិងពួកយោធា និងពេទ្យមកពីកំពង់សោម ដែលមកជួយអន្តរាគមន៍ផង"]។ ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយរបស់ ឯក នី ឆ.4["ពួកយោធាខ្មែរក្រហមទាំងនោះត្រូវបានចាប់ដោយវៀតណាម នៅលើកោះពូលូលៃ្វ ប៉ុន្តែក្រោយមកត្រូវបានដោះលែងឲ្យត្រឡប់មកកម្ពុជាវិញ។ វៀតណាមបានដោះលែងពួកយោធាទាំងនោះនៅសេះស ខេត្តកំពត។ តាមខ្ញុំចាំ នៅពេលនោះ កងទ័ពវៀតណាមបានប្រយុទ្ធ ហើយនិងកាន់កាប់កោះពូលូលៃ្វទាំងពីរនោះបានបីខែ"]។ ឯកសារ D114/261 កំណត់ហេតុស្តាប់ចម្លើយរបស់ ជុំ ជី ឆ.2 [ពន្យល់លម្អិតអំពីកាលៈទេសៈនៃការវាយប្រហាររបស់កងកម្លាំង វៀតណាម នៅលើកោះពូលូវៃ នៅខែមិថុនា ជាការវាយប្រហារដ៏ខ្លាំងក្លា និងការចាប់យោធាកម្ពុជាប្រជាធិបតេយ្យ- កងវរសេនាតូច ៣៨៦, ៤២០- ការឃុំខ្លួនពួកគេនៅលើកោះត្រល់ និងការដោះលែងវិញប៉ុន្មានខែក្រោយបន្ទាប់ពីការចចារគ្នា]។ ឯកសារ D114/263 កំណត់ហេតុស្តាប់ចម្លើយរបស់ ជុំ ជី ឆ.15, 50 [បញ្ជាក់ថា បន្ទាប់ពីការចាប់ខ្លួនពួកគាត់នៅលើកោះពូលូវៃ នៅខែមិថុនា ឆ្នាំ ១៩៧៥ សាក្សីនេះ និងសមាជិកកងកងវរសេនាតូច ៤២០ របស់គាត់ ត្រូវគេយកទៅទុកនៅកោះត្រល់ ជាកន្លែងដែលពួកគាត់នៅជាមួយយោធាកម្ពុជាប្រជាធិបតេយ្យជាង ២០០ នាក់ផ្សេងទៀត ដែលចាប់ខ្លួនបាននៅកោះក្រចកសេះពីរបីថ្ងៃមុនពេលគេចាប់ខ្លួនពួកគាត់]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយរបស់ ព្រុំ សារ៉ាត់ ឆ. 144 ["កងទ័ពទៅល្បាតនៅកោះប៉ូឡូប៉ាំងសង់ [កោះក្រចកសេះ] [...] កងទ័ពវៀតណាមវៃកោះទាំងបីគឺ កោះប៉ូឡូប៉ាំងសង់ [...] កោះពូលូវៃចាស់ និងពូលូវៃថ្មី [...] វៃចាប់កងទ័ពដែលនៅវៃនៅទីនោះ ៧០០ នាក់ យកទៅដាក់នៅកោះត្រល់"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយរបស់ អ៊ុយ ញ៉ិក ឆ.8 ["សៈ តើយោធានៅក្នុងកងណាដែលត្រូវបានវៀតណាមចាប់ពីកោះបូលូវៃ? ឆ.8៖ មានយោធាជាច្រើនមកពីកងផ្សេងៗ រួមទាំងយោធាខ្លះមកបីកងវរសេនាតូចលេខ ៣៨៦ ផងដែរ"]។ សាក្សី ជេត ប៊ុណ្ណា និង ប៉ាង រ៉េត និយាយអំពីកងវរសេនាតូច ៤១០ មិនមែន ៣១០ ទេ៖ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយរបស់ ជេត ប៊ុណ្ណា ឆ.36 ["ពីដំបូង យើងទៅវាយយកកាន់កាប់កោះក្រចកសេះ។ បន្ទាប់មក វៀតណាមក៏វាយយើងកាន់កាប់កោះពូលូវៃ។ ក្រោយមកទៀត វៀតណាមក៏វាយយើង កាន់កាប់កោះពូលូវៃ និងកោះក្រចកសេះឡើងវិញ។ កងដែលទៅវាយនៅទីនោះ មានកងវរសេនាតូច ៤១០ និង ៤២០ របស់កងពលលេខ ៣។ វរសេនាតូចទាំងពីរនេះ មានមេបញ្ជាការឈ្មោះ ទន និង រឿន។ ទន ជាមេបញ្ជាការកងវរៈ ៤២០ ហើយ រឿន ជាមេបញ្ជាការវរៈ ៤១០"]។ ឯកសារ D114/287 កំណត់ហេតុស្តាប់ចម្លើយរបស់ ប៉ាង រ៉េត ឆ. 17, 42-43 ["ពេលដែលវៀតណាមខាងជើងរំដោះខាងត្បូង គេបញ្ជូនទ័ពទៅវៃដណ្ដើមកោះក្រចកសេះ និងកោះពូលូវៃពីយើង ទ័ពមួយចំនួនពីអង្គភាពខ្ញុំ ត្រូវបានគេបញ្ជូនទៅជួយ ហើយទីបំផុតដោយសារយើងមានកម្រិត កប៉ាល់តូចពេក វៀតណាមគេមានកម្រិតកប៉ាល់ធំ ហើយច្រើនជាងយើង គេវៃផ្ដាច់ច្រកស្បៀងយើង ហើយវៃចូលកោះក្រចកសេះ និងចាប់ពួកយើងជាឈ្លើយយកទៅកោះត្រល់ [...] សៈ តើវាជារឿងត្រឹមត្រូវឬ ដែលលោកបាននិយាយថា យោធាដែល

បានដោះលែង និងត្រឡប់ទៅកំពង់សោមវិញ ពួកគេត្រូវបានថ្នាក់ដឹកនាំកងពល ៣/១៦៤ មិនទុកចិត្ត ដោយសង្ស័យថា ពួកគេត្រូវបានវៀតណាមបញ្ចូលមនោគមវិជ្ជា។ ទាហានដែលត្រូវបាន

នៅលើកោះ ហើយនិងយោធាដែលបញ្ជូនទៅធ្វើអន្តរាគមន៍ ត្រូវបានពួកវៀតណាមចាប់ក្នុងពេលនោះ? ឆ.42៖ វាកំពុងតែវ៉ៃទាំងកោះក្រចកសេះ និងពូលូវៃ បន្ទាប់ពីអន្តរាគមន៍ត្រូវបានបញ្ជូនទៅ បានពួកវៀតណាមវ៉ៃយកកម្លាំងទាំងអន្តរាគមន៍ហ្នឹង ហើយចាប់យកទៅកោះត្រល់ [...] ឆ.43៖ ពេលនោះ មានជម្រើសច្រើនកងចម្រុះ តែជាស្នូលមានកងវរសេនាតូច ៤១០ តែដល់ក្រោយមកមិនដឹងដាក់លេខប៉ុន្មាន តែពេលនោះជាកងវរសេនាតូច ៤១០ ហើយក៏មានកង ៤៥០ មួយផ្នែកទៅដែរ"]។ សូមមើលផងដែរ ឯកសារ D54/74.1.15 ខៀវ សំផន ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ KH ERN 00103858 ។ ឯកសារ D98/1.2.11 ណាយ៉ាន់ ចាន់ដា ប្រតិចារឹក ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៩ ម៉ោង 09.33.15-09.37.10, 13.43.59-13.48.02, 13.55.51-14.01.19។ ឯកសារ D1.3.17.5 ណាយ៉ាន់ ចាន់ដា សត្រូវបងប្អូន KH ERN 00191318 ["ដោយយកមកប្រើឡើងវិញនូវការទាមទារមុនមួយរបស់កម្ពុជាទាក់ទងនឹងកោះភូកុក ខ្មែរហៅកោះត្រល់ ខ្មែរក្រហមបានវាយលុកតាមផ្លូវសមុទ្រចូលត្រួតត្រាលើកោះនោះយ៉ាងរហ័ស។ កងទ័ពទាំងនោះបានឡើងទៅលើកោះនៅថ្ងៃទី ៤ ខែឧសភា ឆ្នាំ ១៩៧៥។ ប្រាំមួយថ្ងៃក្រោយមក ខ្មែរក្រហមបានវាយយកកោះពូលូប៉ែងហ្សង់ វៀតណាមហៅ ថូជូ ខ្មែរហៅកោះក្រចកសេះថែមទៀត។ ក្រោមការគំរាមកំហែងអាវុធ ប្រជាជនវៀតណាម ៥០០ នាក់ ត្រូវបានបណ្តេញចេញពីទីនោះ។ ពីរសប្តាហ៍ក្រោយពីការកាន់កាប់របស់ខ្មែរក្រហម វៀតណាមបានបើកការវាយបកមួយសងទៅវិញ ដោយបានសម្លាប់ខ្មែរក្រហមអស់ជាច្រើននាក់ និងចាប់បាន ៣០០ នាក់ជាឈ្លើយសឹក"]។ ឯកសារ D234/2.1.93 ព្រុំ សារ៉ាត់ ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ 11.09.00-11.13.43 ["ពេលនោះមានការប្រយុទ្ធរវាងកងទ័ព និងកងទ័ពកម្ពុជាប្រជាធិបតេយ្យនៅតាមកោះ។ ហើយកងទ័ពវៀតណាមបានចាប់យកកងទ័ពកម្ពុជាប្រជាធិបតេយ្យចំនួន ៧២០ នាក់ ទៅដាក់មន្ទីរឃុំឃាំងជាឈ្លើយសឹកនៅកោះត្រល់ "], 11.13.43-11.19.34។ ឯកសារ D114/27.1 កាសែតញ៉ូវយ៉កថែមស៍ វៀតណាមនិយាយថា នឹងដណ្តើមកោះពីកម្ពុជា ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ១៩៧៥ EN ERN 00165960-61។ ឯកសារ D1.3.12.21 អង្គហេតុ និងឯកសារស្តីអំពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងររបស់កម្ពុជាប្រជាធិបតេយ្យ ទៅលើអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ខែ មករា ឆ្នាំ ១៩៧៨ KH 00283136 ["ការរំលោភបំពានមកលើទឹកដីវៀតណាម ដែលភាគីកម្ពុជាបានប្រព្រឹត្តិនៅដើមខែឧសភា ឆ្នាំ ១៩៧៥ នៅពេលដែលភាគីកម្ពុជាបានចេញបញ្ជាឲ្យកងកម្លាំងប្រដាប់អាវុធរបស់ខ្លួនចូលចតលើកោះហ្វូកុក ហើយបើកការវាយប្រហារកោះថូជូ"] KH ERN 00283136 ["នៅក្នុងអំឡុងថ្ងៃទី ១០ ខែសីហា ឆ្នាំ១៩៧៥ កិច្ចប្រជុំថ្នាក់កំពូលដើម្បីដោះស្រាយផលវិបាកនៃឧប្បត្តិហេតុទាំងអស់នេះ ភាគីកម្ពុជាខ្លួនឯងបាននិយាយថា ការខ្វះការយល់ដឹងទៅលើផែនទីភូមិសាស្ត្រជាប្រភពនៃការឈ្លានពានទាំងអស់នេះ"] KH ERN 00283136 ["ភាគីវៀតណាមបានដោះស្រាយឧប្បត្តិហេតុនេះ ក្នុងស្មារតីប្រកបដោយភាតរភាពរវាងសមមិត្ត និងសមមិត្ត៖ បានប្រគល់ឲ្យទៅភាគីកម្ពុជាវិញនូវមនុស្សទាំងឡាយដែលជាកងម្លាំងប្រដាប់អាវុធកម្ពុជា និងដែលត្រូវបានចាប់ខ្លួនក្នុងពេលមានការប៉ះទង្គិចនោះ"]។

គេដោះលែងទាំងនោះ មិនត្រូវបានបញ្ចូលក្នុងអង្គភាពវិញទេ និងត្រូវបានបោសសម្អាត[1181] ភាគច្រើនត្រូវបានបង្ខំឱ្យធ្វើការក្រោមការឃ្លាំមើលតឹងរ៉ឹង និងលក្ខខណ្ឌដ៏លំបាក ក្នុងកងចល័ត នៅឃុំកងកេង និងឃុំរាម ឬនៅស្ទឹងហាវ[1182] ដោយមេរបស់ពួកគេត្រូវបានចោទពីទោសក្បត់ និងបានបាត់

[1181] ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយរបស់ កង ស៊ុំ ឆ.164-165, 229 ["ស៖ ពេលដែលលោកត្រឡប់មកដល់ខេត្តកំពង់សោមវិញ តើមានរឿងអ្វីកើតឡើង? ឆ.164៖ គេលែងទុកចិត្តយើងហើយ [...] ឆ.165៖ គេថា យើងមកពីស្រុកយួន គេខ្លាចយួនហ្នឹង អប់រំយើងទៅ ចូលជាភ្នាក់ងារ កា.សេ.បេ ឬក៏ចូលជាភ្នាក់ងាររបស់វៀតណាមអស់ហើយ [...] ឆ.229៖ ក្រោយមក គេលែងទុកចិត្តយើងទៀត។ ពួកគេចោទយើងថាជា កា.សេ.បេ ឬ សេ.អ៊ី.អា របស់យួន។ ក្រោយមក ពួកគេបានបញ្ជូនពួកខ្ញុំទាំងអស់គ្នា ទៅធ្វើការនៅកន្លែងវែថ្មនៅអូរម្លូ"]។ ឯកសារ D114/260 កំណត់ហេតុស្តាប់ចម្លើយរបស់ ស៊ិន សុត ឆ.36-37 ["ហ្នឹង តាជី វ៉ៃផ្ទាល់ កងគាត់។ វ៉ៃផ្ទាល់ ចាប់ទៅលែងមកវិញ ខ្មែរក្រហមធ្វើបាបគាត់ ដកគាត់ចេញមយយកងហ្នឹង រំសាយអស់ទៀត។ គេចាប់ឈ្លើយសឹកដល់គេលែងទៅវិញ ដកអស់រលីង អត់ឱ្យធ្វើសឹក។ គេខ្លាចវៀតណាមបំពាក់បំប៉នផ្នែកនយោបាយ បានគេដកចេញ [...] គេដកហ្នឹង ខាងប្រធានកង មានអ្នកណាដក ក្រៅពី តាមុត ហ្នឹង ប្រធានកងពលនៅហ្នឹង"]។

[1182] ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយរបស់ ស៊ិន សុត ឆ.73 ["[កងវរសេនាតូច ៣១០ គឺ] កងទ័ព តាមុត [...] វ៉ៃហ្នឹង នៅកោះពូលូវ៉ៃ ដែលពួកវៀតណាមទៅវ៉ៃកងទ័ព តាម៉ុក ហ្នឹងណា មិនមែនកោះត្រល់ទេ ដល់ពេលវៀតណាមចាប់បាន ទើបបញ្ជូនទៅកោះត្រល់។ ហើយបញ្ជូនទៅកោះត្រល់ហើយ ទើបបញ្ជូនមកវិញតាមកែប ហើយបានបញ្ជូនមកកន្លែងខ្ញុំធ្វើស្រែទាំងអស់ ដោយសារគេខ្លាចថា ពួកវៀតណាមបំពាក់នយោបាយអី គេមិនឱ្យធ្វើទ័ពវិញទេ"]។ ឯកសារ D114/260 កំណត់ហេតុស្តាប់ចម្លើយរបស់ ស៊ិន សុត ឆ.36-37 ["ហ្នឹង តាជី វ៉ៃផ្ទាល់ កងគាត់។ វ៉ៃផ្ទាល់ ចាប់ទៅលែងមកវិញ ខ្មែរក្រហមធ្វើបាបគាត់ ដកគាត់ចេញមយយកងហ្នឹង រំសាយអស់ទៀត។ គេចាប់ឈ្លើយសឹកដល់គេលែងទៅវិញ ដកអស់រលីង អត់ឱ្យធ្វើសឹក។ គេខ្លាចវៀតណាមបំពាក់បំប៉នផ្នែកនយោបាយ បានគេដកចេញ [...] គេដកហ្នឹង ខាងប្រធានកង មានអ្នកណាដក ក្រៅពី តាមុត ហ្នឹង ប្រធានកងពលនៅហ្នឹង"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយរបស់ កង ស៊ុំ ឆ.164-167, 174, 229 ["ស៖ ពេលដែលលោកត្រឡប់មកដល់ខេត្តកំពង់សោមវិញ តើមានរឿងអ្វីកើតឡើង? ឆ.164៖ គេលែងទុកចិត្តយើងហើយ [...] ឆ.165៖គេថា យើងមកពីស្រុកយួន គេខ្លាចយួនហ្នឹងអប់រំយើងទៅ ចូលជាភ្នាក់ងារ ការ.សេ.បេ ឬក៏ចូលជាភ្នាក់ងាររបស់វៀតណាមអស់ [...] ឆ.166៖ គេដកឱ្យមកវ៉ៃថ្ម ៧ ម៉ែត្រគូបក្នុងមួយថ្ងៃនៅអូរម្លូ នៅជិតចំការដូងចេងហេង [...] ឆ.174៖ ទៅទាំងអស់គ្នា។ គេដកតួនាទីអស់ហើយ។ អត់មានអ្នកណាមេអ្នកកូនទេ។ សិទ្ធិស្មើគ្នាតែម្តង [...] ឆ.229៖ ក្នុងមួយថ្ងៃ គេឱ្យយើងវ៉ៃថ្មម្នាក់ឱ្យបាន ៧ ម៉ែត្រគូប។ តាញ៉ាន់ គឺជាអ្នកចេញបញ្ជាឱ្យយើងវ៉ៃថ្មឱ្យបាន ៧ ម៉ែត្រគូបនេះ។ តាញ៉ាន់ គឺជាអនុកងពល ១៦៤ ជាអ្នកក្តាប់ខាងភស្តុភារ។ ពួកយើងទាំងអស់គ្នាត្រូវបានគេដកចេញពីតួនាទី។ ពុំមាននរណាធ្វើជាមេកង ឬអ្វីនោះឡើយ។ យើងទាំងអស់គ្នា គឺស្មើគ្នា"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយរបស់ សាត ចក់ ឆ.111, 113, 119-120 ["ពេលវៀតណាមមកវ៉ៃ គឺវ៉ៃនៅកោះពូលូវ៉ៃ ដោយវាថា កោះនេះ ជាកោះរបស់វា [...] រឿងនេះ វាពិតហើយថា វៀតណាមចាប់មនុស្សពីអង្គភាពរបស់ខ្ញុំ [កងវរសេនាតូច ៣១០] យកទៅ ប៉ុន្តែបើថាឱ្យដឹងរឿងអីផ្សេងពីហ្នឹង ខ្ញុំអត់ដឹងទេ។ ពេលដែលគេបញ្ជូនត្រឡប់មកវិញ គឺបានដឹង។ ពេលគេបញ្ជូនមកវិញ អ្នកដែលគេបញ្ជូនមក ក៏

បានមកនៅក្នុងអង្គភាពខ្ញុំវិញដែរ ប៉ុន្តែអង្គភាពគេមិនឲ្យអ្នកដែលគេចាប់យកទៅមកនៅផ្តុំគ្នាវិញទេ ឧទាហរណ៍ថា ដាក់ទីនេះ ២ នាក់ ទីនោះ ២ នាក់អ៊ីចឹងទៅ។ [...] ដល់ពេលគេពង្រាយអ៊ីចឹងហើយ អ្នកដែលគេចាប់ទៅ គេបានដក ចេញពីអង្គភាពហ្នឹងអស់ គឺឲ្យមកនៅកងផលិត ឲ្យមកធ្វើស្រែនៅម្តុំកងកេង [...] គេថាពួកគាត់ជាអ្នកដែលមានប្រវត្តិ ដែលទៅនៅវៀតណាម [...] ឆ.113៖ កងកេងជាឈ្មោះព្រលានយន្តហោះ គេយកអ្នកដែលមានសមាសភាពមិនល្អ ទៅធ្វើស្រែនៅទីហ្នឹង [...] ឆ.119៖ គេចាប់ពង្រាយ គឺគេមកពីវៀតណាមហើយ គេចូលសាលានយោបាយហើយ [...] ក្រោយមកគេយកមកបញ្ចូលក្នុងអង្គភាព ប៉ុន្តែនៅក្នុងវរសេនាតូចដដែលទេ តែគេមិនដាក់ឲ្យពួកគាត់នៅជាមួយគ្នាទេ ក្នុងមួយក្រុមគេដាក់ ១ មួយកងដាក់ ១ ឬ ២ អ៊ីចឹងទៅ [...] ឆ.120៖ ជំនាន់ហ្នឹងដូចចូលឆ្នាំ ១៩៧៦ [...] ឆ. 121៖ ពេលហ្នឹង គេស្រាវជ្រាវប្រវត្តិរូប ដោយគេឲ្យធ្វើប្រវត្តិរូប ដែលប្រវត្តិរូបគឺសំខាន់ណាស់។ គេមិនដកម្តងទាំងអស់ទេ គឺដកម្តងមួយៗ។ អ្នកដែលសកម្មនឹងការងារ មានសីលធម៌ល្អ ក៏នៅបានយូរអ៊ីចឹងទៅ"]។ ឯកសារ D114/85 កំណត់ហេតុស្តាប់ចម្លើយរបស់ ជេត ប៊ុណ្ណា ឆ.4-5 ["ក្រោយត្រឡប់មកវិញ [ពីកោះត្រល់ / កោះភូកុក] ពួកខ្មែរក្រហមបានសង្ស័យនឹងពួកគេចំពោះអ្វីដែលបានកើតឡើង ចំពោះយោធាទាំងនោះក្នុងអំឡុងពេលដែលជាប់ឃុំខ្លួននៅប្រទេសវៀតណាម។ ពួកខ្មែរក្រហមមានការសង្ស័យចំពោះពួកគេ ហើយបានឲ្យពួកគេឆ្លងកាត់ការរៀនសូត្របន្ថែមទៀត [...] អ្វីដែលពួកវៀតណាមផ្តោតសំខាន់ គឺបង្រៀនឈ្លើយសឹកខ្មែរក្រហមទាំងនោះឲ្យចងចាំថា កោះត្រល់គឺជារបស់ប្រទេសវៀតណាម មិនមែនជារបស់ប្រទេសកម្ពុជាទៀតទេ [...] ឆ.5៖ [...] គេចាត់ទុកអ្នកទាំងនោះជាមនុស្សគួរឲ្យសង្ស័យ ឬសមាសភាពមិនល្អ។ ដូច្នេះហើយ យោធាទាំងនោះ ខ្លះត្រូវបានគេបញ្ចូលនៅក្នុងកងអនុសេនាធំ គេហៅថា កងអនុសេនាធំសមាសភាពមិនល្អ ដែលខ្ញុំ និងយោធាមកពីអង្គភាពផ្សេងៗទៀត ក៏ស្ថិតនៅក្នុងនោះដែរ។ ពួកយើងត្រូវបានគេចាត់ទុកថា ជាអ្នកទោសហើយ គឺគ្រាន់តែមិនឃុំឃាំង តែឲ្យទៅលត់ដំ"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយរបស់ ប្រាក់ សុខា ឆ.2, 4-5, 11, 28 ["គេបានប្រជុំប្រាប់ខ្ញុំ និងយោធាដទៃទៀតថា ខ្ញុំ ហើយ និងយោធាទាំងនោះ ត្រូវផ្លាស់ពីកងហើយ បញ្ជូនទៅនៅកងចល័តព្រែកចាក ដោយសារអង្គការចាត់យើងថា គឺជាពួកមានសមាសភាពមិនល្អ ហើយត្រូវបញ្ជូនទៅលត់ដំ។ នៅក្នុងចល័តនោះ ក៏មានអតីតយោធាវរសេនាតូច ៣១០ ដែលបានទៅវ៉ៃនៅកោះត្រល់ ហើយត្រូវវៀតណាមចាប់បានកាលពីពេលនោះ បន្ទាប់ពីពួកគេត្រូវបានបញ្ជូនត្រឡប់ពីវៀតណាមមកវិញ ពួកគេត្រូវបានបញ្ជូនទៅក្នុងកងចល័តនោះ។ នៅក្នុងកងចល័តនោះ ក៏មានពួកអតីតយោធាភូមិភាគបូព៌ា ក៏ត្រូវបានបញ្ជូនទៅក្នុងកងចល័តជាមួយខ្ញុំដែរ។ ពួកយោធាភូមិភាគបូព៌ា ត្រូវបានគេចាត់ថា ជាពួកក្បត់ [...] សៈ តើមានមនុស្សចំនួនប៉ុន្មាននាក់ នៅក្នុងកងចល័តកាលក្នុងរយៈពេលនោះ? ឆ.4៖ គឺពីរវរសេនាតូចពេញ [...] សៈ តើពេលខ្លះ គេមានដោះលែងមនុស្សពីក្នុងកងនោះ ហើយបញ្ជូនមកធ្វើការក្នុងកងពល ១៦៤ វិញដែរឬទេ? ឆ.5៖ គ្មានទេ។ អ្នកណាក៏ដោយ ដែលបញ្ជូនចូលក្នុងកងនោះ គឺមិនត្រូវបានដោះលែងទេ។ [...] ឆ.11៖ ពួកបូព៌ាមានចំនួន ៥០-៦០នាក់, ប្រជាជន ១៧ មេសា ៣០-៤០នាក់ និងខ្មែរកម្ពុជាក្រោម មានប្រហែល ១០-២០ នាក់ ក្រៅពីនេះ សុទ្ធតែពួកកងវរសេនាតូច ៣១០ ទាំងអស់ និងអតីតយោធាបញ្ជូនមកពីកងដទៃទៀត [...] ឆ.28៖ [នៅស្ទឹងហាវ] គេមិនបានចាត់ទុកយើងជាអតីតយោធា ឬជាមនុស្សទេ គេចាត់យើងថា ជាមនុស្សដែលត្រូវលត់ដំ គេចាត់ទុកយើង និងប្រព្រឹត្តមកលើយើងថា ជាទាសករ"]។ ចំណុចផ្ទុយគ្នា៖ ដោយនិយាយខុសពីកម្លាំងកងវរសេនាតូច ៣១០ លោក ជុំ ជី ជាយុទ្ធជនកងវរសេនាតូច ៤២០ បានអះអាងថា គាត់ត្រឡប់មកអង្គភាពវិញពីរបីថ្ងៃ បន្ទាប់គេដោះលែងគាត់ពីកោះត្រល់ ហើយបានឈរជើងនៅកោះតាង។ ប៉ុន្តែ គាត់មិនបាននិយាយថា មានអ្វីកើតឡើងចំពោះអ្នកធ្វើការជាមួយគាត់

ខ្លួន[1183]។ ដោយសារគេលែងទុកចិត្តលើពួកគេតទៅទៀត គ្រាន់តែប្រព្រឹត្តកំហុសតូចតាច នៅពេលធ្វើការ
ជារឿយៗ ពួកគេត្រូវបានចាប់ខ្លួន និងឃុំឃាំងនៅមន្ទីរសន្តិសុខទឹកសាប[1184]។

*ខ) ទាហានរត់ចោលជួរ/អ្នកចុះចូលជាមួយខ្មាំង (ក្នុងរបបទាំងមូល)*

343. ទាហានកងពល ១៦៤ ដែលរត់ចោលជួរ ឬចុះចូលជាមួយខ្មាំង ត្រូវបានទាហានរបស់ **មាស មុត** ចាប់ខ្លួនជាប្រចាំនៅក្នុងរបបទាំងមូល[1185]។ អ្នកដែលត្រូវបានចាប់ខ្លួនទាំងនោះត្រូវគេចាត់ទុកជាជនក្បត់ និងត្រូវគេសម្លាប់ចោលភ្លាមៗ ឬនៅពេលក្រោយ[1186]។

---

ទេ ហើយក៏មិនបានផ្តល់ព័ត៌មានលម្អិតអំពីការវិលត្រឡប់របស់គាត់ និងការងារគាត់នៅកោះតាងដែរនៅពេលដែលអ្នកស៊ើបអង្កេតសួរគាត់នៅក្នុងការស្តាប់ចម្លើយគាត់ទាំងប្រាំមួយដង៖ ៖ ឯកសារ D114/261 កំណត់ហេតុស្តាប់ចម្លើយរបស់ ជុំ ជី ឆ.6 ["ពីឆ្នាំ ១៩៧៥ គេលែងមក គេបញ្ជូនខ្ញុំកងទ័ព បញ្ជូនមកកោះតាង កោះដដែល ជាវរសេនាតូច ៤២០ ដដែល"]។ ចំពោះភាពយ៉ាប់យឺនក្នុងការរស់នៅ និងការងារនៅការដ្ឋាន ទាំងនោះ សូមមើលផងដែរ VIII.ច. ការដ្ឋានតំបន់រាម និង VIII.ង. ការដ្ឋានស្ទឹងហាវ។

1183 ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយរបស់ សាត ចក់ ឆ.116 ["ស៖ កងពល ៣១០ ដែលត្រូវបានចាប់ខ្លួន ហើយលែងមកវិញ តើមេបញ្ជាការ មេបញ្ជាការរងរបស់កងពលយ៉ាងម៉េច? ឆ.116៖ មិនមែនកងពលទេ ជាកងវរសេនាតូច ៣១០។ មេបញ្ជាការកងវរៈកាលហ្នឹង គាត់មិនបានទៅនៅហ្នឹងទេ មានតែមេបញ្ជាការអនុសេនាតូច អនុសេនាធំប៉ុណ្ណោះ ដែលនៅទីនោះ [...] បានបាត់មេបញ្ជាការឈ្មោះហម ដោយគេចោទថាក្បត់។ រឿងមេបញ្ជាការក្រោយៗ ចេះតែឡើងបន្តបន្ទាប់ទៅ អ្នកខ្លះក៏បាត់ទៅ អ្នកខ្លះក៏ឡើងទៅកាន់នៅឯណាៗទៅ"]។

1184 ឯកសារ D114/85 កំណត់ហេតុស្តាប់ចម្លើយរបស់ ជេត ប៊ុណ្ណា ឆ.5 ["គេចាត់ទុកអ្នកទាំងនោះ [យោធាដែលវៀតណាមគេដោះលែងពីកោះត្រល់] ជាមនុស្សគួរឱ្យសង្ស័យ ឬសមាសភាពមិនល្អ។ ដូច្នេះហើយយោធាទាំងនោះ ខ្លះត្រូវបានគេដាក់បញ្ចូលទៅក្នុងអនុសេនាធំ គេហៅថា កងអនុសេនាធំ សមាសភាពមិនល្អ [...] ពួកយើងត្រូវបានគេចាត់ទុកថា ជាអ្នកទោសហើយ គឺគ្រាន់តែមិនឃុំឃាំង តែឱ្យយើងទៅលត់ដំ។ ប្រសិនបើគេពុំពេញចិត្តនឹងការងាររបស់យើង គឺគេនឹងបញ្ជូនយើងទៅទីសាបភ្លាមតែម្តង។ ចង់មានន័យថា ប្រសិនបើគេមិនពេញចិត្តនឹងឥរិយាបថយើង ការធ្វើការងាររបស់យើង ឬក៏យើងត្អូញត្អែរអំពីការងារអ្វីមួយនោះ គឺគេនឹងបញ្ជូនទៅទឹកសាបភ្លាមតែម្តង [...] គេយកពួកយើងមកដាក់នៅមួយកន្លែង ដើម្បីត្រួតពិនិត្យ តាមដាន និងលត់ដំ។ និយាយទៅ គេប្រព្រឹត្តិចំពោះយើង អាក្រក់ជាងប្រជាជន ១៧ មេសាទៅទៀត[...] ពួកគេបានត្រួត ពិនិត្យពួកយើងយ៉ាងយកចិត្តទុកដាក់ ដូច្នេះបើសិនជាយើងមានកំហុសតិចតួចក៏ដោយ គេនឹងយកយើងទៅដាក់ទោសភ្លាមតែម្តង"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយរបស់ កង ស៊ុំ ឆ.328 ["ស៖ បើសិនគេសង្ស័យថា លោកជាគិញវៀតណាម ហេតុអ្វីបានជាគេទុកឱ្យលោកនៅរស់? ឆ.328៖ គេទុកឱ្យខ្ញុំនៅរស់ តែគេតាមដានខ្ញុំ។ បើសិនជាខ្ញុំធ្វើអីខុស គេនឹងចោទខ្ញុំពេញតែម្តង។ តែខ្ញុំដឹងខ្លួនមុន ហើយខ្ញុំបានពង្រឹងខ្លួនខ្ញុំ"]។

1185 ឯកសារ D22.2.4 របាការណ៍ស្ថិតិរបស់គណៈកងពលធំលេខ ១៦៤ បញ្ជីក្តាប់កម្លាំងប្រចាំថ្ងៃរបស់អង្គភាព ១៦៤ ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ១៩៧៦ EN ERN 00950655 KH ERN 00160118 [នៅក្រោមផ្នែក "បាត់មុខពីអង្គភាព" បញ្ជាក់ថា មនុស្ស ៦ នាក់បាន "រត់" គឺម្នាក់មកពីកងវរសេនាធំ ៦១ និង ៥ នាក់ មកពីកងវរសេនាតូច ១៦៥]។ ឯកសារ D22.2.5 របាការណ៍ស្ថិតិរបស់គណៈកងពលធំលេខ ១៦៤ បញ្ជីក្តាប់កម្លាំងប្រចាំថ្ងៃរបស់អង្គភាព ១៦៤ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៦ EN ERN 00950657, KH ERN 00160123 [នៅក្រោមផ្នែក "បាត់មុខពីអង្គភាព" សរសេរថា មនុស្ស ៣ បាន"រត់"៖ ពីរនាក់មកពីកងវរសេនាធំ ៦១ និងម្នាក់មកពីកងវរសេនាតូច ១៦៨]។ ឯកសារ D1.3.5.3 របាយការណ៍ស្ថិតិរបស់ មាស មុត បញ្ជីក្តាប់កម្លាំងប្រចាំថ្ងៃរបស់អង្គភាព ១៦៤ ថ្ងៃទី ២៧ ខែតុលា ឆ្នាំ EN ERN 00233989, KH ERN 00160147 [នៅក្រោមផ្នែក "បាត់មុខពីអង្គភាព" យោធា ៣ នាក់មកពីកងវរសេនាធំ ១៤០ ត្រូវគេរាយការណ៍បាន "រត់"] (សូមមើលផងដែរ ឯកសារ D54/24.2 របាយការណ៍ស្ថិតិរបស់ មាស មុត បញ្ជីក្តាប់កម្លាំងប្រចាំថ្ងៃរបស់អង្គភាព ១៦៤ ថ្ងៃទី ២៧ ខែតុលា ឆ្នាំ ១៩៧៦ EN ERN 01145323, KH ERN 00955521)។ ឯកសារ D1.3.34.11 ទូរសារ ១១ ពី ឌីម (កងពលធំលេខ ១៦៤) ជូន មាស មុត ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ EN ERN 00233660, KH ERN 00000863, FR ERN 00654897 ["សភាពដីគោកនៅឃុំរៀម និងបឹបុស ពីយើងមានវិធានការចំពោះខ្មាំងមួយដែលបងសំរេច វាមានរត់ចូលព្រៃ ៥ នាក់ ឥឡូវយើងតាមចាប់បានទាំងអស់"], EN ERN 00143522, KH ERN 00000863, FR ERN 00654897 ["ពីរនាក់ (យុទ្ធជន) ទៀត រត់អង្គភាពសង្ហារ យុទ្ធជននេះ នឹងដូរពីកង ៦៣"]។ ឯកសារ D1.3.8.4 កំណត់ហេតុនៃការប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ (សមមិត្តមកពីកងពលធំលេខ ១៦៤ និង សុន សេន) ថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ ១៩៧៦ EN ERN 00657355-56, KH ERN 00162489-90 [ពិភាក្សាអំពីជោគវាសនារបស់យោធា ៤០ នាក់ ដឹកនាំដោយ វង់ ស្រុល នៅសង្ហារ ដែលមានបំណងរត់ចេញ]។

1186 ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយរបស់ អ៊ឹម សុខន ឆ.77 ["ពួកគ្នាខ្ញុំមួយក្រុមហ្នឹង ខ្លះក៏រត់រួច ខ្លះក៏គេសម្លាប់ចោល។ រត់បំបែកគ្នាជាក្រុមៗចូលព្រៃ គេតាមបាញ់សម្លាប់មែន"]។ ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយរបស់ ឯក នី ឆ.6 [ពន្យល់ថា បន្ទាប់ពីសារ៉ាត់ ប្រធានកងវរសេនាតូច ត្រូវគេចាប់ខ្លួនបាន ហើយ យោធាបីនាក់មកពីកងវរសេនាតូចរបស់គាត់ យកកាំភ្លើងរត់ចូលព្រៃ ដោយសារថាពួកគេដឹងថា ពួកគេនឹងអាចត្រូវចាប់ខ្លួន។ ចុងក្រោយ យោធាទាំងបីនោះ (អាន, ឡាយ និង នី) គឺត្រូវកងកម្លាំងអង្គភាពពិសេសរបស់ មាស មុត សម្លាប់ មិនមែនមិនបានតដ៏ទេ]។ ឯកសារ D54/101 កំណត់ហេតុស្តាប់ចម្លើយរបស់ ឯក នី ឆ.10 ["នៅក្នុងពេលនោះ ថ្នាក់ដឹកនាំកងពល គេបានដកពួកអតីតយោធារបស់កងវរសេនាតូច ៣៨៦ ចេញពីកោះ និងកន្លែងផ្សេងៗ រួចបញ្ជូនយកទៅដាក់នៅក្នុងកងផលិត។ ពេលនោះ ខ្ញុំបានឮថាយោធា ដែលត្រូវបានដកចេញ ហើយយកទៅដាក់នៅកងផលិត ជាមួយខ្ញុំនិយាយថា បងរ៉ែម ដែលជាអតីតមេបញ្ជាការកងវរៈសេនាតូច ៣៨៦ ត្រូវបានគេបាញ់សម្លាប់នៅមុខវត្តឥន្ទញ្ញាណ។ មុនដំបូងគេបញ្ជាឲ្យគាត់លើកដៃ ប៉ុន្តែគាត់បានប្រឆាំងតបនឹងគេ ដោយបានដាល់ពួកយោធាដែលជាអ្នកបញ្ជាឲ្យគាត់លើកដៃនោះ។ យោធាទាំងនោះ គឺមកពីកងពិសេសរបស់ តាមុត។ ពួកនោះ គឺដូចជាកងអង្គរក្សរបស់ តាមុត ឬក៏ហៅថាកងដៃស្តាំរបស់គាត់។ បន្ទាប់ពីដាល់ពួកយោធានោះហើយ រ៉ែម បានលោតចុះពីលើឡាន ហើយពួកយោធាបានបាញ់ចំក្បាលរបស់គាត់ ហើយគាត់ដួលស្លាប់នៅលើថ្នល់នៅមុខវត្តឥន្ទញ្ញាណនោះតែម្តង"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយរបស់ សុខ នាង ឆ.34 ["ឈ្មោះ នន [...] ហាក់បីដូចជាអ្នកគ្រប់គ្រង ឬកាន់កាប់

### *ត) ទាហានដែល "ជាប់ពាក់ព័ន្ធ" ជាមួយនឹងរបបសាធារណរដ្ឋខ្មែរចាស់*

344. ស្របតាមគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ[1187] **មាស មុត** បានខិតខំគ្រប់បែបយ៉ាងដើម្បីកំណត់អត្តសញ្ញាណទាហានកងពល ៣/១៦៤ ដែលមានទំនាក់ទំនងជាមួយរបប លន់ នល់។

---

នៅគុកទឹកសាប។ ដោយសារគាត់មានសាច់ញាតិធ្លាប់ធ្វើការនៅក្នុងសម័យ លន់ នល់ ដែរ គាត់ក៏មានការបារម្ភដូចខ្ញុំដែរ។ គាត់ប្រាប់ខ្ញុំថា ប្រសិនបើគេមកចាប់គាត់ គឺគាត់មិនឱ្យចាប់ទេ គាត់សុខចិត្តរត់ ហើយឱ្យគេបាញ់ចុះ [...] ខ្ញុំបានដឹងថា មុនវៀតណាមចូលប្រហែល ១ ខែ គេបានមករកចាប់គាត់មែន តែគាត់បានរត់ ហើយគេបាញ់គាត់សម្លាប់តែម្តងទៅ"]។ ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយរបស់ នង នេត ឆ.33 [ពន្យល់ថា ការរត់ចេញពីការដ្ឋានស្ទឹងហាវ គឺមិនអាចទៅរួចបានទេ ដោយសារពួកគេមិនមានអ្វីហូប ហើយគេនឹងសម្លាប់ចោលប្រសិនបើចាប់បាន]។ សូមមើលផងដែរ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.116 [អតីតទាហានកងវរសេនាតូច ៣៨៦ ត្រូវបានគេបញ្ជូនទៅធ្វើការនៅព្រែកចាក ជិតរាម៖ "មិនងាយមានអ្នកណាអាចរត់ចេញពីការដ្ឋានព្រែកចាកបានឡើយ គឺតឹងរ៉ឹងខ្លាំងណាស់"]។ ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយរបស់ ស៊ិន សុត ឆ.78 ["ខ្ញុំរត់មុនគេ ហើយខ្ញុំប្រុងចុះចូលជាមួយវៀតណាម ដោយបែកការ ខ្មែរក្រហមថា បើខ្ញុំចុះចូលជាមួយវៀតណាម គេនឹងបាញ់ខ្ញុំចោល"]។ ឯកសារ D114/47 កំណត់ហេតុស្តាប់ចម្លើយរបស់ តើ រី ឆ.84 ["តើគេមានពិភាក្សាគ្នាអំពីខ្មាំងដែរឬទេ នៅក្នុងកិច្ចប្រជុំនោះ? ឆ.84៖ គេប្រាប់ថា កុំឱ្យចូលដៃជាមួយយខ្មាំង កុំចាញ់ការលួមលោម និងចុះចូលជាមួយខ្មាំង"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយរបស់ សួន ផ ឆ.47 ["បើតាមខ្ញុំយល់ ប្រសិនជាគេចាប់បាននរណាម្នាក់ព្យាយាមរត់ចេញពីកន្លែងហ្នឹង អ្នកនោះច្បាស់ជាគេសម្លាប់ចោលហើយ"]។

1187 ឯកសារ D114/198 កំណត់ហេតុស្តាប់ចម្លើយរបស់ ពិត សំអូន ឆ.54-55 [សមាជិកកងពលធំ ៣១០ បានពន្យល់ថា កម្មាភិបាលកពលមជ្ឈិម រួមមាន កងទ័ពជើងទឹក បានចូលរួមវគ្គបណ្តុះបណ្តាលរយៈពេលមួយខែនៅស្តាតអូឡាំពិចនៅភ្នំពេញ។ ក្នុងនោះ សុន សេន និង ណាត បានពន្យល់ថា "បើនិយាយ ពីជួរកងទ័ព ឱ្យតែឪពុកម្តាយបងប្អូនជាប់និន្នាការអ្នករដ្ឋការ លន់ នល់ សម័យសង្គមរាស្ត្រនិយម ឬពីសម័យបារាំង គឺគេដកទុក មួយកន្លែងផ្សេង គេហៅថាអ្នកជាប់និន្នាការ ទោះបីក្នុងជួរកងទ័ពក៏ដោយ ឬជួរកម្មាភិបាលក៏ដោយ [...] ឆ.55៖ គឺគេខ្លាចនៅក្នុងជួរបដិវត្តវាមានការសេរីវេ [...] គេខ្លាចក្រែងអ្នកនោះស៊ូទ្រាំនឹងភាពលំបាកមិនបាន ហើយពួកហ្នឹងដឹកនាំធ្វើបដិវត្ត"]។ ឯកសារ D4.1.858 កំណត់ហេតុស្តាប់ចម្លើយរបស់ សុខ ឈឿន EN ERN 00374951, KH ERN 00373487 ["ក្រោយថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ មានការធ្វើប្រវត្តិរូប ដើម្បីស្វែងរកអតីតមន្ត្រីរដ្ឋការរបស់ លន់ នល់ ហើយបើសិនជារកឃើញថា មានយោធាខ្មែរក្រហមណាម្នាក់ជាប់និន្នាការជាមួយនឹង មន្ត្រីរដ្ឋការ លន់ នល់ នឹងត្រូវដកចេញបញ្ចប់តំណែង ហើយឱ្យទៅធ្វើការនៅកន្លែងផ្សេង"]។ ចំពោះគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាមកលើទាហានសាធារណរដ្ឋខ្មែរ សូមមើលឧទាហរណ៍ ឯកសារ D4.1.886 ទង់បដិវត្ត ខែកញ្ញា-តុលា ឆ្នាំ ១៩៧៦ KH ERN 00063094 ["នៅមូលដ្ឋាន មានជាទំនាស់ដែលយើងចាប់បាន មានច្រើន ច្រើនជាអ្នករដ្ឋការ ប៉ូលិស សិស្ស"]។ ឯកសារ D4.1.861 ទង់បដិវត្ត ខែសីហា ឆ្នាំ ១៩៧៥ KH ERN 00063318 ["កំចាត់គិញ្ចារកម្ម សន្តិសម្ព័ន្ធ"]។ ឯកសសារ D98/1.2.17 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹក ថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០១២ ម៉ោង 10.02.56 [នៅក្នុងឆ្នាំ ១៩៧៣ មជ្ឈិមបក្សបានកំណត់និយមន័យ "វណ្ណៈពិសេស" នៃខ្មាំងចំនួនពីរប្រភេទ៖ 'ប៉ូលិស និងទាហាន' និង 'ព្រះសង្ឃ [និង] បញ្ញវ័ន្តដែល

ប្រសិនបើប្រវត្តិរូប ឬការពិនិត្យមើលប្រវត្តិរូប បន្ទាប់ពីត្រួតពិនិត្យរួច បញ្ជាក់ថា បុគ្គលម្នាក់មាន ទំនាក់ទំនងជាមួយអ្នកដែលធ្លាប់ធ្វើការនៅក្នុងរបបសាធារណរដ្ឋខ្មែរ (អ្នករដ្ឋការ ឬយោធា) បុគ្គល នោះត្រូវបានចាត់ទុកជាខ្មាំង ឬ "សមាសភាពអាក្រក់" ហើយគេលែងទុកចិត្តទៀតហើយ[1188]។

ជាពុទ្ធសាសនិក']។ ឯកសារ D4.1.480 កំណត់ហេតុស្ដាប់ចម្លើយរបស់ ឌី យ៉េត ហៅ ពេជ្រ EN ERN 00275129, KH ERN 00212085, FR ERN 00293910 [នៅក្នុងខែមេសា ឆ្នាំ ១៩៧៥ [គឺមានកិច្ចប្រជុំមួយ] "បានប្រជុំគ្នានៅ ក្នុងសហករណ៍ភូមិថ្មីខ្មែរ អំពីការយកមនុស្ស ១៧ មេសា ទាហាន លន់ នល់ ទៅសម្លាប់។ ខ្ញុំបានឮ យាយភឿន និយាយថា ត្រូវយកអ្នកទាំងនោះទៅសម្លាប់ចោល តាមបញ្ជាថ្នាក់លើ"]។ ឯកសារ D234/2.1.138 អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១៦ ម៉ោង 14.19.04-14.27.12 [ពន្យល់ពីរបៀបដែល តាម៉ុក និងតាម៉េត រៀបចំចាប់ខ្លួន និងសម្លាប់អ្នកបើកយន្តហោះរបបសាធារណរដ្ឋខ្មែរទាំងអស់ដែលចាប់បាននៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥]។ ឯក សារ D114/24 កំណត់ហេតុស្ដាប់ចម្លើយរបស់ អ៊ូ ដាវ ឆ.14-41។ ឯកសារ D4.1.799 កំណត់ហេតុស្ដាប់ចម្លើយ របស់ ស ស្រៀង KH ERN 00399195។

1188 ឯកសារ D54/43 កំណត់ហេតុស្ដាប់ចម្លើយរបស់ លុន សេង ឆ.19 [""ពួកសមាសភាពមិនល្អ គឺជាពួកដែលធ្លាប់ បម្រើការក្នុងរបបរដ្ឋាភិបាលមុនៗ ឬក៏មានបងប្អូនធ្លាប់ធ្វើការនៅក្នុងរបបមុនៗ។ ខ្ញុំផ្ទាល់ក៏ស្ថិតនៅក្នុងស្ថានភាពគ្រោះ ថ្នាក់ដែរនៅពេលនោះ ពីព្រោះពូខ្ញុំម្នាក់ពាក់ស័ក្តិ៤អតីតនៅកងទ័ពអាកាសនៅក្នុងរបប សីហនុ និងរបប លន់ នល់ ប៉ុន្តែខ្ញុំបានលាក់ប្រវត្តិខ្ញុំជិត [...] កងពលេ ១៦៤ ដាក់កងផលិតមួយកង ហៅថាកងផលិតធំ ដែលមានអតីតយោធា រាប់ពាន់នាក់ ដែលចាត់ថាមានសមាសភាពមិនល្អ។ ខ្ញុំលើករឿងនេះឡើង ពីព្រោះនៅពេលនោះ ខ្ញុំមានទំនាស់ជាមួយ នឹងមេបញ្ជាការកងវរសេនាតូចឈ្មោះ ទន ជាអ្នកមកពីខេត្តកំពត។ ទន ពេលនោះ ចោទខ្ញុំថាជាអនុធន ដោយសារខ្ញុំ ធ្លាប់រៀន។ ខ្ញុំបានប្រឈមជាមួយគាត់វិញ ថាគាត់ក៏ជាអតីតសាលាអនុវិទ្យាល័យដែរ [...] ទន ក្រោយមក បានបញ្ជូន ទៅកងផលិតធំ នៅភូមិពុទ្ធទេ"]។ ឯកសារ D54/36 កំណត់ហេតុស្ដាប់ចម្លើយរបស់ ប្រាក់ សុខា ឆ.1 ["ស៖ ហេតុអ្វី បានជាលោកត្រូវបានគេចាត់ទុកថា ជាកងសមាសភាពមិនល្អ ហើយដាក់បញ្ចូលក្នុងកងចល័ត? ឆ.1៖ ពីព្រោះមា និង ជីងតារបស់ខ្ញុំ ធ្វើទាហាន លន់ នល់ ដោយសារការពាក់ព័ន្ធនេះ ឪពុករបស់ខ្ញុំត្រូវបានឈ្លបឃុំ តាភេម ចាប់សម្លាប់ក្នុង ឆ្នាំ ១៩៧៣។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់ថា ជាកងសមាសភាពមិនល្អ ពីព្រោះតែការពាក់ព័ន្ធនេះ ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំ គ្មានធ្វើអ្វីខុស"]។ ឯកសារ D54/35.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប្រាក់ សុខន EN ERN 00971212-13, KH ERN 00964250, KH ERN 00964252-53 ["កាលជំនាន់ហ្នឹងមានពាក់ព័ន្ធ តែយើងមានពាក់ ព័ន្ធមានជាប់អីបន្តិចគេដកចេញហើយជំនាន់ហ្នឹង [...] ឆ៖ មូលហេតុកាលហ្នឹង ដោយសារខ្ញុំមានពាក់ព័ន្ធ គេយកប៉ាខ្ញុំ ជាប់និន្នាការ គេយកប៉ាទៅសម្លាប់ជាប់និន្នាការខ្មាំង ខ្ញុំមិនបានដឹងថា គេយកឪពុកខ្ញុំយកទៅសម្លាប់ចោល ខ្ញុំអត់ដឹង ផងហ្នឹង ស៖ ចឹងដោយសារថា អង្គការយកឪពុកទៅសម្លាប់? ឆ៖ បាទ! យកទៅសម្លាប់តាំងពី ៧៣ នោះអត់ដឹង ដល់ ៧៥ គេដកខ្ញុំចេញ ដល់ ៧៧ បានដឹង"]។ ឯកសារ D54/93 កំណត់ហេតុស្ដាប់ចម្លើយរបស់ យ៉ែម សំអុន ឆ.19-20 [ជាកម្មាភិបាលកងពលធំលេខ ១៦៤ ដែលបានបញ្ជូនទៅរៀននៅចិន៖ "លោកទើបតែនិយាយអំពីអ្នកដែលមាន ប្រវត្តិរូបល្អ តើអ្នកដែលមានប្រវត្តិរូបអាក្រក់ជាមនុស្សបែបណា? ឆ.19៖ អ្នកដែលមានប្រវត្តិរូបអាក្រក់ គឺអ្នកដែល ធ្លាប់ពាក់ព័ន្ធ ឬមានបងប្អូនជាប់ពាក់ព័ន្ធការងារក្នុងរបប លន់ នល់ [...] ឆ.20៖ តាមគោលការណ៍របស់ខ្មែរក្រហម

បន្ថែមលើសពីនេះទៀត ទាហានណាដែលត្រូវបានកំណត់អត្តសញ្ញាណថាមានជីវភាពធូរធារ ឬជា "ពួកមូលធន" ត្រូវបានចាត់ទុកថាជាប់ពាក់ព័ន្ធជាមួយនឹងរបបសាធារណរដ្ឋខ្មែរ និងត្រូវបានបោសសម្អាតដូចគ្នាដែរ[1189]។

---

អ្នកដែលជាប់ពាក់ព័ន្ធរបបចាស់ របប លន់ នល់ គឺមិនត្រូវបានគេយកមកធ្វើការនៅក្នុងរបបថ្មីនោះទេ"]។ សូមមើលផងដែរ ឯកសារ D114/139 កំណត់ហេតុស្តាប់ចម្លើយរបស់ ងួន ឡាយ ឆ.20 ["ខ្ញុំទៅនៅកងពល ១៦៤ វរសេនាធំលេខ ៦៣ ខ្ញុំទៅនៅព្រលានយន្តហោះកងកេង។ ខ្ញុំនៅទីនោះបានបីខែ ហើយពេលហ្នឹង គេសម្រិតសម្រាំង ពិនិត្យប្រវត្តិរូបអន្តរាយ ដោយសារពូខ្ញុំ ដែលត្រូវជាប្អូនរបស់ឪពុកខ្ញុំ គាត់ជាទាហានរបស់ ដាប ឈួន ហើយអ៊ំខ្ញុំជាគិញរបស់រដ្ឋាភិបាលនៅជំនាន់ លន់ នល់។ ខ្ញុំជាកូនអ្នកមាន ដោយសារឪពុកខ្ញុំជាថៅកែម្រេច។ ប៉ុន្តែដោយសារសកម្មភាពខ្ញុំល្អ គេដកចេញពីជួរទ័ព ចេញពីអង្គរក្ស"]។

1189 ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយរបស់ ស្វាយ សាម៉េត ឆ.36-37, 39, 41 ["[នៅក្នុងប្រវត្តិរូប] មានផ្នែកដែលនិយាយពីនិន្នាការ ហើយនិងមានការចុះទៅពិនិត្យ ដើម្បីឱ្យដឹងថា តើអ្នកជាប់និន្នាការជាមួយរបស់ លន់ នល់ ឬសាច់ញាតិរបស់អ្នកជាប់និន្នាការជាមួយនឹងរបស់ លន់ នល់។ ស៖ តើវណ្ណៈ និងលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ដែលពាក់ព័ន្ធដើម្បីឱ្យគណៈកម្មាការត្រួតពិនិត្យកំណត់ថា មនុស្សម្នាក់ជាខ្មាំង ឬជាប់និន្នាការខ្មាំង? ឆ.37៖ ខ្មាំងគឺក្រុមវណ្ណៈមូលធន និងឥស្សរជន។ វណ្ណៈទាំង ២ នេះ ចាប់និន្នាការជាមួយនឹងរបប លន់ នល់។ អ្នកដែលស្ថិតនៅក្នុងវណ្ណៈកសិករថ្នាក់កណ្តាលអាច ឬក៏មិនអាចជាប់និន្នាការជាមួយនឹងរបប លន់ នល់។ ប្រសិនបើពួកគេមានជាប់និន្នាការ ពួកគេនឹងលែងទទួលបានការជឿទុកចិត្តទៀត។ ដូចជាក្នុងការណីរបស់ខ្ញុំជាដើម គេបញ្ជូនខ្ញុំទៅនេះទៅនោះ គេមិនឱ្យការងារសំខាន់ខ្ញុំធ្វើ ហើយគេមិនឱ្យចុះទៅទីតាំងសំខាន់ៗឡើយ។ ខ្ញុំត្រូវបានគេចាត់ទុកថាជាវណ្ណៈកសិករថ្នាក់កណ្តាល។ ខ្ញុំមានសាច់ញាតិ ដែលធ្វើការនៅក្នុងរបប លន់ នល់។ ជីទួតមួយរបស់ខ្ញុំម្នាក់ធ្វើជាគ្រូ ហើយជីដូនមួយ ២ នាក់ធ្វើជាទាហាន លន់ នល់។ ប្រសិនបើអ្នកមកពីវណ្ណៈកសិករថ្នាក់កណ្តាល ហើយជាប់ពាក់ព័ន្ធនឹងនិន្នាការ លន់ នល់ ប្រព្រឹត្តកំហុសអ្វីមួយ ពួកគេនឹងត្រូវបានយកទៅកសាង។ ប្រសិនបើពួកគេមិនកែខ្លួននោះទេ ពួកគេនឹងត្រូវយកទៅសម្លាប់ចោល [...] ឆ.39 ៖ មិនដឹងថា មានមនុស្សប៉ុន្មាននាក់ធ្វើការនៅក្នុងគណៈកម្មាការត្រួតពិនិត្យនេះទេ ប៉ុន្តែខ្ញុំដឹងថា ពួកគេបានបញ្ជូនទាហាន ដែលគេទុកចិត្តទៅភូមិកំណើតរបស់យោធា ដើម្បីពិនិត្យប្រវត្តិរូបរបស់ពួកគេ។ គណៈកម្មាការនេះ បានឱ្យកងវរសេនាធំ ធ្វើការជ្រើសរើសយោធា ដែលទុកចិត្តមួយចំនួន ឱ្យចុះទៅពិនិត្យប្រវត្តិរូបនៅតាមភូមិកំណើតរបស់យោធា [...] ស៖ តើនិន្នាការពាក់ព័ន្ធយ៉ាងដូចម្តេច ទៅនឹងការកំណត់វណ្ណៈ ឆ.41៖ ដំបូង គេកំណត់វណ្ណៈសិន។ បន្ទាប់ពីគណៈកម្មាការត្រួតពិនិត្យចុះទៅត្រួតពិនិត្យដល់ផ្ទះរួចហើយ ទើបគេកំណត់និន្នាការ"]។ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយរបស់ ឡុង ផាន់ស៊ី ឆ.30 [អតីតមេបញ្ជាការកងវរសេនាតូចកាំភ្លើងធំ និងកងវរសេនាតូច ៦១២ នៅស្ទឹងហាវ៖ "បញ្ហាដែលគេដកខ្ញុំចេញពីអង្គភាព មកពីគេត្រួតពិនិត្យឃើញថា ខ្ញុំជា សេ.អ៊ី.អា, កា.ហ្សេ.ប្រ។ ក្រោយមក គេយកមកអង្គភាព ៦១២ មក គេតាមដានពិនិត្យខ្ញុំ គឺពេលដែលខ្ញុំចុះធ្វើការងារ ប្រគល់ការងារឱ្យខ្ញុំធ្វើ គេពិនិត្យឃើញថា ក្នុងអង្គភាពរបស់ខ្ញុំមានបាក់ដែកស្បែង រទេះដាច់ហ្វឹត គេចោទខ្ញុំថា បានបំផ្លិចបំផ្លាញ នេះជាហេតុផលទី ១។ ហេតុផលទី ២ គេតាមដានពិនិត្យឃើញថា គ្រួសារខ្ញុំជាអ្នកមាន ដែលជាមុខសញ្ញាគេកម្ចាត់។ បងខ្ញុំម្នាក់ធ្វើការជាវិស្វករខាងភ្លើងនៅភ្នំពេញ គេចាប់យកទៅសម្លាប់ចោល"]។ ឯកសារ D114/25 កំណត់ហេតុស្តាប់ចម្លើយ

345. ទាហានកងពល ៣/១៦៤ ដែលត្រូវបានចាត់ទុកថា "ជាប់ពាក់ព័ន្ធ" ជាមួយនឹងរបបសាធារណរដ្ឋខ្មែរ បានបាត់ខ្លួន ឬត្រូវបានឃុំឃាំង និងសម្លាប់ជារឿយៗ នៅមន្ទីរសន្តិសុខវត្តឥន្ទញាណ[1190] ឬ

---

របស់ អ៊ុំ ដារ ហៅ សឿន ឆ.13-14 ["នៅពេលនោះ ក្នុងអង្គប្រជុំ អង្គការ ឬបក្សមានគម្រោងចម្រាញ់នៅក្នុងកងទ័ព អង្គការមានគម្រោងកម្ទេចពួកមូលធននិយម ហើយពួកអតីតទាហានរបប លន់ នល់ [...] ឆ.14៖ អ្នកដែលធ្វើខ្ទេចខ្ទេស នាមនៅក្នុងអង្គប្រជុំនោះគឺ មាស មុត ហើយក៏មាន កម្មាភិបាលមកពីភ្នំពេញខ្លះដែរ ប៉ុន្តែមិនស្គាល់ឈ្មោះទេ"]។

1190 ឯកសារ D114/78 កំណត់ហេតុស្ដាប់ចម្លើយរបស់ ស្វាយ សាម៉េត ឆ.38 ["ស៖ តើគណៈកម្មាការត្រួតពិនិត្យរបស់កងពលធ្វើដូចម្ដេច ប្រសិនបើនៅក្នុងដំណើរការត្រួតពិនិត្យ គេរកឃើញថា មនុស្សម្នាក់ស្ថិតនៅក្នុងវណ្ណៈមូលធន ឬឥស្សរជន? ឆ.38៖ មនុស្សនេះនេះបាត់ខ្លួន។ ឧទាហរណ៍ ប្រសិនបើមនុស្សម្នាក់មានចំណេះដឹងខ្ពស់ ហើយធ្វើជាមិនដឹងអ្វី មិនយូរទេ គាត់ប្រាកដជានឹងបាត់ខ្លួន"]។ ឯកសារ D114/31 កំណត់ហេតុស្ដាប់ចម្លើយរបស់ មូល ឈិន ឆ. 103 ["ស៖ តើលោកធ្វើប្រវត្តិរូបរាល់ខែទេ? ឆ.103៖ បាទ ត្រឹមត្រូវហើយ។ យើងត្រូវសរសេរក្នុងប្រវត្តិរូប ប្រសិនបើមានបងប្អូនធ្លាប់ធ្វើការក្នុងរបប លន់ នល់ និងជាពិសេសអំពីនិន្នាការនយោបាយរបស់យើង។ ប្រសិនបើគេដឹងថា យើងមានបងប្អូនធ្លាប់ធ្វើការក្នុងរបបចាស់ នោះយើងនឹងមានបញ្ហាហើយ។ បើសិនជាយើងមានកំហុសតិចតួចថែមទៀត គេនឹងបេះយើងចេញ ដូចបេះផ្លែឪឡឹក (យកទៅសម្លាប់ផុយ)"]។ ឯកសារ D114/83 កំណត់ហេតុស្ដាប់ចម្លើយរបស់ សុខ នាង ឆ.34-35 ["ក្នុងគ្រាមួយ ខ្ញុំបានជួបអ្នកភូមិជាមួយគ្នាម្នាក់ឈ្មោះ នន នៅជិតផ្សារលើកំពង់សោម។ កាលនោះ ហាក់បីដូចជាអ្នកគ្រប់គ្រង ឬកាន់កាប់នៅគុកទឹកសាប។ ដោយសារគាត់មានសាច់ញាតិធ្លាប់ធ្វើការនៅក្នុងសម័យ លន់ នល់ ដែរ គាត់ក៏មានការបារម្ភដូចខ្ញុំដែរ។ គាត់ប្រាប់ខ្ញុំថា ប្រសិនបើគេមកចាប់គាត់ គឺគាត់មិនឱ្យចាប់ទេ គាត់សុខចិត្តរត់ ហើយឱ្យគេបាញ់ចុះ [...] ខ្ញុំបានដឹងថា មុនវៀតណាមចូលប្រហែល ១ ខែ គេបានមករកចាប់គាត់មែន តែគាត់បានរត់ ហើយគេបាញ់គាត់សម្លាប់តែម្ដងទៅ [...] ឆ.35៖ ក្នុងជំនាន់នេះ ប្រសិនបើអ្នកជាប់ពាក់ព័ន្ធនឹងរបបមុន អ្នកនោះនឹងទទួលការចាប់អារម្មណ៍ខ្លាំង។ របបខ្មែរក្រហម គឺគេចម្រាញ់យកតែអ្នកល្អៗទេ អ្នកផ្សេងត្រូវតែទៅហើយ។ បើសិនអ្នកពាក់ព័ន្ធទៅនឹងរបបមុន ធ្វើការងារធម្មតាដូចគេដូចឯង ដោយមិនត្អូញត្អែរ ឬក៏ប្រឆាំងនោះ គឺអ្នកនោះមិនមានបញ្ហាអ្វីទេ។ ប៉ុន្តែបើអ្នកនោះ ត្អូញត្អែរ ឬប្រឆាំងរបបកាលនោះ នឹងចាត់ទុកអ្នកនោះថា អ្នកប្រឆាំងរបបខ្លួនហើយ [...] ស៖ ចំពោះអ្នកដែលលោកស្រីរៀបរាប់ខាងលើ តើនឹងមានផលពិបាកអ្វីខ្លះ ដល់ពួកគេ? ឆ.36៖ គឺត្រូវចាប់ខ្លួនសួរចម្លើយ និងទទួលការអប់រំ"]។ ឯកសារ D114/181 កំណត់ហេតុស្ដាប់ចម្លើយរបស់ សែម កុល ឆ. 40-41 [អតីតទាហានកងវរសេនាធំ ១៤០ "កាលជំនាន់នោះ យើងត្រូវលាក់ ដូចថា អ្នករៀនខ្ពស់ យើងដាក់រៀនថ្នាក់ទី ៧ ទីអីហ្នឹង។ យើងកសិករថ្នាក់កណ្ដាល យើងដាក់ថ្នាក់ក្រោមអ៊ីចឹង។ ព្រោះជំនាន់ហ្នឹង ធ្វើបដិវត្តន៍ គេកម្ចាត់របបមូលធន អនុធនអីហ្នឹង កាលហ្នឹង គេបំបាត់របបសក្តិភូមិ នាយទុន។ កាលណាមិនលាក់ ព្រោះគេចង់បំបាត់ស្រទាប់លើ។ បដិវត្តន៍ ទិសដៅ គេបំបាត់របបសក្តិភូមិ បំបាត់នាយទុន ស៖ បំបាត់ហ្នឹង មានន័យម៉េចដែរ? ឆ.41៖ បំបាត់ហ្នឹង កម្ចាត់ពួកហ្នឹង ឱ្យមានថ្នាក់ស្មើៗគ្នា។ កុំឱ្យមានអ្នកមាន អ្នកក្រ"]។ ឯកសារ D114/40 កំណត់ហេតុស្ដាប់ចម្លើយជាមួយ មូល ឈិន ឆ.60-61 ["វត្តឥន្ទញាណ គឺជាគុករបស់កងពល។ អ្នកខ្លះជាយោធាដែលគេដឹងថា មានឪពុកដែលធ្លាប់ធ្វើការនៅក្នុងរបប លន់ នល់។ ស៖ ហេតុអ្វីបានជាលោកដឹងថា យោធាមួយចំនួនដែលឃុំឃាំងជាមួយលោកជាប់

ត្រូវបានបង្ខំឱ្យធ្វើការនៅការដ្ឋាន ដូចជា កងកេង ឬបិតត្រាង (រួមទាំង ភូមិពុទ្ធី/ពុទ្ធទេ/ពុតធឿន នៅក្បែរនោះ ដែលគេបានសាងសង់ទំនប់មួយ)[1191] ក្រោមលក្ខខណ្ឌដូចទាសករ។

*គ) អ្នកដែលគេសន្មតថាជា "ជនក្បត់" នៅក្នុងកងពល ១៦៤ និងបណ្ដាញរបស់ពួកគេ*

346. បុគ្គលិកកងពល ១៦៤ ទាំងនោះដែលត្រូវបានសន្មតថាជាខ្មាំងផ្ទៃក្នុង ត្រូវបាននាំទៅមន្ទីរសន្តិសុខ ដូចជា វត្តឥន្ទញ្ញាណ ទឹកសាប និង ស-២១។ នៅមន្ទីរសន្តិសុខទាំងនោះ ពួកគេត្រូវបានសួរចម្លើយ ដោយទទួលរងការធ្វើទារុណកម្ម ដើម្បីទទួលបានចម្លើយសារភាពលម្អិត និងកំណត់អត្តសញ្ញាណ

នៅទីនោះ ដោយសារតែមានគ្រួសារជាប់និន្នាការនឹងរបប លន់ នល់? ឆ.61៖ យើងនិយាយគ្នានៅក្នុងបន្ទប់នោះ ដោយសារយើងជាប់ខ្នោះនៅក្បែរៗគ្នា។ ហេតុដូច្នេះហើយ បានជាខ្ញុំដឹងរឿងពួកគេ"]។

1191 សូមមើលឧទាហរណ៍ ឯកសារ D114/76 កំណត់ហេតុស្ដាប់ចម្លើយរបស់ ស្វាយ សាម៉េត ឆ.21 ["នៅលើកោះនោះ ក៏មានទាហានមកពីអង្គភាពដទៃទៀតផងដែរ។ ខ្ញុំនៅលើកោះតាង ជាងពីរខែ។ ក្រោយមកមទៀត គេបញ្ជូនខ្ញុំតែឯង ឱ្យមកធ្វើស្រែនៅកងកេង។ ខ្ញុំមិនច្បាស់ពីមូលហេតុដែលគេបញ្ជូនខ្ញុំមកដូច្នេះឡើយ ប៉ុន្តែខ្ញុំគិតថា គេចាត់ទុកខ្ញុំជាអ្នកមាននិន្នាការពាក់ព័ន្ធជាមួយនឹងសាច់ញាតិដែលធ្វើជាទាហាកាលពីរបបមុន។ នោះគឺជាពេលដែលពិបាកសម្រាប់ខ្ញុំ"]។ ឯកសារ D54/7 កំណត់ហេតុស្ដាប់ចម្លើយរបស់ ឌុល សុង ឆ.17 ["ចំពោះរឿងសម្រិតសម្រាំង បើសិនជាគេរកឃើញថា មានយោធាណាមានបងប្អូនធ្វើការនៅក្នុងរបបមុន គេនឹងដកហយោធានោះចេញ យកទៅដាក់មួយកន្លែងផ្សេង គេដាក់កងផ្សេង ឱ្យទៅធ្វើការងារស្រែចម្ការ"]។ ឯកសារ D54/43 កំណត់ហេតុស្ដាប់ចម្លើយរបស់ លុន សេង ឆ.19 ["'ពួកសមាសភាពមិនល្អ គឺជាពួកដែលធ្លាប់បម្រើការក្នុងរបបរដ្ឋាភិបាលមុនៗ ឬក៏មានបងប្អូនធ្លាប់ធ្វើការនៅក្នុងរបបមុនៗ។ ខ្ញុំផ្ទាល់ក៏ស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ដែរនៅពេលនោះ ពីព្រោះពូខ្ញុំម្នាក់ពាក់ស័ក្តិ៤អតីតនៅកងទ័ពអាកាសនៅក្នុងរបប សីហនុ និងរបប លន់ នល់ ប៉ុន្តែខ្ញុំបានលាក់ប្រវត្តិខ្ញុំជិត។ ខ្ញុំចង់បន្ថែមអំពីទីកន្លែងមួយទៀត នៅភូមិពុទ្ធទេ នៅខាងជើងផ្លូវជាតិលេខ ៤ ឆ្លងផ្ទល់ពីវាលយន្តហោះកងកេង។ កន្លែងនោះ គឺជាកន្លែងដែលកងពល ១៦៤ ដាក់កងផលិតមួយកង ហៅថាកងផលិតធំ ដែលមានអតីតយោធារាប់ពាន់នាក់ ដែលចាត់ទុកមានសមាសភាពមិនល្អ"]។ ឯកសារ D114/139 កំណត់ហេតុស្ដាប់ចម្លើយរបស់ ងួន ឡាយ ហៅ អ៊ី ឆ.102, 106, 109 ["អាហ្នឹង [បិតត្រាំង] ទំនប់ពុតធឿង [...] ឆ.106៖ មានច្រើននាក់ ប្រហែលរាប់រយ រាប់ពាន់នាក់ [...] ឆ.109៖ ពួកគេភាគច្រើនជាទាហាន"]។ សូមមើលផងដែរ ឯកសារ D114/95 កំណត់ហេតុស្ដាប់ចម្លើយរបស់ យឹម ស្រឿង ឆ.148, 151, 158, 161, 166 ["ស៖ តើលោកឮគេនាំយកទាហានដែលមានប្រវត្តិមិនល្អញឹកញាប់ប៉ុនណាដែរ? ឆ.148៖ ភាគច្រើនខ្ញុំមិនបានឃើញទេ ព្រោះខ្ញុំនៅតែក្នុងទឹក។ បើគេត្រូវការអ្នកណាម្នាក់ទៅ គឺគេឱ្យយកទូកទៅយកមក។ ជួនកាល ១ ខែ គេទៅពីរដងអីក៏មាន ហើយម្ដង គេយកមនុស្សប្រហែលជា ៥ នាក់ ប៉ុន្តែខែខ្លះ ក៏គ្មានដែរ [...] ស៖ នៅពេលដែលគេនាំពួកនោះទៅ តើលោកធ្លាប់បានជួបពួកគាត់ម្ដងទៀតទេ? ឆ.151៖ អ្នកទាំងនោះស្លាប់អស់ហើយហើយមានអ្នកខ្លះក៏នៅរស់ដែរ នៅពេលដែលចុងរបបខ្មែរក្រហម។ ខ្ញុំបានឃើញពួកគេមានស្នាមនៅកដៃ និងកជើង ដែលគេដាក់ខ្នោះ"]។

អ្នកដែលគេគិតថាស្ថិតក្នុង "បណ្តាញ" របស់ខ្មាំង[1192]។ យុទ្ធជនមេដឹកនាំរបស់កងទ័ពបដិវត្តន៍កម្ពុជា និង ប.ក.ក ត្រូវបានបង្ខំឲ្យសារភាពថាបានឃុបឃិតទាំងកំរោលជាមួយ សេអ៊ីអា កាហ្សេបេ និងភ្នាក់ងារវៀតណាម និងឲ្យរៀបរាប់ឈ្មោះគូកនរបស់ពួកគេទាំងអស់[1193]។ នរណាដែលជាប់ពាក់ព័ន្ធនឹងអ្នកដែលត្រូវបានចាប់ខ្លួនទាំងនេះ ទោះតាមទំនាក់ទំនងការងារក្តី ឬគ្រួសារក្តី ត្រូវបានចាត់ទុកជាស្ថិតក្នុង "ខ្សែ" ហើយទំនងជាត្រូវបានចាប់ខ្លួន នៅពេលដែលរបបនេះបានវណ្តកធ្លាក់ចូលក្នុងអំពើហិង្សាបំផ្លាញខ្លួនឯង។ ពេលកម្មាភិបាលណាត្រូវបានគេឆ្លើយដាក់ ពួកគេនឹងត្រូវ

---

1192 សូមមើល VIII.គ. ៣ មន្ទីរសន្តិសុខវត្តឥន្ទញាណ, VIII.គ.៤ មន្ទីរសន្តិសុខទឹកសាប និង VIII.ឃ មន្ទីរសន្តិសុខស ២១។.

1193 ទាក់ទងនឹងមន្ទីរ ស ២១ ឌុច បានបញ្ជាក់យ៉ាងច្បាស់ថា ការធ្វើទារុណកម្មគឺចៀសសមិនរួចទេសម្រាប់អ្នកទោសទាំងអស់ដែលត្រូវសួរចម្លើយ ៖ ឯកសារ D114/277.3 កាំង ហ្គេចអ៊ាវ ហៅ ឌុច ប្រតិចារឹក ថ្ងៃទី ៩ មិថុនា ២០១៦ ម៉ោង 09.38.34-09.41.04 ["ទារុណកម្មជៀសមិនរួចច្រើនតែជៀសមិនរួច។ ផ្ទាល់ខ្លួនខ្ញុំដែលសួរចម្លើយ មានតែមួយហ្នឹងទេដែលជៀសមិនរួច។ ហើយ មិត្តហ៊ី សួរចម្លើយមានតែមួយហ្នឹងដែរ យឹម សម្បត្តិ។ [...] ក្រៅពីនោះច្រើនតែជៀសមិនរួច"]។ ឯកសារ D98/1.2.19 កាំង ហ្គេចអ៊ាវ ហៅ ឌុច ប្រតិចារឹក ថ្ងៃទី ២៧ មិនា ២០១២ ម៉ោង 09.35.07-09.36.32 ["តើទាំងអស់សុទ្ធតែទទួលទារុណកម្មរឿងអី ខ្ញុំសូមឆ្លើយថា លើកលែងតែម្នាក់គត់ គឺ កុយ ធួន ដែលមេហាមផ្តាច់មិនឲ្យវ៉ៃ មិនឲ្យធ្វើទារុណកម្ម ហើយឲ្យនិយាយត្រឹមត្រូវគួរសម"] ម៉ោង 09.39.30 ["សរុបមក រឿងល្អិតដែលខ្ញុំបានរាយទាំងពីរនេះ ជារឿងលើកលែង ក្រៅពីនោះមានវ៉ៃទាំងអស់"]។ ឯកសារ D10.1.64 កំណត់ហេតុស្តាប់ចម្លើយរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច KH ERN 00412114 ["ចំពោះការធ្វើទារុណកម្មវាមិនអាចចៀសផុតទេនៅស-២១"]។ ឯកសារ D1.3.33.3 កំណត់ហេតុសួរចម្លើយរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច KH ERN 00146486 ["អ្នកណាដែលគេយកទៅសួរ ច្រើនជៀសមិនរួចពីទារុណកម្ម លើកលែងតែករណីពិសេស ដូចករណី កុយ ធួន ដែលមានបញ្ជាមកខ្ញុំមិនឲ្យធ្វើទារុណកម្ម"]។ ជាឧទាហរណ៍មួយអំពីកងពល ១៦៤ ដែលត្រូវគេបង្ខំថ្កោលទោសជនក្បត់ដែលជាប់ពាក់ព័ន្ធ សូមមើល ចម្លើយសារភាព របស់ ហង់ ឌឿន ហៅ ខឹម៖ D234/2.1.55 ចម្លើយសារភាព ហង់ ឌឿន ហៅខឹម នៅស២១ KH ERN 00224085, ឯកសារ D1.3.18.1 ចម្លើយសារភាព ហង់ ឌឿន ហៅ ខឹម នៅស-២១, ឯកសារ D1.3.18.2 ចម្លើយសារភាពរបស់ ហង់ ឌឿន ឬ ហឹង ឌឿន ហៅខឹម នៅសរ២១ EN ERN 00759713-17 និង KH ERN 00177026-30 [បញ្ជីឈ្មោះកម្លាំងបក្ខពួកក្បត់នៅកងពល ១៦៤"ចំនួន ៩៤ នាក់ រួមមាន កម្មាភិបាលមកពីគណៈកងពល ១៦៤ កងវរសេនាធំ ៦២ កងវរសេនាធំ ៦៣ និងកងវរសេនាតូច និងកងធំ ជាច្រើន]។ នៅក្នុងការលើកឡើងជាសម្ងាត់ទៅលើចម្លើយសារភាពដែលទទួលបាននៅមន្ទីរ ស ២១ មាស មុត បានបន្ថែមថា អគ្គបញ្ជាការដ្ឋាន អាច"ស៊ើបអង្កេតប្រវត្តិគេឲ្យបានស៊ីជម្រៅ"។ សូមមើល ឯកសារ D114/307.6 កិច្ចសម្ភាសន៍រវាងវីអូអេខ្មែរ ជាមួយ មាស មុត ថ្ងៃទី ៦ ខែតុលា ឆ្នាំ ២០១១ KH ERN 01380591 ["ស៖ តើអ្នកទាំងបីនោះមានកំហុសអ្វីដែរ [ត្រូវបានគេបញ្ជូនទៅ ស២១]? ឆ៖ ខ្ញុំមិនឃើញមានកំហុសអ្វីទេ ប៉ុន្តែពេលខ្លះយើងមិនអាចស៊ើបអង្កេតប្រវត្តិគេឲ្យបានស៊ីជម្រៅទេ ហើយនៅអគ្គបញ្ជាការ ពួកគេអាចរកឃើញអ្វីដែលយើងមិនបានដឹង។"]។

បានចាប់ខ្លួន តែបន្ទាប់ពីមានការឯកភាពពីមេបញ្ជាការអង្គភាព (ឧទាហរណ៍ លេខាភូមិភាគ មេបញ្ជាការកងពលនៃកងទ័ពបដិវត្តកម្ពុជា និងរដ្ឋមន្ត្រី) ប៉ុណ្ណោះ។ លើសពីនេះទៀត មេបញ្ជាការត្រូវបានស្នើសុំឱ្យកំណត់អត្តសញ្ញាណយ៉ាងសកម្មនូវ "ជនក្បត់" ផ្សេងទៀត នៅក្នុងអង្គភាពរៀងៗខ្លួនរបស់ពួកគេ និងអ្នកដែលជាប់ពាក់ព័ន្ធជាមួយនឹង "ជនក្បត់"[1194]។ ចំពោះកងពល ១៦៤ **មាស មុត** ជាអ្នកទទួលខុសត្រូវសម្រិតសម្រាំង ចាប់ខ្លួន និងបញ្ជូនកម្មាភិបាលពាក់ព័ន្ធទាំងនោះ និងបោសសម្អាតបណ្ដាញរបស់ពួកគេទាំងមូល។ កម្មាភិបាលដែលមានឋានៈខ្ពស់បំផុត ដែលត្រូវគេបោសសម្អាតពីកងពល ១៦៤ ភាគច្រើន ត្រូវបានបញ្ជូនទៅ ស-២១ ដើម្បីធ្វើការសួរចម្លើយស៊ីជម្រៅ[1195] ចំណែកឯអ្នកនៅក្រោមបង្គាប់របស់ពួកគេត្រូវបានបោសសម្អាតនៅកំពង់សោម[1196]។

---

1194 ឯកសារ D4.1.400 កំណត់ហេតុសួរចម្លើយរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច KH ERN 00239838 ["មុនការចាប់ខ្លួននរណាម្នាក់ គេត្រូវពិភាក្សាជាមួយប្រធានអង្គភាពរបស់អ្នកនោះ។ នៅពេលណាដែលបានទទួលចម្លើយសារភាពរួចហើយ ចម្លើយសារភាព ត្រូវបានផ្ញើដោយ សុន សេន បន្ទាប់មក នួន ជា"]។ ឯកសារ D12 កំណត់ហេតុស្ដាប់ចម្លើយរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច KH ERN 00680805 ["ហើយ សុន សេន មុនពេលសម្រេច គាត់តែងតែសុំយោបល់ និងការជួយសម្រេចពីប្រធានកងពលផ្ទាល់នោះ"]។ ឯកសារ D4.1.860 កំណត់ហេតុស្ដាប់ចម្លើយរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច KH ERN 00403906 ["ក្នុងការអនុវត្តជាក់ស្ដែង ពេលដែលមនុស្សម្នាក់ត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព ថ្នាក់លើជូនដំណឹងទៅអ្នកទទួលខុសត្រូវអង្គភាពនីមួយៗ"]។ ឯកសារ D98/1.2.6 កាំង ហ្គេចអ៊ាវ ហៅ ឌុច ប្រតិចារឹក ថ្ងៃទី ២៧ ឧសភា ឆ្នាំ ២០០៩ ម៉ោង 09.32.55 ["ចម្លើយសារភាពរបស់ ស-២១ [...] ដែលខ្ញុំជូនអត់ទៅដៃ ស៊ូ ម៉េត ទេ គឺទៅដៃមេខ្ញុំ--មេខ្ញុំឱ្យទៅ ស៊ូ ម៉េត ហើយស៊ូ ម៉េត ជ្រើសមនុស្សមួយចំនួនដែលនៅក្នុងនៅក្នុងកងពល"] និងម៉ោង 09.57.12-10.00.15 និង 10.34.00។ ឯកសារ D4.1.404 កំណត់ហេតុស្ដាប់ចម្លើយរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច KH ERN 00242921 ["ចម្លើយសារភាព ត្រូវបានផ្ញើទៅប្រធានអង្គភាព ដោយមានគោលបំណង ២ ៖ ទី១ ប្រាប់ដំណឹងដល់គាត់អំពីសកម្មភាពរបស់ខ្មាំងនៅក្នុងអង្គភាពនោះ និង ទី២ អនុញ្ញាតឱ្យគាត់គិតពីការចាប់ខ្លួនមនុស្សដែលគេបានឆ្លើយដាក់"]។

1195 សូមមើល VIII.ឃ. មន្ទីរសន្តិសុខស-២១។

1196 ឧទាហរណ៍ ឯកសារ D114/25 កំណត់ហេតុស្ដាប់ចម្លើយរបស់ អ៊ូ ដាវ ឆ.35 [អតីតប្រធានកងតូច កងពល ១៦៤ កងវរសេនាធំ ១៤០ អតីតកងវរសេនាតូច ១៨០៖ "ខ្ញុំបានជួបអតីតយោធាដែលធ្លាប់ធ្វើការជាមួយគ្នានៅកោះកុង។ ពួកនោះគឺមកពីកងវរសេនាតូចរបស់ខ្ញុំលេខ១៨០។ ពេលដែលចាប់មេបញ្ជាការ គេក៏បានរំសាយកងរបស់ខ្ញុំ ហើយគេបញ្ជូនពួកយោធាមួយចំនួនឱ្យទៅចូលធ្វើជាយោធានៅក្នុងតំបន់ ១១ នៅកោះកុង"]។ ទាក់ទងនឹងខ្សែផ្សេងទៀត (អតីតយោធាកងវរសេនាតូច ៣៨៦ និងអតីតយោធាកងពល ១៦៤ មកពីភូមិភាគបូព៌ា) សូមមើល ខ្សែតំបន់ ៣៧ (អតីតកងវរសេនាតូច ៣៨៦) កថាខណ្ឌ ៣៤៩-៣៥៤ និង ខ្សែភូមិភាគបូព៌ា (តំបន់ ២២) កថាខណ្ឌ ៣៥៥-៣៦០។

347. ឯកសារដែលនៅសេសសល់បង្ហាញថា កម្មាភិបាល និងយុទ្ធជនកងពល ៣/១៦៤ យ៉ាងហោច ណាស់ ៦៧ នាក់ ត្រូវបានឃុំខ្លួន សួរចម្លើយ និងសម្លាប់នៅ ស-២១ នៅចន្លោះពីថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦ រហូតដល់ឆ្នាំ ១៩៧៨[1197]។ ដើម្បីចៀសវាងកុំឲ្យមានការតស៊ូប្រឆាំង ឬការបះ បោរដោយអង្គភាពប្រដាប់អាវុធរបស់ពួកគេ អ្នកដែលត្រូវបានជ្រើសរើសទៅ ស-២១ ជាទូទៅ ត្រូវបានហៅឲ្យចូលរួមវគ្គរៀនសូត្រនៅកំពង់សោម ឬនៅភ្នំពេញ។ បន្ទាប់មក ពួកគេត្រូវបានចាប់ ខ្លួន និងបញ្ជូនទៅ ស-២១[1198]។ នៅក្នុងកិច្ចសម្ភាសន៍ជាមួយ វីរូអេ **មាស មុត** បានទទួលស្គាល់ថា គាត់បានដឹងថា អ្នកនៅក្រោមបង្គាប់របស់គាត់មួយចំនួន ត្រូវបានសេនាធិការនាំយកទៅ ស-២១

---

1197 សូមមើល VIII.ឃ. មន្ទីរសន្តិសុខស-២១។

1198 ឯកសារ D114/226 កំណត់ហេតុស្តាប់ចម្លើយរបស់ គីម ហាវ ឆ.82-85 ["[ឆាន] គាត់ស្លាប់ឆ្នាំ ១៩៧៧ [...] ឆ.83 ៖ ស្លាប់ដោយ ប៉ុល ពត យកទៅរៀនសូត្រយកទៅសម្លាប់។ គេថាទៅរៀនសូត្រៗ ទៅបាត់បណ្តោយ។ ស៖ តើអ្នក ណាមកហៅគាត់ទៅរៀនសូត្រ? ឆ.84៖ ពួកភូមិភាគ [...] ឆ.85៖ កាលជំនាន់នោះ គេថាទៅរៀនសូត្រៗ គឺយកទៅ សម្លាប់ចោល"]។ ឯកសារ D114/241 កំណត់ហេតុស្តាប់ចម្លើយរបស់ ឆេង ជាង ឆ.81-83 ["ខ្ញុំស្គាល់ឈ្មោះមួយ គឺ តាចិន ។ ហើយក្រៅពីនោះមានម្នាក់ទៀត ឃើញបាត់ៗ មុនគាត់ទៅភ្នំពេញ១អាទិត្យ គាត់ប្រាប់ខ្ញុំថា បងប្អូននៅនេះ នៅឲ្យស្ងៀម។ [...] ឆ.82៖ យើងជាកូនចៅគាត់ [...] ឆ.83៖ អត់ដឹងទេ តែគាត់មកប្រាប់ខ្ញុំថា គេដកខ្ញុំទៅភ្នំពេញ"] ។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.16, 19, 91 និង 127-128 ["ឆាន ជាមេបញ្ជាការ [...] ក្រោយមក ឆាន ត្រូវបានគេយកទៅសម្លាប់ចោល [...] ឆ.19៖ ប្រសិនបើខ្ញុំមានឋានៈ និងតួនាទី ដូចជាប្រធាន កងធំ គឺគេច្បាស់ជាយកទៅសម្លាប់អស់ហើយ ព្រោះឋានៈចាប់ពីមេកងធំឡើងទៅ ត្រូវបានគេយកទៅសម្លាប់ទាំងអស់ ក្រោមហេតុផល ហៅយកទៅរៀនសូត្រ។ [...] ឆ.91៖ឲ្យតែមេៗគេហៅមករៀនសូត្រនៅរោងកុន នៅកំពង់សោម គឺ ដឹងតែបាត់ខ្លួនតែម្តង ហើយមិនដែលឃើញវិលត្រឡប់មកវិញទេ [...] ក៏ប៉ុន្តែកន្លងពេលយូររាប់ខែមកហើយ ក៏មិន ដែលឃើញពួកគេត្រឡប់មកវិញនោះទេ [...] ស៖ លោកនិយាយថា មេៗបានបាត់ខ្លួន។ តើលោកអាចផ្តល់ឈ្មោះអ្នក ទាំងនោះបានដែរឬទេ? ឆ.127៖ ឈ្មោះ យាន រ៉ែម និង សួរ [...] ឆ.128៖ បាទ ឆាន ក៏បាត់ខ្លួនដែរ។ និយាយទៅ មេៗគឺបាត់ខ្លួនទាំងអស់។ គឺលើកលែងតែកូនទាហានធម្មតាទេ។"]។ ឯកសារ D114/139 កំណត់ហេតុស្តាប់ចម្លើយ របស់ ងួន ឡាយ ហៅ អ៊ី ឆ.65-66, 74 និង 77 ["[វេត] ក្រោយមកគេចាប់គាត់ [...] ឆ.66៖ ពេលដែលគាត់ទៅ សិក្ខាសាលានៅឈើគោក គេចាប់គាត់ទៅ ខ្ញុំឮគេនិយាយអីចឹង។ ពេលដែលគាត់ទៅគោកអីហ្នឹង ទូកខ្ញុំក៏ដឹកពួកគាត់ទៅ ចូលរួមសិក្ខាសាលា។ [...] ស74៖ មេៗដែលគេហៅទៅសិក្ខាសាលា ដូចវេតជាដើម តើពួកគេមានបានត្រឡប់មក វិញទេ? ឆ.74៖ មានតែមួយហ្នឹងទេ កាលជំនាន់ហ្នឹងដែលមិនត្រឡប់មកវិញ។ [...] ស៖ តើលោកដឹងថា គេចាប់ខ្លួនវេ តនៅពេលហ្នឹងតែម្តង? [...] ឆ.77៖ បាទ ឮពេលដែលអ្នកសិក្ខាសាលាត្រឡប់មកវិញ"]។ ឯកសារ D114/105 កំណត់ហេតុស្តាប់ចម្លើយរបស់ កុច ទុយ ឆ.18។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយរបស់ ឯក នី ឆ.14។

បន្ទាប់បានចូលវគ្គរៀនសូត្រនៅភ្នំពេញ[1199]។ កម្មាភិបាលខ្លះឆ្លងកាត់តាមមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ ឬទឹកសាប មុននឹងបញ្ជូនទៅ ស-២១[1200]។ ក្នុងចំណោមអ្នកដែលត្រូវបានឃុំខ្លួន និងសម្លាប់នៅស-២១ មានកម្មាភិបាលដែលមានតំណែងខ្ពស់នៅក្នុងកងពល។ កម្មាភិបាលទាំងនេះជាកូនចៅជិតស្និទ្ធរបស់ **មាស មុត** និងអ្នកនៅក្រោមបង្គាប់ផ្សេងទៀត រួមមាន មេបញ្ជាការរង ហ៊ីង

1199 ឯកសារ D114/307.6 កិច្ចសម្ភាសន៍រវាងវីអូអេខ្មែរ ជាមួយ មាស មុត ថ្ងៃទី ៦ ខែតុលា ឆ្នាំ ២០១១ KH01380588-91 ["សៈ តើមានកងទ័ពណាត្រូវគេបញ្ជូនទៅស-២១ ដែលជាគុករបស់ឌុច ដើម្បីសម្លាប់ចោលដែរឬទេ [...] ឆៈ តាមដែលខ្ញុំដឹង គឺមានខ្លះដែរ ប៉ុន្តែមិនច្រើនដូចគេប៉ាន់ប្រមាណឡើយ ព្រោះសេនាធិការ (កងទ័ពខ្មែរក្រហម) បានកោះហៅប្រជាជនឱ្យទៅរៀនសូត្រ។ នៅពេលរៀនសូត្រចប់ ពួកគេប្រាប់មកកងវិញថា គេមិនបញ្ជូនគេត្រឡប់មកកងវិញទេ។ ផ្ទុយទៅវិញ សេនាធិការបញ្ជូនពួកគាត់ទៅស-២១។ តាមពិតទៅកងមិនដឹងអំពីមូលហេតុទេ។ ហេតុការណ៍នេះបានកើតឡើងម្តងពីរដងនៅក្នុងកង នៅពេលដែលខ្ញុំនៅគ្រប់គ្រង។ [...] សេនាធិការដែលទទួលខុសត្រូវលើកងពលទាំងអស់ បានកោះហៅផ្ទាល់មេដឹកនាំថ្នាក់ក្រោម និងថ្នាក់កណ្តាល មករៀនសូត្រនៅមជ្ឈិម [...] គឺប្រហែលបីទៅបួនដងក្នុងមួយឆ្នាំ"], KH ERN 01380591 ["សៈ នៅពេលដែលលោកនៅក្នុងកងពល តើមានបញ្ជាឱ្យយកមនុស្សទៅសម្លាប់ ឬកម្ទេចនៅគុករបស់ឌុចទេ? ឆៈ នៅក្នុងកងពលរបស់ខ្ញុំមិនមានបញ្ជាឱ្យធ្វើបែបនេះទេ។ ខ្ញុំឃើញតែម្តងគត់ នៅពេលដែលគេហៅមនុស្សបីនាក់ ទៅរៀនសូត្រ។ គេប្រាប់យើងថាគេទុកអ្នកទាំងបីនៅទីនោះ មិនឱ្យត្រឡប់មកកងវិញទេ។ សៈ តើអ្នកទាំងបីនោះមានកំហុសអ្វីដែរ? ឆៈ ខ្ញុំមិនឃើញមានកំហុសអ្វីទេ ប៉ុន្តែពេលខ្លះយើងមិនអាចស៊ើបអង្កេតប្រវត្តិគេឱ្យបានស៊ីជម្រៅទេ ហើយនៅអគ្គបញ្ជាការ ពួកគេអាចរកឃើញអ្វីដែលយើងមិនបានដឹង" (បញ្ជាក់បន្ថែម)]។

1200 ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយរបស់ ឯក នី ឆ.7 និង 23 ["សៈ ហេតុអ្វីបានជាលោកដឹងថា គេបញ្ជូនអ្នកទោសពីវត្តឥន្ទញ្ញាណទៅភ្នំពេញ? ឆ.7៖ យោធាកងពិសេសបាននិយាយប្រាប់ខ្ញុំអំពីរឿងនេះ ហើយនិងអំពីឡានយោធាដែលប្រើសម្រាប់ដឹកអ្នកទោសពីវត្តឥន្ទញ្ញាណទៅភ្នំពេញ។ ឡានយោធានោះ គេហៅថា ឡានទាហាន ៤ x ៤ របស់ចិន។ ថ្ងៃមួយ ពេលខ្ញុំកំពុងធ្វើការនៅក្បែរល្វកាត់ផ្លូវជាតិលេខ៤ នៅជិតព្រលានយន្តហោះកងកេង ខ្ញុំបានឃើញឡាននោះឈប់ចាក់ទឹក។ ឡាននោះធ្វើដំណើរក្នុងទិសដៅទៅភ្នំពេញ។ ខ្ញុំឃើញមានពួកយោធា ដែលជិះឡាននោះមានកាន់កាំភ្លើងអាកា៤៧ អង្គុយនៅខាងក្រោយឡាន។ ឡាននោះគឺគ្របដំបូលជិត ពេកគេឈប់ ខ្ញុំឮសំឡេងមនុស្សយំ និងថ្ងូរនៅក្នុងឡាននោះតែខ្ញុំមើលមិនឃើញពួកគេទេ។ [...] ឆ.23៖ [...] ទឹកសាប គឺជាគុកសម្រាប់យោធាតូចតាច តែវត្តឥន្ទញ្ញាណគឺជាមន្ទីរឃុំឃាំងបណ្តោះអាសន្នសម្រាប់កម្មាភិបាលថ្នាក់ដឹកនាំ មុនពេលបញ្ជូនទៅកន្លែងផ្សេង"]។ បើតាម អៀម ភង់ និង មាស សារ៉ាន បានឱ្យដឹងថា សុខ ប្រធានពេទ្យកងពល ១៦៤ ជាប់ឃុំនៅមន្ទីរសន្តិសុខទឹកសាប មុនពេលគេបញ្ជូនគាត់ទៅ ស-២១៖ ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយរបស់ អៀម ភង់ ឆ.109, ឯកសារ D54/117 កំណត់ហេតុស្តាប់ចម្លើយរបស់ មាស សារ៉ាន ឆ.11-12 និង 18 និងឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយរបស់ ទូច សឿលី ឆ.28។

ខឿន ហៅ ឌឹម[1201] សមាជិកគណៈកងពល ១៦៤ ជ័យ ហាន ហៅ ឆាន[1202] ម៉ុម ជឹម ហៅ យ៉ាន (កងវរសេនាធំលេខ ៦៣)[1203] និង ម៉ែន ង៉ែត (កងវរសេនាធំ ៦១)[1204] ប្រធានមន្ទីរពេទ្យកងពល

[1201] ឯកសារ D114/230.1.1 បញ្ជីអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ១៦២៤ [ចូលស-២១ ថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៧]។ ឯកសារ D9.3 បញ្ជីអ្នកទោស ស-២១ មកពីកងពល១៦៤ របស់ ក.ស.ច.ស លេខរៀង ១១ [សម្លាប់ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៧៧]។ ឯកសារ D1.3.28.40 បញ្ជីឈ្មោះអ្នកទោសកម្មេស និងថតរូប ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៧៧ EN 00873280-81, KH 00009146 [លេខរៀង ២ នៅក្នុងបញ្ជី]។ ឯកសារ D234/2.1.55 ចម្លើយសារភាព ស-២១របស់ ហង់ ខឿន ហៅ ឌឹម ERN KH 00174375។ ឯកសារ D1.3.18.1 ចម្លើយសារភាពស-២១ របស់ ហង់ ខឿន ហៅ ឌឹម។ ឯកសារ D1.3.18.2 ចម្លើយសារភាពស-២១ របស់ ហង់ ខឿន ហៅ ឌឹម។

[1202] សូមមើលកថាខណ្ឌ៣៤៩-៣៥០។ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង ១៤១៥៦។

[1203] ឯកសារ D114/230.1.1 បញ្ជីអ្នកទោស ស ២១ របស់ ក.ស.ច.ស លេខរៀង ៤៧៩៧ [ចូលថ្ងៃទី១៨ ខែមេសា ឆ្នាំ ១៩៧៧ សម្លាប់ថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៨។ ឯកសារ D9.3 បញ្ជីអ្នកទោស ស-២១ មកពីកងពល១៦៤ រៀបរៀង ដោយ ក.ស.ច.ស លេខរៀង ២៤ (និងលេខរៀង ២៧- ស្ទួន)។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.4-5 ["តាមដែលខ្ញុំចាំឈ្មោះ យ៉ាន មេបញ្ជាការវរៈសេនាធំ២២, ង៉ែត មេបញ្ជាការវរៈសេនាធំ២០ និងមេបញ្ជាការវរៈសេនាតូចរបស់ខ្ញុំឈ្មោះ វេត [...] ឆ.5៖ គេចាប់ក្នុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨។ ខ្ញុំមិនបានឃើញការចាប់នោះដោយផ្ទាល់ភ្នែកទេ ប៉ុន្តែគេប្រជុំតាមកងប្រាប់អំពីការចាប់ចងនេះ។"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.5 ["យ៉ាន ជាសមាជិកគណៈកងពល១៦៤។ យ៉ាន ពីដើមមកពីភូមិភាគនិរតី ទទួលខុសត្រូវបីកងវរៈសេនាតូច គឺ ១៧០, ១៨០, ១៣២។ កងវរៈសេនាតូចទាំងបីនេះគឺស្ថិតក្នុងកងវរៈសេនាធំមួយ [...] យ៉ាន នេះគឺស្ថិតនៅក្នុងចំណោមពួកក្បត់ដែលតាមុត បានលើកមករៀបជាពាក្យជូនដូចកំណាព្យថា "ញ៉ើក, ឆាន, យ៉ាន, ឌឹង គឺជាពួកក្បត់"។ ឯកសារ D54/115 កំណត់ហេតុស្តាប់ចម្លើយ នាក់ យឿន ឆ.13, 15, 18-19, 22-24 [ពន្យល់អំពីរបៀបចាប់ខ្លួន យ៉ាន ដោយសម្ងាត់ និងអំពីរបៀបដែល មាស មុត និងញ៉ាន់ ឲ្យអ្នកចូលរួមវគ្គរៀនសូត្រ ឆ្លើយសំណួរប្រវត្តិរូបឲ្យបានច្បាស់លាស់ដើម្បីកំណត់ថានរណាដែលធ្លាប់ជិតដិតនឹង យ៉ាន]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.1 ["នៅក្នុងអង្គប្រជុំ មាស មុត អានចម្លើយសារភាពរបស់ពួកក្បត់ គាត់បានរៀបរាប់ឈ្មោះកម្មាភិបាលក្បត់ចាប់ពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់មូលដ្ឋាន។ ខ្ញុំនៅចាំថា គាត់ហៅឈ្មោះ អាយ៉ា, អាធុត, អាញ៉ើក, អាយ៉ាន, អាឆាន និងអាឌឹម។ ខ្ញុំនៅចាំ មាស មុត ហៅពួកគេថា "អា" ពីព្រោះ "អា" ជាពាក្យបណ្តុះបង្អាប់សម្រាប់និយាយទៅកាន់ពួកក្បត់"]។ ឯកសារ D114/139 កំណត់ហេតុស្តាប់ចម្លើយ ងួន ឡាយ ហៅ អ៊ី ឆ.23 [ពន្យល់ថា យ៉ាន និងញ៉ាន់ ជាស្នងការនយោបាយ និងជាមេបញ្ជាការកងវរៈសេនាធំ៦៣]។ ឯកសារ D114/116 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.26-33 [ពន្យល់ថា មុំ យ៉ាន មេបញ្ជាការកងវរៈសេនាធំ ៦៣ បានបាត់ខ្លួននៅក្នុងឆ្នាំ១៩៧៧]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.35 ["វរៈសេនាធំ ៦៣ មានមេបញ្ជាការឈ្មោះ បងយ៉ាន កាន់នៅកោះសេះ កោះតាគាវ កោះថ្មី ម៉ូវ៉ាម"]។ ឯកសារ D54/81 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ិច ឆ.14 ["ក្រោយមក យ៉ាន មកកាន់កងពល១៦៤ ជាមួយអ៊ំ មុត។ គាត់ជាអតីតមេបញ្ជាការវរៈសេនាធំ៦៣។ ក្រោយមក ខ្ញុំមិនដឹងថា គាត់

ស៊ីម នាម ហៅ សុក និងប្រពន្ធរបស់គាត់[1205] និងមេបញ្ជាការ មេបញ្ជាការរង និងសមាជិកគណៈ កងវរសេនាធំ[1206] កងវរសេនាតូច[1207] កងអនុសេនាធំ និងកងអនុសេនាតូច[1208]។ អ្នកនៅក្រោម

---

ទៅណាទេ។ ក្រោយមក សារឿន មកជំនួស យ៉ាន។ សារឿន មកពីកងវរៈសេនាធំ១៤០ ប្រហែលជាមក ជំនួស យ៉ាន"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ.64, 67, 226 ["មានឈ្មោះ ង៉ែត, ឈ្មោះ ឌឹម, ឈ្មោះ យ៉ាន, ឈ្មោះ ឆាន និងឈ្មោះ សុខ ជាដើម ដែលគេចោទថាជាគិញវៀតណាម ឬក៏ សេ.អ៊ី.អា [...] ឆ.67៖ បានជាខ្ញុំដឹងពីព្រោះគេបានហៅអ្នកទាំងនោះយកទៅ ហើយបន្ទាប់ពីពីរបីថ្ងៃក្រោយមក ប្រធានអង្គភាពវរៈសេនាធំ ១៤០ ឈ្មោះ ហន បានប្រជុំប្រាប់ថា ទាំងនោះជាខ្មាំងស៊ីរូងផ្ទៃក្នុង [...] ឆ.226៖ រឿងហ្នឹង គឺមេបញ្ជាការខ្ញុំឈ្មោះ ហន បានប្រាប់ខ្ញុំថា អ្នកប៉ុន្មាននាក់ខាងលើនេះសុទ្ធតែជាអ្នកក្បត់ក្នុងជួរទ័ព"]។ ឯកសារ D114/18 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.6 ["ក្រោយមក នៅក្នុងឆ្នាំ១៩៧៦ [...] តាយ៉ាន ត្រូវបានផ្លាស់ចេញទៅកន្លែងផ្សេង ហើយតា ជន បានក្លាយជាមេបញ្ជាការកងវរៈសេនាធំរបស់ខ្ញុំ [លេខ៦៣]]។

1204 ឯកសារ D114/230.1.1 បញ្ជីអ្នកទោស ស ២១ របស់ ក.ស.ច.ស លេខរៀង ៥៣៤២ [ចូល ថ្ងៃទី០២ ខែមិថុនា ឆ្នាំ ១៩៧៧]។ ឯកសារ D9.3 បញ្ជីអ្នកទោស ស-២១ មកពីកងពល១៦៤ រៀបរៀងដោយ ក.ស.ច.ស លេខរៀង ២៦។ ឯកសារ D1.3.5.5 បញ្ជីឈ្មោះកម្មាភិបាលមកពីកងពល១៦៤ KH 00159970 [មនុស្សពីរនាក់ត្រូវកំណត់ថាបានចាប់ខ្លួនរួចហើយ]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.4-5 ["តាមដែលខ្ញុំចាំឈ្មោះ យ៉ាន មេបញ្ជាការវរៈសេនាធំ២២, ង៉ែត មេបញ្ជាការវរៈសេនាធំ២០ និងមេបញ្ជាការវរៈសេនាតូចរបស់ខ្ញុំឈ្មោះ វេត [...] ឆ.5 ៖ គេចាប់ក្នុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨។ ខ្ញុំមិនបានឃើញការចាប់នោះដោយផ្ទាល់ភ្នែកទេ ប៉ុន្តែគេប្រជុំតាមកង ប្រាប់អំពីការចាប់ចងនេះ។"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.4 ["ម៉ែន ង៉ែត ជាសមាជិកគណៈកងពល១៦៤ គាត់ត្រូវបានចាប់ខ្លួន"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ.64, 67, 226។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.8 ["ង៉ែត ជាស្នងការវរៈសេនាធំ២០។ ង៉ែត ត្រូវបាន គេចាប់ក្នុងរយៈពេលបោសសម្អាតប្រហែលក្នុងឆ្នាំ១៩៧៧"]។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ហៅសារ៉េត ឆ.5 ["អនុកងពលពេលនោះឈ្មោះ ង៉ែត [...] ក្រោយមក គាត់បានមុខពីកងពល"]។ ឯកសារ D2/8 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.44-45 [ង៉ែត ជាមេបញ្ជាការកងវរៈសេនាធំ២០ ឬ៦១]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.15 [ង៉ែត ជាសមាជិកម្នាក់នៃកងពល១៦៤]។

1205 អំពីវេជ្ជបណ្ឌិត ស៊ីម នាម ហៅ សុខ៖ ឯកសារ D114/230.1.1 បញ្ជីអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ១៣១៣៧ [សុខ ស្លាប់/ត្រូវសម្លាប់នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ១៩៧៧]។ ឯកសារ D114/241 កំណត់ហេតុស្តាប់ចម្លើយ ឆេង ជាង ឆ.61 ["តាសុខ ជាវេជ្ជបណ្ឌិតនៅកំពង់សោម"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.5 ["យ៉ាន នេះគឺស្ថិតនៅក្នុងចំណោមពួកក្បត់ដែលតាមុត បានលើកមករៀបជាពាក្យជូនដូចកំណាព្យថា "ញឹក, ឆាន, យ៉ាន, ឌឹម ជាពួកក្បត់"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ.64 ["មានឈ្មោះ ង៉ែត, ឈ្មោះ ឌឹម, ឈ្មោះ យ៉ាន, ឈ្មោះ ឆាន និងឈ្មោះ សុខ ជាដើម ដែលគេចោទថាជាគិញវៀតណាម ឬក៏ សេ.អ៊ី.អា"]។ ឯកសារ D114/155 កំណត់ហេតុស្តាប់ចម្លើយ សុខ រ៉េន ឆ.61 [ទាំងពេទ្យសុខ និងប្រពន្ធរបស់គាត់ស្លាប់]។ មុនពេលគេបញ្ជូនគាត់ទៅមន្ទីរ ស-២១ សុខ ជាប់គុកនៅមន្ទីរសន្តិសុខទឹកសាប បើយោងតាម អៀម ភង់ និង មាស

សារ៉ាន់៖ ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.109 ["គេដាក់ តាសុខ នៅគុកទឹកសាប។ គាត់ជាពេទ្យខ្មែរក្រហម។ គាត់ធ្លាប់ធ្វើប្រធានរះកាត់នៅកំពង់សោម"]។ ឯកសារ D54/117 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន ឆ.11-12, 18 ["យើង ត្រឡប់មកនិយាយអំពីមន្ទីរពេទ្យនៅចំការចេក តើអ្នកណាជាប្រធានពេទ្យ? ឆ.11៖ ប្រធានពេទ្យឈ្មោះ សុខ [...] ឆ.12៖ គាត់នៅបានប៉ុន្មានខែ គេចាប់គាត់យកទៅដាក់គុកស្ពានទឹកសាប នៅចុងឆ្នាំ១៩៧៥ [...] ហោ មកជំនួស សុខ នៅដើមឆ្នាំ១៩៧៦ [...] ឆ.18៖ គេឱ្យខ្ញុំទៅនៅសហករណ៍មួយ ហើយនៅសហករណ៍នោះមានកូនសុខ នៅជាមួយដែរ ហើយកូនសុខ ជាអ្នកប្រាប់ខ្ញុំថា គេចាប់សុខ និងប្រពន្ធរបស់គាត់ទៅដាក់នៅស្ពានទឹកសាប"]។ ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន ឆ.8 ["ហោ ជាប្រធានពេទ្យធំ។ ឈ្មោះ ហោ ឡើងជំនួសឈ្មោះ សុខ ដែលជាប្រធានពេទ្យ ក្រោយពីពេលគេចាប់ខ្លួនបាត់ទៅ"]។ ប្រពន្ធគាត់ឈ្មោះ ហែម អាង ហៅ ស៊ីន គឺត្រូវកម្ទេច និងសម្លាប់ដូចគ្នានៅមន្ទីរ ស-២១៖ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង ៧៣៨៣ [នារីពេទ្យ ហែម អាង ហៅ ស៊ីន ត្រូវបានកំណត់អត្តសញ្ញាញជាប្រពន្ធរបស់លេខាសុខ [ចូលថ្ងៃទី២៦ ឬ២៨ ខែមេសា ឆ្នាំ១៩៧៧ សម្លាប់នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៨]។ ឯកសារ D1.3.28.19 បញ្ជីសួរចម្លើយរបស់ ស-២១ ERN KH 00161777 [លេខរៀងទី ១ - ហែម អាង ហៅ ស៊ីន នយោបាយកងធំ ពេទ្យកងពល ប្រពន្ធអាសុក- ចូលថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៧៧]។ ឯកសារ D9.3 បញ្ជីអ្នកទោស ស-២១ មកពីកងពល១៦៤ រៀបរៀងដោយ ក.ស.ច.ស លេខរៀងទី ១០។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.2 ["ស៖ តើលោកប្រាប់យើងបានឬទេថា លោកស្គាល់ឈ្មោះ ហែម អាង ហៅស៊ីន ក្នុងលេខរៀង ៨៩ ក្នុងបញ្ជីនេះយ៉ាងម៉េច? ឆ.2៖ ខ្ញុំស្គាល់ ស៊ិន ជាប្រពន្ធរបស់វេជ្ជបណ្ឌិត សុខ ដែលជាវេជ្ជបណ្ឌិតរបស់កងពល ១៦៤។ នៅពេលនោះ ខ្ញុំឮពីយោធានៅក្នុងកងរបស់ខ្ញុំ និយាយថា គេបានឃើញវេជ្ជបណ្ឌិត សុខ ត្រូវបានគេដាក់ច្រវាក់ និងឃុំនៅរោងម៉ាស៊ីនកិនស្រូវនៅក្នុងវត្តស្មាច់ដែង"]។ ក្រោយការចាប់ខ្លួនសុខ និងហែម អាង ហៅ ស៊ីន កូនរបស់ពួកគេ ត្រូវឱ្យធ្វើការនៅការដ្ឋានពុតទេ បន្ទាប់មកពួកយោធាបានមកនាំយកទៅ ហើយបាត់ខ្លួនរហូត៖ ឯកសារ D54/117 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន ឆ.18-21, 23 ["កូនសុខ ជាអ្នកប្រាប់ខ្ញុំថា គេចាប់សុខ និងប្រពន្ធរបស់គាត់ទៅដាក់នៅស្ពានទឹកសាប [...] ឆ.19៖ កូនស្រីច្បងរបស់សុខ ឈ្មោះ ចាន់ កូនប្រុសរបស់គាត់ ខ្ញុំមិនស្គាល់ឈ្មោះទេ តែអ្នកនៅជាមួយគាត់ពីរនាក់ទៀតឈ្មោះ ប៊ុន និង សារឹម [...] ឆ.20៖ ក្រោយមកគេបានឱ្យមនុស្សបួននាក់នោះ ទៅជួយជញ្ជូនសម្ភារៈមួយភ្លែតមកវិញមិនបាច់ផ្លាស់ខោអាវទេ ហើយក៏ទៅបាត់ទៅ។ នៅសហករណ៍ពុតទេ គេដាក់សុទ្ធតែជាប់ពាក់ព័ន្ធ [ជាអ្នកក្បត់ [...] ឆ.21៖ ខ្ញុំមិនដឹងថា គេយកទៅសម្លាប់ចោល ឬមួយក៏យ៉ាងម៉េចទេ [...] ឆ.23៖ មានទាហានមកហៅទៅ ពេលមកពីស្រែវិញទាំងខោអាវប្រលាក់ភក់ មិនដឹងទៅណា"]។

1206 ក្រៅពីពី យ៉ាន និងង៉ែត គឺ សំ មេបញ្ជាការកងវរសេនាធំ១៤០ និង សាន់ ស៊ាប ហៅ សំ មេបញ្ជាការរងកងវរសេនាធំ៦២ ក៏ជាប់គុក និងត្រូវសម្លាប់នៅមន្ទីរ ស-២១ ផងដែរ៖ សំ មេបញ្ជាការកងវរសេនាធំ១៤០៖ ឯកសារ D114/230.1.1 បញ្ជីអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ១៤៥៦១។ ឯកសារ D9.3 បញ្ជីអ្នកទោស ស-២១ មកពីកងពល១៦៤ រៀបរៀងដោយ ក.ស.ច.ស លេខរៀង ៣៩។ ឯកសារ D1.3.1.8 ចម្លើយសារភាព ស-២១ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៧៦។ សាន់ ស៊ាប ហៅ សំ មេបញ្ជាការរងកងវរសេនាធំ៦៖ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង ៨១៧៦។ ឯកសារ D9.3 បញ្ជីអ្នកទោស ស-២១ មកពីកងពល ១៦៤ រៀបរៀងដោយ ក.ស.ច.ស លេខរៀង ៤០ [ចូលខែមេសា ឆ្នាំ១៩៧៧ សម្លាប់នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៧]

។ ឯកសារ D1.3.28.40 បញ្ជីឈ្មោះអ្នកទោសកម្មេច នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៧ KH 00009083-85, EN 00873165-73 [លេខរៀង ១៧ – សាន់ ស៊ាប ចូលនៅខែមេសា ឆ្នាំ១៩៧៧]។ ឯកសារ D1.3.28.49 កំណត់ត្រាសួរចម្លើយរបស់មន្ទីរ ស-២១ [លេខរៀង ១៨ – កត់ត្រាថា សាន់ ស៊ាប ចូលនៅថ្ងៃទី២១]។ ឯកសារ D1.3.28.27 កំណត់ត្រាសួរចម្លើយកងពល១៦៤ របស់មន្ទីរស-២១ [លេខរៀង ៣ – ចង្អុលបង្ហាញថា សាន់ ស៊ាប ចូលនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៧៧]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ.64 ["មានឈ្មោះ ង៉ែត, ឈ្មោះ ឌីម, ឈ្មោះ យ៉ាន, ឈ្មោះ ឆាន និងឈ្មោះ សុខ ជាដើម ដែលគេចោទថាជាគិញវៀតណាម ឬក៏ សេ.អ៊ី.អា"]។

1207 ឯកសារ D114/230.1.1 បញ្ជីអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង ៤៥០ [ ឈុន លុន ហៅ សំអាត កងវរៈសេនាតូចនយោបាយ [ចូលថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៧៦], លេខរៀង ២៣៦៨ [គង់ គៀន ហៅ អ៊ឹង ឬ អ៊ឹង វ៉េត លេខាកងកវរសេនាតូច៦៣១ នៃកងវរសេនាធំ៦៣ [ចូលនៅខែមេសា ឆ្នាំ១៩៧៧ សម្លាប់នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៨], លេខរៀង ៣២២៣ [គុណា ឌីម អនុលេខាកងវរសេនាតូច១៤១ [ថ្ងៃទី២០ ឬ២៥ ខែមេសា ឆ្នាំ១៩៧៧], លេខរៀង ៣៩៩៤ [គង់ ស៊ាន ហៅ សាន លេខាកងវរសេនាតូច១៤២ [ចូលថ្ងៃទី២៧ ឬ២៨ ខែមេសា ឆ្នាំ១៩៧៧ ស្លាប់ដោយសារជំងឺ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨], លេខរៀង ៤១៥៩ [ណុប នន លេខាកងវរសេនាតូច៦២១- ចូលថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៧៧], លេខរៀង ៧២០៧ [ប៉ែន លេខាកងវរសេនាតូច១៧០ - ចូលថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៧ ស្លាប់ដោយសារជំងឺ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨], លេខរៀង ៧៥២៦ [ចឹក ស្រេង លេខាកងវរសេនាតូច - ចូលថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៧ ស្លាប់ដោយសារជំងឺ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៩៧៨], លេខរៀង៧៥៤៦ [ងួន ឡាក់ ហៅ សារ៉ាត សមាជិកកងវរសេនាតូច១៧០ - ចូលថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៧ សម្លាប់នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៨], លេខរៀង ១៣១៥៥ [សេក ហៀង អនុលេខាកងវរសេនាតូច៦១៣ - ចូលថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៧ ស្លាប់ដោយសារជំងឺ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨]។ ឯកសារ D9.3 បញ្ជីអ្នកទោស ស-២១ មកពីកងពល ១៦៤ រៀបរៀងដោយ ក.ស.ច.ស លេខរៀង ៦ [កំណត់អត្តសញ្ញាណឈ្មោះ ឈុន លុន ជាអនុលេខាកងវរសេនាតូច ១៦៥], លេខរៀង ៨, ១៦ (និងស្ទួន១៨), លេខរៀង ១៧ [គុណា ឌីម សម្លាប់នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៧], លេខរៀង២០, ៣០, ៣៤, ៣៦។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.4 ["អ្នកដែលត្រូវចាប់ខ្លួនៈ [...] មេបញ្ជាការវរៈសេនាតូចរបស់ខ្ញុំឈ្មោះ វ៉េត"]។ ឯកសារ D114/85 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.14-16 [ពន្យល់ថា ប៉ែន ហម ត្រូវបានចាប់ខ្លួនបន្ទាប់ពីការចាប់ខ្លួន ឆាន និងឌីម], ឆ.18 [ពន្យល់ថា គ្រប់គ្នាដឹងអំពីការចាប់ខ្លួន គង់ គៀន ហៅ អ៊ឹង វ៉េត ព្រោះគាត់ជាមនុស្សលេចធ្លោម្នាក់], ឆ.28-29 [លើកឡើងថា គុណា ឌីម គឺ "មកពីកងវរៈសេនាតូច១៤១ នៃកងវរៈសេនាធំ១៤០។ គាត់មកពីតំបន់២២ នៃភូមិភាគបូព៌ា [...] ឆ.29៖ ការចាប់ខ្លួនគាត់គឺធ្វើឡើងដោយសម្ងាត់"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.3 ["វ៉េត គឺជាប្រធានវរៈសេនាតូច៦៣១ [...] វ៉េត នៅកងទ័ពជើងគោក មានទីតាំងនៅព្រលានយន្តហោះកងកេង ហើយគាត់ត្រូវបានចាប់ខ្លួន [...] ខ្ញុំជឿថា គាត់ស្លាប់ហើយ ពីព្រោះនៅពេលដែល តាមុត ប្រជុំប្រាប់អំពីចម្លើយសារភាព ហើយតាមុត បានប្រកាសថា វ៉េត ក្បត់ហើយ"], ឆ.6 [ពន្យល់ថា ណុប នន បោះទីតាំងនៅកោះពូលូវៃ្វ និងជាមេបញ្ជាការនៃកងវរៈសេនាតូច៦២១ ឬ៦២២] ។ ឯកសារ D114/139 កំណត់ហេតុស្តាប់ចម្លើយ ងួន ឡាយ ហៅ អ៊ី ឆ.36, 65-66, 74, 77 ["ដឹងតែកោះសេះ លេខ ៣១ ឈ្មោះវ៉េត គាត់ស្លាប់បាត់ហើយ [...] ឆ.65៖ [វ៉េត] គេចាប់គាត់ [...] ឆ.66៖ ពេលដែលគាត់ទៅសិក្ខាសាលា នៅលើគោក គេចាប់គាត់ទៅ ខ្ញុំឮគេនិយាយអ៊ីចឹង។ ពេលដែលគាត់ទៅគោកអីហ្នឹង ទូកខ្ញុំក៏ដឹកគាត់ទៅចូលរួមសិក្ខា

បង្គាប់ផ្ទាល់ និងសមាជិកគ្រួសាររបស់កម្មាភិបាលទាំងនោះក៏ត្រូវបានចាត់ទុកថាស្ថិតក្នុង "បណ្ដាញជនក្បត់" ផងដែរ និងត្រូវបានបោសសម្អាត[1209]។

---

សាលាអីទៅ [...] សៈ មេៗដែលគេហៅទៅសិក្ខាសាលា ដូចជាវ៉េតជាដើម តើពួកគេមានបានត្រឡប់មកវិញទេ? ឆ. 74៖ មានតែមួយហ្នឹងទេ កាលជំនាន់ហ្នឹងដែលមិនត្រឡប់មកវិញ [...] សៈ តើលោកដឹងថា គេចាប់ខ្លួន វ៉េត នៅពេលហ្នឹងតែម្ដង? [...] ឆ.77៖ បាទ ពួពេលដែលអ្នកសិក្ខាសាលាត្រឡប់មកវិញ"]។ ឯកសារ D1.3.18.4 ចម្លើយសារភាពមន្ទីរស-២១ របស់ គង់ គៀន ហៅ អ៊ឹង វ៉េត (លេខាកងវរសេនាតូច៦៣១) EN 00822048, KH 00017305, FR 00825431 [មានចំណារអក្សរដៃ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៧ ថា "មនុស្សភាគច្រើនពាក់ព័ន្ធខាងកងសមមិត្ត មុត។ មួយចំនួនពាក់ព័ន្ធខាង ៣៣ + ៣៥"]។ ឯកសារD4.1.1066 ចម្លើយសារភាពមន្ទីរស-២១ របស់ ប៉ែន ហម EN 00822394-95, KH 00174141, FR 00966819 [មានចំណារអក្សរដៃថា៖ "អានេះនៅខ្សែអាញ៉ុក, អានាន និងអាសួន លេខាស្រុក៥២ តំបន់៣៣"។ ចំណារអក្សរដៃមួយទៀត៖ "១. ឯកសារនេះពាក់ព័ន្ធនឹង [...] កងពលសមមិត្តមុត [...]។ ៣.ខាងកងពលសមមិត្តមុត កំណត់ឈ្មោះសំខាន់ៗ ។ ខាងយើងនឹងដោះស្រាយ"]។

1208 ឯកសារ D114/230.1.1 បញ្ជីអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ១២៧៣ [ចែត គឹមឈឿន ហៅ គឹម អេង – ចូលថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៦], លេខរៀង ៤១៦០ [សុខ អឿន លេខាកងអនុសេនាធំ២២ កងវរសេនាតូច ៦១១ – ថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៧៧], លេខរៀង ៦៤០២ [អ៊ូច ចាន់ថុល ឬថន – ថ្ងៃទី៣១ ខែឧសភា ឬថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៧៦],លេខរៀង ៦៨៧៦ [ពៅ ឈាន ហៅ ប៊ុន នី មេបញ្ជាការកងអនុសេនាធំ – ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ១៩៧៦], លេខរៀង ៨៦១៨ [សឹង គ្រីន ហៅ ងួន មេបញ្ជាការកងអនុសេនាធំ – ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៦], លេខរៀង ៩៨៧៦ [សូ សុខុម – ថ្ងៃទី៣១ ខែឧសភា ឬថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៧៦], លេខរៀង ១០៥៧១ [សែម សុត – ថ្ងៃទី ១៥ ឬ១៦ ខែមិថុនា ឆ្នាំ១៩៧៦], លេខរៀង ១៣៣៨១ [វង់ ឡឹង ហៅ ថន មេបញ្ជាការកងអនុសេនាតូច – ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ១៩៧៦], លេខរៀង ១៣៦៧៥ [កែន ខុន – ចូលថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៧៦ សម្លាប់នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦], លេខរៀង ១៣៨៧០ [យឹម សារុធ ហៅ ម៉េង – ថ្ងៃទី៣១ ខែឧសភា ឬថ្ងៃទី០១ ខែមិថុនា ឆ្នាំ ១៩៧៦]។

1209 អំពីការពាក់ព័ន្ធនឹងថ្នាក់ក្រោមផ្ទាល់ សូមមើល ឧទាហរណ៍៖ ឯកសារ D54/115 កំណត់ហេតុស្ដាប់ចម្លើយ នាក់ យឿន ឆ.13, 15, 18, 22-24 ["កាលដែលខ្ញុំធ្វើការនៅដីគោក ពេលដែលខ្ញុំនៅកងកេង ខ្ញុំធ្វើការនៅក្រោមបញ្ជារបស់ យ៉ាន។ ក្រោយមក យ៉ាន បានបាត់ខ្លួន ហើយខ្ញុំសួរអំពីបាត់ខ្លួនរបស់ យ៉ាន តែគេប្រាប់ខ្ញុំថាឱ្យឈប់សួរអំពីឈ្មោះ យ៉ាន នេះ។ ក្រោយមក គេបញ្ជូនខ្ញុំឱ្យទៅរៀននៅកំពង់សោម ដែលអ្នកទៅរៀនទាំងអស់ត្រូវបានឱ្យធ្វើប្រវត្តិរូប។ គេឱ្យយើងរាយការណ៍ថា យើងបានធ្វើការនៅក្រោម យ៉ាន ដែរឬអត់។ តែសម្រាប់ខ្ញុំ ខ្ញុំធ្វើការនៅក្នុងកងវរៈសេនាធំជាមួយតែខ្ញុំមិនស្ថិតនៅក្រោមគាត់ផ្ទាល់ទេ [...] ឆ.15៖ កាលនោះ គឺជាការរៀនសូត្រដែលមានរយៈពេល៥ថ្ងៃ។ នៅក្នុងវគ្គរៀនសូត្រនោះ គេឱ្យយើងធ្វើប្រវត្តិរូប។ កម្មាភិបាលកងពល ដែលបញ្ជាឱ្យយើងធ្វើប្រវត្តិរូបនោះមាន តាញ៉ាន់ និងតាមុត [...] ឆ.18៖ តាមខ្ញុំសន្និដ្ឋានគឺគេមានចេតនារកចាប់ខ្លួនអ្នកដែលជាប់ពាក់ព័ន្ធនឹង យ៉ាន [...] ឆ.19៖ មានពាក្យស្លោក និយាយថា ដកស្មៅ គឺដកទាំងឫស។ ការចាប់ យ៉ាន គឺធ្វើជាសម្ងាត់ ហើយមានតែអ្នកនៅក្បែរ និងស្និទ្ធនឹង យ៉ាន ទេដែលអាចដឹង។ ដូច្នេះហើយ ទើបខ្ញុំយល់ថា គេតាមរយៈការចាប់ខ្លួនអ្នកដែលស្និទ្ធនឹងយ៉ាន [...] ឆ.22៖ នៅ

348. ការបោសសម្អាតអ្នកនៅក្រោមបង្គាប់ទាំងអស់របស់ ជ័យ ហាន ហៅ ឆាន (នង ឆាន) និង ហឹង ឡឿន ហៅ ឌឹម ត្រូវបានធ្វើឡើងយ៉ាងតឹងតែង និងជាលក្ខណៈប្រព័ន្ធ ពីព្រោះទាហានទាំងនោះមិន

---

ថ្ងៃចុងក្រោយនៃវគ្គរៀនសូត្រនោះ ពេលគឺក្នុងម៉ោងធ្វើប្រវត្តិរូប សំណួរត្រូវបានសួរ ឱ្យអ្នកចូលរួមឆ្លើយ។ សំណួរមួយក្នុងចំណោមសំណួរទាំងនោះ គឺសួររកអ្នកដែលធ្លាប់ធ្វើការជាមួយនឹង យ៉ាន [...] ឆ.23៖ ម៉ោងធ្វើប្រវត្តិរូបនៅថ្ងៃបិទវគ្គគឺ មាស មុត ជាអ្នកបង្រៀន។ គាត់បានអានសំណួរទាំងអស់ជាមួយនឹងអ្នកចូលរួម។ គាត់បានពន្យល់ដល់អ្នកចូលរួមនូវសំណួរទាំងអស់ក្នុងក្រដាសប្រវត្តិរូប និងចម្លើយដែលត្រូវឆ្លើយ [...] ស៖ តាមលោកដឹង តើមានអ្នកចូលរួមណាបាត់ខ្លួនទេ ក្រោយពីវគ្គរៀនសូត្រនេះ? ឆ.24៖ តាមសង្កេតរបស់ខ្ញុំ មានមនុស្សបីបួននាក់ ដែលធ្វើការផ្ទាល់ជាមួយ យ៉ាន បានបាត់ខ្លួន តែខ្ញុំមិនស្គាល់ឈ្មោះពួកគេទេ។ អ្វីដែលខ្ញុំដឹងគឺថា បន្ទាប់ពីបាត់ខ្លួន យ៉ាន មនុស្សខ្លះដែលស្និទ្ធនឹងគាត់ ត្រូវបានបញ្ជូនទៅធ្វើការនៅអង្គភាពផ្សេងៗនៅកំពង់សោម។ ការរៀនសូត្រ និងការធ្វើប្រវត្តិរូប គឺធ្វើឡើងដើម្បីចម្រាញ់រកអ្នកទាំងនោះ"]។ ពាក់ព័ន្ធនឹងប្រពន្ធ កូន និងបងប្អូនបង្កើត ៖ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.3 ["ដូចជាឧទាហរណ៍ ប្រធានកងវរៈសេនាធំក្តី បើគាត់ត្រូវគេចាប់ខ្លួន គ្រួសារប្រពន្ធគាត់ក៏ត្រូវចាប់ខ្លួនដែរ។ ប៉ុន្តែខ្ញុំមិនដឹងថា គេយកគាត់ទៅធ្វើអ្វីទេក្រោយគឺការចាប់ខ្លួន។ នៅក្នុងពេលនោះ ជាទូទៅបន្ទាប់ពីគេចាប់ខ្លួនរណាម្នាក់ហើយ អ្នកនោះបាត់ខ្លួនរហូត។ បើយោធាណាត្រូវគេចាប់ខ្លួន យោធានោះត្រូវបាត់ខ្លួនរហូត។ ដូចដែលខ្ញុំបានជំរាប បើសិនជាមេបញ្ជាការវរៈសេនាធំណាត្រូវបានចាប់ខ្លួនដោយចោទប្រកាន់ថា ថាជា កា.ហ្សេ.បេ ឬសេ.អ៊ី.អា ប្រពន្ធកូនគាត់ និរសារ និងអ្នកជិតដិតក៏ត្រូវចាប់ខ្លួនដែរ។ ជាពិសេសពួកអ្នកដែលត្រូវបានចោទថា ជាប់ទាក់ទងនឹងខ្មែរយួន"]។ អំពីការបោសសម្អាតប្រពន្ធកម្មាភិបាលកងពល១៦៤ (រួមទាំងអ្នកជាសមាជិកកងពល១៦៤) បន្ទាប់ពីចាប់ខ្លួនប្តី សូមមើល ឯកសារ D54/117 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន ឆ.7-8 [នារីពេទ្យកងពល១៦៤ បង្ខំឱ្យរៀបការជាមួយទាហានម្នាក់នៃកងពល១៦៤ នៅចុងឆ្នាំ១៩៧៦ ឈ្មោះ ឆាន ហៅ អ៊ុង ឬទឹម ហើយក្រោយមក គេថាក្បត់ ហើយចាប់ខ្លួន។ ក្រោយមក នារីពេទ្យត្រូវបញ្ជូនទៅធ្វើស្រែ នៅសហករណ៍ពុតទេ និងកងចល័ត]។ ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន ឆ.69, 74, 77-78, 124 ["សមមិត្ត ពង់ ដែលមកពីស្រុកកំណើតជាមួយខ្ញុំមកប្រាប់ខ្ញុំថា ប្តីរបស់ខ្ញុំគេបានចាប់បាត់ហើយ តែគាត់ប្រាប់ថាកុំឱ្យខ្ញុំនិយាយប្រាប់នរណា។ ហើយប្រហែល ១០ថ្ងៃក្រោយមក គេក៏យកខ្ញុំទៅធ្វើការនៅតាមវាលស្រែ [...] ឆ.74៖ ខ្ញុំឮពាក្យចចាមអ៊ាមថា គេយកគាត់ទៅទឹកសាបនៅកំពង់សោម [...] ឆ.77៖ ខ្ញុំគ្រាន់តែគិតថាមកពីគេចាប់ប្តីខ្ញុំទៅហ្នឹងហើយ បានជាគេបញ្ជូនខ្ញុំមកធ្វើការនៅការដ្ឋានវាលស្រែ។ ស៖ តើលោកស្រីគិតថានេះជាការដាក់ទណ្ឌកម្មចំពោះប្រពន្ធរបស់យោធាដែលគេចាប់ខ្លួនដែរ ឬទេ? ឆ.78 ៖ ចាស វាជាការដាក់ទណ្ឌកម្ម [...] ស៖ តើតាយ៉ាន ជាអ្នកកាន់កងពលរហូតមែនដែរ ឬទេ? ឆ.124៖ កាលគេដឹកខ្ញុំមកដល់សហករណ៍ពុតទេ ខ្ញុំជួបប្រពន្ធគាត់នៅទីនោះ ហើយគាត់ប្រាប់ខ្ញុំថា គេបានចាប់តាយ៉ាន ទៅគុកទួលស្លែង ឬក៏ក្រាំងស្លែង"]។ ឯកសារ D114/185 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.29 ["តាឌឹម ជាអនុរបស់មាស មុត។ គុណ ឌឹម [នៅក្នុងកងវរៈសេនាតូច១៤១] [...] នៅពេលដែលគាត់បាត់ខ្លួន ប្រពន្ធនិងកូនរបស់គាត់ក៏បានបាត់ខ្លួនផងដែរ"]។ សូមមើលផងដែរ ជើងទំព័រ ១២០៥ រៀបរាប់អំពីរបៀបបោសសម្អាត ហែម អាង ហៅ ស៊ីន (ពេទ្យកងពល១៦៤) ប្រពន្ធរបស់សុខ ដែលជាប្រធានពេទ្យកងពល១៦៤ ក្រោយការចាប់ខ្លួនប្តីរបស់គាត់ និងរបៀបស្រដៀងគ្នាដែលកូនទាំងបួនរបស់ពួកគេត្រូវបានចាប់ខ្លួន និងបាត់ខ្លួន។

មែនមកពីកងពលលេខ ៣ នៃភូមិភាគនិរតីដែលគេទុកចិត្ត ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ **មាស មុត** តាំងពីឆ្នាំ ១៩៧៣-១៩៧៤។ ផ្ទុយទៅវិញ មេបញ្ជាការទាំងនោះ តាំងពីដើមមក ស្ថិតនៅក្នុងតំបន់ ៣៧ (ឆាន) និងភូមិភាគបូព៌ា (ឌឹម)[1210]។ ការបោសសម្អាតមេបញ្ជាការទាំងនោះជាវិធីមួយដែល **មាស មុត** បានប្រើប្រាស់ ដើម្បីពង្រឹងសិទ្ធិអំណាចរបស់គាត់លើទាហានរបស់គាត់។ លើសពីនេះទៀត ការចាប់ខ្លួន និងការសួរចម្លើយកម្មាភិបាលទាំងនេះមានហានិភ័យតិចតួច ចំពោះការចូលរួមផ្ទាល់របស់ **មាស មុត** ពីព្រោះពួកគេមិនស្ថិតក្នុងបណ្ដាញផ្ទាល់របស់គាត់នោះទេ។

### បណ្ដាញតំបន់ ៣៧ (កងវរសេនាតូច ៣៨៦ ចាស់) ក្រោមការគ្រប់គ្រងរបស់ ជ័យ ហាន ហៅ ឆាន សមាជិកគណៈកងពល ១៦៤

349. តាឆាន ហៅ នង ឆាន ឬ ជ័យ ហាន ហៅ ឆាន[1211] សមាជិកគណៈតំបន់ ៣៧ ទទួលបន្ទុកកងទ័ពតំបន់ (មុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥)[1212] ដែលមានកងវរសេនាតូចច្រើន (៣៨៥, ៣៨៦,

---

1210 សូមមើល កថាខណ្ឌ៣៤៩, ៣៥៥។ ឯកសារ D114/85 កំណត់ហេតុស្ដាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.19 ["គេចាប់ខ្លួនអ្នកដែលនៅក្រោមៗ ឌឹម និងឆាន ហើយការចាប់ខ្លួនទាំងនេះក៏មិនត្រូវបានប្រកាសជាសាធារណៈដែរ"]។

1211 ឪពុករបស់គាត់ មានឈ្មោះ ជ័យ សួន ឬ នង សួន (ឯកសារ D4.1.26 ចម្លើយសារភាពមន្ទីរស-២១ របស់ ជ័យ សួន ហៅ នន សួន ហៅ សែន អតីតរដ្ឋមន្ត្រីក្រសួងកសិកម្ម)។ ដូច្នេះមានឈ្មោះពីរដែល តាឆាន ផងដែរ៖ ឯកសារ D114/85 កំណត់ហេតុស្ដាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.10 ["គឺប្រហែលក្នុងចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ ដែលមាស មុត បានប្រកាសថា ឈ្មោះ ជ័យ ឆាន ដែលជាកូនរបស់ ជ័យ ឬនង សួន ជារដ្ឋមន្ត្រីសេដ្ឋកិច្ចបានធ្វើជាជនក្បត់ឲ្យវៀតណាម"]។ ឯកសារ D54/29 កំណត់ហេតុស្ដាប់ចម្លើយ លៀត ឡូន (ណាំ ឡូន) ឆ.24 ["ឆាន ជាក្មួយរបស់ នង សួន។ គាត់បានក្លាយជាសមាជិករបស់កងពល១៦៤ បន្ទាប់ពី ឌឹម មកដល់។ ឆាន គឺជាមេបញ្ជាការយោធា ប្រតិបត្តិការនៅតំបន់សងខាងផ្លូវជាតិលេខ៤ នៅកំពង់សិលា និងកំពង់សោម តាំងពីឆ្នាំ១៩៧១ រហូតដល់ឆ្នាំ១៩៧៥។ នៅពេលនោះ តំបន់នោះហៅថាតំបន់៣៧"]។ ឯកសារ D2/9 កំណត់ហេតុស្ដាប់ចម្លើយ សយ ប៊ន ឆ.30-31 ["ក្រោយពីការរៀបចំឡើងវិញរបស់កងពល១៦៤នេះ លោក មុត ជាប្រធាន លោក ឌឹម ជាអនុប្រធានដែលមកពីបូព៌ា និងលោក ឆាន ជាសមាជិក [...] ឆ.31៖ ឆាន នៅពេលនេះ ខ្ញុំសំដៅប្រហែលទៅលើ សួន ឆាន"]។ ឯកសារ D114/277.2 កាំងហ្គេកអ៊ាវ ហៅ ឌុច ប្រតិចារឹកចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ 11.07.31-11.13.08 ["ឆាន់ ឈ្មោះបដិវត្តន៍ទេ។ ឈ្មោះដើមរបស់វា ជ័យ ហាន។ ជ័យ ហាន ហៅ ឆាន់។ វាជាអនុលេខាកងពល១៦៤ ជាមួយបងមុត [...] ឪពុករបស់ឆាន់ ឬឪពុកអាជ័យ ហាន នេះគឺបង នង សួន ហៅជ័យ សួន"]។ ឯកសារ D114/33 កំណត់ហេតុស្ដាប់ចម្លើយ ហែម អាង ឆ.13 [ជ័យ ឆាន់]។ កំណត់ត្រាមន្ទីរស-២១ បាននិយាយអំពីឈ្មោះ ជ័យ ហាន ហៅ ឆាន់៖ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង ១៤១៥៦ [ជ័យ ហាន ហៅ ឆាន់ ចូលស-២១ នៅខែវិច្ឆិកា ឆ្នាំ១៩៧៦]។ ឯកសារ D114/145.1.1 ចម្លើយសារភាពមន្ទីរស-២១ របស់ ជ័យ ហាន ហៅ ឆាន់។ សាក្សីភាគច្រើនស្គាល់គាត់ថាជា តាឆាន ឬ នង ឆាន៖ ឯកសារ D114/89 កំណត់ហេតុស្ដាប់ចម្លើយ សេង ស៊ីន ឆ.

៣៨៧ និង ៣៨៨)[1213]។ សមាជិកកងវរសេនាតូច ៣៨៥, ៣៨៧ និង ៣៨៨ ភាគច្រើន ត្រូវបាន បញ្ជូនទៅភូមិភាគបស្ចិម ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[1214] ខណៈដែលកងទ័ពតំបន់ ៣៧ ផ្សេងទៀត ជាពិសេស កងវរសេនាតូច ៣៨៦ នៅតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ឆាន ក្នុងកងពល ១៦៤ ដដែល ហើយត្រូវបានចាត់ឲ្យយាមនៅតាមកោះផ្សេងៗ[1215]។ កងវរសេនាតូច

15, 60 ["កងពល១៦៤ហ្នឹងមាន មាស មុត ជាស្នងការធំ ហើយមាន នង ឆាន ជាបញ្ជាការកងពល១៦៤។ បន្ទាប់មក គឺ ខឹម ដែលជាបញ្ជាការរង [...] ឆ.60៖ ប្រជុំពីបញ្ហាមេក្បត់ គឺអនុមេបញ្ជាការកងពល១៦៤ នង ឆាន ជាអ្នកក្បត់ ហើយមាស មុត អានចម្លើយសារភាពរបស់ នង ឆាន ហ្នឹង"]។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ឺ រ៉េត ហៅសារ៉េត ឆ.7-8។ ឯកសារ D114/261 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី ឆ.34។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.28។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.168-ឆ.172។

1212 ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.36 ["ស៖ កាលពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលគេបែកភ្នំពេញ តើមេរបស់លោកឈ្មោះអ្វីដែរ? ឆ.36៖ ឈ្មោះឆាន។ គាត់កាន់គណៈតំបន់ និងជាមេបញ្ជាកងទ័ពតំបន់ផងដែរ"]។ ឯកសារ D114/33 កំណត់ហេតុស្តាប់ចម្លើយ ហែម អាង ឆ.13, 35។ ឯកសារ D114/226 កំណត់ហេតុស្តាប់ចម្លើយ គឹម ហាវ ឆ.22, ឆ.30-32 [ឆាន នៅតំបន់៣៧ កាន់ខាងទ័ព និងកាន់កាប់ក្រុងព្រះសីហនុ]។ ឯកសារ D114/140 កំណត់ហេតុស្តាប់ចម្លើយ ជា ផុន ឆ.10-12 [ឆាន គឺជានាយសេនាធិការតំបន់ នៅស្រុកព្រៃនប់ តំបន់៣៧]។ ឯកសារ D114/155 កំណត់ហេតុស្តាប់ចម្លើយ សុខ រ៉េន ឆ.67 ["ខ្ញុំស្គាល់ តាខឹម, តាយ៉ាន និងតាឆាន។ តាឆាន ចូលរួមកងពល១៦៤។ គាត់ធ្លាប់ធ្វើជានាយកសេនាធិការយោធាតំបន់៣៧"]។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ឺ រ៉េត ហៅសារ៉េត ឆ.7-8។

1213 ឯកសារ D114/33 កំណត់ហេតុស្តាប់ចម្លើយ ហែម អាង ឆ.9 [កងវរសេនាតូច៣៨៥ នៅក្នុងតំបន់៣៧]។ ឯកសារ D114/226 កំណត់ហេតុស្តាប់ចម្លើយ គឹម ហាវ ឆ.21-25, 30 [រៀបរាប់អំពីកងវរសេនាតូច ៣៨៥ នៅតំបន់៣៧]។ ឯកសារ D114/120 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ អ៊ុត ឆ.37 [ពន្យល់ថា កងវរសេនាតូច៣៨៨ គឺជាកងនារី នៅតំបន់៣៧]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.5 [ពន្យល់ថា មានកងជាច្រើនដូចជា កងវរសេនាតូច ៣៨៥, ៣៨៦, ៣៨៧ និង៣៨៨ នៅតំបន់៣៧ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥]។

1214 ឧទាហរណ៍ ឯកសារ D114/140 កំណត់ហេតុស្តាប់ចម្លើយ ជា ផុន ឆ.3-5, 19-20 [ពន្យល់ថា កងវរៈសេនាតូច ៣៨៧ ត្រូវបានផ្លាស់ប្តូរទៅកោះកុង និងក្លាយជាកងវរសេនាតូច ៣០៣ នៅក្រោមតំបន់១១ ភូមិភាគបស្ចិម]។ ឯកសារ D114/33 កំណត់ហេតុស្តាប់ចម្លើយ ហែម អាង ឆ.26 [មួយផ្នែកនៃកងវរសេនាតូច ៣៨៥ បញ្ជូនទៅអូរចំណារ ស្រុកព្រៃនប់ ភូមិភាគបស្ចិម។ ចម្លើយនេះពិភាក្សាអំពីការចាប់ខ្លួន និងការឃុំឃាំងនៅមន្ទីរសន្តិសុខកោះខ្យង ភូមិភាគបស្ចិម]។ ឯកសារ D114/120 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ អ៊ុត ឆ.19។

1215 ឯកសារ D22.2.181 ចម្លើយរបស់ មាស មុត អំពីឈ្លើយសឹកអាមេរិកបាត់ខ្លួនក្នុងសង្គ្រាម ERN KH 00741996-97 ["ទីបញ្ជាការដ្ឋានភូមិភាគនិរតីបានបង្កើតកងពលធំលេខ៣ ចេញសមាសភាពនៃតំបន់៣៧ និងកងវរៈសេនាតូចឯករាជ្យនៃភូមិភាគនិរតី [...] នៅពេលមានឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស ទីបញ្ជាការដ្ឋាននៃកងពលធំលេខ៣ មានទីតាំងស្ថិតនៅរាម។ កងពលធំនេះ មានកងវរៈសេនាធំលេខ៣៧, ១៤, ១៥ និង១៦ ស្ថិតនៅក្រោមបង្គាប់។ មូលហេតុដែល

៣៨៦ ស្ថិតក្រោមការគ្រប់គ្រងរបស់មេដឹកនាំកងពលលេខ ៣ ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មុននឹងត្រូវបានច្របាច់ចូលគ្នាជាផ្លូវការជាមួយកងពល ១៦៤ ថ្មី នៅខែ កក្កដា ឆ្នាំ ១៩៧៥[1216]។ ឆាន ជាមេបញ្ជាការរងទីពីរនៃគណៈកងពល ១៦៤ រហូតដល់ពេលគាត់ត្រូវគេបញ្ជូនទៅភ្នំពេញ និងចាប់ខ្លួនក្រោយមកទៀត[1217]។

---

គេដាក់ឈ្មោះថាជាកងវរៈសេនាធំលេខ៣៧ ពីព្រោះកងវរៈសេនាធំនេះ ត្រូវបង្កើតចេញពីកងកម្លាំងមកពីតំបន់៣៧"] ។ ឯកសារ D114/260 កំណត់ហេតុស្តាប់ចម្លើយ ស៊ិន សុត ឆ.6-9 ["សៈ តើមានអ្នកណាផ្សេងនៅក្នុងថ្នាក់ដឹកនាំរបស់កងវរៈសេនាតូចលេខ៣៨៦ ឬទេ? ឆ.6៖ នៅមួយទៀតបង សួន ឆាន ហ្នឹងគាត់ធំជាងគេហើយហ្នឹង គាត់ក្តាប់ប្រធានកងវរៈសេនាធំហើយ [...] ដំបូងគាត់នៅកងវរៈសេនាតូច ដល់ក្រោយមកឡើងដល់ កងវរៈសេនាធំ កាលជំនាន់ ៧៥ ចូលកងពលទី៣ ហ្នឹង កងពលធំលេខ១៦៤។ សៈ តើលោកសំដៅដល់វរៈសេនាធំលេខប៉ុន្មាន? ឆ.7៖ វរៈសេនាធំ ២១ហ្នឹង [...] សៈ សូមលោករៀបរាប់អំពីថ្នាក់ដឹកនាំរបស់អនុសេនាធំ៤២០? ឆ.9៖ កងវរសេនាតូចលេខ៣៨៦ មានបីកងអនុសេនាធំគឺ ៤០៨, ៤០៩ និង៤២០"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ កឹម ម៉េន ឆ.179-182 ["សៈ ពេលដែលនៅកោះតាង តើលោកមានចាំថា មានកងទ័ពប៉ុន្មាននាក់ ដែលមកពីតំបន់៣៧ទេ? ឆ.179៖ មកជាមួយបង ឆាន គឺមួយវរៈសេនាធំ ដែលមានបីកងវរៈសេនាតូច ឯចំនួនខ្ញុំមិនដឹងទេ ហើយគេរាយតាមកន្លែងផ្សេងៗ។ សៈ តើទាំងអស់ហ្នឹងសុទ្ធតែមកពីតំបន់៣៧ មែនទេ? ឆ.180៖ បាទ។ ឲ្យតែមកជាមួយបងឆាន គឺសុទ្ធតែមកពីតំបន់៣៧។"]។ ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.14, 21 ["នៅកោះសេះ វរៈ៣៨៦ មានពីរអនុសេនាតូច ហើយកងពលលេខ៣ មានពីរអនុសេនាតូច គេលាយគ្នា [...] ឆ.21៖ កងតំបន់ [៣៧] និងកងពលទី៣ បញ្ជូនទៅកោះពូលូវ៉ៃ កោះពូលូវ៉ៃថ្មី កោះពូលូវ៉ៃចាស់ កោះរ៉ុងសន្លឹម និងកោះរ៉ុងធំ ហើយនិងកោះម្នាស់ និងកោះតាង។ រួចកម្លាំងនៅសល់ប៉ុន្មាននៅដីគោក និងនៅលើកប៉ាល់"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញឹក ឆ.6 ["ប្រហែលពីរសប្តាហ៍ ក្រោយរំដោះហើយ កងវរៈសេនាតូច៣៨៦ ទាំងមូល ត្រូវបានពង្រាយទៅតាមកោះរ៉ុង កោះពូលូវ៉ៃ កោះតាង និងកោះព្រីង"]។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.39។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មួល ឈិន ឆ.23 ["ពួកខ្ញុំ កងវរៈសេនាតូច ៣៣៦ ដែលស្គាល់ភូមិសាស្ត្រនៅទីនោះច្បាស់ គេឲ្យប្រចាំការនៅលើកោះរ៉ុងហ្វា និងកោះរ៉ុងសន្លឹម"]។

1216 សូមមើលផងដែរ កថាខណ្ឌ ២១២ ជើងទំព័រ៥៨៦-៥៨៨។ ឯកសារ D22.2.181 ចម្លើយរបស់ មាស មុត អំពីល្បើយសឹកអាមេរិកបាត់ខ្លួនក្នុងសង្គ្រាម ERN KH 00741996-97 ["ទីបញ្ជាការដ្ឋានភូមិភាគនិរតីបានបង្កើតកងពលធំលេខ ៣ ចេញសមាសភាពនៃតំបន់៣៧ និងកងវរៈសេនាតូចឯករាជ្យនៃភូមិភាគនិរតី [...] នៅពេលមានឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស ទីបញ្ជាការដ្ឋាននៃកងពលធំលេខ៣ មានទីតាំងស្ថិតនៅរាម។ កងពលធំនេះ មានកងវរៈសេនាធំលេខ៣៧, ១៤, ១៥ និង១៦ ស្ថិតនៅក្រោមបង្គាប់។ មូលហេតុដែលគេដាក់ឈ្មោះថាជាកងវរៈសេនាធំលេខ៣៧ ពីព្រោះកងវរៈសេនាធំនេះ ត្រូវបង្កើតចេញពីកងកម្លាំងមកពីតំបន់៣៧"], ERN KH 00741998 ["គណៈបញ្ជាការនៃការពលធំលេខ ៣ រួមមាន៖ ឆាន ជាមេបញ្ជាការកងពលធំ។ គាត់ជាមេបញ្ជាការទទួលបន្ទុកក្នុងអំឡុងពេលមានឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស ប៉ុន្តែទីបញ្ជាការដ្ឋាននេះ ស្ថិតនៅកំពង់សោម និងរាម"]។ ឯកសារ D114/264 កំណត់ហេតុស្តាប់ចម្លើយ ជុំ

ជី ឆ.36 [“សៈ បើសិនបើកម្លាំងនេះជាការបូកបញ្ចូលគ្នារវាងកងពល១៦៤/កងពល៣ និងអង្គភាពយោធាតំបន់៣៧ តើប្រតិបត្តិការនេះធ្វើឡើងក្រោមការបញ្ជាជាទូទៅរបស់អ្នកណាដែរ? ឆ.36៖ ក្រោមការបញ្ជាទូទៅរបស់ មាស មុត ទាំងអស់”]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.7 [“សៈ កម្លាំងរបស់តំបន់៣៧ ត្រូវបានបញ្ចូលជាមួយនឹងកងពលលេខ៣។ ឆ.7៖ បាទ”]។ ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯកនី ឆ.6-7, 9។ ឯកសារ D54/109 កំណត់ហេតុស្តាប់ចម្លើយ សៅ សំ ឆ.3។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.8។ ឯកសារ D114/261 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី ឆ.2។ ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.13។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.30, 39។ ឯកសារ D54/76 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ឹក ឆ.8-9។ ឯកសារ D114/155 កំណត់ហេតុស្តាប់ចម្លើយ សុខ រ៉េន ឆ.64។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.19។ ឯកសារ D4.1.754 ចម្លើយកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ មិនស្គាល់ឈ្មោះ អំពីឈ្លើយសឹកអាមេរិកបាត់ខ្លួនក្នុងសង្គ្រាម ERN KH 00791380, 00791383។ ឯកសារ D4.1.752 ចម្លើយអ្នកមិនស្គាល់ឈ្មោះ អំពីឈ្លើយសឹកអាមេរិកបាត់ខ្លួនក្នុងសង្គ្រាម ERN KH 01519660។ ឯកសារ D4.1.757 ចម្លើយអ្នកមិនស្គាល់ឈ្មោះ អំពីឈ្លើយសឹកអាមេរិកបាត់ខ្លួនក្នុងសង្គ្រាម ERN KH 01507818-01507819។

1217 ប្រភពភាគច្រើនកំណត់អត្តសញ្ញាណ ឆាន ជាអនុមេបញ្ជាការមួយក្នុងចំណោមអនុមេបញ្ជាការទាំងពីរនៃកងពល១៦៤ (អនុមេបញ្ជាការទី១ គឺ ឌឹម)។ ប្រភពប៉ុន្មាននាក់ផ្សេងទៀតថា គាត់ជាសមាជិកនៃគណៈកងពល១៦៤ (និងគណៈកងពល៣ មួយរយៈពេលក្រោយពេលការច្របាច់បញ្ចូលគ្នារវាងកងពល៣ និងកម្លាំងតំបន់៣៧ របស់ ឆាន់ រួមទាំងកងវរៈសេនាតូច៣៨៦)៖ ឯកសារ D114/277.2 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹកចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ 11.07.31-11.13.08 [“ជ័យ ហាន ហៅ ឆាន់។ វាជាអនុលេខាកងពល១៦៤ ជាមួយបងមុត”]។ ឯកសារ D114/159 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ឆ.3 [“មនុស្សសំខាន់គេចាប់មកពីកំពង់សោម ដូចជា សៅ ឆាន់ ហៅ ហាន ជាកូនប្រុសរបស់ នង សួន។ ខ្ញុំសូមកែឈ្មោះ។ វាគឺ ជ័យ ហាន ហៅ ឆាន់”]។ ឯកសារ D234/2.1.92 ព្រុំ សារ៉ាត ប្រតិចារឹកចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ 15.03.11 [លើកឡើងថា សមាជិកគណៈកងពល រួមមាន មាស មុត, ឌឹម, ឆាន និងញ៉ាន់]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត ឆ.86 [“មេបញ្ជាការកងពល ១៦៤ ឈ្មោះ មាស មុត ទទួលបន្ទុកកិច្ចការនយោបាយ។ ឌឹម មេបញ្ជាការរងកងពល ទទួលបន្ទុកកិច្ចការយោធា។ ឆាន ទទួលបន្ទុកមេបញ្ជាការរង។ ញ៉ាន់ ទទួលបន្ទុកខាងភស្តុភារ”]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.267, 269 [“អ្នកណាជាបញ្ជាការរងកងពល? ឆៈ តាឌឹម និងតាឆាន [...] ឆ.269៖ តាឆាន ជាអនុបញ្ជាការកងពល”]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.28 [“នៅពេលកងពលលេខ៣ ប្តូរទៅជាកងពល ១៦៤ នៅកំពង់សោម មាន មាស មុត ជាមេបញ្ជាការ ហើយមេបញ្ជាការរងត្រូវបានផ្លាស់ប្តូរជាបន្តបន្ទាប់ ដែលរួមមាន តារិន, តាឆាន និងតាឌឹម”]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.9, 12 [“មានអនុពីរផ្សេងទៀត នៅក្រោម [មាស មុត] ឈ្មោះ ឆាន និង ឌឹម [...] ឆ.12៖ មានអនុរបស់គាត់ពីរនាក់ទៀត ឈ្មោះ ឆាន និង ឌឹម។ ឌឹម គឺជាអនុទី១ របស់មាស មុត”]។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ើ រ៉េត ហៅសារ៉េត ឆ. 7 [“ក្រោយពីកងពល៣ ប្តូរទៅជាកងពល១៦៤ មានមនុស្សម្នាក់ឈ្មោះ តាឆាន ដែលមកពីកោះកុង នៃតំបន់៣៧ ជាមួយនឹងយោធាប្រហែលពីរកងវរៈសេនាតូចចូលជាមួយកងពល១៦៤។ តាឆាន មកធ្វើជាអនុម្នាក់របស់កងពល”]។

350. នង ឆាន ត្រូវបានបញ្ជូនពីកងពល ១៦៤ ទៅ ស-២១ ហើយប្រាកដណាស់ គឺដោយមានការឯកភាពពី **មាស មុត**[1218] បន្ទាប់ពីធ្វើការរយៈពេលខ្លីនៅសេនាធិការនៅភ្នំពេញ[1219]។ គាត់ត្រូវ កាំង

ឯកសារ D4.1.746 ចម្លើយរបស់ សំ សុក អំពីល្បើយសឹកអាមេរិកបាត់ខ្លួនក្នុងសង្គ្រាម EN 00387462, KH 00742596 ["មន្ត្រីនយោបាយរបស់កងពលធំលេខ៣ គឺ ((មាស)) មុត។ មន្ត្រីប្រតិបត្តិការកងពលធំលេខ៣ គឺ ((ខំ)) (ស្លាប់) ហើយមេបញ្ជាការរងនៃកងពលធំលេខ៣ គឺ ((ឆាន))"]។ ឯកសារ D114/241 កំណត់ហេតុស្តាប់ចម្លើយ ឆេង ជាង ឆ.87 ["ឆាន អនុ"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.15 ["កងពល១៦៤ហ្នឹងមាន មាស មុត ជាស្នងការធំ ហើយមាន នង ឆាន ជាបញ្ជាការកងពល១៦៤។ បន្ទាប់មក ឌឹម ដែលជាបញ្ជាការរង។ បន្ទាប់មកគឺ ង៉ែត ជាសមាជិកកងពល"]។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.168 ["តាឆាន នៅកម្រិតកងពលលេខ៣ គាត់ជាប្រធានកងពលនៅក្រោមតាមុត"]។ ឯកសារ D114/261 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី ឆ.34។ ឯកសារ D54/81 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ិច ឆ.14 ["មេបញ្ជាការកងពល៣ ឈ្មោះអ៊ំ មុត [...] អនុកងពលឈ្មោះ ឌឹម មកពីភូមិភាគបូព៌ា។ សមាជិកកងពលមកពីខេត្តកោះកុង ឈ្មោះ ឆាន"]។ ឯកសារ D4.1.747 ចម្លើយរបស់ ឯក នី អំពីល្បើយសឹកអាមេរិកបាត់ខ្លួនក្នុងសង្គ្រាម EN 00387291, KH 00640517 ["((ណុង)) ចាន់ គឺជាមន្ត្រីនយោបាយកងពលធំលេខ៣"]។ ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ. 30 ["ក្រោយពីការរៀបចំឡើងវិញរបស់កងពល១៦៤នេះ លោក មុត ជាប្រធាន លោក ឌឹម ជាអនុប្រធានដែលមកពីបូព៌ា និងលោក ឆាន ជាសមាជិក"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ កឹម ម៉េន ឆ.31 ["ក្រោយពីដាក់ទ័ពវាយតាមកោះ គេរៀបចំកងពលសាជាថ្មី ទៅជាកងពលលេខ១៦៤ ដោយមាន មាស មុត ជាមេបញ្ជាការ ឌឹម អនុប្រធាន (មកពីខេត្តព្រៃវែង) និងឆាន ជាសមាជិក។"]។ ឯកសារ D54/17 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.6-7, 10 ["ចំពោះការប្រជុំថ្នាក់វរៈសេនាធំ គេអាចធ្វើឡើងនៅទីបញ្ជាការរបស់ មាស មុត។ សៈ តើអ្នកណាជាគ្រូឧទ្ទេសនាមក្នុងពេលនោះ? ឆ.7៖ កាលចុងឆ្នាំ១៩៧៥ និងដើមឆ្នាំ១៩៧៦ មានឌឹម និងឆាន មកពីថ្នាក់កងពលជាអ្នកបង្រៀន [...] ឆ.10៖ មេបញ្ជាការទទួលបន្ទុកនយោបាយ គឺមាស មុត ត្រូវបង្រៀនអំពីកិច្ចការនយោបាយ សតិអារម្មណ៍ចាត់តាំង។ មេបញ្ជាការទទួលបន្ទុកយោធាគឺ ឌឹម ដែលត្រូវបង្រៀនពីបច្ចេកទេសយោធាប្រយុទ្ធ មេបញ្ជាការខាង ភស្តុភារគឺ ឆាន គាត់ទទួលបន្ទុកអាវុធយុទ្ធភ័ណ្ឌ ការហូបចុក ប្រើប្រាស់ផ្គត់ផ្គង់ និងសុខភាព"]។

1218 សូមមើល ផ្នែក VIII.ឃ. មន្ទីរសន្តិសុខ ស-២១៖ មាស មុត មិនត្រឹមតែដឹងអំពីអត្ថិភាពមន្ទីរ ស-២១, ទទួលចម្លើយសារភាពមន្ទីរស-២១ និងបានអានចម្លើយសារភាពនោះឲ្យកម្មាភិបាលកងពល១៦៤ ស្តាប់ ប៉ុណ្ណោះទេ ប៉ុន្តែការយល់ព្រម និងការចូលរួមយ៉ាងសកម្មរបស់គាត់ ក៏មានសារៈសំខាន់ណាស់ក្នុងចាប់ខ្លួន និងបញ្ជូនអ្នកណាម្នាក់មកពីកងពលរបស់(កងពល ១៦៤) ទៅភ្នំពេញ បន្ទាប់មក បញ្ជូនទៅមន្ទីរ ស-២១។

1219 ឯកសារ D114/277.2 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹកចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៦ 11.07.31-11.13.08 [រៀបរាប់អំពីរបៀបដែល ឆាន់ ត្រូវផ្លាស់ទៅសេនាធិការ ជាបណ្តោះអាសន្ន ដោយសារតែបក្សសង្ស័យគាត់ និងអំពីរបៀបដែលគាត់ស្ថិតក្រោមការតាមដានរបស់ណាត"], 11.15.28-11.19.32 [យោងតាមឌុច បានឲ្យដឹងថា ឆាន់ មិនសមធ្វើជាមេបញ្ជាការយោធាទេ ដោយសារគាត់ "លេងសើចច្រើន" និង "កំប្លុកកំប្លែង"។ ហេតុដូច្នេះ គេដាក់គាត់ឲ្យ

ហ្គេកអ៊ាវ ហៅឌុច ចាប់ខ្លួនជាផ្លូវការ តាមសំណើរបស់ សុន សេន[1220] និងបានចូល ស-២១ នៅខែ តុលា ឆ្នាំ ១៩៧៦[1221]។ បន្ទាប់ពី ឆាន ត្រូវបានចាប់ខ្លួន និងឆ្លើយសារភាព ក្រោមការធ្វើ

---

ស្ថិតនៅក្រោមការតាមដានរបស់ ណាត និងតែងតាំងសាជាថ្មី"ពីអនុលេខាកងពល១៦៤ ទៅជាជំនួយការសេនាធិការ"]។

1220 ឯកសារ D114/277.2 កាំង ហ្គេកអ៊ាវ ហៅ ឌុច ប្រតិចារឹកចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៦ 11.07.31-11.13.08 [ពន្យល់អំពីរបៀបដែល សុន សេន កោះហៅគាត់ទៅប្រជុំ និងប្រាប់ព័ត៌មានគាត់ថា "បក្សឲ្យយើងចាប់ខ្លួនឆាន់ ដែលជាកូនប្រុសរបស់បង នន សួន" និងរបៀបដែលពួកគេសម្រេចចាប់ខ្លួនគាត់នៅផ្ទះឌុច បន្ទាប់ពីឲ្យគាត់ប្រមែប្រមូលរូបថត និងដកយកកាំភ្លើងដែលបានខ្ចីពី ឌុច មកវិញ]។ ឯកសារ D234/2.1.121 កាំង ហ្គេកអ៊ាវ ហៅ ឌុច ប្រតិចារឹកចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦ 11.03.49-11.07.18 ["មួយបែបទៀត អ្នកទោសខ្លះ ដែលខ្ញុំអាចហៅមកចាប់បានដូចជាមិត្ត ជ័យ ហាន ហៅ ឆាន់ [...] បន្ទាប់ពីបក្សសម្រេចឲ្យចាប់ ខ្ញុំទូរសព្ទហៅ មិត្តឆាន់ នេះមកផ្ទះខ្ញុំ ហើយខ្ញុំឲ្យគេចាប់"]។

1221 ឯកសារ D114/230.1.1 បញ្ជីអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង រៀង ១៤១៥៦ [ជ័យ ហាន ហៅ ឆាន់ ចូលស-២១ នៅខែវិច្ឆិកា ឆ្នាំ១៩៧៦]។ ឯកសារ D114/145.1.1 ចម្លើយសារភាពមន្ទីរស-២១ របស់ ជ័យ ហាន ហៅ ឆាន់ EN 01191572, KH 01176817 [មានចំណារអក្សរដៃរបស់អ្នកសួរចម្លើយ ប៉ុន ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៦ បានបញ្ជាក់ថា គាត់ត្រូវបានចាប់ខ្លួនមុនឪពុករបស់គាត់ និងនៅមុនខែវិច្ឆិកា ឆ្នាំ១៩៧៦ ដូចបានលើកឡើងនៅក្នុងឯកសារ D114/230.1.1 EN 01191539, KH 01176685 [ការសួរចម្លើយលើកទី៣ ធ្វើឡើងនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៧៦]។ សូមមើលផងដែរ ការលើកយោងផ្សេងទៀតនៅក្នុងសំណុំរឿង០០៣ ចំពោះចម្លើយសារភាពមន្ទីរស-២១ របស់ ជ័យ ហាន ហៅ ឆាន់៖ D22.2.42, D22.2.26, D22.2.30, D22.2.46, D22.2.39, D22.2.37, D22.2.28, D22.2.33, D22.2.23, D22.2.31, D22.2.32, D22.2.45, D22.2.41, D22.2.35, D22.2.43, D22.2.47, D22.2.38, D22.2.36, D22.2.44, D22.2.29, D22.2.25, D22.2.40, D22.2.34, D22.2.24, D22.2.27។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.10 ["ខ្ញុំធ្លាប់ឃើញឡានឃ្លុបបាំងជិត ដែលមានអ្នកទោសនៅខាងក្នុង បើកឆ្ពោះទៅទិសខាងកើតក្នុងទិសដៅទៅភ្នំពេញនៅម៉ោងប្រហែលពារសៀលរៀងរាល់ថ្ងៃ។ ថ្ងៃមួយ មុនពេលកងរបស់ខ្ញុំត្រូវបានដកអាវុធ និងក្រោយពេល ឌឹម បាត់ខ្លួន ខ្ញុំបានឮសូរពីយោធាក្នុងកងជាមួយគ្នា និយាយថា ឌឹម និងឆានត្រូវបានបញ្ជូនទៅកាន់ម៉ាស៊ីនបូមទឹកនៅជើងឯក។ នៅពេលនោះយើងជឿថា រឿងហ្នឹងជារឿងពិត។ ប៉ុន្តែក្រោយមក នៅពេលដែល តាមុត ប្រកាសនៅក្នុងអង្គប្រជុំអំពីចម្លើយសារភាពរបស់ពួកក្បត់ និងខ្សែរយ:សេ.អ៊ី.អា និង កា.ហ្សេ.បេ ហើយបន្ទាប់ពីបាត់ខ្លួនពួកនោះ ទើបយើងដឹងថា ពួកគេទាំងនោះត្រូវបានចាប់ខ្លួនហើយ។ រហូតដល់ក្រោយឆ្នាំ១៩៧៩ ទើបយើងដឹងថា ស-២១ និងបឹងជើងឯក គឺជាគុក និងកន្លែងសម្លាប់មនុស្ស"]។ ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.11 ["បងឆាន បន្ទាប់ពីតាមុត។ តាមុត ចាប់យកទៅសម្លាប់នៅបឹងជើងឯក នេះនៅភ្នំពេញ"]។ ឯកសារ D114/226 កំណត់ហេតុស្តាប់ចម្លើយ គីម ហាវ ឆ.82-85 ["[ឆាន] ស្លាប់នៅក្នុងឆ្នាំ១៩៧៧ [...] ឆ.83៖ ស្លាប់ ដោយប៉ុល ពត យកទៅរៀនសូត្រយកទៅសម្លាប់។ គេថាទៅរៀនសូត្រៗ ទៅបាត់បណ្តោយ។ ស ៖ តើអ្នកណាមកហៅគាត់ទៅរៀនសូត្រ? ឆ.84៖ ពួកភូមិភាគ [...] ឆ.85៖ កាលជំនាន់នោះ គេថាទៅរៀនសូត្រៗ គឺយកទៅសម្លាប់ចោល"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គីម ម៉េន ឆ.126, 258 ["នៅក្នុងឆ្នាំ១៩៧៧

ទារុណកម្មនៅ ស-២១ **មាស មុត** បានបញ្ជាឲ្យចាប់ខ្លួនអតីតមេដឹកនាំកងវរសេនាតូច ៣៨៦ ទាំងមូល (ឧទាហរណ៍ តារ៉ែម, តាយឺន, តាយាន)[1222] និងកម្មាភិបាលជាច្រើនផ្សេងទៀតដែលធ្វើ

---

[…] បងឌីម ទៅសេនាធិការនៅភ្នំពេញ ហើយឆាន ត្រឡប់ទៅភ្នំពេញ។ ឆាន គឺមកពីតំបន់៣៧ ក្រោយមក គេផ្លាស់គាត់ទៅសេនាធិការនៅភ្នំពេញ […] ឆ.258៖ ក្រែងលោ គេឃោសនាកុហកខ្ញុំថា តាឆាន ត្រូវបានគេឲ្យមកភ្នំពេញធ្វើសេនាធិការនោះ"]។ ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.28 ["តាំងពី [ឆាន] មិនមានកម្លាំងគ្រប់ គាត់ក៏ត្រៀមកប៉ាល់នៅកោះកោះរ៉ុង តែពេលគាត់ទៅតាមទឹក ហើយគេចាប់គាត់យកមកដាក់គុកទួលស្លែង"]។ សូមមើលផងដែរ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ើ រ៉េត ហៅសារ៉េត ឆ.7-8 ["តាឆាន មកធ្វើជាអនុម្នាក់របស់កងពល។ ស៖ តើលោកមានដឹងថា រឿងរ៉ាវអ្វីកើតឡើងចំពោះ ឆាន ទេក្នុងឆ្នាំ១៩៧៦? ឆ.8៖ ខ្ញុំបានឮថា តាឆាន ក្បត់ ហើយត្រូវបានគេដកចេញនិងបាត់ខ្លួនរហូត"]។ ឯកសារ D69.2.20 សារព័ត៌មាន ប៊ីប៊ីស៊ី SWB ទំនាក់ទំនងនៃបណ្តាប្រទេសចុងបូព៌ា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៧៨ EN S 00013194, KH S 00810138, FR S 00793509 [ហ៊ុន សែន និយាយអំពីការបោសសម្អាតផ្ទៃក្នុង និងកម្ទេចសមាជិកបក្សកុម្មុយនីស្តកម្ពុជា៖"បន្ទាប់ពីពួកគេ គឺមាន ឆាន មេបញ្ជាការកងពល១៦៤ ឈរ ជើងនៅកំពង់សោម។ និងខំ ស្នងការនយោបាយកងពល"]។

1222 ឯកសារ D54/101 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.9 (ការកែតម្រូវ ១៦) ["រ៉ែម គឺជាស្នងការនយោបាយកងវរៈសេនាតូច៣៨៦ ដែលត្រូវបានគេបាញ់សម្លាប់នៅមុខវត្តឥន្ទញាណ"]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន យ៉ើ ឆ.12-13, 16 ["មុនបែកភ្នំពេញ ខ្ញុំនៅនឹងអង្គភាពតំបន់៣៧ ជាពេទ្យអង្គភាពវរៈសេនាតូច៣៨៦។ ស៖ តើមេវរៈរបស់លោកឈ្មោះអ្វីដែរ កាលនោះ? ឆ.13៖ មេបញ្ជាការវរៈ៣៨៦ ឈ្មោះលោក យាន […] ឆ.16៖ អនុប្រធានលោក រ៉ែម"]។ ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.74 ["យាន ជាមេបញ្ជាការកងវរៈសេនាតូច៣៨៦"]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.16 ["បាទ ខ្ញុំនឹកឃើញហើយ គឺយឺនហ្នឹងហើយ។ គាត់ធ្លាប់ធ្វើជាអនុមេបញ្ជាការវរៈសេនាតូច៣៨៦ ពេលដែលរ៉ែម ធ្វើជាមេបញ្ជាការ"]។ ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ិន សុត ឆ.15, 17-18 ["តើលោកស្គាល់មនុស្សម្នាក់ឈ្មោះ រ៉ែម ដែលជាស្នងការនយោបាយនៃវរៈសេនាតូច៣៨៦ ដែរ ឬទេ? ឆ.15៖ បាទ បងរ៉ែម មួយទៀតហើយនិង សួន ឆាន […] ពួកគាត់ជាអ្នកក្តាប់រួមវរៈសេនាតូច៣៨៦ និងយោធាតំបន់ […] ឆ.17៖ គេថាពួកខ្ញុំហ្នឹងក្បត់ គេថាយោធាមួយតំបន់៣៧ក្បត់ គឺពួកតាមុតហ្នឹងជាអ្នកចាប់តែម្តង។ ស៖ តើលោកនៅចាំហេតុការណ៍នៃការចាប់ខ្លួនរ៉ែម ដែរ ឬទេ? ឆ.18៖ ចាំ។ មិនមែនចាប់តែគាត់ទេ គឺចាប់តាំងពីថ្នាក់ធំមេបញ្ជាការ រហូតដល់មេក្រុម"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.3 ["ខ្ញុំភ្លេចឈ្មោះ មេបញ្ជាការ [កងវរៈសេនាតូច៣៨៦] ហើយ ប៉ុន្តែខ្ញុំនៅចាំឈ្មោះអនុមេបញ្ជាការឈ្មោះ យាន នៅពេលដែលជម្លៀសប្រជាជនចេញពីក្រុងកំពង់សោមនៅពេលនោះ"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.91, 127-128 [លើកឡើងថា យាន, រ៉ែម និងសួរ គឺជាមេបញ្ជាការដែលត្រូវគេយកទៅសម្លាប់ ក្រោយលេសថា យកទៅរៀនសូត្រ]។ ឯកសារ D114/155 កំណត់ហេតុស្តាប់ចម្លើយ សុខ រ៉េន ឆ .62 ["បាត់ឈ្មោះមួយចំនួនទៀតដែលខ្ញុំស្គាល់ ដូចជាបងរ៉ែម គាត់ជាមេបញ្ជាការវរៈសេនាធំជើងទឹក ដែលធ្លាប់អ្នកតស៊ូនៅជាមួយតំបន់៣៧ […] បងយឺន នេះត្រូវគេចាប់ខ្លួន បាត់ខ្លួន ពេលដែលចាប់ខ្លួនមានឈ្មោះ ឯក នី ជាអ្នកដឹង […] យាន និងទ្រី បាត់ខ្លួនអស់។ យឺន ថ្នាក់វរៈសេនាតូច។ ខ្ញុំអត់ដឹងថា អ្នកទាំងនោះ ត្រូវបានគេចាប់យកទៅលុតដំ

ការក្រោមបញ្ជារបស់ ឆាន នៅកងពល ១៦៤ រួមមាន មេបញ្ជាការកងអនុសេនាធំ និងកងអនុសេនាតូច។ អ្នកដែលត្រូវបានកំណត់គោលដៅទាំងនោះ បានបាត់ខ្លួន បន្ទាប់ពីត្រូវបានហៅទៅ "រៀនសូត្រ" ឬហៅទៅ "ប្រជុំ" នៅកំពង់សោម ឬភ្នំពេញ[1223]។ បន្ទាប់ពីគាត់បានឆ្លើយសារភាព

---

នៅស្ទឹងហាវនោះទេ គ្រាន់តែដឹងថា គេចាប់ទៅបាត់ ហើយក៏មិនដឹងថាយកទៅសម្លាប់ ឬយ៉ាងណាទេ។ ពួកគេបាត់ខ្លួនរហូត"]។ ឯកសារ D114/105 កំណត់ហេតុស្តាប់ចម្លើយ កុច ទុយ ឆ.18 ["តាយឺន មេកងវរៈសេនាតូច និងតាយាន អនុកងវរៈសេនាតូច ស្លាប់ហើយដោយគេហៅឱ្យទៅរៀនសូត្រ នៅខេត្តកំពង់សោម"]។ ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.21 ["តាយឺន ហៅ យឿន ជាមេបញ្ជាការកងវរៈសេនាតូចរបស់ខ្ញុំ គឺកងវរៈសេនាតូច៦២២"]។ ឯកសារ D114/116 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ឹក ឆ.49 ["បងប្រុសខ្ញុំម្នាក់ឈ្មោះ យាន គឺជាមេបញ្ជាការរងកងវរៈសេនាតូច ត្រូវបានបញ្ជូនទៅជួយគ្រួសារកងទ័ព ក្នុងការប្រមូលផល នៅម៉ុតកែងកង ហើយគាត់បានបាត់ខ្លួននៅពេលនោះរហូតមក"]។

1223 ឯកសារ D114/105 កំណត់ហេតុស្តាប់ចម្លើយ កុច ទុយ ឆ.18 ["ខ្ញុំស្ថិតក្នុងកងវរៈសេនាតូច៨៦ តាយឺន មេកងវរៈសេនាតូច និងតាយាន អនុកងវរៈសេនាតូច ស្លាប់ហើយដោយគេហៅឱ្យទៅរៀនសូត្រ នៅខេត្តកំពង់សោម"]។ ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ន សុត ឆ.5, 17-19 ["កងទ័ពតំបន់ពិសេស កងវរៈសេនាតូច៣៨៦ ត្រូវបានបញ្ចូលទៅក្នុងកងពលធំ៣ ក្រោយរំដោះឆ្នាំ១៩៧៥។ ដល់ចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ បានចាប់មេបញ្ជាការទាំងអស់ចោទថាតំបន់ [៣៧] ហ្នឹងក្បត់។ ក្រោយចាប់អស់ ក៏រំលាយពួកខ្ញុំ ហើយបញ្ជូនយកទៅធ្វើស្រែ។ បើសិនជាបងប្អូនមិនតាមទេ គឺត្រូវគេសម្លាប់ចោល។ និយាយរួមទៅ គឺមកពីតាមុត ហ្នឹងតែម្តងដែលជាអ្នកបញ្ជា [...] ឆ.17៖ គេថាពួកខ្ញុំហ្នឹងក្បត់ គេថាយោធាមួយតំបន់៣៧ក្បត់ គឺពួកតាមុត ហ្នឹងជាអ្នកចាប់តែម្តង [...] ឆ.18៖ ចាប់តាំងពីថ្នាក់ធំមេបញ្ជាការ រហូតដល់មេក្រុម [...] ឆ.19៖ ចាប់ពីចុងឆ្នាំ១៩៧៦"]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.14 ["កងពិសេស គឺជាដូចជាកងអង្គរក្សអ៊ីចឹង។ វាគឺជាកងដែលមេគេជឿទុកចិត្ត ហើយគេប្រើយោធាក្នុងកងនេះសម្រាប់ចាប់ចងអ្នកក្បត់ ហើយនិងការងារសំខាន់ៗដទៃទៀត។ នៅពេលដែលគេចង់ចាប់កងវរៈសេនាតូច និងកងវរៈសេនាធំ គេប្រើយោធាកងពិសេស ហៅពួកគេថា បងកងពលឱ្យទៅប្រជុំ"]។ ឯកសារ D54/103 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.7-8, 10, 21-22 ["តាមុត បានមកប្រជុំជាមួយនឹងពួកយើងក្រោយពេលដែលដកកាំភ្លើង នៅពេលដែលគាត់បានប្រកាសនៅក្នុងអង្គប្រជុំថា ឆាន ជាពួកក្បត់ ហើយសម្រាប់ពួកអតីត៨៦ (៣៨៦) គឺមិនគួរទុកចិត្តបានទៀតទេ។ បន្ទាប់ពីគេចាប់ឆាន រួចហើយ ថ្នាក់ដឹកនាំដែលជាស្នងការនយោបាយ និងមេបញ្ជាការថ្នាក់កងវរៈសេនាតូច កងអនុសេនាធំ កអនុសេនាតូច គឺត្រូវបានចាប់ខ្លួនផងដែរ [...] ឆ.8៖ នៅពេលនោះ អ្នកដែលចូលរួមប្រជុំទាំងអស់មានប្រហែល៥០០នាក់ ដែលរួមទាំងអតីតយោធាកង៨៦ (៣៨៦) ប្រហែលជាង១០០នាក់ ដែលគេដកកាំភ្លើង រួច។ នៅពេលនោះ តាមុត បាននិយាយនៅក្នុងអង្គប្រជុំនោះថា ទាំងអស់គ្នាត្រូវតែតាមដានពួកអតីតយោធាកង៨៦នេះ។ គាត់បាននិយាយថា ពួកអតីតយោធាកង៨៦ សុទ្ធតែខ្សែ កា.ហ្សេ.បេ និងសេ.អ៊ី.អា។ គាត់ថា ខ្សែ កា.ហ្សេ.បេ និងសេ.អ៊ី.អា នេះមិនទាន់បានកម្ទេចបានទាំងស្រុងនៅឡើយទេ។ ពួកនេះ គឺនៅលាក់ខ្លួនក្នុងជួរយើង ដូច្នេះយើងត្រូវតែតាមដានពួកនេះឱ្យជាប់។ ក្នុងចំណោមយោធាជាង៥០០នាក់ ដែលចូលរួមប្រជុំនេះ ក្រៅពីអតីតយោធាកង៣៨៦ គឺសុទ្ធតែពួកយោធារបស់ពួកគេ ដើម្បីមកតាមដានពួកអតីតយោធាកង៣៨៦ [...] ឆ.10៖ ថ្នាក់

ដឹកនាំប្រហែល៧០ភាគរយត្រូវបានចាប់ខ្លួនមុនប្រជុំ ហើយអ្នកនៅសល់ត្រូវបានចូលរួមប្រជុំ ហើយក្រោយមកក៏ត្រូវបានគេចាប់ខ្លួនផងដែរ [...] ស៖ តាមលោកស្មាន តើអតីតយោធា៣៨៦ ត្រូវបានបាត់ខ្លួនរហូតនៅក្នុងរយៈពេលឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧[៩] ពេលវៀតណាមចូល? ហើយតើមានប្រហែលជាប៉ុន្មាននាក់នៅរស់រហូតដល់ឆ្នាំ១៩៧៩ ពេលវៀតណាមចូល? ឆ.21៖ ពេលនោះ ក្នុងកងវរៈសេនាតូច៣៨៦ ទាំងមូល មានយោធានៅសល់តែជាង២០០នាក់ទេ។ យោធាទាំងនោះជាងពាក់កណ្ដាលនៃកងវរៈសេនាតូចដែលមានជាង១០០នាក់ត្រូវបានចាប់ខ្លួន ហើយបាត់ខ្លួនរហូត [...] ស៖ តើមានពួកយោធាដែលមានសមាសភាពមិនល្អ ហើយនិងអតីតយោធា៣៨៦ ខ្លះត្រូវបានអប់រំកែប្រែបាន ហើយត្រូវបានបញ្ជូនទៅអង្គភាពដើមវិញដែរ ឬទេ មុនឆ្នាំ១៩៧៩? ឆ.22៖ តាមខ្ញុំដឹង គឺគ្មានទេ"]។ ឯកសារ D54/76 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុយ ញ៉ើក ឆ.16 ["ស៖ ហេតុអ្វីបានជាគេដូរមេបញ្ជាការនៅក្នុងកងអនុសេនាធំរបស់លោក [...]? ឆ.16៖ នៅពេលនោះ គេបានចោទពួកអតីតយោធារបស់កងតំបន់៣៧ និងពួកភូមិភាគបូព៌ា ថាជាសមាសភាពមាននិន្នាការមិនល្អ។ សូម្បីតែអ្នកបញ្ជូនទៅហ្វឹកហ្វឺននៅស្រុកចិន ក៏ត្រូវហៅត្រឡប់មកវិញដែរ"]។ ឯកសារ D114/31 កំណត់ហេតុស្ដាប់ចម្លើយ មូល ឈិន ឆ.16, 19, 91, 127-128 ["ឆាន ជាមេបញ្ជាការ [...] ក្រោយមក ឆាន ត្រូវបានគេយកទៅសម្លាប់ចោល [...] ឆ.19៖ ប្រសិនបើខ្ញុំមានឋានៈ និងតួនាទី ដូចជាប្រធានកងធំ គឺគេច្បាស់ជាយកទៅសម្លាប់អស់ហើយ ព្រោះឋានៈចាប់ពីមេកងធំឡើងទៅ ត្រូវបានគេយកទៅសម្លាប់ទាំងអស់ក្រោមហេតុផល ហៅយកទៅរៀនសូត្រ [...] ឆ.91៖ ឲ្យតែមេៗវរៈ គេហៅមករៀនសូត្រនៅរោងកុន នៅកំពង់សោម គឺដឹងតែបាត់ខ្លួនតែម្ដង ហើយមិនដែលឃើញវិលត្រឡប់មកវិញទេ [...] កន្លងពេលយូររាប់ខែមកហើយ ក៏មិនដែលឃើញពួកគត្រឡប់មកវិញនោះទេ [...]ស៖ លោកនិយាយថា មេវរៈបានបាត់ខ្លួន។ តើលោកអាចផ្ដល់ឈ្មោះអ្នកទាំងនោះបានដែរ ឬទេ? ឆ.127៖ យាន, រ៉ែម និងសួរ [...] ឆ.128៖ ឆាន ក៏បាត់ខ្លួនដែរ។ និយាយទៅ មេៗគឺបាត់ខ្លួនទាំងអស់ គឺលើកលែងតែកូនទាហានធម្មតាទេ"]។ ឯកសារ D114/85 កំណត់ហេតុស្ដាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.23 ["មានតែការចាប់ខ្លួនរបស់ ឆាន និងឌឹម ទេ ដែលគេបានប្រកាសជាសាធារណៈ។ យើងបានដឹងអំពីការចាប់ខ្លួនកូនចៅក្រោមៗរបស់គាត់ ដោយការនិយាយតៗគ្នាប៉ុណ្ណោះ"]។ ឯកសារ D54/12 កំណត់ហេតុស្ដាប់ចម្លើយ ប្រេស មាន ឆ. 30 ["ស៖ តើតាមុត មានបាននិយាយឈ្មោះអ្នកណាខ្លះថា ជាពួកក្បត់ឬទេនៅក្នុងអង្គប្រជុំនោះ? ឆ.30៖ បាទ គាត់បានប្រកាសថា តាញ៉ឹកជាលេខាតំបន់៣៧, តាប៊ុន នៅក្នុងគណៈតំបន់៣៧ និងឆាន នៅក្នុងគណៈតំបន់៣៧ដែរ (ពួកក្បត់)"]។ ឯកសារ D114/33 កំណត់ហេតុស្ដាប់ចម្លើយ ហែម អាង ឆ.32 ["ក្រោយពីគេចោទមេៗនៅតំបន់៣៧ក្បត់ អ្នកដែលទៅពីមជ្ឈិមក៏ឡើងជំនួស ហើយអតីតសមាជិកតំបន់៣៧ ត្រូវបានគេរំសាយចោល ហើយឲ្យទៅធ្វើការ"]។ ឯកសារ D114/226 កំណត់ហេតុស្ដាប់ចម្លើយ គឹម ហាវ ឆ.91-93 ["អ្នកដទៃទៀត ដែលគេយកទៅហ្នឹងអ្នកណាខ្លះ? ឆ.91៖ បងសួ, បងហិន, បងសេត, បងហ៊ន, បងផល ហ្នឹងសុទ្ធតែជាប្រធានវរៈ ដែលគេយកទៅរៀនសូត្រ សុទ្ធតែមេធំៗ មេវរៈ មេកងរយ ហ្នឹងទ័ពណ៌។ សុទ្ធតែប្រធានវរៈ អនុវរៈ និងលេខា។ ស៖ តើអ្នកណាដែលគេយកទៅរៀនសូត្រមុន? ឆ.92៖ គឺអ៊ំឆាន [...] ឆ.93៖ នៅដើមឆ្នាំ១៩៧៧ ខ្ទង់ខែ២ ខែ៣ ហ្នឹងចាប់បណ្ដើរៗ។ ហ្នឹងទ័ពភូមិភាគមកចាប់ ខ្ញុំមិនដឹងភូមិភាគណាដែរ"]។ ឯកសារ D114/135 កំណត់ហេតុស្ដាប់ចម្លើយ ណុប ផន ឆ.3-5 [អតីតសមាជិកកងវរៈសេនាតូច៣៨៦, អនុសេនាធំ៤២០ ឈរជើងនៅលើកោះតាង បានពន្យល់ថា នៅចុងឆ្នាំ១៩៧៦ មេបញ្ជាការទាំងអស់របស់គាត់ ត្រូវបានបញ្ជូនទៅរៀនសូត្រ និងបាត់ខ្លួនរហូត]។

រួច អតីតមេដឹកនាំតំបន់ ៣៧ នៅភូមិភាគបស្ចិម ក៏ត្រូវបានគេចាប់ខ្លួនផងដែរ ក៏ដូចជាឪពុករបស់ នង ឆាន[1224]។

351. សាក្សី ឯក នី បញ្ជាក់ថា រ៉ែម អតីតស្នងការនយោបាយកងវរសេនាតូច ៣៨៦ នៅកងពល ១៦៤ បានព្យាយាមរត់គេចខ្លួន ពេលគាត់ត្រូវបានអង្គរក្សមកពីអង្គភាពពិសេសរបស់ **មាស មុត** ចាប់ខ្លួន និងបាញ់សម្លាប់នៅមុខមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ[1225]។ ប្រពន្ធរបស់ រ៉ែម ដែលមានផ្ទៃពោះ បាន

---

[1224] បើទោះបីជា ញ៉ឹក និងអតីតមេៗផ្សេងទៀតនៃតំបន់៣៧ មិនស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ មាស មុត ក៏ដោយ ក៏នៅភូមិភាគបស្ចិម នៅកោះកុង ការចាប់ខ្លួនបានធ្វើឡើងបន្ទាប់ពីកងពល ១៦៤ បោសម្អាត ឆាន។ សូមមើល ឧទាហរណ៍ ឯកសារ D4.1.1057 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ហៅ ស្វាយ វឿន ឆ.1, 3 [“ខ្ញុំទៅធ្វើការនៅខេត្តកោះកុង នៅក្នុងខែធ្នូ ឆ្នាំ១៩៧៦។ ពេលដែលខ្ញុំទៅដល់ប្រហែលមួយខែ [...] ញ៉ឹក លេខាតំបន់៣៧ ឈ្មោះរ៉ន (ឈ្មោះដើម អ៊ីវ) អនុលេខាតំបន់ និងឈ្មោះ អេវ ជាសមាជិកតំបន់ទទួលបន្ទុកខាងយោធាតំបន់ ត្រូវបានដក [...] ខ្ញុំដឹងថាគេដកមកកន្លែងភូមិភាគ [...] ឆ.3៖ គឺបាត់ឈ្មោះរហូត”]។ ឯកសារ D114/241 កំណត់ហេតុស្តាប់ចម្លើយ ឆេង ជាង ឆ.82, 87 [“ខ្ញុំស្វែងយល់ខ្លួនឯងថា តាញ៉ឹក, តាសារី ត្រូវបានចាប់ខ្លួនហើយ [...] តាញ៉ឹក អនុគណៈតំបន់ [៣៧] [...] សារី ខាងទ័ព”]។ ឯកសារ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.30 [“ស៖ តើតាមុត មានបាននិយាយឈ្មោះអ្នកណាខ្លះថា ជាពួកក្បត់ឬទេនៅក្នុងអង្គប្រជុំនោះ [នៅស្ទឹងហាវ នៅពាក់កណ្តាលឆ្នាំ១៩៧៧]? ឆ.30៖ បាទ គាត់បានប្រកាសថា តាញ៉ឹកជាលេខាតំបន់៣៧, តាប៉ុន នៅក្នុងគណៈតំបន់៣៧ និងឆាន នៅក្នុងគណៈតំបន់៣៧ដែរ (ពួកក្បត់)”]។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.2។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.1 [“នៅក្នុងអង្គប្រជុំ មាស មុត អានចម្លើយសារភាពរបស់ពួកក្បត់ គាត់បានរៀបរាប់ឈ្មោះកម្មាភិបាលក្បត់ចាប់ពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់មូលដ្ឋាន។ ខ្ញុំនៅចាំថា គាត់ហៅឈ្មោះ អាយ៉ា, អាធុត, អាញ៉ឹក, អាយ៉ាន, អាឆាន និងអាឌឹម។ ខ្ញុំនៅចាំ មាស មុត ហៅពួកគេថា “អា” ពីព្រោះ “អា” ជាពាក្យបណ្តុះបង្អាប់សម្រាប់និយាយទៅកាន់ពួកក្បត់”]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.5។ អំពីជ័យ ហាន ហៅ ឪពុករបស់ ឆាន់ គឺ ជ័យ សួន៖ ឯកសារ D114/277.2 កាំង ហ្គេកអ៊ាវ ហៅ ឌុច ប្រតិចារឹកចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ 11.15.28-11.19.32 [“គេចាប់កូនដោយសាររឿងឪមានរឿង ដូចជាមិត្តឆាន់ អ៊ីចឹង អាឆាន់ហ្នឹង។ គេចាប់ អាឆាន់ ដូចចាប់អាឆាន់ មុនចាប់បងសួន បងជ័យ”]។ ឯកសារ D4.1.26 ចម្លើយសារភាពមន្ទីរស-២១ របស់ ជ័យ សួន ហៅ នន សួន ហៅ សែន នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៧៦ [ចូលមន្ទីរស-២១ ពីរបីអាទិត្យ ក្រោយកូនរបស់គាត់ឈ្មោះ ឆាន។ មានកំណត់ត្រាមួយរបស់អ្នកសួរចម្លើយ ប៉ុន នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦ សរសេរថា “ការឃុំខ្លួនរបស់អ្នកត្រូវបានសម្រេចដោយគណៈអចិន្ត្រៃយ៍មជ្ឈិមបក្ស” (KH 00006320-21, FR 00757022, មិនមានលេខ ERN EN)]។

[1225] ឯកសារ D54/101 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.9-10 [“រ៉ែម គឺជាស្នងការនយោបាយកងវរៈសេនាតូច៣៨៦ ដែលត្រូវបានគេបាញ់សម្លាប់នៅមុខវត្តឥន្ទញ្ញាណ [...] ឆ.10៖ នៅក្នុងពេលនោះ ថ្នាក់ដឹកនាំកងពល គេបានដកពួកអតីតយោធារបស់កងវរៈសេនាតូច៣៨៦ ចេញពីកោះ និងកន្លែងផ្សេងៗ រួចបញ្ជូនយកទៅដាក់នៅក្នុងកងផលិត។

សម្រេចចិត្តរំលូតកូនចោល ក្រោយពេលចាប់ខ្លួន វ៉ែម ពីព្រោះ "នាងចង់បង្ហាញថា នាងជាអ្នកបដិវត្តន៍ច្បាស់លាស់ ដោយមិនចង់ឲ្យជាប់ឈាមជាមួយគាត់"[1226]។ ដូច វ៉ែម ដែរ កម្មាភិបាលកងវរសេនាតូច ៣៨៦ ផ្សេងទៀត ក៏បានដឹងច្បាស់ដែរថា ការចាប់ខ្លួនពីទោសក្បត់ មានន័យថា ជាការដាក់គុក ធ្វើទារុណកម្ម និងសម្លាប់។ ដោយដឹងមុនថា ខ្លួននឹងត្រូវបានចាប់ខ្លួន ក្រោយការបោសសម្អាតអតីតមេដឹកនាំកងវរសេនាតូច ៣៨៦ បានចាប់ផ្ដើម មេដឹកនាំកងអនុសេនាធំ ធឿន និង ប៊ុន ថាន បានជ្រើសរើសធ្វើអត្តឃាតនៅលើកោះតាង[1227]។

---

ពេលនោះ ខ្ញុំបានឮយោធា ដែលត្រូវដកចេញ ហើយយកទៅដាក់នៅកងផលិតជាមួយខ្ញុំ និយាយថា បងវ៉ែម ដែលជាអតីតមេបញ្ជាការកងវរៈសេនាតូច៣៨៦ ត្រូវបានគេបាញ់សម្លាប់នៅមុខវត្តឥន្ទញាណ។ មុនដំបូងគេបញ្ជាឲ្យគាត់លើកដៃ ប៉ុន្តែគាត់បានប្រឆាំងតបនឹងគេ ដោយបានដាល់ពួកយោធាដែលជាអ្នកបញ្ជាឲ្យគាត់លើកដៃនោះ។ យោធាទាំងនោះគឺមកពីកងពិសេសរបស់ តាមុត។ ពួកនោះគឺដូចជាកងអង្គរក្សរបស់ តាមុត ឬក៏ហៅថាកងដៃស្ដាំរបស់គាត់។ បន្ទាប់ពីដាល់ពួកយោធានោះហើយ វ៉ែម បានលោកចុះពីលើឡាន ហើយពួកយោធាបានបាញ់ចំក្បាលរបស់គាត់ ហើយគាត់ដួលស្លាប់នៅលើថ្នល់នៅមុខវត្តឥន្ទញាណនោះតែម្ដង"]។ ឯកសារ D54/102 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.1, 3, 5 ["វ៉ែម មានស្រុកកំណើតនៅភូមិកងកេង ឃុំរាម។ ព្រឹត្តិការណ៍ដែលកើតមាននៅនឹងមុខវត្តឥន្ទញាណ គឺកើតឡើងនៅចុងឆ្នាំ១៩៧៦។ រឿងនេះ វាកើតឡើងជិតចូលឆ្នាំ១៩៧៧ហើយ។ នៅពេលនោះ គេបានដកយោធាកង៣៨៦ ទាំងអស់យកទៅដាក់នៅកងផលិត។ បន្ទាប់ពីគេដកអាវុធពីពួកយើងអស់ ពួកគេមិនអនុញ្ញាតឲ្យយើងទុកកាំបិតទេ [...] ឆ.3៖ ការសម្លាប់ វ៉ែម នេះកើតឡើងក្រោយពីការប្រជុំនេះ [ជាមួយ មាស មុត]។ បន្ទាប់ពី វ៉ែម ត្រូវបានសម្លាប់ ប្រពន្ធរស់គាត់ដែលមានផ្ទៃពោះ បានរំលូតកូនចោល ពីព្រោះនាងចង់បង្ហាញថា នាងជាអ្នកបដិវត្តន៍ច្បាស់លាស់ ដោយមិនចង់ឲ្យជាប់ឈាមជាមួយគាត់ [...] ឆ.5៖ ឮអំពីរឿង វ៉ែម តាមរយៈយោធាដូចគ្នា ពីព្រោះរឿងរបស់ វ៉ែម គឺយោធាស្ទើរតែទាំងអស់បានដឹង"]។

1226 ឯកសារ D54/102 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.3 ["សម្លាប់ វ៉ែម នេះកើតឡើងក្រោយពីការប្រជុំនេះ [ជាមួយ មាស មុត]។ បន្ទាប់ពី វ៉ែម ត្រូវបានសម្លាប់ ប្រពន្ធរស់គាត់ដែលមានផ្ទៃពោះ បានរំលូតកូនចោល ពីព្រោះនាងចង់បង្ហាញថា នាងជាអ្នកបដិវត្តន៍ច្បាស់លាស់ ដោយមិនចង់ឲ្យជាប់ឈាមជាមួយគាត់"]។

1227 ឯកសារ D54/103 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.10-11 ["ស៖ នៅក្នុងពេលដែល មាស មុត ធ្វើការប្រកាសក្នុងអង្គប្រជុំនោះ តើអតីស្នងការ និងមេបញ្ជាការវរៈសេនាតូច អនុសេនាធំ និងអនុសេនាតូច កង៨៦(៣៨៦) ត្រូវបានចាប់ខ្លួនអស់ ឬនៅ ឬក៏គេចាប់ខ្លួនពួកនោះមុន ឬក្រោយពេលប្រជុំ? ឆ.10៖ ថ្នាក់ដឹកនាំប្រហែល៧០ភាគរយត្រូវបានចាប់ខ្លួនមុនប្រជុំ ហើយអ្នកនៅសល់ត្រូវបានចូលរួមប្រជុំ ហើយក្រោយមកក៏ត្រូវបានគេចាប់ខ្លួនផងដែរ។ ក្នុងរយៈកាលនៃការចាប់ខ្លួននោះ ខ្ញុំនៅចាំព្រឹត្តិការណ៍មួយ ពេលដែលមេបញ្ជាការកងអនុសេនាធំម្នាក់ និងអនុម្នាក់ត្រូវបានធ្វើអត្តឃាតនៅលើកោះតាង។ មេបញ្ជាការអនុសេនាធំនោះ គឺកងអនុសេនាធំ៤២ ឈ្មោះ ធឿន បានបោកគ្រាប់បែកសម្លាប់ខ្លួនឯង នៅក្នុងលេនដ្ឋានដាក់កាំភ្លើងដេកា៧៥ ហើយអនុសេនាធំ៤១ ឈ្មោះ ប៊ុន ថន បានបាញ់សម្លាប់ខ្លួនឯងនៅពេលដែលគាត់ត្រូវបានដកមកឲ្យនៅកន្លែងកងវរៈសេនាតូច។ ស៖ ហេតុអ្វីបានជាមេបញ្ជាការ និងអនុមេបញ្ជាការ

អនុសេនាធំសម្លាប់ខ្លួនឯង បន្ទាប់ត្រូវបានគេហៅទៅមន្ទីរកងវរៈសេនាតូចនោះ? ឆ.11៖ នៅពេលនោះ ព័ត៌មានអំពីការចាប់ខ្លួនថ្នាក់ដឹកនាំរបស់កង៣៨៦ ដូចជា រ៉េម ដែលជាស្នងការ ដែលត្រូវបានគេបាញ់ចំក្បាលសម្លាប់នៅខាងមុខវត្តឥន្ទញាណ ឈ្មោះ យ៉ឺន ជាមេបញ្ជាការកងវរៈសេនាតូច។ យាន ជាសមាជិក និងសារ៉ាត ខាងភស្តុភារ ត្រូវបានលេចឮក្នុងចំណោម ពួកយើងស្ទើរតែទាំងអស់។ ដូច្នេះពេលដែលកងវរៈសេនាតូចហៅ ប៊ុន ថន ឲ្យទៅកន្លែងមន្ទីកងវរៈសេនាតូច ប៊ុន ថន ដឹងខ្លួនជាមុនស្រេចហើយថា គាត់ច្បាស់ជាមានបញ្ហាហើយ។ សម្រាប់ ធឿន ដែលជាមេបញ្ជាការអនុសេនាធំ៤២ ខាងវរៈគេបញ្ជូននីរសារពីរនាក់ឲ្យទៅរស់នៅជាមួយគាត់ ដើម្បីតាមដានគាត់ឲ្យជាប់។ ដោយសារគាត់ដឹងរឿងនេះ ទើបថ្ងៃមួយ គាត់បានបញ្ចុះបញ្ចូលនីរសារនោះឲ្យទៅជាមួយគាត់នៅកន្លែងលេនដ្ឋានកាំភ្លើងដេកា៧៥ ហើយគាត់បំផ្ទុះគ្រាប់បែក។ តាមខ្ញុំនៅចាំ ព្រឹត្តិការណ៍នេះកើតឡើងមានតាំងមុនពេលចាប់ខ្លួនពួកនារី២០នាក់ ហើយនិងមុនពេលដកកាំភ្លើងទៅទៀត"]។ ឯកសារ D114/260 កំណត់ហេតុស្តាប់ចម្លើយ ស៊ិន សុត ឆ.13, 15 [អំពីកងអនុសេនាធំ៤២០៖ "គេរកចាប់ គាត់បោកគ្រាប់បែក ភ្លេច។ ឈ្មោះថន ៤២០។ អាហ្នឹងគេរកចាប់ គាត់បោកគ្រាប់បែកសម្លាប់ខ្លួនឯង [...] ស៖ តើលោកធ្លាប់ឮឈ្មោះ ចាន់ ប៊ុនថត ទេ? ឆ.15៖ ហ្នឹងហើយ ចាន់ ប៊ុនថន ហ្នឹង។ ខ្ញុំមិនសូវចាំ។ ខ្ញុំនិយាយខុសដែរ គាត់បាញ់ខ្លួនឯង។ នៅកងវរយមួយទៀតទេ ដែលបោកគ្រាប់បែក មិនមែនគាត់ទេ"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.9-12 ["គេប្រជុំនិយាយថានៅក្នុងអង្គភាព៣៧ គឺមេដែលដឹកនាំហ្នឹងក្បត់ [...] ឆ.10៖ ឋានៈកងពល ក្តាប់តំបន់យើងកំពង់សោម។ ម្លោះហើយបានគេទៅសម្រិតសម្រាំង គេចាប់មេអនុធំខ្ញុំហ្នឹង ចាប់អត់បានទេ គាត់សម្លាប់ខ្លួនឯងតែម្តង។ យកកាំភ្លើងខ្លីបាញ់សម្លាប់ខ្លួនគាត់ ចាប់គាត់អត់បានទេ [...] ឆ.11៖ កាលនោះ គេហៅគាត់ទៅប្រជុំនៅវរៈសេនាតូច ហើយគាត់ទៅប្រជុំ ហើយពេលគាត់ចេញមកពីអង្គប្រជុំមកវិញ ស្រាប់តែគាត់ទាញកាំភ្លើងខ្លីបាញ់សម្លាប់ខ្លួនឯងចោល។ គាត់ឈ្មោះ នាមត្រកូលគាត់ ខ្ញុំអត់ស្គាល់ទេ ខ្ញុំចាំតែឈ្មោះគាត់ ថន [...]គាត់ចេញពីកំពង់ស្ពឺយូរហើយ ហើយគេឲ្យគាត់កាន់ទ័ពនៅតំបន់៣៧។ មករៀបអង្គភាពទ័ពនៅហ្នឹង គាត់ឡើងកាន់កាប់ទ័ពនៅហ្នឹង។ ស៖ តើលោកបានឃើញហេតុការណ៍នេះផ្ទាល់ភ្នែកដែរ ឬទេ? ឆ.12៖ បានឃើញលោក មិនមែនចាប់នៅនេះទេ គឺចាប់នៅតំបន់កោះតាង។ ខ្ញុំបានឃើញផ្ទាល់ភ្នែក។ ក្រោយពេលចាប់ខ្លួន គាត់ឈរជើងនៅកោះតាងឯណោះទេ។ កាលហ្នឹងសម្លាប់ពីរអនុសេនាធំទាំងអស់ គាត់បាញ់សម្លាប់ខ្លួនឯងចោលតែម្តង។ ប្រធានអនុសេនាធំដូចគ្នា ស្លាប់ហ្នឹង បាញ់ខ្លួនឯងហ្នឹង។ បងថន មួយ និងបងធឿន មួយ។ ប៉ុន្តែគាត់នៅកាន់ គ ខុសគ្នាមួយកាន់នៅវរៈ៤១៩ និងមួយទៀតនៅ៤១៨"]។ ឯកសារ D114/105 កំណត់ហេតុស្តាប់ចម្លើយ កុច ទុយ ឆ.18 ["ខ្ញុំស្ថិតក្នុងកងវរៈសេនាតូច៨៦ តាយ៉ឺន មេកងវរៈសេនាតូច និងតាយាន អនុកងវរៈសេនាតូច ស្លាប់ហើយដោយគេហៅឲ្យទៅរៀនសូត្រ នៅខេត្តកំពង់សោម។ ខ្ញុំស្ថិតនៅក្នុងកងរយ១២ ប្រធានកងរយ ឈ្មោះ ចាប លៀប មេកងរយ និងប៊ុន ធឿន អនុកងរយ គាត់ស្លាប់អស់ហើយដោយពួកគេបានបោកគ្រាប់បែកសម្លាប់ខ្លួននៅលើកោះនោះតែម្តង"], ឆ.29 [ពន្យល់ថា គាត់ត្រូវគេដកពីកោះតាង បន្ទាប់ពីមេៗរបស់គាត់ធ្វើអត្តឃាតនៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.15, 37 [អតីតយោធាកងវរសេនាតូច៣៨៦ ឈរជើងនៅកោះតាង នៅកងអនុសេនាធំដែលដឹកនាំដោយ ធឿន កងវរសេនាតូច៦២៣ នៃកងវរសេនាធំ៦២៖ "នៅក្នុងកងអនុសេនាធំ២ ប៊ុន ធឿន ជាមេបញ្ជាការ និងប៊ុន ថន ជាមេបញ្ជាការរង [...] ឆ.37៖ ខ្ញុំដឹងថា មេទាំងពីរនាក់ហ្នឹង គឺស្លាប់ទាំងពីរ។ ប៊ុន ធឿន បោកគ្រាប់បែកសម្លាប់ខ្លួនឯង ហើយ ប៊ុន ថន បាញ់សម្លាប់ខ្លួនឯង"]។ ឯកសារ D114/130

352. ចុងឆ្នាំ ១៩៧៦ ឬទំនងនៅចន្លោះដើមឆ្នាំទៅពាក់កណ្តាលឆ្នាំ ១៩៧៧ **មាស មុត** បានប្រកាសពីការចាប់ខ្លួនមេដឹកនាំ ប.ក.ក និងកងទ័ពបដិវត្តន៍កម្ពុជាទៅដល់កម្មាភិបាលនានា នៅក្នុងការប្រជុំធំៗជាច្រើនរបស់បុគ្គលិកកងពល ១៦៤ នៅអូរឈើទាល ស្ទឹងហាវ និងកងកេង។ **មាស មុត** អះអាងថា នង ឆាន ត្រូវបានចាប់ខ្លួន ព្រោះគាត់ជាជនក្បត់។ គាត់ក៏បាននិយាយទៅអ្នកដែលត្រូវបានចាប់ខ្លួន និងលើកឡើងពីអំពើក្បត់របស់៖ កុយ ធួន ហៅ ធុច អតីតលេខាភូមិភាគឧត្តរ និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ម៉ែន សាន ហៅ នៃ សារ៉ាន ហៅ យ៉ា អតីតលេខាភូមិភាគឦសាន និងមេបញ្ជាការរងកងពល ១៦៤ ហឹង ឌឿន ហៅ ឌឹម កម្មាភិបាលសំខាន់ៗផ្សេងទៀតក្នុងកងពល ១៦៤ (ម៉ុម ជឹម ហៅ យ៉ាន និង គង់ គៀន ហៅ វ៉េត ឬ អ៊ឹង វ៉េត) និងអតីតមេដឹកនាំតំបន់ ៣៧[1228]។

---

កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.62 ["ពួកហ្នឹងខ្លះ [នៅលើកោះតាង] ចងកងាប់ បាញ់ខ្លួនឯងងាប់ បោកគ្រាប់បែកងាប់"]។

1228 ឯកសារ D114/85 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.10, 21, 23-24, 26, 34 ["ក្នុងចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ ១៩៧៧ ដែល មាស មុត បានប្រកាសថាឈ្មោះ ជួយ ឆាន ដែលជាកូនរបស់ ជ័យ ឬនង សួន [...] បានធ្វើការជាជនក្បត់ឲ្យវៀតណាម។ ការចាប់ខ្លួនឈ្មោះ ឌឹម ក៏ត្រូវបានប្រកាសក្នុងពេលតែមួយនោះដែរ និងជាមួយបទចោទដូចគ្នា [...] ឆ.21៖ ការប្រកាសនេះធ្វើឡើងនៅថ្ងៃបុណ្យរំឭកថ្ងៃជ័យជម្នះ១៧ មេសា សម្រាប់កងពល១៦៤។ ការប្រកាសនោះធ្វើឡើងនៅឆ្នេរអូរឈើទាលនៅប៉ែកខាងចុង ដែលជាទីបញ្ជាការកងទ័ពជើងទឹក [...] ឆ.23៖ មាស មុត បាននិយាយតែម្នាក់ឯង នៅក្នុងថ្ងៃនោះ ដោយមានការចូលរួមរបស់យោធាប្រហែល១០០នាក់ មកពីកងទ័ពជើងទឹកកងពល ១៦៤ និងមន្ទីរពាក់ព័ន្ធនឹងកងពល១៦៤ ដូចជាអង្គភាពពេទ្យ អង្គភាពដឹកជញ្ជូន អង្គភាពភស្តុភារ [...] ក្នុងចំណោមរឿងផ្សេងៗទៀត មាស មុត ក៏បានប្រកាសថា ឆាន និង ឌឹម ត្រូវបានចាប់ខ្លួនដោយសារពួកគេក្បត់។ តាមខ្ញុំដឹង ឆាន គឺត្រូវបានចាប់ខ្លួនមុនគេចាប់ខ្លួន ឌឹម។ ហើយមានតែការចាប់ខ្លួនរបស់ ឆាន និង ឌឹម ទេដែលគេប្រកាសជាសាធារណៈ។ ចំពោះការចាប់ខ្លួនកងទ័ពក្រោមបង្គាប់របស់ឆាន និង ឌឹម ពុំប្រកាសជាសាធារណៈទេ [...] ឆ.24៖ គឺគេធ្វើចំថ្ងៃ១៧ មេសា ហ្នឹងតែម្តង គឺធ្វើតែមួយព្រឹកទេ [...] ឆ.26៖ មានតែការចាប់ខ្លួនរបស់ ឆាន និង ឌឹម ទេដែលត្រូវបានប្រកាស ហើយខ្ញុំមិនដឹងថា ពួកគេត្រូវបានចាប់ខ្លួនមុនការប្រកាសនោះយូរប៉ុនណាដែរទេ [...] ឆ.34៖ មាស មុត បាននិយាយយ៉ាងច្បាស់ៗថា ឌឹម ហើយនិង ឆាន គឺមានផែនការទម្លាក់រូបគាត់ចេញ ហើយកាន់កាប់កងពលធំ ដើម្បីបង្កើតរដ្ឋាភិបាលមួយខុសពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.64 ["មានឈ្មោះ ង៉ែត, ឈ្មោះ ឌឹម, ឈ្មោះ យ៉ាន, ឈ្មោះ ឆាន និងឈ្មោះ សុខ ជាដើម ដែលគេចោទថាជាគិញវៀតណាម ឬក៏ សេ.អ៊ី.អា"]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.1 ["នៅចុងឆ្នាំ១៩៧៦ ជិតចូលឆ្នាំ១៩៧៧ [...] គេបានដកយោធាកង៣៨៦ ទាំងអស់យកទៅដាក់នៅកងផលិត។ បន្ទាប់ពីគេដកអាវុធពីពួកយើងអស់ [...] មាស មុត បានមកធ្វើមិទ្ទីងជាមួយពួកយើងនៅភូមិគគីរ នៅជិតព្រលានយន្តហោះកងកេង ដោយមានអតីតយោធាចូលរួមប្រហែលរាប់ពាន់នាក់ ដោយមានកងវរៈសេនាតូច៣៨៦ និងកងផ្សេងៗទៀត។ នៅក្នុងអង្គប្រជុំ មាស មុត អានចម្លើយសារភាពរបស់ពួកក្បត់ គាត់បានរៀបរាប់ឈ្មោះកម្មាភិបាលក្បត់ចាប់ពីថ្នាក់មជ្ឈិម រហូតដល់

**មាស មុត** បានអានសម្រង់ចម្លើយសារភាព ស-២១ របស់ ឆាន នៅចំពោះមុខកងទ័ពកងពល ១៦៤ រាប់ពាន់នាក់[1229] ក្នុងនោះក៏មានទាហានដែលស្ថិតក្រោមបង្គាប់របស់ ឆាន ដែលត្រូវបានអង្គ

---

ថ្នាក់មូលដ្ឋាន។ ខ្ញុំនៅចាំថា គាត់ហៅឈ្មោះ អាយ៉ា, អាធុធ, អាញ៉ឹក, អាយ៉ាន, អាឆាន និងអាឌឹម"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.3, 5, 9 ["វ៉េត នៅកងទ័ពជើងគោក មានទីតាំងនៅព្រលានយន្តហោះកងកេង ហើយគាត់ត្រូវបានចាប់ខ្លួន [...] ខ្ញុំជឿថាគាត់ស្លាប់ហើយ ពីព្រោះនៅពេលដែល តាមុត ប្រជុំប្រាប់អំពីចម្លើយសារភាព ហើយ តាមុត បានប្រកាសថា វ៉េត ក្បត់ហើយ។ [...] ឆ.5៖ យ៉ាន នេះគឺស្ថិតនៅក្នុងចំណោមពួកក្បត់ដែល តាមុត បានលើកមករៀបជាពាក្យជូនដូចកំណាព្យថា "ញ៉ឹក, ឆាន, យ៉ាន, ឌឹម ជាពួកក្បត់ [...] ឆ.9៖ ខ្ញុំគិតថា ឌឹម នៅក្នុងឯកសារនេះ គឺជា ឌឹម ដែលខ្ញុំបានប្រាប់លោកខាងដើម ដែលរាប់នៅក្នុងពាក្យជូនថា អាញ៉ឹក, អាឆាន, អាយ៉ាន និង អាឌឹម"]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.30 ["ស៖ តើតាមុត មានបាននិយាយឈ្មោះអ្នកណាខ្លះថា ជាពួកក្បត់ឬទេនៅក្នុងអង្គប្រជុំនោះ [នៅស្ទឹងហាវ នៅពាក់កណ្តាលឆ្នាំ១៩៧៧]? ឆ.30៖ បាទ គាត់បានប្រកាសថា តាញ៉ឹកជាលេខាតំបន់៣៧, តាប៉ុន នៅក្នុងគណៈតំបន់៣៧ និងឆាន នៅក្នុងគណៈតំបន់៣៧ដែរ (ពួកក្បត់)"]។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.2, 4-5 ["តាមុត បាននិយាយថា ញ៉ឹក, ប៉ុន, ឆាន ដែលជាគណៈតំបន់៣៧ ជាអ្នកប្រឆាំងនឹងបដិវត្ត។ គាត់បាននិយាយឈ្មោះជាច្រើន [...] ឆ.4៖ វាមិនមែនជាការប្រជុំជាប្រចាំទេ។ នៅឆ្នាំ១៩៧៧ ស្ថានការណ៍នៅពេលនោះមានការច្របូកច្របល់បក្សកុម្មុយនីស្តកម្ពុជាគាំទ្រដោយចិន ហើយបក្សពលករគាំទ្រដោយវៀតណាម មានពួក សេ.អ៊ី.អា អាមេរិកកាំង និង កា.ហ្សេ.បេ នៅក្នុងជាមួយប្រជាជនដែរ។ ដូច្នេះគេត្រូវសម្រិតសម្រាំងពួកសមាសភាពទាំងនោះចេញ។ ស៖ តើនេះជាគំនិតរបស់លោកផ្ទាល់ ឬក៏គេប្រាប់លោក? ឆ.5៖ តាមុត បានប្រកាសនៅក្នុងអង្គប្រជុំ"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.7-8 ["ស៖ តើលោកដឹងឬទេថា តើមាស មុត ជាអ្នកចេញប្រកាសព័ត៌មាននេះ? ឆ.7៖ បាទ ដោយសារគាត់ជាមេបញ្ជាការកងពល ដូច្នេះគឺមានតែគាត់ហើយជាអ្នកបញ្ជូនសេចក្តីប្រកាសនេះមកថ្នាក់ក្រោម។ ស៖ ម៉េចបានជាលោកដឹងរឿងនេះ? ឆ.8៖ គ្មាននរណាទៀត ក្រៅពីគាត់ដែលអាចចេញការប្រកាសនេះ ពីព្រោះគាត់ជាមេបញ្ជាការកងពល។ ការប្រកាសអំពីការចាប់ចងនេះ គឺសម្រាប់តែចាប់ចងពួកប្រធានកងដែលក្បត់តែប៉ុណ្ណោះ មិនមែនសម្រាប់ការចាប់ចងទូទៅទេ"]។ អំពីការក្បត់របស់ ឆាន សូមមើលផងដែរ ឯកសារ D10.1.59 ទង់បដិវត្ត ខែសីហា ឆ្នាំ ១៩៧៧ EN 00399226, KH 00062952, FR 00611830 [ថ្នាក់ដឹកនាំមជ្ឈិមបក្ស បានពិភាក្សាអំពីការក្បត់របស់ អាឆាន រួមគ្នាជាមួយ អាចុង [និងអាញ៉ឹក ជាភាសាបារាំង] "គឺវាចង់យកកោះកុង [...] ដើម្បីចូលដៃជាមួយអាណុលជាមួយថៃប្រតិកិរិយា [...] យើងដោះស្រាយសមាសភាពជាមេរោគ នៅកោះកុងបាន នៅកំពង់សិលាបាន។ ឥឡូវនេះតំបន់៣៧ ទាំងមូលដែលសរុបទាំង១១ (ចាស់), ៣៧ (ថ្មី) ហៅថា ៣៧ (ថ្មី) គឺស្អាត ស្អាតជាងមុនច្រើនណាស់"]។ ឯកសារ D114/261 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី ឆ.35 ["ស៖ តើមានរឿងអ្វីកើតឡើងចំពោះ តាឆាន់? ឆ.35៖ ក្រោយមក យើងឮមិនច្បាស់ ឮមិនពិត តែគេគ្រាន់ថាជាគណៈតំបន់ក្បត់"]។

1229 ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.1 ["បន្ទាប់ពីគេដកអាវុធពីពួកយើងអស់ [...] មាស មុត បានមកធ្វើមិទ្ទីងជាមួយពួកយើងនៅភូមិគគីរ នៅជិតព្រលានយន្តហោះកងកេង ដោយមានអតីតយោធាចូលរួមប្រហែលរាប់ពាន់នាក់ ដោយមានកងវរៈសេនាតូច៣៨៦ និងកងផ្សេងៗទៀត។ នៅក្នុងអង្គប្រជុំ មាស មុត អានចម្លើយ

ភាពពិសេសរបស់ **មាស មុត** ដកហូតអាវុធ កាលពីលើកមុនផងដែរ[1230]។ មុនពេលចាប់ខ្លួន ឆាន ឌឹម បានចាក់ចម្លើយសារភាពរបស់គាត់ឱ្យអ្នកនៅក្រោមបង្គាប់របស់គាត់ស្តាប់នៅស្ទឹងហាវ[1231]។

---

សារភាពរបស់ពួកក្បត់ គាត់បានរៀបរាប់ឈ្មោះកម្មាភិបាលក្បត់ចាប់ពីថ្នាក់មជ្ឈិម រហូតដល់ថ្នាក់មូលដ្ឋាន។ ខ្ញុំនៅចាំថា គាត់ហៅឈ្មោះ អាយ៉ា, អាធុធ, អាញ៉ុក, អាយ៉ាន, អាឆាន និងអាឌឹម។ ខ្ញុំនៅចាំ មាស មុត ហៅពួកគេថា "អា" ពីព្រោះ "អា" ជាពាក្យបណ្តុះបង្គាប់សម្រាប់និយាយទៅកាន់ពួកក្បត់"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.56-60, 63 ["យើង [យោធាដកអាវុធនៃកងវរៈសេនាតូច៣៨៦ និងយោធាបូព៌ា] ឈប់នៅព្រលានយន្តហោះ កង កេង ហើយគេប្រជុំនៅពេលព្រឹកហ្នឹង។ ហើយ មាស មុត ជាប្រធានអង្គប្រជុំ [...] ឆ.58៖ [អំឡុងពេលប្រជុំ] មានអ្នកយាម មានទាហានយាម [...] ស៖ តើទាហានដែលយាមនោះមានអាវុធទេ? ឆ.59៖ មាន [...] ឆ.60៖ ប្រជុំពីបញ្ហាមេក្បត់ គឺអនុមេបញ្ជាការកងពល១៦៤ នង ឆាន ជាអ្នកក្បត់ ហើយមាស មុត អានចម្លើយសារភាពរបស់ នង ឆាន ហ្នឹង [...] ឆ.63៖ ចាំបានត្រង់គាត់និយាយពីចម្លើយសារភាពរបស់ពួកក្បត់ និយាយពី នង ឆាន និងមេៗរបស់ខ្ញុំទាំងពីរនាក់ហ្នឹង [...] មាស មុត គ្រាន់តែនិយាយថា ពួកគាត់ក្បត់"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.10 ["ខ្ញុំបានឮសួរពីយោធាក្នុងកងជាមួយគ្នា និយាយថា ឌឹម និងឆាន ត្រូវបានបញ្ជូនទៅកាន់ម៉ាស៊ីនបូមទឹកនៅបឹងជើងឯក។ នៅពេលនោះ យើងជឿថា រឿងហ្នឹងជារឿងពិត។ ប៉ុន្តែក្រោយមកនៅពេលដែល តាមុត ប្រកាសនៅក្នុងអង្គប្រជុំអំពីចម្លើយសារភាពរបស់ពួកក្បត់ និងខ្សែរយៈសេ.អ៊ី.អា និង កា.ហ្សេ.បេ ហើយបន្ទាប់ពីបាត់ខ្លួនពួកនោះ ទើបយើងដឹងថា ពួកគេទាំងនោះត្រូវបានចាប់ខ្លួនហើយ"]។ ឯកសារ D54/101 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.11 ["តាមុត បានលើកយករឿងនេះ [...] ដោយមានទាំងចម្លើយសារភាពរបស់ពួកនោះ [កម្មាភិបាល] មកអានប្រាប់យើងស្តាប់ផង ហើយគាត់បានប្រកាសថា ពួកនេះជាខ្សែពួកក្បត់"]។ សូមមើលផងដែរ ការពន្យល់របស់សាក្សី គឹម ហាវ ដែលទំនងជាបានមកពីអ្វីដែលថ្នាក់ដឹកនាំកងពល ១៦៤ បាននិយាយទៅកាន់កងទ័ពអំពីអំពើក្បត់របស់ ឆាន៖ ឯកសារ D114/226 កំណត់ហេតុស្តាប់ចម្លើយ គឹម ហាវ ឆ.97 ["កាលនោះក្នុងឆ្នាំ១៩៧៦ ហ្នឹងគម្រោងការរបស់អង្គការ ដោយ ឆាន ដឹងថាប៉ុល ពត នៅឆ្នាំ៧៧ បង្កើតជាសហករណ៍ ហូបបាយរួម ដូច្នេះគាត់ចង់រំលំប៉ុល ពត ព្រោះចង់ឲ្យប្រជាជនហូបឯកជនវិញ។ គេក្តាប់បាន គេចុះមករំសាយទ័ព ហើយចាប់មេៗ និងកងទ័ព"]។

1230 ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.90, 93, 111 ["ស៖ ហេតុអ្វីបានជាគេរំសាយអង្គភាពរបស់លោក? ឆ.90៖ គេចោទយើងជាខ្សែខ្មាំង ដោយសារមេកងវរៈរបស់ពួកយើងត្រូវបានគេចាប់យកទៅបាញ់សម្លាប់អស់ហើយ [...] ឆ.93៖ បញ្ជាច្បាស់ជាចេញមកពី តាមុត ហើយពួកគេជាមនុស្សរបស់តាមុត ដែលប្រមូលផ្តុំឲ្យពួកយើងប្រជុំ ហើយប្រាប់ពួកយើងថា នឹងត្រូវបញ្ជូនទៅតាមការដ្ឋានខុសៗគ្នា។ ពួកគេរួមបញ្ចូលមនុស្សមកពីអង្គភាពផ្សេងៗគ្នាឲ្យធ្វើការនៅក្នុងកងផលិត [...]ស៖ ដូច្នេះ គឺលោកត្រូវបានគេរំសាយ ហើយឲ្យធ្វើការនៅក្នុងកងផលិតនៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ តើត្រឹមត្រូវដែរ ឬទេ? ឆ.111៖ បាទ ត្រឹមត្រូវហើយ គឺដើមឆ្នាំ១៩៧៧"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ កឹម ម៉េន ឆ.181 ["ស៖ តើលោកមានចាំទេថា ទាហានដែលមកពីតំបន់៣៧ ចេញពីកោះតាង ទៅពេលណា? ឆ.181៖ គេប្រមូលយកទៅវិញ ទៅជាមួយបង ឆាន ទៅអង្គភាពគេវិញ ប្រហែលនៅដើមឆ្នាំ១៩៧៧ ឬចុងឆ្នាំ១៩៧៦"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.19

353. មិនត្រឹមតែគេលែងទុកចិត្ត នៅក្នុងកងពល ១៦៤ ប៉ុណ្ណោះនោះទេ អតីតកងទ័ពតំបន់ ៣៧ (កងវរសេនាតូច ៣៨៦) ក៏ត្រូវបានគេចាត់ទុកថាជាជនក្បត់ផងដែរ ពីព្រោះពួកគេត្រូវបានចាត់ទុកថាស្ថិតនៅក្នុងបណ្តាញរបស់ ឆាន[1232]។ ហេតុដូច្នេះ កងវរសេនាតូច ៣៨៦ ចាស់ ត្រូវបានរំលាយ

---

["គេបញ្ជូនចេញពីកោះមក គេដកសត្រាវុធចេញទាំងអស់ ឱ្យយើងចេញពីកោះ ឱ្យមកតែខ្លួនទេ។ មកដល់ស្ទឹងហាវ គេចាប់ផ្តើមរៀបជាអង្គភាព។"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.20, 22 ["គេបានបញ្ជូនពួកខ្ញុំឱ្យទៅឈរជើងនៅកោះតាង បាន៣ ឬ៤ខែដែរ។ គឺនៅលើកោះតាង នេះឯង ដែលគេរំសាយអង្គភាពខ្ញុំមុននឹងបញ្ជូនពួកខ្ញុំឱ្យមកធ្វើស្រែនៅព្រលានយន្តហោះកងកេង។ ពេលគេរំសាយ គេចែកឱ្យចបម្នាក់មួយៗ ដើម្បីធ្វើការ [...] ឆ.22៖ កង៨៦ទាំងអស់របស់ខ្ញុំត្រូវបានគេដកអាវុធនៅលើកោះតាង ហើយបញ្ជូនត្រឡប់មកផែវាមវិញ ដែលជាទីកន្លែងដែលគេរំសាយពួកខ្ញុំ ហើយឱ្យចបពួកខ្ញុំម្នាក់មួយៗធ្វើការ"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.44-46, 54-56, 60-62 [ពន្យល់ថា ក្រោយពីប្រធានពីរនៃកងអនុសេនាធំ២ របស់គាត់ធ្វើអត្តឃាត ពួកគេទាំងអស់ត្រូវគេដកអាវុធ នៅកោះតាង នៅឆ្នាំ១៩៧៧ បន្ទាប់មកបញ្ជូនទៅដីគោក ជាមួយនឹងយោធាកងអនុសេនាធំ៣ និងយោធាភូមិភាគបូព៌ា។ មាស មុត អានចម្លើយសារភាពរបស់ ឆាន នៅក្នុងអង្គប្រជុំមួយ នៅកងកេង ហើយបញ្ជូនពួកគេទៅធ្វើការនៅកងផលិត ពីព្រោះប្រធានរបស់ពួកគេគឺជាជនក្បត់]។

1231 ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.30-32, 34-35 ["ស៖ តើធ្លាប់មានការប្រកាស ឬការប្រជុំដើម្បីប្រកាសថា តាឆាន ជាជនក្បត់? ឆ.30៖ មាន។ ពេលគេចាប់បានមួយខែ តាខឹម ដែលជាអនុ មកប្រជុំប្រាប់កន្លែងខ្ញុំ ដោយមានសៀវភៅកត់កំណត់ត្រា និងឯកសារសំឡេង។ តែក្រោយមក ពីរខែ គេចាប់តាខឹម ទៀត។ ស៖ តើឯកសារជាសំឡេងដែលលោកបានឮជាអ្វី? ឆ.31៖ សំឡេង តាឆាន គេវៃសួរចម្លើយ ហើយគាត់ឆ្លើយ។ គេចាក់ចម្លើយគាត់ឱ្យយើងស្តាប់ ហើយគេកត់នឹងសៀវភៅ ហើយអានឱ្យយើងស្តាប់ទៀត។ ស៖ តើលោកដឹងថា អ្នកណាជាអ្នកសួរចម្លើយ តាឆាន នៅក្នុងខ្សែអាត់សំឡេងនោះទេ? ឆ.32៖ មេគុកទួលស្លែង។ គាត់ថត ហើយបញ្ជូនទៅ។ [...] ឆ.34៖ សំឡេងតាឆាន? ពេលគេវៃហើយ គាត់ប្រាប់ថា គាត់វៃតាមុត វៃអ៊ីចឹង។ សំឡេងបីបួនកាសែត តែខ្ញុំមិនចាំទេ។ សំឡេងគាត់ដូចត្រូវគេវៃ។ ស៖ លោកថា គាត់ដូចត្រូវគេវៃ។ តើមានន័យថាយ៉ាងម៉េច? ឆ.35៖ ខ្ញុំមិនប្រាកដថាគាត់ត្រូវគេវៃទេ។ តែគាត់ស្តាប់ទៅដូចភ័យ"]។

1232 ឯកសារ D114/105 កំណត់ហេតុស្តាប់ចម្លើយ កុច ទុយ ឆ.79 ["គេថាតំបន់៣៧ ក្បត់ និងប្រុងរត់ចូលយួនអស់ ហើយពួកគេបានចាប់សម្លាប់មេធំនៅទីនោះទៅរៀនសូត្រអស់ ហើយចេះតែបាត់ខ្លួនរហូត ដូចជា ឆាន ជាដើម។ បន្ទាប់មកពួកគេបានរំសាយពួកខ្ញុំដែលជាកូនចៅ ហើយបញ្ជូនពួកខ្ញុំទៅវាមវិញ នៅកងចល័តក្រោម តាប៉ាន់ និងតាជន"]។ ឯកសារ D54/103 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.7-8, 12 ["ស៖ លោកបាននិយាយថា នង ឆាន ត្រូវបានចាប់ខ្លួននៅចុងឆ្នាំ១៩៧៦។ តើក្រោយពីចាប់ខ្លួន នង ឆាន ប៉ុន្មានខែទើបគេ [...] ធ្វើការដកកាំភ្លើងពីកងរបស់លោក? ឆ.7៖ យោធាកងរបស់ខ្ញុំត្រូវបានគេដកកាំភ្លើងនៅដើមខែវស្សា ក្នុងឆ្នាំ១៩៧៧។ នៅពេលនោះ តាមុត បានមកប្រជុំជាមួយនឹងពួកយើងក្រោយពេលដែលដកកាំភ្លើង នៅពេលដែលគាត់បានប្រកាសនៅក្នុងអង្គប្រជុំថា ឆាន ជាពួកក្បត់ ហើយសម្រាប់ពួកអតីត៨៦ (៣៨៦) គឺមិនគួរទុកចិត្តបានទៀតទេ។ បន្ទាប់ពីគេចាប់ ឆាន រួចហើយ ថ្នាក់ដឹកនាំដែលជាស្នងការនយោបាយ និងមេបញ្ជាការថ្នាក់កងវរៈសេនាតូច កងអនុសេនាធំ កងអនុសេនាតូច គឺត្រូវបានគេចាប់

ខ្លួនផងដែរ [...] សៈ នៅពេលដែល មាស មុត បាននិយាយថា កង៨៦ (៣៨៦) ថាជាពួកដែលមិនគួរឱ្យទុកចិត្ត តើ មាស មុត មានបាននិយាយថា ត្រូវចាត់ការពួកនេះយ៉ាងម៉េចទេ នៅពេលអនាគតខាងមុខ? ឆ.8៖ នៅពេលនោះ អ្នកដែលចូលរួមប្រជុំទាំងអស់មានប្រហែល៥០០នាក់ ដែលរួមទាំងអតីតយោធាកង៨៦ (៣៨៦) ប្រហែលជាង១០០នាក់ ដែលគេដកកាំភ្លើងរួច [...] តាមុត បាននិយាយនៅក្នុងអង្គប្រជុំនោះថា ទាំងអស់គ្នាត្រូវតែតាមដានពួកអតីតយោធាកង៨៦នេះ។ គាត់បាននិយាយថា ពួកអតីតយោធាកង៨៦ សុទ្ធតែខ្សែ កា.ហ្សេ.បេ និងសេ.អ៊ី.អា។ គាត់ថា ខ្សែកា.ហ្សេ.បេ និងសេ.អ៊ី.អា នេះមិនទាន់បានកម្ទេចបានទាំងស្រុងនៅឡើយទេ។ ពួកនេះ គឺនៅលាក់ខ្លួនក្នុងជួរយើង ដូច្នេះយើងត្រូវតែតាមដានពួកនេះឱ្យជាប់។ ក្នុងចំណោមយោធាជាង៥០០នាក់ ដែលចូលរួមប្រជុំនេះ ក្រៅពីអតីតយោធាកង៣៨៦ គឺសុទ្ធតែពួកយោធារបស់ពួកគេ ដើម្បីមកតាមដានពួកអតីតយោធាកង៣៨៦ [...] ឆ.12៖ យោធាកង៣៨៦ទាំងអស់ គឺត្រូវបានគេដកកាំភ្លើងមិនមាននៅសល់ទេ [យោធារបស់ មាស មុត] គេបានធ្វើការស្រាវជ្រាវជីវប្រវត្តិយ៉ាងច្បាស់ រួចហើយបានគេហៅអតីតយោធាដែលនៅក្នុងកង៣៨៦ ឱ្យចូលខ្លួនមក ហើយគេធ្វើការដកកាំភ្លើង”]។ ឯកសារ D114/112 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.15 [ពន្យល់ថា អតីតយោធាតំបន់៣៧ ត្រូវបានដកចេញពីកោះ និងបញ្ជូនទៅស្ទឹងហាវ នៅខែកក្កដា ឆ្នាំ១៩៧៧ ក្រោយប្រធានតំបន់៣៧ ត្រូវបានគេប្រកាសថាមិនស្មោះត្រង់]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.45-46, 56, 60-62 [អំពីអតីតសមាជិកកងវរសេនាតូច៣៨៦ ឈរជើងនៅកោះតាង៖ “កងខ្ញុំត្រូវគេដកអាវុធអស់ហើយ តែកាលហ្នឹងវាមិនមែនតែខ្ញុំមួយកងទេ ព្រោះគេបញ្ចូលគ្នា។ ពេលគេដកអាវុធអស់ហើយ គេបញ្ជូនមកដីគោកវិញ [...] ឆ.46៖ នៅឆ្នាំ១៩៧៧ [...] ឆ.56៖ គេបញ្ជូនមកហ្នឹង ឈប់នៅព្រលានយន្តហោះកងកេង ហើយគេប្រជុំនៅពេលព្រឹកហ្នឹង។ ហើយ មាស មុត ជាប្រធានអង្គប្រជុំ [...] ឆ.60៖ ប្រជុំពីបញ្ហាមេក្បត់ គឺអនុមេបញ្ជាការកងពល១៦៤ នង ឆាន ជាអ្នកក្បត់ ហើយ មាស មុត អានចម្លើយសារភាពរបស់ នង ឆាន ហ្នឹង [...] ឆ.61៖ គាត់បញ្ជូនពួកខ្ញុំទៅកងផលិតពេលប្រជុំចប់។ កងហ្នឹងដូចអ្នកទោសអ៊ីចឹង គឺគ្មានអាវុធទេ គេឱ្យទៅធ្វើស្រែលើកដីបង្កបង្កើនផល ដូចប្រជាជនធម្មតាអ៊ីចឹង [...] ឆ.62៖ គេសន្និដ្ឋានថាមេរបស់ពួកខ្ញុំក្បត់”]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.1-2 [“ម្សិលមិញ យើងបាននិយាយអំពីសេចក្តីប្រកាសដែលធ្វើឡើងដោយ មាស មុត ក្នុងកម្មវិធីរំឭកជ័យជម្នះធ្វើឡើងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៧។ ដោយសារហេតុការណ៍នេះកើតឡើងជាយូរណាស់មកហើយ តើលោកនៅចាំថាកាលនោះ មានតែការប្រកាសអំពីការចាប់ខ្លួន ឆាន ហើយនិង ឌឹម ឬក៏មានការប្រកាសអំពីវិធានការដែលគេត្រូវអនុវត្តបន្តទៀតពាក់ព័ន្ធនឹងបញ្ហានេះ? ឆ.1៖ មាស មុត ក៏បានថ្លែងដែរថា នៅថ្ងៃខាងមុខនឹងធ្វើការស្រាវជ្រាវរកអ្នកដែលពាក់ព័ន្ធនឹងជនក្បត់ទាំងនេះ [ឆាន និង ឌឹម] [...] ឆ.2៖ គាត់បាននិយាយបែបនេះថា ប្រសិនបើអ្នកណាពាក់ព័ន្ធនឹងជនក្បត់ទាំងនេះ សូមចេញមកសារភាព”]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.89-90, 92-93, 100 [“ក្រោយមកគេរំសាយកងទ័ព ហើយប្រែក្លាយអង្គភាពយើងទៅជាកងផលិត ដោយឱ្យធ្វើស្រែ លើកទំនប់ និងជីកប្រឡាយ។ សៈ ហេតុអ្វីបានជាគេរំសាយអង្គភាពរបស់លោក? ឆ.90៖ គេចោទយើងជាខ្សែខ្មាំង ដោយសារមេកង វរៈរបស់ពួកយើងត្រូវបានគេចាប់យកទៅបាញ់សម្លាប់អស់ហើយ [...] ឆ.92៖ តាមពិត កងពលត្រូវបានរំសាយ គឺមានទាហានរាប់ពាន់នាក់។ ពួកគេត្រូវបានចាត់តាំងឱ្យធ្វើការងារក្នុងកងផលិតខុសៗគ្នា និងបញ្ជូនទៅតាមមុខព្រួញការងារខុសៗគ្នា [...] ឆ.93៖ បញ្ហាច្បាស់ជាចេញមកពី តាមុត ហើយពួកគេជាមនុស្សរបស់តាមុត ដែលប្រមូលផ្តុំឱ្យពួកយើងប្រជុំ ហើយប្រាប់ពួកយើងថា នឹងត្រូវបញ្ជូនទៅតាមការដ្ឋានខុសៗគ្នា [...] សៈ តើក្នុងខែណាឆ្នាំណា ដែលគេចោទពួកលោកថាជាខ្សែខ្មាំង? ឆ.

ចោលទាំងស្រុង ហើយកម្មាភិបាលមានឋានៈទាប ឬយុទ្ធជន ត្រូវគេដាក់ឲ្យធ្វើជាទាសករ និងធ្វើបាបដោយអមនុស្សធម៌ នៅការដ្ឋានធ្វើការដោយបង្ខំ ដូចជានៅ កងកេង[1233] ការដ្ឋានផ្សេងទៀត

---

100៖ គឺចុងឆ្នាំ១៩៧៧ ហើយកងពលចាស់ទាំងមូលត្រូវបានវំសាយទាំងស្រុង"]។ ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ន សុត ឆ.5, 18 ["កងទ័ពតំបន់ពិសេស កងវរៈសេនាតូច៣៨៦ ត្រូវបានបញ្ចូលទៅក្នុងកងពលធំ៣ ក្រោយរំដោះឆ្នាំ១៩៧៥។ ដល់ចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ បានចាប់មេបញ្ជាការទាំងអស់ចោទថាតំបន់ ហ្នឹងក្បត់។ ក្រោយចាប់អស់ ក៏រំលាយពួកខ្ញុំ ហើយបញ្ជូនយកទៅធ្វើស្រែ។ បើសិនជាបងប្អូនមិនតាមទេ គឺត្រូវគេសម្លាប់ចោល [...] ឆ.18៖ នៅរស់តែកូនទាហានទេ។ ហើយកូនទាហានក៏គេចាប់ដែរឲ្យតែរឹងទទឹង យើងត្រូវតែធ្វើការតាមពួកវារហូត គឺត្រូវលត់ដំ"]។ ឯកសារ D114/135 កំណត់ហេតុស្តាប់ចម្លើយ ណុប ផន ឆ.19 ["មានទាហានប្រហែលជា៦០ ទៅ១០០នាក់ នៅក្នុងកងអនុសេនាធំ [៤២០] របស់ខ្ញុំ ដែលត្រូវបានគេរំសាយ។ ទាហាននៅក្នុងអង្គភាពផ្សេងទៀត ក៏ត្រូវបានគេរំសាយដែរ ប៉ុន្តែខ្ញុំមិនដឹងថា ប៉ុន្មាននាក់ទេ។ យើងត្រូវបានគេរំសាយ ក្រោយពេលដែលមេៗរបស់យើងត្រូវបានគេដកចេញ ហើយគេលែងទុកចិត្តយើងទៀត"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញិក ឆ.24 ["ពួកគេចោទមនុស្សនៅក្នុងតំបន់៣៧ ថាជាសមាសភាពមិនល្អ ពីព្រោះក្នុងតំបន់នេះត្រូវបានរៀបចំដោយ វៀតណាម តាំងពីឆ្នាំ១៩៧០មកម្ល៉េះ។ ដូច្នេះគេចោទពួកយើងថាមានទំនាក់ទំនងខ្សែរយៈជាមួយវៀតណាម"]។ សូមមើលផងដែរ ឯកសារ D114/226 កំណត់ហេតុស្តាប់ចម្លើយ គឹម ហាវ ឆ.94-95 ["តើមានអ្វីកើតឡើងចំពោះទាហានទាំងនោះ នៅពេលដែលពួកគេត្រូវរំសាយ? ឆ.94៖ គេចោទប្រកាន់ថាទ័ពតំបន់៣៧ក្បត់ ចូលដៃជើងជាមួយយួន។ ស៖ តើអ្នកណាជាអ្នកធ្វើការចោទប្រកាន់នេះ? ឆ.95៖ គណៈភូមិភាគ គេចុះមកចោទប្រកាន់ថា ពួកទ័ពតំបន់៣៧ ក្បត់ទាំងប្រជាជន ទាំងទ័ព។ ដូច្នេះមិនអាចទុកបានទេ។ ក្បត់អង្គការ ដូច្នោះមិនអាចទុកបានទ"]។

1233 ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.20-21, 23-24, 33 ["គេបានបញ្ជូនពួកខ្ញុំឲ្យទៅឈរជើងនៅកោះតាង បាន៣ ឬ៤ខែដែរ។ គឺនៅលើកោះតាង នេះឯង ដែលគេរំសាយអង្គភាពខ្ញុំមុននឹងបញ្ជូនពួកខ្ញុំឲ្យមកធ្វើស្រែនៅព្រលានយន្តហោះកងកេង។ ពេលគេរំសាយ គេចែកឲ្យចបម្នាក់មួយៗ ដើម្បីធ្វើការ [...] ឆ.21៖ ខ្ញុំឮថាគេចោទកម្មាភិបាលមកពីតំបន់៣៧ ថាចូលដៃជាមួយខ្មាំង។ ខ្ញុំចង់ប្រាប់លោកថា ចាស់ៗទាំងអស់ដែលជាកម្មាភិបាលមកពីតំបន់៣៧ ត្រូវបានគេយកទៅសម្លាប់ទាំងអស់ [...] នៅសល់តែខ្ញុំ និងក្មេងប្រុសៗផ្សេងទៀតទេ ដែលគេមិនសម្លាប់ចោល"], ឆ.23-24, 33 [ពន្យល់អំពីស្ថានភាពការងាររបស់អតីតយោធាកងវរសេនាតូច ៣៨៦ ចំនួន២០០/៣០០នាក់ ដែលគេរំសាយ ដោយឲ្យធ្វើការនៅវាលស្រែ ម្តុំកងកេង និងអំពីរបៀបដែលពួកគេទទួលបានការហូបចុកតិចតួចពេក អស់កម្លាំង ហើយគេមិនអនុញ្ញាតឲ្យឈប់សម្រាក ដោយគំរាមចាប់ខ្លួន]។ ឯកសារ D114/135 កំណត់ហេតុស្តាប់ចម្លើយ ណុប ផន ឆ.19-20 ["មានទាហានប្រហែលជា៦០ ទៅ១០០នាក់ នៅក្នុងកងអនុសេនាធំ [៤២០] របស់ខ្ញុំ ដែលត្រូវបានគេរំសាយ។ ទាហាននៅក្នុងអង្គភាពផ្សេងទៀត ក៏ត្រូវបានគេរំសាយដែរ ប៉ុន្តែខ្ញុំមិនដឹងថា ប៉ុន្មាននាក់ទេ។ យើងត្រូវបានគេរំសាយ ក្រោយពេលដែលមេៗរបស់យើងត្រូវបានគេដកចេញ ហើយគេលែងទុកចិត្តយើងទៀត។ គេបញ្ជូនយើងឲ្យទៅចូលតាមកងចល័តនៅកងកេង ដើម្បីធ្វើស្រែ [...] ឆ.20៖ យើងមិនបានយកអាវុធមកតាមខ្លួនឡើយ ហើយគេឲ្យយើងយកតែសម្លៀកបំពាក់តាមខ្លួនប៉ុណ្ណោះ [...] យើងស្នាក់នៅកងកេងមួយយប់ ហើយគេប្រាប់យើងថា គេនឹងបែងចែកយើងទៅតាមកងចល័តផ្សេងៗ នៅព្រឹកបន្ទាប់"]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត

នៅឃុំរាម[1234] ឬស្ទឹងហាវ[1235]។ ពួកគេរស់នៅ និងធ្វើការក្នុងភាពភ័យខ្លាចជាប់ជាប្រចាំថា គេនឹងចាប់ខ្លួន និងសម្លាប់ពួកគេចោល ព្រោះថាគោលបំណងរបស់ថ្នាក់ដឹកនាំកងពល ១៦៤ គឺធ្វើតែស្ត

---

ប៊ុណ្ណា ឆ.4, 7 ["ពួកយើងរស់នៅដោយការភ័យខ្លាច ជាពិសេសពួកខ្ញុំដែលគេប្រមូលទៅរស់នៅមួយកន្លែងនៅអូរឈើទាល និងនៅព្រលានយន្តហោះកងកេង។ ខ្ញុំនៅចាំច្បាស់ថា គេដកខ្ញុំពីកងទ័ពជើងទឹកនៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅរស់នៅព្រលានយន្តហោះកេងកង [...] ឆ.7៖ នៅយប់មួយនោះ មានមនុស្សម្នាក់ដែលខ្ញុំពុំស្គាល់ បានមកសួរនាំឈ្មោះពួកយើង ហើយពួកគេក៏បានពិនិត្យបញ្ជីឈ្មោះ ហើយបានឃើញឈ្មោះមនុស្សបីនាក់ក្នុងអង្គភាពខ្ញុំ រួមទាំងខ្ញុំផង។ ពីរនាក់ផ្សេងទៀត ក្រោយមកត្រូវបានគេបញ្ជូនទៅស្ទឹងហាវ។ គឺមានតែខ្ញុំម្នាក់ទេក្នុងអង្គភាពខ្ញុំត្រូវបានបញ្ជូនទៅព្រលានយន្តហោះកងកេង"]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ុន យ៉ើ ឆ.17, 42 ["ក្រោយបែកភ្នំពេញ១៩៧៥ ខ្ញុំនៅអង្គភាពកងផលិត តំបន់៣៧ ក្រុងព្រះសីហនុ។ ខ្ញុំនៅឯកងកេង ស្នាច់ដែងនៅកងផលិត។ រស់នៅរយៈពេលខ្លី នៅកងកេងនេះ អានេះគេដកដូចជាសិទ្ធិយើងពីអ្នកតំបន់៣៧។ គេយកដាក់ដោយឡែក គេដកអាវុធយើងចេញ [...] ស៖ តើមានការដកសមាជិកពីកងផលិតនៅទីតាំងកងកេងដែរ ឬទេ? ឆ.42៖ មានគឺដកទៅនៅស្ទឹងហាវ"]។

[1234] ឧទាហរណ៍ ឯកសារ D114/105 កំណត់ហេតុស្តាប់ចម្លើយ កុច ទុយ ឆ.81 ["ឲ្យតែមេៗ គេយកចេញទាំងអស់ អ្នកដែលពាក់ព័ន្ធជាមួយតំបន់៣៧ តាំងពីថ្នាក់កងហា កងរយ កងវរៈ សូម្បីតែតានាន នៅថ្នាក់កងពល៤ នៅកោះតាងនោះ ក៏បាត់ខ្លួនដែរ។ ហើយប្រជាជនតំបន់៣៧ ចេះតែស្លាប់ទៅរហូត អ្នកខ្លះអត់បាយ ខ្លះក៏បាក់កម្លាំងស្លាប់អស់ទៅ"], ឆ.86-94 [ពន្យល់អំពីស្ថានភាពការងារ និងការរស់នៅយ៉ាងយាប់យឺននៅកងចល័ត ដែលគេបង្ខំគាត់ឲ្យចូលរួមរួមមានការកសាងសង់ទំនប់ នៅភូមិបបុស ឃុំរាម], ឆ.101, 123 ["ស៖ តើលោក និងអ្នកដែលមកពីកងវរៈសេនាតូច ៨៦ ជាមួយគ្នា ហត់ទេ ពេលធ្វើការនោះ? ឆ.101៖ បាទ ហត់ណាស់ អ្នកខ្លះអង្គុយហត់ពេក ក៏ស្លាប់ទាំងអង្គុយហ្នឹងក៏មាន នៅពេលដែលលើកបង្គី រែកដី ដើរដួលស្លាប់ក៏មាន ជួនកាលពេលយប់មកសម្រាកស្លាប់ក្នុងអង្រឹងក៏មាន។ កន្លែងដែលជីហ្នឹង នៅខាងលិចវត្តរាម ទំបន់ហ្នឹងធំណាស់ មាននៅដល់រាល់ថ្ងៃ។ កាលនោះមានមនុស្សស្លាប់រាល់ថ្ងៃ ស្លាប់មួយថ្ងៃបួន ប្រាំនាក់ [...] ស៖ នៅកងចល័ត អ្នកដែលមកពីកងវរៈសេនាតូច៨៦ ជាមួយលោក ដែលបាត់ខ្លួន ឬស្លាប់នោះ តើមានរណាម្នាក់រស់ នៅក្នុងភូមិកំណើតរបស់លោកដែរ ឬទេ? ឆ.123៖ មានដូចជា កុយ ហំ, សន ធូន់, គូ មី, យួន យន់ [...] ពួកគេសុទ្ធតែជាអ្នកបាត់ខ្លួនទាំងអស់"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មួល ឈិន ឆ. 89, 91-92, 107, 112, 115, 117 ["ក្រោយមក គេបានរំសាយកងទ័ព ហើយប្រែក្លាយអង្គភាពយើងទៅជាកងផលិតដោយឲ្យធ្វើស្រែ លើកទំនប់ និងជីកប្រឡាយ [...] ឆ.91៖ ក្រោយពេលមេកងវរៈរបស់យើងបានបាត់ខ្លួន របបអាហារក៏កាន់តែតិច ហើយម្នាក់ៗគេឲ្យរែកដី៣ម៉ែត្រគូប ក្នុង១ថ្ងៃ ដើម្បីដាក់ខ្នងទំនប់ [...] ឆ.92៖ ពួកគេត្រូវបានចាត់តាំងឲ្យធ្វើការងារក្នុងកងផលិតខុសៗគ្នា និងបញ្ជូនទៅតាមមុខព្រួញការងារខុសៗគ្នា [...] ឆ.107៖ ខ្ញុំធ្វើការនៅព្រែកចាកម្ដុំរាម [...] ឆ.112៖ ៣ម៉ែត្រគូប ម្នាក់ក្នុង១ថ្ងៃ។ គេតម្រូវឲ្យយើងធ្វើឲ្យហើយក្នុង១ថ្ងៃដាច់ខាត បើធ្វើមិនចប់តាមផែនការគេកំណត់ គឺមិនឲ្យឈប់សម្រាកហូបបាយទេ [...] ឆ.115៖ ប្រជាជនមើលទៅស្គមស្គាំងខ្លាំងណាស់ គឺមើលទៅឃើញតែឆ្អឹង [...] ឆ.117៖ ប្រជាជនមានសភាពស្រេកឃ្លាន អស់កម្លាំង ឈឺស្គមស្គាំង ស្បែងឡើតណ៍លឿងដោយសារតែជំងឺគ្រុនចាញ់ និងជំងឺផ្សេងៗទៀត"]។ ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ន សុត ឆ.45

["ទីនោះគឺមានឈ្មោះថាព្រែកចាក កោះសំពោច មានស្រែ២កន្លែង ហើយកន្លែងទាំងពីរនេះមានទីតាំងខាងកើតរាម"], ឆ.61-68 [ពន្យល់អំពីស្ថានភាពការងារ និង្ការរស់នៅយ៉ាងយាប់យឺន រួមមាន ខ្វះការថែទាំសុខភាព ខ្វះអាហារ ដក របបអាហារពីអ្នកដែល "ធ្វើពុត" ជាឈឺ និងរៀបរាប់អំពីមនុស្សស្លាប់ដោយសារជំងឺរាគ និងការដាក់គុកមនុស្សម្នាក់ នៅទីកសាបដោយសារលួចដំឡូង]។

1235 ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.42 ["គេបញ្ជូនខ្ញុំទៅវាយថ្មនៅស្ទឹងហាវ នៅខែមករា ឬកុម្ភៈ ឆ្នាំ១៩៧៨។ ខ្ញុំចង់និយាយថា កងរបស់ខ្ញុំទាំងអស់គ្នាដែលត្រូវរំសាយ និងឲ្យធ្វើការនៅកងកេង ត្រូវបានគេបញ្ជូនទៅ ធ្វើការនៅកងកេង និងបន្ទាប់មកបញ្ជូនទៅស្ទឹងហាវ"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ. 23-24, 31 ["នៅពេលនោះ គេបានប្រហែលជា៨០ភាគរយ នៃពួកអតីតយោធាកងវរៈសេនាតូច៣៨៦ នៃតំបន់៣៧ ហើយបញ្ជូនឲ្យទៅធ្វើការនៅកន្លែងវៃថ្ម នៅស្ទឹងហាវ ដោយសារពួកនោះចាត់ថាជាសមាសភាពមិនល្អ [...] ឆ.24៖ ពួកគេចោទមនុស្សនៅក្នុងតំបន់៣៧ ថាជាសមាសភាពមិនល្អ ពីព្រោះក្នុងតំបន់នេះត្រូវបានរៀបចំដោយ វៀតណាម តាំងពីឆ្នាំ១៩៧០មកម្ល៉ោះ។ ដូច្នេះគេចោទពួកយើងថាមានទំនាក់ទំនងខ្សែរយៈជាមួយវៀតណាម [...] ឆ.31៖ បន្ទាប់ពី គេដកខ្ញុំចេញទៅ ស្ថានភាពរស់នៅរបស់ខ្ញុំ គឺមានការលំបាកខ្លាំងជាងពេលខ្ញុំនៅធ្វើជាយោធា [...] បន្ទាប់ពីខ្ញុំត្រូវបាន បញ្ជូនទៅកងផលិតនៅស្ទឹងហាវ គេមិនឲ្យហូបគ្រប់គ្រាន់ទេ ហើយការងារក៏ធ្ងន់ធ្ងរជាងមុនដែរ"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.17-18, 20, 25-26 ["មុនដំបូងគេហៅពួកខ្ញុំទៅរៀនសូត្រ បើក សាលារៀនសូត្រ។ ក្រោយពីនេះមកថាត្រូវចាប់បញ្ជូនទាហានដែលនៅក្នុងតំបន់៣៧ មកស្ទឹងហាវទាំងអស់ ប្រមូល ទ័ពទាំងអស់ ដើម្បីគេលត់ដំចម្រាញ់ទ័ព ដើម្បីគេសម្រិតសម្រាំងទ័ព ថាយើងហ្នឹងស្មោះត្រង់ជាមួយនឹងពួកគាត់ ឬអ ត់។ ស៖ តើយើងយល់ត្រឹមត្រូវដែរ ឬទេថា នៅគ្រាដំបូងនៃការបោសសម្អាតនោះ វាមិនសំខាន់ទេថា យោធាដូចរូប លោកក្នុងតំបន់៣៧ បានធ្វើអ្វីខុសឆ្គងនោះ គឺយោធាតំបន់៣៧ទាំងអស់ គឺត្រូវបានគេបញ្ជូនទៅស្ទឹងហាវ? ឆ.18៖ បាទ មិនដឹងថាយើងខុស ឬមិនខុសទេ ឲ្យតែក្នុងតំបន់អង្គភាពហ្នឹង ត្រូវបញ្ជូនទាំងអស់ [...] ស៖ តើលោកមាន អារម្មណ៍ថា ការងារហ្នឹងគេបង្ខំឲ្យលោកបំពេញទេ? ឆ.20៖ កន្លែងហ្នឹងជាកន្លែងលត់ដំ គឺដាច់ខាតយើងត្រូវតែធ្វើ អត់ ធ្វើ គឺអត់បាន [...] ឆ.25៖ ពាក្យថា "លត់ដំ" នេះមានន័យថា គេយកទៅធ្វើការងារ ដើម្បីឲ្យយើងកសាងខ្លួន [...] ឆ. 26៖ យើងជីវភាពហូបចុកអត់គ្រប់គ្រាន់ [...] មិនមានថ្នាំពេទ្យបរិបូរ។ ហើយយើងធ្វើការងារកំណត់ពេញៗម៉ោង"] ។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.26, 34 ["នៅកន្លែងវាយថ្ម គេបិទសិទ្ធិមិនឲ្យយើងធ្វើ ដំណើរ ឬទាក់ទាក់ជាមួយអ្នកកន្លែងផ្សេងទៀត បើមិនដូច្នោះទេ យើងនឹងត្រូវគេចាប់បញ្ជូនទៅបាត់ [...] ឆ.34៖ ស្ថាន ភាពរស់នៅ គឺដូចជាប់គុក ពីព្រោះយើងមិនត្រូវបានអនុញ្ញាតឲ្យដើរចេញក្រៅពីកន្លែងការដ្ឋានទេ"]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.7 ["នៅយប់មួយនោះ មានមនុស្សម្នាក់ដែលខ្ញុំពុំស្គាល់ បានមក សួរនាំឈ្មោះពួកយើង ហើយពួកគេក៏បានពិនិត្យបញ្ជីឈ្មោះ ហើយបានឃើញឈ្មោះមនុស្សបីនាក់ក្នុងអង្គភាពខ្ញុំ រួម ទាំងខ្ញុំផង។ ពីរនាក់ផ្សេងទៀត ក្រោយមកត្រូវបានគេបញ្ជូនទៅស្ទឹងហាវ"]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ ចម្លើយ អ៊ិន យ៉ើ ឆ.17, 42 ["ក្រោយបែកភ្នំពេញ១៩៧៥ ខ្ញុំនៅអង្គភាពកងផលិត តំបន់៣៧ ក្រុងព្រះសីហនុ។ ខ្ញុំនៅ ឯកងកេង ស្នាច់ដែង នៅកងផលិត។ រស់នៅរយៈពេលខ្លី នៅកងកេងនេះ អានេះគេដកដូចជាសិទ្ធិយើងពីអ្នកតំបន់ ៣៧។ គេយកដាក់ដោយឡែក គេដកអាវុធយើងចេញ [...] ស៖ តើមានការដកសមាជិកពីកងផលិតនៅទីតាំង កងកេងដែរ ឬទេ? ឆ.42៖ មាន គឺដកទៅនៅស្ទឹងហាវ"]។

និងសម្រិតសម្រាំងទាហានមិនស្មោះត្រង់ ដោយឱ្យពួកគេធ្វើការ និងរស់នៅក្នុងលក្ខខណ្ឌដ៏វេទនា[1236]។ ដោយសារពួកគេជាប់ពាក់ព័ន្ធជាមួយនឹង ឆាន ទាហានកងវរសេនាតូច ៣៨៦ ត្រូវបានចាប់ខ្លួន វាយដំយ៉ាងខ្លាំង ឬសម្លាប់ចោល ពេលពួកគេព្យាយាមរត់គេចខ្លួន ឬមិនអាចសម្រេចការងារដែលគេប្រគល់ឱ្យបាន តវ៉ា ឬប្រព្រឹត្តកំហុសតូចតាច (ដូចជា "លួច" ផ្លែឈើ ឬដំឡូងដោយសារតែការស្រេកឃ្លាន)[1237]។

---

1236 សូមមើលឧទាហរណ៍ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.17, 27 ["ក្រោយពីនេះមកថាត្រូវចាប់បញ្ជូនទាហានដែលនៅក្នុងតំបន់ ៣៧ មកស្ទឹងហាវទាំងអស់ ប្រមូលទ័ពទាំងអស់ ដើម្បីគេលត់ដំចម្រាញ់ទ័ពដើម្បីគេសម្រិតសម្រាំងទ័ព ថាយើងហ្នឹងស្មោះត្រង់ជាមួយនឹងគាត់ឬអត់ [...] ឆ.27៖ បើយើងមិនអនុវត្តតាមផែនការដែលគេដាក់ចុះទេ គេនឹងអាចចាប់បញ្ជូនយើង ជួនកាលគេធ្វើបាប ជួនកាលសម្លាប់ក៏មានដែរ"]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.4-5 ["ស៖ ក្រោយពេលគេប្រកាសអំពីការចាប់ខ្លួននោះ និងការបាត់ខ្លួនមេៗមួយចំនួននោះ តើយោធាក្នុងកងពល១៦៤ មានសតិអារម្មណ៍យ៉ាងម៉េច? ឆ.4៖ ពួកយើងរស់នៅដោយការភ័យខ្លាច ជាពិសេសពួកខ្ញុំដែលគេប្រមូលទៅរស់នៅមួយកន្លែងនៅអូរឈើទាល និងនៅព្រលានយន្តហោះកងកេង។ ខ្ញុំនៅចាំច្បាស់ថា គេដកខ្ញុំពីកងទ័ពជើងទឹកនៅថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅរស់នៅព្រលានយន្តហោះកេងកង។ ការព្រួយបារម្ភនោះគឺថា ពួកយើងមិនអាចដឹងថា គេមកចាប់ខ្លួនពួកយើងទៅនៅពេលណាមួយនោះទេ។ ស៖ យើងកត់សម្គាល់ឃើញថា លោកបាននិយាយច្រើនដងក្នុងបទសម្ភាសន៍អំពីការភ័យខ្លាចរបស់លោក តើលោកអាចបកស្រាយប្រាប់យើងអំពីការព្រួយបារម្ភទាំងនោះ និងពេលវេលាដែលលោកមានការព្រួយបារម្ភទាំងនោះបានដែរ ឬទេ? ឆ.5៖ ពួកយើងពុំមានការព្រួយបារម្ភទេ មុនការប្រកាសការប្រកាសអំពីការចាប់ខ្លួន ឌឹម និង ឆាន ដោយសារតែពួកយើងជាយោធាដែលមានសិទ្ធិពេញលេញ។ ពួកយើងមានកាំភ្លើងប្រើ ពួកយើងអាចទៅណាមកណាបាន។ ប៉ុន្តែក្រោយការប្រកាសអំពីការចាប់ខ្លួន ឌឹម និង ឆាន និងការចាប់ខ្លួនមេវរៈសេនាតូច និងវរៈសេនាធំ (តាហាម និងតាវ៉ែត) មកទៀត ពួកខ្ញុំជាច្រើននាក់កាន់តែភិតភ័យខ្លាំង ដោយសារថាយើងមិនដឹងថា គេមកចាប់យើងនៅពេលណានោះទេ"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.73, 90 ["តើលោកមានអារម្មណ៍យ៉ាងណាដែរ ពេលគេបញ្ជូនលោកមកកងផលិតហ្នឹង? ខ្ញុំភ័យណាស់ ខ្ញុំភ័យតាំងពីមេបោកគ្រាប់បែកសម្លាប់ខ្លួនហើយ [...] ឆ.90៖ ព្រោះដល់ពេលគេប្រកាសថាមេសុទ្ធតែក្បត់ទាំងអស់អ៊ីចឹងហើយ យើងអត់ហ៊ាន យើងខ្លាច"]។

1237 ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.91-93, 99, 101, 104-107 ["ក្រោយពីគេចាប់តាឆានមកយើងមិនហ៊ាននិយាយគ្នាទេ ព្រោះយើងខ្លាចគេថាយើងទំនាក់ទំនងគ្នា [...] ឆ.92៖ បើយើងឆ្លើយមិនត្រូវ គេចាប់យើងហើយ ព្រោះយើងកំពុងតែជាប់និន្នាការផង [...] ឆ.93៖ ឧបមាថា យើងនិយាយគ្នាមិនឱ្យគេឃើញ តែបើមានអ្នកឃើញ គេទៅប្រាប់ប្រធានកងរយ ហើយប្រធានចាប់យើងទៅវ៉ៃសួរចម្លើយយ [...] ឆ.99៖ ពេលតាឆាន ទៅយើងជាប់និន្នាការ គេឱ្យថ្ងៃឡើងវ៉ៃថ្ម រួចហើយគេឱ្យបាយដូចបបរប៉ុននេះ (ប្រហែលមួយកញ្ចុំបាតដៃ) ទេពេលថ្ងៃ និងពេលយប់។ ពេលថ្ងៃវ៉ៃថ្ម ហើយពេលយប់ គេប្រជុំជីវទស្សន៍។ បើអ្នកណាធ្វើខុស គេឱ្យអ្នកវ៉ៃថ្មជាមួយយើងហ្នឹង យកទៅវ៉ៃចោលតែម្តង [...] ឆ.101៖ យកទៅវ៉ៃចោលអស់ពីរបីនាក់។ ពេលយើងធ្វើការ ហើយមានការប្រជុំជីវទស្សន៍

ហើយបើពេលគេសង្ស័យយើង គេយកទៅ ហើយមិនដឹងយកទៅណាទេ គឺមិនដែលឃើញមកវិញទេ [...] ឆ.104៖ គេមានសាច់ឈាមល្អជាង គេអត់រំសាយផង គេហូបគ្រប់គ្រាន់ តែខាងខ្ញុំគេរំសាយ ព្រោះជាប់និន្នាការជាមួយតាឆាន អ៊ីចឹងយើងហូបមិនគ្រាប់គ្រាន់ទេ។ ហើយបើយើងហូបមិនគ្រាប់គ្រាន់ទេ។ ហើយបើសិនជាយើងឃ្លានខ្លាំង យើងរក បេះផ្លែឈើ ឬរកដំឡូង បើគេចាប់បាន គេសម្លាប់ចោលតែម្តង [...] ឆ.105៖ បើឃើញ គេវៃចោលតែម្តង។ ខ្ញុំឃើញ នឹងភ្នែក គេចាប់បានប្រុសម្នាក់ ហើយគេឱ្យក្មេងប៉ុននេះ (ប្រហែលមួយម៉ែត្រកន្លះ) វៃ។ វៃឡើងសន្លប់ឈឹង។ ពេល គាត់ភ្ញាក់ឡើង គេនាំយកទៅបាត់។ ស៖ តើលោកដែលឃើញបុរសដែលគេវៃសន្លប់នោះម្តងទៀតទេ? ឆ.106៖ ទេ គេ យកទៅបាត់ហើយ។ ស៖ តើលោកធ្លាប់ឃើញអ្នកផ្សេងទៀតដែលគេនាំយកទៅឃុំឃាំង នាំទៅ ឬសម្លាប់ទេ? ឆ.107 ៖ មាន រិន ជាមេក្រុម ដែលគេចងវៃ។ រិន លួចថ្នាំជក់ [...] ថ្ងៃឡើងគេយកមកចងហាលថ្ងៃវៃ ហើយទុកចោលទាំង ចំណាងមួយថ្ងៃ។ ហើយក្រោយមក គេយកទៅ។ ខ្ញុំមិនដឹងគេយកទៅណាទេ”]។ ឯកសារ D114/178 កំណត់ហេតុ ស្តាប់ចម្លើយ អ៊ឹម សុខន ឆ.17, 27 [“ក្រោយពីនេះមកថាត្រូវចាប់បញ្ជូនទាហានដែលនៅក្នុងតំបន់៣៧ មកស្ទឹងហាវ ទាំងអស់ ប្រមូលទ័ពទាំងអស់ ដើម្បីគេលត់ដំចម្រាញ់ទ័ព ដើម្បីគេសម្រិតសម្រាំងទ័ព ថាយើងហ្នឹងស្មោះត្រង់ជាមួយ នឹងគាត់ឬអត់ [...] ឆ.27៖ បើយើងមិនអនុវត្តតាមផែនការដែលគេដាក់ចុះទេ គេនឹងអាចចាប់បញ្ជូនយើង ជួនកាលគេ ធ្វើបាប ជួនកាលសម្លាប់ក៏មានដែរ”]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.24, 34 [“បាទ ខ្ញុំ ធ្លាប់ឃើញយោធាម្នាក់ដែលនៅក្នុងកងជាមួយខ្ញុំប្រើប្រេងម៉ាស៊ីនខុសលេខ ធ្វើឱ្យខូចម៉ាស៊ីនកាណូតនោះ គាត់ត្រូវបាន នាំយកទៅបាត់ រហូត។ គាត់គឺជាអ្នកបើកាណូតនៅក្នុងក្រុមនេសាទសម្រាប់ផ្តល់ឱ្យការដ្ឋានវាយថ្ម និងម្នាក់ទៀត បានបើកកាណូតទៅបុកថ្ម ហើយក៏ត្រូវគេយកទៅបាត់ដែរ។ បើសិនជាមានអ្នកណាម្នាក់ បើកឡានបុកអ្វីមួយ គាត់ក៏ ត្រូវយកទៅបាត់ដែរ [...] ឆ.34៖ ប្រសិនបើនរណាម្នាក់លួចដំឡូង គេនឹងចាប់វាយ”]។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.26 [“នៅកន្លែងវាយថ្ម គេបិទសិទ្ធិមិនឱ្យយើងធ្វើដំណើរ ឬទាក់ទាក់ជាមួយ អ្នកកន្លែងផ្សេងទៀត បើមិនដូច្នោះទេ យើងនឹងត្រូវគេចាប់បញ្ជូនទៅបាត់”]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ ចម្លើយ សួន ផ ឆ.47 [“បើតាមខ្ញុំយល់ ប្រសិនជាគេចាប់បាននរណាម្នាក់ព្យាយាមរត់ចេញពីកន្លែងនោះ អ្នកនោះ ច្បាស់ជាគេសម្លាប់ចោលហើយ”]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.7 [“មនុស្សម្នាក់ ដែលខ្ញុំពុំស្គាល់ បានមកសួរនាំឈ្មោះពួកយើង ហើយពួកគេក៏បានពិនិត្យបញ្ជីឈ្មោះ ហើយបានឃើញឈ្មោះមនុស្សបី នាក់ក្នុងអង្គភាពខ្ញុំ រួមទាំងខ្ញុំផង។ ពីរនាក់ផ្សេងទៀត ក្រោយមកត្រូវបានគេបញ្ជូនទៅស្ទឹងហាវ។ គឺមានតែខ្ញុំម្នាក់ទេ ក្នុងអង្គភាពខ្ញុំត្រូវបានបញ្ជូនទៅព្រលានយន្តហោះកងកេង។ ក្រោយពីខ្ញុំបានដឹងថា ខ្ញុំមានឈ្មោះនៅលើបញ្ជីនោះ ខ្ញុំភ័យ បាត់ព្រលឹងរលីង [...] តាមពិតទៅ ពួកយើងពុំមែនជាមនុស្សដែលគេឆ្លើយដាក់នោះទេ ប្រសិនបើគេឆ្លើយដាក់យើង គឺ គេច្បាស់ជាបញ្ជូនយើងទៅភ្នំពេញ ឬទឹកសាបហើយ អាស្រ័យទៅតាមករណីធ្ងន់ ឬស្រាល។ ពួកខ្ញុំ គេនៅចាត់ទុកថា ស្មោះត្រង់នឹងគេនៅឡើយ តែគេចាត់ទុកថាជាសមាសភាពគួរឱ្យសង្ស័យ”]។ ឯកសារ D114/105 កំណត់ហេតុស្តាប់ ចម្លើយ កុច ទុយ ឆ.64 [“ខ្ញុំមានរឿងមួយ អំពីបងម្នាក់ ឈ្មោះ ធឿន អ្នកស្រុកបឹងត្រាច ដែលធ្លាប់ធ្វើការនៅកងវរៈ សេនាតូច៨៦ ជាមួយខ្ញុំ។ គាត់ឃ្លានពេក ពេលនោះគាត់ឃើញល្ហុងទុំមួយ គាត់បេះល្ហុងនោះបានរួចលាក់យកទៅហូប ប៉ុន្តែមានអ្នកឃើញ អ្នកនោះរាយការណ៍ទៅមេកងចល័ត ចុងក្រោយគេក៏បានយកគាត់ទៅទម្លាក់ក្នុងអណ្តូងស្លាប់បាត់ ទៅ”]។

354. យោងតាម ឯក នី ជាអតីតយុទ្ធជនកងវរសេនាតូច ៣៨៦ ទាហានស្រីនៅលើវធម្មតា ២០ នាក់ ដែលធ្វើការស្និទ្ធនឹង ឆាន ជាចុងភៅ ជំនួយការ ឬនីរសារ ត្រូវបាននាំទៅមន្ទីរសន្តិសុខទឹកសាប និង ទទួលរងការធ្វើទារុណកម្ម។ នារីទាំងនោះ គេហៅពួកគេថា "អា" និងត្រូវបានចោទថាជាស្រីកំណាន់របស់ ឆាន។ ទោះគាត់មិនបានដឹងថាតើ ចុងក្រោយ នារីទាំងនោះត្រូវបានសម្លាប់ឬអត់ និងថាតើពួកគេត្រូវបានសម្លាប់ក្រោមកាលៈទេសៈបែណាក៏ដោយ ឯក នី បានទទួលការបញ្ជាក់អះអាងពីសមាជិកគ្រួសាររបស់នារីម្នាក់ក្នុងចំណោមនារីទាំងនោះ ឈ្មោះ ចាំ ថា គាត់មិនដែលត្រឡប់មកផ្ទះវិញទេ ក្រោយឆ្នាំ ១៩៧៩[1238]។

## បណ្ដាញភូមិភាគបូព៌ា (តំបន់ ២២) ក្រោមការគ្រប់គ្រងរបស់ ហ៊ឹង ឡឿន ហៅ ឌឹម មេបញ្ជាការរងកងពល ១៦៤

355. ភ្លាមៗក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ កងពលមជ្ឈិមលេខ ១៦៤ រួមបញ្ចូលទាំងកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យទាំងអស់ ត្រូវបានបង្កើតឡើង ដោយច្របាច់បញ្ចូលគ្នា កងពលលេខ ៣ ចាស់ ជាមួយកងទ័ពតំបន់ ៣៧ របស់ ឆាន មួយចំនួន និងកងកម្លាំងភូមិភាគបូព៌ា

---

[1238] ឯកសារ D54/103 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.3 ["បន្ទាប់ពីគេចាប់ថ្នាក់ដឹកនាំតំបន់៣៧ ហើយនិងបង នង ឆាន ដែលជាអនុរបស់ តាមុត នៃកងពល១៦៤ គេលែងជឿទុកចិត្តយោធាដែលនៅពីក្រោមបង នង ឆាន ទៀតហើយ។ គេបានដកអាវុធពីយោធាបង នង ឆាន អស់ ហើយបញ្ជូនពួកយើងទៅក្នុងកងផលិត ដែលគេហៅថា គុកដាក់អ្នកទោសស្រាល រួចហើយគេឲ្យពួកយើងស្លៀកពាក់ខោអាវពណ៌ខៀវ។ ក្នុងរយៈកាលនោះ ខ្ញុំសូមបន្ថែមរឿងសំខាន់មួយ ដែលកើតឡើងនៅពេលនោះ មានក្រុមនារីក្រមុំប្រហែលជាង ២០ នាក់ ធ្វើការជាប់ជាមួយបង នង ឆាន ក្នុងនាមជាចុងភៅ និរសារ និងជំនួយការរបស់គាត់។ ក្រោយពីគេចាប់បង ឆាន នារីទាំងអស់នោះ ត្រូវបានយកទៅដាក់គុកនៅទឹកសាប ដោយមានអ្នកយាមកាន់កាំភ្លើងជាប់រហូត ចំណែកពួកខ្ញុំមិនមានអ្នកយាមកាន់កាំភ្លើងចាំយាមជាប់រហូតនោះទេ។ ថ្ងៃមួយ ខ្ញុំបានឃើញពួកនារីទាំងនោះ នៅទឹកសាប នៅពេលដែលខ្ញុំត្រូវបានចាត់ឲ្យទៅធ្វើស្រែនៅក្បែរនោះ។ នៅពេលដែលខ្ញុំបានឃើញពួកនារីទាំងនោះភ្លាម ខ្ញុំប្រុងចូលទៅជិតដើម្បីសួរសុខទុក្ខ តែមេកងរបស់ខ្ញុំបានហាមមិនឲ្យនៅជិតទេ ព្រោះពួកនារីទាំងនោះ ជាពួកអ្នកទោស។ បន្ទាប់ពីជ័យជម្នះឆ្នាំ១៩៧៩ ខ្ញុំបានជួបឪពុកម្ដាយនារីម្នាក់ឈ្មោះ ចាំ ក្នុងចំនួននារីទាំង២០នាក់នោះ [...] គាត់ប្រាប់ខ្ញុំថា នារី ឈ្មោះ ចាំ មិនដែលបានឃើញត្រឡប់មកផ្ទះវិញទេ [...] នៅពេលនោះ ខ្ញុំបានឮថា នារីជាង២០ នាក់ ដែលគេចាប់ទៅទឹកសាបនោះ គឺត្រូវបានគេចោទថាជាស្រីកំណាន់របស់ ឆាន"]។ សូមមើលផងដែរ ទាក់ទងនឹងការចោទប្រកាន់អំពីការប្រព្រឹត្តិខុសសីលធម៌៖ ឯកសារ D114/277.4 កាំង ហ្គេកអ៊ាវ ហៅ ឌុច ប្រតិចារឹកចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ 09.49.22-09.52.11 ["មិត្តឆាន់ ហើយនិងមិត្តស៊្មីទេ ស្រីគណៈស្រុកៗអង្គឈ្លួល វានាំគ្នារត់ទៅខ្មាំងបាត់ទៅ វាស្រឡាញ់គ្នា។ អាមិត្តឆាន់ ហ្នឹងក៏គាត់មានប្រពន្ធរួចហើយ"]។

ចាស់ ដែលស្ថិតនៅក្រោមបញ្ជារបស់ ហឹង ឌឿន ហៅ ឌឹម (“ឌឹម”)[1239] រួមទាំងមកពីកងវរសេនាធំឯករាជ្យ ១៥២ ដែរ[1240]។ ឌឹម ដែលពីមុនជាមេបញ្ជាការយោធានៅក្នុងតំបន់ ២២ ភូមិភាគបូព៌ា[1241] ក្លាយជាមេបញ្ជាការរងទីមួយរបស់ **មាស មុត**[1242]។

---

1239 ពេលខ្លះគេសរសេរឈ្មោះថា ហង់ ឌឿន ហៅ ឌឹម ឬ ហឹង ឌឿន ហៅ ឌឹម។

1240 ឯកសារ D114/230.1.1 បញ្ជីអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង ១៦២៤ [ ហឹង ឌឿន ហៅ ហឹង ឌឿ ត្រូវគេចាត់ទុកថាជា “អនុលេខាកងពល១៦៤ មុនពេលធ្វើជាលេខាកងវរៈសេនាធំ១៥២”]។ ឯកសារ D54/96 កំណត់ហេតុស្តាប់ចម្លើយ តេង សារឹម ហៅ ជឹម ជឿន ឆ.18, 20-21 [“សៈ តើលោកដឹងដែរ ឬទេ ថាមានកងទ័ពចំនួនប៉ុន្មានត្រូវបានបញ្ជូនជាមួយ ឌឹម ទៅភ្នំពេញ និងកំពងសោម? ឆ.18៖ គឺកងវរៈសេនាធំ១៥២ ទាំងមូល [...] ឆ. 20៖ គឺមានកងវរៈសេនាធំ១៥២ ក្រោមបញ្ជារបស់ ឌឹម ត្រូវបានបញ្ជូនទៅកំពង់សោមទាំងអស់ គឺមានចំនួនប្រហែលជិត១០០០នាក់ [...] ឆ.21៖ សមាជិករបស់កងវរៈសេនាធំ១៥២ ពុំមែនមកពីតំបន់២២ តែមួយទេ គឺមកពីភូមិភាគបូព៌ាទាំងមូលតែម្តង”]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ឌឹម យ៉ាត ឆ.4, 8, 12 [“ឌឹម ជាអ្នកមកពីតំបន់ ២២ គាត់ទទួលខុសត្រូវមុខព្រួញខាងកើតភ្នំពេញ ជាមួយកងវរៈសេនាធំ៥២ (១៥២) ដែលក្រោមបញ្ជារបស់ ស៊ីម និងសំ ប៉ុន្តែ ឌឹម មានឋានៈខ្ពស់ជាង ស៊ីម និង សំ នេះទៀត [...] ឆ.8៖ មិនមែនយោធាទាំងអស់នៅក្នុងកងវរៈសេនាធំ ៥២ ត្រូវបញ្ជូនទៅកំពង់សោមនោះទេ។ តាមខ្ញុំដឹង យោធាត្រូវបានជ្រើសរើសមកពីកងវរៈខុសៗគ្នា ដើម្បីបញ្ជូនទៅកំពង់សោម លើកលែងតែកងអនុសេនាធំ ឬក៏កងវរៈសេនាតូចពិសេសដែលត្រូវបានគេបញ្ជូនទៅទាំងអស់គ្នា។ សរុបទៅមានយោធាកងវរៈសេនាធំ ប្រហែល៧០០នាក់ ត្រូវបញ្ជូនទៅកំពង់សោម [...] ឆ.12៖ នៅពេលដែល ឌឹម ត្រូវបានបញ្ជូនទៅកំពង់សោមមួយរយៈ គាត់បានត្រឡប់មកប្រមូលកម្លាំងយោធាកងវរៈសេនាធំរបស់គាត់ទៅកំពង់សោមជាមួយគាត់ដែរ។ ដូចខ្ញុំបានពន្យល់កាលពីព្រឹកមិញថា យោធាដែលមានសមត្ថភាពត្រូវបានជ្រើសរើសឲ្យទៅធ្វើការជាមួយ ឌឹម នៅកំពង់សោម ដើម្បីបញ្ចូលក្នុងកងពល១៦៤”]។ ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.16 [“នៅតំបន់២២ ឌឹម ជាមេ ប្រមូលកងទ័ពចំនួនប្រហែលជា១០០០នាក់ មកនៅខាងភូមិភាគហ្នឹង។ កាលហ្នឹង គេហៅភូមិភាគនិរតី”]។ ឯកសារ D114/220 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.23 [“ខ្ញុំមិនដឹងចំនួនទេហ្នឹងប្រហែលទេ។ គាត់ប្រមូលច្រើន ហើយឡើងរទេះភ្លើងវែងម៉ាខ្សែមកកំពង់សោម”]។ ឯកសារ D54/44 កំណត់ហេតុស្តាប់ចម្លើយ លន់ សេង ឆ.5-6, 11 [“សៈ តើមានយោធានៅតំបន់២២ របស់ភូមិភាគបូព៌ា ដែលមកជាមួយ ឌឹម ត្រូវបានដាក់បញ្ជូនទៅនៅក្នុងកងរបស់លោកដែរ ឬទេ បន្ទាប់ពីឆ្នាំ១៩៧៥? ហើយតើមានអ្វីកើតឡើងចំពោះយោធាទាំងនោះ? ឆ.5៖ បាទ មានខ្លះត្រូវបានបញ្ជូនទៅក្នុងកងរបស់ខ្ញុំ ប៉ុន្តែខ្ញុំចាំថា មានយោធា១៥០០នាក់ មកពីភូមិភាគបូព៌ា មកនៅក្នុងកងរបស់ខ្ញុំ។ ពួកគេមកពីរដំណាក់កាល លើកទី១ មានយោធា៧០០នាក់ និងលើកទី២ មានយោធា៨០០នាក់ [...] ឆ.6៖ មុនឆ្នាំ១៩៧៧ ខ្ញុំនៅកំពង់សោមនៅឡើយ ខ្ញុំដឹងថា យោធា១៥០០នាក់ មកពីភូមិភាគបូព៌ា ត្រូវដកកាំភ្លើង ហើយបញ្ជូនទៅដាក់នៅកងផលិត នៅពុតទេ ដោយគេចាត់ថា ជាសមាសភាពមិនល្អ [...] ឆ.11៖ មាស មុត បានប្រកាសថា យោធា១៥០០ នាក់ មកពីភូមិភាគ បូព៌ា ដែលស្ថិតនៅក្រោមការបញ្ជារបស់ ឌឹម នឹងត្រូវបានដាក់បញ្ចូលក្នុងកងពលរបស់យើង ដើម្បីបង្កើតជាកងពលជើងទឹក។ យោធាទាំងអស់នោះ ត្រូវឆ្លងកាត់ដំណើរការជ្រើសរើស មុននឹងត្រូវបានដាក់បញ្ចូលក្នុងកងពលជើងទឹក។ ប៉ុន្តែពួកគេមិនត្រូវបានចាត់ទុកថាជាសត្រូវនោះទេ។

---

យោធាទាំងអស់នោះ ត្រូវបានរៀបចំឱ្យទៅតាមកងផ្សេងៗគ្នារួចទៅហើយ នៅពេលដែលពួកគេមកដល់កងពលនោះ"]។ ឯកសារ D54/94 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង គីមសឿន (ហង្ស គីមសឿន) ឆ.1 [កូនប្រុសរបស់ ឌឹម៖ "កាលនោះ ឪពុកខ្ញុំមិនទាន់ផ្លាស់ទៅកំពង់សោមនៅឡើយទេ គឺគាត់ធ្វើការនៅទីបញ្ជាការកងទ័ព ជើងទឹករបស់អង្គភាព ង-៥២ [កងវរៈសេនាធំ ៥២] [...] ឈរជើងនៅព្រែកលាប [...] ឪពុកខ្ញុំបាននិយាយប្រាប់ថា បន្តិចទៀតអង្គការនឹងឱ្យពួកយើងនៅជុំគ្នានៅកំពង់សោម"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារិកចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ 14.21.14-14.31.59 ["តាឌឹម គាត់នៅភូមិភាគបូព៌ា។ ពេលហ្នឹងគាត់មានកងទ័ពរបស់គាត់ដកពីភូមិភាគបូព៌ាទៅនៅកំពង់សោមចំនួនមួយវរៈសេនាធំ"]។ ឯកសារ D234/2.1.91 ព្រុំ សារ៉ាត ប្រតិចារិកចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ 16.02.46-16.05.47 ["ស៖ នៅក្នុងណោមកងទ័ពទាំង៧០០ មកពីភូមិភាគបូព៌ាហ្នឹង ក៏យកមកទៅផ្គុំគ្នាបង្កើតទៅចំណុះឱ្យ កងពល១៦៤ ត្រឹមត្រូវអីចឹងដែរទេ? ឆ៖ ត្រឹមត្រូវ"]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត ឆ.88 ["ឌឹម មកពីបូព៌ា។ ក្នុងចំណោមយោធា៧០០នាក់ ដែលថ្នាក់លើបញ្ជូនមកពីភូមិភាគបូព៌ា ដើម្បីបង្កើតជាកងទ័ពជើងទឹកមួយនៅកំពង់សោម"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត់ (ប៊ុន សារ៉ាត់) ឆ.158-159 ["គេបានជ្រើសរើសកម្លាំងខាងបូព៌ា៧០០នាក់បន្ថែម ជាការរៀបចំកម្លាំងពីអគ្គសេនាធិការបញ្ជូនទៅ។ ច្របាច់បញ្ចូលកម្លាំងទាំងពីរនេះចូលគ្នា កម្លាំងមកពីបូព៌ាមាន៧០០នាក់។ ស៖ អ៊ីចឹងកងទ័ពបូព៌ាទាំង៧០០នាក់ ដែលច្របាច់បញ្ចូលគ្នាទៅជាកពលអ្វី? ឆ.159៖ កងពល១៦៤ អង្គភាពវរៈសេនាធំ១៤០"]។ ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង អុន ឆ.20 ["នៅពេលនោះ ឌឹម និងយោធា ៧០០ នាក់ មកពីភូមិភាគបូព៌ាបានមកដល់ គេរៀបចំពួកយោធាបូព៌ាបញ្ចូលគ្នានឹងយោធាកងពល៣ ឱ្យទៅជាកងពល១៦៤"]។ ឯកសារ D54/33.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឺ អុន (អ៊ឹង អុន) EN 01073811, KH 00964200 ["បូព៌ាហ្នឹងក្រោយពេលដែលគេរៀបកងជើងទឹកហ្នឹង គេយកពីបូព៌ាមកមាន៧០០នាក់ ហើយយកមកបូកខាងនិរតីនេះ គេច្របាច់ចូលគ្នាដើម្បីបង្កើតជាកងជើងទឹកហ្នឹង ដល់មកគ្មាន មិនដឹងជាស្អីៗច្របូកច្របល់ អត់ត្រូវគ្នាផងហ្នឹង មកច្របូកច្របល់ឈ្លោះគ្នាវហូត"]។ ឯកសារ D22.2.181 ចម្លើយរបស់ មាស មុត អំពីឈ្លើយសឹកអាមេរិកបាត់ខ្លួនក្នុងសង្គ្រាម ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០១ ERN KH 00742001-00742003 ["នៅចុងឆ្នាំ១៩៧៥ កងពលធំលេខ៣ ត្រូវបានរៀបចំរចនាសម្ព័ន្ធទៅជាកងពលធំលេខ១៦៤ និងត្រូវដាក់ឱ្យស្ថិតនៅក្រោមចំណុះកងនាវីកម្ពុជាប្រជាធិបតេយ្យ។ កងពលធំលេខ១៦៤នេះក៏ត្រូវបានរួមបញ្ចូលកងទ័ពបន្ថែមទៀតពីតំបន់ ២២, ២៤ និងកងទ័ពផ្សេងទៀតនៃតំបន់៣៧ ផងដែរ"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ.52 ["កាលពីនៅវរៈសេនាធំ១៤០ គេបញ្ជូនទាហានពីភូមិភាគបូព៌ាមានចំនួនប្រហែលជា៥០០ ទៅ៦០០នាក់ ដើម្បីចូលរួមជាមួយកងនាវានេះដែរ"]។ ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន (ណាំ ឡុន) ឆ.19 ["ឌឹម មកកំពង់សោមជាមួយនឹងយោធាប្រហែលជាពីរកងវរៈសេនាតូច"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.28 ["គេបញ្ជូនទៅស្ទឹងហាវ ខ្ញុំគិតថាប្រហែលពាក់កណ្តាល ឬចុងឆ្នាំ១៩៧៥ នៅពេលដែលពួកបូព៌ាមកដល់"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ. 7 ["ឌឹម មកពីភូមិភាគបូព៌ា [...] គាត់មកចូលជាមួយកងពល១៦៤នេះ ដោយមានយុទ្ធជនរបស់គាត់មកជាមួយផងដែរ។ ខ្ញុំមិនដឹងថា មានយុទ្ធជនប៉ុន្មាននាក់ដែលគាត់យកមកជាមួយគាត់នោះទេ ប៉ុន្តែចំនួនយុទ្ធជននោះគឺមានរាប់រយ"]។ ឯកសារ D54/51 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន (ស្វាយ វឿន) ឆ.12។

1241 ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ឌឹម យ៉ាត ឆ.4, 14-15 [“ឌឹម ជាអ្នកមកពីតំបន់២២ គាត់ទទួលខុសត្រូវមុខព្រួញខាងកើតភ្នំពេញ ជាមួយកងវរៈសេនាធំ៥២ (១៥២) ដែលក្រោមបញ្ជារបស់ ស៊ីម និងសំ ប៉ុន្តែ ឌឹម មានឋានៈខ្ពស់ជាង ស៊ីម និង សំ នេះទៀត [...] ឆ.14៖ ឌឹម មកពីស្រុកអូររាំងឪ [...] ឆ.15៖ ខ្ញុំធ្លាប់ឃើញ ឌឹម ច្រើនដងទាំងនៅកំពង់សោម និងតំបន់២២”]។ ឯកសារ D54/95 កំណត់ហេតុស្តាប់ចម្លើយ ឃុន ថន (ឈុន ថន) ឆ.20 [“ពួកគេត្រឡប់មកភូមិឃុំនានាក្នុងតំបន់២២ ដើម្បីស្រាវជ្រាវប្រវត្តិកូនទាហានរបស់ពួកគេ ដែលគេបញ្ជូនពីតំបន់២២ ទៅកំពង់សោមជាមួយគាត់នោះ [ឌឹម]”]។ ឯកសារ D22.2.181 ចម្លើយរបស់ មាស មុត អំពីឈ្លើយសឹកអាមេរិកបាត់ខ្លួនក្នុងសង្គ្រាម ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០០១ ERN KH 00742001-00742003 [“នៅចុងឆ្នាំ១៩៧៥ កងពលធំលេខ៣ ត្រូវបានរៀបចំរចនាសម្ព័ន្ធទៅជាកងពលធំលេខ១៦៤ និងត្រូវដាក់ឲ្យស្ថិតនៅក្រោមចំណុះកងនាវីកម្ពុជាប្រជាធិបតេយ្យ។ កងពលធំលេខ១៦៤ នេះក៏ត្រូវបានរួមបញ្ចូលកងទ័ពបន្ថែមទៀតពីតំបន់ ២២, ២៤”]។ ឯកសារ D54/96 កំណត់ហេតុស្តាប់ចម្លើយ តេង សារីម ហៅ ជឹម ជ្រឿន ឆ.10-12 [ពន្យល់ថា ឌឹម គឺជាមេបញ្ជាការកងវរៈសេនាធំ១៥២ តំបន់២២ តាំងពីឆ្នាំ១៩៧៣ “ឌឹម ជាអ្នកតស៊ូផ្ទៃក្នុងរបស់ខ្មែរក្រហម ហើយគាត់ពូកែខាងឃោសនាអប់រំនយោបាយ។ បន្ទាប់មក គាត់ក្លាយជាប្រធាននយោបាយយោធាតំបន់។ ក្រោយមកទៀត គាត់ឡើងទៅធ្វើប្រធានវរៈសេនាធំ១៥២ [...] បន្ទាប់ពីរបប លន់ នល់ ដួលរំលំ [...] គាត់បាននិយាយតាមវិទ្យុទាក់ទងប្រាប់ខ្ញុំថា គេបានចាត់តាំងឲ្យគាត់ឲ្យទៅសមុទ្រកំពង់សោម ហើយទទួលបន្ទុកខាងកងទ័ពជើងទឹក”], ឆ.21 [“សមាជិកកងវរៈសេនាធំ១៥២ ពុំមែនមកពីតំបន់២២ តែមួយទេ គឺមកពីភូមិភាគបូព៌ាទាំងមូលតែម្តង”]។ ឯកសារ D54/94 កំណត់ហេតុស្តាប់ចម្លើយ ហ៊ឹង គឹមសឿន (កូនប្រុសរបស់ ឌឹម) ឆ.1 [“កាលនោះ ឪពុកខ្ញុំមិនទាន់ផ្លាស់ទៅកំពង់សោមនៅឡើយទេ គឺគាត់ធ្វើការនៅទីបញ្ជាការកងទ័ពជើងទឹក ង-៥២ [កងវរៈសេនាធំ៥២] [...] គាត់ឈរជើងនៅព្រែកលាប”]។

1242 ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.9 [“ឌឹម គឺជាអនុទី១ របស់ មាស មុត ហើយគាត់មកពីខាងភូមិភាគបូព៌ា”]។ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.12 [“ឌឹម ត្រូវបានគេផ្លាស់ពីភូមិភាគបូព៌ាមកធ្វើជាអនុមេបញ្ជាការកងពលរបស់ មាស មុត”]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ឌឹម យ៉ាត ឆ. 5, 14 [“ឌឹម ទៅកំពង់សោមមុនខ្ញុំ និងសំ ទៅទៀត។ នៅកំពង់សោម ឌឹម ជាអនុមេបញ្ជាការកងពល១៦៤។ សំ នៅកងវរៈសេនាធំ [...] ឆ.14៖ មាស មុត ជាមេបញ្ជាការកងពល ហើយ ឌឹម ជាអនុរបស់ មាស មុត”]។ ឯកសារ D2/16 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី (សឿ ទូច) ឆ.10 [“ឌឹម គឺជាអនុកងពល”]។ ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.21 [“[ឌឹម] មកពីភូមិភាគបូព៌ា [...] ឌឹម គឺជាអនុរបស់ មាស មុត”]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត ឆ.53 [“មេបញ្ជាការរងឈ្មោះ ឌឹម។ គណៈកងពល១៦៤ មានមេបញ្ជាការ មាស មុត, ឌឹម ជាអនុ”]។ ឯកសារ D54/95 កំណត់ហេតុស្តាប់ចម្លើយ ឃុន ថន (ឈុន ថន) ឆ.12 [“ឌឹម ជាយោធាខ្មែរក្រហម ហើយគាត់មានតួនាទីធំជាងបងប្រុសរបស់ខ្ញុំ [ឃុន ឌឹម]។ ឌឹម នៅកងខុសពីបងប្រុសរបស់ខ្ញុំ [នៅតំបន់២២]”]។ ឯកសារ D54/44 កំណត់ហេតុស្តាប់ចម្លើយ លន់ សេង ឆ.5 [“ឌឹម ក្លាយជាអនុរបស់ មាស មុត ទទួលខុសត្រូវខាងបញ្ជាការយោធា នៅក្នុងកងពល១៦៤”]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.15 [“កងពល១៦៤ហ្នឹងមាន មាស មុត ជាស្នងការធំ ហើយមាន នង ផាន ជាបញ្ជាការកងពល ១៦៤។ បន្ទាប់មក គឺ ឌឹម ដែលជាបញ្ជាការរង។ បន្ទាប់មកគឺ ង៉ែត ជាសមាជិកកងពល”]។ ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ បៀត ឡូន (ណាំ ឡូន) ឆ.19 [“នៅពេលដែលគេរៀបចំកងពល១៦៤ នោះ [ឌឹម] បាន

356. មុនពេលគាត់ខ្លួនឯងត្រូវបានចាប់ខ្លួន ក្រោមការគ្រប់គ្រងរបស់ **មាស មុត** ឌឹម ដឹកនាំធ្វើការបោសសម្អាតខ្មាំងផ្ទៃក្នុង នៅក្នុងកងពល ១៦៤[1243] រួមទាំងក្នុងក្រុមរបស់គាត់មកពីភូមិភាគបូព៌ា។ នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ ក្នុងពេលប្រជុំដែល សុន សេន បានប្រកាសថា កម្មាភិបាលខ្លះ (ចាន់ ចក្រី និង ឈូ) មកពីភូមិភាគបូព៌ា ជាជនក្បត់[1244] ឌឹម បានប្រាប់យ៉ាងមុតមាំទៅ សុន សេន និងមេបញ្ជាការ និងមេបញ្ជាការរងកងពលផ្សេងទៀតថា "ពិនិត្យកម្លាំង អាចធានាពី ៩០ ទៅ ៩៥ ភាគរយ ដែលស្មោះត្រង់ជាមួយបក្ស [...] ត្រូវតែតាមដាន សម្រិតសម្រាំងតទៅទៀត"[1245]។ តាម

---

ក្លាយជាមេបញ្ជាការផ្នែកយោធា និងអនុរបស់មាស មុត។ ក្រោយពីខ្ញុំត្រឡប់មកពីស្រុកចិនវិញ ហើយបានសួរយោធាដែលធ្វើការជាមួយគ្នាអំពី ឌឹម ពួកគេបានប្រាប់ខ្ញុំថា ឌឹម ត្រូវបានបញ្ជូនទៅធ្វើការនៅកន្លែងផ្សេងបាត់ទៅហើយ"]។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.50 ["ឈ្មោះ តាឆាន ជាអនុបញ្ជាការ និងឌឹម ជាអនុបញ្ជាការ។ តាឆាន និងឌឹម ត្រូវបានសម្លាប់ដោយចោទថាក្បត់"]។ ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ សៀង EN 00217564 ["អនុររបស់ មាស មុត គឺ ឌឹម មកពីភូមិភាគបូព៌ា។ ឌឹម បានបាត់ខ្លួននៅក្នុងឆ្នាំ១៩៧៧ នៅពេលដែលមានជម្លោះផ្ទៃក្នុង"]។ ឯកសារ D54/92 កំណត់ហេតុស្តាប់ចម្លើយ យ៉ែម សំអុន ឆ.16។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.66។ ឯកសារ D54/81 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.14។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ កឹម ម៉េន ឆ.31។

1243 ឯកសារ D1.3.34.11 ទូរលេខ១១ ពី ឌឹម (កងពល១៦៤) ផ្ញើជូន មាស មុត ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៦ EN 00233660, KH 00000863, FR 00654897 ["សភាពដីគោកនៅឃុំរាម និងបឫស ពីយើងមានវិធានការចំពោះខ្មាំងមួយដែលបងសម្រេច វាមានរត់ចូលព្រៃ៥នាក់ ឥឡូវយើងតាមចាប់បានទាំងអស់"], EN 00143522, KH 00000863, FR 00654897 ["ពីរនាក់ (យុទ្ធជន) ទៀតរត់អង្គភាពពីពីសង្ការ។ យុទ្ធជននេះនឹងដូរពីកង៦៣"]។ ឯកសារ D1.3.34.15 ទូរលេខពី ឌឹម (កងពល១៦៤) ផ្ញើជូន មាស មុត ថ្ងៃទី០៨ ខែតុលា ឆ្នាំ១៩៧៦ EN 00233659, KH 00000867, FR 00800811 [រាយការណ៍អំពីយោធាម្នាក់ពីកងពល១៦៤ ដែលចងគ្រាប់បែក៥គ្រាប់ដាក់នៅកន្លែងដែលកម្មាភិបាល រឿន និងយ៉ាន ធ្លាប់សម្រាក។ ក្រោយការចាប់ខ្លួនបាន យោធានេះរត់រួច"]។

1244 ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៦ EN 00940344, KH 00052407, FR 00334976 [សុន សេន (បង៨៩) បានពន្យល់ថា ចក្រី និងឈូក មកពីតំបន់២៤ ភូមិភាគបូព៌ា គឺជាជន ក្បត់ជាមួយវៀតណាម ហើយត្រូវកម្ទេចរួចហើយ ហើយគាត់បានជំរុញឱ្យអ្នកចូលរួមប្រជុំកម្ទេចខ្មាំងបង្កប់នៅក្នុងកងពលនៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា]។

1245 ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ EN 00940340, KH 00052404, FR 00334974 [ឌឹម បានរាយការណ៍អំពីបញ្ហាសន្តិសុខចំនួនពីរករណីពាក់ព័ន្ធនឹងយុទ្ធជនកងពល និងការចាប់ខ្លួនមនុស្សបួននាក់ផ្សេងទៀត], EN 00940346, KH 00052408, FR 00334977 [តាមការបញ្ជារបស់ សុន សេន ឌឹម និយាយថា "សុំឯកភាពតាមបទឧទ្ទេសនាមរបស់អង្គការ ពីសភាពការណ៍ខ្មាំង ទាំងពីក្នុង ទាំងពីក្រៅ សុំលើកការចាប់អារម្មណ៍ពីឈ្មោះ ដែលអង្គការលើកឡើងពីមុន ខ្លះសង្ស័យ ខ្លះមិនសង្ស័យ ដោយបុគ្គលអស់នោះនៅក្នុងនាទីដឹកនាំសំខាន់។ ដូច្នេះ នាំឱ្យយើងមានការប្រុងប្រយ័ត្នកាន់តែខ្ពស់ថែម។ កន្លងមក កងពលធ្លាប់មានខ្មាំងធ្វើសកម្មភាព តែវិធាន

ពិត ចាប់ពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៧៦ របាយការណ៍ ស-២១ បង្ហាញថា ទាហានភូមិភាគបូព៌ា ១១ នាក់មួយក្រុមមកពីកងវរសេនាធំ ១៥២ ចាស់របស់ ឌឹម ត្រូវគេឃុំខ្លួន រួមទាំងមេបញ្ជាការកងអនុសេនាតូចម្នាក់ផងដែរ[1246]។ ពួកគេត្រូវគេសម្លាប់ ឬ "ស្លាប់ដោយជំងឺ" នៅ ស-២១ នាពេលក្រោយ នៅឆ្នាំ ១៩៧៦[1247]។ និយាយឲ្យជាក់លាក់ទៅ សំ មេបញ្ជាការរងកងវរសេនាធំ ១៤០

---

ការវាយខ្សាំង តែងខ្វះខាត មិនបានយកចិត្តទុកដាក់ខ្ពស់។ បញ្ហានេះ បើគិតដល់សកម្មភាពខ្សាំង ម្នាក់ ពីរនាក់ផ្ទៃក្នុងសុទ្ធតែអាចបំផ្លិចបំផ្លាញកម្លាំងបដិវត្តន៍បាន [...] បញ្ហាខ្សាំងបង្កើតបក្សថ្មី គ្រាន់តែធ្លាប់ដឹង តាមការណែនាំជាបន្តបន្ទាប់របស់បក្ស តែមិនស៊ីជំរៅដូចជាបានស្ដាប់ព័ត៌មានរបស់បក្សនេះទេ។ ពិនិត្យកម្លាំង អាចធានាពី៩០ ទៅ៩៥ភាគរយ ដែលស្មោះត្រង់ជាមួយបក្ស។ តែជំនឿជ្រះស្រឡះថា កងទ័ពនេះស្អាតហើយ ដូចនៅមិនទាន់ស្អាតទេ ត្រូវតែតាមដានសម្រិតសម្រាំងតទៅទៀត" (គូសបញ្ជាក់បន្ថែម)]។

1246 ពួកគាត់ទាំងអស់ត្រូវបានចាត់ទុកថាស្ថិតនៅកងពល១៦៤ អតីតកងវរសេនាធំ១៥២ ៖ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង ៤៣៥ (មាស លឿន ហៅ សារឿន យុទ្ធជន), លេខរៀង ១២៧៣ (ចែត គីម ហៅ គីម អេង ប្រធានក្រុម), លេខរៀង ១៥៣៧ (អៀង សុង ហៅ ស្រ៊ា យុទ្ធជន), លេខរៀង ៥៦១០ (ញ៉ែម ស៊ីម យុទ្ធជន), លេខរៀង ៥៧២៩ (ធិន សឹម ឬ ធិន លឹម យុទ្ធជន), លេខរៀង ១០១៨៩ (សេក សេន ហៅ សុផល យុទ្ធជន), លេខរៀង ១០៥៧១ (សែម សុត ប្រធានក្រុម), លេខរៀង ១០៦៥០ (សាយ ណែន ហៅ ណែម យុទ្ធជន), លេខរៀង ១២២១៩ (តូម សុភាព ឬ តូច សុភាព ហៅ សុគន្ធ យុទ្ធជន), លេខរៀង ១៣៣៨១ (វង់ ឡឹង ហៅ ថន មេបញ្ជាការកងអនុសេនាតូច), លេខរៀង ១៣៩១១ (យីវ ហួត ហៅ ប៊ាន់ យុទ្ធជន)។ សូមមើលផងដែរ ឯកសារ D114/145.1.3 ចម្លើយសារភាព ស-២១ របស់ អៀង សុង ហៅ ស្រ៊ា។ ឯកសារ D114/145.1.22, D114/145.1.23, D114/145.1.24, D114/145.1.25 និង D114/145.1.26 ចម្លើយសារភាព ស-២១ របស់ វង់ ឡឹង ហៅ ថន។

1247 ឧទាហរណ៍ ឯកសារ D1.3.3.2 បញ្ជីឈ្មោះអ្នកទោសស-២១ កម្ទេច នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៧៦ ERN KH 00008776 [លេខរៀង៥ ញ៉ែម ស៊ីម, លេខរៀង៨ អៀង សុង ហៅ ស្រ៉ាង, លេខរៀង១០ សេក សុផល]។ សូមមើលផងដែរ ឯកសារ D1.3.3.2 បញ្ជីឈ្មោះអ្នកទោសស-២១ កម្ទេច ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៧៦ ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៧៦ ERN KH 00008755 [លេខរៀង៥ ញ៉ែម ស៊ីម, លេខរៀង៨ អៀង សុង ហៅ ស្រ៉ាង, លេខរៀង១០ សេក សុផល៖ អ្នកទាំងអស់នេះត្រូវបានរាយការណ៍ថាត្រូវបានកម្ទេចនៅថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៧៦]។ បញ្ជីអ្នកទោសកម្ទេច ឬស្លាប់ដោយសារជំងឺ ចាប់ពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៧៦ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦ ERN KH 00008882 [លេខរៀង១៣ សែម សុត មេក្រុមនៃកងពល១៦៤ ឈឺងាប់ នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៧៦, លេខរៀង ១៦ សាយ ណែម យុទ្ធជនកងពល១៦៤ ឈឺងាប់ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៧៦]។ បញ្ជីឈ្មោះអ្នកទោសកម្ទេច ចាប់ពីថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៧៦ ដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៧៦ ERN KH 00008864 [លេខរៀង៧១ តូច សុភាព ហៅ សុគុណ យុទ្ធជនកងពល១៦៤ ឈឺងាប់ នៅថ្ងៃទី២០ ខែតុលាឆ្នាំ១៩៧៦]។ បញ្ជីឈ្មោះអ្នកទោសកម្ទេច ចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ដល់ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ERN KH 00008881 [លេខរៀង៨៥ យីវ ហួត ឈឺងាប់ នៅថ្ងៃតី០៦ ខែវិច្ឆិកា ឆ្នាំ១៩៧៦]។

ដែលមកជាមួយ ឌឹម ពីបូព៌ា ត្រូវគេចាប់ខ្លួននៅដើមឆ្នាំ ១៩៧៦ និងបង្ខំឲ្យសារភាព នៅ ស-២១ នៅខែ កក្កដា ឆ្នាំ ១៩៧៦[1248]។

357. នៅដើមឆ្នាំ ១៩៧៧ ពីរបីខែក្រោយការចាប់ខ្លួន ជ័យ ហាន ហៅ ឆាន **មាស មុត** បានឯកភាពឲ្យចាប់ ឌឹម មេបញ្ជាការរងទីមួយរបស់ខ្លួន។ ដូចដែល កាំង ហ្កេកអ៊ាវ ហៅ ឌុច បានបញ្ជាក់ "មុនចាប់ខ្លួននរណាម្នាក់ គេត្រូវតែពិភាក្សាជាមួយប្រធានអង្គភាពរបស់អ្នកនោះ។ នៅពេលណាដែលបានទទួលចម្លើយសារភាពរួចហើយ ចម្លើយសារភាពត្រូវបានផ្ញើដោយ សុន សេន (បន្ទាប់មក នួន ជា) ទៅឲ្យប្រធានអង្គភាព"[1249] និង "សុន សេន មុនពេលសម្រេច គាត់តែងសុំយោបល់ និងការជួយសម្រេចពីប្រធានកងពលផ្ទាល់នោះ"[1250]។

358. ឯកសារ ស-២១ បង្ហាញថា ឌឹម ត្រូវបានឃុំឃាំងនៅ ស-២១ នៅពេលដំណាលគ្នានឹងកម្មាភិបាលមានឋានៈខ្ពស់នៃកងពល ១៦៤ មួយក្រុមធំផ្សេងទៀត រួមទាំង គុណ ឌឹម កម្មាភិបាលថ្នាក់

---

[1248] ឯកសារ D114/230.1.1 បញ្ជីអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង ១៤៥៦១។ ឯកសារ D9.3 បញ្ជីអ្នកទោស ស-២១ មកពីកងពល១៦៤ រៀបរៀងដោយ ក.ស.ច.ស លេខរៀង ៣៩។ ឯកសារ D1.3.1.8 ចម្លើយសារភាព ស-២១ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៧៦។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល EN 00968421, KH 00926645 ["ម៉ារៀបដំបូងហ្នឹង [កងវរៈសេនាធំ១៤០] រួមមាន តាសារឿន។ សារឿន ប្រធាន ហើយសំ ហ្នឹងមកពីខាងតាឌឹម មេបញ្ជាការ និងអនុប្រធាន។ ហើយបានតាសេង ដល់នេះគេដក តាសំ ហ្នឹងគេចាប់ទៅ។ បាទ គេចាប់ទៅជំនាន់តាឌឹមហ្នឹង"]។

[1249] ឯកសារ D4.1.400 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច EN 00242880, KH 00239838 ["មុនការចាប់ខ្លួននរណាម្នាក់ គេត្រូវតែពិភាក្សាជាមួយប្រធានអង្គភាពរបស់អ្នកនោះ។ នៅពេលណាដែលទទួលចម្លើយសារភាពរួចហើយ ចម្លើយសារភាព ត្រូវផ្ញើដោយ សុន សេន (បន្ទាប់មក នួន ជា) ទៅឲ្យប្រធានអង្គភាព"]។

[1250] ឯកសារ D12 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច EN 00680799, KH 00680805 ["សុន សេន មុនពេលសម្រេច គាត់តែងតែសុំយោបល់ និងការជួយសម្រេចពីប្រធានកងពលផ្ទាល់នោះ"]។ ឯកសារ D4.1.860 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ERN KH 00403906 ["ក្នុងការអនុវត្តជាក់ស្តែង ពេលដែលមនុស្សម្នាក់ត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព ថ្នាក់លើជូនដំណឹងទៅអ្នកទទួលខុសត្រូវអង្គភាពនីមួយៗ"]។ ឯកសារ D98/1.2.6 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹកចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ 09.32.55 ["ចម្លើយដែលចេញពី ស-២១ [...] គឺជូនអត់ទៅដល់ដៃ ស៊ូ ម៉េត ទេ គឺទៅដៃមេខ្ញុំ។ មេខ្ញុំឲ្យទៅ ស៊ូ ម៉េត ហើយ ស៊ូ ម៉េត ជ្រើសមនុស្សមួយចំនួនដែលនៅក្នុងកងពល៥០២"], 09.55.10-10.03.22, 10.33.21។ ឯកសារ D4.1.404 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច EN 00242932, KH 00242921 ["ចម្លើយសារភាព ត្រូវបានផ្ញើទៅប្រធានអង្គភាព ដោយមានគោលបំណង២៖ ទី១ ប្រាប់ដំណឹងដល់គាត់អំពីសកម្មភាពរបស់ខ្មាំងនៅក្នុងអង្គភាពនោះ និងទី២ អនុញ្ញាតឲ្យគាត់គិតពីការចាប់ខ្លួនមនុស្សដែលគេបានឆ្លើយដាក់"]។

កណ្តាលមកពីភូមិភាគបូព៌ា[1251]៖ ហ៊ីង ឌឿន ហៅ ឌឹម ចូល ស-២១ នៅថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៧ និងត្រូវគេសម្លាប់នៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៧៧[1252]។ ដូច ឆាន និងកម្មាភិបាលកងពល

---

1251 ឯកសារ D114/230.1.1 បញ្ជីអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង ២៣៦៨ [គង់ គៀន ហៅ អ៊ឹង វេត លេខាកងវរៈសេនាតូច៦៣១ នៃកងពល១៦៤ ចូលនៅខែមេសា ឆ្នាំ១៩៧៧ សម្លាប់នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៨], លេខរៀង ៣២២៣ [គុណ ឌឹម អនុលេខាកងវរៈសេនាតូច១៤១ ពីមុននៅតំបន់២២ ចូលនៅថ្ងៃទី២០ ឬ ២៥ ខែមេសា ឆ្នាំ១៩៧៧], លេខរៀង ៣៩៩៤ [គង់ ស៊ាន ហៅ សាន លេខាកងវរៈសេនាតូច១៤២ នៃកងពល១៦៤ ចូលថ្ងៃទី២៧ ឬ២៨ ខែមេសា ឆ្នាំ១៩៧៧ សម្លាប់នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨], លេខរៀង ៤៧៩៧ [ម៉ុ ជឹម ហៅ យ៉ាន សមាជិកកងពល១៦៤ ចូលថ្ងៃទី២៨ ខែមេសា ឬខែឧសភា ឆ្នាំ១៩៧៧ សម្លាប់នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៨], លេខរៀង ៧២០៧ [ប៉ែន ហាម លេខាកងវរៈសេនាតូច១៧០ នៃកងពល១៦៤ ចូលថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៧ សម្លាប់នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨], លេខរៀង ៧៣៨៣ [ហែម អាន ហៅ ស៊ីន ប្រពន្ធវេជ្ជបណ្ឌិត សុខ និងជាពេទ្យកងអនុសេនាធំ១ នៃកងវរៈសេនាតូច១៦៩ ចូលនៅថ្ងៃទី២៦ ឬ២៨ ខែមេសា ឆ្នាំ១៩៧៧ សម្លាប់នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៨]។ លេខរៀង ៧៥២៦ [ចឹក ស្រេង លេខាកងវរៈសេនាតូច នៃកងពល១៦៤ ចូលនៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៧ សម្លាប់នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨], លេខរៀង ៧៥៤៦ [ដួន ឡាក់ ហៅ សារ៉ាត សមាជិកកងវរៈសេនាតូច១៧០ - រោងជាងកងវរៈសេនាធំ នៃកងពល១៦៤ ចូលនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៧ សម្លាប់នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៨], លេខរៀង ៨១៧៦ [សាន់ ស៊ាប ហៅ សំ មេបញ្ជាការរងកងវរៈសេនាធំ៦២ នៃកងពល១៦៤ ចូលនៅថ្ងៃទី២១ (ខែមេសា ឬខែឧសភា) ឆ្នាំ១៩៧៧], លេខរៀង ១៣១៥៥ [សេក ហៀង អនុលេខាកងវរៈសេនាតូច៦១៣ នៃកងពល១៦៤ ចូលថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៧ សម្លាប់នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨]។ សូមមើលផងដែរ ឯកសារ D1.3.28.27 បញ្ជីឈ្មោះអ្នកទោស ស-២១ EN 01215100, KH 00088754 [លេខរៀង១ គុណ ឌឹម មេបញ្ជាការកងវរៈសេនាតូច នៃកងពល១៦៤ ចូលថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៧ សួរចម្លើយចប់នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៧៧, លេខរៀង៣ សាន់ ស៊ាប ហៅ សំ ចូលថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៧៧ សួរចម្លើយចប់នៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៧]។

1252 ឯកសារ D114/230.1.1 បញ្ជីអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង ១៦២៤ [ចូលស-២១ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៧]។ ឯកសារ D9.3 បញ្ជីអ្នកទោស ស-២១ មកពីកងពល១៦៤ រៀបរៀងដោយ ក.ស.ច.ស លេខរៀង ១១ [សម្លាប់នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៧៧]។ ឯកសារ D1.3.28.40 បញ្ជីឈ្មោះអ្នកទោសកម្ទេច និងថតរូប នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៧៧ EN 00873280-81, KH 00009146 [លេខរៀង ២ ហ៊ីង ឌឿន ហៅ ឌឹម អនុលេខាកងពល១៦៤]។ ឯកសារ D1.3.28.40 កំណត់ត្រាកម្ទេចរបស់មន្ទីរ ស-២១ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៧៧ EN 00873621, KH 00009252 [លេខរៀង ១៧២៖ ហ៊ីង ឌឿន ហៅ ឌឹម អនុលេខាកងពល១៦៤]។ ឯកសារ D1.3.28.27 បញ្ជីឈ្មោះអ្នកទោស ស-២១ EN 01215100, KH 00088754 [លេខរៀង២ អ៊ឹង ឌឿ ហៅ ឌឹម អនុមេបញ្ជាការកងពល១៦៤]។ ឯកសារ D234/2.1.55 ចម្លើយសារភាពស-២១ របស់ ហង់ ឌឿន ហៅ ហ៊ីង ឌឿន ហៅ ឌឹម ERN KH 00174375។ ឯកសារ D1.3.18.1 ចម្លើយសារភាពស-២១ របស់ ហង់ ឌឿន ហៅ ឌឹម។ ឯកសារ D1.3.18.2 ចម្លើយសារភាពស-២១ របស់ ហង់ ឌឿន ឬ ហ៊ីង ឌឿន ហៅ ឌឹម។ ឯកសារ D1.3.28.49 កំណត់ត្រាសួរចម្លើយ

១៦៤ ផ្សេងទៀតដែរ គាត់ត្រូវគេបង្ខំដោយការធ្វើទារុណកម្ម[1253] ឲ្យសារភាពថាបានចូលរួមក្នុង "សកម្មភាពក្បត់" និងរាយការណ៍ពី "កម្លាំងក្បត់" ជាងដប់នាក់ នៅក្នុងកងពល ១៦៤ (និងកងវរសេនាធំ ១៥២)[1254]។ ទោះបីជាថ្ងៃខែឆ្នាំចូលក្នុង ស-២១ មានភាពប្រាកដប្រជាក៏ដោយ ក៏ថ្ងៃខែឆ្នាំ

---

របស់មន្ទីរ ស-២១ EN 00937118, KH 00082795-96 [ចាប់ខ្លួននៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៧។ បញ្ចប់ការសួរចម្លើយនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧៧]។ សូមមើលផងដែរ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.50, 53-54 ["តានអាន និង ឌឹម ត្រូវបានសម្លាប់ដោយចោទថាក្បត់ [...] សៈ តើអាន និងតាឌឹម គេយកទៅសម្លាប់ដំណាលគ្នា ឬក៏ក្រោយ? ឆ.53៖ តាអាន គេនាំយកទៅមុនៗ។ តាឌឹម គេនាំទៅក្រោយ។ សៈ តើគេនាំពួកគាត់ទៅណា? ឆ.54៖ ខ្ញុំឮគេថាទៅគុកទួលស្លែង"]។ ឯកសារ D114/85 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.11 ["[នេះគឺជាឯកសារ D1.3.18.1 មានខ្មែរ ERN KH 00162140] ឆ.11៖ ត្រូវហើយ [...] គឺឈ្មោះ ឌឹម ដែលខ្ញុំបាននិយាយនោះឯង។ ពេលខ្ញុំមើលឯកសារនេះ ត្រង់កាលបរិច្ឆេទអាចនិយាយថា វាគឺត្រឹមត្រូវណាស់ ដោយសារគេយកអ្នកទាំងនោះទៅនៅដើមឆ្នាំ១៩៧៧"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.10 ["ថ្ងៃមួយ មុនពេលកងរបស់ខ្ញុំត្រូវបានដកអាវុធ និងក្រោយពេល ឌឹម បាត់ខ្លួន ខ្ញុំបានឮសួរពីយោធាក្នុងកងជាមួយគ្នា និយាយថា ឌឹម និងអាន ត្រូវបានបញ្ជូនទៅកាន់ម៉ាស៊ីនបូមទឹកនៅជើងឯក។ នៅពេលនោះយើងជឿថា រឿងហ្នឹងជារឿងពិត។ ប៉ុន្តែក្រោយមកនៅពេលដែល តាមុត ប្រកាសនៅក្នុងអង្គប្រជុំអំពីចម្លើយសារភាពរបស់ពួកក្បត់ និងខ្សែរយៈសេ.អ៊ី.អា និង កា.ហ្សេ.បេ ហើយបន្ទាប់ពីបាត់ខ្លួនពួកនោះ ទើបយើងដឹងថា ពួកគេទាំងនោះត្រូវបានចាប់ខ្លួនហើយ។ រហូតដល់ក្រោយឆ្នាំ១៩៧៩ ទើបយើងដឹងថា ស-២១ និងបឹងជើងឯក គឺជាគុក និងកន្លែងសម្លាប់មនុស្ស"]។

1253 យោងតាម កាំង ហ្គេកអ៊ាវ ហៅ ឌុច ការធ្វើទារុណកម្មពេលសួរចម្លើយគឺមិនអាចជៀសរួចទេ៖ ឯកសារ D114/277.3 កាំង ហ្គេកអ៊ាវ ប្រតិចារិកចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៦ 09.34.20-09.41.06 ["ទារុណកម្មជៀសមិនរួច ច្រើនតែជៀសមិនរួច។ ផ្ទាល់ខ្លួនខ្ញុំដែលសួរចម្លើយ មានតែមួយហ្នឹងទេដែលជៀសរួច។ ហើយមិត្តហ៊ី សួរចម្លើយមានតែមួយហ្នឹងដែរ [...] ក្រៅពីនោះច្រើនតែជៀសមិនរួច"]។ ឯកសារ D98/1.2.19 កាំង ហ្គេកអ៊ាវ ប្រតិចារិក ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ 09.35.07-09.36.32 ["តើទាំងអស់សុទ្ធតែទទួលទារុណកម្មរឿងអី? ខ្ញុំសូមឆ្លើយថា លើកលែងតែម្នាក់គត់គឺ កុយ ធួន"]។ 09.38.56 ["ដូច្នេះជាទូទៅ ទារុណកម្ម ដូចខ្ញុំជម្រាបហើយចៀសមិនរួច"]។ ឯកសារ D10.1.64 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ERN KH 00404810 ["ចំពោះការធ្វើទារុណកម្ម គឺជៀសមិនរួចទេនៅ ស-២១"]។ ឯកសារ D1.3.33.3 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច EN 00146486 ["អ្នកណាដែលគេយកទៅសួរ ច្រើនចៀសមិនរួចពីទារុណកម្ម លើកលែងតែករណីពិសេស ដូចករណីកុយ ធួន ដែលមាបញ្ជាមកខ្ញុំមិនឲ្យធ្វើទារុណកម្ម"]។

1254 ឯកសារ D234/2.1.55 ចម្លើយសារភាពស-២១ របស់ ហង់ ឌឿន ហៅ ហ៊ីង ឌឿន ហៅ ឌឹម ERN KH 00174375 ។ ឯកសារ D1.3.18.1 ចម្លើយសារភាពស-២១ របស់ ហង់ ឌឿន ហៅ ឌឹម។ ឯកសារ D1.3.18.2 ចម្លើយសារភាព ស-២១ របស់ ហង់ ឌឿន ឬ ហ៊ីង ឌឿន ហៅ ឌឹម EN 00759713-17, KH 00177026-30 [បង្ហាញឈ្មោះមនុស្ស ៩៤នាក់ជា "កម្លាំងក្បត់នៅកងពល១៦៤ មានកម្មាភិបាលមកពីគណៈកងពល១៦៤, កងវរៈសេនាធំ៦២ និង៦៣ និង កងវរសេនាតូច និងកងអនុសេនាធំជាច្រើនទៀត]។ សូមមើលផងដែរ ឯកសារ D1.3.18.1 ចម្លើយសារភាពស-២១

ពិតប្រាកដនៃការចាប់ខ្លួនគាត់នៅតែមិនអាចកំណត់បាន។ ទោះជាយ៉ាងនេះក្តី មានការចង្អុលបង្ហាញថា គាត់មិនត្រូវបានបញ្ជូនទៅ ស-២១ ភ្លាមៗ បន្ទាប់ពីការចាប់ខ្លួននោះទេ[1255]។

---

របស់ ហាង់ ឌឿន ហៅ ឌឹម (សេចក្តីសង្ខេបរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) EN 00187722 ក៏លើកឡើងផងដែរ ថា នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៧ ហឹង ឌឿន ហៅ ឌឹម បានឆ្លើយដាក់ឈ្មោះមនុស្សចំនួន ១១៤ នាក់ ក្នុងនោះមាន ២៣ នាក់ ត្រូវបានចាប់ខ្លួនរួចហើយ]។ ឯកសារ D1.3.18.2 ចម្លើយសារភាពស-២១ របស់ ហាង់ ឌឿន ឬ ហឹង ឌឿន ហៅ ឌឹម EN 00187780-81, KH 00176994-95 [សេចក្តីសង្ខេបរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា លើកឡើងថា នៅផ្នែកមួយទៀតរបស់ចម្លើយសារភាពរបស់គាត់ នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៧ ឌឹម បានបង្ហាញឈ្មោះកម្លាំងក្បត់ចំនួន ២១ នាក់ មកពីកងវរសេនាធំឯករាជ្យ ១៥២ និងកងពល១៦៤ ដែលក្បត់នៅក្នុងខ្សែរបស់គាត់]។

1255 សាក្សី ជេត ប៊ុណ្ណា កម្មាភិបាលកងវរសេនាធំ១៤០ បានផ្តល់សក្ខីកម្មថា មាស មុត បាននិយាយនៅក្នុងពេលប្រជុំ នៅផ្ទះរអូរឈើទាល នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៧ ថា ឌឹម គឺជាជនក្បត់ដែលបានចាប់ខ្លួនរួចហើយ។ មានតែ ឌឹម ប៉ុណ្ណោះដែលចូលមន្ទីរស-២១ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៧ ដូច្នេះ នេះបង្ហាញឲ្យឃើញថា គាត់មិនបានបញ្ជូនទៅមន្ទីរស-២១ ភ្លាមៗទេ គឺ ដំបូង គេឃុំខ្លួនគាត់នៅកន្លែងផ្សេងមួយរយៈសិន គឺប្រហែលជានៅកំពង់សោម៖ ឯកសារ D114/85 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.10-11, 21, 23-24, 26, 34 ["ក្នុងចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ ដែល មាស មុត បានប្រកាសថាឈ្មោះ ជួយ ឆាន ដែលជាកូនរបស់ ជ័យ ឬនង សួន [...] បានធ្វើការជាជនក្បត់ឲ្យវៀតណាម។ ការចាប់ខ្លួនឈ្មោះ ឌឹម ក៏ត្រូវបានប្រកាសក្នុងពេលតែមួយនោះដែរ និងជាមួយបទចោទដូចគ្នា [...] ឆ. 21៖ ការប្រកាសនេះធ្វើឡើងនៅថ្ងៃបុណ្យរំឭកថ្ងៃជ័យជម្នះ១៧ មេសា សម្រាប់កងពល១៦៤។ ការប្រកាសនោះធ្វើឡើងនៅផ្ទះរអូរឈើទាលនៅប៉ែកខាងចុង ដែលជាទីបញ្ជាការកងទ័ពជើងទឹក [...] ឆ.23៖ មាស មុត បាននិយាយតែម្នាក់ឯង នៅក្នុងថ្ងៃនោះ ដោយមានការចូលរបស់យោធាប្រហែល១០០នាក់ មកពីកងទ័ពជើងទឹកកងពល១៦៤ និងមន្ទីរពាក់ព័ន្ធនឹងកងពល១៦៤ ដូចជាអង្គភាពពេទ្យ អង្គភាពដឹកជញ្ជូន អង្គភាពឥស្សុភារ [...] ក្នុងចំណោម រឿងផ្សេងៗទៀត មាស មុត ក៏បានប្រកាសថា ឆាន និង ឌឹម ត្រូវបានចាប់ខ្លួនដោយសារពួកគេក្បត់។ តាមខ្ញុំដឹង ឆាន គឺត្រូវបានចាប់ខ្លួនមុនគេចាប់ខ្លួន ឌឹម។ ហើយមានតែការចាប់ខ្លួនរបស់ ឆាន និង ឌឹម ទេដែលគេប្រកាសជាសាធារណៈ។ ចំពោះការចាប់ខ្លួនកងទ័ពក្រោមបង្គាប់របស់ឆាន និង ឌឹម ពុំប្រកាសជាសាធារណៈទេ [...] ឆ.24៖ គឺគេធ្វើចំថ្ងៃ១៧ មេសា ហ្នឹងតែម្តង គឺធ្វើតែមួយព្រឹកទេ [...] ឆ.26៖ មានតែការចាប់ខ្លួនរបស់ ឆាន និង ឌឹម ទេដែលត្រូវបានប្រកាស ហើយខ្ញុំមិនដឹងថា ពួកគេត្រូវបានចាប់ខ្លួនមុនការប្រកាសនោះយូរប៉ុណ្ណាដែរទេ [...] ឆ.34៖ មាស មុត បាននិយាយយ៉ាងច្បាស់ៗថា ឌឹម ហើយនិង ឆាន គឺមានផែនការទម្លាក់របបគាត់ចេញ ហើយកាន់កាប់កងពលធំ ដើម្បីបង្កើតរដ្ឋាភិបាលមួយខុសពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ"]។ ជេត ប៊ុណ្ណា ក៏បាននិយាយផងដែរ គង់ គៀន ហៅ អ៊ឹង វ៉េត ត្រូវបានចាប់ខ្លួនប្រហែល១ខែ ក្រោយការចាប់ខ្លួន ឌឹម ទោះបីជាគាត់ត្រូវគេចាប់ខ្លួននៅថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៧៧ ក៏ដោយ៖ ឯកសារ D114/85 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.18-19 ["ស៖ យើងចង់បង្ហាញឲ្យលោកមើលឯកសារពីមន្ទីរស-២១ ដែលមានឈ្មោះ គង់ គៀន ហៅ អ៊ឹង វ៉េត ឯកសារ D1.3.18.4 ដែលមានខ្មែរ ERN KH 00017305។ លេខកងវរៈតូច១៦៣ កងវរៈសេនាធំ៦៣ កងពល១៦៤? ឆ.18៖ ខ្ញុំក៏ ស្គាល់គាត់ដែរ ព្រោះគាត់ធ្លាប់បង្រៀនពួកខ្ញុំ និងធ្លាប់និយាយជាមួយពួកខ្ញុំ។ គ្រប់គ្នាគឺបានដឹងពីការចាប់ខ្លួនរបស់គាត់ ព្រោះគាត់ជាមនុស្សលេចធ្លោ

ម្នាក់ដែរ។ កាលនោះ គាត់រស់នៅព្រលានយន្តហោះកងកេងតែម្តង [...] ឆ.19៖ គ្រាន់តែដឹងថា ប្រហែល១ខែ ក្រោយពីការចាប់ខ្លួនរបស់ ឌឹម"]។ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង ២៣៦៨ [គង់ គៀន ហៅ អ៊ឹង ឬ អ៊ឹង វ៉េត លេខាកងវរៈសេនាតូច៦៣១ នៃកងវរៈសេនាធំ៦៣ – ចូលខែមេសា ឆ្នាំ១៩៧៧ សម្លាប់នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៨]។ ឯកសារ D1.3.18.4 ចម្លើយសារភាពមន្ទីរស-២១ របស់ គង់ គៀន ហៅ អ៊ឹង វ៉េត ERN KH 00017310 [សេចក្តីសង្ខេបអ្នកសួរចម្លើយ។ ចាប់ខ្លួននៅថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៧៧]។ កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា គឺស៊ីសង្វាក់គ្នាទៅនឹងកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីពីរផ្សេងទៀត៖ សាក្សី លៀង បៀ បាននិយាយថា ក្រោយការចាប់ខ្លួន ឌឹម "យ៉ាន បានឡើងមកជំនួស ឌឹម [...] យ៉ាន ត្រូវចាប់ខ្លួនក្រោយដឹម"។ សាក្សីនេះមិនបានកត់សម្គាល់ថា ម៉ុម ជឹម ហៅ យ៉ាន ជំនួស ឌឹម ទេ រហូតទាល់តែក្រោយមកទៀត ពេលយ៉ាន កាន់តួនាទីគាត់មួយរយៈពេលទើបគាត់ដឹង មុនពេលគេចាប់ខ្លួនគាត់ផ្ទាល់។ ប៉ុន្តែ មានការបញ្ជាក់ថា យ៉ាន បានចូលមន្ទីរស-២១ នៅខែមេសា ឆ្នាំ១៩៧៧ ដូច ឌឹម៖ ឯកសារ D54/113 កំណត់ហេតុស្តាប់ចម្លើយ លៀង បៀ ឆ. 80-81 ["ស៖ ក្នុងចម្លើយរបស់លោក លោកនិយាយអំពីការចាប់ខ្លួន ឌឹម តើឌឹម ត្រូវចាប់ខ្លួននៅពេលណា? ឆ.80៖ ឌឹម ត្រូវចាប់ខ្លួនប្រហែលជានៅឆ្នាំ១៩៧៦។ ក្រោយមក យ៉ាន បានឡើងមកជំនួស ឌឹម។ ស៖ តើយ៉ាន ត្រូវបានចាប់ខ្លួនមុន ឬក្រោយ ឌឹម? ឆ.81៖ យ៉ាន ត្រូវចាប់ខ្លួននៅក្រោយ ឌឹម"]។ ទោះបីជា បញ្ជីអ្នកទោសស-២១ រៀបចំដោយ ក.ស .ច.ស លើកឡើងថា នៅថ្ងៃទី២៨ ខែមេសា ឬខែឧសភា ឆ្នាំ១៩៧៧ ជាថ្ងៃចូលស-២១ ក៏ដោយ ប៉ុន្តែនៅក្របខាងមុខទំព័រនៃចម្លើយសារភាព របស់គាត់ដាក់ថា ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ ជាថ្ងៃចាប់ខ្លួន នៅកំពង់សោម៖ ឯកសារ D1.3.1.4 ចម្លើយសារភាពស-២១ របស់ ម៉ុម ជឹម ហៅ យ៉ាន KH 00205413 [ចាប់ខ្លួននៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧], KH 00205414-19 [គាត់ត្រូវបានចាប់ខ្លួន បន្ទាប់ពីអ្នកសួរចម្លើយ ប៉ុន បានធ្វើរបាយការណ៍នៅខែធ្នូ ឆ្នាំ១៩៧៦ អំពីសកម្មភាពរបស់គាត់ ផ្អែកលើចម្លើយសាររបស់មនុស្ស២នាក់ផ្សេងទៀត និងប្រវត្តិរូបរបស់ យ៉ាន]។ ឯកសារ D114/230.1.1 បញ្ជីអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង ៤៧៩៧ [ចូលថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៧ – ឬខែឧសភា – សម្លាប់នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៨]។ ឯកសារ D9.3 បញ្ជីអ្នកទោស ស-២១ មកពីកងពល១៦៤ រៀបរៀងដោយ ក.ស.ច.ស លេខរៀង ២៤ (និងលេខរៀង ២៧ – ស្ទួន)។ ឯកសារ D114/116 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.26-33 [ពន្យល់ថា មុំ យ៉ាន មេបញ្ជាការកងវរៈសេនាធំ ៦៣ បានបាត់ខ្លួននៅក្នុងឆ្នាំ១៩៧៧]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.5 ["យ៉ាន ជាសមាជិកគណៈកងពល១៦៤។ យ៉ាន ពីដើមមកពីភូមិភាគនិរតី ទទួលខុសត្រូវបីកងវរៈសេនាតូច គឺ១៧០, ១៨០, ១៣២។ កងវរៈសេនាតូចទាំងបីនេះ គឺស្ថិតក្នុងកងវរៈសេនាធំមួយ [...] យ៉ាន នេះគឺស្ថិតនៅក្នុងចំណោមពួកក្បត់ដែលតាមុត បានលើកមករៀបជាពាក្យជូនដូចកំណាព្យថា "ញឹក, ផាន, យ៉ាន, ឌឹម ជាពួកក្បត់"]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.1 ["នៅក្នុងអង្គប្រជុំ មាស មុត អានចម្លើយសារភាពរបស់ពួកក្បត់ គាត់បានរៀបរាប់ឈ្មោះកម្មាភិបាលក្បត់ចាប់ពីថ្នាក់មជ្ឈិម រហូតដល់ថ្នាក់មូលដ្ឋាន។ ខ្ញុំនៅចាំថា គាត់ហៅឈ្មោះ អាយ៉ា, អាធុត, អាញឹក, អាយ៉ាន, អាផាន និងអាឌឹម។ ខ្ញុំនៅចាំ មាស មុត ហៅពួកគេថា "អា" ពីព្រោះ "អា" ជាពាក្យបណ្តុះបង្អាប់សម្រាប់និយាយទៅកាន់ពួកក្បត់"] ។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.35 ["វរៈសេនាធំ ៦៣ មានមេបញ្ជាការឈ្មោះ បង យ៉ាន កាន់នៅកោះសេះ កោះតាគាវ កោះថ្មី ម្តុំរាម"]។ ឯកសារ D54/81 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ិច ឆ.14, 22 ["ក្រោយមក យ៉ាន មកកាន់កងពល១៦៤ ជាមួយអំ មុត។ គាត់ជាអតីតមេបញ្ជាការវរៈសេនាធំ៦៣។ ក្រោយមក

359. នៅពាក់កណ្ដាលឆ្នាំ ១៩៧៧ **មាស មុត** បានទទួលចម្លើយសារភាព ស-២១ របស់ ឌឹម អនុរបស់គាត់ និងអ្នកក្រោមបង្គាប់ម្នាក់របស់គាត់ក្នុងចំណោមអ្នកក្រោមបង្គាប់ផ្សេងទៀត នៅភូមិភាគបូព៌ា (គុណ ឌឹម) និងបានពិភាក្សាពីខ្លឹមសារនៃចម្លើយសារភាពទាំងនោះជាមួយ សុន សេន។ សុន សេន បានធ្វើចំណារលើចម្លើយសារភាពទាំងពីរនោះ នៅខែ ឧសភា និងខែ កញ្ញា ឆ្នាំ ១៩៧៧[1256]។

---

ខ្ញុំមិនដឹងថា គាត់ទៅណាទេ។ ក្រោយមក សារឿន មកជំនួស យ៉ាន។ សារឿន មកពីកងវរៈសេនាធំ១៤០ ប្រហែលជាមក ជំនួស យ៉ាន [...] ស៖ ក្រោយមកហេតុបានជា យ៉ាន ក្លាយជាអនុរបស់ មាស មុត? ឆ.22៖ ខ្ញុំមិនដឹងច្បាស់អំពីរឿងនេះដែរ ប៉ុន្តែពេលមួយ យ៉ាន បានឱ្យខ្ញុំទៅធ្វើទ្រុងជ្រូកឱ្យគាត់។ ខ្ញុំមានការងឿងឆ្ងល់ ក៏សួរទៅកាន់មិត្តភក្តិរបស់ខ្ញុំថា គាត់ជានរណា? មិត្តភក្តិខ្ញុំនិយាយថា គាត់គឺជាមេបញ្ជាការរងកងពល"]។ ឯកសារ D54/8 កំណត់ហេតុស្ដាប់ចម្លើយ ឌុល សុង ឆ.4-5 ["តាមដែលខ្ញុំចាំឈ្មោះ យ៉ាន មេបញ្ជាការវរៈសេនាធំ ២២, ង៉ែត មេបញ្ជាការវរៈសេនាធំ២០ និងមេបញ្ជាការវរៈសេនាតូចរបស់ខ្ញុំឈ្មោះ វេត [...] ឆ.5៖ គេចាប់ក្នុងឆ្នាំ១៩៧៧ ឬ ដើមឆ្នាំ១៩៧៨។ ខ្ញុំមិនបានឃើញការចាប់នោះ ដោយផ្ទាល់ភ្នែកទេ ប៉ុន្តែគេប្រជុំតាមកងប្រាប់អំពីការចាប់ចងនេះ។"]។ យោងតាមសាក្សី មាស រឿន លេខារង កងពល១ ក្នុងភូមិភាគបស្ចិម (កោះកុង) គឺដំបូង "ឌឹម ត្រូវបានដកចេញ និងបញ្ជូនទៅក្រោយ មុនបាត់ខ្លួន"៖ ឯកសារ D54/51 កំណត់ហេតុស្ដាប់ចម្លើយ មាស រឿន (ស្វាយ រឿន) ឆ.13, 25 [ពន្យល់ថា ដោយសារ ឌឹម ធ្លាប់បើកកប៉ាល់ទៅជិតព្រំដែនថៃ ដើម្បីត្រួតពិនិត្យសកម្មភាពនេសាទរបស់ទូកថៃ គេបានសង្ស័យគាត់ថាមានគម្រោងយកកប៉ាល់រត់គេចទៅប្រទេសថៃ។ ដូច្នេះគេដកគាត់ ហើយបញ្ជូនទៅក្រោយ មុនពេលគាត់បាត់ខ្លួន។ ចម្លើយទាំងនេះពន្យល់បន្ថែមទៀតថា បទបញ្ជាមកពីកងពល១៦៤ គឺមានតែ មាស មុត ម្នាក់គត់ដែលមានសិទ្ធិបញ្ជាលើការបើកបំផ្លាស់ទីកប៉ាល់ ពីព្រោះគាត់សង្ស័យ អនុមេបញ្ជាការកងពល ឌឹម មានបំណងបើកកប៉ាល់រត់]។

1256 ឯកសារ D234/2.1.55 ចម្លើយសារភាពស-២១ របស់ ហង់ ឌឿន ហៅ ហឹង ឌឿន ហៅ ឌឹម (សំណៅមានពណ៌) EN 00224085, KH 00174375 និងឯកសារ D1.3.18.1 KH 00162140, FR 00235668 [ចំណារអក្សរដៃរបស់ សុន សេន នៅលើចម្លើយសារភាពរបស់អនុលេខាកងពល១៦៤៖ "ជូនបងជាពត៌មាន។ អំពីផែនការ គឺត្រូវហើយ។ ឯមនុស្សខ្លះ គឺត្រូវ ឬខ្លះតាមខ្ញុំស្គាល់ មិនមែនទេ។ ខ្ញុំនឹងអញ្ជើញសមមិត្តមុត មកពិនិត្យជាមួយគ្នា។ អានេះឆ្លើយដាក់ផ្សេងទៀត [...] ថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៧"]។ ការបកប្រែផ្សេងទៀត អាចរកបាននៅក្នុង៖ ឯកសារ D54/97.1 ចម្លើយសារភាពស-២១ របស់ ហង់ ឌឿន ឬ ហឹង ឌឿន ហៅ ឌឹម EN 01072501, KH 00988684 ["ជូនបងជាពត៌មាន។ អំពីផែនការ គឺត្រូវហើយ។ ឯមនុស្សខ្លះ គឺត្រូវ ឬខ្លះតាមខ្ញុំស្គាល់ មិនមែនទេ។ ខ្ញុំនឹងអញ្ជើញសមមិត្តមុត ... អាចពិនិត្យចម្លើយរបស់កម្លាំងផ្សេងទៀត"]។ កាំង ហ្គេកអ៊ាវ ហៅ ឌុច បញ្ជាក់អះអាងពីការសរសេរអក្សរដោយដៃរបស់ សុន សេន ចំពោះចំណារនេះ៖ ឯកសារ D4.1.766 កំណត់ហេតុស្ដាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច EN 00398210, KH 00398202 ["ឯកសារទី១ (ERN 00174375) ត្រូវបានធ្វើចំណារដោយ សុន សេន ផ្ញើទៅ ប៉ុល ពត។ ខ្ញុំមិនមែនជាអ្នកសរសេរវាទេ (ខ្ញុំមិនអាចនិយាយទៅកាន់ មាស មុត ថា សមមិត្តទេ ដោយគិតពីឋានៈ និងអាយុរបស់គាត់ ដែលធំ និងច្រើនជាងខ្ញុំ)។ ឯកសារទី២ (ERN 00174384) ត្រូវបានចារទាំងស្រុងដោយ សុន សេន លើកលែងតែអក្សរដែលមានគូសជុំវិញ ដែលខ្ញុំជាអ្នកសរសេរ "ស" មានន័យថា "សម្ងាត់""]។ សូមមើលផងដែរ ភស្តុតាងដែលគាត់ទទួលបាន និងពិភាក្សាអំពីខ្លឹមសារនៃចម្លើយសារភាពពីអ្នកក្រោមបង្គាប់ម្នាក់របស់ ឌឹម នៅកងពល១៦៤

បន្ទាប់មក **មាស មុត** បានប្រកាសអំពីការចាប់ខ្លួន និងអំពើក្បត់របស់ ឌឹម នៅក្នុងការប្រជុំមួយចំនួន ដែលនៅពេលនោះ អំពើក្បត់របស់ ជ័យ ហាន ហៅ ឆាន និងអ្នកដទៃទៀត ត្រូវបានប្រកាសឱ្យដឹងផងដែរ។ **មាស មុត** បានអានឮៗនូវសម្រង់ចម្លើយសារភាព ស-២១ របស់ពួកគេ[1257] ដោយ

(មកពីតំបន់២២)៖ ឯកសារ D234/2.1.54 ចម្លើយសារភាពស-២១ របស់ គុណ ឌឹម ថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៧៧ EN 00822359, KH 00175293 [សុន សេន កត់ត្រានៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៧៧៖ "សមមិត្តមុត កងពល១៦៤ ត្រូវបានលើកឡើង។ [...] ទាក់ទងសមមិត្តមុត ដើម្បីមានវិធានការ។ យើងបានដកខ្សែខាងមុត រួចហើយ" (គូសបញ្ជាក់បន្ថែម)]។

1257 ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.11, 13, 15-16 ["ស៖ តើមានតែតាមុត ដែលនិយាយក្នុងអង្គប្រជុំ ឬក៏មានកម្មាភិបាលផ្សេងទៀតនិយាយដែរ? ឆ.11៖ មានតែតាមុត ម្នាក់គត់ [...] ឆ.13៖ ខ្ញុំដឹងថា ឌឹម ជាអនុរបស់គាត់ ប៉ុន្តែក្នុងពេលប្រជុំ គាត់បានប្រកាសថា ឌឹម បានក្លាយទៅជាជនក្បត់រួចទៅហើយ [...] ស៖ តើមានអ្នកចូលរួមប្រជុំដែលមកពីបូព៌ា ជាមួយឌឹម ដែលបានចូលរួមដែរ ឬទេ? ឆ.15៖ បាទ គឺមានខ្លះបានចូលរួម។ តែខ្ញុំមិនដឹងថាមានចំនួនប៉ុន្មានពិតប្រាកដទេ។ នៅពេលនោះ គេចំរាញ់យកចេញតែពួកថ្នាក់ដឹកនាំដែលមកពីភូមិភាគបូព៌ាតែប៉ុណ្ណោះ។ ចំណែកពួកយោធាធម្មតា គេគ្រាន់តែដកកាំភ្លើង ហើយបញ្ជូនទៅវាយថ្ម [...] ស៖ ចំពោះ ឌឹម តើលោកដឹងថា គាត់បាត់ខ្លួនមុនការប្រជុំ ឬក៏លោកបានដឹងថាគាត់បាត់ខ្លួនក្នុងពេលគេប្រកាសក្នុងអង្គប្រជុំ? ឆ.16៖ ខ្ញុំទើបតែដឹងពីការបាត់ខ្លួនរបស់គាត់នៅពេលគេប្រកាសក្នុងអង្គប្រជុំនេះ ពីព្រោះគាត់នៅកំពង់សោម ឯខ្ញុំនៅស្ទឹងហាវ"]។ ឯកសារ D114/85 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.10, 21, 23-24, 26 ["ក្នុងចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ ដែល មាស មុត បានប្រកាសថាឈ្មោះ ជ័យ ឆាន ដែលជាកូនរបស់ ជ័យ ឬនង សួន [...] បានធ្វើការជាជនក្បត់ឱ្យវៀតណាម។ ការចាប់ខ្លួនឈ្មោះ ឌឹម ក៏ត្រូវបានប្រកាសក្នុងពេលតែមួយនោះដែរ និងជាមួយបទចោទដូចគ្នា [...] ឆ.21៖ ការប្រកាសនេះធ្វើឡើងនៅថ្ងៃបុណ្យរំឭកថ្ងៃជ័យជម្នះ១៧ មេសា សម្រាប់កងពល១៦៤។ ការប្រកាសនោះធ្វើឡើងនៅផ្ទះរអូរឈើទាលនៅប៉ែកខាងចុង ដែលជាទីបញ្ជាការកងទ័ពជើងទឹក [...] ឆ.23៖ មាស មុត បាននិយាយតែម្នាក់ឯងនៅក្នុងថ្ងៃនោះ ដោយមានការចូលរបស់យោធាប្រហែល១00នាក់ មកពីកងទ័ពជើងទឹកកងពល១៦៤ និងមន្ទីរពាក់ព័ន្ធនឹងកងពល១៦៤ ដូចជាអង្គភាពពេទ្យ អង្គភាពដឹកជញ្ជូន អង្គភាពភស្តុភារ [...] ក្នុងចំណោម រឿងផ្សេងៗទៀត មាស មុត ក៏បានប្រកាសថា ឆាន និង ឌឹម ត្រូវបានចាប់ខ្លួនដោយសារពួកគេក្បត់។ តាមខ្ញុំដឹង ឆាន គឺត្រូវបានចាប់ខ្លួនមុនគេចាប់ខ្លួន ឌឹម។ ហើយមានតែការចាប់ខ្លួនរបស់ ឆាន និង ឌឹម ទេដែលគេប្រកាសជាសាធារណៈ។ ចំពោះការចាប់ខ្លួនកងទ័ពក្រោមបង្គាប់របស់ឆាន និង ឌឹម ពុំប្រកាសជាសាធារណៈទេ [...] ឆ.24៖ គឺគេធ្វើចំថ្ងៃ១៧ មេសា ហ្នឹងតែម្តង គឺធ្វើតែមួយព្រឹកទេ [...] ឆ.26៖ មានតែការចាប់ខ្លួនរបស់ ឆាន និង ឌឹម ទេដែលត្រូវបានប្រកាស ហើយខ្ញុំមិនដឹងថាពួកគេត្រូវបានចាប់ខ្លួនមុនការប្រកាសនោះយូរប៉ុណ្ណាដែរទេ"]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.1 ["នៅចុងឆ្នាំ១៩៧៦ ជិតចូលឆ្នាំ១៩៧៧ [...] មាស មុត បានមកធ្វើមិទ្ទីងជាមួយពួកយើងនៅភូមិគគីរ នៅជិតព្រលានយន្តហោះកងកេង ដោយមានអតីត [...] ចូលរួមប្រហែលរាប់ពាន់នាក់។ នៅក្នុងអង្គប្រជុំ មាស មុត អានចម្លើយសារភាពរបស់ពួកក្បត់ គាត់បានរៀបរាប់ឈ្មោះកម្មាភិបាលក្បត់ចាប់ពីថ្នាក់មជ្ឈិម រហូតដល់ថ្នាក់មូលដ្ឋាន។ ខ្ញុំនៅចាំថា គាត់ហៅឈ្មោះ អាយ៉ា, អាធុច, អាញឹក, អាយ៉ាន, អាឆាន និងអាឌឹម"]។ ឯកសារ D54/104 កំណត់ហេតុ

អះអាងថា ឌឹម និងអ្នកដទៃទៀត "មានផែនការទម្លាក់រូបគាត់ចេញ ហើយកាន់កាប់កងពលធំ ដើម្បីបង្កើតរដ្ឋាភិបាលមួយខុសពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ"[1258]។ ទោះពួកគេមានវត្តមាន ក្នុងការប្រជុំមួយក្នុងចំណោមការប្រជុំទាំងនោះដែលដឹកនាំដោយ **មាស មុត** ឬបានដឹងរឿងនេះ តាមរយៈថ្នាក់លើរបស់ពួកគេក្តី កម្មាភិបាល និងទាហានកងពល ១៦៤ ទាំងអស់បានដឹងថា ឌឹម

---

ស្តាប់ចម្លើយ ឯក នី ឆ.5, 9-10 ["យ៉ាន នេះគឺស្ថិតនៅក្នុងចំណោមពួកក្បត់ដែលតាមុត បានលើកមករៀបជាពាក្យជូន ដូចកំណាព្យថា "ញ៉ើក, ឆាន, យ៉ាន, ឌឹម ជាពួកក្បត់ [...] ឆ.9៖ ខ្ញុំគិតថា ឌឹម នៅក្នុងឯកសារនេះ គឺជា ឌឹម ដែលខ្ញុំបានប្រាប់លោកខាងដើម ដែលរាប់នៅក្នុងពាក្យជូនថា អាញ៉ើក, អាឆាន, អាយ៉ាន, អាឌឹម [...] ឆ.10៖ ខ្ញុំបានឮសូរពីយោធាក្នុងកងជាមួយគ្នា និយាយថា ឌឹម និងឆាន ត្រូវបានបញ្ជូនទៅកាន់ម៉ាស៊ីនបូមទឹកនៅបឹងជើងឯង។ នៅពេលនោះ យើងជឿថា រឿងហ្នឹងជារឿងពិត។ ប៉ុន្តែក្រោយមកនៅពេលដែល តាមុត ប្រកាសនៅក្នុងអង្គប្រជុំអំពីចម្លើយសារភាពរបស់ពួកក្បត់ និងខ្សែរយៈសេ.អ៊ី.អា និងកា.ហ្សេ.បេ ហើយបន្ទាប់ពីការបាត់ខ្លួនពួកនោះ ទើបយើងដឹងថាពួកគេទាំងនោះត្រូវបានចាប់ខ្លួនហើយ"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.7-8 ["ស៖ តើលោកដឹងឬទេថា តើមាស មុត ជាអ្នកចេញប្រកាសព័ត៌មាននេះ? ឆ.7៖ បាទ ដោយសារគាត់ជាមេបញ្ជាការកងពល ដូច្នេះគឺមានតែគាត់ហើយជាអ្នកបញ្ជូនសេចក្តីប្រកាសនេះមកថ្នាក់ក្រោម។ ស៖ ម៉េចបានជាលោកដឹងរឿងនេះ? ឆ.8៖ គ្មាននរណាទៀត ក្រៅពីគាត់ដែលអាចចេញការប្រកាសនេះ ពីព្រោះគាត់ជាមេបញ្ជាការកងពល។ ការប្រកាសអំពីការចាប់ចងនេះ គឺសម្រាប់តែចាប់ចងពួកប្រធានកងដែលក្បត់តែប៉ុណ្ណោះ មិនមែនសម្រាប់ការចាប់ចងទូទៅទេ"]។ ខ្សែអាត់សំឡេង ចម្លើយសារភាពស-២១ របស់ ឌឹម (និងអតីតអនុរបស់គាត់ឈ្មោះ ស៊ីម។ អ្នកទាំងពីរត្រូវបានចាត់តាំងឱ្យទៅកងពល១៦៤ នៅកំពង់សោម)។ អ្នកឡើងជំនួស ឌឹម បានចាក់ខ្សែអាត់សំឡេងនេះនៅបញ្ជាការដ្ឋានកងវរសេនាធំឯកងរាជ្យ១៥២ នៅក្នុងកិច្ចប្រជុំមួយ នៅព្រែកលៀប៖ ឯកសារ D54/40 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន វី ឆ.23-24 ["អង្គការថ្នាក់លើនិយាយថា អ្នកតំបន់២២ ជាពួកក្បត់។ នៅពេលនោះ គេបានចាក់ខ្សែអាត់សំឡេងពីការសារភាពរបស់ ឌឹម និង ស៊ីម ឱ្យយោធាស្តាប់ ដើម្បីឱ្យយោធាជឿថា អ្នកទាំងពីរនេះពិតជាក្បត់មែន។ ខ្ញុំស្គាល់សំឡេងគាត់ទាំងពីរនាក់ច្បាស់។ ស៖ តើអ្នកណាជាអ្នកយកខ្សែអាត់សំឡេងអ្នកទាំងពីរចាក់ឱ្យយោធាស្តាប់ ហើយចាក់ខ្សែអាត់នោះនៅកន្លែងណា? ឆ.24៖ គឺមេបញ្ជាការបន្ទាប់ពី ឌឹម ជាអ្នកចាក់ខ្សែអាត់សារភាពរបស់អ្នកទាំងពីរឱ្យយោធាស្តាប់។ ខ្សែអាត់បានចាក់ឱ្យយោធាស្តាប់នៅព្រែកលៀប"]។

[1258] ឯកសារ D114/85 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.34 ["មាស មុត បាននិយាយយ៉ាងច្បាស់ៗថា ឌឹម ហើយនិង ឆាន គឺមានផែនការទម្លាក់រូបគាត់ចេញ ហើយកាន់កាប់កងពលធំ ដើម្បីបង្កើតរដ្ឋាភិបាលមួយខុសពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ"]។ សូមមើលផងដែរ ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ សៀង EN 00217564 ["ឌឹម បានបាត់ខ្លួននៅក្នុងឆ្នាំ១៩៧៧ នៅពេលដែលមានជម្លោះផ្ទៃក្នុង"]។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.50 ["តាឆាន ជាអនុបញ្ជាការ។ តាឌឹម ជាអនុបញ្ជាការ។ តាឆាន និងតាឌឹម ត្រូវបានសម្លាប់ដោយចោទថាក្បត់ ហើយតាមពិតគេមានផែនការក្បត់មែន"]។

ត្រូវគេចាប់ខ្លួន និងសម្លាប់ ពីព្រោះគាត់ត្រូវ **មាស មុត** និងថ្នាក់ដឹកនាំកងទ័ពបដិវត្តន៍កម្ពុជា/ប.ក.ក ចាត់ទុកថាជាជនក្បត់[1259]។

[1259] ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.26-27 [“ខឹម ត្រូវបានចាប់ខ្លួន ពីព្រោះគាត់ក្បត់។ សៈ តើលោកដឹងពីអ្នកណា និងដោយវិធីណា? ឆ.27៖ គេនិយាយតៗគ្នា អ្នកណាក៏ដឹងដែរអំពីរឿងនេះ។ នៅពេលនោះ ខ្ញុំប្រចាំការនៅកោះកុង”]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.64, 66-67, 226 [“[អ្នកដែលត្រូវនាំចេញទៅ] មានឈ្មោះ ង៉ែត, ឈ្មោះខឹម, ឈ្មោះឆាន និងឈ្មោះសុខ ជាដើម ដែលគេចោទថាជាគិញវៀតណាម ឬក៏ សេ.អ៊ី.អា។ សៈ អ្នកដែលលោករៀបរាប់អម្បាញ់មិញនោះ សុទ្ធតែជាខ្មែរ ឬ? [...] ឆ.66៖ សុទ្ធតែអ្នកដែលនៅក្រោម មាស មុត ដូចជា ង៉ែត ជាអនុរបស់ មាស មុត។ ខឹម នៅក្រោម មាស មុត នៅថ្នាក់កងពល។ ឆាននៅថ្នាក់កងពល។ យ៉ាន ប្រធានវរៈសេនាធំ។ សុខ ជាប្រធានពេទ្យនៅកងពល [...] ឆ.67៖ បានជាខ្ញុំដឹង ពីព្រោះគេបានហៅអ្នកទាំងនោះយកទៅ ហើយបន្ទាប់ពីរបីថ្ងៃក្រោយមក ប្រធានអង្គភាពវរៈសេនាធំ១៤០ ឈ្មោះ ហាន បានប្រជុំប្រាប់ថា ទាំងនោះ ជាខ្មាំងស៊ីរូងផ្ទៃក្នុង [...] សៈ កាលម្សិលមិញ លោកបាននិយាយថា មានកម្មាភិបាលខ្លះត្រូវបានគេនាំយកទៅបាត់ មានឈ្មោះ ខឹម, យ៉ាន, ឆាន, ង៉ែត, សុខ តើត្រឹមត្រូវទេ? ឆ.226៖ រឿងហ្នឹង គឺមេបញ្ជាការខ្ញុំឈ្មោះ ហាន បានប្រាប់ខ្ញុំ អ្នកប៉ុន្មាននាក់ខាងលើនេះ សុទ្ធតែជាអ្នកក្បត់ក្នុងជួរកងទ័ព”]។ ឯកសារ D54/51 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន (ស្វាយ វឿន) ឆ.13, 25 [ពន្យល់ថា ដោយសារ ខឹម ធ្លាប់បើកកប៉ាល់ទៅជិតព្រំដែនថៃ ដើម្បីត្រួតពិនិត្យសកម្មភាពនេសាទរបស់ទូកថៃ ទើបគេសង្ស័យគាត់ថាមានគម្រោងយកកប៉ាល់រត់គេចទៅប្រទេសថៃ។ ដូច្នេះគេដកគាត់ ហើយបញ្ជូនទៅក្រោយ មុនពេលគាត់បាត់ខ្លួន។ ចម្លើយនេះពន្យល់បន្ថែមថា បទបញ្ជាមកពីកងពល១៦៤ គឺមានតែ មាស មុត ម្នាក់គត់ដែលមានសិទ្ធិបញ្ជាលើការបើកបំផ្លាស់ទីកប៉ាល់ ពីព្រោះគាត់សង្ស័យ អនុមេបញ្ជាការកងពល ខឹម មានបំណងបើកកប៉ាល់រត់]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.14 [“សៈ ម៉េចបានជាលោកដឹង គេចាប់ ខឹម ដោយចោទថាក្បត់? ឆ.14៖ យើងដឹង តាមរយៈតាមការប្រជុំតាមកង បន្ទាប់ពីការចាប់ចង។ គេធ្វើការប្រកាសនៅក្នុងអង្គប្រជុំថា ពួកទាំងនោះត្រូវបានចាប់។ ខ្ញុំចង់ជម្រាបថាមិនមែនមានតែខ្ញុំម្នាក់ទេ ដែលបានដឹងអំពីការចាប់ចងនេះ អ្នកដទៃទៀតក្នុងកងពល១៦៤ ដែលខ្ញុំបានរាយឈ្មោះនៅក្នុងកិច្ចសម្ភាសរបស់ខ្ញុំជាមួយ អាង ហុក ក៏បានដឹងអំពីរឿងការចាប់ចងនេះដែរ។”]។ ឯកសារ D114/20 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.21 [“ខឹម បានបាត់ខ្លួននៅក្នុងពេលមួយ។ យើងធ្លាប់បាននិយាយគ្នាជាមួយអ្នកនៅក្នុងកងពលអំពីការបាត់ខ្លួនគាត់ក្រោយពេលដែលយើងលែងឮសំឡេងរបស់គាត់នៅក្នុងវិទ្យុទាក់ទងទៀត”]។ ឯកសារ D54/49 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.21-22 [“ខឹម ជាអនុមេបញ្ជាការរបស់ មាស មុត។ ក្រោយមកខ្ញុំទទួលដំណឹងថា គេដកចេញពីកងពល ១៦៤ តែខ្ញុំមិនដឹងថាមានរឿងអ្វីកើតឡើងចំពោះកាត់នៅពេលក្រោយទេ។ សៈ ហេតុអ្វីបានជាលោកដឹងពីការបាត់ខ្លួន ខឹម? ឆ.22៖ មិត្តភក្តិរបស់ខ្ញុំឈ្មោះ ហុក និងម៉ុន ជាមេបញ្ជាការអនុសេនាធំនៃវរៈសេនាតូច៤៨០ បានប្រាប់ខ្ញុំ”]។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.11, 13 16។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.12 [“ខឹម គឺជាអនុទី១ របស់មាស មុត ហើយគាត់ជាអ្នកមកពីខាងភូមិភាគបូព៌ា។ ខឹម ហើយនិង ឆានត្រូវបានចាប់ខ្លួន ហើយកម្ទេចមុនពេលខ្ញុំត្រូវបានគេបញ្ជូនទៅក្នុងកងផលិត”]។ ឯកសារ D114/85 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.10, 21, 23-24, 26, 34។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.1។ ឯក

360. ដោយហេតុថាអ្នកក្រោមបង្គាប់ត្រូវបានចាត់ទុកដោយស្វ័យប្រវត្តិថា "ជាប់ពាក់ព័ន្ធ" ឬស្ថិតក្នុង "ខ្សែ" របស់មេដឹកនាំយោធារបស់ពួកគេ[1260] ហើយ ឌឹម បានឆ្លើយដាក់កម្មាភិបាល និងទាហានកងពល ១៦៤ ជាច្រើននាក់នៅ ស-២១[1261] **មាស មុត** បានបញ្ជាឱ្យបោសសម្អាតកម្មាភិបាល និងទាហានភូមិភាគបូព៌ាទាំងអស់ពី ៧០០ ទៅ ១.០០០ នាក់ នៅក្នុងកងពល ១៦៤[1262]៖ គាត់បាន

---

សារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.5, 9។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ. 7-8។ ធ្វើបើហ៊ុន សែន បានលើកឡើងអំពីការកម្ទេច ឌឹម នៅក្នុងអត្ថបទមួយ ចុះផ្សាយនៅប្រទេសវៀតណាម ឆ្នាំ ១៩៧៨៖ ឯកសារ D69.2.20 សារព័ត៌មាន ប៊ីប៊ីស៊ី SWB ទំនាក់ទំនងនៃបណ្តាប្រទេសចុងបូព៌ា ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៧៨ EN S 00013194, KH S 00810138, FR S 00793509 [ហ៊ុន សែន និយាយអំពីការបោសសម្អាតផ្ទៃក្នុង និងកម្ទេចសមាជិកបក្សកុម្មុយនីស្តកម្ពុជា៖"បន្ទាប់ពីពួកគេ គឺមាន ឆាន មេបញ្ជាការកងពល១៦៤ ឈរជើងនៅកំពង់សោម។ និងឌិ ស្នងការនយោបាយកងពល"]។

1260 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ 14.21.14-14.26.40 ["តាឌឹម [...] ក្រោយមក គាត់បានចាប់ខ្លួន បាទ បាត់ខ្លួន។ ពេលដែលចាប់ខ្លួនទៅ កងទ័ព កងយោធាទាំងអស់ជាកងយុទ្ធភូមិភាគបូព៌ា ឃើញថា ឃើញចាប់ខ្លួនជាបន្តបន្ទាប់រហូតដល់អស់រលីងនៅកំពង់សោម កងភូមិភាគបូព៌ាអត់មាននៅសល់ទេ ក្រោយមកចាប់ទាំងអស់ ចាប់បាត់អស់។ ខ្ញុំក៏អត់ដែលឃើញអីទាំងអស់ មិនដឹងចាប់យកទៅណា ទៅណីទេ អត់ឃើញទេ [...] ក្រោយពីតាឌឹម គេចាប់ខ្លួនបាត់ហើយ ក្រោយមកចាប់យោធា។ ដែលកងពលរបស់គាត់វរៈ មួយវរៈសេនាធំនោះ។ ដោយសារតែគេចាប់ តាឌឹម បាត់ទៅ គឺតាឌឹម នោះគឺគាត់មានចម្លើយយ៉ាងម៉េចទេ ឬដឹងចម្លើយយ៉ាងម៉េចអីយ៉ាងម៉េចទេ ហើយសាច់ទ័ពរបស់គាត់ដែលរស់នៅក្នុងកំពង់សោមនោះ សុទ្ធតែជាប់និន្នាការនយោបាយចម្លើយរបស់ តាឌឹម ទាំងអស់ ក្រោយមកបានគេចាប់ដកចេញទាំងអស់ ប៉ុន្តែមិនដឹងដកចេញទៅកន្លែងណាទេ។ មិនមែនបញ្ជូនទៅភូមិភាគបូព៌ាវិញទេ [...] បាត់ទាំងអស់ បាត់អត់ដែលឃើញទេមួយវរៈសេនាធំហ្នឹង"], 14.26.40 ["យោធាទាំងអស់នុំង ឃើញថាជាប់និន្នាការនយោបាយរបស់គាត់ទាំងអស់ហើយ។ អ៊ីចឹងគេយកមេទៅហើយ អ៊ីចឹងគេសង្ស័យថាទ័ពទាំងអស់ដែលវរៈសេនាធំដែលគាត់មកពីភូមិភាគបូព៌ានោះ គេលែងទុកចិត្តហើយ គេដកចេញ មិនដឹងដកចេញទៅណាទេ"]។ ឯកសារ D98/3.1.89 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹកចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ២០០៩ 16.18.55 ["អារម្មណ៍ជំនាន់នុំងគិតថា ម៉េចខ្សែខ្លាំង"]។

1261 សូមមើល ជើងទំព័រ ១២៥៤។

1262 ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.12 ["ឌឹម ត្រូវបានបញ្ជូនមកពីភូមិភាគបូព៌ាមកធ្វើជាអនុកងពលរបស់ មាស មុត។ នៅពេលនោះ គេចាប់ពួកមកពីបូព៌ាដែលនៅតាមកងនានាដែលនៅក្នុងកងពល"]។ ឯកសារ D2/16 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី (សឿ ទូច) ឆ.20 ["ស៖ តើពួកកម្លាំងដែលបញ្ជូនមកពី បូព៌ាទាំងអស់ដែលចូលមកកងជើងទឹកត្រូវបានគេចាប់ និងដកចេញទាំងអស់ ឬយ៉ាងម៉េច? ឆ.20៖ មុនដំបូងគេហៅមេៗ យកចេញទៅបាត់។ បន្ទាប់មកទៀតគេដកយកអ្នកថ្នាក់ក្រោមៗទាំងអស់"]។ ឯកសារ D59/2/3.14a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ប៉ាក សុខ EN 01185002, KH 00958291 ["ដល់គេចាប់ទៅ [ឌឹម] ខ្សែស្រឡាយដែលគាត់អោបទុកហ្នឹងយកមកមួយកងពលទៅ។ ស៖ យកទៅណា? ឆ៖ យកមកសម្លាប់ កន្លែងហ្នឹងចំណោត

រាម វៃចោលហើយយកអាត្រាក់មកឈូស"]។ ឯកសារ D54/26 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.10, 33, 35-36 ["មេរបស់យើង ឌឹម ក៏ត្រូវបានគេចាប់ខ្លួនពីបទក្បត់ផងដេរ។ ក្រោយគេចាប់ខ្លួន ឌឹម គេបន្តចាប់ខ្លួនថ្នាក់ក្រោម។ នៅកងកេង គេឲ្យយើងធ្វើស្រែជាមួយនឹងចប [...] ដំបូងគេហៅយើង ដោយហេតុផលថា អង្គការ ហៅទៅរៀនសូត្រ។ ពេលយើងទៅដល់ គេឲ្យយើងចាប់ផ្ដើមធ្វើស្រែសនៅទីនោះ។ ប្រជាជនខ្លះក៏បានបាត់ខ្លួនផងដែរ នៅពេលនោះ -- ពួកគេបានបាត់ខ្លួន និងមិនដែលឃើញត្រឡប់មកវិញទេ -- ហើយគ្មាននរណាម្នាក់ហ៊ានសួរ ឬឆ្ងល់អ្វីនោះទេ។ នៅពេលនោះ មានតែថ្នាក់ក្រោម កូនចៅទេ ដែលនៅរស់៖ ថ្នាក់ដឹកនាំទាំងអស់បានបាត់ខ្លួន និងមិនដែលឃើញត្រឡប់មកវិញនោះទេ [...] ឆ.33៖ ឌឹម មកពីភូមិភាគបូព៌ាជាមួយយោធាមួយកងពល មកចូលរួមជាមួយនឹងកងពល១៦៤។ បន្ទាប់ពីការចាប់ខ្លួន ឌឹម ទៅ យោធាភូមិភាគបូព៌ាទាំងនោះត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ដែរ។ នៅពេលនោះ យោធាភូមិភាគបូព៌ាម្នាក់ [...] ជ្រៀន បានបាត់ខ្លួនតែម្ដង។ ខ្ញុំគិតថា យោធារបស់ភូមិភាគបូព៌ាដែលត្រូវបានចាប់ខ្លួនទាំងនោះប្រហែលជាត្រូវបានគេសម្លាប់ចោលនៅកន្លែងសម្លាប់នោះដែរហើយ [ចំណោទរាម] ប៉ុន្តែខ្ញុំមិនច្បាស់ទេ។ ប្រហែល១ខែក្រោយមក មេបញ្ជាការវរៈសេនាតូចរបស់ខ្ញុំ បានបើកវគ្គអប់រំរៀនសូត្រនយោបាយ ដែលនៅក្នុងនោះគាត់ប្រកាសថា ឌឹម, កុយ ធួន ហៅ ធុច ហើយនិងថ្នាក់ដឹកនាំមួយចំនួនទៀត គឺសុទ្ធតែជា កា.ហ្ស.បេ និងសេ.អ៊ី.អា របស់យួន ហើយសុទ្ធតែជាពួកក្បត់ [...] ឆ.35៖ ខ្ញុំដឹងអំពីការបោសសម្អាតភូមិភាគបូព៌ាម្ដង [...] គេបានប្រកាសថាមួយកងវរៈសេនាតូចមានយោធា៥០នាក់ ក៏មិនមានបញ្ហាអ្វីដែរ ដរាបយោធាទាំងនោះជាយោធាល្អ។ យោងទៅតាមការចងចាំរបស់ខ្ញុំ ការបោសសម្អាតយោធាភូមិភាគបូព៌ាចាប់ផ្ដើមក្នុងឆ្នាំ៧៦ មុនគេបញ្ចូលខ្ញុំទៅកងវរសេនាធំ១៤០ មុនឆ្នាំ១៩៧៧ [...] នៅក្នុងពេលនោះ គេចាប់មេដឹកនាំមុន រួចហើយទើបគេចាប់យោធាតាមក្រោយ។ ឆ.36៖ [...] នៅក្នុងរយៈពេលអប់រំនយោបាយថា ការចាប់ចងគឺធ្វើឡើងតាមចម្លើយសារភាពរបស់មេដឹកនាំដែលត្រូវបានចាប់យកទៅមុន"]។ ឯកសារ D54/13 កំណត់ហេតុស្ដាប់ចម្លើយ ប្រេស មាន ឆ.15 ["នៅពេលនោះ គេចំរាញ់យកចេញតែពួកថ្នាក់ដឹកនាំដែលមកពីភូមិភាគបូព៌ាតែប៉ុណ្ណោះ។ ចំណែកពួកយោធាធម្មតា គេគ្រាន់តែដកកាំភ្លើង ហើយបញ្ជូនទៅវាយថ្ម"]។ ឯកសារ D54/36 កំណត់ហេតុស្ដាប់ចម្លើយ ប្រាក់ សុខា ឆ.2 ["ពួកអតីតយោធា ភូមិភាគបូព៌ា ក៏ត្រូវបានបញ្ជូនទៅក្នុងកងចល័តជាមួយខ្ញុំដែរ។ យោធាភូមិភាគបូព៌ាត្រូវបានគេចាត់ថា ជាពួកក្បត់"]។ ឯកសារ D54/33 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុង ឆុន ឆ.20 ["យើងស្នាក់នៅកំពង់សោម ចំនួនមួយអាទិត្យ មុនពេលពួកយើងបញ្ជូនទៅទីរួមខេត្តកោះកុង ដើម្បីទៅជំនួសពួកភូមិភាគបូព៌ានៅលើកប៉ាល់ ប៉េសេអេស (PCF) ដែលបានគេដកចេញ"]។ ឯកសារ D54/33.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ី ឆុន (អ៊ុង ឆុន) EN 01073811, KH 00964200 ["មកពីភូមិភាគបូព៌ាមកពីកងជើងទឹកហ្នឹងដំបូង៧០០នាក់ តែក្រោយមករត់ទៅវិញរួចខ្លះ ហើយគេចាប់មកវិញ យកទៅលុតដំ [...] ចុងបញ្ចប់ពួកមកពីភូមិភាគបូព៌ាហ្នឹងដកចេញទាំងអស់ អត់មានឲ្យនៅទេ [តាឌឹម ក៏ត្រូវបានគេដកផងដែរ [...] ដកទាំងមេ ដកទាំងកូនហ្នឹង ដល់ពេលទំនាស់គ្នាខ្លាំងពេក"]។ ឯកសារ D114/65 កំណត់ហេតុស្ដាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.12 [អំពីរចនាសម្ព័ន្ធបញ្ជាការកងវរៈសេនាធំ១៤០៖ "តាសេង គឺជាមេបញ្ជាការ ហើយតាសំ ដែលមកពីភូមិភាគបូព៌ា គឺជាអនុ ប៉ុន្តែតាសំ ត្រូវបានកម្ទេចនៅពេលនោះ"]។ ឯកសារ D114/86 កំណត់ហេតុស្ដាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.30 ["ស៖ យើងចង់បង្ហាញឲ្យលោកមើលឯកសារមកពីមន្ទីរទួលស្លែង/ស-២១ មួយទៀត D1.3.5.9 ភាសាខ្មែរ ERN 0016147។ ឈ្មោះឯកសារ កម្លាំងពួកក្បត់នៅ ១៦៤ + ១៥២ តើលោកយល់យ៉ាងណាដែរ ចំពោះឯកសារនេះ? ឆ.30៖ ខ្ញុំស្គាល់មនុស្សនៅលេខរៀងទី១ ឈ្មោះ កេត សំ និងឈ្មោះ

ប្រកាសក្នុងពេលប្រជុំថា "ពួកយោធាទាំងអស់ដែលមកពីភូមិភាគបូព៌ា គឺយោធាដែលមានសមាភាពមិនល្អ ដូច្នេះ ពួកគេត្រូវតែដកចេញឱ្យដាច់ពីកងពល"[1263]។ គឺក្នុងបរិបទនេះហើយដែលទាហាន

---

នៅលេខរៀងទី១២ ឈ្មោះ ឌឹម (គុណ ឌឹម) ដែលអ្នកទាំងពីរនេះជាបុគ្គលដែលគេស្គាល់ច្រើន"]។ ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.16, 23 [(យោធាកងពល១៦៤ ភូមិភាគបូព៌ា ដែលនៅរស់)៖ "បានក្រោយមក រួមរស់ជាមួយគ្នាបានរយៈ៣ខែ ក៏លែងទុកចិត្តគ្នាវិញ។ ក្រោយមកទៀត គឺគេចាប់សង្ស័យថា ភូមិភាគបូព៌ាថាខ្មាំងទាំងអស់ [...] ចូលឆ្នាំ១៩៧៧ យកយើងមកកាប់ព្រៃគុប ជិតស្ទឹងហាវ។ ហ្នឹងមានគ្នាច្រើនណាស់ រាប់រយនាក់ [...] ដល់ពេលរួចពីហ្នឹងមក ចំនួនប្រហែលជាពីរបីខែ វាក៏ដកពួកខ្ញុំហ្នឹងថាឡើងទៅរៀន តែខ្ញុំមិនទាន់ទៅទេ [...] ដល់ដកទៅរៀន បាត់រហូត អត់ឃើញមកវិញទេ [...] ក្រោយមក ក៏វាយកខ្ញុំ ខ្លួនខ្ញុំហ្នឹងព្រមទាំងប្អូនប្រាំនាក់ទៀត យកទៅរៀនទៀត ថាទៅរៀននៅភូមិភាគបូព៌ា [...] ដល់ពេលទៅដល់សាលាមួយ ផ្លូវទៅស្ទឹងហាវនេះ ពួកវាឡើងលើផ្ទះធំមួយកន្លែងហ្នឹង ហើយពួកខ្ញុំចូលខាងក្រោមផ្ទះ ពួកវាលោតចុះមកក្រោមព័ទ្ធជុំវិញពួកខ្ញុំ ហើយភ្ជង់ចាប់ពួកខ្ញុំ។ ចាប់ខ្ញុំ បានវៃដំទាត់ធាក់ ហើយចងស្លាបសេក។ ដល់នាំខ្ញុំចូលទៅគុក [...] ដាក់គុក ព្រឹកឡើង វាបញ្ចេញម្នាក់ម្តងៗ វៃសួរចម្លើយ។ វៃសួរចម្លើយហើយ ពេលព្រឹកវាដាក់ច្រវាក់ឱ្យធ្វើការ [...] ក្រោយមក ព្រឹកឡើងបានបញ្ចេញបីនាក់ទៀត វៃនឹងខ្សែភ្លើង សួរចម្លើយ ដូចគ្នាទាំងអស់។ បានចំនួនប្រហែលជាមួយអាទិត្យ ឬ១០ថ្ងៃ ក៏ចាប់ផ្តើមសាថ្មី វៃសួរចម្លើយម្តងទៀត [...] ឆ.23៖ គេបានសង្ស័យពួកខ្ញុំទាំងអស់ ថាពួកបូព៌ាហ្នឹងសុទ្ធតែខ្មាំង"]។ ប៉ែន វី យោធានៅក្នុងកងវរៈសេនាធំឯករាជ្យ១៥២ មិនបានអមដំណើរមេបញ្ជាការរបស់គាត់ឈ្មោះ ឌឹម និងអនុមេបញ្ជាការឈ្មោះ ស៊ីម នៅកំពង់សោមនោះទេ បានផ្តល់សក្ខីកម្មថា ខ្សែអាត់សំឡេងចម្លើយសារភាពរបស់ស៊ីម និងឌឹម ត្រូវបានចាក់ឱ្យស្តាប់នៅក្នុងអង្គប្រជុំនៅព្រៃកលៀប៖ ឯកសារ D54/40 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន វី ឆ.23-24 ["អង្គការថ្នាក់លើនិយាយថា អ្នកតំបន់២២ ជាពួកក្បត់។ នៅពេលនោះ គេបានចាក់ខ្សែអាត់សំឡេងពីការសារភាពរបស់ ឌឹម និង ស៊ីម ឱ្យយោធាស្តាប់ ដើម្បីឱ្យយោធាជឿថា អ្នកទាំងពីរនេះពិតជាក្បត់មែន។ ខ្ញុំស្គាល់សំឡេងគាត់ទាំងពីរនាក់ច្បាស់។ ស៖ តើអ្នកណាជាអ្នកយកខ្សែអាត់សំឡេងអ្នកទាំងពីរចាក់ឱ្យយោធាស្តាប់ ហើយចាក់ខ្សែអាត់នោះនៅកន្លែងណា? ឆ.24៖ គឺមេបញ្ជាការបន្ទាប់ពី ឌឹម ជាអ្នកចាក់ខ្សែអាត់សារភាពរបស់អ្នកទាំងពីរឱ្យយោធាស្តាប់។ ខ្សែអាត់បានចាក់ឱ្យយោធាស្តាប់នៅព្រៃកលៀប"]។

1263 ឯកសារ D54/44 កំណត់ហេតុស្តាប់ចម្លើយ លន់ សេង ឆ.19, 22-24, 26-28 ["ស៖ ហេតុអ្វីបានជាលោកដឹងថាមានយោធា១៥០០នាក់ មកពីភូមិភាគបូព៌ា គេយកទៅដាក់នៅកងផលិតធំ? ឆ.19៖ ប្រធានកងពល មាស មុត បានបើកការប្រជុំ ហើយប្រកាសថា ពួកយោធាទាំងអស់ ដែលមកពីភូមិភាគបូព៌ា គឺជាយោធាដែលមានសមាសភាពមិនល្អ ដូច្នេះពួកគេត្រូវតែដកចេញឱ្យដាច់ពីកងពល។ ខ្ញុំមិនអាចនិយាយឱ្យច្បាស់បានទេ ប៉ុន្តែខ្ញុំជឿថា វាមានការប្រកួតប្រជែងគ្នានៅក្នុងថ្នាក់ដឹកនាំរបស់កងពល ដែលបណ្តាលឱ្យយោធាទាំងនេះមិនអាចដាក់បញ្ចូលគ្នាបាន [...] ឆ.22៖ ខ្ញុំចូលរួមការប្រជុំដែរ បានខ្ញុំដឹង [...] ឆ.23៖ ទីបញ្ជាការកងពល នៅកំពង់សោម [...] ឆ.24៖ ទីបញ្ជាការកងពលមានទីតាំងស្ថិតនៅជិតផ្សារលើ ជាកន្លែងតាមុត គាត់រស់នៅ។ ការប្រជុំ គឺធ្វើនៅអតីតរោងកុនមួយ [...] ស៖ តើការប្រកាសអំពីយោធាភូមិភាគបូព៌ាហ្នឹង ធ្វើនៅក្នុងការប្រជុំជាអចិន្ត្រៃយ៍ ឬក៏ធ្វើនៅក្នុងការប្រជុំពិសេសណាមួយ? ឆ.26៖ ការប្រកាសនោះ ត្រូវធ្វើនៅក្នុងកិច្ចប្រជុំពិសេសមួយដែលថ្នាក់ដឹកនាំផ្នែកវរៈសេនាតូច និងវរៈសេនាធំត្រូវបានគេ

កងពល ១៦៤ ទាំងអស់មកពីភូមិភាគបូព៌ា ដែលត្រូវគេបញ្ជូនទៅរៀនបច្ចេកទេសនៅប្រទេសចិន ត្រូវបានស្នើឲ្យត្រឡប់មកវិញភ្លាមៗ មុនពេលបញ្ចប់ការសិក្សារបស់ពួកគេ[1264]។ ពេលដកចេញរួច អតីតទាហានភូមិភាគបូព៌ាដែលមិនត្រូវបានចាប់ខ្លួន និងសម្លាប់ភ្លាមៗនោះ ត្រូវបានបង្ខំឲ្យធ្វើការនៅការដ្ឋាន (ឃុំរាម កងកេង បិតត្រាង ស្ទឹងហាវ)[1265] ក្នុងលក្ខខណ្ឌដូចទាសករ។ ទាហានជា

---

ជ្រើសរើសឲ្យមកចូលរួម។ ការប្រកាសអំពីយោធាភូមិភាគបូព៌ានោះ គឺមិនបានធ្វើជាសាធារណៈនោះទេ។ ខ្ញុំនៅចាំថា ការប្រកាសអំពីយោធាភូមិភាគបូព៌ានោះ គឺមិនត្រូវបានចាត់ទុកថាជាខ្មាំងនោះទេ។ គេថា យោធាទាំងនោះត្រូវបានបញ្ជូនទៅធ្វើការអប់រំ ដើម្បីឲ្យដឹងថា តើគេអាចទទួលការអប់រំបាន ឬមិនបាន។ បើសិនជាអ្នកណាទទួលការអប់រំបានល្អ អ្នកនោះនឹងត្រូវបញ្ជូនឲ្យទៅកងដើមគេវិញ។ សម្រាប់អ្នកដែលមិនអាចអប់រំបាន គេទុកសម្រាប់អប់រំបន្ត។ អំឡុងពេលអប់រំ គឺគេធ្វើការស្រាវជ្រាវអំពីប្រវត្តិរបស់យោធាម្នាក់ៗ ដោយតាមដានរហូតទៅដល់ស្រុកកំណើតរបស់គេ។ សៈ តើអ្នកណាជាអ្នកប្រកាសនៅក្នុងពេលអប់រំ? ឆ.27៖ ប្រធានកងពល មាស មុត។ សៈ តើពាក្យនិយាយថា "តាមដានរហូតដល់ស្រុកកំណើតហ្នឹង តើជាពាក្យរបស់លោក ឬមួយក៏ជាពាក្យប្រធានកងពល មាស មុត ជាអ្នកថា? ឆ.28 ៖ ប្រធានកងពល មាស មុត ជាអ្នកណែនាំមេបញ្ជាការវរៈសេនាធំឲ្យធ្វើការតាមដានប្រវិត្តយោធារបស់ខ្លួន ទៅដល់ស្រុកកំណើត ដើម្បីឲ្យដឹងថាមនុស្សនោះមានប្រវត្តិស្អាតស្អំ ឬក៏អត់"]។ ឯកសារ D114/85 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.18-20 [អំពីការចាប់ខ្លួន គង់ គៀន ហៅ អ៊ី វ៉េត៖ "ខ្ញុំក៏ស្គាល់គាត់ដែរ ព្រោះគាត់ធ្លាប់បង្រៀនពួកខ្ញុំ និងនិយាយជាមួយពួកខ្ញុំ។ គ្រប់គ្នាបានដឹងពីការចាប់ខ្លួនរបស់គាត់ ព្រោះគាត់ជាមនុស្សលេចធ្លោម្នាក់ដែរ។ កាលនោះ គាត់រស់នៅព្រលានយន្តហោះកងកេងតែម្តង [...] ឆ.19៖ ប្រហែល១ខែក្រោយពីការចាប់ខ្លួនរបស់ ឌឹម និង ឆាន គឺគេចាប់ខ្លួនអ្នកដែលនៅក្រោមៗពួកគាត់ ហើយការចាប់ខ្លួនទាំងនេះក៏មិនត្រូវបានប្រកាសជាសាធារណៈដែរ។ សៈ តើការប្រកាសនោះ គឺធ្វើឡើងដោយ មាស មុត មែនទេ? ឆ.20៖ ត្រឹមត្រូវហើយ គឺគេប្រកាសធ្វើឡើងដោយ មាស មុត"]។

1264 ឯកសារ D54/93 កំណត់ហេតុស្តាប់ចម្លើយ យ៉ែម សំអុន ឆ.32 [កម្មាភិបាលកងពល១៦៤ ត្រូវគេបញ្ជូនទៅសៀងហៃ ក្នុងខែកក្កដា ឆ្នាំ១៩៧៦ ដើម្បីរៀនជួសជុល និងថែទាំនាវា បានពន្យល់ថា យោធាភូមិភាគបូព៌ាមកពីកងពល១៦៤ ដែលគេបញ្ជូនទៅសិក្សាការប្រើប្រាស់នាវានៅប្រទេសចិន ត្រូវបានបញ្ជូនត្រឡប់មកប្រទេសកម្ពុជាវិញ នៅក្នុងឆ្នាំ១៩៧៧ ឬឆ្នាំ១៩៧៨ "ពួកគេរៀនមិនទាន់ចប់ផង"]។

1265 ឯកសារ D54/44 កំណត់ហេតុស្តាប់ចម្លើយ លន់ សេង ឆ.6 ["មុនឆ្នាំ១៩៧៧ ខ្ញុំនៅកំពង់សោមនៅឡើយ ខ្ញុំដឹងថា យោធា១៥០០នាក់ មកពីភូមិភាគបូព៌ា ត្រូវបានដកកាំភ្លើង ហើយបញ្ជូនទៅដាក់នៅកងផលិតធំ នៅពុតទេ ដោយចាត់ទុកថាជាសមាសភាពមិនល្អ"]។ ឯកសារ D54/45 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.13 ["បន្ទាប់មក គេដកពួកយោធា [ភូមិភាគបូព៌ា] ទាំងអស់នេះបញ្ជូនទៅដាក់នៅកងផលិតធំ នៅពុតទេ [ជាប់បិតត្រាង]"]។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.15 ["នៅពេលនោះ គេចំរាញ់យកចេញតែពួកថ្នាក់ដឹកនាំដែលមកពីភូមិភាគបូព៌ាតែប៉ុណ្ណោះ។ ចំណែកពួកយោធាធម្មតា គេគ្រាន់តែដកកាំភ្លើង ហើយបញ្ជូនទៅវាយថ្ម"]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.10, ឆ.29 ["កាលនោះទាំងពួកបូព៌ា និងពួកនិរតីត្រូវបានប្រមូលទាំងអស់គ្នា ដោយគេឮថា ឌឹម ដែលជាមេពួកខ្ញុំក៏ត្រូវបានចាប់ខ្លួនដែរ ដោយគេចោទថាក្បត់។ ក្រោយពីគេចាប់ ឌឹម គេក៏ចាប់ផ្តើមចាប់អ្នកនៅក្រោមៗតទៀត។ នៅកងកេង គេឲ្យធ្វើស្រែដោយកាប់នឹងចប ពុំមែនប្រើគោក្របីភ្ជួររាស់នោះ

ច្រើននាក់បានស្លាប់ដោយសារតែលក្ខខណ្ឌពិបាក ឬការធ្វើទណ្ឌកម្ម និងការឃុំខ្លួន[1266]។ ស្ថានភាពអតីតកងទ័ពភូមិភាគបូព៌ានៃកងពល ១៦៤ កាន់តែអាក្រក់ ដោយសារភូមិភាគបូព៌ាត្រូវបានគេកំណត់ជាគោលដៅ។ ការបោសសម្អាតប្រជាជនស៊ីវិល និងអាជ្ញាធរយោធានៅភូមិភាគបូព៌ាបានចាប់ផ្តើមនៅឆ្នាំ ១៩៧៧ និងមានភាពខ្លាំងក្លា នៅខែ ឧសភា ឆ្នាំ ១៩៧៨ ពេល សោ ភឹម និងអ្នកក្រោមបង្គាប់របស់គាត់ត្រូវគេចោទថាជនក្បត់[1267]។ ទាហានកងពល ១៦៤ ស្ទើរតែទាំងអស់នៅ

---

ទេ។ មនុស្ស២៥នាក់ត្រូវបានចាត់តាំងឱ្យកាប់ (ជំនួសដោយក្របី) ដីស្រែ១ហិចតាក្នុង១ថ្ងៃឱ្យហើយ។ ដំបូងឡើយ គេទៅហៅយើង ដោយនិយាយថាអង្គការឱ្យហៅមករៀនសូត្រ ពេលយើងមកដល់ គេចាប់ផ្តើមឱ្យយើងធ្វើស្រែតែម្តង។ មានអ្នកខ្លះក៏បាត់ខ្លួននៅពេលនោះ គឺបាត់ខ្លួនមិនដែលឃើញត្រឡប់មកវិញទេ ហើយពួកខ្ញុំក៏មិនដែលហ៊ានសួរនាំ ឬក៏ឆ្ងល់អីដែរ។ កាលនោះ គឺមានតែកូនចៅដែលមានឋានៈតូចៗទេ ដែលនៅរស់ ចំណែកមេៗវិញ គឺបាត់ខ្លួនទាំងអស់ហើយមិនដែលឃើញត្រឡប់មកវិញទេ [...] ស៖ តើមានរឿងអ្វីកើតឡើងនៅក្នុងកងពល បន្ទាប់ពីការចាប់ខ្លួន ឌឹម? ឆ.29៖ ក្រោយពីដំណឹងហ្នឹងឮជាទូទៅ ពួកយើងពុំហ៊ានតវ៉ាអ្វីទេ។ គេឱ្យធ្វើអ្វី យើងធ្វើនោះ។ គេឱ្យនៅត្រង់ណា យើងនៅត្រង់នោះ។ ក្រោយពីព្រឹត្តិការណ៍នៃការចាប់ខ្លួននេះ អនុសេនាធំ និងអង្គភាពជាច្រើនត្រូវប្រមូលឱ្យមកធ្វើការនៅកងកេង។"]។ ឯកសារ D2/16 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី (សឿ ទូច) ឆ.21 ["ស៖ លោកធ្លាប់បានប្រាប់ពីរថ្ងៃមុនថា មិនមែនកម្លាំងបូព៌ាទាំងអស់ត្រូវបាត់ខ្លួនទាំងអស់គ្នាទេ ប៉ុន្តែមានកម្លាំងខ្លះត្រូវបានដកយកទៅធ្វើស្រែ តើពិតមែនឬទេ? ឆ.21៖ បាទ ពិតមែនហើយ ខ្ញុំដឹងថា កម្លាំងមួយចំនួនត្រូវបានដកយកទៅធ្វើស្រែនៅម្តុំព្រលានយន្តហោះកងកេង"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.2 ["ពួកអតីតយោធា ភូមិភាគបូព៌ា ក៏ត្រូវបានបញ្ជូនទៅក្នុងកងចល័តជាមួយខ្ញុំដែរ។ យោធាភូមិភាគបូព៌ាត្រូវបានគេចាត់ថា ជាពួកក្បត់"]។ ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.16។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.19 ["នៅពេលនោះ នៅក្នុងកងពល១៦៤ មានបីកងដែលគេចាត់ថា ជាកងសមាសភាពមិនល្អ។ ក្នុងចំណោមទាំងបីកងនេះ [...] កងវរៈសេនាតូច២១ ស្ថិតនៅបឋុស ខាងកើត។ កងនេះស្ថិតនៅក្រោមបញ្ជាការរបស់ តាខេង។ នៅក្នុងកងនេះ មានមនុស្សជាង២០០នាក់ ដែលសុទ្ធតែជាអតីតយោធាមកពីភូមិភាគបូព៌ា។ នៅពេលដែលមានអ្នកណាម្នាក់នៅក្នុងកងសមាសភាពមិនល្អទាំងនេះ ធ្វើខុស គេនឹងត្រូវបញ្ជូនទៅឃុំខ្លួននៅទឹកសាប។ ពេលគេនៅក្នុងមន្ទីរឃុំឃាំងទឹកសាប ពួកអ្នកទោសទាំងនេះ ត្រូវបានគេដាក់ឱ្យធ្វើការនៅត្រើយខាងកើតស្ទឹង។ ចំណែកពួកខ្ញុំ ដែលនៅក្នុងកងបីនេះ ត្រូវបានគេដាក់ឱ្យធ្វើការនៅត្រើយខាងលិចស្ទឹង"]។ ឯកសារ D54/33.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ី អុន (អ៊ឹង អុន) EN 01073812, KH 00964200-01 [ពន្យល់ថា យោធាបូព៌ាមួយចំនួនត្រូវគេលុតដំនៅក្នុងកងចល័ត ប្រហែលជានៅម្តុំព្រលានយន្តហោះកងកេង]។

1266 សូមមើល VIII.ង. ការដ្ឋានស្ទឹងហាវ។ VIII.ច. ការដ្ឋានរាម។

1267 សូមមើល ឧទាហរណ៍ ឯកសារ D22.1.34 កំណត់ហេតុស្តាប់ចម្លើយ មាស សឿន ERN KH 00418512។ ឯកសារ D98/3.1.58 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច EN 00160724។ ឯកសារ D1.3.33.9 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច EN 00178048។ ឯកសារ D4.1.520 កំណត់ហេតុស្តាប់ចម្លើយ កែ ពេជ្រវណ្ណៈ EN 00340569 ["ពួកគេបានបោសសម្អាត ... កម្មាភិបាល ព្រមទាំងមេបញ្ជាការនៅក្នុងភូមិភាគបូព៌ា

តំបន់កំពង់សោម ដែលមកពីភូមិភាគបូព៌ា ត្រូវបានចាប់ ឃុំខ្លួន និង/ឬសម្លាប់ជាចុងក្រោយក្រៅផ្លូវតុលាការ ឬបានបាត់ខ្លួននៅចន្លោះពីពាក់កណ្តាលឆ្នាំ ១៩៧៧ ទៅខែ មករា ឆ្នាំ ១៩៧៨[1268]។

---

ទាំងអស់”]។ ឯកសារ D114/297.1.40 ឡុង សាត ប្រតិចារឹកចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ 15.10.58។ ឯកសារD1.3.17.5, D6.1.1105 ប៊ិន ឃៀវនិន របបប៉ុល ពត EN 01150206-07។

1268 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ 14.21.14-14.26.40 [“តាឌឹម [...] ក្រោយមក គាត់បានចាប់ខ្លួន បាទ បាត់ខ្លួន។ ពេលដែលចាប់ខ្លួនទៅ កងទ័ព កងយោធាទាំងអស់ជាកងយុទ្ធភូមិភាគបូព៌ា ឃើញថា ឃើញចាប់ខ្លួនជាបន្តបន្ទាប់រហូតដល់អស់រលីងនៅកំពង់សោម កងភូមិភាគបូព៌ាអត់មាននៅសល់ទេ ក្រោយមកចាប់ទាំងអស់ ចាប់បាត់អស់។ ខ្ញុំក៏អត់ដែលឃើញអីទាំងអស់ មិនដឹងចាប់យកទៅណា ទៅណីទេ អត់ឃើញទេ [...] ក្រោយពីតាឌឹម គេចាប់ខ្លួនបាត់ហើយ ក្រោយមកចាប់យោធាៗ ដែលកងពលរបស់គាត់វរៈ មួយវរៈសេនាធំនោះ។ ដោយសារតែគេចាប់ តាឌឹម បាត់ទៅ គឺតាឌឹម នោះគឺគាត់មានចម្លើយយ៉ាងម៉េចទេ ឬដឹងចម្លើយយ៉ាងម៉េចអីយ៉ាងម៉េចទេ ហើយសាច់ទ័ពរបស់គាត់ដែលរស់នៅក្នុងកំពង់សោមនោះ សុទ្ធតែជាប់និន្នាការនយោបាយចម្លើយរបស់ តាឌឹម ទាំងអស់ ក្រោយមកបានគេចាប់ដកចេញទាំងអស់ ប៉ុនមិនដឹងដកចេញទៅកន្លែងណាទេ។ មិនមែនបញ្ជូនទៅភូមិភាគបូព៌ាវិញទេ [...] បាត់ទាំងអស់ បាត់អត់ដែលឃើញទេមួយវរៈសេនាធំហ្នឹង”], 14.26.40 [“យោធាទាំងអស់នុំង ឃើញថាជាប់និន្នាការនយោបាយរបស់គាត់ទាំងអស់ហើយ។ អ៊ីចឹងគេយកមេទៅហើយ អ៊ីចឹងគេសង្ស័យថាទ័ពទាំងអស់ដែលវរៈសេនាធំដែលគាត់មកពីភូមិភាគបូព៌ានោះ គេលែងទុកចិត្តហើយ គេដកចេញ មិនដឹងដកចេញទៅណាទេ”]។ ឯកសារ D59/2/3.14a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ប៉ាក សុខ EN 01185002, KH 00958291 [“ដល់គេចាប់ទៅ [ឌឹម] ខ្សែស្រឡាយដែលគាត់អោបទុកហ្នឹងយកមកមួយកងពលទៅ។ ស៖ យកទៅណា? ឆ៖ យកមកសម្លាប់ កន្លែងហ្នឹងចំណោតរាម រើចោលហើយយកអាត្រាក់មកឈូស”]។ សំណៅបកប្រែមួយទៀតនៃកិច្ចសម្ភាសន៍ដូចគ្នានេះ (ដោយមានការកែតម្រូវពីប៉ាក សុខ) អាចស្វែងរកបាន៖ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ប៉ាក សុខ EN 00978580, KH 00955513 [“ដល់ហើយចាប់គាត់ទៅ ខ្សែស្រឡាយដែលគាត់អោបទុកហ្នឹងយកមកមួយកងពលទៅ [មកពីភូមិភាគបូព៌ា]។ ស៖ យកទៅណា? ឆ៖ យកមកសម្លាប់ កន្លែងហ្នឹងឡើងចំណោតរាម រើចោលហើយយកអាត្រាក់មកឈូស”]។ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.10, 33, 35 [“មេរបស់យើង ឌឹម ក៏ត្រូវបានគេចាប់ខ្លួនពីបទក្បត់ផងដែរ។ ក្រោយគេចាប់ខ្លួន ឌឹម គេបន្តចាប់ខ្លួនថ្នាក់ក្រោម។ នៅកងកេង គេឲ្យយើងធ្វើស្រែជាមួយនឹងចប [...] ដំបូងគេហៅយើង ដោយហេតុផលថា អង្គការ ហៅទៅរៀនសូត្រ។ ពេលយើងទៅដល់ គេឲ្យយើងចាប់ផ្តើមធ្វើស្រែសនៅទីនោះ។ ប្រជាជនខ្លះក៏បានបាត់ខ្លួនផងដែរ នៅពេលនោះ -- ពួកគេបានបាត់ខ្លួន និងមិនដែលឃើញត្រឡប់មកវិញទេ -- ហើយគ្មាននរណាម្នាក់ហ៊ានសួរ ឬ្លល់អ្វីនោះទេ។ នៅពេលនោះ មានតែថ្នាក់ក្រោម កូនចៅទេ ដែលនៅរស់៖ ថ្នាក់ដឹកនាំទាំងអស់បានបាត់ខ្លួន និងមិនដែលឃើញត្រឡប់មកវិញនោះទេ [...] ឆ.33៖ ឌឹម មកពីភូមិភាគបូព៌ាជាមួយយោធាមួយកងពល មកចូលរួមជាមួយនឹងកងពល១៦៤។ បន្ទាប់ពីការចាប់ខ្លួន ឌឹម ទៅ យោធាភូមិភាគបូព៌ាទាំងនោះត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ដែរ។ នៅពេលនោះ យោធាភូមិភាគបូព៌ាម្នាក់ [...] ជ្រៀន បានបាត់ខ្លួនតែម្តង។ ខ្ញុំគិតថា យោធារបស់ភូមិភាគបូព៌ាដែលត្រូវបានចាប់ខ្លួនទាំងនោះ ប្រហែលជាត្រូវបានគេសម្លាប់ចោលនៅកន្លែងសម្លាប់នោះ

ដែរហើយ [ចំណោទរាម] ប៉ុន្តែខ្ញុំមិនច្បាស់ទេ។ ប្រហែល១ខែក្រោយមក មេបញ្ជាការវរៈសេនាតូចរបស់ខ្ញុំ បានបើកវគ្គអប់រំរៀនសូត្រនយោបាយ ដែលនៅក្នុងនោះគាត់ប្រកាសថា ឌីម, កុយ ធួន ហៅ ធុច ហើយនិងថ្នាក់ដឹកនាំមួយចំនួនទៀត គឺសុទ្ធតែជា កា.ហ្ស.បេ និងសេ.អ៊ី.អា របស់យួន ហើយសុទ្ធតែជាពួកក្បត់ [...] ឆ.35៖ ខ្ញុំដឹងអំពីការបោសសម្អាតភូមិភាគបូព៌ាម្តង [...] គេបានប្រកាសថាមួយកងវរៈសេនាតូចមានយោធា៥០នាក់ ក៏មិនមានបញ្ហាអ្វីដែរ ដរាបយោធាទាំងនោះជាយោធាល្អ។ យោងទៅតាមការចងចាំរបស់ខ្ញុំ ការបោសសម្អាតយោធាភូមិភាគបូព៌ាចាប់ផ្តើមក្នុងឆ្នាំ៧៦ មុនគេបញ្ជូលខ្ញុំទៅកងវរសេនាធំ១៤០ មុនឆ្នាំ១៩៧៧ [...] នៅក្នុងពេលនោះ គេចាប់មេដឹកនាំមុន រួចហើយទើបគេចាប់យោធាតាមក្រោយ"]។ ឯកសារ D54/33.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ី ធុន (អ៊ីង ធុន) EN 01073811, KH 00964200 [អំពីយោធាភូមិភាគបូព៌ាចំនួន៧០០នាក់៖ "រត់ទៅវិញរួចខ្លះ ហើយគេចាប់មកវិញយកទៅលុតដំ [...] ចុងបញ្ចប់ ពួកមកពីបូព៌ាហ្នឹងដកចេញទាំងអស់អត់មានឱ្យនៅទេ"], EN 01073818, KH 00964206 ["ស៖ ហើយចុះពូ តាឌីម ហើយកូនចៅគាត់៧០០នាក់ជាងហ្នឹង នៅឆ្នាំណាដែលខ្ចាតខ្ចាយគេដកទៅវិញហើយ គេយកទៅលុតដំហ្នឹង? [...] មកបានយូរទេ? ឆ៖ មកបានយូរដែរហ្នឹង ហើយអ្នកខ្លះរត់គេចាប់មកវិញ ខ្ញុំមិនច្បាស់ទេ តែភាគច្រើនគេវៃចោលហើយ។ ស៖ វៃចោល? ឆ៖ បាទ" (បញ្ជាក់បន្ថែម)]។ ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.16, 23, 38 [យោធាកងពល១៦៤ ភូមិភាគបូព៌ា ដែលនៅរស់៖ "ក្រោយមកទៀត គឺគេចាប់សង្ស័យថា ភូមិភាគបូព៌ាថាខ្មាំងទាំងអស់ [...] ចូលឆ្នាំ១៩៧៧ យកយើងមកកាប់ព្រៃគុបជិតស្ទឹងហាវ។ ហ្នឹងមានគ្នាច្រើនណាស់ រាប់រយនាក់ [...] ដល់ពេលរួចពីហ្នឹងមក ចំនួនប្រហែលជាពីរបីខែ វាក៏ដកពួកខ្ញុំហ្នឹងថាឡើងទៅរៀន [...]ពួកវាលោតចុះមកក្រោមព័ទ្ធជុំវិញពួកខ្ញុំ ហើយភ្ជង់ចាប់ពួកខ្ញុំ [...] ដាក់គុក ព្រឹកឡើងវាបញ្ចេញម្នាក់ម្តងៗ វៃសួរចម្លើយ។ វៃសួរចម្លើយហើយ ពេលព្រឹកវាដាក់ច្រវាក់ឱ្យធ្វើការ [...] ឆ.23៖ គេបានសង្ស័យពួកខ្ញុំទាំងអស់ ថាពួកបូព៌ាហ្នឹងសុទ្ធតែខ្មាំង [...] ឆ.38៖ សេង និង [...] ឈី។ ពួកគេរត់ តែគេចាប់ដាក់គុកវិញ ហើយគេវៃដល់ស្លាប់"]។ ឯកសារ D114/209 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង សេង ឆ.46, 52 ["គឺគ្រាន់តែដឹងថា អង្គការ ហៅទៅប្រជុំ ឬក៏ទៅរៀនសូត្រ គឺទៅបាត់រហូតហើយ [...] ឆ.52៖ ខ្លបខ្លាច ដោយឃើញបាត់ សម័យនោះតឹងរ៉ឹង។ ទាំងអស់នេះហើយដែលធ្វើឱ្យខ្ញុំខ្លបខ្លាច"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.19 ["កងវរៈសេនាតូច២១ ស្ថិតនៅបបុស ខាងកើត។ កងនេះស្ថិតនៅក្រោមបញ្ជាការរបស់ តាខេង។ នៅក្នុងកងនេះ មានមនុស្សជាង២០០នាក់ ដែលសុទ្ធតែជាអតីតយោធាមកពីភូមិភាគបូព៌ា។ នៅពេលដែលមានអ្នកណាម្នាក់ នៅក្នុងកងសមាសភាពមិនល្អទាំងនេះ ធ្វើខុស គេនឹងត្រូវបញ្ជូនទៅឃុំខ្លួននៅទឹកសាប។ ពេលគេនៅក្នុងមន្ទីរឃុំឃាំងទឹកសាប ពួកអ្នកទោសទាំងនេះ ត្រូវបានគេដាក់ឱ្យធ្វើការនៅត្រើយខាងកើតស្ទឹង។ ចំណែកពួកខ្ញុំ ដែលនៅក្នុងកងបីនេះ ត្រូវបានគេដាក់ឱ្យធ្វើការនៅត្រើយខាងលិចស្ទឹង"]។ ឯកសារ D2/16 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី (សឿ ទូច) ឆ.21 ["ស៖ លោកធ្លាប់បានប្រាប់ពីរថ្ងៃមុនថា មិនមែនកម្លាំងបូព៌ាទាំងអស់ត្រូវបាត់ខ្លួនទាំងអស់គ្នាទេ ប៉ុន្តែមានកម្លាំងខ្លះត្រូវបានដកយកទៅធ្វើស្រែ តើពិតមែនឬទេ? ឆ.21៖ បាទ ពិតមែនហើយ ខ្ញុំដឹងថា កម្លាំងមួយចំនួនត្រូវបានដកយកទៅធ្វើស្រែនៅម្តុំព្រលានយន្តហោះកងកេង"]។ ក្នុងចំណោមយោធាដែលកម្រនៅមានជីវិត រួមមាន សន ជួន (កំណត់ហេតុស្តាប់ចម្លើយ ឯកសារ D114/219 និង D114/220) និងយោធាម្នាក់ដែលសាក្សី ប៉ាក សុខ បានចាំឈ្មោះ ឈាន ត្រូវគេបង្ខំឱ្យទៅធ្វើការនៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង និងបានរត់រួចមានជីវិតពីស្ថានភាពយ៉ាងលំបាក និងការសម្លាប់អតីតយោធាភូមិភាគបូព៌ា នៅទីនោះ៖ សូមមើល ឯកសារ D234/2.1.92 ប៉ាក សុខ ប្រតិ

ដូចដែលសាក្សី

ឌុល សុង រៀបរាប់សង្ខេប "ការបោសសម្អាតគឺត្រូវបានធ្វើឡើងយ៉ាងខ្លាំង"[1269]។

*ក) ទំនាក់ទំនងផ្សេងទៀតជាមួយបរទេស*

361. **មាស មុត** បានបញ្ជាក់នៅក្នុងកិច្ចសម្ភាសន៍កាលពីខែ តុលា ឆ្នាំ ២០១១ ថា "ប្រសិនបើលោកប្រឆាំងខ្ញុំ ប្រាកដណាស់ខ្ញុំមិនទុកលោកទេ [...] មានមនុស្សជាច្រើនដែលមានគំនិតប្រឆាំងរបបខ្មែរក្រហម ដូចជាអាមេរិក និងវៀតណាម។ ហេតុដូច្នេះ មានភ្នាក់ងាររបស់ពួកគេជាច្រើនបានបង្កប់ខ្លួន ហើយធ្វើឲ្យរបបនោះរង្គោះរង្គើ"[1270]។ តាមពិតទៅ គោលនយោបាយរបស់កងពល ១៦៤ គឺធ្វើការបោសសម្អាតទាហានណាដែលជាប់ពាក់ព័ន្ធជាមួយនឹងបរទេស ឬត្រូវបានចោទថាបានបម្រើផលប្រយោជន៍បរទេស (វៀតណាម សហភាពសាធារណរដ្ឋសង្គមនិយមសូវៀត ថៃ ឬសហរដ្ឋអាមេរិក)[1271]។ ដូចពន្យល់នៅខាងលើ នេះជាករណីនៃទាហានដែលបានត្រឡប់ទៅកំពង់

---

ចាវឹកចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ 10.36.51-10.39.08។ សូមមើលផងដែរ ឯកសារ D54/96 កំណត់ហេតុស្តាប់ចម្លើយ តេង សារឹម ឆ.19 [ពន្យល់ថា ខ្លួនគាត់ផ្ទាល់មិនដឹងថា អតីតកងវរសេនាធំ១៥២ មានអ្នកណាម្នាក់នៅរស់ហើយបានត្រឡប់មកពីកំពង់សោមវិញទេ។ ប៉ុន្តែគាត់ឮពីអតីតអភិបាលស្រុកអូររាំងឪ ថាមានមនុស្សពីរនាក់នៅរស់ឈ្មោះ សារឿន និងយ៉ាត]។

1269 ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.12-13, 15, 18 ["នៅពេលនោះ គេចាប់ពួកមកពីបូព៌ាដែលនៅតាមកងនានាដែលនៅក្នុងកងពល [...] ឆ.13៖ គេយក ខឹម និងពួកបូព៌ាផងទៃទៀតទៅ [...] សៈ តើលោកនៅចាំទេថាឆ្នាំណាដែលគេចាប់ពួកបូព៌ា? ឆ.15៖ [...] ប្រហែលជាក្នុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨។ ការចាប់ពួកបូព៌ាធ្វើឡើងក្នុងពេលជាមួយគ្នានឹងការកើតមានទំនាស់រវាងពួកបូព៌ា និងកងទ័ពវៀតណាមនៅតាមព្រំដែន។ [...] សៈ នៅក្នុងកងវរៈសេនាធំ១៤០ របស់លោក តើមានពួកបូព៌ាប៉ុន្មាននាក់ត្រូវបានដកចេញ និងប៉ុន្មាននាក់ត្រូវបានចាប់ខ្លួន? ឆ.18៖ ខ្ញុំមិនដឹងពីចំនួនទាំងអស់ទេ។ ការបោសសម្អាត គឺត្រូវបានធ្វើឡើងយ៉ាងខ្លាំង។ មិនមែនតែមេបញ្ជាការមកពីបូព៌ាទេ ដែលត្រូវបានចាប់ខ្លួន សូម្បីតែយោធាដទៃទៀតក្នុងកងពលក៏ត្រូវបានគេដក ឬចាប់ខ្លួន"]។

1270 ឯកសារ D114/307.6 ចម្លើយរបស់ មាស មុត ជាមួយវិទ្យុវីអូអេ ជនសង្ស័យរបស់តុលាការយល់ឃើញថា តួនាទីរបស់តុលាការ "មានកម្រិត" នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១១ ERN KH 01380591 ["Sun Tzu និយាយថាសុខចិត្តក្បត់មនុស្សទាំងអស់ តែកុំឲ្យមនុស្សទាំងអស់ក្បត់យើង។ ប្រសិនបើលោកប្រឆាំងខ្ញុំ ប្រាកដណាស់ខ្ញុំមិនទុកលោកទេ [...] មានមនុស្សជាច្រើន ដែលមានគំនិតប្រឆាំងរបបខ្មែរក្រហម ដូចជាអាមេរិក និងវៀតណាម។ ហេតុដូច្នេះមានភ្នាក់ងាររបស់ពួកគេជាច្រើនបានបង្កប់ខ្លួន ហើយធ្វើឲ្យរបបនោះរង្គោះរង្គើ ដូចពាក្យស្លោក "ដុតឲ្យខ្លោច" និង "រោលឲ្យឆៅ""]។

1271 ឯកសារ D1.3.34.60 ទូរលេខ ០០ ពី មាស មុត ផ្ញើជូនគណៈ៨៧០ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ EN 00184995, KH 00001325 ["យើងខ្ញុំបានទទួលមតិណែនាំ និងសេចក្តីថ្លែងការរបស់បក្ស ស្តីពីការឈ្លានពានរបស់យួនមកលេប

ទឹកដីមាតុភូមិកម្ពុជារបស់យើង។ យើងខ្ញុំ [...] ២. ប្តេជ្ញាកសាងកម្លាំង ជាឧបករណ៍ការពារបក្ស ការពាររដ្ឋអំណាច កម្មករ កសិករ សម្ហូហភាព នឹងការពារមាតុភូមិកម្ពុជា សង្គមនិយមដាច់ខាត។ ដោយបោសសម្អាត គ្មានស្មាក់ស្មើរ សមាសបង្កប់របស់ខ្មាំង ជាយួននឹងខ្មាំង ដទៃទៀត" (គូសបញ្ជាក់បន្ថែម)]។ ឯក នី មានមតិយោបល់លើ ខ្លឹមសារនៃទូរលេខនេះ៖ ឯកសារ D114/284 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.4-6 [គូសបញ្ជាក់បន្ថែម] ["ស៖ សារទូរលេខដែល តាមុត ផ្ញើទៅអង្គការលើ ឯកសារជាភាសាអង់គ្លេស ERN 00184995 និងជាភាសាខ្មែរ ERN 00001325 សារទូរលេខគឺពាក់ព័ន្ធនឹងប្រធានបទពួកយួនហ្នឹង។ តើរបៀបដែលគេបញ្ចូលមនោគមន៍វិជ្ជារបស់យើងហ្នឹង គេធ្វើដូចម្តេច ដល់ទាហានថ្នាក់ក្រោមៗហ្នឹង? ឆ.4៖ វាត្រូវដូចខ្ញុំនិយាយមែនហើយ វាត្រូវៗ។ ដាច់ខាតអ៊ីចឹង មិនខុសពីក្នុងហ្នឹងទេ។ បោសសម្អាតផ្ទៃក្នុងផង និងកម្ចាត់ផង គឺដាច់ ខាត។ ស៖ ចង់ឲ្យលោកពន្យល់ ដែលគេនិយាយបោសសម្អាតឬកម្មេច [...] ឆ.5៖ អ្នកដែលមានការពាក់ព័ន្ធជាខ្មែរ កងទ័ព គេនិយាយ "បោសសម្អាត" ក្នុងកងទ័ព ដែលខ្សែរយៈជាយួន ប៉ុន្តែមិនថាខ្សែណាៗទេ។ បោសសម្អាតផ្ទៃក្នុង គឺក្នុងកងទ័ព។ ស៖ ពាក្យសម្តីដែលលោកបានមើល ពាក្យសម្តីដែលគេនិយាយនៅក្នុងសារទូរលេខហ្នឹង ដូចពាក្យសម្តីដែលគេបង្រៀនយើង កាលប្រជុំទេ? ឆ.6៖ ដូច ដូចទាំងស្រុងតែម្តង"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ.57 ["បោសសម្អាតផ្ទៃក្នុង គឺជាការសម្រិតសម្រាងផ្ទៃក្នុង ដែលមានន័យថាអ្នកដែលត្រូវបានរកឃើញថាជាប់ពាក់ព័ន្ធនឹងនយោបាយបរទេស ឬបម្រើផលប្រយោជន៍បរទេស នឹងត្រូវបានបោសសម្អាតក្នុងគោលបំណងធ្វើឲ្យផ្ទៃក្នុងបក្សស្អាតស្អំ។ ពាក្យថា "ស្អាតស្អំ" នេះមានន័យថាពួកគេត្រូវដកចេញ ឬសម្លាប់"]។ នៅពេលដែល សុន សេន បានកោះហៅប្រធានកងពលទាំងអស់៖ ឯកសារ D1.3.27.26 កំណត់ហេតុប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៧៧ EN 00933841, KH 00052308-09, FR 00323927 [សុន សេន៖ "កម្លាំងក្បត់នៅប្រទេសយើង សុទ្ធតែជាប់នឹងខ្មាំងខាងក្រៅ។ ប្រុងប្រយ័ត្នបដិវត្តន៍ មានន័យថា វាយសំរុកខ្មាំងស៊ីរូង" (គូសបញ្ជាក់បន្ថែម)]។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.4-5 ["ស៖ ហេតុអ្វីបានជា តាមុត បើកកិច្ចប្រជុំឡើងនៅពេលនោះ? ឆ.4៖ វាមិនមែនជាការប្រជុំជាប្រចាំទេ។ នៅឆ្នាំ១៩៧៧ ស្ថានការណ៍នៅពេលនោះមានការច្របូកច្របល់បក្សកុម្មុយនីស្តកម្ពុជាគាំទ្រដោយចិន ហើយបក្សពលករគាំទ្រដោយវៀតណាម មានពួក សេ.អ៊ី.អា អាមេរិកកាំង និង កា.ហ្សេ.បេ នៅក្នុងជាមួយប្រជាជនដែរ។ ដូច្នេះគេត្រូវសម្រិតសម្រាំងពួកសមាសភាពទាំងនោះចេញ។ ស៖ តើនេះជាគំនិតរបស់លោកផ្ទាល់ ឬក៏គេប្រាប់លោក? ឆ.5៖ តាមុត បានប្រកាសនៅក្នុងអង្គប្រជុំ។ រឿងនេះត្រូវបានប៉ះពាល់ដល់ខ្ញុំដែរ ពីព្រោះខ្ញុំជាមនុស្សនៅតំបន់៣៧"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.11 ["ស៖ តើឃ្លាដែលថា កសាងកម្លាំង មានន័យដូចម្តេចចំពោះការទទួលខុសត្រូវរបស់ មាស មុត ក្នុងនាមជាមេបញ្ជាការកងពល? ឆ.11៖ តាមការយល់របស់ខ្ញុំ គឺធ្វើការវិសុទ្ធកម្មកម្លាំង ដើម្បីឲ្យយោធាម្នាក់ៗស្អាតស្អំ មិនពាកព័ន្ធសមាសភាពមិនល្អ ហើយនិង CIA ឬ KGB"]។ ឯកសារ D114/58 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ កេត ឆ.26 ["នៅក្នុងវគ្គសិក្សា តើមាស មុត ឬវាគ្មិនដទៃទៀតបាននិយាយអំពីស្ថានភាពខ្មាំង ទាំងខ្មាំងផ្ទៃក្នុង ទាំងខ្មាំងខាងក្រៅដែរ ឬទេ? ឆ.26៖ បាទ ប៉ុន្តែខ្ញុំមិនចាំទេ ហើយខ្ញុំក៏មិនយល់រឿងទាំងអស់នេះដែរ។ ពួកគេនិយាយអំពី កា.ហ្សេ.បេ វៀតណាម និងភ្នាក់ងារជាដើម"]។

សោមវិញ ពេលកងទ័ពវៀតណាមបានដោះលែង បន្ទាប់ពីឃុំខ្លួនជាច្រើនខែនៅលើកោះត្រល់[1272]។ ការសង្ស័យថាមានទំនាក់ទំនងជាមួយបរទេស ជាពិសេស ប្រទេសវៀតណាម ក៏ដើរតួចម្បងក្នុងការបោសសម្អាតអតីតយោធាភូមិភាគបូព៌ា និងកងវរសេនាតូច ៣៨៦ នៅក្នុងកងពល ១៦៤ ផងដែរ[1273]។ ស្រដៀងគ្នានេះដែរ ទាហានដែលសមាជិកគ្រួសារមានទំនាក់ទំនងជាមួយរបប លន់ នល់

---

1272 សូមមើល VIII.ក.៣.a) យោធាកងពល៣ ដែលត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅប្រទេសវៀតណាម នៅឆ្នាំ១៩៧៥ ជើងទំព័រ១១៨០-១១៨៤។

1273 សូមមើល ឧទាហរណ៍ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.33 ["ឌឹម មកពីភូមិភាគបូព៌ាជាមួយយោធាមួយកងពល មកចូលរួមជាមួយនឹងកងពល១៦៤។ បន្ទាប់ពីការចាប់ខ្លួន ឌឹម ទៅ យោធាភូមិភាគបូព៌ាទាំងនោះត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ដែរ។ [...]មេបញ្ជាការវរៈសេនាតូចរបស់ខ្ញុំ បានបើកវគ្គអប់រំរៀនសូត្រនយោបាយ ដែលនៅក្នុងនោះគាត់ប្រកាសថា ឌឹម, កុយ ធួន ហៅ ធុច ហើយនិងថ្នាក់ដឹកនាំមួយចំនួនទៀត គឺសុទ្ធតែជា កា.ហ្ស.បេ និងសេ.អ៊ី.អា របស់យួន ហើយសុទ្ធតែជាពួកក្បត់"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.10 ["ថ្ងៃមួយ មុនពេលកងរបស់ខ្ញុំត្រូវបានដកអាវុធ និងក្រោយពេល ឌឹម បាត់ខ្លួន ខ្ញុំបានឮសួរពីយោធាក្នុងកងជាមួយគ្នា និយាយថា ឌឹម និងឆាន ត្រូវបានបញ្ជូនទៅកាន់ម៉ាស៊ីនបូមទឹកនៅជើងឯក។ នៅពេលនោះយើងជឿថារឿងហ្នឹងជារឿងពិត។ ប៉ុន្តែក្រោយមកនៅពេលដែល តាមុត ប្រកាសនៅក្នុងអង្គប្រជុំអំពីចម្លើយសារភាពរបស់ពួកក្បត់ និងខ្សែរយៈសេ.អ៊ី.អា និង កា.ហ្សេ.បេ ហើយបន្ទាប់ពីបាត់ខ្លួនពួកនោះ ទើបយើងដឹងថា ពួកគេទាំងនោះត្រូវបានចាប់ខ្លួនហើយ។ រហូតដល់ក្រោយឆ្នាំ១៩៧៩ ទើបយើងដឹងថា ស-២១ និងបឹងជើងឯក គឺជាគុក និងកន្លែងសម្លាប់មនុស្ស"]។ ឯកសារ D54/103 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.8 ["នៅពេលនោះ អ្នកដែលចូលរួមប្រជុំទាំងអស់មានប្រហែល៥០០នាក់ ដែលរួមទាំងអតីតយោធាកង៨៦ (៣៨៦) ប្រហែលជាង១០០នាក់ ដែលគេដកកាំភ្លើងរួច [...] តាមុត បាននិយាយនៅក្នុងអង្គប្រជុំនោះថា ទាំងអស់គ្នាត្រូវតែតាមដានពួកអតីតយោធាកង៨៦នេះ។ គាត់បាននិយាយថា ពួកអតីតយោធាកង៨៦ សុទ្ធតែខ្សែ កា.ហ្សេ.បេ និងសេ.អ៊ី.អា។ គាត់ថា ខ្សែកា.ហ្សេ.បេ និងសេ.អ៊ី.អា នេះមិនទាន់បានកម្ទេចបានទាំងស្រុងនៅឡើយទេ។ ពួកនេះ គឺនៅលាក់ខ្លួនក្នុងជួរយើង ដូច្នេះយើងត្រូវតែតាមដានពួកនេះឲ្យជាប់"]។ ឯកសារ D54/76 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ឹក ឆ.19 ["ស៖ តើពួកកងខាងណាជាអ្នកមកធ្វើការបោសសម្អាត និងដកកាំភ្លើងពីពួកយោធាតំបន់៣៧ និងពួកយោធាភូមិភាគបូព៌ា? ឆ.19៖ ពួកមេៗមកពីថ្នាក់លើ គេមកប្រជុំជាមួយយើងក្នុងតំបន់៣៧ ហើយប្រាប់យើងថា ពួកយើងជាប់ពាក់ព័ន្ធជាមួយការចាត់តាំងរបស់វៀតណាម។ នៅក្នុងតំបន់របស់យើងនៅពេលនោះ របបហូបចុកគឺលំបាកណាស់ ហើយយើងហូបតែបបរ"]។ ឯកសារ D114/120 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ អ៊ីត ឆ.28។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.4-5។

ជារឿយៗ ត្រូវគេចាត់ទុកថាជាភ្នាក់ងារ សេអ៊ីអា[1274]។ ក្រៅពីក្រុមទាហានទាំងនោះ ទាហានផ្សេងទៀតនៅតែត្រូវបានចោទថាមានជាប់និន្នាការនោះដដែល។

362. **មាស មុត** បានគាំទ្រ និងចាត់វិធានការ ដើម្បីអនុវត្តគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យក្នុងការកម្ទេចខ្មាំងផ្ទៃក្នុងដែលចូលដៃជាមួយរបបបរទេស។ គោលនយោបាយនេះមានបង្ហាញនៅក្នុងការបោះពុម្ពផ្សាយប្រចាំខែរបស់ ប.ក.ក *ទង់បដិវត្តន៍* ដែលត្រូវបានចែកចាយទៅដល់គ្រប់សមាជិក ប.ក.ក ទាំងអស់[1275]។ ឧទាហរណ៍ ទង់បដិវត្តន៍ចេញផ្សាយនៅខែ មេសា ឆ្នាំ ១៩៧៧ បញ្ជាក់យ៉ាងច្បាស់លាស់ពីគោលជំហររបស់ ប.ក.ក សម្រាប់ឆ្នាំនោះ និងឆ្នាំបន្តបន្ទាប់៖

> ឯចំពោះខ្មាំងជាភ្នាក់ងារ "សអអរ" "កសប" និងភ្នាក់ងារ "យ" [...] យើងត្រូវបន្តវាយវាតទៅទៀត ជាន់កវាថែមទៀត ក្នុងឋានៈយើងមានប្រៀបដាច់ខាត វាយសម្រុកវាជាប់ជានិច្ច ក្នុង ១ ឆ្នាំ ១៩៧៧ នេះ ឲ្យវាកាន់តែខ្ទេចខ្ទីតទៅទៀត ងើបក្បាលមិនរួច។ ធ្វើយ៉ាងនេះ យើងរឹតតែបង្កើនលក្ខណៈសម្បត្តិឲ្យយើងទៅវាយខ្មាំង ឆ្នាំ ១៩៧៨ និងឆ្នាំតៗទៅទៀត កាន់តែខ្លាំង និងកាន់តែបានជ័យជម្នះធំៗថែមទៀត[1276]។

---

1274 សូមមើល ឧទាហរណ៍ ឯកសារ D4.1.480 កំណត់ហេតុស្តាប់ចម្លើយ ឌី យ៉េត ហៅ ពេជ្រ ERN KH 00212087 ["ក្នុងរវាងឆ្នាំ ១៩៧៥-១៩៧៦ និងបន្តមកទៀត មានការចោទប្រកាន់មនុស្សថាជាអតីតមន្ត្រីរបបលន់ នល់ ឬភ្នាក់ងារ សេ.អ៊ី.អា ដែលនេះជាប្រភេទកំហុសធ្ងន់"]។

1275 ឧទាហរណ៍ ឯកសារ D4.1.653 ទង់បដិវត្ត ខែមិថុនា ឆ្នាំ១៩៧៧ EN 00446862, KH 00062809, FR 00487724 ["យើងវាយសំរុកខ្មាំងបោសសម្អាតខ្មាំងតទៅទៀត។ វាយខ្មាំង បោសសម្អាតខ្មាំងជាភ្នាក់ងារអន្តរជាតិ ខ្មាំងជាខ្មាំងបង្កប់ ខ្មាំងជាខ្មាំងវណ្ណៈ មិនឲ្យត្រដេវត្រដរ ធ្វើសកម្មភាព សូម្បីតែបន្តិចបានឡើយ" (គូសបញ្ជាក់បន្ថែម)]។ ឯកសារ D4.1.883 ទង់បដិវត្ត ខែមេសា ឆ្នាំ១៩៧៦ EN 00517853, KH 00062747, FR 00499716 ["សំណល់ចក្រពត្តិ នៅក្នុងប្រទេសយើងត្រូវបញ្ចេញទាំងអស់ គ្មានទុកឲ្យសេសសល់អំពល់រវល់យើងទេ"]។ ឯកសារ D234/2.1.33 សេចក្តីថ្លែងការណ៍របស់ ខៀវ សំផន នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៨ EN S 00010563 KH 00249990, FR 00280380 [ខៀវ សំផន អំពាវនាវឲ្យកម្មាភិបាល "កម្ទេចឲ្យអស់ [...] ភ្នាក់ងារ សេ.អ៊ី.អា"]។

1276 ឯកសារ D4.1.862 ទង់បដិវត្ត ខែមេសា ឆ្នាំ១៩៧៧ EN 00478496, KH 00062986, FR 00499754។ សូមមើលផងដែរ EN 00478502 KH 00062993, FR 00499759 ["បញ្ហាមួយដែលត្រូវយកចិត្តទុកដាក់សំខាន់ណាស់ដែរ គឺវែកមុខពួក "សេ.អ៊ី.អា" និងភ្នាក់ងាររបស់វា "កា.ហ្សេ.បេ" [...]យួន' និងឆ្កែបំរើរបស់វា [...] ឲ្យស្អាតជាស្អាតរ"]។

363. ដូចដែលបានរៀបរាប់នៅក្នុង *VIII.ឆ ប្រល័យពូជសាសន៍វៀតណាម* ខាងក្រោម **មាស មុត** និងអ្នកក្រោមបង្គាប់ជិតស្និទ្ធរបស់គាត់ បានពន្យល់ក្នុងពេលប្រជុំកងពល ១៦៤ ថា វៀតណាមជាសត្រូវស្នូរពូជ ("សត្រូវទី១") រីឯសត្រូវផ្ទៃក្នុងជា "សត្រូវទី២"។ អ្នកណាដែលគាំទ្រ "យួន" ឬបដិសេធមិនសម្លាប់យួនតាមបញ្ជា ត្រូវតែកម្ទេច[1277]។

364. ទាហានកងពល ១៦៤ ដែលត្រូវគេចោទថាជាគិញ ឬមានទំនាក់ទំនងជាមួយ កាហ្សេបេ សេអ៊ីអា ឬវៀតណាម ត្រូវបាននាំចេញទៅ និងបាត់ខ្លួន ឬត្រូវបាននាំទៅមន្ទីរសន្តិសុខ (វត្តឥន្ទញ្ញាណ ទឹកសាប ឬ ស-២១) ឬទៅគុកតូចៗ នៅស្ទឹងហាវ ដែលនៅទីនោះ ពួកគេត្រូវគេធ្វើបាប និងធ្វើ

---

[1277] ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត ឆ.115-116, 119 ["នេះគឺជាផ្នែកនៃគោលនយោបាយដែលខ្ញុំបានប្រាប់នៅខាងលើ សត្រូវទី១ គឺយួន និងសត្រូវទី២ គឺខ្មាំងផ្ទៃក្នុង។ ស៖ លោកបានចូលរួមនៅក្នុងអង្គប្រជុំ ដែលណែនាំឲ្យអនុវត្តគោលនយោបាយសំខាន់ៗ ដែលនៅក្នុងការណែនាំមួយគឺការបោសសម្អាតខ្មាំង និងខ្មាំងយួន។ តើមានបញ្ហាអ្វីដែរ ឬទេ បើកម្មាភិបាលណាមួយមិនអនុវត្តតាមការណែនាំបែបនោះ? ឆ.116៖ បន្ទាប់ពីការប្រជុំផ្សព្វផ្សាយអំពីគោលនយោបាយជាសាធារណៈ និងបានមើលឯកសារហ្នឹងទាំងអស់ហើយ កម្មាភិបាលគ្រប់រូបខិតខំធ្វើទៅតាមការគិតរបស់ខ្លួនឯង ខំធ្វើការឲ្យអស់ពីសមត្ថភាព [...] បើយើងមិនធ្វើតាម អង្គការនឹងយកទៅរៀនសូត្រ និង [...] ឆ. 119៖ មិនមានអ្នកណាម្នាក់ត្រឡប់មកវិញទេ អ្នកទាំងនោះបាត់ខ្លួនរហូត"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.30-33 ["តើលោក ហើយនិងអ្នកនៅក្នុងអង្គភាពជាមួយលោក អាចនឹងបដិសេធមិនធ្វើតាមបញ្ជាសម្លាប់ [ ជនជាតិវៀតណាមនៅលើទូក] បើលោកយល់ថាការសម្លាប់នោះមិនសមហេតុផល? ឆ.30៖ ទេ ដាច់ខាតយើងមិនអាចប្រកែកនឹងបញ្ជាបានទេ។ បើដូច្នេះទេ គេនឹងសម្លាប់យើង។ ស៖ តាមយោបល់ និងគំនិតរបស់លោក ថាតើវាខុស ឬត្រូវ ចំពោះការសម្លាប់អ្នកដែលចាប់បាន? ឆ.31៖ ខ្ញុំគិតថា វាខុសទាំងស្រុង ពីព្រោះប្រជាជនទាំងអស់នោះមិនដឹងអ្វីទាំងអស់ ពួកគេគឺគ្រាន់តែរត់គេចពីសង្គ្រាម ដើម្បីរស់រានមានជីវិតតែប៉ុណ្ណោះ។ ប៉ុន្តែនៅពេលនោះ ខ្មែរក្រហមគិតថា ពួកយួន ជាសត្រូវស្នូពូជ [...] យួនត្រូវបានចាត់ទុកថាជាសត្រូវស្នូពូជ និងសត្រូវលេខ១"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ 10.54.39-10.58.13 ["ជនជាតិវៀតណាម គឺសត្រូវស្នូរពូជជាមួយ ប៉ុល ពត។ មិនអាច ទោះបីអ្នកឯងយោធា មិនយោធាក៏ដោយ ឲ្យតែមានអាវុធតបត គឺបាញ់ពន្លិចចោលតែម្តង"]។ 13.31.54-13.37.54 ["ក្រោយពីឆ្នាំ១៩៧៦ បាទ គឺបើជាវគ្គសាលាសិក្សា ដើម្បីប្រកាស បាទប្រកាសពេញសិទ្ធិ សត្រូវស្នូពូជ គឺវា យួន [...] គណៈបញ្ជាការរបស់ខ្លួន ទាំងសិទ្ធិជាវរៈសេនាតូច ប្រធាននៃវរៈសេនាតូចទទួលផែនការពីលើទៅ [...] នៅក្នុងពេលនុំងឃើញថា ដោយបានសិក្សានូវសត្រូវស្នូពូជរបស់គេបង្ហាត់បង្រៀននូវភាសាខ្លះ ហើយក៏យោធាទាំងអស់ក៏គ្មានអ្នកណាមួយមានពាក្យអ្វីចេញដែរ ហើយអនុវត្តទៅតាមគោលការណ៍ [...] សត្រូវស្នូពូជហ្នឹងគឺថា សម្លាប់អត់មានទុក សូម្បីតែកូនង៉ែតមួយក៏អត់ឲ្យមានដែរ ព្រោះជាសត្រូវស្នូពូជគឺសម្លាប់ចោលតែម្តង"]។ ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹកចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ 14.12.44,14.42.03-14.44.35 ["ជាគោលដៅនៃច្បាប់របស់បដិវត្តន៍កម្ពុជាប្រជាធិបតេយ្យ គឺថាគ្មានទេ គឺវៀតណាមសត្រូវស្នូពូជហើយ អត់មានថាចាប់ហើយ លែងទៅវិញទេ បើលែង អត់មានលែងទេ"]។

ទារុណកម្ម[1278]។ សមាជិកគ្រួសារ និងអ្នកស្គាល់គ្នាជិតស្និទ្ធរបស់ពួកគេ ជារឿយៗ ក៏ត្រូវបានចាប់ខ្លួនដូចគ្នាដែរ[1279]។

---

1278 ឧទាហរណ៍ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.30-32, 35, 40 [អតីតមេបញ្ជាការកងវរសេនាតូច៦១២ កងពល១៦៤៖ "បញ្ហាដែលគេដកខ្ញុំចេញពីអង្គភាព មកពីគេពិនិត្យឃើញថាខ្ញុំជា សេ.អ៊ី.អា, កា.ហ្សេ.បេ។ ក្រោយពីគេយកមកអង្គភាព៦១២ មក គេតាមដានពិនិត្យខ្ញុំ គឺពេលដែលខ្ញុំចុះធ្វើការងារប្រគល់ការងារឱ្យខ្ញុំធ្វើ គេពិនិត្យឃើញថា ក្នុងអង្គភាពរបស់ខ្ញុំមានបាក់ដែកស្បែង រទេះដាច់ហ្វ៊ីត គេចោទខ្ញុំថាបានបំផ្លិចបំផ្លាញ [...] ឆ.31៖ អ្នកដែលមកចាប់ខ្ញុំ គឺវរៈសេនាធំ ឈ្មោះមឿន និងឡុន [...] ឆ.32៖ ពេលនោះគ្រាន់តែគេប្រជុំអង្គុយបើកសៀវភៅចុះឡើងៗហើយ យោធានោះក៏ចាប់ខ្ញុំតែម្តង។ ពេលនោះខ្ញុំមិនបានយកអង្គរក្សខ្ញុំទៅជាមួយទេ [...] គេភ្ជង់ខ្ញុំឱ្យលើកដៃឡើង ហើយចងដៃខ្ញុំទាំងពីរ បន្ទាប់មកគេនាំខ្ញុំពីស្ទឹងហាវ យកទៅដាក់នៅគុកស្ទឹងហាវ ហើយគេសួរចម្លើយ [...] ឆ. 35៖ គេដាក់ច្រវាក់ដៃខ្ញុំទៅក្រោយ និងដាក់ច្រវាក់ជើងខ្ញុំទាំងពីរ។ ពេលព្រឹកឡើងគេចាប់ផ្តើមសួរចម្លើយ ទី១ ថាអ្នកឯងជាសេ.អ៊ី.អា, កា.ហ្សេ.បេ របស់អ្នកណា? ហើយពាក់ស័ក្តិប៉ុន្មាន? ខ្ញុំឆ្លើយថា ខ្ញុំអត់ដឹងរឿងទេ ព្រោះខ្ញុំអត់ដឹងរឿងមែន។ ក្រោយមកគេចាប់ផ្តើមធ្វើទារុណកម្ម [...] រំពាត់តូចៗ វាយខ្ញុំ។ គេវាយខ្ញុំរហូតដល់រំពាត់គរគ្នានៅកន្លែងសួរចម្លើយ។ គេវាយឱ្យខ្ញុំឆ្លើយថាស័ក្តិប៉ុន្មាន ហើយជាក្រុមណា។ ពេលព្រឹកខ្ញុំសន្លប់ពីរដង ពេលថ្ងៃសន្លប់មួយដង។ មួយថ្ងៃខ្ញុំសន្លប់បីដង។ វិធីធ្វើទារុណកម្ម ទី១ វាយនឹងរំពាត់, ទី២ វាយនឹងកន្ទុយត្រីបបែល និងទី៣ វែនក់ខ្សែភ្លើង (ហៅវ៉ាណាកូរវើបញ្ចេញភ្លើងឆក់មនុស្ស)។ បើកន្ទុយត្រីបបែល គេកាត់យកកន្ទុយហាលឱ្យស្ងួត ហើយវារួញតូចដូចខ្សែតីដែរ [...] ឆ.40៖ គុកទាំងពីរនេះស្ថិតនៅក្នុងកងពល១៦៤។ ព្រោះគុកទឹកសាបជាគុកបន្ថយទោស។ គេបន្ថយទោសនៅទឹកសាប"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ.64 ["ស៖ តើលោកអាចប្រាប់ឈ្មោះអ្នកដែលលោកស្គាល់ ហើយគេនាំយកទៅនោះបានដែរទេ? ឆ.64៖ មានឈ្មោះ ង៉ែត, ឈ្មោះ ឌឹម, ឈ្មោះ យ៉ាន, ឈ្មោះ ឆាន និងឈ្មោះ សុខ ជាដើម ដែលគេចោទថាជាគិញវៀតណាម ឬក៏ សេ.អ៊ី.អា"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.91 ["ស៖ ហេតុអ្វីគេលែងទុកចិត្តលោក? ឆ.91៖ ព្រោះគេថាខ្ញុំធ្លាប់ទៅធ្វើការជាមួយវៀតណាម ហើយខ្ញុំទទួលបានការបំពាក់ស្មារតីពីវៀតណាម ហើយឥឡូវនេះ ខ្ញុំជាសមាជិកក្រុម កា.ហ្សេ.បេ ឬក្រុមយកការសម្ងាត់ផ្សេងទៀត"]។ សូមមើលផងដែរ ផ្នែក VIII.ក.៣. ប្រភេទសមាសភាពអាក្រក់ និងសមាសភាពខ្សែនៅក្នុងកងពល១៦៤ ដែលត្រូវកម្ទេស – ខ្សែតំបន់៣៧ (អតីតកងវរៈសេនាតូច ៣៨៦) នៅក្រោម ហ៊ីង ជ័យ ហៅ ឆានសមាជិកគណៈកងពល១៦៤។ ផ្នែក VIII.ក.៣. ប្រភេទសមាសភាពអាក្រក់ និងសមាសភាពខ្សែនៅក្នុងកងពល១៦៤ ដែលត្រូវកម្ទេស- ខ្សែភូមិភាគបូព៌ា (តំបន់២២) នៅក្រោម ហ៊ឹង ឌឿន ហៅ ឌឹម មេបញ្ជាការរងកងពល១៦៤។ និងផ្នែក VIII.ឃ. មន្ទីរសន្តិសុខ ស-២១។

1279 ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.3 ["" ដូចជាឧទាហរណ៍ ប្រធានកងវរៈសេនាធំក្តី បើគាត់ត្រូវគេចាប់ខ្លួន គ្រួសារប្រពន្ធគាត់ក៏ត្រូវចាប់ខ្លួនដែរ។ ប៉ុន្តែខ្ញុំមិនដឹងថា គេយកគាត់ទៅធ្វើអ្វីទេក្រោយគឺការចាប់ខ្លួន។ នៅក្នុងពេលនោះ ជាទូទៅបន្ទាប់ពីគេចាប់ខ្លួននរណាម្នាក់ហើយ អ្នកនោះបាត់ខ្លួនរហូត។ បើយោធាណាត្រូវគេចាប់ខ្លួន យោធានោះត្រូវបាត់ខ្លួន រហូត។ ដូចដែលខ្ញុំបានជំរាប បើសិនជាមេបញ្ជាការវរៈសេនាធំណាត្រូវបានចាប់ខ្លួនដោយចោទប្រកាន់ថា ថាជា កា.ហ្សេ.បេ ឬសេ.អ៊ី.អា ប្រពន្ធកូនគាត់ និរសារ និងអ្នកជិតដិតក៏ត្រូវចាប់ខ្លួនដែរ។ ជាពិសេស

365. ការសួរចម្លើយទាហានកងពល ១៦៤ នៅកំពង់សោម គឺដើម្បីបញ្ជាក់ថា អ្នកដែលត្រូវបានចាប់ខ្លួនទាំងនោះ ពិតជាភ្នាក់ងារ សេអ៊ីអា កាហ្សេបេ និង "យួន" ឬដើម្បីកំណត់អត្តសញ្ញាណអ្នកផ្សេងទៀត[1280]។ ការស្វែងរកភ្នាក់ងារទាំងនោះ ទាំងនៅក្នុងកងពលមជ្ឈិមទាំងអស់នៃកងទ័ពបដិវត្តកម្ពុជា

---

ពួកអ្នកដែលត្រូវបានចោទថា ជាប់ទាក់ទងនឹងខ្សែយួន"]។ វាច្បាស់ជាដោយសារថា គាត់ដឹងថា គាត់នឹងត្រូវគេចាប់ខ្លួន-ទើប ប្រពន្ធរបស់ រ៉ែម បានសម្រេចចិត្តរំលូតកូនចោល ដើម្បីបង្ហាញភាពស្មោះត្រង់ចំពោះបក្សកុម្មុយនីស្តកម្ពុជា៖ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.3 ["សម្លាប់ រ៉ែម នេះកើតឡើងក្រោយពីការប្រជុំនេះ [ជាមួយ មាស មុត]។ បន្ទាប់ពី រ៉ែម ត្រូវបានសម្លាប់ ប្រពន្ធរស់គាត់ដែលមានផ្ទៃពោះ បានរំលូតកូនចោល ពីព្រោះនាងចង់បង្ហាញថា នាងជាអ្នកបដិវត្តន៍ច្បាស់លាស់ ដោយមិនចង់ឱ្យជាប់ឈាមជាមួយគាត់"]។ កំណត់ត្រា ស-២១ បានបង្ហាញជាឧទាហរណ៍ ហែម អាន ហៅ ស៊ីន ប្រពន្ធរបស់ សុខ ប្រធានពេទ្យកងពល១៦៤ ត្រូវបានចាប់ខ្លួន ក្រោយការចាប់ខ្លួនរបស់គាត់ និងមានការបញ្ជាក់ច្បាស់លាស់ថា គាត់ជា "ប្រពន្ធរបស់ អាសុខ" ដែលគេចាត់ទុកថាជា "គិញវៀតណាម ឬសេ.អ៊ី.អា"៖ ឯកសារ D114/230.1.1 បញ្ជីអ្នកទោស ស-២១ លេខរៀង ៧៣៨៣ [នារីពេទ្យ ហែម អាន ហៅស៊ីន កំណត់អត្តសញ្ញាណថា ជាប្រពន្ធរបស់សុខ – ចូលនៅថ្ងៃទី២៦ ឬ២៨ ខែមេសា ឆ្នាំ១៩៧៧ សម្លាប់នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៨], លេខរៀង ១៣១៣៧ [ស៊ឹម នាម ហៅសុខ ប្រធានពេទ្យកងពល១៦៤ សម្លាប់នៅថ្ងៃទី ០៤ ខែឧសភា ឆ្នាំ១៩៧៧]។ ឯកសារ D9.3 បញ្ជីអ្នកទោស ស-២១ មកពីកងពល១៦៤ រៀបរៀងដោយ ក.ស.ច.ស លេខរៀង ១០។ ឯកសារ D1.3.28.19 បញ្ជីសួរចម្លើយរបស់ ស-២១ ERN KH 00161777[ចូល ១ -ហែម អាង ហៅ ស៊ីន នយោបាយកងធំ ពេទ្យកងពល ប្រពន្ធអាសុខ។ ចូលថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៧៣]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.64 ["មានឈ្មោះ ង៉ែត, ឈ្មោះ ឌឹម, ឈ្មោះ យ៉ាន, ឈ្មោះ ឆាន និងឈ្មោះ សុខ ជាដើម ដែលគេចោទថាជាគិញវៀតណាម ឬក៏ សេ.អ៊ី.អា"]។ ឯកសារ D114/155 កំណត់ហេតុស្តាប់ចម្លើយ សុខ រ៉េន ឆ.61 [ទាំងពេទ្យសុខ និងប្រពន្ធរបស់គាត់ស្លាប់]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ. 2។

[1280] ឯកសារ D114/25 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដាវ ឆ.25-26 [យោធាកងពល១៦៤ ត្រូវបានចាប់ខ្លួន បន្ទាប់មកត្រូវសួរចម្លើយ ដោយធ្វើទារុណកម្មនៅលើនាវា នៅក្បែរកោះស្តេច មុននឹងបញ្ជូនទៅលត់ដំនៅកោះកុង៖ "មុនដំបូង គេឱ្យធ្វើប្រវត្តិរូប បន្ទាប់មកគេថាខ្ញុំចូល សេ.អ៊ី.អា ពីពេលណាខែណាឆ្នាំណា ជាមួយអ្នកណា គេបានព្រមានខ្ញុំឱ្យនិយាយតែការពិត បើពុំដូច្នោះទេ បក្សយើងនឹងសម្លាប់អ្នកឯងចោល។ បន្ទាប់ពីសំណួរទី១, ទី២ ដល់សំណួរទី៣ គេបានយកកាំភ្លើងមកភ្ជង់ត្រង់ត្រចៀករបស់ខ្ញុំ ហើយព្រមានខ្ញុំថា បើខ្ញុំមិនឆ្លើយការពិត គេនឹងបាញ់ទម្លាក់ខ្ញុំឱ្យត្រីស៊ី។ ខ្ញុំនៅតែព្យាយាមឆ្លើយប្រាប់គេថា ខ្ញុំមិនមែនជា សេ.អ៊ី.អា ទេ ខ្ញុំបំរើ និងស្មោះត្រង់ជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជាជានិច្ច។ ស៖ បន្ទាប់ពីគេធ្វើទារុណកម្មសួរចម្លើយហើយ តើគេយកលោកទៅណាទៀត? ឆ.26៖ បន្ទាប់ពីសួរចម្លើយ និងធ្វើទារុណកម្មខ្ញុំរួច ពួកអ្នកសួរចម្លើយទាំងនោះបានទៅប្រជុំគ្នា [...] ពេលនោះ គេបានដោះខ្នោះដៃចេញពីអ្នកទាំង៣នោះ ហើយក៏បានដោះខ្នោះដៃខ្ញុំដែរ រួចហើយគេបានប្រាប់ខ្ញុំថា "ត្រូវសន្យាដាក់លក្ខខណ្ឌ បើអង្គការ ឬបក្សដោះលែងមិត្តឯង មិត្តឯងមិនត្រូវនិយាយអំពីទារុណកម្មឆក់ខ្សែភ្លើងអីនោះទេ"។ បន្ទាប់មក គេបានបញ្ជូនខ្ញុំឱ្យទៅកោះកុង ទៅធ្វើការនៅរោងជាងដែក [...] កន្លែងនោះជាកន្លែងដែលខ្ញុំត្រូវលត់ដំ អប់រំ និងកសាង"]។ ឯកសារ D114/208

និងបណ្តាញរបស់ពួកគេ ជាគោលបំណងរបស់ ស-២១ និងជាគំនិតជិតដាមរបស់ថ្នាក់ដឹកនាំ ប.ក.ក និងកងទ័ពបដិវត្តកម្ពុជា[1281]។

កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.35។ សូមមើលផងដែរ ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៦ EN 00940350-51, KH 00052411, FR 00334980 ["សមមិត្ត មុត៖ សុំចាប់អារម្មណ៍ពីសកម្មភាពពួកក្បត់ក្នុងបក្ស [...] គោលជំហរវិភាគចំពោះខ្មាំង ដូចជាចក្រពត្តិអាមេរិក និងពួកសេរីនិយមរបស់បក្ស ដែលមានផែនការវាយបដិវត្តន៍យើង [...] សមាសភាពមិនល្អ ឬខ្មាំង នៅតែពួនបន្លំ បង្កប់នៅក្នុងជួរបានទៀត"]។

1281 ឯកសារ D1.3.27.20 កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ EN ERN 00940344, KH ERN 00052407, FR ERN 00334976 [សុន សេន (បង៨៩) បានពន្យល់ថា ចក្រី យ៉ា ឈូក និង កែវ មាស គឺជាជនក្បត់ឲ្យវៀតណាម ហើយពួកគេត្រូវបានកម្ទេច ដោយលើកឡើងថា៖ "រឿងសំខាន់គឺស្ថិតនៅត្រង់ថា កងទ័ពរបស់យើងត្រូវតែបរិសុទ្ធនិងស្អាតស្អំ"]។ ឯកសារ D1.3.33.12 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH ERN 00187665 ["ប៉ុល ពត [...] បញ្ជាក់ថា កុយ ធួន និង យ៉ា ជាភ្នាក់ងារ សេ.អ៊ី.អា ស្របតាមសេចក្តីសារភាពចេញពី ស-២១"]។ ឯកសារ D1.3.33.5 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH ERN 00146573-00146574 ["មនុស្សទាំងឡាយត្រូវបានចាប់ខ្លួនដោយយោងលើចម្លើយសារភាពរបស់អ្នកដទៃដែលលចោទមកលើពួកគេ។ ការចោទប្រកាន់ដែលធ្ងន់ធ្ងរគឺ ជាសមាជិក CIA។ [...] កង ចាប ត្រូវបានគេចោទថាជាសមាជិក CIA។ [...] ពាក្យ CIA, KGB [...] ជាពាក្យដែលស្នើឡើងដោយអ្នកសួរចម្លើយ។ ពាក្យនេះ កើតចេញពីការជួបប្រជុំពីរដងជាមួយ សុន សេន"]។ ឯកសារ D114/165 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ខន ឆ.10 ["គេមានចំណុចដែលត្រូវសួរ ឧទាហរណ៍គេមានទាក់ទងជាមួយ សេ.អ៊ី.អា កា.ហ្សេ.បេ ឬយួន។ យើងត្រូវសួររកខ្សែ"]។ ឯកសារ កំណត់ហេតុស្តាប់ចម្លើយ បាន សៀក KH ERN 00348797 ["ការប្រជុំគឺ សុន សេន ជាអ្នកដឹកនាំ ដោយគាត់អង្គុយលើតុម្នាក់ឯង ហើយយើងទាំងអស់គ្នាអង្គុយនៅក្រោម។ នៅពេលប្រជុំ គឺគេនិយាយអំពី CIA ជាឆ្អែបម្រើរបស់អាមេរិក ហើយ KGB ជាឆ្អែបម្រើរបស់យួន។ នៅពេលប្រជុំមានការសរសេរពាក្យស្លោកដាក់តាមជញ្ជាំងថា "កម្ទេចឲ្យអស់ពួក CIA និង KGB"]។ ឯកសារ D1.3.17.6 សៀវភៅរៀបរៀងដោយ Stephen Heder និង Brian D. Tittemore បេក្ខជនចំនួនប្រាំពីរនាក់ដែលត្រូវកាត់ទោស KH ERN 00742607-00742608 ["ហេតុនេះ ចម្លើយសារភាពត្រូវបានគេសរសេរឡើងវិញ ទៅតាមការណែនាំរបស់អ្នកសួរចម្លើយ ដើម្បីបង្ហាញពីបរាជ័យក្នុងការអនុវត្តនយោបាយសេដ្ឋកិច្ច យោធា និងគោលនយោបាយដទៃទៀត ដែលកើតចេញពីផែនការប្រឆាំងនឹង ប.ក.ក ដែលដឹកនាំដោយទីភ្នាក់ងារសម្ងាត់បរទេស។ ជាងនេះទៀត ចម្លើយសារភាពត្រូវបានបង្កើតឡើង ដើម្បីបង្ហាញថា គោលនយោបាយរបស់ ប.ក.ក មិនបានសម្រេចទៅតាមទិសដៅទេ ដោយសាររចនាសម្ព័ន្ធដែលមេដឹកនាំ ប.ក.ក បានបង្កើតឡើងដើម្បីអនុវត្តគោលនយោបាយទាំងនេះត្រូវបានជ្រៀតចូលដោយពួកភ្នាក់ងារ សេ.អ៊ី.អា កា.ហ្សេ.បេ វៀតណាម និងអ្នកដទៃទៀតដែលជាប់សង្ស័យថាជាខ្មាំង"]។

### *ខ) កំហុសធ្ងន់ និងស្រាល*

366. កម្មាភិបាល និងទាហានកងពល ១៦៤ ត្រូវគេចាប់ ឃុំខ្លួន ឬសម្លាប់ ដោយគ្មានការកាត់ក្តីក្នុងតុលាការ ប្រសិនបើពួកគេត្រូវបានសង្ស័យថាបានប្រព្រឹត្តកំហុស ឬបទល្មើសមួយ ឬនៅតែប្រព្រឹត្តកំហុស ឬបទល្មើសដដែលៗ រួមមាន មិនគោរពវិន័យយោធា លួច ធ្វើវិច្ឆេទកម្ម ខ្ជិល ប្រឆាំងនឹង ប.ក.ក ឬប្រកាន់ជំហរប្រឆាំងបដិវត្តន៍[1282]។ អ្នកដែលប្រព្រឹត្តកំហុសតូចតាច ត្រូវបាននាំទៅលត់ដំ និងកសាងនៅការដ្ឋាន ដូចជា នៅរាម បិតត្រាង កងកេង ឬស្ទឹងហាវ[1283]។ ទាហានដែលត្រូវបាន

[1282] សូមមើល ឧទាហរណ៍ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.35 ["ខ្ញុំដឹងអំពីការបោសសម្អាតយោធាភូមិភាគបូព៌ាម្តង និងម្តងទៀតនៅចុងឆ្នាំ១៩៧៦ នៅពេលដែលគេចង់សម្រាញ់យកយោធាដែលល្អ ហើយនិងបោសសម្អាតយោធាដែលនិយាយប៉ះពាល់ដល់អង្គការ និងយោធាខ្ជិល។ គេបានប្រកាសថា មួយកងវរសេនាតូចមានយោធា ៥០ នាក់ក៏មិនមានបញ្ហាអ្វីដែរ ដរាបយោធាទាំងនោះជាយោធាល្អ"]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.16-17 ["ក្នុងនាមជាមេបញ្ជាការកងពលទ័ពជើងទឹក មាស មុត [...] ធ្វើការសម្រិតសម្រាំងប្រវត្តិរូបរបស់យោធាជើងទឹក, សម្រេចចាប់ចង និងសម្លាប់អ្នកណាដែលធ្វើខុស។ [...] ឆ.17៖ [...] នៅក្នុងពេលនោះបើនរណាធ្វើខុសហើយត្រូវគេចាប់ខ្លួន គេមិនមានតុលាការសម្រាប់កាត់ក្តីទេ"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.2-3 ["អ្នកធ្វើខុស គឺសំដៅទៅលើ យោធាក្នុងកងពលដែលបានប្រព្រឹត្តខុស"]។

[1283] ឯកសារ D114/25 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដាវ ហៅ សឿន ឆ.20៖ ["កន្លែងវ៉ៃថ្មនៅស្ទឹងហាវនោះ គឺគេយកពួកយោធាដែលធ្វើខុស [...] ឲ្យទៅវាយថ្ម ដើម្បីធ្វើទំនប់ផែបាំងរលកសមុទ្រ។ ហើយខ្ញុំក៏ឮពីកន្លែងផ្សេងទៀតដែលជាកន្លែងដែលយោធាដែលធ្វើខុស [...] ទៅសម្លាប់នៅអូរត្រាវ"]។ ឯកសារ D114/126 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គឹម ឆ.22៖ ["ស៖ ពេលលោកឈរជើងនៅលើកោះតាង តើលោកសម្គាល់ឃើញគេយកមនុស្សទៅ ដោយសារធ្វើខុស ឬក៏មានប្រវត្តិរូបមិនល្អដែរឬទេ? ឆ.22៖ អំឡុងពេលខ្ញុំនៅលើកោះតាងនោះ ខ្ញុំឃើញមានករណីមួយប៉ុណ្ណោះ ដូចជាអ្នកលួចខោអាវគ្នាឯង អ្នកនោះត្រូវបានបញ្ជូនទៅកំពង់សោម [...] គាត់ឈ្មោះ គឿន [...] ខ្ញុំមិនដែលឃើញគាត់ក្រោយមកទេ"]។ ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ិន សុត ឆ.72 ["ពេលនោះគេធ្វើជីវទស្សន៍ ពេលដែលមានបាត់កាំភ្លើងអី ក៏គេដកយកទៅទីនោះដែរ ឲ្យតែមានការធ្វើឲ្យខូចទ្រព្យសម្បត្តិអី បើកឡានឆេះឡានគេ គឺគេចាប់ទៅហើយ កំពុងវ៉ៃៗ ហើយរត់ក៏គេដកយកទៅដែរ មនុស្សទាំងនោះគឺគេដកចេញពីយោធា ហើយបញ្ជូនទៅធ្វើការ"]។ ឯកសារ D54/35 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.17 ["ខ្ញុំត្រូវបានគេបញ្ជូនទៅ កងពលចល័តនៅដើមឆ្នាំ ១៩៧៦។ ក្នុងឆ្នាំ ១៩៧៧ តែខ្ញុំមិនចាំថ្ងៃទេ កងចល័តរបស់ខ្ញុំត្រូវបានដកចេញពីព្រែកចាកមកនៅតំបន់កងកេងដែលគេឲ្យពួកយើងធ្វើការនៅភូមិប្របុស និងភូមិពូធឿង នៅខាងជើងផ្លូវជាតិលេខ៤ ទល់មុខភូមិបិតត្រាំង។ យើងនៅទីនោះដាំស្រូវ និងកសាងទំនប់នៅទីនោះរហូតដល់ចុងឆ្នាំ ១៩៧៧ នៅពេលនោះ គេបានប្រាប់យើងថា ពួកយើងនឹងត្រូវគេបញ្ជូនទៅស្ទឹងហាវ មិនទៅទឹកសាបទេ ដោយសារពួកយើងមានទោសស្រាល។ នៅដើមឆ្នាំ ១៩៧៨ ខ្ញុំត្រូវបានគេបញ្ជូនទៅស្ទឹងហាវ នៅទីនោះ ខ្ញុំត្រូវគេឲ្យជីករណ្តៅមូលមានអង្កត់ផ្ចិត ៣០ ម៉ែត្រ ជម្រៅ ១០ ម៉ែត្រនៅលើភ្នំផ្នែក

ចោទថាបានប្រព្រឹត្តខុសសីលធម៌ ឬ "កំហុស" ធ្ងន់ ឬស្រាលផ្សេងទៀត ត្រូវគេនាំយកទៅឃុំខ្លួនតាមទំនើងចិត្ត នៅមន្ទីរសន្តិសុខ ដូចជា នៅវត្តឥន្ទញ្ញាណ ឬទឹកសាប[1284] ដែលល្បីថាជាកន្លែង

---

ខាងក្រោមភ្នំដែលមានផ្ទះភ្ញៀវចិននៅពីខាងលើ។ ភ្ញៀវចិនមកពិនិត្យស្រះនេះមួយអាទិត្យម្តង ខ្ញុំក៏ត្រូវបានគេប្រើឱ្យបំបែកថ្មផងដែរ ខ្ញុំនៅស្ទឹងហាវរហូតដល់វៀតណាមចូលមក" (គូសបញ្ជាក់បន្ថែម)]។

1284 ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី EN ERN 01070548-01070549,KH ERN 00964126 [ជាប់និន្នាការនយោបាយទាក់ទិនហ្នឹងអ្នកចាត់ចែង ឬនិន្នាការខាងសីលធម៌អីហ្នឹង ហើយសីលធម៌ហ្នឹងវាមានកម្រិតទៀត បើអ្នក ឧទាហរណ៍ថាខុសទាំងសងខាង ឧទាហរណ៍ថា ខាងស្រីក៏ស្រឡាញ់ខ្ញុំ ហើយខ្ញុំក៏ស្រឡាញ់ខាងស្រី មិនអ៊ីចឹង! ដោយមានការប្រាស្រ័យទាក់ទងគ្នា បើអ៊ីចឹងអាហ្នឹងហើយគេឱ្យទៅកន្លែងផ្សេង ឧទាហរណ៍ថា គេឱ្យទៅកន្លែងធ្វើស្រែឱ្យទៅធ្វើស្រែណា ប៉ុន្តែ ម៉្យាងទៀត អ្នកដែលមានបញ្ហាដូចជា ខាងស្រីគេមិនស្រឡាញ់យើង ហើយយើងស្រឡាញ់គេម្ខាង អាហ្នឹងគេហៅទៅជាលក្ខណៈបំពាន បើអ៊ីចឹងគេយកទៅដាក់ទៅវត្តឥន្ទញ្ញាណ ឧទាហរណ៍មានបញ្ហាដូចជាហូបមិនគ្រប់គ្រាន់អ៊ីចឹង ធ្វើការលើសលប់ ដល់ពេលអ៊ីចឹងមានការប៉ះពាល់ ឧទាហរណ៍មិនអីធំដុំទេ ឧទាហរណ៍ថាបេះដូងបេះអី ហូបធម្មតាម្តងម្កាលហ្នឹង ដល់ក្រោយពេលរបៀបដូចថាមុខមាត់អ៊ីចឹងទៅ ចេះរាយការណ៍បំភ្លើសអ៊ីចឹងទៅក៏ចូលវត្តឥន្ទញ្ញាណដែរ"]។ ឯកសារ D54/20 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.12 ["ខ្ញុំបាននៅឯកោះឆ្លាយ ប៉ុន្តែបានឮពីគេថា កាលណាគេចាប់មនុស្ស ឬមានអ្នកបាត់ខ្លួន គេយកអ្នកទាំងនោះទៅដាក់នៅគុកទឹកសាបនោះ ដែលជាគុកថ្នាក់តំបន់ដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ មាស មុត"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.139 ["ក្នុងករណីដែលបុគ្គលណាមួយមានកំហុស ហើយបន្ទាប់ពីណែនាំ៣ដង បុគ្គលនោះនៅតែមិនកែប្រែ គេចាត់ទុកបុគ្គលនោះប្រព្រឹត្តកំហុសធ្ងន់ ហើយត្រូវបញ្ជូនទៅទឹកសាប។"]។ ឯកសារ D123/1/2.11a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង រ៉េត EN ERN 00974121, KH ERN 00926573-00926574 [សុន្ទរកថានៅទឹកសាប៖ "ផ្លាស់ប្តូរកន្លែងយើងមិនស្អាប់ទៀតអាហ្នឹងគេមានវិធានការចាត់តាំងចូលកន្លែងអប់រំអី។ [...] សៈ ចឹងកន្លែងកងពលមានកន្លែងអប់រំដែរ? ឆៈ មានដែរ។"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.22 ["ចំពោះអ្នកដែលចាត់ទុកថាមានទោសធ្ងន់ គេបញ្ជូនទៅទឹកសាប ចំពោះអ្នកដែលចាត់ទុកថាមានទោសស្រាល គេបញ្ជូនទៅស្ទឹងហាវដើម្បីលត់ដំ"]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.14 ["ប្រសិនបើអ្នកណាម្នាក់ធ្វើខុស គេនឹងយកអ្នកនោះ ទៅកន្លែងផ្សេង ដែលខ្ញុំមិនដឹង ប្រហែលជាទៅទឹកសាប។ បើទៅហើយ គឺកម្រត្រឡប់មកវិញណាស់។ ដូចខ្ញុំប្រាប់លោករួចហើយគឺថា គេយកមនុស្សបីនាក់ពីកន្លែងខ្ញុំទៅ ហើយក្រោយរបបខ្មែរក្រហមដួលរលំ ខ្ញុំបានជួបតែម្នាក់ទេ ដែលនៅរស់។ បើសិនជាមិនទាន់បែក គាត់នោះច្បាស់ជាមិនរស់ទេ"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.15 ["យើងខ្លាចកន្លែងនេះណាស់ ពីព្រោះមេៗរបស់យើងតែងនិយាយព្រមានយើង ប្រយ័ត្នខ្លួន កុំធ្វើខុសក្រែងគេបញ្ជូនយកទៅវត្តឥន្ទញ្ញាន"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.31 ["ខ្ញុំឮថាមានគុកមួយឈ្មោះថា ទឹកសាប ហើយអ្នកដែលប្រព្រឹត្តខុស គេយកទៅអប់រំនៅទីនោះ"]។ ឯកសារ D54/27 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.9 ["នៅនឹងទឹកសាប យោធារបស់កងពល ១៦៤ ដែលមានកំហុសតិចតួចត្រូវបានឃុំខ្លួននៅទីនោះ។ ឧទាហរណ៍ ដូចជាពួកយោធាដែលទិតៀនគោលនយោបាយនៃរបបនោះ"]។ ឯកសារ D114/40 កំណត់ហេតុ

ដែលការរស់នៅដូចសត្វធាតុ បង្ខំឱ្យអ្នកទោសធ្វើការ ដាក់ទារុណកម្មអ្នកមានកំហុសធ្ងន់[1285] និងមានការសម្លាប់នៅទីតាំងក្បែរៗនោះ[1286]។ ទាហានកងពល ១៦៤ ដែលត្រូវបានកំណត់ថាជា

---

ស្តាប់ចម្លើយ មូល ឈិន ឆ.2 ["ដំបូងគឺខ្ញុំជាប់ឃុំនៅទឹកសាបរយៈពេល៣ថ្ងៃ។ នៅពេលនោះ គេដាក់ច្រវាក់ជើងខ្ញុំម្ខាងជាប់នឹងសសរមួយ តែគេពុំចងដៃទេ ហើយគេពុំវាយខ្ញុំទេ ក្នុងពេលសួរចម្លើយ។ ចំពោះអ្នកទោសផ្សេងទៀត ដែលគេចាត់ទុកថាជាអ្នកទោសធ្ងន់ គឺគេចងស្លាបសេក និងជើងម្ខាងដាក់ច្រវាក់ជាប់នឹងសសរ។ ក្រោយមកទៀត គេបញ្ជូនខ្ញុំពីទឹកសាបមកឃុំនៅវត្តឥន្ទញ្ញាណ"]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត់ ឆ.118-120។ ឯកសារ D54/37 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.4។ ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.44។ ឯកសារ D54/111 កំណត់ហេតុស្តាប់ចម្លើយ សំ ភីន ឆ.15។

1285 សូមមើល VIII.C.3. មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ។ VIII.C.4. មន្ទីរសន្តិសុខទឹកសាប។ ជាឧទាហរណ៍ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.23 ["ទឹកសាប គឺជាគុករបស់កងពល ១៦៤ ដែរ សម្រាប់អ្នកដែលអ្នកទោសធ្ងន់ៗ។ គេឃុំឃាំងកូនយោធាដែលមានទោសធ្ងន់នៅទឹកសាប ហើយក៏ជាកន្លែងសម្លាប់ដែរ។ ទឹកសាបគឺជាកន្លែងដែលគេធ្វើទារុណកម្មយ៉ាងខ្លាំងទៅលើអ្នកទោស។ វាគឺជាគុក វាមិនមែនជាមន្ទីរសន្តិសុខទេ។ អ្នកទោសខ្លះត្រូវបានគេចោះត្រចៀក ហើយដោតខ្សែបន្តគ្នាពី៥ទៅ១០នាក់ ដើម្បីការពារកុំឱ្យអ្នកទោសរត់គេច។ គេប្រើពួកអ្នកទោសឱ្យសែងឈើសម្រាប់សង់ផ្ទះ និងធ្វើអ្វីផ្សេងៗ"]។ ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ ប៉ែន សារិន EN ERN 00217559 ["សាក្សីបានអះអាងថា វត្តអង្គតាញានជាកន្លែងឃុំឃាំង។ នៅពេលដែលគាត់បានទៅទីនោះជាលើកដំបូង នៅក្នុងខែមេសាឆ្នាំ ១៩៧៩ គាត់បានឃើញច្រវាក់និងឈាម។ នៅលើជញ្ជាំងមួយ ជាកន្លែងដែលជនជាប់ឃុំត្រូវបានដាក់ច្រវាក់នៅនឹងឯក ហើយត្រូវឈរ។ កន្លែងធ្វើទារុណកម្មស្ថិតនៅក្នុងវិហារ នៅក្នុងសាលធំមួយ។ មានខ្នោះជើងឈើប្រហែល១០។ កន្លែងឃុំឃាំងស្ថិតនៅក្រោម [...] មាស មុត ដែលជាអ្នកទទួលខុសត្រូវក្រុង"]។ ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.5, 13-14, 30 ["អ្នកទោសទាំងនោះ គឺគេយកមកអប់រំកែប្រែនៅហ្នឹងវត្តនោះ។ [...] នៅពេលយប់អ្នកទោសទាំងនោះត្រូវបានគេដាក់បញ្ចូលក្នុងកន្លែងឃុំឃាំងហើយដាក់ខ្នោះឈើជើង បន្ទាប់ពីបាយរួច នៅពេលព្រឹកគេបញ្ចេញអ្នកទោសឱ្យបោសសម្អាតទីធ្លារួចហើយគេប្រជុំជួរអ្នកទោស ហើយបានដាក់ច្រវាក់ជើងប្រវែងមួយម៉ែត្រកន្លះជុំវិញជើងអ្នកទោសម្នាក់ៗ រួចហើយគេប្រគល់កាំបិតឱ្យអ្នកទោសម្នាក់ៗមួយឱ្យធ្វើការក្នុងចំការដំឡូង។ [...] ខ្ញុំបានជួបអ្នកទោសខ្លះ គឺជាអតីតយោធាដែលធ្លាប់នៅក្នុងកងជាមួយខ្ញុំ។ [...] ស៖ តើរបបហូបចុកអ្នកទោសដែលលោកបានឃើញនៅវត្តឥន្ទញ្ញាណយ៉ាងដូចម្តេចដែរ? ឆ.13៖ គេទទួលបាន ៥០ភាគរយនៃរបបអាហារធម្មតា គឺមួយកំប៉ុងក្នុងមួយថ្ងៃ។ គេហូបរួមដោយម្នាក់បានបាយមួយវែកក្នុងមួយពេល។ ស៖ ម៉េចបានជាលោកដឹង? ឆ.14៖ ខ្ញុំបានសួរអ្នកទោសដែលខ្ញុំបានជួបនោះ។ [...] ឆ.30៖ ពួកអ្នកទោសមានសភាពស្គមណាស់និងបង្ហាញពីការភ័យខ្លាចយ៉ាងខ្លាំង ជើងខោពួកគេរហែកដោយសារច្រវាក់ដែលដាក់ជុំវិញកជើង"]។

1286 សូមមើល VIII.C.3. មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ។ VIII.C.4. មន្ទីរសន្តិសុខទឹកសាប។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.17-18, 24 ["ខ្ញុំដឹងច្បាស់ថា ទឹកសាប គឺជាកន្លែងគុក និងកន្លែងសម្លាប់នៅទីនោះ។ [...] ខ្ញុំត្រូវបានគេដកចេញពីកងនៅឆ្នាំ ១៩៧៧ ហើយបង្ខំឱ្យធ្វើការនៅស្រែ។ រយៈពេលនោះ ខ្ញុំធ្លាប់ឃើញខ្មោច

"សមាសភាពមិនល្អ" ដោយហេតុផលផ្សេងៗ និងត្រូវគេដកហូតអាវុធកាលពីពេលមុន និងដាក់ឱ្យធ្វើជាទាសករនៅការដ្ឋានដើម្បីកសាងខ្លួន ក៏ត្រូវបានចាប់ និងឃុំខ្លួនផងដែរ នៅក្នុងមន្ទីរសន្តិសុខទាំងនោះ ដោយគ្រាន់តែប្រព្រឹត្តកំហុសតូចតាច ឬត្រូវបានសម្លាប់[1287]។ ដូចអ្នកដែលត្រូវបានចាប់

បណ្ដែតទឹកនៅតាមស្ទឹង នៅជិតគុកទឹកសាបពេល ដែលខ្ញុំត្រូវបានគេចាត់តាំងឱ្យធ្វើការនៅជិតស្ទឹងនោះ។ យើងដឹងថាទឹកសាបគឺជាគុក ដោយសារឈ្មោះ ធូ ដែលនៅក្នុងចំណោមអតីតយោធាក្នុងកងរបស់ខ្ញុំបីនាក់ ដែលត្រូវបានគេចាប់ខ្លួន ហើយបញ្ជូនទៅទីនោះ។ ក្នុងចំណោមអ្នកទាំងបីនោះ ពីរនាក់ ត្រូវបានបាត់ខ្លួនរហូត នៅរស់តែឈ្មោះ ធូ ប៉ុណ្ណោះ [...] ឆ.18៖ ធូ បានប្រាប់ខ្ញុំថា ពេលដែលកងទ័ពវៀតណាមចូលមកដល់ មានអ្នកទោសប្រហែល ២០ នាក់ប៉ុណ្ណោះដែលនៅរស់។ ធូ បាននិយាយថា ពេលដែលគាត់ជាប់នៅទីនោះ គឺមានអ្នកទោសប្រហែលជា ១០០ នាក់ដែលជាប់ជាមួយគាត់។ នៅពេលដែលខ្ញុំសួរ ធូ អំពីយោធាបីរនាក់ទៀតដែលចាប់ពីកងរបស់ខ្ញុំ ដែលមានឈ្មោះ ឌឿន និង វឿន គាត់បានប្រាប់ខ្ញុំថា អ្នកទាំងពីរនោះ ត្រូវបានគេយកចេញពីគុកទឹកសាប ហើយបាត់មុខរហូត"]។ ឯកសារ D114/96 កំណត់ហេតុស្ដាប់ចម្លើយ ចេង ឡុង ឆ.29-30 ["ខ្ញុំឮសួរថា គេយកមនុស្សទៅសម្លាប់ និងកប់នៅកន្លែងទឹកសាប។ [...] ឆ.30៖ ខ្ញុំចាំថា មនុស្សដែលត្រូវបានចាប់ខ្លួនពីកន្លែងផ្សេង ដូចជារាមជាដើម ត្រូវគេយកទៅទឹកសាប។ អ្នកខ្លះនិយាយថា អ្នកដែលគេចាប់ខ្លួនគឺគេយកមកពីតាមកោះផងដែរ។ នៅកន្លែងដែលគេកប់សាកសព សព្វថ្ងៃត្រូវគេឈូសឆាយ និងជីកដីយកទៅធ្វើផ្លូវ និងយកទៅដាក់បំពេញកន្លែងទំនាប"]។ ឯកសារ D114/3 កំណត់ហេតុស្ដាប់ចម្លើយ ឡាក់ សាផាន ឆ.4 ["នៅកន្លែងទឹកសាបនោះ [...] ជាកន្លែងតឹងតែង ហើយគេហាមឃាត់មិនឱ្យទៅជិតទេ [...] មានតែយោធាខ្មែរក្រហមប៉ុណ្ណោះដែលរស់នៅទីនោះ។ កាលពីជំនាន់នោះ អ្នកណាក៏ដឹងដែរ បើសិនជាពួកយោធាខ្មែរក្រហមចាប់មនុស្ស ហើយនាំយកទៅទឹកសាប គឺយើងទាំងអស់គ្នាដឹងថាទីបញ្ចប់ហើយ"]។ សូមមើលផងដែរ ឯកសារ D114/16 កំណត់ហេតុស្ដាប់ចម្លើយ សុក វណ្ណា ឆ.17-18 ["កាលនោះ ទាំងប្រជាជនធម្មតា និងយោធា ត្រូវបានចាប់ខ្លួនយកទៅដាក់គុក ហើយខ្លះទៀតត្រូវបានយកទៅសម្លាប់ចោលតែម្ដង។ ឱ្យតែចាប់ខ្លួន គឺដឹងតែយកទៅសម្លាប់ហើយ ពុំមានដោះស្រាយ ឬចរចាអ្វីទេ។ ស៖ ហេតុអ្វីបានជាលោកដឹង? ឆ.18៖ ឱ្យតែគេចាប់យកទៅ គឺបាត់ខ្លួនតែម្ដង មិនដែលឃើញត្រឡប់មកវិញទេ"]។ ឯកសារ D54/87 កំណត់ហេតុស្ដាប់ចម្លើយ ព្រំ សារ៉ាត់ ឆ.119 ["ស៖ ជាធម្មតាបើអង្គភាពបញ្ជូនអ្នកនោះទៅអប់រំកែប្រែ និងលត់ដំ តើពួកគេត្រឡប់មកអង្គភាពដើមវិញដែរឬទេ? ឆ.119៖ មិនមានអ្នកណាត្រឡប់មកវិញទេ អ្នកទាំងនោះបាត់ខ្លួនរហូត"]។ ឯកសារ D54/78.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល EN ERN 00968415-00968416, KH ERN 00926640 ["ស៖ គ្រាន់ថាដូចថាមករៀនទៅបាត់ទៅ? ឆ៖ អឺ ! បាត់មិនឃើញទៅវិញ"]។

1287 ឯកសារ D114/31 កំណត់ហេតុស្ដាប់ចម្លើយ មូល ឈិន ឆ.123, 125 ["ប្រជាជនមិនត្រូវបានប្រព្រឹត្តមិនល្អ ឬវាយដំនៅពេលធ្វើការងារនោះទេ ប៉ុន្តែ នៅរាល់ល្ងាចគឺមានកិច្ចប្រជុំដើម្បីតិទៀនពីអ្នកអសកម្មនឹងការងារ ហើយចំពោះមនុស្ស ១ នាក់ គឺតិទៀនតែ ៣ ដងប៉ុណ្ណោះ បើលើសពីនេះ គឺគេត្រូវយកទៅហើយ។ គេនិយាយថា "របបកម្ពុជាប្រជាធិបតេយ្យមិនមានគុកសម្រាប់ដាក់មនុស្សទេ គឺមានតែអន្លង់/រណ្ដៅដាក់មនុស្សប៉ុណ្ណោះ។" [...] ឆ.125៖ [និយាយពីទាហានដែលបានរំលាយអាវុធក្នុងកងវរសេនាតូច ៣៨៦] ស៖ ក្នុងការប្រជុំតិទៀននោះ តើគេដែលនិយាយអំពីខ្មាំងដែរឬទេ? ឆ.125៖ គេថាអ្នកដែលឈឺ អស់កម្លាំង ធ្វើការមិនកើត គឺខ្ជិលច្រអូស ធ្វើពុតជាឈឺ និងបម្រើខបាយកល

ខ្មាំង ហើយគេយកអ្នកទាំងនោះទៅសម្លាប់ចោល នៅព្រៃខាងក្រោយសហករណ៍"]។ ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.99-101, 104-107 ["ខ្ញុំអត់ដឹងទេ តែពេលតា ឆាន ទៅ យើងជាប់និន្នាការ គេឲ្យថ្ងៃឡើងវែថ្ម រួចហើយគេឲ្យបាយដូចបបរប៉ុននេះ (ប្រហែលមួយកញ្ចុំបាតដៃ) ទេពេលថ្ងៃ និងពេលយប់។ ពេលថ្ងៃវែថ្ម ហើយពេលយប់ គេប្រជុំជីវទស្សន៍។ បើអ្នកណាធ្វើខុស គេឲ្យអ្នកវែថ្មជាមួយយើងហ្នឹង យកទៅវៃចោលតែម្តង។ ស៖ អ្នកណាជាអ្នកនាំមនុស្សក្នុងអង្គភាពទៅសម្លាប់ចោល? ឆ.100៖ អត់ដឹងផង។ ស៖ តើមានមនុស្សប៉ុន្មាននាក់ដែលគេចាប់ទៅដូចដែលលោកនិយាយនោះ? ឆ.101៖ យកទៅវៃចោលអស់ពីរបីនាក់។ ពេលយើងធ្វើការ ហើយមានការប្រជុំជីវទស្សន៍ ហើយបើពេលគេសង្ស័យយើង គេយកទៅ ហើយមិនដឹងយកទៅណាទេ គឺមិនដែលឃើញមកវិញទេ"]។ ឯកសារ D114/85 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.5-6 ["ពួកយើងត្រូវបានគេចាត់ទុកថាជាអ្នកទោសហើយ គឺគ្រាន់តែមិនឃុំឃាំង តែឲ្យយើងទៅលត់ដំ។ ប្រសិនបើគេមិនពេញចិត្តនឹងឥរិយាបថយើង គឺគេនឹងបញ្ជូនយើងទៅទឹកសាបភ្លាមតែម្តង [...] គេយកពួកយើងមកដាក់នៅមួយកន្លែង ដើម្បីត្រួតពិនិត្យ តាមដាន និងលត់ដំ។ និយាយទៅ គេប្រព្រឹត្តចំពោះពួកយើង អាក្រក់ជាងប្រជាជន ១៧ មេសា ទៅទៀត។ [...] ពួកគេបានត្រួតពិនិត្យពួកយើងយ៉ាងយកចិត្តទុកដាក់ ដូច្នេះទេ បើសិនជាយើងមានកំហុសតិចតួចក៏ដោយ គេនឹងយកទៅដាក់ទោសភ្លាមតែម្តង។ [...] ឆ.6៖ យើងទាំងអស់គ្នាដែលស្ថិតនៅក្នុងកងសមាសភាពមិនល្អនេះ ចាំក្នុងខួរក្បាលខ្លួនឯងជារហូតមកថា បើសិនជាយើងធ្វើអ្វីមួយខុសសូម្បីតែតិចតួច គេនឹងយកទៅដាក់ទោសភ្លាម។ កាលនោះខ្ញុំមានអាយុម្ពុំ ១៨ ឆ្នាំ ជាពេលវេលាដែលត្រូវហូបច្រើន ប៉ុន្តែ ពួកខ្ញុំពុំដែលហូបបានគ្រប់គ្រាន់នោះទេ។ ប្រសិនបើអ្នកណាម្នាក់មកយករបស់អ្វីមួយរបស់គេ ឬលួចរបស់គេ គឺគេយកទៅដាក់គុកភ្លាម។ ដូចខ្ញុំធ្លាប់ជម្រាបក្នុងសម្ភាសលើកមុនហើយ អំពីការចាប់ខ្លួនមនុស្សបីនាក់ពីកន្លែងខ្ញុំទៅដាក់គុកនៅទឹកសាប គឺមានតែម្នាក់ទេ ដែលនៅរស់ត្រឡប់មកវិញ"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.19 ["ពេលខ្ញុំមកដល់ទឹកសាបដំបូង ក្នុងឆ្នាំ ១៩៧៧ តាជន ជាអ្នកទទួលខុសត្រូវនៅទីនោះ។ តាជន គឺជាមេបញ្ជាការវរសេនាធំលេខ ៦៣។ ហើយ តាញ៉ាន់ គឺជាអនុរបស់គាត់។ [...] ជន ត្រូវបានចាប់ខ្លួន ហើយ ញ៉ាន់ ឡើងជំនួស ជន [...] ញ៉ាន់ ហើយនិង សេង នៅចុងរបបខ្មែរក្រហម ចុងឆ្នាំ១៩៧៨ ខ្ញុំតែងតែឃើញគាត់តំណាងឲ្យកងពល រាល់ពេលប្រជុំ។ [...] នៅពេលនោះ នៅក្នុងកងពល១៦៤ មានបីកងដែលគេចាត់ថា ជាកងសមាសភាពមិនល្អ។ ក្នុងចំណោមទាំងបីកងនេះ ពីរកង គឺកងវរសេនាតូចលេខ ២០ និង ២១ ហើយមួយកងទៀត គឺជាកងអនុសេនាធំលេខ ១៩។ កងទាំងបីនេះ ផ្ទុកពួកយោធាដែលចាត់ទុកថា ជាសមាសភាពមិនល្អ។ កងអនុសេនាធំលេខ ១៩ មានអតីតយោធាប្រហែលជា ១០០ នាក់ ដែលពួកទាំងនោះ គេចាត់ថាជាពួកយោធាសេរី។ បញ្ជាការរបស់កងនេះ ឈ្មោះ តាថន។ [...] កាលពីពេលនោះ កងនេះ គឺស្ថិតនៅកន្លែងមួយ ហៅថា ស្រែណិប។ វរសេនាតូចលេខ ២០ ស្ថិតនៅបបុសខាងលិច។ វរសេនាតូចនេះ ស្ថិតក្រោមបញ្ជាការរបស់ តារិត។ យោធាក្នុងកងនេះ គឺជាអតីតយោធា ដែលចេញពីតំបន់ ៣៧។ វរសេនាតូចលេខ ២១ ស្ថិតនៅបបុសខាងកើត។ កងនេះ ស្ថិតនៅក្រោមបញ្ជាការរបស់ តាខេង។ នៅក្នុងកងនេះ មានមនុស្សជាង ២០០ នាក់ ដែលសុទ្ធតែជាអតីតយោធាមកពីភូមិភាគបូព៌ា។ នៅពេលដែលមានអ្នកណាម្នាក់ នៅក្នុងកងសមាសភាពមិនល្អទាំងនេះធ្វើខុស គេនឹងត្រូវបញ្ជូនទៅឃុំខ្លួននៅទឹកសាប។ ពេលគេនៅក្នុងមន្ទីរឃុំឃាំងទឹកសាប ពួកអ្នកទោសទាំងនោះ ត្រូវបានគេដាក់ឲ្យធ្វើការនៅត្រើយខាងកើតស្ទឹង។ ចំណែកពួកខ្ញុំ ដែលនៅក្នុងកងទាំងបីនេះ ត្រូវបានគេដាក់ឲ្យធ្វើការនៅត្រើយខាងលិចស្ទឹង"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.17, 27 ["ថាត្រូវចាប់បញ្ជូនទាហានដែលនៅក្នុងតំបន់៣៧មកស្ទឹងហាវទាំងអស់

ប្រមូលទ័ពទាំងអស់ដើម្បីគេលត់ដំចម្រាញ់ទ័ព ដើម្បីគេសម្រិតសម្រាំងទ័ព ថាយើងហ្នឹងស្មោះត្រង់ជាមួយនឹងពួកគាត់ឬអត់។ [...] ឆ.27៖ បើយើងមិនអនុវត្តតាមផែនការដែលគេដាក់ចុះទេ គេនឹងអាចចាប់បញ្ជូនយើង ជួនកាលគេធ្វើបាប ជួនកាលសម្លាប់ក៏មានដែរ"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN ERN 00978579, KH ERN 00955511 ["កងទ័ពជាមួយគ្នាហ្នឹងអង្គភាពតែមួយហូបបាយជាមួយគ្នាហ្នឹង ណាស់អត់មានខុសអីធំដុំទេ គ្រាន់តែសួរគ្នាឯងចេះសរសេរពាក្យថា ទមិឡ ទេ អាមួយថាអីមិនចេះដល់ចេះចឹងគេសរសេរលេងចឹងទៅណាស់ ហើយអាមួយគេសរសេរចេះគេសរសេរគ្រប់គ្នាទៅណាស់ ហើយអត់ចេះតែពីរនាក់ទេ ដល់អស់ហ្នឹងគេចេញហើយចេះតែសរសេរទៅដល់ម៉ោង ៧ ទៅ ៨ អង្គរក្សគេមកដល់យប់ឡើងគេចាប់អស់រលីង"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.102-104 ["ធ្លាប់យកអ្នកធ្វើការជាមួយខ្ញុំទៅ តែយកទៅណាឬយកទៅសួរចម្លើយអី ខ្ញុំមិនដឹងទេ។ ស៖ ហេតុអ្វីបានជាគេយកពួកគាត់ចេញពីកងផលិតហ្នឹងទៅ? ឆ.103៖ ប្រហែលគេសម្គាល់ឃើញថា យើងខ្ជិល ទម្រុនការងារអីទៅ។ ស៖ តើមានមនុស្សប៉ុន្មាននាក់ដែលគេយកចេញពីកងផលិតហ្នឹងហើយ បាត់ខ្លួនតែម្តងនោះ? ឆ.104៖ ប្រហែល ៤-១០នាក់ដែរហ្នឹង"]។ ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.11-12 ["ការបោសសម្អាតគឺបានអនុវត្តទៅលើមនុស្សដែលចាត់តាមប្រភេទដូចដែលបានលើកឡើងនៅក្នុងឯកសារ [D1.3.27.20] ខាងលើ។ កាលចាប់ចងហ្នឹង គឺមិនមែនធ្វើតែផ្អែកទៅការឆ្លើយដាក់គ្នានោះទេ។ នៅពេលដែលយោធាណាម្នាក់ធ្វើឲ្យបែកចាននាំង យោធានោះនឹងត្រូវចាប់ខ្លួន ដោយចោទប្រកាន់ថាជាខ្មាំង ដែលបំផ្លិចបំផ្លាញរបស់រួម។ [...] ឆ.12៖ ក្នុងការអនុវត្ត នៅពេលដែលយោធាណាធ្វើខុស ដូចជាយាមដេក យោធានោះនឹងត្រូវហៅទៅអប់រំនៅវរៈ ហើយដោះលែងឲ្យត្រឡប់មកកងរបស់គេវិញ។ ប៉ុន្តែ ប្រសិនបើយោធានេះនៅតែធ្វើឲ្យមានកំហុសដដែលៗ យោធានោះនឹងយកទៅសម្លាប់ហើយ។ សម្រាប់យោធាដែលពុំមានមេរបស់ខ្លួនជាប់ពាក់ព័ន្ធនឹងខ្សែក្បត់ យោធានោះអាចគេយកទៅអប់រំជាបន្តបន្ទាប់ បើសិនជាគាត់ធ្វើខុស មុនពេលគេយកគាត់ទៅបាត់។ ប៉ុន្តែសម្រាប់យោធាដូចជាពួកយោធានៅក្នុងកងរបស់ខ្ញុំ គឺយើងមិនមានឱកាសជាលើកទី ២ ទេ ប្រសិនបើយើងហ៊ានភ្លាត់ដេកក្នុងពេលយាម"]។ ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.15 ["តាមដែលខ្ញុំចាំ គេសាងសង់ទំនប់នោះរួចក្នុងរយៈ ២-៣ ខែ ពីព្រោះគេបានប្រមូលប្រជាជនជាច្រើនមកពីសហករណ៍ ពីយោធានិងពីកងចល័តនានាឲ្យមកធ្វើនៅទីនោះតាមផែនការដែលគេកំណត់។ គេបានបែងចែកផែនការ ដូចជាទំនប់ប្រវែង ២០ ម៉ែត្រទៅឲ្យក្រុមនីមួយៗឲ្យបញ្ចប់ក្នុងរយៈពេល ១០ ថ្ងៃ។ ដូចជាគេឲ្យយើងរែកដី ៥ ម៉ែត្រក្នុងម្នាក់ៗក្នុងមួយថ្ងៃ។ ចំពោះអ្នកដែលបានបញ្ចប់ការងារនេះទើបអាចរស់បាន ចំពោះអ្នកណាដែលខ្ជិល ឈឺ ឬប្រឆាំងនឹងការរែកដី គេនឹងយកចេញទៅ ហើយក៏បាត់ខ្លួន តែខ្ញុំមិនដឹងថាគេយកទៅណាទេ"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.328 ["ស៖ បើសិនគេសង្ស័យថាលោកជាគិញវៀតណាម ហេតុអ្វីបានជាគេទុកឲ្យលោកនៅរស់? ឆ.328៖ គេទុកឲ្យខ្ញុំរស់តែគេតាមដានខ្ញុំ។ បើសិនជាខ្ញុំធ្វើអ្វីខុស គេនឹងចោទខ្ញុំពេញតែម្តង"]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.24 ["បាទ ខ្ញុំធ្លាប់ឃើញ យោធាម្នាក់ដែលនៅក្នុងកងជាមួយខ្ញុំបានប្រើប្រេងម៉ាស៊ីនខុសលេខ ធ្វើឲ្យខូចម៉ាស៊ីនកាណូតនោះ គាត់ត្រូវបាននាំយកទៅបាត់រហូត។ គាត់គឺជាអ្នកបើកកាណូតនៅក្នុងក្រុមនេសាទ សម្រាប់ផ្តល់ឲ្យការដ្ឋានវាយថ្ម និងម្នាក់ទៀតបានបើកកាណូតទៅបុកថ្ម ហើយក៏ត្រូវគេយកទៅបាត់ដែរ។ បើសិនជាមានអ្នកណាម្នាក់ បើកឡានបុកអ្វីមួយ គាត់ក៏ត្រូវយកទៅបាត់ដែរ។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយប្រេស មាន ឆ. 26, 34 ["នៅកន្លែងវាយថ្ម គេបិទសិទ្ធិមិនឲ្យយើងធ្វើដំណើរការឬទាក់ទងជាមួយអ្នកកន្លែងផ្សេងទៀត បើមិនដូច្នោះទេ

និងឃុំខ្លួនទាំងអស់នោះ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គ្មាននរណាម្នាក់ត្រូវបានបញ្ជូនទៅតុលាការទេ[1288]។ យុទ្ធជនកងពល ១៦៤ ភាគច្រើនត្រូវបានចាប់ខ្លួនដោយសមាជិកកងវរសេនាតូច ១៦៥ ពិសេស (ពីមុន កងវរសេនាតូច ៤៥០ ដែលគេហៅផងដែរថា "កម្លាំងពិសេស" ឬកងអន្តរាគមពិសេស) ។ កងវរសេនាតូច ១៦៥ ពិសេស មាននីរសារ និងអង្គរក្សរបស់ **មាស មុត** និងស្ថិតក្រោមបញ្ជាផ្ទាល់របស់ **មាស មុត**។ អង្គភាពនេះទទួលបន្ទុកការពារសន្តិសុខរបស់ **មាស មុត** នៅទីបញ្ជាការកងពល និងនៅមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ[1289]។

---

យើងនឹងត្រូវគេចាប់បញ្ជូនទៅបាត់។ [...] ឆ.34: ប្រសិនបើមានអ្នកណាម្នាក់លួចដំឡូង គេនឹងចាប់វាយ"]។ ឯកសារ D114/105 កំណត់ហេតុស្តាប់ចម្លើយ កុច ទុយ ឆ.64 ["ខ្ញុំមានរឿងមួយ អំពីបងម្នាក់ឈ្មោះ ធឿន អ្នកស្រុកបឹងត្រាច ដែលធ្លាប់ធ្វើការនៅកងវរៈ ៨៦ ជាមួយខ្ញុំ។ គាត់ឃ្លានពេក ពេលនោះគាត់ឃើញល្ហុងទុំមួយ គាត់បេះល្ហុងនោះបានរួចលាក់យកទៅហូប ប៉ុន្តែ មានអ្នកឃើញ អ្នកនោះបានរាយការណ៍ទៅមេកងចល័ត ចុងក្រោយគេក៏បានយកគាត់ទៅទម្លាក់ក្នុងអណ្តូងស្លាប់បាត់ទៅ"]។ ឯកសារ D54/35.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប្រាក់ សុខា EN ERN 00971212, KH ERN 00964252 ["កងអ្នកមានកំហុសកងចល័តអីបាត់ខ្លួនគេយកទៅកសាងទឹកសាបអីទៅ"]។

1288 ឯកសារ D114/126 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គឹម ឆ.27៖ ["សៈ តើមានប្រព័ន្ធតុលាការដែរទេ នៅសម័យខ្មែរក្រហម ដែលបុគ្គលណាម្នាក់អាចប្តឹងតវ៉ាអំពីការប្រព្រឹត្តមកលើខ្លួន? ឆ.27៖ ពួកយើងអត់មានសិទ្ធិអ្វីទាំងអស់។ យើងមិនអាចយកបញ្ហារបស់យើងទៅប្រាប់អ្នកណាម្នាក់ ហើយទៅប្តឹងកន្លែងណាបាននោះទេ"]។ ឯកសារ D114/58 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ កេត ឆ.11 ["ខ្ញុំមិនដឹងថាមានប្រព័ន្ធតុលាការអ្វីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ ខ្ញុំគ្រាន់តែដឹងថាមនុស្សទាំងនេះត្រូវបានគេចាប់ខ្លួន។ [...] ខ្ញុំមិនធ្លាប់ឃើញ ឬឮពីប្រព័ន្ធតុលាការអ្វីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ។"]។ ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា ឆ.17 ["សៈ អំឡុងពេលដែលលោកធ្វើការក្នុងអង្គភាពយោធា និងជើងទឹកនៅកំពង់សោម នៅចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ តើលោកដែលសង្កេតឃើញមានតុលាការ ឬអាជ្ញាធរដែលគេបង្កើតឡើង ដើម្បីកាត់ទោស រកយុត្តិធម៌ និងដោះស្រាយបញ្ហាឲ្យប្រជាជនដែរឬទេ? ឆ.17៖ ទេ មិនមានទេ។ កាលនោះ ទាំងប្រជាជនធម្មតា និងយោធា ត្រូវបានចាប់ខ្លួន យកទៅដាក់គុក ហើយខ្លះទៀតត្រូវបានយកទៅសម្លាប់ចោលតែម្តង។ ឲ្យតែចាប់ខ្លួន គឺដឹងតែយកទៅសម្លាប់ហើយ ពុំមានដោះស្រាយ ឬចរចាអ្វីទេ"]។ ឯកសារ D114/48 កំណត់ហេតុស្តាប់ចម្លើយ សុខ ង៉ុន ឆ.26។ ឯកសារ D114/116 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.45។

1289 ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.23-24 ["ក្រោយមកដោយពុំមានការប្រយុទ្ធនៅលើសមរភូមិទៀតទេ កង ៤៥០ នោះ ត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវខាងផ្នែកសន្តិសុខវិញ។ សៈ តើនៅមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណឬយ៉ាងណា? ឆ.24: មិនមែនតែកន្លែងវត្តឥន្ទញ្ញាណហ្នឹងទេ គឺជាកងសន្តិសុខរបស់កងពល ១៦៤ នៅក្រុងកំពង់សោមទាំងមូល"]។ ឯកសារ D54/101 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.10 ["ពួកយោធាដែលជាអ្នកបញ្ជាឲ្យគាត់លើកដៃនោះ។ យោធាទាំងនោះគឺមកពីកងពិសេសរបស់ តា មុត។ ពួកនោះគឺដូចជាកងអង្គ

វក្សរបស់ តា មុត ឬក៏ហៅថាកងដៃស្ដាំរបស់គាត់។ បន្ទាប់ពីដាល់ពួកយោធានោះហើយ រ៉េម បានលោតចុះពីលើឡាន ហើយពួកយោធាបានបាញ់ចំក្បាលរបស់គាត់ ហើយគាត់ដួលស្លាប់នៅលើថ្នល់នៅមុខវត្តឥន្ទញ្ញាណនោះតែម្ដង"]។ ឯកសារ D54/72 កំណត់ហេតុស្ដាប់ចម្លើយ មុត ម៉ៅ ឆ.7 [អតីតនីរសារបងជីដូនគាត់ឈ្មោះ ខុម និងជាអ្នកទទួលខុសត្រូវទំនាក់ទំនងទូរស័ព្ទរបស់ មាស មុត៖ "កងពិសេសគឺដូចជាកងការពាររបស់ មាស មុត អ៊ីចឹងដែរ។ ក្រុមនីរសារ គឺជាក្រុមដែលធ្វើការនៅជិត និងជាប់ជាមួយ តា មុត គ្រប់ពេលវេលា។ ប៉ុន្តែ កងពិសេសគឺសម្រាប់យាមកាម ហើយនិងយាមប៉ុស្តិ៍ឆែកឆេរនៅជុំវិញមន្ទីរ និងផ្ទះរបស់គាត់។ [...] ឆ.8: គឺជាកងវរសេនាតូច។ [...] ឆ.16: តា នន គឺនៅក្នុងកងពិសេសសម្រាប់ការពារកងពល។ មានប៉ុស្តិ៍យាម ហើយនិងផ្ទះមួយដែលស្ថិតនៅច្រកចូលទៅផ្ទះរបស់ តា មុត ជាកន្លែងដែល នន និងយោធារបស់គាត់ស្នាក់នៅ។ ខ្ញុំមិនដែលទៅដល់កន្លែងនោះទេ ដូច្នេះ ខ្ញុំមិនដឹងថា មានយោធាប៉ុន្មាននាក់ទេ នៅទីនោះ"]។ ឯកសារ D54/71 កំណត់ហេតុស្ដាប់ចម្លើយ មុត ម៉ៅ ឆ.39, 42 ["ខ្ញុំមិនដឹងថាយោធាកងណាជាអ្នកយកពួកយួនមកសម្លាប់នៅទីនោះទេ។ ពួកគេអាចមកពីកងពិសេសរបស់កងពល ឬក៏មកពីកងនីរសាររបស់ មាស មុត។ [...] ស៖ ហេតុអ្វីបានជាលោកស្រីនិយាយថា ពួកយោធាដែលនាំយួននោះមកសម្លាប់ជាពួកកងពិសេស ឬក៏ជាពួកនីរសាររបស់ មាស មុត? ឆ.42៖ គឺមានន័យតែយោធារបស់កងពិសេសទេ ដែលមានភារកិច្ចធ្វើការងារនោះ។"]។ ឯកសារ D54/7 កំណត់ហេតុស្ដាប់ចម្លើយ ឌុល សុង ឆ.11 ["ស៖ តើកងវរសេនាតូចពិសេសនេះត្រូវបានចាត់តាំងឱ្យធ្វើអ្វី ក្រោយឆ្នាំ ១៩៧៥ ពេលកងពល ៣/១៦៤ មកនៅកំពង់សោម? ឆ.11៖ កងវរសេនាតូចពិសេសនេះ គឺថិតនៅជាមួយបញ្ជាការឬស្នងការកងពល។ មុខងាររបស់កងពិសេស គឺការពារថ្នាក់ដឹកនាំកងពលនិងចាប់ចងអ្នកដែលមានទោស។ នៅពេលនោះប្រទេសជាតិបានសន្តិភាពហើយ កងពិសេសនេះមិនត្រូវការទៅច្បាំងនៅកន្លែងណាទេ ដូច្នេះ កងពិសេសសម្រាប់ការពារថ្នាក់ដឹកនាំកងពលនិងចាប់អ្នកធ្វើខុស"]។ ឯកសារ D54/46 កំណត់ហេតុស្ដាប់ចម្លើយ អែម សុន ឆ.38 ["សម្រាប់ទ័ពថ្មើរជើងគឺបញ្ជាចេញពីកងពលលេខ ៣ មកវរសេនាធំ។ ពីវរសេនាធំមកវរសេនាតូច។ ហើយពីវរសេនាតូចមកអនុសេនាធំ។ តែសម្រាប់កងពិសេសរបស់ខ្ញុំ វរសេនាតូច ៤៥០ គឺទទួលបញ្ជាផ្ទាល់ពី មាស មុត ដែលជាមេបញ្ជាការកងពលលេខ៣ តែម្ដង"]។ ឯកសារ D54/10 កំណត់ហេតុស្ដាប់ចម្លើយ ម៉ី រ៉េត ហៅ សារ៉េត ឆ.27 ["វរសេនាតូច ៤៥០ គឺកងពិសេសរបស់តា មុត"]។ ឯកសារ D114/15 កំណត់ហេតុស្ដាប់ចម្លើយ សុក វណ្ណា (សួស វណ្ណា) ឆ.18។ ឯកសារ D4.1.762 ចម្លើយរបស់ កាំ ម៉ែន ទាក់ទងនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម KH ERN 00742578-00742579។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង រ៉េត EN ERN 00974081, KH ERN 00926527 ["កងពិសេស បើនិយាយទៅជាកងឯករាជ្យរបស់កងពល។ [...] ស្មើនឹងកងវរសេនាធំដែរ"]។ ឯកសារ D54/98 កំណត់ហេតុស្ដាប់ចម្លើយ ហ៊ាង រ៉េត ឆ.28, 92, 98 ["កងវរសេនាតូច ៤៥០ បានក្លាយជាកងវរសេនាតូច ១៦៥ ដែលជាកងអន្តរាគមន៍ពិសេស។ [...] ឆ.92៖ ខ្ញុំដឹងថាមន្ទីរសន្តិសុខនោះគ្រប់គ្រងដោយនីរសារវរសេនាតូច៤៥០"]។ ឯកសារ D54/87 កំណត់ហេតុស្ដាប់ចម្លើយ ព្រំ សារ៉ាត ឆ.93-95 ["កងវរសេនាតូច ៤៥០ ឈរជើងនៅជុំវិញកងពល។ [...] ឆ.94៖ ពួកគេជាកងការពារ [...] ឆ.95៖ ការងារចម្បងគឺការពារទីបញ្ជាការរបស់កងពល"]។ ឯកសារ D114/83 កំណត់ហេតុស្ដាប់ចម្លើយ សុខ នាង ឆ.19។

367. គេដឹងថា **មាស មុត** បានវាយដំរាងកាយទាហានរបស់គាត់ ពេលពួកគេធ្វើខុស នៅនឹងមុខគាត់។ ឧទាហរណ៍ គាត់បានយកពូថៅវាយមេជាងម្នាក់ចំថ្ងាស ដោយចោទថាបានធ្វើខុស ពេលសង់ដំបូលផ្ទះនៅកំពង់សោម ហើយបានហាមមិនឱ្យនរណាម្នាក់ជួយមេជាងរងរបួសនោះ[1290]។ ដោយសារតែអំណាចផ្តាច់ការ និងអាកប្បកិរិយាអាក្រក់ដែលគេដឹងឮគ្រប់គ្នា **មាស មុត** ធ្វើឱ្យកងទ័ពកងពល ១៦៤ របស់គាត់ខ្លាចគាត់គ្រប់ៗគ្នា[1291]។

---

1290 ឯកសារ D54/37 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.6 ["ខ្ញុំឃើញ មាស មុត មកកន្លែងគេសង់ផ្ទះនោះ ពេលខ្ញុំឃើញគាត់ដើរមើលជុំវិញផ្ទះ ដែលគាត់ប្រើទាហានឱ្យសង់ផ្ទះនោះ គឺជាផ្ទះសម្រាប់ឱ្យភ្ញៀវចិនស្នាក់នៅ ពេលដែលគាត់ឃើញពួកយោធាសង់ផ្ទះនោះមិនធ្វើតាមការណែនាំរបស់គាត់ឱ្យបានត្រឹមត្រូវ នៅលើផ្នែកមួយនៃដំបូលផ្ទះទៅតាមរាងដែលគាត់ចង់បាន គាត់ក៏ហៅមេជាងនោះឱ្យចុះមកដី ពេលមេជាងនោះចុះមកដល់ជិតគាត់ហើយមេជាងបានសួរគាត់ថា តើមានការអ្វីជាមួយការសាងសង់នេះ ពេលនោះគាត់បានមិនឆ្លើយ គាត់បានកញ្ឆក់ពូថៅពីមេជាងនោះហើយវាយចំថ្ងាស់មេជាងនោះ ធ្វើឱ្យឈាមហូរស្រោចពេញមុខ នៅពេលកូនជាងបានឃើញដូច្នោះ គេចង់យកមេជាងនោះទៅពេទ្យ តែពេលនោះតា មុត និយាយថា អ្នកណាហ៊ានយកទៅពេទ្យនឹងទទួលរឿងដូចមេជាងនេះ។ ខ្ញុំបានឮមាស មុត និយាយទៅកាន់មេជាងនោះថា អ្នកឯងប្រាប់ខ្ញុំថា សុទ្ធតែចេះធ្វើទាំងអស់ ប៉ុន្តែ ពេលខ្ញុំប្រាប់ឱ្យធ្វើការងារអ្នកឯងធ្វើមិនកើត បន្ទាប់ពីគាត់និយាយរួចហើយ គាត់ក៏ឡើងជិះឡានទៅបាត់"]។ ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី EN ERN 01070553, KH ERN 00964130 ["មនុស្សគាត់ធម្មតាមិនល្បីល្បាញ [...] មាស មុត នោះភ្នែកសម្លឹងហើយគឺផ្ទះជើងមេឃ ហើយឈ្មោះ មុត នោះគឺត្រូវ មុត ហ្នឹងហ្នងសម្លឹងអាក្រក់ណាស់។ សៈ សម្លឹងម៉េចទៅ? ឆៈ សម្លឹងមិនព្រិចហ្នឹង [...] គាត់ធ្វើកន្លែងផ្ទះទទួលភ្ញៀវនៅជិតផ្ទះប្រពន្ធគាត់ខ្មោច ខ្ញុំ ហ្នឹង ដល់ពេលជាងខ្ញុំមិនដឹងថាភិនភាគយ៉ាងម៉េចទេ ដល់ពេលឃើញធ្វើឃើញប្រក់អីហើយខុសខុសបំណងចិត្តគាត់ ដល់ពេលខុសបំណងចិត្តគាត់លែងហៅជាងឱ្យចុះមកពីលើដំបូលផ្ទះដីលែងកាប់ក្បាលត្រឹមហ្នឹងទាញកូនពូថៅពីដៃជាងហ្នឹងមកទក្បាលត្រឹមហ្នឹងធោះដួលស្រុច"]។

1291 ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា ឆ.23-25 ["តា មុត ដែលជាប្រធានកងពល គឺជាអ្នកដែលមានសិទ្ធិអំណាចធំជាងគេ។ តា មុត កាចណាស់។ គាត់អាចវ៉ៃ និងបាញ់ អ្នកណាម្នាក់យ៉ាងងាយ។ [...] ឆ.24៖ ឧទាហរណ៍សម្រាប់យោធា បើអ្នកណាម្នាក់ធ្វើខុស ឬមិនត្រឹមត្រូវ គាត់មិននិយាយប្រាប់ថាបែបនេះបែបនោះទេ គឺគាត់នៅស្ងៀម ហើយគាត់វ៉ៃអ្នកនោះដល់សន្លប់ក៏មាន។ សៈ តើលោកធ្លាប់ឃើញហេតុការណ៍នេះដែរឬទេ? ឆ.25៖ បាទ ខ្ញុំធ្លាប់ឃើញហេតុការណ៍ម្តងដោយផ្ទាល់ភ្នែក នៅក្រោយពេលជ័យជម្នះលើទីក្រុងភ្នំពេញ។ កាលនោះ គេឱ្យកងខ្ញុំធ្វើផ្លូវរទេះភ្លើងពីវាលរេញទៅកំពត។ យោធាម្នាក់បានយកដុំថ្មគប់លេងចូលក្នុងព្រៃកំប៉ុត តា មុត ឃើញ គាត់ក៏ដើរមក ហើយវ៉ៃយោធាម្នាក់នោះរហូតដល់សន្លប់។ ក្រោយមកទៀត ខ្ញុំក៏នៅតែឮគេនិយាយថា គាត់នៅតែកាចដដែល"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.8-9 ["មាស មុត គឺជាមនុស្សម្នាក់ដែលកាចសាហាវណាស់។ គាត់មិនចេះមាត់ក ហើយមិនដែលញញឹមទេ។ នរណាក៏ខ្លាចគាត់ដែរ។ មិនមាននរណាហ៊ានសម្លឹងមើលមុខគាត់ទេ។ យើងខ្លាចគាត់ណាស់ យើងខ្លាចគាត់ជាងស្តេចទៅទៀត។ [...] ឆ.9៖ គាត់មានអំណាចចាប់ចង និងសម្លាប់

## ៤. ការបញ្ចូលទាហានមួយចំនួនដែលត្រូវបានចោទសម្អាត ទៅក្នុងកងពល ១៦៤ វិញ ដើម្បីតែវាយវៀតណាមប៉ុណ្ណោះ

368. ដោយហេតុថាជម្លោះប្រដាប់អាវុធជាមួយវៀតណាមកាន់តែខ្លាំងឡើងៗ និងបានគំរាមកំហែងដល់ថ្នាក់ដឹកនាំ ប.ក.ក ទាហានកងពល ១៦៤ ជាច្រើននាក់ ដែលត្រូវគេដកហូតអាវុធ និងដាក់ឲ្យធ្វើជាទាសករនៅតាមការដ្ឋាននានា ឬឃុំខ្លួន ដោយសារពួកគេជា "សមាសភាពមិនល្អ" ឬជាប់ពាក់ព័ន្ធជាមួយជនក្បត់ ឬខ្មាំង ទោះមានសុខភាពទ្រុឌទ្រោមក្តី[1292] ត្រូវបាន **មាស មុត** និងថ្នាក់ដឹកនាំ ប.ក.ក បំពាក់អាវុធវិញ នៅចុងឆ្នាំ ១៩៧៨[1293]។

---

ទាំងយោធា និងទាំងប្រជាជនស៊ីវិលដែលនៅក្នុងតំបន់របស់គាត់ ឧទាហរណ៍ បើគាត់សង្កេតឃើញថា គោ ឬសត្វពាហនៈស្គម ហើយមិនត្រូវបានថែទាំជិតដល់ល្អ គាត់នឹងចេញបញ្ជាឲ្យចាប់អ្នកដែលថែទាំគោទាំងនោះ"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.87 ["ខ្ញុំឮថា គាត់ជាមនុស្សកាចណាស់"]។ ឯកសារ D114/159 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ឆ.35 [សេចក្តីអះអាងរបស់ ជ័យ ហាន ហៅ ឆន ដែលមកជួប ឌុច មុនពេលគាត់ត្រូវបានគេចាប់ខ្លួន៖ "រឿងរ៉ាវទាស់នឹងបង មុត មានបញ្ហានេះបញ្ហានោះ វានិយាយថាបង មុត កាចអីចេះ កាចអីចុះ អាក្រក់នេះ អាក្រក់នោះ"]។ ផ្ទុយ ឯកសារ D114/48 សុខ ង៉ុន ឆ.28-29 [អះអាងថា មាស មុត បានធានាឲ្យយោធាគាត់បានបរិភោគឆ្អែត ហេតុនេះគាត់ជាមនុស្សល្អ]។

1292 ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.13 ["ខ្ញុំស្គម ហើយរស់នៅដោយការភ័យខ្លាចដែរ ប៉ុន្តែ ខ្ញុំខំប្រឹងតស៊ូដើម្បីរស់ ខ្ញុំមិនចង់ឲ្យគេបញ្ជូនទៅទឹកសាបទេ"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.24 ["អ្នកទោស គឺទន់ខ្សោយ គ្មានកម្លាំង ហើយស្គមស្គាំង។ ខ្ញុំពុំបានឃើញសាកសពទាំងនោះត្រូវគេចងទេ"]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹន យ៉េ ឆ.26 [នៅកងកេងបន្ទាប់មកស្ទឹងហាវ៖ "ក្នុង ១ ថ្ងៃហូបបានតិចណាស់ ជីវភាពការរស់នៅ រូបស្គម។ តិចហ្នឹង ម៉ាកូននង្គ័លហ្នឹងបានបន្តិចម្នាក់ទេ។ ម្នាក់ប្រហែលកន្លះកំប៉ុងទេក្នុងមួយពេល"]។ ឯកសារ D114/105 កំណត់ហេតុស្តាប់ចម្លើយ កុច ទុយ ឆ.101-102 [អតីតយុទ្ធជនកងវរសេនាតូច ៣៨០៖ "ហត់ណាស់ អ្នកខ្លះអង្គុយហត់ពេកក៏ស្លាប់ទាំងអង្គុយ [...] នៅពេលដែលលើកបង្គី រែកដី ដើរដួលស្លាប់ក៏មាន [...] កាលនោះមានមនុស្សស្លាប់រាល់ថ្ងៃ ស្លាប់មួយថ្ងៃបួនប្រាំនាក់។ ស៖ តើនៅពេលនោះលោកនិងអ្នកផ្សេងទៀតដែលធ្វើការនៅទីនោះស្គមទេ? ឆ.102៖ មានតែស្បែក និងឆ្អឹង ពេលអង្គុយក្បាលជង្គង់ដល់ត្រឹមស្លឹកត្រចៀក"]។ ឯកសារ D54/69 កំណត់ហេតុស្តាប់ចម្លើយ នេត នង ឆ.34។

1293 ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.39 ["នៅខែមករា ឆ្នាំ ១៩៧៩ ក្រោយពេលដែលយោធាកងវរសេនាធំ ៦១ ត្រូវបានបញ្ជូនទៅវាយវៀតណាម ហើយពេលកងទ័ពវៀតណាមចូលមកដល់ក្នុងតំបន់នេះ ពួកយើងដែលជាអ្នកធ្វើការនៅការដ្ឋានវាយថ្ម ត្រូវបានគេបំពាក់អាវុធឡើងវិញ ឲ្យទៅវាយកងទ័ពវៀតណាមនៅវាលយន្តហោះកងកេង និងតាមបណ្តោយផ្លូវជាតិលេខ ៤ រហូតទាល់តែយើងចាញ់"]។ ឯកសារ D114/181 កំណត់ហេតុស្តាប់ចម្លើយ សែម កុល ឆ.47 ["អ្នកទោសនៅហ្នឹង ឮសួរថា ឈ្មោះ រិន ឬក៏ រីន ទេ ស្រី។ គេដាក់ចូលវគ្គឥន្ទញាណ

## ខ. ការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងអ្នកដែលត្រូវបានកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យចាប់ខ្លួននៅក្នុងដែនទឹក និងនៅលើកោះ ដែលអះអាងកាន់កាប់ដោយកម្ពុជាប្រជាធិបតេយ្យ

369. ភ័ស្តុតាងខាងក្រោមបង្ហាញថា **មាស មុត** ជាអ្នកទទួលខុសត្រូវដោយផ្ទាល់ទៅលើឧក្រិដ្ឋកម្មខាងក្រោម ពាក់ព័ន្ធនឹងអ្នកដែលត្រូវបានកងពល ១៦៤ និងកងពលលេខ ១ ចាប់ខ្លួនក្នុងដែនទឹក និងនៅលើកោះ ដែលត្រូវបានអះអាងកាន់កាប់ដោយកម្ពុជាប្រជាធិបតេយ្យ៖ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការបាត់ខ្លួនដោយបង្ខំ និងការធ្វើបាបដោយអមនុស្សធម៌ ក៏ដូចជាអំពើអមនុស្សធម៌ផ្សេងទៀត និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរ ក្នុងនោះមាន ការធ្វើមនុស្សឃាត

---

ហ្នឹង។ កាលនោះ គាត់ធ្វើធំដែរ នៅវរសេនាតូច [...] ប៉ុន្តែ ដល់ក្រោយមក ថាលែងគាត់វិញ។ ដល់ ៧៩ វិញ ឮថាគាត់មកតស៊ូទៀតជាមួយខ្មែរក្រហម វ៉ៃជាមួយវៀតណាម"]។ ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ិន សុត ឆ.69, 76-77 ["ពេលយួនជិតដល់ វាដឹងផែនការ វាដាក់តាបឡូមួយ ហើយវាសរសេរថា វៀតណាមចូលមកដល់កន្លែងនេះៗហើយ វាថាវាមិនយកទោសយកពៃអ្នកដែលជាប់និន្នាការអីទេ យើងត្រូវពង្រឹងឡើង។ ពេលវាដកពួកខ្ញុំ វាមានដកចម្រុះ ហើយក៏មានសមាសភាពពួកវាដែរគឺដើម្បីយកទៅវ៉ៃវៀតណាម ពួកយើងដែលជាប់និន្នាការ គឺវាដកទៅតាមក្រោយទេ គឺរហូតដល់ពេលវៀតណាមចូលដល់ ហើយវ៉ៃប៊ឹងៗហើយបានវាប្រកាសឱ្យបំពាក់អាវុធវ៉ៃ វាថា "មិត្តៗមកយកកាំភ្លើងប្រយុទ្ធខ្លាំង"។ [...] ឆ.76៖ កាលហ្នឹងវ៉ៃនៅទឹកសាប [...] វ៉ៃនៅស្ទាច់ដែង ហើយនិងទឹកសាប ការវ៉ៃគឺវ៉ៃរយៈពេលខ្លីទេ គឺប្រហែលជាម៉ោង ៤ [...] ស៖ តើកាលនោះតាមុតបញ្ជាទ័ពដែរឬទេ? ឆ.77៖ បាទ គឺបញ្ជាជាមួយតា សេង។ តា មុត គឺជាអ្នកបញ្ជាផ្ទាល់"]។ ឯកសារ D114/122 កំណត់ហេតុស្តាប់ចម្លើយ ណុប ផន ["ពួកខ្មែរក្រហម និងវៀតណាមចាប់ផ្តើមវាយប្រយុទ្ធគ្នា គេក៏បំពាក់អាវុធឱ្យពួកខ្ញុំម្តងទៀត ហើយបញ្ជូនពួកខ្ញុំឱ្យទៅឈរជើងនៅរាម ដើម្បីត្រៀមប្រយុទ្ធជាមួយនឹងវៀតណាម ប្រសិនបើពួកវាចូលមក។ ក្រោយពីមានការវាយប្រយុទ្ធគ្នារយៈពេលខ្លីជាមួយវៀតណាម ហើយពួកយើងដឹងថាមិនឈ្នះគេ ទាំងប្រជាជនធម្មតា និងយោធា ក៏បានចាប់ផ្តើមរត់គេចខ្លួន"]។ ឯកសារ D114/25 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដារ ឆ.64៖ [អតីតយោធាកងពល ១៦៤ មកពីវរសេនាតូច ១៨០ ដែលត្រូវបានគេបញ្ជូនទៅកោះកុង ត្រូវបានគេបំពាក់អាវុធជាថ្មីឡើងវិញ ដើម្បីវាយវៀតណាមនៅព្រំដែនខាងកើត]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.27 ["ខ្ញុំស្គាល់អតីតអ្នកទោសនៅទឹកសាបម្នាក់ឈ្មោះ សុខ ប្រាជ្ញ ពីព្រោះគាត់ជាអ្នកនិយាយច្រើន អ្នកពូកែប្រាជ្ញ។ ខ្ញុំបានជួបគាត់នៅក្នុងឆ្នាំ ១៩៧៩ នៅពេលនោះ បន្ទាប់ពីគាត់ត្រូវបានដោះលែងពីទឹកសាប គាត់កាន់កាំភ្លើងដើម្បីវ៉ៃជាមួយកងទ័ពវៀតណាម"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.75 ["គេក៏យកយើងឡើងទៅទប់ទល់ ទៅបំពាក់អាវុធឱ្យយើងគ្រប់ដៃ ដើម្បីជួយទប់ទល់វ៉ៃជាមួយវៀតណាម។ ការរៀបចំនេះគ្រាន់តែបំពាក់អាវុធហើយ គឺវៀតណាមមកពេញទាំងអស់។ ចេញពីស្ទឹងហាវមកចម្ការកៅស៊ូ។ វៀតណាមចូលពេញក្រុងហើយ"]។

ដោយចេតនា ការឃុំខ្លួនដោយខុសច្បាប់ ការធ្វើទារុណកម្ម និងការបង្កដោយចេតនាឲ្យការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ។

## ១. និដ្ឋភាពទូទៅ

370. នៅពេលទៅដល់តំបន់ស្វយ័តកំពង់សោម កងទ័ពកងពលលេខ ៣ ត្រូវបាន **មាស មុត** បញ្ជូនភ្លាមៗឲ្យទៅកាន់កាប់ និងការពារកោះនៅឆ្ងាយពីឆ្នេរដែលត្រូវបានអះអាងថាជាកម្មសិទ្ធិរបស់កម្ពុជា។ កោះទាំងនោះមានកោះរ៉ុង កោះរ៉ុងសន្លឹម កោះឫស្សី កោះថ្មី កោះសេះ កោះនៅប៉ែកខាងត្បូង ដូចជា កោះតាង កោះពូលូវ៉ៃ និងកោះព្រីង[1294]។ នៅខែ ឧសភា ឆ្នាំ ១៩៧៥ កងកម្លាំងរបស់ **មាស មុត** បានវាយវៀតណាមដែលកាន់កាប់កោះមានជម្លោះ កោះក្រចកសេះ[1295] និងកោះត្រល់

---

1294 សូមមើល ឧទាហរណ៍ ឯកសារ D1.3.30.2 របាយការណ៍របស់ មាស មុត ជូនបង៨៩ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៧៦ [ការពិភាក្សាពីការពង្រឹងកម្លាំងកងពល ១៦៤ នៅកោះសេះ កោះថ្មី កោះសំពោច កោះរាម និងវត្តមានរបស់ មាស មុត នៅកោះរ៉ុង និងកោះរ៉ុងក្រៅ ក្នុងពេលធ្វើរបាយការណ៍]។ ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.14, 21 ["នៅកោះសេះ វរៈ ៣៦៨ មានពីរអនុសេនាតូច ហើយកងពលលេខ ៣ មានពីរអនុសេនាតូច គេលាយគ្នា។ [...] ឆ.21៖ កងតំបន់ និងកងពលទី ៣ បញ្ជូនទៅកោះពូឡូវ៉ៃ កោះពូឡូវ៉ៃថ្មី កោះពូឡូវ៉ៃចាស់ កោះរ៉ុងសន្លឹម និងកោះរ៉ុងធំ ហើយនិងកោះម្នាស់ និងកោះតាង។ រួចកម្លាំងនៅសល់ប៉ុន្មាននៅដីគោក និងនៅលើកប៉ាល់ទាំងអស់"]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.4 ["កងខ្ញុំត្រូវបានបញ្ជូនទៅការពារកោះឫស្សី"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញិក ឆ.6 ["ប្រហែល២សប្តាហ៍ក្រោយរំដោះហើយ កងវរសេនាតូច ៣៨៦ ទាំងមូលត្រូវបានពង្រាយទៅតាមកោះរ៉ុង កោះពូឡូវ៉ៃ កោះតាង និងកោះព្រីង"]។ ឯកសារ D22.2.181 ចម្លើយរបស់ មាស មុត ទាក់ទងនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00249699, KH ERN 00742003 ["កងពលនេះ រក្សាទាហានឲ្យឈរជើងនៅតំបន់កំពង់សោម និងរាម និងកោះពូឡូវ៉ៃ [...] កោះព្រីង [...] កោះតាង កោះរ៉ុងសន្លឹម និងកោះសេះ'']។

1295 កោះនេះគេហៅ ពូឡូប៉ង់ហ្សង់ "Poulo Panjuang" (ឬ កោះពូឡូប៉ង់សង់ "Koh Poulo Tang Sang" ជាភាសាខ្មែរ) និង ថូ ចូវ (To Chou) ឬ ថូ ជូ (To Chu) ជាភាសាវៀតណាម។ កោះនេះត្រូវបានរងការវាយប្រហារលើកដំបូងដោយកងនាវាជើងទឹកខ្មែរនៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៥ ហើយត្រូវបានវៀតណាមដណ្តើមយកទៅវិញនៅចុងខែ ឧសភា ឆ្នាំ ១៩៧៥។ សូមមើល ឧទាហរណ៍ ឯកសារ D1.3.17.5 ណាយ៉ាន់ ចាន់ដា សត្រូវបងប្អូនឯង EN ERN 00192197-00912198។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.121, 126, 148-153, 156-163, 229 [ យោធានៃកងវរសេនាតូច ៣១០ ពន្យល់អំពីយោធាប្រហែល ៣០០ នាក់មកពីកងវរសេនាតូចរបស់គាត់រួមទាំងខ្លួនគាត់ផងត្រូវរងការវាយប្រហានៅកោះក្រចកសេះ (កោះពូឡូប៉ាំងសង់) នៅពាក់កណ្តាលឆ្នាំ ១៩៧៥ ហើយត្រូវគេចាប់ចង ចងមុខយើងជិតហើយយកទៅកោះត្រល់ ដែលនៅទីនោះ ពួកគេត្រូវបានឃុំខ្លួន ហើយធ្វើការក្នុងនាមជាឈ្លើយសឹកក្នុងរយៈពេល ៣ ខែ] ។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សាវ៉ាត់ ឆ.144 ["កងទ័ព

ចាប់ជំរិត និងសម្លាប់ប្រជាជន[1296]។ កងទ័ពតំបន់ ៣៧ ចាស់ដឹកនាំដោយ ជ័យ ហាន ហៅ ឆាន[1297] (ជាពិសេស កងវរសេនាតូច ៣៨៦)[1298] ស្ថិតក្រោមការគ្រប់គ្រងរបស់ **មាស មុត** និង

---

នៅល្បាត នៅកោះប៉ូឡូប៉ាំងសង់។ [...] កងទ័ពវៀតណាមវ៉ៃកោះបីគឺកោះប៉ូឡូប៉ាំងសង់ [...] កោះពូឡូវៃចាស់ និងពូលូវៃថ្មី។ [...] វៃចាប់កងទ័ពដែលនៅវៃនៅទីនោះ ៧០០ នាក់ យកទៅដាក់នៅកោះត្រល់"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.36 ["ពីដំបូង យើងទៅវាយយកកាន់កាប់កោះក្រចកសេះ។ បន្ទាប់មក វៀតណាមក៏វាយយើងកាន់កាប់កោះ ពូឡូវៃ។ [...] និងកោះក្រចកសេះឡើងវិញ"]។

1296 សូមមើល ជើងទំព័រ 1011។ ឯកសារ D54/6.1.12 ណាយ៉ាន់ ចាន់ដា ប្រតិចារឹកចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៩ ម៉ោង ០៩.៣២.៥០-០៩.៣៧.២៤, ១៣.៤៤.០០-១៣.៤៨.៤៨, ១៣.៥៥.២២-១៤.០៣.៤៣។ ឯកសារ D1.3.17.5 ណាយ៉ាន់ ចាន់ដា សត្រូវបងប្អូនឯង KH ERN 00191318 ["ដោយយកមកប្រើឡើងវិញនូវការទាមទារពីមុនមួយរបស់របស់កម្ពុជាទាក់ទងនឹងកោះភូកុក ខ្មែរហៅកោះត្រល់ ខ្មែរក្រហមបានវាយលុកតាមផ្លូវសមុទ្រចូលត្រួតត្រាលើកោះនោះយ៉ាងរហ័ស។ កងទ័ពទាំងនោះបានឡើងទៅលើកោះនៅថ្ងៃ ៤ ខែឧសភា ឆ្នាំ ១៩៧៥។ ប្រាំមួយថ្ងៃក្រោយមក ខ្មែរក្រហមបានវាយយកកោះពូឡូប៉ង់ហ្សង់ វៀតណាមហៅ ថូជូ ខ្មែរហៅកោះក្រចកសេះថែមទៀត។ ក្រោមការគំរាមកំហែងនៃអាវុធប្រជាជនវៀតណាម ៥០០ នាក់ត្រូវបានបណ្តេញចេញពីទីនោះ។ ហ្វៀន វ៉ាន់ថូត (Nguyen Van Tot) ដែលជាទាហានវៀតណាមខាងត្បូងនៅ Rach Gia ក្នុងពេលវាយប្រហារ បានបាត់បង់សមាជិកគ្រួសារទាំង ១២ នាក់របស់គាត់។ នៅពេលគាត់ត្រឡប់កោះពូឡូប៉ាំងសង់វិញ ៤ ខែក្រោយមក ផ្ទះរបស់គាត់ត្រូវបានបំផ្លិចបំផ្លាញ ហើយនៅលើកោះមានសុទ្ធតែលលាដ៍ក្បាល។ ពីរសប្តាហ៍ក្រោយការកាន់កាប់របស់ខ្មែរក្រហម វៀតណាមបានបើកការវាយបកមួយសងទៅវិញ ដោយបានសម្លាប់ខ្មែរក្រហមអស់ជាច្រើននាក់ និងចាប់បាន ៣០០ នាក់ជាឈ្លើយសឹក"]។

1297 ក៏មានឈ្មោះថា នង ឈន ដែរ។ ចំពោះតួនាទីរបស់គាត់ក្នុងនាមជាមេបញ្ជាការកងពល ១៦៤៖ ក៏មានឈ្មោះថា នង ឈន ដែរ។ ចំពោះមុខតួនាទីគាត់ជាមេបញ្ជាការកងពល១៦៤៖ ឯកសារ D114/277.2 កាំង ហ្គេកអ៊ាវ ហៅ ឌុច ប្រតិចារឹកចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ១១.០៧.១៣-១១.១០.២៣ ["ជ័យ ហាន ហៅ ឆាន់ [...] វាជាអនុលេខាកងពល ១៦៤ ជាមួយបង មុត"]។ ឯកសារ D114/159 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ឆ.33 ["មនុស្សដែលសំខាន់ជាងគេ ដែលចាប់ពីកំពង់សោមឈ្មោះ សៅ ឆាន ហៅ ហាន ដែលជាកូន នង សួន។ សូមកែឈ្មោះគឺ ជ័យ ហាន ហៅ ឆាន់"]។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ហៅ សារ៉េត ឆ.7 ["ក្រោយពីកងពលលេខ ៣ ប្តូរទៅជាកងពល ១៦៤ មានមនុស្សម្នាក់ឈ្មោះ តា ឆាន ដែលមកពីកោះកុងនៃតំបន់ ៣៧ ជាមួយនឹងយោធាប្រហែលពីរកងវរសេនាតូចចូលជាមួយកងពល ១៦៤។ តា ឆាន មកធ្វើជាអនុម្នាក់របស់កងពល"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.12 ["នៅមានអនុរបស់គាត់ពីរនាក់ទៀត ឈ្មោះ ឆាន និង ឌឹម។ ឌឹម គឺជាអនុទី ១ របស់ មាស មុត"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.267, 269 ["ស៖ អ្នកណាជាបញ្ជាការរងកងពល? ឆ.267៖ តា ឌឹម និង តា ឆាន។ [...] ឆ.269៖ តា ឆាន ជាអនុបញ្ជាការកងពល"]។

ពង្រឹងទីតាំងកងពលលេខ ៣ នៅលើកោះ[1299]។ បន្ថែមលើការការពារកោះដែលកម្ពុជាប្រជាធិបតេយ្យអះអាងថាជាកម្មសិទ្ធិរបស់ខ្លួន នៅក្នុងដែនសមុទ្រកម្ពុជា (សរុបប្រហែល ២០០ កោះ)[1300] កងទ័ព

1298 ឯកសារ D114/282 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.9 ["មុនដំបូងកងពលលេខ ៣ អត់ដឹងភូមិសាស្ត្រកំពង់សោមទេ។ ក្រោយមក ទើបវរៈ ៣៨៦ អ្នកនាំដាក់កន្លែងណា របៀបទៅណា ព្រោះយើងម្ចាស់ផែនដី ម្ចាស់កាន់កាប់ទឹកដី"]។ ឯកសារ D114/31 កំណត់ហេតុស្ដាប់ចម្លើយ មូល ឈិន ឆ.23 ["ពួកខ្ញុំ កងវរសេនាតូច ៣៣៦ ដែលស្គាល់ភូមិសាស្ត្រនៅទីនោះច្បាស់ គេឲ្យប្រចាំការនៅលើ កោះរ៉ុងហ្វា និងកោះរ៉ុងសន្លឹម"]។ ឯកសារ D114/113 កំណត់ហេតុស្ដាប់ចម្លើយ គឹម ម៉ែន ឆ.179-180 ["សៈ ពេលដែលលោកនៅកោះតាង តើលោកមានចាំថា មានកងទ័ពប៉ុន្មាននាក់ដែលមកពីតំបន់៣៧ទេ? ឆ.179៖ មកជាមួយបង ឆាន គឺមួយវរសេនាធំ ដែលមានបីវរសេនាតូច [...] ឆ.180៖ [...] ឲ្យតែមកជាមួយបង ឆាន គឺសុទ្ធតែមកពីតំបន់៣៧"]។ ឯកសារ D114/286 កំណត់ហេតុស្ដាប់ចម្លើយ ហ៊ាង វ៉េត ឆ. 12 ["យើងរៀបចំកងជើងទឹក ១៦៤ មក យើងក៏យកកងតំបន់ ៣៧ បញ្ចូលក្នុងកងពល ដែលកាន់កាប់កប៉ាល់ទាំងនោះ"]។ ឯកសារ D114/260 កំណត់ហេតុស្ដាប់ចម្លើយ ស៊ិន សុត ឆ.6-9។ ឯកសារ D114/104 កំណត់ហេតុស្ដាប់ចម្លើយ អៀម ភង់ ឆ.39។ ឯកសារ D54/101.1 ចម្លើយរបស់ ឯក នី ទាក់ទងនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00992727, KH ERN 01509142 ["កងពលធំខ្វះបុគ្គលិក និងបានប្រើប្រាស់កងវរសេនាតូចទី ៣៨៦ ដើម្បីផ្ដល់បុគ្គលិកដល់កោះសំខាន់ៗចេញពីឆ្នេរសមុទ្រកំពង់សោម"]។

1299 ឯកសារ D22.2.181 ចម្លើយរបស់ មាស មុត ទាក់ទងនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០១ EN ERN 00249693-00249694, KH ERN 00741996-00741997 ["ទីបញ្ជាការដ្ឋានភូមិភាគនិរតីបានបង្កើតកងពលធំលេខ ៣ ចេញពីសមាសភាពនៃតំបន់ ៣៧ និងកងវរសេនាតូចឯករាជ្យនៃភូមិភាគនិរតី។ [...] នៅពេលមានឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស ទីបញ្ជាការដ្ឋាននៃកងពលធំលេខ ៣ មានទីតាំងស្ថិតនៅរាម [...] កងពលធំនេះ មានកងវរសេនាធំលេខលេខ ៣៧, ១៤, ១៥ និង ១៦ ដែលស្ថិតនៅក្រោមបង្គាប់។ មូលហេតុដែលគេដាក់ឈ្មោះថាជាកងវរសេនាធំលេខ ៣៧ ពីព្រោះកងវរសេនាធំនេះ ត្រូវបានបង្កើតចេញពីកងកម្លាំងមកពីតំបន់ ៣៧"]។ ឯកសារ D114/261 កំណត់ហេតុស្ដាប់ចម្លើយ ជុំ ជី ឆ.2 ["ព្រោះកាលនោះ អង្គភាពរបស់ភូមិភាគនិរតីហៅកងពលលេខ ៣ ឆ្នាំ ៧៥ បែកភ្នំពេញ គេបញ្ជូនមកនៅកំពង់សោម។ រួចបានមកបញ្ចូលកងទ័ពតំបន់ ៣៧ និងកងទ័ពភូមិភាគនិរតីហៅកងពលលេខ ៣ បញ្ចូលគ្នាបង្កើតជាកងពល ១៦៤"]។ ឯកសារ D114/264 កំណត់ហេតុស្ដាប់ចម្លើយ ជុំ ជី ឆ.36 ["សៈ ប្រសិនបើកម្លាំងនេះជាការបូកបញ្ចូលគ្នារវាងកងពល ១៦៤/កងពលលេខ ៣ និងអង្គភាពយោធាតំបន់ ៣៧ តើប្រតិបត្តិការនេះធ្វើឡើងក្រោមការបញ្ជាទូទៅរបស់អ្នកណាដែរ? ឆ.36៖ ក្រោមការបញ្ជាទូទៅរបស់ មាស មុត ទាំងអស់"]។ ឯកសារ D4.1.754 សេចក្ដីថ្លែងការណ៍ទាក់ទងនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387427, 00387429, KH ERN 00791381, 00791383 [សេចក្ដីថ្លែងការណ៍របស់យោធាកងវរសេនាតូច ៣៨៦ ពីសម័យកាល ថ្ងៃទី ១៧ មេសា ១៩៧៥ ដូចខាងក្រោម៖ "នៅពេលនោះ កងអនុសេនាធំលេខ ៤០៨ មិនទាន់ក្លាយជាផ្នែកមួយចំណុះឲ្យកងពលធំលេខ ៣ នៅឡើយ" [...] ចម្លើយបន្ទាប់មកនេះ បញ្ជាក់ថាមេបញ្ជាការពលធំលេខ ៣ មានអំណាចទៅលើកងវរសេនាតូចលេខ ៣៨៦ និងកងអនុសេនាធំក្រោមចំណុះទាំងអស់ រួមទាំងកងអនុសេនាធំលេខ ៤០៨ ផង មុនខែកក្កដា ឆ្នាំ ១៩៧៥៖ "ក្រោយពីប្រភពព័ត៌មានបានបោះទីតាំងនៅលើកោះពូឡូវៃ

ជើងទឹកបានធ្វើការឃាមល្បាត ដើម្បីធានាថាគ្មានបរទេសចូលក្នុងដែនទឹកកម្ពុជា។ **មាស មុត** ផ្ដល់ការណែនាំច្បាស់លាស់ពាក់ព័ន្ធនឹងទូក ឬកប៉ាល់បរទេសដែលចូលក្នុងដែនទឹកទាំងនោះ៖ ត្រូវចាប់ ហើយប្រសិនបើទូក ឬកប៉ាល់ទាំងនោះព្យាយាមរត់ ឬតដៃ ត្រូវបាញ់ពន្លិច[1301]។

---

ថ្មី នៅក្នុងខែមេសា-ឧសភា ឆ្នាំ ១៩៧៥ អង្គភាពរបស់គាត់បានចាប់នាវាមួយគ្រឿងដែលបានដឹកជនភៀសខ្លួនវៀតណាមជាង ១០ នាក់ រួមទាំងស្ត្រី និងកុមារ។ [...] បន្ទាប់ពីពួកគេចាប់បាននាវានោះមក មេបញ្ជាការកងអនុសេនាធំលេខ ៤០៨ បានទាក់ទងក្រុងកំពង់សោមដើម្បីសុំការណែនាំស្ដីពីការចាត់ចែងជនភៀសខ្លួនទាំងនោះ។ មេបញ្ជាការថ្នាក់លើនៅក្រុងកំពង់សោមបានបញ្ជាឲ្យមេបញ្ជាការកងអនុសេនាធំនេះសម្លាប់ជនភៀសខ្លួនទាំងនោះ។ [...] មេបញ្ជាការ និងអនុបញ្ជាការកងអនុសេនាធំបានអនុវត្តតាមបញ្ជានេះ"]។ ឯកសារ D4.1.749 ចម្លើយរបស់ សេង ស៊ិន ហៅ កន និង ខៀវ នុក ទាក់ទងនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម KH ERN 00742590 ["នៅពេលលោក សេង ស៊ិន និង លោក ខៀវ នុក បានមកដល់កោះតាង កងវរសេនាតូចលេខ ៣៨៦ ដែលពីមុនស្ថិតក្រោមបញ្ជាការរបស់តំបន់ ៣៧ បានឋិតក្រោមបញ្ជាការនៃអតីតកងពលធំលេខ ៣ ហៅកងពលធំលេខ ១៦៤។ លោក សេង ស៊ិន និង លោក ខៀវ នុក គឺជាសមាជិកនៃកងអនុសេនាតូចលេខ ២ នៃកងអនុសេនាធំលេខ ៤៣ កងវរសេនាតូចលេខ ៣៨៦ កងវរសេនាធំលេខ ៦២ ក្នុងកងពលធំលេខ ១៦៤"]។ សម្រាប់ព័ត៌មានបន្ថែម សូមមើល IV. កងពលធំ ១៦៤ (អតីតកងពលធំលេខ ៣) រចនាសម្ព័ន្ធអំណាច ជាពិសេស កថាខណ្ឌ ២១១ ជើងទំព័រ ៥៨៦។

1300 ឯកសារ D98/1.2.22 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹក ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១២ ម៉ោង ១៤.១៧.៥-១៤.១៩.៣៨, ១៤.២១.១៤-១៤.២៤.២១ ["កងពល ១៦៤ នេះ វាការពារដែនសមុទ្រកម្ពុជា គឺបូរណភាពដែលទឹករបស់កម្ពុជាប្រជាធិបតេយ្យ។ [...] កងពល ១៦៤ គេៗមានភារកិច្ចការពារបូរណភាពដែនសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យរបស់គេ"]។ ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ១៣.៣៣.៤៨-១៣.៣៦.៣៩ ["កងទ័ពជាភារកិច្ចអ្នកការពារនៅទឹកដីព្រំដែនកោះនៅសមុទ្រ"]។ ឯកសារ D114/65 កំណត់ហេតុស្ដាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.11 ["នៅពេលខ្លះ មេបញ្ជាការកងវរសេនាតធំ ជាអ្នកប្រកាសនៅក្នុងរយៈពេលសន្និបាត។ ក្នុងពេលសន្និបាតនោះ គេក៏និយាយអំពីការការពារដែនសមុទ្រ និងព្រំដែនសមុទ្រ ដែលមានប្រវែងជាង ៤០០ គីឡូម៉ែត្រ ហើយនិងការការពារកោះរបស់កម្ពុជាដែលមានជិត ២០០កោះ"]។ ឯកសារ D114/79 កំណត់ហេតុស្ដាប់ចម្លើយ កង សុំ ឆ.114 ["ស៖ តើកងទ័ពជើងទឹកនៅឯណា? ឆ.114៖ នៅផ្សារកំពង់សោម រាម ព្រលានយន្តហោះកងកេង នៅលើមួយជួរកោះទាំងអស់ កោះជាង ២០០ កោះ"]។ ឯកសារ D114/105 កំណត់ហេតុស្ដាប់ចម្លើយ កុច ទុយ ឆ.30 [រៀបរាប់អំពីកោះជាច្រើនផ្សេងៗ រួមមានកោះមួយចំនួនដែលគេមិនសូវស្គាល់៖ កោះតាង កោះរ៉ុងក្រៅ កោះរ៉ុងក្នុង កោះម្នាស់ កោះយ៉ កោះសាលី កោះថ្មី កោះព្រីង]។ ឯកសារ D114/95 កំណត់ហេតុស្ដាប់ចម្លើយ យឹម ស្រឿន ឆ.34 ["ស៖ តើមានគេប្រាប់លោកថា ហេតុអ្វីបានគេបញ្ជូនកងពលធំទៅកំពង់សោមដែរទេ? ឆ. 34៖ គេប្រាប់យើងថា ដើម្បីការពារទឹក ការពារដី និងការពារកោះ។ ទឹក គឺសំដៅសមុទ្រ"]។

1301 ឯកសារ D54/23 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.25-26 ["បើយើងឃើញទូក ឬក៏កប៉ាល់នៅលើដែនទឹករបស់យើង យើងនឹងរាយការណ៍តាមវិទ្យុទាក់ទងទៅវរសេនាតូច ហើយបញ្ជាការដ្ឋានរបស់វរសេនាតូចរាយការណ៍ឲ្យវរសេនាធំ។ វរសេនាធំរាយការណ៍បន្តទៅកងពល។ រួចហើយទើបកងពលបញ្ជាតាមខ្សែរយៈត្រឡប់ចុះមកវិញថា តើ

371. ការអនុវត្តការណែនាំទាំងនេះមានភាពសាំញ៉ាំ ដោយហេតុថា អង្គភាពយោធាកងពល ៣/១៦៤ ដែលឈើជើងនៅលើកោះ មិនបានទទួលការបណ្តុះបណ្តាលណាមួយ ពាក់ព័ន្ធនឹងទីតាំងនៃព្រំដែនសមុទ្ររបស់ប្រទេសកម្ពុជាទេ។ ពួកគេមិនត្រូវបានប្រាប់ថា តើតំបន់ និងកោះណា (រួមទាំងកោះក្រចកសេះ) ស្ថិតក្នុងជម្លោះជាមួយវៀតណាម ឬថៃ ឬថាតើដែនទឹកអន្តរជាតិចាប់ផ្តើមពីកន្លែងណាទៅទេ[1302]។ ជាលទ្ធផល កងពលបានបកស្រាយដែនទឹករបស់ពួកគេក្នុងលក្ខណៈទូទៅ ហើយ

---

យើងគួរធ្វើយ៉ាងម៉េចជាមួយទូក កប៉ាល់ ហើយនិងមនុស្សដែលយើងចាប់បាន។ ពេលនោះ កងវរសេនាតូចនឹងបញ្ជាមកយើងថា តើយើងគួរសម្លាប់អ្នកដែលយើងចាប់នោះនៅសមុទ្រតែម្តង ឬយកឡើងមកកោះ។ បើសិនជាយើងចាប់បានទូកយួន ពេលខ្លះយើងទទួលបញ្ជាឲ្យបាញ់សម្លាប់ចោលនៅនឹងកន្លែង ហើយយកតែទូកមកកោះតែប៉ុណ្ណោះ។ [...] សៈ តើវាជាច្បាប់ឬ ដែលលោកត្រូវតែរាយការណ៍ទៅឲ្យវរសេនាតូចជាមុន មុននឹងអនុវត្តកិច្ចការអ្វីមួយ ឬក៏ [...] ឆ.26៖ ប្រសិនបើយើងបញ្ជាឲ្យកាណូតណាមួយឲ្យឈប់ តែគេមិនស្តាប់តាមបញ្ជាយើងនោះ យើងអាចបាញ់ពន្លិចតែម្តង។ ខ្ញុំផ្ទាល់មិនដែលបាញ់កាណូតដោយខ្លួនឯងទេ តែអ្នកនៅក្នុងអង្គភាពរបស់ខ្ញុំធ្លាប់បានបាញ់ពន្លិចកាណូត ហើយការបាញ់ពន្លិចនេះ គឺជាបញ្ជាអនុវត្តទូទៅរបស់កងពល"]។

1302 ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ១៤.៤៤.៣៥-១៤.៤៧.៤៩ ["គ្មានដឹងច្បាប់ ដឹងទម្លាប់ដែលផ្លូវអន្តរជាតិ មិនអន្តរជាតិទេ"]។ ឯកសារ D234/2.1.92 ព្រុំ សារ៉ាត ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ១៥.៤៩.១២-១៥.៥២.៣៨ ["មានថ្ងៃមួយនោះ ខ្ញុំជួបជនជាតិយួនម្នាក់ និងជនជាតិក្លឹងម្នាក់ ដែលនៅលើកោះ [...] ហ្នឹងតាមដែលខ្ញុំស្គាល់នៅលើផែនទី មិនមែន --។ អ្វីដែលខ្ញុំបញ្ជាក់ពេលនេះគ្រាន់តែថា អ្នកដែលចាប់ហ្នឹង ទៅចាប់ពីណាមក ចាប់ពីដែនទឹកវៀតណាម ឬចាប់នៅដែនទឹកកម្ពុជា"]។ ឯកសារ D114/13 កំណត់ហេតុស្តាប់ចម្លើយ នាក់ យឿន (សមាជិកក្រុមនារីកក្នុងកងវរសេនាធំ ១៤០) ឆ.17 ["សៈ តើអ្នកធ្វើការនៅលើនាវា និងយោធាដែលឈរជើងនៅតាមកោះដឹងអំពីដែនទឹកអន្តរជាតិដោយរបៀបណាទៅ? ឆ.17៖ ខ្ញុំមិនដឹងពីរឿងនេះទេ"]។ វាគឺនៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៨ ដែលថា អៀង សារី បានចេញសេចក្តីថ្លែងការណ៍កំណត់នូវអ្វីដែលជាដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ (ដោយគ្មានការលើកឡើងពីភាពជាក់លាក់បន្ថែម)៖ ឯកសារ D69.1.23 សេចក្តីថ្លែងការណ៍របស់ អៀង សារី ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ១៩៧៨ EN ERN S00011315 ["កម្ពុជាប្រជាធិបតេយ្យបានប្រកាន់យកអធិបតេយ្យភាពពេញលេញ និងទាំងស្រុងនៅលើដែនសមុទ្ររបស់ខ្លួន ដែលមានបណ្តោយប្រវែង ១២ ម៉ាយ៍ ដែលត្រូវបានវាស់វែងចេញពីបន្ទាត់ព្រំដែនមូលដ្ឋាន។ [...] ប្រើប្រាស់សិទ្ធិក្នុងការត្រួតពិនិត្យទៅលើតំបន់ជាប់ឆ្នេរ ដែលលាតសន្ធឹងប្រវែង ១២ ម៉ាយ៍ ពីព្រំដែនទឹកខាងក្រៅ។ [...] កោះទាំងអស់របស់កម្ពុជាប្រជាធិបតេយ្យមានដែនសមុទ្ររបស់ខ្លួន ដែនជាប់ឆ្នេររបស់ខ្លួន ដែនសេដ្ឋកិច្ចផ្តាច់មុខរបស់ខ្លួន និងខ្ពង់រាបក្នុងដីទ្វីបរបស់ខ្លួន។ [...] រដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យចាត់វិធានការសមស្រប ដើម្បីរក្សាទាំងស្រុងនូវអធិបតេយ្យភាព សិទ្ធិ និងផលប្រយោជន៍នៃកម្ពុជាប្រជាធិបតេយ្យនៅលើដែនសមុទ្ររបស់ខ្លួន"]។

ទូកបរទេសជាច្រើនត្រូវបានចាប់ ដោយមិនច្បាស់សោះថា ទូកទាំងនោះបានចូលក្នុងដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យឬអត់[1303]។

372. ក្រោយការបង្កើតកងពលមជ្ឈិម ១៦៤[1304] និងការប្តូរឈ្មោះកងវរសេនាធំលេខ ២០, ២១ និង ២២ ទៅជាកងវរសេនាធំលេខ ៦១, ៦២ និង ៦៣ វិញនៅខែ កក្កដា ឆ្នាំ ១៩៧៥ កងទ័ពកងវរសេនាធំលេខ ៦១ បានកាន់កាប់កោះកុង និងកោះរ៉ុង (កោះរ៉ុងធំ និងកោះរ៉ុងសន្លឹម)[1305]។ កងវរសេនាធំលេខ ៦២ ឈរជើងនៅលើកោះនៅប៉ែកនិរតី គឺកោះតាង កោះពូលូវ៉ៃ (ថ្មី និងចាស់) កោះព្រីង

---

[1303] សាក្សីមួយចំនួនបានឲ្យដឹងថានេះជាករណីនាវាដឹកទំនិញម៉ាយ៉ាហ្គេស៖ ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ០៩.៣០.០៥-០៩.៣៥.១២ ["ហើយក៏បានឡើងទៅលើកប៉ាល់ដែលម៉ាយ៉ាហ្គេសនោះ ដែលចាប់មកពីផ្លូវអន្តរជាតិតែម្តង"]។ ឯកសារ D54/28 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន (កម្មាភិបាលរបស់កងវរសេនាធំ ១៤០) ឆ.18 ["ស៖ ពេលនោះ តើលោករៀនអំពីដែនទឹកប្រទេសកម្ពុជាដែរឬទេ? ឆ.18៖ នៅខ្ញុំត្រូវបានហ្វឹកហ្វឺនអំពីច្បាប់ព្រំដែនទឹកផងដែរ ដោយសារការរៀននោះ ទើបខ្ញុំបានដឹងថា ការចាប់នាវាម៉ាយ៉ាហ្គេស គឺខុស"]។ ឯកសារ D114/58 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.1 ["មានករណីមួយទៀតដែលខ្ញុំបានឮអំពីនាវាមួយដែលត្រូវបានចាប់នៅលើដែនសមុទ្រអន្តរជាតិ។ នោះគឺជានាវាមួយដែលត្រូវបានចាប់ដោយនាវាជើងទឹកនៅចន្លោះកោះពូឡូវ៉ៃ និងកោះក្រចកសេះ។ នាវានោះមានទំហំធំ ហើយមិនអាចអូសយកមកផែកំពង់សោមបានឡើយ។" (គូសបញ្ជាក់បន្ថែម)]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN ERN 00978569, KH ERN 00955497-00955498 ["ស៖ ម៉ាយ៉ាហ្គេសហ្នឹងយ៉ាងម៉េចបានជាគេចាប់? ឆ៖ ទេ មិនដឹងដែរ យើងដូចជាចោរព្រៃតែម្តងយើងទៅចាប់គេដោយខុសច្បាប់។ ស៖ ចឹងយើងចាប់ខុសច្បាប់? ឆ៖ ចាប់ខុសច្បាប់ កប៉ាល់គេហ្នឹងគេរត់នៅលើផ្លូវអន្តរជាតិរបស់គេ ហើយផ្លូវអន្តរជាតិហ្នឹង វាឃ្លាតពីកោះពូឡូវ៉ៃប្រហែលជា ១០ គីឡូ"]។

[1304] សូមមើល កថាខណ្ឌ ២១៤។

[1305] Dឯកសារ D114/57 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ កេត ឆ.8 ["អង្គភាពដែលស្ថិតនៅលើកោះរ៉ុងសន្លឹម គឺស្ថិតនៅក្រោមកងវរសេនាធំ ៦១។ ក្រោមវរសេនាធំលេខ ៦១ មានកោះ ដូចជា កោះកុង កោះរ៉ុងធំ និងកោះរ៉ុង"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន សារ៉ាត់ ឬ ព្រំ សារ៉ាត់ ឆ.141 ["វរសេនាធំ ៦១ បោះនៅកោះតាង"]។ ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.6។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល EN ERN 00968388, KH ERN 00926615 ["ឯអារ៉ុង កោះរ៉ុងធំ អារ៉ុងមានខ្លានោះ នឹងគេដាក់វរសេនាធំ ៦១។"]។ ឯកសារ D59/1/1.7a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ា ឈឿន EN ERN 00969931, KH ERN 00926308 ["៦១ នៅខាងកោះរ៉ុង"]។

កោះវាល និងកោះតូចៗមួយចំនួន[1306] ហើយកងវរសេនាធំលេខ ៦៣ ឈរជើងនៅលើកោះសេះ និងកោះថ្មី នៅជិតកោះត្រល់ (វៀតណាម)[1307]។

373. ដំបូង កងវរសេនាធំ និងកងវរសេនាតូចដែលប្រចាំការនៅលើកោះ មានកប៉ាល់ល្បាតល្បឿនលឿន (ប៉េសេអេហ្វ) របស់អាមេរិកចាស់ពីរបីប៉ុណ្ណោះសម្រាប់ប្រើប្រាស់[1308]។ បន្ទាប់ពីកងវរសេនាធំ

---

1306 ឯកសារ D54/78 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល ឆ.11 ["សួ៖ តើមានកោះប៉ុន្មានដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់កងវរសេនាធំ ៦២? ឆ.11៖ មាន កោះតាង កោះព្រីង កោះវៀ កោះពូឡូវៃថ្មី ហើយនិងកោះតូចៗមួយចំនួនទៀត"]។ ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.6 ["វរសេនាធំលេខ ៦២ គឺជាកងវរសេនាធំជើងទឹកវៃលើគោករបស់កងពល ១៦៤"]។ ឯកសារ D114/57 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ កេត ឆ.9 ["ខ្ញុំបានគូសតំបន់ដែលស្ថិតនៅក្រោមចំណុះកងវរសេនាធំ៦២ កោះទាំងនោះរួមមាន កោះតាង កោះព្រីង និងកោះពូឡូវៃ"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.35 ["មេវរសេនាធំ ៦២ ឈ្មោះ តាមៀញ កាន់នៅកោះពូឡូវៃ កោះព្រីង និងកោះតាង"]។ ឯកសារ D114/283 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ហៅ អ៊ីក ឆ.52 ["នៅកោះតាង គឺវរសេនាធំ ៦២"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន សារ៉ាត់ ឬ ព្រំ សារ៉ាត់ ឆ.141 ["វរសេនាធំ ៦២ បោះនៅកោះតាង និងកោះពូឡូវៃចាស់ និងពូឡូវៃថ្មី"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ.59 ["ក្រោយការរៀបចំជាថ្មី វរសេនាតូច ៦៦២ ទៅនៅកោះពូឡូវៃចាស់ ហើយ ៦២៣ ទៅកោះតាង ហើយ ៤៨០ ទៅកោះពូឡូវៃថ្មី (មានមេបញ្ជាការ ឈ្មោះ នន)"]។ ឯកសារ D54/78.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល EN ERN 00968388, KH ERN 00926615 ["ដែលការពារកោះហ្នឹងមាន ៤ វរៈហ្នឹង កោះដូចខ្ញុំថាអ៊ីចឹង ៦២៤ ហ្នឹងមានកម្លាំងខ្លះមកធ្វើស្រែ តែការពារកោះពូឡូវៃថ្មី កោះតាង កោះព្រីង កោះវៀរ ក្រោយមកបង្រួមនៅប៉ុណ្ណឹង ពីមុនការពារនៅកោះរ៉ុងទៀត។ [...]សួ៖ ចុះអានេះវរសេនាធំ ៦២ ហ៎? ឆ៖ បាទ! អាខាងប៉ុន្មានកោះខ្ញុំរាប់មិញនេះ ៦២"]។

1307 ឯកសារ D114/57 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ កេត ឆ.9 ["ខ្ញុំបានគូសតំបន់ដែលស្ថិតនៅក្រោមចំណុះកងវរសេនាធំលេខ ៦៣ កោះទាំងនោះមានដូចជា កោះសេះ កោះថ្មី និងព្រែកចាក ដែលស្ថិតនៅខាងកើតរាម"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន សារ៉ាត់ ឬ ព្រំ សារ៉ាត់ ឆ.141 ["វរសេនាធំ ៦១ បោះនៅកោះរ៉ុងធំ។ វរសេនាធំ៦២ បោះនៅកោះតាង និងកោះពូឡូវៃចាស់ និងពូឡូវៃថ្មី។ ៦៣ វរសេនាធំ ៦៣ បោះនៅកោះថ្មី និងកោះសេះ "]។ ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.6 ["វរសេនាធំលេខ ៦៣ ក្រោមតា ញ៉ាន់ ប្រតិបត្តិការនៅកោះសេះ កោះអន្លាយ កោះខ្យង។ គេអត់មានកប៉ាល់ចម្បាំងទេ ប៉ុន្តែគេមានកាណូតដឹកជញ្ជូនរបស់គេ"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.35 ["វរសេនាធំ៦៣ មានមេបញ្ជាការឈ្មោះ បង យ៉ាន កាន់នៅកោះសេះ កោះតាគាវ កោះថ្មី ម្តុំរាម មកចម្ការដូង កងកេង"]។

1308 ឯកសារ D54/34 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង ឆុន ឆ.14 ["នៅកោះកុង ក្នុងពេលនោះ គេមាននាវាចម្បាំងធុនប៉េសេអេហ្វ (PCF) ចំនួនពីរគ្រឿង ដែលបោះទីតាំងនៅទីនោះ"]។ ឯកសារ D2/16 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.30 ["សួ៖ ពួក PCF តើជាផ្នែកមួយរបស់កងវរសេនាធំ១៤០ ឬកងជើងទឹកនៅលើដី? ឆ.30៖

១៤០ (កងទ័ពជើងទឹក) ត្រូវបានបង្កើតឡើងនៅខែ កក្កដា ឆ្នាំ ១៩៧៥[1309] ប្រទេសចិនចាប់ផ្តើមផ្តល់ឲ្យកងទ័ពជើងទឹក នូវកប៉ាល់ និងនាវាចម្បាំងបន្ថែមទៀត រួមមាន នាវាប្រដេញ នាវាការពារ នាវាប្រឆាំងនាវាមុជទឹក និងនាវាវាវមីន[1310]។

---

[...] ពួកគេមិនបានចតនៅឆ្នេរអូឈើទាលទេ"]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.24 ["ក្រោយមក គេឲ្យខ្ញុំបើកកប៉ាល់ PCF ហើយនៅវាមកប៉ាល់ PCF មានលេខ ១០១, ១០២, ១០៣, ១០៤"]។ ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល ឆ.3 ["នាវា PCF គឺមានលក្ខណៈសមស្របជាងគេក្នុងការចាប់ទូក។ នាវា PCF មានលក្ខណៈទំនើប លឿន និងបំពាក់ដោយអាវុធគ្រប់គ្រាន់"]។ ឯកសារ D54/115.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នាក់ យឿន EN ERN 01088458, 01088470,KH ERN 01007857, 01007870 ["PCF របស់អាមេរិកាំងដែលយើងវាយបាន។ [...] ប្រើការ អាហ្វ៊ីងមាន ៨០។ [...] កាំភ្លើងត្បាល់ ហើយមាន ១២អី នៅលើហ្វ៊ីងដែរ។ [...] អី PCF ច្រើនណាស់ ១៦ នោះ បើគ្រប់កោះ ម៉ាកោះមួយ កោះ២។ ហើយកោះរ៉ុងប្រចាំការនៅកោះដែរ ប៉ុន្តែ នៅកំពង់សោម នៅជិតគ្នា"]។ ឯកសារ D4.1.758 ចម្លើយរបស់អ្នកដែលគេមិនស្គាល់ឈ្មោះ ទាក់ទងនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387312-00387313, KH ERN 01506014-01506015 ["នាវាការពារ៖ នាវាការពារ រួមមាន កប៉ាល់ចាស់ ២គ្រឿងប្រភេទ PCF របស់អាមេរិក [...] នាវាចាស់ ២គ្រឿងប្រភេទ PCF របស់អាមេរិកបង្កើតបានជាកងនាវា១ និងបោះមូលដ្ឋាននៅកោះកុង"]។

1309 សូមមើល ឧទាហរណ៍ ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.18-19 ["នៅខែសីហា ឆ្នាំ ១៩៧៥ កងពលថ្មី ១៦៤ ត្រូវបានបង្កើតឡើង [...] ឆ.19៖ [...] មឿន ម៉ុន [...] មេបញ្ជាការអនុសេនាធំ និង ហេង ហុក ដែលជាមេបញ្ជាការកងអនុសេនាធំ ដែលស្ថិតនៅក្នុងកងវរសេនាតូច ៤៨០។ ពួកគេបានប្រាប់ខ្ញុំថា កងពលធំលេខ ៣ បានប្តូរទៅជាកងពលធំលេខ ១៦៤ ហើយក៏មានការបង្កើតនូវកងពលតូចមួយទៀតដែរ គឺកងពលតូចលេខ ១៤០ ដែលជាកងជើងទឹក"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.38 ["នៅឆ្នាំ ១៩៧៦ គេបានបង្កើតវរសេនាធំ ១៤០ គឺជាអង្គភាពជើងទឹក។ ចំណែកវរសេនាធំលេខ ៦១, ៦២, ៦៣ គេទៅនៅតាមកោះ។ ពេលនោះ ខ្ញុំរៀនបច្ចេកទេសកប៉ាល់ គឺនាវាចរ"]។ ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.16 ["នៅពេលនោះមានការរៀបចំកងទ័ពជើងទឹក។ គឺគេរើសចេញពីកងវរសេនាធំ ៦១, ៦២, ៦៣ របស់កងពល ១៦៤ រៀបចំទៅជាកង ១៤០ ដោយបញ្ចូលកងវរសេនាធំដែលបញ្ជូនមកពីខាងបូព៌ា ដែលហៅថាកង ១៤០"]។ ឯកសារ D4.1.758 ចម្លើយទាក់ទងនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387312, KH ERN 01506014 ["កងវរសេនាធំលេខ ១៤០ នៃកងទ័ពជើងទឹក៖ នៅអំឡុងខែ សីហា ឆ្នាំ ១៩៧៥ កងពលធំលេខ ១៦៤ (កងពលធំលេខ ៣) បានបង្កើតកងវរសេនាធំលេខ ១៤០ នៃកងទ័ពជើងទឹក។ កងវរសេនាធំនេះមាន ២ ផ្នែក៖ អង្គភាពកងទ័ពជើងទឹក និងអង្គភាពកងទ័ពថ្មើរជើងនៃកងទ័ពជើងទឹក"]។

1310 សូមមើល ឧទាហរណ៍ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត់ ឆ.25 ["ខ្ញុំមិនចាំអំពីចំនួនទូក កាណូតតូចៗនោះទេ តែខ្ញុំនៅចាំចំនួនកប៉ាល់/នាវាជើងទឹករបស់កងវរសេនាធំ ១៤០។ ពីពាក់កណ្តាលឆ្នាំ ១៩៧៦ រហូតដល់ឆ្នាំ ១៩៧៨ កងវរសេនាធំ ១៤០ មាននាវាផុនការពារចំនួន ១០ គ្រឿង នាវាបណ្តែត ១០ គ្រឿង កប៉ាល់ដឹកប្រេង ១ គ្រឿង កប៉ាល់បោសសម្អាតមីនចំនួន ៤ គ្រឿង"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.40

374. នាវាតូចៗដែលជាកម្មសិទ្ធិរបស់កងវរសេនាធំលេខ ៦១, ៦២ និង ៦៣ ត្រូវបានបញ្ជាឱ្យការពារកោះ និងឆ្នេរ និងចាប់កប៉ាល់តូចៗដែលចូលក្នុងដែនទឹក[1311] ខណៈដែលនាវាធំៗ រួមទាំងនាវា

---

["ទូកដែលចិន ជំនួយមកចំនួន៣ សម្រាប់ដោះមីន នៅតាមទន្លេមេគង្គ ត្រូវបានគេយកមកប្រើប្រាស់សម្រាប់ចាប់ទូកនេសាទទាំងនោះនៅសមុទ្រ"]។ ឯកសារ D114/281 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី ឆ.16 ["នាវាការពារ ១២៥ តោន [...] នេះជានាវាជំនួយពីចិនទាំងអស់"]។ ឯកសារ D4.1.758 សេចក្តីថ្លែងការណ៍ទាក់ទងនឹងឈ្លើយសឹកអាមេរិក និងអ្នកបាត់ខ្លួនក្នុងសង្គ្រាម EN ERN 00387312-0037313, KH ERN 01506014-01506015 ["នាវាការពារ៖ នាវាការពារ រួមមាន កប៉ាល់ចាស់ ២ គ្រឿងប្រភេទ PCF របស់អាមេរិក និងនាវាវាយប្រហាររហ័ស ៧ គ្រឿងរបស់ចិន។ [...] នាវាចាស់ ២ គ្រឿងប្រភេទ PCF របស់អាមេរិក បង្កើតបានជាកងនាវា១ និងបោះមូលដ្ឋាននៅកោះកុង។ [...] នាវា ៧ គ្រឿងរបស់ចិនមានលេខរៀងពី ១០១ ដល់ ១០៧"]។

1311 ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.6, 17 ["គេអត់មានកប៉ាល់ចម្បាំងទេ ប៉ុន្តែ គេមានកាណូតដឹកជញ្ជូនរបស់គេ។ កង័ទពទាំងនេះធ្វើការចាប់ចងមនុស្សណាដែលឆ្លងចូលដល់ដែនទឹកកម្ពុជា ក្នុងតំបន់ប្រតិបត្តិការរបស់គេ។ [...] ឆ.17៖ [...] ខ្ញុំបានដឹងថាយោធានៅក្នុងកងវរសេនាធំលេខ ៦២ របស់ខ្ញុំនេះ ក៏ធ្លាប់ចាប់បានកាណូត និងមនុស្សផ្សេងៗទៀតដែរ។ ខ្ញុំធ្លាប់បានឃើញកាណូតដែលពួកកងរបស់ខ្ញុំចាប់បាន ហើយយកមកទុកនៅកោះតាង"]។ ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល ឆ.3 ["កងវរសេនាធំ ៦២ ត្រួតពិនិត្យមើលកិច្ចការសហការរវាងអង្គភាពផ្សេងៗ ដែលចូលរួមនៅក្នុងការចាប់ទូកនោះ ត្រួតពិនិត្យចំនួនមនុស្សនៅលើទូក ចំណុះរបស់ទូក និងសម្ភារៈផ្សេងៗទៀតនៅលើទូក។ [...] តាមការសម្គាល់របស់ខ្ញុំ កងវរសេនាធំ ៦២ គេពិនិត្យទូក និងមនុស្សដែលបានចាប់ និងបញ្ជូនទៅកំពង់សោមជាមួយនឹងរបាយការណ៍"]។ ឯកសារ D114/105 កំណត់ហេតុស្តាប់ចម្លើយ កុច ទុយ ឆ.48, ឆ.53 ["ពេលនោះ ពួកយើងផ្លាស់ចល័តទៅតាមយាម រហូតដល់យាមទី៣ ប្រហែលជាម៉ោងប្រាំបី ឬប្រាំបួនយប់ នៅពេលដែលកប៉ាល់ខ្ញុំទៅដល់បានឃើញទូកឈើថៃនោះតាមរយៈរ៉ាដា។ ពួកខ្ញុំក៏ចេញកប៉ាល់ទៅ និងបានចាប់ទូកនោះ ដោយបញ្ជូនមនុស្សនៅក្នុងនោះទៅកំពង់សោម និងយកទូកឈើមកកោះតាំងដោយយកត្រីពីលើទូក និងអីវ៉ាន់ចេញ ដោយចំណាយបី ឬបួនថ្ងៃ និងយកទូកនោះទៅកងពលលេខ ៤ នៅកំពង់សោមតែម្តង។ មនុស្សនៅលើទូកនោះមានច្រើននាក់ដែរ តែខ្ញុំមិនចាំចំនួនប៉ុន្មានទេ។ [...] ឆ.53៖ ជាធម្មតាប្រសិនពួកគេតដៃ ពួកយើងនឹងបាញ់។ ប៉ុន្តែក្នុងករណីនេះ ពួកគេមិនបានធ្វើអ្វីទេ ដូច្នេះពួកខ្ញុំក៏បានបើកកប៉ាល់អែបនឹងទូក និងបានលោតចូលទូក ហើយប្រាប់ពួកគេឱ្យលើកអួនឡើង យកត្រីទៅដាក់កន្លែងស្តុកត្រីដាក់ទឹកកកអីត្រឹមត្រូវ និងឱ្យមនុស្សនៅមួយឡែក។ រួចហើយ ទើបឱ្យគេបើកកប៉ាល់នោះមកកំពង់សោមដាក់ពួកថៃទាំងនោះចុះ ហើយពួកខ្ញុំបានយកទូករបស់គេទៅកោះតាងវិញ"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ.28 ["កងវរសេនាធំ៦១, ៦២ និង ៦៣ មានភារកិច្ចការពារតាមឆ្នេរសមុទ្រ និងកោះ។ កងវរសេនាធំ ១៤០ គ្រប់គ្រងនាវាទាំងអស់"]។ ឯកសារ D59/1/1.8a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រំ សារ៉ាត់ EN ERN 00974211, 00974208, KH ERN 00926389, 00926390, 00926386 ["តាមការដែលខ្ញុំដឹង ខ្ញុំធ្លាប់ដឹងតែមួយទេ គឺថាជនជាតិខ្លឹងហ្នឹង ខ្លឹងហ្នឹងគឺខ្លឹងពិត ឬខ្លឹងអីទេ [...] ស៖ កាលហ្នឹងយើងចូលមកកោះណា យើងចាប់បាននៅកោះ? ឆ៖ ពូលូវ៉ៃ។ [...] កាណូតពួអ្នក ចាប់បានហើយក៏។ [...] ប្រយុទ្ធលើគោក មានភារកិច្ចការការពារកោះ អ្នកចាប់ពួកហ្នឹង"]។

យោធា ជាទូទៅ ត្រូវបាននាវាកងវរសេនាធំ ១៤០ បណ្តេញចេញ កម្ទេច ឬចាប់[1312]។ នេះតម្រូវឱ្យមានការសម្របសម្រួល និងទំនាក់ទំនងគ្នាជាអចិន្ត្រៃយ៍រវាងអង្គភាពទាំងនោះ និងទីបញ្ជាការកងពល ១៦៤។ គណៈកងពល ១៦៤ ក្រោមបញ្ជារបស់ **មាស មុត** ដើរតួនាទីចម្បងក្នុងប្រព័ន្ធទំនាក់ទំនងនេះ ពីព្រោះអ្វីៗក៏ដោយឱ្យតែពាក់ព័ន្ធនឹងការដេញកប៉ាល់បរទេស ការប្រើប្រាស់កម្លាំង ការបំផ្លាញ ឬចាប់កប៉ាល់បរទេស ឬជោគវាសនារបស់អ្នកដែលជិះលើកប៉ាល់នោះ គឺមានតែ **មាស មុត** ឬអនុរបស់គាត់ប៉ុណ្ណោះ ជាអ្នកសម្រេច[1313]។

## ២. បញ្ជា និងទំនាក់ទំនងរបស់កងពល ១៦៤ ពាក់ព័ន្ធនឹងការចាប់ទូក/ពលរដ្ឋបរទេសនៅសមុទ្រ

375. នាវាកងទ័ពជើងទឹកអាចចុះបេសកម្មបានតែបន្ទាប់ពីបានទទួលបញ្ជាពី **មាស មុត** តាមសារទូរលេខ ឬវិទ្យុប៉ុណ្ណោះ[1314]។ **មាស មុត** បញ្ជូនបញ្ជាឱ្យអ្នកកាន់សារទូរលេខនៅលើកោះ បន្ទាប់

---

[1312] ឯកសារ D2/10 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.1, ឆ.28-29, ឆ.31 ["ភារកិច្ចចម្បងរបស់នាវាប្រដេញនេះ តាមការណែនាំរបស់ថ្នាក់លើ គឺរង់ចាំការបញ្ជាពីថ្នាក់លើនៅពេលណាមានការប្រយុទ្ធ។ [...] ឆ.28៖ ថ្វីបើគេហៅថា នាវាការពារក៏ដោយ ភារកិច្ចរបស់វាគឺសម្រាប់ប្រយុទ្ធ។ នេះគឺសម្រាប់កងនាវាប្រភេទនេះនៅក្នុងប្រទេសកម្ពុជា។ ស៖ តើការខុសគ្នាយ៉ាងដូចម្តេចខ្លះចំពោះភារកិច្ចរបស់កងនាវាប្រដេញ និងកងនាវាការពារហ្នឹង នៅក្នុងកាលៈទេសៈដំណាក់កាលទីមួយ និងដំណាក់កាលទីពីរ? ឆ.29៖ ការខុសគ្នានៃភារកិច្ចរបស់កងនាវាទាំងពីរនេះ គឺមិនមានខុសគ្នាច្រើនទេនៅក្នុងប្រទេសកម្ពុជា។ ភារកិច្ចនៃកងទាំងពីរគឺប្រយុទ្ធ។ ភារកិច្ចដែលខុសគ្នារបស់កងនាវាការពារ គឺកងនេះត្រូវបានរាយទៅប្រចាំការនៅកន្លែងផ្សេងៗតាមកោះ ហើយរង់ចាំបញ្ជាសម្រាប់ប្រយុទ្ធ ប៉ុន្តែ សម្រាប់កងនាវាប្រដេញ គឺមិនរាយទៅគ្រប់កន្លែងអ៊ីចឹងទេ គឺរង់ចាំតែបញ្ជាប្រយុទ្ធ។ [...] ឆ.31៖ សូម្បីតែយើងឃើញនាវាបរទេសរំលោភចូលមកក្នុងដែនយើងក្តី ក៏យើងមិនធ្វើអ្វីតបភ្លាមដែរ ប៉ុន្តែយើងត្រូវរាយការណ៍ភ្លាមទៅអង្គភាពផ្នែកខាងលើ ហើយរង់ចាំបញ្ជាថ្នាក់លើត្រឡប់ទៅវិញថា តើត្រូវធ្វើយ៉ាងម៉េចជាមួយនាវានោះ។ វាមិនមែនជាភារកិច្ចយើងសម្រាប់ចាប់ចងនាវាទូទៅទេ យើងចាំតែប្រយុទ្ធជាមួយនឹងនាវាចម្បាំងប៉ុណ្ណោះ"]។

[1313] ឯកសារ D114/12 កំណត់ហេតុស្តាប់ចម្លើយ នាក់ យឿន នាក់ យឿន ឆ.22 ["ស៖ ហេតុអ្វីបានជាលោកដឹងថា បញ្ជានោះចេញពី តា មុត មិនមែនជាអនុរបស់គាត់ ឬទីបញ្ជាការរបស់គាត់? ឆ.22៖ [...] ការសម្រេចចិត្តទាំងអស់គឺចេញពីមេធំ គឺក្នុងករណីដែល តា មុត អវត្តមានប៉ុណ្ណោះ ដែលអនុរបស់គាត់អាចចេញបញ្ជាបាន"]។ ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.4 ["ស៖ ក្រៅពី តា មុត តើមានអ្នកផ្សេងទៀតអាចចេញបញ្ជាឱ្យចាប់ ឬសម្លាប់ដែរឬទេ? ឆ.4៖ បើ តាមុត អនុវត្តមាន គឺមាន តា សេង ហើយបើ តា សេង អវត្តមានទៀត គឺមាន តា សារឿន"]។

[1314] ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ.90-91 ["ព្រោះថ្នាក់ត្រឹមឈ្មោះ ហន ក៏មិនមានសិទ្ធិបញ្ជាឱ្យកប៉ាល់នោះចេញបានដែរ ទាល់តែមានបញ្ជាចេញពី មាស មុត ទើបកប៉ាល់នោះ អាចចេញបាន។ [...] ឆ.91

មក អ្នកកាន់សារទូរលេខបញ្ជូនបញ្ជាទាំងនោះទៅមេបញ្ជាការនាវា[1315]។ មេបញ្ជាការនាវាត្រូវទទួលបញ្ជាពីថ្នាក់លើក្នុងកងពល មុននឹងតាមចាប់នាវា[1316]។ ស្រដៀងគ្នានេះដែរ មេបញ្ជាការនាវា

៖ គេបញ្ជូនតាមទូរលេខ ឬតាមតេអូ"]។ ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.144 ["បើតាមខ្ញុំយល់គឺមានតែប្រធានកងពលតាមវិទ្យុទាក់ទង ពីព្រោះវាលែងជារឿងសម្ងាត់ទៀតហើយ ពេលដែលការប្រយុទ្ធគ្នាបានផ្ទុះហើយនោះ"]។ ឯកសារ D54/10.2 ទូរលេខលេខ ៤៣ ពីមឿន ផ្ញើទៅ មាស មុត នៅថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ១៩៧៧ EN ERN 00983425, 00983427 [មឿនរៀបរាប់ពីស្ថានភាពរបស់សត្រូវនៅអូរឈើទាល និងកោះរ៉ុងសន្លឹម បានទិតៀនពីការនាំកម្មករនៅអូរឈើទាល ហើយបានស្នើសុំឱ្យមានការសម្រេចពី មាស មុត ថាគួរតែយកនាវាលេខ២ ទៅជួសជុលនៅរាម]។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ហៅ សារ៉េត ឆ.25 ["គឺមានតែមេបញ្ជាការកងពលម្នាក់ប៉ុណ្ណោះដែលមានសិទ្ធិចេញបញ្ជាលើការធ្វើចលនានាវា។ យល់ទៅតាមការយល់ដឹងរបស់ខ្ញុំធ្លាប់មានបញ្ជាពីខាងដើមអំពីអនុកងពល ដែលធ្លាប់ក្បត់ ហើយមានគម្រោងនឹងយកនាវារត់ចេញពីកង នៅក្នុងពេលនោះស្ថានការណ៍មួយរៀតណាមមានការតឹងតែងខ្លាំង ដូច្នេះគេត្រូវតែមានវិធានការការពារ។ ឧទាហរណ៍ក្នុងពេលនោះគេមានការសង្ស័យទៅលើអនុកងពលឈ្មោះ ឌឹម លើរឿងចង់យកនាវារត់ ដូច្នេះហើយ ទើបមានគោលការណ៍"]។

1315 ឯកសារ D54/34 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង ឆុន ឆ.2 ["នៅពេលដែលអ្នកកាន់សារទូរលេខនៅហ្នឹងផែទទួលបញ្ជាពីកន្លែងតា មុត អ្នកកាន់សារទូរលេខនោះផ្តល់បញ្ជានោះទៅឱ្យមេបញ្ជាកប៉ាល់ អ្នកកាន់សារទូរលេខ គេធ្វើការនៅក្នុងមន្ទីររបស់គេនៅជិតផែកប៉ាល់"]។ ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.16 ["នៅពេលដែលខ្ញុំនិយាយវិទ្យុទាក់ទងទៅអ្នកតំណាង ខ្ញុំរាយការណ៍អំពីទាហានអាមេរិកាំង។ អ្នកកាន់វិទ្យុបានធ្វើរបាយការណ៍មួយ ហើយបញ្ជូនទៅឱ្យ មាស មុត បន្ទាប់មក មាស មុត ចេញបញ្ជារបស់គាត់មកឱ្យខ្ញុំ ហើយអ្នកកាន់វិទ្យុបានទាក់ទងមកខ្ញុំប្រាប់តាមវិទ្យុពីបញ្ជារបស់ មាស មុត មកខ្ញុំ"]។

1316 ឯកសារ D234/2.1.93 ព្រុំ សារ៉ាត ប្រតិចារឹកថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ១៥.២៦.២២-១៥.៣០.១៣ ["ជាធម្មតា ការចូលចតខុសពីកប៉ាល់យោធា លុះត្រាណាតែមានការសុំអនុញ្ញាត ហើយការរៀនសូត្រពេលនោះ គឺជាការរៀនសូត្រដែលកម្មាភិបាលយុទ្ធជនទាំងអស់ត្រូវធ្វើការហ្វឹកហ្វឺនបច្ចេកទេស។ អ៊ីចឹងកប៉ាល់ដែលចូលមកនៅក្នុងផែអូរឈើទាល មានតែកប៉ាល់ដែល -- កាណូត មិនមែនកប៉ាល់ទេ កាណូត ដែលមានការពាក់ព័ន្ធក្នុងការទទួលផែនការពីវរសេនាធំ ឬក៏ពីកងពលទេដែលចូលមក ហើយមានការអនុញ្ញាត ដោយយល់ព្រមពីទីបញ្ជាការវរសេនាធំនៅកន្លែងនោះទើបកប៉ាល់ និងកាណូតនោះចូលបាន"]។ ឯកសារ D2/10 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.30 ["មិនមានសិទ្ធិសម្រាប់រើពីមួយកន្លែងទៅមួយកន្លែងទេ។ ត្រូវតែមានបញ្ជាសិនក្នុងការរើពីកន្លែងមួយទៅកន្លែងមួយ។ សូម្បីតែត្រូវទៅបោះយុទ្ធការនៅកន្លែងណាមួយក៏ត្រូវតែមានបញ្ជាឱ្យធ្វើតាមដែរ។ ប្រធាននាវានីមួយៗមិនអាចធ្វើអ្វីដោយខ្លួនឯងបាន ដោយគ្មានបញ្ជានោះទេ។ ការចេញបញ្ជាគឺចេញពីប្រធានកងនាវាមិនមែនចេញមកពីកងពលទេ។ សៈ បើសិនជាកងនាវាត្រូវបានដាក់ពង្រាយនៅហ្នឹងព្រំដែនក្នុងសមុទ្រ រួចហើយបានឃើញនាវាបរទេស ដែលរំលោភលើព្រំដែនរបស់ខ្លួន តើកងនាវាលោកធ្វើយ៉ាងម៉េច? ឆ.31៖ សូម្បីតែយើងឃើញនាវាបរទេសរំលោភចូលមកក្នុងដែនយើងក្តី ក៏យើងមិនធ្វើអ្វីតបភ្លាមដែរ ប៉ុន្តែ យើងត្រូវរាយការណ៍ភ្លាមទៅអង្គភាពផ្នែកខាងលើ ហើយរង់ចាំបញ្ជាថ្នាក់លើត្រឡប់ទៅវិញ

ឬប្រធានអង្គភាពឈរជើងនៅលើកោះ ពុំមានសិទ្ធិអំណាចធ្វើការសម្រេចចិត្តដោយខ្លួនឯងទៅលើទូកដែលចាប់បានទេ ប៉ុន្តែត្រូវគោរពយ៉ាងម៉ឺងម៉ាត់តាមបញ្ជាដែលទីបញ្ជាការកងពលបញ្ជូនមក[1317]។ ឧទាហរណ៍ ណុប ហាល បានផ្ដល់សក្ខីកម្មថា ពេលពួកគេបានទទួលបញ្ជាឲ្យចាប់ទូក ពួកគេមិនអាចបដិសេធមិនគោរពតាមបញ្ជាបានទេ[1318]។ ការមិនស្ដាប់តាមបញ្ជាត្រូវដាក់ទោសដល់ស្លាប់[1319]។

---

ថា តើត្រូវធ្វើយ៉ាងម៉េចជាមួយនាវានោះ។ វាមិនមែនជាភារកិច្ចយើងសម្រាប់ចាប់ចងនាវាទូទៅទេ យើងចាំតែប្រយុទ្ធជាមួយនឹងនាវាចម្បាំងប៉ុណ្ណោះ"]។ ឯកសារ D114/204 កំណត់ហេតុស្ដាប់ចម្លើយ សួស ស៊ីយ៉ាត ឆ.30 ["ស៖ ពេលគេចាត់តាំងលោកទៅនៅលើកោះហ្នឹង តើគេណែនាំយើងឲ្យធ្វើម៉េចខ្លះពេលឃើញនាវាថៃ? ឆ.30៖ យើងត្រូវរាយការណ៍ជូនមកវរសេនាតូច។"]។ ឯកសារ D59/1/1.12 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល KH ERN 00926633 ["ស៖ ពេលដែលយើងទៅជួបទូកនឹងភ្លាម មុននឹងចាប់យើងរាយការណ៍មកខាងវរសេនាធំដែរ? ឆ៖ បាទ! តេអូរាយជាប់"]។

1317 ឯកសារ D54/34 កំណត់ហេតុស្ដាប់ចម្លើយ អ៊ឹង អុន ឆ.22-23 ["ស៖ តើហេតុអ្វីបានជាតា ស៊ីម ចាំបាច់ត្រូវរាយការណ៍អំពីព្រឹត្តិការណ៍ដូចដែលបានរៀបរាប់ក្នុងរបាយការណ៍ដែលយើងបង្ហាញលោក ទៅ ឲ្យបញ្ជាការកងពលវិញ? ឆ.22៖ តា ស៊ីម មិនមានសិទ្ធិសម្រេចលើអ្វីដែលត្រូវធ្វើចំពោះទូកដែលត្រូវចាប់បាននោះ គាត់ត្រូវតែធ្វើតាមបញ្ជាពីកងពល។ ស៖ តាមតែលោកដឹង តើមានព្រឹត្តិការណ៍អ្វីមួយមិនចាំបាច់រាយការណ៍ទៅឲ្យកងពលដែរឬទេ? ឆ.23៖ ទេ, ខ្ញុំមិនដែលបានឃើញហេតុការណ៍ណាដែល តា ស៊ីម គាត់សម្រេចនៅទីកន្លែងនោះ ដោយគ្មានបញ្ជាពីកងពល លើកលែងតែការងារកំប៉ិកកំប៉ុក ដូចជាការកាប់ឈើធ្វើផ្ទះជាដើម ដែល តា ស៊ីម ធ្វើសេចក្ដីសម្រេចដោយខ្លួនគាត់"]។

1318 ឯកសារ D54/79 កំណត់ហេតុស្ដាប់ចម្លើយ ណុប ហាល ឆ.20 ["និយាយតាមត្រង់ទៅ ខ្ញុំនិយាយនេះ គឺតាមបទពិសោធន៍របស់ខ្ញុំពាក់ព័ន្ធនឹងព្រឹត្តិការណ៍ដែលកើតឡើងនៅក្បែរៗកោះពូលូវៃចាស់ និងថ្មីតែប៉ុណ្ណោះ។ ជាទូទៅ ក្រោយពេលទទួលបញ្ជាឲ្យចាប់ទូកណាមួយហើយ គឺគេត្រូវអនុវត្ត និងគ្មានសិទ្ធិដោះលែងទូកណាមួយទេ"]។

1319 ឯកសារ D54/23 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.30 ["ស៖ តើលោក ហើយនិងអ្នកដែលនៅក្នុងអង្គភាពជាមួយលោក អាចនឹងបដិសេធមិនធ្វើតាមបញ្ជាសម្លាប់ បើលោកយល់ថាការសម្លាប់នោះមិនសមហេតុផល? ឆ.30៖ ទេ ដាច់ខាតយើងមិនអាចប្រកែកនឹងបញ្ជាបានទេ។ បើមិនដូច្នេះទេ គេនឹងសម្លាប់យើង"]។ ឯកសារ D2/10 កំណត់ហេតុស្ដាប់ចម្លើយ សយ ប៊ន ឆ.53 ["បើសិនជាគេបញ្ជាឲ្យយើងធ្វើ រួចហើយយើងមិនធ្វើនោះយើងត្រូវតែមានទោស"]។ ឯកសារ D114/31 កំណត់ហេតុស្ដាប់ចម្លើយ មួល ឈិន ឆ.31 ["បើសិនជានរណាហ៊ានប្រកែក ឬជំទាស់នឹងបទបញ្ជា គឺត្រូវគេបាញ់សម្លាប់ និងទម្លាក់ក្នុងសមុទ្រហើយ គឺគេប្រើច្បាប់អាជ្ញាសឹកដាច់ខាតតែម្ដង"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN ERN 00978573, 00978576, KH ERN 00955503, 00955508 ["ស៖មានអ្នកអត់ឈប់ដែរ? ឆ៖ អត់ទេ! អត់ឈប់ យើងបាញ់គំរាមវា ក៏អត់ឈប់។ ស៖ ពូខាងកងពល គេបញ្ជាមក? ឆ៖ បាទ! បញ្ជាមក។ បើថាអត់ឈប់ទេ បាញ់ពន្លិច។ [...] ស៖ ចឹងចាប់បានបញ្ជា

376. រៀងរាល់ពេលដែលអង្គភាពកងពល ១៦៤ ឈរជើងលើនៅកោះ ឬនាវាល្បាតបានឃើញទូក បរទេសចូលមក[1320] មេបញ្ជាការណែនាំឱ្យរាយការណ៍អំពីរឿងនេះទៅថ្នាក់លើបន្ទាប់[1321] ជាទូទៅ

---

ពីកងពលទៅឬមួយធ្វើដោយខ្លួនឯង? ឆ៖ បញ្ជាពីកងពលទៅ។ ស៖ បញ្ជាចេញពីនរណាទៅ? ឆ៖ បញ្ជាចេញពីតា មុត ។ បញ្ជាឱ្យសម្លាប់តែម្តង? ឆ៖ បាទ"]។

1320 នាវា PCF ដែលមានបំពាក់អាវុធរបស់កងវរសេនាធំលេខ ១៤០ ដែលការពារនាវា និងដេញតាមនាវាចតនៅកំពង់សោម កោះពូឡូវៃ ឬ កោះតាង ហើយទទួលខុសត្រូវចាប់ទូកបរទេស៖ ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល ឆ.3 ["ក្រោយមក កងពលធំ ១៦៤ បញ្ជូននាវា PCF របស់កងវរសេនាធំ ១៤០ ដែលជួនកាលស្ថិតនៅកំពង់សោម និងនៅទីតាំងប្រចាំការ។ ជាទូទៅ នាវា PCF របស់វរសេនាធំ ១៤០ ប្រចាំការនៅកោះពូឡូវៃថ្មី ឬកោះតាង"]។ ឯកសារ D2/16 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.27 ["ស៖ នៅក្នុងកងពល ១៦៤ តើនរណាដែលពាក់ព័ន្ធ និងទទួលខុសត្រូវក្នុងការចាប់ចងពួកនេសាទ? ឆ.27៖ អ្នកដែលទទួលខុសត្រូវ គឺពួក PCF"]។ ឯកសារ D2/10 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.29-30 ["ការខុសគ្នានៃភារកិច្ចរបស់កងនាវាទាំងពីរនេះ គឺមិនមានខុសគ្នាច្រើនទេនៅក្នុងប្រទេសកម្ពុជា។ ភារកិច្ចនៃកងទាំងពីរគឺប្រយុទ្ធ។ ភារកិច្ចដែលខុសគ្នារបស់កងនាវាការពារ គឺកងនេះត្រូវបានរាយទៅប្រចាំការនៅកន្លែងផ្សេងៗតាមកោះ ហើយរង់ចាំបញ្ជាសម្រាប់ប្រយុទ្ធ ប៉ុន្តែសម្រាប់កងនាវាប្រដេញ គឺមិនរាយទៅគ្រប់កន្លែងអ៊ីចឹងទេ គឺរង់ចាំតែបញ្ជាប្រយុទ្ធ។ [...] ឆ.30៖ [...] មិនមានសិទ្ធិសម្រាប់រើពីមួយកន្លែងទៅមួយកន្លែងទេ។ ត្រូវតែមានបញ្ជាសិនក្នុងការរើពីកន្លែងមួយទៅកន្លែងមួយ។ សូម្បីតែត្រូវទៅបោះយុត្តការនៅកន្លែងណាមួយក៏ត្រូវតែមានបញ្ជាឱ្យធ្វើតាមដែរ។ ប្រធាននាវានីមួយៗមិនអាចធ្វើអ្វីដោយខ្លួនឯងបានដោយគ្មានបញ្ជានោះទេ។ ការចេញបញ្ជាគឺចេញពីប្រធានកងនាវា មិនមែនចេញមកពីកងពលទេ"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.15 ["កងវរសេនាធំ ១៤០ ត្រូវបានចាត់តាំងការពារកោះនិងព្រំដែនទឹក"]។ ឯកសារ D54/109 កំណត់ហេតុស្តាប់ចម្លើយ សៅ សំ ឆ.11 ["នៅពេលដែលខ្ញុំនៅលើកោះពូលូវៃ ភារកិច្ចរបស់ខ្ញុំគឺសម្រាប់តែយាម។ យើងមិនមានកប៉ាល់សម្រាប់ចម្បាំងប្រយុទ្ធទេ យើងមានតែទូកធម្មតាសម្រាប់នេសាទ។ នៅពេលណាដែលយើងឃើញទូកវៀតណាម ថៃ ឬក៏ទូកបរទេសណាផ្សេងទៀតចូលមកដែនទឹកយើង យើងរាយការណ៍តាមវិទ្យុទាក់ទងទៅឱ្យមូលដ្ឋានកងពល ១៦៤ នៅកំពង់សោម។ ខាងកងពល គេនឹងចេញកប៉ាល់របស់គេដែលជាកប៉ាល់បោសសម្អាតមីន ដែលមានល្បឿនលឿនឱ្យទៅតាមចាប់ទូក ឬកប៉ាល់នោះ"]។ ឯកសារ D1.3.34.64 ទូរស័ព្ទសម្ងាត់ពីមាស មុត ទៅបង៨៩ (សុន សេន) ចុះថ្ងៃទី ២០-៣-៧៨ EN ERN 00233649, KH ERN 00020982, FR ERN 00623220 ["នៅកោះវៃ យប់ថ្ងៃទី ១៩ - ៣ - ៧៨ ម៉ោង ៤ ព្រឹកឡើង ថ្ងៃ ២០-៣-៧៨ បងប្អូនយើងឃើញកាណូតសៀម១គ្រឿងនៅខាងលិចឈៀងខាងជើងកោះវៃចាស់ចម្ងាយ ៣ គ.ម យើងដេញចាប់វាបាននៅម៉ោង ៥ ភ្លឺ កាណូតធុន ២៥០សេះ មានមនុស្ស ២១ នាក់។ [...] នៅកោះតាង វេលាម៉ោង ២.៣០ នាទីថ្ងៃ ២០-៣-៧៨ កាណូត ៨០០សេះរបស់យើង ចេញធ្វើការនៅខាងកើត ភាគខាងត្បូងកោះតាងចម្ងាយ ១២ គ.ម ចាប់បានកាណូតអាយួន ២ គ្រឿង នៅលើកាណូត ២ គ្រឿងនេះ ពេញដោយយួន ៧៦ នាក់ មានក្មេង ចាស់ ប្រុស ស្រី"]។ សូមមើលផងដែរ ឯកសារ D59/1/1.8a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រំ សារ៉ាត់ EN ERN 00974211, KH ERN 00926389 ["តាមការដែលខ្ញុំដឹង ខ្ញុំធ្លាប់ដឹងតែមួយទេ គឺថាជនជាតិខ្លឹងហ្វឹង ខ្លឹងហ្វឹងគឺខ្លឹងពិត

ទីបញ្ជាការកងអនុសេនាធំ ឬកងវរសេនាតូច។ ពេលទទួលបានព័ត៌មាននេះ ជានាទីរបស់ទីបញ្ជាការកងវរសេនាតូច ដែលត្រូវរាយការណ៍អំពីវត្តមានរបស់ទូកនោះទៅថ្នាក់ដឹកនាំកងវរសេនាធំរបស់ខ្លួន ដែលបន្តបញ្ជូនព័ត៌មាននេះទៅទីបញ្ជាការកងពលនៅក្រុងកំពង់សោម[1322]។ បន្ទាប់មក

---

ឬខ្លឹងអីទេ [...] ស៖ កាលហ្នឹងយើងចូលមកកោះណា យើងចាប់បាននៅកោះ? ឆ៖ ពូលូវៃ។ [...] កាណូតពូអ្នក ចាប់បានហើយក៏"]។

1321 ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.25, 28 ["បើយើងឃើញទូក ឬក៏កប៉ាល់នៅលើទឹករបស់យើង យើងនឹងរាយការណ៍តាមវិទ្យុទាក់ទងទៅវរសេនាតូច ហើយបញ្ជាការដ្ឋានរបស់វរសេនាតូចរាយការណ៍ទៅឲ្យវរសេនាធំ។ វរសេនាធំរាយការណ៍បន្តទៅកងពល។ រួចហើយទើបកងពលបញ្ជាតាមខ្សែរយៈត្រឡប់ចុះមកវិញថា តើយើងគួរធ្វើយ៉ាងម៉េចជាមួយទូក កប៉ាល់ ហើយនិងមនុស្សដែលយើងចាប់បាន។ [...] ឆ.28៖ [...] ត្រូវតែរាយការណ៍ឲ្យច្បាស់លាស់នូវអ្វីដែលយើងចាប់បាននោះថា តើជាអ្នកនេសាទ ជាជនជាតិវៀតណាមអៀសខ្លួន ជាអ្នកនេសាទថៃ ឬជាទាហាន យើងត្រូវតែរាយការណ៍ទៅថ្នាក់លើឲ្យបានច្បាស់លាស់ជាមុន"]។ ឯកសារ D2/10 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.31 ["ស៖ បើសិនជាកងនាវាត្រូវបានដាក់ពង្រាយនៅហ្នឹងព្រំដែនក្នុងសមុទ្រ រួចហើយបានឃើញនាវាបរទេស ដែលរំលោភលើព្រំដែនរបស់ខ្លួន តើកងនាវាលោកធ្វើយ៉ាងម៉េច? ឆ.31៖ សូម្បីតែយើងឃើញនាវាបរទេសរំលោភចូលមកក្នុងដែនយើងក្តី ក៏យើងមិនធ្វើអ្វីតបភ្លាមដែរ ប៉ុន្តែ យើងត្រូវរាយការណ៍ភ្លាមទៅអង្គភាពផ្នែកខាងលើ ហើយរង់ចាំបញ្ជាថ្នាក់លើត្រឡប់ទៅវិញថា តើត្រូវធ្វើយ៉ាងម៉េចជាមួយនាវានោះ។ វាមិនមែនជាភារកិច្ចយើងសម្រាប់ចាប់ចងនាវាទូទៅទេ យើងចាំតែប្រយុទ្ធជាមួយនឹងនាវាចម្បាំងប៉ុណ្ណោះ។ សម្រាប់ការចាប់ចងនាវាផ្សេងៗវាជាភារកិច្ចរបស់កងមួយទៀ តដែលគេមានជាទូកឈើសម្រាប់ដើរចាប់ចង"]។ ឯកសារ D54/109 កំណត់ហេតុស្តាប់ចម្លើយ សៅ សំ ឆ.11-12 ["នៅពេលណាដែលយើងឃើញទូកវៀតណាម ថៃ ឬក៏ទូកបរទេសណាផ្សេងទៀតចូលមកដែនទឹកយើង យើងរាយការណ៍តាមវិទ្យុទាក់ទងទៅឲ្យមូលដ្ឋានកងពល ១៦៤ នៅកំពង់សោម។ ខាងកងពល គេនឹងចេញកប៉ាល់របស់គេដែលជាកប៉ាល់បោសសម្អាតមីន ដែលមានល្បឿនលឿនឲ្យទៅតាមចាប់ទូក ឬកប៉ាល់នោះ។ ខ្ញុំមិនបានដឹងថាតើគេយកកប៉ាល់ដែលគេចាប់នោះយកទៅណានោះទេ។ ស៖ ពេលលោកថារាយការណ៍តាមវិទ្យុទាក់ទងទៅកងពលនៅកំពង់សោម តើលោករាយការណ៍តាមរបៀបណា? ឆ.12៖ ដំបូងយើងរាយការណ៍តាមថ្នាក់ គឺរាយការណ៍ទៅកងវរសេនាធំ ហើយកងវរសេនាធំរាយការណ៍បន្តទៅឲ្យកងពល"]។

1322 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ ម៉ោង ១១.០៥.០៦-១១.០៩.៤៦ ["បើយើងចាប់បាន គឺរាយការណ៍ជាបន្ទាន់ទៅវរសេនាតូច វរសេនាតូចរាការណ៍ជាបន្ទាន់ទៅវរសេនាធំ វរសេនាធំរាយការណ៍ជាបន្ទាន់ទៅមន្ទីរកងពល។ បាទ ហើយបានបញ្ជាត្រឡប់មកវិញ បានអាចធ្វើបាន បាទ បញ្ជាទៅយោធាបាន បាទ"]។ ឯកសារE319/55.2.1 D114/140 កំណត់ហេតុស្តាប់ចម្លើយ ជា ផុន ឆ.41 ["ស៖ គេបញ្ជាឲ្យធ្វើអ្វី បើលោកឃើញនាវា ឬក៏យន្តហោះបរទេសចូលមកតំបន់ដែលលោកល្បាត? ឆ.41៖ បើឃើញនាវា ឬយន្តហោះចូលដែនយើង យើងត្រូវរាយការណ៍ឲ្យគេនៅដីគោក ហើយដីគោកបញ្ជាមកនាវាវិញថា តើគួរបាញ់ ឬរង់ចាំកម្លាំងជំនួយមក។"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.25 ["បើយើងឃើញទូក ឬក៏កប៉ាល់នៅលើទឹករបស់យើង យើងនឹងរាយការណ៍តាមវិទ្យុទាក់ទងទៅវរសេនាតូច ហើយបញ្ជាការដ្ឋានរបស់វរសេនាតូចរាយការណ៍

បញ្ជារបស់ **មាស មុត** នឹងត្រូវបានបញ្ជូនភ្លាមៗតាមវិទ្យុតាមខ្សែសង្វាក់នៃការបញ្ជា ទៅអង្គភាពពាក់ព័ន្ធ ឬក្នុងករណីបន្ទាន់ ដោយផ្ទាល់ទៅនាវាដែលទទួលខុសត្រូវចាប់កប៉ាល់បរទេស[1323]។ ការ

---

ទៅឱ្យវរសេនាធំ។ វរសេនាធំរាយការណ៍បន្តទៅកងពល។ រួចហើយទើបកងពលបញ្ជាតាមខ្សែរយៈត្រឡប់ចុះមកវិញថា តើយើងគួរធ្វើយ៉ាងម៉េចជាមួយទូក កប៉ាល់ ហើយនិងមនុស្សដែលយើងចាប់បាន។ ពេលនោះ កងវរសេនាតូចនឹងបញ្ជាមកយើងថា យើងគួរសម្លាប់អ្នកដែលយើងចាប់នោះនៅសមុទ្រតែម្តង ឬយកឡើងមកកោះ"]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត ឆ.138, ឆ.141 ["នៅពេលដែលចាប់បាន គេរាយការណ៍តាមវិទ្យុទាក់ទងពីកោះនានាមកកាន់កងពល។ [...] ឆ.141៖ គេរាយការណ៍តាមវិទ្យុទាក់ទង ហើយអ្នកនៅកន្លែងកាន់វិទ្យុទាក់ទងនោះត្រូវចុះកំណត់ហេតុក្នុងសៀវភៅប្រចាំថ្ងៃ ទោះព័ត៌មានអ្វីក៏ដោយ ដើម្បីបញ្ជូនព័ត៌មានទាំងនោះទៅឱ្យមាស មុត"]។

1323 ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.1, ឆ.19 ["ស៖ ជាទូទៅនៅពេលដែលកងនាវិកនៅលើនាវាទទួលបញ្ជាឱ្យសម្លាប់ ឬមួយក៏បញ្ជូនពួកអ្នកដែលចាប់បាន តើបញ្ជានោះធ្វើដោយផ្ទាល់មាត់តាមវិទ្យុទាក់ទង ឬក៏តាមម៉ាស៊ីនម៉ស? ឆ.1៖ បញ្ជាគឺតាមការនិយាយផ្ទាល់មាត់តាមរយៈវិទ្យុទាក់ទង។ [...] ស៖ ហេតុអ្វីបានជា មាស មុត ដែលជាស្នងការនយោបាយ ត្រូវតែដឹងអំពីព្រឹត្តិការណ៍ទាំងអស់នេះ? ឆ.19៖ ព្រឹត្តិការណ៍អ្វីដែលកើតឡើងត្រូវតែរាយការណ៍ទៅឱ្យកងវរសេនាតូច ហើយកងវរសេនាតូចរាយការណ៍ទៅមេបញ្ជាការកងវរសេនាធំ ហើយកងវរសេនាធំរាយការណ៍ទៅឱ្យមេបញ្ជាការកងពល។ បន្ទាប់មកមេបញ្ជាការកងពលធ្វើសេចក្តីសម្រេច ហើយដាក់បញ្ជាបញ្ជូនចុះមកវិញតាមជាន់ថ្នាក់ទាំងនេះមកវិញ"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ១០.៥១.៣៤-១០.៥៤.៣៩ ["មានការខុសៗគ្នាខ្លះ។ [...] ខ្ញុំផ្ទាល់បានចាប់ជនជាតិវៀតណាមៗមួយទូក ប្រហែលជាប្អូនដប់នាក់ប៉ុណ្ណោះទេ តែជនជាតិនោះមានអាវុធនៅលើកប៉ាល់នោះ លើទូកនោះឃើញថាបាញ់ត បាទ បាញ់តនឹងពួកខ្ញុំ។ បានបញ្ជាពីខាងលើ វាបាញ់តគឺឱ្យបាញ់ពន្លិចចោលតែម្តង"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.26 ["ស៖ តើវាជាច្បាប់ឬ ដែលលោកត្រូវរាយការណ៍ទៅឱ្យវរសេនាតូចជាមុន មុននឹងអនុវត្តកិច្ចការអ្វីមួយ ឬក៏លោកអាចធ្វើអ្វីខ្លួនឯងជាឯករាជ្យសិន មុននឹងរាយការណ៍ឡើងទៅវរសេនាតូច? ឆ.26៖ ប្រសិនបើយើងបញ្ជាឱ្យកាណូតណាមួយឱ្យឈប់ តែគេមិនស្តាប់តាមបញ្ជាយើងនោះ យើងអាចបាញ់ពន្លិចតែម្តង។ ខ្ញុំផ្ទាល់មិនដែលបាញ់កាណូតដោយខ្លួនឯងទេ តែអ្នកនៅក្នុងអង្គភាពរបស់ខ្ញុំធ្លាប់បាញ់ពន្លិចកាណូត ហើយការបាញ់ពន្លិចនេះ គឺជាបញ្ជាអនុវត្តទូទៅរបស់កងពល"]។ ឯកសារ D114/132 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ រ៉ាន់ ឆ.95 ["ពេលអ្នកនៅតាមកោះឃើញមានទូកថៃ គេរាយការណ៍មកថ្នាក់លើ ហើយថ្នាក់លើទាក់ទងមកពួកយើងនៅលើនាវា ឱ្យចេញទៅមើលថា តើវាជាទូកអី បើជាទូកនេសាទ គេបញ្ជាឱ្យចាប់យកមក"]។ ពេលខ្លះ ក្នុងករណីបន្ទាន់បទបញ្ជាត្រូវបានបញ្ជូនដោយផ្ទាល់ពីសេធិការដ្ឋានកងពលទៅកាន់កងនាវា ដោយមិនចាំបាច់ឆ្លងកាត់វរសេនាធំ ១៤០ និងវរសេនាតូចឡើយ៖ ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.142 ["ពេលនាវាទៅដល់កណ្តាលសមុទ្រ ហើយជួបប្រទះហេតុការណ៍ប្រយុទ្ធ គេទាក់ទងមកកងវរសេនាធំ ហើយកងវរសេនាធំទាក់ទងមកកងពល ហើយកងពលចេញបញ្ជាផ្ទាល់ទៅនាវាតែម្តង ដោយមិនឆ្លងកាត់កងវរសេនាធំទៀតទេ ដើម្បីឱ្យការងាររហ័ស"]។

ណែនាំជាទូទៅរបស់ **មាស មុត** គឺថាត្រូវតែចេញចាប់កប៉ាល់បរទេស ឬប្រសិនបើក្រុមនាវិកមិនសហការ ឬប្រឆាំងមិនឱ្យចាប់ ត្រូវវាយពន្លិច[1324]។

---

1324 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ០៩.៦៥.៥៣-១០.០០.៤៦ ["មាននាវាមួយចំនួនដេញចេញទៅការពារ។ បើមានព្រឹត្តិការណ៍អីកើតឡើង បានបញ្ជានាវានោះទៅប្រយុទ្ធតែម្តង"]។ ឯកសារ D114/19 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.16, ឆ.18, ឆ.20 ["តា ជន មេបញ្ជាការវរសេនាធំ ជាអ្នកហៅឱ្យយើងទៅចូលរួមប្រជុំ។ [...] សៈ តើមានការណែនាំអ្វីខ្លះនៅក្នុងការប្រជុំនោះ ពាក់ព័ន្ធនឹងការការពារទឹកដីពីការចូលមកនៃកប៉ាល់នេសាទ និងកប៉ាល់បរទេស? ឆ.18៖ ការណែនាំគឺថា [...] ប៉ុន្តែកាណូតទាំងនោះចូលមកជ្រៅហើយយូរក្នុងដែនទឹកយើង យើងនឹងវៃភ្លាមៗ។ រឿងនេះភាគច្រើនគឺកើតឡើងនៅកន្លែងរបស់ខ្ញុំ។ កន្លែងរបស់ខ្ញុំគឺនៅជិតនឹងព្រំដែនរបស់វៀតណាម ដូច្នេះពួកនេសាទដែលចូលមកនោះគឺភាគច្រើនកាណូតវៀតណាម។ ពួកកាណូតនេសាទនោះ ភាគច្រើនគឺមានកាំភ្លើង និងសព្វាវុធ។ [...] សៈ តើអ្នកណាជាអ្នកផ្តល់ការណែនាំឱ្យវៃទូកទាំងនោះ? ឆ.20៖ បើ តា មុត គាត់ជាអធិបតីនៅក្នុងពេលប្រជុំ គាត់ជាអ្នកចេញសេចក្តីណែនាំនេះ។ បើ ខឹម ជាអធិបតី ខឹម ជាអ្នកប្រាប់ការណែនាំនេះ"]។ ឯកសារ D114/24 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ ដាវ ឆ.89-91, ឆ. 97 ["សៈ ក្នុងវគ្គបណ្តុះបណ្តាល តើលោកធ្លាប់ទទួលបញ្ជាឱ្យចាប់ទូកបរទេសដែលចូលក្នុងដែនទឹកខ្មែរដែរឬទេ? ឆ.89៖ បាទ នៅក្នុងវគ្គបណ្តុះបណ្តាល គេបានប្រាប់ថា បើសិនមានទូកបរទេសចូលមកក្នុងដែនសមុទ្រខ្មែរ គឺត្រូវតែចាប់។ សៈ តើនរណាគេជាអ្នកបញ្ជាឱ្យចាប់ទូកនេះ? ឆ.90៖ គឺថ្នាក់លើ។ សៈ ហេតុដូចម្តេចបានជាលោកដឹងរឿងនេះ? ឆ.91៖ ខ្ញុំដឹងពីការបញ្ជាពីថ្នាក់លើ គឺនៅពេលកងវរសេនាតូច ហៅកងអនុសេនាធំ និងកងអនុសេនាតូចទៅប្រជុំ គឺគេប្រាប់ថាការបញ្ជានោះ គឺមកពីបក្ស មានន័យថាថ្នាក់លើ។ បក្ស គឺសំដៅទៅ មាស មុត។ [...] សៈ តើនរណាជាថ្នាក់លើ? ឆ.97៖ ថ្នាក់លើដែលទទួលខុសត្រូវកងទ័ពជើងទឹកទាំងមូល គឺមានតែ មាស មុត"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.44 ["ក្នុងករណីដែលមានការបាញ់តដៃបីទូកនេសាទ គេបញ្ជូនឱ្យមានកម្លាំងបន្ថែម។ ក្នុងករណីខ្លះ គេបាញ់ទូកនេសាទ នោះពន្លិចចោលតែម្តង"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.26-27 ["សៈ តើវាជាច្បាប់ឬ ដែលលោកត្រូវរាយការណ៍ទៅឱ្យវរសេនាតូចជាមុន មុននឹងអនុវត្តកិច្ចការអ្វីមួយ ឬក៏លោកអាចធ្វើអ្វីខ្លួនឯងជាឯករាជ្យសិន មុននឹងរាយការណ៍ឡើងទៅវរសេនាតូច? ឆ.26៖ ប្រសិនបើយើងបញ្ជាឱ្យកាណូតណាមួយឱ្យឈប់ តែគេមិនស្តាប់តាមបញ្ជាយើងនោះ យើងអាចបាញ់ពន្លិចតែម្តង។ ខ្ញុំផ្ទាល់មិនដែលបាញ់កាណូតដោយខ្លួនឯងទេ តែអ្នកនៅក្នុងអង្គភាពរបស់ខ្ញុំធ្លាប់បាញ់ពន្លិចកាណូត ហើយការបាញ់ពន្លិចនេះ គឺជាបញ្ជាអនុវត្តទូទៅរបស់កងពល។ សៈ ហេតុអ្វីបានជាលោកនិយាយថានេះជាបញ្ជាអនុវត្តទូទៅរបស់កងពល? ឆ.27៖ វាជាបញ្ជាទូទៅរបស់កងពល ទៅគ្រប់កងទាំងអស់។ បញ្ជានេះគឺចេញមកពីកងពល ហើយចុះទៅកងវរសេនាតូច"]។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.76 ["សៈ មុនពេលសម្រាក លោកបានបញ្ជាក់ថា លោកទទួលបញ្ជាមក បើសិនជាយើងឃើញទូកវៀតណាម លោកត្រូវបញ្ឈប់សិន បើគេមិនឈប់ យើងបាញ់។ តើត្រឹមត្រូវទេ? ឆ.76៖ បាទ"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN ERN 00978573, KH ERN 00955503 ["បើយើងដេញចាប់ បើថាវាអត់ឈប់ បាញ់ពន្លិច"]។ ឯកសារ D54/115.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នាក់ យឿន EN ERN 01088462, KH ERN 01007861 ["សៈ

377. ក្រោយចាប់កប៉ាល់រួច អង្គភាពត្រូវរង់ចាំបញ្ជាថាត្រូវធ្វើយ៉ាងណាបន្តទៀត ដែលរួមមានបញ្ជាបញ្ជូនកប៉ាល់ និង/ឬអ្នកទោសទៅកោះ ឬដីគោក (តំបន់កំពង់សោម)[1325]។ រៀងរាល់ពេលដែលទាហានកងពលលេខ ១ ចាប់បានកប៉ាល់បរទេសមួយក្នុងតំបន់កោះកុងរបស់ពួកគេ ពួកគេត្រូវបាន

---

កាលហ្នឹងមានបាញ់ដែរ? ឆ៖ បាញ់ បើឃាត់ឲ្យឈប់ ឃាត់ឲ្យទម្លាក់យុថ្កា"]។ ឧទាហរណ៍ អំពីទូកដែលគេបានបាញ់មាននៅក្នុង៖ ឯកសារ D1.3.34.64 ទូរស័ព្ទសម្ងាត់ពី មាស មុត ទៅបង៨៩ (សុន សេន) ចុះថ្ងៃទី ២០-៣-៧៨ EN ERN 00233649, KH ERN 00020982, FR ERN 00623220 ["១ - នៅកែប វេលាម៉ោង ៨យប់ ថ្ងៃ ១៩-៣-៧៨ យើងបាញ់កាណូតអាយួនលិច ១គ្រឿង ធុន ២២សេះ នៅខាងត្បូងកោះខ្យងចម្ងាយ ១ គ.ម។ ឯយើងមិនមានខូចខាតអីទេ"]។ ឯកសារ D1.3.12.2 កម្ពុជាប្រជាធិបតេយ្យ របាយការណ៍ពី មាស មុត ជូនបង ៨៩ (សុន សេន) ទីគោរពជ្រាប ថ្ងៃ ៦ - ២ (មិនចាំឆ្នាំ ១៩៧៦ ១៩៧៧ ឬ ១៩៧៨) ["ថ្ងៃ ៤-២ មិត្តនៅកោះព្រីងបានបាញ់ទូកនេសាទថៃមួយគ្រឿង [...] ទូកនេសាទប្រហែល ៥ គ.ម រួចវារត់ទៅទិសខាងលិចបាត់ទៅ។ [...] នៅម៉ោង ៦ ល្ងាចថ្ងៃ ៥-២ នេះខាងនេសាទរដ្ឋបាននាំទូកសៀម [...] ចូលកោះរ៉ុង តែពុំទាន់ដឹងហេតុផងអីទេ ក៏នាំចេញទៅវិញបាត់"]។ ឯកសារ D11/2 របាយការណ៍ស្ដីពីពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ រ៉ូប ហាមីល EN ERN 00681116, KH ERN 00710120 ["នៅល្ងាចនោះ ដោយមិនមានការព្រមានឲ្យដឹងជាមុន ទូក Foxy Lady និងនាវិករបស់ខ្លួនបានទទួលរងការបាញ់ប្រហារ"]។

1325 ឯកសារ D114/282 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ហៅ អ៊ីក ឆ.63 ["ដំបូងយើងបញ្ជូនមកដីគោក យើងទទួលបញ្ជាពីកងពល ថាមិនបាច់បញ្ជូនមកដីគោកទេ។ ហើយយើងទទួលបញ្ជាថា យកតែមាស"]។ ឯកសារ D54/23 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.25 ["ពេលនោះ កងវរសេនាតូចនឹងបញ្ជាមកយើងថា យើងគួរសម្លាប់អ្នកដែលយើងចាប់នោះនៅសមុទ្រតែម្ដង ឬយកឡើងមកកោះ"]។ ឯកសារ D54/82 កំណត់ហេតុស្ដាប់ចម្លើយ ហ៊ីង អ៊ុច ឆ.31 ["ស៖ តើលោករាយការណ៍អំពីការចាប់ទូកថៃ និងវៀតណាមដោយរបៀបណា? ឆ.31៖ ដូចខ្ញុំបានជម្រាបខាងដើមហើយ ខ្ញុំគ្រាន់តែជាអ្នកទទួលសេចក្ដីរាយការណ៍ ហើយនិងរាយការណ៍បន្តតែប៉ុណ្ណោះ។ ជាធម្មតា ខ្ញុំត្រូវតែរាយការណ៍ជាប្រចាំថ្ងៃ ហើយខ្ញុំបានដាក់ការចាប់ទូកបរទេសនេះ ជាបញ្ហាអាទិភាពទី១ នៅក្នុងរបាយការណ៍ ដោយសារវាទាក់ទងទៅនឹងការចាប់"]។ ឯកសារ D54/79 កំណត់ហេតុស្ដាប់ចម្លើយ ណុប ហាល ឆ.3 ["បញ្ជា គឺបញ្ជូនពីថ្នាក់លើមកថ្នាក់ក្រោមតាមឋានានុក្រម។ ជាទូទៅ គេថាទូកទាំងនោះ គឺឈ្លានពានចូលទឹកដីយើង ហើយគេបញ្ជាឲ្យចាប់យកមកកងវរសេនាធំ។ ដូចខ្ញុំបានរៀបរាប់ពីមុន បញ្ជាចេញមកពីកងពលធំ ប៉ុន្តែ យើងពុំបានទទួលបញ្ជានោះផ្ទាល់ពីកងពលធំទេ។ ក្នុងករណីចាប់ទូក យើងបានទទួលការណែនាំតាមវិទ្យុទាក់ទងពីកងវរសេនាធំ មកកវរសេនាតូច។ ខ្ញុំសូមពន្យល់អំពីដំណើរការចាប់ទូក ដែលមានដំណាក់កាលដូចតទៅ៖ កងវរសេនាតូចរាយការណ៍ទៅកងវរសេនាធំអំពីទូកដែលចូលមកឈ្លានពាន ហើយជាទូទៅកងវរសេនាធំរាយការណ៍ទៅកងពលធំ ដែលមានទីតាំងនៅកំពង់សោម"]។

តម្រូវឱ្យប្រគល់កប៉ាល់ និងមនុស្សដែលបានចាប់ខ្លួនទៅឱ្យកម្លាំងកងពល ១៦៤ ដែលជាអ្នកបញ្ជូនពួកគេទៅកំពង់សោម[1326]។

378. ជោគវាសនារបស់ក្រុមនាវិក និងអ្នកធ្វើដំណើរបរទេសដែលត្រូវបានចាប់ខ្លួន (ភាគច្រើនពលរដ្ឋថៃ និងវៀតណាម) ត្រូវបានសម្រេចទៅតាមករណី ដោយ **មាស មុត** ឬអនុគាត់ណាម្នាក់ដែលធ្វើការក្នុងនាមគាត់[1327]។ ដោយសារតែជោគវាសនារបស់ជនបរទេសដែលជិះលើកប៉ាល់ អាស្រ័យយ៉ាងខ្លាំងទៅលើសញ្ជាតិរបស់ពួកគេ ជាការសំខាន់ដែលកម្មាភិបាលកងពល ១៦៤ ដែលទាក់ទងជាមួយថ្នាក់ដឹកនាំកងពល រៀបរាប់ឱ្យបានលម្អិតថាតើ មនុស្សដែលត្រូវបានចាប់ខ្លួននៅសមុទ្រជាវៀតណាម ឬថៃ[1328]។

---

1326 ឯកសារ D234/2.1.95 មាស វឿន ប្រតិចារឹកថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង ១៤.០៨.១២-១៤.១២.១២, ១៤.១៧.២០-១៤.១៩.០៤ [មេបញ្ជាការរងទី១៖ "កាណូត បើកាណូតវៀតណាម កន្លងមកវាមកយូរៗម្តងដែរ ក៏ប៉ុន្តែពេលខ្លះដែលគេវង្វេងមក ព្រោះគេចូលមកក្នុងដែនទឹកយើង ដើម្បីគេឡើងទៅប្រទេសថៃអ៊ីចឹងទៅ ពេលណាដែលយើងដឹង យើងចាប់។ ចាប់ហើយយើង ចាប់បានហើយយើងបញ្ជូនទៅតាមៗថ្នាក់ តាមអង្គភាពដែលទទួលខុសត្រូវអ៊ីចឹងទៅ ហើយយើងរាយការណ៍ទៅតាម ប៉ុន្តែចាប់បានកន្លងទៅ គឺចាប់បានតែកាណូតមួយគ្រឿងអ៊ីចឹងទៅ យើងបញ្ជូនទៅតាមខាងកំពង់សោម ខាងកងពល ៦៤<(ស៊ីក)> អ៊ីចឹងទៅ ព្រោះអីគេនៅប្រចាំការជាមួយយើងដែរ។ ហើយបើយើងបញ្ជូនទៅខាងកងពល ៦៤ទៅ អាហ្នឹងគឺថាគេយកទៅខាងកំពង់សោមអ៊ីចឹងទៅ។ [...] រឿងជនភៀសខ្លួនវៀតណាម [...] ដែលចាប់មក ចាប់បានខ្ញុំបញ្ជូនទៅតាមថ្នាក់ដឹកនាំរបស់ខ្ញុំអ៊ីចឹងទៅ ហើយថ្នាក់ដឹកនាំក៏ដោះស្រាយតាមបែបណាក៏ស្រេចតែគាត់ទៅ"]។ ឯកសារ D234/2.1.96 មាស វឿន ប្រតិចារឹកថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង ០៩.២៤.០១-០៩.២៦.០៣ ["យួនដែលខ្ញុំចាប់បានអ៊ីចឹង ខ្ញុំបញ្ជូនមកខាងលើៗ"] ម៉ោង ០៩.២៦.០៣-០៩.២៨.២៧ ["វៀតណាមដែលរត់មកចូលតំបន់កោះកុងដែលខ្ញុំចាប់បានហ្នឹង ខ្ញុំបញ្ជូនមកតាមថ្នាក់ដឹកនាំហ្នឹងមក តាមកងពលខ្ញុំហ្នឹងមក"]។

1327 ឯកសារ D114/12 កំណត់ហេតុស្តាប់ចម្លើយ នាក់ យឿន ឆ.22 ["ហេតុអ្វីបានជាលោកដឹងថា បញ្ជានោះចេញពី តា មុត មិនមែនជាអនុរបស់គាត់ ឬទីបញ្ជាការរបស់គាត់? ឆ.22៖ [...] ការសម្រេចចិត្តទាំងអស់គឺចេញពីមេធំ គឺក្នុងករណីដែល តា១៍ មុត អវត្តមានប៉ុណ្ណោះ ដែលអនុរបស់គាត់អាចចេញបញ្ជាបាន"]។ ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.4 ["ស៖ ក្រៅពី តា មុត តើមានអ្នកផ្សេងទៀតអាចបញ្ជាឱ្យចាប់ ឬសម្លាប់ដែរឬទេ? ឆ.4៖ បើ តា មុត អនុវត្តមានគឺមាន តា សេង ហើយបើ តា សេង អវត្តមានទៀតគឺមាន តា សារឿន។"]។ ទាក់ទងនឹងឈ្មោះអនុប្រធានរបស់លោក មាស មុត នេះ។ សូមមើលផងដែរ IV. រចនាសម្ព័ន្ធអំណាចកងពល ១៦៤ – គណៈកងពល ១៦៤។

1328 ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.28-29 ["បាទ ត្រូវតែរាយការណ៍ឱ្យច្បាស់លាស់នូវអ្វីដែលយើងចាប់បាន។ ឧទាហរណ៍ថា តើគេជាជនជាតិវៀតណាមភៀសខ្លួន ជាអ្នកនេសាទថៃ ឬជាទាហាន យើងត្រូវតែ

379. ផ្អែកលើកាលៈទេសៈនៃការចាប់កប៉ាល់ ទង់ជាតិ និងសញ្ជាតិ ឋានៈ ឬចំនួនមនុស្សលើកប៉ាល់ បញ្ជា **មាស មុត** គឺត្រូវ៖

(ក) សម្លាប់ក្រុមនាវិក និងអ្នកដំណើរ ទុកអ្នកដែលលោតពីកប៉ាល់ចូលក្នុងសមុទ្រដោយគ្មានជំនួយអ្វីទាំងអស់[1329] និងពន្លិចកប៉ាល់[1330] ឬរឹបអូសយកកប៉ាល់[1331]

---

រាយការណ៍ទៅថ្នាក់លើឲ្យបានច្បាស់លាស់ជាមុន។ [...] ឆ.29៖ បញ្ជាគឺគេប្រាប់ច្បាស់លាស់ថា តើត្រូវសម្លាប់នៅនឹងកន្លែង ឬក៏បញ្ជូនទៅលើគោក។ ប្រសិនបើអ្នកដែលត្រូវបានចាប់ខ្លួននោះជាទាហានវៀតណាម យើងត្រូវតែបញ្ជូនពួកនោះទៅដីគោក បន្ទាប់មកគេនឹងធ្វើការចាក់ផ្សាយចម្លើយសារភាពរបស់ទាហានវៀតណាមនៅក្នុងវិទ្យុ មុនពេលគេសម្លាប់"]។

1329 ឯកសារ D1.3.34.28 សេចក្តីរាយការណ៍ "តាមទូរស័ព្ទសម្ងាត់" ពី ស៊ីម ទៅកងពលធំ ១៦៤ ចុះថ្ងៃទី ១៥-៩-៧៧ ["ចំពោះទូកថៃដែលចូលក្នុងសមុទ្រយើងយ៉ាងជ្រៅ ហើយជិតកោះយើង ខ្ញុំបានចេញកប៉ាល់ធ្វើការ ចាប់បានទូក ២ គ្រឿង ធុន ៣០០សេះ ១ គ្រឿ ៤០០សេះ ១ គ្រឿង។ ចំពោះទូក ២ គ្រឿងចាប់បាននៅខាងត្បូងកោះកុង។ នៅលើទូកមានកូឡាំង ២គ្រឿង និងត្រីមួយចំនួន និងប្រេង ចំពោះមនុស្សគ្មានបានទេ ពីព្រោះវាលោតធ្លាក់ទឹក នៅសល់មួយចំនួនបងប្អូនកម្ទេចចោលអស់"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.45 ["ស៖ តើមានរឿងអ្វីកើតឡើងចំពោះអ្នកនេសាទ ដែលនៅលើទូកដែលគេបាញ់ពន្លិចនោះ? ឆ.45៖ គឺស្លាប់លិចទៅជាមួយទូក ហើយប្រសិនបើមានអ្នករួចខ្លួន ហែលរត់ គឺត្រូវគេបាញ់សម្លាប់ចោលផងដែរ គឺគេមិនទុកឲ្យមានភាពរញ៉េរញ៉ៃឡើយ"]។ ឯកសារ D54/34 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង នុន ឆ.28, 30 ["ពេលយើងចូលទៅជិតទូករបស់គេ ហើយគេមិនព្រមលោតចុះទឹក គេនៅតែក្រាញនៅតែលើទូក យើងនឹងបាញ់ពីក្បាលគេ ដើម្បីឲ្យគេលោតចោលទូក យើងចាប់យកទូកនោះ។ [...] ឆ.30៖ តាមច្បាប់ ពេលដែលយោធាលោតចូលទៅក្នុងទូកនោះ គេនឹងសម្លាប់អ្នកណាក៏ដោយដែលនៅលើទូកដែលមិនព្រមលោតគេចខ្លួនទៅក្នុងសមុទ្រ វាមិនមានការចាប់ខ្លួនទេ"]។ ឯកសារ D54/52 កំណត់ហេតុស្តាប់ចម្លើយ មាស រឿន (មេបញ្ជាការរងកងពលទី ១) ឆ.19-20, 22 ["តាមខ្ញុំចាំបាន យើងចាប់បានអ្នកនេសាទថៃប្រហែលចំនួន ១០នាក់ ប៉ុន្តែយើងចាប់បានទូកនេសាទប្រហែល ៥០ ទៅ ៦០ គ្រឿង។ ចំនួនអ្នកនេសាទដែលចាប់បាន គឺតិចជាងចំនួនទូក ពីព្រោះតែពេលដែលយើងចូលមកជិតទូកដើម្បីចាប់ម្តងៗ ពួកអ្នកនេសាទទាំងនោះលោតចូលទឹក ដើម្បីរត់គេចពីការចាប់ខ្លួន។ ស៖ យោងតាមការស្មានរបស់លោក នៅក្នុងពេលនោះ បើសិនជាលោកចាប់បានមនុស្សទាំងអស់នៅលើទូកទាំង ៥០ ទៅ ៦០ គ្រឿងនោះ តើមានមនុស្សចំនួនប៉ុន្មាននាក់? ឆ.20៖ វាអាចមានចំនួនអ្នកនេសាទច្រើនណាស់ ជាមធ្យមទូកនេសាទមួយៗមានមនុស្សពីបីទៅបួននាក់។ [...] ស៖ តើអ្នកនេសាទថៃដែលលោតចូលទៅក្នុងទឹកនោះ តើកងរបស់លោកតាមជួយសង្គ្រោះ ឬក៏ទុកពួកគេចោល? ឆ.22៖ យើងមិនបានទៅជួយសង្គ្រោះអ្នកនេសាទថៃនោះទេ យើងទុកពួកគេទៅតាមវាសនារបស់គេទៅ។ ប៉ុន្តែ ប្រសិនបើយោធាយើងធ្លាក់ចូលទឹក យើងត្រូវតែស្វែងរកដើម្បីជួយសង្គ្រោះមកវិញ"]។

1330 ឯកសារ D1.3.34.28 សេចក្តីរាយការណ៍ "តាមទូរស័ព្ទសម្ងាត់" ពី ស៊ីម ទៅកងពលធំ ១៦៤ ចុះថ្ងៃទី ១៥-៩-៧៧ ["ចំពោះទូកថៃដែលចូលក្នុងសមុទ្រយើងយ៉ាងជ្រៅ ហើយជិតកោះយើង ខ្ញុំបានចេញកប៉ាល់ធ្វើការ ចាប់បានទូក ២

គ្រឿង ធុន ៣០០សេះ ១ គ្រឿ ៤០០សេះ ១ គ្រឿង។ ចំពោះទូក ២ គ្រឿងចាប់បាននៅខាងត្បូងកោះកុង។ នៅលើទូក មានកូឡាំង ២ គ្រឿង និងត្រីមួយចំនួន និងប្រេង ចំពោះមនុស្សគ្មានបានទេ ពីព្រោះវាលោតធ្លាក់ទឹក នៅសល់មួយចំនួន បងប្អូនកម្ទេចចោលអស់"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារិកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ១០.៥៦.៥៣-១០.៥៨.១៣ ["បាទ ក្នុងនុំង គឺជាជនជាតិវៀតណាមខុសប្លែកនឹងគ្នានឹងជនជាតិថៃបាទ។ ជនជាតិវៀត ណាម គឺជាសត្រូវស្លូតជាមួយរបស់ បាទ ប៉ុល ពត។ មិនអាច ទោះបីអ្នកឯងយោធា មិនយោធាក៏ដោយឲ្យតែមាន អាវុធគបត គឺបាញ់ពន្លិចចោលតែម្តង"]។ ឯកសារD114/19 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.24 ["ស៖ តើ ការណែនាំយ៉ាងម៉េចខ្លះ សម្រាប់ពួកអ្នកនេសាទវៀតណាមដែលយើងចាប់បាន? ឆ.24៖ សម្រាប់ការចាប់ពួកវៀតណា ម និងកាណូតវៀតណាម គឺជាសមត្ថកិច្ចរបស់ខាងកងនាវា។ សមត្ថភាពខាងកងខ្ញុំនៅលើកោះ គឺមិនមានសមត្ថភាព ទៅចាប់កាណូតទាំងនោះទេ។ បើយើងជួប យើងនឹងបាញ់គ្នាតែម្តង។ ពេលខ្លះ កាណូតរបស់វៀតណាមត្រូវបានយើង បាញ់ ហើយក៏ត្រឡប់ទៅវិញ ហើយនៅពេលបាញ់គ្នា គឺយើងបាញ់ពន្លិចចោលតែម្តង យើងមិនចាប់យកមនុស្សពីស មុទ្រមកទេ។ ខ្ញុំចង់ជម្រាបថា នៅពេលនោះ ពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៦ ការណែនាំនេះគឺជាការណែនាំទូទៅ"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មួល ឈិន ឆ.45 ["ស៖ តើមានរឿងអ្វីកើតឡើងចំពោះអ្នកនេសាទ ដែលនៅលើទូកដែលគេបាញ់ពន្លិចនោះ? ឆ.45៖ គឺស្លាប់លិចទៅជាមួយទូក ហើយប្រសិនបើមានអ្នករួចខ្លួន ហែលរត់ គឺត្រូវគេបាញ់សម្លាប់ចោលផងដែរ គឺគេមិនទុកឲ្យមានភាពរញ៉េរញ៉ៃឡើយ"]។ ឯកសារ D54/25 កំណត់ហេតុស្តាប់ ចម្លើយ ប៉ាក សុខ ឆ.2, ឆ.11 ["គេប្រើភាសាសាមញ្ញធម្មតានៅពេលបញ្ជា ឧទាហរណ៍គេនិយាយថា "បាញ់ពួកហ្នឹង ចោលទៅ ឬក៏បញ្ជូនពួកហ្នឹងមកដីគោក"។ [...] ស៖ តាមបទពិសោធន៍របស់លោក និងការយល់ដឹងរបស់លោក នៅ ក្នុងកងអង្គភាពរបស់លោក និងអង្គភាពដទៃទៀត នៃកងទ័ពជើងទឹក តើចំនួនប្រជាជនស៊ីវិល ចំនួនជនភៀសខ្លួន អ្នក នេសាទ ចន្លោះពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ឆ្លងមកចូលក្នុងដែនទឹកកម្ពុជា ហើយត្រូវបានចាប់បាន និងសម្លាប់ មាន ចំនួនប្រហែលប៉ុន្មាននាក់? ឆ.11៖ មានចំនួនរាប់ពាន់នាក់ អ្នកទាំងនោះរួមមានពួកនេសាទថៃ និងពួកនេសាទ និងជន ភៀសខ្លួនវៀតណាម ដែលត្រូវចាប់បាន និងសម្លាប់ចោលនៅក្នុងសមុទ្រ នៅលើកោះ និងនៅលើដីគោក"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.25-26 ["វរសេនាធំរាយការណ៍បន្តទៅកងពល។ រួចហើយទើបកង ពលបញ្ជាតាមខ្សែរយៈត្រឡប់ចុះមកវិញថា តើយើងគួរធ្វើយ៉ាងម៉េចជាមួយទូក កប៉ាល់ ហើយនិងមនុស្សដែលយើង ចាប់បាន។ ពេលនោះ កងវរសេនាតូចនឹងបញ្ជាមកយើងថា យើងគួរសម្លាប់អ្នកដែលយើងចាប់នោះនៅសមុទ្រតែម្តង ឬយកឡើងមកកោះ។ បើសិនជាយើងចាប់បានទូកយួន ពេលខ្លះយើងទទួលបញ្ជាឲ្យបាញ់សម្លាប់ចោលនៅនឹងកន្លែង ហើយយកតែទូកមកកោះតែប៉ុណ្ណោះ។ [...] ស៖ តើវាជាច្បាប់ឬ ដែលលោកត្រូវរាយការណ៍ទៅឲ្យវរសេនាតូចជាមុន មុននឹងអនុវត្តកិច្ចការអ្វីមួយ ឬក៏លោកអាចធ្វើអ្វីខ្លួនឯងជាឯករាជ្យសិន មុននឹងរាយការណ៍ឡើងទៅវរសេនាតូច? ឆ.26 ៖ ប្រសិនបើយើងបញ្ជាឲ្យកាណូតណាមួយឲ្យឈប់ តែគេមិនស្តាប់តាមបញ្ជាយើងនោះ យើងអាចបាញ់ពន្លិចតែម្តង។ ខ្ញុំផ្ទាល់មិនដែលបាញ់កាណូតដោយខ្លួនឯងទេ តែអ្នកនៅក្នុងអង្គភាពរបស់ខ្ញុំធ្លាប់បាញ់ពន្លិចកាណូត ហើយការបាញ់ ពន្លិចនេះ គឺជាបញ្ជាអនុវត្តទូទៅរបស់កងពល"]។ ឯកសារ D54/34 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង អុន ឆ.22, 28-30 ["ស៖ តើហេតុអ្វីបានជាតា ស៊ីម ចាំបាច់ត្រូវរាយការណ៍អំពីព្រឹត្តិការណ៍ដូចដែលបានរៀបរាប់ក្នុងរបាយការណ៍ដែល យើងបង្ហាញលោក ទៅ ឲ្យបញ្ជាការកងពលវិញ? ឆ.22៖ តាស៊ីម មិនមានសិទ្ធិ សម្រេចលើអ្វីដែលត្រូវធ្វើចំពោះទូក ដែលត្រូវចាប់បាននោះ គាត់ត្រូវតែធ្វើតាមបញ្ជាពីកងពល។ [...] ស៖ នៅក្នុងការសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯក

សារកម្ពុជា លោកបាននិយាយថា ពេលខ្លះកប៉ាល់របស់លោកគេគ្រាន់តែបាញ់កាំភ្លើងបន្លាចទូកដែលចូលមក តើលោកអាចពន្យល់ប្រាប់យើងថា ការបាញ់បន្លាចនេះមានន័យយ៉ាងម៉េច? ឆ.28៖ ពេលយើងចូលទៅជិតទូករបស់គេ ហើយគេមិនព្រមលោកតចុះទឹក គេនៅតែក្រាញនៅតែលើទូក យើងនឹងបាញ់ពីក្បាលគេ ដើម្បីឱ្យគេលោតចោលទូក យើងចាប់យកទូកនោះ។ ស៖ តើលោកបានប្រើកាំភ្លើងប្រភេទអ្វី សម្រាប់បាញ់បន្លាចទៅលើទូកនេសាទទាំងនោះ? ឆ.29៖ ពេលជួបដំបូង យើងប្រើកាំភ្លើងយន្តធុន ១២.៧ មីលីម៉ែត្រ ដើម្បីបន្លាចពួកគេឱ្យលោតចុះទឹក ពេលយើងទៅដល់ទូករបស់ពួកគេ យើងប្រើកាំភ្លើងអាកា ៤៧ នៅពេលយើងលោតចូលទៅក្នុងទូកនោះ ដើម្បីកាន់ចង្កូតទូក។ ស៖ តើលោកមានន័យថា អ្នកនៅក្នុងទូកនោះនឹងត្រូវបានសម្លាប់ដោយយោធាដែលលោតចូលទៅឬយ៉ាងណា ទោះបីពួកនោះមិនមានអាវុធនិងចុះចូលក៏ដោយ? ឆ.30៖ តាមច្បាប់ ពេលដែលយោធាលោតចូលទៅក្នុងទូកនោះ គេនឹងសម្លាប់អ្នកណាក៏ដោយដែលនៅលើទូក ដែលមិនព្រមលោតគេចខ្លួនទៅក្នុងសមុទ្រ វាមិនមានការចាប់ខ្លួនទេ”]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN ERN 00978573, KH ERN 00955503 [“ស៖ មានអ្នកអត់ឈប់ដែរ? ឆ៖ អត់ទេ! អត់ឈប់ យើងបាញ់គំរាមវា ក៏អត់ឈប់។ ស៖ ពួខាងកងពល គេបញ្ជាមក? ឆ៖ បាទ! បញ្ជាមក។ បើថាអត់ឈប់ទេ បាញ់ពន្លិច”]។ ឯកសារ D11/2 របាយការណ៍ស្ដីពីពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ រ៉ូប ហាមីល EN ERN 00681116, KH ERN 00710120 [“នៅល្ងាចនោះ ដោយមិនមានការព្រមានឱ្យដឹងជាមុន ទូក Foxy Lady និងនាវិករបស់ខ្លួនបានទទួលរងការបាញ់ប្រហារ”]។ ឯកសារ D59/1/1.8a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រំ សារ៉ាត់ EN ERN 00974208, KH ERN 00926386 [“បើថារត់យើងចាប់ យើងបាញ់ ប៉ុន្តែ បើគេមិនរត់យើងចាប់”]។

1331 ឯកសារ D54/23 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.25 [“កងវរសេនាតូចនឹងបញ្ជាមកយើងថា តើយើងគួរសម្លាប់អ្នកដែលយើងចាប់នោះនៅសមុទ្រតែម្ដង ឬយកឡើងមកកោះ។ [...] ពេលខ្លះយើងទទួលបញ្ជាឱ្យបាញ់សម្លាប់ចោលនៅនឹងកន្លែង ហើយយកតែទូកមកកោះតែប៉ុណ្ណោះ”]។ ឯកសារ D54/34 កំណត់ហេតុស្ដាប់ចម្លើយ អ៊ឹង ឆុន ឆ.28 [“ពេលយើងចូលទៅជិតទូករបស់គេ ហើយគេមិនព្រមលោកតចុះទឹក គេនៅតែក្រាញនៅតែលើទូក យើងនឹងបាញ់ពីលើក្បាលគេ ដើម្បីឱ្យគេលោតចោលទូក យើងចាប់យកទូកនោ”]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ១០.៣៤.៤៥-១០.៣៩.៥៩ [“ជនជាតិវៀតណាមនៅលើទូក [...] ក្រៅពីនោះជាប្រជាជន [...] វាថាទៅរត់ទៅប្រទេសថៃតែម្ដង។ ក្រោយមកបានយើងឃើញ យើងចាប់នៅចន្លោះកោះពូឡូវៃ និងកោះគាវ ចាប់មកយកផែអូរឈើទាលនេះបានជួបខ្ញុំផ្ទាល់។ [...] ខ្ញុំចាំ [...] ក្មេងនោះមានការយំស្រែកយ៉ាងខ្លាំង [...] ក្រោយមកក៏ឃើញយោធាចាប់កូនក្មេងនោះបោះទម្លាក់ទឹកចោលតែម្ដង”]។ ម៉ោង ១៣.៤៨.២៨-១៣.៥១.២៩ [“ពេលដែលចាប់បានកាណូតនីមួយៗបាទ។ ពេលនុំងឃើញថា បញ្ជាៗឱ្យយកទៅលើគោក តែបើតិចត្រឹមត្រូវម្នាក់ពីរនាក់តែប៉ុណ្ណោះ គឺថាមិនបានទេ។ បើថាការអនុញ្ញាតថាមិនបាច់យកមកទេ គេមានការបាញ់សម្លាប់នៅលើផ្ទៃសមុទ្រហើយ ហើយយកតែកាណូតដើម្បីមកប្រើប្រាស់ក្នុងអង្គភាពរបស់គេ”]។ ម៉ោង ១៣.៥១.២៩-១៣.៥៣.៥៩ [“ពេលតិចគេឱ្យសម្លាប់នុំង ឃើញថាដោយគេខ្ជិលយកមកសួរចម្លើយ”]។

## (ខ) ឃុំ និងបញ្ជូនអ្នកទោសទៅកោះជុំវិញណាមួយ មុននឹងសម្លាប់ពួកគេ[1332]

---

1332 សាក្សី ឯក នី ចងចាំបានថា អ្នកដែលត្រូវយោធាកងពល ១៦៤ ចាប់ នៅជិតកោះតាងត្រូវបានបញ្ជូនទៅឲ្យ មាស មុត នៅកំពង់សោម។ ទោះជាយ៉ាងណា ក្រោយមក មាស មុត បានបញ្ជាឲ្យសម្លាប់អ្នកចាប់ខ្លួនទាំងអស់ រួចយកទៅធ្វើជីដាក់ដើមដូងនៅលើកោះតាង។ គឺមានបញ្ជាឲ្យសន្សំសំចៃប្រេងសាំងផងដែរ៖ ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.63៖ [“ស៖ ដែលចំនួន ដែលលោកឲ្យហ្នឹង ១២០០ ឬ ១៣០០ នាក់ គឺនិយាយតែមុខព្រួញដែលលោកដឹងទេ ឬទាំងមូល? ឆ.63៖ សម្រាប់តែមុខព្រួញដែលខ្ញុំដឹង។ ដំបូង យើងបញ្ជូនមកដីគោក ក្រោយមក យើងទទួលបញ្ជាពីកងពលថា មិនបាច់បញ្ជូនមកដីគោកទេ។ ហើយយើងទទួលបញ្ជាថា យកតែមាស ហើយមនុស្សធ្វើជាជីរនៅលើកោះហ្នឹងទៅ កុំចំណាយប្រេងដឹកពួកគេមកដីគោក”]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ហៅ អ៊ឹក ឆ.41 [“ស៖ តើលោកមានអ្វីចង់បន្ថែមនៅក្នុងកិច្ចសម្ភាសនេះដែរឬទេពាក់ព័ន្ធនឹងការចាប់ខ្លួនអ្នកនេសាទថៃ និងវៀតណាមទាំងនោះ? ឆ.41៖ [...] ពីដំបូងឡើង ពេលយើងចាប់ពួកវៀតណាម និងថៃបាន យើងបញ្ជូនទៅឲ្យ តា មុត នៅកំពង់សោម ប៉ុន្តែ ក្រោយមក តា មុត បានបញ្ជាមកយើងកុំឲ្យខាតសាំង ដើម្បីដឹកពួកគេមកកំពង់សោមធ្វើអី ឲ្យយកធ្វើជាជីដាក់គល់ដូងនៅលើកោះទាំងអស់ទៅ។ សាកសពម្នាក់ត្រូវកាត់ជាពីរកំណាត់ ហើយមួយកំណាត់ៗកប់នៅក្រោមដើមដូងមួយដើមៗ”]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.25 [“ពេលនោះ កងវរសេនាតូចនឹងបញ្ជាមកយើង ថាតើយើងគួរសម្លាប់អ្នកដែលយើងចាប់នោះនៅសមុទ្រតែម្តង ឬយកឡើងមកកោះ”]។ ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុក ឆ.11, 20 [“ស៖ [...] ចន្លោះពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ឆ្លងមកចូលក្នុងដែនទឹកកម្ពុជា ហើយត្រូវបានចាប់បាន និងសម្លាប់ មានចំនួនប្រហែលប៉ុន្មាននាក់? ឆ.11៖ មានចំនួនរាប់ពាន់នាក់ អ្នកទាំងនោះរួមមានពួកនេសាទថៃ និងពួកនេសាទ និងជនភៀសខ្លួនវៀតណាម ដែលត្រូវចាប់បាន និងសម្លាប់ចោលនៅក្នុងសមុទ្រ នៅលើកោះ និងនៅលើដីគោក។ [...] ឆ.20៖ ខ្ញុំបានឃើញព្រឹត្តិការណ៍ដំបូងគឺជាការចាប់បាន និងសម្លាប់ប្តីប្រពន្ធវៀតណាម និងកូនម្នាក់អាយុប្រហែលមួយឆ្នាំ នៅកោះពូឡូវ៉ៃចាស់ កាលពីចុងឆ្នាំ ១៩៧៦ ឬដើមឆ្នាំ ១៩៧៧។ ប្តីប្រពន្ធ ហើយនិងកូនង៉ែត គឺជាជនភៀសខ្លួនវៀតណាម ដែលធ្វើដំណើរតាមកាណូត កម្លាំងម៉ាស៊ីន ៨សេះ។ ខ្ញុំឃើញកាណូតនោះត្រូវបានគេយកមកចតនៅមាត់ច្រាំងជិតនោះ។ ខ្ញុំបានឃើញប្តីប្រពន្ធត្រូវបានចងស្លាបសេក ហើយឲ្យអង្គុយលត់ជង្គង់លើដី។ យោធាដែលធ្វើក្នុងពេលនោះ គឺជាយោធានៅក្នុងវរសេនាធំលេខ ៦២ របស់ខ្ញុំ។ ដំបូងគេវ៉ៃប្តីនឹងគល់ឫស្សីចំក្បាលខាងក្រោយ។ បន្ទាប់ពីប្តីដួលទៅលើដី ទើបគេវ៉ៃប្រពន្ធដូចគ្នា។ ពេលដែលប្រពន្ធដួលទៅលើដី កូនង៉ែតយំ ហើយវារទៅឱបម្តាយ។ យោធាម្នាក់បានចាប់ជើងកូនង៉ែតនោះបោកនឹងគល់ដូងសម្លាប់តែម្តង។ គេបានកាប់សពប្តីប្រពន្ធនោះជាពីរកំណាត់ដោយចបកាប់ ហើយមួយកំណាត់ៗត្រូវបានកប់នៅក្រោមគល់ដូងមួយៗដើម្បីធ្វើជី”]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.41-46, 49 [“ស៖ នៅក្នុងបទសម្ភាសន៍របស់លោកជាមួយអង្គការអាដហុក លោកបាននិយាយថា លោកឃើញគេសម្លាប់ជនជាតិថៃ ៣០នាក់នៅលើទូក សូមលោករៀបរាប់ប្រាប់យើងអំពីព្រឹត្តិការណ៍នោះបានឬទេ? ឆ.41៖ រឿងរ៉ាវនេះកើតឡើងក្នុងរយៈពេលដែលខ្ញុំហាត់ហ្វឹកហ្វឺនទ័ពជើងទឹក។ ខ្ញុំបានឃើញថៃដែលគេចាប់បានយកមកដាក់នៅលើកោះមួយ។ ស៖ តើវាកើតឡើងក្នុងឆ្នាំណា? ឆ.42៖ នៅឆ្នាំ ១៩៧៧។ ស៖ តើនៅលើកោះណា? ឆ.43៖ នៅកោះពូលូវ៉ៃ។ ស៖ តើជនជាតិថៃទាំងនោះជាពួកអ្វី សូមលោករៀបរាប់ប្រាប់យើង? ឆ.44៖ គឺជាពួកនេសាទថៃ សុទ្ធតែជាមនុស្សប្រុសពេញវ័យ។ ខ្ញុំឃើញទូក

(គ) បញ្ជូនអ្នកទោសទៅដីគោក (រាម ឬអូរឈើទាល)[1333] ដែលនៅទីនោះ ពួកគេត្រូវបានគេទទួលដោយកងកម្លាំង ក្រោមការគ្រប់គ្រងរបស់ **មាស មុត**[1334] និងសម្លាប់នាពេលក្រោយនៅតំបន់កំពង់សោម ឬនៅ ស-២១ ជួនកាលបន្ទាប់ពីឃុំខ្លួនមួយរយៈនៅមន្ទីរសន្តិសុខកងពល ១៦៤[1335] ឬ

---

នេសាទមួយនៅទីនោះដែរ។ សៈ ម៉េចបានជាលោកដឹងថា ជាពួកគេជាអ្នកនេសាទត្រី មិនមែនជាទាហានខ្មាំង? ឆ.45 ៖ ពីព្រោះទូកនោះជាទូកនេសាទ ហើយយោធារបស់យើងនៅលើកោះបាននិយាយថា ពួកទាំងនេះជាពួកនេសាទ។ [...] ឆ.46៖ គេចងដៃ ហើយយោធានៅលើកោះបានប្រាប់ថា គេនឹងសម្លាប់ពួកនេសាទទាំងនោះ។ [...] ឆ.49៖ ខ្ញុំមិនបានឃើញគេសម្លាប់ដោយផ្ទាល់ភ្នែកទេ តែខ្ញុំដឹងថាគេមិនបាញ់ទេ គឺគេវាយសម្លាប់ចោលតែម្តង"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN ERN 00978576, KH ERN 00955507-00955508 [សៈ ចឹងបើចាប់បានពួកយួននោះ? ឆៈ បើពួកយួនចាប់បានគេយកមកសម្លាប់ចោល។ [...] ជួនកាលគេសម្លាប់នៅលើកោះហ្នឹងទៅ។ [...] ច្រើនតែប្រជាជនដែលរត់ភៀសខ្លួនទៅប្រទេសទីបី ភាគច្រើនពួកហ្នឹងរត់គេចពីសង្គ្រាម ដល់រត់ឆ្លងមកយើងចាប់បានបាញ់សម្លាប់ចោលទៅ"]។

1333 ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល ឆ.8 ["នៅពេលទៅដល់ផែអូរឈើទាល ខ្ញុំសង្កេតឃើញថាមានឡានមួយគ្រឿង គេត្រៀមចាំទទួលជនជាតិវៀតណាមដែលគេចាប់បានពីទូក។ ខ្ញុំចង់គូសបញ្ជាក់ជូនលោកឲ្យហើយមុននឹងលោកសួរខ្ញុំ ខ្ញុំជាអ្នកបើកទូកនោះ និងប្រើវិទ្យុទាក់ទងជាមួយនឹងកងវរសេនាធំរបស់ខ្ញុំ។ ខ្ញុំរាយការណ៍អំពីដំណើររបស់ខ្ញុំដល់ណាៗ និងពេលទៅដល់គោលដៅ។ ក្នុងពេលបែបនោះ គេឲ្យបើកវិទ្យុទាក់ទងគ្នារហូត"]។

1334 ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល ឆ.8, 15 ["កម្លាំងដែលមកទទួលពួកវៀតណាមទាំងនោះគឺមកពីមន្ទីរក្នុងរបស់កងពល ១៦៤។ [...] សៈ ហេតុអ្វីបានជាលោកដឹងថា ទាហានដែលមកទទួលជនជាតិវៀតណាមទាំងនោះ គឺជាកម្លាំងមកពីមន្ទីរក្នុងរបស់កងពល ១៦៤? ឆ.15៖ ខ្ញុំដឹង ដោយសារវរសេនាធំណែនាំប្រាប់ខ្ញុំ តាមវិទ្យុទាក់ទង។ បើតាមខ្ញុំចាំ គេថា "ឯងមានភារកិច្ចតែដឹកជញ្ជូនពួកវាទៅទីនោះ។ ពេលទៅដល់ កម្លាំងមកពីមន្ទីរក្នុងរបស់កងពលចាំទទួលស្រេចហើយ"]។ សូមមើលផងដែរ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ១០.៣៤.៤៥-១០.៣៩.៥៩ ["ឃើញថាភាគច្រើនឡាន គេដឹកបញ្ជូនចេញយកទៅក្រុងកំពង់សោមតែម្តង"]។ ឯកសារD54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត ឆ.144 ["តាមដែលខ្ញុំដឹង មាស មុត ជាអ្នករាយការណ៍ទៅភ្នំពេញ ហើយបន្ទាប់ពីទទួលរបាយការណ៍ អ្នកនៅភ្នំពេញបញ្ជូនឡានមកកំពង់សោមដើម្បីដឹកពួកគេទៅភ្នំពេញ"]។

1335 ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.11 ["អ្នកទាំងនោះរួមមានពួកនេសាទថៃ និងពួកនេសាទ និងជនភៀសខ្លួនវៀតណាម ដែលត្រូវចាប់បាន និងសម្លាប់ចោលនៅក្នុងសមុទ្រ នៅលើកោះ និងនៅលើដីគោក"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.25, 29 ["ជាទូទៅ កាលណាចាប់បានតិចជាង ២០ នាក់ គឺបញ្ជាឲ្យសម្លាប់នៅនឹងកន្លែង បើចាប់បានច្រើនជាង ២០ នាក់ ត្រូវបញ្ជូនទៅអូរឈើទាល។ [...] ឆ.29៖ បញ្ជាគឺគេប្រាប់ច្បាស់លាស់ថា តើត្រូវសម្លាប់នៅនឹងកន្លែង ឬក៏បញ្ជូនទៅលើគោក។ ប្រសិនបើអ្នកដែលត្រូវបានចាប់ខ្លួននោះជា

(ឃ) ចំពោះអ្នកនេសាទថៃខ្លះ ដោះលែង ឬដោះដូរពួកគេជាមួយទំនិញ[1336]។

380. ថ្នាក់ដឹកនាំកងពលចេញបញ្ជាជាភាសាសាមញ្ញ និងច្បាស់លាស់ ដូចជា "បាញ់ពួកហ្នឹងចោលទៅ" ឬ "បញ្ជូនពួកហ្នឹងមកដីគោក"[1337]។ សាក្សីម្នាក់បានឆ្លើយថា បញ្ជាពីកងពល ១៦៤ ជាទូទៅ គឺ៖

---

ទាហានវៀតណាម យើងត្រូវតែបញ្ជូនពួកនោះទៅដីគោក បន្ទាប់មក គេនឹងធ្វើការចាក់ផ្សាយចម្លើយសារភាពរបស់ទាហានវៀតណាមនៅក្នុងវិទ្យុជាតិមុនពេលគេសម្លាប់"]។ ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល ឆ.3 ["ក្នុងករណីដែលចាប់ទូក និងមនុស្សនៅលើទូក គឺទាំងមនុស្ស ទាំងទូក ត្រូវបានបញ្ជូនដោយនាវារបស់កងវរសេនាធំ ១៤០ ទៅកំពង់សោម ឬទីតាំងកោះណាមួយរយៈពេលខ្លី មុននឹងបញ្ជូនទៅកំពង់សោម។ បើនាវារបស់កងវរសេនាធំ ១៤០ ចេញមកពីកំពង់សោម ដើម្បីចាប់ទូក បន្ទាប់ពីទូកបានគេនិងយកទូក និងមនុស្សទៅកំពង់សោមត្រង់តែម្តង។ តែបើសិនជា នាវារបស់កងវរសេនាធំ ១៤០ ឈរជើងនៅកោះពូឡូវៃថ្មី ឬកោះតាង បន្ទាប់ពីចាប់ទូកនោះហើយ គឺគេត្រូវត្រឡប់ទៅកោះណាមួយក្នុងរយៈពេលខ្លីសិន ដែលទីតាំងនោះស្ថិតក្រោមការគ្រប់គ្រងរបស់វរសេនាធំ ៦២។ [...] ចុងក្រោយ ទាំងទូក និងមនុស្សត្រូវគេបញ្ជូនទៅកំពង់សោមទាំងអស់។ តាមការសម្គាល់របស់ខ្ញុំ កងវរសេនាធំ ៦២ គេពិនិត្យទូក និងមនុស្សដែលបានចាប់ និងបញ្ជូនទៅកំពង់សោមជាមួយនឹងរបាយការណ៍"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN ERN 00978576, KH ERN 00955508 ["ស៖ ចឹងមានគេបញ្ជូនមកដីគោកដែរឬអត់? ឆ៖ មានបញ្ជូនមក"]។ សូមមើលផងដែរ VIII.C. មន្ទីរសន្តិសុខរបស់កងពល ១៦៤។ VIII.D. មន្ទីរសន្តិសុខ ស-២១។

1336 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ១០.៥១.៣៤-១០.៥៤.៣៩ ["មានការខុសៗគ្នាខ្លះ។ [...] ខ្ញុំចាប់បានទូកប៉ាល់ថៃចំនួនបីគ្រឿង [...] ជនជាតិថៃទាំងអស់នោះនៅលើទូក ក្នុងទូកនីមួយៗមានចំនួន ២០នាក់ ១០ នាក់ ១៥ នាក់។ បាទ ជនជាតិថៃនោះគឺថា បញ្ជូនទៅរាមតែម្តង បាទ ទៅរាម។ ក្រោយមក ខ្ញុំបានទៅធ្វើការនៅរាម ជួបជនជាតិថៃនោះធ្វើការនៅទំនប់នៅរាម -- នៅរាមទេ -- នៅកោះតាគាវៗ។ ខ្ញុំគេឱ្យធ្វើការនៅកោះតាគាវនោះ ក៏ខ្ញុំបានជួបជនជាតិថៃទាំងអស់នោះ។ ខ្ញុំសួរអ្នកយាមថៃនោះថា ជនជាតិថៃទាំងអស់នេះ គេសម្លាប់គាត់ចោល ឬមួយក៏គេយកទៅណាដែរអ្នកយាម? អ្នកយាមនោះក៏បាននិយាយប្រាប់ខ្ញុំថា គេមិនសម្លាប់ចោលទេថៃទាំងអស់នេះ គេអាចបញ្ជូនគេទៅប្រទេសគេវិញ"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN ERN 00978575, KH ERN 00955506-00955507 ["រាមនឹងយកមក មិនមែនយកមកសម្លាប់ទេ ឱ្យបាយហូបធម្មតាយើងប្រើ។ [...] ស៖ អ៊ីចឹងអ្នកនេសាទថៃ ដែលគេចាប់នេះមកនឹងគេឱ្យមកជីកប្រឡាយ? ឆ៖ បាទ! ជីក លើកទំនប់។ [...] គេប្រាប់ខ្ញុំថាមិនឱ្យប៉ះពាល់ទេ ព្រោះឱ្យគេធ្វើការនឹងហើយ គេឱ្យបញ្ជូនឱ្យទៅវិញ។ [...] គេយកមកខ្លះគេឱ្យលើកទំនប់អ៊ីចឹង ខ្ញុំមកឃើញដែរតើ"]។

1337 ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.2 ["ស៖ តើលោកអាចពន្យល់ប្រាប់យើងបានដែរឬទេថា ពាក្យពេចន៍ដែលប្រើក្នុងពេលបញ្ជានោះ និយាយចេញថាម៉េចខ្លះ? ឆ.2៖ គេប្រើភាសាសាមញ្ញធម្មតានៅពេលបញ្ជា ឧទាហរណ៍ គេនិយាយថា "បាញ់ពួកហ្នឹងចោលទៅ ឬក៏បញ្ជូនពួកហ្នឹងមកដីគោក"]។

"'ធ្វើអ្វីក៏ធ្វើទៅកុំទុក' [...] បង្ហិនតែបាយ"[1338]។ ប៉ាក់ សុខ បានរំឭកថា ពេលពលរដ្ឋវៀតណាម តិចជាង ២០ នាក់ត្រូវបានចាប់ខ្លួននៅសមុទ្រ **មាស មុត** បានបញ្ជាឲ្យសម្លាប់ពួកគេនៅលើកោះ ឬ នៅសមុទ្រ តែបើជាក្រុមធំ ត្រូវបញ្ជូនទៅសម្លាប់នៅអូរឈើទាល[1339]។

381. **មាស មុត** ចេញបញ្ជាតាមវិទ្យុ ពាក់ព័ន្ធនឹងការចាប់កប៉ាល់បរទេស[1340]។ ក្រោយពេលអនុវត្តបញ្ជា នេះរួចរាល់ អង្គភាពទទួលខុសត្រូវលើការស្ទាក់ចាប់ ចាប់ខ្លួន បញ្ជូន ឬសម្លាប់ ត្រូវរាយការណ៍

---

1338 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មួល ឈិន ឆ.77-78 ["សៈ តើលោកអាចដឹងទេថា បញ្ជាយកមនុស្ស ដែលគេចាប់បានហ្នឹងទៅសម្លាប់ ចេញមកពីថ្នាក់ (កងវរសេនាតូច វរសេនាធំ កងពល) ណាដែរ? ឆ.77៖ កងវរ សេនាតូច ៣៨៦ នៅលើភ្នំ ដែលខ្ញុំបាននាំបង្ហាញលោក ទំនាក់ទំនងតាមវិទ្យុទាក់ទងទៅកងពលនៅកំពង់សោម។ ជា ទូទៅបទបញ្ជាពីកំពង់សោមវិញ ដោយនិយាយថា ធ្វើអ្វីក៏ធ្វើទៅកុំទុក។ សៈ ហេតុអ្វីបានជាគេនិយាយបែបនេះ? ឆ.78 ៖ ទុកមានប្រយោជន៍អ្វី បង្ហិនតែបាយ"]។

1339 ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ១៤.០០.៣៩-១៤.០៤.៣៧ ["បើចាប់បានពេញ គឺម្នាក់ ពីរនាក់ គឺសម្លាប់ៗចោលនៅលើកោះ និងនៅលើទឹកហើយ។ [...] បើគ្នាតិច អាហ្នឹងយើង សម្លាប់ចោល កាលណាបើដឹកទៅវិញ វាខាត [...] គម្រោងរបស់គេ គឺថាបើគ្នាតិច អាហ្នឹងសម្លាប់នៅលើកោះ និង លើទឹកហ្នឹងហើយ មិនបាច់យកទៅឲ្យខាតអីទេ"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ១១.០៣.០៧-១១.០៥.០៦ ["ហើយជនជាតិវៀតណាម ដែលជាច្រើនលើកច្រើនសា ដែលគេខ្លះក៏ គេបញ្ជូនមក ពេលច្រើនគេបញ្ជូនទៅដីគោក តែបើម្នាក់ពីរនាក់ គឺអត់ទេ អត់បញ្ជូនទៅលើដីគោកទេ គេសម្លាប់នៅលើ កោះក៏មាន"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក់ សុខ ឆ.25, 29 ["ជាទូទៅ កាលណាចាប់បានតិច ជាង ២០ នាក់ គឺបញ្ជាឲ្យសម្លាប់នៅនឹងកន្លែង បើចាប់បានច្រើនជាង២០នាក់ ត្រូវបញ្ជូនទៅអូរឈើទាល។ [...] ឆ. 29៖ បញ្ជាគឺគេប្រាប់ច្បាស់លាស់ថា តើត្រូវសម្លាប់នៅនឹងកន្លែង ឬក៏បញ្ជូនទៅលើគោក។ ប្រសិនបើអ្នកដែលត្រូវបាន ចាប់ខ្លួននោះជាទាហានវៀតណាម យើងត្រូវតែបញ្ជូនពួកនោះទៅដីគោក បន្ទាប់មក គេនឹងធ្វើការចាក់ផ្សាយចម្លើយ សារភាពរបស់ទាហានវៀតណាមនៅក្នុងវិទ្យុជាតិមុនពេលគេសម្លាប់"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់ មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN ERN 00978576, KH ERN 00955507-00955508 ["បើពួក យួនចាប់បានគេយកមកសម្លាប់ចោល។ [...] ជួនកាលគេសម្លាប់នៅលើកោះ។ [...] ច្រើនតែប្រជាជនដែលរត់ភៀស ខ្លួនទៅប្រទេសទីបី ភាគច្រើនពួកហ្នឹងរត់គេចពីសង្គ្រាម ដល់រត់ឆ្លងមកយើងចាប់បានបាញ់សម្លាប់ចោលទៅ។ [...] បញ្ជាពីកងពលទៅ។ សៈ បញ្ជាចេញពីនរណាទៅ? ឆៈ បញ្ជាចេញពីតា មុត។ សៈ បញ្ជាឲ្យសម្លាប់តែម្តង? ឆៈ បាទ ។ សៈ ចឹងមានគេបញ្ជូនមកដីគោកដែរឬអត់? ឆៈ មានបញ្ជូនមក"]។

1340 ឯកសារ D114/13 កំណត់ហេតុស្តាប់ចម្លើយ នាក់ យឿន ឆ.9-10 [អំពីការចាប់យកនិងដោះលែងនាវាដឹកទំនិញធំនៅ ឆ្នាំ ១៩៧៧៖ "សៈ ក៏ប៉ុន្តែលោកបាននិយាយថា លោកបានឮសំឡេង មាស មុត តាមវិទ្យុទាក់ទង។ តើត្រឹមត្រូវទេ? ឆ. 9៖ បាទ ខ្ញុំបានឮគាត់និយាយកុំឲ្យនាវាការពារចូលទៅជិតកប៉ាល់ទំនិញនោះទេ។ ពេលដែលគាត់ចេញទៅ ដោយផ្ទាល់ និងចូលរួមបេសកកម្មនោះ ខ្ញុំបានឮគាត់និយាយតាមវិទ្យុទាក់ទង។ សៈ តើលោកប្រាកដដែរទេថានោះ គឺជាសំឡេង

ត្រឡប់ទៅ **មាស មុត** ឬអនុរបស់ **មាស មុត** វិញ តាមរយៈខ្សែសង្វាក់នៃការបញ្ជាដដែល[1341]។ ដូច មូល ឈិន បានផ្តល់សក្ខីកម្ម "គេធ្វើហើយៗ" ឬ "គេបង្ហើយអ្នកទាំងនោះអស់ហើយ"[1342]។

---

របស់ មាស មុត ដែលនិយាយតាមវិទ្យុទាក់ទង? ឆ.10៖ បុគ្គលិកទាំងអស់នៅលើនាវាខ្ញុំស្គាល់សំឡេង មាស មុត។ ដូច្នេះ ខ្ញុំច្បាស់ណាស់ថាជាសំឡេងគាត់។ ដូចគ្នាផងដែរ នៅលើនាវាខ្ញុំមានកូនមីក្រូមួយដែលយើងអាចស្តាប់ឮការទំនាក់ទំនងគ្នាតាមវិទ្យុទាក់ទងបាន។ ដូច្នេះ បុគ្គលិកទាំងអស់នៅលើនាវាទាំងអស់ នៅលើនាវាខ្ញុំបានឮសំឡេង មាស មុត ទាំងអស់គ្នា។ អ៊ីចឹង [...] នៅក្នុងពេលប្រតិបត្តិការពិសេសនេះ មាស មុត និយាយតាមវិទ្យុទាក់ទងដោយខ្លួនឯង និងបានចេញបញ្ជាដោយផ្ទាល់ទៅឲ្យអង្គភាពពាក់ព័ន្ធ"]។

1341 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ១១.០៥.០៦-១១.០៩.៤៦ ["បើយើងចាប់បាន គឺរាយករាយការណ៍ជាបន្ទាន់ទៅវរសេនាតូច វរសេនាតូចរាយការណ៍ជាបន្ទាន់ទៅវរសេនាធំ វរសេនាធំរាយការណ៍ជាបន្ទាន់ទៅមន្ទីរកងពល។ បាទ ហើយបានបញ្ជាត្រឡប់មកវិញ បានអាចធ្វើបាន បាទ បញ្ជាទៅយោធាបាន បាទ"]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត ឆ.138-139, 141 ["ស៖ តើគេរាយការណ៍ដោយរបៀបណា ទៅអ្នកណា អំពីការចាប់បានវៀតណាមទាំងទាហាន និងស៊ីវិល? ឆ.138៖ នៅពេលដែលចាប់បានគេរាយការណ៍តាមវិទ្យុទាក់ទងពីកោះនានាមកកាន់កងពល។ ស៖ តើគេរាយការណ៍ពីការចាប់បានវៀតណាមទាំងនោះទៅ មាស មុត ឬក៏ទៅអ្នកណា? ឆ.139៖ មានករណីពីរអំពីការរាយការណ៍ នៅពេលដែល មាស មុត នៅកន្លែង គឺគេរាយការណ៍ទៅគាត់ផ្ទាល់។ តែពេលគាត់មិននៅ ឬអវត្តមាន គេរាយការណ៍ទៅអ្នកណាម្នាក់ដែលជំនួសគាត់នោះ។ [...] ឆ.141៖ គេរាយការណ៍តាមវិទ្យុទាក់ទង ហើយអ្នកនៅកន្លែងកាន់វិទ្យុទាក់ទងនោះត្រូវចុះកំណត់ហេតុក្នុងសៀវភៅប្រចាំថ្ងៃ ទោះព័ត៌មានអ្វីក៏ដោយ ដើម្បីបញ្ជូនព័ត៌មានទាំងនោះទៅឲ្យ មាស មុត"]។

1342 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.79-82 ["ស៖ តើលោកដឹងថា នេះគឺជាបញ្ជាចេញមកពីកំពង់សោមថា "ធ្វើអ្វីធ្វើទៅ កុំទុក" ដោយរបៀបណាទៅ? ឆ.79៖ ខ្ញុំអាចស្តាប់ឮបញ្ជានោះ តាមរយៈវិទ្យុទាក់ទងនៅខ្សែត្រៀមជិតផែ។ ជាទូទៅ ទីតាំងដែលគេនាំយកមនុស្សដែលគេចាប់បានទៅ គឺអាស្រ័យទៅលើកន្លែង ដែលគេចាប់អ្នកទាំងនោះបាន។ប្រសិនបើ គេចាប់នៅជិតកោះនេះ គេនឹងយកអ្នកទាំងនោះមកទីបញ្ជាការជិតជាងគេនៅលើកោះនេះតែម្តង។ ដូចគ្នាដែរ ចំពោះអ្នកដែលគេចាប់បាននៅកោះពូឡូវៃ និងកោះតាង។ ពួកអ្នកនេសាទដែលគេចាប់បានត្រូវបាននាំយកមកកាន់ទីបញ្ជាការផ្សេងៗជាច្រើន ចំណុះឲ្យកងពលលេខ ៣។ ស៖ ដូច្នេះអ្វីដែលលោកកំពុងប្រាប់យើងទាក់ទិននឹងការប្រាស្រ័យទាក់ទងគ្នា គឺដូចគ្នាទាំងស្រុងនឹងអ្វីដែលលោកបានឮនៅតាមវិទ្យុទាក់ទងដែរ មែនទេ? ឆ.80៖ ត្រឹមត្រូវហើយ ហើយតាមខ្ញុំយល់រាល់ពេលដែលគេចាប់បានទូក គឺទីបញ្ជាពាក់ព័ន្ធទាំងនោះនៅថ្នាក់កងវរសេនាតូចក្តី កងវរសេនាធំក្តី គឺគេរាយការណ៍ទៅឲ្យកងពលនៅកំពង់សោម។ ស៖ ចំពោះការដែលលោកនៅប្រចាំការ តើមានរបាយការណ៍ ឬការគូសបញ្ជាក់ផ្ញើទៅកងពលប្រាប់អំពីអ្វីដែលបានឡើងចំពោះមនុស្សដែលគេចាប់បានដែរឬទេក្រោយមកទៀត? ឆ.81៖ បាទ គឺតែងតែមានការរាយការណ៍ត្រឡប់ទៅកំពង់សោមវិញអំពីអ្វីដែលកើតឡើងចំពោះអ្នកដែលគេបានចាប់ខ្លួនទាំងនោះ។ ស៖ តើលោកនៅចាំថា គេប្រើពាក្យពេចន៍អ្វី អំពីការទំនាក់ទំនងគ្នា ពាក់ព័ន្ធនឹងការងារនេះ? ឆ.82៖ គេប្រើពាក្យ គេធ្វើហើយៗ ឬក៏បង្ហើយអ្នកទាំងនោះអស់ហើយ"]។

382. ទំនាក់ទំនងនៅក្នុងកងពល ១៦៤ ភាគច្រើន ធ្វើឡើងតាមវិទ្យុសម្រាប់ស្ថានការណ៍បន្ទាន់[1343] ឬតាមសារទូរលេខសម្រាប់របាយការណ៍ពេញលេញ[1344]។ ឧទាហរណ៍ របាយការណ៍តាមសារទូរលេខរបស់កងវរសេនាតូចឈរជើងនៅលើកោះ ត្រូវបានបញ្ជូនរៀងរាល់ល្ងាចទៅទីបញ្ជាការកងពល តាមរយៈកងវរសេនាធំរៀងៗខ្លួនរបស់ពួកគេ ដើម្បី "បូកសរុបការងារពីគ្រប់កោះទាំងអស់" ។ របាយការណ៍ទាំងនោះពិភាក្សាពីបញ្ហាសន្តិសុខ ក៏ដូចជា ការផ្គត់ផ្គង់អាហារ បញ្ហាសុខភាព និង

[1343] ឯកសារ E319/55.2.1 D114/140 កំណត់ហេតុស្តាប់ចម្លើយ ជា ផុន ឆ.36 ["ស៖ លោកប្រើប្រព័ន្ធទាក់ទងអ្វី កាន់កាំភ្លើង ឬក៏ធ្វើអ្វី? ឆ.36៖ ប្រភេទវិទ្យុទាក់ទង គេប្រើ សេវាំងសែង (C25) ដែលបំពាក់នៅលើនាវានោះស្រេចដោយអាមេរិកាំង"]។ ឯកសារ D54/78 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល ឆ.13-17 ["ខ្ញុំដឹងពីព្រោះ ខ្ញុំជាអ្នកបើកកាណូត ហើយខ្ញុំបើកវិទ្យុទាក់ទងខ្ញុំជាប់ជានិច្ច។ វាជាទម្លាប់ការងារដែលយើងបើកវិទ្យុទាក់ទងរៀងរាល់មួយម៉ោងម្តង។ [...] ឆ.14៖ ជាទូទៅគេមានវិទ្យុទាក់ទងតាមកប៉ាល់ កាណូត ហើយគ្រប់អនុសេនាធំ និងវរសេនាធំសុទ្ធតែមានវិទ្យុទាក់ទង ដើម្បីទំនាក់ទំនងគ្នា។ [...] ស៖ តើកងវរសេនាតូចទាំងអស់នៅក្រោមកងវរសេនាធំ ៦២ ប្រើប្រាស់ប្រេកង់ដូចគ្នា ឬក៏យ៉ាងណា? ឆ.15៖ មានប្រេកង់ដូចគ្នា។ [...] ស៖ [...] តើលោកអាចស្តាប់បានការប្រាស្រ័យទាក់ទងគ្នារវាងកងវរសេនាធំ ៦២ និងកងពល ១៦៤ បានឬទេ? ឆ.16៖ អត់ទេ កងវរសេនាធំ ៦២ ប្រើប្រាស់ប្រេកង់ផ្សេងមួយទៀតជាមួយកងពល ១៦៤។ [...] ស៖ តើកងវរសេនាធំ ១៤០ ប្រើប្រាស់ប្រេងកង់វិទ្យុទាក់ទងដែលលោកអាចចាប់បានដែរឬទេ? ឆ.17៖ កងវរសេនាធំមួយមានកងវរសេនាតូចនៅក្រោមបង្គាប់របស់ខ្លួន ដូច្នេះមានតែកងវរសេនាតូចដែលនៅក្រោមកងវរសេនាធំនោះទេ ដែលអាចចាប់ប្រេកង់គ្នាឯងបាន។ កងផ្សេងៗទៀតពុំអាចចាប់ប្រេកង់នេះទេ។ ឧទាហរណ៍ ខ្ញុំអាចស្តាប់ឮតែការទំនាក់ទំនងគ្នាក្នុងចំណោមកងវរសេនាតូចក្រោមចំណុះកងវរសេនាធំ ៦២ ប៉ុណ្ណោះ"]។ ឯកសារ D54/83 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.30 ["ស៖ នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា (ទំព័រ ១៦ ជាភាសាអង់គ្លេស) លោកបាននិយាយថា ករណីខ្លះនៃការចាប់ទូក គេបញ្ជូនព័ត៌មានតាមតេឡេ គឺមិនមែនបញ្ជូនតាមទូរសារទេ។ ហេតុអ្វីបានជាករណីចាប់ទូកបែបនេះ គេបញ្ជូនតាមតេឡេ បែរជាមិនប្រើសារទូរលេខ? ឆ.30៖ ដូចដែលខ្ញុំបានប្រាប់លោកពីខាងដើមអ៊ីចឹងថា ក្នុងករណីបន្ទាន់ ឬចាំបាច់ យើងប្រើប្រាស់ទំនាក់ទំនងតាមតេឡេ ហើយក្រោយមក យើងធ្វើការបូកសរុបនូវអ្វីដែលយើងបានធ្វើបញ្ចូលទៅក្នុងសារទូរលេខ។ អនុញ្ញាតឱ្យខ្ញុំជម្រាបលោកបន្ថែមទៀតថា សារទូរលេខមានភាពយឺតយ៉ាវណាស់ក្នុងករណីបន្ទាន់ ហេតុដូច្នេះហើយទើបយើងប្រើប្រាស់ទំនាក់ទំនងតាមតេឡេជំនួសវិញ ដោយសារតែវាមានភាពឆាប់រហ័សជាង"]។ ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.1 ["ស៖ ជាទូទៅនៅពេលដែលកងនាវិកនៅលើនាវាទទួលបញ្ជាឱ្យសម្លាប់ ឬមួយបញ្ជូនពួកអ្នកដែលគេចាប់បាន តើបញ្ជានោះធ្វើដោយផ្ទាល់មាត់តាមរយៈវិទ្យុទាក់ទង ឬក៏តាមម៉ាស៊ីនម៉ស? ឆ.1៖ បញ្ជាគឺតាមការនិយាយផ្ទាល់មាត់តាមរយៈវិទ្យុទាក់ទង"]។

[1344] ឯកសារ D54/83 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.1 ["ខ្ញុំសូមបញ្ជាក់ថា គេប្រើប្រាស់សារទូរលេខដោយសារវាជាការងារសម្ងាត់"]។ ឯកសារ D54/78 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល ឆ.16 ["មធ្យោបាយទំនាក់ទំនងមួយទៀត ប្រើសារទូរលេខរបស់ចិន គឺគេទំនាក់ទំនងគ្នារវាងកងវរសេនាតូច និងកងវរសេនាធំ និងពីកងវរសេនាធំ ៦២ និងកងពល ១៦៤"]។

សំណង់[1345]។ កងវរសេនាធំ ១៤០ (កងទ័ព) ក៏រាយការណ៍ផងដែរទៅទីបញ្ជាការកងពល ១៦៤[1346]។ **មាស មុត** រាយការណ៍អំពីរាល់បញ្ហាសន្តិសុខទាំងអស់ រួមទាំងការដេញចាប់កប៉ាល់បរទេស ទៅ សុន សេន នៅទីបញ្ជាការសេនាធិការ ជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ក្នុងពេលប្រជុំដែលគាត់ចូលរួមជាទៀងទាត់នៅភ្នំពេញ[1347]។

---

1345 ឯកសារ D54/82 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ិច (អ្នកបកប្រែទូរលេខរបស់កងវរសេនាធំ ៦២ កងពល ១៦៤) ឆ.19-20 ["ជាធម្មតាសម្រាប់កម្រិតរបស់ខ្ញុំ ខ្ញុំត្រូវធ្វើរបាយការណ៍១ថ្ងៃម្តង នៅពេលល្ងាច ដោយបូកសរុបការងារពីគ្រប់កោះទាំងអស់ ដើម្បីផ្ញើទៅកងពល។ ស៖ សូមលោកជួយរៀបរាប់អំពីរបាយការណ៍ប្រចាំថ្ងៃ ទាក់ទងនឹងព្រឹត្តិការណ៍នានា ដូចជាសន្តិសុខ និងការផ្គត់ផ្គង់ស្បៀង។ល។ ឆ.20៖ របៀបនៃការរាយការណ៍ប្រចាំថ្ងៃ ដំបូងយើងប្រមូលសេចក្តីរាយការណ៍ពីគ្រប់កោះទាំងអស់ដែលនៅក្រោមចំណុះកងវរសេនាធំរបស់យើង។ បន្ទាប់មក យើងពិនិត្យរបាយការណ៍ទាំងអស់នោះ ដែលរួមមាន បញ្ហាសុខភាព សភាពការណ៍ផ្សេងៗ និងការងារកសាងទីតាំង រួចហើយបូកសរុបចំណុចនីមួយៗ ហើយយើងសរសេរបញ្ចូលចំណុចសំខាន់ៗ ដោយចំណុចដែលសំខាន់ជាងគេ យើងដាក់នៅក្នុងចំណុចទី១ និងចំណុចសំខាន់បន្ទាប់យើងដាក់នៅក្នុងចំណុចទី២ និងចំណុចទី៣ជាហូរហែ ហើយយើងសរសេរបញ្ចូលគ្រប់ចំណុចទាំងអស់តែក្នុងមួយច្បាប់ទេ បន្ទាប់មកទើបបញ្ជូនទៅកាន់កងពល"]។

1346 សូមមើល V. ទំនាក់ទំនង។

1347 ឯកសារ D1.3.30.25 ទូរស័ព្ទសម្ងាត់ពី មុត ចុះថ្ងៃទី ០១ ខែ ៤ ឆ្នាំ ៧៨ EN ERN 00143507, KH ERN 00017026, FR ERN 00611668 [សេចក្តីរាយការណ៍ "សរុបយួនចាប់បាន និងបាញ់ងាប់ ចាប់ពីថ្ងៃ ២៧-៣-៧៨ មកដល់ ថ្ងៃ ៣០-៣-៧៨ មានចំនួន ១២០ ក្បាល" ហើយជាមូលហេតុនៃការពន្យារពេលក្នុងការដោះដូរអ្នកទោសថៃ "បារី ៣ សុង" គឺដោយសារកំហុសអក្ខរាវិរុទ្ធនៃឈ្មោះរបស់ពួកគេ"]។ ឯកសារ D1.3.12.20 សេចក្តីរាការណ៍ពី មាស មុត ទៅ សុន សេន ថ្ងៃទី ១២-៨- ៧៧ EN ERN 00233972, KH ERN 00020912, FR ERN 00623197 ["ម្សិលមិញ ថ្ងៃទី ១១-៨-៧៧ យើងចេញល្បាតចាប់បានទូក ២ គ្រឿង ១ ធុន ៣៥០សេះ ១ទៀតធុន ១៧៥សេះ។ ទូកធុន ១៧៥សេះ មានមនុស្ស ៥ នាក់ គ្មានប្រដាប់នេសាទទេ។ ចាប់បាននៅកៀកកោះកុង ប្រហែល ២ គ.ម"]។ ឯកសារ D1.3.34.64 ទូរស័ព្ទសម្ងាត់ពី មាស មុត ទៅបង៨៩ (សុន សេន) ចុះថ្ងៃទី ២០-៣-៧៨ EN ERN 00233649, KH ERN 00020982, FR ERN 00623220 ["នៅកោះវៃ យប់ថ្ងៃទី១៩-៣-៧៨ ម៉ោង ៤ ព្រឹកឡើងថ្ងៃ ២០-៣-៧៨ បងប្អូនឃើញកាណូតសៀម ១ គ្រឿង [...] យើងដេញចាប់វាបាននៅម៉ោង ៥ ភ្លឺ កាណូតធុន ២៥០សេះ មានមនុស្ស ២១ នាក់ [...] ៣-នៅកោះតាង វេលាម៉ោង ២.៣០ នាទីថ្ងៃ ២០-៣-៧៨ កាណូត ៨០០សេះរបស់យើងចេញធ្វើការនៅខាងកើត ភាគខាងត្បូងកោះតាង ចម្ងាយ ១២ គ.ម ចាប់បានកាណូតអាយួន ២គ្រឿង នៅលើកាណូត ២ គ្រឿងនេះ ពេញដោយយួន ៧៦ នាក់ មានក្មេង ចាស់ ប្រុស ស្រី។ តែក្នុងពេលយើងចងរួចហើយ កូនកាណូតតូចឃ្លោង បណ្តាលឲ្យធ្លាក់ទឹកបាត់ ២ នាក់ រកពុំឃើញ។ បានឲ្យយកមកដល់ដីគោកហើយ"]។ ឯកសារ D1.3.34.10 ទូរលេខ ៤៤ ពី មាស មុត ទៅបង៨៩ (សុន សេន) ចុះថ្ងៃ ១៣-៨-៧៦ EN ERN 00233647, KH ERN 00000860, FR ERN 00323217 [""ថ្ងៃ ១២-៨ យើងចាប់កប៉ាល់ បានទៅចតនៅផែកោះតាង។ ក្រោយមក មានយ

## ៣. តួនាទីរបស់កងពលលេខ ១ ក្នុងការចាប់ខ្លួន

383. កងពលលេខ ១ នៃភូមិភាពបស្ចិម (ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ **មាស មុត**) ធ្វើប្រតិបត្តិការតាមបណ្ដោយឆ្នេរនៃខេត្តកោះកុង[1348]។ កងពលលេខ ១ មានតួនាទីការពារទឹកដីតាមបណ្ដោយព្រំ

---

ន្តហោះមួយគ្រឿងមកឆ្វែលលើកោះតាង។ [...] ថ្ងៃ ១២-៨ មានការប៉ះទង្គិចរវាងយើង និងកាណូតចាប់ត្រីថៃ អស់ជិត ៤ ម៉ោងនៅមុខកោះកុងក្រៅ ៤,៥ គម.។ លទ្ធផល កាណូតចាប់ត្រីថៃមួយត្រូវយើងចាប់ ឯមនុស្សធ្លាក់ទឹក"]។ ឯកសារ D1.3.12.18 ទូរលេខ ០៩ មកពីលេខាធិការដ្ឋានកងពលធំ ១៦៤, មាស មុត ទៅ សុន សេនចុះថ្ងៃ ២៨ - ៥ - ៧៧ EN ERN 00233992, KH ERN 00162487, FR ERN 00532721 [បានរៀបរាប់ពីការដេញតាមកប៉ាល់នេសាទថៃ បន្ទាប់ពី "ចូលក្នុងដែនទឹករបស់យើងយ៉ាងជ្រៅ" និង "បានជួបហ្វូងកាណូតថៃប្រហែល ៥០ ទៅ ៦០ គ្រឿង។ យើងក៏សំដៅទៅរកវា ឯទៀតនាំគ្នារត់អស់ នៅសល់ធុន ៤០០ សេះមួយគ្រឿងត្រូវយើងចាប់ខ្លួនដោយគ្មានឃើញមនុស្ស តាមមើលវាលោតទម្លាក់ទឹកអស់" និង "កាណូតចាប់ត្រីយួនបានចូលមកចាប់ត្រីក្នុងទឹកយើងរហូតនៅចម្ងាយ ១០ គីឡូដី ពីកោះឫស្សី ពួកអានេះធ្វើយប់មិនបើកភ្លើង យើងមើលឃើញតែតាមរ៉ាដា។ យើងចេញធ្វើការស៊ើរចាប់ទាំងយប់ដែរ តែមិនបានជួបវា។ ថ្ងៃ ២៨-៥ នេះចាប់ពីម៉ោង ៧ ព្រឹកមក យើងមើលឃើញកប៉ាល់ធុនធំរបស់ យួនមួយគ្រឿងនៅខាងកើតឈៀងខាងជើងកោះត្រល់ក្នុងទឹកដីយើង វានៅរហូតដល់យប់ទើបវាទៅខាងត្បូងឈៀងខាងលិចកោះត្រល់ក្នុងទឹកដីយើងទៀត" កំណត់សម្គាល់ពី សុន សេន៖ "ចំពោះកប៉ាល់យួនវាមកបើកចុះឡើង [...] ១-ឲ្យ មិត្តមុក គាត់ទៅសហការមូលដ្ឋាន។ ២-លើកគោលការណ៍ បើវាមិនចេញ វាយប្លួន ៥ ដើមតែ១ព្រិបដាក់វា តែប្រយ័ត្ន"]។ ឯកសារ D1.3.12.7 កម្ពុជាប្រជាធិបតេយ្យ សេចក្ដីរាយការណ៍ ខែសីហា ឆ្នាំ១៩៧៦ EN ERN 00233963, KH ERN 00021503, FR ERN 01248460 ["នៅខាងមុខកោះកុង ថៃបានចូលមកចាប់ត្រី មានទ្រង់ទ្រាយធំ និងលក្ខណៈបំផ្លាញទៀតផង [...] មានការប៉ះទង្គិចគ្នារវាងយើងនិងវាអស់រយៈជិត ៤ ម៉ោង នៅមុខកោះកុងក្រៅចម្ងាយ ៤ គ.ម កន្លះ។ យើងចាប់បានកាណូតចាប់ត្រី ១គ្រឿង មនុស្សធ្លាក់ទឹក។ [...] យើងចាប់បានកាណូតថៃ ២គ្រឿងធុន ៥០សេះ និង ៤០០សេះ មានមនុស្សចំនួន ១៨ នាក់ កាំភ្លើង ៣ ដើមធ្លាក់ទឹកអស់ ២ ដើមនៅសល់ ការ៉ាប៊ីន ១ ដើមនិងវិទ្យុកូឡាំង ១ គ្រឿង"]។ ឯកសារ D54/11 កំណត់ហេតុស្ដាប់ចម្លើយ ម៉ី រ៉េត ឆ.20 ["តាមុតត្រូវរាយការណ៍អំពីព្រឹត្តិការណ៍ទាំងនេះ ដូចជាការបាញ់និងចាប់ទូករៀតណាមទៅឲ្យថ្នាក់លើ ដើម្បីឲ្យថ្នាក់លើមានវិធានការត្រឹមត្រូវ"]។ ឯកសារ D1.3.34.23 ទូរលេខ ២៨ ចុះថ្ងៃទី ១២-៨-៧៧ [កំណត់សម្គាល់ដោយ ខៀវ សំផន៖ "ផ្អែកលើរបាយការណ៍ផ្ទាល់មាត់សមមិត្ត មុត កាលពីម្សិលមិញយើងចាប់បានទូកមួយគ្រឿង កម្លាំង (១៧០ សេះ) នៅកោះកុងក្រៅត្រង់ចុងកោះខាងត្បូង។ កន្លែងបង និងខ្ញុំចតកប៉ាល់។ ចាប់ថៃបាន ៤ នាក់ ខ្មែរ ១ ម្នាក់។ វាឆ្លើយថាទាក់ទង។ មានក្បូនឫស្សីនៅលើទូក។ កំពុងសួរ"]។

[1348] ឯកសារ D54/54 កំណត់ហេតុស្ដាប់ចម្លើយ មាស វឿន ឆ.17 ["ខ្ញុំសូមពន្យល់ប្រាប់លោកអំពីរបៀបចាត់ចែងប្រតិបត្តិការរបស់កងពលលេខ ១ នៅពេលនោះ។ កងពលលេខ ១ មានទីបញ្ជាការកងពលនៅបន្ទាយលង្វែក ដោយសារទឹកដីកោះកុងស្ថិតនៅក្នុងភូមិភាគបស្ចិម ដូច្នេះកងពលលេខ ១ ត្រូវបែងចែកជា ២ [...] មួយវរសេនាធំ ដែលមានបីវរសេនាតូចក្រោមការបញ្ជារបស់ខ្ញុំ យកទៅប្រតិបត្តិការនៅប៉ែកកោះកុង ហើយមួយផ្នែកទៀតស្ថិតនៅទីបញ្ជាការដ្ឋានកងពលនៅបន្ទាយលង្វែក"]។

ដែននៅក្នុងភូមិភាគបស្ចិម[1349]។ កងពលលេខ ១ កាន់កាប់តំបន់ឆ្នេរដែលជាប់ព្រំជាមួយប្រទេសថៃ ហើយដូច្នេះ មានសិទ្ធិអំណាចលើផ្នែកមួយចំនួននៃព្រំដែនសមុទ្រប្រទេសកម្ពុជា និងដែនទឹកអន្តរជាតិ រវាងប្រទេសកម្ពុជា និងប្រទេសថៃ[1350]។ ដូច្នេះ ទំនួលខុសត្រូវរបស់កងពលលេខ ១ និងកងពល ១៦៤ មានផ្នែកខ្លះជាន់គ្នា។ កងពលលេខ ១ មានកាណូតផ្ទាល់ខ្លួន ដើម្បីយាមល្បាតព្រំដែនសមុទ្រ[1351] ប៉ុន្តែ កងពលលេខ ១ ពុំមាននាវាធំៗនោះទេ[1352]។

---

1349 ឯកសារ D54/51 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.17 ["សៈ លោកបាននិយាយពីខាងដើមមកថា កងទ័ពជើងទឹកតែងតែធ្វើប្រតិបត្តិការតាមឆ្នេរសមុទ្រ និងក្នុងសមុទ្រ ហើយកងពលលេខ ១ របស់ភូមិភាគបស្ចិមប្រតិបត្តិការតាមឆ្នេរសមុទ្រនៃខេត្តកោះកុង។ តើលោកអាចពន្យល់ប្រាប់យើងបានឬទេថា តើទំនាក់ទំនងរវាងកងទ័ពជើងទឹក ហើយនិងកងពលលេខ១ ភូមិភាគបស្ចិមយ៉ាងម៉េចខ្លះ? តើអ្នកណាមានអំណាចលើអ្នកណា? ឆ.17៖ [...] រវាងកងទ័ពជើងទឹក និងកងពលលេខ ១ នៃភូមិភាគបស្ចិម គ្មានអ្នកណាមានអំណាចលើអ្នកណាទេ។ កងពលលេខ ១ គឺមិនមានបំពាក់សម្ភារៈសឹកទៅជាកងទ័ពជើងទឹកទេ។ កងពលលេខ ១ គឺជាកងទ័ពជើងគោករបស់ភូមិភាគបស្ចិម។ តួនាទីរបស់កងពលលេខ ១ គឺការពារទឹកដីតាមព្រំដែននៅក្នុងភូមិភាគបស្ចិម ទាំងព្រំដែនទឹក និងព្រំដែនគោក។ ប្រសិនបើមានជម្លោះនៅលើសមុទ្រជាមួយប្រទេសជទៃ កងពលលេខ ១ ធ្វើការទាក់ទងកងទ័ពជើងទឹកដើម្បីអន្តរាគមន៍ទប់ទល់ជាមួយបញ្ហាទាំងនោះ ពីព្រោះកងទ័ពជើងទឹកមាននាវាចម្បាំង ឯកងពលលេខ ១ មិនមាននាវាចម្បាំង គឺមានតែទូកតូចៗសម្រាប់ល្បាត និងដឹកជញ្ជូនប៉ុណ្ណោះ"]។

1350 ឯកសារ D54/51 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.18, 20 ["សៈ រវាងកងពលលេខ ១ របស់ភូមិភាគបស្ចិម និងកងទ័ពជើងទឹក តើអ្នកណាដែលជាអ្នកទទួលខុសត្រូវការពារខ្សែបន្ទាត់សមុទ្រកម្ពុជា និងសមុទ្រអន្តរជាតិ ព្រំដែនសមុទ្រប្រទេសកម្ពុជានិងប្រទេសថៃ និងព្រំដែនសមុទ្រប្រទេសកម្ពុជានិងប្រទេសវៀតណាម?: ឆ.18៖ កងទ័ពជើងទឹកមានទឹកដី និងសមុទ្រ និងបន្ទាត់ព្រំដែននៅក្រោមការត្រួតពិនិត្យរបស់គេ។ ចំណែកកងពលលេខ ១ ក៏មានទឹកដី ហើយនិងខ្សែបន្ទាត់ព្រំដែនរបស់ខ្លួនគេដែរ។ ដោយសារភូមិភាគបស្ចិមមានព្រំដែនជាប់ជាមួយថៃ និងដែនសមុទ្រអន្តរជាតិ ដូច្នេះផ្នែកខ្លះនៃព្រំដែនរវាងសមុទ្រកម្ពុជា និងដែនសមុទ្រអន្តរជាតិ ហើយនិងសមុទ្រកម្ពុជានិងសមុទ្រថៃ គឺស្ថិតក្រោមការត្រួតត្រារបស់កងពលលេខ ១។ ផ្នែកផ្សេងៗទៀតនៃព្រំដែន ស្ថិតនៅក្រោមការត្រួតត្រារបស់កងទ័ពជើងទឹក។ កងពលលេខ ១ មានកាណូតខ្លួនឯងដើម្បីល្បាតតាមបណ្តោយខ្សែបន្ទាត់ព្រំដែន។ ប្រសិនបើមានបញ្ហាធ្ងន់ធ្ងរនៅលើសមុទ្រ កងពលលេខ១ហៅកងទ័ពជើងទឹកមកជួយធ្វើអន្តរាគមន៍។ [...] សៈ តើពេលណាដែលលោកចាំថាកងទ័ពជើងទឹកចូលមកអន្តរាគមន៍កងពលលេខ ១ នៅកោះកុង? ឆ.20៖ ខ្ញុំមិនចាំថាមានព្រឹត្តិការណ៍ដែលកងទ័ពជើងទឹកចូលមកធ្វើអន្តរាគមន៍ទេ ប៉ុន្តែ កងទ័ពជើងទឹកគេតែងតែមកបោះយុថ្កានៅកោះកុងជារឿយៗ គឺមកបោះយុថ្កាម្តងៗ ២ អាទិត្យទើបត្រឡប់ទៅវិញ។ គេមករាល់ៗខែ ហើយម្តងៗមានពីរទៅបីកប៉ាល់"]។

1351 ឯកសារ D54/51 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.18, 20 ["សៈ រវាងកងពលលេខ ១ របស់ភូមិភាគបស្ចិម និងកងទ័ពជើងទឹក តើអ្នកណាដែលជាអ្នកទទួលខុសត្រូវការពារខ្សែបន្ទាត់សមុទ្រកម្ពុជានិងសមុទ្រអន្តរជាតិ ព្រំដែនសមុទ្រប្រទេសកម្ពុជានិងប្រទេសថៃ និងព្រំដែនសមុទ្រប្រទេសកម្ពុជានិងប្រទេសវៀតណាម?: ឆ.18៖ កងទ័ពជើងទឹក

384. កងពលលេខ ១ ឃ្លាំមើលសមុទ្រដើម្បីដឹងថា តើមានកប៉ាល់បរទេសឬអត់ ពីមូលដ្ឋានដីគោករបស់ខ្លួន ដោយប្រើវ៉ាដា និងកែវយិត។ ពេលពួកគេឃើញគោលដៅ ពួកគេរាយការណ៍ទៅ **មាស មុត** ហើយបន្ទាប់មក **មាស មុត** ចេញបញ្ជាទៅនាវាកងពល ១៦៤ ឱ្យចាប់កប៉ាល់បរទេសនោះ[1353]។

---

មានទឹកដី និងសមុទ្រ និងបន្ទាត់ព្រំដែននៅក្រោមការត្រួតពិនិត្យរបស់គេ។ ចំណែកកងពលលេខ ១ ក៏មានទឹកដី ហើយនិងខ្សែបន្ទាត់ព្រំដែនរបស់ខ្លួនគេដែរ។ ដោយសារភូមិភាគបស្ចិមមានព្រំដែនជាប់ជាមួយថៃ និងដែនសមុទ្រអន្តរជាតិ ដូច្នេះ ផ្នែកខ្លះនៃព្រំដែនរវាងសមុទ្រកម្ពុជា និងដែនសមុទ្រអន្តរជាតិ ហើយនិងសមុទ្រកម្ពុជានិងសមុទ្រថៃ គឺស្ថិតក្រោមការត្រួតត្រារបស់កងពលលេខ ១។ ផ្នែកផ្សេងៗទៀតនៃព្រំដែន ស្ថិតនៅក្រោមការត្រួតត្រារបស់កងទ័ពជើងទឹក។ កងពលលេខ ១ មានកាណូតខ្លួនឯងដើម្បីល្បាតតាមបណ្តោយខ្សែបន្ទាត់ព្រំដែន។ ប្រសិនបើមានបញ្ហាធ្ងន់ធ្ងរនៅលើសមុទ្រ កងពលលេខ ១ ហៅកងទ័ពជើងទឹកមកជួយធ្វើអន្តរាគមន៍។ [...] សៈ តើពេលណាដែលលោកចាំថាកងទ័ពជើងទឹកចូលមកអន្តរាគមន៍កងពលលេខ ១ នៅកោះកុង? ឆ.20៖ ខ្ញុំមិនចាំថាមានព្រឹត្តិការណ៍ដែលកងទ័ពជើងទឹកចូលមកធ្វើអន្តរាគមន៍ទេ ប៉ុន្តែ កងទ័ពជើងទឹកគេតែងតែមកបោះយុថ្កានៅកោះកុងជារឿយៗ គឺមកបោះយុថ្កាម្តងៗ ២ អាទិត្យទើបត្រឡប់ទៅវិញ។ គេមករាល់ៗខែ ហើយម្តងៗមានពីរទៅបីកប៉ាល់"]។ ឯកសារ D54/34 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង ឆុន ឆ.11 ["សៈ តើកងពលទី ១ គេមាននាវាឬកប៉ាល់សម្រាប់ការពារដែនឆ្នេរកោះរបស់គេឬ? ឆ.11៖ កងពលទី ១ មានតែទូកឈើតូចៗ សម្រាប់ប្រើប្រាស់ធម្មតា យើងមិនមាននាវាប្រយុទ្ធទេ។ មានតែកងពល ១៦៤ ទេ ដែលមានកប៉ាល់ប្រយុទ្ធ និងកប៉ាល់ធំៗសម្រាប់ការពារដែនទឹករបស់កម្ពុជា"]។

1352 ឯកសារ D54/51 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.17 ["សៈ លោកបាននិយាយពីខាងដើមមកថា កងទ័ពជើងទឹកតែងតែធ្វើប្រតិបត្តិការតាមឆ្នេរសមុទ្រ និងក្នុងសមុទ្រ ហើយកងពលលេខ ១ របស់ភូមិភាគបស្ចិមប្រតិបត្តិការតាមឆ្នេរសមុទ្រនៃខេត្តកោះកុង។ តើលោកអាចពន្យល់ប្រាប់យើងបានឬទេថា តើទំនាក់ទំនងរវាងកងទ័ពជើងទឹក ហើយនិងកងពលលេខ ១ ភូមិភាគបស្ចិមយ៉ាងម៉េចខ្លះ? តើអ្នកណាមានអំណាចលើអ្នកណា? ឆ.17៖ [...] រវាងកងទ័ពជើងទឹក និងកងពលលេខ ១ នៃភូមិភាគបស្ចិម គ្មានអ្នកណាមានអំណាចលើអ្នកណាទេ។ កងពលលេខ ១ គឺមិនមានបំពាក់សម្ភារៈសឹកទៅជាកងទ័ពជើងទឹកទេ។ កងពលលេខ ១ គឺជាកងទ័ពជើងគោករបស់ភូមិភាគបស្ចិម។ តួនាទីរបស់កងពលលេខ ១ គឺការពារទឹកដីតាមព្រំដែននៅក្នុងភូមិភាគបស្ចិម ទាំងព្រំដែនទឹក និងព្រំដែនគោក។ ប្រសិនបើមានជម្លោះនៅលើសមុទ្រជាមួយប្រទេសដទៃ កងពលលេខ ១ ធ្វើការទាក់ទងកងទ័ពជើងទឹកដើម្បីអន្តរាគមន៍ទប់ទល់ជាមួយបញ្ហាទាំងនោះ ពីព្រោះកងទ័ពជើងទឹកមាននាវាចម្បាំង ឯកងពលលេខ ១ មិនមាននាវាចម្បាំង គឺមានតែទូកតូចៗសម្រាប់ល្បាត និងដឹកជញ្ជូនប៉ុណ្ណោះ"]។

1353 ឯកសារ D54/34 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង ឆុន ឆ.1-7 ["សៈ លោកបាននិយាយថា ការងារនៅកន្លែងកន្លែងកោះកុងនោះ គឺចាំតែទទួលបញ្ជាទៅចាប់ទូកនេសាទខុសច្បាប់ សូមលោកពន្យល់ប្រាប់យើងថាអ្នកណាជាអ្នកចេញបញ្ជាឱ្យចេញចាប់នោះ? ឆ.1៖ គឺតាម មុត គាត់ជាអ្នកចេញបញ្ជាតាមទូរលេខទៅមេបញ្ជាការកប៉ាល់។ ខ្ញុំគ្រាន់តែជាយោធាធម្មតាទេ មានមេបញ្ជាការកប៉ាល់នៅពីលើខ្ញុំថា តើតា មុត ទទួលបញ្ជាពីអ្នកណាផ្សេងទៀត គឺខ្ញុំមិនបានដឹងទេ។ សៈ ហេតុដូចម្តេចបានលោកដឹងថា តាមុតជាអ្នកបញ្ជា? ឆ.2៖ នៅកន្លែងតា មុត គាត់មានម៉ាស៊ីនទូរលេខ ហើយគេមានម៉ាស៊ីនសារទូរលេខម្ខាងទៀតនៅជិតផែកប៉ាល់កោះកុងដែលឋិតនៅអតីតដំណាក់ស្តេច។ នៅពេលដែលអ្នកកាន់

ពេលខ្លះ កម្លាំងកងពលលេខ ១ ជាអ្នកចាប់កប៉ាល់បរទេសដោយខ្លួនឯង។ ក្នុងករណីនេះ អង្គភាពពាក់ព័ន្ធរាយការណ៍អំពីហេតុការណ៍ទៅមេបញ្ជាការកងពល តាសឿង។ បន្ទាប់មក តាសឿងបញ្ជាពួកគេឱ្យនាំអ្នកដែលត្រូវបានចាប់ខ្លួនទៅតំបន់កំពង់សោម[1354] ដែលនៅទីនោះ ពួកគេត្រូវបានប្រគល់ទៅឱ្យកងទ័ពជើងទឹក[1355]។

---

សារទូរលេខនៅហ្នឹងផែទទួលបញ្ជាពីកន្លែងតាមុត អ្នកកាន់សារទូរលេខនោះផ្តល់បញ្ជានោះទៅឱ្យមេបញ្ជាការកប៉ាល់ អ្នកកាន់សារទូរលេខ គេធ្វើការនៅក្នុងមន្ទីររបស់គេនៅជិតផែកប៉ាល់។ ស៖ តើអ្នកកាន់សារទូរលេខនៅផែនោះ ហើយគេជាយោធារបស់កងណា? ឆ.3៖ ពួកអ្នកកាន់សារទូរលេខ គឺគេបញ្ជូនពីមន្ទីរកងពល យកមកឱ្យធ្វើការនៅទីនោះ ពីព្រោះអ្នកកាន់សារទូរលេខ គេបានហ្វឹកហ្វឺនខាងផ្នែកទូរលេខ។ ក្នុងនាមជាយោធាលើកប៉ាល់ យើងមិនចេះប្រើទូរលេខទេ។ ស៖ តើលោកដឹងឬទេ សារទូរលេខនោះ ផ្ញើត្រង់ចេញពីកងពលទៅឱ្យមេបញ្ជាការកប៉ាល់តែម្តងឬត្រូវឆ្លងកាត់ថ្នាក់វរសេនាធំឬវរសេនាតូចសិន? ឆ.4៖ ខ្ញុំមិនដឹងអំពីទំនាក់ទំនងកន្លែងណាផ្សេងទេ ប៉ុន្តែ ប្រព័ន្ធទំនាក់ទំនងកន្លែងខ្ញុំ គឺសារទូរលេខផ្ញើត្រង់ចេញពីកងពលមកមន្ទីរទូរលេខកោះកុងតែម្តង។ អ្នកកាន់សារទូរលេខនៅកោះកុង គឺជាយោធារបស់កងពល ១៦៤។ ស៖ តើលោកដឹងឬទេថា អ្នកណាជាអ្នកចាប់បានមុខសញ្ញាពួកទូកនេសាទខុសច្បាប់មុនគេ? ឆ.5៖ នៅពេលនោះមានកងពលថ្មើរជើងទី ១ ដែលបានដាក់ពង្រាយតាមកន្លែងផ្សេងៗនៅកោះកុង ដែលមានតាឿន ជាមេបញ្ជាការកងពល។ នៅកងពលទី ១ គេមានកែវយឺត (ស៊ីម៉ែល) និងរ៉ាដារបស់គេសម្រាប់ចាប់ទិសទូកនេសាទខុសច្បាប់ នៅពេលដែលគេចាប់បានទិសដៅមួយ គេបានបញ្ជូនព័ត៌មានមកកងកប៉ាល់ បន្ទាប់មកកប៉ាល់រាយការណ៍ទៅតា មុត តាមសារទូរលេខ ហើយតា មុត នឹងចេញបញ្ជាត្រឡប់មកមេបញ្ជាការកប៉ាល់វិញថា ត្រូវធ្វើយ៉ាងម៉េចជាមួយទូកនេសាទទាំងនោះ។ តាមការសង្កេតពិនិត្យរបស់ខ្ញុំលើប្រព័ន្ធទាក់ទងគ្នារវាងថ្នាក់ដឹកនាំនៅក្នុងតំបន់កោះកុង នៅពេលនោះ គឺពេលខ្លះគេប្រើនីរសារឱ្យថែវទូកធ្វើទំនាក់ទំនងគ្នាពីកន្លែងមួយទៅកន្លែងមួយ។ គេមិនប្រើវិទ្យុទាក់ទង (តេអូ) ឬសារទូរលេខទេ។ ស៖ កាលពីពេលនោះ តើគេដាក់រ៉ាដា និងកែវយឺតនៅកន្លែងណា? ឆ.6៖ ខ្ញុំជម្រាបបញ្ជាក់លោក នៅពេលនោះកងកប៉ាល់របស់ខ្ញុំគឺមិនមែនឋិតនៅតែមួយក្នុងក្រុងកោះកុងទេ យើងចល័តពីមួយកន្លែងទៅមួយកន្លែង ដើម្បីការពារការវ៉ៃដោយយន្តហោះថៃ ពេលខ្លះយើងទៅចតនៅពយឡាំដាំ និងពេលខ្លះទៅចតនៅពយអារយាយសែន។ កោះទាំងពីរនេះ គឺឋិតនៅកោះកុង។ ប្រព័ន្ធរ៉ាដាត្រូវបានគេដាក់នៅកោះកុង ពីព្រោះគេអាចមើលឃើញលំហសមុទ្រ។ ស៖ តើកងណាកាន់កាប់ ស្ថានីយ៍រ៉ាដានិងកែវយឺតនោះ? ឆ.7៖ ស្ថានីយ៍រ៉ាដានិងកែវយឺត គឺឋិតក្រោមកងពលទី ១"]។

1354 ឯកសារ D54/52 កំណត់ហេតុស្តាប់ចម្លើយ មាស រឿន ឆ.18-19 ["បន្ទាប់ពីចាប់បានទូកនេសាទថៃ យើងបានរាយការណ៍ទៅ តាសឿង បន្ទាប់មក តា សឿង បានប្រាប់យើងថា ឱ្យយើងត្រូវបញ្ជូនមនុស្សដែលចាប់បាននោះទៅកំពង់សោម ហើយឱ្យទុកទូកនេសាទនោះនៅក្រុងខេមរភូមិន្ទ។ ស៖ តាមលោកចាំ ក្នុងអំឡុងពេលនៅកោះកុង តើកងរបស់លោកចាប់បានទូកនេសាទថៃបានចំនួនប៉ុន្មាននាក់? ឆ.19៖ តាមខ្ញុំចាំបាន យើងចាប់បានអ្នកនេសាទថៃប្រហែលចំនួន ១០ នាក់ ប៉ុន្តែ យើងចាប់បានទូកនេសាទប្រហែល ៥០ ទៅ ៦០ គ្រឿង។ ចំនួនអ្នកនេសាទដែលចាប់បាន គឺតិចជាង

## ៤. បញ្ជារបស់ មាស មុត ពាក់ព័ន្ធនឹងពលរដ្ឋវៀតណាម

385. ភស្តុតាងបង្ហាញថា បញ្ជារបស់ **មាស មុត** ពាក់ព័ន្ធនឹងប្រជាជនវៀតណាមដែលត្រូវបានចាប់ខ្លួននៅសមុទ្រ ក្នុងអំឡុងពេលពីចុងខែ មេសា ឆ្នាំ ១៩៧៥ ទៅថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ គឺ៖ សម្លាប់ពួកគេភ្លាមៗនៅនឹងកន្លែង[1356] ឬនាំពួកគេទៅសម្លាប់ចោលនៅលើកោះ ឬដីគោក[1357]។

---

ចំនួនទូក ពីព្រោះតែពេលដែលយើងចូលមកជិតទូកដើម្បីចាប់ម្តងៗ ពួកអ្នកនេសាទទាំងនោះលោតទឹក ដើម្បីរត់គេចពីការចាប់ខ្លួន"]។

1355 ឯកសារ D54/53 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.16-20 ["យើងបញ្ជូនអ្នកនេសាទថៃទាំងនោះតាមកាណូតដោយអមដោយអនុសេនាធំ ១ នាក់ នារីកចំនួន ២ នាក់ និងអ្នកការពារ ៣ នាក់។ ក្នុងរយៈពេលនោះ គឺកងរបស់ខ្ញុំចាប់បាន ១០ នាក់ ប៉ុន្តែយើងបញ្ជូនមនុស្សទៅកំពង់សោមទៅតាមចំនួនក្នុងពេលផ្សេងៗគ្នាទៅតាមចំនួនដែលយើងចាប់បានភ្លាមៗ។ ស៖ ពេលចាប់បានអ្នកនេសាទថៃនៅពេលនោះ តើលោកបញ្ជូនពួកគេទៅកន្លែងណានៅកំពង់សោម? ឆ.17៖ យើងបានបញ្ជូនអ្នកនេសាទទាំងនោះទៅឲ្យកងទ័ពជើងទឹកនៅផែកំពង់សោម។ វាគឺជាផែតូចៗសម្រាប់ចតកាណូតតូចៗ ដែលនៅចម្ងាយប្រហែល ២០០ ម៉ែត្រពីផែកំពង់សោម។ ស៖ តើខាងលោកប្រាប់ទៅឲ្យកងទ័ពជើងទឹកជាមុន មុនពេលដែលលោកបញ្ជូនអ្នកនេសាទទាំងនោះទៅ ឬយ៉ាងណា? ឆ.18៖ យើងបានប្រាប់ទៅ តា សឿង បានជូនដំណឹងទៅឲ្យទ័ពជើងទឹងជាមុន មុននឹងពេលដែលយើងបញ្ជូនអ្នកទាំងនោះទៅ។ ស៖ ហេតុអ្វីបានជាការចាប់បានអ្នកនេសាទទាំងនោះ ត្រូវតែបញ្ជូនទៅឲ្យកងទ័ពជើងទឹក? ឆ.19៖ យោធានៅកំពង់សោម ដែលចាំទទួលអ្នកនេសាទដែលចាប់បានទាំងនោះ គឺមិនមែនជាយោធារបស់កងទ័ពជើងទឹកទេ គឺជាយោធារបស់កងពលលេខ ១។ បន្ទាប់ពីយោធាទាំងនោះទទួលយកអ្នកនេសាទពីខ្ញុំហើយ ភារកិច្ចរបស់ខ្ញុំត្រូវបានបញ្ចប់។ ចំពោះការដែលថាគេធ្វើអ្វីៗចំពោះអ្នកនេសាទនោះ ជាមួយកងទ័ពជើងទឹក ខ្ញុំមិនដឹងទេ។ ស៖ ហេតុអ្វីបានជាយោធាកងពលលេខ ១ ស្ថិតនៅកំពង់សោម? ឆ.20៖ ខ្ញុំមិនដឹងពីមូលហេតុទេ ប៉ុន្តែ បន្ទាប់ពីយោធារបស់ តា សឿង យកអ្នកនេសាទពីខ្ញុំហើយ ខ្ញុំបានត្រឡប់មកវិញ"]។

1356 ឯកសារ D234/2.1.93 ព្រុំ សារ៉ាត ប្រតិចារិកថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ០៩.៥៨.១១-១០.០០.៥៩ ["កងពលចេញបទបញ្ជាឲ្យខ្ញុំអនុវត្ត។ ផែនការការពារដែនទឹក ដែនសមុទ្ររបស់កម្ពុជា ពេលនោះ គាត់សំដៅលើនាវារបស់ជនជាតិវៀតណាមដែលមកដោយមានភាពជាមហិច្ឆតាជាកម្លាំងប្រដាប់អាវុធ ទើបខ្ញុំមានភារកិច្ចទៅបំពេញបេសកកម្មនោះ"] ម៉ោង ១៣.៥៤.២៦-១៣.៥៨.០៣ ["កងទ័ពដែលឈរជើងប្រចាំការនៅលើនាវា ត្រូវបំពេញភារកិច្ចរបស់ខ្លួនត្រៀមប្រយុទ្ធតែចំពោះខ្មាំងសត្រូវខាងជើងទឹក ដែលមានទ្រង់ទ្រាយចូលមករំលោភអធិបតេយ្យដែនទឹក"]។ ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារិកថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ១៣.៥៨.០៦-១៤.០០.៣៩ ["បញ្ជាពីលើមក មកវរសេនាតូច បាទ វរសេនាតូចបានបញ្ជាឲ្យយោធាធ្វើ ធ្វើសកម្មភាព។ បើចាប់បានតិចគឺសម្លាប់ចោល អាហ្នឹងប៊ានធ្វើហើយ។ បើថាអត់ពីខាងលើមកគឺមិនប៊ានធ្វើទេ"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN ERN 00978576, KH ERN 00955507-00955508 ["ស៖ ចឹងបើចាប់បានពួកយួននោះ? ឆ៖ បើពួកយួនចាប់បានគេយកមកសម្លាប់ចោល។ [...] ស៖ អាហ្នឹងច្រើនពួកកងទ័ព

ឬមួយយ៉ាងម៉េច? ឆ៖ ច្រើនតែប្រជាជនដែលរត់គៀសខ្លួនទៅប្រទេសទីបី [...] យើងចាប់បានបាញ់សម្លាប់ចោលទៅ។ ស៖ ចឹងចាប់បានបញ្ជាពីកងពលទៅឬមួយធ្វើដោយខ្លួនឯង? ឆ៖ បញ្ជាពីកងពលទៅ។ ស៖ បញ្ជាចេញពីនរណាទៅ? ឆ៖ បញ្ជាចេញពីតា មុត។ ស៖ បញ្ជាឲ្យសម្លាប់តែម្តង? ឆ៖ បាទ"]។ សូមមើលផងដែរ ឯកសារ D234/2.1.96 មាស វឿន ប្រតិចារឹកថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង ០៩.១៣.៤៦-០៩.១៦.១៤ ["ក្នុងទិសដៅនៃអ្នកដឹកនាំនោះ គឺថាត្រូវតែវាយយួន ដើម្បីកុំឲ្យវាឈ្លានពានមកលើទឹកដីខ្មែរ ទឹកដីកម្ពុជា នេះដែលយួនពីខាងក្រៅ។ [...] ដូច្នេះកម្ទេចយួនខាងក្រៅដែលវាឈ្លានពានជាសំខាន់"]។ ឯកសារ D98/3.1.179 មាស វឿន ប្រតិចារឹកថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ ម៉ោង ១៣.៤២.៣០-១៣.៤៤.២៧ ["មានតែ គឺថា "ផែនការតែកម្ទេចខ្មាំងយួន" មាន។ ហើយនិង "សម្អាតក្រែងលោខ្មាំងយួនបង្កប់នៅក្នុងអង្គភាព ស៊ីរ៉ូងបង្កប់ហ្នឹង" គឺមាន"]។

1357 ឯកសារ D234/2.1.95 មាស វឿន ប្រតិចារឹកថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង ១៤.១៧.២០-១៤.១៩.០៤ ["រឿងជនភៀសខ្លួនរបស់វៀតណាម [...] ខ្ញុំគិតឃើញថា ខ្លួនខ្ញុំដែលចាប់មក ចាប់បានខ្ញុំបញ្ជូនទៅតាមថ្នាក់ដឹកនាំរបស់ខ្ញុំអ៊ីចឹងទៅ ហើយថ្នាក់ដឹកនាំក៏ដោះស្រាយតាមបែបណា ក៏ស្រេចតែគាត់ទៅ"]។ ឯកសារ D234/2.1.96 មាស វឿន ប្រតិចារឹកថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង ០៩.២៤.០១-០៩.២៦.០៣ ["ដូចជាយួនដែលខ្ញុំចាប់បានអ៊ីចឹង ខ្ញុំបញ្ជូនមកខាងៗលើ។ តែផែនការឲ្យខ្ញុំកម្ទេច ខ្ញុំអត់ទាន់បានកម្ទេចណា។ សូមមើលសម្រង់ជើងទំព័រមុន ពីសាក្សីដូចគ្នានេះបញ្ជាក់យ៉ាងច្បាស់ថាមានផែនការបែបនេះ។តើចាំបាច់ត្រូវពន្យល់ដែរទេ?"]។ ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ១៣.៤១.៥២-១៣.៤៦.១៦ ["បញ្ជូនទៅតាមផែអូរឈើទាល ដើម្បីឡានមកដឹក យកមកក្រុងកំពង់សោមបាទ ខ្លះទៀតក៏យកទៅខាងអូរត្រេះ យកទៅខាងចម្ការដូងបាទ ច្រើនកន្លែងដែរ ព្រោះក្នុងមួយខែៗ គឺថាចាប់ៗរហូត ឆ្នាំ ៧៧ ហ្នឹង ៧៨ ហ្នឹង ចាប់ខ្លាំងបាទ"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ១០.០៤.២៤-១០.០៧.៣៧ ["បើបញ្ជាពីកងពលឲ្យបញ្ជូនទៅដីគោក ហ្នឹងទៅដីគោក បាទ យកទៅដីគោក ត្រង់គេបញ្ជូនទៅណាទៀតក៏ខ្ញុំអត់បានដឹងដែរ"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN ERN 00978576-00978577, KH ERN 00955507-0095508 ["ស៖ ចឹងបើចាប់បានពួកយួននោះ? ឆ៖ បើពួកយួនចាប់បានគេយកមកសម្លាប់ចោល។ ស៖ សម្លាប់នៅណា? ឆ៖ ជួនកាលគេសម្លាប់នៅលើកោះហ្នឹងទៅ។ ស៖ គេអត់មានបញ្ជូនមកខាងទេ? ឆ៖ ជួនកាលគេសម្លាប់នៅកោះ។ ស៖ អាហ្នឹងច្រើនពួកកងទ័ពឬមួយយ៉ាងម៉េច? ឆ៖ ច្រើនតែប្រជាជនដែលរត់ភៀសខ្លួនទៅប្រទេសទីបី [...] ស៖ ចឹងចាប់បានបញ្ជាពីកងពលទៅឬមួយធ្វើដោយខ្លួនឯង? ឆ៖ បញ្ជាពីកងពលទៅ។ ស៖ បញ្ជាចេញពីនរណាទៅ? ឆ៖ បញ្ជាចេញពីតា មុត។ ស៖ បញ្ជាឲ្យសម្លាប់តែម្តង? ឆ៖ បាទ។ ស៖ ចឹងមានគេបញ្ជូនមកដីគោកដែរឬអត់? ឆ៖ មានបញ្ជូនមក។"]។ ឯកសារ D1.3.34.64 ទូរស័ព្ទសម្ងាត់ពី មាស មុត ទៅបង៨៩ (សុន សេន) ចុះថ្ងៃទី ២០-៣-៧៨ ["នៅកែបវេលាម៉ោង ៨ យប់ ថ្ងៃ ១៩-៣-៧៨ យើងបាញ់កាណូតអាយួនលិច១គ្រឿង ធុន ២២សេះ នៅខាងត្បូងកោះខ្យងចម្ងាយ ១ គ.ម។ ឯយើងមិនមានខូចខាតអីទេ។ [...] នៅកោះតាង វេលាម៉ោង ២.៣០ នាទីថ្ងៃ ២០-៣-៧៨ កាណូត ៨០០សេះរបស់យើង ចេញធ្វើការនៅខាងកើត ភាគខាងត្បូងកោះតាងចម្ងាយ១២គ.ម ចាប់បានកាណូតអាយួន ២ គ្រឿង នៅលើកាណូត ២ គ្រឿងនេះពេញដោយយួន ៧៦ នាក់ មានក្មេង ចាស់ ប្រុស ស្រី។ តែក្នុងពេលយើងចងរួចហើយ កូនកាណូតតូចឃ្លោង បណ្តាយឲ្យធ្លាប់ទឹកបាត់ ២ នាក់ រកពុំឃើញ។ បានឲ្យយកមកដល់ដីគោកហើយ"]។ ឯកសារ D1.3.30.25 ទូរស័ព្ទសម្ងាត់ពី មាស មុត ទៅ ប៉ុល ពត នួន ជា និង អៀង សារី ចុះថ្ងៃទី ១-

**មាស មុត** បានទទួលស្គាល់នៅក្នុងកិច្ចសម្ភាសន៍មួយថា ទូកវៀតណាមត្រូវបានចាប់ប្រហែលរៀងរាល់បីខែម្តង[1358]។

386. មានភ័ស្តុតាងជាសក្ខីកម្មលើកឡើងថា ការប្រព្រឹត្តិចំពោះប្រជាជនវៀតណាមដែលត្រូវចាប់បាននៅសមុទ្រ គឺមិនរើសមុខ។ មិនថាអ្នកដែលត្រូវបានចាប់ខ្លួនជាយោធា ឬជាជនស៊ីវិលធម្មតា ក្មេងចាស់ ប្រុស ឬស្ត្រីនោះទេ ពួកគេត្រូវបានបាញ់ចោលភ្លាមៗ ឬបញ្ជូនទៅដាក់ក្នុងមន្ទីរឃុំឃាំង និងសម្លាប់ នៅពេលក្រោយ[1359]។ សាក្សី និងរបាយការណ៍ ស-២១ ដែលនៅសេសសល់ បានបង្ហាញថា ជនជាតិវៀតណាមភាគច្រើនដែលត្រូវបានចាប់ខ្លួននៅសមុទ្រ ជាប្រជាជនសាមញ្ញ ដែលត្រូវ

---

៩-៧៨ ["សរុបឃ្មួនដែលចាប់បាននិងបាញ់ងាប់ចាប់ពីថ្ងៃ ២៧-៣-៧៨ មកដល់ ថ្ងៃ ៣០-៣-៧៨ មានចំនួន ១២០ ក្បាល ទូក ១០សេះ ដល់ ៣៧ សេះ ចំនួន ៥ គ្រឿង"]។

1358 ឯកសារ D54/16/1R មាស មុត សម្ភាសដោយ David Kattenburg នៅខែ មេសា ឆ្នាំ ២០០៩ នាទី ៣៥:៣០-៣៩:៣៣ ["ស៖ ដូច្នេះ ខ្ញុំចង់យល់អំពីទូករបស់វៀតណាមដែលត្រូវបានដណ្តើមយកនៅឆ្នាំ ១៩៧៨ នៅលើដែនទឹកនៅលើឈូងសមុទ្រថៃជុំវិញ កោះតាង កោះពូឡូវៃ តើមានប៉ុន្មានដង តើមានរឿងអ្វីកើតឡើងដល់អ្នកបើកនាវាទាំងនោះ? នៅពេលដែលអ្វីៗឡើងកម្តៅ? នៅពេលអ្វីទៅជាតឹងតែង? ឆ៖ វាកើតឡើង៣ដង ក្នុង ១ ខែជាមធ្យម។ ពួកគេក្លែងបន្លំខ្លួនចូលមក ដោយអះអាងថាជាអ្នកនេសាទ ប៉ុន្តែពួកគេមកតាមដានយើងទេ [...] យោធាចាប់ខ្លួនពួកគេ ហើយបញ្ជូនទៅវិញ [...] ពួកគេត្រូវបានបញ្ជូនខ្លួនទៅភ្នំពេញ [...] ស៖ តើយោធាចង់បញ្ជូនពួកគេទៅកោះឬស្សីមែនទេ? ឆ៖ បាទ នៅជាប់នឹងក្រុងព្រះសីហនុ។ ពួកទាហានឃ្មួន"]។

1359 ឯកសារ D234/2.1.93 ព្រុំ សារ៉ាត ប្រតិចារឹកថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ១០.០០.៥៩-១០.០៤.១៧ ["ខ្ញុំធ្លាប់បានឃើញផ្ទាល់នូវព្រឹត្តិការណ៍សម្លាប់ពីរលើក ម្តងគឺការសម្លាប់ឃ្មួននៅលើទឹកសមុទ្រ ហើយយកតែកាណូត ហើយម្តងទៀតគឺការសម្លាប់ឃ្មួនភៀសខ្លួនដែលចាប់នៅលើកោះពូឡូវៃ"] ម៉ោង ១០.១២.១៦-១០.៣១.៣៩ ["មានទូក ឬកាណូតរបស់វៀតណាមចូលមកដល់ដែនទឹក ខាងដែនកោះគឺសម្រេចចាប់បានយ៉ាងម៉េច ហើយធ្វើការងារបញ្ជូនមកយ៉ាងម៉េច"] ម៉ោង ១០.៤៨.៣៨-១០.៥១.១៣ ["កងពលប្រាប់ចេញឲ្យថាពាក្យបទបញ្ជានាវាទាំងអស់ត្រូវមានការប្រុងប្រយ័ត្ន ហើយទទួលដឹងឮថាថ្ងៃនេះគេមានចាប់ (ឃ្មួន និងទូកឃ្មួនប៉ុន្មានៗ) នៅកន្លែងនេះ [...] វាទាក់ទិននឹងកិច្ចការរបស់ដែនកោះ"]។ ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ១៤.២៩.១១-១៤.៣១.៥៨ ["ក្នុងនោះ ខ្ញុំមិនដែលទេ អត់ដែលឮទេ អត់ដែលឮថាមិនឲ្យចាប់ ដែលតែឮឲ្យចាប់តែម្តង បាទអត់"]។ ឯកសារ D234/2.1.92 ព្រុំ សារ៉ាត ប្រតិចារឹកថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ១០.៥៤.០៥-១០.៥៧.២៧ ["គេជាជនជាតិវៀតណាមឆ្លងកាត់តំបន់ដែនទឹកនៅកោះអាគ្នេយ៍ខាងកើតកោះតាង។ ហើយពួកគេបានចាប់គេទាំងពីរនាក់"] ម៉ោង ១៥.៤៩.១២-១៥.៥២.៣៨ ["ចាប់បានកងទ័ពវៀតណាម ឬក៏ទូកវៀតណាមដែលចូលមកដល់ទឹកដីកម្ពុជា"]។

រត់ភៀសខ្លួនពីប្រទេសរបស់ខ្លួនតាមទូកតូចៗ[1360]។ ចំនួនជនភៀសខ្លួនវៀតណាមលើទូកនីមួយៗ មានពីពីរបីនាក់[1361] រហូតទៅដល់ ៥០-៧០ នាក់[1362] ជាមធ្យម ៣០ នាក់[1363]។ ជនភៀសខ្លួនភាគ

---

[1360] ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ១១.០៥.០៦-១១.៤៩.៤៦ ["ថ្ងៃមួយឃើញថា ចាប់បានវៀតណាមបីនាក់ ប្ដីនិងកូនម្នាក់ កូននោះតូច អាយុប្រហែលជាមួយឆ្នាំ។ពេលនោះចាប់យកមកដល់ពូលូវៃ បាទ ដល់កោះពូឡូវៃ។ [...] គេសម្លាប់ៗចង ហើយឱ្យលុតជង្គង់វាយនឹងគល់ឫស្សី និងត្បូងចប [...] យោធាចាប់បោកនឹងគល់ដូងស្លាប់តែម្ដង។ [...] ក្នុងចំណោមទាំងបីនាក់ហ្នឹង គឺប្រជាជន បាទ ប្រជាជនទេ គ្មានសម្លៀកបំពាក់អី ក៏គ្មានយោធាដែរ ហើយជាប្រជាជនធម្មតា។"]។ ឯកសារ D98/3.1.178 មាស វឿន ប្រតិចារឹកថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១២ ម៉ោង ១០.២១.៥៤-១០.២៦.៣៦ ["យូរៗឃើញម្ដងដែរនៅ -- ជួនកាល ១ ខែ ២ ខែ អីឃើញមកម្ដង អី ឃើញមកម្ដង ក៏ប៉ុន្តែ ជួនកាលចាប់បានទូកអីចឹងទៅ ជួនកាលគេទៅហួសទៅ។ [...] ប្រជាជនវៀតណាមមានស្រី មានកូន មានប្រុសប្ដី-ប្រពន្ធគេមិនដឹង។ ប៉ុន្តែទូកតូចៗមិនធំប៉ុន្មាន។ [...] បញ្ជូនតាមរយៈមកកំពង់សោមដែរ។ [...] គាត់ទៅស្រុកថៃ គាត់តម្រង់ទៅស្រុកថៃ។ ហើយគាត់មិនសូវចេះខ្មែរផង ក៏ខ្ញុំមិនសូវចេះស្ដាប់បានភាសាវៀតណាម"]។ ឯកសារ D54/79 កំណត់ហេតុស្ដាប់ចម្លើយ ណុប ហាល ឆ.8, 11, 18, 23 ["ពេលនោះ គឺគេចាប់បានទូកវៀតណាមពីកោះពូឡូវៃចាស់ ហើយមានមនុស្សជាង ១៦ នាក់ មានប្រុស មានស្រី និងក្មេង។ កាលនោះប្រហែលជានៅដើមឆ្នាំ ១៩៧៨ [...] ឆ.11៖ តាមការសង្កេតមើល ពួកគេពុំមែនជាអ្នកនេសាទទេ ប៉ុន្តែ ជាជនភៀសខ្លួន។ ពួកយើងពុំចេះនិយាយភាសាវៀតណាម ដូច្នេះ ពុំបាននិយាយឆ្លើយឆ្លងគ្នាទេ។ ប៉ុន្តែ ពួកគេខ្លះបានលើកដៃបង្ហាញម្រាមដៃបី និងចង្អុលទៅទិសខាងលិច។ តាមឥរិយាបថនេះ ចង់បង្ហាញថា ពួកគេគ្រាន់តែឆ្លងកាត់ទីនោះ ដើម្បីធ្វើដំណើរទៅប្រទេសទី៣ នៅឯលោកខាងលិចប៉ុណ្ណោះ។ [...] ស៖ ក្រៅពីអ្វីដែលលោកបានរៀបរាប់ខាងលើ តើមានអ្វីបញ្ជាក់ច្បាស់ថា ពួកគេគ្រាន់តែជាជនភៀសខ្លួននោះ? ឆ.18៖ តាមការយល់របស់ខ្ញុំផ្ទាល់ បើសិនជាពួកគេជាអ្នកនេសាទច្បាស់ជាមានឧបករណ៍នេសាទដូចជា អួន មង សន្ទូច... ហើយបើសិនជា ពួកគេជាទាហានច្បាស់ជាមានឯកសណ្ឋាន អាវុធ និងគ្រាប់មិនខាន។ ប៉ុន្តែសម្រាប់ពួកគេ គឺអត់មានអ្វីទាំងអស់ ក្រៅពីសម្លៀកបំពាក់ និងម្ហូបអាហារ។ [...] ឆ.23៖ ចំណែកជនជាតិវៀតណាមវិញ ខ្ញុំសង្កេតឃើញមានប្រជាជនសាមញ្ញ មានប្រុស មានស្រី និងក្មេង។ [...] ខ្ញុំបានឮតាមវិទ្យុផ្សាយសំឡេងថា ជនជាតិវៀតណាមទាំងនោះ គឺសុទ្ធតែជាគិញ ដែលចូលមកស៊ើបការណ៍នៅក្នុងទឹកដីកម្ពុជា។ នេះគឺជាពាក្យដែល គេប្រើប្រាស់នៅពេលនោះថា ជនជាតិវៀតណាម គឺជាគិញ ហើយខ្ញុំពុំជឿទាំងអស់នោះទេ។ តាមការសង្កេតរបស់ខ្ញុំ ពួកគេគ្រាន់តែជាប្រជាជនសាមញ្ញ ហើយព្យាយាមភៀសខ្លួនពីប្រទេសមួយទៅប្រទេសមួយទៀតប៉ុណ្ណោះ"]។ ឯកសារ D54/25 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.11-12, 22 ["ស៖ តាមបទពិសោធន៍របស់លោក និងការយល់ដឹងរបស់លោក នៅក្នុងកងអង្គភាពរបស់លោក និងអង្គភាពដទៃទៀត នៃកងទ័ពជើងទឹក តើចំនួនប្រជាជនស៊ីវិល ចំនួនជនភៀសខ្លួន អ្នកនេសាទ ចន្លោះពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ឆ្លងមកចូលក្នុងដែនទឹកកម្ពុជា ហើយត្រូវបានចាប់បាន និងសម្លាប់មានចំនួនប្រហែលប៉ុន្មាននាក់? ឆ.11៖ មានចំនួនរាប់ពាន់នាក់ អ្នកទាំងនោះរួមមាន [...] ពួកនេសាទ និងជនភៀសខ្លួនវៀតណាម ដែលត្រូវចាប់បាន និងសម្លាប់ចោលនៅក្នុងសមុទ្រនៅលើកោះ និងនៅលើដីគោក។ [...] ឆ.12៖ [...] ខ្ញុំបានចូលរួមការចាប់ចងចំនួនបីដង។ លើកទី១ គឺការចាប់ពួកជនភៀសខ្លួនវៀតណាម [...] ឆ.22៖ ខ្ញុំចាប់និងដឹកជនភៀសខ្លួនវៀតណាមចំនួន ១៣ នាក់"]។ ឯកសារ D54/23 កំណត់

ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.28, 31, 37-38 ["ត្រូវតែរាយការណ៍ឲ្យច្បាស់លាស់នូវអ្វីដែលយើងចាប់បាន។ ឧទាហរណ៍ ថាតើគេជាជនជាតិវៀតណាមភៀសខ្លួន ជាអ្នកនេសាទថៃ ឬជាទាហាន យើងត្រូវតែរាយការណ៍ទៅថ្នាក់លើឲ្យបានច្បាស់លាស់ជាមុន។ [...] ស៖ តាមយោបល់ និងគំនិតរបស់លោកថា តើវាខុស ឬត្រូវ ចំពោះការសម្លាប់អ្នកដែលចាប់បាន? ឆ.31៖ ខ្ញុំគិតថា វាខុសទាំងស្រុង ពីព្រោះប្រជាជនទាំងអស់នោះមិនដឹងអ្វីទាំងអស់ ពួកគេគឺគ្រាន់តែរត់គេចពីសង្គ្រាម ដើម្បីរស់រានមានជីវិតតែប៉ុណ្ណោះ។ [...] ឆ.37៖ ពួកយួនទាំងនោះ គឺជាអ្នកភៀសខ្លួន ធ្វើដំណើរទៅកាន់ប្រទេសថៃ ហើយគេបានធ្វើដំណើរឆ្លងកាត់តាមដែនទឹករបស់យើងនៅចន្លោះកោះតាង និងកោះពូឡូវ៉ៃ។ [...] ឆ.38៖ ពួកទាំងនោះពុំមានកាំភ្លើង និងមិនមានបំណងចង់តដៃនោះទេ"]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត ឆ.121-125, 132 ["ខ្ញុំចាំថា ខ្ញុំបានឃើញដោយផ្ទាល់ភ្នែកនូវការចាប់ទូកវៀតណាមចំនួនពីរដង នៅពេលដែលខ្ញុំទៅកោះពូឡូវ៉ៃ។ [...] ឆ.122៖ ខ្ញុំបានឃើញហេតុការណ៍ចំនួនពីរដង [...] ឆ.123៖ ខ្ញុំឃើញប្រជាជនវៀតណាមមានប្រុស មានស្រី និងកុមារ ហើយពួកគេជាជនភៀសខ្លួន។ [...] ឆ.124៖ ខ្ញុំបានឃើញនៅក្នុងឆ្នាំ ១៩៧៧ តែខ្ញុំមិនចាំថ្ងៃខែទេ។ ស៖ តើលោកអាចប៉ាន់ស្មានអំពីចំនួនមនុស្សដែលគេចាប់បាននៅក្នុងទូកនោះដែរឬទេ? ឆ.125៖ ហេតុការណ៍ទី១ គឺចាប់បានវៀតណាមចំនួនប្រហែលពី ៥ ទៅ ៦ នាក់។ អាចមានចំនួនច្រើនជាងហ្នឹង ព្រោះខ្ញុំភ្លេចហើយ។ [...] ស៖ ដោយសារលោកបានរក្សាទុកសៀវភៅកត់ត្រាប្រចាំថ្ងៃ តាមដែលលោកចាំ តើចំនួនវៀតណាមដែលកងទ័ពជើងទឹកដែលប្រចាំការតាមកោះចាប់បានមានចំនួនប៉ុន្មាន? ឆ.132៖ តាមការស្មានគឺចំនួនជនជាតិវៀតណាមដែលចាប់បាន មានចំនួនច្រើនជាងរយនាក់"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN ERN 00978576, KH ERN 00955507-00955508 ["បើពួកយួនចាប់បានគេយកមកសម្លាប់ចោល … ច្រើនតែប្រជាជនដែលរត់ភៀសខ្លួនទៅប្រទេសទីបី ភាគច្រើនពួកហ្នឹងរត់គេចពីសង្គ្រាម ដល់រត់ឆ្លងមកយើង"]។ ឯកសារ D1.3.34.64 ទូរស័ព្ទសម្ងាត់ពី មាស មុត ទៅបង៨៩ (សុន សេន) ចុះថ្ងៃទី ២០-៣-៧៨ ["នៅកោះតាង វេលាម៉ោង ២.៣០ នាទីថ្ងៃ ២០-៣-៧៨ កាណូត [...] យើងចេញធ្វើការ [...] ចាប់បានកាណូតអាយួន ២គ្រឿង នៅលើកាណូត២គ្រឿងនេះពេញដោយយួន ៧៦ នាក់ មានក្មេង ចាស់ ប្រុស ស្រី"]។ ឯកសារ D54/11 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ហៅសារ៉េត ឆ.3 ["ខ្ញុំធ្លាប់បានឃើញទូកឈើប្រវែងប្រហែល ១៥ ម៉ែត្រ ទទឹង ៤ ម៉ែត្រ មានពណ៌ប្រផេះត្រូវបានគេយកមកទុកនៅផែអូរឈើទាលនេះ ខ្ញុំបានឮពីយោធាដទៃទៀតនិយាយថា ទូកនេះជារបស់ពួកភៀសខ្លួនជនជាតិវៀតណាមដែលមានបំណងរត់ទៅប្រទេសទី៣"]។ ឯកសារ D59/1/1.8a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រុំ សារ៉ាត់ KH ERN 00926384, KH ERN 00926399 ["ស៖ ដល់ពេលយើងឃើញទូកយើងទៅមើលឃើញជនជាតិយួន ហើយអ៊ីចឹងម៉េច? ស៖ យើងចាប់គេ [...] ហើយប្រភេទជនជាតិយួននឹងខ្លះគេភៀសខ្លួន [...] ស៖ [...] បើយួនវិញវាមានដូចពូមានប្រសាសន៍អំមិញថាមានដូចជាពួកទំនងជាអ្នកធ្វើការមានអ្នកភៀសខ្លួន មានអ្នកនេសាទដែរអត់ទេ? ឆ៖ អាហ្នឹងក៏មាន! [...] ណែនាំ គឺថាជនស៊ីវិលមិនអាចប៉ះពាល់ទេ ប៉ះពាល់ដោយរបៀបចាំឃាត់ខ្លួនស៊ើបអង្កេតល្អិតល្អន់ណា ថាអ្នកឯងជាជនភៀសខ្លួន ប៉ុនអ្នកឯងចង់ទៅដោយសុវត្ថិភាព ដល់កន្លែងខ្លះ ពេលខ្លះអត់ស្បៀងបញ្ជូនឲ្យទៀត បញ្ជូនដោយសុឆន្ទៈ អ្នកឯងទៅដោយទៅរកខាងលិចគឺថាទៅតាមទូក តែធ្វើម៉េចលើកក្រោយកុំឲ្យមក។ ប៉ុនធម្មតាអ្នកទៅអ៊ីចឹង គ្នាមិនត្រឡប់ទេតែទៅៗហើយ ធម្មតាទូកមួយជិត ៨ នាក់អីកូនទូកណា ផ្សងព្រេង យើងឃើញរបៀបនេះមានតែអាណិត ហើយទូកគ្នាតូចៗ។ ស៖ ហើយចុះបើខាងពួកអ្នកស៊ើបការណ៍ចូលមកកោះយើងអី ខាងកងពលគេណែនាំអីយើង? ឆ៖ គេណែនាំឲ្យឃាត់ខ្លួនហើយ បើយើងចាប់បានរបៀប

នេះ គេត្រូវបញ្ជូនទៅស-២១"]។ ឯកសារ D114/57 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.20-23 ["សៈ ហេតុអ្វីបានជាលោកនិយាយថាទូកនោះមិនមែនជាទូកនេសាទ? ឆ.20៖ ដោយសារតែទូកនោះអាចដាក់មនុស្សបានច្រើន។ បើតាមការសន្និដ្ឋានរបស់ខ្ញុំ វាគឺជាទូកដែលគេប្រើសម្រាប់ដឹកជនចំណាកស្រុក ឬក៏ជនភៀសខ្លួនវៀតណាម។ សៈ តើអ្នកដែលត្រូវបានគេចាប់នោះមានភេទអ្វីខ្លះ? ឆ.21៖ ពួកគេមានប្រុស មានស្រី និងកូនក្មេង។ សៈ ហេតុអ្វីបានជាលោកដឹង? តើលោកឃើញពួកគេនៅពេលណាមួយឬ? ឆ.22៖ ខ្ញុំឃើញក្មេងអាយុចន្លោះពី ៧ ទៅ ១០ ឆ្នាំ។ ក្មេងទាំងនោះមានការភ័យខ្លាច និងយំ។ នៅពេលនោះ ខ្ញុំកំពុងដើរនៅតាមឆ្នេរ។ សៈ លោកបាននិយាយថាពេលនោះជាពេលយប់ តើលោកអាចឃើញដោយដោយរបៀបណា? តើមានពន្លឺដែរឬទេ? ឆ.23៖ វានៅឆ្ងាយពីខ្ញុំប្រហែលពី ១៥ ទៅ ២០ ម៉ែត្រ។ ពេលនោះជាខែភ្លឺ ខ្ញុំអាចឃើញយ៉ាងច្បាស់ ពុំមានអ្វីបាំងនោះឡើយ"]។ ជនជាតិវៀតណាមដែលគេចាប់ខ្លួន ឬសម្លាប់ភាគតិចជាអ្នកនេសាទ៖ ឯកសារ D114/126 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ គឹម ឆ.32៖ ["សៈ ពេលយើងនិយាយអំពីការចាប់ទូកនេសាទ តើលោកចង់សំដៅតែទៅលើទូកនេសាទថៃមែនទេ? ឆ.32៖ គឺទាំងពីរ ទាំងទូកនេសាទថៃ និងទូកវៀតណាម"]។ ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ឆ.42-44 ["សៈ ចំពោះអ្នកនេសាទថៃ និងវៀតណាម ដែលគេចាប់បាន តើគេយកទៅសម្លាប់នៅកន្លែងនោះដែរឬយ៉ាងម៉េច? ឆ.42៖ បាទ, គេយកទៅកន្លែងនោះដែរ។ [...] គឺអ្នកនេសាទវៀតណាម និងថៃដែលគេបានចាប់ខ្លួន"]។ ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.58 ["សៈ ក្នុងករណីដែលពួកកងនាវាប្រដេញចាប់បានពួកនេសាទវៀតណាម ពួកនេសាទថៃ តើគេចាប់ពួកនោះយកទៅឃុំ ឬយកទៅណា ឬធ្វើយ៉ាងដូចម្តេចខ្លះ? [...] ឆ.58៖ [...] ក្រុមចាប់មនុស្ស គឺគេមានទូកឈើ [...] អង្គភាពនេះ គឺជាអង្គភាពសម្រាប់ចាប់អ្នកនេសាទ និងអ្នកដែលឆ្លងដែនខុសច្បាប់"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN ERN 00978573-00978574, KH ERN 00955503 ["យើងបានទូកនេសាទត្រី (សូមមើលកំណែជាភាសាអង់គ្លេស EN ERN 00978573, KH ERN 00955503)] ហើយសួរពួកគេ [...] ធម្មតាមានប្រុសៗ។ [...] [អ្នកនេសាទត្រីដែលគេចាប់បានគឺ] សុទ្ធតែថៃ យួន។"]។ ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.11 ["សៈ តាមបទពិសោធន៍របស់លោក និងការយល់ដឹងរបស់លោក នៅក្នុងកងអង្គភាពរបស់លោក និងអង្គភាពដទៃទៀត នៃកងទ័ពជើងទឹក តើចំនួនប្រជាជនស៊ីវិល ចំនួនជនភៀសខ្លួន អ្នកនេសាទ ចន្លោះពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ឆ្លងមកចូលក្នុងដែនទឹកកម្ពុជា ហើយត្រូវបានចាប់បាន និងសម្លាប់ មានចំនួនប្រហែលប៉ុន្មាននាក់? ឆ.11៖ មានចំនួនរាប់ពាន់នាក់ អ្នកទាំងនោះរួមមាន [...] ពួកអ្នកនេសាទវៀតណាម [...] ដែលត្រូវចាប់បាន និងសម្លាប់ចោលនៅក្នុងសមុទ្រ នៅលើកោះ និងនៅលើដីគោក"]។ ឯកសារ D1.3.32.9 កំណត់ហេតុស្តាប់ចម្លើយ ឈុន ផល KH ERN 00163809 ["អ្នកទោសវៀតណាម ដាក់នៅបន្ទប់តូចៗម្នាក់មួយ ចូលមកប្រហែលក្នុងឆ្នាំ ១៩៧៨។ ខ្ញុំធ្លាប់សួរអ្នកទោសវៀតណាមដែលចេះនិយាយខ្មែរខ្លះ ថាគាត់មកពីតែនិញ ហើយគាត់ជាអ្នកនេសាទត្រី គាត់មិនមែនជាទាហានទេ គាត់កំពុងនេសាទនៅសមុទ្រ នៅព្រំដែន"]។ ឯកសារ D114/19 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.18 ["ការណែនាំគឺថា បើយើងឃើញកប៉ាល់នេសាទណាឆ្លងចូលផុតក្នុងដែនទឹករបស់យើង [...] ប៉ុន្តែ កាណូតទាំងនោះចូលមកជ្រៅ ហើយយូរក្នុងដែនទឹកយើង យើងនឹងវ៉ៃភ្លាមៗ។ រឿងនេះភាគច្រើនគឺកើតឡើងនៅកន្លែងរបស់ខ្ញុំ។ កន្លែងរបស់ខ្ញុំគឺនៅជិតនឹងព្រំដែនរបស់វៀតណាម ដូច្នេះពួកនេសាទដែលចូលមកនោះគឺភាគច្រើនកាណូតវៀតណាម។ ពួកកាណូតនេសាទទាំងនោះ ភាគច្រើនក៏មានកាំភ្លើង និងសញ្ញាវុធ"]។ ឯកសារ D59/1/1.8a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រំ សារ៉ាត់ ចុះថ្ងៃទី ១៩

ច្រើនព្យាយាមរត់ទៅប្រទេសថៃ[1364] រីឯអ្នកខ្លះផ្សេងទៀតអះអាងថា ពួកគេចង់ទៅប្រទេសពីលីពីន សិង្ហបុរី ឬតៃវ៉ាន់[1365]។ ទោះបីជាពួកគេមិនមែនជាគិញ ឬទាហានវៀតណាមយ៉ាងច្បាស់ក្រឡែត

---

ខែ ឧសភា ឆ្នាំ ២០០៧ EN ERN 00974222, KH ERN 00926399 [ស៖ តែបើយួនវិញវាមានដូចពួមានប្រសាសន៍អំមិញថាមានដូចជាពួកទំនងជាអ្នកធ្វើការមានអ្នកភៀសខ្លួន មានអ្នកនេសាទដែរអត់ទេ? ឆ៖ អាហ្នឹងក៏មាន!"]។ ឯកសារ D1.3.13.13 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ ទូច សឿលី EN ERN 00217571 ["ពួកគេត្រូវបានគេប្រាប់ឱ្យល្បាត និងមើលទូកនេសាទវៀតណាម និងកិច្ចការដែនសមុទ្រដទៃទៀត"]។ ឯកសារ D114/283 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.4 ["ស៖ តើពេលនោះ ចំពោះតែពួកវៀតណាម ដែលយើងចាប់បានមក ភាគច្រើនជាពួកកូនជ្រូក ដែលជាជនភៀសខ្លួនតាមទូក ហើយមានពួកនេសាទខ្លះទេ ហើយនិងមានពួកទាហានវៀតណាមខ្លះទេ? ឆ.4៖ អត់ទេ ច្រើនតែពួកកូនជ្រូក ហើយនិងពួកនេសាទវៀតណាម"]។

1361 ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.20 ["ខ្ញុំបានឃើញព្រឹត្តិការណ៍ដំបូងគឺជាការចាប់បាន និងសម្លាប់ប្តីប្រពន្ធវៀតណាម និងកូនម្នាក់អាយុប្រហែល ១ ឆ្នាំ នៅកោះពូឡូវៃចាស់ កាលពីចុងឆ្នាំ ១៩៧៦ ឬដើមឆ្នាំ ១៩៧៧"]។ ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល ឆ.8 ["ពេលនោះ គឺគេចាប់បានទូកវៀតណាមពីកោះពូឡូវៃចាស់ ហើយមានមនុស្សជាង ១៦ នាក់ មានប្រុស មានស្រី និងក្មេង"]។

1362 ឯកសារ D114/127 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គឹម ឆ.3 ["ស៖ យើងចង់គូសបញ្ជាក់បញ្ហាមួយកាលពីម្សិលមិញក្នុងបទសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័រទី ២៣ លោកនិយាយថា ជាមធ្យមមានជនភៀសខ្លួនវៀតណាមពី ៥០ ទៅ ១០០ នាក់។ ក្នុងបទសម្ភាសន៍កាលពីម្សិលមិញ ត្រង់សំណួរចម្លើយទី ៣៨ មានតែម្ភៃ ៣០ នាក់ប៉ុណ្ណោះ។ តើលោកអាចគូសបញ្ជាក់បានដែរឬទេត្រង់ចំណុចនេះ? ឆ.3៖ ខ្ញុំបានប្រាប់លោកពីចំនួនមនុស្សតិចបំផុតនៅលើទូក ប៉ុន្តែ តាមពិតជួនកាលមានមនុស្ស ៥០ នាក់ និងជួនកាលមាន ៧០ នាក់ឯណោះនៅលើទូកមួយ"]។

1363 ឯកសារ D114/126 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គឹម ឆ.36-38 ["តាមខ្ញុំចាំ គឺពុំមានទូកនេសាទវៀតណាមនោះទេ មានតែទូកជនភៀសខ្លួនវៀតណាមប៉ុណ្ណោះ។ ស៖ ពាក់ព័ន្ធនឹងចំនួនទូកថៃ និងទូកវៀតណាម តើលោកអាចគូសបញ្ជាក់ថា ទូកខាងណាមួយច្រើនជាង? ឆ.37៖ ទូកថៃគេចាប់បានច្រើនជាងទូកជនភៀសខ្លួនវៀតណាម។ ស៖ ជាមធ្យម តើមានមនុស្សប៉ុន្មាននាក់នៅលើទូកជនភៀសខ្លួនវៀតណាមមួយៗ? ឆ.38៖ ជាមធ្យម ៣០ នាក់ ហើយមានស្រីមានប្រុស"]។

1364 សូមមើល ឧទាហរណ៍ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.37-38 ["ពួកយួនទាំងនោះ គឺជាអ្នកភៀសខ្លួនធ្វើដំណើរទៅកាន់ប្រទេសថៃ ហើយគេបានធ្វើដំណើរឆ្លងកាត់តាមដែនទឹករបស់យើងនៅចន្លោះកោះតាង និងកោះពូឡូវៃ។ [...] ឆ.38៖ ពួកទាំងនោះពុំមានកាំភ្លើង និងមិនមានបំណងចង់តដៃនោះទេ"]។

1365 ឯកសារ D114/126 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គឹម ឆ.36-41 ["តាមខ្ញុំចាំ គឺពុំមានទូកនេសាទវៀតណាមនោះទេ មានតែទូកជនភៀសខ្លួនវៀតណាមប៉ុណ្ណោះ។ ស៖ ពាក់ព័ន្ធនឹងចំនួនទូកថៃ និងទូកវៀតណាម តើលោកអាចគូសបញ្ជាក់ថា ទូកខាងណាមួយច្រើនជាង? ឆ.37៖ ទូកថៃគេចាប់បានច្រើនជាងទូកជនភៀសខ្លួនវៀតណាម។ ស៖ ជាមធ្យម តើមានមនុស្សប៉ុន្មាននាក់នៅលើទូកជនភៀសខ្លួនវៀតណាមមួយៗ? ឆ.38៖ ជាមធ្យម ៣០ នាក់ ហើយមានស្រីមានប្រុស។ ស៖ ហេតុអ្វីបានជាលោកនិយាយថា អ្នកទាំងនោះជាជនភៀសខ្លួនវៀតណាម? ឆ.39៖ អ្នកខ្លះចេះ

ក្តី[1366] ពួកគេទាំងអស់ត្រូវបានគេប្រព្រឹត្តមកលើខ្លួនដូច្នេះ[1367]។ សាក្សីខ្លះនិយាយថា អ្នកដែលត្រូវបានចាប់ខ្លួនទាំងនោះជាទាហានវៀតណាម ទោះបីពួកគេខ្លះអាចគ្រាន់តែជាជនស៊ីវិលដែលមានអាវុធ ដើម្បីការពារខ្លួន[1368]។

---

និយាយខ្មែរហើយប្រាប់ពួកខ្ញុំថា ពួកគេព្យាយាមធ្វើដំណើរទៅរកប្រទេសថ្មី ដូចជាហ្វីលីពីន សាំងហ្គាពួរ និងតៃវ៉ាន់ជាដើម។ សៈ តើលោកបានឮពាក្យសម្តីនេះដោយខ្លួនលោកផ្ទាល់មែនទេ? ឆ.40៖ អត់ទេ ខ្ញុំឮពីពួកទាហានដែលយាមល្បាតនៅតាមឆ្នេរ។ សៈ ហេតុអ្វីបានជាលោកនិយាយថា ពួកគេចង់ទៅតៃវ៉ាន់ ព្រោះថាវាជាទិសដៅផ្ទុយគ្នាទាំងស្រុងដែលពួកគេធ្វើដំណើរពីវៀតណាមមកកម្ពុជានោះ? ឆ.41៖ ខ្ញុំក៏មិនដឹងដែរ។ ខ្ញុំក៏មិនយល់ដែរ ប៉ុន្តែ ខ្ញុំឮពីពួកទាហាននោះ ដូច្នេះ ហើយពួកទាហាននោះបានឮពីជនភៀសខ្លួននោះបែបនោះដែរ"]។

1366 ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល ឆ.8, 11 ["ពេលនោះ គឺគេចាប់បានទូកវៀតណាមពីកោះពូឡូវៃចាស់ ហើយមានមនុស្សជាង១៦នាក់ មានប្រុស មានស្រី និងក្មេង។ កាលនោះ ប្រហែលជានៅដើមឆ្នាំ១៩៧៨ [...] ឆ.11៖ តាមការសង្កេតមើល ពួកគេពុំមែនជាអ្នកនេសាទទេ ប៉ុន្តែ ជាជនភៀសខ្លួន។ ពួកយើងពុំចេះនិយាយភាសាវៀតណាម ដូច្នេះ ពុំបាននិយាយឆ្លើយឆ្លងទេ។ ប៉ុន្តែ ពួកគេខ្លះបានលើកដៃបង្ហាញម្រាមដៃបី និងចង្អុលទៅទិសខាងលិច។ តាមឥរិយាបថនេះ ចង់បង្ហាញថា ពួកគេគ្រាន់តែឆ្លងកាត់ទីនោះ ដើម្បីធ្វើដំណើរទៅប្រទេសទី៣ នៅឯលោកខាងលិចប៉ុណ្ណោះ"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.31, 37-38 ["សៈ តាមយោបល់ និងគំនិតរបស់លោកថា តើវាខុស ឬត្រូវ ចំពោះការសម្លាប់អ្នកដែលចាប់បាន? ឆ.31៖ ខ្ញុំគិតថា វាខុសទាំងស្រុង ពីព្រោះប្រជាជនទាំងអស់នោះមិនដឹងអ្វីទាំងអស់ ពួកគេគឺគ្រាន់តែរត់គេចពីសង្គ្រាម ដើម្បីរស់រានមានជីវិតតែប៉ុណ្ណោះ។ [...] ឆ.37៖ ពួកយួនទាំងនោះ គឺជាអ្នកភៀសខ្លួន ធ្វើដំណើរទៅកាន់ប្រទេសថៃ ហើយគេបានធ្វើដំណើរឆ្លងកាត់តាមដែនទឹករបស់យើងនៅចន្លោះកោះតាង និងកោះពូឡូវៃ។ [...] ឆ.38៖ ពួកទាំងនោះពុំមានកាំភ្លើង និងមិនមានបំណងចង់តដៃនោះទេ"]។ ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.58 ["សៈ ក្នុងករណីដែលពួកកងនាវាប្រដេញចាប់បានពួកនេសាទវៀតណាម ពួកនេសាទថៃ តើគេចាប់ពួកនោះយកទៅឃុំ ឬយកទៅណា ឬធ្វើយ៉ាងដូចម្តេចខ្លះ? [...] ឆ.58៖ [...] ក្រុមចាប់មនុស្ស គឺគេមានទូកឈើ [...] អង្គភាពនេះ គឺជាអង្គភាពសម្រាប់ចាប់អ្នកនេសាទ និងអ្នកដែលឆ្លងដែនខុសច្បាប់"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN ERN 00978573-00978574, KH ERN 00955503 ["យើងចាប់បាន [ទូកនេសាទ (សូមមើលកំណែជាភាសាអង់គ្លេស EN 00978573, KH ERN 00955503)] ហើយចោទសួរពួកគេ [...] [អ្នកនេសាទដែលបានគឺ] សុទ្ធតែថៃ យួន"]។ ឯកសារ D114/19 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.18 ["ការណែនាំគឺថា បើយើងឃើញកប៉ាល់នេសាទណាឆ្លងចូលផុតក្នុងដែនទឹករបស់យើង [...] ប៉ុន្តែ កាណូតទាំងនោះចូលមកជ្រៅ ហើយយូរក្នុងដែនទឹកយើង យើងនឹងវ៉ៃភ្លាមៗ។ រឿងនេះភាគច្រើនគឺកើតឡើងនៅកន្លែងរបស់ខ្ញុំ។ កន្លែងរបស់ខ្ញុំគឺនៅជិតនឹងព្រំដែនរបស់វៀតណាម ដូច្នេះ ពួកនេសាទដែលចូលមកនោះគឺភាគច្រើនកាណូតវៀតណាម។ ពួកកាណូតនេសាទទាំងនោះ ភាគច្រើនក៏មានកាំភ្លើង និងសព្វាវុធ"]។ ឯកសារ D1.3.13.13 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ ទូច សឿលី EN ERN 00217571 ["ពួកគេត្រូវបានគេប្រាប់ឱ្យល្បាត និងមើលទូកនេសាទវៀតណាម និងកិច្ចការដែនសមុទ្រដទៃទៀត"]។ ឯកសារ D114/127 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គឹម ឆ.4 ["សៈ លោកនិយាយថា មានប្រុស

ស្រី និងក្មេង តើលោកអាចពិពណ៌នាបានទេអំពីរឿងនេះ? ឆ.4៖ ខ្ញុំឃើញមានទារក ក្មេងតូចៗ និងកុមារអាយុ ៦-៧ ឆ្នាំ។ ខ្ញុំសង្កេតឃើញថាពួកគេភាគច្រើនជាកុមារ និងស្ត្រី។ ប្រុសៗភាគច្រើនគឺជាអ្នកបើកបរទូក និងបុគ្គលិកលើទូកប៉ុណ្ណោះ"]។ តើលោកអាចពិពណ៌នាបានទេអំពីរឿងនេះ? ឆ.4៖ខ្ញុំឃើញមានទារក ក្មេងតូចៗ និងកុមារអាយុ ៦-៧ ឆ្នាំ។ ខ្ញុំសង្កេតឃើញថាពួកគេភាគច្រើនជាកុមារនិងស្ត្រី។ ប្រុសៗភាគច្រើនគឺជាអ្នកបើកបរទូក និងបុគ្គលិកលើទូកប៉ុណ្ណោះ"]។

1367 ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល ឆ.23 ["នេះគឺជាពាក្យដែល គេប្រើប្រាស់នៅពេលនោះថា ជនជាតិវៀតណាម គឺជាគិញ"]។ ឯកសារ D114/283 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.18 ["ព្រោះអាហ្នឹងច្បាប់ពីខាងលើមកត្រូវតែកម្ទេច ពូជសាសន៍យួនជាដាច់ខាត ទោះប្រជាជន ឬទេសាទអីត្រូវតែចាប់ទាំងអស់"]។ សូមមើលជាទូទៅ ឯកសារ D1.3.26.7 វិទ្យុ BBC/SWB ចម្លើយសារភាពរបស់គិញវៀតណាម ខែ មេសា ឆ្នាំ ១៩៧៨ EN S ERN 00010459, KH ERN 00225133, FR ERN 00305294-00305295 [សេវាឃោសនាក្នុងស្រុក ផ្សាយចេញពីទីក្រុងភ្នំពេញ (ម៉ោង ២៣០០ GMT ម៉ោងនៅកម្ពុជា ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៧៨) នូវចម្លើយសារភាពរបស់ពលទោវៀតណាមម្នាក់ឈ្មោះ ចឺ លី (Chiu Ly) ដែលត្រូវបានគេចាប់ខ្លួននៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ នៅលើកោះពូឡូវៃ។ ចឺ លី បាននិយាយថា គាត់ត្រូវបានគេជ្រើសរើសជាភ្នាក់ងារស៊ើបការណ៍សម្ងាត់ ដោយស្នងការនគរបាលខេត្តកៀនយ៉ាង"]។ ឯកសារ D234/2.1.92 ព្រំ សារ៉ាត់ ប្រតិចារឹកថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ១៣.៤២.២៤-១៣.៤៦.១១ ["គាត់លើកពីរឿងថា ក្នុងកម្ពុជាយើងមានភ្នាក់ងារសម្ងាត់របស់ផ្ទៃក្នុងកម្ពុជាហ្នឹង គឺមានភ្នាក់ងាររបស់សូវៀត របស់វៀតណាម"]។

1368 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ១០.៥៦.៥៣-១១.០០.៤១ ["បាទ ក្នុងនុំងគឺជាជនជាតិវៀតណាមខុសប្លែកនឹងគ្នានឹងជនជាតិថៃ បាទ ។ ជនជាតិវៀតណាម គឺសត្រូវស្លូពូជជាមួយរបស់ បាទ ប៉ុល ពត។ មិនអាច ទោះបីអ្នកឯងយោធា មិនយោធាក៏ដោយឱ្យតែមានអាវុធតបត គឺបាញ់ពន្លិចតែម្តង។ [...] ក្នុងនុំងគឺថា ដឹងតែជនជាតិវៀតណាមហើយ គឺថាមានអាវុធហើយ គឺថាទោះបីអ្នកឯងមិនយោធា ឬមួយមិនប្រជាជន និងប្រជាជនអីក៏ដោយ គឺថាឱ្យតែពិតប្រាកដជារបស់យួនហើយ មានអាវុធ បាទ អត់មានឱ្យនៅចាប់បានទេ គឺបាញ់ពន្លិចចោលតែម្តង"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាប៉ាក សុខ ឆ.28-29 ["បាទ ត្រូវតែរាយការណ៍ឱ្យច្បាស់លាស់នូវអ្វីដែលយើងចាប់បាន។ ឧទាហរណ៍ ថាតើគេជាជនជាតិវៀតណាមភៀសខ្លួន ជាអ្នកនេសាទថៃ ឬជាទាហាន យើងត្រូវតែរាយការណ៍ទៅថ្នាក់លើឱ្យបានច្បាស់លាស់ជាមុន។ [...] ឆ.29៖ [...] ប្រសិនបើអ្នកដែលត្រូវបានចាប់ខ្លួននោះជាទាហានវៀតណាម យើងត្រូវតែបញ្ជូនពួកនោះទៅដីគោក បន្ទាប់មកគេនឹងធ្វើការចាក់ផ្សាយចម្លើយសារភាពរបស់ទាហានវៀតណាម នៅក្នុងវិទ្យុជាតិមុនពេលគេសម្លាប់"]។ ឯកសារ D59/1/1.8a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រំ សារ៉ាត់ EN ERN 00974206, KH ERN 00926384 ["មានទូកមានអីមកអែបនឹងទៅ ហើយដល់ពេលទៅមើលទូកនឹងទៅវាជាជនជាតិយួន [...] យើងចាប់គេមក [...] ហើយខ្លះគេជាយុវជន ជាឯកសណ្ឋានកាម៉ង់ដូ។ ស៖ ហ្នឹងស្លាកជាទាហានរបស់យួន? ឆ៖ បាទ! ជាទាហានរបស់យួន"]។

387. របាយការណ៍ ស-២១ បង្ហាញថា ចាប់ពីឆ្នាំ ១៩៧៦ ទៅ ពលរដ្ឋវៀតណាមដែលត្រូវបានចាប់ខ្លួននៅសមុទ្រ និងឃុំឃាំងនៅមន្ទីរសន្តិសុខក្នុងតំបន់កំពង់សោម ត្រូវបានបញ្ជូនទៅ ស-២១[1369]។ ប៉ាក់ សុខ បានបញ្ជាក់ថា ចាប់ពីឆ្នាំ ១៩៧៦ **មាស មុត** បានបញ្ជាកងទ័ពរបស់គាត់ឱ្យសម្លាប់ប្រជាជនវៀតណាម ពេលពួកគេត្រូវបានចាប់ខ្លួន[1370]។ ឯក នី អះអាងនៅក្នុងសក្ខីកម្មរបស់គាត់ថា "ព្រោះអាហ្នឹងច្បាប់ពីខាងលើមកត្រូវតែកម្ទេចពូជសាសន៍យួនជាដាច់ខាត ទោះប្រជាជន ឬនេសាទអីត្រូវតែចាប់ទាំងអស់"[1371]។ ថ្នាក់ដឹកនាំកងពល ១៦៤ បង្រៀនទាហានជើងទឹកថា វៀតណាមជា "សត្រូវស្នូរពូជ" និង "សត្រូវទីមួយ"[1372]។ ខ្មាំងវៀតណាមទាំងនោះ ទោះជាទាហាន ឬ

---

1369 សូមមើល VIII.D. មន្ទីរសន្តិសុខ ស-២១។

1370 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ១១.៣១.២៨-១៣.៣៧.៤៥ ["បើកជាវគ្គសាលាសិក្សា ដើម្បីប្រកាស បាទ ប្រកាសពេញសិទ្ធិ សត្រូវស្នូពូជ គឺវា យួន និងកម្ពុជា [...] ជាគោលដៅកុម្មុនីស្តកម្ពុជានោះ គឺថាប្រកាសទូទៅ ទូទាំងអស់នៅក្នុងកងពល ១៦៤ តែម្តង។ [...] ជាការពិតណាស់ សត្រូវស្នូពូជហ្នឹងគឺថា សម្លាប់អត់មានទុក សូម្បីតែកូនង៉ែតមួយក៏អត់ឱ្យមានដែរ ព្រោះនេះជាសត្រូវស្នូពូជ គឺសម្លាប់ចោលតែម្តង ព្រោះទំនាស់បដិបក្ខ"]។ ឯកសារ D234/2.1.95 មាស វឿន ប្រតិចារឹកថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង ១៥.៥៥.៥១-១៥.៥៨.៥១ ["តាំងពីឆ្នាំ ១៩៧០ រហូតមក ៧៥ ក៏ឱ្យទៅដែរ តែគេអត់ចង់ទៅ អាហ្នឹងគេមានទិសដៅ ឬផែនការ។ អ៊ីចឹងតាមអង្គភាពអ៊ីចឹង ឱ្យតែជនជាតិវៀតណាមត្រូវតែកម្ទេចអ៊ីចឹង។ [...] បើកាលណាគេឱ្យទៅហើយ យើងមិនព្រមទៅ"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN ERN 00978576, KH ERN 00955507-00955508 ["ស៖ ចឹងបើចាប់បានពួកយួននោះ? ឆ៖ បើពួកយួនចាប់បានគេយកមកសម្លាប់ចោល។ ស៖ សម្លាប់នៅណា? ឆ៖ ជួនកាលគេសម្លាប់នៅលើកោះហ្នឹងទៅ។ ស៖ គេអត់មានបញ្ជូនមកខាងទេ? ឆ៖ ជួនកាលគេសម្លាប់នៅកោះ។ ស៖ អាហ្នឹងច្រើនពួកកងទ័ពឬមួយយ៉ាងម៉េច? ឆ៖ ច្រើនតែប្រជាជនដែលរត់ភៀសខ្លួនទៅប្រទេសទីបី ភាគច្រើនពួកហ្នឹងរត់គេចពីសង្គ្រាម ដល់រត់ឆ្លងមកយើងចាប់បានបាញ់សម្លាប់ចោលទៅ។ ស៖ ចឹងចាប់បានបញ្ជាពីកងពលទៅឬមួយធ្វើដោយខ្លួនឯង? ឆ៖ បញ្ជាពីកងពលទៅ។ ស៖ បញ្ជាចេញពីនរណាទៅ? ឆ៖ បញ្ជាចេញពីតា មុត។ ស៖ បញ្ជាឱ្យសម្លាប់តែម្តង? ឆ៖ បាទ។"]។ សូមមើលផងដែរ ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ១៣.៣៣.៤៨-១៣.៣៦.៣៩ ["ក្រោយពីរំដោះឆ្នាំ ៧៥ ហើយ កងទ័ពជាភារកិច្ចអ្នកការពារនៅទឹកដីព្រំដែនកោះនៅសមុទ្រ។ [...] គ្រាន់តែការពារតែបើមានវៀតណាមមានអីក៏ដោយចូលមកទឹកដីកម្ពុជាគឺថា មានការទប់ស្កាត់ មានការវាយគ្នា។ អ៊ីចឹងការណែនាំឱ្យទៅវាយគេគឺគ្មានទេ ក្នុងពេលបច្ចុប្បន្ន"]។

1371 ឯកសារ D114/283 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.18។

1372 ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ១៤.៤២.០៣-១៤.៤៤.៣៥ ["ជាគោលដៅនៃច្បាប់របស់បដិវត្តន៍កម្ពុជាប្រជាធិបតេយ្យ គឺថាគ្មានទេ។ គឺវៀតណាមសត្រូវស្នូពូជហើយ អត់មានថាចាប់ហើយលែងទៅវិញទេ បើលែងអត់មានលែងទេ"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦

ជនស៊ីវិលក្តី (អ្នកនេសាទ ឬ "ប្រជាជនជិះទូក" ដែលរត់ពីវៀតណាមទៅថៃ ជារឿយៗត្រូវបានកំណត់ថា ជា "គិញវៀតណាម")[1373] ត្រូវកម្ចាត់ចោលនៅលើទូករបស់ពួកគេ[1374] ឬនៅកោះជិត

ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ១១.៣១.២៨-១៣.៣៧.៤៥ ["បើកជាវគ្គសាលាសិក្សាដើម្បីប្រកាស បាទ ប្រកាសពេញសិទ្ធិសត្រូវស្លូពូជ គឺវា យួននិងកម្ពុជា [...] ជាគោលដៅកុម្មុនីស្តកម្ពុជានោះ គឺថាប្រកាសទូទៅ ទូទាំងអស់នៅក្នុងកងពល ១៦៤ តែម្តង។ [...] ជាការពិតណាស់ សត្រូវស្លូពូជហ្នឹងគឺថា សម្លាប់អត់មានទុក សូម្បីតែកូនង៉ែតមួយក៏អត់ឲ្យមានដែរ ព្រោះនេះជាសត្រូវស្លូពូជ គឺសម្លាប់ចោលតែម្តង ព្រោះទំនាស់បដិបក្ខ"]។ ឯកសារ D234/2.1.92 ព្រុំ សារ៉ាត ប្រតិចារឹកថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ១០.៥៩.២៣-១១.០២.៤២ ["កំណត់យកពីរមុខសញ្ញាច្បាស់ គឺថា មួយខ្មាំងខាងក្រៅ ចំពោះកងទ័ពវៀតណាមដែលវាយទន្ទ្រានកាន់កាប់អធិបតេយ្យភាពកម្ពុជាដែនគោកនិងដែនកោះរបស់កម្ពុជា។ ហើយខ្មាំងខាងក្នុង"] ម៉ោង ១១.០៧.២៨-១១.១២.០៦ ["គោលនយោបាយពេលនោះ បានលើកបញ្ជាក់ថាខ្មាំងដែលប្រឈមនឹងកម្ពុជាប្រជាធិបតេយ្យគឺមានពីរ គឺខ្មាំងវៀតណាម និងខ្មាំងផ្ទៃក្នុង"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក់ សុខ ឆ.31-34 ["ស៖ តាមយោបល់ និងគំនិតរបស់លោកថា តើវាខុស ឬត្រូវ ចំពោះការសម្លាប់អ្នកដែលចាប់បាន? ឆ.31៖ ខ្ញុំគិតថា វាខុសទាំងស្រុង ពីព្រោះប្រជាជនទាំងអស់នោះមិនដឹងអ្វីទាំងអស់ ពួកគេគឺគ្រាន់តែរត់គេចពីសង្គ្រាម ដើម្បីរស់រានមានជីវិតតែប៉ុណ្ណោះ។ ប៉ុន្តែនៅពេលនោះ ខ្មែរក្រហមគិតថា ពួកយួនជាសត្រូវស្លូរពូជ។ [...] ឆ.32៖ [...] ថៃមិនមានទំនាស់ច្រើនជាមួយខ្មែរទេនៅក្នុងប្រវត្តិសាស្ត្រ ប៉ុន្តែ យួនមានទំនាស់ជាមួយខ្មែរច្រើន ទើបយួនត្រូវបានចាត់ទុកថាជាសត្រូវស្លូពូជ និងសត្រូវទី ១។ ស៖ ហេតុអ្វីបានជាលោកដឹងអំពីរឿងអស់ទាំងនេះ? ឆ.33៖ ពីព្រោះមេបញ្ជាការកងវរសេនាតូច និងវរសេនាធំទៅរៀនសូត្រជាមួយនឹងកងពល ហើយពេលគេត្រឡប់មកវិញ គឺគេបង្រៀនយើងអំពីរឿងនេះនៅក្នុងវគ្គអប់រំរៀនសូត្រ។ ស៖ តើអ្នកណាជាអ្នកទទួលខុសត្រូវរួមក្នុងផ្នែកអប់រំនយោបាយនៅក្នុងកងពល ១៦៤ ចាប់ពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩? ឆ.34៖ គឺ មាស មុត ដែលជាស្នងការនយោបាយរបស់កងពល"]។

1373 Dឯកសារ D234/2.1.92 ព្រុំ សារ៉ាត ប្រតិចារឹកថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ១៣.៤២.២៤-១៣.៤៦.១១ ["គាត់លើកពីរឿងថា ក្នុងកម្ពុជាយើងមានភ្នាក់ងារសម្ងាត់របស់ផ្ទៃក្នុងកម្ពុជាហ្នឹង គឺមានភ្នាក់ងាររបស់សូវៀត របស់វៀតណាម"]។ ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល ឆ.23 ["នេះគឺជាពាក្យដែល គេប្រើប្រាស់នៅពេលនោះថា ជនជាតិវៀតណាម គឺជាគិញ ហើយខ្ញុំពុំជឿទាំងអស់នោះទេ។ តាមការសង្កេតរបស់ខ្ញុំ ពួកគេគ្រាន់តែជាប្រជាជនសាមញ្ញ ហើយព្យាយាមភៀសខ្លួនពីប្រទេសមួយទៅប្រទេសមួយទៀតប៉ុណ្ណោះ"]។ ឯកសារ D1.3.26.7 វិទ្យុប៊ីប៊ីស៊ី BBC/SWB ចម្លើយសារភាពរបស់គិញវៀតណាម ខែ មេសា ឆ្នាំ ១៩៧៨ EN ERN S00010459, KH ERN 00225133, FR ERN 00305294-00305295 [សេវាឃោសនាក្នុងស្រុក ផ្សាយចេញពីទីក្រុងភ្នំពេញ (ម៉ោង ២៣00 GMT ម៉ោងនៅកម្ពុជា ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៧៨) នូវចម្លើយសារភាពរបស់ពលទោវៀតណាមម្នាក់ឈ្មោះ ចឺ លី (Chiu Ly) ដែលត្រូវបានគេចាប់ខ្លួននៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ នៅលើកោះពូឡូវៃ។ (ចឺ លី) បាននិយាយថា គាត់ត្រូវបានគេជ្រើសរើសជាភ្នាក់ងារស៊ើបការណ៍សម្ងាត់ដោយស្នងការនគរបាលខេត្តកៀនយ៉ាង"]។

1374 ឯកសារ D114/297.1.20 ប៉ាក់ សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ១៣.៤៨.២៨-១៣.៥១.២៩ ["ពេលដែលចាប់បានកាណូតនីមួយៗបាទ។ ពេលនុំងឃើញថា បញ្ជាៗឲ្យយកទៅលើគោក តែបើតិចត្រឹមត្រូវម្នាក់ពីរ

នោះ[1375] ឬនៅតំបន់កំពង់សោម[1376] ឬត្រូវបានបញ្ជូនទៅ ស-២១ ដើម្បីទាញចម្លើយសារភាព របស់ពួកគេ និងផ្សព្វផ្សាយតាមវិទ្យុកម្ពុជាប្រជាធិបតេយ្យ មុននឹងសម្លាប់ពួកគេ[1377]។ ការប្រព្រឹត្តិ

---

នាក់តែប៉ុណ្ណោះ គឺថាមិនបានទេ។ បើថាការអនុញ្ញាតថាមិនបាច់យកមកទេ គេមានការបាញ់សម្លាប់នៅលើផ្ទៃសមុទ្រ ហើយ ហើយយកតែកាណូតដើម្បីមកប្រើប្រាស់ក្នុងអង្គភាពរបស់គេ"] ម៉ោង ១៣.៥១.២៩-១៣.៥៣.៥៩ ["ពេល តិចគេឲ្យសម្លាប់ទុំង ឃើញថាដោយគេខ្ជិលយកមកសួរចម្លើយ"]។ ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ១៤.០០.៣៩-១៤.០៤.៣៧ ["បើចាប់បានពេញ គឺម្នាក់ ពីរនាក់ គឺសម្លាប់ៗ ចោលនៅលើកោះ និងនៅលើទឹកហើយ។ [...] បើគ្នាតិច អាហ្នឹងយើងសម្លាប់ចោល កាលណាបើដឹកទៅវិញវាខាត បាទ [...] គម្រោងរបស់គេ គឺថាបើគ្នាតិច អាហ្នឹងសម្លាប់នៅលើកោះ និងលើទឹកហ្នឹងហើយ មិនបាច់យកទៅឲ្យខាត អីទេ"]។

1375 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ១០.៣៩.៥៩-១០.៤៣.៣៦ ["តាំង ពីឆ្នាំ៧៧ រហូតដល់ឆ្នាំ ៧៨ [...] អ៊ីចឹងឃើញថាបញ្ជូនមកជាបន្តបន្ទាប់ ពេលនុំងក្នុងប្រជាជនថៃ ជាជននេសាទត្រី និងជនជាតិវៀតណាមដែលរត់ឆ្លងដែនទៅប្រទេសថៃជាច្រើន។ បាទ ខ្ញុំសម្តែងនូវការស្មោះត្រង់ ដោយពិតប្រាកដ ពេលនោះ យកទៅសម្លាប់ចោលតែម្តង អត់មានបញ្ជូនទៅណាទេ ក្នុងពេលនោះ"] ម៉ោង ១១.០៣.០៧-១១.០៥.០៦ ["ហើយជនជាតិវៀតណាម ដែលជាច្រើនលើកច្រើនសា ដែលគេខ្លះក៏គេបញ្ជូនមក ពេលច្រើនគេបញ្ជូនទៅដីគោក តែ បើម្នាក់ពីរនាក់ ទៅបីនាក់ គឺអត់ទេ អត់បញ្ជូនទៅលើដីគោកទេ គេសម្លាប់នៅលើកោះក៏មាន"]។

1376 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ១០.៣៤.៤៥-១០.៣៩.៥៩ ["ឃើញថាភាគច្រើនឡាន គេដឹកជញ្ជូនចេញយកទៅក្រុងកំពង់សោមតែម្តង"]។ ឯកសារ D234/2.1.95 មាស រឿន ប្រតិចារឹកថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង ១៤.០៨.១២-១៤.១២.១២ ["អ៊ីចឹងទៅព្រោះអីគេនៅប្រចាំការជាមួយ យើងដែរ។ ហើយបើយើងបញ្ជូនទៅខាងកងពល ៦៤ (ស៊ុក) ទៅ អាហ្នឹងគឺថាគេយកទៅខាងកំពង់សោមអ៊ីចឹងទៅ"] ។ ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ១៣.៤១.៥២-១៣.៤៦.១៦ ["បញ្ជូនទៅតាមផែអូរឈើទាល ដើម្បីឡានមកដឹក យកមកក្រុងកំពង់សោមបាទ ខ្លះទៀតក៏យកទៅខាងអូរត្រេះ យក ទៅខាងចម្ការដូង"]។

1377 Dឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ១៣.៥១.២៩-១៣.៥៣.៥៩ ["ភាគច្រើនតែវៀតណាមរត់ទៅប្រទេសទី៣ អ៊ីចឹងទៅ អ៊ីចឹងគេចាប់ដែលបានច្រើនអ៊ីចឹងយកទៅសួរចម្លើយ អំពី ព្រឹត្តិការណ៍ដែលនៅក្នុងប្រទេសកម្ពុជាហើយនិងវៀតណាមហ្នឹង តើមានចម្លើយយ៉ាងម៉េច"]។ ឯកសារ D234/2.1.93 ព្រុំ សារ៉ាត ប្រតិចារឹកថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ០៩.៥១.២៤-០៩.៥៣.៥១ ["ខ្ញុំសូម ជម្រាបថា ការបញ្ជូនជនជាតិវៀតណាម ដែលពីសមុទ្រមក ស-២១ [...] គ្រាន់តែប្រាប់ថា ថ្ងៃនេះគេមានចាប់យួន បាន ចាប់វៀតណាមបាន [...] ដូច្នេះ នាវាមិត្តត្រូវប្រុងប្រយ័ត្នឲ្យដល់កម្រិតផង ព្រោះកិច្ចការនេះយើងមិនអាច សន្និដ្ឋានថា តើវានឹងមានផែនការវ៉ៃយើងពេលណានោះទេ"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.25, 28-29 ["ជាទូទៅ កាលណាចាប់បានតិចជាង២០នាក់ គឺបញ្ជាឲ្យសម្លាប់នៅនឹងកន្លែង បើចាប់បានច្រើនជាង ២០ នាក់ ត្រូវបញ្ជូនទៅអូរឈើទាល។ [...] ខ្ញុំធ្លាប់បានឃើញផ្ទាល់នូវព្រឹត្តិការណ៍សម្លាប់ពីរលើក។ ម្តងគឺការសម្លាប់

របស់ **មាស មុត** និងអ្នកក្រោមបង្គាប់ក្នុងកងពល ១៦៤ ទៅលើប្រជាជនវៀតណាមដែលត្រូវបានចាប់ខ្លួននៅសមុទ្រ ស្របទាំងស្រុងតាមគោលនយោបាយប្រល័យពូជសាសន៍របស់ ប.ក.ក ទៅលើប្រជាជនវៀតណាមនៅប្រទេសកម្ពុជា ជាពិសេស ក្នុងអំឡុងពេលពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៩[1378]។ គ្មានការអះអាងណាមួយគួរឱ្យជឿជាក់បានថា ប្រជាជនវៀតណាមដែលត្រូវបានចាប់ខ្លួននៅសមុទ្រ ត្រូវបានបញ្ជូនត្រឡប់ទៅប្រទេសវៀតណាម ឬដោះលែងវិញនោះទេ។ កម្មាភិបាលយោធាពីរបីនាក់ដែលអះអាងថា ជនភៀសខ្លួនវៀតណាមខ្លះត្រូវបានដោះលែង និងអនុញ្ញាតឱ្យបន្តដំណើរទៅប្រទេសថៃ ខ្វះភាពគួរឱ្យជឿជាក់លើចំណុចនេះ[1379]។

---

យួននៅលើទឹកសមុទ្រ ហើយយកតែកាណូត ហើយម្តងទៀតគឺការសម្លាប់យួនភៀសខ្លួនដែលចាប់នៅនឹងលើកោះពូឡូវៃ។ [...] ឆ.28៖ បាទ ត្រូវតែរាយការណ៍ឱ្យច្បាស់លាស់នូវអ្វីដែលយើងចាប់បាន។ ឧទាហរណ៍ថា តើគេជាជនជាតិវៀតណាមភៀសខ្លួន ជាអ្នកនេសាទថៃ ឬជាទាហាន [...] ឆ.29៖ បញ្ហាគឺគេប្រាប់ច្បាស់លាស់ថា តើត្រូវសម្លាប់នៅនឹងកន្លែង ឬក៏បញ្ជូនទៅលើគោក។ ប្រសិនបើអ្នកដែលត្រូវបានចាប់ខ្លួននោះជាទាហានវៀតណាម យើងត្រូវតែបញ្ជូនពួកនោះទៅដីគោក បន្ទាប់មក គេនឹងធ្វើការចាក់ផ្សាយចម្លើយសារភាពរបស់ទាហានវៀតណាម នៅក្នុងវិទ្យុជាតិមុនពេលគេសម្លាប់"]។ ផ្ទុយពី ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.70, 75 ["សះ លោកនិយាយថា ខ្មាំងមានពីរប្រភេទ គឺខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ។ តើលោកគិតថាអ្នកនេសាទវៀតណាមត្រូវបានគេចាត់ទុកជាខ្មាំងខាងក្រៅ ហើយត្រូវគេយកទៅសម្លាប់ចោលដែរឬទេ? ឆ.70៖ ខ្ញុំមិនគិតដូច្នេះទេ។ ខ្មាំងខាងក្រៅ គឺសំដៅទៅលើយោធាវៀតណាមនៅតាមព្រំដែន។ ចំពោះករណីចាប់ទូកនេសាទវៀតណាមនេះ អ្នកនេសាទវៀតណាម តាមខ្ញុំដឹងគឺមិនត្រូវបានចាត់ទុកជាខ្មាំងខាងក្រៅទេ ក៏ប៉ុន្តែ ពួកគេបានរំលោភលើដែនសមុទ្ររបស់កម្ពុជាប្រជាធិបតេយ្យ។ [...] ឆ.75៖ [...] នៅចុងឆ្នាំ ១៩៧៧ ខ្ញុំបានមកចូលរួមប្រជុំសន្និបាតនៅភ្នំពេញធ្វើការបូកសរុបការងារ ក្នុងក្របខ័ណ្ឌការងារកងពល ១៦៤ ខ្ញុំឮ មាស មុត រាយការណ៍ពីទូកវៀតណាមដែលបានចូលក្នុងដែនសមុទ្រកម្ពុជា ហើយ សុន សេន បាននិយាយថា បើវៀតណាមទាំងនោះជាជនភៀសខ្លួនទៅប្រទេសថៃ យើងមិនត្រូវចាប់ពួកគេទេ ហើយឱ្យពួកគេធ្វើដំណើរទៅចុះ"]។

1378 សូមមើល VIII.G.2. វៀតណាមក្នុងឋានៈជាក្រុមគោលដៅជនជាតិជាក់លាក់ - នយោបាយប្រល័យពូជសាសន៍ប្រឆាំងនឹងវៀតណាម។

1379 ឧទាហរណ៍ លោក ណុប ហាល បានបញ្ជាក់យ៉ាងច្បាស់ថា បញ្ជាមកពីថ្នាក់លើ មានភាពច្បាស់លាស់ ចំពោះជនភៀសខ្លួនវៀតណាម៖ ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល ឆ.19-20 ["សះ ប្រសិនជាពួកគេពិតជាជនភៀសខ្លួនដូចលោកបាននិយាយមែន ហេតុអ្វីបានជាចាំបាច់ត្រូវចាប់ខ្លួនពួកគេ ហើយមិនអនុញ្ញាតឱ្យពួកគេឆ្លងកាត់ដោយសេរីទៅ? ឆ.19៖ ខ្ញុំមិនដឹងទេ។ ដូចខ្ញុំបានប្រាប់លោកហើយថា បទបញ្ជាក្នុងការចាប់ទូក និងបញ្ជូនទូកទៅណាៗនោះ គឺចេញមកពីថ្នាក់លើ។ បទបញ្ជា គឺច្បាស់ណាស់ថា យើងត្រូវរាយការណ៍រាល់អ្វីដែលយើងបានសង្កេតឃើញនៅលើដែនសមុទ្រខ្មែរ ហើយបទបញ្ជាថាត្រូវធ្វើអ្វីនោះ គឺចេញមកពីថ្នាក់លើ [...] សះ តើកម្លាំងប្រចាំការនៅតាមទិសដៅមួយៗមានសិទ្ធិដោះលែងទូក ដែលគេបានចាប់ ក្រោយពីដឹងថាជនភៀសខ្លួនដែរឬទេ? ឆ.20៖ [...] ជា

## បញ្ហារបស់ មាស មុត ពាក់ព័ន្ធនឹងពលរដ្ឋថៃ

388. សុន សេន ហៅប្រទេសថៃថាជា "សត្រូវពីបស្ចិម" ដែលអាចដណ្ដើមយកសមុទ្រ និងទឹកដីកម្ពុជាបាន[1380]។ នៅខែ សីហា ឆ្នាំ ១៩៧៦ **មាស មុត** បានរាយការណ៍ទៅ ប៉ុល ពត សុន សេន តាម៉ុក និង វ៉ន វ៉េត អំពី "សភាពការណ៍ខ្លាំង" ដោយបានកត់សម្គាល់ពីការកើនឡើងនៃទូកនេសាទថៃពី "មកម្ដងមកពី ឥឡូវវាមកជាហ្វូងពី ៣០ ទៅ ៤០ កប៉ាល់"[1381]។ មួយខែក្រោយមក គាត់បានប្រាប់ សុន សេនថា "មានការប្រែប្រួលខ្លាំង" ពីព្រោះ "ពួកថៃលបចូលនេសាទក្នុងទឹកយើងកាន់តែច្រើន" ជាក្បួននាវានេសាទចំនួន "មួយរយ ឬមួយរយហាសិបគ្រឿង"[1382]។

---

ទូទៅ ក្រោយពេលទទួលបញ្ជាឱ្យចាប់ទូកណាមួយហើយ គឺគេត្រូវអនុវត្ត និងគ្មានសិទ្ធិដោះលែងទូកណាមួយទេ"]។ សូមមើលផងដែរ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ១០.៣៤.៤៥-១០.៣៩.៥៩ ["ជនជាតិវៀតណាមនៅលើទូកនោះ អ្នកពិការដៃនោះគឺជាទាហាន ក្រៅពីនោះជាប្រជាជន [...] វត់ទៅប្រទេសថៃតែម្ដង។ ក្រោយមកបានយើងឃើញ យើងចាប់ [...] ចាប់យកមកផែ"] ម៉ោង ១០.៣៩.៥៩-១០.៤៣.៣៦ ["អ៊ីចឹងឃើញថា បញ្ជូនមកបន្តបន្ទាប់ ពេលនុំងក្នុងប្រជាជនថៃ ជាជននេសាទត្រី និងជនជាតិវៀតណាមដែលវត់ឆ្លងដែនទៅប្រទេសថៃជាច្រើន។ បាទ ខ្ញុំសម្ដែងនូវការស្មោះត្រង់ ដោយពិតប្រាកដ ពេលនោះ យកទៅសម្លាប់ចោលតែម្ដង អត់មានបញ្ជូនទៅណាទេ ក្នុងពេលនោះ"]។ ឯកសារ D234/2.1.95 មាស វឿន ប្រតិចារឹកថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង ១៤.១៧.២០-១៤.១៩.០៤ ["រឿងជនភៀសខ្លួនរបស់វៀតណាម [...] ខ្ញុំគិតឃើញថា ខ្លួនខ្ញុំដែលចាប់មក ចាប់បានខ្ញុំបញ្ជូនទៅតាមថ្នាក់ដឹកនាំរបស់ខ្ញុំអ៊ីចឹងទៅ ហើយថ្នាក់ដឹកនាំក៏ដោះស្រាយតាមបែបណា ក៏ស្រេចតែគាត់ទៅ"]។

1380 ឯកសារ D234/2.1.92 ព្រុំ សារ៉ាត ប្រតិចារឹកថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៦ ម៉ោង ១៣.៣៩.០៣-១៣.៤២.២៤ ["គាត់លើកពីរឿងខ្មាំងខាងលិច និយាយចំពោះថាខាងប្រទេសថៃ។ [...] ដែលជាខ្មាំងស៊ីជម្រៅក្នុងទឹកដីកម្ពុជាផង ហើយខ្មាំងប្រេបិចទឹកដីកម្ពុជាតាមព្រំដែន និងដែនទឹក និងដែលគោកកម្ពុជាផង"]។

1381 ឯកសារ D1.3.8.3 កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃអង្គប្រជុំការងារយោធានៅកំពង់សោម ថ្ងៃទី ៣-៨-៧៦ KH ERN 00021497 [មាស មុត រាយការណ៍ទៅ ប៉ុល ពត វន វ៉េត និង សុន សេន៖ "ខាងថៃ៖ មានកាណូតមកលួចចាប់ត្រី។ ពីមុនវាមកម្ដង មកពីរ។ ឥឡូវវាមកជាហ្វូងពី ៣០ ទៅ ៤០ កប៉ាល់។ [...] យើងការពារខាងយោធាបាន វាចូលមកចេះតែប៉ះ។ ដោយវិធានការយោធាយើង វាក៏រអា"]។

1382 ឯកសារ D1.3.27.18 កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុប្រជុំ កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុភាររបស់កងពល និងវរសេនាធំ ថ្ងៃទី ១៩-៩-៧៦ EN ERN 00195340-41, KH 00052390, FR 00195356 ["សភាពការណ៍ខ្មាំង - ចូលខែ៩ នេះមក មានការប្រែប្រួលខ្លាំង។ ពួកថៃលបចូលនេសាទក្នុងទឹកយើងកាន់តែច្រើន។ ចូលជាក្បួននាវានេសាទ រហូតចំនួនមួយរយ ឬមួយរយហាសិបគ្រឿង។ វាច្រើនចូលត្រង់មុំកោះកុង និងច្រឡោះកោះតាង។ ថ្ងៃ ១១-៩ យើងចាប់បានមួយគ្រឿង កម្លាំង ៥០សេះ"]។ សូមមើលផងដែរ ឯកសារ D114/27.1.5 កម្ពុជាប្រជាធិបតេយ្យ

389. ព្រុំ សារ៉ាត បានផ្តល់សក្ខីកម្មថា ពេលឃើញទូកថៃ គេចាត់វិធានការដើម្បីដេញ ឬ "បញ្ឈប់"[1383]។ **មាស មុត** បញ្ជាឱ្យឃាត់ទូកនេសាទមកពីប្រទេសថៃ[1384] ហើយការឃាត់ទូកកើតមានឡើងជាប្រចាំ[1385]។ **មាស មុត** បានបញ្ជូន និងទទួលរបាយការណ៍អំពីការបាញ់[1386] និងចាប់ទូកថៃ[1387] និង

---

កំណត់ហេតុប្រជុំ កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភាររបស់កងពល និងវរសេនាធំ ថ្ងៃ ១៩-៩-៧៦ KH ERN 00052390 ["ពួកថៃលបចូលនេសាទក្នុងទឹកយើងកាន់តែច្រើន។ ចូលជាក្បួននាវានេសាទ រហូតចំនួនមួយរយ ឬមួយរយហាសិបគ្រឿង។ វាច្រើនចូលត្រង់ម្តុំកោះកុង និងច្រឡោះកោះតាង។ ថ្ងៃ ១១-៩ យើងចាប់បានមួយគ្រឿង កម្លាំង ៥០សេះ"]។

1383 ឯកសារ D234/2.1.92 ព្រុំ សារ៉ាត ប្រតិចារឹកថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ១៣.៣៩.០៣-១៣.៤២.២៤ ["គាត់លើកពីរឿងខ្មាំងខាងលិច និយាយចំពោះថា ខាងប្រទេសថៃ។ [...] ដែលជាខ្មាំងស៊ីជម្រៅក្នុងទឹកដីកម្ពុជាផង ហើយខ្មាំងប្របិចទឹកដីកម្ពុជាតាមព្រំដែន និងដែនទឹក និងដែនគោកកម្ពុជាផង"] ម៉ោង ១៣.៥៤.៥៤-១៣.៥៥.០៣ ["ការដែលក្រុមនេសាទរបស់ថៃចូលមក អ្វីទាំងអស់ហ្នឹង គឺមានទូកនិងនាវារបស់យុទ្ធជននៅតាមកោះ អាហ្នឹងគេអនុវត្តផែនការដេញ ឬក៏បញ្ឈប់ការរុលចូលរបស់កងនេសាទថៃ ឬក៏ពួកកាណូត ទូករបស់ថៃដែលចូលមកក្នុងអធិបតេយ្យកម្ពុជា"]។

1384 ឯកសារ D59/1/1.8a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រុំ សារ៉ាត់ EN ERN 00974220-00974221, KH ERN 00926397-00926398 ["ខាងថៃ វាច្រើនតែប្រើទូកនេសាទធំៗ។ [...] គាត់ណែនាំថា បើកាលណាមានទូកគេមកអ៊ីចឹង យើងចាប់បានគេយើងត្រូវរាយការណ៍ [...] សៈ តា មុត គាត់ថាអ៊ីចឹង? ឆៈ: បាទ! គាត់ថាអ៊ីចឹង នេះជាការងារមួយដែលយើងសម្រាប់អនុវត្ត"]។

1385 ឯកសារ D1.3.34.10 ទូរលេខ ៤៤ ពី មាស មុត ទៅបង៨៩ (សុន សេន) ចុះថ្ងៃ ១៣-៨-៧៦ EN ERN 00233647, KH ERN 00000860, FR ERN 00323217 ["'ថ្ងៃ ១២-៨ យើងចាប់កប៉ាល់ បានទៅចតនៅផែកោះតាង។ ក្រោយមក មានយន្តហោះមួយគ្រឿងមកឆ្វែលលើកោះតាង។ [...] ថ្ងៃ ១២-៨ មានការប៉ះទង្គិចរវាងយើង និងកាណូតចាប់ត្រីថៃ អស់ជិត ៤ម៉ោងនៅមុខកោះកុងក្រៅ ៤,៥ គ.ម។ លទ្ធផល កាណូតចាប់ត្រីថៃមួយត្រូវយើងចាប់ ឯមនុស្សធ្លាក់ទឹក"]។ បញ្ជាក់នៅក្នុង ឯកសារ D1.3.12.7 សេចក្តីរាយការណ៍ សរុបសភាពការណ៍ចាប់ពីថ្ងៃ ១៥ កក្កដា ដល់ ថ្ងៃ ៣១ សីហា ១៩៧៦ EN ERN 00233963, KH ERN 00021503, FR ERN 01248460 ["១២-៨-៧៦ [...] ថៃបានចូលមកចាប់ត្រី មានទ្រង់ទ្រាយធំ និងលក្ខណៈបំផ្លាញទៀតផង [...] មានការប៉ះទង្គិចគ្នារវាងយើងនិងវា អស់រយៈជិត ៤ ម៉ោង នៅមុខកោះកុងក្រៅចម្ងាយ ៤ គ.ម កន្លះ។ យើងចាប់បានកាណូតចាប់ត្រី ១ គ្រឿង មនុស្សធ្លាក់ទឹក។ [...] ១៣ និង ១៨-៨-៧៦៖ យើងចាប់បានកាណូតថៃ ២គ្រឿងធុន ៥០សេះ និង ៤០០សេះ មានមនុស្សចំនួន ១៨ នាក់ កាំភ្លើង ៣ ដើម ធ្លាក់ទឹកអស់ ២ ដើម នៅសល់កាប៊ីន ១ដើមនិងវិទ្យុកូឡាំង ១ គ្រឿង"]។ ឯកសារ D1.3.34.28 សេចក្តីរាយការណ៍ "តាមទូរស័ព្ទសម្ងាត់" ពី ស៊ឹម ទៅកងពលធំ ១៦៤ ចុះថ្ងៃទី ១៥-៩-៧៧ ["ចំពោះទូកថៃដែលចូលក្នុងសមុទ្រយើងយ៉ាងជ្រៅ ហើយជិតកោះយើង ខ្ញុំបានចេញកប៉ាល់ធ្វើការ ចាប់បានទូក ២ គ្រឿង ធុន ៣០០សេះ ១ គ្រឿ ៤០០សេះ ១ គ្រឿង។ ចំពោះទូក ២ គ្រឿងចាប់បាននៅខាងត្បូងកោះកុង។ នៅលើទូកមានកូឡាំង ២ គ្រឿង និងត្រីមួយចំនួន និងប្រេង ចំពោះមនុស្សគ្មានបានទេ ពីព្រោះវាលោតធ្លាក់ទឹក នៅសល់មួយចំនួន បងប្អូន

កម្ទេចចោលអស់]"]។ ឯកសារ D1.3.34.23 ទូរលេខ ២៨ ចុះថ្ងៃទី ១២-៨-៧៧ [កំណត់សម្គាល់ដោយ ខៀវ សំផន៖ "ផ្អែកលើរបាយការណ៍ផ្ទាល់មាត់សមមិត្ត មុត កាលពីម្សិលមិញយើងចាប់បានទូកមួយគ្រឿង កម្លាំង (១៧០សេះ) នៅកោះកុងក្រៅត្រង់ចុងកោះខាងត្បូង។ កន្លែងបង និងខ្ញុំចតកប៉ាល់។ ចាប់ថៃបាន ៤ នាក់ ខ្មែរ ១ នាក់។ វាឆ្លើយថា ទាក់ទង។ មានក្បួនឬស្សីនៅលើទូក។ កំពុងសួរ"]។ ឯកសារ D1.3.12.18 ទូរលេខ ០៩ ពី មាស មុត ទៅបង៨៩ (សុន សេន) ចុះថ្ងៃ ២៩-៥-៧៧ ["ចុងខែ ៥-៧៧ ចាប់ពីថ្ងៃ ២០ រហូតមក នៅតាមដែនទឹកជាប់នឹងថៃ មានកាណូតចាប់ត្រីដែលការពារដោយកប៉ាល់យោធារបស់ថៃ បានចូលមកក្នុងដែនទឹករបស់យើងយ៉ាងជ្រៅ កន្លែងខ្លះ [...] ដល់ខាងត្បូងកោះកុង និងជុំវិញកោះក្ងរស្រូវ។ ដោយឃើញសភាពការណ៍ទាំងនេះ ខាងយើងខ្ញុំបានសម្រេចឱ្យបងប្អូនដែលប្រចាំការនៅទីនោះចេញ ប៉េសេអេហ្វខាងមុខកោះកុងពី ៦ ទៅ ១០ គ.ម ដី ដើម្បីដេញបណ្តេលហ្វូងកាណូតចាប់ត្រីទាំងនេះកុំឱ្យវាចូលជ្រៅពេក និងច្រើនពេក ដូច្នេះ នៅថ្ងៃទី ២៦-៥ ម៉ោង ១១.៥៤ នាទី ថ្ងៃត្រង់គឺជាពេលដែលយើងចេញធ្វើការនោះ ក៏បានជួបហ្វូងកាណូតថៃប្រហែល ៥០ ទៅ ៦០ គ្រឿង យើងក៏សំដៅទៅរកវា ឯទៀតនាំគ្នារត់អស់នៅសល់ធុន ៤០០សេះមួយគ្រឿង ត្រូវយើងចាប់ខ្លួនដោយគ្មានឃើញមនុស្ស តាមមើលវាលោតទម្លាក់ទឹកអស់"]។ ឯកសារ D1.3.12.20 សេចក្តីរាការណ៍ពី មាស មុត ទៅ សុន សេន ថ្ងៃទី ១២-៨-៧៧ EN ERN 00233972, KH ERN 00020912, FR ERN 00623197 ["ម្សិលមិញ ថ្ងៃទី ១១-៨-៧៧ យើងចេញល្បាតចាប់បានទូក ២ គ្រឿង ១ ធុន ៣៥០សេះ ១ ទៀតធុន ១៧៥សេះ។ ទូកធុន ១៧៥សេះ មានមនុស្ស ៥ នាក់ គ្មានប្រដាប់នេសាទទេ។ ចាប់បាននៅកៀកកោះកុង ប្រហែល ២ គ.ម។ ក្រោយមកយើងបានសាកសួរ [...] ទាំង ៥ នាក់នេះ ម្នាក់ខ្មែរ ក្រៅពីនេះសៀម។ [...] មានក្បួនឬស្សី ១៥"]។ ឯកសារ D54/13.1 កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤ ថ្ងៃ ៩-៩-៧៦ EN ERN 00974008, KH ERN 00936737, FR ERN 00970395 ["សភាពការណ៍ខ្មាំង ថ្ងៃ ៥-៩ មានកូនទូកម៉ាស៊ីនតូចមួយ ជិះមនុស្ស ៦ នាក់ សៀម ៥ និងខ្មែរ ១។ ព្រឹកឡើង ទូកនេះមកដល់កោះរ៉ុងសន្លឹម។ ថាគេឱ្យមក ដាក់ឱ្យចុះទូកនៅខាងលិចកោះរ៉ុងសន្លឹម ដើម្បីស៊ើបការណ៍ តើនៅឃ្សួងកោះនេះមានអ្វីខ្លះ។ សភាពការណ៍នេះកើតក្រោយពីយន្តហោះមកស៊ើបការណ៍លើនាវាយើង ដែលកំពុងហាត់កន្លែងនោះ។ ថ្ងៃ ២-៩ មាននាវានេសាទថៃ ១០ គ្រឿង មកត្រង់កោះកុង មុំកោះស្តេច។ យើងចាប់បាន ១ គ្រឿង កម្លាំង ៤០០សេះ មានគ្នាវា ៩ នាក់- វាលោតទឹកបាត់ ៧នាក់ទៀត"]។ ឯកសារ D1.3.27.18 កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុភាររបស់កងពល និងវរសេនាធំ ថ្ងៃទី ១៩-៩-៧៦ EN ERN 00195340-41, KH 00052390, FR 00195356 ["សភាពការណ៍ខ្មាំង - ចូលខែ ៩ នេះមក មានការប្រែប្រួលខ្លាំង។ ពួកថៃលបចូលនេសាទក្នុងទឹកយើងកាន់តែច្រើន។ ចូលជាក្បួននាវានេសាទ រហូតចំនួនមួយរយ ឬមួយរយហាសិបគ្រឿង។ វាច្រើនចូលត្រង់មុំកោះកុង និងច្រឡោះកោះតាង។ ថ្ងៃ ១១-៩ យើងចាប់បានមួយគ្រឿង កម្លាំង៥០សេះ។"]។ ឯកសារ D1.3.12.2 របាយការណ៍ពី មាស មុត ជូនបង ៨៩ (សុន សេន) ទីគោរពជ្រាប ថ្ងៃ ៦-២ (មិនចាំឆ្នាំ ១៩៧៦ ១៩៧៧ ឬ ១៩៧៨) ["ថ្ងៃ ៤-២ មិត្តនៅកោះព្រីងបានបាញ់ទូកនេសាទថៃមួយគ្រឿង [...] ទូកនេសាទប្រហែល ៥ គ.ម រួចវារត់ទៅទិសខាងលិចបាត់ទៅ។ [...] នៅម៉ោង ៦ ល្ងាចថ្ងៃ ៥-២ នេះ ខាងនេសាទរដ្ឋបាននាំទូកសៀម [...] ចូលកោះរ៉ុង តែពុំទាន់ដឹងហេតុផលអីទេ ក៏នាំចេញទៅវិញបាត់"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង ១០.៥១.៣៤-១០.៥៤.៣៩ ["មានការខុសៗគ្នាខ្លះ។ [...] ខ្ញុំចាប់បាននូវកប៉ាល់ថៃចំនួនបីគ្រឿង [...] ជនជាតិថៃទាំងអស់នោះនៅលើទូក ក្នុងទូកនីមួយៗមានចំនួន ២០ នាក់, ១០ នាក់, ១៥ នាក់។ បាទ ជនជាតិថៃនោះគឺថា បញ្ជូនទៅរាមតែម្តង បាទ ទៅរាម។

ក្រោយមក ខ្ញុំបានទៅធ្វើការនៅរាម ជួបជនជាតិថៃនោះធ្វើការនៅទំនប់នៅរាម -- នៅរាមទេ -- នៅកោះតាគាវ១។ ខ្ញុំគេឱ្យធ្វើការនៅកោះតាគាវនោះ ក៏ខ្ញុំបានជួបជនជាតិថៃទាំងអស់នោះ។ ខ្ញុំសួរអ្នកយាមថៃនោះថា ជនជាតិថៃទាំងអស់នេះ គេសម្លាប់គាត់ចោល ឬមួយក៏គេយកទៅណាដែរអ្នកយាម? អ្នកយាមនោះក៏បាននិយាយប្រាប់ខ្ញុំថា គេមិនសម្លាប់ចោលទេថៃទាំងអស់នេះ គេអាចបញ្ជូនគេទៅប្រទេសគេវិញ"]។ ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.58 ["សៈ ក្នុងករណីដែលពួកកងនាវាប្រដេញចាប់បានពួកនេសាទវៀតណាម ពួកនេសាទថៃ តើគេចាប់ពួកនោះយកទៅឃុំ ឬយកទៅណា ឬធ្វើយ៉ាងដូចម្តេចខ្លះ? [...] ឆ.58៖ [...] ក្រុមចាប់មនុស្ស គឺគេមានទូកឈើ [...] អង្គភាពនេះ គឺជាអង្គភាពសម្រាប់ចាប់អ្នកនេសាទ និងអ្នកដែលឆ្លងដែនខុសច្បាប់"]។ ឯកសារ D54/82 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.33 ["សៈ នៅពេលដែលលោកនិយាយថា ទូកបរទេសហ្នឹង តើលោកសំដៅទៅលើជនជាតិណាមួយ? ឆ.33៖ ភាគច្រើន នៅពេលដែលយើងនិយាយអំពីទូកបរទេស គឺយើងសំដៅទៅលើទូកថៃ និងយួន"]។ ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល ឆ.24 ["ខ្ញុំដឹងថាមានការចាប់ទូកថៃ និងទូកវៀតណាម"]។ ឯកសារ D114/126 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គីម ឆ.42 [សៈ បើនិយាយអំពីអ្នកនេសាទថៃ តើពួកគេភាគច្រើនជាបុរសនារី និងមានអាយុខ្ទង់ប៉ុន្មានដែរ? ឆ.42៖ ពួកគេមានអាយុខ្ទង់ ៣០ ឆ្នាំ ហើយសុទ្ធតែប្រុសៗទាំងអស់"]។ ឯកសារ D114/57 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.29 ["ខ្ញុំក៏ធ្លាប់បានឮផងដែរថា មានទូកថៃត្រូវបានគេចាប់យកមកកោះតាងនោះ ហើយបន្ទាប់មកត្រូវគេយកទៅកំពង់សោម។"]។ ឯកសារ D114/105 កំណត់ហេតុស្តាប់ចម្លើយ កុច ទុយ ឆ.47, 157 ["សៈ តើអង្គភាពរបស់លោកមានដែលបានចាប់ទូកថៃឬទូកវៀតណាមដែលចូលមកនេសាទដែរឬទេ? ឆ.47៖ អង្គភាពរបស់ខ្ញុំធ្លាប់បានចាប់ទូកឈើ របស់ថៃលេខ ៣៣១ ម្តងនៅកោះយ៉ [...] ពួកយើងឃើញពួកគេតាមរយៈរ៉ាដា។ ចំពោះទូកវៀតណាមគឺពុំដែលចាប់បានទេ។ [...] ឆ.157៖ ខ្ញុំធ្លាប់នៅ ក្នុងកងពល ១៦៤ តា ឆាន ជាប្រធាន។ [...] នៅពេលដែលយើងយកអ្នកនេសាទ មកកំពង់សោម គឺពួក តា ឆាន ជាអ្នកទទួល"]។ ឯកសារ D54/52 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.19-20 ["សៈ តាមលោកចាំ ក្នុងអំឡុងពេលនៅកោះកុង តើកងរបស់លោកចាប់បានទូកនេសាទថៃបានចំនួនប៉ុន្មាននាក់? ឆ.19៖ តាមខ្ញុំចាំបាន យើងចាប់បានអ្នកនេសាទថៃប្រហែលចំនួន ១០ នាក់ ប៉ុន្តែ យើងចាប់បានទូកនេសាទប្រហែល ៥០ ទៅ ៦០ គ្រឿង។ ចំនួនអ្នកនេសាទដែលចាប់បាន គឺតិចជាងចំនួនទូក ពីព្រោះតែពេលដែលយើងចូលមកជិតទូកដើម្បីចាប់ម្តងៗ ពួកអ្នកនេសាទទាំងនោះលោតទឹក ដើម្បីរត់គេចពីការចាប់ខ្លួន។ សៈ យោងតាមការស្មានរបស់លោក នៅក្នុងពេលនោះ បើសិនជាលោកចាប់បានមនុស្សនៅលើទូកទាំង ៥០ ទៅ ៦០ គ្រឿងនោះ តើមានមនុស្សចំនួនប៉ុន្មាននាក់? ឆ.20៖ វាអាចមានចំនួនអ្នកនេសាទច្រើនណាស់ ជាមធ្យមទូកនេសាទមួយៗមានមនុស្សពីបីទៅបួននាក់"]។ ឯកសារ D54/11 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ឆ.24 ["ក្នុងឆ្នាំ ១៩៧៦ ខ្ញុំបានឃើញអ្នកនេសាទថៃ ដែលគេចាប់បានយកមកទុកនៅកោះតាគាវ។ ថ្ងៃមួយពេលដែលខ្ញុំទៅបេះដូងនៅកោះតាគាវ ខ្ញុំបានឃើញអ្នកនេសាទថៃនៅទីនោះ។ យោធានៅលើកោះបានប្រាប់ខ្ញុំថា អ្នកទាំងនោះគឺជាអ្នកនេសាទថៃដែលគេចាប់យកមក។ អ្នកនេសាទទាំងនោះមិនត្រូវបានគេចងទេ ពួកគេដើរជុំវិញកន្លែងនោះ អ្នកខ្លះបេះដូង និងខ្លះទៀតកំពុងដាំបាយ។ ពួកគេមានគ្នាប្រហែលជា ១០ នាក់ មានមនុស្សចាស់ខ្លះ ក្មេងខ្លះ ប៉ុន្តែ គ្មានកុមារ និងស្ត្រីទេ។ ពួកគេពាក់ខោអាវចម្រុះពណ៌។ ខ្ញុំបានឮពីយោធានៅលើកោះនិយាយថា ស្ថានទូតថៃនឹងទាក់ទងយកពួកអ្នកនេសាទទាំងនោះទៅថៃវិញ"]។ ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល ឆ.23 ["ជនជាតិថៃដែលគេចាប់ គឺសុទ្ធសឹងតែជាមនុស្សប្រុសពេញវ័យ និងជាអ្នកនេសាទ ដោយសារទូករបស់ពួកគេមានឧបករណ៍នេសាទ

គ្រប់ប្រភេទ"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN ERN 00978573-00978574, KH ERN 00955503 ["យើងបានទូកនេសាទត្រី (សូមមើលកំណែជាភាសាអង់គ្លេស EN ERN 00978573, KH ERN 00955503)] ហើយសួរពួកគេ [...] ធម្មតាមានប្រុសៗ។ [...] [អ្នកនេសាទត្រីដែលគេចាប់បានគឺ] សុទ្ធតែថៃ យួន។"]។ សូមមើល ជាទូទៅ ឯកសារ D1.3.8.3 កម្ពុជាប្រជាធិបតេយ្យកំណត់ហេតុនៃអង្គប្រជុំ ការងារយោធានៅកំពង់សោម ថ្ងៃ ៣-៨-៧៦ KH ERN 00021497 [មាស មុត រាយការណ៍ទៅ ប៉ុល ពត វនវេត និង សុន សេន៖ "ខាងថៃ៖ មានកាណូតមកលួចចាប់ត្រី។ ពីមុនវាមកមួយ មកពីរ។ ឥឡូវវាមកជាហ្វូងពី ៣០ ទៅ ៤០ កប៉ាល់។ [...] យើងការពារខាងយោធាបាន វាចូលមកចេះតែប៉ះ។ ដោយវិធានការយោធាយើង វាក៏រអា"]។

1386 ឯកសារ D1.3.12.2 របាយការណ៍ពី មាស មុត ជូនបង ៨៩ (សុន សេន) ទីគោរពជ្រាប ថ្ងៃ ៦ - ២ (មិនចាំឆ្នាំ ១៩៧៦ ១៩៧៧ ឬ ១៩៧៨) ["ថ្ងៃ ៤-២ មិត្តនៅកោះព្រីងបានបាញ់ទូកនេសាទថៃមួយគ្រឿង [...]ទូកនេសាទប្រហែល ៥ គ.ម រួចវារត់ទៅទិសខាងលិចបាត់ទៅ។ [...] នៅម៉ោង ៦ ល្ងាចថ្ងៃ ៥-២ នេះ ខាងនេសាទរដ្ឋបាននាំទូកសៀម [...] ចូលកោះរ៉ុង តែពុំទាន់ដឹងហេតុផលអីទេ ក៏នាំចេញទៅវិញបាត់"]។

1387 ឯកសារ D1.3.34.10 ទូរលេខ ៤៤ ពី មាស មុត ទៅបង៨៩ (សុន សេន) ចុះថ្ងៃ ១៣-៨-៧៦ EN ERN 00233647, KH ERN 00000860, FR ERN 00323217 ["ថ្ងៃ ១២-៨ យើងចាប់កប៉ាល់ បានទៅចតនៅផែកោះតាង។ ក្រោយមក មានយន្តហោះមួយគ្រឿងមកឆ្វេលលើកោះតាង។ [...] ថ្ងៃ ១២-៨ មានការប៉ះទង្គិចរវាងយើង និងកាណូតចាប់ត្រីថៃ អស់ជិត ៤ម៉ោងនៅមុខកោះកុងក្រៅ ៤,៥ គ.ម។ លទ្ធផល កាណូតចាប់ត្រីថៃមួយត្រូវយើងចាប់ ឯមនុស្សធ្លាក់ទឹក"]។ បញ្ជាក់នៅក្នុង ឯកសារ D1.3.12.7 សេចក្តីរាយការណ៍ សរុបសភាពការណ៍ ចាប់ពីថ្ងៃ ១៥ កក្កដា ដល់ ថ្ងៃទី ៣១ សីហា ១៩៧៦ EN ERN 00233963, KH ERN 00021503, FR ERN 01248460 ["១២-៨-៧៦ [...] ថៃបានចូលមកចាប់ត្រី មានទ្រង់ទ្រាយធំ និងលក្ខណៈបំផ្លាញទៀតផង [...] មានការប៉ះទង្គិចគ្នារវាងហើយនិងវា អស់រយៈជិត ៤ ម៉ោង នៅមុខកោះកុងក្រៅចម្ងាយ ៤ គ.ម កន្លះ។ យើងចាប់បានកាណូតចាប់ត្រី១គ្រឿង មនុស្សធ្លាក់ទឹក។ [...] ១៣ និង១៨-៨-៧៦៖ យើងចាប់បានកាណូតថៃ ២ គ្រឿងធុន ៥០សេះ និង ៤០០សេះ មានមនុស្សចំនួន ១៨ នាក់ កាំភ្លើង ៣ ដើម ធ្លាក់ទឹកអស់ ២ ដើម នៅសល់ការ៉ាប៊ីន ១ដើម និងវិទ្យុកូឡាំង ១ គ្រឿង"]។ ឯកសារ D54/13.1 កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុប្រជុំ កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤ ថ្ងៃ ៩-៩-៧៦ EN ERN 00974008, KH ERN 00936737, FR ERN 00970395 ["សភាពការណ៍ខ្មាំង ថ្ងៃ៥-៩ មានកូនទូកម៉ាស៊ីនតូចមួយមនុស្សជិះ ៦ នាក់ សៀម ៥ និងខ្មែរ ១។ ព្រឹកឡើង ទូកនេះមកដល់កោះរ៉ុងសន្លឹម។ ថាគេឲ្យមកដាក់ឲ្យចុះទូកនៅខាងលិចកោះរ៉ុងសន្លឹម ដើម្បីស៊ើបការណ៍តើនៅឈូងកោះនេះមានអ្វីខ្លះ។ សភាពការណ៍នេះកើតក្រោយពីយន្តហោះមកស៊ើបការណ៍លើនាវាយើង ដែលកំពុងហាត់កន្លែងនោះ។ ថ្ងៃ ២-៩ មាននាវានេសាទថៃ ១០ គ្រឿង មកត្រង់កោះកុង ម្តុំកោះស្តេច។ យើងចាប់បាន ១ គ្រឿង កម្លាំង ៤០០សេះ មានគ្នាវា ៩ នាក់- វាលោតទឹកបាត់ ៧ នាក់ទៀត"]។ ឯកសារ D1.3.27.18 កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុប្រជុំ កំណត់ហេតុនៃការប្រជុំលេខា និង ភស្តុភាររបស់កងពល និងវរសេនាធំ ថ្ងៃទី ១៩-៩-៧៦ EN ERN 00195340-41, KH 00052390, FR 00195356 ["សភាពការណ៍ខ្មាំង - ចូលខែ ៩ នេះមក មានការប្រែប្រួលខ្លាំង។ ពួកថៃលបចូលនេសាទក្នុងទឹកយើងកាន់តែច្រើន។ ចូលជាក្បួននាវានេសាទរហូតចំនួនមួយរយ ឬមួយរយហាសិបគ្រឿង។ វាច្រើនចូលត្រង់ម្តុំកោះកុង និងច្រឡោះកោះតាង។ ថ្ងៃ ១១-៩ យើងចាប់បានមួយគ្រឿង កម្លាំង ៥០សេះ"]។ ឯកសារ D1.3.12.20 សេចក្តីរាការណ៍ពី មាស មុត ទៅ សុន សេន ថ្ងៃទី

អំពីការចាប់ខ្លួន[1388] សម្លាប់[1389] សួរចម្លើយពលរដ្ឋថៃ[1390] ឬអំពីការដែលពលរដ្ឋថៃលោត/ធ្លាក់ចូលក្នុងសមុទ្រ ពេលទូករបស់ពួកគេត្រូវបានវាយប្រហារ[1391]។ អ្នកដែលត្រូវបានចាប់ខ្លួននោះជាទូទៅ

---

១២-៨-៧៧ EN ERN 00233972, KH ERN 00020912, FR ERN 00623197 ["ម្សិលមិញ ថ្ងៃទី ១១-៨-៧៧ យើងចេញល្បាតចាប់បានទូក ២ គ្រឿង ១ ធុន ៣៥០សេះ ១ ទៀតធុន ១៧៥សេះ។ ទូកធុន ១៧៥សេះ មានមនុស្ស ៥ នាក់ គ្មានប្រដាប់នេសាទទេ។ ចាប់បាននៅកៀកកោះកុង ប្រហែល ២ គ.ម។ ក្រោយមកយើងបានសាកសួរ [...] ទាំង ៥ នាក់នេះ ម្នាក់ខ្មែរ ក្រៅពីនេះសៀម។ [...] មានក្បួនឫស្សី ១៥"]។

1388 Dឯកសារ D54/13.1 កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុប្រជុំ កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤ ថ្ងៃ ៩ - ៩ - ៧៦ EN ERN 00974008, KH ERN 00936737, FR ERN 00970395 ["សភាពការណ៍ខ្មាំង៖ ថ្ងៃ ៥-៩ មានកូនទូកម៉ាស៊ីនតូចមួយ មនុស្សជិះ ៦ នាក់ សៀម ៥ និងខ្មែរ ១។ ព្រឹកឡើង ទូកនេះមកដល់កោះរ៉ុងសន្លឹម។ ថាគេឲ្យមកដាក់ឲ្យចុះទូកនៅខាងលិចកោះរ៉ុងសន្លឹម ដើម្បីស៊ើបការណ៍តើនៅឈ្វេងកោះនេះមានអ្វីខ្លះ។ សភាពការណ៍នេះ កើតក្រោយពីយន្តហោះមកស៊ើបការណ៍លើនាវាយើង ដែលកំពុងហាត់កន្លែងនោះ។ ថ្ងៃ ២-៩ មាននាវានេសាទថៃ ១០ គ្រឿង មកត្រង់កោះកុង ម្តុំកោះស្តេច។ យើងចាប់បាន ១ គ្រឿង កម្លាំង ៤០០សេះ មានគ្នាវា ៩ នាក់- វាលោតទឹកបាត់ ៧ នាក់ទៀត"]។

1389 ឯកសារ D1.3.34.28 សេចក្តីរាយការណ៍ "តាមទូរស័ព្ទសម្ងាត់" ពី ស៊ឹម ទៅកងពលធំ ១៦៤ ចុះថ្ងៃទី ១៥-៩-៧៧ ["ចំពោះទូកថៃដែលចូលក្នុងសមុទ្រយើងយ៉ាងជ្រៅ ហើយជិតកោះយើង ខ្ញុំបានចេញកប៉ាល់ធ្វើការចាប់បានទូក ២ គ្រឿង ធុន ៣០០សេះ ១ គ្រឿ ៤០០សេះ ១ គ្រឿង។ ចំពោះទូក ២ គ្រឿងចាប់បាននៅខាងត្បូងកោះកុង។ នៅលើទូកមានកូឡាំង ២ គ្រឿង និងត្រីមួយចំនួន និងប្រេង ចំពោះមនុស្សគ្មានបានទេ ពីព្រោះវាលោតធ្លាក់ទឹក នៅសល់មួយចំនួនបងប្អូនកម្ទេចចោលអស់"]។

1390 ឯកសារ D1.3.12.20 សេចក្តីរាការណ៍ពី មាស មុត ទៅ សុន សេន ថ្ងៃទី ១២-៨-៧៧ EN ERN 00233972, KH ERN 00020912, FR ERN 00623197 ["ម្សិលមិញ ថ្ងៃទី ១១-៨-៧៧ យើងចេញល្បាតចាប់បានទូក ២ គ្រឿង ១ ធុន ៣៥០សេះ ១ ទៀតធុន ១៧៥សេះ។ ទូកធុន ១៧៥សេះ មានមនុស្ស ៥ នាក់ គ្មានប្រដាប់នេសាទទេ។ ចាប់បាននៅកៀកកោះកុង ប្រហែល ២ គ.ម។ ក្រោយមកយើងបានសាកសួរ [...] ទាំង ៥ នាក់នេះ ម្នាក់ខ្មែរ ក្រៅពីនេះសៀម។ [...] មានក្បួនឫស្សី ១៥"]។ ឯកសារ D1.3.34.23 ទូរលេខ ២៨ ចុះថ្ងៃទី ១២-៨-៧៧ [កំណត់សម្គាល់ដោយខៀវ សំផន៖ "ផ្អែកលើរបាយការណ៍ផ្ទាល់មាត់សមមិត្ត មុត កាលពីម្សិលមិញយើងចាប់បានទូកមួយគ្រឿង កម្លាំង (១៧០សេះ) នៅកោះកុងក្រៅត្រង់ចុងកោះខាងត្បូង។ កន្លែងបង និងខ្ញុំចតកប៉ាល់។ ចាប់ថៃបាន ៤ នាក់ ខ្មែរម្នាក់។ វាឆ្លើយថាទាក់ទង។ មានក្បូនឫស្សីនៅលើទូក។ កំពុងសួរ"]។

1391 ឯកសារ D1.3.34.28 សេចក្តីរាយការណ៍ "តាមទូរស័ព្ទសម្ងាត់" ពី ស៊ឹម ទៅកងពលធំ ១៦៤ ចុះថ្ងៃទី ១៥-៩-៧៧ ["ចំពោះទូកថៃដែលចូលក្នុងសមុទ្រយើងយ៉ាងជ្រៅ ហើយជិតកោះយើង ខ្ញុំបានចេញកប៉ាល់ធ្វើការ ចាប់បានទូក ២ គ្រឿង ធុន ៣០០សេះ ១ គ្រឿ ៤០០សេះ ១ គ្រឿង។ ចំពោះទូក ២ គ្រឿងចាប់បាននៅខាងត្បូងកោះកុង។ នៅលើទូកមានកូឡាំង ២គ្រឿង និងត្រីមួយចំនួន និងប្រេង ចំពោះមនុស្សគ្មានបានទេ ពីព្រោះវាលោតធ្លាក់ទឹក នៅសល់មួយចំនួនបងប្អូនកម្ទេចចោលអស់"]។ ឯកសារ D1.3.34.10 ទូរលេខ ៤៤ ពី មាស មុត ទៅបង៨៩ (សុន សេន) ចុះថ្ងៃ ១៣-

ជាអ្នកនេសាទបុរស[1392] ប៉ុន្តែ ក៏មានស្ត្រីដែលត្រូវបានចាប់ខ្លួន និងសួរចម្លើយផងដែរ[1393]។ អ្នកដែលព្យាយាមរត់គេចពីកម្លាំងរបស់ **មាស មុត** មិនត្រូវបានជួយសង្គ្រោះចេញពីសមុទ្រនោះទេ[1394]។

---

៨-៧៦ EN ERN 00233647, KH ERN 00000860, FR ERN 00323217 ["ថ្ងៃ ១២-៨ យើងចាប់កប៉ាល់ បានទៅចតនៅផែកោះតាង។ ក្រោយមក មានយន្តហោះមួយគ្រឿងមកឆ្វេលលើកោះតាង។ [...] ថ្ងៃ ១២-៨ មានការប៉ះទង្គិចរវាងយើង និងកាណូតចាប់ត្រីថៃអស់ជិត ៤ ម៉ោង នៅមុខកោះកុងក្រៅ ៤,៥ គ.ម។ លទ្ធផល កាណូតចាប់ត្រីថៃមួយត្រូវយើងចាប់ ឯមនុស្សធ្លាក់ទឹក"]។ បញ្ជាក់នៅក្នុង ឯកសារ D1.3.12.7 សេចក្តីរាយការណ៍ សរុបសភាពការណ៍ ចាប់ពីថ្ងៃ ១៥ កក្កដា ដល់ ថ្ងៃទី ៣១ សីហា ១៩៧៦ EN ERN 00233963, KH ERN 00021503, FR ERN 01248460 ["១២-៨-៧៦ [...] ថៃបានចូលមកចាប់ត្រី មានទ្រង់ទ្រាយធំ និងលក្ខណៈបំផ្លាញទៀតផង [...] មានការប៉ះទង្គិចគ្នារវាងហើយ និងវាអស់រយៈជិត ៤ ម៉ោង នៅមុខកោះកុងក្រៅចម្ងាយ ៤ គ.ម កន្លះ។ យើងចាប់បានកាណូតចាប់ត្រី ១ គ្រឿង មនុស្សធ្លាក់ទឹក"]។ ឯកសារ D54/13.1 កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុប្រជុំកំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤ ថ្ងៃ ៩-៩-៧៦ EN ERN 00974008, KH ERN 00936737, FR ERN 00970395 ["ថ្ងៃ ២-៩ មាននាវានេសាទថៃ ១០ គ្រឿង មកត្រង់កោះកុង ម្តុំកោះស្តេច។ យើងចាប់បាន ១ គ្រឿង កម្លាំង ៤០០សេះ មានគ្នាវា ៩ នាក់- វាលោតទឹកបាត់ ៧ នាក់ទៀត"]។ ឯកសារ D1.3.12.18 ទូរលេខ ០៩ ពី មាស មុត ទៅ បង៨៩ (សុន សេន) ចុះថ្ងៃ ២៩ - ៥ - ៧៧ ["ចុងខែ ៥-៧៧ ចាប់ពីថ្ងៃ ២០រហូតមក នៅតាមដែនទឹកជាប់នឹងថៃ មានកាណូតចាប់ត្រីដែលការពារដោយកប៉ាល់យោធារបស់ថៃ បានចូលមកក្នុងដែនទឹករបស់យើងយ៉ាងជ្រៅកន្លែងខ្លះ [...] ដល់ខាងត្បូងកោះកុង និងជុំវិញកោះក្ដូរស្រូវ។ ដោយឃើញសភាពការណ៍ទាំងនេះ ខាងយើងខ្ញុំបានសម្រេចឱ្យបងប្អូនដែលប្រចាំការនៅទីនោះចេញ ប៉េសេអេហ្វខាងមុខកោះកុងពី ៦ ទៅ ១០ គ.ម ដី ដើម្បីដេញបង្អើលហ្វូងកាណូតចាប់ត្រីទាំងនេះកុំឱ្យវាចូលជ្រៅពេក និងច្រើនពេក ដូច្នេះ នៅថ្ងៃទី ២៦-៥ ម៉ោង ១១.៥៤ នាទី ថ្ងៃត្រង់ គឺជាពេលដែលយើងចេញធ្វើការនោះ ក៏បានជួបហ្វូងកាណូតថៃប្រហែល ៥០ ទៅ ៦០ គ្រឿង យើងក៏សំដៅទៅរកវា ឯទៀតនាំគ្នារត់អស់ នៅសល់ធុន ៤០០សេះមួយគ្រឿង ត្រូវយើងចាប់ខ្លួនដោយគ្មានឃើញមនុស្ស តាមមើលវាលោតទម្លាក់ទឹកអស់"]។ ឯកសារ D54/52 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.19 ["តាមខ្ញុំចាំបាន យើងចាប់បានអ្នកនេសាទថៃប្រហែលចំនួន ១០ នាក់ ប៉ុន្តែ យើងចាប់បានទូកនេសាទប្រហែល ៥០ ទៅ ៦០ គ្រឿង។ ចំនួនអ្នកនេសាទដែលចាប់បាន គឺតិចជាងចំនួនទូក ពីព្រោះតែពេលដែលយើងចូលមកជិតទូកដើម្បីចាប់ម្តងៗ ពួកអ្នកនេសាទទាំងនោះលោតទឹក ដើម្បីរត់គេចពីការចាប់ខ្លួន"]។

1392 ឯកសារ D114/126 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គីម ឆ.42 ["សៈ បើនិយាយអំពីអ្នកនេសាទថៃ តើពួកគេភាគច្រើនជាបុរស នារី និងមានអាយុខ្ទង់ប៉ុន្មានដែរ? ឆ.42៖ ពួកគេមានអាយុខ្ទង់៣០ឆ្នាំ ហើយសុទ្ធតែប្រុសៗទាំងអស់"]។ ឯកសារ D54/11 កំណត់ហេតុស្តាប់ចម្លើយ ម៉ើ រ៉េត ឆ.24 ["ក្នុងឆ្នាំ ១៩៧៦ ខ្ញុំបានឃើញអ្នកនេសាទថៃដែលគេចាប់បានយកមកទុកនៅកោះតាគារ។ [...] ពួកគេមានគ្នាប្រហែល ១០ នាក់ មានមនុស្សចាស់ខ្លះ ក្មេងខ្លះ ប៉ុន្តែ គ្មានកុមារនិងស្ត្រីទេ"]។ ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល ឆ.23 ["ជនជាតិថៃដែលគេចាប់ គឺសុទ្ធតែជាមនុស្សប្រុសពេញវ័យ និងជាអ្នកនេសាទ ដោយសារទូករបស់ពួកគេមានឧបករណ៍នេសាទគ្រប់ប្រភេទ"]។

## បញ្ហារបស់ មាស មុត ពាក់ព័ន្ធនឹងពលរដ្ឋមិនមែនកម្ពុជាផ្សេងទៀត

390. ពលរដ្ឋអាស៊ាន និងបស្ចិមប្រទេសផ្សេងទៀតក៏ត្រូវបានចាប់ខ្លួនផងដែរនៅសមុទ្រ ឬនៅលើកោះ និងបញ្ជូនទៅដីគោក មុននឹងផ្ទេរទៅមន្ទីរសន្តិសុខវត្តឥន្ទញាណ កំពង់សោម[1395] ឬ ស-២១[1396]។ ក្នុងពេលអនុវត្តការណែនាំរបស់កងពល ១៦៤ កងទ័ពជើងទឹកនៃកម្ពុជាប្រជាធិបតេយ្យបានចាប់ខ្លួនមនុស្សមួយចំនួនមកពីប្រទេសនានា ដូចជា ម៉ាឡេស៊ី[1397] និងឥណ្ឌា[1398] ក្នុងដែនទឹកអន្តរជាតិ

---

1393 ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN ERN 00978573-00978574, KH ERN 00955503-00955504 ["ជារឿយៗចាប់បានទូកនេសាទ (សូមមើលកំណែជាភាសាអង់គ្លេស EN ERN 00978573, KH ERN 00955503) ហើយសួរចម្លើយពួកគេ។ ស៖ ចាប់កាប៉ាល់ខាងណា? ឆ៖ ចាប់កាប៉ាល់ថៃ"]។

1394 ឯកសារ D54/52 កំណត់ហេតុស្តាប់ចម្លើយ មាស រឿន ឆ.21-22 ["ស៖ តើលោកគិតថាអ្នកដែលលោតទឹកនោះមានវាសនានឹងនៅរស់ដែរឬទេ? ឆ.21៖ ខ្ញុំគិតថាគេអាចមានឱកាសនៅរស់ច្រើន ពីព្រោះនៅពេលគេលោតចូលទឹក គេតែងតែមានរបស់សម្រាប់បណ្តែតទឹក សម្រាប់គេតោងយកទៅជាមួយ។ ខ្ញុំនិយាយដូច្នេះ ដោយសារពេលមួយមានយោធារបស់ខ្ញុំពីរនាក់បានធ្លាក់ចូលទៅក្នុងទឹក ហើយខ្ញុំបានរកឃើញគេនៅរស់ក្នុងថ្ងៃបន្ទាប់ ដោយគេមានក្តារឈើសម្រាប់តោងហែល។ ស៖ តើអ្នកនេសាទថៃដែលលោតចូលទៅក្នុងទឹកនោះ តើកងរបស់លោកតាមជួយសង្គ្រោះ ឬក៏ទុកពួកគេចោល? ឆ.22៖ យើងមិនបានទៅជួយសង្គ្រោះអ្នកនេសាទថៃនោះទេ យើងទុកពួកគេទៅតាមវាសនារបស់គេទៅ។ ប៉ុន្តែ ប្រសិនបើយោធាយើងធ្លាក់ចូលទឹក យើងត្រូវតែស្វែងរក ដើម្បីជួយសង្គ្រោះមកវិញ"]។

1395 ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង ០៩.៣០.០៤-០៩.៣៧.១៤, ១០.០៧.៣០-១០.១០.០៥, ០៩.៤៨.២៧-០៩.៥៣.៥៩ ["ដែលពេលចាប់យកទៅហ្នឹង គឺថាអ្នកនៅលើកប៉ាល់ហ្នឹងក៏គេដកចេញពីលើកប៉ាល់ហ្នឹងយកទៅកំពង់សោមតែម្តង [...] គេឱ្យក្រុមខ្ញុំទៅយាមនៅលើកប៉ាល់នោះ ដាក់នៅលើទូក ដើម្បីបញ្ជូនទៅកំពង់សោមតែម្តង [...] អ្នកបញ្ជាចាប់កប៉ាល់ម៉ាយ៉ាហ្គេស បញ្ជាវរសេនា -- ពីកងពលមកវរសេនាធំ បញ្ជាពីវរសេនាធំទៅវរសេនាតូចទៅយោធា។ មិនមែនថាវរសេនាតូចណាមួយ ឬក៏វរសេនាធំណាមួយម្ចាស់ការបានទេ ទាល់តែបញ្ជាពីលើមកបានទៅចាប់"]។

1396 ឯកសារ D59/1/1.8a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រុំ សារ៉ាត់ EN ERN 00974222, KH ERN 00926399 ["ស៖ ហើយចុះបើខាងពួកអ្នកស៊ើបការណ៍ចូលមកកោះយើងអី ខាងកងពលគេណែនាំអីយើង? ឆ៖ គេណែនាំឱ្យឃាត់ខ្លួនហើយ បើយើងចាប់បានរបៀបនេះ គេត្រូវបញ្ជូនទៅ ស-២១។ ស៖ បញ្ជូនទៅ ស-២១ កងពលណែនាំអ៊ីចឹង? ឆ៖ បាទ! ណែនាំអ៊ីចឹង"]។

1397 ឯកសារ D59/1/1.9a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ EN ERN 00963734, KH ERN 00926466-00926467 ["បានជាទាហាន ពួកចោរមកលួចត្រី លួចអីខ្លះបានដែរ។ [...] មានថៃក៏មាន យួនក៏មាន មានម៉ាឡេស៊ីក៏មាន បរទេសច្រើនដែរហ្នឹង ប៉ុន្តែ យើងមិនស្គាល់គេអស់"]។

ដែលកម្ពុជាប្រជាធិបតេយ្យអះអាងថាជាកម្មសិទ្ធិរបស់ខ្លួន[1399]។ ភស្តុតាងជាសក្ខីកម្ម និងរបាការណ៍ ស-២១ បង្ហាញថា អ្នកចាប់ខ្លួនទាំងនោះត្រូវបានសម្លាប់ចោលនាពេលក្រោយ[1400]។

1398 ឯកសារ D234/2.1.92 ព្រុំ សារ៉ាត ប្រតិចារឹកថ្ងៃទី ២៦ ខែ មករា ឆ្នាំ២០១៦ ម៉ោង ១៥.៤៩.១២-១៥.៥២.៣៨ ["មានថ្ងៃមួយនោះ ខ្ញុំជួបជនជាតិយួនម្នាក់ និងជនជាតិក្លឹងម្នាក់ដែលនៅលើកោះ [...] ហ្នឹងតាមដែលខ្ញុំស្គាល់នៅលើផែនទី មិនមែន --។ អ្វីដែលខ្ញុំបញ្ជាក់ពេលនេះគ្រាន់តែថា អ្នកដែលចាប់ហ្នឹង ទៅចាប់ពីណាមក ចាប់ពីដែនទឹកវៀតណាម ឬចាប់នៅដែនទឹកកម្ពុជា"]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត ឆ.127, 151 ["ខ្ញុំឃើញមានជនជាតិក្លឹង(ឥណ្ឌា)ម្នាក់ និងជនជាតិយួនម្នាក់។ [...] ឆ.151៖ ខ្ញុំមិនអាចពន្យល់លម្អិតប្រាប់លោកបានទេ។ ខ្ញុំបានឃើញគេទុកជនជាតិបរទេសនៅក្នុងផ្ទះនៅកោះតាង ហើយខ្ញុំសួរយោធានៅទីនោះថា តើហ្នឹងជនជាតិអី? គេឆ្លើយថា ពួកគេជាជនជាតិក្លឹង និងវៀតណាម។ ខ្ញុំគិតថាគាត់មកពីឥណ្ឌាទៅវៀតណាម ដើម្បីបន្តទៅថៃ"]។ ឯកសារ D59/1/1.8a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រុំ សារ៉ាត់ EN ERN 00974209, KH ERN 00926387 ["មានខ្លះ តែយើងស្គាល់លក្ខណៈ ដូចថាជនជាតិបរទេសដែលមកអ៊ីចឹង យើងស្គាល់ថានេះជាយួន នេះជាខ្លឹង ជាឥណ្ឌាអ៊ីចឹង ព្រោះពួកហ្នឹងច្រើនដើរចន្លោះ។ [...] ប្រហែលដូចមិនដែលមានពួកខ្លឹង ពួកអីមាន"]។

1399 ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.152-154, 156-157 ["ពិតជាមានការចាប់មែន ពេលដែលគេមិនព្រមចាកចេញពីដែនសមុទ្ររបស់យើង តែមិនមែនជាអង្គភាពខ្ញុំជាអ្នកធ្វើទេ គឺខ្ញុំឮតាមរយៈវិទ្យុទាក់ទង។ ស៖ តើលោកឮតាមវិទ្យុទាក់ទងនៅពេលណា? ឆ.153៖ ពេលដែលខ្ញុំនៅលើដីគោក មុនពេលដែលខ្ញុំទៅកោះរ៉ុង។ ស៖ ប៉ុន្តែ នៅព្រឹកមិញ យើងសួរលោកថាលោកធ្លាប់ឮតាមវិទ្យុទាក់ទងថា មានការចាប់មនុស្សនៅសមុទ្រដែរឬទេ ហើយលោកនិយាយថាមិនធ្លាប់ឮទេ ហេតុអ្វី? ឆ.154៖ ខ្ញុំធ្លាប់ឮពីការចាប់ខ្លួនមនុស្សតាមវិទ្យុទាក់ទងមែន។ [...] ស៖ តើលោកស្តាប់ឮការទំនាក់ទំនងពីការចាប់ខ្លួនមនុស្សក្នុងកាលៈទេសៈបែបណាដែរ? ឆ.156៖ ពេលដែលគេចាប់បាន គេរាយការណ៍មកកងពល ដូច្នេះ ខ្ញុំបានឮគេនិយាយតាមវិទ្យុមក។ ដោយសារវិទ្យុទាក់ទងលេខ ២៥ ប្រើប្រេកង់ដូចគ្នា។ ស៖ តាមលោកដឹង តើកងណាជាអ្នកចាប់មនុស្ស? ឆ.157៖ ជាទូទៅអ្នកឈរជើងនៅតាមកោះ ជាអ្នកចាប់និងរាយការណ៍មក"]។ ឯកសារ D59/1/1.8a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រុំ សារ៉ាត់ EN 00974209, KH 00926387 ["យើងចាប់ពួកហ្នឹង មិនមែនគេបុកកោះដូចយើងទេ អត់ដូចយួនទេ ខុសគ្នា។ គេច្រើនបើកនៅសមុទ្រ ដែលជិតកោះយើងអ៊ីចឹងទៅ"]។ ឯកសារ D59/1/1.9a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ EN ERN 00963734, KH ERN 00926467 ["បាទ! ចូលមកជ្រៅៗពេកអ៊ីចឹង។ [...] មានថៃក៏មាន យួនក៏មាន មានម៉ាឡេស៊ីក៏មាន បរទេសច្រើនដែរហ្នឹង ប៉ុន្តែ យើងមិនស្គាល់គេអស់។"]។

1400 សូមមើល VIII.D. មន្ទីរសន្តិសុខស-២១។ ផ្ទុយពី ឯកសារ D59/1/1.9a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ EN ERN 00963734, KH ERN 00926467-00926468 [ពន្យល់ថា បន្ទាប់ពីការចាប់ខ្លួនមក អ្នកនេសាទខុសច្បាប់មកពីវៀតណាម ថៃ ម៉ាឡេស៊ី ត្រូវបានបញ្ជូនទៅសេនាធិការដ្ឋានកងពល ១៦៤ ហើយថាមួយចំនួនត្រូវបានដោះលែង បន្ទាប់ពីបានអប់រំ ខណៈដែលអ្នកផ្សេងទៀតមិនត្រូវបានដោះលែងឡើយ ប៉ុន្តែ ត្រូវបានដាក់ឱ្យធ្វើការ។ គាត់បានពន្យល់បន្ថែមទៀតថា ចំពោះឧប្បត្តិហេតុសំខាន់ៗ នៅពេលដែលបានបញ្ជូនមកដល់ដីគោកនៅរាម ក្រុមដែលត្រូវចាប់ខ្លួនបានក៏ត្រូវអង្គភាពសន្តិសុខ "ប្រឡង់ដែក្រហម" ដែលមកពីភ្នំពេញដឹកតាមឡានកាំមីញ៉ុ

391. របាយការណ៍ ស-២១ និងភស្តុតាងជាសក្ខីកម្ម ក៏បង្ហាញផងដែរថា ពួកបស្ចិមប្រទេសមួយចំនួន ត្រូវបានចាប់ខ្លួនលើទូក ឬទូកក្តោងរបស់ពួកគេដោយកងទ័ពជើងទឹកនៃកម្ពុជាប្រជាធិបតេយ្យដែល ស្ថិតក្រោមការគ្រប់គ្រងរបស់ **មាស មុត**[1401]។ ក្រោយមក អ្នកចាប់ខ្លួនទាំងនោះត្រូវបានបញ្ជូនទៅ

---

ង]។ សូមមើលផងដែរ ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.161-165 [ជនជាប់ឃុំឃាំង ត្រូវបានគេនាំទៅសេនាធិការដ្ឋានកងពល តាមបញ្ជារបស់មេបញ្ជាការកងពល។ អ្នកខ្លះត្រូវបានដោះលែងតាមរយៈ ស្ថានទូតរបស់ពួកគេ។ ទោះជាយ៉ាងណា ឡាយ ប៊ុនហាក់ មិនបានផ្តល់សញ្ជាតិដល់អ្នកដែលត្រូវបានដោះលែងនោះ ទេ]។

1401 សូមមើល ជំពូក VIII.ឃ. មន្ទីរសន្តិសុខ ស-21។ ឯកសារ D11/2.3 ចម្លើយសារភាពនៅមន្ទីរ ស -21 របស់ John Dawson Dewhirst ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៧៨ EN 00681102។ ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នក ទោសមន្ទីរ ស-21 របស់ ក.ស.ច.ស [បញ្ជាក់ថា លរ. 12719, 12720, 13021 និង 13022 ជាជនបរទេស]។ ឯក សារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.44.37-09.47.53 ["មាន១ វៀ តណាម មានជនជាតិអាមេរិកាំង ជនជាតិអូស្ត្រាលី ហ្នឹង ដែលខ្ញុំធ្លាប់ឃើញ [...] ជនជាតិអូស្ត្រាលី ហើយនិងជន ជាតិអាមេរិកាំងម្នាក់ហ្នឹង ខ្ញុំមានម្នាក់ខ្ញុំស្គាល់ ខ្ញុំចាំដោយសារ ឃើញឈ្មោះ តេវីដ ស្កុត សរសេរឆ្លាក់ដាក់នៅនឹងលើ អាវ១ អាវខូវប៊យ"]។ ឯកសារ D1.3.28.140 បញ្ជីឈ្មោះអ្នកទោស មន្ទីរ ស-21, EN 01236389, KH 00088752, FR 01187845 [បញ្ជាក់ថា លរ.១ គឺឈ្មោះ គ្រីស្តូហ្វៃ អេដវ៉ ឌីឡង់ និងលរ.២ ឈ្មោះ មីសែល ស្កុតឌៀត គីម៉ូ]។ ឯក សារ D1.3.33.3 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច EN 00147526-27, KH 00146488 ["ស: ហេតុអ្វីបានជាគេចាប់ជនបរទេសទាំងនេះ ពួកគេមកធ្វើអ្វី? ឆ: គេចូលដែនសមុទ្រខ្មែរ ហើយកងសមុទ្រចាប់បញ្ជូន មកឱ្យ នួន ជា [...] ជនបរទេស ខ្ញុំសំដៅពួកស្អែកស"]។ ឯកសារ D1.3.33.4 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេក អ៊ាវ ហៅ ឌុច EN 00198221, KH 00197971 ["ស: តើក្រសួងការបរទេស បានដឹងពីការចាប់ខ្លួនជនបរទេស៤រូប ដែលសាកសពរបស់ពួកគេ ត្រូវបានដុតដែរឬទេ? ឆ: ខ្ញុំគិតថា ក្រសួងការបរទេសមិនបានដឹងទេ។ ២នាក់ក្នុងចំណោម នោះ ត្រូវបានបញ្ជូនមកឱ្យខ្ញុំដោយ សុន សេន និង២នាក់នាក់ទៀតដោយ នួន ជា។ ខ្ញុំដឹងថា គឺ កងពល១៦៤ ដែលដឹកនាំដោយ មាស មុត ជាអ្នកចាប់ខ្លួន ប៉ុន្តែ ខ្ញុំមិនគិតថា ក្រសួងការបរទេស ត្រូវបានជូនដំណឹងពី រឿងនេះនោះទេ"]។ ឯកសារ D54/22 កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៣ EN 00947622, KH 01002678 [កិច្ចសន្ទនាជាមួយ លោក សុន យីវ អំពីអ្នកនាវាចរ ដែលត្រូវបានចាប់៖ "អ្នកនាវាចរមានកម្ពស់ខ្ពស់ ជាជនជាតិស្បែកស ជាអ្នកមាន និងជាអ្នកទេសចរ [...] គាត់ចាំបានថា គាត់បានឃើញតែពីរនាក់ទេ ប៉ុន្តែត្រូវបាន ប្រាប់ថា មានបីនាក់។ ពួកគេមិនត្រូវបានវាយដំ ឬចាប់ចងទេ។ នៅពេលនោះ ពួកគេហាក់ដូចមានអាការៈធម្មតា"]។ ឯកសារ D114/58 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.2-4 ["ស: តើមានករណីណាផ្សេងទៀត ដែលលោកបាន ដឹងពាក់ព័ន្ធជាមួយនឹងការចាប់ជនបស្ចិមប្រទេសតាមទូកដែរឬទេ? ឆ2: ខ្ញុំបានឮថា មានទូកក្តោងមួយត្រូវបានចាប់ ប៉ុន្តែខ្ញុំមិនចង់ប្រាប់លោកឡើយ ដោយសារនេះជាអ្វីដែលខ្ញុំបានឮប៉ុណ្ណោះ។ [...] ឆ3: កាលពីសម័យនោះ មានផែកង ទ័ពជើងទឹកមួយកន្លែងនៅឆ្នេរអូរ

ឈើទាល។ ហេតុការណ៍នេះបានកើតឡើងនៅពេលដែលខ្ញុំទៅរៀននៅកំពង់សោម។ ខ្ញុំបានឮព័ត៌មានមួយចំនួនពីលោក

ស-២១ ដោយមានការឯកភាព និងសម្របសម្រួលពីថ្នាក់ដឹកនាំកងពល ១៦៤[1402]។ ក្នុងកិច្ចសម្ភាសន៍មួយ **មាស មុត** ដំបូង បានបដិសេធថាពុំបានដឹង ឬចេញបញ្ជាឱ្យចាប់ខ្លួនពួកបរទេសនៅសមុទ្រនោះទេ ដោយអះអាងថា ខ្លួនបានចេញពីកំពង់សោមទៅក្រចេះហើយនៅខែ កុម្ភៈ ឆ្នាំ ១៩៧៨[1403]។ ទោះជាយ៉ាងណាក៏ដោយ ក្រោយមក គាត់បានទទួលស្គាល់ និងមានភ័ស្តុតាងបង្ហាញ

---

មឿន ដែលជាប្រធានគ្រប់គ្រងនាវាទាំងអស់នៅផែរអូរឈើទាលនេះ។ [...] ឆ4: មឿន បាននិយាយថា មានទូកក្ដោងមួយត្រូវបានចាប់យកពីសមុទ្រមក ហើយបញ្ជូនទៅផែរអូរឈើទាល។ ខ្ញុំមិនច្បាស់ថាតើទូកក្ដោងនេះមកពីទីណា"]។ ឯកសារ D54/24.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN 00978577, KH 00955508 ["ជួបប្រទះតែជនជាតិអាមេរិកាំងម្នាក់ដែរ [...] ស្លៀកពាក់ធម្មតាហ្នឹង [...] ជួនកាល ពាក់អាវយឺតវាលក្លៀក [...] សក់វាពណ៌ក្រហម [...] សួរវាទៅអាយុប្រហែលជា២៥អីហ្នឹង អត់មានអីលើសពីហ្នឹងទេ [...] ជិះកាណូតវាមក តែកាណូតវាដូចផ្ទះថ្មចឹង ដងក្ដោងវាមានកំពស់ប្រហែលជាចុងត្នោត [...] កាលហ្នឹង ចាប់មកពីកោះពោល្វៃ [...] ដើមឆ្នាំ១៩៧៦"]។ ឯកសារ D4.1.378 គង់ ផៃ កំណត់ហេតុស្ដាប់ចម្លើយ EN 00163633-34 ["បន្ទាប់មក ខ្ញុំយកបាយទៅឱ្យអ្នកទោសម្នាក់ក្នុងចំណោមបីនាក់នោះ ឃើញ ឌុច កំពុងសួរចម្លើយម្នាក់នោះ ប្រុស សក់ក្រហម រួញវែងដាបស្មា សំបុរស មានរោមទ្រូង ស្លៀកខោខ្លី មុន ឌុច សួរ ម្នាក់នេះ ពាក់អាវប៉ារ៉ាយឺតដៃខ្លី"]។ ឯកសារ D114/301.1 រូបថត David Lloyd Scott ជនជាតិអូស្ត្រាលី EN P 00005293។ ឯកសារ D11/2.3 ចម្លើយសារភាពមន្ទីរស-21 របស់ John Dawson Dewhirst ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៧៨ EN 00681102។ ឯកសារ D114/301.2 រូបថតជនបរទេសបស្ចិមប្រទេស មិនស្គាល់ឈ្មោះ EN P 00005294។ ឯកសារ D114/301.3 រូបថត Ronald Keith Dean, EN P 00525273។

1402 ឯកសារ D1.3.28.140 បញ្ជីឈ្មោះអ្នកទោស មន្ទីរស-21 EN 01236389, KH 00088752, FR 01187845 [បញ្ជាក់ថា លរ.១ គ្រីស្តូហ្វែរ អេដវ៉ឺ ឌីឡុង់ និង ល.រ ២. មីស៊ែល ស្កុតឌៀត គីម៉ូ] ។ ឯកសារ D37 Robert Hamill កំណត់ហេតុស្ដាប់ចម្លើយ EN 00791866-67, KH 00945764 ["ខ្ញុំបានជួប មាស មុត នៅផ្ទះគាត់ក្នុងឆ្នាំ២០១០។ [...] ខ្ញុំបានសួរគាត់ថាតើមានរឿងអ្វីកើតឡើងចំពោះជនបរទេស ដែលត្រូវបានចាប់ខ្លួននៅតាមឆ្នេរសមុទ្រ។ គាត់ឆ្លើយថា ពួកគេមិនត្រូវបានវាយដំទេ ហើយគួរត្រូវបានបញ្ជូនទៅស-២១"]។ ឯកសារ D11/2 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ រ៉ូប ហាមីល (Robert Hamill), EN 00681116, KH 00710120 [បញ្ជាក់ថា ប្រសិនបើ Stuart Glass ត្រូវគេបាញ់ស្លាប់នៅជិតកោះតាង ដូច្នេះ Kerry George Hamill ដែលជាម្ចាស់ទូក និងសហកម្មសិទ្ធិម្នាក់ទៀត និងឈ្មោះ John Dewhirst ដែលជាអ្នកដំណើរបង់ប្រាក់ គឺត្រូវបានចាប់ខ្លួន និងបញ្ជូនមកមន្ទីរ ស-21 ជាក់ជាមិនខាន]។ ឯកសារ D11/4.2.1 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ Timothy Scott Deeds, EN 00741656។

1403 ឯកសារ D54/16/1R បទសម្ភាសន៍ថតសំឡេងរបស់ David Kattenburg ជាមួយ មាស មុត ធ្វើនៅខែមេសា ឆ្នាំ ២០០៩ ម៉ោង [33.32-34:46] ["ខ្ញុំមិនបាននៅកំពង់សោមទេ ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៨ ខ្ញុំបានចេញពីកំពង់សោមបាត់ហើយ [...] គេចាត់តាំងឱ្យខ្ញុំធ្វើការនៅខេត្តក្រចេះ ជិតព្រំដែនឡាវ"]។

ថា គាត់នៅជាមេបញ្ជាការកងពល ១៦៤ ក្នុងរយៈពេលនៅសេសសល់ក្នុងឆ្នាំ ១៩៧៨ នៅឡើយទេ[1404]។ ទោះបីគាត់មានតួនាទីជានាយរងសេនាធិការ និងមានទំនួលខុសត្រូវលើតំបន់ ៥០៥ (តំបន់ក្រចេះ) ពីពាក់កណ្ដាលដល់ចុងឆ្នាំ ១៩៧៨ ក៏ដោយ[1405] **មាស មុត** នៅតែបន្តទទួលរបាយការណ៍ពីកងពល ១៦៤ និងធ្វើសេចក្ដីសម្រេចពាក់ព័ន្ធនឹងកិច្ចការកងពលបន្តទៀត[1406]។ ពេលគេសួរគាត់ថាមានអ្វីកើតឡើងចំពោះពួកបស្ចិមប្រទេស ដែលត្រូវបានចាប់ខ្លួននៅសមុទ្រ នៅខែសីហា ឆ្នាំ ១៩៧៨ **មាស មុត** បានផ្ដល់ចម្លើយលម្អិតបញ្ជាក់ថា គាត់បានដឹងអំពីអ្វីដែលកើតឡើងចំពោះពួកគេ។ គាត់និយាយថា ពួកបស្ចិមប្រទេសត្រូវបានរក្សាទុកនៅលើកោះឫស្សី "ពីរយប់ មុននឹងអ្នកពីភ្នំពេញទៅយកពួកគេ"[1407] និងថា ការឃុំខ្លួនរយៈពេលខ្លីនេះមកពី ប៉ុល ពត, ខៀវ សំផន និង អៀង សារី ខ្លាចថារដ្ឋបរទេសបានដឹងពីរឿងចាប់ខ្លួនពួកគេ[1408]។ យោងតាម **មាស មុត** ពួក

---

[1404] សូមមើល ជំពូក III. ការទទួលខុសត្រូវ និងតួនាទីរបស់ មាស មុត

[1405] សូមមើល ជំពូក III. ការទទួលខុសត្រូវ និងតួនាទីរបស់ មាស មុត។ សូមមើលផងដែរ ឯកសារ D59/1/1.9a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ KH 00926478 ["[តាមុត] រហូតមក ចុង៧៨ គាត់គេដកមកគាត់។ ក្រោយមក គាត់ឡើងនាយអគ្គសេនាធិការរង។ គាត់នៅជំនួស [...] បានប៉ុន្មានខែ ដល់ពេល៧៩ គាត់ត្រឡប់ទៅរកអង្គភាពយើងវិញ"]។

[1406] ឯកសារ D54/16/1R បទសម្ភាសន៍ថតសំឡេងរបស់ David Kattenburg ជាមួយ មាស មុត ធ្វើនៅខែមេសា ឆ្នាំ ២០០៩ ម៉ោង 34:57-35-26 ["ស: ដូច្នេះ គាត់បានចេញពីកងពល១៦៤បាត់ហើយ ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៨? ឆ: ទេ ខ្ញុំនៅតែកាន់តំណែងខ្ញុំដដែល គ្រាន់តែគេបានចាត់តាំងឲ្យបំពេញបេសកកម្មមួយទៀត"]។ ឯកសារ D54/100 កំណត់ហេតុស្ដាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.96 [និយាយដល់ចុងឆ្នាំ១៩៧៨៖ "មាស មុត គាត់ទៅខាងអគ្គសេនាធិការ ដូច្នេះការងារទាំងអស់គាត់បញ្ជា[កងពល១៦៤] ពីខាងលើមកតាមរយៈ ទឹម សេង ហើយ ទឹម សេង ដើរមើលការងារ និងបញ្ជាការងារបន្ត"]។ ។ ឯកសារ D59/1/1.9a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ KH 00926478 ["[តា មុត] រហូតមក ចុង៧៨ គាត់គេដកមកគាត់។ ក្រោយមក គាត់ឡើងនាយអគ្គសេនាធិការរង។ គាត់នៅជំនួស [...] បានប៉ុន្មានខែ ដល់ពេល៧៩ គាត់ត្រឡប់ទៅរកអង្គភាពយើងវិញ។ [...] អនុកងពល [...] ទឹម សេង [ឡើងជំនួស មាស មុត] [...] គាត់ទទួលការងារពី តា មុត ផ្នែកយោធាណា។ ស: បាទ ប៉ុន្តែផ្សេងៗនៃការងារអីនៅតាទាក់ទងមក តាមុត ដដែល? ប៊ុនហាក់៖ បាទ អ្នកទទួលបញ្ជាពីលើមករបាយការណ៍"]។

[1407] ឯកសារ D54/16/1R បទសម្ភាសន៍ថតសំឡេងរបស់ David Kattenburg ជាមួយ មាស មុត ធ្វើនៅខែមេសា ឆ្នាំ ២០០៩ ម៉ោង 43:52-44:28 ["យើងរក្សាទុកនៅកោះឫស្សី កំពង់ស្វាយ [...] ប៉ុន្តែ ពួកបស្ចិមប្រទេស គេមិនទុកយូរដូចពួកមកពីប្រទេសជិតខាងនោះទេ យ៉ាងហោចណាស់ យើងរក្សាទុកពួកគេពីរយប់ មុននឹងអ្នកភ្នំពេញមកទទួលពួកគេ"]។

[1408] ឯកសារ D54/16/1R បទសម្ភាសន៍ថតសំឡេងរបស់ David Kattenburg ជាមួយ មាស មុត ធ្វើនៅខែមេសា ឆ្នាំ ២០០៩ ម៉ោង 44:30-46:09 ["នេះគ្រាន់តែជាយោបល់ ទស្សនៈផ្ទាល់ខ្លួនរបស់ខ្ញុំទេ។ មេដឹកនាំខ្មែរក្រហម មេដឹកនាំ

គេត្រូវបានឃុំឃាំង "នៅក្នុងរោងតូចៗ" គ្មានជញ្ជាំង "ប្រក់ស្បូវ" ពួកគេចម្អិនអាហារដោយខ្លួនឯង និង "គេងក្នុងអង្រឹងធ្វើពីសំណាញ់បង់ត្រី"[1409]។ **មាស មុត** និយាយថា ពួកគេមិនត្រូវបានកម្មាភិបាលកងពល ១៦៤ ធ្វើបាប ឬសួរចម្លើយទេ "ពីព្រោះគ្មាននរណាម្នាក់ចេះអង់គ្លេស" និងថាពួកគេមានសិទ្ធិដើរជុំវិញលើកោះ[1410]។ ពីរយប់ក្រោយមក ពួកគេត្រូវបានបញ្ជូនទៅអូរឈើទាល ដែលមន្ត្រីក្រសួងការបរទេសដែលចេះភាសាអង់គ្លេសជិះឡាន ឬឡានធំមកទទួល និងនាំពួកគេទៅភ្នំពេញ[1411]។ ដោយប៉ុនប៉ងឱ្យរួចផុតពីពិរុទ្ធ **មាស មុត** អះអាងថា មេបញ្ជាការទទួលខុសត្រូវលើការចាប់ទូកពួកបស្ចិមប្រទេសពីកោះតាងនៅឆ្នាំ ១៩៧៨ ទំនងជា ឌឹម[1412]។ ក៏ប៉ុន្តែ នេះជាការកុហកយ៉ាងច្បាស់ក្រឡែតដើម្បីលាក់បាំងពីទំនួលខុសត្រូវរបស់គាត់ផ្ទាល់ ពីព្រោះ ហ៊ីង ឌឿន ហៅ ឌឹម មេបញ្ជាការរងកងពល ១៦៤ ត្រូវបានបោសសម្អាត និងបញ្ជូនចូលទៅ ស-២១ នៅថ្ងៃទី ២១

---

ខ្មែរក្រហមកំពូលៗ ដូចជា ប៉ុល ពត, ខៀវ សំផន និងអៀង សារី បានទៅរៀនសូត្រពីលោកខាងលិច នៅប្រទេសបារាំង។ ហេតុដូច្នេះហើយ បានជាពួកគេដោះស្រាយជាមួយពួកបស្ចិមប្រទេសទាំងនោះលឿនបែបហ្នឹង គឺលឿនជាងអ្នកផ្សេងទៀត ព្រោះថាពួកគេខ្លាច គឺ ប៉ុល ពត និង ខៀវ សំផន គេខ្លាចមនុស្ស ដែលពួកគេស្គាល់។ ហេតុដូច្នេះហើយ បានជាពួកគេខ្វល់ជាងពួកវៀតណាម និងថៃ"]។

1409 D54/16/1R បទសម្ភាសន៍ថតសំឡេងរបស់ David Kattenburg ជាមួយ មាស មុត ធ្វើនៅខែមេសា ឆ្នាំ២០០៩ ម៉ោង 46:10-49:27 ["វាគឺជារោងតូចមួយ។ ប៉ុន្តែ ពួកខ្មែរក្រហមឱ្យចុងភៅ និងម្ហូបទៅពួកគេ ដើម្បីពួកគេអាចផ្គត់ផ្គង់ និងចិញ្ចឹមខ្លួនឯងបាន។ ពួកខ្មែរក្រហមមិនធ្វើម្ហូបឱ្យពួកគេនោះទេ។ ពួកខ្មែរក្រហមផ្ញើចុងភៅ និងអង្ករទៅឱ្យពួកគេ ដើម្បីពួកគេអាចចិញ្ចឹមខ្លួនឯងបាន ក្នុងពេលនោះ ក្នុងពេលជាប់ឃុំ [...] វាដូចរោងនេះដែរ គឺគ្មានប្រហោងធ្លុង គ្មានជញ្ជាំងអ្វីទេ។ ប៉ុន្តែ មានដំបូលស្បូវ តែអត់ជញ្ជាំងទេ។ គ្រែអី ក៏អត់មានដែរ ហើយពួកគេត្រូវដេកលើអង្រឹង ដែលធ្វើពីមុងអូសត្រី"]។

1410 ឯកសារ D54/16/1R បទសម្ភាសន៍ថតសំឡេងរបស់ David Kattenburg ជាមួយ មាស មុត ធ្វើនៅខែមេសា ឆ្នាំ ២០០៩ ម៉ោង 48:28-49:17 ["អត់មានធ្វើបាបអ្វីទេ ហើយសួរចម្លើយក៏អត់មានដែរ ព្រោះអត់មានអ្នកចេះភាសាអង់គ្លេសផង។ ពួកគេដើរហើរសេរី ទៅនេះទៅនោះ ទៅបេះផ្លែដូងអីជាដើម"]។

1411 ឯកសារ D54/16/1R បទសម្ភាសន៍ថតសំឡេងរបស់ David Kattenburg ជាមួយ មាស មុត ធ្វើនៅខែមេសា ឆ្នាំ ២០០៩ ម៉ោង 49:18-50:33 ["ចំពោះជនបរទេស ដែលត្រូវបានចាប់ទាំងនោះ ពួកគេត្រូវដោះស្រាយ តាមរយៈក្រសួងការបរទេស [...] ជាមួយនឹងពួកបស្ចិមប្រទេស គេបញ្ជូនមន្ត្រីខ្មែរក្រហមដែលចេះនិយាយអង់គ្លេស ឬបារាំង មកទទួល [...] ពីភ្នំពេញមក ក្រសួងការបរទេស [...] ឡានចង់ពួកគេនៅឆ្នេរអូរឈើទាល។ ពេលមកដល់ច្រាំង ឡើងឡាន ហើយទៅភ្នំពេញតែម្តង"]។

1412 ឯកសារ D54/16/1R បទសម្ភាសន៍ថតសំឡេងរបស់ David Kattenburg ជាមួយ មាស មុត ធ្វើនៅខែមេសា ឆ្នាំ ២០០៩ ម៉ោង 56:20-57:27 [ពន្យល់ថា ឌឹម មេបញ្ជាការយោធា អាចជាមេបញ្ជាការក្នុងប្រតិបត្តិការនោះ]។

ខែ មេសា ឆ្នាំ ១៩៧៧ ដូច្នេះ ឌឹម មិនអាចជាប់ពាក់ព័ន្ធជាមួយនឹងរឿងនេះឡើយ។ ក្រោយមក ឌឹម ត្រូវបានសម្លាប់នៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៧៧[1413]។

## ការចាប់ខ្លួន និងការបញ្ជូន

392. អ្នកដែលត្រូវគេចាប់បាននៅលើសមុទ្រ ដោយមិនត្រូវបានសម្លាប់ភ្លាមៗ ត្រូវបានឃាត់ខ្លួនដោយកងនាវា ឬទាហានកងវរសេនាតូចឈរជើងនៅលើកោះរបស់កម្ពុជាប្រជាធិបតេយ្យ[1414]។ ភ័ស្តុតាងបង្ហាញថា មានបញ្ជាឲ្យចាប់ និងឃាត់ខ្លួនអ្នកដែលត្រូវស្កាត់ចាប់បាន និងរឹបអូសយកទូក[1415] (រួម

1413 ឯកសារ D234/2.1.55 ចម្លើយសារភាពនៅមន្ទីរ ស-21 របស់ ហង់ ឌឿន ហៅ ឌឹម ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៧ EN 00224086; ។ ឯកសារ D1.3.18.1 ចម្លើយសារភាពនៅមន្ទីរស -21 របស់ ហង់ ឌឿន ហៅ ឌឹម (ឌឹម) ចុះថ្ងៃទី ១៥ ខែឧសភា ឆ្នាំ១៩៧៧ EN 00187721។ ឯកសារ D1.3.18.2 ចម្លើយសារភាពនៅមន្ទីរស -21 របស់ ហង់ ឌឿន ហៅ ឌឹម (ឌឹម) ចុះថ្ងៃទី១ ខែសីហា ឆ្នាំ១៩៧៧។ ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរស-21 របស់ ក.ស.ច.ស [បញ្ជាក់ថា លរ. 1624 គឺឈ្មោះ ហង់ ឌឿន (ហង់ ឌឿរ) ហៅ ឌឹម ដែលបានចូលមន្ទីរស-21 នៅថ្ងៃទី ២១ ខែមេសា ឆ្នាំ១៩៧៧]។ ឯកសារ D1.3.28.49 បញ្ជីឈ្មោះអ្នកទោសមន្ទីរស-21, EN 00937118, KH 00082795 [បញ្ជាក់ថា លរ. 18 គឺឈ្មោះ ហ៊ីង ឌឿ ឌឹម អនុលេខាកងពល១៦៤]។ ឯកសារ D1.3.28.27 បញ្ជីឈ្មោះអ្នកទោសមន្ទីរស-21, EN 01215100, KH 00088754 [បញ្ជាក់ថា លរ. 2 គឺឈ្មោះ ហ៊ីង ឌឿ ហៅ ឌឹម]។ ឯកសារ D4.1.950 បញ្ជីឈ្មោះអ្នកទោសមន្ទីរស-21 របស់ ក.ស.ព [បញ្ជាក់ថា លរ. 2561 គឺឈ្មោះ ហ៊ីង ឌឿន ហៅ ឌឹម ដែលត្រូវបានសម្លាប់នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៧]។

1414 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 13.48.29-13.51.26 ["ហើយនាវិករបស់ខ្ញុំនេះគឺថា មិនងាយបានចេញទេ ទាល់តែបញ្ជាពីថ្នាក់លើអាហ្នឹងបានៗចេញ [...] ឲ្យយកទៅលើគោក តែបើតិច ត្រឹមម្នាក់ពីរនាក់តែប៉ុណ្ណោះ គឺថាមិនបានទេ។ បើថាការអនុញ្ញាតថា មិនបាច់យកមកទេ គេមានការបាញ់សម្លាប់នៅលើផ្ទៃសមុទ្រហើយ ហើយយកតែកាណូតដើម្បីមកប្រើប្រាស់ក្នុងអង្គភាពរបស់គេ"]។

1415 ឯកសារ D234/2.1.93 ព្រំ សាវ៉ាត ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ម៉ោង 11.02.28-11.04.02 ["នាវាល្បាតនៅតាមកោះ ហើយមានភារកិច្ចចាប់ទូក ដែលចូលមកអធិបតេយ្យដែនទឹក [...] ខាងនាវាពីរហ្នឹងអ្នកដើរចាប់នៅតាមកោះចំណុចមួយៗ"]។ ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៦ ម៉ោង 10.07.27-10.09.17 ["ហើយក្នុងការចាប់នោះ ខ្ញុំដឹងថា ចាប់មិនមែនត្រូវច្បាប់ទេ កាលទើបតែចប់សង្គ្រាមភ្លាម មិនទាន់មានច្បាប់អីចែងមក អត់ទាន់មានច្បាប់អីទេ គឺថាឲ្យមាន ឲ្យតែកប៉ាល់នៅលើផ្ទៃទឹកនៅសមុទ្រ ជិតកោះកម្ពុជា គឺចាប់ទាំងអស់។ អីចឹង បញ្ជាពីខាងលើមកអីចឹង គឺថាខាងក្រោមក៏អនុវត្តតាម បើមិនអនុវត្តទៅតាម ខុសគោលការណ៍នយោបាយរបស់គេ"] ម៉ោង 11.29.04-11.31.20 ["យើងខ្ញុំជាអ្នកកងការពារនៅផ្ទៃសមុទ្រព្រំដែនកោះ បាទ ទាំងកោះតាង កោះពូឡូវ៉ៃចាស់ ទាំងកោះពូឡូវ៉ៃថ្មី។ ដោយបញ្ជា គឺដាច់ខាតត្រូវតែចាប់ ឲ្យតែចូលទឹកដីកម្ពុជា"]។ ឯកសារ D234/2.1.95 មាស វឿន ប្រតិចារឹក ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 14.06.06-14.08.07 ["តែដល់ពេលកាណូ

ទាំងអ្នកដែលមិនទាន់ចូលក្នុងដែនទឹកកម្ពុជា[1416])។ ក្រោយពីចាប់បាន អ្នកទាំងនេះត្រូវបានសម្លាប់ចោលនៅលើសមុទ្រ ឬបញ្ជូនទៅកាន់កោះណាមួយរបស់កម្ពុជាប្រជាធិបតេយ្យ ហើយនៅទីនោះពួកគេត្រូវបានឃុំជាបណ្ដោះអាសន្ន មុននឹងសម្លាប់ចោល ឬបញ្ជូនទៅកំពង់សោម[1417]។

---

តថៃ ឬក៏កាណូតយួនមកពីណាមក ក៏យើងសហការគ្នាមានវិធានការចាប់ដែរ"]។ ឯកសារ D234/2.1.92 ព្រំ សារ៉ាត ប្រតិចារឹក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ ម៉ោង 10.55.25-10.58.17 ["គេជាជនជាតិវៀតណាមឆ្លងកាត់តំបន់ដែនទឹកនៅកោះអាគ្នេយ៍ខាងកើតកោះតាង ហើយពួកគេបានចាប់គេ"] ម៉ោង 15.49.55-15.53.04 ["ចាប់បានកងទ័ពវៀតណាម ឬក៏ទូកវៀតណាមដែលចូលមកដល់ទឹកដីកម្ពុជា"]។ ឯកសារ D234/2.1.93 ព្រំ សារ៉ាត ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ម៉ោង 11.02.28-11.04.02 ["នាវាល្បាតនៅតាមកោះ ហើយមានភារកិច្ចចាប់ទូកដែលចូលមកអធិបតេយ្យដែនទឹក"]។ ឯកសារ D234/2.1.95 មាស វឿន ប្រតិចារឹក ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 14.06.06-14.08.07 ["តែដល់ពេលកាណូតថៃ ឬក៏កាណូតយួនមកពីណាមក ក៏យើងសហការគ្នាមានវិធានការចាប់ដែរ"]។

1416 ឯកសារ D234/2.1.92 ព្រំ សារ៉ាត ប្រតិចារឹក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ ម៉ោង 15.49.55-15.53.04 ["មានថ្ងៃមួយនោះ ខ្ញុំជួបជនជាតិយួនម្នាក់ និងជនជាតិក្លឹងម្នាក់។ [...] អ្វីដែលខ្ញុំបញ្ជាក់ពេលនេះគ្រាន់តែថា អ្នកដែលចាប់ហ្នឹងទៅចាប់ពីណាមក ចាប់ពីដែនទឹកវៀតណាម ឬចាប់នៅដែនទឹកកម្ពុជា"]។ ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៦ ម៉ោង 09.32.54-09.34320 ["ចាប់ម៉ាយ៉ាហ្គេសនោះ ចាប់មកពីផ្លូវអន្តរជាតិតែម្ដង"] ម៉ោង 14.45.02-14.46.20 ["គ្មានដឹងច្បាប់ ដឹងទម្លាប់ដែលផ្លូវអន្តរជាតិ មិនអន្តរជាតិទេ"].

1417 ឯកសារ D234/2.1.95 មាស វឿន ប្រតិចារឹក ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 14.10.55-14.14.10 ["បើកាណូតវៀតណាម [...] ចាប់ហើយយើង ចាប់បានហើយយើងបញ្ជូនទៅតាមៗថ្នាក់ តាមអង្គភាពដែលទទួលខុសត្រូវអីចឹងទៅ។ គឺចាប់បានតែកាណូតមួយគ្រឿងអីចឹងទៅ យើងបញ្ជូនទៅតាមខាងកំពង់សោម ខាងកងពល៦៤ (ស៊ុក) អីចឹងទៅ ព្រោះអីគេនៅប្រចាំការជាមួយយើងដែរ។ ហើយបើយើងបញ្ជូនទៅខាងកងពល៦៤ (ស៊ុក) ទៅ អាហ្នឹងគឺថាគេយកទៅខាងកំពង់សោមអីចឹងទៅ"]។ ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៦ ម៉ោង 13.44.05-13.46.19 ["បញ្ជូនទៅតាមផែអូរឈើទាល ដើម្បីឡានមកដឹក យកមកក្រុងកំពង់សោមបាទខ្លះទៀត ក៏យកទៅខាងអូរគ្រេះ យកទៅខាងចម្ការដូង"]។ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 10.37.31-10.39.57 ["ឃើញថាមកដល់ផែនោះ ឃើញថា ភាគច្រើនឡានគេដឹកបញ្ជូនចេញយកទៅក្រុងកំពង់សោមតែម្ដង"]។ ឯកសារ D234/2.1.96 មាស វឿន ប្រតិចារឹក ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 11.07.13-11.08.54 ["ការដែលៗខ្ញុំបញ្ជូនទៅកន្លែងនែ កន្លែងកងអគ្គសេនាធិការគេនៅកំពង់សោមហ្នឹង អាហ្នឹងខ្ញុំទៅជូនហើយ គេដោះស្រាយយ៉ាងណា អានោះខ្ញុំអត់បានដឹងទេ រឿងផ្សេងរបស់គេខាងនោះ"]។ ឯកសារ D98/3.1.178 មាស វឿន ប្រតិចារឹក ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 10.06.41-10.11.41 ["អត់មានបញ្ហាពីណាទេ ខ្ញុំឃើញថាបើដើរជួបគាត់ទៅ ក៏យកមកគាត់ ហើយក៏រាយការណ៍មកកងពលមក កងពលគាត់ថា ឲ្យបញ្ជូនគាត់មកខាងក្រោយមក"] ម៉ោង 10.20.29-10.23.23 ["គេបញ្ជា កងពលគេបញ្ជាមក។ [...] បើចាប់បានទូកហើយ គេឲ្យខ្ញុំយកមកទុក ហើយបើមានមនុស្សនៅលើទូក គេឲ្យខ្ញុំបញ្ជូនមកកំពង់សោម"] ម៉ោង 10.26.02-10.28.18 ["ការដែលយើង

393. ប្រជាជនវៀតណាម ដែលចាប់បាននៅលើសមុទ្រ ត្រូវគេធ្វើបាបយ៉ាងខ្លាំង ក្នុងអំឡុងពេលបញ្ជូនទៅកោះ ឬដីគោក[1418]។ ប៉ាក សុខ នៅចាំបានថា ចំពោះការបញ្ជូនទៅដីគោក ជនជាតិវៀតណាម ដែលចាប់បាន ត្រូវគេឃុំក្នុងបន្ទប់កាណូតរបស់កងនាវា ដើម្បីបង្ការកុំឲ្យពួកគេតដៃ។ ដោយសារតែបន្ទប់បិទជិតនោះក្ដៅពេក អ្នកខ្លះថប់ដង្ហើមប្រកាច់ស្ទើរស្លាប់[1419]។ នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ **មាស មុត** បានរាយការណ៍ថា កាណូតវៀតណាមពីរគ្រឿង ដែលមានជនជាតិវៀតណាម ៧៦ នាក់ ក្មេងចាស់ ប្រុសស្រី ត្រូវចាប់បាននៅកោះតាង។ អ្នកទាំងនោះត្រូវបានចង ហើយពីរនាក់លោតចូលក្នុងទឹក (ប្រហែលជាស្លាប់)។ អ្នកដែលគេចាប់បានត្រូវបញ្ជូនទៅដីគោក[1420]។ វៀតណាម

---

ចាប់មកពីទូកមកតាមឆ្នេរចូលដែនសមុទ្រយើង យើងត្រូវតែមានការចាប់ដើម្បីសួរសាកដែរ។ [...] នៅពេលដែលចាប់បានទាំងទូកហ្នុង ខ្ញុំរាយការណ៍ទៅលេខាកងពល។ ខ្ញុំស្ដាប់មិនសូវបានទេ ហើយក៏បញ្ជូនមកខាងកំពង់សោមវិញមក"]។

1418 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 10.11.47-10.36.43 ["អ្នកទាំងនោះ [ជនជាតិវៀតណាមទាំងនោះ] ដែលគេចាប់បាន ខ្ញុំបានឃើញផ្ទាល់នឹងភ្នែករបស់ខ្ញុំនៅផែអូរឈើទាល ដែលគេចាប់បញ្ជូនមកទេបាទ"]។ ឯកសារ D234/2.1.96 មាស វឿន ប្រតិចារឹក ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 11.16.47-11.20.10 ["គាត់ថា បើចាប់ជនជាតិវៀតណាម ឬក៏ជនជាតិណាក៏ដោយ គឺត្រូវបញ្ជូនឲ្យ រាយការណ៍ឲ្យគាត់ដឹង គាត់នឹងមានវិធានការឲ្យបញ្ជូនទៅតាមថ្នាក់"]។ ឯកសារ D98/3.1.178 មាស វឿន ប្រតិចារឹក ចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 10.23.23-10.26.02 ["យូរៗឃើញម្ដងដែរ ជួនកាល១ខែ ២ខែ អីឃើញមកម្ដង ក៏ប៉ុន្តែជួនកាលចាប់បានអីចឹងទៅ ជួនកាលគេទៅហួសទៅ។ [...] ប្រជាជនវៀតណាម មានស្រី មានកូន មានប្រុស។ [...] បញ្ជូនតាមរយៈមកកំពង់សោមដែរ"]។

1419 ឯកសារ D54/23 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.36-38 ["ខ្ញុំធ្លាប់ដឹកអ្នកដែលចាប់បានម្ដងតាមកប៉ាល់របស់ខ្ញុំយកមកកន្លែងផែអូរឈើទាល។ ពេលនោះ អ្នកដែលខ្ញុំដឹកនោះ មាន១២ ទៅ១៣នាក់។ ខ្ញុំនៅចាំថា ក្នុងចំណោមនោះមានបុរសម្នាក់ដាច់ដៃម្ខាង។ ខ្ញុំនៅចាំថា នៅពេលដែលដឹកអ្នកដែលចាប់បាននោះពីសមុទ្រមកគោក គឺដាក់ក្នុងឃ្លុបកាណូត។ ហើយកាណូតរបស់ខ្ញុំមានឃ្លុបបីបួន។ យើងមិនឲ្យគេអង្គុយនៅខាងលើទេ ពីព្រោះយើងការពារកុំឲ្យគេវ៉ៃតដៃនឹងយើង។ ពួកប្រុសៗត្រូវបានចង តែពួកស្រីៗ និងកូនក្មេងមិនបានចងទេ។ ពេលនោះ នៅក្នុងឃ្លុបគឺក្ដៅណាស់ ខ្ញុំឃើញពួកទាំងនោះញ័រទទ្រើក។ ខ្ញុំដឹងថា បើសិនជាយើងគ្របឃ្លុបមួយសន្ទុះ អ្នកទាំងនោះ នឹងស្លាប់អស់មិនខាន។ ស: ហេតុអ្វីបានជាពួកយួនអ្នកទាំងនោះត្រូវបានចាប់ខ្លួន? ឆ.37: ពួកយួនទាំងនោះ គឺជាអ្នកភៀសខ្លួន ធ្វើដំណើរទៅកាន់ប្រទេសថៃ ហើយគេបានធ្វើដំណើរឆ្លងកាត់តាមដែនទឹករបស់យើង នៅចន្លោះកោះតាង និងកោះពូលៃ។ ស: ពេលដែលចាប់នោះ តើពួកអ្នកទាំងអស់នោះមានកាំភ្លើង ឬក៏ចង់តដៃវិញដែរ ឬទេ? ឆ.38: ពួកទាំងនោះពុំមានកាំភ្លើង និងមិនមានបំណងចង់តដៃនោះទេ"]។

1420 ឯកសារ D1.3.34.64 ទូរស័ព្ទសម្ងាត់ពីមាស មុត ទៅ បង៨៩ (សុន សេន) ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ ["នៅកែបវេលាម៉ោង៨យប់ ថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨ យើងបាញ់កាណូតអាយួន លេខ១គ្រឿង ធុន២២សេស នៅខាងត្បូង

ខ្លះត្រូវបានវាយដំ នៅពេលទៅដល់ដីគោក នៅកំពង់សោម មុនពេលគេនាំយកទៅបាត់[1421]។ សាក្សី អ៊ឹង ឆុន ក៏នៅចាំបានថា អង្គភាពរបស់គាត់ចាប់បានប្រជាជនវៀតណាម ២៣ នាក់ រួមមានស្ត្រីចំណាស់ វៀតណាមម្នាក់ ស្ត្រីមេម៉ាយវៀតណាមម្នាក់ ក្មេងប្រុសវៀតណាម ៩ នាក់ ក្មេងស្រីវៀតណាម ៩ នាក់ និងប្ដី-ប្រពន្ធខ្មែរមួយគូ ព្រមទាំងកូនប្រុស អាយុ ៧ ឆ្នាំ[1422]។

394. ជារឿយៗ ការវាយប្រហារទៅលើទូកនេសាទថៃឈានទៅដល់ការចាប់មនុស្សនៅលើទូក[1423]។ នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ **មាស មុត** បានធ្វើកំណត់ហេតុអំពីឧប្បត្តិហេតុពីរនៃការចាប់ខ្លួន

---

កោះខ្ចង ចម្ងាយ១គ.ម។ ឯយើង មិនមាន ខូចខាតអីទេ។ [...] នៅកោះតាង វេលាម៉ោង២.៣០នាទី ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ កាណូត៨០០សេសរបស់យើង ចេញធ្វើការនៅខាងកើត ភាគខាងត្បូងកោះតាង ចម្ងាយ១២គ.ម ចាប់បាន កាណូតអាយួន២គ្រឿង នៅលើកាណូត២គ្រឿងនេះ ពេញដោយយួន៧៦នាក់ មានក្មេង ចាស់ ប្រុស ស្រី។ តែក្នុងពេល យើងចងរួចហើយ កូនកាណូតតូចឃ្លោង បណ្ដាលឲ្យធ្លាក់ទឹកបាត់២នាក់ រកពុំឃើញ។ បានឲ្យយកមកដល់ដីគោក ហើយ"]។

1421 ឯកសារ D54/25 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.22 ["ខ្ញុំបានឃើញព្រឹត្តិការណ៍មួយទៀត នៅពេលដែលខ្ញុំ ចាប់ និងដឹកជនភៀសខ្លួនវៀតណាមចំនួន១៣នាក់មកអូរឈើទាល[...]។ នៅក្នុងពេលដែលពួកភៀសខ្លួនវៀតណាម ត្រូវបាននាំចេញពីទូក ដើម្បីធ្វើដំណើរទៅឡើងឡានដែលរង់ចាំដឹក ពួកយោធាបានទាត់ ធាក់ និងវ៉ៃពួកនោះយ៉ាងខ្លាំង នៅពេលធ្វើដំណើរទៅកាន់ឡាន"]។ ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៦ ម៉ោង 13.53.50-13.54.59 ["ចាប់ថៃ ចាប់យួនក៏យកទៅហ្នឹងនៅផែរាម ឬផែអូរឈើទាល ហើយគេចាប់បានហើយ ធ្វើទារុណកម្មនៅលើផែក៏មាន"]។

1422 ឯកសារ D54/34 កំណត់ហេតុស្ដាប់ចម្លើយ អ៊ឹង ឆុន ឆ.19 ["សម្រាប់កប៉ាល់របស់ខ្ញុំ យើងមិនដែលចាប់បានមនុស្ស ទាំងរស់ទេ ទោះជាថៃ ឬវៀតណាមក៏ដោយ។ លើកលែងតែព្រឹត្តិការណ៍មួយ ពេលយើងចាប់បានជនជាតិវៀតណាម ២៣ទាំងរស់។ ពីយប់មិញ បន្ទាប់ពីខ្ញុំរំលឹករឿងចាប់នេះឡើងវិញ ខ្ញុំសុំធ្វើការកែតម្រូវលើចំនួនមនុស្សដែលត្រូវបាន ចាប់ ដែលបានចុះនៅក្នុងកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ចំនួន៣៣នោះ មិនមែនជាចំនួនមនុស្ស ដែលចាប់បានទេ គឺជាចំនួនកម្លាំងសេះម៉ាស៊ីនរបស់ទូកទេ មនុស្សដែលចាប់បានគឺមានចំនួន២៣នាក់ គឺរួមមាន យាយ ចាស់វៀតណាមមួយ និងស្ត្រីមេម៉ាយវៀតណាមមួយ ហើយមានកំលោះវៀតណាម៩នាក់ និងក្រមុំវៀតណាមចំនួន៩ នាក់។ ហើយមានខ្មែរប្ដីប្រពន្ធ និងកូនប្រុសអាយុពីរឆ្នាំម្នាក់ កំលោះក្រមុំវៀតណាមទាំងនេះជាគូដណ្ដឹងរបស់ពួកគេ បើតាមអ្នកបើកទូកនោះប្រាប់ខ្ញុំ។ អ្នកបើកកាណូតនេះមានស្រុកកំណើតនៅស្រុកកំពត ហើយទៅរស់នៅស្រុកយួន"]។

1423 ឯកសារ D54/24.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ KH 00955503-04 ["ស: ចាប់កាប៉ាល់ខាងណា? ឆ: ចាប់កាប៉ាល់ថៃ [...] យើងអត់ទេ គ្រាន់បញ្ជាវាមកដល់គោក ចង មកដល់ [...] ស: បញ្ជា មកដល់កន្លែងកោះនឹងបានចាប់ចង? ឆ: បាទ បានចាប់ចងហើយៗ យើងកាត់កប៉ាល់នេះ កប៉ាល់យើងបញ្ជូនមក។ ស: ចងនឹង ចងយ៉ាងម៉េច ចងស្ដាបសេក? ឆ: បាទ មកចងស្ដាបសេកប្រសាយគ្នាទៅ។ ស: ចងប្រសាយគ្នាទៅ? ឆ: បាទ"]។ ឯកសារ D2/17 កំណត់ហេតុស្ដាប់ចម្លើយ អ៊ិន សារឿន ហៅ អ៊ិន វ៉ែន ឆ.19-20 ["កាលនោះ អ្នកដែលត្រូវ

គេបានចងមានចំនួន៦នាក់ […] ៦នាក់នោះត្រូវបានគេចងបិទមុខ និងចងជារបៀបស្ពាបសេកដៃទាំងពីរទៅខាងក្រោយ"]។ ឯកសារ D1.3.13.8 បទសម្ភាសន៍របស់ការិយាល័យសហព្រះរាជអាជ្ញាជាមួយ ប៉ែន សារិន EN 002175661-62 ["ពួកគេត្រូវបានចង នៅពេលនាំចូលទៅក្នុងអគារ"]។ ឯកសារ D54/79 កំណត់ហេតុស្ដាប់ចម្លើយ ណុប ហាល់ ឆ.23 ["ដោយមនុស្សពេញវ័យ គេចងដៃមកក្រោយ"]។ ឯកសារ D54/8 កំណត់ហេតុស្ដាប់ចម្លើយ ឌុល សុង ឆ.41, 45 ["ខ្ញុំបានឃើញថៃដែលគេចាប់បាន យកមកដាក់នៅលើកោះមួយ។ […]ស: ម៉េចបានជាលោកដឹងថាជាពួកគេជាអ្នកនេសាទត្រី មិនមែនជាទាហានខ្មាំង? ឆ.45: ពីព្រោះទូកនោះជាទូកនេសាទ ហើយយោធារបស់យើងនៅលើកោះបាននិយាយថា ពួកទាំងនោះ (ពួកនេសាទថៃទាំងអស់នោះ)ជាពួកនេសាទ"]។ សូមមើលផងដែរ ឯកសារ D2/9 សយ ប៊ិន កំណត់ហេតុស្ដាប់ចម្លើយ ឆ.58 ["ស: ក្នុងករណីដែលពួកកងនាវាប្រដេញចាប់បានពួកនេសាទវៀតណាម ពួកនេសាទថៃ តើគេចាប់ពួកនោះយកទៅឃុំ ឬយកទៅណា ឬធ្វើយ៉ាងដូចម្ដេចខ្លះ? […] ស.58: […] ក្រុមចាប់មនុស្ស គឺគេមានទូកឈើ […] អង្គភាពនេះ គឺជាអង្គភាពសម្រាប់ចាប់អ្នកនេសាទ និងអ្នកដែលឆ្លងដែនខុសច្បាប់"]។ ឯកសារ D54/24.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN 00978573-74, KH 00955503 ["ចាប់បាន [ទូកនេសាទត្រី (សូមមើល កំណែនៅលើ EN 00978573)] ហើយសួរចម្លើយពួកគេ […] ធម្មតាមានប្រុសៗ។ […] [អ្នកនេសាទដែលត្រូវបានចាប់ខ្លួន] សុទ្ធតែថៃ យួន"]។ ឯកសារ D54/23 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.28 ["បាទ ត្រូវតែរាយការណ៍ឲ្យច្បាស់លាស់នូវអ្វីដែលយើងចាប់បាន។ ឧទាហរណ៍ថាតើគេជា […] ជាអ្នកនេសាទថៃ"]។ ឯកសារ D54/25 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.11-16 ["ស: តាមបទពិសោធន៍របស់លោក និងការយល់ដឹងរបស់លោក នៅក្នុងកងអង្គភាពរបស់លោក និងអង្គភាពដទៃទៀត នៃកងទ័ពជើងទឹក តើចំនួនប្រជាជនស៊ីវិល ចំនួនជនភៀសខ្លួន អ្នកនេសាទ ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឆ្លងមកចូលក្នុងដែនទឹកកម្ពុជា ហើយត្រូវបានចាប់បាន និងសម្លាប់ មានចំនួនប្រហែលប៉ុន្មាននាក់? ឆ.11: មានចំនួនរាប់ពាន់នាក់ អ្នកទាំងនោះ រួមមាន […] ពួកនេសាទវៀតណាម ដែលត្រូវចាប់បាន និងសម្លាប់ចោល នៅក្នុងសមុទ្រនៅលើកោះ និងនៅលើដីគោក […]។ ឆ.12: ព្រឹត្តិការណ៍មួយទៀត គឺចាប់បានទូកនេសាទថៃ ដែលមានកម្លាំងម៉ាស៊ីន ៤០០សេស ដែលមានអ្នកនេសាទថៃចំនួន២០នាក់នៅក្នុងទូកនោះ។ ព្រឹត្តិការណ៍មួយទៀត គឺចាប់បានទូកនេសាទថៃ ដែលមានកម្លាំងម៉ាស៊ីន១៨០០សេស ដែលមានអ្នកនេសាទ៣០នាក់នៅលើនោះ […] ឆ.13: ការចាប់បានទូកនេសាទថៃ កម្លាំងម៉ាស៊ីន៤០០សេស គឺក្នុងខែ៦ ឆ្នាំ១៩៧៦។ ការចាប់នោះ គឺធ្វើឡើង ចម្ងាយ១២គីឡូម៉ែត្រនៅខាងលិចកោះពូល្វៃចាស់។ ក្នុងពេលចាប់ទូននេសាទនោះ បានចូលជិតដែនទឹកអន្តរជាតិទៅហើយ។ អ្នកនេសាទថៃទាំងអស់នោះ ត្រូវដឹកបញ្ជូនទៅរាម។ ខ្ញុំបានជួបពួកនេសាទថៃទាំងនោះនៅលើកោះតាគាវ ប្រហែល៦-៧ខែក្រោយមក។ ឆ.14: ខ្ញុំបានឮពីអ្នកយាមនៅលើកោះថា អ្នកនេសាទថៃទាំងអស់នោះនឹងត្រូវបញ្ជូនទៅប្រទេសគេវិញ តែខ្ញុំមិនដឹងថារឿងទាំងអស់នោះពិតឬមិនពិតនោះទេ […] ឆ.15: ការចាប់បានទូកនេសាទថៃ កម្លាំងម៉ាស៊ីន១៨០០សេស គឺនៅចុងឆ្នាំ១៩៧៦។ ការចាប់នេះ គឺនៅប្រហែលជា៣០គីឡូម៉ែត្រភាគនិរតីនៃកោះពូល្វៃចាស់ […] ឆ.16: [ពួកនេសាទថៃទាំងអស់នោះ] ត្រូវបានបញ្ជូនទៅរាម ហើយក្រោយមកបញ្ជូនឲ្យទៅធ្វើការនៅលើកោះតាគាវ ជាមួយពួកមុនដែរ ព្រោះខ្ញុំបានជួបពួកគេនៅពេលដែលខ្ញុំទៅធ្វើការនៅទីនោះ"]។

ជនជាតិថៃ កាលពីមួយសប្តាហ៍មុន[1424]។ គាត់បានរាយការណ៍ថា ទូកនេសាទថៃមួយគ្រឿងត្រូវចាប់បាន នៅតំបន់កោះកុង និងកោះស្តេច កាលពីថ្ងៃទី ០២ ខែ កញ្ញា ដោយមនុស្ស ៩ នាក់ ត្រូវចាប់បាន ហើយ ៧ នាក់ទៀត បានលោតចូលក្នុងសមុទ្រ[1425]។ គាត់ក៏បានអះអាងផងដែរថា ជនជាតិថៃ ៥ នាក់ និងខ្មែរម្នាក់ ដែលចាប់បាននៅលើទូកតូចមួយគ្រឿង នៅថ្ងៃទី ០៥ ខែ កញ្ញា បានសារភាពថាពួកគេជាគិញ[1426]។ **មាស មុត** បន្តរាយការណ៍អំពីឧប្បត្តិហេតុបែបនេះរហូត ពេញមួយរបបនោះ។ ក្នុងការសន្ទនាសម្ងាត់តាមទូរស័ព្ទ នៅខែ មីនា ឆ្នាំ ១៩៧៨ គាត់បានជូនដំណឹង

---

1424 ឯកសារ D54/13.1 កំណត់ហេតុប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំសមមិត្ត១៦៤ នាថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦ EN 00974008, KH 00936737, FR 00970395 ["សភាពការណ៍ខ្មាំង៖ ថ្ងៃទី៥ ខែកញ្ញា មានកូនទូកម៉ាស៊ីនតូចមួយ ជិះមនុស្ស៦នាក់ សៀម៥ និងខ្មែរ១។ ព្រឹកឡើង ទូកនេះមកដល់កោះរង់សន្លឹម។ ថាគេឲ្យមកដាក់ឲ្យចុះទូកនៅខាងលិចកោះរង់សន្លឹម ដើម្បីស៊ើបការ តើនៅឈូងកោះនេះ មានអ្វីខ្លះ។ សភាពការណ៍នេះ កើតក្រោយពីយន្តហោះមកស៊ើបការណ៍លើនាវាយើង ដែលកំពុងហាត់កន្លែងនោះ។ ថ្ងៃទី៦ ខែកញ្ញា មាននាវានេសាទថៃ ១០គ្រឿង មកត្រង់កោះកុង មុំកោះស្តេច។ យើងចាប់បាន១គ្រឿង កំលាំង៤០០សេះ មានគ្នាវា៨នាក់ ថាលោតទឹកបាត់ ៧នាក់ទៀត"]។

1425 ឯកសារ D54/13.1 កំណត់ហេតុប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំសមមិត្ត១៦៤ នាថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦ EN 00974008, KH 00936737, FR 00970395 ["សភាពការណ៍ខ្មាំង៖ ថ្ងៃទី៥ ខែកញ្ញា មានកូនទូកម៉ាស៊ីនតូចមួយ ជិះមនុស្ស៦នាក់ សៀម៥ និងខ្មែរ១។ ព្រឹកឡើង ទូកនេះមកដល់កោះរង់សន្លឹម។ ថាគេឲ្យមកដាក់ឲ្យចុះទូកនៅខាងលិចកោះរង់សន្លឹម ដើម្បីស៊ើបការ តើនៅឈូងកោះនេះ មានអ្វីខ្លះ។ សភាពការណ៍នេះ កើតក្រោយពីយន្តហោះមកស៊ើបការណ៍លើនាវាយើង ដែលកំពុងហាត់កន្លែងនោះ។ ថ្ងៃទី៦ ខែកញ្ញា មាននាវានេសាទថៃ ១០គ្រឿង មកត្រង់កោះកុង មុំកោះស្តេច។ យើងចាប់បាន១គ្រឿង កំលាំង៤០០សេះ មានគ្នាវា៨នាក់ ថាលោតទឹកបាត់ ៧នាក់ទៀត"]។

1426 ឯកសារ D54/13.1 កំណត់ហេតុប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំសមមិត្ត១៦៤ នាថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦ EN 00974008, KH 00936737, FR 00970395 ["សភាពការណ៍ខ្មាំង៖ ថ្ងៃទី៥ ខែកញ្ញា មានកូនទូកម៉ាស៊ីនតូចមួយ ជិះមនុស្ស៦នាក់ សៀម៥ និងខ្មែរ១។ ព្រឹកឡើង ទូកនេះមកដល់កោះរង់សន្លឹម។ ថាគេឲ្យមកដាក់ឲ្យចុះទូកនៅខាងលិចកោះរង់សន្លឹម ដើម្បីស៊ើបការ តើនៅឈូងកោះនេះ មានអ្វីខ្លះ។ សភាពការណ៍នេះ កើតក្រោយពីយន្តហោះមកស៊ើបការណ៍លើនាវាយើង ដែលកំពុងហាត់កន្លែងនោះ។ ថ្ងៃទី៦ ខែកញ្ញា មាននាវានេសាទថៃ ១០គ្រឿង មកត្រង់កោះកុង មុំកោះស្តេច។ យើងចាប់បាន១គ្រឿង កំលាំង៤០០សេស មានគ្នាវា៨នាក់ ថាលោតទឹកបាត់៧នាក់ទៀត"]។

ដល់ សុន សេន ថា ទូកថៃមួយគ្រឿងត្រូវចាប់បាន ដោយមានមនុស្ស ២១ នាក់ នៅចម្ងាយបីគីឡូម៉ែត្រ ពីកោះចាស់[1427]។

395. សាក្សីបានរៀបរាប់លម្អិតអំពីការចាប់ ឃុំ និងបញ្ជូនអ្នកនេសាទថៃ។ ឧទាហរណ៍ ឌុល សុង ជាទាហាននៃកងវរសេនាធំ ១៤០ ធ្វើការនៅលើនាវាចម្បាំង បានឃើញការចាប់អ្នកនេសាទថៃ ៣០ នាក់ រួចនាំទៅកោះពូលូវ៉ៃ នៅឆ្នាំ ១៩៧៧[1428]។ ម៉ី រ៉េត បញ្ជាក់ថា គាត់បានឃើញអ្នកនេសាទថៃ ១០ នាក់ ត្រូវគេចាប់បញ្ជូនទៅកោះតាគាវ (កោះនៅជិតរាម) ក្នុងឆ្នាំ ១៩៧៦[1429]។ នូ សារឿន នៅកងកុមារ ពេលគាត់ឃើញអ្នកនេសាទថៃ ២៥ នាក់ ត្រូវគេនាំយកទៅចម្ការទុរេនទី ១ នៅឃុំរាម

---

[1427] ឯកសារ D1.3.34.64 សារទូរស័ព្ទសំងាត់ ពី មាស មុត ទៅ បង ៨៩ (សុន សេន) ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ EN 00233649, KH 00020982, FR 00623220 ["2. នៅកោះវ៉ៃ យប់ថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨ ម៉ោង៤ ព្រឹកឡើងថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ បងប្អូនឃើញកាណូតសៀម១គ្រឿង នៅខាងលិច ឈៀងខាងជើង កោះវ៉ៃចាស់ ចម្ងាយ ៣គ.ម យើងដេញចាប់វាបាននៅម៉ោង៥ភ្លឺ កាណូតផុន២៥០សេស មានមនុស្ស២១នាក់"]។

[1428] ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.41-49 ["ស: នៅក្នុងបទសម្ភាសន៍របស់លោកជាមួយអង្គការអាដហុក លោកបាននិយាយថា លោកឃើញគេសម្លាប់ជនជាតិថៃ៣០នាក់នៅលើទូក សូមលោករៀបរាប់ប្រាប់យើងអំពីព្រឹត្តិការណ៍នោះបានឬទេ? ឆ41: រឿងរ៉ាវនេះកើតឡើងក្នុងរយៈពេល ដែលខ្ញុំហាត់ហ្វឹកហ្វឺនទ័ពជើងទឹក។ ខ្ញុំបានឃើញថៃដែលគេចាប់បាន យកមកដាក់នៅលើកោះមួយ។ ស: តើវាកើតឡើងក្នុងឆ្នាំណា? ឆ.42: នៅឆ្នាំ១៩៧៧។ ស: តើនៅលើកោះណា? ឆ43: នៅកោះពូលូវ៉ៃ។ ស: តើជនជាតិថៃទាំងនោះជាពួកអ្វី សូមលោករៀបរាប់ប្រាប់យើង? ឆ.44: គឺជាពួកនេសាទថៃ សុទ្ធតែជាមនុស្សប្រុសពេញវ័យ។ ខ្ញុំឃើញទូកនេសាទមួយនៅទីនោះដែរ។ ស: ម៉េចបានជាលោកដឹងថាជាពួកគេជាអ្នកនេសាទត្រី មិនមែនជាទាហានខ្មាំង? ឆ.45: ពីព្រោះទូកនោះជាទូកនេសាទ ហើយយោធារបស់យើងនៅលើកោះបាននិយាយថា ពួកទាំងនោះជាពួកនេសាទ។ ស: តើស្ថានភាពរបស់អ្នកដែលគេចាប់នោះយ៉ាងម៉េច ពេលលោកបានឃើញ? ឆ.46: គេចងដៃ ហើយយោធានៅលើកោះបានប្រាប់ថា គេនឹងសម្លាប់ពួកនេសាទទាំងនោះ។ ស: តើយោធាដែលចាប់អ្នកនេសាទនោះឋិតនៅក្នុងកងណាមួយ? ឆ.47: ពួកគេជាកងថ្មើរជើងរបស់កងពល១៦៤ ដែលឈរជើងនៅតាមកោះ។ ខ្ញុំមិនដឹងថា គេនៅក្នុងកងវរៈសេនាធំលេខប៉ុន្មានទេ។ ស: តើលោកមានស្គាល់យោធាណាខ្លះ ដែលនៅក្នុងកងដែលបានចាប់អ្នកនេសាទនោះ ហើយនៅរស់ដល់សព្វថ្ងៃនេះដែរទេ? ឆ.48: ទេ ខ្ញុំមិនស្គាល់ទេ"]។

[1429] ឯកសារ D54/11 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ឆ.24 ["ក្នុងឆ្នាំ១៩៧៦ ខ្ញុំបានឃើញអ្នកនេសាទថៃ ដែលគេចាប់បានយកមកទុកនៅកោះតាគាវ។ ថ្ងៃមួយ ពេលដែលខ្ញុំទៅបេះដូងនៅកោះតាគាវ ខ្ញុំបានឃើញអ្នកនេសាទថៃនៅទីនោះ។ យោធានៅលើកោះបានប្រាប់ខ្ញុំថា អ្នកទាំងនោះគឺជាអ្នកនេសាទថៃ ដែលគេចាប់យកមក។ អ្នកនេសាទទាំងនោះមិនត្រូវបានគេចងទេ ពួកគេដើរជុំវិញកន្លែងនោះ អ្នកខ្លះបេះដូង និងខ្លះទៀតកំពុងដាំបាយ។ ពួកគេមានគ្នាប្រហែលជា១០នាក់ មានមនុស្សចាស់ខ្លះ ក្មេងខ្លះ ប៉ុន្តែគ្មានកុមារ និងស្ត្រីទេ។ ពួកគេពាក់ខោអាវចម្រុះពណ៌។ ខ្ញុំបានឮពីពួកយោធានៅលើកោះនិយាយថា ស្ថានទូតថៃនឹងទាក់ទងយកពួកអ្នកនេសាទទាំងនោះទៅថៃវិញ"]។

ក្រោយពីទាហានចាប់ទូកពីរគ្រឿងរបស់ពួកគេ និងរឹបអូសយកត្រីនៅលើទូក[1430]។ កុច ទុយ បានផ្តល់សក្ខីកម្មថា គាត់ និងអង្គភាពរបស់គាត់ បានចាប់ទូកនេសាទថៃមួយគ្រឿង នៅកោះយ៉ា។ ក្រោយពីប្រមូលយកត្រីអស់ហើយ ពួកគាត់ត្រូវបានមេបញ្ជាការកងវរសេនាតូចបញ្ជាឲ្យនាំទូក និងមនុស្ស ទៅកំពង់សោម[1431]។ នៅទីនោះ ពួកគេត្រូវទទួលដោយទាហានមកពីកងពល ១៦៤[1432]។

1430 ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ហៅ មា ឆ.35-36 ["ខ្ញុំបានឃើញម្តងដែលយោធាខ្មែរក្រហមចាប់បានទូកនេសទធំចំនួនពីរ យោធាខ្មែរក្រហមបញ្ជូនអ្នកនេសាទទាំងនោះទៅចម្ការធូរេន ហើយយោធាខ្មែរក្រហមបានដឹកត្រីមួយឡានពីទូកទាំងពីរនោះមកចែកឲ្យពួកកងកុមារខ្ញុំហូប។ ខ្ញុំចាំហេតុការណ៍នេះច្បាស់ ពីព្រោះថ្ងៃនោះកងរបស់ខ្ញុំបានហូបត្រីច្រើន។ ស: តើលោកបានឃើញគេបណ្តើរអ្នកនេសាទចំនួនប៉ុន្មាននាក់ទៅចម្ការធូរេន? ឆ.36: ខ្ញុំចាំថា អ្នកនេសាទថៃប្រហែលចំនួន២៥នាក់ ដែលគេចាប់មកពីកាណូតហាក់រិនទាំងពីរ។ ពីព្រោះកាណូតថៃទាំងពីរនោះមានសរសេរសញ្ញាជាអក្សរថៃ ពេលនោះ ពួកទូកយោធាខ្មែរក្រហមដែលល្បាតតាមសមុទ្រជាអ្នកចាប់បាន"]។

1431 ឯកសារ D114/105 កំណត់ហេតុស្តាប់ចម្លើយ កុច ទុយ ឆ.47, 48, 52, 54, 57 ["ស: តើអង្គភាពរបស់លោកមានដែលបានចាប់ទូកថៃ ឬទូកវៀតណាមដែលចូលមកនេសាទដែរ ឬទេ? ឆ.47: អង្គភាពរបស់ខ្ញុំធ្លាប់បានចាប់ទូកឈើរបស់ថៃលេខ៣៣១ ម្តងនៅកោះយ៉ា។ [...] ពួកយើងឃើញពួកគេតាមរយៈរ៉ាដា [...] ឆ.48: ពេលនោះ ពួកយើងផ្លាស់ចល័តទៅតាមយាម រហូតដល់យាមទី៣ ប្រហែលជាម៉ោងប្រាំបី ឬប្រាំបួនយប់ នៅពេលដែលកប៉ាល់ខ្ញុំទៅដល់បានឃើញទូកឈើថៃនោះតាមរយៈរ៉ាដា។ ពួកខ្ញុំក៏ចេញកប៉ាល់ទៅ និងបានចាប់ទូកនោះ ដោយបញ្ជូនមនុស្សនៅក្នុងនោះទៅកំពង់សោម និងយកទូកឈើមកកោះតាំង ដោយយកត្រីពីលើទូក និងឥវ៉ាន់ចេញ ដោយចំណាយបី ឬបួនថ្ងៃ និងយកទូកនោះទៅកងពលលេខ៤ នៅកំពង់សោមតែម្តង។ មនុស្សនៅលើទូកនោះ មានច្រើននាក់ដែរ តែខ្ញុំមិនចាំចំនួនប៉ុន្មានទេ។ [...] ស: នៅពេលដែលលោកឃើញទូកថៃនោះ តើពួកគេកំពុងធ្វើអ្វី? ឆ.52: ពួកគេកំពុងអូសត្រី។ [...] ស: នៅពេលនៅចាប់ទូកបាន តើពួកលោកមានរាយការណ៍ទៅថ្នាក់លើដែរទេ? ឆ.54: មេកង ចាប លៀប បានរាយការណ៍ទៅមេកងវរៈ អំពីការចាប់បានទូកថៃបាន ហើយមេកងពលបានបញ្ជាឲ្យយកទូកទៅកំពង់សោម។ នៅកំពង់សោមមេកងពល តាឆាន មេបញ្ជាការកងពលក៏នៅទីនោះដែរ។ ហើយពួកយើងក៏យកទូកដែលចាប់បានទៅកន្លែងកងវរៈ ទៅកោះតាំងវិញ។ ក្រោយមកទៀត ខ្ញុំក៏មិនដឹងថាយកទូកនោះទៅណាទៀតទេ [...] ស: ពួកថៃទាំងនោះ តើពួកគេស្លៀកពាក់ជាជនស៊ីវិល ឬទាហាន? ឆ. 57: ពួកគេ ស្លៀកពាក់ជាប្រជាជនស៊ីវិលធម្មតា។ តាមពិត ពួកគេពាក់តែអាវយឺតទេ ព្រោះគេខ្លាចទាក់ខ្សែអាវនឹងមោង"]។

1432 ឯកសារ D114/105 កំណត់ហេតុស្តាប់ចម្លើយ កុច ទុយ ឆ.55-56 ["ស: នៅពេលដែលលោកទៅកំពង់សោមជាមួយនឹងទូកថៃនោះ តើមាននរណានៅនឹងផែចាំទទួលដែរ ឬទេ? ឆ.55: មាន គឺនីរសាររបស់កងពល។ ខ្ញុំមិនដឹងចំនួនប៉ុន្មានដែរ។ ស: តើអ្នកទាំងនោះជាទាហានឬ? ឆ.56: បាទ ពួកគេជានីរសារកងពល ពួកគេមានកាន់កាំភ្លើង"]។

396. ជនជាតិថៃខ្លះត្រូវគេទុកជីវិតឲ្យ ដើម្បីប្រើប្រាស់សម្រាប់គោលបំណងដោះដូរជាមួយទំនិញ[1433]។ ឧទាហរណ៍ **មាស មុត** បានរាយការណ៍ជូន ប៉ុល ពត, នួន ជា និង អៀង សារី នៅខែ មេសា ឆ្នាំ ១៩៧៨ ថា កងពល ១៦៤ បានដូរអ្នកទោសថៃជាមួយបារីបីសុង និងប្រេងកូឡាមួយដប[1434]។

---

1433 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 10.51.34-10.54.54 ["បាទ មានការខុសៗគ្នាខ្លះ [...] ខ្ញុំចាប់បានទូកប៉ាល់ថៃចំនួនបីគ្រឿងទៀត [...] ជនជាតិថៃទាំងអស់នោះនៅលើទូក ក្នុងទូកនីមួយៗមានចំនួន២០នាក់ ១០នាក់ ១៥នាក់។ ជនជាតិថៃនោះគឺថា បញ្ជូនទៅរាមតែម្តង បាទទៅរាម [ទៅធ្វើការងារ] ។ អ្នកយាម [នៅរាម] ប្រាប់ខ្ញុំថា ជនជាតិថៃទាំងអស់នេះ គេមិនសម្លាប់ចោលទេថៃទាំងអស់នេះ គេអាចបញ្ជូនគេទៅប្រទេសគេវិញ"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ.80 ["ស: តើអ្នកនេសាទថៃដែលចាប់បាននោះត្រូវបញ្ជូនទៅទីណាដែរ? ឆ.80: ខ្ញុំមិនដឹងថា គេបញ្ជូនពួកគេទៅឃុំនៅទីណាទេ ប៉ុន្តែក្រោយមក ការចរចារវាងអាជ្ញាធរកម្ពុជា និងថៃ នៅដើមឆ្នាំ១៩៧៧ ហើយមានការដោះដូរអ្នកនេសាទថៃទាំងនោះនៅលើកោះស្តេច"]។ ឯកសារ D114/12 កំណត់ហេតុស្តាប់ចម្លើយ នាក់ យឿន ឆ.36 ["ស: លោកនិយាយអំពីការចាប់ទូកអាលុយមីញ៉ូមមួយ [...] លោកក៏បាននិយាយដែរថា តាមុត ក៏បានទៅទីនោះដែរ ប៉ុន្តែពុំបាននិយាយគ្នាទេ ដោយសារគាត់ពុំចេះភាសាអង់គ្លេស ដូច្នេះហើយគេបានបញ្ជូនឈ្មោះផលឲ្យទៅជួយបកប្រែ។ សូមលោករៀបរាប់ពីហេតុការណ៍នោះ? ឆ. 36: គឺការចាប់កប៉ាល់ទំនិញមួយយ៉ាងធំដឹកជញ្ជូនទំនិញផ្សេងៗ ដូចជា ធ្យូងថ្ម ជាដើម។ នាវ PCF មួយព្យាយាមដេញចាប់កប៉ាល់នោះ [...] ដើម្បីជួយដល់នាវា PCF នោះ កប៉ាល់ការពារមួយ តែមិនមែនជាកប៉ាល់របស់ខ្ញុំ ត្រូវបានបញ្ជូនទៅចាប់កប៉ាល់ធំនេះ [...] ក្រោយមកទៀត កងពលចេញបញ្ជាឲ្យបញ្ជូនកប៉ាល់ខ្ញុំទៅជួយ ដោយមានកប៉ាល់ការពារពីរគ្រឿងអមនៅសងខាងកប៉ាល់ធំនោះ កប៉ាល់ធំនោះក៏ព្រមឈប់។ ក្រោយមក តាមុត បានធ្វើដំណើរមកដល់ជាមួយនាវា PCF មួយផ្សេងទៀត ហើយបានឡើងទៅលើកប៉ាល់ធំ ដែលឈប់នោះ។ តាមុត បាននិយាយតាមវិទ្យុទាក់ទងថា កុំឲ្យកប៉ាល់ការបាររបស់ខ្ញុំចូលទៅជិតកប៉ាល់នោះ។ ខណៈនោះ យើងចតនៅឆ្ងាយពីកប៉ាល់ទំនិញនោះ។ ចុងក្រោយ នៅវេលាប្រហែលម៉ោង៣រសៀល កប៉ាល់ធំនោះក៏បានចេញពីកន្លែងនោះទៅ ហើយនាវា PCF និងកប៉ាល់របស់ខ្ញុំបានវិលត្រឡប់មកវិញដែរ។ ខ្ញុំមិនដឹងថា កប៉ាល់នោះបង់ប៉ុន្មានឲ្យកងពលនោះទេ"]។ ឯកសារ D114/13 កំណត់ហេតុស្តាប់ចម្លើយ នាក់ យឿន ឆ.1 ["នេះគឺជាការស្មានរបស់ខ្ញុំទេ។ តាមបទពិសោធន៍ និងការកត់សម្គាល់របស់ខ្ញុំ នៅពេលដែលគេចាប់បានទូកនេសាទ គឺមានការប្តូរទំនិញផ្សេងៗ ដើម្បីឲ្យដោះលែងអ្នកនេសាទទាំងនោះ។ ដូច្នេះ ហើយបានជាខ្ញុំគិតថា រឿងនេះកើតឡើងដូចគ្នាដែរចំពោះកប៉ាល់ទំនិញធំនោះ"]។

1434 ឯកសារ D1.3.30.25 សារទូរស័ព្ទសម្ងាត់ពី មុត ចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨ ["សៀម ដែលត្រូវដោះលែងមានការយឺតយូរ មិនបានតាមការកំណត់ មូលហេតុពីមានការខុសឈ្មោះ អ្នកដែលមកទទួលខ្លះ តែខុសនេះ តាមពិនិត្យ គឺមិនមានខុសទាំងស្រុងទេ គឺខុសចុងឈ្មោះបន្តិចៗ ជាមូលដ្ឋានត្រូវ ឯការទាក់ទងដល់យោបល់ ក៏មិនបានតាមសំណូមពរដោយតែអូរមិនព្រួគ្នា ផ្អែកលើទូរលេច ខាងសមមិត្ត ឡូញ ហើយដោយមានការបញ្ជូនសារយឺត និងបាត់ បានធ្វើឲ្យការប្រគល់ថៃនេះ ពន្យារហូតដល់ម៉ោង២០ ថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៧៨។ អ្នកមកទទួលមានចៅហ្វាយស្រុកខ្លងយ៉ៃម្នាក់ និងម្នាក់ទៀត អ្នកប្រជាសង្គ្រោះ។ អាសៀម ដែលមកទទួលនេះបានឲ្យបារី៣សុង ប្រេងកូឡា១ដប ដល់មិត្តយើង"]។ ។ ឯកសារ D54/53 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន ឆ.22 ["ស: យើងបង្ហាញឯកសារ D1.3.30.25 ភាសា

សាក្សី សឹម នី បានឃើញអ្នកនេសាទថៃ ៤០ នាក់ ត្រូវគេឃុំនៅពយបារាំង (ឃុំថ្មស ស្រុកថ្មបាំង ខេត្តកោះកុង) នៅចុងឆ្នាំ ១៩៧៥ ឬដើមឆ្នាំ ១៩៧៦។ ទាហានតំបន់ម្នាក់បានប្រាប់គាត់ថា អ្នកនេសាទទាំងនេះត្រូវបានបញ្ជូនត្រឡប់ទៅថៃវិញ ក្រោយពីមានការចរចាការទូត[1435]។

397. ដូចគ្នានេះដែរ សាក្សី អ៊ូ ដាវ បានរៀបរាប់លម្អិតអំពីការចូលរួមរបស់គាត់ក្នុងឧប្បត្តិហេតុពីរនៃការចាប់អ្នកនេសាទថៃ និងដោះដូរជាមួយទំនិញ។ ក្នុងអំឡុងខែ មិថុនា ឆ្នាំ ១៩៧៥ អ៊ូ ដាវ និងអង្គភាពរបស់គាត់ ចាប់បានទូកនេសាទថៃមួយគ្រឿង ហើយពួកគាត់ទទួលបញ្ជាឲ្យនាំទូកនោះទៅកំពង់សោម រួចប្រគល់ជូនអនុមេបញ្ជាការរបស់ **មាស មុត**[1436]។ បន្ថែមពីលើនេះទៀត ពួកគាត់ទទួល

---

អង់គ្លេស EN: 00143507-00143508 និងភាសាខ្មែរ EN: 00017026។ សូមលោកអានឯកសារនេះ ដោយមានមន្ត្រីបកប្រែជាជំនួយ យោងទៅលើព្រឹត្តិការ ដែលរៀបរាប់នៅចំណុចទី២ ក្នុងសារទូរលេខនេះ ព្រឹត្តិការណ៍គឺកើតនៅកោះកុង ជាកន្លែងដែលលោកនៅកាលពីពេលនោះ។ តើលោកនឹងឃើញព្រឹត្តិការណ៍នេះដែរ ឬទេ? ឆ.22: ខ្ញុំបានដឹងអំពីព្រឹត្តិការណ៍នោះដែរ ពីព្រោះខ្ញុំស្គាល់មនុស្សម្នាក់ដែលទទួលខុសត្រូវខាងដោះដូរអ្នកនេសាទថៃដែលចាប់បាន។ គាត់ឈ្មោះ ឡូញ ដែលគាត់ទទួលខុសត្រូវខាងអង្គភាពនេសាទ។ ឡូញ ត្រូវបានមជ្ឈិមជ្រើសរើសចេញពីកងពលលេខ ១របស់ខ្ញុំ ដើម្បីទទួលខុសត្រូវខាងនេសាទរបស់មជ្ឈិម"]។

1435 ឯកសារ D54/32 កំណត់ហេតុស្ដាប់ចម្លើយ ស៊ឹម នី ឆ.23-24, 26 ["ស: តើលោកធ្លាប់បានឃើញមានអ្នកទោសថៃ និងវៀតណាមនៅវត្តឥន្ទញាណដែរ ឬទេ? ឆ. 23: ទេ ខ្ញុំមិនបានឃើញថៃ និងវៀតណាមនៅវត្តឥន្ទញាណ តែខ្ញុំបានឃើញអ្នកនេសាទថៃ ចំនួន៤០នាក់នៅហ្នឹងថ្មបាំង។ នៅលើផែនទីកន្លែងដែលគេដាក់អ្នកនេសាទថៃនោះ គេហៅថា ពយបារាំង ដែលជាអតីតរោងចក្រធ្វើត្រីខ វាឋិតនៅក្នុងឃុំថ្មស ស្រុកថ្មបាំង ក្នុងខេត្តកោះកុង។ ខ្ញុំបានឃើញពួកនេសាទថៃទាំងនោះនាចុងឆ្នាំ១៩៧៥ និងដើមឆ្នាំ១៩៧៦ ពេលដែលខ្ញុំទៅនៅទីនោះ អស់រយៈពេល៣ខែ ដើម្បីជួយធ្វើព្រួលចាប់ត្រីក្នុងសមុទ្រ។ ស: តើពួកអ្នកនេសាទថៃទាំងនោះ ជាអ្នកណា? ឆ. 24: ពួកគេជាអ្នកនេសាទខុសច្បាប់ដែលចូលមកនេសាទក្នុងដែនទឹកកម្ពុជា។ [...] ស: តាមដែលលោកដឹង តើពួកអ្នកនេសាទថៃទាំងនោះ ត្រូវបានគេយកទៅណា? ឆ. 26: ពេលដែលខ្ញុំបានសួរយោធាតំបន់នៅទីនោះ គេប្រាប់ខ្ញុំថា អ្នកនេសាទថៃទាំងនេះ គឺមិនត្រូវបានធ្វើបាបទេ ហើយឲ្យហូបចុកជាធម្មតារង់ចាំដំណោះស្រាយរវាងរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលថៃ"]។

1436 ឯកសារ D114/24 កំណត់ហេតុស្ដាប់ចម្លើយ អ៊ូ ដាវ ឆ.94, 105-106, 109-113 ["ស: តើការចាប់ទូកលើកទី១ហ្នឹងនៅក្នុងខែណាដែរ? ឆ. 94: ប្រហែលនៅចុងខែមិថុនា [...] ស: តើនៅពេលនោះ គេឆ្លើយតបយ៉ាងម៉េចដែរ? ឆ.105: គេបញ្ជាឲ្យយើងនាំទូកដែលចាប់បាននោះ ទៅកំពង់សោម។ ស: តើលោករង់ចាំបញ្ជាឆ្លើយតបមកវិញក្នុងរយៈពេលប៉ុន្មានដែរ? ឆ. 106: យើងរង់ចាំប្រហែលជាកន្លះម៉ោង [...] ស: តើលោកយកមនុស្ស ដែលចាប់បាននៅលើទូកទៅទីណាដែរ? ឆ.109: មនុស្សចំនួន៦ ឬ៧ ត្រូវបានចាប់បញ្ចូលដាក់ក្នុងឃ្លុបទូកខាងក្រោមដែលត្រជាក់ ហើយទើបបើកទូកបញ្ជូនទៅកំពង់សោម។ ស: នៅពេលដែលលោកទៅដល់កំពង់សោម តើលោកទៅកន្លែងណាឲ្យជាក់ច្បាស់? ឆ. 110: ខ្ញុំយកទូក និងមនុស្សដែលបានចាប់ទៅប្រគល់ឲ្យអ្នកដែលគេចាំទទួលនៅផែ។ ស: តើនរណាគេដែលនៅចាំទទួលនៅទីនោះ? ឆ. 111: មេបញ្ជាការរងរបស់មាស មុត រួមជាមួយនឹងកងទ័ពជាច្រើននាក់ទៀតនៅចាំទទួល។ ស: ហេតុដូច

បញ្ជាឲ្យទុកជីវិតដល់អ្នកនេសាទថៃដែលចាប់បាន ដើម្បីដោះដូរជាមួយសាំង[1437]។ ក្រោយមក ក្នុងឆ្នាំដដែលនោះ អ៊ូ ដាវ និងអង្គភាពរបស់គាត់ ចាប់បានទូកនេសាទធំពីរគ្រឿង ដែលមានជនជាតិថៃប្រហែល ១៥ នាក់[1438]។ អ៊ូ ដាវ បានរាយការណ៍អំពីការចាប់នេះ តាមវិទ្យុទាក់ទង ទៅកាន់មេបញ្ជាការកងវរសេនាតូច ដែលបានបញ្ជាគាត់ឲ្យនាំទូកទៅកំពង់សោមភ្លាម[1439]។ បន្ទាប់មក ទូក

---

ម្តេចបានជាលោកដឹងថា អ្នកហ្នឹងគឺជាមេបញ្ជាការរងរបស់ មាស មុត? ឆ. 112: ខ្ញុំដឹង ព្រោះអ្នកហ្នឹងស្និទនឹង មាស មុត។ ស: ហេតុដូចម្តេចបានជាលោកដឹងថា អ្នកហ្នឹងស្និទនឹង មាស មុត? ឆ. 113: ខ្ញុំឃើញអ្នកហ្នឹងចូលរួមប្រជុំជាមួយ មាស មុត។ ក្នុងក្រុមហ្នឹង គឺមាន៣នាក់ គឺ មាស មុត និង២នាក់ទៀត ខ្ញុំមិនស្គាល់ទេ”]។

1437 ឯកសារ D114/24 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដាវ ឆ.105-107, 128-129, 131 [“ស: តើនៅពេលនោះ គេឆ្លើយតបយ៉ាងម៉េចដែរ? ឆ. 105: គេបញ្ជាឲ្យយើងនាំទូក ដែលចាប់បាននោះ ទៅកំពង់សោម។ ស: តើលោករង់ចាំបញ្ជាឆ្លើយតបមកវិញក្នុងរយៈពេលប៉ុន្មានដែរ? ឆ.106: យើងរង់ចាំប្រហែលជាកន្លះម៉ោង។ ពួកយើងទទួលបញ្ជាមិនឲ្យសម្លាប់ពួកដែលនៅលើទូកនេសាទនោះទេ ដោយរក្សាពួកគេដើម្បីប្តូរប្រេង ជាមួយម្ចាស់ទូកនេសាទ។ ស: តើលោកទទួលព័ត៌មានអំពីការទុកមនុស្សប្តូរជាមួយប្រេងហ្នឹងមកទីណា? ឆ. 107: ក្រោយពេលដែលខ្ញុំបញ្ជូនទូកនេសាទ និងមនុស្សទៅកំពង់សោម មេបញ្ជាការកងវរសេនាតូច ប្រាប់ខ្ញុំថា គេយកមនុស្ស និងទូកនេសាទទុកដូរយកប្រេង។ [...] ស: អ្នកដែលត្រូវបានចាប់ខ្លួនហ្នឹង គឺជាអ្នកនេសាទ ឬទាហាន? ឆ. 128: ពួកគេជាអ្នកនេសាទ។ ស: តើពួកគេមកពីប្រទេសថៃទាំងអស់ឬ? ឆ. 129: ភាគច្រើនថៃ ហើយអ្នកខ្លះស៊ីឈ្នួលឲ្យថៃ [...] ស: តើលោកធ្លាប់ឮរឿងអ្វីចំពោះអ្នកដែលត្រូវបានចាប់ខ្លួននោះដែរ ឬទេ? ឆ. 131: ខ្ញុំធ្លាប់ឮថា គេយកពួកអ្នកនោះទៅប្តូរយកប្រេង”]។

1438 ឯកសារ D114/24 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដាវ ឆ.132-134, 150-152 [“ស: យើងសូមលើកឡើងអំពីការចាប់ទូកលើកទី២។ តើការចាប់ទូកលើកទី២ នៅពេលណាដែរ? ឆ.132: នៅចុងឆ្នាំ១៩៧៥ (មិនចាំខែ) [...] ស: តើមានអ្វីកើតឡើងបន្ទាប់មក? ឆ. 133: ក្រោយពីចាប់បានទូកនេសាទ ក៏បញ្ជូនទៅឲ្យផែកំពង់សោម។ ក្រោយមកក៏មានហេតុការណ៍ប៉ះទង្គិចគ្នាជាមួយប្រទេសថៃ។ ស: តើមានទូកនេសាទចំនួនប៉ុន្មានដែលចាប់បាន? ឆ. 134: មានទូកនេសាទធំៗចំនួន២ [...] ស: តើពួកគេជាអ្នកនេសទ ឬជាទាហាន? ឆ. 150: ពួកគេជាអ្នកនេសាទមកពីប្រទេសថៃ [...] ស: តើពួកគេមានអាវុធដែរ ឬទេ? ឆ. 151: បាទ មាន។ ក្នុង១ទូក មានអាវុធ អែស ខេ (កាំភ្លើងវែងរបស់ថៃ) ២ដើម និងមានកាំភ្លើងខ្លី ១ដើម។ ស: តើអ្នកទាំងអស់នោះ ពាក់ឯកសណ្ឋានអ្វីដែរឬទេ? ឆ. 152: អ្នកខ្លះពាក់អាវស៊ីវិលធម្មតា និងអ្នកខ្លះទៀតពាក់អាវទាហានថៃ”]។

1439 ឯកសារ D114/24 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដាវ ឆ.146-147 [“ស: ក្រោយពីលោកចាប់ទូកនេសាទហើយ តើលោកមានការទាក់ទងតាមវិទ្យុដែរ ឬទេ? ឆ. 146: ក្រោយពីចាប់ទូកនេសាទបានហើយ ខ្ញុំបានរាយការណ៍តាមវិទ្យុទៅមេបញ្ជាការកងវរសេនាតូច។ ហើយគាត់ឲ្យនាំទូកនេសទនោះមក។ ស: តើមេបញ្ជាការកងវរសេនាតូច បានរាយការណ៍ទៅថ្នាក់លើ ឬក៏ឆ្លើយតបមកវិញភ្លាមៗ? ឆ. 147: ខ្ញុំទទួលការឆ្លើយតបភ្លាមៗ ដោយឲ្យនាំទូកទាំងនោះទៅកំពង់សោម [...] ស: តើពួកគេជាអ្នកនេសាទ ឬជាទាហាន? ឆ. 150: ពួកគេជាអ្នកនេសាទមកពីប្រទេសថៃ [...] ស: តើពួកគេមានអាវុធដែរ ឬទេ? ឆ. 151: បាទ មាន។ ក្នុង១ទូក មានអាវុធ អែស ខេ (កាំភ្លើងវែងរបស់ថៃ) ២ដើម

និងអ្នកទោសថៃ ត្រូវបានប្រគល់ជូនទាហានក្រោមបង្គាប់របស់ **មាស មុត**[1440]។ អ៊ំ ដាវ បានឮថា អ្នកទោសត្រូវគេដោះលែងជាថ្នូរនឹងសាំង[1441]។ សាក្សី ឡាយ ប៊ុនហាក់ បានបញ្ជាក់ថា ថ្វីត្បិតតែអង្គភាពរបស់គាត់មិនចូលរួមពាក់ព័ន្ធក្នុងការចាប់អ្នកនេសាទថៃ ឬម៉ាឡេស៊ី ប៉ុន្តែ គាត់ឮអំពីរឿងនេះ តាមវិទ្យុទាក់ទង រៀងរាល់ពីរបីខែម្តង[1442]។ គាត់បានអះអាងថា ទាហានឃាមកោះជាអ្នកទទួលខុសត្រូវក្នុងការចាប់អ្នកនេសាទទាំងនេះ[1443] ហើយអ្នកខ្លះត្រូវបញ្ជូនទៅទីបញ្ជាការ ឯអ្នកខ្លះទៀតត្រូវបានដោះលែង ក្រោយពីចរចាជាមួយស្ថានទូតថៃ[1444]។ ភស្តុតាងផ្សេងទៀតបង្ហាញលម្អិត

និងមានកាំភ្លើងខ្លី ១ដើម។ ស: តើអ្នកទាំងអស់នោះ ពាក់ឯកសណ្ឋានអ្វីដែរឬទេ? ឆ. 152: អ្នកខ្លះពាក់អាវស៊ីវិលធម្មតា និងអ្នកខ្លះទៀតពាក់អាវទាហានថៃ"]។

1440 ឯកសារ D114/24 កំណត់ហេតុស្តាប់ចម្លើយ អ៊ំ ដាវ ឆ.153 ["ស: នៅពេលដែលលោកទៅដល់ផែកំពង់សោម តើនរណាគេជាអ្នកចាំទទួលនៅទីនោះ? ឆ. 153: មនុស្សដដែល គឺមេបញ្ជាការរង និងកងទ័ពរបស់ពួកគេ"]។

1441 ឯកសារ D114/24 កំណត់ហេតុស្តាប់ចម្លើយ អ៊ំ ដាវ ឆ.157-158 ["ស: តើលោកបានឮអ្វីកើតឡើងចំពោះទូក និងអ្នកនេសាទនោះ ក្រោយមកទៀត? ឆ. 157: ខ្ញុំគ្រាន់តែឮព័ត៌មានថា អ្នកទោសដែលចាប់បាននោះត្រូវទុកសម្រាប់ប្តូរប្រេងជាមួយថៅកែទូក។ បើថៅកែទូកមិនមកដោះដូរទេ គេនឹងទុកទូកនេសាទជាសម្បត្តិអង្គការ។ ស: តើលោកមានធ្លាប់ឮថាមានអ្វីកើតឡើងចំពោះអ្នកទោសទាំងនោះដែរ ឬទេ? ឆ. 158: ខ្ញុំឮនូវអ្វីដែលខ្ញុំបានប្រាប់ប៉ុណ្ណឹង"]។

1442 ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.152-155 ["ពិតជាមានការចាប់មែន ពេលដែលគេមិនព្រមចាកចេញពីដែនសមុទ្ររបស់យើង តែមិនមែនជាអង្គភាពខ្ញុំជាអ្នកធ្វើទេ គឺខ្ញុំឮតាមរយៈវិទ្យុទាក់ទង។ ស: តើលោកឮតាមវិទ្យុ ទាក់ទងនៅពេលណា? ឆ. 153: ពេលដែលខ្ញុំនៅលើដីគោក មុនពេលដែលខ្ញុំទៅកោះរ៉ុង។ ស: ប៉ុន្តែនៅព្រឹកមិញ យើងសួរលោកថា លោកធ្លាប់ឮតាមវិទ្យុទាក់ទងថា មានការចាប់មនុស្សនៅសមុទ្រដែរ ឬទេ ហើយលោកនិយាយថា មិនធ្លាប់ឮទេ ហេតុអ្វី? ឆ. 154: ខ្ញុំធ្លាប់ឮពីការចាប់ខ្លួនមនុស្សតាមវិទ្យុទាក់ទងមែន [...] ស: តើលោកធ្លាប់ឮពីការចាប់មនុស្ស តាមវិទ្យុទាក់ទងញឹកញាប់ដែរទេ? ឆ. 155: វាមិនញឹកញាប់ទេ គឺ៤ទៅ៥ខែ មានម្តង"]។

1443 ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.157 ["ស: តាមលោកដឹង តើកងណាជាអ្នកចាប់មនុស្ស? ឆ.157: ជាទូទៅ អ្នកឈរជើងនៅតាមកោះ ជាអ្នកចាប់ និងរាយការណ៍មក"]។

1444 ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.160-162 ["ស: ក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយថា អ្នកដែលត្រូវបានចាប់ខ្លួនមួយចំនួន ត្រូវបានបញ្ជូនទៅទីបញ្ជាការ ហើយមួយចំនួនទៀតត្រូវបានដោះលែង តើលោកដឹងរឿងនោះ ដោយរបៀបណា? ឆ.160: ខ្ញុំដឹងតាមរយៈវិទ្យុទាក់ទងដែលគេនិយាយមក ពេលនោះ គេប្រើតេអូ គឺសំខាន់ជាងគេបង្អស់។ ស: តើនរណាជាអ្នករាយការណ៍រឿងទាំងអស់នោះ? ឆ.: 161: តាមពិត គេទាក់ទងតាមរយៈកងពល បើកងពលគេថាឲ្យយកមក គឺគេនឹងបញ្ជូនមក។ ស: តើលោកមានដឹងរឿងអ្វីខ្លះពីអ្នកដែលត្រូវបានគេដោះលែងទៅវិញទេ? ឆ. 162: ខ្ញុំមិនដឹងទេ។"] ឆ.165 ["ស: ក្នុងបទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបាននិយាយថា អ្នកដែលគេចាប់ខ្លួនបានត្រូវបញ្ជូនទៅភ្នំពេញ រួចអ្នកទាំងនោះត្រូវបានគេបញ្ជូនទៅស្ថានទូត។ សូមលោកជួយបញ្ជាក់ពីរឿងនេះបានទេ ហើយលោកដឹងដោយរបៀបណា? ឆ.

ថាតើអ្នកនេសាទថៃត្រូវបានដោះលែងដោយរបៀបណា ក្រោយពីត្រូវបានបង្ខំឲ្យធ្វើការនៅការដ្ឋានរាមជាមុនសិន[1445]។

398. ណុប ហាល រៀបរាប់អំពីការចាប់ពួកបស្ចិមប្រទេសពីរនាក់ ម្នាក់ស្បែកស និងម្នាក់ទៀតស្បែកខ្មៅ លើទូកជិះកម្សាន្តមួយ នៅដើមឆ្នាំ ១៩៧៨ នៅភាគនិរតីនៃកោះពូលូវ៉ៃ។ អ្នកទាំងពីរត្រូវបានចាប់បញ្ជូនទៅកោះតាង រួចសួរចម្លើយនៅទីនោះ ហើយបញ្ជូនទៅតំបន់កំពង់សោម[1446]។

## ៥. ឧក្រិដ្ឋកម្ម

### មនុស្សឃាត ការសម្លាប់ដោយចេតនា និងការសម្លាប់ផ្តាច់ពូជ

*ក) ការសម្លាប់នៅលើសមុទ្រ*

399. នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧៨ កងពល ១៦៤ បានបាញ់ពន្លិចកាណូតវៀតណាមមួយគ្រឿង នៅចម្ងាយមួយគីឡូម៉ែត្រ ខាងត្បូងកោះខ្យង។ **មាស មុត** បានរាយការណ៍អំពីហេតុការណ៍នេះជូន

---

165: ខ្ញុំដឹងដោយសារការប្រជុំរួមរបស់អង្គភាព ដោយគេប្រាប់ថា ទូកបានចរចាជាមួយរដ្ឋាភិបាលរបស់យើង ហើយអ្នកដែលត្រូវចាប់ខ្លួនត្រូវបានដោះលែងហើយ។ ហើយកិច្ចប្រជុំនោះធ្វើម្តងក្នុងមួយខែ"]។

1445 ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុន ហាក់ ឆ.160-162, 165 ["ស: ក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយថា អ្នកដែលត្រូវបានចាប់ខ្លួនមួយចំនួន ត្រូវបានបញ្ជូនទៅទីបញ្ជាការ ហើយមួយចំនួនទៀតត្រូវបានដោះលែង តើលោកដឹងរឿងនោះ ដោយរបៀបណា? ឆ.160: ខ្ញុំដឹងតាមរយៈវិទ្យុទាក់ទង ដែលគេនិយាយមក ពេលនោះ គេប្រើតេអូ គឺសំខាន់ជាងគេបង្អស់។ ស: តើនរណាជាអ្នករាយការណ៍រឿងទាំងអស់នោះ? ឆ.: 161: តាមពិត គេទាក់ទងតាមរយៈកងពល បើកងពលគេថាឲ្យយកមក គឺគេនឹងបញ្ជូនមក។ ស: តើលោកមានដឹងរឿងអ្វីខ្លះពីអ្នកដែលត្រូវបានគេដោះលែងទៅវិញទេ? ឆ. 162: ខ្ញុំមិនដឹងទេ។ [...] ស: ក្នុងបទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបាននិយាយថា អ្នកដែលគេចាប់ខ្លួនបានត្រូវបញ្ជូនទៅភ្នំពេញ រួចអ្នកទាំងនោះត្រូវបានគេបញ្ជូនទៅស្ថានទូត។ សូមលោកជួយបញ្ជាក់ពីរឿងនេះបានទេ ហើយលោកដឹងដោយរបៀបណា? ឆ. 165: ខ្ញុំដឹងដោយសារការប្រជុំរួមរបស់អង្គភាព ដោយគេប្រាប់ថា ទូកបានចរចាជាមួយរដ្ឋាភិបាលរបស់យើង ហើយអ្នកដែលត្រូវចាប់ខ្លួនត្រូវបានដោះលែងហើយ។ ហើយកិច្ចប្រជុំនោះធ្វើម្តងក្នុងមួយខែ"]។

1446 ឯកសារ D54/78.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ EN 00968388, KH 00926615។

សុន សេន ក្នុងការសន្ទនាសម្ងាត់តាមទូរស័ព្ទ នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨[1447]។ ពេលមួយ ទាហានម្នាក់នៃកងពល ១៦៤ បានឃើញទាហានម្នាក់សម្លាប់ទារកកំពុងយំ ដោយបោះចូលទៅក្នុងសមុទ្រ[1448]។ មូល ឈិន ជាទាហាននៃកងវរសេនាតូច ៣៨៦ ឈរជើងនៅកោះរ៉ុងសន្លឹម ក្នុងឆ្នាំ ១៩៧៥ និង ១៩៧៦ បានបញ្ជាក់ថា ជារឿយៗ ទូកជនភៀសខ្លួនវៀតណាមត្រូវបានបាញ់ពន្លិចភ្លាមៗ ដើម្បីឱ្យមនុស្សស្លាប់ មុនពេលនាំយកទៅ ឬជាជម្រើសម្យ៉ាងទៀត ពួកគេត្រូវបានបាញ់ រួចបោះចូលក្នុងសមុទ្រ[1449]។ ការសម្លាប់អ្នកនេសាទ ឬជនភៀសខ្លួនវៀតណាមរបៀបនេះ ត្រូវបានបញ្ជាក់អះអាងដោយ ប៉ាក សុខ[1450]។

---

1447 ឯកសារ D1.3.34. សារទូរស័ព្ទសម្ងាត់ពីមាស មុត ទៅ បង៨៩ (សុន សេន) ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ ["នៅកែប វេលាម៉ោង៨យប់ ថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨ យើងបាញ់កាណូតអាយួន លេខ១គ្រឿង ធុន២២សេស នៅខាងត្បូងកោះខ្ចង ចម្ងាយ១គ.ម។ ឯយើង មិនមាន ខូចខាតអីទេ។

1448 ឯកសារ D54/25 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.22 ["ខ្ញុំបានឃើញព្រឹត្តិការណ៍មួយទៀត នៅពេលដែលខ្ញុំចាប់ និងដឹកជនភៀសខ្លួនវៀតណាមចំនួន១៣នាក់មកអូរឈើទាល។ នៅពេលនោះ កូនង៉ែតយំខ្លាំងពេក ធ្វើឱ្យរំខានដល់យោធាដែលនៅក្បែរនោះ យោធានោះក៏ទាញកូនង៉ែតដែលយំនោះចេញពីម្ដាយ ហើយបោះចូលទៅក្នុងសមុទ្រតែម្ដង"]។ ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៦ ម៉ោង 14.36.38-14.38.16 ["គឺថា ពីលើកប៉ាល់របស់វៀតណាមហ្នឹងតែម្ដង ព្រោះគេឡើងទៅនៅលើកប៉ាល់ហ្នឹងហើយ គេក៏ចាប់កូនក្មេងនោះឃើញយំខ្លាំងពេកក៏គេចាប់បោះទម្លាក់ទៅចោលតែម្ដង"]។

1449 ឯកសារ D114/31 កំណត់ហេតុស្ដាប់ចម្លើយ មូល ឈិន ឆ.73-75 ["ស: ក្នុងពេលលោកប្រចាំការនៅលើកោះ តើលោកដែលសង្កេតឃើញគេចាប់បានទូកនេសាទវៀតណាមដែរ ឬទេ? ឆ. 73: បាទ មាន គឺទូកវៀតណាមដែលព្យាយាមរត់គេចទៅប្រទេសថៃ។ ម្ដងៗ គេចាប់បានពី៣ទៅ៥ទូក គឺជាទូកតូចៗ កម្លាំង១៥សេស ទៅ២៥សេស។ ដូច្នេះ មិនពិបាកនឹងចាប់នោះទេ ហើយក៏ងាយនឹងបើកគ្រឿងឱ្យលិចផងដែរ។ ស: តើគេចាប់អ្នកនៅលើទូកវៀតណាមនោះដែរ ឬទេ? ឆ. 74: ទាំងទូក និងមនុស្ស គឺគេកម្រនឹងចាប់យកមកណាស់ គឺគេបាញ់ពន្លិចនៅលើសមុទ្រតែម្ដង។ ស: តើនៅលើទូកវៀតណាមទាំងនោះ មានមនុស្សប្រភេទណាខ្លះ? ឆ.75: មានស្រី មានប្រុស មានទាំងក្មេង ទាំងគ្រួសារៗ ជួនកាល មានគ្នាពី៥ទៅ២០នាក់ [...] ស: តើគេសម្លាប់ពួកជនជាតិវៀតណាមទាំងអស់នោះដូចម្ដេចដែរ? ឆ. 81: អ្នកខ្លះត្រូវបានវ៉ៃសម្លាប់ទម្លាក់សមុទ្រ ខ្លះត្រូវបានគេចងដៃ រួចធាក់ទម្លាក់ចូលក្នុងទឹក។ អ្នកខ្លះដែលពូកែហែលទឹកក៏ត្រូវគេបាញ់សម្លាប់ផងដែរ។ [...] ស: តើលោកអាចមើលឃើញតាមសាម៉ែល (កែវយិត) ដែរ ឬទេ? ឆ. 83: បាទ ខ្ញុំមើលតាមសាម៉ែល ឃើញហេតុការណ៍ទាំងនោះ គឺគេចេញទូកប្រហែលបានជា២០០ម៉ែត្រប៉ុណ្ណោះពីផែ នៅលើកោះ ហើយបាញ់សម្លាប់ពួកគេទម្លាក់ចូលក្នុងសមុទ្រ។ ខ្ញុំអាចមើលឃើញច្បាស់តាមរយៈសាម៉ែល"]។

1450 ឯកសារ D54/25 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.11 ["ស: តាមបទពិសោធន៍របស់លោក និងការយល់ដឹងរបស់លោក នៅក្នុងកងអង្គភាពរបស់លោក និងអង្គភាពដទៃទៀត នៃកងទ័ពជើងទឹក តើចំនួនប្រជាជនស៊ីវិល ចំនួនជនភៀសខ្លួន អ្នកនេសាទ ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឆ្លងមកចូលក្នុងដែនទឹកកម្ពុជា ហើយត្រូវបានចាប់បាន

400. ប៉ាក សុខ បានរៀបរាប់អំពីការសម្លាប់មនុស្សរាប់ពាន់នាក់ នៅលើសមុទ្រ រួមបញ្ចូលទាំងអ្នកនេសាទថៃ[1451]។ របាយការណ៍ផ្លូវការក៏បានកត់ត្រាអំពីការសម្លាប់បែបនេះផងដែរ។ ឧទាហរណ៍ ក្នុងខែ កញ្ញា ឆ្នាំ ១៩៧៧ ស៊ឹម ប្រធានកងពល ១៦៤ នៅកោះកុង បានរាយការណ៍ថា គាត់បានដឹកនាំការចាប់ទូកថៃពីរគ្រឿង ដែលផ្ទុកត្រី និងប្រេង។ គាត់បានបញ្ជាក់ថា អ្នកខ្លះបានលោតចូលក្នុងទឹក អ្នកខ្លះទៀត "ត្រូវបាន [បងប្អូនយើង] សម្លាប់"[1452]។

*ខ) ការសម្លាប់នៅលើកោះ*

401. ពេលគេចាប់មនុស្សបាននៅលើសមុទ្រ គេបញ្ជូនអ្នកទាំងនោះទៅទីបញ្ជាការកងទ័ពជើងទឹកនៅជិតបំផុត[1453]។ អ្នកដែលគេចាប់បានត្រូវនាំទៅកំពង់ផែកោះរ៉ុងសន្លឹម រួចសម្លាប់ចោលភ្លាមៗពេលទៅ

---

និងសម្លាប់ មានចំនួនប្រហែលប៉ុន្មាននាក់? ឆ: មានចំនួនរាប់ពាន់នាក់ អ្នកទាំងនោះ រួមមាន ពួកនេសាទថៃ ពួកនេសាទ និងជនអៀសខ្លួនវៀតណាម ដែលត្រូវចាប់បាន និងសម្លាប់ចោល នៅក្នុងសមុទ្រ នៅលើកោះ និងនៅលើដីគោក។

1451 ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.11-13 ["មានចំនួនរាប់ពាន់នាក់ អ្នកទាំងនោះរួមមាន ពួកនេសាទថៃ [...] ឆ.13: ដែលត្រូវចាប់បាន និងសម្លាប់ចោលនៅក្នុងសមុទ្រ នៅលើកោះ និងនៅលើដីគោក"]។

1452 ឯកសារ D1.3.34.28 សេចក្តីរាយការណ៍កម្ពុជាប្រជាធិបតេយ្យ ដោយ ស៊ឹម (កងពល១) ជូន កងពល១៦៤ ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ១៩៧៧ EN 00233654, KH 00161729 ["ចំពោះទូកថៃ ដែលចូលក្នុងសមុទ្រយើងយ៉ាងជ្រៅ ហើយជិតកោះរបស់យើង ខ្ញុំបានចេញកប៉ាល់ធ្វើការ ចាប់បានទូក២គ្រឿង ធុន៣០០សេស១គ្រឿង ៤០០សេស១គ្រឿង។ ចំពោះទូក២គ្រឿងចាប់បាននៅខាងត្បូងកោះកុង។ នៅលើទូកមានកូឡាំង២គ្រឿង និងត្រីមួយចំនួន និងប្រេង ចំពោះមនុស្សគ្មានបានទេ ពីព្រោះវាលោតធ្លាក់ទឹក នៅសល់មួយចំនួន [បងប្អូន]កំទេចចោលអស់"]។

1453 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.79-82 ["ស: តើលោកដឹងថា នេះគឺជាបញ្ជាចេញមកពីកំពង់សោមថា "ធ្វើអីធ្វើទៅ កុំទុក" ដោយរបៀបណាទៅ? ឆ.79: ខ្ញុំអាចស្តាប់ឮបញ្ជានោះ តាមរយៈវិទ្យុទាក់ទងនៅខ្សែត្រៀមជិតផែ។ ជាទូទៅ ទីតាំងដែលគេនាំយកមនុស្សដែលគេចាប់បានទៅ គឺអាស្រ័យទៅលើកន្លែងដែលគេចាប់អ្នកទាំងនោះបាន។ ប្រសិនបើគេចាប់នៅជិតកោះនេះ គេនឹងយកអ្នកទាំងនោះមកទីបញ្ជាការជិតជាងគេនៅលើកោះនេះតែម្តង។ ដូចគ្នាដែរ ចំពោះអ្នកដែលគេចាប់បាននៅកោះពូលូវៃ និងកោះតាង។ ពួកអ្នកនេសាទ ដែលគេចាប់បានត្រូវបាននាំយកមកកាន់ទីបញ្ជាការផ្សេងៗជាច្រើន ចំណុះឲ្យកងពលលេខ៣។ ស: ដូច្នេះ អ្វីដែលលោកកំពុងប្រាប់យើងទាក់ទិននឹងការប្រាស្រ័យទាក់ទងគ្នា គឺដូចគ្នាទាំងស្រុងនឹងអ្វីដែលលោកបានឮនៅតាមវិទ្យុទាក់ទងដែរមែនទេ? ឆ. 80: ត្រឹមត្រូវហើយ ហើយតាមខ្ញុំយល់ រាល់ពេលដែលគេចាប់បានទូក គឺទីបញ្ជាការពាក់ព័ន្ធទាំងនោះនៅថ្នាក់កងវរៈសេនាតូចក្តី កងវរៈសេនាធំក្តី គឺគេរាយការណ៍ទៅឲ្យកងពលនៅកំពង់សោម។ ស: ចំពោះកោះដែលលោកនៅប្រចាំការ តើមានរបាយការណ៍ ឬការគូសបញ្ជាក់ផ្ញើទៅកងពលប្រាប់អំពីអ្វី ដែលបានកើតឡើងចំពោះមនុស្សដែលគេចាប់បានដែរ ឬទេ ក្រោយមកទៀត? ឆ. 81: បាទ គឺតែងតែមានការរាយការណ៍ត្រឡប់ទៅកំពង់សោមវិញ អំពីអ្វីដែលកើត

ដល់[1454]។ ជាធម្មតា អ្នកដែលគេចាប់បាននៅលើសមុទ្រ ជិតកោះពូលូវ៉ៃ ត្រូវនាំទៅកោះ[1455]។ អ្នកទោសត្រូវគេឃុំពីរបីថ្ងៃ[1456] នៅក្នុងផ្ទះមួយជិតផែ រួចបំបែកយកទៅដាក់នៅតាមអង្គភាពឈរជើងនៅលើកោះ[1457]។ គេជ្រើសរើសទាហានឱ្យសម្លាប់អ្នកទោស ដោយវាយឱ្យស្លាប់ រួចកប់[1458]។

---

ឡើងចំពោះអ្នកដែលគេបានចាប់ខ្លួនទាំងនោះ។ ស: តើលោកនៅចាំថា គេប្រើពាក្យពេជន៍អំពីការទំនាក់ទំនងគ្នា ពាក់ព័ន្ធនឹងការងារនេះ? ឆ. 82: គេប្រើពាក្យ គេធ្វើហើយៗ ឬក៏គេបង្ហើយអ្នកទាំងនោះអស់ហើយ"]។

1454 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.88 ["ខ្ញុំនៅលើផែ។ នៅពេលថ្ងៃ ខ្ញុំជួនកាល ខ្ញុំមកលេងនៅផែ ហើយមើលទៅណេះ ទៅណោះជុំវិញហ្នឹង។ ខ្ញុំចង់គូសបញ្ជាក់ថា រាល់ពេលដែលគេចាប់ទូកបាន គឺគេយកអ្នកទាំងអស់នោះ ទៅសម្លាប់ចោលទាំងអស់ ក្នុងពេលដ៏ខ្លីក្រោយពេលយកមកដល់ផែ ព្រោះថា កងវរៈសេនាតូចខ្លាចអ្នកទាំងនោះតដៃ ហើយអាចរំដោះពួកគ្នាគេរួច"]។ ឯកសារ D54/115.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នាក់ យឿន EN 01088467-68, KH 01007867 ["ស: ចុះក្រោយមកទៀត មានដូចថា ខាងចាប់ខាងថៃ ចាប់ខាងយួនអីអត់? ឆ.: មានចាប់ [...] ស: ចាប់យកទៅខាងណា? យឿន៖ ចាប់យកបាញ់ចោល។ ស: ចាប់បាញ់ចោលនៅ? ឆ.: នៅកោះរ៉ុង [...] ស: មានចាប់បញ្ជូនមកកន្លែងកងពលដែរ? ឆ.: មកៗដល់ ចាប់ដូចថា ឥឡូវចាប់នៅកោះរ៉ុងៗ គេតេអូមកកងពលនេះ។ កងពលៗថាឯងធ្វើម៉េចធ្វើទៅ កុំទុក។ ហើយចាប់ដឹងមិនមែនយកកាប៉ាល់ពួកខ្ញុំមកចាប់ទេ បញ្ជោះម្តងម៉ាស៊ីន៤ អគ្គិសនី២ទៀត បញ្ចូលអាគុយទៀត ទៅជាមួយពួក PCF មកចាប់។ ស: ចាប់យកមកកោះរ៉ុង? ឆ.: បញ្ជូនមកកោះរ៉ុង"]។

1455 ឯកសារ D114/127 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គីម ឆ.7-8 ["ស: តើអ្នកដែលគេចាប់ខ្លួនទាំងនោះមានសភាពយ៉ាងដូចម្តេចដែរ ពេលដែលពួកគេឡើងមកដល់កោះពូលូវ៉ៃ? តើពួកគេមានត្រូវបានចង វាយ និងហែរហត់អស់កម្លាំងដែរឬទេ តាមដែលការកត់សម្គាល់របស់លោក? ឆ. 7: ភាគច្រើន ពួកគេស្ទើរតែទាំងអស់ត្រូវបានចង។ ស: តើគេចងស្ត្រី និងកុមារ ដែរឬទេ? ឆ.8: ទេ គេមិនចងទេ គេចងតែបុរស។ អ្នកដែលខ្លាំង ទំនងនឹងតដៃជាមួយពួកគេ គេនឹងត្រូវចងហើយ"]។

1456 ឯកសារ D114/127 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គីម ឆ.11 ["ខ្ញុំសូមគូសបញ្ជាក់ថា តាមខ្ញុំចាំ គឺពុំមានផែបេតុងនោះទេ ហើយចំពោះអ្នកដែលគេចាប់បាន គឺរក្សាទុកនៅក្នុងផ្ទះដូចខ្ញុំរៀបរាប់ខាងលើ រយៈពេល២ទៅ៣ថ្ងៃ ដូចខ្ញុំបាននិយាយនៅក្នុងបទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។ ចំពោះការទំនាក់ទំនងគ្នារវាងពួកគេ និងទីបញ្ជាការនៅកំពង់សោម អាចជារឿងត្រឹមត្រូវ។ ខ្ញុំនិយាយបែបនេះដោយសារថា ខ្ញុំមិនស្ថិតនៅក្នុងចំណោមពួកគេ និងពុំបានដឹងរឿងនេះដោយផ្ទាល់"]។

1457 ឯកសារ D114/127 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គីម ឆ.29 ["ខ្ញុំមិនដឹងថា គេឱ្យមនុស្សដែលគេចាប់បានទាំងនោះហូប ឬក៏អត់នោះទេ ពេលដែលគេទុកនៅទីនោះ។ យ៉ាងណាមិញ ២ឬ៣ថ្ងៃក្រោយមក គេចែកប្រជាជនទាំងនោះឱ្យទៅតាមកងធំនីមួយៗ ដើម្បីចាត់ចែង។ ឧទាហរណ៍ បើគេចាប់បាន៣០នាក់ គឺត្រូវចែកនឹង៤កងអនុសេនាធំ ហើយក្រោយមកទៀត មនុស្សទាំងនោះត្រូវបានគេបញ្ចេញពីផ្ទះនោះ ហើយបញ្ជូនទៅតាមកងអនុសេនាធំផ្សេងៗ ដែលឈរជើងនៅទីតាំងខុសៗគ្នា"]។

402. មនុស្សរាប់ពាន់នាក់[1459] ជាជនភៀសខ្លួនវៀតណាម និងជនជាតិថៃ ត្រូវចាប់បាននៅលើសមុទ្រ រួចនាំយកទៅសម្លាប់ នៅកោះតាង។ អ្នកខ្លះត្រូវគេសួរចម្លើយ[1460]។ ពួកគេត្រូវបានឃុំខ្លួនយ៉ាងយូរបំផុតមួយយប់ រួចនាំយកទៅសម្លាប់[1461]។ ជនរងគ្រោះត្រូវគេចង រួចវាយនឹងដំបងរហូតដល់ស្លាប់ ហើយកូនក្មេងត្រូវគេចាប់បោកនឹងដើមឈើ[1462]។ ក្រោយមក គេយកសាកសពទៅកប់នៅក្រោមដើមដូងដើម្បីធ្វើជី[1463]។

---

1458 ឯកសារ D114/127 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គីម ឆ.34 ["ស: តើគេសម្លាប់អ្នកទាំងនេះដោយមធ្យោបាយអ្វីដែរ? ឆ. 34: ខ្ញុំបានដឹងពីអ្នកដែលគេជ្រើសរើសឲ្យធ្វើការងារនេះថា មនុស្សដែលគេចាប់បាន គឺត្រូវបានវៃនឹងដំបង ហើយកប់"]។

1459 ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.58 ["ស: តាមលោកស្មានមើល ពួកជើងទឹកកាលពីពេលហ្នឹង រយៈពេលនៃរបបហ្នឹង តាមមើលចាប់មនុស្ស ហើយសម្លាប់នៅក្នុងសមុទ្រ ប្រហែលប៉ុន្មាននាក់? ឆ. 58: អាចចូលខ្ទង់ពាន់ មិនមែនរយទេ"]។

1460 ឯកសារ D114/283 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.30, 39-40 ["ពេលខ្លះគេសួរចម្លើយតែម្នាក់ពីរទេ។ ក្នុងពេលសួរចម្លើយហ្នឹង គឺដាច់ខាតគេត្រូវឆែកទាំងអស់ អត់ឲ្យសល់ទេ។ ស: តើលោកដឹងទេ ពួកអ្នកដែលរងគ្រោះ ដែលគេចាប់ដល់ហ្នឹង គេមានវៃ ធ្វើបាបសិនទេ មុនគេសម្លាប់ទេ? ឆ. 39: វៃសួរចម្លើយហើយអស់ គេយកទៅសម្លាប់ហើយ។ ស: កាលហ្នឹង គោលបំណងយកសួរចម្លើយ ដើម្បីអ្វី? ឆ. 40: ចម្លើយគេសួរហ្នឹង គេចោទថា ពួកហ្នឹងមកស៊ើបការណ៍តែប៉ុណ្ណឹង មានកម្លាំងបង្កប់ប៉ុន្មានទៀត មកវៃពេលណា"]។

1461 ឯកសារ D114/283 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.32 ["ស: ជាមធ្យម ពេលដែលគេយកមនុស្សដល់កោះប្រហែលប៉ុន្មានម៉ោង ប៉ុន្មានថ្ងៃបានគេសម្លាប់? ឆ. 32: អស់យូរបំផុត១យប់ បើពេលថ្ងៃគឺ១ថ្ងៃ អាហ្នឹងយូរបំផុត"]។

1462 ឯកសារ D114/283 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.30 ["ស: ពេលដែលគេយកមកសម្លាប់ ហើយកប់នៅក្រោមដើមដូង គេសម្លាប់ដោយរបៀបណា? ឆ. 30: វៃដោយដំបងរហូតស្លាប់ អត់បាញ់ទេ ចងខ្សែអត់មានខ្នោះទេ"]។ ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.20 ["ខ្ញុំបានឃើញព្រឹត្តិការណ៍ដំបូង គឺជាការចាប់បាន និងសម្លាប់ប្តីប្រពន្ធវៀតណាម និងកូនម្នាក់អាយុប្រហែល១ឆ្នាំ នៅកោះពូលៃចាស់ កាលពីចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧។ [...] ខ្ញុំបានឃើញប្តីប្រពន្ធនោះត្រូវបានចងស្លាបសេក ហើយឲ្យអង្គុយលត់ជង្គង់លើដី។ យោធាដែលធ្វើក្នុងពេលនោះ គឺជាយោធានៅក្នុងកងវរសេនាធំលេខ៦២របស់ខ្ញុំ។ ដំបូងគេវៃប្តីនឹងគល់ឫស្សីចំក្បាលខាងក្រោយ។ បន្ទាប់ពីប្តីដួលទៅលើដី ទើបគេវៃប្រពន្ធដូចគ្នា។ ពេលដែលប្រពន្ធដួលទៅលើដី កូនង៉ែតយំ ហើយវារទៅឱបម្តាយវា។ យោធាម្នាក់បានចាប់ជើងកូនង៉ែតនោះបោកនឹងគល់ដូងសម្លាប់តែម្តង។ គេបានកាប់សពប្តីប្រពន្ធនោះជាពីរកំណាត់ដោយចបកាប់ ហើយមួយកំណាត់ៗត្រូវបានកប់នៅក្រោមគល់ដូងមួយៗដើម្បីធ្វើជី"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 11.03.07-11.06.59 ["ថ្ងៃមួយ ឃើញថា ចាប់បានវៀតណាមបីនាក់ ប្តី និងកូនម្នាក់។ ពេលនោះ ចាប់យកមកដល់កោះពូធីវៃ បាទដល់កោះពូធីវៃ។ [...] គេសម្លាប់ៗផង ហើយឲ្យលុតជង្គង់វាយនឹងគល់ឫស្សី និងត្បូងចប. [...] យោធាចាប់បោកកូនង៉ែតនោះនឹងគល់ដូងស្លាប់តែម្តង"] ម៉ោង

403. **មាស មុត** បានរាយការណ៍ជូនមេដឹកនាំមជ្ឈិម ប.ក.ក ថា ពីថ្ងៃទី ២៧ ដល់ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៨ ប្រជាជនវៀតណាម ១២០ នាក់ ត្រូវចាប់បាន និងបាញ់សម្លាប់ចោល[1464]។ ជនរងគ្រោះទាំងនេះមកពីទូកប្រាំគ្រឿង[1465]។ សំ សោម ទាហានកងវរសេនាតូច ៦២៣ នៃកងវរសេនាធំ ១៦២ បានឃើញ កងនាវា (កងវរសេនាធំ ១៤០) ឃាត់ទូកវៀតណាមមួយគ្រឿង និងចាប់អ្នកដំណើរ ពេលគាត់ឈរជើងនៅកោះតាង ក្នុងរដូវប្រាំង ពីឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៨[1466]។ កងនាវា

---

11.06.59-11.07.31 ["ក្នុងចំណោមទាំងបីនាក់ហ្នឹង គឺប្រជាជន បាទ ប្រជាជនទេ គ្មានសម្លៀកបំពាក់អី ក៏គ្មានយោធាដែរ ហើយជាប្រជាជនធម្មតា"]។

1463 ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.20 ["ខ្ញុំបានឃើញព្រឹត្តិការណ៍ដំបូង គឺជាការចាប់បាន និងសម្លាប់ប្តី ប្រពន្ធវៀតណាម និងកូនម្នាក់អាយុប្រហែល១ឆ្នាំ នៅកោះពូល្វៃចាស់ កាលពីចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧។ [...] គេបានកាប់សពប្តីប្រពន្ធនោះជាពីរកំណាត់ដោយចបកាប់ ហើយមួយកំណាត់ៗត្រូវបានកប់នៅក្រោមគល់ដូងមួយៗដើម្បីធ្វើជី"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.36 ["គឺពួកយើងចាំឃ្លាំមើល ក្រែងមានទូកសត្រូវចូលមកដែនទឹកកម្ពុជា។ [...] នៅពេលដែលចាប់បានទូកហើយ គេមិនលែងទូកទាំងអស់នោះទេ ចំណែកមនុស្សដែលនៅលើទូកនោះ ក៏ទុកនៅនឹងគល់ដូង (សម្លាប់ និងកប់នៅនឹងគល់ដូង)ផងដែរ"]។

1464 ឯកសារ D1.3.30.25 សារទូរស័ព្ទសម្ងាត់ពី មុត ចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨ EN 00183357, 00143507។ សម្គាល់៖ មានសំណៅជាភាសាអង់គ្លេសពីរច្បាប់ គឺទី១ ឯកសារ ដែលមាន ERN 00143507 ជាសំណៅបកប្រែពេញលេញ និងមួយទៀត គឺឯកសារ ដែលមាន ERN 00183357 ជាសំណៅបកប្រែចោះៗ។ សំណៅទាំងពីរខុសគ្នាត្រង់ចំនួនជនរងគ្រោះ (១០២នាក់នៅលើឯកសារ EN 00143507 និង១២០នាក់ នៅលើឯកសារ EN 00183357) ហើយភាសាដែលប្រើប្រាស់ ដើម្បីពណ៌នាអំពីការសម្លាប់ជនជាតិវៀតណាម ("ចាប់ និងបាញ់" នៅលើឯកសារ EN 00143507 និង "ចាប់ និងបាញ់សម្លាប់" នៅលើឯកសារ EN 00183357)។ ឯកសារដើមជាភាសាខ្មែរ គឺ ERN 00017026 បញ្ជាក់ថា មានជនរងគ្រោះចំនួន១២០នាក់ និងថា ជនរងគ្រោះទាំងនោះត្រូវបានបាញ់សម្លាប់។

1465 ឯកសារ D1.3.30.25 សារទូរស័ព្ទសម្ងាត់ពី មុត ចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨ EN 00143507។

1466 ឯកសារ D114/57 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.10-14 ["ស: តើលោកអាចពន្យល់ប្រាប់យើងខ្ញុំអំពីអ្វីដែលលោកបានឃើញដែរ ឬទេ? ឆ.11: យប់មួយនោះ នៅពេលដែលខ្ញុំនៅលើកោះតាង ខ្ញុំបានឃើញទូកមួយត្រូវបាននាវាកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យចាប់យកមក ដែលមានជនជាតិវៀតណាមនៅលើទូកនោះ។ ស: តើវាកើតឡើងនៅពេលណា? ឆ. 12: ប្រហែលជាចន្លោះឆ្នាំ ១៩៧៧-១៩៧៨ ប៉ុន្តែមិនមែននៅក្នុងឆ្នាំ១៩៧៦ឡើយ។ ស: តើលោកចាំថា នៅពេលណាមួយនៃឆ្នាំដែរ ឬទេ? ឆ. 13: ប្រហែលជានៅរដូវប្រាំង ចន្លោះពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨។ ស: តើអ្នកណាជាអ្នកចាប់ទូកនោះ? ឆ. 14: ជានាវារបស់កងទ័ពជើងទឹក"]។

បាននាំអ្នកភៀសខ្លួនជាអ្នកទោស មានបុរស ស្ត្រី និងកុមារ ទៅកោះតាង[1467]។ សំ សោម បានឮពីទាហានផ្សេងទៀតថា ក្រោយមក ជនជាតិវៀតណាមទាំងនេះត្រូវគេសម្លាប់ចោល[1468]។

404. សំ សោម ក៏បានរៀបរាប់ផងដែរថា ក្នុងអំឡុងពេលដដែលនោះ ទូកវៀតណាមមួយគ្រឿងត្រូវបានកងនាវាចាប់។ អ្នកដំណើរសុទ្ធតែជាជនស៊ីវិល រួមមាន បុរស ស្ត្រី និងកុមារ។ ពួកគេត្រូវបាននាំទៅកោះតាង រួចសម្លាប់ចោល[1469]។ សាក្សី ជុំ ជី បានអះអាងថា ពេលមួយ គេចាប់ទូកមួយគ្រឿង

---

1467 ឯកសារ D114/57 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.20-21 ["ស: ហេតុអ្វីបានជាលោកនិយាយថា ទូកនោះមិនមែនជាទូកនេសាទ? ឆ. 20: ដោយសារតែទូកនោះអាចដាក់មនុស្សបានច្រើន។ បើតាមការសន្និដ្ឋានរបស់ខ្ញុំ វាគឺជាទូកដែលគេប្រើសម្រាប់ដឹកជនចំណាកស្រុក ឬក៏ជនភៀសខ្លួនវៀតណាម។ ស: តើអ្នកដែលត្រូវបានគេចាប់នោះមានភេទអ្វីខ្លះ? ឆ.21: ពួកគេមានប្រុស មានស្រី និងកូនក្មេង"]។

1468 ឯកសារ D114/57 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.26-28 ["ស: តើលោកឃើញទូក ឬក៏មនុស្សទាំងនោះនៅព្រឹកថ្ងៃបន្ទាប់ដែរ ឬទេ? ឆ. 26: នៅថ្ងៃបន្ទាប់នោះ ខ្ញុំមិនបានត្រឡប់មកកន្លែងនេះវិញឡើយ តែក្រោយមក ខ្ញុំបានឮពីយោធាដែលធ្វើការជាមួយគ្នាថា អ្នកទាំងនោះត្រូវបានគេសម្លាប់អស់ហើយ។ ស: តើអ្នកដែលធ្វើជាយោធាជាមួយលោកដឹងរឿងនេះដោយរបៀបណា? ឆ. 27: ខ្ញុំមិនច្បាស់ទេ គេបានប្រាប់រឿងនេះតគ្នា។ បើតាមការសន្និដ្ឋានរបស់ខ្ញុំ អាចមានលទ្ធភាពចំនួនពីរកើត
ឡើង។ ទី១ អ្នកទាំងនោះត្រូវបានគេយកទៅសម្លាប់នៅលើកោះនោះតែម្តង ឬពួកគេត្រូវបានគេយកទៅទុកនៅលើកោះនោះ ២-៣ថ្ងៃសិន រួចយកមកដីគោកវិញ។ ស: ហេតុអ្វីបានជាលោកនិយាយថា លោកអាចគិតឃើញលទ្ធភាពទាំងពីរនេះ? ឆ. 28: ខ្ញុំមិនចង់និយាយបំភ្លើសឡើយ ខ្ញុំគ្រាន់តែចង់ប្រាប់លោកអំពីអ្វីដែលខ្ញុំដឹងច្បាស់ប៉ុណ្ណោះ។ អ្វីដែលខ្ញុំដឹងច្បាស់នោះ គឺខ្ញុំបានឮពីយោធាដូចគ្នាថា អ្នកទាំងនោះត្រូវបានគេសម្លាប់។ លទ្ធភាពទាំងពីរដែលខ្ញុំនិយាយខាងដើមគ្រាន់តែជាកាសន្និដ្ឋានរបស់ខ្ញុំប៉ុណ្ណោះ"]។

1469 ឯកសារ D114/57 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.10-26 ["ស: តើលោកបានសង្កេតឃើញស្ថានភាពអ្វីដែរ ឬទេ ពាក់ព័ន្ធនឹងទូកវៀតណាមដែលគេចាប់បានមក? ឆ. 10: ខ្ញុំបានឃើញហេតុការណ៍បែបនេះតែម្តងប៉ុណ្ណោះ នៅពេលដែលខ្ញុំស្ថិតនៅកោះតាង។ ឆ. 11: យប់មួយនោះ នៅពេលដែលខ្ញុំនៅលើកោះតាង ខ្ញុំបានឃើញទូកមួយត្រូវបាននាវាកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យចាប់យកមក ដែលមានជនជាតិវៀតណាមនៅលើទូកនោះ។ ស: តើវាកើតឡើងនៅពេលណា? ឆ. 12: ប្រហែលជាចន្លោះឆ្នាំ ១៩៧៧-១៩៧៨ ប៉ុន្តែមិនមែននៅក្នុងឆ្នាំ១៩៧៦ឡើយ។ ស: តើលោកចាំថា នៅពេលណាមួយនៃឆ្នាំដែរ ឬទេ? ឆ. 13: ប្រហែលជានៅរដូវប្រាំង ចន្លោះពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨។ ស: តើអ្នកណាជាអ្នកចាប់ទូកនោះ? ឆ. 14: ជានាវារបស់កងទ័ពជើងទឹក។ ស: តើលោកដឹងដោយរបៀបណា? ឆ. 15: នាវានេះច្បាស់ជារបស់កងទ័ពជើងទឹក និយាយបែបនេះ ដោយសារតែមានកាំភ្លើងតម្លើងភ្ជាប់នឹងនាវាតែម្តង។ មានតែនាវាកងទ័ពជើងទឹកប៉ុណ្ណោះ ដែលមានតម្លើងកាំភ្លើងនៅជាប់នាវាដូច្នេះ។ នាវានេះជារបស់កងទ័ពជើងទឹកកងពល១៦៤។ មាស មុត គឺជាបញ្ជាការកងពលធំនេះ។ ខ្ញុំមិនដឹងឲ្យប្រាកដថា មានអ្វីកើតឡើងនៅពេលនោះទេ ប៉ុន្តែខ្ញុំឃើញច្បាស់ថា នាវាកងទ័ពជើងទឹកនោះបានចាប់ទូកដែលមានជនជាតិវៀតណាមនោះយកមក។ បន្ទាប់មក នាវា

មានជនភៀសខ្លួនវៀតណាម ៧-៨ នាក់ រួចនាំទៅជិតផែថ្ម ខាងកើតកោះពូលូវ៉ៃ។ ក្រោយមក សាក្សីបានឮថា ជនភៀសខ្លួនទាំងនេះត្រូវគេសម្លាប់[1470]។ ជនរងគ្រោះទាំងនេះធ្វើដំណើរតាមទូកឈើខ្នាតតូច ឬមធ្យម និងស្លៀកសម្លៀកបំពាក់មិនមែនយោធា[1471]។

---

របស់កងទ័ពជើងទឹកនោះ បានយកទូករួមជាមួយនឹងមនុស្សដែលគេចាប់បាននោះមកកាន់កោះនេះ។ ស៖ តើលោកចង់និយាយអំពីកោះណា? ឆ. 16: កោះតាង។ ស: តើលោកឃើញហេតុការណ៍នេះពីកន្លែងណា? ឆ. 17: នៅពេលនោះ ខ្ញុំត្រឡប់មកពីលេងនៅផែ ហើយខ្ញុំដើរទៅកន្លែងស្នាក់នៅ។ កន្លែងដែលខ្ញុំស្នាក់នៅមានចម្ងាយប្រហែល១គីឡូម៉ែត្រពីផែនោះ។ វាជារឿងចៃដន្យ ដែលខ្ញុំបានឃើញហេតុការណ៍នោះ។ ស: តើទូកវៀតណាមនោះ ជាទូកប្រភេទអ្វី? តើលោកឃើញអ្វីខ្លះនៅពេលនោះ? ឆ. 18: ខ្ញុំឮគេនិយាយថា ទូកនោះមានគ្នាប្រហែលជា១០នាក់។ ទូកនោះមានទំហំប្រហែលជា១០ម៉ែត្រ គុណនឹង១.៥ទៅ២ម៉ែត្រ។ ស: តើលោកឃើញទូកនោះនៅលើទឹក ឬក៏នៅច្រាំង? ឆ. 19: ខ្ញុំឃើញទូកនោះនៅច្រាំង។ ទូកវៀតណាមនោះត្រូវបានគេយកមកឆ្នេរ។ ពាក្យផែ ដែលខ្ញុំនិយាយនេះ គឺឆ្នេរខ្សាច់ នៅលើកោះតាង ដូចឆ្នេរអូរឈើទាលដែរ។ ស: ហេតុអ្វីបានជាលោកនិយាយថា ទូកនោះមិនមែនជាទូកនេសាទ? ឆ. 20: ដោយសារតែទូកនោះអាចដាក់មនុស្សបានច្រើន។ បើតាមការសន្និដ្ឋានរបស់ខ្ញុំ វាគឺជាទូកដែលគេប្រើសម្រាប់ដឹកជនចំណាកស្រុក ឬក៏ជនភៀសខ្លួនវៀតណាម។ ស: តើអ្នកដែលត្រូវបានគេចាប់នោះមានភេទអ្វីខ្លះ? ឆ.21: ពួកគេមានប្រុស មានស្រី និងកូនក្មេង។ ស: ហេតុអ្វីបានជាលោកដឹង? តើលោកឃើញពួកគេនៅពេលណាមួយឬ? ឆ. 22: ខ្ញុំឃើញក្មេងអាយុចន្លោះពី៧ទៅ១០ឆ្នាំ។ ក្មេងទាំងនោះមានការភ័យខ្លាច និងយំ។ នៅពេលនោះ ខ្ញុំកំពុងដើរនៅតាមឆ្នេរ។ ស: លោកបាននិយាយថា ពេលនោះជាពេលយប់ តើលោកអាចឃើញដោយរបៀបណា? តើមានពន្លឺដែរឬទេ? ឆ. 23: វានៅឆ្ងាយពីខ្ញុំប្រហែលពី១៥ទៅ២០ម៉ែត្រ។ ពេលនោះ ជាខែភ្លឺ ខ្ញុំអាចឃើញយ៉ាងច្បាស់ ពុំមានអ្វីបាំងនោះឡើយ។ ស: តើលោកបានឃើញថា អ្នកណាម្នាក់ត្រូវបានគេចងដែរ ឬទេ? ឆ.24: ពួកគេមិនត្រូវបានចងឡើយ។ ស: តើលោកអាចឃើញថាអាចមានអ្វីកើតឡើងចំពោះអ្នកទាំងនោះទេ? ឆ. 25: ខ្ញុំមិនដឹងពីអ្វីដែលកើតឡើងបន្ទាប់នោះទេ ដោយសារតែខ្ញុំបានចាកចេញពីទីនោះភ្លាម នៅពេលដែលខ្ញុំឃើញអ្វីដែលបានកើតឡើង។ ខ្ញុំឃើញក្មេង១យំ ហើយឮពួកគេនិយាយវៀតណាម។ ស: តើលោកឃើញទូក ឬក៏មនុស្សទាំងនោះនៅព្រឹកថ្ងៃបន្ទាប់ដែរ ឬទេ? ឆ. 26: នៅថ្ងៃបន្ទាប់នោះ ខ្ញុំមិនបានត្រឡប់មកកន្លែងនេះវិញឡើយ តែក្រោយមក ខ្ញុំបានឮពីយោធាដែលធ្វើការជាមួយគ្នាថា អ្នកទាំងនោះត្រូវបានគេសម្លាប់អស់ហើយ។"]។

1470 ឯកសារ D114/262 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី ឆ.46-53 ["ឆ: [...] សូមយើងបន្តពិភាក្សាបន្ថែមទៀតទៅលើព្រឹត្តិការណ៍នៃការចាប់ជនភៀសខ្លួនវៀតណាម និងបញ្ហាក់ដំបូងសិនអំពីហេតុការណ៍នេះ មុននឹងយើងពិភាក្សាតទៅទៀត។ តើលោកអាចប្រាប់យើងបន្ថែមទៀតបានទេ អំពីហេតុការណ៍នេះ? ឧទាហរណ៍ តើកាលនោះ មានជនភៀសខ្លួនប៉ុន្មាននាក់ដែរ? ឆ. 46: ចំនួនមិនច្បាស់ទេ ប្រហែលជាង៧-៨នាក់។ ស្រី ប្រុស ក៏អត់បានយល់ដែរ។ ស: តាមការចងចាំរបស់លោក តើគេសរសេរត្រឹមត្រូវដែរ ឬទេ នៅក្នុងរបាយការណ៍នេះថា ជនភៀសខ្លួនទាំងនោះ ត្រូវបានគេដាក់ឲ្យនៅក្បែរផែថ្ម នៅខាងកើតកោះនោះ? ឆ. 47: ត្រឹមត្រូវ ព្រោះលោកបានជួយរំឭកទើបខ្ញុំយល់ ព្រោះយូរឆ្នាំពេក ខ្ញុំភ្លេចៗ អរគុណ ដែលជួយរំឭក។ ស: តើមានអគារ ឬរោងអ្វីដែរនៅផែថ្មខាងកើតនោះ ឆ.48: បើតាមពិត មិនមានជាអគារ ជារោងអីទេ ឧទាហរណ៍ ដូចជាថ្មធំ ទឹកជ្រៅ យើងសុំចតទូក ឬកប៉ាល់បាន គេឲ្យឈ្មោះថា "ផែថ្ម"។ នៅកោះ

405. ក្នុងឧប្បត្តិហេតុមួយទៀត លើកោះពូលូវ៉ៃថ្មី នៅខែ មេសា ឬខែ ឧសភា ឆ្នាំ ១៩៧៥ កម្លាំងខ្មែរក្រហមចាប់បានទូកមួយគ្រឿង ដឹកជនភៀសខ្លួនវៀតណាមជាង ១០ នាក់ រួមទាំងស្ត្រី និងកុមារ។ ពួកគេត្រូវបាននាំទៅភាគខាងកើតនៃកោះ រួចឃុំ និងផ្តល់អាហារហូប បានពីរបីថ្ងៃ។ ក្រោយពីការចាប់ មេបញ្ជាការកងវរសេនាតូច ៤០៨ "បានទាក់ទងទៅកំពង់សោម ដើម្បីសុំសេចក្តីណែនាំអំពីចំណាត់ការលើជនភៀសខ្លួនទាំងនេះ។ ទីបញ្ជាការធំនៅកំពង់សោមបានបញ្ជាឱ្យមេបញ្ជាការនោះសម្លាប់ជនភៀសខ្លួន។ មេបញ្ជាការ និងមេបញ្ជាការរងបានអនុវត្តតាមបញ្ជា[1472]។

---

តាង ក៏មានផែដែលគេចតកប៉ាល់បាន កដបហ្នឹង ហ្នឹងគេហៅ "ផែថ្ម" ដែរ មិនមែនជាផែថ្ម ដែលយើងសាងសង់ទេ។ វាដុះថ្មដោយឯងៗ។ ស: តើលោកនៅចាំថា នរណាគេជាអ្នកចាប់ទូកជនភៀសខ្លួននេះ? ឆ. 49: ខ្ញុំមិនបានយល់ទេ ព្រោះកាលហ្នុង យើងចម្រុះគ្នាជាមួយកងតំបន់៣៧ និងវរសេនាតូច៤២០ ព្រោះអ្វីដែលយើងមិនបានធ្វើផ្ទាល់ និងដឹងផ្ទាល់ ក៏មិនអាចឆ្លើយជាការពិតបានដែរ។ ស: តើលោកអាចដឹងថា មេបញ្ជាការអនុសេនាធំលេខ៤០៨ ដែលបានទាក់ទងក្រុងកំពង់សោម សុំការណែនាំឈ្មោះអ្វីដែរទេ? ឆ50: ព្រោះអត់បានយល់ អត់បានស្គាល់ទេ យើងទើបតែច្របាច់ចូលគ្នាដំបូង អត់បានស្គាល់ទេ។ ស: តើលោកដឹងអំពីហេតុការណ៍នេះ ពីណាមកវិញកាលនោះ? ឆ. 51: ហេតុការណ៍ដែលកើតមាន ដឹងពីមិត្តភក្តិនៅក្នុងកងទ័ពជាមួយគ្នា។ ស: តាមលោកដឹង តើមានរឿងអ្វីកើតឡើងទៅដល់ជនភៀសខ្លួនវៀតណាម ដែលគេចាប់បានពេលនោះ? ឆ.52: ពេលដែលយើងដឹង ខ្ញុំដឹង គេបានសម្លាប់ទៅហើយ អត់ដឹងផែនការគេយកទៅសម្លាប់ជាមុនទេ។ ស: តើលោកដឹងថា គេសម្លាប់អ្នកទាំងនោះដោយមធ្យោបាយអ្វី និងនៅទីណាដែរ ឬទេ? ឆ.53: ដឹងចំណុច តែមិនបានពិតប្រាកដទេ ព្រោះកាលហ្នឹងនៅវ័យក្មេង មិនបានចាប់អារម្មណ៍ពីការកាប់សម្លាប់របស់ថ្នាក់លើ។ គេធ្វើអ្វី គេមិនដែលប្រាប់យុទ្ធជនឱ្យបានដឹងច្បាស់ទេ។ គេសម្រេចតែខាងលើៗយើងតទៅទៀត។ ពេលគេសម្លាប់ហើយ ទើបយើងដឹង សម្រាប់ដោយបាញ់កាំភ្លើង។ សពហ្នឹងតាមមើលនៅថ្មនៅម្តុំជិតផែថ្ម"]។

1471 ឯកសារ D114/264 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី ឆ.2-6 ["តាមខ្ញុំដឹង និងខ្ញុំយល់ ប្រភេទទូកដែលជនជាតិវៀតណាមឆ្លងកាត់ដែនសមុទ្ររបស់យើង គឺជាទូកប្រភេទឈើទេ។ វាជាទូកឈើប្រភេទតូចល្មម [...] ខ្ញុំសូមជម្រាបបន្តថា សាកសពជាជនជាតិ មិនមែនជាលក្ខណៈឯកសណ្ឋានដូចយោធាទេ សម្លៀកបំពាក់គឺចម្រុះពណ៌ ខៀវ ស លឿង នេះជាលក្ខណៈរបស់ជាតិសាសន៍ និងប្រជាជន"]។

1472 ឯកសារ D4.1.754 ព័ត៌មានសម្ងាត់របស់សហរដ្ឋអាមេរិក ពាក់ព័ន្ធនឹងហេតុការណ៍ និងឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេសនៅលើកោះពូឡូវ៉ៃ នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៥ EN 00387429, KH 00791383 ["នៅក្នុងខែមេសា ឧសភា ឆ្នាំ ១៩៧៥ អង្គភាពរបស់គាត់បានចាប់នាវាមួយគ្រឿង ដែលបានដឹកជនជនភៀសខ្លួនវៀតណាមជាង១០នាក់ រួមទាំងស្ត្រី និងកុមារ។ អង្គភាពរបស់ប្រភពព័ត៌មានបានផ្តល់ចំណីអាហារ និងយកជនជាតិវៀតណាមទាំងនោះទៅទុកនៅជិតផែថ្ម ភាគខាងកើតនៃកោះពូឡូវ៉ៃថ្មី អស់រយៈពេលពីរ ឬបីថ្ងៃ។ បន្ទាប់ពីពួកគេចាប់បាននាវានោះមក មេបញ្ជាការកងអនុសេនាធំលេខ៤០៨ បានទាក់ទងក្រុងកំពង់សោម ដើម្បីសុំការណែនាំស្តីពីការចាត់ចែងជនភៀសខ្លួនទាំងនោះ។ មេបញ្ជាការថ្នាក់លើនៅក្រុងកំពង់សោមបានបញ្ជាឱ្យមេបញ្ជាការកងអនុសេនាធំនេះសម្លាប់ជនភៀសខ្លួនទាំងនោះចោល។ មេបញ្ជាការ និងអនុបញ្ជាការកងអនុសេនាធំបានអនុវត្តតាមបញ្ជានេះ"]។

406. សាក្សី ឯក នី បានបញ្ជាក់ថា ខណៈដែលជាទូទៅ អ្នកទោសវៀតណាម និងថៃ ត្រូវបាននាំយកទៅសម្លាប់នៅតំបន់កំពង់សោម **មាស មុត** ក៏ "បានបញ្ជាមកយើងកុំឱ្យខាតសាំង ដើម្បីដឹកពួកគេមកកំពង់សោមធ្វើអី [ហើយ] ប្រាប់យើងឱ្យយកធ្វើជាជីដាក់គល់ដូងលើកោះទាំងអស់ទៅ"[1473]។ ពួកមេកងបានប្រាប់ ឯក នី ថា៖ "យើងមិនបាច់បញ្ជូនអ្នកទាំងនោះទៅកំពង់សោមទៀតទេ ពីព្រោះបងប្រធានកងពលបានប្រាប់យើងឱ្យបញ្ចប់ពួកនោះនៅនឹងកន្លែងទៅម្តង"[1474]។ សេចក្តីណែនាំបែបនេះត្រូវបានអនុវត្តតាម ហើយការសម្លាប់ត្រូវបានធ្វើនៅលើកោះ។ ឧទាហរណ៍ ឌុល សុង ទាហានកងវរសេនាធំ ១៤០ បានឃើញគេចាប់អ្នកនេសាទថៃ ៣០ នាក់ នៅលើសមុទ្រ ក្នុង

---

1473 ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.29, 41-44 ["កន្លែងនៅខាងលិចចម្ការដូង ជាប់នឹងជើងភ្នំ គឺជាចម្ការធូរ៉េន ដែលជាកន្លែង តាមុត យកជនជាតិថៃទៅសម្លាប់ ហើយកប់សាកសពនៅក្រោយដើមធូរ៉េនសម្រាប់ធ្វើជី។ ប្រសិនបើ ជនជាតិថៃចង់ស្វែងរកឆ្អឹងបងប្អូនពួកគេ ពួកគេអាចទៅរកនៅចម្ការធូរ៉េននោះចុះ។ ពេលគេចាប់បានទូកនេសាទថៃ១៤០០សេស ចំនួនពីរគ្រឿង និង១៨០០សេស ១គ្រឿង គេយកអ្នកនេសាទថៃទាំងអស់ទៅសម្លាប់ទីនោះ។ នៅពេលនោះ គេប្រើនាវាបោសសម្អាតមីន ដែលមានល្បឿនលឿនដើម្បីចាប់ទូកនេសាទថៃ។ នាវានោះលឿនណាស់ ដូចយន្តហោះអីចឹង។ អំឡុងពេលនោះ នៅពេលដែលគេចាប់បានជនភៀសខ្លួនជនជាតិវៀតណាម ដែលធ្វើដំណើរតាមទូកភៀសខ្លួនទៅប្រទេសទី៣ គេយកពួកវៀតណាមទាំងនោះទៅសម្លាប់ដាក់នៅចម្ការធូរ៉េនផងដែរ។ គេ [ខ្មែរក្រហម] ហៅអ្នកភៀសខ្លួនវៀតណាមទាំងនោះថាជា កូនជ្រូក។ គេថា គេយកអ្នកទាំងនោះទៅធ្វើជីដាក់ដើមធូរ៉េន [...] ឆ.41: ពីដំបូងឡើង ពេលយើងចាប់ពួកវៀតណាម និងថៃបាន យើងបញ្ជូនទៅឱ្យ តា មុត នៅកំពង់សោម ប៉ុន្តែ ក្រោយមក តា មុត បានបញ្ជាមកយើងកុំឱ្យខាតសាំង ដើម្បីដឹកពួកគេមកកំពង់សោមធ្វើអី ឱ្យយកធ្វើជាជីដាក់គល់ដូងនៅលើកោះទាំងអស់ទៅ។ សាកសពម្នាក់ត្រូវកាត់ជាពីរកំណាត់ ហើយមួយកំណាត់ៗកប់នៅក្រោមដើមដូងមួយដើមៗ។ ស: តើលោកបានឃើញការកាត់សាកសពជាពីរកំណាត់ដោយផ្ទាល់ភ្នែករបស់លោកដែរ ឬទេ? ឆ.42: ទេ ខ្ញុំមិនបានឃើញពេលដែលគេកំពុងកាត់សាកសពនោះទេ ប៉ុន្តែគ្រប់ៗគ្នាដឹងអំពីរឿងនេះ ដោយសារក្លិន ហើយនិងស្នាមហើយនៅខាងក្រោមរណ្តៅដូងតូចៗនោះ។ ស: នៅពេលដែលលោកនិយាយថា ពេលចាប់ពួកវៀតណាម និងថៃ គឺបញ្ជូនទៅឱ្យ តា មុត នៅកំពង់សោម សូមលោកពន្យល់ ថាតើលោកនិយាយនេះមានន័យថាម៉េច? ឆ.43: អ្នកណាក៏ដោយ ដែលចាប់បានដោយកងជងទឹកត្រូវតែបញ្ជូនទៅឱ្យ តាមុត នៅកំពង់សោម ហើយយើងឮថា ពួកគេនឹងត្រូវបង្ហើយនៅចម្ការធូរ៉េនទាំងអស់។ នៅពេលនោះ កន្លែងសម្លាប់របស់កងពល១៦៤ គឺមានតែនៅចម្ការធូរ៉េនទេ"]។

1474 ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.43 ["អ្នកណាក៏ដោយ ដែលចាប់បានដោយកងជើងទឹកត្រូវតែបញ្ជូនទៅឱ្យ តាមុត នៅកំពង់សោម ហើយយើងឮថា ពួកគេនឹងត្រូវបង្ហើយនៅចម្ការធូរ៉េនទាំងអស់។ នៅពេលនោះ កន្លែងសម្លាប់របស់កងពល១៦៤ គឺមានតែនៅចម្ការធូរ៉េនទេ"]។ ស: ម៉េចបានជាលោកដឹងថា តាមុត ប្រាប់មិនឱ្យបញ្ជូនអ្នកដែលចាប់បានទាំងនោះទៅកំពង់សោមទៀត? ឆ.44: ពួកមេកងៗប្រាប់ថា យើងមិនបាច់បញ្ជូនអ្នកទាំងនោះទៅកំពង់សោមទៀតទេ ពីព្រោះបងប្រធានកងពលបានប្រាប់យើងឱ្យបញ្ចប់ពួកនោះនៅនឹងកន្លែងតែម្តង"]។

ឆ្នាំ ១៩៧៧។ អ្នកនេសាទត្រូវគេចងដៃ រួចនាំទៅកោះពូលូវ៉ៃ ហើយវាយសម្លាប់ដោយកម្លាំងកងពល ១៦៤[1475]។

## ការប្រព្រឹត្តិខុសគ្នាចំពោះជនជាតិវៀតណាម និងថៃ

407. ទោះបីជាទាំងវៀតណាម និងថៃ ត្រូវបានចាត់ទុកជា "ខ្មាំង" ក៏ដោយ ក៏កងកម្លាំងរបស់ **មាស មុត** បានប្រព្រឹត្តខុសគ្នាទៅលើវៀតណាម និងថៃ ដែលចាប់បាននៅលើសមុទ្រ[1476]។ វៀតណាមត្រូវគេ

1475 ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.41-49 ["សៈ នៅក្នុងបទសម្ភាសន៍របស់លោកជាមួយអង្គការអាដហុក លោកបាននិយាយថា លោកឃើញគេសម្លាប់ជនជាតិថៃ៣០នាក់នៅលើទូក សូមលោករៀបរាប់ប្រាប់យើងអំពីព្រឹត្តិការណ៍នោះបានឬទេ? ឆ41: រឿងរ៉ាវនេះកើតឡើងក្នុងរយៈពេល ដែលខ្ញុំហាត់ហ្វឹកហ្វឺនទ័ពជើងទឹក។ ខ្ញុំបានឃើញថៃដែលគេចាប់បាន យកមកដាក់នៅលើកោះមួយ។ សៈ តើវាកើតឡើងក្នុងឆ្នាំណា? ឆ.42: នៅឆ្នាំ១៩៧៧។ សៈ តើនៅលើកោះណា? ឆ43: នៅកោះពូលូវ៉ៃ។ សៈ តើជនជាតិថៃទាំងនោះជាពួកអ្វី សូមលោករៀបរាប់ប្រាប់យើង? ឆ.44: គឺជាពួកនេសាទថៃ សុទ្ធតែជាមនុស្សប្រុសពេញវ័យ។ ខ្ញុំឃើញទូកនេសាទមួយនៅទីនោះដែរ។ សៈ ម៉េចបានជាលោកដឹងថាជាពួកគេជាអ្នកនេសាទត្រី មិនមែនជាទាហានខ្មាំង? ឆ.45: ពីព្រោះទូកនោះជាទូកនេសាទ ហើយយោធារបស់យើងនៅលើកោះបាននិយាយថា ពួកទាំងនោះជាពួកនេសាទ។ សៈ តើស្ថានភាពរបស់អ្នកដែលគេចាប់នោះយ៉ាងម៉េច ពេលលោកបានឃើញ? ឆ.46: គេចងដៃ ហើយយោធានៅលើកោះបានប្រាប់ថា គេនឹងសម្លាប់ពួកនេសាទទាំងនោះ។ សៈ តើយោធាដែលចាប់អ្នកនេសាទនោះឋិតនៅក្នុងកងណាមួយ? ឆ.47: ពួកគេជាកងថ្មើរជើងរបស់កងពល១៦៤ ដែលឈរជើងនៅតាមកោះ។ ខ្ញុំមិនដឹងថា គេនៅក្នុងកងវរៈសេនាធំលេខប៉ុន្មានទេ។ សៈ តើលោកមានស្គាល់យោធាណាខ្លះ ដែលនៅក្នុងកងដែលបានចាប់អ្នកនេសាទនោះ ហើយនៅរស់ដល់សព្វថ្ងៃនេះដែរទេ? ឆ.48: ទេ ខ្ញុំមិនស្គាល់ទេ"]។

1476 ឯកសារ D234/2.1.95 មាស វឿន ប្រតិចារឹក ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 14.10.55-14.14.10 ["បើសិនជាយើងចាប់បាន ក៏យើងបញ្ជូនទៅស្រុកថៃវិញដែរ។ តែបើជនជាតិវៀតណាម ក៏យើងបញ្ជូនទៅតាមផ្លូវនយោបាយហ្នឹងដែរ។ តែខ្ញុំចាប់បានកន្លងទៅ ខ្ញុំបញ្ជូនទៅតាមៗថ្នាក់ដឹកនាំ [...] តាមថ្នាក់កងពល[164]អីចឹងទៅ"]។ ឯកសារ D234/2.1.96 មាស វឿន ប្រតិចារឹក ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 09.54.58-09.56.22 ["តើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកធ្លាប់ឮថា វៀតណាមដែលនៅក្នុង ឬក៏ក្រៅទឹកដីកម្ពុជា គឺជាសត្រូវស្នូលរបស់ខ្មែរទេ? ឆ: បាទ ឮ ប្រជាជនខ្មែរក៏ឮ ខ្ញុំក៏ឮទាំងអស់គ្នា ជាសត្រូវស្នូលជ"]។ សូមមើលផងដែរ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.32 ["បាទ ពីព្រោះថៃមិនមានទំនាស់ច្រើនជាមួយខ្មែរទេនៅក្នុងប្រវត្តិសាស្ត្រ ប៉ុន្តែយួនមានទំនាស់ជាមួយខ្មែរច្រើន ទើបយួនត្រូវបានចាត់ទុកថាជាសត្រូវស្នូលពូជ និងសត្រូវទី១"]។ ឯកសារ D114/283 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.18 ["ព្រោះអាហ្នឹងច្បាប់ពីខាងលើមកត្រូវតែកម្ទេច ពូជសាសន៍យួនជាដាច់ខាត ទោះប្រជាជន ឬនេសាទអី ត្រូវតែចាប់ទាំងអស់"]។

ចាត់ទុកជា "សត្រូវស្បូរពូជ"[1477] ជាខ្មាំងឈ្លានពានដែលមិនអាចអត់ឱនឲ្យបាន និងត្រូវកម្ទេច[1478]។ គំនិតនេះត្រូវបានថ្នាក់លើផ្សព្វផ្សាយ ហើយត្រូវបានថ្នាក់ក្រោមអនុវត្តតាម[1479]។ ផ្ទុយទៅវិញ ជនជាតិថៃត្រូវបានកំណត់មុខសញ្ញាសម្រាប់ចាប់ ឃុំ និងសម្លាប់ ប៉ុន្តែ អាចរួចជីវិតផងដែរ ប្រសិនបើកងកម្លាំងរបស់ **មាស មុត** មិនចង់សម្លាប់[1480]។

---

[1477] ឯកសារ D114/264 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី ឆ.12 ["បើខ្ញុំឆ្លើយជូនលោកថា ជនជាតិវៀតណាម និងកម្ពុជាពេលនោះ កម្ពុជាប្រជាធិបតេយ្យលោកយល់ហើយថា វាជាសត្រូវស្បួពូជពីមុនមក ដែលយើងបានឮពីដូនតាយើង"]។

[1478] ឯកសារ D114/283 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.11, 14 ["ស: ពេលហ្នឹងតាមលោកដឹង ថាហេតុអ្វីគេសម្លាប់ពួកវៀតណាមហ្នឹង? ឆ.11: គឺវាចាត់ថា យួនជាពួកឈ្លានពាន ឲ្យតែជួប វាអត់ទុកតែម្តង ត្រូវតែកម្ទេច។ [...] ស: សូមលោកជួយពន្យល់ពាក្យ "គូមុខពេញទី"។ ឆ.14: ឃើញគ្នាមិនបានទេ សត្រូវស៊ីសាច់គ្នា ឃើញគ្នាអត់បានហើយ អត់មានលើកលែងទេ"]។ ឯកសារ D234/2.1.96 មាស វឿន ប្រតិចារឹក ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 10.07.02-10.08.43 ["បើអីចឹង បើខ្ញុំចាប់ កន្លងមកបើខ្ញុំចាប់យួនបាន ខ្ញុំកម្ទេចទាំងអស់នៅតាមមុខសញ្ញាកោះកុង ខ្ញុំបាត់ទៅហើយ។ ដូចខ្ញុំ អីចឹងបានជាខ្ញុំបញ្ជូនទៅតាមថ្នាក់ដឹកនាំរបស់ខ្ញុំ គេដោះស្រាយតាមមធ្យោបាយយ៉ាងម៉េច អាហ្នឹងវាជារឿងមួយផ្នែកខាងគេទៀត។ ខ្ញុំគិតអីចឹង ព្រោះអីខ្ញុំឃើញថាចាប់បាន វាមិនមានជាទ័ព មិនមានជាកាំភ្លើង មិនមានជាគ្រឿងអាវុធ ខ្ញុំគិតឃើញថាជាប្រជាជនធម្មតា"]។

[1479] ឯកសារ D114/283 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.11, 15, 18-20 ["ស: ពេលហ្នឹងតាមលោកដឹង ថាហេតុអ្វីគេសម្លាប់ពួកវៀតណាមហ្នឹង? ឆ.11: គឺវាចាត់ថា យួនជាពួកឈ្លានពាន ឲ្យតែជួប វាអត់ទុកតែម្តង ត្រូវតែកម្ទេច។ [...] ស: ពេលដែលយើងថា គូមុខដាក់គ្នា អ្នកណាជាអ្នកឲ្យគំនិតថា យើងគូមុខដាក់គ្នាជាមួយវៀតណាម វាចេញមកពីណា? ឆ.15: ចេញពីថ្នាក់លើមក។" [...] ស: យោលទៅតាមសមាសភាពវៀតណាម ដែលរត់ភៀសខ្លួនក្នុងពេលហ្នឹង មានស្រី ប្រុស ក្មេង អត់អាវុធ ដែលឆ្លងចូលមកដែនទឹករបស់កម្ពុជាហ្នឹង មើលទៅពួកគេ ដូចជា មិនមានស្អីដែលត្រូវគំរាមកំហែងយើងទេ។ ហេតុអ្វីបានពួកយោធាក្នុងពេលហ្នឹងគិតថា ត្រូវតែសម្លាប់ពួកហ្នឹង? ឆ.18: ព្រោះអាហ្នឹងច្បាប់ពីខាងលើមកត្រូវតែកម្ទេច ពូជសាសន៍យួនជាដាច់ខាត ទោះប្រជាជន ឬនេសាទអី ត្រូវតែចាប់ទាំងអស់។ ស: យើងចង់ឲ្យលោកជួយរៀបរាប់ប្រាប់ ជាឧទាហរណ៍ របៀបដែលថ្នាក់លើបញ្ចូលមនោគមន៍វិជ្ជាឲ្យយើងស្អប់ពួកយួន រហូតដល់សម្លាប់ហ្នឹង។ តើរបៀបគេបញ្ចូលមនោគមន៍វិជ្ជាដាក់យើងធ្វើតាមរបៀបម៉េច? ឆ.19: ផែនការគេហៅប្រធានកងវរៈ ឬប្រធានកងអនុសេនាធំទៅរៀននៅកន្លែងកងពល។ ស: ចុះចំពោះយើងដែលជាយោធាធម្មតា ដូចលោក តើគេបង្រៀនយើងឲ្យយើងរៀនសូត្ររបៀបការស្អប់ពួកយួនហ្នឹងញឹកញាប់ទេ? ឆ.20: គឺបើកប្រជុំតាមក្រុម គឺប្រជុំរាល់ថ្ងៃ លើកភារកិច្ចការពារប្រទេសជាចម្បង ភារកិច្ចទី១។ ភារកិច្ចទី២ កសាងប្រទេស តែចម្បងការពារប្រទេស អាទិភាពសំខាន់"]។

[1480] ឯកសារ D1.3.30.25 សារទូរស័ព្ទសម្ងាត់ពី មុត ចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨ EN 00143507, KH 00017026, FR 00611668 ["2. ["សៀម ដែលត្រូវដោះលែងមានការយឺតយូរ មិនបានតាមការកំណត់ មូលហេតុពីមានការខុសឈ្មោះ អ្នកដែលមកទទួលខ្លះ តែខុសនេះ តាមពិនិត្យ គឺមិនមានខុសទាំងស្រុងទេ គឺខុសចុងឈ្មោះបន្តិចៗ ជាមូលដ្ឋាន

ត្រូវ ឯការទាក់ទងដល់យោបល់ ក៏មិនបានតាមសំណូមពរ ដោយតេអូរមិនឮគ្នា ផ្អែកលើទូរលេខ ខាងសមមិត្ត ឡូញ ហើយដោយមានការបញ្ជូនសារយឺត និងបាត់ បានធ្វើឱ្យការប្រគល់ថៃនេះ ពន្យារហូតដល់ម៉ោង២០ ថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៧៨។ អ្នកមកទទួលមានចៅហ្វាយស្រុកខ្លងយ៉ៃម្នាក់ និងម្នាក់ទៀត អ្នកប្រជាសង្គ្រោះ។ អាសៀម ដែលមកទទួលនេះបានឱ្យបារីពាសុង ប្រេងកូឡា១ដប ដល់មិត្តយើង"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.80 ["ស: តើអ្នកនេសាទថៃ ដែលចាប់បាននោះត្រូវបញ្ជូនទៅទីណាដែរ? ឆ.80: ខ្ញុំមិនដឹងថា គេបញ្ជូនពួកគេទៅឃុំនៅទីណាទេ ប៉ុន្តែក្រោយមកការចរចារវាងអាជ្ញាធរកម្ពុជា និងថៃ នៅដើមឆ្នាំ១៩៧៧ ហើយមានការដោះដូរអ្នកនេសាទថៃទាំងនោះនៅលើកោះស្តេច"]។ ឯកសារ D54/11 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ហៅ សារ៉េត ឆ.24-26 ["ក្នុងឆ្នាំ១៩៧៦ ខ្ញុំបានឃើញអ្នកនេសាទថៃ ដែលគេចាប់បាន យកមកទុកនៅកោះតាគាវ។ ថ្ងៃមួយ ពេលដែលខ្ញុំទៅបេះដូងនៅកោះតាគាវ ខ្ញុំបានឃើញអ្នកនេសាទថៃនៅទីនោះ។ យោធានៅលើកោះបានប្រាប់ខ្ញុំថា អ្នកទាំងនោះគឺជាអ្នកនេសាទថៃ ដែលគេចាប់យកមក។ អ្នកនេសាទទាំងនោះមិនត្រូវបានគេចងទេ ពួកគេដើរជុំវិញកន្លែងនោះ អ្នកខ្លះបេះដូង និងខ្លះទៀតកំពុងដាំបាយ។ ពួកគេមានគ្នាប្រហែលជា១០នាក់ មានមនុស្សចាស់ខ្លះ ក្មេងខ្លះ ប៉ុន្តែគ្មានកុមារ និងស្ត្រីទេ។ ពួកគេពាក់ខោអាវចម្រុះពណ៌។ ខ្ញុំបានឮពីពួកយោធានៅលើកោះនិយាយថា ស្ថានទូតថៃនឹងទាក់ទងយកពួកអ្នកនេសាទទាំងនោះទៅថៃវិញ។ ស: តើយោធាដែលប្រាប់នោះជាយោធាឋិតនៅក្រោមបញ្ជាកងណា? ឆ.25: ខ្ញុំមិនដឹងថា ពួកយោធាទាំងនោះឋិតក្នុងកងណាទេ តែយោធាទាំងនោះឋិតក្នុងកងពល១៦៤។ ស: យោងទៅតាមការយល់ឃើញរបស់លោក តើពួកអ្នកដែលគេចាប់នោះជាអ្នកនេសាទ ឬយ៉ាងណា? ឆ.26: បាទ ពួកគេសុទ្ធតែជាអ្នកនេសាទ"]។ ឯកសារ D1.3.13.11 បទសម្ភាសន៍របស់ការិយាល័យសហព្រះរាជអាជ្ញាជាមួយ សៀង EN 00217565 ["ការល្បាតនេះ គឺដើម្បីការពារដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ និងដេញពួកនេសាទថៃចេញពីដែនទឹកកម្ពុជាប្រជាធិបតេយ្យ។ នៅពេលគេឃើញទូកនេសាទថៃ គេបាញ់ទៅលើទូកនោះ ហើយបើគេឃើញទូកដដែលៗច្រើនដង គេនឹងចាប់ទូកនោះ ហើយនិងចាប់កម្មករលើទូកនោះទាំងអស់។ ជួនកាល គេព្រមានពួកនេសាទ ហើយលែងពួកគេទៅវិញ។ ជួនកាលទៀត គេចាប់ពួកនេសាទ ហើយទុកទូក។ អាចនឹងមានការចរចារវាងកម្មាភិបាលថ្នាក់ខ្ពស់ និងអាជ្ញាធរថៃ ដើម្បីឱ្យដោះលែងអ្នកនេសាទទាំងនោះ។ រឿងនេះកើតឡើង លុះត្រាណាតែពួកអាជ្ញាធរថៃគេទាក់ទងមកខាងកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ"]។ ឯកសារ D54/115.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នាក់ យឿន EN 01088470, KH 01007869 ["ស: ចាប់រហូតដល់ពេលឆ្នាំណាទៅបានឈប់ចាប់? យឿន: អេ ដល់ឆ្នាំដល់រត់បានឈប់ចាប់ៗទៅ ដល់យួនចាប់បានអត់រស់ទេ។ ស: យួនចាប់បានអត់រស់? យឿន: អត់រស់ទេ បើថៃអត់។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.80 ["ស: តើអ្នកនេសាទថៃដែលចាប់បាននោះត្រូវបញ្ជូនទៅទីណាដែរ? ឆ.80: ខ្ញុំមិនដឹងថា គេបញ្ជូនពួកគេទៅឃុំនៅទីណាទេ ប៉ុន្តែក្រោយមក ការចារចារវាងអាជ្ញាធរកម្ពុជា និងថៃ នៅដើមឆ្នាំ១៩៧៧ ហើយមានការដោះដូរអ្នកនេសាទថៃទាំងនោះនៅលើកោះស្តេច"]។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ ឆ.121 ["ស: ចុះអ្នកនេសាទ ហើយនិងអ្នកបើកទូកថៃនោះ គេធ្វើយ៉ាងម៉េចដែរ? ឆ.121: ពេលគេចាប់បាន គេយកមកដាក់នៅដីគោក នៅរាម កោះតាគាវ ហើយពេលដែលគេចាប់បានច្រើន ប្រជាជនជា១០ ឬ២០នាក់ គេឱ្យទូកវាមួយទៅជិះទៅស្រុកវិញ។ ពេលខ្លះ គេទុកវាកន្លះខែឱ្យរៀននិយាយខ្មែរ រួចទើបឱ្យទៅស្រុកវិញ"]។ ឯកសារ D1.3.13.11 បទសម្ភាសន៍របស់ការិយាល័យសហព្រះរាជអាជ្ញាជាមួយ សៀង ["ជួនកាល គេព្រមានពួកនេសាទ ហើយលែងពួកគេទៅវិញ។ ជួនកាលទៀត គេចាប់ពួក

## ឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេយ៍

---

នេសាទ ហើយទុកទូក។ អាចនឹងមានការចរចារវាងកម្មាភិបាលថ្នាក់ខ្ពស់ និងអាជ្ញាធរថៃ ដើម្បីឱ្យដោះលែងអ្នកនេសាទទាំងនោះ។ រឿងនេះកើតឡើង លុះត្រាណាតែពួកអាជ្ញាធរថៃគេទាក់ទងមកខាងកងកម្លាំងកម្ពុជាប្រជាធិបតេយ្យ"]។ ឯកសារ D54/78.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល់ (ប្រតិចារឹក), KH 00926625-26 ["ស: ចុះករណីពីអ្នកនេសាទថៃវិញ យើងមុននឹងចាប់យើងមានព្រមានគេ ឬក៏យ៉ាងម៉េច ឬក៏ចាប់ហើយបញ្ជូនមកកងពល ហើយយើងប្រលែង បើពួកអ្នកនេសាទថៃ? ហាល់: មិនដែលប្រលែង។ ស: អត់ដែលប្រលែងទេ? ហាល់: បាទ។ ស: យើងបញ្ជូនមកខាងកងពល? ហាល់: វាខ្ញុំជំនាន់នឹង វានឹកឃើញវាចេះ ព្រោះ គេចាប់ទូកថៃ ដែលនៅថៃដែលគេមកនេសាទនេះ គេច្រើនថា ចូលជ្រៅពេក។ ហើយគេទុកពេលឱ្យយូរអញ្ចឹងណា អាខ្លះនៅម៉ាយប់វ៉ាននឹង បាទ វាអត់ចេញពីនឹង។ ស: រំលោភលើដែនដី? ហាល់: បាទ រំលោភលើដែនដី ហើយចាប់មិនៗមែនករណីយប់ទេ ចាប់តែថ្ងៃទេ។ ស: ចាប់តែថ្ងៃ? ហាល់: បាទ ដូច្នេះអានឹងគេតាមដាន ព្រោះយើងនៅកោះ គឺមានដូចកោះប៉ូឡូវ៉ៃ ចាប់ដែលខ្ញុំទៅនៅនឹង មានភ្លើងហ្វាមួយចាស់។ អឺ គេថា ដងចាស់ ប៉ុនឥឡូវ វាមិនមានភ្លើងទេ ឥឡូវអឺកាលនឹងណា ប៉ុនវាមានកន្លែងសម្រាប់អង្គុយមើលជាសព្វថ្ងៃអញ្ចឹង។ អញ្ចឹង យើងតាមដានវាតាំងពីម៉ាថ្ងៃ។ អឺ តាំងពីម៉ាយប់អញ្ចឹង យប់មានឃើញភ្លើងមិនអញ្ចឹងព្រូ។ ដល់ថ្ងៃយើងឃើញរៀងវាអញ្ចឹង។ បាទ នៅនឹងវាអត់ចេញ។ ដល់អញ្ចឹងយើងវាយហើយ ព្រោះតេអូម៉ាម៉ោងទាក់ទងគ្នាម្តង។ មកៗអញ្ចឹងណា ហើយទីតាំងវរសេនាធំ៦២នឹងអឺ គឺនៅកោះតាង យើងនឹង។ ស: មន្ទីរកោះតាង? ហាល់: បាទ ទីតាំងវរសេនាធំនៅនឹងដែរ។ អញ្ចឹងយើងកោះតាងវរសេនាតូច គឺរាយការណ៍ទៅវរសេនាតូច គឺរាយការណ៍ទៅវរសេនាធំ។ ដល់វរសេនាធំ គេវាយទៅលើតាមផែរបស់គេទៀតទៅ។ ឯអារឿងទេចាប់អញ្ចឹង មិនមានកាណូតធម្មតាទេ។ សុទ្ធតែ កប៉ាល់នៅផែទៅចាប់ បានចាប់គេបានព្រោះកាណូតៗដូចគ្នា ល្បឿនប៉ុនគ្នា ដេញគ្នាម៉េចនឹងទាន់"]។ ឯកសារ D54/100 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.160-162, 165 ["ស: ក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយថាអ្នកដែលត្រូវបានចាប់ខ្លួនមួយចំនួន ត្រូវបានបញ្ជូនទៅទីបញ្ជាការ ហើយមួយចំនួនទៀតត្រូវបានដោះលែង តើលោកដឹងរឿងនោះ ដោយរបៀបណា? ឆ.160: ខ្ញុំដឹងតាមរយៈវិទ្យុទាក់ទង ដែលគេនិយាយមក ពេលនោះ គេប្រើតេអូ គឺសំខាន់ជាងគេបង្អស់។ ស: តើនរណាជាអ្នករាយការណ៍រឿងទាំងអស់នោះ? ឆ.: 161: តាមពិត គេទាក់ទងតាមរយៈកងពល បើកងពលគេថាឱ្យយកមក គឺគេនឹងបញ្ជូនមក។ ស: តើលោកមានដឹងរឿងអ្វីខ្លះពីអ្នកដែលត្រូវបានគេដោះលែងទៅវិញទេ? ឆ. 162: ខ្ញុំមិនដឹងទេ។ [...] ស: ក្នុងបទសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបាននិយាយថាអ្នកដែលគេចាប់ខ្លួនបានត្រូវបញ្ជូនទៅភ្នំពេញ រួចអ្នកទាំងនោះត្រូវបានគេបញ្ជូនទៅស្ថានទូត។ សូមលោកជួយបញ្ជាក់ពីរឿងនេះបានទេ ហើយលោកដឹងដោយរបៀបណា? ឆ. 165: ខ្ញុំដឹងដោយសារការប្រជុំរួមរបស់អង្គភាព ដោយគេប្រាប់ថា ទូកបានចរចាជាមួយរដ្ឋាភិបាលរបស់យើង ហើយអ្នកដែលត្រូវចាប់ខ្លួនត្រូវបានដោះលែងហើយ។ ហើយកិច្ចប្រជុំនោះធ្វើម្តងក្នុងមួយខែ"]។

408. នាវាម៉ាយ៉ាហ្គេយ៍ ជានាវាដឹកទំនិញស៊ីវិលដ៏ធំរបស់អាមេរិក ត្រូវបានកម្លាំងកងពលលេខ ៣ ឬកងពល ១៦៤ ចាប់ នៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៧៥ តាមបញ្ជារបស់ **មាស មុត**[1481]។ កម្ពុជាប្រជាធិបតេយ្យអះអាងថា នាវានេះចូលក្នុងដែនទឹកកម្ពុជា[1482]។ នាវាម៉ាយ៉ាហ្គេយ៍ត្រូវបាននាំយកទៅចតនៅជិតកំពង់ផែកំពង់សោម[1483]។ **មាស មុត** បានបញ្ជាឱ្យចាប់ពួកនាវិក រួចបញ្ជូនទៅកំពង់

1481 ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត (ប៊ុន សារ៉ាត) ឆ.150 ["ការនាំនាវាម៉ាយ៉ាហ្គេសមកកំពង់សោម ការចេញបញ្ជាពីអគ្គមេបញ្ជាការភ្នំពេញទៅកងពល"]។ ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៦ ម៉ោង 09.37.10-09.38.40 ["បញ្ជាពីកងពលទៅចាប់។ អ្នកនៅលើកោះនោះឃើញកប៉ាល់ៗហ្នឹងក៏រាយការណ៍ទៅថ្នាក់លើ។ ថ្នាក់លើក៏ឱ្យនាវាប្រដេញពីរគ្រឿង"] ម៉ោង 10.07.27-10.09.17 ["អ្នកបញ្ជាចាប់កប៉ាល់ម៉ាយ៉ាហ្គេស បញ្ជាពីកងពលមកវរសេនាធំ បញ្ជាពីវរសេនាធំទៅវរសេនាតូច បញ្ជាវរសេនាតូចទៅយោធា។ មិនមែនថា វរសេនាតូចណាមួយ ឬក៏វរសេនាធំណាមួយម្ចាស់ការបានទេ ទាល់តែបញ្ជាពីលើមកបានទៅចាប់"] ម៉ោង 10.40.40-10.43.41 ["បញ្ជាពីលើទៅមាន តាមុត កងពលបញ្ជាទៅសមាជិកនៃកងនាវាកប៉ាល់ ខាងកប៉ាល់ឱ្យទៅចាប់បាទ។ អាហ្នឹងៗគេតាមបញ្ជាបាទ ទៅតាមបញ្ជា បញ្ជាទៅវរសេនាតូច វរសេនាតូចគេបញ្ជាទៅយោធាទៅចាប់ ហើយនៅក្នុងអង្គភាពរបស់គេ [...] កាលហ្នុង គេចាប់ម៉ាយ៉ាហ្គេសហ្នឹងមកបាទ ចាប់ម៉ាយ៉ាហ្គេសហ្នុងមានខាងនាវាខាងជើងទឹកបាទ កងជើងទឹករបស់គេ គឺខាងគេចាប់មក។ ចាប់មកៗ ហ្នឹងគេបញ្ជា គេស្តាប់ពីខាងលើ ទាល់តែខាងលើបញ្ជាបាទ គឺកងពលបញ្ជា បានគេហ៊ានចាប់ បើថាអត់បញ្ជាទេ គឺអត់ចាប់ជាដាច់ខាត"]។

1482 ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត (ប៊ុន សារ៉ាត) ឆ.84 ["បានដឹងថា នាវាម៉ាយ៉ាហ្គេសត្រូវបានឃាត់ខ្លួននៅកោះពូលូវៃ។ ថ្ងៃហ្នឹង គឺមានសេចក្តីប្រកាសរបស់ប្រមុខដឹកនាំរដ្ឋ លោក ខៀវ សំផន។ គាត់ចេញសេចក្តីប្រកាសបន្ទាន់ទទួលស្គាល់ថា នាវាម៉ាយ៉ាហ្គេសចូលមកក្នុងដែនអធិបតេយ្យកម្ពុជា"]។ ឯកសារ D54/38.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ លន់ សេង EN 01072384, KH 00967310 ["ដល់ហើយចឹងទៅទទួលរ៉ាដាគេពីបូកគោនេះ រ៉ាដាគេមើលផ្ទៃទឹក គេឃើញកាប៉ាល់នឹងមកៗ ក៏គេបញ្ជាអោយយើងនៅតាមកោះនោះឱ្យទៅពិនិត្យមើល។ ដល់ទៅពិនិត្យមើលម៉ាយីហ្គេសនឹងវាចូលក្នុងដីយើងប្រហែល៤គីឡូទឹក ចូលមកកោះប៉ូឡូវៃ។ កោះប៉ូឡូវៃយើងជាកោះនៅឆ្ងាយជាងគេ"]។

1483 ឯកសារ D54/31 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.4 ["ពេលខ្ញុំធ្វើការនៅផែកំពង់សោម មានព្រឹត្តិការណ៍ចាប់កប៉ាល់ម៉ាយ៉ាហ្គេ។ ខ្ញុំបានឃើញកប៉ាល់នោះត្រូវយកមកចតនៅជិតផែកំពង់សោមដែរ"]។ D114/263 កំណត់ហេតុស្តាប់ចម្លើយ ជុំ ជី ឆ.7-8 ["ពេលដែលយើងត្រូវចាប់ ជាកប៉ាល់ធុនធំ ឬមធ្យម ដូចជា កប៉ាល់ម៉ាយ៉ាហ្គេស ជាដើម យើងមិនអាចអូសបានទេ ធំណាស់។ គ្រាន់តែមានបទបញ្ជាឱ្យអេសស្កត ទៅតាមកប៉ាល់ដែលយើងនាំទៅ [...] ខ្ញុំបញ្ជាក់ប្រាប់លោកបានតែប៉ុណ្ណឹង ពេលត្រូវបញ្ជូនកប៉ាល់ម៉ាយ៉ាហ្គេស មកកំពង់សោម [...] ឆ.8: ពេលទៅដល់ចន្លោះកោះរុង និងកំពង់សោម ព្រោះកប៉ាល់ (ម៉ាយ៉ាហ្គេស) នោះធំមិនអាចចូលផែកំពង់សោមបានទេ។ ពេលដល់ចំណុចកប៉ាល់ចត ខ្ញុំ និងអង្គភាពដែលទៅ គឺវិលមកកោះពូលូវៃវិញ។ ពីរ ឬបីថ្ងៃក្រោយមក សង្គ្រាមបានកើតមាននៅលើដែនកោះតាំង និងចំណុចកំពង់សោម មួយចំនួន"]។

សោម ហើយក្រោយមក នាំទៅនាវាម៉ាយ៉ាហ្គេយ៍វិញ[1484]។ ក្រោយពីនាវាម៉ាយ៉ាហ្គេយ៍ត្រូវបាន ដោះលែង[1485] ឧទ្ធម្ភាគចក្រអាមេរិកបានទម្លាក់គ្រាប់បែក លើកោះតាង ដើម្បីជាការសងសឹក[1486]

---

1484 ឯកសារ D114/285 កំណត់ហេតុស្ដាប់ចម្លើយ ព្រុំ សារ៉ាត (ប៊ុន សារ៉ាត) ឆ.148, 150-151 ["ស: តើអ្នកណាជាអ្នកនាំអ្នកនៅលើនាវាម៉ាយ៉ាងហ្គេសទៅកំពង់សោម និងត្រឡប់មកនាវាវិញ? ឆ.148: ជាយុទ្ធជនកងទ័ព ដែលប្រចាំនៅកោះ លើកោះពូលូវៃចាស់ និងពូលូវៃថ្មី [...] ស: តើមានអ្នកណាបញ្ជាកងទ័ពទាំងនេះ ឱ្យនាំមនុស្សនៅលើទូកម៉ាយ៉ាហ្គេសទៅកំពង់សោម ឬក៏ពួកគាត់ធ្វើដោយខ្លួនឯង? ឆ.150: ការនាំនាវាម៉ាយ៉ាហ្គេសមកកំពង់សោម ការចេញបញ្ជាពីអគ្គមេបញ្ជាការភ្នំពេញទៅកងពល។ កងពលទៅកោះ ទៅវរសេនាធំ៦២ ទើបនាំនាវានេះចូលមក [...] ស: ពេលដែលអគ្គបញ្ជាការ គឺលោក សុន សេន បានបញ្ជាទៅកងពល តើគាត់ទាក់ទងទៅអ្នកណានៅថ្នាក់កងពល? ឆ.151: គាត់ទំនាក់ទំនងជាមួយ មាស មុត ដែលជាមេបញ្ជាការ នៅដែនសមុទ្រ"]។ ឯកសារ D54/100 កំណត់ហេតុស្ដាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.54 ["ស: លោកបាននិយាយថា លោកស្ដាប់ឮតាមវិទ្យុទាក់ទង ថានាវិករបស់កប៉ាល់ម៉ាយីហ្គេមកកំពង់សោម តើលោកនៅតែទទួលយកអ្វីដែលលោកបានលើកឡើងនោះដែរទេ? ឆ. 54: បាទ ខ្ញុំរក្សាទុកដដែល"]។ ឯកសារ D54/38.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ លន់ សេង EN 01072385, KH 00967311 ["ស: ពេលនឹងលោកពូមានទូរស័ព្ទអ្នកណាប្រាប់ ដែលរាយការណ៍ទៅមេ មេហ្នឹងបញ្ជាឱ្យចាប់ ឬពួសម្រេចចិត្តចាប់ខ្លួនឯង? ឆ: កាលហ្នឹង មេគេបញ្ជាដែរនឹង មេកងពលធំដែលខ្ញុំថា មាស មុតនឹង គេបញ្ជាឱ្យហៅមក ដើម្បីមកជួយនាវិកគេ គេសាក គេសួរអីៗ។ ស: លោកពូទទួលបញ្ជាគាត់ផ្ទាល់ ឬក៏? ឆ: ទទួលបញ្ជា។ ស: ផ្ទាល់ ឬតាមរយៈពូមឿន? ឆ: មឿន អត់ទេ"], EN 01072391, KH 00967317 ["ស: ពេលដែលយក៤២នាក់ទៅកាប៉ាល់ម៉ាយីហ្គេចបន្ទាប់ពីទៅជួបសួរដូចថា សាកសួរប្រហែលជា៥-៦ម៉ោង ពេលនឹងយក៤២នាក់នឹងឡើងលើកាប៉ាល់វិញ? ឆ: បាទមកកាប៉ាល់វិញ [...] ស: លោកពូឃើញថាឡើង? ឆ: បាទ ឃើញឡើង ហើយគេក៏ប្រាប់ថា គេឱ្យមកវិញហើយយើងមិនដឹងថា។ [...] ស: ទាំងអស់៤២នាក់ ឬក៏មានយក? ឆ: ៤២នាក់។ ស: អត់មានបាត់? ឆ: អត់"]។ ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៦ ម៉ោង 09.34.20-09.37.10 ["ដែលពេលចាប់បានយកមកហ្នឹង គឺថា អ្នកនៅលើកប៉ាល់ម៉ាយ៉ាហ្គេសហ្នឹង ក៏គេដកចេញពីលើកប៉ាល់ហ្នឹងយកទៅកំពង់សោមតែម្ដង"] ម៉ោង 09.48.58-09.51.07 ["គេឱ្យក្រុមខ្ញុំទៅឃាមនៅលើកប៉ាល់ ហើយចាប់អ្នកនៅលើកប៉ាល់នោះដាក់នៅលើទូក ដើម្បីបញ្ជូនទៅកំពង់សោមតែម្ដង"]។

1485 ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៦ ម៉ោង 14.22.19-14.24.47 ["ពេលដែលយើងឱ្យវាត្រឡប់ទៅវិញហើយ បានចាប់ផ្ដើមវៃគ្នា បាទឱ្យបានកប៉ាល់ គ្រាន់តែកប៉ាល់ម៉ាយ៉ាហ្គេសនោះចេញ គឺចាប់វៃគ្នាតែម្ដង"]។

1486 ឯកសារ D114/285 កំណត់ហេតុស្ដាប់ចម្លើយ ព្រុំ សារ៉ាត (ប៊ុន សារ៉ាត) ឆ.84 ["ប្រើកងទ័ពថ្មើរជើង យន្តហោះឧទ្ធម្ភាគចក្រមកវៃកោះតាង។ ពេលនោះ កងទ័ពនៅកោះ និងកងទ័ពរបស់អាមេរិកាំងមានការប្រយុទ្ធគ្នា"]។ ឯកសារ D114/263 កំណត់ហេតុស្ដាប់ចម្លើយ ជុំ ជី ឆ.8 ["ពីរ ឬបីថ្ងៃក្រោយមក សង្គ្រាមបានកើតមាននៅលើដែនកោះតាំង និងចំណុចកំពង់សោមមួយចំនួន [...] ឧទ្ធម្ភាចក្រអាមេរិកជាច្រើនគ្រឿងដែលហោះកាត់ដែនទឹកអន្តរជាតិមកចំណុចកោះតាំង ទៅជាការប្រយុទ្ធរវាងកងទ័ពអាមេរិក និងកងទ័ពកម្ពុជាប្រជាធិបតេយ្យ"]។ ឯកសារ D114/132

។ ទាហាននៃកងពលលេខ ៣ ឈរជើងនៅកោះតាង និងកងទ័ពអាមេរិក បានវាយប្រយុទ្ធគ្នា នៅថ្ងៃទី១៤-១៥ ខែ ឧសភា ឆ្នាំ ១៩៧៥ បណ្ដាលឲ្យស្លាប់ និងរបួសទាំងសងខាង។ ឧទ្ធម្ភាគចក្រពីរគ្រឿង ដែលដឹកទាហានអាមេរិក ត្រូវបានបាញ់ទម្លាក់ ក្នុងពេលប្រយុទ្ធគ្នា[1487]។ ឯក នី បានឃើញឧទ្ធម្ភាគចក្រទាំងពីរគ្រឿងធ្លាក់ និងសាកសពទាហានអាមេរិកនៅក្នុងឧទ្ធម្ភាគចក្រមួយគ្រឿង[1488]។ ក្នុងអំឡុងពេលនោះ កងទ័ពនៅលើកោះតាងបានទាក់ទងជាមួយទីបញ្ជាការកងពល ហើយទទួល

---

កំណត់ហេតុស្ដាប់ចម្លើយ ម៉ៅ រ៉ាន់ ឆ.49 [“ដល់ថ្ងៃទី១៤ ទ័ពអាមេរិកាំងចាប់ផ្ដើមវ៉ៃកោះតាំង ដោយប្រើឧទ្ធម្ភាគចក្រមិច និងឧទ្ធម្ភាគច្រកដទៃទៀត ដើម្បីទម្លាក់គ្រាប់បែក”]។

1487 ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៦ ម៉ោង 09.51.07-09.53.30 [“បាញ់ធ្លាក់យន្តហោះពីរគ្រឿងទៀត បាទបានធ្លាក់នៅលើផ្ទៃសមុទ្រ ហើយនិងនៅលើកោះ នៅលើឆ្នេរសមុទ្រហ្នឹងមួយគ្រឿង”] ម៉ោង10.02.02-10.04.03 [“កាប៉ាល់ហោះ ឧទ្ធម្ភាគច្រកណោះ... ខ្ញុំបាញ់ធ្លាក់ខ្លួនឯងដោយផ្ទាល់តែម្ដង]។ ឯកសារ D114/32 កំណត់ហេតុស្ដាប់ចម្លើយ ម៉ៅ រ៉ាន់ ឆ.48-49 [“ខ្ញុំដឹង ហើយក៏បានទាំងប្រយុទ្ធបីថ្ងៃ គឺនៅថ្ងៃទី១៤, ១៥ និង១៦ ខែឧសភា ឆ្នាំ១៩៧៥ គឺប្រយុទ្ធជាមួយកប៉ាល់របស់អាមេរិកាំង [...] ឆ.49: ដល់ថ្ងៃទី១៤ ទ័ពអាមេរិកាំងចាប់ផ្ដើមវ៉ៃកោះតាំង ដោយប្រើឧទ្ធម្ភាគចក្រមិច និងឧទ្ធម្ភាគច្រកដទៃទៀត ដើម្បីទម្លាក់គ្រាប់បែក [...]។ ព្រឹកឡើងថ្ងៃទី១៥ មានឧទ្ធម្ភាគចក្រជាច្រើនគ្រឿងមកបាញ់យើងទៀត ហើយត្រូវបានកងទ័ពយើងបាញ់ទម្លាក់ចំនួនពីរគ្រឿង ដោយមួយធ្លាក់នៅក្នុងទឹក និងមួយទៀត ធ្លាក់នៅលើដីនៅមុខត្រង់ស្បៃ [...] តែពួកវាបន្តទម្លាក់គ្រាប់ជាបន្តបន្ទាប់រហូតដល់ព្រឹកឡើងថ្ងៃទី១៦ [...] ទើបយន្តហោះរបស់អាមេរិកាំងមកយកគ្នាវាទៅអស់ ទាំងអ្នកនៅរស់ និងសាកសព។ យើងមិនដឹងថា សាកសពអាមេរិកាំងនៅសេសសល់ប៉ុន្មានទេ ព្រោះមានខ្លះយើងបានអូសទម្លាក់ទឹកចោល”]។ ឯកសារ D54/48 កំណត់ហេតុស្ដាប់ចម្លើយ អែម សុន ឆ. 32 [“យោធាយើង១៣នាក់បានស្លាប់ និង៦នាក់រងរបួស”]។ ឯកសារ D114/186 កំណត់ហេតុស្ដាប់ចម្លើយ សាត ចក់ ឆ.44-45 [“ក្រោយមកឃើញមានយន្តហោះនៅទីនោះចំនួន២ អត់បានយកទៅវិញផង [...] ឆ.45: មួយគឺនៅលើឆ្នេរ ហើយមួយទៀតនៅក្នុងទឹក ប៉ុន្តែមិននៅក្នុងទឹកជ្រៅប៉ុន្មានទេ គឺនៅនឹងទឹកបក់ឆាច់ៗ”]។

1488 ឯកសារ D114/283 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.60 [“គេរកបានតែឆ្អឹងមួយនៅក្នុងឧទ្ធម្ភាគច្រក។ ឧទ្ធម្ភាគច្រកមួយត្រូវបានបាញ់ធ្លាក់ ហើយបាញ់បេការ៉ង់ (បេ៤០) ថែមទៀត រលាយដែក ហើយមានសាកសព១៤នៅក្នុងហ្នឹង ចំណែកឧទ្ធម្ភារចក្រមួយទៀត ដែលបាញ់ដាច់កន្ទុយ ហើយទាហានរត់ចេញបាត់អស់ទៅ”]។ ឯកសារ D4.1.747 របាយការណ៍របស់សហរដ្ឋអាមេរិក ពាក់ព័ន្ធបទសម្ភាសន៍ជាមួយ ឯក នី EN 01172488, KH 00640514 [“ខណៈពេលឈរជើងលើកោះ លោក នី បានទទួលភារកិច្ចឲ្យចូលទៅក្នុងឧទ្ធម្ភាគចក្រដែលខ្ទេចកន្ទុយ និងទាយកប្រេងយន្តហោះសម្រាប់ប្រើប្រាស់ចម្អិនអាហារ។ លោក យល់ថា រូបលោកប្រហែលជាបានចូលទៅក្នុងឧទ្ធម្ភាគចក្រនេះជាង២៥ដងរួចមកហើយ]។ ឯកសារ D114/132 កំណត់ហេតុស្ដាប់ចម្លើយ ម៉ៅ រ៉ាន់ EN 01172487, KH 01154116 [“ហើយត្រូវបានកងទ័ពយើងបាញ់ទម្លាក់ចំនួនពីរគ្រឿង ដោយមួយធ្លាក់នៅក្នុងទឹក និងមួយទៀត ធ្លាក់នៅលើដីនៅមុខត្រង់ស្បៃ”]។

បានសេចក្តីណែនាំពី **មាស មុត**[1489]។ ទាហានអាមេរិកខ្លះ ដែលមិនទាន់ស្លាប់ ក្នុងការធ្លាក់ឧទ្ធម្ភាគចក្រទីពីរ នៅរស់លើកោះ នៅពេលកងទ័ពអាមេរិកដកថយ ឯសាកសពទាហានស្លាប់ត្រូវគេទុកចោល[1490]។ អែម សុន មេដឹកនាំកងវរសេនាតូច ៤៥០ ឈរជើងនៅកោះតាង បានបញ្ជាក់ថា ទាហានអាមេរិកត្រូវចាប់បាននៅលើកោះតាងនាពេលក្រោយ បន្ទាប់ពីការប្រយុទ្ធគ្នា ប៉ុន្តែ ទាហានម្នាក់ត្រូវបានបាញ់សម្លាប់ ពេលគាត់ព្យាយាមរត់[1491]។ ក្រោយពេល អែម សុន រាយការណ៍ជូនកង

---

[1489] ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត (ប៊ុន សារ៉ាត) ឆ.89-90, 92 ["ឆ: ហើយមានសភាពការប្រយុទ្ធនៅលើកោះ វិទ្យុទាក់ទងក៏បានបើក ចង់ដឹងការប្រយុទ្ធនៅលើកោះ ហើយនិងអាមេរិកដឹកនាវាឡើងមកលើគោក [...] ឆ90: ចេញបទបញ្ជាតាមតេអូ ហើយកងពលបញ្ជាត្រឡប់មកវិញថាត្រូវធ្វើម៉េច១ [...] ឆ.92: អ្នកកាន់តេអូ ក្រោមបញ្ជារបស់លោក មាស មុត [...] ស: តើមានគេចេញបញ្ជាមកវរសេនាតូចថា ឱ្យត្រៀមខ្លួនដែរទេ? ឆ.95: មាន។ កងទ័ពកាន់កាំភ្លើងចូលលេណដ្ឋាន។ ស: តើអ្នកណាគេជាអ្នកចេញបញ្ជា? ឆ.96: លោក មាស មុត"]។

[1490] ឯកសារ D114/283 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.60 ["អ្នកដែលច្បាំងគ្នាស្លាប់ គឺយកកប់តាមមាត់សមុទ្រជាជួរ។ គេមិនកប់ចូលគ្នាទេ។[...] ចំណែកទាហានអាមេរិកាំងគេទុកចោលកណ្តាលវាលនៅមាត់សមុទ្រ ហើយឆ្អឹងនោះបាត់អស់ហើយ។ គេរកបានតែឆ្អឹងមួយនៅក្នុងឧទ្ធម្ភាគច្រក។ ឧទ្ធម្ភាគច្រកមួយត្រូវបានបាញ់ធ្លាក់ ហើយបាញ់បេការ៉ង់ (បេ៤០) ថែមទៀត រលាយដែក ហើយមានសាកសព១៤នៅក្នុងហ្នឹង ចំណែកឧទ្ធម្ភាចក្រមួយទៀត ដែលបាញ់ដាច់កន្ទុយ ហើយទាហានរត់ចេញបាត់អស់ទៅ"]។ ឯកសារ D114/132 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ វ៉ាន់ ឆ.49 ["ប៉ុន្មានថ្ងៃក្រោយពេលប្រយុទ្ធគ្នានោះ យើងឃើញមានអាមេរិកាំងម្នាក់បាននៅរស់ ហើយក្រោយមកបានរត់ចូលព្រៃ ដល់ពេលយើងដើររកអាមេរិកាំងម្នាក់នោះព្យាយាមហក់ចាប់កងទ័ពយើង ហើយវាក៏ត្រូវកងទ័ពយើងបាញ់ស្លាប់ទៅ"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ ឆ.49 ["ប៉ុន្តែ ក្រោយៗមកមានទាហានអាមេរិកវង្វេង ហើយត្រូវគេចាប់បាន ឬក៏យ៉ាងម៉េច ខ្ញុំអត់ដឹងទេ។ កោះគឺធំណាស់ ប្រហែលជាមានអ្នកវង្វេង ឬក៏ឡើងយន្តហោះអត់ទាន់ បន្ទាប់មក គេចាប់បាន ឬក៏អត់ ខ្ញុំអត់ដឹងទេ [...] ឆ.50: គ្រាន់តែឮគេនិយាយថា មានសពស្លាប់ដោយសារអត់បាយ អីចឹង"]។ ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.2, 5 ["ឆ: ប៉ុន្តែទាហានអាមេរិកាំងទាំងបីនាក់ ដែលខ្ញុំបានចាប់នោះ មិនត្រូវរបួសទេ [...] ឆ.5. ដូចដែលខ្ញុំបាននិយាយពីមុនអីចឹង ទាហានអាមេរិកាំងម្នាក់ដែលបានបាញ់សម្លាប់នៅលើកោះនោះគ្មានរបួសទេ ហើយទាហានអាមេរិកាំងពីរនាក់ទៀត ត្រូវបានបញ្ជូនទៅកំពង់សោម"]។ ឯកសារ D114/59.1 របាយការណ៍លម្អិតនៃការស៊ើបអង្កេតរបស់អង្គភាពស៊ើបការណ៍របស់សហរដ្ឋអាមេរិក (Stony Beach Report) ចុះខែមករា ឆ្នាំ១៩៩៩ EN 0108011 ["ទាហានកងកម្លាំងជើងទឹកទាំង៣នាក់ នេះកំពុងធ្វើការវាយប្រហារចុងក្រោយនៅស្តាបខាងស្តាំបង្អស់ [...] ក្រោយពេលដែលឧទ្ធម្ភាគចក្របានហោះឡើង កងទ័ពអាមេរិករកឃើញថា កងទ័ពជើងទឹកទាំង៣នាក់នេះ មិនស្ថិតនៅលើឧទ្ធម្ភាគចក្រឡើយ"]។

[1491] ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.4 ["ដូចដែលខ្ញុំនិយាយពីមុនអីចឹង ទាហានអាមេរិកាំងម្នាក់ត្រូវបានបាញ់ស្លាប់ដោយយោធារបស់ខ្ញុំសម្លាប់នៅកោះតាង"]។ ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.49 ["ក្រោយពីការប្រយុទ្ធគ្នាចំនួន៥ថ្ងៃ ជាមួយទាហានអាមេរិកាំងនៅលើកោះនោះ ហើយពួកគេបានដកថយទៅវិញ។ យើងបានបាត់បាយកកជាប្រចាំ ហើយយើងចាំឃ្លាំមើល ហើយនៅយប់ទី២ នៅក្រុមទី៦ បានឃើញមនុស្សម្នាក់

ពល **មាស មុត** បានបញ្ជាគាត់ឲ្យនាំទាហានអាមេរិកទៅកំពង់សោម[1492]។ ពេលទៅដល់អូរឈើទាល គាត់បានប្រគល់ទាហានអាមេរិកពីរនាក់ទៅឲ្យបុគ្គលិកមន្ទីរនៃកងពល ១៦៤ រួចរាយការណ៍ផ្ទាល់មាត់អំពីហេតុការណ៍នេះជូន **មាស មុត** បីថ្ងៃក្រោយមក[1493]។ ពីរបីសប្តាហ៍ក្រោយ

---

ហើយចាប់មនុស្សនោះនៅប្រហែលម៉ោង៣ភ្លឺ។ គាត់ជាជនអាមេរិកាំង ហើយយើងបានសួរចម្លើយគាត់ ហើយគាត់និយាយថាមានគ្នាបីនាក់នៅលើកោះនេះ។ យើងបានចងគាត់ ហើយនៅពេលព្រឹកឡើង យើងបានបណ្តើរទៅរកគ្នាគាត់ពីរនាក់ទៀត។ នៅពេលបណ្តើរ គាត់ព្យាយាមរត់គេច ដូច្នេះខ្ញុំបានបាញ់គាត់ឲ្យដួល ហើយយោធាម្នាក់ទៀតបានបាញ់សម្លាប់ទៅ។ យើងបានកប់គាត់នៅទីនោះតែម្តង។ យើងបានបន្តល្បាតមួយថ្ងៃពេញ នៅម៉ោង៦ល្ងាច យើងបានឃើញអាមេរិកាំងពីរនាក់នៅក្នុងល្អាងថ្មនៅប៉ែកនិរតីនៃកោះ។ ពួកគេបានលើកដៃ ហើយពួកយើងបានចាប់ពួកគេចង។ ពួកគេមានកាំភ្លើងបីដើម។ យើងបានដកកាំភ្លើងទុក ហើយបណ្តើរមកមូលដ្ឋានរបស់យើង។ នៅពេលបណ្តើរពួកគេមក ខ្ញុំបានសួរចម្លើយពួកគេ ពួកគេឆ្លើយថា ពួកគេនៅលើកោះដោយសារពួកគេឡើងយន្តហោះមិនទាន់"]។ សូមមើលផងដែរ ឯកសារ D114/283 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.61 ["ស: ពេលបន្ទាប់ពីវ៉ៃគ្នាហើយ មានសល់ទាហានអាមេរិចកាំងពីរនាក់នៅរស់ គេចាប់នៅលើកោះតាង ហើយគេបញ្ជូនមកកំពង់សោម។ តើលោកឮរឿងហ្នឹងទេ? ឆ. 61: រឿងនេះអត់មានទេ។ [...] អារឿងខ្មែរក្រហមចាប់ជាឈ្លើយសឹក អត់មានទេ"]។ ឯកសារ D114/132 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ រ៉ាន់ ឆ.49, 52 ["ប៉ុន្មានថ្ងៃក្រោយពេលប្រយុទ្ធគ្នានោះ យើងឃើញមានអាមេរិកាំងម្នាក់បាននៅរស់ ហើយក្រោយមកបានរត់ចូលព្រៃ ដល់ពេលយើងដើររក អាមេរិកាំងម្នាក់នោះព្យាយាមហក់ចាប់កងទ័ពយើង ហើយវាក៏ត្រូវកងទ័ពយើងបាញ់ស្លាប់ទៅ [...] ស: តើមានចាប់អាមេរិកាំងបានទាំងរស់ដែរ ឬទេ? ឆ.52: អត់ទេ"]។

1492 ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.49 ["នៅពេលដែលយើងមកកន្លែងប៉ុស្តិ៍យោធាយើងវិញ យើងបានទាក់ទងតាមវិទ្យុមកកងពលរបស់ មាស មុត ដើម្បីរាយការណ៍ថា យើងបានបាញ់អាមេរិកាំងម្នាក់ស្លាប់ និងចាប់បានពីរនាក់ហើយដោយសារពួកគេហ្នឹងឡើងយន្តហោះមិនទាន់។ មាស មុត បានបញ្ជា គាត់ ដោយផ្ទាល់បើកទូកបេអឺ មកដឹកទាហានអាមេរិកាំងពីរនាក់នោះ និងសមាជិកកងវរសេនាតូច៤៥០ (៣នាក់ស្លាប់នៅពេលប្រយុទ្ធគ្នា) របស់ខ្ញុំត្រឡប់ទៅកំពង់សោមវិញ"]។ ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.5, 14 ["ហើយទាហានអាមេរិកាំងពីរនាក់ទៀត ត្រូវបានបញ្ជូនទៅកំពង់សោម [...] ឆ.14: ដំបូង ខ្ញុំបាននិយាយតាមវិទ្យុទៅអ្នកកាន់វិទ្យុ (តេអូ) ដែលមានឈ្មោះ សារ៉ន និងឌុល។ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំចង់និយាយជាមួយ៦៣/មាស មុត បន្ទាប់មក ៦៣/មាស មុត និយាយជាមួយខ្ញុំតាមវិទ្យុ ហើយចេញបញ្ជាឲ្យខ្ញុំនាំទាហានអាមេរិកាំងពីរនាក់ដែលនៅរស់"]។

1493 ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.32, 34 ["ខ្ញុំបានទៅជួប មាស មុត នៅមន្ទីររបស់គាត់ ហើយគាត់បានសួរខ្ញុំឲ្យពន្យល់អំពីស្ថានការណ៍នៅកោះតាង។ ខ្ញុំពន្យល់ទៅគាត់អំពីព្រឹត្តិការណ៍នៅទីនោះ និងការប្រយុទ្ធគ្នានៅកោះតាង [...] ស: នៅពេលដែល មាស មុត ហៅលោកទៅមន្ទីររបស់គាត់ តើគាត់មានបានពិភាក្សាជាមួយលោក ថាតើមានរឿងអ្វីកើតឡើងចំពោះទាហានអាមេរិកាំងពីរនាក់នោះទេ បន្ទាប់ពីលោកប្រគល់ឲ្យទៅ មាស មុត? ឆ. 34: ចំពោះទាហានអាមេរិកាំងពីរនាក់ មាស មុត បាននិយាយថា "ទុកឲ្យគេអ្នកចាត់ចែងទៅ"។ ខ្ញុំមិនដឹងថាគេនោះជាអ្នកណាទេ ហើយខ្ញុំក៏មិនប៉ានសួរដេញដោល"]។ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.33

មក អែម សុន បានប្រាប់ថា គាត់បានឃើញសាកសពទាហានអាមេរិកទាំងពីរនាក់ នៅលើឆ្នេរពីរនៃទីក្រុងកំពង់សោម ដោយសាកសពទាំងពីរបែកលលាដ៍ក្បាលខ្ទេច[1494]។

409. ភ័ស្តុតាងបង្ហាញថា **មាស មុត** បានគ្រប់គ្រងទាំងស្រុងលើទាហានឈរជើងនៅកោះ និងនៅតំបន់កំពង់សោម ពេលនាវាម៉ាយ៉ាហ្គេយ៍ត្រូវបានចាប់ និងប៉ុន្មានសប្តាហ៍ក្រោយមក[1495] ទោះបីជាគាត់បានអះអាងថា គាត់កំពុងសម្រាកពេទ្យ នៅទីក្រុងភ្នំពេញ ពេលនោះក៏ដោយ[1496]។

---

["ស: តើពេលណាដែលជាពេលចុងក្រោយ ដែលលោកបានឃើញទាហានអាមេរិកាំងពីរនាក់ដែលនៅរស់នោះ? ឆ.33: នៅផែអូរឈើទាល តាមពិតនៅពេលដែលកាណូតមកជិតដល់ឆ្នេរនោះ ខ្ញុំបានទាក់ទងតាមវិទ្យុទៅមន្ទីរសេនាធិការកងពល១៦៤ថា ពួកយើងជិតមកដល់ហើយ ហើយគេបានបញ្ជូនឡានហ្ស៊ីពមួយមកផែដើម្បីរង់ចាំដឹកទាហានអាមេរិកាំងពីរនាក់នោះ"]។

1494 ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.35, 36, 39, 42 ["ប្រហែល២០ថ្ងៃក្រោយមក ទើបដឹងខ្ញុំថា ពួកគេបានសម្លាប់ ម្នាក់ត្រូវបានគេសម្លាប់នៅក្បែរឆ្នេរមាត់សមុទ្រកំពង់សោមខាងក្រោយសណ្ឋាគារប្រាំពីរជាន់ និងម្នាក់ទៀតត្រូវបានសម្លាប់នៅខាងលិចខាងក្រោមដំណាក់ស្តេច [...] ឆ.36: ខ្ញុំដើរល្បាតពីតំបន់សណ្ឋាគារប្រាំពីរជាន់ទៅដល់ផែកំពង់សោម។ អំឡុងពេលដើរល្បាតនោះ ខ្ញុំបានឃើញសាកសពទាហានអាមេរិកាំងទាំងពីរនាក់នោះ នៅឆ្នេរទាំងពីរនោះ [...] ឆ.39: សាកសពនោះមានសម្បុរ និងមុខមាត់ខុសពីខ្មែរយើង។ នៅពេលខ្ញុំទៅដល់កន្លែងសាកសពទី២ សពនោះក៏មានសម្បុរ មុខមាត់ខុសពីខ្មែរយើងដែរ។ ដូច្នេះ ខ្ញុំសន្និដ្ឋានថា សពទាំងពីរនោះគឺជាទាហានអាមេរិកាំង [...] ឆ. 42: សាកសពទី១ នៅសណ្ឋាគារប្រាំពីរជាន់ ខ្ញុំឃើញសពនោះដេកផ្អៀង ចុងជើងនៅក្នុងទឹក បែកក្បាលខាងក្រោយដោយមានកកឈាម ហើយមានរុយរោម និងមានក្លិនស្អុយ។ ចំណែកសាកសពទី២ នៅដំណាក់ស្តេច សពដេកផ្កាប់មុខ ក្បាលទៅលិចជើងទៅកើត បែកក្បាលខាងក្រោយដោយមានកកឈាម ហើយមានរុយរោម និងមានក្លិនស្អុយ។ នៅពេលដែលឃើញស្ថានភាពនៃសាកសព និងក្លិនស្អុយនេះ ខ្ញុំអាចសន្និដ្ឋានថា ពួកគេត្រូវបានសម្លាប់កាលព្រលប់ ដោយខ្ញុំបានឃើញនៅថ្ងៃត្រង់"]។ សូមមើលផែនទីរដ្ឋបាល អំពីទីតាំងដែល អែម សុន ប្រទះឃើញសាកសពទាំងពីរនេះ ដូចមានបង្ហាញជូនក្នុង ឯកសារ D54/48.3 ផែនទីរដ្ឋបាល ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ (រៀបរាប់ដោយ អែម សុន) KH 00969463។

1495 ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.20-21, 25 ["នៅពេលលោកនៅកោះតាង តើ មាស មុត ធ្លាប់អវត្តមានដែរឬទេ? ឆ.20: នៅពេលដែលខ្ញុំនៅកោះតាង គាត់មិនដែលអវត្តមានទេ។ ស: ហេតុអ្វីលោកដឹង នៅពេលដែលលោកនៅកោះតាងថា មាស មុត មានវត្តមាន ឬអវត្តមាន? ឆ. 21: ខ្ញុំដឹងថា មាស មុត មានវត្តមាន នៅពេលខ្ញុំរាយការណ៍ទៅអ្នកកាន់វិទ្យុទាក់ទង ដើម្បីរាយការណ៍ទៅ មាស មុត។ [...]ឆ.25: មុនពេលព្រឹត្តិការណ៍កប៉ាល់ម៉ាយ៉ាហ្គេស មាស មុត មិនអវត្តមានទេ។ អំឡុងពេលព្រឹត្តិការណ៍កប៉ាល់ម៉ាយ៉ាហ្គេស និងការប្រយុទ្ធគ្នា មាស មុត ក៏មិនអវត្តមានទេ ហើយគាត់បានបញ្ជាក្រុមរបស់ខ្ញុំ [...] ឆ.26: ខ្ញុំបាននិយាយផ្ទាល់តាមវិទ្យុជាមួយ មាស មុត ម្តងក្រោយពេលវ៉ៃគ្នាធំជាមួយទាហានអាមេរិកាំង"]។ សូមមើល ជំពូក III. ការទទួលខុសត្រូវនិងតួនាទីរបស់មាស មុត។

### គ) ការសម្លាប់នៅកំពង់សោម

410. ប្រសិនបើអ្នកដែលកងនាវាចាប់បាន មិនត្រូវបានសម្លាប់នៅលើសមុទ្រ ឬនៅលើកោះ ពួកគេត្រូវបញ្ជូនទៅដីគោក។ អាស្រ័យតាមបញ្ជា អ្នកដែលគេចាប់បានត្រូវនាំទៅរាម[1497] ឬកំពង់សោម[1498]

---

1496 ឯកសារ D22.2.181 បទសម្ភាសន៍ លោក មាស មុត លើករណីកោះតាង ធ្វើនៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ ២០១២ EN 00741996 ["សង្ខេប [...] ((មាស)) មុត បានទៅព្យាបាលជំងឺនៅមន្ទីរពេទ្យក្នុងទីក្រុងភ្នំពេញ ក្នុងអំឡុងពេលមានឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស។ គ្មានទាហានអាមេរិកណាម្នាក់ត្រូវបានចាប់ខ្លួននៅលើកោះតាងនោះទេ ហើយមានតែសាកសពទាហានអាមេរិកម្នាក់ ដែលត្រូវបានរកឃើញបន្ទាប់ពីការប្រយុទ្ធគ្នាចប់។ លោកមិនដឹងព័ត៌មានទាក់ទងនឹងការរៀបចំអដ្ឋិធាតុរបស់ទាហានអាមេរិកនោះទេ"] KH 00741997 ["ពីខែឧសភា ដល់ខែកក្កដា ឬខែសីហា ឆ្នាំ ១៩៧៥ លោក មាស មុត បានចូលសម្រាកព្យាបាលជំងឺ ក្នុងមន្ទីរពេទ្យនៅទីក្រុងភ្នំពេញ ដោយសារតែលោកមានជំងឺពោះវៀនធ្ងន់ធ្ងរ។ ប្រពន្ធរបស់លោក គឺជាប្រភពតែមួយគត់ ដែលផ្តល់ព័ត៌មានដល់លោក ទាក់ទងនឹងឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស នៅពេលនោះ។ ប្រពន្ធរបស់លោកបានថ្លែងប្រាប់លោកអំពីការចាប់នាវាម៉ាយ៉ាហ្គេស និងការវាយប្រហាររបស់អាមេរិកក្នុងអំឡុងពេលដែលអ្នកស្រីបានមកសួរសុខទុកលោករយៈពេលខ្លី ប្រហែលពីរថ្ងៃបន្ទាប់ឧប្បត្តិហេតុនោះ ហើយបានទទួលព័ត៌មានពីការវាយប្រហាររបស់សហរដ្ឋអាមេរិក ប្រហែលពីរទៅបីថ្ងៃ បន្ទាប់ពីឧប្បត្តិហេតុនេះបានបញ្ចប់។ [...] KH 00741998 ((ឆាន)) – ជាមេបញ្ជាការកងពលធំ។ គាត់ជាមេបញ្ជាការទទួលបន្ទុកក្នុងអំឡុងពេលមានឧប្បត្តិហេតុនាវាម៉ាយ៉ាងហ្គេស ប៉ុន្តែទីបញ្ជាការដ្ឋាននេះ ស្ថិតនៅកំពង់សោម និងរាម"]។

1497 ឯកសារ D54/24.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN 00978574, KH 00955506 ["ប៉ុនកងពលតែមួយ ជួនកាល គេឱ្យយកទៅរាមទៅ។ ស: ប៉ុន្តែមនុស្សដែលបញ្ជូនមកនឹងៗ បញ្ជូនមករាម ឬមកដំណាក់ស្តេច? ឆ.: មករាម"]។ ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.13 ["ការចាប់បានទូកនេសាទថៃ កម្លាំងម៉ាស៊ីន៤00សេស គឺក្នុងខែ៦ ឆ្នាំ១៩៧៦។ [...] អ្នកនេសាទថៃទាំងអស់នោះ ត្រូវដឹកជញ្ជូនទៅរាម"]។ ឯកសារ D1.3.13.13 បទសម្ភាសន៍របស់ការិយាល័យសហព្រះរាជអាជ្ញាជាមួយ ទូច សឿលី EN 00217575 ["ជួនកាល គេចាប់បានអ្នកនេសាទថា ។ វាអាស្រ័យទៅតាមបញ្ជា គេអាចឱ្យនាំអ្នកនេសាទទាំងនោះមកអូរឈើទាល ឬរាម"]។ ឯកសារ D54/22 កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ EN 00947622, KH 01002679 ["សាក្សីបានឃើញនាវា ប៉ុន្តែ មិនបានឃើញអ្នកនាវាចរទេ។ គាត់អះអាងថា គាត់បានឮថា អ្នកនាវាចរចំនួនពីរនាក់ ត្រូវបានដឹកជញ្ជូនទៅរាម"]។

1498 ចំពោះទូក និង/ឬនាវាចរ ដែលត្រូវបានដឹកជញ្ជូនទៅកំពង់សោម ជាទូទៅ (ពុំមានផ្តល់ព័ត៌មានពិស្តារទាក់ទងនឹងទីតាំងពិតប្រាកដទេ) សូមមើល ឯកសារ D54/83 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ិច ឆ.33 ["ជាធម្មតា នៅពេលចាប់បានទូក និងមនុស្សនៅលើទូក អង្គភាពរបស់ខ្ញុំត្រូវបញ្ជូនពួកគេទៅកំពង់សោម ព្រោះយើងគ្មានសិទ្ធិទៅលើមនុស្ស និងទូកទាំងនេះឡើយ។ លុះត្រាតែកងពលបានត្រួតពិនិត្យលើបញ្ហានេះរួចរាល់ហើយ ទើបគេសម្រេចទៅលើការបែងចែកវត្ថុទាំងនេះទៅឱ្យអង្គភាព។ នេះគឺជាការទទួលខុសត្រូវរបស់កងពល ដោយឡែកយើងខ្ញុំគ្រាន់តែទទួលខុសត្រូវទៅលើការចាប់ និងការបញ្ជូនមនុស្ស និងទូកទៅកំពង់សោមប៉ុណ្ណោះ។ ខ្ញុំមិនដឹងថា មានរឿងកើតឡើងចំពោះមនុស្សទាំងនោះទេក្រោយពេលបានបញ្ជូនពួកគេទៅកំពង់សោម ព្រោះវាលែងស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្ញុំទៀតហើយ។ កងពល១៦៤ គឺ

(ឆ្នេរអូរឈើទាល[1499] ទីបញ្ជាការកងពល ១៦៤ ឬព្រះរាជដំណាក់[1500])។ អ្នកដែលគេមិនទាន់ចង ត្រូវគេចង ពេលទៅដល់កំពង់ផែ[1501]។ ភ័ស្តុតាងបង្ហាញថា ជនជាតិថៃខ្លះត្រូវគេនាំទៅរាម និងបង្ខំ

---

ជាអ្នកដែលមានសមត្ថកិច្ច ហើយពួកគេជាអ្នកសម្រេចទៅលើវាសនារបស់អ្នកទាំងនោះ"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ ឆ.82 ["ធម្មតា ទូកដែលគេចាប់គឺគេអូសសណ្តោងទៅកំពង់សោម ហើយយើងមិនអាចឃើញទេ គ្រាន់តែយើងឡើងទៅលើកោះ យើងមើលពីចម្ងាយទៅគឺយើងអាចមើលឃើញគេសណ្តោងទៅកំពង់សោមបាន"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.68-69 ["ស: នៅពេលដែលចាប់ទូកវៀតណាមបានហើយ តើអ្នកដែលនៅលើទូកនោះត្រូវបានគេបញ្ជូនទៅណា? ឆ. 68: ខ្ញុំគ្រាន់តែដឹងថា អ្នកនេសាទវៀតណាម ដែលគេបានដឹកមកដល់ផែ គឺត្រូវបានគេដឹកចេញពីផែតាមឡានទ្រង់របស់កងពល១៦៤។ ប៉ុន្តែ ខ្ញុំមិនដឹងថា ពួកគេត្រូវបានបញ្ជូនទៅទីណាទេ។ ស: តើលោកដឹងថា មានអ្វីកើតឡើងចំពោះអ្នកនេសាទវៀតណាម ដែលចាប់ខ្លួននោះដែរ ឬទេ? ឆ. 69: ខ្ញុំមិនដឹងទេ។ ក្រោយពេលដែលអ្នកនេសាទវៀតណាមទាំងនោះត្រូវបានគេដឹកតាមឡានចេញទៅ ខ្ញុំមិនដែលឃើញពួកគេទៀតទេ"]។

[1499] ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.4 ["ស: លោកបាននិយាយថា លោកបានឃើញទូក និងជនបរទេសនោះនៅនឹងផែ តើវាជាផែអូរឈើទាល ឬផែណាដែរ? ឆ. 4: គឺនៅហ្នឹងផែអូរឈើទាល"]។ ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល់ ឆ.8 ["គេក៏ចាត់តាំងខ្ញុំឱ្យបើកទូកវៀតណាមនោះមកអូរឈើទាល"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.25, 35-36 ["បើចាប់បានច្រើនជាង២០នាក់ ត្រូវបញ្ជូនទៅអូរឈើទាល។ តាមខ្ញុំដឹង អ្នកដែលបញ្ជូនមកដីគោកទាំងនោះ ក្រោយមកត្រូវគេសម្លាប់ចោលដែរ […] ឆ.35: អ្នកដែលគេចាប់បាន ពេលដែលនាំមកដល់ផែអូរឈើទាលនៅកំពង់សោម ត្រូវបានគេនាំចេញពីកប៉ាល់ ហើយដាក់ក្នុងឡានដឹកចេញទៅភ្លាមៗ […] ឆ. 36: ខ្ញុំធ្លាប់ដឹកអ្នកដែលចាប់បានម្តង តាមកប៉ាល់របស់ខ្ញុំ យកមកកន្លែងផែអូរឈើទាល។ ពេលនោះ អ្នកដែលខ្ញុំដឹកនោះ មាន១២ទៅ១៣នាក់"]។ ឯកសារ D54/11 កំណត់ហេតុស្តាប់ចម្លើយ ម៉ើ រ៉េត ហៅ សារ៉េត ឆ.3 ["ខ្ញុំធ្លាប់បានឃើញទូកឈើប្រវែង១៥ម៉ែត្រទទឹង ៤ម៉ែត្រមានពណ៌ប្រផេះ ត្រូវបានគេយកមកទុកនៅផែអូរឈើទាលនេះ។ ខ្ញុំបានឮពីយោធាដទៃទៀតនិយាយថា ទូកនេះជារបស់ពួកអៀសខ្លួនជនជាតិវៀតណាមដែលមានបំណងរត់ទៅប្រទេសទី៣"]។ ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.6 ["នៅពេលដែលពួកយោធាតាមកោះចាប់បានពួកមនុស្សទាំងនោះ [អ្នកដែលចូលដែនទឹកកម្ពុជា] ក៏បញ្ជូនមកដីគោក ហើយគេតែងតែយកអ្នកទាំងនោះចូលមកដាក់នៅផែអូរឈើទាល"]។ ឯកសារ D54/22 កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ EN 00947622, KH 01002678 ["ទំនងជាក្នុងឆ្នាំ១៩៧៨ ក្នុងអំឡុងរដូវវស្សា ពេលនៅបោះទីតាំងនៅឆ្នេរអូរឈើទាល គាត់បានឃើញនានាកំសាន្តមួយដែលត្រូវបានចាប់។ ក្នុងនាវានោះ មានអ្នកនាវាចរចំនួនពីរបីនាក់ ដែលបានចតនៅផែ។ គាត់ថា អ្នកនាវាចរមានកម្ពស់ខ្ពស់ ជាជាតិស្បែកស ជាអ្នកមាន និងជាអ្នកទេសចរ […]។ ពួកគេមិនត្រូវបានវាយដំ ឬចាប់ចងទេ"]។ ឯកសារ D1.3.13.13 ឆ បទសម្ភាសន៍របស់ការិយាល័យសហព្រះរាជអាជ្ញាជាមួយ ទូច សឿលី EN 00217575 ["វាអាស្រ័យតាមបញ្ហា គេអាចយកអ្នកនេសាទទាំងនោះទៅអូរឈើទាល ឬរាម"]។

ឱ្យធ្វើការជាបណ្តោះអាសន្នសិន[1502] មុនពេលបញ្ជូនត្រឡប់ទៅថៃវិញ[1503]។ អ្នកដែលគេចាប់បាន ខ្លះទៀតត្រូវបញ្ជូនទៅទឹកសាបនៅខាងកើតរាម[1504]។ សាក្សីម្នាក់បានឆ្លើយថា ជនជាតិវៀតណាម

---

1500 ឯកសារ D59/1/1.9a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនហាក់ EN 00963734, KH 00926467 ["ស: ចុះពេលដែលយើងពួកអាមកចាប់ត្រីខុសច្បាប់ក្នុងទឹកដីយើងហ្នឹង យើងចាប់យើងបញ្ជូនមកណាទៅ? ឆ.: បញ្ជូនមកទីបញ្ជាការមក ជូនណា គេដោះលែងទៅវិញ គេជូនណា គេមានប្រាក់១បង់ យើងមើលទៅសមហេតុផង [...]។ យើងយកមកអប់រំ យកមកព្រមានអីថែមទៀតទៅ គេលែងទៅវិញ"]។ ឯកសារ D54/24.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN 00978574, KH 00955505 ["ស: លើគោកបញ្ជូនមកខាងណា? ឆ.: ខាងកំពង់សោម។ ស: ខាងកំពង់សោម កន្លែងណា? ឆ.: មកខាងកោះស្តេច ដំណាក់ស្តេច"]។

1501 ឯកសារ D54/24.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN 00978574, KH 00955505 ["យើងអត់ទេ គ្រាន់បញ្ជាវាមកដល់គោក ចង មកដល់ [...] បាទ! មកចងស្លាបសេកប្រសាយគ្នាទៅ [...] [ពួកគេ] សុទ្ធតែថៃ យួន"]។

1502 ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយរបស់ ប៉ាក សុខ ឆ.13, 15, 16 ["ឆ.13: ការចាប់បានទូកនេសាទថៃកម្លាំងម៉ាស៊ីន៤០០សេស គឺក្នុងខែ៦ ឆ្នាំ១៩៧៦។ ការចាប់នោះ គឺធ្វើឡើង ចម្ងាយ១២គីឡូម៉ែត្រនៅខាងលិចកោះពូលូវៃចាស់។ ក្នុងពេលចាប់ទូននេសាទនោះ បានចូលជិតដែនទឹកអន្តរជាតិទៅហើយ។ អ្នកនេសាទថៃទាំងអស់នោះ ត្រូវដឹកបញ្ជូនទៅរាម។ ខ្ញុំបានជួបពួកនេសាទថៃទាំងនោះនៅលើកោះតាគាវ ប្រហែល៦-៧ខែក្រោយមក។ [...] ឆ.15: ការចាប់បានទូកនេសាទថៃ កម្លាំងម៉ាស៊ីន១៨០០សេស គឺនៅចុងឆ្នាំ១៩៧៦។ ការចាប់នេះ គឺនៅប្រហែលជា៣០គីឡូម៉ែត្រភាគនិរតីនៃកោះពូលូវៃចាស់ [...] ស: តើមានរឿងរ៉ាវអ្វីកើតឡើងចំពោះពួកអ្នកនេសាទថៃទាំងនោះ? ឆ.16: [ពួកនេសាទថៃទាំងអស់នោះ] ត្រូវបានបញ្ជូនទៅរាម ហើយក្រោយមកបញ្ជូនឱ្យទៅធ្វើការនៅលើកោះតាគាវ ជាមួយពួកមុនដែរ ព្រោះខ្ញុំបានជួបពួកគេនៅពេលដែលខ្ញុំទៅធ្វើការនៅទីនោះ"]។ ឯកសារ D54/24.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN 00978575, KH 00955506-07 ["ស: អញ្ចឹងអ្នកនេសាទថៃដែលគេចាប់នេះមកនឹងគេឱ្យមកជួយដឹកប្រឡាយ? ឆ.: បាទ ដឹក លើកទំនប់។ [...]។ គេយកមកខ្លះគេឱ្យលើកទំនប់អីចឹង ខ្ញុំមកឃើញដែរតើ"]។

1503 ឯកសារ D54/24.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN 00978575, KH 00955506-07 ["ប៉ុនគេប្រាប់ខ្ញុំថា មិនឱ្យប៉ះពាល់ទេ ព្រោះឱ្យគេធ្វើការនឹងហើយ គេឱ្យបញ្ជូនទៅវិញ [ប្រទេសគេវិញ]"]។ ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.14 ["ខ្ញុំបានឮពីអ្នកយាមនៅលើកោះថា អ្នកនេសាទថៃទាំងអស់នោះនឹងត្រូវបញ្ជូនទៅប្រទេសគេវិញ តែខ្ញុំមិនដឹងថា រឿងទាំងអស់នោះពិត ឬមិនពិតនោះទេ"]។ ឯកសារ D234/2.1.95 មាស វឿន ប្រតិចារឹក ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 14.10.55-14.14.10 ["បើសិនជាយើងចាប់បាន ក៏យើងបញ្ជូនទៅស្រុកថៃវិញដែរ។"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 09.53.36-09.58.05 ["បើមានព្រឹត្តិការណ៍អីដែលដូចជាទូកថៃ ទូកអីទៅ ឃើញថា បើគេបញ្ជាឱ្យទៅចាប់ អាហ្នឹងបានទៅចាប់"]។ ឯកសារ D234/2.1.92 ព្រំ សាវ៉ាត ប្រតិចារឹក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦

ភាគច្រើនត្រូវគេនាំទៅកំពង់សោម មិនមែនទៅកោះទេ[1505]។ ពេលខ្លះ ជនជាតិវៀតណាមត្រូវបាន "មន្ទីរផ្ទៃក្នុង" នៃកងពល ១៦៤ មកយកពីអូរឈើទាល រួចនាំទៅកំពង់សោម រួមជាមួយវត្ថុមានតម្លៃ និងរបស់របរផ្សេងទៀតដែលរឹបអូសបាន[1506]។

411. ក្នុងករណីខ្លះ ទូក និងអ្នកដំណើរ ត្រូវគេនាំទៅកោះណាមួយ ដើម្បី "ឆែកឆេរ និងធ្វើរបាយការណ៍" មុនពេលបញ្ជូនទៅតំបន់កំពង់សោម[1507]។ ជាចុងក្រោយ អ្នកនេសាទ ទាហាន ជនភៀសខ្លួន និងជនបរទេសផ្សេងទៀត ដែលចាប់បាន ត្រូវគេនាំទៅកន្លែងផ្សេងៗ នៅលើដីគោក រួចសម្លាប់ចោល

---

ម៉ោង 14.02.55-14.04.20 ["អ្វីដែលកើតមាននៅដែនសមុទ្រ យើងចាប់បានទូកនេសាទថៃក្តី ទូកណាក្តី គឺយើងត្រូវប្រគល់ជូនទៅផ្នែកទាក់ទងអន្តរជាតិ ដើម្បីឱ្យក្រុមពួកនេសាទទាំងអស់នេះ ដោះស្រាយយ៉ាងណាៗទៅតាមកិច្ចការរបស់ក្រសួងការបរទេស"]។

1504 ឯកសារ D54/24.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN 00978579, KH 00955511 ["គេចាប់មកដាក់កន្លែងទឹកសាប នៅជិតកោះកេង [កងកេង] ខាងកើតរាម"]។

1505 ឯកសារ D54/113 កំណត់ហេតុស្តាប់ចម្លើយ លៀង ប៉ៀ ឆ.57-58 ["ស: តើទាហានខ្មែរក្រហមនាំវៀតណាមដែលចាប់បានពីទូកទៅដាក់លើឆ្នេរដីគោក ឬយកទៅដាក់លើកោះ? ឆ.57: ភាគច្រើន យកមកដាក់លើដីគោកនៅកំពង់សោម មិនមានយកទៅលើកោះទេ។ ស: តើលោកដឹងថា គេយកអ្នកទាំងនោះទៅណាទេ? ឆ. 58: ទេ ខ្ញុំមិនដឹងទេ"]។

1506 ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល់ ឆ.8, 12, 14 ["នៅពេលទៅដល់ផែអូរឈើទាល ខ្ញុំសង្កេតឃើញថា មានឡានមួយគ្រឿង គេត្រៀមចាំទទួលជនជាតិវៀតណាមដែលគេចាប់បានពីទូក [...] កម្លាំងដែលមកទទួលពួកវៀតណាមទាំងនោះ គឺមកពីមន្ទីរក្នុងរបស់កងពល១៦៤ [...] ខ្ញុំសង្កេតឃើញមានមាសសន្លឹកជាង១០សន្លឹក។ នៅពេលពួកគេត្រូវបានចាប់ខ្លួន សម្ភារៈទាំងនោះក៏ត្រូវបានរឹបអូស និងសរសេរដាក់ក្នុងរបាយការណ៍ដែរ។ ទាំងមនុស្សទាំងទូក សម្ភារៈ និងរបាយការណ៍ត្រូវបានបញ្ជូនទៅកំពង់សោមទាំងអស់ [...] ពួកគេត្រូវបានដកហូតអ្វីៗទាំងអស់ដែលគេយកមកតាមខ្លួន"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 10.58.13-11.00.37 ["អ្នកដែលគ្មានអាវុធនោះ ឃើញថា ចាប់បញ្ជូនទៅផែអូរឈើទាល ដើម្បីយកទៅកន្លែងមន្ទីរកងពល បាទ"]។

1507 ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល់ ឆ.3, 27 ["ក្នុងករណីដែលចាប់ទូក និងមនុស្សនៅលើទូក គឺទាំងមនុស្ស ទាំងទូកត្រូវបានបញ្ជូនដោយនាវារបស់កងវរសេនាធំ១៤០ទៅកំពង់សោម ឬទីតាំងកោះណាមួយរយៈពេលខ្លី មុននឹងបញ្ជូនទៅកំពង់សោម។ បើនាវារបស់កងវរសេនាធំ១៤០ ចេញមកពីកពង់សោម ដើម្បីចាប់ទូក បន្ទាប់ពីចាប់ទូកបានគេនឹងយកទូក និងមនុស្សទៅកំពង់សោមត្រង់។ តែបើសិនជា នាវារបស់កងវរសេនាធំ១៤០ ឈរជើងនៅកោះពូលូវៃថ្មី ឬកោះតាង បន្ទាប់ពីចាប់ទូកនោះហើយ គឺគេត្រូវត្រឡប់ទៅកោះណាមួយក្នុងរយៈពេលខ្លីសិន ដែលទីតាំងនោះស្ថិតក្រោយការគ្រប់គ្រងរបស់វរសេនាធំ៦២ [...] ឆ. 27: ប៉ុន្តែ របាយការណ៍នេះពុំបានបញ្ជាក់អំពីការចូលចតនៅកោះតាង និងកោះពូលូវៃមួយរយៈខ្លី ដើម្បីត្រួតពិនិត្យ និងធ្វើរបាយការណ៍ មុននឹងបញ្ជូនមកកំពង់សោមនោះទេ"]។

តាមបញ្ជារបស់កងពល ១៦៤[1508]។ ជនជាតិវៀតណាម ដែលចាប់បាន ត្រូវគេសម្លាប់ចោល ជាប្រព័ន្ធ[1509]។ ទីតាំងសម្លាប់មនុស្ស រួមមាន ចម្ការទុរេនទី ១ ចម្ការដូង និងចម្ការក្រូច[1510] ដែលស្ថិត

---

1508 ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.11 ["ស: តាមបទពិសោធន៍របស់លោក និងការយល់ដឹងរបស់លោក នៅក្នុងកងអង្គភាពរបស់លោក និងអង្គភាពដទៃទៀត នៃកងទ័ពជើងទឹក តើចំនួនប្រជាជនស៊ីវិល ចំនួនជនភៀសខ្លួន អ្នកនេសាទ ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឆ្លងមកចូលក្នុងដែនទឹកកម្ពុជា ហើយត្រូវបានចាប់បាន និងសម្លាប់ មានចំនួនប្រហែលប៉ុន្មាននាក់? ឆ.11: មានចំនួនរាប់ពាន់នាក់ អ្នកទាំងនោះ រួមមាន ពួកនេសាទថៃ និងពួកនេសាទ និងជនភៀសខ្លួនវៀតណាម ដែលត្រូវចាប់បាន និងសម្លាប់ចោល នៅក្នុងសមុទ្រ នៅលើកោះ និងនៅលើដីគោក។

1509 ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.25, 29 ["បើសិនជាយើងចាប់បានទូកយួន ពេលខ្លះយើងទទួលបញ្ជាឱ្យបាញ់សម្លាប់ចោលនៅនឹងកន្លែង ហើយយកតែទូកមកកោះតែប៉ុណ្ណោះ។ ជាទូទៅ កាលណាចាប់បានតិចជាង២០នាក់ គឺបញ្ជាឱ្យសម្លាប់នៅនឹងកន្លែង បើចាប់បានច្រើនជាង២០នាក់ ត្រូវបញ្ជូនទៅអូរឈើទាល។ តាមខ្ញុំដឹង អ្នកដែលបញ្ជូនមកដីគោកទាំងនោះ ក្រោយមកត្រូវគេសម្លាប់ចោលដែរ។ ពួកអ្នកដែលចាប់បាន ហើយបញ្ជូនទៅកំពង់សោម ត្រូវគេសម្លាប់ ហើយកប់ចោលនៅក្រោមដើមធូរ៉េន ដើមដូង [...] ឆ. 29: បញ្ជាគឺគេប្រាប់ច្បាស់លាស់ថាតើត្រូវសម្លាប់នៅនឹងកន្លែង ឬក៏បញ្ជូនទៅលើគោក។ ប្រសិនបើអ្នកដែលត្រូវបានចាប់ខ្លួននោះជាទាហានវៀតណាម យើងត្រូវតែបញ្ជូនពួកនោះទីដីគោក បន្ទាប់មកគេនឹងធ្វើការចាក់ផ្សាយចម្លើយសារភាពរបស់ទាហានវៀតណាមនៅក្នុងវិទ្យុជាតិមុនពេលគេសម្លាប់"]។ ឯកសារ D54/24.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN 00978578, KH 00955510 ["ចង បើជាយួន គេ [ខ្មែរក្រហម] បញ្ជាមកឱ្យវ៉ៃចោល"]។

1510 ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.34 ["ស: តើលោកដឹង ឬទេ តើកងលេខប៉ុន្មាន ដែលបោះទីតាំងនៅចម្ការក្រូចហ្នឹង? ឆ. 34: ទេ ខ្ញុំមិនដឹងថា កងណាមួយច្បាស់លាស់ទេ ដែលបោះទីតាំងនៅកន្លែងនោះ ប៉ុន្តែខ្ញុំដឹងថា ពួកយោធាដែលមានភារកិច្ចសម្រាប់សម្លាប់មនុស្ស គឺត្រូវបានដាក់ឱ្យនៅកន្លែងចម្ការក្រូចនេះ។ បន្ទាប់ពីគេចាប់ផ្តើមប្រើកន្លែងទាំងនេះជាកន្លែងសម្លាប់មនុស្សមក គ្មាននរណាម្នាក់ត្រូវបានអនុញ្ញាតឱ្យចូលទៅជិតកន្លែងនោះទេ"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.25, 35 ["ពួកអ្នក [វៀតណាម] ដែលចាប់បាន ហើយបញ្ជូនទៅកំពង់សោម ត្រូវគេសម្លាប់ ហើយកប់ចោលនៅក្រោមដើមធូរ៉េន ដើមដូង [...] ស: ហេតុអ្វីបានលោកដឹងថាអ្នកដែលគេចាប់បាន ហើយបញ្ជូនទៅកំពង់សោមត្រូវគេសម្លាប់ ហើយកប់នៅក្រោមដើមធូរ៉េន និងដើមដូង? ឆ.35: ខ្ញុំឮតាមរយៈយោធា ដែលធ្វើការនៅកំពង់សោម។ យោធាដែលធ្វើការនៅនឹងកំពង់សោម គឺជាយោធារបស់កងពល ១៦៤។ អ្នកដែលគេចាប់បាន ពេលដែលនាំមកដល់ផែអូរឈើទាល នៅកំពង់សោម ត្រូវបានគេនាំចេញពីកប៉ាល់ ហើយដាក់ក្នុងឡានដឹកចេញទៅភ្លាមៗ"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ២០១៥ ម៉ោង 10.41.42-10.45.27 ["ថាដឹកទៅក្រុងកំពង់សោម ប៉ុន្តែរឿងសម្លាប់ៗទាំងអស់ ប៉ុន្តែអត់ដឹងកន្លែងចំណុចនៃសម្លាប់ទេ។ តែក្រៅពីកន្លែងកំពង់សោមនោះ ដូចជា ចម្ការក្រូច ចម្ការធុរេនអីមួយចំនួនទៀត ហ្នឹងយើងខ្ញុំអាចបានដឹងខ្លះ បាទ [...] សភាពការណ៍ដែលគេយកទៅសម្លាប់នោះ ភាគច្រើននៅកងពលដែលខ្ញុំធ្លាប់រស់នៅពីមុន

នៅជិតៗគ្នា[1511]។ ជនជាតិថៃ និងវៀតណាមជាច្រើន ដែលចាប់បាន ត្រូវគេសម្លាប់នៅទីតាំងទាំងនោះ ហើយសាកសពត្រូវគេយកទៅធ្វើជីដាក់ដើមឈើហូបផ្លែ[1512]។

---

បាទ [...] ពេលហ្នឹង វរសេនាធំ៦២នោះ គេចាប់បាន គេបញ្ជាឲ្យយកទៅចម្ការក្រូច និងចម្ការដូង យកទៅសម្លាប់ចោលនៅទីនោះ ហើយគេយកសាកសពនោះធ្វើជាជីតែម្តង។ [...] ជាទូទៅ ឃើញថា ថៃ និងវៀតណាមតែម្តង"]។

1511 ឯកសារ D2/17 កំណត់ហេតុស្តាប់ចម្លើយ អ៊ិន សារឿន ហៅ អ៊ិន វ៉ែន ឆ.7, 10, 11, 43 ["នៅឯចំការធូរេននៅជំនាន់ ប៉ុល ពត យោធា ប៉ុល ពត បានយកមនុស្សទៅសម្លាប់នៅទីនោះ [...] ឆ. 10: ខ្ញុំបានឃើញយោធា ប៉ុល ពត យកជនជាតិថៃទៅសម្លាប់នៅទីនោះ។ [...] ឆ. 11: ខ្ញុំឃើញយោធា ប៉ុល ពត ចងពួកគេ ហើយបណ្តើរពួកគេក្នុងទឹកទៅឆ្នេរ ហើយខ្ញុំបានឮថាពួកគេត្រូវបានយកទៅសម្លាប់នៅឯចំការធូរេន [...] ឆ. 43: ខ្ញុំមើលឃើញច្បាស់ គ្មានអ្វីបាំងទេ ហើយខ្ញុំមើលឃើញពីម្តុំដើមដូង។ ពីរបីថ្ងៃក្រោយមក ឪពុកខ្ញុំប្រាប់ថា គេចាប់មនុស្សយកទៅសម្លាប់នៅក្នុងចំការធូរេន"]។ ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ហៅ មា ឆ.33-44។

1512 ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ឆ.40-43 ["ស: តើលោកអាចពន្យល់ប្រាប់យើងអំពីចម្ការធូរេនបានដែរ ឬទេ? ឆ. 40: ខ្ញុំមិនបានឃើញនោះទេ ប៉ុន្តែ តាមខ្ញុំឮពីអ្នកផ្សេងនិយាយថា គេចាប់អ្នកដែលបានប្រព្រឹត្តខុស ហើយបញ្ជូនទៅកន្លែងនោះដើម្បីធ្វើជាជីសម្រាប់ដើមធូរេន។ កន្លែងនោះជាកន្លែងស្ងាត់ ដូច្នេះ គ្មានប្រជាជនចូលទៅដល់ទេ។ ស: ពេលដែលលោកនិយាយថា គេយកទៅធ្វើជី តើមានន័យយ៉ាងម៉េច? ឆ. 41: មានន័យថា យកទៅសម្លាប់ គឺសម្លាប់ដាក់គល់ធូរេន ដើម្បីធ្វើជី។ ស: ចំពោះអ្នកនេសាទថៃ និងវៀតណាម ដែលគេចាប់បាន តើគេយកទៅសម្លាប់នៅកន្លែងនោះដែរ ឬយ៉ាងម៉េច? ឆ.42: បាទ គេយកទៅកន្លែងនោះដែរ [...] ឆ. 43: គឺពួកខាងកងវរសេនាធំលេខ៦២ ដែលពួកគេមានទីតាំងនៅរាម ហើយវរសេនាធំលេខ២២ មានទីតាំងនៅទឹកសាប។ ដូច្នេះ ពួកវរសេនាធំ៦២ ជាអ្នកយកមនុស្សមកពីរាម ទៅចម្ការធូរេន ដើម្បីសម្លាប់"]។ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.11-13, 16 ["ស: តើលោកធ្លាប់បានឮកន្លែងចម្ការធូរ៉េន នៅរាម ដែលនៅជិតកន្លែងចម្ការដូងដែរ ឬទេ? ឆ. 11: បាទ ខ្ញុំធ្លាប់ស្គាល់ទីកន្លែងទាំងនោះ។ កន្លែងទាំងនោះជាកន្លែងដែលយួនជាច្រើនត្រូវបានសម្លាប់។ [...] ឆ. 12: តាមខ្ញុំដឹង គឺមានយួនរាប់រយនាក់ ដែលត្រូវបានសម្លាប់នៅទីនេះ។ ស: តើយោធានៅក្នុងកងណា ដែលបោះទីតាំងនៅកន្លែងទាំងនោះ? ឆ. 13: មានមួយកងវរសេនាតូច ដែលមានយោធាប្រហែល១៥០នាក់ របស់កងវរសេនាធំលេខ៦២ ដែលបោះទីតាំងនៅកន្លែងនោះ។ តួនាទីរបស់យោធាទាំងនោះ គឺសម្រាប់ចាំទទួលយួនដែលចាប់បានយកទៅសម្លាប់នៅចម្ការធូរ៉េន និងចម្ការដូង។ ចម្ការធូរ៉េន ចម្ការដូង និងចម្ការក្រូច គឺនៅជិតគ្នា។ ស: តើលោកដឹងគេយកយួនមកសម្លាប់នៅទីនោះដោយរបៀបណា? ឆ. 16: ខ្ញុំដឹងតាមរយៈយោធា ដែលធ្វើការនៅទីនោះ គេប្រាប់យើងថា គេបានសម្លាប់ពួកយួនជាច្រើននៅទីនោះ ហើយកប់សាកសពនៅក្រោមដើមធូរ៉េន ដើម្បីធ្វើជី"]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.29 ["ចម្ការដូងរបស់ ចេង ហេង ស្ថិតនៅចន្លោះចុងព្រលានយន្តហោះកងកេង និងភ្នំ។ កន្លែងនៅខាងលិចចម្ការដូង ជាប់នឹងជើងភ្នំ គឺជាចម្ការធូរ៉េន ដែលជាកន្លែង តាមុត យកជនជាតិថៃទៅសម្លាប់ ហើយកប់សាកសពនៅក្រោមដើមធូរ៉េន សម្រាប់ធ្វើជី។ ប្រសិនបើ ជនជាតិថៃចង់ស្វែងរកឆ្អឹងបងប្អូនពួកគេ ពួកគេអាចទៅរកនៅចម្ការធូរ៉េននោះចុះ។ ពេលគេ [ខ្មែរក្រហម] ចាប់បានទូកនេសាទថៃ១៤០០សេស ចំនួនពីរគ្រឿង និង១៨០០សេស ១គ្រឿង គេយកអ្នកនេសាទថៃទាំងអស់ទៅសម្លាប់ទីនោះ"]។ សូមមើលផងដែរ ឯកសារ D2/16 កំណត់ហេតុស្តាប់ចម្លើយ ទូច

412. សាក្សីម្នាក់បានផ្តល់សក្ខីកម្មថា គាត់បានឃើញឆ្អឹង និងសម្លៀកបំពាក់ នៅក្នុងចម្ការទុរេនមួយ។ គាត់អាចចំណាំជនជាតិខ្មែរបានតាមរយៈខោអាវខ្មៅ ចំណែកឯខោអាវរបស់សាកសពថៃមានពណ៌ចម្រុះ[1513]។ លើសពីនេះទៅទៀត ឡាក់ សាផន បានឃើញទាហានពីរនាក់បណ្តើរមនុស្សមួយក្រុមមានគ្នា ៤-៥ នាក់ ដែលជាប់ចំណង ឆ្ពោះទៅចម្ការទុរេននៅទឹកសាប តាមផ្លូវជាតិលេខ ៤ នៅរដូវវស្សា ក្នុងឆ្នាំ ១៩៧៥។ គាត់ប្រាប់ថា គាត់បានឮប្រជាជននិយាយថា អ្នកទាំងនេះជាអ្នកនេសាទថៃ ដែលត្រូវគេចាប់បាននៅលើសមុទ្រ រួចសម្លាប់ចោលនៅទីនោះ[1514]។ ពេលសាក្សីត្រឡប់ទៅចម្ការ

---

សឿលី ហៅ សឿ ទូច ឆ.32-33 ["ស: ក្នុងរយៈពេលដែលយើងធ្វើការបង្ហាញពីអត្តសញ្ញាណអំពីទីកន្លែង ពីរថ្ងៃកន្លងទៅនេះ គឺយើងបានបើកឡានទៅតាមផ្លូវជាតិលេខ៤។ យើងបានបើកឆ្ពោះទៅទិសខាងជើង ហើយកាត់ក្បែរវាលយន្តហោះកងកេង។ ខ្ញុំបានសួរលោកថា តើលោកដែលឮទីកន្លែងចំការធូរេនដែរ ឬទេ? លោកបានប្រាប់យើងថា លោកធ្លាប់ឮអំពីចំការធូរេន ហើយក៏បាននាំយើងបើកឡានឆ្ពោះទៅទិសខាងជើងនៃវាលយន្តហោះកងកេង តើពិតមែនទេ? ឆ.32: ខ្ញុំចង់ប្រាប់លោកថា ខ្ញុំអត់ស្គាល់ទីកន្លែង ប៉ុន្តែត្រូវហើយដែលខ្ញុំប្រាប់ថា នៅខាងឆ្វេងដៃកាលពីយើងកំពុងបើកឡាន ការពិតគឺមិនមាននរណាប្រាប់យើងអំពីព័ត៌មាននេះទេ វាគឺជាការឮតៗគ្នា។ ខ្ញុំបានឮថា ពួកថៃ និងវៀតណាមដែលគេចាប់បាន និងត្រូវបានយកទៅសម្លាប់នៅកន្លែងមួយហៅថា ចំការធូរេន។ ស: តើលោកបានឮពីមាត់មួយទៅមាត់មួយក្នុងរឿងហ្នឹង គឺក្នុងចន្លោះរយៈកាលពីឆ្នាំ១៩៧៥ទៅ១៩៧៩ពីអ្នកដែលនៅជាមួយគ្នាក្នុងកងពល១៦៤ ឬយ៉ាងណា? ឆ.33: ពេលខ្ញុំបានឮរឿងនេះ គឺក្រោយឆ្នាំ ១៩៧៩ គឺនៅពេលយើងជួបគ្នានៅព្រំដែន នៅក្នុងចន្លោះឆ្នាំ១៩៨០ ទៅ ១៩៨១"]។

1513 ឯកសារ D114/2 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.7 ["ស: លោកបាននិយាយពីលើកមុនថា លោកបនឃើញឆ្អឹងសាកសព ដែលកប់នៅចម្ការធូរេននោះ គឺជាឆ្អឹងរបស់ពួកខ្មែរ អ្នកនេសាទថៃ និងវៀតណាម ហើយលោកនិយាយថា លោកអាចស្គាល់ថាជាឆ្អឹងអ្នកទាំងនោះ តាមរយៈខោអាវដែលនៅសេសសល់កន្លែងនោះ។ តើលោកអាចពន្យល់ប្រាប់អំពីភាពខុសគ្នានៃខោអាវអ្នកទាំងនោះបានដែរ ឬទេ? ឆ.7: ខោ និងអាវរវាងខ្មែរ និងវៀតណាម គឺខុសគ្នា។ ចំណែកខោអាវពួកថៃ គឺមានពណ៌ចម្រុះ ចំពោះពួកខ្មែរពីជំនាន់ខ្មែរក្រហម ភាគច្រើនគេពាក់តែពណ៌ខ្មៅ"]។

1514 ឯកសារ D114/2 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.7, 13, 15 ["កាលពីក្នុងរបបខ្មែរក្រហម ពេលល្ងាចមួយនោះ ពេលដែលខ្ញុំដើរមកពីធ្វើការនៅការដ្ឋានលើកទំនប់ទឹកសាប ដើម្បីត្រឡប់មកភូមិវិញ ខ្ញុំបានឃើញយោធាបណ្តើរមនុស្សមួយក្រុមតាមផ្លូវជាតិលេខ៤ ទៅទិសចម្ការធូរេននៅទឹកសាប។ ពេលដែលគេកំពុងដើរនោះ ខ្ញុំឮសួរយោធាដែលបណ្តើរពួកនោះនិយាយថា ពួកទាំងនេះគឺជាពួកនេសាទថៃ ដែលគេចាប់ពីសមុទ្រមក។ នៅក្នុងពេលនោះ ខ្ញុំមិនដឹងថា គេនាំអ្នកទាំងនោះទៅកន្លែងណានោះទេ។ [...] ស: ពេលដែលលោកថា លោកបានឃើញពួកយោធាខ្មែរក្រហមបណ្តើរមនុស្សទៅទិសទឹកសាប តើលោកនៅចាំឬទេ លោកឃើញហ្នឹងនៅក្នុងឆ្នាំណា? ឆ.13: គឺនៅក្នុងរដូវភ្លៀង ឆ្នាំ១៩៧៥។ [...] ស: តើលោកឃើញយោធាប៉ុន្មាននាក់បណ្តើរមនុស្សទាំងនោះ? ឆ. 15: មានយោធាក្មេងៗពីរនាក់ ដោយមានស្ពាយកាំភ្លើងផង បានបណ្តើរអ្នកទោស៤ទៅ៥នាក់"]។

ទុរអេនវិញ ក្រោយឆ្នាំ ១៩៧៩ គាត់បានឃើញឆ្អឹង និងសម្លៀកបំពាក់នៅទីនោះ ដែលគាត់ជឿថាជារបស់ជនជាតិថៃ[1515]។

413. ពេលមួយនៅចុងឆ្នាំ ១៩៧៨[1516] ជនជាតិវៀតណាមបីនាក់ គឺស្ត្រីចំណាស់ម្នាក់ និងក្មេងជំទង់ពីរនាក់[1517] ត្រូវគេបណ្តើរទៅកាន់ទីបញ្ជាការរបស់ **មាស មុត** នៅក្រុងកំពង់សោម។ សាក្សី មុត ម៉ៅ បានឆ្លើយថា "ក្មេងទាំងនោះយំស្រែក"[1518] ហើយគាត់ដឹងថា អ្នកទាំងនេះ "ត្រូវគេចាប់បានលើទូកនៅសមុទ្រ"[1519]។ ពួកគេត្រូវបានសម្លាប់នៅជិតដើមឈើហូបផ្លែ[1520] ចម្ងាយពីរបីម៉ែត្រពីផ្ទះរបស់ **មាស មុត**។ សាក្សីបានឃើញរណ្តៅពីរបី ដែលកប់សាកសពជនជាតិវៀតណាម[1521]។

---

1515 ឯកសារ D114/2 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.7 ["ប៉ុន្តែ ក្រោយពីឆ្នាំ១៩៧៩ ពេលដែលខ្ញុំទៅដល់កន្លែងចម្ការធូរេន ទឹកសាប ខ្ញុំឃើញឆ្អឹង និងខោអាវខ្លះនៅទីនោះ ទើបខ្ញុំគិតថា ពួកថៃទាំងអស់នោះ ត្រូវបានគេយកមកបញ្ចប់នៅចម្ការធូរេនទឹកសាបនេះ"]។

1516 ឯកសារ D54/71 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.60 ["រឿងនេះកើតឡើងនៅចុងឆ្នាំ១៩៧៨ គឺប្រហែល២-៣ខែ មុនវៀតណាមចូល"]។

1517 ឯកសារ D54/71 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.56, 59 ["ខ្ញុំបានឃើញទាំងអស់៣នាក់ មនុស្សចាស់ស្រីម្នាក់ និងក្មេងជំទង់២នាក់ អាយុប្រហែល១០ឆ្នាំជាង។ [...] ស: តើស្ត្រីវៀតណាមចាស់នោះមានអាយុប៉ុន្មាន? ឆ.59: គាត់មានអាយុជិត៧០ឆ្នាំ"]។

1518 ឯកសារ D54/71 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.39 ["នៅយប់មួយ ខ្ញុំបានឃើញគេយកស្ត្រីយួនចាស់ម្នាក់ ហើយនិងក្មេងៗពីរបីនាក់ យកមកសម្លាប់នៅក្នុងបរិវេណមន្ទីរក្នុង។ ពួកក្មេងអស់ទាំងនោះស្រែកយំ"]។

1519 ឯកសារ D54/71 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.61 ["ស: តើលោកស្រីដឹងថា ពួកយួនទាំងនោះ គេយកមកពីណា? ឆ. 61: ទេ ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំបានឮតាមពួកនីរសារនិយាយគ្នានៅទីនោះ ពួកវៀតណាមទាំងនោះ គឺគេចាប់បានជាមួយទូករបស់ពួកគេមកពីសមុទ្រ"]។

1520 ឯកសារ D54/71 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.53, 56, 63 ["ស: តើផ្ទះដែលលោកស្រីស្នាក់នៅ ស្ថិតនៅចម្ងាយណាពីផ្ទះ មាស មុត ស្នាក់នៅ? ឆ.53. វាស្ថិតនៅឆ្ងាយពីគ្នា ប្រហែល៥០៦០ម៉ែត្រ។ ដំបូងផ្ទះរបស់គាត់ បន្ទាប់មកផ្ទះបាយ បន្ទាប់មកទៀត បានផ្ទះរបស់ខ្ញុំស្នាក់នៅ។ [...] ឆ. 56: ខ្ញុំឃើញយោធាបណ្តើរពួកនោះម្តងមួយៗ។ ខ្ញុំបានឃើញទាំងអស់៣នាក់ មនុស្សចាស់ស្រីម្នាក់ និងក្មេងជំទង់២នាក់ អាយុប្រហែល១០ឆ្នាំជាង។ ស្ត្រីចាស់នោះត្រូវបានសម្លាប់នៅចម្ងាយប្រហែល៣០ម៉ែត្រពីផ្ទះរបស់ខ្ញុំ ហើយនិងក្មេងៗជំទង់២នាក់ទៀត ត្រូវបានសម្លាប់នៅចម្ងាយប្រហែល១០០ម៉ែត្រពីផ្ទះរបស់ខ្ញុំ។ ស: តើកន្លែងនោះ គេប្រើជាកន្លែងសម្លាប់មនុស្សផ្សេងទៀតដែរ ឬទេ? ឆ. 63: ទេ តាមខ្ញុំដឹង គេមិនសម្លាប់មនុស្សផ្សេងទៀតនៅទីនោះទេ"]។

1521 ឯកសារ D54/71 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.64-65 ["ស: លោកស្រីបាននិយាយថា គេសម្លាប់ស្ត្រីវៀតណាមចាស់ម្នាក់ ប្រហែល៣០ម៉ែត្រពីផ្ទះដែលលោកស្រីស្នាក់នៅ តើក្រោយមក លោកស្រីធ្លាប់ទៅឃើញកន្លែងរណ្តៅ

414. **មាស មុត** បានបញ្ជាឱ្យសម្លាប់ជនជាតិថៃ ក្នុងចម្ការទុរេន នៅកំពង់សោម រួចកប់នៅក្រោមដើមទុរេនសម្រាប់ធ្វើជី[1522]។ ឯក នី បានអះអាងថា ក្រោយពីចាប់ជនជាតិថៃបាននៅលើសមុទ្រ គេនាំយកទៅសម្លាប់នៅចម្ការទុរេន បន្ទាប់មក សាកសពត្រូវគេកាត់ជាពីរកំណាត់ រួចកប់ក្រោមដើមទុរេន[1523]។ សាក្សីជាច្រើនផ្តល់ភ័ស្តុតាងប្រហាក់ប្រហែលគ្នាពាក់ព័ន្ធនឹងការសម្លាប់បែបនេះ[1524]។ នៅចុងឆ្នាំ ១៩៧៦ នូ សារឿន ដែលធ្វើការនៅកងកុមារ ក្នុងឃុំរាម បានឃើញអ្នកនេសាទថៃ ២៥ នាក់ ដែលចាប់បាននៅលើសមុទ្រ ត្រូវគេបណ្តើរទៅចម្ការទុរេនមួយ[1525]។ នៅទីនោះ ពួកគេត្រូវបានសម្លាប់ចោល[1526]។ នូ សារឿន មិនបានឃើញការសម្លាប់នោះទេ ប៉ុន្តែ គាត់បានឃើញរណ្តៅ និងផ្នូរនៅទីនោះក្នុងឆ្នាំ ១៩៧៩[1527]។

415. ព្រំ កែម ដឹងពីទាហានកងនាវាខ្មែរក្រហមថា ទូកនេសាទមួយគ្រឿង រួមនឹងមនុស្ស ១០ នាក់ ត្រូវគេចាប់បាននៅឆ្នាំ ១៩៧៦។ គាត់អះអាងថា អ្នកនេសាទត្រូវគេនាំចេញពីទូក សម្រាតខោអាវ

---

នោះដែរ ឬទេ? ឆ. 64: ដោយសារកន្លែងនោះ វានៅចម្ងាយ៣០ម៉ែត្រពីក្រោយផ្ទះរបស់ខ្ញុំ ខ្ញុំចាំថា ខ្ញុំបានទៅដល់ទីនោះ ហើយបានឃើញរណ្តៅពីរបី។ ស: តើលោកស្រី បានឃើញរណ្តៅនោះ ជារណ្តៅកប់សាកសពរួម ឬក៏រណ្តៅកប់សាកសពមួយៗ? ឆ. 65: រណ្តៅនីមួយៗគឺជារណ្តៅតូចៗ សម្រាប់កប់សាកសពម្នាក់ៗ។ ខ្ញុំបានឃើញចំនួនពីរបីរណ្តៅទេ ដែលស្ថិតនៅជិតដើមខ្នុរ និងដើមស្វាយ"]។

1522 ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ. 41។

1523 ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ. 29, 41-44។

1524 ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ឆ. 40-44 ["ស: តើលោកអាចពន្យល់ប្រាប់យើងអំពីចម្ការធូរេនបានដែរ ឬទេ? ឆ. 40: ខ្ញុំមិនបានឃើញនោះទេ ប៉ុន្តែ តាមខ្ញុំឮពីអ្នកផ្សេងនិយាយថា គេចាប់អ្នកដែលបានប្រព្រឹត្តខុស ហើយបញ្ជូនទៅកន្លែងនោះដើម្បីធ្វើជាជីសម្រាប់ដើមធូរេន។ កន្លែងនោះជាកន្លែងស្ងាត់ ដូច្នេះ គ្មានប្រជាជនចូលទៅដល់ទេ។ ស: ពេលដែលលោកនិយាយថា គេយកទៅធ្វើជី តើមានន័យយ៉ាងម៉េច? ឆ. 41: មានន័យថា យកទៅសម្លាប់ គឺសម្លាប់ដាក់គល់ធូរេន ដើម្បីធ្វើជី។ ស: ចំពោះអ្នកនេសាទថៃ និងវៀតណាម ដែលគេចាប់បាន តើគេយកទៅសម្លាប់នៅកន្លែងនោះដែរ ឬយ៉ាងម៉េច? ឆ.42: បាទ គេយកទៅកន្លែងនោះដែរ [...] គឺអ្នកនេសាទវៀតណាម និងថៃ ដែលគេបានចាប់ខ្លួន"]។

1525 ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ហៅ មា ឆ. 33-43។

1526 ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ហៅ មា ឆ. 33-43។

1527 ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ហៅ មា ឆ. 43-44។

ចងដៃជាមួយខ្សែអង្រឹង រួចនាំទៅចម្ការទុរេន[1528]។ អ្នកភូមិនៅតំបន់នោះជឿថា អ្នកនេសាទត្រូវគេសម្លាប់ចោល រួចកប់នៅគល់ទុរេនសម្រាប់ធ្វើជី[1529]។

416. ប៉ែន សារិន ធ្វើការនៅមូលដ្ឋានកងទ័ពជើងទឹករាមក្នុងឆ្នាំ ១៩៧៦ ហើយគាត់បានឃើញអ្នកនេសាទថៃពីរក្រុម មានគ្នាពី ១៥ ទៅ ២០ នាក់ ត្រូវគេចង រួចនាំទៅអគារមួយនៅក្នុងមូលដ្ឋាននោះ[1530]។ អ្នកនេសាទត្រូវគេចាប់បាននៅកោះតាង និងកោះរ៉ុង។ ប៉ែន សារិន ជឿថា ពួកគេត្រូវបានសម្លាប់ចោល[1531]។

---

[1528] ឯកសារ D54/120 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.4 ["ស: សូមលោកពន្យល់ប្រាប់យើងនូវអ្វីដែលលោកបានដឹង បានឬអំពីពួកអ្នកនេសាទថៃ ដែលត្រូវបានពួកខ្មែរក្រហមចាប់ខ្លួនកាលនោះ? ឆ. 4: កាលនោះ គឺក្នុងឆ្នាំ១៩៧៦។ ខ្ញុំនិងអ្នកភូមិផ្សេងទៀត ត្រូវបានគេចាត់តាំងឱ្យទៅកាប់ដើមកោងកាងធ្វើធ្យូង។ អ្នកដែលនៅកន្លែង ដែលគេបញ្ជូនខ្ញុំទៅកាប់ព្រៃកោងកាង បាននិយាយប្រាប់ខ្ញុំ និងគ្នាខ្ញុំថា ទូកនេសាទថៃប្រភេទ "បេអឺ" ត្រូវបានចាប់ដោយយោធាខ្មែរក្រហម ដែលនៅលើទូកនោះមានអ្នកនេសាទថៃចំនួន១០នាក់។ ទូកនោះត្រូវបានគេនាំយកមកចតនៅមាត់ពាម ហើយអ្នកនេសាទថៃទាំងនោះត្រូវបានគេយកចេញពីទូក បញ្ជូនមកដីគោក ហើយសម្រាតខោអាវចោលទាំងអស់ ទុកតែខោទ្រនាប់។ ពួកគេត្រូវបានចងដៃនឹងខ្សែអង្រឹងជាជួរៗ ហើយយកទៅចម្ការធូរេន។ អ្នកភូមិទាំងនោះសន្មតដោយខ្លួនឯងថា អ្នកនេសាទថៃទាំងនោះច្បាស់ជាត្រូវបានសម្លាប់ដាក់គល់ធូរេន ដើម្បីធ្វើជីដាក់ជាមិនខាន"]។

[1529] ឯកសារ D54/120 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.4 ["ស: សូមលោកពន្យល់ប្រាប់យើងនូវអ្វីដែលលោកបានដឹង បានឬអំពីពួកអ្នកនេសាទថៃ ដែលត្រូវបានពួកខ្មែរក្រហមចាប់ខ្លួនកាលនោះ? ឆ. 4: កាលនោះ គឺក្នុងឆ្នាំ១៩៧៦។ ខ្ញុំនិងអ្នកភូមិផ្សេងទៀត ត្រូវបានគេចាត់តាំងឱ្យទៅកាប់ដើមកោងកាងធ្វើធ្យូង។ អ្នកដែលនៅកន្លែង ដែលគេបញ្ជូនខ្ញុំទៅកាប់ព្រៃកោងកាង បាននិយាយប្រាប់ខ្ញុំ និងគ្នាខ្ញុំថា ទូកនេសាទថៃប្រភេទ "បេអឺ" ត្រូវបានចាប់ដោយយោធាខ្មែរក្រហម ដែលនៅលើទូកនោះមានអ្នកនេសាទថៃចំនួន១០នាក់។ ទូកនោះត្រូវបានគេនាំយកមកចតនៅមាត់ពាម ហើយអ្នកនេសាទថៃទាំងនោះត្រូវបានគេយកចេញពីទូក បញ្ជូនមកដីគោក ហើយសម្រាតខោអាវចោលទាំងអស់ ទុកតែខោទ្រនាប់។ ពួកគេត្រូវបានចងដៃនឹងខ្សែអង្រឹងជាជួរៗ ហើយយកទៅចម្ការធូរេន។ អ្នកភូមិទាំងនោះសន្មតដោយខ្លួនឯងថា អ្នកនេសាទថៃទាំងនោះច្បាស់ជាត្រូវបានសម្លាប់ដាក់គល់ធូរេន ដើម្បីធ្វើជីដាក់ជាមិនខាន"]។

[1530] ឯកសារ D1.3.13.8 ឆ បទសម្ភាសន៍របស់ការិយាល័យសហព្រះរាជអាជ្ញាជាមួយ ប៉ែន សារិន EN 002175661-62 ["សាក្សីធ្វើការនៅលើមូលដ្ឋានកងទ័ពជើងទឹកបាន១អាទិត្យ ក្នុងឆ្នាំ១៩៧៦ ហើយក្នុងអំឡុងពេលនោះ ពួកនេសាទថៃចំនួនពីរលើក (១៥-២០នាក់ ក្នុងមួយលើកៗ) ត្រូវបានគេនាំយកទៅក្នុងអគារបន្ទាយ។ ពួកគេត្រូវបានចង នៅពេលនាំចូលទៅនោះ។ អ្នកនេសាទទាំងនោះត្រូវបានចាប់ខ្លួននៅកោះតាង និងកោះរ៉ុង។ គាត់ជឿជាក់ថា អ្នកនេសាទទាំងនោះត្រូវគេយកទៅសម្លាប់ ពីព្រោះពួកគេត្រូវបានចាប់ នៅពេលចូលមកនេសាទក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ"]។

[1531] ឯកសារ D1.3.13.8 បទសម្ភាសន៍របស់ការិយាល័យសហព្រះរាជអាជ្ញាជាមួយ ប៉ែន សារិន EN 002175661-62 ["សាក្សីធ្វើការនៅលើមូលដ្ឋានកងទ័ពជើងទឹកបាន១អាទិត្យ ក្នុងឆ្នាំ១៩៧៦ ហើយក្នុងអំឡុងពេលនោះ ពួកនេសាទថៃ

## *ឃ) ការសម្លាប់នៅមន្ទីរ ស-២១*

417. អ្នកខ្លះ ដែលចាប់បាននៅលើសមុទ្រ ត្រូវគេដឹកយកទៅសម្លាប់នៅមន្ទីរ ស-២១ ក្រុងភ្នំពេញ[1532]។ ទាំងជនជាតិវៀតណាម និងថៃ ត្រូវគេដឹកតាមឡាន ពីរាម ដោយអង្គភាពនគរបាល/សន្តិសុខ ទៅ

---

ចំនួនពីរលើក (១៥-២០នាក់ ក្នុងមួយលើកៗ) ត្រូវបានគេនាំយកទៅក្នុងអគារបន្ទាយ។ ពួកគេត្រូវបានចង នៅពេលនាំចូលទៅនោះ។ អ្នកនេសាទទាំងនោះត្រូវបានចាប់ខ្លួននៅកោះតាង និងកោះរ៉ុង។ គាត់ជឿជាក់ថា អ្នកនេសាទទាំងនោះត្រូវគេយកទៅសម្លាប់ ពីព្រោះពួកគេត្រូវបានចាប់ នៅពេលចូលមកនេសាទក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ"]។

1532 ឯកសារ D1.3.28.140 បញ្ជីឈ្មោះអ្នកទោសមន្ទីរស-21 ត្រូវបានដាក់ចំណាត់ថ្នាក់ជាតិញយួន និងអាមេរិកាំង ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៨ EN 01236389, KH 00088752, FR 01187845 [បញ្ជាក់ថា អាមេរិកាំងពីរនាក់ ឈ្មោះ គ្រីស្តូហ្វៃ អេដវ័ ឌីឡុង់ និង មីសែល ស្កុត ឌីត គីម្ង ត្រូវបានទទួលនៅមន្ទីរស-21 ពីកំពង់សោម នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៨]។ ឯកសារ D1.3.33.3 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច EN 00147526-27, KH 00146488 ["ស: តើមានជនបរទេសតែ៤នាក់ទេនៅស-២១? ឆ.: បាទ ដោយឡែកជនបរទេស៤នាក់នេះ នួន ជា បញ្ជាឱ្យដុតឱ្យសុះ ដោយប្រើសំបកកង់ឡាន។ [...] ឆ.: មានអង់គ្លេស អាមេរិកាំង និងប្រហែល អូស្ត្រាលី និងសាសន៍ដទៃទៀត ដែលខ្ញុំមិនចាំ [...] គេចូលដែនសមុទ្រខ្មែរ ហើយកងសមុទ្រ ចាប់បញ្ជូនមកឱ្យ នួន ជា។ សហព្រះរាជអាជ្ញាសួរថា: តើមានបរទេស ចាម វៀតណាមទេ ឬមានតែបួននាក់នេះ? ឆ.: ជនបរទេស ខ្ញុំសំដៅពួកស្បែកស"]។ ឯកសារ D114/145.2.15 ប្រវត្តិរូបនៅមន្ទីរស២១ របស់ ដាំង យ៉ាំង ថាន់ (លរ. 132 ទឹកសាប, ដាំង យ៉ាំង ថាន់, អ្នកនេសាទ, ចាប់ខ្លួននៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៦ នៅម៉ូព្រែកលេខ II និងបញ្ជូនទៅស-២១ នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៧៧)។ ឯកសារ D4.1.5 របាយការណ៍វិភាគរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្រោមចំណងជើងថា "បញ្ជីឈ្មោះជនរងគ្រោះបរទេស ដែលបានកម្ទេចនៅមន្ទីរស-២១" [ដែលមានឈ្មោះជនជាតិថៃ៦០នាក់ ភាគច្រើនជាអ្នកនេសាទ និងសិស្ស ដែលចាប់បាននៅកំពង់សោម ចន្លោះថ្ងៃទី៧ ខែឧសភា ឆ្នាំ១៧៦ ណឹងថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ពួកគេត្រូវបានសម្លាប់]។ បញ្ជីឈ្មោះនេះ ក៏មានឈ្មោះជនជាតិវៀតណាមចំនួន១១៣នាក់ផងដែរ ភាគច្រើនជា "គិញ" ដែលត្រូវបានចាប់ខ្លួននៅទីតាំងផ្សេងៗ (កំពង់សោម, កំពត, ភូមិភាគពាយ័ព្យ, តំបន់២៥, ស្វាយរៀង, ក្រចេះ, មណ្ឌលគិរី និងវៀតណាម) ចន្លោះថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៨ និងថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៧៨។ ទាំងអស់សុទ្ធតែត្រូវបានសម្លាប់ លើកលែងតែប្រាំនាក់ ដែលស្លាប់ដោយជំងឺ)។ ឯកសារ D114/145.2.1 ប្រវត្តិរូបនៅមន្ទីរស-21 ដែលមានឈ្មោះ ឡេ វ៉ាន់ធឿ, ង៉ៀង វ៉ាន់សឺន, ង៉ៀង វ៉ាន់ង៉ុក នៅ លរ. 26, 27, 28 ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧៨។ ឯកសារ D114/145.2.11 ប្រវត្តិរូបនៅមន្ទីរស-21 ដែលមានឈ្មោះ ត្រឹង យ៉ាំងឃ្វេ, ជឹម យ៉ាំងគី, ជឹម យ៉ាំងយុប, ជឹម យ៉ាំងកឹង, ង្វៀង ខិនអ៊ី នៅ លរ. 121, 122, 123, 124, 125 ធ្វើនៅទឹកសាប ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៧៦។ ឯកសារ D114/145.2.12 ប្រវត្តិរូបនៅមន្ទីរស-21 ដែលមានឈ្មោះ ង្វៀង ធី ធឿង, ង្វៀង ហ៊ីវ ឡាង, ចឹង ថាន់ហឿន នៅ លរ . 126, 127, 128 ធ្វើនៅទឹកសាប ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៧៦។ ឯកសារ D114/145.2.13 ប្រវត្តិរូបនៅមន្ទីរស-21 ដែលមានឈ្មោះ ឡេ យ៉ាំង ហាយ, គឹម ងុក ទឿង នៅ លរ. 129, 130 ធ្វើនៅទឹកសាប ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៧៦។ D114/145.2.14 ប្រវត្តិរូបនៅមន្ទីរស-21 ដែលមានឈ្មោះ ផាម យ៉ាំងថាន់ (ផាន់) នៅ លរ.131 ធ្វើនៅទឹកសាប ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៧៥។ ឯកសារ D114/145.2.15 ប្រវត្តិរូបនៅមន្ទីរស-21 ដែលមានឈ្មោះ ដាំង យ៉ាំ

ទីក្រុងភ្នំពេញ[1533]។ ប៉ាង រ៉េត អនុប្រធានកងអនុសេនាធំលេខ ៤ កងវរសេនាតូច ១៦៥ កងពល ១៦៤ ចាំបានថា អ្នកទោសវៀតណាម ដែលគេនាំទៅកំពង់ផែកំពង់សោម ត្រូវបានដឹកចេញតាម

ឯងថាន់ នៅ លរ. 132 ផ្ញើទៅទឹកសាប ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៦។ ឯកសារ D114/145.2.16 ចម្លើយសារភាពនៅមន្ទីរស-21របស់ ឡោ អៀង គង់ នៅ លរ. 134 ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៨។ ឯកសារ D114/145.2.17 របាយការណ៍មន្ទីរស-២១ យោងទៅលើចម្លើយសារភាពរបស់ វិញ មិញ, ចូវ វ៉ាងឡោ, វិន ភី ឡុង នៅ លរ. 140, 141, 142 ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ១៩៧៨។ ឯកសារ D114/145.2.18 ចម្លើយសារភាពនៅមន្ទីរស-២១ របស់ ង៉ៀង ថាញ់ ក្វាង នៅលរ. 155 ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៧៨។ ឯកសារ D114/145.2.192 ចម្លើយសារភាពនៅមន្ទីរស-២១របស់ វិញ មិញ ចូវ នៅលរ. 162 ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៧៨។ ឯកសារ D11/2 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ រ៉ប ហាមិល KH 00710121 [ដើមបណ្ដឹងនិយាយថា បងប្រុសរបស់ខ្លួន (Kerry Hamill) និង John Dewhirst "ត្រូវបានដាក់ខ្នោះជើង និងបិទមុខ បន្ទាប់មកត្រូវបានបញ្ជូនទៅកាន់រោងភាពយន្តមួយនៅក្រុងព្រះសីហនុ ដែលជាកន្លែងដែលពួកគេត្រូវបានឃុំខ្លួនអស់រយៈពេលមួយថ្ងៃ ឬពីរថ្ងៃ មុនពេលដែលត្រូវបានបញ្ជូនទៅទួលស្លែង (ស២១) នៅក្រុងភ្នំពេញ។ [...] នៅទួលស្លែង ពួកគេទាំងពីរនាក់ត្រូវបានគេសួរចម្លើយ និងធ្វើទារុណកម្មដោយការឆក់ខ្សែភ្លើង ដែលប្រហែលជាត្រូវបានធ្វើឡើងដោយប្រធានសួរចម្លើយឈ្មោះ សមមិត្ត ចាន់។ ចុងបញ្ចប់អ្នកទាំងពីរត្រូវបានបង្ខំឲ្យចុះហត្ថលេខាលើចម្លើយសារភាព ដែលថា ពួកគេជាភ្នាក់ងារ សេអ៊ីអា"។ ដើមបណ្ដឹងសន្និដ្ឋានថា បន្ទាប់ពីត្រូវបានចាប់ខ្លួនប្រមាណជាពីរខែមក បងប្រុសរបស់ខ្លួន បានចុះហត្ថលេខាលើចម្លើយសារភាពរបស់គាត់ ហើយគាត់ត្រូវបានសម្លាប់នៅពេលនោះ។ ដើមបណ្ដឹងពុំដឹងអំពីវិធីដែលគាត់ត្រូវបានសម្លាប់នោះទេ តែគាត់ប្រហែលជាត្រូវបានគេចងមុខយកចេញក្រៅបរិវេណមន្ទីរស២១ ទៅកាន់រណ្ដៅដែលជីករួចជាស្រេច រួចគេបង្ខំគាត់ឲ្យលុតជង្គង់ចុះនៅមាត់រណ្ដៅនោះ ក្រោយមកត្រូវគេវាយនឹងដំបងដែកត្រង់ក្បាល និងអារបំពង់ក រួចកប់ [...] គាត់សំណាងហើយ] [...] មានដំណាលថា មានជនជាតិបរទេសពីរនាក់ត្រូវបានដាក់ក្នុងរង្វង់កង់ឡាន រួចស្រោចសាំងដុត"]។

[1533] ឯកសារ D59/1/1.9a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡាយ ប៊ុនសាក់ EN 00963735-37, KH 00926467-69 ["មនុស្សគេបញ្ជូនទៅគោក មិនដឹងបញ្ជូនទៅណា ខ្ញុំមិនដឹងដែរ។ [...] គេមាន១ កាលហ្នឹងមានស្ថានទូត គេបញ្ជូនទៅស្ថានទូត បើថៃ បញ្ជូនទៅថៃទៅ បើយួន គេបញ្ជូនទៅទូតយួនទៅ។ [...] ទូតនៅភ្នំពេញ។ ស: ទីបញ្ជាការកងពល គេមិនទាន់បញ្ជូនមកផែណាដែរ? ឆ.: មកផែធំ [...] ផែធំរាម។ [...] មនុស្សគេជិះ ដឹកឡានទៅមិនដឹងនៅត្រង់ណា។ [...] ខ្ញុំមិនដែលឃើញដោយផ្ទាល់ទេ ព្រោះអាហ្នឹងជាការងាររបស់ពួកដៃក្រហម។ [...] ស: ឡានហ្នឹង ឡានមកពីភ្នំពេញ ឬឡានក្រុង ឡានរបស់ជើងទឹក? ឆ.: ឡានទៅទីបញ្ជាការក៏មាន ឡានមកពីភ្នំពេញក៏មាន"]។ ឯកសារ D1.3.28.140 បញ្ជីឈ្មោះអ្នកទោសមន្ទីរស-21 ត្រូវបានដាក់ចំណាត់ថ្នាក់ជាគិញយួន និងអាមេរិកាំង ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៨ EN 01236389, KH 00088752, FR 01187845 [បញ្ជាក់ថា អាមេរិកាំងពីរនាក់ឈ្មោះ គ្រីស្តូហ្វែ អេដវី ឌឺឡង់ និង មីសែល ស្កុត ឌីត គីម្ម ត្រូវបានទទួលនៅមន្ទីរស-21 ពីកំពង់សោម នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៨]។ ឯកសារ D54/87 កំណត់ហេតុស្ដាប់ចម្លើយ ព្រំ សារ៉ាត ឆ. 135, 137, 144 ["ស: លោកបាននិយាយនៅក្នុងកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានបញ្ជាក់ថា កងទ័ព ឬក៏ទាហានវៀតណាម

ដែលកងពល១៦៤ចាប់បាននៅដែនសមុទ្រ ត្រូវបានបញ្ជូនទៅកងពល ហើយកងពលបញ្ជូនទៅស-២១។ តើព័ត៌មាននេះត្រឹមត្រូវដែរ ឬទេ? ឆ. 135: បាទ ខ្ញុំសូមបញ្ជាក់ថា ព័ត៌មាននេះជាការពិត ពីព្រោះខ្ញុំឮពីមិត្តភក្តិរបស់ខ្ញុំ ដែលធ្វើការនៅកងពល១៦៤ថា គេបញ្ជូនអ្នកដែលចាប់បានទៅភ្នំពេញ។ ក្នុងសម័យនោះ ខ្ញុំជឿជាក់ថា ពួកគេនិយាយប្រាប់ខ្ញុំជារឿងពិត។ ឧទាហរណ៍ យើងបានឃើញមនុស្ស៣នាក់ចម្លែកនៅក្នុងផ្ទះមួយនៅឯកងពល ហើយខ្ញុំក៏សួរមិត្តភក្តិខ្ញុំថាតើពួកនោះជានរណា? មិត្តភក្តិខ្ញុំប្រាប់ថា យប់មិញចាប់បានយួនបីនាក់។ ខ្ញុំសួរថា ចាប់នៅណា? គាត់ឆ្លើយថាចាប់បាននៅកោះពូលូវៃ លុះព្រឹកឡើងខ្ញុំសួរមិត្តភក្តិខ្ញុំ គេយកយួនទាំងនោះទៅណា គេឆ្លើយថា យកទៅភ្នំពេញ [...]។ ស: នៅក្នុងកិច្ចសម្ភាសរបស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានបញ្ជាក់ថា ទាហានវៀតណាមដែលចាប់បាននៅសមុទ្រដោយកងពល១៦៤ ត្រូវបានបញ្ជូនទៅមន្ទីរកងពល រួចហើយកងពលបញ្ជូនបន្តទៅស-២១។ តើលោកដឹងថា គេបញ្ជូនជនស៊ីវិលវៀតណាមទាំងនោះដូចគ្នានឹងពួកទាហានដែរ ឬទេ? ឆ. 137: ខ្ញុំដឹងថា គេបញ្ជូនជនស៊ីវិលទៅភ្នំពេញដែរ តែខ្ញុំមិនដឹងថា គេប្រព្រឹត្តិយ៉ាងម៉េចចំពោះពួកគេទេ។ [...] ស: តើលោកដឹងទេថាអ្នកណាជាអ្នកសម្រេចត្រូវបញ្ជូនទាហាន និងជនស៊ីវិល ដែលចាប់បានត្រូវបញ្ជូនទៅស-២១? ឆ. 144: តាមដែលខ្ញុំដឹង មាស មុត ជាអ្នករាយការណ៍ទៅភ្នំពេញ ហើយបន្ទាប់ពីទទួលរបាយការណ៍ អ្នកនៅភ្នំពេញបញ្ជូនឡានមកកំពង់សោម ដើម្បីដឹកពួកគេទៅភ្នំពេញ"]។ ឯកសារ D1.3.33.3 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច EN 00147526-27, KH 00146488 ["ស: ហេតុអ្វីបានជាគេចាប់ជនបរទេសទាំងនេះ ពួកគេមកធ្វើអ្វី? ឆ: គេចូលដែនសមុទ្រខ្មែរ ហើយកងសមុទ្រចាប់បញ្ជូនមកឱ្យ នួន ជា"]។ ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ. 28 ["ខ្ញុំគិតថា វត្តឥន្ទញ្ញាណនេះ មិនមែនជាកន្លែងឃុំអ្នកទោសចាប់រហូតទេ គឺវាជាកន្លែងដែលឃុំ បណ្តោះអាសន្នចំពោះជនដែលគេសង្ស័យ ឬជាប់ចោទរឿងរ៉ាវផ្សេងៗ។ បន្ទាប់ពី គេរកឃើញកំហុសរបស់ជននោះហើយ គេបញ្ជូនចេញទៅភ្នំពេញ ឬកន្លែងផ្សេងទៀត"]។ ឯកសារ D59/1/1.8a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រំ សារ៉ាត EN 00974217, KH 00926394-95 ["ស: គេនិយាយថាម៉េច? ឆ.: គេនិយាយថា បើមានរឿងតូចធំអី ផ្នែកសន្តិសុខរបស់ស២១នឹង គេរាប់រងទទួល [...] ហើយគេយកមនុស្សនឹងទៅណា យើងអត់ដឹង។ ស: បាទ បានន័យថា យើងមិនមែនជាអ្នកបញ្ជូនទៅដល់ភ្នំពេញ គេមកទទួលគាត់? ឆ.: អត់ទេ ខ្សែរបស់យើងអត់មានសិទ្ធិអីហៅ ស-២១ ទេ។ [...] បើថានៅយើងកោះតាងខាងអី អានឹងខាងកំពង់សោម ហៅទៅ ហៅមកភ្នំពេញមក ហើយភ្នំពេញគេឡើងមក។ [...] ស: ប៉ុន្តែដឹងថាគេហៅមក អ្នកដែលគេចាប់បានពីតាមកោះអីនឹង គេមិនដែលទុកយូរទេ? ឆ.: បាទ!"], EN 00974222, KH 00926399 ["ស: ហើយចុះបើខាងពួកអ្នកស៊ើបការណ៍ចូលមកកោះយើងអី ខាងកងពលគេណែនាំអីយើង? ឆ.: គេណែនាំឱ្យឃាត់ខ្លួនហើយ បើយើងចាប់បានរបៀបនេះ គេត្រូវបញ្ជូនទៅស-២១។ ស៖ ប៉ុន្តែ គេបញ្ជូនត្រង់មកអូរឈើទាល មករាម? មកកន្លែងកងពលនៅកំពង់សោម ឬបញ្ជូនមករាម ហើយបានបញ្ជូនតាមឡានមកងពល? ឆ.: ដូចនែក! អានឹងដូចខ្ញុំនិយាយអញ្ចឹង រវាងបញ្ហាថាតើចូលរាម ឬចូលកំពង់សោម នៅពេលនឹងគឺថាដាច់ពីគ្នាយើង ដូចមិនអាចមើលឃើញគ្រប់ពេលណា ពេលដែលយើងឃើញៗ ប៉ុនដល់ចេញផុតៗ"]។ ឯកសារ D37 កំណត់ហេតុស្តាប់ចម្លើយ Robert Hamill EN 00791866-67, KH 00945764 ["ខ្ញុំបានជួប មាស មុត នៅផ្ទះគាត់ក្នុងឆ្នាំ២០១០។ [...] ខ្ញុំបានសួរគាត់ថាតើមានរឿងអ្វីកើតឡើងចំពោះជនបរទេស ដែលត្រូវបានចាប់ខ្លួននៅតាមឆ្នេរសមុទ្រ។ គាត់ឆ្លើយថា ពួកគេមិនត្រូវបានវាយដំទេ ហើយគួរត្រូវបានបញ្ជូនទៅស-២១"]។

ឡានរបស់កងពល ១៦៤។ គាត់មិនដឹងថា តើឡានដឹកអ្នកទោសទាំងនេះទៅណាទេ[1534]។ រៀងរាល់មួយ ឬពីរខែម្តង ជនស៊ីវិលវៀតណាមត្រូវគេនាំយកទៅមន្ទីរ ស-២១[1535]។ សាក្សី ព្រុំ សារ៉ាត់

1534 ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ. 68 [“ស: នៅពេលដែលចាប់ទូកវៀតណាមបានហើយ តើអ្នកដែលនៅលើទូកនោះ ត្រូវបានគេបញ្ជូនទៅណា? ឆ. 68: ខ្ញុំគ្រាន់តែដឹងថា អ្នកនេសាទវៀតណាម ដែលគេបានដឹកមកដល់ផែ គឺត្រូវបានគេដឹកចេញពីផែតាមឡានទ្រុងរបស់កងពល១៦៤។ ប៉ុន្តែខ្ញុំមិនដឹងថាពួកគេត្រូវបានបញ្ជូនទៅទីណាទេ”]។

1535 ឯកសារ D114/43 កំណត់ហេតុស្តាប់ចម្លើយ សួស ធី ឆ. 17-19 [“ស: តើលោកចាំបានទេ ថានៅពេលណាក្នុងរបបនោះ ដែលលោកបានទួលគ្រួសារជនជាតិវៀតណាមពីកំពង់សោម? តើលោកបានទទួលគ្រួសារជនជាតិវៀតណាមញឹកញាប់កម្រិតណា? ឆ.17: ដើម្បីឲ្យដឹងអំពីកាលបរិច្ឆេទពិតប្រាកដ ខ្ញុំត្រូវមើលឯកសាររបស់ខ្ញុំ។ ប៉ុន្តែខ្ញុំអាចប៉ាន់ស្មានបានថា ខ្ញុំបានទទួលគ្រួសារជនជាតិវៀតណាម ក្នុងអំឡុងពាក់កណ្តាលរបបខ្មែរក្រហម។ ខ្ញុំចាំថា ខ្ញុំបានទទួលពួកគេ១ ឬ២ខែម្តង។ វាមិនសូវញឹកញាប់ ដូចការទទួលអ្នកទោសទូទៅទេ។ ការទទួលជនជាតិវៀតណាមទាំងនេះ មិនបានកើតឡើងញឹកញាប់នោះទេ។ ខ្ញុំមិនចាំថាតើខ្ញុំបានទទួលគ្រួសារជនជាតិវៀតណាមញឹកញាប់ដល់កម្រិតណា ឬបានទទួលគ្រួសារជនជាតិវៀតណាមនៅក្នុងដំណាក់កាលបន្តបន្ទាប់ទៀតឡើយ។ ស: នៅក្នុងចម្លើយរបស់លោកកាលពីមុន E1/55.1 ទំព័រ៤៤ជួរ១១-១២ លោកបាននិយាយថា “ពុំមានអ្នកទោសសង្គ្រាមជនជាតិវៀតណាមឡើយក្នុងឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧។ នៅពេលដែលជម្លោះបានកើតមានប៉ុណ្ណោះ ទើបលោកចាប់ផ្តើមទទួលបានអ្នកទោសសង្គ្រាម”។ តើលោកអាចពន្យល់អំពីចំណុចនេះបានដែរ ឬទេ ទាក់ទងទៅនឹងអ្វីដែលលោកទើបបាននិយាយអំពីជនជាតិវៀតណាមទាំងនេះ? ឆ.18: នេះគឺជារឿងដោយឡែក ហើយខ្ញុំសូមបញ្ជាក់អះអាងឡើងវិញអំពីអ្វី ដែលខ្ញុំបាននិយាយកាលពីលើកមុន។ ចម្លើយកាលពីមុននោះ សំដៅចំពោះទាហាន ដែលត្រូវបានចាប់ខ្លួនពីតាមបណ្តាលខេត្ត ដែលស្ថិតនៅជាប់ព្រំដែនវៀតណាម។ អ្វីដែលខ្ញុំបាននិយាយខាងលើ គ្រាន់តែសំដៅចំពោះគ្រួសារជនជាតិវៀតណាមដែលចាប់ខ្លួននៅឯសមុទ្រ ដែលខ្ញុំបានទទួលពីកំពង់សោមប៉ុណ្ណោះ។ ស: យើងពិបាកយល់ថា តើជនជាតិវៀតណាម ដែលត្រូវចាប់ខ្លួននៅឯសមុទ្រអាចដឹង និងប្រាប់លោកថា នៅពេលដំបូងពួកគេត្រូវបាននាំខ្លួនទៅកំពង់សោម និងអាចប្រាប់លោកអំពីហេតុការណ៍នេះដោយរបៀបណា? តើលោកអាចដឹងថា ពួកគេមកពីកំពង់សោមយ៉ាងដូចម្តេច? ឆ. 19: គឺអ្នកការពារខាងក្រៅដែលនាំជនជាតិវៀតណាមទាំងនោះមក ប្រាប់ខ្ញុំថា ជនជាតិវៀតណាមទាំងនោះ ត្រូវបាននាំមកពីកំពង់សោម។ ខ្ញុំគ្រាន់តែកត់ឈ្មោះជនជាតិវៀតណាមទាំងនោះប៉ុណ្ណោះ”]។ ឯកសារ D114/41 កំណត់ហេតុស្តាប់ចម្លើយ សួស ធី ឆ. 5-9 [“ស: តាមរយៈការអានបញ្ជីមួយចំនួនពីមន្ទីរស S-21 យើងឃើញថា អ្នកទោសត្រូវបានសរសេរបញ្ជាក់ថា “បញ្ជូនមកពីផែកំពង់សោម” ឬគេសរសេរថាតែ “កំពង់សោម” ប៉ុណ្ណោះ។ តើលោកដឹងទេថា ហេតុអ្វីបានជាគេធ្វើរបៀបនេះ? ឆ. 5: នៅពេលនោះ គេគ្រាន់តែកំណត់ភូមិភាគដែលគេបញ្ជូនអ្នកទោសមកប៉ុណ្ណោះ ដូចជា ភូមិភាគពាយ័ព្យ ភូមិភាគនិរតី ។ល។ ប្រសិនបើ គេកំណត់ថា បុគ្គលម្នាក់មកពីកំពង់សោម គេគ្រាន់តែប្រាប់អំពីទីកន្លែងទូទៅប៉ុណ្ណោះ ពុំមែនស្រុក ឬឃុំជាក់លាក់ឡើយ។ គេគ្រាន់តែ ចង់ដឹងថា កើតគោលដៅមកពីណា។ ហ៊ី គឺជាអ្នកដែលទទួលបញ្ជីពី ឌុច។ អ្វីដែលខ្ញុំបានធ្វើ គឺខ្ញុំគ្រាន់ស្រង់ចំនួន និងឈ្មោះអ្នកទោស ដើម្បីឲ្យដឹងថា តើមានអញ្ញនកទោសចេញចូលប៉ុន្មាននាក់ បន្ទាប់មក ខ្ញុំផ្តល់បញ្ជីទាំងនោះទៅឲ្យ ហ៊ី នៅព្រឹកស្អែក។ ស: ប៉ុន្តែ ហេតុអ្វីបានជាមានភាពខុសគ្នារវាង

ឮតាមវិទ្យុជាញឹកញាប់អំពីការចាប់ជនអៀសខ្លួន ទាហាន និងអ្នកនេសាទវៀតណាម នៅសមុទ្រ ហើយបញ្ជូនទៅមន្ទីរកងពល ១៦៤ រួចដឹកទៅមន្ទីរ ស-២១[1536]។ នៅឆ្នាំ ១៩៧៨ ជនជាតិវៀតណាម

---

ពាក្យថា "កំពង់សោម" និង "ផែកំពង់សោម" អាស្រ័យដោយទីកន្លែងទាំងពីរនេះស្ថិតនៅក្នុងភូមិភាគ ឬតំបន់តែមួយ? តើលោកអាចពន្យល់ឱ្យយើងបានដឹងបានដែរ ឬទេ? ឆ.6: លោកអាចមិនយល់អំពីភាពខុសគ្នារវាងកំពង់សោម និងផែកំពង់សោម។ ខ្ញុំសូមពន្យល់លោក ប្រសិនបើគេសរសេរថា "ផែកំពង់សោម" គឺមានន័យថា កម្មករ និងបុគ្គលិក ដែលធ្វើការងារនៅឯផែកំពង់សោម ដែលត្រូវបានចាប់ខ្លួន។ នៅពេលដែលគេសរសេរថា "កំពង់សោម" មានន័យថា គេសំដៅចំពោះជនជាតិខ្មែរ និងជនបរទេស ដែលយោធាចាប់ខ្លួននៅសមុទ្រកំពង់សោម។ វាក៏មានន័យដែរថា គេសំដៅចំពោះអ្នកដែលរត់គេចខ្លួនពីប្រទេស និងត្រូវបានចាប់ខ្លួន។ ស: តើលោកមានន័យដូចម្តេច នៅពេលដែលលោកនិយាយថា អ្នកដែលរត់គេចខ្លួនពីប្រទេស? តើលោកចង់សំដៅចំពោះការរត់គេចខ្លួនពីប្រទេសកម្ពុជា ឬប្រទេសដទៃទៀត? ឆ.7: គឺទាំងពីរតែម្តង។ ខ្ញុំចង់និយាយសំដៅចំពោះអ្នកដែលព្យាយាមរត់គេចខ្លួនពីប្រទេសកម្ពុជា ហើយត្រូវបានចាប់ខ្លួន ហើយវាក៏សំដៅចំពោះអ្នកដែលចូលមកក្នុងដែនទឹករបស់ប្រទេសកម្ពុជា និងត្រូវបានកងទ័ពចាប់ខ្លួនផងដែរ។ ស: តើលោកដឹងដោយរបៀបណា? ឆ.8: ព្រោះខ្ញុំសួរអ្នកទោស ដើម្បីឱ្យដឹងអំពីតួនាទី និងការងាររបស់ពួកគេ ហើយពួកគេបាននិយាយប្រាប់ថា ពួកគេធ្វើការងារនៅឯកំពង់ផែ។ នៅពេលសួរអ្នកទោស ខ្ញុំបានសួរឈ្មោះ តួនាទី និងតើពួកគេមក ភូមិភាគណា។ ស: តើលោកដឹងដោយរបៀបណាថា អ្នកទោសត្រូវបានចាប់ខ្លួនដោយសារតែពួកគេចូលមកក្នុងដែនទឹកកម្ពុជា? ឆ. 9: មានន័យថា ជាអ្នកដែលត្រូវបានកងទ័ពចាប់ខ្លួននៅឯសមុទ្រ។ គេតែងសរសេរបញ្ជាក់ថា កំពង់សោម បើទោះបីជាសមុទ្រ ស្ថិតនៅក្នុងខេត្តដទៃទៀតរបស់ប្រទេសកម្ពុជាក៏ដោយ។ អ្នកដែលគេចាប់ខ្លួន រមែងតែងត្រូវបានបញ្ជាក់ថា មកពីកំពង់សោមជានិច្ច។ ហើយមូលហេតុ ដែលខ្ញុំដឹង គឺ ហ៊ី ជាអ្នកប្រាប់ខ្ញុំ"]។ ឯកសារ D114/42 កំណត់ហេតុស្តាប់ចម្លើយ សួស ធី ឆ. 21 ["ស: តើលោកអាចទំនាក់ទំនងជាមួយអ្នកទោស ដែលត្រូវបានចាប់ខ្លួននៅឯសមុទ្រ ដូចជាអ្នកនេសាទជនជាតិថៃ និងវៀតណាម ដោយរបៀបណា? ឆ.21: ខ្ញុំមិនដែលបានជួបអ្នកនេសាទជនជាតិថៃឡើយ ខ្ញុំធ្លាប់តែជួបអ្នកនេសាទជនជាតិវៀតណាមប៉ុណ្ណោះ"]។ ឯកសារ D234/2.1.93 ព្រំ សារ៉ាត ប្រតិចារឹក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ម៉ោង 09.51.04-09.52.48 ["ការបញ្ជូនជនជាតិវៀតណាម ដែលពីសមុទ្រមកស-២១ [...] គ្រាន់តែប្រាប់ថា ថ្ងៃនេះគេមានចាប់យួនបាន ចាប់វៀតណាមបាននៅ [...] ដូច្នេះ នាវាមិត្តត្រូវប្រុងប្រយ័ត្នឱ្យដល់កម្រិតផង ព្រោះកិច្ចការនេះយើងមិនអាចសន្និដ្ឋានថា តើវានឹងមានផែនការអីយ៉ាងពេលណានោះទេ"]។

1536 ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត ឆ.129-130 ["ស: នៅកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ទំព័រ៥៤ (ជាភាសាអង់គ្លេស) និងទំព័រ៤៥ (ជាភាសាខ្មែរ) លោកបាននិយាយថា "អំឡុងពេល២ឆ្នាំ យោធាតាមកោះចាប់បានជនជាតិវៀតណាមស្ទើរតែរៀងរាល់ខែចូលមកកោះតាង និងកោះពូលូវ៉ៃ"។ លោកបន្ថែមថា "ពួកគេជាច្រើន ត្រូវបានបញ្ជូនទៅកងពលបន្ទាប់ពីចាប់ខ្លួនបាន ហើយក្រោយមកកងពលក៏បញ្ជូនអ្នកទាំងនោះទៅស-២១"។ តើលោកអាចពន្យល់អ្វីបានបន្ថែមដែរ ឬទេ? ឆ. 129: ខ្ញុំសូមបញ្ជាក់ថា ព័ត៌មាននេះត្រឹមត្រូវ។ ខ្ញុំដឹងព័ត៌មាននេះតាមវិទ្យុទាក់ទងនៅកន្លែងខ្ញុំ ក្នុងពេលនោះ។ ស: តើលោកអាចបញ្ជាក់អំពីព័ត៌មាននេះពិតជាត្រឹមត្រូវដែរ ឬទេ? ឆ. 130: ខ្ញុំសូមបញ្ជាក់ថា ហេតុការណ៍នេះពិតជាកើតឡើងនៅពេលនោះមែន គឺជាហេតុការណ៍ដែលខ្ញុំបាន

មួយចំនួន ដែលចាប់បាននៅលើសមុទ្រ ត្រូវគេបញ្ជូនពីកំពង់សោម ទៅសួរចម្លើយនៅមន្ទីរ ស-២១ ដើម្បីទទួលបានចម្លើយសារភាព សម្រាប់គោលបំណងឃោសនា[1537]។ ជាញឹកញាប់ ចម្លើយសារភាពទាំងនេះត្រូវបានចាក់ផ្សាយតាមវិទ្យុជាតិភ្នំពេញ[1538]។ ឧទាហរណ៍ នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៧៨ ចម្លើយសារភាពរបស់ "គិញ" វៀតណាម ដែលចាប់បាន នៅថ្ងៃទី ១០ ខែ កុម្ភៈ លើកោះពូលូវៃ ត្រូវបានចាក់ផ្សាយ[1539]។

---

ឮ តាមវិទ្យុទាក់ទង។ នៅពេលដែលគេចាប់បានទូក មនុស្សនៅលើកោះប្រាប់កប៉ាល់របស់ខ្ញុំថា ឲ្យមានការប្រុងប្រយ័ត្ន ដោយគេបញ្ជាក់ថា នៅតាមកោះមានគេចាប់ទូកយួនបាន"]។ ឯកសារ D234/2.1.93 ប្រតិចារឹក ព្រំ សារ៉ាត ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ២០១២ ម៉ោង 09.51.04-09.52.48 ["ការបញ្ជូនជនជាតិវៀតណាម ដែលពីសមុទ្រមកស-២១ [...] គ្រាន់តែប្រាប់ថា ថ្ងៃនេះគេមានចាប់យួនបាន ចាប់វៀតណាមបាននៅ [...] ដូច្នេះ នាវាមិត្តត្រូវប្រុងប្រយ័ត្នឲ្យដល់កម្រិតផង ព្រោះកិច្ចការនេះយើងមិនអាចសន្និដ្ឋានថា តើវានឹងមានផែនការវ៉ៃយ៉ាងពេលណានោះទេ"]។

1537 ឯកសារ D114/43 កំណត់ហេតុស្ដាប់ចម្លើយ សួស ធី ឆ.12 ["ស: ឥឡូវនេះចូលយើងផ្លាស់ប្ដូរប្រធានបទមកនិយាយអំពីការទទួលអ្នកទោសជនជាតិវៀតណាមមកពីកំពង់សោមវិញម្ដង។ លោកបាននិយាយពេលមុនថា ទាក់ទងទៅនឹងអ្នកដែលត្រូវបានចាប់ខ្លួននៅឯសមុទ្រ គេតែងសរសេរបញ្ជាក់ថា "កំពង់សោម" នៅក្នុងកំណត់ហេតុ បើទោះបីជាពួកគេត្រូវបានចាប់ខ្លួននៅឯសមុទ្រក្នុងខេត្តដទៃទៀតក៏ដោយ។ តើត្រឹមត្រូវដែរ ឬទេ? ឆ.12: បាទ ត្រឹមត្រូវហើយ"]។ ឯកសារ D54/23 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.29 ["ប្រសិនបើអ្នកដែលត្រូវបានចាប់ខ្លួននោះជាទាហានវៀតណាម យើងត្រូវតែបញ្ជូនពួកនោះទីដីគោក បន្ទាប់មកគេនឹងធ្វើការចាក់ផ្សាយចម្លើយសារភាពរបស់ទាហានវៀតណាមនៅក្នុងវិទ្យុជាតិ មុនពេលគេសម្លាប់"]។

1538 ឯកសារ D1.3.26.5 របាយការណ៍ BBC/SWB Report ចម្លើយសារភាពរបស់ទាហានជើងទឹកសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលត្រូវបានចាប់ខ្លួន ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ EN S 00008894-96, KH 00224832-36, FR 00292683-85 [ធ្វើសេចក្ដីរាយការណ៍អំពីសេវាផ្សាយសំឡេងក្នុងស្រុក ភ្នំពេញ នាថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៧៨ ចាក់ផ្សាយចម្លើយសារភាពរបស់ Vu Dinh Ngo]។ ឯកសារ D1.3.25.40 FBIS ប្រទេសកម្ពុជារាយការណ៍អំពីការបន្តទម្លាក់គ្រាប់បែករបស់វៀតណាម ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៨។

1539 ឯកសារ D1.3.26.7 របាយការណ៍ BBC/SWB ចម្លើយសារភាពរបស់គិញវៀតណាម ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ ១៩៧៨ EN S 00010459, KH 00225133, FR 00305294-95 [ធ្វើសេចក្ដីរាយការណ៍អំពីសេវាផ្សាយសំឡេងក្នុងស្រុក ភ្នំពេញ នាថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៨ ចាក់ផ្សាយចម្លើយសារភាពរបស់ពលទោវៀតណាមម្នាក់ឈ្មោះ ចឺ លី (Chiu Ly) ដែលត្រូវបានគេចាប់ខ្លួននៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៧៨ នៅលើកោះប៉ូឡូវៃ និងបាននិយាយថា គាត់ត្រូវបានគេជ្រើសរើសជាភ្នាក់ងារស៊ើបការណ៍សម្ងាត់ ដោយស្នងការនគរបាលខេត្ត កៀនយ៉ាង]។ ឯកសារ D1.3.26.5 របាយការណ៍ BBC/SWB Report ចម្លើយសារភាពរបស់ទាហានជើងទឹកសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលត្រូវបានចាប់ខ្លួន ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ EN S 00008894-96, KH 00224832-36, FR 00292683-85 [ធ្វើសេចក្ដីរាយការណ៍អំពីសេវាផ្សាយសំឡេងក្នុងស្រុក ភ្នំពេញ នាថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៧៨ ចាក់ផ្សាយចម្លើយ

418. ជនជាតិវៀតណាមទាំងគ្រួសារៗ រួមមាន បុរស ស្ត្រី មនុស្សចាស់ ក្មេងជំទង់ និងកុមារ ដែលត្រូវគេបញ្ជូនពីតំបន់កំពង់សោម ចូលមន្ទីរ ស-២១ ក្នុងឆ្នាំ ១៩៧៨[1540]។ ឈ្មោះអ្នកទោសវៀតណាមចូលមិនត្រូវបានកត់ត្រាទាំងអស់នោះទេ។ ពេលខ្លះ ឈ្មោះមនុស្សចាស់ និងក្មេងៗអាយុលើសពី ១៥ ឆ្នាំ ត្រូវគេដកចេញពីបញ្ជីឈ្មោះអ្នកទោស ខណៈដែលឈ្មោះក្មេងៗអាយុក្រោម ១៥ ឆ្នាំ ត្រូវបានដកចេញទាំងស្រុង[1541]។ អ្នកនេសាទវៀតណាមភាគច្រើនមិនត្រូវគេសួរចម្លើយទេ ប៉ុន្តែ ត្រូវគេនាំយកទៅសម្លាប់ភ្លាមៗតែម្តង ក្រោយពីនាំចូលមន្ទីរ ស-២១[1542]។

---

សារភាពរបស់ Vu Dinh Ngo]។ ឯកសារ D1.3.25.40 FBIS ប្រទេសកម្ពុជារាយការណ៍អំពីការបន្តទម្លាក់គ្រាប់បែករបស់វៀតណាម ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៨។

1540 ឯកសារ D114/43 កំណត់ហេតុស្តាប់ចម្លើយ សួស ធី ឆ. 13 ["ស: តើលោកអាចប្រាប់យើងបានទេថា តើវាមានលក្ខណៈដូចម្តេចនៅពេលដែលលោកទទួលអ្នកនេសាទជនជាតិវៀតណាមពីកំពង់សោម? ឆ.13: អ្នកនេសាទជនជាតិវៀតណាមរមែងតែងតែចាប់ខ្លួននៅក្នុងទូកជាគ្រួសារ។ អ្នកទាំងនេះត្រូវបាននាំមកឱ្យខ្ញុំជាគ្រួសារ ដែលមានន័យថា ក្នុងនោះរួមមានមនុស្សស្រី ប្រុស ក្មេង ចាស់ រួមទាំង កុមារផងដែរ"]។

1541 ឯកសារ D114/43 កំណត់ហេតុស្តាប់ចម្លើយ សួស ធី ឆ.20 ["ស: ចុះចំណែកឯកុមារ និងទារកវិញ? ឆ.20: ខ្ញុំគ្រាន់តែស្រង់ឈ្មោះមនុស្សចាស់ និងកុមារ ដែលមានអាយុចាប់ពី១៥ឆ្នាំឡើងប៉ុណ្ណោះ។ ដោយឡែក អ្នកដែលមានអាយុតិចជាងនេះ ខ្ញុំមិនបានស្រង់ឈ្មោះពួកគេឡើយ"]។

1542 ឯកសារ D114/43 កំណត់ហេតុស្តាប់ចម្លើយ សួស ធី ឆ. 21-23 ["ស: លោកបានរៀបរាប់អំពីគ្រួសារជនជាតិវៀតណាម ជាមួយនឹងកូនរបស់ពួកគេ។ បើតាមខ្ញុំស្តាប់មើលទៅ ពួកគេហាក់បីដូចពុំមែនជាអ្នកនេសាទទូទៅឡើយ។ តើលោកដឹងដោយរបៀបណាថា ពួកគេជាអ្នកនេសាទ? ឆ.21: ដោយសារតែយើងមិនចេះភាសាវៀតណាម ដើម្បីសួរពួកគេអំពីព័ត៌មានលម្អិត ដូច្នេះហើយទើប ហ៊ី សម្រេចចិត្តឱ្យចុះបញ្ជីគ្រួសារជនជាតិវៀតណាមទាំងនេះ ដែលមកពីកំពង់សោមថាជាអ្នកនេសាទ។ ស: ឥឡូវនេះ យើងចង់បង្ហាញលោកនូវឯកសារ D1.3.28.139 ភាសាអង់គ្លេស EN 00181757 ទៅ 00181764 និងភាសាខ្មែរ EN 00021210 ទៅ 000212111។ យើងចង់ឱ្យលោកផ្តោតតែលើភាសាខ្មែរ ទំព័រ 00021210 នៅលេខរៀង១៧, ១៨, និង១៩ប៉ុណ្ណោះ។ ជនជាតិវៀតណាមទាំងនេះមកពីកំពង់សោម និងត្រូវបានកំណត់ថាជាចារកិច្ចយួន។ ឆ.22: នេះគឺជាបញ្ជីរបស់ខ្ញុំ។ ជនជាតិវៀតណាម ដែលរាយនាមនៅក្នុងបញ្ជីនេះ ពុំមែនជាគ្រួសារវៀតណាម ដែលខ្ញុំបាននិយាយខាងដើមឡើយ។ ជនជាតិវៀតណាមទាំងនេះត្រូវបានយោធាកំពង់សោមចាប់ខ្លួន។ ស: ហេតុអ្វីបានជាលោកកំណត់ថាពួកគេជាចារកិច្ច និងហេតុអ្វីបានជាគ្រួសារ ដែលត្រូវបានទទួលពីកំពង់សោមត្រូវបានកំណត់ថាជាអ្នកនេសាទ? ឆ. 23: ជាថ្មីម្តងទៀតគឺ ហ៊ី ជាអ្នកនិយាយថា យើងគ្មានវិធីសួរឱ្យដឹងថា តើជនជាតិវៀតណាមទាំងនេះជាអ្នកណានៅពេលដែលពួកគេមកដល់ឡើយ។ ដូច្នេះ ពួកគេត្រូវកំណត់ថាជាចារកិច្ចយួន។ ប៉ុន្តែ អ្នកទាំងអស់នេះរមែងតែបានបញ្ជូនឱ្យធ្វើការសួរចម្លើយជានិច្ច ប៉ុន្តែគ្រួសារជនជាតិវៀតណាមមិនត្រូវបានសួរចម្លើយនោះទេ។ ខ្ញុំសន្និដ្ឋានថា គ្រួសារទាំងនេះ គេមិនទុកនៅក្នុងមន្ទីរស-២១ យូរឡើយ ដោយពួកគេនឹងត្រូវយកទៅសម្លាប់ចោលក្នុងពេលឆាប់ៗ"]។

419. សាក្សី គក ស្រស់ ដែលធ្លាប់ធ្វើជាអ្នកយាម នៅមន្ទីរ ស-២១ បានផ្តល់សក្ខីកម្មថា គាត់បានឃើញជនជាតិឥណ្ឌា ថៃ និងវៀតណាម នៅមន្ទីរ ស-២១ ដែលត្រូវគេនាំទៅសម្លាប់នៅជើងឯក[1543]។ គាត់ក៏បានឮតាមវិទ្យុផងដែរអំពីការចាប់ជនជាតិវៀតណាម នៅជិតកោះតាង និងកោះពូលូវ៉ៃ[1544]។ ករណីនេះកើតឡើងស្ទើរតែរៀងរាល់ខែ ក្នុងរយៈពេលពីរឆ្នាំ។ អ្នកដែលចាប់បានត្រូវគេបញ្ជូនទៅកងពលជាមុនសិន ហើយអ្នកខ្លះត្រូវបញ្ជូនទៅមន្ទីរ ស-២១[1545]។ បញ្ជី ស-២១ ក៏បង្ហាញផងដែរថា យ៉ាងហោចណាស់ អ្នកនេសាទថៃ ៥៩ នាក់ ដែលចាប់បាននៅលើសមុទ្រ ត្រូវបានឃុំ រួចសម្លាប់ចោល ចន្លោះពីខែ ឧសភា ដល់ខែ វិច្ឆិកា ឆ្នាំ ១៩៧៦[1546]។

---

1543 ឯកសារ D1.3.32.21 កំណត់ហេតុស្តាប់ចម្លើយ គក ស្រស់ KH 00186799 [“ស: តើមានអ្វីកើតឡើងសម្រាប់អ្នកទោសទាំងអស់នោះ? ឆ.: អ្នកទោសទាំងនោះ ត្រូវបានគេសួរចម្លើយ រួចបញ្ជូនទៅសម្លាប់នៅបឹងជើងឯក។ ឌុច ជាអ្នកបញ្ជាឲ្យយកទៅសម្លាប់ ហើយក្រុមពេជ្ឈឃាតជាអ្នកដឹកតាមឡានយកទៅសម្លាប់។ ខ្ញុំដឹងយ៉ាងនេះ ដោយសារអ្នកបើកឡានដឹកអ្នកទោសទៅជើងឯកខ្សឹបប្រាប់ខ្ញុំ។ ខ្ញុំបានឮ ហើយដឹងថា គេដឹកទៅជើងឯកតាំងពី ខ្ញុំចូលមកធ្វើជាកងការពារនៅស-២១។ ការដឹកជញ្ជូនទៅជើងឯក ត្រូវបានធ្វើឡើងជារឿយៗ។ អ្នកទោសជាកម្មាភិបាលសំខាន់ៗ ត្រូវបានគេសម្លាប់នៅខាងក្រៅរបងគុកស-២១ (ខាងត្បូង និងខាងលិច) តែមានចំនួនតិចតួច។ អ្នកទោសឥណ្ឌា ថៃ និងវៀតណាម ត្រូវបានគេសម្លាប់នៅក្រៅបរិវេណស-២១ (ខាងត្បូង និងខាងលិច)”]។

1544 ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត ឆ.129 [“ស: នៅកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ទំព័រ៥៤ (ជាភាសាអង់គ្លេស) និងទំព័រ៤៥ (ជាភាសាខ្មែរ) លោកបាននិយាយថា “អំឡុងពេល២ឆ្នាំ យោធាតាមកោះចាប់បានជនជាតិវៀតណាមស្ទើរតែរៀងរាល់ខែចូលមកកោះតាង និងកោះពូលូវៃ”។ លោកបន្ថែមថា “ពួកគេជាច្រើន ត្រូវបានបញ្ជូនទៅកងពលបន្ទាប់ពីចាប់ខ្លួនបាន ហើយក្រោយមកកងពលក៏បញ្ជូនអ្នកទាំងនោះទៅស-២១”។ តើលោកអាចពន្យល់អ្វីបានបន្ថែមដែរ ឬទេ? ឆ. 129: ខ្ញុំសូមបញ្ជាក់ថា ព័ត៌មាននេះត្រឹមត្រូវ។ ខ្ញុំដឹងព័ត៌មាននេះតាមវិទ្យុទាក់ទងនៅកន្លែងខ្ញុំ ក្នុងពេលនោះ”]។

1545 ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត ឆ.129 [“ស: នៅកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ទំព័រ៥៤ (ជាភាសាអង់គ្លេស) និងទំព័រ៤៥ (ជាភាសាខ្មែរ) លោកបាននិយាយថា “អំឡុងពេល២ឆ្នាំ យោធាតាមកោះចាប់បានជនជាតិវៀតណាមស្ទើរតែរៀងរាល់ខែចូលមកកោះតាង និងកោះពូលូវៃ”។ លោកបន្ថែមថា “ពួកគេជាច្រើន ត្រូវបានបញ្ជូនទៅកងពលបន្ទាប់ពីចាប់ខ្លួនបាន ហើយក្រោយមកកងពលក៏បញ្ជូនអ្នកទាំងនោះទៅស-២១”។ តើលោកអាចពន្យល់អ្វីបានបន្ថែមដែរ ឬទេ? ឆ. 129: ខ្ញុំសូមបញ្ជាក់ថា ព័ត៌មាននេះត្រឹមត្រូវ។ ខ្ញុំដឹងព័ត៌មាននេះតាមវិទ្យុទាក់ទងនៅកន្លែងខ្ញុំ ក្នុងពេលនោះ”]។

1546 សូមមើល ឧបសម្ព័ន្ធ ឃ.៦។ សូមមើលផងដែរ ឯកសារ D4.1.5 របាយការណ៍វិភាគរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក្រោមចំណងជើងថា “បញ្ជីឈ្មោះជនរងគ្រោះបរទេស ដែលបានកម្ទេចនៅមន្ទីរស-២១” [ដែលមានឈ្មោះជនជាតិថៃ៦០នាក់ ភាគច្រើនជាអ្នកនេសាទ និងសិស្ស ដែលចាប់បាននៅកំពង់សោម ចន្លោះថ្ងៃទី៧ ខែឧសភា ឆ្នាំ១៧៦ ណឹងថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ពួកគេត្រូវបានសម្លាប់]។ ឯកសារ D1.3.28.11 បញ្ជីឈ្មោះមន្ទីរស-២១ ដែលមាន

420. ចំពោះអ្នកទោសបរទេស នៅមន្ទីរ ស-២១ នួន ជា បានបញ្ជាឲ្យ "កម្ទេចពួកច្រមុះវែង" ហើយសាកសព "ត្រូវដុតឲ្យក្លាយជាផេះ ដើម្បីបំបាត់ភស្តុតាង"[1547]។ យោងតាមសាក្សី ប្រាក់ ខន

ឈ្មោះអ្នកទោសជាជនបរទេស EN 00181627-28។ ឯកសារ D114/42 កំណត់ហេតុស្តាប់ចម្លើយ សួស ធី ឆ.21-26 ["ស: តើលោកអាចទំនាក់ទំនងជាមួយអ្នកទោស ដែលត្រូវបានចាប់ខ្លួននៅឯសមុទ្រ ដូចជា អ្នកនេសាទជនជាតិថៃ និងវៀតណាមដោយរបៀបណា? ឆ.21: ខ្ញុំមិនដែលបានជួបអ្នកនេសាទជនជាតិថៃឡើយ ខ្ញុំធ្លាប់តែជួបអ្នកនេសាទជនជាតិវៀតណាមប៉ុណ្ណោះ។ ខ្ញុំបានព្យាយាមរៀនសូត្រពីអ្នកដទៃ ដែលចេះនិយាយភាសាវៀតណាម អំពីពាក្យពេចន៍ និងឃ្លាមូលដ្ឋាន ហើយខ្ញុំបានកត់ត្រានូវអ្វីដែលពួកគេបានប្រាប់ខ្ញុំ។ ខ្ញុំចង់ពន្យល់ថា ខ្ញុំសរសេរឈ្មោះជនជាតិវៀតណាមជាភាសាខ្មែរ។ ខ្ញុំចាំថា ខ្ញុំធ្លាប់មានអ្នកទោសជនជាតិខ្មែរម្នាក់ ដែលខ្ញុំធ្លាប់សុំឲ្យជួយបកប្រែឲ្យខ្ញុំនៅពេលសាកសួរអ្នកទោសជនជាតិវៀតណាម។ អ្នកទោសម្នាក់នោះ ពុំមែនជាបុគ្គលិករបស់មន្ទីរយើងឡើយ។ ខ្ញុំគិតថា ខ្ញុំទទួលជំនួយសម្រាប់ការបកប្រែនេះនៅពាក់កណ្តាលរបបខ្មែរក្រហម។ អ្នកទោសម្នាក់នេះត្រូវបានគេឃុំខ្លួននៅក្នុងបន្ទប់ឃុំឃាំងពិសេសមួយសម្រាប់ជាង។ ខ្ញុំមិនចាំឈ្មោះគាត់ ហើយខ្ញុំក៏មិនចាំអំពី ពេលដែលអ្នកទោសម្នាក់នេះត្រូវបានគេសម្លាប់ដែរ។ ស: តើលោកប្រាកដក្នុងចិត្តហើយឬ ថាលោកមិនធ្លាប់បានជួបអ្នកនេសាទជនជាតិថៃ? ឆ.22: ទេ ខ្ញុំមិនដែលជួបពួកគេទេ។ ស: ខ្ញុំចង់បង្ហាញលោកនូវឯកសារ D1.3.28.11 ភាសាអង់គ្លេស ERN 00181627។ តើលោកអាចជួយពន្យល់អំពីឯកសារនេះបានដែរ ឬទេ? ឯកសារនេះរាយនាមអ្នកនេសាទថៃចំនួន៣១នាក់ ដែលបានចូលនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦? ឆ.23: ខ្ញុំមិនដឹងអំពីបញ្ជីឈ្មោះនេះទេ។ ប្រសិនបើ ខ្ញុំជាអ្នករៀបចំបញ្ជីឈ្មោះនេះ ខ្ញុំប្រាកដជាចាំ។ ខ្ញុំពុំមានបញ្ហាអ្វីឡើយ ក្នុងការនិយាយប្រាប់លោក ប៉ុន្តែបញ្ជីឈ្មោះនេះ ពុំមែនខ្ញុំជាអ្នករៀបចំទេ។ ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំគិតថា បញ្ជីឈ្មោះនេះអាចមានប្រភពមកពីមន្ទីរសួរចម្លើយ។ ខ្ញុំក៏សូមបញ្ជាក់ផងដែរថា ប្រសិនបើខ្ញុំជាអ្នករៀបចំបញ្ជីនេះ ខ្ញុំប្រាកដជាមានអ្នកបកប្រែភាសាថៃម្នាក់ ដើម្បីកត់ត្រាព័ត៌មានទាំងនេះ ប៉ុន្តែខ្ញុំមិនធ្លាប់មានអ្នកបកប្រែភាសាថៃឡើយ។ ស: ហេតុអ្វីបានជាលោកមិនមែនជាអ្នករៀបចំបញ្ជីនេះ? ឆ. 24: ព្រោះមន្ទីររបស់ ឌុច អាចរៀបចំបញ្ជីដោយខ្លួនឯង ហើយគេមិនបញ្ជូនបញ្ជីនេះមកឲ្យខ្ញុំឡើយ។ ស: ចំណុចនេះហាក់មានលក្ខណៈផ្ទុយគ្នាបន្តិចទៅនឹងអ្វីដែលលោកបាននិយាយនៅក្នុងសក្ខីកម្មរបស់លោក។ ការដកស្រង់ពាក្យសម្តីពី E1/55.1 ទំព័រ១៧ ជួរ១៣-២២។ យើងចង់ឲ្យអ្នកបកប្រែអានការដកស្រង់សម្តីនេះ ដែលលោកបាននិយាយថា អ្នកទោសសំខាន់ៗ និងជនបរទេស ត្រូវបានបញ្ជូនទៅគុកពិសេស ហើយ ហ៊ី គឺជាអ្នករៀបចំបញ្ជីឈ្មោះពីគុកពិសេស និងក្រោយមក ហ៊ី នឹងផ្តល់បញ្ជីនោះមកឲ្យលោក ដើម្បីធ្វើការចងក្រងនៅក្នុងបញ្ជីរបស់លោក។ តើហេតុអ្វីបានជាលោកមិនដឹងអំពីបញ្ជីឈ្មោះអ្នកនេសាទជនជាតិថៃទាំងនេះ?? ឆ.25: សម្រាប់បញ្ជីឈ្មោះអ្នកទោសសំខាន់ៗ ថ្នាក់លើរបស់ខ្ញុំមានសិទ្ធិមិនឲ្យបញ្ជីឈ្មោះទាំងនោះមកខ្ញុំ។ ខ្ញុំប្រាកដក្នុងចិត្តថា ខ្ញុំមិនធ្លាប់បានឃើញបញ្ជីឈ្មោះនេះទេ។ ខ្ញុំក៏អាចភ្លេចបញ្ជីឈ្មោះនេះផងដែរ ព្រោះ វាបានកន្លងផុតទៅអស់រយៈពេលជាយូរណាស់មកហើយ។ ប៉ុន្តែខ្ញុំប្រាកដជាប្រាប់លោកតាមត្រង់ ប្រសិនបើ ខ្ញុំចាំ។ ខ្ញុំគ្មានបញ្ហាក្នុងការចងចាំ និងប្រាប់លោកអំពីជនជាតិវៀតណាមឡើយ ដូច្នេះ វាក៏គ្មានភាពខុសគ្នាអ្វីដែរ សម្រាប់ខ្ញុំក្នុងការប្រាប់លោកអំពីជនជាតិថៃទាំងនេះ។ ស: តើលោកធ្លាប់បានឃើញជនជាតិថៃនៅក្នុងមន្ទីរ-២១ ដែរ ឬទេ? ឆ.26: ទេ"]។

[1547] ឯកសារ D114/277.3 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 15.08.59 ម៉ោង 15.13.31-15.17.28។ ឯកសារ D113/277.6 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 10.06.52។

ដែលធ្លាប់ធ្វើការនៅមន្ទីរ ស-២១ បានឱ្យដឹងថា ឌុច ជាអ្នកសួរចម្លើយអ្នកទោសបស្ចិមប្រទេសដោយផ្ទាល់ ហើយក្រោយមក នាំយកទៅសម្លាប់ចោល[1548]។ បញ្ជី ស-២១ បញ្ជាក់អះអាងអំពីវត្តមានរបស់អ្នកទោសបស្ចិមប្រទេស នៅមន្ទីរ ស-២១[1549]។ ជាទូទៅ ពួកបស្ចិមប្រទេស[1550] ត្រូវ

---

ឯកសារ D98/1.2.23 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១២ ម៉ោង 09.33.00-09.35.23។ ឯកសារ D98/3.1.147 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០១២ ម៉ោង 14.29.20-14.35.52 [ពាក់ព័ន្ធនឹងការបញ្ជូនជនបរទេសទៅស-២១៖ "ការដុតកម្ទេចឱ្យអស់កុំឱ្យសល់ [...] ខ្ញុំធ្វើតាមបញ្ជារបស់ នួន ជា ហើយខ្ញុំអនុវត្តបទបញ្ជា [...] ស: ហើយហេតុអ្វីបានចាំបាច់ដុតពួកគេឱ្យសល់តែផេះ? ឆ៖ មូលហេតុនោះ គឺកុំឱ្យមានភស្តុតាងស្លាកស្នាម"]។ ឯកសារ D4.1.1117 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ EN 00154194។ ឯកសារ D1.3.33.3 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ EN 00147526។

1548 ឯកសារ D4.1.245 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក់ សុខ EN 00161555-56 ["ស: ចំពោះអ្នកទោសដែលជាវៀតណាម ឬថៃ ឬបរទេសផ្សេងទៀតហ្នឹងគេមានអង្គភាពពិសេស អីទៀតសម្រាប់សួរទេ? ឆ: ខ្ញុំឃើញតែ ចាន់, ប៉ុន, ម៉េង ដែលជាសាស្ត្រាចារ្យចេះភាសាច្រើន ហើយពេលណាខ្លះ ឌុច សួរផ្ទាល់។ ស: ឌុច គាត់សួរជនជាតិអីគេ? ឆ: ខ្ញុំឃើញដូចជា អូស្ត្រាលី អាមេរិកាំង ដូចចាំម្នាក់ ដូចជា តេរីឌ ស្កុត អាមេរិកាំង។ ស: ឌុច ជាអ្នកសួរផ្ទាល់? ឆ: ឃើញឌុចឃើញចាន់ ព្រោះសួរចម្លើយបរទេសអត់មានយកទៅសួរក្រៅទេ គឺសួរជាសាធារណៈហ្នឹង ព្រោះអត់មាននរណាស្តាប់បានទេ។ ស: អញ្ចឹងលោកផ្ទាល់ឃើញផ្ទាល់ភ្នែកទេ? ឆ: ខ្ញុំឃើញផ្ទាល់ ព្រោះខ្ញុំយកអ្នកទោសទៅទុក ខ្ញុំឃើញសួរ ខ្ញុំឈរស្តាប់ តែខ្ញុំស្តាប់មិនបាន សួរជាភាសាអង់គ្លេស ឈ្មោះវា តេរីត ស្កុត សរសេរនៅនឹងអាវ នៅលេវអាវឃើធ្លាក់ ហើយខ្ញុំមើលរួច ហើយគឺ តេរីដ ស្កុត ធ្លាក់ឈ្មោះហ្នឹងហ្នង គ្រប់លេវ។ ស: ពេលលោកឈរស្តាប់ហ្នឹង លោកឃើញឌុចធ្វើទារុណកម្មអ្នកទោសហ្នឹងទេ? ឆ: ខ្ញុំឃើញឌុចសួរ ហើយទាត់ ដល់ពេលសួរហើយ វាឆ្លើយថា វាជាជនជាតិអាមេរិកាំង ម្នាក់ជាជនជាតិអូស្ត្រាលី ជិះទូកថ្មចូលម៉ោហ្នឹង មានរបស់របរស៊ីគ្រប់គ្រាន់បីខែ ចូលម៉ោដើម្បីស៊ើបការណ៍ពីស្រុកខ្មែរ។ ស: គេឆ្លើយថាទូកស៊ីម៉ង់អញ្ចឹង? ឆ: អាណឹងពេលសួរហើយ គេនិយាយជាមួយចាន់ហ្នឹងថា គេជិះទូកស៊ីម៉ង់ម៉ោ ហើយពីរនាក់ហ្នឹងទៀត ពេលយកទៅសម្លាប់ចោលខ្ញុំដឹងតាមរយៈសឿ អញ្ចឹងសឿហ្នឹងថា យកទៅចងដាក់ខ្នោះ ចងសេក ហ្នឹងហើយ ដាក់នៅកណ្តាលថ្នល់ទៅទួលទំពូង ដាក់នៅកាច់ជ្រុងហើយយកអាកង់ឡាន ចាស់ៗហ្នឹងដាក់ជុំវិញខ្លួនហើយ ពាក់ក្បាលចាក់សាំងដុតបណ្តោយ។ ស: លោកមើលឃើញ? ឆ: ខ្ញុំអត់ឃើញទេ តែសឿ ប្រាប់ខ្ញុំ សឿនៅកំពង់ឆ្នាំង កំពង់ត្រឡាច។ ស: សឿហ្នឹងគាត់អ្នកការពារដែរ? ឆ: គាត់កងការពារនៅផ្នែកច្រកហ្នឹងហ្នង។ ស: តើមានបច្ចេកទេសប្លែកគ្នាទេរវាងអ្នកទោសខ្មែរ និងបរទេស? ឆ: ការសួរចម្លើយមិនដូចគ្នាទេ ព្រោះអ្នកទោសបរទេសសួរជាសាធារណៈ អត់មានលាក់ការណ៍អីទេ ព្រោះគ្មានណាគេស្តាប់បាន ហើយសួរមិនយូរ សួរមិនច្រើន អញ្ចឹងវាអត់ដូចខ្មែរយើង អានោះសួរ តែម៉ាថ្ងៃពីរថ្ងៃអីបាត់ហើយ ចប់ហើយ"]។

1549 សូមមើល VIII.ឃ. មន្ទីរស-21 ។ ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសមន្ទីរ ស-21 របស់ក.ស.ច.ស [បញ្ជាក់ថា លរ. 12719, 12720, 13021 និង លរ. 13022 ជាជនបរទេសដែលបានចូលមកមន្ទីរស-21 ក្នុងឆ្នាំ១៩៧៨]។ ឯកសារ D11/2.3 ចម្លើយសារភាពមន្ទីរស-21 របស់ឈ្មោះ John Dawson Dewhirst ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៧៨ EN 00681102។

1550 សូមមើល VIII.ឃ. មន្ទីរស-21។ ឯកសារ D234/2.1.113 ប៉ាក សុខ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.44.37-09.47.53 [“មានៗ វៀតណាម មានជនជាតិអាមេរិកាំង ជនជាតិអូស្ត្រាលី ហ្នឹងដែលខ្ញុំធ្លាប់ឃើញ […] បាទ ជនជាតិអូស្ត្រាលី ហើយនិងជនជាតិអាមេរិកាំងម្នាក់ហ្នឹង ខ្ញុំមានម្នាក់ខ្ញុំស្គាល់ ខ្ញុំចាំដោយសារ ឃើញឈ្មោះតេវីដ ស្កុត សរសេរធ្លាក់ដាក់នៅនឹងលើអាវៗ អាវខូវប៊យ”]។ ឯកសារ D54/24.1។ បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ EN 00978577, KH 00955508 [“ជួបប្រទះតែជនជាតិអាមេរិកាំងម្នាក់ដែរ […] ស្លៀកពាក់ធម្មតាហ្នឹង […] ជួនកាល ពាក់អាវយឺតវាលក្លៀក […] សក់វាពណ៌ក្រហម […] សួរវាទៅអាយុប្រហែលជា២៥អីហ្នឹង អត់មានអីលើសពីហ្នឹងទេ […] ជិះកាណូតវាមក តែកាណូតវាដូចផ្ទះថ្មចឹង ដងក្ដោងវាមានកំពស់ប្រហែលជាចុងត្នោត […] កាលហ្នឹងចាប់មកពីកោះពោល្វៃ […] ដើមឆ្នាំ១៩៧៦”]។ សូមមើលផងដែរ ឯកសារ D11/2.3 ចម្លើយសារភាពនៅមន្ទីរស-២១ របស់ John Dawson Dewhirst ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៧៨ EN 00681102។ ឯកសារ D1.3.28.140 បញ្ជីអ្នកទោសមន្ទីរស-21, EN 01236389, KH 00088752, FR 01187845 [លរ.១. គ្រីស្តូហ្វែរ អេដវ៉ ឌីឡង់ និង ល.រ ២. មីស៊ែល ស្កុតឌៀត គីម៉ូ]; ឯកសារ D1.3.33.3 កំណត់ហេតុស្ដាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច EN 00147526-27, KH 00146488 [“ស: ហេតុអ្វីបានជាគេចាប់ជនបរទេសទាំងនេះ ពួកគេមកធ្វើអ្វី? ឆ: គេចូលដែនសមុទ្រខ្មែរ ហើយកងសមុទ្រចាប់បញ្ជូនមកឱ្យ នួន ជា […] ជនបរទេស ខ្ញុំសំដៅពួកភ្នែកស”]។ ឯកសារ D54/22 កំណត់ហេតុស្ដាប់ចម្លើយ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ EN 00947622, KH 01002678 [កិច្ចសន្ទនាជាមួយ លោក សុន យីវ អំពីអ្នកនាវាចរ ដែលត្រូវបានចាប់៖ “អ្នកនាវាចរមានកម្ពស់ខ្ពស់ ជាជនជាតិស្បែកស ជាអ្នកមាន និងជាអ្នកទេសចរ […] គាត់ចាំបានថា គាត់បានឃើញតែពីរនាក់ទេ ប៉ុន្តែត្រូវបានប្រាប់ថា មានបីនាក់។ ពួកគេមិនត្រូវបានវាយដំ ឬចាប់ចងទេ។ នៅពេលនោះ ពួកគេហាក់ដូចមានអាការៈធម្មតា”]។ ឯកសារ D114/58 កំណត់ហេតុស្ដាប់ចម្លើយ សំ សោម ឆ. 2-4 [“ស: តើមានករណីណាផ្សេងទៀត ដែលលោកបានដឹងពាក់ព័ន្ធជាមួយនឹងការចាប់ជនបស្ចិមប្រទេសតាមទូកដែរ ឬទេ? ឆ2: ខ្ញុំបានឮថា មានទូកក្ដោងមួយត្រូវបានចាប់ ប៉ុន្តែខ្ញុំមិនចង់ប្រាប់លោកឡើយ ដោយសារនេះជាអ្វីដែលខ្ញុំបានឮប៉ុណ្ណោះ។ […] ឆ3: កាលពីសម័យនោះ មានផែកងទ័ពជើងទឹកមួយកន្លែងនៅឆ្នេរអូរឈើទាល។ ហេតុការណ៍នេះបានកើតឡើងនៅពេលដែលខ្ញុំទៅរៀននៅកំពង់សោម។ ខ្ញុំបានឮព័ត៌មានមួយចំនួនពីលោក មឿន ដែលជាប្រធានគ្រប់គ្រងនាវាទាំងអស់នៅផែអូរឈើទាលនេះ។ […] ឆ4: មឿន បាននិយាយថា មានទូកក្ដោងមួយត្រូវបានចាប់យកពីសមុទ្រមក ហើយបញ្ជូនទៅផែអូរឈើទាល។ ខ្ញុំមិនច្បាស់ថាតើទូកក្ដោងនេះមកពីទីណា”]។ ឯកសារ D4.1.378 កំណត់ហេតុស្ដាប់ចម្លើយ គង់ ផៃ KH 00163628 [“បន្ទាប់មកខ្ញុំយកបាយទៅឱ្យអ្នកទោសម្នាក់ក្នុងចំណោមបីនាក់នោះ ឃើញឌុច កំពុងសួរចម្លើយម្នាក់នោះ ប្រុស សក់ក្រហម រួញ វែងដាបស្មា សំបុរស មានរោមទ្រូង ស្លៀកខោខ្លី មុន ឌុច សួរម្នាក់នេះ ពាក់អាវប៉ារ៉ាយឺតដៃខ្លី”]។ ឯកសារ D114/301.1 រូបថតរបស់ David Lloyd Scott ជនជាតិអូស្ត្រាលី EN P 00005293។ ឯកសារ D114/301.3 រូបថត Ronald Keith Dean, EN P 00525273។

បានឃុំដាច់ដោយឡែកពីអ្នកទោសផ្សេងទៀត[1551] ហើយសម្លាប់ចោលនៅជិតមន្ទីរ ស-២១[1552]។ សាកសពរបស់ពួកគេត្រូវបានដុត ក្រោយពីសម្លាប់ដើម្បីបំបាត់ភ័ស្តុតាង[1553]។

## ៦. កម្រិតញឹកញាប់នៃការចាប់ និងសម្លាប់

421. ការចាប់ និងសម្លាប់នៅលើសមុទ្របានកើតឡើងជាទៀងទាត់[1554]។ យើងមិនអាចធ្វើការប៉ាន់ប្រមាណឲ្យបានត្រឹមត្រូវអំពីចំនួនមនុស្សសរុបដែលត្រូវបានសម្លាប់នោះឡើយ ពីព្រោះការអនុវត្ត

---

[1551] ឯកសារ D98/3.1.85 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ម៉ោង 15.37.06-15.39.11 ["ជនបរទេស [...] គឺឃុំ និងសួរចម្លើយនៅគុកពិសេស"]។ ឯកសារ D98/1.2.9 សួស ធី ប្រតិចារឹក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 14.42.48-14.45.09 ["ចំពោះអ្នកទោសបស្ចិមប្រទេស គឺបើតាមខ្ញុំដឹង គឺមិនបានចូល ចេញចូលទៅតាមកន្លែងខ្ញុំទេ គឺគេយកទៅដាក់គុកពិសេសហ្នឹងតែម្តង"]។

[1552] ឯកសារ D234/2.1.116 ហ៊ីម ហ៊ុយ ប្រតិចារឹក ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.15.53-15.18.40 [ពិភាក្សាអំពីការសម្លាប់អ្នកទោសបស្ចិមប្រទេស៖ "គេយកគាត់មកសម្លាប់នៅខាងជើងផ្លូវហ្នឹង"]។

[1553] ឯកសារ D114/277.3 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 15.08.59 [ពាក់ព័ន្ធនឹងជនជាតិបរទេសពួកបស្ចិមប្រទេសនៅមន្ទីរស-21: "ពួកអស់នេះ សុទ្ធតែបានទទួលការសួរចម្លើយ ហើយយកទៅកម្ទេច។ កម្ទេចនេះមានការណែនាំដាច់ខាត ឲ្យដុតនឹងកៅស៊ូកង់ឡានឲ្យអស់ កុំឲ្យសល់ឆ្អឹង"] ម៉ោង 15.13.31-15.17.28 [នួន ជា ណែនាំឲ្យឌុច ថា "ពួកអាច្រមុះស្រួចកម្ទេច ហើយដុតវាឲ្យឆេះសុះទៅ កុំឲ្យសល់...។ ដុតឲ្យសុះឲ្យអស់ទៅ កុំឲ្យវាសល់ភស្តុតាង"]។ ឯកសារ D114/277.6 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 10.06.52។ ឯកសារ D98/3.1.19 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១២ ម៉ោង 09.33.00-09.35.23។ ឯកសារ D98/3.1.147 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹក ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០១២ ម៉ោង 14.29.20-14.35.52។ ឯកសារ D4.1.1117 កាំង ហ្កេកអ៊ាវ កំណត់ហេតុស្តាប់ចម្លើយ EN 00154194។ ឯកសារ D1.3.33.3 កាំង ហ្កេកអ៊ាវ ហៅ ឌុច កំណត់ហេតុស្តាប់ចម្លើយ EN 00147526។ ឯកសារ D234/2.1.116 ហ៊ីម ហ៊ុយ ប្រតិចារឹក ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.15.53-15.18.40 ["តាឌុចបញ្ជាថាឲ្យៗ តាហ៊ិ ហ្នឹងកុំឲ្យកប់ ឲ្យគរឈើដុត ព្រោះជនជាតិបរទេសអត់ឲ្យកប់ទេ គេថាជាតិខស្វ័នជាតិអីគេ។ ពេលនោះ គឺពួកខ្ញុំដើរយាមជុំវិញៗបរិវេណហ្នឹងទាំងអស់ [...] ឃើញគេដុតនៅកន្លែងហ្នឹង"]។ ឯកសារ D98/3.1.54 ហ៊ីម ហ៊ុយ ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 13.45.42-13.49.27 ["ឃើញគេដាក់កង់ឡានដុត"]។ ឯកសារ D234/2.1.113 ប៉ាក សុខ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.49.05។ ឯកសារ D98/3.1.212 ប្រាក់ ខន ប្រតិចារឹក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 14.02.59-14.06.41។ ឯកសារ D98/3.1.19 ចៀម សឿ ប្រតិចារឹក ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០០៩ ម៉ោង 09.39.32-09.49.25។

[1554] ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.10-12 ["មនុស្សដែលចាប់បាន គឺមានចំនួនរាប់ពាន់នាក់ បើគិតជាចំនួនទាំងអស់ ដែលតាមខ្ញុំដឹង។ ក្នុង១ខែៗ គេបញ្ជូនមនុស្សមកតាមផែអូរឈើទាលពី៤ទៅ៥ដង។ ហើយក្នុងម្តងៗ មានមនុស្សចន្លោះពី១០នាក់ទៅ៥០នាក់។ ស: [...] ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ ឆ្លងមកចូលក្នុងដែនទឹកកម្ពុ

នេះលាតសន្ធឹងក្នុងរយៈពេលវែង និងនៅលើដែនដីទូលំទូលាយ។ សាក្សី ឯក នី ប៉ាន់ប្រមាណថា យ៉ាងហោចណាស់ ជនជាតិវៀតណាម និងថៃ ១.២០០ ឬ ១.៣០០ នាក់ ត្រូវបានសម្លាប់ "នៅសមុទ្រដោយកម្លាំងកងទ័ពជើងទឹកក្នុងរបបនោះ"[1555]។ ក្រៅពីការចាប់ទូកវៀតណាមជាញឹកញាប់

ជា ហើយត្រូវបានចាប់បាន និងសម្លាប់ មានចំនួនប្រហែលប៉ុន្មាននាក់? ឆ.11: មានចំនួនរាប់ពាន់នាក់ អ្នកទាំងនោះ រួមមាន ពួកនេសាទថៃ ពួកនេសាទ និងជនភៀសខ្លួនវៀតណាម ដែលត្រូវចាប់បាន និងសម្លាប់ចោល នៅក្នុងសមុទ្រ នៅលើកោះ និងនៅលើដីគោក"]។ […] ឆ. 12: សម្រាប់កងវរសេនាតូចរបស់ខ្ញុំ ខ្ញុំពិបាកនិយាយប្រាប់ណាស់។ គេចាប់ចងបានច្រើនដងក្នុង១ឆ្នាំ។ […] សម្រាប់កងវរសេនាតូចរបស់ខ្ញុំ ខ្ញុំអាចចាំបានថា ពេលខ្លះ ខែខ្លះ គឺយើងចាប់បានបីទៅបួនដងក្នុង១ខែ ប៉ុន្តែពេលខ្លះ ២ទៅ៣ខែ យើងមិនមានចាប់បានទេ។ ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំបានចូលរួមការចាប់ចងចំនួនបីដង"]។ ឯកសារ D59/1/1.8a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រុំ សារ៉ាត KH 00926387 ["ស: ម៉ាខែប៉ុន្មាននាក់ទៅ? សារ៉ាត៖ យ៉ាងអន់ក៏២ ៣នាក់ដែរ។ ស: ចាប់ពីល្បាតនឹងតាំងពីចុង៧៦មក យើងចាប់បានរហូត? សារ៉ាត៖ បាទ! ស: នឹងច្រើនតែពួកយួនហ្នឹង? សារ៉ាត៖ បាទៗ ពួកយួន"]។ ឯកសារ D1.3.13.8 បទសម្ភាសន៍របស់ការិយាល័យសហព្រះរាជអាជ្ញា ជាមួយ ប៉ែន សារិន EN 002175661-62 ["សាក្សីធ្វើការនៅលើមូលដ្ឋានកងទ័ពជើងទឹកបាន១អាទិត្យ ក្នុងឆ្នាំ១៩៧៦ ហើយក្នុងអំឡុងពេលនោះ ពួកនេសាទថៃចំនួនពីរលើក (១៥-២០នាក់ ក្នុងមួយលើកៗ) ត្រូវបានគេនាំយកទៅក្នុងអគារបន្ទាយ។ ពួកគេត្រូវបានចង នៅពេលនាំចូលទៅនោះ។ អ្នកនេសាទទាំងនោះត្រូវបានចាប់ខ្លួននៅកោះតាង និងកោះរ៉ុង។ គាត់ជឿជាក់ថា អ្នកនេសាទទាំងនោះត្រូវគេយកទៅសម្លាប់ ពីព្រោះពួកគេត្រូវបានចាប់ នៅពេលចូលមកនេសាទក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារិក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 09.53.36-09.58.05 ["បើមានព្រឹត្តិការណ៍អីដែលដូចជាទូកថៃ ទូកអីទៅ ឃើញថា បើគេបញ្ជាឲ្យទៅចាប់ អាហ្នឹងបានទៅចាប់"]។ ឯកសារ D234/2.1.93 ព្រុំ សារ៉ាត ប្រតិចារិក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៦ ម៉ោង 10.45.42-10.47.35 ["យើងជាកប៉ាល់យោធាដើរល្បាត បើគេចូលមកនឹងត្រូវរងការចាប់ ឬថាការបាញ់ប្រហារនៅលើដែនទឹក អីចឹងភាពទាំងអស់នេះ គឺជាភាពមួយដែលយោធាប្រឈមជាមួយនឹងយោធា។ អីចឹង ជនជាតិវៀតណាម វាដឹងច្បាស់ថា កប៉ាល់យោធាមានភារកិច្ចធ្វើអី"]។

1555 ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.61 ["ស: បើគិតជាតួលេខ យ៉ាងតិចបំផុតប៉ុន្មាន ហើយយ៉ាងច្រើនបំផុតប៉ុន្មាននាក់? ឆ. 61: បើយ៉ាងតិច ក៏មិនក្រោម១២០០ ទៅ ១៣០០នាក់ដែរ។ បើទូកកូនជ្រូកយួនរត់ទៅក្រៅមានម្តងបីទូក ហើយមួយទូកៗ មានពី៥០ទៅ៦០នាក់ ហើយគេចាប់បានជាអចិន្ត្រៃយ៍"]។ សូមមើលផងដែរ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៊ាង រ៉េត ឆ. 64-66, 76 ["ស: យោងតាមកិច្ចសម្ភាសរបស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយថា "ទាហានកងពល១៦៤ ចាប់បានទូកវៀតណាម" តើការចាប់ទូកវៀតណាមនេះកើតឡើងញឹកញាប់ដែរ ឬទេ? ឆ. 64: ការចាប់ទូកវៀតណាមនេះ គឺមិនទៀងទេ ជួនកាល១ខែចាប់បាន១ ជួនកាល២ទៅ៣ខែទើបចាប់បានមួយ។ ស: លោកអាចបញ្ជាក់បានទេក្នុងរយៈពេល១ឆ្នាំ តើទូកវៀតណាមចំនួនប៉ុន្មានត្រូវបានទាហានកងពល១៦៤ចាប់បាន? ឆ. 65: ខ្ញុំមិនដឹងចំនួន ដែលចាប់បានក្នុង១ឆ្នាំទេ ពីព្រោះការចាប់ទូកនេះធ្វើឡើងនៅពេលយប់ ដោយក្រុមល្បាត។ ពេលចាប់បានហើយ គេក៏សណ្តោងទូកនោះមកផែ។ ចំណែកខ្ញុំវិញ ខ្ញុំនៅលើកប៉ាល់ ហើយជួនកាល កប៉ាល់នោះទៅចតនៅទីកន្លែងផ្សេងៗគ្នាដូចជានៅ កោះរ៉ុង រាម និងស្ទឹងហាវ ដូច្នេះ ខ្ញុំមិន

(ជារឿយៗ មានអ្នកដំណើរពី ៥០ ទៅ ៦០ នាក់) ឯក នី បានផ្តល់ឧទាហរណ៍អំពីការចាប់ទូកថៃធំៗចំនួនបួនគ្រឿង ក្នុងហេតុការណ៍តែមួយ។ យោងតាមការប៉ាន់ប្រមាណរបស់គាត់ "យ៉ាងហោចណាស់ មានមនុស្ស ១៥០ នាក់ នៅលើទូកបួនគ្រឿង"[1556]។ ហ៊ីង អ៊ុច បានសង្កេតឃើញដោយផ្ទាល់អំពីការចាប់ទូកថៃ ម្តង ឬពីរដង និងទូកវៀតណាម បីដង[1557]។ សាក្សី នាក់ យឿន បានអះអាងថា គាត់បានឮអំពីការចាប់ទូកវៀតណាម រៀងរាល់ពីរ ឬបីខែម្តង ប៉ុន្តែ ទទួលស្គាល់ថាគាត់គ្រាន់តែឮ "ហេតុការណ៍នោះ" ខ្លះៗប៉ុណ្ណោះ[1558]។ សៅ សំ បានផ្តល់សក្ខីកម្មថា គាត់បានឃើញការចាប់ទូក បីដង[1559]។

---

អាចដឹងពីចំនួនពិតប្រាកដទេ។ [...] ស: យោងទៅលើកិច្ចសម្ភាសរបស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយថា "ទូកថៃ និងជនជាតិថៃដែលនៅលើទូកនោះក៏ត្រូវបានកងទ័ពជើងទឹកចាប់បានដែរ" តើព្រឹត្តិការណ៍នេះកើតឡើងញឹកញាប់ដែរ ឬទេ? ឆ.76: កើតឡើងយូរៗម្តង។ តាមខ្ញុំចាំ ក្នុងរយៈពេល៦ខែ គឺចាប់បានទូកថៃចំនួន១"]។

1556 ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.58-60 ["ស: តាមលោកស្មានមើល ពួកជោះងទឹកកាលហ្នឹងរយៈពេលនៃរបបហ្នឹង តាមមើលចាប់មនុស្ស ហើយសម្លាប់នៅក្នុងសមុទ្រ ប្រហែលប៉ុន្មាននាក់?? ឆ.58: អាចចូលខ្ទង់ពាន់ មិនមែនរយទេ។ ស: យោងទៅតាមការស្មានរបស់លោក និយាយរាប់ពាន់នាក់... (កំណត់សម្គាល់អ្នកស៊ើបអង្កេត៖ សាក្សីគាត់បានចាប់ផ្តើមឆ្លើយមុនពេលដែលបញ្ចប់សំនួរ ដោយសារគាត់ហាក់ដូចជាយល់ពីសំនួរ ដែលសួរ) ឆ.59: ខ្ញុំនិយាយតែមួយរឿងទេ ពួកថៃ ទូកថៃ៤គ្រឿង គឺ១៨០០សេស ១៧០០សេស និង១៤០០សេសចំនួនពីរគ្រឿង។ ទូក១៨០០សេស មានមនុស្សមិនក្រោម៥០នាក់ទេ។ ទូកហ្នឹងមិនប្រើទឹកកកទេ គឺផ្ទុះឱ្យត្រជាក់ ហើយនៅលើសមុទ្ររាប់ខែ។ ដូច្នេះ ទូកបួនគ្រឿងហ្នឹងវៃយ៉ាងហោចណាស់ក៏១៥០នាក់ដែរ។ ស: តាមលោកស្មាន បើនិយាយក្នុងរបបហ្នឹងពេលដែលចាប់បានទូក ហើយយកមកសម្លាប់ហ្នឹងថា រាប់ពាន់ ប្រហែលប៉ុន្មានពាន់ដែរ? ឆ.60: បើខ្ញុំយល់ ប្រហែលខ្ពស់មួយពាន់ជាង ខ្ញុំមិនថាច្រើនទេ"]។

1557 ឯកសារ D54/82 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ. 34 ["ស: តើកងវរៈសេនាធំ៦២ចាប់បានទូកបរទេសញឹកញាប់ដែរ ឬទេ? ឆ.34: ខ្ញុំបានដឹងអំពីបញ្ហានេះ នៅពេលដែលខ្ញុំទៅនៅកោះតាង។ គេចាប់បានទូកនេសទ យូរៗម្តងប៉ុណ្ណោះ ក្នុងនោះទូកថៃ គឺចាប់បានម្តង ឬពីរដង។ ចំពោះទូកយួន គឺចាប់បានបីដង។ ខ្ញុំនៅកោះតាងពីចុងឆ្នាំ១៩៧៧រហូតដល់វៀតណាមចូល"]។

1558 ឯកសារ D114/11 កំណត់ហេតុស្តាប់ចម្លើយ នាក់ យឿន ឆ.13-14 ["ស: ពេលលោកធ្វើការនៅលើកប៉ាល់ តើលោកឮ ឬក៏ដឹងអំពីការចាប់ទូកយួនញឹកញាប់ប៉ុនណាដែរ? ឆ.13: ខ្ញុំឮអំពីរឿងនេះ២ ឬ៣ខែម្តង។ ស: តើលោកឮថាតំបន់ដែលគេតែងតែចាប់ទូកបានហ្នឹងមានទំហំប៉ុនណាដែរ? ឆ.14: ភាគច្រើន គឺសំដៅទៅភាគខាងត្បូងសមុទ្រខ្មែរ។ ខ្ញុំមិនដឹងថា មានទំហំប៉ុនណាទេ ដែលយើងអាចទំនាក់ទំនងគ្នាបានតាមវិទ្យុទាក់ទង។ ខ្ញុំមិនដឹងរឿងទាំងអស់នេះទេ ហើយខ្ញុំគ្រាន់តែឮអំពីហេតុការណ៍នេះខ្លះប៉ុណ្ណោះ ព្រោះអីយើងធ្វើការតាមតួនាទី និងតាមផ្នែកប៉ុណ្ណោះ។ ក្រោយពីយើងដឹង

422. ប៉ាក់ សុខ ក៏បានប៉ាន់ប្រមាណថា មនុស្សរាប់ពាន់នាក់ត្រូវគេចាប់បាននៅលើសមុទ្រ រួចបញ្ជូនទៅផែអូរឈើទាល[1560]។ យោងតាម អ៊ូ គឹម មនុស្សប្រហែល ១.០០០ នាក់ (ថៃ និងវៀតណាម) ត្រូវគេសម្លាប់នៅកោះពូលូវ៉ៃ[1561]។ សាក្សី មាស វឿន ចាំបានអំពីការចាប់ទូកនេសាទប្រមាណពី ៥០

---

អំពីហេតុការណ៍នេះ តាមវិទ្យុទាក់ទង យើងឃើញកប៉ាល់ PGP ត្រឡប់មកវិញ ដោយមានសណ្តោងទូកដែលចាប់បានមកជាមួយផង"]។

1559 ឯកសារ D54/109 កំណត់ហេតុស្តាប់ចម្លើយ សៅ សំ ឆ. 16 ["ស: តើលោកធ្លាប់បានឃើញការចាប់ទូកហ្នឹងប្រហែលជាបានចំនួនប៉ុន្មានដងក្នុង១ខែ? ឆ. 16: តាមការចងចាំរបស់ខ្ញុំ គឺក្នុងរយៈពេលដែលខ្ញុំរស់នៅលើកោះហ្នឹង ខ្ញុំធ្លាប់ឃើញការចាប់ទូកហ្នឹងបានចំនួនប្រហែល៣ដងប៉ុណ្ណោះ។ មានយោធានៅលើកោះតាង និងកោះដទៃៗទៀតក៏គេធ្លាប់បានមើលឃើញ ហើយរាយការណ៍ឲ្យចាប់ទូកទាំងនេះដែរ។ ពេលខ្លះរ៉ាដានៅលើភ្នំបូកគោ ក៏អាចមើលឃើញទូកដោយខ្លួនគេដែរ"]។

1560 ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក់ សុខ ឆ. 9-12 ["ស: តើលោកធ្វើការនៅផែអូរឈើទាលអស់រយៈពេលប៉ុន្មាន? ឆ. 9: ខ្ញុំធ្វើការនៅទីនោះពេញមួយឆ្នាំ១៩៧៨ រហូតដល់វៀតណាមចូល។ ស: តើគេបញ្ជូនមនុស្សមកតាមផែអូរឈើទាលហ្នឹងញឹកញាប់ប៉ុណ្ណា ហើយចំនួនមនុស្សជាមធ្យមប៉ុន្មាននាក់ ក្នុងពេលម្តងៗមកផែអូរឈើទាលនោះ? ឆ. 10: មនុស្សដែលចាប់បាន គឺមានចំនួនរាប់ពាន់នាក់ បើគិតជាចំនួនទាំងអស់ ដែលតាមខ្ញុំដឹង។ ក្នុង១ខែៗ គេបញ្ជូនមនុស្សមកតាមផែអូរឈើទាលពី៤ទៅ៥ដង។ ហើយក្នុងម្តងៗ មានមនុស្សចន្លោះពី១០នាក់ទៅ៥០នាក់។ ស: តាមបទពិសោធន៍របស់លោក និងការយល់ដឹងរបស់លោក នៅក្នុងកងអង្គភាពរបស់លោក និងអង្គភាពដទៃទៀត នៃកងទ័ពជើងទឹក តើចំនួនប្រជាជនស៊ីវិល ចំនួនជនភៀសខ្លួន អ្នកនេសាទ ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ឆ្លងមកចូលក្នុងដែនទឹកកម្ពុជា ហើយត្រូវបានចាប់បាន និងសម្លាប់ មានចំនួនប្រហែលប៉ុន្មាននាក់? ឆ.11: មានចំនួនរាប់ពាន់នាក់ អ្នកទាំងនោះ រួមមាន ពួកនេសាទថៃ ពួកនេសាទ និងជនភៀសខ្លួនវៀតណាម ដែលត្រូវចាប់បាន និងសម្លាប់ចោលនៅក្នុងសមុទ្រ នៅលើកោះ និងនៅលើដីគោក"]។

1561 ឯកសារ D114/126 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គឹម ឆ. 43-46 ["ស: ក្នុងបទសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័រទី២៧ លោកនិយាយថា មនុស្ស៣០០ទៅ៤០០នាក់ត្រូវបានចាប់បាន ហើយសម្លាប់នៅលើកោះ។ ហេតុអ្វីបានជាលោកនិយាយបែបនេះ? ឆ. 43: តួលេខនេះគ្រាន់តែជាការប៉ាន់ស្មានរបស់ខ្ញុំ តាមអ្វីដែលខ្ញុំសង្កេតឃើញប៉ុណ្ណោះ។ ចំនួន៣០០ទៅ៤០០នាក់ អាចជាចំនួនតិចបំផុតដែលខ្ញុំគិតថា ត្រូវបានសម្លាប់នៅលើកោះនេះ។ ពេលខ្លះមួយទូកមាន៥០នាក់ ហើយខ្លះទៀតមួយទូកមាន៧០នាក់ ពេលដែលគេចាប់បាន គឺមកបញ្ចប់នៅលើកោះទាំងអស់ ហើយទូកថៃបែបនេះច្រើនណាស់ត្រូវបានចាប់នៅពេលនោះ។ ស: តើលោកដឹងថា អ្នកនេសាទដែលគេចាប់បាន ហើយនាំមកកោះពូលូវ៉ៃ ត្រូវបានគេទុកនៅលើកោះ ឬក៏យកចេញពីកោះ ក្រោយពេលចាប់បាន? ឆ. 44: តាមខ្ញុំដឹង អ្នកដែលគេចាប់បានពីសមុទ្រយកមកកោះ គឺមិនត្រូវបានយកទៅណាក្រៅពីកោះនោះទេ។ ស: ក្នុងបទសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័រ២៤ ជាភាសាខ្មែរ លោកបាននិយាយថា "មិនក្រោមពី១០០០ទេ...។ បញ្ហាលើកោះហ្នឹង មួយចំនួនដែលគេត្រូវតែបញ្ចប់ដំណើររបស់គាត់។ ហើយមួយចំនួនទៀតមិនដឹងគេបញ្ជូនទៅណា ព្រោះគេថា គេបញ្ជូនៗ ហើយបញ្ជូនហ្នឹង។ បើសិនគេបញ្ជូន គេបើកឲ្យទូកហ្នឹង ជិះលើទូក

ទៅ ៦០ គ្រឿង ប៉ុន្តែ អះអាងថា មានតែអ្នកនេសាទប្រហែល ១០ នាក់ប៉ុណ្ណោះ ត្រូវចាប់បាន ដោយសារតែអ្នកនេសាទជាច្រើនបានលោតចូលទឹកដើម្បីគេចខ្លួន[1562]។ ពុំមានការប៉ុនប៉ងជួយសង្គ្រោះអ្នកដែលលោតចូលទឹកនោះទេ[1563]។ យោងតាម មាស វឿន កម្រិតញឹកញាប់នៃការចាប់

ហ្នឹង ទៅណាទៅ១។ គេអត់រករឿងទេ ហ្នឹងគេបញ្ជូនទៅវិញ។ តែបើសិនជាគេមិនបញ្ជូនទេ គេអត់ឲ្យទូកហ្នឹងទៅវិញទេ។ គេដោយចាត់វិធានការវិធីរបស់គេ"។ តើតួលេខនេះពាក់ព័ន្ធនឹងចំនួនមនុស្ស៣០០ទៅ៤០០នាក់ ដែលត្រូវបានសម្លាប់យ៉ាងដូចម្ដេចដែរ? ឆ.45: អ្វីដែលខ្ញុំនិយាយថា នេះគឺវាមានករណីពីរ។ ករណីទី១គឺថា គេចាប់ទាំងទូក និងចាប់ទាំងមនុស្សនៅលើទូក ហើយអ្នកទាំងនោះត្រូវបានបញ្ចប់នៅលើកោះនោះទាំងអស់។ ករណីមួយទៀតគឺ គេឲ្យទូកអ្នកទាំងនោះជិះមួយ ហើយត្រឡប់ទៅវិញ ធ្វើយ៉ាងម៉េចធ្វើទៅ។ ស: តើលោកដឹងពីហេតុផលដែលគេអនុញ្ញាតឲ្យទូកត្រឡប់ទៅវិញដែរទេ? ឆ.46: នេះគ្រាន់តែជាការកត់សម្គាល់របស់ខ្ញុំប៉ុណ្ណោះ។ ខ្ញុំពុំបានតាមដានការពិភាក្សារបស់ពួកគេផ្ទាល់នោះទេ។ ក្នុងអំឡុងពេលខ្ញុំនៅលើកោះ ខ្ញុំបានឃើញហេតុការណ៍នៃការអនុញ្ញាតឲ្យមនុស្សដែលគេចាប់បានត្រឡប់ទៅវិញតែមួយលើកប៉ុណ្ណោះ គឺគេឲ្យទូកថ្មីផ្សេង ដើម្បីត្រឡប់ទៅវិញ។ យ៉ាងណាមិញ ខ្ញុំមិនដឹងថា អ្នកទាំងនោះជាថៃ ឬវៀតណាមនោះទេ។ តាមពិតទៅ ខ្ញុំមិនដែលបាននៅជិតទូកទាំងនោះទេ។ តួលេខ១០០០នេះ ជាចំនួនសរុបទាំងជនជាតិទាំងពីរ ថៃ និងវៀតណាម"]។

1562 ឯកសារ D54/52 កំណត់ហេតុស្ដាប់ចម្លើយ មាស វឿន ឆ.19-20 ["ស: តាមលោកចាំ ក្នុងអំឡុងពេលលោកនៅកោះកុង តើកងរបស់លោកចាប់បានទូកនេសាទថៃបានចំនួនប៉ុន្មាន? ឆ.19: តាមខ្ញុំចាំបាន យើងចាប់បានអ្នកនេសាទថៃប្រហែលចំនួន១០នាក់ ប៉ុន្តែយើងចាប់បានទូកនេសាទប្រហែល៥០ទៅ៦០គ្រឿង។ ចំនួនអ្នកនេសាទដែលចាប់បាន គឺតិចជាងចំនួនទូក ពីព្រោះតែពេលដែលយើងចូលមកជិតទូក ដើម្បីចាប់ម្ដង១ ពួកអ្នកនេសាទទាំងនោះលោតចូលទឹកដើម្បីរត់គេចពីការចាប់ខ្លួន។ ស: យោងតាមការស្មានរបស់លោក នៅក្នុងពេលនោះ បើសិនជាលោកចាប់បានមនុស្សទាំងអស់នៅលើទូក ទាំង៥០ទៅ៦០គ្រឿងនោះ តើមានមនុស្សចំនួនប៉ុន្មាននាក់? ឆ. 20: វាអាចមានចំនួនអ្នកនេសាទច្រើនណាស់ ជាមធ្យមទូកនេសាទមួយៗមានមនុស្សពីបីទៅបួននាក់"]។

1563 ឯកសារ D54/52 កំណត់ហេតុស្ដាប់ចម្លើយ មាស វឿន ឆ.21-22 ["ស: តើលោកគិតថា អ្នកដែលលោតទឹកនោះមានវាសនានឹងនៅរស់ដែរ ឬទេ? ឆ.21: ខ្ញុំគិតថា គេអាចមានឱកាសនៅរស់ច្រើន ពីព្រោះនៅពេលគេលោតចូលទឹក គេតែងតែមានរបស់សម្រាប់បណ្ដែតទឹក សម្រាប់គេតោងយកទៅជាមួយ។ ខ្ញុំនិយាយដូច្នេះ ដោយសារពេលមួយមានយោធារបស់ខ្ញុំពីរនាក់បានធ្លាក់ចូលទៅក្នុងទឹក ហើយខ្ញុំបានរកឃើញគេនៅរស់ក្នុងថ្ងៃបន្ទាប់ ដោយគេមានក្ដារឈើសម្រាប់តោងហែល។ ស: តើអ្នកនេសាទថៃ ដែលលោតចូលទៅក្នុងទឹកនោះ តើកងរបស់លោកតាមជួយសង្គ្រោះ ឬក៏ទុកពួកគេចោល? ឆ. 22: យើងមិនបានទៅជួយសង្គ្រោះអ្នកនេសាទថៃនោះទេ យើងទុកពួកគេទៅតាមវាសនារបស់គេទៅ។ ប៉ុន្តែ ប្រសិនបើយោធាយើងធ្លាក់ចូលទឹក យើងត្រូវតែស្វែងរក ដើម្បីជួយសង្គ្រោះមកវិញ"]។

បានទូកថៃមានភាពប្រែប្រួល៖ ពេលខ្លះ គេចាប់បានទូកពីរគ្រឿង ក្នុងរយៈពេលមួយសប្តាហ៍ ឯពេលខ្លះទៀត គេចាប់បានតែទូកមួយគ្រឿងប៉ុណ្ណោះ ក្នុងរយៈពេលមួយខែពេញ[1564]។

423. ព្រុំ សារ៉ាត់ បានរក្សាទុកបញ្ជី នៅលើនាវារបស់គាត់ អំពីការចាប់ទូកវៀតណាម។ គាត់បានប៉ាន់ប្រមាណថា ជនជាតិវៀតណាមជាង ១០០ នាក់ ត្រូវបានចាប់ ពេលគាត់នៅទីនោះ[1565]។ គាត់បានបញ្ជាក់ថា គាត់បានឃើញការចាប់ទូកវៀតណាម ពីរដង ពេលគាត់ឈរជើងនៅកោះពូលូវ៉ៃ[1566]។ គាត់ក៏បានស្តាប់ឮតាមវិទ្យុអំពីការចាប់ជនជាតិវៀតណាម នៅជិតកោះតាង និងកោះពូលូវ៉ៃ ស្ទើរ

---

1564 ឯកសារ D114/126 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គីម ឆ.31 ["ស: ក្នុងឆ្នាំដែលលោកឈរជើងនៅលើកោះ តើលោកដឹងថា មានការចាប់ទូកនេសាទបានប៉ុន្មានគ្រឿងដែរ? ឆ. 31: ខ្ញុំមិនអាចប្រាប់លោកពីចំនួនជាក់លាក់ណាមួយបានទេ ប៉ុន្តែគេចាប់ទូកនេសាទថៃបានជាច្រើនគ្រឿង។ ខ្ញុំអាចនិយាយបានថា ជួនកាល ១អាទិត្យ គេចាប់បានទូកពីរ និងជួនកាល ១ខែ ចាប់បានទូកមួយ"]។

1565 ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត ឆ.129-132 ["ស: នៅកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ទំព័រ៥៤ (ជាភាសាអង់គ្លេស) និងទំព័រ៤៥ (ជាភាសាខ្មែរ) លោកបាននិយាយថា "អំឡុងពេល២ឆ្នាំ យោធាតាមកោះចាប់បានជនជាតិវៀតណាមស្ទើរតែរៀងរាល់ខែចូលមកកោះតាង និងកោះពូលូវ៉ៃ"។ លោកបន្ថែមថា "ពួកគេជាច្រើន ត្រូវបានបញ្ជូនទៅកងពលបន្ទាប់ពីចាប់ខ្លួនបាន ហើយក្រោយមកកងពលក៏បញ្ជូនអ្នកទាំងនោះទៅស-២១"។ តើលោកអាចពន្យល់អ្វីបានបន្ថែមដែរ ឬទេ? ឆ. 129: ខ្ញុំសូមបញ្ជាក់ថា ព័ត៌មាននេះត្រឹមត្រូវ។ ខ្ញុំដឹងព័ត៌មាននេះតាមវិទ្យុទាក់ទងនៅកន្លែងខ្ញុំ ក្នុងពេលនោះ។ ស: តើលោកអាចបញ្ជាក់អំពីព័ត៌មាននេះពិតជាត្រឹមត្រូវដែរ ឬទេ? ឆ. 130: ខ្ញុំសូមបញ្ជាក់ថា ហេតុការណ៍នេះពិតជាកើតឡើងនៅពេលនោះមែន គឺជាហេតុការណ៍ដែលខ្ញុំបានឮ តាមវិទ្យុទាក់ទង។ នៅពេលដែលគេចាប់បានទូក មនុស្សនៅលើកោះប្រាប់កប៉ាល់របស់ខ្ញុំថា ឱ្យមានការប្រុងប្រយ័ត្ន ដោយគេបញ្ជាក់ថា នៅតាមកោះមានគេចាប់ទូកយួនបាន។ ស: តើលោកបានដឹង ឬក៏លោកផ្ទាល់បានរក្សាទុកនូវសៀវភៅកំណត់ហេតុប្រចាំថ្ងៃ ដែលកត់ត្រាពីចំនួនមនុស្ស និងទូកដែលគេចាប់បានក្នុង១លើកៗដែរ ឬទេ? ឆ.131: ខ្ញុំបានទុកសៀវភៅកំណត់ហេតុប្រចាំថ្ងៃនៅលើនាវា ប៉ុន្តែបន្ទាប់មកសៀវភៅនោះត្រូវបានលិចទៅក្នុងសមុទ្រជាមួយនាវា។ ស: ដោយសារលោកបានរក្សាទុកសៀវភៅកត់ត្រាប្រចាំថ្ងៃ តាមដែលលោកចាំ តើចំនួនវៀតណាមដែលកងទ័ពជើងទឹក ដែលប្រចាំការតាមកោះចាប់បានមានចំនួនប៉ុន្មាន? ឆ.132: តាមការស្មាន គឺចំនួនជនជាតិវៀតណាមដែលចាប់បាន មានចំនួនច្រើនជាងរយនាក់"]។

1566 ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សារ៉ាត ឆ.121 ["ស: នៅក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័រ៥៣ ជាភាសាអង់គ្លេស និងទំព័រទី៤៤ ជាភាសាខ្មែរ លោកបាននិយាយអំពីការចាប់បាននូវទូករបស់វៀតណាម។ តើកងពល១៦៤ចាប់បានទូកនេសាទវៀតណាមហ្នឹងញឹកញាប់ដែរ ឬទេ? ឆ. 121: មិនមានញឹកញាប់ទេ។ ខ្ញុំចាំថា ខ្ញុំបានឃើញដោយផ្ទាល់ភ្នែកនូវការចាប់ទូកពួកវៀតណាមចំនួនពីរដង នៅពេលដែលខ្ញុំទៅកោះពូលូវ៉ៃ"]។

តែជារៀងរាល់ខែក្នុងរយៈពេលពីរឆ្នាំ[1567]។ ព្រំ សារ៉ាត់ ក៏បាននឹកឃើញហេតុការណ៍មួយ ដែលទូកនេសាទថៃត្រូវចាប់បាននៅជិតកោះតាង។ គាត់មិនដឹងថា តើទូកថៃដែលចាប់បានសរុបទាំងអស់ប៉ុន្មាននោះទេ[1568]។

424. សាត ចក់ បានអះអាងថា គាត់បានឃើញកងនាវាចាប់បានទូកបរទេសតិចជាង ១០ ដង ប៉ុន្តែ គាត់ក៏ទទួលស្គាល់ផងដែរថា គាត់ឈរជើងនៅតែមួយចំហៀងកោះពូលូវៃ ហើយគាត់មិនដឹងសភាពការណ៍រួមនោះទេ[1569]។ មូល ឈិន បានឆ្លើយថា "មានការចាប់ទូកនេសាទជាច្រើនគ្រឿង។ ជាទូទៅ គេចាប់ទូកបានបី ទៅបួនគ្រឿងក្នុងមួយថ្ងៃ"។ គាត់បានឃើញទូក "ទម្លាក់មងចាប់ត្រី" ហើយជាមធ្យម មានមនុស្សប្រហែល ៦ នាក់ នៅលើទូកតូច និងរហូតដល់ ២០ ទៅ ៣០ នាក់ នៅលើទូកធំ[1570]។

---

[1567] ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត ឆ.129 ["ស: នៅកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ទំព័រ៥៤ (ជាភាសាអង់គ្លេស) និងទំព័រ៤៥ (ជាភាសាខ្មែរ) លោកបាននិយាយថា "អំឡុងពេល២ឆ្នាំ យោធាតាមកោះចាប់បានជនជាតិវៀតណាមស្ទើរតែរៀងរាល់ខែចូលមកកោះតាង និងកោះពូលូវៃ"។ លោកបន្ថែមថា "ពួកគេជាច្រើន ត្រូវបានបញ្ជូនទៅកងពលបន្ទាប់ពីចាប់ខ្លួនបាន ហើយក្រោយមកកងពលក៏បញ្ជូនអ្នកទាំងនោះទៅស-២១"។ តើលោកអាចពន្យល់អ្វីបានបន្ថែមដែរ ឬទេ? ឆ. 129: ខ្ញុំសូមបញ្ជាក់ថា ព័ត៌មាននេះត្រឹមត្រូវ។ ខ្ញុំដឹងព័ត៌មាននេះតាមវិទ្យុទាក់ទងនៅកន្លែងខ្ញុំ ក្នុងពេលនោះ"]។

[1568] ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត ឆ. 146-148 ["ស: នៅក្នុងកិច្ចសម្ភាសរបស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅទំព័រ៦៨ ជាភាសាអង់គ្លេស លោកបាននិយាយអំពីការចាប់បានទូកនេសាទរបស់ថៃ តាមអ្វីដែលលោកដឹងតើមានទូកថៃប៉ុន្មាន ដែលកងទ័ពជើងទឹកចាប់បាននៅក្នុងរបបនោះ? ឆ. 146: ខ្ញុំមិនដឹងថា មានចំនួនប៉ុន្មាននោះទេ តែខ្ញុំដឹងថា ចាប់បានទូកថៃមួយគ្រឿង។ ស: តើនៅលើទូកនេសាទនោះមានមនុស្សចំនួនប៉ុន្មាននាក់? ឆ. 147: ទេ ខ្ញុំមិនដឹងទេ។ ស: ថាតើគេចាប់ទូកនេសាទថៃនោះនៅកន្លែងណា? ឆ.148: ចាប់បាននៅខាងលិចកោះតាង"]។

[1569] ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ ឆ.85 ["ស: យើងមិនថាឲ្យលោកចាំច្បាស់ទេ ប៉ុន្តែលោកអាចនិយាយពីភាពប្រហាក់ប្រហែលបានទេ ថាតើតិចជាង១០ដង លើស១០ដង តិចជាង២០ដង ឬក៏ច្រើនជាង២០ដែរ? ឆ.85: បើយើង វាអាចថាតិចជាង១០ដងចុះ។ យើងនៅចំហៀងកោះ គឺយើងអាចឃើញតែមួយជ្រុងកោះនោះទេ យើងមិនអាចមើលឃើញបានជុំវិញកោះនោះទេ គឺមានតែអ្នកដែលនៅប្រចាំការនៅលើកំពូលកោះប៉ុណ្ណោះ ដែលអាចមើលឃើញបានជុំវិញកោះទាំងមូលបាន"]។

[1570] ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ឆ.39, 41-42 ["មានការចាប់ទូកនេសាទច្រើនណាស់។ ជាទូទៅ គេចាប់បានទូក៣ ឬ៤ក្នុង១ថ្ងៃៗ។ [...] ស: តើលោកសង្កេតឃើញទូកទាំងនោះនេសាទត្រីដែរ ឬទេ? ឆ.41: បាទ ឃើញ។ យើងមើលឃើញគេទម្លាក់មងចាប់ត្រី។ ស: តើមានអ្នកនេសាទប៉ុន្មាននាក់

## គ. មន្ទីរសន្តិសុខកងពល ១៦៤

### ១. បណ្តាញមន្ទីរសន្តិសុខ

425. **មាស មុត** និងកងពល ១៦៤ បានប្រតិបត្តិការបណ្តាញមន្ទីរសន្តិសុខ ឬ “មន្ទីរអប់រំកែប្រែ” នៅតំបន់កំពង់សោម។ មន្ទីរសន្តិសុខដ៏សំខាន់បំផុត គឺនៅវត្តឥន្ទញ្ញាណ[1571] និងទឹកសាប[1572]។ គុកមួយក៏ដំណើរការនៅស្ទឹងហាវផងដែរ[1573]។ អ្នកក្រោមបង្គាប់របស់ **មាស មុត** បានដាក់គុកតាមទំនើងចិត្តនៅតាមទីតាំងទាំងនោះ នូវទាហានកងពល ១៦៤ និងជនស៊ីវិលមកពីតំបន់ស្វយ័តកំពង់សោម ក៏ដូចជាជនជាតិវៀតណាម ថៃ និងជនបរទេសផ្សេងទៀត ដែលចាប់បាននៅលើសមុទ្រ និងកោះដែលកម្ពុជាប្រជាធិបតេយ្យអះអាងថាជាកម្មសិទ្ធិរបស់ខ្លួន។ អ្នកទោសត្រូវបានឃុំក្នុងលក្ខខណ្ឌអមនុស្សធម៌គួរឲ្យអាណោចអាធ័ម ហើយជាញឹកញាប់ ត្រូវគេធ្វើទារុណកម្ម និងជាចុងក្រោយភាគច្រើន ត្រូវគេសម្លាប់ចោល ដោយគ្មានការកាត់សេចក្តីតាមផ្លូវច្បាប់។ កងពល ១៦៤ ប្រតិបត្តិការនៅវត្តឥន្ទញ្ញាណ និងទឹកសាប ជាផ្នែកមួយនៃប្រព័ន្ធសន្តិសុខជាតិរបស់កម្ពុជាប្រជាធិបតេយ្យ ដោយអ្នកទោសត្រូវគេឃុំនៅតាមទីតាំងទាំងនេះនៅកំពង់សោមជាមុនសិន រួចដឹកទៅទីក្រុងភ្នំពេញ ដើម្បីឃុំ ធ្វើទារុណកម្ម និងសម្លាប់នៅមន្ទីរ ស-២១។

*ក) នៅក្នុងកំពង់សោម*

426. ការដែលមន្ទីរឃុំឃាំងទាំងអស់របស់កងពល ១៦៤ ជាផ្នែកមួយនៃប្រព័ន្ធមន្ទីរសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យដែលមានការរៀបចំដូចគ្នា និងមានទំនាក់ទំនងរវាងគ្នា និងគ្នា ត្រូវបានស្តែងឡើងតាមរយៈការរៀបរាប់របស់អតីតអ្នកទោសថា ពួកគេត្រូវគេផ្ទេរពីកន្លែងមួយ ទៅកន្លែងមួយទៀត

---

នៅលើទូក១? ឆ.42: ចំពោះទូកតូច គឺមានអ្នកនេសាទប្រហែល៦នាក់។ ចំពោះទូកធំ ដែលមានកម្លាំង១១០សេស មានអ្នកនេសាទប្រហែល២០នាក់ ទៅ៣០នាក់”]។

[1571] ហៅថា វត្តក្រោម, វត្តឥន្ទញ្ញាណ ឬវត្តឥន្ទញ្ញាណ ត្រូវបានសរសេរច្រើនរបៀបជាភាសាអង់គ្លេស Wat It Nhean, Wat Entanhien, Wat En Ta Nhien/Nhean, Wat Eng Tea Nhien/Nhean, Ti Nean/Nhean, Wat Kroam/Krom/Kraom, Annhean/Anyean, Wat Entta-Nhean, Intheak Nhean, In Theak Nhean, Inth Nhean, Intra Nhean, Entheak Nhean។

[1572] “ទឹកសាប” ត្រូវបានសរសេរច្រើនរបៀបជាភាសាអង់គ្លេស ពោលគឺ ‘Toek Sab’, ‘Tuek Sab’, ‘Teuk Sap’, ‘Tuek Sap’, ‘Tik Sap’, ‘Tik Sab’ ឬ ‘fresh water’។

[1573] សូមមើលផងដែរ ជំពូក VIII.ង. ការដ្ឋានស្ទឹងហាវ – 3. ឧក្រិដ្ឋកម្ម –ការដាក់គុកមនុស្សដោយខុសច្បាប់ និងការធ្វើទារុណកម្ម

ក្នុងអំឡុងពេល "កសាង"។ ឡុង ផាន់ស៊ី ប្រធានកងវរសេនាតូច ៦១២ រហូតដល់ពេលចាប់ខ្លួន នៅឆ្នាំ ១៩៧៧ ឬឆ្នាំ ១៩៧៨ ត្រូវគេបញ្ជូនទៅមន្ទីរសន្តិសុខទឹកសាប ក្រោយពីត្រូវគេឃុំក្នុងគុកនៅស្ទឹងហាវ អស់រយៈពេលជាច្រើនខែ[1574]។ ដូចគ្នានេះដែរ កងពល ១៦៤ បានផ្ទេរ មូល ឈិន ជាយុទ្ធជននៃអតីតកងវរសេនាតូច ៣៨៦ ពីមន្ទីរសន្តិសុខទឹកសាប ទៅវត្តឥន្ទញ្ញាណ ទៅវិញទៅមក ក្នុងរយៈពេលជាច្រើនថ្ងៃ[1575]។

*ខ) បណ្តាញសន្តិសុខទូលំទូលាយជាងនេះរបស់កម្ពុជាប្រជាធិបតេយ្យ*

427. អ្នកទោសខ្លះត្រូវគេឃុំបណ្តោះអាសន្ននៅកំពង់សោម មុនពេលបញ្ជូនទៅកន្លែងផ្សេង ជាធម្មតា គឺទៅមន្ទីរ ស-២១។ សាក្សីមួយចំនួនបានរៀបរាប់ថា វត្តឥន្ទញ្ញាណ[1576] និងទឹកសាប[1577] ជា "កន្លែង

---

[1574] ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ. 27, 50 ["ខ្ញុំធ្វើជាមេវរសេនាតូច៦១២ រហូតដល់គេចាប់ខ្លួនខ្ញុំ នៅក្នុងខែ១ ឬខែ២ ឆ្នាំ១៩៧៧ ឬឆ្នាំ១៩៧៨ [...] ស: លោកថា គេចាប់ខ្លួនលោកក្នុងខែមករា ឬកុម្ភៈ ឆ្នាំ ១៩៧៨ និងបានជាប់គុកនៅទឹកសាប រយៈពេល២ខែ មុនពេលវៀតណាមចូល។ ដូច្នេះ ត្រឹមត្រូវដែរឬទេថា លោកជាប់នៅគុកទី១នោះបានលើស
រយៈពេល៦ខែ? ឆ.50: ខ្ញុំចាំមិនច្បាស់ទេ។ ខ្ញុំគ្រាន់តែដឹងថា ខ្ញុំមកជាប់គុកនៅទឹកសាបនេះមានរយៈពេលខ្លីជាងនៅគុកនៅស្ទឹងហាវ។ ខ្ញុំមិនបានចាំទេ ពីព្រោះខ្ញុំត្រូវគេធ្វើទារុណកម្មរហូត។"] ឆ.39-40 ["គឺជា [ស្ទឹងហាវ និងទឹកសាប] គុកយោធាទាំងពីរ។ [...] ឆ.40: គុកទាំងពីរនេះស្ថិតនៅក្នុងកងពល១៦៤"]។

[1575] ឯកសារ D114/31 មូល ឈិន កំណត់ហេតុស្តាប់ចម្លើយ, ឆ. 159 ["ខ្ញុំជាប់គុក៣ថ្ងៃនៅវត្តឥន្ទញ្ញាណ ជាប់៣ថ្ងៃនៅទឹកសាប និង៣ថ្ងៃនៅព្រៃនុប។ អំឡុងពេល២៩ថ្ងៃ ដែលខ្ញុំជាប់គុក គឺនៅកន្លែងផ្សេងៗគ្នា"]។ ឯកសារ D114/40 មូល ឈិន កំណត់ហេតុស្តាប់ចម្លើយ ឆ.2 ["ដំបូង គឺខ្ញុំជាប់ឃុំនៅទឹកសាបរយៈពេល៣ថ្ងៃ [...] ក្រោយមកទៀត គេបញ្ជូនខ្ញុំពីទឹកសាបមកឃុំនៅវត្តឥន្ទញ្ញាណ។ ពេលខ្ញុំរួចខ្លួនពីវត្តឥន្ទញ្ញាណមក [...] គេឲ្យខ្ញុំត្រឡប់មកកន្លែងទឹកសាបដដែលវិញ"]។

[1576] ឯកសារ D54/25 ប៉ាក សុខ កំណត់ហេតុស្តាប់ចម្លើយ ឆ.25 ["ខ្ញុំបានឮពីយោធាដទៃទៀតនៅក្នុងកងរបស់ខ្ញុំថា វត្តឥន្ទញ្ញាណ គឺជាកន្លែងឃុំឃាំងអ្នកទោស ដែលមានឋានៈថ្នាក់វរសេនាតូច វរសេនាធំ និងកងពលមុនពេលដែលគេបញ្ជូនពួកនេះទៅភ្នំពេញ"]។ ឯកសារ D54/102 ឯក នី កំណត់ហេតុស្តាប់ចម្លើយ ឆ.6-7, 23 ["វត្តឥន្ទញ្ញាណគឺជាមន្ទីរសន្តិសុខ និងមន្ទីរឃុំឃាំងរបស់កពល១៦៤របស់ មាស មុត។ វាគឺជាកន្លែងដែលគេឃុំ និងកន្លែងសួរចម្លើយអ្នកទោស មុនពេលគេបញ្ជូនទៅភ្នំពេញ។ [...] ស: ហេតុអ្វីបានជាលោកដឹងថា គេបញ្ជូនអ្នកទោសពីវត្តឥន្ទញ្ញាណទៅភ្នំពេញ? ឆ.7: យោធាកងពិសេសបាននិយាយអំពីរឿងនេះប្រាប់ខ្ញុំ ហើយនិងអំពីឡានយោធាដែលគេប្រើសម្រាប់ដឹកអ្នកទោសពិវត្តឥន្ទញ្ញាណទៅភ្នំពេញ។ [...] ឆ.23: វត្តឥន្ទញ្ញាណគឺជាមន្ទីរឃុំឃាំងបណ្តោះអាសន្នសម្រាប់កម្មាភិបាលថ្នាក់ដឹកនាំ មុនពេលបញ្ជូនទៅកន្លែងផ្សេង"]។ ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.28 ["ខ្ញុំគិតថា វត្តឥន្ទញ្ញាណនេះ មិនមែនជាកន្លែងឃុំអ្នកទោសចាប់រហូតទេ គឺវាជាកន្លែងដែលឃុំ បណ្តោះអាសន្ន

ឃុំឃាំងបណ្ដោះអាសន្ន" ដែលគេប្រើប្រាស់សម្រាប់ដាក់អ្នកទោសដែលត្រូវបញ្ជូនទៅកន្លែងផ្សេង ជាធម្មតា គឺទៅទីក្រុងភ្នំពេញ និយាយឲ្យចំ គឺមន្ទីរ ស-២១។ សាក្សី ឯក នី បានបញ្ជាក់ថា គាត់បានឃើញឡានដឹកអ្នកទោសទៅទីក្រុងភ្នំពេញ ក្នុងឆ្នាំ ១៩៧៧ ដោយមានអ្នកយាមប្រដាប់អាវុធ ហើយពួកគេ "ថ្ងូរ" "យំ" "ស្រែក ក្នុងលក្ខខណ្ឌដែលពួកគេខ្លួនឯងចាត់ទុកថាពិបាកជាងស្លាប់ទៅទៀត[1578]។

428. បញ្ជីនៅសេសសល់ពីមន្ទីរ ស-២១ ក៏បង្ហាញផងដែរថា ជនជាតិថៃ និងវៀតណាម ដែលចាប់បាននៅលើសមុទ្រ[1579] រួមទាំងកុមារ[1580] និងប្រជាជនរបស់កម្ពុជាប្រជាធិបតេយ្យ[1581] ត្រូវគេបញ្ជូនក្នុង

---

ចំពោះជនដែលគេសង្ស័យ ឬជាប់ចោទរឿងរ៉ាវផ្សេងៗ។ បន្ទាប់ពី គេរកឃើញកំហុសរបស់ជននោះហើយ គេបញ្ជូនចេញទៅភ្នំពេញ ឬកន្លែងផ្សេងទៀត"]។ ឯកសារ D1.3.13.13 បទសម្ភាសន៍របស់ការិយាល័យសហព្រះរាជអាជ្ញាជាមួយ ទូច សឿលី EN 00217575 ["វាមិនមែនជាកន្លែងអចិន្ត្រៃយ៍ទេ គឺគ្រាន់តែជាមណ្ឌលបណ្ដោះអាសន្ន មុនគេបញ្ជូនទៅកន្លែងផ្សេងទៀត"]។ សូមមើលផងដែរ ឯកសារ D54/98 Heang Ret កំណត់ហេតុស្ដាប់ចម្លើយ ឆ.89 ["មន្ទីរសន្តិសុខនោះ គេប្រើសម្រាប់ឃុំខ្លួនមនុស្សបណ្ដោះអាសន្ន ដែលមានបញ្ហាបន្តិចបន្តួច"]។

1577 ឯកសារ D54/20 កំណត់ហេតុស្ដាប់ចម្លើយ សំ សោម ឆ.12 [គេដាក់អ្នកទោសខ្លួនបណ្ដោះអាសន្ននៅគុកទឹកសាប មុននឹងបញ្ជូនទៅភ្នំពេញ]។

1578 ឯកសារ D54/102 ឯក នី កំណត់ហេតុស្ដាប់ចម្លើយ ឆ. 7-8, 10 ["អំពីឡានយោធាដែលគេប្រើសម្រាប់ដឹកអ្នកទោសពីវត្តឥន្ទញ្ញាណទៅភ្នំពេញ។ ឡានយោធានោះ គេហៅថា ឡានទាហាន៤x៤របស់ចិន ដែលគេប្រើសម្រាប់ចាប់ និងដឹកអ្នកទោស។ ថ្ងៃមួយ ពេលខ្ញុំកំពុងធ្វើការនៅក្បែរលូកាត់ផ្លូវជាតិលេខ៤ នៅជិតព្រលានយន្តហោះកងកេង ខ្ញុំបានឃើញឡាននោះឈប់ចាក់ទឹក។ ឡាននោះធ្វើដំណើរក្នុងទិសដៅទៅភ្នំពេញ។ ខ្ញុំឃើញមានពួកយោធា ដែលឆ្មាំឡាននោះមានកាន់កាំភ្លើងអាកា៤៧ អង្គុយនៅខាងក្រោយឡាន។ ឡាននោះ គឺគ្របដំបូលជិត ពេលគេឈប់ ខ្ញុំឮសំឡេងមនុស្សយំ និងថ្ងូរនៅក្នុងឡាននោះ តែខ្ញុំមើលមិនឃើញពួកគេទេ។ [...] ឆ.8: ខ្ញុំឮពួកគេស្រែកថ្ងូរថា អូយឈឺណាស់ ចងតឹងណាស់ ម្ដេចបានមិនសម្លាប់ចោលតែម្ដងទៅ។ [...] ឆ.10: ក្នុងខែវស្សា ឆ្នាំ១៩៧៧"]។

1579 សូមមើល ខ. ឯកសារ D114/230.1.1 បញ្ជីអ្នកទោសមន្ទីរស-21 របស់ក.ស.ច.ស លរ.592-594 ["គិញយួន" – នេសាទ។ សម្គាល់៖ លរ. 14786 ជាន់គ្នានឹង លរ. 592], លរ.596-597 ["គិញយួន" – អ្នកនេសាទ។ សម្គាល់៖ លរ. 14782 គឺជាន់គ្នានឹង លរ.597], លរ.600 ["គិញថៃ" – អ្នកនេសាទ], លរ.602 ["គិញយួន"], លរ.604 ["គិញថៃ"], លរ.606-607 ["គិញយួន"], លរ.609 ["គិញថៃ"], លរ.612 ["គិញយួន"], លរ.613-615 ["គិញថៃ"], លរ.616 [អ្នកនេសាទថៃ], លរ.620 ["គិញថៃ"], លរ.625 ["គិញយួន"], លរ.628-629 ["គិញថៃ"], លរ.645-646 ["គិញថៃ"], លរ.649-650 ["គិញថៃ"], លរ.651-653 ["គិញយួន" – បញ្ជាក់ជាអ្នកនេសាទ], លរ.663 ["គិញយួន" – អ្នកនេសាទ។ សម្គាល់៖ លរ.14784 ជាន់គ្នានឹង លរ.663], លរ.676 ["គិញយួន"], លរ.678 ["គិញយួន" - អ្នកនេសាទ], លរ.679-680 ["គិញថៃ" – បញ្ជាក់ថា ម្នាក់ ជាអ្នកនេសសាទ], លរ.12981 [អ្នកនេសាទថៃ], លរ.12983-12985 ["គិញថៃ" - អ្នកនេសាទ], លរ.12987-12988 ["គិញថៃ" - អ្នកនេសាទ], លរ.12989 ["ជនជាតិថៃ"], លរ.

ទ្រង់ទ្រាយធំ ក្នុងអំឡុងថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦ ពីកំពង់សោមទៅមន្ទីរ ស-២១ រួចសម្លាប់ចោលនៅទីនោះ។ នេះគឺជាភ័ស្តុតាងដែលបង្ហាញថា មនុស្សជាច្រើនត្រូវគេចាប់ ចន្លោះពីខែ កញ្ញា

---

12999 [“គិញថៃ” - អ្នកនេសាទ], លរ.13001-13002 [ជនជាតិថៃ – បញ្ជាក់ថា ម្នាក់ជាអ្នកនេសាទ 1 “គិញថៃ”], លរ.13005-13006 [“គិញថៃ”], លរ.13023 [“គិញថៃ”], លរ.13031 [“គិញថៃ”], លរ.13052-13053 [“គិញថៃ”], លរ.13055 [“គិញថៃ”], លរ.13431-13434 [“គិញយួន”], លរ.13436-13437 [“គិញយួន” – បញ្ជាក់ថា ម្នាក់ជាអ្នកនេសាទ], លរ.13642-13643 [“វៀតណាម”។ សម្គាល់៖ លរ.14783 គឺជាន់គ្នានឹង លរ.13642], លរ.13645 [“ប្រជាជនថៃ”], លរ.13653 [“ប្រជាជនថៃ - អ្នកនេសាទ”], លរ.14785 [អ្នកនេសាទវៀតណាម]។ អ្នកទោសប្រាំបីនាក់ផ្សេងទៀត ដែលត្រូវបានចាប់ខ្លួននៅសមុទ្រ ពុំមានថ្ងៃចូលនោះទេ ក្នុងបញ្ជីឈ្មោះអ្នកទោសមន្ទីរស-២១ របស់ក.ស.ច.ស ប៉ុន្តែអាចត្រូវបានបញ្ជាក់ថា ជាក្រុមជនជាតិថៃតែមួយ ដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១ នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ ដោយផ្អែកទៅលើឈ្មោះទូកនេសាទ ដែលពួកគេនៅលើហ្នឹង ពេលចាប់ខ្លួន ហើយ លេខចម្លើយសារភាពនៅទួលស្លែងរបស់ពួកគេ គឺ “TH”៖ ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសមន្ទីរស-២១ របស់ក.ស.ច.ស លរ. 14696 [ខាំ ស៊ីរៈ ផាន់ ទូកនេសាទ៦៧ ហារិន ផានិច], លរ.14697 [ ការ ស៊ីង ទូកនេសាទ៥ សារិ ឈូក], លរ.14698 [ ល្ហួម សំប៊ូន អាយុ៦៧ឆ្នាំ ទូកនេសាទ៥ សារិ ឈូក], លរ.14699 [ ម៉ុន ទ្រី ស៊ីឆាណៈ ទូកនេសាទ ៦៧ ហារិន ផានិច] លរ. 14700 [ប្រសើត លប កើត កាពីទែនទូកនេសាទ ហារិន ផានិច], លរ.14701 [សំប៊ូន សេត បុផា ទូកនេសាទ៥ សារិ ឈូក], លរ.14702 [ធម្មរ៉ាត គេផង ទូកនេសាទ៦៧ ហារិន ផានិច], លរ.14703 [ឡា សិម ខា ទូកនេសាទ៥ សារិ ឈូក]។ សូមមើលផងដែរ ឯកសារ D1.3.3.2 បញ្ជីកម្មេចរបស់មន្ទីរស-២១ EN 00874373-75 [លរ. 1-31 ជាអ្នកនេសាទថៃ ដែលត្រូវបានបញ្ជូនទៅមន្ទីរស២១ នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ ១៩៧៦], 00874556-60 [លរ. 251-284]។

1580 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសមន្ទីរស-២១ របស់ ក.ស.ច.ស លរ. 12983 [ផ្កាត ឡុន អាយុ១៥ឆ្នាំ កូនគិញថៃ (ប្រជាជនថៃ)(នេសាទ) (អ្នកលាងចាននៅលើទូកនេសាទ ហារិន ផានិច), លរ.12988 [ ឡូយ ឡោត អាយុ១៥ឆ្នាំ កូនគិញថៃ (ប្រជាជនថៃ) (ទូកនេសាទថង ម៉ូលីណា), លរ.13031 [យុត ផុង អាយុ១៦ឆ្នាំ កូនគិញថៃ (ប្រជាជនថៃ), លរ.13434 [ង្វៀង ខិនអ៊ី អាយុ១៦ឆ្នាំ។ គិញវៀតណាម (សូមមើល ឯកសារ D114/145.2.11 ប្រវត្តិរូបនៅមន្ទីរស២១ របស់ ង្វៀង ខិនអ៊ី (VN125), EN 01191493 [“អាយុ១៦ឆ្នាំ ប្រុស ជនជាតិវៀតណាម នៅលីវ”])]

1581 ឯកសារ D114/230.1.1 បញ្ជីអ្នកទោស ស-២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត លេខ 587-588, 590, 601, 610-611, 618, 627, 634-637, 639, 641-643, 655, 660-661, 664, 667, 670, 674-675, 681-682, 1576, 2249, 4139, 4168, 4707, 5025, 5308, 5465, 5911, 6084, 6090, 6390, 6650, 8223, 10590, 11611, 12616, 13616, 13823, 13873។

ដល់ខែ ធ្នូ ឆ្នាំ ១៩៧៥[1582] ហើយត្រូវបានឃុំជាច្រើនខែ នៅកំពង់សោម មុននឹងផ្ទេរចេញ។ យ៉ាងហោចណាស់ អ្នកខ្លះត្រូវគេឃុំឲ្យធ្វើការនៅទឹកសាប[1583]។

[1582] សូមមើល ឧទាហរណ៍ 592 និង 14786 (ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៧៥។ សូមមើល ឯកសារ D114/145.2.15 ប្រវត្តិរូប ស-២១ ដាំង យ៉ាំង ថាន់ (VN132), KH ERN 01180427 ["ពេលចាប់ខ្លួន ដាំង យ៉ាំង ថាន់ បញ្ជូនមកនៅកោះខៀវចំនួនកន្លះខែ ទើបត្រូវបញ្ជូនទៅនៅកន្លែងទឹកសាបធ្វើស្រែ។ ដាំង យ៉ាំង ថាន់ ត្រូវបានចាប់ខ្លួននៅថ្ងៃទី ១២ ខែ ធ្នូ [ឆ្នាំ ១៩៧៥]"]), 663 និង 14784 (ខែ ធ្នូ ឆ្នាំ ១៩៧៥), 678 (ខែ ធ្នូ ឆ្នាំ ១៩៧៥), 12981 (ខែ ធ្នូ ឆ្នាំ ១៩៧៥), 12983 (ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៧៥), 12984 (ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៧៥) 12985 (ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៧៥), 12987 (ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៧៥), 12988 (ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៧៥), 12989 (ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៧៥), 12999 (ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៧៥), 13001 (ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៧៥), 13002 (ថ្ងៃទី ០៩ ខែ ធ្នូ), 13005 (ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៧៥), 13006 (ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៧៥), 13023 (ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៧៥), 13031 (ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៧៥), 13052 (ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៧៥), 13053 (ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៧៥), 13431 (ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥។ សូមមើល ឯកសារ D114/145.2.11 ប្រវត្តិរូប ស-២១ ជឹម យ៉ាំង គី (VN122), KH ERN 01180403 ["ពេលចាប់ខ្លួនហើយ អ/ក បញ្ជូនមកកន្លែងកោះខៀវចំនួន១៨ថ្ងៃ ទើបបញ្ជូនមកន្លែងទឹកសាបឲ្យធ្វើការ ដូចជារែកដីដាក់គល់ធូរេន និងសៅម៉ៅ។ [...] ចាប់ខ្លួននៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥"]), 13432 (ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥។ សូមមើល ឯកសារ D114/145.2.11 ស-២១ ប្រវត្តិរូបរបស់ ជឹន យ៉ាំង យុប ឈ្មោះប្រែ ឡេ យ៉ាំងម៉ាយ (VN123), KH ERN 01180405 ["ពេលចាប់ខ្លួនហើយ អ/ក បញ្ជូនមកកន្លែងកោះខៀវចំនួន ១៨ ថ្ងៃ។ រួចទើបបញ្ជូនមកន្លែងទឹកសាប។ ចាប់ខ្លួននៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥"]), 13433 (ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥។ សូមមើល ឯកសារ D114/145.2.11 ស-២១ ប្រវត្តិរូបរបស់ ជឹម យ៉ាំងគីង ឈ្មោះប្រែ លេ យ៉ាំងភឿក (VN 124), KH ERN 01180407 ["ពេលចាប់ខ្លួនហើយ អ/កបញ្ជូនមកកន្លែងកោះខៀវចំនួន១៨ថ្ងៃ ទើបបញ្ជូនមកន្លែងទឹកសាបឲ្យធ្វើការ ដូចជារែកដីដាក់គល់ធូរេន និងសៅម៉ៅ។ [...] ចាប់ខ្លួននៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥"]), 13434 (ខែ វិច្ឆិកា ឆ្នាំ ១៩៧៥។ សូមមើល ឯកសារ D114/145.2.11 ស-២១ ប្រវត្តិរូបរបស់ ង្វៀង ឌិន អ៊ី (VN125), KH ERN 01180409 ["ពេលចាប់ខ្លួនហើយ អ/ក បញ្ជូនមកកន្លែងកោះខៀវចំនួន១៨ថ្ងៃ ទើបបញ្ជូនមកន្លែងទឹកសាបឲ្យធ្វើការ ដូចជារែកដីដាក់គល់ធូរេន និងសៅម៉ៅ។ [...] ចាប់ខ្លួននៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥"]), 13436 (ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៧៥។ សូមមើល ឯកសារ D114/145.2.12 ស-២១ ប្រវត្តិរូបរបស់ ង្វៀង ធីធឿង (VN126), KH ERN 01180412 ["ចាប់ខ្លួននៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៧៥ [...] ពេលចាប់ខ្លួន អ/ក បានបញ្ជូនឲ្យទៅនៅកន្លែងទឹកសាបថែរក្សាចំការធូរេន។"]), 13437 (ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៧៥។ សូមមើល ឯកសារ D114/145.2.12 ស-២១ ប្រវត្តិរូបរបស់ ង្វៀង ហ៊ីវឡាង (VN127) ["ចាប់ខ្លួននៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៧៥ [...] ពេលចាប់ខ្លួន អ/ក បានបញ្ជូនឲ្យទៅនៅកន្លែងទឹកសាបថែរក្សាចំការធូរេន។"]), 14782 និង 597 (ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥។ សូមមើលផងដែរ ឯកសារ D114/145.2.11 ស-២១ ប្រវត្តិរូបរបស់ ត្រឹង យ៉ាំងឃ្វេ (VN121), KH ERN 01195301 ["កំណត់សម្គាល់៖ កាលបរិច្ឆេទនៃការចាប់ខ្លួន៖ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥។ ពេលចាប់ខ្លួនហើយ អ/កបញ្ជូនមកន្លែងទឹកសាបឲ្យធ្វើការ ដូចជារែកដីដាក់គល់ធូរេន និងសៅម៉ៅ។"]),

429. ប្រធានមន្ទីរពេទ្យកងពលឈ្មោះ ស៊ឹម នាម ហៅសុខ និងប្រពន្ធឈ្មោះ ហែម អាង ហៅស៊ីន ត្រូវគេបញ្ជូនទៅទឹកសាប មុនពេលគេឃុំ និងសម្លាប់នៅមន្ទីរ ស-២១[1584]។ ដូចបានបង្ហាញក្នុងផ្នែក

13642 និង 14783 (ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៧៥។ សូមមើលផងដែរ ឯកសារ D114/145.2.12 ស-២១ ប្រវត្តិរូបរបស់ ចឹង ថាន់ ហឿង (VN128), KH ERN 01180416 ["ចាប់ខ្លួននៅថ្ងៃទី ១២ ខែ ធ្នូ [ឆ្នាំ ១៩៧៥]។ ពេលចាប់ខ្លួនហើយ ត្រូវបានបញ្ជូនទៅកោះ [...] រយៈពេល ០៦ ថ្ងៃ។ អ/កបញ្ជូនមកន្លែងទឹកសាបឱ្យធ្វើការ ដូចជារែកដីដាក់គល់ធូរេន និងសៅម៉ៅ។"]), 14785 (ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥។ សូមមើលផងដែរ ឯកសារ D114/145.2.14 ស-២១ ប្រវត្តិរូបរបស់ ផាម យ៉ាំង ផាន់ KH ERN 01180424 ["កំណត់សម្គាល់៖ ត្រូវបានចាប់ខ្លួននៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ and អ/កបញ្ជូនមកន្លែងទឹកសាបឱ្យធ្វើការ ដូចជារែកដីដាក់គល់ធូរេន និងសៅម៉ៅ។ នៅថ្ងៃទី ០៧ ខែឧសភា ឆ្នាំ ១៩៧៦ ត្រូវបញ្ជូនទៅ ស-២១"])។

1583 សូមមើល ឧទាហរណ៍ ឯកសារ D114/230.1.1 បញ្ជីអ្នកទោស ស-២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត លេខ 592 និង 14786 [ដាំង យ៉ាំង ថាន់-ត្រូវបានចាប់ខ្លួននៅសមុទ្រនៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៧៥ ហើយត្រូវឃុំខ្លួននៅទឹកសាបរហូតដល់ត្រូវបញ្ជូនទៅ ស-២១ នៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៦], 663 និង 14784 [គីម ង៉ុកទ្រៀង – ត្រូវបានចាប់ខ្លួននៅខែ ធ្នូ ឆ្នាំ ១៩៧៥ នៅលើកោះប្រជៀវ ហើយត្រូវឃុំខ្លួននៅទឹកសាបរហូតដល់ត្រូវបញ្ជូនទៅ ស-២១ នៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៦], 14785 [ផាម យ៉ាំង ថាន់ – ត្រូវបានចាប់ខ្លួននៅសមុទ្រនៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ហើយត្រូវឃុំខ្លួននៅទឹកសាបរហូតដល់ត្រូវបញ្ជូនទៅ ស-២១ នៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦]។ សូមមើលផងដែរ លេខ 600 [ឡាក អ្នកចាប់ត្រីជនជាតិសៀម ចូលក្នុង ស-២១ នៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦], 641 [ចាន់ សួន អ្នកធ្វើចំការ ចូលក្នុង ស-២១ នៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦], 642 [ចិន ញឹម កម្មករស្រែអំបិល ចូលក្នុង ស-២១ នៅថ្ងៃ ទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦], 649-650 [សំ ឃីត និង ថាំ ម៉ាឡាក អ្នកនេសាទសៀម ចូលក្នុង ស-២១ នៅថ្ងៃ ទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦], 12987 [ផេង ចាន់សេន អ្នកនេសាទសៀម ចូលក្នុង ស-២១ នៅថ្ងៃ ទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦], 13031 [យុទ្ធភុង សំរាន អ្នកនេសាទសៀម ត្រូវបានចាប់ខ្លួនពីកោះតាងនៅថ្ងៃ ទី ០៦ ខែ កញ្ញា ឆ្នាំ ១៩៧៥ ចូលក្នុង ស-២១ នៅថ្ងៃ ទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦], 13052 [ឆើតអិមផង អ្នកនេសាទសៀម ត្រូវបានចាប់ខ្លួនពីកោះកាពីនៅថ្ងៃ ទី ២២ ខែ ធ្នូ ឆ្នាំ ១៩៧៥, ចូលក្នុង ស-២១ នៅថ្ងៃ ទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦], 13053 [ដេន ណេនយីម ត្រូវបានចាប់ខ្លួនពីកោះរុងនៅថ្ងៃ ទី ២១ ខែ ធ្នូ ឆ្នាំ ១៩៧៥, ចូលក្នុង ស-២១ នៅថ្ងៃ ទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦], 13055 [កូវីត អ្នកនេសាទសៀម ចូលក្នុង ស-២១ នៅថ្ងៃ ទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦]។ និងជើងទំព័រ 1582 [យោងតាមឯកសារ D114/230.1.1 បញ្ជីអ្នកទោស ស-២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត លេខ 678, 13431-13434, 13436-13437, 13642 និង 14783, 14782 និង 597]។

1584 ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.109 ["គេដាក់ តាសុខ នៅគុកទឹកសាបហ្នឹង។ គាត់ជាពេទ្យខ្មែរក្រហម។ គាត់ធ្លាប់ធ្វើជាប្រធានរះកាត់នៅកំពង់សោម។"]។ ឯកសារ D54/117 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន ឆ.11-12, 18 ["ស៖ [...] អំពីមន្ទីរពេទ្យចំការចេក តើអ្នកណាជាប្រធានពេទ្យ? ឆ.11៖ ប្រធានពេទ្យឈ្មោះ សុខ។ [...] ឆ.12៖ គាត់នៅបានប៉ុន្មានខែ គេចាប់គាត់យកទៅដាក់គុកនៅស្ថានទឹកសាបកំពង់សោម នៅចុងឆ្នាំ

*ការបោសសម្អាតនៅក្នុងកងពល ១៦៤* មានសេចក្តីចង្អុលបង្ហាញយ៉ាងច្បាស់ថា មេបញ្ជាការរងកងពល ១៦៤ ឈ្មោះ ហឹង ឌឿន ហៅ ឌឹម ក៏ត្រូវបានចាប់ខ្លួនផងដែរ រួចបញ្ជូនទៅមន្ទីរ ស-២១ នៅថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៧៧[1585]។

430. ឧទាហរណ៍ទាំងនេះបង្ហាញអំពីគោលនយោបាយឃុំឃាំងដោយមានការរៀបចំ និងជាប្រព័ន្ធ ផ្តែកលើការសហការ រវាងមន្ទីរសន្តិសុខនីមួយៗ និងមន្ទីរសន្តិសុខមជ្ឈិមក្រុងភ្នំពេញ[1586]។ ប្រតិបត្តិការចាប់ដាក់គុកអនុវត្តតាមប្រព័ន្ធឃុំឃាំងដែលត្រូវបានប្រើប្រាស់ ដើម្បីទប់ទល់នឹងគំរាមកំហែងរបស់ខ្មាំងផ្ទៃក្នុង និងឥទ្ធិពលបរទេស។ **មាស មុត** រាយការណ៍ជាទៀងទាត់ជូនមជ្ឈិមបក្ស និងអនុវត្តគោលនយោបាយខ្មាំងដោយគ្មានធម៌មេត្តា នៅមន្ទីរសន្តិសុខ ក្រោមការគ្រប់គ្រងរបស់គាត់[1587]។

---

១៩៧៥។ [...] ហោ មកជំនួស សុខ នៅដើមឆ្នាំ ១៩៧៦ [...] ឆ.18៖ គេឲ្យខ្ញុំទៅសហករណ៍មួយ ហើយនៅសហករណ៍នោះមានកូនសុខ នៅជាមួយដែរ ហើយកូនសុខ ជាអ្នកប្រាប់ខ្ញុំថា គេចាប់សុខ និងប្រពន្ធរបស់គាត់ទៅដាក់នៅស្ពានទឹកសាប។"]។ ឯកសារ D114/155 កំណត់ហេតុស្តាប់ចម្លើយ សុខ ម៉េន ឆ.61 ["ក្រោយរំដោះ១៩៧៥ ដែលក្នុងនោះមានកងទ័ព៣៨៦ ដែលបញ្ចូលទៅក្នុងកងពល១៦៤ ដែលបញ្ជូនទៅ ប៉ុន្តែអ្នកទាំងនោះស្លាប់ហើយ។ តែខ្ញុំឮព័ត៌មានថាមានគុកនៅទឹកសាប, ទី២ នៅស្ទឹងហាវ ដែលប្រើសម្រាប់ដាក់អ្នកជាប់ពាក់ព័ន្ធនឹងនយោបាយ។ [...] ក្នុងនោះ ឮព័ត៌មានថា គេចាប់ [...] ប្រពន្ធពេទ្យ សុខ ដាក់គុកនៅទឹកសាប តែអត់ដឹងថា ពេទ្យ សុខ គេចាប់បញ្ជូនទៅណាទេ។ [...] ទាំងពីរនាក់ប្តីប្រពន្ធស្លាប់អស់ហើយ។ សុខ អតីតប្រធានមន្ទីរពេទ្យតំបន់៣៧។"]។ ឯកសារ D114/230.1.1 បញ្ជីអ្នកទោស ស-២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត លេខ 7383 [ពេទ្យស្រី ហែម អាង ហៅ ស៊ីន ជាប្រពន្ធរបស់ សុក– ចូលមកនៅថ្ងៃទី ២៦ ឬ ២៨ ខែ មេសា ឆ្នាំ ១៩៧៧ ត្រូវបានសម្លាប់នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ១៩៧៨], 13137 [ស៊ឹម នាម ហៅ សុក ប្រធានមន្ទីរពេទ្យកងពល កងពល១៦៤ ស្លាប់ឬត្រូវបានសម្លាប់នៅថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៧៧]។ ឯកសារ D1.3.28.19 បញ្ជីសួរចម្លើយ ស-២១ KH ERN 00161777 [លេខ០១- ហែម អាង ហៅ ស៊ីន នយោបាយកងពលធំ ពេទ្យកងពល ប្រពន្ធអាសុក កាលបរិច្ឆេទចូល៖ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៧៧]។ ឯកសារ D9.3 បញ្ជីការិយាល័យសហចៅក្រមស៊ើបអង្កេតស្តីពី អ្នកទោស ស-២១ ប្រចាំកងពល ១៦៤ [កំណត់លេខ ១០ ឈ្មោះ ហែម អាង ហៅ ស៊ីន សមាជិកកងពលនៃកងពល ១៦៤ ដែលចូលក្នុង ស-២១ នៅខែ មេសា ឆ្នាំ ១៩៧៧]។

1585 សូមមើល កថាខណ្ឌ ៣៥៨។

1586 សូមមើល VII. គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាទាក់ទងនឹងសំណុំរឿងប្រឆាំង មាស មុត–ការកម្ទេចខ្មាំង និងពួកប្រឆាំងថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា។

1587 សូមមើល VIII.A. ការបោសសម្អាតក្នុងកងពលធំ ១៦៤។

## ២. ការចាប់ និងឃុំខ្លួន នៅមន្ទីរសន្តិសុខកងពល ១៦៤

### ការអនុវត្តការចាប់ខ្លួន

431. ក្នុងឋានៈជាលេខា និងជាមេបញ្ជាការក្តាប់រួមនៃកងពលលេខ ៣ ឬកងពល ១៦៤[1588] និងជាលេខាតំបន់ស្វយ័តកំពង់សោម[1589] **មាស មុត** មានសិទ្ធិអំណាចចុងក្រោយក្នុងការចាប់ ឃុំខ្លួន ដោះលែង និងសម្លាប់[1590] ទាហានកងពលលេខ ៣ ឬកងពលលេខ ១៦៤ និងក្រុមគ្រួសារ ជនស៊ីវិលរស់នៅតំបន់កំពង់សោម និងអ្នកដែលចាប់បាននៅលើសមុទ្រ និងនៅលើកោះ ក្រោមការគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ (រួមមាន កោះពូលូវៃ កោះតាង កោះព្រីង កោះរ៉ុង កោះរ៉ុងសន្លឹម កោះសេះ កោះថ្មី និងកោះតូចៗផ្សេងទៀត)។

---

1588 សូមមើល III.2. តួនាទីរបស់ មាស មុត ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ – លេខាកងពលធំ ១៦៤។ IV. លេខាកងពលធំ ១៦៤ (អតីតកងពលធំ ០៣) រចនាសម្ព័ន្ធអំណាច - កងពលធំ ០៣ (ឆ្នាំ ១៩៧៣/១៩៧៤ – ខែ កក្កដា ឆ្នាំ ១៩៧៥); IV. កងពលធំ ១៦៤ (អតីតកងពលធំ ០៣) - គណៈកងពលធំ ១៦៤។

1589 សូមមើល III.2. តួនាទីរបស់ មាស មុត ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ – លេខាតំបន់ស្វយ័តកំពង់សោម។ IV. កងពលធំ ១៦៤ (អតីតកងពលធំ ០៣) រចនាសម្ព័ន្ធអំណាច- កងពលធំ ១៦៤ (ខែ កក្កដា ឆ្នាំ ១៩៧៥ – ខែ មករា ឆ្នាំ ១៩៧៩)។

1590 ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.14, 16 ["សៈ យោងទៅតាមការអង្កេតរបស់លោក តើអ្នកណាមានអំណាចខ្លាំងជាងគេក្នុងការចាប់ចង ការដកអាវុធការបញ្ជូនយោធាឱ្យទៅធ្វើពលកម្ម? ឆ.14៖ គឺមានតែបង មុត ទេ [...] ឆ.16៖ បាទ មាស មុត មានសិទ្ធិអំណាចចាប់ចងប្រជាជនស៊ីវិល យោធា ហើយនិងគ្រួសារយោធាដែលស្ថិតនៅក្រោមការត្រួតត្រារបស់កងពល១៦៤។"]។ ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.2 ["សៈ តើ មាស មុត មានសិទ្ធិអំណាចដោះលែងអ្នកណាម្នាក់បានទេ បើសិនជាគាត់ចង់ដោះលែងអ្នកនោះ? ឆ.2៖ បាទ មាស មុត មានសិទ្ធិអំណាចធ្វើការដោះលែង ហើយអំណាចរបស់គាត់គឺលើសគេទៀត"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.9 ["[មាស មុត] មានអំណាតចាប់ចងនិងសម្លាប់ទាំងយោធា និងទាំងប្រជាជនស៊ីវិលដែលនៅក្នុងតំបន់របស់គាត់ ឧទាហរណ៍ បើគាត់សង្កេតឃើញថា គោ ឬសត្វពាហនៈ ស្គម ហើយមិនត្រូវបានថែទាំមិតដល់ល្អ គាត់នឹងចេញបញ្ជាឱ្យចាប់អ្នកដែលថែទាំគោទាំងនោះ។"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.128-130 ["តាមុត គាត់កំណត់ណាស់ គឺមានន័យថាការសម្លាប់មនុស្សគឺត្រូវធ្វើឡើងតាមការសម្រេច៥ថ្នាក់។ [...] ឆ.129៖ ឧទាហរណ៍សម្រាប់យុទ្ធជនធម្មតាម្នាក់គឺទាល់តែមានសេចក្តីសម្រេចពីប្រធានក្រុម កងហា កងរយ កងវរសេនាធំ និងកងពល។ ហើយនៅក្នុងថ្នាក់នីមួយៗ គឺសេចក្តីសម្រេចត្រូវធ្វើឡើងដោយគណៈកម្មធិការដែលរួមមានប្រធាន អនុប្រធាន និងសមាជិក [...] ឆ.130៖ នៅថ្នាក់នីមួយៗសេចក្តីសម្រេចត្រូវធ្វើឡើងដោយគណៈកម្មាធិការនៅថ្នាក់នោះ។ មាស មុត ជាមេបញ្ជាការកងពលដែលជាថ្នាក់ចុងក្រោយក្នុងការសម្រេច ហើយសេចក្តីសម្រេចនេះត្រូវធ្វើឡើងដោយ មាស មុត អនុប្រធានរបស់គាត់ ហើយសមាជិកនៅក្នុងគណៈកងពលនេះ។"]។

432. យុទ្ធជនជាច្រើននៃកងពល ១៦៤ ត្រូវបានចាប់ខ្លួនដោយសមាជិកកងវរសេនាតូចពិសេស[1591] ១៦៥ (អតីតកងវរសេនាតូច ៤៥០ នៃកងពលលេខ ៣)[1592] ជាកងមួយស្ថិតនៅក្រោមបញ្ជាផ្ទាល់របស់ **មាស មុត**[1593]។ ពីដំបូង ជាកងស្រួចប្រយុទ្ធដែលជួយដល់កងវរសេនាធំនៅសមរភូមិ មុនខែ មេសា

---

1591 ឯកសារ D234/2.1.92 ព្រុំ សារ៉ាត ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ 14.39.40-15.03.11 ["កង៤៥០ ជាកងពិសេសរបស់កងពលប្រចាំជុំវិញកងពល១៦៤ [...] ជាប់ឈ្មោះជាកងពិសេសហ្នឹង ដោយកងហ្នឹងជាកងពិសេសប្រចាំកងពលទី៣"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុក នាង ឆ.19 ["១៦៥ ខ្ញុំគិតថាជាកងវរៈសេនាតូចពិសេស"]។ ឯកសារ D114/286 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.13 ["១៦៥ សំដៅកងរបស់ខ្ញុំ គេហៅកងពិសេសរបស់កងពល។"]។ ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.20 ["បាទ វាជាកងតែមួយ គឺកងវរៈ៤៥០ ឬកងពិសេសរបស់កងពល១៦៤។"]។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ហៅ សារ៉េត ឆ.27 ["វរៈសេនាតូច ៤៥០ គឺជាកងពិសេសរបស់តាមុត។"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.11 ["កងវរសេនាតូចលេខ៤៥០ ហៅថាកងពិសេស"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុក នាង ឆ.19 ["១៦៥ ខ្ញុំគិតថាជាកងវរៈសេនាតូចពិសេស"]។ ឯកសារ D4.1.762 កាំ ម៉ែន កំណត់ហេតុរបស់សហរដ្ឋអាមេរិកស្តីពី POW/MIA, EN 00387328, KH ERN 00742578 ["កងពលធំលេខ ១៦៤ ត្រូវបានរៀបចំជាកងទ័ពថ្មើរជើង ក្រោមឱវាទចំនួនបីកងវរៈសេនាធំគឺ កងវរៈសេនាធំលេខ ៦១ ៦២ និង ៦៣ រួមទាំងកងវរៈសេនាតូចប្រតិបត្តិការពិសេសលេខ ៤៥០។"]។ ឯកសារ D114/187 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.47 ["កង ៤៥០ ជាកងពិសេសកងពល ដូច្នេះអាចទទួលបញ្ជាផ្ទាល់ហើយ។"]។

1592 ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.28 ["កងវរសេនាតូច៤៥០ បានក្លាយជាកងវរសេនាតូច ១៦៥ ដែលជាកងអន្តរាគមន៍ពិសេស"]។ ឯកសារ D114/287 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត KH ERN 01357553 ["កំណត់សម្គាល់អ្នកស៊ើបអង្កេត៖ [...] សាក្សីគាត់និយាយថា "ពីដំបូង ខ្ញុំនៅកងថ្មើរជើងលេខ២២ ហើយបានផ្លាស់ប្តូរទៅកងថ្មើរជើងវរសេនាធំលេខ២០ បន្ទាប់មកទៀត គេផ្លាស់ខ្ញុំទៅវរសេនាតូចហៅថាកងពិសេសលេខ៤៥០។ [...] សូមជម្រាបថាកងពិសេស៤៥០ ក្រោយមកទៅជាវរសេនាតូច១៦៥"]។

1593 ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ហៅ សារ៉េត ឆ.27 ["វរៈសេនាតូច ៤៥០ គឺជាកងពិសេសរបស់តាមុត។"]។ ឯកសារ D54/46 កំណត់ហេតុស្តាប់ចម្លើយ អ៊ែម សុន ឆ.31, 38 ["នៅពេលដែលគាត់មកប្រជុំ [មាស មុត] ប្រកាសថា កងវរសេនាតូច ៤៥០ ជាកងពិសេសចំណុះឲ្យកងពលលេខ៣ ដោយមិនចំណុះឲ្យកងវរៈសេនាធំណាមួយទេ។ គាត់បានប្រកាសថា ពីខែ កុម្ភៈ ឆ្នាំ ១៩៧៥ទៅ គឺត្រូវរៀបចំដើម្បីវាយរំដោះភ្នំពេញ [...] ឆ.38 ៖ កងពិសេសរបស់ខ្ញុំ វរសេនាតូច ៤៥០ គឺទទួលបញ្ជាផ្ទាល់ពី មាស មុត ដែលជាមេបញ្ជាការកងពលលេខ៣តែម្តង។"]។ ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អ៊ែម សុន ឆ.11-12 ["ពួកយើងជាកងពិសេស ហើយយើងរាយការណ៍ផ្ទាល់ទៅ មាស មុត។ [...] ឆ.12៖ ខ្ញុំប្រើតេអ្វដើម្បីរាយការណ៍ទៅគាត់។ ខ្ញុំប្រើតេអ្វ C-25 ឬក៏ VHF-46។"]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.14, 19 ["កងពិសេស គឺដូចជាកងអង្គរក្សអ៊ីចឹង។ វាគឺជាកងដែលមេគេជឿទុកចិត្ត [...] ឆ.19៖ យោធាម្នាក់ៗនៅក្នុងកងពិសេស គឺគេចម្រាញ់ពីប្រវត្តិរូបយ៉ាងល្អិតល្អន់ណាស់មុនពេលដែលគេបញ្ចូលទៅក្នុងកងពិសេស"]។ ឯកសារ D54/103 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.14, 16

ឆ្នាំ ១៩៧៥[1594] មុខងារចម្បងរបស់កងវរសេនាតូច ១៦៥/៤៥០ បានផ្លាស់ប្តូរក្រោយពីខ្មែរក្រហមដណ្តើមបានទីក្រុងភ្នំពេញ ដោយកងនេះទទួលខុសត្រូវខាងសន្តិសុខ ជំនួសឱ្យកងពល ១៦៤[1595]។

---

["មានតែយោធារបស់ មាស មុត ទេ ដែលមានកាំភ្លើងកាន់។ ឧទាហរណ៍ មានកងមួយហៅថា កងពិសេស ដែលតែងតែធ្វើការចាប់ចង គឺជាកងរបស់ តាមុត។ [...] ឆ.16៖ យើងហៅកងពិសេសនោះថា ជាកងអនុសេនាតូចពិសេសរបស់តាមុត"]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.10-11, 13 ["កងវរៈសេនាតូចពិសេសនេះពុំស្ថិតនៅក្រោមបញ្ជារបស់វរៈសេនាធំណាមួយទេ វាឋិតនៅក្រោមបញ្ជាការរបស់កងពល [៣/១៦៤]។ [...] ឆ.11៖ កងវរៈសេនាតូចពិសេសនេះ គឺឋិននៅជាមួយបញ្ជាការឬស្នងការកងពល។ [...] ឆ.13៖ ខ្ញុំដឹងច្បាស់ថា កងវរៈពិសេសនេះឋិតនៅក្រោមបញ្ជាការផ្ទាល់របស់កងពល។ កងវរៈពិសេសនេះមិនឋិតនៅក្រោមបញ្ជាការរបស់វរៈសេនាធំណាមួយទេ។ ឋានៈរបស់មឿន ដែលជាមេបញ្ជាការរបស់វរៈសេនាតូចពិសេសនេះ គឺមានឋានៈដូចមេបញ្ជាការកងវរៈសេនាធំដទៃទៀតក្នុងកងពលដែរ។ ពេលដែលមានប្រជុំ មេបញ្ជាការវរៈសេនាធំទាំងអស់ត្រូវបានហៅទៅចូលរួមប្រជុំ ហើយមឿនក៏ត្រូវបានហៅទៅចូលរួមប្រជុំជាមួយដែរ។"]។ ឯកសារ D114/15 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា ឆ.18 ["ស៖ តើលោកធ្លាប់ឮអំពីកងវរៈសេនាតូចពិសេស ៤៥០ នៃកងពលលេខ៣ ដែរឬទេ? ឆ.18៖ បាទ ខ្ញុំឮអំពីកងនេះ គឺនៅក្រោម មាស មុត"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង រ៉េត EN 00974081, KH ERN 00926527 ["កងពិសេសគឺជាកងេករាជ្យរបស់កងពល។ [...] ស្មើនឹងកងវរៈសេនាធំដែរ"]។ សូមមើលផងដែរ ឯកសារ D114/187 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.47 ["ស៖ តើនៅពេល ស សាមឿន ទទួលខុសត្រូវនៅអង្គភាព ៤៥០ តើគាត់ទទួលបញ្ជាពី មាស មុត ផ្ទាល់ដែរឬទេ? ឆ.47៖ កង ៤៥០ ជាកងពិសេសកងពល ដូច្នេះអាចទទួលបញ្ជាផ្ទាល់ហើយ។"]។ ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.20-24 ["បាទ វាជាកងតែមួយ គឺកងវរៈ៤៥០ ឬកងពិសេសរបស់កងពល១៦៤។ ស៖ ពីម្សិលមិញលោកបានប្រាប់យើងថា កងវរៈ៤៥០ គឺមិនមែនស្ថិតនៅក្រោមវរៈសេនាធំណាទេ គឺអង្គភាពនេះគឺជាកងពិសេសរបស់កងពល១៦៤តែម្តង តើត្រឹមត្រូវដែរឬទេ? ឆ.21៖ បាទ ត្រឹមត្រូវហើយ"]។ ឯកសារ D114/286 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ.35-38 [ទាហានមកពីកងវរៈសេនាតូច ៤៥០ បានរៀបរាប់ពីការប្រជុំនៅកំពង់សោមក្នុងឆ្នាំ ១៩៧៥ ដែល មាស មុត បានប្រកាសរឿងរ៉ាវមួយចំនួនទៅដល់អ្នកចូលរួមប្រជុំរួមទាំងសមាជិកកងវរៈសេនាតូច ៤៥០]។

1594 ឯកសារ D114/187 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.48, 50 ["[កងវរៈសេនាតូច ៤៥០] គឺកងប្រយុទ្ធ កងទ័ពពិសេសប្រយុទ្ធ។ គេជាអ្នកពិសេសជាងគេ សម្រាប់តែប្រយុទ្ធតែម្តង។ [...] ឆ.50៖ មនុស្សដែលរើសមកកង ៤៥០ ហ្នឹងគឺរើសពីអង្គភាពផ្សេង។ អ្នកគេរើសហ្នឹងគឺដូចថាជាមនុស្សពិសេសជាងគេ។ កងប្រយុទ្ធហ្នឹង គឺគេពូកែខ្លាំង មានស្មារតី។ ដូចថាមានទីតាំងណាដែលតឹងតែង គេប្រើឱ្យទៅប្រយុទ្ធហើយ។ កាលឆ្នាំ ក្រោយថ្ងៃ ១៧ ក៏អ៊ីចឹងកង ៤៥០ ទៅដំបូង ក៏ទៅវៃជាមួយយួន នៅកោះប៉ូឡូវៃ។"]។ ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.22 ["ស៖ តើហេតុអ្វីកងនេះជាកងពិសេសរបស់កងពល? ឆ.22៖ ពីព្រោះចាប់កងវរៈសេនាតូចឡើងទៅលើ ត្រូវតែមានកងពិសេសប្រចាំនៅក្នុងអង្គភាពនីមួយៗ។ ពីព្រោះកងពិសេសនេះ គឺសម្រាប់ប្រើនៅក្នុងកាលៈទាសៈបន្ទាន់ចាំបាច់ និងករណីពិសេសផ្សេងៗក្នុងសមរភូមិ។"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សា

## កងវរសេនាតូចពិសេស ១៦៥/៤៥០ ធ្វើជានីរសារ និងកងការពាររបស់ **មាស មុត**[1596] ធានាសន្តិសុខទាំងនៅទីបញ្ជាការកងពល[1597] ទាំងនៅមន្ទីរសន្តិសុខវត្តឥន្ទ្រញាណនៅកំពង់សោម[1598] និងធ្វើការចាប់ខ្លួន នៅក្នុងដែនអំណាចរបស់ **មាស មុត**[1599]។

---

រ៉ាត់ ឬ ប៊ុន សារ៉ាត់ ឆ.173 ["តាមការរៀបចំ [កងវរៈសេនាតូច ៤៥០] ទទួលខុសត្រូវសម្រាប់អន្តរាគមន៍ ពេលព្រឹត្តិការណ៍យោធា នៅចំណុចមួយណា ដែលវរសេនាធំដទៃមានជួបឧបទ្ទវហេតុ គឺកងនេះ ជួយទាន់ពេលវេលា។"]។ ឯកសារ D54/46 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.27, 32, 35 ["ប្រហែលខែ មីនា ឆ្នាំ ១៩៧៥ គេបានផ្លាស់ខ្ញុំពីកងវរសេនាតូច៤១៥ ដោយបង្កើតជាកងពិសេស កងវរៈសេនាតូច ៤៥០ របស់កងពល៣។ [...] ឆ.32៖ គេហៅកងពិសេស ដោយសារកងនោះជាកងជំនួយ។ នៅពេលដែលកងថ្មើរជើងហ្នឹងត្រូវការជំនួយ កងពិសេសនេះ ជាអ្នកជួយ។ [...] ឆ.35៖ មាស មុត ប្រកាសក្នុងអង្គប្រជុំថា កងពិសេសត្រូវបានបង្កើតឡើង ហើយតែងនៅពីក្រោយកងថ្មើរជើង។"]។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ើ រ៉េត ឆ.28 ["ស៖ តើមាសមុត គាត់ប្រើវរៈសេនាតូច ៤៥០នេះយ៉ាងម៉េច? ឆ.28៖ ក្នុងពេលសង្គ្រាម គាត់តែងបញ្ជូនកងពិសេសនេះទៅសមរភូមិដែលតឹងតែងខ្លាំង។"]។

1595 ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.23-24 ["ក្រោយមកដោយពុំមានការប្រយុទ្ធនៅលើសមរភូមិទៀតទេ កង៤៥០នោះ ត្រូវបានចាត់តាំងឲ្យទទួលខុសត្រូវខាងផ្នែកសន្តិសុខវិញ។ [...] ឆ.24៖ មិនមែនតែកន្លែងវត្តឥណ្ឌញាណហ្នឹងទេ គឺជាកងសន្តិសុខរបស់កងពល១៦៤ នៅក្រុងកំពង់សោមទាំងមូល"]។ ឯកសារ D114/187 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.57-58, 61 ["ខ្លះទៀតត្រូវទៅធ្វើជាកងសន្តិសុខ [...] ឆ.58៖ ពួកគេទទួលខុសត្រូវខាងសន្តិសុខ និងសណ្តាប់ធ្នាប់។ [...] ឆ.61៖ មានអង្គភាព ៤៥០ ដែលនៅសល់ ដែលដឹកនាំដោយ តានន កាន់នៅសន្តិសុខនោះ។"]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.11 ["នៅពេលនោះ ប្រទេសជាតិមានសន្តិភាពហើយ កងពិសេសនេះមិនត្រូវការទៅច្បាំងនៅកន្លែងណាទេ ដូច្នេះកងពិសេសសម្រាប់ការពារថ្នាក់ដឹកនាំកងពលនិងចាប់ចងអ្នកធ្វើខុស។"]។

1596 ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.14, 20 ["កងពិសេស គឺដូចជាកងអង្គរក្សអ៊ីចឹង។ វាគឺជាកងដែលមេគេជឿទុកចិត្ត។ [...] ស៖ សាក្សីដទៃទៀតបាននិយាយប្រាប់យើងថា មាស មុត មានកងការពារផង និងមានកងនីរសារផង យើងមិនយល់ថា តើអាហ្នឹងជាកងតែមួយ ឬយ៉ាងម៉េច? ឆ.20៖ វាជាកងតែមួយ"]។ ឯកសារ D54/103 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.15 ["នៅក្នុងកងពិសេស គឺមានទាំងកងការពាររបស់ មាស មុត ដែលតាមការពារគាត់គ្រប់ទីកន្លែង"]។ ឯកសារ D54/72 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.1, 7 ["ខ្ញុំឃើញតែនីរសារចំនួនតែ២ ទៅ៤នាក់ទេ ដែលនៅជាមួយគាត់ជាប់។ បើគាត់ទៅកន្លែងជិតៗ គាត់យកនាក់បើកឡានម្នាក់ អ្នកការពារម្នាក់ទៅតាម។ បើគាត់ទៅកន្លែងឆ្ងាយៗ គាត់មានអ្នកបើកឡានម្នាក់ អ្នកកាន់វិទ្យុទាក់ទងម្នាក់ ហើយនិងពីរនាក់ទៀតជាអ្នកការពារ និងជានីរសារ។ [...] ឆ.7៖ កងពិសេសគឺដូចជាកងការពាររបស់ មាស មុត អ៊ីចឹងដែរ។ ក្រុមនីរសារគឺជាក្រុមដែលធ្វើការនៅជិត និងជាប់ជាមួយ តា មុត គ្រប់ពេលវេលា។ ប៉ុន្តែកងពិសេស គឺសម្រាប់យាមកាម ហើយនិងយាមប៉ុស្តិ៍ឆែកឆេរនៅជុំវិញមន្ទីរ និងផ្ទះរបស់គាត់។"]។ ឯកសារ D54/101 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ. 10 ["យោធាទាំងនោះ ដែលមកចាប់ [រ៉ែម] គឺមកពីកងពិសេសរបស់ តា មុត។ ពួកនោះគឺដូចជាកងអង្គរក្សរបស់ តា មុត ឬក៏ហៅថាកងដៃស្តាំរបស់គាត់។"]។

1597 ឯកសារ D234/2.1.92 ព្រុំ សារ៉ាត ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ 14.39.40-15.03.11 ["កង៤៥០ ជាកងពិសេសរបស់កងពលប្រចាំជុំវិញកងពល១៦៤ [...] ជាប់ឈ្មោះជាកងពិសេសហ្នឹង ដោយកងហ្នឹងជាកងពិសេសប្រចាំកងពលទី៣"]។ ឯកសារ D54/87 កំណត់ហេតុស្ដាប់ចម្លើយ ព្រុំ សារ៉ាត ឆ.93-95 ["កងវរៈសេនាតូច៤៥០ ឈរជើងនៅជុំវិញកងពល។ [...]ឆ.94៖ ពួកគេជាកងការពារ។ [...]ឆ.95៖ ការពារចម្បងគឺការពារទីបញ្ជាការរបស់កងពល។"]។ ឯកសារ D54/72 កំណត់ហេតុស្ដាប់ចម្លើយ មុត ម៉ៅ ឆ.7 ["កងពិសេស គឺសម្រាប់យាមកាម ហើយនិងយាមប៉ុស្តិ៍ឆែកឆេរនៅជុំវិញមន្ទីរ និងផ្ទះរបស់គាត់។"]។ ឯកសារ D54/7 កំណត់ហេតុស្ដាប់ចម្លើយ ឌុល សុង ឆ. 11 ["កងពិសេសសម្រាប់ការពារថ្នាក់ដឹកនាំកងពលនិងចាប់ចងអ្នកធ្វើខុស។"]។

1598 សូមមើល VIII.C.3. មន្ទីរសន្តិសុខឥន្ទញាណ –ទីកន្លែង ពិពណ៌នាពីទីតាំង និងប្រតិបត្តិការ – រចនាសម្ព័ន្ធអំណាច។

1599 ឯកសារ D54/102 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.14 ["កងពិសេស [...] គឺជាកងដែលមេគេជឿទុកចិត្ត ហើយគេប្រើយោធាក្នុងកងនេះសម្រាប់ចាប់ចងអ្នកក្បត់ ហើយនិងការងារសំខាន់ៗដទៃទៀត។ នៅពេលដែលគេចង់ចាប់កងវរៈសេនាតូច និងកងវរៈសេនាធំ គេប្រើយោធាកងពិសេសទៅហៅពួកគេថា បង [មេបញ្ជាការ] កងពលមកឲ្យប្រជុំ"]។ ឯកសារ D54/103 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.14 ["មានតែយោធារបស់ មាស មុត ទេ ដែលមានកាំភ្លើងកាន់។ ឧទាហរណ៍ មានកងមួយហៅថា កងពិសេស ដែលតែងតែធ្វើការចាប់ចង គឺជាកងរបស់ តាមុត។"]។ ឯកសារ D54/7 កំណត់ហេតុស្ដាប់ចម្លើយ ឌុល សុង ឆ.11 ["កងពិសេសសម្រាប់ការពារថ្នាក់ដឹកនាំកងពលនិងចាប់ចងអ្នកធ្វើខុស។"]។ ឯកសារ D2/16 កំណត់ហេតុស្ដាប់ចម្លើយ ទូច សឿលី ឆ.18-19 ["មនុស្សជាច្រើនត្រូវបានចាប់ ត្រូវបានដកចេញ ដែលធ្វើឲ្យមនុស្សជាច្រើនមានការភ័យខ្លាច។ [...] ឆ.19៖ អ្នក [ដែល] មកចាប់គឺកងសន្តិសុខ៤៥០។ ខ្ញុំមិនដឹងថាការចាប់ចងនោះកើតឡើងដោយរបៀបម៉េចទេ ខ្ញុំគ្រាន់តែដឹងថាការចាប់ចងជាបន្តបន្ទាប់។"]។ ឯកសារ D54/71 កំណត់ហេតុស្ដាប់ចម្លើយ មុត ម៉ៅ ឆ.42-43 ["ស៖ ហេតុអ្វីបានជាលោកស្រីនិយាយថា ពួកយោធាដែលនាំយួននោះមកសម្លាប់ជាពួកកងពិសេស ឬក៏ជាពួកនីរសាររបស់ មាស មុត? ឆ.42៖ គឺមានតែយោធារបស់កងពិសេសទេ ដែលមានភារកិច្ចធ្វើការងារនេះ។ ស៖ ហេតុអ្វីបានជាលោកស្រីដឹង ពួកយោធាទាំងអស់នោះមកពីកងពិសេស? ឆ.43៖ ខ្ញុំបានឮអំពីរឿងនេះតាមរយៈនីរសាររបស់ មាស មុត ដែលធ្វើការនៅមន្ទីរក្នុងជាមួយគ្នា។"]។ ឯកសារ D54/105 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.6 [រៀបរាប់ថាកងពិសេសរបស់ មាស មុត បានធ្វើធ្វើការចាប់ខ្លួនអតីតកម្មាភិបាលកងវរៈសេនាតូច ៣៨៦], ឆ.18 [រៀបរាប់ព្រឹត្តិការណ៍នៅស្ទឹងហាវនៅចុងឆ្នាំ ១៩៧៨ ដែលកងកម្លាំងពិសេសរបស់ មាស មុត បានចាប់ខ្លួនកម្មករបុរសធ្វើផ្លូវរថភ្លើង ហើយបោះចូលក្នុងឡាន]។ ឯកសារ D54/48 កំណត់ហេតុស្ដាប់ចម្លើយ អែម សុន ឆ.52 ["ខ្ញុំចាំនូវព្រឹត្តិការណ៍មួយដែលកូនទាហានរបស់ខ្ញុំមួយចំនួនពីរនាក់ត្រូវបានចាប់ខ្លួនរយៈពេលខ្លីនៅវត្តឥន្ទញាណ។ ពួកគេបានទៅរកជ័រដើម្បីយកបិទទូក ហើយត្រូវបានអ្នកយាមវត្តឥន្ទញាណឃាត់ខ្លួន។"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ KH ERN 00955512 [រៀបរាប់ពីការចាប់ខ្លួនទាហានមួយចំនួនក្នុងកងរបស់គាត់៖ "គេមកដល់យប់ឡើងគេចាប់អស់រលីង។"]។

433. ពេលកងវរសេនាតូចពិសេស ១៦៥/៤៥០ ទៅដល់កំពង់សោម ជាមួយនឹងទាហាននៅសេសសល់នៃកងពលលេខ ៣ នៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥[1600] សា មឿន ជាមេបញ្ជាការ[1601]។ គាត់

[1600] ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.12 ["លុះព្រឹកឡើងថ្ងៃ ១៨ ខែ មេសា [ឆ្នាំ ១៩៧៥] កងវរៈ៤២០ និងកងពិសេសត្រូវបានបញ្ជូនមកកំពង់សោម។ កងវរៈ៤២០ ពេលនោះគេទៅស្នាក់នៅរាម និងកងពិសេសនៅកំពង់សោម។"]។ ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.6 ["១៨ មេសា កងពលលេខ៣ ចូលដល់កំពង់សោម។"]។ សូមមើលផងដែរ ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.1 ["នៅថ្ងៃទី១៨ មេសា ខ្មែរក្រហមបានចូលទៅកាន់កាប់ខេត្តព្រះសីហនុ"]។

[1601] ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ.93 ["ស មឿន គឺជាមេបញ្ជាការវរសេនាតូច៤៥០"]។ ឯកសារ D54/46 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.27 ["ប្រហែលខែ មីនា ឆ្នាំ ១៩៧៥ គេបានផ្លាស់ខ្ញុំ [...] ដោយបង្កើតជាកងពិសេស កងវរៈសេនាតូច ៤៥០ របស់កងពល៣។ ដែលមានប្រធានកងវរៈសេនាតូច៤៥០ ឈ្មោះ មឿន"]។ ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.10 ["នៅពេលដែលខ្ញុំទៅដល់កោះតាងនោះ ខ្ញុំនៅមិនទាន់ទទួលបានដំណឹងពីមេបញ្ជាការ មឿន នៅឡើយទេ។ មឿន គឺត្រូវរបួស"]។ ឯកសារ D114/67 កំណត់ហេតុស្តាប់ចម្លើយ សរ សារិន ឆ.14 ["សរ មឿន គឺជាមេបញ្ជាការវរៈសេនាតូចលេខ៤៥០"]។ ឯកសារ D54/10 កំណត់ហេតុស្តាប់ចម្លើយ ម៉ី រ៉េត ឆ.22, 27 ["ឯឈ្មោះមឿន ពីដើមជាអតីតមេបញ្ជាការកងពិសេសរបស់មាស មុត ហើយនៅក្នុងនោះគាត់ជាមេបញ្ជាការកងវរៈសេនាតូច ១៤១នៃវរៈសេនាធំ ១៤០។ [...] សៈ យោងតាមយល់ដឹងរបស់លោក តើមឿន ធ្លាប់ធ្វើជាមេបញ្ជាការវរៈសេនាតូច ៤៥០នៃកងពល៣ដែរឬទេ? ឆ.27៖ បាទ គាត់ធ្លាប់"]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.8, 13 ["មឿនជាស្នងការកងវរៈសេនាតូចពិសេស [កងពល៣]។ [...] ឆ.13៖ មឿន គឺជាមេបញ្ជាការកងវរៈសេនាតូចពិសេសនេះ"]។ ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.12 ["ពេលនោះមេបញ្ជាការរបស់ខ្ញុំ ស សាមឿន បានត្រូវរបួស ខ្ញុំ [ចាកចេញពីកងពិសេស] ហើយខ្ញុំវិលមកកងចាស់របស់ខ្ញុំវិញគឺវរៈ៤២០។ លុះព្រឹកឡើងថ្ងៃ ១៨ ខែ មេសា [ឆ្នាំ ១៩៧៥] កងវរៈ៤២០ និងកងពិសេសត្រូវបានបញ្ជូនមកកំពង់សោម។ កងវរៈ៤២០ ពេលនោះគេទៅស្នាក់នៅរាម និងកងពិសេសនៅកំពង់សោម។"]។ ឯកសារ D114/187 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.7, 11 ["បាទ ខ្ញុំនៅជាមួយ ស សាមឿន ដែលជាមេបញ្ជាការនៅក្នុងកងពល ៤៥០ ចំណុះឱ្យកងពលធំ ១៦៤ [...] ឆ.11៖ ស សាមឿន គាត់ជាមេបញ្ជាការនៅក្នុងកងវរសេនាតូច ៤៥០"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង រ៉េត EN 00974081, KH ERN 00926527 ["កាលហ្នឹងគ្រប់គ្រងដោយលោកមឿននិងធាន។"]។ ឯកសារ D4.1.751 គ្មានឈ្មោះ កំណត់ហេតុរបស់សហរដ្ឋអាមេរិកស្តីពី POW/MIA ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥ EN 00387258, KH ERN 01519652 ["ប្រភព បម្រើការជាអង្គរក្សរបស់ ((ស)) មឿន ដែលជាមេបញ្ជាការកងវរសេនាតូចទី ៤៥០"]។ ឯកសារ D4.1.745 គ្មានឈ្មោះ កំណត់ហេតុរបស់សហរដ្ឋអាមេរិកស្តីពី POW/MIA, EN 00387261, KH ERN 01513914 ["មឿន មេបញ្ជាការកងវរៈសេនាតូច ៤៥០ ឈរជើងនៅកំពង់សោម"]។

រាយការណ៍ផ្ទាល់ទៅ **មាស មុត**[1602]។ ផាន និងសាក្សី អែម សុន ក៏កាន់តួនាទីជាមេដឹកនាំផងដែរ នៅពេលនោះ[1603]។ នៅខែ សីហា ឆ្នាំ ១៩៧៥ ពេលកងវរសេនាធំ ១៤០ ត្រូវបានបង្កើតឡើង សាមឿន ត្រូវបានផ្ទេរទៅកងទ័ពជើងទឹក (មេបញ្ជាការកងវរសេនាតូច ១៤១)[1604] ហើយ នន គឺជាមេបញ្ជាកងវរសេនាតូចពិសេស[1605] រួចក្លាយជាប្រធានមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ[1606]។ ឈុន

---

1602 ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.94 ["ស មឿន រាយការណ៍ផ្ទាល់ទៅកងពល១៦៤ គឺមាស មុត"]។ ឯកសារ D54/7 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.13 ["មឿនជាស្នងការកងវរៈសេនាតូចពិសេស។ គឺមានឋានៈដូចមេបញ្ជាការកងវរៈសេនាធំដទៃទៀតក្នុងកងពលដែរ។"]។ សូមមើលផងដែរ ឯកសារ D114/187 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.7 ["បាទ ខ្ញុំនៅជាមួយ ស សាមឿន ដែលជាមេបញ្ជាការនៅក្នុងកងពល ៤៥០ ចំណុះឲ្យកងពលធំ ១៦៤"]។

1603 ឯកសារ D54/46 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.27, 35 ["ប្រហែលខែ មីនា ឆ្នាំ ១៩៧៥ គេបានផ្លាស់ខ្ញុំពីកងវរសេនាតូច៤១៥ ដោយបង្កើតជាកងពិសេស កងវរៈសេនាតូច ៤៥០ របស់កងពល៣ [...] ដែលមានប្រធានកងវរៈសេនាតូច៤៥០ ឈ្មោះ មឿន។ ខ្ញុំ និង ផាន ជាសមាជិក [...] ឆ.35៖ នៅពេលនោះ ខ្ញុំទទួលខុសត្រូវអនុសេនាធំទី២។ លោកមឿន ទទួលខុសត្រូវអនុសេនាធំទី១ និងទី៣ សារុន គួក ទទួលខុសត្រូវអនុសេនាធំទី៤ និងទី៥ ផាន ទទួលខុសត្រូវអនុសេនាធំទី ៦ និងទី ៧។ បន្ទាប់ មឿន មានរបួសជើង នៅពេលការប្រយុទ្ធគ្នាដំបូង ខ្ញុំទទួលខុសត្រូវអនុសេនាធំទី១ ទី២ និងទី៣ ដែរ។"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង រ៉េត EN 00974081, KH ERN 00926527 ["កាលហ្នឹងគ្រប់គ្រងដោយលោកមឿននិងផាន។"]។ ឯកសារ D4.1.759 ខែម ងួន កំណត់ហេតុរបស់សហរដ្ឋអាមេរិកស្តីពី POW/MIA, EN 00387265, KH ERN 00658135-36 ["មេបញ្ជាការនៃកងវរសេនាតូចទី ៤៥០ វ៉ាន់នី ហើយមេបញ្ជាការរងគឺ ទៀន"]។ ឯកសារ D4.1.745 គ្មានឈ្មោះ កំណត់ហេតុរបស់សហរដ្ឋអាមេរិកស្តីពី POW/MIA, EN 00387261, KH ERN 01513914 ["មេបញ្ជាការរងនៃកងវរសេនាតូចទី ៤៥០ វ៉ាន់នី និងសមាជិកគណៈកម្មាធិការបញ្ជាការដ្ឋាន ទៀន គឺជាមេបញ្ជាការឈរជើងផ្ទាល់នៅលើកោះនេះ។"]។

1604 ឯកសារ D114/67 កំណត់ហេតុស្តាប់ចម្លើយ សរ សារិន ឆ.14 ["ក្រោយមក [សរ មឿន] បានចូលទៅខាងជើងទឹក ហើយវរៈសេនាតូចរបស់គាត់ គឺលេខ១៤១"]។ ឯកសារ D1.3.30.5 របាយការណ៍លេខាធិការរបស់កម្ពុជាប្រជាធិបតេយ្យ តារាងស្ថិតិសិក្ខាកាម រៀនវគ្គលេខាធិការ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៧៦, KH ERN 00095537 [ឈ្មោះសមមិត្ត ស មឿន គឺជាលេខាកងវរៈសេនាតូច កងពល១៦៤]។ សូមមើលផងដែរ ឯកសារ D114/187 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.45 ["ស៖ តើ ស សាមឿន ទទួលខុសត្រូវកងវរសេនាតូច ៤៥០ រហូតដល់ដាច់របបទេ? ឆ.45 ៖ ទេ យើងចេញទៅរៀនជាមួយគ្នា តាំងឆ្នាំ៧៥"]។

1605 ឯកសារ D114/187 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.45-46, 59 ["សតើ ស សាមឿន ទទួលខុសត្រូវកងវរសេនាតូច ៤៥០ រហូតដល់ដាច់របបទេ? ឆ.45៖ ទេ យើងចេញទៅរៀនជាមួយគ្នា តាំងឆ្នាំ៧៥ ដោយឡែក អង្គភាពតានន នៅតែនៅអង្គភាពហ្នឹងទៀត។ ស៖ តើនរណាជាមេបញ្ជាការអង្គភាព ៤៥០ ពេល ស សាមឿន បានផ្លាស់ទៅកងទ័ពជើងទឹក? ឆ.46៖ តាមគេនិយាយតាមគ្នា [...] បងនន គឺនៅទទួលខុសត្រូវនៅអង្គភាព ៤៥០។ តែមានគ្នានៅ

លន់ ហៅ សំអាត ហៅស៊ុន ជាមេបញ្ជាការរង មួយរយៈពេលខ្លី មុនពេល **មាស មុត** បញ្ជូនគាត់ទៅមន្ទីរ ស-២១ ក្នុងខែ មិថុនា ឆ្នាំ ១៩៧៦[1607]។ សាក្សីបានឃើញ នន ចេញចូលផ្ទះរបស់ **មាស មុត**[1608]។ នៅឆ្នាំ ១៩៧៨ នន ត្រូវបានចាប់ខ្លួន ពីបទរំលោភអ្នកទោសស្រី នៅវត្តឥន្ទញ្ញាណ[1609]។

---

តិច មិនមែននៅច្រើនដូចមុនទេ។ [...] ឆ.59៖ តែយើងចាំឈ្មោះតែ បងនន ដែលជាអ្នកទទួលខុសត្រូវ [...] ឆ.61៖ តែដឹងថា មានអង្គភាព ៤៥០ ដែលនៅសល់ ដែលដឹកនាំដោយ តានន កាន់នៅសន្តិសុខនោះ។"]។ ឯកសារ D54/72 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.10, 16 ["ស៖ តើអ្នកណាជាមេបញ្ជាការកងវរៈសេនាតូចកងពិសេស? ឆ.10៖ ឈ្មោះ នន តែគាត់ស្លាប់ហើយ។ [...] ឆ.16៖ តា នន នៅក្នុងកងពិសេសសម្រាប់ការពារកងពល។ មានប៉ុស្តិ៍យាមហើយនិងផ្ទះមួយដែលស្ថិតនៅច្រកចូលទៅផ្ទះរបស់ តា មុត ដែលជាកន្លែងដែល នន និងយោធារបស់គាត់ស្នាក់នៅ។ ខ្ញុំមិនដែលទៅដល់កន្លែងនោះទេ។ ដូច្នេះខ្ញុំមិនដឹងថាមានយោធាប៉ុន្មាននាក់ទេ។"]។

1606 ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.33 ["តាមខ្ញុំដឹងនៅពេលនោះ តា នន ជាអ្នកទទួលខុសត្រូវក្នុងអង្គភាពសន្តិសុខ [នៅក្នុងឆ្នាំ ១៩៧៧]"]។ សូមមើលផងដែរ ឯកសារ D114/187 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.43-44, 59, 61 ["ស៖ នៅក្នុងការសម្ភាសលើកមុន លោកបាននិយាយថា តានន គឺជាអ្នកទទួលខុសត្រូវនៅមន្ទីរសន្តិសុខឥន្ទញ្ញាណនោះ។ តើត្រឹមត្រូវទេ? តើ តានន ជាទាហាននៅអង្គភាព ៤៥០ ដែរឬទេ? ឆ. 43៖ តានន ជាមនុស្សនៅអង្គភាព ៤៥០ ជាមួយគ្នាពីដើម។ គាត់ជាបញ្ជាការអនុសេនាធំចំណុះឲ្យ ៤៥០ ចាស់។ តែដល់យើងទៅកងទ័ពជើងទឹក គាត់អត់បានទៅកងទ័ពជើងទឹកទេ។ ស៖ តើ ស សាមឿន ជាមេរបស់ តានន ទេ? ឆ.44 ៖ បាទ។ ស៖ តើ ស សាមឿន ទទួលខុសត្រូវកងវរសេនាតូច ៤៥០ រហូតដល់ដាច់របបទេ? ឆ.45៖ ទេ យើងចេញទៅរៀនជាមួយគ្នា តាំងឆ្នាំ៧៥ ដោយឡែក អង្គភាព តានន នៅតែនៅអង្គភាពហ្នឹងទៀត។ ស៖ តើនរណាជាមេបញ្ជាការអង្គភាព ៤៥០ ពេល ស សាមឿន បានផ្លាស់ទៅកងទ័ពជើងទឹក? ឆ.46៖ តាមគេនិយាយតាមគ្នា [...] បងនន គឺនៅទទួលខុសត្រូវនៅអង្គភាព ៤៥០។ តែមានគ្នានៅតិច មិនមែននៅច្រើនដូចមុនទេ។ [...] ឆ.59៖ តែយើងចាំឈ្មោះតែ បង នន ដែលជាអ្នកទទួលខុសត្រូវ។ ហើយ បងនន មិនអាចនៅរហូតដែរ ប្រហែលនៅចុងឆ្នាំ ៧៨ ក៏បាត់ខ្លួនទៀត ដោយឮសូរថាជាប់ពាក់ព័ន្ធការរំលោភអ្នកទោសហ្នឹង។ ប៉ុន្តែរឿងហ្នឹង ខ្ញុំដឹងអត់ច្បាស់ទេ តែខ្ញុំឮថា ដែលពាក់ព័ន្ធការរំលោភអ្នកទោស។ ហើយដែលថាអ្នកទោសហ្នឹង ការពិតអត់មានទោសអីទេ ដល់លែងទៅ ក៏អត់មានទៅណា។ អ្នកទោសហ្នឹងរស់នៅជិតអង្គភាពគេហ្នឹង ពួកគេអត់ទៅណាទេ។ [...] ឆ.61៖ តែដឹងថា មានអង្គភាព ៤៥០ ដែលនៅសល់ ដែលដឹកនាំដោយ តានន កាន់នៅសន្តិសុខនោះ។"]។

1607 ឯកសារ D1.3.14.1 ទូរលេខពី មាស មុត ជម្រាបបង ៨៩ (សុន សេន) ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៧៦ [រាយការណ៍ពីការទទួលបានសំបុត្រពីកងពលផ្ញើមកលេខាកងវរៈសេនាតូច ១៦៥ សំអាត ហៅ សុន និងកម្មាភិបាលឈ្មោះ "ប៊ុននី" ឬ "ស៊ុននី"។]។ ឯកសារ D114/230.1.1 បញ្ជីអ្នកទោស ស-២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត លេខ 450 [ឈ្មុន លុន ហៅ សំអាត មេបញ្ជាការរង –ចូលមកនៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៧៦]។ ឯកសារ D9.3 បញ្ជីការិយាល័យសហចៅក្រមស៊ើបអង្កេតស្តីពី អ្នកទោស ស-២១ ប្រចាំកងពល ១៦៤ [កំណត់លេខ ០៦ ឈ្មោះ ឈុន លន ជាអនុលេខាកងវរៈសេនាតូច ១៦៥]។ ឯកសារ D1.3.3.2 បញ្ជីអ្នកត្រូវសម្លាប់នៅ ស-២១ បញ្ជីឈ្មោះអ្នកទោសដែលត្រូវបានសម្លាប់នៅថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៧៦ KH

434. ពេលការបោសសម្អាតកាន់តែមានសភាពខ្លាំងក្លាឡើង តួនាទីរបស់កងវរសេនាតូច ១៦៥/៤៥០ ក្នុងការចាប់ទាហានកងពល ១៦៤ ក្លាយជាល្បីល្បាញ រហូតដល់ថ្នាក់គ្រាន់តែឃើញសមាជិកកងនេះ និងជាពិសេស នន ម្នាក់ៗខ្លាចគ្រប់គ្នា។ ទូច សឿលី អតីតនីរសាររបស់ សាមឿន បាននិយាយថា "នៅពេលនោះ កាលណាគេឃើញឡានរបស់ តា នន ទៅដល់ទីណា ម្នាក់ៗតែងតែមានការបារម្ភ និងភ័យខ្លាច ពីព្រោះគេមិនដឹងថានឹងមានការចាប់ខ្លួននរណាទៀតទេ[1610]។

---

ERN 00008859 [លេខ 132 ឈ្មោះ ឈុន លុន (ឈ្មោះហៅមើលមិនច្បាស់) ជាសមាជិកកងវរៈសេនាតូចក្នុងកងពល ១៦៤ ចូលមកនៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៧៦ ថ្ងៃស្លាប់៖ ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៧៦ (ស្លាប់ដោយសារជម្ងឺ)]។ ឯកសារ D54/27.2 បញ្ជីអ្នកដែលត្រូវបានចាប់ខ្លួនមកពីកងពល១៦៤ EN 01185462, KH ERN 00955556 [ឈ្មោះ ឈុន លុន ហៅ អាត ជាអនុលេខាកងវរៈសេនាតូច ១៦៥]។

1608 ឯកសារ D54/72 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.10-11, 13, 15-16, 19 ["ស៖ តើអ្នកណាជាមេបញ្ជាការកងវរៈសេនាតូចកងពិសេស? ឆ.10៖ ឈ្មោះ នន តែគាត់ស្លាប់ហើយ។ [...] ឆ.11៖ ខ្ញុំមិនដឹងថា នង ស្លាប់នៅពេលណា និងនៅកន្លែងណាទេ ប៉ុន្តែខ្ញុំឮពីប្តីរបស់ខ្ញុំថា នន ស្លាប់ហើយ។ [...] ឆ.13៖ ខ្ញុំធ្លាប់ឃើញគាត់ចេញចូលផ្ទះ តា មុក។ [...] ឆ.14៖ នន ស្ថិតនៅក្រោមបញ្ជារបស់ តា មុត [...] ឆ.15៖ [ទីបញ្ជាការដ្ឋានរបស់ នន] នៅច្រកចូលផ្ទះរបស់តាមុត។ [...] ឆ.16៖ តា នន គឺស្ថិតក្នុងកងពិសេសសម្រាប់ការពារកងពល។ មានប៉ុស្តិ៍យាម ហើយនិងផ្ទះមួយដែលស្ថិតនៅច្រកចូលទៅផ្ទះរបស់ តា មុត ដែលជាកន្លែងដែល នន និងយោធារបស់គាត់ស្នាក់នៅ។ [...] ឆ.19៖ នន មកជួប មាស មុត គឺនៅពេលមានហេតុការណ៍ម្តងម្កាលកើតឡើង"]។

1609 ឯកសារ D114/187 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.59 ["តែយើងចាំឈ្មោះតែ បង នន ដែលជាអ្នកទទួលខុសត្រូវ។ ហើយ បងនន មិនអាចនៅរហូតដែរ ប្រហែលនៅចុងឆ្នាំ ៧៨ ក៏បាត់ខ្លួនទៀត ដោយឮសូរថាជាប់ពាក់ព័ន្ធការរំលោភអ្នកទោសហ្នឹង។"]។ ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.35, 37 ["រឿងតា នន វាចម្លែកបន្តិច ខ្ញុំមិនបានឃើញដោយផ្ទាល់ភ្នែកទេ ប៉ុន្តែឮគេថា តា នន បានរំលោភផ្លូវភេទទៅលើអ្នកទោសដែលជាស្ត្រី។ ក្រោមពី តា នន បានរំលោភអ្នកទោសរួចហើយគាត់ក៏លែងអ្នកទោសនោះ ក្រោយមកទៀត តា នន ត្រូវបានចាប់ខ្លួន។ [...] ស៖ លោកអាចប្រាប់ឈ្មោះអ្នកទោសស្រីដែល តា នន នោះរំលោភបានដែរឬទេ? ឆ.37៖ អ្នកទោសដែល តា នន រំលោភនោះមានឈ្មោះ រីម។"]។

1610 ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.34 ["នៅពេលនោះ កាលណាគេឃើញឡានរបស់ តា នន ទៅដល់ទីណា ម្នាក់ៗតែងតែមានការបារម្ភ និងភ័យខ្លាច ពីព្រោះគេមិនដឹងថានឹងមានការចាប់ខ្លួននរណាទៀតទេ"]។ សូមមើលផងដែរ ឯកសារ D114/187 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.61, 106-107 ["មានអង្គភាព ៤៥០ ដែលនៅសល់ ដែលដឹកនាំដោយ តានន កាន់នៅសន្តិសុខនោះ។ [...] ឆ.106៖ ក្នុងឆ្នាំ ១៩៧៧ បើកាលណាមានឃើញអង្គភាពហ្នឹង ទៅកន្លែងណាគឺមានការព្រួយបារម្ភថានឹងមានបញ្ហាកើតឡើងនៅកន្លែងហ្នឹង [...] ឆ.107៖ យើងគ្រាន់តែដឹងថា ក្នុងឆ្នាំ ១៩៧៧ ហ្នឹង អង្គភាព ៤៥០ ហ្នឹងគឺជាកង ជាក្រុមសន្តិសុខ។ ដូច្នេះបើកាលណាឃើញគេទៅកន្លែងណា ច្បាស់ជាមានបញ្ហានៅកន្លែងហ្នឹងហើយ។"]។

435. កម្មាភិបាលជាច្រើននៃកងពល ១៦៤ ត្រូវបានចាប់ខ្លួនដោយមេបញ្ជាការអង្គភាពរបស់ពួកគេ[1611]។ កម្មាភិបាលរំសាយ ដែលធ្វើការនៅការដ្ឋានណាមួយនៅកំពង់សោម ជារឿយៗ ត្រូវបានចាប់ដោយអតីតសមមិត្តរបស់ខ្លួន ដែលពេលនោះ នៅជា "កម្មាភិបាលសកម្ម"[1612] នៅឡើយ និងមានអ្នកកាន់កាំភ្លើងចាំយាម[1613]។

436. ជាទូទៅ ជនស៊ីវិលត្រូវបានចាប់ដោយទាហានកងពល ១៦៤[1614] ឬប្រធានសហករណ៍[1615]។

437. ចំពោះការចាប់នៅលើសមុទ្រ នាវារបស់កងវរសេនាធំលេខ ៦១, ៦២ និង ៦៣ ត្រូវបានណែនាំឲ្យចាប់ទូកតូចៗដែលចូលក្នុងដែនទឹកកម្ពុជាកងវរសេនាធំ[1616]។ នាវាប៉េសេអេហ្វបំពាក់អាវុធរបស់

---

[1611] ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា ឆ.19 ["ចំពោះយោធា គឺមេអង្គភាពជាអ្នកចាប់។"]។ ឯកសារ D54/27 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.6 [រៀបរាប់ការឃុំខ្លួនទាហាន០៣នាក់ដោយមេបញ្ជាការកងវរៈសេនាធំរបស់ពួកគេ មុននឹងពួកគេត្រូវបានបញ្ជូនទៅទឹកសាប]។

[1612] ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.173 ["ស៖ ទាហានតំបន់៣៥ យាមតំបន់ទាំងបីនោះឬ? ឆ.173៖បាទ។"]។ ឯកសារ D114/135 កំណត់ហេតុស្តាប់ចម្លើយ ណុប ផន ឆ.30 ["បាទ មានគេយាម និងត្រួតពិនិត្យ ថាតើយើងបានធ្វើការងាររបស់យើងដែរឬទេ។"]។ សូមមើលផងដែរ ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ន សុត ឆ.64 ["មេៗគេដើរពិនិត្យមើលយើងធ្វើការតែនៅលើភ្លឺស្រែទេ។"]។

[1613] ឯកសារ D54/89 Kuy Nen កំណត់ហេតុស្តាប់ចម្លើយ ឆ.25។

[1614] ឯកសារ D54/114 កំណត់ហេតុស្តាប់ចម្លើយ ហែម សម្បត្តិ ឆ.47 ["ជាទ័ព [ដែលនាំពួកគេទៅ]។ មួយគ្រួសារនោះត្រូវគេផ្លាស់ទៅនៅសហករណ៍ថ្មីនៅជិតទឹកសាប។ ពេលពួកគេ [ទាហាន] មកដល់ ខ្ញុំភ័យញាក់ព្រោះថានៅសម័យនោះពេលដែលយើងឃើញកងទ័ពខ្មែរក្រហមមកហើយ យើងដឹងថាហ្នឹងមានរឿងរ៉ាវហើយ។"]។ ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.43 ["បាទ ខ្ញុំចង់និយាយបន្ថែមថា នៅកន្លែងការដ្ឋានលើកទំនប់និងប្រឡាយនោះ ពួកយោធាតែងតែចាប់យកមនុស្ស២ឬ៣នាក់នាំយកទៅ ជួនកាល៣ ឬ៤ថ្ងៃម្តង។ គ្មានអ្នកណាម្នាក់ដឹងពីមូលហេតុនៃការចាប់ចងនោះទេ។ មនុស្សគ្រប់ៗគ្នាមានការភ័យខ្លាចយ៉ាងខ្លាំងចំពោះស្ថានភាពបែបនេះ។ ពួកយោធាមកចាប់មនុស្សទាំងកណ្តាលថ្ងៃ"]។ សូមមើលផងដែរ ឯកសារ D59/1/4.25 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡុង លី KH ERN 00930813 [ប្រធានសហករណ៍រៀបរាប់ពីរបាយការណ៍កំហុស៖ "យើងរាការណ៍មកបើយើងឃើញពីណាខុសឆ្គង យើងរាយការណ៍ទៅ [ប្រធាន] ហើយគេហៅប្រជុំកសាង"]។

[1615] ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹង ណុច ឆ.132 ["គេមានសំបុត្រទៅឲ្យមេសហករណ៍ បន្ទាប់មកមេសហករណ៍បានប្រាប់សមាជិកសហករណ៍ថា ឯងត្រូវទៅតាមឪពុកម្តាយអ្នកឯងនៅខាងក្រោយ។"]។

[1616] ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.6, 17 ["វរសេនាធំលេខ៦១ ក្រោម តា ជន ប្រតិបត្តិការនៅកោះរ៉ុង និងកោះព្រីង កោះម្នាស់ និងកោះរ៉ុងក្រៅ។ កងវរសេនាធំលេខ៦២ ក្រោមតា យាង ប្រតិបត្តិការនៅ កោះតាងកោះពូលែ្វចាស់ និងពូលែ្វថ្មី។ វរសេនាធំលេខ៦៣ ក្រោមតា ញ៉ាន់ ប្រតិបត្តិការនៅកោះសេះ កោះអន្លាយ កោះខ្យង។

កងវរសេនាធំ ១៤០ ដែលជានាវាការពារ និងប្រដេញ ចតនៅកំពង់សោម កោះពូលូវៃ ឬកោះតាង ហើយក៏មានភារកិច្ចចាប់ទូកបរទេសផងដែរ[1617]។ ក្នុងឋានៈជាមេបញ្ជាការកងពល ១៦៤ និងជា

គេអត់មានកប៉ាល់ចម្បាំងទេ ប៉ុន្តែគេមានកាណូតដឹកជញ្ជូនរបស់គេ។ កងទ័ពទាំងនោះធ្វើការចាប់ចងមនុស្សណាដែលឆ្លងចូលដល់ដែនទឹកកម្ពុជាក្នុងតំបន់ប្រតិបត្តិការរបស់គេ។ […] ឆ.17៖ […] កងវរសេនាធំលេខ៦២របស់ខ្ញុំនេះ ក៏ធ្លាប់ចាប់បានកាណូត និងមនុស្សផ្សេងៗទៀតដែរ។ ខ្ញុំធ្លាប់ឃើញកាណូតដែលពួកកងរបស់ខ្ញុំចាប់បាន ហើយយកមកទុកនៅកោះតាង"]។ ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល់ ឆ.3 ["កងវរៈសេនាធំ៦២ត្រួតពិនិត្យមលើកិច្ចសហការរវាងអង្គភាពផ្សេងៗ ដែលចូលរួមនៅក្នុងការចាប់ទូកនោះ ត្រួតពិនិត្យចំនួនមនុស្សនៅលើទូក ចំណុះរបស់ទូក និងសម្ភារៈផ្សេងៗទៀតនៅលើទូក។ […] តាមការសម្គាល់របស់ខ្ញុំ កងវរៈសេនាធំ៦២ គេពិនិត្យទូក និងមនុស្សដែលបានចាប់ និងបញ្ជូនទៅកំពង់សោមជាមួយនឹងរបាយការណ៍"]។ ឯកសារ D114/105 កំណត់ហេតុស្តាប់ចម្លើយ កុច ទុយ ឆ.48, ឆ.53 ["ពេលនោះពួកយើងផ្លាស់ចល័តទៅតាមយាម រហូតដល់យាមទី៣ ប្រហែលជាម៉ោងប្រាំបី ឬប្រាំបួនយប់នៅពេលដែលកប៉ាល់ខ្ញុំទៅដល់បានឃើញទូកឈើថៃនោះតាមរយៈរ៉ាដា។ ពួកខ្ញុំក៏ចេញកប៉ាល់ទៅនិងបានចាប់ទូកនោះ ដោយបញ្ជូនមនុស្សទៅកំពង់សោម និងទូកឈើមកកោះតាំងដោយយកត្រីពីលើទូក និងឥវ៉ាន់ចេញ ដោមចំណាយបី ឬបួនថ្ងៃ និងយកទូកនោះទៅកងពលលេខ ៤ នៅកំពង់សោមតែម្តង។ មនុស្សលើទូកមានច្រើននាក់ តែខ្ញុំមិនចាំចំនួនប៉ុន្មានទេ។ […] ឆ.53៖ ជាធម្មតាប្រសិនពួកគេតដៃ ពួកយើងនឹងបាញ់។ ប៉ុន្តែក្នុងករណីនេះ ពួកគេមិនបានធ្វើអ្វីទេ ដូច្នេះពួកខ្ញុំក៏បានបើកកប៉ាល់អែបនឹងទូក និងបានលោតចូលទូក ហើយបានប្រាប់ពួកគេឲ្យលើកអួនឡើង យកត្រីទៅដាក់នៅកន្លែងស្តុបត្រីដាក់ទឹកកកអីត្រឹមត្រូវ និងឲ្យមនុស្សនៅមួយឡែក។ រួចហើយ ទើបគេបើកកប៉ាល់នោះមកកំពង់សោមដាក់ពួកថៃទាំងនោះចុះ ហើយពួកខ្ញុំបានយកទូករបស់គេទៅកោះតាំងវិញ"]។ ឯកសារ D59/1/1.8a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រំ សារ៉ាត់ EN 00974211, KH ERN 00926389 ["តាមការដែលខ្ញុំដឹង ជនជាតិខ្លីងនឹងត្រូវគេចាប់ […] ស៖ កាលនឹងយើងចូលមកកោះណា យើងចាប់បាននៅកោះ? ឆ៖ ប៉ូឡូវៃ […] ពួអ្នក កាណូតពួអ្នក ចាប់បានហើយក៏"], EN 00974208, KH ERN 00926386 ["អ្នកដែលគេចាត់តាំងឲ្យទៅការពារកោះនោះចាប់ពួកគេ"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ.28 ["នៅពេលកងពលលេខ៣ ប្តូរទៅកងពល១៦៤ នៅកំពង់សោម មាន មាស មុត ជាមេបញ្ជាការ។ ហើយមេបញ្ជាការរងត្រូវបានផ្លាស់ប្តូរជាបន្តបន្ទាប់ ដែលរួមមាន តារិន, តាឆាន និងតាឌឹម។ កងពល ១៦៤ រួមមានកងវរសេនាធំ ៦១,៦២,៦៣ និង ១៤០។ កងវរសេនាធំ៦១,៦២ និង៦៣ មានភារកិច្ចការពារតាមឆ្នេរសមុទ្រ និងកោះ។ កងវរសេនាធំ ១៤០ គ្រប់គ្រងនាវាទាំងអស់។"]។

1617 ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល់ ឆ.3 ["ក្រោយមក កងពលធំ១៦៤ បញ្ជូននាវា PCF របស់កងវរៈសេនាធំ១៤០ [ទៅចាប់ទូក] ដែលជួនកាលស្ថិតនៅកំពង់សោម និងនៅទីតាំងប្រចាំការ។ ជាទូទៅ នាវាPCF របស់កងវរៈសេនាធំ១៤០ ប្រចាំការនៅកោះពូលូវៃថ្មី ឬកោះតាង។"]។ ឯកសារ D2/16 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.27 ["ស៖ នៅក្នុងកងពល១៦៤ តើនរណាដែលពាក់ព័ន្ធ និងទទួលខុសត្រូវក្នុងការចាប់ចងពួកនេសាទ? ឆ.27៖ អ្នកដែលទទួលខុសត្រូវ គឺពួក PCF។"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.15 ["យោធាកងវរៈសេនាធំ១៤០ ត្រូវបានចាត់តាំងការពារកោះនិងព្រំដែនទឹក។"]។ ឯកសារ D54/109

មេបញ្ជាការកងទ័ពជើងទឹក **មាស មុត** ជាអ្នកសម្រេចអំពីជោគវាសនារបស់នាវិក និងអ្នកដំណើរ ដែលចាប់បាន អាស្រ័យតាមករណី[1618]។ ប្រសិនបើគាត់អវត្តមាន អនុរបស់គាត់ម្នាក់ឡើងជំនួស

---

កំណត់ហេតុស្តាប់ចម្លើយ សៅ សំ ឆ.11, 14 [“ស៖ អំឡុងពេលដែលលោកនៅលើកោះពូលូវៃ្ល តើលោកមានឃើញគេចាប់បានពួកវៀតណាមយកទៅដាក់នៅលើកោះនោះដែរឬទេ? ឆ.11៖ នៅពេលដែលលោកនៅលើកោះពូលូវៃ្ល ភារកិច្ចរបស់ពួកខ្ញុំគឺសម្រាប់តែយាម។ យើងមិនមានកប៉ាល់សម្រាប់ច្បាំងប្រយុទ្ធទេ យើងមានតែទូកធម្មតាសម្រាប់នេសាទ។ នៅពេលណាដែលយើងឃើញទូក វៀតណាម ថៃ ឬក៏ទូកបរទេសណាផ្សេងទៀតចូលមកដែនទឹកយើង យើងរាយការណ៍តាមវិទ្យុទាក់ទងទៅឱ្យមូលដ្ឋានកងពល១៦៤នៅកំពង់សោម។ ខាងកងពល គេនឹងចេញកប៉ាល់របស់គេដែលជាកប៉ាល់បោសសម្អាតមីន ដែលមានល្បឿនលឿនឱ្យទៅតាមចាប់ទូក ឬកប៉ាល់នោះ។ [...] ឆ.14៖ បន្ទាប់ពីយើងរាយការណ៍តាមវិទ្យុទាក់ទងឱ្យមូលដ្ឋានកងពល១៦៤ កងពលហ្នឹងគេចេញទៅចាប់ទូកហ្នឹងដោយខ្លួនឯង។ យើងអាចឃើញពួកគេយកទូកនោះ ហើយនាំមកក្រោយ តាមរយៈកែវពង្រីករបស់យើង។”]។ ឯកសារ D2/10 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.1, ឆ.29-ឆ.31 [“ភារកិច្ចចម្បងរបស់ [នាវាប្រដេញនេះ] តាមការណែនាំរបស់ថ្នាក់លើនៅពេលមានការប្រយុទ្ធ [...] ឆ.29៖ កងនាវាប្រដេញ គឺមិនរាយទៅគ្រប់កន្លែងអ៊ីចឹងទេ គឺរង់ចាំតែបញ្ជាប្រយុទ្ធ។ ស៖ តើកងនាវាហ្នឹងអាចចេញធ្វើការប្រយុទ្ធដោយខ្លួនឯងបានឬទេ ឬក៏ទាល់តែមានការទទួលបញ្ជាសម្រាប់ធ្វើអ្វីមួយ? ឆ.30៖ ទេ។ មិនមានសិទ្ធិសម្រាប់រើពីមួយកន្លែងទៅមួយកន្លែងទេ។ ត្រូវតែមានបញ្ជាសិនក្នុងការរើពីកន្លែងមួយទៅកន្លែងមួយ។ សូម្បីតែត្រូវទៅបោះយុត្កការនៅកន្លែងណាមួយក៏ត្រូវតែមានបញ្ជាឱ្យធ្វើតាមដែរ។ ប្រធានវានាទីមួយៗមិនអាចធ្វើអ្វីដោយខ្លួនឯងបានដោយគ្មានបញ្ជានោះទេ។ ការចេញបញ្ជាគឺចេញពីប្រធានកងនាវាមិនមែនចេញមកពីកងពលទេ។ ស៖ ប្រសិនជាកងនាវាត្រូវបានដាក់ពង្រាយនៅហ្នឹងព្រំដែនក្នុងសមុទ្រ រួចហើយបានឃើញនាវាបរទេសដែលរំលោភលើព្រំដែនរបស់ខ្លួន តើកងនាវាលោកធ្វើយ៉ាងដូចម្តេច? ឆ.31៖ សូម្បីតែយើងឃើញនាវាបរទេសរំលោភចូលក្នុងដែនយើងក្តី ក៏យើងមិនធ្វើអ្វីតបភ្លាមដែរ ប៉ុន្តែត្រូវការរាយការណ៍ភ្លាមទៅអង្គការផ្នែកខាងលើ ហើយរង់ចាំបញ្ជាថ្នាក់លើត្រឡប់ទៅវិញ ថាតើត្រូវធ្វើយ៉ាងម៉េចជាមួយនាវានោះ។ វាមិនមែនជាភារកិច្ចយើងសម្រាប់ចាប់ចងនាវាទូទៅទេ យើងចាំតែប្រយុទ្ធជាមួយនឹងនាវាចម្បាំងប៉ុណ្ណោះ។ សម្រាប់ការចាប់ចងនាវាផ្សេងៗវាជាភារៈកិច្ចរបស់កងមួយទៀតដែលគេមានជាទូកឈើសម្រាប់ដើរចាប់ចង។”]។ ឯកសារ D1.3.34.64 ការនិយាយទូរស័ព្ទសំងាត់ពី មាស មុត ជូនបង ៨៩ (សុន សេន) ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨, EN 00233649, KH ERN 00020982, FR 00623220 [“នៅកោះវៃ ព្រឹកឡើងថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ នៅម៉ោង ០៤ ព្រឹក បងប្អូនឃើញកាណូត សៀម ១ គ្រឿង (២៥០ សេស) ចំងាយ ៣ គ.ម នៅខាងលិចឈៀងខាងជើងកោះវៃ។ យើងចាប់បាននៅម៉ោង ០៥ភ្លឺ មានមនុស្ស២១នាក់ [...] នៅកោះវៃ នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៨ វេលាម៉ោង ២.៣០ នាទីកាណូត៨០០សេសរបស់យើងចាប់បានកាណូតយួន២គ្រឿង ពេញដោយយួន៧៦នាក់ មានក្មេង ចាស់ ប្រុស ស្រី។”]។

1618 ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.2-3 [“គេប្រើភាសាសាមញ្ញធម្មតានៅពេលបញ្ជា ឧទាហរណ៍គេនិយាយថា “បាញ់ពួកហ្នឹងចោលទៅ ឬក៏បញ្ជូនពួកហ្នឹងមកដីគោក។” ស៖ ហេតុអ្វីបានជាលោកនិយាយនៅក្នុងកិច្ចសម្ភាសជាមួយ [មជ្ឈមណ្ឌលឯកសារកម្ពុជា] ថា ការបញ្ជាឱ្យសម្លាប់ គឺជាទូទៅ គឺចេញមកពីតាមុត? ឆ.3៖ តាមការយល់ដឹងរបស់ខ្ញុំ នេះគឺជារបៀបរបបការងារទូទៅរបស់កងពល។”]។ ឯកសារ D1.3.33.4

គាត់[1619]។ សេចក្ដីសម្រេចរបស់ **មាស មុត** ត្រូវបញ្ជូនភ្លាមៗទៅថ្នាក់ក្រោម តាមខ្សែសង្វាក់បញ្ជាទៅកាន់កងវរសេនាតូច កងអនុសេនាធំ ឬអង្គភាពពាក់ព័ន្ធ[1620]។

## កង្វះដំណើរការក្ដីតាមផ្លូវច្បាប់

438. យុទ្ធជនម្នាក់នៃកងពល ១៦៤ បានរៀបរាប់ថាជា "សម័យកាលផ្ដាច់ការ"[1621] គឺគ្មានតុលាការ គ្មានក្រមព្រហ្មទណ្ឌ និងគ្មានការកាត់សេចក្ដីតាមផ្លូវច្បាប់ ក្នុងពេល **មាស មុត** គ្រប់គ្រងតំបន់ស្វយ័ត

---

កំណត់ហេតុស្ដាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅឌុច EN 00198221, KH ERN 00197971 ["ខ្ញុំដឹងថាគឺកងពល ១៦៤ ដែលដឹកនាំដោយមាសមុត ជាអ្នកចាប់ខ្លួន"]។ ឯកសារ D54/79 កំណត់ហេតុស្ដាប់ចម្លើយ ណុប ហាល់ ឆ.3, 26 ["កងវរៈសេនាតូចរាយការណ៍ទៅកងពលធំអំពីទូកដែលចូលមកឈ្លានពាន ហើយជាទូទៅកងវរៈសេនាធំរាយការណ៍ទៅកងពលធំដែលមានទីតាំងនៅកំពង់សោម។ [...] ឆ.26៖ ដូចខ្ញុំបានរៀបរាប់កន្លងមក វរៈសេនាតូចដែលប្រចាំការរាយការណ៍ទៅថានទុក្រមថ្នាក់លើ នូវអ្វីដែលគេបានឃើញចូលក្នុងទឹកដីកម្ពុជា។ តាមុត គឺជាមេកងពល ហើយគាត់ និង តាសេង ជាអ្នកកាន់កងពល។ តាមុត ជាថានទុក្រមថ្នាក់លើ និងកាន់កងពលយូរមកហើយ។"]។

1619 ឯកសារ D54/25 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.4 ["ស៖ ក្រៅពីតា មុត តើមានអ្នកផ្សេងទៀតអាចចេញបញ្ជាឲ្យចាប់ ឬសម្លាប់ដែរឬទេ? ឆ.4៖ បើតា មុត អវត្តមានគឺមាន តា សេង ហើយបើតា សេង អវត្តមានទៀតគឺមាន តា សាវឿន។"]។

1620 ឯកសារ D54/23 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.25 ["រួចហើយទើបកងពលបញ្ជាតាមខ្សែរយៈត្រឡប់ចុះមកវិញ ថាតើយើងគួរធ្វើយ៉ាងម៉េចជាមួយទូក កប៉ាល់ ហើយនិងមនុស្សដែលយើងចាប់បាន។ ពេលនោះ កងវរសេនាតូចនឹងបញ្ជាមកយើង ថាតើយើងគួរសម្លាប់អ្នកដែលយើងចាប់នោះនៅសមុទ្រតែម្ដង ឬយកឡើងមកកោះ។ បើសិនជាយើងចាប់បានទូកយួន ពេលខ្លះយើងទទួលបញ្ជាឲ្យបាញ់សម្លាប់ចោលនៅនឹងកន្លែង ហើយយកតែទូកមកកោះតែម្ដង"]។ ឯកសារ D54/25 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.1, 19 ["ស៖ ជាទូទៅនៅពេលដែលកងនាវីកនៅលើនាវាទទួលបញ្ជាឲ្យសម្លាប់ ឬមួយក៏បញ្ជូនពួកអ្នកដែលចាប់បាន តើបញ្ជានោះធ្វើដោយផ្ទាល់មាត់តាមវិទ្យុទាក់ទង ឬក៏តាមម៉ាស៊ីនម៉ស? ឆ.1៖ បញ្ជាគឺតាមការនិយាយផ្ទាល់មាត់តាមរយៈវិទ្យុទាក់ទង [...] ឆ.19៖ ព្រឹត្តិការណ៍អ្វីដែលកើតឡើងត្រូវរាយការណ៍ទៅឲ្យកងវរសេនាតូច ហើយកងវរសេនាតូចរាយការណ៍ទៅមេបញ្ជាការកងវរសេនាធំ ហើយកងវរសេនាធំរាយការណ៍ទៅបញ្ជាការកងពល។ បន្ទាប់មកមេបញ្ជាការកងពលធ្វើសេចក្ដីសម្រេច ហើយដាក់បញ្ជូនចុះមកវិញតាមជាន់ថ្នាក់ទាំងនេះមកវិញ។"]។ ឯកសារ D114/186 កំណត់ហេតុស្ដាប់ចម្លើយ សាត ចក់ ឆ.109 ["អង្គភាពមួយដូចថាមានអ្នកណាជាមេអ៊ីចឹងទៅ ពេលដែលគេទៅទទួលព័ត៌មាន ឬផែនការពីមេធំៗ ពេលត្រឡប់មកវិញ គេហៅសមាជិកក្នុងអង្គភាពមកប្រជុំដើម្បីផ្សព្វផ្សាយ"]។ ពេលខ្លះ ក្នុងករណីបន្ទាន់ បញ្ជាត្រូវចេញផ្ទាល់មកពីទីបញ្ជាការកងពលទៅដល់នាវាចម្បាំងដែលពាក់ព័ន្ធដោយមិនឆ្លងកាត់កងវរៈសេនាធំ ១៤០ និងកងវរៈសេនាតូចដែលជាប់ពាក់ព័ន្ធទេ៖ ឯកសារ D54/100 កំណត់ហេតុស្ដាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.142 ["ពេលនាវាទៅដល់កណ្ដាលសមុទ្រហើយជួបប្រទះហេតុការណ៍ប្រយុទ្ធ គេទាក់ទងមកកងវរសេនាធំ ហើយកងវរសេនាធំទាក់ទងមកកងពល ហើយកងពលចេញបញ្ជាផ្ទាល់តែម្ដង ដោយមិនឆ្លងកាត់កងវរសេនាធំទៀតទេ ដើម្បីឲ្យការងាររហ័ស។"]។

កំពង់សោម[1622]។ គ្មានស្ថាប័នច្បាប់ នីតិវិធីច្បាប់ ឬការការពារ នៅកន្លែងណាមួយឡើយ ក្នុងរបប កម្ពុជាប្រជាធិបតេយ្យ[1623]។ គ្មានការអនុញ្ញាតតាមផ្លូវតុលាការ ឬការពិនិត្យមើលឡើងវិញនូវការ

---

1621 ឯកសារ D114/126 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គីម ឆ.26 ["បើសិនជាយើងរអ៊ូរទាំតវ៉ាថាយើងហូបមិនឆ្អែត ឬធ្វើការងារច្រើននោះ គេនឹងចោទយើងថាប្រឆាំងនឹងបក្ស។ កាលនោះគឺជាសម័យផ្តាច់ការ បើគេឲ្យទៅឆ្វេង យើងត្រូវតែទៅឆ្វេង បើគេឲ្យទៅស្តាំ យើងត្រូវតែទៅស្តាំ យើងមិនអាចសួរនាំ ឬឆ្លល់បានឡើយ។"]។

1622 ឯកសារ D114/20 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.1 ["ស៖ តើមានប្រព័ន្ធតុលាករយោធា ឬតុលាការសឹក នៅក្នុងកងពល១៦៤ សម្រាប់កាត់ទោសយោធាណាដែលបានធ្វើខុសដែរឬទេ? ឆ.1៖ ទេ មិនមានតុលាការបែបនោះទេ"]។ ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា ឆ.17, 20 ["ស៖ អំឡុងពេលដែលលោកធ្វើការក្នុងអង្គភាពយោធា និងជើងទឹកនៅកំពង់សោម នៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ តើលោកដែលសង្កេតឃើញមានតុលាការ ឬអាជ្ញាធរដែលគេបង្កើតឡើង ដើម្បីកាត់ទោស រកយុត្តិធម៌ និងដោះស្រាយបញ្ហាឲ្យប្រជាជនដែរឬទេ? ឆ. 17៖ ទេ មិនមានទេ។ កាលនោះ ទាំងប្រជាជនធម្មតា និងយោធា ត្រូវបានចាប់ខ្លួន យកទៅដាក់គុក ហើយខ្លះទៀតត្រូវបានយកទៅសម្លាប់ចោលតែម្តង។ ឲ្យតែចាប់ខ្លួន គឺដឹងតែយកទៅសម្លាប់ហើយ ពុំមានដោះស្រាយ ឬចរចាអ្វីទេ។ [...] ស៖ តើមានស្ថាប័ន ឬអង្គភាពណាមួយដែលប្រជាជនអាចតវ៉ា ឬប្តឹងផ្តល់អំពីការចាប់ខ្លួនដែរឬទេ? ឆ.20៖ ទេ មិនមានទេ"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.48-49, 180-181 [(យុទ្ធជនកងវរៈសេនាតូច ៣៨៦ (អតីតតំបន់៣៧)) "អ្នកនេសាទទាំងអស់នោះត្រូវបានបញ្ជូនតាមទូក មកផែនៅលើកោះ ហើយបណ្តើរទៅទីបះញ្ជាការកងវរៈសេនាធំ ហើយបញ្ចប់នៅទីនោះតែម្តង។ ទីនោះ គឺជាតុលាការតែម្តង។ ស៖ តើលោកដឹងថា បន្ទាប់ពីបញ្ជូនទៅទីបញ្ជាការកងវរៈសេនាធំរួចហើយ គេយកអ្នកនេសាទទាំងអស់នោះទៅទីណាដែរ? ឆ.49៖ ពួកគេត្រូវបាននាំខ្លួនយកទៅកន្លែងផ្សេងៗដើម្បីសម្លាប់ចោល។ [...] ឆ.180៖ ពុំមានតុលាការពិតប្រាកដទេ គឺប្រធានវរៈនោះឯងដែលជាចៅក្រម និងជាតុលាការ។ ស៖ តើមានសាលាក្តី មានចៅក្រម មេធាវី និងច្បាប់ ដែរឬទេនៅក្នុងសម័យនោះ? ឆ.181៖ ទេ អត់មានទេ។"]។ ឯកសារ D114/85 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.32-33 ["ពួកគេមិនបាននិយាយអំពីប្រព័ន្ធតុលាការ ពីចៅក្រម ឬការចោទប្រកាន់ជាផ្លូវការពីប្រព័ន្ធតុលាការណាមួយរបស់ពួកគាត់ទេ។ គេគ្រាន់តែនិយាយថា ចំពោះជនក្បត់ អង្គការត្រូវតែ [កម្ទេចចោល]។ ស៖ តើនរណាជាអ្នកនិយាយបែបនេះ? ឆ៖ មាស មុត"]។ ឯកសារ D114/126 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គីម ឆ.27 ["ស៖ តើមានប្រព័ន្ធតុលាការដែរឬទេ នៅសម័យខ្មែរក្រហម ដែលបុគ្គលណាម្នាក់អាចប្តឹងតវ៉ាអំពីការប្រព្រឹត្តមកលើខ្លួន? ឆ.27៖ ពួកយើងអត់មានសិទ្ធិអ្វីទាំងអស់។ យើងមិនអាចយកបញ្ហារបស់យើងទៅប្រាប់អ្នកណាម្នាក់ ហើយទៅប្តឹងកន្លែងណាបាននោះទេ។"]។ ឯកសារ D114/58 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ហៅ កេត ឆ.11 ["ខ្ញុំមិនដឹងថាមានប្រព័ន្ធតុលាការអ្វីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ ខ្ញុំគ្រាន់តែដឹងថាមនុស្សទាំងនោះត្រូវបានចាប់ខ្លួន [...] ខ្ញុំមិនធ្លាប់ឃើញ ឬឮពីប្រព័ន្ធតុលាការអ្វីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើង។"]។ ឯកសារ D54/122 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.11-12 [(ជនស៊ីវិលនៅរាម) "ស៖ តើនរណាជាអ្នកកាត់សេចក្តី ឬដាក់ទោសដល់ប្រជាជន នៅកន្លែងដែលលោករស់នៅ នូវទង្វើខុសឆ្គង? ឆ.11៖ កាលនោះ ពិបាកពន្យល់ណាស់ ព្រោះពុំមានចៅក្រមទេ គឺមានតែយោធា។ ខ្ញុំសង្កេតឃើញថាមានមនុស្សបាត់ខ្លួន ហើយមិនឃើញត្រឡប់មកវិញទេ [...] ឆ.12៖ ខ្ញុំឃើញតែយោធា មិនឃើញមាន

ចៅក្រមទេ។ ពួកយើងខ្លាចពួកគេខ្លាំងណាស់។ បើសិនជាមានអ្នកណាលួចអ្វីម្យ៉ាង ឬទៅដណ្តើមគេហូប អ្នកនោះនឹងបាត់ខ្លួនហើយ។ កាលនោះ គឺពួកគេធ្វើតាមតែចិត្ត ពោលគឺពួកយោធាធ្វើអ្វីតាមតែគេចង់។ ពុំមានអ្នកណាម្នាក់កាត់សេចក្តី ឬក៏សាកសួរអំពីសកម្មភាពរបស់យោធាទាំងនោះទេ។"]។ ឯកសារ D114/48 កំណត់ហេតុស្តាប់ចម្លើយ សុក ង៉ុន ឆ.26 ["ស៖ តើមានតុលាការនៅកំពង់សោមដែរឬទេ នៅសម័យនោះ? ឆ.26៖ ទេ មិនមានទេ"]។ ឯកសារ D114/116 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.44-45 ["មានមនុស្សជាច្រើនមកពីតាមកងវរសេនាតូចផ្សេងៗ ដែលក្នុងនោះរួមទាំងបងជីដូនមួយខ្ញុំផងបានបាត់ខ្លួន ហើយយើងភ័យខ្លាចបាត់បង់អាយុជីវិត។ ស៖ តើមានតុលាការ ដែលអាចឲ្យប្រជាជនដាក់ពាក្យបណ្តឹងអំពីករណីបាត់ខ្លួនបែបនេះដែរឬទេ? ឆ.45៖ ពុំមានទេ"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.167 ["ស៖ តើមានក្រមច្បាប់ក្នុងការបញ្ជូនលោក ឬអ្នកដទៃទៀតទៅក្នុងកងផលិតនោះដែរឬទេ? ឆ.167៖ អត់ដែលឮច្បាប់អីទេ ហើយយើងក៏មិនអាចបដិសេធស៊ុំតវ៉ាបានដែរ"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.12-13 ["ស៖ តើលោកដឹងថានៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យមានតុលាការកាត់ទោសដែរឬទេ? ឆ.12៖ ទេ មិនមានទេ។ ស៖ អំឡុងពេលគេធ្វើការដកអាវុធ និងពេលការបាត់ខ្លួនថ្នាក់ដឹកនាំនិងយោធានៃកងពល១៦៤ តើមានដំណើរការនីតិវិធីផ្លូវច្បាប់សម្រាប់អនុវត្ត ឬប្រតិបត្តិទៅលើទៅដំណើរការបោសសម្អាត និងដំណើរការចោទប្រកាន់អ្នកដែលត្រូវបានគេចោទថា ជាជនក្បត់ ជាខ្មែរកាហ្សេបេ ខ្មែរសេអ៊ីអា ដែរឬទេ? ឆ.13៖ នៅពេលនោះពុំមានដំណើរការនីតិវិធីទេ។ អ្នកដែលត្រូវចាប់ខ្លួននៅពេលនោះ មិនត្រូវបានប្រាប់ដំណឹងជាមុនទេ។"]។

1623 ឯកសារ D4.1.191, ឯកសារ D114/37.1.7 កំណត់ហេតុ UNHCHR របស់ កាំងហ្កេចអ៊ាវ ហៅ ឌុច ថ្ងៃទី ០៤-០៦ ខែ មីនា ឆ្នាំ ១៩៩៩ KH ERN 00160903-00160904 ["នៅកម្ពុជាប្រជាធិបតេយ្យគ្មានតុលាការ គ្មានគុក គ្មានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សភាមានចាត់តាំងមែន ប៉ុន្តែមិនដែលប្រជុំទេ។ ប្រធានតុលាការជាន់ខ្ពស់ក៏ត្រូវចាប់មក ស-២១ ដែរ កង ចាប។ ដូច្នេះមនុស្សម្នាក់ៗចូលទៅក្នុង ស-២១ ទោះបីមានចម្លើយសារភាព ឬ អត់ អាចយកទៅសម្លាប់ដោយឥតមានបញ្ហា។ ដូច្នេះ តួនាទីរបស់សេចក្តីសារភាព មិនមានតួនាទីខាងផ្លូវច្បាប់ដូចគេដូចឯងទេ។ [...] អ្នកណាដែលចាប់ហើយគឺពិតជាត្រូវស្លាប់"]។ ឯកសារ D4.1.1109 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច KH ERN 00177581 ["ស៖ តើលោកនៅតែបញ្ជាក់អះអាងថាគ្មានពេលណាមួយដែលនៅ ស-២១ មានការដាក់ឲ្យដំណើរការនូវការធានាផ្នែកនីតិវិធីដែលមានទិសដៅវាយតំលៃភាពចាំបាច់ក្នុងការចាប់ខ្លួន និងឃុំខ្លួន និងផ្តល់ឲ្យជនជាប់ឃុំនូវការកាត់សេចក្តីមួយមុនពេលសម្លាប់ឡើយឬ? ឆ៖ ខ្ញុំទទួលស្គាល់ចំណុចនេះ។ រាល់សេចក្តីសម្រេចសំខាន់ៗត្រូវបានធ្វើដោយបក្ស ដែលដឹកនាំប្រទេសផ្តាច់មុខ និងតាមរបៀបផ្តាច់ការ [...] គោលការណ៍នេះ គឺមានវិសមិតភាពជាមួយនឹងអត្ថិភាពនៃតុលាការ និងការធានាផ្នែកនីតិវិធី។"]។ ឯកសារ D114/37.1.73 ដេវីដ ឆេនដ៍ល័រ ប្រតិចារឹក ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៩ 10.21.01-10.24.33 ["មិនមានច្បាប់ មិនមានចៅក្រម មិនមានមេធាវី មិនមានតុលាការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ យើងឃើញមានថា តុលាការថែងនៅក្នុងរដ្ឋធម្មនុញ្ញ ប៉ុន្តែចៅក្រមក៏បានគេសម្លាប់ផងដែរ។ ប៉ុន្តែអត់មានការជំនុំជម្រះផ្សេងទេ"]។

ចាប់ ឃុំ ឬសម្លាប់ឡើយ។ អ្នកទោសមិនទទួលបានការជូនដំណឹងអំពីបទចោទប្រឆាំងនឹងខ្លួន។ គ្មានអ្នកទោសណាម្នាក់មានសិទ្ធិជំទាស់តវ៉ានឹងការចាប់ដាក់គុក តាមរយៈយន្តការតាមផ្លូវតុលាការ ឬទទួលបានការជំនុំជម្រះក្តីឡើយ។

439. មិនត្រឹមតែការចាប់ខ្លួនគ្មានការកាត់សេចក្តីតាមផ្លូវច្បាប់នោះទេ ស្ទើរតែគ្រប់ករណីទាំងអស់ គឺថែមទាំងគ្មានភ័ស្តុតាងបង្ហាញថា ជនណាម្នាក់បានប្រព្រឹត្តអំពើអ្វីមួយ ដើម្បីបញ្ជាក់ហេតុផលនៃការដាក់ទណ្ឌកម្មទៀតផង។ ក្នុងករណីជាច្រើន "ការសង្ស័យ" របស់របបនោះលើអ្នកដែលចាប់ខ្លួន ផ្អែកតែលើចម្លើយសារភាពដែលទទួលបានតាមរយៈការធ្វើទារុណកម្មទៅលើអ្នកដែលចូលមន្ទីរ ស-២១ និងមន្ទីរសន្តិសុខផ្សេងទៀតរបស់កម្ពុជាប្រជាធិបតេយ្យ[1624]។ ដូចមេដឹកនាំ ប.ក.ក បានដឹងស្រាប់ហើយ[1625] ចម្លើយសារភាព ដែលទទួលបានក្នុងកាលៈទេសៈបែបនេះ មិនអាចជឿទុកចិត្តបានទេ។

---

1624 ឧទាហរណ៍នៃបុគ្គលដែលមកពីកងពល១៦៤ដែលត្រូវបានគេបង្ខំឲ្យទទួលទោសថាជាប់ពាក់ព័ន្ធនឹងខ្សែក្បត់នៅ ស-២១ សូមមើល ចម្លើយសារភាពរបស់ ហង់ ខឿន ហៅ ឌឹម៖ ឯកសារ D234/2.1.55 ចម្លើយសារភាពរបស់ ហង់ ខឿន ហៅ ឌឹម នៅ ស-២១ EN 00224085 ឯកសារ D1.3.18.1 ចម្លើយសារភាពរបស់ ហង់ ខឿន ហៅ ឌឹម នៅ ស-២១។ ឯកសារ D1.3.18.2 ចម្លើយសារភាពរបស់ ហង់ ខឿន ហៅ ឌឹម នៅ ស-២១ EN 00759713-17, KH ERN 00177026-30 [បញ្ជី ៩៤ "កងកម្លាំងក្បត់នៅក្នុងកងពល១៦៤" រួមមានកម្មាភិបាលមកពីគណៈនៃកងពល ១៦៤ កងវរៈសេនាធំ ៦២ និង ៦៣ និងកងវរៈសេនាតូច និងកងអនុសេនាធំជាច្រើន]។ សូមមើលផងដែរ ឯកសារ D54/6.1.14 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹក ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០៩ 10.18.09-10.29.11, ["ការចាប់ខ្លួនដែលពឹងផ្អែកទៅលើសេចក្តីសារភាពរបស់អ្នកដទៃ"]។ ឯកសារ D4.1.191, ឯកសារ D114/37.1.7 កំណត់ហេតុ UNHCHR របស់ កាំងហ្កេចអ៊ាវ ហៅ ឌុច ថ្ងៃទី ០៤-០៦ ខែ មីនា ឆ្នាំ ១៩៩៩ KH ERN 00160904 ["តួនាទីរបស់ចម្លើយសារភាពមានតែមួយគត់ គឺសម្រាប់ផ្តល់ឲ្យខាងលើគេតាមដានរកខ្សែក្បត់ [...] តទៅទៀត"]។ ឯកសារ D4.1.406 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច KH ERN 00408229 ["ការងារស្នូលនៃមន្ទីរសន្តិបាលជំនាន់នោះ គឺបញ្ជូនចម្លើយសារភាពទៅថ្នាក់លើនេះឯង។ គឺចម្លើយសារភាពហ្នឹងហើយ ដែលខាងលើត្រូវការ ដើម្បីបង្កើនការសង្ស័យ បន្តការចាប់ចងកាប់សម្លាប់មនុស្ស ដែលជាសាច់ឯងឈាមឯងយ៉ាងងងឹតងងល់តទៅទៀត"]។ ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦ 15.49.58-15.52.12 ["ការដែលខ្ញុំនៅសួរចម្លើយ វាមានការទាក់ទងទៅនឹងខ្សែបណ្តាញជនក្បត់អ៊ីចឹង"]។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦ 11.21.41-11.25.00 ["តាមការឆ្លើយដាក់ពីអ្នកទោសមុនៗមក ឆ្លើយដាក់ទៅបានចាប់អ្នកក្រោយទៀត"], 15.43.38-15.46.26។

1625 សូមមើល ឧទាហរណ៍, ឯកសារ D4.1.191, ឯកសារ D114/37.1.7 កំណត់ហេតុ UNHCHR របស់ កាំងហ្កេចអ៊ាវ ហៅ ឌុច ថ្ងៃទី ០៤-០៦ ខែ មីនា ឆ្នាំ ១៩៩៩ ទំព័រ ៣៩, ៤៥ KH ERN 00160911 ["ដើម្បីយល់ការពិត ដើម្បីយល់ថាស្អីដែលគេធ្វើមកលើកម្ពុជា ស្អីដែលនាំឲ្យកម្ពុជាប្រជាធិបតេយ្យរលំរលាយ។ [...] គ្មានអ្នកណាជឿទេ"]។

ស្របតាមគោលនយោបាយរបស់ ប.ក.ក ក្នុងការ "ដកស្មៅគាស់ទាំងឫស" បណ្ដាញខ្មាំង ការគ្រាន់តែជាប់ពាក់ព័ន្ធជាមួយនឹងមេបញ្ជាការ ឬកម្មាភិបាលដែលត្រូវគេបោសសម្អាត គឺជាមូលហេតុគ្រប់គ្រាន់សម្រាប់ការចាប់ខ្លួន។ មេបញ្ជាការត្រូវគេស្នើឲ្យស្វែងរក "ជនក្បត់" បន្ថែមទៀត និងអ្នកជាប់ខ្សែ "ជនក្បត់" ឲ្យបានសកម្ម នៅក្នុងអង្គភាពរៀងៗខ្លួន[1626]។ **មាស មុត** បានរៀបចំវគ្គរៀនសូត្រ ហើយតម្រូវឲ្យអ្នកចូលរួមសរសេរប្រវត្តិរូប ដើម្បីបញ្ជាក់អំពីការជាប់ពាក់ព័ន្ធពីអតីតកាល ជាមួយកម្មាភិបាលដែលត្រូវគេបោសសម្អាតរួចហើយ[1627]។

---

[1626] ឯកសារ D4.1.400 កាំង ហ្គេកអ៊ាវ ហៅ ឌុច កំណត់ហេតុស្ដាប់ចម្លើយ KH ERN 00239838 ["មុនការចាប់ខ្លួននរណាម្នាក់ គេ ត្រូវតែពិភាក្សាជាមួយប្រធានអង្គភាពរបស់អ្នកនោះ។ នៅពេលណាដែលបានទទួលចម្លើយសារភាពរួចហើយ ចម្លើយត្រូវបានផ្ញើដោយសុនសេន (Son Sen) (បន្ទាប់មក នួន ជា (Nuon Chea)) ទៅឲ្យប្រធានអង្គភាព"]។ ឯកសារ ឯកសារ D12 កាំង ហ្គេកអ៊ាវ ហៅ ឌុច កំណត់ហេតុស្ដាប់ចម្លើយ KH ERN 00680805 ["សុន សេន Son Sen មុនពេលសម្រេច គាត់តែងតែសុំយោបល់ និងការជួយសម្រេចពីប្រធានកងពលផ្ទាល់នោះ"]។ ឯកសារ D4.1.860 កាំង ហ្គេកអ៊ាវ ហៅ ឌុច កំណត់ហេតុស្ដាប់ចម្លើយ KH ERN 00403906 ["ក្នុងការអនុវត្តជាក់ស្ដែង ពេលដែលមនុស្សម្នាក់ត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព ថ្នាក់លើជូនដំណឹងទៅអ្នកទទួលខុសត្រូវអង្គភាពនីមួយៗ"]។ ឯកសារ D98/1.2.6 កាំង ហ្គេកអ៊ាវ ហៅ ឌុច ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៩ 09.33.54 ["ចម្លើយសារភាពពី ស-២១ [...] ឲ្យទៅស៊ូ ម៉េត ហើយ ស៊ូ ម៉េត ជ្រើសមនុស្សមួយចំនួនដែលនៅក្នុងកងពល ៥០២"], 09.57.12-10.00.15, 10.34.00។ ឯកសារ D4.1.404 កាំង ហ្គេកអ៊ាវ ហៅ ឌុច កំណត់ហេតុស្ដាប់ចម្លើយ KH ERN 00242921 ["ចម្លើយសារភាពត្រូវបានផ្ញើរទៅប្រធានអង្គភាព ដោយមានគោលបំណង២៖ ទី១ ប្រាប់ដំណឹងដល់គាត់អំពីសកម្មភាពរបស់ខ្មាំងនៅក្នុងអង្គភាពនោះ និងទី២ អនុញ្ញាតឲ្យគាត់គិតពីការចាប់ខ្លួនមនុស្សដែលគេបានឆ្លើយដាក់"]។ ឯកសារ D1.3.17.6 ស្ទីវហ្វិន ហេដឌ័រ និង ប្រាយអ៊ិន ធីតធឺម័រ បេក្ខជនចំនួនប្រាំពីរនាក់ដែលត្រូវកាត់ទោស KH ERN 00742607-00742608 ["ហេតុនេះ ចម្លើយសារភាពត្រូវបានសរសេរឡើងវិញទៅតាមការណែនាំរបស់អ្នកសួរចម្លើយ ដើម្បីបង្ហាញពីបរាជ័យក្នុងការអនុវត្តគោលនយោបាយសេដ្ឋកិច្ច យោធា និងគោលនយោបាយដទៃទៀត ដែលកើតចេញពីគោលនយោបាយប្រឆាំង ប.ក.ក ដែលដឹកនាំដោយទីភ្នាក់ងារសម្ងាត់បរទេស។ ជាងនេះទៀត ចម្លើយសារភាពត្រូវបានបង្កើតឡើង ដើម្បីបង្ហាញថា គោលនយោបាយរបស់ ប.ក.ក មិនបានសម្រេចទៅតាមទិសដៅទេ ដោយសាររចនាសម្ព័ន្ធដែលមេដឹកនាំ ប.ក.ក បានបង្កើតឡើងដើម្បីអនុវត្តគោលនយោបាយទាំងនេះត្រូវបានជ្រៀតចូលដោយពួកភ្នាក់ងារសេអ៊ីអា កេហ្សេបេ វៀតណាម និងអ្នកដទៃទៀតដែលជាប់សង្ស័យថាជាខ្មាំង"]។

[1627] ឯកសារ D54/115 កំណត់ហេតុស្ដាប់ចម្លើយ នាក់ យឿន ឆ.15-27 [រៀបរាប់ពីវគ្គរៀនសូត្រដែលធ្វើនៅផ្សារកំពង់សោមបន្ទាប់ពីមានការចាប់ខ្លួន មុំ ជិន ហៅ យ៉ាន មេបញ្ជាការកងវរៈសេនាធំ ៦៣ ដែលត្រូវរៀបចំឡើង និងមាន មាស មុត ជាប្រធាន។ ទាហាន "មកពីកោះ និងមូលដ្ឋានដីគោកផ្សេងៗគ្នា" ត្រូវបានរៀនសូត្រពាក្យស្លោក "ដកស្មៅគឺដកទាំងឫស"ហើយ មាស មុត បានសួរសំណួរឲ្យអ្នកចូលរួមឆ្លើយ "ថាតើក្នុងចំណោមពួកយើងមានអ្នកណាធ្លាប់ធ្វើ

440. អ្នកទោសមិនត្រូវបានគេប្រាប់អំពីមូលហេតុនៃការចាប់ខ្លួនឡើយ។ ដើម្បីចៀសវាងការតដៃ ឬការបះបោរពីអង្គភាពប្រដាប់អាវុធរៀងៗខ្លួន[1628] អ្នកដែលគេកំណត់មុខសញ្ញាយកទៅឃុំ ត្រូវគេកោះហៅទៅចូលរួមវគ្គរៀនសូត្រ[1629] ឬត្រូវគេប្រាប់ឲ្យផ្ទេរទៅសហករណ៍ថ្មី[1630]។

---

ការជាមួយ យ៉ាន ទេកាលពីមុន"។ ក្រោយពីវគ្គរៀនសូត្រនេះ "មានមនុស្សបីបួននាក់ ដែលធ្វើការផ្ទាល់ជាមួយ យ៉ាន បានបាត់ខ្លួន"។ សាក្សីបានសន្និដ្ឋានថា "ការរៀនសូត្រ និងការធ្វើប្រវត្តិរូបគឺធ្វើឡើងដើម្បីចម្រាញ់រកអ្នកទាំងនោះ"]។

1628 ឯកសារ D114/187 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.73 ["ចាប់ និងនាំ គឺខុសគ្នា។ 'នាំទាហាន' គឺគ្រាន់តែនាំយកទៅលើឡានតែប៉ុណ្ណោះ ហើយវាមានការការពារ។ គ្រាន់តែ 'នាំ' ទៅលើឡាន ដោយការពារតែប៉ុណ្ណោះ។ ចាប់ គឺមានន័យថាចាប់ចង។ ដូច្នេះមិនអាចចាប់ចងទេ ព្រោះមនុស្សវាច្រើន"]។

1629 សូមមើល ឧទាហរណ៍ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.23 ["មិនមានអ្នកណាអាចដឹងបានទេនៅពេលគេនាំមនុស្សនាំយកចេញទៅបាត់ ពីព្រោះគេតែងនិយាយថា យកអ្នកនោះទៅរៀនសូត្រ។ នៅពេលដែលគេយកមនុស្សទៅសម្លាប់ឬបញ្ជូនទៅកងផ្សេងទៀតឬយកទៅរៀបការក៏គេប្រាប់ថា យកទៅរៀនសូត្រដែរ"]។ ឯកសារ D114/135 កំណត់ហេតុស្តាប់ចម្លើយ ណុប ផន ឆ.3-5 [អតីតសមាជិកកងវរៈសេនាតូច ៣៨៦ កងអនុសេនាធំ ៤២០ បានពន្យល់ពីកោះតាងថា នៅចុងឆ្នាំ ១៩៧៦ មេបញ្ជាការរបស់គាត់ត្រូវបានបញ្ជូនឲ្យទៅរៀនសូត្រ និងបាត់ខ្លួន]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.19, 91 ["ឋានៈចាប់ពីមេកងធំឡើងទៅ ត្រូវបានគេយកទៅសម្លាប់ទាំងអស់ ក្រោមហេតុផលយកទៅរៀនសូត្រ។ [...] ឆ.91៖ ឲ្យតែមេៗវរៈគេហៅមករៀនសូត្រនៅរោងកុន នៅកំពង់សោម គឺដឹងតែបាត់ខ្លួនតែម្តង ហើយមិនឃើញវិលត្រឡប់មកវិញទេ [...] កន្លងពេលយូររាប់ខែមកហើយ ក៏មិនឃើញពួកគេត្រឡប់មកវិញនោះទេ"]។ ឯកសារ D114/105 កំណត់ហេតុស្តាប់ចម្លើយ កុច ទុយ ឆ.79 ["គេថាតំបន់ ៣៧ ក្បត់ និងប្រុងរត់ចូលយួនអស់ ហើយពួកគេបានចាប់សម្លាប់មេធំនៅទីនោះទៅរៀនសូត្រអស់"]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.10 ["ក្រោយពីគេចាប់ ខឹម គេក៏ចាប់ផ្តើមចាប់អ្នកនៅក្រោមៗតទៅទៀត។ នៅកងកេង គេឲ្យធ្វើស្រែដោយកាប់នឹងចប [...] ដំបូងឡើយ គេទៅហៅយើងដោយនិយាយថាអង្គការឲ្យហៅមករៀនសូត្រ ពេលយើងមកដល់ គេចាប់ផ្តើមឲ្យយើងធ្វើស្រែតែម្តង។ មានអ្នកខ្លះក៏បាត់ខ្លួនដែរនៅពេលនោះ គឺបាត់ខ្លួនមិនឃើញត្រឡប់មកវិញទេ។ ហើយពួកខ្ញុំមិនដែលហ៊ានសួរនាំ ឬក៏ឆ្ងល់អីដែរ"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.13 ["នៅពេលនោះពុំមានដំណើរការនីតិវិធីទេ។ អ្នកដែលត្រូវចាប់ខ្លួននៅពេលនោះ មិនត្រូវបានប្រាប់ដំណឹងជាមុនទេ។ អ្នកដែលហៅទៅនោះ គឺគេហៅទៅរៀនសូត្រ ហើយបាត់ខ្លួនតែម្តង។ លិខិតដែលអញ្ជើញឲ្យទៅរៀនសូត្រ គឺផ្ញើមកពីកងពល។ បន្ទាប់ពីការបាត់ខ្លួន ថ្នាក់ដឹកនាំ បានប្រកាសប្រាប់នៅក្នុងចំណោមយោធាឲ្យធ្វើការប្រយ័ត្នប្រយែងចំពោះភារកិច្ចរបស់ខ្លួន ដូចជាការយាមកាម ហើយមិនឲ្យពាក់ព័ន្ធជាមួយសកម្មភាពរបស់ខ្មាំងទេ"]។

1630 ឯកសារ D54/114 កំណត់ហេតុស្តាប់ចម្លើយ ហែម សម្បត្តិ ឆ.45-51 [បាននិយាយថា គាត់បានឃើញដោយផ្ទាល់គ្រួសារដែលរស់នៅក្បែរគាត់ "ត្រូវទៅរៀនសូត្រ"– គ្រួសារមួយដែលមានសមាជិកប្រហែល០៥នាក់ "ប្រជាជនថ្មី"- ខ្មែរក្រហមទាំងអស់នោះនិយាយថានាំពួកគាត់មួយគ្រួសារដែលរស់នៅក្បែរខ្ញុំទៅសហករណ៍ថ្មី។ ទាហានខ្មែរក្រហមប្រាប់មេក្រុមខ្ញុំ ហើយមេក្រុមប្រាប់មកខ្ញុំថាប្រជាជនថ្មី នាំយកទៅជិតទឹកសាប"។ សាក្សីបានដឹងថា គ្រួសារនោះត្រូវ

## ៣. មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ[1631]

### ទីតាំង ការពណ៌នាអំពីទីតាំង និងប្រតិបត្តិការ

441. វត្តឥន្ទញ្ញាណ ហៅថា វត្តក្រោម[1632] ស្ថិតនៅក្នុងក្រុងកំពង់សោម[1633] នៅជិតទីតាំងទាំងពីរនៃទីបញ្ជាការកងពល ១៦៤[1634] ដែល **មាស មុត** រស់នៅ[1635]។

---

បានគេសម្លាប់ ដោយសារទាហានខ្មែរក្រហមបានយកពួកគេទៅ ហើយប្រាប់ពួកគេថាមិនបាច់យកអង្ករទៅទេ ហើយគាត់បានឃើញរម៉កដដែលត្រឡប់មកវិញពេលមួយម៉ោងមកជាមួយនឹងខោអាវរបស់គ្រួសារនោះ]។

1631 ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៥៥-៥៧។

1632 ឯកសារ D114/111 កំណត់ហេតុស្តាប់ចម្លើយ សុខ ឡាង ឆ.6 ["វត្តឥន្ទញ្ញាណហៅមួយទៀតថា "វត្តក្រោម" ក៏បាន""]។ ឯកសារ D54/64 កំណត់ហេតុស្តាប់ចម្លើយ ខិន ជុន ឆ.1 ["វត្តនេះហៅថាវត្តឥន្ទញ្ញាណ ឬ វត្តក្រោម"]។ ឯកសារ D54/33.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ី អុន KH ERN 00964205 ["ស៖ ហើយចុះមានវត្តក្រោម តែខ្ញុំអត់ច្បាស់ព្រោះឮពូមួយគាត់និយាយថាមានវត្តក្រោមមួយកន្លែងដូចថាអ្នកដែលធ្វើខុសធ្វើអី? ឆ៖ វត្តក្រោមនៅណា? ស៖ គេហៅវត្តឥន្ទញ្ញាណ"]។ ឯកសារ D54/106.2 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សាន់ កាន ហៅ ប៊ុត KH ERN 00993477 ["វត្តឥន្ទញ្ញាណត្រូវបានគេហៅថាវត្តក្រោម"]។

1633 សូមមើល ឧទាហរណ៍ ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.36 ["ស៖ លោកបាននិយាយក្នុងការស្តាប់ចម្លើយលើកមុនអំពីការជាប់ឃុំឃាំងរបស់លោកនៅវត្តឥន្ទញ្ញាណ។ ក្នុងពេលកំណត់អត្តសញ្ញាណទីតាំង យើងបាននាំលោកទៅវត្តមួយនៅក្នុងក្រុងកំពង់សោមហៅវត្តឥន្ទញ្ញាណ ឬវត្តក្រោម។ តើកន្លែងនេះមែនទេ ដែលលោកត្រូវបានឃុំឃាំង? ឆ.36៖ ត្រឹមត្រូវហើយ។"]។ ឯកសារ D54/35.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប្រាក់ សុខា KH ERN 00964252 ["នៅកំពង់សោមវត្តឥន្ទញ្ញាណមាននៅហ្នឹង"]។ ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ឬ ណាំ ឡូន ឆ.22 ["តាមខ្ញុំដឹង វត្តឥន្ទញ្ញាណគឺនៅលើកំពូលភ្នំមួយនៅកំពង់សោម"]។ ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.22 ["ខ្ញុំគ្រាន់តែឮថាវត្តឥន្ទញ្ញាណនេះស្ថិតក្នុងខេត្តកំពង់សោម"]។ ឯកសារ D54/48.3 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឧបសម្ពន្ធ៖ ផែនទីរដ្ឋបាលនៃស្រុកមិត្តភាព KH ERN 00969463 [បង្ហាញពីវត្តឥន្ទញ្ញាណ]។ ឯកសារ D114/30 មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ សាក្សី ខិន ជុន និងសាក្សី នួន យឹម របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំង KH ERN 01363892, 01363901 ["ទីតាំងនេះ ស្ថិតនៅក្នុងក្រុងកំពង់សោម/ក្រុងព្រះសីហនុ នៅក្នុងបរិវេណនៃវត្តឥន្ទញ្ញាណនោះ។ [...] រូបភាពបង្ហាញពីទីតាំងនៃវត្តឥន្ទញ្ញាណ"]។

1634 ព័ត៌មានលម្អិតពីរចនាសម្ព័ន្ធចាត់តាំងកងពលធំ ១៦៤ (អតីតកងពលធំលេខ៣) ទីតាំងពិតប្រាកដរបស់ទីបញ្ជាការកងពល១៦៤ ហាក់ដូចជាមានការផ្លាស់ប្តូរក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ចាប់ពីតំបន់ជិតផ្សារលើតែម្តង និងភាគខាងជើងនៃផ្លូវឯករាជ្យបច្ចុប្បន្ន (សូមមើល ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.8, ឆ.46 និង ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឧបសម្ពន្ធ៖ ផែនទីរដ្ឋបាលនៃស្រុកមិត្តភាពដែលលើកឡើង

442. នៅពេលដែលខ្មែរក្រហមបានគ្រប់គ្រងទីតាំងនេះ អគារខ្លះដែលមានពីដើមមក មានទាំងវិហារជាទីគោរពបូជាផង ត្រូវបានកម្ទេចចោល នៅសល់តែអគារចំនួនបីជាសំខាន់ យកមកធ្វើមន្ទីរសន្តិសុខ៖ កុដិព្រះសង្ឃពីរ និងសាលាឆាន់មួយ[1636]។ កុដិព្រះសង្ឃទីមួយត្រូវបានធ្វើជាផ្ទះដែលមេបញ្ជាការ

ដោយ អែម សុន KH ERN 00969463 [បង្ហាញពី វត្តឥន្ទញ្ញាណ និងមន្ទីរដំបូងរបស់ មាស មុត]) ស្ថិតនៅខាងត្បូងផ្សារលើ និងនៅខាងជើងឆៀងខាងកើតសណ្ឋាគារសុខា។ សូមមើល ឧទាហរណ៍ ឯកសារ D54/72.2 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឧបសម្ព័ន្ធ៖ ផែនទីទេសចរណ៍ ក្រុងព្រះសីហនុ ដែលកំណត់សម្គាល់ដោយ មុត ម៉ៅ KH 00979285 [នៅលើផែនទីនោះ គាត់បានគូសរង្វង់ទីតាំងមន្ទីរផ្ទៃក្នុង] ដែលត្រូវនឹងពីទីតាំងដែលកំណត់ដោយ ក.ស.ច.ស. សូមមើល ឧទាហរណ៍ ឯកសារ D114/46 មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ និងទីតាំងពាក់ព័ន្ធផ្សេងៗទៀត របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងរបស់សាក្សី ស៊ឹម នី KH ERN 01307866 [បង្ហាញពីទីបញ្ជាការកងពល ១៦៤]។ សាក្សី និងអ្នកស៊ើបអង្កេតទីតាំងបានកំណត់ទីតាំងនេះប្រហែល២គីឡូម៉ែត្រពីវត្តឥន្ទញ្ញាណ។ សូមមើល ក្នុងចំណោមនោះ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.3 ["មន្ទីរបញ្ជាការរបស់ មាស មុត ហើយ និងផ្ទះស្នាក់នៅរបស់គាត់មានចម្ងាយប្រហែល២គីឡូម៉ែត្រពីវត្តឥន្ទញ្ញាណ"]។ ឯកសារ D2/22 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងនៃមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ KH ERN 00662120 ["ចម្ងាយពីទីបញ្ជាការកងពល១៦៤ ប្រហែល ២.៤គីឡូម៉ែត្រ (ចម្ងាយលំហរ) ទៅវត្តឥន្ទញ្ញាណ"]។ ឯកសារ D114/46 មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ និងទីតាំងពាក់ព័ន្ធផ្សេងៗទៀត របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងរបស់សាក្សី ស៊ឹម នី KH ERN 01307866 ["តាមទីតាំងយោងនេះ វត្តឥន្ទញ្ញាណគឺនៅក្នុងដែននៃកងពល១៦៤ ដែលទីបញ្ជាការស្ថិតនៅចម្ងាយប្រហែល ២.៤ គីឡូម៉ែត្រ [ពី] មន្ទីរសន្តិសុខក្នុងក្រុងកំពង់សោម"]។

1635 ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.3 ["ផ្ទះរបស់ មាស មុត គឺនៅនឹងកន្លែងមន្ទីរធ្វើការរបស់គាត់តែម្តង"]។ ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.8 ["ខ្ញុំគ្រាន់តែដឹងមន្ទីរដំបូងមានទីតាំងនៅជិតផ្សារលើ។ មន្ទីរនោះ ជាផ្ទះថ្ម ហើយ មាស មុត ស្នាក់នៅមន្ទីរនោះដែរ។ តាមការប៉ាន់ស្មានរបស់ខ្ញុំ ប្រហែលមានបុគ្គលិក ១០០ នាក់ធ្វើការនៅផ្នែកផ្សេងៗក្នុងមន្ទីរនោះ"]។ ឯកសារ D54/71 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ. 20 ["តើមន្ទីរក្នុងរបស់កងពល១៦៤ ហ្នឹងមានមុខងារធ្វើអ្វីខ្លះ? ឆ.20៖ វាគឺជាផ្ទះដែល មាស មុត ស្នាក់នៅ"]។

1636 ឯកសារ D2/4 កំណត់ហេតុស្តាប់ចម្លើយ ប៉ូច កុយ ឆ.21 ["ពេលដែលខ្ញុំមកដល់នៅខែកក្កដា ឆ្នាំ១៩៧៩ ព្រះវិហារត្រូវបានបែកបាក់ដល់ដីអស់ហើយ។ ចំណែកឯកុដ្ឋពីរ និងសាលាឆាន់មួយ គឺនៅល្អដដែល"]។ ឯកសារ D54/65 កំណត់ហេតុស្តាប់ចម្លើយ ខិន ជុន ឆ.36 ["មានតែសាលាឆាន់មួយ និងកុដ្ឋលោកមួយឬពីរ"]។ ឯកសារ D2/22 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងនៃមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ KH ERN 00662110 ["សាក្សី ទូច សឿលី បានកំណត់អត្តសញ្ញាណ "កុដិទីមួយ" កុដិលោក។ [...] "កុដិទីពីរ" [និង] [...] អគារទីបី "សាលាឆាន់"], KH ERN 00662134-00662150 [ផែនទី ការបង្ហាញពីទីតាំងតាមរយៈ GPS និងរូបភាពអគារទាំងបី]។ ឯកសារ D114/39 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន KH ERN 01065092 ឆ.2 ["KH ERN 01065092៖ សាក្សីបានកំណត់អត្តសញ្ញាណពីផ្នែកខាងក្រៅនៃអតីតសាលាឆាន់ [...] សាក្សីក៏បានគូសបញ្ជាក់អំពីទីតាំងកុដិលោកមួយខ្នង និងខ្លោងទ្វារចូលវត្តឥន្ទញ្ញាណ"]។ សូមមើល ផងដែរ ឯកសារ D1.3.13.12 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ សុខ

វរសេនាតូច ៤៥០/១៦៥ រស់នៅ[1637] ហើយក៏កន្លែងដាក់ពេទ្យ អ្នកកាន់វិទ្យុទាក់ទង និង នីរសារផងដែរ។[1638] ដូចរៀបរាប់ពិស្តារខាងក្រោមនេះ[1639] អគារទាំងបីត្រូវបានប្រើសម្រាប់ឃុំឃាំងមនុស្ស។ សាក្សីម្នាក់បានរៀបរាប់ផងដែរថា ក្នុងបរិវេណវត្តមានរោងចំនួនប្រហែល២០ បានប្រើជាកន្លែងបន្ថែមទៀតសម្រាប់ឃុំឃាំង[1640]។ ក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ចម្ការក្រូចមួយ

---

ឡាង EN 00217568 ["វត្តឥន្ទញាណត្រូវបានប្រើប្រាស់ដោយទាហានខ្មែរក្រហម និងនៅពេលទាហានដកចេញទៅមានតែអគារនៅក្នុងវត្តពីរប៉ុណ្ណោះត្រូវនៅមិនបាក់បែក"]។

1637 ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.14-15 ["ស៖ ពេលនោះ តើមេបញ្ជាការកងពិសេសហ្នឹង គេរៀបទីតាំងនៅកន្លែងណា? ឆ.14៖ ពេលមកដល់ដំបូង គាត់ស្នាក់នៅកន្លែងឃ្លាំងប្រាក់ ឬធនាគារជាតិនៅជិតផែកប៉ាល់។ ពីរបីថ្ងៃក្រោយមកទើបរើទៅវត្តឥន្ទញាណ។ ស៖ ពីម្សិលមិញ លោកបានបង្ហាញកុដមួយនៅវត្តឥន្ទញាណ តើកុដនឹងឬដែលជាកន្លែងដែលគាត់ស្នាក់នៅ? ឆ.15៖ បាទ គឺកុដខាងជើង ដែលសង់បណ្តោយថ្ងៃ"]។ សូមមើល ផងដែរ ឯកសារ D2/22 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងនៃមន្ទីរសន្តិសុខវត្តឥន្ទញាណ EN 00634143, FR 00725839, KH ERN 00662109-10 ["សាក្សី ទូច សឿលី បានបង្ហាញថា "កុដិ" កុដិទីមួយ - កុដិព្រះសង្ឃ-ជាកន្លែងដែលគាត់បានស្នាក់នៅដោយផ្ទាល់ជាមួយនឹងមេបញ្ជាការកងវរសេនាតូច៤៥០"]។

1638 ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.18 ["បន្ទប់បែកខាងលិចគេបង្កស់មានពេទ្យ និងគេអ្នស្នាក់នៅ។ បន្តបន្ទាប់មកជាបន្ទប់របស់មេបញ្ជាការ។ ហើយបន្ទាប់មកទៀត បន្ទប់ទីបីជាបន្ទប់របស់ខ្ញុំជានិរសាស្នាក់នៅ។ ពេលនោះមេបញ្ជាការ ពេទ្យ វិទ្យុទាក់ទង និងនិរសាស្នាក់នៅជាប់ៗគ្នា។ ហើយបន្ទប់ជាន់ខាងក្រោមផ្នែកកណ្តាល គឺជាបន្ទប់សម្រាប់ដាំបាយ។ រីឯកុដមួយទៀតនៅខាងក្រោយ និងសាលា គឺគ្មានមនុស្សរស់នៅទេ"]។ សូមមើល ផងដែរ ឯកសារ D114/187 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.18 ["ពេលហ្នឹងកន្លែងវត្តហ្នឹង វាមានទីទួល ដូច្នេះហ្នឹងត្រូវបានបង ស សាមឿន នៅកន្លែងហ្នឹងដើម្បីដាក់វិទ្យុទាក់ទង។ វាអាចមានទំនាក់ទំនងល្អព្រោះវាមានរលកខ្ពស់"]។

1639 សូមមើល VIII.C.3. បន្ទីរសន្តិសុខវត្តឥន្ទញាណ – ឧក្រិដ្ឋកម្ម - ការឃុំឃាំងក្នុងគុក។

1640 ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី KH ERN 00987074 ["សាក្សីបានប្រាប់ថាកាលពីជំនាន់នោះនៅកន្លែងដែលយើងកំពុងអង្គុយសម្ភាសនេះគឺមានខ្ទមប៉ុនៗខ្ទមដែលនៅជិតយើងនេះ ជាខ្ទមដាក់អ្នកទោស"], ឆ.1-2 ["ខ្ញុំឃើញមានខ្ទមចំនួនប្រហែលច្រើន២០ខ្ទម និងមានអ្នកទោសពី៤០នាក់ទៅ៥០នាក់។ ខ្ញុំមិនអាចប្រាប់អំពីចំនួនខ្ទមឲ្យបានពិតប្រាកដនោះទេ។ ខ្ទមទាំងនោះមិនមែនសង់នៅជាជួរត្រឹមត្រូវនោះទេ។ គឺវារាស់នៅតាមចន្លោះថ្ម ក្រោមដើមឈើធំៗនៅក្នុងទីធ្លាវត្ត ហើយនិងនៅប៉ែកខាងក្រោមនៃទីធ្លាវត្ត។ [...] ឆ.2៖ ខ្ទមទាំងនោះមិនមានជញ្ជាំងទេ ខ្ទមនោះគឺប្រក់ដំបូលដោយស្លឹកត្នោត ឬក៏ស្បូវ។ ទំហំខ្ទមនីមួយៗ គឺមានទំហំប្រហែល៤ម៉ែត្របួនជ្រុង"]។ សូមមើល ផងដែរ ឯកសារ D114/46 មន្ទីរសន្តិសុខវត្តឥន្ទញាណ និងទីតាំងពាក់ព័ន្ធផ្សេងៗទៀត របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងរបស់សាក្សី ស៊ឹម នី KH ERN 01307882-01307883 ["រូបភាពបង្ហាញពីអតីតទីតាំងរោងដាក់អ្នកទោស"]។

ដែលបានប្រើជាទីតាំងសម្លាប់មនុស្ស[1641] ស្ថិតនៅខាងកើតហើយលើដីទាបជាងមន្ទីរសន្តិសុខដែលបានសង់ក្នុងបណ្តាឆ្នាំនៃការកាន់អំណាច[1642]។

## រយៈពេលនៃដំណើរការ

443. ពេលភ្លាមៗក្រោយកម្លាំងកងពល៣ បានចូលដល់កំពង់សោមនៅថ្ងៃទី ១៨ ខែ មេសាឆ្នាំ ១៩៧៥[1643] កងទ័ពរបស់ **មាស មុត** បានបណ្តេញព្រះសង្ឃដែលគង់នៅវត្តឥន្ទញ្ញាណឱ្យចេញ[1644]

---

1641 សូមមើល VIII.C.3. មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ – ឧក្រិដ្ឋកម្ម - ការសម្លាប់, ការសម្លាប់ផុតពូជ និងការបាត់ខ្លួនដោយបង្ខំ។

1642 ឯកសឧសារ D2/4 កំណត់ហេតុស្តាប់ចម្លើយ ប៉ូច កុយ ឆ.36-37 ["ផ្ទៃដីលាននោះ មិនរាបស្មើទេ គឺខ្ពស់ទាប។ គេមានដាំក្រូចឆ្មារជាជួរច្រើន [...] ស៖ ពេលដែលលោកថា "គេ" តើលោកសំដៅលើអ្នកណា? ឆ.37៖ គឺសំដៅលើ ប៉ុល ពត"]។ ឯកសារ D2/22 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងនៃមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ KH ERN 00662123 ["ភាគខាងកើតខាងលើនៃបរិវេណវត្ត មានជម្រាល [ចុះមក] ដែលនាំទៅកាន់ជណ្តើរឆ្ពោះទៅកាន់ទីជម្រាលខាងក្រោមមួយ ដែលជាចំការក្រូចឆ្មារ/វាលរណ្តៅសាកសព ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ បច្ចុប្បន្ននេះ មានរៀងអារ៉ាមជាច្រើនបោះទីតាំងនៅលើទីវាលនេះ បន្ទាប់ពីមានផ្ទះប្រជាជនសាងសង់នៅក្រៅបរិវេណវត្តអារ៉ាមរួមមក"], 00662153 [រូបភាពនៃចម្ការក្រូចឆ្មារដែលបង្ហាញដោយ ប៉ូច កុយ]។

1643 ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.6 ["នៅថ្ងៃតី ១៨ ខែ មេសា កងពលធំលេខ៣ ចូលមកក្នុងកំពង់សោម"]។ សូមមើល ផងដែរ ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.1 ["នៅថ្ងៃទី ១៨ ខែ មេសា ខ្មែរក្រហមបានមកកាន់កាប់ខេត្តកំពង់សោម"]។ ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ. 22 ["ការចាប់ផ្តើមគឺពីថ្ងៃ ១៨ (ខែ មេសា ឆ្នាំ ១៩៧៥) ពេលនោះកងទ័ពរបស់តំបន់ [៣៧] បានចូលមកដល់ក្រុងកំពង់សោមដោយពុំមានការតដៃពីទាហាន លន់ នល់ ទេ ដោយកងទ័ព លន់ នល់ ដាក់អាវុធ ហើយយើងប្រាប់ឱ្យគេដាក់អាវុធ ហើយចេញទៅ"]។ ឯកសារ D114/68 កំណត់ហេតុស្តាប់ចម្លើយ គុយសម្បត្តិ ឆ.9 ["នៅថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ពេលដែលយោធាខ្មែរក្រហមចូលភ្នំពេញ ហើយយោធាខ្មែរក្រហមនៅកំពង់សោម ក៏ចូលកំពង់សោមដែរ។ ពួកទាហាន លន់ នល់ បានរៀបចំខ្លួននៅកំពង់សោមដើម្បីចាំទទួលពួកខ្មែរក្រហម។ ក្រុងកំពង់សោមពេលនោះគឺត្រូវពួកខ្មែរក្រហមព័ន្ធជុំអស់ហើយ។ បន្ទាប់មក មានយោធាខ្មែរក្រហម ចូលមកដល់ក្រុងកំពង់សោម តាមរយៈឡានហ្ស៊ីបទាហានជាច្រើន"]។

1644 ឯកសារ D2/4 កំណត់ហេតុស្តាប់ចម្លើយ ប៉ូច កុយ ឆ.7 ["ស៖ នៅថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ នៅពេលដែលកំពង់សោមរលំទៅ តើលោកនៅចាំថា វត្តទាំងពីរនេះនៅមានដំណើរការជាកន្លែងសាសនាដែរឬទេ? ឆ.7៖ បាទ គេបានដេញប្រជាជន និងលោកសង្ឃចេញទាំងអស់នៅថ្ងៃដែលពួកខ្មែរក្រហមមកដល់។ លោកសង្ឃ និងប្រជាជនត្រូវបានគេដេញចេញទៅតាមផ្លូវជាតិលេខ៤ ដោយមានរ៉ែកមាន់ រ៉ែកទា ចានឆ្នាំងទៅជាមួយផង"]។

ហើយកាន់កាប់ទីនោះ[1645]។ មានភស្តុតាងបង្ហាញថា នៅខែ ឧសភា-មិថុនា ឆ្នាំ ១៩៧៥[1646] នៅវត្ត ឥន្ទញ្ញាណ មានអ្នកទោសចំនួនតិចតួច តែវត្តនេះដំណើរការជាមន្ទីរសន្តិសុខពេញលេញ នៅពាក់ក

1645 ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.12, 14, 25 ["លុះព្រឹកឡើងថ្ងៃទី ១៨ ខែ មេសា កងវរៈ៤២០ និងកងពិសេសត្រូវបានបញ្ជូនមកក្រុងកំពង់សោម។ កងវរៈ៤២០ ពេលនោះគេទៅស្នាក់នៅរាម ហើយកងពិសេស [កងវរៈ៤៥០] នៅកំពង់សោម។ ក្រោយពីមេបញ្ជាការរបស់ខ្ញុំ ស សាមឿន ជារបួស គាត់ក៏បាន មកកាន់អង្គភាពកងពិសេសរបស់គាត់នៅកំពង់សោម។ នៅពេលនោះគាត់មកយកខ្ញុំពីរាមមកនៅជាមួយគាត់នៅកំពង់ សោមវិញ។ [...] ឆ.14៖ ពេលមកដល់ដំបូង គាត់ស្នាក់នៅកន្លែងឃ្លាំងប្រាក់ ឬធនាគារជាតិនៅជិតផែកប៉ាល់។ ពីរបី ថ្ងៃក្រោយមកទើបរើទៅនៅវត្តឥន្ទញ្ញាណ [...] ឆ.25៖ ខ្ញុំនៅទីនោះចាប់ពីខែ៥ រហូតដល់ខែ៨ ឬខែ៩ ឆ្នាំ១៩៧៥"]។ ឯកសារ D114/187 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.17-18 ["សៈ តើលោកអាចប្រាប់យើងបានទេ តើកង វរសេនាតូច ៤៥០ មានទីតាំងនៅឯណាដែរ? ឆ.17៖ អង្គភាពនេះទៅដល់ក្រុងព្រះសីហនុ ៧៥ យើងនៅតំបន់ឃ្លាំង ប្រាក់ ប៉ោយលំហែកាយមាននៅវត្តឥន្ទញ្ញាណ ហើយមានកន្លែងផ្សេងទៀត នៅកំពង់សោមហ្នឹងហ្នង [...] ឆ.18៖ ពេលហ្នឹងកន្លែងវត្តហ្នឹង វាមានទីទូល ដូច្នេះហ្នឹងត្រូវបានបង ស សាមឿន នៅកន្លែងហ្នឹងដើម្បីដាក់វិទ្យុទាក់ទង។ [...] ពេលហ្នឹងខ្ញុំនៅវត្តឥន្ទញ្ញាណដែរនៅឆ្នាំ ៧៥ កាលហ្នឹង"]។

1646 ដូចមានពន្យល់ខាងក្រោមនេះ ទាហានអាមេរិកាំងចំនួនពីរនាក់ត្រូវបានឃុំឃាំងនៅវត្តឥន្ទញ្ញាណក្នុងខែ ឧសភា-មិថុនា ឆ្នាំ ១៩៧៥។ សូមមើល ផងដែរ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.88 ["សៈ តើលោកបាន មានទៅវត្តឥន្ទញ្ញាណដែរឬទេ? ឆ.88៖ ខ្ញុំធ្លាប់បានទៅវត្តឥន្ទញ្ញាណម្តងនៅក្នុងឆ្នាំ ១៩៧៥។ ខ្ញុំឃើញថាវត្តនោះស្ងាត់ អត់មានមនុស្សនៅ ហើយនៅស្អាត។ ខ្ញុំបានចូលទៅវត្តនោះក្រោយពីព្រឹត្តិការណ៍ចាប់នាវាម៉ាយ៉ាហ្គេស"]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.13 ["ខ្ញុំធ្លាប់ទៅវត្តឥន្ទញ្ញាណហ្នឹង បន្ទាប់ពីរំដោះហើយភ្លាម ឆ្នាំ ១៩៧៥ មុនពេលគេប្រើធ្វើជាមន្ទីរសន្តិសុខ។ [...] នៅពេលដែលគេមានបញ្ហារឿងពួកក្បត់។ ខ្ញុំមិនដឹងថាឆ្នាំណាពិត ប្រាកដទេ ដែលគេប្រើធ្វើជាមន្ទីរសន្តិសុខនោះ"]។ សាក្សី ទូច សឿលី បាននិយាយថា មិនមានអ្នកទោសនៅវត្តឥន្ទ ញ្ញាណទេ នៅពេលដែលគាត់បានចេញពីទ័ពជើងទឹកជាមួយ សាមឿន នៅខែ៨ ឬខែ៩ ក្នុងឆ្នាំ ១៩៧៥ (សូមមើល ឯក សារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.19, 25 ["សៈ នៅទីនោះកាលពីដំបូងលោកថា អត់មានអ្នកទោសនៅទេ តើមែនទេ? ឆ.19៖ បាទ ពិតមែនហើយ។ [...] សៈ តើនៅពេលនោះ តើលោករស់នៅនឹងវត្ត ឥន្ទញ្ញាណរហូត ឬយ៉ាងណា? ឆ.25៖ ខ្ញុំនៅទីនោះចាប់ពីខែ៥ រហូតដល់ខែ៨ ឬខែ៩ ឆ្នាំ ១៩៧៥។ ខ្ញុំចេញពីវត្តទៅនៅ ទួលមួយចម្ងាយប្រហែល១៥០០ម៉ែត្រពីខាងកើតវត្ត។ ពីរបីខែក្រោយមក ប្រហែលជានៅខែ១១ ឬខែ១២ ឆ្នាំ១៩៧៥ ខ្ញុំមកស្នាក់នៅ [...] ដើម្បីមករៀននយោបាយ"]។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយបន្ទាប់មកទៀត ទូច សឿលី បាន កំណត់កាលបរិច្ឆេទការចាកចេញរបស់គាត់នៅខែ តុលា ឬ ខែ វិច្ឆកា ឆ្នាំ ១៩៧៥ (សូមមើល ឯកសារ D114/187 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.20-21 ["សៈ តើលោកដឹងថាមន្ទីរសន្តិសុខបានកើតឡើងនៅឆ្នាំណាដែរ? ឆ. 20៖ ខ្ញុំមិនដឹងកើតឡើងឆ្នាំណាទេ។ ពេលខ្ញុំចេញពីហ្នឹងទៅ ប្រហែលជាខែ ១០ ១១ ឆ្នាំ៧៥។ ខ្ញុំចេញទៅរៀននៅ សាលារោងកុន។ សៈ តើមានអ្នកទោសត្រូវគេឃុំនៅវត្តឥន្ទញ្ញាណ នៅពេលដែលលោកចាកចេញពីវត្តនោះដែរឬទេ? ឆ.21៖ អត់មានទេ។ ពេលដែលខ្ញុំនៅហ្នឹង គឺចេញទៅទាំងអស់គ្នា"]។) ដោយសារ ស សាមឿនត្រូវបានចាត់តាំងឲ្យ

ណ្តាល ឆ្នាំ១៩៧៥ ទំនងប្រហែលខែ សីហា ឆ្នាំ ១៩៧៥ ពេលដែល នន កាន់នាទីជាមេបញ្ជាការវរសនាតូចពិសេសលេខ៤៥០/១៦៥[1647]។ វត្តឥន្ទញ្ញាណបានបន្តប្រើជាមន្ទីរសន្តិសុខរហូតដល់ចុងនៃរបបកម្ពុជាប្រជាធិបតេយ្យ។[1648] តាមពិត មូល ឈិន បានជាប់ឃុំឃាំងនៅវត្តឥន្ទញ្ញាណ រហូតប៉ុន្មានថ្ងៃមុនវៀតណាមមកដល់ក្នុងឆ្នាំ១៩៧៩[1649]។

---

ទៅកងវរៈសេនាធំ ១៤០ នៅពេលដែលកងនេះត្រូវបានបង្កើតនៅក្នុងខែ សីហា ឆ្នាំ ១៩៧៥ ដូច្នេះ កាលបរិច្ឆេទមុននេះគឺទំនងជាអាចត្រឹមត្រូវបំផុត។

1647 ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ.89-90, 96 ["មន្ទីរសន្តិសុខនោះ [និយាយអំពីវត្តឥន្ទញ្ញាណ] គេប្រើសម្រាប់ឃុំខ្លួនមនុស្សបណ្តោះអាសន្នដែលមានបញ្ហាបន្តិចបន្តួច ហើយក្រោយមកគេបញ្ជូនអ្នកទាំងនោះចេញ ក៏ប៉ុន្តែខ្ញុំមិនដឹងថាគេបញ្ជូនទៅទីណាទេ។ [...] ឆ.90៖ ព្រឹត្តិការណ៍កើតឡើងនៅក្នុងឆ្នាំ ១៩៧៥។ សៈ តើលោកដឹងថាវត្តហ្នឹងគេប្រើជាមន្ទីរសន្តិសុខនៅពេលណាដែរ? ឆ.96៖ ខ្ញុំដឹងថាវត្តហ្នឹងគេប្រើជាមន្ទីរសន្តិសុខ នៅ៣ខែក្រោយ ថ្ងៃរំដោះ ១៧ មេសា ឆ្នាំ១៩៧៥"]។ ឯកសារ D114/217 កំណត់ហេតុស្តាប់ចម្លើយ នាក់ ខឿន ឆ.9 ["ឮថាវត្តឥន្ទញ្ញាណ ឮថាកន្លែងគេដាក់អ្នកទោស។ កាលពេលនោះ ខ្ញុំនាំគ្នាដើរកាលឆ្នាំ១៩៧៥ ឬ១៩៧៦ ខ្ញុំភ្លេចហើយ ព្រោះយូរហើយ ខ្ញុំទៅគ្នាពីរបីនាក់ ដើររកដកដំឡូងហូប។ ស្រាប់តែខ្ញុំដើរកាត់មុខវត្តហ្នឹង ឃើញអ្នកទោសត្រូវដាក់ច្រវាក់"]។ សូមមើល ផងដែរ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.13 ["ខ្ញុំធ្លាប់ទៅវត្តឥន្ទញ្ញាណ [...] គេ [ខ្មែរក្រហម] ចាប់ប្រើវត្តហ្នឹងធ្វើជាមន្ទីរសន្តិសុខ នៅពេលដែលគេមានបញ្ហារឿងពួកក្បត់"]។

1648 ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.18, ឯកសារ D54/37 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.2 និង ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.9 [បញ្ជាក់ថាគាត់មានឃើញមន្ទីរសន្តិសុខនេះដំណើរការត្រឹមឆ្នាំ ១៩៧៦]។ ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964127 ["សៈ [និយាយពីវត្តឥន្ទញ្ញាណ] កន្លែងហ្នឹងមានតាំងពីឆ្នាំណាមក? ឆៈ មាននៅក្នុងឆ្នាំ ចុងឆ្នាំ ៧៦។ សៈ ចុងឆ្នាំ៧៦? ឆៈ បាទ! សៈ ហើយរហូតដល់ពេលណា? ឆៈ រហូតដល់ទល់គ្នាឆ្នាំ៧៩ហ្នឹងហ្មង"]។ ឯកសារ D1.3.12.20 (សូមមើលផងដែរ ឯកសារ D4.1.639) របាយការណ៍កម្ពុជាប្រជាធិបតេយ្យ "សេចក្តីរាយការណ៍តាមទូរសព្ទសម្ងាត់" ពី មាស មុត ទៅ សុន សេន នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៧ EN 00233972, FR 00623197-00623198, KH ERN 00020912 [រៀបរាប់ភាគច្រើនពីការចាប់អ្នកនេសាទថៃនៅឯសមុទ្រ និងការសួរចម្លើយជាបន្តបន្ទាប់នៅកំពង់សោម]។ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.1 ["ខ្ញុំមិនដឹងថាមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណចាប់ផ្តើមដំណើរការនៅឆ្នាំណាទេ។ នៅឆ្នាំ១៩៧៧ ពេលដែលខ្ញុំរស់នៅទីនោះ ខ្ញុំឃើញថាមន្ទីរសន្តិសុខនោះដំណើរការហើយ ហើយវាដំណើរការរហូតដល់របបកម្ពុជាប្រជាធិបតេយ្យដួលរលំនៅឆ្នាំ១៩៧៩"]។ ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.27, 41 ["សៈ ក្នុងឆ្នាំ១៩៧៧ លោកបានធ្វើដំណើរទៅវត្តឥន្ទញ្ញាណមួយភ្លែត ហើយលោកបានឃើញអ្នកទោស តើលោកអាចរៀបរាប់លម្អិតក្នុងរឿងនេះបានទេ? [...] ឆ.27៖ ជាចៃដន្យខ្ញុំបានជួបអ្នកដែលធ្លាប់ស្គាល់គ្នាម្នាក់បានខ្សិបប្រាប់ខ្ញុំថាបន្ទប់ជាន់ក្រោមនោះ គឺមានដាក់ឃុំឃាំងមនុស្ស។ ដោយខ្ញុំមានការចង់ដឹង ថាពិត ឬមិនពិត ខ្ញុំបានលៀងដើរកាត់មុខបន្ទប់ទើបឃើញថាមានអ្នកទោសនៅក្នុងនោះ

## រចនាសម្ព័ន្ធអំណាច

444. វត្តឥន្ទញ្ញាណ គឺជាមន្ទីរសន្តិសុខនិងឃុំឃាំង នៃកងពល ១៦៤របស់ **មាស មុត**[1650] ហើយច្បាស់ណាស់ស្ថិតក្នុងក្របខណ្ឌនៃការទទួលខុសត្រូវរបស់គាត់[1651]។ **មាស មុត** ចាត់ចែង"ផ្ដាច់មុខ" វត្តឥន្ទញ្ញាណ[1652] ហើយបានពាក់ព័ន្ធស៊ីជម្រៅក្នុងការដំណើរការមន្ទីរនេះ។

---

មែន។ [...] ឆ.41៖ នៅឆ្នាំ១៩៧៧ គឺស្ថានភាពទូទៅគឺវាមានភាពច្របូកច្របល់ណាស់ សូម្បីតែខ្លួនខ្ញុំ ក៏ខ្ញុំមានការភ័យខ្លាចសម្រាប់ខ្លួនឯងដែរ"]។ ឯកសារ D114/187 កំណត់ហេតុស្ដាប់ចម្លើយ ទូច សឿលី ឆ.34 ["ស៖ តើលោកចាំទេថា នៅខែណា ដែលលោកបានត្រឡប់ទៅវត្តហ្នឹងវិញនៅក្នុងឆ្នាំ ១៩៧៧? ឆ.34៖ ខ្ញុំមិនចាំថ្ងៃខែទេ ប៉ុន្តែគ្រាន់តែដឹងថាក្នុងឆ្នាំ៧៧"]។ ឯកសារ D54/48 កំណត់ហេតុស្ដាប់ចម្លើយ អែម សុន ឆ.44 ["នៅពេលដែលខ្ញុំធ្វើការនៅផែ ពេលខ្លះខ្ញុំបានដើរឆ្លងកាត់វត្តឥន្ទញ្ញាណ ខ្ញុំបានឃើញអ្នកទោសធ្វើការនៅទីនោះ ហើយមានអ្នកយាម។ គ្រប់ៗគ្នាបានដឹងថាវត្តឥន្ទញ្ញាណជាមន្ទីរសន្តិសុខរបស់កងពល១៦៤។ ខ្ញុំដឹងថាវាជាមន្ទីរសន្តិសុខនៅចុងឆ្នាំ១៩៧៧ ឬក៏ដើមឆ្នាំ១៩៧៨"]។

1649 ឯកសារ D114/40 កំណត់ហេតុស្ដាប់ចម្លើយរបស់ មូល ឈិន ឆ.1-2 ["ដំបូងខ្ញុំជាប់គុកនៅទឹកសាបពាថ្ងៃ មុនពេលដែលគេយកខ្ញុំទៅដាក់គុកនៅវត្តឥន្ទញ្ញាណពាថ្ងៃទៀត។ ក្រោយមក គេដោះលែងខ្ញុំ ហើយខ្ញុំក៏បានធ្វើដំណើរដោយថ្មើរជើងដោយខ្លួនឯងពីវត្តឥន្ទញ្ញាណទៅទឹកសាបវិញ ជាកន្លែងដែលខ្ញុំបានសម្រាក១យប់ ហើយនៅព្រឹកបន្ទាប់ ខ្ញុំបានឃើញកងទ័ពវៀតណាមចូលមកដល់តែម្ដង ហើយខ្ញុំបានរួចខ្លួនពីគុកនោះ [...] ឆ.2៖ ពេលខ្ញុំរួចខ្លួនពីវត្តឥន្ទញ្ញាណមក [...] គេឲ្យខ្ញុំត្រឡប់មកកន្លែងទឹកសាប [...] គេឲ្យខ្ញុំជួយសែងឈើនៅក្នុងរោងអារឈើនោះ តែពុំបានធ្វើផង វៀតណាមចូលមកដល់"]។ សូមមើល ផងដែរ ឯកសារ D114/31 កំណត់ហេតុស្ដាប់ចម្លើយ មូល ឈិន ឆ.160 ["គឺជាអតីតវត្ត ហើយដោយសារទីធ្លាធំ គឺគេប្រើសម្រាប់ដាក់អ្នកទោស។ តាមខ្ញុំដឹងគេប្រើវត្តនេះជាគុក រហូតដល់ចុងរបបខ្មែរក្រហមនៅឆ្នាំ ១៩៧៩"]។

1650 ឯកសារ D114/66 កំណត់ហេតុស្ដាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.14 ["ស៖ តើលោកធ្លាប់ឮកន្លែងមួយ ហៅថា វត្តឥន្ទញ្ញាណ ហៅវត្តក្រោមដែរឬទេ? ឆ.14៖ បាទ វាគឺជាគុករបស់កងពល១៦៤ របស់ តាមុត"]។ ឯកសារ D54/102 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.6 ["វត្តឥន្ទញ្ញាណគឺជាមន្ទីរសន្តិសុខ និងមន្ទីរឃុំឃាំងរបស់កងពល១៦៤ របស់ មាស មុត។"]។ ឯកសារ D54/25 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.23 ["កាលខ្ញុំនៅកងវរសេនាធំ១៤០ គឺខ្ញុំរស់នៅក្នុងផ្ទះមួយជិតវត្តឥន្ទញ្ញាណ។ វត្តឥន្ទញ្ញាណ គឺជាកន្លែងឃុំឃាំងអ្នកទោស"]។ ឯកសារ D54/26 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.4, 6-7 ["ខ្ញុំអាចមើលពីខាងក្រៅឃើញចេតិយធំៗ។ យើងឃើញរបងធ្វើពីលួសបន្លា និងបង្គោលឈើ។ ខ្ញុំមិនដឹងថាមានអ្វីទៀតទេ ពីព្រោះខ្ញុំមិនហ៊ានចូលទៅជិតទីនោះទៀតទេ។ [...] ស៖ តើមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណស្ថិតនៅក្រោមការគ្រប់គ្រងថ្នាក់ណា? ឆ.6៖ មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណស្ថិតនៅក្រោមកងពល១៦៤។ ស៖ ហេតុអ្វីបានជាលោកដឹងថាវាស្ថិតនៅក្រោមថ្នាក់កងពល? ឆ.7៖ ពីព្រោះវាជាកន្លែងហាមឃាត់។ កាលណាវាកន្លែងហាមឃាត់ដូច្នេះ វាជារបស់កងពល"]។ ឯកសារ D114/31 កំណត់ហេតុស្ដាប់ចម្លើយ មូល ឈិន ឆ.160 ["ស៖ តើលោកដឹងអ្វីខ្លះពីវត្តឥន្ទញ្ញាណ? ឆ.160៖ គឺជាអតីតវត្ត ហើយដោយសារទីធ្លាធំ គឺគេប្រើសម្រាប់ដាក់អ្នកទោស"]។ ឯកសារ D114/40 កំណត់ហេតុស្ដាប់ចម្លើយរបស់ មូល ឈិន ឆ.4, 36, 45 ["គុកទឹកសាប និងគុកវត្តឥន្ទញ្ញាណ គឺ

គ្រប់គ្រងដោយយោធាកងពលលេខ៣ [...] ស៖ លោកបាននិយាយក្នុងការស្តាប់ចម្លើយលើកមុនអំពីការជាប់ឃុំឃាំងរបស់លោកនៅវត្តឥន្ទញ្ញាណ។ ក្នុងពេលកំណត់អត្តសញ្ញាណទីតាំង យើងបាននាំលោកទៅវត្តមួយនៅក្នុងក្រុងកំពង់សោមហៅវត្តឥន្ទញ្ញាណ ឬវត្តក្រោម។ តើកន្លែងនេះមែនទេ ដែលលោកត្រូវបានឃុំឃាំង? ឆ.36៖ ត្រឹមត្រូវហើយ។ [...] ស៖ តើពេលនោះលោកស្គាល់វត្តឥន្ទញ្ញាណដែរឬទេ? ឆ.45៖ នៅពេលនោះ គេដឹងថាជាកន្លែងយកអ្នកទោសទៅឃុំឃាំង”]។ ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.44 [“គ្រប់ៗគ្នាបានដឹងថាវត្តឥន្ទញ្ញាណជាមន្ទីរសន្តិសុខរបស់កងពល១៦៤”]។ ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី EN 01070563, FR 00976267, KH ERN 00964137 [“មានតែ មុត ម្នាក់ទេដែលចាត់ចែង អ្នកសម្រេច [...] ឯខាង មាស មុត ខាងយោធា។ ស៖ អញ្ចឹងយោធាជាអ្នកគ្រប់គ្រងកន្លែងឥន្ទញ្ញាណហ្នឹង? ឆ៖ បាទ! យោធាជាអ្នកគ្រប់គ្រង”]។ ឯកសារ D1.3.13.8 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ ប៉ែន សារិន EN 00217562 [“សាក្សីបាននិយាយថាវត្តឥន្ទញ្ញាណគឺជាកន្លែងឃុំឃាំង [...] កន្លែងឃុំឃាំងស្ថិតនៅក្រោមកងពលធំលេខ១ ដែលដឹកនាំដោយ មាស មុត ដែលជាអ្នកទទួលខុសត្រូវគ្រប់គ្រោងក្រុង”]។ ឯកសារ D54/111 កំណត់ហេតុស្តាប់ចម្លើយ សំ ភីន ឆ.14 [“ស៖ តើលោកធ្លាប់ស្គាល់កន្លែងមួយនៅកំពង់សោមហៅថា វត្តឥន្ទញ្ញាណដែរឬទេ? ឆ.14៖ បាទ ខ្ញុំធ្លាប់ឮកន្លែងវត្តឥន្ទញ្ញាណ វាជាគុក ឬមន្ទីរសន្តិសុខ”]។ សូមមើល ផងដែរ ឯកសារ D1.3.13.13 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ ទូច សឿលី EN 00217575 [“សាក្សីនិយាយថា វត្តឥន្ទញ្ញាណគឺជាកន្លែងឃុំឃាំង។ [...] វត្តឥន្ទញ្ញាណគឺជាកន្លែងឃុំឃាំង។ គាត់ដឹងពីអ្នកដែលធ្វើការនៅកន្លែងជាមួយគ្នាថាជាកន្លែងឃុំឃាំង។”]។ ឯកសារ D1.3.13.1 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ ប៉ូច កុយ EN 00217557 [“ក្នុងអំឡុងរបបខ្មែរក្រហម វត្តឥន្ទញ្ញាណត្រូវបានប្រើប្រាស់ជាមន្ទីរឃុំឃាំង”]។

1651 ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.9 [“តំបន់ទឹកដីដែលស្ថិតនៅក្រោមបញ្ជារបស់ មាស មុត លាតសន្ធឹងតាំងពី ទឹកសាប កងកេង រាម កំពង់សោម ហើយនិងកោះទាំងអស់នៅក្នុងសមុទ្រ។ កន្លែងតំបន់ទាំងអស់នេះហៅថាតំបន់ស្វយ័តដែលស្ថិតនៅក្រោមអំណាចរបស់ មាស មុត”]។ ឯកសារ D54/51 កំណត់ហេតុស្តាប់ចម្លើយ មាស វឿន (ស្វាយ វឿន) ឆ.17 [“កងទ័ពជើងទឹកត្រួតត្រាដីគោក ចាប់ពីវាលរេញរហូតដល់កំពង់សោម”]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.83 [“មានតែកងពល ១៦៤ នៅខេត្តកំពង់សោម”]។ សូមមើល ផងដែរ ឯកសារ D2/22 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងនៃមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ EN 00634139, FR 00725835, KH ERN 00662103 [“វត្តឥន្ទញ្ញាណគឺជាមន្ទីរសន្តិសុខក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ នៅក្រោមតំបន់ទទួលខុសត្រូវ និងក្រោមការគ្រប់គ្រោងរបស់កងពលធំ១៦៤ (កងពលធំលេខ៣)”]។

1652 ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964137 [“ស៖ ប៉ុន្តែនៅ វត្តឥន្ទញ្ញាណមិនមែន តាគ្រិន ទៅគ្រប់គ្រងទេ? ឆ៖ អត់ទេ។ ស៖ ទៅតែ តាមុត ម្នាក់ទេ? ឆ៖ បាទ! មានតែ មុត ម្នាក់ទេដែលចាត់ចែង អ្នកសម្រេច ហើយការផ្គត់ផ្គង់ពី តាឡូញ ទេ។ [...] ឆ៖ [មុត] ផ្តាច់មុខអស់ហើយ”]។ សូមមើល ផងដែរ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.33 [“ឈ្មោះ ឡូញ គឺជាអ្នកទទួលខុសត្រូវផ្នែកភស្តុភារ និងនេសាទ ហើយប្រចាំការនៅកំពង់សោម”]។

445. ដូចបានរៀបរាប់ពិស្តារខាងលើ វរសេនាតូចពិសេស១៦៥/៤៥០ របស់**មាស មុត** គ្រប់គ្រងមន្ទីរនេះ[1653] ជាផ្នែកមួយនៃការទទួលខុសត្រូវរបស់ខ្លួនចំពោះសន្តិសុខកងពល ១៦៤[1654]។ **មាស មុត** មកវត្តឥន្ទញ្ញាណយ៉ាងហោចណាស់មួយខែម្តង[1655] ដើម្បី "មកមើលស្ថានការណ៍នៅវត្តឥន្ទញ្ញាណ"[1656] ហើយប្រហែលយកស្បៀងមកឱ្យអ្នកយាមទីនោះ។[1657] ការិយាល័យកងពល ១៦៤និងផ្ទះរស់នៅរបស់គាត់ផ្ទាល់ស្ថិតនៅជិតគ្នា[1658] ហើយ **មាស មុត** ជារឿយៗ សរុបជាមួយគ្នា តែម្តងការចុះពិនិត្យទីនេះផង និងទៅប្រជុំនៅទីតាំងផ្សេងៗផង ដែលប្រតិបត្តិការដោយកងពល

---

1653 ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.23-24, 30 ["កង៤៥០ត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវខាងផ្នែកសន្តិសុខវិញ។ ស៖ តើនៅមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណឬយ៉ាងណា? ឆ.24៖ មិនមែនតែកន្លែងវត្តឥន្ទញ្ញាណហ្នឹងទេ [...] ស៖ នៅពេលនោះ [ឆ្នាំ ១៩៧៧] លោកទៅកន្លែងវត្តឥន្ទញ្ញាណ តើអ្នកដែលយាមនៅទីនោះជាយោធារបស់កងវរៈ៤៥០ ឬយ៉ាងណា? ឆ.30៖ បាទពិតមែន"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.12, 92 ["យោធាខ្លះ [ក្នុងកងវរៈសេនាតូច៤៥០] ត្រូវបានបញ្ជូនទៅការពារនៅតំបន់ផ្សេងគ្នានៅកំពង់សោម ដោយខ្លះបញ្ជូនទៅការពារនៅតាមឆ្នេរ [...] និងវត្តឥន្ទញ្ញាណ។ [...] ឆ.92៖ ខ្ញុំដឹងថាមន្ទីរសន្តិសុខនោះ [នៅវត្តឥន្ទញ្ញាណ] គ្រប់គ្រងដោយនីរសាវរៈសេនាតូច៤៥០"]។

1654 សូមមើល ឯកសារខាងលើ VIII.C.2 ការចាប់ខ្លួន និងការឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខកងពល១៦៤ –ការសម្លាប់អ្នកដែលត្រូវចាំខ្លួន។

1655 ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.13 ["យើងតាមការដឹងរបស់ខ្ញុំ គាត់មកវត្តឥន្ទញ្ញាណ១ខែម្តង [...] គាត់មកមួយខែម្តង បន្ទាប់ពីគាត់ត្រឡប់មកពីការប្រជុំនៅស្ទឹងហាវ។"]។ ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964129 ["ស៖ តាមុត មានដែលទៅកន្លែងហ្នឹងដែរទេ? ឆ៖ គាត់ចេញចូលហ្នឹងដែរ"]។

1656 ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.38 ["បើតាមខ្ញុំគិត តាមុតមកជួបអ្នកទទួលខុសត្រូវ ហើយមកមើលស្ថានការណ៍នៅវត្តឥន្ទញ្ញាណ"]។

1657 ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.12-15 ["មាស មុត បានយកម្ហូបអាហារនៅក្នុងឡានហ្ស៊ីបរបស់គាត់យកទៅឱ្យអ្នកយាមនៅវត្តឥន្ទញ្ញាណ [...] ឆ.13៖ យោងតាមការដឹងរបស់ខ្ញុំ គាត់មកវត្តឥន្ទញ្ញាណមួយខែម្តង [...] ឆ.14៖ ខ្ញុំសម្គាល់ឃើញ មាស មុត យកម្ហូបអាហារទៅផ្តល់ឱ្យអ្នកយាមនៅវត្តឥន្ទញ្ញាណ១ខែម្តង។ [...] ឆ.15៖ ខ្ញុំដឹងតាមរយៈអ្នកយាមនៅវត្តឥន្ទញ្ញាណពីរនាក់ថា មាស មុត នាំយកម្ហូបអាហារមកឱ្យពួកគេ"]។

1658 សូមមើល កថាខណ្ឌ ៤៤១។ សូមមើល បន្ថែមទៀត ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.37 ["ឧទាហរណ៍ ក្រោយពីពេលគាត់មកពីរាម ឬកងកេង តាមុតគ្រាន់តែឈប់នៅក្នុងវត្តមួយភ្លែត ហើយគាត់វិលត្រឡប់ទៅផ្ទះគាត់នៅផ្សារលើវិញ"]។ ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964129 ["ស៖ តាមុត មានដែលទៅកន្លែងហ្នឹងដែរទេ? ឆ៖ គាត់ចេញចូលហ្នឹងដែរ"]។ ស៖ ផ្ទះគាត់នៅក្បែរហ្នឹងដែរអត់ទេ [វត្តឥន្ទញ្ញាណ]? ឆ៖ មុត ផ្ទះនៅនេះហ្នឹង"]។

១៦៤ ដូចជាស្ទឹងហាវ[1659] រាម ឬ កង កេង។[1660] សាក្សី ស៊ឹម នី ដែលបំភ្លឺថាគាត់បានធ្វើការនៅចម្ការនៅខាងក្រៅវត្តឥន្ទញ្ញាណនោះ ពីពាក់កណ្ដាលឆ្នាំ ១៩៧៦ ដល់ដើមឆ្នាំ ១៩៧៧[1661] ពន្យល់ថាគាត់ផ្ទាល់បានឃើញ **មាស មុត** មកពិនិត្យវត្តពីរដង[1662]។ គាត់ចាំបានថា **មាស មុត** ជិះឡានហ្ស៊ីបចិនមក[1663] ដូចគ្នានឹងសាក្សីម្នាក់ទៀតបំភ្លឺដែរ[1664]។ សហការីរបស់ **មាស មុត** ឈ្មោះឡូញ សមាជិក ប.ក.ក ក្រុងកំពង់សោម (មកពីខាងនេសាទរដ្ឋ)[1665] ក៏បានមកពិនិត្យមន្ទីរសន្តិសុខនេះដែរ ពេលខ្លះមកជាមួយ មាស មុត[1666] យកស្បៀងមក[1667]។

---

1659 ឯកសារ D54/88 កំណត់ហេតុស្ដាប់ចម្លើយ ស៊ឹម នី ឆ.13 ["គាត់មក១ខែម្ដង បន្ទាប់ពីគាត់ត្រឡប់មកពីការប្រជុំនៅស្ទឹងហាវ"]។

1660 ឯកសារ D54/32 កំណត់ហេតុស្ដាប់ចម្លើយ ស៊ឹម នី ឆ.37 ["ឧទាហរណ៍ ក្រោយពីពេលគាត់មកពីរាម ឬកងកេង តាមុតគ្រាន់តែឈប់នៅក្នុងវត្តមួយភ្លែត ហើយគាត់វិលត្រឡប់ទៅផ្ទះគាត់នៅផ្សារលើវិញ"]។

1661 ឯកសារ D54/88 កំណត់ហេតុស្ដាប់ចម្លើយ ស៊ឹម នី ឆ.9 ["តាមការអង្កេតរបស់ខ្ញុំនេះ គឺចាប់ពីពាក់កណ្ដាល១៩៧៦ រហូតមកដល់១៩៧៧"]។ ឯកសារ D54/32 កំណត់ហេតុស្ដាប់ចម្លើយ ស៊ឹម នី ឆ.5 ["នៅពេលនោះ ខ្ញុំបានឃើញអ្វីៗដែលកើតឡើង នៅវត្តឥន្ទញ្ញាណ ដោយសារ ខ្ញុំទៅដាំបន្លែនៅទីនោះ"]។

1662 ឯកសារ D54/88 កំណត់ហេតុស្ដាប់ចម្លើយ ស៊ឹម នី ឆ.12, 18 ["ខ្ញុំធ្លាប់ឃើញ មាស មុត ពីរដង។ មាស មុត ធ្វើដំណើរដោយឡានហ្ស៊ីព A2 សំដៅទៅទិសវត្តឥន្ទញ្ញាណ [...] ឆ.18៖ ខ្ញុំឃើញ មាស មុត ជិះឡានទៅវត្តឥន្ទញ្ញាណចំនួនពីរដង"]។ សូមមើល ផងដែរ ឯកសារ D54/32 កំណត់ហេតុស្ដាប់ចម្លើយ ស៊ឹម នី ឆ.35 ["តាមុតគាត់មក [វត្តឥន្ទញ្ញាណ] ដោយជិះឡានហ្ស៊ីបចិនដោយមានអ្នកបើកម្នាក់ និងនីរសាររបស់គាត់កម្នាក់"]។

1663 ឯកសារ D54/32 កំណត់ហេតុស្ដាប់ចម្លើយ ស៊ឹម នី ឆ.35 ["តាមុតគាត់មក [វត្តឥន្ទញ្ញាណ] ដោយជិះឡានហ្ស៊ីបចិនដោយមានអ្នកបើកម្នាក់ និងនីរសាររបស់គាត់កម្នាក់"]។

1664 ឯកសារ D114/116 កំណត់ហេតុស្ដាប់ចម្លើយ ស្វាយ សំអាន ឆ.8 ["ស៖ នៅពេលលោកឃើញ មាស មុត មកដល់ [ទឹកសាប] [...] [តើ]វាជាប្រភេទឡានអ្វី? ឆ.8៖ ឡានហ្ស៊ីបចិន"]។

1665 ឯកសារ D54/31 កំណត់ហេតុស្ដាប់ចម្លើយ ស៊ឹម នី ឆ.10-12 ["មាស មុត ជា គ្រិន និងតាឡូញ គឺជាគណៈកម្មការមជ្ឈឹមនៅកំពង់សោម។ មាស មុត ទទួលខុសត្រូវខាងយោធា ហើយ ជា គ្រិន ទទួលខុសត្រូវខាងកំពង់ផែ និងរោងចក្រប្រេងកាត ឯ ឡូញ ទទួលខុសត្រូវខាងនេសាទ [...] ឆ.11៖ មាស មុត គឺជាប្រធានធំជាងគេ បន្ទាប់មក ជា គ្រិន និង ឡូញ [...] ឆ.12៖ ពួកគេត្រូវបានចាត់តាំងឱ្យទទួលខុសត្រូវមុខងារផ្សេងៗគ្នា ប៉ុន្តែស្ថិតនៅក្រោមការត្រួតត្រារបស់ មាស មុត"]។ ឯកសារ D22.1.10 ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបរទេស (FBIS) គណៈប្រតិភូចិនបានមកទស្សនកិច្ចនៅតំបន់កំពង់សោមថ្ងៃទី ១២ ខែ ធ្នូ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 01509279 ["សមមិត្ត ចិន យ៉ុងកុអេ [Chen Yung-kuei] និងសមមិត្តចិនដទៃទៀតត្រូវបានទទួលស្វាគមន៍យ៉ាងកក់ក្ដៅពីសំណាក់សមមិត្ត (ម៉ុត) លេខាធិការនៃគណៈកម្មាធិការបក្សកុម្មុយនីស្តកម្ពុជាប្រចាំក្រុងកំពង់សោម និងប្រធានគណៈកម្មាធិការបម្រើប្រជាជន

446. **មាស មុត** គឺជាអ្នក"បញ្ជូនបញ្ជេញ" ហើយ ក៏បានសួរចម្លើយអ្នកទោសយកភ័ស្តុតាងពីសកម្មភាពដែលបានចោទថាក្បត់[1668]។ តាមពិត ទូរលេខមួយក្នុងឆ្នាំ ១៩៧៧ បង្ហាញថា **មាស មុត** បានរាយការណ៍ពីការសួរចម្លើយអ្នកនេសាទថៃនៅកំពង់សោមៈ

> ម្សិលមិញថ្ងៃទី ១១-៨-៧៧ យើងចេញល្បាតចាប់បានទូក២ គ្រឿងៈ ៣៥០ សេះ និង ១៧៥ សេះ។ ទូកធុន១៧៥ សេះ មានមនុស្ស៥ នាក់ គ្មានប្រដាប់នេសាទទេ។ [...] យើងបានសួរ[...] ឥឡូវទាំង៥នាក់បានយកមកដល់កំពង់សោមហើយ។យើងកំពុងសួរថែមទៀត[1669]។

ប្រចាំក្រុងកំពង់សោម។ សមមិត្ត គ្រិន អនុលេខាធិការនៃគណៈកម្មាធិការបក្សកុម្មុយនីស្តកម្ពុជាប្រចាំក្រុងកំពង់សោម។ សមមិត្ត ឡាញ សមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជាប្រចាំក្រុងកំពង់សោម"]។

1666 ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.34 ["ខ្ញុំគ្រាន់តែឃើញតាមុត តាឡាញចូលទៅទីនោះ"]។

1667 ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964133 ["តាឡាញគាត់គ្រាន់តែមានការផ្គត់ផ្គង់ប៉ុណ្ណឹងឯង។ សៈ គាត់ផ្គត់ផ្គង់ជាស្បៀង? ឆៈ បាទ!"]។ ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.35 ["តាឡាញ គាត់ច្រើនតែជិះម៉ូតូហុងដាសេះអិលមកម្នាក់ឯង"]។ ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.20 ["សៈ តើលោកឃើញ ឡាញ ជិះម៉ូតូទៅកាន់វត្តឥន្ទញាណញឹកញាប់ប៉ុនណា? ឆ.20ៈ តែម្តងទេ [...] ប៉ុន្តែ ខ្ញុំជួប ឡាញ ស្ទើររាល់ថ្ងៃ ពេលគាត់ជិះម៉ូតូតាមផ្លូវនៅជិតចម្ការរបស់ខ្ញុំ។ [...] ពេលខ្លះគាត់ឆ្លើយថា គាត់ទៅវត្តឥន្ទញាណ ដើម្បីមើលពួកធ្វើការនៅទីនោះ"]។

1668 ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964133 ["ឯចំពោះការសួរចម្លើយកំណត់ហេតុអីនោះ តាឡាញ អត់ទេ។ សៈ ពីណាគេវិញអញ្ចឹង? ឆៈ មាស មុត ដដែលហ្នឹង តាឡាញគាត់គ្រាន់តែមានការផ្គត់ផ្គង់ប៉ុណ្ណឹងឯង។ [...] សៈ អញ្ចឹងអ្នកសួរចម្លើយបញ្ជូនបញ្ជេញអី [មនុស្ស] គឺ តាមុត? ឆៈ ហ្នឹងហើយ មាស មុត ទេជាអ្នកបញ្ជូនបញ្ជេញ"]។

1669 ឯកសារ D1.3.12.20 (សូមមើលផងដែរ ឯកសារ D4.1.639) របាយការណ៍កម្ពុជាប្រជាធិបតេយ្យ "សេចក្តីរាយការណ៍តាមទូរសព្ទសម្ងាត់" ពី មាស មុត ទៅ សុន សេន នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៧ EN 00233972, FR 00623197-00623198, KH ERN 00020912 ["ម្សិលមិញ ថ្ងៃទី ១១-៨-៧៧ យើងចេញល្បាតចាប់បានទូល ០២ គ្រឿងៈ ១ធុន ៣៥០-[សេះ] និងមួយទៀត ១៧៥-[សេះ]។ ទូកធុន ១៧៥សេះ មានមនុស្ស ០៥ នាក់ គ្មានប្រដាប់នេសាទទេ [...] យើងកំពុងសួរថែមទៀត [...] [ឥឡូវ ទាំង០៥នាក់បានយកមកដល់កំពង់សោមហើយ។] យើងកំពុងសួរថែមទៀត។ ទាំង៥នាក់នេះ មានខ្មែរម្នាក់ ក្រៅពីនេះសៀម។ [នៅលើទូក ១៧៥សេះ មានក្បូនឫស្សី១៥ (ចំណារពន្យល់ៈ បន្ទាប់ពីការទាក់ទងតាមទូរស័ព្ទជាមួយសមមិត្ត មុត សៀមបានបញ្ជាក់ថាមានក្បូនតែមួយប៉ុណ្ណោះ)]"។ (ការបកប្រែនៅក្នុងវង់ក្រចកត្រូវបានបកប្រែក្រៅផ្លូវការដោយ ក.ស.ព និងស្របតាមការបកប្រែជាភាសាខ្មែរ និងបារាំងរបស់ឯកសារនេះ)]។

សុន សេន ឆ្លើយថា៖

យើងខ្ញុំឲ្យ*សួរ*កខ្មែរខាងក្នុង[1670]។

447. ប្រហែលជាដោយសារគាត់បានពាក់ព័ន្ធផ្ទាល់នឹងទីតាំងនេះហើយ ទើបបានជា **មាស មុត** មិននិយាយការពិតអំពីការដឹងឮរបស់គាត់ចំពោះវត្តឥន្ទញាណ ហើយទោះជាមានការពាក់ព័ន្ធក៏ដោយ ក៏ពេលសម្ភាសន៍ជាមួយ David Kattenberg គាត់បានអះអាងថា "នៅកំពង់សោម អត់មានមន្ទីរឃុំឃាំងទេ"[1671] ក្នុងលក្ខណៈផ្ទុយគ្នាពីកាលពីឆ្នាំ ២០០១ ដែលគាត់បានប្រាប់ដល់អ្នកស៊ើបអង្កេតព័ត៌មានទាហ៊ានអាមេរិកបាត់ខ្លួនថា គាត់បានដឹងអំពី "វត្តទីនាំង" ហើយបានបន្ថែមថា "តើយើងអាចប្រើវត្តនេះធ្វើជាគុកឃុំឃាំងអាមេរិកម៉េចកើត បើយើងមិនបានចាប់ខ្លួនជនជាតិអាមេរិកណាម្នាក់ផង"[1672]។

---

1670 ឯកសារ D1.3.12.20 (សូមមើលផងដែរ ឯកសារ D4.1.639) របាយការណ៍កម្ពុជាប្រជាធិបតេយ្យ "សេចក្តីរាយការណ៍តាមទូរសព្ទសម្ងាត់" ពី មាស មុត ទៅ សុន សេន នៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៧៧ EN 00233972, FR 00623197-00623198, KH ERN 00020912 [សេចក្តីជូនដំណឹងបន្ថែមដោយ សុន សេន (ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៧៧) នៅ ខាងឆ្វេង៖ "១. យើងស្នើសុំឱ្យមានសំនួរទាំងនេះដើម្បីកំណត់អត្តសញ្ញាណបណ្តាញផ្ទៃក្នុង"]។

1671 ឯកសារ D54/16/1R បទសម្ភាសន៍ថតសម្លេងជាមួយ មាស មុត ដោយ ដេវិដ ខេតធិនបើក នៅខែ មេសា ឆ្នាំ ២០០៩ 42៖46-43៖50 ["ស៖ តើមានរឿងអ្វីកើតឡើងចំពោះពួកគេ? ពួកគេត្រូវបានត្រូវបានចាប់ដោយទូកមួយនៅកោះតាង នេះជាអ្វីដែលបានកើតឡើង តើពួកគេត្រូវបានយកទៅណា ? មាស មុត៖ តាមពិត អ្នកដឹងហើយថាមិនមានមន្ទីរឃុំឃាំងនៅកំពង់សោមទេ ប៉ុន្តែយើងហៅវាថាជាកន្លែងរក្សាទុកពួកគេយ៉ាងហោចណាស់មួយសប្តាហ៍ រង់ចាំមន្ត្រីមកពីរាជធានីភ្នំពេញមកហើយយកពួកគេទៅ។ ស៖ ប៉ុន្តែគាត់មិនបានសំដៅទៅមនុស្សទាំងនេះទេ បើនិយាយពីមនុស្សទូទៅ។ ស៖ មនុស្សត្រូវបានចាប់? មាស មុត៖ បាទ"]។

1672 ឯកសារ D22.2.181 បទសម្ភាសន៍ US POW/MIA ជាមួយ មាស មុត EN 00249697-98 ["មាស មុត បានស្គាល់ឈ្មោះ វត្តធិនៀន ប៉ុន្តែមិនមានព័ត៌មានអំពីការប្រើប្រាស់វត្តនោះជាពន្ធនាគារនោះទេ គ្រាន់តែសួររកថាហេតុអ្វីបានជាយើងប្រើវាជាគុកសម្រាប់ជនជាតិអាមេរិកាំង ពេលដែលយើងមិនបានចាប់ជនជាតិអាមេរិកាំងណាម្នាក់នោះ?"]។

# ឧក្រិដ្ឋកម្ម

## ការដាក់មន្ទីរឃុំឃាំង

448. *ការដកហូតសេរីភាពដោយគ្មានទីតិវិធីត្រឹមត្រូវ៖* នៅវត្តឥន្ទញ្ញាណ អ្នកទោស ត្រូវបានដកសិទ្ធិនិងសេរីភាពទាំងស្រុងក្នុងការដើរហើរ។ វត្តនេះត្រូវបានព័ទ្ធដោយរបងលួសបន្លា[1673]។ អ្នកទោសត្រូវបានដាក់ឃុំជាប់ ហើយមានអ្នកយាម[1674] នៅកុដិទីមួយ[1675] និងទីពីរ[1676] និងសាលាឆាន់[1677]។

---

[1673] ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.4 ["សៈ តើវត្តឥន្ទញ្ញាណមើលពីខាងក្រៅមានរូបរាងដូចម្តេច? [...] ឆ.4៖ យើងឃើញរបងធ្វើពីលួសបន្លា និងបង្គោលឈើ។ ខ្ញុំមិនដឹងថាមានអ្វីទៀតទេ ពីព្រោះខ្ញុំមិនបានចូលទៅជិតទីនោះទៀតទេ"]។

[1674] ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.8 ["មានអ្នកយាមមួយទៀត នៅជិតកន្លែងរោងបាយ"]។ ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.44 ["នៅពេលដែលខ្ញុំធ្វើការនៅផែ ពេលខ្លះខ្ញុំបានដើរឆ្លងកាត់វត្តឥន្ទញ្ញាណ ខ្ញុំបានឃើញអ្នកទោសធ្វើការនៅទីនោះ ហើយមានអ្នកយាម។ គ្រប់ៗគ្នាបានដឹងថាវត្តឥន្ទញ្ញាណជាមន្ទីរសន្តិសុខរបស់កងពល១៦៤។ ខ្ញុំដឹងថាវាជាមន្ទីរសន្តិសុខនៅចុងឆ្នាំ១៩៧៧ ឬក៏ដើមឆ្នាំ១៩៧៨"]។

[1675] ឯកសារ D2/4 កំណត់ហេតុស្តាប់ចម្លើយ ប៉ូច កុយ ឆ.22 [សាក្សីបានរៀបរាប់ពីការត្រឡប់ទៅវត្តឥន្ទញ្ញាណវិញនៅខែកក្កដា ឆ្នាំ ១៩៧៩។ "នៅពេលនោះក្នុងអគារ គេមានរៀបជាបន្ទប់៥ មានជញ្ជាំងជុំវិញ។ ឥឡូវនេះ យើងឃើញអគារនេះចំហល្ហល្ហេវ។ ពេលមកដល់ ខ្ញុំឃើញអគារនេះមានជញ្ជាំងពីខាងក្រៅជុំវិញ ហើយខាងក្នុងអគារគេសង់ជាបន្ទប់ឃុំឃាំងចំនួន៥។"], ឆ.22-25, 27-28 [សាក្សីបានរៀបរាប់ថាបានឃើញខ្នោះពីរក្រុម ក្នុងមួយក្រុមមាន១០ខ្នោះ ឃើញមានប្រលាក់ឈាមនៅជាប់នឹងជញ្ជាំង]។ ឯកសារ D1.3.13.1 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ ប៉ូច កុយ EN 00217557 ["នៅពេលសាក្សីបានទៅដល់វត្តឥន្ទញ្ញាណនៅខែ សីហា ឆ្នាំ ១៩៧៩ គាត់ប្រាប់ថា មានខ្នោះជើងពី៥០ទៅ៦០នៅក្នុងសាលាឆាន់ដ៏វែងដែលបែរមុខទៅខាងកើតឆៀងខាងលិចនៅប៉ែកខាងត្បូងវត្ត។ មានរបារដែក និងជញ្ជាំងដែលប្រលាក់ឈាម។ ខ្នោះជើងត្រូវគេដាក់ភ្ជាប់ទៅនឹងកំរាលឥដ្ឋ និងមានកន្លែងសម្រាប់ដាក់មនុស្សបានប្រហែល១០នាក់ក្នុងមួយជួរ"]។ សូមមើល ផងដែរ ឯកសារ D2/22 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងនៃមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ EN 00634143, FR 00725839, KH ERN 00662109-10 ["សាក្សី ទូច សឿលី បានបង្ហាញថា "កុដិ" កុដិទីមួយ -កុដិព្រះសង្ឃ-ជាកន្លែងដែលគាត់បានស្នាក់នៅដោយផ្ទាល់ជាមួយនឹងមេបញ្ជាការកងវរសេនាតូច៤៥០។ នៅក្នុងកុដិនោះ នៅជាន់ផ្ទាល់ដី សក្សី ប៉ូច កុយ ឃើញមានបន្ទប់ឃុំឃាំងចំនួនប្រាំ។ គាត់បានឃើញនៅក្នុងខែកក្កដា ឆ្នាំ ១៩៧៩ ដោយនៅក្នុងបន្ទប់ឃុំឃាំងនីមួយៗ មានខ្នោះជើងអាចដាក់បានយ៉ាងហោចណាស់មនុស្សចំនួន២០នាក់។"], KH ERN 00662139-00662140 [រូបភាពនៃកុដិលោកទីមួយដែលបង្ហាញពីអតីតបន្ទប់]។

[1676] ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.27, 41 ["សៈ ក្នុងឆ្នាំ១៩៧៧ លោកបានធ្វើដំណើរទៅវត្តឥន្ទញ្ញាណមួយភ្លែត ហើយលោកបានឃើញអ្នកទោស តើលោកអាចរៀបរាប់លម្អិតក្នុងរឿងនេះបានទេ? ឆ.27៖ [...] ជាចៃដន្យខ្ញុំបានជួបអ្នកដែលធ្លាប់ស្គាល់គ្នាម្នាក់បានខ្សឹបប្រាប់ខ្ញុំថាបន្ទប់ជាន់ក្រោមនោះ គឺមានដាក់ឃុំឃាំងមនុស្ស។ ដោយខ្ញុំមានការចង់ដឹង ថាពិត ឬមិនពិត ខ្ញុំបានឈៀងដើរកាត់មុខបន្ទប់ទើបឃើញថាមានអ្នកទោស

សាក្សីម្នាក់បំភ្លឺថា បានឃើញអ្នកទោសចំនួន៤០-៥០ នាក់ នៅរោងក្នុងបរិវេណវត្តនោះ[1678]។ ដូច បានរៀបរាប់ពិស្តារខាងក្រោមក្នុងផ្នែក *ការប្រព្រឹត្តិដោយអមនុស្សធម៌* អ្នកទោសនៅវត្តឥន្ទញ្ញាណ បានដាក់ខ្នោះតាំងពីមកដល់ដំបូង រួមទាំងពេលយប់ផងដែរ។

---

នៅក្នុងនោះមែន។ [...] ឆ.41៖ នៅឆ្នាំ១៩៧៧ គឺស្ថានភាពទូទៅគឺវាមានភាពច្របូកច្របល់ណាស់ សូម្បីតែខ្លួនខ្ញុំ ក៏ខ្ញុំមានការភ័យខ្លាចសម្រាប់ខ្លួនឯងដែរ"]។ ឯកសារ D114/187 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.28-29 ["គេនិយាយថា មានគេឃុំមនុស្សនៅក្រោមកុដិ។ យើងក៏ទៅលួចមើល តើគេឃុំនរណាគេ? [...] តើវាមានមូលហេតុអីបានគេឃុំនៅក្រោមកុដិហ្នឹង [...] ឆ.29៖ នៅពេលខ្ញុំដើរចូលទៅ ខ្ញុំឃើញមានម្នាក់"]។ ឯកសារ D1.3.13.13 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ ទូច សឿលី EN 00217575 ["អ្នកដែលគេចាប់ខ្លួនត្រូវបានដាក់នៅក្នុងកុដ្ឋលោក"]។ សូមមើល ផងដែរ ឯកសារ D2/22 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងនៃមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ EN 00634143, FR 00725839, KH ERN 00662109-10 ["សាក្សី ទូច សឿលី បានបង្ហាញ "កុដិទីពីរ" នៅក្នុងឆ្នាំ ១៩៧៧ ជាកន្លែងដែលសមាជិកកងពលធំ១៦៤ ត្រូវឃុំខ្លួនក្នុងបន្ទប់ស្ថិតនៅជាន់ផ្ទាល់ដី"], 00662144 ["សាក្សីឈរនៅចំពីមុខ [...] នៃកុដិទីពីរ គឺផ្នែកខាងកើតនៃអគារនេះហើយ ដែលសាក្សីធ្លាប់បានឃើញ មនុស្សត្រូវគេឃុំខ្លួននៅក្នុងកុដិ"]។

1677 ឯកសារ D2/4 កំណត់ហេតុស្តាប់ចម្លើយ ប៊ូច កុយ ឆ.34-35 [នៅពេលដែលសាក្សីបានទៅដល់ក្នុងខែកក្កដា ឆ្នាំ ១៩៧៩ គាត់បានឃើញខ្នោះជាច្រើន និងស្នាមប្រលាក់ឈាមនៅក្នុងសាលាឆាន់]។ ឯកសារ D54/65 កំណត់ហេតុស្តាប់ចម្លើយ ខិន ជុន ឆ.15, 37, 40 ["នៅក្នុងសាលាឆាន់នោះមានខ្នោះដែកសម្រាប់ដាក់ជើងច្រើនណាស់រាប់មិនអស់ទេ។ ឆ.37៖ ខ្ញុំនៅចាំថាខ្ញុំបានឃើញមានបន្ទប់ឃុំឃាំង ហើយនិងខ្នោះជើង នៅសាលាឆាន់។ ឆ.40៖ ខ្ញុំឃើញមានចបកាប់ ប៉ែល ដែកគ្នៀរទេះ នៅសល់ជាមួយនឹងខ្នោះជើងនៅនឹងសាលាឆាន់"]។ ឯកសារ D54/66 កំណត់ហេតុស្តាប់ចម្លើយ នួន យឹម ឆ.5, 22, 24-25, 27-29 [សាក្សីបានទៅដល់វត្តឥន្ទញ្ញាណនៅឆ្នាំ ១៩៧៩ នៅពេលដែលគាត់បានឃើញខ្នោះជើង និងសាកសពនៅក្នុងសាលាឆាន់]។ ឯកសារ D114/39 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន KH ERN 01065092 ឆ.2 និង ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.41, 49, 51 [បញ្ជាក់ថាមានការឃុំខ្លួនគាត់នៅក្នុងសាលាឆាន់ក្នុងវត្តឥន្ទញ្ញាណ]។

1678 ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.1-2, 4 ["ឃើញមានខ្ទមចំនួនប្រហែលច្រើន២០ខ្ទម និងមានអ្នកទោសពី៤០នាក់ទៅ៥០នាក់។ ខ្ញុំមិនអាចប្រាប់អំពីចំនួនខ្ទមឲ្យបានពិតប្រាកដនោះទេ។ ខ្ទមទាំងនោះមិនមែនសង់នៅជាជួរត្រឹមត្រូវនោះទេ។ គឺវារាស់នៅតាមចន្លោះថ្ម ក្រោមដើមឈើធំៗនៅក្នុងទីធ្លាវត្ត ហើយនិងនៅប៉ែកខាងក្រោមនៃទីធ្លាវត្ត។ [...] ឆ.2៖ ខ្ទមទាំងនោះមិនមានជញ្ជាំងទេ ខ្ទមនោះគឺប្រក់ដំបូលដោយស្លឹកត្នោត ឬក៏ស្បូវ។ ទំហំខ្ទមនីមួយៗ គឺមានទំហំប្រហែល៤ម៉ែត្របួនជ្រុង។ [...] ឆ.4៖ ក្នុងខ្ទមនីមួយៗមានដាក់អ្នកទោសប្រហែលពី៣ទៅ៤នាក់។"]។ សូមមើល ផងដែរ ឯកសារ D114/46 មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ និងទីតាំងពាក់ព័ន្ធផ្សេងៗទៀត របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងរបស់សាក្សី ស៊ឹម នី KH ERN 01307882-01307883 ["រូបភាពបង្ហាញពីអតីតទីតាំងរោងដាក់អ្នកទោស"]។

449. ប្រភេទនៃ អ្នកទោស៖

*ក) កម្មាភិបាលនិងយុទ្ធជនវាំសាយ របស់កងពល ១៦៤*

450. នៅវត្តឥន្ទញ្ញាណ អ្នកទោសភាគច្រើនគឺជាទាហានមកពីវរសេនាតូចនិងវរសេនាធំផ្សេងៗក្នុងកងពល ១៦៤[1679]។ វត្តឥន្ទញ្ញាណ បានប្រើជា ទីឃុំឃាំងជនណាដែលចោទថា "ក្បត់ឬមិនស្មោះត្រង់"[1680] ជនណាដែលចោទថា "ជាប់និន្នាការសង្ស័យ"[1681] ឬ បានប្រព្រឹត្ត "កំហុស"[1682] -

---

1679 ឯកសារ D114/40 កំណត់ហេតុស្ដាប់ចម្លើយរបស់ មួល ឈិន ឆ.54 ["អ្នកទោសទាំងអស់នោះសុទ្ធតែអតីតយោធារបស់កងពលធំលេខ៣"]។ ឯកសារ D54/102 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.6, 22 ["វត្តឥន្ទញ្ញាណ [...] ជាមន្ទីរសន្តិសុខយោធា [...] ឆ.22៖ បន្ទាប់ពីគេចាប់មនុស្សនៅក្នុងកងពល១៦៤ ពីកន្លែងផ្សេងៗនោះ គេបញ្ជូនទៅដាក់នៅមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ"]។ ឯកសារ D54/25 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.25 ["ខ្ញុំបានឮពីយោធាដទៃទៀតនៅក្នុងកងរបស់ខ្ញុំថា វត្តឥន្ទញ្ញាណ គឺជាកន្លែងឃុំឃាំងអ្នកទោសដែលមានឋានៈថ្នាក់វរសេនាតូច វរសេនាធំ និងកងពលមុនពេលដែលគេបញ្ជូនពួកនេះទៅភ្នំពេញ"]។ ឯកសារ D54/32 កំណត់ហេតុស្ដាប់ចម្លើយ ស៊ឹម នី ឆ.20-21 ["ស៖ តើលោកចាំឈ្មោះពួកយោធាដែលធ្លាប់នៅក្នុងកងជាមួយលោក ដែលបានជាប់នៅវត្តឥន្ទញ្ញាណដែរឬទេ? ឆ.20៖ ខ្ញុំស្គាល់ឈ្មោះ៣នាក់ មានឈ្មោះ ១.ឈ្មោះវុធមកពីស្រុកសំរោង ២.ឈ្មោះលីមមកពីស្រុកព្រៃកប្បាស ៣.ឈ្មោះធី មកពីស្រុកបាទីឃុំព្រាំរាម។ នៅពេលនោះខ្ញុំស្គាល់យោធាបួនអ្នកទៀតដែលនៅក្នុងកងវរៈជាមួយគ្នាកាលពីដើម"]។ ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964125 ["វត្តហ្នឹងគឺអ្នកមាននិន្នាការ អ្នកមាននិន្នាការហ្នឹងគឺយកមកដាក់នៅវត្ត។ [...] ស៖ ហ្នឹងសុទ្ធតែពួកកងទ័ពទេ? ឆ៖ សុទ្ធតែពួកកងទ័ព។ ស៖ កងទ័ពនៅកងជើងទឹកហ្នឹងដែរ អ្នកដែលជាប់និន្នាការដែលគេចាប់មកជាប់ច្រវ៉ាក់ជាប់អីហ្នឹង? ឆ៖ ហ្នឹងហើយ"]។ ឯកសារ D1.3.13.13 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ ទូច សឿលី EN 00217575 ["សាក្សី [...] ប្រាប់ថាអ្នកទោសត្រូវបានគេដាក់នៅក្នុងវត្ត ភាគច្រើនជាកងទ័ពដែលគេដកចេញ (អតីតភូមិភាគបូព៌ា) មួយចំនួនមកពីកងពលផ្ទាល់តែម្ដងដែលត្រូវគេចោទថាក្បត់ ឬមិនស្មោះត្រង់។ វត្តឥន្ទញ្ញាណគឺជាកន្លែងឃុំឃាំង"]។ ឯកសារ D54/48 កំណត់ហេតុស្ដាប់ចម្លើយ អែម សុន ឆ.52 [កម្មាភិបាលកងវរៈសេនាតូច ៤៥០/១៦៥៖ "ខ្ញុំចាំព្រឹត្តការណ៍មួយដែលកូនទាហានរបស់ខ្ញុំចំនួនពីរនាក់ត្រូវបានចាប់ខ្លួនរយៈពេលខ្លីនៅវត្តឥន្ទញ្ញាណ។ ពួកគេបានទៅរកជ័រដើម្បីយកបិទទូក ហើយត្រូវបានអ្នកយាមវត្តឥន្ទញ្ញាណឃាត់ខ្លួន។ ខ្ញុំបានទៅវត្តឥន្ទញ្ញាណដើម្បីស្នើសុំឲ្យគេដោះលែងកូនចៅរបស់ខ្ញុំវិញ"]។ សូមមើល ផងដែរ ឯកសារ D114/217 កំណត់ហេតុស្ដាប់ចម្លើយ នាក់ ខឿន ឆ.19 ["ខ្ញុំបានសន្និដ្ឋានថាប្រហែលជាកងទ័ព ព្រោះកំពង់ផែត្រឹមវត្តឥន្ទញ្ញាណមកនេះ ពីត្រឹមនោះទៅនោះទៀតជាកងទ័ព។ ហើយមកកន្លែងនេះ ជាកំពង់ផែ ហើយគ្មានប្រជាជននៅជាមួយទេ កាលហ្នឹង"]។

1680 ឯកសារ D1.3.13.13 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ ទូច សឿលី EN 00217575 ["សាក្សីប្រាប់ថាអ្នកទោសត្រូវបានគេដាក់នៅក្នុងវត្ត ភាគច្រើនជាកងទ័ពដែលគេដកចេញ (អតីតភូមិភាគបូព៌ា) មួយចំនួនមកពីកងពលផ្ទាល់តែម្ដងដែលត្រូវគេចោទថាក្បត់ ឬមិនស្មោះត្រង់"]។ ឯកសារ D54/102 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.13 ["ខ្ញុំធ្លាប់

ទោះជាធ្ងន់[1683] ឬស្រាល[1684]- នឹងត្រូវចាត់ចូលក្នុងប្រភេទនេះ។ សាក្សី ស៊ឹម នី បានបំភ្លឺថា **មាស មុត** ជាពិសេសមិនអត់អោនចំពោះកំហុសណាមួយនោះទេ៖

> មុត អត់ទេ អត់បាច់មានលើកទី២លើកទី៣អីទេ។ សួរ៖តែខុស? ឆ្លើយ៖តែខុសដឹងហើយ[1685]

ទៅវត្តឥន្ទញ្ញាណ [...] គេ [ខ្មែរក្រហម] ចាប់ប្រើវត្តហ្នឹងធ្វើជាមន្ទីរសន្តិសុខ នៅពេលដែលគេមានបញ្ហារឿងពួកក្បត់"]។

1681 ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.5 ["នៅពេលនោះខ្ញុំបានឃើញអ្វីៗដែលកើតឡើងនៅវត្តឥន្ទញ្ញាណ [...] ម្ខាងផ្សេងទៀតគឺជាចំការរបស់អ្នកទោសដែលជាប់និន្នាការសង្ស័យ"]។

1682 ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.15 ["យើងខ្លាចកន្លែងនេះណាស់ ពីព្រោះមេៗរបស់យើង តែងនិយាយព្រមានយើងថា ប្រយ័ត្នខ្លួន កុំធ្វើខុស ក្រែងគេបញ្ជូនទៅវត្តឥន្ទញ្ញាណ"]។

1683 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.2 ["ពេលខ្ញុំរួចខ្លួនពីវត្តឥន្ទញ្ញាណមក គេឈប់ចាត់ទុកខ្ញុំជាអ្នកទោសធ្ងន់ទៀតហើយ"]។ ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964137 ["ស៖ ចុះដូចថាអ្នកដែលខុសនៅកំពង់ផែអញ្ចឹង បើគេមាននិន្នាការដូចទាហានហ្នឹងដែរអត់ទេ? ឆ៖ ទាល់តែខ្លាំង"]។ សូមមើល ផងដែរ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.95 ["ស៖ តើលោកដឹងថាមានរឿងអ្វីកើតឡើងចំពោះកម្មករកំពង់ផែ៣ ទៅ ៤ នាក់ដែលគេយកទៅដាក់ក្នុងមន្ទីរសន្តិសុខក្នុងវត្តនោះដែរឬទេ? ឆ.95៖ ខ្ញុំមិនដឹងថាមានរឿងអ្វីកើតឡើងចំពោះពួកគេទេ តែខ្ញុំឮថាអង្គភាពរបស់ពួកគេបានយកពួកគេទៅវិញព្រោះពួកគេមិនបានប្រព្រឹត្តកំហុសអ្វីធ្ងន់ធ្ងរទេ"]។

1684 ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.89 ["មន្ទីរសន្តិសុខនោះ គេប្រើសម្រាប់ឃុំខ្លួនមនុស្សបណ្តោះអាសន្នដែលមានបញ្ហាបន្តិចបន្តួច ហើយក្រោយមកគេបញ្ជូនអ្នកទាំងនោះចេញ ក៏ប៉ុន្តែខ្ញុំមិនដឹងថាគេបញ្ជូនទៅទីណាទេ"]។ ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.6, 28 ["បាទ ខ្ញុំអាចនិយាយទៅកាន់ពួកគេបានខ្លះ។ ខ្ញុំបានសួរពួកអ្នកទោសខ្លះថា ហេតុអ្វីបានជាពួកគេត្រូវបានគេយកមកដាក់នៅទីនេះ? គេបានប្រាប់ថា គេមិនបានធ្វើអ្វីខុសធំដុំទេ គេគ្រាន់តែលួចដកដំឡូងមី ឬបេះដូងហូប ពីព្រោះម្ហូបអាហាររបស់ពួកគេមិនគ្រប់គ្រាន់ [...] ឆ.28៖ តាមខ្ញុំដឹង វត្តឥន្ទញ្ញាណជាកន្លែងសម្រាប់លុតដំ ដែលគេដាក់អ្នកទោសស្រាល ហើយភាគច្រើនជាយុទ្ធជន"]។ ឯកសារ D54/37 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.4 ["សម្រាប់អ្នកទោសធ្ងន់ គេបញ្ជូនទៅដាក់នៅទឹកសាប ឯអ្នកទោសស្រាលត្រូវបានគេយកមកដាក់ឃុំនៅវត្តឥន្ទញ្ញាណ"]។ ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ. 8 ["មានផ្ទះអ្នកយាមមួយទៀត នៅជិតកន្លែងរោងបាយ។ នៅទីនោះមានអ្នកយាមប្រហែលពី៣ទៅ៤នាក់ដែលស្នាក់នៅជាមួយអ្នកទោសស្រាលៗ ដែលគេប្រើឲ្យធ្វើការ និងដាំស្លនៅរោងបាយ"]។ ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.39 ["គេយកខ្ញុំមកឃុំ ដោយគ្រាន់តែមានកំហុសតិចតួចប៉ុណ្ណោះ គឺគ្រាន់តែចង់ជួបឪពុកម្តាយខ្ញុំ ដោយពុំមានកំហុសអ្វីធ្ងន់ធ្ងរនោះទេ"]។

1685 ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964138។

451. ជនក្បត់ ឬ "សមាសភាពមិនល្អ" ក៏រាប់បញ្ចូលផងដែរ អ្នកជាប់ "និន្នាការ"[1686] មានន័យថា "ជាប់និន្នាការនយោបាយទាក់ទិនអ្នកចាត់តាំង"[1687] ស៊ឹម នី ពន្យល់ថែមទៀតថា៖

> និន្នាការដូចថាទាក់ទិន ឧទាហរណ៍ថាខ្ញុំអញ្ចឹង ជាប់ខ្សែចាត់តាំងពីគណៈស្រុកគណៈតំបន់មកអញ្ចឹង រួចគេស្រាវជ្រាវតាមប្រវត្តិ អញ្ចឹងទៅដឹងហេតុផល អញ្ចឹងទៅគេដកចេញពីអង្គភាពឱ្យមកនៅហ្នឹងទៅ ហើយប្រើប្រាស់ដោយច្រវ៉ាក់ប្រវែងនេះ ទាក់ជាប់ហ្នឹងកជើងហ្នឹង...[1688]។

452. យុទ្ធជនកងពល ១៦៤ ដែលមានមុខសញ្ញា "សមាសភាពមិនល្អ" ឧទាហរណ៍ ដោយសារ យុទ្ធជនទាំងនោះ ជាប់ "ខ្សែ" ដែលសង្ស័យថាបានពាក់ព័ន្ធជាមួយមេបញ្ជាការណាមួយក្នុងកងពល ១៦៤ ដូចជា ខ្សែ នង ឆាន (អតីតវរសេនាតូច៣៨៦) តំបន់៣៧ ឬ ហ៊ឹង ដើម ហៅ ខឹម អតីតយោធាភូមិភាគបូព៌ា ស្ថិតក្នុងគ្រោះថ្នាក់ជាពិសេស ដែលត្រូវចាប់ខ្លួននិងដាក់មន្ទីរសន្តិសុខ។ "បើថ្នាក់លើត្រូវចោទថាក្បត់ហើយ ថ្នាក់ក្រោមគាត់ទាំងអស់ជាស្វ័យប្រវត្តិចោទថាក្បត់ដែរហើយ"[1689]។ អតីតកម្មាភិបាលម្នាក់ត្អូញត្អែរពីការសង្ស័យមិនរើសមុខនេះថា "គេបានសង្ស័យពួកខ្ញុំទាំងអស់ ថាពួកបូព៌ាហ្នឹងសុទ្ធតែខ្មាំង"[1690]។

453. ឯក នី បានបំភ្លឺថា៖

> ក្នុងការអនុវត្ត នៅពេលដែលយោធាណាធ្វើខុស ដូចជាឃាមដេក យោធានោះនឹងត្រូវហៅទៅអប់រំនៅវរៈ ហើយដោះលែងឱ្យត្រលប់មកកងរបស់គេវិញ។ ប៉ុន្តែបើយោធានៅតែធ្វើឱ្យមានកំហុសដដែលៗ យោធានោះនឹងត្រូវយកទៅសម្លាប់ហើយ។ សម្រាប់យោធាដែលពុំមានមេរបស់ខ្លួនជាប់ពាក់ព័ន្ធនឹងខ្សែក្បត់ យោធានោះអាចគេយកទៅអប់រំបន្តបន្ទាប់ បើសិនជាគាត់ធ្វើខុស មុនពេលគេយកទៅបាត់។ ប៉ុន្តែ

---

[1686] ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964125 ["វត្តហ្នឹងគឺអ្នកមាននិន្នាការ អ្នកមាននិន្នាការហ្នឹងគឺយកមកដាក់នៅវត្ត"]។

[1687] ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964127។

[1688] ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964126។

[1689] ឯកសារ D114/79.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ កង សុំ KH ERN 01104498។

[1690] ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.23។

សម្រាប់យោធាដូចជាពួកយោធានៅក្នុងកងរបស់ខ្ញុំ គឺយើងមិនមានឱកាសជាលើកទី ២ ទេ ប្រសិនបើយើងហ៊ានភ្លាត់ដេកក្នុងពេលយាម[1691]។

454. មានភស្តុតាងបញ្ជាក់ថា ទាំងកម្មាភិបាលភូមិភាគបូព៌ា[1692] ទាំងអតីតយុទ្ធជនវរសេនាតូច៣៨៦ បានជាប់ឃុំវត្តឥន្ទញ្ញាណ។ រេម អតីតស្នងការនយោបាយវរសេនាតូច៣៨៦ ក្នុងពល១៦៤ បានសម្លាប់ពេលតដែគេចាប់គាត់នៅខាងក្រៅវត្តឥន្ទញ្ញាណ ខណៈដែលមានការបោសសម្អាតអតីតកម្មាភិបាលតំបន់៣៧ (ដូចដែលបានរៀបរាប់បន្ថែមក្នុងផ្នែក *ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការបាត់ខ្លួនដោយបង្ខំ*) ហើយសាក្សីមូល ឈិន អតីតយុទ្ធជនរំសាយនៃវរសេនាតូច ៣៨៦ បានជាប់ក្នុងមន្ទីរសន្តិសុខនេះ អស់បីថ្ងៃ ក្រោយពីគាត់បានចេញពីសហករណ៍ទៅសួរសុខទុក្ខឪពុកម្តាយរបស់គាត់”[1693]។

455. បណ្តាមេបញ្ជាការក្នុងកងពល ១៦៤ បានបញ្ជូនមនុស្សមកដាក់មន្ទីរសន្តិសុខ ដោយសារ “ខុសសីលធម៌”[1694]៖

ខាងស្រីក៏ស្រលាញ់ខ្ញុំ ហើយខ្ញុំក៏ស្រលាញ់ខាងស្រី មិនអញ្ចឹង! ដោយមានការប្រាស្រ័យទាក់ទងគ្នា បើអញ្ចឹងអាហ្នឹងហើយគេឲ្យទៅកន្លែងផ្សេង ឧទាហរណ៍ថាគេ

---

1691 ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.12។

1692 ឯកសារ D1.3.13.13 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ ទូច សឿលី EN 00217575 [“សាក្សី [...] ប្រាប់ថាអ្នកទោសត្រូវបានគេដាក់នៅក្នុងវត្ត ភាគច្រើនជាកងទ័ពដែលគេដកចេញ (អតីតភូមិភាគបូព៌ា) មួយចំនួនមកពីកងពលផ្ទាល់តែម្តងដែលត្រូវគេចោទថាក្បត់ ឬមិនស្មោះត្រង់។ វត្តឥន្ទញ្ញាណគឺជាកន្លែងឃុំឃាំង”]។

1693 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.1, 39 [“ខ្ញុំសូមគូសបញ្ជាក់ថា ដំបូងខ្ញុំជាប់គុកនៅទឹកសាប៣ថ្ងៃ មុនពេលដែលគេយកខ្ញុំទៅដាក់គុកនៅវត្តឥន្ទញ្ញាណ៣ថ្ងៃទៀត។ [...] ឆ.39៖ គេយកខ្ញុំមកឃុំ ដោយគ្រាន់តែមានកំហុសតិចតួចប៉ុណ្ណោះ គឺគ្រាន់តែចង់ជួបឪពុកម្តាយខ្ញុំ ដោយពុំមានកំហុសអ្វីធ្ងន់ធ្ងរនោះទេ”]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.116 [“ស៖ តើមូលហេតុអ្វីបានជាគេដាក់គុកលោក? ឆ.116៖ នៅពេលមួយ ហើយកាលនោះ ខ្ញុំធ្វើការនៅកងផលិត នៅព្រែកចាក ក្បែររាម នៅឡើយ។ ដោយនឹកផ្ទះ និងឪពុកម្តាយខ្ញុំពេក ខ្ញុំបានរួចរត់ នឹងដើរកាត់ព្រៃ ១ ថ្ងៃពេញ ដើម្បីទៅលេងឪពុកម្តាយខ្ញុំ ហើយនៅភូមិកំណើត គឺភូមិតាទាត់ ក្បែរព្រៃនុប ចម្ងាយប្រហែល៩គីឡូម៉ែត្រពីកន្លែងធ្វើការរបស់ខ្ញុំ។ គេមកជួបនិងសួរនាំខ្ញុំច្រើនដងនៅផ្ទះឪពុកម្តាយរបស់ខ្ញុំ ហើយចុងក្រោយ គេយកខ្ញុំទៅដាក់គុកតែម្តង”]។

1694 ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964126 [“អ្នកមាននិន្នាការខាងសីលធម៌ ក៏ចូលវត្តឥន្ទញ្ញាណដែរ”]។

ឲ្យទៅកន្លែងធ្វើស្រែ ប៉ុន្តែម្យ៉ាងទៀត អ្នកដែលមានបញ្ហាដូចជា ខាងស្រីគេមិនស្រលាញ់យើង ហើយយើងស្រលាញ់តែម្ខាង អាហ្នឹងគេហៅជាលក្ខណៈបំពាន បើអញ្ចឹងគេយកទៅដាក់វត្តឥន្ទញ្ញាណ[1695]។

*ខ) ជនស៊ីវិល*

456. ទោះជា សាក្សីខ្លះ បំភ្លឺថា មិនមានជនស៊ីវិលជាប់ឃុំនៅវត្តឥន្ទញ្ញាណក៏ដោយ[1696] ក៏នៅមានភ័ស្តុតាងគាំទ្រថា មានជនស៊ីវិលយ៉ាងណាស់មួយចំនួនដែរ ដែលមកពីតំបន់កំពង់សោមបានជាប់ឃុំឃាំង។ សាក្សីខ្លះ បានបំភ្លឺវត្តមានកម្មករកំពង់ផែដែលមាន "បញ្ហាជាមួយអាជ្ញាធរនៅទីនោះ"[1697] និងអ្នកនេសាទមកពីអង្គភាពនេសាទរបស់ឡូញ[1698]។

*គ) ជនបរទេស*

457. មានភ័ស្តុតាងគាំទ្រផងដែរថា ជនបរទេសចាប់ពីសមុទ្រ បានដាក់ឃុំនៅវត្តឥន្ទញ្ញាណ។ ក្រោយពីព្រឹត្តការណ៍កប៉ាល់ *Mayaguez* ក្នុងខែ ឧសភា ឆ្នាំ ១៩៧៥ ដែលមានលើកឡើងថែមទៀតត្រង់ផ្នែក *VIII.ខ. ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តមកលើជនដែលកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យចាប់បាន លើទឹក និងកោះដែលអះអាងថាស្ថិតក្នុងបូរណៈភាពដែនដីកម្ពុជាប្រជាធិបតេយ្យ*

---

[1695] ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964127។

[1696] ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.6 ["វត្តឥន្ទញ្ញាណ [...] ជាមន្ទីរសន្តិសុខយោធា មិនមែនជារបស់ប្រជាជនទេ។ ខ្ញុំដឹងអំពីរឿងនេះតាមរយៈពួកយោធាកងពិសេស ដែលបានដកចេញ ហើយបញ្ជូនទៅកងផលិតជាមួយខ្ញុំ"]។ ឯកសារ D54/111 កំណត់ហេតុស្តាប់ចម្លើយ សំ ភីន ឆ.15 ["សៈ តើលោកដឹងថា អ្នកទោសប្រភេទណាខ្លះដែលគេបញ្ជូនយកទៅដាក់នៅវត្តឥន្ទញ្ញាណ? ឆ.15៖ តាមខ្ញុំដឹងស [...] ខ្ញុំគិតថាគេមិនយកប្រជាជនស៊ីវិលទៅដាក់កន្លែងនោះទេ"]។

[1697] ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ.91 ["ខ្ញុំឮគេនិយាយថាអ្នកដែលធ្វើការនៅកំពង់ផែ ហើយមានបញ្ហាជាមួយអាជ្ញាធរនៅទីនោះត្រូវបានគេបញ្ជូនទៅវត្តនោះ"]។ ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964137 ["ក្លាប់កម្លាំងដែលនៅជាមួយ ជា គ្រិន ហ្នឹង បើខុសជាលើកទីមួយមានការណែនាំអប់រំ លើកទីពីរមានការណែនាំអប់រំ ហើយលើកទីបីកែប្រែអាហ្នឹងរុញបញ្ចូលទៅហ្នឹងដែរ។ សៈ ទៅវត្តឥន្ទញ្ញាណហ្នឹងដែរ? ឆៈ បាទ"]។

[1698] ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.21 ["សៈ តើលោកដឹងថា អ្នកទោសទាំងនោះជាអ្នកទោសប្រភេទណា? ឆ.21៖ គឺមានយោធា កម្មករ និងពួកនេសាទមកពីអង្គភាពនេសាទ"]។

មេបញ្ជាការឈ្មោះ ឯម សុន នៃវរសេនាតូចពិសេស៤៥០/១៦៥[1699] បានបំភ្លឺក្នុងពេលសម្ភាសន៍ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេតថា ទាហានអាមេរិកពីរនាក់ បានចាប់មកពីកោះតាង[1700] ហើយតាមបញ្ជារបស់ **មាស មុត**[1701] គាត់បានយកទាហានទាំងនោះមកដីគោក ហើយប្រគល់ដោយផ្ទាល់ទាហានទាំងនោះ ទៅឱ្យកងពល ១៦៤ នៅកំពង់សោម[1702]។

---

1699 ឯកសារ D54/46 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.27, 35 ["ប្រហែលខែមីនា ឆ្នាំ ១៩៧៥ គេបានផ្លាស់ខ្ញុំពីកងវរសេនាតូច៤១៥ ដោយបង្កើតកងពិសេសកងវរសេនាតូច៤៥០ របស់កងពល៣ ដែលមានប្រធានកងវរសេនាតូច៤៥០ ឈ្មោះ មឿន ហើយ សារុន គួក ជាអនុប្រធាន ខ្ញុំ និង ធាន ជាសមាជិក។ [...] ឆ.35៖ នៅពេលនោះ ខ្ញុំទទួលខុសត្រូវអនុសេនាធំទី២។ លោក មឿន ទទួលខុសត្រូវអនុសេនាធំទី១ និងទី៣ សារុន គួក ទទួលខុសត្រូវអនុសេនាធំទី៤ និងទី៥ ធាន ទទួលខុសត្រូវអនុសេនាធំទី៦ និងទី៧។ បន្ទាប់ មឿន មានរបួសជើង នៅពេលការប្រយុទ្ធគ្នាដំបូង ខ្ញុំទទួលខុសត្រូវអនុសេនាធំទី១ ទី២ និងទី៣ ដែរ"]។

1700 ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.49 ["យើងបានឃើញអាមេរិកាំងពីរនៅក្នុងល្អាងថ្មនៅប៉ែកនិរតីនៃកោះ [កោះតាង]។ ពួកគេបានលើកដៃ ហើយពួកយើងបានចាប់ពួកគេចង។ ពួកគេមានកាំភ្លើងបីដើម។ យើងបានដកកាំភ្លើងទុក ហើយបណ្តើមកមូលដ្ឋានរបស់យើង។ នៅពេលបណ្តើរពួកគេមក ខ្ញុំបានសួរចម្លើយពួកគេ ពួកគេឆ្លើយថាពួកគេនៅកោះដោយសារពួកគេឡើងយន្តហោះមិនទាន់"]។

1701 ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.49 ["នៅពេលដែលយើងមកន្លែងប៉ុស្តិ៍យោធាយើងវិញ យើងបានទាក់ទងតាមវិទ្យុមកកងពលរបស់ មាស មុត ដើម្បីរាយការណ៍ថាយើងបានបាញ់អាមេរិកាំងម្នាក់ស្លាប់ និងចាប់បានពីរនាក់ ហើយដោយសារពួកគេឡើងយន្តហោះមិនទាន់។ មាស មុត បានបញ្ជា គាត់ ដោយផ្ទាល់បើកទូក បេអឺ មកដឹកទាហានអាមេរិកាំងពីរនាក់នោះ និងសមាជិកកងវរសេនាតូច៤៥០ (៣នាក់ស្លាប់នៅពេលប្រយុទ្ធគ្នា) របស់ខ្ញុំត្រឡប់ទៅកំពង់សោមវិញ"]។ ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.4-5, 7, 14-18 ["ពីរនាក់ទៀតត្រូវបានបញ្ជូនមកកំពង់សោម តែខ្ញុំមិនដឹងថាមានរឿងអ្វីកើតឡើងចំពោះពួកគេទេ។ [...] ឆ.5៖ ទាហានអាមេរិកាំងពីរនាក់ទៀតត្រូវបានបញ្ជូនទៅកំពង់សោម។ [...] ឆ.7៖ អៀង គឺជាប្រធានមន្ទីរ ហើយមន្ទីរនោះគេហៅថាមន្ទីរតាមុក។ [...] ឆ.14៖ ដំបូង ខ្ញុំបាននិយាយតាមវិទ្យុទៅកាន់អ្នកកាន់វិទ្យុ (តេអូ) ដែលមានឈ្មោះ សារ៉ន និងឌុល។ ខ្ញុំបានប្រាប់គាត់ថា ខ្ញុំចង់និយាយជាមួយ ៦៣/មាស មុត បន្ទាប់មក ៦៣/មាស មុត និយាយជាមួយខ្ញុំតាមវិទ្យុ ហើយចេញបញ្ជាឱ្យខ្ញុំនាំទាហានអាមេរិកាំងដែលនៅរស់។ [...] ឆ.15៖ ខ្ញុំចង់ធ្វើការបញ្ជាក់ចម្លើយខាងលើរបស់ខ្ញុំ តាមពិត មាស មុត មិនដែលនិយាយជាមួយខ្ញុំដោយផ្ទាល់ទេ តាមវិទ្យុ គឺមានតែ សារ៉ន និង ឌុល ទេ ដែលបាននិយាយតាមវិទ្យុជាមួយខ្ញុំ។ ចំពោះខ្ញុំ អ្នកទាំងពីរគឺតំណាងឱ្យ មាស មុត នៅពេលនិយាយជាមួយខ្ញុំ។ ពួកគេបានផ្តល់បញ្ជាពី មាស មុត មកឱ្យខ្ញុំ។ [...] ឆ.16៖ នៅពេលដែលខ្ញុំនិយាយវិទ្យុទាក់ទងទៅនាក់តំណាង ខ្ញុំរាយការណ៍អំពីទាហានអាមេរិកាំង។ អ្នកកាន់វិទ្យុបានធ្វើរបាយការណ៍មួយ ហើយបញ្ជូនទៅឱ្យ មាស មុត បន្ទាប់មក មាស មុត ចេញបញ្ជារបស់គាត់មកឱ្យខ្ញុំ ហើយអ្នកកាន់វិទ្យុបានទាក់ទងមកខ្ញុំប្រាប់តាមវិទ្យុពីបញ្ជារបស់ មាស មុត មកខ្ញុំ។ ស៖ តើបញ្ជាចេញពី មាស មុត មានអ្វីខ្លះ? ឆ.17៖ បញ្ជាមានដូចជា គាត់ បើកកាណូត បេអឺ ដោយដឹកយោធាវរសេនាតូច៤១០ ទៅកោះ

458. នៅក្នុងសៀវភៅចំណងជើងថា *សមរភូមិចុងក្រោយ* Ralph Watterhahn សរសេរថា ឯម សុន ទទួលបញ្ជា "ពីកំពង់សោម" ឲ្យដឹកទាហានអាមេរិកពីរនាក់ ពីកោះតាងទៅដីគោក និងដាក់នៅវត្តឥន្ទញាណ ដែលនៅទីនោះ ពួកគេត្រូវសម្លាប់ "ប្រហែលមួយសប្តាហ៍ក្រោយ" ហើយកប់នៅចុងខាងជើងឆ្នេរ និងខាងត្បូងវត្ត[1703]។ សាក្សី ឯម សុន បានបំភ្លឺគាំទ្រព្រឹត្តការណ៍នាំចំណាប់ខ្មាំងទៅដីគោក ប៉ុន្តែឥឡូវគាត់បានបដិសេធថាមិនបានដឹងពីវាសនារបស់អារិកទាំងនោះពេលដែលប្រគល់ភ្លាមៗទៅឲ្យការិយាល័យរបស់ **មាស មុត** នោះទេ[1704]។ ឯម សុន បានបំភ្លឺនៅក្នុងកំណត់ ហេតុ

---

តាង ដើម្បីទៅប្តូរក្រុមរបស់ខ្ញុំ។ បន្ទាប់មក គាត់ត្រូវដឹកទាហានអាមេរិកាំងពីរនាក់ និងកងវរសេនាតូចរបស់ខ្ញុំមកដីគោកវិញ។ ស៖ តើបញ្ជាហ្នឹងជាបញ្ជាចេញពីមេបញ្ជាការកងពល មាស មុត ឬ? ឆ.18៖ អ្នកកាន់វិទ្យុហៅ មាស មុត ថា អ៊ំ។ គេបានបញ្ជាក់ប្រាប់ថា បញ្ជានេះចេញមកពីអ៊ំ"]។

1702 ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.49 ["មាស មុត បានបញ្ជា គាត់ ដោយផ្ទាល់បើកទូក បេអឹមកដឹកទាហានអាមេរិកាំងពីរនាក់នោះ និងសមាជិកកងវរសេនាតូច៤៥០ (៣នាក់ស្លាប់នៅពេលប្រយុទ្ធគ្នា) របស់ខ្ញុំត្រឡប់ទៅកំពង់សោមវិញ។ បន្ទាប់មក កងវរសេនាតូច៤១០ បានទៅជំនួសពួកយើងនៅទីនោះ។ នៅដែលយើងមកដល់កំពង់សោម ខ្ញុំបានប្រគល់ទាហានអាមេរិកាំងពីរនាក់នោះទៅអគ្គសេនាធិការរបស់ មាស មុត។ ខ្ញុំមិនដឹងថាគេយកពួកគេទៅណាទេ។ ចំណែកខ្ញុំ ខ្ញុំបានត្រឡប់ផែកំពង់សោមវិញ"]។

1703 ឯកសារ D26/1/1.1.27 រ៉ាល់ វិតធ័រហា (Ralph Wetterhahn) សមរភូមិចុងក្រោយ EN 00728231-33 [រៀបរាប់ឡើងវិញពីរឿងរ៉ាវរបស់ ឯម សុន ដែលទទួលបញ្ជា "ពីកំពង់សោម" ស្របតាមការដែលលោកបាននាំជនជាតិអាមេរិកាំងពីរនាក់ពីកោះតាង ទៅ កំពង់សោម ហើយបន្តទៅវត្តឥន្ទញាណ ដែលទាហានអាមេរិកាំងទាំងពីរនោះត្រូវបានឃាត់ខ្លួនរយៈពេលមួយសប្តាហ៍ ហើយបន្ទាប់មកត្រូវបានសម្លាប់ដោយកម្មាភិបាលខ្មែរក្រហមនៅវត្តនោះ។ ទាហានពីរនាក់នេះត្រូវបានគេបោះចោលនៅចំណុចឆ្នេរសមុទ្រផ្សេងៗគ្នាមួយនៅខាងជើង និងមួយទៀតទៅខាងត្បូងវត្តឥន្ទញាណ]។ សូមមើល ផងដែរ ឯកសារ D114/73.1 កាសែតបាងកកប៉ុស្តិ៍ អតីតទាហានឧបត្ថិហេតុនាវាម៉ាយ៉ាហ្គេសដក់ជាប់នៅអារម្មណ៍សោកស្តាយចំពោះទាហានដែលនៅសេសសល់ ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៥ EN 01097311 ["អ្នកដែលបានសម្ភាស សុន ពីមុនបាននិយាយថា លោកបានផ្តល់ព័ត៌មានយ៉ាងច្រើនស្តីពីជោគវាសនារបស់ទាហានជើងទឹកដែលបាត់ខ្លួន ដោយរៀបរាប់អំពីរបៀប និងកន្លែងដែលពួកគេត្រូវបានសម្លាប់នៅវត្តឥន្ទញាណ និងកន្លែងដែលសាកសពត្រូវបានគេបោះចោលនៅពេលចុងក្រោយ។ [...] អតីតទាហានអាមេរិកាំងបានទៅមើលវត្តនោះ និងមានគេប្រាប់ពីកន្លែងជាក់លាក់ជាងគេបំផុតដែលមិត្តរួមការងាររបស់ពួកគេទាំងពីរនាក់ត្រូវបានគេសម្លាប់"]។

1704 ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.47 ["ស៖ យើងសូមឲ្យអ្នកបកប្រែអានកថាខណ្ឌនៅសៀវភៅរបស់អ្នកនិពន្ធ Ralph Wetterhahn ត្រង់ជំពូក 'វិធានចុងក្រោយ' (Last Full Measure) ចាប់ពីកថាខណ្ឌ៤ នៃទំព័រ២៨៧ ពីលើចុះមកក្រោយរហូតមកដល់ចុងទំព័រ២៨៩។ តើលោកមានយោបល់ដូចម្តេចដែរ? ឆ.47៖ ខ្លឹមសារភាគច្រើនអត្ថបទគឺត្រឹមត្រូវ។ ប៉ុន្តែខ្ញុំចង់បញ្ជាក់ពីចំណុចមួយ នៅពេលដែលខ្ញុំត្រឡប់មកពីកោះតាងវិញគឺមានទូកតែ

ស្តាប់ចម្លើយសាក្សីថា គាត់បានឃើញសាកសព ២០ ថ្ងៃក្រោយគាត់បានប្រគល់ឲ្យយុទ្ធជនរបស់ **មាស មុត៖** ម្នាក់ឃើញនៅជិតផ្ទេរកំពង់សោមក្រោយសណ្ឋាគារ៧ជាន់ (ហៅថាសណ្ឋាគារសុខា)[1705] ហើយម្នាក់ទៀត នៅខាងលិចផ្នែកខាងក្រោមនៃសំណាក់ស្តេច[1706] ចម្ងាយមួយគីឡូម៉ែត្រពីវត្តឥន្ទញ្ញាណ[1707]។

459. ទោះបីជាព្រឹត្តការណ៍ដែល ឯម សុន បំភ្លឺដល់ការិយាល័យសហចៅក្រមស៊ើបអង្កេតខុសពីអ្វីដែល Ralph Watterhahn បានសរសេរទាក់ទងនឹងការឃុំឃាំងទាហានអាមេរិកនៅវត្តឥន្ទញ្ញាណក៏ដោយ ក៏សហព្រះរាជអាជ្ញាកត់សម្គាល់ថា វាមិនផ្ទុយគ្នានោះទេទាក់ទងនឹងការឃុំឃាំងចំនួន២០ថ្ងៃដែល ឯម សុន លែងបានដឹងក្រោយពីគាត់បានប្រគល់ទាហានទាំងនោះទៅឲ្យកម្លាំងរបស់ មាស មុត។ លើសពីនេះទៀត ទីតាំងកប់សពដែល ឯម សុន បំភ្លឺការិយាល័យសហចៅក្រមស៊ើបអង្កេត និងទីតាំងដែលសរសេរក្នុងសៀវភៅរបស់ Ralph Watterhahn គឺដូចគ្នាបេះបិទ។

---

មួយទេ ហើយខ្ញុំជិះទូកនោះ។ ខ្ញុំមិនមានទូកផ្ទាល់ខ្លួនទេ។ ខ្ញុំមិនដឹងថាមានរឿងអ្វីកើតឡើងចំពោះទាហានអាមេរិកាំងនោះទេ នៅពេលដែលគេដឹកតាមឡានហ្ស៊ីពនោះ តែក្រោយមកទើបខ្ញុំបានឃើញសាកសពរបស់ពួកគេ”]។

1705 ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.125 [“ស៖ តើស្គាល់ឈ្មោះសណ្ឋាគារ៧ជាន់នោះទេ? […] ឆ.125៖ គេក៏ហៅថាអូតែល សុខា ដែរ”]។

1706 ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.35-36, 38-41, 43 [“ប្រហែល២០ថ្ងៃក្រោយមក ទើបខ្ញុំដឹងថាពួកគេបានសម្លាប់ ម្នាក់ត្រូវបានសម្លាប់នៅក្បែរផ្ទេរមាត់សមុទ្រកំពង់សោមខាងក្រោយសណ្ឋាគារប្រាំពីរជាន់ និងម្នាក់ទៀតត្រូវបានសម្លាប់នៅខាងលិចខាងក្រោមដំណាក់ស្តេច។ […] ឆ.36៖ ខ្ញុំដើរល្បាតនៅក្បែរសណ្ឋាគារប្រាំពីរជាន់ ទៅដល់ផែកំពង់សោម។ អំឡុងពេលដើរល្បាតនោះ ខ្ញុំបានឃើញសាកសពទាហានអាមេរិកាំងទាំងពីរនាក់នោះនៅផ្ទេរទាំងពីរនោះ។ ស៖ តើលោកដឹងថាមានអ្វីកើតឡើងចំពោះទាហានអាមេរិកាំងទាំងពីរនាក់នោះ នៅមុនពេលលោកឃើញសាកសព? ឆ.38៖ ខ្ញុំមិនដឹងថាមានរឿងអ្វីកើតឡើងចំពោះពួកគេទេ [ឬ] ថាតើពួកគេត្រូវដាក់នៅកន្លែងណា ឬសម្លាប់នៅទីណាទេ។ […] ឆ.39៖ ខ្ញុំបានដល់កន្លែងសាកសពទី១ សាកសពនោះមានសម្បុរ និងមុខមាត់ខុសពីខ្មែរយើង។ នៅពេលដែលខ្ញុំទៅដល់កន្លែងសាកសពទី២ សពនោះក៏មានសម្បុរ មុខមាត់ខុសពីខ្មែរយើងដែរ។ ដូច្នេះ ខ្ញុំសន្និដ្ឋានថា សពទាំងពីរនោះគឺជាទាហានអាមេរិកាំង។ […] ឆ.40៖ អ្វីដែលខ្ញុំសម្គាល់លើសពនោះ គឺមានមុខមាត់វែងសក់វែង។ តែពួកគេមិនស្លៀកពាក់ឯកសណ្ឋានយោធាទេ តែសពទាំងពីរស្លៀកខោខ្លីពណ៌អាចម៍សេះ តែគ្មានខោទេ។ ស៖ តើសាកសពទាំងពីរនោះមានខោខ្លីដូចគ្នាឬ? ឆ.41៖ បាទ សពទាំងពីរមានខោខ្លីដូចគ្នា។ […] ស៖ តើលោកមើលទៅឃើញសាកសពនោះត្រូវគេចង ឬក៏ឃើញមានស្នាមចងដៃរឬទេ? ឆ.43៖ ទេ ដៃរបស់ពួកគេមិនបានចងទេ ហើយក៏មិនបានឃើញស្នាមចងដៃរ”]។

1707 ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.45 [“ស៖ តើពីកន្លែងសាកសពដែលលោកបានឃើញ ទៅវត្តឥន្ទញ្ញាណ មានចម្ងាយប៉ុន្មាន? ឆ.45៖ មានចម្ងាយប្រហែលជា១គីឡូម៉ែត្រ”]។

460. ការឃុំឃាំងជនបរទេសផ្សេងៗទៀតនៅវត្តឥន្ទញ្ញាណ មានភ័ស្តុតាង ដូចជា មានសពពីរនាក់បានរកឃើញថាបានកប់ជិតទីតាំងនេះក្នុងឆ្នាំ ១៩៧៩៖ សពស្ត្រីម្នាក់ ដែលសាក្សីកំណត់ថា មានមាឌធំច្រើនជាងមាឌជាមធ្យមរបស់ខ្មែរ ហើយសពទីពីរ មាន "សក់រួញខ្លីដូចអាហ្រ្វិច"[1708]។

*ឃ) ស្ត្រី និងកុមារ*

461. ស្ត្រី និងកុមារ បានជាប់ឃុំឃាំង[1709] ទទួលទារុណកម្ម[1710] និងសម្លាប់[1711] នៅវត្តឥន្ទញ្ញាណ។

---

1708 ឯកសារ D54/64 កំណត់ហេតុស្តាប់ចម្លើយ ខិន ជុន ឆ.2 [រៀបរាប់ថាស្ត្រីម្នាក់បានរកឃើញសាកសពនៅក្រោយផ្ទះរបស់គាត់ "ខ្ញុំគិតថាសពនោះមិនមែនជាសពស្ត្រីខ្មែរទេ ព្រោះឆ្អឹងស្មងជើងវែងជាងឆ្អឹងស្មងជើងខ្ញុំទៅទៀត ពេលនោះខ្ញុំបានយកឆ្អឹងស្មងជើងចេញពីច្រវ៉ាក់យកមកផ្ទឹមជាមួយឆ្អឹងស្មងជើងរបស់ខ្ញុំហើយវាវែងជាងស្មងជើងខ្ញុំប្រហែល១០សង់ទីម៉ែត្រ"]។ ឯកសារ D54/66 កំណត់ហេតុស្តាប់ចម្លើយ នួន យឹម ឆ.4 [កូនប្រុសរបស់ ខិន ជុន រៀបរាប់ពីសាកសពដែលរកឃើញកប់នៅក្នុងរណ្តៅជិតវត្តឥន្ទញ្ញាណ៖ "រណ្តៅសាកសពទី២ រកឃើញដោយឪពុករបស់ខ្ញុំ នៅពេលដែលគាត់ជីកដំឡូង និងជីកធ្វើបង្គន់ ហើយគាត់បានឃើញក្រណាត់ផ្លាស់ស្ទីកក្រឡេក្រឡាពណ៌បៃតង បន្ទាប់មកគាត់បានបើកក្រណាត់ផ្លាស់ស្ទីកដែលរុំសាកសពនោះ ឃើញក្បាលខ្មោច ដែលមានសក់ខ្លីរួញដូចសក់ពួកអាហ្រ្វិក សាច់ពណ៌ខ្មៅ ហើយរលួយអស់ទៅហើយ"]។

1709 ឯកសារ D114/181 កំណត់ហេតុស្តាប់ចម្លើយ សែម កុល ឆ.47 ["មិនដឹងអង្គភាពណា មិនដឹងតួនាទី។ អ្នកទោសនៅហ្នឹង ពួស្សរថា ឈ្មោះ រិន ឬក៏ រីន ទេ [...] ស្រី។ គេដាក់ចូលវត្តឥន្ទញ្ញាណហ្នឹង។ កាលនោះ គាត់ធ្វើធំដែរ នៅវរសេនាតូច"]។ ឯកសារ D2/15 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.35 ["ឮគេថា តា នន បានរំលោភផ្លូវភេទទៅលើអ្នកទោសដែលជាស្ត្រី"]។ សូមមើល ផងដែរ ឯកសារ D54/65 កំណត់ហេតុស្តាប់ចម្លើយ ខិន ជុន ឆ.31 ["ចាស មានខ្មោចប្រុស និងខ្មោចស្រី ដោយខ្ញុំគិតថា ឆ្អឹងខ្មោចប្រុសវែងជាឆ្អឹងខ្មោចស្រី ហើយនៅពេលនោះខ្ញុំក៏បានឃើញមានខោអាវ សំពត់ និងអាវទ្រនាប់របស់ស្ត្រី"]។

1710 ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.16 ["ពួកនោះបានប្រាប់ខ្ញុំថា អំឡុងពេលសួរចម្លើយ និងធ្វើទារុណកម្ម គេបានសម្រាតខោអាវស្រីៗចេញអស់"]។

1711 ឯកសារ D54/65 កំណត់ហេតុស្តាប់ចម្លើយ ខិន ជុន ឆ.30-31 ["ចាស មានឆ្អឹងតូចៗខ្លះដែលជាឆ្អឹងកូនក្មេង។ [...] ឆ.31៖ ចសទ មានខ្មោចប្រុស និងខ្មោចស្រី ដោយខ្ញុំគិតថា ឆ្អឹងខ្មោចប្រុសវែងជាឆ្អឹងខ្មោចស្រី ហើយនៅពេលនោះខ្ញុំក៏បានឃើញមានខោអាវ សំពត់ និងអាវទ្រនាប់របស់ស្ត្រី"]។ ឯកសារ D54/64 កំណត់ហេតុស្តាប់ចម្លើយ ខិន ជុន ឆ.2-5 [សាក្សីបានរៀបរាប់ថាបានរកឃើញសាកសពស្ត្រីម្នាក់ដែលស្អុយរលួយដែលកប់នៅជិតវត្តឥន្ទញ្ញាណក្នុងឆ្នាំ ១៩៧៩]។ សូមមើល ផងដែរ ឯកសារ D54/66 កំណត់ហេតុស្តាប់ចម្លើយ នួន យឹម ឆ.3 ["លលាដ៏ក្បាលមានសក់វែងពណ៌ខ្មៅ ប្រវែងប្រហែលជិត១ម៉ែត្រ។ នៅលើសាកសពនៅឃើញមានខោទ្រនាប់ តែខ្ញុំមិនចាំថាតើមានអាវទ្រនាប់ ឬក៏អត់នោះទេ"]។

462. *ចំនួនអ្នកទោស*៖ ភ័ស្តុតាងបង្ហាញថា មន្ទីរសន្តិសុខនេះ អាចដាក់បានអ្នកទោសជាង២០០ នាក់ ក្នុងពេលមួយ។ នៅកុដិទីមួយ ប៉ូច កុយ បំភ្លឺថា បានឃើញបន្ទប់ឃុំឃាំងចំនួន៥ ដែលបន្ទប់នីមួយៗអាចដាក់ទោស បាន២០ នាក់[1712]។ ដូចបានសរសេរពិស្តារក្នុងផ្នែក *ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការបាត់ខ្លួនដោយបង្ខំ* នួន យ៉ឹម បានឃើញផ្ទាល់ភ្នែក សាកសពចំនួនប្រហែល ១០០ នាក់ ជាប់ខ្នោះនៅក្នុងសាលាឆាន់ នៅពេលដែលគាត់បានទៅដល់ទីតាំងនោះ នៅពាក់កណ្ដាលឆ្នាំ១៩៧៩។

463. ទោះជាយ៉ាងក៏ដោយ ការកំណត់តួលេខដោយសុក្រឹតមិនអាចធ្វើទៅរួចទេ ចំពោះអ្នកទោសដែលបានឃុំឃាំងនៅវត្តឥន្ទញ្ញាណ ក្នុងអំឡុងពេលទាំងមូលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ សាក្សីមួយចំនួនបានផ្ដល់ភ័ស្តុតាងដោយអន្លើអំពីតួលេខ៖ ស៊ឹម នី បំភ្លឺតួលេខអ្នកជាប់ឃុំប្រមាណ៧០ទៅ៨០ នាក់នៅពេលណាមួយក៏ដោយក្នុងអំឡុងឆ្នាំ១៩៧៦-១៩៧៧[1713] ឯម សុន បានឃើញអ្នកទោសប្រហែល២០ នាក់ធ្វើការនៅខាងក្រោមមន្ទីរសន្តិសុខ តែមិនអាចកំណត់អ្នកនៅខាងក្នុង[1714] ហើយ

---

[1712] ឯកសារ D2/4 កំណត់ហេតុស្តាប់ចម្លើយ ប៉ូច កុយ ឆ.22-24 ["នៅពេលនោះក្នុងអគារ គេមានរៀបជាបន្ទប់៥ មានជញ្ជាំងជុំវិញ។ ឥឡូវនេះ យើងឃើញអគារនេះចំហលួលៃ្វ។ ពេលមកដល់ ខ្ញុំឃើញអគារនេះមានជញ្ជាំងពីខាងក្រៅជុំវិញ ហើយខាងក្នុងអគារគេសង់ជាបន្ទប់ឃុំឃាំងចំនួន៥។ [...] ឆ.23៖ ខ្ញុំបានឃើញមានមួយក្រុមដប់ខ្នោះ [...] ស៖ តាមយើងយល់ លោកថាក្នុងមួយក្រុមមានដប់ខ្នោះ នៅក្នុងបន្ទប់នីមួយៗ តើដូច្នេះមែនទេ? ឆ.24៖ ខ្ញុំឃើញនៅក្នុងបន្ទប់នីមួយៗ មានខ្នោះពីរក្រុម ក្នុងមួយក្រុមមាន១០ខ្នោះ"]។ សូមមើល ផងដែរ ឯកសារ D2/22 របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីតាំងនៃមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ EN 00634142, FR 00725839, KH ERN 00662109 ["ភស្តុតាងបង្ហាញថា វត្តឥន្ទញ្ញាណមានទំហំធំគ្រប់គ្រាន់ដែលអាចផ្ទុកអ្នកទោសបានលើសពី១០០នាក់ នៅក្នុងបន្ទប់ ឬបន្ទប់តូចៗនៅក្នុងអគារទាំងបីនោះ" (សហព្រះរាជអាជ្ញាស៊ើបអង្កេតបានកត់សម្គាល់ថា នៅក្នុងចំណុចនេះ ក.ស.ច.ស មិនបានទទួលភស្តុតាងពី នួន យឹម ដែលបានឃើញសាកសពចំនួន ១០០ នៅក្នុងសាលាឆាន់វត្តឥន្ទញ្ញាណ)]។

[1713] ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.15 ["ខ្ញុំបានសួរអ្នកទោសដែលខ្ញុំជួប គេបានប្រាប់ខ្ញុំថា គេមិនបានដឹងពីចំនួនពិតប្រាកដទេ ប៉ុន្តែគេគិតថាមានអ្នកទោសប្រហែលពី៧០-៨០នាក់។"]។ ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964127 ["ស៖ អ្នកដែលជាប់និន្នាការនៅហ្នឹងច្រើនទេ? ឆ៖ ច្រើន ខ្ញុំសួរអាមួយដែលជួបខ្ញុំ ហើយខ្ញុំឱ្យបាយឱ្យអីហ្នឹងវា៧០-៨០ នាក់ហ្នឹង។ ស៖ ៧០-៨០ នាក់? ឆ៖ បាទ ច្រើនដែរ"]។

[1714] ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.52 ["ខ្ញុំចង់ធ្វើការបញ្ជាក់ថា តាមពិត ខ្ញុំឃើញអ្នកទោសនៅទីនោះតែម្ដងទេ។ នៅពេលនោះ ខ្ញុំជិះកង់ឆ្លងកាត់វត្តឥន្ទញ្ញាណនោះ ខ្ញុំបានឃើញអ្នកទោសប្រហែល២០នាក់នៅខាងក្រៅ [គុក]។ ក៏ប៉ុន្តែខ្ញុំមិនដឹងថា មានអ្នកទោសផ្សេងទៀតនៅក្នុងវត្តឥន្ទញ្ញាណនោះអត់ទេ។ ខ្ញុំចាំព្រឹត្តការណ៍មួយដែលកូនទាហានរបស់ខ្ញុំចំនួនពីរនាក់ត្រូវបានចាប់ខ្លួនរយៈពេលខ្លីនៅវត្តឥន្ទញ្ញាណ។ ពួកគេបានទៅរកជ័រដើម្បីយកបិទ

មូល ឈិន រាប់ឃើញអ្នកទោសចំនួន២០ នាក់នៅសាលាឆាន់ជាមួយគាត់ ពេលដែលគាត់ជាប់ឃុំនៅវត្តឥន្ទញ្ញាណនៅចុងបំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ[1715]។ ទោះជាយ៉ាងណាភ័ស្តុតាងនីមួយៗនេះផ្តិតយកតែរូបភាពនៅពេលជាក់លាក់មួយ ឬយកតែជ្រុងមួយនៃមន្ទីរសន្តិសុខ វត្តឥន្ទញ្ញាណ។ ភ័ស្តុតាងនេះមិនបានបង្ហាញពីចំនួនអ្នកជាប់ឃុំឃាំងអស់នោះទេ។ លើសពីនេះទៀត ស៊ឹម នី បំភ្លឺថា ចំនួនអ្នកទោសមានឡើងមានចុះ[1716]។

464. ទោះជាយ៉ាងនេះក្តី យើងអាចអះអាងដោយមានការជឿជាក់ថា អ្នកជាប់ឃុំនៅវត្តឥន្ទញ្ញាណ មានតួលេខខ្ពស់ច្រើនជាងសពចំនួនប្រមាណ៥០០-១០០០ នាក់ ដែលបានឃើញនៅទីនោះភ្លាមៗក្រោយការបរាជ័យនៃរបបកម្ពុជាប្រជាធិបតេយ្យ[1717]។ ទីមួយ ដូចបានសរសេរពិស្តារក្នុងផ្នែក *ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការបាត់ខ្លួនដោយបង្ខំ* មិនមែនគ្រប់រណ្តៅទាំងអស់ នៅវត្តឥន្ទញ្ញាណសុទ្ធតែបានកាយធ្វើកោសល្យវិច័យនោះទេក្នុងឆ្នាំ ១៩៧៩ ដោយមានរបាយការណ៍ពីររណ្តៅសពថ្មីៗបានរកឃើញនៅទីតាំងនោះ ក្នុងឆ្នាំ ១៩៩២ និងឆ្នាំ ២០០៣។ មានរណ្តៅច្រើនទៀតអាចនឹងមិនទាន់បានរកឃើញ។ ទីពីរ តួលេខទាំងនេះ ត្រូវតែរាប់ចូលបន្ថែមនូវបណ្តាអ្នកទោសដែលបានដោះលែង នៅក្នុង និងចុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ឬក្រោយមកបានបញ្ជូនមកសម្លាប់នៅស-២១។

## ការប្រព្រឹត្តិដោយអមនុស្សធម៌

465. ចាប់តាំងពីពេលដែលអ្នកទោស បានចូលដល់ក្នុងរបងវត្តឥន្ទញ្ញាណ ពួកគេបានដាក់ក្នុងសភាពយ៉ាងអមនុស្សធម៌ ហើយបាត់អស់នូវសេចក្តីថ្លៃថ្នូរ និងក្តីសង្ឃឹម។

---

ទូក ហើយត្រូវបានអ្នកយាមវត្តឥន្ទញ្ញាណឃាត់ខ្លួន។ ខ្ញុំបានទៅវត្តឥន្ទញ្ញាណដើម្បីស្នើសុំឱ្យគេដោះលែងកូនចៅរបស់ខ្ញុំវិញ។ គេមិនឱ្យខ្ញុំចូលទៅវត្តទេ ហើយយើងបានដោះស្រាយគ្នានៅច្រកចូលវត្ត។ ក្រោយពេលខ្ញុំបានបញ្ជាក់ថា អ្នកទាំងពីរនោះជាកូនចៅខ្ញុំ គេក៏ដោះលែងវិញ"]។

1715 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.52 ["អ្នកទោសប្រហែល២០នាក់នៅក្នុងបន្ទប់នោះ"]។

1716 ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.17 ["ចំនួនអ្នកទោស គឺឡើងចុះមិនទៀតទាត់ទេ ពេលខ្លះច្រើន ពេលខ្លះតិច"]។

1717 សូមមើល VIII.C.3. បន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ – ឧក្រិដ្ឋកម្ម - ការសម្លាប់, ការសម្លាប់ផុតពូជ និងការបាត់ខ្លួនដោយបង្ខំ។

466. <u>*ការដាក់ខ្នោះនិងច្រវ៉ាក់៖*</u> អ្នកទោសដាក់ឃុំភ្លាមពេលដែលមកដល់[1718] ទាំងយប់ទាំងថ្ងៃ[1719]។ អ្នកទោសភាគច្រើនបានដាក់នៅសាលាឆាន់ យ៉ាងហោចណាស់អ្នកទោស ពី២០ នាក់[1720] អាចឡើងដល់១០០នាក់[1721] បានដាក់ខ្នោះជើងជាប់នឹងដែករបាតែមួយ ជាទូទៅដោយបានចងដៃទៅ

---

1718 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.49 ["ក្រោយពេលទៅដល់បរិវេណវត្ត យោធាដែលយកខ្ញុំទៅបានប្រគល់ខ្ញុំឱ្យទៅយោធាពីរនាក់ដែលប្រចាំការនៅនឹងវត្ត។ ពេលចូលដល់ក្លោងទ្វារ គេប្រគល់ខ្ញុំទៅឱ្យយោធាទាំងនោះ ហើយគេយកខ្ញុំភ្លាមៗទៅដាក់ក្នុងសាលាឆាន់ ដើម្បីដាក់ខ្នោះតែម្តង"]។ ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964128 ["គ្រាន់តែដឹងថាអ្នកដែលមានបញ្ហានាំខ្លួនចូលដំបូង យប់គឺដាក់ខ្នោះជើង អ្នកខ្នោះឈើយើងណា៎ ដល់ពេលថ្ងៃឡើង ខ្នោះជើងគេកំណត់ដាក់៣យប់៣ថ្ងៃ"]។ សូមមើល ផងដែរ ឯកសារ D1.3.13.8 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ ប៉ែន សារិន EN 00217562 ["នៅពេលគាត់ចូលទីនោះដំបូង [ក្នុងវត្តឥន្ទញ្ញាណ] នៅខែ មេសា ឆ្នាំ ១៩៧៩ គាត់បានឃើញច្រវ៉ាក់ជើង និងស្នាមក្រលាក់ឈាម។ នៅលើជញ្ជាំងមួយមានកន្លែងដាក់ខ្នោះករអ្នកទោសដោយឈរ [...] មានខ្នោះឈើប្រហែល១០"]។

1719 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.57 ["ទោះបីជានៅពេលយប់ ក៏គេចងស្លាបសេក និងដាក់ខ្នោះជើងអ្នកទោសដែរ"]។ ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.5 ["នៅពេលយប់អ្នកទោសទាំងនោះត្រូវបានគេដាក់បញ្ចូលក្នុងមន្ទីរឃុំឃាំងហើយដាក់ខ្នោះជើង"]។ ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.4 ["មានខ្នោះជើងធ្វើពីឈើដែលសម្រាប់ដាក់កជើងទាំងពីររបស់អ្នកទោសនៅពេលយប់"]។ ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964128 ["យប់ឡើងគេដាក់"]។

1720 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.52 ["អ្នកទោស៥ទៅ៦នាក់អង្គុយជាជួរទល់មុខគ្នា។ អ្នកទាំងនោះសុទ្ធតែជាប់ខ្នោះជើង ភ្ជាប់ពីអ្នកទោសម្នាក់ទៅអ្នកទោសម្នាក់ទៀតដោយរនុកដែកមួយ។ មានន័យថា មានអ្នកទោសបីជួរ និងមានរនុកដែកថ្នាំងអំពៅបីដើម។ [...] ខ្ញុំពុំឃើញអ្នកទោសដាក់នៅដាច់ដោយឡែកទេ។ ខ្ញុំអាចនិយាយថាមានអ្នកទោសប្រហែល២០នាក់នៅក្នុងបន្ទប់នោះ"]។ ឯកសារ D2/4 កំណត់ហេតុស្តាប់ចម្លើយ ប៊ូច កុយ ឆ.34 ["ស៖ [...] តើលោកអាចប្រាប់យើងបានទេ កាលពីខែកក្កដា ឆ្នាំ១៩៧៩ ពេលដែលលោកចូលមកដល់ លោកបានឃើញអ្វីខ្លះក្នុងសាលាឆាន់? ឆ.34៖ ខ្ញុំឃើញមានខ្នោះពីរក្រុម ក្នុងមួយក្រុមមាន១០ខ្នោះ ខ្នោះទាំងនោះនៅពីមុខរូបបដិមាព្រះ"]។

1721 ឯកសារ D54/66 កំណត់ហេតុស្តាប់ចម្លើយ នួន យឹម ឆ.28-30 ["ឆ្អឹងសាកសពត្រូវគេដាក់ខ្នោះជាមួយគ្នាជាជួរប្រហែល១០០នាក់។ ស៖ យើងមានបញ្ហាមិនជឿលោកថាសាកសព១០០នាក់ អាចដាក់ជាជួរតែមួយជួររួមគ្នាកើត? ឆ.30៖ ខ្ញុំឃើញសាកសពអ្នកទោសដាក់ខ្នោះមួយជួរ លាតសន្ធឹងពីចុងជញ្ជាំងម្ខាងទៅចុងជញ្ជាំងម្ខាងទៀតតាមបណ្តោយអាគារសាលាឆាន់នោះ"]។ សូមមើល ផងដែរ ឯកសារ D114/30 កងពលធំជើងទឹក ១៦៤ (កងពលធំលេខ ៣) របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំង KH ERN 01363940 ["ការប៉ាន់ស្មាននូវប្រវែងទទឹងស្មាមនុស្សជាមធ្យម គឺមានចំនួនពី ៣០ សង់ទីម៉ែត្រទៅ ៥០ សង់ទីម៉ែត្រនៃមនុស្សម្នាក់ គេអាចនិយាយសរុបបានថា ក្នុងមួយជួរមានមនុស្សចំនួនពី ៣៩ នាក់ទៅ ៦៥ នាក់ ដែលអាចតម្រៀបជាជួរបាន។ នេះមានន័យថា វាមានលទ្ធផលសម្រាប់

ក្រោយ[1722]។ អ្នកទោសផ្សេងៗទៀតបានក្នុងបន្ទប់យ៉ាងចង្អៀតក្នុងកុដិទីមួយ មានរហូតដល់២០ នាក់ដាក់ខ្នោះក្នុងបន្ទប់នីមួយៗ[1723]។ សាក្សីម្នាក់ក៏បានបំភ្លឺផងដែរថា បានឃើញខ្នោះក្នុងរោងឃុំឃាំងដោយឡែកមួយ ខណៈដែលគាត់បានមកទីតាំងនេះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[1724]។

---

ចំនួនមនុស្សពី ៨០ នាក់ទៅ ១៣០ នាក់ក្នុងមួយជួរ ប្រសិនបើពួកគេត្រូវបានដាក់ច្រវាក់ នៅលើផ្នែកទាំងពីរនៃមួយជួរនោះ។ ដោយដាក់ជាបន្តគ្នានូវការរៀបរាប់របស់សាក្សីនោះ ការសង្កេតឃើញរបស់អ្នកស៊ើបអង្កេតនៅទីកន្លែងនោះ និនការវាស់វែងដែលបានធ្វើឡើង ហេតុដូច្នេះហើយ ផ្តល់នូវភាពគួរឱ្យជឿជាក់បានរបស់សាក្សីនោះ ដោយសន្មតនូវលទ្ធភាពនៃការគណនារបស់សាក្សីនោះនូវចំនួនសាកសពប្រហែលជា ១០០ នាក់ +/-"]។

1722 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មួល ឈិន ឆ.51, 57 ["ដោយសាររយៈពេល៣ថ្ងៃហ្នឹង ខ្ញុំជាប់ខ្នោះក្នុងសាលាឆាន់នោះរហូត [...] ឆ.57៖ អ្នកទោសទាំងអស់ត្រូវបានដាក់ខ្នោះជើងធ្វើពីឈើនៅជុំវិញកងជើងរបស់ពួកគេ និងមានរនុកដែកថ្នាំងអំពៅមួយផង។ អ្នកទោសទាំងអស់ លើកលែងតែខ្ញុំត្រូវបានគេចងស្លាបសេក។ ការជាប់ខ្នោះផង និងដៃជាប់ចំណងផង គឺពិបាកខ្លាំងណាស់ក្នុងការដេក ដូច្នេះអ្នកទោសដេកលើដៃខ្លួនឯង។ អ្នកទោសជាប់គុកកាន់តែយូរ ក្នុងឥរិយាបថនេះ កជើង ជើង និងកដៃ កដៃឡើងហើម និងជាំ។ ទោះបីជានៅពេលយប់ ក៏គេចងស្លាបសេកនឹងដាក់ខ្នោះជើងដែរ។ ដូច្នេះអ្នកទោសតែងតែដេកនៅលើដៃខ្លួនឯងដែលជាប់ចំណង"]។ ឯកសារ D54/65 កំណត់ហេតុស្តាប់ចម្លើយ ខិន ជុន ឆ.15, 37, 40 ["នៅក្នុងសាលាឆាន់ មានខ្នោះដែករាប់មិនអស់ [...] ឆ.37៖ ខ្ញុំបានឃើញមានបន្ទប់ឃុំឃាំង ហើយនិងខ្នោះជើងនៅក្នុងសាលាឆាន់។ [...] ឆ.40ខ្ញុំឃើញមាន ចបកាប់ ប៉ែល ដែកភ្លៅរទេះ នៅសល់ជាមួយនឹងខ្នោះជើងនៅនឹងសាលាឆាន់"]។ ឯកសារ D54/66 កំណត់ហេតុស្តាប់ចម្លើយ នួន យឹម ឆ. 22, 24 ["តាមទ្វារនិងបង្អួច មានខ្នោះជើងធ្វើពីដែកជាច្រើន ហើយនិងសាកសពខ្លះនៅក្នុងសាលាឆាន់នោះ។ [...] ឆ. 24៖ មានសាកសពប្រហែល១០០ ដែលស្អុយរលួយ ដោយមានខ្នោះជើងជាប់កជើងសាកសព"]។ ឯកសារ D1.3.13.8 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ ប៉ែន សារិន EN 00217562 ["នៅពេលគាត់ចូលទីនោះដំបូង [ក្នុងវត្តឥន្ទញាណ] នៅខែ មេសា ឆ្នាំ ១៩៧៩ គាត់បានឃើញច្រវ៉ាក់ជើង និងស្នាមក្រលាក់ឈាម។ នៅលើជញ្ជាំងមួយមានកន្លែងដាក់ខ្នោះករអ្នកទោសដោយឈរ [...] មានខ្នោះឈើប្រហែល១០"]។ សូមមើល ផងដែរ ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964127 ["ស៖ ចុះកន្លែងគេដាក់ច្រវ៉ាក់ដាក់អីហ្នឹង នៅកន្លែងណាទេ? ឆ៖ វត្តហ្នឹងនៅកន្លែងវិហារ នៅកន្លែងកុដហ្នឹង តែឥឡូវប្រហែលជាគេកសាងច្រើនហើយ កាលពីមុនអត់មានប៉ុន្មាន អត់មានទេ មានតែសាលាឆាន់"]។

1723 ឯកសារ D2/4 កំណត់ហេតុស្តាប់ចម្លើយ ប៉ូច កុយ ឆ.22-25, 29-31 ["ខាងក្នុងអគារគេសង់ជាបន្ទប់ឃុំឃាំងចំនួន៥។ រួចហើយខ្ញុំបានឃើញខ្នោះជើងនៅក្នុងបន្ទប់ឃុំឃាំងនីមួយៗ។ [...] ឆ.23៖ ខ្ញុំបានឃើញមួយក្រុមដប់ខ្នោះ ហើយមានដែកវែងសម្រាប់ស៊ុកបញ្ចូលតាមប្រហោងខ្នោះ។ [...] ឆ.24៖ ខ្ញុំឃើញនៅក្នុងបន្ទប់នីមួយៗ មានខ្នោះពីរក្រុម ក្នុងមួយក្រុមមាន១០ខ្នោះ។ [...] ឆ.25៖ គេចាប់ភ្ជាប់ទៅនឹងផ្ទៃខាងក្រោមនៃឥដ្ឋ។ [...] ឆ.29៖ ក្នុងមួយបន្ទប់មានទ្វារមួយ និងបង្អួចមួយ។ [...] ឆ.30៖ បន្ទប់ឃុំឃាំងទាំងអស់ គឺមានទ្វារមួយៗផ្ទាល់មកខាងក្រៅ។ [...] ឆ.31៖ [បន្ទប់នីមួយៗ] ប្រហែលជាបីម៉ែត្រ បួនជ្រុង"]។

1724 ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.4 ["ខុមនីមួយៗគឺមានខ្នោះជើងធ្វើពីឈើ"]។

សាក្សីម្នាក់ទៀតដែលមកទីតាំងនេះ ក្នុងឆ្នាំ ១៩៧៩ បានឃើញជញ្ជាំងមួយដែលអ្នកទោសអាចត្រូវបានដាក់ខ្នោះត្រង់ ក[1725]។ សាក្សីនានាបំភ្លឺថា បានឃើញឈាម នៅកន្លែងឃុំឃាំង[1726]។

467. ដោយបានជាប់ខ្នោះជើង និងចងដៃរយៈពេលយូរ បានធ្វើឱ្យអ្នកទោសហើមដៃ និងជើង[1727]។ បើអ្នកទោសត្រូវទៅជុះអាចម៍ ឬនោម ពេលខ្លះបានដោះខ្នោះមួយភ្លែត[1728] តែជារឿយៗបានតែក្នុងករណីត្រូវចងដៃជំនួសជាមុនសិន[1729]។ ស្រដៀងគ្នាដែរ ពេលអ្នកទោសបានដោះលែងឱ្យមកធ្វើការខាងក្រោមទីរសន្តិសុខ[1730] គេបានដោះខ្នោះតែដាក់ច្រវ៉ាក់វិញ[1731]។ ដោយសារដៃ និងជើងអ្នក

---

1725 ឯកសារ D1.3.13.8 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ ប៉ែន សារិន EN 00217562 ["នៅពេលគាត់ចូលទីនោះដំបូង [ក្នុងវត្តឥន្ទញ្ញាណ] នៅខែ មេសា ឆ្នាំ ១៩៧៩ គាត់បានឃើញច្រវ៉ាក់ជើង និងស្នាមក្រលាក់ឈាម។ នៅលើជញ្ជាំងមួយមានកន្លែងដាក់ខ្នោះករអ្នកទោសដោយឈរ [...] មានខ្នោះឈើប្រហែល១០"]។

1726 ឯកសារ D2/4 កំណត់ហេតុស្តាប់ចម្លើយ ប៉ូច កុយ ឆ.27-28, 35 ["ខ្ញុំបានឃើញមានប្រលាក់ឈាមជាប់នឹងជញ្ជាំងនៅក្នុងបន្ទប់ដែលអ្នកទោសដេក។ [...] ឆ.28៖ មានឈាមនៅលើផ្ទៃខាងក្រោម ខ្ញុំអាចដឹងថាវាជាឈាមមនុស្សពីព្រោះវាមើលទៅដូចជាឈាមជ្រូកដែរ។ [...] ស៖ នៅពេលនោះសាលាឆាន់ គឺមានជញ្ជាំងព័ទ្ធជុំវិញ ពេលដែលលោកមកដល់ តើលោកមានឃើញស្នាមប្រលាក់ឈាមដែរឬទេ? ឆ.35៖ បាទ មាន"]។ ឯកសារ D1.3.13.8 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ ប៉ែន សារិន EN 00217562 ["នៅពេលគាត់ចូលទីនោះដំបូង [ក្នុងវត្តឥន្ទញ្ញាណ] នៅខែ មេសា ឆ្នាំ ១៩៧៩ គាត់បានឃើញច្រវ៉ាក់ជើង និងស្នាមក្រលាក់ឈាម។ នៅលើជញ្ជាំងមួយមានកន្លែងដាក់ខ្នោះករអ្នកទោសដោយឈរ [...] មានខ្នោះឈើប្រហែល១០"]។

1727 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.57 ["អ្នកទោសទាំងអស់ត្រូវបានដាក់ខ្នោះជើងធ្វើពីឈើនៅជុំវិញកងជើងរបស់ពួកគេ និងមានរនុកដែកថ្នាំងអំពៅមួយផង។ អ្នកទោសទាំងអស់ លើកលែងតែខ្ញុំត្រូវបានគេចងស្ពាបសេក។ [...]អ្នកទោសជាប់គុកកាន់តែយូរ ក្នុងឥរិយាបថនេះ កជើង ជើង និងកដៃ កដៃឡើងហើម និងជាំ"]។

1728 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.51, 56 ["គេបញ្ចេញខ្ញុំទៅក្រៅសាលាឆាន់ម្តងៗនៅពេលដែលខ្ញុំសូមបត់ដៃបត់ជើងប៉ុណ្ណោះ។ [...] ឆ.56៖ ពេលចង់នោម ជួនកាលគេមកដោះអ្នកទោសពីខ្នោះឱ្យចេញទៅនោមនៅក្រៅបន្ទប់"]។

1729 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.56 ["ជួនកាលគេចងដៃអ្នកទោស ហើយនាំអ្នកទោសទៅកន្លែងបត់ជើង ដោយបន្ធូរខ្សែល្មមអ្នកទោសអាចបត់ជើងបាន"]។

1730 សូមមើល កថាខណ្ឌ ៤៧២។

1731 ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.4 ["មានខ្នោះជើងធ្វើពីឈើដែលសម្រាប់ដាក់កជើងទាំងពីររបស់អ្នកទោសនៅពេលយប់។ រាល់ៗពេលព្រឹកអ្នកយាមគោះជួងដើម្បីដាស់អ្នកទោសណោះវេលាម៉ោងបួនព្រឹក ហើយយកច្រវាក់មកដាក់កជើងអ្នកទោសមុននឹងបញ្ជូនឱ្យចេញទៅធ្វើការនៅតាមទីកន្លែងរៀងៗខ្លួន"]។ ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.5 ["បន្ទាប់ពីបាយរួច នៅពេលព្រឹកគេបញ្ចេញអ្នកទោសឱ្យបោស

ទោសជាប់ចំណង និងខ្នោះនៅពេលយប់ ពួកគេបង្ខំត្រូវដេកលើដៃខ្លួនឯង។ ការណ៍នេះ ធ្វើឱ្យពិបាកដេកលក់ អវៈយវៈកាន់តែហើមខ្លាំង[1732]។ ដោយសារអ្នកទោសដាក់ជាប់គ្មានចលនារហូត ពួកគេ មិនអាចដាក់រើមូសខាំបានឡើយ[1733]។

468. *ការខ្វះអនាម័យ៖* នៅវត្តឥន្ទញ្ញាណ អនាម័យមានការខ្វះខាតខ្លាំង។ មានការលើកលែងតិចតួច ក្រៅពីនោះ អ្នកទោសជាច្រើនមិនដែលបានកាត់សក់[1734] ហើយពួកគេមិនបានស្លៀកពាក់គ្រប់គ្រាន់ ដោយសារខោរហែកនឹងច្រវ៉ាក់ដែលបានដាក់ជើង[1735]។ ទោះបីជាពេលខ្លះអ្នកទោសបានអនុញ្ញាត

---

សំអាតទីធ្លា [គុក] រួចហើយគេប្រជុំជួរអ្នកទោស ហើយបានដាក់ច្រវាក់ជើងប្រហែលមួយម៉ែត្រកន្លះជុំវិញកជើងអ្នកទោសម្នាក់ៗ រួចហើយគេប្រគល់កាំបិតឱ្យអ្នកទោសម្នាក់ៗមួយឱ្យទៅធ្វើការក្នុងចំការដំឡូង"]។ ឯកសារ D114/217 កំណត់ហេតុស្តាប់ចម្លើយ នាក់ ខឿន ឆ.9, 16-17, 22 ["កាលពេលនោះ ខ្ញុំនាំគ្នាដើរកាលឆ្នាំ១៩៧៥ ឬ១៩៧៦ ខ្ញុំភ្លេចហើយ ព្រោះយូរហើយ ខ្ញុំទៅគ្នាពីរបីនាក់ ដើររកដកដំឡូងហូប។ ស្រាប់តែខ្ញុំដើរកាត់មុខវត្តហ្នឹង ឃើញអ្នកទោសត្រូវដាក់ច្រវាក់ [...] ឆ.16៖ ខ្ញុំសន្និដ្ឋានថាអ្នកទោសហើយ ព្រោះឃើញជើងជាប់ច្រវាក់។ [...] ឆ.17៖ ម្នាក់ជាប់ច្រវាក់ជើង ត្បាញបង្គី [...] ឆ.22៖ ឃើញតែអ្នកជាប់ច្រវាក់ជើងអង្គុយពីមុខ កំពុងតែត្បាញបង្គីហ្នឹង"]។

1732 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.57 ["អ្នកទោសទាំងអស់ត្រូវបានដាក់ខ្នោះជើងធ្វើពីឈើនៅជុំវិញកងជើងរបស់ពួកគេ និងមានរនុកដែកថ្នាំងអំពៅមួយផង។ អ្នកទោសទាំងអស់ លើកលែងតែខ្ញុំត្រូវបានគេចងស្លាបសេក។ ការជាប់ខ្នោះផង និងដៃជាប់ចំណងផង គឺពិបាកខ្លាំងណាស់ក្នុងការដេក ដូច្នេះអ្នកទោសដេកលើដៃខ្លួនឯង។ អ្នកទោសជាប់គុកកាន់តែយូរ ក្នុងឥរិយាបថនេះ កជើង ជើង និងកដៃ កដៃឡើងហើម និងជាំ។ ទោះបីជានៅពេលយប់ ក៏គេចងស្លាបសេកនឹងដាក់ខ្នោះជើងដែរ។ ដូច្នេះអ្នកទោសតែងតែដេកនៅលើដៃខ្លួនឯងដែលជាប់ចំណង"]។

1733 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.57 ["អ្នកទោសទាំងអស់ត្រូវបានដាក់ខ្នោះជើងធ្វើពីឈើនៅជុំវិញកងជើងរបស់ពួកគេ និងមានរនុកដែកថ្នាំងអំពៅមួយផង។ អ្នកទោសទាំងអស់ លើកលែងតែខ្ញុំត្រូវបានគេចងស្លាបសេក។ ការជាប់ខ្នោះផង និងដៃជាប់ចំណងផង គឺពិបាកខ្លាំងណាស់ក្នុងការដេក ដូច្នេះអ្នកទោសដេកលើដៃខ្លួនឯង។ អ្នកទោសជាប់គុកកាន់តែយូរ ក្នុងឥរិយាបថនេះ កជើង ជើង និងកដៃ កដៃឡើងហើម និងជាំ។ ទោះបីជានៅពេលយប់ ក៏គេចងស្លាបសេកនឹងដាក់ខ្នោះជើងដែរ។ ដូច្នេះអ្នកទោសតែងតែដេកនៅលើដៃខ្លួនឯងដែលជាប់ចំណង។ បន្ថែមលើនេះទៀត ពួកគេមិនអាចដេញមូសដែលមកខាំពួកគេបានទេ នៅពេលយប់។ ខ្ញុំចាំថា ជួនកាលខ្ញុំបានជួយបក់មូសឱ្យអ្នកទោសផ្សេងទៀត ដោយសារគេមិនចងស្លាបសេកខ្ញុំ។"]។

1734 ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.30 ["គេមិនដែលបានកាត់សក់ទេ ប៉ុន្តែមានអ្នកខ្លះកោរក្បាលតែម្តង"]។

1735 ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.30 ["ជើងខោពួករបស់គេរហែកដោយសារច្រវាក់ដែលដាក់ជុំវិញកជើង ហើយគេទាំងអស់មិនមានពាក់អាវទេ"]។

ឱ្យចេញក្រៅនោម និងជុះអាចម៍ក៏ដោយ[1736] ពេលខ្លះទៀត អ្នកយាមមិនអនុញ្ញាត ធ្វើឱ្យអ្នកទោសបង្ខំនោម ឬជុះអាចម៍លើផ្ទៃបន្ទប់ឃុំឃាំងនោះ[1737]។ ពេលដែល មូល ឈិន មកដល់សាលាឆាន់ដំបូង ភ្លាមនោះគាត់មានការលំបាកនឹងក្លិនស្អុះនោមទៅហើយ[1738]។ មានឃើញផងដែរ ឈាមមនុស្សនៅលើជញ្ជាំងកុដិទីមួយ និងសាលាឆាន់[1739]។

469. សូម្បីតែការបន្ទោរបង់នៅខាងក្រៅបន្ទប់ក៏គ្មានលក្ខណៈឯកជន ឬថ្លៃថ្នូរដែរ។ អ្នកយាមកាន់កាំភ្លើងអាកា៤៧ តាមមើលជាប់[1740] បង្ខំអ្នកទោស បើសិនពួកគាត់មិនបានបន្ទោរបង់បានលឿន[1741]។

---

1736 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.51, 56 ["គេបញ្ចេញខ្ញុំទៅក្រៅសាសាឆាន់ម្តងៗនៅពេលដែលខ្ញុំសូមបត់ជើងប៉ុណ្ណោះ។ [...] ឆ.56៖ ពេលចង់នោម ជួនកាលគេមកដោះអ្នកទោសពីខ្នោះឱ្យចេញទៅនោមនៅក្រៅបន្ទប់។ [...]។ ជួនកាលគេចងដៃអ្នកទោស ហើយនាំអ្នកទោសទៅកន្លែងបត់ជើង ដោយបន្ធូរខ្សែឲ្យល្មមអ្នកទោសអាចបត់ជើងបាន"]។

1737 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.56 ["ជួនកាលទៀតអ្នកយាមប្រាប់ថាគេគ្មានពេលដោះអ្នកទោសឱ្យទៅនោមនៅខាងក្រៅទេ ដូច្នេះអ្នកទោសក៏នោមនៅក្នុងបន្ទប់នោះទៅ"]។

1738 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.52 ["ភ្លាមៗពេលចូលទៅដល់ខ្ញុំធុំក្លិនស្អុះទឹកនោមដែលជាបរិយាកាសដ៏គួរឱ្យភ័យខ្លាច"]។

1739 ឯកសារ D2/4 កំណត់ហេតុស្តាប់ចម្លើយ ប៊ូច កុយ ឆ.27-28 [កុដ្ឋលោកទីមួយ៖ "ខ្ញុំបានឃើញមានប្រលាក់ឈាមជាប់នឹងជញ្ជាំង នៅក្នុងបន្ទប់ដែលអ្នកទោសដេក។ ស៖ ហេតុអ្វីបានជាលោកដឹងថា ស្នាមនោះជាឈាម មិនមែនជាថ្នាំពណ៌ ឬជាអ្វីផ្សេង? ឆ.28៖ មានឈាមនៅលើផ្ទៃខាងក្រោម ខ្ញុំអាចដឹងថាវាជាឈាមមនុស្ស ពីព្រោះវាមើលទៅដូចជាឈាមជ្រូកដែរ។"], 35 [សាលាឆាន់៖ ស៖ នៅពេលនោះសាលាឆាន់ គឺមានជញ្ជាំងព័ទ្ធជុំវិញ ពេលដែលលោកមកដល់ តើលោកមានឃើញស្នាមប្រលាក់ឈាមដែរឬទេ? ឆ.35៖ បាទ មាន។"]។ ឯកសារ D1.3.13.1 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ ប៊ូច កុយ EN 00217557 ["នៅពេលសាក្សីបានទៅដល់វត្តឥន្ទញ្ញាណនៅខែ សីហា ឆ្នាំ១៩៧៩ គាត់ប្រាប់ថា មានខ្នោះជើងពី៥០ទៅ៦០នៅក្នុងសាលាឆាន់ដ៏វែងដែលបែរមុខទៅខាងកើតឆៀងខាងលិចនៅប៉ែកខាងត្បូងវត្ត។ មានរបារដែក និងជញ្ជាំងដែលប្រលាក់ឈាម"]។ ឯកសារ D1.3.13.8 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ ប៉ែន សារិន EN 00217562 ["នៅពេលគាត់ចូលទីនោះដំបូង [ក្នុងវត្តឥន្ទញ្ញាណ] នៅខែ មេសា ឆ្នាំ១៩៧៩ គាត់បានឃើញច្រវ៉ាក់ជើង និងស្នាមក្រលាក់ឈាម។

1740 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.56 ["ពេលចង់បត់ជើងធំ គេយកអ្នកទោស ហើយបណ្តើរអ្នកទោសទៅទីតាំងមួយដែលខ្ញុំបានបង្ហាញប្រាប់លោក ហើយគេឈរនៅចម្ងាយប្រហែលបីបួនម៉ែត្រពីអ្នកទោស ដើម្បីយាមអ្នកទោសដោយកាន់អាវុធអាកា (អាកា៤៧) ដើម្បីកុំឱ្យអ្នកទោសរត់"]។ ឯកសារ D114/54 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំង KH ERN 01353043-01353044 ["រូបថតពណ៌នាពីទីតាំងខាងក្រៅដែលត្រូវបានគេប្រើជាបង្គន់នៅពេលដែលឆ្មាំគុកបណ្តើរអ្នកទោសទៅចូលបង្គន់"]។

470. *__របបអាហារមិនគ្រប់គ្រាន់៖__* អ្នកទោសបានទទួលអាហារត្រឹមតែពាក់កណ្ដាលនៃរបបតិចតួចដែលពលរដ្ឋទូទៅបានទទួលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[1742]។ មូល ឈិន បានត្រឹម "បបរពាវ មានអង្ករពីរបីគ្រាប់លាយស្លឹកដំឡូង"[1743]។ អាស្រ័យហេតុនេះ បានជាអ្នកទោស "មានសភាពស្គមណាស់"[1744] ហើយ "រូបរាងនិងទឹកមុខរបស់អ្នកជាប់ឃុំឃាំងនោះ មានស្ថានភាពខុសពីធម្មតា"[1745] អ្នកទោសស្រេកឃ្លានខ្លាំង រហូតដល់អ្នកដែលមានសំណាងបានមកធ្វើការក្រៅ បានសុំអាហារពីយុទ្ធជនដែលធ្វើការនៅស្រែជិតៗនោះ ប៉ុន្តែពួកគាត់ត្រូវធ្វើម៉េចលាងដៃ និងមាត់ឱ្យស្អាតពេលមកវិញកុំឱ្យដឹងដល់កម្មាភិបាលយាមមន្ទីរសន្តិសុខ[1746]។

471. *__ការប្រព្រឹត្តិមកលើអ្នកទោសភេទស្រី៖__* អ្នកទោសភេទស្រី បានទទួលនូវការប្រព្រឹត្តិយ៉ាងអមនុស្សធម៌បំផុត។ ដូចបានសរសេរក្នុងផ្នែក*ការធ្វើទារុណកម្ម* ខាងក្រោមនេះ ពួកគាត់បានទទួលទារុណកម្មគួរឱ្យស្អប់ខ្ពើម ហើយយ៉ាងហោចណាស់ អ្នកទោសស្រីម្នាក់បានរំលោភផ្លូវភេទដោយ នន ប្រធានមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ[1747]។

---

1741 ឯកសារ D114/40 កំណត់ហេតុស្ដាប់ចម្លើយរបស់ មូល ឈិន ឆ.56 ["អ្នកយាមក៏ជម្រុញឱ្យអ្នកទោសបត់ដៃបត់ជើងឱ្យរហ័សរហួនផងដែរ"]។

1742 ឯកសារ D54/32 កំណត់ហេតុស្ដាប់ចម្លើយ ស៊ឹម នី ឆ.13 ["គេទទួលបាន ៥០ភាគរយនៃរបបអាហារធម្មតា គឺមួយកំប៉ុងក្នុងមួយថ្ងៃ។ គេហូបរួម ដោយម្នាក់បានបាយមួយវែកក្នុងមួយពេល"]។

1743 ឯកសារ D114/31 កំណត់ហេតុស្ដាប់ចម្លើយ មូល ឈិន ឆ.162។

1744 ឯកសារ D54/32 កំណត់ហេតុស្ដាប់ចម្លើយ ស៊ឹម នី ឆ.30 ["ស៖ តើស្ថានភាពរូបរាងនិងផ្លូវចិត្តរបស់ពួកអ្នកទោសទាំងនោះ ដែលលោកជួបនៅចំការដំឡូងមីនោះយ៉ាងម៉េចដែរ? ឆ.30៖ ពួកអ្នកទោសមានសភាពស្គមណាស់"]។

1745 ឯកសារ D2/15 កំណត់ហេតុស្ដាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.31។

1746 ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964126 ["ដល់ពេលសម្រាកពួកហ្នឹងវាចេញមក ហើយធម្មតាគ្នាអ្នកទោស គេឱ្យហូបចុកមិនគ្រប់គ្រាន់ ឯសម្រាប់ពួកខ្ញុំគឺបបូរអញ្ចឹងគ្នាមកកេបាយរកអីហូប អញ្ចឹងចេះតែឱ្យទៅ ចុះស្គាល់គ្នាហើយបើមិនអញ្ចឹងទេ ឱ្យដកដំឡូងដកអីដុតទៅ តែហូបហើយលាងមាត់លាងដៃចេញឱ្យស្អាតចាំទៅតិចគេឃើញ"]។ សូមមើល ផងដែរ ឯកសារ D54/88 កំណត់ហេតុស្ដាប់ចម្លើយ ស៊ឹម នី KH ERN 00987080 ["ពេលខ្លះសាក្សីបានផ្ដល់បារី និងម្ហូបអាហារទៅឱ្យពួកអ្នកទោសទាំងនោះ"]។

1747 ឯកសារ D114/187 កំណត់ហេតុស្ដាប់ចម្លើយ ទូច សឿលី ឆ.59 ["តែយើងចាំតែឈ្មោះបង នន ដែលជាអ្នកទទួលខុសត្រូវ។ ហើយ បងនន មិនអាចនៅរហូតដែរ ប្រហែលនៅចុងឆ្នាំ ៧៨ ក៏បាត់ខ្លួនទៀត ដោយឮសូរថាជាប់ពាក់ព័ន្ធការរំលោភអ្នកទោសហ្នឹង។ ប៉ុន្តែរឿងហ្នឹង ខ្ញុំដឹងអត់ច្បាស់ទេ តែខ្ញុំឮថា ដែលពាក់ព័ន្ធការរំលោភអ្នកទោស"]។ ឯកសារ D2/15 កំណត់ហេតុស្ដាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.35-37 ["រឿង តា នន វាចម្លែកបន្តិច ខ្ញុំមិនបាន

472. *ការធ្វើពលកម្មដោយបង្ខំ៖* អ្នកទោសនៅវត្តឥន្ទញ្ញាណ ត្រូវបង្ខំឱ្យធ្វើការបម្រើផលប្រយោជន៍នៃរបបនោះ[1748]។ អ្នកទោសងើបម៉ោង៤ ព្រឹក ជាប់ច្រវ៉ាក់[1749] ហើយត្រូវសម្អាតមន្ទីរសន្តិសុខ[1750] មុននឹងទៅធ្វើការកន្លែងរៀងៗខ្លួន[1751]។ អ្នកទោសជាច្រើនត្រូវទៅធ្វើការនៅចម្ការដាំដំឡូងឈើនៅ

ឃើញដោយផ្ទាល់ភ្នែកទេ ប៉ុន្តែឮគេថា តា នន បានរំលោភផ្លូវភេទទៅលើអ្នកទោសដែលជាស្ត្រី។ ក្រោយពី តានន បានរំលោភអ្នកទោសរួចហើយគាត់ក៏លែងអ្នកទោសនោះ ក្រោយមកទៀត តា នន ត្រូវបានចាប់ខ្លួន។ [...] ឆ.36៖ ខ្ញុំចាំមិនច្បាស់ វាប្រហែលកើតឡើងនៅចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨។ ស៖ តើលោកអាចប្រាប់ឈ្មោះអ្នកទោសស្រីដែល តា នន នោះរំលោភបានដែរឬទេ? ឆ.37៖ អ្នកទោសដែល តា នន រំលោភនោះមានឈ្មោះ រីម"]។

1748 ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.44, 51-52 ["នៅពេលដែលខ្ញុំធ្វើការនៅផែ ពេលខ្លះខ្ញុំបានដើរឆ្លងកាត់វត្តឥន្ទញ្ញាណ ខ្ញុំបានឃើញអ្នកទោសធ្វើការនៅទីនោះ។ [...] ឆ.51៖ នៅពេលដែលខ្ញុំឆ្លងកាត់ទីនោះហើយបានឃើញអ្នកទោសនោះ ខ្ញុំមិនស្គាល់ពួកគេទេ ហើយខ្ញុំក៏មិនហ៊ានមើលពួកគេដែរ។ [...] ឆ.52៖ ខ្ញុំចង់ធ្វើការបញ្ជាក់ថា តាមពិត ខ្ញុំឃើញអ្នកទោសនៅទីនោះតែម្តងទេ។ នៅពេលនោះ ខ្ញុំជិះកង់ឆ្លងកាត់វត្តឥន្ទញ្ញាណនោះ ខ្ញុំបានឃើញអ្នកទោសប្រហែល២០នាក់នៅខាងក្រៅ [គុក]។"]។ ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.4 ។

1749 ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.4 ["រាល់ៗពេលព្រឹកអ្នកយាមគោះជួងដើម្បីដាស់អ្នកទោសណោវេលាម៉ោងបួនព្រឹក ហើយយកច្រវ៉ាក់មកដាក់កជើងអ្នកទោសមុននឹងបញ្ជូនឱ្យចេញទៅធ្វើការនៅតាមទីកន្លែងរៀងៗខ្លួន"]។ ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.5 ["ច្រវាក់ជើងប្រហែលមួយម៉ែត្រកន្លះជុំវិញកជើងអ្នកទោសម្នាក់ៗ"]។ សូមមើល ផងដែរ ឯកសារ D114/217 កំណត់ហេតុស្តាប់ចម្លើយ នាក់ ខឿន ឆ.9, 15-17 ["ឮថាវត្តឥន្ទញ្ញាណ ឮថាកន្លែងគេដាក់អ្នកទោស។ កាលពេលនោះ ខ្ញុំនាំគ្នាដើរកាលឆ្នាំ១៩៧៥ ឬ១៩៧៦ ខ្ញុំភ្លេចហើយព្រោះយូរហើយ ខ្ញុំទៅគ្នាពីរបីនាក់ ដើររកដកដំឡូងហូប។ ស្រាប់តែខ្ញុំដើរកាត់មុខវត្តហ្នឹង ឃើញអ្នកទោសត្រូវដាក់ច្រវាក់ ខ្ញុំក្រឡេកឃើញ ខ្ញុំទៅៗ អត់ហ៊ាននៅជិតទេ ហើយខ្ញុំទៅកន្លែងខ្ញុំវិញ។ [...] ឆ.15៖ ខ្ញុំ [...] ឃើញអ៊ីៗ ឃើញគេអង្គុយ ខ្ញុំនៅឆ្ងាយ [...] ឆ.16៖ ៖ ខ្ញុំសន្និដ្ឋានថាអ្នកទោសហើយ ព្រោះឃើញជើងជាប់ច្រវាក់។ [...] ឆ.17៖ ម្នាក់ជាប់ច្រវាក់ជើង ត្បាញបង្គី"]។

1750 ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.5 ["បន្ទាប់ពីបាយរួច នៅពេលព្រឹកគេបញ្ចេញអ្នកទោសឱ្យបោសសំអាតទីធ្លា [គុក]"]។

1751 ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.4 ["រាល់ៗពេលព្រឹកអ្នកយាមគោះជួងដើម្បីដាស់អ្នកទោសណោវេលាម៉ោងបួនព្រឹក ហើយយកច្រវ៉ាក់មកដាក់កជើងអ្នកទោសមុននឹងបញ្ជូនឱ្យចេញទៅធ្វើការនៅតាមទីកន្លែងរៀងៗខ្លួន"]។

ក្បែរវត្ត[1752] ទៅឆ្ការព្រៃជិតចម្ការដំឡូង[1753] ឬដាំដើមឈើ[1754]។ អ្នកទោសក្រៅពីនោះត្រូវធ្វើការខាងក្នុងមន្ទីរសន្តិសុខ[1755]។

473. *បរិយាកាសភ័យខ្លាច*៖ អ្នកទោសមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរ ហើយបាត់បង់នូវសេចក្តីថ្លៃថ្នូរបណ្តាលមកពីលក្ខខណ្ឌអមនុស្សធម៌ និងការធ្វើបាបផ្សេងៗទៀតនៅវត្តឥន្ទញាណ។ នៅពេលដែល មូល ឈិន ចូលដល់សាលាឆាន់នោះ "ងងឹត និងស្ងាត់ខ្លាំងណាស់" បានឃើញអ្នកទោសផ្សេងជាប់ខ្នោះ ហើយ

---

1752 ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.5, 18 ["ខ្ញុំទៅដាំបន្លែនៅទីនោះ ខ្ញុំមានចំការដំបន្លែពីរ មួយគឺចំការសណ្តែកគួរដែលឋិតនៅជាប់នឹងអតីតប៉ុស្តិ៍វិទ្យុផ្សាយសម្លេងដែលឋិតនៅជាប់នឹងវត្តឥន្ទញាណពីខាងជើង។ ចំការសណ្តែកគួររបស់ខ្ញុំគឺឋិតនៅជាប់ប៉ុស្តិ៍វិទ្យុនោះ ចំការរបស់ខ្ញុំមួយទៀតគឺចំការដំឡូងមីដែលឋិតនៅខាងកើតវត្ត។ នៅហ្នឹងចំការដំឡូងមីនោះមានផ្លូវកាត់មួយ ដែលម្ខាងផ្លូវគឺជាចំការរបស់ខ្ញុំ ហើយម្ខាងផ្លូវទៀតគឺជាចំការរបស់អ្នកទោសដែលជាប់និន្នាការសង្ស័យ [...] ចំការរបស់ខ្ញុំនិងចំការអ្នកទោសនោះគឺនៅម្ខាងផ្លូវម្នាក់ [...] បន្ទាប់ពីបាយរួច នៅពេលព្រឹកគេបញ្ចេញអ្នកទោសឱ្យបោសសំអាតទីធ្លា [គុក] រួចហើយគេប្រជុំជួរអ្នកទោស ហើយបានដាក់ច្រវាក់ជើងប្រហែលមួយម៉ែត្រកន្លះជុំវិញកជើងអ្នកទោសម្នាក់ៗ រួចហើយគេប្រគល់កាំបិតឱ្យអ្នកទោសម្នាក់ៗមួយឱ្យទៅធ្វើការក្នុងចំការដំឡូង [...] ឆ.18៖ ខ្ញុំឃើញពួកអ្នកទោសនៅវត្តឥន្ទញាណ ជាប្រចាំនៅពេលដែលគេមកធ្វើការនៅចំការដំឡូងមីជិតចំការខ្ញុំ"]។ សូមមើល ផងដែរ ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964125 ["គេដកចេញពីអង្គភាពឱ្យមកនៅហ្នឹងទៅ ហើយប្រើប្រាស់ដោយច្រវ៉ាក់ប្រវែងនេះទាក់ជាប់នឹងកជើងហ្នឹង ហើយឱ្យទៅធ្វើការប្រចាំថ្ងៃ ស្ការព្រៃ កាប់ដីដាំដំឡូងមីអីហ្នឹង"]។ សូមមើលបន្ថែមទៀត ឯកសារ D54/37 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.3 ["ពេលនោះពួកអ្នកយាមនាំពួកអ្នកទោសទៅធ្វើចំការអស់ហើយ"]។

1753 ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី KH ERN 00987080 ["សាក្សីបាននាំយើងទៅបង្ហាញចម្ការដំឡូងពីរកន្លែងដែលនៅវាលខាងក្រោម នៅខាងត្បូងឆៀងខាងកើតវត្តឥន្ទញាណ។ ចម្ការដំឡូងមួយជាកន្លែងដែលសាក្សីធ្វើការ។ ចម្ការនោះគឺនៅម្ខាងថ្នល់ពីវត្តឥន្ទញាណ ហើយនៅម្ខាងថ្នល់ទៀតខាងវត្តគឺជាចម្ការដំឡូងមួយទៀតដែលសាក្សីថា គាត់បានឃើញ អ្នកទោសដែលជាប់ច្រវាក់ធ្វើការ។ ចម្ការនោះគឺខ័ណ្ឌដោយទឹកអូរមួយពីចម្ការរបស់សាក្សីធ្វើការ។ គាត់ថាគាត់បានឃើញអ្នកទោសជាប់ច្រវាក់ធ្វើការនៅចម្ការ និងកាប់ឆ្ការព្រៃ។ ពេលខ្លះសាក្សីបានផ្តល់បារី និងម្ហូបអាហារទៅឱ្យពួកអ្នកទោសទាំងនោះ"]។

1754 ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី KH ERN 00987074 ["សក្សីនៅចាំថាមានដើមឈើធំៗក្នុងកន្លែងនេះ ហើយនិងផ្ទាំងថ្មធំៗ។ សាក្សីបានចង្អុលបង្ហាញថា ដើមស្វាយ និងខ្នុរដែលនៅជិតកន្លែងសម្ភាសនេះ គឺដាំដោយពួកអ្នកទោសកាលពីពេលនោះ"]។

1755 ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.8 ["មានផ្ទះអ្នកយាមមួយទៀត នៅជិតកន្លែងរោងបាយ។ នៅទីនោះមានអ្នកយាមប្រហែលពី៣ទៅ៤នាក់ដែលស្នាក់នៅជាមួយអ្នកទោសស្រាលៗ ដែលគេប្រើឱ្យធ្វើការ និងដាំស្លនៅរោងបាយ"]។

ក្លិនផ្អែះនោម គាត់ក៏ "ភ័យខ្លាច"[1756] ក្រោយបានជាប់ឃុំត្រឹមតែបីថ្ងៃ មូល ឈិន លែងមានសង្ឃឹមបានរស់ជីវិត។ គាត់បាន "គិតឃើញតែរឿងស្លាប់ប៉ុណ្ណោះ"[1757] សាក្សីផ្សេងៗទៀតបំភ្លឺថា ពួកគេបានឃើញ អ្នកទោសក្នុងសភាពភ័យខ្លាច និងកើតទុក្ខក្រៀមក្រំ[1758]។

## ការធ្វើទារុណកម្ម

474. ការសួរចម្លើយដោយប្រើវិធីធ្វើទារុណកម្មដូចនៅស-២១ និងមន្ទីរសន្តិសុខផ្សេងៗទៀតនៃប្រព័ន្ធនៃកម្ពុជាប្រជាធិបតេយ្យ ក៏បានអនុវត្តដែរនៅវត្តឥន្ទញ្ញាណ ក្រោមការញុះញង់ និងការដឹងឮពី **មាស មុត**[1759]។ បន្ថែមលើជំងឺផ្លូវចិត្តធ្ងន់ធ្ងរបណ្តាលមកពីអ្នកទោសទទួលរងការប្រព្រឹត្តិដោយអមនុស្សធម៌ និងការខ្លាចទារុណកម្មនោះ អ្នកទោសក៏បានទទួលរងផងដែរ នូវទារុណកម្មលើរាងកាយដែលកម្មាភិបាលនៃវត្តឥន្ទញ្ញាណប្រព្រឹត្តក្នុងទម្រង់ជាការសួរចម្លើយយកព័ត៌មាន ឬទម្រង់ជាការធ្វើទណ្ឌកម្ម។

475. យោងតាមសាក្សី ប៉ែន សារិន អ្នកទោសត្រូវធ្វើទារុណកម្ម នៅក្នុងបន្ទប់ធំមួយក្នុងវិហារ[1760]។ សាក្សី ឯក នី បានបំភ្លឺយ៉ាងរស់រវើកពីព្រឹត្តការណ៍ធ្វើទារុណកម្មអ្នកទោសស្រី ដែលគាត់បានដឹងផ្ទាល់ពីយុទ្ធជននៃវរសេនាតូចពិសេស៤៥០/១៦៥៖

---

1756 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.52 ["ភ្លាមៗពេលចូលទៅដល់ខ្ញុំធុំក្លិនផ្អែះទឹកនោមដែលជាបរិយាកាសដ៏គួរឱ្យភ័យខ្លាច"]។

1757 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.39 ["ក្នុងពេលជាប់គុកក្នុងបន្ទប់នោះរយៈពេល៣ថ្ងៃ ខ្ញុំពុំមានសង្ឃឹមថាបានរស់ទេ។ ខ្ញុំគិតឃើញតែរឿងស្លាប់ប៉ុណ្ណោះ"]។

1758 ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.30 ["បង្ហាញពីការភ័យខ្លាចយ៉ាងខ្លាំង"]។ ឯកសារ D114/187 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.32 ["តាមពិតទៅ យើងឃើញថាមនុស្សស្ថិតនៅកន្លែងហ្នឹង មិនធម្មតា គឺថាមានទឹកមុខស្លូត ដូចថាមិនសប្បាយ គិតច្រើន បារម្ភរឿងអ្វីផ្សេង អត់មានសួរអីផង។ យើងឃើញអង្គុយគិតរឿងច្រើន"]។

1759 សូមមើល VIII.C.3. មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ – ទីតាំង, ដំណើរការ និងការពិពណ៌នាទីតាំង – ២. រចនាសម្ព័ន្ធចាត់តាំង។

1760 ឯកសារ D1.3.13.8 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ ប៉ែន សារិន EN 00217562 ["ឧបករណ៍ធ្វើទារុណកម្មនៅក្នុងវត្ត នៅក្នុងសាលាធំមួយ"]។

ពួកនោះបានប្រាប់ខ្ញុំថា អំឡុងពេលសួរចម្លើយ និងធ្វើទារុណកម្ម គេបានសម្រាតខោអាវស្រីៗចេញអស់...។ ពួកស្រីៗបន្ទាប់ពីសម្រាតខោអាវអស់ហើយ គេដាក់ស្រីៗទាំងនោះ ទៅក្នុងពាងដែលមានទឹក និងឈ្លើង។ ពេលនោះពួកអ្នកទោសស្រីៗទាំងនោះ មានការភ័យខ្លាចយ៉ាងខ្លាំង ហើយឆ្លើយសារភាពទាំងអស់ ទោះជាពួកគេមិនក្បត់ ក៏ថាក្បត់ដែរ[1761]។

## ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការបាត់ខ្លួនដោយបង្ខំ

476. មានសេចក្តីបំភ្លឺថា អ្នកទោសបានបញ្ជូនមក "អប់រំ" និង "កែប្រែ" នៅវត្តឥន្ទញ្ញាណ[1762] ប៉ុន្តែពាក្យទាំងនេះគ្មានអ្វីក្រៅពីវោហាសាស្ត្របិទបាំងការពិតប៉ុណ្ណោះ។ ទោះជាមានភ័ស្តុតាងថា អ្នកទោសបានដោះលែងពីមន្ទីរសន្តិសុខនេះក៏ដោយ[1763] តាមការពិត អ្នកទោសជាង១០០០ នាក់ត្រូវ

1761 ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.16។

1762 ឯកសារ D54/32 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.5, 17 ["នៅពេលនោះខ្ញុំបានឃើញអ្វីៗដែលកើតឡើងនៅវត្តឥន្ទញ្ញាណ [...] ម្ខាងផ្សេងទៀតគឺជាចំការរបស់អ្នកទោសដែលជាប់និន្នាការសង្ស័យ។ អ្នកទោសទាំងនោះ គឺគេយកមកអប់រំកែប្រែនៅហ្នឹងវត្តនោះ។ [...] ឆ.17៖ បន្ទាប់ពីអ្នកទោសខ្លះត្រូវបានចាត់ថា បានទទួលអប់រំកែប្រែហើយ ពួកគេត្រូវបានបញ្ជូនទៅធ្វើការតាមវាលស្រែ ហើយចំនួនអ្នកទោសថ្មីក៏បានបញ្ជូនចូលមកដែរ"]។ ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964137 ["ស៖ ចុះដូចថាអ្នកដែលខុសនៅកំពង់ផែអញ្ចឹង បើគេមាននិន្នាការដូចទាហានហ្នឹងដែរអត់ទេ? ឆ៖ ទាល់តែខ្លាំង ក្តាប់កម្លាំងដែលនៅជាមួយ ជា គ្រិន ហ្នឹង បើខុសជាលើកទីមួយមានការណែនាំអប់រំ លើកទីពីរមានការណែនាំអប់រំ ហើយលើកទីបីកែប្រែអាហ្នឹងរុញបញ្ចូលទៅហ្នឹងដែរ។ ស៖ ទៅវត្តឥន្ទញ្ញាណហ្នឹងដែរ? ឆ៖ បាទ"]។

1763 ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.52 ["ខ្ញុំចាំព្រឹត្តការណ៍មួយដែលកូនទាហានរបស់ខ្ញុំចំនួនពីរនាក់ត្រូវបានចាប់ខ្លួនរយៈពេលខ្លីនៅវត្តឥន្ទញ្ញាណ។ ពួកគេបានទៅរកជ័រដើម្បីយកបិទទូក ហើយត្រូវបានអ្នកយាមវត្តឥន្ទញ្ញាណឃាត់ខ្លួន។ ខ្ញុំបានទៅវត្តឥន្ទញ្ញាណដើម្បីស្នើសុំឱ្យគេដោះលែងកូនចៅរបស់ខ្ញុំវិញ។ [...] ក្រោយពេលខ្ញុំបានបញ្ជាក់ថា អ្នកទាំងពីរនោះជាកូនចៅខ្ញុំ គេក៏ដោះលែងវិញ"]។ ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.2 ["ពេលខ្ញុំរួចខ្លួនពីវត្តឥន្ទញ្ញាណមក គេឈប់ចាត់ទុកខ្ញុំជាអ្នកទោសធ្ងន់ទៀតហើយ"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.95 ["ស៖ តើលោកដឹងថាមានរឿងអ្វីកើតឡើងចំពោះកម្មករកំពង់ផែ ៣ ទៅ៤នាក់ដែលគេយកទៅដាក់ក្នុងមន្ទីរសន្តិសុខក្នុងវត្តនោះដែរឬទេ? ឆ.95៖ ខ្ញុំមិនដឹងថាមានរឿងអ្វីកើតឡើងចំពោះពួកគេទេ តែខ្ញុំឮថាអង្គភាពរបស់ពួកគេបានយកពួកគេទៅវិញព្រោះពួកគេមិនបានប្រព្រឹត្តកំហុសអ្វីធ្ងន់ធ្ងរទេ"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.89 ["មន្ទីរសន្តិសុខនោះ គេប្រើសម្រាប់ឃុំខ្លួនមនុស្សបណ្តោះអាសន្នដែលមានបញ្ហាបន្តិចបន្តួច ហើយក្រោយមកគេបញ្ជូនអ្នកទាំងនោះចេញ ក៏ប៉ុន្តែខ្ញុំមិនដឹងថាគេបញ្ជូនទៅទីណាទេ"]។

បានសម្លាប់នៅវត្តឥន្ទញ្ញាណ។ ដូចបានសរសេរនៅផ្នែកខាងលើនេះ[1764] អ្នកទោសផ្សេងទៀតរាប់មិនអស់ ត្រូវយកពីមន្ទីរសន្តិសុខនេះទៅដាក់នៅ ស-២១ និងនៅទីតាំងផ្សេងទៀតដែលមិនបានដឹង។

477. ក្នុងពេលបោសសម្អាតអតីតវរសេនាតូច៣៨៦ ក្នុងកងពល ១៦៤ ស្នងការវរៈនេះឈ្មោះ រេម ត្រូវសម្លាប់ដោយយោធាអង្គភាពពិសេសវរសេនាតូច៤៥០/១៦៥ របស់ **មាស មុត** នៅពីមុខវត្តឥន្ទញ្ញាណ ខណៈដែល រេម ព្យាយាមតដៃនឹងការចាប់ខ្លួនគាត់[1765]។ នៅលើកំណត់ហេតុមួយក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងឡាយរបស់គាត់ ឯក នី បំភ្លឺថា **មាស មុត** បានរំឭកពីសាច់រឿងរបស់ រេម ពេលដែល **មាស មុត** អានចម្លើយសារភាពកម្មាភិបាលផ្សេងទៀតដែលបានបោសសម្អាតឱ្យយុទ្ធជនកងពល ១៦៤ ស្តាប់ពេលប្រជុំ[1766]។ តាមពិត "យុទ្ធជនស្ទើរទាំងអស់បានដឹងពីរឿងរបស់ រេម"[1767]។

---

[1764] សូមមើល VIII.C.1 បណ្តាញមន្ទីរសន្តិសុខ។

[1765] ឯកសារ D54/101 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.10, 12 ["នៅពេលនោះ ថ្នាក់ដឹកនាំកងពល គេបានដកពួកអតីតយោធារប់កងវរៈសេនាតូច៣៨៦ ចេញពីកោះ និងកន្លែងផ្សេងៗ រួចបញ្ជូនយកទៅដាក់នៅក្នុងកងផលិត។ ពេលនោះ ខ្ញុំបានឮយោធា ដែលត្រូវដកចេញ ហើយយកទៅដាក់នៅកងផលិតជាមួយខ្ញុំនិយាយថា បង រ៉េម ដែលជាអតីតមេបញ្ជាការកងវរៈសេនាតូច៣៨៦ ត្រូវបានគេបាញ់សម្លាប់នៅមុខវត្តឥន្ទញ្ញាណ។ មុនដំបូង គេបញ្ជាឱ្យគាត់លើកដៃ ប៉ុន្តែគាត់បានប្រឆាំងតបនឹងគេ ដោយបានដាល់ពួកយោធាដែលជាអ្នកបញ្ជាឱ្យគាត់លើកដៃនោះ។ យោធាទាំងនោះគឺមកពីកងពិសេសរបស់ តា មុត។ ពួកនោះគឺដូចជាកងអង្គរក្សរបស់ តា មុត ឬក៏ហៅថាកងដៃស្តាំរបស់គាត់។ បន្ទាប់ពីដាល់ពួកយោធានោះហើយ រ៉េម បានលោតចុះពីលើឡាន ហើយពួកយោធាបានបាញ់ចំក្បាលរបស់គាត់ ហើយគាត់ដួលស្លាប់នៅលើថ្នល់នៅមុខវត្តឥន្ទញ្ញាណនោះតែម្តង។ [...] ឆ.12៖ ខ្ញុំឮរឿងនេះតាមរយៈពួកយោធាដែលធ្លាប់នៅក្នុងកងពិសេស ហើយដែលត្រូវបានដកយកទៅដាក់នៅកងផលិតដែរ"]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.1 ["ព្រឹត្តិការណ៍នៅវត្តឥន្ទញ្ញាណកើតឡើងនៅឆ្នាំ ១៩៧៦។ រឿងនេះ វាកើតឡើងជិតចូលឆ្នាំ១៩៧៧ហើយ។ នៅពេលនោះ គេបានដកយោធាកង៣៨៦ ទាំងអស់យកទៅដាក់នៅកងផលិត"]។ ឯកសារ D54/103 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.11 ["នៅពេលនោះ ព័ត៌មានអំពីការចាប់ខ្លួនថ្នាក់ដឹកនាំរបស់កងពល៣៨៦ ដូចជា រ៉េម ដែលជាស្នងការ ដែលត្រូវបានគេបាញ់ចំក្បាលសម្លាប់នៅខាងមុខវត្តឥន្ទញ្ញាណ"]។ សូមមើល ផងដែរ ឯកសារ D4.1.747 កិច្ចសម្ភាសន៍របស់ US POW/MIA ជាមួយ ឯក នី (កែសម្រួលដោយ ឯកសារ D54/101 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.9) EN 00387291, KH ERN 00640517 ["[រ៉េម] ត្រូវបានសម្លាប់នៅក្នុងការបោសសម្អាតមេបញ្ជាការនៅក្នុងកងពលនេះក្នុងឆ្នាំ ១៩៧៦ នៅជិតវត្តឥន្ទញ្ញាណនៅកំពង់សោម"]។

[1766] ឯកសារ D54/101 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.11 ["តា មុត បានលើកយករឿងនេះមកបង្រៀនពួកយើងនៅពេលនោះ ដោយមានទាំងចម្លើយសារភាពរបស់ពួកនោះ [កម្មាភិបាល] មកអានប្រាប់យើងស្តាប់ផង ហើយគាត់បាន

478. ក្នុងឆ្នាំ១៩៧៩ ភ្លាមៗក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ជនស៊ីវិលដែលចូលដល់វត្តឥន្ទញ្ញាណ បានឃើញសាកសពរលួយជាប់ខ្នោះចំនួនប្រហែល១០០នាក់ នៅក្នុងសាលាឆាន់[1768]។ នៅជិតសាលាឆាន់មានពាងទឹកធំៗ យោងតាមអតីតយុទ្ធជន ដែលស្គាល់វត្តឥន្ទញ្ញាណ ក្នុងរបបនោះ[1769] ក្រោយមកទៀត ពាងទាំងនោះបានរកឃើញថាមានដាក់សាកសព[1770]។ នៅក្នុងវត្តចំនួន

---

ប្រកាសថា ពួកនេះជាខ្មែរយៈពួកក្បត់"]។ សូមមើល ផងដែរ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ .5 ["ស៖ តើ មាស មុត បាននិយាយអំពីរឿង រ៉ែម នៅក្នុងអង្គប្រជុំណាមួយដែរឬទេ? ឆ.5៖ អត់មានទេ យើងឮអំពីរឿង រ៉ែម តាមរយៈយោធាដូចគ្នា ពីព្រោះរឿងរបស់ រ៉ែម គឺយោធាស្ទើរទេទាំងអស់បានដឹង"]។

[1767] ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.5។

[1768] ឯកសារ D54/66 កំណត់ហេតុស្តាប់ចម្លើយ នួន យឹម ឆ.5, 22, 24, 27-30 [សាក្សីបានរៀបរាប់ថាបានចូលក្នុងវត្តឥន្ទញ្ញាណកាលនៅក្មេងក្នុងឆ្នាំ ១៩៧៩។ "ខ្ញុំចូលក្នុងបរិវេណវត្តដំបូងគឺប្រហែល២ទៅ៣ខែ បន្ទាប់ពីគ្រួសាររបស់ខ្ញុំមករស់នៅទីនេះ។ [...] វានៅក្នុងឆ្នាំ១៩៧៩។ [...] ឆ.22៖ តាមទ្វារនិងបង្អួច មានខ្នោះជើងធ្វើពីដែកជាច្រើន ហើយនិងសាកសពខ្លះនៅក្នុងសាលាឆាន់នោះ។ [...] ឆ.24៖ មានសាកសពប្រហែល១០០ ដែលស្អុយរលួយ ដោយមានខ្នោះជើងជាប់កជើងសាកសព។ មានក្លិនស្អុយខ្លាំងនៅជិតសាលាឆាន់នោះ មានដង្កូវជាច្រើនវារពេញសាលាឆាន់ មានរុយជាច្រើននៅខាងក្នុងនិងខាងក្រៅសាលាឆាន់ ហើយនិងទឹករលួយរបស់សាកសពហូរចេញមកក្រៅពីសាលាឆាន់នៅលើដីជុំវិញកន្លែងនោះ។ ជើងរបស់ខ្ញុំរមាស់ បន្ទាប់ពីដើរជាន់ដីកន្លែងនោះ។ [...] ឆ.27៖ នៅពេលដែលយើងបានឃើញនោះ យើងមិនបានយកឆ្អឹងសាកសពទាំងនោះចេញពីសាលាឆាន់ទេ ក្រោយមកពេលដែលមានព្រះសង្ឃចូលមកគង់ក្នុងវត្ត ខ្ញុំនិងប្រជាជនដទៃទៀត បានជួយព្រះសង្ឃធ្វើការជញ្ជូនយកឆ្អឹងខ្មោចទាំងនោះចេញសាលាឆាន់។ [...] ឆ.28៖ ទេ ខ្ញុំមិនអាចមើលស្គាល់អំពីភេទ ឬអាយុរបស់ពួកគេទេ ពីព្រោះសាកសពរលួយសាច់សល់តែឆ្អឹងទៅហើយ។ ឆ្អឹងខ្លះត្រូវគេដាក់ខ្នោះជើង ហើយចងដៃទៅមុខ ឆ្អឹងខ្លះទៀតដាក់ខ្នោះជើង ដោយឆ្កាងដៃដោយចងភ្ជាប់ទៅនឹងដែកបំពង់ដាក់ពីលើស្មាខាងក្រោយ ក។ [...] ឆ.29៖ ឆ្អឹងសាកសពត្រូវគេដាក់ខ្នោះជាមួយគ្នាជាជួរប្រហែល១០០នាក់។ ស៖ យើងមានបញ្ហាមិនជឿលោកថាសាកសព១០០នាក់ អាចដាក់ជាជួរតែមួយជួររួមគ្នាកើត? [...] ឆ.30៖ ខ្ញុំឃើញសាកសពអ្នកទោសដាក់ខ្នោះមួយជួរ លាតសន្ធឹងពីចុងជញ្ជាំងម្ខាងទៅចុងជញ្ជាំងម្ខាងទៀតតាមបណ្តោយអាគារសាលាឆាន់នោះ"]។ សាក្សី ឌិន ជុន ដែលជាម្តាយរបស់ នួន យឹម បានរៀបរាប់ថាបានឃើញខ្នោះជើងនៅក្នុងសាលាឆាន់នៅពេលដែលគាត់បានចូលវត្តដើម្បីចូលរួមបោសសម្អាតបរិវេណក្នុងវត្ត៖ ឯកសារ D54/65 កំណត់ហេតុស្តាប់ចម្លើយ ឌិន ជុន ឆ.15 ["នៅពេលនោះ យើងបានចូលទៅក្នុងបរិវេណវត្ត ដើម្បីរៀបចំបោសសម្អាតបរិវេណវត្ត ដើម្បីនិមន្តព្រះសង្ឃឱ្យមកគង់នៅក្នុងវត្ត។ ពេលនោះខ្ញុំឃើញសាលាឆាន់ដែលធ្វើអំពីឈើ ហើយមានជញ្ជាំងស៊ីម៉ង់ត៍។ នៅក្នុងសាលាឆាន់នោះ មានខ្នោះដែកសម្រាប់ដាក់ជើងរាប់មិនអស់"]។

[1769] ឯកសារ D54/88 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹម នី ឆ.3 ["ខ្ញុំឃើញមានពាងទឹកនៅជិតរោងបាយនៃប៉ែកខាងក្រោមនៃទីធ្លាវត្ត។"]។

[1770] ឯកសារ D54/65 កំណត់ហេតុស្តាប់ចម្លើយ ឌិន ជុន ឆ.15 ["នៅក្នុងបរិវេណវត្តមានពាងទឹកប្រហែល៣០ពាង ហើយពាងនីមួយៗមានឆ្អឹងខ្មោចសាកសពរលួយសាច់អស់២ទៅ៣នាក់។ ពាងខ្លះបានបែកអស់ហើយ តែពាងខ្លះនៅល្អ

សពមានច្រើនរហូតរយៈពេលចន្លោះពីរអាទិត្យទៅមួយខែទើបព្រះសង្ឃ និងជនស៊ីវិល១៥ នាក់ បានប្រមូលឆ្អឹងចេញអស់[1771]។ ឆ្អឹង សម្លៀកបំពាក់ និងសាកសពរលួយជាច្រើនទៀត នៅរាយប៉ាយក្នុងទីតាំងនោះ ក្នុងរណ្ដៅរាក់ៗមិនទាន់កប់[1772]។ រណ្ដៅដោយឡែកផ្សេងៗទៀតបានរកឃើញដោយប្រជាជនដែលរស់មូលដ្ឋាននោះ[1773]។ ក្លិនស្អុយនៅក្នុងនិងជុំវិញវត្តឥន្ទញ្ញាណ និង

---

ទេ"]។ ឯកសារ D54/66 កំណត់ហេតុស្ដាប់ចម្លើយ នួន យឹម ឆ.8 ["[នៅទិសអាគ្នេយ៍របស់វត្ត] ខ្ញុំបានឃើញពាងដាក់ទឹក និងធុងសាំងប្រហែល២០ ទៅ៣០ នៅក្រោមដើមឈើធំៗ ដែលពាងទឹក និងធុងសាំងនីមួយៗមានខ្មោចមួយ ឬពីរ ឬបី ហើយខ្លះក្បាលចុះក្រោយ ជើងឡើងលើ។ ខ្ញុំឃើញដង្កូវវារពេលលើមាត់ពាង ហើយពាង និងធុងសាំងនីមួយៗមានទឹកពេញ។ យើងមានការភ័យខ្លាចយ៉ាងខ្លាំងនូវអ្វីដែលយើងបានឃើញ ដូច្នេះយើងមិនទៅទីនោះយូរទេ"]។

1771 ឯកសារ D54/65 កំណត់ហេតុស្ដាប់ចម្លើយ ខិន ជុន ឆ.26 ["ប្រជាជន ហើយនិងព្រះសង្ឃចំនាយពេលប្រមូលឆ្អឹងនោះប្រហែលកន្លះខែ។ មានមនុស្សប្រហែល១០នាក់មកពីរដ្ឋករទឹក និងព្រះសង្ឃ៥អង្គ មកជួយប្រមូលឆ្អឹងនោះ"]។ ឯកសារ D54/66 កំណត់ហេតុស្ដាប់ចម្លើយ នួន យឹម ឆ.17 ["មានរយៈពេលប្រហែល១ខែ ដើម្បីប្រមូលឆ្អឹងទៅរក្សាទុកនៅចេតិយ"]។

1772 ឯកសារ D54/65 កំណត់ហេតុស្ដាប់ចម្លើយ ខិន ជុន ឆ.15, 19-21 [សាក្សីបានចូលក្នុងវត្តឥន្ទញ្ញាណនៅឆ្នាំ១៩៧៩ ដើម្បីជួយសម្អាតបរិវេណវត្ត។ "នៅលើដីក្បែរបរិវេណវត្ត មានខោអាវជាច្រើន ហើយនិងឆ្អឹងខ្មោចមនុស្សជាច្រើន។ [...] នៅលើផ្ទៃដីចុះពីលើភ្នំក្នុងបរិវេណវត្តគឺមានខោអាវជាច្រើន ហើយនិងសាកសពដែលស្អុយរលួយសាច់អស់ចោលនៅតាមប្រហោះ និងកៀនៗថ្មភ្នំ។ [...] មានឆ្អឹងជាច្រើននៅលើដី តែខ្ញុំមិនដឹងថាចំនួនប៉ុន្មានទេ។ នៅក្នុងបរិវេណវត្តក៏មានរណ្ដៅដែលគេកប់ខ្មោចរាក់ៗជាច្រើនផងដែរ។ [...] ស៖ តើមានជនរងគ្រោះប្រហែលប៉ុន្មាននាក់ដែលត្រូវបានស្លាប់ចោលឆ្អឹងលើទីវាលមិនបានកប់ ពេលដែលលោកស្រើមកដល់ដំបូង? ឆ.19៖ ខ្ញុំឃើញឆ្អឹងលលាដ៍ក្បាល ហើយនិងឆ្អឹងជាច្រើន តាមការស្មានរបស់ខ្ញុំ ខ្ញុំឃើញឆ្អឹង ហើយឆ្អឹងលលាដ៍ក្បាលប្រហែល៤០០ទៅ៥០០ដែលចោលលើដី នៅក្នុងបរិវេណវត្តនោះ។ [...] ឆ.20៖ ក្រោយមក នៅពេលដែលប្រជាជនឆ្ការព្រៃ និងជីកដីដើម្បីដាំដំណាំផ្សេងៗ គេប្រមូលបានឆ្អឹង និងលលាដ៍ក្បាលប្រហែល៤០០-៥០០ ថែមទៀត។ [...] ឆ.21៖ យើងនាំគ្នាជីកតែរណ្ដៅណាដែលរាក់ៗ ហើយប្រមូលយកឆ្អឹងទៅទុកនៅក្នុងវត្ត"]។ ឯកសារ ឯកសារ D54/66 កំណត់ហេតុស្ដាប់ចម្លើយ នួន យឹម ឆ.8, 12 ["មានឆ្អឹងខ្មោចជាច្រើននៅរាយប៉ាយនៅលើដីផ្នែកខាងអាគ្នេយ៍នៃវត្ត។ [...] ឆ.12៖ ខ្ញុំឃើញឆ្អឹងសាកសពជាច្រើននៅលើដីនៅជិតព្រៃឬស្សី។ សាកសពខ្លះមានសម្លៀកបំពាក់នៅជាប់ខ្លួន ហើយសាកសពខ្លះមិនមានសម្លៀកបំពាក់ទេ ហើយសាកសពខ្លះមានតែខោ។"]។ ឯកសារ D114/111 កំណត់ហេតុស្ដាប់ចម្លើយ សុខ ឡាង ឆ. 6, 12-23, 25 [អតីតសមាជិកមន្ទីររណសិរ្សសាមគ្គីសង្គ្រោះជាតិបាននិយាយថា ព្រះសង្ឃមកពីវត្តឥន្ទញ្ញាណបានប្រាប់គាត់ថាបានឃើញឆ្អឹងទាហានខ្មែរក្រហម ០៧ នាក់ដោយមានឯកសណ្ឋានខ្មែរក្រហមនៅក្នុងរណ្ដៅនៅក្នុងបរិវេណវត្ត ហើយលោកបានបូជាឆ្អឹងទាំងនោះ និងដាក់នៅក្នុងចេតិយនៅក្នុងវត្ត]។

1773 ឯកសារ D54/64 កំណត់ហេតុស្ដាប់ចម្លើយ ខិន ជុន ឆ.2-5 [សាក្សីបានរៀបរាប់ថាបានរកឃើញសាកសពពីរដែលនៅជិតផ្ទះគាត់ក្រោយវត្តឥន្ទញ្ញាណក្នុងឆ្នាំ ១៩៧៩។ ចំពោះសាកសពទីមួយ៖ "នៅពេលដែលខ្ញុំមករស់នៅទីនេះនៅឆ្នាំ ១៩៧៩ ខ្ញុំបានសង់ខ្ទមមួយនៅម្ខាងផ្លូវខាងក្រោយវត្ត។ ពេលដែលខ្ញុំបានទៅជីកដំឡូងព្រៃនៅក្រោយផ្ទះរបស់ខ្ញុំ ខ្ញុំមានធំ

វត្តមាននៃឆ្អឹង បង្ហាញថា យ៉ាងហោចណាស់ក៏មានជនរងគ្រោះខ្លះ ទើបតែស្លាប់ថ្មីៗ[1774]។ សាកសពខ្លះ មើលទៅគឺ មនុស្សស្រី[1775] និងកុមារ[1776]។ សពខ្លះនៅជាប់ច្រវ៉ាក់ឬខ្សែនីឡុង/

ក្លិនស្អុយនៅកន្លែងនោះ ហើយខ្ញុំហៅកូនរបស់ខ្ញុំឱ្យទៅជួយជីកកន្លែងស្អុយនោះ ក៏ឃើញខ្មោចរុំនឹងក្រណាត់ផ្លាស់ស្ទីក។ [...] នៅក្នុងក្រណាត់ផ្លាស់ស្ទីកនោះ ខ្ញុំបានឃើញសាកសពរបស់មនុស្សស្រីម្នាក់ដែលកំពុងតែស្អុយរលួយនៅសល់តែឆ្អឹង សក់វែង [...] ឆ.3៖ មានប្រអប់ដែកដូចវិទ្យុ ហើយនិងប៉ែលមួយ នៅពីលើក្រណាត់ផ្លាស់ស្ទីក។ [...] ឆ.4៖ ខ្ញុំកប់របស់ទាំងនោះ និងសាកសពនោះចូលទៅក្នុងរណ្ដៅនោះវិញទៅ។ សពនោះនៅកន្លែងនោះរហូតដល់សព្វថ្ងៃ។" ចំពោះសាកសពទីពីរ៖ "ខ្ញុំមិនអាចប្រាប់ទាំងអស់អំពីរណ្ដៅទីពីរទេ កូនប្រុសរបស់ខ្ញុំទើបដឹងច្បាស់។ ពេលនោះយើងជីកដីដើម្បីធ្វើបង្គន់ ហើយក៏ឃើញរណ្ដៅនោះ។ ដោយសារមានក្លិនស្អុយពេក ខ្ញុំក៏ចេញមក តែកូនប្រុសរបស់ខ្ញុំនៅតែជីក [រណ្ដៅនោះ] បន្តទៀត"]។ ឯកសារ D54/66 កំណត់ហេតុស្ដាប់ចម្លើយ នួន យឹម ឆ.1, 4 [កូនប្រុសរបស់ ខិន ជុន រៀបរាប់ពីរណ្ដៅពីរដូចគ្នានៅឆ្នាំ ១៩៧៩៖ "នៅពេលឪពុកម្ដាយរបស់ខ្ញុំកំពុងជីកដំឡូងព្រៃ ពួកគាត់បានឃើញក្រណាត់ផ្លាស់ស្ទីកពណ៌ក្រឡេក្រឡាដែលរុំខ្មោចម្នាក់ពីខាងក្នុង ហើយពេលនោះមានក្លិនស្អុយយ៉ាងខ្លាំងចេញមក។ ឪពុកម្ដាយរបស់ខ្ញុំបានហៅខ្ញុំទៅមើលខ្មោចដែលជីកឃើញនោះ។ ពេលខ្ញុំទៅដល់ ខ្ញុំឃើញដែកថ្នាំងអំពៅចំនួន២ដើម មួយៗប្រហែល១ម៉ែត្រ នៅពីលើក្រណាត់ផ្លាស់ស្ទីក មានប្រអប់ដែកអាលុយពីញ៉ូមមួយ ដែលមានទំហំប្រហែល៣តឹងបួនជ្រុង ដើលមើលទៅដូចវ៉ាឡ្ស ប៊ីដុងទឹកទាហាន កាទឹកអាលុយមីញ៉ូមរបស់ទាហាន ច្រវ៉ាក់រុំកជើងដែលមានចាក់សោ។ នៅក្នុងរណ្ដៅនោះមានកៅអីដែកបត់ពណ៌ក្រហមប្រហែល៣០ ប៉ែលបត់របស់ទាហានមួយដែលកប់នៅក្នុងរណ្ដៅជាមួយគ្នា។ យើងមិនយកអ្វីមកប្រើទេ ពីព្រោះវាកខ្វក់ និងមានក្លិនស្អុយ។ [...] យើងក៏កប់របស់របរនោះនៅក្នុងរណ្ដៅនោះវិញទៅ។ [...] ឆ.4៖ រណ្ដៅសាកសពទី២ រកឃើញដោយឪពុករបស់ខ្ញុំ នៅពេលដែលគាត់ជីកដំឡូង និងជីកធ្វើបង្គន់ ហើយគាត់បានឃើញក្រណាត់ផ្លាស់ស្ទីកក្រឡេក្រឡាពណ៌បៃតង បន្ទាប់មកគាត់បានបើកក្រណាត់ផ្លាស់ស្ទីកដែលរុំសាកសពនោះ ឃើញក្បាលខ្មោច ដែលមានសក់ខ្លីរួញដូចសក់ពួកអាហ្រិក សាច់ពណ៌ខ្មៅ ហើយរលួយអស់ទៅហើយ។ ដូច្នេះយើងមិនអាចកំណត់ថាតើសាកសពនោះបុរសឬស្ត្រីទេ។ ដោយសារក្លិនស្អុយខ្លាំងពេក យើងមិនបានបើកក្រណាត់ផ្លាស់ស្ទីកដែលរុំខ្មោចទាំងអស់ទេ បន្ទាប់មកយើងកប់ទៅវិញដោយធ្វើបង្គន់លើនោះ"]។

1774 ឯកសារ D54/64 កំណត់ហេតុស្ដាប់ចម្លើយ ខិន ជុន ឆ.2, 5 [សាក្សីបានរៀបរាប់ថាបានរកឃើញសាកសពពីរដែលនៅជិតផ្ទះគាត់ក្រោយវត្តឥន្ទញ្ញាណក្នុងឆ្នាំ ១៩៧៩។ ចំពោះសាកសពទីមួយ៖ ឆ.2៖ "ពេលដែលខ្ញុំបានទៅជីកដំឡូងព្រៃនៅក្រោយផ្ទះរបស់ខ្ញុំ ខ្ញុំមានធំក្លិនស្អុយនៅកន្លែងនោះ [...]ក៏ឃើញខ្មោចរុំនឹងក្រណាត់ផ្លាស់ស្ទីក។ [...]នៅក្នុងក្រណាត់ផ្លាស់ស្ទីកនោះ ខ្ញុំបានឃើញសាកសពរបស់មនុស្សស្រីម្នាក់ដែលកំពុងតែស្អុយរលួយ"។ ចំពោះសាកសពទីពីរ៖ ឆ.5៖ "ដោយសារមានក្លិនស្អុយពេក ខ្ញុំក៏ចេញមក តែកូនប្រុសរបស់ខ្ញុំនៅតែជីក [រណ្ដៅនោះ] បន្តទៀត"]។ ឯកសារ D54/65 កំណត់ហេតុស្ដាប់ចម្លើយ ខិន ជុន ឆ.15, 18, 25 ["ទោះបីសាកសពរលួយសាច់អស់ក្ដី តែក្លិននៅតែស្អុយខ្លាំង។ [...] ឆ.18៖ ដោយសារស្ថានភាពទីកន្លែងនោះរញ៉េរញ៉ៃ ហើយនិងមានក្លិនមិនល្អ គ្មានអ្នកណារស់នៅក្នុងបរិវេណវត្តនោះបានទេ។ [...] ស៖ ហេតុអ្វីបានជាលោកស្រីជឿថារណ្ដៅសាកសពទាំងនោះ ខោអាវ ឆ្អឹង និងឆ្អឹងលលាដ៍ក្បាល ជាសពដែលស្លាប់នៅក្នុងសម័យខ្មែរក្រហម មិនមែនជាខ្មោចពីមុនមក? ឆ.25៖ ដោយសារតែក្លិននៅថ្មីៗនៅឡើយ សម្រាប់ខ្មោចស្លាប់ធម្មតា គេមិនទុកចោលនៅកណ្ដាលវាល ឬក៏កប់នៅក្នុងរណ្ដៅរាក់ៗដូច្នេះទេ"]។ ឯកសារ

អង្រឹង[1777]។ ហើយខ្លះពាក់ខោអាវខ្មៅ[1778]។ ឧបករណ៍ឃោធាបានរកឃើញដែរក្នុងរណ្ដៅសព[1779]។ លើសពីនេះ ឆ្អឹងលលាដ៍ក្បាលខ្លះ ឃើញមានស្នាមបែកដោយវត្ថុមិនមុតស្រួច[1780] បង្ហាញថា មាន

---

D54/66 កំណត់ហេតុស្ដាប់ចម្លើយ នួន យឹម ឆ.1, 4, 8 [កូនប្រុសរបស់ ខិន ជុន រៀបរាប់ពីសាកសពនៅក្នុងរណ្ដៅទីមួយ និងទីពីរ៖ "នៅពេលឪពុកម្ដាយរបស់ខ្ញុំកំពុងជីកដំឡូងព្រៃ ពួកគាត់បានឃើញក្រណាត់ផ្ដាស់ស្ទីកពណ៌ក្រឡេក្រឡាដែលរុំខ្មោចម្នាក់ពីខាងក្នុង ហើយពេលនោះមានក្លិនស្អុយយ៉ាងខ្លាំងចេញមក។ [...]យើងមិនយកអ្វីមកប្រើទេ ពីព្រោះវាកខ្វក់ និងមានក្លិនស្អុយ។ [...] ឆ.4៖ រណ្ដៅសាកសពទី២ រកឃើញដោយឪពុករបស់ខ្ញុំ នៅពេលដែលគាត់ជីកដំឡូង និងជីកធ្វើបង្គន់ ហើយគាត់បានឃើញក្រណាត់ផ្ដាស់ស្ទីកក្រឡេក្រឡាពណ៌បៃតង [...] ដោយសារក្លិនស្អុយខ្លាំងពេក យើងមិនបានបើកក្រណាត់ផ្ដាស់ស្ទីកដែលរុំខ្មោចទាំងអស់ទេ [...] ឆ.8៖ រៀបរាប់ពីបរិវេណវត្តឥន្ទញាណនៅពេលដែលគាត់បានចូលនៅក្នុងឆ្នាំ ១៩៧៩៖ "នៅពេលដែលខ្ញុំចូលក្នុងបរិវេណវត្តផ្នែកអាគ្នេយ៍ ខ្ញុំធុំក្លិនស្អុយយ៉ាងខ្លាំង។ មានដង្កូវធំៗប៉ុនម្រាមដៃរបស់ខ្ញុំវារនៅពេញដី។ [...] ពាងទឹក និងធុងសាំងនីមួយៗមានខ្មោចមួយ ឬពីរ ឬបី ហើយខ្លះក្បាលចុះក្រោយ ជើងឡើងលើ។ ខ្ញុំឃើញដង្កូវវារពេលលើមាត់ពាង ហើយពាង និងធុងសាំងនីមួយៗមានទឹកពេញ"]។

1775 ឯកសារ D54/65 កំណត់ហេតុស្ដាប់ចម្លើយ ខិន ជុន ឆ.31 ["ចាស មានខ្មោចប្រុស និងខ្មោចស្រី ដោយខ្ញុំគិតថា ឆ្អឹងខ្មោចប្រុសវែងជាឆ្អឹងខ្មោចស្រី ហើយនៅពេលនោះខ្ញុំក៏បានឃើញមានខោអាវ សំពត់ និងអាវទ្រនាប់របស់ស្ត្រី"]។

1776 ឯកសារ D54/65 កំណត់ហេតុស្ដាប់ចម្លើយ ខិន ជុន ឆ.30 ["ស៖ តើលោកស្រីមានឃើញឆ្អឹងកូនក្មេងនៅក្នុងចំណោមឆ្អឹងដែលលោកស្រីប្រមូលនោះដែរឬទេ? ឆ.30៖ ចាស មានឆ្អឹងតូចៗខ្លះ ដែលជាឆ្អឹងកូនក្មេង"]។

1777 ឯកសារ D54/65 កំណត់ហេតុស្ដាប់ចម្លើយ ខិន ជុន ឆ.28 [រៀបរាប់ពីសាកសពដែលបានរកឃើញនៅលើដី និងនៅក្នុង រណ្ដៅរាក់ៗក្នុងបរិវេណវត្តឥន្ទញាណ៖ "ទោះបីជារលួយសាច់អស់ហើយក្ដី ឆ្អឹងខ្លះមានចងដៃនឹងខ្សែអង្រឹងទៅក្រោយ"]។ ឯកសារ D54/64 កំណត់ហេតុស្ដាប់ចម្លើយ ខិន ជុន ឆ.2 [រៀបរាប់ពីស្ត្រីម្នាក់ដែលបានរកឃើញសាកសពនៅក្រោយផ្ទះគាត់៖ "ដៃទាំងពីរចងមកមុខជាប់នឹងច្រវាក់ដោយចាក់សោ។ ចំណែកជើងទាំងពីរក៏ដាក់ច្រវាក់និងចាក់សោដែរ។ សោមានទំហំប៉ុនកដៃខ្ញុំ"]។ ឯកសារ D54/66 កំណត់ហេតុស្ដាប់ចម្លើយ នួន យឹម ឆ.1, 4-5 [កូនប្រុសរបស់ ខិន ជុន រៀបរាប់ពីស្ត្រីនៅក្នុងរណ្ដៅនីមួយៗ៖ "នៅពេលខ្ញុំទៅដល់ ខ្ញុំឃើញដែកថ្នាំងអំពៅចំនួនពីរដើម មួយៗប្រហែល១ម៉ែត្រ [...] ច្រវាក់រុំកជើងដែលមានចាក់សោ"]។

1778 ឯកសារ D54/65 កំណត់ហេតុស្ដាប់ចម្លើយ ខិន ជុន ឆ.28, 32-33 ["ចាស លលាដ៍ក្បាលខ្លះគឺមានក្រណាត់រុំមុខនៅចងនៅឡើយ [...] ឆ.32៖ ឆ្អឹងសាកសពខ្លះនៅមានខោអាវខ្មៅៗនៅជាប់ជាមួយ។ ស៖ តើលោកស្រីអាចពន្យល់ប្រាប់យើងថា លោកស្រីចង់មានន័យថាម៉េចសម្រាប់ ខោអាវខ្មៅៗនោះ? ឆ.33៖ ខ្ញុំមិនអាចប្រាប់បានទេ ពីព្រោះនៅពេលនោះយោធា និងប្រជាជនធម្មតាស្លៀកសំលៀកបំពាក់ពណ៌ខ្មៅដូចគ្នា"]។

1779 ឯកសារ D54/66 កំណត់ហេតុស្ដាប់ចម្លើយ នួន យឹម ឆ.1 ["ក្នុងរយៈពេលខ្លីបន្ទាប់ពីយើងឆ្ការដីនេះ ហើយសង់ខ្ទមសម្រាប់នៅ ថ្ងៃមួយយើងបានរកជីកដំឡូងព្រៃដើម្បីហូប។ នៅពេលឪពុកម្ដាយរបស់ខ្ញុំកំពុងជីកដំឡូងព្រៃ ពួកគាត់បានឃើញក្រណាត់ផ្ដាស់ស្ទីកពណ៌ក្រឡេក្រឡាដែលរុំខ្មោចម្នាក់ពីខាងក្នុង ហើយពេលនោះមានក្លិនស្អុយយ៉ាងខ្លាំងចេញមក។ ឪពុកម្ដាយរបស់ខ្ញុំបានហៅខ្ញុំទៅមើលខ្មោចដែលជីកឃើញនោះ។ ពេលខ្ញុំទៅដល់ ខ្ញុំឃើញដែកថ្នាំងអំពៅចំនួន២ដើម មួយៗប្រហែល១ម៉ែត្រ នៅពីលើក្រណាត់ផ្ដាស់ស្ទីក មានប្រអប់ដែកអាលុយពីញ៉ូមមួយ ដែលមានទំហំប្រហែល

ការសម្លាប់ដោយវាយក្បាលនឹងវត្ថុមិនមុតស្រួចទាំងនោះ។ តាមពិត នៅទីតាំងនោះមានឃើញនៅសល់ចប[1781]។

479. ឆ្អឹងនៃជនរងគ្រោះជាច្រើន ក្រោយមក បានប្រមូលដាក់ក្នុងបរិវេណវត្តក្នុងចេតិយ ដែលមានបួនជាន់[1782]។

---

ពាតឹងបួនជ្រុង ដើលមើលទៅដូចរ៉ាដ្យូ ប៊ីដុងទឹកទាហាន កាទឹកអាលុយមីញ៉ូមរបស់ទាហាន ច្រវាក់រុំកជើងដែលមានចាក់សោ។ នៅក្នុងរណ្តៅនោះមានកៅអីដែកបត់ពណ៌ក្រហមប្រហែល៣០ ប៉ែលបត់របស់ទាហានមួយដែលកប់នៅក្នុងរណ្តៅជាមួយគ្នា។ យើងមិនយកអ្វីមកប្រើទេ ពីព្រោះវាកខ្វក់ និងមានក្លិនស្អុយ។ នៅពេលនោះ ឪពុកម្តាយ បងប្រុសម្នាក់ និងប្អូនស្រីរបស់ខ្ញុំម្នាក់ ហើយនិងខ្ញុំនាំគ្នាកាយរកមើលមាស ឬក៏គ្រឿងអលង្ការនៅក្នុងរណ្តៅនោះ ប៉ុន្តែពេលនោះយើងពុំឃើញមានរបស់របរអ្វីទេ យើងក៏កប់របស់របរនោះនៅក្នុងរណ្តៅនោះវិញទៅ។"]។ ឯកសារ D54/64 កំណត់ហេតុស្តាប់ចម្លើយ ខិន ជុន ឆ.3 ["មានប្រអប់ដែកដូចវិទ្យុ ហើយនិងប៉ែលមួយ នៅពីលើក្រណាត់ផ្លាស់ស្ទីក"]។

1780 ឯកសារ D2/22 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងនៃមន្ទីរសន្តិសុខវត្តឥន្ទញាណ EN 00634155, FR 00725853, KH ERN 00662133 ["ឆ្អឹងលលាដ៍មួយចំនួន បង្ហាញឱ្យឃើញនូវសញ្ញា blunt trauma"], KH ERN 00662156-00662157 ["រូបភាពនៃឆ្អឹងលលាដ៍ក្បាល។"]។

1781 ឯកសារ D54/65 កំណត់ហេតុស្តាប់ចម្លើយ ខិន ជុន ឆ.15, 37, 40 ["នៅក្នុងសាលាឆាន់នោះ មានខ្នោះដែករាប់មិនអស់។ [...] ឆ.37៖ ខ្ញុំបានឃើញបន្ទប់ឃុំឃាំង និងខ្នោះជើង នៅក្នុងសាលាឆាន់។ [...] ឆ.40៖ ខ្ញុំឃើញមាន ចបកាប់ ប៉ែល ដែកថ្លូវរទេះ នៅសល់ជាមួយនឹងខ្នោះជើងនៅនឹងសាលាឆាន់"]។

1782 ឯកសារ D54/66 កំណត់ហេតុស្តាប់ចម្លើយ នួន យឹម ឆ.15, 18 ["ខ្ញុំបានចូលមកជួយម្តាយខ្ញុំ ហើយនិងព្រះសង្ឃ ដើម្បីប្រមូលឆ្អឹង និងលលាដ៍ក្បាលនៅក្នុងបរិវេណវត្តទៅរក្សាទុកនៅក្នុងចេតីយ៍ [...] ឆ.18៖ ចេតីយ៍នោះមាន៤ជាន់ មានទំហំប្រហែល១២ម៉ែត្របួនជ្រុង និងមានកម្ពស់ប្រហែល១៥ម៉ែត្រ"]។ ឯកសារ D114/111 កំណត់ហេតុស្តាប់ចម្លើយ សុខ ឡាង ឆ.6, 18 ["ប្រហែលនៅក្នុងឆ្នាំ ១៩៨១ ឬ១៩៨២ ព្រះសង្ឃ និងគណៈកម្មការវត្តឥន្ទញាណ បានប្រាប់ខ្ញុំថា ពេលដែលពួកគាត់ធ្វើការសម្អាតទីធ្លាក្នុងវត្ត ពួកគាត់ក៏បានប្រទះឃើញឆ្អឹងសាកសពម្តងមួយៗ សរុបមានប្រាំពីរសាកសព។ ពួកគាត់ក៏បានយកឆ្អឹងទាំងនោះទៅបូជា ហើយខ្ចប់ក្នុងក្រណាត់ស ហើយតម្កល់ក្នុងចេតិយរួមគ្នាមួយ។ [...] ឆ.18៖ ខ្ញុំបានទៅវត្តឥន្ទញាណ ហើយសួរព្រះសង្ឃអំពីសាកសពទាំងនោះ។ ព្រះសង្ឃបានប្រាប់ខ្ញុំថាលោកបានបូជាឆ្អឹងសាកសពទាំងនោះអស់ហើយ ហើយបានបង្ហាញស្បោងក្រណាត់សចំនួនប្រាំពីរកញ្ចប់ដែលដាក់អដ្ឋិធាតុសាកសពទាំងប្រាំពីរនាក់នោះ"]។ ឯកសារ D1.3.13.12 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ សុខ ឡាង EN 00217568 ["គាត់ប្រាប់ថាគាត់បានដឹងពីការគាស់ឆ្អឹងសាកសពដែលនៅសល់ជិតវត្ត ដែលព្រះសង្ឃបានប្រមូល និងបានដាក់នៅក្នុងចេតីយ៍រួមមួយ"]។ ឯកសារ D1.3.13.1 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ ប៉ូច កុយ EN 00217558 ["ឆ្អឹងខ្មោចខ្លះត្រូវបានដាក់ក្នុងចេតិយនៅ 48P US 3628974626 +/-18m។ [ការពិនិត្យលលាដ៍ក្បាលដែលនៅសេសសល់បង្ហាញសញ្ញានៃការប៉ះទង្គិចទៅតំបន់ខាងស្តាំនៅលើលលាដ៍ក្បាលមួយ និងផ្នែកខាងលើនៃលលាដ៍

480. សាក្សីពីរនាក់ដែលបានមកដល់ទីតាំងនេះក្នុងឆ្នាំ ១៩៧៩ ប៉ាន់ប្រមាណថា នៅវត្តឥន្ទញ្ញាណ ចំនួនសពមានប្រហែល១០០០ នាក់។ សាក្សីម្នាក់បំភ្លឺថា "ចំនួនឆ្អឹងខ្មោចមានប្រហែលជាមានរាប់រយ ហើយយ៉ាងច្រើនខ្លាំងណាស់មួយពាន់"[1783]។ សាក្សីម្នាក់ទៀតបំភ្លឺថា "ឆ្អឹងលលាដ៍ក្បាលនៅក្នុងបរិវេណវត្តមានប្រហែលពី៤០០ទៅ៥០០"[1784] ហើយឃើញមានចំនួនដូចគ្នានេះ ម្តងទៀតពេលកាយចេញពីរណ្តៅក្នុងបរិវេណនោះ[1785]។ នៅជុំវិញវត្តឥន្ទញ្ញាណ ទំនងជាមិនមែនរាល់រណ្តៅទាំង

---

ក្បាល ក៏ដូចជាការខូចខាតខាងផ្នែកខាងស្តាំចំពោះលលាដ៍ក្បាលទីពីរ។ លលាដ៍ក្បាលទាំងនោះមិនត្រូវបានប៉ះពាល់ទេ ហើយការត្រួតពិនិត្រត្រូវបានធ្វើឡើងពីអ្វីដែលអាចមើលឃើញ ដោយមិនបានប៉ះពាល់ឆ្អឹងទាំងនោះទេ។ កោដ្ឋជាច្រើនត្រូវបានរក្សាទុកនៅក្នុងចេតិយនោះផងដែរ"]។ សូមមើល ផងដែរ ឯកសារ ឯកសារ D54/65 កំណត់ហេតុស្តាប់ចម្លើយ ខិន ជុន ឆ.21, 25 ["យើងនាំគ្នាជីករណ្តៅណាដែលរាក់ៗ ហើយប្រមូលយកឆ្អឹងទៅទុកនៅក្នុងវត្ត។ [...] ឆ. 25៖ សម្រាប់ខ្មោចខ្មែរ គេច្រើនតែដុត"]។ សូមមើល បន្ថែមទៀត ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.23 ["ស៖ តើលោកធ្លាប់ឮឈ្មោះវត្តក្រោម ឬវត្តឥន្ទញ្ញាណដែរឬទេ នៅកំពង់សោម? ឆ.23៖ បាទ ខ្ញុំស្គាល់កន្លែងនេះច្បាស់ណាស់ ពីព្រោះខ្ញុំធ្លាប់រស់នៅជិតកន្លែងនោះ កាលពីពេលនោះ។ [...] គេឃុំអ្នកទោសនៅក្នុងចេតិយនៅក្នុងបរិវេណវត្ត"]។

[1783] ឯកសារ D54/66 កំណត់ហេតុស្តាប់ចម្លើយ នួន យឹម ឆ.13-14, 18 ["យោងតាមការស្មានរបស់ខ្ញុំ ចំនួនឆ្អឹងខ្មោចប្រហែលជាមានចំនួនរាប់រយ ហើយយ៉ាងច្រើនណាស់មួយពាន់។ [...] ឆ.14៖ ខ្ញុំបានឃើញឆ្អឹងសាកសពជាច្រើននៅពេញដី នៅក្នុងពាងនិងធុងសាំង ហើយនិងក្បែរព្រៃឫស្សី។ [...] ស៖ នៅពេលដែលលោកប្រាប់យើងអំពីចំនួនសាកសពពីខាងដើម ថា១០០០នាក់ តើលោកគិតពីចំនួននោះតាមរយៈការឃើញរបស់លោកពីដំបូង ហើយនិងបន្ទាប់ពីការប្រមូលឆ្អឹងឬយ៉ាងណា? ឆ.18៖ បាទ ខ្ញុំស្មានចំនួននេះ ដោយសារក្រោយពីរក្សាទុកឆ្អឹងនិងលលាដ៍ក្បាលនៅចេតីយ៍រហូតដល់ពេញ។ ចេតីយ៍នោះមាន៤ជាន់ មានទំហំប្រហែល១២ម៉ែត្របួនជ្រុង និងមានកម្ពស់ប្រហែល១៥ម៉ែត្រ"]។

[1784] ឯកសារ D54/65 កំណត់ហេតុស្តាប់ចម្លើយ ខិន ជុន ឆ.19 ["ខ្ញុំឃើញឆ្អឹងលលាដ៍ក្បាល ហើយនិងឆ្អឹងជាច្រើន តាមការស្មានរបស់ខ្ញុំ ខ្ញុំឃើញឆ្អឹង ហើយឆ្អឹងលលាដ៍ក្បាលប្រហែល៤០០ទៅ៥០០ដែលចោលលើដី នៅក្នុងបរិវេណវត្តនោះ"]។

[1785] ឯកសារ D54/65 កំណត់ហេតុស្តាប់ចម្លើយ ខិន ជុន ឆ.19-20, 27 ["ខ្ញុំឃើញឆ្អឹងលលាដ៍ក្បាល ហើយនិងឆ្អឹងជាច្រើន តាមការស្មានរបស់ខ្ញុំ ខ្ញុំឃើញឆ្អឹង ហើយឆ្អឹងលលាដ៍ក្បាលប្រហែល៤០០ទៅ៥០០ដែលចោលលើដី នៅក្នុងបរិវេណវត្តនោះ។ [...] ឆ.20៖ ក្រោយមក នៅពេលដែលប្រជាជនឆ្ការព្រៃ និងជីកដីដើម្បីដាំដំណាំផ្សេងៗ គេប្រមូលបានឆ្អឹង និងលលាដ៍ក្បាលប្រហែល៤០០-៥០០ ថែមទៀត។ [...] ស៖ នៅពេលដែលយើងនិយាយជាមួយសាក្សីឈ្មោះ ប៉ូច កុយ គាត់បានប្រាប់យើងថា មានខ្មោចប្រហែល២០០ប៉ុណ្ណោះ ដែលត្រូវបានគាស់ពីរណ្តៅកាលពីដើមឆ្នាំ ១៩៨០ តើលោកស្រីអាចប្រាប់យើងបានទេ ហេតុអ្វីបានជាចំនួនខ្មោចដែល តា កុយ ប្រាប់ មិនដូចនឹងចំនួនខ្មោចដែលលោកស្រីបានប្រាប់យើង? ឆ.27៖ ចំនួនឆ្អឹង និងលលាដ៍ក្បាលមានចំនួនពី២០០ ទៅ៥០០។ ខ្ញុំគិតថា តា កុយ ភ្លេចប្រាប់លោកអំពីឆ្អឹង និងឆ្អឹងលលាដ៍ក្បាលដែលប្រមូលបាននៅលើដីអំឡុងពេលដែលយើងសម្អាតបរិវេណវត្តជាមួយលោកសង្ឃ។ តា កុយ នៅពេលនោះមិនបានចូលរួមសម្អាតជារៀងរាល់ថ្ងៃទេ ពីព្រោះគាត់រវល់ការងាររបស់គាត់នៅ

អស់ សុទ្ធតែបានកាយធ្វើកោសល្យវិច័យនោះទេ[1786]។ តាមពិត មានរណ្តៅថែមទៀត បានរកឃើញប្រហែលឆ្នាំ១៩៨២[1787] និងក្នុងឆ្នាំ២០០៣[1788]។

---

រដ្ឋករទឹក។ ខ្ញុំ ជាមួយនិងស្ត្រីដទៃទៀត ហើយនិងព្រះសង្ឃបានធ្វើការសម្អាតកន្លែងនោះជារៀងរាល់ថ្ងៃ ដើម្បីយកដីដាំដំណាំផ្សេងៗ។ មានយាយម្នាក់ឈ្មោះ យាយពៅ ស្លាប់ប្រហែលមួយឆ្នាំមុន ប្រសិនបើគាត់នៅរស់ គាត់ជាប្រភពព័ត៌មានល្អអំពីរឿងនេះ។ គាត់រស់នៅក្នុងវត្តដើម្បីដាំបាយទឹកបម្រើព្រះសង្ឃ។ គាត់បានដេកនៅក្បែរឆ្អឹងខ្មោចដែលប្រមូលបាននៅពេលនោះ រៀងរាល់ថ្ងៃ។ គាត់ស្លាប់នៅអាយុប្រហែល១០០ឆ្នាំ"]។ សូមមើល ផងដែរ ឯកសារ D1.3.13.1 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ ប៉ូច កុយ EN 00217558 [កែសម្រួលដោយ ឯកសារ D2/4 កំណត់ហេតុស្តាប់ចម្លើយ ប៉ូច កុយ ស/ឆ 2] ["គាត់បាននិយាយថានៅចន្លោះឆ្នាំ ១៩៨០ និងឆ្នាំ ១៩៨២ មានគ្រោងឆ្អឹងប្រហែល២០០ត្រូវបានគាស់ចេញពីទីតាំងដែលគេស្គាល់ថាជា "ចម្ការក្រូចឆ្មារ""]។

1786 ឯកសារ D54/65 កំណត់ហេតុស្តាប់ចម្លើយ ខិន ជុន ឆ.21, 35 ["សៈ តើរណ្តៅសាកសពជំនាន់ខ្មែរក្រហមទាំងអស់ត្រូវបានគេជីកប្រមូលឆ្អឹងក្នុងពេលនោះ ឬយ៉ាងណា? ឆ.21៖ ខ្ញុំមិនអាចដឹងបានទេ ពីព្រោះនៅពេលនោះ យើងនាំគ្នាជីកតែរណ្តៅណាដែលរាក់ៗ ហើយប្រមូលយកឆ្អឹងទៅទុកនៅក្នុងវត្ត។ [...] ឆ.35៖ យើងមិនបានជីករណ្តៅគ្រប់កន្លែងនោះទេ។ យើងជីកតែ រណ្តៅណាដែលមានស្នាមជ្រុកព្រៃឈ្មួសចំហ ពីព្រោះចោលក្លិនស្អុយខ្លាំងមកក្រៅ"]។

1787 ឯកសារ D54/66 កំណត់ហេតុស្តាប់ចម្លើយ នួន យឹម ឆ.31 ["ប្រហែល៤-៥ ខែ បន្ទាប់ពីការមកដល់របស់អ៊ុនតាក់ នៅពាក់កណ្តាលយប់មួយ មានឡានហ្សីបទាហានចំនួន៣គ្រឿង មានទាហានប្រហែល២០នាក់ អាវុធគ្រប់ដៃមកជីករណ្តៅនោះ។ គេប្រើភ្លើងឡានបំភ្លឺកន្លែងនោះអំឡុងពេលជីករណ្តៅ។ ខ្ញុំ ព្រះសង្ឃផ្សេងទៀត និងព្រះចៅអធិការវត្ត បានភ្ញាក់ដោយសារឮ សម្លេងឆ្កែព្រូស ទើបដឹង ថាគេមកជីកកន្លែងនោះ។ ពេលនោះយើងមិនចូលទៅជិតទេ យើងនៅពួនពីក្រោយថ្ម លួចមើលគេ ជីករណ្តៅ។ យើងឃើញពួកគេលើករបស់ដូចជា មាស ខ្សែក និងគ្រឿងអលង្ការផ្សេងៗ ដាក់ចូលទៅក្នុងបាវ។ ខ្ញុំឃើញរបស់ទាំងអស់នោះដោយចាំងផ្លាតពីភ្លើងឡានផ្លេចៗ។ ព្រឹកឡើង ខ្ញុំនិងចៅអធិការវត្តទៅមើលកន្លែងជីកនោះ បានឃើញពាងទទេចំនួន៥នៅក្នុងរណ្តៅនោះ។ យើងមិនបានប៉ះពាល់ពាងទាំងនោះទេ។ ប្រហែលមួយអាទិត្យក្រោយមក ពួកទាហាននោះមកម្តងទៀត មកយកពាងទាំងនោះចេញពីរណ្តៅទៅជាមួយគេ។ ខ្ញុំមិនដឹងថាទាហានទាំងនោះមកពីខាងណាទេ។ ខ្ញុំឃើញពួកគេស្លៀកឯកសណ្ឋានប៉ារ៉ា។ ពួកគេជាទាហានខ្មែរ ពីព្រោះគេនិយាយភាសាខ្មែរ។ យើងឮពួកគេនិយាយថា ប្រមូលឲ្យលឿនៗ ដើម្បីចាកចេញឲ្យបានឆាប់"]។ សូមមើល ផងដែរ ឯកសារ D114/30 មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ៖ សាក្សី នួន យឹម របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំង KH ERN 01363950 ["ទីតាំងនៃពាងនៅក្រោមដីដែលមានមាស និងគ្រឿងអលង្ការដែលត្រូវគេយកទៅ"]។

1788 ឯកសារ D2/22 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងនៃមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ EN 00634155, FR 00725852, KH ERN 00662131 ["មានពេលមួយផ្សេងទៀត ក្នុងឆ្នាំ២០០៣ ក្នុងពេលស្ថិតក្នុងដំណាក់កាលសាងសង់អគារដែលមានបណ្តោយវែងមួយ (សាលាព្រះសង្ឃ/កុដិសិក្ខាសាលា) គេបានឃើញសំណល់ឆ្អឹងជាច្រើនថែមទៀត"]។

## ៤. មន្ទីរសន្តិសុខទឹកសាប[1789]

### ទីតាំង ការពណ៌នាអំពីទីតាំង និងប្រតិបត្តិការ

481. ទឹកសាប គឺជាមន្ទីរសន្តិសុខ ឬ "អប់រំកែប្រែ" និងជាទីតាំងសម្លាប់មនុស្ស[1790] ស្ថិតក្នុងបរិវេណធំមួយដែលមានអគារជាច្រើនប្រើប្រាស់ដោយកងពល ១៦៤។ ការដ្ឋានទឹកសាប (ប្រែជាភាសាអង់គ្លេសពាក្យដោយពាក្យតែម្តង ហៅថា "fresh water site" ស្ថិតក្នុងស្រុកព្រៃនប់ ដែលបានចូលក្នុងតំបន់ឯករាជ្យកំពង់សោម[1791] ចន្លោះកងកេង និងវាលរេញ[1792] ចម្ងាយប្រហែល២០ គីឡូម៉ែត្រ

---

[1789] ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៥២-៥៤, ៥៩-៦១។ ឯកសារ ឯកសារ D120 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម កថាខណ្ឌ ១០-១១។

[1790] សូមមើល ឧទាហរណ៍ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.66 ["ទឹកសាបគឺជាគុក"]។ ឯកសារ D114/18 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.42 ["តាមដែលខ្ញុំដឹង [ទឹកសាប] គឺជាមន្ទីរឃុំឃាំង"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.17 ["ខ្ញុំដឹងច្បាស់ថា ទឹកសាប គឺជាកន្លែងគុក និងកន្លែងសម្លាប់"]។ ឯកសារ D114/25 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដាវ ឆ.32 ["បាទ ខ្ញុំធ្លាប់ឮថា កន្លែងទឹកសាបហ្នឹងក៏ជាកន្លែងមន្ទីរសន្តិសុខធំមួយ ហើយខ្ញុំថាមានកន្លែងសម្លាប់ផ្សេងៗទៀត តែខ្ញុំមិនចាំកន្លែងទាំងនោះទេ។ ខ្ញុំដឹងរឿងនេះតាមរយៈអតីតទាហានខ្មែរក្រហម"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ.137 ["ស៖ នៅក្នុងកិច្ចសម្ភាសរបស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ជាភាសាអង់គ្លេស ទំព័រ៥៦ និងទំព័រ៥៧ លោកនិយាយថា "មានមន្ទីរអប់រំកែប្រែរបស់កងពល" តើលោកអាចបញ្ជាក់បានទេ មន្ទីរអប់រំកែប្រែនោះមានទីតាំងនៅកន្លែងណា? ឆ. 137៖ មន្ទីរកែប្រែនោះគឺស្ថិតនៅទឹកសាប"]។ ឯកសារ D114/19 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.8 ["ស៖ តើលោកស្គាល់កន្លែងឃុំឃាំងដទៃៗទៀត នៅក្រោមកងពល១៦៤ ដែរទេ? ឆ.8៖ ទេ ខ្ញុំមិនស្គាល់ទេ ខ្ញុំស្គាល់តែមន្ទីរឃុំឃាំងទឹកសាបមួយប៉ុណ្ណោះ"]។ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.39 [រៀបរាប់ពីទឹកសាបថាជា "គុកយោធា"]។ ឯកសារ D114/242 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ប៊ុននី ឆ.84, 97 ["មន្ទីរធំបំផុត គឺមន្ទីរគុកនៅទឹកសាបហ្នឹង គុកធំរបស់ពួកវា។ [...] ឆ.97៖ [តំបន់ទឹកសាប] ខាងយោធា"]។ សូមមើល ផងដែរ ឯកសារ D114/146 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ើក ឆ.57 [" ចំការធូរេន គឺនៅហ្នឹងទឹកសាប។ ខ្ញុំធ្លាប់ឮថា ជាកន្លែងដែលគេទុកពួកអ្នកទោស"]។

[1791] ឯកសារ D114/15 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា ឆ.9 ["គេបញ្ជូនពួកយើងទៅប្រចាំការណ៍នៅទឹកសាបស្រុកព្រៃ នប់"]។ ឯកសារ D54/111 កំណត់ហេតុស្តាប់ចម្លើយ សំ ភីន ឆ.16 ["តាមខ្ញុំដឹង ទឹកសាបស្ថិតនៅក្រោមកងវរៈសេនាធំ៦៣។ ទឹកសាបនៅជិតព្រៃនប់"]។ ឯកសារ D114/54 កងម៉ារីនកងពលធំ ១៦៤ (អតីតកងពលធំលេខ ៣) របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំង KH ERN 01353020 ["ទឹកសាប គឺជាឃុំតូចមួយនៅតាមបណ្តោយផ្លូវជាតិលេខ៤ នៅក្នុងស្រុកព្រៃនប់ ខេត្តព្រះសីហនុ"]។

ពីក្រុងកំពង់សោម និងមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ[1793]។ មន្ទីរនេះ ស្ថិតនៅទិសឦសាន នៃសហករណ៍រាម និងអាកាសយាដ្ឋានកងកេង[1794]។

482. ទីតាំងនេះ គឺជាអតីតបន្ទាយទាហានលន់ នល់[1795] ក្បែរស្ពានទឹកសាប[1796] ដែលមួយភាគធំស្ថិតក្នុងភាគឦសាននៃចំណុចផ្លូវជាតិលេខ៤ កាត់ស្ទឹងទឹកសាប[1797]។ បន្ទាប់ពីបោះទីតាំងនៅកងកេង[1798]

---

[1792] ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.140 ["ទឹកសាបមានទីតាំងស្ថិតនៅចន្លោះកងកេង និងវាលរិញ"]។ ឯកសារ D114/33 កំណត់ហេតុស្តាប់ចម្លើយ ហែម អាង ឆ.81, 85 ["ទឹបសាបស្ថិតនៅជិតតារាងយន្តហោះកងកេង ក្នុងឃុំរាម ខេត្តកំពង់សោម មិនដឹងថា ស្ថិតក្នុងភូមិអីទេ។ [...] ទឹកសាបសំដៅទៅព្រែកមួយដែលមានទឹកសាបហូរពីភ្នំធ្លាក់ទៅសមុទ្រ។ គេសង់ស្ពានមួយឆ្លងកាត់អូរទឹកសាបនោះ ត្រង់ផ្លូវជាតិលេខ៤ ពីភ្នំពេញទៅកំពង់សោម"]។

[1793] ឯកសារ D114/54 កងម៉ារីនកងពលធំ ១៦៤ (អតីតកងពលធំលេខ៣) របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំង KH ERN 01353020 ["ពីស្ពានទឹកសាប វាមានចម្ងាយប្រហែលជា ២០/២២ គីឡូម៉ែត្រ ពីវត្តឥន្ទញ្ញាណនោះនៅក្នុងក្រុងព្រះសីហនុ"]។ ឯកសារ D114/141 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំង ទឹកសាប KH ERN 01517366 ["ទឹកសាបនៅចម្ងាយប្រហែល២០គីឡូម៉ែត្រពីកំពង់សោម"]។

[1794] ឯកសារ D54/48 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.53 ["តើលោកស្គាល់តំបន់ទឹកសាបនៅរាមដែរឬទេ? ខ្ញុំស្គាល់តំបន់ហៅថាទឹកសាប ដែលមានស្ពានទឹកសាបនៅទីនោះ គឺវាស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ៤ នៅខាងកើតរាម"]។ ឯកសារ D54/45 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.18 ["ខ្ញុំស្គាល់តែកន្លែងមួយគេហៅថា អូរទឹកសាប ស្ថិតនៅខាងកើតភូមិស្នាច់ដែង តាមផ្លូវជាតិលេខ៤"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ KH ERN 00955512-00955513 ["មានគេចាប់មកដាក់កន្លែងទឹកសាបនៅជិតកោះកេង ខាងកើតរៀម [...] ឆ្ងាយដែលចាប់មើលចេញពីកងកេងមកទៅកើតទៅតាមថ្នល់ជាតិ ទៅដល់ហ្នឹងមិនមានស្ពានមួយ ស្ពានឆ្លងព្រែកនោះ"]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.24 ["នៅពេលនោះ ខ្ញុំស្នាក់នៅនិងធ្វើការនៅភូមិតាធៀង ដែលនៅត្រើយខាងលិចស្ទឹង [ទឹកសាប]។ ពួកអ្នកទោសស្ថិតនៅខាងកើតស្ទឹង"]។ ឯកសារ D114/141 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំង ទឹកសាប KH ERN 01517366 [រូបភាពទូទៅនៃទីតាំងរៀម/កងកេង – ស្នាច់ដែង – ទឹកសាប –ទីតាំងដែលបង្ហាញដោយ គុយ សម្បត្តិ]។ សូមមើល ផងដែរ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.17 ["កងចល័តរបស់ខ្ញុំក៏ធ្វើការនៅប៉ែកខាងត្បូងផ្លូវជាតិលេខ៤ដែរ។ យើងធ្វើការនៅតំបន់ជុំវិញព្រលានកងកេង ហើយនិងតំបន់ជិតទឹកសាប"]។

[1795] សូមមើល ឧទាហរណ៍ ឯកសារ D114/3 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.2 ["ស៖ កាលនៅជំនាន់ លន់ នល់ តើនៅទឹកសាបជាកន្លែងអ្វី? ឆ.2៖ គឺជាបន្ទាយទាហាន លន់ នល់"]។ ឯកសារ D114/18 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.35-36 ["បញ្ជាការដ្ឋានរបស់វរៈសេនាតូច៥៣០ គឺនៅក្នុងកន្លែងមូលដ្ឋានទ័ព លន់ នល់ នោះ។ [...] ឆ.36៖ បញ្ជាការដ្ឋាន [វរៈសេនាតូច៥៣០] នៅនឹងកន្លែងទឹកសាប"]។ ឯកសារ D54/121 កំណត់ហេតុស្តាប់ចម្លើយ លិន សារិន ឆ.6 ["គ្រាន់តែឮគេនិយាយថា ទាហាន លន់ នល់ ឈរជើងនៅទឹកសាប។ ខ្ញុំមិនបានដឹងរឿងនេះ

ដោយខ្លួនឯងទេ"]។ ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយរបស់ មូល ឈិន ឆ.7 ["សៈ នៅពេលចុះត្រួតពិនិត្យដល់ទីតាំង លោកបានប្រាប់យើងថា នៅជិតស្ពានទឹកសាប គឺត្រើយខាងកើត (ខាងភ្នំពេញ) មានអតីតមូលដ្ឋានកងទ័ព លន់ នល់។ អតីតមូលដ្ឋានកងទ័ព លន់ នល់ នេះត្រូវបានគេបោះបង់ចោលនៅឆ្នាំ១៩៦៣ [...] តើត្រឹមត្រូវដែរឬទេ? ឆ.7៖ បាទ ត្រឹមត្រូវហើយ"]។ ឯកសារ D114/39 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន KH ERN 01065090 ["នៅទីតាំងមានឈ្មោះថាទឹកសាប សាក្សីបានបង្ហាញដល់ក្រុមការងារស៊ើបអង្កេតដូចខាងក្រោម៖ [...] ទីតាំងស្ពានទឹកសាប រួមទាំងប៉មយាម ដែលនៅសេសសល់ពីជំនាន់ លន់ នល់"]។ ឯកសារ D114/141 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំង ទឹកសាប KH ERN 01517391 ["ក្នុងអំឡុងសម័យ លន់ នល់ មានមូលដ្ឋានកងទ័ពលន់នល់មួយនៅលើជ្រុងដីខាងជើង/ខាងកើតនៃចំណុចខ្វែងជើងក្អែករវាងព្រែកនិងផ្លូវជាតិលេខ៥។ យើងអាចមើលឃើញជើងសរសរគ្រឹះតូចៗ/លេនដ្ឋាននៅជិតផ្លូវជាតិទាំងសងខាងស្ពាន"]។ សូមមើល ផងដែរ ឯកសារ D114/114 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.23 ["មានបន្ទាយ លន់ នល់ ចាស់មួយកន្លែងនៅជាតិស្ពានបាក់ ត្រង់ទឹកសាប"]។

1796 សូមមើល ឧទាហរណ៍ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.92-93 ["កាលហ្នឹង បើសិនជាមានទោស គេបញ្ជូនទៅគុក។ [...] ឆ.93៖ គុកហ្នឹងនៅស្ពានទឹកសាប"]។ ឯកសារ D54/35.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប្រាក់ សុខា KH ERN 00964252 ["ហ្នឹងនៅទឹកសាបនៅក្បាលស្ពាពទឹកសាប ឃើញគេ [ខ្មែរក្រហម] បញ្ជូនមកខាងហ្នឹងគេយកមកទឹកសាបហ្នឹងហើយ"]។ សូមមើល ផងដែរ ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន ឆ.87 [រៀបរាប់ពីការធ្វើដំណើរទៅទីតាំងទឹកសាបរបស់គាត់ ចាប់ពីពេលដែលគាត់ "ចុះពីលើឡាន នៅកន្លែងស្ពានទឹកសាប"]។

1797 ឯកសារ D114/114 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.42 ["វាស្ថិតនៅខាងឆ្វេងដៃ ប្រសិនបើយើងធ្វើដំណើរពីកំពង់សោមមក។ វាដល់ក្រោយស្ពាន នៅខាងឆ្វេងដៃនៅជិតភ្នំ។ វាពងឆ្ងាយពីស្ពានបន្តិច ខ្ញុំមិនអាចប្រាប់លោកថាឆ្ងាយប៉ុនណានោះទេ"]។ ឯកសារ D114/242 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ប៊ុននី ឆ.88-90 ["កន្លែងស្ពានវែងហ្នឹងគេហៅទឹកសាបហើយ។ កំណត់សម្គាល់អ្នកស៊ើបអង្កេត៖ សាក្សីបានចង្អុលទៅទីតាំងទឹកសាប ដែលស្ថិតនៅខាងកើងវត្តស្នាច់ដែង គឺនៅតាមបណ្តោយផ្លូវជាតិលេខ៤។ សៈ តើចំណុចទឹកសាបស្ថិតនៅខាងណាផ្លូវជាតិលេខ៤ដែរ? ឆ.89៖ ខាងជើង។ សៈ ហេតុអ្វីបានលោកដឹង? ឆ.90៖ ព្រោះអីខ្ញុំនៅស្រុកហ្នឹង ខ្ញុំដឹង"]។ ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.26 ["[មន្ទីរឃុំឃាំង] នៅខាងកើតអូរ ខាងជើងផ្លូវជាតិ"]។ ឯកសារ D114/3 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.7 ["នៅពេលនោះ កន្លែងធ្វើការរបស់ខ្ញុំនៅខាងលិចព្រែកទឹកសាប ហើយខ្ញុំមើលឃើញយោធាខ្មែរក្រហមនៅខាងកើតព្រែកទឹកសាប"]។ ឯកសារ D54/89.1 ផែនទីរដ្ឋបាលស្រុកព្រៃនប់ដែលបង្ហាញដោយ កុយ ណៃន EN-KH 00987086 [គូររង្វង់តំបន់ទឹកសាបស្ថិតនៅក្នុងជ្រុងខាងជើងភាគខាងកើតនៃទន្លេសាប/ផ្លូវជាតិលេខ៤]។ ឯកសារ D114/156.1 គំនូសបង្ហាញទីតាំងក្នុងរបបកម្ពុជាប្រជាធិបតេយ្យដោយ សឹង ណុច EN 01197078, KH ERN 01374692 [ដែលសាក្សីនេះបានកំណត់បរិវេណទឹកសាបស្ថិតនៅភាគខាងជើងនៃផ្លូវជាតិលេខ៤]។

1798 ឯកសារ D114/114 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.11, 15 ["ក្រោយរំដោះឆ្នាំ ១៩៧៥ ខ្ញុំធ្វើការនៅព្រលានយន្តហោះកងកេង។ គេឲ្យខ្ញុំយាមឃ្លាំងគ្រាប់។ [...] សៈ នៅពេលដែលលោកមកដល់កងកេងដំបូងតើលោក

បានមួយរយៈខ្លី ទីបញ្ជាការ (មជ្ឈមណ្ឌលភស្តុភារ) នៃវរសេនាធំ២២/៦៣[1799] និងវរសេនាតូច ៥៣០/៦៣១[1800] បានផ្លាស់មកទឹកសាបនេះ នាំមកជាមួយនូវសម្ភារៈឧបត្ថម្ភ ដូចជា ឧបករណ៍ស្នាក់

---

ចូលក្នុងអង្គភាពណា? ឆ.15៖ កងវរសេនាធំលេខ៦៣ នៃកងពលលេខ១៦៤។"]។ ឯកសារ D114/155 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.10, 15 ["នៅចុងឆ្នាំ ១៩៧៥ ខ្ញុំប្តូរទៅតំបន់ទឹកសាបជិតស្ពាន។ ឃ្លាំងទាំងអស់ក៏ត្រូវបានផ្លាស់ប្តូរទៅទឹកសាបដែរ។ [...] ឆ.15៖ មុនពេលដែលឃ្លាំងរើទៅកន្លែងថ្មី ផ្ទះរបស់មេបញ្ជាការនេះ គឺនៅកងកេងជាប់នឹងអគារខ្ពស់ក្នុងព្រលានយន្តហោះ។"]។ ឯកសារ D114/116 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.30 ["ស៖ តើ មុំ យ៉ាន ស្ថិតនៅអង្គភាពណា ហើយគាត់មានមុខងារអ្វីដែរ? ឆ.30៖ គាត់គឺជាមេបញ្ជាការកងវរសេនាធំ៦៣ នៃកងពល១៦៤ តាំងពីដើមដំបូងមកម្លេះ។ នោះគឺជាពេលដែលកងវរសេនាធំស្ថិតនៅកងកេង"]។ ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉ែត ឆ.30 ["ស៖ តើលោកស្គាល់មនុស្សម្នាក់ឈ្មោះ មុំ យ៉ាន ដែរឬទេ? ឆ.30៖ បាទ ខ្ញុំស្គាល់ គាត់គឺជា មេបញ្ជាការកងវរៈសេនាធំលេខ៦៣។ មូលដ្ឋានរបស់គាត់នៅក្នុងព្រលានយន្តហោះកងកេង ជិតផ្លូវបំបែករវាងផ្លូវចូលទៅព្រលានយន្តហោះ និងផ្លូវជាតិត្រង់ស្នាច់ដែង។ [...] ជន ចូលមកកាន់ជំនួស"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.22-23 [" វរៈសេនាធំ ២២ របស់ខ្ញុំបោះទីតាំងនៅព្រលានយន្តហោះ កងកេង។ ហើយកន្លែងធ្វើការរបស់យើង គឺនៅជុំវិញព្រលានយន្តហោះ កងកេងនោះ។ ក្រោយមកប្រហែលដើមឆ្នាំ១៩៧៦ ខ្ញុំបានចេញពីវរៈសេនាធំ ២២ ទៅក្នុងវរៈសេនាធំ១៤០ នៅរាម។ [...] ឆ.23៖ កងកេងគឺជាមូលដ្ឋានកងវរៈសេនាធំ២២"]។ ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.3 ["ស៖ បញ្ជាការកងវរៈសេនាធំ២២មានទីតាំងនៅកន្លែងណា? ឆ.3៖ ទីតាំងរបស់កងវរៈសេនាធំស្ថិតនៅភូមិថ្មធំ ជាប់ព្រលានយន្តហោះ"]។ ឯកសារ D114/139 កំណត់ហេតុស្តាប់ចម្លើយ ងួន ឡាយ ហៅ អ៊ី ឆ.20 ["ខ្ញុំទៅនៅកងពល១៦៤ វរៈសេនាធំលេខ៦៣ ខ្ញុំទៅនៅព្រលានយន្តហោះកងកេង។ ខ្ញុំទៅនៅទីនោះបានបីខែ"]។ ឯកសារ D114/18 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿ ឆ.26-28 ["ទីបញ្ជាការវរៈសេនាធំលេខ៦៣ នៅក្នុងបរិវេណវាលយន្តហោះកងកេង។ [...] ឆ.27៖ ទីបញ្ជាការវរៈសេនាធំ៦៣នោះ គឺនៅក្នុងវាលយន្តហោះកងកេងតែម្តង ប៉ុន្តែមានកងដែលនៅខាងក្រោម ដូចជាកងភ័ស្តុភាររបស់កងវរៈសេនាធំ៦៣ មានទីតាំងនៅទឹកសាប។ [...] ឆ.28៖ ផ្ទះរបស់មេបញ្ជាការវរៈសេនាធំ៦៣ ដែលស្នាក់នៅ គឺស្ថិតនៅបរិវេណវាលយន្តហោះកងកេងតែម្តង។ នៅពេលនោះ វាលយន្តហោះកងកេងមិនមានដំណើរការទេ ដូច្នេះមេបញ្ជាការស្នាក់នៅនឹងអគារដែលនៅក្នុងបរិវេណវាលយន្តហោះតែម្តង"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន សារ៉ាត់ ឬ ព្រំ សារ៉ាត់ ឆ.20 ["បញ្ជាក់បោះទីតាំង ១៦ យ៉ាន នៅព្រលានយន្តហោះកងកេង"]។ សូមមើល ផងដែរ ឯកសារ D59/2/3.17a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ យ៉ែម សំអុន KH ERN 00958350 ["ស៖ កងពលទី៣ទាំងអស់ត្រូវទៅកន្លែងកងកេង? ឆ៖ បាទ ទៅដល់កន្លែងហ្នឹង ទាល់តែមូលគ្នា បានដឹងថាកងពលទី៣ទាំងអស់"]។

1799 ឯកសារ D114/115 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.8, 14, 30 ["គុកទឹកសាបស្ថិតនៅក្រោមកងវរសេនាធំលេខ៦៣ នៃកងពល១៦៤ [...] ឆ.14៖ បញ្ជាការកងវរសេនាធំ៦៣ឈ្មោះ ជន ផ្ទះរបស់គាត់គឺនៅជិតទឹកសាប។ [...] ស៖ តើបញ្ជាការដ្ឋានកងវរៈសេនាធំនៅកន្លែងណាបន្ទាប់ពីផ្លាស់ទៅទឹកសាប? ឆ.30៖ បញ្ជាការដ្ឋាននោះ មានទីតាំងនៅក្នុងអគារថ្មនៅផែទឹកសាប"]។ ឯកសារ D54/41 កំណត់ហេតុស្តាប់ចម្លើយ អ៊ួ សារ៉ាន់ ឆ.21 ["ស៖ តើមន្ទីរ

អាស្រ័យរបស់យុទ្ធជន និងផ្ទះបាយ[1801]។ ស្របនឹងតួនាទីភស្តុភារនៃកងពល ១៦៤ ទីតាំងនេះ ក៏មានផងដែរ នូវឃ្លាំងរំសេវ[1802]។ ការចេញចូលទីតាំងទឹកសាប ត្រូវពិនិត្យនិងតាមដានយ៉ាងតឹងរ៉ឹង។

---

បញ្ជាការរបស់កងវរៈសេនាធំលេខ៦៣ នៅកន្លែងណា? ឆ.21៖ នៅទឹកសាប"]។ ឯកសារ D114/116.1 គំនូសទីតាំងទឹកសាបដោយ ស្វាយ សំអាន (រៀបរាប់ឡើងវិញជាមួយឯកសារបកប្រែជាភាសាអង់គ្លេសនៅក្នុងឯកសារ D114/141 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំង ទឹកសាប KH ERN 01517401) [នៅក្នុងរូបភាពនេះ គាត់បង្ហាញពី "ទីបញ្ជាការកងវរសេនាធំ"]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.137-138, 249 ["[នៅទឹកសាប] មានអគាររបស់កងវរៈសេនាធំ។ សៈ កងវរៈសេនាធំមួយណា? ឆ.138៖ កងវរៈសេនាធំលេខ ៦៣ [...] សៈ តើលោកមានដឹងថា បញ្ជាការដ្ឋានកងវរៈសេនាធំ៦៣ នៅទីណាទេ? ឆ.249៖ នៅទឹកសាប"]។ ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ឆ.38, 43 ["កងវរសេនាធំ២២ នៅទឹកសាប ខ្ញុំនៅក្នុងកងវរសេនាធំ២២ នៅស្នាច់ដែង [...] ឆ.43៖ ហើយវរសេនាធំ២២ មានទីតាំងនៅទឹកសាប"]។ ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា ឆ.5 ["យ៉ាន ជាមេបញ្ជាការកងវរៈសេនាធំលេខ៣៣ ដែលមានទីបញ្ជាការនៅទឹកសាប"]។ ឯកសារ D4.1.746 កិច្ចសម្ភាសន៍របស់ US POW/MIA ជាមួយ សំ សុក KH ERN 00742598 ["កងវរៈសេនាធំលេខ៦៣ មានមូលដ្ឋាននៅទឹកសាប"]។ ឯកសារ D114/18 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.34 ["ទីបញ្ជាការដ្ឋានរបស់វរៈសេនាតូច៥៣០ របស់ វ៉េត នៅទឹកសាប នៅជិតកន្លែងភស្តុភាររបស់វរៈសេនាធំ៦៣]។ សូមមើលផងដែរ ឯកសារ D54/89 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.17-18 ["សៈ កន្លែងទឹកសាប តើនៅសម័យខ្មែរក្រហម គេហៅថាជាកន្លែងអ្វី? ឆៈ គេហៅថា ទីបញ្ជាការកងវរៈសេនាធំលេខ១៦៤។ សៈ ពេលនោះ តាមដែលលោកឃើញទឹកន្លែងទឹកសាបនោះមានអ្វីខ្លះ? ឆៈ ខ្ញុំឃើញមានផ្ទះ រោង អគារ ក្លោងទ្វារដោយមានដាក់សញ្ញាថាជាទីបញ្ជាការ១៦៤ និងទង់ជាតិ ឡាន ម៉ូតូ និងយោធា"]។

1800 ឯកសារ D114/18 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.34-36 ["ទីបញ្ជាការដ្ឋានរបស់វរៈសេនាតូច៥៣០ របស់ វ៉េត នៅទឹកសាប នៅជិតកន្លែងភស្តុភាររបស់វរៈសេនាធំ៦៣។ [...] ឆ.35៖ បញ្ជាការដ្ឋានរបស់វរៈសេនាតូច ៥៣០ គឺនៅក្នុងកន្លែងមូលដ្ឋានទ័ព លន់ នល់ នោះ។ [...] ឆ.36៖ តាមខ្ញុំដឹង យោធានៅក្នុងកងវរៈសេនាតូច៥៣០ ត្រូវបានបញ្ជូនចេញទៅធ្វើការនៅកន្លែងផ្សេងៗ។ [...] នៅនឹងកន្លែងទឹកសាបមានតែកន្លែងបញ្ជាការដ្ឋានទេ ប៉ុន្តែចាប់តាំងពីខ្ញុំចាកចេញទៅនៅលើកោះ ខ្ញុំមិនដឹងថាមានទីបញ្ជាការវរៈសេនាតូច៥៣០ទេ នៅកន្លែងហ្នឹងបានប៉ុន្មានទេ។ ខ្ញុំមិនដឹងថាតើមានរឿងអ្វីកើតឡើងចំពោះវរៈសេនាតូច៥៣០ទេ ក្នុងពេលក្រោយមកទៀត។ ខ្ញុំឮថាក្នុងឆ្នាំ១៩៧៧ វរៈសេនាតូច ៥៣០នេះ ប្រហែលជាត្រូវរំសាយ នៅពេលនោះ វ៉េត បានបាត់ខ្លួនទៅ ហើយយោធាក្នុងកងរបស់គាត់អាចនឹងបញ្ចូលទៅក្នុងកងជើងទឹកខ្លះ"]។ ឯកសារ D114/19 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.29 [បង្ហាញពីផែនទី (ឯកសារ D114/19.2) ដោយ "ទីបញ្ជាការនៃកងវរៈសេនាតូច៥៣០ នៃកងវរៈសេនាធំ៦៣ នៅទឹកសាប"]។

1801 ឯកសារ D114/3 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.៤ ["មានតែយោធាខ្មែរក្រហមប៉ុណ្ណោះដែលរស់នៅទីនោះ"] ឆ.៩ [យោងទៅលើ "បរិវេណអតីតទាហាន លន់ នល់ ដែលក្រោយមកយកមកប្រើប្រាស់ជាកន្លែងរស់នៅរបស់យោធាខ្មែរក្រហម"]។ ឯកសារ D54/117 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស សារ៉ាន ឆ .៦៤-៦៥ ["[នៅគុកទឹកសាប] ខ្ញុំនៅខាងក្រៅរោងមួយដែលគេធ្វើពីឈើប្រក់ស្លឹក [...] ឆ.៦៥៖ មានពួកទាហានពីរបី

ជនស៊ីវិលមិនអនុញ្ញាតឱ្យមកជិត ឬចូលបរិវេណនោះឡើយ[1803] ហើយក៏មិនអនុញ្ញាតឱ្យមកជិតអ្នកទោសណា ដែលជនស៊ីវិលនោះបានឃើញដែរ[1804]។

---

នាក់ដែរ មានស្តាយកាំភ្លើងដើរទៅដើរមក ប៉ុន្តែខ្ញុំមិនដឹងថា គេយាមខ្ញុំឬអត់ទេ។ កន្លែងនោះគេធ្វើដូចរោងបាយ។ មានកងទ័ពអីរស់នៅទីនោះ"]។ ឯកសារ D114/115 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.២៦, ៣០ ["មានផ្ទះបួន-ប្រាំ សម្រាប់អ្នកយាមដេក ហើយមានកន្លែងដាំស្លមួយ [...] ឆ.៣០៖ ឃ្លាំងគ្រាប់នោះនៅខាងស្តាំដៃផ្លូវចូលមក នៅលើទួលខ្ពស់។ បន្ទាប់ពីឃ្លាំងគ្រាប់នោះ មានខាងស្តាំដៃមានរោងដាំបាយ"]។ សូមមើលផងដែរ ឯកសារ D114/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ឆ.១៥៤ ["[នៅទឹកសាប] ឃើញអគារ ហើយនិងរោង"]។

1802 ឯកសារ D114/115 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.២៩-៣០ ["មានឃ្លាំងគ្រាប់ចំនួនបីកន្លែងនៅទីនោះ ហើយយើងឃ្លាំងគ្រាប់ទាំងនោះ [...] ឆ.៣០៖ ឃ្លាំងគ្រាប់នោះនៅខាងស្តាំដៃផ្លូវចូលមក នៅលើទួលខ្ពស់"]។ ឯកសារ D114/116.1 គំនូសបង្ហាញទីកន្លែងនៅទឹកសាប នៅក្នុងអំឡុងរយៈពេលកម្ពុជាប្រជាធិបតេយ្យ ដោយឈ្មោះ ស្វាយ សំអាន (ដែលបានធ្វើឡើងវិញ ដោយមានការបកប្រែជាភាសាអង់គ្លេសនៅក្នុងឯកសារ D114/141 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងទឹកសាប KH 01517401) [ដែលឈ្មោះ ស្វាយ សំអាន បានគូសសញ្ញាសម្គាល់ឃ្លាំងគ្រាប់រំសេវទាំងនោះ]។ ឯកសារ D114/141 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងទឹកសាប KH 01517391-01517392 [យោងទៅលើតំបន់ដែលសាក្សីឈ្មោះ គុយ សម្បត្តិ បានកំណត់អត្តសញ្ញាណ នៅពេលដែលគាត់បានទៅមើលការដ្ឋានទឹកសាបនៅក្នុងឆ្នាំ ១៩៧៩ "ហើយសម្គាល់ឃើញអដ្ឋិធាតុមនុស្ស ខ្មោះជើង និងឃ្លាំង/កន្លែងស្តុកគ្រាប់រំសេវដែលបាក់បែកខ្ទេចខ្ទីរ។ល។"អ្នកស៊ើបអង្កេតបានកត់សម្គាល់ថា "ទីកន្លែងទាំងឡាយដែលសាក្សី គុយ សម្បត្តិ បានកំណត់អត្តសញ្ញាណនោះ (ឃ្លាំងស្តុកអាវុធ [...]) ត្រូវបានកំណត់អត្តសញ្ញាណដោយសាក្សីដទៃទៀត" ហើយ "អ្វីដែលសំខាន់បំផុតគឺដំណើររឿងរបស់សាក្សី គុយ សម្បត្តិ ដែលនិយាយពីផ្លូវដីនិងទីតាំងនៃកន្លែងស្តុកគ្រាប់រំសេវ គឺស៊ីសង្វាក់គ្នាឥតខ្ចោះទៅនិងសេចក្តីអធិប្បាយរបស់សាក្សី ស្វាយ សំអាន និងគំនូសប្លង់ដែលសាក្សីនោះបានគូស"] KH 01517394 [បង្ហាញអំពីចំណុចនៃប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្រ និងផែនទី ២៩៣ ឃ្លាំងស្តុកគ្រាប់រំសេវដែលសាក្សីបានកំណត់អត្តសញ្ញាណ។ រូបថតពង្រីកនៃតំបន់ ដែលបានបង្ហាញនៅ KH 01517395]។ ឯកសារ D114/176 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ សារឿន ឆ.៨ [យើងសូមធ្វើការសង្ខេបនូវគំហើញពីការធ្វើការកំណត់អត្តសញ្ញាណទីតាំងកាលពីម្សិលមិញនេះ ដែលក្នុងនោះរួមមានដូចតទៅ [...] ទី ៤ គឺជាអគារ ឬក៏រោងឃ្លាំងដាក់គ្រាប់សល់ពីសម័យខ្មែរក្រហម ហើយក៏ពុំមាននៅសេសសល់អគារនៅពីសម័យខ្មែរក្រហមទៀតដែរ។ តើអ្វីដែលយើងសង្ខេបខាងលើនេះ លោកយល់ថាត្រឹមត្រូវដែរឬទេ? ឆ.៨៖ ត្រឹមត្រូវ"]។

1803 ឯកសារ D54/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណៃន ឆ.២០ ["គេមិនអនុញ្ញាតឲ្យប្រជាជនស៊ីវិលចូលទៅក្នុងបរិវេណទឹកសាបនោះទេ មានតែអ្នកដែលត្រូវចាប់យកទៅសម្លាប់ គឺគេយកចូលទៅកន្លែងនោះ"]។ ឯកសារ D114/3 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.៤ ["ខ្ញុំមិនដឹងច្បាស់ទេ ថាជាអ្វីនៅកន្លែងទឹកសាបនោះ ពីព្រោះនៅពេលនោះ កន្លែងនោះជាកន្លែងតឹងតែង ហើយគេហាមឃាត់មិនឲ្យទៅជិតទេ គឺមានតែខ្មែរក្រហមនៅទីនោះប៉ុណ្ណោះ"]។ ឯកសារ D114/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ុន ឆ.១២២ ["មាន កាលនៅ

483. ទីឃុំឃាំងធំជាងគេ គឺជាអគារវែងធ្វើអំពីឈើ[1805] នៅចុងខាងកើតនៃបរិវេណទឹកសាប នៅជើងភ្នំមួយ[1806]។ នៅច្រាំងខាងលិចនៃស្ទឹងទឹកសាប ជិតផ្លូវជាតិលេខ៤ ហើយនៅខាងជើងផ្លូវជាតិលេខ

---

ចេញចូល គេមានប៉ុស្តិ៍មួយ។ បន្ទាប់ពីហ្នឹង គ្មានប៉ុស្តិ៍ទៀតទេ ព្រោះគេមិនចង់ឱ្យមានមនុស្សអ្នកចេញចូលកន្លែងទាហាន"]។ ឯកសារ D114/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ឆ.១៤១, 153-154 ["ពីសម័យនោះ ខ្ញុំពិបាកណាស់ព្រោះគេមិនឱ្យចូល [...] ឆ.១៥៣៖ ទៅ តែយើងឆ្លងកាត់ពីមុខ នៅក្បែរៗ ពេលដឹកកណ្តាប់ស្រូវ គេមិនឱ្យយើងទៅជិតទេ [...] ឆ.១៥៤៖ ឃើញអគារ ហើយនិង រោង"]។ សូមមើលផងដែរ ឯកសារ D114/202 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ សារ៉ាន់ ឆ.១៧ ["ស.៖ ពេលអង្គភាពលោកឈរជើងនៅព្រលានយន្តហោះកងកេង តើកងវរសេនាធំ ៦៣ ស្ថិតនៅណា? ឆ.១៧៖ ខ្ញុំឮថា នៅទឹកសាបៗ។ តែខ្ញុំមិនច្បាស់ទេ ព្រោះគេមិនឱ្យអ្នកណាទៅទីបញ្ជាការគេទេ។ បើចូលផ្តេសផ្តាស គេចាប់"]។ ឯកសារ D114/69 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុយ សម្បត្តិ ឆ.៧ ["ខ្ញុំមិនដឹងថា តើអ្នកណាជាអ្នកគ្រប់គ្រង ឬកាន់ការកន្លែងឃុំឃាំងនោះឡើយ ខ្ញុំគ្រាន់តែដឹងថា វាជាកន្លែងឃុំឃាំង។ ខ្មែរក្រហម លាក់អាថ៌កំបាំងខ្លាំងណាស់ អំពីរឿងរ៉ាវទាំងនេះ។ ប្រជាជនធម្មតា មិនដឹងថា តើអ្នកណាជាអ្នកធ្វើរឿងទាំងនោះឡើយ"]។

1804 ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.២៤, ២៦ ["ពួកខ្ញុំត្រូវបានគេហាមឃាត់មិនឱ្យទៅទៅជិតពួកអ្នកទោសទេ អំឡុងពេលដែលពួកគេកំពុងធ្វើការ [...] ឆ.២៦៖ ខ្ញុំមិនត្រូវបានអនុញ្ញាតឱ្យចូលជិតកន្លែងនោះទេ ពេលនោះ"]។

1805 ឯកសារ D114/115 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.១៨, ២០, ៣៩ ["គុកនោះគឺជាអគារជាឈើ ប្រក់ស័ង្កសី និងបាំងជញ្ជាំងដែក។ ជញ្ជាំងនោះគឺធ្វើពីបន្ទះដែកមកពីអាមេរិក [...] ឆ.២០៖ អគារនោះគឺទទឹងចន្លោះពី៧-៨ម៉ែត្រ និងបណ្តោយ១០០ម៉ែត្រ [...] ស.៖ តើនៅបរិវេណគុកនោះមានរបងព័ទ្ធជុំវិញដែរឬទេ? ឆ.៣៩៖ ទេ អត់មានទេ"]។ ឯកសារ D54/27 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ឆ.១១ ["ខ្ញុំបានឃើញរោងវែងពីរ គឺទទឹងប្រវែងប្រហែល៥ម៉ែត្រ និងបណ្តោយប្រហែល២០ម៉ែត្រ។ កន្លែងនោះមិនមានរបងទេ ប៉ុន្តែមានអ្នកយាមជាប្រចាំ"]។ ឯកសារ D114/242 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ប៊ុននី ឆ.៩១, ៩៣ ["ពីជំនាន់មុនអគារធ្វើពីឈើ គុកវាធ្វើពីឈើវែងៗដូចអ៊ីចឹង។ មិនផ្ទះថ្មទេ គឺធ្វើពីឈើ។ [...] ឆ.៩៣៖ រដ្ឋប្រហារហើយ ខ្មែរក្រហមដួលរលំហើយ បានខ្ញុំទៅឃើញ"]។

1806 ឯកសារ D114/115 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.២១ ["ប្រសិនបើលោកមកពីកងកេង លោកត្រូវឆ្លងស្ពាន។ ក្រោយពីឆ្លងស្ពានរួច លោកទៅត្រង់ប្រហែល២០នាទីនៅខាងឆ្វេងដៃ បត់ចូលទៅរកភ្នំ។ គុកនោះគឺនៅជើងភ្នំ"]។ ឯកសារ D114/114 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.៤២ ["វាស្ថិតនៅខាងឆ្វេងដៃ ប្រសិនបើយើងធ្វើដំណើរពីកំពង់សោមមក។ វាដល់ក្រោយស្ពាន នៅខាងឆ្វេងដៃនៅជិតភ្នំ។ វារាងឆ្ងាយពីស្ពានបន្តិច"។ គាត់បានពន្យល់ជាបន្ថែមថា វាមានចម្ងាយប្រហែលជាដើររយៈពេល២០នាទីពីស្ពាននោះទៅកាន់គុកនោះ]។ ឯកសារ D114/116.1 គំនូសបង្ហាញទីកន្លែងនៅទឹកសាប នៅក្នុងអំឡុងរយៈពេលកម្ពុជាប្រជាធិបតេយ្យដោយឈ្មោះ ស្វាយ សំអាន (ដែលបានធ្វើឡើងវិញ ដោយមានការបកប្រែជាភាសាអង់គ្លេសនៅក្នុងឯកសារ D114/141 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងទឹកសាប KH 01517401) [ដែលឈ្មោះ ស្វាយ សំអាន

៤ មាន រោងអារឈើដែលបានបោះបង់ចោល[1807] បានយកធ្វើទីតាំងឃុំឃាំងអ្នកទោស និងបង្ខំឱ្យធ្វើការ[1808]។ ខាងជើង និងខាងលិចនៃរោងអារឈើ មានវាលស្រែ ដែលអ្នកទោសក៏បានបង្ខំឱ្យធ្វើការ ក្នុងលក្ខណៈមិនអចិន្ត្រៃយ៍ដែរ[1809]។

484. ចម្ការធូរេន ដូង សាវម៉ាវ និងម្រេច ដែលសាក្សីបំភ្លឺជាញឹកញាប់ថាជារបស់ លោក ឆាន[1810] មានផ្ទៃដី៣០ហិកតានៃទីតាំងទឹកសាប[1811] លាតសន្ធឹងលើបរិវេណដីទាបជិតឃ្លាំងរំសេវ[1812] ព្រមទាំង

---

បានគូសសញ្ញាសម្គាល់គុកខាងជើងផ្លូវជាតិលេខ ៤ ហើយនៅខាងកើតនៃទីកន្លែងទឹកសាប]។ ឯកសារ D114/69 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុយ សម្បត្តិ ឆ.២៦ ["វានៅខាងកើតអូរ ខាងជើងផ្លូវជាតិ"]។ ឯកសារ D114/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ឆ.៩៣, ១២៥ ["គុកហ្នឹងនៅស្ពានទឹកសាប [...] ឆ.១២៥៖ គុកនៅខាងជិតស្ពាន និងភ្នំនោះ"]។ សូមមើលផងដែរ ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៉ុណ្ណា ឆ.២៦ ["អគារគុក ពុំត្រូវបានមើលឃើញទេ ព្រោះវាស្ថិតនៅពីក្រោយព្រៃ"]។

1807 ឯកសារ D114/39 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន KH 01065090 ["នៅទីតាំងមានឈ្មោះថាទឹកសាប សាក្សីបានបង្ហាញដល់ក្រុមការងារស៊ើបអង្កេតដូចខាងក្រោម៖ -ទីតាំងរោងអារឈើ ដែលសាក្សីត្រូវបានបង្ខំឱ្យធ្វើការ។ - ទីតាំងផ្ទះ ដែលមានទំហំប្រហែល៥គុណ៧ម៉ែត្រ ប្រក់ស័ង្កសី ក្បែររោងអារឈើ ដែលសាក្សី និងអ្នកទោសផ្សេងៗទៀតត្រូវបានគេឃុំឃាំងនៅទីនោះ"]។ ឯកសារ D114/40 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.២, ៩ ["គេឱ្យខ្ញុំត្រឡប់មកកន្លែងទឹកសាបដដែលវិញ គឺនៅផ្ទះដូចមុន។ នោះគឺជាផ្ទះដែលស្ថិតនៅខាងលិចរោងអារឈើ [...] ឆ.៩៖ ផ្ទះនោះគឺជាផ្ទះដែលគេបោះបង់ចោល"]។ ឯកសារ D114/54 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង កងពល កងទ័ពជើងទឹក ១៦៤ (កងពលលេខ ៣) KH 01353018-01353028 [ផែនទី និងរូបថត ដែលបង្ហាញអំពីទីតាំងនៅក្បែរស្ពានទឹកសាប ខាងលិចនៃស្ទឹង និងខាងជើងនៃផ្លូវជាតិលេខ ៤ នៃរោងអារឈើ និងផ្ទះឃុំឃាំង ដែលនៅទីនោះ ឈ្មោះ មូល ឈិន ត្រូវបានឃុំឃាំង]។ ឯកសារ D114/202 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុំ សារ៉ាន់ ឆ.១៩ ["ស.៖ តើរោងអារឈើ ឬការដ្ឋានអារឈើនោះ ស្ថិតនៅទីណាដែរ? ឆ.១៩៖ នៅទឹកសាប នៅក្បែរផ្លូវ ជាប់ក្បាលស្ពានទឹកសាប"]។ ឯកសារ D114/139 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ងួន ឡាយ ឆ.៤០, ៤២, ៨៨ ["ក្រោយមក គេដកខ្ញុំទៅកន្លែងអារឈើ។ ខ្ញុំអារឈើនៅទឹកសាប [...] ឆ.៤២៖ នៅជិតស្ពានទឹកសាបហ្នឹងតែម្តង នៅជិតទន្លេហ្នឹង [...] ស.៖ ពេលដែលលោកធ្វើការនៅកន្លែងអារឈើ តើលោកគេង និងញុំាបាយនៅឯណា? ឆ.៨៨៖ នៅហ្នឹង គេមានរោង គេមានចុងភៅនៅហ្នឹង គេមានចង្ក្រានបាយ"]។ ឯកសារ D114/116 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.១៩ [បញ្ជាក់ថាមានរោងអារឈើមួយនៅទឹកសាប]។

1808 សូមមើល ផ្នែក VIII.គ.៤ មន្ទីរសន្តិសុខទឹកសាប - ឧក្រិដ្ឋកម្ម - ការដាក់គុក និងការឃុំឃាំងដោយខុសច្បាប់។ ផ្នែក VIII.គ.៤ មន្ទីរសន្តិសុខទឹកសាប - ឧក្រិដ្ឋកម្ម - ការប្រព្រឹត្តដោយអមនុស្សធម៌ និងដោយចេតនា ដែលបង្កឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬឱ្យរងរបួសយ៉ាងធ្ងន់ធ្ងរ - ការបង្ខំឱ្យធ្វើការ។

1809 សូមមើល ផ្នែក VIII.គ.៤ មន្ទីរសន្តិសុខទឹកសាប - ឧក្រិដ្ឋកម្ម - ការប្រព្រឹត្តដោយអមនុស្សធម៌ និងដោយចេតនា ដែលបង្កឱ្យមានការឈឺចាប់យ៉ាងខ្លាំង ឬឱ្យរងរបួសយ៉ាងធ្ងន់ធ្ងរ - ការបង្ខំឱ្យធ្វើការ។

កន្លែងដីខ្ពស់/ខាងជើងទាំងមូល[1813]។ មិនមាននៅសល់អគារណាមួយពីជំនាន់កម្ពុជាប្រជាធិបតេយ្យនោះទេ[1814] ហើយផ្នូរជនរងគ្រោះនៅក្នុងចម្ការ ក៏បានរាបស្មើ ជីកកាយ និងបំពេញដីវិញហើយដែរ[1815]។

1810 ឯកសារ D114/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹង ណុច ឆ.១៤១ ["កន្លែងនោះ មានដើមធូរេន ដើមសាវម៉ាវ ដែលជារបស់លោក ឆន"]។ ឯកសារ D114/177 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉េង ស៊ឹក ឆ.២៩, ៤៧ ["នៅជិតព្រែក។ ផ្ទះលោក ឆន នៅអឺចឹង ហើយកន្លែងហ្នឹងនៅអឺចឹង។ កាលមុន គាត់ធ្វើវិឡាទុំង។ កើតអាពតមក គេរត់ទៅបាត់ទៅ។ [...] ឆ.៤៧៖ រាប់រយដើម ចម្ការលោក ឆន អ្នកមាន គាត់ដាំ"]។ ឯកសារ D114/3 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.៦ ["ស.៖ តើកន្លែងទឹកសាបនោះ ជាកន្លែងដែលមានគេកប់ខ្មោចពីដើមដែរឬទេ? ឆ.៦៖ ទេ ទឹកសាបគឺជាកន្លែងគេធ្វើចម្ការ ដែលមានចម្ការធូរេន និងចម្ការផ្លែឈើផ្សេងៗទៀត។ ចម្ការទាំងនោះគឺជាកម្មសិទ្ធិរបស់លោក ឆន ដែលជាអតីតប្រធានមេព្រៃប្រចាំតំបន់នេះ ក្នុងរបបសម្តេច សីហនុ"]។

1811 ឯកសារ D54/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ឆ.៥ ["ចម្ការធូរេន និងចម្ការម្រេច [...] ដែលមានទំហំប្រហែល៣០ហិកតា"]។ ឯកសារ D54/121 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លិន សារិន ឆ.៨ ["នៅពេលនោះ ខ្ញុំ និងក្មេងៗផ្សេងទៀតត្រូវបានចាត់តាំងឲ្យទៅដើរកាប់ដើមទន្ទ្រានខេត្រ នៅត្រើយខាងលិចព្រែកទឹកសាប គឺទល់មុខចម្ការធូរេន សាវម៉ាវទឹកសាប"]។ ឯកសារ D114/115 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.២៩ ["មានឃ្លាំងគ្រាប់ចំនួនបីកន្លែងនៅទីនោះ ហើយយើងយាមឃ្លាំងគ្រាប់ទាំងនោះ។ នៅកន្លែងនោះមានចម្ការសាវម៉ាវ ធូរេន និងខ្នុរផងដែរ។ មានទំនប់បេតុងជាប់ជាមួយកន្លែងស្តុកទឹកនៅទីនោះ"]។ ឯកសារ D114/3 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.៦, ១០ ["ទេ ទឹកសាបគឺជាកន្លែងគេធ្វើចម្ការ ដែលមានចម្ការធូរេន និងចម្ការផ្លែឈើផ្សេងៗទៀត [...] ឆ.១០៖ ចម្ការធូរេននៅទឹកសាប តាមខ្ញុំស្មានមានទំហំប្រហែលជា១០ហិកតា"]។ ឯកសារ D114/16 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក វណ្ណា ឆ.៤៩ ["ខ្ញុំចាំថា មានដើមដូង ធូរេន សាវម៉ាវ និងដើមខ្នុរ"]។ ឯកសារ D114/202 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ សាវ៉ាន់ ឆ.២៨ [បញ្ជាក់អំពីដើមធូរេននៅក្បែរទឹកសាប]។ សូមមើលផងដែរ ឯកសារ D114/34 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាប់ សុម៉ាលី ឆ.១៨១ [មានចម្ការធូរេននៅវាលវិញ។ មានចម្ការទូរេនជាច្រើននៅជើងភ្នំ។ ចម្ការនីមួយៗមានទំហំ១-២ហិចតា។ មានទាំងចម្ការធូរេន មានទាំងចម្ការម្រេច"]។ សូមមើលបន្ថែម ផ្នែក VIII.គ.៤ មន្ទីរសន្តិសុខទឹកសាប - ឧក្រិដ្ឋកម្ម - ការធ្វើមនុស្សឃាត ការសម្លាប់ដោយចេតនា ការសម្លាប់រង្គាល និងការបាត់ខ្លួនដោយបង្ខំ។

1812 ឯកសារ D114/115 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.២៩ ["មានឃ្លាំងគ្រាប់ចំនួនបីកន្លែងនៅទីនោះ ហើយយើងយាមឃ្លាំងគ្រាប់ទាំងនោះ។ នៅកន្លែងនោះមានចម្ការសាវម៉ាវ ធូរេន និងខ្នុរផងដែរ។ មានទំនប់បេតុងជាប់ជាមួយកន្លែងស្តុកទឹកនៅទីនោះ"]។

1813 ឯកសារ D114/99 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចម្ការធូរេន II ទឹកសាប បិតត្រាង KH 01519494-01519495 [ផែនទី ចង្អុលបង្ហាញតំបន់នៅផ្នែកខាងលើខាងកើតនៃកន្លែងទឹកសាប (ចំណុច WP 205-207) ដែលឈ្មោះ កុយ ណែន បានកំណត់អត្តសញ្ញាណទៅកាន់ក្រុមអ្នកស៊ើបអង្កេតថាជាទីកន្លែងកប់សាកសព ដែលគាត់បានរកឃើញនៅក្នុងឆ្នាំ ១៩៧៩ នៅក្នុងតំបន់អតីតចម្ការនោះ]។ ឯកសារ D114/177 កំណត់ហេតុនៃការស្តាប់

ចម្លើយសាក្សី ម៉េង សឹក ឆ.៤៥-៤៦ [“ខាងលើ [...] ស.៖ តើលោកឃើញនៅទឹកសាបហ្នឹងមានពីរកន្លែង [...] មួយទៀតនៅចម្ការធូរេននៅខាងលើឬ? ឆ.៤៦៖ បាទ”]។ ឯកសារ D54/121 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លិន សារិន ឆ.៤ [អតីតសមាជិកម្នាក់នៃកងកុមារបានមើលឃើញដោយផ្ទាល់ភ្នែកនូវការសម្លាប់នៅទឹកសាប ដែលគាត់បានពណ៌នាថាជា “ចម្ការធូរេន និងសារម៉ាវ”]។ ឯកសារ D114/56 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង EN 01075849-53 [ការពណ៌នា ផែនទី និងរូបថត ដែលបង្ហាញប្រហែលជាទីតាំង នៅទិបញ្ចប់ខាងលិចខាងក្រោមនៃតំបន់ខាងលើនៃកន្លែងទឹកសាប ដែលជាទីកន្លែងដែលឈ្មោះ លិន សារិន បានមើលឃើញដោយផ្ទាល់ភ្នែកនូវការសម្លាប់ នៅក្នុងចម្ការធូរេន និងចម្ការសារម៉ាវ]។

1814 ឯកសារ D114/176 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ សាវឿន ឆ.៩, ១៦ [“ស.៖ លោកពន្យល់ប្រាប់យើងថា ទីតាំងទាំងអស់ដែលលោកបាននាំក្រុមការងារទៅ លើកលែងតែទីតាំងទី១ ចេញ គឺត្រូវបានគេឈូសឆាយរាបស្មើបាត់លក្ខណៈដើមអស់ហើយ។ តើត្រឹមត្រូវដែរឬទេ? ឆ.៖ ត្រឹមត្រូវ [...] ស.៖ លោកបាននាំក្រុមការងារទៅកាន់ទីតាំងមួយដែលមានដើមឈើដុះច្រើន ដែលស្ថិតនៅខាងកើតក្បែរទីតាំងទី១ដែរ។ លោកបានបញ្ជាក់ថា ធ្លាប់បានឃើញមានសំណល់សល់ពីសម័យខ្មែរក្រហមដែរ។ [...] បានរើសំណល់ចោលអស់។ [...] តើយើងសង្ខេបត្រឹមត្រូវដែរឬទេ? ឆ.១៦៖ ត្រឹមត្រូវ”]។ ឯកសារ D114/54 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង កងពល កងទ័ពជើងទឹក ១៦៤ (កងពលលេខ ៣) KH 01353020-01353021, FR 01380191 [“ទីកន្លែងនៃរោងចក្រអារឈើនោះ នាពេលសព្វថ្ងៃនេះ គឺជាទីទំនេរមួយ នៅជិតនឹងត្រើយខាងលិចនៃស្ទឹងទឹកសាបនោះ។ គ្មានអ្វីជាគ្រឿងបរិក្ខារដើម ដែលគេអាចមើលឃើញទៀតនោះទេ”]។

1815 ឯកសារ D114/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង ឡុង ឆ.៣០ [“នៅកន្លែងដែលគេកប់សាកសព សព្វថ្ងៃត្រូវគេឈូសឆាយ និងជីកដីយកទៅធ្វើផ្លូវ និងយកទៅដាក់បំពេញកន្លែងទំនេរ”]។ ឯកសារ D114/177 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉េង សឹក ឆ.៤៦ [“ស.៖ តើលោកឃើញនៅទឹកសាបហ្នឹងមានពីរកន្លែង កន្លែងខាងក្រោមដែលជ្រូកកាយឆ្អឹង និងមួយទៀតនៅចម្ការធូរេននៅខាងលើឬ? ឆ.៤៦៖ បាទ តែកន្លែងនោះគេឈូសធ្វើចម្ការអស់ហើយ”]។ ឯកសារ D114/99 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង KH 01519491-01519493 [“ទីកន្លែងត្រង់ម្តុំ WP 205-207 ត្រូវបានចាក់ឡើងខ្ពស់។ នៅត្រង់ម្តុំដែលសង្ស័យថាជាកន្លែងលានកប់សាកសពត្រង់ WP 205 វាបានបង្ហាញឱ្យឃើញថាដីម្តុំនោះត្រូវបានចាក់ដីបំពេញយ៉ាងតិចឡើងកំពស់ ៥០ សង់ទីម៉ែត្រទៅ ១ ម៉ែត្រពីលើ (ការប៉ាន់ស្មាន) កំរិតដីចាស់ តែនៅម្តុំកន្លែង WP 207 ផ្នែកខាងលើត្រូវបានកាយយកចេញអស់។ លោក សែម ពុតសាលីន (អតីតអ្នកបើកត្រាក់ទ័រកាយដី) ដែលកំពង់រស់នៅទឹកសាប បានបញ្ជាក់ថាដីជាច្រើនត្រូវបានកាយនាពេលថ្មីៗនេះនៅត្រង់កន្លែងដែលសង្ស័យថាជាកន្លែងលានកប់សាកសព។ ភារៈកិច្ចរបស់គាត់គឺត្រូវឈូសឆាយដីត្រង់ម្តុំកន្លែងដែលគាត់សង្កេតឃើញមានរណ្តៅសាកសព (តែគាត់ពុំបានដឹងអំពីប្រភពដើមនៃរណ្តៅឬក៏មានអ្វីខ្លះនៅក្នុងរណ្តៅទេ)”]។ សូមមើល ឯកសារ D114/99 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចម្ការធូរេន II ទឹកសាប បិតត្រាង KH 01519493-01519495, 01519497-01519498 [ផែនទី និងរូបថត ដែលបង្ហាញអំពីចំណុច WP 205-207 កន្លែងកប់សាកសពនៅក្នុងអតីតចម្ការ ដែលសាក្សី កុយ ណែន បានកំណត់អត្តសញ្ញាណ។ នៅ KH 01519497-01519498 រូបថត បង្ហាញថា តំបន់នោះគឺនៅចន្លោះចំណុច WP 205 ដល់ចំណុច 207 “ដែលត្រូវបានគេចាក់ដីបំពេញ”]។

## រយៈពេលនៃដំណើរការ

485. មុនខែមេសាឆ្នាំ១៩៧៥ ទឹកសាប និង អូរកំបុតដែលនៅជិតនោះ គឺជាខ្សែត្រៀមរវាងទាហានលន់ នល់ និងយោធាខ្មែរក្រហម[1816]។ ស្មើរតែភ្លាមៗក្រោយកម្លាំងកងពល៣ ចូលដល់កំពង់សោមនៅថ្ងៃទី១៨ ខែ មេសា ឆ្នាំ ១៩៧៥[1817] មានភស្តុតាងបង្ហាញថា យោធារបស់ **មាស មុត** បានមកកាន់

[1816] ឯកសារ D114/182 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ួង ខន ឆ.៤-៥, ១២-១៣, ១៨ [ឈរជើងជាមួយវរៈសេនាធំខ្មែរក្រហម ៨៥ នៅក្បែរទឹកសាប ខ្ទង់បីបួនខែ មុនខែមេសា ឆ្នាំ ១៩៧៥ ដើម្បីការពារ "តំបន់រំដោះ"]។ ឯកសារ D114/104 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ភង់ ឆ.៣៤ ["ពេលគេវាយភ្នំពេញ កម្លាំងរបស់ខ្ញុំបានវាយនៅទឹកសាបកំពង់សោម រៀបរួមជាមួយកងពលលេខ១"]។ ឯកសារ D114/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ឆ.២១ ["ស.៖ តើលោកនៅឯណាថ្ងៃ ១៧ មេសា ១៩៧៥? ឆ.២១៖ ខ្ញុំនៅសមរភូមិទឹកសាប ដែលជាកន្លែងប្រយុទ្ធ"]។ ឯកសារ D114/226 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម ហាវ ឆ.៦៨ ["សមរភូមិមុខនៅតាមស្ពាន ដូចជា នៅព្រៃនប់ នៅអូរឧកញ៉ាហេង នៅទឹកសាប"]។ ឯកសារ D114/112 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សុខន ឆ.១៣ ["មុនថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំអាយុប្រហែល១៥ឆ្នាំ ធ្វើជានិរសាឲ្យឈ្មោះថន ដែលជាអនុសេនាធំ៤២០ ឈរជើងនៅម្តុំទឹកសាប និងអូរកំបុត ក្នុងតំបន់៣៥។ ទឹកសាប និងអូរកំបុត ស្ថិតនៅឆ្ងាយពីគ្នាប្រហែល២គីឡូម៉ែត្រ"]។ ឯកសារ D114/194 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ឆ.១០ ["ដោយក្នុងនេះជាតំបន់ខ្មែរក្រហមចាប់ពីអូរចំណា កន្លែងហ្នឹងពីអូរចំណា ដល់កំពង់សោមគឺជាតំបន់ទាហាន លន់ នល់ ពេលគេបញ្ជូនខ្ញុំទៅវ៉ៃទឹកសាប"]។ ឯកសារ D114/68 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុយ សម្បត្តិ ឆ.៩ ["នៅពេលនោះ អូរកំបុត ប្រហែលជាមួយគីឡូម៉ែត្រខាងកើតស្ពានទឹកសាបនេះ គឺជាបន្ទាត់ព្រំដែនទី១ រវាងកងទ័ពខ្មែរក្រហម និងកងទ័ព លន់ នល់។ កន្លែងនោះ ត្រូវបានគេហៅថា បន្ទាត់សមរភូមិមុខទី១"]។ ឯកសារ D114/282 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.២២[៣] ["ក្រុងកំពង់សោម មានប្រជាជនស៊ីវិល និងទាហាន។ តាមស្មាន សាច់ទាហានទាំងអស់ចាប់ពីរោងចក្រប្រេងកាត ដល់រាម ក្រវ៉ាត់ក្រុង ខ្ញុំស្មានថាសាច់ទាហានមិនក្រោម ៣០០០នាក់ទេ ព្រោះឃើញទាហានច្រើន។ រោងចក្រប្រេងកាត គឺសំដៅរោងចក្រដែលនៅចន្លោះស្ទឹងហាវ និងកំពង់សោម។ ខ្សែត្រៀមវាពីរជាន់ គឺចាប់ពីរោងចក្រប្រេងកាតស្ទឹងហាវ ដល់កំពង់សោម ហើយចុះរហូតដល់ទឹកសាប ព្រោះគេចង់ការពារព្រលានយន្តហោះកងកេង"]។

[1817] ឯកសារ D114/282 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៦ ["១៨ មេសា កងពលលេខ ៣ ចូលដល់កំពង់សោម"]។ សូមមើលផងដែរ ឯកសារ D114/69 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុយ សម្បត្តិ ឆ.១ ["នៅថ្ងៃទី ១៨ មេសា ខ្មែរក្រហមបានចូលកាន់កាប់ខេត្តព្រះសីហនុ"]។ ឯកសារ D114/282 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.២២ ["ការចាប់ផ្តើមគឺពីថ្ងៃ១៨ (មេសា ឆ្នាំ១៩៧៥) ពេលនោះកងទ័ពតំបន់បានចូលមកដល់ក្រុងកំពង់សោម ដោយពុំមានការតដៃពីទាហាន លន់ នល់ ទេ ដោយកងទ័ព លន់ នល់ ដាក់អាវុធ"]។ ឯកសារ D114/68 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុយ សម្បត្តិ ឆ.៩ ["នៅក្នុងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ពេលដែលយោធាខ្មែរក្រហម ចូលភ្នំពេញ ហើយយោធាខ្មែរក្រហមនៅកំពង់សោម ក៏ចូលក្រុងកំពង់សោមដែរ។ ពួកទាហាន

កាប់ការដ្ឋានទឹកសាប[1818]។ កងពល ១៦៤ បានចាប់ផ្ដើមដំណើរការមន្ទីរឃុំឃាំងនៅទឹកសាប យ៉ាងយឺតបំផុតត្រឹមពាក់កណ្ដាលខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ពីព្រោះថា មានឯកសារស-២១ ដែលនៅសល់ បានបង្ហាញថា អ្នកនេសាទចាប់ពីសមុទ្រមក បានឃុំឃាំងនៅទឹកសាប ហើយដាក់ឱ្យធ្វើការនៅចម្ការទុរេន និងសារម៉ាវ មុនបញ្ជូនមកមន្ទីរស-២១ នៅដើមខែ ឧសភា ឆ្នាំ ១៩៧៦[1819]។ មន្ទីរ

---

លន់ នល់ បានរៀបចំខ្លួននៅកំពង់សោម ដើម្បីចាំទទួលពួកខ្មែរក្រហម។ ក្រុងកំពង់សោមពេលនោះ គឺត្រូវបានខ្មែរក្រហមព័ទ្ធជុំអស់ហើយ។ បន្ទាប់មក មានយោធាខ្មែរក្រហម ចូលមកដល់ក្រុងកំពង់សោម តាមរយៈឡានហ្ស៊ីបទាហានជាច្រើន"]។

1818 ឯកសារ D54/92 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យ៉ែម សំអុន ឆ.៣៤-៣៦ ["ទឹកសាប គឺស្ថិតតាមបណ្ដោយផ្លូវជាតិលេខ៤ នៅក្បែរសមុទ្រ។ នៅពេលដែលគេបញ្ជូនខ្ញុំពីភ្នំពេញ មកកំពង់សោម នៅក្នុងឆ្នាំ១៩៧៥ ខ្ញុំបានឈប់សម្រាកដាំបាយនៅកន្លែងទឹកសាប [...] ឆ.៣៥៖ នៅទឹកសាប ខ្ញុំឃើញមានតែផ្ទះប្រក់ស័ង្កសីតែប៉ុណ្ណោះ [...] ឆ. ៣៦៖ ខ្ញុំមិនបានឃើញរបងទេ ខ្ញុំគ្រាន់តែឈប់សម្រាកដាំបាយ ហើយបានឃើញប្រជាជនត្រូវបានជម្លៀសដើរតាមផ្លូវ"]។ ឯកសារ D114/16 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុក វណ្ណា ឆ.៤៣, ៥២ ["ក្រោយជ័យជម្នះលើទីក្រុងភ្នំពេញ កងពលលេខ៣បានត្រឡប់មកកំពង់សោម។ ខ្ញុំចាំថា ពួកយើងចាកចេញ ២ថ្ងៃមុននឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ [...] កងពលលេខ៣ទាំងអស់បានធ្វើដំណើរដោយថ្មើរជើងពីភ្នំពេញតាមផ្លូវជាតិលេខ៤មកវាលរេញ។ ការធ្វើដំណើរនោះមានរយៈពេល៤-៥ថ្ងៃ។ យើងធ្វើដំណើរពេលថ្ងៃ និងសម្រាកនៅពេលយប់។ [...] ក្រោយពីសម្រាកនៅវាលរេញបានប្រហែល១អាទិត្យ ពួកយើងចាប់ផ្ដើមចុះជួសជុលផ្លូវដែកពីវាលរេញទៅកំពត។ ក្រោយពីជួសជុលចប់ប្រហែល១ខែ ពួកយើងបានទៅឈរជើងនៅទឹកសាប។ [...] ឆ.៥២៖ ទីបញ្ជាការកងវរៈសេនាធំ៣៣ នៅទឹកសាប ក្រោយពីជ័យជម្នះលើភ្នំពេញ ព្រោះពួកគេបានមកឈរជើងនៅទីនោះមុនខ្ញុំ"]។ ឯកសារ D54/116 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី នាក់ យឿន ឆ.១០, ១២ ["ខ្ញុំស្គាល់កន្លែងទឹកសាប។ ប្រហែល១ខែក្រោយជ័យជម្នះរបស់ខ្មែរក្រហមលើរបប លន់ នល់ [...] គេបានឱ្យយើងស្នាក់នៅអតីតបន្ទាយ លន់ នល់ ដែលមានទីតាំងនៅទឹកសាប ប្រហែល២ខែ។ ទឹកសាបមានទីតាំងនៅជាប់ផ្នែកខាងជើងផ្លូវជាតិលេខ៤ ក្បែរព្រែក នៅជិតស្ពាន និងនៅជាប់នឹងជើងភ្នំ។ ក្រោយមកពីស្នាក់នៅទីនោះបាន២ខែ គេបញ្ជូនពួកខ្ញុំទៅ [...] ឆ.១២៖ អំឡុងពេលដែលខ្ញុំនៅទឹកសាប ខ្ញុំស្ថិតនៅក្នុងអង្គភាពមួយក្រោមកងពលលេខ៣ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ តាមុត"]។ ឯកសារ D54/89 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កុយ ណែន ឆ.១៣ ["វាចាប់ផ្ដើមភ្លាមៗបន្ទាប់ពីខ្មែរក្រហមឡើងកាន់ប្រទេសក្នុងខែមេសា ឆ្នាំ១៩៧៥។ វាគឺជាទីតាំងរបស់កងវរៈសេនាធំ។ ខ្ញុំមិនចាំឈ្មោះមេបញ្ជាការនៅកន្លែងនោះទេ ប៉ុន្តែខ្ញុំនៅចាំថាលេខវរៈសេនាធំ គឺលេខ១៦៤។ មានកងជើងគោក កងជើងទឹក ហើយនិងកោះទាំងអស់គឺស្ថិតនៅក្រោមវរៈសេនាធំ១៦៤នោះ"]។ សូមមើលផងដែរ ឯកសារ D22/1441a ទម្រង់បែបបទព័ត៌មានបន្ថែមរបស់ ឈួន គុន KH 00586904 ["បងប្រុសទីពីររបស់ខ្ញុំជាសង្ឃមុនឆ្នាំ ១៩៧៥ ក្រោយឆ្នាំ ១៩៧៥ គេចាប់ផ្សឹកនៅថ្ងៃ ៣០ មេសា ១៩៧៥ ដើម្បីយកគាត់ទៅសម្លាប់ចោលទឹកសាប"]។

1819 សូមមើល ឧ. ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសនៅស-២១ របស់ ក.ស.ច.ស លេខរៀង ៥៩២ និង ១៤៧៨៦ [Daing Yaing Thann (ជនជាតិវៀតណាម) - ត្រូវបានចាប់ខ្លួននៅសមុទ្រនៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៧៥

ហើយត្រូវបានឃុំខ្លួននៅទឹកសាបរហូតដល់មានការបញ្ជូនទៅកាន់ស-២១ នៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៦] លេខរៀង ៦៦៣ និង ១៤៧៨៤ [Kim Ngok Troeung (ជនជាតិវៀតណាម) – ត្រូវបានចាប់ខ្លួននៅខែ ធ្នូ ឆ្នាំ ១៩៧៥ នៅលើកោះប្រជៀវ ក្រោយមកត្រូវបានឃុំខ្លួននៅទឹកសាបរហូតដល់មានការបញ្ជូនទៅកាន់ស-២១ នៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៦] លេខរៀង ១៣៤៣១ [ជីម យាំង គឺ (CHIM Yaing Koeu) (ជនជាតិវៀតណាម) – ត្រូវបានចាប់ខ្លួននៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ត្រូវបានឃុំខ្លួនអស់រយៈពេល ៣ ថ្ងៃ នៅលើកោះកៀវ ក្រោយមកត្រូវបានឃុំខ្លួននៅទឹកសាប រហូតដល់មានការបញ្ជូនទៅកាន់ស-២១ នៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៦។ សូមមើល ឯកសារ D114/145.2.11 ប្រវត្តិរូបនៅស-២១ របស់ ជីម យាំង គឺ (CHIM Yaing Koeu) (លេខរៀងទី ១២២) នៅស-២១ KH 01180403 ["ពេលចាប់ខ្លួនហើយ អង្គការបញ្ជូនមកកន្លែងកោះកៀវ ចំនួន ៣ ថ្ងៃ ទើបបញ្ជូនមកកន្លែងទឹកសាប ឲ្យធ្វើការ ដូចជា រែកជីដាក់គល់ធូរេន និងសាវម៉ាវ។ មកដល់ថ្ងៃ ០៦ ខែ ឧសភា ឆ្នាំ ១៩៧៦ ទើបបញ្ជូនមកកន្លែងនេះ។ ចាប់ខ្លួននៅថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥"]] លេខរៀង ១៣៤៣២ [ឡេ យ៉ាំង ម៉ាយ (Le Yang May) (ជនជាតិវៀតណាម) – ត្រូវបានចាប់ខ្លួននៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ត្រូវបានឃុំខ្លួនអស់រយៈពេល ៣ ថ្ងៃ នៅលើកោះកៀវ ក្រោយមកត្រូវបានឃុំខ្លួននៅទឹកសាប រហូតដល់មានការបញ្ជូនទៅកាន់ស-២១ នៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៦។ សូមមើល ឯកសារ D114/145.2.11 ប្រវត្តិរូបនៅស-២១ របស់ ជីម យាំង យុប ឈ្មោះប្រែ ឡេ យ៉ាំង ម៉ាយ (CHIM Yaing Yop alias LE Yaing May) (លេខរៀងទី ១២៣) KH 01180405 ["ចាប់ខ្លួនហើយ អង្គការបញ្ជូនមកនៅលើកោះកៀវ អស់រយៈ ៣ ថ្ងៃ។ រួចទើបបញ្ជូនមកកន្លែងទឹកសាប។ ចាប់ខ្លួននៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥។ ដល់មកថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៦ បញ្ជូនមកភ្នំពេញ"]] លេខរៀង ១៣៤៣៣ [លេ យ៉ាំង ភឿក ឈ្មោះប្រែ ជីម យ៉ាំងកឹង (LE Yang Phoeuk alias CHIM Yang Koeng) (ជនជាតិវៀតណាម) – ត្រូវបានចាប់ខ្លួននៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ បញ្ជូនមកកន្លែងកោះកៀវ ចំនួន ១៨ ថ្ងៃ ទើបបញ្ជូនមកកន្លែងទឹកសាប ទើបបញ្ជូនមកស-២១ នៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៦។ សូមមើល ឯកសារ D114/145.2.11 ប្រវត្តិរូបនៅស-២១ របស់ ជីម យ៉ាំងកឹង ឈ្មោះប្រែ លេ យ៉ាំងភឿក (CHIM Yaing Koeng alias LE Yaing Phoeuk) (លេខរៀងទី ១២៤) KH 01180407 ["ចាប់ខ្លួនហើយ អង្គការបញ្ជូនមកកន្លែងកោះកៀវ ចំនួន ១៨ថ្ងៃ។ ទើបបញ្ជូនមកកន្លែងទឹកសាប ឲ្យធ្វើការ ដូចជា រែកជីចាក់គល់ធូរេន និងសាវម៉ាវ។ ដល់ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៦ ទើបបញ្ជូនមកកន្លែងនេះតែម្តង។ ចាប់ខ្លួននៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥"]] លេខរៀង ១៣៤៣៤ [ង្វៀង ឌិន អ៊ី (NGVIENG Din Y) (ជនជាតិវៀតណាម) – ត្រូវបានចាប់ខ្លួននៅសមុទ្រ នៅខែ វិច្ឆិកា ឆ្នាំ ១៩៧៥ បញ្ជូនមកកន្លែងកោះកៀវ ចំនួន ១៨ ថ្ងៃ ទើបត្រូវបានឃុំខ្លួននៅទឹកសាប មុនពេលបញ្ជូនទៅកាន់ស-២១ នៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៦។ សូមមើល ឯកសារ D114/145.2.11 ប្រវត្តិរូបនៅស-២១ របស់ ង្វៀង ឌិន អ៊ី (KVIENG Din Y) (លេខរៀងទី ១២៥) KH 01180409 ["ចាប់ខ្លួនហើយ អង្គការបញ្ជូនមកកន្លែងកោះកៀវ ចំនួន ១៨ថ្ងៃ។ ទើបបញ្ជូនមកកន្លែងទឹកសាប ឲ្យធ្វើការ ដូចជា ធ្វើស្មៅធូរេន និងសាវម៉ាវ។ ដល់ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៦ ទើបបញ្ជូនមកកន្លែងនេះតែម្តង។ ចាប់ខ្លួននៅខែ វិច្ឆិកា ឆ្នាំ ១៩៧៥"]] លេខរៀង ១៣៤៣៦ [ង្វៀង ធីធឿង (NGVIENG Thithoeung) (ជនជាតិវៀតណាម) – ត្រូវបានចាប់ខ្លួននៅសមុទ្រ នៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៧៥ បន្ទាប់មកត្រូវបានបញ្ជូនទៅទឹកសាប ឲ្យធ្វើការនៅក្នុងចម្ការធូរេន។ សូមមើល ឯកសារ D114/145.2.12 ប្រវត្តិរូបនៅស-២១ របស់ ង្វៀង ធី ធឿង (KVIENG Thy Thoeung) (លេខរៀងទី ១២៦) KH 01180411 ["កំណត់សសម្គាល់៖ បញ្ជូនមកស-២១ នៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ

សន្តិសុខនេះ បន្តដំណើរការរហូតដល់ចុងនៃរបបកម្ពុជាប្រជាធិបតេយ្យ[1820]។ ទោះបីជាមានសាក្សីខ្លះបំភ្លឺថា អ្នកទោសបានដោះលែងមុនចុងបញ្ចប់នៃរបបខ្មែរក្រហមក៏ដោយ[1821] ក៏មានសាក្សីបីនាក់

---

១៩៧៦ KH 01180412 ["ចាប់ខ្លួននៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៧៥ នៅក្នុងសមុទ្រ គឺកន្លែងម្តុំគេហៅថា ព្រែកលេខ II ។ ពេលចាប់ខ្លួន អង្គការបានបញ្ជូនទៅឱយទៅនៅកន្លែងទឹកសាប ថែរក្សាចម្ការធូរេន"]] លេខរៀង ១៣៤៣៧ [Ngvieng Hour Lang (ជនជាតិវៀតណាម) – ត្រូវបានចាប់ខ្លួននៅថ្ងៃទី ១០ ខែ ធ្នូ ហើយបន្ទាប់មកត្រូវបានបញ្ជូនឱ្យទៅធ្វើការនៅក្នុងចម្ការធូរេន។ សូមមើល ឯកសារ D114/145.2.12 ប្រវត្តិរូបនៅស-២១ របស់ ង្វៀង ហ៊ីវ ឡាង (KVIENG Hiv Lang) (លេខរៀងទី ១២៧) KH 01180414-01180415 ["ចាប់ខ្លួននៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៧៥ នៅក្នុងសមុទ្រ ហួសកោះថាស [...] ពេលចាប់ខ្លួនហើយ អង្គការបញ្ជូនទៅកន្លែងទឹកសាប ឱ្យធ្វើស្មៅចម្ការធូរេន"]] លេខរៀង ១៤៧៨២ និង ៥៩៧ [ត្រឹង យ៉ាំង ឃ្វេ (TROENG Yaing Khve) (ជនជាតិវៀតណាម) – ត្រូវបានចាប់ខ្លួននៅសមុទ្រនៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ហើយត្រូវបានឃុំខ្លួននៅទឹកសាបរហូតដល់មានការបញ្ជូនទៅកាន់ស-២១ នៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៦។ សូមមើល ឯកសារ D114/145.2.11 ប្រវត្តិរូបនៅស-២១ របស់ ត្រឹង យ៉ាំង ឃ្វេ (TROENG Yaing Khve) (លេខរៀងទី ១២១) នៅស-២១ KH 01180402 ["កំណត់សម្គាល់៖ ចាប់ខ្លួននៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥។ ពេលចាប់ខ្លួនហើយ អង្គការបានបញ្ជូនទៅនៅកន្លែងទឹកសាប ឱ្យធ្វើការ គឺធ្វើស្មៅធូរេន និងសាវម៉ាវ ដល់មកថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៦ ទើបអង្គការបញ្ជូនមកកន្លែងស-២១នេះ "]] លេខរៀង ១៤៧៨៣ និង ១៣៦៤២ [ចឹង ថាន់ហឿន (CHOENG Thann Hoeun) (ជនជាតិវៀតណាម) – ត្រូវបានចាប់ខ្លួននៅសមុទ្រនៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៧៥ ហើយត្រូវបានបញ្ជូនទៅកោះ ចំនួន ០៦ ថ្ងៃ ហើយបន្ទាប់មកត្រូវបានឃុំខ្លួននៅទឹកសាប រហូតដល់មានការបញ្ជូនទៅកាន់ស-២១ នៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៥។ សូមមើល ឯកសារ D114/145.2.12 ប្រវត្តិរូបនៅស-២១ របស់ ចឹង ថាន់ហឿន (CHOENG Thann Hoeun) (លេខរៀងទី ១២៨) KH 01180417 ["ចាប់ខ្លួននៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៧៥។ ពេលចាប់ខ្លួនហើយ បញ្ជូនទៅកោះ [...] ចំនួន ០៦ ថ្ងៃ ហើយបញ្ជូនទៅទឹកសាប ឱ្យថែដំណាំធូរេន និងសាវម៉ាវ ដល់ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៥ ទើបបញ្ជូនមកកន្លែងនេះ"]] លេខរៀង ១៤៧៨៥ [ផាម យ៉ាំងថាន់ (PHAM Yaing Thann) (ជនជាតិវៀតណាម) – ត្រូវបានចាប់ខ្លួននៅសមុទ្រនៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ហើយត្រូវបានឃុំខ្លួននៅទឹកសាបរហូតដល់មានការបញ្ជូនទៅកាន់ស-២១ នៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦។ សូមមើល ឯកសារ D114/145.2.14 ប្រវត្តិរូបនៅស-២១ របស់ ផាម យ៉ាំងថាន់ (PHAM Yaing Thann) KH 011804424-01180425 ["កំណត់សម្គាល់៖ ចាប់ខ្លួននៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ហើយអង្គការបញ្ជូនទីនៅទឹកសាប ឱយធ្វើការ គឺថែទាំងចម្ការធូរេនជាដើម។ ទើបតែនៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦ បញ្ជូនមកកន្លែងស-២១ តែម្តង"]។

1820 ឯកសារ D54/27 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ឆ.១០ ["ស.៖ តើមន្ទីរទឹកសាបចាប់ដំណើរការពីឆ្នាំណាដល់ឆ្នាំណា? ឆ.១០៖ ខ្ញុំមិនដឹងច្បាស់ទេ ប៉ុន្តែនៅពេលដែលខ្ញុំមកដល់ក្បែរនោះក្នុងឆ្នាំ ១៩៧៦ ខ្ញុំបានឃើញមន្ទីរនោះបានដំណើរការរួចហើយ។ វាដំណើរការរហូតដល់ឆ្នាំ១៩៧៩ ពេលដែលវៀតណាមចូលមកដល់"]។ ឯកសារ D54/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ឆ.៣៤ ["បាទ កន្លែងទឹកសាបនៅប្រតិបត្តិការរហូតដល់វៀតណាមចូល ឆ្នាំ ១៩៧៩"]។ ឯកសារ D114/115 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.១១

ដែរ មូល ឈិន, ងួន ឡាយ និង ឡុង ផានស៊ី បានដោះលែងពីទឹកសាប ទើបតែនៅពេលវៀតណាម មកដល់កម្ពុជា នៅ ខែមករា ឆ្នាំ ១៩៧៩[1822] ដូចនេះ គាំទ្របញ្ជាក់ពីការប្រើប្រាស់ទីតាំងរហូតដល់ចុងបំផុតនៃរបបនេះ។

---

["បង្កើតឡើងនៅសម័យបីឆ្នាំ។ ខ្ញុំមិនដឹងថាបង្កើតឡើងនៅពេលណាទេ ដោយសារខ្ញុំមិនមែនជាអ្នកយាមនៅទីនោះ ប៉ុន្តែគុកនោះបង្កើតឡើងជាយូរមកហើយ"]។ ឯកសារ D54/20 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ឆ.៩ [សាក្សីត្រូវបានអ្នកយាមនៅទឹកសាបនិយាយប្រាប់ថា គុកនោះបានបិទនៅក្នុងឆ្នាំ ១៩៧៩]។ សូមមើលផងដែរ ឯកសារ D114/135 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ផន ឆ.៣៥-៣៦ ["ខ្ញុំធ្លាប់ឮអំពីមន្ទីរឃុំឃាំងនៅទឹកសាបប៉ុន្តែខ្ញុំមិនបានឃើញផ្ទាល់ខ្លួនឯងឡើយ។ ខ្ញុំដឹងនៅក្នុងសម័យខ្មែរក្រហម"]។

1821 ឯកសារ D54/98 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាង រ៉េត ឆ.១៤១ ["ខ្ញុំមិនដឹងមន្ទីរនេះចាប់ផ្តើមនៅក្នុងឆ្នាំណាទេ។ ប៉ុន្តែខ្ញុំឮថានៅចុងឆ្នាំ១៩៧៨ នៅពេលដែលមានឯកសារមាគ៌ាសង្គ្រោះនោះ អ្នកដែលជាប់ឃុំនៅទឹកសាបត្រូវបានគេដោះលែង"]។ ឯកសារ D114/18 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ឆ.៣៨ ["ខ្ញុំធ្លាប់ឃើញមន្ទីរឃុំឃាំងនោះដោយខ្លួនខ្ញុំ ហើយក្រោយមក ខ្ញុំឮគេថាអ្នកដែលជាប់នៅក្នុងមន្ទីរនោះត្រូវបានដោះលែងអស់ហើយ"]។

1822 មូល ឈិន៖ ឯកសារ D114/31 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.១១៥, ១៦៤, ១៧៦ ["ខ្ញុំធ្លាប់ជាប់គុកម្តងដែរ គឺជាប់គុក២៩ថ្ងៃ មុនវៀតណាមចូល ហើយខ្ញុំបានរួចខ្លួននៅថ្ងៃដែលវៀតណាមចូលមកដល់ [...] ឆ.១៦៤៖ ៣ថ្ងៃចុងក្រោយ ខ្ញុំជាប់គុកនៅទឹកសាប គឺចំពេលដែលកងទ័ពវៀតណាមចូលមកក្នុងឆ្នាំ ១៩៧៩ [...] ឆ.១៧៦៖ "តាមពិត វៀតណាមបានចូលមកដល់នៅម៉ោង១២យប់ ហើយខ្ញុំត្រូវបានគេដោះលែងឱ្យទៅអារឈើនៅទឹកសាបនៅព្រឹកនោះតែម្តង"]។ ឯកសារ D114/40 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.១-២ ["នៅព្រឹកបន្ទាប់ ខ្ញុំបានឃើញកងទ័ពវៀតណាមចូលមកដល់តែម្តង ហើយខ្ញុំក៏បានរួចខ្លួនពីគុកនោះ [...] ឆ.២៖គេឱ្យខ្ញុំជួយសែងឈើនៅក្នុងរោងអារឈើនោះ តែពុំបានធ្វើផង វៀតណាមក៏ចូលមកដល់"]។ ងួន ឡាយ៖ ឯកសារ D114/139 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ងួន ឡាយ ឆ.៤០-៤១ ["ក្រោយមកគេដកខ្ញុំទៅកន្លែងអារឈើ។ ខ្ញុំអារឈើនៅទឹកសាប។ [...] ឆ.៤១៖ នៅរហូតដល់វៀតណាមចូល"]។ ឡុង ផាន់ស៊ី៖ ឯកសារ D114/208 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ឆ.៤៣, ៤៦ ["អ្នកយាមនៅទឹកសាបភាគច្រើន គឺក្រោយពេលវៀតណាមចូល ខ្ញុំបានសុំគេគាស់ខ្នោះ ហើយនាំគ្នារត់ទៅព្រំដែនថៃ។ ខ្ញុំសុំគេគាស់ ពីព្រោះពេលនោះសភាពការណ៍ច្របូកច្របល់ហើយ។ ខ្ញុំបានជួបគេនៅព្រំដែនថៃនៅពេលរត់នោះ [...] ឆ.៤៦៖ បើគ្មានវៀតណាមចូលមកទេ ខ្ញុំគិតថាជីវិតខ្ញុំមានតែផ្លូវស្លាប់ទេ"]។

## រចនាសម្ព័ន្ធអំណាច និងការទំនាក់ទំនង

486. ទឹកសាប ស្ថិតក្នុងកងពល ១៦៤ និងក្នុងការគ្រប់គ្រងរបស់ **មាស មុត**[1823] ហើយមន្ទីរសន្តិសុខនេះស្ថិតក្រោមដែនសមត្ថកិច្ចរបស់គាត់[1824]។ ទូរលេខមួយច្បាប់ចុះឆ្នាំ ១៩៧៦ ផ្ញើពី**មាស មុត** ទៅ សុន សេន បង្ហាញពីការគ្រប់គ្រងរបស់**មាស មុត** លើទីតាំងនេះ បានសរសេរថា៖

---

1823 ឯកសារ D114/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.៩ ["តំបន់ទឹកដីដែលស្ថិតនៅក្រោមបញ្ជារបស់ មាស មុត លាតសន្ធឹងតាំងពីទឹកសាប កងកេង រាម កំពង់សោម ហើយនិងកោះទាំងអស់នៅក្នុងសមុទ្រ។ កន្លែងតំបន់ទាំងអស់នេះ គឺហៅថា តំបន់ស្វ័យតដែលស្ថិតនៅក្រោមអំណាចរបស់ មាស មុត"]។ ឯកសារ D54/51 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ឈ្មោះបដិវត្តន៍ ស្វាយ វឿន ឆ.១៧ ["កងទ័ពជើងទឹកត្រួតត្រាដីគោក ចាប់ពីវាលរេញរហូតដល់កំពង់សោម"]។ ឯកសារ D114/79 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កង សុំ ឆ.៨៣ ["មានតែ ១៦៤ មួយទេដែលនៅខេត្តកំពង់សោម"]។

1824 ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.២៣ ["ទឹកសាប គឺជាគុករបស់កងពល ១៦៤ ដែរ"]។ ឯកសារ D114/208 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ឆ.៤១ ["គុកទឹកសាប ស្ថិតនៅក្នុងតំបន់កាន់កាប់របស់កងពល ១៦៤ ដែរ"]។ ឯកសារ D54/20 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ឆ.១០, ១២ ["គឺឋិតក្រោមបញ្ជាការកងពល ១៦៤ របស់ មាស មុត [...] ឆ.១២៖ បានឮពីគេថា កាលណាគេចាប់មនុស្សឬមានអ្នកបាត់ខ្លួន គេយកអ្នកទាំងនោះទៅដាក់នៅគុកទឹកសាបនោះ ដែលជាគុកថ្នាក់តំបន់ដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ មាស មុត"]។ ឯកសារ D54/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ឆ.៤០-៤១ ["ខ្ញុំដឹងកន្លែងមួយ ដែលជាមន្ទីរឃុំឃាំងរបស់កងពល១៦៤ ដែលស្ថិតនៅទឹកសាប។ នៅទីនោះ មានមន្ទីរសន្តិសុខ និងមន្ទីរឃុំឃាំង [...] ឆ.៤១៖ ពេលយោធាត្រូវបានគេចាប់ខ្លួន គេបញ្ជូនយកទៅកន្លែងទឹកសាប។ ទីកន្លែងនោះ ជាកន្លែងអប់រំកែប្រែផងដែរ"]។ ឯកសារ D114/19 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ឆ.៨ ["ស.៖ តើលោកស្គាល់កន្លែងឃុំឃាំងដទៃៗទៀត នៅក្រោមកងពល១៦៤ ដែរទេ? ឆ.៨៖ ទេ ខ្ញុំមិនស្គាល់ទេ ខ្ញុំស្គាល់តែមន្ទីរឃុំឃាំងទឹកសាបមួយប៉ុណ្ណោះ"]។ ឯកសារ D54/98 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ាង រ៉េត ឆ.១៤២ ["ខ្ញុំមិនដឹងថាអង្គភាពយោធាណាជាអ្នកគ្រប់គ្រងមន្ទីរអប់រំនៅទឹកសាបទេ តែខ្ញុំដឹងថាមន្ទីរអប់រំនេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពល១៦៤"]។ ឯកសារ D54/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណៃន ឆ.១៣, ៣១ ["វាចាប់ផ្តើមភ្លាមៗបន្ទាប់ពីខ្មែរក្រហមឡើងកាន់ប្រទេសក្នុងខែ មេសា ឆ្នាំ ១៩៧៥។ វាគឺជាទីតាំងរបស់កងវរៈសេនាធំ។ ខ្ញុំមិនចាំឈ្មោះមេបញ្ជាការនៅកន្លែងនោះទេ ប៉ុន្តែខ្ញុំនៅចាំថាលេខវរៈសេនាធំគឺលេខ ១៦៤។ មានកងជើងគោក កងជើងទឹក ហើយនិងកោះទាំងអស់ គឺស្ថិតនៅក្រោមកងវរៈសេនាធំ១៦៤នោះ [...] ឆ.៣១៖ យើងជាប្រជាជនទាំងអស់ក្នុងតំបន់នេះដឹងថា កន្លែងនោះជាកន្លែងបញ្ជាការទីតាំងរបស់យោធាខ្មែរក្រហម"]។ ឯកសារ D114/40 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.៤ ["ដោយសារទាំងគុកនៅទឹកសាប និងគុកនៅវត្តឥន្ទញ្ញាណ គឺគ្រប់គ្រងដោយយោធាកងពលលេខ៣"]។ សូមមើលផងដែរ ឯកសារ D114/242 កំណត់ហេតុនៃការស្តាប់ចម្លើយ

> សភាពការណ៍ខ្មាំង ពួក ៧ នាក់ ដែលចាប់នៅសង្វារ តាមចម្លើយ អាមួយចាប់បាន ខាងទឹកសាប វាថាជាក្រុមរបស់វា[1825]។

487. ជាការឆ្លើយតប ក្នុងការប្រជុំមួយនៃមេបញ្ជាការកងពល សុន សេន ដាក់ចេញការណែនាំដល់កងពល ១៦៤ ពាក់ព័ន្ធនឹងទីតាំងទឹកសាប[1826]។ កំណត់ហេតុប្រជុំកងទ័ពបដិវត្តន៍កម្ពុជា ក៏បានបង្ហាញផងដែរថា **មាស មុត** មានវត្តមាន ពេលដែលអនុរបស់គាត់ឈ្មោះឌឹម បានរាយការណ៍ពីតំបន់ទឹកសាប៖

> ចាប់បាននារីម្នាក់ អាយុ១៣ ឆ្នាំ ម្តុំទឹកសាប សារភាពថា មានគ្នា ៣ នាក់ ប្រហែលវានៅអូរផុស[1827]។

ការណ៍ដែល **មាស មុត** បានសរសេរក្នុងទូរលេខអំពី "ចម្លើយ" របស់មនុស្សដែលបានចាប់ខ្លួន និងក្នុងកំណត់ហេតុប្រជុំកងទ័ពអំពី "ចម្លើយសារភាព" កុមារីអាយុ១៣ឆ្នាំនោះ បានបង្ហាញថា **មាស មុត** បានដឹងសព្វគ្រប់អំពីលទ្ធផលនៃការងារសួរចម្លើយក្នុងតំបន់ ដែលគាត់គ្រប់គ្រង។ លើសពីនេះ ទៀត **មាស មុត** បានមកពិនិត្យទឹកសាបជាទៀងទាត់[1828]។

---

សាក្សី ប្រាក់ ប៊ុនទី ឆ.៨៧-៨៨ ["ខាងយោធា។ [...] ឆ.៨៨៖ ព្រោះអី កាលជំនាន់ហ្នឹង មនុស្សយើងទាំងចាស់ទាំងក្មេង គេដឹងថា កន្លែងហ្នឹងគឺគុក ប្រជាពលរដ្ឋនៅម្តុំហ្នឹងគឺ គេយកទៅដាក់គុកហ្នឹង"]។

1825 ឯកសារ D1.3.12.3 សាទូរលេខមកពី មាស មុត ទៅបង ៨៩ (សុន សេន) ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ KH00021461 ["សភាពការណ៍ខ្មាំង៖ តាមចំលើយ អាមួយដែលចាប់នៅខាងកើតទឹកសាប ពួក ៧ នាក់ ដែលចាប់នៅសង្វារ វាថាជាក្រុមរបស់វា"]។

1826 ឯកសារ D114/27.1.5 កំណត់ហេតុការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា ភស្តុភាររបស់កងពល និងវរៈសេនាធំ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH 00052396-00052397, 00052399-00052400 ["មតិសរុបរបស់បង ៨៩៖ [...] កងពល ១៦៤ ត្រូវទប់ទឹកជើងភ្នំ ទប់ព្រែកទឹកសាប ឱយបានដាច់ខាត។ ត្រូវធ្វើអាងទឹកឱយបាន"]។

1827 ឯកសារ D1.3.27.20 កំណត់ហេតុការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា អនុលេខា និង វរៈសេនាធំអំពីសភាពការណ៍ ការការពារប្រទេស និងវិធានការការការពារប្រទេស ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH 00052404-00052405 ["សមមិត្ត ឌឹម (ពេលមានវត្តមាន មាស មុត)៖ ចាប់បាននារីម្នាក់ អាយុ ១៣ ឆ្នាំ ម្តុំទឹកសាប សារភាពថា មានគ្នា ៣ នាក់ ប្រហែលវានៅអូរផុស"]។

1828 ឯកសារ D114/116 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.៥-ឆ.១១ ["បាទ ខ្ញុំបានឃើញគេចុះមកម្តងម្កាល។ [...] ឆ.៦៖ មាស មុត មេបញ្ជាការកងពល១៦៤។ [...] ឆ.៧៖ ខ្ញុំឃើញគាត់ជិះឡានមក ខ្ញុំឃើញគាត់នៅ

488. នៅក្នុងកម្រិតវរសេនាធំ វរសេនាធំ៦៣ នៃកងពល ១៦៤ (អតីតវរសេនាធំ២២នៃកងពល៣)[1829] បានគ្រប់គ្រងលើការដ្ឋានទឹកសាប[1830] រួមមាន ដូចដែលបានសរសេរខាងលើនេះ ទីបញ្ជាការរបស់វរសេនាធំនោះផ្ទាល់ ក៏ដូចជា អគារឃុំឃាំង ទីតាំងសម្លាប់មនុស្ស និងការដ្ឋាន។ យុទ្ធជនយាមមន្ទីរសន្តិសុខនេះ ចេញមកពីអង្គភាព (សន្តិសុខ) ពិសេស របស់វរសេនាធំ៦៣[1831] ហើយសាក្សីម្នាក់បានចង្អុលឈ្មោះ ញ៉ែន ប្អូនថ្លៃប្រុសរបស់ **មាស មុត** ថា ជាប្រធានមន្ទីរសន្តិសុខ យ៉ាងហោចណាស់រហូតដល់ ១៩៧៧[1832]។

---

ក្នុងឡាន ហើយចុះទៅផែ ដែលនៅមាត់ស្ទឹងទឹកសាប។ [...] ឆ.៨៖ ឡានហ្ស៊ីពចិន។ [...] ឆ.៩៖ ខ្ញុំមិនដឹងថាគាត់ចុះមកទឹកសាបនេះញឹកញាប់ប៉ុនណាឡើយ។ ខ្ញុំគ្រាន់តែដឹងថា គាត់ចុះទៅទឹកសាបនេះម្តងម្កាលប៉ុណ្ណោះ។ ខ្ញុំដឹងតាមក្មេងដែលមកប្រាប់ខ្ញុំ។ ក្មេងមកប្រាប់ខ្ញុំថា មានមេៗចុះមកទឹកសាប [...] ឆ.១០៖ ក្មេងៗមកប្រាប់ខ្ញុំថា មេបញ្ជាការនៅកំពង់សោមចុះមក។ ពួកគេនិយាយថា គាត់ជា មាស មុត។ [...] ឆ.១១៖ មាស មុត ចុះមកទឹកសាបប្រហែលជា ៤-៥ខែម្តង។ ក្មេងៗជាអ្នកមកប្រាប់ខ្ញុំថា គាត់ជាអ្នកចុះមក"]។

1829 ឯកសារ D2/8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ន ឆ.៣៩ ["ស.៖ តើកងវរៈសេនាធំលេខ ១៦៣ មានឈ្មោះដើមជាកងវរៈសេនាធំលេខប៉ុន្មាន? ឆ.៣៩៖ កងវរៈសេនាធំលេខ២២"]។ អ្នកដទៃទៀតកំណត់អត្តសញ្ញាណកងវរៈសេនាធំដើមនេះថាជាលេខ ១១, ១២ និងលេខ ១៣។ លេខ១៤, ១៥ និងលេខ ១៦។ ឬក៏លេខ ៣១, ៣២ និងលេខ ៣៣។ សូមមើលបន្ថែម កថាខណ្ឌ ២១៧។

1830 ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.១១-១២, ១៩ [មាន តា ញ៉ាន់ និងតា ជន ដែលជាមេបញ្ជាការកងវរៈសេនាធំលេខ ៦៣ និងជាអនុ ជាអ្នកទទួលខុសត្រូវនៅគុកទឹកសាបនោះ]។ ឯកសារ D114/77 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សាម៉េត ឆ.២០ ["ស.៖ តើអង្គភាពមួយណាស្ថិតក្រោមចំណុះកងពលធំ១៦៤ ដែលគ្រប់គ្រងតំបន់ទឹកសាប? ឆ.២០៖ កងវរៈសេនាធំលេខ ៦៣"]។ ឯកសារ D114/139 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ងួន ឡាយ ឆ.៨៨ ["កន្លែងនោះជាក្របខណ្ឌ នៅក្រោមវរៈសេនាធំ ៦៣ ដដែលហ្នឹង តែមានតួនាទីតាមផ្នែក ហើយខ្ញុំនៅកន្លែងអារឈើ"]។ ឯកសារ D54/111 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ភីន ឆ.១៦ ["តាមខ្ញុំដឹង ទឹកសាបស្ថិតនៅក្រោមកងវរៈសេនាធំលេខ៦៣។ ទឹកសាប នៅជិតព្រៃនប់ងណោះ ប៉ុន្តែខ្ញុំធ្វើការនៅកំពង់សោមឯណោះ"]។ ឯកសារ D114/115 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.៨, ៣០ ["គុកទឹកសាបស្ថិតនៅក្រោមកងវរៈសេនាធំលេខ៦៣ នៃកងពល១៦៤ [...] ស.៖ តើបញ្ជាការដ្ឋានកងវរសេនាធំនៅកន្លែងណាបន្ទាប់ពីផ្លាស់ទៅទឹកសាប? ឆ.៣០៖ បញ្ជាការដ្ឋាននោះ មានទីតាំងនៅក្នុងអគារថ្មនៅផែទឹកសាប"]។

1831 ឯកសារ D114/115 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.៣៦ ["អ្នកយាមគុកស្ថិតនៅក្នុងកងពិសេសនៅក្រោមកងវរសេនាធំ៦៣"]។

1832 ឯកសារ D114/116 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.៤៧ ["នៅពេលដែលលោកចេញពីទឹកសាបនៅឆ្នាំ ១៩៧៧ តើ ញ៉ែន នៅតែកាន់គុកទឹកសាបទៀតដែរឬទេ? ឆ.៤៧៖ បាទ គាត់នៅកាន់ទុកទឹកសាប"]។ ឯក

489. សមាជិកគណៈកងពល៣/១៦៤[1833] ឈ្មោះ ម៉ុម ជឹម ហៅ យ៉ាន គឺជាមេបញ្ជាការដំបូងនៃវរសេនាធំ២២/៦៣ ស្រស់ អនុមេបញ្ជាការ និង គឹម ញ៉ាន់ ពីដំបូងជាសមាជិក[1834]។ យ៉ាន ធ្វើការ

---

សារ D114/115 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.៣, ៥ ["បងថ្លៃរបស់ខ្ញុំឈ្មោះ ញ៉ែន [...] គឺជាអ្នកសួរចម្លើយនៅក្នុងគុកនេះ ហើយខ្ញុំធ្លាប់ដឹកម្ហូបទៅឱ្យ ញ៉ែន នៅគុកនេះផ្ទាល់តែម្តង [...] ស.៖ តើលោកអាចប្រាប់យើងបានទេ ថាតើអ្នកណាជាប្រធានគុក? ឆ.៥៖ ញ៉ែន តែខ្ញុំមិនស្គាល់ត្រកូលរបស់គាត់ទេ។ ញ៉ែន ជាបងថ្លៃរបស់ខ្ញុំ តែគាត់ស្លាប់ហើយ។ ញ៉ែន ជាប្តីបងស្រីរបស់ខ្ញុំ"]។

1833 ឯកសារ D54/104 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៥ ["យ៉ាន ជាសមាជិកគណៈកងពល១៦៤"]។ ឯកសារ D114/32 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស សារ៉ាន ឆ.២៦ ["តាមខ្ញុំដឹង យ៉ាន ហ្នឹង គឺគាត់នៅកាន់គណៈកងពលធំលេខ៣"]។ ឯកសារ D114/282 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.១២ ["ថ្នាក់កងពលមាន ឆាន៎ អ៊ំម៉ែត៎ បងយ៉ាន៎ បងខឹម"]។ ឯកសារ D114/116 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.២៧ ["មុំ យ៉ាន គឺជាមនុស្សម្នាក់ដែលស្ថិតនៅក្នុងកងពល១៦៤ នៅក្នុងឆ្នាំ ១៩៧៥"]។ ឯកសារ D114/155 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រ៉េន ឆ.៦៧ ["តាខឹម តាយ៉ាន និង តាឆាន។ តាឆាន ចូលរួមកងពល១៦៤"]។ ឯកសារ D54/81 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ីង អ៊ុច ឆ.១៤ ["អនុកងពលឈ្មោះ ខឹម មកពីភូមិភាគបូព៌ា។ សមាជិកកងពលមកពីខេត្តកោះកុង ឈ្មោះ បង ឆាន។ ក្រោយមក យ៉ាន មកកាន់កងពល១៦៤ជាមួយ អ៊ំ មុត ដែរ"]។ ឯកសារ D1.3.30.5 របាយការណ៍របស់សេនាធិការកម្ពុជាប្រជាធិបតេយ្យ តារាងស្ថិតិសិក្ខាកាម វៀនវគ្គសេនាធិការលើកទី ១ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៧៦ KH 00095536-00095537 [ចុះបញ្ជីសមមិត្ត មុំ យ៉ាន ជា "កងពល" រួមជានឹង ហឹង ខឹម]។ សូមមើលផងដែរ ឯកសារ D1.3.28.45 បញ្ជីឈ្មោះអ្នកទោសនៅស-២១ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៧៧ KH 00161776 [ចុះបញ្ជី ម៉ម ជឹម ហៅ យ៉ាន ជាសមាជិក កងពល ១៦៤]។ ឯកសារ D1.3.28.2 បញ្ជីឈ្មោះអ្នកទោសនៅស-២១ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៧៧ KH 00086996 [ចុះបញ្ជី មុំ យ៉ាន ជាសមាជិកកងពល ១៦៤]។ សូមមើលបន្ថែម ឯកសារ D114/69 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុយ សម្បត្តិ ឆ.១ ["ខ្ញុំមិនដឹងថា អ្នកណាខ្លះជាសមាជិករបស់គណៈតំបន់នោះឡើយ ប៉ុន្តែមានម្នាក់ឈ្មោះ តាខឹម និងម្នាក់ទៀតឈ្មោះ តាយ៉ាន"]។

1834 ឯកសារ D2/8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ន ឆ.៤០ ["យ៉ាន គឺជាស្នងការ ឈ្មោះ ស្រស់ គឺជាអនុ ឈ្មោះ ញ៉ាន់ គឺជាសមាជិក"]។ ឯកសារ D54/104 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៥ ["តាស្រស់ គឺជាស្នងការរបស់វរៈសេនាធំនោះ ហើយ យ៉ាន គឺជាបញ្ជាការ"]។ ឯកសារ D114/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត់ (ប៊ុន សារ៉ាត់) ឆ.៣, ២០ ["វរសេនាធំឈ្មោះ យ៉ាន (ស្លាប់) ស្រស់ [...] ឆ.២០៖ បញ្ជាក់បោះទីតាំង ១៦ យ៉ាន នៅព្រលានយន្តហោះកងកេង"]។ ឯកសារ D54/112.1 កិច្ចសម្ភាសន៍របស់ ផ្លុង ឈា ជាមួយ មជ្ឈមណ្ឌលឯកសារកម្ពុជា KH 00926490-00926491 ["ស.៖ ចាំ អីប្រធានទេ? [...] ឆ.៖ លោក យ៉ាន"]។ ឯកសារ D54/46 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ឆ.៣៥[៣៧] ["ស្រស់ ជាមេបញ្ជាការកវរសេនាធំលេខ ២២"]។ ឯកសារ D114/16 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក វណ្ណា ឆ.៥ ["យ៉ាន ជាមេបញ្ជាការកវរសេនាធំលេខ ៣៣ ដែលមានទីបញ្ជាការនៅទឹកសាប"]។ ឯកសារ D114/178 កំណត់ហេតុនៃការស្តាប់ចម្លើយ

នៅទីបញ្ជាការទឹកសាប[1835] ហើយជាទៀងទាត់គេបានឃើញគាត់ហូបបាយ នៅរោងបាយនៃទីតាំងនោះ[1836]។ បន្ទាប់ពី យ៉ាន បានចាប់ខ្លួន និងបញ្ជូនទៅ ស-២១ នៅខែ មេសា ឬឧសភាឆ្នាំ ១៩៧៧[1837] **មាស មុត** បានប្រកាសប្រាប់កម្មាភិបាលនាឱកាសប្រជុំធំៗជាច្រើនលើកនៃកងពល

---

សាក្សី អ៊ុំ សុខន ឆ.៣៥ ["វរសេនាធំ៦៣ មានមេបញ្ជាការឈ្មោះ បងយ៉ាន កាន់នៅកោះសេះ កោះតាគាវ កោះថ្មី ម្តុំរាម"]។ ឯកសារ D54/81 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ីង អ៊ុច ឆ.១៤ ["ក្រោយមក យ៉ាន មកកាន់កងពល១៦៤ ជាមួយ អ៊ំ មុត ដែរ។ គាត់ជាអតីតមេបញ្ជាការកវរៈសេនាធំ៦៣"]។ ឯកសារ D114/116 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.៣០ ["គាត់គឺជាបញ្ជាការកងវរសេនាធំ៦៣ នៃកងពល១៦៤ តាំងពីដើមមកម្លេះ"]។ ឯកសារ D54/33 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង អុន ឆ.៩ ["វរៈសេនាតូច ៥៣០៤ ៥៤០ និង ៥៥០ ឋិតនៅក្នុងវរៈសេនាធំក្រោមបញ្ជាការរបស់ តា យ៉ាន"]។ ឯកសារ D54/7 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ឆ.៦ ["ឈ្មោះតា យ៉ាន ស្នងការវរៈសេនាធំ ២២"]។ សូមមើលផងដែរ ឯកសារ D54/116 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ យឿន ឆ.១ ["យ៉ានធ្វើជាមេបញ្ជាការកងវរៈសេនាធំ តែខ្ញុំមិនដឹងថាវរៈសេនាធំអ្វីនោះទេ"]។

1835 ឯកសារ D114/116 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.៣៣-៣៤ ["ស.៖ តើ មុំ យ៉ាន ធ្វើការនៅបញ្ជាករដ្ឋាននៅផែ ដែលលោកបានពន្យល់មុននេះមែនឬ? ឆ.៣៣៖ បាទ គាត់ធ្វើការនៅទីនោះ គាត់ជាអ្នកគ្រប់គ្រងតំបន់នោះ [...] ស.៖ តើ មុំ យ៉ាន ជាអ្នកទទួលខុសត្រូវលើបញ្ជាការដ្ឋាននៅពេលដែល មាស មុត ចុះទៅទីនោះ ដូចដែលលោកបានពន្យល់មុននេះដែរឬទេ? ឆ.៣៤៖ បាទ"]។

1836 ឯកសារ D114/116 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.៣០៤ ៣២ ["គាត់គឺជាបញ្ជាការកងវរៈសេនាធំ៦៣ នៃកងពល១៦៤ តាំងពីដើមដំបូងមកម្លេះ។ [...] ឆ.៣២៖ ជាធម្មតា គាត់មកហូបបាយនៅរោងបាយនៅទឹកសាប"]។

1837 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសនៅស-២១ របស់ ក.ស.ច.ស លេខ 4797 [បានចូលនៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៧ ឬក៏ខែ ឧសភា ឆ្នាំ ១៩៧៧ បានសម្លាប់នៅថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៧៨]។ ឯកសារ D1.3.28.2 បញ្ជីឈ្មោះអ្នកទោសនៅស-២១ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៧៧ KH 00086996 [កំណត់អត្តសញ្ញាណ មុំ យ៉ាន ជាសមាជិកកងពល១៦៤ ដែលត្រូវបានបញ្ជូនទៅកាន់ស-២១ នៅក្នុងខែ ឧសភា ឆ្នាំ ១៩៧៧]។ ឯកសារ D1.3.28.45 បញ្ជីឈ្មោះអ្នកទោសនៅស-២១ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៧៧ [ចុះបញ្ជី ម៉ម ជឹម ហៅ យ៉ាន]។ ឯកសារ D54/7 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុល សុង ឆ.៦ ["តាយ៉ាននិងវេតត្រូវបានចាប់ខ្លួន ក្នុងរយៈពេលគេធ្វើការបោសសម្អាតនៅក្នុងកងពល ១៦៤ នៅកំពង់សោម"]។ ឯកសារ D114/95 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម ស្រឿង ឆ.៦៤៤ ៦៦ ["ស.៖ តើលោកអាចប្រាប់ឈ្មោះអ្នកដែលលោកស្គាល់ ហើយគេនាំយកទៅនោះបានដែរទេ? ឆ.៦៤៖ មានឈ្មោះ [...] យ៉ាន [...] ដែលគេចោទថា ជាគិញវៀតណាម ឬក៏សេអ៊ីអា។ [...] ឆ.៦៦៖ សុទ្ធជាអ្នកដែលនៅក្រោម មាស មុត។ [...] យ៉ាន ប្រធានវរសេនាធំ"]។ ឯកសារ D54/104 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៥ ["យ៉ាន ជាសមាជិកគណៈកងពល ១៦៤ [...] ឈ្មោះ យ៉ាន នេះគឺស្ថិតនៅក្នុងចំណោមពួកក្បត់ដែល តា មុត បានលើកមករៀបជាពាក្យជូនដូចកំណាព្យ"]។ ឯកសារ D54/8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី

១៦៤ អំពីការចាប់ខ្លួន និងអំពើក្បត់ដែលបានចោទដាក់យ៉ាន[1838]។ ស្រស់ ត្រូវបានចាប់ខ្លួនក្នុងលក្ខណៈប្រហែលគ្នាដែរ[1839]។ មុនការចាប់ខ្លួនទាំងនេះ ប្រហែលជាចុងឆ្នាំ ១៩៧៦ យ៉ាន បានដកចេញពីនាទីជាមេបញ្ជាការវរសេនាធំ៦៣ ហើយដាក់ជំនួសដោយ ស៊ិន ជន[1840] ដែលរស់នៅតំបន់ទឹក

---

ឌុល សុង ឆ.៤-៥ ["តាមដែលខ្ញុំចាំឈ្មោះ យ៉ាន មេបញ្ជាការវរៈសេនាធំ ២២, ង៉ែត មេបញ្ជាការវរៈសេនាធំ ២០ និង មេបញ្ជាការវរៈសេនាតូចរបស់ខ្ញុំឈ្មោះ វេត [...] ឆ.៥៖ គេចាប់ក្នុងឆ្នាំ ១៩៧៧ ឬដើមឆ្នាំ ១៩៧៨។ ខ្ញុំមិនបានឃើញការចាប់នោះដោយផ្ទាល់ភ្នែកទេ ប៉ុន្តែគេប្រជុំតាមកងប្រាប់អំពីការចាប់ចងនេះ"]។ ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.១ ["នៅក្នុងអង្គប្រជុំ មាស មុត អានចម្លើយសារភាពរបស់ពួកក្បត់ គាត់បានរៀបរាប់ឈ្មោះកម្មាភិបាលក្បត់ចាប់ពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់មូលដ្ឋាន។ ខ្ញុំនៅចាំថា គាត់ហៅឈ្មោះ អា យ៉ាប់ អាធុចប់ អាញ៉ិកប់ អាយ៉ានប់ អាផានប់ និង អាឌឹម។ ខ្ញុំនៅចាំ មាស មុត ហៅពួកគេថា "អា" ពីព្រោះ "អា" ជាពាក្យបន្តុះបង្អាប់សម្រាប់និយាយទៅកាន់ពួកក្បត់"]។ ឯកសារ D114/116 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.២៦-៣៣[៣២] [ពន្យល់ថា មុំ យ៉ាន ជាមេបញ្ជាការកងវរសេនាធំ ៦៣ បានបាត់ខ្លួននៅក្នុងឆ្នាំ ១៩៧៧]។

1838 ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.១ ["នៅចុងឆ្នាំ ១៩៧៦ [...] ជិតចូលឆ្នាំ ១៩៧៧ ហើយ នៅពេលនោះ គេបានដកយោធាកង ៣៨៦ ទាំងអស់យកទៅដាក់នៅកងផលិត។ បន្ទាប់ពីគេដកអាវុធពីពួកយើងអស់ [...] មាស មុត បានមកធ្វើមីទ្ទីងជាមួយពួកយើងនៅភូមិគគីរ នៅជិតព្រលានយន្តហោះកងកេង ដោយមានអតីតយោធាចូលរួមប្រហែលរាប់ពាន់នាក់ ដោយមានកង ៣៨៦ និងកងផ្សេងៗទៀត។ នៅក្នុងអង្គប្រជុំ មាស មុត បានរៀបរាប់ឈ្មោះកម្មាភិបាលក្បត់ចាប់ពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់មូលដ្ឋាន។ ខ្ញុំនៅចាំថា គាត់ហៅឈ្មោះ អា យ៉ាប់ អា ធុចប់ អាញ៉ិកប់ អាយ៉ានប់ អាផានប់ និង អាឌឹម។ ខ្ញុំនៅចាំ មាស មុត ហៅពួកគេថា "អា" ពីព្រោះ "អា" ជាពាក្យបន្តុះបង្អាប់សម្រាប់និយាយទៅកាន់ពួកក្បត់"]។ ឯកសារ D54/104 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៥ប់ ៩ ["ឈ្មោះ យ៉ាន នេះគឺស្ថិតនៅក្នុងចំណោមពួកក្បត់ដែល តា មុត បានលើកមករៀបជាពាក្យជួនដូចកំណាព្យថា "ញ៉ិកប់ ផានប់ យ៉ានប់ ឌឹម ជាពួកក្បត់ [...] ឆ.៩៖ ["ខ្ញុំគិតថា ឌឹម នៅក្នុងឯកសារនេះ គឺជា ឌឹម ដែលខ្ញុំបានប្រាប់លោកខាងដើម ដែលរាប់នៅក្នុងពាក្យជួនថា អាញ៉ិកប់ អាផានប់ អាយ៉ានប់ អាឌឹម"]។

1839 ឯកសារ D54/48 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សុន ឆ.៥៨ ["តែខ្ញុំឮថា ង៉ែត និង ស្រស់ ត្រូវបានចាប់ខ្លួន តែខ្ញុំមិនដឹងថាគេបញ្ជូនពួកគេទៅណាទេ"]។

1840 ឯកសារ D114/77 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សាម៉េត ឆ.២០ប់ ៣០ ["មេបញ្ជាការកងវរៈសេនាធំលេខ៦៣នេះ ឈ្មោះ ជន ហើយនិង ញ៉ាន់ ដែលជាអនុរបស់ ជន [...] ឆ.៣០៖ គាត់គឺជាមេបញ្ជាការកងវរៈសេនាធំលេខ៦៣ មុនពេលដែល ជន ចូលមកកាន់ជំនួស។ ខ្ញុំមិនដឹងពីអ្វីដែលបានកើតឡើងចំពោះគាត់ឡើយ"]។ ឯកសារ D114/18 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ឆ.៦ ["មេបញ្ជាការកងវរៈសេនាធំនោះឈ្មោះ យ៉ាន ។ ក្រោយមក ពេលដែលយើងនៅកំពង់សោមក្នុងឆ្នាំ១៩៧៦ តាយ៉ាន ត្រូវបានផ្លាស់ចេញទៅកន្លែងផ្សេង ហើយតាជនបានក្លាយជាមេបញ្ជាការកងវរៈសេនាធំរបស់ខ្ញុំ នៅពេលនោះកងវរៈសេនាធំរបស់ខ្ញុំគឺលេខ៦៣។ ដល់ឆ្នាំ១៩៧៧ តាជន បានបាត់ខ្លួនទៅ"]។ ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.១២, ១៩ ["មាន តា ញ៉ាន់ និងតា ជន ដែលជាមេបញ្ជាការកងវរៈសេនាធំលេខ ៦៣ [...] ឆ.១៩៖ ពេលខ្ញុំមកដល់ទឹកសាបដំបូង ក្នុងឆ្នាំ

សាប[1841]។ ជន "ទទួលបញ្ជាផ្ទាល់ពី **មាស មុត**"[1842]។ តាមពិត ក្នុងនាទីជាមេបញ្ជាការកងពល **មាស មុត** ធ្វើអធិបតីអង្គប្រជុំជាទៀងទាត់ជាមួយនឹងមេបញ្ជាការវរសេនាធំ[1843]។

---

១៩៧៧ តាជន ជាអ្នកទទួលខុសត្រូវនៅទីនោះ។ តាជន គឺជាមេបញ្ជាការវរៈសេនាធំលេខ៦៣ ហើយ តាញ៉ាន់ គឺជាអនុរបស់គាត់"]។ ឯកសារ D114/115 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.១៤ ["មេបញ្ជាការកងវរសេនាធំ៦៣ ឈ្មោះ ជន ផ្ទះរបស់គាត់គឺនៅជិតទឹកសាបគាត់"]។ ឯកសារ D114/139 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ងួន ឡាយ ឆ.៩៣ ["ស.៖ មុននេះ លោកប្រាប់ពីឈ្មោះប្រធាននមន្ទីរអារឈើ តើនរណាដែលជាមេវរៈសេនាធំ លេខ ៦៣? ឆ.៩៣៖ ដំបូង ឈ្មោះជន"]។ ឯកសារ D54/110 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លុន សេង ឆ.៧ ["ខ្ញុំស្គាល់អ្នកទាំងនេះតាំងពីដើមមក។ ញ៉ាន់ ជាមេបញ្ជាការកងវរៈសេនាធំ៦១៤ សុន ជាមេបញ្ជាការកងវរៈសេនាធំ៦២។ មៀញ និង ជន ជាមេបញ្ជាការកងវរៈសេនាធំ៦៣"]។ ឯកសារ D114/114 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.១៩ ["តើអ្នកណាជាមេបញ្ជាការកងពលធំ១៦៤ និងកងវរសេនាធំ៦៣? ឆ.១៩ [...] បញ្ជាការកវរសេនាធំឈ្មោះ ជន"]។ ឯកសារ D1.3.30.5 របាយការណ៍របស់សេនាធិការកម្ពុជាប្រជាធិបតេយ្យ តារាងស្ថិតិសិក្ខាកាម វៀនវគ្គសេនាធិការលើកទី ១ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៧៦ KH 00095536-00095537 [ចុះបញ្ជីសមមិត្ត ស៊ិន ជន ជាលេខាកងវរៈសេនាធំនៅក្នុងកងពល១៦៤]។

[1841] ឯកសារ D114/115 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.៨៤ ១៤ ["គុកទឹកសាបស្ថិតនៅក្រោមកងវរសេនាធំលេខ៦៣ នៃកងពល១៦៤ [...] ឆ.១៤៖ បញ្ជាការកងវរសេនាធំ៦៣ ឈ្មោះ ជន ផ្ទះរបស់គាត់គឺនៅជិតទឹកសាប"]។

[1842] ឯកសារ D114/15 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សុក (សួស) វណ្ណា ឆ.២៦ ["ជន ទទួលបញ្ជាដោយផ្ទាល់ពី មាស មុត"]។

[1843] ឯកសារ D54/7 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឌុល សុង ឆ.១៤-១៥ ["សម្រាប់សំណួរ ដែលថា អ្នកណាជាអ្នកដឹកនាំប្រជុំជាប្រចាំនៃមេបញ្ជាការវរៈសេនាធំ និងកងវរៈពិសេស គឺជាមេបញ្ជាការរបស់កងពលលេខ៣/១៦៤ [...] ឆ.១៥៖ មេបញ្ជាការគឺ មាស មុត"]។ ឯកសារ D114/66 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.២០ ["ខ្ញុំមិនដែលឃើញមនុស្សណា ដែលមានលក្ខណៈឬកពារដូច តាមុត ទេ។ គាត់តឹងរ៉ឹងណាស់។ គាត់តែងតែហៅបញ្ជាការវរៈសេនាធំ និង វរៈសេនាតូច ឲ្យទៅកន្លែងគាត់ ហើយទទួលបញ្ជាពីគាត់។ ពួកមេបញ្ជាការវរៈទាំងនោះយល់ច្បាស់ណាស់ថា អ្វីដែលគេនឹងត្រូវធ្វើទៅតាមបញ្ជារបស់ តាមុត។ បើគេធ្វើតាមបញ្ជាកាត់ពុំមានជោគជ័យ គេនឹងមានបញ្ហាមិនខាន"]។ ឯកសារ D54/44 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លុន សេង ឆ.២៦៤ ២៨ [អំពីការប្រកាសដោយ មាស មុត ថា ពួកយោធាភូមិភាគបូព៌ា គឺជាយោធាសមាសភាពមិនល្អ៖ "ការប្រកាសនោះត្រូវធ្វើនៅក្នុងកិច្ចប្រជុំពិសេសមួយដែលថ្នាក់ដឹកនាំផ្នែកវរសេនាតូច និងវរសេនាធំត្រូវបានគេជ្រើសរើសឲ្យមកចូលរួម [...] ឆ.២៨៖ ប្រធានកងពល មាស មុត ជាអ្នកណែនាំមេបញ្ជាការវរសេនាធំឲ្យធ្វើការតាមដានប្រវត្តិយោធារបស់ខ្លួនទៅដល់ស្រុកកំណើត"]។ ឯកសារ D114/19 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ាក ឈឿន ឆ.១៦-១៧ ["ពេលខ្លះ តាឌឹម ជាអធិបតីក្នុងអង្គប្រជុំ ហើយពេលខ្លះតាមុតជាអធិបតីក្នុងអង្គប្រជុំ [...] ឆ.១៧៖ ពេលខ្លះ ការប្រជុំរួមមេបញ្ជាការវរៈសេនាតូច វរៈសេនាធំទាំងអស់ និងកងទ័ពជើងទឹក ជើកគោករបស់កងពល១៦៤"]។ ឯកសារ D54/31

490. ទោះជាមានព្រឹត្តការណ៍ថា នៅខែ កក្កដា ឆ្នាំ ១៩៧៥ នៅអង្គប្រជុំនៃបណ្ដាមេបញ្ជាការក្នុងកងពល ៣/១៦៤ មាស មុត បានស្ដីបន្ទោស គឹម ញ៉ាន់ ដោយសារមិនបានសុំអនុញ្ញាតសម្លាប់មនុស្ស ក៏ដោយ[1844] ញ៉ាន់ បានក្លាយជាកម្មាភិបាលម្នាក់ក្នុងចំណោមកម្មាភិបាលដែល **មាស មុត** ទុកចិត្តជាងគេ ហើយដែលបានទទួលឋានៈកាន់តែខ្ពស់ក្នុងកងពល ១៦៤ នៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់មានចេតនាដូចមាសមុតដែរ ក្នុងការបោសសម្អាតកងពល ១៦៤ ឲ្យអស់ "ខ្មាំងខាងក្នុង។" ទាំងពីរនាក់នេះ បានដឹកនាំវគ្គរៀនសូត្រជាមួយគ្នា ដែលក្នុងនោះ អ្នកចូលរួមត្រូវបំពេញប្រវត្តិរូប សំដៅដកចេញ និងចាប់ "ខ្សែ" អតីតមេបញ្ជាការវរសេនាធំ៦៣ ឈ្មោះ យ៉ាន[1845]។ នៅ

កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ឆ.៥ ["នៅពេលនោះទីបញ្ជាការដ្ឋានកងពល និងផ្ទះរបស់មេបញ្ជាការកងពលគឺនៅជាមួយគ្នា។ ជារៀងរាល់ខែ ពួកមេបញ្ជាការវរៈសេនាធំនីមួយៗមកប្រជុំនៅទីនោះរៀងរាល់ថ្ងៃទី ១០, ថ្ងៃទី ២០ និងថ្ងៃទី ៣០"]។

1844 ឯកសារ D54/98 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ាង រ៉េត ឆ.១២០-១២៤ ["ស.៖ យោងទៅលើកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ជាភាសាអង់គ្លេស ទំព័រ៧១ លោកនិយាយថា "បន្ទាប់ពីបានស្តាប់របាយការណ៍ហើយ បងមាស មុត បានសួរតាញ៉ាន់អំពីការសម្លាប់មនុស្ស គាត់សួរថា៖ តើនរណាគេឱ្យសម្លាប់ប្រជាជនទាំងនោះ? តើនរណាគេអនុញ្ញាតឲ្យឯងស៊ើបសួរប្រជាជនតាមផ្ទះរបស់គេ? ឯងសមនឹងប្រជាជនធ្វើអ៊ីចឹងដាក់ហើយ តាមពិតទៅប្រជាជនគួរតែចាក់ទឹកក្តៅលើក្បាលឯង។ ឯងគ្មានសិទ្ធិតាមដានពួកគេទេ។ មុននឹងឯងសម្លាប់មនុស្សតើឯងមានការអនុញ្ញាតពីមេរបស់ឯងដែរឬទេ? តើលោកបានឮ មាស មុត ស្តីឱ្យតាញ៉ាន់ផ្ទាល់ដែរឬទេ? ឆ. ១២០៖ បាទ ខ្ញុំបានឮដោយផ្ទាល់ ពីព្រោះពេលនោះ គឺមានសន្និបាតដែលមេៗនៅក្នុងកងពល១៦៤បានចូលរួមប្រជុំ។ ស.៖ នៅពេលមាស មុត និយាយជាមួយតាញ៉ាន់ ថា "មុននឹងឯងសម្លាប់មនុស្ស ឯងត្រូវមានការអនុញ្ញាតពីមេរបស់ឯងជាមុនសិន" តើមេដែលគាត់និយាយនោះ គឺសំដៅទៅលើអ្នកណាដែរ? ឆ.១២១៖ តាញ៉ាន់ គឺជាមេបញ្ជាការវរៈសេនាធំ៦៣ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពល១៦៤ ដែលមានមាស មុត ជាមេបញ្ជាការ។ ដូច្នេះក្នុងន័យនេះ មានន័យថាគាត់ត្រូវមានការអនុញ្ញាតពីមាស មុត ជាមុនសិន។ ស.៖ តើលោកដឹងថានៅក្នុងកលៈទេសៈណាដែលប្រជាជនទាំងនោះត្រូវបានតាញ៉ាន់យកទៅសម្លាប់ដែរ? ឆ.១២២៖ ខ្ញុំមិនដឹងថាប្រជាជនទាំងនោះត្រូវបានតាញ៉ាន់សម្លាប់ក្នុងកាលៈទេសៈណានោះទេ។ ប៉ុន្តែខ្ញុំចាំបានថា នៅក្នុងអង្គប្រជុំនោះ តាញ៉ាន់បានរាយការណ៍ប្រាប់មាស មុត ថាគាត់បានសម្លាប់មនុស្ស។ ស.៖ តើកិច្ចប្រជុំសន្និបាតកើតឡើងនៅពេលណាដែរ? ឆ.១២៣៖ កិច្ចប្រជុំធ្វើឡើងក្នុងឆ្នាំ ១៩៧៥។ ស.៖ តើលោកអាចប៉ាន់ស្មានថាតើកិច្ចប្រជុំនោះកើតឡើងនៅក្នុងពេលណា? ឆ.១២៤៖ តាមការចងចាំរបស់ខ្ញុំ កិច្ចប្រជុំនោះកើតឡើងនៅក្នុងខែកក្កដា ឆ្នាំ ១៩៧៥"]។

1845 ឯកសារ D54/115 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ យឿន ឆ.១៥, ២១-២៤ ["ស.៖ តើអ្នកណាជាអ្នកបញ្ជាឲ្យធ្វើប្រវត្តិរូប ក្រោយពី យ៉ាន បាត់ខ្លួន? ឆ.១៥៖ កាលនោះ គឺជាការរៀនសូត្រដែលមានរយៈពេល៥ថ្ងៃ។ [...] កម្មាភិបាលកងពល ដែលបញ្ជាឲ្យយើងធ្វើប្រវត្តិរូបនោះមាន តាញ៉ាន និង តាមុត។ កម្មាភិបាលទាំងពីរនេះ ក៏បង្រៀនយើងដែរនៅក្នុងវគ្គរៀនសូត្រនេះ [...] ស.៖ តើ ញ៉ាន់ និង មាស មុត បង្រៀនអ្វីខ្លះនៅក្នុងវគ្គរៀនសូត្រ? ឆ.២១៖ ពួក

ពេលជន ឡើងកាន់ជាមេបញ្ជាការវរសេនាធំ៦៣ ញ៉ាន់ កាន់នាទីជាអនុបញ្ជាការ[1846]។ ក្រោយពី ជន ខ្លួនឯងត្រូវបានចាប់ដែរក្នុងឆ្នាំ ១៩៧៧[1847] ញ៉ាន់ បានឡើងឋានៈទៀត លើកនេះ ជាមេបញ្ជាការវរសេនាធំ៦៣[1848]។ ជាមេបញ្ជាការវរសេនាតូច៦៣៣ និងជាសាក្សីផងដែរ ឈ្មោះ ម៉ាកឈឿន

---

គេបង្រៀនអំពីចលនាតស៊ូ និងនយោបាយជុំវិញយើង [...] ឆ.២២៖ គឺស្ងាត់ឃើងពាក់ព័ន្ធនឹងករណីរបស់ យ៉ាន។ នៅថ្ងៃចុងក្រោយនៃវគ្គរៀនសូត្រនោះ ពេលគឺក្នុង "ម៉ោងធ្វើប្រវត្តិរូប" សំណួរត្រូវបានសួរ ឲ្យអ្នកចូលរួមឆ្លើយ។ សំណួរមួយក្នុងចំណោមសំណួរទាំងនោះ គឺសួររកអ្នកដែលធ្លាប់ធ្វើការជាមួយនឹង យ៉ាន [...] ឆ.២៣៖ ក្នុងពេលនោះ មាស មុត សរសេរនៅលើក្ដាខៀននូវសំណួរ។ [...] ឆ.២៤៖ តាមសង្កេតរបស់ខ្ញុំ មានមនុស្សបីបួននាក់ ដែលធ្វើការផ្ទាល់ជាមួយ យ៉ាន បានបាត់ខ្លួន"]។

1846 ឯកសារ D114/66 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.១៩ ["ពេលខ្ញុំមកដល់ទឹកសាបដំបូង ក្នុងឆ្នាំ ១៩៧៧ តាជន ជាអ្នកទទួលខុសត្រូវនៅទីនោះ។ តាជន គឺជាមេបញ្ជាការវរៈសេនាធំលេខ៦៣ ហើយ តាញ៉ាន់ គឺជាអនុរបស់គាត់"]។ ឯកសារ D114/18 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ាក ឈឿន ឆ.១១ ["នៅក្នុងឆ្នាំ១៩៧៦ គឺ តាជន បានឡើងមកជំនួស តាយ៉ាន ដែលជាមេបញ្ជាការកវរៈសេនាធំ៦៣ ហើយ តាញ៉ាន់ គឺជាអនុរបស់តាជន។ ក្នុងឆ្នាំ ១៩៧៧ ពេលដែលតាជន បាត់ខ្លួនទៅ តាញ៉ាន់ ដែលជាអនុរបស់គាត់បានឡើងកាន់បញ្ជាការកងវរៈសេនាធំជំនួស"]។

1847 ឯកសារ D114/66 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.១២៤ ១៩ ["មាន តាញ៉ាន់ និងតាជន ដែលបញ្ជាការកងវរៈសេនាធំ៦៣ [...] ឆ.១៩៖ ក្រោយមក ជន ត្រូវបានចាប់ខ្លួន ហើយ ញ៉ាន់ ឡើងជំនួស ជន"]។ ឯកសារ D114/18 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ាក ឈឿន ឆ.៦ ["ខ្ញុំមិនចាំលេខកងវរៈសេនាធំទេ តែមេបញ្ជាការកងវរៈសេនាធំនោះឈ្មោះ យ៉ាន។ ក្រោយមក ពេលដែលយើងនៅកំពង់សោមក្នុងឆ្នាំ ១៩៧៦ តាយ៉ាន ត្រូវបានផ្លាស់ចេញទៅកន្លែងផ្សេង ហើយតាជន បានក្លាយជាមេបញ្ជាការកងវរៈសេនាធំរបស់ខ្ញុំ នៅពេលនោះកងវរៈសេនាធំរបស់ខ្ញុំគឺលេខ៦៣។ ដល់ឆ្នាំ ១៩៧៧ តាជន បានបាត់ខ្លួនទៅ"]។

1848 ឯកសារ D114/18 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ាក ឈឿន ឆ.១១-១២ ["ក្នុងឆ្នាំ ១៩៧៧ ពេលដែលតាជន បាត់ខ្លួនទៅ តាញ៉ាន់ ដែលជាអនុរបស់គាត់ បានឡើងកាន់បញ្ជាការកងវរៈសេនាធំជំនួស [...] ឆ.១២៖ នៅពេលនោះ មានតែតាញ៉ាន់ ម្នាក់ទេ មិនមានចាត់តាំងអនុរបស់តាញ៉ាន់ នៅឡើយទេ។ ហើយក៏ពុំមានការប្រកាសជាផ្លូវការថាតាញ៉ាន់ ជាអ្នកជំនួសផងដែរ ប៉ុន្តែការងារប្រចាំថ្ងៃរបស់កងវរៈសេនាធំ គឺតាញ៉ាន់ ជាអ្នកទទួលខុសត្រូវ"]។ ឯកសារ D114/66 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.១២៤ ១៩ ["មាន តាញ៉ាន់ និងតាជន ដែលបញ្ជាការកងវរៈសេនាធំ៦៣ [...] ឆ.១៩៖ ក្រោយមក ជន ត្រូវបានចាប់ខ្លួន ហើយ ញ៉ាន់ ឡើងជំនួស ជន"]។ ឯកសារ D114/86 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.២៦ ["តាញ៉ាន់ គឺជាមេវរៈសេនាធំ ៦៣"] ឯកសារ D54/23 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ាក សុខ ឆ.២ ["វរៈសេនាធំលេខ៦៣ គឺតា ញ៉ាន់"]។ ឯកសារ D54/98 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ាង រ៉េត ឆ.២៨៤ ១២១ ["ខ្ញុំចាំថាតាញ៉ាន់ ជាមេបញ្ជាការកវរសេនាធំ៦៣ [...] ឆ.១២១៖ តាញ៉ាន់ គឺជាមេបញ្ជាការវរសេនាធំ៦៣ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពល ១៦៤ ដែលមាន មាស មុត ជាមេបញ្ជាការ"]។ ឯកសារ D114/17.1 កិច្ចសម្ភាសន៍របស់ ម៉ាក ឈឿន ជាមួយ

បំភ្លឺ ថា "តា ញ៉ាន់ ជាអ្នកទំនាក់ទំនងទៅជាមួយកងពល"[1849] ហើយជាការច្បាស់ណាស់ថា គាត់ចាត់ការអ្វីៗតាមតែបញ្ជារបស់មាសមុត[1850]។ បន្ទាប់ពីគាត់បានបោសសម្អាតសមាជិកពីរនាក់នៃកងពល ១៦៤ (ឌឹម និងឆាន) **មាស មុត** តែងតាំង ញ៉ាន់ ជាអនុបញ្ជាការកងពល ១៦៤ ទទួលខាងភស្តុភារ[1851]។ មកត្រឹមពេលនេះ ញ៉ាន់ ក៏បានមកស្នាក់នៅវ្ញចហើយដែរ ក្នុងបរិវេណរបស់

---

មជ្ឈមណ្ឌលឯកសារកម្ពុជា KH 01033986-01033987 ["ស.៖ ពីណាគេទទួលខាងវរៈសេនាធំ៦៣? ឆ.៖ តាញ៉ាន់"]។ ឯកសារ D114/103 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡូន ឆ.៣៧៤ ១១១ ["តើអ្នកណាជាអ្នកគ្រប់គ្រងកងទ័ពជើងគោក? ញ៉ាន់។ គាត់ស្លាប់បាត់ហើយ [...] ស.៖ តើលោកស្គាល់ឈ្មោះបញ្ជាការពិសេសៗដែល មាស មុត បញ្ជូនទៅច្បាំងដែរឬទេ? ឆ.១១១៖ ឈ្មោះ ឡូន (ស្លាប់) និងឈ្មោះ ញ៉ាន់ (កាន់ភស្តុភារកងពលលេខ ៣)"]។ ឯកសារ D114/139 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ងួន ឡាយ ឆ.១៤៤ ១៧-១៨៤ ១៩-២០ ["ខ្ញុំក៏ធ្វើជាអង្គរក្សផ្ទាល់របស់ ញ៉ាន់ [...] ឆ.១៧៖ តាញ៉ាន់ហ្នឹងគេឱ្យគាត់ទៅនៅកំពង់សោមវិញ [...] ឆ.១៨៖ ខ្ញុំទៅតាមគាត់ ជាអង្គរក្ស។ [...] ឆ.១៩៖ នៅចុងឆ្នាំ៧៥ ជិតចូលឆ្នាំ ៧៦ ខ្ញុំទៅ។ [...] ឆ.២០៖ ខ្ញុំទៅនៅកងពល ១៦៤ វរៈសេនាធំលេខ ៦៣"]។ ឯកសារ D114/202 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ សារ៉ាន ឆ.១៤៤ ៣៨ ["តើមេបញ្ជាការកងវរសេនាធំ ៦៣ នៅពេលនោះឈ្មោះអ្វីដែរ? ឆ.១៤៖ គេហៅថា អ៊ំញ៉ាន់ៗ [...] ឆ.៣៨៖ ឈ្មោះ សមមិត្ត វេត ដដែល ហើយ ញ៉ាន់ នៅវរសេនាធំ នៅតែលើគោកទេ"]។ ឯកសារ D114/16 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក វណ្ណា ឆ.៣, ៣៧ ["គាត់ឡើងពីប្រធានកងអនុសេនាធំ ទៅប្រធានកងវរៈសេនាតូច ទៅប្រធានកងវរៈសេនាធំ រហូតឡើងដល់ធ្វើជាអនុរបស់តាមុត [...] ឆ.៣៧៖ ខ្ញុំធ្លាប់ចូលរួមប្រជុំជាច្រើនដងនៅថ្នាក់វរៈសេនាធំ ដែលដឹកនាំដោយតាញ៉ាន់។ គឺមានតែអ្នកដែលមានប្រវត្តិរូបល្អ ដែលគហៅឱ្យទៅចូលរួមប្រជុំទាំងនេះ"]។

1849 ឯកសារ D114/18 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន ឆ.១២ ["ការងារប្រចាំថ្ងៃរបស់កងវរៈសេនាធំ គឺតាញ៉ាន់ ជាអ្នកទទួលខុសត្រូវ ពីព្រោះតាញ៉ាន់ ជាអ្នកទំនាក់ទំនងទៅជាមួយកងពល"]។

1850 ឯកសារ D59/1/4.25 កិច្ចសម្ភាសន៍របស់ ឡុង លី ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា KH 00930812-00930813 ["អ៊ំញ៉ាន់ ហ្នឹងវរសេនាធំ គាត់ទ័ព។ ស.៖ អីចឹងមានការអីមកតាម អ៊ំញ៉ាន់ ហ្នឹងបាន អ៊ំញ៉ាន់ ទៅអ៊ំមុត? ឆ.៖ ទៅ អ៊ំមុត ទៀតទៅ"]។

1851 ឯកសារ D114/113 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម ម៉េន ឆ.១២៦ ["នៅឆ្នាំ ១៩៧៧ [...] នៅកងពល ១៦៤វិញ មានមនុស្សមកជំនួសអ្នកទាំងនោះ ដូចជា បងញ៉ាន់ ជាដើម និងម្នាក់ទៀតខ្ញុំភ្លេចឈ្មោះហើយ មកធ្វើជាអនុរបស់ មាស មុត"]។ ឯកសារ D234/2.1.92 ប្រតិចារឹក ព្រុំ សារ៉ាត ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 15.03.11-15.09.33 និង ឯកសារ D234/2.1.93 ប្រតិចារឹក ព្រុំ សារ៉ាត ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 09.16.07-09.22.33 [ផ្តល់សក្ខីកម្មថា សមាជិកគណៈកងពល ១៦៤ រាប់ទាំងឈ្មោះ គឹម ញ៉ាន់]។ ឯកសារ D22.2.181 បទសម្ភាសន៍ មាស មុត អ្នកទោសសង្គ្រាម/អ្នកបាត់ខ្លួនក្នុងពេលបេសកកម្ម សហអាមេរិក KH 00741996-00741998 ["គណៈបញ្ជាការនៃកងពលធំលេខ ៣ រួមមាន [...] ញ៉ាន ជាសមាជិកនៃគណៈកម្មាការទទួលបន្ទុកភស្តុភារ"]។ ឯកសារ D114/16 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក វណ្ណា ឆ.១ ["តា ញ៉ាន់ គឺជាអនុប្រធានរបស់តាមុត ដែលមេបញ្ជាការកងពល១៦៤"]។ ឯកសារ D114/79 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី

**មាស មុត** នៅកំពង់សោម[1852] ហើយជារឿយៗ គេឃើញថា គាត់បានធ្វើជាតំណាងឱ្យកងពល[1853]។ មកត្រឹមចុងឆ្នាំ ១៩៧៨ **មាស មុត** ចាត់តាំង គឹម ញ៉ាន់ ទៅក្រចេះ កាន់នាទីជាលេខាកងពល ១១៧ បន្ទាប់ពីគាត់បានបោសសម្អាតថ្នាក់ដឹកនាំមុនៗនៃកងពលនេះ[1854]។

---

កង ស៊ុ ឆ.២២៩ ["តាញ៉ាន់ គឺជាអនុកងពល ១៦៤ ជាអ្នកក្ដាប់ខាងភស្ដុភារ"]។ ឯកសារ D54/73 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មុត ម៉ៅ ឆ.៦៉ ៩៉ ១៦ [នៅក្នុងគណៈកងពល ១៦៤៖ "មានគ្នាបីនាក់ គឺមាន តា មុត៉ តា សារឿន៉ និង តា ញ៉ាន់ [...] ឆ.៩៖ តា សារឿន ក្រោយមកត្រូវបានបញ្ជូនទៅធ្វើការនៅផែកំពង់សោម [...] ឆ.១៦៖ បន្ទាប់ពី តា សារឿន ត្រូវបានបញ្ជូនទៅធ្វើការនៅកំពង់ផែ តា សេង បានមកដល់។ អំឡុងពេលដែល មាស មុត អវត្តមាន គឺមាន តា សេង និង តា ញ៉ាន់"]។ ឯកសារ D114/103 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លៀត ឡូន ឆ.២៥៉ ១១១ ["ស.៖ តើមានអ្នកណាផ្សេងទៀត ជាសមាជិកកងពល? ឆ.២៥៖ ញ៉ាន់ (ស្លាប់)។ គាត់ជាមនុស្សមកពីកងពលទី៣ [...] ឆ.១១១៖ ឈ្មោះ ឡូន (ស្លាប់) និងឈ្មោះ ញ៉ាន់ (កាន់ភស្ដុភារកងពលលេខ៣)"]។ ឯកសារ D2/16 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទូច សឿលី ហៅ សឿ ទូច ឆ.១២ ["នៅពេលនោះ មាស មុត មានមុខងារជាប្រធានកងពល ហើយ តា ញ៉ាន ជាសមាជិកកងពល"]។

1852 ឯកសារ D54/73 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មុត ម៉ៅ ឆ.៨ ["ពួកគាត់ទាំងអស់គ្នាស្នាក់នៅបរិវេណក្នុងមន្ទីរ ប៉ុន្តែនៅផ្ទះផ្សេងៗគ្នា។ ពួកគាត់ហូបបាយនៅផ្ទះបាយរួម ហើយពេលខ្លះនិរសារបស់ពួកគាត់មកលើកម្ហូបអាហារយកទៅឱ្យគាត់ហូបនៅផ្ទះរបស់ពួកគាត់រៀងៗខ្លួន"]។

1853 ឯកសារ D114/66 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.១៩ ["ពេលខ្ញុំមកដល់ទីកសាបដំបូង ក្នុងឆ្នាំ ១៩៧៧ តាជន ជាអ្នកទទួលខុសត្រូវនៅទីនោះ។ តាជន គឺជាមេបញ្ជាការវរៈសេនាធំលេខ៦៣ ហើយ តាញ៉ាន់ គឺជាអនុរបស់គាត់ [...] ជន ត្រូវបានចាប់ខ្លួន ហើយ ញ៉ាន់ ឡើងជំនួស ជន [...] ខ្ញុំតែងតែឃើញគាត់តំណាងឱ្យកងពលរាល់ពេលប្រជុំ នៅចុងរយៈពេលនៃចុងរបបខ្មែរក្រហមនោះ"]។

1854 សូមមើល ផ្នែក VIII.I. ការបោសសម្អាតនៅកងពល ១១៧ និងតំបន់ ៥០៥ - ៣. ការបោសសម្អាត៉ ការដាក់ជំនួស៉ ការគ្រប់គ្រង។ សូមមើលបន្ថែម ឯកសារ D114/18 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ាក ឈឿន ឆ.១៦-១៧ ["រហូតទៅដល់ជិតចុងបញ្ចប់របបខ្មែរក្រហម គឺខ្ញុំបានឈប់រាយការណ៍ទៅឱ្យតាញ៉ាន់ ទៀតហើយ ដោយសារពេលនោះ តាញ៉ាន់ ត្រូវបានបញ្ជូនចេញទៅបាត់។ ខ្ញុំគិតថា គាត់ត្រូវគេបញ្ជូនឱ្យទៅវ៉ៃជាមួយវៀតណាមនៅតាមព្រំដែន នៅខេត្តតាកែវ [...] ស.៖ តើលោកអាចរកនឹកមើលឱ្យបានច្បាស់ដែរឬទេ ពីពេលវេលាដែលតាញ៉ាន់ ចាកចេញពីកំពង់សោម? ឆ.១៧៖ ខ្ញុំមិនអាចប្រាប់ ឬប៉ាន់ស្មានពីពេលវេលានេះបានទេ។ ខ្ញុំគ្រាន់តែដឹងថា គឺមានរយៈពេលខ្លីមុនពេលវៀតណាមចូលមកដល់ តាញ៉ាន់ ត្រូវបានបញ្ជូនចេញពីកំពង់សោម ដែលអាចទៅវ៉ៃជាមួយវៀតណាមនៅតាមព្រំដែន នៅខេត្តតាកែវ"]។ ឯកសារ D54/110 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លុន សេង ឆ.៥-៧ ["ញ៉ាន់ គឺជាមនុស្សម្នាក់ដែលបានទៅក្រចេះជាមួយ មាស មុត [...] ឆ.៦៖ នៅពេលនោះ ដោយសារកងទ័ពវៀតណាមបានចូលមកដល់តំបន់ក្រចេះហើយ ដូច្នេះ តា មុត ទៅទីនោះ ដើម្បីវ៉ៃពួកវៀតណាម។ ដូច្នេះ មាស មុត ត្រូវតែនាំទៅជាមួយគាត់ដូចជា ញ៉ាន់៉ បញ្ជាការកងពិសេស៉ និងបញ្ជាការផ្សេងៗទៀតដែលគាត់ជឿទុកចិត្ត។ ខ្ញុំបានដឹងអំពីរឿងពួកអ្នកទាំងនេះទៅក្រចេះ ពីព្រោះនៅពេលប្រជុំ មេបញ្ជាការរបស់ខ្ញុំបានធ្វើការប្រកាសប្រាប់ពួកយើង អំពីឈ្មោះថ្នាក់ដឹកនាំណាទៅ

# ឧក្រិដ្ឋកម្ម

## ការដាក់ក្នុងមន្ទីរឃុំឃាំង និងការឃុំខ្លួនដោយខុសច្បាប់

491. មន្ទីរសន្តិសុខទឹកសាប ត្រូវបានប្រើប្រាស់ដោយកងពលធំលេខ ១៦៤ ដើម្បីឃុំខ្លួនទាំងយោធា និង ជនស៊ីវិល ដែលពួកគេចាត់ទុកថាជា "ខ្មាំង" របស់បដិវត្តន៍។

492. *ការដកហូតសេរីភាពដោយគ្មាននីតិវិធីត្រឹមត្រូវតាមច្បាប់៖* ដូចបានរៀបរាប់ខាងលើ[1855] មិនមាន ភ័ស្តុតាងគួរឱ្យទុកចិត្តដែលថា អ្នកដែលត្រូវបានចាប់ខ្លួន និងឃុំឃាំង និង/ឬសម្លាប់ដោយកងពល ធំលេខ១៦៤ មានពិរុទ្ធភាពនៃបទល្មើសណាមួយនោះឡើយ។ ក្នុងករណីណាក៏ដោយ គ្មាន ជនរងគ្រោះណាម្នាក់អាចទទួលបាន សូម្បីតែនីតិវិធីត្រឹមត្រូវតាមច្បាប់បន្តិចបន្តួចក៏ដោយ។

493. *ប្រភេទអ្នកជាប់ឃុំ៖* អ្នកទោសនៅទឹកសាប មានទាំងយោធា និងជនស៊ីវិល[1856]។

---

កន្លែងណាខ្លះ។ ស.៖ តើលោកដឹងថា មានយោធាចំនួនប៉ុន្មាននាក់ទៅក្រចេះជាមួយ មាស មុត? ឆ.៧៖ យោធាភាគ ច្រើននៃកងជើងគោករបស់កងកម្លាំងកងទ័ពជើងទឹកត្រូវបានបញ្ជូនទៅក្រចេះទៅរើជាមួយ តាមុត លើកលែងតែអ្នក កាន់នាវា"]។ ឯកសារ D114/193 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សារុន ឆ.៦៤ ["អាហ្នឹងឮតែគេថា ថាគាត់ជាកងពលជើងទឹកមកក្រចេះហ្នឹង មកចាប់មកចងហ្នឹង ពេលវៀតណាមចូលមក នៅ៧ មករា រឿងហ្នឹងក៏ចប់ ទៅ"]។ ឯកសារ D54/29 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀត ឡុន ឬ ណាំ ឡុន ឆ.១៤-១៥ ["បន្ទាប់ពី បែកឆ្នាំ ១៩៧៩ ខ្ញុំបាននិយាយជាមួយយោធានៃកងពល១៦៤ ខ្លះ ដែលបានរត់មកនៅនឹងព្រំដែនថៃ។ ពួកអ្នកទាំងនោះ បានប្រាប់ថា មានកន្លែងជាច្រើនដែលគេត្រូវបានបញ្ជូនទៅរើ [...] តែខ្ញុំមិនចាំឈ្មោះទីកន្លែងទាំងអស់នោះទេ តែខ្ញុំបាន ចាំតែឈ្មោះខេត្តតែនិញមួយប៉ុណ្ណោះ។ [...] ឆ.១៥៖ ខ្ញុំដឹងថាមេបញ្ជាការនៅសមរភូមិដែលទៅរើជាមួយគេនោះ គឺ មាន តា ញ៉ាន់ និង តា ឡុន ដែលទៅពីកងពល១៦៤ ដែរ។"]។

1855 សូមមើល ផ្នែក VIII.គ.២ ការចាប់ខ្លួន និងការឃុំខ្លួននៅក្នុងមន្ទីរសន្តិសុខកងពល ១៦៤ - ការខ្វះដំណើរការត្រឹមត្រូវ តាមច្បាប់។

1856 ឯកសារ D54/20 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ឆ.១១ ["ជនរងគ្រោះដែលគេបញ្ជូនទៅទីនោះគឺ ជាយុទ្ធជនមកពីកងពល១៦៤ ហើយក៏មានជនស៊ីវិលផងដែរ"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់ ប៉ាក សុខ ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា KH 000955510 ["មានគេចាប់មកដាក់កន្លែងទឹកសាប [...] កន្លែហ្នឹងគេដាក់គុក មិនថាកងទ័ពមិនថាប្រជាជនអីទេ"]។ ឯកសារ D54/20 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ឆ.១២ ["បានឮពីគេថា កាលណាគេចាប់ឬមានអ្នកបាត់ខ្លួន គេយកអ្នកទាំងនោះទៅដាក់នៅគុកទឹកសាប [...] សម័យនោះ អ្នកណាក៏មានសិទ្ធិចាប់និងសម្លាប់មនុស្សពាសវាលពាសកាលដែរ។ ខ្ញុំក៏មានការភ័យខ្លាចគេចាប់យកទៅសម្លាប់ដែរ"] ។ ឯកសារ D114/242 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ប៊ុននី ឆ.១០១-១០២ ["គុកនេះមិនសម្រាប់ដាក់

### *ក) កម្មាភិបាលកងពលធំលេខ ១៦៤ និងទាហានរំសាយ*

494. កម្មាភិបាលកងពលធំលេខ១៦៤ ដែលត្រូវបានចោទប្រកាន់ពីបទថាបានប្រព្រឹត្ត "កំហុស" ឬប្រព្រឹត្ត "បទល្មើស" តូចតាច ឬធ្ងន់ធ្ងរ[1857] បានរិះគន់គោលនយោបាយរបស់របបនេះ[1858] ឬបាន

តែប្រជាជនទេ គឺទុកសម្រាប់កងទ័ពផង និងប្រជាជនផង គឺគុករួម។ [...] ឆ.១០២៖ កន្លែងមូលដ្ឋានកងទ័ព ដូច្នេះបើប្រជាជនធ្វើខុស គេយកទៅកន្លែងនុំងហើយ"]។

1857 ឯកសារ D114/297.1.20 ប្រតិចារឹក ប៉ាក សុខ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 10.46.23-10.51.34, 13.58.05-14.14.44 [ផ្តល់សក្ខីកម្មថា យោធាដែលជាយុទ្ធមិត្តនៅក្នុងកងវរៈសេនាធំនៃកងពល ១៦៤ ត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅកាន់ទឹកសាប ដោយសារតែសរសេរពាក្យ "ទមិឡកុម្មុយនីស្ត"។ សាក្សីនោះបានពន្យល់ថា "ជាទូទៅឃើញថា យោធាទាំងអស់ ដែលខ្ញុំធ្លាប់ស្គាល់ហើយធ្លាប់ដឹង យោធាដែលនៅក្នុងរង្វង់កងពល ១៦៤ឃើញថា ជាទូទៅឃើញថា បើអ្នកមានសកម្មភាពៗប្រឆាំងអ្វីមួយ គឺថាមិនថាកងវរសេនាធំ ៦១៤ ៦២៤ ៦៣៤ ៦៤ អីទេ គឺថាចាប់យកទៅដាក់នៅទីកន្លែងនោះទាំងអស់ បើថាទោសធ្ងន់ យកទៅដាក់នៅទឹកសាបតែម្តង"]។ ឯកសារ D54/27 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ឆ.៦ ["ក្នុងចំណោមក្រុមអារឈើរបស់យើងមានយោធាបីនាក់ [...] បានសរសេរនៅលើឈើថា "ទមិឡ"។ ពេលនោះមេបញ្ជាការវរៈបានដើរមកកន្លែងធ្វើការរបស់យើង ហើយបានឃើញពាក្យនោះ។ ក្រោយមក គាត់បានហៅយោធាទាំងបីនាក់យកទៅឃុំនៅកន្លែងមន្ទីររបស់វរសេនាតូច។ [...] ថ្ងៃមួយពេលដែលខ្ញុំដើរទៅធ្វើការ យោធាទាំងបីនាក់នោះ ត្រូវបានដាក់ច្រវាក់នឹងឯកជើង ដែលកំពុងធ្វើការនៅជិតទឹកសាប"]។ ឯកសារ D54/98 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ាង រ៉េត ឆ.១៣៨-១៣៩ ["ក្នុងករណីដែលកំហុសនោះធ្ងន់ធ្ងរ បុគ្គលនោះនឹងត្រូវបញ្ជូនទៅមន្ទីរអប់រំកែប្រែនៅទឹកសាប [...] ឆ.១៣៩៖ ក្នុងករណីដែលបុគ្គលណាមួយមានកំហុស ហើយបន្ទាប់ពីណែនាំ៣ដង បុគ្គលនោះនៅតែមិនកែប្រែ គេចាត់ទុកបុគ្គលនោះប្រព្រឹត្តកំហុសធ្ងន់ ហើយត្រូវបញ្ជូនទៅទឹកសាប"]។ ឯកសារ D54/35.1 កិច្ចសម្ភាសន៍របស់ ប្រាក់ សុខា ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា KH 00964251-00964252 ["ស.៖ ចឹងនៅក្នុងអង្គភាពពូក្រោយមកមានបាត់ខ្លួនមានចាប់ខ្លួនខ្លះទេមានទេ? ឆ.៖ មានហើយកងអ្នកមានកំហុសកងចល័តអីបាត់ខ្លួនគេយកទៅកសាងទឹកសាបទឹកអីទៅ កាលហ្នឹងដឹងថាអង្គការយកទៅកសាង។ [...] ហ្នឹងនៅទឹកសាបនៅក្បាលស្ពានទឹកសាប ឃើញគេបញ្ជូនមកខាងហ្នឹងគេយកមកទឹកសាបហ្នឹងហើយ"]។ ឯកសារ D54/37 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹម នី ឆ.៤ ["ដូចខ្ញុំបាននិយាយពីខាងដើម គេបែងចែកអ្នកទោសតាមកំរិតនៃកំហុសដែលគេប្រព្រឹត្ត។ សម្រាប់អ្នកទោសធ្ងន់ ត្រូវបានគេបញ្ជូនទៅដាក់នៅទឹកសាប ឯអ្នកទោសស្រាលត្រូវបានគេយកមកដាក់ឃុំនៅវត្តន្ទញាណ"]។ ឯកសារ D54/20 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ឆ.១២ ["ខ្ញុំបាននៅឯកោះឆ្លាយ ប៉ុន្តែបានឮពីគេថា កាលណាគេចាប់មនុស្សឬមានអ្នកបាត់ខ្លួន គេយកអ្នកទាំងនោះទៅដាក់នៅគុកទឹកសាបនោះដែលជាគុកថ្នាក់តំបន់ដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ មាស មុត"]។ ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.២៣ ["ទឹកសាប គឺជាគុករបស់កងពល១៦៤ ដែរសម្រាប់អ្នកដែលអ្នកទោសធ្ងន់ៗ។ គេឃុំឃាំងកូនយោធាដែលមានទោសធ្ងន់នៅទឹកសាប"]។ ឯកសារ D54/117 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស សារ៉ាន ឆ.៥៥៤ ៥៦៤ ៦៩ [ប្រពន្ធយោធាកងពល ១៦៤៖ "ខ្ញុំឮគេថា កន្លែងស្ពានហ្នឹង គឺជាគុក សម្រាប់ដាក់អ្នកទោសដែលមានកម្រិតធ្ងន់ជាងអ្នកដែលនៅសហករណ៍ពុតទេ។ ហើយខ្ញុំឮ

តវ៉ាប្រឆាំងនឹងការងារ[1859] ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរសន្តិសុខទឹកសាប។ ជាទូទៅ កូនទាហាន ត្រូវបានឃុំខ្លួននៅគុកទឹកសាប ជាជាងបញ្ជូនទៅមន្ទីរ ស-២១[1860]។ មេបញ្ជាការកងវរសេនាធំលេខ ២១/១៦២[1861] ឈ្មោះ អៀក មៀញ (ឬ មាញ) ត្រូវបានឃុំខ្លួននៅទីនោះផងដែរ[1862]។

---

គេថា អ្នកទោសធ្ងន់ជាងនេះ គេយកទៅដាក់នៅក្រាំងស្តែង [...] ឆ.៥៦៖ ក្រាំងស្តែង ជាគុកដែរ ប៉ុន្តែខ្ញុំមិនដឹងថា នៅឯងណាទេ។ ខ្ញុំដឹងតាម ញ៉ូន ជាមិត្តភក្តិខ្ញុំប្រាប់ថា៖ ប្តីឯងជាប់គុកនៅកំពុងសោម ចំណែកប្តីរបស់ខ្ញុំជាប់គុកធំក្រាំងស្តែង។ [...] ឆ.៦៩៖ ខ្ញុំដឹងថា ប្តីរបស់ខ្ញុំជាប់នៅគុកទឹកសាបនោះ"]។ ឯកសារ D114/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ឆ.៩២-៩៣ ["កាលហ្នឹង បើសិនជា មានទោស គេបញ្ជូនទៅគុក [...] ឆ.៩៣៖ គុកហ្នឹងនៅស្ពានទឹកសាប"]។ សូមមើលផងដែរ ឯកសារ D114/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ឆ.៥៧៤ ៦០៤ ៦៣៤ ១៣៩ [ប្រពន្ធយោធាកងពល ១៦៤៖ "ស.៖ នៅក្នុងពាក្យបណ្តឹងរបស់លោកស្រី លោកស្រីនិយាយថា គេចាប់ប្តីរបស់លោកស្រីទៅដក់គុកនៅទឹកសាប។ តើត្រឹមត្រូវដែរឬទេ? ឆ.៥៧៖ ចាស ត្រឹមត្រូវ។ គាត់ត្រូវបានចាប់ដាក់គុកនៅទឹកសាបពីរដង [...] ឆ.៦០៖ មានពាក្យចចាមអារាមនិយាយថា គេយកគាត់ទៅដាក់គុកទឹកសាប ហើយខ្ញុំបានសួរនាំគេបន្តៗទៀត ហើយដឹងថា គេចាប់គាត់ដាក់គុកនៅទីនោះមែន [...] ឆ.៦៣៖ គាត់បានប្រាប់ខ្ញុំថា គាត់បានឃើញប្តីខ្ញុំជាបគុកនៅទឹកសាប [...] ឆ.១៣៩៖ ខ្ញុំសូមបញ្ជាក់ថា ប្តីខ្ញុំជាប់គុកនៅទឹកសាប"]។

1858 ឯកសារ D54/27 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ឆ.៩ ["យោធារបស់កងពល១៦៤ ដែលមានកំហុសតិចតួចត្រូវបានឃុំខ្លួននៅទីនោះ។ ដូចជាពួកយោធា ដែលទិតៀនគោលនយោបាយនៃរបបនោះ"]។ ឯកសារ D114/242 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ប៊ុនធី ឆ.៨២ ["ខ្ញុំឮសួរមេៗខ្ញុំនិយាយថា សុទ្ធតែកងទ័ពខុសនយោបាយ ខុសអី"]។

1859 ឯកសារ D54/36 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ឆ.៣១ ["គេបានប្រាប់យើង ថាយើងត្រូវតែធ្វើតាមផែនការអង្គការ។ បើយើងតវ៉ា យើងនឹងត្រូវបញ្ជូនទៅទឹកសាប។ បើយើងមិនអាចបញ្ចប់ការងាររបស់យើងបាន គេធ្វើការតិះទៀនយើង ហើយបញ្ជូនយើងឲ្យទៅធ្វើបន្តរហូតទាល់តែចប់ បើយើងតវ៉ា គេនឹងបញ្ជូនយើងទៅទឹកសាប"]។

1860 ឯកសារ D114/86 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.៧ ["ប្រសិនបើគេឆ្លើយដាក់យើង គឺគេច្បាស់ជាបញ្ជូនយើងទៅភ្នំពេញ ឬទឹកសាបហើយ អាស្រ័យទៅតាមករណីធ្ងន់ ឬស្រាល"]។ ឯកសារ D114/32 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស សាវ៉ាន ឆ.៨៩ ["អ្នកធំៗហ្នឹងគឺបានត្រូវគេចាប់ទៅដាក់គុកក្រាំងស្តែង មិនមែនទួលស្លែងទេ តែពួកទាហានថ្នាក់ក្រោមដូចប្តីខ្ញុំជាដើម គេយកទៅឃុំនៅគុកទឹកសាប នៅកំពង់សោម"]។ ឯកសារ D114/194 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ន សុត ឆ.៣៩ ["ហើយអ្នកធំៗគេមិនយកទៅដាក់នៅហ្នឹងទេ គឺគេយកទៅដាក់កន្លែងផ្សេង"]។

1861 សូមមើល ឧ. ឯកសារ D1.3.30.5 របាយការណ៍របស់សេនាធិការកម្ពុជាប្រជាធិបតេយ្យ តារាងស្ថិតិសិក្ខាកាម រៀនវគ្គសេនាធិការលើកទី ១ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៧៦ KH 00095536-00095537 [ចុះបញ្ជីសមមិត្ត អៀក មាញ ជាលេខាវរៈសេនាធំនៅក្នុងកងពល ១៦៤]។ ឯកសារ D114/132 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ៅ វ៉ាន់ ឆ.៣០ ["ស.៖ តើនរណាជាមេបញ្ជាការវរសេនាធំលេខ២១? ឆ.៣០៖ ឈ្មោះ តាមាញ"]។ ឯកសារ D54/20

ដូចបានពិភាក្សាក្នុងផ្នែកខាងលើ[1863] ប្រធានមន្ទីរពេទ្យកងពលធំលេខ ១៦៤ ឈ្មោះ ស៊ឹម នាម ហៅ សុក (សុខ) និងប្រពន្ធរបស់គាត់ ក៏ត្រូវបានបញ្ជូនទៅទឹកសាបផងដែរ មុនពេលបញ្ជូនទៅកាន់មន្ទីរ ស-២១ ដើម្បីសម្លាប់[1864]។

---

កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ឆ.៧ ["មេបញ្ជាការវរៈសេនាធំ២១ដំបូងឈ្មោះ មាញ តែក្រោយមកទៀត ខ្ញុំមិនបានដឹងថាជាអ្នកណាមកជំនួសគាត់ទេ"]។ ឯកសារ D114/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារ៉ាត់ (ប៊ុន សារ៉ាត់) ឆ.១៨ ["ព្រោះ១៥ ជាវរសេនាធំរបស់បញ្ជាការឈ្មោះ មេង"]។ ឯកសារ D2/8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សយ ប៊ិន ឆ.៤៥ ["ឈ្មោះ មាញ ជាស្នងការកងវរៈសេនាធំ២១ ឬ៦២ [...] ស្នងការ គេមិនដូរទេ គឺនៅដដែល តាំងពីមុនពេលភ្នំពេញបែក និងក្រោយភ្នំពេញបែក"]។

1862 ឯកសារ D54/20 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ សោម ហៅ សំ កេត ឆ.៨-៩ ["គឺជាកងវរៈសេនាតូចនៃកងវរៈសេនាធំ២១ [...] មាញត្រូវបានគេបញ្ជូនទៅរៀនសូត្រក្នុងឆ្នាំ ១៩៧៧ ប៉ុន្តែខ្ញុំបានចាំថា គេដាក់គុកគាត់នៅគុកទឹកសាប [...] ស.៖ ហេតុអ្វីបានជាលោកដឹងថា មាញត្រូវបានគេបញ្ជូនទៅគុកទឹកសាប? ឆ.៩៖ ក្នុងឆ្នាំ ១៩៨១ ឬ១៩៨២ ខ្ញុំបានដឹងរឿងនេះពីឈ្លបស្វាយ សំអាន ដែលជាអ្នកយាមគុកនៅទឹកសាប។ សំអានបានប្រាប់ខ្ញុំថា គេចាប់តាមាញដាក់គុកនៅទីនោះ។ ខ្ញុំបានសួរសំអានថា តើគាត់ដឹងអ្វីខ្លះពីតាមាញ? ខ្ញុំមិនបានសួរគាត់ថា គុកទឹកសាបនោះ ឋិតនៅកន្លែងណាទេ ហើយក៏មិនបានដឹងថា គេសម្លាប់តាមាញនៅទីណាដែរ"]។ សូមមើលផងដែរ ឯកសារ D114/113 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គីម ម៉េន ឆ.៩២ ["ស.៖ តើតាមាញ ដូរចេញពេលណា? ឆ.៩២៖ នៅឆ្នាំ ១៩៧៦ ហើយដាក់ឈ្មោះ យាង ចូលវិញ។ គាត់ដូរមកកំពង់សោម"]។ ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៤៥-៤៨ ["ស.៖ តើមេកងដែលទទួលលើកោះតាងឈ្មោះអ្វី? ឆ.៤៥៖ គាត់ឈ្មោះ មៀញ គាត់ជាស្នងការនយោបាយកងវរៈសេនាធំ៦២។ ក្រោយមក គាត់ត្រូវបាន តាមុត ចាប់ខ្លួន [...] ឆ.៤៦៖ តាមខ្ញុំដឹង មៀញ ត្រូវបានចាប់ខ្លួន ហើយ បញ្ជូនទៅភ្នំពេញ [...] ឆ.៤៧៖ ក្រោយមក ពួកមេៗបាននិយាយថា មៀញ ក្សត់ហើយ [...] ឆ.៤៨៖ នៅក្នុងឆ្នាំ ១៩៧៧"]។ ឯកសារ D114/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ឆ.២០៧ ["ខ្ញុំស្គាល់គាត់ តែខ្ញុំមិនដឹងថាមានរឿងអ្វីកើតឡើងចំពោះគាត់ទេ តែខ្ញុំគ្រាន់តែដឹងថាគាត់បានបាត់ខ្លួន"]។

1863 សូមមើល ផ្នែក VIII.គ.១ បណ្តាញមន្ទីរសន្តិសុខ - ខ) បណ្តាញដ៏ធំធេងនៃកម្ពុជាប្រជាធិបតេយ្យ។

1864 ឯកសារ D114/130 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ភង់ ឆ.១០៩ ["គេដាក់ តាសុខ នៅគុកទឹកសាប។ គាត់ជាពេទ្យខ្មែរក្រហម។ គាត់ធ្លាប់ធ្វើប្រធានវះកាត់នៅកំពង់សោម"]។ ឯកសារ D54/117 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស សារ៉ាន ឆ.១១-១២៌ ១៨ ["អំពីមន្ទីរពេទ្យនៅចម្ការចេក។ តើអ្នកណាជាប្រធានពេទ្យ? ឆ.១១៖ ប្រធានពេទ្យឈ្មោះ សុខ [...] ឆ.១២៖ គាត់នៅបានប៉ុន្មានខែ គេចាប់គាត់យកទៅដាក់គុកនៅស្ពានទឹកសាបកំពង់សោម នៅចុងឆ្នាំ ១៩៧៥ [...] ឈ្មោះ ហោ មកជំនួស សុខ នៅដើមឆ្នាំ ១៩៧៦ [...] ឆ.១៨៖ នៅពេលដែលគេឲ្យខ្ញុំទៅនៅសហករណ៍មួយ ហើយនៅសហករណ៍នោះមានកូន សុខ នៅជាមួយដែរ ហើយកូន សុខ ជាអ្នកប្រាប់ខ្ញុំថា គេចាប់សុខ និងប្រពន្ធរបស់គាត់ ទៅដាក់នៅស្ពានទឹកសាម"]។ ឯកសារ D114/155 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ រ៉េន ឆ.៦១ ["ខ្ញុំឮព័ត៌មានថា មានគុកនៅទឹកសាប ទី២ នៅស្ទឹងហាវ ដែលប្រើសម្រាប់ដាក់អ្នកជាប់ពាក់ព័ន្ធនឹងនយោបាយ។ [...] ក្នុងនោះ ឮព័ត៌មានថា គេចាប់ បងរី ដែលជាប្រពន្ធពេទ្យ សុខ ដាក់គុកនៅទឹកសាប តែអត់

495. យោងតាមគោលនយោបាយរបស់ ប.ក.ក ក្នុងការ "ជីកឫសគល់"នៃបណ្ដាញដែលត្រូវបានសន្មតថាជាខ្មាំង ដូចជា សមាជិកនៃគណៈកម្មាធិការកងពលធំលេខ១៦៤ ដែលត្រូវបានបោសសម្អាត ឈ្មោះ នង ឆាន់ ឬ ហ៊ីង ខឿន ហៅ ខឹម គ្រាន់តែជាប់ពាក់ព័ន្ធជាមួយមេបញ្ជាការ ឬកម្មាភិបាលដែលត្រូវបានបោសសម្អាតម្នាក់ អាចជាសំបុត្រទៅទឹកសាប។ យោងតាមសាក្សី ឯក នី ទាហាននារីចំនួន ២០ នាក់ ដែលកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយ ឆាន់ ជាចុងភៅ ជំនួយការ ឬនីរសារ ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខទឹកសាប[1865]។

496. កម្មាភិបាលជាច្រើនដែលត្រូវបានចាត់ទុកថាជា "សមាសភាពមិនល្អ" ពីកងពលធំលេខ១៦៤ ដែលពីមុនត្រូវបានដកហូតអាវុធ និងធ្វើឲ្យទៅជាទាសករសម្រាប់គោលបំណងកសាងខ្លួននៅតាមការដ្ឋាន ឬនៅតាមសហករណ៍នានា ដូចជា នៅរាម ឬកងកេង[1866] ត្រូវបានឃុំឃាំង និង/ឬសម្លាប់

---

ដឹងថា ពេទ្យ សុខ គេចាប់បញ្ជូនទៅណាទេ។ [...] ទាំងពីរនាក់ប្ដីប្រពន្ធស្លាប់អស់ហើយ។ សុខ អតីតប្រធានមន្ទីរពេទ្យតំបន់៣៧"]។

1865 ឯកសារ D54/103 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី ឆ.៣ ["បន្ទាប់ពីចាប់ថ្នាក់ដឹកនាំតំបន់៣៧ ហើយ បង នង ឆាន ដែលជាអនុរបស់ តាមុត នៃកងពល ១៦៤ គេលែងទុកចិត្តយោធាដែលនៅពីក្រោមបង នង ឆាន ទៀតហើយ។ [...] មានក្រុមនារីក្រមុំប្រហែលជាង ២០ នាក់ ធ្វើការជាប់ជាមួយបង នង ឆាន ក្នុងនាមជាចុងភៅ និរសា និងជំនួយការរបស់គាត់។ ក្រោយពីគេចាប់បង ឆាន នារីទាំងអស់នោះត្រូវបានយកទៅដាក់គុកនៅទឹកសាប ដោយមានអ្នកយាមកាន់កាំភ្លើងជាប់រហូត។ ចំណែកពួកខ្ញុំមិនមានអ្នកយាមកាន់កាំភ្លើងចាំយាមជាប់រហូតនោះទេ។ ថ្ងៃមួយ ខ្ញុំបានឃើញពួកនារីទាំងនោះ នៅទឹកសាប នៅពេលដែលខ្ញុំត្រូវបានចាត់ឲ្យទៅធ្វើស្រែនៅក្បែរនោះ។ នៅពេលដែលខ្ញុំបានឃើញពួកនារីទាំងនោះភ្លាម ខ្ញុំប្រុងចូលទៅជិតដើម្បីសួរសុខទុក្ខ តែមេរបស់ខ្ញុំបានហាមមិនឲ្យទៅជិតទេ ព្រោះពួកនារីទាំងនោះជាពួកអ្នកទោស។ បន្ទាប់ពីជ័យជម្នះឆ្នាំ ១៩៧៩ ខ្ញុំបានជួបឪពុកម្ដាយពួកនារីម្នាក់ ឈ្មោះ ចាំ [...] មិនដែលបានឃើញត្រឡប់មកផ្ទះវិញទេ [...] នៅពេលនោះ ខ្ញុំបានឮថា នារីជាង ២០ នាក់ដែលគេចាប់ទៅទឹកសាបនោះ គឺត្រូវបានគេចោទថាជាស្រីកំណាន់របស់ ឆាន"]។

1866 សូមមើល ឧ. ឯកសារ D54/35 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រាក់ សុខា ឆ.១៩៨ ១៧ ["កងចល័តនោះ គឺមានអតីតៈយោធាកងពល ១៦៤ ណា ដែលចាត់ទុកថា សមាសភាពមិនល្អ កងចល័តនោះ គឺឋិតនៅក្រោមការគ្រប់គ្រងរបស់កងពល១៦៤ដដែល ហើយគេបញ្ជូនទៅឲ្យធ្វើការនៅកន្លែងមួយហៅថា ភូមិព្រៃកចាក ឋិតនៅប្រហែលពីរគីឡូម៉ែត្រខាងកើតផែរាម [...] ឆ.១៧៖ ក្នុងឆ្នាំ ១៩៧៧ តែខ្ញុំមិនចាំថ្ងៃទេ កងចល័តរបស់ខ្ញុំត្រូវបានដកចេញពីព្រៃកចាកមកតំបន់កងកេង ដែលគេឲ្យពួកយើងធ្វើការនៅភូមិប្របុស និងភូមិពូធឿង នៅខាងជើងផ្លូវជាតិលេខ ៤ ទល់មុខភូមិឋិតត្រាំង"]។ ឯកសារ D114/40 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មូល ឈិន ឆ.២៣-២៤ ["ស.៖ តើលោក និងអ្នកដទៃទៀតរាយការណ៍ឲ្យអ្នកណានៅទីតាំងលើកទំនប់នោះ? ឆ.២៣៖ នៅពេលនោះ យើងត្រូវតែរាយការណ៍ទៅឲ្យ គឿន ដែលជាមេកងវរៈក្រោមកងពលលេខ៣។ ស.៖ តើលោកអាចគូសបញ្ជាក់ឲ្យកាន់តែច្បាស់

ថែមទៀតទេថា តើកងវរៈនេះមានលេខប៉ុន្មាន? ឆ.២៤៖ កងវរៈនេះពុំមានលេខទេ។ គឿន ជាមេកងដែលមានអ្នកធ្វើការ៣០០នាក់។ វាគឺជាអង្គភាពចល័តដែលសមាជិកគឺជាយោធាដែលគេរំសាយចេញពីកងពលលេខ៣"]។ ឯកសារ D114/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.១៦ ["ចូលដល់ឆ្នាំ ១៩៧៧ ខ្ញុំក៏ត្រូវបានគេដកចេញហើយបញ្ជូនឲ្យទៅនៅកងផលិត។ កងផលិតរបស់ខ្ញុំ មានឈ្មោះថា កងវរៈសេនាតូចលេខ២០។ ខ្ញុំត្រូវបានគេចាត់តាំងឲ្យលើកទំនប់ និងជីកប្រឡាយ អស់រយៈពេលបួនខែ នៅកន្លែងស្នាច់ដែង និបបុស។ ខ្ញុំធ្វើការនៅទីនោះ រហូតដល់ខែកញ្ញា ឆ្នាំ ១៩៧៨ នៅពេលនោះ ខ្ញុំ ហើយនិងកងវរៈលេខ២០របស់ខ្ញុំ ត្រូវបានគេបញ្ជូនឲ្យទៅវាយថ្មនៅការដ្ឋានវាយថ្មស្ទឹងហាវ។ ខ្ញុំធ្វើការនៅទីនោះរហូតរៀតណាមចូលដល់"]។ ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.១៩ ["នៅពេលនោះ នៅក្នុងកងពល១៦៤ មានបីកងដែលគេចាត់ថា ជាកងសមាសភាពមិនល្អ។ ក្នុងចំណោមទាំងបីកងនេះ ពីរកង គឺកងវរៈសេនាតូចលេខ២០ និង ២១ ហើយមួយទៀត គឺជាកងអនុសេនាធំលេខ១៩។ កងទាំងបីនេះ ផ្ទុកពួកយោធាដែលចាត់ទុកថាជាសមាសភាពមិនល្អ"]។ កងអនុសេនាធំលេខ១៩ មានអតីតយោធាប្រហែលជា១០០នាក់ ដែលពួកទាំងនោះ គេចាត់ថា ជាពួកយោធាសេរី។ បញ្ជាការរបស់កងនេះ ឈ្មោះ តាថន [...] កាលពីពេលនោះ កងនេះ គឺស្ថិតនៅកន្លែងមួយ ហៅថា ស្រែណិប។ វរៈសេនាតូចលេខ២០ ស្ថិតនៅបបុសខាងលិច។ វរៈសេនាតូចនេះ ស្ថិតក្រោមបញ្ជាការរបស់ តារិត។ យោធាក្នុងកងនេះ គឺជាអតីតយោធា ដែលចេញពីតំបន់៣៧។ វរៈសេនាតូចលេខ ២១ ស្ថិតនៅបបុសខាងកើត។ កងនេះ ស្ថិតនៅក្រោមបញ្ជាការរបស់ តាខេង ។ នៅក្នុងកងនេះ មានមនុស្សជាង២០០នាក់ ដែលសុទ្ធតែជាអតីតយោធាមកពីភូមិភាគបូព៌ា"]។ ឯកសារ D114/297.1.20 ប្រតិចារឹក ប៉ាក សុខ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 14.07.12-14.14.44 ["ស.៖ អ្នកដែលមានប្រវត្តិរូបមិនល្អ ជាពិសេសអ្នកដែលមានបងប្អូនធ្វើការនៅក្នុងជួរកងទ័ព ឬក៏នៅក្នុងរដ្ឋបាលនៃរបបចាស់ហ្នឹង គឺថាគេដកចេញ។ ដកចេញហ្នឹងលោកចង់មានន័យថាយ៉ាងម៉េច? គេយកអ្នកទាំងអស់ហ្នឹងទៅណា? ហើយក្រោយមកមានរឿងអ្វីកើតឡើងទៀតចំពោះអ្នកទាំងអស់នេះ? ឆ.៖ នៅក្នុងកងពល១៦៤ របស់យើងខ្ញុំហ្នឹង តាមការក្តាប់ មានកងចល័តមួយ កងចល័តមួយគេហៅថា "កងតាចាយ" កងទ័ពយោធាដែលមានជាប់និន្នាការនយោបាយដែលមិនល្អ ឧទាហរណ៍ថា ខ្ញុំមានឪពុកម្តាយ គេឆ្លើយថា មានឪពុកម្តាយ ឬសាច់បងប្អូនហ្នឹងមានជាប់ដែលថាជា កា.ហ្សេ.បេ របស់យួន ឬមួយកា.ហ្សេ.បេ៤ សេ.អ៊ី.អា របស់អាមេរិកាំង គេលែងទុកចិត្តខ្ញុំហើយ គេដកខ្ញុំនេះឲ្យទៅកងចល័តហ្នឹង សម្រាប់ធ្វើស្រែទេ នៅផ្តិបបុស្ស នៅជិតស្នាច់ដែង។ កន្លែងនោះហើយជាកន្លែង ជាអ្នកជាប់និន្នាការជាប់នឹងនយោបាយ ហៅថាកម្ពែលចាស់ពីសម័យ។ [...] មានចំនួនច្រើនដែរ ប្រហែលជាបួនទៅ ៥០០នាក់ដែរ អាហ្នឹងកងតាចាយ ហ្នឹង គឺកងផលិត"]។ ឯកសារ D114/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ឆ.៧៥៖ ["សុទ្ធតែអ្នកដែលគេបញ្ជូនមកពីកោះមានប្រហែលជា ៥០-៦០នាក់"]។ ឯកសារ D54/43 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេង ឆ .១៩ ["កងផលិតធំ ដែលមានអតីតយោធារាប់ពាន់នាក់ ដែលចាត់ថាមានសមាសភាពមិនល្អ"]។ ឯកសារ D2/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ូង ជ្រោង ឆ.២៨ ["ទាហានទាំងនោះ គឺគ្រប់កងទាំងអស់ ដែលមកពីកងពលវរៈសេនាធំ២២។ នៅពេលដែលពួកគេមានបញ្ហាអី ឬក៏ទិន្នាការមិនល្អ គេនឹងត្រូវដកចេញពីវរសេនាធំ យកទៅដាក់នៅកងផលិតវិញ"]។ ឯកសារ D114/53 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក សុក ឆ.២១៨ ["ស.៖ មានប្រជាជនប៉ុន្មាននាក់ដែលធ្វើស្រែ? ឆ. ២១៨៖ មិនមានប្រជាជនស៊ីវិលច្រើនទេ ដល់ខែធ្វើស្រែមានទាហានច្រើននាក់ចុះមកជួយធ្វើ"]។ ឯកសារ D114/79.1 កិច្ចសម្ភាសន៍របស់ កង សុំ ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា KH

នៅទីកសាបដោយសារកំហុសតូចតាចបំផុត[1867]។ អតីតទាហានកងវរសេនាតូចលេខ៣៨៦ ម្នាក់ដែលធ្វើការនៅវាលស្រែនៅជិតរាម[1868] បានឃើញដោយផ្ទាល់ភ្នែកនូវយុទ្ធជនរំសាយដែលត្រូវបានចាប់ខ្លួនដោយសារបានប្រព្រឹត្តកំហុសតូចតាច។ ជនរងគ្រោះម្នាក់ត្រូវបានចាប់ខ្លួនពីបទលួចដំឡូង

---

01104491-01104492 ["ស.៖ ដល់ពេលមកធ្វើស្រែ ប្រជាជនដែលនៅជិតៗហ្នឹងអ្នកធ្វើ ឬកងទ័ពអ្នកធ្វើ? ឆ.៖ កងទ័ពអ្នកធ្វើ កងពល១៦៤។ ចាប់ពីចម្ការដូងចេងហេងមកត្បូង ទល់គ្នាគល់ស្ពានទឹកសាប"]។

1867 ឯកសារ D114/194 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ឆ.៣៩ [អតីតយុទ្ធជននៃកងវរៈសេនាតូច ៣៨៦ ដែលគេបានដកហូតអាវុធ និងបញ្ជូនទៅធ្វើស្រែ៖ "ស.៖ តើលោកដែលធ្លាប់ឮ ទីកន្លែងមួយឈ្មោះទឹកសាបដែរឬទេ?ឆ.៣៩៖ ចឹមិនដែល។ អាហ្នឹងជាកន្លែងសម្រាប់ដាក់អ្នកទោស។ ដាក់ពួកខ្ញុំ អ្នកធ្វើស្រែជាមួយខ្ញុំពេលដែលធ្វើខុសគេយកដាក់នៅហ្នឹង"]។ ឯកសារ D114/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៉ុណ្ណា ឆ.៥-៦ ["ពួកយើងត្រូវបានគេចាត់ទុកថាជាអ្នកទោសហើយ គឺគ្រាន់តែមិនឃុំឃាំង តែឲ្យយើងទៅលត់ដំ។ ប្រសិនបើគេពុំពេញចិត្តនឹងការងាររបស់យើង គឺគេនឹងបញ្ជូនយើងទៅទឹកសាបភ្លាមតែម្តង។ ចង់មានន័យថា ប្រសិនបើគេមិនពេញចិត្តនឹងឥរិយាបទយើង ការធ្វើការងាររបស់យើង ឬយើងត្អូញត្អែរអំពីការងារអ្វីមួយនោះ គឺគេនឹងបញ្ជូនទៅទឹកសាបភ្លាមតែម្តង [...] គេយកពួកយើងមកដាក់នៅមួយកន្លែង ដើម្បីត្រួតពិនិត្យ តាមដាន និងលត់ដំ។ និយាយទៅ គេប្រព្រឹត្តចំពោះពួកយើង អាក្រក់ជាងប្រជាជន១៧ មេសាទៅទៀត [...] ពួកគេបានត្រួតពិនិត្យពួកយើងយ៉ាងយកចិត្តទុកដាក់។ ដូច្នេះទេបើសិនជាយើងមានកំហុសតិចតួចក៏ដោយ គេនឹងយកយើងទៅដាក់ទោសភ្លាមតែម្តង [...] ឆ.៦៖ យើងទាំងអស់គ្នាដែលស្ថិតនៅក្នុងកងសមាសភាពមិនល្អនេះ ចាំក្នុងខួរក្បាលខ្លួនឯងជារហូតមកថា បើសិនជាយើងធ្វើអ្វីមួយខុស សូម្បីតែតិចតួច គេនឹងយកទៅដាក់ទោសភ្លាម។ កាលនោះខ្ញុំមានអាយុម្ភៃ ១៨ ឆ្នាំ ជាពេលវេលាដែលត្រូវហូបច្រើន ប៉ុន្តែពួកខ្ញុំពុំដែលហូបបានគ្រប់គ្រាន់នោះទេ។ ប្រសិនបើអ្នកណាម្នាក់មកយករបស់អ្វីមួយរបស់គេ ឬលួចរបស់គេ គឺគេយកទៅដាក់គុកភ្លាម។ ដូចខ្ញុំធ្លាប់ជម្រាបក្នុងសម្ភាសន៍លើកមុនហើយ អំពីការចាប់ខ្លួនមនុស្សបីនាក់ពីកន្លែងខ្ញុំទៅដាក់គុកនៅទឹកសាប គឺមានតែម្នាក់ទេដែលនៅរស់ត្រឡប់មកវិញ"]។ ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៉ុណ្ណា ឆ.១៩ ["នៅពេលណាដែលមានអ្នកណាម្នាក់នៅក្នុងកងសមាសភាពមិនល្អទាំងនេះ ធ្វើខុស គេនឹងត្រូវបញ្ជូនទៅឃុំខ្លួននៅទឹកសាប។ ពេលគេនៅក្នុងមន្ទីរឃុំឃាំងទឹកសាប ពួកអ្នកទោសទាំងនេះ ត្រូវបានគេដាក់ឲ្យធ្វើការនៅត្រើយខាងកើតស្ទឹង។ ចំណែកពួកខ្ញុំ ដែលនៅក្នុងកងទាំងបីនេះ ត្រូវបានគេដាក់ឲ្យធ្វើការនៅត្រើយខាងលិចស្ទឹង។"]។

1868 ឯកសារ D114/194 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ឆ.៥៤ ២២ ["កងទ័ពតំបន់ពិសេស កងវរសេនាតូច៣៨៦ ត្រូវបានបញ្ជូនទៅក្នុងកងពលធំទី៣ ក្រោយរំដោះឆ្នាំ ១៩៧៥។ ដល់ចុងឆ្នាំ ១៩៧៧ ឬដើមឆ្នាំ ១៩៧៧ បានចាប់មេបញ្ជាការទាំងអស់ចោទថាតំបន់ហ្នឹងក្បត់។ ក្រោយចាប់អស់ ក៏រំលាយពួកខ្ញុំ ហើយបញ្ជូនយកទៅធ្វើស្រែ។ [...] ឆ.២២៖ ខ្ញុំនៅធ្វើស្រែនៅព្រែកចាក និងនៅកោះសំពោចទៅខាងកើតរាម"]។

មួយមើម[1869]។ មនុស្សម្នាក់ទៀត ត្រូវបានចាប់ខ្លួនក្រោមលេសថាយកគាត់ទៅព្យាបាលធ្មេញ ដោយសារគាត់បានសម្លាប់គោមួយក្បាលដោយប្រើរនាស់របស់គាត់[1870]។ អតីតយុទ្ធជនកងវរសេនាតូចលេខ ៣៨៦[1871] គឺសាក្សី មូល ឈិន ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅកាន់មន្ទីរសន្តិសុខទឹកសាប ពីព្រោះគាត់បានព្យាយាមទៅសួរសុខទុក្ខឪពុកម្ដាយរបស់គាត់[1872]។ សាក្សីម្នាក់ទៀត បានឃើញទាហានតំបន់ ៣៧ ដែលត្រូវបានរំសាយ ត្រូវបានបញ្ជូនទៅធ្វើស្រែនៅស្នាច់ដែង ដែលបានព្យាយាមរត់គេចចេញពី"ការចាប់ខ្លួន ដាក់ខ្នោះ និងបញ្ជូនទៅទឹកសាប"[1873]។ ជាក់ស្ដែង

---

1869 ឯកសារ D114/194 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស៊ិន សុត ឆ.៦៦ ["ពេលគ្នាហូបអត់ឆ្អែត ពេលគ្នាលួចដកដំឡូង គេក៏ចាប់គ្នាចងបញ្ជូនទៅទឹកសាបបាត់ទៅ។ គាត់នោះឈ្មោះដែលគេហៅតៗគ្នាថា ឡក់តក់ៗ គាត់គឺជាអ្នកដែលគេដកចេញជាមួយខ្ញុំ"]។

1870 ឯកសារ D114/194 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស៊ិន សុត ឆ.៤៨ ["ចាប់ម្នាក់ដែលធ្វើការជាមួយខ្ញុំមានឈ្មោះថា ណឹង គេចាប់យកទៅ។ គាត់កំពុងភ្ជួរស្រែដោយគោ ស្រាប់តែគាត់បានវៃគោ១ក្បាលដល់ស្លាប់។ ហើយគាត់ត្រូវគេចាប់ខ្លួនយកទៅទឹកសាប ដោយគេនិយាយថា គាត់ត្រូវទៅព្យាបាលធ្មេញឈឺរបស់គាត់ ពេលនោះគាត់ឈឺធ្មេញ"]។

1871 ឯកសារ D114/31 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មូល ឈិន ឆ.១៣, ២២, ៨៩-៩០ ["ខ្ញុំស្ថិតនៅក្នុងអង្គភាព ៣៣៦ តំបន់៣៧ [...] ក្រោយខ្មែរក្រហមទទួលជ័យជម្នះនៅទីក្រុងភ្នំពេញ កងវរៈសេនាតូចរបស់ខ្ញុំ ត្រូវបានបញ្ចូលជាមួយកងវរៈសេនាតូចផ្សេងទៀត បង្កើតបានជាកងវរៈសេនាធំ៣៨៦ [...] ឆ.៨៩៖ ក្រោយមក គេបានរំសាយកងទ័ព ហើយប្រែក្លាយអង្គភាពយើងទៅជាកងផលិត ដោយឱ្យធ្វើស្រែ លើកទំនប់ និងជីកប្រឡាយ។ ស.៖ ហេតុអ្វីបានជាគេរំសាយអង្គភាពរបស់លោក? ឆ.៩០៖ គេចោទយើងជាខ្សែខ្មាំង ដោយសារមេកងវរៈរបស់ពួកយើងត្រូវបានគេចាប់យកទៅបាញ់សម្លាប់អស់ហើយ"]។

1872 ឯកសារ D114/31 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មូល ឈិន ឆ.១១៦ ["ស.៖ តើមូលហេតុអ្វី បានជាគេដាក់គុកលោក? ឆ.១១៦៖ នៅពេលមួយ ហើយកាលនោះ ខ្ញុំធ្វើការនៅកងផលិត នៅព្រែកចាក ក្បែររាម នៅឡើយ។ ដោយនឹកផ្ទះ និងឪពុកម្ដាយពេក ខ្ញុំបានលួចរត់ និងដើរកាត់ព្រៃ ១ថ្ងៃពេញ ដើម្បីទៅលេងឪពុកម្ដាយខ្ញុំ នៅឯភូមិកំណើត គឺភូមិតាទាត់ ក្បែរព្រៃនុប ចម្ងាយប្រហែល៩គីឡូម៉ែត្រពីកន្លែងធ្វើការរបស់ខ្ញុំ។ គេមកជួប និងសួរនាំខ្ញុំច្រើនដងនៅផ្ទះឪពុកម្ដាយខ្ញុំ ហើយចុងក្រោយ គេបានយកខ្ញុំទៅដាក់គុកតែម្ដង ដោយសារតែពួកគេស្គាល់ខ្ញុំ គេមិនវៃដំខ្ញុំទេ គ្រាន់តែយកទៅដាក់គុកតែប៉ុណ្ណោះ"]។ ឯកសារ D114/40 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មូល ឈិន ឆ.៣៩ ["គេយកខ្ញុំមកដាក់គុក ដោយគ្រាន់តែមានកំហុសតិចតួចប៉ុណ្ណោះ គឺគ្រាន់តែខ្ញុំចង់មកជួបឪពុកម្ដាយខ្ញុំ ដោយពុំមានកំហុសអ្វីធ្ងន់ធ្ងរនោះទេ"]។ សូមមើលផងដែរ ឯកសារ D114/31 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មូល ឈិន ឆ.១៦៥ ["សំណួរដែលគេតែងតែសួរខ្ញុំ គឺ "ហេតុអ្វីបានជាមកជាប់នៅទីនេះ?" ខ្ញុំក៏ឆ្លើយទៅវិញទាំងមិនខ្លាចរអាថា "អញទៅលេងម៉ែឪអញ ព្រោះអញខានជួបគាត់យូរមកហើយ""]។

1873 ឯកសារ D114/109 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រំ សម្បត្តិ ឆ.១៣៩-១៤៤, ២១៣-២១៤។ សូមមើលជាបន្ថែម ឯកសារ D114/242 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រាក់ ប៊ុនធី ឆ.៨២ ["ខ្ញុំឮសួរមេៗខ្ញុំនិយាយថា

សាក្សី ឯក នី បានឃើញអ្នកទោសដែលមកពីកងវរសេនាតូចលេខ ៣៨៦ របស់គាត់ កំពុងធ្វើការនៅទឹកសាប[1874]។

*ខ) ជនស៊ីវិលនៅក្នុងតំបន់កំពង់សោម*

497. ជនស៊ីវិល ដែលត្រូវបានបញ្ជូនទៅទឹកសាប ដើម្បីឃុំខ្លួន និង/ឬសម្លាប់ រួមមាន ប្រជាជនជម្លៀសនៅថ្ងៃទី ១៧ ខែ មេសា រួមទាំងអ្នកដែលត្រូវបានចាត់ទុកថាជា "បញ្ញវ័ន្ត" និងអ្នកជាប់ពាក់ព័ន្ធនឹងអតីតរបប លន់ នល់[1875]។ កម្មករនៅតាមសហករណ៍ជុំវិញនោះ ដូចជា សហករណ៍បរិបូរណ៍[1876] (ដែលមានប្រធានជាស្ត្រីឈ្មោះមិត្ត រី បានរាយការណ៍ទៅកងវរសេនាធំលេខ ៦៣ នៅទឹកសាប)[1877]

---

សុទ្ធតែកងទ័ពខុសនយោបាយ ខុសអី។ មេ ប្រាប់ពួកខ្ញុំថា នែ! ពួកហ្អែង ប្រយ័ត្នដូចអាម្នាក់ជាប់ច្រវាក់ហ្នឹង។ស.៖ តើអ្នកដែលជាប់ទោសទាំងនោះ ត្រូវបានគេយកចេញទៅណាទៀតទេ? ឆ.៨៣៖ អ្នកជាប់ទោសទាំងនោះ កាលជំនាន់ហ្នឹង គេយកមកមន្ទីរឃុំឃាំង នៅទឹកសាបនេះ [...] ឆ.៨៤៖ ព្រោះអី មន្ទីរធំបំផុត គឺមន្ទីរគុកនៅទឹកសាបហ្នឹង គុកធំរបស់ពួកវា"]។

1874 ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.២៦ [ពន្យល់ថា អ្នកទោសខ្លះ ដែលគាត់បានស្គាល់ធ្លាប់ធ្វើការនៅទឹកសាប គឺមកពីកងវរៈសេនាតូច ៣៨៦]។

1875 ឯកសារ D4.1.477 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សម្បត្តិ KH 00206377-00206378 ["ចាប់សាស្ត្រាចារ្យ និងមេភ្លើង ហើយមានចាប់អ្នករាជការ យកទៅសម្លាប់ចោលនៅទឹកសាប ដោយគេប្រាប់ថាផ្លាស់ភូមិ។ [...] គឺឃើញគេដឹកប្រជាជនទៅ ហើយឃើញគេដឹកខោអាវជនរងគ្រោះមកវិញ។ ខ្ញុំមិនបានឃើញទេ"] ដោយមានការបរិយាយលម្អិតបន្ថែមនៅក្នុង ឯកសារ D54/114 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម សម្បត្តិ ឆ.៤៥ [៤៩]៉ ៥១ [បញ្ជាក់ថា គាត់ដឹងថា ពួកអ្នកដែលគេដឹកទៅសុទ្ធតែជា "អ្នកចេះដឹង" ទាហានខ្មែរក្រហមប្រាប់មេក្រុមខ្ញុំ ហើយមេក្រុមប្រាប់មកខ្ញុំថា "ប្រជាជនថ្មីនាំយកទៅនៅជិតទឹកសាប" សាក្សីដឹងថា គេបានសម្លាប់គ្រួសារនោះពីព្រោះគេថាមិនបាច់យកអង្ករទៅទេ។ រ៉ឺម៉កនោះដឹកមនុស្សទៅហើយដឹកខោអាវមកវិញ]។

1876 ឯកសារ D54/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ឆ.៩ ["ប្រសិនបើគេចាប់មនុស្សពីសហករណ៍ភូមិបបុស គេនឹងយកទៅសម្លាប់នៅទឹកសាប"]។ ឯកសារ D54/90 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ឆ.១៧ ["គាត់និយាយថា ប្រសិនបើមនុស្ស ដែលចាប់ខ្លួនពីសហករណ៍បបុស នឹងត្រូវយកទៅចម្ការធូរេននៅទឹកសាប"]។ សូមមើលជាបន្ថែម ឯកសារ D54/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ឆ.៥ ["ការសម្លាប់គឺមានចាប់ផ្តើមខ្លាំងពីដើមឆ្នាំ ១៩៧៦ ពេលនោះគឺខ្មែរក្រហមបានចាប់ប្រជាជនពីតាមសហករណ៍ និងភូមិទៅសម្លាប់នៅទឹកសាប"]។

1877 ឯកសារ D54/90 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ឆ.១៣៉ ១៥ ["សមមិត្ត រី ធ្វើជាប្រធានសហករណ៍បបុសតាំងពីឆ្នាំ ១៩៧៥ រហូតដល់ឆ្នាំ ១៩៧៩។ [...] ឆ.១៥៖ តាមដែលខ្ញុំដឹង សមមិត្ត រី រាយការណ៍ទៅកន្លែងទីតាំងរបស់កងវរៈសេនាធំនៅទឹកសាប"]។

ពីស្នាច់ដែង ឬ រាម ឬ ពីចម្ការដូង ចេង ហេង[1878] ដែលបានប្រព្រឹត្តកំហុសតូចតាចក្នុងអំឡុងពេលធ្វើការងាររបស់ខ្លួន មិនអាចធ្វើការងារធ្ងន់សម្រេចបានតាមផែនការ លួចម្ហូបអាហារ ឬម្យ៉ាងវិញទៀត ត្រូវបានគេរកឃើញថាជាជនក្បត់ ត្រូវបានបញ្ជូនចេញ និងយកទៅទឹកសាប[1879]។

498. ប្រជាជនខ្មែរក្រោម ឬយ៉ាងហោចណាស់អ្នកដែលត្រូវបានខ្មែរក្រហមចាត់ទុកថាជាខ្មែរក្រោម ក៏ត្រូវបានបញ្ជូនពីកងចល័តតាមមូលដ្ឋានទៅទឹកសាប ដើម្បីឃុំខ្លួន និង/ឬសម្លាប់ផងដែរ[1880]។ ដូច

---

1878 ឯកសារ D114/176 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ សារឿន ឆ.១០, ២៧ ["ស.៖ លោកនិយាយថា ឮពីឪពុកក្មេកលោកថា គេយកមនុស្សពីស្នាច់ដែង រាម និងចម្ការដូងទៅសម្លាប់នៅទីនោះដែរ។ ឪពុកក្មេកលោកដឹងពីហេតុការណ៍នេះ ដោយសារថាគាត់នៅទឹកសាប នៅក្បែរទីតាំងនេះតែម្តង [...] បាន១ឆ្នាំក្នុងសម័យខ្មែរក្រហម បានគេបញ្ជូនគាត់ពីទឹកសាប [...] តើអ្វីដែលយើងសង្ខេបខាងលើត្រឹមត្រូវដែរឬទេ? ឆ.១០៖ ត្រឹមត្រូវ [...] ឆ.២៧៖ វាមានអ្នកខ្ជិល មានអ្នកឧស្សាហ៍ មានអ្នកក្បត់អ៊ីចឹង បានគេយកទៅសម្លាប់ចោល"]។ ឯកសារ D54/121 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លិន សារិន ឆ.១៤៖ "ខ្ញុំមិនអាចប្រាប់លោកពីចំនួនមនុស្សបានទេ ពីព្រោះវាស្ថិតនៅចម្ងាយឆ្ងាយ។ ពយយើងគ្រាន់តែឮសំឡេងស្រែក និងសំឡេងវ៉ៃប៉ុណ្ណោះ គឺពុំដឹងពីចំនួនជនរងគ្រោះ និងចំនួនជនដែលដល់ទេ។ [...] ខ្ញុំមិនដឹងថាពួកថាជាប្រុស ស្រីនោះទេ ប៉ុន្តែគ្រាន់តែដឹងថាជាប្រជាជនមកពីឃុំនេះតែម្តង។ ខ្ញុំនិយាយបែបនេះដោយសារក្នុងពេលព្រឹត្តិការណ៍នេះកើតឡើង ក៏មានមនុស្សពីសហករណ៍បាត់ខ្លួនដែរ។ ដូច្នេះខ្ញុំសន្និដ្ឋានថា អ្នកដែលបាត់ខ្លួននោះ គឺត្រូវគេយកមកសម្លាប់នៅទីនោះតែម្តង"]។ ឯកសារ D114/242 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ប៊ុននី ឆ.៩៨-៩៩៤ ១០១-១០២ "គេដឹងថា កន្លែងហ្នឹងគឺគុក ប្រជាពលរដ្ឋនៅម្តុំហ្នឹងគឺ គេយកទៅដាក់គុកហ្នឹង [...] ឆ.៩៩៖ បើនិយាយទៅច្រើនដែរ ច្រើនណាស់ ប្រជាជនស្រុកនេះគេយកទៅ ឲ្យតែខុស គេយកទៅសម្លាប់នៅទឹកសាប។ [...] ឆ.១០១៖ គុកនេះ មិនសម្រាប់ដាក់តែប្រជាជនទេ គឺទុកសម្រាប់កងទ័ពផង និងប្រជាជនផង គឺគុករួម។ [...] ឆ.១០២៖ ជាកន្លែងមូលដ្ឋានកងទ័ព ដូច្នេះបើប្រជាជនធ្វើខុស គេយកទៅកន្លែងនុ៎ងហើយ"]។

1879 ឯកសារ D114/242 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ប៊ុននី ឆ.១០៣ ["ស.៖ តើកំហុសអ្វីខ្លះដែរទៅដែលគេយកទៅទីនោះ? ឆ.១០៣៖ កំហុសច្រើនបំផុត គឺរឿងយើងធ្វើការ ដូចជាធ្វើការខ្ជិល ឬលួចនេះលួចនោះ"]។ ឯកសារ D114/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹង ណុច ឆ.១៣៦ ["ស.៖ ហេតុអីបានគេចាប់ តើគាត់ធ្វើអី? ឆ.៖ ដាំដំឡូង បេះដូងអីដូចខ្ញុំអ៊ីចឹង"]។ ឯកសារ D114/194 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុតឆ.៣៩ ["ស.៖ តើលោកដែលធ្លាប់ឮ ទីកន្លែងមួយឈ្មោះទឹកសាបដែរឬទេ? ស.៖ ចឺមិនដែល។ អាហ្នឹងជាកន្លែងសម្រាប់ដាក់អ្នកទោស ដាក់ពួកខ្ញុំ អ្នកធ្វើស្រែជាមួយខ្ញុំពេលដែលធ្វើខុសគេយកដាក់នៅហ្នឹង"]។ ឯកសារ D114/176 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ សារឿន ឆ.២៧ ["វាមានអ្នកខ្ជិល មានអ្នកឧស្សាហ៍ មានអ្នកក្បត់អ៊ីចឹងបានគេយកទៅសម្លាប់ចោល"]។ សូមមើលផងដែរ ឯកសារ D114/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង ឡុង ឆ.២៦ ["ខ្ញុំឮគេនិយាយថា អ្នកដែលលួចបន្លែហូប ត្រូវគេចាប់យកទៅ"]។

1880 ឯកសារ D54/36 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ឆ.៦-៧ ["មានប្រជាជន១៧មេសាខ្លះ ដែលជាខ្មែរកម្ពុជាក្រោមត្រូវបានគេដាក់នៅក្នុងកងចល័តនោះ ហើយខ្មែរក្រោមត្រូវបានគេបញ្ជូនទៅទឹសាប បន្ទាប់ពីគេដាក់

បានរៀបរាប់លម្អិតនៅក្នុងផ្នែក *VIII.ច. ការដ្ឋានតំបន់វាម*[1881] សាក្សី គុយ សម្បត្តិ បានរំឭកពីឧប្បត្តិហេតុមួយនៅក្នុងខែ មេសា ឬ ឧសភា ឆ្នាំ ១៩៧៧[1882] នៅពេលជនស៊ីវិលប្រហែល ៣៦០ នាក់ ដែលមានទាំងបុរស ស្ត្រី និងកុមារ រួមទាំង ទារកទើបកើត និងមនុស្សចាស់ បានប៉ុនប៉ងគេចខ្លួនចេញពីស្ថានភាពរស់នៅដ៏លំបាកក្នុងសហករណ៍វាម ដោយចុះឈ្មោះខ្លួនឯងថាជាកម្ពុជាក្រោម។ ពួកគេសង្ឃឹមថានឹងទទួលបានការអនុញ្ញាតឱ្យឆ្លងកាត់ទៅកាន់ប្រទេសវៀតណាម។ ផ្ទុយទៅវិញ ពួកគេត្រូវបានបញ្ជូនទៅទឹកសាបដើម្បីសម្លាប់។

499. មុនខែ មេសា ឆ្នាំ ១៩៧៥ តំបន់ទឹកសាប គឺជាទីតាំងសមរភូមិមុខរវាងទាហានលន់ នល់ និងកងទ័ពខ្មែរក្រហម[1883]។ បន្ទាប់ពីការដួលរលំនៃទីក្រុងភ្នំពេញ ខ្មែរក្រហមបានកាន់កាប់កំពង់សោម[1884]

---

ក្នុងកងនោះបានពី ៤-៥ ខែ។ ខ្មែរក្រោម គេមិនដែលទុកយូរទេនៅក្នុងកងចល័ត។ [...] ឆ.៧៖ មានខ្មែរក្រោមជាច្រើននៅតាមកងផ្សេងៗ តែខ្ញុំបានស្គាល់ខ្លះដែលនៅក្នុងកងរបស់ខ្ញុំ ខ្ញុំនៅចាំឈ្មោះ ថាច់ ប៊ិន៤ ឡាំ ស៊ិក និង ឡាំ សាញ់ (អ្នកទាំងពីរនាក់នេះជាបងប្អូនបង្កើត)។ ខ្ញុំចាំឈ្មោះអ្នកទាំង៣នាក់នេះ ពីព្រោះគេនៅក្នុងក្រុមជាមួយខ្ញុំ គេត្រូវបានយកទៅទឹកសាប បន្ទាប់ពីគេនៅក្នុងកងជាមួយខ្ញុំបាន ៤-៥ ខែ។ អ្នកណាក៏ដោយឱ្យតែគេបញ្ជូនទៅទឹកសាប គឺមិនដែលរស់ទេ"]។

1881 សូមមើល កថាខណ្ឌ ៧១១-៧១៣។

1882 ឯកសារ D114/69 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុយ សម្បត្តិ ឆ.៩ ["វាស្ថិតនៅក្នុងខែមេសា ឬឧសភា ឆ្នាំ ១៩៧៧។ ខ្ញុំចាំថា វាស្ថិតនៅរដូវប្រាំងនៅឡើយ"]។

1883 ឯកសារ D114/182 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហួង ខន ឆ.៤-៥, ១២-១៣, ១៨ [ឈរជើងជាមួយវរៈសេនាធំខ្មែរក្រហម ៨៥ នៅក្បែរទឹកសាប ខ្ទង់បីបួនខែ មុនខែមេសា ឆ្នាំ ១៩៧៥ ដើម្បីការពារ "តំបន់រំដោះ"]។ ឯកសារ D114/104 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ភង់ ឆ.៣៩៤ ៤៤ ["ពេលគេវាយភ្នំពេញ កម្លាំងរបស់ខ្ញុំបានវាយនៅទឹកសាបកំពង់សោម វៃរួមជាមួយកងពលលេខ១"]។ ឯកសារ D114/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ឆ.២១ ["តើលោកនៅឯណាថ្ងៃ១៧ មេសា ១៩៧៥? ឆ.២១៖ ខ្ញុំនៅសមរភូមិទឹកសាប ដែលជាកន្លែងប្រយុទ្ធ"]។ ឯកសារ D114/226 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម ហាវ ឆ.៦៨ ["សមរភូមិមុខនៅតាមស្ពាន ដូចជា នៅព្រៃនប់ នៅអូរឧកញ៉ាហេង នៅទឹកសាប"]។ ឯកសារ D114/112 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម សុខន ឆ.១៣ ["មុនថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំអាយុប្រហែល១៥ឆ្នាំ ធ្វើជានិរសាឱ្យឈ្មោះ ថន ដែលជាអនុសេនាធំ៤២០ ឈរជើងនៅម្តុំទឹកសាប និងអូរកំបុត ក្នុងតំបន់៣៥។ ទឹកសាប និងអូរកំបុត ស្ថិតនៅឆ្ងាយពីគ្នាប្រហែល២គីឡូម៉ែត្រ"]។ ឯកសារ D114/194 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ឆ.១០ ["ដោយក្នុងនេះជាតំបន់ខ្មែរក្រហមចាប់ពីអូរចំណា វាលរេញ ទៅដល់កំពង់សោម កន្លែងហ្នឹងពីអូរចំណាដល់កំពង់សោមគឺជាតំបន់ទាហាន លន់ នល់ ពេលគេបញ្ជូនខ្ញុំទៅវៃទឹកសាប"]។ ឯកសារ D114/68 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុយ សម្បត្តិ ឆ.៩ ["នៅពេលនោះ អូរកំបុត ប្រហែលជាមួយគីឡូម៉ែត្រខាងកើតស្ពានទឹកសាបនេះ គឺជាបន្ទាត់ព្រំដែនទី ១ រវាងកងទ័ពខ្មែរក្រហម និងកងទ័ព លន់ នល់។ កន្លែងនោះ ត្រូវបានគេហៅថា បន្ទាត់សមរភូមិ

ទាហានលន់ នល់ ជាច្រើនបានដកថយទៅអាកាសយានដ្ឋានកងកេង[1885] ហើយបានចុះចាញ់[1886]។ ទាហានលន់ នល់ ទាំងនោះ ត្រូវបានយកទៅសម្លាប់នៅទីតាំងចម្ការទឹកសាបក្នុងចំនួនយ៉ាងច្រើន[1887]។ ជាក់ស្តែង ឯកសណ្ឋានយោធាលន់ នល់ មួក និងស្បែកជើង ដែលជាកម្មសិទ្ធិរបស់

---

មុខទី ១"]។ ឯកសារ D114/282 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.២៣ ["ក្រុងកំពង់សោម មានប្រជាជនស៊ីវិល និងទាហាន។ តាមស្មាន សាច់ទាហានទាំងអស់ចាប់ពីរោងចក្រប្រេងកាត ដល់រាម ក្រវ៉ាត់ក្រុង ខ្ញុំស្មានថាសាច់ទាហានមិនក្រោម៣០០០នាក់ទេ ព្រោះឃើញទាហានច្រើន។ រោងចក្រប្រេងកាត គឺសំដៅរោងចក្រដែលនៅចន្លោះស្ទឹងហាវ និងកំពង់សោម។ ខ្សែត្រៀមវាពីរជាន់ គឺចាប់ពីរោងចក្រប្រេងកាតស្ទឹងហាវ ដល់កំពង់សោម ហើយចុះរហូតដល់ទឹកសាប ព្រោះគេចង់ការពារព្រលានយន្តហោះកងកេង"]។

1884 សូមមើល ខ. ឯកសារ D114/282 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.២២ ["ការចាប់ផ្តើមគឺពីថ្ងៃ ១៨ (មេសា ឆ្នាំ ១៩៧៥)។ ពេលនោះ កងទ័ពរបស់តំបន់ បានចូលមកដល់ក្រុងកំពង់សោម ដោយពុំមានការតដៃពីទាហាន លន់ នល់ ទេ ដោយកងទ័ព លន់ នល់ ដាក់អាវុធ"]។ ឯកសារ D114/68 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុយ សម្បត្តិ ឆ.៩ ["នៅក្នុងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ពេលដែលយោធាខ្មែរក្រហម ចូលភ្នំពេញ ហើយយោធាខ្មែរក្រហម នៅកំពង់សោម ក៏ចូលក្រុងកំពង់សោមដែរ។ ពួកទាហាន លន់ នល់ បានរៀបចំខ្លួននៅកំពង់សោម ដើម្បីចាំទទួលពួកខ្មែរក្រហម។ ក្រុងកំពង់សោមពេលនោះ គឺត្រូវបានខ្មែរក្រហមព័ទ្ធជុំអស់ហើយ។ បន្ទាប់មក មានយោធាខ្មែរក្រហម ចូលមកដល់ក្រុងកំពង់សោម តាមរយៈឡានហ្ស៊ីបទាហានជាច្រើន"]។

1885 ឯកសារ D114/3 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.៣ ["ខ្ញុំគ្រាន់តែឃើញពួកទាហាន លន់ នល់ ដកថយពីទឹកសាប នៅពេលដែលខ្មែរក្រហមវៃនៅទឹកសាប។ ពួកទាហាន លន់ នល់ ដកថយមកវាលយន្តហោះកងកេង"]។

1886 ឯកសារ D114/68 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុយ សម្បត្តិ ឆ.៩ ["នៅក្នុងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ពេលដែលយោធាខ្មែរក្រហម ចូលភ្នំពេញ ហើយយោធាខ្មែរក្រហមនៅកំពង់សោម ក៏ចូលក្រុងកំពង់សោមដែរ។ ពួកទាហាន លន់ នល់ បានរៀបចំខ្លួននៅកំពង់សោម ដើម្បីចាំទទួលពួកខ្មែរក្រហម។ ក្រុងកំពង់សោមពេលនោះ គឺត្រូវបានខ្មែរក្រហមព័ទ្ធជុំអស់ហើយ។ បន្ទាប់មក មានយោធាខ្មែរក្រហម ចូលមកដល់ក្រុងកំពង់សោម តាមរយៈឡានហ្ស៊ីបទាហានជាច្រើន។ អ្នកមានបណ្តាសក្តិខ្ពស់នៃពួកទាហាន លន់ នល់ នឹងពួកជើងទឹក បានគេចខ្លួនទៅស្រុកថៃអស់ហើយ។ យោធាខ្មែរក្រហម នៅក្នុងក្រុងកំពង់សោម បានប្រកាសតាមមីក្រូថា កុំឲ្យពួកយើងរត់គេចខ្លួន ដោយគេនឹងផ្តល់បុណ្យសក្តិឲ្យវិញ ចំពោះពួកយើងជាអតីតទាហាន លន់ នល់។ ពេលនោះ ខ្ញុំជាកូនទាហាន ពលទោ។ មុនថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ខ្ញុំមិនចាំពេលច្បាស់លាស់ទេ ស្ពានទឹកសាប ត្រូវបានដាក់មីនផ្តាច់ ដោយពួកខ្មែរក្រហម។ ស្ពានមួយកំណាត់ ត្រូវបានបាក់បែក។ នៅក្នុងក្រុងកំពង់សោមពេលនោះ ឪពុកក្មេករបស់ខ្ញុំ បានប្រាប់ខ្ញុំឲ្យដោះឯកសណ្ឋានទាហាន លន់ នល់ ចេញ។ បន្ទាប់មក នៅក្នុងថ្ងៃជាមួយគ្នានោះ ពួកខ្មែរក្រហមបានប្រកាសតាមមីក្រូ ឲ្យប្រជាជនចេញឲ្យអស់ពីក្រុងកំពង់សោម ដោយអាមេរិកាំង នឹងទម្លាក់គ្រាប់បែកបីថ្ងៃទៀត"]។

1887 ឯកសារ D54/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុយ ណែន ឆ.៤-៥ ["យោធាខ្មែរក្រហមបានប្រកាសថា អតីតយោធា លន់ នល់ មានជើងគោក ជើងទឹក ជើងអាកាស ត្រូវទៅជួបជុំគ្នានៅព្រលានយន្តហោះកងកេង ដើម្បី

ទាហាននៃអតីតរបបសាធារណរដ្ឋខ្មែរ ត្រូវបានគេឃើញមាននៅទីតាំងទឹកសាបក្នុងឆ្នាំ ១៩៧៩[1888]។ ការប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហម និងទាហានលន់ នល់ បានបញ្ចប់នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ

---

ទទួលភារកិច្ចដើមរបស់ខ្លួនវិញ [...] ឆ.៥៖ ពេលនោះខ្ញុំឮថា មានអតីតកូនទាហាន លន់ នល់ បានឆ្លើយកុហកទៅខ្មែរក្រហមថាខ្លួនមានបណ្ដាសក្តិនៅក្នុងសម័យ លន់ នល់។ អ្នកមានបណ្ដាសក្តិពិតត្រូវបានគេទុកនៅវាលយន្តហោះកងកេង ហើយបន្ទាប់មកគេចាប់ចង រួចយកទៅសម្លាប់នៅទឹកសាប។ ពួកអតីតទាហាន លន់ នល់ ចំនួនរាប់ពាន់នាក់ត្រូវបានសម្លាប់នៅទឹកសាបនោះ។ ខ្ញុំបានឮថា មានអតីតទាហាន លន់ នល់ ខ្លះដែលដឹងថាគេនឹងត្រូវជួបគ្រោះថ្នាក់ ពួកគេបានប្រាប់ខ្មែរក្រហមថា ពួកគេមិនមែនជាទាហាន លន់ នល់ ទេ បន្ទាប់មកពួកគេទាំងនោះត្រូវបានរួចខ្លួនមួយចំនួន [...] ឆ.២៨៖ បន្ទាប់ពីខ្មែរក្រហមគ្រប់គ្រងប្រទេសនៅខែមេសា ឆ្នាំ ១៩៧៥ ខ្មែរក្រហមបានប្រមូលអតីតទាហាន លន់ នល់ ទាំងអស់យកទៅដាក់នៅព្រលានយន្តហោះកងកេង។ ក្រោយមកពួកទាហាន លន់ នល់ ទាំងនោះត្រូវបាននាំយកទៅបាត់"]។ ឯកសារ D114/2 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.១០ ["សូម្បីតែពួកទាហាន លន់ នល់ ដែលបានចុះចាញ់ពេលរបបខ្មែរក្រហមឡើងកាន់អំណាច ក៏ត្រូវបានខ្មែរក្រហមនាំយកទៅសម្លាប់នៅចម្ការធូរេនទាំងពីរនេះដែរ"]។ សូមមើលផងដែរ ឯកសារ D114/282 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី ឆ.២៩ ["ស.៖ យើងចង់ដឹងពួកទាហាន លន់ នល់ ៣០០០នាក់ ទៅណាទៅ? ឆ.២៩៖ អត់ដឹង កម្លាំងបញ្ជូនមកក្រោយ នៅក្នុងគណៈតំបន់ គេកាន់កាប់ហើយ"]។ ឯកសារ D114/68 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គុយ សម្បត្តិ ឆ.៩ ["នៅក្នុងថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ពេលដែលយោធាខ្មែរក្រហម ចូលភ្នំពេញ ហើយយោធាខ្មែរក្រហមនៅកំពង់សោម ក៏ចូលក្រុងកំពង់សោមដែរ។ ពួកទាហាន លន់ នល់ បានរៀបចំខ្លួននៅកំពង់សោម ដើម្បីចាំទទួលពួកខ្មែរក្រហម។ ក្រុងកំពង់សោមពេលនោះ គឺត្រូវបានខ្មែរក្រហមព័ទ្ធជុំអស់ហើយ។ បន្ទាប់មក មានយោធាខ្មែរក្រហម ចូលមកដល់ក្រុងកំពង់សោម តាមរយៈឡានហ្ស៊ីបទាហានជាច្រើន។ អ្នកមានបណ្ដាសក្តិខ្ពស់នៃពួកទាហាន លន់ នល់ នឹងពួកជើងទឹក បានគេចខ្លួនទៅស្រុកថៃអស់ហើយ។ យោធាខ្មែរក្រហម នៅក្នុងក្រុងកំពង់សោម បានប្រកាសតាមមីក្រូថា កុំឲ្យពួកយើងរត់គេចខ្លួន ដោយគេនឹងផ្ដល់បុណ្យសក្តិឲ្យវិញ ចំពោះពួកយើងជាអតីតទាហាន លន់ នល់។ ពេលនោះ ខ្ញុំជាកូនទាហាន ពលទោ។ មុនថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ខ្ញុំមិនចាំពេលច្បាស់លាស់ទេ ស្ពានទឹកសាប ត្រូវបានដាក់មីនផ្ដាច់ ដោយពួកខ្មែរក្រហម។ ស្ពានមួយកំណាត់ ត្រូវបានបាក់បែក។ នៅក្នុងក្រុងកំពង់សោម [...] ឪពុកក្មេករបស់ខ្ញុំ បានប្រាប់ខ្ញុំឲ្យដោះឯកសណ្ឋានទាហាន លន់ នល់ ចេញ"]។

1888 ឯកសារ D54/89 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កុយ ណែន ឆ.៥៤ ២៨៤ ៣០៤ ៣២ ["ក្រោយឆ្នាំ ១៩៧៩ ខ្ញុំបានទៅដល់កន្លែងទឹកសាប ខ្ញុំបានឃើញឆ្អឹងខ្មោច ឯកសណ្ឋាន និងស្បែកជើងរបស់ទាហាន លន់ នល់ ទាំងនោះនៅនឹងកន្លែងសម្លាប់នៅទឹកសាប [...] ឆ.២៨៖ ក្រោយឆ្នាំ ១៩៧៩ ខ្ញុំបានទៅដល់កន្លែងទឹកសាប ខ្ញុំឃើញឯកសណ្ឋានទាហាន លន់ នល់ ស្បែកជើង និងឆ្អឹងនៅតាមរណ្ដៅកន្លែងទឹកសាបនោះ [...] ឆ.៣០៖ យើងបានឃើញសាកសពឯកសណ្ឋាន ស្បែកជើង ឆ្អឹងខ្មោច និងមួក [...] ឆ.៣២៖ ឯកសណ្ឋានយោធាខ្មែរក្រហម គឺពណ៌ខ្មៅ ឬបៃតង ក្រណាត់តេតារ៉ុង ហើយស្តើងៗ។ ឯកសណ្ឋានទាហាន លន់ នល់ មានហៅប៉ោច្រើន ហើយខ្លះមានពណ៌ប៉ាវ៉ា។ យោធាខ្មែរក្រហមមិនប្រើមួកដែកទេ"]។ សូមមើផងដែរ ឯកសារ D114/177 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉េង

១៩៧៥[1889]។ អតីតទាហានទាំងនេះ មិនត្រូវបានចាប់ខ្លួន ឬសម្លាប់នៅក្នុងសមរភូមិឡើយ ប៉ុន្តែ បានចុះចូលទៅក្នុងកងកម្លាំងរបស់ **មាស មុត** បន្ទាប់ពីពួកគេបានមកដល់តំបន់កំពង់សោម នៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៥។ ដូច្នេះ ពួកគេមែនមែនជាយុទ្ធជនតទៅទៀតទេ ហើយក៏មិនបានទទួលឋានៈជាស៊ីវិលសាជាថ្មីដែរ។

*គ) ជនបរទេសដែលត្រូវបានចាប់ខ្លួននៅសមុទ្រ*

500. មនុស្សមួយចំនួនក្នុងចំណោមអ្នកដែលត្រូវចាប់ខ្លួននៅសមុទ្រ ត្រូវបានបញ្ជូនទៅទឹកសាបដើម្បីឃុំខ្លួន ធ្វើការ និង/ឬសម្លាប់។ ដូចបានរៀបរាប់ខាងលើ កំណត់ត្រានៅមន្ទីរ ស-២១ បង្ហាញថា ជនជាតិថៃ និងជនជាតិវៀតណាមមួយចំនួន ត្រូវបាននាំយកទៅធ្វើការនៅចម្ការទុរេន និងសាវម៉ាវ នៅទឹកសាប មុនពេលបញ្ជូនទៅមន្ទីរ ស-២១។ សាក្សីមួយចំនួន បានពិពណ៌នាពីការដឹងឮថា ជនជាតិថៃ វៀតណាម និងជនបរទេសផ្សេងៗទៀត ដែលត្រូវបានចាប់ខ្លួននៅសមុទ្រ ត្រូវបានបញ្ជូនទៅទឹកសាបដើម្បីសម្លាប់[1890]។ ឡាក់ សាផាន ជាជនស៊ីវិលធ្វើការនៅការដ្ឋានសាងសង់ទំនប់មួយនៅជិតទឹកសាប បានឃើញទាហានពីរនាក់ បណ្តើរមនុស្សមួយក្រុមដែលជាប់ចំណងមានគ្នាប្អូន ឬប្រាំនាក់ ទៅចម្ការទុរេននៅទឹកសាប តាមបណ្តោយផ្លូវជាតិលេខ ៤ ក្នុងរដូវវស្សាឆ្នាំ ១៩៧៥។ គាត់និយាយថា គាត់បានឮទាហាននិយាយថា អ្នកទាំងនេះគឺជាអ្នកនេសាទថៃ ដែលត្រូវបានចាប់ខ្លួននៅសមុទ្រ[1891]។ គាត់បានបញ្ជាក់ថា ចម្ការទុរេន អ៊ឹង ក្រពុំផ្ការ (ចម្ការទុរេនទី ២) និង

---

សឹក ឆ.២៥ ["ស.៖ លោកនិយាយថា បានឃើញខោអាវ តើខោអាវម៉េចទៅ? ឆ.២៥៖ ខោអាវទាហាន ខោអាវខ្មៅក៏មាន"]។

1889 សូមមើល កថាខណ្ឌ ៤២៨៤ ៤៨៥។

1890 ឯកសារ D54/123 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.៨-៩៤ ១២ ["តាមការសង្កេតរបស់ខ្ញុំ អ្នកដែលចាប់បានមកពីសមុទ្រ មានខ្មែរ និងវៀតណាម ហើយត្រូវបានគេនាំទៅទឹកសាប ហើយក៏បង្ហើយនៅទីនោះទាំងអស់ ពុំមានអ្នកណាមួយវិលត្រឡប់មកវិញទេ"]។ ឯកសារ D114/176 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ សារឿន ឆ.៧ [បញ្ជាក់ថា គាត់បានដឹងពីឪពុកក្មេកគាត់ ឈ្មោះ ម៉េង សឹក (ម៉េង សេត) ថា អ្នកនេសាទថៃ និងអ្នកនេសាទជនបរទេសផ្សេងទៀត ដែលគេចាប់ពីសមុទ្រមកសម្លាប់នៅហ្នឹង]។ ឯកសារ D114/177 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉េង សឹក ឆ.១៥-១៦ [បញ្ជាក់ថា គាត់បានឮពីអ្នកដទៃទៀតថា ក្រុមអ្នកនេសាទថៃត្រូវបានគេយកទៅសម្លាប់នៅទឹកសាប]។

1891 ឯកសារ D114/2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.៧៤ ១៣-១៥៤ ១៨ ["កាលពីក្នុងរបបខ្មែរក្រហម ពេលល្ងាចមួយនោះ ពេលដែលខ្ញុំដើរមកពីធ្វើការនៅការដ្ឋានលើទំនប់នៅទឹកសាប ខ្ញុំបានឃើញយោធាបណ្តើរមនុស្សមួយក្រុមតាមផ្លូវជាតិលេខ៤ ទៅទិសចម្ការធូរេននៅទឹកសាប។ ពេលដែលគេកំពុងដើរនោះ ខ្ញុំឮសួរយោធា

ចម្ការទុរេនទឹកសាប គឺជាកន្លែងសម្លាប់មនុស្សដែលប្រជាជនមូលដ្ឋាននៅកន្លែងនោះបានដឹងទាំងអស់គ្នា[1892]។ នៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍នេះ គាត់ក៏បានឮចុងភៅនៅរោងបាយសហករណ៍ដែលមានកូនធ្វើជាហានខ្មែរក្រហមនៅរាម និងទឹកសាប និយាយថា មនុស្សដែលត្រូវបានចាប់ខ្លួននៅសមុទ្រ ហើយបញ្ជូនទៅកំពង់ផែកំពង់សោម ត្រូវបាននាំទៅសម្លាប់នៅចម្ការទុរេនទី ២ ចំណែកអ្នកដែលត្រូវបានបញ្ជូនឆ្លងកាត់កំពង់ផែរាម ត្រូវបានដឹកជញ្ជូនទៅទឹកសាបដើម្បីសម្លាប់[1893]។

---

ដែលបណ្ដើរពួកនោះនិយាយថា ពួកទាំងនេះគឺជាពួកនេសាទថៃដែលគេចាប់ពីសមុទ្រមក។ នៅក្នុងពេលនោះ ខ្ញុំមិនដឹងថា គេនាំអ្នកទាំងនោះទៅកន្លែងណានោះទេ។ ប៉ុន្តែក្រោយពីឆ្នាំ ១៩៧៩ ពេលដែលខ្ញុំទៅដល់កន្លែងចម្ការធូរេនទឹកសាប ខ្ញុំឃើញឆ្អឹង និងខោអាវខ្លះនៅទីនោះ ទើបខ្ញុំគិតថាពួកថៃទាំងអស់នោះ ត្រូវបានគេយកមកបញ្ចប់នៅចម្ការធូរេនទឹកសាបនោះ [...] ឆ.១៣៖ គឺនៅក្នុងរដូវភ្លៀង ឆ្នាំ ១៩៧៥។ ឆ.១៤៖ ខ្ញុំបានឃើញនៅចម្ងាយប្រហែល១គីឡូម៉ែត្រ ខាងលិចស្ពានទឹកសាប គឺនៅប្រហែលម៉ោង៦ល្ងាច។ [...] ឆ.១៥៖ មានយោធាក្មេងៗពីរនាក់ ដោយមានស្ពាយកាំភ្លើងបានបណ្ដើរអ្នកទោស៤នាក់ទៅ៥នាក់ [...] ឆ.១៨៖ អ្នកទោសម្នាក់ៗត្រូវបានចងដៃទៅក្រោយ"]។

1892 ឯកសារ D114/2 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.១០ ["ពួកប្រជាជនមូលដ្ឋាននៅកន្លែងនេះគេដឹងទាំងអស់គ្នាថា កន្លែងសម្លាប់មនុស្សមានពីរកន្លែង គឺមួយនៅចម្ការធូរេន អ៊ុំង ក្រពុំភ្កា និងមួយទៀតនៅចម្ការធូរេនទឹកសាប"]។

1893 ឯកសារ D114/2 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.២០ ["ខ្ញុំបានឮរឿងទាំងអស់នេះតាមរយៈពួកចុងភៅ ដែលធ្វើការនៅកន្លែងរោងបាយរួម។ ចុងភៅទាំងអស់នោះ មានកូនធ្វើជាយោធាខ្មែរក្រហមនៅតំបន់រាម និងទឹកសាប ហើយកូនពួកគេជាអ្នកប្រាប់ពួកគេអំពីរឿងទាំងអស់នេះ។ ចុងភៅទាំងនោះបាននិយាយថា អ្នកទោសដែលចាប់បាន ហើយចូលតាមផែកំពង់សោម គឺត្រូវបញ្ជូនទៅសម្លាប់នៅចម្ការធូរេន អ៊ុំង ក្រពុំផ្ការ។ សម្រាប់អ្នកទោសដែលចាប់បាន ហើយចូលតាមរាម គឺត្រូវបញ្ជូនទៅសម្លាប់នៅចម្ការធូរេននៅទឹកសាប"] ឯកសារ D54/123 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.៨-៩ ១២ ["តាមការសង្កេតរបស់ខ្ញុំ អ្នកដែលចាប់បានមកពីសមុទ្រ មានខ្មែរ ថៃ និងវៀតណាម ហើយត្រូវបានគេនាំទៅទឹកសាប ហើយក៏បង្ហើយនៅទីនោះទាំងអស់ ពុំមានអ្នកណាមួយវិលត្រឡប់មកវិញទេ [...] ឆ.៩៖ រឿងបែបនេះមិនអាចលាក់បាននោះទេ គឺមនុស្សនិយាយពីមាត់មួយទៅមាត់មួយ តៗគ្នា។ វាកាន់តែបញ្ជាក់ឲ្យកាន់តែច្បាស់ ក្រោយពេលខ្ញុំវិលត្រឡប់មកវិញ ថាមានការសម្លាប់នៅទីនោះមែន ដោយសារខ្ញុំបានទៅ និងឃើញឆ្អឹង ព្រមទាំងលលាដ៍ក្បាលនៅទីនោះ [...] ឆ.១២៖ តាមការសង្កេតមើលមានអ្នកនេសាទថៃច្រើននាក់ត្រូវបានគេយកទៅសម្លាប់នៅទឹកសាប។ គេជីករណ្ដៅនៅក្រោមដើមធូរេន។ បើសិនជាខ្ញុំមិនច្រឡំទេ អ្នកទាំងនោះត្រូវបានគេវៃនឹងត្បូងចប ហើយព្រោះខ្ញុំបានឃើញចបនៅរាយប៉ាយនៅទីនោះ"]។

501. សាក្សី សឹង ណុច បានឃើញជនបរទេសពីរនាក់ ដែលគាត់ជឿជាក់ថាជាជនជាតិអូស្ត្រាលី ឬអាមេរិក ត្រូវបានគេបណ្ដើរតាមផ្លូវជាតិលេខ ៤ ទៅទឹកសាប[1894]។

*ឃ) កុមារ*

502. មានភស្តុតាងយ៉ាងច្រើនផងដែរថា កុមារ រួមទាំងកុមារជនជាតិវៀតណាម ដែលត្រូវបានចាប់ខ្លួននៅសមុទ្រ[1895] ត្រូវបានឃុំខ្លួននៅទឹកសាប[1896]។ ដូចបានរៀបរាប់លម្អិតនៅក្នុងផ្នែក *ការធ្វើមនុស្សឃាត ការសម្លាប់ដោយចេតនា ការសម្លាប់រង្គាល និងការបាត់ខ្លួនដោយបង្ខំ* ខាងក្រោម សាក្សីមួយចំនួនបានឃើញអដ្ឋិធាតុរបស់កុមារនៅចម្ការទឹកសាប។

503. *ចំនួនអ្នកទោស* ៖ ភស្តុតាងបង្ហាញថា គុកធំបានដាក់អ្នកទោសរហូតដល់ទៅ ១០០ នាក់ក្នុងពេលតែមួយ[1897]។ នៅចុងបញ្ចប់នៃរបបខ្មែរក្រហម តួលេខអាចទាបជាងនេះ ដូចសាក្សី ឡុង ផាន់ស៊ី

---

1894 ឯកសារ D114/156 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សឹង ណុច ឆ.១៤៤ ["នៅក្នុងឆ្នាំ ៧០ ប៉ុន្មានទេ ខ្ញុំឃើញបរទេសពីរនាក់។ គេបណ្ដើរបរទេសនោះមិនដឹងជាអូស្ត្រាលី ឬអាមេរិកាំង។ គេបណ្ដើរតាមផ្លូវជាតិលេខ ៤ ទៅទឹកសាប អត់មានពាក់អាវទេ ហើយស្លៀកខោទាហាន"]។

1895 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសនៅស-២១ របស់ ក.ស.ច.ស លេខ 13434 [ង្វៀង ឌិន អ៊ី (NGVIENG Din Y) "គិញវៀតណាម" អាយុ ១៦ ឆ្នាំ]។ សូមមើល ឯកសារ D114/145.2.11 ប្រវត្តិរូបនៅស-២១ របស់ ង្វៀង ឌិន អ៊ី (NGVIENG Din Y) (លេខរៀងទី ១២៥) KH 01180400 ["ង្វៀង ឌិន អ៊ី អាយុ ១៦ ឆ្នាំ"] KH 01180409 ["ង្វៀង ឌិន អ៊ី [...] អាយុ៖ ១៦ ឆ្នាំ ជនជាតិយួន"]។

1896 ឯកសារ D114/156 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សឹង ណុច ឆ.១៣១-១៣២៤ ១៣៥-១៣៦ ["ដូចខ្ញុំនិយាយខាងដើមថា មិត្តខ្ញុំត្រូវគេយកទៅ គឺយកទៅសម្លាប់នៅហ្នឹង។ ស.៖ អ្នកណាជាអ្នកយកពួកគេទៅសម្លាប់នៅទឹកសាប? ឆ.១៣២៖ [...] គេមានសំបុត្រទៅឲ្យមេសហករណ៍ បន្ទាប់មកមេសហករណ៍បានប្រាប់សមាជិកសហករណ៍ថា "ឯងត្រូវទៅតាមឪពុកម្ដាយអ្នកឯងនៅខាងក្រោយ"។ [...] ឆ.១៣៥៖ ប្រហែល ១៥ ឬ ១៦ឆ្នាំ។ អាយុប្រហែលខ្ញុំ។ [...] ស.៖ ហេតុអីបានគេចាប់ តើគាត់ធ្វើអី? ឆ.១៣៦៖ ដាំដំឡូង បេះដូងអីដូចខ្ញុំអីចឹង គេថា គេផ្លាស់ឪពុកម្ដាយទៅក្រោយហើយ ឯងទៅក្រោយទៅ"]។ សូមមើលផងដែរ ឯកសារ D114/114 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.៤៦-៤៨ ["ខ្ញុំក៏បានសង្កេតឃើញផងដែរនូវក្រុមកុមារមួយក្រុមបានស្នាក់នៅក្បែរឃ្លាំងគ្រាប់។ ពួកគេបាននៅទីនោះដើម្បីរៀនសូត្រ និងដាំដំឡូង។ ឈ្មោះ ជួប គឺជាអ្នកគ្រប់គ្រងឃ្លាំងគ្រាប់ ក៏ដូចជាក្រុមកុមារនោះ។ ស.៖ តើពួកកុមារនោះ មានអាយុចាប់ពីប៉ុន្មាន? ឆ.៤៧៖ ចាប់ពីដប់ទៅដប់ពីរឆ្នាំ។ ស.៖ តើលោកបានឃើញពួកកុមារទាំងនោះប៉ុន្មាននាក់? ឆ.៤៨៖ ជាង ៣០ នាក់"]។

1897 ឯកសារ D114/66 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជេត ប៉ុណ្ណា ឆ.១៨ ["ស.៖ រឿងអ្វីខ្លះដែលលោកធ្លាប់ឮពីមិត្តភក្តិរបស់លោកឈ្មោះ ធូ? ឆ.៖ ធូ បានប្រាប់ខ្ញុំថា ពេលដែលកងទ័ពវៀតណាមចូលមកដល់ មានអ្នកទោស

បានពិពណ៌នាពីការឃុំខ្លួនគាត់ជាមួយអ្នកទោសចំនួន ១២ នាក់ផ្សេងទៀត នៅពេលគាត់នៅទីនោះ នៅចុងឆ្នាំ ១៩៧៨[1898]។ សាក្សីដែលបានមើលឃើញពីចម្ងាយនូវអ្នកទោសទឹកសាប ដែលធ្វើការនៅជុំវិញ និងនៅក្បែរការដ្ឋាននេះ បានគាំទ្រដល់ការប៉ាន់ស្មាននេះ[1899]។ សាក្សីដែលត្រូវបានឃុំខ្លួននៅក្នុងរោងចក្រអារឈើបានរាយការណ៍ថា មានអ្នកទោសរហូតដល់ ៦០ នាក់បន្ថែមទៀតនៅទីនោះ[1900]។ ដូចបានពិពណ៌នានៅក្នុងផ្នែក*ការធ្វើមនុស្សឃាត ការសម្លាប់ដោយចេតនា ការសម្លាប់*

---

ប្រហែល២០នាក់ប៉ុណ្ណោះ ដែលនៅរស់។ ធូ បាននិយាយថា ពេលដែលគាត់ជាប់នៅទីនោះ គឺមានអ្នកទោសប្រហែលជា១០០នាក់ ដែលជាប់ជាមួយគាត់”]។

1898 ឯកសារ D114/208 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ឆ.៤២ [“ខ្ញុំឃើញមានអ្នកទោសចំនួន ១២ នាក់ តែមានម្នាក់ក្នុងចំណោម១២នាក់គេកសាងខ្លួនបានល្អវិញ គេក៏ឲ្យធ្វើការនៅខាងក្រៅគុកវិញ”]។ ឧទាហរណ៍ ឯកសារ D114/208 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ឆ.៣០-៣២៉ ៣៥៉ ៤០ [“បញ្ហាដែលដកគេខ្ញុំចេញពីអង្គភាព មកគេពិនិត្យឃើញថា ខ្ញុំជា សេ.អ៊ី.អារ៉ កា.ហ្សេ.បេ។ ក្រោយពីគេយកមកអង្គភាព៦១២មក គេតាមដានពិនិត្យខ្ញុំ គឺពេលដែលខ្ញុំចុះធ្វើការងារ ប្រគល់ការងារឲ្យខ្ញុំធ្វើ គេពិនិត្យឃើញថា ក្នុងអង្គភាពរបស់ខ្ញុំមានបាក់ដែកស្បែង រទេះដាច់ហ្វ្រឹត គេចោទខ្ញុំថាបានបផ្លិចបំផ្លាញ [...] ឆ.៣១៖ អ្នកដែលមកចាប់ខ្ញុំគឺវរៈសេនាធំ ឈ្មោះ មឿន និង ឡុន [...] ឆ.៣២៖ ពេលនោះគ្រាន់តែគេអង្គុយបើសៀវភៅចុះឡើង១ហើយ យោធានោះក៏ចាប់ខ្ញុំតែម្តង។ ពេលនោះខ្ញុំមិនបានយកអង្គរក្សខ្ញុំទៅជាមួយទេ [...] ភ្ជង់ខ្ញុំឲ្យលើកដៃឡើង ហើយចងដៃខ្ញុំទាំងពីរ បន្ទាប់មកគេនាំខ្ញុំពីស្ទឹងហាវ យកទៅដាក់នៅគុកស្ទឹងហាវ ហើយគេសួរចម្លើយខ្ញុំ [...] ឆ.៣៥៖ គេដាក់ច្រវាក់ដៃខ្ញុំទៅក្រោយ និងដាក់ច្រវាក់ជើងខ្ញុំទាំងពីរ។ ពេលព្រឹកឡើង គេចាប់ផ្តើមសួរចម្លើយ ទី១ ថា អ្នកឯងជា សេ.អ៊ី.អារ៉ កា.ហ្សេ.បេ របស់អ្នកណា? ហើយពាក់សក្តិប៉ុន្មាន? ខ្ញុំឆ្លើយថាខ្ញុំអត់ដឹងរឿងទេ ពីព្រោះ ខ្ញុំអត់ដឹងរឿងមែន។ ក្រោយមកគេចាប់ផ្តើមធ្វើទារុណកម្មដែលមានរំពាត់តូចៗ វាយខ្ញុំ។ គេវាយខ្ញុំរហូត ដល់រំពាត់គរគ្នានៅកន្លែងសួរចម្លើយ។ គេវាយឲ្យខ្ញុំឆ្លើយថាស័ក្តិប៉ុន្មាន ហើយជាក្រុមណា។ ពេលព្រឹកខ្ញុំសន្លប់ពីរដង ពេលថ្ងៃសន្លប់មួយដង។ វិធីធ្វើទារុណកម្ម ទី១ វាយនឹងរំពាត់ វាយនឹងកន្ទុយត្រីបបែល និងទី៣ រវៃកក់នឹងខ្សែភ្លើង (ហៅរ៉ាកាណូវបញ្ចេញភ្លើងឆក់មនុស្ស)។ បើកន្ទុយត្រីបបែល គេកាត់យកកន្ទុយហាលឲ្យស្ងួត ហើយវារួញតូចដូចខ្សែតីដែរ [...] ឆ.៤០៖ គុកទាំងពីរនេះស្ថិតនៅក្នុងកងពល១៦៤ ព្រោះគុកទឹកសាបជាគុកបន្ថយទោស។ គេបន្ថយទោសនៅទឹកសាប”]។

1899 ឯក នី បានឃើញអ្នកទោស ២០-៣០ នាក់ធ្វើការ៖ ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.២៦ [“ខ្ញុំឃើញអ្នកទោសមានតែ២០-៣០នាក់ប៉ុណ្ណោះ នៅពេលដែលគេបញ្ជូនឲ្យទៅសែងឈើ”]។ ប៉ាក សុខ បានផ្តល់សក្ខីកម្មថាបានឃើញអ្នកទោសប្រហែលពី ៥០-៦០ នាក់៖ ឯកសារ D114/297.1.20 ប្រតិចារឹក ប៉ាក សុខ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 13.58.05-14.14.44 [ចំនួនមនុស្សដែលនៅទឹកសាប មានប្រហែលជា ៥០-៦០នាក់។ [...] ខ្ញុំបានឃើញផ្ទាល់ម្តងជាពីរដងដែរ”]។

1900 ឯកសារ D114/139 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ងួន ឡាយ ឆ.៩២ [“ស.៖ មានទាហាន មានអ្នកធ្វើការនៅកន្លែងអារឈើ តើមានអ្នកធ្វើការងារជាមួយលោកប៉ុន្មាននាក់? ឆ.៩២៖ ដំបូងមាន២០ នាក់ តែក្រោយមកមានដល់ ៥០៉ ៦០ នាក់ឯណោះ”]។ សូមមើលផងដែរ ឯកសារ D114/39 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន

*វង្គាល និងការបាត់ខ្លួនដោយបង្ខំ* មនុស្សជាច្រើនផ្សេងទៀតត្រូវបានចាប់ខ្លួន និងយកទៅទឹកសាប ដើម្បីសម្លាប់ ប្រហែលដោយមិនបានឆ្លងកាត់កន្លែងឃុំឃាំងផងដែរ។

504. ដូចទៅវត្តឥន្ទញ្ញាណដែរ គេមិនអាចគណនាឲ្យបានត្រឹមត្រូវនូវចំនួនអ្នកទោសសរុបដែលត្រូវបានចាប់ខ្លួន និងឃុំឃាំងតាមទំនើងចិត្ត នៅទឹកសាបក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យនោះឡើយ។ ភ័ស្តុតាងបានបង្ហាញថា ចំនួនអ្នកជាប់ឃុំខ្ពស់បំផុត ជាពិសេស បន្ទាប់ពី "អំឡុងពេលនៃការសម្លាប់យ៉ាងខ្លាំង" បានចាប់ផ្ដើមនៅក្នុងឆ្នាំ ១៩៧៦ នៅពេលដែលជនស៊ីវិលត្រូវបានយកចេញពីសហករណ៍ និងភូមិ ដើម្បីយកទៅសម្លាប់នៅទឹកសាប[1901]។ សាក្សី ប្រាក់ ប៊ុនធី បាននិយាយថា មនុស្សប្រហែល ១០ នាក់មកពីស្រុករបស់គាត់ ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខទឹកសាបជារៀងរាល់ខែ[1902]។

505. ទោះយ៉ាងនេះក្ដី គេអាចបញ្ជាក់យ៉ាងច្បាស់ថា ចំនួនជនរងគ្រោះនៅទឹកសាប មានចំនួនលើសយ៉ាងច្រើនពី (ជាង ១.០០០ នាក់) ដែលសាកសពរបស់ពួកគេ ត្រូវបានរកឃើញនៅតំបន់ទឹកទាប[1903]។ សាក្សី ជេត ប៊ុណ្ណា បានថ្លែងថា សាកសពមួយចំនួនត្រូវបានទម្លាក់ទៅក្នុងទន្លេទឹកសាប[1904] ហើយ

---

KH 01065090 ["សាក្សីបានពន្យល់ថា គាត់ត្រូវបានឃុំឃាំងនៅទឹកសាប បានតែ១យប់ទេ ជាមួយនឹងអ្នកទោសបួនដប់នាក់ផ្សេងទៀត"]។

1901 ឯកសារ D54/89 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កុយ ណែន ឆ.៥ ["ការសម្លាប់គឺមានចាប់ផ្ដើមខ្លាំងពីដើមឆ្នាំ១៩៧៦ ពេលនោះគឺខ្មែរក្រហមបានចាប់ប្រជាជនពីតាមសហករណ៍ និងភូមិទៅសម្លាប់នៅទឹកសាប។ ដោយសារសាកសពច្រើនហួសហេតុពេលយកទៅកប់នៅកន្លែងនោះ ដើមឈើ និងដំណាំត្រូវងាប់អស់"]។

1902 ឯកសារ D114/242 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រាក់ ប៊ុនធី ឆ.៩៩-១០០ ["ស.៖ តាមលោកដឹង តើមានមនុស្សប្រហែលប៉ុន្មាននាក់បញ្ជូនទៅដាក់គុកទឹកសាប? ឆ.៩៩៖ បើនិយាយទៅច្រើនដែរ ច្រើនណាស់ ប្រជាជនស្រុកនេះគេយកទៅ ឲ្យតែខុស គេយកទៅសម្លាប់នៅទឹកសាប។ ស.៖ តើលោកអាចផ្ដល់តួលេខប្រហាក់ប្រហែលបានទេ? ឆ.១០០៖ ក្នុង១ខែ១ប្រហែលបួនដប់នាក់ ប្រជាជនដែលខុស ហើយគេយកទៅហ្នឹង"]។

1903 សូមមើល ផ្នែក VIII.គ.៤ មន្ទីរសន្តិសុខទឹកសាប - ឧក្រិដ្ឋកម្ម - ការធ្វើមនុស្សឃាត ការសម្លាប់ដោយចេតនា ការសម្លាប់រង្គាល និងការបាត់ខ្លួនដោយបង្ខំ។

1904 ឯកសារ D114/66 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.១៧៤ ២៤ ["ខ្ញុំដឹងច្បាស់ថា ទឹកសាប គឺជាកន្លែងគុក និងកន្លែងសម្លាប់ ដោយសារខ្ញុំឃើញគេសម្លាប់នៅទីនោះ។ [...] រយៈពេលនោះ ខ្ញុំធ្លាប់ឃើញ ខ្មោចអណ្ដែតទឹកនៅតាមស្ទឹង នៅជិតគុកទឹកសាប ពេលដែលខ្ញុំត្រូវបានគេចាត់តាំងឲ្យធ្វើការនៅជិតស្ទឹងនោះ។ [...] ឆ.២៤៖ យើងដឹងថា សាកសពទាំងនោះ គឺជាសាកសពអ្នកទោស។ អ្នកទោស គឺទន់ខ្សោយ គ្មានកម្លាំង ហើយស្គមស្គាំង។ ខ្ញុំពុំបានឃើញសាកសពទាំងនោះ ត្រូវគេចងទេ។ ខ្ញុំសូមជម្រាបតាមត្រង់ថា អ្នកទោសនៅពេលនោះ គឺទន់ខ្សោយ ហើយ

វាអាចថា ទីតាំងកប់សាកសពបន្ថែមទៀតបានបាត់អត្តសញ្ញាណ មុនពេលដែលដីត្រូវបានជីករុករក និងលុបបំពេញឡើងវិញបន្ទាប់ពីសម័យខ្មែរក្រហម។ ការគណនានេះក៏ត្រូវបានពិចារណាផងដែរ ចំពោះអ្នកទោសដែលត្រូវបានដោះលែងក្នុងអំឡុងពេល និងនៅចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ឬក្រោយមកត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ ដើម្បីសម្លាប់។

<u>ប្រព្រឹត្តកម្មអមនុស្សធម៌ និងការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬការឈឺចាប់ធ្ងន់ធ្ងរ</u>

506. *<u>ការប្រើខ្នោះជើង និងចំណង</u>* ៖ អ្នកទោសនៅទឹកសាបបានរៀបរាប់ពីការដាក់ខ្នោះជើង និងខ្នោះដៃ[1905] ថា "អ្នកទោសធ្ងន់ គឺគេចងស្លាបសេក និងជើងម្ខាងដាក់ច្រវាក់ជាប់នឹងសសរ"[1906]។ ខ្នោះជើង ត្រូវបានគេប្រទះឃើញនៅកន្លែងនោះ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យបានបញ្ចប់[1907]។

---

ស្គមស្គាំង ដូច្នេះ ពេលគេយកទៅសម្លាប់ គេពុំចាំបាច់ចាប់ចងទេ។ យើងពុំបានឃើញសាកសពអណ្តែតទឹករាល់ថ្ងៃនោះទេ យើងឃើញសាកសពអណ្តែតទឹក បួនប្រាំថ្ងៃម្តង"]។

[1905] ឯកសារ D114/208 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ឆ.៣៧៤ ៤៣ ["ពេលគេបញ្ជូនទឹកសាបនោះ ខ្ញុំដេកបានស្រួល តែនៅតែជាប់ខ្នោះ ហើយនិងទទួលទារុណកម្មដោយរំពាត់ខ្សែភ្លើង [...] ឆ.៤៣៖ [...] អ្នកយាមនៅទឹកសាបភាគច្រើន គឺក្រោយពេលវៀតណាមចូល ខ្ញុំបានសុំគេគាស់ខ្នោះ ហើយនាំគ្នារត់ទៅព្រំដែនថៃ។ ខ្ញុំសុំគេគាស់ ពីព្រោះពេលនោះសភាពការណ៍ច្របូកច្របល់ហើយ។ ខ្ញុំបានជួបគេនៅតាមព្រំដែនថៃនៅពេលរត់នោះ"]។ ឯកសារ D114/31 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.១៦៧ ["នៅទឹកសាប គេបានដាក់ច្រវាក់ខ្ញុំតែមួយរយៈខ្លីប៉ុណ្ណោះ ដោយសារតែស្គាល់ថាខ្ញុំជានរណា"]។ ឯកសារ D114/40 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.២ ["ដូចខ្ញុំបាននិយាយថា ដំបូងគឺខ្ញុំជាប់ឃុំនៅទឹកសាបរយៈពេល៣ថ្ងៃ។ នៅពេលនោះ គេដាក់ច្រវាក់ជើងខ្ញុំម្ខាងជាប់នឹងសសរមួយ"]។ សូមមើលផងដែរ ឯកសារ D114/208 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ឆ.៥៦ ["នៅក្នុងគុកទាំងពីរនោះ ខ្ញុំអត់បានឃើញទេ តែខ្ញុំឃើញអ្នកទោសពីរនាក់បាត់ពីគុក ដោយសារតែពួកគេមានដំបៅរលួយសាច់ធ្ងន់ធ្ងរ ដោយសារជាប់ខ្នោះយូរ ហើយគេមិនអាចទុកទៀតបាន"]។

[1906] ឯកសារ D114/40 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.២ ["អ្នកទោសផ្សេងទៀត ដែលគេចាត់ទុកថាជាអ្នកទោសធ្ងន់ គឺគេចងស្លាបសេក និងជើងម្ខាងដាក់ច្រវាក់ជាប់និងសសរ"]។

[1907] ឯកសារ D114/69 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុយ សម្បត្តិ ឆ.៧ ["ក្រៅតែពីឆ្អឹង និងក្បាលខ្មោចដែលខ្ញុំបានប្រាប់លោក ខ្ញុំបានឃើញខ្នោះជើង និងកាំភ្លើងធំតូចផងដែរ"]។ ឯកសារ D114/105 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុច ទុយ ឆ.១៣០-១៣២ ["ប្រពន្ធរបស់ខ្ញុំនិយាយថា មានកន្លែងគុកមួយនៅទីនោះ [...] ឆ.១៣១៖ ពូរបស់គាត់នៅទីនោះ ហើយបានប្រាប់គាត់អំពីរឿងនេះ។ នៅក្នុងឆ្នាំ ១៩៨៦ ឬ១៩៨៧ ពេលជិតរៀបការ គាត់បានទៅរស់នៅជាមួយពូរបស់គាត់ ហើយពូគាត់បានប្រាប់អំពីរឿងនេះ ដោយពូរបស់គាត់បានឃើញច្រវាក់ ខ្នោះនិងស្នាមឈាមនៅទីនោះ [...] ឆ.១៣២៖ នៅពេលដែលវៀតណាមចូលស្រុក បានគាត់ទៅភូមិកំណើតគាត់នៅជិតទឹកសាបនោះ ដូច្នេះគាត់អាចគុកនៅទីនោះ"]។

សាក្សី ឯក នី អតីតទាហានតំបន់ ៣៧ ដែលត្រូវបានរំសាយ ហើយត្រូវបានចាត់តាំងឱ្យទៅធ្វើស្រែនៅជិតទឹកសាប[1908] បានឃើញដោយផ្ទាល់ភ្នែកនូវអ្នកទោសដែលកំពុងធ្វើការនៅទីនោះ៖

> អ្នកទោសខ្លះត្រូវបានគេចោះត្រចៀក ហើយដោតខ្សែបន្តគ្នាពី ៥ ទៅ ១០ នាក់ ដើម្បីការពារកុំឱ្យអ្នកទោសរត់គេច។ [...] វាជាកន្លែងព្រៃផ្សៃណាស់ ពីព្រោះអ្នកទោសត្រូវបានចោះត្រចៀក[1909]។

507. ដោយគ្មានករណីលើកលែង[1910] អ្នកជាប់ឃុំនៅទឹកសាបបានទទួលអាហារមិនគ្រប់គ្រាន់ និងមានរាងកាយស្គមស្គាំងដោយសារកង្វះជីវជាតិ[1911]។ អ្នកយាមគុកបានប្រមាថដល់អ្នកជាប់ឃុំឃាំង

---

[1908] ឯកសារ D54/103 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៣ ["បន្ទាប់ពីចាប់ថ្នាក់ដឹកនាំតំបន់៣៧ ហើយ បង នង ឆាន [...] គេលែងទុកចិត្តយោធាដែលនៅពីក្រោមបង នង ឆាន ទៀតហើយ។ គេបានដកអាវុធយោធាបង ឆាន នង អស់ ហើយបញ្ជូនពួកយើងទៅក្នុងកងផលិត ដែលគេហៅថា គុកដាក់អ្នកទោសស្រាល [...] ខ្ញុំត្រូវបានចាត់ឱ្យទៅធ្វើស្រែនៅក្បែរនោះ"]។ ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.២៤ ["នៅពេលនោះ ខ្ញុំស្នាក់នៅ និងធ្វើការនៅភូមិតាធឿង ដែលនៅត្រើយខាងលិចស្ទឹង។ ពួកអ្នកទោសស្ថិតនៅខាងកើតស្ទឹង"]។

[1909] ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.២៣៤ ២៥ ["ទឹកសាបគឺជាកន្លែង ដែលគេធ្វើទារុណកម្មយ៉ាងខ្លាំងទៅលើអ្នកទោស។ វាគឺជាគុក វាមិនមែនជាមន្ទីរសន្តិសុខទេ។ អ្នកទោសខ្លះត្រូវបានគេចោះត្រចៀក ហើយដោតខ្សែបន្តគ្នាពី៥ទៅ១០នាក់ ដើម្បីការពារកុំឱ្យអ្នកទោសរត់គេច [...] ឆ.២៥៖ វាជាកន្លែងគឺព្រៃផ្សៃណាស់ ពីព្រោះអ្នកទោសត្រូវបានចោះត្រចៀក"]។

[1910] ឯកសារ D114/39 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.១៦៦ ["របបអាហារ គឺដូចគ្នាសម្រាប់អ្នករាល់គ្នានៅក្នុងគុកនោះ"]។

[1911] ឯកសារ D114/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ឆ.៨៤ [ប្រពន្ធកម្មាភិបាលកងពល១៦៤ម្នាក់ ត្រូវបានគេឃុំខ្លួននៅទឹកសាប៖ នៅពេលគាត់ត្រូវបានគេដោះលែង "គាត់មើលទៅមិនមានសាច់ឈាមទេ ស្លេកស្លាំង និងស្គម ដូចអត់ឈាមក្នុងខ្លួន"]។ ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៉ុណ្ណា ឆ.២៤ ["ស.៖ នៅពេលដែលលោកថា ឃើញខ្មោចអណ្តែតទឹក ក្នុងស្ទឹងទឹកសាប តើលោកអាចរៀបរាប់ប្រាប់យើងបានឬទេ អំពីស្ថានភាពសាកសពដែលអណ្តែតទឹកទាំងនោះ? ឆ.២៤៖ យើងដឹងថា សាកសពទាំងនោះ គឺជាសាកសពអ្នកទោស។ អ្នកទោស គឺទន់ខ្សោយ គ្មានកម្លាំង ហើយស្គមស្គាំង។ ខ្ញុំពុំបានឃើញសាកសពទាំងនោះ ត្រូវគេចងទេ។ ខ្ញុំសូមជម្រាបតាមត្រង់ថា អ្នកទោសនៅពេលនោះ គឺទន់ខ្សោយ ហើយស្គមស្គាំង"]។ ឯកសារ D114/40 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.៨ ["ខ្ញុំមិនដែលបានឃើញអ្នកណាម្នាក់ម្តងទៀតទេ។ តាមខ្ញុំយល់ អ្នកដែលជាប់គុកនៅទីនោះមិនអាចរស់រានមានជីវិតបានទេ គឺអាចស្លាប់ដោយសារគេយកទៅសម្លាប់ ឬស្លាប់ដោយដាច់ពោះស្លាប់តែម្តង"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់ប៉ាក សុខ ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា KH 00955510-00955511 ["ចុះកាលហ្នឹងគេប្រើឱ្យទៅធ្វើការចុះៗ ធ្វើចឹងស្គាល់ៗគ្នាធ្លាប់ធ្វើការជាមួយគ្នាស្គមដែជាប់ច្រវាក់ហើយកាប់ដី"]។

ដោយហៅពួកគេថា "មី ហាង" [1912] ដែលមានន័យថាពួកគេគ្មាន "សិទ្ធិអ្វីទៀតទេ"[1913]។ ដូចបានរៀបរាប់លម្អិតខាងក្រោម អ្នកទោសនៅទឹកសាប ត្រូវប្រឈមនឹងការសួរចម្លើយ និងការធ្វើទារុណកម្ម[1914] ដោយពួកគេមាន "ស្នាមនៅលើមុខរបស់គេ ហើយនិងដៃជើងមានពក"[1915]។ អ្នកទោសខ្លះមានស្លាកស្នាមរាងកាយជាអចិន្ត្រៃយ៍[1916]។

508. ជាលទ្ធផលនៃការឃុំខ្លួនពួកគេនៅទឹកសាប អ្នកទោសក៏មានការឈឺចាប់ខាងសតិអារម្មណ៍ធ្ងន់ធ្ងរផងដែរ។ ពួកគេមាន "ការភ័យខ្លាច និងរន្ធត់យ៉ាងខ្លាំង"[1917] ហើយមានបំណងឱ្យគេសម្លាប់ដើម្បីបន្ថយទុក្ខវេទនារបស់ពួកគេ[1918]។

509. *ការងារដោយបង្ខំ*៖ ការងារដោយបង្ខំ ដើម្បីជាប្រយោជន៍ដល់របបនេះ ត្រូវបានប្រើជាទម្រង់នៃការដាក់ទណ្ឌកម្មនៅមន្ទីរសន្តិសុខទឹកទាប។ ភារកិច្ចមានលក្ខណៈចម្រុះ។ នៅដើមឆ្នាំនៃរបបកម្ពុជាប្រជាធិបតេយ្យ អ្នកនេសាទជនជាតិវៀតណាម ដែលត្រូវបានចាប់ខ្លួននៅសមុទ្រ តម្រូវឱ្យធ្វើការ ភាគច្រើនគឺការងារបោចសម្អាតស្មៅ និងរែកដី នៅចម្ការទុរេន និងសាវម៉ាវ[1919]។ អ្នកជាប់

---

1912 ឯកសារ D54/103 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី ឆ.៥ ["ពួកអ្នកយាម ពុំបានហៅនារីទាំងនោះថាជាសមមិត្តទៀតទេ គេប្រើពាក្យ "មី ហាង"]។

1913 ឯកសារ D54/103 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី ឆ.៦ ["បើសិនជាគេប្រើពាក្យ "មី ហាង" ទៅកាន់មនុស្សណាហើយ មនុស្សនោះត្រូវបានគេចាត់ទុកថាជាខ្មាំង ហើគ្មានសិទ្ធិទៀតទេ"]។

1914 សូមមើល ផ្នែក VIII.គ.4. មន្ទីរសន្តិសុខទឹកសាប - ឧក្រិដ្ឋកម្ម - ការធ្វើទារុណកម្ម។

1915 ឯកសារ D54/103 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី ឆ.៥ [បញ្ជាក់ថា គាត់បានឃើញអ្នកទោសទឹកសាប "មានស្នាមនៅលើមុខរបស់គេ ហើយនិងដៃជើងមានពក" ដែលស្របតាមការធ្វើទារុណកម្ម]។

1916 ឯកសារ D114/208 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ឆ.៥៧ ["មានបន្សល់ស្លាកស្នាមនៅកជើងទាំងសងខាង"]។

1917 ឯកសារ D54/103 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឯក នី ឆ.៥ ["ពេលដែលខ្ញុំបានឃើញពួកនារីទាំងនោះ [...]មុខរបស់គេមើលទៅគឺមានការភ័យខ្លាច និងរន្ធត់ខ្លាំង"]។

1918 ឯកសារ D114/208 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ឆ.៤៧-៤៨ ["គ្រាន់តែមានពាក្យមួយសម្រាប់បញ្ឆសគេវិញ គឺ "ចុះពេលណាបាន ឯងយកអញទៅសម្លាប់? ហើយគេក៏តបមកវិញមកវា ឯងពិតជាចង់ស្លាប់មែន?" នេះគ្រាន់តែជាការសម្រាលទោសខ្ញុំតែប៉ុណ្ណោះ នៅទឹសាប [...] ឆ.៤៨៖ ខ្ញុំលែងខ្វល់អស់ហើយ គឺគ្រាន់ចង់ឱ្យគេយកខ្ញុំទៅសម្លាប់ទេ ពីព្រោះខ្ញុំធុញទ្រាន់នឹងជីវិត ហើយពិបាកខ្លាំងពេក"]។

1919 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសនៅស-២១ របស់ ក.ស.ច.ស លេខ 592 និង 14786 [ដាំង យ៉ាំង ថាន់ (DAING Yaing Thann) (ជនជាតិវៀតណាម)។ ត្រូវបានគេបញ្ជូនទៅទឹកសាប ដើម្បីធ្វើចម្ការ - សូមមើល ឯក

សារ D114/145.2.15 ប្រវត្តិរូបនៅស-២១ របស់ ដាំង យ៉ាំង ថាន់ (DAING Yaing Thann) (លេខរៀង ១៣២) KH 01180427-01180428 ["គាត់ទើបត្រូវបានបញ្ជូនទៅកន្លែងទឹកសាប ធ្វើចម្ការ"]) 13431 [ជីម យ៉ាំងគឺ (CHIM Yang Keu) (ជនជាតិវៀតណាម) - ត្រូវឃុំខ្លួននៅទឹកសាប "រែកដីដាក់គល់ធូរេន និងសារម៉ាវ"។ សូមមើល ឯកសារ D114/145.2.11 ប្រវត្តិរូបនៅស-២១ របស់ ជីម យ៉ាំងគឺ (CHIM Yang Keu) (លេខរៀង ១២២) KH 01180403 ["ទើបបញ្ជូនទៅកន្លែងទឹកសាប ឲ្យធ្វើការ ដូចជារែកដីដាក់គល់ធូរេន និងសារម៉ាវ"]] 13433 [ឡេ យ៉ាំង ភឿក (LE Yang Phoeuk) ហៅ ជីម យ៉ាំងកឹង (CHIM Yang Koeng) (ជនជាតិវៀតណាម) - ត្រូវបានគេឃុំខ្លួននៅទឹកសាប "ធ្វើការ ដូចជាទៅរែកដីដាក់គល់ធូរេន និងសារម៉ាវ"។ សូមមើល ឯកសារ D114/145.2.11 ប្រវត្តិរូបនៅស-២១ របស់ ជីម យ៉ាំងកឹង (CHIM Yang Koeng) ហៅ ឡេ យ៉ាំង ភឿក (LE Yang Phoeuk) (លេខរៀង ១២៤) KH 01180407 ["ទើបបញ្ជូនមកកន្លែងទឹកសាប ឲ្យធ្វើការ ដូចជារែកដីដាក់គល់ធូរេន និងសារម៉ាវ"]] 13434 [ង្វៀង ឌិន អ៊ី (NGVIENG Din Y) (ជនជាតិវៀតណាម) - ត្រូវបានគេឃុំខ្លួននៅទឹកសាប "ឲ្យធ្វើការ ដូចជាធ្វើស្មៅធូរេន និងសារម៉ាវ"។ សូមមើល ឯកសារ D114/145.2.11 ប្រវត្តិរូបនៅស-២១ របស់ ង្វៀង ឌិន អ៊ី (NGVIENG Din Y) (លេខរៀង ១២៥) KH 01180409 ["ទើបបញ្ជូនមកកន្លែងទឹកសាប ឲ្យធ្វើការ ដូចជាធ្វើស្មៅធូរេន និងសារម៉ាវ"]] 13436 [ង្វៀង ធី ធឿង (NGVIENG Thithoeung) (ជនជាតិវៀតណាម) - ត្រូវបានគេទៅទឹកសាប "ថែរក្សាចម្ការធូរេន"។ សូមមើល ឯកសារ D114/145.2.12 ប្រវត្តិរូបនៅស-២១ របស់ ង្វៀង ធី ធឿង (KVIENG Thy Thoeung) (លេខរៀង ១២៦) KH 01180412 ["ពេលចាប់ខ្លួន អង្គការ បានបញ្ជូនឱយទៅនៅកន្លែងទឹកសាប ថែរក្សាចម្ការធូរេន"]] 13437 [Ngvieng Hour Lang (ជនជាតិវៀតណាម) – ត្រូវបានបញ្ជូនឲ្យទៅធ្វើស្មៅចម្ការធូរេន។ សូមមើល ឯកសារ D114/145.2.12 ប្រវត្តិរូបនៅស-២១ របស់ ង្វៀង ហ៊ីវ ឡាង (KVIENG Hiv Lang) (លេខរៀងទី ១២៧) KH 01180414-01180415 ["ចាប់ខ្លួននៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៧៥ នៅក្នុងសមុទ្រ ហួសកោះថាស [...] ពេលចាប់ខ្លួនហើយ អង្គការបញ្ជូនទៅកន្លែងទឹកសាប ឲ្យធ្វើស្មៅចម្ការធូរេន"]] 14782 [ត្រឹង យ៉ាំង ឃ្វេ (TROENG Yaing Khve) (ជនជាតិវៀតណាម) – ត្រូវបានឃុំខ្លួននៅទឹកសាប "ឲ្យធ្វើការ គឺធ្វើស្មៅធូរេន និងសារម៉ាវ"។ សូមមើល ឯកសារ D114/145.2.11 ប្រវត្តិរូបនៅស-២១ របស់ ត្រឹង យ៉ាំង ឃ្វេ (TROENG Yaing Khve) (លេខរៀងទី ១២១) នៅស-២១ KH 01180402 ["ពេលចាប់ខ្លួនហើយ អង្គការបានបញ្ជូនទៅនៅកន្លែងទឹកសាប ឲ្យធ្វើការ ដូចជាធ្វើស្មៅធូរេន និងសារម៉ាវ"]) 14783 ចឹង ថាន់ហឿន (CHOENG Thann Hoeun) (ជនជាតិវៀតណាម) – ត្រូវបានចាប់ខ្លួននៅសមុទ្រនៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៧៥ ហើយត្រូវបានបញ្ជូនទៅកោះ ចំនួន ០៦ ថ្ងៃ ហើយបន្ទាប់មកត្រូវបានឃុំខ្លួននៅទឹកសាប រហូតដល់មានការបញ្ជូនទៅកាន់ស-២១ នៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៥។ សូមមើល ឯកសារ D114/145.2.12 ប្រវត្តិរូបនៅស-២១ របស់ ចឹង ថាន់ហឿន (CHOENG Thann Hoeun) (លេខរៀងទី ១២៨) KH 01180417 ["ចាប់ខ្លួននៅថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩៧៥។ ពេលចាប់ខ្លួនហើយ បញ្ជូនទៅកោះ [...] ចំនួន ០៦ ថ្ងៃ ហើយបញ្ជូនទៅទឹកសាប ឲ្យថែដំណាំធូរេន និងសារម៉ាវ ដល់ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៥ ទើបបញ្ជូនមកកន្លែងនេះ"]] 14785 [ផាម យ៉ាំងថាន់ (PHAM Yaing Thann) (ជនជាតិវៀតណាម) – ត្រូវបានឃុំខ្លួននៅទឹកសាប ដើម្បីថែទាំងចម្ការធូរេន ។ សូមមើល ឯកសារ D114/145.2.14 ប្រវត្តិរូបនៅស-២១ របស់ ផាម យ៉ាំងថាន់ (PHAM Yaing Thann) KH 011804424-01180425 ["កំណត់សសម្គាល់៖ ចាប់ខ្លួននៅថ្ងៃទី ១២

ឃុំផ្សេងទៀត ធ្វើការនៅរោងអារឈើ[1920]។ អ្នកទោសក៏បានធ្វើការនៅតាមមាត់ទន្លេទាំងសងខាងនៃទន្លេទឹកសាបផងដែរ ដូចជា ភ្ជួររាស់ និងដកស្ទូង[1921] កាប់ដី[1922] សែងឈើហ៊ុប ឬសាងសង់ផ្ទះ[1923]។ សាក្សី ឡុង ផាន់ស៊ី បានពិពណ៌នាអំពីការដាំបន្លែ និងការបង្ខំឱ្យភ្ជួរក់លាមក ដែលត្រូវប្រើធ្វើជាជី ជាផ្នែកមួយនៃការងាររបស់គាត់[1924]។

510. ក្រៅពីការចាត់តាំងការងារដែលទាក់ទងទៅនឹងប្រតិបត្តិការនៃមន្ទីរសន្តិសុខនេះ ពេលខ្លះ អ្នកទោសត្រូវបានចាត់ឱ្យទៅធ្វើការនៅការដ្ឋានក្បែរនោះ។ ឯក នី និង ជេត ប៊ុណ្ណា បានធ្វើការនៅវាលស្រែភាគខាងលិចទន្លេទឹកសាប[1925]។ ឯក នី បានបញ្ជាក់ថា អ្នកទោសបានជួយពួកគេនៅពេលត្រូវការ

---

ខែ វិច្ឆិកា ឆ្នាំ ១៩៧៥ ហើយអង្គការបញ្ជូនទីនៅទឹកសាប ឱយធ្វើការ គឺថែទាំងចម្ការធូរេនជាដើម។ ទើបតែនៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦ បញ្ជូនមកកន្លែងស-២១ តែម្តង"]។

1920 ឯកសារ D114/139 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ងួន ឡាយ ឆ.៤០ ["ក្រោយមកគេដកខ្ញុំទៅកន្លែងអារឈើ។ ខ្ញុំអារឈើនៅទឹកសាប"]។ ឯកសារ D114/77 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សាម៉េត ឆ.១៦ ["ខ្ញុំអាចប្រាប់លោកបានថា នៅក្នុងជំរំជនភៀសខ្លួននៅប្រទេសថៃ ខ្ញុំបានជួបជាមួយនិងមនុស្សម្នាក់ឈ្មោះ ងួន ឡាយ ដែលបានប្រាប់ខ្ញុំថា គាត់នៅទឹកសាប គាត់ធ្វើការងារនៅកន្លែងអារឈើនៅទឹកសាប"]។ ឯកសារ D114/40 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.២ ["គេឱ្យខ្ញុំត្រឡប់មកកន្លែងទឹកសាបដដែលវិញ គឺនៅផ្ទះដូចមុន។ នោះគឺផ្ទះដែលស្ថិតនៅខាងលិចរោងអាឈើ ហើយតាមផែនការ គឺគេឱ្យខ្ញុំជួយលីសែងឈើនៅក្នុងរោងអារឈើនោះ តែពុំបានធ្វើផង វៀតណាមក៏ចូលមកដល់"]។

1921 ឯកសារ D114/175 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ស៊ីថា ឆ.២០ ["កន្លែងហ្នឹងជាកន្លែងគេធ្វើការ គាប់ដី ធ្វើស្រែ ស្ទូង ច្រូត អត់មានពេលឈប់"]។

1922 ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់ ប៉ាក សុខ ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា KH 00955510-00955511 ["ចុះកាលហ្នឹងគេប្រើឱ្យទៅធ្វើការចុះ១ ធ្វើចឹងស្គាល់១គ្នាធ្លាប់ធ្វើការជាមួយគ្នាស្គមដៃជាប់ច្រវ៉ាក់ហើយកាប់ដី"]។

1923 ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.២៣ ["គេប្រើអ្នកទោសឱ្យសែងឈើ សម្រាប់សង់ផ្ទះ និងធ្វើអ្វីផ្សេង១"]។

1924 ឯកសារ D114/208 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ឆ.៤៦ ["បើគ្មានវៀតណាមចូលមកទេ ខ្ញុំគិតថាជីវិតខ្ញុំមានតែផ្លូវស្លាប់ទេ ព្រោះពេលទំនេរគេឱ្យដាំបន្លែ ដាំស្ពៃ ដាំត្រកួន។ តួនាទីរបស់ខ្ញុំ គឺភ្ជួរក់ជីលាមក"]។

1925 ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.១៩ ["ពេលគេនៅក្នុងមន្ទីរឃុំឃាំងទឹកសាប ពួកអ្នកទោសទាំងនេះ ត្រូវបានគេដាក់ឱ្យធ្វើការនៅត្រើយខាងកើតស្ទឹង។ ចំណែកពួកខ្ញុំ ដែលនៅក្នុងកងទាំងបីនេះ ត្រូវបានគេដាក់ឱ្យធ្វើការនៅត្រើយខាងលិចស្ទឹង"]។ ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.២៤ ["នៅពេលនោះ ខ្ញុំធ្វើការនៅត្រើយខាងលិចស្ទឹង"]។

កម្លាំងពលកម្មបន្ថែម[1926]។ ជេត ប៊ុណ្ណា គិតថា អ្នកទោសហាក់ដូចជាត្រូវបានប្រើដើម្បីបំភិតបំភ័យកម្មករនៅតាមការដ្ឋានក្បែរនោះ "ដើម្បីឱ្យយើងមើលឃើញ ហើយខ្លាចពួកគេ និងកុំឱ្យធ្វើអីខុស" [1927]។

511. អ្នកទោសនៅទឹកសាប "ត្រូវធ្វើការយ៉ាងលំបាកដើម្បីឱ្យបានរស់"[1928] ក្រោមស្ថានភាពលំបាក និងគ្មានការសម្រាក[1929]។ អ្នកជាប់ឃុំត្រូវបានដាក់ច្រវាក់ខណៈពេលដែលពួកគេធ្វើការ[1930] ហើយអ្នកយាម បានតាមមើលពួកគេជាប់ជានិច្ច ដោយគំរាមកំហែងឱ្យពួកគេធ្វើការឱ្យលឿនជាងមុន[1931]។

---

1926 ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.២៤ ["ពេលខ្លះនៅពេលដែលយើងត្រូវការកម្លាំងដើម្បីជួយធ្វើការយើង យើងបានស្នើសុំអ្នកទោសឱ្យមកជួយយើងដែរ"]។ សូមមើលផងដែរ ឯកសារ D64.1.29 សារព័ត៌មាន FBIS អង្គភាពកងទ័ពជើងគោក ជួយកិច្ចខិតខំប្រឹងប្រែងស្ទូវស្រូវក្នុងតំបន់ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៧៧ ["នៅក្នុងអំឡុងពេលរដូវវស្សានាបច្ចុប្បន្ននេះ បន្ទាប់ពីជួយកសិករសហករណ៍របស់យើង ស្ទូងស្រូវដើមរដូវ កងទ័ពជើងគោកបដិវត្តន៍របស់យើងនៅស្រុកកោះអណ្តែត បានបន្តខិតខំធ្វើការយ៉ាងខ្លាំងនៅក្នុងការស្ទូវស្រូវវស្សា [...] នៅការដ្ឋាន [...] ទឹកសាប"]។

1927 ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.២៧ ["មានពេលខ្លះ គេបានយកអ្នកទោសដែលមានជាប់ច្រវាក់នៅកដៃ ឱ្យមកធ្វើការនៅកន្លែងជិតពួកយើងធ្វើការដែរ។ គេធ្វើដូច្នេះ ដើម្បីឱ្យយើងមើលឃើញ ហើយខ្លាចពួកគេ និងកុំឱ្យធ្វើអីខុស"]។

1928 ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.២៦ ["អ្នកទោសខ្លះ ដែលខ្ញុំស្គាល់ធ្លាប់នៅក្នុងកងជាមួយគ្នាពីមុនមក បានប្រាប់ខ្ញុំថា ពួកគេព្យាយាមធ្វើការយ៉ាងលំបាក ដើម្បីឱ្យបានរស់"]។ សូមមើលផងដែរ ឯកសារ D114/175 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ស៊ីថា ឆ.១៣ ["ស.៖ តើលោកស្រីអាចប្រាប់យើងថា លោកស្រីបានដឹងអ្វីខ្លះពីទីតាំងនោះ? ឆ.៖ កន្លែងធ្វើការដូចតែគ្នា ក្តៅគគុកដូចតែគ្នាហ្នឹង"]។

1929 ឯកសារ D114/175 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នាក់ ស៊ីថា ឆ.១៤៤ ១៩ ["កន្លែងដែលមនុស្សធ្វើការមិនឈប់ [...] ឆ.១៩៖ មានគេនៅហ្នឹងគេប្រាប់ខ្ញុំថា នៅហ្នឹងធ្វើការក្តៅណាស់ ឈប់អត់បានទេ អត់មានពេលសម្រាក"]។

1930 ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.២៧ ["មានពេលខ្លះ គេបានយកអ្នកទោសដែលមានជាប់ច្រវាក់នៅកដៃ ឱ្យមកធ្វើការនៅកន្លែងជិតពួកយើងធ្វើការដែរ។ គេធ្វើដូច្នេះ ដើម្បីឱ្យយើងមើលឃើញ ហើយខ្លាចពួកគេ និងកុំឱ្យធ្វើអីខុស"]។ ឯកសារ D114/146 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ញ៉ឹក ឆ.៥៨ ["ខ្ញុំឮថា កន្លែងនោះ គឺជាកន្លែងដែលគេដាក់អ្នកទោស ហើយដាក់ច្រវ៉ាក់ នាំយកមកធ្វើការនៅខាងក្រៅ"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់ ប៉ាក សុខ ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា KH 00955510-00955511 ["ចុះកាលហ្នឹងគេប្រើឱ្យទៅធ្វើការចុះៗ ធ្វើចឹងស្គាល់ៗគ្នាធ្លាប់ធ្វើការជាមួយគ្នាស្លមដៃជាប់ច្រវ៉ាក់ហើយកាប់ដី"]។

1931 ឯកសារ D54/103 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៥ ["ពេលដែលខ្ញុំបានឃើញពួកនារីទាំងនោះ [...]មុខរបស់គេមើលទៅគឺមានការភ័យខ្លាច និងរន្ធត់ខ្លាំង"]។

សាក្សី ឡុង ផាន់ស៊ី បានពន្យល់ថា គាត់ត្រូវបានគេធ្វើទារុណកម្មបន្ថែមទៀត ប្រសិនបើគាត់ត្រូវបានគេមើលឃើញថាមិនអាចបញ្ចប់ការងារដែលចាត់ឲ្យធ្វើ[1932]។

## ការធ្វើទារុណកម្ម

512. ដូចដែល **មាស មុត** បានដឹង[1933] កម្មាភិបាលកងពលធំលេខ ១៦៤ បានសួរចម្លើយអ្នកជាប់ឃុំនៅទឹកសាប[1934] ដោយធ្វើឲ្យមានការឈឺចាប់ធ្ងន់ធ្ងរខាងផ្លូវកាយ និងផ្លូវចិត្ត ដើម្បីឲ្យអ្នកជាប់ឃុំ "សារភាព"ចំពោះឧក្រិដ្ឋកម្មរបស់ពួកគេ និងចោទប្រកាន់អ្នកដទៃទៀត។ បច្ចេកទេសសួរចម្លើយដែលត្រូវបានប្រើប្រាស់នៅទឹកសាប គឺឃោរឃៅយ៉ាងខ្លាំង។ ឯក នី បាននិយាយថា៖

> ទឹកសាបគឺជាកន្លែងដែលគេធ្វើទារុណកម្មយ៉ាងខ្លាំងទៅលើអ្នកទោស។ វាគឺជាគុក វាមិនមែនជាមន្ទីរសន្តិសុខទេ[1935]។

513. អតីតអ្នកទោស ឡុង ផាន់ស៊ី បានពិពណ៌នាអំពីការធ្វើទារុណកម្មជាប់ជានិច្ចដែលគាត់បានស៊ូទ្រាំក្នុងអំឡុងពេលគាត់នៅទឹកសាប[1936] ជាទីកន្លែងដែលកម្មាភិបាលបានដាក់ច្រវ៉ាក់ និងធ្វើទារុណកម្ម

---

1932 ឯកសារ D114/208 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ឆ.៤៦ ["តួនាទីរបស់ខ្ញុំ គឺភ្ជក់ជីលាមក។ បើស្តែងាប់ ឬស្វិត ខ្ញុំត្រូវគេធ្វើទារុណកម្មបន្ថែមទៀត លើទារុណកម្មប្រចាំថ្ងៃ"]។

1933 ឯកសារ D1.3.12.3 សារទូរលេខមកពី មាស មុត ជូន បង ៨៩ (សុន សេន) ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ["សភាពការណ៍ខ្មាំង៖ តាមចំលើយ អាមួយ ដែលចាប់នៅខាងកើតទឹកសាប ពួក ៧ នាក់ ដែលចាប់នៅសង្ហារ វាថាជាក្រុមរបស់វា"]។ ឯកសារ D1.3.27.20 កំណត់ហេតុការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា អនុលេខា និង វរៈសេនាធំអំពីសភាពការណ៍ ការការពារប្រទេស និងវិធានការការការពារប្រទេស ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH 00052404-00052405 ["សមមិត្ត ឌឹម (ពេលមានវត្តមាន មាស មុត)៖ ចាប់បាននារីម្នាក់ អាយុ ១៣ ឆ្នាំ មុំទឹកសាប សារភាពថា មានគ្នា ៣ នាក់ ប្រហែលវានៅអូរផុស"]។

1934 ឯកសារ D114/40 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.២៤ ៩ ["ក្នុងពេលសួរចម្លើយ [...] ឆ.៩៖ ផ្ទះនោះគឺជាផ្ទះដែលគេបោះបង់ចោល ដែលគេយកមនុស្សទៅឃុំឃាំង។ គេសួរចម្លើយអ្នកជាប់ឃុំឃាំងនៅទីនោះដូចខ្ញុំដែរ"]។ ឯកសារ D114/115 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.៣ ["បងថ្លៃរបស់ខ្ញុំឈ្មោះញៀន [...] គឺជាអ្នកសួរចម្លើយនៅក្នុងគុកនេះ"]។

1935 ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.២៣។

1936 ឯកសារ D114/208 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ឆ.៣៧៤ ៤៦-៤៧៤ ៥០ ["តាំងពីដើមខែ ១ ខែ ២ ឆ្នាំ ១៩៧៨ ខ្ញុំមកនៅទឹកសាបបានប្រហែលជា ពីរទៅបីខែ ក៏វៀតណាមចូលមកដល់។ ពេលគេបញ្ជូនទឹកសាបនោះ ខ្ញុំដេកបានស្រួល តែនៅតែជាប់ខ្នោះ ហើយនិងទទួលទារុណកម្មដោយរំពាត់ខ្សែភ្លើង [...] ឆ.៤៦៖ បើគ្មានវៀត

គាត់ដោយរំពាត់ខ្សែភ្លើង[1937]។ ប្រសិនបើគាត់ត្រូវបានគេមើលឃើញថាមិនអាចបញ្ចប់ការងាររបស់គាត់ ក្នុងតួនាទីជាអ្នកភ្ជក់ជីលាមក ពួកគេ "បានធ្វើទារុណកម្មគាត់បន្ថែមទៀត លើទារុណកម្មប្រចាំថ្ងៃ"[1938]។ អ្នកទោសដទៃទៀត ត្រូវបានគេវាយដំក្នុងអំឡុងដំណើរការសួរចម្លើយ[1939]។ ហើយជាការពិតណាស់ ឧបករណ៍ធ្វើទារុណកម្មជាច្រើន ដូចជា ញញួរ ឧបករណ៍ដកក្រចក ដំបង ព្រនង់ និងត្បូងចប ត្រូវបានគេទុកចោលក្រោយរបបកម្ពុជាប្រជាធិបតេយ្យ[1940]។

514. អំពើទារុណកម្មដែលត្រូវបានអនុញ្ញាតនៅទឹកសាប បង្កឱ្យមានការឈឺចាប់ និងការរងទុក្ខខាងផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ ដល់អ្នកដែលត្រូវបានសួរចម្លើយ។ សាក្សីបានពិពណ៌នាថាបានឃើញអ្នកទោសមានស្លាកស្នាមរាងកាយ និងរបួសដែលស្របគ្នាទៅនឹងការធ្វើទារុណកម្ម។ សាក្សី សឹង ណុច បានសង្កេតឃើញបុរសម្នាក់ ដែលត្រូវបានគេដោះលែងពីទឹកសាប មាន "ស្នាមគេចាក់ភ្លៅ

---

ណាមចូលមកទេ ខ្ញុំគិតថាជីវិតខ្ញុំមានតែផ្លូវស្លាប់ទេ ព្រោះពេលទំនេរគេឱ្យដាំបន្លែ ដាំស្ពៃ ដាំត្រកួន។ តួនាទីរបស់ខ្ញុំ គឺភ្ជក់ជីលាមក។ បើសិនស្តែងាប់ ឬស្វិត ខ្ញុំត្រូវគេធ្វើទារុណកម្មបន្ថែមទៀត លើទារុណកម្មប្រចាំថ្ងៃ។ ស.៖ តើមូលហេតុអីបានជាគេនៅបន្តធ្វើទារុណកម្មលោកទៀតនៅក្នុងដំណាក់កាលនោះ? ឆ.៤៧៖ ខ្ញុំមិនយល់ដែរ ពីព្រោះខ្ញុំគ្មានសិទ្ធិសួរគេទេ។ គ្រាន់តែមានពាក្យមួយសម្រាប់បញ្ឈូសគេវិញ គឺ "ចុះពេលណាបាន ឯងយកអញទៅសម្លាប់? ហើយគេក៏តបមកវិញមកវា ឯងពិតជាចង់ស្លាប់មែន?" នេះគ្រាន់តែជាការសម្រាលទោសខ្ញុំតែប៉ុណ្ណោះ នៅទឹសាប [...] ឆ.៥០៖ [...] ខ្ញុំត្រូវគេធ្វើទារុណកម្មរហូត"]។

1937 ឯកសារ D114/208 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ឆ.៣៧ ["ពេលគេបញ្ជូនទឹកសាបនោះ ខ្ញុំដេកបានស្រួល តែនៅតែជាប់ខ្នោះ ហើយនិងទទួលទារុណកម្មដោយរំពាត់ខ្សែភ្លើង"]។

1938 ឯកសារ D114/208 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ឆ.៤៦ ["តួនាទីរបស់ខ្ញុំ គឺភ្ជក់ជីលាមក។ បើសិនស្តែងាប់ ឬស្វិត ខ្ញុំត្រូវគេធ្វើទារុណកម្មបន្ថែមទៀត លើទារុណកម្មប្រចាំថ្ងៃ"]។

1939 ឯកសារ D114/40 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.៩ ["អ្នកខ្លះដែលគេសួរចម្លើយ ត្រូវបានវ៉ៃទាត់ធាក់"]។

1940 ឯកសារ D114/242 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ប៊ុននី ឆ.៩៣-៩៤ ["រដ្ឋប្រហារហើយ ខ្មែរក្រហមដួលរលំហើយ បានខ្ញុំទៅឃើញ [...] ឆ.៩៤៖ មានឃើញដូចជា ញញួរ ប្រដាប់ដកក្រចក ឈើវ៉ៃ ដំបង ចបអីហ្នឹង។ វាមានភស្តុតាងវានៅហ្នឹង"]។

ទាំងសងខាង"[1941]។ ឯក នី បានឃើញស្ត្រីដែលត្រូវបានចាប់ខ្លួនពីបទជាប់ពាក់ព័ន្ធជាមួយ ឆាន់ ដោយមាន "ស្នាមនៅលើមុខ និងដៃជើងមានពក"[1942]។

515. បន្ថែមពីលើការប៉ះទង្គិចផ្លូវកាយជាប់ជានិច្ច ដែលកើតមាននៅទឹកសាប អ្នកទោសបានទទួលរង ទុក្ខវេទនាធ្ងន់ធ្ងរខាងផ្លូវចិត្ត ហើយត្រូវបានបន្សល់ទុកនូវពិការភាពផ្លូវចិត្តរយៈពេលយូរ[1943]។ ការ ឃុំខ្លួននៅទឹកសាបបានបណ្តាលឱ្យ ឡុង ផាន់ស៊ី ឈានដល់ចំណុចនៃការអស់សង្ឃឹមចង់ធ្វើអត្តឃាត៖

> បើគ្មានវៀតណាមចូលមកទេ ខ្ញុំគិតថាជីវិតខ្ញុំមានតែផ្លូវស្លាប់ទេ [...] ខ្ញុំលែងខ្វល់អស់ ហើយ គឺគ្រាន់ចង់ឱ្យគេយកខ្ញុំទៅសម្លាប់ទេ ពីព្រោះខ្ញុំធុញទ្រាន់នឹងជីវិត ហើយពិបាក ខ្លាំងពេក[1944]។

តាមពិត គាត់បានចាត់ទុកការស្លាប់គឺ "គ្រាន់តែជាការសម្រាលទោស [របស់គាត់] តែប៉ុណ្ណោះ នៅ ទឹកសាប"[1945]។

<u>ការធ្វើមនុស្សឃាត ការសម្លាប់ដោយចេតនា ការសម្លាប់រង្គាល និងការបាត់ខ្លួនដោយបង្ខំ</u>

516. អ្នកទោសរាប់រយនាក់ ដែលត្រូវបានបញ្ជូនទៅទឹកសាបត្រូវបានសម្លាប់ ឬយកចេញទៅ ហើយមិន ដែលឃើញម្តងទៀតឡើយ ដោយមានព័ត៌មានតិចតួចអំពីការបាត់ខ្លួនរបស់ពួកគេ។ នៅក្នុងរបប

---

1941 ឯកសារ D114/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ឆ.១៤៧ ["ក្នុងឆ្នាំ ១៩៧៧ គេលែងគាត់មក វិញ ហើយមានស្លាកស្នាមគេចាក់ភ្លៅទាំងសងខាង"]។

1942 ឯកសារ D54/103 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៥ [បញ្ជាក់ថា គាត់បានឃើញអ្នកទោសទឹក សាប "មានស្នាមនៅលើមុខរបស់គេ ហើយនិងដៃជើងមានពក" ដែលស្របតាមការធ្វើទារុណកម្ម]។

1943 ឯកសារ D114/208 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ឆ.៤៧-៤៨ ["ខ្ញុំមិនយល់ដែរ ពីព្រោះខ្ញុំគ្មាន សិទ្ធិសួរគេទេ។ គ្រាន់តែមានពាក្យមួយសម្រាប់បញ្ឈសគេវិញ គឺ "ចុះពេលណាបាន ឯងយកអញទៅសម្លាប់? ហើយ គេក៏តបមកវិញមកវា ឯងពិតជាចង់ស្លាប់មែន?" នេះគ្រាន់តែជាការសម្រាលទោសខ្ញុំតែប៉ុណ្ណោះ នៅទឹសាប [...] ខ្ញុំ លែងខ្វល់អស់ហើយ គឺគ្រាន់ចង់ឱ្យគេយកខ្ញុំទៅសម្លាប់ទេ ពីព្រោះខ្ញុំធុញទ្រាន់នឹងជីវិត ហើយពិបាកខ្លាំងពេក។ ខ្ញុំមិន បានចាំពីព្រោះវាយូរពេក ម្យ៉ាងទៀតខ្ញុំមានរបួសក្បាលផង ដូចនេះពេលខ្ញុំគិតម្តងៗ ធ្វើឱ្យខ្ញុំឈឺក្បាលចង់បែក"]។

1944 ឯកសារ D114/208 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ឆ.៤៦៤ ៤៨។

1945 ឯកសារ D114/208 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុង ផាន់ស៊ី ឆ.៤៧ ["ខ្ញុំមិនយល់ដែរ ពីព្រោះខ្ញុំគ្មានសិទ្ធិ សួរគេទេ។ គ្រាន់តែមានពាក្យមួយសម្រាប់បញ្ឈសគេវិញ គឺ "ចុះពេលណាបាន ឯងយកអញទៅសម្លាប់? ហើយគេក៏ តបមកវិញមកវា ឯងពិតជាចង់ស្លាប់មែន?" នេះគ្រាន់តែជាការសម្រាលទោសខ្ញុំតែប៉ុណ្ណោះ នៅទឹសាប"]។

មួយ ដែលត្រូវបានគេសំដៅជាញឹកញាប់ថាជា"របបលាក់ការណ៍សម្ងាត់"[1946] ការបាត់ខ្លួនកម្រត្រូវបានគេពិភាក្សាណាស់ ដោយសារតែការភ័យខ្លាចនៃផលវិបាកផ្ទាល់ខ្លួនជាបន្តបន្ទាប់[1947]។ គ្មានតុលាការ ឬប្រព័ន្ធផ្សេងទៀត ដើម្បីប្ដឹងពីការបាត់ខ្លួនទាំងនេះឡើយ[1948]។

---

1946 ឯកសារ D54/87 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រុំ សារ៉ាត ឆ.១៦០ ["ខ្ញុំមិនដឹងទេ។ សម័យនោះ ថ្នាក់លើគេនិយាយថារបបលាក់ការណ៍សម្ងាត់។ បើសិនជាគេចាប់ ឬបញ្ជូនអ្នកណាទៅអប់រំរៀនសូត្រ គឺគេចាប់ដោយសម្ងាត់ យើងមិនអាចដឹងបានទេ។ ខ្ញុំដឹងតែរឿងមួយទេ គឺ សាន ដែលជាអ្នកធ្វើការជាមួយខ្ញុំ គឺបាត់ខ្លួននៅឆ្នាំ ១៩៧៧"]។ ឯកសារ D234/2.1.140 ប្រតិចារឹក ធុច ស៊ីថន ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ម៉ោង 14.30.20-14.35.34 ["ធម្មតាពិបាកដែរនៅជំនាន់ហ្នឹងគឺថា ការសម្ងាត់គឺម្នាក់ៗអត់មានមានហ៊ាននិយាយលេងអី ឬក៏ចេញអីទេ"]។ ឯកសារ D4.1.195 សេចក្ដីថ្លែងការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា ជូនចំពោះបក្សកម្មករកុម្មុយនីស្តដាណឺម៉ាក ខែ កក្កដា ឆ្នាំ ១៩៧៨ KH 00224469 ["ស.៖ ហេតុអ្វីបានជាការងារមិនស្របច្បាប់នៅតែជាការងារមូលដ្ឋាន? ឆ.៖ នៅក្នុងអំឡុងពេលនេះ ក្រោយពីការរំដោះ ការងារសម្ងាត់ជាការងារមូលដ្ឋាន។ យើងលែងប្រើពាក្យ "ស្របច្បាប់" និង "មិនស្របច្បាប់" តទៅទៀតហើយ យើងប្រើពាក្យថា "សម្ងាត់" និង "ចំហ" វិញ។ ការងារសម្ងាត់គឺជាការងារមូលដ្ឋានសំរាប់អ្វីៗទាំងអស់ដែលយើងធ្វើ។ ឧទាហរណ៍ ការបោះឆ្នោតជ្រើសរើសកម្មាភិបាល សំរាប់ការងារដឹកនាំ គឺធ្វើឡើងដោយសម្ងាត់។ ទីកន្លែងដែល ថ្នាក់ដឹកនាំរបស់យើងរស់នៅ គឺត្រូវរក្សាជាការសម្ងាត់។ យើងរក្សាការសម្ងាត់ចំពោះពេលវេលា និងទីកន្លែងប្រជុំ។ ម្យ៉ាង នេះជាបញ្ហាគោលការណ៍ទូទៅ និងម្យ៉ាងទៀតនេះជាមធ្យោបាយមួយក្នុងការពារខ្លួនយើងពីគ្រោះថ្នាក់នៃការជ្រៀតចូលរបស់សត្រូវ។ ឲ្យតែមានការតស៊ូវណ្ណៈ ឬចក្រពត្តិនិយម ការងារសម្ងាត់នឹងនៅតែជាការងារមូលដ្ឋាន។ គឺមានតែតាមរយៈការងារសម្ងាត់ប៉ុណ្ណោះ ទើបយើងអាចម្ចាស់ការលើស្ថានភាពបាន ហើយទទួលជោគជ័យលើសត្រូវ ដ្បិតសត្រូវមិនអាចដឹងបានថា នរណាជានរណាឡើយ។ ការងារនេះក៏អាចអនុវត្តចំពោះកិច្ចការបរទេសបានដែរ។ ឧទាហរណ៍ សូវៀតបានស្នើសុំមកភ្នំពេញនៅពេលរំដោះ ហើយ គេបានរៀបចំបញ្ជូនមនុស្ស ២០០នាក់មកកាន់ស្ថានទូត។ យើងខ្ញុំបានឆ្លើយថា យើងខ្ញុំមិនអាចទទួលពួកគេបានទេ ហើយពួកគេខឹងសម្បារយ៉ាងខ្លាំង។ យើងពឹងផ្អែកអ្វីៗទាំងអស់ទៅលើការងារសម្ងាត់។ ធ្វើដូចនេះគឺដើម្បីផលប្រយោជន៍របស់វណ្ណៈអធន។"]

1947 ឯកសារ D54/98 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហ៊ាង រ៉េត ឆ.៥៣ ["ស.៖ តើលោកមានការភ័យខ្លាចដែរឬទេ នៅពេលដែលមនុស្សនៅក្នុងកងពលរបស់លោកបាត់ខ្លួន? ឆ.៥៣៖ បាទ ខ្ញុំមានការភ័យខ្លាច ប៉ុន្តែមិនហ៊ានសួរនាំគេទេ។ ជាទូទៅចំពោះកូនទាហានធម្មតា ដែលបានបាត់ខ្លួន គឺមានន័យថាគេអាចត្រូវបានបញ្ជូនទៅធ្វើការនៅកន្លែងផ្សេង។ ប៉ុន្តែ ចំពោះកម្មាភិបាលថ្នាក់លើ ដែលបាត់ខ្លួន គឺយើងមិនដឹងទេ។ មូលហេតុដែលយើងមិនហ៊ានសួរអំពីការបាត់ខ្លួនមនុស្ស ពីព្រោះយើងខ្លាចគេចោទថាមានការពាក់ព័ន្ធ និងមានមនោសញ្ចេតនាជាមួយអ្នកដែលបាត់ខ្លួននោះ ហើយយើងអាចនឹងបានគេទិតៀននៅក្នុងប្រជុំទិតៀន និងស្វ័យទិតៀន"]។

1948 ឯកសារ D114/116 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ស្វាយ សំអាន ឆ.៤៤-៤៥ ["មានមនុស្សជាច្រើនមកពីតាមកងវរសេនាតូចផ្សេងៗ ដែលក្នុងនោះរួមទាំងបងជីដូនមួយខ្ញុំផងបានបាត់ខ្លួន ហើយយើងភ័យខ្លាចបាត់បង់អាយុជីវិត។ ស.៖ តើមានប្រព័ន្ធតុលាការ ដែលអាចឲ្យប្រជាជនដាក់ពាក្យបណ្ដឹងអំពីករណីបាត់ខ្លួនបែបនេះដែរឬទេ? ឆ.៤៥

517. មានអ្នករស់រានមានជីវិតតិចតួចពីការអប់រំកែប្រែនៅទឹកសាប។ អតីតទាហានរំសាយមួយចំនួនត្រូវបានដោះលែង និងបំពាក់អាវុធសាជាថ្មីដើម្បីប្រយុទ្ធប្រឆាំងនឹងវៀតណាម[1949]។ សាក្សី មូល ឈិន សាក្សី ងួន ឡាយ និង ឡុង ផាន់ស៊ី និងអ្នកទោសនៅជាមួយពួកគាត់ផ្សេងទៀត[1950] ត្រូវបានសង្គ្រោះដោយការលុកលុយរបស់វៀតណាម[1951]។ សាក្សីពីរបីនាក់បានរៀបរាប់ពីបុគ្គលដាច់ដោយឡែកដែលបានរស់រានមានជីវិតពីទឹកសាប[1952]។ ប៉ុន្តែអ្នកទាំងនេះគឺជាករណីលើកលែងដែលមានសំណាង។ មានភស្តុតាងយ៉ាងច្រើនដែលបង្ហាញថា ជនរងគ្រោះភាគច្រើនដែលត្រូវបានគេ

៖ ពុំមានទេ"]។ សូមមើលផងដែរ ផ្នែក VIII.គ.២ ការចាប់ខ្លួន និងការឃុំខ្លួននៅក្នុងមន្ទីរសន្តិសុខកងពល ១៦៤ - ការខ្វះដំណើរការត្រឹមត្រូវតាមច្បាប់។

1949 ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.២៧ ["ខ្ញុំស្គាល់អតីតអ្នកទោសនៅទឹកសាបម្នាក់ឈ្មោះ សុខ ប្រាជ្ញ ពីព្រោះគាត់ជាអ្នកនិយាយច្រើន អ្នកពូកែប្រាជ្ញ។ ខ្ញុំបានជួបគាត់នៅក្នុងឆ្នាំ ១៩៧៩ នៅពេលនោះបន្ទាប់ពីគាត់ត្រូវបានដោះលែងពីទឹកសាប គាត់កាន់កាំភ្លើងដើម្បីវ៉ៃជាមួយកងទ័ពវៀតណាម"]។ សូមមើលផងដែរ ឯកសារ D114/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ឆ.១១៤ ១១៦៤ ១២៤ [ប្រពន្ធយោធាកងពល១៦៤ បញ្ជាក់ថា គេបានដាក់គុកប្តីរបស់គាត់នៅទឹកសាបពីរដង។ ពេលគេដោះលែងគាត់ គេបញ្ជូនគាត់ទៅកងយោធារបស់គាត់វិញ ហើយបញ្ជូនទៅបូព៌ា ដើម្បីប្រយុទ្ធ]។

1950 សូមមើល ខ. ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.១៧-១៨ ["យើងដឹងថា ទឹកសាប គឺជាគុក ដោយសារឈ្មោះ ធូ ដែលនៅក្នុងចំណោមអតីយោធាក្នុងកងរបស់ខ្ញុំបីនាក់ ដែលត្រូវបានគេចាប់ខ្លួនហើយបញ្ជូនទៅទីនោះ។ [...] ឆ.១៨៖ ធូ បានប្រាប់ខ្ញុំថា ពេលដែលកងទ័ពវៀតណាមចូលមកដល់ មានអ្នកទោសប្រហែល២០នាក់ប៉ុណ្ណោះ ដែលនៅរស់"]

1951 សូមមើល ផ្នែក VIII.គ.៤ មន្ទីរសន្តិសុខទឹកសាប - ទីតាំង ការពណ៌នាអំពីទីកន្លែង និងប្រតិបត្តិការ - រយៈពេលប្រតិបត្តិការ។

1952 ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.១៧ ["យើងដឹងថា ទឹកសាប គឺជាគុកដោយសារឈ្មោះ ធូ ដែលនៅក្នុងចំណោមអតីយោធាក្នុងកងរបស់ខ្ញុំបីនាក់ ដែលត្រូវបានគេចាប់ខ្លួន ហើយបញ្ជូនទៅទីនោះ។ ក្នុងចំណោមអ្នកទាំងបីនោះ ពីរនាក់ ត្រូវបានបាត់ខ្លួនរហូត នៅរស់តែឈ្មោះ ធូ ប៉ុណ្ណោះ"]។ ឯកសារ D114/86 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.១៤ ["ដូចខ្ញុំប្រាប់លោករួចហើយគឺថា គេយកមនុស្សបីនាក់ពីកន្លែងខ្ញុំទៅ ហើយក្រោយរបបខ្មែរក្រហមដួលរលំ ខ្ញុំបានជួបតែម្នាក់ទេ។ បើសិនជាមិនទាន់បែក គាត់នោះច្បាស់ជាមិនរស់ទេ"]។ ឯកសារ D54/98 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ាង រ៉េត ឆ.១៤០ ["ខ្ញុំដឹងថាមានមនុស្សម្នាក់ដែលត្រូវបានគេបញ្ជូនទៅទឹកសាប ហើយនៅរស់បច្ចុប្បន្ននេះ"]។ ឯកសារ D114/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ឆ.១៤៧ ["ក្នុងឆ្នាំ ១៩៤៧ គេលែងគាត់មកវិញ ហើយមានស្លាកស្នាមគេចាក់ភ្លៅទាំងសងខាង"]។

យកទៅទឹកសាប ត្រូវបានសម្លាប់ក្នុងពេលមកដល់ ឬបន្ទាប់ពីការឃុំខ្លួនក្នុងស្ថានភាពអមនុស្សធម៌បានមួយរយៈ។

518. ទីតាំងទឹកសាប[1953] និងជាពិសេសជាងនេះទៀត ចម្ការទុរេន ម្រេច និងសាវម៉ាវនៅទីនោះ[1954] ត្រូវបានគេស្គាល់ថាជាកន្លែងសម្លាប់មនុស្សដែលជាយោធា និងជនស៊ីវិល។ ដូចដែលសាក្សី ឡាក់ សាផាន បានពន្យល់ថា "អ្នកណាក៏ដឹងដែរ បើសិនជាពួកយោធាខ្មែរក្រហមចាប់មនុស្ស ហើយនាំយកទៅទឹកសាប គឺយើងទាំងអស់គ្នាដឹងថាជាទីបញ្ចប់ហើយ"[1955]។ ការគំរាមកំហែងពីការបាត់ខ្លួន បានបណ្តាលឲ្យមានការភ័យខ្លាចជាប់ជានិច្ចចំពោះជនស៊ីវិល និងកម្មាភិបាលខ្មែរក្រហមក្នុងអំឡុង

---

[1953] ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.២៣ ["ទឹកសាប [...] ក៏ជាកន្លែងសម្លាប់ដែរ"]។ ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៉ុណ្ណា ឆ.១១ ["តាមខ្ញុំដឹង ពួកយោធាថាកងពល គឺគេសម្លាប់នៅជិតកន្លែងគុកទឹកសាប"]។ ឯកសារ D114/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង ឡូង ឆ.២៩-៣០ ["ខ្ញុំឮសួរថា គេយកមនុស្សទៅសម្លាប់ និងកប់នៅកន្លែងទឹសាប [...] ឆ.៣០៖ ខ្ញុំចាំថា មនុស្សដែលត្រូវបានចាប់ខ្លួនពីកន្លែងផ្សេង ត្រូវគេយកទៅទឹកសាប។ អ្នកខ្លះនិយាយថា អ្នកដែលគេចាប់ខ្លួន គឺគេយកមកពីតាមកោះផងដែរ"]។ ឯកសារ D114/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ឆ.១២៨៤ ១៣១ [កម្មករនៅក្នុងចម្ការដូងនៅកងកេង៖ "នៅជិតផ្ទះខ្ញុំឥឡូវហ្នឹង។ ជាកន្លែងដែលគេសម្លាប់មនុស្ស [...] ឆ.១៣១៖ មិត្តខ្ញុំត្រូវគេយកទៅ គឺយកទៅសម្លាប់នៅហ្នឹង"]។

[1954] ឯកសារ D114/2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.១០ ["ពួកប្រជាជនមូលដ្ឋាននៅកន្លែងនេះគេដឹងទាំងអស់គ្នាថា កន្លែងសម្លាប់មនុស្សមានពីរកន្លែង គឺមួយនៅចម្ការធូរេន អ៊ុំង ក្រពុំផ្ការ និងមួយទៀតនៅចម្ការធូរេននៅទឹកសាប"]។ ឯកសារ D54/121 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លិន សារិន ឆ.៤៤ ២២ [អតីតសមាជិកកងកុមារ បានមើលឃើញដោយផ្ទាល់ភ្នែកនូវការសម្លាប់នៅទឹកសាប នៅក្នុងតំបន់មួយ ដែលគាត់បានពណ៌នាថាជា "ចម្ការធូរេន និងសាវម៉ាវ" គាត់បាននិយាយថា ការមើលឃើញការសម្លាប់នៅទីកន្លែងនោះ "បញ្ជាក់នូវអ្វីដែលខ្ញុំបានឮសួរ ថាកន្លែងនេះ គឺសម្រាប់ការសម្លាប់។ យើងបានទទួលស្គាល់ភ្លាមៗថា ពាក្យចរចាមអារាម គឺជាការពិត"]។ ឯកសារ D114/177 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉េង ស៊ឹក ឆ.៩ ["គេយកទៅដាក់ទឹកសាប អាខ្លះគេសម្លាប់នៅទីនោះ អាខ្លះយកទៅសម្លាប់នៅចម្ការម្រេច"]។ ឯកសារ D54/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណៃន ឆ.៥ ["កន្លែងសម្លាប់ គឺនៅចម្ការធូរេន និងចម្ការម្រេច ដែលមានទំហំប្រហែល៣០ហិកតា"]។ ឯកសារ D1.3.13.8 កិច្ចសម្ភាសន៍របស់ ប៉ែន សារិន ជាមួយ ក.ស.ព EN 00217562 ["កន្លែងសម្លាប់មនុស្សមួយទៀត គឺនៅទឹកសាប នៅក្នុងស្រុកព្រៃនប់"]។

[1955] ឯកសារ D114/3 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.៤ ["កាលពីជំនាន់នោះ អ្នកណាក៏ដឹងដែរ បើសិនជាពួកយោធាខ្មែរក្រហមចាប់មនុស្ស ហើយនាំយកទៅទឹកសាប គឺយើងទាំងអស់គ្នាដឹងជាទីបញ្ចប់ហើយ"]។

ពេលនៃកម្ពុជាប្រជាធិបតេយ្យ[1956]។ តាមពិត ជនរងគ្រោះជាច្រើនដែលត្រូវបានបញ្ជូនទៅទឹកសាប "មិនដែលឃើញត្រឡប់មកវិញ" "មិនដែលរស់រានមានជីវិត" ឬ "បាត់ខ្លួន" [1957]។ អតីតអ្នកជាប់ឃុំនៅទឹកសាបឈ្មោះ មូល ឈិន គិតថា៖

---

[1956] ឯកសារ D54/98 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាង រ៉េត ឆ.៥១-៥៣ ["នៅក្នុងកងពល១៦៤ ក៏មានមនុស្សបាត់ខ្លួនដែរ ដូចជាមេបញ្ជាការរងជាដើម ប៉ុន្តែខ្ញុំមិនដឹងថាគេយកពួកគាត់ទៅណាទេ។ [...] ឆ.៥៣[៥២]៖ នៅសម័យនោះ គឺមានការភ័យខ្លាចថាយើងមានការពាក់ព័ន្ធជាមួយមនុស្សដែលបាត់ខ្លួនទាំងនោះ។ ហេតុដូច្នេះហើយបានជាយើងមិនសួរនាំ។ នៅពេលនោះ គេនិយាយប្រាប់យើងថា ការងារមិនត្រូវដឹង គឺមិនបាច់ចង់ដឹងទេ។ ស.៖ តើលោកមានការភ័យខ្លាចដែរឬទេ នៅពេលដែលមនុស្សនៅក្នុងកងពលរបស់លោកបាត់ខ្លួន? ឆ.៥៣៖ បាទ ខ្ញុំមានការភ័យខ្លាច ប៉ុន្តែមិនហ៊ានសួរនាំគេទេ"]។

[1957] ឯកសារ D114/242 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ប៊ុននី ឆ.៨៦-៩៨ ["ខ្ញុំក៏មិនបានដឹងថា អ្នកទោសដែលគេបញ្ជូនទៅនោះ អត់ឃើញត្រឡប់មកវិញទេ។ ខ្ញុំសួរគ្នីគ្នា ដែលធ្លាប់ឃើញហ្នឹង គេថាបញ្ជូនទៅទឹកសាបបាត់អស់ហើយ [...] ឆ.៩៨[៩៩]៖ ប្រជាពលរដ្ឋនៅម្តុំហ្នឹងគឺ ឲ្យតែខុស គេយកទៅដាក់គុកហ្នឹង។ យកទៅដាក់ហើយ អត់ឃើញត្រឡប់មកវិញទេ សម្លាប់ចោលអស់ហើយ"]។ ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.១៧-១៨ ["យើងដឹងថា ទឹកសាប គឺជាគុក ដោយសារឈ្មោះ ធូ ដែលនៅក្នុងចំណោមអតីយោធាក្នុងកងរបស់ខ្ញុំបីនាក់ ដែលត្រូវបានគេចាប់ខ្លួន ហើយបញ្ជូនទៅទីនោះ។ ក្នុងចំណោមអ្នកទាំងបីនោះ ពីរនាក់ ត្រូវបានបាត់ខ្លួនរហូត នៅរស់តែឈ្មោះ ធូ ប៉ុណ្ណោះ [...] ឆ.១៨៖ នៅពេលដែលខ្ញុំសួរ ធូ អំពីយោធាពីរនាក់ទៀតដែលចាប់ពីកងរបស់ខ្ញុំ ដែលមានឈ្មោះ ឌឿន និង វឿន គាត់បានប្រាប់ខ្ញុំថា អ្នកទាំងពីរនោះ ត្រូវបានគេយកចេញពីគុកទឹសាប ហើយបាត់មុខរហូត"]។ ឯកសារ D114/86 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.១៤ ["ប្រសិនបើអ្នកណាម្នាក់ធ្វើអ្វីខុស គេនឹងយកអ្នកនោះ ទៅកន្លែងផ្សេង ដែលខ្ញុំមិនដឹង ប្រហែលជាទៅទឹកសាប។ បើទៅហើយ គឺកម្រត្រឡប់មកវិញណាស់"]។ ឯកសារ D114/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ឆ.១៤៧ ["ស.៖ មានអ្នកណាដែលបញ្ជូនទៅទឹកសាបហើយ បានត្រឡប់មកវិញទេ? ឆ.១៤៧៖ អត់"]។ ឯកសារ D54/36 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ឆ.៦-៧ ["អ្នកណាក៏ដោយឲ្យតែគេបញ្ជូនទៅទឹកសាប គឺមិនដែលរស់ទេ [...] ឆ.៨៖ ក្រោយពេលដែលខ្ញុំរត់គេចពីវៀតណាមក្នុងឆ្នាំ ១៩៧៩ ខ្ញុំបានជួបឈ្មោះ សឿន ដែលជាអតីតៈនៅកង ៣១០ ជាមួយគ្នា គាត់បានប្រាប់ខ្ញុំថា អ្នកដែលគេបញ្ជូនទៅទឹកសាបហើយ គឺត្រូវបានគេសម្លាប់ចោលទាំងអស់ហើយ ហើយបងរបស់គាត់ ឈ្មោះ សៀក ក៏ត្រូវបានសម្លាប់នៅទីនោះដែរ"]។ ឯកសារ D54/123 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.៨-៩, ១២ ["តាមការសង្កេតរបស់ខ្ញុំ អ្នកដែលចាប់បានមកពីសមុទ្រ មានខ្មែរ ថៃ និងវៀតណាម ហើយត្រូវបានគេនាំទៅទឹកសាប ហើយក៏បង្ហើយនៅទីនោះទាំងអស់ ពុំមានអ្នកណាមួយវិលត្រឡប់មកវិញទេ"]។ ឯកសារ D54/90 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ឆ.៤៤ ["ស.៖ តើលោកធ្លាប់ឃើញអ្នកដែលត្រូវបានចាប់ខ្លួនដោយយោធាខ្មែរក្រហមនៅពេលនោះ ធ្លាប់ត្រឡប់មកវិញដែរឬទេ? ឆ.៤៤៖ ទេ គ្មាននរណាម្នាក់ត្រឡប់មកវិញទេ។ មានតែប្រពន្ធ ដែលនៅមេម៉ាយ"]។ សូមមើលផងដែរ ឯកសារ D54/103 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.២២ ["តើមានពួកយោធាដែលមានសមាសភាពមិនល្អ ហើយនិងអតីតយោធា៣៨៦

អ្នកដែលជាប់គុកនៅទីនោះ មិនអាចរស់រានមានជីវិតបានទេ គឺអាចស្លាប់ដោយសារគេយកទៅសម្លាប់ ឬស្លាប់ដោយដាច់ពោះស្លាប់តែម្តង[1958]។

519. សមាជិកគ្រួសារជាច្រើនរបស់អ្នកដែលត្រូវបានបញ្ជូនទៅទឹកសាប មិនដែលបានជួបជុំគ្នាជាមួយមនុស្សជាទីស្រលាញ់របស់ពួកគេទេ។ អ្នកខ្លះឮពាក្យចចាមអារ៉ាមថា សាច់ញាតិទាំងនោះបានស្លាប់នៅទីនោះ[1959]។ សាក្សីជាច្រើនបានរៀបរាប់ថា ជនរងគ្រោះត្រូវបានបញ្ជូនទៅទឹកសាបដើម្បីសម្លាប់[1960]។

ខ្លះត្រូវបានអប់រំកែប្រែបានហើយ ត្រូវបានបញ្ជូនទៅអង្គភាពដើមវិញដែរឬទេ មុនឆ្នាំ ១៩៧៩? ឆ.២២៖ តាមខ្ញុំដឹង គឺគ្មានទេ”]។ ឯកសារ D54/87 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ឆ.១១៩ [(កងវរៈសេនាតូច ៤៤ កងវរៈសេនាធំ ១៤០) “ស.៖ ជាធម្មតា បើអង្គភាពបញ្ជូនអ្នកនោះទៅអប់រំកែប្រែ និងលត់ដំ តើពួកគេត្រឡប់មកអង្គភាពដើមវិញដែរឬទេ? ឆ.១១៩៖ មិនមានអ្នកណាម្នាក់ត្រឡប់មកវិញទេ អ្នកទាំងនោះបាត់ខ្លួនរហូត។”]។ ឯកសារ D54/78.1 កិច្ចសម្ភាសន៍របស់ ណុប ហាល ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា KH 00926640 [“ស.៖ គ្រាន់ថាដូចថាមករៀនទៅបាត់ទៅ? ឆ.៖ អឺ! បាត់មិនឃើញទៅវិញ”]។ សូមមើលផងដែរ ឯកសារ D54/122 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.១១-១២ [ពួកប្រជាជនស៊ីវិល នៅរាម “ខ្ញុំសង្កេតឃើញថាមនុស្សបាត់ខ្លួន ហើយមិនឃើញត្រឡប់មកវិញទេ”]។

1958 ឯកសារ D114/40 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.៨។

1959 ឯកសារ D114/32 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស សារ៉ាន ឆ.៧៤-៧៦ [ពេទ្យកងពល ១៦៤ ប្រពន្ធយោធាកងពល ១៦៤៖ “ខ្ញុំឮពាក្យចរចាមអារ៉ាមថា គេយកគាត់ទៅទឹកសាប នៅកំពង់សោម [...] ឆ.៧៥៖ មិនដែលជួបទេ [...] ឆ.៧៦៖ ខ្ញុំជឿ ព្រោះខ្ញុំឮគេនិយាយថាគាត់ស្លាប់បាត់ទៅហើយ”]។ ឯកសារ D54/103 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.៣ [“មានក្រុមនារីក្រមុំប្រហែលជាង២០នាក់ធ្វើការជាប់ជាមួយ បង នង ឆាន ក្នុងនាមជាចុងភៅ និរសា និងជំនួយការរបស់គាត់។ ក្រោយពីគេចាប់បង ឆាន នារីទាំងអស់នោះត្រូវបានយកទៅដាក់គុកនៅទឹកសាប [...] បន្ទាប់ពីជ័យជម្នះឆ្នាំ ១៩៧៩ ខ្ញុំបានជួបឪពុកម្តាយនារីម្នាក់ ឈ្មោះ ចាំ [...] គាត់ប្រាប់ថា នារីឈ្មោះ ចាំ មិនដែលបានឃើញត្រឡប់មកផ្ទះវិញទេ [...] នៅពេលនោះ ខ្ញុំបានឮថា នារីជាង២០នាក់ដែលគេចាប់ទៅទឹកសាបនោះ គឺត្រូវបានគេចោទថាជាស្រីកំណាន់របស់ ឆាន”]។

1960 ឯកសារ D54/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ឆ.៤-៥ [ពណ៌នាអំពីទាហាន លន់ នល់ ដែលគេយកទៅសម្លាប់នៅទឹកសាប] ឆ.១៩៖ [“តាមដែលខ្ញុំឮថាការចាប់មនុស្សទៅកន្លែងទឹកសាបនោះ គឺសម្លាប់ភ្លាមៗតែម្តង”]។ ឯកសារ D114/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង ឡុង ឆ.២៩ [“ខ្ញុំឮសួរថា គេយកមនុស្សទៅសម្លាប់ និងកប់នៅកន្លែងទឹកសាប”]។ ឯកសារ D1.3.13.8 កិច្ចសម្ភាសន៍របស់ ប៉ែន សារិន ជាមួយ ក.ស.ព EN 00217562 [“កន្លែងសម្លាប់មនុស្សមួយទៀត គឺនៅទឹកសាប នៅក្នុងស្រុកព្រៃនប់”]។ ឯកសារ D114/2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.១០ [“ពួកប្រជាជនមូលដ្ឋាននៅកន្លែងនេះ គេដឹងទាំងអស់គ្នាថា កន្លែង

520. សាក្សីផ្ទាល់ភ្នែកបានប្រាប់អំពីការសម្លាប់នៅទីតាំងទឹកសាប។ ជេត ប៉ុណ្ណា ដែលត្រូវបានរំសាយ និងបញ្ជូនឱ្យទៅធ្វើការក្នុងវាលស្រែនៅក្បែរនោះ[1961] បានពណ៌នាពីការមើលឃើញសាកសពដែលស្គមរីងរៃអណ្តែតតាមស្ទឹងទឹកសាបនៅជិតគុកនេះ[1962]។ លិន សារិន ដែលជាសមាជិកម្នាក់នៃកងកុមារនៅត្រើយម្ខាងពីបរិវេណទីតាំងទឹកសាបនោះ[1963] កន្លងមកបានឮថា ទឹកសាបគឺជាកន្លែងសម្លាប់មនុស្ស[1964]។ នៅពេលនោះ ខ្លួនគាត់ផ្ទាល់បានឃើញជនរងគ្រោះនៅទឹកសាប ត្រូវបានគេ

---

សម្លាប់មនុស្សមានពីរកន្លែង គឺមួយនៅចម្ការធូរេន អ៊ុំង ក្រពុំផ្ការ និងមួយទៀតនៅចម្ការធូរេននៅទឹកសាប"]។ ឯកសារ D54/121 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លិន សារិន ឆ.១ ["អ្វីដែលខ្ញុំបានឃើញនោះគឺ គេបានទាញមនុស្សចេញពីក្នុងឡាន ហើយវាយកញ្ចឹងកអ្នកទាំងនោះនឹងដំបងរហូតដល់ស្លាប់"]។ សូមមើលផងដែរ ឯកសារ D114/16 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក វណ្ណា ឆ.១៧ ["កាលនោះ ទាំងប្រជាជនធម្មតា និងយោធា ត្រូវបានចាប់ខ្លួន យកទៅដាក់គុក ហើយខ្លះទៀតត្រូវបានយកទៅសម្លាប់ចោលតែម្តង"]។

1961 ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៉ុណ្ណា ឆ.១៧-១៩ ["ខ្ញុំត្រូវបានគេដកចេញពីកងនៅឆ្នាំ១៩៧៧ ហើយបង្ខំឱ្យធ្វើការនៅស្រែ។ ពេលដែលខ្ញុំត្រូវបានគេចាត់តាំងឱ្យធ្វើការនៅជិតស្ទឹងនោះ"]។ [...] ឆ.១៩៖ បន្ទាប់ពីត្រូវគេដកចេញអង្គភាព ខ្ញុំត្រូវបានគេចាត់ទុកថាជាសមាភាពមិនល្អ។ [...] ពេលគេនៅក្នុងមន្ទីរឃុំឃាំងទឹកសាប ពួកអ្នកទោសទាំងនេះ ត្រូវបានគេដាក់ឱ្យធ្វើការនៅត្រើយខាងកើតស្ទឹង។ ចំណែកពួកខ្ញុំ ដែលនៅក្នុងកងទាំងបីនេះ ត្រូវបានគេដាក់ឱ្យធ្វើការនៅត្រើយខាងលិចស្ទឹង"]។

1962 ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៉ុណ្ណា ឆ.១៧៤ ២៤ ["ខ្ញុំដឹងច្បាស់ថា ទឹកសាប គឺកន្លែងគុក និងកន្លែងសម្លាប់ ដោយសារខ្ញុំឃើញគេសម្លាប់នៅទីនោះ [...] ពេលដែលខ្ញុំត្រូវបានគេចាត់តាំងឱ្យធ្វើការនៅជិតស្ទឹងនោះ ខ្ញុំធ្លាប់ឃើញ ខ្មោចអណ្តែតទឹកនៅតាមស្ទឹង នៅជិតគុកទឹកសាប [...] ឆ.២៤៖ យើងដឹងថា សាកសពទាំងនោះ គឺជាសាកសពអ្នកទោស។ អ្នកទោស គឺទន់ខ្សោយ គ្មានកម្លាំង ហើយស្គមស្គាំង។ ខ្ញុំពុំបានឃើញសាកសពទាំងនោះ ត្រូវគេចងទេ។ ខ្ញុំសូមជម្រាបតាមត្រង់ថា អ្នកទោសនៅពេលនោះ គឺទន់ខ្សោយ ហើយស្គមស្គាំង ដូច្នេះ ពេលគេយក់ទៅសម្លាប់ គេពុំចាំបាច់ចាប់ចងទេ។ យើងពុំបានឃើញសាកសពអណ្តែតទឹករាល់ថ្ងៃនោះទេ យើងឃើញសាកសពអណ្តែតទឹក បួនប្រាំថ្ងៃម្តង"]។

1963 ឯកសារ D54/121 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លិន សារិន ឆ.៧-៨ ["នៅក្នុងចន្លោះខែកក្កដា និងខែសីហា ឆ្នាំ ១៩៧៦ គឺក្នុងរដូវភ្លៀង និងធ្វើស្រែ។ [...] ឆ.៨៖ នៅពេលនោះ ខ្ញុំ និងក្មេងៗផ្សេងទៀតត្រូវបានចាត់តាំងឱ្យទៅដើរកាប់ដើមទន្ទ្រានខេត្រ នៅត្រើយខាងលិចព្រែកទឹកសាប គឺទល់មុខចម្ការធូរេន សាវម៉ាវទឹកសាប។ កាលនោះ ទាំងខ្ទងទំនប់ និងចម្ការនៅទឹកសាប ដែលនៅឆ្ងាយពីគ្នាប្រហែលជាង ២០០ ម៉ែត្រ ត្រូវបានគេកាប់អម្ពាតព្រៃអស់ ធ្វើឱ្យយើងអាចមើលឃើញគ្នាទៅវិញទៅមក"]។

1964 ឯកសារ D54/121 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លិន សារិន ឆ.២២ ["យើងមានអារម្មណ៍ភ័យខ្លាចដោយសារវាគួសបញ្ជាក់នូវអ្វីដែលយើងបានឮពីមុនមកថានេះជាកន្លែងសម្លាប់មនុស្ស។ យើងដឹងភ្លាមៗថា ពាក្យចចាមអារាមនោះគឺជារឿងពិត"]។

"ទាញមនុស្សចេញពីក្នុងឡាន ហើយវាយកញ្ជើងកអ្នកទាំងនោះរហូតដល់ស្លាប់"[1965] ព្រមទាំងអ្នកដែលគេ "វ៉ៃច្រើនដងដែរ ប៉ុន្តែមិនស្លាប់ភ្លាមៗនោះទេ"[1966]។ គាត់ "បានឮសំឡេងគេវ៉ៃមនុស្សនឹងដំបង និងឮសំឡេងមនុស្សស្រែកថ្ងូរ"[1967]។ ជាលទ្ធផល គាត់ក៏សន្និដ្ឋានថា មនុស្សផ្សេងទៀតមកពីឃុំរបស់គាត់ដែលគាត់បានឃើញគេយកទៅទឹកសាប ឬអ្នកដែលបានបាត់ខ្លួននោះ ត្រូវបានគេយកទៅសម្លាប់នៅទីនោះ[1968]។

521. នៅក្នុងឆ្នាំ ១៩៧៩ បន្ទាប់ពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ អដ្ឋិធាតុមនុស្ស និងសាកសពត្រូវបានគេរកឃើញនៅកន្លែងសម្លាប់មនុស្សទឹកសាប ដែលមានទីតាំងនៅក្នុងចម្ការទុរេន សាវម៉ាវ និងម្រេច នៅក្នុងរណ្ដៅ និងនៅលើដីគ្មានអ្វីបិទបាំង[1969]។ រណ្ដៅជាច្រើនមានទីតាំងនៅជាប់ដើម

---

1965 ឯកសារ D54/121 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លិន សារិន ឆ.១៤ ១៣-១៥ ["អ្វីដែលខ្ញុំបានឃើញនោះគឺគេបានទាញមនុស្សចេញពីក្នុងឡាន ហើយវាយកញ្ជើងកអ្នកទាំងនោះនឹងដំបងរហូតដល់ស្លាប់។ [...] នៅពេលដែលខ្ញុំនិយាយថា វ៉ៃត្រង់កញ្ចើងក គឺចង់បញ្ជាក់អំពីរបៀបទូទៅដែលជនរងគ្រោះទាំងនោះត្រូវបានគេយកទៅសម្លាប់ [...] ឆ.១៣៖ ឡានដឹកមនុស្សមកឈប់ក្រោមដើមធូរេន និងដើមសាវម៉ាវ។ មិនស្គាល់ម៉ាកឡានទេ ប៉ុន្តែឡាននោះធំ ហើយទ្រុងខាងក្រោយបិតជិត។ តាមខ្ញុំសន្និដ្ឋាន ពួកគេទាញមនុស្សចេញពីឡាន ហើយវ៉ៃភ្លាមៗ។ [...] ខ្ញុំមិនអាចប្រាប់លោកថាវាជាប្រភេទឡានអ្វីទេ ព្រោះពួកខ្ញុំមិនបានចាប់អារម្មណ៍ទេ ប៉ុន្តែវាជាប្រភេទឡានធំ។ [...] ឆ.១៤៖ ខ្ញុំមិនអាចប្រាប់លោកពីចំនួនមនុស្សបានទេ ពីព្រោះវាស្ថិតនៅចម្ងាយឆ្ងាយ។ [...] ពុំដឹងពីចំនួនជនរងគ្រោះ និងចំនួនជនដែលដល់ទេ។ [...] ឆ.១៥៖ ខ្ញុំមិនដឹងថាពួកថាជាប្រុស ស្រីនោះទេ"]។

1966 ឯកសារ D54/121 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លិន សារិន ឆ.១ ["ប៉ុន្តែខ្ញុំក៏បានឃើញអ្នកដែលគេវ៉ៃច្រើនដងដែរ ប៉ុន្តែមិនស្លាប់ភ្លាមៗនោះទេ"]។

1967 ឯកសារ D54/121 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លិន សារិន ឆ.១២ ["ពួកខ្ញុំបានឮសំឡេងគេវ៉ៃមនុស្សនឹងដំបង និងឮសំឡេងមនុស្សស្រែកថ្ងូរ"]។ សូមមើលជាបន្ថែម ឯកសារ D54/121 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លិន សារិន ឆ.៨៤ ១៤ ["ដូច្នេះពួកខ្ញុំក្មេងៗអាចមើលឃើញគេវ៉ៃមនុស្ស និងឮសំឡេងថ្ងូររបស់មនុស្ស ដែលត្រូវបានគេវ៉ៃនៅទឹកសាប [...] ឆ.១៤៖ ពួកយើងគ្រាន់តែឮសំឡេងស្រែក និងសំឡេងវ៉ៃប៉ុណ្ណោះ"]។

1968 ឯកសារ D54/121 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លិន សារិន ឆ.១៤ ១៥ ["តាមខ្ញុំស្មាន មនុស្សទាំងអស់ដែលខ្ញុំបានឃើញ គេយកទៅទីតាំងសម្លាប់នៅទឹកសាប គឺបញ្ចប់នៅទីនោះទាំងអស់ ពោលគឺគេពុំបាននាំពួកនោះវិលត្រឡប់មកវិញទេ [...] ឆ.១៥៖ គ្រាន់តែដឹងថាជាប្រជាជនមកពីឃុំនេះតែម្ដង។ ខ្ញុំនិយាយបែបនេះ ដោយសារក្នុងពេលព្រឹត្តិការណ៍នេះកើតឡើង ក៏មានមនុស្សពីសហករណ៍បាត់ខ្លួនដែរ។ ដូច្នេះខ្ញុំសន្និដ្ឋានថា អ្នកដែលបាត់ខ្លួននោះ គឺត្រូវគេយកមកសម្លាប់នៅទីនោះតែម្ដង"]។

1969 ឯកសារ D54/89 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កុយ ណែន ឆ.៥៤ ២៨-៣០ [បញ្ជាក់ថា នៅក្នុងឆ្នាំ ១៩៨០ គាត់ត្រូវបានចាត់តាំងឱ្យធ្វើជាប្រធានភូមិពូធឿង ដោយអាជ្ញាធរវៀតណាមថ្មី។ ហើយទទួលបន្ទុកលើជ្រើសរើសកម្លាំងសេនាជនក្នុងមូលដ្ឋានបោសសម្អាតនៅក្នុងតំបន់នោះ។ នៅចម្ការធូរេន និងចម្ការម្រេច ពួកគេបានឃើញ

សាកសព និងឆ្អឹងខ្មោច ឯកសណ្ឋានទាហាន លន់ នល់ ស្បែកជើង និងមួក នៅពាសពេញដី និងនៅក្នុងរណ្តៅផងដែរ]។ ឯកសារ D114/3 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.៩-១០ ["នៅខែឧសភា ឬខែមិថុនា ឆ្នាំ ១៩៧៩ [...] ខ្ញុំបានទៅកន្លែងទឹកសាប ដើម្បីរកកាប់អំពៅមកធ្វើស្ករហូប [...] មុនពេលទៅដល់ចម្ការអំពៅ យើងត្រូវដើរកាត់ចម្ការធូរេនទឹកសាបសិន ដែលជាកន្លែងដែលយើងឃើញឆ្អឹង និងនិងខោអាវរាយប៉ាយនៅលើដីពាសពេញ [...] ឆ.១០៖ ខ្ញុំមិនបានដើរលុកគ្រប់កន្លែងក្នុងចម្ការនោះទេ ប៉ុន្តែគ្រប់ដើមធូរេនដែលខ្ញុំទៅឃើញ គឺមានរណ្តៅសាកសពនៅក្រោមដើមធូរេននីមួយៗ។ដើមធូរេនស្ទើរតែទាំងអស់ដែលមានរណ្តៅសាកសពនៅពីក្រោម គឺងាប់។ ចំនួនរណ្តៅសាកសព បើតាមខ្ញុំស្មានអាចមានចំនួនរាប់រយ"]។ ឯកសារ D54/123 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.៩ំ ១២ ["វាកាន់តែបញ្ជាក់ឱ្យកាន់តែច្បាស់ ក្រោយពេលខ្ញុំវិលត្រឡប់មកវិញ ថាមានការសម្លាប់នៅទីនោះមែន ដោយសារខ្ញុំបានទៅ និងឃើញឆ្អឹង ព្រមទាំងលលាដ៍ក្បាលនៅទីនោះ។"]។ [...] ឆ.១២៖ គេជីករណ្តៅនៅក្រោមដើមធូរេន។ បើសិនជាខ្ញុំមិនច្រឡំទេ អ្នកទាំងនោះត្រូវបានគេវ៉ៃនឹងត្បូងចបហើយ ព្រោះខ្ញុំឃើញចបនៅរាយប៉ាយនៅទីនោះ"]។ ឯកសារ D54/121 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លិន សារិន ឆ.២៤-២៥ ["ស.៖ តើលោកដែលធ្លាប់ទៅខាងកើតព្រែកទឹកសាបដែលជាកន្លែងព្រឹត្តិការណ៍នោះកើតឡើងដែរឬទេ? ឆ.២៤៖ ខ្ញុំបានទៅកន្លែងនោះ ក្រោយពីរបបខ្មែរក្រហម។ [...] ឆ.២៥៖ ខ្ញុំឃើញមានរណ្តៅ ជួនកាលមួយ ឬពីរនៅគល់ដើមធូរេន/សាម៉ាវ នៅជិតផ្លូវ ដែលឡានអាចចូលទៅបាន។ ជាសរុប ខ្ញុំគិតថា មានប្រហែលពី២០ទៅ៣០រណ្តៅ។"]។ ឯកសារ D114/177 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉េង សឹក ឆ.១០ំ ១៩ំ ២១-២៩ំ ៣៤ំ ៤២-៤៩ [សាក្សីបានឃើញឆ្អឹងខ្មោច និងខោអាវនៅកន្លែងទឹកសាបនោះពីរដង។ លើកទីមួយ [ឆ.១០ំ ១៩ំ ២១-២៩ំ ៤៥] គាត់បានឃើញជ្រុកឈ្មួសចេញ ឈ្មួសឡើងមួយកំភ្លូសៗនៅពេញវាលទាំងអស់ ប្រហែលជាងមួយហិចតា នៅខាងក្រោមផ្លូវទៅខាងជើងផ្លូវជាតិលេខ៤ នៅជិតព្រែក ផ្ទះលោក ឆន គាត់ធ្វើវីឡាន់ទុំង។ គាត់មិនអាចប៉ាន់ស្មានអំពីចំនួនសាកសពបានទេ។ គាត់ក៏បានឃើញខោអាវទាហាននៅក្នុងតំបន់ដដែលផងដែរ។ លើកទីពីរ [ឆ.៣៤ំ ៤២-៤៩] គាត់បានឃើញរណ្តៅច្រើនណាស់ គ្រប់ដើមធូរេន បួនជ្រុងៗ រាប់រយដើមនៅខាងលើនៃកន្លែងទឹកសាប។ បើទោះបីគាត់មិនបានជីករណ្តៅទាំងនោះ គាត់បានឃើញដើមធូរេនងាប់ ដែលបញ្ជាក់ថារណ្តៅទាំងនោះមានសាកសព]។ ឯកសារ D114/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង ឡូង ឆ.៤១ ["ខ្ញុំបានឃើញឆ្អឹងខ្មោចចំនួនតិចទេ។ ខ្ញុំគិតថាគេកប់រាក់ៗ ហើយសត្វអាចកកាយឆ្អឹងទាំងនោះចេញមកក្រៅ។ ឧទាហរណ៍ ខ្ញុំបានឃើញឆ្អឹងដៃ ឬជើងនៅរាយប៉ាយលើដី"]។ ឯកសារ D114/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ឆ.១៤១-១៤៣ំ ១៤៥ំ ១៥៥ំ ១៦២ំ ១៦៤ំ ៣១១-៣១២ ["ដល់ក្រោយឆ្នាំ ៨០ គេឱ្យខ្ញុំទៅគាស់រណ្តៅយកឆ្អឹង មកដាក់នៅកន្លែងមួយដែលគេប្រើជាភស្តុតាងសម្រាប់តុលាការឥឡូវ។ កន្លែងនោះ មានដើមធូរេន ដើមសាវម៉ាវ ដែលជារបស់លោក ឆន។ ខ្មែរក្រហមចាប់ផ្តើមកាប់រណ្តៅ នៅចំកណ្តាល ៤ ដើមហ្នឹង ហើយវ៉ៃមនុស្សចូលក្នុងរណ្តៅហ្នឹងធំ ហើយត្រូវប្រើធ្វើជី។ [...] ឆ.១៤២៖ [...] ខាងឃោសនាការគេឱ្យជីកយកឆ្អឹងដាក់សារមន្ទីរ។ នៅក្នុងរណ្តៅមានក្បាលកូនក្មេង មនុស្សចាស់ និងបរទេសក៏មាន ស.៖ លោកយកឆ្អឹង យកក្បាលប្រហែលជាប៉ុន្មាន? ឆ.១៤៣៖ ក្បាលប្រហែល៤ទៅ១០ និងឆ្អឹង ដាក់ក្នុងបាវយកមកដល់នៅថ្នល់ជាតិលេខ៤ ហើយខាងឃោសនាការគេយកឡានដឹកមកភ្នំពេញ។ [...] ឆ.១៤៥៖ តែច្រើន។ [...] ឆ.១៥៥៖ ខ្ញុំអត់បានរាប់ទេ តែខ្ញុំជីកបានតែបីរណ្តៅទេ។ [...] ស.៖ លោកអាចដឹងថា ក្បាលសរុបដែលលោកជីកពីទីនោះ ប្រហែលប៉ុន្មាន? ឆ.១៦២៖ ប្រហែល ១០ ក្បាលទេ។ [...] ឆ.១៦៤៖ មិនមានអ្នកណាជីកផ្សេងទៀតទេ ខ្ញុំជី

ទុរេន និងសាវម៉ាវ ដែលផ្តល់ជីវជាតិទៅដល់ដើមឈើទាំងនេះ ប៉ុន្តែចំនួនសាកសពមានច្រើនពេក ដែលបណ្តាលឲ្យដើមឈើ និងដំណាំហួបផ្លែទាំងអស់ងាប់[1970]។ មានផ្នូរកប់សពរួមប្រហែលបួន នៅក្រោមដើមទុរេននីមួយៗ ដែលសរុបមានផ្នូរកប់សពរួមចំនួនរាប់រយ[1971]។

---

កប្រហែល ១០ ក្បាល។ ខ្ញុំមិនហ៊ានស្មានទេ។ [...] ឆ.៣១១៖ ខ្ញុំជីក ៣រណ្តៅ។ [...] ឆ.៣១២៖ ខ្ញុំយក នេះពីរបីក្បាល នោះពីរបីក្បាល"]។ ឯកសារ D114/241 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆេង ជាង ឆ.១១៨៤ ១២០ [អ្នកស្រុកនៅភូមិរាម បញ្ជាក់ថា គាត់ "ឮថា មានខ្មោចកប់នៅក្បែរទឹកសាប ហើយមនុស្សទៅជីករកមាសនៅទីនោះ។ នៅហួសផ្ទះខ្ញុំ បត់ចូលខាងឆ្វេងដៃ [...] ស្រុកខ្ញុំនៅនេះ ត្រូវតែដឹងតែម្តង ព្រោះពាក្យចចាមអារាមពេលតែភូមិហ្នឹង"]។ ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៉ុណ្ណា ឆ.២៧ ["ដល់ភូមិស្នាច់ដែង ពួកប្រជាជននៅទីនោះ បានប្រាប់ខ្ញុំថា គេបានឃើញឆ្អឹងខ្មោចមនុស្សជាច្រើន ដែលស្ថិតនៅកន្លែងជិតគុកទឹកសាប។ ខ្ញុំបានប្រាប់ពួកគេវិញថា ខ្ញុំជឿថា មានឆ្អឹងខ្មោចនៅទីនោះមែន ដោយសារកន្លែងនោះ ជាបរិវេណគុករបស់ខ្មែរក្រហម។ ហើយកាលជំនាន់នោះ ខ្ញុំធ្លាប់បាននៅធ្វើការជិតទីនោះផង"]។ ឯកសារ D114/40 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.១០ ["គេយកសាកសពទៅកប់នៅជុំវិញទឹកសាបនោះតែម្តង គឺនៅក្រោមដើមដូង សាវម៉ាវ ធូរេន។ បច្ចុប្បន្ននេះ គឺពិបាករកឃើញកន្លែងទាំងនោះណាស់ ព្រោះមានគេផ្ទះពាសពេញទីនោះអស់ហើយ។ ខ្ញុំពុំដែលឃើញការសម្លាប់មនុស្សនៅទឹកសាបទេ គឺគ្រាន់តែដឹងថា គេយកមនុស្សទៅបាត់ ហើយអ្នកទាំងនោះមិនដែលវិលត្រឡប់មកវិញទេ។ អ្នកដែលធ្វើការនៅទីនោះ និយាយប្រាប់ខ្ញុំថា គេយកមនុស្សទៅសម្លាប់ហើយកប់នៅតាមក្រោមដើមឈើ នៅទឹកសាប"]។

1970 ឯកសារ D54/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ឆ.៥ ["ដោយសារសាកសពច្រើនហួសហេតុ ពេលយកទៅកប់នៅកន្លែងនោះ ដើមឈើ និងដំណាំត្រូវងាប់អស់"]។ D114/3 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.១០ ["ដើមធូរេនស្ទើរតែទាំងអស់ ដែលមានរណ្តៅសាកសពនៅពីក្រោម គឺងាប់"]។ ឯកសារ D114/177 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉េង សឹក ឆ.៣៩៤ ៤៤ ["គេកាប់រណ្តៅកប់ខ្មោចរហូតដល់ដើមធូរេងាប់អស់ [...] ឆ.៤៤៖ កប់មនុស្សមិនកប់ តែឃើញដើមធូរេនងាប់"]។

1971 ឯកសារ D114/3 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.១០-១១ ["ចម្ការដើមធូរេននៅទឹកសាប តាមខ្ញុំស្មានមានទំហំប្រហែលជា១០ហិចតា។ ខ្ញុំមិនបានដើរលុកគ្រប់កន្លែងក្នុងចម្ការនោះទេ ប៉ុន្តែគ្រប់ដើមធូរេនដែលខ្ញុំទៅឃើញ គឺមានរណ្តៅសាកសពនៅក្រោមដើមធូរេននីមួយៗ។ ដើមធូរេនស្ទើរតែទាំងអស់ដែលមានរណ្តៅសាកសពនៅពីក្រោម គឺងាប់។ ចំនួនរណ្តៅសាកសព បើតាមខ្ញុំស្មានអាចមានចំនួនរាប់រយ [...] ឆ.១១៖ ខ្ញុំមិនមែនជាអ្នកជំនាញ ខ្ញុំមិនដឹងរឿងនេះទេ។ ខ្ញុំគ្រាន់តែដឹងថា ខ្ញុំបានឃើញឆ្អឹង។ អ្វីដែលខ្ញុំឃើញនៅពេលនោះ នៅជុំវិញដើមធូរេននីមួយៗ មានរណ្តៅសាកសពបួននៅពីក្រោម ដូច្នេះខ្ញុំអាចសន្និដ្ឋានថា ក្នុងដើមធូរេននីមួយៗមានសាកសពយ៉ាងតិចចំនួនបួន ដែលកប់នៅក្រោមដើម។ ខ្ញុំនៅចាំថាបានឃើញឆ្អឹងស្មងជើងមនុស្សវែងៗ ដែលកប់នៅតាមរណ្តៅខ្លះ"]។ ឯកសារ D114/177 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉េង សឹក ឆ.៤៣៤ ៤៧ [សាក្សីបានឃើញរណ្តៅច្រើនណាស់ គ្រប់ដើមធូរេន បួនជ្រុងៗ រាប់រយដើម"]។ សូមមើលផងដែរ D114/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង ឡុង ឆ.៤៦-៤៨ ["ស.៖ តើលោកបានឃើញផ្នូរខ្មោចចំនួនប្រហែលប៉ុន្មាន? ឆ.៤៦៖ ប្រហែល ១០ផ្នូរ។

522. រណ្តៅខ្លះមានអដ្ឋិធាតុរបស់មនុស្សមកពីគ្រួសារទាំងមូលរួមទាំងកុមារផងដែរ[1972]។ សាក្សី គុយ សម្បត្តិ បានឃើញ "រណ្តៅ និងផ្នូរកប់សពរួមជាច្រើន" ព្រមទាំងគ្រោងឆ្អឹងប្រហែល ១.០០០ រួមទាំងលលាដ៍ក្បាលកុមារ និងទារកផងដែរ[1973]។ សាកសពផ្សេងទៀតត្រូវបានរកឃើញនៅក្នុង និងជុំវិញអាងទឹកបេតុងមួយដែលត្រូវបានប្រើប្រាស់សម្រាប់ផលិតជី[1974]។ គ្រាប់កាំភ្លើង និងខ្សែនីឡុងក៏ត្រូវបានរកឃើញនៅលើទីតាំងនោះដែរ[1975]។ ដៃជើងរបស់ជនរងគ្រោះមួយចំនួន ត្រូវបានជាប់ចំណង ដែលបង្ហាញថា ការពិតជនរងគ្រោះត្រូវបានសម្លាប់ ហើយមិនមែនស្លាប់នៅក្នុងការប្រយុទ្ធ

---

ស.៖ សូមលោកជួយពិពណ៌នាអំពីផ្នូរទាំងនោះ? ឆ.៤៧៖ មានផ្នូរតូចៗ សម្រាប់ដាក់សាកសពមួយៗ។ ស.៖ តើលោកចំណាយរយៈពេលប៉ុន្មាននៅទីនោះ ដើម្បីពិនិត្យមើលកន្លែងនោះ? ឆ.៤៨៖ ខ្ញុំមិនបានចំណាយពេលច្រើននៅទីនោះទេ ខ្ញុំគ្រាន់តែបានឃើញផ្នូរខ្មោច ខ្ញុំខ្លាច ហើយខ្ញុំចាកចេញ"]។

1972 ឯកសារ D114/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ឆ.១៤៥៤ ១៦៤ ["តែច្រើន [...] ឆ.១៦៤៖ ជួនកាល មួយគ្រួសារ មានទាំងកូនក្មេង"]។

1973 ឯកសារ D114/69 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុយ សម្បត្តិ ឆ.១ ["ក្រោយឆ្នាំ ១៩៧៩ ខ្ញុំត្រឡប់ទៅមើលកន្លែងនោះ ខ្ញុំបានឃើញរណ្តៅ និងផ្នូរកប់សពរួមជាច្រើន។ ខ្ញុំឃើញមានឆ្អឹងខ្មោចនៅទីនោះ ខ្ញុំប៉ាន់ស្មានថា នៅតំបន់នោះ មានមនុស្សរហូតដល់១ពាន់នាក់ត្រូវបានគេកប់។ ខ្ញុំគិតថា មិនច្រើនជាងចំនួននេះទេ។ ខ្ញុំក៏បានឃើញក្បាលខ្មោចកុមារ និងទារកផងដែរ"]។

1974 ឯកសារ D114/176 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ សារឿន ឆ.៧-៨៤ ១០៤ ១២-១៣៤ ២១ [អ្នកភូមិមូលដ្ឋាន ដែលបានដឹកគោក្របីឱ្យស៊ីស្មៅនៅកន្លែងទឹកសាបនៅក្នុងរដូវប្រាំងចុងឆ្នាំ ១៩៧៩ បានបញ្ជាក់ថា គាត់បានឃើញលលាដ៍ក្បាលចំនួនប្រាំមួយ (៦) និងឆ្អឹងជាច្រើននៅក្នុង និងនៅជុំវិញសំណង់អាងមួយដែលធ្វើពីបេតុងដែលមានបណ្តោយពី ៣០-៤០ ម៉ែត្រ ដែលបានប្រើប្រាស់ដើម្បីធ្វើជីនៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម។ លលាដ៍ក្បាល និងឆ្អឹងទាំងនោះនៅរាយប៉ាយនៅក្នុងតំបន់នោះ ហើយលែងជាលលាដ៍ក្បាលនៅជាប់គ្នាទៀតហើយ។ មានខ្ទម និងអគារតូចៗនៅជុំវិញតំបន់ដដែលនោះ ដែលលែងមានសេសសល់ទៀតហើយ]។ ឯកសារ D114/227 ទីតាំងកងពលជើងទឹក ១៦៤ (កងពលលេខ៣)៖ កន្លែងសម្លាប់មនុស្សទឹកសាប កន្លែងពលកម្មដោយបង្ខំ សាក្សីលោក ចាន់ សារឿន របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង KH 01397159-01397166 [ដោយមានលេខកូអរដោនេភូមិសាស្ត្រ ផែនទី និងរូបថតទីតាំង និងសំណល់នៃអាងបេតុងសម្រាប់ធ្វើជី ដែលនៅទីនោះ សាក្សីបានសង្កេតឃើញឆ្អឹងខ្មោច នៅក្នុងឆ្នាំ ១៩៧៩]។

1975 ឯកសារ D114/3 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.១៣ ["ខ្ញុំមិនបានឃើញលលាដ៍ក្បាលដែលមានក្រណាត់ចងមុខទេ ប៉ុន្តែខ្ញុំឃើញមានខ្សែនីឡុងចំណងខ្លះនៅសល់នៅកន្លែងនោះ ហើយនិងលលាដ៍ក្បាលខ្លះមានស្នាមបែក"]។ ឯកសារ D114/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង ឡុង ឆ.៣៥៤ ៣៧ ["ពីព្រោះនៅទីនោះ មានផ្នូរខ្មោចពាសពេញ ហើយគ្រាប់រំសេវមានច្រើននៅរាយប៉ាយលើដី [...] ឆ.៣៧៖ នៅទីនោះ ខ្ញុំបានឃើញផ្នូរខ្មោចច្រើន ប៉ុន្តែឆ្អឹងខ្មោចដែលខ្ញុំបានឃើញមានចំនួនតិចជាងផ្នូរ ហើយខ្ញុំបានឃើញគ្រាប់រំសេវរាយប៉ាយលើដីផងដែរ"]។

នោះទេ[1976]។ តំបន់នេះមិនត្រូវបានប្រើប្រាស់ធ្វើជាទីតាំងកប់សាកសពនោះឡើយ មុនពេលដែលខ្មែរក្រហមបានកាន់កាប់ទីតាំងទឹកសាបនេះ។ តំបន់នេះគឺជាដីចម្ការដែលជាកម្មសិទ្ធិរបស់លោក ឆាន[1977]។ លើសពីនេះទៀត លលាដ៍ក្បាលមួយចំនួនដែលត្រូវបានរកឃើញនៅចម្ការទុរេន មានស្នាមប្រេះដែលអាចមើលឃើញ ដែលបង្ហាញឱ្យឃើញថាជាការសម្លាប់ដោយការវាយទៅលើក្បាលដោយប្រើឧបករណ៍រឹង[1978]។ ជាការពិត សំណល់ចបកាប់ត្រូវបានរកឃើញនៅទីតាំងនោះ[1979]។

<u>ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ - វត្តឥន្ទញាណ និងទឹកសាប</u>

523. នៅវត្តឥន្ទញាណ និងទឹកសាប **មាស មុត** និងកងពលធំលេខ ១៦៤ បានឃុំខ្លួនមនុស្សក្នុងស្ថានភាពអមនុស្សធម៌ ធ្វើទារុណកម្ម និងសម្លាប់បុគ្គលទាំងឡាយណាដែលពួកគេចាត់ទុកថាជាខ្មាំងនយោបាយ ឬម្យ៉ាងវិញទៀត អ្នកទាំងឡាយណាដែលត្រូវបានចាត់ទុកថាប្រឆាំងការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជា និងមិនស្មោះត្រង់ចំពោះមេដឹកនាំរបស់បក្ស។ ដូចដែលបានពិពណ៌នានៅក្នុងសេចក្តីលម្អិតជាងនេះនៅក្នុងផ្នែកទី *VII. គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដែលពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំងនឹង **មាស មុត** - ការជម្រុះចោលសត្រូវ និងការប្រឆាំងនឹងមេដឹកនាំបក្ស*

---

[1976] ឯកសារ D54/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ឆ.៣១ ["ខ្ញុំអាចបញ្ជាក់ថា កន្លែងនោះជាកន្លែងសម្លាប់មនុស្ស ពីព្រោះសាកសពខ្លះដែលនៅទីនោះគឺស្លាប់ទាំងដៃនៅជាប់ចំណងនៅឡើយ"]។

[1977] សូមមើល ឧ. ឯកសារ D114/3 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.៦ ["ស.៖តើកន្លែងទឹកសាបនោះ ជាកន្លែងដែលមានគេកប់ខ្មោចពីដើមដែរឬទេ? ឆ.៦៖ ទេ ទឹកសាបគឺជាកន្លែងគេធ្វើចម្ការ ដែលមានចម្ការធូរេន និងចម្ការផ្លែឈើផងទៀត។ ចម្ការទាំងនោះគឺជាកម្មសិទ្ធរបស់លោក ឆន ដែលជាអតីតប្រធានមេព្រៃប្រចាំតំបន់នេះក្នុងរបបសម្តេច សីហនុ"]។

[1978] ឯកសារ D114/3 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.១៣ ["ខ្ញុំមិនបានឃើញលលាដ៍ក្បាលដែលមានក្រណាត់ចងមុខទេ ប៉ុន្តែខ្ញុំឃើញមានខ្សែនីឡុងចំណងខ្លះនៅសល់នៅកន្លែងនោះ ហើយនិងលលាដ៍ក្បាលខ្លះមានស្នាមបែក"]។ សូមមើលផងដែរ ឯកសារ D2/22 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខវត្តឥន្ទញាណ KH 00662131-00662133 ["ឆ្អឹងលលាដ៍ក្បាលមួយចំនួន បង្ហាញឱ្យឃើញនូវសញ្ញាណ blunt trauma"] ។ KH 00662156-00662157 ["រូបថតឆ្អឹងលលាដ៍ក្បាល"]។

[1979] ឯកសារ D54/123 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.១២ ["បើសិនជាខ្ញុំមិនច្រឡំទេ អ្នកទាំងនោះត្រូវបានគេវ៉ៃនឹងត្បូងចបហើយ ព្រោះខ្ញុំបានឃើញចបនៅរាយប៉ាយនៅទីនោះ"]។ ឯកសារ D114/242 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ប៊ុននី ឆ.៨៣-៨៤ ["រដ្ឋប្រហារហើយ ខ្មែរក្រហមដួលរលំហើយ បានខ្ញុំទៅឃើញ [...] ឆ.៨៤៖ មានឃើញដូចជា [...] ចបអីហ្នឹង"]។

*កម្មុយនីស្តកម្ពុជា* គោលនយោបាយនេះត្រូវបានអនុវត្តចំពោះបុគ្គល ឬក្រុមណាមួយដែលត្រូវបានគេចាត់ទុកថាប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ឬត្រូវបានគេចាត់ទុកថាជាការគំរាមកំហែង។

*ក) កម្មាភិបាលកងពលធំលេខ ១៦៤ និងទាហានរំសាយ*

524. ភាគច្រើននៃអ្នកទោសដែលត្រូវបានឃុំខ្លួន ធ្វើទារុណកម្ម និងសម្លាប់នៅមន្ទីរសន្តិសុខទាំងពីរនេះ គឺជាកម្មាភិបាលក្នុងកងពលធំលេខ ១៦៤ ដែលត្រូវបានគេកំណត់ទិសដៅ ពីព្រោះពួកគេត្រូវបានចាត់ទុកថាជា "សត្រូវផ្ទៃក្នុង" ឬជនក្បត់ ដោយបក្សកុម្មុយនីស្តកម្ពុជា កងទ័ពបដិវត្តន៍កម្ពុជា និង **មាស មុត**។ លើសពីនេះទៀត អ្នកដែលស្ថិតក្នុងអាជីព និង "បណ្តាញ" ផ្ទាល់ខ្លួនរបស់ពួកគេ ត្រូវបានចាត់ទុកថាជាជនក្បត់ និង "សត្រូវផ្ទៃក្នុង"។

*ខ) ប្រជាជនថ្មី (១៧ មេសា) និងអ្នកដែលមានទំនាក់ទំនងជាមួយរបប លន់ នល់*

525. ដូចដែល សេង ស្រ៊ុន បានផ្តល់សក្ខីកម្មថា៖

> គោលដៅគេពួកខ្មែរក្រហមហ្នឹង សត្រូវគេទី១ គឺប្រជាជនថ្មីៗ ប្រជាជន ៧៥ ហ្នឹង ហើយនិងពួកមន្ត្រីរាជការដែលធ្លាប់បម្រើឱ្យសម័យសធារណៈ និងសម័យរាជានិយម[1980]។

526. "ប្រជាជនថ្មី" ដែលជួនកាលគេហៅថា "ប្រជាជន ១៧ មេសា" មិនទទួលបានការទុកចិត្តពីរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានបដិសេធសិទ្ធិ និងអត្ថប្រយោជន៍នានាដែលត្រូវបានផ្តល់ជូន "ប្រជាជនមូលដ្ឋាន"[1981] និងភ័យខ្លាចការបាត់បង់ជីវិតរបស់ខ្លួន[1982]។

---

1980 ឯកសារ D234/2.1.77 ប្រតិចារឹក សេង ស្រ៊ុន ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៥ ម៉ោង 11.27.53-11.30.56។

1981 សូមមើល ឧ. ឯកសារ D114/69 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុយ សម្បត្តិ ឆ.១ ["ខ្ញុំក៏បានកត់សម្គាល់ផងដែរថា មានការបែងចែករវាងប្រជាជនចាស់ និងប្រជាជនថ្មី ឬប្រជាជន ១៧ មេសា។ ហើយយើងមិនអាចធ្វើអ្វីបានឡើយ"]។ ឯកសារ D234/2.1.67 ប្រតិចារឹក Elizabeth Becker ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ ម៉ោង 14.22.47-14.25.33 ["ខ្ញុំបានឃើញអ្វី ដែលជាភាពខុសគ្នារវាងប្រជាជនចាស់ និងប្រជាជនថ្មី។ មានអ្វីប្រហាក់ប្រហែលនឹងប្រព័ន្ធវណ្ណៈនៅទីនោះ។ ប្រជាជន ដែលគេទុកចិត្តគឺប្រជាជនចាស់ អ្នកបដិវត្តន៍ អ្នកទាំងនោះគេយកចិត្តទុកដាក់ជាង ហើយគេចិញ្ចឹមឱ្យរស់នៅប្រសើរជាង"]។ ឯកសារ D234/2.1.68 ប្រតិចារឹក Elizabeth Becker ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ ម៉ោង 09.41.20-09.43.02 ["វាគឺជាប្រព័ន្ធអភ័យឯកសិទ្ធិ ដែលថាប្រជាជនថ្មីត្រូវបានគេប្រព្រឹត្តអាក្រក់ខ្លាំងជាងប្រជាជនចាស់ ដូចជាចំណីអាហារជាដើម ដូចជាពេលវេលាការងារ កម្លាំងពលកម្ម គឺគ្រប់វិធីទាំងអស់ វាគឺជាឋានានុក្រម"]។

*គ) ជនបរទេស*

527. ជនបរទេសមកពីប្រទេសនានាដែលរដ្ឋាភិបាលរបស់ពួកគេ មិនទទួលបានការទុកចិត្តពីកម្ពុជាប្រជាធិបតេយ្យ រួមទាំងជនជាតិថៃ វៀតណាម និងអាមេរិកផងដែរនោះ ត្រូវបានចាត់ទុកថាជាការគំរាមកំហែងចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ហើយជនជាតិរបស់ប្រទេសទាំងនោះត្រូវបានចាត់ទុកថាជា "សត្រូវ"។ ដូចដែលបានប្រកាសនៅក្នុងកិច្ចប្រជុំក្នុងឆ្នាំ ១៩៧៦ របស់កងពលធំមជ្ឈិម និងមេបញ្ជាការកងវរសេនាធំឯករាជ្យ៖

> ក្នុងឋានៈជាកងទ័ព ត្រូវស្គាល់កម្មវត្ថុ ដែលត្រូវវាយ គឺចក្រពត្តិអាមេរិក ពួកសើរីវៀតណាម និងដៃជើងក្បត់របស់វា[1983]។

*ឃ) ខ្មែរក្រោម*

528. ខ្មែរក្រោមក៏ត្រូវបានបញ្ជូនទៅកាន់ទីកសាបផងដែរ។ និយមន័យសត្រូវរបស់បក្សកម្មុយនីស្តកម្ពុជារាប់បញ្ចូលទាំងខ្មែរក្រោមផងដែរ ពីព្រោះពួកគេមានដើមកំណើតមកពីដែនដីដែលបច្ចុប្បន្នស្ថិតនៅក្នុងព្រំដែនរបស់ប្រទេសវៀតណាម។ ដូចដែលសាក្សី ប្រាក់ សុខា បានពន្យល់ "ខ្មែរក្រហមបានចោទខ្មែរក្រោមថា មានទំនាក់ទំនងជាមួយយួន ពីព្រោះពួកគេរស់នៅវៀតណាម"[1984]។

---

[1982] ឯកសារ D11/210/3 ប្រតិចារឹក អ៊ុន រ៉ន ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ម៉ោង 09.48.33-09.51.24 ["តែយើងអ្នកថ្មីមិនអាច ហ៊ានទេ ខ្លាចស្លាប់"]។

[1983] ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH 00052413-00052414។

[1984] ឯកសារ D54/36 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ឆ.១០ ["ខ្មែរក្រហមបានចោទខ្មែរកម្ពុជាក្រោមថា មានទំនាក់ទំនងជាមួយយួន ពីព្រោះពួកគេរស់នៅវៀតណាម"]។

## ឃ) មន្ទីរសន្តិសុខ ស-២១

### ១. សេចក្តីផ្តើម

529. មន្ទីរសន្តិសុខ ស-២១ គឺជាមន្ទីរសន្តិសុខកម្ពុជាប្រជាធិបតេយ្យធំបំផុតនៅក្នុងរបបគ្រប់គ្រងកម្ពុជាប្រជាធិបតេយ្យ បើគិតតាមចំនួនបុគ្គលិក[1985]។ មន្ទីរសន្តិសុខនេះបានធ្វើការងារដោយផ្ទាល់ក្រោមការគ្រប់គ្រងរបស់ និងរាយការណ៍ទៅកាន់មេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា[1986] និងបានទទួលអ្នកទោសពីទូទាំងប្រទេស និងគ្រប់កងពលធំរបស់កងទ័ពបដិវត្តន៍កម្ពុជា ភូមិភាគ និងក្រសួង[1987]។ មន្ទីរ ស-២១ គឺជាកងវរសេនាធំឯករាជ្យមួយស្ថិតក្រោមសេនាធិការនៃកងទ័ពបដិវត្តន៍កម្ពុជា ជាទីដែល **មាស មុត** ជាចុងក្រោយក្លាយជាអនុលេខា។ មន្ទីរ ស-២១ ក៏ត្រូវបានលើកយកមកពិភាក្សាជាញឹកញាប់ផងដែរ នៅក្នុងកិច្ចប្រជុំរបស់មេបញ្ជាការកងពលធំនានាដែល **មាស មុត** បានចូលរួម និងជាឧបករណ៍ដ៏សំខាន់មួយនៃការបោសសម្អាតផ្ទៃក្នុងរបស់កងទ័ព

---

[1985] ឯកសារ D98/1.2.7 ប្រតិចារឹក CRAIG Etcheson ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ម៉ោង 11.44.27-11.50.30 [“បើសិនជាយើងធ្វើការវាស់វែងទំហំ វាអាស្រ័យទៅលើការវាស់វែងទៅលើចំនួនបុគ្គលិកដែលធ្វើការនៅតាមមន្ទីរសន្តិសុខនោះ គឺនឹងមិនមែនជាសំណួរទៀតទេ។ ស-២១ គឺជាមន្ទីរសន្តិសុខ ដែលធំជាងគេបង្អស់”]។ D1.3.30.9 របាយការណ៍យោធាកម្ពុជាប្រជាធិបតេយ្យ ស្ថិតិកំលាំងរួម ខែ មីនា ឆ្នាំ ១៩៧៧ [មន្ទីរស-២១ បានចុះបញ្ជីថាមានកំលាំងសរុបចំនួន ២.៣២៧ នាក់]។ ឯកសារ D114/27.1.7 របាយការណ៍កម្ពុជាប្រជាធិបតេយ្យ គំរោងចំណាយស្រូវ នៅក្នុងឆ្នាំ ១៩៧៦ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៧៦ KH 00160081 [មនុស្សចំនួន ២.០៤៨ សម្រាប់មន្ទីរ ២១ នៅត្រឹមខែមករា ឆ្នាំ ១៩៧៦]

[1986] ឯកសារ D54/6.1.9 ប្រតិចារឹក កាំង ហ្កេកអ៊ាវ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង 16.06.05-16.17.41។ ឯកសារ D114/277.1 ប្រតិចារឹក កាំង ហ្កេកអ៊ាវ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង 15.56.44-15.58.32។ ឯកសារ D114/277.1 ប្រតិចារឹក កាំង ហ្កេកអ៊ាវ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង 11.24.05-11.31.10។ ឯកសារ D98/1.2.17 ប្រតិចារឹក កាំង ហ្កេកអ៊ាវ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ ម៉ោង 10.09.47-10.14.39។ ឯកសារ D98/1.2.21 ប្រតិចារឹក កាំង ហ្កេកអ៊ាវ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១២ ម៉ោង 11.37.54-11.40.00។ ឯកសារ D98/1.2.7 ប្រតិចារឹក CRAIG Etcheson ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ម៉ោង 12.01.07-12.08.51។

[1987] ឯកសារ D54/6.1.9 ប្រតិចារឹក កាំង ហ្កេកអ៊ាវ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង 16.06.05-16.16.20។ ឯកសារ D98/1.2.2 ប្រតិចារឹក CRAIG Etcheson ថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ម៉ោង 15.16.10-15.09.57។ ឯកសារ D234/2.1.118 ប្រតិចារឹក សួស ធី ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង 14.31.27-14.33.34។ ឯកសារ D234/2.1.112 ប្រតិចារឹក ប្រាក់ ខន ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង 10.44.15-10.50.06, ម៉ោង 15.54.01-15.57.07។ ឯកសារ D114/37.1.73 ប្រតិចារឹក DAVID Chandler ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៩ ម៉ោង 09.34.18-09.37.50។

បដិវត្តន៍កម្ពុជាដែល **មាស មុត** បានចូលរួម។ មនុស្សជាច្រើននៃអ្នកដែលត្រូវបានសម្លាប់នៅមន្ទីរ ស-២១ ត្រូវបានបញ្ជូនទៅកាន់ទីនោះដោយ **មាស មុត** រួមទាំងអ្នកនៅក្រោមបង្គាប់របស់ **មាស មុត** ផងដែរ ដែលជាជនរងគ្រោះនៃការបោសសម្អាតផ្ទៃក្នុងរបស់កងទ័ពបដិវត្តន៍កម្ពុជា ជនបរទេសដែលត្រូវបានចាប់ខ្លួននៅសមុទ្រ និង "ខ្មាំង" ផ្សេងទៀតមកពីកំពង់សោម និងកោះនានារបស់កម្ពុជា និងខេត្តក្រចេះ។

## ២. ទីតាំង និងប្រតិបត្តិការ

530. មន្ទីរសន្តិសុខ ស-២១ ត្រូវបានបង្កើតឡើងក្រោយមានកិច្ចប្រជុំមួយនៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៧៥ ដែលប្រធានសេនាធិការ សុន សេន បានណែនាំ អ៊ិន លន ហៅ ណាត លេខាកងពលធំ លេខ ៧០៣ នៃកងទ័ពបដិវត្តន៍កម្ពុជា និង កាំង ហ្កេកអ៊ាវ ហៅ ឌុច ឲ្យបង្កើតមន្ទីរសន្តិសុខនេះឡើង[1988]។ មន្ទីរសន្តិសុខនេះបានចាប់ផ្តើមប្រតិបត្តិការនៅរដូវស្លឹកឈើជ្រុះក្នុងឆ្នាំ ១៩៧៥[1989] ហើយបានដំណើរការរហូតដល់ថ្ងៃទី ៧ ខែ មករា ឆ្នាំ ១៩៧៩ នៅពេលដែលកងកម្លាំងវៀតណាមបានចូលមកដល់ទីក្រុងភ្នំពេញ[1990]។

---

1988 ឯកសារ D114/277.2 ប្រតិចារឹក កាំង ហ្កេកអ៊ាវ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង 09.16.37-09.19.17។ ឯកសារ D98/1.2.16 ប្រតិចារឹក កាំង ហ្កេកអ៊ាវ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ ម៉ោង 09.49.36-09.54.37។ ឯកសារ D98/3.1.81 ប្រតិចារឹក កាំង ហ្កេកអ៊ាវ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង 15.18.49-15.24.19។ ឯកសារ D1.3.33.3 កាំង ហ្កេកអ៊ាវ (KAING Guek Eav) កំណត់ហេតុនៃការសួរចម្លើយ KH 00146478-00146479។

1989 ឯកសារ D98/3.1.81 ប្រតិចារឹក កាំង ហ្កេកអ៊ាវ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង 15.24.19-15.33.42។ ឯកសារ D4.1.1116 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH 00153458-00153459 ["មន្ទីរ ស២១ បានចាប់ផ្តើមដំណើរការពេញលេញនៅខែ តុលា ឆ្នាំ ១៩៧៥ ប៉ុណ្ណោះ"]។ ឯកសារ D1.3.33.3 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអាវ KH 00146480-00146481។ ឯកសារដែលនៅសល់ពីចុងខែ សីហា និងខែ កញ្ញា ឆ្នាំ ១៩៧៥ បង្ហាញថា ប្រតិបត្តិការមួយចំនួនបានចាប់ផ្តើមឡើងរួចស្រេចហើយ នៅពេលនោះ៖ សូមមើល ឧ. ឯកសារ D10.1.108 ចម្លើយសារភាពនៅស-២១ របស់ អ៊ុំ សឿន (សេចក្តីដកស្រង់) EN 00223146 [ចំណាររបស់ ឌុច នៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៧៥]។

1990 ឯកសារ D98/3.1.82 ប្រតិចារឹក កាំង ហ្កេកអ៊ាវ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង 10.22.50-10.30.35។ ឯកសារ D1.3.33.3 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH 00146480-00146481 ["ការសម្លាប់ បានបន្តតាំងពីពេលចាប់ដំណើរការស២១ រហូតដល់ម៉ោង ១២ ថ្ងៃ ០៧ មករា ១៩៧៩"]។

531. នៅក្នុងរយៈពេលប៉ុន្មានខែដំបូងនៃវត្តមានរបស់ខ្លួន មន្ទីរ ស-២១ បានប្រើប្រាស់សម្ភាររូបវន្ត បណ្ដោះអាសន្ននានា ដូចជា ដំបូងឡើយ ការសួរចម្លើយត្រូវបានធ្វើឡើងនៅក្នុងផ្ទះមួយដែលមានទីតាំងស្ថិតនៅកែងផ្លូវលេខ ១៦៣ និង ៣៦០ ខណៈពេលដែលផ្ទះនៅជុំវិញនោះត្រូវបានប្រើប្រាស់សម្រាប់ឃុំខ្លួនអ្នកទោស[1991]។ នៅខែ វិច្ឆិកា ឆ្នាំ ១៩៧៥ មន្ទីរ ស-២១ ត្រូវបានប្ដូរទៅកាន់បរិវេណ *នគរបាលយុត្តិធម៌* ស្ថិតនៅលើផ្លូវលេខ ៥១[1992]។ ពីរខែក្រោយមកគឺនៅខែ មករា ឆ្នាំ ១៩៧៦ ដោយសារក្ដីបារម្ភថា អ្នកទស្សនកិច្ចជនជាតិចិនអាចមើលឃើញប្រតិបត្តិការរបស់គុកនេះនៅទីតាំងនោះ មន្ទីរ ស-២១ ត្រូវបានប្ដូរត្រលប់ទៅកាន់ទីតាំងដើមវិញគឺស្ថិតនៅលើផ្លូវលេខ ១៦៣ កែងផ្លូវលេខ ៣៦០[1993]។

532. ក្នុងអំឡុងដំណាក់កាលដំបូងរបស់មន្ទីរ ស-២១ អ្នកទោសក៏ត្រូវបានឃុំខ្លួននៅគុកនៅតាខ្មៅផងដែរ ដែលជាអតីតផ្នែកមួយនៃកងពលធំលេខ ៧០៣[1994] និងត្រូវបានបញ្ជូនទៅកាន់ទីក្រុងភ្នំពេញ

---

[1991] ឯកសារ D98/3.1.82 ប្រតិចារឹក កាំង ហ្គេកអ៊ាវ EN 00153567 ["ដំបូង អគារឃុំខ្លួន និងសួរចម្លើយ ស្ថិតនៅកែងផ្លូវ ១៦៣ និងផ្លូវ ៣៦០ (អក្សរ "អា" ក្នុងប្លង់លេខ ១) [...] អ្នកទោស ត្រូវបានគេដាក់នៅក្នុងផ្ទះតំបន់អក្សរ អា"] EN 00153575 [ប្លង់លេខ ១]។ ឯកសារ D98/3.1.82 ប្រតិចារឹក កាំង ហ្គេកអ៊ាវ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង 10.09.49-10.22.50។ ឯកសារ D10.1.19 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជេត សុខា KH 00186504-00186505 [ចម្លើយរបស់ជនទីមួយ រស់នៅផ្ទះលេខ ២ អឺ០ នៅផ្លូវលេខ ៣៦០ នៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ៖ "ពេលខ្ញុំមក ខ្ញុំឃើញខ្នោះដៃ ខ្នោះជើងច្រើន"]។

[1992] ឯកសារ D4.1.1116 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH 00153458-00153459 ["នៅចុងខែ វិច្ឆិកា ឆ្នាំ ១៩៧៥ មន្ទីរស២១ ត្រូវបានផ្លាស់ប្ដូរទៅកាន់អគ្គស្នងការដ្ឋាននគរបាលជាតិ នៅផ្លូវប៉ាស្ទ័រ"]។ ឯកសារ D98/3.1.81 កាំង ហ្គេកអ៊ាវ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង 15.24.19-15.33.42។ ឯកសារ D234/2.1.118 ប្រតិចារឹក សួស ធី ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង 09.29.33-09.34.55 [គាត់បានធ្វើការនៅកន្លែងប៉េហ្សី ដែលជាមន្ទីរស-២១ នៅចុងឆ្នាំ ៧៥]។ ម៉ោង 10.03.57-10.09.21 [បង្ហាញអត្តសញ្ញាណស-២១អា ជាប៉េហ្សី]។ ឯកសារ D234/2.1.110 ប្រតិចារឹក ឡាច មាន ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង 14.10.13-14.15.05។

[1993] ឯកសារ D4.1.1116 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH 00153458-00153459 ["នាខែ មករា ឆ្នាំ ១៩៧៦ អ្នកទោសត្រូវនាំត្រឡប់ទៅចំណុច A ហើយនៅទីនោះប្រហែលជា ៣ ទៅ៤ខែ"]។ ឯកសារ D98/3.1.81 ប្រតិចារឹក កាំង ហ្គេកអ៊ាវ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង 15.24.19-15.33.42។

[1994] ឯកសារ D4.1.1100 កំណត់ដៃរបស់ កាំង ហ្គេកអ៊ាវ លើបញ្ជីអ្នកទោសនៅក្នុងទស្សនាវដ្ដី "ស្វែងរកការពិត" KH 00172309-00172310 ["មន្ទីរស.២១ គឺជាតំណរបស់មន្ទីរនគរបាលកងពល ៧០៣ របស់ អ៊ិន លន ហៅ ណាត [...] គុកសាមញ្ញ យកមន្ទីរពេទ្យឆ្កួតតាខ្មៅយកមកធ្វើ"]។ ឯកសារ D98/3.1.81 ប្រតិចារឹក កាំង ហ្គេកអ៊ាវ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង 15.24.19-15.31.17។ ឯកសារ D98/3.1.85 ប្រតិចារឹក កាំង ហ្គេកអ៊ាវ ថ្ងៃទី ២៨

សម្រាប់ការសួរចម្លើយនៅក្នុងបរិវេណ *នគរបាលយុត្តិធម៌* និងទីតាំងផ្សេងៗទៀត[1995]។ តាខ្មៅ ដែលក្រោយមកត្រូវបានគេហៅថា មន្ទីរ ស-២១គ[1996] នោះ ត្រូវបានប្រើប្រាស់ដោយមន្ទីរ ស-២១ សម្រាប់ការឃុំខ្លួន និងសម្លាប់រហូតដល់ពាក់កណ្តាលឆ្នាំ ១៩៧៦[1997] និងត្រូវបានគ្រប់គ្រងដោយ ឃឹម វ៉ាត ហៅ ហ៊ (អនាគតអនុប្រធានមន្ទីរ ស-២១)[1998]។

533. នៅខែ មេសា ឆ្នាំ ១៩៧៦ បន្ទាប់ពីការតែងតាំងគាត់ជាប្រធានមន្ទីរ ស-២១ ឌុច បានប្តូរមន្ទីរ សន្តិសុខនេះទៅកាន់ទីតាំងអចិន្ត្រៃយ៍របស់ខ្លួននៅក្នុង *វិទ្យាល័យពញាយ៉ាត* ដែលសព្វថ្ងៃត្រូវបានគេ

---

ខែ មេសា ឆ្នាំ ២០០៩ ម៉ោង 15.31.15-15.37.56។ D234/2.1.111 ប្រតិចារឹក ឡាច មាន ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង 11.23.18-13.31.02។

1995 ឯកសារ D98/3.1.81 ប្រតិចារឹក កាំង ហ្គេកអ៊ាវ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង 15.24.19-15.33.42 ["គាត់ឲ្យគេដឹកអ្នកទោសយកពីតាខ្មៅមកដាក់ទុកនៅនឹងផ្ទះមួយឲ្យកម្មាភិបាលសួរចម្លើយ [...] គុកតាខ្មៅនៅជាគុកធំ"]។ ម៉ោង 15.45.39-15.50.44។ ឯកសារ D1.3.32.21 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គក ស្រស់ KH 00186797-00186798 [អ្នកទោសតាខ្មៅត្រូវបានគេយកទៅសួរចម្លើយនៅឯប៉េហ្សី បន្ទាប់មក បានវិលត្រឡប់ទៅតាខ្មៅវិញ]។

1996 ឯកសារ D234/2.1.118 ប្រតិចារឹក សួស ធី ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង 09.29.33-09.34.55 [គាត់បានធ្វើការនៅកន្លែងប៉េហ្សី ដែលជាមន្ទីរស-២១ នៅចុងឆ្នាំ ៧៥]។ ប្រតិចារឹក សួស ធី ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង 09.58.37-10.01.06 [កំណត់អត្តសញ្ញាណ ស-២១ គ ជាផ្នែកមួយនៃស-២១ ដែលពីមុននៅក្រោមកងពល ៧០៣]។

1997 ឯកសារ D114/277.2 ប្រតិចារឹក កាំង ហ្គេកអ៊ាវ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង 14.09.44-14.19.03។ ឯកសារ D98/3.1.84 ប្រតិចារឹក កាំង ហ្គេកអ៊ាវ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង 09.48.05-09.57.43។ ឯកសារ D98/3.1.95 ប្រតិចារឹក កាំង ហ្គេកអ៊ាវ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៩ ម៉ោង 09.00.00, 09.28.36។ ឯកសារ D98/3.1.81 ប្រតិចារឹក កាំង ហ្គេកអ៊ាវ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង 15.45.39-15.50.44 ["គុកនៅពេទ្យឆ្កួតនេះ ប្រហែលជាដល់ខែ ៥ ឬខែ ៧ បានចប់"] ម៉ោង 15.50.44-15.53.04។ ឯកសារ D1.3.32.21 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គក ស្រស់ KH 00186797-00186798។ ឯកសារ D4.1.363 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉េស ម៉ាត់ KH 00186560-00186561 [អ្នកទោសនៅគុកមន្ទីរពេទ្យឆ្កួតតាខ្មៅ បាត់តែខ្លួនក្នុងឆ្នាំ ១៩៧៦]។ ឯកសារ D10.1.27 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ធុន KH 00163757-00163758។

1998 ឯកសារ D98/3.1.84 ប្រតិចារឹក កាំង ហ្គេកអ៊ាវ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង 09.53.12-09.57.43។ ឯកសារ D98/3.1.85 ប្រតិចារឹក កាំង ហ្គេកអាវ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង 10.25.37-10.39.49។ ឯកសារ D1.3.32.21 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គក ស្រស់ KH 00186797-00186798។

ស្គាល់ថាជា ទួលស្លែង[1999]។ ក្រោយមកនៅឆ្នាំ ១៩៧៦ ដោយបារម្ភអំពីការរីកសាយភាយរណ្ដៅសាកសពរួមនៅតំបន់នេះ និងហានិភ័យនៃជំងឺ ឌុច បានសម្រេចចិត្តបង្កើតទីតាំងថ្មីមួយសម្រាប់ការសម្លាប់ និងកប់អ្នកទោស ហើយបានជ្រើសរើសទីបញ្ចុះសពជនជាតិចិនឈ្មោះជើងឯក ដែលមានទីតាំងស្ថិតនៅក្នុងខេត្តកណ្ដាល ចម្ងាយ ១៥ គីឡូម៉ែត្រនៅភាគនិរតីទីក្រុងភ្នំពេញ[2000]។ មន្ទីរ ស-២១ បានចាប់ផ្ដើមប្រើប្រាស់តំបន់ជើងឯកធ្វើជាទីកន្លែងសម្លាប់ដ៏ចម្បងរបស់ខ្លួន នៅដើមឆ្នាំ ១៩៧៧[2001]។

---

1999 ឯកសារ D4.1.1116 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ KH 00153458-00153459 ["នៅខែមេសា ឆ្នាំ ១៩៧៦ ខ្ញុំបានសម្រេចផ្ទេរមន្ទីរស២១ ទៅកាន់ទីតាំងនៃវិទ្យាល័យពញាយ៉ាត (អក្សរ ក្នុងប្លង់លេខ ១)។ ខ្ញុំបានសុំការអនុញ្ញាតពី សុន សេន"] KH 00153467 [ប្លង់លេខ ១]។ ឯកសារ D98/3.1.82 ប្រតិចារឹក កាំង ហ្កេកអ៊ាវ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង 10.30.35-11.20.00។ ឯកសារ D98/3.1.81 ប្រតិចារឹក កាំង ហ្កេកអ៊ាវ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង 15.45.39-15.50.44។ ឯកសារ D234/2.1.118 ប្រតិចារឹក សួស ធី ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង 10.03.57-10.09.21, 10.31.37-10.36.26។ ឯកសារ D4.1.347 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សួស ធី KH 00162596-00162598។ ឯកសារ D1.3.32.21 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គក ស្រស់ KH 00186797-00186798។

2000 ឯកសារ D98/3.1.95 ប្រតិចារឹក កាំង ហ្កេកអ៊ាវ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៩ ម៉ោង 10.23.32-10.27.23។ ឯកសារ D1.3.33.8 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ KH 00146671-00146672។ ឯកសារ D10.1.117 កំណត់ហេតុនៃការតទល់មុខគ្នារបស់ កាំង ហ្កេកអ៊ាវ KH 00165427-00165428 ["ឆ្លើយដោយជនត្រូវចោទ៖ [...] វាមានការភ័យខ្លាចពីជំងឺឆ្លងនៅស២១ ដោយសារមានសាកសពអ្នកទោសច្រើនពេក"]។ ឯកសារ D234/2.1.116 ប្រតិចារឹក ហ៊ឹម ហ៊ុយ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង 10.36.16-10.40.47 ["ខ្ញុំឮ ព្រោះគាត់និយាយថា កន្លែងនេះវាស្អុយ ហើយមួយទៀត ខ្លាចនែ មួយទៀត វាច្រើនពេកហើយ កប់ហ្នឹង។ អ៊ីចឹង គេដូរទីតាំងទៅជើងឯកវិញ"]។ ឯកសារ D10.1.114 កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ ជើងឯក KH 00181318-00181319, 00181320-00181322។ ឯកសារ D10.1.115 ឧបសម្ព័ន្ធ ១៖ កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ ជើងឯក KH 00181369។

2001 ឯកសារ D234/2.1.115 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.25.39-15.29.42 [អះអាងបញ្ជាក់ថា ការសម្លាប់មនុស្សបានចាប់ផ្ដើមនៅបឹងជើងឯកក្នុងឆ្នាំ១៩៧៧]។ ឯកសារ D98/3.1.54 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 13.54.15-13.58.39 KH ERN 00354154-55 ["បឹងជើងឯកត្រូវគេជ្រើសរើសយកធ្វើជាកន្លែងសម្លាប់មនុស្ស គឺនៅក្នុងឆ្នាំ១៩៧៧"។ ឯកសារ D10.1.117 កំណត់ហេតុនៃការតទល់មុខគ្នាជាមួយ កាំង ហ្កេកអ៊ាវ KH ERN 00165427-28 [ចម្លើយរបស់ ហ៊ឹម ហ៊ុយ បញ្ជាក់ថា ផ្ទះឈើដែលគេប្រើសម្រាប់ដាក់អ្នកទោសនៅបឹងជើងឯក បានសាងសង់ក្នុងឆ្នាំ១៩៧៧ និងការអះអាងបញ្ជាក់របស់ ឌុច ដែលថា ផ្ទះនោះមានរួចទៅហើយ នៅពេលដែលគាត់"ចុះទៅមើលជើងឯកក្នុងឆ្នាំ១៩៧៧"]។ ឯកសារ D10.1.114 របាយការណ៍នៃ

## ៣. រចនាសម្ព័ន្ធអំណាច និងទំនាក់ទំនង

## នៅក្នុងមន្ទីរសន្តិសុខ

534. *គណៈកម្មាធិការមន្ទីរ ស-២១៖* ជាមួយនឹងអង្គការកម្ពុជាប្រជាធិបតេយ្យផ្សេងទៀត មន្ទីរ ស-២១ ត្រូវបានគ្រប់គ្រងដោយគណៈម្មាធិការចំនួនបីនាក់[2002]។ នៅក្នុងរយៈពេលរបស់ ណាត ក្នុងឋានៈជាលេខាមន្ទីរ ស-២១[2003] ឌុច បានកាន់កាប់តំណែងជាអនុលេខា ដោយគ្រប់គ្រងការសួរចម្លើយ[2004]។ នៅខែ មីនា ឆ្នាំ ១៩៧៦ នៅពេលដែល ណាត ត្រូវបានផ្ទេរទៅកាន់សេនាធិការ ឌុច ត្រូវបានដំឡើងតួនាទីជាលេខាមន្ទីរ ស-២១ ជាតួនាទីមួយដែលគាត់បានកាន់កាប់រហូតដល់ចុងរបបនេះ[2005]។ ហ៊ី បានក្លាយជាអនុលេខា[2006]ហើយ នន់ ហ៊ុយ ហៅ ហ៊ុយ ស្រែ គឺជាសមាជិកទីបី

---

ការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត KH ERN 00181320។ ឯកសារ D114/35.3 សៀវភៅនិពន្ធដោយ ដេវីដ ឆាណ្ឌល័រ (David Chandler) ៖ សម្លេងពីមន្ទីរស-២១ EN ERN 00192832 [“ក្នុងអំឡុងឆ្នាំ១៩៧៧ នៅពេលដែលការបោសសម្អាតបានកើតឡើងខ្លាំង អគារនៅមន្ទីរស-២១ ពោរពេញទៅដោយអ្នកទោស ហើយកន្លែងកប់ខ្មោចនៅជិតនោះក៏មានសាកសពពេញហូរហៀរដែរ។ មានពេលមួយក្នុងឆ្នាំ ១៩៧៧ កន្លែងបញ្ចុះសាកសពចិនមួយកន្លែងនៅជិតភូមិជើងឯក ចម្ងាយ១៥ គីឡូម៉ែត្រខាងត្បូងរដ្ឋធានី ត្រូវបានគេប្រើប្រាស់ជាកន្លែងសម្លាប់មនុស្ស”]។

2002 ឯកសារ D98/3.1.95 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.57.23-10.01.56 KH ERN 00344048-49។ ឯកសារ D4.1.347 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ធី KH ERN 00162597។

2003 ឯកសារ D1.3.33.3 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00146479 [មុនខែមីនា ឆ្នាំ១៩៧៦ ណាត ជា “ប្រធានធំសម្រេចរាល់កិច្ចការទាំងអស់”]។ ឯកសារ D4.1.346 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ម ណៃ KH ERN 00162882; ឯកសារ D4.1.387 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន ហេង KR ERN 00163688។

2004 ឯកសារ D98/3.1.95 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 13.54.35-14.01.04 KH ERN 00344083-84។ ឯកសារ D1.3.33.3 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00146479។

2005 ឯកសារ D98/3.1.95 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.20.02, 09.55.27 KH ERN 00344047។ ឯកសារ D1.3.33.3 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00146479 [“តែងតាំងជាប្រធានស២១ ផ្លូវការ មិនចាំថ្ងៃទេ គឺខែមីនា ១៩៧៦”]។ ឯកសារ D234/2.1.118 ប្រតិចារឹក សួស ធី ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 10.06.23 KH ERN 01307481 [“នៅពេលដែលគុកស-២១ ដែលមកនៅទួលស្លែងនេះគឺ ឌុច គេជំនួសហើយ គេដកតាណាតចេញវិញ”]។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 11.21.41-11.25.00 KH ERN 01249377-78។ ឯកសារ D4.1.387 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន ហេង KR ERN 00163688។ ឯកសារ D4.1.346 កំណត់ហេតុនៃការស្តាប់ចម្លើយ

នៃគណៈកម្មាធិការនេះ[2007] ដោយទទួលខុសត្រូវលើព្រៃស (ដែលគេស្គាល់ថា មន្ទីរ ស-២៤ ឬ ស-២១ឃ)[2008]។

535. *អង្គភាពរបស់មន្ទីរ ស-២១៖* មន្ទីរ ស-២១ មានអង្គភាពមួយចំនួន ដែលស្ថិតក្រោមចំណុះរបស់គណៈកម្មាធិការមន្ទីរ ស-២១ ដែលរួមមាន (i) អង្គភាពការពារ ដែលដឹកនាំដោយ ហ៊ី[2009] ដោយមានក្រុមឆ្មាំខាងក្នុង ក្រុមឆ្មាំខាងក្រៅ និង "អង្គភាពពិសេស" មួយ ដែលទទួលខុសត្រូវលើការដឹក

---

សាក្សី ម៉ម ណៃ KH ERN 00162878។ ឯកសារ D4.1.386 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ហន KH ERN 00163676។ ឯកសារ D114/35.3 សៀវភៅនិពន្ធដោយ ដេវីដ ឆាណ្ឌល័រ) ៖ សម្លេងពីមន្ទីរស-២១ EN ERN 00192683)។

2006 ឯកសារ D98/3.1.95 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.57.23-10.01.56 KH ERN 00344049។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.21.41-11.25.00 KH ERN 01249378 ["បងហ៊ី ជាអនុប្រធាន"]។ ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.12.18-15.15.08 KH ERN 01247402-03។ ឯកសារ D1.3.32.17 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹម ហ៊ុយ KH ERN 00146646។ ឯកសារ D114/37.1.66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉េប ហូ KH ERN 00162686។ ឯកសារ D4.1.386 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ហន KH ERN 00163676។

2007 ឯកសារ D234/2.1.115 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.42.46 KH ERN 01252063-64 ["បងហ៊ុយ ជាសមាជិករបស់ស-២១"]។ ឯកសារ D114/37.1.66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉េប ហូ KH ERN 00162686 ["ខ្ញុំនៅស-២១ [...] សមាជិកគឺហ៊ុយនៅព្រៃសរ"]។

2008 ឯកសារ D98/3.1.95 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.01.56-10.05.10។ ឯកសារ D98/3.1.82 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ ម៉ោង 11.46.02-12.03.05 KH ERN 00325357; ឯកសារ D234/2.1.115 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.40.00 KH ERN 01252063 ["បងហ៊ុយធំ ក្តាប់នៅហ្នឹង]"។ ឯកសារ D234/2.1.118 ប្រតិចារឹក សួស ធី ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 11.20.17-11.22.12 KH ERN 01307496 ["អ្នកគ្រប់គ្រង ស-២១(ឃ)នេះ គឺឈ្មោះហ៊ុយ"]។ ឯកសារ D10.1.29 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស ប៉េងគ្រី KH ERN 00163702។

2009 ឯកសារ D234/2.1.117 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 10.59.25-11.01.09 KH ERN 01301891 ["តាហ៊ី [...] ព្រោះគាត់កាន់កាប់កងការពារទាំងអស់"]។ ឯកសារ D114/35.3 សៀវភៅនិពន្ធដោយលោក ដេវីដ ឆាណ្ឌល័រ៖ សម្លេងពីមន្ទីរ-២១ EN ERN 00192702 ["អនុប្រធានរបស់ឌុច នៅមន្ទីរស-២១ ឃឹម វ៉ាត [ហៅ ហ៊ី] [...] ដែលនៅពេលដំណាលគ្នានោះ ធ្វើជាប្រធានកងការពារប្រចាំគុកនេះ"]។

ជញ្ជូន និងសម្លាប់អ្នកទោស[2010] (ii) អង្គភាពសួរចម្លើយ ដែលមានអ្នកសួរចម្លើយប្រហែល ៣០ នាក់ មុនពេលបោសសម្អាតក្នុងឆ្នាំ ១៩៧៨[2011] (iii) អង្គភាពឯកសារ ដែលដឹកនាំដោយ សួស ធី[2012] (iv) អង្គភាពរូបថត ដែលដឹកនាំដោយ នឹម គឹមស្រ៉ាង[2013] និង (v) អង្គភាពពេទ្យ ដែលដឹកនាំ

---

[2010] ឯកសារ D234/2.1.115 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.02.00-15.04.42 KH ERN 01252051-52។ ឯកសារ D1.3.32.17 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹម ហ៊ុយ KH ERN 00146646 [“ផ្នែកការពារគេរៀបចំការពារខាងក្រៅ ខាងក្នុង និងចាំទទួលអ្នកទោស”]។ ឯកសារ D234/2.1.119 សួស ធី ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 13.54.49-13.58.47 KH ERN 01307586-87។ ឯកសារ D4.1.1117 កំណត់ហេតុនៃការសួរចម្លើយកាំង ហ្កេកអ៊ាវ KH ERN 00154228-29 [អង្គការលេខមន្ទីរស-២១ បង្ហាញថា ប៉េង ជាប្រធានកងពិសេស ដំបូងគេ បន្ទាប់មក ហ៊ឹម ហ៊ុយ ឡើងបន្តពីគាត់]។ ឯកសារ D114/277.5 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.43.16-09.47.14 KH ERN 01311904-05 [កំណត់អត្តសញ្ញាណប៉េង ជា “ប្រធានកងពិសេស”]។ ឯកសារ D98/3.1.83 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ម៉ោង 10.06.30-10.11.22 KH ERN 00325490-91។ ឯកសារD4.1.343 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចៀម សឿKH ERN 00162762[“មានការយាមបីជាន់”]។

[2011] ឯកសារ D114/277.2 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 15.56.46-16.00.00 KH ERN 01307842 [“អ្នកសួរចម្លើយដំបូង គឺមាន៣៣ នាក់ ពិតមែន។ ហើយចែកជាពួកទី១ អ្នកណា, ពួកទី២ អ្នកណា, ពួកទី៣ អ្នកណា, ពួកទី៤ អ្នកណា គឺចែកអ៊ីចឹងមែន”]។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.16.03-11.19.16 KH ERN 01249376-77 [“បាទ អ្នកសួរចម្លើយនៅក្រុមខ្ញុំបាទ កន្លងមក ហ្នឹងវាមានមួយក្រុមហ្នឹងវាមាន១២ នាក់ពេញៗ ហើយបីក្រុមមានជាង៣០ នាក់។ ប៉ុន្តែក្នុង១ឆ្នាំៗចេះតែ រង្គោះរង្គើ អស់ទៅ អស់ម្នាក់ពីរនាក់ ម្នាក់ពីរនាក់”]។ ឯកសារ D234/2.1.118 ប្រតិចារឹក សួស ធី ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.49.00-09.53.57 KH ERN 01307477-78; ឯកសារ D234/2.1.53 បញ្ជីខ្មៅខ្មែរក្រហម EN ERN 00602543 [មានឈ្មោះអ្នកសួរចម្លើយប្រមាណជា៣០ នាក់ នៅក្នុងកងសួរចម្លើយ]។

[2012] ឯកសារ D114/277.9 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.56.34-10.00.27 KH ERN 01323543-44 [“មិត្តធីនេះ ជាអ្នកកាន់កាប់បញ្ជីមួយរយខាងអ្នកទោសចេញចូល ដូច្នេះបញ្ជី នៅលើគាត់មែន”]។ ឯកសារ D234/2.1.118 សួស ធី ប្រតិចារឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 13.33.03-13.35.24 KH ERN 01307499-01307500 [“ការធ្វើបញ្ជី [...] អ្នកទោសចូល និងបញ្ជីអ្នកទោសចេញ នៅក្នុងមន្ទីរស-២១នោះ គឺមានតែខ្ញុំម្នាក់”]។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.36.03-09.38.08 KH ERN 01249351 [“សួស ធី ជាអ្នកកត់ត្រាបញ្ជី”]។

[2013] ឯកសារ D234/2.1.121 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 11.13.16-11.16.58 KH ERN 01323476-77។ ឯកសារ D234/2.1.131 នឹម គឹមស្រ៊ាន ប្រតិចារឹក ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 13.33.27-13.36.34 KH ERN 01382303-04, ម៉ោង 15.41.06-15.43.19 KH ERN 01382336-37 [“គឺពេលនោះខ្ញុំថតវាបានមួយចំនួន មិនបានដូចប្រហែលជាកូនចៅខ្ញុំទេ”]។ ឯកសារ D4.1.741 កំណត់ហេតុនៃការស្តាប់

ដោយ ទ្រី[2014]។ អង្គការលេខ ដែលរៀបចំដោយ ឌុច បង្ហាញឲ្យឃើញពីរចនាសម្ព័ន្ធរបស់អង្គភាពផ្សេងៗរបស់មន្ទីរ ស-២១[2015]។

**ទំនាក់ទំនងជាមួយសេនាធិការ**

536. មន្ទីរសន្តិសុខ ស-២១ គឺជាកងវរសេនាធំឯករាជ្យមួយ ដែលស្ថិតក្រោមសេនាធិការកងទ័ពបដិវត្តន៍កម្ពុជា។ សេនាធិការកងទ័ពបដិវត្តន៍កម្ពុជាទទួលខុសត្រូវលើការធានាចំពោះភ័ស្តុភារ បុគ្គលិក ផលិតកម្មស្រូវ និងបញ្ហារដ្ឋបាលផ្សេងៗរបស់មន្ទីរ ស-២១[2016]។ អ្នកតំណាងរបស់មន្ទីរ ស-២១ បានចូលរួមក្នុងកិច្ចប្រជុំលេខាកងពលធំ[2017] និងបានចូលរួមក្នុងវគ្គសិក្សាសេនាធិការ[2018] ដែលពួក

---

ចម្លើយសាក្សី នឹម គឹមស្រ៊ាន KH ERN 00162710 [“សៈ ពេលនោះក្នុងក្រុមចតុរូបអ្នកណាជាប្រធាន? ឆៈ ខ្ញុំមេពួក”]។

2014 ឯកសារ D234/2.1.115 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 09.15.03-09.16.52 KH ERN 01251993 [“ខ្ញុំរាយការណ៍ប្រាប់ប្រធាន ឈ្មោះទ្រី ពេទ្យប្រធានហ្នឹង ឈ្មោះ ទ្រី”]។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 13.49.13-13.50.45 KH ERN 01249385-86 [“បាទ ពេទ្យ ទ្រី ខ្ញុំស្គាល់ ជាប្រធានពេទ្យនៅប្រចាំ ស-២១”]។ ឯកសារ D114/277.7 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.23.20-09.28.02 KH ERN 01319750.

2015 ឯកសារ D4.1.1117 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00154228-29។

2016 ឯកសារ D4.1.1106 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00164319 [“ស២១ គឺជាអង្គភាពកងទ័ព និយាយឲ្យចំទៅ គឺជាកងវរសេនាធំឯករាជ្យ ដែលធ្វើសកម្មភាពដោយនៅក្រោមការគ្រប់គ្រងមួយផ្នែករបស់អគ្គសេនាធិការ ទាក់ទងនឹងបញ្ហាបង្កបង្កើនផល បុគ្គលិក ស្ថិតិ ភ័ស្តុភារ វគ្គរៀនសូត្រប្រចាំឆ្នាំ និងមួយផ្នែកទៀតក្រោមការគ្រប់គ្រងផ្ទាល់មុខរបស់គណៈកម្មាធិការអចិន្ត្រៃយ៍សម្រាប់ការងារសន្តិសុខទាំងប្រាំ ដែលមន្ទីរនេះត្រូវបំពេញ”]។ ឯកសារ D98/3.1.83 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ម៉ោង 11.56.16 KH ERN 00325510 [ស-២១ “អង្គភាពខាងសេនាធិការ វាមានតម្លៃជាវរសេនាធំឯករាជ្យ។ ភ័ស្តុភារក៏ទៅបើកពីសេនាធិការ។ បញ្ជីកម្លាំងក៏បើកខាង […] ផែនការបង្កបង្កើនផលស្រូវក៏ទៅទាក់ទងនឹងសេនាធិការ”]។ ឯកសារ D4.1.1122 ចម្លើយរបស់ឌុចចំពោះសំណួរសរសេរទាំង១៣របស់សហចៅក្រមស៊ើបអង្កេត KH ERN 00234078 [កថាខណ្ឌ (ឃ)]។ ឯកសារ D1.3.30.9 របាយការណ៍យោធារបស់កម្ពុជាប្រជាធិបតេយ្យ៖ ស្ថិតិកម្លាំងរួម – ខែមីនា ឆ្នាំ១៩៧៧ [លេខរៀងទី១៣ គឺ “មន្ទីរស-២១”]។ ឯកសារ D114/27.1.7 គម្រោងចំណាយស្រូវ ចុះថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៦ KH ERN 00160081 [លេខរៀងទី១១ – “ម-២១”]។

2017 សូមមើល ឧទាហរណ៍ ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា និងភ័ស្តុភាររបស់កងពល និងវរៈសេនាធំ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦ KH ERN 0052393 [ការប្រជុំមានការចូលរួមពីសមមិត្ត ហ៊ុយ ជាសមាជិកគណៈកម្មាធិការមន្ទីរស-២១]។ ឯកសារ

D1.3.27.10 កំណត់ហេតុនៃការប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពល លេខា និងអនុលេខាវរៈសេនាធំ ថ្ងៃទី២ ខែសីហា ឆ្នាំ១៩៧៦ KH ERN 00052356 [មតិរបស់សមមិត្ត ហ៊ុយ]។ ឯកសារ D1.3.27.19 កំណត់ហេតុនៃការប្រជុំរបស់កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំការងារបង្កបង្កើនផល ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦ KH ERN 0088915 [របាយការណ៍របស់តំណាងមន្ទីរស-២១]។ សូមមើលឯកសារ D4.1.1106 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00164321 [ទទួលស្គាល់ថា នុន ហ៊ុយ ត្រូវបានចាត់តាំងឲ្យធ្វើជាតំណាងរបស់ស-២១ ដើម្បីនិយាយតែរឿង “បង្កបង្កើនផល” […] ធ្វើរបាយការណ៍អំពីស្ថានភាពផ្ទៃក្នុងរបស់ស-២១ (បុគ្គលិក ភ័ស្តុភារ ។ល។)”]។

2018 ឯកសារ D1.3.30.5 របាយការណ៍យោធារបស់កម្ពុជាប្រជាធិបតេយ្យ បញ្ជីសិក្ខាកាមមករៀន - វគ្គសេនាធិការលើកទី១ ថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៦ KH ERN 00897665 [សិក្ខាកាម១២ នាក់មកពីមន្ទីរស-២១ រួមមាន ឌុច (លេខរៀងទី២៨៤), ហ៊ី (លេខរៀងទី២៨៦) និង ហ៊ុយ (លេខរៀងទី២៨៧)]។ ឯកសារ D98/3.1.83 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ម៉ោង 11.56.16 KH ERN 00325510 [“ការរៀនសូត្រប្រចាំឆ្នាំ ដែលខាងលើហៅខ្ញុំបីនាក់ទៅ ខ្ញុំ មិត្តហ៊ី និងមិត្ត ហ៊ុយ គឺទៅរៀនក្រោមការឧទ្ទេសនាមរបស់សេនាធិកា រហូតដល់ឆ្នាំ១៩៧៧”]។ ឯកសារ D114/277.8 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 10.09.45-10.36.14 KH ERN 01323383-85, ម៉ោង 10.57.59-11.00.47 KH ERM 01323392។ ឯកសារ D98/1.2.16 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ម៉ោង 13.37.39-13.39.31 KH ERN 00791953-54 [“វគ្គនយោបាយ សុន សេន គាត់បង្រៀន រាល់ថ្ងៃ”]។ ឯកសារ D98/1.2.17 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ ម៉ោង 13.55.00-13.57.26 KH ERN 00792513-14។ ឯកសារ D1.3.33.5 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00146572 [“ជារៀងរាល់ឆ្នាំ ខ្ញុំត្រូវបានកោះហៅដោយ សុន សេន ឲ្យទៅចូលរួមរៀនសូត្រ ដែលក្នុងនោះមានការបង្ហាញមាគ៌ារបស់បក្ស”]។ ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 09.21.10-09.24.06 KH ERN 01297755-56, ម៉ោង 13.32.20-13.35.49 KH ERN 01297791-92 [“សុន សេន ហៅ ខៀវ ហ្នឹងគឺគាត់មកបង្រៀនពួកខ្ញុំឆ្នាំ៧៧”], ម៉ោង 15.26.54-15.35.00 KH ERN 01297819-21។ ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.12.09-09.16.18 KH ERN 01249428-29, ម៉ោង 13.34.09-13.36.51 KH ERN 01249464-65។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.44.15-10.46.56 KH ERN 01249368-69, ម៉ោង 11.00.04-11.02.11 KH ERN 01249372-73 [“សុន សេន មានម្តងនោះ មាន សុន សេន ចូលមកបង្រៀនជារួមនៅក្នុងសាលានយោបាយ របស់ឌុច នៅក្បែរផ្ទះឌុចហ្នឹង”]។ ឯកសារ D234/2.1.111 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.24.12-14.28.39 KH ERN 01249312-13។ ឯកសារ D98/3.1.147 ឡាច មាន ប្រតិចារឹក ថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៩ ម៉ោង 15.37.37-15.40.40 KH ERN 00360524-25 [អធិប្បាយអំពី សុន សេន មកប្រជុំបង្រៀនអំពី “មាគ៌ានយោបាយរបស់អង្គការ” ដល់កម្មាភិបាលស-២១”]។

គេត្រូវបានណែនាំអំពីខ្មាំង[2019] និងគោលនយោបាយដែលថា មនុស្សទាំងអស់ដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ គឺជាខ្មាំងដែលត្រូវ "កម្ទេច"[2020]។

537. ប្រធានមន្ទីរ ស-២១ បានរាយការណ៍ទៅកាន់ និងប្រតិបត្តការដោយផ្ទាល់ស្ថិតក្រោមការគ្រប់គ្រងរបស់សមាជិកគណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា[2021]។ ក្នុងរយៈពេលពីរឆ្នាំដំបូងនៃប្រតិបត្តិការ ប្រធានមន្ទីរ ស-២១ បានរាយការណ៍ផ្ទាល់ទៅកាន់ប្រធានសេនាធិការ សុន សេន[2022]។

---

[2019] ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 09.04.46-09.06.15 KH ERN 01297750-51, ម៉ោង 15.32.32-15.35.00 KH ERN 01297820-21 [ការណែនាំពី សុន សេន ទាក់ទងនឹង "ខ្មាំងស៊ីរូងផ្ទៃក្នុង"]។

[2020] ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.54.54-15.56.52 KH ERN 01247414-15 ["គេណែនាំ គេពន្យល់ គេប្រាប់យើងមកថាអ្នកដែលចូលមកក្នុងមន្ទីរស-២១នេះ គឺសុទ្ធតែជាខ្មាំងក្បត់ជាតិទាំងអស់ បានគេយកមកដល់កន្លែងនេះ។ នេះជាការណែនាំ ការប្រាប់ពីថ្នាក់លើមក គឺថាអ៊ីចឹងតែម្តង [...] ជាគោលនយោបាយរបស់គេ គឺឲ្យតែខ្មាំង គឺគេត្រូវតែកម្ទេច ត្រូវតែកម្ចាត់ចោល"]។ ឯកសារ D234/2.1.111 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.30.01-14.33.48 KH ERN 01249313-14 [សុន សេន បានណែនាំក្នុងវគ្គរៀនសូត្រថា "ជនក្បត់ជាតិ យើងត្រូវតែកម្ទេចចោល"]។ ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 09.04.46-09.06.15 KH ERN 01297750-51។

[2021] ឯកសារ D1.3.33.5 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00146571 ["ស២១ ត្រូវគ្រប់គ្រងដោយ គណៈកម្មាធិការអចិន្ត្រៃយ៍មជ្ឈិមបក្ស"]។ ឯកសារ D4.1.1107 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00164353 [ឌុច "រាយការណ៍ឯកសារសន្តិបាលជូនគណៈកម្មាធិការអចិន្ត្រៃយ៍មជ្ឈិម" ខាងអចិន្ត្រៃយ៍មជ្ឈិម មានតែសុន សេន ហើយធំពីលើសុន សេន ទៅទៀត គឺនួន ជា ដែលមានភារកិច្ចជាប្រចាំគ្រប់គ្រងស២១ ខាងការងារសន្តិបាល"]។ ឯកសារ D114/277.3 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 15.57.44-15.58.30 KH ERN 01312031-32 ["ឯចំណែកបញ្ហារាយការណ៍ គឺទាំងអស់គ្នាគេរាយការណ៍មក មិត្តហ៊ី, មិត្តហ៊ី រាយការណ៍មកខ្ញុំ។ ខ្ញុំបានដំណឹង ខ្ញុំតែទៅមេ ឬក៏ខ្ញុំរាយការណ៍ [...] ប៉ុន្តែខ្ញុំច្រើនតែតេទៅ ព្រោះគាត់មកជួបខ្ញុំរាល់តែល្ងាច។ តាមរយៈទូរស័ព្ទ នេះជាមួយសុន សេន។ ដល់ជាមួយ ពូនួន គឺខ្ញុំទៅជួបគាត់បានខ្ញុំនិយាយ"]។ ឯកសារ D98/1.2.17 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ ម៉ោង 10.12.16-10.14.39 KH ERN 00792478 ["ហើយក្រោយមក ខ្ញុំកាន់កាប់កិច្ចការហ្នឹង ខ្ញុំនឹងមេទាក់ទងគ្នាជាប់រាល់ថ្ងៃ។ បើជាមួយ សុន សេន រាល់ថ្ងៃតាមទូរស័ព្ទ បើជាមួយ ពូនួន ពីរបីថ្ងៃគាត់ហៅទៅម្តង"]។ ឯកសារ D98/1.2.42 ដេវីដ ឆាណ្ឌល័រ ប្រតិចារឹក ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១២ ម៉ោង 11.31.19-11.32.48 KH ERN 00826661-62។ ឯកសារ D114/35.3 សៀវភៅនិពន្ធដោយ ដេវីដ ឆាណ្ឌល័រ៖ សម្លេងពីមន្ទីរស២១ EN ERN 00192693-94។

[2022] ឯកសារ D98/1.2.21 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ ម៉ោង 09.47.53-09.50.12 KH ERN 00795489-90 ["ខ្ញុំសូមឆ្លើយថា ខ្ញុំឡើងចុះទៅរាយការណ៍ និងទៅធ្វើការឲ្យ សុន សេន រហូតដល់ថ្ងៃ១៥ សីហា

ឌុច បានទូរស័ព្ទប្រចាំថ្ងៃទៅកាន់ សុន សេន ក្នុងពេលរសៀល ដែលគាត់បានរាយការណ៍អំពីបញ្ហាអ្នកទោស និងបានទទួលការណែនាំ[2023] ហើយក៏នឹងជួប សុន សេន នៅការិយាល័យសេនាធិការរបស់គាត់ផងដែរ[2024]។ នៅពេលខ្លះ សុន សេន បានទៅជួប ឌុច នៅមន្ទីរ ស-២១[2025]។

---

១៩៧៧។ ដូច្នេះរយៈកាលដែលសាវាចរនេះចេញ គឺខ្ញុំនៅក្រោមការគ្រប់គ្រងរបស់ សុន សេន ខាងការងារសន្តិបាល"]។ ឯកសារ D98/1.2.19 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ ម៉ោង 11.07.40-11.11.01 KH ERN 00794049-50, ម៉ោង 11.19.03-11.22.39 KH ERN 00794052-53។ ឯកសារ D4.1.1107 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00164347 ["មុនថ្ងៃទី១៥ សីហា ១៩៧៧ ខ្ញុំធ្វើរបាយការណ៍តែទៅសុន សេនមួយនាក់ទេ"]។ ឯកសារ D1.3.33.3 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00146481-82។ ឯកសារ D234/2.1.114 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 11.09.47-11.12.08 KH ERN 01297865-66 [បញ្ជាក់ថា សុន សេន ជាមេរបស់ឌុច]។ ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 11.24.33-11.26.18 KH ERN 01297788 ["បាទ ពីមុនមកគឺ សុន សេន មេរបស់តាឌុច"]។ ឯកសារ D4.1.855 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ដុស KH ERN 00357492 ["មន្ទីរ ស២១ ស្ថិតនៅចំណុះសេនាធិការដែរ ពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៧។ ខ្ញុំធ្លាប់ឃើញ ឌុច មកប្រជុំផ្ទាល់ជាមួយ សុន សេន"]។

2023 ឯកសារ D114/277.2 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.48.29-09.51.09 KH ERN 01307786-87 [ផ្តល់សក្ខីកម្មថា គាត់ និង សុន សេន "មានការទាក់ទងគ្នា [...] ស្ទើរតែរាល់ថ្ងៃ" តាមទូរស័ព្ទ ពេលគាត់ហៅមក សុន សេន "សួរសព្វគ្រប់អំពីការឆ្លើយសារភាព" ហើយគាត់ណែនាំឌុចច្រើន"]។ ឯកសារ D114/277.3 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.56.31 KH ERN 01311979 ["ខ្ញុំជាមួយនឹងបង សុន សេន ជួបគ្នារាល់ល្ងាចតាមរយៈទូរស័ព្ទ"] ម៉ោង 15.57.44-15.58.30 KH ERN 01312031-32។ ឯកសារ D114/277.6 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.48.12-09.50.44 KH ERM 01319688។ ឯកសារ D98/1.2.18 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ ម៉ោង 15.15.02 KH ERN 00793478 ["ដោយឡែកនៅស២១ ក៏ត្រូវអនុវត្តក្រឹតក្រមនេះជាមួយនឹង សុន សេន [...] មួយថ្ងៃគាត់ទូរស័ព្ទមកខ្ញុំ [...] រាល់ល្ងាច ប្រហែលជាពីម៉ោងបួន ដល់ម៉ោងប្រាំ។ គាត់សួរអ្នកនេះឆ្លើយហើយម៉េច? ជាពិសេសមនុស្សណា [...] ដែលគាត់យកចិត្តទុកដាក់។ គាត់សួរអ៊ីចឹងជាប់"]។ ឯកសារ D1.3.33.3 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00146481 ["គាត់ជាអ្នកណែនាំខ្ញុំមុននឹងបញ្ជូនទៅលើ [...] ទាក់ទងការរាយការណ៍ជាមាត់ទទេ គឺតាមរយៈទូរស័ព្ទ"]។ ឯកសារ D1.3.33.11 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00146557 ["កាលពីសម័យសុន សេននៅធ្វើជាមេខ្ញុំផ្ទាល់ ចំណាររបស់ខ្ញុំនៅលើសេចក្តីសារភាព ខ្ញុំតែងតែធ្វើតាមការណែនាំរបស់គាត់តាមទូរស័ព្ទ"]។ សូមមើល ឯកសារ D4.1.964 បទសម្ភាសន៍ជាមួយ អៀង សារី ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦ KH EN 00062488 ["ក៏ប៉ុន្តែឌុចនេះហើយសុន សេន ទាក់ទងសឹងតែរាល់ថ្ងៃ"]។

2024 ឯកសារ D114/277.3 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.56.31-09.59.20 KH ERN 01311979-80 ["ដូច្នេះ៣ថ្ងៃ យ៉ាងច្រើន៤ថ្ងៃ ជួបគ្នាម្តង។ កន្លែងជួបគ្នារបស់បង សុន សេន គឺ [...] នៅខាង

538. ក្នុងអំឡុងឆមាសទីពីរក្នុងឆ្នាំ ១៩៧៧ បន្ទាប់ពី សុន សេន បានចាកចេញពីទីក្រុងភ្នំពេញ ដើម្បីទៅគ្រប់គ្រងជម្លោះប្រដាប់អាវុធប្រឆាំងនឹងវៀតណាម នួន ជា បានចូលមកគ្រប់គ្រងដោយផ្ទាល់លើមន្ទីរ ស-២១ ហើយ ឌុច បានរាយការណ៍ដោយផ្ទាល់ទៅកាន់រូបគាត់រហូតដល់ចប់របបគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ[2026]។ ឌុច បានជួប នួន ជា ដោយផ្ទាល់រៀងរាល់បីទៅប្រាំថ្ងៃម្តង ដែលជាធម្មតាជួបនៅការិយាល័យរបស់ នួន ជា នៅក្នុងសាលាពុទ្ធិកព្រះសុរាម្រិតស្ថិតនៅលើផ្លូវ

---

ជើងបុរីកីឡា"]។ ឯកសារ D98/3.1.82 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ ម៉ោង 10.30.35-10.44.00 KH ERN 00325347-49 [កំណត់ទីតាំងដែលគាត់ "បានធ្វើការជាមួយ លោកគ្រូ សុន សេន"]។ ឯកសារ D4.1.1116 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00153461 ["ចំណែកផង 'B' ស្ថិតនៅកន្លែងដែលជាការិយាល័យទី២ របស់សុន សេន [...] ខ្ញុំបានទៅការិយាល័យនោះរៀងរាល់បី ឬបួនថ្ងៃម្តង ប៉ុន្តែមិនលើសពី១អាទិត្យទេ ដើម្បីទទួលការណែនាំពីសុន សេន"], KH ERN 00153468 [ផែនទីទីតាំងការិយាល័យរបស់សុន សេន សម្គាល់ដោយអក្សរ "B"]។ ឯកសារ D4.1.855 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុញ ដុស KH ERN 00357492 [សក្ខីកម្មរបស់មន្ត្រីកាន់វិទ្យុទាក់ទងនៃអគ្គសេនាធិការ៖ "ខ្ញុំធ្លាប់ឃើញ ឌុច មកប្រជុំជាមួយ សុន សេន"]។

2025 ឯកសារ D98/1.2.25 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១២ ម៉ោង 10.02.19 KH ERN 00797564 ["បង នួន មិនដែលទៅដល់ ស-២១ ទេ។ បង ខៀវ ទៅបួនដង"]។ ឯកសារ D1.3.33.3 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00146482 ["អ្នកដែលមកពិនិត្យ ស ២១ មានតែម្នាក់ទេ គឺសុន សេន។ ទី១ គាត់មកដល់ទ្វារគុក ទី២ និងទី៣ មកត្រឹមផ្ទះខ្ញុំ"]។

2026 ឯកសារ D114/277.1 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 11.31.10 KH ERN 01307733, ម៉ោង 13.51.05-13.56.37 KH ERN 01307741 [រៀបរាប់អំពីការប្រជុំជាមួយនួន ជា នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧៖ "បងនួនប្រាប់ខ្ញុំថា មិត្តខៀវ ទៅសមរភូមិហើយ មិត្តមកធ្វើការជាមួយនឹងខ្ញុំ"]។ ឯកសារ D98/1.2.24 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១២ ម៉ោង 15.16.08-15.18.24 KH ERN 00797233 ["ពីថ្ងៃ១៥ ខែសីហា ១៩៧៧ សុន សេង លែងហៅខ្ញុំទៅធ្វើការមួយទល់មុខ មួយម៉ែត្រ ឬកន្លះម៉ែត្រពីគ្នាទៀតហើយ។ ខ្ញុំចាប់ផ្តើមធ្វើការងារជាមួយ បងនួន ម្តង [...] ក្រោយពីបង សុន សេន ដាច់ពីខ្ញុំទៅ ខ្ញុំនៅមានទំនាក់ទំនងនឹងគាត់ បួនដប់ថ្ងៃ កន្លះខែ ឬក៏យូរ យ៉ាងយូរមួយខែម្តង"]។ ឯកសារ D98/1.2.19 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ ម៉ោង 11.41.56-11.43.42។ ឯកសារ D98/1.2.25 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១២ ម៉ោង 10.15.46 KH ERN 00797568។ ឯកសារ D98/1.2.27 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១២ ម៉ោង 15.44.08-15.46.23 KH ERN 00799648-49។ ឯកសារ D1.3.33.3 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00146482។ ឯកសារ D4.1.1107 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00164347។ ឯកសារ D4.1.964 បទសម្ភាសន៍ជាមួយ អៀង សារី ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦ KH ERN 00062488 [បញ្ជាក់ថា សុន សេន ផ្លាស់ទៅបូព៌ានៅ "ចុង៧៧ ឬដើម៧៨" "ក្រោយពីពេលនោះមក ឌុច "ធ្វើការផ្ទាល់ជាមួយ នួន ជា"]។

លេខ ២៤០ ដើម្បី "រាយការណ៍ និងទទួលការណែនាំ"[2027]។ ឌុច បានផ្ញើរបាយការណ៍ជាលាយលក្ខណ៍អក្សរជាប្រចាំ និងបានចារចម្លើយសារភាពទៅកាន់ នួន ជា និង សុន សេន[2028] ហើយបានទទួលសំបុត្រត្រលប់មកវិញដែលមានការណែនាំនានាពីថ្នាក់លើរបស់គាត់[2029]។

---

2027 ឯកសារ D114/277.5 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 14.25.06-14.34.50 KH ERN 01311940-42។ ឯកសារ D114/277.3 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 15.57.44-15.58.30 KH ERN 01312031-32។ ឯកសារ D114/277.6 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.48.12 KH ERM 01319688។ ឯកសារ D98/1.2.18 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ ម៉ោង 15.15.02-15.18.33 KH ERN 00793478, ម៉ោង 15.47.59-15.51.31 KH ERN 00793488-89។ ឯកសារ D98/1.2.17 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ ម៉ោង 10.09.47-10.14.39 KH ERN 00792477-78។ ឯកសារ D98/3.1.82 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ ម៉ោង 10.30.35-10.44.00 KH ERN 00325347-49 [កំណត់ទីតាំងដែលគាត់បានជួប នួន ជា រួមមាន "ពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ដែល ពូនួន ហៅខ្ញុំទៅធ្វើការញ៉ែកញាប់កន្លែងនេះជាងគេ"]។ ឯកសារ D1.3.33.3 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00146481-83 ["ជាមួយ នួន ជា គឺប្លែកជាង។ គាត់មិននិយាយតាមទូរស័ព្ទទេ [...] ជួប នួន ជា នៅ២កន្លែង ទី១ បូរីកីឡា ទី២ ពុទ្ធិកសុរាម្រិត។ [...] មូលហេតុដែលទៅជួបគឺគេហៅឲ្យទៅរាយការណ៍ និងទទួលសេចក្តីណែនាំ។ ជួបរៀងរាល់បីថ្ងៃ ជាលក្ខណៈទូទៅតែម្តង [...] រាយការណ៍ទូទៅអំពី ស ២១ និងសង្ខេបការសួរចម្លើយ។ អំពីសេចក្តីណែនាំ និយាយថា សេចក្តីបញ្ញាល្អជាង"]។ ឯកសារ D1.3.33.11 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00146555។ ឯកសារ D4.1.1116 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00153461-62, 00153468 [ផែនទីទីតាំងការិយាល័យរបស់ នួន ជា នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត សម្គាល់ដោយអក្សរ "G"]។ ឯកសារ D114/29.1.13 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00398157។

2028 ឯកសារ D114/277.8 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.28.53-09.37.19 KH ERN 01323373-74។ ឯកសារ D114/277.3 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.41.06-09.44.50 KH ERN 01311975-76, 09.54.25-09.56.31 KH ERN 01311979។ ឯកសារ D98/1.2.21 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១២ ម៉ោង 14.19.10 KH ERN 00795539 ["បើសិនជាឯកសារដែលបញ្ជូនទៅខាងលើ ខ្ញុំត្រូវតែបញ្ជូនទៅអចិន្ត្រៃយ៍មជ្ឈិមបក្ស។ ដំបូង គឺបញ្ជូនទៅ សុន សេន ចាប់តាំងពីថ្ងៃ១៥ ខែសីហា ១៩៧៧ មកខ្ញុំបញ្ជូនទៅ នួន ជា"]។ ឯកសារ D98/1.2.26 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ ម៉ោង 15.28.34-15.30.41។ ឯកសារ D98/1.2.18 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ ម៉ោង 11.08.52-11.11.30 KH ERN 00793439-40, ម៉ោង 15.15.02, 15.18.33 KH ERN 00793478 ["ឯកសារណាបន្ទាន់ ចម្លើយសារភាពណាចាំបាច់ ខ្ញុំតែទៅមេ សុន សេន ឲ្យមកយក ឲ្យគេមកយក ឲ្យនីរសារមកយកភ្លាម"]។ ឯកសារ D4.1.1107 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00164347។ ឯកសារ D4.1.1118 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00195594។ ឯកសារ D4.1.404

## ៤. ការទទួលខុសត្រូវរបស់ មាស មុត ចំពោះអ្នកទោសដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១

539. ក្នុងនាមជាលេខាកងពលធំលេខ ១៦៤ និងគណៈកម្មាធិការក្រុងកំពង់សោម **មាស មុត** មានការទទួលខុសត្រូវរួមជាមួយថ្នាក់ដឹកនាំរបស់មជ្ឈិមបក្សនៅភ្នំពេញ ចំពោះការកំណត់សមាសភាពក្នុងកងពលធំលេខ ១៦៤ និងសមាសភាពមកពីក្រុងកំពង់សោម ដែលត្រូវចាប់ខ្លួន និងបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១។ តួនាទីសំខាន់របស់លេខាកងពលធំក្នុងកងទ័ពបដិវត្តន៍កម្ពុជា (និងមេដឹកនាំអង្គការផ្សេងទៀត) ក្នុងការសម្រេចកំណត់អ្នកទោសដែលត្រូវបញ្ជូនទៅមន្ទីរ ស-២១ ត្រូវបានបញ្ជាក់យ៉ាងច្បាស់ក្នុងសក្ខីកម្មរបស់ ឌុច[2030] ដែលជាប្រធានមន្ទីរ ស-២១ និងរបស់អតីតកម្មាភិបាលជាន់

---

កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00242921។ ឯកសារ D98/1.2.29 សូត្រ ទៀង ប្រតិចារឹក ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ ម៉ោង 09.31.15-09.48.25 KH ERN 00801691-96។ ឯកសារ D4.1.850 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូត្រ ទៀង ឆ.105, 117។ ឯកសារ D4.1.247 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ម ណៃ KH ERN 00164387-88 ["ខ្ញុំដឹងថា ឌុច បញ្ជូនចម្លើយទៅថ្នាក់លើ [...] ខ្ញុំដឹងថា បញ្ជីអ្នកទោសទាំងអស់ត្រូវបញ្ជូនទៅខាងមជ្ឈិម ដែលជាអ្នកធ្វើការសម្រេច"]។ ឯកសារ D234/2.1.14 សៀវភៅនិពន្ធដោយ Gina Chon និង Thet Sambath, Behind the Killing Fields, EN 00757537។ សូមមើល ឧទាហរណ៍ ឯកសារ D1.3.18.4 ចម្លើយសារភាពរបស់ គង់ គៀន ហៅ អ៊ឹង វ៉េត នៅមន្ទីរស-២១ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៧ KH ERN 00017305 [ទំព័រគម្របមុខមានចំណាររបស់ ឌុច ថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៧៧ ជូន "បងជាទីគោរព" និងចំណារ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៧ "ជូនបងនួនផ្ទាល់"]។

2029 ឯកសារ D114/277.8 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.39.41-09.44.49 KH ERN 01323375-76។ ឯកសារ D4.1.406 សេចក្តីអត្ថាធិប្បាយ និងចម្លើយជាលាយលក្ខណ៍អក្សររបស់ ឌុចចំពោះសំណួរសរសេរ KH ERN 00408238 ["កាលខ្ញុំនៅធ្វើជាប្រធាន ស-២១ ខ្ញុំធ្លាប់បានទទួលសំបុត្ររបស់ សុន សេន និង នួន ជា។ បើតាមខ្ញុំចាំ គឺជាសំបុត្រខ្លីៗ តែពីរបីម៉ាត់ ជាបទបញ្ជាខ្លីៗ បន្ទាន់"]។ ឯកសារ D1.3.33.10 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00195564។ ឯកសារ D98/1.2.28 សូត្រ ទៀង ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ ម៉ោង 13.42.33-13.44.11 KH ERN 00801396។ ឯកសារ D4.1.850 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូត្រ ទៀង ឆ.104, 106-113។

2030 ឯកសារ D4.1.404 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH ERN 00242921 ["ចម្លើយសារភាព ត្រូវបានផ្ញើទៅប្រធានអង្គភាព ដោយមានគោលបំណងពីរ៖ ទី១ ប្រាប់ដំណឹងដល់គាត់អំពីសកម្មភាពរបស់ខ្មាំងនៅក្នុងអង្គភាពនោះ និងទី២ អនុញ្ញាតឲ្យគាត់គិតពីការចាប់ខ្លួនមនុស្សដែលគេបានឆ្លើយដាក់"]។ ឯកសារ D4.1.860 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00403906 ["ក្នុងការអនុវត្តជាក់ស្តែង ពេលដែលមនុស្សម្នាក់ត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព ថ្នាក់លើជូនដំណឹងទៅអ្នកទទួលខុសត្រូវអង្គភាពនីមួយៗ"]។ ឯកសារ D4.1.400 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00239838 ["មុនការចាប់ខ្លួននរណាម្នាក់ គេត្រូវតែពិភាក្សាជាមួយប្រធានអង្គភាពរបស់អ្នកនោះ។ នៅពេលណាដែលបានទទួលចម្លើយ

ខ្ពស់ផ្សេងទៀតរបស់ ប.ក.ក[2031] និងឯកសារសហកាលដែលនៅសេសសល់ដូចជា ចំណារលើចម្លើយសារភាពនៅមន្ទីរ ស-២១ ដែលបង្ហាញថា អ្នកទោសត្រូវបានបញ្ជូនទៅថ្នាក់ដឹកនាំអង្គការ

---

សារភាពរួចហើយ ចម្លើយសារភាពត្រូវបានផ្ញើដោយសុន សេន (បន្ទាប់មក នួន ជា) ទៅឱ្យប្រធានអង្គភាព"]។ ឯកសារ D4.1.1156 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00205162។ ឯកសារ D4.1.1118 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00195593។ ឯកសារ D114/277.5 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 14.34.50-15.00.04 KH ERN 01311943-44 ["មួយបែបទៀត កាលណាបានឯកសារហើយ គេបំបែកទៅតាមភូមិភាគ ឱ្យភូមិភាគរួមចំណែកជាមួយនឹងគេ "សូមសមមិត្តពិនិត្យមើលតាមជាក់ស្ដែង" នេះជារឿងរ៉ាវដែលខ្ញុំបានរាយការណ៍ជូនថ្មី ប៉ុន្តែភូមិភាគក៏ដោយច្រើនតែខាងលើប្រគល់រុញទៅហើយខ្ទាំងឆ្លើយដាក់ប៉ុន្មានដែលខាងលើគិតថា អាណាមានលទ្ធភាពធំជាងគេ ចាប់ហើយ"]។ ឯកសារ D98/1.2.6 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ ម៉ោង 09.32.55 KH ERN 00336770 ["ចម្លើយដែលចេញពី ស-២១ [...] គឺខ្ញុំជូនទៅដៃមេខ្ញុំ។ មេខ្ញុំឱ្យទៅ ស៊ូ ម៉េត ហើយ ស៊ូ ម៉េត ជ្រើសមនុស្សមួយចំនួន ដែលនៅក្នុងកងពល ៥០២"] ម៉ោង 09.55.10-10.16.21 KH ERN 00336776-77, 10.33.21 KH ERN 00336786។ ឯកសារ D12 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ KH ERN 00680805 ["ហើយសុន សេន មុនពេលសម្រេចគាត់តែងតែសុំយោបល់ និងការជួយសម្រេចពីប្រធានកងពលផ្ទាល់"]។

2031 ឯកសារ D98/3.1.20 ឆោម សែ ប្រតិចារឹក ថ្ងៃទី១១ ខែមករា ឆ្នាំ២០១៣ ម៉ោង 15.28.00-15.38.49 KH ERN 00878919-22 [សក្ខីកម្មរបស់ប្រធានសន្តិសុខកងពល៨០១ ថា បន្ទាប់ពីលេខាកងពលឈ្មោះ សារឿន បានទទួលចម្លើយសារភាពពីភ្នំពេញដែលមាន "ឈ្មោះមនុស្សដែលត្រូវបានគេឆ្លើយដាក់" គាត់ត្រូវធ្វើសេចក្ដីសម្រេចចិត្តថា "តើត្រូវចាប់ខ្លួនបុគ្គលនោះ ឬក៏ត្រូវមានវិន័យលើបុគ្គលនោះ"]។ ឯកសារ D4.1.805 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឆោម សែ ឆ.6; ឯកសារ D4.1.443 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហាំ អនស៊ី KH ERN 00242413 [ប្រធានយោធាតំបន់១០៥ បានទទួលចម្លើយសារភាពពីមជ្ឈិម ដែលកងពល៩២០ "បានឆ្លើយដាក់អ្នកស្គាល់គ្នា"]។ ឯកសារ D98/1.2.33 សៅ សារុន ប្រតិចារឹក ថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១២ ម៉ោង 11.08.44-11.13.09 KH ERN 00814329-31 [បញ្ជាក់ថា ក្នុងនាមជាលេខាតំបន់១០៥ គាត់បានទទួលសារទូរលេខពីប៉ុល ពត ដែលជូនដំណឹងគាត់ថា ចម្លើយសារភាពរបស់កម្មាភិបាលម្នាក់នៃតំបន់១០៥ បានប្រាប់ឈ្មោះ "សមមិត្ត សុទ" ជាជនក្បត់"]។ ឯកសារ D4.1.578 ទូរលេខ៥៤ ពីសារុន ជូនបងជាទីគោរព ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៨ [សារទូរលេខពីលេខាតំបន់១០៥ និយាយអំពីការចាប់ខ្លួនឈ្មោះ សុទ ដែលបាន"ជាប់ក្នុងចម្លើយពួកអាក្បត់ អាជួន"]។ ឯកសារ D98/3.1.221 រ៉ែចាម តុន ហៅ ភី ភួន ប្រតិចារឹក ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ ម៉ោង 11.35.29-11.44.49 KH ERN 00829506-09 [សក្ខីកម្មរបស់ប្រធានសន្តិសុខក្រសួងការបរទេសថា អៀង សារី បានទទួលចម្លើយសារភាពដែលមានចំណារពីមន្ទីរ៨៧០ ដែលបានឆ្លើយដាក់គ្នាថាជា "កា.ហ្សេ.បេ ឬ សេ.អ៊ី.អា"]។ ឯកសារ D4.1.241 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី រ៉ែចាម តុន ហៅ ភី ភួន KH ERN 00228845 ["ឈ្មោះដែលគេឆ្លើយដាក់នោះ ត្រូវបានបញ្ជូនមកអ៊ំអៀង សារី ដើម្បីឱ្យគាត់បញ្ជាក់ប្រាប់ថា ជននោះជាអ្នកណា ហើយធ្វើការនៅផ្នែកណា"]។ ឯកសារ D98/3.1.198 សួង ស៊ីគឿន ប្រតិចារឹក ថ្ងៃទី៧ ខែសីហា ឆ្នាំ២០១២ ម៉ោង 09.27.10-09.29.26 KH ERN 00832517-18 [បញ្ជាក់

ដែលពាក់ព័ន្ធនឹងកម្មាភិបាល[2032] កំណត់ហេតុកិច្ចប្រជុំដែលលេខាកងទ័ពបដិវត្តន៍កម្ពុជា បានចូលរួមក្នុងការធ្វើសេចក្តីសម្រេចលើការចាប់ខ្លួនកម្មាភិបាលរបស់ខ្លួន[2033] និងលិខិតឆ្លើយឆ្លងគ្នាដែលបញ្ជូន

---

ថា អៀង សារី បានអានពីចម្លើយសារភាព]។ ឯកសារ D98/3.1.244 សួង ស៊ីគឿន ប្រតិចារិក ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១២ ម៉ោង 11.33.40-11.36.38 KH ERN 00832550 [ផ្តល់សក្ខីកម្មថា គាត់ត្រូវបានគេកោះហៅទៅកាន់មន្ទីររបស់អៀង សារី ហើយប្រាប់ថា គាត់ត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាពមួយ]។ ឯកសារ D4.1.835 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាឡុត បាន KH ERN 00357530-31 [បញ្ជាក់ថា ចម្លើយសារភាពនៅមន្ទីរ ស-២១ ត្រូវបានបញ្ជូនទៅក្រសួងការបរទេស]។

2032 សូមមើល ឧទាហរណ៍ ឯកសារ D234/2.1.55 សម្រង់ចម្លើយសារភាពរបស់ ហង់ ខឿន ហៅខឹម ចំណារ & ឯកសារ D1.3.18.1 សម្រង់ចម្លើយសារភាពរបស់ ហង់ ខឿន ហៅ ខឹម KH ERN 00162140 [ចំណាររបស់សុន សេន នៅលើចម្លើយសារភាពរបស់អនុលេខាកងពល១៦៤៖ "ខ្ញុំនឹងអញ្ជើញសមមិត្តមុតមកពិនិត្យជាមួយគ្នា"]។ ឯកសារ D234/2.1.54 ចម្លើយ គុណ ខឹម ថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៧៧ KH ERN 00175293 [ចំណារ៖ "កងពល១៦៤របស់សមមិត្តមុត [...] ទាក់ទងសមមិត្តមុតដើម្បីមានវិធានការ"]។ ឯកសារ D10.1.105 ចម្លើយ សួរ ទូន ហៅ ម៉ៅ ថ្ងៃទី ១៥ ខែឧសភា ឆ្នាំ១៩៧៧ KH ERN 00173999 [កំណត់ត្រាសរសេរដោយដៃ របស់សុន សេន ជូនទៅសារឿន លេខា កងពល៨០១៖ "សុំសមមិត្តអានឯកសារម៉ៅ ហើយស្រង់ឈ្មោះដែលទាក់ទងនឹងកង៨០១"]។ ឯកសារ D1.3.1.10 ចម្លើយរបស់ ស្រី សារឿន ថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៧ KH ERN 00235162 [ចំណារនៅលើចម្លើយសារភាពរបស់អតីតលេខាវរសេនាតូចកងពល៥០២៖ "ជូនសមមិត្តម៉េតមួយច្បាប់"]។ ឯកសារ D1.3.1.5 ស ២១ ចម្លើយសារភាពរបស់ ណៃ ចាប ថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៧៧ KH ERN 00162395 [ចំណារនៅលើចម្លើយសារភាពរបស់លេខាវរសេនាតូចកងពល៥០២៖ "ជូនសមមិត្តម៉េតមួយច្បាប់"]។ ឯកសារ D4.1.35 ចម្លើយសារភាពរបស់ សៀង ផុន ហៅ ផា ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៧ KH ERN 00004458 [ចំណារនៅលើ ចម្លើយសារភាពរបស់ជំនួយការវរសេនាតូចកងពល១៧៤ក្នុងភូមិភាគកណ្តាល៖ "ជូនបងនួនមួយច្បាប់ទៅភូមិភាគកណ្តាល"]។ ឯកសារ D10.1.1 ចម្លើយសារភាពរបស់ យង់ ពៅ ថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៧៧ KH ERN 00004599 [ចំណារនៅលើចម្លើយសារភាពរបស់ប្រធានសន្តិសុខតំបន់១០៦៖ "មួយច្បាប់ជូនសមមិត្ត ពក"]។ឯកសារ D1.3.18.4 ចម្លើយរបស់ គង់ គៀន ហៅអ៊ីង វ៉េត ថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៧ KH ERN 00017305 [ចំណារ៖ "ដកស្រង់ជូនសមមិត្តម៉ុកហើយ"]។

2033 សូមមើល ឧទាហរណ៍ ឯកសារ D1.3.27.17 កំណត់ហេតុនៃការប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំសមមិត្តតាល់ កងពល២៩០និង កងពល១៧០ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ KH ERN 00002234 [ការប្រជុំចូលរួមដោយ សុន សេន,ឌុច, សុខ លេខាកងពល១៧០ និង តាល់ លេខាកងពល ២៩០ ដែលបានឯកភាពលើការចាប់ខ្លួនកម្មាភិបាលចំនួន ២៩ នាក់ពីកងពល១៧០ ព្រមទាំង"ប្រពន្ធ និងក្មួយរបស់អាចក្រី"]។ ឯកសារ D4.1.1156 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00205154 [ឆ្លើយថា គាត់បានចូលរួម"ការពិភាក្សាបែបនេះតែ២ ឬ ៣ដង" ដែលថ្នាក់លើ និងប្រធានអង្គភាព មិនបានឯកភាពគ្នាថាតើត្រូវចាប់ខ្លួនមនុស្សម្នាក់ដែលគេឆ្លើយដាក់ឬអត់នោះទេ រួមទាំងការពិភាក្សារវាង សុន សេន និងមិត្តសុខដែលជាលេខាកងពល ១៧០ ទាក់ទងទៅនឹងមនុស្សដែល

ទៅ ឌុច ដោយលេខាកងទ័ពបដិវត្តន៍កម្ពុជាពាក់ព័ន្ធនឹងកម្មាភិបាលដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរ ស-២១[2034]។

ជាប់ក្នុងចម្លើយសារភាពរបស់ចាន់ ចក្រី]។ ឯកសារ D98/1.2.21 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៩ ខែមីនា ឆ្នាំ ២០១២ ម៉ោង 09.07.39-09.14.15 KH ERN 00795478-80 [ពិភាក្សាអំពីការប្រជុំដែលមាន សុន សេន, លេខាកងពល សុខ និង ឌុច ចូលរួម៖ "ការប្រជុំនេះ គឺធ្វើឡើង ដើម្បីពិភាក្សាអំពីមនុស្សនៅក្នុងកងពល១៧០ ដែលជាខ្សែរបស់ ចាន់ ចក្រី [...] មនុស្សនៅក្នុងកងពល១៧០ ត្រូវបានចាប់ខ្លួន"]។

2034 សូមមើល ឧទាហរណ៍ កងពល ៥០២៖ ឯកសារ D1.3.23.3 សំបុត្ររបស់ ស៊ូ ម៉េត លេខាកងពលលេខ ៥០២ ផ្ញើជូន ឌុច ថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៧ KH ERN 00052994 ["ក្រោយពីបានចម្លើយសារភាពរបស់ឈ្មោះសោម ម ៦២ យើងខ្ញុំបានបញ្ជូនមនុស្សទៅស ២១"]។ ឯកសារ D1.3.28.35 សំបុត្ររបស់ ស៊ូ ម៉េត ផ្ញើជូន ឌុច ថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៧ KH ERN 00002416 [សំដៅលើ "ពួកក្បត់ ២៧ នាក់ដែលមកពីខ្សែក្បត់ កងពល ៣១០ ហើយ និង ៤៥០" ដែលបញ្ជូនទៅស ២១ នៅល្ងាច ថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧ និងស្នើឱ្យផ្តល់ "ផ្តល់ចម្លើយសារភារភាពរបស់ឈ្មោះម៉ៅ" ដើម្បីឱ្យ ម៉េតអាច "ស្រាវជ្រាវខ្លាំងបន្តទៀត"]។ ឯកសារ D1.3.30.17 សំបុត្ររបស់ស៊ូ ម៉េត ផ្ញើជូន ឌុច ថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៧ KH ERN 00002422 ["នៅវេលាម៉ោង ២:៣០ នាទី ខ្ញុំបានបញ្ជូនឈ្មោះស៊ុន ហេង តាមចម្លើយរបស់ឈ្មោះ ម៉ៅ ឈ្មោះសោម ឈ្មោះប៉ាង ដែលបានធ្វើសកម្មភាពដូចមានក្នុងសំណុំរឿងជាបន្តបន្ទាប់"]។ ឯកសារ D234/2.1.57 លិខិតរបស់ស៊ូ ម៉េត ផ្ញើជូន ឌុច ថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៧ KH ERN 00173329 [កំណត់អត្តសញ្ញាណមនុស្សចំនួន ៣នាក់ទៀតដែលត្រូវបញ្ជូនទៅស ២១ នៅថ្ងៃនោះ ជាមនុស្សដែល ម៉េតបានចាប់ខ្លួន "យូរមកហើយ" – សូមមើល លេខរៀង 4291-4293 នៅលើបញ្ជីឈ្មោះអ្នកទោស ស ២១ របស់ ក.ស.ច.ស]។ ឯកសារ D4.1.391 លិខិតរបស់ម៉េត ជូនទៅឌុច ថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៧៧ KH ERN 00173330 [កំណត់អត្តសញ្ញាណកម្មាភិបាល ៣ នាក់ទៀតដែលបានបញ្ជូនទៅស ២១ រួមទាំងម្នាក់ ដែលម៉េតកំណត់ថាជាខ្មាំង តាមដែលគាត់"ពិនិត្យផ្ទាល់"]។ ឯកសារ D1.3.23.4 លិខិតរបស់ ម៉េត ជូនទៅឌុច ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៧៧ KH ERN 00002436 ["ខ្ញុំសូមបញ្ជូនឈ្មោះសែម លេខាអនុសេនាធំនៃវរសេនាតូច៥១២។ ចំពោះឈ្មោះនេះ គឺមានឈ្មោះ សាអ៊ុំ ឈ្មោះរើន ក៏មានឆ្លើយសារភាពបញ្ជាក់ថាជាខ្សែបណ្តាញ របស់វា" – សូមមើល បញ្ជីឈ្មោះអ្នកទោស ស ២១ របស់ ក.ស.ច.ស លេខរៀង ៨២៨៣]។ ឯកសារ D1.3.30.22 លិខិតរបស់ ម៉េត ជូនទៅឌុច ថ្ងៃទី១០ ខែសីហា ឆ្នាំ ១៩៧៧ KH ERN 00002078 [ស្នើឱ្យឌុច ផ្តល់ចម្លើយសារភាពរបស់ឈ្មោះសែម]។ ឯកសារ D4.1.395 លិខិតរបស់ ម៉េត ជូនទៅឌុច ថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៧៧ KH ERN 00175362[ស្នើឱ្យបញ្ជូនអតីតកម្មាភិបាលនៅតំបន់ ២៥ និងកងពល ៧០៣ ដែលជាប់នៅក្នុងចម្លើយសារភាពរបស់អ្នកទោសមកពីអង្គភាពទាំងនោះ]។ ឯកសារ D10.1.72 សំបុត្ររបស់ ម៉េត ជូនទៅឌុច ថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៧៧។ កងពល ៣១០៖ ឯកសារD1.3.30.8 របាយការណ៍របស់ សន (គណៈកងពល៣១០) ជូនទៅឌុច ថ្ងៃទី ៣ ខែមេសា ឆ្នាំ១៩៧៧ KH ERN 00002404 [សូម "ប្រគល់ជូននូវមនុស្ស៧នាក់" ដោយម្នាក់ៗមានបង្ហាញឈ្មោះនិងតួនាទី]។ ឯកសារ D1.3.30.14 សេចក្តីរាយការណ៍របស់ សន ជូនទៅឌុច ថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧៧ KH ERN 00002397 [បង្ហាញអត្តសញ្ញាណ មនុស្ស ៦នាក់ដែលមកពីកងពលលេខ ៣១០ និង៤៥០]។ ឯកសារ D1.3.30.12 លិខិតរបស់សន ជូនទៅឌុច ថ្ងៃទី៥ ខែឧសភា ឆ្នាំ

540. តួនាទីរបស់ **មាស មុត** ក្នុងការទទួលបានចម្លើយសារភាពនៅមន្ទីរ ស-២១ និងការចូលរួមក្នុងការធ្វើសេចក្តីសម្រេចពាក់ព័ន្ធកម្មាភិបាលកងពលធំលេខ ១៦៤ ត្រូវបានគូសបញ្ជាក់ដោយចំណាររបស់ សុន សេន លើចម្លើយសារភាព ២ នៅមន្ទីរ ស-២១ ដូចជា កំណត់សម្គាល់របស់ សុន សេន ដែលបញ្ជាក់ថា គាត់នឹង "អញ្ជើញសមមិត្ត **មុត** មកពិនិត្យ" ថាតើបុគ្គលដែលពាក់ព័ន្ធក្នុងចម្លើយសារភាពនៅមន្ទីរ ស-២១ របស់ ហង់ ឌឿន ហៅ ខឹម ដែលជាអនុលេខាកងពលធំលេខ ១៦៤ គឺជា "មនុស្សត្រឹមត្រូវ[2035]" ឬទេ។ ការដឹងឮរបស់ **មាស មុត** ពាក់ព័ន្ធនឹងមន្ទីរ ស-២១ ក៏ត្រូវបានបង្ហាញឡើងផងដែរ ក្នុងកំណត់ហេតុកិច្ចប្រជុំរបស់កងទ័ពបដិវត្តន៍កម្ពុជាដែលគាត់បានចូលរួម និងមានវត្តមានតំណាងរបស់មន្ទីរ ស-២១[2036] ឬដែលលេខាកងពលធំបានរាយការណ៍ពីអ្នកទោសដែលត្រូវ

១៩៧៧ KH ERN 00002406["សូមប្រគល់ជូននូវមនុស្ស១៧នាក់ឲ្យសមមិត្ត [...] មូលហេតុដែលចាប់មកពីមានចម្លើយក្នុងឯកសារថាឈ្មោះទាំងអស់នេះបានចូល សេអ៊ីអា ចម្លើយរបស់ម៉ឺន ខន"]។ ឯកសារ D4.1.391 លិខិតរបស់ សន ជូនទៅឌុច ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៧ KH ERN 00173331 ["ខ្ញុំសូមប្រគល់ជូននូវមនុស្សចំនួន៧នាក់ឲ្យទៅសមមិត្ត [...] មូលហេតុដែលចាប់ មកពីមានចម្លើយក្នុងឯកសារ សកម្មភាពដូចមានដាក់នៅក្នុងឯកសារស្រាប់"]។

2035 ឯកសារ D234/2.1.55 សម្រង់ចម្លើយរបស់ហង់ ឌឿន ហៅខឹម ចំណារ & ឯកសារ D1.3.18.1 ស ២១ ចម្លើយសារភាពរបស់ ហង់ ឌឿន ហៅខឹម KH ERN 00162140 [ចំណាររបស់សុនសេនថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៧៧ នៅលើចម្លើយសារភាពរបស់អនុលេខាកងពល១៦៤៖ "មនុស្សខ្លះត្រូវ, តែតាមនាំស្គាល់ដូចមិនសមទេ។ ខ្ញុំនឹងអញ្ជើញសមមិត្តមុតមកពិនិត្យជាមួយគ្នា" (គូសបញ្ជាក់បន្ថែម)]។ ឯកសារ D234/2.1.54 ចម្លើយ គុណ ខឹម ថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៧៧ KH ERN 00175293 [កំណត់សម្គាល់របស់សុន សេន៖ "កងពល១៦៤ របស់សមមិត្តមុត [...] ទាក់ទងសមមិត្តមុត ដើម្បីមានវិធានការ។ ខាងសមមិត្តមុត យើងដកអស់ជាមូលដ្ឋានហើយ"]។ ឯកសារ D4.1.766 កំណត់តហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00398202 [បង្ហាញអត្តសញ្ញាណថា សុន សេន ជាអ្នកធ្វើចំណារនៅលើចម្លើយសារភាព របស់ ហង្ស ឌឿន]។

2036 ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំ លេខានិងភស្តុភារ របស់កងពលនិងវរសេនាធំ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦ KH ERN 00195344 [ការប្រជុំមានការចូលរួមពីសមាជិកគណៈកម្មាធិការ ស២១ ហ៊ុយ]។ សូមមើល ឯកសារ D1.3.27.10 កំណត់ហេតុនៃការប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ,កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពល លេខានិងអនុលេខាវរសេនាធំ ថ្ងៃទី២ ខែសីហា ឆ្នាំ១៩៧៦ KH ERN 00052356 [សេចក្តីសង្ខេបរបស់សមមិត្តហ៊ុយ]។ ឯកសារ D1.3.27.19 កំណត់ហេតុនៃការប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំការងារបង្កើនផល ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦ [សេចក្តីរាយការណ៍របស់តំណាងស ២១]។

បានបញ្ជូនទៅមន្ទីរ ស-២១[2037]។ ថ្វីបើមានភស្តុតាងច្បាស់លាស់យ៉ាងនេះក្តី ក៏ **មាស មុត** បានផ្តល់ចម្លើយដែលមិនស៊ីចង្វាក់គ្នា និងមិនស្មោះត្រង់អំពីមន្ទីរ ស-២១ ក្នុងបទសម្ភាសន៍របស់គាត់ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់ធ្លាប់អះអាងថា "គ្មាននរណាម្នាក់" ក្នុងកងពលធំរបស់គាត់ត្រូវបានចាប់ខ្លួន ឬបញ្ជូនទៅមន្ទីរ ស-២១ ឡើយ[2038] ប៉ុន្តែក្នុងបទសម្ភាសន៍មួយទៀត គាត់ទទួលស្គាល់ថា សមាជិកកងពលធំលេខ ១៦៤ ត្រូវបានចាប់ខ្លួនដោយ ឌុច ដែលជាប្រធានមន្ទីរ ស-២១[2039]។

541. ឯកសារសហកាលក៏បានបញ្ជាក់ផងដែរពីការដឹងឮ និងការចូលរួមដោយសុទ្ធចិត្តរបស់ **មាស មុត** ក្នុងការបោសសម្អាតកម្មាភិបាលក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជា។ ក្នុងកិច្ចប្រជុំរវាង សុន សេន និងលេខាកងពលរបស់កងទ័ពដិវត្តន៍កម្ពុជា និងក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សរផ្ញើជូនថ្នាក់លើរបស់គាត់ **មាស មុត** បានឯកភាពលើផែនការបោសសម្អាតសមាសភាពទាំងអស់ក្នុងកងពលរបស់កងទ័ពបដិវត្តន៍កម្ពុជា ដែលគេចាត់ទុកថាជាអ្នកប្រឆាំង ឬខ្មាំងរបស់ ប.ក.ក ដូចជា "សមាសធាតុមិនល្អ ឬខ្មាំង" នៅតែ "ពួនបន្លំ បង្កប់ក្នុងជួរបក្សទៀត[2040]"។ ក្នុងកិច្ចប្រជុំលេខាកងពលកាលពីថ្ងៃ

---

[2037] សូមមើល ឧទាហរណ៍ ឯកសារ D1.3.27.26 កំណត់ហេតុនៃការប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ, កំណត់ហេតុនៃការប្រជុំលេខា អនុលេខាកងពល និងវរសេនាធំឯករាជ ថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៧ KH ERN 00052304 [សេចក្តីរាយការណ៍របស់ម៉េត លេខាកងពល ៥០២ ៖"ពួកមិនល្អបានបញ្ជូនទៅស ២១ ជាង ៥០ នាក់"]។

[2038] ឯកសារ D1.3.33.16 កិច្ចសម្ភាសន៍ មាស មុត ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០១ KH ERN 00283078-00283079 ["នៅក្នុងកងពល របស់ខ្ញុំគ្មានអ្នកណាម្នាក់ត្រូវគេចាប់នោះទេ"]។

[2039] ឯកសារ D1.3.7.8 កាសែត ឌឺ ឃែមបូឌា ដេលី មានចំណងជើងថា សូមបំភ្លេចរឿងអតីតកាលចោល ចេញផ្សាយថ្ងៃទី១ ខែមីនា ឆ្នាំ២០០៨ EN ERN 00165821 ["មនុស្សត្រូវបានចាប់ខ្លួនពីកងពលរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនដឹងថាប៉ុន្មាននាក់ទេ។ ឌុច បានចុះទៅចាប់ពួកគេផ្ទាល់"]។

[2040] ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខានិងវរសេនាធំឯករាជ ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦ KH ERN 00052411 [កំណត់សម្គាល់របស់មាស មុត "យល់ព្រមឯកភាព"ជាមួយបក្សទាំងស្រុង លើតម្រូវការក្នុងការកំណត់ និងកំចាត់ "សមាសភាពមិនល្អឬខ្មាំង"ប្រឆាំងនឹងបដិវត្តដែល "នៅតែពួនបន្លំ បង្កប់ក្នុងជួរបានទៀត"]។ ឯកសារ D1.3.34.60 ទូរលេខរបស់មាស មុត ជូនគណៈម ៨៧០ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ KH ERN 00001325 [ប្តេជ្ញា "ឯកភាពទាំងស្រុង" ជាមួយបក្ស ដោយ"[បោស] សំអាតគ្មានស្នាក់ស្នើរសមាសបង្កប់របស់ខ្មាំង"]។ ឯកសារ D1.3.27.26 កំណត់ហេតុនៃការប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា អនុលេខាកងពល និងវរសេនាធំឯករាជ ថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៧ KH ERN 00052305 [សេចក្តីរាយការណ៍របស់មាស មុត អំពីការបន្តសំរិតសំរាំងអនុសេនាតូច], KH ERN 00052309 [សុន សេន៖ "ត្រឹមការអប់រំមិនគ្រប់គ្រាន់ទេ។ ត្រូវបន្តសំរិតសំរាំងដាច់ខាតតទៅទៀត"]។សូមមើល ឯក

ទី ៩ ខែ តុលា ឆ្នាំ ១៩៧៦ ដែលចូលរួមដោយ **មាស មុត** និងអនុលេខា ឌឹម អគ្គសេនាធិការ សុន សេន បានផ្តល់របាយការណ៍លម្អិតស្តីពីការចាប់ខ្លួនថ្នាក់ដឹកនាំ ប.ក.ក ជាច្រើន រួមទាំងលេខាកងពលធំលេខ ១៧០ ឈ្មោះ ចាន់ ចក្រី[2041] និងបានណែនាំថា "ត្រូវសម្រិតសម្រាំងសមាសភាពមិនល្អ[2042]"។ លេខា និងអនុលេខាកងពលទាំងអស់ ដែលមានវត្តមាន ដូចជា **មាស មុត** និង ឌឹម បានបង្ហាញការឯកភាពរបស់ខ្លួន និងរាយការណ៍ពីការចាប់ខ្លួនក្នុងអង្គការ និងតំបន់របស់ខ្លួន[2043]។

---

សារ D1.3.27.13 កំណត់ហេតុនៃការប្រជុំឃោសារបស់កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខាកងពល និងវរសេនាធំឯករាជ ថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧៦ KH ERN 00052381[ការបញ្ជាក់របស់សុន សេន គឺ"ត្រូវសំរិតសំរាំងសមាសភាពមិនល្អទៅទៀត" ជាបញ្ជាក់ដើម្បីឆ្លើយតបទៅនឹងរបាយការណ៍ពីលេខាកងពល និងកងវរសេនាធំអំពីកម្មាភិបាលដែលរិះគន់បដិវត្តន៍ ឬជំរុញឲ្យមានការរត់ចោលជួរ]។ ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំឃោសារបស់កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភាររបស់កងពលនិងវរសេនាធំ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦ KH ERN 00052398 [ការបញ្ជាក់របស់សុន សេន៖ "ត្រូវមានជំហរដាច់ខាត សំរិតសំរាំងសមាសភាពប្រឆាំងបដិវត្ត កុំស្ទាក់ស្ទើរ"]។

2041 ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំឃោសារបស់កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខានិងអនុលេខានិងវរសេនាធំឯករាជ ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦ KH ERN 00052405-06។

2042 ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំឃោសារបស់កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខានិងអនុលេខានិងវរសេនាធំឯករាជ ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦ KH ERN 00052413-00052414 ["ពិសោធនេះ នាំឲ្យចាប់អារម្មណ៍កាន់តែខ្ពស់ទៀត ចំពោះសមាសភាពមានប្រវត្តិមិនល្អ [...] មេរៀនមួយទៀត នាំឲ្យយើងចាប់សកម្មភាពវាយបដិវត្តកំប៉ិកកំប៉ុក ដូចជាលួច និយាយបញ្ឆិតបញ្ឆៀង វាយបដិវត្ត សុទ្ធតែចេញពីខ្សែក្បត់នេះ [...] ត្រូវសំរិតសំរាំងសមាសភាពមិនល្អដាច់ខាត"]។

2043 ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំឃោសារបស់កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខានិងអនុលេខានិងវរសេនាធំឯករាជ្យ ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦ KH ERN 00052404 [ឌឹម អនុលេខាកងពល១៦៤ រាយការណ៍អំពីការចាប់ចោរព្រៃ និងនារីម្នាក់អាយុ១៣ ឆ្នាំ], KH ERN 00052408 [ ឌឹម អនុលេខាកងពល១៦៤៖ "សុំឯកភាពតាមបទឧទ្ទេសនាមរបស់អង្គការ [...] ត្រូវតែតាមដានសំរិតសំរាំងតទៅទៀត" សុខ លេខាកងពល១៧០៖ "កងពល១៧០ បានសំរិតសំរាំងពួកមិនល្អ [...] សុំឯកភាពជាមួយបក្ស"។ តាល់ លេខាកងពល២៩០៖ "សភាពការណ៍អង្គការឧទ្ទេសនាម [...] នៅមានច្រើនទៀត"។ ពីន លេខាកងពល៧០៣ ៖"បញ្ហាពួកក្បត់និងវិធានការរបស់បក្ស ខ្ញុំយល់ស្រប់ទាំងស្រុង [...] ទោះបីមេវាត្រូវយើងចាប់ ក៏នៅតែធ្វើសកម្មភាព"។សួង លេខាកងពល៤៥០៖ "សមាសភាពមិនល្អបានប្រមូល តែមិនទាន់សំរិតសំរាំងទាំងអស់ទេ"។ អឿន លេខាកងពល៣១០៖ "ពួកមិនល្អបាន ៣៦នាក់ [...]សុំឯកភាពលើវិធានការត្រៀមរៀបចំកំលាំងរបស់បក្ស"។ ភាព លេខាវរសេនាធំ៤៨៨៖ "សុំឯកភាពលើបទឧទ្ទេសនាមរបស់អង្គការ"។ ណៃ លេខាវរសេនាធំ៣៧៧៖ "ចំពោះពួកក្បត់ [...] មានភាពរីករាយចំពោះវិធានការរបស់បក្ស ដែលបានរកឃើញ ចាប់បាន"។ម៉េត លេខាកងពល៥០២៖ "ត្រូវតែប៉ានសំរិតសំរាំងដាច់ខាត"។មុត

542. កម្មាភិបាលមួយចំនួនក្នុងកងពលធំលេខ ១៦៤ ដែលត្រូវបានបោសសម្អាតដោយ **មាស មុត** ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ក្នុងទីក្រុងភ្នំពេញ ចំណែកកម្មាភិបាលផ្សេងទៀតត្រូវបានឃុំខ្លួន និងសម្លាប់នៅមន្ទីរសន្តិសុខវត្តឥន្ទញាណ និងមន្ទីរសន្តិសុខទឹកសាប នៅកំពង់សោម (ដូចការពិភាក្សាក្នុងផ្នែកទាំងនោះ)។ ភាគច្រើននៃអ្នកដែលត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ កាន់មុខតំណែងសំខាន់ៗក្នុងកងពលនេះ ហើយ **មាស មុត** ប្រាកដជាបានដឹងពីការចាប់ខ្លួនពួកគេ។ សរុប មានកម្មាភិបាល ៦៧ នាក់ (ហុកសិបប្រាំពីរ) មកពីកងពលធំលេខ ១៦៤ ដែលត្រូវបានកំណត់អត្តសញ្ញាណក្នុងបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ ដូចជា ៖

(ក) អនុលេខាកងពល ហង់ ឌឿន ហៅ ឌឹម[2044]

(ខ) សមាជិកគណៈកម្មាធិការកងពល ម៉ុម ជឹម ហៅ យ៉ាន[2045] និង ម៉ែន ង៉េត[2046]

(គ) ដៃ ហាន ហៅ ឆាន់ កូនប្រុសរដ្ឋមន្ត្រីក្រសួងកសិកម្ម ដៃ សួន[2047] ដែលជាប្រធានគណៈកម្មាធិការក្រុងកំពង់សោម និងសមាជិកកងពលធំលេខ ១៧៤[2048]

---

លេខាកងពល១៦៤៖ "ជ័យជំនះមួយធំរបស់បក្សយើង [...] ដោយជំហរវិភាគចំពោះខ្មាំងជាចក្រពត្តិអាមេរិកនិងពួកសេរីរើរបស់បក្សដែលមានផែនការវាយបដិវត្តយើង [...] សមាសភាពមិនល្អឬខ្មាំងនៅតែពួនបង្កប់ក្នុងជួរបានទៀត [...]ត្រូវរៀបចំវិធានការចាត់ការជាមុន។ស៊ុយល់ព្រម ឯកភាពជាមួយបក្សទាំងស្រុង" អនុអគ្គសេនាធិការ ណាត៖ "ព្រឹត្តិការណ៍ជ័យជំនះរបស់បក្ស បានកំទេចខ្សែក្បត់"។ ស៊ឹម លេខាវរសេនាធំ១៥២៖ "ចំពោះពួកអាក្បត់ ដែលត្រូវចាប់ [...] ចាត់ទុកជាមហាជ័យជំនះ"។ មតិសរុបរបស់សុន សេន៖ "អង្គប្រជុំបានឯកភាពជាមួយបក្ស ចាត់ទុកការចាប់ពួកក្បត់នេះជាមហាជ័យជំនះលើពួកសេរីរើនិយម [...] ដែលវាបង្កប់ជាង១០ឆ្នាំហើយ"]។

2044 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀងទី១៦២៤ [ចូលថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៧]។ ឯកសារ D9.3 បញ្ជីឈ្មោះអ្នកទោសស ២១ មកពីកងពល១៦៤ របស់ ក.ស.ច.ស, លេខរៀងទី១១ [កម្ទេចថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៧]។ ឯកសារ D1.3.28.40 ឈ្មោះអ្នកទោសដែលកំទេច ហើយថត ថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៩៧ KH ERN 00009146 [លេខរៀងទី២ នៅក្នុងបញ្ជី]។

2045 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស , លេខរៀងទី៤៧៩៧ [ចូលថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៧ កម្ទេចថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៨]។ ឯកសារ D9.3 បញ្ជីឈ្មោះអ្នកទោសស-២១ មកពីកងពល១៦៤ របស់ ក.ស.ច.ស, លេខរៀងទី២៤ (និងលេខរៀងទី២៧ - ស្ទួន)។

2046 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស, លេខរៀងទី៥៣៤២ [ចូលថ្ងៃទី២ ខែមិថុនា ឆ្នាំ១៩៧៧]។ ឯកសារ D9.3 បញ្ជីឈ្មោះអ្នកទោសស-២១ មកពីកងពល១៦៤ របស់ ក.ស.ច.ស, លេខរៀងទី២៦។

(ឃ) សាន់ ស៊ាប ហៅ សំ[2049] អនុលេខាកងវរសេនាធំលេខ ៦២ និង សំ[2050] មេបញ្ជាការកងវរសេនាធំលេខ ១៤០

(ង) ស៊ឹម នាម ហៅ សុក[2051] ប្រធានមន្ទីរពេទ្យកងពល និងពេទ្យទាហាន ហែម អាង[2052]

(ច) វង សំកុល ប្រធានមន្ទីរភ្ញៀវរបស់កងពល[2053]

---

2047 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀងទី១៤១៥២ [ជ័យ សួន ចូលថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ១៩៧៦]។

2048 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀងទី១៤១៥៦ [ជ័យ ហាន ចូលខែវិច្ឆិកា ឆ្នាំ១៩៧៦]។ ឯកសារ D9.3 បញ្ជីឈ្មោះអ្នកទោសស-២១ មកពីកងពល១៦៤ របស់ ក.ស.ច.ស, លេខរៀងទី៣។ ឯកសារ D114/145.1.1 ស ២១ ចម្លើយសារភាពរបស់ ជ័យ ហាន ហៅនាន់ (XVII), KH ERN 01176685 [ចម្លើយ "XVII" លើកទីបី ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៧៦], KH ERN 01176817 [កំណត់សម្គាល់របស់អ្នកសួរចម្លើយឈ្មោះប៉ុន ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៦]។ សូមមើល ឯកសារ D54/10 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ី រ៉េត ឆ.7-8។ ឯកសារ D114/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.10។ ឯកសារ D54/29 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៀត ឡូន ឆ.24។ ឯកសារ D114/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ឆ.60។ ឯកសារ D114/159 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ឆ.34-36 KH ERN 01202359-01202360 [ជ័យ ហាន "វាទាស់នឹងបងមុត"]។

2049 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀងទី៨១៧៦។ ឯកសារ D9.3 បញ្ជីឈ្មោះអ្នកទោស ស-២១ មកពីកងពល១៦៤ របស់ ក.ស.ច.ស, លេខរៀងទី៤០ [ចូលខែមេសា ឆ្នាំ១៩៧៧ កម្ទេចថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៧]។ ឯកសារ D1.3.28.40 បញ្ជីឈ្មោះអ្នកទោសកំទេច ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៧ KH ERN 00009083 [លេខរៀងទី១៧– សាន់ ស៊ាប ចូលខែមេសា ឆ្នាំ១៩៧៧]។

2050 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀងទី១៤៥៦១។ ឯកសារ D9.3 បញ្ជីឈ្មោះអ្នកទោស ស ២១ មកពីកងពលលេខ១៦៤ របស់ ក.ស.ច.ស, លេខរៀងទី៣៩។ ឯកសារ D1.3.1.8 ចម្លើយសារភាពរបស់សំ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៧៦។

2051 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀងទី១៣១៣៧ [អ្នកទោសចងកសម្លាប់ខ្លួននៅថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៧]។

2052 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀងទី៧៣៨៣ [ពេទ្យនារី ហែម អាង ហៅស៊ិន ជាប្រពន្ធរបស់លេខា សុក-ចូលថ្ងៃទី២៦ ឬ២៨ ខែមេសា ឆ្នាំ១៩៧៧ កម្ទេចថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៨]។ ឯកសារ D9.3 បញ្ជីឈ្មោះអ្នកទោសស-២១ មកពីកងពល១៦៤ របស់ ក.ស.ច.ស, លេខរៀងទី១០។

(ឆ) លេខា អនុលេខា ឬសមាជិកកងវរសេនាតូច ៩ នាក់[2054]

(ជ) ប្រធានកងអនុសេនាតូច ប្រធានកងអនុសេនាធំ ឬប្រធានអង្គភាព ១០ នាក់[2055]

---

2053 ឯកសារ D9.3 បញ្ជីឈ្មោះអ្នកទោសស-២១ មកពីកងពល១៦៤ របស់ ក.ស.ច.ស, [វង សំកុល-ចូលថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៧ កម្ទេចថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៧។ ឯកសារ D1.3.28.40 បញ្ជីឈ្មោះអ្នកទោសកំទេច ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៧ KH ERN 00009293 [លេខរៀងទី១]។

2054 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀងទី៤៥០ [ឈុន លុន ហៅ សំអាត , កងវរសេនាតូចនយោបាយ - ចូលថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៧៦], លេខរៀងទី២៣៦៨ [គង់ គៀន ឬគង គៀន ហៅ អ៊ឹង វ៉េត លេខាកងវរសេនាតូច៦៣១-ចូលខែមេសា ឆ្នាំ១៩៧៧ កម្ទេចថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៨], លេខរៀងទី៣២២៣ [គុណ ឌឹម អនុលេខាកងវរសេនាតូច១៤១ - ចូលថ្ងៃទី២០ ឬ២៥ ខែមេសា ឆ្នាំ១៩៧៧], លេខរៀងទី៣៩៩៤ [គង់ ស៊ាន ហៅ សាន លេខាកងវរសេនាតូច១៤២ - ចូលថ្ងៃទី២៧ ឬ២៨ ខែមេសា ឆ្នាំ១៩៧៧, ស្លាប់ដោយសារជំងឺនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨], លេខរៀងទី៤១៥៩ [ណុប នន លេខាកងវរសេនាតូច៦២១ - ចូលថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៧៧], លេខរៀងទី៧២០៧ [ប៉ែន ហាំ (Pen Ham) លេខាកងវរសេនាតូច១៧០ - ចូលថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៧ ស្លាប់ដោយសារជំងឺនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨], លេខរៀងទី៧៥២៦ [ចឹក ស្រេង (Choek Sreng), លេខាកងវរសេនាតូច-ចូលថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៧ ស្លាប់ដោយសារជំងឺនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨], លេខរៀងទី៧៥៤៦ [ងួន ឡាក់ (Nguon Lakk) ហៅ សារ៉ាត់ សមាជិកកងវរសេនាតូច១៧០-ចូលថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៧ កម្ទេចថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៨], លេខរៀងទី១៣១៥៥ [សេក ភាង(Sek Phieng) អនុលេខាកងវរសេនាតូច៦១៣-ចូលថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៧ ស្លាប់ដោយសារជំងឺនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨]។ ឯកសារ D9.3 បញ្ជីឈ្មោះអ្នកទោសស-២១ មកពីកងពល១៦៤ របស់ ក.ស.ច.ស, លេខរៀងទី៦ [ប្រាប់អត្តសញ្ញាណ ឈុន លុន ជាអនុលេខាកងវរសេនាតូច១៦៥] , លេខរៀងទី៨, ១៦ (និង១៨ ស្ទួន), លេខរៀងទី១៧ [គុណ ឌឹម កម្ទេចថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៧], លេខរៀងទី២០, ៣០, ៣៤, ៣៦។ (គួរកត់សម្គាល់ថា បញ្ជីអ្នកទោស ស-២១ របស់ ក.ស.ច.ស បង្ហាញថា បួននាក់ក្នុងចំណោមលេខា ឬអនុលេខាកងវរសេនាតូចទាំងនេះ បានស្លាប់ដោយសារជំងឺនៅថ្ងៃតែមួយ គឺថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨ ចំណែកឯ ជាក់ស្តែង ឯកសារយោង(KH 00016147-50 មិនមាននៅក្នុងសំណុំរឿងនេះ ប៉ុន្តែមាននៅក្នុងឃ្លាំងផ្ទុកឯកសាររួមដែលភាគីទាំងអស់ប្រើប្រាស់បាន) គឺជាបញ្ជីឈ្មោះអ្នកទោសឈឺចំនួន ១០៥ នាក់ដែលបានកម្ទេចនៅថ្ងៃនោះ)។

2055 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស, លេខរៀងទី១២៧៣ [ចិត្រ គឹមឈឿន (Chet Kim Chhoeun) ហៅ គឹម អេង-ចូលថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៦], លេខរៀងទី៤១៦០ [សុក អឿន លេខាកងអនុសេនាធំ២២ កងវរសេនាតូច៦១១ - ថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៧៧], លេខរៀងទី៦៤០២ [អ៊ុច ចាន់ថុល ឬថន -ថ្ងៃទី៣១ ខែឧសភា ឬថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៦], លេខរៀងទី៦៨៧៦ [ពៅ ឈាន ហៅ ប៊ុន្នី មេបញ្ជាការកងអនុសេនាធំ – ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៧៦], លេខរៀងទី៨៦១៨ [សឹង គ្រិន (Soeng Krin) ហៅ ងួន (Nguon) មេបញ្ជាការកងអនុសេនាធំ – ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៦], លេខរៀងទី៩៨៧៦ [សូ សុខុម – ថ្ងៃទី៣១ ខែឧសភា ឬថ្ងៃទី១

(ឈ) កងទ័ព ២០ នាក់[2056] និង

(ញ) អ្នកបកប្រែភាសាចិន ៨នាក់[2057]។

ខែមិថុនា ឆ្នាំ១៩៧៦], លេខរៀងទី១០៥៧១ [សែម សុត –, ថ្ងៃទី១៥ ឬ១៦ ខែមិថុនា ឆ្នាំ១៩៧៦], លេខរៀងទី១៣៣៨១ [វង់ ឡឹង ហៅ ថន (Vong Loeng alias Than) មេបញ្ជាការកងអនុសេនាតូច – ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៦], លេខរៀងទី១៣៦៧៥ [កែន ខុន – ចូលថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៩៧៦ កម្មេចថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦], លេខរៀងទី១៣៨៧០ [យឹម សារុត ហៅ មេង – ថ្ងៃទី៣១ ខែឧសភា ឬថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៦]។ ឯកសារ D9.3 បញ្ជីឈ្មោះអ្នកទោស ស-២១ មកពីកងពល១៦៤ របស់ ក.ស.ច.ស, លេខរៀងទី២, ១៥, ៣៥,៣៧, ៤១, ៤៥-៤៧, ៥២, ៥៣ (និង៥៤ ស្ទួន)។

2056 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស, លេខរៀងទី៤៣៥ (មាស លឿន ហៅ សារឿន – ចូលថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៦), លេខរៀងទី៤៤៤ (អឿម ខេង ហៅ សុផល – ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៦), លេខរៀងទី៦២៧ (គង់ អឿន – ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦), លេខរៀងទី៦៤៣ (សំ សិត – ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ មកពីកងកេង), លេខរៀងទី១៤៤៨ (ឃឿ វ៉េង – ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៦), លេខរៀងទី១៥៣៧ (អៀង សុង ហៅ ស្រ៊ាង – ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៦), លេខរៀងទី៤៧០៧ (មាស ទន ហៅ វ៉ាន់ – ចូលថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ កម្មេចថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦), លេខរៀងទី៥៣០៨ (មាស ឈាន ហៅ សារី – ចូលថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦), លេខរៀង៥៦១០ (ញ៉ែម ស៊ីម(Nhem Sim) – ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៦), លេខរៀង៥៧២៩ (ងិន ស៊ឹម ឬ លឹម (Ngin Soem or Lim) – ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៦), លេខរៀង៦០៨៤ (អ៊ុំ គឺន/កែន (Om or Um Keun/Kaen) – ចូលថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ មកពីកងកេង កម្មេចថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៦), លេខរៀង៦០៩០ (អ៊ុន ភ្លុក ហៅ សំណាង (Un Phluok alias Samnang) – ថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦), លេខរៀង៦៦២២ (ព្រុំ ទឹម (Prum Tim) – ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៦), លេខរៀង១០១៨៩ (សេក សែន ហៅ សុផល – ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៦), លេខរៀង១០៦៥០ (សាយ នេន ហៅ ណែម – ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៦), លេខរៀង១១៤៧៨ (ស៊ា ហ៊ឹម (Sie Him) – ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៦), លេខរៀង១២១៦៤ (ឈឹម ហុង ហៅ ស្រៀង – ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៦ ឬឆ្នាំ១៩៧៨), លេខរៀង១២២១៩ (តូម ឬ តូច សុភាព (Taum or Tauch Sopheap) ហៅ សុគុន – ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៦), លេខរៀង១៣៩១១ (អ៊ីវ ហួត ហៅ ហ៊ាន់ (Yiv Huot alias Hoan) – ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៦)។ ឯកសារ D9.3 បញ្ជីឈ្មោះអ្នកទោសស-២១ មកពីកងពល១៦៤ របស់ ក.ស.ច.ស, លេខរៀង១ (និង៧ ស្ទួន), លេខរៀង៩,១៤, ១៩, ២៥, ២៨, ៣២, ៣៨, ៤២-៤៤, ៤៩-៥០, ៥៥, ២៣ [លឹម ហួត យុទ្ធជន – ចូលថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៦ ស្លាប់ដោយសារជំងឺនៅថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៧៦]។

2057 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស, លេខរៀង៦០៩៥ [អ៊ូ ស៊ូម៉េង (Ou Soumeng) ហៅ លាង យុទ្ធជនបកប្រែភាសាចិន – ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ១៩៧៧], លេខរៀង៩២៩៥ [លឹម ហុងគ្រៃ ហៅ សាន (Lim Hong Krai alias San) – ថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៨], លេខរៀង៩៧២៤ [អៀង លី ហៅ ហួង (Ieng Ly alias Huong) – ថ្ងៃទី១៩ ឬ២០ ខែមេសា ឆ្នាំ១៩៧៨], លេខរៀង៩៧២៥ [ប៉ុយ ហុង ហៅ ផល – ថ្ងៃទី

543. បញ្ជីឈ្មោះអ្នកទោសចូលក្នុងមន្ទីរ ស-២១ បង្ហាញពីកាលបរិច្ឆេទជាច្រើនដែលមានការចាប់ខ្លួនកម្មាភិបាលកងពលធំលេខ ១៦៤ យ៉ាងច្រើន ដូចជា កងទ័ព ៦ នាក់ដែលចូលមកមន្ទីរនេះនៅថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ១៩៧៦[2058] កម្មាភិបាល ១១ នាក់ នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៧៦[2059] កម្មាភិបាល ៥ នាក់នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៧៦[2060] និងអ្នកបកប្រែភាសាចិន ៦ នាក់នៅខែ មេសា ឆ្នាំ ១៩៧៨[2061]។ នៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៧៦ កម្មាភិបាល ២ នាក់មកពីកងវរសេនាតូចលេខ ១៦៥ ដែល **មាស មុត** បានរាយការណ៍ពីឈ្មោះរបស់ពួកគេដល់ សុន សេន តាមសារទូរលេខជាមុននៅខែនោះពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទឃុបឃិតគ្នា ត្រូវបានបញ្ជូនទៅមន្ទីរ ស-២១[2062]។ ភាគ

---

១៩ ឬ២០ ខែមេសា ឆ្នាំ១៩៧៨], លេខរៀង៩៧២៦ [ង៉ោ អ៊ុយ (Ngau Uy) ហៅ តុង – ថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៨], លេខរៀង៩៧២៧ [ឡាំ ហ្វាត ហៅ ហួត (Laim Fatt alias Huot) – ថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៨], លេខរៀង១០២៣៣ [ជីវ ឃុន កំណត់អត្តសញ្ញាណជាអ្នកបកប្រែភាសាចិននៅស្ទឹងហាវ ផែកំពង់សោម – ថ្ងៃទី៣ ខែកុម្ភៈ ឬថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨], លេខរៀង១២២១៨ [តាំង វេងស៊ី ឬ សឹង ហៅ ឈិន (Taing Veng Sy or Soeng alias Chhin) – ថ្ងៃទី១៩ ឬ២០ ខែមេសា ឆ្នាំ១៩៧៨]។ ឯកសារ D9.3 បញ្ជីឈ្មោះអ្នកទោសស-២១ ដែលមកពីកងពល១៦៤ របស់ ក.ស.ច.ស, លេខរៀង១២, ១៣, ២១, ២២, ២៩, ៤៨។ សូមមើល ឯកសារ D54/87 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៤ ឆ.158 KH ERN 00985339 [រៀបរាប់ពីការបាត់ខ្លួនរបស់អ្នកបកប្រែភាសាចិន "សាន ហៅ លីម" ជាការយោងជាក់ស្តែងលើលេខរៀង៩២៩៥ របស់ ក.ស.ច.ស លឹម ហឹងគ្រី ហៅសាន]។

2058 D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង៦២៧, ៦៤៣, ៤៧០៧, ៥៣០៨, ៦០៨៤, ៦០៩០។

2059 D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 435, 1273, 1537, 5610, 5729, 10189, 10571, 10650, 12219, 13381, 13911។

2060 D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 444, 1448, 6622, 8618, 11478។

2061 D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 9295, 9724-9727, 12218។ ក្នុងអំឡុងខែដដែលនោះ អ្នកបកប្រែភាសាចិនមួយក្រុមមានគ្នាប្រាំនាក់មកពីកងពល ៥០២ ត្រូវបានបោសសម្អាត (ក.ស.ច.ស, លេខរៀង 9213-9217) បង្ហាញថា នេះគឺជាទង្វើដែលត្រូវបានរៀបចំផែនការ ឬសម្របសម្រួលរួមគ្នាដោយ មាស មុត និងមេ ដឹកនាំកងទ័ពបដិវត្តកម្ពុជាដទៃទៀត។

2062 ឯកសារ D1.3.14.1 ទូរលេខពី មុត (មាស មុត) ជំរាបបង៨៩ (សុន សេន) ថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៦ KH ERN 00003702 [រាយការណ៍អំពីសំបុត្រមួយស្នាក់បានដោយកងពលដែលផ្ញើទៅអនុលេខាកងវរសេនាតូច ១៦៥ ឈ្មោះសំអាតហៅ ស៊ុន និងកម្មាភិបាលម្នាក់ឈ្មោះ"ប៊ុននី" ឬ "ស៊ុននី"]។ ឯកសារ D9.3 បញ្ជីឈ្មោះអ្នកទោសស-២១ មកពីកងពល១៦៤ របស់ ក.ស.ច.ស, លេខរៀង៦ [កំណត់អត្តសញ្ញាណ ឈុន លុន ហៅ សំអាត ជាអនុលេខាកងវរសេនាតូច១៦៥], លេខរៀង ៣៧ [កំណត់អត្តសញ្ញាណ ពៅ ឈាន ហៅ ប៊ុន្នី ជាលេខាកងអនុសេនាធំទី២ កងវរ

ច្រើននៃការបោសសម្អាតកម្មាភិបាលជាន់ខ្ពស់ក្នុងកងពលធំលេខ ១៦៤ ធ្វើឡើងនៅខែ មេសា ឆ្នាំ ១៩៧៧ ដែលរួមមានអនុលេខា និងសមាជិកកងពល អនុលេខាកងវរសេនាធំម្នាក់ និងលេខា ឬអនុលេខាកងវរសេនាតូច ៦ នាក់[2063]។ ក្នុងកិច្ចប្រជុំដែលបានធ្វើឡើង **មាស មុត** បានចោទប្រកាន់កម្មាភិបាលកងពលធំលេខ ១៦៤ ដែលត្រូវបានបោសសម្អាតថាជាជនក្បត់ និងបានពិភាក្សា និងអានចម្លើយសារភាពរបស់ពួកគេ[2064]។

544. អ្នកទោសនៅមន្ទីរ ស-២១ ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ **មាស មុត** ក៏រួមមាន ជនជាតិវៀតណាម និងជនជាតិថៃ ដែលត្រូវបានឃាត់ ឬចាប់ខ្លួននៅដែនសមុទ្រដោយកងពលធំលេខ ១៦៤ និងអតីតទាហាន និងមន្ត្រីរដ្ឋការ លន់ នល់ ដែលត្រូវបានចាប់ខ្លួននៅកំពង់សោមផងដែរ[2065]។ ការ

---

សេនាតូច១៦៥]។ ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស, លេខរៀង៤៥០ [ឈុន លុន ហៅ សំអាត ចូលថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៧៦], លេខរៀង៦៨៧៦ [ពៅ ឈាន ហៅ ប៊ុន្នី មេបញ្ជាការកងអនុសេនាធំ ក៏ចូលថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៧៦ដែរ]។

2063 D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស, លេខរៀង1624, 2368, 3223, 3994, 4797, 7207, 7526, 8176, 13155។

2064 សូមមើល ឧទាហរណ៍, ឯកសារ D54/104 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.3, 5, 10 KH ERN 00992787-00992788,00992790 ["តាមុត ប្រជុំប្រាប់អំពីចម្លើយសារភាព ហើយតាមុត បានប្រកាសថា [ប្រធានវរសេនា៦៣១] វើត ក្បត់ហើយ [...] ឆ.5៖ [...] ឈ្មោះ យ៉ាន នេះស្ថិតនៅក្នុងចំណោមពួកក្បត់ដែលតាមុតបានលើកមករៀបជាពាក្យជូន ដូចកំណាព្យថា 'ញ៉ឹក,ឆាន,យ៉ាន,ឌឹម ជាពួកក្បត់' [...] ឆ.10៖ [...] ក្រោយមកនៅពេលដែលតាមុត ប្រកាសនៅក្នុងអង្គប្រជុំអំពីចម្លើយសារភាពរបស់ពួកក្បត់និងខ្សែរយៈសេអ៊ីអា និងកាហ្សេបេ ហើយបន្ទាប់ពីការបាត់ខ្លួនពួកនោះ ទើបយើងដឹងថាពួកទាំងនោះត្រូវបានចាប់ខ្លួនហើយ"]។ ឯកសារ D54/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក នី ឆ.1។ ឯកសារ D114/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.10, 20-23, 32-34។ ឯកសារ D54/12 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រេស មាន ឆ.25-30 KH ERN 00936725 [ការប្រជុំពាក់កណ្តាលឆ្នាំ១៩៧៧ ធ្វើឡើងដោយមាស មុត នៅស្ទឹងហាវ ដែលគាត់បានចោទថា ឆាន និងអនុ ឌឹម ជាពួកក្បត់]។ ឯកសារ D54/13 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រេស មាន ឆ.1-5។ ឯកសារ D114/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ឆ.60, 63 KH ERN 01111037 ["មាស មុត អានចម្លើយសារភាពរបស់ នង ឆាន ហ្នឹង។ [...] ឆ.63៖ [...] [ពួកគេ] មេខ្ញុំគាត់មិនបានសារភាពទេ។ មាស មុត គ្រាន់តែនិយាយថាពួកគាត់ ក្បត់"]។

2065 ឯកសារ D53/2.1.30 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២ ខែមេសា ឆ្នាំ២០១២ ម៉ោង 14.21.14 KH ERN 00800356-00800357 [អ្នកនេសាទថៃដែលបញ្ជូនទៅស ២១ គឺជាអ្នកនេសាទដែល"កងពល១៦៤ ចាប់"]បាន។ ឯកសារ D114/277.7 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 10.38.31 KH ERN 01319763-01319764 [ពិភាក្សាអំពី អ្នកនេសាទវៀតណាមដែលបញ្ជូនទៅមន្ទីរស ២១]។ ឯកសារ D234/2.1.119 សួស ធី

ទទួលខុសត្រូវរបស់ **មាស មុត** លើការឃាត់ខ្លួន ចាប់ខ្លួន និងសម្លាប់ក្រុមទាំងនេះត្រូវបានគូស បញ្ជាក់ក្នុងរបាយការណ៍របស់កងពលនេះដែលផ្ញើជូន សុន សេន[2066] ពាក់ព័ន្ធនឹងបញ្ហាទាំងនោះ។

---

ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.48.40 KH ERN 01307555-01307556 [អ្នកទោសជនជាតិវៀតណាមនៅស ២១ គឺមានទាំងស៊ីវិល មានទាំងទាហាន រួមទាំងគ្រួសារផងដែរ], ម៉ោង 09.54.20 KH ERN 01307557-01307558 [ការចាប់វៀតណាមដែលភៀសខ្លួនទៅថៃនោះមិនៗសម្មតថាកំពង់សោមទេ], ម៉ោង 10.39.50 KH ERN 01307565-01307566 [ច្រើនតែពួកដែលមកពីខាងគ្រួសារមកទៅតាមផែកំពង់សោម ជាពិសេសជនជាតិវៀតណាម]។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.57.07 KH ERN 01249417 [អ្នកទោសជនជាតិវៀតណាមនៅស ២១ មានទាំងប្រជាជនដែល "យកមកទាំងប្តីទាំងប្រពន្ធទាំងកូន"]។ ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.02.22-09.05.33 KH ERN 01249425-01249426។ ឯកសារ D114/165 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីប្រាក់ ខន KH ERN 01202839-40។ ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.33.03 KH ERN 01247408 [សក្ខីកម្មរបស់កម្មាភិបាលមន្ទីរស-២១៖ "ចំពោះវៀតណាមគឺឃើញមានច្រើនដែរ វៀតណាមនៅឆ្នាំ៧៨ហ្នឹងគឺមានគេដឹកមកទាំងឡានៗដែរ ពីរបីឡានដែរក្នុងឆ្នាំ៧៨ហ្នឹង"]។ ឯកសារ D98/3.1.146 ឡាច មាន ប្រតិចារឹក ថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៩ ម៉ោង 14.13.58-14.19.32 KH ERN 00359012-00359013។ ឯកសារ D114/132 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ៅ រ៉ាន់ ឆ.91 KH ERN 01154122 [រៀបរាប់អំពីកងទ័ពកម្ពុជាប្រជាធិបតេយ្យ ចាប់ទូកជនជាតិថៃស៊ីវិល]។ ឯកសារ D114/159 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ឆ.30 KH ERN 01202358-01202359 [មាស មុត បោសសម្អាត មាន "ភូមិប្រជាជនជុំវិញផែ និងជុំវិញក្រុងកំពង់សោម"]។ ឯកសារ D114/41 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ធី ឆ.7 KH ERN 01065129 [នៅក្នុងបញ្ជីស ២១ សំដៅលើអ្នកដែលគេចាប់ខ្លួនពីកំពង់សោម រួមមានជនបរទេស ទាហាន និងជនស៊ីវិលដែលរត់គេចខ្លួនពីប្រទេសខ្លួន ហើយ"ចូលមកក្នុងដែនទឹករបស់ប្រទេសកម្ពុជា និងត្រូវបានកងទ័ពចាប់ខ្លួនផងដែរ"]។

2066 ឯកសារ D1.3.34.64 ទូរសព្ទសម្ងាត់របស់មាស មុត ជូន បង៨៩ (សុន សេន) ថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៧៨ KH ERN 00020982 [របាយការណ៍អំពីការចាប់ខ្លួន"យួន៧៦នាក់ មានក្មេង ចាស់ ប្រុស ស្រី" នៅលើកាណូត ២ គ្រឿង នៅកោះតាង និងការចាប់ខ្លួនមនុស្ស២១ នាក់លើទូកនៅកោះវៃ]។ ឯកសារ D54/73.1 សេចក្តីរាយការណ៍ពីមាស មុត ថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨ KH ERN 00979298 ["សរុបយួនដែលចាប់បាន និងបាញ់ងាប់ ចាប់ពីថ្ងៃទី២៧ ខែមីនា ឆ្នាំ៧៨ មកដល់ ថ្ងៃទី៣០ ខែមីនា ឆ្នាំ៧៨ មានចំនួន ១២០ក្បាល"]។ ឯកសារ D1.3.12.20 សេចក្តីរាយការណ៍ពីមាស មុត ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧ KH ERN 00020912 [សេចក្តីរាយការណ៍របស់មុត អំពីការចាប់ទូកនេសាទថៃ ការចាប់ខ្លួនថៃ ៤ នាក់ និង ខ្មែរម្នាក់ ដែលនឹងត្រូវសួរចម្លើយ]។ ឯកសារ D1.3.12.3 សេចក្តីរាយការណ៍ពីមាស មុត ជូន បង៨៩ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ [រាយការណ៍អំពីការចាប់ខ្លួនក្រុមចោរព្រៃពីតំបន់វាលរេញ ក្នុងនោះចោរព្រៃម្នាក់ត្រូវបានសួរចម្លើយ]។ ឯកសារ D1.3.34.23 ទូរលេខពីសៀងជូនអង្គការ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧។ ឯកសារ D1.3.8.4 កំណត់ហេតុនៃការប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំ

545. នៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ ពលរដ្ឋវៀតណាម ៥ នាក់ត្រូវបានចាប់ខ្លួននៅឆ្ងាយពីកោះពូលូវ៉ៃ និងបញ្ជូនទៅមន្ទីរ ស-២១[2067]។ នៅថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ១៩៧៦ ក្រៅពីកងទ័ព ៦ នាក់ក្នុងកងពលធំលេខ ១៦៤ (ដូចបានកំណត់អត្តសញ្ញាណខាងលើ) មានអ្នកទោស ១០៥ នាក់ផ្សេងទៀតមកពីកំពង់សោម ត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ រួមទាំង ជនជាតិវៀតណាម ២៥ នាក់[2068] (ភាគ

---

សមមិត្ត១៦៤ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៦ KH ERN 00162489 [របាយការណ៍អំពីការចាប់ខ្លួនមនុស្សលើទូកនេសាទថៃពីរគ្រឿង និងការចាប់ខ្លួនទាហានសក្តិ២[របបចាស់]], KH ERN 00162490 [ការណែនាំពីសុន សេន ឱ្យប្រមូល "សមាសភាពទាហាន" ហើយ"ពួកទូកចូលមកកោះរ៉ុងសន្លឹមបញ្ជូនមកឱ្យសួរចម្លើយ"]។ ឯកសារ D1.3.27.18 កំណត់ហេតុនៃការប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភាររបស់កងពល និងវរៈសេនាធំ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៦ KH ERN 00052390 [សេចក្តីរាយការណ៍របស់មាស មុត អំពីការចាប់ទូកនេសាទថៃ]។ ឯកសារ D1.3.34.28 សេចក្តីរាយការណ៍ពីកងពល១៦៤ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៧៧ KH ERN 00161729 [របាយការណ៍អំពីទូកថៃ២គ្រឿង និងការសម្លាប់មនុស្សនៅលើទូកទាំងនោះ]។ ឯកសារ D1.3.34.11 ទូរលេខ ១១ ពីសមមិត្ត ឌឹម ជូនបងមុត (មាស មុត)ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៦ KH ERN 00000863 [ចម្លងជូនសុន សេន និងនួន ជា៖ រាយការណ៍អំពីការចាប់ខ្លួនខ្មាំង៥នាក់ដែលរត់គេចពីឃុំរៀម និងបបុស តាមការសម្រេចរបស់មាស មុត]។ ឯកសារ D1.3.34.12 ទូរលេខ១២ ពីសមមិត្តឌឹមជូនបងមុត (មាស មុត)ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៧៦ KH ERN 00021528 [របាយការណ៍អំពីការចាប់បានក្មេងម្នាក់ អាយុ១៦ ឆ្នាំ ហើយក្មេងនេះសារភាពថា ខ្លួនមានជាតិញុះញង់ ស៊ើបការឱ្យ"ពួកចោរព្រៃ"]។ ឯកសារ D1.3.34.13 ទូរលេខ១៦ ពីឌឹម ជូនមុត ថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៦ KH ERN 00000865 [រៀបរាប់អំពីប្រើប្រាស់ក្មេង និងកម្លាំងឃាមស្ទាក់ដើម្បី"រកពួកចោរព្រៃ" និង"អាក្បត់ដែលបង្កប់នៅក្នុងភូមិ"]។

2067 សូមមើល ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស, លេខរៀង 14799 [Le Thithouyaing ជាប្រពន្ធរបស់ ង៉ោ ចិនឡុង (Ngao Chen Long) បានចាប់ខ្លួនពីកោះប៉ូឡូវ៉ៃ ហើយចូលមន្ទីរស-២១ នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៧៦], លេខរៀង 14795 [ង៉ោ ចិនឡុង (Ngao Chen Long), "គុណាការរដ្ឋប្បវេណីក្រុងព្រៃនគរ" – ក៏ចូលមន្ទីរស-២១ នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៧៦ ផងដែរ គឺនៅថ្ងៃតែមួយជាមួយប្រពន្ធគាត់]។ អ្នកទោសបីនាក់ទៀតដែលមានឈ្មោះវៀតណាម បានចូលមន្ទីរស-២១ នៅថ្ងៃដូចគ្នានឹងពីរនាក់ប្ដីប្រពន្ធខាងលើ ហើយអាចសន្មតថាត្រូវបានចាប់ខ្លួននៅពេលវេលា និងទីកន្លែងតែមួយ៖ លេខរៀង 14796 [Daing Yaing Phou ជាងជួសជុលយន្តហោះក្រុមហ៊ុនបារាំង], លេខរៀង 14797 [Le Min Try សក្តិ ២ និងអតីតនិស្សិតពេទ្យ], លេខរៀង 14798 [Vit Beuy Laim និស្សិតច្បាប់ និងពេទ្យ]។

2068 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស, លេខរៀង 592 [ដាន់ យ៉ឹង ថាន់- Daing Yaing Thann – ស្ទួនដូចលេខរៀង 14786], លេខរៀង 593 [យ៉ យ៉ាង ថាន់- Yor Yang Thann], លេខរៀង 594 [ចឹង វ៉ាង លី- Choeng Vang Ly], លេខរៀង 596 [យ៉ យ៉ាង ដាង- Yor Yang Dang], លេខរៀង 597 [ចឹង ឬត្រឹង យ៉ាងក្វេ- Choeng or Troeng Yang Kve – ស្ទួនដូចលេខរៀង 14782], លេខរៀង 602 [វៀ យ៉ាវ- Vie Yav], លេខរៀង 606 [ផាំ យ៉ាងថឹង- Phaim Yang Thoeng], លេខរៀង 607 [ចាង ជិនអឹង], លេខរៀង 612 [ឡេ យ៉ាង

ច្រើនត្រូវបានសន្មតជាគិញក្នុងកំណត់ត្រារបស់មន្ទីរ ស-២១) ជនជាតិថៃ ៤៣ នាក់[2069] (ភាគច្រើនត្រូវបានកំណត់អត្តសញ្ញាណជាអ្នកនេសាទ និង/ឬ ចោទប្រកាន់ថាជាគិញ) មនុស្ស ៧ នាក់ដែល

---

ង៉ៀ], លេខរៀង 625 [តាំង ង៉ុកហុង], លេខរៀង 651 [សឺន ចាំងឡាយ], លេខរៀង 652 [ចាង យ៉ាងឡឹម], លេខរៀង 653 [ដាង យ៉ាងថា], លេខរៀង 663 [គីម ង៉ុកទើ ឬង៉ុកទ្រឿង – ស្ទួនដូចលេខរៀង14784], លេខរៀង 676 [ចាំង យ៉ាងហេវ], លេខរៀង 678 [ឡេ យ៉ាងហាយ], លេខរៀង 13431 [Chim Yang Keu], លេខរៀង13432 [ឡេ យ៉ាងម៉ាយ], លេខរៀង 13433 [Le Yang Phoeuk ហៅ Chim Yang Koeng], លេខរៀង 13434 [Ngvieng Din-Y អាយុ១៦ ឆ្នាំ], លេខរៀង 13436 [Ngvieng Thithoeung ស្រី], លេខរៀង 13437 [Ngvieng Hour Lang], លេខរៀង 13642 [Chaing Thann Hoeung – ស្ទួនដូចលេខរៀង 14783], លេខរៀង 13643 [Le Thakk Leuy], លេខរៀង 14785 [Pham Yaing Thann]។ សូមមើល ឯកសារ D114/277.7 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 10.40.48 KH ERN 01319764-01319765 [អំពីអ្នកនេសាទជនជាតិវៀតណាមដែលគេបញ្ជូនទៅស ២១៖ "គេចាប់បញ្ជូនមកដល់ស ២១ ខាងលើគេសម្រេចហើយ ទុកចាត់ទុកជាគិញ"]។ ឯកសារ D98/3.1.91 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.37.55 KH ERN 00339794 ["ខាងលើគេប្រាប់មក អាហ្នឹងគិញយួន"]។

[2069] ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 600 [ឡាក], 604 [សារួម], 609 [សាម ឡូយ], 613 [ប៉ាក ផាន់], 614 [ឡេក], 615 [សឺត (សឺត ស៊ីត)], 616 [ទី ណាត], 620 [អា ណុប], 628 [ផាន់ សាមុ], 629 [ឥន្ទ្រី], 645 [មុង ឃុន], 646 [ប៊ុន ប៉េង], 649 [សម ឃិត], 650 [ចាំ ម៉ាឡាក], 679 [ចាន់ សុំ], 680 [ស្រិត ការ], 12981 [Cha Rieng], 12983 [ក្មេងប្រុសអាយុ១៥ ឆ្នាំ ឈ្មោះឡាត់ កុមារ ឬស៊ិរ៉ាផាន់ ដែលធ្វើការជាអ្នកលាងចាននៅលើទូកនេសាទឈ្មោះ ហារិន ផានិច], 12984 [មូន ស៊ុន ចារ៉ែន ហៅ តៃ (Moun Sun Charaen alias Tai) មេក្រុមទូកនេសាទ សេរីឈោគ ៥], 12985 [ម៉ាណូក ជុយ ចែម សៃ (Manaok Chuy Chem Sai)], 12987 [ផេង ចាន់សែន], 12988 [ក្មេងប្រុសអាយុ១៥ ឆ្នាំ ឈ្មោះឡូយ ឬរ៉យ ឡូត ណុក្រាសែ (Lauy or Raoy Laot Nokrase)], 12989 [វិឈៃ អាំហ្វា ណាន់ (Vichhey Amphva Nann)], 12999 [វី ឆៃ ហៅ ភុង (Vi Chhai alias Phung)], 13001 [សុផាន់ ប៉ាវ៉ុង សា (Sophann Pavong Sa)], 13002 [ចារ៉ួន ណុក្រសែ (Charoun Nokrase)], 13005 [សម ស៊ី អាន ឆាវៀង (Sam Sy An Chhavieng)], 13006 [សា ហាត់ ហៅ ពៀក (Sa Hatt alias Peak)], 13023 [ឈុត តា ឬ សុតា ប្រុង រេណូ (Chhut Ta or Sota Prong Reno)], 13031 [ក្មេងប្រុសអាយុ១៦ ឆ្នាំ ឈ្មោះយុត ផុង សាំ រ៉ាន (Yut Phong Saim Ran)], 13052 [ឆែត អ៊ឹម ថាង (Chhaet Im Thang)], 13053 [ដេត ដែន នេន យីម (Det Den Nen Yim)], 13055 [កូវិត (Kovit)], 13645 [ប៊ុន ទ្រី], 13653 [ឃឹម(Khoem)]។ អ្នកទោសប្រាំបីនាក់ទៀតដែលចាប់ខ្លួននៅសមុទ្រ ពុំមានកាលបរិច្ឆេទចូលទេនៅក្នុងបញ្ជីអ្នកទោសមន្ទីរស-២១ របស់ ក.ស.ច.សទេ ប៉ុន្តែអាចកំណត់អត្តសញ្ញាណស្ថិតនៅក្នុងក្រុមជនជាតិថៃតែមួយដែលបញ្ជូនទៅស-២១ នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ ផ្អែកលើឈ្មោះទូកនេសាទដែលចាប់បាន និងលេខចម្លើយសារភាពទួលស្លែង "TH" របស់ពួកគេ៖ លេខរៀង 14696 [ខាំ ស៊ីវៀក ផាន់ ទូកនេសាទ ហារិន ផានិច៦៧], 14697 [ការ ស៊ិង ទូកនេសាទ សេរី ឈោក ៥], 14698 [ឡួម សំប៊ូន អាយុ៦៧ ឆ្នាំ ទូកនេសាទ សេរី ឈោក ៥], 14699 [ម៉ុន ទ្រី ស៊ិចឆាន់ណាក់ ទូកនេសាទ ហារិន

ត្រូវបានកំណត់អត្តសញ្ញាណជាកងទ័ពមកពីកងពលធំលេខ ១ លេខ ២ ឬលេខ ៣ នៃភូមិភាគនិរតី[2070] (ដែលមួយចំនួនគឺជាកម្មាភិបាលកងពលធំលេខ ១៦៤ នៅពេលចាប់ខ្លួន) អតីតទាហាន ឬប្តី/ប្រពន្ធរបស់អតីតទាហាន លន់ នល់ ៦ នាក់[2071] និងពលរដ្ឋ ២៤ នាក់មកពីកំពង់សោម[2072]។

546. ជនជាតិវៀតណាម និងថៃ ជាច្រើនដែលត្រូវបានបញ្ជូនមកពីកំពង់សោមទៅមន្ទីរ ស-២១ នៅថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ១៩៧៦ ត្រូវបានកំណត់អត្តសញ្ញាណក្នុងបញ្ជីឈ្មោះអ្នកទោសរបស់ ក.ស.ច.ស ថាត្រូវបានចាប់ខ្លួនកាលពីប៉ុន្មានខែមុន (ខែ កញ្ញា ឬធ្នូ ឆ្នាំ ១៩៧៥) នៅដែនសមុទ្រ ឬដីគោក (កោះ

---

ផានិច ៦៧], 14700 [ប្រាសែត ឡុប កែត មេក្រុមទូកនេសាទ ហារិន ផានិច], 14701 [សាំប៊ុន សិត បុផា ទូកនេសាទ ស៊េរី ឈោក ៥], 14702 [ថោម វ៉ាត់ កែផាង ទូកនេសាទ ហារិន ផានិច ៦៧], 14703 [ឡា ស៊ីម ខា ទូកនេសាទ ស៊េរី ឈោក ៥]។សូមមើល ឯកសារ D1.3.3.2 ឈ្មោះអ្នកទោសកំទេច KH ERN 00008835-00008836 [លេខរៀង១-៣១ គឺជាអ្នកនេសាទជនជាតិថៃចូលស ២១ នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦], KH ERN 00008900-00008901 [លេខរៀង២៥១-២៨៥]។

2070 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 588 [ហែម សន ហៅ ណែម កងពលទី១], 590 [អ៊ូច សារិន ប្រធានក្រុម កងពលទី៣], 601 [មិត ម៉េត ហៅ ម៉ុន យុទ្ធជនកងពលទី១ ឬទី២], 611 [ជុំ សុត ប្រធានកង កងពលទី១ និងទី៣], 667 [ម៉ែ ផាត់ យុទ្ធជនកងពលទី៣], 675 [ឆែ ដេង ប្រធានក្រុម កងពលទី ១ និងទី៣], 4168 [គឹម យុង ហៅ យុល ពេទ្យកងពលទី៣]។

2071 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 655 [ជី ឬជឺ លៀន ប្រពន្ធរបស់អតីតពលទោឈ្មោះ សៀង ទ្រឹង, ក.ស.ច.ស លេខរៀង 8223], 670 [ទ្រឹង សារី ហៅ សារ៉ុម ពលទោជើងទឹក], 1576 [ហួ យុយ ពលទោ], 6650 [ផាន់ ប្រាក់ ពលទោ], 8223 [សៀង ទ្រឹង ពលទោ], 13616 [អ៊ុំ វ៉ែន ប្រពន្ធទាហានពាក់ដោយ]។

2072 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស, លេខរៀង 587 [សែន ប៊ិន ឬសែន ប៊ុន យុវជនពីតំបន់៣៣], 610 [សួស ព្រិញ កម្មករធ្វើទូក], 618 [យឿង ផុក កូនសិស្ស], 634 [អ៊ុង ផាន និស្សិតនៅកងកេង], 635 [ផៃ សុវណ្ណ ហៅ ងីម កម្មករនេសាទត្រីនៅអូរត្រេះ], 636 [ទូន មឿន កម្មករចំការដូងរាម], 637 [កៅ គឹមលី ហៅ ទ្រី សិស្ស និងកម្មករនេសាទត្រីនៅអូរត្រេស], 639 [ឈុន ហួយ ហៅ គី ប្រជាជនថ្មី និងអ្នករត់ឡឺម៉កម៉ូតូ], 641 [ចាន់ សួន ធ្វើចំការ], 642 [ចិន ញឹម កម្មករស្រែអំបិល], 661 [សុផល ផល្លី អ្នកបម្រើតាមបារ និងលក់បន្លែនៅព្រៃនប់], 664 [អ៊ុន សារី ហៅ ចាន់ ប្រជាជនថ្មី និងកម្មករនេសាទត្រីនៅរាម], 674 [ញ៉ែម យ៉ាំ ហៅ សារ៉េត, បើកឡាន], 681 [ទិត ធុំ, កម្មករនេសាទត្រីនៅអូរត្រេស], 682 [កែវ ជឿន, ធ្វើស្រែនៅជាមួយគិញ], 2249 [ឃឹម បារាំង, កម្មករនេសាទត្រី/ទាហាន], 5025 [មូល វ៉ាន់ឌី ប្រជាជនថ្មីធ្វើការនៅ "វិចិត្រសិល្បៈ"], 5465 [នឹម ណាន ហៅ សារិន, ប្រជាជនថ្មី និងកម្មករនេសាទត្រី], 6390 [អ៊ុន ហាន, អ្នកនេសាទត្រី], 10590 [សំរិត ចក់, ប្រជាជនថ្មី និងកម្មករចំការដូង], 11611 [ត្រឹល សឹម, អ្នកនេសាទត្រីនៅអូរត្រេស], 12616 [ប៉ែត ទ្រី, កម្មករផ្លូវដែក], 13823 [នារី យិន ត្រឹង], 13873 [យុន យ៉ាន ហៅ យ៉េន, កម្មករនេសាទត្រី]។

រ៉ុង កោះតាង កោះពូលូវ៉ៃ កោះកាពិ ឬកោះថាស)[2073] ដូចជា អ្នកនេសាទថៃ ៦ នាក់នៅលើទូកនេសាទ *Seri Chhaok* ដែលត្រូវបានចាប់ខ្លួននៅថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ១៩៧៥[2074] និងអ្នកនេសាទថៃ ៩ នាក់នៅលើទូកនេសាទ *Harin Phanich* ដែលត្រូវបានចាប់ខ្លួននៅថ្ងៃទី ២១ ឬ ២២ ខែ ធ្នូ ឆ្នាំ ១៩៧៥[2075]។ អ្នកទោសទាំងនេះប្រហែលជាត្រូវបានឃុំខ្លួនជាច្រើនខែនៅមន្ទីរសន្តិសុខក្នុងកំពង់សោម ដូចជា គុកទឹកសាប ដែលគ្រប់គ្រងដោយកងវរសេនាធំលេខ ៦៣ របស់កងពលធំលេខ ១៦៤[2076] មុនពេលបញ្ជូនទៅមន្ទីរ ស-២១។ ចំណុចនេះត្រូវបានគូសបញ្ជាក់ក្នុងបញ្ជីឈ្មោះ

---

2073 សូមមើល ឧទាហរណ៍ ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 592 [ដាំង យ៉ាំងថាន់ (ស្ទួនដូចលេខរៀង 14786) - ចាប់ខ្លួននៅសមុទ្រថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៥ ហើយឃុំឃាំងនៅទឹកសាបរហូតដល់ពេលបញ្ជូនមកមន្ទីរស-២១], 663 [គឹម ង៉ុកទ្រៀង (ស្ទួនដូចលេខរៀង 14784) – ចាប់ខ្លួនក្នុងខែធ្នូ ឆ្នាំ១៩៧៥នៅកោះបាតហើយឃុំឃាំងនៅទឹកសាបរហូតដល់ពេលបញ្ជូនមកមន្ទីរស-២១], 678 [ឡេ យ៉ាំងហាយ – ចាប់ខ្លួននៅសមុទ្រក្នុងខែធ្នូ ឆ្នាំ១៩៧៥], 12981 [ថា រៀង – ចាប់ខ្លួនក្នុងខែធ្នូ ឆ្នាំ១៩៧៥នៅលើកោះថាស់], 12988 [ក្មេងប្រុសអាយុ១៥ ឆ្នាំ ឈ្មោះឡូយ ឬ រ៉យ ឡុត ណុក្រសៃ – ចាប់ខ្លួននៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៧៥], 12989 [វិធី អាំហ្វាណាន់ – ចាប់ខ្លួននៅកោះរ៉ុង នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៥], 12999 [វី ឆៃ – ចាប់ខ្លួននៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៧៥ នៅកោះតាង], 13002 [ចារ៉ូន ណុក្រាសៃ – ចាប់ខ្លួននៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៥ នៅកោះតាង], 13005 [សម ស៊ី អានឆារៀង – ចាប់ខ្លួននៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៥], 13006 [សា ហាត់ – ចាប់ខ្លួននៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៧៥ នៅចន្លោះកោះតាង និងកោះប៉ូឡូវ៉ៃ], 13023 [ឈុត តា ឬ សុតា ប្រុង រេណូ – ចាប់ខ្លួននៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៥ នៅកោះកាពិ], 13031 [ក្មេងប្រុសអាយុ១៦ ឆ្នាំ ឈ្មោះយុត ផុង សាំ រ៉ាន – ចាប់ខ្លួននៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៧៥ នៅកោះតាង], 14783 [ចឹង ឬ ចាំង ចាន់ហឿង (ស្ទួនដូចលេខរៀង 13642) – ចាប់ខ្លួននៅសមុទ្រ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៥], 14785 [ផាំ យ៉ាំងថាន់ – ចាប់ខ្លួននៅសមុទ្រ នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ហើយឃុំខ្លួននៅទឹកសាបរហូតដល់ថ្ងៃបញ្ជូនមកមន្ទីរស-២១]។ ព័ត៌មានទាក់ទងនឹងទីតាំង និងកាលបរិច្ឆេទចាប់ខ្លួនអ្នកទោស ឃើញមានជាពិសេសនៅផ្នែក "យោបល់ផ្សេងៗ និង/ឬថ្ងៃចាប់" នៃបញ្ជីឈ្មោះអ្នកទោសមន្ទីរស-២១ របស់ ក.ស.ច.ស។

2074 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 12984 [ប្រធានក្រុមនាវា], 13001, 14697, 14698, 14701, 14703.

2075 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 12983 [កុមារអាយុ១៥ ឆ្នាំ ដែលធ្វើការជាអ្នកលាងចាននៅលើទូកនេសាទ], 12985, 12987, 13052, 13053, 14696, 14699, 14700 [ប្រធានក្រុមនាវា], 14702.

2076 ឯកសារ D114/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ.11-12,19 KH ERN 01096742,01096744 [តាជន គឺជាមេបញ្ជាការវរៈសេនាធំលេខ៦៣ហើយតាញ៉ាន់គឺជាអនុរបស់គាត់ ដែលទទួលខុសត្រូវលើគុកទឹកសាប]។ ឯកសារ D114/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ឆ.137-138, 146, 249។ ឯកសារ D54/41 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូ សារ៉ាន់ ឆ.21 KH ERN 00967441[មន្ទីរបញ្ជាការរបស់កងវរៈសេនាលេខ៦៣ នៅទឹកសាប]។ ឯកសារ D54/20 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ

អ្នកទោសរបស់ ក.ស.ច.ស និងប្រវត្តិរូបអ្នកជាប់ឃុំជាច្រើននាក់នៅមន្ទីរ ស-២១[2077]។ អ្នកទោសដែលត្រូវបានចាប់ខ្លួននៅឆ្នាំ ១៩៧៥ និងឃុំខ្លួនរយៈពេលជាច្រើនខែនៅមន្ទីរសន្តិសុខទឹកសាប ឬមន្ទីរសន្តិសុខផ្សេងទៀតនៅកំពង់សោម ក៏មាន កុមារអាយុ ១៥ និង ១៦ ឆ្នាំផងដែរ[2078]។ អ្នកទោសជនជាតិវៀតណាម និងថៃស្ទើរតែទាំងអស់ដែលត្រូវបានបញ្ជូនខ្លួនពីកំពង់សោមទៅមន្ទីរ ស-២១ នៅថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ១៩៧៦ ត្រូវបានសម្លាប់រង្គាលក្នុងរយៈពេលប៉ុន្មានសប្តាហ៍ បន្ទាប់ពីបានមកដល់ កាលពីថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៧៦[2079]។

---

សោម ឆ.10, 12 KH ERN 00947219 ["[គុកនៅទឹកសាប]គឺស្ថិតក្រោមបញ្ជាការកងពល ១៦៤ របស់មាស មុត។ [...] ឆ.12៖ [...] គេដាក់អ្នកទោសខ្លះ [ទឹកសាប] បណ្តោះអាសន្នមុននឹងបញ្ជូនទៅភ្នំពេញ"]។

2077 សូមមើល ឧទាហរណ៍ ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 592 [ដាំង យ៉ុំងថាន់ - ចាប់ខ្លួននៅសមុទ្រនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៥ ហើយឃុំឃាំងនៅទឹកសាបរហូតដល់ពេលបញ្ជូនមកមន្ទីរស-២១], 663 [គឹម ង៉ុកទ្រឿង – ចាប់ខ្លួនក្នុងខែធ្នូ ឆ្នាំ១៩៧៥ នៅកោះប្រចៀវ ហើយឃុំឃាំងនៅទឹកសាបរហូតដល់ពេលបញ្ជូនមកមន្ទីរស-២១], 14785 [ផាំ យ៉ុំងថាន់ – ចាប់ខ្លួននៅសមុទ្រនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ហើយឃុំឃាំងនៅទឹកសាបរហូតដល់ពេលបញ្ជូនមកមន្ទីរស-២១]។ សូមមើលលេខរៀង 600, 641-642, 649-650, 12987, 13031, 13052-13053, 13055 [អ្នកទោសដទៃទៀតមកពីកំពង់សោមចូលមន្ទីរស-២១ នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ រួមមានអ្នកនេសាទថៃដែលចាប់ខ្លួននៅក្នុងខែកញ្ញា ឬខែធ្នូ ឆ្នាំ១៩៧៥ ហើយបានកំណត់អត្តសញ្ញាណថាបានបញ្ជូនមកពី"ទឹកសាប"]។ សូមមើល ឯកសារ D114/145.2.15 ស ២១ ប្រវត្តិរូបរបស់ ដាំង យ៉ុំង ថាន់ EN 01396238។ ឯកសារ D114/145.2.14 ស ២១ ប្រវត្តិរូបរបស់ ផាម យ៉ុំងថាន់ EN 013168091។ ឯកសារ D114/145.2.12 ស ២១ ប្រវត្តិរូបរបស់ ង្វៀង ធីធឿង, ង្វៀង ហ៊ីវឡាង, ចឹង ថាន់ហឿង [ជឿថាជាបញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង 13436, 13437 និង 14783 - ជនជាតិវៀតណាមដែលស្ថិតនៅក្នុងក្រុមមនុស្សបញ្ជូនពីកំពង់សោមមកមន្ទីរស-២១ នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦]។ ឯកសារ D114/145.2.13 ស ២១ ប្រវត្តិរូបរបស់ ឡេ យ៉ាំងហាយ,គឹម ងុកទឿង [បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស, លេខរៀង 678 & 663]។ ឯកសារ D114/145.2.11 ស ២១ ប្រវត្តិរូបរបស់ ត្រឹង យ៉ាំង ឃ្វេ, ជីម យ៉ាំងគី, ជីម យ៉ាំង យុប,ជីម យ៉ាំង កឹង, ង្វៀង ខិន អ៊ី [បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរងៀង 13431, 13432, 13433, 13434, 14782]។

2078 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង 12983, 12988, 13031, 13434។

2079 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង 592-593, 596-597, 600, 604, 609, 613, 615-616, 620, 625, 645-646, 649-650, 653, 663, 676, 679-680, 12981, 12983-85, 12987-88, 12999, 13001-02, 13005-06, 13023, 13031, 13052-53, 13055, 13432-34, 13436-37, 13642-43, 13645, 13653។ ឯកសារ D1.3.3.2 ឈ្មោះអ្នកទោសកំទេច KH ERN 00008835-00008836 [លេខរៀង១-៣១ គឺសុទ្ធជាអ្នកនេសាទជនជាតិថៃចូលមន្ទីរ ស ២១ នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៧៦ ហើយកម្ទេសនៅថ្ងៃទី២៤ ខែឧស

547. អតីតទាហាន នគរបាល មន្ត្រីរដ្ឋការ លន់ នល់ និងសាច់ញាតិរបស់ពួកគេ ២១ នាក់ (អ្នកម្ដាយ)[2080] និងយ៉ាងហោចណាស់កងទ័ពកងពល ៣ នាក់[2081] និងជនស៊ីវិលរាប់រយនាក់[2082] ត្រូវបានបញ្ជូនខ្លួន

---

ភា ឆ្នាំ១៩៧៦], KH ERN 00008900-00008901[លេខរៀងទី២៣៤-២៨៤ គឺជនជាតិវៀតណាម ១៧ នាក់ និងថៃ ៣៤ នាក់ បញ្ជូនមកពីកំពង់សោម នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ ហើយកម្ទេស នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៧៦] ។

2080 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស, លេខរៀង 453 [ឈឹម សុភាព ហៅ ធី, ពលទោ – ចូលថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៦], 685 [សេន សារឿន ហៅ សេង, ទាហានពលទោ – ចូលថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៦], 691 [នៅ គុច ហៅ ផន, អធិការប៉ូលីស – ចូលថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៦ ស្លាប់ដោយសារជំងឺនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៧៦], 692 [ស៊ី តៃស្រុង, ទាហានស័ក្តិ២ – ចូលថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៦ ស្លាប់ដោយសារជំងឺនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៧៦], 693 [ទិន គឹមហុង, ទាហានស័ក្តិ២ – ចូលថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៦ ស្លាប់ដោយសារជំងឺនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៧៦], 694 [ខៀវ វ៉ាន់ថន, ទាហានស័ក្តិ៣ – ចូលថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៦], 695 [គឹម សាន, ទាហានស័ក្តិ២ – ចូលថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៦], 696 [ណន ខ្នាក់, ប៉េអឹមស័ក្តិ៤ – ចូលថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៦ ស្លាប់ដោយសារជំងឺនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧៦], 697 [អាំ វង់, ស័ក្តិ២ – ចូលថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៦], 698 [គឹម វង់, ស័ក្តិ២ – ចូលថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៦], 1404 [សៀង សុក ហៅ ថន ត្រូវបានកំណត់អត្តសញ្ញាណជា "ខ្មែរស, ចោរព្រៃ" និងអតីតទាហានពលទោនៅពោធិ៍ចិនតុង – ចូលថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៦ កម្ទេចថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៦], 6601 [ពេជ្រ ចិន្តា, ស័ក្តិ៣ – ចូលថ្ងៃទី២៩ ខែឧសភា, 7297 [ប៉ែន សារិត ត្រូវបានកំណត់អត្តសញ្ញាណជា "អ្នករត់រ៉ឺម៉ក និងចោរព្រៃ (ទាហាន)" – ចូលថ្ងៃទី៥ ឬ២៩ ខែឧសភា ឆ្នាំ១៩៧៦ កម្ទេចថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧៦], 13182 [អ៊ុំ ឆេងហួត, ប្រធានការិយាល័យពន្ធដារ – ចូលថ្ងៃទី២៨ ឬ២៩ ខែឧសភា ឆ្នាំ១៩៧៦ កម្ទេចថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៦], 13659 [ស៊ុត ហែម, នាយទោ (កាប៉ូរ៉ាល់) – ចូលថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៦ កម្ទេចថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៦]។ សូមមើល ឧបសម្ព័ន្ធ ឃ.៨។

2081 សូមមើលឧបសម្ព័ន្ធ ឃ.១ រាប់បញ្ចូលទាំង ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 13333 [ម៉ាន មាន ត្រូវបានកំណត់អត្តសញ្ញាណថាជាយុទ្ធជននៃអង្គភាពយោធាលេខ ៨០៨ នៅកំពង់សោម – ចូលថ្ងៃទី៥ ខែមេសា ឬឧសភា ឆ្នាំ១៩៧៦ កម្ទេចថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៦], 13343 [អ៊ូច ខន, យុទ្ធជនកង៥៣០ – ចូលថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៧៦ កម្ទេចថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៦], 13373 [ប្រាក់ សារឿន, យុទ្ធជនកង៤៨០ កងពលទី៣ – ចូលថ្ងៃទី២ ខែមករា ឆ្នាំ១៩៧៦ កម្ទេចថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៦]។ ដូចក្រុមដទៃទៀតដែលត្រូវបានកំណត់អត្តសញ្ញាណជាទាហានកងពលទី៣ដែរ អ្នកទោសទាំងនេះអាចមានតួនាទីជាកម្មាភិបាលកងពល ១៦៤ នៅពេលចាប់ខ្លួន។

2082 សូមមើល ឧបសម្ព័ន្ធឃ.៨, ឃ.៩ និងឃ.១០ រាប់បញ្ចូលទាំងឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 660 [ប៉ុក ង៉ែត, នារីនៃសាទត្រីនៅអូរត្រេះ – ចូលថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៦ កម្ទេចថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៦], 683 [តេង ផាត ហៅ វុត, លក់ក្តាមប្រៃ – ចូលថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៦], 684 [សុក មួយ ហៅ ជី, លក់ក្តាមប្រៃ និងកាត់ដេរ – ចូលថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦], 690 [អ៊ុន សឿន, យុវជន – ចូលថ្ងៃទី

ពីកំពង់សោមទៅមន្ទីរ ស-២១ នៅកាលបរិច្ឆេទផ្សេងទៀតក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដូចជា អតីតមន្ត្រីរដ្ឋការ លន់ នល់ ៨ នាក់ដែលត្រូវបានបញ្ជូនខ្លួននៅថ្ងៃទី ២១ ខែ សីហា ឆ្នាំ ១៩៧៦[2083]។ អ្នកទោសដែលត្រូវបានបញ្ជូនពីកំពង់សោមទៅមន្ទីរ ស-២១ ក៏រួមមាន អតីតកម្មករផ្លូវដែក និងប្តី/

---

៨ ខែសីហា ឆ្នាំ១៩៧៦], 699 [អ៊ុយ ឡេង ហៅ ម៉ាន់, កម្មករនេសាទត្រី – ចូលថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៦ ស្លាប់ដោយសារជំងឺនៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៧៦], 700 [លឹម ហួត, កម្មករនេសាទត្រី – ចូលថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៦ ស្លាប់ដោយសារជំងឺ], 701 [សាំង គាត, កម្មករនេសាទត្រី – ចូលថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៦], 702 [គឹម វ៉ា , ជាងម៉ាស៊ីន – ចូលថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៦ ស្លាប់ដោយសារជំងឺនៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៧៦], 703 [ញ៉យ ផេង, កម្មករនេសាទត្រី – ចូលថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៦ ស្លាប់ដោយសារជំងឺនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៧៦], 708 [សុក វណ្ណា, កងចល័ត – ចូលថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៧៦], 714 [អែម ម៉េត ហៅ វីន, ប្រធានក្រុម – ចូលថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៧៦], 1281 [ម៉ូវ ហឿង, យុវជនតំបន់៣៣ – ចូលថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៧៦ ឬថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៥ កម្ទេចថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៦], 1755 [ហាំង ឆេង, អនុប្រធានក្រុម –ចូលថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៧៦], 2109 [អ៊ិត ស៊ិន ហៅ សាន, ប្រធានក្រុម, ចូលថ្ងៃទី៩ ឬ១០ ខែតុលា ឆ្នាំ១៩៧៦], 3645 [គង់ អាន ត្រូវបានកំណត់អត្តសញ្ញាណជា “អតីតអ្នកទោស” – ចូលថ្ងៃទី៣០ ខែមីនា ឬទី២ ខែមេសា ឆ្នាំ១៩៧៦], 4856 [យុទ្ធ អឿង ហៅ យ៉ាន, ប្រធានកងតូចនៅរោងចក្រចំរាញ់ប្រេង – ចូលថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៧៧], 5305 [ហ៊ុង នន់, ប្រធានកងតូចផ្នែកនេសាទសមុទ្រ – ចូលថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៧], 5306 [អែ សៅ, យុទ្ធជន “សេដ្ឋកិច្ចវរសេនាធំ៤៤” – ចូលថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៧៧], 5555 [ញ៉េប សួង ហៅ ផាន់, អនុប្រធានកងនេសាទ – ចូលថ្ងៃទី២១ ឬ២២ ខែតុលា ឆ្នាំ១៩៧៦], 5911 [នួច ទឹម, ប្រពន្ធកម្មករនេសាទ – ចូលថ្ងៃទី៧ ខែឧសភា ឬថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៦ កម្ទេចថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៦], 6168 [អ៊ុំ ថា ត្រូវបានកំណត់អត្តសញ្ញាណជាប្រពន្ធចោរព្រៃឈ្មោះ ថាច់ ថោម (លេខរៀង 12739) – ចូលថ្ងៃទី១១ ខែកុម្ភៈ ឬថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៧៦ កម្ទេចថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៦], 6172 [អ៊ុំ ធីម ហៅ ព្រុំ, ចោរព្រៃ – ចូលថ្ងៃទី៥ ឬ៦ ខែមេសា ឆ្នាំ១៩៧៦ កម្ទេចថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៧៦], 8472 [សុខ ជួន, កម្មករអគ្គិសនីកំពង់សោម និងជាចោរព្រៃក្នុងតំបន់៣៧ – ចូលថ្ងៃទី១០ ឬ១៦ ខែមីនា ឆ្នាំ១៩៧៦], 12739 [ថាច់ ថោម, ត្រូវគេចោទជាចោរព្រៃ – ចូលថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៦ កម្ទេចថ្ងៃទី៨ ខែកក្កដា ឆ្នាំ១៩៧៦], 12766 [ទី លីសេង ហៅ ធុង, ប្រធានមន្ទីរទទួលភ្ញៀវ – ចូលថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ១៩៧៦], 13571 [ទៀង មិត្ត, កម្មករនៅកំពង់សោម – ចូលថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ឬថ្ងៃទី៨ ខែកមរា ឆ្នាំ១៩៧៦ កម្ទេចថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៧៦], 13604 [អ៊ុក ខន កម្មករ –កម្ទេចថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៦], 13824 [សំ ហ៊ី ហៅ សាមេន, វិស្វករភស្តុភារ – ចូលថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៧៥], 13825 [អ៊ុក ឈន កម្មករកប៉ាល់ – ចូលថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៦], 13829 [យ៉ក យិន, ត្រូវគេចោទជាចោរព្រៃ – ចូលថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៧៦]។

2083 ឯកសារ D114/230.1.1បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង 691-698។

ប្រពន្ធរបស់ពួកគេ ១០ នាក់ (៦ នាក់ចូលមកមន្ទីរ ស-២១ នៅកាលបរិច្ឆេទតែមួយ នៅថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៧៦)[2084]។

548. នៅឆ្នាំ ១៩៧៨ ជនជាតិវៀតណាមយ៉ាងហោចណាស់ ១៥០ នាក់ត្រូវបានចាប់ខ្លួន និងបញ្ជូនមក មន្ទីរ ស-២១ ដោយកងពលធំលេខ ១៦៤ បន្ទាប់ពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យកាត់ផ្តាច់ ចំណងការទូតជាមួយវៀតណាមនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ ហើយ **មាស មុត** បានប្រកាសក្នុង សារទូរលេខដែលបានផ្ញើទៅមន្ទីរ ៨៧០ នៅថ្ងៃតែមួយនោះថា គាត់នឹង "បោសសម្អាតគ្មានស្ទាក់ស្ទើរ សមាសភាពបង្កប់របស់ខ្មាំង ជាយួន និងខ្មាំងដទៃទៀត"[2085]។ អ្នកទោសជាជនជាតិវៀតណាម ដែលត្រូវបានបញ្ជូនពីកំពង់សោមមកមន្ទីរ ស-២១ នៅឆ្នាំ ១៩៧៨ រួមមាន ៖

(ក) Vu Dinh Ngor ទាហានជើងទឹកវៀតណាម ដែលត្រូវបានចាប់ខ្លួន និងបញ្ជូនមកមន្ទីរ ស-២១ នៅថ្ងៃទី ៣ ខែ មករា ឆ្នាំ ១៩៧៨[2086]។ នេះជាអ្នកទោសដែល ឌុច រំឮកថាជា កងទ័ពវៀតណាមទីមួយដែលត្រូវបានចាប់ខ្លួន ក្រោយការផ្តាច់ទំនាក់ទំនងរវាងកម្ពុជា

---

2084 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង 754 [អ៊ូច ហ៊ែល, កម្មករផ្លូវដែក ចាស់ – ចូលថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៧៦], 844 [អ៊ឹង វ៉ាន់,ប្រពន្ធពៅ សាម៉េត (លេខរៀង 7613) – ចូលថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៧៦], 845 [អ៊ុក សៀប, ប្រពន្ធយឹម ដាំ (លេខរៀង 13583) – ចូលថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៧៦], 846 [តាំង គឹម លាន, ប្រពន្ធនាំ ខន (លេខរៀង 849) – ចូលថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៧៦], 849 [នាំ ខន, កម្មករផ្លូវដែកចាស់ និងជាប្តីរប ស់តាំង គឹមលាន – ចូលថ្ងៃទី២៧ ឬ២៨ ខែធ្នូ ឆ្នាំ១៩៧៦ កម្ទេចថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧], 3685 [ខៀវ ឈឿន, កម្មករផ្លូវដែក – ចូលថ្ងៃទី៣០ ខែកញ្ញា ឬថ្ងៃទី៤ ខែតុលា ឆ្នាំ១៩៧], 4527 [លី ស្រឿន – ចូលថ្ងៃទី១០ ខែមិថុនា ឆ្នាំ ១៩៧៧], 7613 [ពៅ សាម៉េត, កម្មករផ្លូវដែកចាស់ និងជាប្តីរបស់អ៊ឹង វ៉ាន់ – ចូលថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៧៦], 13395 [វ៉ឺ វឿត (Veu Voeut), កម្មករផ្លូវដែក – ចូលថ្ងៃទី៤ ឬ១៥ ខែតុលា ឆ្នាំ១៩៧៦], 13583 [យិន ដាំ, កម្មករផ្លូវដែក ចាស់ និងជាប្តីរបស់អ៊ុក សៀប – ចូលថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៧៦]។

2085 ឯកសារ D1.3.34.60 ទូរលេខពីមុត (មាស មុត)ជូន ម ៨៧០ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧។

2086 ឯកសារD114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង13474[វូ ឌិញង៉, នាយចំណាង់និង ជាអតីតទាហានជើងទឹកធីរគីមកវៀតណាម ចូលស-២១នៅថ្ងៃទី៣ ឬទី៩ ខែមករា ឆ្នាំ១៩៧៨ - ចម្លើយសារភាព លេខVN167]។

ប្រជាធិបតេយ្យ និងវៀតណាម[2087] ហើយចម្លើយសារភាពរបស់គាត់ត្រូវបានផ្សព្វផ្សាយតាមរលកវិទ្យុកម្ពុជាប្រជាធិបតេយ្យនៅអំឡុងខែនោះ[2088]។

(ខ) អនុសេនីយ៍វៀតណាមម្នាក់ដែលត្រូវបានចាប់ខ្លួននៅដែនសមុទ្រ និងបញ្ជូនមកមន្ទីរ ស-២១ នៅថ្ងៃទី ១៨ ខែ មករា ឆ្នាំ ១៩៧៨[2089]។ កងទ័ព ២ នាក់មកពីកោះត្រល់ (Phu Quoc) ដែលត្រូវបានចាប់ខ្លួននៅដែនសមុទ្រនៅថ្ងៃទី ២៤ និង ២៥ ខែ មករា ឆ្នាំ ១៩៧៨[2090]។ នាយទោ ៣ នាក់ និងអនុសេនីយ៍ ២ នាក់ដែលត្រូវបានបញ្ជូនមកនៅខែ កុម្ភៈ ឆ្នាំ ១៩៧៨[2091] និងនាយទោ ៣ នាក់ និងអនុសេនីយ៍ ២ នាក់ផ្សេងទៀតដែលត្រូវបានចាប់ខ្លួននៅដែនសមុទ្រ និងបញ្ជូនមកមន្ទីរ ស-២១ នៅខែ មីនា ឆ្នាំ ១៩៧៨[2092]។

---

2087 ឯកសារD114/277.4 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 15.03.33 KH ERN 01311869-01311870 ["ឈ្មោះ វូ ឌិញង៉ ពីដើមគេជាទាហានអាធីវគី បានន័យថា ទាហានរបស់សាធារណរដ្ឋវៀតណាម[...] ត្រូវខ្មែរចាប់បាន[...] អ្នកទោសឈ្មោះវូ ឌិញង៉ នេះមកដល់ ហើយក៏បងនួន ក៏បញ្ជាឲ្យខ្ញុំថតសំលេងសារភាពរបស់ទាហានវៀតណាម"]។

2088 ឯកសារ D1.3.26.5 BBC-SWB ចម្លើយសារភាពរបស់ទហានជើងទឹកសាធារណរដ្ឋសង្គមនិយមវៀតណាមដែលចាប់ខ្លួនបាន ថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៧៨ KH ERN 00224832 [ការចាក់ផ្សាយតាមវិទ្យុពី"ចម្លើយសារភាពរបស់ (វូ ឌិញង៉) អតីតទាហានចំណង់នាវាចរណ៍នៃកងនាវាអាយ៉ងធៀវគី ដែលយើងចាប់ខ្លួនបានកាលពីថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៨"]។ ឯកសារ D64.1.40 សារព័ត៌មាន FBIS ចម្លើយសារភាពប្រាប់អំពីការប៉ុនប៉ងរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បី 'រំលាយ'មេដឹកនាំកម្ពុជា ថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៧៨ KH ERN 00224833-36 ["ចម្លើយសារភាពរបស់ទាហានជើងទឹកសាធារណរដ្ឋសង្គមនិយមវៀតណាម (វូ ឌិញង៉)ដែលចាប់ខ្លួនបាន"]។

2089 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 9888 [ឧត្តមសេនីផ្កាយ៤ ត្រឹន វ៉ាន់ ធឿង (Troen Vann Thoeung)]។ ឯកសារ D64.1.38 សារព័ត៌មាន FBIS ចម្លើយសារភាពលាតត្រដាងថាសាធារណរដ្ឋសង្គមនិយមវៀតណាមមានផែនការយកខេត្តតាកែវជាខេត្តរណប ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៧៨ EN 00169232-36 [ការផ្សាយរបស់វិទ្យុកម្ពុជាប្រជាធិបតេយ្យអំពីចម្លើយសារភាពរបស់ត្រាន់ វ៉ាន់ធឿង "ចាប់ខ្លួននៅថ្ងៃទី១៨ ខែមករា នៅក្នុងដែនសមុទ្រកម្ពុជា"]។

2090 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 14728 [តាំង ង៉ុកតៃ (Taing Ngok Tay), កាប៉ូរ៉ាល់ផ្កាយ១ផ្នែកការពារសមុទ្រ, កោះភូគុក – ចាប់ខ្លួននៅសមុទ្រនៅថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៧៨], 14816 [ទ្រឿង ដាន់ហុង ហៅ តូ, "សន្តិសុខនៅកោះត្រល់ (ភូគុក)" – ចាប់ខ្លួននៅកោះពូឡូវៃនៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៨]។

2091 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 8403 [កាប៉ូរ៉ាល់ផ្កាយ១ ទាវឡុក – កម្មេចថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៨], 8400 [កាប៉ូរ៉ាល់ផ្កាយ៣ ដាំង វិនខឺយ (Daing Vin Khoey) – ចូលថ្ងៃទី

(គ) ជនជាតិចិនម្នាក់អាយុ ៥០ ឆ្នាំ ដែលបានភៀសខ្លួនចេញពីប្រទេសវៀតណាមនៅឆ្នាំ ១៩៧០ ម៉េកានិកទូកម្នាក់អាយុ ៥៤ ឆ្នាំ និងអ្នកនេសាទចិនម្នាក់អាយុ ១៨ ឆ្នាំ មកពី

---

១៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ កម្ទេចថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៨], 13488 [ង៉ូ យ៉ាំងឡើយ (Ngou Yaing Laey), អ្នកនេសាទ និងជាកាប៉ូរ៉ាល់ផ្កាយ១ – ចូលថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨ កម្ទេចថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៨], 8257 [ស័ក្តិ២ សំ គឹម – ចូលថ្ងៃទី១៤ ឬ២១ ខែកុម្ភៈ ឆ្នាំ១៩៧], 13469 [កាឡឹង កុងវ៉ាយ (Loeung Kong Vay) អ្នកនេសាទ និងជាទាហានស័ក្តិ២ – ចូលថ្ងៃទី៩ ឬ១៤ ខែកុម្ភៈ ឆ្នាំ១៩៧៨]។ សូមមើល ឯកសារ D64.1.38 សារព័ត៌មាន FBIS ចម្លើយសារភាពលាតត្រដាងថា សាធារណរដ្ឋសង្គមនិយមវៀតណាមមានផែនការដណ្តើមកាន់កាប់កោះរបស់កម្ពុជា ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៧៨, EN ERN 00169276-77 [ការផ្សាយរបស់វិទ្យុកម្ពុជាប្រជាធិបតេយ្យអំពីចម្លើយសារភាពរបស់ ផៀវ ឡុក "ចាប់ខ្លួនកាលពីថ្ងៃទី១ ខែកុម្ភៈក្នុងដែនសមុទ្រកម្ពុជា"]។ ឯកសារ D64.1.41 សារព័ត៌មាន FBIS វិទ្យុចាក់ផ្សាយចម្លើយសារភាពរបស់គិញវៀតណាមដែលចេះនិយាយភាសាខ្មែរ, ថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៧៨, EN ERN 00169934-36 [ការផ្សាយរបស់វិទ្យុកម្ពុជាប្រជាធិបតេយ្យអំពីចម្លើយសារភាពរបស់អនុសេនីទោ សំ គឹម "ចាប់ខ្លួននៅថ្ងៃទី១៤ ខែកុម្ភៈ នៅលើកោះព្រីងរបស់កម្ពុជា"]។

2092 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង 8689 [កាប៉ូរ៉ាល់ផ្កាយ៣ ឡាំ វុកទិន – ចូលថ្ងៃទី១៣ ឬទី២០ ខែមីនា ឆ្នាំ១៩៧៨], 13458 [ស័ក្តិ១ ង្វៀង ថាញ់ក្វាង – ចូលថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៨], 13463 [ស័ក្តិ២ វិញ មិនចាវ – ចូលថ្ងៃទី១៣ ឬទី២០ ខែមីនា ឆ្នាំ១៩៧៨], 13486 [កាប៉ូរ៉ាល់ផ្កាយ២ យិនហៀង – ចូលថ្ងៃទី១៣ ឬទី២០ ខែមីនា ឆ្នាំ១៩៧៨], 13529 [កាប៉ូរ៉ាល់ផ្កាយ២ វិញ ទីភឿង (ស្ទួនដូចលេខរៀង 14760) – ចាប់ខ្លួននៅសមុទ្រនៅថ្ងៃទី២៨ ខែមីនា ហើយត្រូវបានបញ្ជូនទៅមន្ទីរស-២១ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៨]។ សូមមើល ឯកសារ D64.1.35 សារព័ត៌មាន FBIS នាយទាហានជើងទឹកដែលចាប់ខ្លួនបានប្រាប់អំពីការបង្អិតបង្អំ ថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៨, EN ERN 00168793-94 [ការផ្សាយរបស់វិទ្យុកម្ពុជាប្រជាធិបតេយ្យអំពីចម្លើយសារភាពរបស់វិញ មិនចាវ "ចាប់ខ្លួននៅកោះអង្រ្កងក្នុងខែមីនា"]។ ឯកសារ D10.1.68 សារព័ត៌មាន FBIS នាយទាហានវៀតណាមដែលចាប់ខ្លួនបាននិយាយអំពីផែនការវាយប្រហារ ថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៧៨ EN ERN 00169799-800 [ការផ្សាយរបស់វិទ្យុកម្ពុជាប្រជាធិបតេយ្យអំពីចម្លើយសារភាពរបស់អនុសេនី ង្វៀន ថាញ់កាង (Nguyen Thanh Quang) "ចាប់ខ្លួននៅក្នុងដែនទឹកកម្ពុជានៅថ្ងៃទី១៣ ខែមីនា"] ចម្លើយសារភាពរបស់ពលបាលជាគិញ ចាប់ខ្លួននៅថ្ងៃទី២៩ ខែមីនា ត្រូវបានរាយការណ៍, ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៧៨, EN ERN 00169865-66 [ការផ្សាយរបស់វិទ្យុកម្ពុជាប្រជាធិបតេយ្យអំពីចម្លើយសារភាពរបស់ វិញ ទូភឿង (Vinh Tu Phuong) "ចាប់ខ្លួនដោយកម្លាំងរបស់កម្ពុជានៅកោះពូឡូវ៉ៃក្នុងខែមីនា"]។

វៀតណាម និងអ្នកនេសាទខ្មែរក្រោមម្នាក់ ដែលត្រូវបានបញ្ជូនមកមន្ទីរ ស-២១ នៅថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៨[2093]។

(ឃ) កុមារវៀតណាមពីរនាក់អាយុ ១៥ និង ១៧ ឆ្នាំ ដែលត្រូវបានចាប់ខ្លួននៅដែនសមុទ្រ និងចោទប្រកាន់ថាជា "គិញ" និងត្រូវបានបញ្ជូនមកមន្ទីរ ស-២១ នៅថ្ងៃទី ១១ និង ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ និងយកទៅសម្លាប់នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៧៨[2094]។

(ង) ជនជាតិវៀតណាម ៣ នាក់ដែលត្រូវបានបញ្ជូនមកមន្ទីរ ស-២១ នៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៨[2095] និងជនជាតិវៀតណាម ១៦ នាក់ដែលត្រូវបានបញ្ជូនមកមន្ទីរ ស-២១ នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៧៨[2096] រួមទាំងក្មេងប្រុសអាយុ ១៥ និង ១៦ ឆ្នាំ[2097] បុរសវៀតណាម ៥ នាក់ដែលត្រូវបានបញ្ជូនមកនៅថ្ងៃទី ២៤ ខែ កុម្ភៈ និងថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៧៨[2098] និងជនជាតិវៀតណាមម្នាក់ទៀតដែលត្រូវបានចាប់ខ្លួននៅដែនសមុទ្រនៅខែ មីនា ឆ្នាំ ១៩៧៨[2099]។

---

2093 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 8164 [ឡេង ង៉ុន ហៅ ង្វៀន យ៉ាងធីន, ជាងធ្វើទូក], 8165 [វ៉ាន់ ថន ហៅ ម៉េង "រត់គៀសខ្លួនទៅវៀតណាមក្នុងឆ្នាំ១៩៧០ (ចិន)"], 8166 [ចាវ ងី អ្នកនេសាទជនជាតិចិន មកពីវៀតណាម], 8167 [ជីវ ឡុក អ្នកនេសាទកម្ពុជាក្រោម]។

2094 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 8401 [ទ្រិន វិនហុង អាយុ១៧ ឆ្នាំ – ចូលថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ១៩៧៨ កម្ទេចថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៨], 8405 [ល្អឿង មិញ តុនហាយ អាយុ១៥ ឆ្នាំ – ចូលថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧៨ កម្ទេចថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៨]។

2095 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 8402 [ទ្រឿង វ៉ាន់ថាញ់ "គិញវៀតណាម" – កម្ទេចថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៨], 8406 [ថាច់ ទេព – កម្ទេចថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៨], 13483 [ង្វៀន យ៉ាំងណាំ, អ្នកនេសាទ – កម្ទេចថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៧៨]។

2096 ឯកសារD114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង 8250-8256, 8258-8263,8407-8409។

2097 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 8255 [តែ កុកហួរ អាយុ១៦ ឆ្នាំ], 8258 [លាង មីង ទុងង៉ែ អាយុ១៥ ឆ្នាំ], 8408 [ទ្រិញ វ៉ុកហួរ អាយុ១៦ ឆ្នាំ – កម្ទេចថ្ងៃទី២៧ ខែមីនា ឆ្នាំ ១៩៧៨]។

2098 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 8271 [ដង មិនចិន – ចូលថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៧៨], 8272 [ង្វៀង យ៉ាងវ៉ូ - ចូលថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៧៨], 8410 [ង្វៀង វ៉ាន់វ៉ូ - ចូលថ្ងៃទី២៤

(ច) អ្នកជំនួញវៀតណាម ឬចិនកាត់វៀតណាម ១៥ នាក់[2100] និងអ្នកនេសាទ ឬកសិករខ្មែរក្រោម ៥ នាក់[2101] មកពីកោះត្រល់ (Phu Quoc) ដែលត្រូវបានបញ្ជូនមកមន្ទីរ ស-២១ នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៧៨។

(ឆ) បុរស និងស្ត្រីវៀតណាម ៣០ នាក់ (ភាគច្រើនមកពីកោះពូលូវៃ) ដែលត្រូវបានចាប់ខ្លួននៅដែនសមុទ្រនៅថ្ងៃទី ២៨ ឬ ៣០ ខែ មីនា ឆ្នាំ ១៩៧៨ និងបញ្ជូនមកមន្ទីរ ស-២១ នៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៧៨[2102]។

---

ខែកុម្ភៈ ឆ្នាំ១៩៧៨, កម្ទេចថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៨], 13895 [វិត ធីមុង - ចូលថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៨], 13896 [ង្វៀន យ៉ាំងកុក - ចូលថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៨]។

2099 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង 14758 [ទ្រិន ង៉ុកធីង – ចាប់ខ្លួននៅសមុទ្រក្នុងខែមីនា ឆ្នាំ១៩៧៨]។

2100 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 13917 [ចឹង តន, មេកានិក], 13918 [ចឹង តឹងយុង, លក់កាសែត], 13919 [លី ហុក, លក់សណ្ដែក], 13920 [ថៃ ជិនទៀង, ជាងជួសជុលនាឡិកា], 13921 [វឹង ធុកជៀ, លក់បង្អែម], 13922 [អៀក ឡៀនតេន, ជាងអគ្គិសនី], 13923-13925 [ង្វៀង យ៉ាំងហ៊ីវ, ង្វៀង យ៉ាំងបា និងង្វៀង យ៉ាំងទឹង, អ្នកនេសាទ], 13926 [ង្វៀង យ៉ាំងតាំ, ធ្វើស្រែ], 13927 [ឈៀង ថាន់, អ្នកលក់ចាប់ហួយ], 13928 [ចេង អ៊ីវ៉ី ផេង, អ្នកផលិតសម្លៀកបំពាក់], 13929-13930 [ចេន ង៉ុកហ្វុង និងត្រឹង អាន់, អ្នកលក់ដូរ - នារីទាំងពីរ], 13931 [ចាវ ទូកឹម នារីអ្នកលក់នំ]។

2101 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង 13912 [តែ ស៊ីវខេង នារីអាយុ ៤០ ឆ្នាំ], 13913 [ភូ ផុងតៃ], 13914 [អ៊ី សំអាត], 13915 [អ៊ាវ ហាតហាត], 13916 [អ៊ឹង ម៉េងហុង]។

2102 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 8982-8984, 8987-8990, 8992-8994, 9899-9900, 13007 [ស្ទួនដូចលេខរៀង 14761], 13008-13012, 13013 [ស្ទួនដូចលេខរៀង 14792], 13014-13020, 13453, 13532-13533, 13535។ អ្នកទោសទាំងអស់ លើកលែងតែម្នាក់ នៅក្នុងក្រុមនេះ ត្រូវបានសួរចម្លើយ និងមានចម្លើយសារភាព ហើយ ក.ស.ច.ស កត់សម្គាល់ជាមនុស្សដែលចាប់ខ្លួននៅសមុទ្រ (សូមមើលលេខរៀង 8982-83, 8988, 9899-9900, 13008, 13010, 13012-13, 13453, 13532, 13535) និងអ្នកទោសដែលមានកំណត់ហេតុកាលបរិច្ឆេទចាប់ខ្លួននៅថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៨។ ទាំងនេះគាំទ្រសេចក្ដីសន្និដ្ឋានដែលថា អ្នកទោសភាគច្រើន ឬអ្នកទោសទាំងអស់នៃក្រុមអ្នកទោសវៀតណាមចំនួន៣០ នាក់ដែលបានបញ្ជូនពីកំពង់សោមនៅថ្ងៃទី ១ ខែមេសា គឺចាប់ខ្លួនបាននៅសមុទ្រប្រហែលជានៅពេលដូចគ្នា រាប់បញ្ចូលទាំងអ្នកទោសក្នុងក្រុម(លេខរៀង 13009-17) ដែលគេបង្ហាញថាបានបញ្ជូនមកពីផែកំពង់សោម។

(ជ) ជនជាតិវៀតណាម ៧ នាក់ (ដែលខ្លះត្រូវបានកំណត់អត្តសញ្ញាណជា "ចោរព្រៃ Binh Nhy) (អតីតកងទ័ព) ដែលត្រូវបានបញ្ជូនមកមន្ទីរ ស-២១ នៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៧៨ និងសម្លាប់នៅរយៈពេល ១០ ថ្ងៃបន្ទាប់[2103]។

(ឈ) នាយទោវៀតណាម ២ នាក់ ដែលត្រូវបានបញ្ជូនមកមន្ទីរ ស-២១ នៅថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៧៨[2104]។

(ញ) ជនជាតិវៀតណាម ៣ នាក់ "ដែលកំពុងធ្វើស្រែ" ដែលត្រូវបានបញ្ជូនមកមន្ទីរ ស-២១ នៅថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៨ និងសម្លាប់នៅរយៈពេលមួយសប្តាហ៍ក្រោយមក[2105] ជនជាតិវៀតណាម ១២ នាក់ដែលត្រូវបានបញ្ជូនមកនៅថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ១៩៧៨[2106] (ដែលភាគច្រើនត្រូវបានសម្លាប់ក្រោយរយៈពេល ៥ ថ្ងៃ[2107]) និងមនុស្ស ១១ នាក់ផ្សេងទៀតដែលត្រូវបានបញ្ជូនមកនៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៧៨[2108] ដែលរួមមានសិស្សអាយុ ១៤ ឆ្នាំម្នាក់[2109]។

---

2103 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង 9647, 9650-9653, 13541, 13543។

2104 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 13498-13499។

2105 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 9857-9859។

2106 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 9917-9928។

2107 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង 9920 [ង្វៀង ណាក់, ជាងធ្វើឡាន], លេខរៀង 9922, 9924-9925 [សិស្សពីរនាក់អាយុ១៦ ឆ្នាំ], លេខរៀង 9926-9927។

2108 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 10257-10262, 10264, 10265 [ចាប់ខ្លួនពីកោះពូឡូវៃនៅថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៧៨], លេខរៀង 10267, 13501 ["កម្ពុជាក្រោម ធ្វើស្រែ"], លេខរៀង 13528។

2109 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 10262 [ទឹង យ៉ាំងញាន, សិស្សអាយុ១៤ ឆ្នាំ]។

(ង) ជនជាតិចិន ៦ នាក់មកពីវៀតណាមដែលត្រូវបានបញ្ជូនមកមន្ទីរ ស-២១ នៅថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៧៨[2110]។

(ច) មនុស្សម្នាក់អាយុ ៤៩ ឆ្នាំ ដែលគេសន្មតថាជា "គិញ" ដែលត្រូវបានចាប់ខ្លួននៅកោះពូលូវ៉ៃ នៅថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៧៨[2111] និងអ្នកនេសាទវៀតណាម ៩ នាក់ ដែលត្រូវបានបញ្ជូនមកមន្ទីរ ស-២១ នៅថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ១៩៧៨[2112] រួមទាំងក្មេងប្រុសអាយុ ១៥ ឆ្នាំម្នាក់[2113] និង

(ឆ) ជនជាតិវៀតណាម ៤ នាក់ដែលគេសន្មតថាជាគិញ ដែលត្រូវបានបញ្ជូនមកមន្ទីរ ស-២១ នៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨[2114]។

549. អ្នកទោសនៅមន្ទីរ ស-២១ ដែលត្រូវបានបញ្ជូនមកដោយកងពលធំលេខ ១៦៤ ក៏រួមមានពួកបរទេសជាច្រើននាក់ដែលត្រូវបានចាប់ខ្លួននៅដែនសមុទ្រ ដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ និងបញ្ជូនមកមន្ទីរ ស-២១ ផងដែរ[2115] ដូចជា៖

---

2110 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 11872 [ភូ ភុងជិន, អ្នកនេសាទ], 11873 [ឈិន អាយសេត បុគ្គលិកពេទ្យ], 11874 [គី ឃុន, ធ្វើស្រែ], 11875 [ត្រឹង ហេង, លក់ត្រី], 11877 [តាំង សេងវ៉ា, រកត្រី], 13446 [ឡៅ យាវគង់ ធ្វើស្រែ]។

2111 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 14820 [ទ្រិន វ៉ាន់ឡុង, ប្រុស, អាយុ៤៩ ឆ្នាំ – ចម្លើយសារភាពលេខ VN186]។ ឯកសារ D64.1.45 សារព័ត៌មាណ FBIS ចម្លើយសារភាពរបស់គិញវៀតណាម ចាប់ខ្លួននៅកោះពូឡូវ៉ៃ, ថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៧៨, EN ERN 00170273-74 [ការផ្សាយរបស់វិទ្យុកម្ពុជាប្រជាធិបតេយ្យអំពីចម្លើយសារភាពរបស់ "ជនល្មើយសឹកវៀតណាម ត្រាន់ វ៉ាន់ឡុង ចាប់ខ្លួននៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៧៨ នៅកោះពូឡូវ៉ៃ" និងត្រូវបានកំណត់ថា មានអាយុ៤៩ ឆ្នាំ]។

2112 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 12490-12498។

2113 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 12496 [ង្វៀង កុងវៀង]។

2114 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 12653-12656។

2115 ឯកសារ D98/3.1.93 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.05.29 KH ERN 00341897-00341901 [ពួកបរទេសបួននាក់នោះដែលបញ្ជូនមកមន្ទីរ ស ២១ "ពួកនេះត្រូវកងទ័ពជើងទឹកដែលយើងខ្ញុំធ្លាប់ហៅថា កងពល១៦៤ បញ្ជូនពីកំពង់សោមមក"]។ ឯកសារ D1.3.33.3 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00146488 [អ្នកមកពីតំបន់ Caucasus ជាប់ឃុំ និងសម្លាប់នៅមន្ទីរស-២១ "គេចូលដែនសមុទ្រខ្មែរ ហើយកងសមុទ្រចាប់បញ្ជូនមកឲ្យខ្ញុំនូវជា"]។ ឯកសារ D1.3.33.4 កំណត់ហេតុនៃការសួរចម្លើយ កាំង

(ក) ជនជាតិអាមេរិកឈ្មោះ Lance (ឬ Lee) McNamara និង Jamew William Clark ដែលចូលមកមន្ទីរ ស-២១ នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៧៨[2116]

(ខ) Kerry George Hamill មកពីនូវែលសេឡង់ និង John Dawson Dewhirst មកពីចក្រភពអង់គ្លេស ដែលត្រូវបានចាប់ខ្លួននៅលើទូកក្ដោង *Foxy Lady* នៅជិតកោះតាង នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៧៨[2117]។

---

ហ្គេកអ៊ាវ KH ERN 00197971-72។ ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹក ថ្ងៃ២៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.46.04 KH ERN 01249438 ["មានៗ វៀតណាម មានជនជាតិអាមេរិកាំង ជនជាតិអូស្ត្រាលី ហ្នឹងដែលខ្ញុំធ្លាប់ឃើញ"]។ ឯកសារ D4.1.742 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម អេន KH ERN 00162844-00162845 [អតីតកម្មាភិបាលស-២១ បានថតរូប "ជនជាតិពីរនាក់មកពីសមុទ្រ" "មាឧធំ ច្រមុះស្រួច" និងពុកចង្កា]។ ឯកសារ D114/302 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គង់ ផៃ ឆ.73-85 [ រៀបរាប់អំពីអ្នកទោសអាមេរិកពីរនាក់បញ្ជូនមកមន្ទីរស-២១ នៅឆ្នាំ១៩៧៨ ត្រូវបានសួរចម្លើយដោយ ឌុច និងយកទៅសម្លាប់ បន្ទាប់ពីសួរចម្លើយរួច និងបង្ហាញអត្តសញ្ញាណរូបថតរបស់អ្នកទោសទាំងនោះ]។ ឯកសារ D114/301 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈុន ផល ឆ.62-69។ឯកសារ D114/132 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ៅ វ៉ាន់ ឆ.196-199 [រៀបរាប់អំពីកប៉ាល់ដែលកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ ចាប់បាន]។ ឯកសារ D2/15 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទូច សឿលី ឆ.1, ឆ.8 [រៀបរាប់អំពីជនបរទេសបញ្ជូនមកផែអូរឈើទាល តាមរយៈយោធាកងពល១៦៤]។ ឯកសារ D37 កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី Robert Hamil KH ERN 00945764 [ការឆ្លើយសារភាពរបស់ មាត មុត ដែលថា ជនបរទេសដែលចាប់ខ្លួននៅសមុទ្រ"ត្រូវបានបញ្ជូនទៅស ២១"]។ ឯកសារ D88.1.17 សៀវភៅនិពន្ធដោយ ដេវីដ ខាតថិនប៊ឺក(David Kattenburg) មានចំណងជើងថា៖ Foxy Lady, EN ERN 00916182 [សង្ខេបអំពីការសម្ភាសន៍របស់ Stony Beach ជាមួយអតីតកម្មាភិបាលកងពល ១៦៤ ទាក់ទងនឹងការចាប់កប៉ាល់បរទេស]។

2116 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 13021 [លី ម៉ាក់ណាម៉ារ៉ា (Lee McNamara)], 13022 [ជេមស៍ ខ្លាក (James Clark)]។ ឯកសារ D88.1.17 សៀវភៅនិពន្ធដោយ ដេវីដ ខាតថិនប៊ឺក (David Kattenburg), មានចំណងជើងថា៖ Foxy Lady, EN ERN 00916181-85 [រួមមានរូបថតចម្លើយសារភាពរបស់ខ្លាកនៅស-២១ និងការដកស្រង់ពីរបាយការណ៍ស៊ើបការណ៍យោធាអាមេរិក ដែលរៀបរាប់អំពីការទាក់ទងគ្នារបស់កម្ពុជាប្រជាធិបតេយ្យដែលស្ទះបាន៖ "នៅថ្ងៃទី២៣ កងពល១៦៤ ដែលការពារឆ្នេរសមុទ្រ បានចេញបញ្ជាឱ្យរដ្ឋអំណាចតំបន់ឆ្នេរ កោះកុង បញ្ជាកកម្លាំងទាំងអស់ កុំឱ្យនិយាយអំពីជនជាតិអាមេរិកដែលចាប់ខ្លួនបានឱ្យសោះ"], EN ERN 00916143 [រូបថតម៉ាក់ណាម៉ារ៉ា និងខ្លាកនៅហាវ៉ៃ មុនពេលចេញដំណើរតាមកប៉ាល់មកអាស៊ីអាគ្នេយ៍]។

2117 ឯកសារ D11/2.3 ចម្លើយសារភាពរបស់ John Dawson Dewhirst ពីស ២១ (សេចក្ដីដកស្រង់)។ ឯកសារ D98/3.1.85 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ម៉ោង 15.37.56 KH ERN 00326126-00326128[ពួកបស្ចិមប្រទេស រួមមាន អង់គ្លេសម្នាក់ នូវែលហ្សេឡង់ម្នាក់]។ ឯកសារ D98/3.1.93 កាំង ហ្គេក អ៊ាវ

(គ) ជនជាតិអូស្ត្រាលីឈ្មោះ Ronald Keith Dean និង David Lloyd Scott ដែលត្រូវបានចាប់ខ្លួននៅជិតកោះពូលូវ៉ៃនៅថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨[2118] និង

(ឃ) ជនជាតិអាមេរិកឈ្មោះ Christopher Edward Delance និង Michael Scott Deeds ដែលចូលមកមន្ទីរ ស-២១ នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨[2119]។

---

ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 11.59.17-12.00.47 KH ERN 00341920-00341921 [ឌុចបានជួបអ្នកទោសជនជាតិអង់គ្លេសដោយផ្ទាល់ ដែលជាប់ឃុំដាច់ដោយឡែកពីអ្នកទោសខ្មែរ មុនធ្វើទារុណកម្ម]។ ឯកសារ D98/3.1.42 Robert Hamill ប្រតិចារឹក ថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០០៩ ម៉ោង 14.10.00-16.21.20 KH ERN 00366087-00366091។ ឯកសារ D37 កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីរបស់ Robert Hamill ។ ឯកសារ D88.1.17 សៀវភៅនិពន្ធដោយ ដេវីដ ខាតធិនប៊ឹក(David Kattenburg), មានចំណងជើងថា៖ Foxy Lady, EN ERN 00916033, 00916203-05, 00916235 [រូបថតចម្លើយសារភាពរបស់ Kerry Hamill នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៧៨], 00916142 [រូបថតរបស់ Kerry Hamill នៅលើកប៉ាល់ Foxy Lady]។ ឯកសារ D11/2 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ រ៉ូប៊ឺត ហាមីល។

2118 ឯកសារ D54/4.1 ស ២១ ចម្លើយរបស់ឈ្មោះ រ៉ូណាល់ គីស ឌីន ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៧៨។ ឯកសារ D54/4.2 របាយការណ៍សង្ខេបរបស់ ចាន់ អំពីចម្លើយសារភាពរបស់ រ៉ូណាល់ គីស ឌីន, មីហ្សែល ស្កុត ឌីដ និង គ្រីស្តូហ្វែរ អេដវ៉ឺ ឌីឡង់ នៅស-២១, ថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៩។ ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.46.06 KH ERN 01249438។ ឯកសារ D98/3.1.85 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ ម៉ោង 15.37.56 KH ERN 00326126-00326128 [ពួកបស្ចិមប្រទេសនៅស ២១ មានអូស្ត្រាលីទៀត]។ ឯកសារ D4.1.245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ខន KH ERN 00146597 [បានឃើញឌុចសួរចម្លើយដោយផ្ទាល់ និងទាត់អ្នកទោសអូស្ត្រាលី ឬអាមេរិកាំងម្នាក់មានឈ្មោះថា តេវីដ ស្កុត]។ ឯកសារ D88.1.17 សៀវភៅនិពន្ធដោយ ដេវីដ ខាតធិនប៊ឹក(David Kattenburg) មានចំណងជើងថា៖ Foxy Lady, EN ERN 00916219-20, 00916237-38 [រូបថតចម្លើយសារភាពរបស់ Dean នៅស-២១ ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៧៨ និងចម្លើយសារភាពរបស់ ដេវីដ ឡយ ស្កុត នៅស-២១ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៨]។

2119 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 12719 [គ្រីស្តូហ្វែរ អេដវ៉ឺ ឌីឡង់], 12720 [មីស៊ែល ស្កុតឌៀត]។ ឯកសារ D1.3.28.140 ស ២១ ឈ្មោះអ្នកទោសចូល ថ្ងៃទី២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨ KH ERN 00088752 [លេខរៀងទី១ - គ្រីស្តូហ្វែរ អេដវ៉ឺ ឌីឡង់, លេខរៀងទី២ - មីស៊ែល ស្កុតឌៀត]។ ឯកសារ D11/4.2.4 ស ២១ សេចក្តីសារភាពរបស់មីហ្សែល ស្កុត ឌីដ។ ឯកសារ D54/4.2 របាយការណ៍សង្ខេបរបស់ ចាន់ អំពីចម្លើយសារភាពរបស់ Ronald Keith Dean, មីស៊ែល ស្កុតឌៀត និង គ្រីស្តូហ្វែរ អេដវ៉ឺ ឌីឡង់, ថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៩។ ឯកសារ D114/277.3 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 15.08.51 KH ERN 01312019-01312020 ["ជនជាតិអាមេរិកាំងនេះ ចាប់បញ្ជូនដោយកងពលសមុទ្រពីកំពង់សោម"]។ ឯកសារ D88.1.17 សៀវភៅនិពន្ធដោយ ដេវីដ ខាតធិនប៊ឹក(David Kattenburg), មានចំណងជើងថា៖ Foxy Lady, EN

550. ក្រៅពីនេះ អ្នកទោសនៅមន្ទីរ ស-២១ ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ **មាស មុត** រួមមានមនុស្ស ៣៨ នាក់មកពីខេត្តក្រចេះដែលត្រូវបានចាប់ខ្លួននៅខែ ធ្នូ ឆ្នាំ ១៩៧៨[2120] ដូចការពិភាក្សាលម្អិតក្នុង*ផ្នែក VIII.I.ការបោសសម្អាតកងពលធំលេខ ១១៧ និងតំបន់ ៥០៥*។ អ្នកទោសដែលត្រូវបានបញ្ជូនមកមន្ទីរ ស-២១ ពីតំបន់ ៥០៥ និងកងពលធំលេខ ១១៧ ក្នុងសកម្មភាពបោសសម្អាតនៅចុងឆ្នាំ ១៩៧៨ រួមមាន ៖

(ក) មាស មឿន លេខាតំបន់ ៥០៥ (បងប្អូនជីដូនមួយរបស់ **មាស មុត**)[2121] និង ឈឹម ខុន[2122] អនុលេខាតំបន់ ៥០៥

(ខ) ឈុំ ចិន លេខាស្រុកស្នួល (ឬ ចិន) ហៅ ភ័ន និង ហួន យ៉េង[2123] លេខាស្រុកក្រចេះ

---

ERN 00916222 [Delance និង Deeds ត្រូវបានចាប់ខ្លួននៅលើកប៉ាល់ឈ្មោះ អុីវ៉ាឡានី (Iwalani)]។ ឯកសារ D11/4.2.1 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ Timothy Scott Deeds EN ERN 00741650-58។

2120 សូមមើល ឧទាហរណ៍ ឯកសារ D114/297.1.23 ម៉ឺង វេត ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ ម៉ោង 09.35.25-09.41.29 KH ERN 01329779-01329782។ ឯកសារ D54/63 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឺង វេត ឆ.2 KH ERN 00975792 [រៀបរាប់អំពីការប្រជុំដែលមាស មុត និយាយថាគាត់នឹងកម្ចាត់មេឃោជាក្នុងតំបន់ព្រោះពួកគេគឺ"មិនដាច់ខាតក្នុងការវែជាមួយយួន"]។ ឯកសារ D4.1.810 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សេង សឿន ឆ. 35-36។ ឯកសារ D114/169 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សេង សឿន ឆ.7-30 [មាស មុត បានបញ្ជាឲ្យគេសម្លាប់មេបញ្ជាការតំបន់ក្រចេះ]។ ឯកសារ D54/60.2 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ឺង វេត KH ERN 00992994 [ការប្រជុំដែលមាស មុត "ប្រកាសប្រាប់មេក្បត់ហើយ" រួមមានទាំងក្មួយប្រុសគាត់ផងដែរ លេខាកងពល១១៧ ឈ្មោះ រ៉ុម]។

2121 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 13396 [មាស មឿន, លេខាតំបន់៥០៥ – ចូលថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៨]។ ឯកសារ D1.3.28.137 ផ្នែកគុកពិសេស, សៀវភៅកំណត់ត្រាការសួរចម្លើយនៅមន្ទីរស-២១សម្រាប់គុកពិសេស [លេខរៀង១៥]។ សូមមើល ឯកសារ D114/216 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មាស អ៊ឹម ឆ.34-43 ផង។ ឯកសារ D114/101 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អែម សារិន ឆ.15 KH ERN 0112707 [មាស មឿន មកនិយាយប្រាប់សាក្សីថា ថ្នាក់លើហៅគាត់ហើយគាត់ត្រូវទៅភ្នំពេញ]។ ឯកសារ D114/170 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រំ ម៉ុន ឆ.42។

2122 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 1039 [ឈឹម ខុន, អនុលេខាតំបន់៥០៥ – ចូលថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨]។ ឯកសារ D1.3.28.137 ផ្នែកគុកពិសេស, សៀវភៅកំណត់ត្រាការសួរចម្លើយនៅមន្ទីរស-២១ សម្រាប់គុកពិសេស, KH ERN 00086822 [លេខរៀងទី៤–ការកត់ត្រាថាការសួរចម្លើយរបស់គាត់គឺ "ចប់"]។

(គ) ឃុន វ៉ុ ឬរ៉ុម លេខាកងពលធំលេខ ១១៧ (ក្មួយរបស់ **មាស មុត**) រ័ត្ន លាង អនុលេខាកងពល និង ស្វាយ ណូញ[2124] ប្រធានមន្ទីរកងពល

---

[2123] ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 12903-12904 [ទាំងពីរនាក់ចូលថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៨ និងកម្ទេចនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៨]។ ឯកសារ D1.3.28.146 ឈ្មោះអ្នកទោសស ២១ ខែធ្នូ ឆ្នាំ១៩៧៨ KH ERN 00086832 [លេខរៀងទី១០-១១]។ឯកសារ D4.1.810 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.35-36 KH ERN 00402510-00402511[បានឃើញ យ៉េង ប្រធានស្រុកក្រចេះ និងភាន់ គណៈស្រុកស្នួល "ដឹកតាមយន្តហោះ"យកទៅភ្នំពេញដើម្បីសម្លាប់ហើយមាស មុត និយាយថា "មនុស្សទាំងនោះត្រូវបានគេយកទៅកម្ទេច"]។ ឯកសារ D114/101 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន ឆ.20-28 [ជាអ្នករៀបចំជើងយន្តហោះដឹកយ៉េង និងភាន់ទៅភ្នំពេញ]។ ឯកសារ D54/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.24, 32-33 [គេឱ្យកម្មាភិបាលក្រចេះទៅភ្នំពេញរួមមានពូគាត់ (លេខាស្រុកស្នួលឈ្មោះភាន់) និងលេខាស្រុកក្រចេះឈ្មោះយ៉េង]។ ឯកសារ D54/60.2 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ឹង វេត EN 00992992-95។

[2124] ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 4032 [ឃុន វុន, លេខាកងពល ១១៧, – ចូលថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៨], 7862 [រ័ត្ន លាង (Roat Leang), អនុលេខាកងពល១១៧ – ចូលថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៧៨], 8471 [ស្វាយ ណូញ, ប្រធានមន្ទីរកងពល១១៧– ចូលថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៧៨]។ ឯកសារ D1.3.28.137 ផ្នែកគុកពិសេស, សៀវភៅកំណត់ត្រាការសួរចម្លើយនៅមន្ទីរស-២១សម្រាប់គុកពិសេស KH ERN 00086822 [លេខរៀង 6, 8 & 18 – កំណត់ត្រាថា ស្វាយ ណូញ ត្រូវបានសួរចម្លើយដោយទិត]. សូមមើលឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ ឆ.2-6, 28-34 KH ERN 01071594-01071599 [រៀបរាប់អំពីការបោសសម្អាតកងពល ១១៧ រួមមានថ្នាក់ដឹកនាំឈ្មោះ វ៉ុ និងលាង ក្រោយពីកម្លាំងកងពលនេះត្រូវបង្ខំដកថយដោយសារ កងទ័ពវៀតណាម នៅខែតុលា ឆ្នាំ១៩៧៨], ឆ.39-42 KH ERN 01071601 [ការទទួលខុសត្រូវរបស់មាស មុត ក្នុងការរៀបចំកងពល១១៧ ឡើងវិញ]។ ឯកសារ D88.1.5 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សេង សឿន KH ERN 00059338 ["ស៖ចុះពីណាគេឡើងជំនួសវិញពេលចាប់រ៉ុមបាត់ទៅ?ឆ៖ គេយកអាហា ឱ្យតាញ៉ាន់មកធ្វើប្រធានសិន ញ៉ាន់គាត់នៅកងពលសមុទ្រ១៦៤ នោះ។[...] អារ៉ុមហ្នឹងក្មួយបងមុតបង្កើត"]។ ឯកសារ D54/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.24, 29 KH ERN 00975784-00975785 [សំបុត្រមកពីមន្ទីរ ម ៨៧០ ឱ្យ វ៉ុ ទៅភ្នំពេញ ទទួលបានពីនិរសាររបស់មាស មុត]។ ឯកសារ D54/63 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.1 KH ERN 00975792 [ការប្រជុំដែលមាស មុតប្រកាសថា ញ៉ាន់ មកទទួលដឹកនាំជំនួស វ៉ុ នៅក្នុងកងពល១១៧]។ ឯកសារ D54/60.2 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារ កម្ពុជាជាមួយ ម៉ឹង វេត EN 00992992-95។ ឯកសារ D114/170 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ ម៉ុន ឆ.32-40 KH ERN 01204168-01204169 [កិច្ចសម្ភាសន៍ជាមួយប្រពន្ធរបស់ឃុន រ៉ុម និយាយថា ការចាប់ខ្លួនប្ដីគាត់ គឺមាស មុត ជាអ្នកបញ្ជា ដោយសារតែការប្រកែកនឹងយុទ្ធសាស្ត្រយោធា]។

(ឃ) មេបញ្ជាការកងវរសេនាធំ ៣ នាក់ មកពីកងពលធំលេខ ១១៧ ៖ កិល សុផន ហៅ ផន លេខាកងវរសេនាធំលេខ ១៥ ចាប ហឿន លេខាកងវរសេនាធំលេខ ៨១ និង ប៊ី រ៉ី (ឬ រី) លេខាកងវរសេនាធំលេខ ៨២[2125]

(ង) មនុស្ស ២២ នាក់ផ្សេងទៀតមកពីតំបន់ ៥០៥ ដូចជា គណៈឃុំ និងប្រធានសហករណ៍ជាច្រើន ដែលសុទ្ធតែបានចូលមកមន្ទីរ ស-២១ នៅថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៧៨ និងត្រូវបានសម្លាប់ក្រោយរយៈពេល ៤ ថ្ងៃ នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៨[2126] និង

(ច) មនុស្ស ៦ នាក់ដែលគេសន្មតថាជាគិញវៀតណាម និងត្រូវបានបញ្ជូនពីខេត្តក្រចេះនៅថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៧៨[2127]។

---

2125 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 3979 [កិល សុផន ហៅ ផន, លេខាកងវរសេនាធំលេខ១៥, កងពល១១៧ – ចូលថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៨, កម្ទេចថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៨], 893 [ចាប ហឿន, លេខាកងវរសេនាធំ៨១, កងពល១១៧ – ចូលថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៨, កម្ទេចថ្ងៃទី៣១ ខែធ្នូ ១៩៧៨], 12895 [ប៊ី រី, លេខាកងវរសេនាធំ៨២, កងពល១១៧ – ចូលថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៨ កម្ទេចថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៧៨] ។ ឯកសារ D1.3.28.141 បញ្ជីឈ្មោះអ្នកទោសសួរចម្លើយនៅមន្ទីរស-២១ ខែធ្នូ ឆ្នាំ១៩៧៨ KH ERN 00086766 [លេខរៀងទី២, ៣, ៥]។ ឯកសារ D54/60.2 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ឹង វេត KH ERN 00975737 [កម្មាភិបាលដែលបានចាប់ខ្លួនបញ្ជូនទៅភ្នំពេញតាមយន្តហោះ រួមមានមេបញ្ជាការវរសេនាធំឈ្មោះ ផន ដែរ]។

2126 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 12905 [ពិន យិម, ប្រធានឃុំថ្មី], 12906 [ប៉ៀន លុន អាយុ៥៧ ឆ្នាំ], 12907 [សេក ណន, ប្រធានអ្នកឃ្វាលគោនៅសហករណ៍សំបុក], 12908 [ម៉ឹង សឹង ហៅ សេន អាយុ៦៣ ឆ្នាំ], 12909 [ហង់ ហុន], 12910 [យិម យ៉ន, សមាជិកកងតូចចំការកៅស៊ូស្នួល], 12911 [យ៉ាវ ផូ], 12912 [សួន យុត ហៅ យា, យុទ្ធជនវរសេនាតូច], 12913 [ឆ ឃីម អាយុ៦០ ឆ្នាំ (Chhor Khim)], 12914 [ញិល សំ (Nhil Sam), មេឃុំសំបុក], 12915 [មាន ផន], 12916 [នុន យុទ្ធ, អនុលេខាឃុំថ្មី], 12917 [ម៉ុប ប៊ិន ហៅ សុខា, ប្រធានសេដ្ឋកិច្ចពេទ្យស្រុកស្នួល], 12918 [អ៊ុន គឹមហោ, សមាជិកគណៈឃុំ១០០], 12919 [ឃួន គឹមស៊ុត (Khuon Kim Sut)], 12920 [ចៃ ច្រឹក ហៅ សម្បត្តិ], 12921 [កែ ផុន], 12922 [ម៉ី គឿន ហៅ ស៊ីថា], 12923 [គួប ហ៊ីម], 12924 [យុន គេង, ប្រធានក្រុមភ្ជួរឃុំសំបុក], 12925 [ទុយ សៀន, ប្រធានកងតូច], 12926 [ចាន់ យឿន, ប្រធានកងតូច]។ ឯកសារ D1.3.28.146 ឈ្មោះអ្នកទោស ខែធ្នូ ឆ្នាំ១៩៧៨ KH ERN 00086833-34 [លេខរៀងពី១-២២ ក្នុងបញ្ជីឈ្មោះអ្នកទោសផ្នែកតំបន់៥០៥]។

2127 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 13981-13986។

551. ជារួម ផ្អែកតាមការរៀបរាប់លម្អិតខាងលើ យ៉ាងហោចណាស់មានអ្នកទោស ៧០៦ នាក់ត្រូវបានបញ្ជូនមកមន្ទីរ ស-២១ ពី ឬដោយអង្គការកម្ពុជាប្រជាធិបតេយ្យដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ **មាស មុត** ដូចជា កម្មាភិបាល ៦៧ នាក់មកពីកងពលធំលេខ ១៦៤ ឬអតីតកងពលធំលេខ ៣ មកពីភូមិភាគនិរតី កម្មាភិបាល ២ នាក់មកពីកងពលធំលេខ ១ និងលេខ ២ មនុស្ស ៣២ នាក់មកពីខេត្តក្រចេះ (កងពលធំលេខ ១១៧ និងតំបន់ ៥០៥ ដោយមិនរាប់បញ្ចូលគិញវៀតណាម ៦ នាក់ដែលត្រូវបានចាប់ខ្លួននៅខេត្តក្រចេះ) ជនជាតិវៀតណាម ឬខ្មែរក្រោម ១៩៤ នាក់ (រួមទាំង គិញវៀតណាម ៦ នាក់ដែលត្រូវបានចាប់ខ្លួននៅខេត្តក្រចេះ) ជនជាតិថៃ ៥៨ នាក់ និងពួកបស្ចិមប្រទេស ៨ នាក់ដែលត្រូវបានចាប់ខ្លួននៅសមុទ្រ ឬដីគោក អតីតទាហាន ឬមន្ត្រីរដ្ឋការ លន់ នល់ ២១ នាក់ពីក្រុងកំពង់សោម ពលរដ្ឋនៅកំពង់សោម ៧៣ នាក់ និងកម្មករកំពង់ផែកំពង់សោម ២៥១ នាក់[2128]។

552. លើសពីនេះទៀត ដូចការបញ្ជាក់ក្នុងកំណត់ហេតុកិច្ចប្រជុំរបស់លេខាកងពលនៃកងទ័ពបដិវត្តន៍កម្ពុជាដែលមានវត្តមានរបស់គាត់[2129] **មាស មុត** បានចូលរួមក្នុងគោលដៅផែនការឧក្រិដ្ឋកម្មរួមក្នុងការបោសសម្អាត (ចាប់ខ្លួន ឃុំខ្លួន និងជាទូទៅសម្លាប់ដោយគ្មានដំណើរការផ្លូវច្បាប់) កងពលទាំងអស់ក្នុងកងទ័ពបដិវត្តន៍កម្ពុជា កងវរសេនាធំឯករាជ្យ និងអគ្គសេនាធិការដែលស្ថិតក្រោមការសង្ស័យរបស់ ប.ក.ក ពាក់ព័ន្ធនឹងការមិនស្មោះត្រង់នឹងនយោបាយ។ ដូចការរៀបរាប់ខាងលើ **មាស មុត** មានការពាក់ព័ន្ធយ៉ាងច្រើនក្នុងផែនការនេះ ហើយគាត់ពិតជាបានយល់ និងមានបំណងចាប់ខ្លួន ឃុំខ្លួន និងសម្លាប់មនុស្សជាច្រើនមកពីកងពលផ្សេងទៀត នៅមន្ទីរ ស-២១ និងមន្ទីរសន្តិសុខ

---

2128 សូមមើលឧបសម្ព័ន្ធ D.1-D.10។

2129 ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខា និងវរៈសេនាធំឯករាជ ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦ KH ERN 00052411 [កំណត់ត្រាថា មាស មុត "យល់ព្រមឯកភាព"ជាមួយបក្សទាំងស្រុង លើតម្រូវការក្នុងការកំណត់ និងកំចាត់ "សមាសភាពមិនល្អ ឬខ្មាំង"ប្រឆាំងបដិវត្តដែល"នៅតែពួនបន្លំ បង្កប់ក្នុងជួរបានទៀត"]។ ឯកសារ D1.3.27.26 កំណត់ហេតុនៃការប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា និងអនុលេខា កងពលនិង វរៈសេនាធំឯករាជ ថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៧។ សូមមើល ឯកសារ D1.3.34.60 ទូរលេខរបស់មុត (មាស មុត) ជូន ម. ៨៧០ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ KH ERN 00001325 [ប្តេជ្ញាថា "ឯកភាពទាំងស្រុង" ជាមួយបក្ស និង "[បោស] សំអាតគ្មានស្នាក់ស្នើរ សមាសភាពបង្កប់របស់ខ្មាំង"]។

ផ្សេងទៀតរបស់កងទ័ពបដិវត្តន៍កម្ពុជា[2130]។ ក្នុងនាមជាសមាជិកម្នាក់ក្នុងសហឧក្រិដ្ឋកម្មរួម **មាស មុត** ត្រូវទទួលខុសត្រូវលើអ្នកទោសប្រហែល ៤.៨០០ នាក់ផ្សេងទៀតក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជាដែលត្រូវបានបញ្ជូនមកមន្ទីរ ស-២១[2131]។

## ៥. ឧក្រិដ្ឋកម្ម

### ការដាក់ពន្ធនាគារ និងការឃុំឃាំងដោយខុសច្បាប់

*ក) ការដកហូតសេរីភាពបុគ្គលដែលបានបញ្ជូនទៅមន្ទីរ ស-២១*

553. អ្នកទោសដែលបានចូលក្នុងមន្ទីរស-២១ ត្រូវបានដាក់ខ្នោះដៃ និងបិទមុខ[2132] និងស្ថិតនៅសភាពដូចនេះដដែល ខណៈពេលចុះឈ្មោះ[2133] បន្ទាប់មកត្រូវបានពួកឆ្មាំយកទៅកាន់បន្ទប់ឃុំឃាំង និងដាក់

---

[2130] សូមមើល ឧទាហរណ៍ ឯកសារ D1.3.27.26 កំណត់ហេតុនៃការប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា អនុលេខា កងពល និងវរៈសេនាធំឯករាជ ថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៧ KH ERN 00052304 [ ម៉េត លេខាកងពល៥០២៖ "ពួកមិនល្អ បានបញ្ជូនទៅ ស.២១ ជាង៥០នាក់"], KH ERN 00052307 [យ៉ាន ប្រធានថ្មីកងពល៤៥០៖ "សមាសភាព ត្រូវដកប្រហែល ៦០០ នាក់"]។ ឯកសារ D1.3.27.20 កំណត់ហេតុនៃការប្រជុំយោធារបស់កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំ លេខានិងអនុលេខា និងវរៈសេនាធំឯករាជ ថ្ងៃទី ៩ ខែតុលា ឆ្នាំ១៩៧៦ KH ERN 00052404 [សាន អនុកងពល ៥០២៖ "បានដកសមាសភាពនិន្នាការនយោបាយជាង៨០នាក់ហើយ"], KH ERN 00052408 [សុខ លេខាកងពល១៧០៖ "កងពល១៧០ បានសំរិតសំរាំងពួកមិនល្អទុកមួយកន្លែង ចំនួន៧០នាក់"]។

[2131] បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស (D114/230.1.1) កំណត់អត្តសញ្ញាណចំនួនអ្នកទោសខាងក្រោមនេះជាអ្នកទោស"ចាប់ខ្លួនពី"កងពល កងវរសេនាធំ និងមន្ទីរផ្សេងដែលមានកងទ័ពបដិវត្តកម្ពុជា និងថ្នាក់ដឹកនាំរបស់ខ្លួនដែលបានចូលរួមជាមួយ មាស មុត ក្នុងការប្រជុំរបស់លេខាកងពល៖ កងពល១៧០ – អ្នកទោស ស-២១ ចំនួន៤០៣ នាក់; កងពល២៩០ – អ្នកទោសចំនួន៤៤១ នាក់; កងពល៣១០ – អ្នកទោសចំនួន១១១៧ នាក់; កងពល៤៥០ – អ្នកទោសចំនួន៥០៩ នាក់; កងពល៥០២ – អ្នកទោសចំនួន៣៥៧ នាក់; កងពល៧០៣ – អ្នកទោសចំនួន៦៧៦ នាក់; កងពល៨០១ –អ្នកទោសចំនួន៣៥ នាក់; កងពល៩២០ – អ្នកទោសចំនួន៣៩៥ នាក់; កងវរសេនាធំ១៥២ – អ្នកទោសចំនួន២៩១ នាក់; កងវរសេនាធំ៣៧៧ – អ្នកទោសចំនួន៥៣ នាក់; កងវរសេនាធំ៤៨៨ – អ្នកទោសចំនួន៧៧ នាក់; អគ្គសេនាធិការ – អ្នកទោសចំនួន៤៥៣ នាក់។

[2132] ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.12.38-14.15.05 KH ERN 01247390-01247391។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.38.08-09.41.59 KH ERN 01249351-01249353។ឯកសារ D98/3.1.212 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 09.56.38-10.03.42 KH ERN 00355298-00355301។ ឯកសារ D234/2.1.115 ហ៊ឹម ហ៊ុ

ខ្នោះជើង[2134]។ ដូចដែលបានរៀបរាប់លម្អិតនៅក្នុងផ្នែក អំពើអមនុស្សធម៌ដទៃទៀត ខាងក្រោម អ្នកទោសស្ថិតក្នុងសភាពជាប់ខ្នោះជើងជាអចិន្ត្រៃយ៍ នៅក្នុងបន្ទប់ឃុំឃាំងរបស់ខ្លួនគ្រប់ពេលវេលា

---

យ ប្រតិចារឹក ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.52.42-15.55.34 KH ERN 01252066-67។ ឯកសារ D98/3.1.54 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 09.59.38-10.03.44 KH ERN 00354119-00354121 ,ម៉ោង 10.12.57 KH ERN 00354124,ម៉ោង 10.18.48-10.21.22 KH ERN 00354125-00354126។ ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.56.43-09.58.38 KH ERN 01246984។ ឯកសារ D98/3.1.93 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.19.09 KH ERN 00341901-05 ["មនុស្សដែលទៅទទួលពីខាងក្រៅ [...] មានខ្នោះជើងមួយទៅ ខ្នោះដៃខ្លះ ហើយប្រហែលជាសំពត់រុំមុខមួយផងខ្លះទៀត"]។ ឯកសារ D4.1.1115 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00146659។ឯកសារ D98/3.1.313 វ៉ាន់ ណាត់ ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.49.08-09.59.07 KH ERN 00347843-00347846។ ឯកសារ D4.1.388 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ណាត KH ERN 00163716 ["គេដាក់ខ្នោះដៃជាប់គ្នាពីរនាក់ៗ រួចដោះខ្នោះជើង [...] រួចគេចងភ្នែក យកខ្សែមកច្រកក ដឹកចូលទៅ (រូបទី៦)"]។ ឯកសារ D1.3.32.21 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គក ស្រស់ KH ERN 00186798។ ឯកសារ D10.1.29 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស ប៉េងគ្រី KH ERN 00163701 [រៀបរាប់ពីការដឹកអ្នកទោសពីបាត់ដំបងទៅស ២១៖ "អ្នកទោសគឺសុទ្ធតែគេចងស្លាបសេក និង ចងមុខ [...] ខ្ញុំដឹកចូលមកដល់ត្រឹមមាត់ច្រក ហើយមានកងការពារគេមកយកអ្នកទោសចូលទៅក្នុងគុក"]។ឯកសារ D114/37.1.2 OCIJ កំណត់ហេតុនៃការចុះស៊ើបអង្កេតដល់កន្លែងកើតហេតុ របស់ ក.ស.ច.ស EN 00198000-01។

2133 ឯកសារ D234/2.1.119 សួស ធី ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 14.06.34 KH ERN 01307589 ["ទាំងខ្នោះ ទាំងបិទមុខអស់ហើយ [...] ហើយមកដល់ខ្ញុំ"]។ឯកសារ D98/1.2.9 សួស ធី ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 14.26.33 KH ERN 00356755។

2134 ឯកសារ D234/2.1.119 សួស ធី ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 14.09.14-14.12.10 KH ERN 01307590។ ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.23.23-14.25.35 KH ERN 01247394។ ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.00.18 KH ERN 01246985 [បញ្ជាក់ថា បន្ទាប់ពីការសួរចម្លើយរួច គាត់ត្រូវបានគេ "បញ្ចូលក្នុង" បន្ទប់ ហើយ "ដាក់ខ្នោះជើង"]។ ឯកសារ D98/3.1.54 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.12.57 KH ERN 00354124។ឯកសារ D1.3.32.22 កិច្ចសម្ភាសន៍ គក ស្រស់ EN 00164564។ ឯកសារ D4.1.388 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ណាត KH ERN 00163716 ["ពេលថតហើយគេចងមុខខ្ញុំវិញ ហើយនាំទៅខាងលើអគារ D សព្វថ្ងៃ រួចគេដាក់ខ្នោះរួមវែង"]។ ឯកសារ D4.1.386 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ហាន KH ERN 00163674 ["ខ្ញុំជាអ្នកនាំអ្នកទោសទៅដាក់ក្នុងបន្ទប់ រួចដោះក្រណាត់ចងមុខ និងដាក់ខ្នោះជើង ហើយបានដោះខ្នោះដៃ"]។

ដែលពួកគេស្ថិតក្នុងបរិវេណមន្ទីរស-២១ លើកលែងតែពេលដែលពួកគេត្រូវបាននាំទៅសួរចម្លើយ ឬសម្លាប់ចោលប៉ុណ្ណោះ។

554. មន្ទីរស-២១ ជាធម្មតាដាក់អ្នកទោសបានចំនួនពី ១.០០០ ទៅ ១៥០០ នាក់[2135]។ អ្នកទោសត្រូវបានឃុំឃាំងនៅក្នុងអគារសិក្សាដែលមានកម្ពស់បីជាន់ ស្ថិតក្នុងបរិវេណមន្ទីរស-២១ នោះ។ អគារ ខ អគារ គ និងអគារ ឃ ត្រូវបានប្រើសម្រាប់ឃុំឃាំងអ្នកទោសធម្មតា[2136] និងមានបន្ទប់ឃុំឃាំងធំ និងតូច ដែលមានទំហំតែ ២ គុណនឹង ១,៥ ម៉ែត្រប៉ុណ្ណោះ[2137]។ កម្មាភិបាលជាន់ខ្ពស់នៃបក្ស

---

[2135] ឯកសារ D114/35.3 សៀវភៅនិពន្ធដោយលោក ដេវីដ ឆាណ្ឌល័រ៖ សម្លេងពីមន្ទីរ-២១ EN ERN 00192714 ["ចំនួនអ្នកទោសនៅមន្ទីរ ស-២១ មានភាពខុសគ្នា ដោយឆ្លុះបញ្ចាំងពីការកើនឡើង និងថយចុះនៃការបោសសម្អាត ដែលបានរីករាលដាលយ៉ាងលឿនក្នុងកម្ពុជាប្រជាធិបតេយ្យចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៦ [...] សមត្ថភាពអតិបរមារបស់គុកនេះ ដែលបានកើនឡើងលើសចំណុះក្នុងឆ្នាំ១៩៧៧ គឺអាចដាក់អ្នកទោសបានប្រមាណ១៥០០០ នាក់ច្រើនបំផុត"]។

[2136] ឯកសារ D98/3.1.82 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ ម៉ោង 11.27.08 KH ERN 00325353-00325354 ["អគារ C, D, ហើយនិង B ជា [...] អគារឃុំឃាំង"]។ ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.23.23 KH ERN 01247394 ["នៅកន្លែងឃុំខ្លួនអ្នកទោសនោះគឺមានអគារចំនួន អគារធំៗចំនួនបី"]។ ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.44.06 KH ERN 01246993 [ជាប់ឃាំងនៅអគារ C]។ ឯកសារ D234/2.1.115 ហ៊ីម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.04.42-15.08.02 KH ERN 01252052-53។ ឯកសារ D114/37.1.2 កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ របស់ ក.ស.ច.ស EN 00198000-02, 00198005-06។

[2137] ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.25.35 KH ERN 01247394-01247395 [អគារឃុំឃាំងគឺមានបន្ទប់តូចៗមួយៗម្នាក់ និងបន្ទប់ធំវាល]។ ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.00.18 KH ERN 01246985 [បន្ទប់ដែលឃុំឃាំងគាត់ដំបូង គឺប្រហែលជាមួយម៉ែត្រកន្លះបួនជ្រុង], ម៉ោង 10.44.06-10.46.19 KH ERN 01246993-01246994 [ក្រោយពីឃុំឃាំងក្នុងបន្ទប់តូច គាត់ផ្លាស់ទៅ "បន្ទប់ធំ"នៅអគារ សេ ដែលមានអ្នកទោសផ្សេងទៀតប្រហែល៤០នាក់]។ ឯកសារ D234/2.1.107 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.48.39-10.00.06 KH ERN 01247070-01247073។ ឯកសារ D98/3.1.34 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 14.18.22-14.20.56 KH ERN 00347975-00347976។ ឯកសារ D234/2.1.116 ហ៊ីម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 09.27.52-09.32.45 KH ERN 01297757-01297759។ ឯកសារ D114/37.1.2 កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ របស់ ក.ស.ច.ស KH ERN 00181341 [វ៉ាន់ ណាត ជាប់ឃុំនៅក្នុងបន្ទប់ធំមួយនៅ"ជាន់ផ្ទាល់ដីនៃអគារ D" ដែល "ចំនួនអ្នកទោសប្រែប្រួលទៅតាមថ្ងៃពី ៤០ ទៅ ៦០នាក់"]។ ឯកសារ D4.1.344 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច មាន KH ERN 00162774 ["អគារខាងជើងនៅជាន់កណ្តា

កុម្មុយនីស្តកម្ពុជា ជនបរទេស និងអ្នកទោសជនជាតិវៀតណាម ត្រូវបានបញ្ជូន និងឃុំឃាំងនៅមន្ទីរឃុំឃាំងពិសេស[2138] ដែលដំបូងមានទីតាំងស្ថិតក្នុងផ្ទះនាភាគខាងត្បូងនៃបរិវេណមន្ទីរ ប៉ុន្តែក្រោយមកនៅក្នុងអគារ ក (ដែលត្រូវបានប្រើសម្រាប់ការសួរចម្លើយផងដែរ)[2139]។ បញ្ជីឈ្មោះនៃ

---

លមានបន្ទប់ធំៗគេដាក់អ្នកទោស ហើយដាក់ខ្នោះជើងដែកវែង អគារកណ្តាលគេធ្វើបន្ទប់តូចៗទាំងជាន់កណ្តាល និងជាន់ក្រោម"]។

2138 ឯកសារ D98/1.2.18 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ ម៉ោង 15.51.31KH ERN 00793489 ["អ្នកទោសសំខាន់មកដល់ គេទុកនៅនឹងគុកពិសេស"]។ ឯកសារ D98/3.1.85 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ម៉ោង 15.37.56 KH ERN 00326126-00326127 [អ្នកទោសល្បើយសឹកវៀតណាម និងជនបរទេស ជាប់ឃុំ និងត្រូវសួរចម្លើយនៅគុកពិសេស]។ ឯកសារ D98/1.2.19 កាំង ហ្គេក អ៊ាវ ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១២ ម៉ោង 09.16.33 KH ERN 00794026។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.11.06-10.32.38 KH ERN 01249362-01249364។ ឯកសារ D234/2.1.117 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 10.06.59-10.30.27 KH ERN 01301881-82 [កន្លែងហ្នឹងដាក់អ្នកធំៗ ដាក់កន្លែងហ្នឹង]។ ឯកសារ D234/2.1.118 សួស ធី ប្រតិចារឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 11.06.08-11.09.10 KH ERN 01307492,ម៉ោង 15.31.45-15.35.24 KH ERN 01307528។ឯកសារ D98/1.2.9 សួស ធី ប្រតិចារឹក ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 14.37.26 KH ERN 00356758-00356759 ["អ្នកទោសសំខាន់ៗគឺគេដាក់ដោយឡែក [...] គុកពិសេសគេតែម្តង"], ម៉ោង 14.40.53 KH ERN 00356759-00356760 ["អ្នកទោសបស្ចិមប្រទេសគឺ [...] យកទៅដាក់គុកពិសេសហ្នឹងតែម្តង"]។ ឯកសារ D54/6.1.24 សួស ធី ប្រតិចារឹក ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.00.15 KH ERN 00356901។ ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.25.35 KH ERN 01247394-01247395 ["ចំពោះអ្នកទោសដែលធំពិសេសនោះគឺបើនិយាយឲ្យចំទៅ គេមិនចង់អ្នកដែលដទៃ អ្នកកងការពារ ឬឃើញចំពោះអ្នកធំ ដែលជាប់ទោសនៅកន្លែងហ្នឹង"]។

2139 ឯកសារ D98/3.1.82 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ ម៉ោង 11.27.08 KH ERN 00325353។ ឯកសារ D98/3.1.85 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ម៉ោង 15.37.56 KH ERN 00326126-00326127 [គុកពិសេសផ្លាស់ទៅ អគារ អា "ចុងកណ្តាលឆមាសទីពីរ១៩៧៨"]។ ឯកសារ D234/2.1.117 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 10.33.31-10.36.33 KH ERN 01301883-84។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.11.06-10.32.38 KH ERN 01249362-01249364។ ឯកសារ D234/2.1.118 សួស ធី ប្រតិចារឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 11.06.08-11.09.10 KH ERN 01307492។ ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 11.44.37-11.47.57 KH ERN 00347870-00347871។ ឯកសារ D234/2.1.107 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.58.37 KH ERN 01247072-01247073 [គាត់ត្រូវបានសួរចម្លើយនៅអគារ អា]។ ឯកសារ D4.1.247 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ម ណៃ KH ERN 00164386

មន្ទីរស-២១ បញ្ជាក់ថា កម្មាភិបាលជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជាដែលត្រូវបានឃុំឃាំងនៅមន្ទីរឃុំឃាំងពិសេសនោះ រួមមានទាំងអ្នកទោសមួយចំនួន ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ **មាស មុត**[2140] ដូចដែលបានពិភាក្សានៅក្នុងផ្នែកខាងដើម។

555. បរិវេណមន្ទីរឃុំឃាំងនោះត្រូវបានហ៊ុំព័ទ្ធដោយរបងស័ង្កសីពីខាងក្រៅ[2141] និងរបងដែកបន្ទះពីខាងក្នុង "ដែលគ្របដណ្តប់ដោយលួសបន្លា"[2142]។ របងមន្ទីរឃុំឃាំងមួយក្នុងចំណោមនោះត្រូវបាន

---

["អគារខាងត្បូងចន្លោះផ្លូវ ១១៣, ៣៦០, ១៤៣ និង៣៥០ គឺជាកន្លែងសួរចម្លើយអ្នកទោសពិសេសដូចជា [វ៉ន] វ៉េត"]។

2140 សូមមើល ឧទាហរណ៍ ឯកសារ D1.3.28.137 ផ្នែកគុកពិសេស បញ្ជីឈ្មោះអ្នកទោស ស-២១ ដែលបានសួរចម្លើយហើយនៅគុកស-២១ KH ERN 00086822-00086823 លេខរៀងទី៤ [ឈឹម ខុន អនុលេខាតំបន់៥០៥],ទី ៦ [ស្វាយ ណូញ ប្រធានមន្ទីរកងពល១១៧],ទី ៨ [រ័ត្ន លាង អនុលេខាកងពល១១៧], ទី១៥ [មាស មឿន លេខាតំបន់៥០៥], ទី១៨ [ឃុន រុំ លេខាកងពល១១៧]។

2141 ឯកសារ D234/2.1.118 សួស ធី ប្រតិចារឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 10.55.21 KH ERN 01307489-01307490 ["នៅវិទ្យាល័យពញាយ៉ាតហ្នឹងមានរបងពីរជាន់ [...]បើរបងនៅខាងក្រៅគឺមានតែស័ង្កសីទេ"]។ ឯកសារ D234/2.1.117 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.13.11-15.16.11, 15.22.58-15.26.26 KH ERN 01301927-30 [សំដៅលើ"របងធ្វើពីស័ង្កសី"]។ ឯកសារ D234/2.1.111 ឡាច មាន ប្រតិចារឹក ថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១៦ ម៉ោង 13.48.18 KH ERN 01249302-01249303 ["របងលួស" នៅតាមផ្លូវខាងក្រៅស ២១ គឺ "នៅខាងក្រៅពីអគារហ្នឹងប្រហែលជាតែ៥០ម៉ែត្រហ្នឹង"]។ ឯកសារ D234/2.1.113 ប្រាក់ ខនប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 13.49.08 KH ERN 01249468-01249469 [រៀបរាប់អំពីរបង "ស័ង្កសី" នៅ"បរិវេណខាងក្រៅ"]។

2142 ឯកសារ D234/2.1.111 ឡាច មាន ប្រតិចារឹក ថ្ងៃទី ២៦ ខែមេសា ឆ្នាំ២០១៦ ម៉ោង 13.48.18 KH ERN 01249302-01249303 [រៀបរាប់អំពីរបងខាងក្នុង "ហ៊ុមព័ទ្ធរបងលួសក្នុងអគារ"]។ ឯកសារ D234/2.1.109 តយ តេង ប្រតិចារឹក ថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.59.00 KH ERN 01247305 ["របងព័ទ្ធជុំវិញដោយមានលួសបន្លា និងបាំងដោយស័ង្កសីព័ន្ធជុំវិញហ្នឹង"]។ ឯកសារ D234/2.1.118 សួស ធី ប្រតិចារឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 10.55.21 KH ERN 01307489-01307490 [រៀបរាប់អំពីរបងខាងក្នុង"ហ៊ុមព័ន្ធជុំវិញ" ជា "របងបន្លាលួស ហើយមានស័ង្កសីអ៊ែភ្ជិតទៀត"]។ ឯកសារ D234/2.1.117 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.13.11-15.16.11 KH ERN 01301927-28។ ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 14.38.22 KH ERN 00347897-00347898 ["ក្រោយអគារ B និងអគារ នេះគឺមានរបងលួសបន្លា"]។ ឯកសារ D114/35.3 សៀវភៅនិពន្ធដោយលោក ដេវីដ ឆាណ្ឌល័រ៖ សម្លេងពីមន្ទីរ-២១ EN 00192681 ["ទីតាំងស្ងប់ស្ងាត់ មានក្លិនស្អុយ ហ៊ុំព័ទ្ធដោយរបងស័ង្កសីមានបន្លាលួសពីលើ"]។ ឯកសារ D114/37.1.3 [រូបថតបង្ហាញពីផ្នែកខាងក្នុងនៃរបងស័ង្កសីមានបន្លាលួសពីលើ]។

ដាក់អគ្គិសនីសម្រាប់ឆក់[2143]។ អ្នកជាប់ឃុំក៏ត្រូវបានរារាំងមិនឲ្យរត់គេចផងដែរដោយអ្នកយាមបីកម្រិត[2144] ដែលត្រូវបានចាត់ឲ្យល្បាតនៅក្នុងមន្ទីរឃុំឃាំង[2145] នៅខាងក្រៅជញ្ជាំងនៃបរិវេណ[2146]

---

[2143] ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 14.38.22 KH ERN 00347897-00347898["របងហ្នឹងគឺមានអគ្គិសនី"]។ ឯកសារ D1.3.32.22 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គក ស្រស់ KH ERN 00241949 ["បើសិនជារឿងនេះកើតឡើងនៅពេលយប់ គាត់នឹងត្រូវឆក់របងខ្សែភ្លើងអគ្គិសនីដែលបានបើកនៅពេលម៉ោង ៦ ល្ងាចដល់ម៉ោង៦ព្រឹក"]។ ឯកសារ D114/37.1.68 សៀវភៅនិពន្ធដោយ វ៉ាន់ ណាត មានចំណងជើងថា៖ គំនូរគុកមួយរបស់កម្ពុជា EN 00396875 [រៀបរាប់អំពីការត្រឡប់ទៅគុកទួលស្លែងវិញក្នុងខែសីហា ឆ្នាំ១៩៧៩៖ "អ្វីៗមានសភាពដូចពីមុនទាំងអស់ [...] របងអគ្គិសនីធ្វើពីស័ង្កសី និងបន្លាលួស គឺនៅដូចដើមនៅឡើយ"]។

[2144] ឯកសារ D234/2.1.115 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.04.42 KH ERN 01252052 ["គេចាត់កម្លាំងជាក្រុម ជាកង [...] ឲ្យយាម មានយាមខាងក្នុង មានយាមខាងក្រៅ"]។ ឯកសារ D1.3.32.17 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹម ហ៊ុយ KH EN 00146644។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.21.41-11.25.00 KH ERN 01249377-01249378។ ឯកសារ D4.1.343 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចៀម សឿ KH ERN 00162762 ["ស៖តើមានអ្នកទោសរត់រួចទេ?ឆ៖គ្មានឃើញអ្នករត់រួចទេ ព្រោះអ្វីខាងក្នុងនោះយាមបីជាន់ហើយ"]។ ឯកសារ D4.1.386 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ហាន KH ERN 00163673-74។ ឯកសារ D98/3.1.83 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ម៉ោង 10.06.30 KH ERN 00325490-00325491 ["អ្នកកងការពាររបស់ មិត្តប៉េង យាមនៅខាងក្នុងកងពិសេសរបស់មិត្តហ៊ុយ នៅខាងក្រៅ"]។

[2145] ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.01.43-15.04.30 KH ERN 01247400។ ឯកសារ D4.1.344 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច មាន KH ERN 00162773 ["ខ្ញុំជាកងការពារដែរ ការពារអ្នកទោសនៅតាមបន្ទប់"]។ ឯកសារ D4.1.383 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខៀវ ចេស ហៅ ពៅ KH ERN 00163638-39។ ឯកសារ D114/37.1.66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉េប ហ៊ូ KH ERN 00162683-00162684 ["យាមខាងក្នុង [...] ៥ក្រុមយាមពីម៉ោង៦-១១ ហើយបាន៥ក្រុមទៀតយាមបន្តទៀតទល់ពេលល្ងាច"]។ ឯកសារ D4.1.380 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆែម ឈិន KH ERN 00163787-88។ ឯកសារ D98/3.1.29 ឈុន ផល ប្រតិចារឹកថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ 09.57.50 KH ERN 00362751។ ឯកសារ D1.3.32.9 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុន ផល KH ERN 00163808 ["ខ្ញុំយាម [...] នៅអគារ [...] វេនយាមមានបួនវេន ហើយក្នុងមួយថ្ងៃមួយយប់ ម្នាក់យាមពីរវេនឆ្លាស់គ្នា"]។

[2146] ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.29.42 KH ERN 01249349-01249350 ["សកម្មភាពប្រចាំគឺយាម បើកច្រកចេញចូល និងការពារមើលខ្លាចមានអ្នកផ្សេងចូលមកក្នុងបរិវេណស.២១"]។ ឯកសារ D234/2.1.110 តយ តេង ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.10.45 KH ERN 01247341-01247342 [សាក្សីគឺនៅចម្ងាយ២០០-៣០០ ម៉ែត្រ ពីអគារស ២១ "ផ្លូវហ្នឹងចំមាត់

និងនៅបរិវេណក្បែរៗខាងជុំវិញមន្ទីរឃុំឃាំង[2147]។ ជាលទ្ធផលនៃវិធានការសន្តិសុខទាំងនេះ ស្ទើរតែគ្មាននរណាម្នាក់ធ្លាប់អាចរត់គេចផុតពីមន្ទីរស-២១ នេះបាន[2148]។

*ខ) កង្វះដំណើរការនីតិវិធីផ្លូវច្បាប់ត្រឹមត្រូវ*

556. មិនមានដំណើរការនីតិវិធីត្រឹមត្រូវ ឬដំណើរការផ្លូវច្បាប់ណាមួយឡើយ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ការសម្រេចឲ្យចាប់ខ្លួន និងឃុំឃាំងមនុស្សក្នុងមន្ទីរស-២១ ត្រូវបានធ្វើឡើងតាមបំណងរបស់អ្នកទាំងឡាយណាដែលមានអំណាច ដូចជា **មាស មុត** ជាដើម ដោយគ្មានការចូលរួម ឬការត្រួតពិនិត្យមើលពីសំណាក់ស្ថាប័នតុលាការណាមួយឡើយ។ បុគ្គលទាំងឡាយជា

---

ទ្វារចូលទៅក្នុងមន្ទីរធំ អគារធំហ្នឹង"]។ ឯកសារ D4.1.379 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តយ តេង KH ERN 00163776-77។ ឯកសារ D98/3.1.83 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ម៉ោង 10.11.22 KH ERN 00325491-00325492 ["កងពិសេសមានភារកិច្ចប្រាំមួយយ៉ាង។ ភារកិច្ចទីមួយ គឺយាមការពារនៅខាងក្រៅ"]។ ឯកសារ D1.3.32.17 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹម ហ៊ុយ KH ERN 00146645។ឯកសារ D1.3.32.22 កិច្ចសម្ភាសន៍ គក ស្រស់ KH ERN 00241949["នៅក្នុងក្រុមរបស់ខ្ញុំមានចំនួន១០០នាក់ [...] ពួកគេបានចាត់តាំង ពួកយើងម្នាក់ៗឲ្យយាមបរិវេណ៥ម៉ែត្រការ៉េ និងមិនឲ្យយើងអង្គុយចុះទេ"]។ឯកសារ D1.3.32.9 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុន ផល KH ERN 00163808-09។

2147 ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.12.30-15.16.21 KH ERN 01297815-01297816។ ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.08.41 KH ERN 01249427-01249428 [រៀបរាប់អំពីសម័យដែលគាត់ "នៅការពារខាងក្រៅក្បែរឡានទឹក"]។ ឯកសារ D4.1.387 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន ហេង KH ERN 00163687 ["ខ្ញុំយាមប្រចាំការនៅតាមផ្ទះខាងលិចឈាងខាងត្បូងទួលស្លែង ដែល [...] មានអ្នកទោសគេដាក់"]។ឯកសារ D4.1.343 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចៀម សឿ KH ERN 00162761-62, 00162762-63។

2148 ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.24.32 KH ERN 01297818-01297819 [សាក្សី ដឹងថាមានករណីតែម្តងទេដែលអ្នកទោសម្នាក់រត់រួចពីស ២១]។ ឯកសារ D234/2.1.119 សួស ធី ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 11.02.28 KH ERN 01307572 [សាក្សីដឹងអំពីករណីមួយដែលអ្នកទោសម្នាក់រត់រួច]។ ឯកសារ D4.1.343 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចៀម សឿ KH ERN 00162762-63។ ឯកសារ D114/277.9 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.23.35 KH ERN 01323534-01323535 [គោលបំណងទី១ នៃការហ៊ុមរបងនៅមន្ទីរស ២១ គឺ "ទប់ទល់អាការដែលអ្នកទោសរត់រួច"]។ ឯកសារ D98/3.1.93 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 11.45.22 KH ERN 00341916-00341919 ["ករណីរត់រួចមានតែម្តងគត់ទៅដល់អង្គភាព ម្ចាស់អង្គភាពគេចាប់បញ្ជូនមកស ២១ វិញគឺអង្គភាពពួក ១៧០ នេះម្តង"]។

ញឹកញាប់ត្រូវបានចាប់ខ្លួនដោយផ្អែកតែលើចម្លើយសារភាព ដែលបានមកដោយការធ្វើទារុណកម្ម ដែលរាយជាបញ្ជីឈ្មោះដ៏វែងនៃអ្នកដែលត្រូវបានសន្មតថាជាជនក្បត់ ឬជាខ្មាំងរបស់របបនោះតែប៉ុណ្ណោះ[2149]។ *ដោយមិន*គិតថាតើអ្នកទោសទាំងនោះត្រូវបានចាប់បញ្ជូនទៅមន្ទីរស-២១ យ៉ាងណាឡើយ ពួកគេមិនត្រូវបានជូនដំណឹងអំពីសិទ្ធិ ឬបទចោទប្រកាន់ប្រឆាំងនឹងខ្លួនឡើយ ឬសូម្បីតែពីមូលហេតុនៃការចាប់ខ្លួនក៏គ្មានដែរ[2150]។ ពួកគេក៏មិនត្រូវបានផ្តល់សិទ្ធិឱ្យតវ៉ាប្រឆាំងនឹងការចាប់

---

[2149] ឯកសារ D98/3.1.93 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.18.09 KH ERN 00341901-05 ["ការចាប់ខ្លួនដែលពឹងផ្អែកទៅលើសេចក្តីសារភាពរបស់អ្នកដទៃ"]។ ឯកសារ D1.3.33.5 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00146573-74។ ឯកសារ D4.1.191, D114/37.1.7 ចម្លើយរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ទៅនឹងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា, ថ្ងៃទី៤-៦ ខែឧសភា ឆ្នាំ១៩៩៩ EN 00185023 ["គោលបំណងនៃការយកចម្លើយសារភាព គឺដើម្បីអាចឱ្យថ្នាក់លើយកទៅវិភាគ និងរកពួកក្បត់ [...] ដើម្បីឱ្យថ្នាក់លើអាចតាមដានរកខ្សែពួកក្បត់"]។ ឯកសារ D4.1.406 សេចក្តីអត្ថាធិប្បាយ និងចម្លើយជាលាយលក្ខណ៍អក្សររបស់ ឌុចចំពោះសំណួរសរសេរ KH ERN 00408229 ["ការងារស្នូលនៃមន្ទីរសន្តិបាលជំនាន់នោះ គឺបញ្ជូនចម្លើយសារភាពទៅថ្នាក់លើនេះឯង។ គឺចម្លើយសារភាពហ្នឹងហើយ ដែលខាងលើត្រូវការដើម្បីបង្កើនការសង្ស័យ បន្តការចាប់ចងកាប់សម្លាប់មនុស្សដែលជាសាច់ឯង ឈាមឯងទាំងងងឹតងងល់តទៅទៀត"]។ ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.49.58 KH ERN 01247413 ["យើងសួរចម្លើយដើម្បីរកខ្សែបណ្តាញ រកខ្សែដែលទាក់ទងខ្សែរយៈក្បត់"]។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែ មេសា ឆ្នាំ២០១៦ ម៉ោង 11.21.41 KH ERN 01249377-01249378 ["ការឆ្លើយដាក់ពីស ២១ ទៅ អាហ្នឹងវា គេត្រូវស្រាវជ្រាវតាមខ្សែបណ្តាញដែលឆ្លើយដាក់ហ្នឹង"]។ ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.40.02-10.44.06 KH ERN 01246991-92 [អ្នកទោសដែលរួចជីវិតនេះត្រូវគេសួរចម្លើយ និងធ្វើទារុណកម្មជាដដែលៗអំពីថាតើគាត់ជាប់ខ្សែខាងណា រហូតទាល់តែគាត់ឆ្លើយដាក់គេពាសទឹកពាសដី], ម៉ោង 13.44.05 KH ERN 01247011 ["[អ្នកសួរចម្លើយ] បង្ខំខ្ញុំឱ្យឆ្លើយដាក់គេដាក់ឯងអ៊ីចឹង"]។

[2150] ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 14.00.49 KH ERN 01297799-01297800 [ពេលត្រូវគេចាប់ខ្លួនបញ្ជូនទៅ ស ២១ គេមិនបានប្រាប់ពីសិទ្ធិទេ]។ ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.00.35 KH ERN 00348013-00348014 ["ខ្ញុំភ័យស្លន់ស្លោពេក ភ័យថាមិនដឹងរឿងអីគេចាប់មក ដល់អ៊ីចឹងវាភ័យមិនបានគិតគូរ មិនដឹងជាបានសរសេរ ឬមួយយ៉ាងម៉ាទេ ឬក៏ប្រវត្តិរូបគេផ្ញើមកមុនក៏មិនដឹង"], ម៉ោង14.11.53 KH ERN 00348051-00348052["ខ្ញុំមិនដឹងធ្វើបុណ្យអ្វីបានជួបប្រទះ [...] ប៉ុន្តែគេនិយាយចេញមកថា ហេស មិនដែលអង្គការភ្នែកម្នាស់មិនដែលចាប់មនុស្សមកភ្លើទេ"]។ ឯកសារ D55/8.1.5 ជិន ម៉េត ប្រតិចារឹក ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 14.25.19 KH ERN 00350408-00350409 ["ស៖គេបានប្រាប់ទេ ថាតើអ្នកស្រីមានកំហុសអ្វីឬក៏មានរឿងអ្វីបានជាគេចាប់? តើគេមានប្រាប់អំពីមូលហេតុនៃការចាប់ខ្លួនដែរឬទេ?ឆ៖គេអត់មានសួរ អត់មានប្រាប់ទេ"]។ ឯកសារ D54/6.1.21 ណាំ ម៉ុន ប្រតិចារឹក ថ្ងៃទី៩ ខែកក្កដា

ខ្លួន និងការដាក់ក្នុងមន្ទីរឃុំឃាំងរបស់ខ្លួនតាមរយៈយន្តការតុលាការណាមួយដែរ ព្រោះអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យមិនបានបង្កើតតុលាការ ក្រមព្រហ្មទណ្ឌ ឬដំណើរការនីតិវិធីផ្លូវច្បាប់ឡើយ[2151]។

---

ឆ្នាំ២០០៩ ម៉ោង15.30.25 KH ERN 00350752។ ឯកសារ D4.1.386 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ហាន KH ERN 00163675 [“ខ្ញុំមិនដឹងមូលហេតុអ្វីទេ”]។ ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.53.56 KH ERN 01246983-01246984 [ហ្នឹងគេយកខ្ញុំទៅទួលស្លែង គេកុហកខ្ញុំឱ្យទៅជួយធ្វើឡានគេនៅប្រទេសយៀកណាម]។ឯកសារ D234/2.1.107 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ម៉ោង11.12.36 KH ERN01247088-01247090 ។ ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.13.12 KH ERN 00347850-00347851[“គេ [អ្នកដែលចាប់គាត់] អត់បានប្រាប់ទេ”], ម៉ោង 11.47.57 KH ERN 00347871-00347873 [“អ្នកដែលមកជាមួយខ្ញុំដល់ស ២១ ភាគច្រើនគឺមិនដឹងរឿងៗរឿងថាខ្លួនឯងបានធ្វើអ្វីខុស បានត្រូវគេចាប់ខ្លួនគឺអត់ដឹងទាំងអស់គ្នា ធ្វើម៉េងម៉ង់ៗសួរគ្នារឿងអីៗដូចគ្នាអត់ដឹងទាំងអស់”]។

2151 ឯកសារ D234/2.1.118 សួស ធី ប្រតិចារឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 13.46.14 KH ERN 01307502-01307503[“ចំពោះសម័យនោះ គឺអ្នកដែលថ្មីមកដល់ គឺអត់មានចៅក្រមអត់មានអីណាមេធាវីណាមកជួយការពារក្តីទេ។ គឺគេចាប់មកគឺគេដាក់គុកហើយតែប៉ុណ្ណឹង។ អត់មានមូលហេតុអីដែលយើងថាត្រូវតវ៉ាបាន”]។ ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.23.23 KH ERN 01247394 [“ចំពោះអ្នកទោសជំនាន់នោះ អត់មានវិធីអីដើម្បីការពារខ្លួនគេទេ”]។ ឯកសារ D234/2.1.116 ហ៊ុម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៦ ម៉ោង14.07.14 KH ERN 01297801-01297802 [“អ្នកទោសដែលចូលមកហើយ គឺគ្មានសិទ្ធិទេគឺគេចោទថាជាខ្មាំងហើយ។ចោទថាជាខ្មាំងហើយអ្នកទោសមានសិទ្ធិអីណាទៀត”]។ ឯកសារ D98/3.1.54 ហ៊ុម ហ៊ុយ ប្រតិចារឹក ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 15.12.46 KH ERN 00354170-00354171 [“កាលជំនាន់ខ្មែរក្រហមហ្នឹង អត់មានតុលាការអីទេ គឺដឹងតែគេបញ្ជូនយកទៅសម្លាប់ៗបណ្តោយ”]។ ឯកសារ D114/37.1.73 ដេវីដ ឆាណ្ឌល័រ ប្រតិចារឹក ថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩ ម៉ោង 10.21.01 KH ERN 00361493-00361494 [“គឺមិនមានច្បាប់ មិនមានចៅក្រម មិនមានមេធាវី មិនមានតុលាការ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។យើងឃើញមានថា តុលាការចែងនៅក្នុងរដ្ឋធម្មនុញ្ញប៉ុន្តែចៅក្រមក៏បានគេសម្លាប់ផងដែរ។ប៉ុន្តែអត់មានការជុំនុំជំរះផ្សេងទេ”]។ ឯកសារ D114/35.3 សៀវភៅនិពន្ធដោយ ដេវីដ ឆាណ្ឌល័រ ៖ សម្លេងពីមន្ទីរស-២១ EN 00192813។ ឯកសារ D114/37.1.7 បទសម្ភាសន៍តាមខ្សែអាត់ជាមួយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី៤-៦ ខែឧសភា ឆ្នាំ១៩៩៩ EN ERN 00185022-23 [“ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គ្មានតុលាការ គ្មានពន្ធនាគារ គ្មានរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ [...] អ្នកដែលចូលដល់ ស-២១ ហើយ ទោះមាន ឬគ្មានចម្លើយសារភាព អាចត្រូវបានសម្លាប់ដោយគ្មានបញ្ហាឡើយ។ ដូច្នេះ គោលបំណងនៃចម្លើយសារភាព មិនមែនជាចម្លើយផ្លូវច្បាប់ ដូចប្រទេសផ្សេងទៀតទេ [...] អ្នកដែលត្រូវបានចាប់ខ្លួន ប្រាកដជាត្រូវស្លាប់”]។ ឯកសារ D1.3.33.12 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ ថ្ងៃទី៨ ខែឧសភា KH ERN 00187670 [ព្រមទទួល “ការឃាត់ខ្លួនអត់ច្បាប់” និង “ធ្វើឃាតអត់ជំនុំជំរះ”]។ ឯក

557. ឌុច បានទទួលស្គាល់ពីភាពគ្មានទោសរបស់មនុស្សដែលបានជាប់ឃុំនៅមន្ទីរស-២១ ដោយសារភាពថា អ្នកទោសជាច្រើននាក់ដែលគាត់ខ្លួនឯងដឹង គឺត្រូវបានចាប់ខ្លួន "មិនត្រឹមត្រូវ"[2152]។ ដូចដែលបានអះអាងដោយ ឌុច និងកម្មាភិបាលនៃមន្ទីរស-២១ ផ្សេងៗទៀត នៅពេលណាដែលជនរងគ្រោះទាំងនេះត្រូវបានមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដាក់ស្លាកថាជាខ្មាំង និងបញ្ជូនទៅមន្ទីរស-២១ ហើយ ជោគវាសនារបស់ពួកគេត្រូវបានបញ្ចប់[2153]។

---

សារD4.1.1109 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00177581 ["សះតើលោកនៅតែបញ្ជាក់អះអាងថា គ្មានពេលណាមួយដែលនៅស២១មានការដាក់ឱ្យដំនើរការនូវការធានាផ្នែកនីតិវិធីដែលមានទិសដៅវាយតំលៃភាពចាំបាច់ក្នុងការចាប់ខ្លួននិងឃុំខ្លួននិងផ្តល់ឱ្យ ជនជាប់ឃុំនូវការកាត់សេចក្តីមួយមុនពេលសម្លាប់ឡើយឬ?ឆះខ្ញុំទទួលស្គាល់ចំនុចនេះ។រាល់សេចក្តីសម្រេចសំខាន់ៗត្រូវបានធ្វើដោយបក្សដែលដឹកនាំដោយប្រទេសផ្តាច់មុខនិងតាមរបៀបផ្តាច់ការ [...] គោលការណ៍នេះគឺមានវិសមតិភាពជាមួយនឹងអត្ថិភាពនៃតុលាការនិងការធានាផ្នែកនីតិវិធី"]។

2152 ឯកសារ D4.1.191, D114/37.1.7 បទសម្ភាសន៍តាមខ្សែអាត់ជាមួយកាំង ហ្គេកអ៊ាវ ហៅឌុច ថ្ងៃទី៤-៦ ខែឧសភា ឆ្នាំ១៩៩៩ EN 00185040 ["សង្កត់ធ្ងន់ថា អ្នកដែលខ្ញុំស្គាល់ផ្ទាល់ដែលត្រូវបានចាប់ខ្លួន លទ្ធភាពដែលពួកគេអាចត្រូវបានចាប់ច្រឡំ មានច្រើនណាស់ គឺចាប់ពួកគេដោយច្រឡំ"]។

2153 ឯកសារ D98/3.1.93 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 11.23.06 KH ERN 00341911-00341912 ["គុករបស់មន្ទីរស-២១ មិនមែនជាគុក ដូចគុករបស់ប្រទេសនីតិរដ្ឋផ្សេងទេ[...] កន្លែងទុកមនុស្សមុននឹងយកទៅប្រហារជីវិត។ដូច្នេះអត់មានស្ទីការពារសិទ្ធិគេទេ [...] មានន័យថា យើងខ្ញុំទុកគេជាមនុស្សស្លាប់រួចទៅហើយ ឆ្លងពេលសម្រាប់តែយកទៅសម្លាប់តែប៉ុន្នុង"]។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.29.21 KH ERN 01249397-01249398 ["ពាក្យនេះខ្ញុំអត់ដែលឮថា ភ័ន្តច្រឡំទេ គឺថាចាប់មក សុទ្ធតែខ្មាំងទាំងអស់"]។ ឯកសារ D234/2.1.118 សួស ធី ប្រតិចារឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 13.52.49 KH ERN 01307504-01307505 ["ខ្ញុំបានដឹងថា អ្នកទោសដែលចូលមកដល់គុក មកដល់មន្ទីរស២១ហ្នឹង គឺឱ្យតែមកដឹងតែពីស្លាប់ហើយ [...] ឱ្យតែអ្នកទោសមក ដឹងតែស្លាប់ហើយអត់បានរស់ទៅវិញទេ"]។ ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 09.10.36-09.12.38 KH ERN 01297752-01297753។ ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.54.54 KH ERN 01247414-01247415["គេប្រាប់យើងមកថា អ្នកដែលចូលមកមន្ទីរស២១នេះគឺសុទ្ធតែជាខ្មាំងក្បត់ជាតិទាំងអស់បានគេយកមកដល់កន្លែងនេះ។នេះជាការណែនាំការប្រាប់ពីថ្នាក់លើមកគឺថាអ៊ីចឹងតែម្តង"]។ ឯកសារ D98/3.1.185 បទសម្ភាសន៍ជាមួយ ញ៉ែម អេន ខែមិនា ឆ្នាំ១៩៨៧ KH ERN 00826562 ["ខ្ញុំបានឃើញអ្វីដែលពួកគេធ្វើគឺ ផ្តាច់ការ សាហាវ គ្មានការសម្រេចចិត្ត។ពួកគេមិនបានធ្វើការស៊ើបអង្កេតមុនពេលសម្លាប់មនុស្ស"]។

## គ) ការចងក្រងឯកសារស្តីពីការចូលរបស់អ្នកទោស

558. មន្ទីរស-២១ បានប្រើប្រាស់ប្រព័ន្ធកត់ត្រាលម្អិតយ៉ាងប្រយ័ត្នប្រយែង ដើម្បីតាមដានអ្នកទោស ដោយរាប់បញ្ចូលទាំងបញ្ជីឈ្មោះចូលប្រចាំថ្ងៃ[2154] រូបថត[2155] ប្រវត្តិរូបអ្នកទោស[2156] កំណត់ហេតុសួរចម្លើយ[2157] និងបញ្ជីឈ្មោះអ្នកដែលត្រូវសម្លាប់[2158]។ ភាគច្រើននៃកំណត់ត្រាទាំងនេះត្រូវបានរៀបចំដោយ សួស ធី និងកងចងក្រងឯកសារ[2159] ដែលមានទីតាំងនៅអគារ ង និងបានកត់ត្រាឈ្មោះ មុខតំណែង និងទីកន្លែងនៃប្រភពដើមរបស់អ្នកទោស នៅពេលពួកគេមកដល់មន្ទីរស-

---

[2154] សូមមើល ឧទាហរណ៍ ឯកសារ D1.3.28.40 ឈ្មោះអ្នកទោសចូល ថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៧៧ KH EN 00009270 ។

[2155] ឯកសារ D234/2.1.119 សួស ធី ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 14.23.15 KH ERN 01307593-01307594 ["ចំពោះអ្នកទោសដែលចូលមកដល់ហើយ នៅពេលដែលកងការពារគេយកមកកត់ឈ្មោះថតហើយ"]។ ឯកសារ D1.3.33.8 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00146670 ["ថតពេលជនរងគ្រោះទើបចូលមកដល់"]។ ឯកសារ D234/2.1.131 នឹម អ៊ីម ប្រតិចារឹក ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 14.34.52-14.58.24 KH ERN 01382323-01382325 ម៉ោង 15.25.01-15.28.04 KH ERN 01382332-01382334 ។ ឯកសារ D4.1.741 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នឹម គឹមស្រ៊ាង KH ERN 00162713-15។ ឯកសារ D114/37.1.2 កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ របស់ ក.ស.ច.ស KH ERN 00181331["ពេលចុះបញ្ជីរួចហើយ សួស ធីបញ្ជូនពួកគេទៅឱ្យអ្នកថតរូបដែលនៅជាប់នោះ"]។

[2156] សូមមើល ឧទាហរណ៍ ឯកសារ D59/1/3.51b ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង ហ៊ួន យ៉េង EN 01531794។ ឯកសារ D114/36.1.56 ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង ប៊ូ សូ EN 00332647។

[2157] សូមមើល ឧទាហរណ៍ ឯកសារ D1.3.28.110 or D4.1.122 ឈ្មោះអ្នកទោសយកមកសួរ ថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៨។ឯកសារ D1.3.28.63 ឈ្មោះខ្មាំងដែលយកមកសួរ ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៧៨ EN 00224659។

[2158] សូមមើល ឧទាហរណ៍ ឯកសារ D1.3.21.2 បញ្ជីឈ្មោះអ្នកទោសផ្នែកកងពលកំទេច ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៧។ ឯកសារ D1.3.28.40 បញ្ជីឈ្មោះអ្នកទោសកំទេច ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៧ KH ERN 00009083 [លេខរៀងទី ១៧ និង១៨ គឺជាអ្នកទោសមកពីកងពល១៦៤]។

[2159] ឯកសារ D234/2.1.118 សួស ធី ប្រតិចារឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 11.00.42 KH ERN 01307490-01307491 [សាក្សីមានតួនាទីចុះបញ្ជីអ្នកទោសចូល ស ២១], KH ERN 13.33.03-13.35.24។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ 09.48.54 KH ERN 01249355 ["កាលណាអ្នកទោសចូលមកដល់ហ្នឹង ខ្ញុំធ្លាប់ចូលទៅឃើញពេលខ្ញុំទៅយកអ្នកទោស ខ្ញុំចូលទៅឃើញទៅកន្លែង សួស ធី ថតហើយនិងវាស់កំពស់ហើយនិងធ្វើជាប្រវត្តិរូប"]។

២១[2160] កត់ត្រាលេខអគារ និងបន្ទប់ឃុំឃាំងដែលអ្នកទោសម្នាក់ៗត្រូវដាក់ឃុំ[2161] និងរៀបចំឯកសារដោយឡែកៗសម្រាប់អ្នកទោសម្នាក់ៗ ដែលរួមមានទាំងព័ត៌មានប្រវត្តិរូប និងរូបថតរបស់ពួកគេផង[2162]។ កំណត់ត្រាដែលមានស្រាប់ទាំងនេះបានបង្ហាញទាំងចំនួន និងអត្តសញ្ញាណរបស់ជនរងគ្រោះដែលជាប់ឃុំនៅមន្ទីរស-២១។

---

[2160] ឯកសារ D234/2.1.118 សួស ធី ប្រតិចារឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 15.20.30 KH ERN 01307525-01307526 ["គេយកម្ដងប្រហែលជា៣០ នាក់។ ៣០នាក់ហើយ យើងកត់ប្រវត្តិរូបរបស់អ្នកទោសហ្នឹង គឺវាកត់ខ្លីៗទេ គ្រាន់តែឈ្មោះ ឪពុកម្ដាយ ហើយនិងរបរនៅអង្គភាពតែប៉ុណ្ណឹង"]។ ឯកសារ D234/2.1.119 សួស ធី ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំង២០១៦ ម៉ោង 10.34.23 KH ERN 01307564។ ឯកសារ D98/1.2.9 សួស ធី ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 13.52.42-13.56.59 KH ERN 00356747-00356749,ម៉ោង 14.24.05-14.26.33 KH ERN 00356755-00356757។ ឯកសារ D54/6.1.24 សួស ធី ប្រតិចារឹក ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 09. 17.45 KH ERN 00356892-00356893 [កំណត់អត្តសញ្ញាណ បញ្ជីអ្នកទោសចូលដែលរៀបចំដោយក្រុមរបស់គាត់]។ ម៉ោង 09.59.53-10.02.17 [បញ្ជាក់អះអាងពីការអនុវត្តសម្រាប់ការចុះឈ្មោះអ្នកទោសថ្មី]។ ឯកសារ D98/3.1.93 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង11.17.09-11.20.00 KH ERN 0034190900341911។ ឯកសារ D98/3.1.82 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ ម៉ោង 11.27.08 KH ERN 00325353-00325354 ["អគារ E នេះជាកន្លែងសំរាប់ថតរូប សំរាប់ធ្វើបញ្ជីមួយរយ"]។ ឯកសារ D4.1.1116 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00153458-59, 00153467។ ឯកសារ D114/37.1.2 កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ របស់ក.ស.ច.ស EN 00198000។ ឯកសារ D98/3.1.313 វ៉ាន់ ណាត់ ប្រតិចារឹក ថ្ងៃទិ២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.53.06 KH ERN 00347844-00347845 ["អាណាមុនគេសួរអ្នក អ្អែងមកពីណា? អ្អែងឈ្មោះអី? ប្រាប់ឈ្មោះទៅ មកទៅឈ្មោះសហករណ៍ប្រាំទៅ ស្រុកស្រែមួយ តំបន់បួន ភូមិភាគពាយព្យ"]។ឯ កសារ D114/230.1.1បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស, លេខរៀង 7992 [ហេង ណាត អាយុ ៣៤ ឆ្នាំ អតីតជាងគំនូរនៅសហករណ៍៥ តំបន់៤ ភូមិភាគពាយ័ព្យ]។

[2161] ឯកសារ D234/2.1.119 សួស ធី ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 14.23.15 KH ERN 01307593-01307594 ["ខ្ញុំត្រូវតែដើរចូលទៅដើម្បីចម្លងលេខបន្ទប់ លេខផ្ទះយកមកវិញដែរ"]។ ឯកសារ D98/1.2.9 សួស ធី ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 14.26.33 KH ERN 00356755-00356757។ឯកសារ D114/37.1.2 កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ របស់ ក.ស.ច.ស EN 00198000។

[2162] ឯកសារ D234/2.1.119 សួស ធី ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 14.18.22-14.20.57 KH ERN 01307592-01307593។ ឯកសារ D234/2.1.120 សួស ធី ប្រតិចារឹក ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 15.30.36-15.32.54 KH ERN 01307681-01307682,ម៉ោង 15.32.54 KH ERN 01307681-01307682។

559. ដោយផ្អែកលើការពិនិត្យឡើងវិញលើកំណត់ត្រាមន្ទីរស-២១ ដែលបានរកឃើញ ដោយផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើបញ្ជីឈ្មោះអ្នកទោសចូល[2163] អ្នកវិភាគរបស់ ក.ស.ច.ស បានចងក្រងបញ្ជីមួយដែលកំណត់អត្តសញ្ញាណមនុស្សសរុបចំនួន ១៥.១០១ នាក់ ដែលត្រូវបានចងក្រងជាឯកសារថាត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខស-២១ នេះ[2164]។

**អំពើអមនុស្សធម៌ផ្សេងទៀត ដែលបង្កដោយចេតនាឲ្យមានការរងទុក្ខ និងរបួសធ្ងន់ធ្ងរ**

560. អ្នកទោសមន្ទីរស-២១ បានស្ថិតក្រោមលក្ខខណ្ឌអមនុស្សធម៌យ៉ាងខ្លាំងរហូតដល់កម្រិតមួយដែលអ្នកនៅរស់រានមានជីវិតមានអារម្មណ៍ថា ពួកគេមិនមែនជាមនុស្សឡើយ[2165]។ ឌុច បានសារភាព

[2163] ឯកសារ D234/2.1.144 ហ៊ិន សុធានី ប្រតិចារឹក ថ្ងៃទី៩ ខែមករា ឆ្នាំ២០១៧ ម៉ោង 09.56.09 KH ERN 01486695 ["ខ្ញុំធ្លាប់ធ្វើឯកសារទាក់ទងនឹងបញ្ជីស២១។បានន័យថា ទាក់ទងនឹងបញ្ជីអ្នកទោសចូល", ម៉ោង 10.37.28 KH ERN 01486703 ម៉ោង11.01.15 KH ERN 01486710 [ "ជ្រើសរើសដំបូង គឺចំនួន គឺបញ្ជីអ្នកទោសចូល […] នាងខ្ញុំអត់មានពេលវេលាគ្រប់គ្រាន់ដើម្បីបានពិនិត្យមើលរូបថតបន្តទៀតទេ"], ម៉ោង 11.06.02 KH ERN 01486711-01486712 ["ឯកសារបញ្ជីអ្នកទោសសម្លាប់គឺនាងខ្ញុំមិនបានផ្តោតទាំងស្រុងនៅក្នុងបញ្ជីហ្នឹងទេ"], ម៉ោង 13.34.20 KH ERN01486726-01486727 ["សម្រាប់វិធីសាស្ត្រដែលនាងខ្ញុំបានធ្វើ គឺដំបូងបំផុតគឺនាងខ្ញុំផ្តោតទៅលើ បញ្ជីអ្នកទោសចូលនៅឆ្នាំ៧៥ ៧៦ ៧៧និង៧៨ឬក៏៧៩ […] ធម្មតាបញ្ជីអ្នកទោសចូលមានចំនួនបញ្ជីអ្នកទោសចូលប្រចាំថ្ងៃប្រចាំខែ ប្រចាំឆ្នាំ។ បន្ទាប់មកទៀត បាននាងខ្ញុំរកឯកសារផ្សេងទៀតដែលមាននៅក្នុង ខូឡឹមបន្ទាប់មកទៀតដូចថា ប្រវត្តិរូប ឬក៏ជាបញ្ជីអីផ្សេងទៀត"]។

[2164] ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស។ បន្ទាប់មក ជាពិសេសដោយសារថាពុំមានការពិនិត្យឡើងវិញឲ្យបានគ្រប់ជ្រុងជ្រោយលើឈ្មោះអ្នកទោស ស-២១ ដែលបានកម្ទេច ទើប ក.ស.ព បានកំណត់អត្តសញ្ញាណអ្នកទោសជាង ២០០០ នាក់ ថែមទៀតដែលមានឈ្មោះលុបចេញពីបញ្ជីរបស់ ក.ស.ច.ស។ សូមមើល ឯកសារ D234/2.1.144 ហ៊ិន សុធានី ប្រតិចារឹក ថ្ងៃទី៩ ខែមករា ឆ្នាំ២០១៧ ម៉ោង 13.54.53 KH ERN 01486732-01486733 ["ស៖ តើខ្ញុំយល់ត្រឹមត្រូវទេដែលថា លោកស្រីមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យទៅលើបញ្ជីអ្នកទោសដែលត្រូវកម្ទេច ហើយលោកស្រីមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីបញ្ចូលទៅក្នុងតារាងស្ព្រេតស៊ីតរបស់លោកស្រីនោះទេ? ឆ៖ចាស លោកប្រធានត្រឹមត្រូវ"], ម៉ោង 14.13.45 KH ERN 01486738 [បញ្ជាក់ថា ថ្ងៃខែឆ្នាំពីបញ្ជីឈ្មោះអ្នកដែលត្រូវសម្លាប់ទាំងបួនបញ្ជីគឺមិនបានបញ្ចូលទេដោយសារមិនមាន"ពេលវេលាគ្រប់គ្រាន់"]។

[2165] ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.55.59 KH ERN 00347845-00347846 ["ជីវភាពរបស់យើងមិនអាចរស់បានជាមនុស្សកើតទេ ពីព្រោះបបរគេឲ្យតែពីរបីស្លាបព្រាទេមួយពេលនោះ។ […] ខ្ញុំបាត់បង់លក្ខណៈជាដែលអាចរស់បាន ពីព្រោះមើលទៅកន្លែងហ្នឹងវាអ្នកទោសនិងអ្នកយាមហ្នឹងវាដូចមិនមែនមនុស្សនិងមនុស្ស។វាដូចជាសត្វ បើចិញ្ចើមក៏គេឲ្យហូបដែរ"]។ ឯកសារ D234/2.1.107 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.12.36 KH ERN 01247088-01247090 ["ខ្ញុំគិតសព្វៗ ខ្ញុំមិនមែនជាមនុស្សទេ

ថា "ការឃុំឃាំង និងលក្ខខណ្ឌរស់នៅយ៉ាងអមនុស្សធម៌" គឺជាឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តនៅមន្ទីរស-២១[2166]។ ភស្តុតាងបង្ហាញថា អ្នកទោសទាំងអស់ដែលត្រូវបានឃុំឃាំងនៅមន្ទីរស-២១ រួមទាំងអ្នកដែលត្រូវបានបញ្ជូនពីកងពល ១៦៤ និងកំពង់សោមផង បានទទួលរងនូវអំពើអមនុស្សធម៌បែបនោះ។ លើសពីនេះទៀត លក្ខខណ្ឌនៅមន្ទីរស-២១ គឺមានលក្ខណៈដូចគ្នាទៅនឹងលក្ខខណ្ឌនៅមន្ទីរសន្តិសុខកងពល ១៦៤ ដែលមាន **មាស មុត** ជាអ្នកទទួលខុសត្រូវ ដូចបានលើកឡើងនៅក្នុងផ្នែកផ្សេងៗទៀតនៃដីកាសន្និដ្ឋានស្ថាពរនេះ។

561. <u>ការប្រើប្រាស់ខ្នោះជើង៖</u> អ្នកទោសភាគច្រើនបំផុតត្រូវបានដាក់ឃុំនៅក្នុងបន្ទប់ឃុំឃាំងរួមដ៏ធំដោយមានអ្នកទោសពី ២០ ទៅ ៤០នាក់ ដែលត្រូវបានដាក់ខ្នោះនៅនឹងកជើងភ្ជាប់ទៅនឹងរបារដែកវែងៗជាជួរដែលមានខ្នោះជើងចំនួន ១០ ក្នុងមួយជួរ[2167]។ ពួកគេស្ថិតនៅសភាពជាប់ខ្នោះជើង

---

ដូចសត្វធាតុអ៊ីចឹង ដូចឆ្កែអ៊ីចឹង"]។ ឯកសារ D98/3.1.34 ជុំ មុី ប្រតិចារឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.57.38 KH ERN 00347948-00347949 ["ពេលមកឃើញអាកេសគ្រាប់នៅកន្លែងហ្នឹង បត់ជើងធំហ្នឹង ហើយកាដុងបត់ជើងតូចហ្នឹង ហើយគេឲ្យយើងដេកនៅនឹងឥដ្ឋ គឺថាមានលាមកក៏មាននៅហ្នឹង ទឹកនោមក៏មាននៅហ្នឹង ស្អុយឆ្អាបពេញហ្នឹង"], ម៉ោង 14.03.40 KH ERN 00347971-00347972 ["បើសត្វជ្រូកទៅ គេឲ្យបាយស៊ីតែចំពោះខ្ញុំគេឲ្យទឹកបបរមួយវែកៗ"]។ ឯកសារD98/3.1.8 ប៊ូ ម៉េង ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.10.42 KH ERN 00348016-00348017 ["ខ្ញុំនឹកអាណោចក្នុងចិត្ត ថា អ!ធ្វើបាបមនុស្សដូចសត្វដូចធាតុ"]។

2166 ឯកសារ D4.1.1114 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ EN 00209175។ឯកសារ D54/6.1.5 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ ម៉ោង 10.25.01 KH ERN 00320895-00320896 ["ក្នុងថ្នាក់ជាប្រធានមន្ទីរស២១ ក៏ដោយ ឧក្រិដ្ឋកម្មគ្រប់យ៉ាងទាំងដាក់ឃុំឃាំង ក្នុងលក្ខខណ្ឌអមនុស្សធម៌ជាទីបំផុតទៅលើមនុស្ស រួមទាំងស្ត្រី និងកុមារផង រហូតទៅដល់សម្លាប់ទាំងស្ត្រី ទាំងកុមារផង។ ខ្ញុំទទួលទាំងអស់"]។

2167 ឯកសារ D234/2.1.106 ជុំ មុី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.46.19 KH ERN 01246994 ["វានៅក្នុងបន្ទប់ហ្នឹងយើងមើលឃើញប្រហែលជា ៤០ នាក់ ប៉ុន្តែសុទ្ធតែដាក់ខ្នោះជើង អាខ្នោះវែងៗ"]។ ឯកសារ D98/3.1.34 ជុំ មុី ប្រតិចារឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 11.23.43 KH ERN 00347955-00347956, ម៉ោង 11.32.01 KH ERN 00347957-00347959។ ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.28.42 KH ERN 01247395-01247396 ["គេដាក់ខ្នោះកងហ្នឹង គេដាក់ខ្នោះជើងទៅ គេស៊កដែកវែងមួយអ៊ីចឹង គេស៊កតម្រៀបជួរគ្នាស៊កកងជើងទៅ តម្រៀបជួរគ្នាស៊កអ៊ីចឹងហើយគេកិបសោរម្ខាងទៅមនុស្សនៅជាប់គ្នាទាំងអស់ហ្នឹងទៅ"]។ ឯកសារ D98/3.1.146 ឡាច មាន ប្រតិចារឹក ថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៩ ម៉ោង 14.22.11 KH ERN 00359014-00359016។ ឯកសារ D98/3.1.146 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច មាន EN 00363554។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 13.41.25 KH ERN 01249382-01249383។ ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩

ជាអចិន្ត្រៃយ៍នៅក្នុងបន្ទប់ឃុំឃាំងរបស់ខ្លួន ២៤ ម៉ោងក្នុងមួយថ្ងៃ[2168] សូម្បីតែពេលហូបចុក[2169] គេង[2170] ទៅបន្ទប់ទឹក[2171] លាងជម្រះខ្លួនដោយបំពង់បង្ហូរទឹក[2172] ឬពេលទទួលការព្យាបាលក្តី[2173]

---

ម៉ោង10.07.10 KH ERN 00348015-00348016[“មានគ្នាច្រើន មួយស្នូរហ្នឹង មួយរនងហ្នឹង ប្រហែលជាគ្នាប្រាំនាក់ ដប់នាក់ មួយអាររនងៗ វែងៗ ហើយដេកទល់ក្បាលគ្នា”]។ ឯកសារ D54/6.1.19 លី ហ៊ា ប្រតិចារឹក ថ្ងៃទី៦ ខែកក្កដា ឆ្នា ២០០៩ ម៉ោង10.10.25-10.14.27 KH ERN 00349178-00349180។ ឯកសារ D54/6.1.21 ណាំ ម៉ុន ប្រតិចារឹក ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 14.29.44 KH ERN 00350740-00350741 [អ្នកទោសស្រី៖ “គេដាក់ខ្នោះជើងម្ខាង”]។ ឯកសារ D4.1.388 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ណាត KH ERN 00163716 [“គេដាក់ខ្នោះរួមវែងមានអ្នកទោសចំនួនប្រហែល២០នាក់ក្នុងមួយខ្នោះ (រូបទី៨)”]។ ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.59.07-10.05.50 KH ERN 00347846-00347850។ឯកសារ D234/2.1.114 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.06.44-15.08.30 KH ERN 01297901-01297902។ឯកសារ D98/3.1.55 ហ៊ីម ហ៊ុយ ប្រតិចារឹក ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.09.00-KH ERN 00354806-00354808។ឯកសារ D98/3.1.93 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 11.37.44 KH ERN 00341914-00341916។ ឯកសារ D4.1.1115 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេក អ៊ាវ KH ERN 00146659។ ឯកសារ D4.1.386 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ហាន KH ERN 00163673-74។ ឯកសារ D4.1.383 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខៀវ ចេស KH ERN 00163638 [“អ្នកទោសទាំងនោះដាក់ខ្នោះរហូត ពេលឈឺជើងមួយចំហៀង ដោះដាក់មួយចំហៀងទៀត”]។ ឯកសារ D4.1.380 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆែម ឈិន KH ERN 00163787-88។ ឯកសារ D4.1.384 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ម៉េត KH ERN 00163653។ ឯកសារ D114/37.1.2 កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ របស់ ក.ស.ច.ស EN ERN 00198004-06 [ប្រាក់ ខន, សួស ធី, វ៉ាន់ ណាត, និងប៊ូ ម៉េង បញ្ជាក់ថា អ្នកទោសជាប់ខ្នោះជើងនៅក្នុងបន្ទប់ធំរួម]។

2168 ឯកសារ D98/3.1.93 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 11.35.00 KH ERN 00341914 [“ដាក់ខ្នោះជើង២៤ម៉ោងលើ២៤ម៉ោង […] លើកលែងតែពេលយកទៅសួរចម្លើយនៅពេលបណ្តើរប៉ុណ្ណឹងឯង”]។ ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង14.30.45 KH ERN 01247396 [“ចំពោះអ្នកទោសដែលដាក់កង […] ដាក់ៗរហូតទាល់តែបញ្ចេញៗហើយ គេអត់ដែលដោះទេ”]។ឯកសារ D98/3.1.147 ឡាច មាន ប្រតិចារឹក ថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៩ ម៉ោង13.45.05 KH ERN 00360493-00360494 [“អ្នកទោសទាំងនោះដាក់ខ្នោះរហូត ពេលឈឺជើងមួយចំហៀង ដោះដាក់មួយចំហៀងទៀត”]។ ឯកសារ D54/6.1.21 ណាំ ម៉ុន ប្រតិចារឹក ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 14.29.44 KH ERN 00350740-00350741 [អ្នកទោសស្ត្រីជាប់ខ្នោះរហូតរយៈពេលបីខែ]។ ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០០៩ ម៉ោង 09.59.07 KH ERN 00347846-00347847 [“ព្រឹកឡើងគេឱ្យយើងហាត់ប្រាណ ហើយរបៀបហាត់ប្រាណអ្នកទោសនៅបន្ទប់ហ្នឹង គឺយើងជាប់អានងដែក គឺយើងដេកនៅហ្នឹង យើងបត់ជើងតូចនៅហ្នឹង បត់ជើងធំនៅ

ហ្នឹង ហូបនៅហ្នឹង ស្អីនៅហ្នឹងទាំងអស់។ យើងសូម្បីតែមួយតឹក មួយចំអាមចេញពីការ៉ូ ដែលយើងអង្គុយគឺយើងអត់មានសិទ្ធិចេញបានដែរ”]។

2169 ឯកសារ D1.3.32.17 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹម ហ៊ុយ KH ERN 00146651[“ពេលហូបចុកគឺគេមិនដោះខ្នោះជើងទេ។ អ្នកយាមគឺដើរបើកសោរតាមបន្ទប់ ហើយដួសម្នាក់មួយចាន”]។ ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.59.07 KH ERN 00347846-00347847។

2170 ឯកសារ D234/2.1.119 សួស ធី ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.21.36 KH ERN 01307548-01307549 [“ចំពោះអ្នកទោសដែលមកចូលក្នុងគុកហ្នឹង [...] គេឲ្យដេកទាំងជាប់ខ្នោះហ្នឹង”]។ ឯកសារ D98/3.1.34 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 11.15.15 KH ERN 00347952-00347955 [“ហើយពេលអាគេដាក់ច្រវាក់ជើងយើងហ្នឹង គេប្រាប់យើងថា បើកាលណាប្រែខ្លួនឲ្យសុំគេ”]។

2171 ឯកសារ D234/2.1.107 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.12.36 KH ERN 01247088-01247090 [“ពេលដែលនៅក្នុងបន្ទប់ខ្ញុំមានកេសគ្រាប់មួយប៉ុណ្ណេះ កេសគ្រាប់អាមេរិកាំង វាឲ្យយើងបត់ជើងធំនៅហ្នឹងៗ។ពេលហ្នឹងគឺថាយើងបត់វាមិនចំទេ ពីព្រោះថាអាជើងវាជាប់ខ្នោះផងនោះដល់យើងបត់ទៅវា កាលហ្នឹងវាអត់មានណាមករឹងទេមានតែទឹកៗ”]។ ឯកសារD98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.59.07-10.01.48 KH ERN 00347846-00347848។ ឯកសារ D114/37.1.68 សៀវភៅនិពន្ធដោយ វ៉ាន់ ណាត ៖ គំនូរគុកមួយរបស់កម្ពុជា (សេចក្តីដកស្រង់), EN 00396821។ ឯកសារ D4.1.384 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ម៉េត KH ERN 00163651។

2172 ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង11.20.05-11.23.26 KH ERN 01247004-01247005។ ឯកសារ D98/3.1.54 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 11.30.20 KH ERN 00354140-00354142។ ឯកសារ D4.1.386 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ហន KH ERN 00163676-77។ ឯកសារ D4.1.383 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខៀវ ចេស KH ERN 00163638 [“ពេលឆ្អេះយកទឹកបាញ់ឲ្យអ្នកទោសងូត”]។ ឯកសារ D4.1.384 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ម៉េត KH ERN 00163654។ ឯកសារD4.1.380 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆែម ឈិន KH ERN 00163787-88។ ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.01.48-10.05.50 KH ERN 00347847-00347850។

2173 ឯកសារ D234/2.1.114 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.06.44 KH ERN 01297901-01297902 [“អត់មានព្យាបាលយកអ្នកទោសមកព្យាបាលនៅក្រៅអី អត់ទេ [...]ឲ្យនៅព្យាបាលក្នុងច្រវាក់ខ្នោះឃ្នាងនៅនុង”]។

។ ខ្នោះជើងរបស់អ្នកទោសនៅតែជាប់នឹងកជើងដដែល នៅលើពេលពួកគេត្រូវបានយកទៅសួរចម្លើយ ដូច្នេះពួកគេអាចនឹងត្រូវបានបង្ខាំងទុកនៅក្នុងបន្ទប់សួរចម្លើយ[2174]។ អ្នកទោសមួយចំនួននៅតែមានស្លាកស្នាមពីការជាប់ខ្នោះជើងនោះជាច្រើនទសវត្សរ៍ក្រោយមកទៀត[2175]។

562. បទបញ្ជាអ្នកទោសនៅមន្ទីរស-២១ ដទៃទៀតក៏ត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹងផងដែរ[2176]។ អ្នកទោសមិនត្រូវបានអនុញ្ញាតឲ្យជជែកគ្នា ឬបញ្ចេញសំឡេងឡើយ[2177]។ សូម្បីតែពេលដេកនៅពេលយប់

---

[2174] ឯកសារ D234/2.1.107 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.12.36 KH ERN 01247088-01247090។ ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.40.05 KH ERN 01249436-01249437។ ឯកសារ D1.3.32.36 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ខន KH ERN 00146630 ["អ្នកទោសតែគេយកចេញពីក្នុងគុកដល់បន្ទប់យើងសួរ យើងយកសោរចាក់កងជើងដាក់នឹងតុ"]។ ឯកសារ D54/6.1.21 ណាំ ម៉ុន ប្រតិចារឹក ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 14.33.52 KH ERN 00350741-00350742 ["ពេលសួរចម្លើយខ្ញុំ [...] វាវីតនឹងខ្នោះជើងតែម្តង"]។ ឯកសារ D10.1.7 សៀវភៅសរសេរ ស ២១ "បញ្ញើសិក្ខិរបស់សន្តិបាល ស២១" KH ERN 00007475 ["មិត្តយើងអ្នកសួរ ត្រូវកំណត់ទស្សនៈថា បញ្ហាការពារខ្លាំងឲ្យជាប់គឺជាភារកិច្ចទី១ [...] ដាក់ខ្នោះ ដាក់កង ដាក់រនង ច្រវាក់"]។

[2175] ឯកសារ D54/6.1.20 ឡាយ ចាន់ ប្រតិចារឹក ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.53.33 KH ERN 00349665-00349666 ["នៅពេលបច្ចុប្បន្ននេះ យើងនឹងបង្ហាញនូវអាជើងដែលខ្ញុំសម្លាកជាងសាមសិបឆ្នាំមកនេះ គឺខ្ញុំសម្លាកនៅមាន ជើងខាងឆ្វេង ហើយនិងខាងស្តាំឃើញស្នាមតិចៗដោយរយៈពេលវាយូរដែរហើយ"]។ សូមមើល ឯកសារ D114/297.1.47 វឿន វុទ្ធី ប្រតិចារឹក ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ម៉ោង 14.24.59 KH ERN 01377598 ["ពួកយើងវិភាគគឺផ្តែកទៅលើសំណល់ស្លាកស្នាមនៅលើឆ្អឹង [...] កន្លែងដែលចំណងឬដែកនៅគឺវាពណ៌ខុសពីកន្លែងដែលគ្មានដែកនៅ នៅជិតដាម"]។

[2176] ឯកសារ D10.1.26 សេចក្តីណែនាំអំពី"បទបញ្ជាសន្តិបាល"។ ឯកសារD98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.59.07 KH ERN 00347846-00347847 ["ក្នុងអាគ្គារខៀន សាលារៀនហ្នឹង គេដាក់បញ្ជាផ្ទៃក្នុងស្រេច [...] ចង់ធ្វើអីសុំច្បាប់អ្នកយាមអនុញ្ញាត បានយើងអាចធ្វើបាន"]។ ឯកសារ D234/2.1.111 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.22.11-14.24.12 KH ERN 01249311-01249313។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.03.00 KH ERN 01249402-01249403 [វិន័យសន្តិបាលគឺ "មានឃើញដាក់នៅក្នុងអគារ ក្នុងគុក"]។

[2177] ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.07.03 KH ERN 01246987-01246988 ["គេគ្រាន់តែប្រាប់យើងថា កុំឲ្យនិយាយទៅនិយាយគ្នានៅអាបន្ទប់ជិតៗ ហ្នឹង យើងនៅឲ្យស្ងៀម"], ម៉ោង 14.33.22 KH ERN 01247024-01247025 ["ខ្ញុំបាទខ្លាច[អ៊ឹង ប៊ុច] កាលណាយើងនិយាយជាមួយ [...] គេវ៉ៃយើងហើយ"]។ ឯកសារ D98/3.1.34 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 14.43.09 KH ERN 00347983-00347985។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង

បើអ្នកទោសណា "កម្រើក ហើយឮសំឡេងច្រវាក់" នោះ ពួកគេនឹងត្រូវគេវាយដំ[2178]។ អ្នកទោសមិនត្រូវបានអនុញ្ញាតឲ្យចេញក្រៅបន្ទប់ឃុំឃាំងរបស់ខ្លួនដើម្បីស្រូបយកខ្យល់អាកាស ត្រូវពន្លឺព្រះអាទិត្យ ឬធ្វើលំហាត់ប្រាណឡើយ[2179]។ ពួកគេមិនត្រូវបានអនុញ្ញាតឲ្យឈរ ដើបអង្គុយ ឬផ្លាស់ទីដោយគ្មានការអនុញ្ញាតពីអ្នកយាមឡើយ[2180]។

563. __របបអាហារ៖__ អ្នកទោសនៅមន្ទីរស-២១ បានទទួលរងនូវភាពអត់ឃ្លាន ខណៈពេលដែលស្បៀងដែលគេផលិតបានលើសពីតម្រូវការនៅព្រៃស ត្រូវបានបញ្ជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍[2181]។

---

15.08.25 KH ERN 01249404-01249405 ["វិធានការរបស់ឌុចដែលហាមមិនឲ្យអ្នកទោសនិយាយគ្នា"]។ ឯកសារ D4.1.1115 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00146660 ["ការជជែកគ្នារវាងជនជាប់ឃុំត្រូវហាមឃាត់"]។ ឯកសារD98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.59.07-10.01.48 KH ERN 00347846-00347847។ ឯកសារ D4.1.386 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ហន KH ERN 00163674-75។ ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.10.42 KH ERN 00348016-00348017 ["អ្នកណាមាត់ចេកចាចចុះឡើងប្រកែកគ្នាអី គេលេងដងរែកពីលើស្មាហ្នឹងវ៉ៃតែម្តង"]។ ឯកសារD54/6.1.19 លី ហ៊ី ប្រតិចារឹក ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.18.28 KH ERN 00349180-00349181 ["និយាយស្តីគ្នាឮៗក៏គេមិនឲ្យយើងនិយាយដែរ គេឡើងមកវ៉ៃយើង"]។

2178 ឯកសារ D234/2.1.107 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ម៉ោង 11.12.36 KH ERN 01247088-01247090។

2179 ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.30.45 KH ERN 01247396 ["ចំពោះអ្នកទោសដែលគ្នាច្រើនហ្នឹង គឺនៅតែមួយកន្លែងហ្នឹង"]។ ឯកសារ D98/3.1.93 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 11.45.22 KH ERN 00341916-00341919។ ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.59.07-10.01.48 KH ERN 00347846-00347848 ["គេឲ្យហាត់ប្រាណ អាជើងមួយចំហៀង យើងជាប់នៅក្នុងកងហ្នឹង លោតទៅៗ"]។

2180 ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.28.42-14.32.54 KH ERN 01247395-012473977។ ឯកសារ D98/3.1.93 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 11.45.22 KH ERN 00341916-00341919 ["បើមិនសុំគេ ឈរមិនបានទេ"]។ ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.59.07-10.01.48 KH ERN 00347846-00347848 ["តែយើងអង្គុយអត់សុំគេ ចូលមកគេវាយហើយ"]។ ឯកសារ D98/3.1.34 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.38.42 KH ERN 00347931-00347932 ["មានពួកគេហ្នឹងម្នាក់មកប្រាប់ថា [...] សុំគេទៅ បងៗខ្ញុំសុំប្រែខ្លួន"]។

2181 ឯកសារ D98/3.1.97 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 11.28.11 KH ERN 00346379-00346381 ["ឆ្នាំទីបី នៅសល់ស្រូវ [...] ខ្ញុំបានជូនផលស្រូវដែលនៅសល់នេះទៅអចិន្ត្រៃយ៍តាមរយៈពួ

ពួកគេទទួលបានអាហារតិចតួចចំនួនពីរដងក្នុងមួយថ្ងៃ ដែលជាធម្មតាមានតែបបររាវៗពីរបីស្លាបព្រាប៉ុណ្ណោះ[2182]។ ជាលទ្ធផលនៃរបបអាហារដ៏តិចតួចនេះ អ្នកជាប់ឃុំបានជួបប្រទះនឹងភាពអត់ឃ្លានធ្ងន់ធ្ងរ[2183] និងមានសភាពស្គមស្គាំង ធ្លាក់ខ្លួនឈឺ និងចុះខ្សោយ[2184]។

---

នួន")។ ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.37.49 KH ERN 01297821-01247822 ["បាយដាំសល់ច្រើនៗណាស់ ទាំងម្ហូបទាំងអី"]។

2182 ឯកសារ D234/2.1.106 ជុំ មុី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង10.48.01-10.50.27 KH ERN01297796 -01297797។ ឯកសារ D234/2.1.107 ជុំ មុី ប្រតិចារឹក ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.12.36 KH ERN 01247088-01247090 [អំឡុងពេលជាប់ឃុំសួរចម្លើយ ចំពោះគាត់គឺ "ក្នុងមួយថ្ងៃបានតែពីរវែកទេ"]។ ឯកសារ D98/3.1.34 ជុំ មុី ប្រតិចារឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.36.08-09.38.42 KH ERN 00347930-00347932, ម៉ោង14.03.40 KH ERN 00347971-00347973។ ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំង២០១៦ ម៉ោង 15.37.49 KH ERN 01297821-01297822 ["អ្នកទោសដែលនៅឃុំឃាំងគឺបបររាវៗឲ្យ"]។ ឯកសារ D98/3.1.54 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 11.30.20-11.38.44 KH ERN 00354141-00354144។ ឯកសារ D1.3.32.17 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹម ហ៊ុយ KH ERN 00146650។ ឯកសារ D234/2.1.114 ម៉ក់ ស៊ីធីម ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ ម៉ោង15.35.51-15.38.17 KH ERN 01297910-01297911។ ឯកសារD98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.55.59 KH ERN 00347845- 00347846 ["បបរគេវែកមកច្រើនមែនមួយចានធំប៉ុណ្ណឹងមែន ប៉ុន្តែគ្នាវាច្រើនគ្នាហាហុកសិបនាក់ចែកបានតែពីរបីស្លាបព្រាម្នាក់ទេមួយពេលនោះ។ ពីរបីស្លាបព្រាម្នាក់ហ្នឹង មិនមែនបានស្លាបព្រាធំទេ គេឲ្យស្លាបព្រាកាហ្វេហ្នឹងប្រើ"]។ ឯកសារ D4.1.388 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ណាត KH ERN 00163716។ ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 09.47.15-09.48.21 KH ERN 00348010-00348011។ ឯកសារ D54/6.1.20 ភោគ ខន ប្រតិចារឹក ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 15.27.15 KH ERN 00349709 ["តែបបរមួយវែកៗរហូតគ្រប់គ្នាទៅ"]។ ឯកសារ D55/8.1.5 ជិន ម៉េត ប្រតិចារឹក ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 14.34.54-14.38.06 KH ERN 00350410-003504412។ ឯកសារ D98/3.1.212 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 13.43.55 KH ERN 00355325-00355326។ ឯកសារ D98/1.2.9 គក ស្រស់ ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 09.08.48 KH ERN 00356701-00356703។ ឯកសារ D4.1.1108 កំណត់ហេតុនៃការសួរចម្លើយកាំង ហ្គេកអ៊ាវ KH ERN 00178025 ["ជាអាទិ៍ ក្នុងការដែលមិនបានផ្តល់អាហារហូបចុកគ្រប់គ្រាន់ដល់អ្នកទោស ហើយខ្ញុំមានវិប្បដិសារីយ៉ាងខ្លាំងចំពោះអ្វីដែលបានកើតឡើង"]។

2183 ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.01.48 KH ERN 00347847-00347848 ["កុំតែមានសត្វអីរោមភ្លើងធ្លាក់ចូលមួយអត់បានទេ ធ្លាក់ចូលពីបនៅក្បែរខ្លួនដាក់ចូលមាត់ផ្លុក ទំពារលេបហើយ [...] អត់មានគិតអីក្រៅពីឃ្លានទេ គឺឃ្លានណាស់ ឃ្លានដល់កំពូល ដែលក្នុងមួយជីវិតខ្ញុំមិនដែលជួបប្រទះនឹងដំណាក់កាលហ្នឹង។ បើសិនជាដាក់អីឲ្យរហូតទៅ ដាក់សាច់មនុស្សឲ្យក៏ត្រូវតែហូបដែរ"]។ ឯកសារ D98/3.1.8 ប៊ូ

564. <u>កង្វះអនាម័យ៖</u> លក្ខខណ្ឌអនាម័យនៅមន្ទីរស-២១ គឺគួរឲ្យភ័យខ្លាច។ អ្នកទោសត្រូវបានបង្ខំឲ្យបន្ទោរបង់ក្នុងប្រអប់ដាក់គ្រាប់រំសេវ និងធុងជ័រនៅក្នុងបន្ទប់ឃុំឃាំងរបស់ខ្លួន[2185] ខណៈពេល

---

ម៉េង ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 14.11.53 KH ERN 00348051-00348052 ["ខ្ញុំវាឃ្លានៗហើយឃើញជីងចក់វារលើក្បាល នឹងថាបើធ្លាក់មកនឹងច្បាស់ជាស៊ី ហូបឲ្យមានកំលាំង"]។

2184 ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.17.43-11.20.05 KH ERN 01247003-0127005។ ឯកសារ D234/2.1.107 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.12.36 KH ERN 01247088-01247090។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 13.44.13 KH ERN 01249383-01249384 ["រឹតតែស្គមទៅៗព្រោះអត់មានអីហូបគ្រប់គ្រាន់"]។ ឯកសារ D234/2.1.119 សួស ធី ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.24.31KH ERN 01307549-01307550 ["មួយចំនួនច្រើនស្គមៗទាំងអស់ ពីព្រោះវាការហូបចុកការសម្រាក ការអីគីវា គឺថាអត់មានកន្លែងស្រួលសោះ។ការជីវភាព ក៏អត់មានត្រឹមត្រូវដែរ ដូច្នេះគ្នាចុះស្គមទាំងអស់"]។ ឯកសារ D54/6.1.24 សួស ធី ប្រតិចារឹក ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 09.53.44 KH ERN 00356899-00356900 [រៀបរាប់ពីការយកអ្នកទោសចេញទៅសម្លាប់៖ "មុននឹងឡើងរថយន្ត គឺមានសភាពគឺស្គម [...] សភាពគឺស្គមគឺស្គម ស្គមមែនទែន"]។ ឯកសារ D4.1.347 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ធី KH ERN 00162604-05។ ឯកសារ D234/2.1.114 ម៉ក់ ស៊ីធីម ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.35.51 KH ERN01297910-01297911["គ្នាជាប់រាប់ខែ រាប់ឆ្នាំ រាប់ថ្ងៃ [...] ជីវភាពអត់គ្រប់គ្រាន់ នៅហ្នឹងថ្នាំពេទ្យអត់មានប្រសិទ្ធិភាព [...] កាន់តែស្គមទៅៗ"]។ ឯកសារ D234/2.1.115 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 10.39.12 KH ERN 01252013។ឯកសារ D98/3.1.29 ឈុន ផល ប្រតិចារឹក ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ម៉ោង 09.57.50-10.07.26 KH ERN 00362751-00362753។ ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 09.47.15-09.48.21 KH ERN 00348010-00348011។ ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០០៩ ម៉ោង 10.01.48 KH ERN 00347847-00347848 ["ខ្ញុំវាអស់សាច់ អស់ឈាមទៅ អស់កម្លាំងទៅ"]។ ឯកសារ D1.3.28.42 សេចក្តីរាយការណ៍ស្តីអំពីសភាពជំងឺរបស់ខ្មាំង ថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៧៧ KH ERN 00064652 [ភាគច្រើនរៀបរាប់អំពីអ្នកទោសក្នុងបញ្ជីថា"ស្គមខ្លាំង"]។

2185 ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង10.04.51-10.07.03 KH ERN 01246987-01246988,ម៉ោង 10.48.35 KH ERN 01246994-01246995។ ឯកសារ D98/3.1.34 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.27.52-10.57.38 KH ERN 00347946-00347948,ម៉ោង 14.19.52-14.22.54 KH ERN 00347975-00347977។ ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ ២០១៦ ម៉ោង 09.40.05 KH ERN 01249436-01249437។ ឯកសារ D234/2.1.119 សួស ធី ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.21.36-09.24.31 KH ERN 01307548-01307550។ ឯកសារ D234/2.1.114 ម៉ក់ ស៊ីធីម ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ម៉ោង 15.35.51-15.38.17 KH ERN 01297910-01297911។ ឯកសារ D98/3.1.8 ប៊ូ ម៉េងប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.03.43-10.10.42 KH ERN 00348014-

ដែលខ្លួននៅជាប់ខ្នោះដដែល[2186]។ បន្ទប់ឃុំឃាំងត្រូវបានសម្អាតតែនៅពេលណាដែលគេទ្រាំនឹងក្លិនស្អុយលែងបានប៉ុណ្ណោះ[2187]។ ប្រសិនបើទឹកនោម ឬលាមកលេចធ្លាយពីធុងទៅលើកម្រាលឥដ្ឋ

---

00348017។ ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.13.12-10.15.43 KH ERN 00347850-00347852។ ឯកសារ D54/6.1.19 លី ហ៊ ប្រតិចារឹក ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.18.28 KH ERN 00349180-00349181, ម៉ោង11.10.52-11.14.12 KH ERN 00349187-00349189 ។ ឯកសារ D54/6.1.20 សោត ខន ប្រតិចារឹក ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 14.21.51-14.25.54 KH ERN 00349694-00349698។ ឯកសារ D98/3.1.146 ឡាច មាន ប្រតិចារឹក ថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៩ ម៉ោង 14.34.00-14.38.10 KH ERN 00359017-00359019។ ឯកសារ D98/3.1.147 ឡាច មាន ប្រតិចារឹក ថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៩ ម៉ោង 10.23.20 KH ERN 00360464-00360465 [ពិភាក្សាអំពីអ្នកទោសដែលស្លាប់ដោយសារជំងឺរាកមួល៖ "តែតាមការសន្និដ្ឋានរបស់ខ្ញុំ គឺឆ្លងពីគ្នាទៅពីមួយទៅមួយ ព្រោះការបន្ទោរបង់ គឺដាក់កែសតែមួយជាមួយគ្នា"]។ ឯកសារ D4.1.344 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច មាន KH ERN 00162774។ ឯកសារD114/37.1.66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញេប ហូ KH ERN 00162684-85។ ឯកសារ D4.1.386 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ហន KH ERN 00163676-77។ ឯកសារ D10.1.15 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វណ្ណ សុភា KH ERN 00186461-62។ ឯកសារ D4.1.383 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខៀវ ចេស KH ERN 00163638-39។ ឯកសារD98/3.1.93 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 11.37.44 KH ERN 00341914-00341916 ["ការបន្ទោរបង់គឺនៅនឹងកន្លែងដែលគាត់សម្រាក ដែលគាត់ដេក ដែលគាត់រស់នៅ។ បើកាលណាបន្ទោរបង់លាមក ប្រហែលជាប្រើធុងគ្រាប់ អឹមស៊ី ហើយបន្ទោរបង់ទឹកនោមគឺត្រូវប្រើប៊ីដុងតូចៗ"]។

2186 ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.17.43-11.20.05 KH ERN 01247003-01247005។ ឯកសារ D4.1.384 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ម៉េត KH ERN 00163652 ["យើងអត់បណ្តើរអ្នកទោសចេញមកបត់ជើងនៅខាងក្រៅបន្ទប់ទេ"]។ ឯកសារ D98/3.1.147 ឡាច មាន ប្រតិចារឹក ថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៩ ម៉ោង 13.45.05 KH ERN 00360493-00360494 ["អ្នកទោសទាំងនោះដាក់ខ្នោះរហូត"]។ ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.07.10 KH ERN 00348015-00348016 [អ្នកឃាម "រែកលាមកហ្នឹង ហើយនិងទឹកនោមហ្នឹងចុះមកក្រោម [...] ដេកក្នុងគុកគិតតែពីដេកតែម្តង"]។ ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.59.07-10.01.48 KH ERN 00347846-00347848។ ឯកសារ D114/37.1.68 វ៉ាន់ ណាត គំនូរគុកមួយរបស់កម្ពុជា KH ERN 00323460 ["គេមិនដែលបានដោះខ្នោះជើងឲ្យខ្ញុំម្តងណាទេ [...] បើសិនជាខ្ញុំត្រូវការបត់ជើងធំត្រូវសុំទៅឆ្មាំពន្ធនាគារឲ្យគេយកធុងមកឲ្យ"]។

2187 ឯកសារ D234/2.1.119 សួស ធី ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.21.36 KH ERN 01307548-01307549 ["នៅពេលដែលខ្ញុំដើរកាត់ហ្នឹង វាក្លិនគឺធុំក្លិនអត់"]។ ឯកសារ D98/3.1.93 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 16.06.28 KH ERN 00341950-00341953 ["ក្លិនៗដែលយ៉ាប់ហ្នឹង ពិតជាមាន

នោះអ្នកទោសនឹងត្រូវគេវាយដំ ឬបង្ខំឲ្យលិឍអ្វីដែលលេចមកនោះឲ្យអស់[2188]។ អ្នកទោសមិនត្រូវបានអនុញ្ញាតឲ្យលាងសម្អាតដោយខ្លួនឯងនោះទេ ហើយជំនួសមកវិញត្រូវបានលាងជម្រះខ្លួនតាមរយៈបំពង់បង្ហូរទឹកជាក្រុមៗ ដោយអ្នកយាមជាអ្នកបាញ់ទឹក ពេលណាដែលបន្ទប់ឃុំឃាំងត្រូវបានលាងសម្អាត[2189]។

---

[…] ដឹងហើយរឿងក្លិនវាខ្លាំង"]។ ឯកសារ D98/3.1.54 ហ៊ីម ហ៊ុយ ប្រតិចារឹក ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 11.30.20 KH ERN 00354140-00354142 ["ធុំក្លិនស្អុយតាមបន្ទប់នីមួយៗ ហ្នឹងគឺមិនបានសម្អាតឲ្យទេ"]។ ឯកសារ D98/3.1.147 ឡាច មាន ប្រតិចារឹក ថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៩ ម៉ោង 13.45.05 KH ERN 00360493-00360494 ["ពេលឆ្អែះយកទឹកបាញ់ឲ្យអ្នកទោសងូត"]។ ឯកសារ D4.1.383 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខៀវ ចេស KH ERN 00163638-39។

2188 ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.51.13-10.56.35 KH ERN 01246995-01246997។ ឯកសារ D234/2.1.107 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.12.36 KH ERN 01247088-01247090 ["ពេលហ្នឹងគឺយើងបត់វាមិនចំទេ ពីព្រោះថាអាជើងជាប់ខ្នោះផងនោះដល់យើងបត់ទៅវា កាលហ្នឹងវាមានឈាមករឹងទេមានតែទឹកៗដល់ហើយវាវាកមកក្រៅប៊ីដុងហ្នឹងខ្លះទៅ វាមកឃើញវាថាអ្វែងលិតអាហ្នឹងឲ្យស្អាត អ្វែងមិនលិត អញវាយអ្វែងចុយម៉ាយ"]។ ឯកសារ D54/6.1.19 លី ហ៊ី ប្រតិចារឹក ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.18.28 KH ERN 00349180-00349181 ["ឡាំង កែសគ្រាប់ ដែលគេដាក់ឲ្យបន្ទោរបង់ហ្នឹង គឺបានកំពប់គេវ៉ៃ"]។

2189 ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.30.45 KH ERN 01247396 ["ពេលត្រូវការងូតទឹក គេងូតទាំងអស់ គេបាញ់ទុយោដាក់ឲ្យ ងូតទាំងអស់គ្នាអ៊ីចឹងទៅ […] បាញ់ទាំងអស់ លាងបន្ទប់លាងអី"]។ ឯកសារ D98/3.1.147 ឡាច មាន ប្រតិចារឹក ថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៩ ម៉ោង 13.45.05-13.48.54 KH ERN 00360493-00360496។ ឯកសារD4.1.344 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច មាន KH ERN 00162775-00162776 ["ចំពោះបន្ទប់ធំៗ គេបាញ់ទឹកទុយយោទៅលើហើយឲ្យមុជទឹករួមតែម្តង មុជនៅកន្លែងដេកតែម្តង"]។ ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.17.43 KH ERN 01247003-01247004។ ឯកសារ D98/3.1.34 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.27.52-10.57.38 KH ERN 00347946-00347949, ម៉ោង14.03.40 KH ERN 00347971-00347973។ ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.15.15 KH ERN 00348017-00348018 ["ស្រាតខោទាំងអស់គ្នាហើយ បាញ់ពីក្រៅទៅ ពីបង្អួចទៅ ពីក្រៅទៅ បាញ់ទុយោស្រោចអ៊ីចឹង […] ដូចស្រោចក្របី"]។ ឯកសារ D54/6.1.20 អោគ ខន ប្រតិចារឹក ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង15.27.15 KH ERN 003497០9។ ឯកសារ D98/3.1.54 ហ៊ីម ហ៊ុយ ប្រតិចារឹក ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 11.30.20 KH ERN 00354140-00354142។ ឯកសារ D98/3.1.29 ឈុន ផល ប្រតិចារឹក ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ម៉ោង 10.12.54-10.18.53 KH ERN 00362754-00362757។ ឯកសារD4.1.383 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី

565. <u>អ្នកទោសដែលញាំញីដោយជំងឺ៖</u> អ្នកទោសជាច្រើនបានធ្លាក់ខ្លួនឈឺ ដោយសារតែលក្ខខណ្ឌទាំងនេះ ដោយកើតជំងឺរាករូស រាកមួល រោគស្អើក គ្រុនចាញ់ និងជំងឺដទៃទៀត[2190]។ ពួកគេបានចេញកន្ទួលស្បែក និងមានកើតចៃ[2191]។ អ្នកទោសមន្ទីរស-២១ បានស្លាប់ ដោយសារជំងឺស្ទើរតែរៀងរាល់ថ្ងៃ ជាពិសេសក្នុងអំឡុងឆ្នាំ ១៩៧៧-៧៨ នៅពេលដែលមន្ទីរឃុំឃាំងមានផ្ទុកអ្នកទោសច្រើនបំផុត[2192]។

---

ខៀវ ចេស KH ERN 00163638-39។ ឯកសារ D98/3.1.313 វ៉ាន់ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.01.48 KH ERN 00347847-00347848 ["ឆ្នាំគុកតូចៗ ហ្នឹងអាយុដប់បួនដប់ប្រាំឆ្នាំ គេប្រចាច់ទុយោឲ្យត្រប៉ែតទៅ វាស្រោចទៅលើយើងអ្នកទោសសាមសែហាសិបនាក់ហ្នឹង"]។ ឯកសារ D114/37.1.68 វ៉ាន់ ណាត គំនូរគុកមួយរបស់កម្ពុជា EN 00396821។ ឯកសារ D114/37.1.2 កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុរបស់ ក.ស.ច.ស EN 00198005។ សូមមើល ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.32.54 KH ERN 01247396-01247397 ["ពួកអ្នកនៅបន្ទប់តូចៗ គឺអត់ដែលបានមុជទឹកទេ អត់ដែលឲ្យងូតទឹកផង"]។

2190 ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.48.35 KH ERN 01246994-01246995 ["គិតតែខ្លួនហ្នឹងហើមពេញហ្នឹងតែទាំងអស់ទៅហើយ"]។ ឯកសារ D234/2.1.114 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.35.51-15.38.17 KH ERN 01297910-01297911។ ឯកសារ D98/3.1.146 សេក ដន ប្រតិចារឹក ថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៩ ម៉ោង 09.33.05 KH ERN 00358965-00358967 ["អ្នកទោសភាគច្រើនជំងឺមិនសូវឈឺប៉ុន្មានទេ ដូចរាក ដូចគ្រុនឈឺក្បាលអី"]។ ឯកសារ D1.3.28.42 សេចក្តីរាយការណ៍ស្តីអំពីសភាពជំងឺរបស់ខ្មាំង ថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៧៧។

2191 ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 14.37.16 KH ERN 00348058-00348059 ["ហើយកើតរមាស់កើតចៃសរៗ តាមចង្កេះខោហ្នឹង ខាំកើតរមាស់ ខ្ញុំកើតរមាស់ រហូតទៅដល់ទៅគូរនៅតែរមាស់អ៊ីចឹង"]។ ឯកសារ D54/6.1.19 លី ហ៊ី ប្រតិចារឹក ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 11.14.12 KH ERN 00349187-00349189 ["ដោយសារចៃខាំ សត្វខាំរមាស់ពេញខ្លួនរហូតដល់ដំបៅពេញខ្លួន"]។ ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.01.48 KH ERN 00347847-00347848 ["យើងវាអត់ដែលត្រូវទឹក អត់ដែលត្រូវសាប៊ូ ត្រូវអីហ្នឹង វារមាស់ វាកើតចៃចង្កេះ វាកើតចៃ ស"]។ ឯកសារ D114/37.1.68 វ៉ាន់ ណាត គំនូរគុកមួយរបស់កម្ពុជា (សេចក្តីដកស្រង់) KH ERN 00323460 ["សក់ខ្ញុំ ... ក្លាយទៅជាសម្បុកចៃ។ ខ្ញុំមានកើតរមាស់ពេញខ្លួន"]។

2192 ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 13.50.45 KH ERN 01249386 ["ស្លាប់ជាបន្តបន្ទាប់ ហើយពេទ្យហ្នឹងឃើញតែខ្វែងខ្វាត់រាល់តែថ្ងៃហ្នឹង"]។ ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.32.54 KH ERN 01247396-01247397 ["ធ្លាប់ឃើញស្លាប់ដែរ ស្លាប់ដោយសារជំងឺ។កាល ជំងឺគ្រាំគ្រាមិនដឹង ក៏ជំងឺអាសន្នរោគក៏មិនដឹងដែរ"]។ ឯកសារ D4.1.344 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច មាន KH ERN 00162775។ ឯកសារ D114/35.3 សៀវភៅនិពន្ធដោយ ដេវីដ ឆាណ្ឌល័រ ៖ សម្លេងពីមន្ទីរស-២១ EN ERN 00192710 ["សៀវភៅកំណត់ត្រាពីឆ្នាំ១៩៧៧របស់កម្មាភិបាលម្នាក់បានកត់

សាកសពរបស់ពួកគេនៅតែស្ថិតក្នុងបន្ទប់ឃុំឃាំង ដោយជាប់ខ្នោះដដែល នៅក្បែរអ្នកទោសផ្សេងទៀតជាច្រើនម៉ោង[2193]។ អ្នកទោសដែលបានស្លាប់នៅទីបំផុតត្រូវបានកម្មាភិបាលមន្ទីរស-២១ យកចេញទៅកប់ក្នុងបរិវេណជិតមន្ទីរសន្តិសុខនេះ[2194]។

---

ត្រា [...] អ្នកទោសស្លាប់សរុបចំនួន២៣៤ នាក់ ក្នុងរយៈពេលជាងបួនខែ។ អ្នកស្លាប់ជាច្រើន ខ្សោះកម្លាំងដោយសារ ដំបៅ ការអត់ឃ្លាន និងទារុណកម្ម មុនពេលស្លាប់"]។ ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.01.48 KH ERN 00347847-00347848។ ឯកសារD4.1.388 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ណាត KH ERN 00163717 ["អ្នកស្លាប់ច្រើនយកចេញនៅពេលយប់។នៅក្នុងបន្ទប់ខ្ញុំ ក្នុង១ខែ មានស្លាប់ប្រហែល៨ឬ៩នាក់"]។ ឯកសារ D234/2.1.115 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 09.12.21 KH ERN 01251992-01251993 [ពេទ្យឃើញអ្នកទោសស្លាប់ដោយផ្ទាល់ "៣ ទៅ៤ ថ្ងៃ ទៅ១អាទិត្យ"]។ ឯកសារD10.1.30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ ធីម KH ERN 00163711["ពេលព្យាបាលពេលខ្លះខ្ញុំឃើញមានអ្នកទោសខ្លះស្លាប់ដែរ ១ថ្ងៃ មួយ ជួនកាល ២ ឬ៣ថ្ងៃ មួយ"]។ ឯកសារ D98/3.1.146 សេក ដន ប្រតិចារឹក ថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៩ ម៉ោង 09.48.00 KH ERN 00358970-00358971[ពេទ្យស ២១៖ "មានអ្នកទោសឈឺស្លាប់ក្នុងនុងមាន ធ្លាប់ឃើញ [...] មានច្រើនណាស់រាប់ទៅប្រហែលជារាប់រយនាក់"]។ ឯកសារ D4.1.382 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេក ដន KH ERN 00163818-19។ ឯកសារ D1.3.32.17 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹម ហ៊ុយ KH ERN 00146650។ ឯកសារ D4.1.380 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ង៉ែម ឈិន KH ERN 00163788។ ឯកសារ D234/2.1.119 សួស ធី ប្រតិចារឹក ថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.24.31 KH ERN 01307549-01307550 ["ពេលដែលមានការស្លាប់ មានការឈឺធ្ងន់អីហ្នឹង ពេទ្យហ្នឹងគេរាយការណ៍ទៅឲ្យហ៊ី ហើយ។ ហើយហ៊ី គេយករបាយការណ៍ពីពេទ្យហ្នឹង យកមកឲ្យខ្ញុំចុះក្នុងបញ្ជីប្រចាំថ្ងៃ"], ម៉ោង 09.35.58 KH ERN 01307552-01307553[ការស្លាប់វាច្រើនក្នុងមួយថ្ងៃ ខ្ញុំសន្និដ្ឋានមួយពីរតែប៉ុណ្ណឹងទេ]។ ឯកសារ D234/2.1.119 សួស ធី ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 15.27.49 KH ERN 01307603-01307604។ ឯកសារ D4.1.347 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ធី KH ERN 00162604-05។

2193 ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.01.48 KH ERN 00347847-00347848 ["ការស្លាប់ជាបន្តបន្ទាប់ ទាល់យប់ម៉ោងដប់មួយយប់អីនោះ បានគេយកចេញ ម៉ោងមួយអីនោះ។អាយើងបើកបបរមកហួបហ្នឹងទៅ អាខ្មោចដេកហ្នឹង យើងហ្នឹងទៅ យើងលែងគិតអស់ហើយពេលហ្នឹង"]។

2194 ឯកសារ D234/2.1.115 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 09.12.21 KH ERN 01251992-01251993 ["ពេលស្លាប់ហ្នឹង គេឲ្យពេទ្យអង្គភាពពេទ្យនោះ [...] យកទៅកប់ៗខាងក្រៅរបងគុក [...] គេបញ្ជាឲ្យកប់ហ្នឹងហើយ កប់សាកសពនៅក្រៅរបងគុក"]។ ឯកសារ D10.1.30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ ធីម KH ERN 00163711។ ឯកសារ D98/3.1.146 សេក ដន ប្រតិចារឹក ថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៩ ម៉ោង 09.48.00 KH ERN 00358970-00358971["សាកសពនុងគេឲ្យកូនពេទ្យ ឲ្យពេទ្យសែងជញ្ជូនចេញយកមកកប់នៅខាងក្រៅ ឬក៏កប់ជិតៗ កន្លែងនុងឲ្យតែផុតៗទៅ"]។ ឯកសារ D4.1.382 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី

566. អ្នកទោសដែលបានស្លាប់ដោយសារជំងឺនៅមន្ទីរស-២១ រួមមានអ្នកទោស ៨ នាក់ ក្នុងចំណោម ១៣ នាក់ ដែលមកពីកំពង់សោម និងកងពល ១៦៤ ដែលបានចូលនៅថ្ងៃទី ២១ និង ទី ២៨ ខែ សីហា ឆ្នាំ ១៩៧៦ ដែលអ្នកទាំងអស់នោះបានស្លាប់ក្នុងរយៈពេលពីរបីថ្ងៃ ឬពីរបីសប្តាហ៍ បន្ទាប់ពីពួកគេមកដល់មន្ទីរស-២១[2195] ដែលបង្ហាញថា អ្នកទោសក្រុមនេះត្រូវបានបញ្ជូនដោយ **មាស មុត** ក្នុងលក្ខខណ្ឌសុខភាពខ្សោយខ្លាំងមែនទែន។

567. <u>កង្វះការថែទាំផ្នែកវេជ្ជសាស្ត្រ៖</u> អ្នកជាប់ឃុំនៅមន្ទីរស-២១ មិនបានទទួលការថែទាំផ្នែកវេជ្ជសាស្ត្រ ត្រឹមត្រូវសម្រាប់ជំងឺ និងរបួសរបស់ពួកគេនោះទេ។ ជាធម្មតា ការថែទាំផ្នែកវេជ្ជសាស្ត្រត្រូវបាន ផ្តល់ តែនៅពេលណាដែលគេចង់រក្សាជីវិតរបស់អ្នកទោស ឲ្យបានយូរល្មមនឹងបញ្ចប់ការសួរ ចម្លើយប៉ុណ្ណោះ[2196]។ គ្រូពេទ្យធ្វើការនៅមន្ទីរស-២១ មិនបានទទួលការបណ្តុះបណ្តាល និងបំពាក់

---

សេក ផន KH ERN 00163818-19។ ឯកសារ D1.3.32.17 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ឹម ហ៊ុយ KH ERN 00146650។ ឯកសារ D4.1.388 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ណាត KH ERN 00163716។

2195 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស ២១ របស់ ក.ស.ច.ស, លេខរៀង 691 [នៅ គុច ហៅ ផន – បញ្ជូនពីកំពង់សោមទៅមន្ទីរ ស-២១ នៅថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៦ ស្លាប់ដោយសារជំងឺនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ១៩៧៦], 692 [ស៊ី តៃស្រុង – ចូលថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៦ ស្លាប់ដោយសារជំងឺនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៧៦], 693 [ទិន គឹមហុង – ចូលថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៦ ស្លាប់ដោយសារជំងឺនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៧៦], 696 [ណាន ខ្មាក់ – ចូលថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៦ ស្លាប់ដោយសារជំងឺនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧៦], 699 [អ៊ុយ ឡេង ហៅ ម៉ាន់ – ចូលថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៦ ស្លាប់ដោយសារជំងឺនៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៧៦], 700 [លឹម ហួត – ចូលថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៦ ស្លាប់ដោយសារជំងឺ], 702 [គិន វ៉ា – ចូលថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៦ ស្លាប់ដោយសារជំងឺនៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៧៦], 703 [ញ៉ៅយ ផេង – ចូលថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៦ ស្លាប់ដោយសារជំងឺនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៧៦]។ ឯកសារ D1.3.3.2 បញ្ជីឈ្មោះអ្នកទោសសម្លាប់មន្ទីរ ស-២១ បញ្ជីឈ្មោះអ្នកទោសកម្ទេចពីថ្ងៃទី១ ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៧៦ EN ERN 00874318 [កំណត់អត្តសញ្ញាណលេខរៀងទី១៣៨ ឈ្មោះ លឹម ហួត, យុទ្ធជនកងពល១៦៤ ឈឺស្លាប់នៅថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៧៦]។ ឯកសារ D9.3 បញ្ជីឈ្មោះអ្នកទោសស ២១ មកពីកងពល១៦៤ របស់ ក.ស.ច.ស [កំណត់អត្តសញ្ញាណលេខរៀងទី២៣ ឈ្មោះ លឹម ហួត]។

2196 ឯកសារ D98/3.1.93 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 16.22.39 KH ERN 00341953-00341954 ["សេវាពេទ្យ គឺមាន [...] ក្នុងគោលបំណងសម្រាប់តែសួរចម្លើយឲ្យចប់ប៉ុណ្ណឹងឯង"]។ ឯកសារD98/3.1.83 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ម៉ោង 10.26.30 KH ERN 00325494-003254495។ ឯកសារ D234/2.1.114 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 09.18.20 KH ERN 01297839-01297840 ["ទាល់តែអ្នកហ្នឹងថា វាយទៅវារបួសបែកឈាម ដំបៅពេញខ្លួន អាហ្នឹងបានមានពេទ្យ

បរិក្ខារគ្រប់គ្រាន់នោះទេ[2197]។ ឱសថត្រូវបានផ្គត់ផ្គង់ក្នុងរយៈពេលខ្លី ហើយជាញឹកញាប់មានតែផលិតផលដែលផលិតក្នុងស្រុកគ្មានប្រសិទ្ធភាពប៉ុណ្ណោះ[2198]។ គ្រូពេទ្យនៅមន្ទីរស-២១ ជាច្រើន

---

ទៅព្យាបាលយកចិត្តទុកដាក់"]។ ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.04.30-15.07.11 KH ERN 01247400-01247402។ ឯកសារ D98/3.1.165 ណាំ ម៉ុន ប្រតិចារឹក ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 11.06.25 KH ERN 00351042-00351043 ["គាត់បញ្ជាខ្ញុំឱ្យខិតខំ ឱ្យអ្នកជំងឺហ្នឹងមានកំលាំងកំហែងគ្រាន់តែសួរចម្លើយហ្នឹង"]។ ឯកសារ D98/3.1.146 សេក ដន ប្រតិចារឹក ថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៩ ម៉ោង 10.03.16 KH ERN 00358974-00358978 [ពេទ្យស ២១៖ "ឱ្យថ្នាំគ្រាន់តែបាន ពេលដែលគេសួរចម្លើយចប់ហើយ គេយកទៅបាត់ គេគ្រាន់តែដូចបណ្តោះអាសន្នអ៊ីចឹង"]។ ឯកសារ D4.1.382 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេក ដន KH ERN 00163818-19។ ឯកសារ D234/2.1.114 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.17.33 KH ERN 01297905 [គេ "ប្រាប់ខ្ញុំថា" អ្នកទោសណាដែលសំខាន់ហ្នឹង មើលមែនទែន ព្រោះអី "សួរចម្លើយអត់ទាន់អស់ទេ"]។ ឯកសារ D10.1.30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ ធីម KH ERN 00163711។

2197 ឯកសារ D234/2.1.114 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 14.55.42 KH ERN 01297898 ["ខ្ញុំរៀនវាមិនចេះជ្រៅជ្រះប៉ុន្មាន ល្មមម៉ាល្មម ហើយចេះតាមប្រធានពេទ្យហ្នឹងប្រាប់ថ្នាំនេះថ្នាំនោះមក ហើយខ្ញុំចេះបន្តៗទៀតមក បានខ្ញុំចាប់ផ្តើមពេទ្យហ្នឹង គេចាត់តាំងខ្ញុំដើរចែកថ្នាំហ្នឹង ចែកថ្នាំនៅស២១ហ្នឹងឯង"]។ ឯកសារ D98/3.1.146 សេក ដន ប្រតិចារឹក ថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៩ ម៉ោង 09.26.29 KH ERN 00358963-00358964 ["ខ្ញុំអត់ដែលបានរៀនវិជ្ជាពេទ្យទេ"]។ ឯកសារ D4.1.382 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេក ដន KH ERN 00163818 ["ប្រហែលដើមឆ្នាំ១៩៧៨ខ្ញុំបានមកធ្វើជាពេទ្យកុមារ [...] ខ្ញុំមិនបានរៀនពេទ្យពីមុនមកទេ [...] ខ្ញុំមិនចេះអក្សរតែខ្ញុំចំណាំកំប៉ុងពេលមេប្រាប់ឱ្យយកថ្នាំទៅចែក"]។ ឯកសារ D98/3.1.165 ណាំ ម៉ុន ប្រតិចារឹក ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 09.37.09 KH ERN 00351024-00351025 [គេឱ្យសាក្សីធ្វើពេទ្យនៅស២១ នៅអាយុ១៥ឆ្នាំ], ម៉ោង 09.49.32 KH ERN 00351028 [ដោយសារសាក្សីមិនចេះអក្សរ ទើបគាត់មិនអាចអានឈ្មោះថ្នាំបានទេ ហើយអាចត្រឹមចំណាំស្លាក]។ ឯកសារ D1.3.32.9 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុន ផល KH ERN 00163809 ["ពេទ្យសំរាប់អ្នកទោសផ្សេងពេទ្យសំរាប់អ្នកធ្វើការផ្សេង ពេទ្យពេលនោះជាពេទ្យធម្មតា មិនមែនជាដុកទ័រទេគឺសំរាប់ដុសលាងរបួស ព្យាបាលគ្រុន"]។ ឯកសារ D4.1.384 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ម៉េត KH ERN 00163654 ["គេមានឱ្យពេទ្យមកព្យាបាលដែរតែគ្រាន់តែលាបថ្នាំក្រហមតែប៉ុណ្ណោះទេ មិនមានថ្នាំអ្វីផ្សេងទេ គ្រាន់តែយកថ្នាំក្រហមនោះមកជូតប៉ាតៗលើរបួសតែប៉ុណ្ណឹង"]។

2198 ឯកសារ D234/2.1.114 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.35.51 KH ERN 01297910-01297911 ["ថ្នាំពេទ្យអត់មានប្រសិទ្ធិភាព"]។ ឯកសារ D234/2.1.115 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 09.30.00 KH ERN 01251997-01251998 ["ថ្នាំគឺព្យាបាល គឺអស់ផុតអាណត្តិហើយ"], ម៉ោង 10.32.31 KH ERN 01252011-01252012 ["គ្រាន់តែខ្វះខាតថ្នាំពេទ្យ [...] ថ្នាំដូចជា បេ ឌូ បេ អង សុទ្ធតែផលិតនៅនឹងយើងនឹងទេអត់មានថ្នាំពីនាយទេ ថ្នាំបារាំងថ្នាំអីអត់មានទេ"]។ ឯកសារ D10.1.30 កំណត់ហេតុនៃការស្តាប់

ត្រូវបានចាប់ខ្លួន និងដាក់ឃុំឃាំង រួមទាំងមេកង និងគ្រូពេទ្យ ២០ នាក់ផ្សេងទៀតដែលត្រូវគេចាប់ខ្លួននៅពាក់កណ្ដាលឆ្នាំ ១៩៧៨[2199]។ នៅចុងបញ្ចប់នៃរបបនេះ មានតែគ្រូពេទ្យកុមារប៉ុណ្ណោះដែលនៅសល់[2200]។

---

ចម្លើយសាក្សីម៉ក់ ធីម KH ERN 00163712-13។ ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹក ថ្ងៃទី៧១ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.33.11 KH ERN 00348023-00348024 ["គ្មានថ្នាំទេ ទឹកអំបិលយើងមួយចានគ្រោងអ៊ីចឹង ថាខ្ញុំញាក់អូយលើសឈឺ លើសវើទៀត"]។ ឯកសារ D98/3.1.212 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 13.43.55-13.48.17 KH ERN 00355325-00355327។ ឯកសារ D98/3.1.165 ណាំ ម៉ុន ប្រតិចារឹក ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 09.37.09 KH ERN 00351024-00351025 [ថ្នាំនោះអស់ទៅ គេឲ្យ "ថ្នាំបុកជាឬសឈើ" យកមកឲ្យអ្នកទោស]។ ឯកសារ D98/3.1.146 សេក ដន ប្រតិចារឹក ថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៩ ម៉ោង 09.22.34-09.26.29 KH ERN 00358962-00358964, ម៉ោង 09.48.00-09.55.33 KH ERN 00358970-00358973។ ឯកសារ D4.1.388 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វ៉ាន់ ណាត KH ERN 00163716។

2199 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស ២១ របស់ ក.ស.ច.ស លេខរៀង 6965 [ផេង ទ្រី ប្រធានមន្ទីរពេទ្យ ស-២១ ចូលស-២១ ថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៨], 9251 [ឈឹម សំអឿន ហៅ សិត, អនុប្រធាន ចូលស-២១ ថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៧៨], 10143 [ឆេង ប៉ោ, ប្រធានក្រុមពេទ្យ ចូលស-២១ថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៧៨] និងលេខរៀង 4826, 6698, 8805-8808, 8849-8850, 9081, 9244-9249, 9744, 11664, 12028, 12052។ សូមមើល ឯកសារ D234/2.1.115 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 09.22.41 KH ERN 01251995 ["ខ្ញុំស្គាល់តែទ្រី ហើយ ហួរ ហ្នឹង [...] តែបច្ចុប្បន្ន ខ្ញុំព្យាបាលនោះ គាត់ជាប់គុកអស់បាត់ហើយ [...] ខ្ញុំដើរចែកថ្នាំឃើញនៅក្នុងបន្ទប់"]។ ឯកសារ D234/2.1.118 សួស ធី ប្រតិចារឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 11.20.17 KH ERN 01307495 ["ចំពោះពេទ្យដែលលោកក្នុងមន្ទីរស២១ហ្នឹង ពីមុនមកពីខាងកងពល៧០៣ទាំងអស់។ប៉ុន្តែដល់ក្រោយមកពេទ្យគឺគេចាប់ទាំងអស់"]។ ឯកសារD234/2.1.113 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.31.11 KH ERN 01249434-01249435 [ពេទ្យ ទ្រី គឺគាត់ជាប្រធានក៏ត្រូវគេចាប់យកមកដាក់គុក យកទៅសម្លាប់ចោល]។ ឯកសារ D4.1.382 កំណត់ហេតុនៃការស្ដាប់សចម្លើយសាក្សី សេក ដន KH ERN 00163818 ["ប្រធានក្រុមរបស់ខ្ញុំមានបុរសម្នាក់ឈ្មោះប៉ោ [...] ចាក់ថ្នាំកម្មាភិបាលម្នាក់ក្នុងអង្គភាពស្លាប់ ត្រូវគេចាប់ចោទថាជាខ្មាំង"]។ ឯកសារ D98/3.1.83 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ម៉ោង 10.24.30 KH ERN 00325495។

2200 ឯកសារ D4.1.382 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សេក ដន KH ERN 00163818 ["រហូតដល់ចុងក្រោយខ្ញុំឃើញនៅសល់តែពេទ្យក្មេងៗ ហើយពេទ្យចាស់ត្រូវបានចាប់សម្លាប់អស់"]។ ឯកសារ D234/2.1.118 សួស ធី ប្រតិចារឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 11.20.17 KH ERN 01307495 ["ឌុច គេយកខាងអមឈាំង កុមារៗមកធ្វើពេទ្យនៅជំនួសវិញ"]។ ឯកសារ D234/2.1.115 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 10.03.58-10.05.56 KH ERN 01252007-01252008 [សាក្សីស្ថិតនៅក្នុងចំណោម"បណ្ដុំពេទ្យចុងក្រោយ"។ គាត់បញ្ជាក់ថា ពេទ្យគ្នាគាត់គឺភាគច្រើន"អាយុប្រហែល១៧ ឆ្នាំ"]។ ឯកសារ D98/3.1.93 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃ

568. <u>បរិយាកាសនៃភាពភ័យខ្លាច/ការធ្វើអត្តឃាត៖</u> លក្ខខណ្ឌអមនុស្សធម៌ និងការធ្វើបាបផ្សេងៗទៀត បានដកហូតសេចក្ដីថ្លៃថ្នូរ និងក្ដីសង្ឃឹមទាំងអស់ពីអ្នកទោសនៅមន្ទីរស-២១[2201]។ អ្នកទោសតែងតែឮជាប្រចាំថា អ្នកទោសផ្សេងទៀតត្រូវរងការធ្វើទារុណកម្ម[2202] និងបានឃើញពួកគេត្រឡប់ទៅ

---

ទី១៥ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 16.22.39 KH ERN 00341953-00341954 ["ដល់ក្រោយមក បុគ្គលិកពេទ្យខ្លួនឯងហ្នឹង ក៏ចេះតែត្រូវចាប់បណ្ដើរៗទៅណា វាទៅជាសេវាពេទ្យមួយដែលរខេករខាក [...] សេវាពេទ្យវារខេករខាកអស់ហើយ"]។

2201 ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.06.54 KH ERN 01247017 ["យើងអត់សង្ឃឹមថាយើងនៅរស់រានមានជីវិតដល់សព្វថ្ងៃហ្នឹងទេ"]។ ឯកសារ D98/3.1.34 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.27.52-10.57.38 KH ERN 00347946-00347949, ម៉ោង 14.03.40 KH ERN 00347971-00347973។ ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.01.48 KH ERN 00347847-00347848 ["គិតថាយកទៅណាក៏យកទៅចុះ វាដល់ដំណាក់កាលនេះហើយ។បើសិនជាវាឆាប់ៗទៅ ក៏ដូចម្យ៉ាងដែរ ពីព្រោះវាវេទនា"], ម៉ោង 15.06.17 KH ERN 00347901-00347902 ["បើសត្វបើគេចិញ្ចឹមគេមានរបបរហូបចុកត្រឹមត្រូវ ពេលបាយគេឲ្យបាយទៅ គេមិនដែលទៅវ៉ៃ ទៅទាត់ទៅធាក់ នឹកឃើញទាត់ព្រឹក ទាត់ល្ងាច ធាក់ព្រឹក ធាក់ល្ងាចទេ"]។ ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.10.42 KH ERN 00348016-00348017។ ឯកសារ D234/2.1.114 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.52.48 KH ERN 01297915-01297916 ["សួរចម្លើយហើយដឹងតែស្លាប់ គាត់និយាយតែប៉ុណ្ណឹង អស់សង្ឃឹមគាត់"]។

2202 ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 13.53.30 KH ERN 01249469។ ឯកសារ D54/6.1.19 លី ហ៊ ប្រតិចារឹក ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 14.12.35 KH ERN 00349212-00349213 ["ខ្ញុំឮសូរតែសំឡេងស្រែកអូយៗតែអ៊ឹចឹងសឹងរាល់ល្ងាច"]។ ឯកសារ D98/3.1.34 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.18.27-10.21.20 KH ERN 00347943-00347945, ម៉ោង 14.39.42-14.43.09 KH ERN 00347982-00347985។ ឯកសារ D4.1.379 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី តយ តេង KH ERN 00163777-78។ ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 14.32.54 KH ERN 00347895-00347896,ម៉ោង 15.08.49 KH ERN 00347902-00347905។ ឯកសារ D4.1.388 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី វ៉ាន់ ណាត KH ERN 00163718-19។ ឯកសារ D114/37.1.68 សៀវភៅនិពន្ធដោយ វ៉ាន់ ណាត មានចំណងជើងថា៖ គំនូរគុកមួយរបស់កម្ពុជា KH ERN 00163718-19 ["យើងអាចឮសម្លេងអ្នកសួរចម្លើយស្រែកសម្លុត និងសម្លេងស្រែកថ្ងូររបស់អ្នកទោស។ ខ្ញុំឮសម្លេងរហូត"]។ ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 15.10.38 KH ERN 00348063-00348064 ["ឮសូរស្រែកយំច្បាស់ចែស ឮសូរពេញជុំវិញបរិវេណគុកទួលស្លែង"]។ ឯកសារ D114/37.1.66 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញៀប ហូ KH ERN 00162686-87។ ឯកសារ D4.1.384 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សោម ម៉េត KH ERN 00163653 ["ខ្ញុំឮសូរពេលគេធ្វើទារុណកម្មអ្នកទោសៗក៏ស្រែកអង្វរលន់តួកុំឲ្យគេធ្វើបាប

បន្ទប់ឃុំឃាំងវិញដោយមានរបួសស្តែងៗ[2203]។ ស្ថានភាពអស់សង្ឃឹមទាំងស្រុងរបស់អ្នកទោស បាននាំឲ្យអ្នកទោសជាច្រើនប៉ុនប៉ងធ្វើអត្តឃាត ពេលខ្លះបានសម្រេច[2204] រួមទាំងប្រធានមន្ទីរពេទ្យ

ដោយសុខចិត្តឆ្លើយ សុខចិត្តនិយាយ"]។ ឯកសារ D4.1.378 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ ផៃ KH ERN 00163629-30។ ឯកសារ D114/37.1.2 កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុរបស់ ក.ស.ច.ស EN 00197804។ឯកសារ D54/80.1.38 សៀវភៅសរសេរ ស ២១ ប៊ុន-ទុយ KH ERN 00077493 ["បញ្ហាវ៉ៃពួទៅក្រៅ"]។ ឯកសារ D114/35.3 សៀវភៅនិពន្ធដោយ ដេវីដ ឆាណ្ឌល័រ ៖ សម្លេងពីមន្ទីរស-២១ EN ERN 00192822 [រៀបរាប់ពីការសន្ទនាដំណាលគ្នារវាងអ្នកសួរចម្លើយរបស់មន្ទីរស-២១ ដែលក្នុងនោះអ្នកសួរចម្លើយម្នាក់កត់សម្គាល់ថា៖ "នៅក្នុងក្រុមសួរចម្លើយទី១ អ្វីដែលយើងឮគ្រប់ទីកន្លែង គឺសម្លេងវ៉ៃ និងសម្លេងមនុស្សសួរអ្នកទោសថា តើពួកគេជា សេ.អ៊ី.អា មែនឬអត់"]។

2203 ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.07.11 KH ERN 01247401-01247402 ["ធ្លាប់ឃើញមានស្នាមបែកខ្នង ដំបៅខ្នង ដំបៅដៃជើងអីអ៊ីចឹង ធ្លាប់ឃើញ"]។ ឯកសារ D4.1.344 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច មាន KH ERN 00162775 ["មានអ្នកត្រូវធ្វើទារុណកម្ម ហើមខ្លួន បែកខ្នងជាដើម"]។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.18.42 KH ERN 01249407 [ក្រោយពីវ៉ៃនៅក្នុងពេលសួរចម្លើយហើយ,អ្នកទោសមាន "ដាច់ និងដំបៅ"នៅលើដងខ្លួន]។ ឯកសារ D4.1.381 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ សុផាត KH ERN 00163799 ["ខ្ញុំបានឃើញអ្នកទោសភាគច្រើនមានរបួស មានហើមមុខ និងខ្លោចម្ជុំត្រចៀកដោយសារឆក់ខ្សែភ្លើង"]។ ឯកសារ D4.1.380 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆែម ឈិន KH ERN 00163787 ["ពេលដែលគេនាំអ្នកទោសត្រឡប់មកវិញ [...]មានស្នាមរបួសនៅខ្នង គឺជាស្នាមរំពាត់ដែលគេវាយអ្នកទោស"]។ ឯកសារ D4.1.383 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខៀវ ចេស KH ERN 00163641["ពេលមកវិញមានជាំមុខ បែកខ្នង"]។ ឯកសារ D114/37.1.66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញេប ហូ KH ERN 00162690 ["ពេលអ្នកទោសត្រឡប់មកវិញគឺមានស្នាមរំពាត់"]។ ឯកសារ D4.1.388 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ណាត KH ERN 00163719 ["ពេលខ្ញុំកំពុងធ្វើរូប ប៉ុល ពត មានអ្នកសួរចម្លើយម្នាក់មកសុំស៊ីម៉ង់ខ្ញុំមួយកញ្ចប់ ក្រោយមកខ្ញុំឃើញអ្នកទោសដែលគេបណ្តើរមក ប្រលាក់ស៊ីម៉ង់ពេញមុខ"]។

2204 ឯកសារ D234/2.1.111 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.11.22 KH ERN 01249280-01249281 [រំឭកពីហេតុការណ៍ដែលអ្នកទោសស្ត្រីព្យាយាមវះពោះខ្លួនឯងនឹងឡាម]។ ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.35.40 KH ERN 01247397-01247398 [អ្នកទោសដែលបង្អត់អាហារខ្លួនឯង], ម៉ោង 15.04.30 KH ERN 01247400-01247401 ["អ្នកទោសវាអាចថាធ្វើអត្តឃាត ប្រព្រឹត្តនូវអំពើបែបនេះក្រែងលោនេះគឺជាការគិតខូចចិត្តឬក៏ខ្លាច ភ័យខ្លាច [...] អ្នកទោសឆក់កាំភ្លើងយកពីអ្នកយាម អ្នកការពារហ្នឹង យកទៅបាញ់សម្លាប់ខ្លួន"]។ ឯកសារ D98/3.1.146 ឡាច មានប្រតិចារឹក ថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៩ ម៉ោង 14.03.35-14.06.27 KH ERN 00359009-00359010។ ឯកសារ D98/3.1.147 ឡាច មាន ប្រតិចារឹក ថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៩ ម៉ោង 10.03.28-10.05.00 KH ERN 00360458-

00360459។ ឯកសារ D4.1.344 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡាច មាន KH ERN 00162775។ ឯកសារ D98/3.1.93 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 11.45.22-11.55.10 KH ERN 00341916-00341920, ម៉ោង15.55.58-16.06.28 KH ERN 00341949-00341953។ឯកសារ D4.1.1113 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00185493-00185494 ["អ្នកទោសម្នាក់ [...] បានលេបខ្មៅមួយហើយយើងបានហៅពេទ្យមករះយកខ្មៅ នោះចេញដើម្បីអាចបន្តការសួរចម្លើយទៀត"]។ ឯកសារ D4.1.1117 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00154224-25។ ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.37.29 KH ERN 01249435-01249436 [ពាក្យដាស់តឿនរបស់ឌុច និង ហ៊ំ នៅកន្លែងប្រជុំរៀនសូត្រអំពីអ្នកទោសដែលព្យាយាមធ្វើអត្តឃាត]។ ឯកសារ D98/3.1.212 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 13.51.45 KH ERN 00355327-00355329 ["គាត់បានប្រាប់ថា ខ្លះលោតទម្លាក់ពីលើអគារ ខ្លះពេលភ្លើងរលត់ យកចង្កៀងដុត ខ្លះយកស្លាបប៉ាកាឬប៊ិចចាក់ខ្លួន"]។ ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 15.36.06 KH ERN 00347910-00347911 ["សៈតើលោកដែលធ្លាប់ឃើញស្ត្រីលោតពីលើ អាជាន់ខាងលើសម្លាប់ខ្លួនមកខាងក្រោមទេ?មានដែលឃើញគេលោតទេ? ឆ៖ [...]ខ្ញុំឃើញម្ដង "]។ ឯកសារ D114/37.1.66 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉េប ហូ KH ERN 00162686 ["អ្នកទោសនោះលោតពីលើអាគារស្លាប់។អាណឹងខ្ញុំឃើញផ្ទាល់ភ្នែក"]។ ឯកសារ D54/6.1.21 ជិន ម៉េត ប្រតិចារឹក ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.25.10 KH ERN 00350700-00350701 ["នៅពេលដែលពួកយើងនៅក្នុងបន្ទប់ទាំងបីនាក់ហ្នឹង បាននិយាយគ្នាថា បើសិនជាគេអាចស្រាយចំណងដៃយើង គេចងតែជើង ដៃយើងទាំងពីរអាចមាន មិនជាប់ចំណងទេ ពេលនោះពួកនាងខ្ញុំថា បើមានកន្លែងឯណាគួរសម ឬមួយក៏មានអ្វីមួយនៅជិតខ្លួនយើងទាំងអស់គ្នា បានរួមចិត្តរួមថ្លើមគ្នាថា យើងនឹងអាចសម្លាប់ខ្លួន ឬក៏ធ្វើឃាតជាអ្វីមួយ [...] គឺថាចង់ធ្វើឃាត តែវាអត់មានឱកាស"]។ ឯកសារ D98/3.1.29 សោម ម៉េត ប្រតិចារឹក ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ម៉ោង 15.37.27 KH ERN 00362804-00362807 ["ពេលនុង ខ្ញុំបានឃើញម្នាក់ដែរពេលដែលគេយកអ្នកទោសចេញពីកន្លែងខ្ញុំយាមទៅ"]។ ឯកសារ D98/3.1.257 សោម ម៉េត ប្រតិចារឹក ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ម៉ោង 15.32.30-15.35.55 KH ERN 00364024-00364026។ ឯកសារ D4.1.384 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សោម ម៉េត KH ERN 00163655 ["អ្នកទោសក៏ឈោងយកក្រមានោះមកចងក"]។ ឯកសារ D234/2.1.115 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 09.30.00-09.33.30 KH ERN 01251997-01251999។ ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.10.42 KH ERN 00348016-00348017 ["ស្លាបព្រាគឺឲ្យគ្រប់គ្នាអ៊ីចឹង ដល់ហូបហើយគេប្រមូលទៅវិញអស់ហើយគេមិនហ៊ានទុកទេរបស់របរដែលធ្វើអត្តឃាតខ្លួនឯងកើតនោះ"]។ ឯកសារ D98/1.2.9 គក ស្រស់ ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.17.29-10.20.04 KH ERN 00356719-00356721,ម៉ោង 11.20.00 KH ERN 00356731-003567732។ ឯកសារ D98/3.1.29 ឈុន ផល ប្រតិចារឹក ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ម៉ោង 09.57.35 KH ERN 00356714-00356715។ ឯកសារ D1.3.32.9 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈុន ផល KH ERN 00163808 ["វិន័យនៃការយាម គឺខ្លាចអ្នកទោសចងកសម្លាប់ខ្លួន [...] ព្រោះថាអ្នកទោសគឺសំរាប់ទុកសួរយកឯកសារ"]។ ឯកសារ D1.3.3.2 បញ្ជីឈ្មោះអ្នកទោសសម្លាប់ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៦ KH ERN 00008759 [កំណត់

កងពល ១៦៤ សឹម នាម ហៅ សុខ ផង ដែលបានចងកសម្លាប់ខ្លួននៅថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ១៩៧៧[2205]។

## ការសួរចម្លើយ និងការប្រើប្រាស់ទារុណកម្ម

569. ដូចដែលបានសារភាពដោយប្រធានមន្ទីរឃុំឃាំង និងអ្នកសួរចម្លើយនៅមន្ទីរស-២១ និងកត់ត្រាក្នុងចំណារ និងសៀវភៅកត់ត្រាដែលនៅសេសសល់របស់អ្នកសួរចម្លើយទាំងនោះ ការធ្វើទារុណកម្មត្រូវបានប្រើជាប្រព័ន្ធលើអ្នកទោសទាំងអស់ដែលត្រូវបានសួរចម្លើយនៅមន្ទីរស-២១ ដើម្បីទទួលបានចម្លើយសារភាពរបស់ពួកគេ។

### *ក) ការប្រើទារុណកម្មជាប្រព័ន្ធក្នុងអំឡុងពេលសួរចម្លើយនៅមន្ទីរស-២១*

570. ការសួរចម្លើយនៅមន្ទីរស-២១ ត្រូវបានធ្វើឡើងក្នុងបរិយាកាសបង្ខិតបង្ខំយ៉ាងខ្លាំង។ អ្នកទោសត្រូវបានជាប់ខ្នោះដៃ និងបិទមុខ នៅពេលដែលពួកគេត្រូវបានយកចេញពីបន្ទប់ឃុំឃាំងរបស់ពួកគេ និងត្រូវបានបណ្តើរដោយអ្នកយាមទៅកាន់បន្ទប់សួរចម្លើយ[2206] ដែលនៅទីនោះ ពួកគេត្រូវបានដាក់ខ្នោះជើងជាប់នឹងតុនៅពេលសួរចម្លើយ[2207]។ ពួកគេត្រូវបានសួរចម្លើយ ពេលខ្លះអស់រយៈពេលជា

---

អត្តសញ្ញាណលេខរៀងទី៦៥ គឺអេង ម៉ាការីន, “ចងកស្លាប់” នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៦]។ ឯកសារ D10.1.7 សៀវភៅសរសេរ ស ២១ “បញ្ជីសិក្ខិរបស់សន្តិបាលស២១” KH ERN 00007476 [“ដូចនេះយើងត្រូវប្រុងប្រយ័ត្ន [...] វាធ្វើអត្តឃាតខ្លួនវា ដើម្បីលក្ខខ្សែសង្វាក់”]។

2205 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសស ២១ របស់ ក.ស.ច.ស [កំណត់អត្តសញ្ញាណលេខរៀងទី១៣១៣៧ ជាអ្នកទោសដែលបានចងកសម្លាប់ខ្លួននៅថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៧]។

2206 ឯកសារ D234/2.1.107 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.12.36 KH ERN 01247088-01247090។ ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.40.05 KH ERN 01249436-01249437។ ឯកសារ D98/3.1.212 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.07.19-10.13.31 KH ERN 00355301-00355303,ម៉ោង 11.15.37 KH ERN 00355312-00355313។ ឯកសារ D1.3.32.36 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ខន KH ERN 00146629។ ឯកសារ D98/3.1.8 ប៊ូ ម៉េងប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.17.36-10.24.44 KH ERN 00348018-00348021។ ឯកសារ D98/3.1.94 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.59.07 KH ERN 00342768-00342769។

2207 ឯកសារ D234/2.1.107 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.12.36 KH ERN 01247088-01247090 [“វាដាក់ខ្នោះជើងឲ្យហើយ បានវាដោះខ្នោះដៃចេញ ស្រាយមុខចេញ។ អ៊ីចឹងពេលនោះខ្ញុំមើលឃើញ

ច្រើនខែ ជាវគ្គៗ ដែលចាប់ផ្តើមនៅម៉ោង ៧ ព្រឹក និងបញ្ចប់នៅម៉ោង ១០ ឬ ១១ យប់[2208] ក្នុងស្ថានភាពខ្សោយ ដោយសារតែកង្វះម្ហូបអាហារ និងដេកមិនគ្រប់គ្រាន់[2209]។ ដោយអាស្រ័យលើ

---

ហើយ អ្វីៗនៅក្នុងហ្នឹងខ្ញុំមើលឃើញទាំងអស់ មើលឃើញតាំងពីឈាមនៅមុំខាងស្តាំខ្ញុំហ្នឹងឈាមមួយកំភ្លួសហើយ អារំពាត់ហ្នឹងគឺថាមួយបាច់ធំនៅជិតអាតុវាហ្នឹង ហើយតុវាមានអង្គុលីលេខ មួយវាយដាក់ទីឡូហ្នឹង មានដាក់ទីឡូវាយ។ ពេលហ្នឹងវាសួរខ្ញុំ"]។ ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.40.05 KH ERN 01249436-01249437។ ឯកសារ D1.3.32.36 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ខន KH ERN 00146630 ["អ្នកទោសតែគេយកចេញពីក្នុងគុកដល់បន្ទប់យើងសួរ យើងយកសោរចាក់កងជើងដាក់នឹងតុ"]។ ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.21.25 KH ERN 00348019-0348020 ["គេចាប់ផ្តើមដាក់ខ្នោះ ដាក់រនងខ្លីហ្នឹងហើយ បានគេដាក់ខ្នោះដៃចេញ ហើយបានគេស្រាយមុខ។ គេស្រាយមុខ គេចាប់ផ្តើមវៃសួរចម្លើយ។គេសួរថា ខ្ញុំចូលសេអ៊ីអា កាហ្សេបេ ថ្ងៃណា?ខែណា?"]។ ឯកសារ D98/3.1.94 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.59.07-10.04.39 KH ERN 00342768-00342770។ ឯកសារ D4.1.354 បញ្ជីក្តាប់អ្នកទោសប្រចាំថ្ងៃ ពួកទី៥ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៦ KH ERN 00052815 [ង៉ាន់ គីមស៊ន់៖ "កងជើងដាក់មួយ [...] ខ្វាស់តុពីរ"], KH ERN 00052816 [សៅ ប៉េង៖"សោរខ្នោះ ច្រវ៉ាក់ ពិនិត្យត្រឹមត្រូវ ។កងជើងតឹងល្មម"], KH ERN 00052819 [គុយ ឆេងឡាយ: "ការដាក់ខ្នោះកង ២ តឹងល្មម ច្រវាក់ពាតឹកភ្ជាប់ជើងតុ"]។

2208 ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.40.05-09.43.48 KH ERN 01249436-01249438 ["មានតែរាប់ខែ [...] ជាក្រឹត្យក្រមនៅក្នុងនោះគឺអ្នកទោសត្រូវយកមកសួរម៉ោង ៧ ដល់ម៉ោង ១១ថ្ងៃពីម៉ោង២ទៅម៉ោង៥ពីម៉ោង៧យប់ទៅម៉ោង១១យប់"]។ ឯកសារ D98/3.1.212ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 11.30.04-11.34.02 KH ERN 00355306-00355308។ ឯកសារ D1.3.32.36 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ខន KH ERN 00146631-32។ ឯកសារD234/2.1.111 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.49.18 KH ERN 01249274-01249275 ["ការសួរចម្លើយរយៈពេលខ្លីបំផុតហ្នឹង អ្នកដែលអាចឆ្លើយមកដល់ឆ្លើយភ្លាម [...] គឺ១០ថ្ងៃ ទៅកន្លះខែ"]។ ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.07.03 KH ERN 01246987-01246988 ["វាវៃពេលព្រឹកហ្នឹងពីម៉ោង៧ព្រឹករហូតដល់ម៉ោងម៉ាដណ្តប់ម៉ោងមួយរហូតដល់ម៉ោង៥ ពីម៉ោង៦រហូតដល់ម៉ោង១០យប់"]។ ឯកសារ D4.1.247 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ម ណៃ KH ERN 00164387 ["មានអ្នកទោសខ្លះសួរយូររហូតដល់២ខែ"]។ ឯកសារ D98/3.1.94 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.15.14 KH ERN 00342772-00342773 [អធិប្បាយអំពី "បីវេន" នេះ "កម្មវិធីប្រចាំថ្ងៃរបស់កម្មាភិបាលសួរចម្លើយ"]។

2209 ឯកសារ D234/2.1.107 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.12.36 KH ERN 01247088-01247090 ["ខ្ញុំថាប្រហែលគេឲ្យខ្ញុំហូបទឹកបបរនឹងប្រហែលគេមិនចង់ឲ្យខ្ញុំតតាំងនឹងគេហើយបានគេឲ្យទឹកបបរហ្នឹង"]។ ឯកសារD234/2.1.106 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.17.23-11.20.05 KH ERN 01247003-01247004។ ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 09.48.21

ស្ថានភាពនៃការសួរចម្លើយរបស់ពួកគេ អ្នកទោសត្រូវបានចាត់ចែងឲ្យចូលក្រុមណាមួយដូចជា៖ *(i)* ក្រុមក្ដៅ ដែលវាយដំ និងធ្វើទារុណកម្មអ្នកទោសដើម្បីទទួលបានចម្លើយ *(ii)* ក្រុមអង្កៀម ដែលគេស្គាល់ថាជាក្រុមចងក្រងឯកសារ ដែលធ្វើការសួរចម្លើយយូរ ដែលក្នុងនោះអ្នកទោសត្រូវបានសួរសំណួរដដែលៗម្ដងហើយម្ដងទៀត និងត្រូវទទួលរងទារុណកម្មលើរូបរាងកាយ ដើម្បីទទួលបានចម្លើយតបដែលគេចង់បាន ឬ *(iii)* ក្រុមត្រជាក់ ដែលប្រើការបញ្ឆោត ការឃាឃី និងការគំរាមកំហែងជាពាក្យសម្ដី ប៉ុន្តែមិនធ្វើបាបរាងកាយឡើយ[2210]។

---

KH ERN 00348010-00348011 [“អត់មានកាកទេ [បបរ] […]ហើយខ្ញុំស្គមៗនៅតែកដៃប៉ុនដងវែកអស់ហើយ កំលាំងស្គមមែនទែន សឹងថា សិនបើលើកព្រនង់តដៃគេ ក៏តមិនកើតដែលពេលនុង […]”], ម៉ោង 15.05.44 KH ERN 00348062-00348063 [“ដល់យើងស្គមកំលាំងយើងអន់ហើយ បានគេបកស្បែកយើង ពាក្យថាបកស្បែកហ្នឹង គេយកទៅវ៉ៃ”]។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 13.44.13 KH ERN 01249383-01249384 [“អ្នកទោសដែលខ្ញុំសួរចម្លើយហ្នឹង […] រឹតតែស្គមទៅៗ ព្រោះអត់មានអីហូបគ្រប់គ្រាន់នៅក្នុងគុក”]។ ឯកសារ D4.1.386 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អៀម ហាន KH ERN 00163675 [“ដាក់ច្រវ៉ាក់ខ្ញុំ […] គេបង្អត់បាយនិងទឹកអស់រយៈពេលមួយអាទិត្យ”]។

2210 ឯកសារ D98/3.1.94 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.44.54 KH ERN 00342763-00342764 [“ផ្នែកខាងសួរចម្លើយ ចែកជាពាក្រុម […] ក្រុមត្រជាក់និយាយឲ្យចំគឺមិនប្រើទារុណកម្ម។ ក្រុមក្ដៅគឺដែកក្ដៅតែម្ដង សួរបានមួយរយៈហ្នឹងទៅ មើលទៅមិនកើតទេ គេវ៉ៃ។ ឯចំណែកក្រុមអង្កៀម គេប្រើពេលវេលាយូរចំពោះអ្នកទោសណាដែលគេត្រូវការចម្លើយគេសួរហើយសួរទៀត មួយលើកហើយមួយលើកទៀត”], ម៉ោង 09.56.38 KH ERN 00342767-00342768 [“ការសួរចម្លើយនៅស២១ គេមានហៅមានក្រុមមួយ យើងហៅថាក្រុមត្រជាក់ក៏ថាបាន ក៏ប៉ុន្តែខ្ញុំចូលចិត្តហៅថាពួកសួរបឋម ឬក្រុមសួរបឋម។មកដល់អត់វាយទេ ពួកហ្នឹងសួរ គិតតែពីសួរ ហើយសរុបដើម្បីយកសារសំខាន់។ដល់យកសារសំខាន់របស់ជនដែលត្រូវសួរហ្នឹងហើយ បាន មិត្តហ៊ី គាត់សម្រេចដោយពិគ្រោះនឹងខ្ញុំឬក៏មិនបាច់ពិគ្រោះគាត់សម្រេចរុញទៅឲ្យក្រុមណា?ក្រុមត្រជាក់ ក្រុមក្ដៅឬក៏ក្រុមអង្កៀម? ដល់គេរុញទៅបើក្រុមត្រជាក់វាពុះពារមិនរួចទេ គេរុញទៅឲ្យក្រុមអង្កៀមឬក៏រុញទៅឲ្យក្រុមក្ដៅលមើលសិន”]។ ឯកសារ D4.1.1117 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00154224-00154225 [“វិធីសាស្ត្រត្រជាក់៖មិនការប្រើទារុណកម្ម និងការជេរស្ដីទេ ប៉ុន្តែជាការប្រើការបញ្ចុះបញ្ចូលឃោសនា […] វិធីសាស្ត្រក្ដៅ៖មានការជេរស្ដី ការវាយដំ និងការធ្វើទារុណកម្មផ្សេងទៀតដែលបទបញ្ជាអនុញ្ញាតឲ្យធ្វើ។ វិធីសាស្ត្រអង្គាម៖ជាការពន្យល់លួងលោមដើម្បីបង្កើតភាពទុកចិត្តគ្នា និងបន្ទាប់មកជំរុញសួរដោយឲ្យគាត់សរសេរ។ទារុណកម្មត្រូវបានប្រើផងដែរ ប៉ុន្តែកម្រណាស់”]។ ឯកសារ D1.3.33.13 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00154925 [“ជាមួយ [យ៉ា]នេះ យើងបានប្រើវិធីអង្គាម – បានន័យថា វិធីត្រជាក់លាយឡំនឹងការធ្វើទារុណកម្ម”]។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.41.54 KH ERN 01249368 [“អ្នកទោសដែលគេធ្វើទារុណកម្មហើយអស់ចិត្តអស់ចង់ហើយ បានបញ្ជូនឲ្យខ្ញុំយកមកសួរថែមទៀតហៅថាជាក្រុមអង្កៀម

571. អ្នកសួរចម្លើយនៅមន្ទីរស-២១ ត្រូវបានណែនាំឲ្យប្រកាន់យក "ជំហរដាច់ខាត" ថា អ្នកទោសទាំងអស់គឺជាខ្មាំង ដែលគេត្រូវតែទាញយកចម្លើយសារភាពឲ្យទាល់តែបាន[2211]។ ក្នុងនាមជាប្រធាន

---

អង្កៀមសួរជីកឬសជីកគល់តទៅទៀត។មិនមែនឲ្យសុទ្ធជាអ្នកថ្មីទេ មានដែរ មានតិចតួចណាស់អ្នកថ្មី"]។ ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.09.18 KH ERN 01249472-01249473 ["ការសួរចម្លើយក្នុងក្រុមអង្កៀមនេះ គឺមិនមែនដឹងតែសួរ មិនធ្វើទារុណកម្មទេគឺសួរ ផង សួរត្រជាក់ផង សួរក្ដៅផង ធ្វើហិង្សាផង អ៊ីចឹងវារួមផ្សំទាំងអស់"]។ ឯកសារD98/3.1.212 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.38.445 KH ERN 00355308-00355309 ម៉ោង 15.30.44 KH ERN 003553487-00355348។ ឯកសារ D1.3.32.36 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប្រាក់ ខន KH ERN 0146623 ["ធម្មតាអ្នកទោសចូលម៉ោ ដូចថា អ្នកសំខាន់ៗគេចូលទៅក្រុមក្ដៅ"]។ ឯកសារ D4.1.346 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ម ណៃ KH ERN 00162885-86។ ឯកសារ D4.1.96 សៀវភៅសរសេរ ស២១ របស់ ម៉ម ណៃ ហៅចាន់ KH ERN 00077895 ["តាំងពីខែមេសា ឆ្នាំ៧៧ មានពួក៖ត្រជាក់,ក្ដៅ,ធ្វើឯកសារ,ពួកក"]។ ឯកសារD1.3.28.98 បញ្ជីឈ្មោះអ្នកទោស ស-២១ ដែលបានសួរចម្លើយហើយ ថ្ងៃទី៩ ខែមេសា ឆ្នាំ១៩៧៨។ ឯកសារ D1.3.28.110 បញ្ជីឈ្មោះអ្នកទោស ស-២១ ដែលបានសួរចម្លើយហើយ ថ្ងៃទី៩-១០ ខែឧសភា ឆ្នាំ១៩៧៨ KH ERN 00039908-00039911 [បែងចែកបញ្ជីសំរាប់អ្នកទោសដែលត្រូវសួរចម្លើយដោយក្រុមត្រជាក់ ក្រុមក្ដៅនិងក្រុមធ្វើឯកសារ]។ ឯកសារ D234/2.1.53 សៀវភៅកត់ត្រាមន្ទីរ ស ២១ KH ERN 00443015 [តារាងកំណត់អត្តសញ្ញាណ អ្នកសួរចម្លើយទាំង៤ ក្រុមនៅ ស ២១]។

2211 ឯកសារ D98/3.1.94 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.11.44 KH ERN 00342771-00342772 ["ក្នុងការអប់រំអ្នកសួរ សំខាន់ណាស់ហើយ ជាគន្លឹះគឺត្រូវតែឲ្យអ្នកសួរមានជំហរមួយដាច់ខាត។ មនុស្សដែលចាប់មកហើយ ត្រូវចាត់ទុកជាខ្មាំងបើមិត្តឯងមិនចាត់ទុកជាខ្មាំងមិត្តឯងសួរចម្លើយមិនចេញទេ នេះជាបញ្ហាធំ"]។ ឯកសារ D98/3.1.89 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 11.33.36-11.40.23 KH ERN 00338780-00338782។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.02.10-15.05.47 KH ERN 01249402-01249404។ ឯកសារ D98/3.1.136 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 09.53.58 KH ERN 00356210-00356212 [កម្មាភិបាល ស-២១ ត្រូវបានបញ្ចុះបញ្ចូលឲ្យប្រកាន់"គោលជំហរដាច់ខាតជាមួយខ្មាំង [...] យើងមើលខ្មាំងដូចជាសត្វជាធាតុអ៊ីចឹង អាហ្នឹងបានហ៊ានធ្វើទារុណកម្មខ្លាំង បានហ៊ានសួរចម្លើយខ្លាំង"]។ ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 09.04.46 KH ERN 01297750-01297751["ហើយមួយទៀតឲ្យស្គាល់ថា អ្នកដែលចាប់មក គឺជាខ្មាំងរបស់អង្គការ"]។ ឯកសារ D98/3.1.54 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 14.28.15 KH ERN 00354163-00354165 ["គោរពអង្គការវិន័យឲ្យទៅជាវណ្ណៈអធនរបស់អង្គការហើយឲ្យដាច់ខាតចំពោះខ្មាំង"]។ ឯកសារ D10.1.7 សៀវភៅកត់ត្រាមន្ទីរ ស២១ "បញ្ជីសិក្ខិរបស់សន្តិបាលស២១" KH ERN 00007447 ["ប្ដេជ្ញាសំរុកសួរឲ្យបានចម្លើយជូនបក្សដាច់ខាត"]។ ឯកសារ D4.1.96 ម៉ម ណៃ ហៅចាន់ សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយ ស ២១ EN 00184602។

មន្ទីរស-២១ ភារកិច្ចមួយក្នុងចំណោមភារកិច្ចដែលទទួលស្គាល់ដោយ ឌុច គឺត្រូវបណ្តុះបណ្តាលអ្នកសួរចម្លើយឱ្យ "ហ៊ានធ្វើទារុណកម្ម"[2212] ហើយគាត់បានរៀបចំវគ្គបណ្តុះបណ្តាលជាទៀងទាត់ ដែលក្នុងវគ្គទាំងនោះ អ្នកសួរចម្លើយនៅមន្ទីរស-២១ ត្រូវបានណែនាំអំពីរបៀបសួរចម្លើយ និងធ្វើទារុណកម្មអ្នកទោស[2213]។

572. ឌុច បានសារភាពថា ការប្រើប្រាស់ទារុណកម្មផ្លូវកាយ គឺ "ជៀសមិនរួច" នោះទេ ហើយថា មានតែមួយ ឬពីរករណីប៉ុណ្ណោះ ដែលអ្នកជាប់ឃុំនៅមន្ទីរស-២១ មិនត្រូវបានធ្វើទារុណកម្ម នៅពេល

---

2212 ឯកសារ D98/3.1.82 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ ម៉ោង 11.54.54 KH ERN 00325358 ["ទីពីរ ការអប់រំរៀនសូត្រដែលជំរុញឱ្យគេហ៊ានសួរ ហ៊ានធ្វើទារុណកម្ម [...] វាសុទ្ធតែនាំមកនូវការដែលចាប់មនុស្សថ្មីថែមទៀតមនុស្សដែលកំពុងមានសេរីភាព យើងត្រូវឱ្យមានចម្លើយឆ្លើយដាក់គេ។នេះការងារខ្ញុំដែលនៅជាប់នឹងមេ"]។

2213 ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.44.15 KH ERN 01249368-01249369 ["កន្លះខែមួយខែអីហ្នឹង គឺហៅទៅរៀនសូត្រនៅសាលានយោបាយមួយក្បែរផ្ទះឌុច បំពាក់បំប៉នពីវិធីសាស្ត្រសួរនិង វិធីសាស្ត្រធ្វើឯកសារនិងធ្វើទារុណកម្ម"], ម៉ោង 14.07.37 KH ERN 01249391-01249392 ["ចំពោះឌុចក៏ធ្លាប់បង្រៀនជាទូទៅដែរ ពេលហៅបុគ្គលិកនៅក្នុងសាលានយោបាយហ្នឹង បង្រៀនជាទូទៅ គឺប្រាប់ប្រើពីវិធីធ្វើបាបអ្នកទោស ធ្វើកុំឱ្យធ្ងន់ធ្ងរពេកខ្លាចស្លាប់ដាច់ចម្លើយ"]។ ឯកសារ D98/3.1.212 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.22.31-10.30.04 KH ERN 00355304-00355307។ ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.45.17 KH ERN 01247411-01247412 [ឌុចបានណែនាំថា "សួរចម្លើយធ្វើម៉េចឱ្យឆាប់បានចម្លើយពីអ្នកទោស"]។ ឯកសារ D4.1.344 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច មាន KH ERN 00162774, 00162776-77។ ឯកសារ D98/3.1.84 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ ម៉ោង 11.30.06 KH ERN 00325796-00325797 ["ខ្ញុំបង្រៀនបណ្តុះបណ្តាលកម្មាភិបាលសួរចម្លើយអំពីរបៀបសួរចម្លើយ [...] ខ្ញុំបង្រៀននេះ ក៏អាស្រ័យដោយខ្ញុំបានទៅជួបមេជាញឹកញាប់ មេណែនាំមកខ្ញុំយកមកបង្រៀន"]។ ឯកសារ D98/3.1.89 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 11.33.36-11.40.23 KH ERN 00338780-00338782, ម៉ោង11.51.05-12.03.28 KH ERN 00338785-00338791 ,ម៉ោង 15.59.48-16.03.23 KH ERN 00338823-00338825។ ឯកសារ D98/3.1.94 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 11.30.00 KH ERN 00342786-00342787 ["និយាយពីសារៈសំខាន់នៃទារុណកម្មច្បាស់ឱ្យគេ"]។ ឯកសារ D10.1.7 សៀវភៅកត់ត្រា ស ២១ បញ្ជីសិក្ខិរបស់សន្តិបាលស ២១ KH ERN 00007487 ["បក្សឱ្យវ៉ៃយើងវ៉ៃ ដោយម្ចាស់ការ វ៉ៃឱ្យនិយាយ មិនឱ្យងាប់ មិនឱ្យរត់រួច មិនឱ្យគ្រាំគ្រារហូតដល់ឈឺខាតយើង" (គូសបញ្ជាក់បន្ថែម)]។

សួរចម្លើយ[2214]។ កម្មាភិបាលផ្សេងទៀតនៅមន្ទីរស-២១ ក៏បានបញ្ជាក់ផងដែរថា ទារុណកម្មត្រូវបានប្រើប្រាស់ជាទៀងទាត់ក្នុងអំឡុងពេលសួរចម្លើយអ្នកទោស[2215]។ ដូចដែលបានណែនាំនៅក្នុងវគ្គបណ្តុះបណ្តាលមួយរបស់អ្នកសួរចម្លើយនៅមន្ទីរស-២១៖

> ខ្មាំងមិនសារភាពប្រាប់យើងដោយស្រួលៗនោះទេ។ ពេលណាពួកគេសារភាព នៅពេលយើងធ្វើនយោបាយ នោះពួកគេសារភាពនៅកម្រិតទាបបំផុតប៉ុណ្ណោះ។ **ទារុណកម្មគឺមិនអាចជៀសផុតនោះទេ។ វាគ្រាន់តែខុសគ្នា ទាក់ទងនឹងថាតើទារុណកម្មនោះតិច ឬច្រើន** តែប៉ុណ្ណឹង[2216]។

---

[2214] ឯកសារ D114/277.3 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.38.34 KH ERN 01311974-01311975 ["ទារុណកម្មចៀសមិនរួច ច្រើនតែចៀសមិនរួច។ផ្ទាល់ខ្លួនខ្ញុំដែលសួរចម្លើយ មានតែមួយហ្នឹងទេដែលជៀសរួច។ហើយមិត្តហ៊ិ សួរចម្លើយមានតែមួយហ្នឹងដែរ [...] ក្រៅពីនោះច្រើនតែជៀសមិនរួច"]។ឯកសារ D98/1.2.19 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៧ ខែមិនា ឆ្នាំ២០១២ ម៉ោង 09.35.07 KH ERN 00794030 ["ឯចំណែកទីពីរ តើទាំងអស់សុទ្ធតែទទួលទារុណកម្មរឿងអី? ខ្ញុំសូមឆ្លើយថា លើកលែងតែម្នាក់គត់គឺកុយ ធួន"], ម៉ោង 09.38.56 KH 00794031["ជាទូទៅទារុណកម្ម ចៀសមិនរួច"]។ ឯកសារ D10.1.64 សេចក្តីសន្និដ្ឋានដែលសរសេរចុងក្រោយរបស់ជនត្រូវចោទ កាំង ហ្កេកអ៊ាវ KH ERN 00404810 ["ទារុណកម្មច្រើនតែជៀសមិនរួច"]។ ឯកសារ D1.3.33.3 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00146486 ["អ្នកណាដែលគេយកទៅសួរច្រើនជៀសមិនរួចពីទារុណកម្ម លើកលែងករណីពិសេស ដូចករណី កុយ ធួនដែលមានបញ្ជាមកខ្ញុំមិនឲ្យធ្វើទារុណកម្ម"]។

[2215] ឯកសារ D234/2.1.111 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.44.59 KH ERN 01249273 ["មានតែម្នាក់នោះហើយ ដែលថាបានសួរចម្លើយដោយមិនបង្ខិតបង្ខំ មិនបានធ្វើទារុណកម្ម"]។ ឯកសារ D98/3.1.257 សោម ម៉េត ប្រតិចារឹក ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ម៉ោង 09.41.31 KH ERN 00363958-00363959 [បញ្ជាក់ពីចម្លើយលើកមុនថា "អ្នកទោសគ្រប់គ្នាត្រូវបានធ្វើទារុណកម្ម" និងកត់សម្គាល់ថា៖ "ការសួរចម្លើយគឺថាតែងតែមានហិង្សាហើយ"]។ ឯកសារ D98/3.1.212 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 11.35.00 KH ERN 00355317-00355318["ជាទូទៅអ្នកទោសគេ ត្រូវតែឲ្យធ្វើអំពើហិង្សា មិនថាស្ត្រី មិនថាបុរសទេ"]។ ឯកសារ D114/37.1.66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ្ចេប ហូ KH ERN 00162690 ["ខ្ញុំសង្កេតមើលទៅគឺថាទារុណកម្មទៅលើអ្នកទោសហ្នឹងគឺថាមួយរយភាគរយ [...] ខ្ញុំយាមនៅក្នុងគុកហ្នឹងគឺថាពេលអ្នកទោសត្រឡប់មកវិញគឺមានស្នាមរំពាត់"]។

[2216] ឯកសារ D10.1.7 សៀវភៅកត់ត្រា ស ២១ បញ្ជីសិក្ខាបទរបស់សន្តិបាលស២១ KH ERN 00007465 (គូសបញ្ជាក់បន្ថែម)។

*ខ) វិធីសាស្ត្រ និងទម្រង់ទារុណកម្មដែលបានប្រើនៅមន្ទីរស-២១*

573. ឌុច បានផ្តល់សក្ខីកម្មថាមានការធ្វើទារុណ ៤ បែប ដែលត្រូវបានប្រើជាចម្បងនៅមន្ទីរស-២១ ដោយមានការយល់ព្រមពីថ្នាក់លើរបស់គាត់៖ *(១)* វាយនឹងរំពាត់ *(២)* ឆក់ខ្សែភ្លើង *(៣)* យកស្បោងប្លាស្ទិកច្រកលើក្បាលដើម្បីឲ្យថប់ដង្ហើម និង *(៤)* ជ្រមុជក្បាលចូលក្នុងទឹក[2217]។

574. ការវាយអ្នកជាប់ឃុំដោយរំពាត់ ខ្សែ និងដំបង គឺជាវិធីសាស្ត្រលេចធ្លោនៃការធ្វើទារុណកម្មនៅមន្ទីរស-២១[2218]។ អ្នកសួរចម្លើយនៅមន្ទីរស-២១ ក៏បានប្រើប្រាស់វិធីឆក់ខ្សែភ្លើងជាប្រចាំផង

---

2217 ឯកសារ D4.1.1115 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00146662 ["មានការធ្វើទារុណកម្ម ៤ បែបដែលត្រូវបានប្រើដោយមានការយល់ព្រមពីសុន សេនៈទី១ វាយជនជាប់ឃុំនឹងរំពាត់ ទី២ ឆក់នឹងខ្សែភ្លើង ទី៣ យកស្បោងប្លាស្ទិកច្រកពីលើក្បាលដើម្បីថប់ដង្ហើម ទី៤ ដាក់កន្សែងគ្របលើមាត់និងច្រមុះនិងកំសៀវចាក់ទឹកត្រដាក់ពីលើ"]។ ឯកសារ D114/277.3 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.26.20 KH ERN 01311971-01311972 ["វិធីសាស្ត្រនេះ បងវនជាអ្នកណែនាំ [វ៉េត] [...] ខ្ញុំបាននិយាយជាមួយបងសុន សេនពីបញ្ហានេះ គាត់យល់ស្រប"]។ ឯកសារ D98/3.1.85 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ម៉ោង 09.55.13 KH ERN 00326077-00326079 ["នៅពេលដែលខ្ញុំចាប់ផ្តើមកាន់កាប់កិច្ចការហ្នឹងនៅស-២១ វិធីធ្វើទារុណកម្ម ដែលយើងខ្ញុំពិគ្រោះជាមួយនឹងណាត"]។ ឯកសារ D98/3.1.94 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.41.30 KH ERN 00342762-00342763["ខ្ញុំបានអនុញ្ញាតឲ្យធ្វើបួនយ៉ាង"], ម៉ោង 11.30.00 KH ERN 00342786-00342787 ["របៀបធ្វើទារុណកម្មវាឯកភាពគ្នារវាងខ្ញុំនិងណាត។កំណត់យក៤រូបភាពហ្នឹង"]។ សូមមើល ឯកសារ D98/3.1.212 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.26.29 KH ERN 00355305-00355306 ["បច្ចេកទេសធ្វើទារុណកម្ម [...] ទារុណកម្មឲ្យវ៉ៃនឹងរំពាត់ ឲ្យឆក់ខ្សែភ្លើង ឬក៏ច្រកស្បោង"]។ ឯកសារ D1.3.32.36 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ខន KH ERN 00146620។

2218 ឯកសារ D98/3.1.94 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.41.30 KH ERN 00342762-00342763["ខ្ញុំបានអនុញ្ញាតឲ្យធ្វើបួនយ៉ាង។ទីមួយ គឺវ៉ៃ វ៉ៃនេះមិនកំណត់វ៉ៃនឹងរំពាត់វ៉ៃនឹងអីៗទេ"], ម៉ោង 11.30.00 KH ERN 00342786-00342787 ["ទារុណកម្មជាទូទៅ ទាំងពីរនាក់ខ្ញុំហើយនិងណាត យល់ឃើញថាឯកភាពដូចគ្នាហ្នឹង គឺវ៉ៃ"]។ ឯកសារ D98/3.1.85 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ម៉ោង 09.55.13 KH ERN 00326077-00326079 ["វិធីបែបវ៉ៃដែលមានលក្ខណៈទូទៅនៅមន្ទីរស-២១"]។ ឯកសារ D4.1.1115 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00146662 ["វិធីដែលត្រូវបានប្រើច្រើនជាងគេ គឺការវាយនឹងរំពាត់ ពីព្រោះវិធីផ្សេងទៀតនាំខាតពេលវេលា"]។ ឯកសារ D114/277.3 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 10.30.01 KH ERN 01311983 [អ្នកសួរចម្លើយប្រើប្រាស់ "ផ្តៅ"]។ ម៉ោង 11.06.34 KH ERN 01311992 [ពួកគេប្រើខ្សែភ្លើងនៅតាមផ្ទះហើយ "វេញបញ្ចូលគ្នា ហើយក៏គេវាយ"]។ ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.12.27 KH ERN 01249473-

01249474 ["កាច់មែកត្របែក មែកទៀប ក្បែរៗកន្លែងនៅហ្នឹង យកមកវ៉ៃ ដៃ វ៉ៃជើង វ៉ៃខ្នងអីហ្នឹង"]។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.14.35 KH ERN 01249405-01249406, ម៉ោង 15.18.42 KH ERN 01249407។ ឯកសារ D234/2.1.114 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 09.13.54-09.18.20 KH ERN 01297838-01297840។ ឯកសារ D98/3.1.212 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.26.29 KH ERN 00355305-00355306 ["ទារុណកម្មឱ្យវ៉ៃនឹងរំពាត់"]។ ឯកសារ D234/2.1.106 ជុំ មុី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.26.25-11.28.30 KH ERN 01247005-01247007 ["អាទិត ហ្នឹងវាថា (ប្រាប់អាហ៊ី) វាថា បងអ្លែងមើល វាអត់ព្រមអត់អីទេ ពេលនោះអាហ៊ី ទាញរំពាត់ក្រាកមក វ៉ៃខ្ញុំ [...] វាយកអារំពាត់ហ្នឹង វ៉ៃក្បាលជង្គង់ខ្ញុំ"]។ឯកសារ D98/3.1.34 ជុំ មុី ប្រតិចារឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.59.03-10.03.34 KH ERN 00347937-00347939 ["មានរំពាត់ឫស្សី មានអាយើងបន្ទះរនាបមានមែកឈើអីធំៗប៉ុនមេដៃ ហើយពេលនុងគឺថាខ្ញុំមើលទៅម្ខាងហ្នឹង គឺថាមួយបាច់ៗប៉ុណ្ណឹង តែម្តងរំពាត់សម្រាប់[ប្រើ] វ៉ៃខ្ញុំបាទហ្នឹង [...]វ៉ៃមួយមែកឫស្សី [...] បាក់អស់ទៅ ឃើញគេយកមកទៀត"]។ ឯកសារ D234/2.1.111 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.24.45 KH ERN 01249266-01249267 ["ខ្ញុំឃើញតែការវ៉ៃនឹងមែកឈើ"]។ ឯកសារ D4.1.344 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច មាន KH ERN 00162777 ["ពេលអ្នកទោសមិនឆ្លើយ ខ្ញុំប្រាប់ហ៊ី ពេលនោះគាត់ឱ្យខ្ញុំកាច់មែកត្របែក មកឱ្យគាត់វាយ"]។ ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 09.37.17-09.41.37 KH ERN 00348008-00348009 ["គេសួរមើលស្រលាញ់មួយណា? [...] ម៉ម ណៃ ស្ទុះឆ្កែតចាប់រំពាត់វ៉ៃខ្ញុំ វ៉ៃមួយឆ្អែតមួយឆ្អន់បានម្នាក់មកវាយទៀត [...] គាត់ថារាប់ ហើយខ្ញុំរាប់ គាត់វាយដប់ ខ្ញុំរាប់បានដប់ គាត់អ្លែ! អញទើបតែវាយបានមួយអ្លែងរាប់ដប់ម៉េច។ខ្ញុំឈឺចុកចាប់ណាស់ [...] ពេលវាយម្តងៗគេសួរខ្ញុំ សួរអ្លែងចូល សេអ៊ីអា ថ្ងៃណា?ខែណា?ឆ្នាំណា?អ្នកណានាំចូល?ឈ្មោះអី?អ្នកនាំចូល។ខ្ញុំមិនដឹង ខ្ញុំឆ្លើយថា មិនដឹង [...] គេចេះតែវ៉ៃៗទាល់តែបែកអស់ហើយខ្នង"]។ ឯកសារ D98/3.1.29 សោម ម៉េត ប្រតិចារឹក ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ម៉ោង 15.30.15 KH ERN 00362803-00362804 ["គាត់ [អ្នកសួរចម្លើយឈ្មោះ ទុយ] បានសួរថា 'ម៉េចយើងឆ្លើយមិនឆ្លើយ និយាយមិននិយាយ និយាយឱ្យអស់មើល វាយការណ៍ជូនបក្សឱ្យអស់ទៅ លាក់អីទៀត' [...] អ្នកទោសក៏ឆ្លើយថា 'ខ្ញុំវាយការណ៍ជូនបក្ស ជូនអង្គការអស់ហើយ ខ្ញុំមិនដឹងមានពាក្យអីឆ្លើយទៀតទេ' អាទុយទាញរំពាត់ផ្តៅ វាយអ្នកទោស"]។ ឯកសារ D4.1.384 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ម៉េត KH ERN 00163654 ["គេគ្រាន់តែដើរចុះដើរឡើងៗ ដល់ពេលអ្នកទោសដឹងខ្លួនគេយករំពាត់ផ្តៅវ៉ៃម្តងទៀត"]។ ឯកសារ D114/37.1.70 របាយការណ៍ចម្លើយរបស់ឈ្មោះដាញ់ ស៊ីយ៉ាន ថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៦ KH ERN 00172772 [ចំណារ៖ "សួរឱ្យច្បាស់និងទារុណកម្មឱ្យធ្ងន់មធ្យមទិសដៅគឺរកខ្សែសង្វាក់។ វាយឱ្យឈប់និយាយថាទៅស្រុកឃុនឱ្យជីតាព្យាបាលរោគម្រេញ និងរាំងថ្ងៃ"]។ឯកសារ D4.1.1113 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00185492 [បង្ហាញថា ចំណារនៅលើឯកសារ D114/37.1.70 គឺជាសំណេរគាត់]។ ឯកសារ D10.1.108 សម្រង់ចម្លើយសារភាពរបស់អ៊ុំ សឿន (សេចក្តីដកស្រង់)ថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧៥ EN ERN 00223146, 00223142 [ចំណារថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧៥៖ "គាត់ក្មេងតែក្បាលរឹង ដូច្នេះគេវ៉ៃគាត់ទាល់តែសន្លប់", ចំណារ៖ "មិនឆ្លើយ! ធ្វើទារុណកម្ម!"]។ ឯកសារ D98/3.1.84 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩ ម៉ោង 15.45.08 KH ERN 00325833-

ដែរ[2219]។ ពួកគេបានឆក់ដោយភ្ជាប់ខ្សែភ្លើងទៅនឹងត្រចៀក ម្រាមជើង និងប្រដាប់ភេទរបស់អ្នកទោស[2220] ដែលជាញឹកញាប់នាំឱ្យពួកគេសន្លប់បាត់ស្មារតី[2221]។ លោក *David Chandler* បញ្ជាក់

00325834 [បង្ហាញថា ចំណារចុងក្រោយគឺជាសំណេរគាត់]។ ឯកសារ D10.1.7 សៀវភៅកត់ត្រា មន្ទីរ ស ២១ បញ្ជីសិក្ខិរបស់សន្តិបាល ស ២១ KH ERN 00007474 ["បក្សឲ្យវ៉ៃអ្នកទោសស្រី នឹងរំពាត់ដាច់ខាតមិនវាយនឹងដៃ យើងកុំល្មើស"]។ ឯកសារ D114/35.3 សៀវភៅនិពន្ធដោយ ដេវីដ ឆាណ្ឌល័រ ៖ សម្លេងពីមន្ទីរស-២១ EN ERN 00192823 [បញ្ជីវិធីសាស្ត្រធ្វើទារុណកម្មនៅស-២១ រួមមាន៖ "ការវ៉ៃនឹងដៃ រំពាត់ មេឃឈើ ឆក់ខ្សែភ្លើង"]។

2219 ឯកសារ D98/3.1.94 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.41.30 KH ERN 00342762-00342763 ["ទីពីរ គឺអនុញ្ញាតឲ្យឆក់ខ្សែភ្លើងដោយប្រើទូរសព្ទដៃ"]។ ឯកសារ D114/277.3 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 10.30.01 KH ERN 01311983 ["មិត្តប៉ុន គាត់ប្រើអាខ្សែភ្លើងជញ្ជាំងតែម្តងអា២២០វ៉ុល"]។ ឯកសារ D98/3.1.85 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ម៉ោង 09.55.13 KH ERN 00326077-00326078 ["នេះជារូបភាពដែលណាត គាត់ពេញចិត្ត"]។ ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.37.43 KH ERN 01246991 ["ឆក់ខ្សែភ្លើងហ្នឹងមានពីរផង"]។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.21.00 KH ERN 01249407-01249408 ["ឆក់ខ្សែភ្លើងគឺមិនមែនខ្សែភ្លើងអគ្គីសនីយើងប្រើតាមផ្ទះធម្មតាទេ គឺឆក់គេហៅថាអាគីង្កក់ៗ ទូរសព្ទជំនាន់អាមេរិកាំង"]។ ឯកសារ D4.1.245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ខន KH ERN 00146595។ ឯកសារ D1.3.32.36 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ខន KH ERN 00146620 [គាត់ត្រូវបានណែនាំដោយឌុចលើការឆក់ខ្សែភ្លើង]។ ឯកសារ D234/2.1.111 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.24.45 KH ERN 01249266-01249267 ["ប្រដាប់គេឆក់ វ៉ៃអាហ្នឹងគេ ហៅគួកវ៉ៃ អាហ្នឹងជាដូចឌីណាម៉ូ គេ [កាក់, ជាអ្នកសួរចម្លើយជាន់ខ្ពស់] វ៉ៃទៅចេញភ្លើងខ្លាំង ភ្លើងតិចអ៊ីចឹងទៅ វ៉ៃតាមគេចង់ឲ្យវ៉ៃខ្លាំង គឺឆក់ខ្លាំង វ៉ៃតិចឆក់តិច"]។ ឯកសារ D4.1.344 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច មាន KH ERN 00162779។ ឯកសារ D4.1.378 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ ផៃ KH ERN 00163629 ["ឃើញអ្នកសួរចម្លើយ [...]ឆក់ខ្សែភ្លើង [អ្នកទោស]"]។ ឯកសារ D4.1.379 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តយ តេង KH ERN 00163777-78។ ឯកសារ D234/2.1.114 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី២ ខែឧសភាឆ្នាំ២០១៦ ម៉ោង 15.46.38 KH ERN 01297913-01297914["បាទ មាន ឆក់ខ្សែភ្លើង"]។ឯកសារ D10.1.30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ ធីម KH ERN 00163713 [ពេទ្យនៅស-២១ បានព្យាបាល" អ្នកទោសដែលត្រូវសួរចម្លើយដោយឆក់ខ្សែភ្លើង"]។ ឯកសារ D114/35.3 សៀវភៅនិពន្ធដោយ ដេវីដ ឆាណ្ឌល័រ ៖ សម្លេងពីមន្ទីរស-២១ EN ERN 00192823។ ឯកសារ D10.1.3 របាយការណ៍ស-២១អំពីការសួរចម្លើយ កែ គឹមហួត ហៅ សុទ្ធ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៧៧ ["ដល់ពេលយប់ យើងទៅសួរចម្លើយគាត់ម្តងទៀតដោយប្រើខ្សែភ្លើងឆក់ លើកនេះធ្ងន់ធ្ងរណាស់។ គាត់វង្វេងវង្វាន់និយាយមិនចេញ"]។ ឯកសារ D10.1.111 ចម្លើយរបស់ឈ្មោះសួរ ហ៊ាង ហៅ យ៉ុម ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៨ KH ERN 00173743 ["តែពីរឿងខ្សែសង្វាក់ វាមិនសុខចិត្តនិយាយ ទទឹមនឹងនេះខ្ញុំក៏ដាក់ខ្សែភ្លើងវាខ្លះទៀត"]។ ឯកសារ D10.1.51 ចម្លើយសារភាពរបស់ ប៊ូ ផាត ហៅហង្ស ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ EN ERN

00768234 [“របាយការណ៍ម្សិលមិញគ្មានមូលដ្ឋានទេ ពីព្រោះខ្ញុំសរសេរក្រោមការបង្ខិតបង្ខំពីអ្នកសួរចម្លើយសន្តិបាល ដែលបានគម្រាមវ៉ៃ និងឆក់ខ្សែភ្លើងខ្ញុំឱ្យស្លាប់”]។ ឯកសារ D10.1.108 សម្រង់ចម្លើយសារភាពរបស់អ៊ុំ សឿន (សេចក្តីដកស្រង់) KH ERN 00172863 [បញ្ជាក់ថាគាត់“មានចិត្តចង់ចងក សម្លាប់ខ្លួន” ក្រោយពីអ្នកសួរចម្លើយ “វាយឆក់ខ្សែភ្លើងដោយសារខ្ញុំមិនសារភាពកំហុសខ្លួនប្រាប់ដល់អង្គការដែលមកពន្យល់ខ្ញុំតាំងពីដំបូងមក”]។ ឯកសារ D114/277.3 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 11.14.41 KH ERN 01311994 [កំណត់អត្តសញ្ញាណ ប៊ុន ជាអ្នកដែលសួរចម្លើយអ្នកទោសឈ្មោះ អ៊ុំ សឿន]។

2220 ឯកសារ D234/2.1.107 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.12.36 KH ERN 01247088-01247090 [“ក្រោយមកបានវាយកអាខ្សែភ្លើងដាក់ក្នុងរុនត្រចៀករបស់ខ្ញុំ”]។ ឯកសារ D234/2.1.111 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.24.45 KH ERN 01249266-01249267 [“ភាគច្រើនកៀបនៅលើស្លឹកត្រចៀក”]។ ឯកសារ D4.1.344 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច មាន KH ERN 00162777។ ឯកសារD98.3.1.29 សោម ម៉េត ប្រតិចារឹក ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ម៉ោង 15.30.15 KH ERN 00362803-00362804 [“បានមួយសន្ទុះទុយ ទាញខ្សែភ្លើងមកទៀត យកខ្សែភ្លើងមកចងមេជើងអ្នកទោស ហើយយកឫស្សីមួយកំណាត់ប្រហែលជាមួយម៉ែតជាងហ្នឹង គេយកគជាមួយខ្សែភ្លើងយករុកត្រចៀកអ្នកទោស”]។ ឯកសារ D4.1.384 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ម៉េត KH ERN 00163653 [“ជួនកាលមានឱ្យអ្នកទោសស្រាតខោ ហើយយកប្រដាប់ឆក់ៗប្រដាប់ភេទ ឬក៏ឆក់ត្រចៀក”]។ ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.27.40 KH ERN 00348021-00348023 [រៀបរាប់អំពីការឆក់ខ្សែភ្លើងក្បែរកេរ្តិ៍ភេទគាត់“ក្បែរភ្លៅ”]។ ឯកសារ D114/277.3 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 11.11.47 KH ERN 01311993-01311994 [ណាត ឬ អ្នកផ្សេងបានប្រាប់ថាខ្សែភ្លើងនោះគឺ “ចងមេជើងម្ខាងមួយ”]។ ឯកសារ D98/3.1.94 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 13.48.10 KH ERN 00342797-00342798 [“ខ្ញុំដែលតែឮការឆក់មនុស្សប្រុសម្នាក់ ហើយធ្វើឱ្យប្រដាប់ភេទរបស់មនុស្សប្រុសនោះស្លាប់”]។ ឯកសារ D98/3.1.89 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 16.18.55 KH ERN 00338828-00338829 [រៀបរាប់អំពីហេតុការណ៍ដែលប៊ុន ប្រើប្រាស់ខ្សែភ្លើងឆក់ពងស្វាសអ្នកទោស]។

2221 ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.21.00-15.23.56 KH ERN 01249407-01249409។ ឯកសារ D4.1.245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ខន KH ERN 00146600 [“ពេលធ្វើទារុណកម្មពេលហ្នឹង គឺអត់មានសារភាពទេ ទាល់តែអ្នកទោសនារីហ្នឹង សន្លប់ឆក់ខ្សែភ្លើងពេកទៅ វ៉ៃហើយឆក់ខ្សែភ្លើងសន្លប់អត់ដឹងខ្លួន”]។ ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.37.43 KH ERN 01246991។ ឯកសារ D234/2.1.107 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.12.36 KH ERN 01247088-01247090។ ឯកសារ D98/3.1.34 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.09.44-10.13.52 KH ERN 00347940-00347943។ ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.27.40 KH ERN 00348021-00348023[រៀបរាប់ពីការឆក់ខ្សែភ្លើងដែលធ្វើឱ្យគាត់ដួល “សន្លប់បាត់មាត់ឈឹង”]។ ឯកសារ D98/3.1.29 សោម ម៉េត ប្រតិចារឹក ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ម៉ោង 15.30.15 KH ERN 00362803-00362804។ ឯកសារ D4.1.384 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី

ថា វិធីឆក់ខ្សែភ្លើងត្រូវបានប្រើ "ញឹកញាប់មែនទែន" នៅមន្ទីរស-២១ ដល់ថ្នាក់អ្នកទោសទទួលបានការណែនាំ "កុំឱ្យស្រែកនៅពេលដែលគេឆក់នោះ"[2222]។

575. លេខាធិការភូមិភាគពិសេស (និងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នាពេលអនាគត) វន វ៉េត បានបង្រៀន ឌុច អំពីបច្ចេកទេសនៃការប្រើថង់ប្លាស្ទិចដើម្បីខ្ទប់ដង្ហើមអ្នកទោសក្នុងអំឡុងពេលសួរចម្លើយ[2223]។ អ្នកសួរចម្លើយនៅមន្ទីរស-២១ បញ្ជាក់ថា ពួកគេត្រូវបានទទួលការណែនាំ និងប្រើវិធីសាស្ត្រនៃការធ្វើទារុណកម្មនេះ[2224]។ ឌុច បានសារភាពថា អ្នកទោសម្នាក់បានស្លាប់ ខណៈ

---

សោម ម៉េត KH ERN 00163653។ឯកសារ D114/35.3 សៀវភៅនិពន្ធដោយ ដេវីដ ឆាណ្តល័រ ៖ សម្លេងពីមន្ទីរស-២១ EN ERN 00192825 ["កំណត់សម្គាល់របស់អ្នកសួរចម្លើយលើចម្លើយសារភាពមួយចំនួនបង្ហាញថា ជាញឹកញាប់ អ្នកទោសដួល និងឆ្លើយសារភាព 'យ៉ាងពេញលេញ' នៅពេលអ្នកសួរចម្លើយគំរាមឆក់ខ្សែភ្លើង"]។

2222 ឯកសារ D114/35.3 សៀវភៅនិពន្ធដោយ ដេវីដ ឆាណ្តល័រ ៖ សម្លេងពីមន្ទីរស-២១ EN ERN 00192824 ["ការឆក់ខ្សែភ្លើង បានប្រើមកលើអ្នកទោសជាទូទៅមែនទែន រហូតដល់គេសរសេរសេចក្តីណែនាំអ្នកទោសគ្រប់រូបកុំឱ្យស្រែកនៅពេលគេឆក់ខ្សែភ្លើង។ សេចក្តីណែនាំប្រាប់ថា បើមិនស្តាប់តាមអ្នកសួរចម្លើយ ត្រូវពិន័យ១០ រំពាត់ ឬ'ត្រូវឆក់ខ្សែភ្លើងប្រាំដង'"]។ សូមមើល ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.05.47 KH ERN 01249403-01249404 ["មិនឱ្យអ្នកទោសនិយាយខ្លាំងៗ"]។

2223 ឯកសារ D114/277.3 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.24.45-09.27.42 KH ERN, ម៉ោង 10.53.26-11.02.27 KH ERN 01311989-01311992។ ឯកសារ D98/3.1.85 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៨ ម៉ោង 09.55.13 KH ERN 00326077-00326079 ["កាលដែលខ្ញុំនៅម១៣ នោះគឺបងវន គឺ វន វ៉េត គាត់ពេញចិត្តណាស់នឹង ច្រកស្បោងផ្លាស្ទិក"]។ ឯកសារ D98/3.1.94 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ម៉ោង 11.30.00 KH ERN 00342786-00342787។ ឯកសារ D98/1.2.15 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៩ ខែមិនា ឆ្នាំ២០១២ ម៉ោង 15.41.09 KH ERN 00791573 [វ៉ន វេត បានណែនាំថាក្រោយពីគ្របក្បាលអ្នកទោសនឹងស្បោងហើយ៖ "មិត្តត្រូវមើលអាសរសៃកត្រង់ណេះ បើវាភ័យតក់ៗ អាហ្នឹងហើយមានខ្លួនគិញ"]។

2224 ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.14.10 KH ERN 01249393-01249394 ["មានអ្នកមិនៗទទួលកំហុស មិនសារភាព ទាល់ធ្វើទារុណកម្មវ៉ៃ ច្រកស្បោង [...] ច្រកអីចឹងទៅបាន សារភាព"], ម៉ោង 14.21.16 KH ERN 01249395 ["ច្រកស្បោង ច្រកអី"]។ម៉ោង 15.23.56 KH ERN 01249408-01249409 ["ដល់ពេលឱ្យប្រើប្លាស្ទិកច្រកក្បាលហ្នឹង គឺយើងមើលតាមសភាពការណ៍ដែរ តែពេលណាអ្នកទោសហ្នឹងរាងថប់ខ្លាំងយើងដកចេញមក កាលណាអ្នកទោសហ្នឹងមិនទាន់ដូចថា នៅអាចរកដង្ហើមបានអាហ្នឹងទុកហ្នឹងហើយ។ដល់តែពេលរាងថប់ខ្លាំងដកចេញមក។ មើលតាមសភាពការណ៍ ដាក់ស្តែងមិនកំណត់នាទីទេ"]។ ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.18.47-14.22.52 KH ERN 01249475-01249477។ ឯកសារD234/2.1.114 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ ម៉ោង

ពេលខ្ទប់ដង្ហើម[2225]។ ឌុច ក៏បានផ្តល់សក្ខីកម្មផងដែរថា សុន សេន បានឯកសារឱ្យប្រើទម្រង់ជ្រមុជក្បាលចូលក្នុងទឹក ដែលតាមរយៈវិធីនេះ អ្នកសួរចម្លើយបានប្រើក្រម៉ា ឬកន្សែងគ្របមុខអ្នកទោស ហើយចាក់ទឹកលើពួកគេ[2226]។

---

09.54.50-09.56.29 KH ERN 01297850-01297851។ ឯកសារ D98/3.1.212 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.26.29 KH ERN 00355305-00355306 [“គេបង្រៀនឱ្យ […]ច្រកស្បោង”], ម៉ោង 11.08.05 KH ERN 00355310-00355311[រៀបរាប់អំពីការធ្វើទារុណកម្មអ្នកទោសនារី៖ “អ្នកធ្វើទារុណកម្មវ៉ៃឆក់ខ្សែភ្លើង ច្រកស្បោងរហូតដល់សន្លប់”]។ ឯកសារ D4.1.245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ខន KH ERN 00146595 [“គេប្រាប់ថា ឱ្យធ្វើទារុណកម្មគ្របស្បោងកៅស៊ូ ឆក់ខ្សែភ្លើង ដើម្បីកុំឱ្យខ្មាំងដំបៅពេញខ្លួនរបួសពេញខ្លួន”]។ ឯកសារ D1.3.32.36 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ខន KH ERN 00146620។ ឯកសារ D98.3.1.29 សោម ម៉េត ប្រតិចារឹក ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ម៉ោង 15.48.03-16.00.00 KH ERN 00362807-00362811 បញ្ជាក់ពី ឯកសារ D4.1.384 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ម៉េត KH ERN 00163653 [“ធ្វើទារុណកម្មវ៉ៃអ្នកទោសឱ្យឆ្លើយ […] ច្រកស្បោងឱ្យថប់ដង្ហើម”]។

2225 ឯកសារ D98/3.1.95 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.34.58 KH ERN 00344042-00344043 [“ម្នាក់នោះត្រូវគេច្រកស្បោងផ្លាស្ទិកស្លាប់ ឯការដែលរាយការណ៍ដល់ខ្ញុំឃើញមានច្បាស់លាស់បំផុត គឺអារឿងដែលស្លាប់ឈ្មោះពីង គឹមសៀ ហ្នឹងឯង ព្រោះពីង គឹមសៀ នោះសំខាន់គួរសមដែរ”]។ ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស ២១ របស់ ក.ស.ច.ស [កំណត់អត្តសញ្ញាណលេខរៀងទី៦៩៤៦ ឈ្មោះ ពីង គឹមសៀ អតីតគ្រូពេទ្យនៅភូមិភាគពាយ័ព្យ ចូលមន្ទីរស-២១ ថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៧ និង “ស្លាប់ដោយការធ្វើទារុណកម្ម […] នៅនឹងកន្លែងសួរចម្លើយ” នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ១៩៧៧]។

2226 ឯកសារ D114/277.3 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.24.10-09.26.20 KH ERN 01311971-01311972។ ឯកសារ D98/3.1.85 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩ ម៉ោង 09.55.13 KH ERN 00326077-00326079 [“ឯចំណែកវិធីទី៤ គឺវិធីរបស់អធិការនគរបាលជាតិ ប៉ូលីសរបស់ លន់ នល់ និយាយឱ្យចំដាក់កន្សែងលើច្រមុះអីចេះហើយ យកទឹកកំសៀវច្រូចចូលច្រមុះ”]។ ឯកសារ D98/3.1.94 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.41.30 KH ERN 00342762-00342763 [“ឱ្យច្រកទឹកតាមច្រមុះ”], ម៉ោង 11.55.07 KH ERN 00342793-00342794 [“ការធ្វើទារុណកម្មបែបនេះ […] ជនរងគ្រោះពិតជាមានអារម្មណ៍ដូចជាលង់ទឹកស្លាប់អ៊ីចឹងមែន”]។ ឯកសារ D4.1.1115 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00146662 [វិធីធ្វើទារុណកម្ម “ប្រើដោយមានការយល់ព្រមពីសុន សេន”]។ សូមមើល ឯកសារ D234/2.1.112 ប្រាក់ ខនប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.07.37 KH ERN 01249391-01249392 [“មានបង្រៀនជាបន្តបន្ទាប់ វិធីច្រកស្បោង ច្រកទឹក […] សុទ្ធតែវិធីប្រើរបស់ឌុចបង្រៀន”]។ ឯកសារ D114/35.3 សៀវភៅនិពន្ធដោយ ដេវីដ ឆាណ្ឌល័រ ៖ សម្លេងពីមន្ទីរស-២១ EN ERN 00192823។ ឯកសារ D54/80.1.38 ប៊ុន-ទុយ សៀវភៅកំណត់ហេតុរបស់អ្នកសួរចម្លើយនៅមន្ទីរស-២១ EN ERN 00184511 [“យើង

576. វិធីសាស្ត្រធ្វើទារុណកម្មដទៃទៀតដែលត្រូវបានប្រើនៅមន្ទីរស-២១ រួមមាន៖ ការដុតដោយភ្លើងបារី និងចង្កៀង[2227] ធ្វើឲ្យត្រជាក់ដោយប្រើទឹកត្រជាក់ និងកង្ហារ[2228] ចោះ ឬដកក្រចកដៃ និងក្រចកជើង[2229] បញ្ចូលលាមក និងទឹកនោមដោយបង្ខំ[2230] ប្រើឈើរុកចូលប្រដាប់បន្តពូជរបស់ស្ត្រី[2231] និងរឹតបន្តឹងខ្នោះជើងរបស់អ្នកទោស[2232]។

---

ភ្លេចរឿងធ្វើទារុណកម្ម នៅពេលណាដែលយើងខឹង មិនទប់កំហឹង ដូចជានៅពេលដែលខ្លាំងសរសេរមិនត្រឹមត្រូវ។ មួយទៀត នៅពេលដែលយើងសប្បាយជ្រុលនឹងការស្រោចទឹកលើអ្នកទោស"]។

2227 ឯកសារ D114/35.3 សៀវភៅនិពន្ធដោយ ដេវីដ ឆាណ្ឌលរ័ ៖ សម្លេងពីមន្ទីរស-២១ EN ERN 00192823 [បញ្ជីនៃវិធីសាស្ត្រធ្វើទារុណកម្មនៅមន្ទីរស-២១ រួមមាន "ការអុជនឹងបារី"]។ ឯកសារ D98/1.2.8 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 14.38.12 KH ERN 00344425-00344427 ["រឿងដុតបារីទៅលើក្រចកអីៗហ្នឹង ខ្ញុំជឿថា អាចខ្លះធ្វើ"]។ ឯកសារ D1.3.32.24 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ ផៃ KH ERN 00078670-00078671["ពេលខ្ញុំយាម ខ្ញុំបានឃើញវាយការធ្វើទារុណកម្មលើអ្នកទោស [...] បញ្ចាំងភ្លើងហ្វាដាក់ខ្លួនដើម្បីឲ្យអ្នកទោសក្តៅ ដូចជាហាលថ្ងៃក្តៅ បែកក្រហែង។ ឧបករណ៍បញ្ចាំងភ្លើងហ្វាដាក់នេះ ធ្វើឲ្យអ្នកទោសក្តៅរហូតទ្រាំមិនបាន ហើយព្រមឆ្លើយ"]។

2228 ឯកសារ D114/277.5 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 11.21.57-11.27.31 KH ERN 01311924-01311926 [រៀបរាប់អំពីការធ្វើទារុណកម្មដែលប្រើនៅក្នុងពេលសួរចម្លើយ វ៉ន វេត៖ "ខែ១១ នេះជាខែរងារ គេយកកង្ហារទៅបើកៗហើយគេបាចទឹក ឬក៏ស្រោចទឹក បងវននោះ ឲ្យរងារ [...] គេដាក់ទឹកកកទៅក្នុងធុង ហើយគេជះអាទឹកកកហ្នឹង ទៅលើអាកង្ហារ គេបើកទៅ"]។ ឯកសារ D114/37.1.7 បទសម្ភាសន៍ជាមួយឌុច ថ្ងៃទី៤-៦ ខែឧសភា ឆ្នាំ១៩៩៩ EN 001850261។ ឯកសារ D4.1.384 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ម៉ែត KH ERN 00163654 ["មានពេលខ្លះ ពេលធ្វើទារុណកម្មខ្លាំង គេចាក់ទឹកលើខ្លួនអ្នកទោស ហើយនឹងកម្រាលសំរាប់គេង ហើយបើកកង្ហារធ្វើឲ្យអ្នកទោសរងារ"]។

2229 ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.21.16 KH ERN 01249395 ["រឿងផ្នែកទារុណកម្ម គេយកដង្កាប់ចាប់ក្រចក យកម្ជុលចាក់ក្រចក"]។ ឯកសារ D234/2.1.114 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 11.02.31KH ERN 01297863-01297864 ["របៀបរបបធ្វើបាបអ្នកទោស រឿងដកក្រចកហ្នឹង គឺឌុចបានហៅទៅសាលានយោបាយហ្នឹងគឺបង្រៀនប្រាប់ជាការយកម្ជុល អាម្ជុលបារាំងមានក្បាលមូលៗហ្នឹងយកទៅចាក់"]។ ឯកសារ D1.3.32.36 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ខន KH ERN 00146620។ ឯកសារ D4.1.245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ខន KH ERN 00146595។ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៩៨ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.35.40-10.37.43 KH ERN 01246990-01246991,ម៉ោង 11.28.30-11.31.30 KH ERN 01247006-01247007,ម៉ោង 13.44.05-13.46.33 KH ERN 01247011-01247012។ ឯកសារ D234/2.1.107 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.12.36 KH ERN 01247088-01247090។ឯកសារ D98/3.1.34 ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩

ម៉ោង 10.03.34-10.06.55 KH ERN 00347938-00347940។ ឯកសារ D234/2.1.114 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី ២ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.19.19 KH ERN 01297905-01297906 ["គេប្រាប់ៗប្រធានពេទ្យ ហើយខ្ញុំអ្នកដើរចែកថ្នាំព្យាបាលដូចជារបួស ដកក្រចក ដកអីហ្នឹង ខ្ញុំព្យាបាលថាមើលប្រយ័ត្នប្រយែងមែនទែន"], ម៉ោង 15.42.26 KH ERN 01297912-01297913["អ្នកទោសគេប្រាប់ដែរថា អ្នកសួរចម្លើយដកពីរដង្កាប់ដូចជាក្រចកដៃ ក្រចកជើង"]។ ឯកសារ D234/2.1.115 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 09.10.14 KH ERN 01251991-012519992។ ឯកសារ D10.1.30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ ធីម KH ERN 00163711 ។ ឯកសារ D98/3.1.146 សេក ដន ប្រតិចារឹក ថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៩ ម៉ោង 09.33.05 KH ERN 00358965-00358966 [ពេទ្យស ២១៖ "បាត់ក្រចកដៃ"]។ ឯកសារ D4.1.384 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោម ម៉េត KH ERN 00163653 [សាក្សីបានឃើញគេដកក្រចកដៃជើងពេលកំពុងឃាមបន្ទប់សួរចម្លើយ]។ ឯកសារ D4.1.364 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពឿយ ប៉ែល KH ERN 00186567។ ឯកសារ D4.1.388 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ ណាត KH ERN 00163718-19។ ឯកសារ D98/3.1.94 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង, 15.11.27 KH ERN 00342810-00342812 [សារភាពថា "ការចាក់ឬការដកក្រចកជើង"មានកើតឡើង តែអះអាងថាក្រោយមកគាត់ "កំហែង" អ្នកសួរចម្លើយឲ្យឈប់]។

2230 ឯកសារ D10.1.3 របាយការណ៍ស-២១ អំពីការសួរចម្លើយ កែ គឹមហួត [បកប្រែក្រៅផ្លូវការពីភាសាបារាំង៖ "នៅរសៀលថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៧៧ យើងបានវ៉ៃវាមួយលើកទៀត។ ឆក់ខ្សែភ្លើង និងឲ្យវាស៊ីអាចម៍។ លើកនេះ វាដេរអ្នកវ៉ៃវាយ៉ាងចាស់ដៃ ហើយនិយាយថា 'សូមអញ្ជើញវ៉ៃអញឲ្យងាប់ទៅ'។ យើងបានឲ្យវាស៊ីអាចម៍អស់ពីរបីស្លាបព្រា"]។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.07.37 KH ERN 01249391-01249392 ["ឲ្យផឹកទឹកនោម ឲ្យស៊ីលាមកអីហ្នឹង អាហ្នឹងគឺសុទ្ធតែវិធីប្រើរបស់ឌុចបង្រៀន"]។ ឯកសារ D98/3.1.212 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 15.26.18-15.30.44 KH ERN 00355346-003553348។ ឯកសារ D114/277.6 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 14.15.12 KH ERN 01319718-01319719 [ពិភាក្សាអំពី កែ គឹមហួត៖ "គឺអ្នកទោសហ្នឹងហើយ ដែលឌុយវ៉ៃបង្ខំគាត់ឲ្យហូប ពិសាលាមកខ្លួនឯង"]។ ឯកសារ D98/3.1.94 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 15.41.58 KH ERN 00342818-00342819 ["ខ្ញុំដឹងក៏ដោយ មិនដឹងក៏ដោយ វាពិតជាកើតទៅលើគ្រូខ្ញុំ។គេធ្វើមែនក៏ប៉ុន្តែ ខ្ញុំអនុគ្រោះគេ"]។ ឯកសារ D98/3.1.76 ការដាក់តម្កល់ការអត្ថាធិប្បាយជាភាសាខ្មែររបស់លោក កាំង ហ្គេកអ៊ាវ KH ERN 00188746 ["មិត្តឌុយបង្ខំ លោកសាស្ត្រាចារ្យ កែ គឹមហួត ឲ្យហូបអាចម៍ [...] ថ្វីត្បិតតែធ្ងន់ធ្ងរ ថ្វីត្បិតតែប៉ះពាល់អារម្មណ៍ ខ្ញុំយ៉ាងជូរចត់ ក៏ខ្ញុំមិនមានសេចក្តីក្លាហាន គ្រប់គ្រាន់ សូមឃាត់ខ្លួនជនល្មើស ដោយរង់ចាំឲ្យសុន សេន ដែលដឹងរឿងនេះថា តែគាត់មិនថា"]។ ឯកសារ D4.1.1111 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00177623 ["ចំពោះការប្រើទារុណកម្ម ខ្ញុំបានប្រគល់ការសួរចម្លើយឲ្យទៅ ទុយ ខ្ញុំលែងហ៊ានអះអាងថា ទារុណកម្មដែលរៀបរាប់នោះ មិនត្រូវបានប្រើប្រាស់ទៀតហើយ។តាមការពិតខ្ញុំទទួលស្គាល់ថាមានការប្រើទារុណកម្មពិតមែន"]។

2231 ឯកសារ D114/277.4 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 09.04.48-09.14.16 KH ERN 01311814-013118817។ ឯកសារ D98/3.1.94 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩

577. ទម្រង់នៃការសួរចម្លើយដែលហៅថា "វិធីសាស្ត្រត្រជាក់" មួយចំនួន ត្រូវបានបង្កើតឡើងដើម្បី ឲ្យមានការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ ភាពតានតឹងផ្លូវចិត្តយ៉ាងខ្លាំង និងដូច្នេះ ក៏ជាទារុណកម្មផងដែរ។ ទារុណកម្មផ្លូវចិត្តដែលប្រើប្រាស់ដោយអ្នកសួរចម្លើយរួមមាន៖ ការគំរាមកំហែងដល់ "សុខុមាលភាព" របស់ប្តី ឬប្រពន្ធ និងកូនរបស់អ្នកទោស[2233] ការបង្ខំអ្នកទោសឲ្យសំពះរូបភ្លែដែលមានក្បាលជា ហូជីមិញ និងប្រធានាធិបតីសហរដ្ឋអាមេរិក[2234] និង "ការគំរាមកំហែង បង្វែរអារម្មណ៍

---

ម៉ោង 15.17.17 KH ERN 00342812 ["អ្នកសួរចម្លើយប្រុសយកឈើទៅដាក់ក្នុងប្រដាប់ភេទស្ត្រីម្នាក់គឺអ្នកគ្រូខឹម សារឿន"]។

[2232] ឯកសារ D54/6.1.21 ណាំ ម៉ុន ប្រតិចារឹក ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 14.33.52 KH ERN 00350741-00350742 [អ្នកទោសស្ត្រី៖ "ពេលសួរចម្លើយខ្ញុំគឺវាអត់វាយនឹងរំពាត់ទេ វារឹតនឹងខ្នោះជើងតែម្តង"]។

[2233] ឯកសារ D4.1.729 សេចក្តីរាយការណ៍របស់ប៉ុនជូន ខុច ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៧៦ KH ERN 00053000 ["យើងទទួលការណែនាំពីបងខុច [...] រំលឹកអំពីសុខទុក្ខប្រពន្ធកូន ឃាត់ខ្លួនប្រពន្ធកូនដឹងទេ ពេលមកនេះប្រពន្ធដឹងថាទៅណាដែរ"]។ ឯកសារ D114/277.3 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 13.42.13-13.44.40 KH ERN 01312001-01312002 [ពិភាក្សាអំពីឯកសារឯកសារ D4.1.729 និងការសួរចម្លើយ យ៉ា៖ "ប្រពន្ធគាត់ទើបតែសម្រាលកូន និងរំលឹកគាត់ថា ការឆ្លើយសារភាពធ្វើឲ្យគាត់គិតគូរពីសុខទុក្ខរបស់ប្រពន្ធកូន។ នេះជាការអនុវត្តនៅពេលនោះ"]។ ឯកសារ D4.1.1107 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00164349 ["យើងបានសម្រេចគាបសង្កត់គាត់ ដោយនិយាយអំពីប្រពន្ធនិងកូនរបស់គាត់ ដែលគាត់ស្រឡាញ់យ៉ាងខ្លាំង (គំនិតនេះចេញមកពីសុន សេន ប៉ុន្តែ យើងទាំងបីនាក់ សុន សេន ប៉ុន និង ខ្ញុំ សុទ្ធតែយល់ព្រមក្នុងការធ្វើរបៀបនេះ"]។ ឯកសារ D234/2.1.111 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ម៉ោង 09.46.55-09.49.18 KH ERN 01249273-01249275 [បញ្ជាក់ថា គាត់បានទទួល"ការណែនាំស្រដៀងគ្នា"នឹងការណែនាំដែលបានរៀបរាប់នៅក្នុងឯកសារ D4.1.729]។ ឯកសារ D234/2.1.114 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 09.32.18 KH ERN 01297842-01297843 ["សួរឲ្យគាត់នឹកគិតពីប្រពន្ធកូនរបស់គាត់ ទើបបានគាត់សារភាព"]។ ឯកសារ D10.1.7 សៀវភៅកត់ត្រា ស ២១ បញ្ជីស្ថិតិរបស់សន្តិបាលស២១ KH ERN 00007466-00007467 ["រូបភាពឃោសនា"ចំនួនប្រាំបួន ឬ "គៀបខាងនយោបាយ" ប្រើជាវិធីសាស្ត្រសួរចម្លើយ រួមមាន៖ "(ឃ) អូសទាញសញ្ចេតនាឲ្យវាវិលវល់នៅក្នុងរង្វង់គ្រួសារប្រពន្ធកូន អាយុជីវិតវា [...]កុំរឹងរូសនាំឲ្យរឿងកាន់តែធ្ងន់ កុំឲ្យធ្វើទារុណកម្មទាន់ឬក៏ធ្វើអ្វីធ្ងន់ទៀតនាំឲ្យលំបាកដល់សុខភាពផង"], KH ERN 00007469 ["ឲ្យវានឹកឃើញគ្រួសារ ឪពុកម្តាយ ប្រពន្ធកូនវា អាយុជីវិតវា"]។ ឯកសារ D114/277.3 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 13.39.04 KH ERN 01312000-01312001 [យោងលើការដកស្រង់ពីឯកសារ D10.1.17៖ "ខ្ញុំកាលនោះ ចាត់ទុកវិធីសាស្ត្រនេះ ជាវិធីសាស្ត្រត្រជាក់"]។

[2234] ឯកសារ D114/277.3 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 10.33.18-10.36.03 KH ERN 01311983-01311984,ម៉ោង 11.22.35-11.25.40 KH ERN 01311996-01311997។ ឯកសារ D98/3.1.94 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 13.48.10 KH ERN 00342797-00342798 ["បានជា

បំបែកពួកគេដោយភាពប៉ិនប្រសព្វ រៀបចំឈុតឆាកតូចៗ ដើម្បីឲ្យពួកគេងាយប្រៀនប្រដៅ និង អស់សង្ឃឹម ដោយមើលឃើញថា ពួកគេមិនអាចទប់ទល់បានតទៅទៀតទេ ”[2235]។

*គ) របួសដែលបង្កឡើងលើអ្នកទោសក្នុងអំឡុងពេលសួរចម្លើយ*

578. ទម្រង់នៃការធ្វើទារុណកម្មដែលត្រូវបានអនុញ្ញាតឲ្យប្រើជាទូទៅនៅមន្ទីរស-២១ បានបង្កឲ្យមាន ការឈឺចាប់ និងការរងគ្រោះធ្ងន់ធ្ងរ ទាំងផ្លូវកាយ និងផ្លូវចិត្ត ដល់អ្នកទោសដែលត្រូវបានសួរចម្លើយ។ ប៊ូ ម៉េង ត្រូវរងការវាយដំ វាត់នឹងរំពាត់ និងឆក់ខ្សែភ្លើងដែលភ្ជាប់នឹងភ្លៅខាងក្នុងរបស់គាត់ក្បែរ ប្រដាប់ភេទជាច្រើនដង[2236]។ ការវាយដំលើខ្នង និងក្បាលរបស់គាត់បានបន្សល់ទុកស្នាមជាអចិន្ត្រៃ

---

ឃើញគេប្រើរូបភាពមួយសំពះរូបឆ្កែ [...] សំពះរូបឆ្កែក៏វាជាឧក្រិដ្ឋកម្មមួយបែបខាងផ្លូវចិត្ត [...] ខ្ញុំឲ្យសំពះរូបឆ្កែនេះ – ឆ្កែមួយគូររូបក្បាលហូជីមិញ ឆ្កែមួយទៀតគូររូបក្បាលជេសុន"], ម៉ោង 15.41.58 KH ERN 00342818-00342819 ["មានៗ ការអប់រំពីខាងលើទៅពីខ្ញុំ"]។ ឯកសារ D98/1.2.8 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 14.38.12 KH ERN 00344425-00344427 ["សំពះរូបឆ្កែដំបូងគេធ្វើមែន ដល់ក្រោយមកខ្ញុំឃើញ ខ្ញុំអនុម័តទទួលយក [...] អានេះទារុណកម្ម ខាងផ្លូវចិត្តហើយ"]។ ឯកសារ D98/3.1.89 កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង16.10.17-14.14.09 KH ERN00338826-00338828 ។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.08.25 KH ERN 01249404-01249405 ["គោលដៅគឺ បន្ទាបបន្ថោកអ្នកទោស។ បើអ្នកឯងមិនព្រមនិយាយ មិនព្រមសារភាព ទៅសំពះរូបឆ្កែទៅ"]។ ឯកសារ D10.1.111 ចម្លើយរបស់ឈ្មោះសួរ ប៉ាង ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៨ KH ERN 00173743 ["ខ្ញុំក៏ឲ្យវាថ្វាយបង្គំរូបឆ្កែ ពីរយៈនោះវាក៏មិនសុខចិត្តថ្វាយដែរ ទន្ទឹមនឹងនោះខ្ញុំក៏បានវ៉ៃវាខ្លះរយៈនោះវាក៏សុខចិត្តទទួលខ្លួនវាថាក្បត់"]។ ឯកសារ D114/35.3 សៀវភៅនិពន្ធដោយ ដេវីដ ឆាណ្ឌល័រ ៖ សម្លេងពីមន្ទីរស-២១, EN ERN 00192825-27 ["'ការសំពះ' គឺជាការប្រព្រឹត្តបន្ថោកបន្ទាបមួយក្នុងចំណោមការប្រព្រឹត្តបន្ថោកបន្ទាបជាច្រើន ដែលមានបំណងបង្ខំអ្នកទោសឲ្យទទួលស្គាល់ឋានៈរបស់ខ្លួនជាសត្វធាតុ។ ចៅហ្វាយបរទេសរបស់អ្នកទោសត្រូវគេបង្ហាញជាសត្វ ហើយមានតែសត្វប៉ុណ្ណោះដែលសំពះពួកគេ"]។ សូមមើល ឯកសារ D4.1.96 សៀវភៅកំណត់ហេតុរបស់ម៉ម ណៃ ហៅចាន់ សៀវភៅកំណត់ហេតុរបស់អ្នកសួរចម្លើយនៅមន្ទីរស-២១ [រៀបរាប់ដូចគ្នានៅក្នុងផ្នែកដែលមិនបានបកប្រែជាភាសាអង់គ្លេសនៅក្នុងសំណុំរឿងនេះ]។

2235 ឯកសារ D10.1.7 សៀវភៅកត់ត្រា ស ២១ បញ្ជីសិក្ខិរបស់សន្តិបាលស២១ KH ERN 00007465-00007467 [កថាខណ្ឌ(ខ) "រូបភាពឃោសនា" ចំនួនប្រាំបួន ឬ "គៀបខាងនយោបាយ" ប្រើដើម្បី"គៀបវាជាប់ជានិច្ច ជាបន្តបន្ទាប់គ្រប់ពេលវេលា"]។

2236 ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 09.41.37 KH ERN 00348009 ["ដំបៅពេញខ្នងបែកខ្នងខ្ទេចហើយ លើកម្រាលឥដ្ឋដែលខ្ញុំដេកផ្កាប់មុខ ហ្នឹងគឺសុទ្ធតែឈាមពេញឥដ្ឋអស់ហើយ"], ម៉ោង 10.33.11 KH ERN 00348023-00348024 ["យើងខ្ញុំដេកវាឈឺពេក វាសុទ្ធតែដំបៅ [...] ហ៊ឹម ហ៊ុយ យកឈើ ឬ

យ៍ដល់គាត់ និងធ្វើឲ្យគាត់ថ្លង់[2237]។ ជុំ មុី ត្រូវបានសួរចម្លើយ និងរងការធ្វើទារុណកម្មអស់រយៈពេល ១២ ថ្ងៃ និង ១២ យប់[2238]។ គាត់បានរងការវាយដំ[2239] ឆក់[2240] និងដកក្រចកជើងចេញពីជើងរបស់គាត់[2241]។ ជាលទ្ធផល ជុំ មុី បានក្លាយជាមនុស្សថ្លង់ និងពិការភ្នែក[2242]។

---

ស្សីរំពាត់រុកដំបៅខ្នង ដេកខ្នងផ្ទាល់ដីសុទ្ធតែគ្រាប់គ្រោះ គ្រាប់អីចូលក្នុងដំបៅ"], ម៉ោង14.28.16 KH ERN 00348056-00348057 ["នៅចំគល់ភ្លៅតែម្ដង។ គ្រាន់តែឆក់វ៉ាប់ សន្លប់ភ្លឹងតែម្ដង"]។

2237 ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹក ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 10.33.11 KH ERN 00348023-00348024 ["សៈ [...] ឥលូវស្លាកស្នាមដែលរបួសដោយសារវ៉ៃហ្នឹង នៅៗសល់ដល់សព្វថ្ងៃទេអ៊ំ ឬក៏ផ្សះជាអស់ហើយ? ឆៈផ្សះជាហើយ។ ប៉ុន្តែស្លាកស្នាមពេញខ្នងហ្នឹងតាំងពីដែមកក៏ឃើញដែរ វាត់ចុងរំពាត់ ដេកផ្កាប់មុខវ៉ៃតាមចិត្ត"]។ ឯកសារ D1.3.32.4 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៊ូ ម៉េង KH ERN 00080534។ សូមមើល ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 15.19.00-15.21.50 KH ERN 00347905-00347906 បញ្ជាក់ពីឯកសារ D114/37.1.68 វ៉ាន់ ណាត គំនូរគុកមួយរបស់កម្ពុជា KH ERN 00323463 [សាក្សីបានឃើញប៊ូ ម៉េង "ដោយមានបង់រុំនៅកន្លែងរបួសដែលមានឈាមពេញខ្លួន រូបរាងស្គមស្គាំងនៅតែស្បែកនិងឆ្អឹង"]។

2238 ឯកសារ D234/2.1.106 ជុំ មុី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.07.03 KH ERN 01246987-01246988 ["យើងនៅក្នុងអាបន្ទប់តូចហ្នឹង គឺថាវាវ៉ៃ វាសួរចម្លើយ វាវ៉ៃ១២ថ្ងៃ ១២យប់"]។ ឯកសារ D98/3.1.34 ជុំ មុី ប្រតិចារឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.36.08-09.38.42 KH ERN 00347930-00347932។

2239 ឯកសារ D234/2.1.106 ជុំ មុី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.35.40 KH ERN 01246990-01246991 ["ពេលវាយ ខ្ញុំយកដែររងអ៊ីចឹង បាក់អាកូនដៃហ្នឹងមួយ"]។ ឯកសារ D98/3.1.34 ជុំ មុី ប្រតិចារឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.59.03-10.06.55 KH ERN 00347937-00347940។

2240 ឯកសារ D234/2.1.106 ជុំ មុី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.37.43 KH ERN 01246991 ["វាយកអាខ្សែភ្លើងមកញាត់ស្លឹកត្រចៀកយើងហ្នឹង [...] យើងសន្លប់មួយសន្ទុះធំ [...] ឆក់ពីរដង"]។ ឯកសារ D98/3.1.34 ជុំ មុី ប្រតិចារឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.09.44 KH ERN 00347940-00347941។

2241 ឯកសារ D234/2.1.107 ជុំ មុី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.12.36 KH ERN 01247088-01247090 ["វាដកក្រចកមេជើងយើងម្ខាងវាដកទាញអត់ដាច់ វាកន្ត្រាក់ៗអ៊ីចឹងយើងចង់សន្លប់"]។ ឯកសារ D234/2.1.106 ជុំ មុី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 11.28.30 KH ERN 01247006-01247007 ["ការដកក្រចកជើង គឺថាវាដកទាំងពីរ [...] វាគ្រាន់តែយកអាល់កុលមកចាក់តែប៉ុណ្ណឹងទេ អត់មានលាបថ្នាំលាបអីទេ"]។ ឯកសារ D98/3.1.34 ជុំ មុី ប្រតិចារឹក ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.03.34-10.09.44 KH ERN 00347938-00347941។

2242 ឯកសារ D234/2.1.106 ជុំ មុី ប្រតិចារឹក ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៦ ម៉ោង 10.37.43 KH ERN 01246991 ["ភ្នែកមើលឃើញព្រិលៗទេ បានតែមួយខាងនេះទេ"]។ ឯកសារ D234/2.1.107 ជុំ មុី ប្រតិចារឹក ថ្ងៃទី១៩ ខែមេសា

579. ការបង្កឱ្យមានរបួសយ៉ាងធ្ងន់ធ្ងរទៅលើអ្នកទោស ដែលបានឆ្លងកាត់ការសួរចម្លើយ ក៏ត្រូវបានបញ្ជាក់អះអាងផងដែរ ដោយចម្លើយសារភាពរបស់កម្មាភិបាលមន្ទីរស-២១ និងកំណត់ត្រាពីមន្ទីរឃុំឃាំងដែលនៅសេសសល់។ អ្នកយាមមន្ទីរស-២១ បានផ្តល់សក្ខីកម្មថា អ្នកទោសដែលវិលត្រឡប់ពីការសួរចម្លើយវិញ ឃើញមានរបួស និងស្នាមវាយដំយ៉ាងច្បាស់[2243]។ គ្រូពេទ្យនៅមន្ទីរស-២១ ដែលបានទទួលការចាត់តាំងឱ្យព្យាបាលរបួសអ្នកទោសដែលរងទារុណកម្ម ដើម្បីឱ្យការ

---

ឆ្នាំ២០១៦ ម៉ោង 11.12.36 KH ERN 01247088-01247090 ["ម្ខាងហ្នឹងឥលូវប្រើការអត់កើតទេ អត់បានទេ។គោះអ៊ីចឹង ដូចទឹកចូលអ៊ីចឹង ទឹងៗ ហើយបិទម្ខាងនេះស្រែកម៉េចក៏អត់ឮដែរ"]។

2243 ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.07.11 KH ERN 01247401-01247402 ["ធ្លាប់ឃើញមានស្នាមបែកខ្នង ដំបៅខ្នង ដំបៅដៃជើងអីអ៊ីចឹង"]។ ឯកសារ D98/3.1.147 ឡាច មាន ប្រតិចារឹក ថ្ងៃទី៤ ខែសីហា ឆ្នាំ២០០៩ ម៉ោង 13.54.33 KH ERN 00360497-00360498 [អ្នកទោសត្រឡប់មកវិញ "ជាំមុខ បែកខ្នង"ហើយនិយាយថាត្រូវគេវាយពេលដែលអ្នកសួរចម្លើយចោទពួកគេថា"លាក់"]។ ឯកសារ D4.1.344 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច មាន KH ERN 00162775។ ឯកសារ D234/2.1.116 ហ៊ីម ហ៊ុយ ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.02.55-15.04.52 KH ERN 01297812-01297814។ ឯកសារ D4.1.244 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ីម ហ៊ុយ KH ERN00146638 ["គ្រាន់តែឃើញមានបែកខ្នងអី ហ្នឹងពេលគេយកអ្នកទោសមកវិញ"]។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.18.42KH ERN 01249407 [ក្រោយពេលសួរចម្លើយ អ្នកទោសមាន"ដាច់ និងដំបៅ"នៅលើដងខ្លួន]។ ឯកសារ D98/3.1.212 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២១ ខែ កក្កដា ឆ្នាំ២០០៩ ម៉ោង 11.04.00 KH ERN 00355309-00355310 ["អ្នកទោសក្រុមអង្កៀមហ្នឹងគឺច្រើនតែអ្នកទោសមានរបួសមានដំបៅហើយអ៊ីចឹង ទៅហើយបញ្ជូនឱ្យខ្ញុំខាងក្រុមអង្កៀមហ្នឹងយកមកសួរបន្តទៀត"]។ ឯកសារ D98/3.1.136 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 09.13.30 KH ERN 00356198-00356202។ ឯកសារ D1.3.32.36 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ខន KH ERN 00146627។ ឯកសារ D98/3.1.29 ឈុន ផល ប្រតិចារឹក ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ម៉ោង 10.32.30 KH ERN 00362760 ["ខ្ញុំគ្រាន់ឃើញជាស្នាមជារបួសតែប៉ុណ្ណឹង"]។ ឯកសារ D1.3.32.9 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុន ផល KH ERN 00163808-09។ ឯកសារ D98/3.1.29 សោម ម៉េត ប្រតិចារឹក ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ម៉ោង 15.37.27 KH ERN 00362804-00362805 ["ឃើញខ្នងហ្នឹងក៏បែកឈាម ឃើញក្រចកហ្នឹងក៏ស្នាមឃើញគេដក"]។ ឯកសារ D4.1.386 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អៀម ហន KH ERN 00163676 ["នាំយកមកវិញ អ្នកខ្លះមានស្នាមរបួស។ ខ្លះស្លាប់នៅក្នុងបន្ទប់ក្រោយពេលត្រឡប់មកវិញ"]។ ឯកសារ D4.1.383 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខៀវ ចេស KH ERN 00163641["ពេលមកវិញ មានជាំមុខ បែកខ្នង"]។ ឯកសារ D4.1.387 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ែន ហេង KH ERN 00163688 ["ជួនកាលខ្ញុំឃើញអ្នកទោស ខ្លះសន្លប់ត្រូវ គេសែងយកមកទុកនៅកន្លែងអ្នកយាមវិញ។ អ្នកទោសមានតែខោខ្លីមួយទេ ហេតុដូច្នេះហើយទើបខ្ញុំអាចមើលឃើញស្នាមគេវៃលើខ្នង"]។

សួរចម្លើយរបស់ពួកគេអាចបន្តទៀតបាន[2244] បញ្ជាក់ថា អ្នកទោសបែបនោះ "បានរងរបួសជាខ្លាំង" ដោយមាន "របួសនៅលើខ្នង" ដែល "មានរបួសស្បែកខាងក្រៅ" បាត់ក្រចកជើង និងក្រចកដៃ និង "របែក" ស្លឹកត្រចៀក[2245]។ កំណត់ត្រាពីមន្ទីរស-២១ ដែលនៅសេសសល់ មានកត់ត្រា

2244 ឯកសារ D98/3.1.83 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩ ម៉ោង 10.24.30 KH ERN 00325494-00325495។ ឯកសារ D98/3.1.93 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 16.22.39 KH ERN 00341953-00341954 ["សេវាពេទ្យគឺមាន [...] ក្នុងគោលបំណងថែរក្សាមនុស្ស សម្រាប់តែសួរចម្លើយឱ្យចប់ប៉ុណ្ណឹងឯង"]។ ឯកសារ D98/3.1.146 សេក ដន ប្រតិចារឹក ថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៩ ម៉ោង 10.03.16 KH ERN 00358974-00358978។ ឯកសារ D4.1.382 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេក ដន KH ERN 00163818។ ឯកសារ D234/2.1.114 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.15.20-15.17.33 KH ERN 01297904-01297905។ ឯកសារ D10.1.30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ ធីម KH ERN 00163711។ ឯកសារ D234/2.1.114 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 09.18.20 KH ERN 01297839-01297840។ ឯកសារ D98/3.1.165 ណាំ ម៉ុន ប្រតិចារឹក ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 11.06.25 KH ERN 00351042-00351043។

2245 ឯកសារ D234/2.1.114 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 15.04.14 KH ERN 01297901 [រៀបរាប់អំពីទម្លាប់ប្រចាំថ្ងៃរបស់គាត់៖ "ពេលព្រឹកខ្ញុំចែកថ្នាំឱ្យអ្នកទោស លាងរបួសឱ្យអ្នកទោស [...] ខ្ញុំមានរវល់គក់កុំប្រេស គក់បង់ បង់ដែលបិទរបួស"], ម៉ោង 15.39.54 KH ERN 01297911-01297912 ["អ្នកទោសខ្ញុំដែលខ្ញុំទៅព្យាបាលលាងរបួសហ្នឹងគឺប្រាប់ខ្ញុំថា គេវាយ បានគេសួរចម្លើយវាយៗខ្នង"], ម៉ោង 15.55.27 KH ERN 01297916-01297917 ["គាត់ឈឺចាប់ជាខ្លាំងណាស់។ រកស្អីប្រៀបធៀបផ្ទឹមមិនបាន បើដកក្រចក វ៉ៃផង"]។ ឯកសារ D234/2.1.115 ម៉ក់ ធីម ប្រតិចារឹក ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 09.10.14 KH ERN 01251991-01251992 ["បានឃើញដាក់ស្តែង បានដកក្រចកដៃ ក្រចកជើង ហើយវាយខ្នងបានជាខ្ញុំបានលាងរបួស ព្យាបាលអ្នកទោស"], ម៉ោង 09.12.21 KH ERN 01251992-01251993["វាមានទ្រង់ទ្រាយធំ ហើយនិងតូចហើយវាមានស្នាមឆ្នូតៗវែងៗហើយមិនមែនតែរូងដល់ក្នុង ប៉ុន្តែបកស្បែកស្នាម"], ម៉ោង 10.49.56-10.53.43 KH ERN 01252016-01252017 [សាក្សីបានឃើញដោយផ្ទាល់គេដកក្រចកអ្នក "១ខែ ឬមួយក៏កន្លះខែ" ហើយឃើញអ្នកទោសបីបួននាក់បែកខ្នងរបួស"ធ្ងន់ៗ"]។ ឯកសារ D10.1.30 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ក់ ធីម KH ERN 00163711។ ឯកសារ D4.1.363 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉េស ម៉ាត់ KH ERN 00186562 ["ខ្ញុំធ្លាប់នៅយាមជិត ម៉ក់ ស៊ីធីម ឃើញគាត់លាងរបួស"]។ ឯកសារ D98/3.1.146 សេក ដន ប្រតិចារឹក ថ្ងៃទី៣ ខែសីហា ឆ្នាំ២០០៩ ម៉ោង 09.29.56-09.33.05 KH ERN 00358964-00358966 ["មានដំបៅ ក្រចកដៃ ពិសេសខ្នង [...] ច្រើនតែរបួសខ្នង របក បាត់ក្រចកដៃក្រចកជើង"], ម៉ោង 09.33.05 KH ERN 00358965-00358967 ["ខ្ញុំដឹងឮថា យប់ឡើងមានស្រែក មានដំបៅ រួចខ្ញុំអ្នកព្យាបាលខ្ញុំដឹងខ្ញុំលបសួរតិចៗថា អាម៉េចបានដំបៅម្លឹងៗ? គេថា សួរចម្លើយ អ្នកទោសថាសួរចម្លើយ"], ម៉ោង 09.53.51-09.55.33 KH ERN 00358972-00358973 ["ប្រភេទរបួស [...] ភាគច្រើននៅខ្នង នៅដៃ នៅជើង [...] ត្រចៀកខ្ញុំធ្លាប់ឃើញ ត្រចៀកជួនកាលដាច់ឆែក ជួនកាលដំបៅ"]។ ឯកសារ D4.1.382

សេចក្តីយោងទៅលើរបួសដែលអ្នកទោសបានទទួលរង ដោយសារការវាយដំ និងទម្រង់នៃទារុណកម្មផ្សេងៗទៀតដែលបានប្រើ[2246]។

*ឃ) ការប្រើប្រាស់ទារុណកម្មដើម្បីទទួលបានចម្លើយសារភាព*

580. គោលបំណងនៃការធ្វើទារុណកម្មលើអ្នកទោសមន្ទីរស-២១ គឺដើម្បីបង្ខំឲ្យពួកគេផ្តល់ចម្លើយសារភាព និងកំណត់អត្តសញ្ញាណបណ្តាញជនដែលគេសន្មតថាជាជនក្បត់។ ដូចដែលបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នកសួរចម្លើយនៅមន្ទីរស-២១ ម្នាក់៖

> គោលបំណងនៃការធ្វើទារុណកម្មនេះ គឺយកចម្លើយរបស់ពួកគេ ពុំមែនធ្វើដើម្បីសប្បាយទេ។ ដូច្នេះ ត្រូវវាយឈឺចាប់ ដើម្បីឲ្យវាឆាប់ឆ្លើយ។ គោលបំណងមួយទៀត គឺកាច់វាឲ្យខ្លាច *[...]* ដូច្នេះ វាយឲ្យវាខ្លាច តែមិនឲ្យងាប់ដាច់ខាត។ ពេលធ្វើទារុណកម្ម ត្រូវពិនិត្យសុខភាពវាមុន ត្រូវពិនិត្យមើលរំពាត់។ កុំលោភចង់ឆាប់ នាំឲ្យស្លាប់ និងបាត់ឯកសារ ខាត[2247]។

581. កម្មាភិបាលមន្ទីរស-២១ បញ្ជាក់ថា ទារុណកម្មត្រូវបានប្រើប្រាស់ក្នុងគោលបំណងទាញយកចម្លើយសារភាព[2248]។ ឌុច សារភាពថា អ្នកសួរចម្លើយនៅក្នុងកងក្តៅ ត្រូវបានអនុញ្ញាតឲ្យ 'វាយ

---

កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេក ដន KH ERN 00163818 ["មិនដែលមានរយៈពេលណាមួយដែលអ្នកទោសគ្មានរបួសនោះទេ"]។

2246 សូមមើល ឧទាហរណ៍ ឯកសារ D1.3.3.2 បញ្ជីអ្នកទោសសម្លាប់នៅមន្ទីរស-២១ បញ្ជីអ្នកទោសដែលឈឺងាប់ និងកម្ទេចចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧៦ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៦ KH ERN 00008891-93 [បញ្ជីឈ្មោះអ្នកទោស ៣៧ នាក់ដែលស្លាប់ដោយជំងឺ ឬកម្ទេចចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៦ ក្នុងនោះ ១៣ នាក់មានជំងឺ "ក្រុំ" និង"ស្តឹក"]។ ឯកសារ D4.1.357 សេចក្តីរាយការណ៍ប្រចាំថ្ងៃ ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ១៩៧៧ KH ERN 00090172 [បញ្ជីឈ្មោះអ្នកទោស១៩នាក់ ក្នុងនោះ ពីរនាក់ (លេខរៀងទី៥ និង៧) ដាក់ថាមាន"ដំបៅខ្នង"]។ ឯកសារ D10.1.108 សម្រង់ចម្លើយសារភាពរបស់ អ៊ុំ សឿន (សេចក្តីដកស្រង់) EN 00223146 [ចំណារចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ១៩៧៥៖ "វាយឲ្យសន្លប់"]។

2247 ឯកសារ D10.1.7 បញ្ជីសិក្ខិរបស់សន្តិបាលស ២១ EN 00007467។

2248 ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ ម៉ោង 15.56.52 KH ERN 01247415 ["ចំពោះអ្នកទោសដែលសួរចម្លើយហើយមិនឆ្លើយ គឺអ្នកទោសនោះ គឺអាចធ្វើទារុណកម្ម"]។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 13.38.34 KH ERN 01249382 ["ផ្នែកទារុណកម្មគឺ មិនថាស្រី ថាប្រុសទេ គឺឲ្យធ្វើទាំងអស់ ឲ្យតែមិនសារភាព"]។ ឯកសារ D98/3.1.212 ប្រាក់ ខន ប្រតិ

ដំអ្នកទោសភ្លាមៗ ប្រសិនបើចម្លើយសារភាពមិនត្រូវបានទទួលតាមការចង់បានរបស់ពួកគេ"[2249] ។ អ្នកសួរចម្លើយនៅមន្ទីរស-២១ ប្រាក់ ខាន់ បានផ្តល់សក្ខីកម្មថា "៩៩ ភាគរយ" នៃអ្នកទោសដំបូងបដិសេធថាមិនបានធ្វើខុសអ្វីឡើយ ហើយឆ្លើយសារភាពតែនៅក្រោយពីការសួរចម្លើយប៉ុន្មានថ្ងៃ ឬសប្តាហ៍ ដោយប្រើ "វិធីសាស្ត្រត្រជាក់"និងទម្រង់នៃការធ្វើទារុណកម្មដទៃទៀតប៉ុណ្ណោះ[2250] ។ អ្នកសួរចម្លើយត្រូវបានរំពឹងថានឹងទទួលបានឈ្មោះបុគ្គលផ្សេងទៀតដែលជា "បណ្តាញ" របស់អ្នកទោស[2251]។ ឯកសារពីសម័យនោះបង្ហាញយ៉ាងច្បាស់ពីការប្រើប្រាស់ទារុណកម្មដោយអ្នកសួរ

---

ចារឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៩ ម៉ោង 11.08.05 KH ERN 00355310-00355311។ ឯកសារ D4.1.245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ ខន KH ERN 00146601["ក្នុងការសួរចម្លើយខ្លាំង ធ្វើទារុណកម្មគឺគោលបំណងយកចម្លើយតែមួយមុខគត់"]។ ឯកសារ D4.1.378 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ ផៃ KH ERN 00163629 [ឌុច និងប្រធានសហការីបានណែនាំថា "អ្នកទោសគឺជាខ្មាំង ហើយបើមិនឆ្លើយអាចធ្វើទារុណកម្មបាន"]។ ឯកសារ D1.3.32.9 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុន ផល KH ERN 00163808 ["អ្នកសួរចម្លើយមានតួនាទី និងមានសិទ្ធិ វាយសួរចម្លើយដើម្បីយកឯកសារ"]។ ឯកសារ D98/3.1.29 សោម ម៉េត ប្រតិចារឹក ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ម៉ោង 15.30.15 KH ERN 00362803-00362804 [រៀបរាប់អំពីអ្នកទោសម្នាក់ដែលទុយ ធ្វើទារុណកម្ម ក្រោយពីអ្នកទោសនោះឆ្លើយថា"មិនដឹងមានពាក្យអីឆ្លើយទៀតទេ"]។ ឯកសារ D98/3.1.94 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.41.30-09.44.54 KH ERN 00342762-00342764។

2249 ឯកសារ D98/3.1.94 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 09.41.30-09.44.54 KH ERN 00342762-00342764។ សូមមើល ឯកសារ D98/3.1.94 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ ២០០៩ ម៉ោង 09.53.10 KH ERN 00342766-00342767 ["បានគេដោះស្រាយមិនរួចតាមវិធីត្រជាក់ បានគេចូលវិធីក្តៅ"]។ ឯកសារ D98/1.2.19 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី២៧ ខែមិនា ឆ្នាំ២០១២ ម៉ោង 09.32.54-09.36.32 KH ERN 00794029-00794031។ ឯកសារ D114/277.2 កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 15.38.13 KH ERN 01307837-01307838 [បើក្រុមត្រជាក់សួរទៅមិនបានផលទេ អ្នកទោសត្រូវបានប្តូរទៅ "ក្រុមក្តៅ" ឬមិត្តទុយ "សួរប្រើយុទ្ធវិធីក្តៅផ្តេសផ្តាស"]។

2250 ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ ម៉ោង 14.14.10 KH ERN 01249393-01249394 ["ខ្លះយូរទៅ ក៏សួរដេញដោលពីវិធីត្រជាក់ ខ្លះក៏សារភាពទៅ មិនមែនថា សួរមួយម៉ាត់ពីរម៉ាត់ឆ្លើយសារភាពទេ ម៉ែពីរថ្ងៃ ឬបួនដប់ថ្ងៃ។ អ៊ីចឹងខ្លះក៏ទាល់តែធ្វើទារុណកម្មវៃ ច្រកស្បោង ច្រកអ៊ីចឹងទៅ បានសារភាព ខ្លះក៏មិនព្រមសារភាព"]។

2251 ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹកថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង ១១:២១:៤១-១១:២៥:00, ១៥:៤៣:៣៨-១៥:៤៦:២៦ ។ ឯកសារ D98/3.1.212 ប្រាក់ ខន ប្រតិចារឹកថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ១០:៣៤:០២ ["ពេលសួរចម្លើយ គឺគាត់បានប្រាប់ថា សំខាន់រឿងចម្លើយសារភាពពីខ្សែបណ្តាញរបស់អ្នកទោស"], ម៉ោង ១១:២៣:៤៧-១១:២៧:៥៥ [រៀបរាប់ពីចំណាររបស់ ឌុច នៅលើចម្លើយសារភាព "ចម្លើយដែលមិនទាន់គ្រប់ជ្រុងជ្រោយ គឺមានចំណារចារមកដាក់ថា "មិត្តត្រូវសួរចំណុចនេះតទៅទៀតទាក់ទងនឹងខ្សែរយៈ"]។ ឯកសារ

ចម្លើយមន្ទីរស-២១ ដើម្បីទាញយកចម្លើយសារភាព[2252]។ ដំណើររឿងពីអ្នកជាប់ឃុំដែលនៅរស់រានមានជីវិត ក៏បានផ្តល់នូវរូបភាពយ៉ាងច្បាស់មួយអំពីរបៀបដែលទារុណកម្មត្រូវបានប្រើនៅមន្ទីរ ស-២១ ដើម្បីបង្ខំប្រជាជនកម្ពុជាសាមញ្ញ ដែលមិនធ្លាប់ឮសោះពី សេអ៊ីអា ឬកាហ្សេបេជាដើម ឲ្យសារភាពថា ពួកគេគឺជាអ្នកស៊ើបការណ៍ឲ្យអង្គការទាំងនោះ[2253]។

---

D1.3.32.36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ខន KH ERN 00146622-23។ ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹកថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង ១៥:៤៩:៥៨-១៥:៥៤:៥៤ [“គេឲ្យយើងសួរចម្លើយដើម្បីរកខ្សែបណ្តាញ រកខ្សែដែលទាក់ទងខ្សែរយៈក្បត់ ... អានេះជាការណែនាំរបស់គេ គេឲ្យយើងសួរចម្លើយរកខ្សែបណ្តាញមានបក្ស សេ.អ៊ី.អា បក្សពលករវៀតណាម បក្សកា.ហ្សេ.បេ”]។ ឯកសារD98/3.1.146 ឡាច មាន ប្រតិចារឹកថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៩ ម៉ោង ១៥:០៩:៤១ [“ការសួរចម្លើយអ្នកទោស គឺមានការចង់បានតែចម្លើយពីអ្នកទោសដែលក្បត់ ចង់បានពីចម្លើយ និងខ្សែបណ្តាញរបស់អ្នកក្បត់”]។ ឯកសារ D98/1.2.6 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៩ ម៉ោង ១២:០១:១២-១២:០៧:២៤។ ឯកសារ D98/1.2.19 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១២ ម៉ោង ០៩:៣៨:៥៦-០៩:៤៣:២០។ ឯកសារ D54/80.1.38 សៀវភៅកំណត់ហេតុ ស-២១ របស់ ប៉ុង-ទុយ KH ERN 00077487 [“ការសម្រិតសម្រាំងពួកក្បត់ផ្ទៃក្នុងជាការចាំបាច់បំផុត។ ត្រូវតែធ្វើដោយខានមិនបាន”]។

2252 សូមមើលឧទាហរណ៍ ឯកសារ D10.1.111 របាយការណ៍ស-២១ អំពីចម្លើយសារភាពរបស់ សួរ ប៊ាង ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨ KH ERN 00173743 [“ខ្ញុំក៏បានដាក់ខ្សែភ្លើងវាខ្លះទៀត ហើយនិងធ្វើនយោបាយឲ្យវាស្រពេចស្រពិលមួយចំនួន រយៈនោះវាក៏សុខចិត្តនិយាយខ្សែសង្វាក់ សេ.អ៊ី.អា”]។ ឯកសារ D10.1.108 (E3/24) ស-២១ ចម្លើយសារភាព អ៊ុំ សឿន (ដកស្រង់) KH ERN 00172792 [ចំណារ៖ “កុំសួរ! ធ្វើទារុណកម្ម!”]។ ឯកសារ D10.1.3 ស-២១ របាយការណ៍ចម្លើយសារភាពរបស់ កែ គឹមហួត ហៅ សុត ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៧៧ KH ERN 00014094 [“យើងបង្ខំវាឲ្យស៊ីលាមកពីរបីស្លាបព្រា”]។ ឯកសារ D10.1.7 សៀវភៅកំណត់ហេតុ ស-២១ បញ្ជីស្ថិតិសន្តិបាល KH ERN 00007470, 00007487 [“បក្សឲ្យវ៉ៃយើងវ៉ៃដោយម្ចាស់ការ វ៉ៃឲ្យនិយាយ”]។ ឯកសារ D114/37.1.70 ស-២១ ចម្លើយសារភាពរបស់ ដាញ់ ស៊ីយ៉ាន ថ្ងៃទី ៨ ខែ មករា ឆ្នាំ ១៩៧៦ KH ERN 00172772 [ចំណារ៖ “សួរឲ្យច្បាស់ និង ទារុណកម្មឲ្យធ្ងន់ធ្ងរមធ្យម ទិសដៅគឺរកខ្សែសង្វាក់”]។

2253 ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹកថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ១០:២១:២៥-១០:២៧:៤០ [“គេចាប់ផ្តើមវ៉ៃសួរចម្លើយ។ គេសួរថា ខ្ញុំចូល សេ.អ៊ី.អា កា.ហ្សេ.បេ ខ្ញុំមិនដឹងឆ្លើយថាម៉េច បើខ្ញុំអត់ដែលឃើញ អត់ដែលដឹង អត់ដែលអ្នកនាំសោះ ធ្វើការសុខៗហើយគេហៅមក គេចោទថាខ្ញុំចូល សេ.អ៊ី.អា ថ្ងៃណា ខែណា អ្នកណានាំចូល? ហើយខ្ញុំមិនដឹងឆ្លើយថាម៉េច និយាយដដែលៗ គេវ៉ៃអើយវ៉ៃ [...] វាគ្មានពេលណានឹងដឹកខ្សែរយៈឯណា ចូលឯណា ខ្ញុំអត់ដឹង សេ.អ៊ី.អា ហ្នឹងយ៉ាងម៉េចផង”]។ ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹកថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០៦ ម៉ោង ១០:៣៥:៤០-១០:៤២:២៧ [“គេវាយអ៊ំសួរថា “គ្នាឯងមានប៉ុន្មាននាក់ចូល សេ.អ៊ី.អា ចូល កា.ហ្សេ.បេ?” ហើយខ្ញុំប្រាប់គេថា “ខ្ញុំអត់ស្គាល់ សេ.អ៊ី.អា កា.ហ្សេ.បេ ទេ” [...] យើងឆ្លើយថា យើងអត់ស្គាល់ សេ.អ៊ី.អា កា.ហ្សេ

*ង) ការសួរចម្លើយ និងការធ្វើទារុណកម្មអ្នកទោសដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១ ដោយ មាស មុត*

582. ដូចដែលបានបញ្ជាក់អះអាងដោយបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរស-២១ របស់ ក.ស.ច.ស អ្នកទោសជាច្រើនដែលត្រូវបានបញ្ជូនពីកងពល ១៦៤ កំពង់សោម តំបន់ ៥០៥ និងកងពល ១១៧ បានឆ្លងកាត់ការសួរចម្លើយនៅមន្ទីរស-២១ និងបានផ្តល់ចម្លើយសារភាព[2254]។ ភ័ស្តុតាងដែល

---

.បេ ហ្នឹងទេ។ ពេលនុំ គឺថាវាវាយថែមទៀត គឺថាវាយហើយ វាយកអាខ្សែភ្លើងមកញាត់ស្លឹកត្រចៀកយើងហ្នឹង"], ម៉ោង ១០:៤០:០២-១០:៤៤:០៦ ["អ្នកសួរចម្លើយបានឈប់ធ្វើទារុណកម្ម ជុំ ម៉ី បន្ទាប់ពីសួរចម្លើយ ១២ ថ្ងៃ គាត់បានឆ្លើយកុហក់ថា គាត់បាន "ចូល សេ.អ៊ី.អា កា.ហ្សេ.បេ" ហើយនិងបានឆ្លើយដាក់មនុស្ស ៦៨ នាក់ផ្សេងទៀត"], ម៉ោង ១១:២៦:២៥-១១:៣១:៣០ ["បានធ្វើទារុណកម្មបន្ទាប់ពីអ្នកសួរចម្លើយគាត់បានប្រាប់ ហ៊ំ ថាគាត់ "មិនសារភាព"]។ ឯកសារ D98/3.1.34 ជុំ ម៉ី ប្រតិចារឹកថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៩ ម៉ោង ១០:០៣:៣៤-១០:០៩:៤៤ ["ពេលនោះគឺថា គេសួរតែរឿង សេ.អ៊ី.អា កា.ហ្ស.បេ ហ្នឹង គេអត់មានសួរអីទេ ហើយបើយើងឆ្លើយក្រៅពី សេ.អ៊ី.អា ហ្នឹង គេវ៉ៃយើង [...] ខ្ញុំអត់ស្គាល់រឿង សេ.អ៊ី.អា កា.ហ្សេ.បេ ខ្ញុំអត់ដែលស្គាល់ទេ។ ក្រោយមក វាដកដង្កាប់ហ្នឹងមួលក្រចកជើងអ៊ំ"], ម៉ោង ១០:១៣:៥២-១០:២១:២០ ["មូលហេតុដែលឈប់សួរខ្ញុំហ្នឹង ដោយសារខ្ញុំទទួលសារភាពថា ខ្ញុំចូល សេ.អ៊ី.អា ចូល កា.ហ្សេ.បេ មែន ខ្ញុំសារភាព [...] ខ្ញុំឆ្លើយថា ចូល សេ.អ៊ី.អា កា.ហ្សេ.បេ មែន តែអារឿងដែលខ្ញុំឆ្លើយនេះមិនមែនជាការពិត ដោយសារគេវ៉ៃខ្ញុំខ្លាំងពេក ម្ល៉ោះហើយខ្ញុំចេះឆ្លើយគេពេញទឹកពេញដីទៅ"]។ ឯកសារ D114/37.1.68 សៀវភៅនិពន្ធដោយ វ៉ាន់ ណាត គំនូរគុកមួយរបស់កម្ពុជា EN ERN 00396834-35 ["ពេលខ្ញុំនៅជាន់លើ ខ្ញុំអាចឮពួកគេ (អ្នកសួរចម្លើយ) សម្លុតដាក់អ្នកទោស "អ្នែង សេ.អ៊ី.អា!" ឬក៏ "អ្នែង កា.ហ្ស.បេ!" ពាក្យ "សេ.អ៊ី.អា" និង "កា.ហ្សេ.បេ" ជាបញ្ហាស្លាប់របស់យើង ហើយតាមពិតទៅ ពួកយើងមិនដឹងថា សេ.អ៊ី.អា កា.ហ្សេ.បេ ជាអ្វីទេ"]។

2254 សូមមើលឧទាហរណ៍ ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ៤៥០, ១២៧៣, ១៤៤៨, ១៥៣៧, ១៦២៤, ២៣៦៨, ៣២២៣, ៣៩៩៤, ៤៧០៧, ៤៧៩៧, ៥៣០៨, ៥៣៤២, ៥៦១០, ៥៧២៩, ៦០៨៤, ៦០៩០, ៦០៩៥, ៦៤០២, ៦៦២២, ៦៨៧៦, ៧២០៧, ៨១៧៦, ៨៦១៨, ៩៨៧៦, ១០១៨៩, ១០៥៧១, ១០៦៥០, ១១៤៧៨, ១២២១៨, ១២២១៩, ១៣៣៨១, ១៣៨៧០, ១៣៩១១, ១៤១៥៦ [អ្នកទោសកងពល១៦៤ ដែលមានចម្លើយសារភាពនៅ ទួលស្លែង], លេខរៀង ១០៣៩, ៤០៣២, ៧៨៦២, ៨៤៧១ [ចម្លើយសារភាពនៅទួលស្លែងរបស់អ្នកទោស តំបន់ ៥០៥ និងកងពល ១១៧], លេខរៀង ៤៥៣, ៥៩២, ៦៦៣, ៦៧៨, ១៥៧៦, ១៧៥៥, ២១០៩, ២២៤៩, ៣៦៤៥, ៣៦៨៥, ៤១៦៨, ៥០២៥, ៥៤៦៥, ៥៥៥៥, ៥៩១១, ៦១៦៨, ៦១៧២, ៦៣៩០, ៦៦០១, ៦៦៥០, ៧២៩៧, ៧៦១៣, ៨២២៣, ៨៤៧២, ៨៩៨២-៨៣, ៨៩៨៨, ៩៨៩៩-៩៩០០, ៩៩២៦, ១០២៦៥, ១០៥៩០, ១១៦១១, ១១៧៨១, ១២៦១៦, ១២៧៣៩, ១២៧៦៦, ១២៩៨១, ១២៩៨៣-៨៥, ១២៩៨៧-៨៩, ១២៩៩៩, ១៣០០១-០២, ១៣០០៥-០៦, ១៣០០៨, ១៣០២៣, ១៣០៣១, ១៣០៥២-៥៣, ១៣០៥៥, ១៣១៨២, ១៣៣៩៥, ១៣៤៣១-៣៤, ១៣៤៣៦-៣៧, ១៣៤៤៦, ១៣៤៥៣, ១៣៤៧៤, ១៣៤៨៣, ១៣៤៨៨, ១៣៥០១, ១៣៥២៨, ១៣៥៣២-៣៣, ១៣៥៣៥, ១៣៥៤១, ១៣៥៤៣, ១៣៥៨៣, ១៣៨៧៣ [អ្នកទោសបញ្ជូនមកពីកំពង់សោម ដោយមានចម្លើយ

បញ្ជាក់លម្អិតនៅខាងលើ បង្ហាញយ៉ាងច្បាស់ថា អ្នកទោសដែលឆ្លងកាត់ការសួរចម្លើយបែបនោះនៅមន្ទីរស-២១ បានទទួលរងគ្រោះជាប្រព័ន្ធពីឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្ម។

583. ភស្តុតាងនោះក៏បានបង្ហាញផងដែរពីការដឹងឮរបស់ **មាស មុត** អំពីការសួរចម្លើយបុគ្គលដែលកងពលរបស់គាត់បានចាប់ខ្លួន ដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១។ ដូចដែលបានពិភាក្សាលម្អិតនៅក្នុងផ្នែក *VIII*.ឃ.៤. ការទទួលខុសត្រូវរបស់ **មាស មុត** លើអ្នកទោសដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១ ខាងលើ ចម្លើយសារភាពពីមន្ទីរស-២១ ត្រូវបានបញ្ជូនទៅ **មាស មុត** និងត្រូវបានគាត់អានឱ្យកម្មាភិបាលស្តាប់នៅពេលមានការប្រជុំក្នុងកងពល ១៦៤[2255]។ ចម្លើយសារភាពនៅមន្ទីរស-២១ ដែលត្រូវបានបញ្ជូនបន្តទៅថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ជាញឹកញាប់មានរបាយការណ៍សង្ខេប ដោយអ្នកសួរចម្លើយដែលរៀបរាប់ច្បាស់ៗអំពីការប្រើទារុណកម្ម[2256] ដូចដែលបាន

---

សារភាពនៅទួលស្លែង]។ សូមមើលផងដែរ ឯកសារ D1.3.28.137 ផ្នែកសួរចម្លើយសម្រាប់គុកពិសេស ខែ ធ្នូ ឆ្នាំ ១៩៧៨ លេខរៀងទី ៤ [ឈឹម ខុន អនុលេខាតំបន់ ៥០៥ អ្នកសួរចម្លើយដាក់សម្គាល់ថា “ចប់”], ៦ [ស្វាយ ណួញ ប្រធានមន្ទីរកងពល ១១៧ ស្ថិតក្រោមការសួរម្លើយរបស់ ទិត], ៨, ១៥, ១៨។ ឯកសារ D4.1.1115 កំណត់ហេតុសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00146662 [“ចំពោះពួកបស្ចិមប្រទេស ខ្ញុំឲ្យមិត្ត ប៊ុន សួរចម្លើយ”]។ ឯកសារ D114/302 កំណត់ហេតុស្តាប់ចម្លើយ គង់ ផៃ ឆ.73-75 [រៀបរាប់ពីការនាំអ្នកទោសជនជាតិអាមេរិកាំងទៅ ស-២១ ក្នុងឆ្នាំ ១៩៧៨ ដែលត្រូវបានសួរចម្លើយដោយ ឌុច]។ ឯកសារ D54/4.1 ស-២១ ចម្លើយសារភាពរបស់ Ronald Keith Dean ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨។ ឯកសារ D11/4.2.4 ស-២១ ចម្លើយសារភាពរបស់ Michael Scott Deeds។ ឯកសារ D54/4.2 របាយការណ៍សង្ខេបរបស់ ចាន់ លើចម្លើយសារភាព ស-២១ របស់ Ronald Keith Dean, Michael Scott Deeds និង Christopher Edward Delance ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ១៩៧៩។

2255 សូមមើលឧទាហរណ៍ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.3, 10 [“តា មុត ប្រជុំប្រាប់ចម្លើយសារភាព ហើយ តា មុត បានប្រកាសថា [ប្រធានវរសេនាតូច ៦៣១] វេត ក្បត់ហើយ [...] ឆ.10៖ តា មុត ប្រកាសនៅក្នុងអង្គប្រជុំ អំពីចម្លើយសារភាពរបស់ពួកក្បត់ និងខ្សែរយៈ សេ.អ៊ី.អា និងខ្សែរយៈ កា.ហ្សេ.បេ”]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.60 [“មាស មុត អានចម្លើយសារភាពរបស់ នង ឆាន ហ្នឹង [...] ឆ.63៖ ចាំបានត្រង់គាត់ [មាស មុត] និយាយពីចម្លើយសារភាពរបស់ពួកក្បត់”]។

2256 សូមមើលឧទាហរណ៍ ឯកសារ D10.1.111 របាយការណ៍ ស-២១ អំពីចម្លើយសារភាពរបស់ សួរ ប៉ាង ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៧៨ KH ERN 00173743 [“ទន្ទឹមនឹងនេះ ខ្ញុំក៏បានវ៉ៃវាខ្លះ រយៈនោះវាសុខចិត្តទទួលខ្លួនវាថាក្បត់ ហើយតែពីរឿងខ្សែសង្វាក់វាមិនសុខចិត្តនិយាយ ទន្ទឹមនឹងនេះ ខ្ញុំក៏បានដាក់ខ្សែភ្លើងវាខ្លះទៀត [...] រយៈនោះ វាសុខចិត្តនិយាយខ្សែសង្វាក់ សេ.អ៊ី.អា”]។ ឯកសារ D10.1.103 ស-២១ ចម្លើយសារភាពសង្ខេបរបស់ ជួក ញ៉ៅ KH ERN 00005406 [“វាមិននិយាយ ក៏បានធ្វើទារុណកម្មខ្លះ ទើបវាសុខចិត្តទទួលខ្លួនវាក្បត់”]។ ឯកសារ D10.1.3 ស-២១ ចម្លើយសារភាពសង្ខេបរបស់ កែ គឹមហួត ហៅ សុត ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៧៧ KH ERN 00014095-

បញ្ជាក់ដោយប្រធានមន្ទីរស-២១ ឌុច និងប្រភពផ្សេងៗទៀតនោះដែរ[2257]។ លើសពីនេះទៀត ចម្លើយសារភាពនៅមន្ទីរស-២១ របស់អ្នកទោសវៀតណាម ដែលត្រូវបានចាប់ខ្លួនបាននៅសមុទ្រ ដោយកងពល ១៦៤ ត្រូវបានចាក់ផ្សាយនៅតាមវិទ្យុរបស់កម្ពុជាប្រជាធិបតេយ្យពេញមួយឆ្នាំ ១៩៧៨[2258] ហើយខ្សែភាពយន្តឃោសនាការត្រូវបានថតអំពីការចាប់ខ្លួន និងឃុំខ្លួនពួកទាហាន

---

96, EN ERN 00183285-90, FR ERN 00951214-15 [ផ្នែកទី IV ផ្តល់លម្អិតអំពីទារុណបានប្រើក្នុងរយៈពេល ៣ ថ្ងៃ នៅដើមដំបូងនៃការដាក់គុកលេខាតំបន់ ៧ ឈ្មោះ សុត ដែលគាត់ត្រូវបាន "បុក" ខ្សែភ្លើងពីរលើក ហើយបង្ខំឱ្យ "ស៊ីអាចម៍ពីរបីស្លាបព្រា" ហើយនៅក្នុងផ្នែកទី VI និយាយថា៖ "មាគ៌ាដំណើរការរបស់ខ្ញុំ គឺធ្វើទារុណកម្មដោយម្ចាស់ការតទៅទៀត ព្រោះខ្មាំងកំពុងបាត់ផ្នែកសតិ ហើយទ័លច្រក [...] ស្នើសុំមតិតំរែតម្រង់ពីអង្គការ ដើម្បីដំណើរសម្រេចភារកិច្ច"]។

2257 ឯកសារ D114/277.3 កាំង ហ្គេកអ៊ាវ ប្រតិចារឹកថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ០៩:២៨:៤៥ ["របាយការណ៍នេះ គឺរបាយការណ៍ដែលគេសរសេរសារភាពរបស់ខ្មាំង ហើយគេសរសេរថា "មនុស្សនេះ ខ្ញុំបានសួរចម្លើយបានធ្វើទារុណកម្មកម្រិតនេះ"], ម៉ោង ០៩:២៨:៤៥-០៩:៣១:៤៤ ["សហចៅក្រមស៊ើបអង្កេតសួរថា "ការធ្វើទារុណកម្ម ខាងលើអនុញ្ញាតទេ?" ខ្ញុំថា "អនុញ្ញាត ទើបមានរបាយការណ៍ថាខ្ញុំវាយអ្នកនេះ ខ្ញុំ មនុស្សនេះឆ្លើយទាល់តែខ្ញុំវាយ ធ្វើទារុណកម្ម"។ ដូច្នេះវាមានរបាយការណ៍នៅជាប់នឹងនុ៎ង"], ម៉ោង ០៩:៣៨:៣៤-០៩:៤១:០៦ [បង សុនសេន ណែនាំ ឌុច "ឱ្យប្រាប់ទៅអ្នកសួរ គេធ្វើទារុណកម្មប៉ុន្មានដង អីប៉ុន្មានឱ្យសរសេរមកផង"], ម៉ោង ០៩:៤១:០៦-០៩:៤៧:១៤ [រៀបរាប់ការពិភាក្សាអំពីរបាយការណ៍សួរចម្លើយចំនួនពីរដែលប្រើទារុណកម្ម រួមទាំងឯកសារ D10.1.111]។ ឯកសារ D98/1.2.16 កាំង ហ្គេកអ៊ាវ ប្រតិចារឹកថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ ម៉ោង ១០:០៧:០០-១០:១១:៩៩។ ឯកសារ D98/1.2.18 កាំង ហ្គេកអ៊ាវ ប្រតិចារឹកថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១២ ម៉ោង ១៥:៣៨:២៨-១៥:៤១:១៨។ ឯកសារ D4.1.1115 កំណត់ហេតុសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00146662 [រៀបរាប់ថាគាត់ដឹងច្បាស់វិធីធ្វើទារុណកម្មដែលប្រើនៅស-២១ "តាមរយៈការអានរបាយការណ៍"]។ សូមមើលផងដែរ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង ១១:០៧:៥៩-១១:១៤:០៤ ["បាទ គោលបំណងនៃការសួរចម្លើយអ្នកទោសជំនាន់នោះ គឺសម្រេចឱ្យបាននូវចម្លើយ និងគោលបំណងចុងក្រោយ គឺបានចម្លើយហើយ រាយការណ៍ឱ្យថ្នាក់លើ ... ខ្ញុំបាទរាយការណ៍ទៅ ក៏គេទទួលយកទៅ"]។

2258 ឯកសារ D1.3.26.5 BBC-SWB, ចម្លើយសារភាពរបស់ទាហានជើងទឹក សាធារណរដ្ឋសង្គមនិយមវៀតណាម ដែលត្រូវបានចាប់ខ្លួន ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00224832-36 [វិទ្យុផ្សាយអំពី "ចម្លើយសារភាពរបស់ (Vu Dinh Ngo បញ្ជីអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង ១៣៤៧៤) អតីតនាយចំណង់នាវាចរណ៍នៃកងនាវាអាយ៉ងធៀវគី ដែលយើងចាប់បានកាលពីថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៧៨"]។ ឯកសារ D64.1.38 សេវាផ្សព្វផ្សាយព័ត៌មានបរទេស ចម្លើយសារភាពបង្ហាញពីផែនការ របស់សាធារណរដ្ឋសង្គមនិយមវៀតណាម យកខេត្តតាកែវជាឧបសម្ព័ន្ធ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ EN ERN 00169232-36 [វិទ្យុកម្ពុជាប្រជាធិបតេយ្យផ្សាយអំពីចម្លើយសារភាពរបស់ Tran Van Thuong (ក.ស.ច.ស លេខ ៩៨៨៨) "អ្នកដែលត្រូវចាប់ខ្លួននៅថ្ងៃទី ១៨ ខែ មករា ក្នុងដែនសមុទ្រប្រទេសកម្ពុជា"]។ ឯកសារ D64.1.38 សេវាផ្សព្វផ្សាយព័ត៌មានបរទេស ចម្លើយសារភាពបង្ហាញពី

ផែនការ របស់សាធារណរដ្ឋសង្គមនិយមវៀតណាម ច្បាមយកកោះប្រទេសកម្ពុជា ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ EN ERN 00169276-77 [វិទ្យុកម្ពុជាប្រជាធិបតេយ្យផ្សាយអំពីចម្លើយសារភាពរបស់ Thieu Loc (ក.ស.ច.ស លេខ ៨៤០៣) "ចាប់នៅថ្ងៃទី ០១ ខែ កុម្ភៈ ក្នុងដែនសមុទ្រប្រទេសកម្ពុជា"]។ ឯកសារ D64.1.41 សេវាផ្សព្វផ្សាយព័ត៌មានបរទេស វិទ្យុផ្សាយពីចម្លើយសារភាពជាភាសាខ្មែរ របស់ចារកម្មសាធារណរដ្ឋសង្គមនិយមវៀតណាម EN ERN 00169934-36 [វិទ្យុកម្ពុជាប្រជាធិបតេយ្យផ្សាយអំពីចម្លើយសារភាព របស់អនុសេនីយ៍ទោ Sam Kim (ក.ស.ច.ក លេខ ៨២៥៧) ចាប់ "នៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ នៅលើកោះព្រីងប្រទេសកម្ពុជា"]។ ឯកសារ D64.1.35 សេវាផ្សព្វផ្សាយព័ត៌មានបរទេស ចាប់ខ្លួនមន្ត្រីកងទ័ពជើងទឹកដោយបង្ខំ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៩៧៨ EN ERN 00168793-94 [វិទ្យុកម្ពុជាប្រជាធិបតេយ្យផ្សាយអំពីចម្លើយសារភាពរបស់ Vinh Minh Chau (ក.ស.ច.ស លេខ ១៣៤៦៣) "បានចាប់នៅកោះអង្រ្កង ក្នុងខែ មីនា"]។ ឯកសារ D1.3.1.13 ស-២១ ចម្លើយសារភាពរបស់ វិញ មិញ ចូវ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ១៩៧៨។ ឯកសារ D10.1.68 សេវាផ្សព្វផ្សាយព័ត៌មានបរទេស ចាប់ខ្លួនមន្ត្រីសាធារណរដ្ឋសង្គមនិយមវៀតណាមទាក់ទងនឹងផែនការវាយប្រហារ ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ១៩៧៨ EN ERN 00169799-800 [វិទ្យុកម្ពុជាប្រជាធិបតេយ្យផ្សាយអំពីចម្លើយសារភាពរបស់អនុសេនីយ៍ទោល Nguyen Thanh Quang (ក.ស.ច.ស លេខ ១៣៤៥៨) "បានចាប់ខ្លួននៅក្នុងដែនទឹកប្រទេសកម្ពុជា នៅថ្ងៃទី ១៣ ខែ មីនា"]។ ចម្លើយសារភាពរបស់គិញពលបាលឯក បានចាប់ខ្លួនថ្ងៃទី ២៩ ខែ មីនា រាយការណ៍ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៧៨ EN ERN 00169865-66 [វិទ្យុកម្ពុជាប្រជាធិបតេយ្យផ្សាយអំពីចម្លើយសារភាពរបស់ Vinh Tu Phuong (ក.ស.ច.ស លេខ ១៣៥២៩) "បានចាប់ខ្លួនដោយកម្លាំងកម្ពុជានៅកោះពូលូវៃក្នុងខែមីនា"]។ ឯកសារ D64.1.45 សេវាផ្សព្វផ្សាយព័ត៌មានបរទេស ចម្លើយសារភាពរបស់គិញវៀតណាម ចាប់ខ្លួននៅលើកោះពូលូវៃ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៧៨ EN ERN 00170273-74 [វិទ្យុកម្ពុជាប្រជាធិបតេយ្យផ្សាយចម្លើយសារភាពរបស់ "អ្នកទោសក្រោមជនជាតិវៀតណាម Tran Van Long (ក.ស.ច.ស លេខ ១៤៨២០) ចាប់ខ្លួននៅថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៧៨ នៅកោះពូលូវៃ"]។ សូមមើលផងដែរ ឯកសារ D98/1.2.1 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៩ ម៉ោង ១១:៣៩:៤០-១១:៤៩:៤៣ ["ការផ្សព្វផ្សាយសេចក្តីសារភាពទាំងស្រុង គេយកតែចម្លើយរបស់វៀតណាមទេ ទាហានវៀតណាមទេ"]។ ឯកសារ D98/3.1.85 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង ១៥:៥៥:១៣-១៦:០៥:០៨។ ឯកសារ D98/3.1.91 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ម៉ោង ០៩:៣១:៥៨-០៩:៣៧:៥៥។ ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹកថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង ០៩:០២:២២-០៩:០៨:៤១។ ឯកសារ D98/3.1.212 ប្រាក់ ខន ប្រតិចារឹកថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ១១:២៧:៥៥-១១:៣៥:០០ ["ឈ្លើយសឹកវៀតណាម តាមខ្ញុំឃើញនៅកន្លែងហ្នឹង គឺមាន តា ចាន់ គាត់អ្នកសួរ។ សួរហើយ គាត់ថតជាខ្សែអាត់ចាក់ផ្សាយតាមវិទ្យុ"]។ ឯកសារ D4.1.245 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ខន KH ERN 00146597-98។ ឯកសារ D4.1.346 កំណត់ហេតុស្តាប់ចម្លើយ ម៉ម ណៃ KH ERN 00162888 ["ស៖ ទាហានវៀតណាមដែលបានសួរនោះ មានបានធ្វើចម្លើយសារភាពដែរ? ឆ៖ មានធ្វើដែរ រួចហើយបញ្ជូនទៅឲ្យខាងលើ ហើយអ្នកខ្លះធ្វើថតសំឡេងចាក់តាមវិទ្យុ [...] យើងសួរជាយួនហើយ បកប្រែ រួចហើយយើងទៅផ្សាយ"]។ ឯកសារ D98/3.1.290 ស សៀក ប្រតិចារឹកថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១២ ម៉ោង ១៤:១៤:៤៨-១៤:២២:១០។ ឯកសារ D4.1.408 កំណត់ហេតុស្តាប់

វៀតណាមនៅមន្ទីរស-២១[2259]។ សាក្សីជាច្រើនបានបញ្ជាក់ជាពិសេសថា ទារុណកម្មត្រូវបានប្រើប្រាស់ក្នុងអំឡុងពេលសួរចម្លើយអ្នកទោសជនជាតិវៀតណាម ដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១ នោះ[2260]។

ចម្លើយ ឈូក រិន KH ERN 00194469 [កម្មាភិបាលភូមិភាគនិរតីបញ្ជាក់ថាឮ "វិទ្យុកម្ពុជាប្រជាធិបតេយ្យបានចាក់ផ្សាយព័ត៌មានចម្លើយសារភាពរបស់ឈ្លើយសង្គ្រាមវៀតណាម"]។

2259 ឯកសារ D114/277.4 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ១៥:១១:៤៣-១៥:១៩:១២ [រៀបរាប់ពីកុនរបស់អ្នកទោសវៀតណាមស្លៀកឯកសណ្ឋាន ដែលបញ្ជាដោយ នួន ជា ថតដោយក្មួយប្រុស ប៉ុល ពត ឈ្មោះ ថេង ហើយផ្នែកខ្លះត្រូវបានថតនៅខាងក្នុង ស-២១]។ ឯកសារ D234/2.1.111 ឡាច មាន ប្រតិចារឹកថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង ១០:៤៨:២៤-១០:៥២:២០ ["កុនគេឲ្យមើលហ្នឹង ឲ្យឃើញពីការសួរចម្លើយថាកងទ័ពវៀតណាមហ្នឹងឆ្លើយ"]។ ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ (ហ៊ឹម ហ៊ុយ) ប្រតិចារឹកថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៦ ១៤:២៧:១៩-១៤:៣៤:០៩, ម៉ោង ១៥:០៤:៥២-១៥:០៩:២៧ ["ឃើញថតទាំងខ្សែៗឲ្យដើរឲ្យអីហ្នឹង ហើយឃើញរូបភាពគេសម្លាប់វះពោះ វះអីហ្នឹង អាហ្នឹងឃើញ ត្រង់អាកន្លែងទារុណកម្ម គឺខ្ញុំអត់បានពិនិត្យមើលដែរភ្លេច"], ម៉ោង ១៥:០៩:២៧-១៥:១៦:២១ ។ ឯកសារ D4.1.346 កំណត់ហេតុស្តាប់ចម្លើយ ម៉ម ណៃ KH ERN 00162890 [ទាក់ទងអ្នកទោសសង្គ្រាមជនជាតិវៀតណាម "ខ្ញុំដឹងថាមានពេលមួយនោះ គេថតកុន"]។

2260 ឯកសារ D114/277.7 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ០៩:៤៨:៣៣ ["ស៖ តើអ្នកទោសវៀតណាមទាំងអស់នេះ ត្រូវបានធ្វើទារុណកម្មដែរឬទេ? ឆ៖ ខ្ញុំជឿថាធ្វើ ប៉ុនមិនខ្លាំង។ [...] សុខចិត្តនិយាយប៉ុណ្ណេះ ការនិយាយប៉ុណ្ណេះ មិនៗមែនជាទារុណកម្មធ្ងន់ទេ។ នេះចំពោះឈ្លើយសឹកប៉ុន្មានហ្នឹង ហើយក៏ដូចចំពោះគិញដែលចូលមកយកការណ៍ក៏អ៊ីចឹងដែរ ទារុណកម្មមាន។ ក៏ប៉ុន្តែ ឲ្យសារភាពបំណងប៉ុណ្ណឹង ខ្ញុំយល់ថាមិនជាការចាត់ធ្ងន់ធ្ងរប៉ុន្មានទេ ទារុណកម្ម ពិតជាមាន"]។ ឯកសារ D98/3.1.91 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ម៉ោង ០៩:៣១:៥៦-០៩:៣៧:៥៥ ["ទិសដៅគេកំណត់ពីលើមកច្បាស់លាស់។ ផ្ទាល់ខ្លួនខ្ញុំបានបញ្ជាទៅឲ្យអ្នកសួរ ធ្វើម៉េចឲ្យបានន័យមួយ ដែលខាងលើត្រូវការ គឺវៀតណាមឈ្លានពានកម្ពុជា ដើម្បីយកទៅដាក់សម្ព័ន្ធឥណ្ឌូចិន។ នេះជារឿងពិត"], ម៉ោង ០៩:៣១:៥៨-០៩:៤១:៤៩ [អះអាងថាមាន "ទារុណកម្មបន្តិចបន្តួច" ពីព្រោះការសួរចម្លើយត្រូវបានធ្វើដោយ ម៉ម ណៃ], ម៉ោង ១០:០៤:០៥-១០:០៨:១៣ ["ទទួលស្គាល់ថា ទារុណកម្មត្រូវបានប្រើទាហាន និងជនស៊ីវិលវៀតណាម "ពេលដែលមិនអាចចៀសរួច"], ម៉ោង ១១:៥៦:៤៥ ["ស៖ មានន័យថា បង្ខំឲ្យគេឆ្លើយតាមអ្វីដែលយើងចង់បាន? ឆ៖ តម្រង់ទិសឲ្យគេឆ្លើយតាមដែលយើងចង់បានៗ។ យើងចង់បានឲ្យគេនិយាយថាកងទ័ពវៀតណាមអត់បាយស៊ី ស៊ីតែកន្ទក់ គេនិយាយតាមហ្នឹង"]។ ឯកសារ D114/301 កំណត់ហេតុស្តាប់ចម្លើយ ឈុន ផល ឆ.47-51 [ចម្លើយអតីតអ្នកយាម ស-២១ ដែលបានឃើញស្លាកស្នាមនៅលើអ្នកទោសវៀតណាម បន្ទាប់ពីត្រឡប់ពីការសួរចម្លើយ អ្នកទោសជួនកាលមាន "ធ្វើទារុណកម្មខ្លាំង"]។ ឯកសារ D114/302 កំណត់ហេតុស្តាប់ចម្លើយ គង់ ផៃ ឆ.101 ["អ្នកទោសវៀតណាមធ្វើទារុណកម្មដូចខ្មែរដែរ វ៉ៃផង ឆក់ផង"]។

## ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការសម្លាប់ដោយចេតនា

### *ក) ការសម្លាប់រង្គាលជាលក្ខណៈប្រព័ន្ធនូវអ្នកទោសដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១*

584. ឌុច និងកម្មាភិបាលមន្ទីរស-២១ ផ្សេងទៀត បញ្ជាក់ថា ស្ទើរតែគ្រប់បុគ្គលដែលឃុំឃាំងនៅមន្ទីរស-២១ ត្រូវបានសម្លាប់[2261]។ ករណីលើកលែងតែមួយគត់ គឺករណីតិចតួចប៉ុណ្ណោះចំពោះអ្នក

[2261] ឯកសារ D114/277.6 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ១៣:៥២:១២-១៣:៥៧:២០, ១៤:២៧:៤៨-១៤:៣៣:៣៦ ["តែគេបញ្ជូនមក [ស-២១] ហើយ គឺត្រូវតែកម្ទេច"]។ ឯកសារ D234/2.1.121 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ០៩:៤៦:៣៥-០៩:៤៩:១៣។ ឯកសារ D98/1.2.22 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២ ម៉ោង ១៤:៤៨:៣៤-១៤:៥៣:១៣។ ឯកសារ D54/6.1.9 កាំង ហ្កេកអាវ ប្រតិចារឹកថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង ០៩:៤៤:២០-០៩:៥២:២៨។ ឯកសារ D98/3.1.89 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០០៩ ម៉ោង ០៩:៤៣:៥៦-០៩:៥២:១៦ ["មនុស្សដែលគេចាប់ មកចូលមន្ទីរ ស-២១ ហើយ គេចាត់ទុកជាខ្មាំងទាំងអស់ត្រូវតែកម្ទេច។ នេះជាគោលការណ៍ដែលអ្នកណាមិនអាចអ្នកណាល្មើសបាន"]។ ឯកសារ D4.1.1112 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00185470 ["គ្រប់មនុស្សដែលត្រូវបានចាប់ខ្លួន ត្រូវតែសម្លាប់ លើកលែងតែករណីពិសេស ដែលមានភាពបណ្តោះអាសន្ន [...] សេចក្តីសម្រេចតែមួយគត់ដែលត្រូវធ្វើ គឺទាក់ទងនឹងពេលវេលានៃការសម្លាប់តែប៉ុណ្ណោះ"]។ ឯកសារ D4.1.1116 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00153460-61។ ឯកសារ D114/37.1.7 កិច្ចសម្ភាសន៍របស់ កាំង ហ្កេកអ៊ាវ ថ្ងៃទី ៤-៦ ខែ ឧសភា ឆ្នាំ ១៩៩៩ EN ERN 00185053 ["គោលការណ៍សំខាន់ទៅ១ អ្នកណាក៏ដោយឲ្យតែចូល ស-២១ គឺត្រូវតែកម្ទេច"]។ ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ (ហ៊ឹម ហ៊ុយ) ប្រតិចារឹកថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង ០៩:១០:៣៦-០៩:១៤:៥៤ [ឌុច "អ្នកដែលចូលមកកន្លែងទួលស្លែងហ្នឹង គឺមិនអាចវិលត្រឡប់ទៅវិញបានទេ គឺគេត្រូវសម្លាប់ចោលទាំងអស់"]។ ឯកសារ D98/3.1.54 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ១១:២៦:១៣-១១:៣៨:៤៤, ១១:៤៥:៥៨-១១:៥៧:៥៨។ ឯកសារ D98/3.1.55 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ១០:០៤:៣៨-១០:០៩:០០, ១៣:៤៣:២៧-១៣:៤៨:១៧ ។ ឯកសារ D4.1.244 កំណត់ហេតុស្តាប់ចម្លើយ ហ៊ឹម ហ៊ុយ KH ERN 00146638-39។ ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹកថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង ១១:២៦:០២-១១:៣០:០០ ["ខ្ញុំធ្លាប់ដឹងថា នៅក្នុងមន្ទីរស-២១ ហ្នឹង គឺអ្នកចូលក្នុងហ្នឹងហើយគឺមិនដែលឃើញចេញទេ"]។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង ១៤:២៩:២១-១៤:៣១:៤៦។ ឯកសារ D98/3.1.212 ប្រាក់ ខន ប្រតិចារឹកថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ១០:៣០:០៤-១០:៣៤:០២។ ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹកថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង ១៥:៥៤:៥៤-១៥:៥៨:៥១។ ឯកសារ D234/2.1.118 សួស ធី ប្រតិចារឹកថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ១៣:៥១:១៤-១៣:៥៨:៣០ ["ខ្ញុំនិយាយអ៊ីចឹង ពីព្រោះកន្លែងមកអ្នកទោសឲ្យតែចូលមកដល់ ស-២១ ហ្នឹង គឺត្រូវតែក្រោយពីសួរចម្លើយហើយ ដឹងតែស្លាប់ហើយ [...] គេដែលយកមក ដឹងតែគេសម្លាប់"], ម៉ោង ១៣:៥៨:៣០-១៤:០២:៥០។ សូមមើលផងដែរ ឯកសារ D114/35.3 ដេវីដ ឆេន

ដែលគេចាត់ទុកថាមានប្រយោជន៍ដោយសារជំនាញរបស់ពួកគេ និងអ្នកដែលបានរត់ផុតពីសេចក្តីស្លាប់នៅចំពេលដែលកងទ័ពវៀតណាមមកដល់នៅដើមឆ្នាំ ១៩៧៩[2262]។ ដូចនេះ អ្នកទោសស្ទើរតែទាំងអស់ដែលត្រូវបានបញ្ជូនទៅមន្ទីរស-២១ (រួមទាំងអ្នកដែលត្រូវបានបញ្ជូនពីកងពល ១៦៤ និងកំពង់សោមផង) គឺជាជនរងគ្រោះនៃការធ្វើមនុស្សឃាតក្រៅប្រព័ន្ធតុលាការ។

585. ភស្តុតាងនេះក៏បង្ហាញយ៉ាងច្បាស់ផងដែរថា ការសម្លាប់រង្គាលបានកើតឡើងនៅមន្ទីរស-២១។ បញ្ជីឈ្មោះអ្នកដែលត្រូវបានសម្លាប់ ដែលរៀបចំដោយអនុប្រធានមន្ទីរស-២១ ឈ្មោះ ហោ និង ស្សួស ធី[2263] កត់ត្រាយ៉ាងហោចណាស់ ២៧ ករណីនៃការសម្លាប់រង្គាលអ្នកទោសលើសពី

---

ដល់ស សំឡេងពីមន្ទីរស-២១ KH ERN 00191883 [រៀបរាប់ពី ស-២១ ជា "គម្រោងដ៏គួរឱ្យស្អប់ខ្ពើម ដែលតាមរយៈគម្រោងការនេះ អ្នកទោសទាំងអស់ទោះបីជាបានប្រព្រឹត្តអ្វីក៏ដោយ មុនពេលដែលខ្លួនរៀបនិយាយត្រូវបានផ្តន្ទាទោសដល់ជីវិតរួចស្រេច"], KH ERN 00191846 ["បើនិយាយឱ្យកាន់តែច្បាស់ជាងនេះទៅទៀត ស-២១ មានលក្ខណៈជាកន្លែងសម្រាប់សួរចម្លើយ និងធ្វើទារុណកម្ម ជាជាងកន្លែងសម្រាប់ឃុំឃាំងមនុស្ស [...] ស-២១ ត្រូវបានប្រើប្រាស់ក្នុងគោលដៅចម្បងសម្រាប់តែបញ្ជូនមនុស្សទៅរកសេចក្តីស្លាប់ប៉ុណ្ណោះ"]។

2262 ឯកសារ D234/2.1.121 កាំង ហ្គេកអ៊ាវ ប្រតិចារឹកថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ០៩:៤៣:៥៦-០៩:៤៦:៣៥។ ឯកសារ D234/2.1.106 ជុំ ម៉ី ប្រតិចារឹកថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០៦ ម៉ោង ១០:៥៤:៤៧-១០:៥៨:២៣ ["វាមានពីរចំណុច ជីវិតខ្ញុំ។ អាចំណុចទី១ ដោយសារយើងចេះជួលជុសអាម៉ាស៊ីនអង្គុលីលេខហ្នឹង។ អាម៉ាស៊ីនអង្គុលីលេខហ្នឹងវាសម្រាប់តែវៃអ្នកទោសសួរចម្លើយទេ ដល់អាហ្នឹងខូចទៅ មានតែខ្ញុំទេចេះជួលជុលអាហ្នឹង អ៊ីចឹងវាទុកយើងប្រើសិន។ ទទួលទុកប្រើទៅ កងទ័ពរណសិរ្ស និងកងទ័ពវៀតណាមគេចូលមក [...] កុំមានថ្ងៃ ០៧ មករា ខ្ញុំអត់បានជួបមុខក្អួយៗ គេសម្លាប់ខ្ញុំបាត់ហើយ"], ម៉ោង ១៤:៤៨:៥០ ["នៅសល់បានប្រាំពីរនាក់។ ឥឡូវគាត់ស្លាប់អស់ប្រាំ នៅសល់តែពីរទេ"]។ ឯកសារ D98/3.1.313 វ៉ាន់ ណាត ប្រតិចារឹកថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៩ ម៉ោង ១០:១៣:១២, ១១:៤៤:៣៧-១១:៤៧:៥៧ [ពិភាក្សាចំនួនអ្នកទោសនៅសល់ នៅថ្ងៃទី ៧ ខែ មករា ឆ្នាំ ១៩៧៩៖ "ពេលនោះ ព្រោះខ្ញុំចេញពីក្នុងបន្ទប់គូររូបហ្នឹង មានជាងឈើ មានជាងភ្លើង ជាងដែកអីនោះ ជាងម៉ាស៊ីនហ្នឹង ប្រហែលជា ១៣ នាក់ [...] អ្នកទោសក្រៅពីនោះនៅក្នុងគុកហ្នឹង គឺអត់មានទេ"]។ ឯកសារ D98/3.1.8 ប៊ូ ម៉េង ប្រតិចារឹកថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ០៩:៥៥:៣១-១០:០៣:៤៣, ១១:០២:០០-១១:១៧:៤៩។ ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹកថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង ០៩:៥៥:៣៨-១០:០០:២៥។ ឯកសារ D98/3.1.95 កាំង ហ្គេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៨ ម៉ោង ០៩:៤៩:៤៧-០៩:៥៧:២៣ ["[អ្នកទោស] ទុកជាទោសរួចជីវិត [...] ពួកគូន្លាក់ ហើយនិងទន្តពេទ្យ ឌី ផុន។ ក្រៅពីនោះ យើងខ្ញុំមានទុកសម្រាប់ជួបការងារនៅនឹងមន្ទីរ ស-២១ ច្រើនដែរ [...] ប្រហែលជា ១៥ នាក់ យកមកប្រើជាបណ្តោះអាសន្ននៅហ្នឹង ក្នុងសវនាការយើងហ្នឹងមានមួយ គឺលោក ជុំ ម៉ី"]។

2263 ឯកសារ D234/2.1.119 ស្សួស ធី ប្រតិចារឹកថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ០៩:៥៩:៥៤-១០:០៥:៣៣ ["ខ្ញុំធ្វើបញ្ជី [...] អ្នកទោសចេញ"]។ ឯកសារ D234/2.1.118 ស្សួស ធី ប្រតិចារឹកថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង

១០០ នាក់ ដែលភាគច្រើនក្នុងអំឡុងពេលនៃការបោសសម្អាតខ្លាំងក្លានាឆ្នាំ ១៩៧៧ និង ឆ្នាំ ១៩៧៨[2264]។ ការសម្លាប់ក្នុងរយៈពេលតែ ២៧ ថ្ងៃប៉ុណ្ណោះ បានឆក់យកជីវិតរបស់អ្នកទោស

---

១៥:០២:៣៤-១៥:០៤:៣៣។ ឯកសារ D98/1.2.9 សួស ធី ប្រតិចារឹកថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ១៥:៣៦:៤០-១៥:៤៨:៤៣ ["ហ៊ី ប្រគល់ឲ្យខ្ញុំស្រង់បញ្ជីជាថ្មី ដើម្បីខ្ញុំស្រង់ឲ្យដឹងអ្នកទោសណាដែលនៅ អ្នកទោសណាដែលគេយកទៅកម្ទេច។ ស្រង់ឲ្យដឹងចំណុច អ្នកដែលយកកម្ទេចហើយ ខ្ញុំត្រូវចុះនៅក្នុងបញ្ជីហ្នឹង [...] រួចពីខ្ញុំចុះបញ្ជី គឺថាលេខផ្ទះលេខអស់ហើយ គឺបញ្ជីនោះខ្ញុំត្រូវប្រគល់ឲ្យទៅ ហ៊ី វិញ ដើម្បី ហ៊ី គេចាត់តាំងកម្លាំងយកចេញមកក្រៅ"]។ ឯកសារ D54/6.1.24 សួស ធី ប្រតិចារឹកថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ០៩:៥៨:១៨-១០:០០:១៥ [ពេលដែលអ្នកទោសត្រូវបានយកចេញទៅសម្លាប់ សាក្សីបញ្ជាក់ថា "ឈ្មោះអ្នកជាប់ឃុំទាំងអស់ត្រូវបានសម្លាប់"]។ ឯកសារ D4.1.347 កំណត់ហេតុស្តាប់ចម្លើយ សួស ធី KH ERN 00162601-03។

2264 ឯកសារ D1.3.3.2 ឈ្មោះអ្នកទោសនៅ ស-២១ ឈ្មោះអ្នកទោសដែលបានកម្ទេចនៅថ្ងៃ ១៦ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00008860-63 [អ្នកទោស ១០៦ នាក់]។ បញ្ជីឈ្មោះអ្នកទោសដែលបានកម្ទេចថ្ងៃ ០៦ ខែ ធ្នូ ឆ្នាំ ១៩៧៦ KH ERN 00008756-57 [អ្នកទោស ១០២ នាក់ត្រូវបានសម្លាប់ (អ្នកទោសពីរនាក់បន្ថែម គឺឈ្មោះដែលស្លាប់ដោយសារជំងឺ)]។ ឯកសារ D1.3.28.40 បញ្ជីសម្លាប់នៅ ស-២១ បញ្ជីឈ្មោះអ្នកទោសដែលបានកម្ទេច ថ្ងៃទី ១៥-៣១ ខែមករា ឆ្នាំ ១៩៧៧ EN ERN 00873378-92 [បញ្ជាក់ថា លេខរៀង ១-១៤៦ នៅលើបញ្ជីត្រូវបានសម្លាប់នៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៧៨]។ បញ្ជីឈ្មោះអ្នកទោសដែលបានកម្ទេច ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៧៧ EN ERN 00873336-44 [កម្មាភិបាលកងទ័ពបដិវត្តន៍កម្ពុជា ១០១ នាក់ត្រូវបានសម្លាប់ (អ្នកទោសពីរនាក់បន្ថែមពីកងទ័ពបដិវត្តន៍កម្ពុជានៅក្នុងបញ្ជី ត្រូវបានកម្ទេចនៅថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៧)]។ បញ្ជីឈ្មោះអ្នកទោសដែលត្រូវបានកម្ទេចនៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧៧ EN ERN 00873356-65 [១០៩ នាក់]។ ផ្នែកអគ្គិសនី បានកម្ទេចនៅថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៧៧ EN ERN 00873155-65 [ឈ្មោះកម្មករអគ្គិសនី ១០០ នាក់ត្រូវបានកម្ទេច]។ បញ្ជីឈ្មោះអ្នកទោសដែលបានកម្ទេចនៅថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៧៧ EN ERN 00873392-405 [១៥២ នាក់]។ បញ្ជីឈ្មោះអ្នកទោសកងពលដែលបានកម្ទេចនៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៧៧ EN ERN 00873500-20 [កម្មាភិបាលកងទ័ពបដិវត្តន៍កម្ពុជាចំនួន ១៩៨ នាក់]។ បញ្ជីឈ្មោះអ្នកទោសចូល និងកម្ទេចនៅថ្ងៃទី ២០ មិថុនា ឆ្នាំ ១៩៧៧ EN ERN 00873568-91 [២៥៦ នាក់]។ បញ្ជីឈ្មោះអ្នកទោសដែលបានកម្ទេចនៅថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ១៩៧៧ EN ERN 00873450-61 [កម្មាភិបាល ១២៧ នាក់ នៃកងពល ៣១០ និង ៤៥០]។ បញ្ជីឈ្មោះអ្នកទោសដែលបានកម្ទេចនៅថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៧៧ EN ERN 00873130-43 [អ្នកទោស ១១០ នាក់]។ បញ្ជីឈ្មោះអ្នកទោសដែលកម្ទេចនៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៧៧ EN ERN 00873466-86 [មនុស្ស ២៣១ នាក់ត្រូវបានសម្លាប់]។ បញ្ជីឈ្មោះអ្នកទោសពីផ្នែកបង ហ៊ុយ ស្រែ ដែលបានកម្ទេចថ្ងៃទី ០៣ សីហា ឆ្នាំ១៩៧៧ EN ERN 00873521-40 [អ្នកទោស ២២៩ នាក់ មកពីកងពល ៣១០ និង ៤៥០]។ បញ្ជីឈ្មោះអ្នកទោសដែលបានកម្ទេចនៅថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៧៧ EN ERN 00873557-58 [អ្នកទោស ១២ នាក់ត្រូវបានសម្លាប់បន្ថែមនៅថ្ងៃដដែល ដូច្នេះ សរុប ២៤១ នាក់]។ បញ្ជីឈ្មោះអ្នកទោសដែលបានកម្ទេចនៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៧៧ EN ERN 00873281-320 [អ្នកទោស ៤១៨ នាក់]។ បញ្ជីឈ្មោះអ្នកទោសដែលបានកម្ទេចនៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៧៧ EN ERN 00873633-

មន្ទីរស-២១ ជាង ៥.០០០ នាក់[2265]។ ទាក់ទងទៅនឹងការសម្លាប់ជាទៀងទាត់ពីមួយថ្ងៃទៅមួយថ្ងៃ អ្នកយាមមន្ទីរស-២១ ដែលទទួលខុសត្រូវខាងដឹកជញ្ជូនអ្នកទោសចេញពីមន្ទីរស-២១ ទៅជើងឯក បានផ្ដល់សក្ខីកម្មថា ការសម្លាប់អ្នកទោស "ជាមធ្យម" គឺ "ពី ៥០ ទៅ ១០០ នាក់ ក្នុងចំណោមពួកគេ"[2266]។ ការសម្លាប់រង្គាលមួយក្នុងចំណោមនោះនៅមន្ទីរស-២១ ដែលបានធ្វើឡើងនៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៧៦ មានទាំងអ្នកទោសជនជាតិវៀតណាម និងថៃ ដែលត្រូវបានចាប់ខ្លួនដោយកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យ និងបញ្ជូនពីកំពង់សោមទៅមន្ទីរស-២១ នៅថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ១៩៧៦ ផង[2267]។

---

50 [១៧៩ នាក់]។ បញ្ជីឈ្មោះអ្នកទោសដែលបានកម្ទេចនៅថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៧៧ EN ERN 00873592-605 [១៥០ នាក់]។ បញ្ជីឈ្មោះអ្នកទោសដែលបានកម្ទេចនៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ EN ERN 00873321-31 [១០៧ នាក់]។ បញ្ជីឈ្មោះអ្នកទោសដែលបានកម្ទេចនៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៧៧ EN ERN 00873605-33 [៣០១ នាក់]។

2265 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស មានត្រឹមតែ ៥.៥១២ នាក់ ដែលចុះកាលបរិច្ឆេទសម្លាប់ ពីព្រោះអ្នកវិភាគដែលជាអ្នករៀបចំបញ្ជីនេះ ផ្ដោតលើការពិនិត្យឈ្មោះចូលរបស់អ្នកទោសមកដល់ ស-២១ ដោយមិនបានពិនិត្យបញ្ជីសម្លាប់ទាំងអស់ និងកត់ត្រាកាលបរិច្ឆេទទាំងនោះនៅក្នុងបញ្ជីដោយឡែករបស់ ក.ស.ច.ស។ ឯកសារ D234/2.1.144 ហ៊ិន សុធានី ប្រតិចារឹកថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០១៧ ម៉ោង ០៩:៥៦:០៩, ១០:៣៣:២៥-១០:៤១:២៥, ១១:០១:១៥, ១១:០៦:០២-១១:០៩:៤៧, ១១:៣៤:១៥-១១:៣៧:០០, ១១:៣៤:២០-១៣:៣៧:២៨, ១៣:៥៤:៥៣-១៣:៥៧:៤៩ "ស៖ តើខ្ញុំយល់ត្រឹមត្រូវទេ ដែលថាលោកស្រីមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យទៅលើបញ្ជីអ្នកទោសដែលត្រូវកម្ទេច ហើយលោកស្រីមិនមានពេលគ្រប់គ្រាន់ ដើម្បីបញ្ចូលទៅក្នុងតារាងស្ព្រេតស៊ីតរបស់លោកស្រីនោះទេ? ឆ៖ ចាស លោកប្រធានត្រឹមត្រូវ"], ម៉ោង ១៤:០៦:៣៩-១៤:១៨:៤២ [បញ្ជាក់ថា កាលបរិច្ឆេទពីបញ្ជីសម្លាប់ធំៗទាំងបួន មិនត្រូវបានបញ្ចូលទេ ព្រោះខ្វះ"ពេលវេលា"]។ ការពិនិត្យឡើងវិញជាបន្តបន្ទាប់នូវបញ្ជីសម្លាប់របស់ ស-២១ ដែលរៀបចំដោយ ក.ស.ព បានបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់អ្នកទោសបន្ថែមចំនួន ៥.៦០០ នាក់ ច្រើនជាងពីរដងនៃចំនួនអ្នកទោសនៅក្នុងឯកសារ ដែលមានកាលបរិច្ឆេទសម្លាប់។

2266 ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ (ហ៊ីម ហ៊ុយ) ប្រតិចារឹកថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង ១០:៤៥:១១-១០:៥០:២៤ [លើកឡើងថា "ជាមធ្យម" ការសម្លាប់គឺ "ពី ៥០ នាក់ឡើងទៅចូល ១០០ នាក់" ហើយពេលខ្លះគេត្រូវដឹកទៅជើងឯងច្រើនជើង ព្រោះមានឡានតែពីរ ហើយឡានមួយអាចដឹកអ្នកទោសបានពី "៣០ ទៅ ៤០ នាក់"]។ ឯកសារ D234/2.1.115 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង ១៥:១៦:៥២-១៥:២០:៣០ ["រាប់ពី ៥០ ឡើង ជិតដល់ ១០០ នាក់"]។ ឯកសារ D234/2.1.109 តយ តេង ប្រតិចារឹកថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង ១៥:២៨:០៥-១៥:៣៤:៥៨ [អ្នកទោសយកទៅជើងឯកជាក្រុម "ម្ដងៗ ២០ ឬ ៣០ ឬ ៥០ នាក់"]។

2267 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ៥៩២-៥៩៣, ៥៩៦-៥៩៧, ៦០០, ៦០៤, ៦០៩, ៦១៣, ៦១៥-៦១៦, ៦២០, ៦២៥, ៦៤៥-៦៤៦, ៦៤៩-៦៥០, ៦៥៣, ៦៦៣, ៦៧៦, ៦៧៩-៦៨០,

## ខ) ការសម្លាប់នៅក្នុងបរិវេណមន្ទីរស-២១ និងនៅតាខ្មៅ

586. នៅក្នុងដំណាក់កាលដំបូងនៃមន្ទីរស-២១ ការសម្លាប់អ្នកទោសត្រូវបានធ្វើឡើងនៅឯមន្ទីរឃុំឃាំងតាខ្មៅ[2268]។ បន្ទាប់ពីមន្ទីរឃុំឃាំងបានចាប់ផ្ដើមប្រតិបត្តិការនៅសាលារៀនពញាយ៉ាត នៅខែមេសា ឆ្នាំ ១៩៧៦ ការសម្លាប់ត្រូវបានធ្វើឡើងនៅក្នុងតំបន់ជុំវិញបរិវេណមន្ទីរស-២១[2269]។ កង

១២៩៨១, ១២៩៨៣-៨៥, ១២៩៨៧-៨៨, ១២៩៩៩, ១៣០០១-០២, ១៣០០៥-០៦, ១៣០២៣, ១៣០៣១, ១៣០៥២-៥៣, ១៣០៥៥, ១៣៤៣២-៣៤, ១៣៤៣៦-៣៧, ១៣៦៤២-៤៣, ១៣៦៤៥, ១៣៦៥៣។ ឯកសារ D1.3.3.2 ឈ្មោះអ្នកទោសនៅស-២១ ឈ្មោះអ្នកទោសកម្ទេចនៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00008835-36 [លេខរៀង ១-៣១ គឺអ្នកនេសាទសៀម បានបញ្ជូនទៅស-២១ នៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦ និងកម្ទេចនៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៧៦], KH ERN 00008888-89 [លេខរៀង ២៣៤-២៨៤ គឺមានវៀតណាមចំនួន ១៧ នាក់ និងថៃ ៣៤ នាក់ ត្រូវបានបញ្ជូនពីកំពង់សោមនៅថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៧៦ ហើយសម្លាប់នៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៧៦]។

2268 ឯកសារ D114/277.2 កាំង ហ្គេកអ៊ាវ ប្រតិចារឹកថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ១៤:០៩:៤៤-១៤:១៩:០៣។ ឯកសារ D98/3.1.95 កាំង ហ្គេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៨ ម៉ោង ០៩:១៥:៥៤-០៩:២០:០២, ០៩:២៨:៣៦-០៩:៣៤:៥៨ ["ពេទ្យឆ្កួតតាខ្មៅ" មួយនៃ "ទីកន្លែងសំខាន់" ប្រើដោយ ស-២១ សម្រាប់សម្លាប់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ [...] "នៅ ប៉េហ្ស៊ី គេមិនសម្លាប់ ហើយនិងគេមិនកប់នៅទីនោះទេ [...] តាមខ្ញុំសន្និដ្ឋាន គឺពេលនោះគេសម្លាប់នៅតាខ្មៅ ហើយប៉េហ្ស៊ីហ្នឹងគ្រាន់តែជាកន្លែងស្តុកទុកសម្រាប់សួរចម្លើយបណ្ដឹង"]។ ឯកសារ D98/3.1.84 កាំង ហ្គេកអ៊ាវ ប្រតិចារឹកថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង ០៩:៤៨:០៥, ០៩:៥៣:១២-០៩:៥៧:៤៣។ ឯកសារ D4.1.860 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00403913-14។

2269 ឯកសារ D114/277.2 កាំង ហ្គេកអ៊ាវ ប្រតិចារឹកថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ១០:០៦:៥៨-១០:១០:០០ ។ ឯកសារ D98/3.1.95 កាំង ហ្គេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៨ ម៉ោង ០៩:២០:០២-០៩:២៨:៣៦, ១០:៣៧:៤០-១០:៤០:០៤, ១០:០៦:៥៨-១០:១០:០០, ១១:០៥:០០-១១:១០:៤៦, ១១:១៤:០៣-១០:២៦:០២ ["កន្លែងទី២" ប្រើដោយ ស-២១ សម្រាប់សម្លាប់ គឺ "នៅជុំវិញ ស-២១ មជ្ឈមណ្ឌលភ្នំពេញ [...] មនុស្សដែលគេសម្លាប់នៅក្នុងមន្ទីរស-២១ ហើយនិងបរិវេណ ស-២១ មានចំនួនច្រើន", រៀបរាប់អំពីអ្នកទោសត្រូវបានយកចេញទៅក្រៅ "ចងមុខ" ទៅសម្លាប់ "ពីរឬបីនាក់ម្ដង រហូតដល់អ្នកទោសចំនួន២៨នាក់ក្នុងមួយថ្ងៃ"]។ ឯកសារ D98/1.2.8 កាំង ហ្គេកអ៊ាវ ប្រតិចារឹកថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៩ ម៉ោង ០៩:៣៥:០០-០៩:៣៨:០៨។ ឯកសារ D1.3.33.8 កំណត់ហេតុសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00149911។ ឯកសារ D234/2.1.115 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង ១៥:១០:៤១-១៥:១៦:៥២, ១៥:២១:៥៦-១៥:២៧:២៨ [អ្នកទោសត្រូវបានសម្លាប់ ហើយកប់ក្នុងរណ្ដៅ "ចំហ" ខាងលិចបរិវេណ [...] អ្នកទោសត្រូវបានសម្លាប់ ហើយកប់នៅទីតាំងមួយប្រហែល១០០ម៉ែត្រខាងត្បូងបរិវេណ]។ ឯកសារ D98/3.1.54 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ១១:៤៩:២០-១១:៥៧:៥៨ ។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦

អ្នកយាមបានយកអ្នកទោសចេញពីបរិវេណនៅពេលយប់ និងបានសម្លាប់ពួកគេតាមលក្ខណៈដូចគ្នានឹងនៅជើងឯកដែរ៖ អ្នកទោសត្រូវបានវាយត្រង់ក្បាល អារក ហើយសាកសពរបស់ពួកគេត្រូវបានបោះចូលទៅក្នុងរណ្តៅ រួចកប់[2270]។

587. សូម្បីតែបន្ទាប់ពីជើងឯកត្រូវបានបង្កើតឡើងក្តី ក៏ក្រុមអ្នកទោសមួយចំនួនត្រូវគេបន្តសម្លាប់នៅតំបន់ក្រៅបរិវេណមន្ទីរស-២១ សំខាន់ៗ ក្នុងទីក្រុងភ្នំពេញ។ កម្មាភិបាលជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជា និងអ្នកទោសសំខាន់ៗដទៃទៀត ដែលត្រូវបានឃុំឃាំងដាច់ដោយឡែកនៅមន្ទីរឃុំឃាំងពិសេស មិនត្រូវបានបញ្ជូនទៅសម្លាប់នៅជើងឯកឡើយ ប៉ុន្តែជំនួសមកវិញ ត្រូវបានសម្លាប់នៅក្នុងបរិវេណតំបន់ទួលស្លែង[2271]។ រូបថតត្រូវបានថតផ្តិតយកសាកសពអ្នកទោស

---

ម៉ោង ០៩:២៥:២៩-០៩:២៩:៤២, ០៩:៤៨:៤៥-០៩:៥៣:២៨, ០៩:៥៤:៥៤-០៩:៥៩:៤៥ [នៅពេលចាប់ផ្តើមការងាររបស់គាត់នៅ ស-២១ អ្នកទោស "ត្រូវបានយកទៅសម្លាប់ខាងក្រៅក្បែរៗកន្លែងនោះ"], ម៉ោង ០៩:៥៤:៤៥-០៩:៥៩:៤៥ ["ខ្ញុំឃើញការកប់រណ្តៅសាកសព ពិសេសនៅកន្លែងរោងល្ខោន សាំង សារុន ពីដើម។ រុះរោងល្ខោនហើយ កន្លែងហ្នឹងរណ្តៅសាកសព តាំងពីខឿងហែម កន្លែងក្បែរឡានទឹកទៅត្បូងទៅ គឺរហូតសុទ្ធតែរណ្តៅសាកសពតាមផ្លូវខឿងហែមហ្នឹង"]។ ឯកសារ D4.1.387 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន ហេង KH ERN 00163688-89។

2270 ឯកសារ D234/2.1.115 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង ១៥:១២:២២-១៥:២០:៣០ ["ក្រុមប៉េង ទាំងអស់ហ្នឹង អ្នកជីករណ្តៅ ហើយនិងសម្លាប់ [...] គ្នាទាំងអស់ប្រហែលជាង១០០នាក់ ទាំងការពារ [...] [អ្នកទោស] គេលួចយកទៅ [សម្លាប់] ម៉ោងប្រាំបី ម៉ោងប្រាំបួនយប់"]។ ឯកសារ D98/3.1.54 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ១១:៤៩:២០-១២:០៤:០០ ["ពេលដែលគេយកទៅសម្លាប់ហ្នឹង គេឱ្យទៅអង្គុយនៅមាត់រណ្តៅហ្នឹង ហើយលត់ជង្គង់ទៅ ហើយគេវ៉ៃ វ៉ៃហើយគេអារក។ អារកហើយ គេដោះខោអាវ ដោះសម្លៀកបំពាក់ហ្នឹង ហើយគេដោះខ្នោះដៃ។ ដោះខ្នោះដៃហើយ បានដោះសម្លៀកបំពាក់ហ្នឹង"]។ ឯកសារ D4.1.387 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន ហេង KH ERN 00163689 ["ខ្ញុំឃើញពេលខ្ញុំបណ្តើរអ្នកទោសទៅជួនកាលអ្នកទោសខ្លះ គេឱ្យអង្គុយ ខ្លះឈរនៅមាត់រណ្តៅ តែអ្នកទោសជាប់ចំណងដដែល ហើយគេយកដែកបំពង់ទីបវ៉ៃកញ្ចឹងក ហើយធាក់ទម្លាក់រណ្តៅ"]។

2271 ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ (ហ៊ឹម ហ៊ុយ) ប្រតិចារឹកថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង ១០:៣១:១៧-១០:៣៦:១៦។ ឯកសារ D234/2.1.117 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង ១៣:៤១:៤៥-១៣:៤៧:១៨ ["អ្នកសំខាន់ៗ គេសម្លាប់ចោលកន្លែងនេះ គេអត់ដឹកយកទៅជើងឯកទេ"]។ ឯកសារ D98/3.1.54 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ១៤:០៧:៥២-១៤:១៩:៤៤។ ឯកសារ D4.1.244 កំណត់ហេតុស្តាប់ចម្លើយ ហ៊ឹម ហ៊ុយ KH ERN 00146639-40។ ឯកសារ D98/3.1.95 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៨ ម៉ោង ០៩:២០:០២-០៩:២៨:៣៦, ០៩:៤១:៤២-០៩:៤៥:៣៩ [អ្នកទោសសំខាន់ ត្រូវគេ "សម្លាប់នៅក្បែរផ្លូវម៉ៅសេទុង"]។ ឯកសារ D4.1.1117 កំណត់ហេតុសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00154224 [រៀបរាប់ពីត្រពាំង "នៅកែងផ្លូវម៉ៅសេទុង និងផ្លូវ ១៦៣។ នាពេលនោះ មានត្រពាំងមួយនៅទីនោះ

សំខាន់ៗ និងបញ្ជូនទៅឲ្យ សុន សេន ឬ នួន ជា ធ្វើជាភ័ស្តុតាងនៃការសម្លាប់របស់ពួកគេ[2272]។ អ្នកទោសនៅមន្ទីរស-២១ ដែលសាកសពត្រូវគេសម្លាប់រួចរបស់ពួកគេត្រូវបានថត រួមបញ្ចូលទាំងអនុលេខាធិការកងពល ១៦៤ ហ៊ីង ឡឿន ហៅ ឌឹម និងកម្មាភិបាលកងទ័ពបដិវត្តន៍កម្ពុជាជាន់ខ្ពស់ដទៃទៀត[2273]។

588. អ្នកទោសជនជាតិវៀតណាម អ្នកទោសមកពីបស្ចិមប្រទេស និងថៃ រួមទាំងអ្នកដែលត្រូវបានចាប់ខ្លួនដោយកងពល ១៦៤ ក៏ត្រូវបានសម្លាប់នៅក្នុងតំបន់ជុំវិញបរិវេណមន្ទីរស-២១ ជាជាងបញ្ជូនទៅជើងឯកផងដែរ[2274]។ ប្រធានមន្ទីរស-២១ ឌុច បានសារភាពថា អ្នកនេសាទថៃដែលចាប់ខ្លួន

---

ហើយគឺនៅទីនោះហើយ ដែល វន វេត, ឆាយ គឹមហ៊្វរ និង ណាត ត្រូវបានសម្លាប់"]។ ឯកសារ D4.1.920 កំណត់ហេតុសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00410184។ ឯកសារ D1.3.32.21 កំណត់ហេតុស្តាប់ចម្លើយ គក ស្រស់ KH ERN 00186799-800។

[2272] ឯកសារ D114/277.6 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ០៩:៤៨:១២-០៩:៥៦:៤៣, ១០:០៣:១៨-១០:០៦:៥១ ["ណាត, បង វន ហើយនិងបង ហុក ក៏ខ្ញុំថតដែរ ខាងលើបញ្ជាឲ្យថត"]។ ឯកសារ D98/3.1.95 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៨ ម៉ោង ០៩:៤១:៤២-០៩:៤៥:៣៩ ["ក្រោយពីសម្លាប់ហើយគេឲ្យថតរូប។ ដូច្នេះ ដើម្បីទុកជាស្លាកស្នាមឲ្យខាងលើឃើញ ច្រើនតែកាត់បំពង់កសិនបានថត"]។ ឯកសារ D54/6.1.24 សួស ធី ប្រតិចារឹកថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ១១:៣២:៣៩-១១:៣៨:៥៤។ ឯកសារ D1.3.33.3 កំណត់ហេតុសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00146487-88 ["[សុន សេន] បញ្ជាឲ្យថតរូបអ្នកដែលត្រូវបានសម្លាប់ ប៉ុន្តែ ថតតែអ្នកដែលសំខាន់ និងជិតស្និទ្ធអ្នកនៅ ស-២១ ប៉ុណ្ណោះ [...] ខ្ញុំទទួលរូបថត រួចបញ្ជូនទៅឲ្យ នួន ជា"]។ ឯកសារ D98/3.1.147 ឡាច មាន ប្រតិចារឹកថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០៩ ម៉ោង ១៦:០៨:៤៥-១៦:១៤:00 ["មិត្តស្រី គាត់ជាកងពិសេស ថតកន្លែងណាដែលគេសម្លាប់"]។ ឯកសារ D234/2.1.131 នឹម អ៊ីម ហៅ នឹម គឹមស្រ៊ាង ប្រតិចារឹកថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង ១៣:៥០:៤៥-១៣:៥២:៣៧, ១៥:៤៣:១៩-១៥:៥៨:២៧ [សក្ខីកម្មរបស់ប្រធានកងថតរូប ស-២១ បញ្ជាក់ថា មិត្តស្រី "ថតរូបអ្នកធំៗ"]។

[2273] ឯកសារ D1.3.28.40 បញ្ជីអ្នកទោសដែលត្រូវកម្ទេច ហើយបានថតរូប នៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 00009146 [អនុលេខាកងពល ១៦៤ ឈ្មោះ ឌឹម លេខរៀងទី២នៅក្នុងបញ្ជី ដែលរួមមានអនុសេនាធិការ សៀត ឆែ ហៅ ទុំ លេខាវរសេនាធំ ១៥២ និងអនុប្រធានកងពល ២៩០]។ ឯកសារD4.1.253 បញ្ជីអ្នកទោសពីសេនាធិការ លេខរៀង ៥-៧, ១១ [បញ្ចូលសម្រាប់កម្មាភិបាល ស-២១ ជាមួយចំណារ "ដក និងថត"]។ សូមមើលផងដែរ ឯកសារ D114/230.1.1 បញ្ជីអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ២០៤៧ [លេខាកងពល ១៧០], លេខរៀង ១១៤៦០ [លេខាកងពល ៨០៥]។

[2274] ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង ០៩:៥៣:៥៩-០៩:៥៨:០៩ ["កងទ័ពវៀតណាមដែលចាប់បានយកមក គេសួរចម្លើយហើយ គឺគេសម្លាប់នៅខាងក្រោយគុកទួលស្លែង ហើយនិងខាងត្បូងហ្នឹង [...] ក្រុម ប៉េង ដែលអ្នកយកទៅសម្លាប់នៅកន្លែងហ្នឹង"], ម៉ោង ១៤:២៩:៣៣-១៤:៣៤:០៩។ ឯក

បានដោយកងពល ១៦៤ ត្រូវបានសម្លាប់ទាំងអស់[2275] ហើយអ្នកទោសវៀតណាម "រាប់រយនាក់" ដែលបានបញ្ជូនទៅមន្ទីរស-២១ ក៏ត្រូវបានសម្លាប់ដែរ[2276]។ អ្នកទោសវៀតណាមជាធម្មតាត្រូវបានសម្លាប់ភ្លាមៗ បន្ទាប់ពីពួកគេមកដល់មន្ទីរស-២១[2277] រួមទាំងក្រុមដែលបានពិភាក្សានៅខាងលើ ដែលត្រូវបានបញ្ជូនពីកំពង់សោមនៅថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ១៩៧៦ និងសម្លាប់នៅថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៧៦។ អ្នកទោសវៀតណាមដែលត្រូវបានសម្លាប់នៅមន្ទីរស-២១ រួម ទាំងកូន

---

សារ D98/3.1.54 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ១៣:៤៧:៣៦-១៣:៥៥:១៥។ ឯកសារ D4.1.244 កំណត់ហេតុស្តាប់ចម្លើយ ហ៊ឹម ហ៊ុយ KH ERN 00146638-39។ ឯកសារ D1.3.32.21 កំណត់ហេតុស្តាប់ចម្លើយ គក ស្រស់ KH ERN 00186799-800 ["អ្នកទោស ថៃ និង វៀតណាម ត្រូវបានគេសម្លាប់នៅក្រៅបរិវេណស-២១ (ខាងត្បូង និងខាងលិច)"]។

2275 ឯកសារ D53/2.1.30 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៧ ម៉ោង ១៤:២៥:០៨ ["ពួកអ្នកនេសាទថៃ អត់ទុកជាសំខាន់ទេ មកដល់គេគិតតែពីកម្ទេចទៅ"]។ ឯកសារ D114/277.7 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ១០:៣៨:៣១-១០:៤៤:០០ ["ពួកសៀមដែលមកនេសាទត្រី ក៏គេចាត់ទុកជាតិញ ហើយគេកម្ទេច"]។ ឯកសារ D114/277.6 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ១១:២០:៥៨-១១:២៧:១២ [រៀបរាប់ផងដែរ ដែល ហ៊ី ចេញពី ស-២១ ទៅកម្ទេច "ជនជាតិថៃនៅកំពង់សោម" រាប់រយនាក់]។

2276 ឯកសារ D114/277.4 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ១៥:០៩:០៤-១៥:១១:៤៣, ១៥:២០:៥៤-១៥:២៣:២០ ["ទាហានយួនមកច្រើនណាស់ ចាប់បានមកច្រើនណាស់" [...] បញ្ជាក់ថា វៀតណាម "ទាំងទាហាន ទាំងស៊ីវិល គឺកម្ទេច"]។ ឯកសារ D98/3.1.91 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ម៉ោង ០៩:៣១:៥៨-០៩:៤១:៤៩, ១០:០៤:០៥-១០:០៨:១៣ ["ចាប់តាំងពីថ្ងៃ ០៦ មករា [១៩៧៨] ដែលយើងខ្ញុំចងចាំកាលបរិច្ឆេទនេះជាងគេ ទាហានវៀតណាមចេះតែមក មកកាន់តែច្រើនឡើងៗ។ [...] សុទ្ធតែបញ្ជាឱ្យកម្ទេចទាំងអស់"។ យល់ស្របថា វៀតណាមយ៉ាងតិច ៣៤៥ នាក់ ត្រូវបានឃុំឃាំង ហើយសម្លាប់នៅ ស-២១]។ ឯកសារ D4.1.1109 កំណត់ហេតុសួរចម្លើយ កាំង ហ្កេកអ៊ាវ KH ERN 00177579-80 ["ចំពោះចំនួនជនជាតិវៀតណាមដែលត្រូវបានគេឃុំខ្លួន ខ្ញុំមិនដឹងច្បាស់ទេ ប៉ុន្តែ ប្រហែលជារាប់រយនាក់ ហើយអ្នកទាំងនោះត្រូវបានសម្លាប់ចោល [...] ចំពោះទាហាន ត្រូវបានបញ្ជូនមកដោយពាក់ឯកសណ្ឋាន ហើយត្រូវបានសម្លាប់ ភ្លាមបន្ទាប់ពីការផ្សព្វផ្សាយចម្លើយសារភាពរបស់ពួកគេតាមវិទ្យុ ឬការឆ្លើយសារភាពរបស់ពួកគេ"]។

2277 ឯកសារ D4.1.244 កំណត់ហេតុស្តាប់ចម្លើយ ហ៊ឹម ហ៊ុយ KH ERN 00146639 ["ស៖ [...] តើទាហានវៀតណាមគេយកមកទុកយូរបានយកទៅសម្លាប់ ឬយ៉ាងណា? ឆ៖ គេទុកប្រហែលកន្លះខែ សួរចម្លើយរួចបានយកទៅសម្លាប់"]។ ឯកសារ D4.1.245 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ខន KH ERN 00146597 ["សួរមិនយូរ សួរមិនច្រើន អ៊ីចឹងវាអត់ដូចខ្មែរយើង អានោះសួរ តែម៉ាថ្ងៃពីរថ្ងៃអីបាត់ហើយ ចប់ហើយ"]។

តូចៗ[2278] និងកុមារផ្សេងៗទៀត[2279]។ ការសម្លាប់រង្គាលអ្នកទោសវៀតណាមនៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៧៨ រួមទាំងកុមារវៀតណាមចំនួន ៣ នាក់ ដែលត្រូវបានចាប់ខ្លួនបាននៅសមុទ្រ ដែលមានអាយុ ១៥ ១៦ និង ១៧ ឆ្នាំ[2280]។

589. ជនជាតិពីបរស្ទិមប្រទេស ដែលត្រូវបានចាប់ខ្លួននៅសមុទ្រ និងបញ្ជូនទៅមន្ទីរស-២១ ដោយកងពល ១៦៤ ក៏ត្រូវបានសម្លាប់ផងដែរ នៅជិតបរិវេណទួលស្លែង[2281]។ សាកសពរបស់ពួកគេត្រូវបានដុតបន្ទាប់ពីសម្លាប់រួច ដោយធ្វើដូច្នេះដើម្បីកុំឱ្យបន្សល់ភស្តុតាងនៃឆ្អឹងរបស់ពួកគេ[2282]។

---

[2278] ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹកថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង ០៩:០៨:៤១-០៩:១២:០៩ ។ ឯកសារ D98/3.1.212 ប្រាក់ ខន ប្រតិចារឹកថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ១០:០៧:១៩-១០:១៣:៣១, ១៤:០៤:០៥-១៤:១០:០០។ ឯកសារ D98/3.1.136 ប្រាក់ ខន ប្រតិចារឹកថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ០៩:១៣:៣១-០៩:២៦:៥៧។

[2279] សូមមើលឧទាហរណ៍ ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ៩៨៥៦ [អាយុ ១៤ ឆ្នាំ Troeung Thinhieng "កសិករ វៀតណាម (សិក្ស)" ចូល ស-២១ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៧៨, សម្លាប់ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៧៨], ៩៩០២ [អាយុ ១៤ ឆ្នាំ Ngvieng Thimom សម្លាប់ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៧៨], ១២៦១៩ [អាយុ ១៣ ឆ្នាំ Ngvieng Yaing Vin ជា "គិញវៀតណាម" ចូលថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៧៨, សម្លាប់ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៧៨], ១២៦២៣ [អាយុ ៧ ឆ្នាំ Troeng Yaing Fak ជា "គិញវៀតណាម" ចូលថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៧៨, សម្លាប់ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៧៨], ១០១៣០ [អាយុ ១៣ ឆ្នាំ ក្មេងស្រីវៀតណាម Vin Thi Ngok ជា "ទាហាន យៀកកុង វៀតណាម" ចូលថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ១៩៧៨, សម្លាប់ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ១៩៧៨]។ ដកស្រង់ ឯកសារ D114/37.1.11 រូបថត ស-២១ របស់ Vin Thi Ngoc EN ERN P 00000223។

[2280] ឯកសារ D114/230.1.1 បញ្ជីអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ៨៤០១ [អាយុ ១៧ឆ្នាំ Trin Vin Hong ជាគិញ "វៀតណាម"], ៨៤០៥ [អាយុ ១៥ឆ្នាំ Loeung Minh Tun Hay ជា "គិញវៀតណាម"], ៨៤០៨ [អាយុ ១៦ ឆ្នាំ Trinh Vok Hour ជា "វៀតណាម"]។

[2281] ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង ១៥:១២:៣០-១៥:១៩:២៨ [ពិភាក្សាអំពីការសម្លាប់ពួកបស្ចិមប្រទេសពីរនាក់៖ "គេយកគាត់មកស្លាប់នៅផ្លូវធំបេប្លេហឹមហ្នឹង ចំហៀងខាងជើងផ្លូវ"]។

[2282] ឯកសារ D114/277.3 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ១៥:០៨:៥១-១៥:១១:៣៧, ១៥:១១:៣៧-១៥:១៧:២៨ [ទាក់ទងនឹងពួកបស្ចិមប្រទេសនៅ ស-២១ "យកទៅកម្ទេច។ កម្ទេចនេះមានការណែនាំដាច់ខាត ឱ្យដុតនឹងកៅស៊ូកង់ឡានឱ្យអស់ កុំឱ្យសល់ឆ្អឹង"។ [...] ឌុច ត្រូវបានណែនាំដោយ នួន ជា ថា "ពួកអាច្រមុំស្រួចកម្ទេច ហើយដុតវាឱ្យឆេះសុះទៅ កុំឱ្យសល់"]។ ឯកសារ D114/277.6 កាំង ហ្កេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១៥ ខែ

### *គ) ការសម្លាប់នៅជើងឯក*

590. បន្ទាប់ពីមន្ទីរស-២១ បានចាប់ផ្តើមប្រើប្រាស់ជើងឯកជាកន្លែងសម្លាប់ នៅដើមឆ្នាំ ១៩៧៧ អ្នកទោសភាគច្រើនបំផុតត្រូវបានសម្លាប់នៅទីនោះ និងកប់ក្នុងរណ្តៅធំៗ ដែលជីកដោយក្រុមអ្នកយាមដែលឈរជើងនៅទីតាំងនោះ[2283]។ ការសម្លាប់ជាធម្មតាធ្វើឡើងនៅពេលយប់[2284]។ បន្ទាប់ពី

---

មិថុនា ឆ្នាំ ២០១៦ ម៉ោង ១០:០៦:៥១-១០:០៩:០០។ ឯកសារ D98/1.2.23 កាំង ហ្គេកអ៊ាវ ប្រតិចារឹកថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១២ ម៉ោង ០៩:៣២:៤៤-០៩:៣៥:៤៥។ ឯកសារ D98/1.2.22 កាំង ហ្គេកអ៊ាវ ប្រតិចារឹកថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១២ ម៉ោង ១៤:២៨:៥៩-១៤:៣៦:៣៤។ ឯកសារ D4.1.1117 កំណត់ហេតុសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00154224។ ឯកសារ D1.3.33.3 កំណត់ហេតុសួរចម្លើយ កាំង ហ្គេកអ៊ាវ KH ERN 00146487-88។ ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង ១៥:១២:៣០-១៥:១៩:២៨ ["តាឌុច បញ្ជាថាឲ្យ តាហ៊ី ហ្នឹងកុំឲ្យកប់ ឲ្យគរឈើដុត ព្រោះជនជាតិបរទេសអត់ឲ្យកប់ទេ [...] ពួកខ្ញុំយាម ដើរព័ទ្ធជុំវិញហ្នឹង ឃើញគេដុតនៅកន្លែងហ្នឹង"]។ ឯកសារ D98/3.1.54 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ម៉ោង ១៣:៤៤:០៧-១៣:៥៤:១៥ ["ខ្ញុំឃើញគេដាក់កង់ឡានដុត"]។ ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹកថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង ០៩:៤៨:២៣-០៩:៥៣:៥៩។ ឯកសារ D98/3.1.212 ប្រាក់ ខន ប្រតិចារឹកថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ១៣:៥៨:៤៥-១៤:០៧:២០។ ឯកសារ D98/3.1.19 ចៀម សឿ ប្រតិចារឹកថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៩ ម៉ោង ០៩:៣៨:០០-០៩:៥១:៤៩។

2283 ឯកសារ D234/2.1.115 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង ១៥:២៧:២៨-១៥:៣០:១៩ [លើកឡើងថា កងការពារត្រូវបានចាត់ឲ្យជើងឯង ដើម្បី "ជីករណ្តៅ និងសម្លាប់អ្នកទោស"]។ ឯកសារ D234/2.1.109 តយ តេង ប្រតិចារឹកថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង ១៤:៣១:៣១-១៤:៣៧:២៥, ១៥:១៥:០០-១៥:១៧:១៩, ១៥:៤៨:២៥-១៥:៥០:៤៣។ ឯកសារ D4.1.248 កំណត់ហេតុស្តាប់ចម្លើយ តយ តេង KH ERN 00164401។ ឯកសារ D10.1.117 កំណត់ហេតុនៃការតទល់មុខគ្នា កាំង ហ្គេកអ៊ាវ KH ERN 00165427-28 [ឈ្មុន ផល បញ្ជាក់អំពីការជីករណ្តៅរួម និងកប់សាកសព]។ ឯកសារ D98/3.1.83 កាំង ហ្គេកអ៊ាវ ប្រតិចារឹកថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០០៩ ម៉ោង ១០:១១:២២-១០:២០:២២ ["កងដែលទៅប្រចាំការនៅជើងឯងហ្នឹង ជាផ្នែកមួយតូចនៃកងពិសេសៗទេ [...] គ្នាមានភារកិច្ចត្រឹមតែជីករណ្តៅ ហើយលុបរណ្តៅឲ្យគេទេ"]។ ឯកសារ D98/3.1.95 កាំង ហ្គេកអ៊ាវ ប្រតិចារឹកថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៨ ម៉ោង ម៉ោង ១០:៣៣:៥០-១០:៤០:០៤។

2284 ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង ១០:៤២:៥៨-១០:៤៥:១១, ១០:៥០:២៤-១០:៥៦:១០។ ឯកសារ D98/3.1.54 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ១៣:៥៤:១៥-១៣:៥៨:៣៩។ ឯកសារ D234/2.1.109 តយ តេង ប្រតិចារឹកថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង ១៥:១៩:៤៨-១៥:២៤:២៤ ["គេដឹកអ្នកទោសចូលទៅក្នុងអំឡុងម៉ោងប្រាំពីរយប់"], ១៥:២៨:០៥-១៥:៣២:៤២។ ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹកថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង ០៩:១៨:៣០-០៩:២២:៥៩។ ឯកសារ D4.1.248 កំណត់ហេតុស្តាប់ចម្លើយ តយ តេង KH ERN 00164401-02។

ទទួលបានឈ្មោះអ្នកទោសដែលត្រូវសម្លាប់ពីអនុប្រធានមន្ទីរស-២១ រួចមក ឈ្មោះ ហោ និង សួស ធី រៀបចំបញ្ជីមួយសម្រាប់ឱ្យអ្នកយាមប្រើដើម្បីប្រមូលអ្នកទោសទាំងនោះ[2285]។ កងអ្នកយាមរបស់ ហ៊ឹម ហ៊ុយ បានយកអ្នកទោស ដែលមានរាយក្នុងបញ្ជីចេញពីបន្ទប់ឃុំឃាំងរបស់ពួកគេ ដាក់ពួកគេលើរថយន្តដឹកទំនិញ ដោយដៃជាប់ខ្នោះ និងបិទមុខ និងដឹកអ្នកទោសពីបរិវេណមន្ទីរស-២១ ទៅផ្ទះឈើនៅជើងឯក[2286]។

---

[2285] ឯកសារ D234/2.1.118 សួស ធី ប្រតិចារឹកថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ១៥:០២:៣៤-១៥:០៤:៣៣ ។ ឯកសារ D234/2.1.119 សួស ធី ប្រតិចារឹកថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង ០៩:៤៣:៤២-០៩:៤៨:៥០។ ឯកសារ D4.1.347 កំណត់ហេតុស្តាប់ចម្លើយ សួស ធី KH ERN 00162602-03 ["ពេលដែលបានចំណារពី ឌុច ឱ្យមក ហ៊ ហ៊ឱ្យមកខ្ញុំ។ ហ៊ឱ្យខ្ញុំស្រង់ឈ្មោះធ្វើជាបញ្ជីរួម [...] ក្រោយពីបានធ្វើបញ្ជីរួចហើយ សរុបចំនួនអ្នកដែលត្រូវដកហើយ ខ្ញុំបានចុះលេខបន្ទប់អគារហ្នឹងហើយ បានបញ្ជូនទៅឱ្យហ៊ ហើយ ហ៊ បញ្ជូនទៅឱ្យកងអនុសេនាធំ ដើម្បីយកមនុស្សចេញ [...] ការពិនិត្យបញ្ជីអ្នកទោសដកចេញហ្នឹង គេប្រុងប្រយ័ត្នណាស់ [...] ដូច្នេះ អ្នកទោសដែលយកចេញពីបន្ទប់ហ្នឹង គឺខាងការពារគេទៅយកមក ហើយខ្ញុំនៅចាំមាត់ទ្វារដើម្បីពិនិត្យ"]។

[2286] ឯកសារ D10.1.117 កំណត់ហេតុនៃការតទល់មុខគ្នា កាំង ហ្កេកអ៊ាវ KH ERN 00165428 [ហ៊ឹម ហ៊ុយ៖ "ទាក់ទងនឹងតួនាទីពិសេសរបស់ខ្ញុំ ខ្ញុំជាប្រធានរបស់អង្គភាពដែលទទួលបន្ទុកដឹកជញ្ជូនអ្នកទោសពីស-២១ ទៅជើងឯក"]។ ឯកសារ D234/2.1.115 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង ១៥:៣៣:៣២-១៥:៤០:០០។ ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង ០៩:៤៦:១៨-០៩:៤៧:៥១ ["បងធី ហ្នឹងទៅបង្ហាញឈ្មោះណាៗ ឱ្យពួកខ្ញុំយកម៉ែឪហ្នឹងមក យកទៅជើងឯក"], ម៉ោង ១០:៥២:៤៦-១១:០០:៤៣ ["ឡើងឡានៗទៅ ហើយដាក់មួយឡានប៉ុន្មាន ឱ្យរាប់មើលក្នុងមួយឡានប៉ុន្មាន មួយឡានប៉ុន្មានឱ្យដឹង ហើយដឹកយកទៅ។ ទៅដល់នោះ ពេលយកទៅចូលក្នុងផ្ទះនោះ ដាក់ចេញពីឡានយកចូលក្នុងផ្ទះដែលនៅជើងឯកហ្នឹង ហើយរាប់ឱ្យដឹងចំនួន"]។ ឯកសារ D98/3.1.54 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ១៣:៥៤:១៥-១៤:០៧:៥២ ["ពេលដែលគេរៀបចំឈ្មោះហើយ អ្នកណានៅបន្ទប់ណាៗ គេដឹង [...] គេចាប់ផ្តើមយកចេញមក គេដាក់ខ្នោះ ចងមុខ ចងអីហើយ ដល់ហើយគេបណ្តើរចេញពីគុកមក គឺពួកខ្ញុំយកឡានទៅនៅចាំមាត់ទ្វារច្រកដែលចូលគុកហ្នឹង [...] ជួនកាលដាក់បានទៅដល់ទៅ៧០ នាក់ ៨០ នាក់ ឬក៏ ១០០ នាក់ឯណោះក្នុងពេលម្តង [...] ពួកខ្ញុំទៅ ពួកខ្ញុំដឹងថាចំនួនប៉ុន្មាន ខ្ញុំយកទៅ ទៅដល់នោះខ្ញុំកត់ឈ្មោះ គេឱ្យខ្ញុំកត់ឈ្មោះ ដើម្បីឈ្មោះហ្នឹងដើម្បីទូរទាត់ក្នុងបញ្ជីរបស់គេ ដែលយកទៅចំនួនប៉ុន្មាននាក់ ហើយឈ្មោះអ្វីខ្លះ ធ្វើយ៉ាងម៉េចកុំឱ្យបាត់ [...] ទៅដល់នោះ គឺកត់ឈ្មោះទៀត ឈ្មោះអី ឈ្មោះ "ក" កត់ឈ្មោះ "ក" អ៊ីចឹងទៅ"]។ ឯកសារ D4.1.347 កំណត់ហេតុស្តាប់ចម្លើយ សួស ធី KH ERN 00162603។ ឯកសារ D1.3.32.9 កំណត់ហេតុស្តាប់ចម្លើយ ឈុន ផល EN ERN 00163813។ ឯកសារ D234/2.1.109 គយ តេង ប្រតិចារឹកថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង ១៥:១៩:៤៨-១៥:២៨:០៥។ ឯកសារ D4.1.248 កំណត់ហេតុស្តាប់ចម្លើយ គយ តេង KH ERN 00164401 ["អ្នកទោស គេដឹកពីស-២១ [...] និង

591. នៅឯជើងឯក អ្នកទោសត្រូវបានទទួលដោយកងរបស់ តាយ តេង និងយកចេញពីផ្ទះឈើ ម្តងម្នាក់ទៅសម្លាប់[2287]។ ជនរងគ្រោះត្រូវគេបញ្ជាឱ្យអង្គុយ ឬលុតជង្គង់ចុះនៅគែមរណ្តៅ ហើយត្រូវគេវាយពីក្រោយត្រង់កញ្ចឹងក ដោយប្រើ "របារដែក" "ភ្លៅរទេះ" "បំពង់" ឬឧបករណ៍ស្រដៀងគ្នានឹងដំបង ដែលក្រោយមក ពួកគេត្រូវបានប្រើកំបិតអារក ដោះខ្នោះ និងសម្លៀកបំពាក់ចេញ ហើយសាកសពរបស់ពួកគេត្រូវបានទម្លាក់ចូលទៅក្នុងរណ្តៅកប់[2288]។ ការសម្លាប់នៅជើងឯក

ឈ្មោះ ហ៊ុយ និងក្រុមរបស់គាត់មកជាមួយឡានពេលដឹកមកម្តងៗ"]។ ឯកសារ D10.1.29 កំណត់ហេតុស្តាប់ចម្លើយ មាស ប៉េងគ្រី KH ERN 00163701-02។

2287 ឯកសារ D10.1.117 កំណត់ហេតុនៃការតទល់មុខគ្នា កាំង ហ្កេកអ៊ាវ KH ERN 00165427-28 ["មាស ប៉េងគ្រី៖ អ្នកទោសចុះពីរថយន្តរួចត្រូវបាននាំចូលទៅក្នុងផ្ទះឈើ។ [...] ហ៊ឹម ហ៊ុយ៖ [...] ហ៊ី បានបញ្ជាខ្ញុំឱ្យចាត់តាំងមនុស្សមួយនាក់ចាំទទួល និងយាមអ្នកទោសនៅជើងឯង។ ក្រុមរបស់ តយ តេង ជាអ្នកទទួលខុសត្រូវលើការងារនេះ។ ក្រុមនេះមានគ្នា ៨ នាក់ ត្រូវជីករណ្តៅ និងសម្លាប់អ្នកទោស។ [...] តយ តេង៖ គឺពិតប្រាកដហើយ។ បង ហ៊ុយ ជាមេរបស់ខ្ញុំ"]។ ឯកសារ D234/2.1.109 តយ តេង ប្រតិចារឹកថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង ១៥:២៨:០៥-១៥:៣៤:៥៨ ["គេយកអ្នកទោសទៅសម្លាប់ហ្នឹង គឺគេនាំចេញទៅម្តងមួយៗ រហូតទាល់តែសម្លាប់អស់"]។ ឯកសារ D4.1.248 កំណត់ហេតុស្តាប់ចម្លើយ តយ តេង KH ERN 00164401-02។ ឯកសារ D234.2.1.116 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង ១០:៤០:៤៧-១០:៤២:៥៨, ១០:៤២:៥៨-១០:៤៥:១១, ១០:៥២:៤៦-១០:៥៦:១០, ១១:០០:៤៣-១១:០២:៥៩។ ឯកសារ D98/3.1.54 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ១៤:០២:១៤-១៤:០៧:៥២។

2288 ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង ១១:០០:៤៣-១១:០២:៥៩, ១១:០៤:៥៣-១១:១០:១០, ១៤:១៣:៤៧-១៤:១៦:១០ ["បណ្តើរទៅដល់មាត់រណ្តៅហ្នឹង ហើយគេឱ្យអង្គុយចោងហោងទៅ ហើយគេយកដែក ដែកខ្នោះហ្នឹងវ៉ៃកញ្ចឹងកពីក្រោយ។ វ៉ៃកញ្ចឹងកក្រោយហើយ ក៏គេអារក អារអី។ [...] គេរះពោះរះអី ដោះខ្នោះដោះអី រះពោះរះអី បោះចូលទៅក្នុងរណ្តៅ។ [...] នៅកន្លែងនោះគឺមានកាំបិតចិតត្នោត។ កាំបិតចិតត្នោងហ្នឹង គេវ៉ៃដួលព្រួសហើយ គេអារកបណ្តោយទៅ។ [...] តាឌុច តាហ៊ី អ្នកបង្រៀនការសម្លាប់មនុស្សហ្នឹង។ [...] តាហ៊ី និង តាឌុច ហ្នឹងឱ្យថាវ៉ៃហើយ ឱ្យអារក អារករហើយបានរះពោះ។ បើកាលណាមិនរះពោះ គឺហើមមួយរបើករណ្តៅហ្នឹងតែម្តង អ៊ីចឹងស្អុយគេដឹង"។ ឯកសារ D98/3.1.54 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ១៤:០៧:៥២-១៤:១៥:៣៦, ១៤:២៨:១៥-១៤:៣៩:១០, ១៦:០៧:១៩-១៦:១៥:០០ ["មុននឹងយកទៅសម្លាប់ហ្នឹង គេណែនាំឱ្យអ្នកទោសលុតជង្គង់ ហើយចាំឱ្យវ៉ៃ វ៉ៃហើយបានអារក ព្រោះវ៉ៃមិនទាន់ងាប់ទេ ទាល់តែអារកទៀតបានងាប់"]។ ឯកសារ D234/2.1.109 តយ តេង ប្រតិចារឹកថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង ១៥:៣៤:៥៨-១៥:៣៩:៤៣, ១៥:៣៩:៤៣-១៥:៤៣:១០, ១៥:៥៣:០០-១៥:៥៦:៥៤ ["គេឱ្យអង្គុយនៅមាត់រណ្តៅហើយ គេនៅកន្លែងធ្វើការហ្នឹងគេសម្លាប់ទៅ គេវ៉ៃពីក្រោយ"។ [...] បញ្ជាក់ថាចម្លើយរបស់គាត់នៅក្នុងឯកសារ D4.1.248 បានរៀបរាប់ "ការសម្លាប់មនុស្សគេធ្វើតែអ៊ីចឹង"។ បញ្ជាក់ថាកងរបស់គាត់ "សម្លាប់មនុស្សមួយចំនួននៅជើងឯក"]។ ឯកសារ D234/2.1.110 ឡាច មាន ប្រតិចារឹកថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង ០៩:១៨:

"ចំណាយពេលជាច្រើនម៉ោង"[2289] និងត្រូវបានត្រួតពិនិត្យដោយអនុប្រធានមន្ទីរស-២១ ហោ[2290]។ ហ៊ឹម ហ៊ុយ បានកត់ត្រាឈ្មោះអ្នកទោសដែលបានសម្លាប់រួចនីមួយៗ និងបញ្ជូនបញ្ជីនោះត្រឡប់ទៅ ស្ងួស ធី វិញ[2291]។

592. ការសម្លាប់រង្គាលនៅជើងឯកត្រូវបានបញ្ជាក់ដោយការគាស់ផ្នូរដែលបានធ្វើឡើង នៅរវាងឆ្នាំ ១៩៨១ និងឆ្នាំ ១៩៨៣ ដែលក្នុងនោះផ្នូររួមចំនួន ៨៦ ក្នុងចំណោម ១២៩ នៅជើងឯក ត្រូវបាន

---

៣០-០៩:២៥:០៦ ["គេប្រើដែកវាយសម្លាប់ [...] ដូចដែកក្ដៅរទេះ ដូចដែកអីទំហំវាប៉ុនដងកាំបិតហ្នឹងង ហ្នឹង ប្រហែលជាកន្លះម៉ែត្រ"]។ ឯកសារ D4.1.248 កំណត់ហេតុស្ដាប់ចម្លើយ តយ តេង KH ERN 00164401-02 ["គេមកអង្គុយនៅចម្ងាយពីមាត់រណ្ដៅប្រហែលជា ១ ម៉ែត្រ [...] គេយកបំពង់ទីបវាយកញ្ចឹងក ពេលអ្នកទោសដួលគេដោះខ្នោះដៃចេញ។ ពេលនោះគេយកកាំបិតទៅសម្លាប់បន្ថែម"]។

2289 ឯកសារ D98/3.1.54 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ១៤:០២:១៤-១៤:០៧:៥២ ["ស ៖ [...] ចំនួនច្រើនសន្ធឹកសន្ធាប់ដូចប៉ុណ្ណេះ ប្រហែលជារយពេលប៉ុន្មានទៅបានអស់? ឆ៖ បាទ រយៈពេលយូរមក តាំងពីម៉ោងចេញពីភ្នំពេញ ប្រហែលជាម៉ោងប្រាំបី ទៅដល់ណោះវាចូលម៉ោងប្រាំបីកន្លះ [...] ប្រហែលជាម៉ោងមួយ ម៉ោងពីរបានហើយ"]។

2290 ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង ១១:០០:៤៣-១១:០២:៥៩, ១១:០៧:៣០-១១:១៣:០២ ["តាហ៊ី ក៏គាត់ទៅហ្នឹង រៀបចំការសម្លាប់ រៀបចំឲ្យបណ្ដើរអ្នកទោសម្ដងមួយៗ ក៏គាត់រៀបចំរបស់គាត់។ [...] តាហ៊ី ជិះឡានទៅជាមួយពួកខ្ញុំ។ [...] ស៖ ខ្ញុំសុំសួរបញ្ជាក់ឲ្យច្បាស់។ រាល់ពេលដែលលោកទៅជើងឯក ហ៊ី ទៅជាមួយគ្នារាល់ជើងអីចឹងដែរ ឬក៏ ហ៊ី ទៅដោយពេលទេ? ឆ៖ បាទ គាត់ទៅរាល់ពេលតែម្ដង។ [...] ព្រោះតែយកទៅគឺ តាហ៊ី ទៅ យកទៅ តាហ៊ី ហើយ"]។

2291 ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ (ហ៊ឹម ហ៊ុយ) ប្រតិចារឹកថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង ១០:៥៨:៣១-១១:០២:៥៩, ១១:០៤:៥៣-១១:០៧:៣០, ១៤:១៣:៤៧-១៤:២០:០៩ ["ពេលដែលគេបញ្ចេញ [អ្នកទោស] ពីក្នុងផ្ទះហ្នឹងទៅ [] ខ្ញុំមានកៅអីមួយ ខ្ញុំអង្គុយកត់ឈ្មោះ ដាក់ក្រដាសនៅលើកៅអីហ្នឹងទៅ ហើយខ្ញុំអង្គុយកត់លើក្រដាសហ្នឹង។ ហើយគេកត់ឈ្មោះហើយ គេបញ្ជូនអ្នកទោសទៅសម្លាប់។ [...] នៅក្បែរភ្លើងមានកៅអីមួយអង្គុយនឹងដី ហើយកត់ត្រាក្រដាសហ្នឹង។ កត់ឈ្មោះហើយ បនាគេយករណ្ដៅបណ្ដោយ។ [...] ខ្ញុំកត់ឈ្មោះ ហើយនិងចុះលេខ លេខ ១ លេខ ២ លេខ ៣ រៀងរហូត។ [...] ឈ្មោះដែលចេញពីមន្ទីរទួលស្លែងមកហ្នឹង គឺឈ្មោះនៅលើ បងធី ណោះ ហើយគាត់ឲ្យខ្ញុំមកកត់ឈ្មោះនេះម្ដងទៀត ដើម្បីគាត់យកទៅទូរជាមួយគ្នា។ [...] ដល់ទួលស្លែងវិញ គឺយកឈ្មោះហ្នឹងទៅឲ្យបង ស្ងួង ធី ហ្នឹង"]។ ឯកសារ D234/2.1.115 ហ៊ឹម ហ៊ុយ ប្រតិចារឹកថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង ១៥:៣៣:៣២-១៥:៤០:០០ ["ពេលដែលខ្ញុំទៅជើងឯក [...] ខ្ញុំទៅ គឺខ្ញុំគោលដៅគឺកត់ឈ្មោះអ្នកទោសឲ្យគ្រប់ចំនួនយកមកឲ្យ បងស្ងួស ធី វិញ។ ព្រោះបងស្ងួស ធី ឲ្យខ្ញុំកត់ឲ្យគ្រប់ចំនួនយកមកឲ្យគាត់ បាត់ក៏មិនបាន គឺខ្ញុំទទួលខុសត្រូវ"]។ ឯកសារ D98/1.2.9 ស្ងួស ធី ប្រតិចារឹកថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៩ ម៉ោង ១៥:៤៨:៤៣-១៥:៥៥:៣៥ [រៀបរាប់ពីការបញ្ជាក់បញ្ជីឈ្មោះបន្ទាប់ពីសម្លាប់]។

គាស់ ហើយបានរកឃើញសាកសពសរុបចំនួន ៨.៩៨៥ សាកសព[2292]។ ឆ្អឹងនៅតែមាននៅលើដីជាប់នឹងរណ្ដៅយ៉ាងហោចណាស់រយៈពេលពីរឆ្នាំ[2293] និងក្រោយមកត្រូវបានរក្សាទុកនៅក្នុងខ្ទមឈើគ្មានជញ្ជាំងដែលគ្មានអ្វីការពារ រយៈពេលបីទៅបួនឆ្នាំបន្ថែមទៀត[2294]។ ជាលទ្ធផល មានលលាដ៍ក្បាលចំនួនតែ ៧.៥០០ ប៉ុណ្ណោះដែលនៅមាន នៅពេលដែលក្រុមកោសល្យវិច័យវៀតណាមបានរាប់នៅឆ្នាំ ១៩៨៨ មុនពេលដាក់ចូលក្នុងបូជនីយដ្ឋានដែលមានគម្របបិទបាំង[2295]។ ការបាត់បង់ឆ្អឹងបន្ថែមទៀតបានកើតឡើង ក្នុងរយៈពេលជាច្រើនទសវត្សរ៍ក្រោយមកទៀត ដោយសារចេតិយនោះមិនត្រូវបិតជិតគ្រប់គ្រាន់ដើម្បីការពារការបំផ្លាញពីសត្វកណ្ដុរ និងសត្វល្អិត[2296] ហើយលលាដ៍ក្បាលមួយចំនួនទៀតត្រូវបានយកចេញសម្រាប់ពិព័រណ៍ ឬការសិក្សា និងមិនដែលយកត្រឡប់មកវិញឡើយ[2297]។

---

2292 ឯកសារ D234/2.1.142 រឿន វុទ្ធី ប្រតិចារឹកថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៦ ម៉ោង ០៩:២៧:២៧-០៩:៣១:២០, ០៩:៣៦:០១-០៩:៣៩:៣៤, ១៣:៤៩:៣០-១៣:៥៥:៣៨, ១៤:០៥:២២-១៤:១០:០០ ["តួលេខដែលថា ៨.៩៨៥ នេះ គឺជាតួលេខរបស់មន្ទីរឃោសនាការ និងវប្បធម៌ [...] រណ្ដៅសាកសពទាំងអស់វាមានជាងមួយរយ។ ប៉ុន្តែ រណ្ដៅតែ ៨៦ ប៉ុណ្ណោះទើបត្រូវបានគេជីក"។ រៀបរាប់ពីទីតាំងរណ្ដៅដែលមិនទាន់ជីក]។

2293 ឯកសារ D234/2.1.142 រឿន វុទ្ធី ប្រតិចារឹកថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៦ ម៉ោង ០៩:៣៩:៣៤-០៩:៤១:៤៨, ១៥:០៩:២៥-១៥:១៥:៥០ ["អដ្ឋិធាតុដែលនៅផ្ទាល់ដីរយៈពេលប្រហែលជា ២ ឬ ៣ ឆ្នាំ"]។

2294 ឯកសារ D234/2.1.142 រឿន វុទ្ធី ប្រតិចារឹកថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៦ ម៉ោង ១៥:០៩:២៥-១៥:១៦:៣២ [លើកឡើងថា អដ្ឋិធាតុនៅក្នុងស្តូបឈើ "៣ ទៅ ៤ ឆ្នាំ" បញ្ជាក់ថា រូបថតគ្រោង និងលើកឡើង៖ "មិនទាន់មានការគ្រប់គ្រងឲ្យបានជិតដល់ [...] ការបាត់បង់តួលេខដែលបាត់បង់នោះ វាបាត់បង់ទៅតាមរយៈហ្នឹង [...] មិនមានអីការពារសម្រាប់សព្វពាហនៈដើរទៅស៊ីឆ្អឹងហ្នឹងទេ"]។

2295 ឯកសារ D234/2.1.142 រឿន វុទ្ធី ប្រតិចារឹកថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៦ ម៉ោង ០៩:៣៩:៣៤-០៩:៤៤:៣០, ០៩:៥០:០០-០៩:៥២:២០ ["ពេលដែលគេធ្វើស្តូបនៅចន្លោះឆ្នាំ១៩៨៥-៨៨ ហ្នឹង គេប្រមូលអដ្ឋិធាតុនោះឡើងទៅស្តូបថ្មី។ ពេលនោះហើយដែលគេមានរាប់ថា ៧.៥០០ [...] ចំនួនដែលផ្លាស់ប្ដូរតួលេខនេះ គឺដោយសារតែមានការបាត់បង់ដោយសារសត្វពាហនៈស៊ី និងការរមៀលធ្លាក់ចុះទៅវិញ [...] នៅក្នុងទសវត្សរ៍ឆ្នាំ ៨៨ ចន្លោះ៨៨ ៨៧-៨៨ មានក្រុមគ្រូពេទ្យវៀតណាមមួយក្រុមបានចូលមកពិនិត្យសាកសពទាំងនោះ។ ពេលនោះ គេបានបង់លេខៗលើអដ្ឋិធាតុ"]។ សូមមើលផងដែរ ឯកសារ D234/2.1.142 រឿន វុទ្ធី ប្រតិចារឹកថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៦ ម៉ោង ១៥:២២:៥៤-១៥:២៤:៤៦។

2296 ឯកសារ D234/2.1.142 រឿន វុទ្ធី ប្រតិចារឹកថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៦ ម៉ោង ១៥:១៦:៣២-១៥:២២:៥៤។

2297 ឯកសារ D234/2.1.142 រឿន វុទ្ធី ប្រតិចារឹកថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៦ ម៉ោង ១៥:២៨:២២-១៥:៣៤:២៣។

593. ពីឆ្នាំ ២០១៣ ដល់ឆ្នាំ ២០១៥ ក្រុមការងារមួយដែលដឹកនាំដោយអ្នកជំនាញ វឿន វុទ្ធី បានធ្វើការវិភាគយ៉ាងទូលំទូលាយមួយអំពីឆ្អឹងនៅក្នុងចេតិយជើងឯក[2298]។ ក្នុងចំណោមលលាដ៍ក្បាលចំនួន ៦.៤២៦ ដែលបានពិនិត្យដោយក្រុមការងាររបស់ វឿន វុទ្ធី "មានតែលលាដ៍ក្បាលមួយប៉ុណ្ណោះ" ដែលមិនមានបង្ហាញភ័ស្តុតាងនៃការរងរបួស[2299]។ ស្នាមរបួសសរុបចំនួន ២៨.០០០ ស្នាម ត្រូវបានកំណត់បាននៅលើលលាដ៍ក្បាល ដោយលលាដ៍ក្បាលនីមួយៗមានស្នាមបាក់ រន្ធ ឬសញ្ញាបែបនោះផ្សេងៗទៀតជាច្រើនកន្លែង[2300]។ ទម្រង់ទូទៅបំផុតនៃរបួសដែលបានសង្កេតឃើញនៅលើលលាដ៍ក្បាល គឺត្រូវគ្នានឹងជនរងគ្រោះដែលត្រូវបានវាយត្រង់ក្បាល ដោយប្រើដំបង ព្រនង់ ភ្លៅរទេះ ឬឧបករណ៍ស្រដៀងៗគ្នានោះ៖ ៩.៨០២ ស្នាម បណ្តាលមក "ព្រនង់ឈើ ឬឫស្សី" ៥.៨០៦ ស្នាម បណ្តាលមកពីរបារដែក ឬរបារភ្លៅរទេះ និង ២.៤៣៥ ស្នាម បណ្តាលមកពី "ដំបងបួនជ្រុងស្មើ"[2301]។ ភ័ស្តុតាងបានពីការសិក្សារបស់ វឿន វុទ្ធី ជួយកំណត់ពីទំហំនៃ

---

[2298] ឯកសារ D114/297.1.47 វឿន វិទ្ធី ប្រតិចារឹកថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ ម៉ោង ១៣:៥០:០២-១៣:៥៧:០៩។ ឯកសារ D234/2.1.142 វឿន វុទ្ធី ប្រតិចារឹកថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៦ ម៉ោង ១០:០៨:៥៣-១០:១២:៤១, ១៣:៥៣:៣២-១០:៥៩:៥៥, ១១:០២:៣៩-១១:០៤:០៥ [ផ្តល់សក្ខីកម្មថា សាកសពទាំងនោះត្រូវបានបញ្ជាក់ថាមកពីជើងឯក ដោយផ្អែកលើការវិភាគភក់លើឆ្អឹង និងពន្យល់អំពីភាពខុសគ្នារវាងសាកសព ដែលបានកប់នៅក្នុងមឈូសនៅកន្លែងទីបញ្ចុះសពរបស់ចិន។ [...] "យើងធ្វើរហូតដល់ពុះឆ្អឹងមួយផ្នែកណានៃអដ្ឋិធាតុ ដែលយើងយកមកនោះ យើងយកមកពង្រីកនៅក្នុងម៉ៃក្រូស្កុប [...] ហើយយើងពង្រីកនូវអាលលាដ៍ក្បាលមួយៗ យើងពង្រីកធំមែនទែន។ យើងពង្រីកទៅតាមអារុន្ធតូចៗដែលភក់ចូល។ បានជាយើងហ៊ានសន្និដ្ឋានបាទ"]។

[2299] ឯកសារ D114/297.1.47 វឿន វិទ្ធី ប្រតិចារឹកថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ ម៉ោង ១៤:១៦:៥៤-១៤:១៩:៤៦ ["ក្នុង ៦.៤២៦ អដ្ឋិធាតុនេះ ក្រុមការងាររបស់យើងខ្ញុំក្រោយពីធ្វើកោសល្យវិច័យទៅ យើងរកឃើញតែឆ្អឹងលលាដ៍ក្បាលមួយគត់ ពុំបានបង្ហាញពីការធ្វើទារុណកម្ម និងការវាយដំនឹងឧបករណ៍ធ្ងន់ធ្ងរ មានតែមួយគត់បាទ"]។ សូមមើលផងដែរ ឯកសារ D114/297.1.47 វឿន វិទ្ធី ប្រតិចារឹកថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ ម៉ោង ១៣:៥៣:២០-១៣:៥៧:០៩ [រៀបរាប់ពីវិធីដែលលលាដ៍ក្បាលត្រូវបានធ្វើកោសល្យវិច័យ ហើយ "ស្លាកស្នាម ឬស្នាមប្រេះស្រាំ" ត្រូវបានកត់ត្រា និងថត], ម៉ោង ១៤:១៩:៤៦-១៤:២១:៣៦ ["យើងពង្រីកនៅក្នុងមៃក្រូស្កុប ដើម្បីឲ្យឃើញស្លាកស្នាម បើជាដំបងគល់ឫស្សី វាអាចមានជាប់តិចតួចនៅទីនោះ ហើយជាពិសេសឈើជ្រុង យើងបានឃើញអដ្ឋិធាតុខ្លះមាននៅជាប់ដោយសារវ៉ៃទៅ ផុងលលាដ៍ វាជាប់កម្ទេចហ្នឹងខ្លះ"]។ ឯកសារ D234/2.1.142 វឿន វុទ្ធី ប្រតិចារឹកថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៦ ម៉ោង ម៉ោង ១៥:៣៤:២៣ [ធ្វើកោសល្យវិច័យតែលលាដ៍ក្បាលសម្រាប់ជាភស្តុតាងនៃការប្រេះស្រាំ]។

[2300] ឯកសារ D234/2.1.142 វឿន វុទ្ធី ប្រតិចារឹកថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៦ ម៉ោង ១៥:៤១:៣៣-១៥:៤៤:៣០ ["សាកសពរងគ្រោះនីមួយៗ នៅលើលលាដ៍ក្បាលគាត់មានតិចបំផុតពីរ ពុំដែលមានស្លាកស្នាមតែមួយទេ"]។

[2301] ឯកសារ D234/2.1.142 វឿន វុទ្ធី ប្រតិចារឹកថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៦ ម៉ោង ១៥:៣៩:០២-១៥:៤២:៣៣ ["ស្លាកស្នាម" គឺ "ការវាយសម្លាប់"]។ ឯកសារ D114/297.1.47 វឿន វិទ្ធី ប្រតិចារឹកថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦

ការសម្លាប់ ដែលបានកើតឡើងនៅជើងឯក និងជួយបញ្ជាក់អះអាងលើសក្ដីភាពរបស់កម្មាភិបាល មន្ទីរស-២១ ទាក់ទងនឹងវិធីសាស្រ្តធម្មតា ដែលគេប្រើសម្រាប់សម្លាប់ជនរងគ្រោះនៅកន្លែងនោះ។

## ខ. ការដ្ឋានស្ទឹងហាវ

### ១. ការពិពណ៌នាពីទីកន្លែង

594. ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ស្ទឹងហាវ គឺជាបណ្តុំនៃការដ្ឋាន និងកន្លែងដែលទាក់ទង ដែលប្រតិបត្តិការក្រោមកងពល ១៦៤ នៅភាគខាងជើងនៃតំបន់កំពង់សោម ក្នុងឃុំស្ទឹងហាវ[2302]។

---

ម៉ោង ១៤:០២:៣០-១៤:០៦:០៧ ["មានស្លាកស្នាមសម្លាប់ដោយដំបង យើង -- ទីនេះខ្ញុំសូមបញ្ជាក់ថា ដំបងនេះ បូកសរុបទាំងឈើ និងគល់ឫស្សី។ យើងរកឃើញស្លាកស្នាម ៩.៨០២ ស្លាកស្នាម"]។

2302 ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714347-50 ["កងពល ១៦៤ បានគ្រប់គ្រងការដ្ឋានការងារ ដោយបង្ខំឱ្យវាយថ្មមួយកន្លែងនៅជិតស្ទឹងហាវ ក្រុងកំពង់សោម។ [...] ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធទាំងនេះ មានទីតាំងស្ថិតនៅក្នុងឃុំស្ទឹងហាវ ខេត្តកំពង់សោម"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.32 ["ស្ទឹងហាវស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពល ១៦៤"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.33 ["ជាទូទៅកន្លែងទាំងអស់នៅស្ទឹងហាវ គឺស្ថិតនៅក្រោមកងពលលេខ១៦៤"]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.10 ["ក្រោយមក គេបញ្ជូនខ្ញុំទៅស្ទឹងហាវ។ [...] អ្នកដែលធ្វើការសែងថ្មនៅរូងភ្នំនោះ គឺមកពីកងពល ១៦៤ ហើយអ្នកគ្រប់គ្រងក៏ជាអ្នកមកពីកងពល១៦៤ ដែរ"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.13-14 ["ស៖ នៅស្ទឹងហាវ តើលោកស្រីធ្វើការក្រោមបញ្ជារបស់អ្នកណាខ្លះ? ឆ.13៖ ស្ទឹងហាវគឺស្ថិតក្រោមការគ្រប់គ្រងរបស់កងពល ១៦៤។ ស៖ តើលោកស្រីអាចពន្យល់ប្រាប់យើងបន្ថែមអំពីវរសេនាតូចរបស់លោកស្រីបានដែរឬទេ? ឆ.14៖ ពួកយើងគឺធ្វើការផ្ទាល់ក្រោមបញ្ជារបស់កងពលធំ ១៦៤"]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.22 ["ស៖ តើតំបន់ស្ទឹងហាវស្ថិតក្រោមបញ្ជារបស់កងពល ១៦៤ មែនទេ? ឆ.22៖ បាទ ត្រឹមត្រូវហើយ"]។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.161 ["ស៖ បានន័យថា ទាល់តែមកដល់ស្ទឹងហើយបានលោកដឹងថាខ្លួនលោកស្ថិតនៅក្រោមកងពល ១៦៤ អ៊ីចឹងមែនទេ? ឆ.161៖ តាមពិតទៅ ខ្ញុំនៅកងពលលេខ ៣ ប៉ុន្តែ ពេលខ្ញុំត្រូវបានគេឱ្យមកធ្វើការនៅស្ទឹងហាវ គេបង្កើតកងពលថ្មីមួយហៅថា កងពល ១៦៤ ជាកងទ័ពជើងទឹក"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.16 ["តំបន់គ្រប់គ្រងរបស់កងពល ១៦៤ មានព្រំដែនខាងកើតនៅចំទឹកសាប ខាងជើងនៅស្ទឹងហាវ"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ុម សុខន ឆ.30 ["ស៖ តើអង្គភាពណាមួយដែលទទួលខុសត្រូវនៅកន្លែងលត់ដំស្ទឹងហាវ? ឆ.30៖ មានអង្គភាពមួយ ប៉ុនចង់ភ្លេចវរសេនាតូចហ្នឹងហើយ ព្រោះមានគេដាក់យោធាកងពិសេសនៅលើខ្ញុំ។ កងវរសេនាតូច តែចំណុះកងពល ១៦៤"]។ ឯកសារ D54/9 កំណត់ហេតុស្តាប់ចម្លើយ មិន ផុន ឆ.5 ["នៅស្ទឹងហាវ កងអនុសេនាធំរបស់ខ្ញុំត្រូវបានដាក់បញ្ចូលទៅក្រោមបញ្ជាកាកងវរសេនាតូចមួយរបស់វរសេនាធំ៦១ នៃកងពល១៦៤"]។ ឯកសារ

មានគម្រោងសំខាន់ៗពីរនៅស្ទឹងហាវក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ៖ ការសាងសង់កំពង់ផែយោធាថ្មីមួយ[2303] ក្នុងនោះរួមទាំងផែនៅចំណុចភាគខាងជើងបំផុតនៃឃុំស្ទឹងហាវ[2304] និងការសាងសង់ផ្លូវមួយដែលតភ្ជាប់កំពង់ផែថ្មីនេះ ទៅកាន់រោងចក្រចម្រាញ់ប្រេងនៅភាគខាងលិច[2305]។ ការសាងសង់កំពង់ផែ ផែ និងផ្លូវនេះ តម្រូវឱ្យមានការដ្ឋាន និងគម្រោងបន្ទាប់បន្សំជាច្រើន។ គម្រោងទាំងនេះរួមមាន បន្ថែមពីលើការសាងសង់ផ្លូវ និងផែ មាន៖ ជម្រះ និងឈូសឆាយដីឱ្យស្មើ

---

D114/48 កំណត់ហេតុស្តាប់ចម្លើយ សុខ ង៉ុន ឆ.34 ["សៈ តើយោធាកងណាដែលធ្វើការនៅស្ទឹងហាវ? ឆ.34៖ ខ្ញុំមិនដឹងកងណាទេ តែកងនោះស្ថិតនៅក្រោមកងពល ១៦៤។ នៅក្នុងកងពល ១៦៤ មានកងជើងគោក និងកងជើងទឹក"]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ុន យ៉ើ ឆ.77 ["អង្គភាពផលិតនេះ វានៅក្រោមការគ្រប់គ្រងរបស់កងពល ១៦៤"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.30 ["សៈតើស្ថិតនៅក្រោមបញ្ជាការរបស់ខាងណា កាលពីលោកនៅស្ទឹងហាវ? ឆ.30៖ វាស្ថិតនៅក្រោមបញ្ជាការរបស់កងពល ១៦៤"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.105 ["សៈ តើវរសេនាតូចទាំងពីរនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពល ១៦៤ ដែរឬទេ? ឆ.105៖ បាទ"]។

2303 ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.17 ["ទើបគេបញ្ជូនខ្ញុំឱ្យទៅធ្វើការនៅស្ទឹងហាវ។ នៅទីនោះ គេឱ្យខ្ញុំបំបែកថ្មដើម្បីយកថ្មទៅធ្វើទំនប់រលក និងផែសម្រាប់ឱ្យកប៉ាល់ចម្បាំងចូលចត។ គេមិនចង់យកកប៉ាល់ចម្បាំងទៅចតនៅផែស៊ីវិលទេ"]។ ឯកសារ D59/1/1.11a បទសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង ហៀង រ៉េត KH ERN 00926545 ["សៈ អាហ្នឹងជាផែរបស់ជើងទឹក? ឆៈ បាទ"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ.173 ["នៅពេលនោះ ស្ទឹងហាវមិនមានធ្វើអ្វីទេ គឺគេកំពុងកសាងផែមួយ ជាផែយោធាសម្ងាត់"]។

2304 ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714380 ["ការដ្ឋានវាយថ្មស្ទឹងហាវ ដែលស្ថិតនៅភាគខាងជើងបំផុត មានចម្ងាយប្រមាណ ៧៥០ ម៉ែត្រ (ក្នុងលំហអាកាស) កំពង់ផែថ្ម ដែលជាចំណុចចាប់ផ្តើម។ កំពង់ផែថ្មស្ថិតនៅភាគខាងជើងបំផុត នៃជ្រោយឃុំស្ទឹងហាវ"], KH ERN 00714365 ["ជាមួយនឹងចម្ងាយត្រឹមប្រមាណ ៧៥០ ម៉ែត្រ (ក្នុងលំហអាកាស) ពីការដ្ឋានវាយថ្ម កំពង់ផែ មានទីតាំងស្ថិតនៅចំណុចខាងជើងបង្អស់នៃស្ទឹងហាវ"], KH ERN 00714383-84 [រូបថត]។ ឯកសារ D54/109 កំណត់ហេតុស្តាប់ចម្លើយ សៅ សំ ឆ.15 ["ខ្មែរក្រហមក៏បានទៅធ្វើផែយោធាមួយខ្លួនឯងនៅស្ទឹងហាវ ហើយប្រើផែនៅរាមជាផែស៊ីវិលវិញ"]។ សូមមើលផងដែរ ឯកសារ D114/60 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង អំពីការដ្ឋានធ្វើការងារដោយបង្ខំនៅផែយោធាស្ទឹងហាវ EN ERN 01082179 ["ត្រឹមរយៈចម្ងាយប្រហែល ៧៥០ ម៉ែត្រ (ពីលំហអាកាស) ពីកន្លែងយកថ្ម ផែគឺមានទីតាំងនៅប៉ែកខាងជើងស្ទឹងហាវ"]។

2305 ឯកសារ D114/60 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង អំពីការដ្ឋានធ្វើការងារដោយបង្ខំនៅផែយោធាស្ទឹងហាវ EN ERN 01082178 ["ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានគម្រោងសាងសង់ផ្លូវពីផែស្ទឹងហាវទៅរោងចក្រប្រេងកាត ក្រៅក្រុងព្រះសីហនុ (ក្រោយមកហៅថា កំពង់សោម) ហើយនិងគម្រោងសាងសង់ផែយោធានៅស្ទឹងហាវ"]។

ពង្រឹង និងរៀបចំខ្សែច្រាំង គាស់ បំបែក និងដឹកជញ្ជូនថ្មសម្រាប់ប្រើប្រាស់ក្នុងការសាងសង់កំពង់ផែ ផែ និងផ្លូវ[2306] សាងសង់ផ្លូវរថភ្លើងថ្មីមួយ សាងសង់អាងស្តុកទឹក និងដាំដុះដំណាំផ្សេងៗ។

595. អគារនានានៅស្ទឹងហាវ រួមមាន ទីបញ្ជាការកណ្តាលមូលដ្ឋានកងវរសេនាធំនៃកងពល ១៦៤[2307] មន្ទីរសម្រាប់ទីប្រឹក្សាបច្ចេកទេសចិន[2308] មន្ទីរឃុំឃាំង កន្លែងស្នាក់នៅសម្រាប់ពលករ[2309] និងជាសក្តានុពល កន្លែងព្យាបាល[2310]។

---

2306 ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.19 ["គេហៅថាទំនប់រលកនៅស្ទឹងហាវ។ ត្រឹមពេលដែលគេបញ្ជូនខ្ញុំទៅទីនោះ អ្នកធ្វើការទាំងអស់នៅស្ទឹងហាវ គឺគេតម្រូវឱ្យរើថ្មនៅការដ្ឋានយកថ្មទាំងអស់គ្នា។ តាមផែនការរបស់គេ គេគ្រោងយកថ្មនោះធ្វើជាចំណតសម្ងាត់ ដែលគេអាចជួសជុលកប៉ាល់ និងជាកន្លែងស្តុកគ្រឿងផ្ទុះឬអាវុធ"]។ ឯកសារ D54/106.2 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង សាន់ កាន KH ERN 00993445 ["ស៖ ចឹងថាមានផែស្ទឹងហាវ? ឆ៖ ផែស្ទឹងហាវមិនទាន់មានអីទេ គ្រាន់តែគម្រោងថាធ្វើផែយោធា។ ស៖ ចឹងបានធ្វើនៅ? ឆ៖ នៅទេ កាលហ្នឹងទើបតែចាប់ផ្តើមទេ ទើបតែចាប់ថ្មចាប់អី [...] បើសួរ រ៉េត ច្បាស់ព្រោះគាត់បានបុកថ្មអីនៅហ្នឹង សួរកម្លាំងនៅហ្នឹងគេច្បាស់ហើយ"]។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ. 39 ["ក្រោយមកគេរំសាយ គេឱ្យកាំបិតទៅកាប់ឈើធ្វើផ្ទះ ឱ្យទៅវាយថ្មចាក់ផែនៅស្ទឹងហាវជាមួយពួកចិន"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញិក ឆ.17 ["ខ្ញុំនៅកងកាំភ្លើងធំរហូតដល់ប្រហែលចុងឆ្នាំ១៩៧៧ បានគេរំសាយខ្ញុំពីកងកាំភ្លើងធំ ហើយបញ្ជូនខ្ញុំទៅធ្វើការនៅការដ្ឋានវាយថ្ម ដើម្បីធ្វើផែននៅស្ទឹងហាវ"]។ ឯកសារ D54/28.1 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង ណាំ ឡន KH ERN 00955620 ["គេឱ្យទៅធ្វើនៅស្ទឹងហាវទៀត វាយថ្មវាយអីកាលហ្នឹង គេឱ្យទៅធ្វើផែធំ នៅស្ទឹងហាវ ហើយអាថ្មអីហ្នឹងហើយ ធ្វើផែហើយ បោសហើយ"]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.22 ["គេឱ្យអ្នកធ្វើការលីថ្មទាំងដុំៗដាក់លើឡាន ដើម្បីគេយកទៅចាក់ធ្វើផែកប៉ាល់"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.32 ["កងអនុសេនាតូចរបស់ខ្ញុំបំបែកថ្ម ដើម្បីកសាងផែ និងកាប់ឆ្ការព្រៃ"]។ សូមមើលផងដែរ ឯកសារ D114/86.7 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឧបសម្ព័ន្ធ៖ គំនូសផ្ទាល់ដៃដែលគូសដោយសាក្សី KH ERN 01110642។ ឯកសារ D54/8.3 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាល ខ័ណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ២០០៨-២០១០ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣ KH-EN ERN 00936754។

2307 ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714351 ["ចម្ងាយពីការដ្ឋានវាយថ្ម (ទី១) ទៅកាន់ទីបញ្ជាការធំរបស់កងពល ១៦៤ ក្នុងក្រុងកំពង់សោមមានចម្ងាយប្រមាណ ១៧,៥៣ គីឡូម៉ែត្រ (លើអាកាស) និងមានចម្ងាយ ២,៣ គីឡូម៉ែត្រ ទៅកាន់ទីបញ្ជាការប្រតិបត្តិការកងវរសេនាធំ កងពល ១៦៤ (អតីតកងពលលេខ ៣ នៅស្ទឹងហាវ"], KH ERN 00714354 ["នៅច្រកចូលទៅលកាន់ការដ្ឋានវាយថ្មស្ទឹងហាវ គឺជាទីតាំងប៉ុស្តិ៍បញ្ជាការរបស់កងវរសេនាធំនៃកងពល ១៦៤ វាអាចជាកងវរសេនាធំ ៦១ (កងវរសេនាធំចាស់លេខ២២)"]។ សូមមើលផងដែរ ឯកសារ D54/9 កំណត់ហេតុស្តាប់ចម្លើយ មិន ផុន ឆ.5, 17 ["[...] ខ្ញុំនៅក្នុងកងកាំភ្លើងត្បាល់៨២មីលីម៉ែត្រ។ កងកាំភ្លើងត្បាល់របស់ខ្ញុំស្ថិតនៅម្ខាងថ្មល់នៃបញ្ជា

596. ការងារបានចាប់ផ្ដើមនៅស្ទឹងហាវពីពាក់កណ្ដាល ឬចុងឆ្នាំ ១៩៧៥ ឬដើមឆ្នាំ ១៩៧៦[2311] និងបន្តរហូតដល់កងទ័ពវៀតណាមបានផ្តួលរំលំរបបខ្មែរក្រហម[2312]។ អាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ

---

ការដ្ឋានកងវរសេនាតូច និងផ្ទះរបស់មេបញ្ជាការវរសេនាតូច។ [...] ឆ.17៖ ខ្ញុំនៅតែធ្វើការតែជាមួយកន្លែងកាំភ្លើងត្បាល់របស់ខ្ញុំ"]។

2308 ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.32 ["នៅខាងជើងបន្តិច គឺជាកន្លែងធ្វើការរបស់ចិន"]។ ឯកសារ D54/77.1 ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាល ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ឆ្នាំ ២០០៨-២០១០ KH ERN 00982557 [កំណត់សម្គាល់ "ផ្ទះចិន"]។ សូមមើលផងដែរ ឯកសារ D54/33.1 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង អ៊ឹង ផុន (អ៊ី ផុន) KH ERN 00964202-03 ["កាលខ្ញុំជួបពូ ពូហ្នឹងគាត់ថាមានផែមួយទៀត ដែលគេកំពុងតែសាងសង់នៅសម័យ ៣ ឆ្នាំហ្នឹងដែរ នៅខាងស្ទឹងហាវ? ឆ៖ អាហ្នឹងគ្រាន់តែគម្រោងរបស់ចិន គេធ្វើដែរ តែទើបតែធ្វើបានបន្តិចហ្នឹង មិនទាន់បានចតបានអីស្រួលបួលផង គ្រាន់តែជាគម្រោងធ្វើ ដល់ពេលស្រុកយើងអីចឹងទៅគម្រោងផែនការរបស់ចិន អាហ្នឹងគម្រោងរបស់គេធំណាស់ បើថាធ្វើគេធ្វើមាំតែម្តង តែមានទាន់បានធ្វើណា គេទើបតែធ្វើបានបន្តិចហ្នឹង"]។

2309 ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.32 ["រោងកងរបស់ខ្ញុំស្ថិតនៅប្រហែល ១ គីឡូម៉ែត្រខាងជើងការដ្ឋានវាយថ្មរបស់ខ្ញុំ"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.10 ["ស៖ តើលោកស្រីស្នាក់នៅទីណា និងធ្វើការនៅទីណាខ្លះនៅស្ទឹងហាវ? ឆ.10៖ ពួកយើងស្នាក់នៅកន្លែងមួយឈ្មោះចម្ការត្របែក"]។ ឯកសារ D114/83.2 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឧបសម្ព័ន្ធ៖ គំនូសផ្ទាល់ដៃដែលគូសដោយសាក្សី KH ERN 01110589។

2310 ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.29 ["តាមខ្ញុំដឹង គឺមានមន្ទីរពេទ្យចំនួនបីកន្លែងនៅក្រោមកងពលធំ១៦៤ [...] មួយទៀតនៅចម្ការត្របែក នៅស្ទឹងហាវ"]។ ឯកសារ D114/83.2 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឧបសម្ព័ន្ធ៖ គំនូសផ្ទាល់ដៃដែលគូសដោយសាក្សី KH ERN 01110589 ["ពេទ្យ"]។

2311 ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.28 ["ស៖ តើនៅពេលណាគេបញ្ជូនលោកទៅស្ទឹងហាវ? ឆ.28៖ ខ្ញុំគិតថា ប្រហែលពាក់កណ្តាល ឬចុងឆ្នាំ ១៩៧៥ នៅពេលដែលពួកប៉ូព៉ិមកដល់កំពង់សោមចូលជាមួយកងពល ១៦៤ ខ្ញុំនៅចាំពេលដែលមកដល់ស្ទឹងហាវដំបូងគឺមានសត្វទាកជាច្រើន"]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.11 ["ស៖ បន្ទាប់ពីលោកត្រូវបានបញ្ជូនត្រឡប់ទៅកោះតាងវិញ ពេលណាទើបគេបញ្ជូនលោកទៅស្ទឹងហាវ? ឆ.11៖ ប្រហែលជានៅពាក់កណ្តាលឆ្នាំ ១៩៧៦ ខ្ញុំត្រូវបានគេបញ្ជូនទៅស្ទឹងហាវ"]។ ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.62 ["ការដ្ឋានស្ទឹងហាវនេះចាប់ផ្តើមធ្វើពីពាក់កណ្តាល ១៩៧៦ មក"]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ុន យ៉ើ ឆ.44 ["ស៖ តើគេដកនោះ ក្នុងខែឆ្នាំណាដែរ? ឆ.44 ៖ ជិតដាច់ ១៩៧៦ ខ្ញុំទៅខាងផ្នែកស្ទឹងហាវ"]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត់ ឆ.102 ["ស ៖ តើលោកចាំថា ពេលដែលលោកទៅកាប់ឆ្ការព្រៃនៅទីនោះ នៅក្នុងឆ្នាំណា? ឆ.102៖ នៅប្រហែលខែមីនា ឬខែមេសា ឆ្នាំ ១៩៧៦"]។ សូមមើលផងដែរ ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714352 ["ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ដោយយោងលើភស្តុ

តាងផ្តល់ដោយសាក្សីមួយចំនួននាពេលបច្ចុប្បន្ននេះ អាចឱ្យដឹងបានថា ពេលវេលាចាប់ផ្តើម ដំណើរការរបស់ទីតាំងនេះ គឺប្រហែលជាស្ថិតនៅក្នុងចន្លោះពាក់កណ្តាលឆ្នាំ ១៩៧៥ និង/ឬនៅដើមឆ្នាំ ១៩៧៦"]។

2312 ឯកសារ D4.1.745 របាយការណ៍ Stony Beach KH ERN 01513916 ["អង្គភាពរបស់គាត់នៅតែឈរជើងនៅស្ទឹងហាវនេះរហូតដល់ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៩ នៅពេលដែលកងទ័ពប្រជាជននៃកងកម្លាំងលុកលុយវៀតណាម (PAVN) បានចូលមកដល់កំពង់សោម"]។ ឯកសារ D54/9 កំណត់ហេតុស្តាប់ចម្លើយ មិន ផុន ឆ.6, 8, 10 ["ខ្ញុំរស់នៅស្ទឹងហាវពីពាក់កណ្តាលឆ្នាំ ១៩៧៨ រហូតដល់បែកឆ្នាំ ១៩៧៩។ [...] ឆ.8៖ [...] ខ្ញុំឮសូរសំឡេងបំផ្ទុះថ្មរាល់ថ្ងៃ។ [...] ឆ.10៖ ខ្ញុំបានឃើញ និងឮសំឡេងឡានរាល់ថ្ងៃ ដែលបើកឆ្ពោះសំដៅទៅការដ្ឋានវាយថ្ម"]។ ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ សៀង EN ERN 00217566 ["នៅឆ្នាំ ១៩៧៨ គាត់បានផ្លាស់ទៅធ្វើការនៅផ្លូវរទេះភ្លើងនៅស្ទឹងហាវ ហើយធ្វើជាជំនួយការប្រធាន។ [...] ធ្វើបន្តរហូតដល់ការលុកលុយរបស់វៀតណាម"]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.12 ["ខ្ញុំនៅស្ទឹងហាវធ្វើការសាងសង់ផែថ្មចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៦ រហូតដល់ឆ្នាំ ១៩៧៩ ពេលវៀតណាមចូលមកដល់"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.16 ["ខ្ញុំ ហើយនិងកងវរៈលេខ ២០ របស់ខ្ញុំ ត្រូវបានគេបញ្ជូនឱ្យទៅវាយថ្មនៅការដ្ឋានវាយថ្មស្ទឹងហាវ។ ខ្ញុំនៅធ្វើការនៅទីនោះរហូតដល់វៀតណាមចូលដល់"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.15 ["ស៖ តើលោកស្រីធ្វើការនៅស្ទឹងហាវរហូតដល់វៀតណាមចូលមែនទេ? ឆ.15៖ ចាស ត្រឹមត្រូវហើយ"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.35 ["ខ្ញុំនៅស្ទឹងហាវរហូតដល់វៀតណាមចូលក្នុងឆ្នាំ ១៩៧៩"]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន យ៉ើ ឆ.46 ["ស៖ តើលោកបានទៅធ្វើការនៅស្ទឹងហាវអស់រយៈពេលយូរប៉ុនណាដែរ? ឆ.46៖ ធ្វើរហូតដល់១៩៧៩"]។ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.211-212 ["ស៖ តើគេបញ្ជូនលោកទៅធ្វើការនៅស្ទឹងហាវនៅពេលណា? ឆ.211៖ ប្រហែលពាខែមុនវៀតណាមចូល។ ស៖ ពេលដែលវៀតណាមវៃចូលមក តើលោកនៅស្ទឹងហាវឬ? ឆ.212៖ បាទ"]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.10 ["នៅពេលនោះ យើងបានឮថាកងទ័ពវៀតណាមបានចូលមកដល់ កងទ័ពកងពល ១៦៤ បានបង្ខំយើងឱ្យរត់ទៅជួរភ្នំក្រវ៉ាញ"]។ សូមមើលផងដែរ ឯកសារ D59/2/2.14a កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង លាង បៀ KH ERN 00732812 ["មានម្នាក់នោះធ្លាប់តែទៅនេះ ដល់ពេលវៀតណាមចូលមកហ្នឹង"]។ ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714352-53 ["មិនមានកាលបរិច្ឆេទចាប់ផ្តើម និងបញ្ចប់ឱ្យបានជាក់លាក់ពីប្រតិបត្តិការរបស់ទីតាំងការដ្ឋានវាយថ្មនេះទេ។ [...] ប៉ុន្តែ នៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតនេះ គេអាចនិយាយបានដោយប្រុងប្រយ័ត្នថា ការដ្ឋានការងារមួយនេះត្រូវបានបង្កើតឡើង និងដំណើរការក្រោមការគ្រប់គ្រងរបស់កងពល ១៦៤ នៅកំពង់សោមរហូតដល់របបនោះបានបញ្ចប់។ សាក្សីសំខាន់មួយរូប ដែលស្ថិតនៅក្នុងក្រុមពលករមួយនៅស្ទឹងហាវនេះ បានសរសេរនៅក្នុងសៀវភៅរបស់គាត់ស្តីអំពីការដ្ឋាននេះ និងបានរៀបរាប់ពីព្រឹត្តិការណ៍មួយចំនួនដែលគាត់បានជួបប្រទះនៅក្នុងឆ្នាំ ១៩៧៨ នៅស្ទឹងហាវ រហូតដល់ថ្ងៃទី ០៧ ខែមករា ឆ្នាំ ១៩៧៩"]។

បានបន្តបញ្ជូនពលករទៅស្ទឹងហាវរហូតដល់ឆ្នាំ ១៩៧៨[2313]។ ការសាងសង់កំពង់ផែ[2314] និងផ្លូវ បានចាប់ផ្ដើមនៅឆ្នាំ ១៩៧៦។ ផ្លូវត្រូវបានសាងសង់រួចរាល់នៅឆ្នាំ ១៩៧៦ ចំណែកឯការងារសាង

[2313] ឯកសារ D54/77 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.34 ["ខ្ញុំត្រូវបានបញ្ជូនទៅស្ទឹងហាវ នៅខែ វិច្ឆិកា ឬខែ ធ្នូ ឆ្នាំ ១៩៧៧"]។ ឯកសារ D54/83 កំណត់ហេតុស្ដាប់ចម្លើយ ហ៊ីង អ៊ិច ឆ.36 ["ខ្ញុំនៅស្ទឹងហាវបានប្រហែល ១-២ ខែ គឺនៅដើមឆ្នាំ ១៩៧៧"]។ ឯកសារ D54/98 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាង រ៉េត ឆ.106, 113 ["ស៖ តើលោកបានទៅការដ្ឋានរ៉ែថ្មស្ទឹងហាវនៅក្នុងឆ្នាំណាដែរ? ឆ.106៖ ខ្ញុំបានទៅទីនោះម្ដងនៅក្នុងឆ្នាំ ១៩៧៧ នៅពេលដែលការដ្ឋាននោះត្រូវបានសម្ពោធ។ [...] ឆ.113៖ ខ្ញុំចាំបានថា ខ្ញុំទៅទីនោះទាំងពីរលើកនៅក្នុងឆ្នាំ ១៩៧៧"]។ ឯកសារ D114/83 កំណត់ហេតុស្ដាប់ចម្លើយ សុខ នាង ឆ.8 ["នៅចុងឆ្នាំ១៩៧៧ គេបញ្ជូនពួកយើងទៅស្ទឹងហាវ"]។ ឯកសារ D114/95 កំណត់ហេតុស្ដាប់ចម្លើយ យឹម ស្រឿង ឆ.178 ["ស៖ តើលោកទៅស្ទឹងហាវនៅឆ្នាំណាដែរ? ឆ.178៖ ខ្ញុំទៅទីនោះនៅពាក់កណ្ដាលឆ្នាំ ១៩៧៧"]។ ឯកសារ D114/112 កំណត់ហេតុស្ដាប់ចម្លើយ អ៊ឹម សុខន ឆ.15 ["ក្នុងប្រហែលខែកក្កដា ឆ្នាំ១៩៧៧ ខ្ញុំនិងមនុស្សជាច្រើននាក់ទៀត មកពីតំបន់៣៧ ត្រូវបានគេបញ្ជូនទៅលត់ដំ នៅស្ទឹងហាវ"]។ ឯកសារ D114/219 កំណត់ហេតុស្ដាប់ចម្លើយ សន ជួន KH ERN 01301516 ["ពួកវាយកខ្ញុំមកចូលឆ្នាំ១៩៧៧ យកយើងមកកាប់ព្រៃគុប ជិតស្ទឹងហាវ"]។ ឯកសារ D54/106.2 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង សាន់ កាន KH ERN 00993436 ["ស៖ ចឹងកាលហ្នឹង ៧៧ និងជាខែប្រាំង ឬខែវស្សា ឬក៏ខែណា? ឆ៖ ប្រហែលកាលហ្នឹងបង សារឿន ហ្នឹងហៅខ្ញុំទៅស្ទឹងហាវ"]។ ឯកសារ D114/283 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.2 ["ស៖ ចង់និយាយតែពីពេលលោកទៅនៅកោះ ពី ៧៥ ដល់ ៧៧ ដែលគេដកពីកោះមកវិញ មកនៅស្ទឹងហាវហើយ? ឆ.2៖ និយាយពី៧៥ដល់៧៧"]។ ឯកសារ D54/35 កំណត់ហេតុស្ដាប់ចម្លើយ ប្រាក់ សុខា ឆ.17 ["នៅដើមឆ្នាំ ១៩៧៨ ខ្ញុំត្រូវបានគេបញ្ជូនទៅស្ទឹងហាវ"]។ ឯកសារ D54/68 កំណត់ហេតុស្ដាប់ចម្លើយ នង នេត ឆ.13 ["ស៖ តើក្នុងរដូវណានៅឆ្នាំ ១៩៧៨ ដែលលោកធ្វើដំណើរពីត្រពាំងក្រឡឹងទៅស្ទឹងហាវ? ឆ.13៖ ខ្ញុំទៅនៅក្នុងរដូវប្រាំង ជិតដាច់ឆ្នាំ ១៩៧៨ ពីព្រោះប្រហែល១ខែក្រោយ ខ្ញុំទៅដល់កន្លែងនោះ វៀតណាមចូលមកដល់។ ជាទូទៅយើងធ្វើស្ពានលូអំឡុងខែប្រាំង"]។ ឯកសារ D54/67.3 កិច្ចសម្ភាសរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង នង នេត KH ERN 00977453 ["ស៖ ចុង ៧៨? ឆ៖ ចុង៧៨។ ស៖ គេយកពូទៅណាដែរ? ឆ៖ យកខ្ញុំទៅឱ្យធ្វើស្រែនៅសហករណ៍ស្ទឹង។ ចេញពីភ្នំពេញទៅ"]។ ឯកសារ D54/9 កំណត់ហេតុស្ដាប់ចម្លើយ មិន ផុន ឆ.6 ["ខ្ញុំរស់នៅស្ទឹងហាវពីពាក់កណ្ដាលឆ្នាំ ១៩៧៨ រហូតដល់បែកឆ្នាំ ១៩៧៩"]។ ឯកសារ D114/86 កំណត់ហេតុស្ដាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.16 ["ស៖ តើលោកអាចប្រាប់យើងអំពីការដ្ឋានយកថ្មនៅស្ទឹងហាវ ដែលលោកបានប្រាប់យើងក្នុងបទសម្ភាសន៍មុនបានដែរឬទេ? ឆ.16៖ តាមខ្ញុំចាំ គេបញ្ជូនឱ្យខ្ញុំទៅធ្វើការនៅទីនោះនៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៨"]។ ឯកសារ D114/121 កំណត់ហេតុស្ដាប់ចម្លើយ សួន ផ ឆ.42 ["តាមខ្ញុំចាំ គេបញ្ជូនពួកខ្ញុំទៅវាយថ្មនៅស្ទឹងហាវនៅខែ មករា ឬ កុម្ភៈ ឆ្នាំ ១៩៧៨"]។ ឯកសារ D114/66 កំណត់ហេតុស្ដាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.25 ["ស៖ ចាប់ពីឆ្នាំ ១៩៧៧ តើលោកស្នាក់នៅធ្វើការនៅទឹកសាប បានរយៈពេលប៉ុន្មាន មុននឹងគេបញ្ជូនលោកទៅស្ទឹងហាវ? ឆ.25៖ ខ្ញុំនៅធ្វើការនៅទឹកសាប ពីឆ្នាំ ១៩៧៧ រហូតដល់ខែកញ្ញា ឆ្នាំ១៩៧៨ ទើបគេបញ្ជូនខ្ញុំឱ្យទៅធ្វើការវាយថ្មនៅស្ទឹងហាវ"]។ សូមមើលផងដែរ ឯកសារ D114/275

សង់កំពង់ផែ និងផែមិនទាន់បានបញ្ចប់ឡើយ នៅត្រឹមពេលដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ[2315]។ ផ្លូវពីផែទៅរោងចក្រចម្រាញ់ប្រេង មានប្រវែង ១៣ គីឡូម៉ែត្រ និងចំណាយពេលប្រាំមួយខែដើម្បី

---

របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង អូរកំបុត EN ERN 01346014 ["កងរបស់គាត់ត្រូវបានបញ្ជូនទៅផ្ការព្រៃនៅស្ទឹងហាវ នៅអំឡុងឆ្នាំ ១៩៧៧"]។

2314 ឯកសារ D54/49 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.32, 36, 37 ["ខ្ញុំទៅស្ទឹងហាវញ៉ឹកញាប់ [...] ផែនោះចាប់ផ្តើមធ្វើនៅដើមឆ្នាំ ១៩៧៧។ [...] ស៖ ហេតុអ្វីបានជាលោកដឹងថាគេធ្វើផែនៅស្ទឹងហាវហ្នឹងនៅដើមឆ្នាំ ១៩៧៧? ឆ. 36៖ ពីព្រោះខ្ញុំបានដឹកកម្មករចិនទៅធ្វើការនៅទីនោះ ហើយពេលល្ងាចខ្ញុំបានដឹកពួកគេមកសម្រាកនៅផែកំពង់សោមវិញ។ [...] ឆ.37៖ តាមពិតគម្រោងការងារធ្វើផែចាប់ផ្តើមនៅឆ្នាំ ១៩៧៦ ជាមួយការចាក់ដីបំពេញ។ ប៉ុន្តែ ការងារជាក់ស្តែងចាប់ផ្តើមនៅឆ្នាំ ១៩៧៧"]។

2315 ឯកសារ D54/9 កំណត់ហេតុស្តាប់ចម្លើយ មិន ផុន ឆ.15 ["ផែនោះដូចជាធ្វើពុំទាន់ហើយទាំងស្រុងទេ កាលពីខែមករា ឆ្នាំ ១៩៧៩។ យោធាដែលនៅលើផែនោះបាននិយាយប្រាប់ខ្ញុំថា គេគ្រោងធ្វើបញ្ចប់ក្នុងរវាងមួយ ឬពីរឆ្នាំទៀត"]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.12 ["ខ្ញុំនៅស្ទឹងហាវធ្វើការសាងសង់ផែថ្មចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៦ រហូតដល់ឆ្នាំ ១៩៧៩ ពេលវៀតណាមចូលមកដល់"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង វ៉េត ឆ.111 ["តាមខ្ញុំដឹង ផែនោះធ្វើមិនទាន់ហើយនៅឡើយទេ នៅពេលដែលរបបខ្មែរក្រហមត្រូវបានផ្តួលរលំ"]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន យ៉ើ ឆ.75 ["ស៖ តើទំនប់រលកនោះ ឬក៏ផែហ្នឹងធ្វើរួចរាល់នៅក្នុងខែឆ្នាំណាដែរ? ឆ.75៖ ធ្វើមិនចប់ទេឆ្នាំ ១៩៧៩ ហ្នឹង បែកគ្នាអស់ហើយ"]។ ឯកសារ D54/33.1 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង អ៊ឹង ឆុន (អ៊ី ឆុន) KH ERN 00964202-03 ["កាលខ្ញុំជួបពូ ពូហ្នឹងគាត់ថាមានផែមួយទៀត ដែលគេកំពុងតែសាងសង់នៅសម័យ៣ឆ្នាំហ្នឹងដែរ នៅខាងស្ទឹងហាវ? ឆ៖ អាហ្នឹងគ្រាន់តែគម្រោងរបស់ចិន គេធ្វើដែរ តែទើបតែធ្វើបានបន្តិចហ្នឹង មិនទាន់បានចតបានអីស្រួលបួលផង គ្រាន់តែជាគម្រោងធ្វើដល់ពេលស្រុកយើងអ៊ីចឹងទៅ គម្រោងផែនការរបស់ចិន អាហ្នឹងគម្រោងរបស់គេធំណាស់ បើថាធ្វើគេធ្វើម៉ាំតែម្តង តែមានទាន់បានធ្វើណា គេទើបតែធ្វើបានបន្តិចហ្នឹង។ សៈ៖ អ៊ីចឹងទើបតែធ្វើបានបន្តិចទេ? ឆ៖ ធ្វើបានបន្តិចហ្នឹង គេទើបតែចាក់ដីចូលបនាបន្តិចហ្នឹង គេកំពុងតែស្រាវជ្រាវ"]។ ឯកសារ D54/49 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.32 ["ទៅស្ទឹងហាវញ៉ឹកញាប់។ ខ្ញុំបើកឡានដឹកគណៈប្រតិភូចិន ឬក៏កម្មករចិនទៅស្ទឹងហាវ ហើយនៅពេលនោះ គេកំពង់កសាងផែ។ [...] រហូតដល់ដើមឆ្នាំ ១៩៧៩ ផែនោះនៅមិនទាន់ធ្វើរួចហើយទេ"]។ ឯកសារ D54/35.1 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង ប្រាក់ សុខា KH ERN 00964253 ["ស៖ កាលហ្នឹងផែនៅស្ទឹងហាវហ្នឹង ដូចថាជិតហើយឬនៅ ឬធ្វើមិនទាន់ហើយទេ? ឆ៖ នៅទេ ធ្វើមិនទាន់ហើយផង វៀតណាមចូលប្រើបមកធ្វើមិនទាន់ហើយផង"]។

សាងសង់[2316]។ យ៉ាងហោចណាស់ កន្លែងគាស់យកថ្មមួយកន្លែងនៅតែត្រូវបានប្រើប្រាស់ដដែល នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ[2317]។

597. ផែនេះគឺស្ថិតនៅចុងផ្លូវ ដែលចេញពីស្ទឹងហាវទៅរោងចក្រចម្រាញ់ប្រេង ដែលមានទីតាំងស្ថិតនៅភាគខាងលិចនៅលើជ្រោយមួយក្បែរក្រុងកំពង់សោម[2318]។ នៅត្រឹមពេលដែលវៀតណាមបានផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ ផែនោះបានសង់រួចត្រឹមប្រវែង ៤០០ ម៉ែត្រ ទទឹង ១២ ម៉ែត្រ និងជម្រៅប្រហែល ៥ ម៉ែត្រ។ ខ្សែបន្ទាត់ឆ្នេរនៅកំពង់ផែ ត្រូវបានលុបចេញ និងត្រូវបានតម្រង់ឱ្យត្រង់ដោយថ្មដែលមានប្រវែង ៣០០ ម៉ែត្រ និងជម្រៅ ៥០ ម៉ែត្រ[2319]។ ជារឿងអាចទៅរួចដែលថា

---

2316 ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714387 ["សាក្សី ប៉ែន សារិន បនាលើកឡើងថាការសាងសង់ផ្លូវនេះ ត្រូវបានបញ្ចប់នៅក្នុងឆ្នាំ ១៩៧៦ ដោយចំណាយពេលសាងសង់អស់រយៈពេល ៦ ខែ។ ផ្លូវនោះមានប្រវែង ១៣ គីឡូម៉ែត្រ។ [...] ចម្ងាយពីរោងចក្រចម្រាញ់ប្រេងទៅកាន់កំពង់ផែថ្មស្ទឹងហាវ គឺប្រាកដជាមានប្រវែង ១៣ គីឡូម៉ែត្រ"]។ ឯកសារ D2/7 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សរិន ឆ.10 ["ស៖ សូមលោករៀបរាប់ប្រាប់យើងអំពីស្ថានភាពការងារយ៉ាងម៉េច ក្នុងករាកសាងផ្លូវពីស្ទឹងហាវទៅកំពង់សោម? ឆ.10៖ ផ្លូវនេះបានសាងសង់ចប់នៅចុងឆ្នាំ ១៩៧៦។ ខ្ញុំជាមេជាង ការងារមានលក្ខណៈពិបាក ប៉ុន្តែ យើងចេះតែទ្រាំធ្វើការទៅ។ យើងត្រូវធ្វើការទាំងភ្លៀង ទាំងយប់រហូតដល់ម៉ោងប្រាំបួន ឬដប់ពីរយប់ ដោយមានដាក់ភ្លើងធ្វើការរហូត។ ផ្លូវដែលយើងសាងសង់នេះ មានប្រវែងតែ ១៣ គីឡូម៉ែត្រប៉ុណ្ណោះ ដោយមិនសាងសង់ទៅដល់កំពង់សោមទេ គឺទៅដល់ត្រឹមរោងចក្រប្រេងកាតប៉ុណ្ណោះ។ ផ្លូវនេះកសាងអស់រយៈពេល ៦ ខែ"]។

2317 ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.5, 13 ["ខ្ញុំអាចឮសំឡេងបំផ្ទុះបំបែកថ្ម ហើយនិងឃើញផ្សែងឡើងលើពីកន្លែងធ្វើការរបស់ខ្ញុំរៀងរាល់ថ្ងៃរវាងម៉ោងពីរ និងម៉ោងបីរសៀល។ [...] ឆ.13៖ ខ្ញុំទៅនៅក្នុងរដូវប្រាំង ជិតដាច់ឆ្នាំ១៩៧៨ ពីព្រោះប្រហែល១ខែក្រោយខ្ញុំទៅដល់កន្លែងនោះ វៀតណាមចូលមកដល់"]។

2318 ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714351 ["កំពង់ផែនេះក៏បង្ហាញឱ្យឃើញផងដែរ នូវចំណុចបញ្ចប់របស់ផ្លូវភ្ជាប់ពីកំពង់ផែស្ទឹងហាវទៅកាន់រោងចក្រប្រេង"], KH ERN 00714351 ["ផ្លូវពីស្ទឹងហាវទៅកាន់រោងចក្រប្រេងជិតកំពង់សោម/ក្រុងព្រះសីហនុ"]។

2319 ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714354 ["កំពង់ផែថ្មនោះមានប្រវែង ៤០០ ម៉ែត្រ ទទឹងប្រមាណ ១២ ម៉ែត្រ និងមានជម្រៅប្រមាណ៥ ម៉ែត្រ។ ព្រំសឆ្នេរសមុទ្រនៅត្រង់កំពង់ផែនេះ ស្ថិតនៅក្នុងស្ថានភាពស្រឡះ និងក្រាលទៅដោយថ្ម ដែលមានប្រវែង ៣០០ ម៉ែត្រ និងជម្រៅប្រមាណ ៥០ ម៉ែត្រ"], KH ERN 00714382 ["នៅក្នុងដំណើររឿងនោះ នៅបានពិពណ៌នាអំពីច្រាំងសមុទ្រ ដែលជាគម្រោងកំពង់ផែមួយដ៏ធំផងដែរ ដោយថ្មីជាច្រើនយកចេញពីការដ្ឋានវាយថ្ម ត្រូវបានយកមកតំរៀបដើម្បីឱ្យច្រាំងសមុទ្រមានសភាពត្រង់"]។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស

នៅភាគខាងកើតផែនេះ ខ្មែរក្រហមបានសាងសង់ទំនប់ទឹកសមុទ្រក្នុងកំពង់ផែ ដែលគេស្គាល់ថាជាទំនប់រលកថ្មី ដើម្បីការពារផែ និងកំពង់ផែ ឬភ័ស្តុតាងនេះអាចនឹងកំពុងពិភាក្សាអំពីការសាងសង់ផែនេះដោយខ្លួនឯង[2320]។

598. មានការដ្ឋានវាយថ្មជាច្រើនកន្លែងដែលផ្តល់ថ្មសម្រាប់កំពង់ផែ ផ្លូវ និងផែ និង/ឬទំនប់ទឹកសមុទ្រក្នុងកំពង់ផែ[2321]។ សាក្សីម្នាក់បានបញ្ជាក់ថា នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ការដ្ឋាន

---

មាន ឆ.18 [“ស៖ កាលពីពេលហ្នឹង តើផែថ្មត្រូវបានកសាងបានប្រវែងប៉ុន្មានម៉ែត្រទៅក្នុងសមុទ្រ? ឆ.18៖ នៅពេលនោះខ្ញុំបានឮថា គេកសាសងប្រវែងប្រហែល ៥០០ ម៉ែត្រលយចូលទៅក្នុងសមុទ្រ។

2320 ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.80 [“ខ្ញុំបានគូសទីតាំងការដ្ឋានធំនៅស្ទឹងហាវ និងទំនប់ដែលគេហៅថាទំនប់រលក ដែលជាតំនប់គេសាងសង់ឡើង ដើម្បីការពាររលកធំៗ”]។ ឯកសារ D114/215.3 ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាល ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ឆ្នាំ ២០០៨-២០១០ KH ERN 01301427។ ឯកសារ D114/215.1 មាស អ៊ឹម របាយការណ៍គម្រោងលើកកម្ពស់គណនេយ្យភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា EN ERN 01301423 [“ខ្មែរក្រហមមានផែនការសាងសង់ទំនប់ការពារការខូចខាត ដែលបណ្តាលមកពីរលកសមុទ្រធំៗ។ តែទំនប់នេះសាងសង់បានតែ ៧០០ ម៉ែត្រក៏កងទ័ពវៀតណាមចូលក្នុងប្រទេសកម្ពុជា ខែ មករា ឆ្នាំ ១៩៧៩”]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ិន យ៉ើ ឆ.48 [“វាមានពីរការដ្ឋានសម្រាប់ការងារ។ ការដ្ឋានហ្នឹង គេជីកដី រ៉ែថ្ម ដើម្បីបង្កើតជាចាក់ទំនប់រលកថ្មី។ ការដ្ឋានមួយទៀត រ៉ែថ្មដូចគ្នា។ រ៉ែថ្ម ដើម្បីចាក់ទំនប់រលកថ្មី”]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.19 [“គេបញ្ជូនខ្ញុំ និងពួកខ្ញុំឱ្យទៅរ៉ែបំបែកថ្ម ដើម្បីយកទៅធ្វើផែទំនប់រលកស្ទឹងហាវ”]។ ឯកសារ D54/35.1 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង ប្រាក់ សុខា KH ERN 00964253 [“ស៖ អ៊ីចឹងកាលហ្នឹងរ៉ែថ្មយកទៅធ្វើអីគេ? ឆ៖ យកទៅធ្វើផែយកទៅធ្វើអីហ្នឹង យកទៅធ្វើផែធ្វើទំនប់អីហ្នឹង នៅជីកអណ្តូងជីកអីហ្នឹង”]។

2321 ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.16, 19, 21 [“ឆ.16៖ គេបញ្ជូនឱ្យខ្ញុំទៅធ្វើការនៅទីនោះនៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៨។ [...] ឆ.19៖ នៅស្ទឹងហាវមានការដ្ឋានយកថ្មចំនួនបី។ [...] ឆ.21៖ តាមពិតទៅមានការដ្ឋានបួនមែន មុនខ្ញុំមកដល់ គឺពីរស្ថិតនៅជិតគ្នាត្រង់ការដ្ឋានយកថ្ម ដែលខ្ញុំសរសេរដាក់ថាលេខ១ តែពេលខ្ញុំមកដល់ គេឈប់យកថ្មពីទីនោះហើយ ដូច្នេះ ក៏សល់តែការដ្ឋានចំនួនបី ដូចដែលខ្ញុំគូសបញ្ជាក់ទៅ”]។ ឯកសារ D114/86.7 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឧបសម្ព័ន្ធ៖ គំនូសផ្ទាល់ដៃដែលគូសដោយសាក្សី KH ERN 01110642។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.21 [“ស៖ សូមលោកប្រាប់យើងថា តើមានការដ្ឋានវាយថ្មចំនួនប៉ុន្មាននៅស្ទឹងហាវ? ឆ.21៖ បាទ តាមដែលខ្ញុំចងចាំបានគឺមានបួនការដ្ឋានវាយថ្ម ខ្ញុំធ្វើការនៅការដ្ឋានទី៤”]។ ឯកសារ D54/13.2 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាលខ័ណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ឆ្នាំ ២០០៨-២០១០ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ KH-EN ERN 00936753។ ឯកសារ D114/60 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង អំពីការដ្ឋានធ្វើការងារដោយបង្ខំនៅផែយោធាស្ទឹងហាវ EN ERN 01082174 [“សាក្សីគឺជាអ្នកបើកទូកនៅស្ទឹងហាវ។ គាត់ធ្វើការធូន់ធ្ងរដោយបំបែកថ្មនៅការដ្ឋានមួយ ហៅ

វាយថ្មនីមួយៗត្រូវគេស្គាល់តាមរយៈឈ្មោះកងដែលឈរជើងនៅទីនោះ[2322]។ មានការដ្ឋានវាយថ្ម យ៉ាងហោចណាស់បីនៅភាគខាងលិចនៃផ្លូវភាគខាងជើង/ត្បូង ឆ្ពោះទៅកាន់ផែ[2323] ក៏ដូចជា

---

ថា ការដ្ឋានរ៉ែថ្មទី ៤"], EN ERN 01082180 ["កន្លែងដែលស្គាល់ថាជាការដ្ឋានរ៉ែថ្មទី ៤ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ គឺនៅតែប្រើប្រាស់ជាការដ្ឋានរ៉ែថ្មដដែល"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.42 ["នៅស្ទឹងហាវមានការដ្ឋានវាយថ្មចំនួនបី"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញឹក ឆ.41-42 ["ស៖ តើលោកដឹងថាការដ្ឋានវាយថ្មមានចំនួនប៉ុន្មាននៅស្ទឹងហាវ? ឆ.41៖ តាមខ្ញុំដឹង នៅស្ទឹងហាវមានការដ្ឋានវាយថ្មចំនួនបីកន្លែង។ ស៖ តើការដ្ឋានវាយថ្មទាំងបីកន្លែងនោះ មានទីតាំងស្ថិតនៅកន្លែងណាខ្លះ? ឆ.42៖ ការដ្ឋានវាយថ្មមួយនៅចម្ងាយប្រហែល៥០០ ម៉ែត្រពីការដ្ឋានរបស់ខ្ញុំ និងមួយទៀតមានចម្ងាយប្រហែល ១,៥ គីឡូម៉ែត្រខាងកើតការដ្ឋានរបស់ខ្ញុំ"]។ សូមមើលផងដែរ ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714347 ["តាមពិត ការដ្ឋានវាយថ្មស្ទឹងហាវ មិនមែនជាទីតាំងការដ្ឋានវាយថ្មតែមួយនោះទេ គឺមានការដ្ឋានវាយថ្មចំនួនបីនៅជិតគ្នា រួមទាំងជំរំយោធាផង"], KH ERN 00714350-51 ["ទីតាំងវាយថ្មនេះ ស្ថិតនៅតាមបណ្តោយឆ្នេរខាងលិចនៃជ្រោយស្ទឹងហាវតូចនេះ ដែលមានយ៉ាងហោចណាស់កន្លែងជីកថ្មដែលមានរណ្តៅចំនួនបី ជីកចូលទៅក្នុងថ្ម និងទីតាំងជំរំមួយរបស់ទាហានកងពល១៦៤"], KH ERN 00714352 ["ការដ្ឋានវាយថ្មីទាំងនេះ បានផ្តល់ថ្មីយ៉ាងហោចណាស់សម្រាប់គម្រោងពីរ នោះគឺ ការសាងសង់កំពង់ផែថ្ម និងផ្លូវទៅកាន់ស្ទឹងហាវ"], KH ERN 00714369 ["សាក្សី សៀង ជាអ្នកចង្អុលបង្ហាញពីទីតាំងការដ្ឋានវាយថ្មទាំងបី និងទីតាំងកងអនុសេនាធំរបស់កងពល ១៦៤"], KH ERN 00714375។ ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.17 ["ខ្ញុំធ្វើការនៅកងកេងរហូតដល់ពាក់កណ្តាលឆ្នាំ ១៩៧៨ ទើបគេបញ្ជូនខ្ញុំឱ្យទៅធ្វើការនៅស្ទឹងហាវ។ នៅទីនោះ គេឱ្យខ្ញុំបំបែកថ្មដើម្បីយកថ្មទៅធ្វើទំនប់រលក និងផែសម្រាប់ឱ្យកប៉ាល់ចម្បាំងចូលចត។ គេមិនចង់យកកប៉ាល់ចម្បាំងទៅចតនៅផែស៊ីវិលទេ"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៊ាង រ៉េត ឆ.107 ["ស៖ តើលោកអាចរៀបរាប់ពីស្ថានភាពនៅការដ្ឋានស្ទឹងហាវបានដែរឬទេ? ឆ.107៖ ខ្ញុំឈរមើលពីចម្ងាយ ហើយឃើញមានឡានដឹកថ្មធំៗពីខេត្តកំពតទម្លាក់នៅការដ្ឋានស្ទឹងហាវ ហើយមានម៉ាស៊ីនកិនបំបែកថ្មដើម្បីសាងសង់ផែ"]។ ឯកសារ D54/77.1 ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាល ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ឆ្នាំ ២០០៨-២០១០ KH ERN 00982557 [កំណត់សម្គាល់ "ការដ្ឋានរ៉ែថ្មក្រុមមួយផ្សេងទៀត"]។

2322 ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.21 ["ដូច្នេះ ការដ្ឋានយកថ្មទាំងនេះត្រូវបានគេស្គាល់ក្នុងសម័យខ្មែរក្រហមទៅតាមឈ្មោះអង្គភាពដែលទៅធ្វើការនៅទីនោះវិញ"]។

2323 ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714368 ["ការដ្ឋានវាយថ្មស្ទឹងហាវ គឺស្ថិតនៅក្នុងឃុំស្ទឹងហាវ ប៉ែកខាងលិចជ្រោយស្ទឹងហាវ។ ទីតាំងនោះស្ថិតនៅចន្លោះផ្លូវខាងជើង/ខាងត្បូង និងឆ្នេរខាងលិច។ ធ្វើដំណើរតាមផ្លូវធំនៅស្ទឹងហាវឆ្ពោះទៅទិសខាងជើង នឹងទៅដល់កំពង់ផែថ្មស្ថិតនៅផុតផ្លូវនោះទិសខាងជើង។ នៅពីមុខច្រកចូលទៅកាន់កំពង់ផែថ្មនោះ មានផ្លូវបត់ទៅប៉ែកខាងលិច រួចឆ្ពោះទៅតំបន់ស្នាក់អាស្រ័យតូចមួយ ស្ថិតនៅទិសខាងត្បូងនៅលើផ្លូវដីដ៏តូចមួយ។ ធ្វើដំណើរតាមផ្លូវនេះនឹងឆ្ពោះទៅដល់ទីតាំងការដ្ឋានវាយថ្មចំនួនបីកន្លែងផ្សេងទៀត"], KH ERN 00714372 ["ជាដំបូង សាក្សីបាន

ការដ្ឋានវាយថ្មទៅភាគខាងលិចកាន់តែឆ្ងាយទៀត នៅភាគខាងត្បូងនៃផ្លូវឆ្ពោះទៅកាន់រោងចក្រចម្រាញ់ប្រេង (រួមទាំងការដ្ឋានវាយថ្មមួយកន្លែងដែលគេស្គាល់ថាជា ភ្នំ ១០៣[2324])[2325]។ ការដ្ឋានវាយថ្មនៅភាគខាងលិចនៃផ្លូវភាគខាងជើង/ត្បូង ស្ថិតនៅលើអ័ក្សជើងត្បូង និងមានទីតាំងស្ថិតនៅចម្ងាយតិចជាង ១០០ ម៉ែត្រពីគ្នា។ ការដ្ឋានវាយថ្មទាំងបីមានទំហំខុសៗគ្នា ចាប់ពីទទឹងរហូតដល់ ៤៤ ម៉ែត្រ ជម្រៅ ៤០-៦០ ម៉ែត្រ និងកម្ពស់ ៦ ម៉ែត្រ[2326]។ ពួកខ្មែរក្រហមប្រហែលជាមានបំណងចង់ប្រែក្លាយការដ្ឋានវាយថ្មមួយចំនួនទៅជាតំបន់ស្តុកថ្មនៅចុងបញ្ចប់[2327]។

---

ប្រាប់អត្តសញ្ញាណកំពង់ផែថ្មនោះជូនដល់មន្ត្រីស៊ើបអង្កេត ក.ស.ច.ស។ គាត់បានពន្យល់ថា គាត់មានវត្តមានក្នុងរយៈពេលដែលកំពង់ផែនេះត្រូវគេសាងសង់ ហើយដុំថ្មជាសម្ភារៈប្រើប្រាស់សម្រាប់ការសាងសង់នេះ ត្រូវគេយកមកពីការដ្ឋានវាយថ្មទាំងបី និងត្រូវបានដឹកជញ្ជូនទៅកាន់កំពង់ផែថ្មនោះ"]។ ឯកសារ D54/9.1 ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាល ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ឆ្នាំ ២០០៨-២០១០ KH-EN ERN 00936755។ ឯកសារD54/77.1 ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាល ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ឆ្នាំ ២០០៨-២០១០ KH ERN 00982557។

2324 ឯកសារ D2/7 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សរិន ឆ.13-15 ["ស៖ ចំពោះថ្មដែលយកទៅធ្វើផ្លូវនោះ តើយកពីកន្លែងវាយថ្មនៅតំបន់ស្ទឹងហាវទាំងអស់ ឬយ៉ាងណា? ឆ.13៖ ពេលធ្វើនៅស្ទឹងហាវ គឺថ្មយកចេញពីកន្លែងស្ទឹងហាវ ពេលទៅដល់កន្លែងផ្សេង គេយកថ្មពីកន្លែងដែលនៅជិតៗនោះ។ មានកន្លែងយកថ្មមួយទៀត ដែលតូចជាងស្ទឹងហាវ គឺមានឈ្មោះថា ភ្នំ១០៣ ក៏ជាកន្លែងដែលគេយកថ្មសម្រាប់ធ្វើផ្លូវដែរ។ ស៖ តើភ្នំ១០៣ នៅកន្លែងណា? ឆ.14៖ ភ្នំ១០៣ បើធ្វើដំណើរពីរោងចក្រប្រេងកាតមក គឺចុះជម្រាលមួយ ហើយឡើងទួលមួយ កន្លែងនោះហើយដែលហៅថា ភ្នំ ១០៣។ ស៖ តើនៅតំបន់ស្ទឹងហាវមានកន្លែងយកថ្មប៉ុន្មានកន្លែង? ឆ.15៖ មានកន្លែងយកថ្មច្រើននៅតំបន់នេះ។ ប៉ុន្តែមានពីរដែលធំ គឺកន្លែងយកថ្មនៅស្ទឹងហាវ ដែលគេយកទៅសង់ផែ និងថ្នល់ ហើយនិងមួយកន្លែងទៀតនៅភ្នំ១០៣ ដែលគេយកថ្មតិចតួចសម្រាប់ធ្វើថ្នល់"]។ សូមមើលផងដែរ ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១០ KH ERN 00714354-55 ["ការដ្ឋានស្ទឹងហាវ គឺជាការដ្ឋានវាយថ្មសំខាន់មួយនៅក្នុងតំបន់នោះ ក្រៅពីការដ្ឋានមួយដែលគេហៅថា ភ្នំ១០៣។ សាក្សីមួយរូបបាននិយាយថា ថ្មីសម្រាប់សាងសង់នោះត្រូវបានគេយកមកពីកន្លែងផ្សេងៗទៀតជាច្រើន ដើម្បីសាងសង់ផ្លូវពីរោងចក្រចម្រាញ់ប្រេងទៅកាន់ស្ទឹងហាវផង ឬដើម្បីការសាងសង់គម្រោងផ្សេងៗទៀតផង ដូចជាអាងស្តុកទឹកនៅក្នុងតំបន់នោះជាដើម"]។

2325 ឯកសារ D114/60 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង អំពីការដ្ឋានធ្វើការងារដោយបង្ខំនៅផែយោធាស្ទឹងហាវ EN ERN 01082176។

2326 ការដ្ឋានវាយថ្មទី១៖ ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714377-78, 00714371 ["ការដ្ឋានវាយថ្មទីមួយ មានសណ្ឋានជា "ក្រចកជើងសេះ" បែរមុខទៅទិសនិរតី និងមានព្រំប្រទល់ជាប់នឹងផ្លូវ។ ទទឹងមានប្រវែង ៤០ ម៉ែត្រ (វាស់ដោយ GPS) បណ្តោយមានប្រវែងវែងជាងទទឹង ពោលគឺមានប្រវែងពី ៤០ ទៅ ៦០ ម៉ែត្រ។ កម្ពស់ប៉ាន់ស្មានមានប្រមាណជា ៦

599. មិនមែនការដ្ឋានវាយថ្មទាំងអស់សុទ្ធតែដំណើរការ ពេញមួយអំឡុងពេលនៃការងារក្នុងតំបន់នេះនោះទេ។ លើសពីនេះ មានភស្តុតាងដែលបង្ហាញថា ថ្មត្រូវបាននាំចូលពីការដ្ឋានវាយថ្មផ្សេងៗទៀតនៅក្រៅស្ទឹងហាវ ដែលរួមមាន ពីអូរម្ល (ជិតកងកេង)[2328] ឃ្លាំងលើ[2329] ស្ពានតាអោន និងកំពង់ត្រាច[2330]។ ក៏មានការដ្ឋានវាយថ្មជាច្រើនកន្លែងផងដែរនៅស្ទឹងហាវ ដែលនៅទីនោះ ថ្មដែលគាស់

---

ម៉ែត្រ ឬខ្ពស់ជាងនេះ"]។ ឯកសារ D2/23.6 រូបថត P 00643532។ ការដ្ឋានវាយថ្មទី២៖ ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714378, 00714371 ["ការដ្ឋានវាយថ្មទីពីរ ស្ថិតនៅក្នុងចន្លោះចម្ងាយប្រមាណជា ៣៥ ម៉ែត្រពីការដ្ឋានវាយថ្មទីមួយ។ ការដ្ឋាននេះមានសណ្ឋានរាងមូលជាងការដ្ឋានទីមួយ និងមានទទឹងប្រវែងប្រមាណជា ៣១ ម៉ែត្រ (វាស់ដោយ GPS) មានជម្រៅប្រហាក់ប្រហែលគ្នា (តាមការប៉ាន់ស្មាន) [...] មានការប៉ាន់ស្មានថា កម្ពស់របស់ការដ្ឋានវាយថ្មមួយនេះ គឺដូចគ្នាទៅនឹងកម្ពស់របស់ការដ្ឋានវាយថ្មទីមួយដែរ"]។ ឯកសារ D2/23.7 រូបថត P 00643533។ ការដ្ឋានវាយថ្មទី៣៖ ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714379, 00714371-72 ["ការដ្ឋានវាយថ្មទីបី មានប្រវែងប្រមាណ ៦៣ ម៉ែត្រ (វាស់ដោយ GPS) ស្ថិតនៅភាគខាងជើងនៃការដ្ឋានវាយថ្មទីពីរ។ ការដ្ឋាននេះមានរាងមូល និងមានមុខកាត់ប្រវែង ៤៤ ម៉ែត្រ (វាស់ដោយ GPS)។ [...] មានកម្ពស់ប៉ាន់ស្មានដូចគ្នា គឺប្រហាមាណជា៦ម៉ែត្រ"]។ ឯកសារ D2/23.8 រូបថត P 00643534។

2327 ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.10 ["គេគ្រោងយករូងភ្នំនោះធ្វើជាឃ្លាំង ហើយរូបភ្នំនោះនៅជិតនឹងផែនោះដែរ"]។

2328 ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង សុំ ឆ.272-273 ["ថ្មីហ្នឹង គេយកមកសាងសង់កំពង់ផែនៅស្ទឹងហាវ។ សៈ ហេតុអ្វីបានជាលោកដឹង? ឆ.273៖ ព្រោះ តា ញ៉ាន់ គាត់និយាយពេលដែលគាត់មកការដ្ឋាន"]។

2329 ឯកសារ D54/49 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.38 ["សៈ តើលោកមានឃើញការដ្ឋានវាយថ្មនៅស្ទឹងហាវដែរឬទេ? ឆ.38៖ ទេ ខ្ញុំមិនបានឃើញការដ្ឋានវាយថ្មនៅទីនោះទេ ប៉ុន្តែ ថ្មដែលគេយកមកសាងសង់ផែនោះ គឺយកមកពីតំបន់ឃ្លាំងលើ]។

2330 ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.9-10 ["ឆ.9៖ ស្ពានតាអោន នៅខាងកើតក្រុងកំពត (មិនដឹងឆ្ងាយប៉ុនណាពីក្រុងទេ) ហើយទីតាំងកំពង់ត្រាចនៅទីរួមស្រុកកំពង់ត្រាច តែចម្ងាយប៉ុន្មានពីទីរួមស្រុក ខ្ញុំអត់ដឹង។ សៈ ហេតុអ្វីបានជាលោកមកដឹកថ្មពីទីដាច់ស្រយាលនៅក្នុងខេត្តកំពតទៅស្ទឹងហាវ ខណៈដែលមានការដ្ឋានថ្មដែរនៅស្ទឹងហាវនោះ? ឆ.10៖ ជាផែនការចិន វាត្រូវការថ្មពីស្ពានតាអោន និងថ្មពីកំពង់ត្រាច"]។ ឯកសារ D114/215.1 មាស អ៊ឹម របាយការណ៍គម្រោងលើកកម្ពស់គណនេយ្យភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា EN ERN 01301422 ["កងរបស់ អ៊ឹម ត្រូវបានចាត់តាំងបន្តដើម្បីដឹកថ្មពីស្ពានតាអោន និងកំពង់ត្រាចទៅការដ្ឋានសាងសង់ផែស្ទឹងហាវ។ ម្តងក្នុងមួយថ្ងៃ ឡានដឹកថ្មទៅកំពង់ផែ"]។

យកបាននឹងត្រូវបំបែកឲ្យបានទំហំខុសៗគ្នា អាស្រ័យលើតម្រូវការនៃគម្រោង មុនពេលដឹកជញ្ជូនទៅកាន់តំបន់នោះ[2331]។

600. គ្រឿងចក្រមួយចំនួនដែលចិនផ្តល់ឲ្យ ត្រូវបានប្រើប្រាស់នៅស្ទឹងហាវ ហើយទំនងជាថា ការប្រើប្រាស់គ្រឿងចក្រអាចកើនឡើងជាបន្តបន្ទាប់[2332]។ ភ័ស្តុតាងបង្ហាញថា រថយន្តដឹកទំនិញពេលខ្លះ

---

2331 ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.58 ["ការដ្ឋានទាំងមូលហ្នឹងមានការដ្ឋានវ៉ៃថ្ម ការដ្ឋានខួងថ្ម អាត្រាក់ធ្វើផ្លូវ"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.33 ["ស៖ តើកន្លែងបំបែកថ្មនៅឆ្ងាយប៉ុនណាពីទីតាំងផែ? ឆ.33៖ វាមានចម្ងាយប្រហែល ៥០ ទៅ ១០០ ម៉ែត្រពីកន្លែងផែ ឬមាត់សមុទ្រ។ យើងពុំទាន់បានវាយយកថ្មនៅឯភ្នំទេ"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.40 ["ស៖ តើការដ្ឋានវាយថ្មស្ថិតនៅចម្ងាយប៉ុន្មានពីផែ? ឆ.40៖ មានចម្ងាយប្រហែល ១ គីឡូម៉ែត្រ"]។ ឯកសារD54/77.1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាល ស្រុកស្ទឹងហាវ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៤ KH ERN 00982557។ ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀង ភង់ ឆ.117 ["កន្លែងវ៉ៃថ្ម និងកន្លែងផែនៅប្រហែល ១ គីឡូម៉ែត្រពីគ្នា"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.64-65 ["ស៖ តើការដ្ឋានវាយថ្មនោះស្ថិតនៅចម្ងាយប៉ុនណាពីកំពង់ផែ? ឆ.64៖ ការដ្ឋានដែលបាញ់ថ្ម និងលើកដាក់ឡានចម្ងាយដីប្រហែលជា បើគិតទៅ ១.២០០ ម៉ែត្រពីកន្លែងចាក់ថ្ម។ ស៖ លោកចាំចម្ងាយនេះបានច្បាស់លាស់ខ្លាំងណាស់ ហេតុអ្វី? ឆ.65៖ ហេតុមកពីខ្ញុំដើរចុះឡើង កាលដែលខ្ញុំនៅកន្លែងនោះ"]។ សូមមើលផងដែរ ឯកសារ D114/178.1 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឧបសម្ព័ន្ធ៖ គំនូសផ្ទាល់ដៃដែលគូសដោយសាក្សី KH ERN 01211380។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.19 ["តាមខ្ញុំសង្កេតមើល គេបានយកថ្មទៅចាក់ធ្វើកំពង់ផែនោះបានប្រហែល ៥០០ ម៉ែត្រប៉ុណ្ណោះពីឆ្នេរ"]។ ឯកសារ D114/86.7 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឧបសម្ព័ន្ធ៖ គំនូសផ្ទាល់ដៃដែលគូសដោយសាក្សី ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ KH ERN 01110642។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ិន យ៉ើ ឆ.49-50, 63 ["ស៖ តើនៅស្ទឹងហាវ គេឲ្យលោកធ្វើអ្វីខ្លះដែរ? ឆ.49៖ នៅស្ទឹងហាវ គេឲ្យខ្ញុំវ៉ៃថ្មដើម្បីដឹកចាក់ទំនប់រលក។ ស៖ តើលោកអាចប្រាប់អំពីទីតាំងការដ្ឋានវ៉ៃថ្មនោះបានដែរឬទេ? ឆ.50៖ ទីតាំងវ៉ៃថ្ម គេហៅចម្ការត្របែក នៅខាងលិចស្ពានដែក។ [...] ស៖ តើការដ្ឋានវាយថ្ម នៅឆ្ងាយពីផែ ដែលកំពុងសាងសង់ហ្នឹង ឆ្ងាយប៉ុនណាដែរ? ឆ.63៖ ឆ្ងាយពីគ្នាប្រហែលជា ៤ គីឡូម៉ែត្រដីតែប៉ុណ្ណោះ"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.10 ["ស៖ តើលោកស្រីស្នាក់នៅទីណា និងធ្វើការនៅទីណាខ្លះនៅស្ទឹងហាវ? ឆ.10៖ ពួកយើងស្នាក់នៅកន្លែងមួយឈ្មោះចម្ការត្របែក"]។ ឯកសារ D114/83.2 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឧបសម្ព័ន្ធ៖ គំនូសផ្ទាល់ដៃដែលគូសដោយសាក្សី ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៥ KH ERN 01110589 ។ ឯកសារ D114/215.3 ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាល ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ឆ្នាំ ២០០៨-២០១០ KH ERN 01301427។

2332 ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.19 ["នៅឆ្នាំ ១៩៧៧ ការដ្ឋានវាយថ្មមានចំនួនកើនឡើង នៅពេលនោះមានឡាន ត្រាក់ទ័រច្រើនសម្រាប់ឈូសផ្លូវថ្នល់ និងដឹកថ្មយកទៅធ្វើផែ"]។

ត្រូវបានប្រើដឹកជញ្ជូនថ្ម ម៉ាស៊ីនត្រូវបានប្រើកម្ទេចថ្ម[2333] ហើយរថយន្តកិនបង្ហាប់ រថយន្តជីកដី និង ត្រាក់ទ័រឈ្លូសឆាយត្រូវបានប្រើនៅលើផ្លូវ[2334]។ លើសពីនេះទៀត រំសេវគ្រាប់បែក ត្រូវបានប្រើ ដើម្បីជួយបំបែកថ្ម[2335]។ ទោះជាយ៉ាងណា ភ័ស្តុតាងក៏បានបង្ហាញផងដែរថា ភាគច្រើននៃការងារ វាយយកថ្ម សាងសង់ និងការងារផ្សេងៗទៀត ត្រូវបានធ្វើឡើងដោយដៃ[2336]។ ដូចដែលសាក្សីម្នាក់ បាននិយាយថា៖ "ខ្ញុំមានការលំបាក និងរងទុក្ខលំបាកវេទនា នៅពេលដែលខ្ញុំបានធ្វើការ និងស្នាក់ នៅការដ្ឋានវាយថ្មនោះ។ ពួកគេមិនប្រើគ្រឿងចក្រដើម្បីលើកដុំថ្មនោះទេ។ ពួកគេប្រើពលកម្មមនុស្ស។ យើងត្រូវប្រើថាមពលទាំងអស់របស់យើងដើម្បីសែងថ្មទាំងនោះ"[2337]។

601. មានអាងទឹកចំនួនពីរដែលត្រូវបានសាងសង់នៅភាគខាងត្បូងស្ទឹងហាវ ដែលទំនងជានៅ ឆ្នាំ ១៩៧៧ ឬឆ្នាំ ១៩៧៨[2338]។ កន្លែងដាក់អាងទឹកទីមួយ គឺស្ថិតនៅតាមបណ្តោយផ្លូវធំក្នុងភូមិ និង

2333 ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.12 ["មួយកន្លែងទៀត គេហៅថាកន្លែងខាំថ្ម ដែលគេយក ថ្មធំៗទៅកិនជាថ្មតូចៗ ដោយប្រើម៉ាស៊ីន"]។ ឯកសារ D114/83.2 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឧបសម្ព័ន្ធ៖ គំនូសផ្ទាល់ដៃដែលគូសដោយសាក្សី KH ERN 01110589។ ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀង ភង់ ឆ.118 ["ស៖ នៅផែមានទាហានច្រើនទេ? ឆ.118៖ មានកងទ័ពការពារចិនបួនប្រាំនាក់។ គេមានម៉ាស៊ីនថ្មអីនៅទី នោះ"]។

2334 ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍រវាង ក.ស.ព និង ប៉ែន សារិន EN ERN 00217560 ["រថយន្ត សាងសង់មកពីតំបន់ ១, ៣ និង ៥ ទាំងអស់ ត្រូវប្រមូលមកធ្វើការនៅទីនេះ។ មានរ៉ូឡូ ១៥ គ្រឿង អេស្កាវេទ័រ ១០ គ្រឿង និង អាប៊ុលដូស័រ ១៨ គ្រឿង"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.31 ["ក្រោយមក ទើបគេយកត្រាក់ទ័រឈ្លូសធ្វើផ្លូវ"]។

2335 ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.187 ["ស៖ តើលោកមានដឹងរឿងទាក់ទងកន្លែងវ៉ៃថ្ម នៅស្ទឹងហាវដែរឬទេ? ឆ.187៖ អត់ទេ ប៉ុន្តែ ខ្ញុំគ្រាន់តែឮសូរគេដាក់រំសេវដើម្បីបំបែកថ្ម"]។

2336 ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.19 ["នៅពេលនោះ យើងខួងថ្មដោយដៃ"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.42 ["ពួកយើងធ្វើការជាក្រុមដោយការងារចម្បង គេឲ្យវាយថ្មបំបែក នឹងញញួរ"]។ ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ សៀង EN ERN 00217566 ["ពេលនៅជីគោក គាត់បានចូលរួមធ្វើស្រែចំការនៅស្ទឹងហាវ ដាំដំឡូង អំពៅ និងស្រូវ ក្នុងស្រែតូចៗ។ គ្មានគ្រឿង ម៉ាស៊ីន ឬសត្វពាហនៈដើម្បីជួយការងារទេ"]។

2337 ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ុម សុខន ឆ.73។

2338 ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714354 ["នៅក្នុងការដ្ឋានវាយថ្មស្ទឹងហាវផ្នែកខាងត្បូង ក៏ជាទីតាំងគម្រោងអាងស្តុកទឹកចំនួនពីរ របស់កម្ពុជាប្រជាធិបតេយ្យផងដែរ"], KH ERN 00714394 ["នៅលើអាងស្តុកទឹកដំបូងស្ថិតនៅលើទួល គេអាច

នៅភាគខាងកើតនៃការដ្ឋានវាយថ្ម[2339]។ អាងទឹកនោះត្រូវបានបញ្ចប់រួចរាល់ក្នុងរយៈពេលមួយខែ ដោយមានជំនួយពីទីប្រឹក្សាចិន[2340]។ កន្លែងដាក់អាងទឹកទីពីរ គឺស្ថិតនៅចម្ងាយប្រហែលមួយគីឡូម៉ែត្រពីអាងទឹកទីមួយ និងទៅទិសខាងត្បូងឆ្ងាយជាងអាងទឹកទីមួយ[2341]។

602. ទីប្រឹក្សាចិនប្រមាណ ៤០នាក់[2342] ដែលបានផ្តល់ដោយកងពល ១៦៤ ត្រូវបានដាក់ឱ្យឈរជើងនៅក្នុងផ្ទះមួយ ដែលមានចម្ងាយប្រហែលពីរគីឡូម៉ែត្រភាគខាងត្បូងផែ[2343] កៀកនឹងទីបញ្ជាការក

---

មើលឃើញអក្សរចំណារ/ការគូសវាស មានន័យថា៖ "កសាងនៅឆ្នាំ ៧៧"។ អក្សរចំណារនេះផ្តល់ចំណាប់អារម្មណ៍ការឆ្លាក់អក្សរ/ចំណារនេះ ត្រូវបានធ្វើឡើងនៅលើជញ្ជាំងស៊ីម៉ង់ត៍ដែលមិនទាន់ស្ងួត នៅលើជញ្ជាំង"]។

2339 ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714392 ["កន្លែងអាងស្តុកទឹកទី១ គឺស្ថិតនៅតាមបណ្តោយភូមិធំមួយលាតសន្ធឹងពីជើង ចាប់ពីពាក់កណ្តាលផ្លូវបំបែកទី២ រហូតដល់កំពង់ផែ នៅលើទួលប៉ែកខាងលិចផ្លូវ និងខាងកើតការដ្ឋានវាយថ្មនានា"]។ ឯកសារ D2/23.1 រូបថត P 00643523។ ឯកសារ D2/23.20 រូបថត P 00643524។

2340 ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714392 ["សាក្សី សៀង បានពន្យល់ថា ទីតាំងនេះ ធ្លាប់ជាគម្រោងមួយរបស់កងពល ១៦៤ ដែលត្រូវបានសាងសង់បញ្ចប់រួចរាល់ក្នុងរយៈពេលលើសពី១ខែ ក្នុងឆ្នាំ ១៩៧៨ ដោយមានជំនួយពីទីប្រឹក្សាចិន"]។

2341 ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714393 ["ទីកន្លែងអាងស្តុកទឹកទីពីរ ស្ថិតនៅខាងត្បូងផ្លូវបំបែកទីពីរនៃផ្លូវ ចាប់ពីផ្លូវបំបែកនេះកាត់តាមទីតាំងអតីតទីកន្លែងស្នាក់អាស្រ័យទីប្រឹក្សាចិន និងស្ថិតនៅចម្ងាយ ១,១ គីឡូម៉ែត្រ ពីផ្លូវបត់ទីពីរនៅស្ទឹងហាវ"]។ សូមមើលផងដែរ ឯកសារ D54/13.2 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាលខ័ណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ឆ្នាំ ២០០៨-២០១០ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ KH-EN ERN 00936753។ ឯកសារ D114/108 របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត KH ERN 01218454-56។ ឯកសារ D114/108.1 របាយការណ៍នៃសកម្មភាពការស៊ើបអង្កេត ឧបសម្ព័ន្ធ៖ ផែនទីដើមកន្លែងទឹកស្អាននៅស្ទឹងហាវ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៥ KH ERN 01133450។ ឯកសារ D2/23.26 រូបថត P 00643520។

2342 ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍រវាង ក.ស.ព និង ប៉ែន សារិន EN ERN 00217560 ["មាស មុត មកទស្សនកិច្ចច្រើនដង ហើយពេលដែលគាត់ដេកនៅស្ទឹងហាវ គាត់ដេកនៅកន្លែងអ្នកបច្ចេកទេសចិន នៅអគារមួយនៅប៉ែកខាងជើង នៃទីតាំងមន្ទីរស្រុកសព្វថ្ងៃ។ គម្រោងនេះ មានអ្នកបច្ចេកទេសចិនចំនួន ៤២ នាក់ធ្វើការ"]។

2343 ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714382 ["ទីប្រឹក្សាចិនរបស់កងពល ១៦៤ បានស្នាក់អាស្រ័យនៅក្នុងផ្ទះមួយ មានទីតាំងស្ថិតនៅខាងត្បូងកំពង់ផែថ្ម (ប្រមាណជា ២,៣ គីឡូម៉ែត្រ) និងខាងត្បូងការដ្ឋានវាយថ្មទាំងនោះ (ប្រមាណ ១,៥ គីឡូម៉ែត្រ)"]។ ឯកសារ D54/13.2 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាលខ័ណ្ឌស្ទឹងហាវ ក្រុងព្រះ

ណ្តាលមូលដ្ឋានកងវរសេនាធំ[2344]។ ទីប្រឹក្សាទាំងនេះ[2345] បានផ្តល់ជំនាញទាក់ទងនឹងបញ្ហាបច្ចេកទេសជាច្រើន រួមទាំងការអង្កេត[2346] វិធីសាស្ត្រវាយថ្ម[2347] ការសាងសង់ផ្លូវ[2348] និងការសាងសង់ផែ[2349] និង/ឬ ទំនប់ទឹកសមុទ្រក្នុងកំពង់ផែ[2350]។

---

សីហនុ ឆ្នាំ ២០០៨-២០១០ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ KH-EN ERN 00936753។ សូមមើលផងដែរ ឯកសារ D2/23.1 រូបថត P 00643523។

2344 ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714354 ["នៅជិតទីតាំងជំរំកងពល ១៦៤ គឺជាទីតាំងកន្លែងស្នាក់អាស្រ័យរបស់ទីប្រឹក្សាចិន"], KH ERN 00714365 ["ក្នុងរយៈកាលរបបកម្ពុជាប្រជាធិបតេយ្យ មានទីប្រឹក្សាចិន ជាប់ពាក់ព័ន្ធនៅក្នុងគម្រោងទាំងនេះរបស់កងពលជើងទឹកលេខ ១៦៤ (អតីតកងពលធំលេខ ៣)។ ផ្ទះមួយខ្នងសម្រាប់ទីប្រឹក្សាចិនទាំងនោះស្នាក់អាស្រ័យ មានទីតាំងស្ថិតនៅក្នុងចម្ងាយមួយជិតសម្រាប់ធ្វើដំណើរទៅកាន់ការដ្ឋានការងារនានា ដែលបានបញ្ជាក់អត្តសញ្ញាណរួច និងមានចម្ងាយជិតនឹងទីបញ្ជាការប្រតិបត្តិការកងវរសេនាធំនៃកងពល ១៦៤ ផងដែរ។ ទីបញ្ជាការនេះមានទីតាំងស្ថិតនៅខាងក្រៅភូមិស្ទឹងហាវ ប៉ែកខាងអាគ្នេយ៍ ភូមិស្ថិតនៅចំខាងត្បូងផ្លូវមកពីស្ទឹងហាវទៅកាន់កំពង់សោម មានប្រវែង ១,៧ គីឡូម៉ែត្រពីផ្លូវបែកទីពីរ"]។ សូមមើលផងដែរ ឯកសារ D54/13.2 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាលខ័ណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ឆ្នាំ ២០០៨-២០១០ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ KH-EN ERN 00936753។ ឯកសារ D2/23.1 រូបថត P 00643523។ ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714365 ["ផ្ទះមួយខ្នងសម្រាប់ទីប្រឹក្សាចិនទាំងនោះស្នាក់អាស្រ័យ មានទីតាំងស្ថិតនៅក្នុងចម្ងាយមួយជិតសម្រាប់ធ្វើដំណើរទៅកាន់ការដ្ឋានការងារនានា ដែលបានបញ្ជាក់អត្តសញ្ញាណរួច និងមានចម្ងាយជិតនឹងទីបញ្ជាការប្រតិបត្តិការកងវរសេនាធំនៃកងពល ១៦៤ ផងដែរ។ ទីបញ្ជាការនេះមានទីតាំងស្ថិតនៅខាងក្រៅភូមិស្ទឹងហាវ ប៉ែកខាងអាគ្នេយ៍ ភូមិស្ថិតនៅចំខាងត្បូងផ្លូវមកពីស្ទឹងហាវ ទៅកាន់កំពង់សោម"]។ ឯកសារ D54/13.2 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឧបសម្ព័ន្ធ ៖ ផែនទីរដ្ឋបាលខ័ណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ឆ្នាំ ២០០៨-២០១០ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ KH-EN ERN 00936753។

2345 ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត់ ឆ.100 ["ខ្ញុំស្គាល់កន្លែងនេះហៅថា ស្ទឹងហាវ ហើយវាជាការដ្ឋានសាងសង់ផែ។ មានពួកជំនាញការចិនរស់នៅ និងធ្វើការនៅកន្លែងនោះផងដែរ"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ.102,108 ["ស៖ តើនរណាជាអ្នកគ្រប់គ្រងនៅការដ្ឋានវែថ្មស្ទឹងហាវ? ឆ.102 ៖ ខ្ញុំមិនដឹងថាអ្នកណាជាអ្នកគ្រប់គ្រងនៅទីនោះទេ។ ប៉ុន្តែនៅការដ្ឋាននោះមានជនជាតិចិន និងមានយោធាជាច្រើនក្នុងកងវរសេនាតូចធ្វើការនៅទីនោះ។ [...] ស៖ តើលោកស្គាល់កម្មករដែលធ្វើការនៅការដ្ឋាននោះដែរឬទេ? ឆ.108៖ តាមខ្ញុំដឹង កម្មករនៅទីនោះគឺជាយោធាដែលគេដកពីកងពល ១៦៤ ហើយពួកគេធ្វើការជាមួយកម្មករចិន"]។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.39 ["ឱ្យទៅវាយថ្មចាក់ផែនៅស្ទឹងហាវជាមួយពួកចិន"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.44, 50 ["យូរៗម្តង ខ្ញុំបានឃើញពួកអ្នកបច្ចេកទេសចិន និងអមដំណើរដោយកម្មាភិបាលខ្មែរក្រហមផងដែរ តែខ្ញុំពុំស្គាល់ពួកគេនោះទេ។ [...] ស៖ តើលោកដែលឃើញកម្មាភិបា

លជាន់ខ្ពស់មកទស្សនកិច្ចនៅការដ្ឋានវាយថ្មនោះដែរឬទេ? ឆ.50៖ ខ្ញុំប្រាប់លោករួចហើយថា យូរៗម្តងខ្ញុំឃើញពួកចិនមកទស្សនកិច្ច អមដំណើរដោយកម្មាភិបាលខ្មែរក្រហមដែរ តែខ្ញុំមិនស្គាល់គេនោះទេ"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.39 ["ក្រោយមកទើបមានពួកចិនមកជួយ ពេលចិនមក គេខួងថ្មដាក់កិបឱ្យថ្មផ្ទុះ។ នៅពេលនោះ ទើបការងារស្រួលជាងបំបែកដោយដៃបន្តិច"]។ ឯកសារ D54/9 កំណត់ហេតុស្តាប់ចម្លើយ មិន ផុន ឆ.20 ["ខ្ញុំគ្រាន់តែឮថា មានវិស្វករចិននៅក្នុងតំបន់នោះ"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.13 ["ខ្ញុំចង់ប្រាប់ថា នៅទីនោះក៏មានជនជាតិចិនដែលជាទីប្រឹក្សាផ្នែកបច្ចេកទេស ហើយធ្វើការនៅទីនោះផងដែរ"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.184 ["ស៖ តើលោកដឹងថា អ្នកណាជាអ្នកសាងសង់នៅស្ទឹងហាវទេ? ឆ.184៖ គឺចិន"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.21, 67 ["ពួកអនិកជនចិន គេអ្នកកាន់ស្មានធំៗ មានក្បាលម៉ាតូគេខួង រួចដាក់រំសេវបំផ្ទុះ ហើយពួកខ្ញុំជាអ្នកទៅគាស់ថ្ម ហើយលើថ្មដាក់ឡាន។ [...] ឆ.67៖ មានតែក្រុមខ្ញុំ ជាមួយជនជាតិចិន ៧ នាក់"]។ ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍រវាង ក.ស.ព និង ប៉ែន សារិន EN ERN 00217560 ["គាត់បានចូលរួមសាងសង់ផ្លូវពីរោងចក្រប្រេងកាតទៅភូមិស្ទឹងហាវ។ ការងារនេះគ្រប់គ្រងត្រួតពិនិត្យដោយអ្នកបច្ចេកទេសចិន [...] មាស មុត មកទស្សនកិច្ចច្រើនដង ហើយពេលដែលគាត់ដេកនៅស្ទឹងហាវ គាត់ដេកនៅកន្លែងអ្នកបច្ចេកទេសចិន នៅអគារមួយនៅប៉ែកខាងជើង នៃទីតាំងមន្ទីរស្រុកសព្វថ្ងៃ។ គម្រោងនេះ មានអ្នកបច្ចេកទេសចិនចំនួន ៤២ នាក់ធ្វើការ"]។ ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714391 ["ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ទីប្រឹក្សាចិនបានចូលប្រឡូកនៅក្នុងគម្រោងការងាររបស់កងពលធំជើងទឹកលេខ ១៦៤ (អតីតកងពលលេខ ៣)"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ ឆ.149 ["ស៖ តើលោកបានឮអ្វីខ្លះពីការដ្ឋានស្ទឹងហាវ? ឆ.149៖ [...] ការដ្ឋានហ្នឹងគឺចិនគេអ្នកធ្វើ"]។ ឯកសារ D1.3.13.13 កំណត់ហេតុនៃកិច្ចសម្ភាសន៍រវាង ក.ស.ព និង ទូច សឿលី EN ERN 00217574 ["ការសាងសង់បានចាប់ផ្តើមនៅស្ទឹងហាវ ក្នុងឆ្នាំ ១៩៧៦ ដោយការសាងសង់សំខាន់ៗធ្វើនៅក្នុងឆ្នាំ ១៩៧៧ ដោយចាក់ដីចូលក្នុងទឹកសមុទ្រ។ ការសាងសង់ប្រហែលធ្វើដោយយោធាកងវរសេនាធំ ២២ ប៉ុន្តែ គាត់មិនចាំឈ្មោះមេបញ្ជាការទេ។ មានអ្នកបច្ចេកទេសចិននៅទីនោះផងដែរ"]។ ឯកសារ D54/49 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.32 ["ស៖ តើលោកបានទៅស្ទឹងហាវធ្វើអ្វី ហើយទៅញឹកញាប់ដែរឬទេ? ឆ.32៖ ខ្ញុំទៅស្ទឹងហាវញឹកញាប់។ ខ្ញុំបើកឡានដឹកគណៈប្រតិភូចិន ឬក៏កម្មករចិនទៅស្ទឹងហាវ ហើយនៅពេលនោះ គេកំពង់កសាងផែ"]។ សូមមើលផងដែរ ឯកសារ D54/13.2 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាលខ័ណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ឆ្នាំ ២០០៨-២០១០ ថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ ២០១៣ KH-EN ERN 00936753។ ឯកសារ D54/3.1 ហ្សូ ជា បួនឆ្នាំជាមួយខ្មែរក្រហម (សម្រង់) KH ERN 01506936 ["ភ្ញៀវចិនជាច្រើននាក់ និងអ្នកបច្ចេកទេសដែលមកជួយការងារសាងសង់ "កំពង់ផែយោធាសម្ងាត់"]។

2346 ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.22 ["ស៖ តើខ្មែរក្រហមជាអ្នកដាក់លេខការដ្ឋានទី ១, ២, ៣, ៤ ឬ? តើលេខទាំងនេះមានន័យដូចម្តេច? ឆ.22៖ បាទ គេដាក់លេខការដ្ឋានវាយថ្មយោលទៅតាមជម្រៅរបស់ថ្មនៅតាមកន្លែងមួយៗ។ ជាឧទាហរណ៍ ការដ្ឋានវាយថ្មលេខ ៤ របស់ខ្ញុំ នៅកន្លែងការដ្ឋានរបស់ខ្ញុំមានថ្មជម្រៅរហូតដល់ ៧០ ម៉ែត្រ ដោយយោងទៅតាមការរុករកឃើញរបស់ចិន"]។

603. មានកន្លែងបោះជំរុំជាច្រើនសម្រាប់ពលករ។ ជំរុំមួយដាក់ក្រុមពលករប្រហែល ១០០ នាក់[2351] ដែលមានដាក់ស្លាកថាជា 'សមាសភាពមិនល្អ'។ ក្រុមនេះ ប្រហែលជាមានឈ្មោះថា កងអនុសេនាធំ ១៧ មានទីតាំងស្ថិតនៅភាគខាងត្បូងបន្តិចប៉ុណ្ណោះពីការដ្ឋានវាយថ្ម នៅភាគខាងលិចនៃផ្លូវភាគ

---

2347 ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714357 ["ទីប្រឹក្សាជនជាតិចិនបានបង្រៀនបុគ្គលិកនៃកងពល ១៦៤ អំពីរបៀបបំបែកថ្មចេញពីភ្នំ ដោយគិតពីបច្ចេកទេស ទំហំ និងរូបរាងជាដើម"]។ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ. 25 ["ក្នុងពេលប្រជុំខ្លះ ក៏មានអ្នកបច្ចេកទេសចិនមកប្រជុំប្រាប់យើងពីរបៀបបំផ្ទុះថ្ម ខួងថ្ម ប្រើរទេះអូសថ្ម និងប្រើម្សៅបំផ្ទុះថ្មដែរ"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ ឆ.149 ["ស៖ តើលោកបានឮអ្វីខ្លះពីការដ្ឋានស្ទឹងហាវ? ឆ.149៖ [...] ការដ្ឋានហ្នឹងគឺចិនគេអ្នកធ្វើ គេបំបែកថ្មដោយប្រេវសេវ"]។ សូមមើលផងដែរ ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714372-73 ["សាក្សី សៀង បានធ្វើការបកស្រាយថា ខ្លួនគាត់ផ្ទាល់គឺជាសមាជិកកងពលលេខ៣/កងពលលេខ ១៦៤ ហើយគាត់បានធ្វើការងារនៅទីតាំងស្ទឹងហាវនេះ។ [...] នៅត្រង់ទីតាំងនេះ គាត់បានពន្យល់ថា ទីប្រឹក្សាចិនបានពន្យល់ឲ្យពួកគាត់បានយល់ពីរបៀបនៃការបំបែកថ្ម ដោយគិតពីរូបរាង និងទំហំ ដើម្បីប្រើប្រាស់សម្រាប់ជាសម្ភារៈសាងសង់កំពង់ផែថ្ម"]។

2348 ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍រវាង ក.ស.ព និង ប៉ែន សារិន EN ERN 00217560 ["ការងារនេះគ្រប់គ្រងត្រួតពិនិត្យដោយអ្នកបច្ចេកទេសចិន"]។

2349 ឯកសារ D54/33.1 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង អ៊ឹង អុន (អ៊ុ អុន) KH ERN 00964203 ["ស៖ ប៉ុន្តែ កាលហ្នឹងពូមានបានទៅធ្វើទេ? ឆ៖ អត់ទេ។ ស៖ ក្រុមណាដែលទៅធ្វើហ្នឹង ចិន ឬខាងកងទ័ពយើងធ្វើ? ឆ៖ កាលហ្នឹងមិនទាន់បានធ្វើស្រួលបួលណា គ្រាន់តែគេស្រាវជ្រាវមានចិនមានខ្មែរយើង គេចុះមុជមើលបាតសមុទ្រមើលអី ហើយគម្រោងគេមិនដឹងគេធ្វើម៉េច ពិនិត្យស្អីម៉េចៗខ្ញុំអត់ដឹងទេ ហើយឃើញចិនគេដើរបោស អាណាទុំក្រហមៗហ្នឹង (ដើរដោតទង់ក្រហម)"], KH ERN 00964203-04 ["ស៖ ហើយដែលឃើញចិនគេមកធ្វើដែរអត់? ឆ៖ ឃើញ កាលហ្នឹងគេកែនទ័ព ដែលមិនទាន់មានទ័ពមានអីនៅហ្នឹង គេកែនទៅធ្វើរោងធ្វើអីសម្រាប់កម្មករ កាលហ្នឹងគេថាធ្វើផ្លូវរថភ្លើងទៅដល់ហ្នឹង គេមិនយកកម្មករទៅហ្នឹងឲ្យទៅធ្វើរោងធ្វើអី ធ្វើរោងវែងៗ ហើយយកទ័ពទៅធ្វើណា គេថាសម្រាប់កម្មករដែលមកធ្វើផ្លូវរទេះភ្លើងហ្នឹងមកស្នាក់"]។

2350 ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ុន យ៉ើ ឆ.65-66 ["កាលខ្ញុំនៅស្ទឹងហាវ ធ្លាប់ចិនឲ្យជាបញ្ជាឲ្យការដ្ឋានហ្នឹង មានជនជាតិចិន។ ស៖ តើពួកជនជាតិចិនទាំងនោះមានតួនាទីអ្វីខ្លះដែរ? ឆ.66៖ តួនាទីរបស់ចិនសម្រាប់ឲ្យយើងចាក់ទំនប់រលកហ្នឹង ចម្ងាយប៉ុន្មានម៉ែត្រៗប៉ុណ្ណោះ"]។

2351 ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714356 ["សាក្សី សៀង បានពន្យល់បកស្រាយថា មានទាហានចំនួនប្រមាណ ១០០ នាក់ស្ថិតនៅក្នុងទីតាំងនេះ។ គាត់បាននិយាយថា អង្គភាព "ដែលគេលែងមានការជឿជាក់" មួយដែលមានទំហំស្មើនឹងកងអនុសេនាធំ មានទីតាំងស្ថិតនៅត្រង់នោះ"]។

ខាងជើង/ត្បូង[2352]។ ប៉ុន្តែ ក៏មានទីតាំងផ្សេងទៀតដែលជាកន្លែងពលកររស់នៅផងដែរ[2353]។ កម្លាំងពលកម្មជាចម្បងបានមកពីកម្មាភិបាលដែលគេបញ្ចេញពីកំណែនទ័ព[2354] ប៉ុន្តែ ប្រហែលជា

---

2352 ឯកសារ D114/60 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង អំពីការដ្ឋានធ្វើការងារដោយបង្ខំនៅផែយោធាស្ទឹងហាវ EN ERN 01082179 ["ចូលស្ទឹងហាវតាមទិសដៅពីកំពង់សោម មូលដ្ឋានកងអនុសេនាធំ ១៧ ស្ថិតនៅច្រកចូលស្ទឹងហាវ រវាងស្ពានឆ្លងស្ទឹង និងផ្លូវប្រសព្វ (ចំណុចដៅ ២១)។ ទីតាំងស្ថិតនៅខាងជើងផ្លូវធំ គឺនៅក្បែរចំណុចរវាងស្ទឹង និងផ្លូវធំ"], EN ERN 01082180-81 ["សាក្សីត្រូវបានចាត់ទៅកងអនុសេនាធំ ១៧ ដែលគេហៅថា "សមាសភាពកងមិនល្អ"។ សាក្សីប៉ាន់ស្មានថា មានមនុស្សប្រហែល ១០០ នាក់ត្រូវបានចាត់ចូលទៅកងអនុសេនាធំ ១៧ នេះ"]។ ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714351 ["ការដ្ឋានវាយថ្មត្រូវបានបង្កើតឡើងជាការដ្ឋានការងារមួយ សម្រាប់ឱ្យសមាជិកកងពល ១៦៤ និងជនស៊ីវិលប្រើកម្លាំងពលកម្ម។ ភ្ជាប់ជាមួយនឹងការដ្ឋានវាយថ្មទាំងនោះ យ៉ាងហោចណាស់មានជំរំ "យោធាដែលគេលែងទុកចិត្ត" មួយដែលនេះគឺជាពាក្យសម្គាល់សម្រាប់ប្រើចំពោះអតីតទាហានភូមិភាគបូព៌ាដែលទម្លាក់អាវុធ និងដកចេញពីកាតព្វកិច្ចប្រដាប់អាវុធកងពល១៦៤"], KH ERN 00714354 ["នៅខាងត្បូងការដ្ឋានវាយថ្ម គឺជាទីតាំងទាហាន "ដែលគេលែងទុកចិត្ត និងដកហូតអាវុធ" នៃកងពល ១៦៤"], KH ERN 00714367, KH ERN 00714375, KH ERN 00714376-77។ សូមមើលផងដែរ ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714355-56 ["សាក្សី សៀង បានបង្ហាញឱ្យអ្នកស៊ើបអង្កេត ក.ស.ច.ស ឃើញក្នុងអំឡុងពេលចុះត្រួតពិនិត្យទីតាំងអង្គភាពមួយក្នុងចំណោមអង្គភាពនានារបស់កងពល ១៦៤ ជាទីកន្លែងដែលទាហានបោះទីតាំងនៅ ដោយផ្ទាល់ ស្ថិតនៅទិសខាងត្បូងជាប់នឹងការដ្ឋានវាយថ្ម និងធ្វើការងារនៅក្នុងទីតាំងនេះ។ អង្គភាពនេះរួមមានអតីតទាហាន ដែលធ្លាប់ត្រូវបានចាប់ខ្លួន និងក្រោយមក ត្រូវគេដោះលែងនៅទីតាំងការដ្ឋាននេះ។ អង្គភាពនេះត្រូវបានដកហូតអាវុធ ព្រមទាំងចាត់ទុកថាជាអង្គភាព "ដែលគេលែងទុកចិត្ត" ដើម្បីជាការបង្ហាញយ៉ាងសាមញ្ញមួយថា អតីតទាហានភូមិភាគបូព៌ាទាំងនេះ ជាអ្នកដែលរួចផុតពីការបោសសម្អាត ប៉ុន្តែ ត្រូវគេដកចេញពីកម្លាំងប្រតិបត្តិការ និងយកទៅធ្វើការ។ សាក្សី សៀន បានពន្យល់បកស្រាយថា មានទាហានចំនួនប្រមាណ ១០០ នាក់ស្ថិតនៅក្នុងទីតាំងនេះ។ គាត់បាននិយាយថា អង្គភាព "ដែលគេលែងមានការជឿជាក់" មួយដែលមានទំហំស្មើនឹងកងអនុសេនាធំ មានទីតាំងស្ថិតនៅត្រង់នោះ។ សាក្សីបន្តពន្យល់បកស្រាយថា ទាហានដែលមានពីអង្គភាពនេះ គឺជាកម្មាភិបាលថ្នាក់ទាបនៃកងពល ១៦៤ (អតីតកងពលធំលេខ ៣)។ បុគ្គលទាំងនេះធ្លាប់ត្រូវបានគេចាប់ខ្លួនកាលពីពេលមុន ហើយបន្ទាប់មកត្រូវគេដោះលែង និងបញ្ជូនទៅកាន់ការដ្ឋានវាយថ្មដើម្បីសែងថ្ម"]។ ឯកសារ D2/23.2 រូបថត EN-KH ERN 00643546។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.24 ["យោធាដែលគេរំសាយចេញពីកងរបស់ខ្ញុំមានប្រហែលជា ២០០ ទៅ ៣០០ នាក់"]។

2353 ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714356 ["នៅក្នុងទីតាំងជំរំមួយផ្សេងទៀត ជាទីតាំងសម្រាប់ "កងអនុសេនាធំបុរសពេញកម្លាំងមួយក្រុមមានចំនួន ៣០០ នាក់" ជាកម្មករបម្រើការងារនៅការដ្ឋានវាយថ្ម/កំពង់ផែស្ទឹងហាវ មានទីតាំងស្ថិតនៅប្រមាណជា ២ គីឡូម៉ែត្រពីការដ្ឋានវាយថ្មនោះ។ នៅត្រង់ទីតាំងនេះជាទីតាំងស្នាក់នៅរបស់កម្មកមកពីភូមិភាគបូព៌ា"]

មានប្រជាជនស៊ីវិលមួយចំនួនតូច ដែលត្រូវបានបញ្ជូនទៅស្ទឹងហាវដើម្បីលត់ដំផងដែរ[2355]។ ទោះបីជាមានតែបុរសធ្វើការនៅការដ្ឋានវាយថ្មក្តី ស្ត្រីក៏បានធ្វើការនៅស្ទឹងហាវផងដែរ រួមទាំងនៅការដ្ឋានសំណង់ផ្លូវ និងកំពង់ផែ[2356]។

---

។ ឯកសារ D54/83.3 ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាល ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ឆ្នាំ ២០០៨-២០១០ KH-EN ERN 00984400។

2354 ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.53 [“សៈ និយាយដល់ការដ្ឋានសំណង់នៅស្ទឹងហាវ តើមានតែយោធាធ្វើការនៅការដ្ឋាននោះ ឬក៏មានកម្លាំងស៊ីវិលខ្លះដែរ ធ្វើការនៅទីនោះ? ឆ.53៖ អត់មានទេ មានតែយោធា”]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.40 [“កន្លែងនៅស្ទឹងហាវនេះមិនមានប្រជាជននៅទីនេះទេ គឺមានសុទ្ធតែទ័ពទាំងអស់”]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.41 [“ពុំមានប្រជាជនធម្មតាធ្វើការនៅស្ទឹងហាវទេ គឺមានតែយោធាប៉ុណ្ណោះ”]។

2355 ឯកសារ D54/33.1 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង អ៊ឹង ឆុន (អ៊ី ឆុន) KH ERN 00964202-03 [“កម្មករទៅហ្នឹងឱ្យទៅធ្វើរោងធ្វើអី ធ្វើរោងវែងៗ ហើយយកទ័ពទៅធ្វើណា គេថាសម្រាប់កម្មករដែលមកធ្វើផ្លូវរទេះភ្លើងហ្នឹងមកស្នាក់។ [...] សៈ កម្មករហ្នឹងមិនមែនទ័ពទេ? ឆៈ មិនមែនកងទ័ពទេ កម្មករ តែខ្មែរយើងហ្នឹង”]។ ឯកសារ D2/7 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សរិន ឆ.17 [“សៈ តើលោកអាចប្រាប់យើងបានទេ មនុស្សដែលធ្វើការនៅកន្លែងរ៉ែថ្ម តើជាអ្នកដែលមានជាប់និន្នាការ ឬជាប្រជាជនធម្មតា ឬជាទាហាន? ឆ.17៖ ភាគច្រើនអ្នកដែលធ្វើការនៅកន្លែងនោះជាយោធារបស់គេ។ ប៉ុន្តែ គេក៏មានប្រើប្រជាជន ១៧ មេសា ផងដែរ ដែលគេហៅអ្នកទាំងអស់នោះថា ឈ្លើយសឹក”]។ សូមមើលផងដែរ ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714351 [“ការដ្ឋានវាយថ្មត្រូវបានបង្កើតឡើងជាការដ្ឋានការងារមួយ សម្រាប់ឱ្យសមាជិកកងពល ១៦៤ និងជនស៊ីវិលប្រើកម្លាំងពលកម្ម”], KH ERN 00714355 [“កម្មករសាងសង់ផ្លូវ គឺជាទាហានកងពលធំលេខ ១៦៤។ នៅមានប្រជាជន ១៧ មេសា ក៏ត្រូវបានគេប្រើនៅក្នុងការសាងសង់ផ្លូវទៅស្ទឹងហាវ និងការដ្ឋានវាយថ្មនានា”]។

2356 ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.9, 40 [“មានអង្គភាពផ្សេងៗទៀតធ្វើការនៅទីនោះដែរ។ ពួកយើងធ្វើការរួមដៃគ្នាជាមួយនឹងពួកបុរសៗនៅការដ្ឋាននោះ។ [...] ឆ.40៖ [...] ខ្ញុំបានប្រាប់លោកពីមុនថា មានកងអនុសេនាធំនារីចំនួនពីរកងធ្វើការនៅទីនោះ។ ដូច្នេះមានគ្នារហូត ២០០ នាក់ហើយ។ បន្ថែមលើនោះទៀត ក៏មានក្រុមបុរសៗធ្វើការនៅទីនោះដែរ។ នៅការដ្ឋានយកថ្ម គឺមានតែបុរសទេ ដែលធ្វើការនៅតីនោះ។ កន្លែងគេខាំថ្មក៏មានតែបុរសដែរ ដែលធ្វើការ។ រីឯនៅកន្លែងដែលគេចាក់ពុម្ពសសរមានទាំងនារី និងបុរសធ្វើការនៅទីនោះ”]។ ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍រវាង ក.ស.ព និង ប៉ែន សារិន EN ERN 00217560 [“ការងារសាងសង់នេះគេប្រើយោធាប្រុសៗ និងកម្មករស្រីៗ។ គ្រប់គ្នាធ្វើការដូចកម្មករ។ ស្រីៗមានចំនួនប្រហែល ៤០-៥០ នាក់ គឺជានារី ១៧ មេសា ចំពោះប្រុសៗវិញគឺមកពីវរសេនាធំ ៤៦០ កងកាំភ្លើងធំ ដែលស្ថិតក្រោមបញ្ជារបស់ នង ឆាន”]។ ឯកសារ D2/7 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សរិន ឆ.12 [“សៈ នៅក្នុងបទសម្ភាសន៍លើកមុន លោកនិយាយថា មានមនុស្សស្រី ៤០ ទៅ ៥០ នាក់ ដែលចូលរួមក្នុងការសាងសង់ផ្លូវនេះ។ ឆ.12៖ បាទ, កម្លាំងនោះមិនមែនធ្វើការជា

604. ក្រៅពីកម្មាភិបាលដែលត្រូវបានបញ្ជូនពីកំណែនទ័ពកម្មាភិបាល ដែលកំពុងបម្រើការនៅកងពល ១៦៤ ក៏ត្រូវបានដាក់ឱ្យឈរជើងនៅស្ទឹងហាវ ដើម្បីបំពេញមុខងារគ្រប់គ្រង និងរក្សាសន្តិសុខ[2357] ។

## ២. រចនាសម្ព័ន្ធអំណាច

605. ការដ្ឋានស្ទឹងហាវបានដំណើរការក្រោមការគ្រប់គ្រងរបស់កងពល ១៦៤[2358]។ សាក្សីជាច្រើនបានអះអាងថា **មាស មុត** បានចុះទៅពិនិត្យការដ្ឋានស្ទឹងហាវ ជាច្រើនលើក ពេលខ្លះជាញឹកញាប់ដល់

---

ប្រចាំទេ គឺគេមកជួយម្តងម្កាលប៉ុណ្ណោះ"]។ សូមមើលផងដែរ ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714355 ["ស្ត្រីត្រូវបានគេប្រើឱ្យធ្វើកិច្ចការសំណង់ផ្លូវថ្នល់"]។

2357 ឯកសារ D2/7 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សរិន ឆ.3 ["សៈ លោកអាចពន្យល់ប្រាប់យើងបានទេ ថាហេតុអ្វីបានជាលោកត្រូវចូលមកក្នុងកងនៅស្ទឹងហាវ? ឆ.3៖ ខ្ញុំសូមឆ្លើយជម្រាបជូន ជាដំបូងក្នុងឆ្នាំ ១៩៧៥ ពេលនោះកងកម្លាំងប៉ុល ពត ទទួលជ័យជម្នះថ្ងៃទី ១៧ ខែ មេសា។ ក្រោយពីការចូលមកដល់ គេបានធ្វើការស្រាវជ្រាវរកមនុស្សមួយចំនួនដែលគេអាចប្រើប្រាស់បាន ដូចជាជាងម៉ាស៊ីន ខាងជាងផ្សា ដោយពួកគេទុកឱ្យនៅក្នុងជួរកងទ័ព។ [...] ខ្ញុំមិនបានទៅណាទេ ដោយសារខ្ញុំមានសមត្ថភាពចេះធ្វើការខាងផ្នែកម៉ាស៊ីនបម្រើពួកគេ"]។

2358 ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.32 ["ស្ទឹងហាវស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពល ១៦៤"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញិក ឆ.33 ["ជាទូទៅ កន្លែងទាំងអស់នៅស្ទឹងហាវ គឺស្ថិតនៅក្រោមកងពល ១៦៤"]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.10 ["ក្រោយមកគេក៏បញ្ជូនខ្ញុំទៅស្ទឹងហាវ [...] អ្នកដែលធ្វើការសែងថ្មនៅភ្នំនោះ គឺមកពីកងពល ១៦៤ ហើយអ្នកគ្រប់គ្រងក៏ជាអ្នកមកពីកងពល ១៦៤ ដែរ"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.13-14 ["សៈ នៅស្ទឹងហាវ តើលោកស្រីធ្វើការក្រោមបញ្ជារបស់អ្នកណាខ្លះ? ឆ.13៖ ស្ទឹងហាវគឺស្ថិតក្រោមការគ្រប់គ្រងរបស់កងពល ១៦៤ [...]។ សៈ តើលោកស្រីអាចពន្យល់ប្រាប់យើងបន្ថែម អំពីកងវរសេនាតូចរបស់លោកស្រីបានដែរឬទេ? ឆ.14៖ ពួកយើងគឺធ្វើការផ្ទាល់ក្រោមបញ្ជាការរបស់កងពលធំ ១៦៤"]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.22 ["សៈ តើតំបន់ស្ទឹងហាវស្ថិតក្រោមបញ្ជារបស់កងពល ១៦៤ មែនឬទេ? ឆ.22៖ បាទ ត្រឹមត្រូវហើយ"]។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.161 ["សៈ បានន័យថា ទាល់តែមកដល់ស្ទឹងហើយបានលោកដឹងថាខ្លួនលោកស្ថិតនៅក្រោមកងពល ១៦៤ អ៊ីចឹងមែនទេ? ឆ.161៖ តាមពិតទៅ ខ្ញុំនៅកងពលលេខ ៣ ប៉ុន្តែ ពេលខ្ញុំត្រូវបានគេឱ្យមកធ្វើការនៅស្ទឹងហាវ គេបង្កើតកងពលថ្មីមួយហៅថា កងពល១៦៤ ជាកងទ័ពជើងទឹក"]។ ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.16 ["តំបន់គ្រប់គ្រងរបស់កងពល ១៦៤ មានព្រំដែនខាងកើតនៅចំទឹកសាប ខាងជើងនៅស្ទឹងហាវ"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.30 ["សៈ តើមានអង្គភាពណាមួយដែលទទួលខុសត្រូវនៅកន្លែងលត់ដំស្ទឹងហាវ? ឆ.30៖ មានអង្គភាពមួយ ប៉ុនចង់ភ្លេចវរសេនាតូចហ្នឹង

ថ្នាក់មួយសប្តាហ៍ម្តង[2359] ដែលនៅទីនោះ គាត់បានជួបជាមួយទីប្រឹក្សាចិនដើម្បីចុះមើលផ្លូវ ផែកំពង់ផែ ការដ្ឋានវាយថ្ម និងកន្លែងយកថ្ម[2360]។ ប្អូនប្រុសរបស់ **មាស មុត** មាស អ៊ឹម ដែលបានធ្វើ

---

ហើយ ព្រោះមានគេដាក់យោធាកងពិសេសនៅលើខ្ញុំ។ កងវរសេនាតូចតែចំណុះកងពល ១៦៤"]។ ឯកសារ D114/48 កំណត់ហេតុស្តាប់ចម្លើយ សុខ ង៉ុន ឆ.34 ["សៈ តើយោធាកងណាដែលធ្វើការនៅស្ទឹងហាវ? ឆ.34៖ ខ្ញុំមិនដឹងកងណាទេ តែកងនោះស្ថិតនៅក្រោមកងពល ១៦៤។ នៅក្នុងកងពល ១៦៤ មានកងជើងគោក និងកងជើងទឹក"]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន យ៉ើ ឆ.77 ["អង្គភាពផលិតនេះវានៅក្រោមការគ្រប់គ្រងកងពល ១៦៤"]។ ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ សៀង EN ERN 00217566 ["មានការដ្ឋានយកថ្មនៅស្ទឹងហាវ ដែលគ្រប់គ្រងដោយកងពល ១៦៤"]។ សូមមើលផងដែរ ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714347-48 ["កងពល ១៦៤ បានគ្រប់គ្រងការដ្ឋានការងារដោយបង្ខំឱ្យវាយថ្មមួយកន្លែងនៅជិតស្ទឹងហាវ [...] ទីតាំងទាំងនេះត្រូវបានកងពល ១៦៤ (អតីតកងពលលេខ ៣) បង្កើតឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ"]។ ឯកសារ D54/9 កំណត់ហេតុស្តាប់ចម្លើយ មិន ផុន ឆ.5 ["នៅស្ទឹងហាវ កងអនុសេនាធំរបស់ខ្ញុំ ត្រូវបានដាក់បញ្ចូលទៅក្រោមបញ្ជាកងវរសេនាតូចរបស់វរសេនាធំ ៦១ នៃកងពល ១៦៤"]។ ឯកសារ D54/30.1 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង ស៊ឹម នី KH ERN 00964124 ["ស្ទឹងហាវ អាហ្នឹងកន្លែងពួបូ ហ្នឹងឯង គាត់នៅស្ទឹងហាវ ស្ទឹងហាវហ្នឹងវាមអត់មាននាវាអីមកទេ មានមកដូចជា កប៉ាល់នេសាទ ឬក៏ថ្មើជើងដែលមកនៅស្ទឹងហាវ"]។

2359 ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.12, 39, 43, 64 ["សៈ តើ មាស មុត បានទៅធ្វើទស្សនកិច្ចនៅទីតាំងសំណង់ស្ទឹងហាវញឹកញាប់ប៉ុនណាដែរ? ឆ.12៖ ធម្មតា មាស មុត ១អាទិត្យមកជួបភ្ញៀវចិននៅការដ្ឋានស្ទឹងហាវម្តង។ [...] ឆ.39៖ ដើមឆ្នាំ៧៧ បានជួប ដូចខ្ញុំកំណត់អីចឹង នៅស្ទឹងហាវ គាត់មក១អាទិត្យម្តង តែដល់ពាក់កណ្តាលឆ្នាំ ៧៧ ដល់ចុង ៧៧ និងឆ្នាំ ៧៨ អត់ដែលជួបទេ។ [...] ឆ.43៖ កាលខ្ញុំធ្វើការនៅស្ទឹងហាវ ខ្ញុំបានជួប ១អាទិត្យម្តង ពេលគាត់មកជួបេះជាមួយភ្ញៀវចិន។ [...] សៈ តើលោក មាស មុត ចាប់ផ្តើមទៅធ្វើទស្សនកិច្ចនៅការដ្ឋាននេះ នៅពាក់កណ្តាលឆ្នាំ ១៩៧៦ ដែរ មែនទេ? ឆ.64៖ មែន"]។ ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍រវាង ក.ស.ព និង ប៉ែន សារិន EN ERN 00217560 ["មាស មុត មកទស្សនកិច្ចច្រើនដង ហើយពេលដែលគាត់ដេកនៅស្ទឹងហាវ គាត់ដេកនៅកន្លែងអ្នកបច្ចេកទេសចិន នៅអគារមួយនៅប៉ែកខាងជើង នៃទីតាំងមន្ទីរស្រុកសព្វថ្ងៃ"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.52-57 ["សៈ តើលោកធ្លាប់ឃើញថ្នាក់ដឹកនាំធំរបស់កងពល ១៦៤ មកមើលកន្លែងធ្វើការនៅស្ទឹងហាវ ឬក៏រៀបប្រជុំដែរឬទេ? ឆ.52៖ ខ្ញុំធ្លាប់ឃើញ តា មុត ជិះឡានមកមើលតាមកន្លែងធ្វើការនៅស្ទឹងហាវ តែគាត់មិនដែលឈប់ និងចេញពីឡានទេ។ សៈ ហេតុដូចម្តេចបានជាលោកដឹងថា មាស មុត នៅក្នុងឡាន? ឆ.53៖ ពីព្រោះឡានហ្ស៊ីពអាឌី មិនមានទ្វារ និងកញ្ចក់ទេ។ នៅពេលនោះ មិនមានឡានហ្ស៊ីពអាឌីច្រើនទេ មានតែឡានហ្ស៊ីពមួយគ្រឿងរបស់កងពល។ សៈ តើលោកអាចមើលឃើញមុខ មាស មុត ស្គាល់ដែរឬទេ? ឆ.54៖ ពីព្រោះខ្ញុំឃើញគាត់ញឹកញាប់ជិះឡានហ្ស៊ីព ដូច្នេះ ខ្ញុំអាចមើលមុខគាត់ច្បាស់។ សៈ តើ មាស មុត មកស្ទឹងហាវញឹកញាប់ប៉ុនណា? ឆ.55៖ គាត់មកប្រហែល២អាទិត្យម្តង។ សៈ ពេលលោកនៅស្ទឹងហាវ ហើយឃើញ មាស មុត ជិះឡាន តើលោកនៅកន្លែងណា? ឆ.56៖ ខ្ញុំឃើញគាត់ពីការដ្ឋានវាយថ្មរបស់ខ្ញុំ។ នៅពេលនោះ គេមិន

អនុញ្ញាតឱ្យនរណាម្នាក់ត្រូវដើរចេញពីការដ្ឋានរបស់ខ្លួនទេ។ សៈ តើចម្ងាយពីការដ្ឋានវាយថ្មរបស់លោកធ្វើការទៅផ្លូវដែល មាស មុត បើកឡានមានចម្ងាយប៉ុន្មាន? ឆ.57៖ មានចម្ងាយប្រហែលជា ៣០ ទៅ ៤០ ម៉ែត្រ"]។ ឯកសារ D114/146 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.52-53 ["នៅពេលនោះ យើងវាយថ្ម យកទៅធ្វើជាផែទាហាន។ ហើយពេលនោះ តា មុត ជិះឡានហ្ស៊ីពអាឌី ទៅមើលកន្លែងធ្វើការជាញឹកញាប់។ សៈ ពេលដែលលោកនិយាយថា តា មុត តើលោកចង់មានន័យថា មាស មុត ឬយ៉ាងណា? ឆ.53៖ បាទ តា មុត គឺ មាស មុត"]។ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.26 ["សៈ តើលោកធ្លាប់ឃើញ មាស មុត មកទស្សនកិច្ចនៅផែស្ទឹងហាវ ឬការដ្ឋានស្ទឹងហាវ ដែលកាលនោះលោកនៅមេវរសេនាតូច ៦១២ ដែរឬទេ? ឆ.26៖ បាទ, ខ្ញុំបានឃើញគាត់នៅពេលគេទៅសម្ពោធបើកការដ្ឋាន ឬពេលពួកចិនមកធ្វើទស្សនកិច្ចម្តងៗ ក៏ខ្ញុំឃើញគាត់ដែរ។ គេលែងឱ្យខ្ញុំទៅជិតហើយដោយសារគេលែងទុកចិត្តខ្ញុំ"]។ សូមមើលផងដែរ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.25 ["ប៉ុន្តែ ខ្ញុំធ្លាប់ឮថា គាត់ធ្លាប់ទៅពិនិត្យការងារនៅទីនោះ មុនពេលដែលខ្ញុំទៅធ្វើការនៅទីនោះ"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.55 ["សៈ តើ មាស មុត មកស្ទឹងហាវញឹកញាប់ប៉ុនណា? ឆ.55៖ គាត់មកប្រហែល២អាទិត្យម្តង"]។

2360 ឯកសារ D114/146 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.52-53 ["នៅពេលនោះ យើងវាយថ្ម យកទៅធ្វើជាផែទាហាន។ ហើយពេលនោះ តា មុត ជិះឡានហ្ស៊ីពអាឌី ទៅមើលកន្លែងធ្វើការជាញឹកញាប់។ សៈ ពេលដែលលោកនិយាយថា តា មុត តើលោកចង់មានន័យថា មាស មុត ឬយ៉ាងណា? ឆ.53៖ បាទ តាមុត គឺ មាស មុត"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.52-57 ["សៈ តើលោកធ្លាប់ឃើញថ្នាក់ដឹកនាំធំរបស់កងពល ១៦៤ មកមើលកន្លែងធ្វើការនៅស្ទឹងហាវ ឬក៏រៀបប្រជុំដែរឬទេ? ឆ.52៖ ខ្ញុំធ្លាប់ឃើញ តា មុត ជិះឡានមកមើលតាមកន្លែងធ្វើការនៅស្ទឹងហាវ តែគាត់មិនដែលឈប់ និងចេញពីឡានទេ។ សៈ ហេតុដូចម្តេចបានជាលោកដឹងថា មាស មុត នៅក្នុងឡាន? ឆ.53៖ ពីព្រោះឡានហ្ស៊ីពអាឌី មិនមានទ្វារ និងកញ្ចក់ទេ។ នៅពេលនោះ មិនមានឡានហ្ស៊ីពអាឌីច្រើនទេ មានតែឡានហ្ស៊ីពមួយគ្រឿងរបស់កងពល។ សៈ តើលោកអាចមើលឃើញមុខ មាស មុត ស្គាល់ដែរឬទេ? ឆ.54៖ ពីព្រោះខ្ញុំឃើញគាត់ញឹកញាប់ជិះឡានហ្ស៊ីព ដូច្នេះ ខ្ញុំអាចមើលមុខគាត់ច្បាស់។ សៈ តើ មាស មុត មកស្ទឹងហាវញឹកញាប់ប៉ុនណា? ឆ.55៖ គាត់មកប្រហែល២អាទិត្យម្តង។ សៈ ពេលលោកនៅស្ទឹងហាវ ហើយឃើញ មាស មុត ជិះឡាន តើលោកនៅកន្លែងណា? ឆ.56៖ ខ្ញុំឃើញគាត់ពីការដ្ឋានវាយថ្មរបស់ខ្ញុំ។ នៅពេលនោះ គេមិនអនុញ្ញាតឱ្យនរណាម្នាក់ត្រូវដើរចេញពីការដ្ឋានរបស់ខ្លួនទេ។ សៈ តើចម្ងាយពីការដ្ឋានវាយថ្មរបស់លោកធ្វើការទៅផ្លូវ ដែល មាស មុត បើកឡាន មានចម្ងាយប៉ុន្មាន? ឆ.57៖ មានចម្ងាយប្រហែលជា ៣០ ទៅ ៤០ ម៉ែត្រ"]។ ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.12, 39, 43 ["សៈ តើ មាស មុត បានទៅធ្វើទស្សនកិច្ចនៅទីតាំងសំណង់ស្ទឹងហាវញឹកញាប់ប៉ុនណាដែរ? ឆ.12៖ ធម្មតា មាស មុត ១អាទិត្យមកជួបភ្ញៀវចិននៅការដ្ឋានស្ទឹងហាវម្តង។ [...] ឆ.39 ៖ ដើមឆ្នាំ ៧៧ បានជួប ដូចខ្ញុំកំណត់អ៊ីចឹង នៅស្ទឹងហាវ គាត់មក១អាទិត្យម្តង តែដល់ពាក់កណ្តាលឆ្នាំ ៧៧ ដល់ចុង ៧៧ និងឆ្នាំ ៧៨ អត់ដែលជួបទេ។ [...] ឆ.43៖ កាលខ្ញុំធ្វើការនៅស្ទឹងហាវ ខ្ញុំបានជួប១អាទិត្យម្តង ពេលគាត់មកជួបេះជាមួយភ្ញៀវចិន"]។ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.26 ["សៈ តើលោកធ្លាប់ឃើញ មាស មុត មកទស្សនកិច្ចនៅផែស្ទឹងហាវ ឬការដ្ឋានស្ទឹងហាវ ដែលកាលនោះលោកនៅមេវរសេនាតូច ៦១២

ការនៅការដ្ឋាននោះ បានប្រាប់អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ថា **មាស មុត** បានចុះទៅពិនិត្យការដ្ឋានស្ទឹងហាវយ៉ាងជាប់លាប់ ចាប់ពីយ៉ាងហោចណាស់ពាក់កណ្តាលឆ្នាំ ១៩៧៦[2361] រហូតដល់ **មាស មុត** បានផ្លាស់ទៅភ្នំពេញ និងភូមិភាគបូព៌ា[2362]។ **មាស មុត** ក៏នឹងស្នាក់នៅស្ទឹងហាវមួយយប់ម្តងម្កាលផងដែរ នៅពេលដែលគាត់ទៅចុះពិនិត្យនោះ[2363]។

606. **មាស មុត** បានរៀបចំការប្រជុំនៅស្ទឹងហាវ នៅពេលដែលគាត់នៅទីនោះ[2364]។ នៅពាក់កណ្តាលឆ្នាំ ១៩៧៧ **មាស មុត** បានរៀបចំការប្រជុំនៅទីតាំងមួយប្រមាណជាពីរគីឡូម៉ែត្រពីកំពង់ផែ[2365] ដើម្បីបង្ហាញគោលនយោបាយបក្សដល់កម្មាភិបាល។ នៅក្នុងការប្រជុំនោះ គាត់បានប្រកាសពីអត្ថិភាពនៃបក្សកុម្មុយនីស្តកម្ពុជា[2366] និង "បាននិយាយអំពីជនទាំងឡាយណាដែលក្បត់

---

ដែរឬទេ? ឆ.26៖ បាទ, ខ្ញុំបានឃើញគាត់នៅពេលគេទៅសម្ពោធបើកការដ្ឋាន ឬពេលពួកចិនមកធ្វើទស្សនកិច្ចម្តងៗ ក៏ខ្ញុំឃើញគាត់ដែរ។ គេលែងឲ្យខ្ញុំទៅជិតហើយ ដោយសារគេលែងទុកចិត្តខ្ញុំ"]។

2361 ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.64 ["សៈ តើលោក មាស មុត ចាប់ផ្តើមទៅធ្វើទស្សនកិច្ចនៅការដ្ឋាននោះ នៅពាក់កណ្តាលឆ្នាំ ១៩៧៦ មែនទេ? ឆ.64៖ មែន"]។

2362 ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.16, 25 ["គេបញ្ជូនខ្ញុំទៅធ្វើការនៅទីនោះនៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៧៨។ [...] សៈ តើលោកដែលឃើញ មាស មុត មេបញ្ជាការកងពល ១៦៤ ទៅស្ទឹងហាវដែរឬទេ? ឆ.25៖ ខ្ញុំមិនដែលឃើញគាត់ទេ ប៉ុន្តែ ធ្លាប់ឮថា គាត់ធ្លាប់ទៅពិនិត្យការងារនៅទីនោះ មុនពេលដែលខ្ញុំទៅធ្វើការនៅទីនោះ"]។

2363 ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍រវាង ក.ស.ព និង ប៉ែន សារិន EN ERN 00217560 ["មាស មុត មកទស្សនកិច្ចច្រើនដង ហើយពេលដែលគាត់ដេកនៅស្ទឹងហាវ គាត់ដេកនៅកន្លែងអ្នកបច្ចេកទេសចិន នៅអគារមួយនៅប៉ែកខាងជើងនៃទីតាំងមន្ទីរស្រុកសព្វថ្ងៃ។ គម្រោងនេះមានអ្នកបច្ចេកទេសចិនចំនួនប្រហែល ៤២ នាក់ធ្វើការ"]។

2364 ឯកសារ D114/60 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង អំពីការដ្ឋានធ្វើការងារដោយបង្ខំនៅផែយោធាស្ទឹងហាវ EN ERN 01082176, 0108217679 ["មានមូលដ្ឋានយោធាក្បែរការដ្ឋានរ៉ែថ្មស្ទឹងហាវ និងផែធំ (ខាងកើតផែ ក្បែរមាត់សមុទ្រ) ជាកន្លែងដែលមានកិច្ចប្រជុំមួយដឹកនាំដោយ មាស មុត នៅពាក់កណ្តាលឆ្នាំ ១៩៧៧"]។

2365 ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.17 ["កន្លែងប្រជុំគឺចិតនៅទួលខ្ពស់ ហើយផែនៅកន្លែងទំនាប។ យើងអាចមើលឃើញផែថ្មនោះពីកន្លែងប្រជុំ ព្រោះវាចិតនៅចម្ងាយប្រហែល ២ គីឡូម៉ែត្រប៉ុណ្ណោះ"]។

2366 ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.23, 25 ["នៅពាក់កណ្តាលឆ្នាំ ១៩៧៧ តា មុត បានមកបើកកិច្ចប្រជុំមួយដោយប្រកាសថា មានបក្សកុម្មុយនីស្ត។ [...] សៈ លោកបាននិយាយថា តា មុត បានបើកប្រជុំនៅពាក់កណ្តាលឆ្នាំ ១៩៧៧ តើកិច្ចប្រជុំធ្វើនៅកន្លែងណា? ឆ.25៖ បាទ ការប្រជុំនេះគឺធ្វើនៅអង្គភាពយោធានៅស្ទឹងហាវ នៅពេលនោះគេបានប្រកាសមិនឲ្យអ្នកណាម្នាក់យកកាំភ្លើងទៅទីនោះទេ មានតែកងការពាររបស់ តា មុត ប្អូនប្រាំនាក់តែប៉ុណ្ណោះបានអនុញ្ញាតឲ្យកាន់កាំភ្លើង"]។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.1 ["ខ្ញុំមិនចាំខែណាច្បាស់លាស់ទេ តែខ្ញុំបានដឹងថានៅពាក់កណ្តាលឆ្នាំ ១៩៧៧"]។

នឹងបក្ស ហើយគាត់បាននិយាយថា អ្នកណាដែលត្រូវបានចោទប្រកាន់ពីបទក្បត់ ដាច់ខាតត្រូវតែប្រមូលដាក់មួយកន្លែង*”*[2367]។ នៅក្នុងសុន្ទរកថារបស់គាត់ **មាស មុត** បានចោទប្រកាន់ទាហាននៃកងពល ១៦៤ ជាពិសេសថាជា *“*ជនក្បត់*”* រួមទាំង នង ឆន ហៅ ឆាន និង ហង់ ឌឿន ហៅ ឌីម ផងដែរ[2368]។ **មាស មុត** បាននិយាយរយៈពេល ២-៣ ម៉ោង ហើយគាត់គឺជាអ្នកនិយាយតែម្នាក់គត់[2369]។

607. *ស្ទឹងហាវត្រូវបានលើកមកពិភាក្សាក្នុងការប្រជុំរបស់កងពល ១៦៤*[2370]។ កំណត់ហេតុប្រជុំដែលនៅសេសសល់បង្ហាញថា ទាក់ទងទៅនឹងស្ទឹងហាវ **មាស មុត** ត្រូវជូនដំណឹងអំពីបញ្ហាទាក់ទងនឹងការកំណត់គោលដៅ “មនុស្សអាក្រក់” ការចាប់ខ្លួនអ្នកដែលប៉ុនប៉ងរត់គេច ការចាត់ថ្នាក់អ្នកដែលជា “ខ្មាំង” ការប្រើប្រាស់ “ប្រវត្តិរូប” ដើម្បីកំណត់ថា នរណាគឺជាខ្មាំង ដើម្បីចាប់ខ្លួន និងសួរចម្លើយខ្មាំង ដើម្បីកំណត់ថា ខ្មាំងដែលជា “សមាសភាពទាហានត្រូវតែប្រមូលផ្ដុំ” និងអំពីពាក្យត្អូញត្អែររបស់ពលករដែលថា លក្ខខណ្ឌនៅស្ទឹងហាវយ៉ាប់យ៉ឺនខ្លាំងណាស់ “យើងទាំងអស់គ្នានឹងស្លាប់មិនខាន”[2371]។

608. មាស អ៊ីម បានធ្វើការនៅក្នុងកងសាងសង់ស្ទឹងហាវ។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់គាត់ គាត់បាននិយាយថា មេកងរបស់គាត់ គឺ លេខាធិការកងវរសេនាធំ អៀក ម៉ាញ់[2372] ដែលបាន

---

[2367] ឯកសារ D54/12 កំណត់ហេតុស្ដាប់ចម្លើយ ប្រេស មាន ឆ.28។

[2368] ឯកសារ D54/12 កំណត់ហេតុស្ដាប់ចម្លើយ ប្រេស មាន ឆ.30 [“បាទ គាត់បានប្រកាសថា តា ញឹក ជាលេខាតំបន់ ៣៧ តា ប៉ុន នៅក្នុងគណៈតំបន់ ៣៧ និង ឆាន នៅក្នុងគណៈតំបន់ ៣៧ ដែរ តែខ្ញុំមិនដឹងថាតួនាទីអ្នកទាំងពីរនេះឲ្យច្បាស់ទេ ហើយ ឌីម ជាអនុរបស់ តា មុត នៃកងពល ១៦៤”]។

[2369] ឯកសារ D54/13 កំណត់ហេតុស្ដាប់ចម្លើយ ប្រេស មាន ឆ.10-11 [“សៈ តើការប្រជុំនោះមានរយៈពេលប៉ុន្មានម៉ោង? ឆ.10៖ ការប្រជុំនោះមានរយៈពេលប្រហែលជា ២ ទៅ ៣ ម៉ោង។ សៈ តើមានតែ តា មុត ម្នាក់ដែលនិយាយក្នុងអង្គប្រជុំ ឬក៏មានកម្មាភិបាលផ្សេងទៀតនិយាយដែរ? ឆ.11៖ មានតែ តា មុត ម្នាក់គត់”]។

[2370] ឯកសារD1.3.8.4 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំសមមិត្ត១៦៤ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00162488-90។

[2371] ឯកសារD1.3.8.4 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00162489-90។

[2372] សរសេរជា អៀក មៀញ ផងដែរ។

រាយការណ៍ទៅកាន់បងប្រុសរបស់ មាស អ៊ឹម គឺ **មាស មុត**[2373]។ **មាស មុត** បានចេញបញ្ជាទៅ មាស អ៊ឹម តាមរយៈ ម៉ាញ់[2374]។ អៀក ម៉ាញ់ មានទូរស័ព្ទ និងម៉ាស៊ីនទូរលេខនៅក្នុងផ្ទះរបស់គាត់ នៅស្ទឹងហាវ ដើម្បីសម្រួលដល់ការទាក់ទងជាមួយ **មាស មុត** ហើយថា ម៉ាស៊ីននោះត្រូវបានប្រើ ដើម្បីទទួលបញ្ជាពីគាត់[2375]។ បញ្ជារបស់ **មាស មុត** រួមទាំងការណែនាំឱ្យសាងសង់ផ្លូវទៅកាន់ រោងចក្រចម្រាញ់ប្រេង និងទៅកាន់ផែ និងឱ្យឈូសឆាយដីឱ្យស្មើ "ពីជើងភ្នំរហូតដល់ឆ្នេរស្ទឹង

---

2373 ឯកសារ D114/214 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.30, 32-33 ["ស៖ តើមេអង្គភាពសំណង់ ដែលលោកធ្វើការនោះមានឈ្មោះអ្វីដែរ? ឆ.30៖ មៀញ។ [...] ស៖ តើឈ្មោះ មៀញ ត្រូវរាយការណ៍ជូនដល់ថ្នាក់លើគាត់ឈ្មោះអ្វីដែរ? ឆ.32៖ ឈ្មោះ មៀញ រាយការណ៍ទៅ មាស មុត ហ្នឹង។ ស៖ តើគាត់រាយការណ៍ទៅ មាស មុត ដោយផ្ទាល់តែម្តង? ឆ.33៖ បាទ ផ្ទាល់"]។ ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.4, 6, 66, 77-79 ["ឈ្មោះ មៀញ នេះតួនាទីរបស់គាត់ជាមេបញ្ជាការវរសេនាធំ។ [...] ស៖ យោងទៅតាមឯកសាររបស់យើង គឺមានតែឈ្មោះ មៀញ ម្នាក់ទេក្នុងកងពល១៦៤ ដែលមានឈ្មោះពេញ អៀក មៀញ ហើយគាត់គឺជាមេកងវរសេនាធំ ៦២ ក្រោមកងពល ១៦៤។ តើយើងកំពុងនិយាយអំពីឈ្មោះមនុស្សតែមួយមែនទេ? ឆ.6៖ មួយតែមួយទេ។ [...] ស៖ ពាក់ព័ន្ធនឹងការងារនៅការដ្ឋាន តើឈ្មោះ មៀញ នេះធ្លាប់ទទួលការណែនាំពីណាមកវិញដែរ? ឆ.66៖ ពីមុនមក គាត់ទទួលបញ្ជាផ្ទាល់ពី មាស មុត ហ្នឹង។ [...] ស៖ តើ មៀញ ស្នាក់នៅ និងធ្វើការនៅត្រង់ចំណុចណាដែរ? ឆ.77៖ ស្ទឹងហាវ នៅក្បែរស្ទឹង ផ្ទះគាត់ធ្វើនៅក្បែរស្ទឹង ហើយឃ្លាតពីស្ទឹងប្រហែល១០០ ម៉ែត្រ។ ស៖ ជិតស្ពាន ដែលជាកន្លែងផ្លូវទេះភ្លើងហ្នឹងឬ? ឆ.78៖ កន្លែងហ្នឹង គេហៅព្រែករលួស ខាងលើផ្លូវរទេះភ្លើង ខាងកើតផ្លូវរទេះភ្លើង។ ខ្ញុំបញ្ជាក់បន្តិច ផ្លូវរទេះភ្លើង វាកោងត្រង់ហ្នឹង កន្លែងនៅហ្នឹង គឺនៅខាងកើតហើយ។ ស៖ តើលោកអាចបង្ហាញទីតាំងនេះ នៅលើផែនទីដែលខ្ញុំបង្ហាញនេះបានដែរឬទេ? តើលោកអាចគូសបង្ហាញប្រាប់យើងអំពីទីតាំងការដ្ឋាននានា ដែលយើងបាននិយាយគ្នាមុននេះបានទេ? ឆ.79៖ កន្លែងផ្ទះ មៀញ គឺនៅចម្ងាយប្រហែល ១០០ ម៉ែត្រពីព្រែក ចំណែកកន្លែងខ្ញុំនៅ គឺមានចម្ងាយប្រហែល ១០០ ម៉ែត្រពីផ្ទះ មៀញ។ ចំពោះកន្លែងផ្សេងៗទៀត ខ្ញុំមិនចាំ ហើយក៏មិនអាចរកឃើញដែរ"]។ សូមមើលផងដែរ ឯកសារ D114/215.3 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាល ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ឆ្នាំ ២០០៨-២០១០ KH ERN 01301427។

2374 ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.70, 75, 76 ["ស៖ តើការងារបច្ចេកទេសអ្វីខ្លះ ពាក់ព័ន្ធនឹងការងារលោក ដែលបងប្រុសលោកផ្តល់មកខាងលោក តាមរយៈលោក មៀញ នោះ? ឆ.70៖ ការងារបច្ចេកទេសទី ១ ធ្វើផ្លូវ។ ផ្លូវធ្វើពីរោងចក្រប្រេងកាតមកដល់ស្ទឹងហាវ។ ទី២ ធ្វើអាផ្លូវចុះឡើងក្នុងការដ្ឋានស្ទឹងហាវហ្នឹង ហើយនិងឈូសពីជើងភ្នំនៅមាត់សមុទ្រស្ទឹងហាវហ្នឹងឱ្យទៅជារាបស្មើ។ [...] ស៖ តើបងប្រុសលោកប្រាស្រ័យទាក់ទងគ្នាជាមួយឈ្មោះ មៀញ ដោយមធ្យោបាយអ្វីដែរ? ឆ.75៖ ដោយមធ្យោបាយតេអូ ហើយនិងទូរលេខ។ ស៖ ហេតុអ្វីបានលោកដឹង? ឆ.76៖ បើនៅផ្ទះ មៀញ ហ្នឹងខ្ញុំនៅជិតហ្នឹងដែរ ហើយឃើញប្រដាប់ប្រដាហ្នឹង"]។

2375 ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.75-76 ["ស៖ តើបងប្រុសលោកប្រាស្រ័យទាក់ទងគ្នាជាមួយឈ្មោះ មៀញ ដោយមធ្យោបាយអ្វីដែរ? ឆ.75៖ ដោយមធ្យោបាយតេអូ ហើយនិងទូរលេខ។ ស៖ ហេតុអ្វីបានលោកដឹង? ឆ.76៖ បើនៅផ្ទះ មៀញ ហ្នឹងខ្ញុំនៅជិតហ្នឹងដែរ ហើយឃើញប្រដាប់ប្រដាហ្នឹង"]។

ហារ"[2376]។ បន្ថែមពីលើការធ្វើដំណើរដោយខ្លួនឯងទៅកាន់ស្ទឹងហារ **មាស មុត** បានទទួលទូរលេខទាក់ទងនឹងបញ្ហានៅស្ទឹងហារ[2377]។ នៅមុនការចាប់ខ្លួនរបស់ពួកគេ នាយរងរបស់ **មាស មុត** ទាំងពីរ គឺ ឌឹម និង ឆាន មានការទទួលខុសត្រូវមួយចំនួនលើស្ទឹងហារ[2378] ហើយពួកគេ និងអ្នកផ្សេងទៀតនឹងរៀបចំការប្រជុំនៅទីនោះ ដែលនៅពេលប្រជុំនោះ គេបានសង្កត់ធ្ងន់ឲ្យអ្នករាល់គ្នាប្រឹងប្រែងធ្វើការ[2379]។

---

2376 ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.70 ["ការងារបច្ចេកទេសទី១ ធ្វើផ្លូវ។ ផ្លូវធ្វើពីរោងចក្រប្រេងកាតមកដល់ស្ទឹងហារ។ ទី២ ធ្វើអាផ្លូវចុះឡើងក្នុងការដ្ឋានស្ទឹងហារហ្នឹង ហើយនិងឈ្លូសពីជើងភ្នំទៅមាត់សមុទ្រស្ទឹងហារហ្នឹងឲ្យទៅជារាបស្មើ"]។

2377 ឯកសារ D4.1.699 ទូរលេខ ១១ ពី ឌឹម ជូនបង មុត ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00092628 ["ពីរនាក់ទៀតរត់អង្គភាពពីសង្ហារ យុទ្ធជននេះនឹងដូរពីកង ៦៣"]។

2378 ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍រវាង ក.ស.ព និង ប៉ែន សារិន EN ERN 00217562 ["អនុប្រធានរបស់ មាស មុត គឺ ឌឹម និង នង ឆាន។ ក្នុងឆ្នាំ ១៩៧៦ នង ឆាន ជាអ្នកគ្រប់គ្រងតំបន់ស្ទឹងហារ"]។ ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀង ភង់ ឆ.22, 24 ["តា ឆាន គាត់ទៅប្រជុំទៅណែនាំ គាត់ថា បើកន្លែងគាតមានបញ្ហាផ្ទុះអាវុធ គាត់សួរថា ពួកយើងជួយគាត់អត់។ [...] សៈ តើគាត់បង្ហាត់អ្វីដល់លោក? ឆ.23៖ គាត់បង្រៀនគាត់ពន្យល់ ធ្វើការងារវ៉ៃថ្មវ៉ៃអី។ ដល់ពេលគាត់សួរវិញ គាត់សួរអ៊ីចឹង។ សៈ តើនេះនៅស្ទឹងហារឬ? ឆ.24៖ បាទ"]។ ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ សៀង EN ERN 00217564 ["អនុទី១របស់មុត គឺ ឌឹម មកពីភូមិភាគបូព៌ា"]។ ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.63 ["ខ្ញុំដឹងតែត្រឹមលោក ឌឹម យកខ្ញុំទៅធ្វើការនៅនុំងទេ ក្រៅពីហ្នឹងទៀត ខ្ញុំមិនដឹងទេ"]។ ឯកសារ D4.1.699 ទូរលេខ ១១ ពី ឌឹម ជូនបង មុត ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00092628 ["ពីរនាក់ទៀតរត់អង្គភាពពីសង្ហារ យុទ្ធជននេះនឹងដូរពីកង ៦៣"]។

2379 ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀង ភង់ ឆ.87-88 ["សៈ លោកនិយាយពីការប្រជុំជាមួយតាឆានក្រោយមកមានប្រជុំថា តា ឆាន ក្បត់។ តើនៅស្ទឹងហារមានការប្រជុំញឹកញាប់ទេ? ឆ.87៖ មានប្រជុំពីរដងហ្នឹងទេ តែក្រោយពីហ្នឹង អត់មានការប្រជុំទៀតទេ។ សៈ អ្នកណាជាអ្នកចាត់ចែងកិច្ចប្រជុំទាំងពីរនោះ? ឆ.88៖ កងខ្ញុំនៅកន្លែងនេះអ៊ីចឹងទៅ តា ឆាន មកគាត់ក៏បើកប្រជុំទៅ។ ហើយពេលក្រោយមក តា ឆាន មិនបានមក គឺ តា ឌឹម ជាអ្នកបើកកិច្ចប្រជុំ"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.46 ["ក្នុងការប្រជុំទាំងនោះ គេនិយាយតែការខិតខំប្រឹងប្រែងធ្វើការងារ"]។

609. យ៉ាងហោចណាស់ មួយផ្នែកនៃកងវរសេនាធំ ៦១ នៃកងពល ១៦៤ ត្រូវបានដាក់ឱ្យឈរជើងនៅស្ទឹងហាវក្នុងរយៈពេលមួយ[2380]។ សាក្សីម្នាក់បាននិយាយថា កងវរសេនាតូចមួយនៅក្នុងចំណោមកងវរសេនាធំ ៦១ គឺជាកងឆ្មាំនៅស្ទឹងហាវ[2381]។

---

2380 ឯកសារ D54/83 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.37-38 ["សំ៖ ហេតុអ្វីបានជាលោកទៅស្ទឹងហាវ? ឆ.37៖ ពីព្រោះអង្គភាពរបស់ខ្ញុំកងវរសេនាធំ ៦១ ត្រូវបានផ្ទេរទៅស្ទឹងហាវ ហើយមានទីតាំងនៅទីនោះ។ [...] ឆ.38៖ មានបួនកងវរសេនាតូចនៅក្នុងកងវរសេនាធំ ៦១។ មានតែបីវរសេនាតូចដែលផ្ទេរទៅបោះទីតាំងនៅស្ទឹងហាវ"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.39 ["សំ៖ តើនៅស្ទឹងហាវហ្នឹងគឺជាទៅបញ្ជាការកងវរសេនាធំ ៦១ ឬគ្រាន់តែជាមូលដ្ឋានមួយរបស់កងវរសេនាធំ ៦១? ឆ.39៖ ទីបញ្ជាការវរសេនាធំ ៦១"]។ ឯកសារ D54/83.3 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង អ៊ុច ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាល ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ឆ្នាំ ២០០៨-២០១០ ថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ១៩៧៦ KH-EN ERN 00984400។ ឯកសារ D4.1.750 ប្រវត្តិសង្ខេបកងពលលេខ ៣ របស់ចលនាកុម្មុយនីស្តខ្មែរ KH ERN 01496677 ["កងវរសេនាធំលេខ ២០ ឈរជើងនៅស្ទឹងហាវ"]។ ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714358 ["កងវរសេនាធំលេខ ២០/៦០ នៃកងពល ១៦៤ មានមូលដ្ឋានស្ថិតនៅស្ទឹងហាវ និងរោងចក្រចម្រាញ់ប្រេង"]។ ឯកសារ D54/9 កំណត់ហេតុស្តាប់ចម្លើយ មិន ផុន ឆ.5 ["សំ៖ តើកងរបស់លោកនៅក្រោមបញ្ជារបស់កងណាពេលនៅស្ទឹងហាវ? ឆ.5៖ នៅស្ទឹងហាវ កងអនុសេនាធំរបស់ខ្ញុំត្រូវបានដាក់បញ្ចូលទៅក្រោមបញ្ជាកងវរសេនាតូចរបស់វរសេនាធំ ៦១ នៃកងពល ១៦៤"]។ ឯកសារ D54/9.1 ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាល ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ឆ្នាំ ២០០៨-២០១០ KH-EN ERN 00936755។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.7-8, 27, 30 ["គឺមានមនុស្សច្រើនបានចូលរួម។ អ្នកចូលរួមប្រជុំមានចំនួនមួយកងវរសេនាធំ។ កងវរសេនាធំ ៦១ នៃកងពល ១៦៤។ [...] ឆ.8៖ ខ្ញុំចាំតែយោធានៃកងវរសេនាធំ៦១ នៅស្ទឹងហាវដែលបានចូលរួមប្រជុំនោះ តែខ្ញុំមិនចាំថាតើកងសមាសភាពមិនល្អ ដែលធ្វើការនៅកន្លែងវាយថ្មនៅកន្លែងផ្សេងៗ ត្រូវបានចូលប្រជុំ ឬអត់ដែរទេ។ [...] ឆ.27៖ មិនមានអ្នកយាមនៅការដ្ឋានទេ ប៉ុន្តែយោធារបស់វរសេនាធំ៦១ គេធ្វើការនៅតាមកន្លែងរបស់គេ។ សំ៖ តើកងអនុសេនាធំទាំងបី បង្កើតឡើងដោយកងវរសេនាធំ ៦១ ឬកងពល ១៦៤? [...] ឆ.30៖ អនុសេនាធំទាំងបីនេះ គឺជាពួកសមាសភាពមិនល្អនៅក្នុងវរសេនាធំ ៦១។ សូមមើលផងដែរ ឯកសារ D54/13.2 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាលខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ឆ្នាំ ២០០៨-២០១០ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ KH-EN ERN 00936753។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.180, 185 ["សំ៖ នៅស្ទឹងហាវ តើមានទាហានបោះទីតាំងនៅជីគោកដែរទេ? ឆ.180៖ បាទ មាន គឺវរសេនាធំលេខ ៦១។ [...] សំ៖ តើមានខ្មែរសាងសង់ដែរឬទេ? ឆ.185៖ បាទ មានកងទ័ពមួយវរសេនាតូច ដែលប្រចាំនៅក្នុងវរសេនាធំ ៦១"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.34, 36-37 ["ចំណោះនៅក្នុងវរសេនាធំ ៦១។ [...] សំ៖ តើលោកដឹងថា កងវរសេនាធំ ៦១ មានមូលដ្ឋាននៅទីណាដែរ នៅស្ទឹងហាវ? [...] ឆ.36៖ ចាប់ពីឆ្លងស្ពានដែក (ស្ពានក្រពើពង) ក្នុងឃុំស្ទឹងហាវ ហើយចាប់ពីរោងចក្រប្រេងកាតទៅ។ គាត់ដាក់បណ្តាញកងទ័ពគាត់មកពីស្ទឹងហាវមកដល់ព្រះអង្គកែវ។ សំ៖ តើលោកចង់និយាយអំពីស្ពានដែក ដែលនៅក្បែរព្រែក នៅជិតវាំងទេះភ្លើងចូលទៅស្ទឹងហាវមែនទេ? [...] ឆ

610. មាស អ៊ីម ក៏មានសិទ្ធិអំណាចខ្លះផងដែរនៅស្ទឹងហាវ។ ដំបូង គាត់បានថ្លែងថា គាត់ត្រូវបានតែងតាំងដោយ ឌីម ឲ្យកាន់មុខតំណែងជាប្រធានយន្តការីនៃកងពលនៅស្ទឹងហាវ[2382] ប៉ុន្តែក្រោយមក បានអះអាងថា គាត់ "បានគ្រប់គ្រងលើត្រាក់ទ័រតែពីរ ឬបីប៉ុណ្ណោះ"[2383]។

---

.37៖ បាទ ផ្លូវហ្នឹងកាត់មកមានផ្លូវដែក ហើយនិងស្ទឹងដែលចាក់ទៅសមុទ្រ"]។ ឯកសារ D114/178.4 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ សុខន ឧបសម្ព័ន្ធ៖ ផែនទីភូមិសាស្ត្រ និងបណ្តាញផ្លូវខេត្តព្រះសីហនុ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៦ KH ERN 01211383។ ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714381-82 ["សាក្សី សៀង បានបង្ហាញកំពង់ផែថ្មនោះ ដល់មន្ត្រីស៊ើបអង្កេត ក.ស.ច.ស ដោយបញ្ជាក់ថា កំពង់ផែនោះត្រូវបានសាងសង់ឡើងដោយកងពលលេខ ៣/១៦៤ នៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ដោយប្រើថ្មយកមកពីការដ្ឋានវាយថ្មស្ទឹងហាវ។ សាក្សី សៀង បានបង្ហាញអត្តសញ្ញាណខ្លួន ជាសមាជិកមួយរូបរបស់កងពលលេខ ៣/១៦៤។ គាត់ប្រាប់ថា កងវរសេនាធំលេខ ៦១ (ឬតាមផ្នែកៗរបស់កងវរសេនាធំ) មានទីតាំងស្ថិតនៅក្នុងស្ទឹងហាវ"]។ ឯកសារ D54/83 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីង អ៊ុច ឆ.38 ["មានបួនកងវរសេនាតូចនៅក្នុងកងវរសេនាធំ ៦១។ មានតែបីវរសេនាតូចដែលផ្ទេរទៅបោះទីតាំងនៅស្ទឹងហាវ។ ខ្ញុំមិនដឹងអំពីកងវរសេនាតូចផ្សេងទៀតទេ តែសម្រាប់កងវរសេនាតូចរបស់ខ្ញុំគឺទៅរៀនបច្ចេកទេស។ កងវរសេនាតូចរបស់ខ្ញុំលេខ ៤១២ ឬ ៣១២ ព្រោះខ្ញុំចាំមិនសូវច្បាស់ទេ"]។ ឯកសារ D54/9 កំណត់ហេតុស្តាប់ចម្លើយ មិន ផុន ឆ.5 ["នៅស្ទឹងហាវ កងអនុសេនាធំរបស់ខ្ញុំត្រូវបានដាក់បញ្ចូលទៅក្រោមបញ្ជាកងវរសេនាតូចរបស់វរសេនាធំ ៦១ នៃកងពល ១៦៤។ កងវរសេនាតូចថ្មីរបស់ខ្ញុំមានទីតាំងនៅខាងក្រៅស្ទឹងហាវ។ ខ្ញុំមិនចាំលេខកងវរសេនាតូចរបស់ខ្ញុំទេ ប៉ុន្តែ ខ្ញុំនៅចាំថា ទីតាំងរបស់កងវរសេនាតូចគឺនៅតាមបណ្តោយផ្លូវលំ និងផ្លូវរថភ្លើងលើខ្នងភ្នំមួយចម្ងាយប្រហែលជាង ១ គីឡូម៉ែត្រពីកន្លែងការដ្ឋានវាយថ្ម។ ខ្ញុំនៅចាំឈ្មោះមេបញ្ជាការវរសេនាធំ ៦១ កាលពីពេលនោះឈ្មោះ ភាព តែមិនដឹងថាគាត់ស្លាប់ ឬរស់ទេ។ មេបញ្ជាការវរសេនាតូចរបស់ខ្ញុំឈ្មោះ វ៉ាន់នី និងអនុរបស់គាត់ឈ្មោះ ផេង"]។ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.21 ["ខ្ញុំរាយការណ៍ឡើងទៅមេវរសេនាធំ ឈ្មោះ ភាព និង ឡួន"]។

2381 ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ សុខន ឆ.34 ["ចំណុះនៅក្នុងវរសេនាធំ ៦១"]។

2382 ឯកសារ D114/215.1 មាស អ៊ីម របាយការណ៍គម្រោងលើកកម្ពស់គណនេយ្យភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា EN ERN 01301422 [ក្នុងឆ្នាំ ១៩៧៦ អនុប្រធានកងពល ១៦៤ ឌីម បានតម្លើង អ៊ីម ទៅកាន់តួនាទីជាប្រធានបច្ចេកទេសសម្រាប់កងពល។ គាត់ទទួលខុសត្រូវជួសជុលឡាន និងត្រាក់ទ័រ។ យោធាចំនួន ៨០០ នាក់ស្ថិតក្រោមការគ្រប់គ្រងរបស់គាត់"]។

2383 ឯកសារ D114/214 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ីម ឆ.8។ ប៉ុន្តែ សូមមើល ឯកសារ D114/77.1 បញ្ជីវត្តមានវគ្គលេខាធិការលើកទី២ KH ERN 01101693។ ឯកសារ D54/49 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.34-35 ["អ៊ីម ជាគណៈកម្មាធិការសាងសង់ផែស្ទឹងហាវ។ អ៊ីម ជាប្អូនប្រុសរបស់ មាស មុត ដែលមានឪពុកផ្សេងគ្នា។ សះ តើ អ៊ីម មានតួនាទី និងមុខងារជាអ្វី? ឆ.35៖ ខ្ញុំឮថា ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ គាត់ជាប្រធានសហករណ៍។ បន្ទាប់ពីរំដោះឆ្នាំ ១៩៧៥ មាស មុត បានយកគាត់ទៅជាមួយ ហើយតែងតាំងគាត់ជាគណៈស្ទឹងហាវ"]។ ឯកសារ

611. សមាជិកនៃកងផ្សេងៗ ដែលចុងក្រោយសុទ្ធតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់ **មាស មុត** ទាំងអស់ បានបម្រើការ ឬធ្វើការនៅស្ទឹងហាវចាប់តាំងពីមានការដ្ឋាននោះមក។ ពេលខ្លះ កម្មាភិបាលដែលត្រូវបានបញ្ចេញពីកំណែនទ័ព ពីកងផ្សេងៗគ្នានៃកងពល ១៦៤ ត្រូវបានដាក់នៅក្នុង "កងផលិតកម្ម" ថ្មី និងបញ្ចូលគ្នា[2384] នៅពេលពួកគេបានមកដល់ស្ទឹងហាវ។ កងដែលមានវត្តមាននៅស្ទឹងហាវ មិនថាស្ថិតក្នុងចំណុះសកម្ម ឬបញ្ចេញពីកំណែននោះទេ រួមមាន៖ កងក្នុងកងវរសេនាធំ ៦៣ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់លេខាធិការ ស៊ិន ចន ហៅ ចន[2385] និងអនុលេខាធិការ គីម ញ៉ាន ហៅ ញ៉ាន[2386] កងវរសេនាតូចឯករាជ្យ ១៦៥/៤៥០[2387] កងវរសេនាធំ ១៤០ ដែល

---

D54/78.1 កិច្ចសម្ភាសរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល KH ERN 00926615 ["តា អ៊ឹម ហ្នឹងប្អូន មាស មុត"]។

2384 ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.103 ["បន្ទាប់មក គេចុចឈ្មោះមនុស្សមួយចំនួនឲ្យមកស្ទឹងហាវ ក្នុងនោះមានទាំងខ្ញុំផងដែរ។ អ៊ីចឹងអង្គភាពរបស់ខ្ញុំ គឺនៅកោះតាងនៅឡើយ ចំណែកខ្ញុំមកស្ទឹងហាវ គឺអង្គភាពចម្រុះគ្នា នៅក្រោមកងពល១ ៦៤ ដែលជាទ័ពជើងទឹក តែគេឲ្យយើងមកវាយថ្ម"]។

2385 ឯកសារ D54/35.1 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង ប្រាក់ សុខា KH ERN 00964253-54 ["ស៖ អ៊ីចឹងអ្នកគ្រប់គ្រងតាមអង្គភាពតាមវរៈហ្នឹងពីណាគេ មានស្គាល់ទេ? ឆ៖ មានបងផន បងឈន។ ស៖ អ៊ីចឹងអ្នកគ្រប់គ្រងផ្ទាល់? ឆ៖ បាទ បងផន កងវរៈ បងឈន ជាប្រធានវរសេនាធំ។ ស៖ បងឈន? ឆ៖ បាទ។ ស៖ អ៊ីចឹងបងឈន ជាប្រធានវរសេនាធំ? ឆ៖ បងផន ជាប្រធានវរសេនាតូច ប្រធានកងចល័តហ្នឹង។ ស៖ អ៊ីចឹងបង ឈន? បងឈន ជាប្រធានវរសេនាធំ"]។

2386 ឯកសារ D4.1.699 ទូរលេខ ១១ ពី ខឹម ជូនបង មុត ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00092628 ["ពីរនាក់ទៀតរត់អង្គភាពពីសង្ការ យុទ្ធជននេះនឹងដូរពីកង ៦៣"]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.23-24, 26 ["ស៖ តើអ្នកណាគ្រប់គ្រងការដ្ឋានស្ទឹងហាវ? ឆ.23៖ ឈ្មោះ កាន ជាអ្នកគ្រប់គ្រងនៅការដ្ឋានខ្ញុំ គឺការដ្ឋានទី១។ ខ្ញុំមិនដឹងថាឈ្មោះ តា សេង ឬឈ្មោះ តា ញ៉ាន់ ទេ ដែលជាអ្នកគ្រប់គ្រងនៅស្ទឹងហាវ។ ស៖ តើលោកចង់និយាយអំពីឈ្មោះ តា ញ៉ាន់ ដែលក្រោយមកទៅស្រុកអន្លង់វែងមែនទេ? ឆ.24៖ ត្រឹមត្រូវហើយ គឺមនុស្សដដែលហ្នឹង។ [...] ស៖ តើតា សេង និងតា ញ៉ាន់ មានតួនាទីអ្វីដែរនៅពេលនោះ? ឆ.26៖ កាលខ្ញុំនៅក្នុងកងទ័ពជើងទឹកនៅឡើយ តាសេង គឺជាមេវរសេនាធំ ១៤០ រីឯតា ញ៉ាន់ គឺជាមេវរសេនាធំ ៦៣ តែខ្ញុំមិនដឹងថា ពួកគាត់ត្រូវបានគេតម្លើងឲ្យធ្វើអ្វីទេ ក្រោយពីគេដកខ្ញុំចេញពីកងទ័ពជើងទឹក"]។ សូមមើលផងដែរ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.6, 11 ["ពេលនោះ ខ្ញុំក្លាយទៅជាកងទ័ពមជ្ឈិមនៅក្នុងកងនាវាចរកងពល ១៦៤។ ខ្ញុំមិនចាំលេខកងវរសេនាតូចរបស់ខ្ញុំទេ តែខ្ញុំនៅក្នុងកងវរសេនាធំ ២២។ [...] ឆ.11៖ ប្រហែលជានៅពាក់កណ្តាលឆ្នាំ ១៩៧៦ ខ្ញុំត្រូវបានគេបញ្ជូនទៅស្ទឹងហាវ"]។ ឯកសារ D1.3.13.13 កំណត់ហេតុនៃកិច្ចសម្ភាសន៍រវាង ក.ស.ព និង ទូច សឿលី KH ERN 01555821 ["ការសាងសង់បានចាប់ផ្តើមនៅស្ទឹងហាវក្នុងឆ្នាំ ១៩៧៦ ដោយការសាងសង់កាន់តែសម្រុកខ្លាំងជាង

ស្ថិតក្រោមការគ្រប់គ្រងរបស់ ស៊ុន ម៉ុត[2388] កងវរសេនាធំ ៤៦០ ក្រោមការគ្រប់គ្រងរបស់ ឆាន់[2389]; កងវរសេនាតូចស្ត្រីឯករាជ្យ ១៦៧[2390] ក្រោមការគ្រប់គ្រងរបស់ លឹម លាង[2391] ដោយ

---

មុននៅឆ្នាំ ១៩៧៧ ដោយមានការចាក់ដីក្នុងទឹក។ ការសាងសង់អាចត្រូវបានធ្វើឡើងដោយយោធាកងវរសេនាធំ ២២ ប៉ុន្តែ គាត់មិនចាំឈ្មោះមេបញ្ជាការទេ"]។

2387 ឯកសារ D4.1.745 របាយការណ៍ Stony Beach KH ERN 01513916 ["កងវរសេនាតូចទី ៤៥០ នេះទទួលខុសត្រូវលើការងារសាងសង់ផែស្ទឹងហាវពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៨។ អង្គភាពរបស់គាត់នៅតែឈរជើងនៅស្ទឹងហាវនេះរហូតដល់ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៧៩ នៅពេលដែលកងទ័ពប្រជាជននៃកងកម្លាំងលុកលុយវៀតណាម (PAVN) បានចូលមកដល់កំពង់សោម"]។ ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១០ KH ERN 00714352 ["សាក្សីមួយរូបបាននិយាយថា កងវរសេនាតូចលេខ ៤៥០ ជាអ្នកមើលការខុសត្រូវការសាងសង់កំពង់ផែថ្មស្ទឹងហាវពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៦។ [...] កងវរសេនាតូចលេខ ៤៥០ ឈរជើងនៅជិតស្ទឹងហាវ ក្នុងឆ្នាំ ១៩៧៥ បន្ទាប់ពីត្រូវបញ្ជូនមកពីកោះតាង ដោយព្រឹត្តិការណ៍នេះបានកើតឡើងនៅក្នុងខែ ឧសភា ឆ្នាំ១៩៧៥"]។ ឯកសារ D4.1.45 របាយការណ៍ Stony Beach EN ERN 00387261 ["ប្រហែលក្នុងខែ សីហា ឬខែ កញ្ញា ឆ្នាំ ១៩៧៥ កងវរសេនាធំទី៤៥០ ត្រូវបានដកពីកោះតាងមកបោះទីតាំងនៅក្បែរស្ទឹងហាវវិញ"]។

2388 ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណារ សុខន ឆ.269, 273, 275 ["ស៖ តើគាត់ជាទាហាន ឬជាប្រជាជនធម្មតា? ឆ.269៖ គាត់ជាមេកងវរសេនាធំ ១៤០។ [...] ឆ.273៖ [រៀបការ]នៅស្ទឹងហាវវាជាទូលខ្ពស់។ [...] ឆ. 275៖ [...] ប្រុសៗនៅទីនោះរួចហើយ ព្រោះវាជាកន្លែងរបស់គេ"]។ សូមមើលផងដែរ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.23-24, 26 ["ស៖ តើអ្នកណាគ្រប់គ្រងការដ្ឋានស្ទឹងហាវ? ឆ.23៖ ឈ្មោះ កាន ជាអ្នកគ្រប់គ្រងនៅការដ្ឋានខ្ញុំ គឺការដ្ឋានទី១។ ខ្ញុំមិនដឹងថាឈ្មោះ តា សេង ឬឈ្មោះ តា ញ៉ាន់ ទេ ដែលជាអ្នកគ្រប់គ្រងនៅស្ទឹងហាវ។ ស៖ តើលោកចង់និយាយអំពីឈ្មោះ តា ញ៉ាន់ ដែលក្រោយមកទៅស្រុកអន្លង់វែងមែនទេ? ឆ. 24៖ ត្រឹមត្រូវហើយ គឺមនុស្សដដែលហ្នឹង។ [...] ស៖ តើតា សេង និងតា ញ៉ាន់ មានតួនាទីអ្វីដែរនៅពេលនោះ? ឆ.26 ៖ កាលខ្ញុំនៅក្នុងកងទ័ពជើងទឹកនៅឡើយ តា សេង គឺជាមេវរសេនាធំ ១៤០ រីឯតា ញ៉ាន់ គឺជាមេវរសេនាធំ ៦៣ តែខ្ញុំមិនដឹងថា ពួកគាត់ត្រូវបានគេតម្លើងឱ្យធ្វើអ្វីទេ ក្រោយពីគេដកខ្ញុំចេញពីកងទ័ពជើងទឹក"]។

2389 ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍រវាង ក.ស.ព និង ប៉ែន សារិន EN ERN 00217560 ["គ្រប់គ្នាធ្វើការដូចកម្មករ។ ស្រីៗមានចំនួនប្រហែល ៤០-៥០ នាក់ គឺជានារី ១៧ មេសា ចំពោះប្រុសៗវិញគឺមកពីវរសេនាធំ ៤៦០ កងកាំភ្លើងធំ ដែលស្ថិតក្រោមបញ្ជារបស់ នង ឆាន"]។

2390 ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.14, 19 ["ពួកយើងគឺធ្វើការផ្ទាល់ក្រោមបញ្ជារបស់កងពលធំ១៦៤។ សមាជិករបស់កងវរសេនាតូច១៦៧ ទាំងអស់សុទ្ធតែជានារី។ កងវរសេនាតូច ១៦៧ មានកងអនុសេនាធំបី គឺ កងអនុសេនាធំ ៣២, ៣៣ និង៣៥។ កងអនុសេនាធំចំនួនពីរ គឺកងអនុសេនាធំ៣២ និង៣៣ ត្រូវបានបញ្ជូនទៅធ្វើការនៅស្ទឹងហាវ។ [...] ឆ.19៖ កងវរសេនាតូចរបស់ខ្ញុំ ត្រូវបានគេស្គាល់ថាជាកងវរសេនាតូចនារី"]។ សូមមើលផង

រួមបញ្ចូលកងអនុសេនាធំ ៣២[2392] និងកងអនុសេនាធំលេខ ៣៣[2393] កងវរសេនាតូច ២០[2394] កងវរសេនាតូច ២១[2395] កងវរសេនាតូច ៣៨៦[2396] កងវរសេនាតូច ៦១២[2397] និងកង 'សមាសភាព

ដែរ ឯកសារ D114/83.2 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឧបសម្ព័ន្ធ៖ គំនូសផ្ទាល់ដៃដែលគូសដោយសាក្សី ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៥ KH ERN 01110589 ។

2391 ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.13 ["ចំពោះខ្ញុំ គឺស្ថិតក្រោមកងវរៈសេនាតូច ១៦៧ ដដែល។ ខ្ញុំនៅចាំថា មេបញ្ជាការរបស់កងវរសេនាតូចខ្ញុំ គឺជានារីឈ្មោះ បង លាង ហើយគាត់ក៏បានមកធ្វើការ និងស្នាក់នៅស្ទឹងហាវជាមួយពួកយើងផងដែរ"]។

2392 ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.14 ["ពួកយើងគឺធ្វើការផ្ទាល់ក្រោមបញ្ជារបស់កងពលធំ ១៦៤។ សមាជិករបស់កងវរសេនាតូច ១៦៧ ទាំងអស់សុទ្ធតែជានារី។ កងវរសេនាតូច ១៦៧ មានកងអនុសេនាធំបីគឺ កងអនុសេនាធំ ៣២, ៣៣ និង ៣៥។ កងអនុសេនាធំចំនួនពីរគឺកងអនុសេនាធំ ៣២ និង ៣៣ ត្រូវបានបញ្ជូនទៅធ្វើការនៅស្ទឹងហាវ"]។

2393 ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង .14 ["ពួកយើងគឺធ្វើការផ្ទាល់ក្រោមបញ្ជារបស់កងពលធំ ១៦៤។ សមាជិករបស់កងវរសេនាតូច ១៦៧ ទាំងអស់សុទ្ធតែជានារី។ កងវរសេនាតូច ១៦៧ មានកងអនុសេនាធំបីគឺ កងអនុសេនាធំ ៣២, ៣៣ និង ៣៥។ កងអនុសេនាធំចំនួនពីរគឺកងអនុសេនាធំ ៣២ និង ៣៣ ត្រូវបានបញ្ជូនទៅធ្វើការនៅស្ទឹងហាវ"]។

2394 ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.16 ["កងផលិតរបស់ខ្ញុំ មានឈ្មោះថា កងវរសេនាតូចលេខ២០។ [...] ខ្ញុំ ហើយនិងកងវរៈលេខ ២០ របស់ខ្ញុំ ត្រូវបានគេបញ្ជូនឱ្យទៅវាយថ្មនៅការដ្ឋានវាយថ្មស្ទឹងហាវ។ ខ្ញុំនៅធ្វើការនៅទីនោះរហូតដល់វៀតណាមចូលដល់"]។ ឯកសារ D54/35.1 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង ប្រាក់ សុខា KH ERN 00964254 ["ស៖ អ៊ីចឹងអ្នកដែលមកវៃថ្មធ្វើស្ទឹងហាវមានគ្នាច្រើនទេ? ឆ៖ មានច្រើន មានពីរកងវរៈ ឬបីកងវរៈទេ កាលហ្នឹងខ្ញុំភ្លេច។ ស៖ ប្រហែលជាប៉ុន្មានរយនាក់ពូមានដឹងទេ? ឆ៖ យី! ស្មានជំនាន់ហ្នឹង បើមិនពីរកងវរៈបីកងវរៈភ្លេចហើយជំនាន់ហ្នឹង កង២០ កង២១"]។

2395 ឯកសារ D54/35.1 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង ប្រាក់ សុខា KH ERN 00964254 ["ស៖ អ៊ីចឹងអ្នកដែលមកវៃថ្មធ្វើស្ទឹងហាវមានគ្នាច្រើនទេ? ឆ៖ មានច្រើន មានពីរកងវរៈ ឬបីកងវរៈទេ កាលហ្នឹងខ្ញុំភ្លេច។ ស៖ ប្រហែលជាប៉ុន្មានរយនាក់ពូមានដឹងទេ? ឆ៖ យី! ស្មានជំនាន់ហ្នឹង បើមិនពីរកងវរៈបីកងវរៈភ្លេចហើយជំនាន់ហ្នឹង កង ២០ កង២១"]។

2396 ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.23 ["នៅពេលនោះ គេបានដកប្រហែលជា ៨០ ភាគរយនៃពួកអតីតយោធាកងពលវរសេនាតូច ៣៨៦ នៃតំបន់ ៣៧ ហើយបញ្ជូនឱ្យទៅធ្វើការនៅកន្លែងវៃថ្មនៅស្ទឹងហាវដោយសារពួកនោះចាត់ថាជាសមាសភាពមិនល្អ"]។ ឯកសារ D114/112 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.15 ["ក្នុងប្រហែលខែ កក្កដា ឆ្នាំ ១៩៧៧ ខ្ញុំ និងមនុស្សជាច្រើននាក់ទៀតមកពីតំបន់ ៣៧ ត្រូវបានគេបញ្ជូនទៅលត់ដំនៅស្ទឹងហាវ"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.17-18 ["ក្រោយពីនេះមក ថាត្រូវចាប់បញ្ជូនទាហានដែលនៅក្នុងតំបន់ ៣៧ មកស្ទឹងហាវទាំងអស់ ប្រមូលទ័ពទាំងអស់ដើម្បីគេលត់ដំចម្រាញ់ទ័ព ដើម្បីគេ

មិនល្អ" គឺកងអនុសេនាធំ ១៧[2398] កងអនុសេនាធំ ១៨[2399] កងអនុសេនាធំ ១៩[2400] និងកងអនុសេនាធំ ២៣[2401]។ អ្នកគ្រប់គ្រងផ្សេងៗទៀតនៅស្ទឹងហាវនៅថ្នាក់កងវរសេនាធំ ឬកងវរសេនា

---

សម្រិតសម្រាំងទ័ព ថាយើងហ្នឹងស្មោះត្រង់ជាមួយនឹងពួកគាត់ឬអត់។ [...] ឆ.18៖ [...] ឱ្យតែក្នុងតំបន់អង្គភាពហ្នឹងត្រូវបញ្ជូនទាំងអស់"]។ សូមមើលផងដែរ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន យ៉ើ ឆ.12 ["មុននឹងបែកភ្នំពេញ ខ្ញុំនៅនឹងអង្គភាពតំបន់ ៣៧ ជាពេទ្យ អង្គភាពវរសេនាតូច ៣៨៦"]។

2397 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.16-17 ["គេដកពីកាំភ្លើងធំ ហើយឱ្យមកកាន់មួយវរសេនាតូច ដែលមានស្រាប់នៅស្ទឹងហាវ"។ ស៖ តើកងវរសេនាតូច ដែលមានស្រាប់នោះមានឈ្មោះអ្វីដែរ? ឬលេខប៉ុន្មានដែរ? ឆ.17៖ កងវរសេនាតូចលេខ ៦១២"]។

2398 ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.21 ["ដំបូងឡើងកងអនុសេនាធំ ១៧ ជាអ្នកធ្វើ តែក្រោយមកទៀត កងអនុសេនាធំ ២៣"]។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.24 ["ពួកសមាសភាពមិនល្អ គេបានរៀបចំទៅជាបីកងអនុសេនាធំ ដែលមានកងអនុសេនាធំទី ១៧, ១៨ និង ១៩។ កងរបស់ខ្ញុំជាកងអនុសេនាធំទី ១៧"]។ សូមមើលផងដែរ ឯកសារ D54/13.2 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាលខ័ណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ឆ្នាំ ២០០៨-២០១០ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ KH-EN ERN 00936753។ ឯកសារ D114/60 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង អំពីការដ្ឋានធ្វើការងារដោយបង្ខំនៅផែយោធាស្ទឹងហាវ EN ERN 01082175 ["សាក្សីបញ្ជាក់ថា ការដ្ឋានរ៉ែថ្មរបស់កងអនុសេនាធំ ១៧ ជាការដ្ឋានរ៉ែថ្មទី ៤។ សាក្សីបញ្ជាក់ថាជាទីតាំងមូលដ្ឋានកងអនុសេនាធំ ១៧"], EN ERN 01082179 ["ចូលស្ទឹងហាវតាមទិសដៅពីកំពង់សោម មូលដ្ឋានកងអនុសេនាធំ ១៧ ស្ថិតនៅច្រកចូលស្ទឹងហាវ រវាងស្ពានឆ្លងស្ទឹង និងផ្លូវប្រសព្វ (ចំណុចដៅ ២១)។ ទីតាំងស្ថិតនៅខាងជើងផ្លូវធំ គឺនៅក្បែរចំណុចរវាងស្ទឹង និងផ្លូវធំ"], EN ERN 01082180-01082181 ["សាក្សីមិនមានបញ្ហាអំពីការបង្ហាញទីតាំងមូលដ្ឋានរបស់កងអនុសេនាធំ ១៧ ទេ។ សាក្សីត្រូវបានចាត់ទៅកងអនុសេនាធំ ១៧ ដែលជាទូទៅស្គាល់ថា "សមាភាពកងមិនល្អ"។ សាក្សីប៉ាន់ស្មានថាមានមនុស្សប្រហែល ១០០ នាក់ត្រូវបានចាត់ចូលកងអនុសេនាធំ ១៧ នេះ"]។

2399 ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.24 ["ពួកសមាសភាពមិនល្អគេបានរៀបចំទៅជាបីកងអនុសេនាធំ ដែលមានកងអនុសេនាធំទី១៧, ១៨ និង ១៩"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.31 ["អនុសេនាធំ ១៨ និង១៩ គេដាក់នៅស្ទឹងហាវហ្នឹង"]។ សូមមើលផងដែរ ឯកសារ D114/86.7 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឧបសម្ព័ន្ធ៖ គំនូសផ្ទាល់ដៃដែលគូសដោយសាក្សី ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ KH ERN 01110642។

2400 ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.24 ["ពួកសមាសភាពមិនល្អគេបានរៀបចំទៅជាបីកងអនុសេនាធំ ដែលមានកងអនុសេនាធំទី១៧, ១៨ និង ១៩។ កងរបស់ខ្ញុំជាកងអនុសេនាធំទី ១៧"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.31 ["អនុសេនាធំ ១៨ និង ១៩ គេដាក់នៅស្ទឹងហាវហ្នឹង"]។ សូមមើលផងដែរ ឯកសារ D114/86.7 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឧបសម្ព័ន្ធ៖ គំនូសផ្ទាល់ដៃដែលគូសដោយសាក្សី ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ KH ERN 01110642។

តូច ដែលត្រូវបានវាយឈ្មោះនៅក្នុងភស្តុតាងរួមមាន ហឿន[2402] ឡាន[2403] កាន[2404] ដាន[2405] និង ផាន[2406]។

---

2401 ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.21 ["ដំបូងឡើងកងអនុសេនាធំ១៧ ជាអ្នកធ្វើ តែក្រោយមកទៀត កងអនុសេនាធំ ២៣"]។

2402 ឯកសារ D54/67.3 កិច្ចសម្ភាសរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង នង នេត KH ERN 00977455 ["គេទៅឱ្យធ្វើលូនៅម៉ុស្ទីងហាវ។ ស៖ ម៉េចទៀតពូ? ឆ៖ អាហ្នឹង ដឹងហើយអាហ្នឹងមេ ហឿន ទៀត។ ឈ្មោះ អា ហឿន តែវាភ្លេចអាត្រកូលតាវាទៀតណា"]។ ឯកសារ D54/67 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.24 ["ខ្ញុំគ្រាន់តែដឹងថា ហឿន ជាអ្នកទទួលខុសត្រូវការដ្ឋានផ្លូវរទេះភ្លើងនៅត្រពាំងក្រឡឹង និងការដ្ឋានរទេះភ្លើងនៅស្ទឹងហាវ។ ខ្ញុំដឹងថា ហឿន ជាអ្នកមកពីខេត្តតាកែវ ពីព្រោះគាត់និយាយរដឹន១"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.79 ["ស៖ យើងចង់សំដៅទៅលើហេតុការណ៍មួយទៀត តើលោកនៅចាំឈ្មោះកម្មាភិបាលម្នាក់ឈ្មោះ ហឿន គាត់ជាកម្មាភិបាលគ្រប់គ្រងកម្មករ ដែលធ្វើការនៅផ្លូវរទេះភ្លើងនៅស្ទឹងហាវដែរឬទេ? ឆ.79៖ គាត់អង្គភាពខុសគ្នា ខ្ញុំមិនស្គាល់គាត់ច្បាស់ទេ ប៉ុនឈ្មោះនេះ ខ្ញុំឮគេហៅមែន។ ប៉ុន្តែធ្វើការនៅអង្គភាពខុសគ្នា ខ្ញុំមិនអាចដឹងអស់ទេ។"]។ សូមមើលផងដែរ ឯកសារ D54/67.2 មជ្ឈមណ្ឌលឯកសារកម្ពុជា ស្វែងរកការពិត នេត ជីវិតសល់ពីសេចក្តីស្លាប់ KH ERN 01374689 ["នេត និង មិត្តភក្តិមួយចំនួន ត្រូវបានបញ្ជូនឱ្យទៅធ្វើលូនៅម៉ុស្ទីងហាវ ក្រោមការគ្រប់គ្រងរបស់សមមិត្ត ហឿន"]។

2403 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.21 ["ខ្ញុំរាយការណ៍ឡើងទៅមេវរសេនាធំឈ្មោះ ភាព និងឡាន"]។

2404 ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.23 ["ឈ្មោះ កាន ជាអ្នកគ្រប់គ្រងនៅការដ្ឋានខ្ញុំ ការដ្ឋានទី ១"]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ុន យ៉ើ ឆ.52, 53, 55 ["ស៖ តើអ្នកណាគេជាអ្នកគ្រប់គ្រងឬកាន់កាប់ការដ្ឋានស្ទឹងហាវ? ឆ.52៖ កាន់កាប់ការដ្ឋានស្ទឹងហាវ មានបញ្ជាការវរៈ លោក កាន។ លោក កាន ប្រធានវរសេនាតូច។ ស៖ តើវរសេនាតូច ដែលលោក កាន កាន់កាប់នោះ មានឈ្មោះ ឬលេខអ្វីដែរ? ឆ.53៖ មានឈ្មោះកងផលិតដដែលហ្នឹង។ [...] ស៖ តើមេផ្ទាល់របស់លោកឈ្មោះអ្វីដែរ ពេលធ្វើការនៅស្ទឹងហាវ? ឆ.55៖ មេផ្ទាល់ លោក កាន ហ្នឹងហើយ"]។ សូមមើលផងដែរ ឯកសារ D54/67 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.25 ["ស៖ យើងនិយាយអំពីឈ្មោះ កាន តើលោកជួប កាន ដំបូងនៅពេលណា ហើយនៅកន្លែងណា? ឆ.25៖ ខ្ញុំបានេះជួប កាន ដំបូងនៅពេលដែលខ្ញុំទៅធ្វើការនៅស្ទឹងហាវ។ ខ្ញុំមិនបានឃើញគាត់នៅការដ្ឋានផ្លូវរទេះភ្លើង នៅត្រពាំងក្រឡឹងទេ"]។

2405 ឯកសារ D59/1/1.27 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង ម៉ុយ សុត KH ERN 00733417 ["តា ដនគាត់នៅហ្នឹងកាន់កងពល កាលហ្នឹងគាត់ក្តាប់កងពលតាំងពីប៉ោយប៉ែតមករហូត មកទល់នឹងប៉ៃលិន វរសេនាធំពីរបីអ៊ីចឹងទៅ វរសេនាធំ ១១ វរសេនាធំស្ទឹងហាវ វរសេនាធំផ្សេងៗរហូតអ៊ីចឹងទៅ"]។

2406 ឯកសារ D54/35.1 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង ប្រាក់ សុខា KH ERN 00964253-54 ["ស៖ អ៊ីចឹងអ្នកគ្រប់គ្រងតាមអង្គភាពតាមវរៈហ្នឹងពីណាគេ មានស្គាល់ទេ? ឆ៖ មានបងផន បងឈន។ ស៖ អ៊ីចឹងអ្នកគ្រប់គ្រងផ្ទាល់? ឆ៖ បាទ បងផន កងវរៈ បងឈន ជាប្រធានវរសេនាធំ។ ស៖ បងឈន? ឆ៖ បាទ។ ស៖ អ៊ីចឹងបង

612. ការប្រជុំត្រូវបានរៀបចំឡើងជាទៀងទាត់ក្នុងចំណោមអ្នកគ្រប់គ្រងនៅស្ទឹងហាវ ដែលបានចូលរួម ដោយប្រធានៗនៃកងដែលមានសមាជិកមួយរយនាក់ និងកង ព្រមទាំងក្រុមដែលមានសមាជិកហាសិបនាក់[2407]។ សាក្សី ឡុង ផាន់ស៊ី មេបញ្ជាការនៃកងវរសេនាតូច ៦១២ នៅស្ទឹងហាវ បានរៀបរាប់ថា ខ្លួនបានចូលរួមក្នុងការប្រជុំនៅស្ទឹងហាវ ជាមួយប្រធាននៃកងវរសេនាធំនៅឯទីបញ្ជាការកណ្តាលនៃកងវរសេនាធំ ដែលត្រូវបានធ្វើឡើងមិនថារៀងរាល់ថ្ងៃ ឬរៀងរាល់បីថ្ងៃម្តងនោះទេ[2408]។ ដំបូង គាត់បានជួបជាមួយប្រធានកងអនុសេនាធំរបស់គាត់ មុនពេលចូលរួមការប្រជុំទាំងនេះ[2409]។

## ៣. ឧក្រិដ្ឋកម្ម

### ការធ្វើឱ្យទៅជាទាសករ

613. ស្ទឹងហាវគឺជាកន្លែងលត់ដំមួយសម្រាប់កម្មាភិបាលកងពល ១៦៤ រាប់រយ និងអាចរាប់ពាន់នាក់ផង[2410] ដែលត្រូវបានរំសាយដោយការសង្ស័យ ត្រូវបានបង្ខំឱ្យទៅរស់នៅ និងធ្វើការនៅក្នុង

---

ឈន ជាប្រធានវរសេនាធំ? ឆ៖ បងផន ជាប្រធានវរសេនាតូច ប្រធានកងចល័តហ្នឹង។ ស៖ អ៊ីចឹងបង ឈន? បង ឈន ជាប្រធានវរសេនាធំ"]។

2407 ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀង ភង់ ឆ.122 ["ស៖ តើអ្នកណាគេទៅចូលរួមប្រជុំនោះ? ឆ.122 ៖ អ្នកមេក្រុមកងរយ កងហា។ ថ្ងៃប្រជុំ គេទៅ ហើយមកវិញ គេដាក់ការងារឱ្យយើងធ្វើ។

2408 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.24-25 ["ស៖ ការប្រជុំជាមួយមេៗវរសេនាធំធ្វើឡើងនៅទីណាដែរ? ឆ.24៖ ការប្រជុំជាមួយវរសេនាធំ គឺធ្វើឡើងមន្ទីរវរសនាធំ នៅស្ទឹងហាវតែម្តង។ ស៖ តើនរណាខ្លះទៀតដែលចូលរួមប្រជុំជាមួយមេៗកងវរសេនាធំ? ឆ.25៖ ខ្ញុំប្រជុំតែម្នាក់ឯង រាល់ពេល ១ ថ្ងៃ ឬ ៣ ថ្ងៃម្តង ខ្ញុំប្រជុំជាមួយមេអនុសេនាធំរបស់ខ្ញុំ មុនពេលទៅប្រជុំជាមួយមេវរសេនាធំ"]។

2409 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.25 ["ខ្ញុំប្រជុំជាមួយមេអនុសេនាធំរបស់ខ្ញុំ មុនពេលទៅប្រជុំជាមួយមេវរសេនាធំ"]។

2410 ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.39 ["នៅកំពង់សោមគេហៅថា កងពល ១៦៥ ខាងជើងទឹក។ ខ្ញុំឮគេថា កងពលលេខ ៣ និង ១៦៤ ហ្នឹង គឺនៅជាមួយគ្នា។ ក្រោយមកគេរំសាយ គេឱ្យកាំបិតទៅកាប់ឈើធ្វើផ្ទះ ឱ្យទៅវាយថ្មចាក់ផែនៅស្ទឹងហាវជាមួយពួកចិន"]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.19 ["នៅស្ទឹងហាវមានការដ្ឋានយកថ្មចំនួនបី។ គេបានបញ្ជូនកម្លាំងដែលគេរំសាយចេញពីកងទ័ពជើងទឹកទៅធ្វើការនៅទីនោះ ចាប់តាំងពីឆ្នាំ១៩៧៧ មក"]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.10 ["ពួកយើងត្រូវបានច្របាច់បញ្ចូលទៅក្នុងកងពល ១៦៤ ក្រោមបញ្ជាការរបស់ មាស មុត"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.26, 186-187 ["ខ្ញុំនៅកងពល ១៦៤។ [...] ឆ.186៖ ពេលហ្នឹងគេបញ្ជូនខ្ញុំមកស្ទឹងហាវ។ [...]

លក្ខខណ្ឌមួយដែលស្មើនឹងឧក្រិដ្ឋកម្មនៃការធ្វើឱ្យទៅជាទាសករ[2411]។ ចំនួនពិតប្រាកដនៃពលករនៅការដ្ឋានស្ទឹងហាវ ប្រែប្រួលជានិច្ច ក្នុងរយៈពេលប៉ុន្មានឆ្នាំដែលការដ្ឋាននេះប្រតិបត្តិការ។ មាស អ៊ឹម បានផ្តល់សក្ខីភាពថា មានពលករម្តង ៨០០ នាក់នៅការដ្ឋានស្ទឹងហាវ[2412]។ សាក្សីផ្សេងទៀតបានផ្តល់ភស្តុតាងដែលបង្ហាញថា មានពលកររាប់រយនាក់នៅស្ទឹងហាវ រួមទាំងកងវរសេនាតូច

ឆ.187៖ ទាហាន ៣០០ នាក់នោះ បែកគ្នាអស់ហើយពេលនោះ។ ខ្លះគេបញ្ជូនមកស្ទឹងហាវ ខ្លះទៅកន្លែងផ្សេង"]។ សូមមើលផងដែរ ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714347 ["កងពល ១៦៤ បានគ្រប់គ្រងការដ្ឋានការងារដោយបង្ខំ ឱ្យវាយថ្មមួយកន្លែងនៅជិតស្ទឹងហាវ [...] ទីតាំងទាំងនេះត្រូវបានកងពល ១៦៤ (អតីតកងពលលេខ ៣) បង្កើតឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ"]។

2411 ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.10 ["អ្នកដែលធ្វើការសែងថ្មនៅរូងភ្នំនោះ គឺមកពីកងពល ១៦៤"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.20 ["សៈ តើលោកមានអារម្មណ៍ថាការងារហ្នឹងគេបង្ខំឱ្យលោកបំពេញទេ? ឆ.20៖ កន្លែងហ្នឹងគឺជាកន្លែងលត់ដំ គឺដាច់ខាតយើងត្រូវតែធ្វើ អត់ធ្វើ គឺអត់បាន"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.28-30 ["សៈ តើគេប្រព្រឹត្តមកលើលោកដូចម្តេចខ្លះនៅពេលនោះ តើចាត់ទុកថាលោកអតីតៈយោធា ឬជាមនុស្សធម្មតាម្នាក់? ឆ.28៖ គេមិនបានចាត់ទុកយើងជាអតីតៈយោធា ឬជាមនុស្សទេ គេចាត់យើងថាជាមនុស្សដែលត្រូវលត់ដំ គេចាត់ទុកយើងនិងប្រព្រឹត្តមកលើយើងថាជាទាសសករ។ សៈ តើលោកមានសិទ្ធិបញ្ចេញយោបល់ ឬទាមទារអ្វីបានដែរឬទេ? ឆ.29៖ គ្មានទេ, មិនបានទាល់តែសោះ។ សៈ តើលោកអាចបដិសេធឬតវ៉ាមិនព្រមធ្វើការបានដែរឬទេនៅពេលនោះ? ឆ.30៖ ទេ, យើងត្រូវតែធ្វើតាមផែនការរបស់គេ បើមិនដូច្នោះទេ យើងត្រូវមាន"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ ស្បួន ផ ឆ.44, 46-47 ["ពេលធ្វើការ គេពុំឃាមកាមយើងអ្វីទេ ហើយគេក៏មិនកម្រិតឱ្យយើងគោរពតាមច្បាប់អ្វីដែរ តែពួកយើងទាំងអស់គ្នាដឹងខ្លួនថាត្រូវធ្វើអ្វី ពោលគឺត្រូវធ្វើការប្រឹងប្រែងបំផុត និងវាយថ្មឱ្យបានច្រើនបំផុតតាមដែលអាចធ្វើបាន។ [...] សៈ តើលោកអាចឈប់សម្រាក ឬទៅលេងគ្រួសារបានដែរឬទេ? ឆ.46៖ ខ្ញុំមិនដែលសុំច្បាប់គេទៅផ្ទះទេ ព្រោះខ្ញុំគិតថាគេក៏មិនឱ្យដែរ បើខ្ញុំសុំ។ ពួកខ្ញុំធ្វើការពេញមួយអាទិត្យ និងពេញមួយខែ ពុំមានពេលសម្រាកទេ លើកលែងតែមានការប្រជុំទើបបានឈប់សម្រាកខ្លះ។ ក្នុងការប្រជុំទាំងនោះ គេនិយាយតែការខិតខំប្រឹងប្រែងធ្វើការងារ ហើយប្រសិនបើយើងធ្វើការងារល្អ គេក៏សរសើរយើងដែរ។ [...] សៈ តើលោកចង់ធ្វើការងារនោះដែរឬទេ? តើលោកមានជម្រើសធ្វើអ្វីផ្សេងដែរឬទេ? ឆ.47៖ ខ្ញុំអត់ចង់ទេ តែខ្ញុំត្រូវតែធ្វើការងារនោះដើម្បីជាថ្នូរនឹងជីវិតរបស់ខ្ញុំ"]។

2412 ឯកសារ D114/214 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.28-29, 54 ["នៅក្នុងការដ្ឋានដែលខ្ញុំធ្វើការហ្នឹងមានអ្នកធ្វើការ៨០០ នាក់។ សៈ តើលោកចង់សំដៅទៅលើការដ្ឋានណាមួយដែរ? ឆ.29៖ ការដ្ឋានស្ទឹងហាវ"]។ ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.54 ["កម្លាំងហ្នឹងមកពីអង្គភាពផ្សេងៗក្រោមកងពល ១៦៤ ហ្នឹង។ កម្លាំងសរុបទាំងអស់គឺ ៨០០ នាក់ ធ្វើការនៅការដ្ឋានសំណង់ស្ទឹងហាវ"]។

ទាំងមូលទាំងបីផង[2413] និងកម្មាភិបាល ដែលគេរំសាយពីមុខតំណែងនៅលើកោះនានាប្រមាណជា ២៥០ នាក់ផង[2414]។ សាក្សីបានរៀបរាប់ថា មាន "មនុស្សជាច្រើន" ធ្វើការនៅការដ្ឋានវាយថ្ម[2415] និងបានប៉ាន់ប្រមាណថា មានពលករ ប្រហែល ១០០ នាក់ នៅក្នុងកងនីមួយៗ នៅកន្លែងផ្សេងៗគ្នាក្នុងស្ទឹងហាវ[2416]។ ឧទាហរណ៍ នៅការដ្ឋានវាយថ្ម មានក្រុមពលករផ្សេងៗគ្នា រួមទាំងក្រុមអ្នកបើកបរឡាន ក្រុមអ្នកខួងថ្ម និងបំផ្ទុះ និងក្រុមដឹកជញ្ជូនថ្មផង[2417]។

---

2413 ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង ឆុន ឆ.20 ["បន្ទាប់ពីហ្នឹងមក គេបានដកយកបីកងវរសេនាតូចឱ្យទៅធ្វើការលត់ដំនៅស្ទឹងហាវ កងរបស់ខ្ញុំទៅស្នាក់នៅជិតផ្លូវរថភ្លើងនៅស្ទឹងហាវ"]។ ឯកសារ D54/35.1 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង ប្រាក់ សុខា KH ERN 00964254 ["មានច្រើន មានពីរកងវរៈ ឬបីកងវរៈ [...] យី! ស្មានកាលហ្នឹងបើមិនពីរកងវរៈ បីកងវរៈ"]៖

2414 ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.41 ["យោធាដែលដកចេញពីកោះមក គឺឈរជើងនៅលើស្ទឹងហាវហ្នឹងទាំងអស់។ ទាហានវរៈសេនាតូចហ្នឹងខ្លះក៏គេចាប់ ក៏គេអី នៅសល់តែប្រហែល ២០០ នាក់ជាង មិនដល់ ៣០០ នាក់ទេ។ អ្នកដែលគេដកមកនៅលើដីនៅស្ទឹងហាវនេះ មានទាហានចំនួនប្រហែល ២៥០ នាក់ ព្រោះមានគេចាប់យកទៅធ្វើបាប ធ្វើអី រញ៉េរញ៉ៃពេញហ្នឹងទាំងអស់"]។

2415 ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.20 ["មានមនុស្សជាច្រើនដែលធ្វើការនៅការដ្ឋានវាយថ្មជាមួយខ្ញុំ"]។

2416 ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ សៀង EN ERN 00217566 ["មានកន្លែងយកថ្មនៅស្ទឹងហាវដែលគ្រប់គ្រងដោយកងពល ១៦៤ [] មានមនុស្សប្រហែល ១០០ នាក់ធ្វើការនៅកន្លែងយកថ្មនោះ"]។ ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.31 ["មានមនុស្សប្រហែល ១០០ នាក់នៅការដ្ឋានស្ទឹងហាវដែលធ្វើការក្រោមបញ្ជា ហឿន"]។ ឯកសារ D114/178 អ៊ឹម សុខន កំណត់ហេតុស្តាប់ចម្លើយ ឆ.67 ["មានតែក្រុមខ្ញុំជាមួយជនជាតិចិន ដែលគេទៅស្វានបំបែកថ្ម។ ពួកគេហ្នឹង ៧ នាក់ ក្រៅពីនេះ ពួកខ្ញុំទាំងអស់។ គឺមួយអនុសេនាធំចំនួន ១១០ នាក់ រួមទាំងពួកគាត់ទៀត"]។ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.18 ["តាមពិត គឺមួយកងវរសេនាធំឈរជើងនៅស្ទឹងហាវ ប៉ុន្តែ គេឱ្យខ្ញុំកាន់តែមួយកងវរសេនាតូច ដែលមានសមាជិកប្រហែល ១០០ ទៅ ២០០ នាក់ប៉ុណ្ណោះ"]។ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.226-28 ["ស៖ នៅស្ទឹងហាវមានអ្នកធ្វើការប៉ុន្មាននាក់? ឆ.226៖ ប្រហែលជា ១០០ នាក់។ ស៖ តើគេបញ្ជូនកងទាំងមូលរបស់លោកទៅឬ? ឆ.227៖ បាទ។ ស៖ តើលោកមានឃើញអ្នកផ្សេងទៀតក្រៅពីក្រុមរបស់លោកធ្វើការនៅទីនោះទេ? ឆ.228៖ មានអ្នកផ្សេងទៀតនៅទីនោះដែរ"]។ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន KH ERN 01301516 ["ពួកវាយកខ្ញុំមកចូលឆ្នាំ ១៩៧៧ យកយើងមកកាប់ព្រៃគុប ជិតស្ទឹងហាវ។ ហ្នឹងមានគ្នាច្រើនណាស់ រាប់រយនាក់"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.44-47 ["ស៖ តើនៅការដ្ឋានវាយថ្មរបស់លោក មានមនុស្សប៉ុន្មាននាក់ធ្វើការ? ឆ.44៖ នៅការដ្ឋានវាយថ្មរបស់ខ្ញុំមានមនុស្ស ១៤ នាក់ធ្វើការ ហើយមានឡានចំនួនពីរគ្រឿង។ ស៖ តើមានមនុស្សប៉ុន្មាននាក់ធ្វើការនៅទំនប់ផែ? ឆ.45៖ ៨០ ភាគរយដែលដកពីកងវរៈសេនាតូច ៣៨៦ គឺធ្វើការនៅកន្លែង

614. ប៉ែន សារិន បានប៉ាន់ប្រមាណថា កម្មករគ្មានជំនាញប្រហែល ៣០ នាក់ធ្វើការជាធម្មតាលើគម្រោងសង់ផ្លូវនៅគ្រប់ពេលទាំងអស់ និងមានអ្នកបច្ចេកទេសមួយចំនួនបន្ថែមទៀតជាអ្នកកាន់ម៉ាស៊ីន[2418]។ ទោះជាយ៉ាងនេះក្តី ចំនួនមានការប្រែប្រួល ហើយក៏មានស្ត្រី ៤០ ទៅ ៥០ នាក់មួយក្រុមបន្ថែមទៀតដែលទំនងជាត្រូវបានបញ្ជូនម្តងម្កាលទៅធ្វើផ្លូវដែរ[2419]។

615. របបកម្ពុជាប្រជាធិបតេយ្យមានសិទ្ធិអំណាចផ្សេងៗ ដែលភ្ជាប់ទៅនឹងសិទ្ធិជាម្ចាស់លើកម្មករទាំងអស់នៅស្ទឹងហាវ[2420]។ របបរឹតបន្តឹងសេរីភាពជាសារវន្តទាំងអស់របស់កម្មករ និងបង្ខំពួកឲ្យធ្វើ

---

ទំនប់ផែទាំងអស់។ ស៖ តើប្រហែលប៉ុន្មាននាក់គិតជាចំនួន? ឆ.46៖ ប្រហែល ១០០ នាក់។ ស៖ តើមានមនុស្សប៉ុន្មាននាក់ដែលធ្វើការនៅការដ្ឋានវាយថ្មផ្សេងទៀតនោះ? ឆ.47៖ វាអាស្រ័យលើថ្មនោះលំបាក ឬស្រួលបំបែក។ កន្លែងខ្លះមានមនុស្សធ្វើការ ១៥ នាក់ ហើយកន្លែងខ្លះមានចំនួនច្រើន"]។ សូមមើលផងដែរ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.20 ["ស៖ តើមានចំនួនអ្នកបំបែកថ្មប៉ុន្មាននាក់ ដែលធ្វើការនៅការដ្ឋានវាយថ្មជាមួយលោកនៅពាក់កណ្តាលឆ្នាំ ១៩៧៦? ឆ៖ មានប្រហែលចំនួន ២០ នាក់"]។ ឯកសារ D54/49 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.41 ["ខ្ញុំបានអង្កេតមើលតែនៅការដ្ឋានផែប៉ុណ្ណោះ គឺមានកម្មករប្រហែល ១០០ នាក់ រួមទាំងកម្មករចិន។ ជាទូទៅ ខ្ញុំបានឃើញកម្មករទាំងនោះនៅពេលល្ងាច នៅពេលដែលពួកគេត្រឡប់ទៅកន្លែងស្នាក់នៅរបស់ពួកគេវិញ ក្នុងឆ្នាំ ១៩៧៧។ ខ្ញុំបានឃើញពីទីកន្លែងខ្ញុំចតឡានក្រុងចាំទទួលកម្មករ ទីនោះ គឺជាកន្លែងតែមួយគត់ដែលខ្ញុំបានអង្កេតឃើញ"]។ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.40 ["មនុស្សធ្វើការនៅតំបន់កំពង់ផែមានមនុស្សជាង ២០០ នាក់។ ខ្ញុំបានប្រាប់លោកពីមុនថា មានកងអនុសេនាធំនារីចំនួន ២ កងធ្វើការនៅទីនោះ។ ដូច្នេះ មានគ្នារហូត ២០០ នាក់ហើយ។ បន្ថែមលើនោះទៀត ក៏មានក្រុមបុរសៗធ្វើការនៅទីនោះដែរ។ នៅការដ្ឋានយកថ្ម គឺមានតែបុរសទេ ដែលធ្វើការនៅទីនោះ។ កន្លែងដែលគេខាំថ្មក៏មានតែបុរសដែរ ដែលធ្វើការ។ រីឯនៅកន្លែងដែលគេចាក់ពុម្ពសសរ មានទាំងនារី និងបុរសធ្វើការនៅទីនោះ"]។

2417 ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ. 23 ["នៅការដ្ឋានវាយថ្ម គេចែកការងារធ្វើជាក្រុមដូចមាន ក្រុមបើកឡាន ក្រុមខួងថ្មបំផ្ទុះ និងក្រុមជញ្ជូនថ្ម"]។

2418 ឯកសារ D2/7 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សារិន ឆ.11 ["ស៖តើមានមនុស្សប៉ុន្មាននាក់ ដែលធ្វើការនៅក្នុងគំរោងសាងសង់ផ្លូវនេះ? ឆ.11៖ ចំពោះចំនួនមនុស្សមិនទៀងទេ អ្នកដែលគ្មានបច្ចេកទេសមានប្រហែល ៣០ នាក់។ ចំពោះអ្នកបច្ចេកទេសគឺនៅក្នុងគ្រឿងចក្រមួយមានអ្នកបច្ចេកទេសពីរនាក់"]។

2419 ឯកសារ D2/7 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សារិន ឆ.12 ["ស៖នៅក្នុងបទសម្ភាសន៍លើកមុន លោកនិយាយថាមានមនុស្សស្រី ៤០ ទៅ ៥០ នាក់ ដែលចូលរួមក្នុងការសាងសង់ផ្លូវនេះ? ឆ.12៖ បាទ, កម្លាំងនោះមិនមែនធ្វើការជាប្រចាំទេ គឺគេមកជួយម្តងម្កាលប៉ុណ្ណោះ"]។

2420 ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.26 ["តែលក្ខខណ្ឌការងារនៅត្រពាំងក្រឡឹង និងស្ទឹងហាវ គឺមានការលំបាកខ្លាំងណាស់។ ខ្ញុំគិតថាមនុស្សយើងគឺមិនអាចទទួលយកបាននូវការងារក្នុងស្ថានភាពនៅត្រពាំងក្រឡឹង និងស្ទឹងហាវទេ"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.26 ["ស៖ តើការរស់នៅ និងហូបចុកនៅ

ការក្រោមលក្ខខណ្ឌដ៏សែនលំបាក ដើម្បីជាប្រយោជន៍របស់កម្ពុជាប្រជាធិបតេយ្យ។ កម្មករមិនអាចនិយាយគ្នា[2421] ឬទៅណាមកណាដោយសេរីបានទេ[2422]។ ដូចជនរងគ្រោះម្នាក់បាននិយាយ "ស្ថានភាពរស់នៅគឺដូចជាប់គុក ពីព្រោះយើងមិនត្រូវបានអនុញ្ញាតឱ្យដើរចេញក្រៅពីកន្លែងការដ្ឋានទេ"[2423]។ សាក្សីសង្កេតថាមានអ្នកយាមកាន់អាវុធ ពេលពួកគេធ្វើការ[2424] ហើយអ្នកដែល

---

ស្អឹងហារយ៉ាងណាដែរ? ឆ.26៖ ស្ថានការរស់នៅ និងហូបចុក គឺមានលក្ខណៈដូចគ្នានៅកងកេងដែរ គឺមានការលំបាកដូចគ្នា"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.44 ["ពួកយើងទាំងអស់គ្នាដឹងថាខ្លួនត្រូវធ្វើអ្វី ពោលគឺត្រូវធ្វើការប្រឹងប្រែងបំផុត និងវាយថ្មឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន"]។

2421 សូមមើលឧទាហរណ៍ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.29 ["សៈ តើលោកមានសិទ្ធិបញ្ចេញយោបល់ ឬទាមទារអ្វីបានដែរឬទេ? ឆ.29៖ គ្មានទេ, មិនបានទាល់តែសោះ"]។

2422 ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.82 ["សៈ តើលោកអាចចេញពីកន្លែងវ៉ៃថ្ម ឬកន្លែងដែលលោកស្នាក់នៅទេ? ឆ.82៖ ទាល់តែគេចាត់តាំងទើបចេញបាន"]។ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.23, 33 ["ប្រសិនបើអ្នកដែលមិនស្តាប់បង្គាប់ដើរហើរសេរី គេនឹងប្រជុំស្ទ័យតិទៀន។ [...] សៈ ហេតុអ្វីបានជាលោកមិនរកវិធីរត់គេចពីទីនោះ នៅពេលដែលស្ថានភាពការងារនៅទីនោះមានការលំបាកខ្លាំង? ឆ.33៖ មិនមានផ្លូវរត់ចេញទេ ពីព្រោះយើងហូបបាយរួម ដូច្នេះ បើយើងរត់គេចទៅកន្លែងផ្សេង យើងនឹងមិនមានអាហារហូបចុកទេ ហើយយើងនឹងចាប់ខ្លួន ហើយនឹងត្រូវសម្លាប់ដោយយោធាដែលល្បាតនៅតំបន់នោះ"]។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.26, 34 ["ប៉ុន្តែ នៅកន្លែងវាយថ្ម គេបិទសិទ្ធិមិនឱ្យយើងធ្វើដំណើរឬទាក់ទងជាមួយអ្នកកន្លែងផ្សេងទៀត បើមិនដូច្នោះទេ យើងនឹងត្រូវគេចាប់បញ្ជូនទៅបាត់។[...] ឆ.34៖ ពីព្រោះគេមិនអនុញ្ញាតឱ្យដើរហើរទេ។ ការដើរហើរគឺត្រូវបានរឹតបន្តឹង។ [...] ស្ថានភាពរស់នៅគឺដូចជាប់គុក ពីព្រោះយើងមិនត្រូវបានអនុញ្ញាតឱ្យដើរចេញក្រៅពីកន្លែងការដ្ឋានទេ"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.35 ["គេមិនអនុញ្ញាតឱ្យយើងចេញទៅកន្លែងណាក្រៅពីកន្លែងធ្វើការរបស់យើងទេ"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.52 ["ក្នុងសម័យនោះ គឺគេឱ្យយើងនៅតែមួយកន្លែងទេ បើមិននៅកន្លែងធ្វើការ គឺមានតែនៅកន្លែងដេកប៉ុណ្ណោះ មិនអាចទៅកន្លែងណាផ្សេងទៀតបានឡើយ"]។

2423 ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.34។

2424 ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.143-44 ["នៅកន្លែងវាយថ្ម មានអ្នកយាម ហើយនៅកន្លែងចិន ក៏មានកន្លែងយាមដែរ។ [...] ឆ.144៖ គេដើរពិនិត្យមើលយើងវាយថ្ម"]។ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.229 ["សៈ តើមានអ្នកយាមធ្វើការនៅទីនោះទេ? ឆ.299៖ បាទ"]។ ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.80, 85-86 ["កន្លែងធ្វើការមានអ្នកយាម។ [...] សៈ តើគេមានអាវុធទេ? ឆ.85៖ មាន។ សៈ តើលោកមានអាវុធទេ? ឆ.86៖ អត់មាន។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.30, 32 ["មានគេដាក់យោធាកងពិសេសនៅលើខ្ញុំ។ [...] ឆ.32៖ យើងនៅក្រោមនេះ ផ្នែកខាងលត់ដំ យកថ្មអីហ្នឹង"]។

ព្យាយាមរត់គេច ត្រូវគេចាប់ និងសម្លាប់ចោល[2425]។ របបនេះបញ្ជូនកម្មករទៅទីតាំងផ្សេងទៀត ហើយកម្មករគ្មានសិទ្ធិបដិសេធបានឡើយ[2426]។ ប្រសិនបើគេសង្ស័យ ជនរងគ្រោះខ្លះត្រូវបានបញ្ជូន

[2425] ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.47-48 ["សៈ តើលោកចង់ធ្វើការងារនោះដែរឬទេ? តើលោកមានជម្រើសធ្វើអ្វីផ្សេងដែរឬទេ? ឆ.47៖ ខ្ញុំអត់ចង់ទេ តែខ្ញុំត្រូវតែធ្វើការងារនោះដើម្បីជាថ្នូរនឹងជីវិតរបស់ខ្ញុំ។ បើតាមខ្ញុំយល់ ប្រសិនជាគេចាប់បាននរណាម្នាក់ព្យាយាមរត់ចេញពីកន្លែងនោះ អ្នកនោះច្បាស់ជាគេសម្លាប់ចោលហើយ។[...] ឆ.48៖ បាទ ខ្ញុំតែងតែរស់នៅដោយការភ័យខ្លាចថាថ្ងៃណាមួយនឹងអស់ជីវិត"]។ ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.1, 33 ["គេមិនអនុញ្ញាតឲ្យពួកយើងដើរទៅកន្លែងណាផ្សេងក្រៅពីកន្លែងធ្វើការរបស់យើងទេ។ [...] ហេតុអ្វីបានជាលោកមិនរកវិធីរត់គេចពីទីនោះ នៅពេលដែលស្ថានភាពការងារនៅទីនោះមានការលំបាកខ្លាំង? ឆ.33៖ មិនមានផ្លូវរត់ចេញទេ ពីព្រោះយើងហូបបាយរួម ដូច្នេះ បើយើងរត់គេចទៅកន្លែងផ្សេង យើងនឹងមិនមានអាហារហូបចុកទេ ហើយយើងនឹងចាប់ខ្លួន ហើយនឹងត្រូវសម្លាប់ដោយយោធាដែលល្បាតនៅតំបន់នោះ"]។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.26 ["គេបិទសិទ្ធិមិនឲ្យយើងធ្វើដំណើរ ឬទាក់ទងជាមួយអ្នកកន្លែងផ្សេងទៀត បើមិនដូច្នោះទេ យើងនឹងត្រូវគេចាប់បញ្ជូនទៅបាត់"]។

[2426] ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.83។

ទៅស្ទឹងហាវតែម្តងពីកន្លែងផ្សេងៗ ដូចជា ជ្រោយចង្វារ[2427] កំពង់ផែរាម[2428] និងកោះតាង[2429] ខណៈដែលអ្នកដទៃទៀតត្រូវបានផ្ទេរទៅទីនោះពីការដ្ឋានផ្សេងទៀត[2430]។

---

2427 ឯកសារ D54/13.1 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤ ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ១៩៧៦ KH ERN 00936737 ["កម្លាំងទៅពីជ្រោយចង្វារ នៅស្ទឹងហាវបានប្រជុំគ្នាដាក់ផែនការរត់"]។ ឯកសារ D54/8.1 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤ ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ១៩៧៦ KH ERN 00936685 ["កម្លាំងទៅពីជ្រោយចង្វារ ទៅស្ទឹងហាវបានប្រជុំគ្នាដាក់ផែនការរត់។ មេដឹកនាំឈ្មោះ វង់ ស្រួល កម្មាភិបាលអនុលេខាតូច"]។

2428 ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.16-17 ["ស៖ តើកងកាំភ្លើងធំរបស់លោកនៅរាម មានទីតាំងស្ថិតនៅកន្លែងណា? ឆ.16៖ នៅជិតកំពង់ផែកប៉ាល់រាម គឺស្ថិតនៅចម្ងាយប្រហែល ៨០០ ម៉ែត្រ។ ស៖ តើលោកនៅកងកាំភ្លើងធំរហូតដល់ពេលណា? ឆ.17៖ ខ្ញុំនៅកងកាំភ្លើងធំរហូតដល់ប្រហែលចុងឆ្នាំ ១៩៧៧ បានគេរំសាយខ្ញុំពីកងកាំភ្លើងធំ ហើយបញ្ជូនខ្ញុំទៅធ្វើការនៅការដ្ឋានវាយថ្ម ដើម្បីធ្វើផែនៅស្ទឹងហាវ"]។

2429 ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.14 ["ស៖ តើនរណាគេជាអ្នកបញ្ជូនលោកពីកោះតាងមកស្ទឹងហាវ? ឆ.14៖ គឺមានបញ្ជាពីមេបញ្ជាការឱ្យបញ្ជូនខ្ញុំជាមួយនឹងយោធាប្រហែលជា ២០ នាក់ទៀតឱ្យមកនៅស្ទឹងហាវ"]។ ឯកសារD114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.103 ["ខ្ញុំសូមរៀបរាប់បន្តិច។ ពេលយើងនៅកោះតាង យើងសង់ផ្ទះតាមខ្សែត្រៀមតាមឆ្នេរសមុទ្រ ដាំឬស្សីធ្វើរបងជាដើម។ បន្ទាប់មក គេចុចឈ្មោះមនុស្សមួយចំនួនឱ្យមកស្ទឹងហាវ ក្នុងនោះមានទាំងខ្ញុំផងដែរ។ អ៊ីចឹងអង្គភាពរបស់ខ្ញុំ គឺនៅកោះតាងនៅឡើយ ចំណែកខ្ញុំមកស្ទឹងហាវ គឺអង្គភាពចម្រុះគ្នា នៅក្រោមកងពល ១៦៤ ដែលជាទ័ពជើងទឹក តែគេឱ្យយើងមកវាយថ្ម"]។

2430 ឯកសារ D54/35.1 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង ប្រាក់ សុខា KH ERN 00964253 ["គេដកពីកងកេងមកនៅស្ទឹងហាវ ធ្វើផែធ្វើអី ធ្វើទំនប់ធ្វើអី"]។ ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.17 ["ខ្ញុំធ្វើការនៅកងកេងរហូតដល់ពាក់កណ្តាលឆ្នាំ ១៩៧៨ ទើបគេបញ្ជូនខ្ញុំឱ្យទៅធ្វើការនៅស្ទឹងហាវ។ នៅទីនោះគេឱ្យខ្ញុំបំបែកថ្មដើម្បីយកថ្មទៅធ្វើទំនប់រលក និងផែសម្រាប់ឱ្យកប៉ាល់ចម្បាំងចូលចត"]។ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.16 ["ខ្ញុំត្រូវបានគេចាត់តាំងឱ្យលើកទំនប់ និងជីកប្រឡាយ អស់រយៈពេលបួនខែ នៅកន្លែងស្នាច់ដែង និងបបុស។ បន្ទាប់មកគេបញ្ជូនខ្ញុំឱ្យទៅមើលក្របី និងភ្ជួរស្រែ។ ខ្ញុំធ្វើការនៅទីនោះរហូតដល់ខែកញ្ញា ឆ្នាំ ១៩៧៨។ នៅពេលនោះខ្ញុំហើយនិងកងវរៈលេខ ២០ របស់ខ្ញុំ ត្រូវបានគេបញ្ជូនឱ្យទៅវាយថ្មនៅការដ្ឋានស្ទឹងហាវ។ ខ្ញុំនៅធ្វើការនៅទីនោះរហូតវៀតណាមចូលដល់"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ. 186 ["ពេលហ្នឹងគេបញ្ជូនខ្ញុំ[ពីអូរឬស្សី] ទៅស្ទឹងហាវ"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.8 ["ចាប់ពីឆ្នាំ ១៩៧៦ រហូតមក គេឱ្យពួកយើងទៅស្នាក់នៅកណ្តាលវាលស្រែនៅស្នាច់ដែង ដោយទទួលការងារច្រូតកាត់ ដកស្ទូងនៅទីនោះអស់រយៈពេលជិត ២ ឆ្នាំ។ នៅចុងឆ្នាំ ១៩៧៧ គេបញ្ជូនពួកយើងទៅស្ទឹងហាវ"]។ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.210 ["ស៖ ចន្លោះពីខែ ៧ ឆ្នាំ ៧៧ រហូតដល់ពេលវៀតណាមវ៉ៃចូលមក ក្រៅពីលើកទំនប់ និងធ្វើស្រែ តើលោកមានធ្វើអ្វីផ្សេងទៀតទេ? ឆ.210៖ គេឱ្យខ្ញុំទៅវាយថ្មធ្វើទំនប់រលកនៅស្ទឹងហាវ"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.23 ["ខ្ញុំរស់នៅ និងធ្វើការម៉ុប្រលានយន្ត

616. ក្រោយពេលបញ្ជូនទៅស្ទឹងហាវរួច[2431] ជនរងគ្រោះត្រូវគេបង្ខំឲ្យធ្វើការរៀងរាល់ថ្ងៃ គ្មានពេលសម្រាក[2432] មិនថាក្នុងអាកាសធាតុបែបណាក៏ដោយ[2433]។ សាក្សីបញ្ជាក់ថា ពួកខ្មែរក្រហម "ចាត់ទុកយើង និងប្រព្រឹត្តមកលើយើងថាជាទាសករ" និងដូចសត្វ[2434]។ ជនរងគ្រោះមិនអាចបដិសេធមិនធ្វើការបានទេ ព្រោះខ្លាចទណ្ឌកម្ម ឬស្លាប់[2435] ហើយពួកគេក៏មិនអាចស្នើសុំឲ្យមានការបន្ធូរ

---

ហោះកងកេង ប្រហែល ១ ឆ្នាំ។ ក្រោយមកទៀត គេបញ្ជូនខ្ញុំមកវាយថ្មនៅស្ទឹងហាវ ហើយខ្ញុំរស់នៅ និងធ្វើការនៅទីនោះបានប្រហែលជិត ១ ឆ្នាំ"]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន យឿ ឆ.42["តើមានការដកសមាជិកពីកងផលិតទៅទីតាំងកងកេងដែរឬទេ? ឆ៖ មាន គឺដកទៅនៅស្ទឹងហាវ"]។ ឯកសារ D54/67.3 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង នង នេត KH ERN 00977455 ["គេទៅឲ្យធ្វើល្អនៅម៉ុស្ទឹងហាវ"]។

2431 ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.18, 20 ["ស៖ តើលោកផ្លាស់ទៅស្ទឹងហាវដោយស្ម័គ្រចិត្តឬ? ឆ.18៖ ទេ, គេបញ្ជាខ្ញុំឲ្យទៅទីនោះ។ ក្នុងរយៈពេលនោះ មិនមាននរណាអាចស្ម័គ្រចិត្តធ្វើអ្វីបានទេ។ យើងធ្វើតាមតែបញ្ជា។ [...] ឆ.20៖ នៅក្នុងពេលនោះខ្ញុំធ្វើតាមតែបញ្ជារបស់គេ គេថាវាជាភារៈកិច្ច ដូច្នេះខ្ញុំត្រូវតែធ្វើតាម មានមនុស្សជាច្រើនដែលធ្វើការនៅការដ្ឋានវាយថ្មជាមួយខ្ញុំ"]។

2432 ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.46 ["ពួកយើងធ្វើការពេញមួយអាទិត្យ និងពេញមួយខែ ពុំមានពេលសម្រាកទេ លើកលែងតែមានការប្រជុំទើបបានឈប់សម្រាកខ្លះ"]។ សូមមើលផងដែរ ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.24 ["ស៖ តើលោកមានសិទ្ធិ សម្រាប់ស្នើសុំឲ្យគេបន្ធូរបន្ថយលក្ខខណ្ឌការងារនៅកន្លែងលោកធ្វើការហ្នឹងដែរឬទេ? ឆ.24៖ ទេ គ្មាននរណាមានសិទ្ធិទេ គឺស្ងួតស្ងៀមតែម្តង"]។ ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍រវាង ក.ស.ព និង ប៉ែន សារិន EN ERN 00217561 ["សាក្សីនិយាយថា ពួកគេត្រូវបានផ្តល់អាហារមិនគ្រប់គ្រាន់ ហើយជាញឹកញាប់ធ្វើការ ២៤ ម៉ោងក្នុងមួយថ្ងៃ"]។

2433 ឯកសារ D2/7 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សារិន ឆ.10 ["យើងត្រូវធ្វើការទាំងភ្លៀង ទាំងយប់រហូតដល់ម៉ោង ០៩ ឬ ១២ យប់"]។

2434 ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.28 ["ស៖ តើគេប្រព្រឹត្តមកលើលោកដូចម្តេចខ្លះនៅពេលនោះ តើចាត់ទុកថាលោកអតីតៈយោធាឬជាមនុស្សម្នាក់? ឆ.28៖ គេមិនបានចាត់ទុកយើងជាអតីតៈយោធាឬជាមនុស្សទេ គេចាត់យើងថាជាមនុស្សដែលត្រូវលត់ដំ គេចាត់ទុកយើងនិងប្រព្រឹត្តមកលើយើងថាជាទាសសករ"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ក ឆ.38 ["យើងត្រូវបានគេប្រព្រឹត្តមកលើដូចសត្វមាន់ ទាអ៊ីចឹង។ ប្រសិនបើគេមិនចូលចិត្តយើង គេដកយើងទៅ ហើយបាត់តែម្តង។ សូម្បីតែបងប្អូនយើងក៏មិនហ៊ានសួរនាំអំពីស្ថានភាពរបស់យើងដែរ។ សូមមើលផងដែរ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.73 ["កាលដែលខ្ញុំរួមរស់នៅការងារនៅការដ្ឋាននោះ គឺឆ្លងកាត់ការលំបាកវេទនាខ្លាំងណាស់។ គេមិនប្រើដោយគ្រឿងម៉ាស៊ីនទៅលើកដាក់ទេ គឺប្រើកម្លាំងមនុស្សទាំងស្រុង ដើម្បីលីសែងថ្មដាក់ឡាន។ អ៊ីចឹងហើយបានកម្លាំងពួកខ្ញុំប្រឹងលីខ្លាំងឥតឈប់ឈរ ដូច្នេះហើយបានទប់ទំនប់ធ្វើផែបានវែង"]។

2435 ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.20 ["ស៖ តើលោកមានអារម្មណ៍ថា ការងារហ្នឹងគេបង្ខំឲ្យលោកបំពេញទេ? ឆ.20៖ កន្លែងហ្នឹងគឺជាកន្លែងលត់ដំ គឺដាច់ខាតយើងត្រូវតែធ្វើ អត់ធ្វើ គឺអត់បាន"]។ ឯកសារ

បន្ថយការងារបានដែរ[2436]។ "ដឹងថាព្រលឹមឡើងចេញធ្វើការទៅ គេឲ្យឈប់ៗទៅ គេឲ្យធ្វើការៗ"[2437]។ ជនរងគ្រោះត្រូវបង្ខំចិត្តធ្វើការដែលពួកគេមិនចង់ធ្វើ ដោយការភ័យខ្លាច ដើម្បីបានរស់[2438]។ សាក្សីម្នាក់ឆ្លើយថា "អ្វីដែលប្រសើរបំផុតគឺយើងនៅស្ងាត់ស្ងៀម ហើយយើងធ្វើតាមគេបញ្ជា"[2439]។ សាក្សីម្នាក់ទៀតនិយាយថា "ការងារមានលក្ខណៈពិបាក តែយើងចេះតែទ្រាំធ្វើការទៅ"[2440]។ សាក្សី នង នេត មានអារម្មណ៍ថា ពួកគេធ្វើការរហូតដល់ស្លាប់៖ "ក្នុងនាមជាមនុស្សជាតិ ស្ថិតនៅក្នុងលក្ខខណ្ឌការងារបែបនេះ គឺខ្មែរក្រហមគេចង់បង្ខំឲ្យមនុស្សធ្វើការងារលើសកម្លាំងរហូតដល់យើងស្លាប់។ ខ្មែរក្រហមឃោរឃៅណាស់ គេធ្វើយ៉ាងដូច្នេះ គឺដើម្បីឲ្យមនុស្សស្លាប់ ដោយមិនបាច់ប្រើមធ្យោបាយផ្សេងទៀត"[2441]។

---

D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.30 ["ស៖ តើលោកអាចបដិសេធឬតវ៉ាមិនព្រមធ្វើការបានដែរឬទេនៅពេលនោះ? ឆ.30៖ ទេ, យើងត្រូវតែធ្វើតាមផែនការរបស់គេ បើមិនដូច្នោះទេ យើងត្រូវមានទោស"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.47 ["ស៖ តើលោកចង់ធ្វើការងារនោះឬទេ? តើលោកមានជម្រើសធ្វើអ្វីផ្សេងដែរឬទេ? ឆ.47៖ ខ្ញុំអត់ចង់ទេ តែខ្ញុំត្រូវតែធ្វើការងារនោះដើម្បីជាថ្នូរនឹងជីវិតរបស់ខ្ញុំ។ បើតាមខ្ញុំយល់ប្រសិនជាគេចាប់បាននរណាម្នាក់ព្យាយាមរត់ចេញពីកន្លែងនោះ អ្នកនោះច្បាស់ជាគេសម្លាប់ចោលហើយ"]។

2436 ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.24 ["ស៖ តើលោកមានសិទ្ធិសម្រាប់ស្នើសុំឲ្យគេបន្ធូបន្ថយលក្ខខណ្ឌការងារនៅកន្លែងលោកធ្វើការហ្នឹងដែរឬទេ? ឆ.24៖ ទេ គ្មាននរណាមានសិទ្ធិទេ គឺស្ងួតស្ងៀមតែម្តង"]។

2437 ឯកសារ D54/35.1 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង ប្រាក់ សុខា KH ERN 00964262។

2438 ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.47-48 ["ស៖ តើលោកចង់ធ្វើការងារនោះដែរឬទេ? តើលោកមានជម្រើសធ្វើអ្វីផ្សេងដែរឬទេ? ឆ.47៖ ខ្ញុំអត់ចង់ទេ តែខ្ញុំត្រូវតែធ្វើការងារនោះដើម្បីជាថ្នូរនឹងជីវិតរបស់ខ្ញុំ។ បើតាមខ្ញុំយល់ ប្រសិនជាគេចាប់បាននរណាម្នាក់ព្យាយាមរត់ចេញពីកន្លែងនោះ អ្នកនោះច្បាស់ជាគេសម្លាប់ចោលហើយ។ [...] ឆ.48៖ បាទ ខ្ញុំតែងតែរស់នៅដោយការភ័យខ្លាចថាថ្ងៃណាមួយនឹងអស់ជីវិត"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.20 ["ស៖ តើលោកមានអារម្មណ៍ថា ការងារហ្នឹងគេបង្ខំឲ្យលោកបំពេញទេ? ឆ.20 កន្លែងហ្នឹងគឺជាកន្លែងលត់ដំ គឺដាច់ខាតយើងត្រូវតែធ្វើ អត់ធ្វើ គឺអត់បាន"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.30 ["ស៖ តើលោកអាចបដិសេធ ឬតវ៉ាមិនព្រមធ្វើការបានដែរឬទេនៅពេលនោះ? ឆ.30៖ ទេ , យើងត្រូវតែធ្វើតាមផែនការរបស់គេ បើមិនដូច្នោះទេ យើងត្រូវមានទោស"]។

2439 ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.9។

2440 ឯកសារ D2/7 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សាវិន ឆ.10។

2441 ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.25 ["ក្នុងនាមជាមនុស្សជាតិស្ថិតនៅក្នុងលក្ខខណ្ឌការងារបែបនេះ គឺខ្មែរក្រហមគេចង់បង្ខំឲ្យមនុស្សធ្វើការងារលើសកម្លាំងរហូតដល់យើងស្លាប់។ ខ្មែរក្រហមឃោរឃៅណាស់ គេធ្វើយ៉ាងដូច្នេះគឺដើម្បីឲ្យមនុស្សស្លាប់ ដោយមិនបាច់ប្រើមធ្យោបាយផ្សេងទៀត"]។

617. កម្មករទាំងឡាននៗត្រូវបាននាំទៅការដ្ឋានវាយថ្មរៀងរាល់ថ្ងៃ[2442] ដើម្បីវាយ បំបែក និងដឹកថ្ម[2443]។ កម្មករប្រើត្រសេះ ដែកគាស់ ដែកស្បែង និងញញួរ[2444]។ ថ្មខ្លះធំណាស់ទាល់តែមនុស្សពីរបីនាក់

---

[2442] ឯកសារ D54/9 កំណត់ហេតុស្តាប់ចម្លើយ មិន ផុន ឆ. 8, 10-11 ["ខ្ញុំពុំដឹកជំរឺតាមផ្លូវទេ ព្រោះមានឡានទ្រុងដឹកកម្មករធ្វើការតាមផ្លូវរាល់ថ្ងៃ ហើយជំរឺវាខ្លាចឡាន។ [...] ឆ.10 ["ខ្ញុំបានឃើញ និងឮសម្លេងឡានរាល់ថ្ងៃ ដែលបើកឆ្ពោះសំដៅទៅការដ្ឋានវាយថ្ម។ [...] ឆ.11៖ ខ្ញុំបានឃើញនឹងឮសម្លេងឡានចេញពីការដ្ឋានវាយថ្ម ពេលព្រឹកប្រហែលជាម៉ោង ៧ និងពេលថ្ងៃប្រហែលជាម៉ោង ២ និងពេលល្ងាចប្រហែលជាម៉ោងប្រាំ"]។

[2443] ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.33 ["ស៖ លោកបាននិយាយថា ពួកយោធាដែលគេចាត់ថាពួកសមាសភាពមិនល្អ ត្រូវគេបញ្ជូនទៅវាយថ្ម ហេតុអ្វីបានជាការងារវាយថ្ម និងលីសែងត្រូវបានដាក់ទៅឲ្យសមាសភាពមិនល្អជាអ្នកធ្វើ? ឆ.33៖ ពីព្រោះការងារវាយថ្ម និងលីថ្មគឺជាការងារធ្ងន់"]។ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ ឆ.157 ["គាត់ថាគាត់នឿយហត់ខ្លាំងណាស់ ដោយគេឲ្យគាត់ខួងថ្ម រើសថ្ម ប៉ុន្តែគាត់ដឹងថាគាត់រើសថ្ម ខួងថ្ម និងចុចរំសេវ"]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.10 ["ក្រោយមកទៀត គេក៏បញ្ជូនខ្ញុំទៅស្ទឹងហាវ។ ពួកខ្ញុំធ្វើការនៅទីនោះបានប្រហែលកន្លះឆ្នាំ។ គេឲ្យយើងសែងថ្មចេញពីរូងភ្នំដែលគេគ្រោងនឹងបង្កើតធ្វើជាឃ្លាំង។ យើងសែងថ្មពីរូងនោះយកទៅដាក់ឡាន ហើយឡានទាំងនោះយកថ្មទៅចាក់នៅសមុទ្រដើម្បីធ្វើកំពង់ផែ"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.24 ["មានការដ្ឋានធ្វើការជាច្រើននៅតំបន់ស្ទឹងហាវ រាល់ព្រឹកៗ ពួកយើងជួបជុំគ្នា ដើម្បីការរង់ការចាត់តាំងការងារផ្សេងៗគ្នា ពួកយើងខ្លះត្រូវគេបញ្ជូនឲ្យបំបែកថ្ម និង ខ្លះទៀតឲ្យទៅជីកងណ្តូង និងខ្លះទៀតគេបញ្ជូនឲ្យទៅកសាងផែ"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.27, 32 ["ក្រោយមកគេបញ្ជូនកងរបស់ខ្ញុំទៅស្ទឹងហាវ ដើម្បីកាប់ឆ្ការព្រៃ កសាងផ្លូវថ្នល់ និងវាយបំបែកថ្ម។ [...] ឆ.32៖ កងអនុសេនាតូចរបស់ខ្ញុំបំបែកថ្ម ដើម្បីកសាងផែ និងកាប់ឆ្ការព្រៃ"]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.19 ["ខ្ញុំ និងមួយចំនួនទៀតត្រូវគេបញ្ជូនឲ្យទៅធ្វើការនៅកន្លែងវាយថ្ម"]។ ឯកសារD114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.39, 55, 103 ["ឲ្យទៅវាយថ្មចាក់ផែនៅស្ទឹងហាវជាមួយពួកចិន។ [...] ឆ.55៖ ខ្ញុំនៅកន្លែងវាយថ្មនៅស្ទឹងហាវ។ [...] ឆ.103៖ ចំណែកខ្ញុំមកស្ទឹងហាវ គឺអង្គភាពចម្រុះគ្នា នៅក្រោមកងពល ១៦៤ ដែលជាទ័ពជើងទឹក តែគេឲ្យយើងមកវាយថ្ម"]។ ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.79 ["ខ្ញុំរែថ្មហ្នឹង"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.23, 42 ["ក្រោយមកទៀត គេបញ្ជូនខ្ញុំមកវាយថ្មនៅស្ទឹងហាវ ហើយខ្ញុំរស់នៅ និងធ្វើការនៅទីនោះបានប្រហែលជិត ១ ឆ្នាំ។ [...] ឆ.42៖ ពួកយើងធ្វើការជាក្រុម ដោយការងារចម្បងគេឲ្យវាយថ្មបំបែកនឹងញញួរ ចំណែកក្រុមផ្សេងៗទៀត គេសែងថ្មឡើងឡាន និងខ្លះទៀតទទួលបន្ទុកបាញ់ថ្ម"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.16 ["ខ្ញុំ ហើយនិងកងវរៈលេខ២០ របស់ខ្ញុំ ត្រូវបានគេបញ្ជូនឲ្យទៅវាយថ្មនៅការដ្ឋានវាយថ្មស្ទឹងហាវ"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.19 ["គេបញ្ជូនខ្ញុំ និងពួកខ្ញុំឲ្យទៅរែបំបែកថ្ម ដើម្បីយកទៅធ្វើផែទំនប់រលកស្ទឹងហាវ"]។ ឯកសារ D114/178.1 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឧបសម្ព័ន្ធ៖ គំនូសផ្ទាល់ដៃដែលគូសដោយសាក្សី ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៦ KH ERN 01211380។ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.23 ["នៅវរសេនាតូច ៦១២ តួនាទីរួមមាន ខួងថ្ម បំបែកថ្ម និងលើកថ្មមក

ទើបលើកវាដាក់ឡានរួច ហើយពួកគេវាយថ្មបានតែមួយឡានទេក្នុងមួយថ្ងៃ[2445]។ ក៏ប៉ុន្តែ ដោយសារការងារនៅស្ទឹងហាវដំណើរការទៅមុខ ចិនបាននាំយកម៉ាស៊ីនវាយបំបែកថ្ម រថយន្តស្ទូច

---

បាំងនៅការដ្ឋាន និងធ្វើការងារផ្សេងៗទៀត"]។ ឯកសារD114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.210, 225, 232 ["គេឱ្យខ្ញុំទៅវាយថ្មធ្វើទំនប់រលកនៅស្ទឹងហាវ។ [...] ឆ.225៖ គេឱ្យយើងរើថ្ម ហើយដឹកជញ្ជូនថ្មដាក់ឡាន។ [...] ឆ.232៖ [...] គេឱ្យយើងទៅរើថ្មនៅទីនោះ"]។ ឯកសារ D114/66 ជេត ប៊ុណ្ណា ឆ.25 ["គេបញ្ជូនខ្ញុំឱ្យទៅធ្វើការវាយថ្មនៅស្ទឹងហាវ"]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ុន យ៉ើ ឆ.48-49 ["ស៖ តាមលោកដឹង តើមានមនុស្សធ្វើការនៅការដ្ឋានស្ទឹងហាវសរុបប្រហែលប៉ុន្មាននាក់ដែរ? ឆ.48៖វាមានពីរការដ្ឋានសម្រាប់ការងារ។ ការដ្ឋានហ្នឹងគេជីកដី រើថ្មដើម្បីបង្កើតជាចាក់ទំនប់រលកថ្មី។ ការដ្ឋានមួយទៀត រើថ្មដូចគ្នា។ រើថ្មដើម្បីចាក់ទំនប់រលកថ្មី។ ស៖តើនៅស្ទឹងហាវ គេឱ្យលោកធ្វើអ្វីខ្លះដែរ? ឆ.49៖ នៅស្ទឹងហាវ គេឱ្យខ្ញុំរើថ្ម ដើម្បីដឹកចាក់ទំនប់រលក"]។ សូមមើលផងដែរ ឯកសារ D114/155 កំណត់ហេតុស្តាប់ចម្លើយ សុខ រ៉េន ឆ.62 ["ខ្ញុំស្គាល់អ្នកនៅស្ទឹងហាវ អ្នករើថ្ម"]។ ឯកសារ D2/23 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714357 ["ប្រជាជនត្រូវគេប្រើឱ្យសែងថ្ម "]។ ឯកសារ D54/35.1 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង ប្រាក់ សុខា KH ERN 00964253 ["អង្គការឱ្យរើថ្ម"]។ ឯកសារ D54/33.1 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកកម្ពុជា និង អ៊ុង អុន (អ៊ី អុន) KH ERN 00964204 ["បើថាផ្លូវដែលចេញបំបែកជាប់រោងចក្រប្រេងកាតហ្នឹង ទ័ពរើថ្មខ្លួនឯងហ្នឹង ហើយអត់មានបានធ្វើទេផ្លូវ"]។

2444 ឯកសារ D54/33.1 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង អ៊ី អុន KH ERN 00964204 ["មានម៉ាស៊ីនខ្វងម៉ាស៊ីនអីមកពីណា សុទ្ធតែមនុស្សបុកហ្នឹង ដែកប្រវែងហ្នឹងបុក"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.39 ["ពីដំបូងឡើយ យើងធ្វើការដោយផ្ទាល់ដៃ។ គេឱ្យដែកត្បែងមួយដើម ឱ្យជីកថ្មនៅលើកូនភ្នំ បន្ទាប់មកយើងលើថ្មដាក់ចូលទៅក្នុងឡានទ្រុង"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.27 ["ការងារនៅការដ្ឋានវាយថ្ម គឺពិបាក ពីព្រោះយើងអ្វីៗដោយដៃ យើងប្រើត្រសេះ និងដែកស្បែងដើម្បីបំបែកថ្ម ហើយយើងលីសែងបំណែកថ្មនោះយកទៅកន្លែងផែ"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.42 ["ពួកយើងធ្វើការជាក្រុមដោយការងារចម្បងគេឱ្យវាយថ្មបំបែកនឹងញញួរ"]។

2445 ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.39 ["ដំបូងឡើយ យើងធ្វើការដោយផ្ទាល់ដៃ។ គេឱ្យដែកត្បែងមួយដើម ឱ្យជីកថ្មនៅលើកូនភ្នំ បន្ទាប់មកយើងលើថ្មដាក់ចូលទៅក្នុងឡានទ្រុង។ ដុំថ្មខ្លះទាល់តែមនុស្ស ២-៣ នាក់ ទើបលើកដាក់លើឡានរួច។ ក្នុងមួយថ្ងៃយើងធ្វើបានតែមួយឡានទេ"]។ ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.117 ["យើងរើថ្មហើយ លីដាក់ត្រាក់ទ័រ"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.42 ["ពួកយើងធ្វើការជាក្រុមដោយការងារចម្បងគេឱ្យវាយថ្មបំបែកនឹងញញួរ។ ចំណែកក្រុមផ្សេងទៀតគេសែងថ្មឡើងឡាន"]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ុន យ៉ើ ឆ.61 ["ឡានគេចូលដឹកថ្មចេញ យើងសម្រាក"]។

និងគ្រឿងរំសេវមួយចំនួន[2446]។ កម្មករខ្លះបានរៀបរាប់ពីបរិមាណការងារដែលត្រូវសម្រេចឲ្យបាន[2447]។ ឧទាហរណ៍ ក្រុមដឹកថ្មត្រូវបានរំពឹងថាអាចដឹកថ្មចំនួន ១០ ឡានក្នុងមួយថ្ងៃ[2448]។ សាក្សី

2446 ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញិក ឆ.39 [“ក្រោយមកទើបមានពួកចិនមកជួយ ពេលចិនមក គេខួងថ្ម ដាក់កិបឲ្យថ្មផ្ទុះ”]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ.107 [“ខ្ញុំឈរមើលពីចម្ងាយ ហើយឃើញមានឡានដឹកថ្មធំៗពីខេត្តកំពតមកទម្លាក់នៅការដ្ឋានស្ទឹងហាវ ហើយមានម៉ាស៊ីនកិចបំបែកថ្មដើម្បីសាងសង់ផែ”]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.22 [“ក្នុងមួយថ្ងៃមនុស្សម្នាក់តម្រូវឲ្យជីករុន្ធសម្រាប់ដាក់រំសេវបំផ្ទុះថ្មឲ្យបានសម្រៅមួយម៉ែត្រ។ រហូតដល់ឆ្នាំ ១៩៧៧-១៩៧៨ ទើបចិននាំយកម៉ាស៊ីនខួងថ្មមក។ គេបំផ្ទុះក្រោយម៉ោង ៥ ល្ងាច ហើយនៅពេលព្រឹកបន្ទាប់ គេឲ្យអ្នកធ្វើការលីថ្មទាំងដុំៗដាក់លើឡាន ដើម្បីគេយកទៅចាក់ធ្វើផែកប៉ាល់”]។ ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.5 [“ស៖ តើលោកនៅចាំថាមានការដ្ឋានវ៉ៃថ្មនៅជិតកន្លែងលោកធ្វើការដែរឬទេ? ឆ.5៖ បាទ មានការដ្ឋានវ៉ៃថ្មនៅជិតកន្លែងធ្វើការរបស់ខ្ញុំ ពីព្រោះគេបានដាក់គ្រឿងបំផ្ទុះដើម្បីបំបែកថ្ម ដែលមានចម្ងាយប្រហែល ២ គីឡូម៉ែតពីកន្លែងធ្វើការរបស់ខ្ញុំ។ ខ្ញុំអាចឮសំឡេងផ្ទុះបំបែកថ្ម ហើយនឹងឃើញផ្សែងឡើងលើពីកន្លែងធ្វើការរបស់ខ្ញុំរៀងរាល់ថ្ងៃរវាងម៉ោង ២ និងម៉ោង ៣ រសៀល។ ការដ្ឋានវ៉ៃថ្មនោះស្ថិតនៅខាងត្បូងការដ្ឋានធ្វើការរបស់ខ្ញុំ”]។ ឯកសារ D54/9 កំណត់ហាតុស្តាប់ចម្លើយ មិន ផុន ឆ.8 [“យើងឮសូរសម្លេងផ្ទុះបំបែកថ្មរាល់ៗថ្ងៃ។ ខ្ញុំឮសូរសម្លេងបំបែកផ្ទុះថ្មរាល់ថ្ងៃនៅវេលាម៉ោង ១១ ថ្ងៃ មុនពេលខ្ញុំឈប់សំរាកហូបបាយ។ នៅពេលដែលមានការបំផ្ទុះថ្មយើងដឹងថាវាជិតដល់ពេលសំរាកបាយហើយ។ ១៥ នាទីបន្ទាប់ពីការផ្ទុះ យើងហូបបាយថ្ងៃ។ តាមតែខ្ញុំចងចាំបាន គេបំផ្ទុះយកថ្មក្នុងមួយថ្ងៃមួយម្តង”]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿន ឆ.187 [“ស៖ តើលោកមានដឹងរឿងទាក់ទងកន្លែងវ៉ៃថ្មនៅស្ទឹងហាវដែរទេ? ឆ.187៖អត់ទេ ប៉ុន្តែខ្ញុំគ្រាន់តែឮសូរគេដាក់រំសេវដើម្បីបំបែកថ្ម”]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.42 [“នឹងខ្លះទៀតទទួលបន្ទុកបាញ់ថ្ម”]។ ឯកសារ D2/7 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សារិន ឆ.16 [“ខ្ញុំបានចូលរួមក្នុងការយកថ្ម ដោយខ្ញុំជាអ្នកប្រើសន្ទូចក្នុងការស្ទូចថ្ម នាំយកទៅដាក់កន្លែងធ្វើផែ”]។ ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.118 [“គេមានម៉ាស៊ីនថ្មអីនៅទីនោះ”]។ សូមពិនិត្យផងដែរ ឯកសារ D2/23 បាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714357 [“ក្រៅពីពលកម្មមនុស្ស នៅមានគ្រឿងម៉ាស៊ីន ម៉ាស៊ីនស្ទូច និងគ្រឿងផ្ទុះ ត្រូវបានប្រើប្រាស់ផងដែរ”]។ ឯកសារ D54/12កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.22 [“មនុស្សម្នាក់តម្រូវឲ្យជីករុន្ធសម្រាប់ដាក់រំសេវបំផ្ទុះថ្មឲ្យបានសម្រៅមួយម៉ែត្រ។ រហូតដល់ឆ្នាំ ១៩៧៧-១៩៧៨ ទើបចិននាំយកម៉ាស៊ីនខួងថ្មមក”]។

2447 ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.21 [“ការងារដែលធ្វើនោះ គឺចាំបាច់ត្រូវតែធ្វើ ព្រោះគេដាក់ផែនការមកឲ្យធ្វើ”]។

2448 ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.23 [“ឧទាហរណ៍: ក្រុមជញ្ជូនថ្មអាចជញ្ជូនឲ្យបានដប់ឡានក្នុងមួយថ្ងៃ បើសិនជាមាននរណាម្នាក់យឺត ឬខ្ជិលច្រអូស គេនឹងធ្វើការប្រជុំធ្វើការទិទៀនអ្នកនោះ”]។

ម្នាក់ដែលត្រូវបានបញ្ជូនទៅធ្វើការនៅការដ្ឋានវាយថ្ម បានឆ្លើយថា ប្រសិនបើពួកគេមិនអាចសម្រេចការងារតាមផែនការកំណត់នោះទេ បរិមាណការងារនឹងត្រូវដំឡើងថែមទៀត[2449]។

618. កម្មករមិនត្រឹមតែតម្រូវឲ្យធ្វើការតែនៅការដ្ឋានវាយថ្ម និងការដ្ឋានបំបែកថ្មប៉ុណ្ណោះទេ ប៉ុន្តែ ពួកគេក៏ត្រូវធ្វើការនៅការដ្ឋានធ្វើផ្លូវ[2450] ការដ្ឋានសង់កំពង់ផែ[2451] និងការដ្ឋានសង់ផែ និង/ឬទំនប់

2449 ឯកសារ D54/33.1 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង អ៊ី ឆុន KH ERN 00964204 ["មិនថាទ័ពមិនថាអីជំនាន់ហ្នឹងលុតដំទាំងអស់ ហើយទ័ពហ្នឹងក៏យ៉ាប់ដែរ។ ស៖ លត់ដំដែរ? ឆ៖ បាទ! គេសុទ្ធតែកំណត់ ថ្មមុនដំបូងវ៉ៃ ២ នាក់អញ្ចឹងតែ ៤ ម៉ែត្រគីបទេ បើយើងវ៉ៃបានចេះតែដំឡើងរហូតដល់ ៦ នាក់ ១២ ម៉ែត្រគីប គេកំណត់ហ្មង បើយើងនេះវេទនាណាស់ ហើយមានម៉ាស៊ីនខ្លួងម៉ាស៊ីនអីមកពីណា សុទ្ធតែមនុស្សបុកហ្នឹង ដែកប្រវែងហ្នឹងបុក ហើយអ្នកបុកគេកំណត់មួយថ្ងៃរន្ធមួយម៉ែត្រ ព្រោះថ្មមិនមែនងាយស្រួលបុកទេលោកអើយ"]។

2450 ឯកសារD54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.31 ["ក្រោយមកទើបគេយកត្រាក់ទ័រឈ្លូសធ្វើផ្លូវ"]។ ឯកសារ D114/215 កំណត់ហេតុស្តាប់ចម្លើយ មាស អ៊ឹម ឆ.70 ["ការងារបច្ចេកទេសទី១ ធ្វើផ្លូវ។ ផ្លូវធ្វើពីរោងចក្រប្រេងកាតមកដល់ស្ទឹងហាវ។ ទី២ ធ្វើអាផ្លូវចុះឡើងក្នុងការដ្ឋានស្ទឹងហាវហ្នឹង ហើយនឹងឈូសពីជើងភ្នំទៅមាត់សមុទ្រស្ទឹងហាវឲ្យទៅជារាបស្មើរ"]។ ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍រវាង ក.ស.ព និង ប៉ែន សារិន EN ERN 00217560 ["ពីថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៧៦ រហូតដល់ខែ មិថុនា ឆ្នាំ ១៩៧៦ គាត់បានចូលរួមការសាងសង់ផ្លូវពីរោងចក្រប្រេងកាតទៅភូមិស្ទឹងហាវ"]។

2451 ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.22 ["គេឲ្យអ្នកធ្វើការលីថ្មទាំងដុំៗដាក់លើឡាន ដើម្បីគេយកទៅចាក់ធ្វើផែកប៉ាល់។"]។ ឯកសារ D114/60 កំពង់ផែយោធាស្ទឹងហាវ ការដ្ឋានធ្វើការងារដោយបង្ខំ របាយការណ៍ទីតាំងការដ្ឋានការងារ EN ERN 01082175 ["សាក្សីបានកំណត់អត្តសញ្ញាណទំនប់រលកនៅស្ទឹងហាវដែលធ្វើឡើងដោយថ្មដែលយកពីការដ្ឋានវាយថ្ម"] EN ERN 01082181 ["សាក្សីបានបង្ហាញទំនប់រលកទៅកាន់ ការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយបានកត់សម្គាល់ពីផ្ទាំងថ្មធំៗ ដែលធ្វើឡើងដោយអង្គភាពដែលមាន "សមាសភាពមិនល្អ" ពីការដ្ឋានវាយថ្ម"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.32 ["កងអនុសេនាតូចរបស់ខ្ញុំបំបែកថ្ម ដើម្បីកសាងផែ និងកាប់ឆ្ការព្រៃ។ យើងទើបតែយកថ្មដាក់ចូលទៅក្នុងទឹក។ ប៉ុន្តែខ្ញុំចាកចេញពីស្ទឹងហាវ ផែនោះមិនទាន់ចេញជារូបរាងនៅឡើយនោះទេ។"]។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.39 ["ក្រោយគេរំសាយ គេឲ្យកាំបិតទៅកាប់ឈើធ្វើផ្ទះ ឲ្យទៅវាយថ្មចាក់ផែនៅស្ទឹងហាវជាមួយពួកចិន។"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញិក ឆ.17 ["ខ្ញុំនៅកងកាំភ្លើងធំរហូតដល់ប្រហែលចុងឆ្នាំ១៩៧៧ បានគេរំសាយខ្ញុំពីកងកាំភ្លើងធំ ហើយបញ្ជូនខ្ញុំទៅធ្វើការនៅការដ្ឋានវាយថ្ម ដើម្បីធ្វើផែនៅស្ទឹងហាវ។"]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត់ ឆ.100-101 ["ខ្ញុំមិនចាំឈ្មោះភូមិឃុំដែលជាទីតាំងនៃការដ្ឋានវាយថ្មស្ទឹងហាវនោះទេ ប៉ុន្តែខ្ញុំស្គាល់កន្លែងនេះហៅថាស្ទឹងហាវ ហើយវាជាការដ្ឋានសាងសង់ផែ។ [...] ឆ.101៖ ខ្ញុំដឹងថាគេសាងសង់ផែថ្មីនៅកន្លែងនោះ តែខ្ញុំមិនដឹងថាមានចំនួនមនុស្សប៉ុន្មាននាក់ធ្វើការនៅកន្លែងនោះទេ។"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.8, 20, 39-40 ["នៅស្ទឹងហាវ អង្គភាពរបស់ខ្ញុំ បានចូលរួមសាងសង់កំពង់ផែ។

[...] ឆ.20៖ ដោយសារតែពុំមានសង្គ្រាមក្រោយឆ្នាំ១៩៧៥ កងអនុសេនាតូចរបស់ខ្ញុំគឺចូលរួមធ្វើស្រែ លើកទំនប់នៅអូរឈើទាល និងសាងសង់កំពង់ផែនៅស្ទឹងហាវប៉ុណ្ណោះ។ [...] ស៖ ឥឡូវយើងប្តូរប្រធានបទទៅនិយាយអំពីស្ទឹងហាវវិញម្តង។ តើលោកស្រីអាចពិពណ៌នាអំពីគម្រោងកសាងកំពង់ផែបានដែរឬទេ? ឆ.39៖ នៅស្ទឹងហាវយើងមានម៉ោងធ្វើការច្បាស់លាស់ គឺមានអ្នកធ្វើការយប់ និងមានអ្នកធ្វើការនៅវេនថ្ងៃ។ បន្ទុកការងារគឺវាអាស្រ័យទៅលើការងារដែរ។ កាលនោះយើងត្រឹមតែបានចាក់ពុម្ពសសរសម្រាប់ធ្វើកំពង់ផែប៉ុណ្ណោះ ហើយយើងធ្វើការដូចកម្មករសំណង់ដែរ។ [...] ឆ.40៖ គ្រាន់តែមនុស្សធ្វើការនៅតំបន់កំពង់ផែមានមនុស្សជាង២០០នាក់។ ខ្ញុំបានប្រាប់លោកពីមុនថា មានកងអនុសេនាធំនារីចំនួន២កងធ្វើការនៅទីនោះ។ ដូច្នេះមានគ្នារហូត២០០នាក់ហើយ។ បន្ថែមលើនោះទៀតក៏មានក្រុមបុរសៗធ្វើការនៅទីនោះដែរ។ នៅការដ្ឋានយកថ្ម គឺមានតែបុរសទេ ដែលធ្វើការទៅទីនោះ។ កន្លែងដែលគេខាំថ្មក៏មានតែបុរសដែរ ដែលធ្វើការ។ រីឯនៅកន្លែងដែលគេចាក់ពុម្ពសសរមានទាំងនារី និងបុរសធ្វើការនៅទីនោះ។"] ។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ.173, 179 ["នៅពេលនោះ ស្ទឹងហាវ មិនមានធ្វើអ្វីទេ គឺគេកំពង់សាងផែមួយ ជាផែយោធាសម្ងាត់។ [...] ស៖ លោកបាននិយាយថា កន្លែងនោះ ជាផែយោធាសម្ងាត់ តើមានកប៉ាល់ច្រើន នៅទីនោះទេ? ឆ.179៖ ជួនកាលមានកប៉ាល់ធុនបណ្តែតពីរបី ហើយជួនកាលមានកប៉ាល់ការពារពីរបី អ៊ីចឹងដែរ។"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.42 ["គេប្រាប់ពួកខ្ញុំថា គេរៀបចំកសាង ឬក៏ធ្វើកំពង់ផែ។"]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ដេត ប៊ុណ្ណា ឆ.19 ["គេហៅទំនប់រលកនៅស្ទឹងហាវ។ ត្រឹមពេលដែលគេបញ្ជូនខ្ញុំទៅទីនោះ អ្នកធ្វើការទាំងអស់នៅស្ទឹងហាវ គឺគេតម្រូវឱ្យវៃថ្មនៅការដ្ឋានយកថ្មទាំងអស់គ្នា។ តាមផែនការរបស់គេ គេគ្រោងយកថ្មនោះធ្វើជាចំណតសម្ងាត់ ដែលគេអាចជួសជុលកប៉ាល់ និងជាកន្លែងស្តុកគ្រឿងផ្ទុះ ឬអាវុធ។"]។ សូមមើល ផងដែរ ឯកសារ D114/86.7 កំណត់ហេតុស្តាប់ចម្លើយ ដេត ប៊ុណ្ណា ឧបសម្ព័ន្ធ៖ គំនូសបង្ហាញទីតាំង ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ KHN ERN 01110642។ ឯកសារ D54/109 កំណត់ហេតុស្តាប់ចម្លើយ សៅ សំ ឆ.15 ["ខ្មែរក្រហមក៏បានទៅធ្វើផែយោធាមួយខ្លួនឯងនៅស្ទឹងហាវ ហើយប្រើផែនៅរាមជាផែស៊ីវិលវិញ។"]។ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ុ ឆ.15 ["គេក៏បានដកខ្ញុំពីកងវរសេនាតូចកាំភ្លើងធំ ឱ្យទៅនៅស្ទឹងហាវ។"]។ ឯកសារ D54/45 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.21 ["ស៖ តើលោកស្គាល់ស្ទឹងហាវដែរឬទេ? ឆ.21៖ បាទ ខ្ញុំស្គាល់ស្ទឹងហាវ ពីព្រោះនៅពេលដែលខ្ញុំ និងយោធាផ្សេងទៀតមកពីកោះទៅចូលរួមវគ្គរៀនសូត្រ យើងទៅចូលលេងនៅផែដែលគេសង់ថ្មី។ ពេលនោះ មិត្តភក្តិមកជាមួយគ្នាប្រាប់ខ្ញុំថា គេកំពុងសង់ផែថ្មីសម្រាប់ចតកប៉ាល់ចម្បាំង។ អ្នកដែលធ្វើការនៅផែនោះប្រាប់ខ្ញុំថា ផែថ្មីនេះគឺជាកន្លែងសម្ងាត់ ហើយមិនបើកឱ្យអ្នកណាចេញចូលបានទេ។ ដោយសារតែខ្ញុំធ្វើការនៅជាមួយគ្នា គេបើកឱ្យខ្ញុំចូលមើលបាន។"]។ ឯកសារ D59/2/2.16a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00735592 ["ស៖ មកស្ទឹងហាវគឺនេះទេ តែគេមានធ្វើផែធ្វើអីដែរ? ឆ៖ មាន។"]។ ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964124 ["ស៖ មកនៅស្ទឹងហាវគឺនេះទេ តែគេមានធ្វើផែធ្វើអីដែរ? ឆ៖ មាន។"]។ ឯកសារ D54/42.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហេង វៀច KH ERN 00967574-00967575 ["យកមកដឹកផ្លូវធ្វើផែយោធានៅស្ទឹងហាវ [...] អាហ្នឹងកន្លែងខ្ញុំនៅ និងស្ទឹងហាវដីប្រហែល៩គីឡូ"] KH ERN 00967575 ["ស៖ ទៅកន្លែងសាងសង់កំពង់ផែ? ឆ៖ បាទ ព្រោះខ្ញុំមានភារកិច្ចទៅក្រឡឹងព្រោះយើងជាងខាង១៧០"]។ ឯកសារ D54/106.2 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សាន់ កា

រលកដែរ[2452]។ ការធ្វើផ្លូវ គឺធ្វើផ្លូវពីរោងចក្រប្រេងកាត[2453] ទៅស្ទឹងហាវ និងធ្វើ "ផ្លូវចុះឡើងក្នុងការដ្ឋានស្ទឹងហាវ"[2454]។ លើសពីនេះទៀត ការងាររួមមាន៖ លើកថ្មដាក់លើឡាន[2455] គាស់ដុំថ្ម[2456]

---

ន ហៅ ប៊ុត EN ERN 0093445 ["ចឹងថាមានផែស្ទឹងហាវ? ឆ៖ ផែស្ទឹងហាវមិនទាន់មានអីទេ គ្រាន់តែគម្រោងថាធ្វើផែយោធា។"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ ឆ.141-142, 149 ["សៈ ពេលលោកនៅក្នុងកងទ័ពជើងទឹកខ្មែរក្រហមនៅកំពង់សោម តើលោកធ្លាប់ឮឈ្មោះស្ទឹងហាវទេ? ឆ.141៖ បាទ។ សៈ តើលោកបានឮអ្វីខ្លះពីស្ទឹងហាវ? ឆ.142៖ គេប្រាប់ជាផែនការតែម្តង គឺគេធ្វើជាកំពង់ផែយោធា។ [...] ឆ.149៖ ការដ្ឋានហ្នឹង ខ្ញុំធ្លាប់ឮមានតែកន្លែងធ្វើកំពង់ផែហ្នឹង"]។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.18 ["កាលពីពេលហ្នឹង តើផែថ្មត្រូវបានកសាងបានប្រវែងប៉ុន្មានម៉ែត្រទៅក្នុងសមុទ្រ? ឆ.18៖នៅពេលនោះ ខ្ញុំបានឮថា គេកសាងបានប្រវែងប្រហែល ៥០០ម៉ែត្រលយចូលទៅក្នុងសមុទ្រ។"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ.111 ["តាមខ្ញុំដឹង ផែនោះធ្វើមិនទាន់ហើយនៅឡើយទេនៅពេលដែលរបបខ្មែរក្រហមត្រូវបានផ្តួលរលំ។"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង សុំ ឆ.271-272 ["សៈ ឥឡូវយើងត្រឡប់មកឆ្នាំ ១៩៧៦វិញ។ នៅឆ្នាំ ១៩៧៦ អ្នកណាជាអ្នកគ្រប់គ្រងការដ្ឋានរ៉ែថ្មនៅអូរម្លូ? ឆ.271: តាញ៉ាន់។ គាត់កាន់ខាងភស្តុភារ។ សៈ តើលោកដឹងថាគេយកថ្មដែលគេរ៉ៃនោះទៅធ្វើអ្វីទេ? ឆ.272៖ ថ្មហ្នឹង គេយកមកសាងសង់កំពង់ផែនៅស្ទឹងហាវ។"]។ ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.118 ["សៈ នៅផែមានទាហានច្រើនទេ? ឆ.118៖ មានកងទ័ពការពារចិនប្អូនប្រាំនាក់។ គេមានម៉ាស៊ីនថ្មអីនៅទីនោះ។"]។ ឯកសារ D1.3.13.13 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ ទូច សឿលី EN ERN 00217574 ["នៅក្នុងរបបសីហនុ និង លន់ នល់ មូលដ្ឋានកងនាវាធំជាងគេគឺស្ថិតនៅរាម។ នៅក្នុងសម័យខ្មែរក្រហមមូលដ្ឋានកងនាវាត្រូវបានផ្លាស់ប្តូរ។ ពួកគេដឹកគ្រាប់រំសេវទៅរាម បន្ទាប់មកក៏បើកកប៉ាល់ទៅកាន់អូរឈើទាល កោះរ៉ុង ឬស្ទឹងហាវ។ ការសាងសង់បានចាប់ផ្តើមនៅស្ទឹងហាវនៅក្នុងឆ្នាំ១៩៧៦ ការសាងសង់នោះកាន់តែសំរុកខ្លាំងនៅឆ្នាំ១៩៧៧ ដោយមានការចាក់ដីចូលទៅក្នុងទឹក។ សំណង់នោះប្រហែលជាត្រូវបានធ្វើឡើងដោយយោធាកងវរសេនាធំលេខ២២ ប៉ុន្តែគាត់មិនបានចាំឈ្មោះមេបញ្ជាការឡើយ។ មានអ្នកបច្ចេកទេសចិនដែរ។ មិនមែនជាការសាងសង់ចាំបាច់អីទេ ពួកគេគ្រាន់តែបានចាក់ដីចូលទៅក្នុងទឹកប៉ុណ្ណោះ។"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហៀង រ៉េត KH ERN 009266545 ["សៈ កាលហ្នឹងផែកប៉ាល់ជើងទឹកមានប៉ុន្មាន? ឆ៖ កាលហ្នឹងមានតែផែរាមទេ ដល់ក្រោយមកយើងបង្កើតផែបណ្តោះអាសន្នហ្នឹងនៅកោះរ៉ុងមួយ នៅអូរឈើទាលមួយ តែត្រៀមធ្វើផែថ្មមួយទៀតហ្នឹងនៅស្ទឹងហាវ។"]។

2452 ឯកសារ D54/35.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប្រាក់ សុខា KH ERN ERN 00964253 ["សៈ ចឹងកាលហ្នឹងរ៉ៃថ្មយកទៅធ្វើអ្វីគេ? ឆ៖ យកទៅធ្វើផែយកទៅធ្វើអីហ្នឹង យកទៅធ្វើផែធ្វើទំនប់អីហ្នឹង នៅជីកអណ្តូងជីអីហ្នឹង។"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ សុខន ឆ.73 ["កាលដែលខ្ញុំរួមរស់នៅការងារនៅការដ្ឋាននោះ គឺឆ្លងកាត់ការលំបាកវេទនាខ្លាំងណាស់។ គេមិនប្រើដោយគ្រឿងម៉ាស៊ីនទៅលើកដាក់ទេ គឺប្រើកម្លាំងមនុស្សទាំងស្រុង ដើម្បីលីសែងថ្មដាក់ឡាន។ អ៊ីចឹងហើយបានកម្លាំងពួកខ្ញុំប្រឹងលីខ្លាំងឥតឈប់ឈរ ដូច្នេះហើយបានទប់ទំនប់ធ្វើផែបានវែង។"]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ុន យ៉ើ ឆ.48-49 ["សៈ តាមលោកដឹង តើមានមនុស្សធ្វើការនៅការដ្ឋានស្ទឹងហាវសរុបប្រហែលប៉ុន្មានដែរ? ឆ.48៖ វាមានពីរការដ្ឋានសម្រាប់ការ

ចាក់គ្រួស[2457] កាប់ព្រៃ[2458] សង់ជម្រក និងរចនាសម្ព័ន្ធផ្សេងទៀត[2459] ជួសជុលនាវាយោធា[2460] ធ្វើផ្លូវដែក[2461] នេសាទ[2462] ជីករណ្ដៅ[2463] ជីកស្រះ[2464] ជីកអណ្ដូង[2465] ធ្វើស្រែ និងដាំដំណាំផ្សេងទៀត[2466] និងឃ្វាលគោក្របី[2467]។

---

ងារ។ ការដ្ឋានហ្នឹង គេជីកដី រែថ្ម ដើម្បីបង្កើតជាចាក់ទំនប់រលកថ្មី។ ការដ្ឋានមួយទៀត រែថ្មដូចគ្នា។ រែថ្ម ដើម្បីចាក់ទំនប់រលកថ្មី។ សៈ តើនៅស្ទឹងហាវ គេឲ្យលោកធ្វើអ្វីខ្លះដែរ? ឆ.49៖ នៅស្ទឹងហាវ គេឲ្យខ្ញុំរែថ្ម ដើម្បីដឹកចាក់ទំនប់រលក។"]។

2453 សូមមើល ឧទាហរណ៍ ឯកសារ D114/113 កំណត់ហេតុស្ដាប់ចម្លើយ កឹម ម៉េន ឆ.176 ["សៈ តើស្ទឹងហាវជាអ្វី? ឆ.176៖ ពីដើមថាមានរោងចក្រចម្រាញ់ប្រេងកាត។"]។ សូមមើល ផងដែរ ឯកសារ D114/83.2 កំណត់ហេតុស្ដាប់ចម្លើយ សុខ នាង ឧបសម្ព័ន្ធ៖ គំនូសបង្ហាញទីកន្លែង ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៥ KH ERN 00977483។ ឯកសារ D54/68.1 កំណត់ហេតុស្ដាប់ចម្លើយ នង នេត ឧបសម្ព័ន្ធ៖ គំនូសបង្ហាញទីកន្លែងនិងផ្លូវ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00977482។ ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977456 ["អាផ្លូវដដែលទប់ស្កាត់នៅមាត់សមុទ្រណោក នៅសង្កាត់ស្ទឹងហាវណោក ទៅធ្វើនុំង។"]។

2454 ឯកសារ D114/215 កំណត់ហេតុស្ដាប់ចម្លើយ មាស អ៊ឹម ឆ.70 ["ការងារបច្ចេកទេសទី១ ធ្វើផ្លូវ។ ផ្លូវធ្វើពីរោងចក្រប្រេងកាតមកដល់ស្ទឹងហាវ។ ទី២ ធ្វើអាផ្លូវចុះឡើងក្នុងការដ្ឋានស្ទឹងហាវហ្នឹង ហើយនិងឈូសពីជើងភ្នំនៅមាត់សមុទ្រស្ទឹងហាវហ្នឹងឲ្យទៅជារាបស្មើ។"]។

2455 ឯកសារ D54/77 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.39 ["ពីដំបូងឡើយ យើងធ្វើការដោយផ្ទាល់ដៃ។ គេឲ្យដែកត្បែងមួយដើម ឲ្យជីកថ្មនៅលើកូនភ្នំ បន្ទាប់មកយើងលើកថ្មដាក់ចូលទៅក្នុងឡានទ្រុង។ ដុំថ្មខ្លះទាល់តែមនុស្ស២-៣នាក់ ទើបលើកដាក់លើឡានរួច។ ក្នុង១ថ្ងៃ យើងធ្វើបានតែមួយឡានទេ។ ក្រោយមកទើបមានពួកចិនមកជួយ ពេលចិនមក គេខួងថ្ម ដាក់កិបឲ្យថ្មផ្ទុះ។ នៅពេលនោះ ទើបការងារស្រួលជាងបំបែកដោយដៃបន្តិច។"]។ ឯកសារ D114/121 កំណត់ហេតុស្ដាប់ចម្លើយ សួន ផ ឆ.42 ["ពួកយើងធ្វើការជាក្រុមដោយការងារចម្បងគេឲ្យវាយថ្មបំបែកនឹងញញួរ ចំណែកក្រុមផ្សេងៗទៀត គេសែងថ្មឡើងឡាន និងខ្លះទៀតទទួលបន្ទុកបាញ់ថ្ម។"]។

2456 ឯកសារ D54/3.1 ហួរ ជា ប្អូនឆ្នាំជាមួយខ្មែរក្រហម (សម្រង់) KH ERN 01506936 ["ការងារយើងគឺត្រូវគាស់ដុំថ្មដែលនៅជាប់នឹងកៀនសមុទ្រធម្មជាតិ មានរាងជាអក្សរ "អ៊ុយ" ដែលមានទទឹងប្រហែលជាង ៥០ម៉ែត្រ និងបណ្ដោយ ៣០០ម៉ែត្រ។"]។

2457 ឯកសារ D4.1.754 ការចាត់ចែងតំបន់ ៣៧ និងកម្លាំងកងពលធំលេខ ៣/១៦៤ នៅលើកោះតាង បន្ទាប់ពីការនាវាម៉ាយ៉ាហ្គេសរួចមក KH ERN 00791383 ["នៅក្នុងឆ្នាំ ១៩៧៨ ប្រភពព័ត៌មានត្រូវបានបញ្ជូនទៅវាយបំបែកថ្មនៅជិតស្ទឹងហាវ"]។

2458 ឯកសារ D54/8 កំណត់ហេតុស្ដាប់ចម្លើយ ឌុល សុង ឆ.27, 32 ["ក្រោយមកគេបញ្ជូនកងរបស់ខ្ញុំទៅស្ទឹងហាវ ដើម្បីកាប់ឆ្ការព្រៃ កសាងផ្លូវថ្នល់ និងវាយបំបែកថ្ម។ [...] ឆ.32៖ កងអនុសេនាតូចរបស់ខ្ញុំបំបែកថ្ម ដើម្បីកសាងផែ និងកាប់ឆ្ការព្រៃ។"]។ ឯកសារ D54/100 ឡាយ ប៊ុនហាក់ ឆ.65 ["ខ្ញុំបានទៅកាប់ឆ្ការព្រៃនៅស្ទឹងហាវ"]។ ឯកសារ D54/77 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.36 ["នៅពេលដែលយើងមកដល់ដំបូង គេឲ្យយើងកាប់ព្រៃ និងសង់

រោងសម្រាប់ស្នាក់នៅ។"]។ ឯកសារ D54/87 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត់ ឆ.100 ["ខ្ញុំទៅទីនោះដំបូង គឺគេឱ្យទៅកាប់ឆ្ការព្រៃ ដើម្បីឱ្យធ្វើទៅការដ្ឋាននោះឯង។"]។ ឯកសារ D54/99 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.32-33 ["ពេលរៀនចប់ គេបញ្ជូនខ្ញុំទៅធ្វើការជាមួយចិន ទៅកាប់ឆ្ការព្រៃដើម្បីចិនសិក្សាពីគម្រោងសាងសង់ផែនាវាថ្មីនៅស្ទឹងហាវ។ [...] ឆ.33៖ ខ្ញុំធ្វើការនៅទីនោះបាន៣ខែ ខ្ញុំបានទៅកាប់ឆ្ការព្រៃនៅស្ទឹងហាវ។ "]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.19 ["ទៅដល់ឆ្នាំដំបូង គេឱ្យកាប់ព្រៃ [...] ឆ្ការព្រៃហ្នឹងក៏លើសលុបប្រហែល៥០ទៅ១០០ហិចតា។"]។ ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន KH ERN 01301516 ["ពួកវាយកខ្ញុំមកចូលឆ្នាំ១៩៧៧ យកយើងមកកាប់ព្រៃគុប ជិតស្ទឹងហាវ។"]។

2459 ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.36 ["នៅពេលដែលយើងមកដល់ដំបូង គេឱ្យយើងកាប់ព្រៃ និងសង់រោងសម្រាប់ស្នាក់នៅ។"]។ ឯកសារ D114/104 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.39 ["ក្រោយមកគេរំសាយ គេឱ្យកាំបិតទៅកាប់ឈើធ្វើផ្ទះ ឱ្យទៅវាយថ្មចាក់ផែនៅស្ទឹងហាវជាមួយចិន។"]។ ឯកសារ D54/33.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ី ឆុន KH ERN 00964204 ["គេកែនទ័ពដែលមិនទាន់មានទ័ពអីនៅហ្នឹង គេកែនទៅធ្វើរោងធ្វើអីសម្រាប់ឱ្យកម្មករ កាលហ្នឹងគេថាគេធ្វើផ្លូវរថភ្លើងទៅដល់ហ្នឹង គេមិនយកកម្មករទៅហ្នឹងឱ្យទៅធ្វើរោងធ្វើអី ធ្វើរោងវែងៗ ហើយយកទ័ពទៅធ្វើណា គេថាសម្រាប់កម្មករដែលមកធ្វើផ្លូវរទេះភ្លើងហ្នឹងមកស្នាក់ តែឃើញមកដែរហ្នឹង [...] ស៖ កម្មករហ្នឹងមែនកងទ័ពទេ? ឆ៖ មិនមែនកងទ័ពទេ កម្មករ តែខ្មែរយើងហ្នឹង។"]។ ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.2, 4 ["នៅពេលនោះ ហឿន បាននាំពួកខ្ញុំពីត្រពាំងក្រឡឹងតាមឡានទៅកំពង់សោម ហើយបន្ទាប់មកទៅស្ទឹងហាវ ដើម្បីធ្វើស្ពានលូឆ្លងកាត់ផ្លូវរថភ្លើងនៅកន្លែងនោះ។ [...] ឆ.4៖ [...] មានផ្លូវរថភ្លើងឆ្លងកាត់ផ្លូវថ្នល់នោះ ដែលនៅជិតការដ្ឋានធ្វើការរបស់ខ្ញុំ។ កន្លែងធ្វើការរបស់ខ្ញុំស្ថិតនៅចម្ងាយប្រហែល៤០ ទៅ ៥០ម៉ែត្រភាគខាងជើងកន្លែងផ្លូវរថភ្លើងឆ្លងកាត់នោះ។"]។ សូមមើលផងដែរ ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.24 ["ឱ្យខ្ញុំ ធ្វើការដូចខ្ញុំនិយាយកាលមុនអ៊ីចឹង ឱ្យរែកដីដាក់អំពៅ ដាក់អី។ ដាំដំឡូងឈើយូរ ធ្វើស្ពានអូរត្រេះ ហ្នឹងថ្ងៃជាមួយគ្នា។"]។

2460 ឯកសារ D54/113 កំណត់ហេតុស្តាប់ចម្លើយ លៀង បៀ ឆ.100 ["នៅក្នុងចម្លើយរបស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយអំពីសំណង់មួយនៅស្ទឹងហាវ តើសំណង់នោះជាអ្វី? ឆ.100៖ សំណង់នោះគឺសម្រាប់ជួសជុលកប៉ាល់យោធា។"]។

2461 ឯកសារ D234/2.1.138 នង នេត ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ម៉ោង 11.04.23-11.06.35 ["ចេញទៅពីត្រពាំងក្រឡឹង ឡើងទៅកំពង់សោមហ្នឹង តំបន់ស្ទឹងហាវ ត្រង់នុំង គេដាក់ឈ្មោះ ស្ទឹងហាវៗ គេឱ្យខ្ញុំទៅធ្វើផ្លូវរទេះភ្លើងថ្មីនោះ ហើយធ្វើលូ ដាក់លូកន្លែងនោះ។ គេដកពីត្រពាំងក្រឡឹងទៅ ទៅកន្លែងនុំងទៀតហើយ ទៅដល់ម្តុំស្ទឹងហាវនោះ។"]។ ឯកសារ D54/33.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ី ឆុន KH ERN 00964204 ["ហើយយកកងទ័ពទៅធ្វើណា គេថាសម្រាប់កម្មករដែលមកធ្វើផ្លូវរទេះភ្លើងហ្នឹងមកស្នាក់ [...] ស៖ កម្មករហ្នឹងមែនកងទ័ពទេ? ឆ៖ មិនមែនកងទ័ពទេ កម្មករ តែខ្មែរយើងហ្នឹង។"]។ ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយសុក វណ្ណា ឆ.28 ["ស៖ តើកងពលលេខ៣ ទទួលបន្ទុកធ្វើផ្លូវរថភ្លើងពីចំណុចណាដល់ចំណុចណា? ឆ.28៖ តាមខ្ញុំដឹង កងវរសេនាធំរបស់ខ្ញុំធ្វើពីវាលរេញទៅកំពត ហើយវរសេនាធំលេខ៣១ ដែលមានមេបញ្ជាការឈ្មោះ សារី ធ្វើពីវាលរេញទៅស្ទឹងហាវ។"]។ សូមមើល ផងដែរ ឯកសារ D1.3.32.35 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ

ប្រាជ្ញ សាក់ KH ERN 00051830 ["ទៅខ្លួនទទេទៅឡើងកប៉ាល់ទៅឡើងកោះឆ្លងពីកោះមកតាមស្ទឹងហាវមកកើតមកតាមព្រៃផ្លូវរទេះភ្លើងថ្មីគេទើបកាប់"]។ ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.4 ["នៅពេលនោះ គេធ្វើផ្លូវរថភ្លើងថ្មីតាមបណ្តោយផ្លូវរថភ្លើងចាស់។"]។ ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.18 ["ចំពោះពួកកម្មករផ្លូវរថភ្លើងថ្មី។"]។

2462 ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.13 ["ពេលខ្ញុំចេញពីកោះតាងនៅពាក់កណ្តាលឆ្នាំ ១៩៧៦ ខ្ញុំត្រូវបានចាត់តាំងឱ្យខួងថ្ម។ នៅដើមឆ្នាំ ១៩៧៧ ខ្ញុំត្រូវបានគេចាត់តាំងឱ្យមកនៅយោធាជើងគោកឱ្យធ្វើជាអ្នកបើកទូក។ នៅក្នុងកងនេសាទមានទូកចំនួន៤។ ក្នុងទូកមួយមានអ្នកធ្វើការ៧នាក់នៅលើទូក។ យើងនេសាទត្រីដើម្បីផ្គត់ផ្គង់ការដ្ឋានវាយថ្ម។"]។

2463 ឯកសារ D54/35 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.17 ["ខ្ញុំត្រូវបានគេបញ្ជូនទៅស្ទឹងហាវ នៅទីនោះ ខ្ញុំត្រូវគេឱ្យជីករណ្តៅមូលមានអង្កត់ផ្ចិត ៣០ម៉ែត្រជម្រៅ១០ម៉ែត្រនៅលើភ្នំផ្នែកខាងក្រោមភ្នំដែលមានផ្ទះភៀវចិននៅពីខាងលើ។"]។

2464 ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ឹម នី KH ERN 00964125 ["ដោយកំណត់ឱ្យធ្វើការការងារអ៊ីចឹងណ៎ា ត្រូវធ្វើការងារអី ត្រូវរែកដី ឬក៏ជីកដីធ្វើស្រះធ្វើអីណា"]។

2465 ឯកសារ D54/35.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប្រាក់ សុខា KH ERN ERN 00964253 ["ស៖ ចឹងកាលហ្នឹងវ៉ៃថ្មយកទៅធ្វើអ្វីគេ? ឆ៖ យកទៅធ្វើផែយកទៅធ្វើអីហ្នឹង យកទៅធ្វើផែធ្វើទំនប់អីហ្នឹង នៅជីកអណ្តូងជីអីហ្នឹង។"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.24 ["គឺមានការដ្ឋានធ្វើការជាច្រើននៅតំបន់ស្ទឹងហាវ រាល់ព្រឹកៗ ពួកយើងជួបជុំគ្នា ដើម្បីការរង់ចាំការចាត់តាំងការងារផ្សេងៗគ្នា ពួកយើងខ្លះត្រូវគេបញ្ជូនឱ្យបំបែកថ្ម និងខ្លះទៀតឱ្យទៅជីអណ្តូង និងខ្លះទៀត គេបញ្ជូនឱ្យទៅកសាងផែ។"]។

2466 ឯកសារ D54/33.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ី ឆុន KH ERN 00964206 ["ជួនកាលគេឱ្យធ្វើស្រែផង មិនថាទ័ពមិនថាប្រជាជនទេ កន្លែងណាក៏ធ្វើដែរ អត់ទំនេរទេ សូម្បីតែទ័ពហ្នឹងក៏អ៊ីចឹងដែរ។"]។ ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.24 ["ឱ្យខ្ញុំ ធ្វើការដូចខ្ញុំនិយាយកាលមុនអ៊ីចឹង ឱ្យរែកជីដាក់អំពៅដាក់អី។ ដាំដំឡូងឈើយូរ ធ្វើស្ពានអូរត្រេះ ហ្នឹងថ្ងៃជាមួយគ្នា។"]។ ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ សៀង EN ERN 00217566 ["ពេលនៅជីគោក គាត់បានចូលរួមធ្វើស្រែចំការនៅស្ទឹងហាវដាំដំឡូង អំពៅ និងស្រូវក្នុងស្រែតូចៗ។"]។ ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង ឆុន ឆ.20 ["គេឱ្យយើងដាំស្រូវធ្វើស្រែ"]។ ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977454 ["ដល់ទៅគេឱ្យធ្វើស្រែនៅសហករណ៍ស្ទឹង។ ទៅបានប្រហែល១០ថ្ងៃ គេឱ្យខ្ញុំកាន់ក្របីម៉ានឹមទៀត។"]។ ឯកសារ D59/2/2.14a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ លាង បៀ KH ERN 00732812 ["ស៖ ចឹងគេថាយកទៅវ៉ៃថ្មយកអ្នកមានកំហុសហ្នឹងទៅវ៉ៃថ្មហើយយកទៅធ្វើផែនៅស្ទឹងហាវអៅនោះ ពូដឹងដែរហ្នឹង? ឆ៖ អត់ដឹង បើដឹង ដឹងរឿងធ្វើស្រែ ព្រោះមានម្នាក់នោះធ្លាប់តែទៅនេះដល់ពេលវៀតណាមចូលមកហ្នឹង។"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.19 ["ទៅដល់ឆ្នាំដំបូង គេឱ្យកាប់ព្រៃ ដាំដំណាំដូចជាដាំអំពៅ ចេក និងដំឡូង។ "]។ ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន KH ERN 01301516 ["ឱ្យពួកខ្ញុំដាំដំណាំ ដូចជាពោត"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.36 ["រួចហើយគេឱ្យ

619. ជាទូទៅ ជនរងគ្រោះតម្រូវឲ្យធ្វើការពីម៉ោង ៦ ឬ ៧ ទៅដល់ម៉ោង ១១ ព្រឹក[2468] និងពីម៉ោង ១ រសៀល ដល់ម៉ោង ៥ ល្ងាច[2469]។ ប៉ុន្តែ មានកម្មករខ្លះត្រូវងើបពីម៉ោង ៤ ភ្លឺ[2470] និងធ្វើការរហូត

---

យើងដាំដំឡូងមី និងអំពៅ។"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.19 ["ទៅដល់ឆ្នាំដំបូង គេឲ្យកាប់ព្រៃ ដាំដំណាំ ដូចជាដាំអំពៅ ចេក និងដំឡូង។"]។ ឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ សៀង EN ERN 00217566 ["ពេលនៅដីគោក គាត់បានចូលរួមធ្វើស្រែចំការនៅស្ទឹងហាវ ដាំដំឡូង អំពៅ និងស្រូវក្នុងស្រែតូចៗ។"]។ ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន EN ERN 01301516 ["គេឲ្យពួកខ្ញុំដាំដំណាំ ដូចជាពោត ដំឡូងជ្វា ដំឡូងឈើ អំពៅ"]។

2467 ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977454 ["ដល់ទៅគេឲ្យធ្វើស្រែនៅសហករណ៍ស្ទឹង។ ទៅបានប្រហែលជា១០ថ្ងៃ គេឲ្យខ្ញុំកាន់ក្របីម៉ានឹមទៀត។"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង សុំ ឆ.303 ["ស៖ តើលោកធ្វើអ្វីនៅស្ទឹងហាវ? ឆ.303៖ គេឲ្យខ្ញុំទៅចិញ្ចឹមមាន់។"]។ ឯកសារ D54/9 កំណត់ហេតុស្តាប់ចម្លើយ មិន ផុន ឆ.6 ["ក្នុងរយៈពេលរស់នៅស្ទឹងហាវខ្ញុំហ្វឹកហ្វឺនបាញ់កាំភ្លើងត្បាល់ ៨២ម.ម។ ខ្ញុំត្រូវបានចាត់តាំងឲ្យថែទាំដំរីមួយក្នុងចំណោមដំរីរបស់កងខ្ញុំដែលទុកប្រើសម្រាប់ដឹកនាំសម្ភារៈធ្ងន់ៗ។"]។

2468 ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.21 ["ធ្វើការពីម៉ោង៧ព្រឹក ដល់ម៉ោង១១ ហើយឈប់សម្រាកបាយថ្ងៃត្រង់ ហើយពេលថ្ងៃចាប់ពីម៉ោង១៣ រហូតដល់ម៉ោង១៧។"]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.21 ["យើងធ្វើការចាប់ពីម៉ោង ៧ព្រឹក ដល់ម៉ោង ១១ថ្ងៃត្រង់ សម្រាកហូបបាយ។ ពេលរសៀលពីម៉ោង ១ ដល់ម៉ោង ៥ល្ងាច។"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.36 ["ម៉ោង៧ព្រឹក ទើបយើងទៅធ្វើការនៅកន្លែងវាយថ្ម ហើយធ្វើការរហូតដល់ម៉ោង១១ ទើបឡើងហូបបាយ។"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.42 ["យើងធ្វើការម៉ោង៧ព្រឹករហូតដល់ម៉ោង៥ល្ងាចដោយសម្រាកហូបថ្ងៃត្រង់ពីម៉ោង១១ ដល់ម៉ោង១។"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.44 ["ពួកយើងចេញពីកន្លែងរស់នៅម៉ោងប្រាំពីរកន្លះ ហើយឈប់ធ្វើការនៅម៉ោងដប់មួយថ្ងៃត្រង់ ដើម្បីហូបបាយថ្ងៃត្រង់។"]។ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.235 ["ធ្វើពីម៉ោង៧ព្រឹក ដល់ម៉ោង១១"]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន យ៉ើ ឆ.61 ["ស៖ តើលោកធ្វើការពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានដែរ កាលនៅការដ្ឋានស្ទឹងហាវ? ឆ.61៖ ពីម៉ោង៧ ទល់ម៉ោង១១ សម្រាក។"]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.28 ["ម៉ោងការងារគឺតិចជាង ដោយយើងចាប់ផ្តើមម៉ោងប្រាំមួយដល់ម៉ោងដប់កន្លះ ហើយបន្តពៅម៉ោងមួយកន្លះ ដល់ម៉ោងបួនកន្លះ ឬប្រាំល្ងាច។"]។

2469 ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.21 ["ធ្វើការពីម៉ោង៧ព្រឹក ដល់ម៉ោង១១ ហើយឈប់សម្រាកបាយថ្ងៃត្រង់ ហើយពេលថ្ងៃចាប់ពីម៉ោង១៣ រហូតដល់ម៉ោង១៧។"]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាស ឆ.21 ["យើងធ្វើការចាប់ពីម៉ោង ៧ព្រឹក ដល់ម៉ោង ១១ថ្ងៃត្រង់ សម្រាកហូបបាយ។ ពេលរសៀលពីម៉ោង១ ដល់ម៉ោង ៥ល្ងាច។"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.36 ["ពេលថ្ងៃយើងចាប់ធ្វើការពីម៉ោង១ថ្ងៃត្រង់ រហូតដល់ម៉ោង៥ល្ងាច ទើបឡើងហូបបាយល្ងាច។"]។ ឯកសារ D114/121

ដល់ម៉ោង ៩ យប់[2471]។ សាក្សី នង នេត បានពន្យល់ថា កម្មករអាចសម្រាកបាន ១០ នាទី ពីរដង ក្នុងមួយថ្ងៃប៉ុណ្ណោះ[2472]។ បន្ទាប់ពីធ្វើការងារប្រចាំថ្ងៃរួច កម្មករខ្លះត្រូវបានតម្រូវឱ្យដាំអំពៅ និងដំឡូងរហូតដល់ម៉ោង ៧ យប់[2473] ហើយសាក្សីផ្សេងទៀតបានរៀបរាប់ពីការងារពេលយប់ រួមទាំងក្នុងពេលភ្លៀងផងដែរ[2474]។ ដូចសាក្សីម្នាក់បានបញ្ជាក់ "យើងធ្វើការយ៉ាងធ្ងន់ទាំងយប់ទាំងថ្ងៃ"[2475]។

620. ធាតុផ្សំបន្ថែមនៃការបង្ហាញពីភាពជាម្ចាស់របស់ខ្មែរក្រហមទៅលើទាសករទាំងនោះ ក៏មានរៀបរាប់នៅក្នុងឧក្រិដ្ឋកម្មផ្សេងទៀតនៅទីតាំងឧក្រិដ្ឋកម្មនេះដែរ។

---

កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.42 ["យើងធ្វើការពីម៉ោង៧ព្រឹករហូតដល់ម៉ោង៥ល្ងាចដោយសម្រាកហូបបាយថ្ងៃត្រង់ពីម៉ោង១១ ដល់ម៉ោង១។"]។ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.235 ["ចាប់ផ្តើមធ្វើម្តងទៀតពីម៉ោង១ ដល់ម៉ោង ៥ល្ងាច។"]។ សូមមើលផងដែរ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.44 ["ពួកយើងចេញពីកន្លែងរស់នៅម៉ោងប្រាំពីរកន្លះ ហើយឈប់ធ្វើការនៅម៉ោងដប់មួយថ្ងៃត្រង់ ដើម្បីហូបបាយថ្ងៃត្រង់។ យើងបន្តធ្វើការទៀតនៅម៉ោងពីររសៀលរហូតដល់ម៉ោងប្រាំល្ងាចបានឈប់។"]។

2470 ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន KH ERN 01301516 ["ពួកយើងត្រូវក្រោកធ្វើការពីម៉ោងបួនព្រឹក"]។ ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង អុន ឆ.20 ["ជួនកាលយើងភ្ញាក់ទៅធ្វើការនៅម៉ោង ៤ ព្រឹក"]។

2471 ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង អុន ឆ.20 ["ជួនកាលយើងភ្ញាក់ទៅធ្វើការនៅម៉ោង ៤ព្រឹក ហើយឈប់នៅម៉ោង ៩យប់។"]។

2472 ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.22 ["យើងគ្រាន់តែធ្វើការពីម៉ោង៧ព្រឹក រហូតម៉ោង១១ ហើយឈប់សម្រាក១០នាទី នៅម៉ោង៩កន្លះ។ នៅពេលថ្ងៃរសៀល ចាប់ធ្វើការពីម៉ោង១ ដល់ម៉ោង៥ល្ងាច ហើយឈប់សម្រាក១០នាទីនៅម៉ោង៣កន្លះរសៀល។"]។

2473 ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.36 ["នៅម៉ោង៥កន្លះ យើងទៅដាំអំពៅនិងដំឡូងទៀតរហូតដល់ម៉ោង៧យប់។"]។

2474 ឯកសារ D2/7 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សារិន ឆ.10 ["យើងត្រូវធ្វើការទាំងភ្លៀង ទាំងយប់រហូតដល់ម៉ោង ០៩ ឬ ១២ យប់។"]។ ឯកសារ D2/7 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សារិន ឆ.10 ["យើងត្រូវធ្វើការទាំងភ្លៀង ទាំងយប់រហូតដល់ម៉ោង ០៩ ឬ ១២ យប់។"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.39 ["ស៖ ឥឡូវយើងប្តូរប្រធានបទទៅនិយាយអំពីស្ទឹងហាវវិញម្តង។ តើលោកស្រីអាចពិពណ៌នាអំពីគម្រោងកសាងកំពង់ផែបានដែរឬទេ? ឆ.39៖ នៅស្ទឹងហាវយើងមានម៉ោងធ្វើការច្បាស់លាស់ គឺមានអ្នកធ្វើការយប់ និងមានអ្នកធ្វើការនៅវេនថ្ងៃ។"]។

2475 ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង អុន ឆ.20។

## ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

621. ស្ទឹងហាវជាការដ្ឋានលត់ដំ[2476] ហើយកម្មករជាទាសករនៅស្ទឹងហាវភាគច្រើននៅទីនោះ ពីព្រោះពួកគេត្រូវបានធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ ដោយពួកគេត្រូវបានសង្ស័យថាជាខ្មាំង[2477]។ ដោយហេតុថាកម្មាភិបាលជាន់ខ្ពស់ដែលគេចាត់ទុកថាជាខ្មាំង ត្រូវបាននាំយកទៅ

---

2476 ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ ប៉ែន សារិន EN ERN 00217561 ["ប្រសិនបើមាននរណាម្នាក់ប្រព្រឹត្តកំហុសបច្ចេកទេស ពួកគេនឹងត្រូវនាំយកទៅលត់ដំ"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.20, 25, 31-32, 41 ["កន្លែងហ្នឹងគឺជាកន្លែងលត់ដំ គឺដាច់ខាតយើងត្រូវតែធ្វើ អត់ធ្វើគឺអត់បាន។ [...] ស៖ លោកបាននិយាយថា ស្ទឹងហាវជាកន្លែងលត់ដំ។ ចំពោះលោកជាយោធាម្នាក់ តើពាក្យថា "លត់ដំ" នេះមានន័យថាម៉េចដែរទៅ? ឆ.25៖ ពាក្យថា "លត់ដំ" នេះមានន័យថា គេយកទៅធ្វើការងារ ដើម្បីឱ្យយើងកសាងខ្លួន។ [...] ឆ.26៖ នៅពេលដែលគេយកទៅលត់ដំហ្នឹង វាមានបញ្ហា។ [...] ឆ.31៖ អនុសេនាធំ១៩ គ១៩ កងលត់ដំពួកខ្ញុំហ្នឹងហើយ។ [...] ឆ.32៖ យើងនៅក្រោមនេះ ផ្នែកខាងលត់ដំ យកថ្មអីហ្នឹង។ [...] ឆ.33៖ ព្រោះពួកគាត់ហ្នឹង អង្គភាពផ្សេង ហើយពួកខ្ញុំជាក្រុមលត់ដំផ្សេង។ ពួកខាងគាត់នោះមានសិទ្ធិនៅខាងកងពល ហើយពួកខ្ញុំជាពួកលត់ដំ អត់មានសិទ្ធិកាន់អាវុធអីទេ។ [...] ស៖ តើលោកអាចប៉ាន់ស្មានបានទេថា មានយោធាប៉ុន្មាននាក់ ដែលត្រូវបានលត់ដំនៅស្ទឹងហាវនៅពេលនោះ? ឆ.41៖ យោធាដែលដកចេញពីកោះមក គឺឈរជើងនៅលើស្ទឹងហាវហ្នឹងទាំងអស់។ ទាហានវរសេនាតូចហ្នឹង ខ្លះក៏គេចាប់ ក៏គេអី នៅសល់តែប្រហែល២០០នាក់ជាង មិនដល់៣០០នាក់ទេ។ អ្នកដែលគេដកមកនៅលើដីនៅស្ទឹងហាវនេះមានទាហានចំនួនប្រហែល២៥០នាក់ ព្រោះមានគេចាប់យកទៅធ្វើបាប ធ្វើអីរញ៉េរញ៉ៃពេញហ្នឹងទាំងអស់។"]។

2477 Dឯកសារ D1.3.13.11 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ សៀង EN ERN 00217566 ["មនុស្សដែលគេបញ្ជូនទៅការដ្ឋានវ៉ៃថ្ម គឺជាមនុស្សដែលគេគិតថា ជាប់និន្នាការ ឬជាសមាសភាពមិនល្អ ហើយរួមមានទាំងទាហាន និងសាច់ញាតិ អ្នកដែលធ្លាប់ជាសមាជិកនៃរបបមុន"]។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ. 33 ["ស៖ លោកបាននិយាយថា ពួកយោធាដែលគេចាត់ថាពួកសមាសភាពមិនល្អ ត្រូវបានគេបញ្ជូនទៅវាយថ្ម ហេតុអ្វីបានជាការងារវាយថ្មនិងលីសែងត្រូវបានដាក់ទៅឱ្យសមាសភាពមិនល្អជាអ្នកធ្វើ? ឆ.33៖ ពីព្រោះការងារវាយថ្មនិងលីថ្មជាការងារធ្ងន់។"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញិក ឆ.23-24 ["នៅពេលនោះ គេបានដកប្រហែលជា៨០ភាគរយនៃពួកអតីតយោធាកងវរសេនាតូច៣៨៦ នៃតំបន់៣៧ ហើយបញ្ជូនឱ្យទៅធ្វើការនៅកន្លែងវ៉ៃថ្មនៅស្ទឹងហាវ ដោយសារពួកនោះចាត់ថាជាសមាសភាពមិនល្អ។ [...] ឆ.24៖ ពួកគេចោទមនុស្សនៅក្នុងតំបន់៣៧ ថាជាសមាសភាពមិនល្អ ពីព្រោះក្នុងតំបន់នេះត្រូវបានរៀបចំដោយវៀតណាមតាំងពីឆ្នាំ១៩៧០ម្ល៉េះ។ ដូច្នេះគេចោទពួកយើងថាមានទំនាក់ទំនងខ្សែរយៈជាមួយវៀតណាម។"]។ ឯកសារ D54/35.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប្រាក់ សុខា KH ERN 00964252 ["ស៖ ចឹងពូពាក់ព័ន្ធមិនទុកចិត្តយ៉ាងម៉េច ហើយដកមកខាងកងចល័តគ្រួសារពូមានមូលហេតុអីកាលហ្នឹង? ឆ៖ មូលហេតុកាលហ្នឹងដោយសារខ្ញុំមានពាក់ព័ន្ធគេយកប៉ាខ្ញុំជាប់និន្នាការ គេយកប៉ាទៅសម្លាប់ជាប់និន្នាការខ្មាំង ខ្ញុំមិនបានដឹងថាគេយកឪពុកខ្ញុំយកទៅសម្លាប់ចោល ខ្ញុំអត់ដឹងផងហ្នឹង

សម្លាប់ដោយផ្ទាល់ ឬទៅមន្ទីរសន្តិសុខ[2478] ស្ទឹងហាវត្រូវបានប្រើប្រាស់ធ្វើជាកន្លែងដែលកម្ពុជាប្រជាធិបតេយ្យបញ្ជូនកម្មាភិបាលសង្ស័យ "ដើម្បីគេលត់ដំចម្រាញ់ទ័ព ដើម្បីគេសម្រិតសម្រាំងទ័ពថាយើងហ្នឹងស្មោះត្រង់ជាមួយពួកគាត់ឬអត់"[2479]។ ដោយសារនេះជាផ្នែកនៃដំណើរការ ការអង្កេតលើប្រវត្តិរូបរបស់កម្មករនៅស្ទឹងហាវ ចេះតែបន្តធ្វើរហូត[2480]។ ខ្មែរក្រហមប្រើប្រាស់ពាក្យ

---

។"]។ សូមមើលផងដែរ ឯកសារ D2/23 របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ការដ្ឋានវាយថ្ម និងទីតាំងដែលជាប់ពាក់ព័ន្ធ KH ERN 00714347 ["ប្រជាជនដែលត្រូវបានគេគិតថាជា "សមាសភាពមិនល្អ" ឬមាន "និន្នាការ" ត្រូវបានបញ្ជូនទៅស្ទឹងហាវ។ ជនទាំងនេះរួមទាំងប្រជាជនដែលមានបងប្អូន ដែលធ្លាប់ជាសមាជិកនៃរបបមុន។ "]។ ឯកសារ D54/12 កំណត់ហេតុស្ដាប់ចម្លើយ ប្រេស មាន ឆ.13 ["នៅចុងឆ្នាំ ១៩៧៧ គេបានស្រាវជ្រាវប្រវត្តិរូបរបស់ខ្ញុំ ហើយគេបានរកឃើញថា ខ្ញុំមានប្រវត្តិរូបមិនល្អ ហើយគេដកកាំភ្លើងពីខ្ញុំនិងដកខ្ញុំពីអង្គភាពនេសាទឲ្យមកធ្វើជាអ្នកលីសែងថ្មវិញ។"]។ ឯកសារ D114/109 កំណត់ហេតុស្ដាប់ចម្លើយ ព្រំ សម្បត្តិ ឆ.224 ["សៈ គេបញ្ជូនលោកទៅស្ទឹងហាវជាការដាក់ទោស ឬយ៉ាងណា? ឆ.224៖ បាទ វាដូចជាការដាក់ទោស ព្រោះគេដកសិទ្ធិក្រុមរបស់ខ្ញុំអស់ហើយ។"]។ ឯកសារ D54/8.1 កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុអង្គប្រជុំយោធា កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤ ថ្ងៃ ៩ - ៩ - ៧៦ KH ERN 00936685 ["កន្លងមកគណៈកងពលបានបំបែកពួកមិនល្អ ឲ្យនៅដោយឡែក ដើម្បីកុំឲ្យច្របូកច្របល់នឹងពួកល្អ។"]។

2478 សូមមើល ឧទាហរណ៍ ឯកសារ D54/36 ប្រាក់ សុខន ឆ.22 ["ចំពោះអ្នកដែលចាត់ទុកថាមានទោសធ្ងន់ គេបញ្ជូនទៅទឹកសាប ចំពោះអ្នកដែលចាត់ទុកថាមានទោសស្រាល គេបញ្ជូនទៅស្ទឹងហាវ ដើម្បីលត់ដំ។"]។

2479 ឯកសារ D114/178 កំណត់ហេតុស្ដាប់ចម្លើយ អ៊ឹម សុខន ឆ.17។ សូមមើលផងដែរ ឯកសារ D114/208 កំណត់ហេតុស្ដាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.15 ["ក្រោយមកគឺថា ឆ្នាំ១៩៧៦ គេមិនទុកចិត្តខ្ញុំ។ គេក៏បានដកខ្ញុំពីកងវរសេនាតូចកាំភ្លើងធំ ឲ្យទៅនៅស្ទឹងហាវ។"]។

2480 ឯកសារ D54/8.1 កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុអង្គប្រជុំយោធា កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤ ថ្ងៃ ៩ - ៩ - ៧៦ KH ERN 00936686 ["សភាពការណ៍ផ្ទៃក្នុង៖ ឈ្មោះ វង់ ស្រួល នោះចាប់សួរចម្លើយទៅ។ បញ្ហាបំបែកពួករត់ឲ្យទៅកងផ្សេងៗ ដូចមិនចំណេញ ព្រោះបើមានខ្មាំងវាធ្វើសកម្មភាពបានទៀត។ ត្រូវភ្ជាប់ប្រវត្តិរូបឲ្យច្បាស់ ហើយប្រមូលឲ្យបង្កបង្កើនផលមួយជុំចុះ។ - សមាសភាពទាហាន ត្រូវប្រមូល។"]។ ឯកសារ D114/121 កំណត់ហេតុស្ដាប់ចម្លើយ សួន ផ ឆ.29 ["គេបានយកប្រវត្តិរូបខ្ញុំម្ដង ពេលខ្ញុំធ្វើការនៅព្រលានយន្តហោះកងកេងគេយកមកដង និងម្ដងទៀតនៅស្ទឹងហាវ។"]។ ឯកសារ D114/178 កំណត់ហេតុស្ដាប់ចម្លើយ អ៊ឹម សុខន ឆ.47-48 ["សៈពេលលត់ដំនៅស្ទឹងហាវ តើលោក និងអ្នកផ្សេងទៀត ប្រឈមនឹង ឬក៏ត្រូវបានគេយកប្រវត្តិរូប ឬក៏ធ្វើប្រវត្តិរូបដែរឬទេ? ឆ.47៖ ធ្វើប្រវត្តិរូបស្រាវជ្រាវតាមម្នាក់ៗ ពេលនៅស្ទឹងហាវ។ យើងនិយាយ គេអ្នកកត់។ សៈ តើអ្នកដែលធ្វើប្រវត្តិរូបហ្នឹង ឈ្មោះអី? ឆ.48៖ មេ គ យើង គាត់ក្ដាប់នៅហ្នឹង ឈ្មោះ ប៊ុន។"]។ ឯកសារ D114/130 កំណត់ហេតុស្ដាប់ចម្លើយ អៀម ភង់ ឆ.108, 129-131 ["សៈ តើលោកដែលឃើញ រិន ម្ដងទៀតទេ? ឆ.108៖ ទេ គេយកទៅបាត់ហើយ។ [...] សៈ តើលោកឃើញមានអ្នកណាដែលត្រូវបានគេចាប់យកទៅក្រោយពីស្រង់ប្រវត្តិរូបហើយ? ឆ.129៖ គេយកទៅពីរបីនាក់ដែរ ខ្ញុំឃើញ។ [...] សៈ តើលោកដែលឃើញអ្នកដែលគេនាំទៅម្ដងទៀតទេ? ឆ.130៖ ទេ។ [...]

សម្រាលផ្សេងៗសម្រាប់អ្នកដែលខ្មែរក្រហមគិតថាជាប់សង្ស័យថាជា "សត្រូវ" នយោបាយ រួមទាំង "សមាសភាពមិនល្អ"[2481] និងអ្នកដែលមាន "និន្នាការអាក្រក់"[2482]។ ប្រភេទនៃបុគ្គលិកយោធាដែលសង្ស័យថាជាខ្មាំង មានអ្នកដែលមកពីភូមិបូព៌ា តំបន់ ៣៧ ទាំងអស់ អ្នកទាំងអស់ដែលនៅក្រោមបង្គាប់របស់មេដឹកនាំកងពល ១៦៤ ដែលត្រូវបានបោសសម្អាត និងអ្នកដែលគេរកឃើញថាមានទំនាក់ទំនងជាមួយរបប លន់ នល់ ចាស់ ទោះដោយផ្ទាល់ខ្លួនក្តី ឬតាមរយៈសមាជិកគ្រួសារក្តី[2483]។ នៅស្ទឹងហាវ "សមាសភាពមិនល្អ" ត្រូវបានកំណត់ទុកសម្រាប់ការងារពិបាក និងគ្រោះថ្នាក់ជាងគេ ពោលគឺការងារបំបែក និងដឹកជញ្ជូនថ្ម[2484]។ សាក្សី អ៊ឹម សុខន បានពណ៌នាពីអ្វីដែលគេហៅថាលត់ដំនៅស្ទឹងហាវ៖

> នៅពេលដែលគេយកយើងទៅលត់ដំហ្នឹង វាមានបញ្ហា។ ជួបម្យ៉ាងយើងជីវភាពហូបចុកអត់គ្រប់គ្រាន់ អត់បរិបូរ។ ហូបមិនបានគ្រប់គ្រាន់ ណាមួយពេលមានឈឺថ្កាត់ ក៏មិនមានថ្នាំពេទ្យបរិបូរ។ ហើយយើងធ្វើការងារកំណត់ពេញៗម៉ោង។

---

សៈ តើលោកធ្លាប់ឮពីអ្នកផ្សេងថាមានអ្វីកើតឡើងចំពោះអ្នកទាំងនោះទេ? ឆ.131៖ ខ្ញុំស្មានខ្លួនឯងថា បើគេយកទៅ គឺគេវៃចោលហើយ។"]។

2481 ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.8, 24-25, 30 ["ខ្ញុំចាំថាតើកងសមាសភាពមិនល្អដែលធ្វើការនៅកន្លែងវាយថ្មនៅកន្លែងផ្សេងៗ ត្រូវបានចូលប្រជុំឬអត់ដែរទេ។ [...] ឆ.24៖ [...] ពួកសមាសភាពមិនល្អគេបានរៀបចំទៅជាពកងអនុសេនាធំ ដែលមានកងអនុសេនាធំទី១៧, ១៨ និង ១៩។ [...] ឆ.25៖ តាមខ្ញុំស្មានមានមនុស្សប្រហែល១០០នាក់ក្នុងមួយកងៗ។ [...] ឆ.30៖ ["កងអនុសេនាធំទាំង៣ នេះ គឺជាពួកសមាសភាពមិនល្អនៅក្នុងវរសេនាធំ ៦១។"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ ឆ.151 ["តាមខ្ញុំដឹងអតីតទាហានមក ប៉ុន្តែជាទាហានដែលមានសមាសភាពមិនល្អ ប្រវត្តិរូបមិនល្អ អ្នកដែលមានកំហុសតិចតួចដែលមិនអាចយកទៅដាក់គុកបាន គឺគេយកទៅដាក់នៅទីនោះឯង។"]។

2482 ឯកសារ D54/76 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ឹក ឆ.16-17 ["នៅពេលនោះ គេបានចោទពួកអតីតយោធារបស់កងតំបន់៣៧ និងពួកភូមិភាគបូព៌ា ថាជាសមាសភាពមាននិន្នាការមិនល្អ។ [...] ឆ.17៖ នៅឆ្នាំ ១៩៧៧ គឺពេលដែលគេបញ្ជូនខ្ញុំទៅធ្វើការនៅក្នុងកងផលិត។"]។

2483 ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ ប៉ែន សារិន EN ERN 00217561 ["សាក្សីបាននិយាយថា នៅពេលដែលប្រជាជនត្រូវបានគេកំណត់ថាមានជាប់និន្នាការជាមួយរបបចាស់ ពួកគេត្រូវបានដកចេញដែលមានន័យថាពួកគេត្រូវបានយកទៅសម្លាប់។"]។

2484 ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.33 ["សៈ លោកបាននិយាយថ ពួកយោធាដែលគេចាត់ថាពួកសមាសភាពមិនល្អ ត្រូវបានគេបញ្ជូនទៅវាយថ្ម ហេតុអ្វីបានជាការងារវាយថ្មនិងលីសែងត្រូវបានដាក់ទៅឱ្យសមាសភាពមិនល្អជាអ្នកធ្វើ? ឆ.33៖ ពីព្រោះការងារវាយថ្មនិងលីថ្មគឺជាការងារធ្ងន់។"]។

ត្រូវធ្វើការពេញៗ ក្នុង១ថ្ងៃ បើឈឺឲ្យដឹងថាឈឺ បើជា បើឈឺតិចតួចក៏ត្រូវតែធ្វើដែរ។ [...] បើយើងមិនអនុវត្តតាមផែនការដែលគេដាក់ចុះទេ គេនឹងអាចចាប់បញ្ជូនយើង ជួនកាលគេធ្វើបាប ជួនកាលសម្លាប់ក៏មានដែរ[2485]។

623. **មាស មុត** បានដឹងច្បាស់អំពីការបែងចែកប្រជាជននៅស្ទឹងហាវជាប្រភេទសមាសភាព "មិនល្អ" និង "ល្អ" និងបានចូលរួមដោយខ្លួនឯងផ្ទាល់ក្នុងការកំណត់អត្តសញ្ញាណ និងបែងចែកពួកគេ។ កំណត់ហេតុប្រជុំរបស់កងពល ១៦៤ តាំងពីខែ កញ្ញា ឆ្នាំ ១៩៧៦ បញ្ជាក់ថា មនុស្សមួយក្រុមដែលប៉ុនប៉ងរត់ចេញពីស្ទឹងហាវ ជា "ពួកមិនល្អ"[2486]។ ក្រោយមក កំណត់ហេតុប្រជុំបានបញ្ជាក់ថា "កន្លងមក គណៈកងពលបានបំបែកពួកមិនល្អឲ្យនៅដោយឡែក ដើម្បីកុំឲ្យច្របូកច្របល់នឹងពួកល្អ"[2487]។ នៅក្នុងការប្រជុំដដែលនោះ សុន សេន បានណែនាំឲ្យ "ចាប់សួរចម្លើយ" មេដឹកនាំក្រុម និងឲ្យអ្នកផ្សេងទៀតធ្វើការ ខណៈដែលខ្មែរក្រហមធ្វើការដើម្បី "ក្តាប់ប្រវត្តិរូបឲ្យបានច្បាស់"[2488]។ សុន សេន សន្និដ្ឋានថា "សមាសភាពទាហានត្រូវប្រមូល"[2489]។

624. អ្នកដែលជាប់សង្ស័យ គ្មានឱកាសលុបលាងកំហុស ហើយការប្រព្រឹត្តិដ៏ឃោរឃៅដែលពួកគេទទួលរង អាចកាន់តែអាក្រក់ឡើង ប្រសិនបើពួកគេត្រូវបានសង្ស័យថាបានប្រព្រឹត្តបទល្មើសផ្សេងៗ[2490]។ ប្រសិនបើពួកគេត្រូវបានកំណត់ថាជាខ្មាំងដោយមិនអាចកែប្រែបាន ពួកគេត្រូវបាន

[2485] ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.26-27។

[2486] Dឯកសារ D1.3.8.4 កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុអង្គប្រជុំយោធា កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤ ថ្ងៃ ៩ - ៩ - ៧៦ KH ERN 00162489។

[2487] ឯកសារ D1.3.8.4 កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុអង្គប្រជុំយោធា កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤ ថ្ងៃ ៩ - ៩ - ៧៦ KH ERN 00162489។ សូមមើលផងដែរ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.38 ["បាទ, ដូចដែលខ្ញុំប្រាប់ពីម្សិលមិញថា សមាសភាពមិនល្អបញ្ជូនទៅធ្វើការកន្លែងផ្សេង។"]។

[2488] ឯកសារ D1.3.8.4 កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុអង្គប្រជុំយោធា កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤ ថ្ងៃ ៩ - ៩ - ៧៦ KH ERN 00162490។

[2489] ឯកសារ D1.3.8.4 កម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុអង្គប្រជុំយោធា កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤ ថ្ងៃ ៩ - ៩ - ៧៦ KH ERN 00162490។

[2490] ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ ប៉ែន សារិន EN ERN 00217561 ["ប្រសិនបើមាននរណាម្នាក់ប្រព្រឹត្តកំហុសបច្ចេកទេស ពួកគេនឹងត្រូវនាំយកទៅលត់ដំ"]។

ចាប់ខ្លួន ឬសម្លាប់[2491]។ ប្រសិនបើ "គេថាខ្មាំងសុទ្ធតែខ្មាំងតែម្តង គេយកទៅវៃចោល"[2492]។ ស្ថានការណ៍ផ្សេងទៀតដែលអាចនាំឱ្យមានការចាប់ខ្លួន ឬសម្លាប់អ្នកដែលគេសង្ស័យ គឺការរកឃើញប្រវត្តិរូបអវិជ្ជមានបន្ថែម[2493] ការចោទប្រកាន់ពីបទលួច[2494] ការចោទប្រកាន់ពីបទខ្ជិលធ្វើការ[2495]

---

[2491] សូមមើលជាទូទៅ VIII.E.3. ឧក្រិដ្ឋកម្ម – អំពើមនុស្សឃាត និងការចាប់ខ្លួនដោយបង្ខំ ។ VIII.E.3. ឧក្រិដ្ឋកម្ម - ការចាប់ដាក់ឃុំឃាំង និងទារុណកម្មខុសច្បាប់។

[2492] ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977454 ["គេថាជន្ទួញនង្គ័លគេថាខ្មាំងសុទ្ធតែខ្មាំងតែម្តង ហើយគេយកទៅវៃចោលរាល់ថ្ងៃនុំង។"]។

[2493] ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.127 ["គេសួរ តើយើងអ្នកក្រ ឬកណ្តាល ឬមកពីណា? បើយើងថា យើងមកពីថ្នាក់ក្រ ឬកណ្តាល គេតាមដានយើងតាមហ្នឹង។ បើយើងកម្មករថ្នាក់កណ្តាល គេថាអ្នកគ្រាន់បើ ហើយគេយកវៃចោល។ បើយើងថាយើងអ្នកក្រ វាមិនសូវមានបញ្ហា ព្រោះយើងក្រ ហើយយើងនៅថ្នាក់ទាប។"]។ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.30 ["ស៖ តើលោកអាចប្រាប់អំពីការចាប់ខ្លួនលោកបានដែរឬទេ? សូមលោកជួយរៀបរាប់។ ឆ.30៖ [...] ហេតុផលទី២ គេតាមដានពិនិត្យឃើញថា គ្រួសារខ្ញុំជាអ្នកមានដែលជាមុខសញ្ញាគេកម្ចាត់។"]។

[2494] ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.99, 104-105, 107, 127 ["ពេលយប់ គេប្រជុំជីវទស្សន៍។ បើអ្នកណាធ្វើខុស គេឱ្យអ្នកវៃថ្មជាមួយយើងហ្នឹង យកទៅវៃចោលតែម្តង។ [...] ឆ.104៖ [...] យើងឃ្លានខ្លាំង យើររកបេះផ្លែឈើ ឬរកដំឡូង បើគេចាប់បាន គេសម្លាប់ចោលតែម្តង។ [...] ឆ.105៖ [...] តែបើឃើញ គេវៃចោលតែម្តង។ ខ្ញុំឃើញនឹងភ្នែក គេចាប់បានប្រុសម្នាក់ ហើយគេឱ្យក្មេងប៉ុននេះ (ប្រហែលមួយម៉ែត្រកន្លះ)វៃ។ វៃឡើងសន្លប់ឈឹង។ ពេលគាត់ភ្ញាក់ឡើង គេនាំយកទៅបាត់។ [...] ស៖ តើធ្លាប់ឃើញអ្នកផ្សេងទៀតដែលគេនាំយកទៅឃុំឃាំង នាំទៅ ឬសម្លាប់ទេ? ឆ.107៖ រិន ជាមេក្រុម ដែលគេចងវៃ។ រិន លួចថ្នាំជក់។ គេបានថ្នាំ យប់ឡើងលួចបាត់ គេដឹង ហើយថ្ងៃឡើងគេយកមកចងហាលថ្ងៃវៃ ហើយទុកចោលទាំងចំណងមួយថ្ងៃ។ ហើយក្រោយមក គេយកទៅ។ ខ្ញុំមិនដឹងគេយកទៅណាទេ។ [...] ស៖ លោកនិយាយថា គេឱ្យលោកទៅប្រជុំជីវទស្សន៍។ តើគេសួរអ្វីខ្លះ? ឆ.127៖ គេសួរដំបូងឡើងយើង ចូលអ្នកណានាំចូល? តើយើងធ្វើខុសអីអត់? មានលួចឬអត់? គេសួរ តើយើងអ្នកក្រ ឬកណ្តាល ឬមកពីណា? បើយើងថា យើងមកពីថ្នាក់ក្រ ឬកណ្តាល គេតាមដានយើងតាមហ្នឹង។ បើយើងកម្មករថ្នាក់កណ្តាល គេថាអ្នកគ្រាន់បើ ហើយគេយកវៃចោល។ បើយើងថាយើងអ្នកក្រ វាមិនសូវមានបញ្ហា ព្រោះយើងក្រ ហើយយើងនៅថ្នាក់ទាប។"]។

[2495] ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.36, 38, 51 ["ប្រសិនបើអ្នកណាក្រោកមិនទាន់ ឬក៏យឺតយ៉ាវ មេក្រុមនឹងវៃនឹងដំបង ឬរំពាត់ ដោយចោទថាខ្ជិល។ បើពីរបីដងហើយ អ្នកនោះនៅមិនប្តូរ ឬកែប្រែ គេនឹងដកចេញហើយបាត់ខ្លួនរហូត។ [...] ឆ.38៖ [...] ប្រសិនបើគេមិនចូលចិត្តយើង គេដកយើងទៅ ហើយបាត់តែម្តង។ [...] ឆ.51៖ [...] ប៉ុន្តែពួកគេដកចេញទៅហើយ មិនដែលឃើញត្រឡប់មកវិញទេ។"]។

ឬប្រព្រឹត្ត "កំហុស" ពេលធ្វើការ[2496]។ ក្នុងពេល "ប្រជុំជីវទស្សន៍" ដឹកនាំដោយខ្មែរក្រហម អ្នកដែលបានប្រព្រឹត្តកំហុស ឬត្រូវបានចោទពីបទលួច ឬត្រូវរកឃើញថាមកពីវណ្ណៈធូរធារ ត្រូវបានកំណត់អត្តសញ្ញាណ ដកចេញ និងយកទៅសម្លាប់ចោល[2497]។

---

2496 ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ ប៉ែន សារិន EN ERN 00217561 ["ប្រសិនបើមាននរណាម្នាក់ប្រព្រឹត្តកំហុសបច្ចេកទេស ពួកគេនឹងត្រូវយកទៅលត់ដំ។ ហើយអ្នកដែលគេកោះហៅទៅនោះ បាត់ខ្លួន។ បើតាមសាក្សីជឿជាក់ថា ពួកគេត្រូវបានគេនាំទៅកាន់តំបន់ភ្នំបូកគោក្នុងខេត្តកំពត។"]។ ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977454 ["ដល់ទៅគេឱ្យធ្វើស្រែនៅសហករណ៍ស្ទឹងហាវ។ ទៅបានប្រហែលជា១០ថ្ងៃ គេឱ្យខ្ញុំកាន់ក្របីម៉ានីមទៀត។ កាន់ក្របីម៉ានីមធំៗ គេថាមិត្តឯងមើលកក្របី បើបាត់ក្របីម៉ានីមគឺអ្នកឯង សម្លាប់ចោល។"]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ. 24 ["ខ្ញុំធ្លាប់ឃើញ យោធាម្នាក់ដែលនៅក្នុងកងជាមួយខ្ញុំបានប្រើប្រេងម៉ាស៊ីនខុសលេខ ធ្វើឱ្យខូចម៉ាស៊ីនកាណូតនោះ គាត់ត្រូវបាននាំយកទៅបាត់រហូត។ គាត់គឺជាអ្នកបើកកាណូតនៅក្នុងនៅក្នុងក្រុមនេសាទ សម្រាប់ផ្តល់ឱ្យការដ្ឋានវាយថ្ម និងម្នាក់ទៀតបានបើកកាណូតទៅបុកថ្ម ហើយក៏ត្រូវគេយកទៅបាត់ដែរ។ បើសិនជាមានអ្នកណាម្នាក់ បើកឡានបុកអ្វីមួយ គាត់ក៏ត្រូវយកទៅបាត់ដែរ។"]។ សូមមើលផងដែរ ឯកសារ D114/60 កំពង់ផែយោធាស្ទឹងហាវ ការដ្ឋានធ្វើការងារដោយបង្ខំ របាយការណ៍ទីតាំងការដ្ឋានការងារ EN ERN 01082175 ["សាក្សីបាននាំយើងទៅកាន់ស្ទឹងមួយដែលនៅទីនោះគ្រោះថ្នាក់កប៉ាល់មួយបានកើតឡើង ដែលនាំឱ្យមានការសម្លាប់មិត្តរួមការងាររបស់គាត់ម្នាក់"] EN ERN 01082181 ["ដោយយោងទៅសេចក្តីអះអាងរបស់ខ្លួន សាក្សីបានបង្ហាញដុំថ្មនៅក្នុងស្ទឹងត្រង់កន្លែងដែលអ្នកបើកកប៉ាល់បានបុកថ្ម។ បន្ទាប់ពីនោះ អ្នកបើកបរកប៉ាល់ត្រូវបានគេដកចេញ ហើយក៏បានបាត់ខ្លួន។"]។ ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.61 ["សះ តើគេធ្វើទារុណកម្មលើពួកលោកក្នុងគោលបំណងអ្វីដែរ? ឆ.61៖ គេធ្វើទារុណកម្ម ទី១ គេចោទយើងថា យើងហ្នឹងខ្មាំងអីណាចូលដៃយួន ព្រោះយើងអត់ដឹងទេ ព្រោះគេចោទអ៊ីចឹង។ ទី២ ហើយនិងបាក់ចបបាក់បង្គី យើងជីកដំឡូងហូបអី ហើយវាឃើញទៅ វាចោទថាខ្មាំង។"]។ ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.99, 127 ["ពេលយប់ គេប្រជុំជីវទស្សន៍។ បើអ្នកណាធ្វើខុស គេឱ្យអ្នកវែថ្មជាមួយយើងហ្នឹង យកទៅវៃចោលតែម្តង។ [...] សះ លោកនិយាយថា គេឱ្យលោកទៅប្រជុំជីវទស្សន៍។ តើគេសួរអ្វីខ្លះ? ឆ.127៖ គេសួរដំបូងឡើងយើងចូល អ្នកណានាំចូល? តើយើងធ្វើខុសអីអត់? មានលួចឬអត់? គេសួរ តើយើងអ្នកក្រ ឬកណ្តាល ឬមកពីណា? បើយើងថា យើងមកពីថ្នាក់ក្រ ឬកណ្តាល គេតាមយើងតាមហ្នឹង។ បើយើងកម្មករថ្នាក់កណ្តាល គេថាអ្នកគ្រាន់បើ ហើយគេយកវៃចោល។ បើយើងថាយើងអ្នកក្រ វាមិនសូវមានបញ្ហា ព្រោះយើងក្រ ហើយយើងនៅថ្នាក់ទាប។"]។

2497 ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.99, 127 ["ពេលយប់ គេប្រជុំជីវទស្សន៍។ បើអ្នកណាធ្វើខុស គេឱ្យអ្នកធ្វើខុស គេឱ្យអ្នកវែថ្មជាមួយយើងហ្នឹង យកទៅវៃចោលតែម្តង។ [...] សះ លោកនិយាយថា គេឱ្យលោកទៅប្រជុំជីវទស្សន៍។ តើគេសួរអ្វីខ្លះ? ឆ.127៖ គេសួរដំបូងឡើងយើងចូល អ្នកណានាំចូល? តើយើងធ្វើខុសអីអត់? មានលួចឬអត់? គេសួរ តើយើងអ្នកក្រ ឬកណ្តាល ឬមកពីណា? បើយើងថា យើងមកពីថ្នាក់ក្រ ឬកណ្តាល គេតាមយើងតាមហ្នឹង។ បើយើងកម្មករថ្នាក់កណ្តាល គេថាអ្នកគ្រាន់បើ ហើយគេយកវៃចោល។ បើយើងថាយើងអ្នកក្រ

625. កម្មាភិបាលដែលជាប់សង្ស័យថាជាខ្មាំងជាទូទៅត្រូវបានគេរំសាយ[2498] និងដកហូតអាវុធ[2499] បន្ទាប់មកបញ្ជូនទៅ "អង្គភាពផលិត"[2500]។ មានភាពខុសគ្នាគួរឱ្យកត់សម្គាល់រវាងជីវិតជាកម្មាភិបាលសកម្មនៅក្នុងកងពល ១៦៤ និងកម្មាភិបាលរំសាយដែលរស់នៅក្រោមការសង្ស័យ។ កម្មាភិបាលរំសាយមិនត្រឹមតែត្រូវគេដកហូតអាវុធទេ ពួកគេថែមទាំងរស់នៅក្នុងលក្ខខណ្ឌដ៏សែនអាក្រក់ទៀតផង[2501]។

626. កម្មាភិបាលរំសាយត្រូវគេដកសិទ្ធិអំណាចពីមុនរបស់ពួកគេក្នុងសង្វាក់នៃការបញ្ជា។ "គេដកតួនាទីអស់ហើយ។ អត់មានអ្នកណាមេអ្នកណាកូនទេ។ សិទ្ធិស្មើគ្នាតែម្តង"[2502]។ តាមពិតទៅ ការដែលត្រូវបានបញ្ជូនទៅធ្វើការនៅស្ទឹងហាវ ជា "ការដាក់ទោស ព្រោះគេដកសិទ្ធិក្រុមរបស់ខ្ញុំអស់ហើយ"[2503]។ ឋានន្តរសក្តិខ្លះត្រូវបានបង្កើតឡើងវិញ សម្រាប់អតីតកម្មាភិបាល ក្នុងអង្គភាពការងារនៅស្ទឹងហាវ ប៉ុន្តែទោះយ៉ាងណាក៏ដោយ គឺស្ថិតក្រោមការគ្រប់គ្រងរបស់កម្មាភិបាល

---

វាមិនសូវមានបញ្ហា ព្រោះយើងក្រ ហើយយើងនៅថ្នាក់ទាប។"]។ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.30 ["ហេតុផលទី២ គេតាមដានពិនិត្យឃើញថា គ្រួសារខ្ញុំជាអ្នកមាន ដែលជាមុខសញ្ញាគេកម្ចាត់។"]។

2498 ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.19 ["កម្លាំងដែលគេរំសាយចេញពីកងទ័ពជើងទឹកទៅធ្វើការនៅទីនោះ ចាប់តាំងពីឆ្នាំ១៩៧៧មក។"]។

2499 ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.19, 33 ["គេបញ្ជូនចេញពីកោះមក គេដកសត្រាវុធចេញទាំងអស់។ [...] ឆ.33៖ [...] ពួកខ្ញុំជាពួកលត់ដំ អត់មានសិទ្ធិកាន់អាវុធអីទេ។ "]។ ឯកសារ D54/76 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ឹក ឆ.18 ["ខ្ញុំមិនដឹងថាអ្នកណាម្នាក់ឱ្យដាក់លាក់ទេថា ជាអ្នកធ្វើសេចក្តីសម្រេចពីរឿងដកអាវុធចេញពីអតីតយោធារបស់តំបន់៣៧នេះ ហើយបញ្ជូនឱ្យទៅធ្វើការនៅតាមការដ្ឋាននានានោះ។"]។ សូមមើលផងដែរ ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.18 ["ចំពោះកងរបស់ខ្ញុំ គេមិនហៅកងផលិតទៀតទេ គេហៅពួកយើងថាកងកម្លាំងរបស់ការដ្ឋានទំនប់រលក។"]។

2500 ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ិន យ៉ើ ឆ.53 ["មានឈ្មោះកងផលិតដែរហ្នឹង។"]។

2501 ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.31 ["បន្ទាប់ពីគេដកខ្ញុំចេញទៅ ស្ថានភាពរស់នៅរបស់ខ្ញុំគឺមានការលំបាកខ្លាំងជាងពេលខ្ញុំនៅធ្វើជាយោធា។ ពេលខ្ញុំនៅជាយោធា ម្ហូបអាហារហូបចុកគ្រប់គ្រាន់ ហើយការងារមិនលំបាកទេ ប៉ុន្តែបន្ទាប់ពីខ្ញុំត្រូវបានបញ្ជូនទៅកងផលិតនៅស្ទឹងហាវ គេមិនឱ្យហូបចុកគ្រប់គ្រាន់ទេ ហើយការងារក៏ធ្ងន់ធ្ងរជាងមុនដែរ។"]។ សូមមើលផងដែរ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.5, 12។

2502 ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.174។

2503 ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.224 ["ស៖ គេបញ្ជូនលោកទៅស្ទឹងហាវជាការដាក់ទោស ឬយ៉ាងណា? ឆ.224៖ បាទ វាដូចជាការដាក់ទោស ព្រោះគេដកសិទ្ធិក្រុមរបស់ខ្ញុំអស់ហើយ។"]។

សកម្មនៅទីនោះ។ ឡុង ផាន់ស៊ី ពីមុនជាលេខាកងវរសេនាតូច ៦១២ ត្រូវបានគេសង្ស័យ និងបញ្ជូនទៅស្ទឹងហាវ "គ្រប់គ្រងមួយកងវរសេនាតូចកសាងកំពង់ផែ"[2504]។ គាត់បានបញ្ជាក់ថា តាមការជឿជាក់របស់គាត់ គាត់ស្ថិត "នៅក្នុងជួរយោធាដដែល ហើយនៅមានកាំភ្លើងកាន់ដដែល"[2505] ទោះបីគាត់មិនអាចកាន់អាវុធនោះបានក៏ពិតមែន ព្រោះ "អាវុធដាក់នៅក្នុងឃ្លាំង"[2506]។ ម្យ៉ាងវិញទៀត គាត់បានទទួលស្គាល់ថា គេបានប្រព្រឹត្តមកលើគាត់មិនដូចពីមុនទេ។ ខ្មែរក្រហម "តាមដានពិនិត្យ [គាត់]"[2507] និងចុងក្រោយ ពួកគេបានសម្រេចចិត្តថាគាត់ជាខ្មាំង ពេលដែលសមាជិកកងដែលគាត់គ្រប់គ្រងធ្វើឲ្យបាក់សម្ភារៈខ្លះ ហើយពួកគេរកឃើញថា "គ្រួសារ[គាត់] ជាអ្នកមាន ដែលជាមុខសញ្ញាគេកម្ចាត់" និងដែលធ្វើឲ្យគាត់ក្លាយជា "សេអ៊ីអា-កាហ្សេបេ"[2508]។ បន្ទាប់មក ពួកគេបានចាប់ខ្លួនគាត់[2509]។

627. ផ្ទុយពីការប្រព្រឹត្តិទៅលើកម្មាភិបាលរំសាយ កម្មាភិបាលសកម្មប្រចាំការនៅស្ទឹងហាវ "អាចទៅណាមកណាដោយសេរី"[2510]។ "គេមានសាច់ឈាមល្អជាង គេអត់រំសាយផង គេហូបគ្រប់គ្រាន់ តែខាងខ្ញុំគេរំសាយ ព្រោះជាប់និន្នាការជាមួយតាឆាន អីចឹង យើងហូបមិនគ្រប់គ្រាន់ទេ"[2511]។

---

2504 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.15។

2505 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.19។

2506 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.20។

2507 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.30 ["ក្រោយពីគេយកមកអង្គភាព៦១២មក គេតាមដានពិនិត្យខ្ញុំ"]។

2508 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.30 ["បញ្ហាដែលគេដកខ្ញុំចេញពីអង្គភាព មកគេពិនិត្យឃើញថា ខ្ញុំជា សេ.អ៊ី.អា, កា.ហ្សេ.បេ។ ក្រោយពីគេយកមកអង្គភាព៦១២មក គេតាមដានពិនិត្យខ្ញុំ គឺពេលដែលខ្ញុំចុះធ្វើការងារប្រគល់ការងារឲ្យខ្ញុំធ្វើ គេពិនិត្យឃើញថា ក្នុងអង្គភាពរបស់ខ្ញុំមានបាក់ដែកស្បែង រទេះដាច់ហ្វ៊ីត គេចោទខ្ញុំថាបានបំផ្លិចបំផ្លាញ នេះជាហេតុផលទី១។ ហេតុផលទី២ គេតាមដានពិនិត្យឃើញថា គ្រួសារខ្ញុំជាអ្នកមាន ដែលជាមុខសញ្ញាគេកម្ចាត់។ បងខ្ញុំម្នាក់ ធ្វើការជាវិស្វករខាងភ្លើងនៅភ្នំពេញ គេបានចាប់យកទៅសម្លាប់ ហើយប្អូនរបស់ខ្ញុំពីរនាក់ទៀត ក៏ស្លាប់ដោយមិនដឹងហេតុផលដែរ។"]។

2509 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.31 ["វរសេនាធំហៅមកប្រជុំ ដើម្បីត្រៀមចាប់ តែត្រង់បញ្ហាមកពីណាខ្ញុំមិនបានដឹងទេ។ អ្នកដែលមកចាប់ខ្ញុំគឺវរសេនាធំ ឈ្មោះមឿន និង ឡុន។ អ្នកទាំងពីរនៅកន្លែងប្រជុំហ្នឹង កាលនោះម៉ោងប្រហែលប្រាំបី ទៅប្រាំបួនយប់ ទើបប្រជុំ ហើយចាប់ខ្ញុំតែម្តង។"]។

2510 ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.35។

2511 ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.104។

កម្មាភិបាលសកម្មធ្វើការជាអ្នកគ្រប់គ្រងនៅស្ទឹងហាវ។ "គេឲ្យពួកដែលមានសមាសភាពល្អ ឲ្យមកគ្រប់គ្រងពួកយើង។ គេថាពួកខ្ញុំក្បត់ ហើយពួកខ្ញុំមិនទាំងដឹងខ្លួនថាខ្លួនឯងបានធ្វើអ្វីខុសផង"[2512]។

628. កម្មករមួយក្រុមធំដែលត្រូវគេធ្វើទុក្ខបុកម្នេញនៅស្ទឹងហាវ ជាអតីតកម្មាភិបាលភូមិភាគបូព៌ា និងកម្មាភិបាលតំបន់ ៣៧[2513]។ ពេលអតីតកម្មាភិបាលភូមិភាគបូព៌ាដែលមានឋានៈខ្ពស់ និងកម្មាភិបាលតំបន់ ៣៧ នៅកងពល ១៦៤ ត្រូវគេបោសសម្អាត ទាហានធម្មតាដែលស្ថិតក្រោមបញ្ជាពួកគេក៏ជាប់សង្ស័យ និងត្រូវបានបញ្ជូនទៅលត់ដំនៅស្ទឹងហាវផងដែរ[2514]។ សាក្សីម្នាក់ឆ្លើយ

---

2512 ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.32។

2513 ឯកសារ D234/2.1.138 នង នេត ប្រតិចារឹកថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ម៉ោង 11.06.35-11.07.54 ["មកពីបូព៌ាទាំងអស់"]។ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.18 ["ខ្ញុំចង់ប្រាប់លោកអំពីរឿងដ៏រន្ធត់មួយដែលកើតឡើងនៅស្ទឹងហាវ ចំពោះកម្មករផ្លូវរថភ្លើងថ្មី។ កម្មករផ្លូវរថភ្លើងថ្មីទាំងនោះមកពីភូមិភាគឧត្តរ និងភូមិភាគបូព៌ា។ [...] ធ្វើការចាប់ចងពួកកម្មករប្រុសៗ ចងដៃ បោះដាក់ទៅលើឡានដឹកដីដែលនៅចាំទីនោះ។ ពេលនោះ បើពួកប្រពន្ធកូនកម្មករស្រែយំ គេនឹងចាប់ប្រពន្ធនោះបោះចូលទៅក្នុងឡានជាមួយប្តីរបស់ពួកគេដែរ។"]។ ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.57 ["ស៖ តើក្រុមរបស់លោក ដែលមានគ្នាប្រហែល១០នាក់នោះ សុទ្ធតែជាយោធាមកពីភូមិភាគបូព៌ាមែនទេ? ឆ.57៖ យើងមកជាយោធា មកពីភូមិភាគបូព៌ា មកនៅភូមិភាគនិរតីហ្នឹង គេបញ្ជាគេធ្វើមេទាំងអស់។"]។ សូមមើលផងដែរ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.19 ["គេបានបញ្ជូនកម្លាំងដែលគេរំសាយចេញពីកងទ័ពជើងទឹកទៅធ្វើការ [...] ចាប់តាំងពីឆ្នាំ១៩៧៧មក។"]។ ឯកសារ D114/275 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ស្ទឹងហាវ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ EN ERN 01346014 ["សាក្សីជាយោធាក្នុងកងពល១៦៤ មកពីភូមិភាគបូព៌ាហើយត្រូវបញ្ចូលចូលទៅក្នុងកងពល ៣/១៦៤ ក្រោយខែ មេសា ឆ្នាំ ១៩៧៥ [...] សាក្សីបានរៀបរាប់ពីការបោសសម្អាតទាហានចេញពីអង្គភាពភូមិភាគបូព៌ា នៅក្នុងកងពល១៦៤ ហើយថាអង្គភាពរបស់គាត់ត្រូវបានគេបញ្ជូនឲ្យកាប់ព្រៃនៅស្ទឹងហាវក្នុងកន្លែងខ្លះក្នុងឆ្នាំ ១៩៧៧។ "]។

2514 ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.15 ["នៅពេលនោះគេចម្រាញ់យកចេញតែពួកថ្នាក់ដឹកនាំដែលមកពីភូមិភាគបូព៌ាតែប៉ុណ្ណោះ។ ចំណែកពួកយោធាធម្មតា គេគ្រាន់តែដកកាំភ្លើងហើយបញ្ជូនទៅវាយថ្ម។"]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.10 ["កាលនោះទាំងបូព៌ា និងពួកនិរតីត្រូវបានប្រមូលទាំងអស់គ្នា ដោយឮគេថា ខឹម ដែលជាមេពួកខ្ញុំក៏ត្រូវបានចាប់ខ្លួនដែរ ដោយគេចោទថាក្បត់។ ក្រោយពីគេចាប់ ខឹម គេក៏ចាប់ផ្តើមចាប់អ្នកនៅក្រោមៗតទៅទៀត។ [...] ក្រោយមកទៀត គេក៏បញ្ជូនខ្ញុំទៅស្ទឹងហាវ។"]។ ឯកសារ D114/112 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ សុខន ឆ.2 ["បន្ទាប់ពីមេតំបន់៣៧ ត្រូវបានគេបោសសម្អាត រីឯយោធាថ្នាក់ក្រោម ត្រូវបានគេបញ្ជូនឲ្យទៅធ្វើការ។"]។ ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.99 ["តែពេល តានាន ទៅយើងជាប់និន្នាការ គេឲ្យថ្ងៃឡើងរែថ្ម រួចហើយគេឲ្យហូបបាយដូចបបរប៉ុននេះ (ប្រហែលមួយកញ្ចុំបាតដៃ) ទេពេលថ្ងៃ និងពេលយប់។ ពេលថ្ងៃរែថ្ម ហើយពេលយប់ គេប្រជុំជីវទស្សន៍។ បើអ្នកណាធ្វើខុស គេ

ថា មេដឹកនាំតំបន់ និងកងអនុសេនាធំត្រូវបានដកចេញ ចំណែកឯងអ្នកក្រោមបង្គាប់ត្រូវបានបញ្ជូនទៅស្ទឹងហាវ[2515]។

629. សាក្សី សន ជួន ដែលមកពីភូមិបូព៌ា និងត្រូវគេបញ្ជូនទៅស្ទឹងហាវ បានបញ្ជាក់ថា គាត់ត្រូវគេកំណត់ថាជាខ្មាំង ក្រោយពីកប៉ាល់ដែលគេឱ្យគាត់មើលខុសត្រូវ បានលិច។ ក្នុងកងចល័តរបស់គាត់ "មានគ្នាច្រើន" សុទ្ធតែ "ជាប់និន្នាការដូចខ្ញុំ កាប់បាក់ចបអី លិចទូកអី គេចោទថាខ្មាំង"[2516]។ "កង" ដែលគេដាក់គាត់ឱ្យនៅ ហៅថា "កងជាប់ចោទ កងប្រមូលផ្តុំ"[2517]។ ចុងក្រោយ សន ជួន ត្រូវបានឃុំឃាំងនៅស្ទឹងហាវ ហើយពេលគាត់ត្រូវគេធ្វើទារុណកម្មសួរចម្លើយ គាត់ត្រូវបានចោទថាជា "ខ្មាំង" និង "ចូលដៃយួន"[2518]។

630. អតីតកម្មាភិបាលមួយក្រុមទៀតដែលត្រូវបានកំណត់គោលដៅ ដោយសារពួកគេត្រូវបានសន្មតថាមានទំនាក់ទំនងជាមួយវៀតណាម ជាទាហានខ្មែរក្រហមមួយក្រុមដែលត្រូវវៀតណាមចាប់ខ្លួនពីកោះនៅឆ្ងាយពីឆ្នេររបស់កម្ពុជាប្រជាធិបតេយ្យ ដែលពួកគេការពារ[2519]។ បន្ទាប់ពីត្រូវឃុំខ្លួនរយៈ

ឱ្យអ្នកវៃថ្មជាមួយយើងហ្នឹង យកទៅវៃចោលតែម្តង។"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.18 ["បាទ មិនដឹងថាយើងខុស ឬមិនខុសទេ ឱ្យតែក្នុងតំបន់អង្គភាពហ្នឹង ត្រូវបញ្ជូនទាំងអស់។"]។

2515 ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.24 ["គេដកតាំងពីថ្នាក់តំបន់ រហូតដល់ប្រធាន គ អនុសេនាធំ ហើយខ្ញុំថ្នាក់តូច។"]។

2516 ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.24។

2517 ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.24។

2518 ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.61, 64 ["គេធ្វើទារុណកម្ម ទី១ គេចោទយើងថា យើងហ្នឹងខ្មាំងអីណាចូលដៃយួន ព្រោះយើងអត់ដឹងទេ ព្រោះគេចោទអ៊ីចឹង។ ទី២ ហើយនិងបាក់ចបបាក់បង្គី យើងជីកដំឡូងហូបអី ហើយវាឃើញទៅ វាចោទថាខ្មាំង។ [...] ឆ.64៖ កន្លែងហ្នឹងអត់ គេដឹងថាត្រង់យើង លិចទូក បាក់ចប គេចោទយើងថាខ្មាំង ចូលយួន។"]។

2519 ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង សុំ ឆ.150 ["កងទ័ពវៀតណាមចូលទៅកោះនោះតាមជ្រោះដែលនៅជាប់សមុទ្រ ហើយពួកគេឡើងទៅលើភ្នំដែលមានតារាងខ្ទម្កាតចក្រ ហើយបានគេវាយចុះមកបន្ទាយរបស់យើងដែលនៅជាប់ឆ្នេរសមុទ្រ។ ហើយគេចាប់ចងពួកខ្ញុំ ហើយយកទៅដាក់នៅកោះត្រល់។"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ ឆ.111 ["រឿងនេះវាពិតហើយថាវៀតណាមចាប់មនុស្សពីអង្គភាពរបស់ខ្ញុំយកទៅ [...] ពេលហ្នឹង ពេលគេបញ្ជូនមកវិញ អ្នកដែលគេបញ្ជូនមក ក៏បានមកនៅក្នុងអង្គភាពខ្ញុំវិញដែរ ប៉ុន្តែអង្គភាពគេមិនឱ្យអ្នកដែលគេចាប់យកទៅមកនៅផ្តុំគ្នាវិញទេ [...] ដល់ពេលពង្រាយអ៊ីចឹងហើយ អ្នកដែលគេចាប់ទៅ គឺបានដក

ពេលបីខែ ពួកគេត្រូវបានដោះលែងឲ្យត្រឡប់ទៅកម្ពុជាប្រជាធិបតេយ្យវិញ[2520]។ ពេលពួកគេត្រឡប់ទៅវិញ "គេលែងទុកចិត្ត"[2521] ពួកគេ ពីព្រោះខ្មែរក្រហម "ខ្លាចយួនហ្នឹងអប់រំយើងទៅចូលជាភ្នាក់ងារ កាហ្សេបេ ឬក៏ចូលជាភ្នាក់ងាររបស់វៀតណាមអស់ហើយ"[2522]។ ពួកគេត្រូវបានដកតួនាទី[2523] ហើយទាហានមួយផ្នែកដែលត្រូវបានចាប់ និងត្រឡប់ទៅវិញ ត្រូវបានបញ្ជូនជាចុងក្រោយទៅធ្វើការនៅស្ទឹងហាវ[2524]។

631. មិនត្រឹមតែកម្មាភិបាលវំសាយនោះទេ ប្រជាជន "១៧ មេសា" ឬប្រជាជន "ថ្មី" ក៏ត្រូវបានបញ្ជូនទៅធ្វើការនៅស្ទឹងហាវដែ[2525]។

632. ឧទាហរណ៍ផ្សេងទៀតនៃការធ្វើទុក្ខបុកម្នេញទៅលើអ្នក ដែលត្រូវបានបញ្ជូនទៅលត់ដំនៅស្ទឹងហាវ អាចមាននៅក្នុងឧក្រិដ្ឋកម្មផ្សេងទៀតក្នុងទីតាំងឧក្រិដ្ឋកម្មនេះ។

## ការធ្វើមនុស្សឃាត និងការបាត់ខ្លួនដោយបង្ខំ

633. ការធ្វើមនុស្សឃាត និងការបាត់ខ្លួនដោយបង្ខំរបស់កម្មករនៅស្ទឹងហាវមានលក្ខណៈទូទៅ[2526]៖ "នៅស្ទឹងហាវ ជាកន្លែងលត់ដំអ្នកដែលត្រូវសម្លាប់ ឬអ្នកដែលត្រូវទុក"[2527]។ សាក្សី អៀម ផុង រៀបរាប់អំពីព្រឹត្តិការណ៍នោះដែលគាត់បានឃើញ៖

---

ចេញពីអង្គភាពហ្នឹងអស់ គឺឲ្យមកនៅកងផលិត [...] គេថាពួកគាត់ជាអ្នកដែលមានប្រវត្តិដែលទៅនៅវៀតណាម។"]។

[2520] ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.157-58 ["បីខែ។ [...] ឆ.158៖ [...] បន្ទាប់មក ពួកវៀតណាមដោះលែងពួកខ្ញុំនិងបញ្ជូនពួកយើងមកតាមច្រកហាទៀង។"]។

[2521] ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.164។

[2522] ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.165។

[2523] ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.174។

[2524] ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.187 ["ទាហាន ៣០០នាក់នោះ បែកគ្នាអស់ហើយពេលនោះ។ ខ្លះគេបញ្ជូនមកស្ទឹងហាវ ខ្លះទៅកន្លែងផ្សេង។"]។

[2525] ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ ប៉ែន សារិន EN ERN 00217560 ["ស្ត្រី អាយុប្រហែលពី ៤០ ទៅ ៥០ គឺស្ត្រី ១៧មេសា"]។

[2526] ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.34 ["ខ្ញុំចង់ប្រាប់អំពីព្រឹត្តិការណ៍ដែលខ្ញុំបានឃើញផ្ទាល់ភ្នែកនៅស្ទឹងហាវក្នុងពេលនោះ ខ្ញុំបានសង្កេតឃើញមានមនុស្សបាត់ខ្លួនដោយពុំដឹងអំពីហេតុផលទេ ខ្ញុំក៏បានឃើញ

យប់មួយប្រហែលម៉ោង ៧ ឬ ៨ គេមកយកមេកងខ្ញុំទៅ។ គេមិននិយាយថា គេយកគាត់ទៅសម្លាប់ទេ គេថាយកគាត់ទៅរៀនសូត្រ។ ក្រោយមក ប្រពន្ធគាត់មកសួរថាឃើញប្ដីគាត់ ឬអត់? ខ្ញុំថា បាត់យូរហើយមិនដឹងថា គេយកទៅណាទេ[2528]។

634. សាក្សីជាច្រើនបានផ្ដល់សក្ខីកម្មអំពីកាលៈទេសៈផ្សេងៗទៀត ដែលជាមូលហេតុធ្វើឱ្យអ្នកដែលស្ថិតក្នុងប្រភេទ "និន្នាការ" មានគ្រោះថ្នាក់ ត្រូវគេយកទៅសម្លាប់ចោល[2529] ឬមិនដែលឃើញ

---

ព្រឹត្តិការណ៍ក្នុងយប់មួយ គេបានចាប់មនុស្ស៣នាក់នៅជិតខ្ញុំយកទៅសម្លាប់ អ្នករងគ្រោះម្នាក់ដែលខ្ញុំស្គាល់ឈ្មោះ ឈាង ហើយពីរនាក់ទៀតខ្ញុំមិនស្គាល់ទេ អ្នកដែលសម្លាប់នៅពេលនោះឈ្មោះ អ៊ែល ដែលជាប្រធានកងអនុសេនាតូច ខ្ញុំស្គាល់ស្រុកកំណើតរបស់ អ៊ែលនិងឈាង អ៊ែលមកពីភូមិអង្គត្នោតក្នុងឃុំអង្គតាសោមជាមួយខ្ញុំ។ ខ្ញុំមិនដឹងថា អ៊ែលនោះស្លាប់ឬរស់ទេ តែពេលដែលខ្ញុំបានទៅលេងស្រុកកំណើត ខ្ញុំមិនបានឃើញអ៊ែលទេ។ អ្នករងគ្រោះនៅពេលនោះត្រូវបានគេចាត់ថា មិនគោរពអង្គការវិន័យ។ គេយក ឈាង ទៅសម្លាប់ តែគាត់មិនស្លាប់ហើយគាត់ត្រឡប់មករកសុំទឹកផឹក គាត់មានរបួសក្បាល ពេលដែលអ៊ែលឃើញឈាម គាត់បានយកឈាងទៅសម្លាប់ម្ដងទៀត ខ្ញុំពុំដឹងថា គេសម្លាប់ឈាងតាមរបៀបណាទេ ហើយ ឈាងមកពីភូមិតាគាំក្នុងឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ។"]។ ឯកសារ D114/130 កំណត់ហេតុស្ដាប់ចម្លើយ អៀម ភង់ ឆ.99, 101, 104-105, 107-08 ["បើអ្នកណាធ្វើខុស គេឱ្យអ្នកវ៉ៃថ្មជាមួយយើងហ្នឹង យកទៅវ៉ៃចោលតែម្ដង។ [...] ឆ.101៖ យកទៅវ៉ៃចោលអស់ពីរបីនាក់។ [...] ឆ.104៖ [...] យើងហូបមិនគ្រប់គ្រាន់ទេ។ ហើយបើសិនជាយើងឃ្លានខ្លាំង យើងរកបេះផ្លែឈើ ឬរកដំឡូង បើគេចាប់បាន គេសម្លាប់ចោលតែម្ដង។ [...] ឆ.105៖ [...] បើឃើញ គេវ៉ៃចោលតែម្ដង។ ខ្ញុំឃើញនឹងភ្នែក គេចាប់បានប្រុសម្នាក់ ហើយគេឱ្យក្មេងប៉ុននេះ (ប្រហែលមួយម៉ែត្រកន្លះ) វ៉ៃ។ វ៉ៃឡើងសន្លប់ឈឹង។ ពេលគាត់ភ្ញាក់ឡើង គេនាំយកទៅបាត់។ [...] ស៖ តើធ្លាប់ឃើញអ្នកផ្សេងទៀតដែលគេនាំយកទៅឃុំឃាំង នាំទៅ ឬសម្លាប់ទេ? ឆ.107៖ មាន រិន ជាមេក្រុម ដែលគេចងវ៉ៃ។ រិន លួចថ្នាំជក់។ គេបានថ្នាំ យប់ឡើងលួចបាត់ គេដឹង ហើយថ្ងៃឡើងគេយកមកចងហាលថ្ងៃវ៉ៃ ហើយទុកចោលទាំងចំណងមួយថ្ងៃ។ ហើយក្រោយមក គេយកទៅ។ ខ្ញុំមិនដឹងគេយកទៅណាទេ។ ស៖ តើលោកដែលឃើញ រិនម្ដងទៀតទេ? ឆ.108៖ ទេ គេយកទៅបាត់ហើយ។"]។ ឯកសារ D114/121 កំណត់ហេតុស្ដាប់ចម្លើយ សួន ផ ឆ. 47 ["បើតាមខ្ញុំយល់ ប្រសិនជាគេចាប់បាននរណាម្នាក់ព្យាយាមរត់គេចចេញពីកន្លែងនោះ អ្នកនោះច្បាស់ជាគេសម្លាប់ចោលហើយ។"]។ សូមមើលផងដែរ ឯកសារ D114/155 កំណត់ហេតុស្ដាប់ចម្លើយ សុខ រ៉េន ឆ.61 ["នៅស្ទឹងហាវជាកន្លែងលត់ដំអ្នកដែលត្រូវសម្លាប់ ឬអ្នកដែលត្រូវទុក។"]។

2527 ឯកសារ D114/155 កំណត់ហេតុស្ដាប់ចម្លើយ សុខ រ៉េន ឆ.61។

2528 ឯកសារ D114/130 កំណត់ហេតុស្ដាប់ចម្លើយ អៀម ភង់ ឆ.132។

2529 ឯកសារ D114/130 កំណត់ហេតុស្ដាប់ចម្លើយ អៀម ភង់ ឆ.127 ["គេសួរ តើយើងអ្នកក្រ ឬកណ្ដាល ឬមកពីណា? បើយើងថា យើងមកពីថ្នាក់ក្រ ឬកណ្ដាល គេតាមដានយើងតាមហ្នឹង។ បើយើងកម្មករថ្នាក់កណ្ដាល គេថាអ្នកគ្រាន់បើ ហើយគេយកវ៉ៃចោល។ បើយើងថាយើងអ្នកក្រ វាមិនសូវមានបញ្ហា ព្រោះយើងក្រ ហើយយើងនៅថ្នាក់ទាប។"]។

សោះ[2530]។ កាលៈទេសៈទាំងនេះរួមបញ្ចូលការប៉ុនប៉ងរត់គេចខ្លួនពីស្ទឹងហាវ[2531]។ ពេលជនរងគ្រោះបាត់ខ្លួន ឬត្រូវគេសម្លាប់ ពេលខ្លះ ខ្មែរក្រហមបានប្រកាសថា ពួកគេត្រូវបាននាំទៅអប់រំ[2532]

---

ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.30 ["ស៖ តើលោកអាចរៀបរាប់អំពីការចាប់ខ្លួនលោកបានដែរឬទេ? សូមលោកជួយរៀបរាប់។ ឆ.30៖ [...] ហេតុផលទី២ គេតាមដានពិនិត្យឃើញថា គ្រួសារខ្ញុំជាអ្នកមាន ដែលជាមុខសញ្ញាគេកម្ចាត់។"]។ ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.99, 104, 127 ["ពេលយប់ គេប្រជុំជីវទស្សន៍។ បើអ្នកណាធ្វើខុស គេឲ្យអ្នករិះគន់ជាមួយយើងហ្នឹង យកទៅវៃចោលតែម្តង។ [...] ឆ.104៖ [...] យើងហូបមិនគ្រប់គ្រាន់ទេ។ ហើយបើសិនជាយើងឃ្លានខ្លាំង យើងរកបេះផ្លែឈើ ឬរកដំឡូង បើគេចាប់បាន គេសម្លាប់ចោលតែម្តង។ [...] ស៖ លោកនិយាយថា គេឲ្យលោកទៅប្រជុំជីវទស្សន៍។ តើគេសួរអ្វីខ្លះ? ឆ.127៖ គេសួរដំបូងឡើងយើងចូល អ្នកណានាំចូល? តើយើងធ្វើខុសអីអត់? មានលួចឬអត់? គេសួរ តើយើងអ្នកក្រ ឬកណ្តាល ឬមកពីណា? បើយើងថា យើងមកពីថ្នាក់ក្រ ឬកណ្តាល គេតាមយើងតាមហ្នឹង។ បើយើងកម្មករថ្នាក់កណ្តាល គេថាអ្នកគ្រាន់បើ ហើយគេយកវៃចោល។ បើយើងថាយើងអ្នកក្រ វាមិនសូវមានបញ្ហា ព្រោះយើងក្រ ហើយយើងនៅថ្នាក់ទាប។"]។ ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ ប៉ែន សារិន EN ERN 00217561 ["សាក្សីបាននិយាយថា នៅពេលដែលប្រជាជនត្រូវបានគេកំណត់ថាមានជាប់និន្នាការជាមួយរបបចាស់ ពួកគេត្រូវបានដកចេញ ដែលមានន័យថាពួកគេត្រូវបានយកទៅសម្លាប់"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.28 ["ស៖ តើលោកអាចប្រាប់បានទេថា តើគេអាចធ្វើបាបអ្វីខ្លះដែរទៅ? ឆ.28៖ បើយើងប្រឆាំងជាមួយគេ ព្រោះសម័យនោះ គេអត់មានគុកដាក់យើងទេ។ ជួនកាលគេចាប់យើងយកទៅវៃចោលក៏មាន ជួនកាលគេយកទៅបាញ់សម្លាប់ចោលក៏មាន ឲ្យតែមានទំនាស់។"]។

2530 ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.107 ["ស៖ តើធ្លាប់ឃើញអ្នកផ្សេងទៀតដែលគេនាំយកទៅឃុំឃាំង នាំទៅ ឬសម្លាប់ទេ? ឆ.107៖ មាន រិន ជាមេក្រុម ដែលគេចងវៃ។ រិន លួចថ្នាំជក់។ គេបានថ្នាំ យប់ឡើងលួចបាត់ គេដឹង ហើយថ្ងៃឡើងគេយកមកចងហាលថ្ងៃវៃ ហើយទុកចោលទាំងចំណងមួយថ្ងៃ។ ហើយក្រោយមក គេយកទៅ។ ខ្ញុំមិនដឹងគេយកទៅណាទេ។"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.36, 38, 51 ["ប្រសិនបើអ្នកណាក្រោកមិនទាន់ ឬក៏យឺតយ៉ាវ មេក្រុមនឹងវៃនឹងដំបង ឬរំពាត់ ដោយចោទថាខ្ជិល។ បើពីរបីដងហើយ អ្នកនោះនៅមិនប្តូរ ឬកែប្រែ គេនឹងដកចេញហើយបាត់ខ្លួនរហូត។ [...] ឆ.38៖ [...] ប្រសិនបើគេមិនចូលចិត្តយើង គេដកយើងទៅ ហើយបាត់តែម្តង។ [...] ឆ.51៖ [...] ប៉ុន្តែពួកគេដកចេញទៅហើយ មិនដែលឃើញត្រឡប់មកវិញទេ។"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.34 ["ខ្ញុំចង់ប្រាប់អំពីព្រឹត្តិការណ៍ដែលខ្ញុំបានឃើញផ្ទាល់ភ្នែកនៅស្ទឹងហាវក្នុងពេលនោះ ខ្ញុំសង្កេតឃើញមានមនុស្សបាត់ខ្លួនដោយពុំដឹងហេតុផលទេ"]។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.38 ["ខ្ញុំឃើញគេយកមនុស្សទៅបាត់ កាលពីខ្ញុំនៅកងនេសាទ។"]។ ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ ប៉ែន សារិន EN ERN 00217561 ["ប្រសិនបើមាននរណាម្នាក់ប្រព្រឹត្តកំហុសបច្ចេកទេស ពួកគេនឹងត្រូវយកទៅលត់ដំ។ ហើយអ្នកដែលគេកោះហៅទៅនោះ បាត់ខ្លួន។ បើតាមសាក្សីជឿជាក់ថា ពួកគេត្រូវបានគេនាំទៅកាន់តំបន់ភ្នំបូកគោក្នុងខេត្តកំពត។"]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.24 ["ខ្ញុំធ្លាប់ឃើញ យោធាម្នាក់ដែលនៅក្នុងកងជាមួយខ្ញុំបានប្រើ

ប្រេងម៉ាស៊ីនខុសលេខ ធ្វើឲ្យខូចម៉ាស៊ីនកាណូតនោះ គាត់ត្រូវបាននាំយកទៅបាត់រហូត។ គាត់គឺជាអ្នកបើកកាណូតនៅក្នុងក្រុមនេសាទសម្រាប់ផ្តល់ឲ្យការដ្ឋានវាយថ្ម និងម្នាក់ទៀតបានបើកកាណូតទៅបុកថ្ម ហើយក៏ត្រូវគេយកទៅបាត់ដែរ។ បើសិនជាមានអ្នកណាម្នាក់ បើកឡានបុកអ្វីមួយ គាត់ក៏ត្រូវយកទៅបាត់ដែរ។"]។ សូមមើលផងដែរ ឯកសារ D114/60 កំពង់ផែយោធាស្ទឹងហាវ ការដ្ឋានធ្វើការងារដោយបង្ខំ របាយការណ៍ទីតាំងការដ្ឋានការងារ EN ERN 01082175 ["សាក្សីបាននាំយើងទៅកាន់ស្ទឹងមួយដែលនៅទីនោះគ្រោះថ្នាក់កប៉ាល់មួយបានកើតឡើង ដែលនាំឲ្យមានការសម្លាប់មិត្តរួមការងាររបស់គាត់ម្នាក់"] EN ERN 01082181 ["ដោយយោងទៅសេចក្តីអះអាងរបស់ខ្លួន សាក្សីបានបង្ហាញដុំថ្មនៅក្នុងស្ទឹងត្រង់កន្លែងដែលអ្នកបើកកប៉ាល់បានបុកថ្ម។ បន្ទាប់ពីនោះ អ្នកបើកបរកប៉ាល់ត្រូវបានគេដកចេញ ហើយក៏បានបាត់ខ្លួន។"]។ ឯកសារ D114/217 កំណត់ហេតុស្តាប់ចម្លើយ នាក់ ខឿន ឆ.7 ["ខ្ញុំឃើញថ្ងៃមួយនោះ កម្មករកំពុងហូបបាយ ជួបជុំនៅកន្លែងហូបបាយ ស្រាប់តែប្រធានកងហៅឈ្មោះមនុស្សប្អូនប្រាំនាក់ទៅ តែខ្ញុំចាំតែម្នាក់ទេ ហើយគាត់រស់នៅដល់សព្វថ្ងៃ គឺឈ្មោះ បងហ៊ិត មេភូមិនៅជិតស្ពានកំពង់ស្មាច់។ ឃើញតែមួយហ្នឹងទេ នៅរស់ ក្រៅពីហ្នឹង មិនដឹងនៅណាទេ។"]។ ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.60 ["ស៖ តើលោកដែលធ្លាប់ឃើញផ្លូវ ឬរណ្តៅកប់ខ្មោចនៅក្នុង ឬម្តុំគុកស្ទឹងហាវនោះដែរឬទេ? ឆ.60៖ កន្លែងនោះ អត់ឃើញដែរ ព្រោះអ្នកទោសគេបញ្ជូនចេញ។ អ្នកទោសនៅជាមួយខ្ញុំ យូរៗម្តងបាត់ម្នាក់ ពីរនាក់។"]។ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.52 ["ស៖ មុននេះលោកនិយាយថា ពេលខ្លះលោកឮសំឡេងឡានចូលមកក្នុងគុក ហើយព្រឹកឡើង អ្នកទោសខ្លះក៏បានបាត់ខ្លួន។ តើមែនដែរឬទេ? ឆ.52៖ ពិតមែន។"]។

2531 ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.47 ["ស៖ តើលោកចង់ធ្វើការងារនោះដែរឬទេ? តើលោកមានជម្រើសធ្វើអ្វីផ្សេងដែរឬទេ? ឆ.47៖ ខ្ញុំអត់ចង់ទេ តែខ្ញុំត្រូវតែធ្វើការងារនោះដើម្បីជាថ្នូរនឹងជីវិតរបស់ខ្ញុំ។ បើតាមខ្ញុំយល់ ប្រសិនបើជាគេចាប់បាននរណាម្នាក់ព្យាយាមរត់ចេញពីកន្លែងនោះ អ្នកនោះច្បាស់ជាគេសម្លាប់ចោលហើយ។"]។ ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.33 ["មិនមានផ្លូវរត់ចេញទេ ពីព្រោះយើងហូបបាយរួម ដូច្នេះបើយើងរត់គេចទៅកន្លែងផ្សេង យើងនឹងមិនមានអាហារហូបចុកទេ ហើយយើងនឹងចាប់ខ្លួន ហើយនឹងត្រូវសម្លាប់ដោយយោធាដែលល្បាតនៅតំបន់នោះ។"]។

2532 ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.108, 129-132 ["ស៖ តើលោកដែលឃើញ រិន ម្តងទៀតទេ? ឆ.108៖ ទេ គេយកទៅបាត់ហើយ។ [...] ស៖ តើលោកឃើញមានអ្នកណាដែលត្រូវបានគេចាប់យកទៅក្រោយពីស្រង់ប្រវត្តិរូបហើយ? ឆ.129៖ គេយកទៅពីរបីនាក់ដែរ ខ្ញុំឃើញ។ ស៖ តើលោកដែលឃើញអ្នកដែលគេនាំទៅម្តងទៀតទេ? ឆ.130៖ ទេ។ ស៖ តើលោកធ្លាប់ឮពីអ្នកផ្សេងថាមានអ្វីកើតឡើងចំពោះអ្នកទាំងនោះទេ? ឆ.131៖ ខ្ញុំស្មានខ្លួនឯងថា បើគេយកទៅ គឺគេវ៉ៃចោលហើយ។ [...] ឆ.132៖ យប់មួយប្រហែលម៉ោង៧ ឬ៨យប់ គេយកមេកងខ្ញុំទៅ។ គេមិននិយាយថា គេយកគាត់ទៅសម្លាប់ទេ គេថាយកគាត់ទៅរៀនសូត្រ។ ក្រោយមកប្រពន្ធគាត់មកសួរថាឃើញប្តីគាត់ឬអត់? ខ្ញុំថា បាត់យូរហើយមិនដឹងថា គេយកទៅណាទេ។ អ្នកនាំមកគឺកងផ្សេងដែលគេទទួលបញ្ជាពីថ្នាក់លើមក។"]។ ឯកសារ D54/12 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.23 ["មិនមាននរណាអាចដឹងបានទេនៅពេលដែលគេនាំមនុស្សនាំយកចេញទៅបាត់ ពីព្រោះគេតែនិយាយថា យកអ្នកនោះទៅរៀនសូត្រ។ ពេលដែលគេយកមនុស្សទៅសម្លាប់ឬបញ្ជូនទៅកងដទៃទៀត ឬយកទៅរៀបការក៏គេប្រាប់ថា យកទៅរៀនសូត្រដែរ។"]។

ឬទៅរៀនសូត្រ[2533] ឬបញ្ជូនទៅធ្វើការនៅកន្លែងផ្សេងទៀត[2534]។ "បើពេលគេសង្ស័យយើង គេយកទៅ ហើយមិនដឹងយកទៅណាទេ គឺមិនដែលឃើញមកវិញទេ"[2535]។ ជនរងគ្រោះដែលជាប់ឃុំនៅគុកស្ទឹងហាវក៏បាត់ខ្លួនផងដែរ[2536]។ អ្នកបាត់ខ្លួនទាំងនោះទំនងជាជួបជោគវាសនាដូចគ្នានឹងអ្នកដែលជាប់ឃុំជាមួយ នង នេត ដែលត្រូវគេបញ្ជូនចេញក្រៅ និងសម្លាប់ក្រោយការចាប់ខ្លួន[2537]។

635. ប្រហែលមួយសប្តាហ៍ មុនវៀតណាមចូលមកដល់ កម្មករប្រុសមកពីភូមិភាគបូព៌ាត្រូវសមាជិកកងវរសេនាតូចពិសេសនៅស្ទឹងហាវចាប់ដាក់លើឡាន[2538]។ អ្នកក្នុងក្រុមនេះខ្លះអាចរត់គេចខ្លួនចូល

[2533] ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន KH ERN 01301517 ["វាក៏ដកពួកខ្ញុំហ្នឹងថាឡើងទៅរៀន តែខ្ញុំមិនទាន់ទៅទេ ទៅតែពួកខ្ញុំនៅក្នុងកងហ្នឹង។ ដល់ដកទៅរៀន បាត់រហូត អត់ឃើញមកវិញទេ។"]។

[2534] ឯកសារ D114/146 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.47 ["គេគ្រាន់តែប្រាប់ថា គេបញ្ជូនគាត់ ឬពួកគាត់ឱ្យទៅធ្វើការនៅកន្លែងផ្សេង។ ហើយបន្ទាប់មក គេចាត់តាំងមនុស្សផ្សេងឱ្យឡើងដឹកនាំវិញ។ អ្នកដែលគេបញ្ជូនទៅ គឺត្រូវបាត់ខ្លួន ហើយយើងពុំដឹងថា ពួកនោះ ត្រូវគេបញ្ជូនទៅទីណាទេ។"]។

[2535] ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.101។

[2536] ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.60 ["ស៖ តើលោកដែលធ្លាប់ឃើញផ្ទះ ឬរណ្តៅកប់ខ្មោចនៅក្នុង ឬម្តុំគុកស្ទឹងហាវនោះដែរឬទេ? ឆ.60៖ កន្លែងនោះ អត់ឃើញដែរ ព្រោះអ្នកទោសគេបញ្ជូនចេញ។ អ្នកទោសនៅជាមួយខ្ញុំ យូរៗម្តងបាត់ម្នាក់ ពីរនាក់។"]។

[2537] ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977459 ["ស្រាប់តែម៉ោង៧ព្រឹក ថ្ងៃទី៧ មកវាហ្នឹងគេបណ្តើរទៅដាក់តែម្តងព្រាត។ ម៉ាខ្សែដប់នាក់ៗឃោតអ្នស់ ឃោតខ្ញុំ ដើរដាក់រ៉ឺកាត់ព្រឹកតែម្តង កាត់ព្រឹកអ្នស់ម៉ោង៧។ ទៅដល់ហ្នឹងគេហូតមួយទៅខ្វោក អ! ញ៉ូរទាំងអស់គ្នាហើយ អានាក់កាន់ដំបងក៏ញ៉ូរដែរ ខ្មៅគ្រាក់តែម្តងសម្បុរវា។ ហើយអាមេបញ្ជាការវាថាឯងមិនរើរើស វាប្រុងបាញ់ចោលទៀតណា។ [...] ស្រាប់តែគេហូតមួយទៅអង្គុយ គេថាអង្គុយឱ្យស្ងៀម ស្រាប់តែដាក់គឹង ឃើញប្រកាច់ញ៉ូរតែម្តងទៅហើយ។ ស៖ គ្នា៥០នាក់ហ្នឹងរើម្តងមួយៗ? ឆ៖ បាទ។"]។ ឯកសារ D234/2.1.138 នង នេត ប្រតិចារឹកថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ម៉ោង 11.29.20-11.31.06 ["រើចាក់ រើចាក់ ពួកខ្ញុំ"]។ ឯកសារ D54/68.1 គំនូសបង្ហាញផែនទី EN-KH ERN 00977482 [បង្ហាញពីទីកន្លែងសម្លាប់មនុស្សចម្ងាយពី២-៣០០ម៉ែត្រពីមូលដ្ឋានយោធា]។ សូមមើល ផងដែរ ឯកសារ D54/69 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.42។

[2538] ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.17-18 ["ខ្ញុំធ្វើការនៅកងកេងរហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៨ ទើបគេបញ្ជូនខ្ញុំឱ្យទៅធ្វើការនៅស្ទឹងហាវ។ [...] ឆ.18៖ [...]ខ្ញុំចង់ប្រាប់លោកអំពីរឿងដ៏រន្ធត់មួយដែលកើតឡើងនៅស្ទឹងហាវ ចំពោះកម្មករផ្លូវរថភ្លើងថ្មី។ កម្មករផ្លូវរថភ្លើងថ្មីទាំងនោះមកពីភូមិភាគឧត្តរ និងភូមិភាគបូព៌ា។ នៅពេលនោះ មនុស្សទាំងនោះ មានទីកន្លែងស្នាក់នៅប្រហែល១០០ម៉ែត្រពីកន្លែងខ្ញុំ។ ថ្ងៃមួយ ខ្មែរក្រហមបើអង្គប្រជុំប្រាប់យើងថា ពួកវៀតណាមបានចូលកាន់កាប់ខេត្តក្រចេះប្រហែលជា១ខែហើយ។ [...] ថ្ងៃមួយ ប្រហែលជា ៦ ឬ ៧ថ្ងៃមុនពេលវៀតណាមចូលមកដល់តំបន់ស្ទឹងហាវ កំពង់សោម មានឡានបែនដឹកដីមួយចំនួនចូលមកកន្លែងពួកកម្មកររថ

ក្នុងព្រៃ[2539]។ សាក្សី អ៊ឹម សុខន បានអះអាងថា មួយសប្តាហ៍មុនវៀតណាមចូលមកដល់ មានការសម្លាប់ទ្រង់ទ្រាយធំទៅលើកម្មករនៅស្ទឹងហាវ ដែលប៉ុនប៉ងរត់ចូលក្នុងព្រៃ[2540]។

## ការឃុំខ្លួនដោយខុសច្បាប់ និងការធ្វើទារុណកម្ម

636. ការចាប់ខ្លួននៅស្ទឹងហាវមានលក្ខណៈទូទៅ ហើយគ្មានមូលដ្ឋានច្បាប់ដែលមានសំអាងហេតុច្បាស់លាស់ចំពោះការចាប់ខ្លួនទាំងនេះ និងគ្មាននីតិវិធីតុលាការដើម្បីជជែកដេញដោលរឿងនេះទេ[2541]។ យ៉ាងហោចណាស់ មានគុកមួយដំណើរការនៅស្ទឹងហាវ ដែលត្រូវបានសាងសង់ បន្ទាប់

---

ភ្លើងថ្មី។ បន្ទាប់មកក៏មានយោធាជាច្រើនមកពីកងពិសេសមកដល់ តាមឡានរបស់គេ ហើយធ្វើការចាប់ចងពួកកម្មករប្រុសៗ ចងដៃ បោះដាក់ទៅលើឡានដឹកដីដែលនៅចាំទីនោះ។ ពេលនោះ បើពួកប្រពន្ធ កូនកម្មករស្រែយំ គេនឹងចាប់ប្រពន្ធនោះបោះចូលទៅក្នុងឡានជាមួយប្តីរបស់ពួកគេដែរ។ ខ្ញុំឃើញព្រឹត្តិការណ៍ដ៏រន្ធត់នេះ ខ្ញុំជឿថាព្រឹត្តិការណ៍នេះកើតឡើងតាមបញ្ជារបស់ តាមុត ពីព្រោះយោធាដែលមកចាប់ចងនេះជាយោធាកងពិសេស។ ខ្ញុំឃើញព្រឹត្តិការណ៍នេះខ្ញុំក្រៀមក្រំណាស់ ពីព្រោះខ្ញុំធ្លាប់ឃើញមនុស្សមួយចំនួននៅក្នុងក្រុមកម្មករផ្លូវរថភ្លើងថ្មីនេះ"]។

2539 ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.18 ["ខ្ញុំគិតថាមានមនុស្សខ្លះដែលអាចរត់រួចពីការចាប់ចងពីពេលនោះ ហើយរត់គេចចូលទៅក្នុងព្រៃ។"]។

2540 ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.77-78 ["ស៖ យើងសួរលោកពីបញ្ហានេះ ក្រែងលោកនឹកឃើញអំពីព្រឹត្តិការណ៍មួយចំនួននៃការសម្លាប់កម្មករទ្រង់ទ្រាយធំមួយនៅស្ទឹងហាវ នៅសប្តាហ៍ចុងក្រោយ មុនវៀតណាមចូល។ យើងបានទទួលព័ត៌មានមកថាកម្មករមួយក្រុមធ្វើការនៅជិតផ្លូវរថភ្លើង ក្បែរស្ពានផ្លូវចូលទៅស្ទឹងហាវ (ទីតាំងក្បែរលោកធ្វើការដែរ) បានបះបោរប្រឆាំងនឹងកម្មាភិបាលនៅទីនោះ ហើយក្រោយមកត្រូវបានចាប់ខ្លួនដោយយោធា និងសម្លាប់ចោល។ ឆ.77៖ មានមែន ពួកគ្នាខ្ញុំមួយក្រុមហ្នឹង ខ្លះក៏រត់រួច ខ្លះក៏សម្លាប់ចោល។ ព្រឹត្តិការណ៍ហ្នឹងមានមែន។ រត់បំបែកគ្នាជាក្រុមៗចូលព្រៃ គេតាមបាញ់សម្លាប់មែន។ កម្លាំងទ័ពស្រួចហ្នឹង គេខ្លាចបះបោរចូលជាមួយយួន គេបាញ់កម្ទេចតែម្តង។ នាំគ្នារត់ចូលព្រៃទៅ ចេះតែរត់ផ្សងព្រេង អត់បាយអត់ទឹក បែកគ្នាអស់។ ស៖ តើលោកដឹងថា អ្នកដែលរត់ពេលនោះ ត្រូវបានគេចាប់បាន ឬសម្លាប់អស់ប៉ុន្មាននាក់ទេ? ឆ.78៖ រត់បែកគ្នាមួយប្រាវហ្នឹង មិនដឹងប៉ុន្មាន ប៉ុន្តែមានស្លាប់ច្រើន។"]។

2541 សូមមើល ឧទាហរណ៍ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.30 ["ស៖ តើលោកអាចប្រាប់អំពីការចាប់ខ្លួនលោកបានដែរឬទេ? សូមលោកជួយរៀបរាប់។ ឆ.30៖ បាទ ខ្ញុំអាចប្រាប់បាន។ បញ្ហាដែលគេដកខ្ញុំចេញពីអង្គភាព មកពីគេពិនិត្យឃើញថា ខ្ញុំជា សេ.អ៊ី.អា, កា.ហ្សេ.បេ។ ក្រោយពីគេយកមកអង្គភាព៦១២មក គេតាមដានពិនិត្យខ្ញុំ គឺពេលដែលខ្ញុំចុះធ្វើការងារ ប្រគល់ការងារឱ្យខ្ញុំធ្វើ គេពិនិត្យឃើញថា ក្នុងអង្គភាពរបស់ខ្ញុំមានបាក់ដែកស្បែង រទេះដាច់ហ្វ៊ីត គេចោទខ្ញុំថាបានបំផ្លាញ នេះជាហេតុផលទី១។ ហេតុផលទី២ គេតាមដានពិនិត្យឃើញថាគ្រួសារខ្ញុំជាអ្នកមាន ដែលជាមុខសញ្ញាគេកម្ចាត់។"]។ ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.27 ["ស៖ តើលោកអាចជួយឱ្យយើងយល់បានបន្ថែមទៀត តើផ្ទះដែលគេចាប់ពួកលោកហ្នឹង ស្ថិតនៅត្រង់ចំណុចណាដែរ?

ពីខ្មែរក្រហមកាន់កាប់អំណាច[2542]។ គុកនោះមានទីតាំងនៅ ឬជិតភូមិស្ទឹងហាវ[2543] និងមាន ប្រហែល ២០ បន្ទប់ ដែលបន្ទប់នីមួយៗមានទទឹងមួយម៉ែត្រ បណ្តោយមួយម៉ែត្រកន្លះ ហើយមួយ

---

ឆ.27៖ កាលគេចាប់ខ្ញុំហ្នឹង ផ្លូវទៅស្ទឹងហាវ អាផ្លូវបត់ កែង ហើយចំច្រុងហ្នឹង។ វាលោតពីលើផ្ទះមក ទាត់ធាក់ ភ្លង់ខ្ញុំ ហើយចាប់យកទៅ។ ចាប់ចងស្លាបសេក យកចូលគុក ហើយសួរចម្លើយ។"]។ ឯកសារ D234/2.1.138 នង នេត ប្រតិចារឹកថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ម៉ោង 11.26.32-11.28.00 ["ចងរយៈពេល១៣ថ្ងៃ ១៣យប់"]។ សូមមើល ផងដែរ ឯកសារ D54/69 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.4 ["ហើយបន្ទាប់មកចាប់ចង និងឃុំឃាំងពួកយើង ព្រមទាំងសួរចម្លើយធ្វើទារុណកម្មចំនួន១៣ថ្ងៃ ១៣យប់ មុនពេលដែលនាពួកយើងយកទៅសម្លាប់។"]។ ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977458 ["ដល់គេចាប់គេច ងហើយគេស្រាតខោស្រាតអាវទុកតែខោខ្លីមួយ។"]។ ឯកសារ D54/67.2 មជ្ឈមណ្ឌលឯកសារកម្ពុជា ទស្សនាវដ្តី "ស្វែងរកការពិត" ជីវិតដល់ពីសេចក្តីស្លាប់ (នេត) KH ERN 01374689 ["នៅកន្លែងប្រជុំ ក្រុមទាហាន បានដោះលែង ហឿន ហើយបែរមកចាប់ នេត និងមិត្តភក្តិទាំងអស់ចង ហើយចោទប្រកាន់ពីបទបះបោរប្រឆាំងនឹងអង្គការទៅវិញ។"]។ ឯកសារ D114/275 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ស្ទឹងហាវ ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ EN ERN 01346014 ["គាត់ត្រូវបានគេចាប់ខ្លួនក្នុងផ្ទះមួយនៅស្ទឹងហាវ។ បន្ទាប់មកគាត់ត្រូវបានគេបញ្ជូនទៅដាក់គុកនៅស្ទឹងហាវ ដែលជាកន្លែងដែលគាត់ត្រូវបានឃុំខ្លួននិងធ្វើទារុណកម្ម។"]។

2542 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.27, 34 ["ខ្ញុំចាប់ខ្លួនខ្ញុំ នៅក្នុងខែ១ ឬខែ២ ឆ្នាំ១៩៧៧ ឬ ១៩៧៨។ [...] ឆ.34៖ គុកធ្វើថ្មីទេ។"]។

2543 ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.30-32 ["ស៖ យើងអាចធ្វើបែបនេះ ពេលក្រោយ។ តើទីតាំងផ្ទះ និងទីតាំងគុកនោះមានឈ្មោះអ្វីដែរឬទេ? ឆ.30៖ អត់ទេ ហ្នឹងគេហៅថាភូមិស្ទឹងតែម្តង កាច់ចូលទៅ ថ្ងៃនេះវានាំខ្ញុំដើរទៅព្រៃចេក ហើយទៅដល់គុកតែម្តង។ ស៖ តើផ្ទះដែលគេចាប់ខ្លួនពួកលោកនៅឆ្ងាយប៉ុន្មានដែរគុកនោះ? ឆ. 31៖ កន្លែងចាប់ហ្នឹងទៅដល់ស្ទឹងហាវហ្នឹង ដើរមួយសន្ទុះធំដែរ។ ស៖ ដូច្នេះតើផ្ទះដែលគេចាប់ខ្លួនពួកលោក និងគុកនោះស្ថិតនៅក្នុងបរិវេណស្ទឹងហាវមែនទេ? ឆ.32៖ អាកន្លែងហ្នឹងវាចូល ដូចទៅដល់ហ្នឹង"]។ ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977458 ["ស៖ គុកនៅណា? ឆ៖ នៅជើងភ្នំហ្នឹង។ ស៖ នៅជើងភ្នំហ្នឹង? ឆ៖ បា! ស៖ នៅភូមិអី សង្កាត់អីដែរ? ឆ៖ ស្ទឹងហាវ។"]។ ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.33 ["ស៖ តើគុកនេះស្ថិតនៅទីណាដែរ? ឆ.33៖ នៅខាងជើងវរសេនាធំ នៅស្រុកស្ទឹងហាវ។"]។ ឯកសារ D54/69 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.37 ["ស៖ តើបរិវេណកន្លែងឃោធាមានចម្ងាយប៉ុន្មានពីផ្លូវទៅស្ទឹងហាវ? ឆ.37៖ ទីតាំងឃោធានោះមានចម្ងាយប្រហែល១០ម៉ែត្រជាងពីផ្លូវទៅស្ទឹងហាវ។"]។ សូមមើល ផងដែរ ឯកសារ D54/68.1 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឧបសម្ព័ន្ធ៖ គំនូសបង្ហាញទីកន្លែង និងផ្លូវ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៤ KH ERN 01145014។ ឯកសារ D54/68.2 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាលនៃស្រុកស្ទឹងហាវ ក្រុងសីហនុ ឆ្នាំ ២០០៨-២០១០ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០១៤ KH ERN 00977483។

បន្ទប់ៗដាក់អ្នកទោសម្នាក់[2544]។ អ្នកដែលគេសង្ស័យជាខ្មាំងត្រូវបានចាប់ ឃុំឃាំង សួរចម្លើយ និងធ្វើទារុណកម្មនៅទីនោះ។

637. សាក្សី សន ជួន, នង នេត និង ឡុង ផាន់ស៊ី ត្រូវបានឃុំឃាំង និងធ្វើទារុណកម្មនៅស្ទឹងហាវទាំងអស់គ្នា ហើយអ្នកផ្សេងទៀតបានឮគេនិយាយអំពីគុកនៅទីនោះ[2545]។ ហេតុការណ៍ដែលកើតឡើងចំពោះ នង នេត ជាឧទាហរណ៍គួរឱ្យតក់ស្លុតដែលមិនត្រឹមតែបង្ហាញអំពីចេតនាធ្វើទុក្ខបុកម្នេញទៅលើជនរងគ្រោះនៅស្ទឹងហាវប៉ុណ្ណោះនោះទេ ថែមទាំងបង្ហាញអំពីអ្វីដែលកើតឡើងចំពោះម្នាក់ៗដែលបានជំទាស់នឹងលក្ខខណ្ឌគំរាមកំហែងជីវិតនៅទីនោះផងដែរ។ នង នេត ស្ថិតក្នុងក្រុមកម្មករដែលងើបឡើងប្រឆាំងនឹងកង្វះអាហារគ្រប់គ្រាន់[2546] និងបានឃុំអ្នកគ្រប់គ្រងរបស់ពួកគេ

---

[2544] ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.48-49 ["ស៖ ឥឡូវចូលយើងត្រឡប់មកនិយាយពីគុកនៅស្ទឹងហាវឡើងវិញ។ តើគុកនោះមានបន្ទប់ប៉ុន្មានដែរ? ឆ.48៖ ខ្ញុំមិនបានរាប់ទេ តែប្រហែលជាមានបន្ទប់២០។ មានទទឹងមួយម៉ែត្រ បណ្តោយអីចេះមួយម៉ែត្រកន្លះ។ ស៖ ជាមធ្យម តើលោកដឹងថា មួយបន្ទប់ គេដាក់អ្នកទោសប៉ុន្មាននាក់ដែរ មួយលើកៗ? ឆ.49៖ ខ្ញុំដឹងតែលើកខ្ញុំ មួយបន្ទប់ គេដាក់មួយនាក់។"]។

[2545] ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.37 ["ប៉ុន្តែខ្ញុំបានឮពីអ្នកផ្សេងនិយាយថាមានគុកនៅស្ទឹងហាវ ប៉ុន្តែខ្ញុំពុំស្គាល់អ្នកធ្លាប់ជាប់ទោសណាម្នាក់នៅរស់ទេ ហើយខ្ញុំក៏មិនដឹងអំពីគុកនៅស្ទឹងហាវនោះដែរ។ អ្នកដែលប្រាប់ខ្ញុំអំពីរឿងគុកនៅស្ទឹងហាវឈ្មោះ ប៉ែន មកពីខេត្តតាកែវ ប៉ុន្តែខ្ញុំមិនដឹងថាគាត់នៅទីណាទេ នាពេលនេះ។"]។ ឯកសារ D114/155 កំណត់ហេតុស្តាប់ចម្លើយ សុខ រ៉េន ឆ.61 ["ខ្ញុំឮព័ត៌មានថាមានគុកនៅទឹកសាប, ទី២ នៅស្ទឹងហាវដែលប្រើសម្រាប់ដាក់អ្នកជាប់ពាក់ព័ន្ធនឹងនយោបាយ។"]។

[2546] ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977456 ["យើងអត់មិនបាន ទៅប្រឹងថាមិនដឹងជាគិតយ៉ាងម៉េច មិនប្រឆាំងទេ ដល់វើបំរាស់ឡើងក្នុងមែន។ [...] វើបំរាស់ឡើងចាប់អាហឿនហ្នឹងពួកខ្ញុំ។"]។ ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.26, 34 ["តែលក្ខខណ្ឌការងារនៅត្រពាំងក្រឡឹង និងស្ទឹងហាវ គឺមានការលំបាកខ្លាំងណាស់។ ខ្ញុំគិតថាមនុស្សយើងគឺមិនអាចទទួលរួចនូវការងារក្នុងស្ថានភាពនៅត្រពាំងក្រឡឹង និងស្ទឹងហាវទេ។ ចុងបញ្ចប់ យើងមិនអាចទ្រាំទ្រទៀតបាន ពួកយើងខាង ហើយយើងបានបះបោរប្រឆាំងនឹង ហឿន ហើយយើងចាប់ខ្លួន ហឿន។ [...] ឆ.34៖ នៅថ្ងៃមួយនៅពេលល្ងាចម៉ោង៥ក្រោយពីសម្រាកការងារ យើងនិយាយជាមួយកម្មករគ្នាឯង ដើម្បីរៀបចំផែនការចាប់ ហឿន។ យើងបានដេញចាប់ ហឿន ដល់វាលស្រែ ហើយយើងចាប់បានគាត់នៅប្រហែល១០០ម៉ែត្រពីការដ្ឋាន ហើយយើងក៏ចង ហឿន នឹងក្រមា រួចបញ្ជូនទៅឱ្យយោធា។"]។ ឯកសារ D234/2.1.138 នង នេត ប្រតិចារឹកថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ម៉ោង 11.07.54-11.10.16 ["យើងត្រូវមានកម្លាំងមួយសាមគ្គីគ្នាតស៊ូ ដេញចាប់មេប្រធានដាំបាយនោះ។ ដល់ចាប់អាមេប្រធាននោះឈ្មោះ ហឿន។ [...] មេដាំបាយ"]។

ឈ្មោះ ហឿន ដែលទទួលខុសត្រូវផ្ទះបាយ[2547] និងដែលពួកគេយល់ដោយភន្តច្រឡំថាជាអ្នកសម្រេចចិត្តបង្អត់អាហារពួកគេដោយឯកឯង[2548]។ "ខ្ញុំ និងកម្មករផ្សេងទៀតបានដឹងថា បើសិនជាពួកយើងនៅតែរស់នៅក្នុងស្ថានភាពជីវិតបែបនេះទៀត យើងនឹងត្រូវស្លាប់ជាមិនខាន។ ហេតុដូច្នេះហើយបានជាយើងបះបោរប្រឆាំងជាមួយ ហឿន"[2549]។ ពួកគេនោតក៏យក ហឿន ទៅកម្មាភិបាលគ្រប់គ្រងស្ទឹងហាវ ដោយជឿថា គាត់នឹងត្រូវបានស្តីបន្ទោស។ "ហេតុផលដែលយើងយក ហឿន ទៅឱ្យពួកយោធា ពីព្រោះយើងចង់ឱ្យពួកយោធាណែនាំ ហឿន ឱ្យផ្តល់ម្ហូបអាហារឱ្យយើងហូបចុកបានគ្រប់គ្រាន់"[2550]។ កម្មករទាំងនោះ ៥០ នាក់ដែលចូលរួមក្នុងការចាប់ ហឿន ត្រូវបានខ្មែរក្រហមចាប់ខ្លួនម្តងម្នាក់ៗ[2551]។ ពេលពួកគេប្រាប់ទៅកម្មាភិបាលថា ពួកគេ "ស៊ីបាយមិនគ្រប់

---

2547 ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.34 ["សៈ តើលោកអាចរៀបរាប់ប្រាប់យើងអំពីការចាប់ខ្លួន ហឿន បានដែរឬទេ? ឆ.34៖ នៅថ្ងៃមួយនៅពេលល្ងាចម៉ោង៥ក្រោយពីសម្រាកការងារ យើងនិយាយជាមួយកម្មករគ្នាឯង ដើម្បីរៀបចំផែនការចាប់ ហឿន។ យើងបានដេញចាប់ ហឿន ដល់វាលស្រែ ហើយយើងចាប់បានគាត់នៅប្រហែល១០០ម៉ែត្រពីការដ្ឋាន ហើយយើងក៏ចង ហឿន នឹងក្រមា រួចបញ្ជូនទៅឱ្យយោធា។ នៅថ្ងៃបន្ទាប់យោធាម្នាក់បានជិះម៉ូតូមកប្រាប់យើងនៅការដ្ឋាន ឱ្យយើងមុជទឹក និងរៀបចំខ្លួនទៅប្រជុំនៅកន្លែងយោធា។ យោធានោះបានហៅឈ្មោះមនុស្ស៥០នាក់ពីក្នុងបញ្ជី។ ពេលដែលយើងមកដល់កន្លែងយោធាៗបានឱ្យយើងទៅអង្គុយរង់ចាំនៅក្រោមផ្ទះ ហើយខ្ញុំបានឃើញ ហឿន នៅជាប់ចំណងអង្គុយនៅក្រោមផ្ទះនោះដែរ។ យោធាម្នាក់បានបញ្ជាឱ្យយើងទាំង៥០នាក់អង្គុយនៅក្រោមផ្ទះ ហើយគេបានស្រាយចំណង ហឿន ដោយប្រាប់ឱ្យ ហឿន ត្រឡប់ទៅធ្វើការវិញ។ បន្ទាប់មក មេយោធាបានមកដល់ ក៏ចាប់ផ្តើមនិយាយប្រាប់យើងអំពីរបៀបបំពេញការងារឱ្យបក្ស។ នៅពេលជាមួយគ្នានោះ មានយោធាប្រហែល១០នាក់ទៀតចេញមកពីគ្រប់ទិស ដោយអាម៉េកាំភ្លើងដាក់ពួកយើង។ ពេលនោះ មេយោធានោះបានប្រាប់យើងថាកុំឱ្យយើងរត់។ បន្ទាប់មកពួកយោធាក៏បានចាប់ផ្តើមចងពួកយើងទាំង៥០នាក់នឹងក្រមារបស់ពួកយើង។"]។ ឯកសារ D234/2.1.138 នង នេត ប្រតិចារឹកថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១៦ ម៉ោង 11.07.54-11.10.16 ["យើងត្រូវមានកម្លាំងមួយសាមគ្គីគ្នាតស៊ូ ដេញចាប់អាមេប្រធានដាំបាយនោះ។ ដល់ចាប់អាមេប្រធាននោះ ឈ្មោះ ហឿន។ [...] ហ្នឹងប្រធានរោងកន្លែងធ្វើការនៅម្តុំស្ទឹងហាវហ្នឹង។"]។

2548 ឯកសារ D234/2.1.138 នង នេត ប្រតិចារឹកថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ម៉ោង 11.07.54-11.10.16 ["ហើយខ្ញុំថា ចុយ! មានខ្លាំងឯណា អាហឿន ហ្នឹង ពួកហ្នឹងសុទ្ធតែចាប់ មិនឱ្យឯងហូបបាយគ្រប់គ្រាន់តើ! មានអីទៅជាអាហឿន ត្រូវវិញ អាអ្នកដាំបាយ មកខុសយើង។ មកខុសយើង គេចងយើងតែម្តង ៥០នាក់ ចងក្រឹបៗ"]។

2549 ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.27។

2550 ឯកសារ D54/69 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.5។

2551 ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977456 ["ហេកហាកថាខ្មែរក្រហមម៉ោហើយ ដេញចាប់ធ្វើបាបយើងពេក។"]។ ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.29, 34 ["ក្នុងពេលនោះមានមនុស្សច្រើនបះបោរប្រឆាំងជាមួយ ហឿន ប៉ុន្តែបន្ទាប់មក គឺមានតែមនុស្ស៥០

គ្រាន់"[2552] "ប៉ុល ពត គេថាត្រូវហើយ ហឿន នោះ វាខុសពួកខ្ញុំ វាយើងបះបោរប្រឆាំង"[2553]។ "វាកាន់ជើងគ្នាគេហ្នឹង អាឲ្យបាយយើងស៊ីមិនគ្រប់គ្រាន់"[2554]។ ហឿន ត្រូវបានដោះលែង ហើយពួក

---

នាក់ប៉ុណ្ណោះ ដែលត្រូវបានចាប់ខ្លួន។ [...] នៅថ្ងៃបន្ទាប់យោធាម្នាក់បានជិះម៉ូតូមកប្រាប់យើងនៅការដ្ឋានឲ្យយើងមុជទឹក និងរៀបចំខ្លួនទៅប្រជុំនៅកន្លែងយោធា។ យោធានោះបានហៅឈ្មោះមនុស្ស៥០នាក់ពីក្នុងបញ្ជី។ [...] ឆ.34៖ [...] យោធាម្នាក់បានបញ្ជាឲ្យយើងទាំង៥០នាក់អង្គុយនៅក្រោមផ្ទះ ហើយគេបានស្រាយចំណង ហឿន ដោយប្រាប់ឲ្យ ហឿន ត្រឡប់ទៅធ្វើការវិញ។ បន្ទាប់មក មេយោធាបានមកដល់ ក៏ចាប់ផ្ដើមនិយាយប្រាប់យើងអំពីរបៀបបំពេញការងារឲ្យបក្ស។ នៅពេលជាមួយគ្នានោះ មានយោធាប្រហែល១០នាក់ទៀតចេញមកពីគ្រប់ទិស ដោយអាម៉េកាំភ្លើងដាក់ពួកយើង។ ពេលនោះមេយោធានោះបានប្រាប់យើងថាកុំឲ្យយើងរត់។ បន្ទាប់មកពួកយោធាក៏បានចាប់ផ្ដើមចងពួកយើងទាំង៥០នាក់នឹងក្រមារបស់ពួកយើង។"]។ ឯកសារ D234/2.1.138 នង នេត ប្រតិចារឹកថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ម៉ោង 11.07.54-11.10.16 ["គេមកនាំពួកខ្ញុំទៅ ទៅប្រជុំដោះស្រាយបញ្ហាចាប់ ហឿន ហ្នឹង។ ដល់ទៅដល់ទៅ ហឿន នៅនុ៎ងមែន នៅកន្លែងទាហានគេនុ៎ង ប៉ុ ហឿន ហ្នឹង។ ហើយគេឲ្យខ្ញុំអង្គុយកៅអីស្រួលបួល ៥០នាក់អង្គុយកៅអីស្រួលបួលអ៊ីចឹង ប៉ុន្តែមិនមែនកៅអ៊ីចឹងទេ កៅអីឈើធម្មតា ឲ្យអង្គុយក្រោមផ្ទះគំរូនោះ សម្រាប់ឲ្យគេហៅប្រជុំៗ គេថាទៅប្រជុំដោះស្រាយបញ្ហាឲ្យជ្រះស្រឡះឲ្យចេញ ព្រោះចាប់មេដាំបាយនៅនោះ ហើយ មេហឿន ហ្នឹងប្រធានរោងកន្លែងធ្វើការនៅម្ដុំស្ទឹងហាវហ្នឹង។ អ៊ីចឹងទេ ខ្ញុំក៏ព្រមព្រៀង គេហៅឈ្មោះខ្ញុំ មាន៥០នាក់គេហៅឈ្មោះហៅឈ្មោះ៥០នាក់ នាំគ្នាទៅពេលថ្ងៃត្រង់ គេថាងូតទឹកឲ្យស្រួលទៅ សម្លៀកបំពាក់ឲ្យស្អាតទៅ ប៉ុន្តែខោខ្មៅ អាវខ្មៅទេ ហើយក្រមាខៀវ។ ទៅៗ ៥០នាក់ ឈ្មោះនេះ ឈ្មោះនោះ ខ្ញុំអត់បានចាំគ្រប់គ្នាទេ។ ដល់ពេលទៅដល់នោះ គេប្រជុំៗ ស្រាប់តែអាម៉េច្រេវច្រាវៗ គេថា កុំរត់! កុំរត់! កុំរត់! ហើយខ្ញុំថា ចុយ! មានខ្លាំងឯណា អាហឿន ហ្នឹង ពួកហ្នឹងសុទ្ធតែចាប់ មិនឲ្យឯងហូបគ្រប់គ្រាន់តើ! មានអីទៅជាអាហឿន ត្រូវវិញ អាអ្នកដាំបាយ មកខុសយើង។ មកខុសយើង គេចងយើងតែម្ដង ៥០នាក់ ចងក្រឹបៗ ប៉ុន្តែខ្ញុំភ្លេចហើយថ្ងៃខែខ្ញុំ ខ្ញុំអត់បានចំណាំ នាឡិកាខ្ញុំ គេដកទៅ ចងប៉ុន្តែខ្ញុំដឹងតែរយៈដប់--"] ម៉ោង 11.26.30-11.28.00 ["ដល់ទៅដល់អាកន្លែងនោះ ស្រាប់វានាំគ្នាប្រជុំទៅ ហើយឃើញទាហានវាព័ទ្ធជុំវិញអស់ ដល់ប្រជុំទៅ ស្រាប់គេអាមេច្រេវច្រាវ គេថាកុំរត់! កុំរត់! គេយកអាក្រមាខៀវចងពួកខ្ញុំ ៥០នាក់គ្រប់គ្នា។ ចងគ្រប់គ្នាទៅ ហើយខ្ញុំថា ឯងមានពាក់ព័ន្ធមានខ្លាំងឯណា ឥឡូវមកចាប់គ្នាឯងមនុស្សស្លូតត្រង់។ នឹកក្នុងចិត្តអ៊ីចឹងថា ខ្លួនខ្ញុំវាស្លូតត្រង់ អង្កាល់នុ៎ងខ្ញុំអាយុនៅក្មេងដែរជំនាន់នុ៎ង អាយុទើប២០ជាង។ អ៊ីចឹងទៅ ឯងមិនដែលធ្វើអីឲ្យខុសឆ្គង គ្រាន់តែរឿងអារ៉ាវ បាយហូបប៉ុណ្ណឹង ចាប់ អាប៉ុហឿន មកវាធ្វើបាបយើងពេក មិនឲ្យបាយឲ្យបាយយើងមិនគ្រប់គ្រាន់អ៊ីចឹង ខ្ញុំថាចាប់ហើយឲ្យកែប្រែ ទៅជាមិនកែប្រែ គេយកយើងជាខ្មាំងសត្រូវវិញ។ រួចខ្លួនអាហឿន។ គេយកខ្ញុំដើម្បីចងខ្ញុំ ដើម្បីសម្លាប់ខ្ញុំតែម្ដង ៥០នាក់ ចងរយៈពេល១៣ថ្ងៃ ១៣យប់។"]។

[2552] ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977456។

[2553] ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977456។

[2554] ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977456។

គេត្រូវគេបង្រៀនពី "របៀបបំពេញការងារឲ្យបក្ស"[2555]។ ក្រោយមក ពួកគេត្រូវគេចាប់[2556] ឃុំខ្លួន[2557] បង្អត់អាហារ[2558] សួរចម្លើយ[2559] និងធ្វើទារុណកម្មដោយការវាយដំ ឆក់ខ្សែភ្លើង ធ្វើឲ្យថប់

---

2555 ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.34 ["យោធាម្នាក់បានបញ្ជាឲ្យយើងទាំង៥០នាក់អង្គុយនៅក្រោមផ្ទះ ហើយគេបានស្រាយចំណង ហឿន ដោយប្រាប់ឲ្យ ហឿន ត្រឡប់ទៅធ្វើការវិញ។ បន្ទាប់មក មេយោធាបានមកដល់ ក៏ចាប់ផ្តើមនិយាយប្រាប់យើងអំពីរបៀបបំពេញការងារឲ្យបក្ស។"]។

2556 ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977457 ["ហើយឡើងពីធ្វើការអារសុទ្ធតែអារថ្មី ក្រមាមួយម្នាក់ទៅ ពេលដែលគេប្រជុំនៅកន្លែងគេនុំង អង្គុយទាហានគេព័ទ្ធព្រាត គេព័ទ្ធតែម្តងព័ទ្ធក្រឡឹងជុំវិញហើយ ដល់ទំពទៅគេអាល័យតែនិយាយក្នុងតែម្តង អាមេកុំរត់១ព័ទ្ធ ចងយើងតែម្តង ចងយើងគ្រឹប១ ក្រមាយើងហ្នឹងចងយើងទាំងអស់៥០នាក់តែម្តង។"]។ ឯកសារ D54/69 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.11 ["ពួកគេស្រាយក្រមានោះចេញ ហើយគេចងយើងនឹងខ្សែភ្លើងជំនួសវិញ។"]។ ឯកសារ D234/2.1.138 នង នេត ប្រតិចារឹកថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ម៉ោង 11.26.32-11.28.00 ["គេយកអាក្រមាខៀវចងពួកខ្ញុំ"]។

2557 ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977458 ["គុកនៅជើងភ្នំហ្នឹង។ [...] ស៖ នៅភូមិអី សង្កាត់អីដែរ? ឆ៖ ស្ទឹងហាវ។"]។ ឯកសារ D54/69 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.33 ["សម្រាប់ថ្ងៃផ្សេង១ គេគ្រាន់តែដាក់យើងឲ្យដេកនៅលើដីក្រោយផ្ទះឈើនោះទាំងយប់ទាំងថ្ងៃ។ យើងត្រូវបានគេចងជាប់ជាប្រចាំ ហើយគេបញ្ជាឲ្យយើងនៅដាច់ពីគ្នាចម្ងាយពី២ម៉ែត្រ។"]។

2558 ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977457 ["ដល់ពេលហ្នឹងចាប់ផ្តើមហើយកំសត់វេទនា គេចងយើងគ្រឹប១ គេបង្អត់"]។ ឯកសារ D54/69 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.34 ["អំឡុងពេលនោះ ពួកយើងធ្លាក់ខ្លួនស្គមយ៉ាងខ្លាំង។"]។ ឯកសារ D234/2.1.138 នង នេត ប្រតិចារឹកថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ម៉ោង 11.28.00-11.29.26 ["គេទុកឲ្យខ្ញុំហ្នឹងបាក់កម្លាំង គេឲ្យដំឡូងមើម មួយមើមពេលល្ងាច អាដំឡូងមីយើងហ្នឹង អាដំឡូងសៀមហ្នឹង។ គេឲ្យយើងហូបមួយពេលហ្នឹង ឲ្យទឹកផឹកទៅ។"]។

2559 ឯកសារ D54/69 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.14-17 ["នៅព្រឹកបន្ទាប់ ពួកគេបានហៅពួកយើងម្តង២នាក់១ ទៅបន្ទប់សួរចម្លើយដែលមានទំហំ៣ម៉ែត្រការ៉េ ដែលនៅក្បែរផ្ទះឈើនោះ។ នៅបន្ទប់សួរចម្លើយនោះ ពួកគេទុកមនុស្សម្នាក់ឲ្យចាំនៅខាងក្រៅ បន្ទប់ជាមួយអ្នកយាម ហើយយកម្នាក់ទៀតចូលទៅក្នុងបន្ទប់ដើម្បីសួរចម្លើយ។ [...] ឆ.15៖ ក្នុងករណីសួរចម្លើយខ្ញុំ គឺមានអ្នកសួរចម្លើយចំនួន២នាក់នៅក្នុងបន្ទប់ ហើយមានម្នាក់យាមនៅខាងក្រៅ។ អ្នកសួរចម្លើយម្នាក់នៅឈរ បានចាប់ផ្តើមសួរខ្ញុំថា តើអ្នកណាជាអ្នកឧទ្ទេសនាមខ្ញុំចូលបដិវត្តន៍ [...] បន្ទាប់មកគេយកខ្ញុំចេញពីបន្ទប់សួរចម្លើយ ហើយទុកខ្ញុំនៅខាងក្រៅជាមួយអ្នកយាមម្នាក់ ហើយគេយកម្នាក់ដែលចាំនៅខាងក្រៅទៅសួរចម្លើយបន្ត។ ខ្ញុំមិនអាចឮច្បាស់ ថាតើគេសួរអ្នកនោះអំពីអ្វីទេ តែខ្ញុំគិតថាគេសួរសំណួរដូចគេសួរខ្ញុំដែរ។ បន្ទាប់មកគេយកពួកយើងទាំងពីរនាក់ត្រឡប់ទៅដាក់នៅផ្ទះឈើវិញ។ [...] ឆ.16៖ អំឡុង១៣ថ្ងៃ ១៣យប់ ខ្ញុំត្រូវបានគេសួរចម្លើយចំនួន២ដង។ [...] ឆ.17៖ ខ្ញុំមិនចាំថាមានចំនួនប៉ុន្មានថ្ងៃបន្ទាប់ពីការសួរចម្លើយលើកទី១នោះទេ តែខ្ញុំនៅចាំការសួរចម្លើយលើកទី២ គឺថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ គេបានយកខ្ញុំទាំងពីរនាក់ទៅបន្ទប់សួរចម្លើយម្តងទៀត។ ហើយពេលដែល គេនាំខ្ញុំចូលទៅបន្ទប់សួរចម្លើយ គេបានសួរសំណួរខ្ញុំដូចលើកមុនដែរ"]។

ដង្ហើម និងឲ្យស្រមោចក្រហមខាំ[2560]។ ពួកគេត្រូវគេឃុំឃាំង ១៣ ថ្ងៃ ១៣ យប់[2561] និងចុងក្រោយ ត្រូវគេយកទៅសម្លាប់ចោល (ទោះបីជាយោងតាមចម្លើយរបស់សាក្សី ការសម្លាប់កើតឡើង ក្រោយយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ក៏ដោយ)[2562]។

---

2560 ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977457 ["ធ្វើវ៉ៃសួរចម្លើយ។"]។ KH ERN 00977458-00977459 ["ដល់គេចាប់គេចងហើយ គេស្រាតខោស្រាតអាវទុកតែខោខ្លីមួយ។ មូសខាំតាមចិត្ត គេសួរចម្លើយយើង ម៉ាថ្ងៃគេសួរម្ដង គេសួរថា ឯងសក្តិម៉ាន ហ្នឹងចូលហើយ គេសួរថាឯងសក្តិម៉ាន អាណាឧទ្ទេសនាមឲ្យឯងមកធ្វើការហ្នឹង? គ្មានទេលោកអើយខ្ញុំសឹកពីលោកទេមកហ្នឹង ខ្ញុំគ្មានមានសក្តិអីខ្ញុំមិនដែលស្គាល់សក្តិអីទេ ខ្ញុំមកសឹកពីលោកដើម្បីមកធ្វើកម្មករនៅភ្នំពេញ ហើយខ្ញុំមានដឹងសក្តិអីណា ហើយគេក៏វ៉ៃទៅ វ៉ៃចុះឡើងៗ ទៅក៏គេឈប់វ៉ៃទៅថ្ងៃហ្នឹង។ [...] ស្អែកតទៀតហើយគេបណ្ដើរពីរៗនាក់ទៅលើកហ្នឹងគេឆក់ខ្សែភ្លើងវ៉ៃវ៉ាវៗ... ឯងឆ្លើយមិនឆ្លើយ ឯងសក្តិម៉ាន? អត់មានសក្តិទេលោកអើយ ឆក់អញ្ជីញាក់អ៊ីចឹង។ ឯងមិនឆ្លើយអ្អែស ពឹងៗរាល់ថ្ងៃវ៉ៃ។ [...] ឯងមិនឆ្លើយអ្អែស ដាក់ទុងៗ វ៉ៃហើយឆក់ខ្សែភ្លើង ចាប់ផ្ដើមរុំកៅស៊ូវីប ឯងឆ្លើយមិនឆ្លើយ? ដល់ថាអ៊ីចឹងបានវាបើក [...] អ៊ុ!ថាវេទនា... ហើយដល់ពេលវ៉ៃខ្ញុំ ហើយអ៊ីចឹងក៏យកខ្ញុំទៅចង អាដៃហ្នឹងចងអស់ហើយសុទ្ធតែខ្សែភ្លើងអគ្គិសនីអាបណ្ដូលមូលអ្នាស់ពូ យកទៅចងដាក់នៅអាដើមត្របែកព្រៃ វ៉ៃសំបុកអង្ក្រងដាក់ខ្ញុំប្វូសំបុក។ វ៉ៃទៀតហើយ វ៉ៃហើយក៏អស់ការងារ គេឈប់វ៉ៃហើយណ៎ា។"]។ ឯកសារ D54/69 កំណត់ហេតុស្ដាប់ចម្លើយ នង នេត ឆ.13, 15, 17, 23, 25, 27-29 ["ក្រោយពីគេចងយើងហើយ គេដាក់ឲ្យយើងអង្គុយនៅចម្ងាយឃ្លាតពីគ្នាប្រហែល២ម៉ែត្រ។ ពួកគេមិនអនុញ្ញាតឲ្យពួកយើងនិយាយ ឬខ្សឹបដាក់គ្នាទេ។ ប្រសិនបើអ្នកណាម្នាក់ប៉ានិយាយទៅរកអ្នកណាម្នាក់ អ្នកនោះនឹងត្រូវវ៉ៃដោយកាំភ្លើងខ្លី។ ខ្ញុំនៅចាំថាមានមនុស្សម្នាក់ តែខ្ញុំភ្លេចឈ្មោះហើយ គាត់ជាអតីតសិស្សថ្នាក់ទីបញ្ចប់ គាត់ត្រូវបានយោធាវាយយ៉ាងខ្លាំង ដោយសារគាត់និយាយជាមួយមនុស្សម្នាក់ទៀត។ ពួកយោធាមានគ្នា១០នាក់យាមជុំវិញពួកយើង។ [...] ឆ.15៖ [...] បន្ទាប់មកគេបានឲ្យខ្ញុំដេកនៅលើដី រួចហើយវាបានវ៉ៃខ្ញុំនឹងខ្សែភ្លើងដែលវេញបញ្ចូលគ្នាចំនួន២រំពាត់ ហើយវាសួរទៀតថា តើខ្ញុំមានសក្តិប៉ុន្មានពីរបបចាស់ តែខ្ញុំបានប្រាប់គេថា ខ្ញុំមិនមានសក្តិទេ ខ្ញុំបានសឹកពីលោកសង្ឃ។ [...] ឆ.17៖ [...] គេធ្វើទារុណកម្មខ្ញុំដោយឆក់ខ្សែភ្លើង ហើយគេសួរខ្ញុំថា តើពាក់សក្តិប៉ុន្មាននៅជាមួយយួន? ខ្ញុំនៅតែប្រាប់គេថា ខ្ញុំគ្មានសក្តិទេ។ ប៉ុន្តែគេនៅតែសួរខ្ញុំដដែលថា ដោយគេថា ខ្ញុំក្បាលយួនខ្លួនខ្មែរ។ ដោយសារតែខ្ញុំនៅតែឆ្លើយថា អត់មានសក្តិ គេបានយកថង់ផ្លាស្ទិកមកគ្របមុខខ្ញុំជិត ដើម្បីឲ្យខ្ញុំថប់ដង្ហើម។ ដោយទ្រាំទ្រនឹងការឈឺចាប់មិនបាន ពេលគេដកថង់ចេញពីក្បាល ខ្ញុំបានឆ្លើយថា ខ្ញុំពាក់សក្តិ៣ នៅពេលនោះទើបគេនាំខ្ញុំចេញមកក្រៅទៅចងនឹងដើមត្របែកព្រៃមួយក្បែរនោះ ហើយគេបានបំបែកសំបុកអង្ក្រងបីដាក់ខ្ញុំ ដើម្បីឲ្យអង្ក្រងខាំខ្ញុំពេញខ្លួន។ បន្ទាប់មក គេបាននាំអ្នកទោសម្នាក់ទៀតចូលក្នុងបន្ទប់សួរចម្លើយ។ អំឡុងពេលសួរចម្លើយអ្នកទោសនោះ ខ្ញុំបានឮអ្នកទោសនោះត្រូវបានគេសួរចម្លើយ ហើយស្រែកថ្ងូរដោយសារឈឺចាប់ខ្លាំង ទើបអ្នកទោសនោះបានឆ្លើយថា ពាក់សក្តិ១០។ ខ្ញុំបានឮយោធាសួរចម្លើយនោះស្រែកជេរអ្នកទោសនោះ "កន្ទុយម៉ែហ្អែង មិនដែលមានសក្តិ១០ទេ"។ [...] ឆ.23៖ មានអ្នកសួរចម្លើយពីរនាក់ ម្នាក់ជាអ្នកវ៉ៃឌីណាម៉ូ ដើម្បីបង្កើតអគ្គិសនី ហើយម្នាក់ទៀតជាអ្នកយកខ្សែភ្លើងមកចុចលើខ្លួនខ្ញុំគ្រប់កន្លែង។ គេបានយកចុងខ្សែភ្លើងមកឆក់ខ្ញុំ ហើយគេបានសួរខ្ញុំដដែលៗ រហូតដល់ចម្លើយរបស់ខ្ញុំត្រូវតាមចំណង់គេ ទើបគេឈប់ បើមិនដូច្នោះទេ គេនៅតែឆក់ខ្ញុំរហូត។ [...] ឆ.25៖ គេដាក់ឲ្យខ្ញុំដេកនឹងដី ហើយ

638. សាក្សី ឡុង ផាន់ស៊ី ត្រូវគេចាប់ខ្លួន ពេលចូលរួមប្រជុំនៅទីបញ្ជាការកងវរសេនាធំនៅស្ទឹងហាវ[2563] ។ គាត់បានផ្តល់សក្ខីកម្មថា មេដឹកនាំកងវរសេនាធំ មឿន និង ឡូន ជាអ្នកទទួលខុសត្រូវលើការចាប់ខ្លួនគាត់[2564] ហើយថា ពួកគេក៏ជាអ្នកកាន់កាប់គុក និងសួរចម្លើយអ្នកទោសផងដែរ[2565]។ ឡុង ផាន់ស៊ី ត្រូវគេសួរចម្លើយអំពីទំនាក់ទំនងរបស់គាត់ជាមួយ "សេអ៊ីអា-កាហ្សេបេ" និង "ជួរ" គាត់ខណៈដែលគាត់ត្រូវបានធ្វើទារុណកម្ម[2566]។ គេដាក់ច្រវាក់ដៃ និងច្រវាក់ជើងគាត់ ហើយបន្ទាប់មក

---

យកចុងខ្សែភ្លើងដាក់លើក្បាលពោះ និងនៅលើដើមទ្រូងខ្ញុំ។ [...] សៈ តើលោកនៅជាប់ចំណងដែរឬទេ នៅពេលឆក់ខ្សែភ្លើងនោះ? ឆ.27៖ បាទ ដៃរបស់ខ្ញុំចងទៅក្រោយដោយខ្សែភ្លើង (ចងដើមដៃទៅក្រោយ)។ [...] ឆ.28៖ គេឆក់ខ្សែភ្លើងខ្ញុំរយៈពេលប្រហែល៥នាទី នៅពេលដែលខ្ញុំស្រែក គេបានបញ្ឈប់។ [...] ឆ.29៖ ខ្ញុំសន្លប់អត់ដឹងខ្លួនមួយភ្លែតៗ នៅពេលដែលដាក់ខ្សែភ្លើងលើខ្ញុំ។"]។

2561 ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977458 ["ខ្ញុំដូចជាវេទនាកំសត់ខ្លួនណាស់ ១៣ថ្ងៃ១៣យប់"]។ ឯកសារ D234/2.1.138 នង នេត ប្រតិចារឹកថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ម៉ោង 11.28.00-11.29.26 ["ខ្ញុំរាប់ថ្ងៃគឺ១៣ថ្ងៃ ១៣យប់។"]។

2562 ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977459 ["ម៉ោង ៧ព្រឹកថ្ងៃទី៧ មកវាហ្នឹងគេបណ្តើរទៅដាក់តែម្តងព្រាត។ ម៉ាខ្សែជាប់នាក់ៗ ដោតម្នាស់ ដោតខ្ញុំដើរដាក់រើកាត់ព្រឹកម្តងកាត់ព្រឹកម្នាស់ម៉ោង៧។ ទៅដល់ហ្នឹងគេហូតមួយទៅខ្វោក អ! ញ៉ូវទាំងអស់គ្នាហើយ អានាក់កាន់ដំបងក៏ញ៉ូវដែរ ខ្មៅគ្រាក់តែម្តងសម្បុរវា។ ហើយអាមេបញ្ជាការវាថាឯងមិនរើរ៉ែស្អែស វាប្រុងបាញ់ចោលទៀតណា។ [...] ស្រាប់តែគេហូតមួយទៅអង្គុយ គេថាអង្គុយឱ្យស្ងៀម ស្រាប់តែដាក់ភឹង ឃើញប្រកាច់ញ៉ូវតែម្តងទៅហើយ។ សៈ គ្នា៥០នាក់ហ្នឹងរើតែម្តងមួយៗ? ឆៈ ម្តងមួយៗ។"]។ ឯកសារ D234/2.1.138 នង នេត ប្រតិចារឹកថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ម៉ោង 11.29.26-11.31.15 ["រើចាក់ រើចាក់ ពួកខ្ញុំ"]។ ឯកសារ D54/68.1 គំនូសបង្ហាញផែនទី KH ERN 00977482 [បង្ហាញពីទីកន្លែងសម្លាប់មនុស្សចម្ងាយពី២-៣០០ម៉ែត្រពីមូលដ្ឋានយោធា]។ សូមមើលផងដែរ ឯកសារ D54/69 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.42។

2563 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.31 ["វរសេនាធំហៅមកប្រជុំ ដើម្បីត្រៀមចាប់ តែត្រង់បញ្ជាមកពីណាខ្ញុំមិនបានដឹងទេ។ អ្នកដែលមកចាប់ខ្ញុំគឺ វរសេនាធំ ឈ្មោះមឿន និង ឡូន។ អ្នកទាំងពីរនៅកន្លែងប្រជុំហ្នឹង កាលនោះម៉ោងប្រហែលប្រាំបី ទៅប្រាំបួនយប់ ទើបប្រជុំ ហើយចាប់ខ្ញុំតែម្តង។"]។

2564 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.31 ["អ្នកដែលមកចាប់ខ្ញុំគឺវរសេនាធំ ឈ្មោះមឿន និង ឡូន។"]។

2565 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.35 ["អ្នកសួរចម្លើយមានឈ្មោះ មឿន និងឈ្មោះ ឡូន ដែលសួរចម្លើយ និងជាអ្នកគ្រប់គ្រងនៅទីនោះ។"]។

2566 ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.67 ["ពេលដែលវាចាប់ដាក់ក្នុងគុកហ្នឹង វាបានស្រាតខោយើង ពេលយប់វាចងច្រវាក់ក្រពាត់ដៃទៅក្រោយ ឱ្យយើងដេក។ ពេលថ្ងៃស្អែកទៀត វារើសួរចម្លើយពីរឿងហ្នឹង ហើយវាឱ្យចងច្រវាក់ដៃ ស្នាមដល់ឥឡូវ ច្រវាក់ជើង ហើយវាឱ្យលោតទៅធ្វើការ។"]។

គេវ៉ៃ នឹងរំពាត់ និងឆក់ រហូតដល់គាត់សន្លប់[2567]។ ច្រវាក់ដៃច្រវាក់ជើងកកិតចុះកកិតឡើង បង្កជាដំបៅរលួយសាច់ចំពោះអ្នកខ្លះ[2568] និងធ្វើឲ្យគាត់មានស្លាកស្នាមជាប់រហូត[2569]។ គាត់ត្រូវនៅក្នុងបន្ទប់ឃុំឃាំងគ្រប់ពេល រួមទាំងពេលបត់ជើងផងដែរ[2570]។ គាត់ជាប់ខ្នោះ "មួយថ្ងៃ មួយយប់ពេញ"[2571]។ យូរៗម្តង មានឡានមកដល់គុកពេលយប់ ហើយអ្នកទោសបាត់ខ្លួននៅព្រឹកបន្ទាប់[2572]

---

2567 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.35 ["គេដាក់ច្រវាក់ដៃខ្ញុំទៅក្រោយ និងដាក់ច្រវាក់ជើងខ្ញុំទាំងពីរ។ ពេលព្រឹកគេចាប់ផ្តើមសួរចម្លើយ ទី១ ថាអ្នកឯងជាសេ.អ៊ី.អា, កា.ហ្សេ.បេ របស់អ្នកណា? ហើយពាក់សក្តិប៉ុន្មាន? ខ្ញុំឆ្លើយថាខ្ញុំអត់ដឹងរឿងទេ ព្រោះខ្ញុំអត់ដឹងរឿងមែន។ ក្រោយមកគេចាប់ផ្តើមធ្វើទារុណកម្ម ដែលមានរំពាត់តូចៗ វាយខ្ញុំ។ គេវាយខ្ញុំរហូត ដល់រំពាត់គរគ្នានៅកន្លែងសួរចម្លើយ។ គេវាយឲ្យខ្ញុំឆ្លើយថាសក្តិប៉ុន្មាន ហើយជាក្រុមណា។ ពេលព្រឹកខ្ញុំសន្លប់ពីរដង ពេលថ្ងៃសន្លប់មួយដង។ មួយថ្ងៃខ្ញុំសន្លប់បីដង។ វិធីធ្វើទារុណកម្ម ទី១ វាយនឹងរំពាត់, វាយនឹងកន្ទុយត្រីបបែល និងទី៣ វៃឆក់នឹងខ្សែភ្លើង (ហៅរ៉ាកាណូវវ៉ៃបញ្ចេញភ្លើងឆក់មនុស្ស)។ បើកន្ទុយត្រីបបែលគេកាត់យកហាលឲ្យស្ងួត ហើយវារួញតូចដូចខ្សែតីដែរ។ អ្នកដែលសួរចម្លើយមានឈ្មោះ មឿន និងឈ្មោះ ឡន ដែលសួរចម្លើយ និងជាអ្នកគ្រប់គ្រងនៅទីនោះ។"]។

2568 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.56 ["ខ្ញុំឃើញអ្នកទោសពីរនាក់បាត់ខ្លួនពីគុក ដោយសារតែពួកគេមានដំបៅរលួយសាច់ធ្ងន់ធ្ងរ ដោយសារជាប់ខ្នោះយូរ ហើយគេមិនអាចទុកទៀតបាន។"]។

2569 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.57 ["មានបន្សល់ស្លាកស្នាមនៅកជើងទាំងសងខាង"]។

2570 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.49 ["សូម្បីតែជុះអាចម៍ ក៏ជុះក្នុងបន្ទប់ ហើយហូបក៏ហូបក្នុងបន្ទប់ដែរ។"]។

2571 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.51 ["ខ្ញុំជាប់ខ្នោះមួយថ្ងៃ មួយយប់ពេញ។ ជួនកាល វាចិត្តល្អ វាក៏ដោះខ្នោះខ្ញុំ ពេលហូបបាយ។"]។

2572 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.34, 52, 54 ["គេធ្វើជារោង ហើយខណ្ឌជាបន្ទប់តូចៗ។ មានបណ្តោយប្រហែល៤០ម៉ែត្រ ទទឹងប្រហែលជា៤ម៉ែត្រតែប៉ុណ្ណោះ។ នៅក្នុងបន្ទប់គុកតូចៗមួយមានខណ្ឌក្តារពីរបន្ទះ ប៉ុនខ្នងមនុស្ស។ ដេកស្មើរតែមិនផុតជើងទេ។ នៅទីនោះខ្ញុំឃើញមានអ្នកទោសច្រើនដែរ ប្រហែលពី២០ ទៅ៣០នាក់។ ជួនកាលឃើញឡានបើកចូលនៅពេលយប់ ព្រឹកឡើងអ្នកទោសខ្លះក៏បាត់។ [...] ស៖ មុននេះលោកនិយាយថា ពេលខ្លះលោកឮសំឡេងឡានចូលមកក្នុងគុក ហើយព្រឹកឡើង អ្នកទោសខ្លះក៏បានបាត់ខ្លួន។ តើមែនដែរឬទេ? ឆ. 52៖ ពិតមែន។ [...] ស៖ ក្នុងពេលលោកជាប់ក្នុងគុកនោះ តើលោកសង្កេតឃើញហេតុការណ៍នេះប៉ុន្មានដងដែរ? ឆ. 54៖ ខ្ញុំបានឃើញប្រហែលជាពីរដងដែរ មុនពេលខ្ញុំចេញពីគុកនោះ។"]។

។ ឡុង ផាន់ស៊ី ជាប់ឃុំក្នុងគុកនៅស្ទឹងហាវប្រហែល ៧ ខែ មុននឹងត្រូវគេបញ្ជូនទៅមន្ទីរសន្តិសុខទឹកសាប[2573]។

639. សាក្សី សន ជួន អតីតកម្មាភិបាលភូមិភាគបូព៌ា ត្រូវគេចាប់ បន្ទាប់ពីគេប្រាប់គាត់ឲ្យទៅ "រៀននៅបូព៌ា"[2574]។ គាត់បានឆ្លើយថា អ្នកទោសត្រូវបាននាំចេញពីគុកស្ទឹងហាវជាច្រើនដង យកទៅវ៉ៃនឹងរំពាត់ សួរចម្លើយ និងធ្វើពលកម្ម ទាំងជាប់ខ្នោះ[2575]៖

> គុកនៅស្ទឹងហាវមានការដាក់ច្រវាក់ដៃ ហើយនិងជើង។ ដល់ពេលចេញធ្វើការ វាដាក់រុំចង្កេះ ឲ្យយើងលោត ឬឲ្យដើរតិចៗអីចេះ។ ដល់អីចឹង ខ្ញុំនិយាយមិនចង់ចេញ[2576]។

640. សន ជួន បានបញ្ជាក់ថា ពេលគាត់ជាប់ឃុំ រងទារុណកម្ម និងសួរចម្លើយ គាត់ត្រូវគេចោទជា "ខ្មាំង" ឬ "ចូលយួន"[2577]។ អ្នកសួរចម្លើយគាត់បានកត់ត្រា ពេលពួកគេធ្វើទារុណកម្ម និងសួរចម្លើយគាត់[2578]។ ចុងក្រោយ សន ជួន ក៏ត្រូវបានបញ្ជូនទៅទឹកសាបផងដែរ[2579]។

---

2573 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.37 ["ស៖ មុនគេបញ្ជូនលោកមកគុកទឹកសាបលោកជាប់អស់រយៈពេលប៉ុន្មានដែរ? ឆ.37៖ តាំងពីដើមខែ១ ខែ២ ឆ្នាំ១៩៧៨ ខ្ញុំមកនៅទឹកសាបបានប្រហែលជា ពីរទៅបីខែ ក៏វៀតណាមចូលមកដល់។"]។

2574 ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.24។ សូមមើល ផងដែរ ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.27 ["ស៖ តើលោកអាចជួយឲ្យយើងយល់បានបន្ថែមទៀត តើផ្ទះដែលគេចាប់ពួកលោកហ្នឹង ស្ថិតនៅត្រង់ចំណុចណាដែរ? ឆ.27៖ កាលគេចាប់ខ្ញុំហ្នឹង ផ្លូវទៅស្ទឹងហាវ អាផ្លូវបត់ កែងហើយចំជ្រុងហ្នឹង។ វាលោតពីលើផ្ទះមក ទាត់ធាក់ ភ្លង់ខ្ញុំ ហើយចាប់យកទៅ។ ចាប់ចងស្លាបសេក យកចូលគុក ហើយសួរចម្លើយ។"]។

2575 ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន KH ERN 01301517 ["ព្រឹកឡើង វាបញ្ចេញម្នាក់ម្តងៗ វ៉ៃសួរចម្លើយ។ វ៉ៃសួរចម្លើយហើយ ពេលព្រឹកវាដាក់ច្រវាក់ឲ្យធ្វើការ ដាក់ច្រវាក់កជើងមកចង្កេះ ឲ្យលោតៗ ចេញមកដាំដំណាំ។ ក្រោយមក ព្រឹកឡើងបានបញ្ចេញបីនាក់ទៀត វ៉ៃនឹងខ្សែភ្លើង សួរចម្លើយ ដូចគ្នាទាំងអស់។ បានចំនួនប្រហែលជាមួយអាទិត្យ ឬ១០ថ្ងៃ ក៏ចាប់ផ្តើមសាថ្មី វ៉ៃសួរចម្លើយម្តងទៀត។"]។

2576 ឯកសារ D114/220 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.5។

2577 ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.61, 64 ["គេធ្វើទារុណកម្ម ទី១ គេចោទយើងថា យើងហ្នឹងខ្មាំងអីណាចូលដៃយួន ព្រោះយើងអត់ដឹងទេ ព្រោះគេចោទអីចឹង។ ទី២ ហើយនិងបាក់ចបបាក់បង្គី យើងជីកដំឡូងហូបអី ហើយវាឃើញទៅ វាចោទថាខ្មាំង។ [...] ឆ.64៖ [...] គេចោទយើងថាខ្មាំង ចូលយួន។"]។

641. អ្នកទោសទាំងបីនាក់នេះមិនមែននៅតែឯងក្នុងគុកស្ទឹងហាវនោះទេ។ នង នេត បានឆ្លើយថា គាត់ជាប់ឃុំជាមួយជនរងគ្រោះប្រហែល ៥០ នាក់ផ្សេងទៀត[2580]។ សន ជួន បានឃើញអ្នកទោស

[2578] ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.66 [“គេមានកត់ត្រាដែរ ហើយយើងបានឆ្លើយរឿងចបទូកលិចដែរ ហើយគេចោទយើងថាខ្មាំងយួនអីហ្នឹង ខ្មាំងអាកន្លែងហ្នឹង។”]។

[2579] ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន KH ERN 01301517។

[2580] ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977456 [“ហេកហាកថាខ្មែរក្រហមមកហើយ ដេញចាប់ធ្វើបាបយើងពេក។”]។ ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.29, 34 [“ក្នុងពេលនោះមានមនុស្សច្រើនបះបោរប្រឆាំងជាមួយ ហឿន ប៉ុន្តែបន្ទាប់មក គឺមានតែមនុស្ស៥០នាក់ប៉ុណ្ណោះ ដែលត្រូវបានចាប់ខ្លួន។ [...] ឆ.34៖ [...] នៅថ្ងៃបន្ទាប់យោធាម្នាក់បានជិះម៉ូតូមកប្រាប់យើងនៅការដ្ឋាន ឲ្យយើងមុជទឹក និងរៀបចំខ្លួនទៅប្រជុំនៅកន្លែងយោធា។ យោធានោះបានហៅឈ្មោះមនុស្ស៥០នាក់ពីក្នុងបញ្ជី។ ពេលដែលយើងមកដល់កន្លែងយោធាៗបានឲ្យយើងទៅអង្គុយរង់ចាំនៅក្រោមផ្ទះ ហើយខ្ញុំបានឃើញ ហឿន នៅជាប់ចំណងអង្គុយនៅក្រោមផ្ទះនោះដែរ។ យោធាម្នាក់បានបញ្ជាឲ្យយើងទាំង៥០នាក់អង្គុយនៅក្រោមផ្ទះ ហើយគេបានស្រាយចំណង ហឿន ដោយប្រាប់ឲ្យ ហឿន ត្រឡប់ទៅធ្វើការវិញ។ បន្ទាប់មក មេយោធាបានមកដល់ ក៏ចាប់ផ្តើមនិយាយប្រាប់យើងអំពីរបៀបបំពេញការងារឲ្យបក្ស។ នៅពេលជាមួយគ្នានោះ មានយោធាប្រហែល១០នាក់ទៀតចេញមកពីគ្រប់ទិស ដោយអាម៉េកាំភ្លើងដាក់ពួកយើង។ ពេលនោះ មេយោធានោះបានប្រាប់យើងថាកុំឲ្យយើងរត់។ បន្ទាប់មកពួកយោធាក៏បានចាប់ផ្តើមចងពួកយើងទាំង៥០នាក់នឹងក្រមារបស់ពួកយើង។”]។ ឯកសារ D234/2.1.138 នង នេត ប្រតិចារឹកថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ម៉ោង 11.26.32-11.28.00 [“ដល់ទៅដល់អាកន្លែងនោះ ស្រាប់វានាំគ្នាប្រជុំទៅ ហើយឃើញទាហានវាព័ទ្ធជុំវិញអស់ ដល់ប្រជុំទៅ ស្រាប់គេអាមេច្រេវច្រាវ គេថាកុំរត់! កុំរត់! គេយកអាក្រមាខៀវចងពួកខ្ញុំ ៥០នាក់គ្រប់គ្នា។ ចងគ្រប់គ្នាទៅ ហើយខ្ញុំថា ឯងមានពាក់ព័ន្ធមានខ្មាំងណា ឥឡូវមកចាប់គ្នាឯងមនុស្សស្លូតត្រង់។ នឹកក្នុងចិត្តអ៊ីចឹងថា ខ្លួនខ្ញុំវាស្លូតត្រង់ អង្កាល់នុ៎ងខ្ញុំអាយុនៅក្មេងដែរជំនាន់នុ៎ង អាយុទើប២០ជាង។ អ៊ីចឹងទៅឯងមិនដែលធ្វើអីឲ្យខុសឆ្គង គ្រាន់តែរឿងអារ៉ាវ បាយហូបប៉ុណ្ណឹង ចាប់ អាប៉ិហឿន មកវាធ្វើបាបយើងពេក មិនឲ្យបាយ ឲ្យបាយយើងមិនគ្រប់គ្រាន់អ៊ីចឹង ខ្ញុំថាចាប់ហើយឲ្យកែប្រែ ទៅជាមិនកែប្រែ គេយកយើងជាខ្មាំងសត្រូវវិញ ។ រួចខ្លួន អាហឿន។ គេយកខ្ញុំដើម្បីចងខ្ញុំ ដើម្បីសម្លាប់ខ្ញុំតែម្តង ៥០នាក់ ចងរយៈពេល១៣ថ្ងៃ ១៣យប់។”]។ ម៉ោង 11.07.54-11.10.16 [“ស្អែកឡើងបានគេមកនាំពួកខ្ញុំទៅ ទៅប្រជុំដោះស្រាយបញ្ហាចាប់ ហឿន ហ្នឹង។ ដល់ទៅដល់ទៅ ហឿន នៅនុ៎ងមែន នៅអាកន្លែងទាហានគេនុ៎ង ប៉ិហឿន ហ្នឹង។ ហើយគេឲ្យខ្ញុំអង្គុយកៅអីស្រួលបួល ៥០នាក់អង្គុយកៅអីស្រួលបួលអ៊ីចឹង ប៉ុន្តែមិនមែនកៅអីអ៊ីចឹងទេ កៅអីឈើធម្មតា ឲ្យអង្គុយក្រោមផ្ទះគំរូនោះ សម្រាប់ឲ្យគេហៅប្រជុំៗ គេថាទៅប្រជុំដោះស្រាយបញ្ហាឲ្យជ្រះស្រឡះឲ្យចេញ ព្រោះចាប់មេដាំបាយនៅនោះ ហើយ មេហឿនហ្នឹងប្រធានរោងកន្លែងធ្វើការនៅម្តុំស្ទឹងហាវហ្នឹង។ អ៊ិចឹងទេ ខ្ញុំក៏ព្រមព្រៀង គេហៅឈ្មោះខ្ញុំ មាន៥០នាក់គេហៅឈ្មោះ ហៅឈ្មោះ៥០នាក់ នាំគ្នាទៅពេលថ្ងៃត្រង់ គេថាងូតទឹកឲ្យស្រួលទៅ សម្លៀកបំពាក់ឲ្យស្អាតទៅ ប៉ុន្តែខោខ្មៅអាវខ្មៅទេ ហើយកក្រមាខៀវ។ ទៅៗ ៥០នាក់ ឈ្មោះនេះ ឈ្មោះនោះ ខ្ញុំអត់បានចាំគ្រប់គ្នាទេ។ ដល់ពេលទៅនោះ គេប្រជុំៗ ស្រាប់តែអាម៉េច្រេវច្រាវៗ គេថា កុំរត់! កុំរត់! កុំរត់! ហើយខ្ញុំថាចុយ! មានខ្មាំងឯងណា អាហឿន ហ្នឹង ពួក

ប្រហែល ១០ នាក់ក្នុងគុក ពេលគាត់នៅទីនោះ[2581] ហើយ ឡុង ផាន់ស៊ី បានឆ្លើយថា គាត់បានឃើញអ្នកទោសពី ២០ ទៅ ៣០ នាក់នៅទីនោះ[2582]។

642. ជនរងគ្រោះដែលធ្វើការនៅស្ទឹងហាវ ក៏ត្រូវបានបញ្ជូនទៅ ស-២១ ផងដែរ[2583]។

---

ហ្នឹងសុទ្ធតែចាប់ មិនឱ្យឯងហូបបាយគ្រប់គ្រាន់តើ! មានអីទៅជាអាហៀន ត្រូវវិញ អាអ្នកដាំបាយ មកខុសយើង។ មកខុសយើង គេចងយើងតែម្តង ៥០នាក់ ចងក្រឹបៗ ខ្ញុំចងទៅ ប៉ុន្តែខ្ញុំភ្លេចហើយថ្ងៃខែខ្ញុំ ខ្ញុំអត់បានចំណាំ នាឡិកាខ្ញុំគេដកទៅ ចង ប៉ុន្តែខ្ញុំដឹងតែរយៈដប់-- "]។

2581 ឯកសារ D114/219 កំណត់ហេតុស្តាប់ចម្លើយ សន ជួន ឆ.55 ["ស៖ តើលោកនិយាយថា "មានតែពួកខ្ញុំ" តើមានប៉ុន្មាននាក់? ឆ.55៖ ពួកខ្ញុំហ្នឹង វាចំនួនទាំងអស់ភ្លេចហើយ ស្មានប្រហែល១០នាក់អីចឹងទៅ។"]។

2582 ឯកសារ D114/208 កំណត់ហេតុស្តាប់ចម្លើយ ឡុង ផាន់ស៊ី ឆ.34 ["គេធ្វើរោង ហើយខណ្ឌជាបន្ទប់តូចៗ។ មានបណ្តោយប្រហែល៤០ម៉ែត្រ ទទឹងប្រហែលជា៤ម៉ែត្រតែប៉ុណ្ណោះ។ នៅក្នុងបន្ទប់គុកតូចៗមួយមានខណ្ឌក្តារពីរបន្ទះប៉ុនខ្នងមនុស្ស។ ដេកស្ទើរតែមិនផុតជើងទេ។ នៅទីនោះខ្ញុំឃើញមានអ្នកទោសច្រើនដែរ ប្រហែលពី២០ ទៅ៣០នាក់។ ជួនកាលឃើញឡានបើកចូលនៅពេលយប់ ព្រឹកឡើងអ្នកទោសខ្លះក៏បាត់។"]។

2583 ឯកសារ D114/230.1.1 ការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) បញ្ជីឈ្មោះអ្នកទោស ស-២១ លេខរៀង ៨៧៣៤ [ឡុង ប៊ុន [ឡុង ប៊ុន] (ឡុង វួន [ឡុង វួន]) (ឡុក វួន) អ្នកបកប្រែចិននៅស្ទឹងហាវ កំពង់ផែកំពង់សោម "ចិន" ត្រូវបានចាប់ខ្លួនពីផែកំពង់សោម (ឧស្សាហកម្ម) ], ៨៧៣៥ [ឡុង ឌី [ឡុង ឌី] អ្នកបកប្រែចិននៅស្ទឹងហាវ កំពង់ផែកំពង់សោម "ចិន" ត្រូវបានចាប់ខ្លួនពីកំពង់ផែកំពង់សោម ហើយជាប្អូនប្រុសរបស់ ឡុង ប៊ុន "ចិន" ត្រូវចាប់បានចាប់ខ្លួនមកពីកំពង់ផែកំពង់សោម], ១០២២៨ [លឹម តឹក អ្នកបកប្រែចិននៅស្ទឹងហាវ "ចិន" ត្រូវបានចាប់ខ្លួននៅកំពង់ផែកំពង់សោម], ១០២២៩ [លឹម អេ អ្នកបកប្រែចិននៅស្ទឹងហាវ "ចិន" ត្រូវបានចាប់ខ្លួននៅកំពង់ផែកំពង់សោម], ១០២៣០ [ឈួ យុយ អ្នកបកប្រែចិននៅស្ទឹងហាវ "ចិន" ត្រូវបានចាប់ខ្លួននៅកំពង់ផែកំពង់សោម], ១០២៣១ [ស៊ូ ជាមីង អ្នកបកប្រែចិននៅស្ទឹងហាវ "ចិន" ត្រូវបានចាប់ខ្លួននៅកំពង់ផែកំពង់សោម], ១០២៣២ [ជេន វើន អ្នកបកប្រែចិននៅស្ទឹងហាវ "ចិន" ត្រូវបានចាប់ខ្លួននៅកំពង់ផែកំពង់សោម], ១០២៣៣ [ជីវ ឃុន (ជីវ ឃួន) អ្នកបកប្រែចិននៅស្ទឹងហាវ "ចិន" ត្រូវបានចាប់ខ្លួននៅកំពង់ផែកំពង់សោម], ១០២៣៤ [ហុង ធៀង អ្នកបកប្រែចិននៅស្ទឹងហាវ "ចិន" ត្រូវបានចាប់ខ្លួននៅកំពង់ផែកំពង់សោម]។ សូមមើល ផងដែរ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.33 ["ខ្ញុំគ្រាន់តែបានឃើញភ្ញៀវចិននិងអ្នកបកប្រែរបស់គេមកត្រួតពិនិត្យនៅការដ្ឋាន"]។ សូមមើលជាទូទៅ ឯកសារ D59/1/1.8a កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារ៉ាត់ KH ERN 00926363-00926365។

## អំពើអមនុស្សធម៌ផ្សេងទៀត

### *ក) ការធ្វើបាបដោយអមនុស្សធម៌*

643. ជនរងគ្រោះនៅស្ទឹងហាវធ្វើការច្រើនហួសកំណត់[2584] និងហូបមិនគ្រប់គ្រាន់[2585]។ កម្មករទទួលអាហារតែពីរពេលក្នុងថ្ងៃប៉ុណ្ណោះ[2586] មួយពេលនៅម៉ោង ១១ ព្រឹក និងមួយពេលទៀត នៅម៉ោង

[2584] ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.21-22 ["ទី២ ស្ថានភាពការងារគឺធ្ងន់ធ្ងរណាស់ដោយសារយើងត្រូវសែងដីធ្ងន់ក្នុងប៉ែលធំៗដើម្បីយកទៅធ្វើខ្សែផ្លូវរថភ្លើង។ [...] ឆ.22៖ [...] មនុស្ស២នាក់ត្រូវតែសែងដីដាក់ក្នុងប៉ែលដែលមានទម្ងន់ប្រហែល៤០ទៅ៥០គីឡូក្រាមក្នុងមួយជើងៗ។"]។

[2585] ឯកសារ D234/2.1.138 នង នេត ប្រតិចារឹកថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ម៉ោង 11.08.54-11.10.16 ["ពួកខ្ញុំហូបមិនគ្រប់គ្រាន់ ខ្ញុំវាបាក់កម្លាំង កំហែងខ្លាំង"]។ ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ ប៉ែន សារិន EN ERN 00217561 ["សាក្សីបាននិយាយថា ពួកគេឱ្យអាហារហូបមិនគ្រប់គ្រាន់ [...] នៅទីនោះ ពួកគេទទួលបានបបរតែពីរស្លាបព្រាបាយ ដូចនៅស្ទឹងហាវដែរ"]។ ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.26 ["ហូបចុកអត់គ្រប់គ្រាន់ អត់បរិបូរ។"]។ ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង ឆុន ឆ.20 ["របបហូបចុកមិនគ្រប់គ្រាន់ទេ គេឱ្យហូបបាយពេលថ្ងៃ និងបបរពេលយប់។"]។ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.31 ["បន្ទាប់ពីគេដកខ្ញុំចេញទៅ ស្ថានភាពរស់នៅរបស់ខ្ញុំគឺមានការលំបាកខ្លាំងជាងពេលខ្ញុំនៅធ្វើការជាយោធា។ ពេលខ្ញុំនៅជាយោធា ម្ហូបអាហារហូបចុកគ្រប់គ្រាន់ ហើយការងារមិនលំបាកទេ ប៉ុន្តែបន្ទាប់ពីខ្ញុំត្រូវបានបញ្ជូនទៅកងផលិតនៅស្ទឹងហាវ គេមិនឱ្យហូបចុកគ្រប់គ្រាន់ទេ ហើយការងារក៏ធ្ងន់ធ្ងរជាងមុនដែរ។"]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.28 ["ម្ហូបអាហារ បើប្រៀបធៀបនៅកងកែងគឺប្រសើរជាងតែនៅតែមិនគ្រប់គ្រាន់ដដែល។"]។ ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.21 ["ទី១ របបអាហារហូបចុកមិនគ្រប់គ្រាន់ទេ គឺទទួលបានបាយប្រហែល២វែកម្នាក់ក្នុងមួយពេលជាមួយម្ហូបត្រីសមុទ្រ។"]។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.26 ["ប៉ុន្តែនៅកងរបស់ខ្ញុំ គេឱ្យបាយពីរពេលក្នុងមួយថ្ងៃ។"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.42 ["នៅពេលព្រឹកគេឱ្យដំឡូងជ្វាម្នាក់មួយដុំ និងបន្ទាប់មកទៀត គេឱ្យអំពៅប្រហែលកន្លះម៉ែត្រដើម្បីហូបយកកម្លាំង។ គេឱ្យហូបបាយ២ពេល"]។ ឯកសារ D114/48 សុខ ង៉ុន ឆ.30-31, 33 ["កប៉ាល់របស់ខ្ញុំត្រូវបានគេបញ្ជូនឱ្យទៅនៅស្ទឹងហាវ។ នៅទីនោះ គឺយើងទទួលបានរបបម្ហូបអាហារដែលអន់បំផុត។ យើងហូបម្ហូបអាហារដែលចម្អិនលាយជាមួយស្លឹកឈើ (ស្រដៀងស្លឹកគូរាយ) ធ្វើឱ្យយើងទន់ខ្សោយកម្លាំង។ [...] ឆ.31៖ [...] នៅពេលដែលកប៉ាល់របស់ខ្ញុំនៅឯស្ទឹងហាវ យើងហូបរបបអាហារជាមួយអង្គភាពមួយនៅទីនោះ ដែលម្ហូបអាហាររបស់គេមានលក្ខណៈអន់។ [...] ឆ.33៖ [...] ម្ហូបអាហារនៅស្ទឹងហាវគឺមិនគ្រប់គ្រាន់។"]។ ឯកសារ D54/35.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប្រាក់ សុខា KH ERN 00964254 ["ស៖ ចឹងនៅពេលដែលបានមកធ្វើកម្មករនៅស្ទឹងហាវហ្នឹងរបបហូបចុកមានគ្រប់គ្រាន់ដែរ? ឆ៖ មានពេលខ្លះខ្វះខាតមួយខែពីរចឹង អង្គការថាខ្វះស្បៀងអីហ្នឹងហូបបបរ។ ស៖ ចឹងកាលហ្នឹងមានខ្វះខាតបន្តិចបន្តួច? ឆ៖ បាទ។"]។ ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977456 ["ហើយដល់

៥ ល្ងាច[2587] មួយពេលៗ បានបបរពីរវែក[2588] ឬបាយមួយចានតូច[2589] ហើយយូរៗម្តង មានថែមត្រីខ្លះ[2590]។ សាក្សីខ្លះបានរំឭកថា ពួកគេបានទទួលអំពៅមួយដើម ដំឡូង ឬដំឡូងជ្វានៅពេល

---

គ្នាវាយ៉ាប់ស៊ីមិនគ្រប់គ្រាន់ មនុស្សគរគោកគរដី ស៊ីមិនគ្រប់គ្រាន់"]។ ឯកសារ D54/67.2 មជ្ឈមណ្ឌលឯកសារកម្ពុជា ទស្សនាវដ្តី "ស្វែងរកការពិត" ជីវិតសល់ពីសេចក្តីស្លាប់ (នេត) KH ERN EN 00977438 ["នេត និងមិត្តរួមការងារមួយចំនួន ត្រូវបានបញ្ជូនឲ្យទៅធ្វើលូនៅម្តុំស្ទឹងហាវ ក្រោមការគ្រប់គ្រងរបស់សមមិត្តហឿន។ ការងារនៅទីនោះ មានការលំបាកខ្លាំងណាស់។ ដោយសារហូបមិនគ្រប់គ្រាន់ ហើយទទួលបានការចោទប្រកាន់និងការធ្វើទុក្ខបុកម្នេញ"]។ ឯកសារ D114/186 កំណត់ហេតុស្តាប់ចម្លើយ សាត ចក់ ឆ.157 ["អាហារហូបខ្ញុំជឿថាវាមិនបានគ្រប់គ្រាន់ទេ សូម្បីតែខ្ញុំនៅកន្លែងស្រួលហើយ ក៏ខ្ញុំមិនបានអាហារគ្រប់គ្រាន់ផង ចុះទម្រាំតែពួកគាត់ទៀត។"]។ សូមមើលផងដែរ ឯកសារ D54/30.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ស៊ីម នី KH ERN 00964125 ["កាត់បន្ថយការហូបចុក ហើយមនុស្សកំណត់ឲ្យធ្វើតែកាត់បន្ថយការហូបចុក"]។ ឯកសារ D54/3.1 ហួរ ជា បួនឆ្នាំជាមួយខ្មែរក្រហម (សម្រង់) KH ERN 01506936 ["ផលនេសាទល្អៗត្រូវបានត្រៀមទុកធ្វើម្ហូបជាពិសេសសម្រាប់ភ្ញៀវចិនជាច្រើននាក់ និងអ្នកបច្ចេកទេសដែលមកជួយការងារសាងសង់ "កំពង់ផែយោធាសម្ងាត់" នេះ។ ត្រីពុំសូវល្អ ត្រូវបានបែងចែកក្នុងចំនួនសមរម្យទៅតាមកងធំ ហើយគេក៏ធ្វើការជ្រើសរើសទៅតាមជាក់ស្តែង នៅតាមកងធំនោះទៀត។ គេទុកត្រីល្អៗ រីឯត្រីនៅសល់ ត្រូវយកទៅចាក់ចោលក្នុងរណ្តៅធ្វើជាជីសរីរាង្គ។ ក្រោយមក ខ្ញុំដឹងថាប្រជាជនដែលរស់នៅជុំវិញទីនោះ ពុំមានអ្វីហូបទាល់តែសោះ។ ដូច្នេះ ខ្ញុំក៏ស្អប់អំពើខ្ជះខ្ជាយនេះខ្លាំងណាស់។ ខ្ញុំពុំយល់ថាហេតុអ្វីបានជាបក្សសុខចិត្តយកត្រីទៅបោះចោល មិនព្រមឲ្យគេយកទៅហូបបែបនេះនោះទេ។ ប្រជាជនស្រេកឃ្លាន នឹងសប្បាយរីករាយនៅពេលទទួលបានត្រីសម្បូរឆ្អឹងនិងកូនបង្គាខូចទាំងនេះ! គេសុខចិត្តទុកឲ្យពួកគេស្លាប់ដោយក្តីស្រេកឃ្លាន! វាពិតជាមិនអាចអត់ឱនឲ្យបាន និងជាអំពើអមនុស្សធម៌ជាទីបំផុត! តើនេះជាល្បិចសងសឹករបស់បក្សកុម្មុយនីស្តកម្ពុជាមែនដែរឬទេ?"]។

2586 ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.21 ["ទី១ របបអាហារហូបចុកមិនគ្រប់គ្រាន់ គឺ ទទួលបានបាយប្រហែល២វែកក្នុងម្នាក់ក្នុងមួយពេល ជាមួយម្ហូបត្រីសមុទ្រ។ ក្នុងមួយថ្ងៃពីរពេល រួមមានអាហារថ្ងៃត្រង់នៅម៉ោង១១ថ្ងៃត្រង់ និងពេលល្ងាចនៅម៉ោងប្រាំល្ងាច។"]។ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ. 26 ["ប៉ុន្តែនៅកងរបស់ខ្ញុំ គេឲ្យបាយពីរពេលក្នុងមួយថ្ងៃ។"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.42 ["នៅពេលព្រឹកគេឲ្យដំឡូងជ្វាម្នាក់មួយដុំ និងបន្ទាប់មកទៀត គេឲ្យអំពៅប្រហែលកន្លះម៉ែត្រដើម្បីហូបយកកម្លាំង។ គេឲ្យហូបបាយ២ពេល"]។ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.238 ["គេឲ្យហូបមួយថ្ងៃពីរពេល។"]។

2587 ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.21 ["ក្នុងមួយថ្ងៃពីរពេល រួមមានអាហារថ្ងៃត្រង់នៅម៉ោង១១ថ្ងៃត្រង់ និងពេលល្ងាចនៅម៉ោងប្រាំល្ងាច។"]។

2588 ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង អុន ឆ.20 ["របបហូបចុកមិនគ្រប់គ្រាន់ទេ គេឲ្យហូបបាយពេលថ្ងៃ និងបបរពេលយប់។"]។ ឯកសារ D54/35.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប្រាក់ សុខា KH ERN 00964254 ["អង្គការថាខ្វះស្បៀងអីហ្នឹងហូបបបរ។"]។ ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.

ព្រឹក[2591]។ ទោះអត់ឃ្លានក៏ដោយ ប្រសិនបើនរណាម្នាក់ព្យាយាមលួចអាហារ ហើយគេចាប់បាន ពួកគេនឹងត្រូវគេសម្លាប់៖

> បើសិនជាយើងឃ្លានខ្លាំង យើងរកបេះផ្លែឈើ ឬរកដំឡូង បើគេចាប់បាន គេម្លាប់ចោលតែម្តង។ [...] តែបើគេឃើញ គេវ៉ៃចោលតែម្តង។ ខ្ញុំឃើញនឹងភ្នែក គេចាប់បានប្រុសម្នាក់ ហើយគេឲ្យក្មេងប៉ុននេះ (ប្រហែលមួយម៉ែត្រកន្លះ) វ៉ៃ។ វ៉ៃឡើងសន្លប់ឈឹង។ ពេលគាត់ភ្ញាក់ឡើង គេនាំយកទៅបាត់[2592]។

---

ស.ព ជាមួយ ប៉ែន សារិន EN ERN 00217561 ["សាក្សីបាននិយាយថា ពួកគេឲ្យអាហារហូបមិនគ្រប់គ្រាន់ [...] នៅទីនោះ ពួកគេទទួលបានបបរតែពីរស្លាបព្រាបាយ ដូចនៅស្ទឹងហាវដែរ"]។

2589 ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.36 ["អាហារថ្ងៃត្រង់ គេឲ្យបាយមួយកូនចានតូច ហើយនៅពេលល្ងាចក៏ផ្តល់បានឲ្យមួយកូនចានតូចដែរ។"]។ ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.21 ["ទី១ របបអាហារហូបចុកមិនគ្រប់គ្រាន់ទេ គឺទទួលបានបាយប្រហែល២វែងក្នុងម្នាក់ក្នុងមួយពេល។"]។ ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង អុន ឆ.20 ["របបហូបចុកមិនគ្រប់គ្រាន់ទេ គេឲ្យហូបបាយពេលថ្ងៃ និងបបរពេលយប់។"]។ សូមមើល ផងដែរ ឯកសារ D54/3.1 ជា ហួរ បួនឆ្នាំជាមួយខ្មែរក្រហម (សម្រង់) KH ERN 01506936 ["មុខម្ហូប (ប្រសិនជាគេអាចហៅដូច្នេះបាន) មានតែសម្លត្រីរសជាតិឆ្ងាញ់ និងបាយមួយកូនចាន។"]។

2590 ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.21 ["ទី១ របបអាហារហូបចុកមិនគ្រប់គ្រាន់ទេ គឺទទួលបានបាយប្រហែល២វែងក្នុងម្នាក់ក្នុងមួយពេល ជាមួយម្ហូបត្រីសមុទ្រ។ ក្នុងមួយថ្ងៃពីរពេល រួមមានអាហារថ្ងៃត្រង់នៅម៉ោង១១ថ្ងៃត្រង់ និងពេលល្ងាចនៅម៉ោងប្រាំល្ងាច។"]។

2591 ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.36 ["ចំពោះរបបម្ហូបអាហារពេលព្រឹក គេឲ្យអំពៅមួយកង់ប្រវែងប្រហែលពាតឹក និងដំឡូងមីមួយដុំ។"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.42 ["នៅពេលព្រឹកគេឲ្យដំឡូងជ្វាម្នាក់មួយដុំ និងបន្ទាប់មកទៀត គេឲ្យអំពៅប្រហែលកន្លះម៉ែត្រដើម្បីហូបយកកម្លាំង។"]។

2592 ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.104-105 ["យើងហូបមិនគ្រប់គ្រាន់ទេ។ ហើយបើសិនជាយើងឃ្លានខ្លាំង យើងរកបេះផ្លែឈើ ឬរកដំឡូង បើគេចាប់បាន គេសម្លាប់ចោលតែម្តង។ [...] ឆ.105៖ [...] បើឃើញ គេវ៉ៃចោលតែម្តង។ ខ្ញុំឃើញនឹងភ្នែក គេចាប់បានប្រុសម្នាក់ ហើយគេឲ្យក្មេងប៉ុននេះ (ប្រហែលមួយម៉ែត្រកន្លះ) វ៉ៃ។ វ៉ៃឡើងសន្លប់ឈឹង។ ពេលគាត់ភ្ញាក់ឡើង គេនាំយកទៅបាត់។"]។ សូមមើលផងដែរ ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.34 ["នៅពេលយប់គេចាត់គ្នាក្នុងកងឲ្យយាមរោងស្នាក់នៅ។ ប្រសិនបើនរណាម្នាក់លួចដមឡូង គេនឹងចាប់វាយ។"]។

644. ការបង្អត់អាហារ គឺធ្វើឡើងដោយមានចេតនា។ ដូចកម្មាភិបាលគ្រប់គ្រងបានប្រាប់ នង នេត ពេល គាត់ និងអ្នកផ្សេងទៀតតវ៉ាថាពួកគេត្រូវបានបង្អត់អាហារដល់ស្លាប់៖ "អាឲ្យបាយយើងស៊ីមិនគ្រប់គ្រាន់ហ្នឹងថាមានគិតអី"[2593]។

645. **មាស មុត** បានដឹងអំពីរបបអាហារមិនគ្រប់គ្រាន់នៅស្ទឹងហាវ។ គាត់បានបញ្ជាកប៉ាល់របស់កម្មាភិបាលសកម្មនៃកងពល ១៦៤ ដែលចតនៅស្ទឹងហាវ ឲ្យត្រឡប់ទៅកំពង់សោមវិញ "ដោយសារម្ហូបអាហារនៅស្ទឹងហាវមានមិនគ្រប់គ្រាន់។ គាត់បាននិយាយថា បើសិនជាយោធាហូបអាហារមិនគ្រប់គ្រាន់ ដូច្នេះ តើយោធាអាចច្បាំងនៅសមរភូមិយ៉ាងម៉េចកើត?"[2594]។

646. កម្មករម្នាក់ៗទទួលបានសម្លៀកបំពាក់តែពីរកំប្លេប៉ុណ្ណោះក្នុងមួយឆ្នាំ[2595] ពុំមានការថែទាំវេជ្ជសាស្ត្រគ្រប់គ្រាន់[2596] កន្លែងគេងចង្អៀត[2597]។ អ្នកឈឺពុំត្រូវបានអនុញ្ញាតឲ្យសម្រាកទេ និងត្រូវបានចោទថាខ្ជិល និង "គេចវេះការងារបក្ស"[2598]។ ជនរងគ្រោះនឹកគ្រួសាររបស់ពួកគេ និងអ្នកដែលពួកគេស្រឡាញ់ ប៉ុន្តែមិនហ៊ានសុំអនុញ្ញាតទៅលេងទេ[2599]។

---

2593 ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977456។

2594 ឯកសារ D114/48 កំណត់ហេតុស្តាប់ចម្លើយ សុខ ង៉ុយ ឆ.33។

2595 ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.28 ["ពួកគេផ្តល់ឲ្យយើងតែម្ហូបអាហារ និងសម្លៀកបំពាក់ទេ ពុំផ្តល់ប្រាក់កម្រៃអ្វីទេ។ ចំពោះសម្លៀកបំពាក់ គេឲ្យពីរកំប្លេក្នុង១ឆ្នាំ"]។

2596 ឯកសារ D114/178 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម សុខន ឆ.26 ["ពេលមានឈឺថ្កាត់ក៏មិនមានថ្នាំពេទ្យបរិបូរ។"]។

2597 ឯកសារ D54/13 កំណត់ហេតុស្តាប់ចម្លើយ ប្រេស មាន ឆ.32 ["គេសង់រោងប្រក់ស្លឹកស្បូវ ហើយគេធ្វើគ្រែផុតពីដីដែលគ្រែមួយសម្រាប់មនុស្សពី២ទៅ៣នាក់ដេក។ រោងនោះជារោងវែងដាក់មនុស្សក្នុងកងប្រហែលជា ១០០នាក់។"]។

2598 ឯកសារ D54/68 កំណត់ហេតុស្តាប់ចម្លើយ នង នេត ឆ.21 ["បើមានមនុស្សធ្វើការធ្ងន់ហួសកម្លាំង ធ្វើឲ្យឈឺ ហើយពេលយើងឈឺគេមិនអនុញ្ញាតឲ្យឈប់សម្រាកទេ។ ខ្មែរក្រហមចោទអ្នកឈឺទាំងនោះថា ខ្ជិល និងគេចវេសការងារបក្ស។"]។ ឯកសារ D54/67.3 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នង នេត KH ERN 00977456 ["អាឈឺក៏ប្រើៗ គ្មានដឹងខ្យល់អីទេ គ្មានដឹងឈឺស្អាត់អីទេចេះតែប្រើទៅ។"]។

2599 ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.46, 48 ["ស៖ តើលោកអាចឈប់សម្រាក ឬទៅលេងក្រុមគ្រួសារបានដែរឬទេ? ឆ.46៖ ខ្ញុំមិនដែលសុំច្បាប់គេទៅលេងផ្ទះទេ ព្រោះខ្ញុំគិតថាគេក៏មិនឲ្យដែរបើខ្ញុំសុំ។ [...] ឆ.48៖ [...] ជាច្រើនលើកច្រើនសា ខ្ញុំនឹកផ្ទះនិងឪពុកម្តាយខ្លាំងណាស់ តែខ្ញុំមិនហ៊ានសុំច្បាប់គេមកលេងគាត់ទេ។"]។ សូមមើលផងដែរ ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញិក ឆ.38 ["សូម្បីតែបងប្អូនយើងក៏មិនហ៊ានសួរនាំអំពីស្ថានភាពរបស់យើងដែរ។"]។

647. ការងារមានគ្រោះថ្នាក់ និងពិបាក ហើយកម្មករ ជារឿយៗ រងរបួស ឬស្លាប់ក្នុងគ្រោះថ្នាក់ពេលធ្វើការ[2600]។ បើសិនជាបានល្មើសយ៉ាងពិតប្រាកដ ឬគេសន្មតថាបានល្មើសនឹងច្បាប់ដ៏តឹងតែងរបស់ ប.ក.ក កម្មករត្រូវគេវ៉ៃ[2601] និងដាក់ទណ្ឌកម្ម[2602]។

648. អ្នកដែលត្រូវគេបង្ខំឱ្យធ្វើការនៅការដ្ឋានទាំងនេះមានជំងឺថប់អារម្មណ៍ជាទូទៅ និងជំងឺតានតឹងផ្លូវចិត្ត។ ជនរងគ្រោះនីមួយៗបានដឹងថា ខ្លួនឯងគ្មានសិទ្ធិ ត្រូវគេសង្ស័យហើយ និងថា ប្រសិនបើបានប្រព្រឹត្តខុសយ៉ាងពិតប្រាកដ ឬគេសន្មតថាបានប្រព្រឹត្តខុស អាចទទួលទណ្ឌកម្មធ្ងន់ធ្ងរ ឬស្លាប់[2603]។

---

[2600] ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.28 ["វាគឺជាការងារគ្រោះថ្នាក់ណាស់ ដោយកម្មករប្រឈមមុខនឹងការងាររបួសជាប្រចាំ។ អ្នកខ្លះក៏ត្រូវថ្មរមៀលកិនស្លាប់។"]។ ឯកសារ D54/33.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ឹង ឆុន KH ERN 00964204 ["ទ័ពហ្នឹងក៏យ៉ាប់ដែរ។ ស៖ លត់ដំដែរ? ឆ៖ បាទ! គេសុទ្ធតែកំណត់ ថ្មមុនដំបូងវ៉ៃ២នាក់អ៊ីចឹងតែ៤ម៉ែត្រគូបទេ បើយើងវ៉ៃបានចេះតែដំឡើងរហូតដល់៦នាក់១២ម៉ែត្រគូប គេកំណត់ហ្នឹង បើយើងនេះវេទនាណាស់ ហើយមានម៉ាស៊ីនខួងម៉ាស៊ីនអីមកពីណា សុទ្ធតែមនុស្សបុកហ្នឹងដែកប្រវែងហ្នឹងបុក ហើយអ្នកបុកគេកំណត់មួយថ្ងៃរន្ធមួយម៉ែត្រ ព្រោះថ្ម មិនមែនងាយបុកទេលោកអើយ ហើយខ្ញុំមុនដំបូងបុក តែអាថ្មហ្នឹងវារឹងប្រហែលជាពាក់កទេ ដល់ចូលទៅដល់បន្តិចវាមិនដូចដីណ៎ា ដល់ពេលចូលទៅដល់ក្រោមបន្តិចវាឆាប់បានរន្ធទៅជ្រៅបន្តិច។ ស៖ វារាងផុយៗដែរ? ឆ៖ បាទ! វាបុកដាក់ទឹក បុកហើយ គេដាក់ទឹក គេមានទឹកដបបុកមូលៗ ហើយបើថាមុនដំបូងអត់ចេះបុកវេទនាណាស់។ ស៖ បែកដៃបែកជើង? ឆ៖ បាទ! ដូចថាមុនដំបូងបុកទៅវារន្ធបីជ្រុង ដល់ហើយបុកជាប់ៗហ្នឹង ដល់ពេលអ៊ីចឹងគេបុកមួយក្រិតអ៊ីចឹងទៅ គេបង្វិលមួយជុំបានគេដក អ៊ីចឹងបានរន្ធវាមូលណា អត់ជាប់ទេ។"]។

[2601] ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញិក ឆ.36 ["ប្រសិនបើអ្នកណាក្រោកមិនទាន់ ឬក៏យឺតយ៉ាវ មេក្រុមនឹងវ៉ៃនឹងដំបង ឬរំពាត់ ដោយចោទថាខ្ជិល។"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.31 ["ពេលខ្លះ មានអ្នកដែលមិនអាចធ្វើការបញ្ចប់បានត្រូវបានគេវាយនឹងរំពាត់ផ្តៅ។"]។ ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.93 ["ប្រធានកងរយ។ ឧបមាថា យើងនិយាយគ្នាមិនឱ្យគេឃើញ តែបើមានអ្នកឃើញ គេទៅប្រាប់ប្រធានកងរយ ហើយប្រធានចាប់យើងទៅវ៉ៃសួរចម្លើយ។"]។

[2602] ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.31 ["ប្រសិនបើយើងនិយាយរឿងអ្វីអវិជ្ជមានចំពោះអង្គការ យើងនឹងត្រូវគេធ្វើទោស។"]។

[2603] ឯកសារ D54/77 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញិក ឆ.37 ["សេចក្តីភ័យខ្លាចរបស់ខ្ញុំគឺមិនអាចពិពណ៌នាបានទេ។ ខ្ញុំរស់នៅក្នុងភាពតក់ស្លុត និងភ័យខ្លាចជារៀងរាល់ថ្ងៃ។ ខ្ញុំស្ទើរតែមិនជឿថា ខ្ញុំមានជីវិតរស់នៅដល់សព្វថ្ងៃនេះទេ បើតាមគេប្រព្រឹត្តមកលើខ្ញុំនៅពេលនោះ។"]។ ឯកសារ D114/130 កំណត់ហេតុស្តាប់ចម្លើយ អៀម ភង់ ឆ.91 ["អត់ដែលជួបទេ តែជួបគ្នាក៏អត់ហ៊ានិយាយគ្នាទេ។ ក្រោយពីគេចាប់តាអាន មក យើងមិនហ៊ាននិយាយគ្នាទេ ព្រោះយើង

## ច. ការដ្ឋាននៅតំបន់រាម

### ១. ការពណ៌នាអំពីការដ្ឋាន

649. ការដ្ឋាននៅតំបន់រាមជាកន្លែងដ៏សំខាន់សម្រាប់ដាំដំណាំ ស្ថិតក្រោមការគ្រប់គ្រងរបស់ **មាស មុត**។ ការដ្ឋាន និងទីតាំងសម្ដាប់ចំនួន ៣ ដែលជាចំណុចសំខាន់ក្នុងទីតាំងឧក្រិដ្ឋកម្មរាម ស្ថិតនៅខាងជើង និងខាងត្បូងផ្លូវជាតិលេខ ៤ នៅចន្លោះទឹកសាបនៅខាងកើត និងក្រុងកំពង់សោមនៅខាងលិច។ ក្នុងពេលបច្ចុប្បន្ន ទីតាំងទាំងនេះស្ថិតនៅក្នុងឃុំបិតត្រាងផង និងឃុំរាមផង ក្នុងស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ ក៏ប៉ុន្តែ ឃុំបិតត្រាងមិនទាន់មានទេ រហូតដល់ក្រោយពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ[2604]។ ពលកម្មចម្បងនៅការដ្ឋានទាំងនេះគឺធ្វើចម្ការ ជាពិសេស ស្រូវ ព្រមទាំងដំណាំផ្សេងទៀត និងសាងសង់ប្រព័ន្ធស្រោចស្រព (ឧទាហរណ៍ ទំនប់ ប្រឡាយ) ដើម្បីគាំទ្រដល់ការធ្វើកសិកម្ម។ ការងារផ្សេងទៀតក្នុងតំបន់នោះ រួមមានការធ្វើឥដ្ឋ វាយថ្ម និងស្លដែក។

---

ខ្លាចគេថាយើងទំនាក់ទំនងគ្នា។"]។ ឯកសារ D114/121 កំណត់ហេតុស្ដាប់ចម្លើយ សួន ផ ឆ.48 ["បាទ ខ្ញុំតែងតែរស់នៅដោយការភ័យខ្លាចថាថ្ងៃណាមួយនឹងអស់ជីវិត"]។ ឯកសារ D114/130 កំណត់ហេតុស្ដាប់ចម្លើយ អៀម ភង់ ឆ.92-93, 103 ["អ្នកនៅក្នុងកងរយ មកកងហាររបស់យើងហ្នឹង។ ឲ្យតែឃើញយើងនិយាយគ្នា គេហៅទៅសួរ បើយើងឆ្លើយត្រូវ មិនអីទេ បើឆ្លើយមិនត្រូវគេចាប់យើងហើយ ព្រោះយើងកំពុងតែជាប់និន្នាការផង។ [...] ស៖ អ្នកណាជាអ្នកហៅទៅសួរចម្លើយ? ឆ.93៖ ប្រធានកងរយ។ ឧបមាថា យើងនិយាយគ្នាមិនឲ្យគេឃើញ តែបើមានអ្នកឃើញ គេទៅប្រាប់ប្រធានកងរយ ហើយប្រធានចាប់យើងទៅរ៉ែសួរចម្លើយ។ [...] ឆ.103៖ [...] អត់ហ៊ានសួរគេទេ។ បើយើងសួរអ្នកយើងស្គាល់ទៅ ហើយគេនិយាយតៗគ្នាទៅ ខ្លាចគេដឹងដែរ ហើយមានបញ្ហា។ បើយើងសួរច្រើន គេថាយើងចង់ដឹងផែនការគេ ហើយគេថាយើងខ្មាំង។"]។

2604 ឯកសារ D54/123 កំណត់ហេតុស្ដាប់ចម្លើយ ឡាក់ សាផាន ឆ.3 ["កាលនោះ មានតែឃុំមួយទេ គឺឃុំរាម មិនទាន់មានឃុំបិតត្រាំងទេ។"]។ ឯកសារ D54/18 កំណត់ហេតុស្ដាប់ចម្លើយ នូ សារឿន ឆ.11-12 ["សហករណ៍នោះចិតនៅឃុំរាម តែឥឡូវគេហៅឃុំបិតត្រាំងវិញ។ នៅទីនោះពីដើមគេហៅទំនប់អូរព្រៃ ភូមិឰឿង ឃុំរាមទេ មិនមែនហៅថាឃុំបិតត្រាំងទេ។ [...] ឆ.12៖ តាមពិតបន្ទាប់ពីឆ្នាំ ១៩៧៩ គេបានហៅទីនោះថាបិតត្រាំង"] បញ្ជាក់ ឯកសារ D54/22 របាយការណ៍នៃសកម្មភាពស៊ើបអង្កេត KH ERN 01002672 ["សាក្សីបានបញ្ជាក់ថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កន្លែងនោះមានឈ្មោះថាទំនប់អូរព្រៃ មានទីតាំងនៅភូមិឰឿង (O'Brien) សង្កាត់រាម។ ក្រោយឆ្នាំ ១៩៧៩ ឈ្មោះទៅកន្លែងនោះត្រូវបានប្ដូរទៅជាបិតត្រាំង។ ប្រជាជនភាគច្រើនហៅ ទំនប់នោះថាជាបិតត្រាំង/ទំនប់បិតត្រាំង ឬទំនប់អូរព្រៃ។"]។

650. គម្រោងទំនប់ចម្បងក្នុងតំបន់នេះ សព្វថ្ងៃនេះ គេស្គាល់ទាំងអស់គ្នាថាគឺ "ទំនប់បិតត្រាង"។ ជាទំនប់ដ៏ធំមួយដែលផ្នែកម្ខាងនៅប៉ែកឦសានពីផ្លូវជាតិលេខ ៤[2605] (ពេលខ្លះ ហៅថា "ទំនប់បិតត្រាង" តែម្តង[2606] ហើយក៏ត្រូវបានភូមិផ្សេងៗដែលវាឆ្លងកាត់តាម[2607] ហៅថា ទំនប់ពូធឿង/ទំនប់

---

[2605] ឯកសារ D114/54 របាយកាណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខវត្តឥន្ទញាណនិងទីកន្លែងពាក់ព័ន្ធ កំពង់សោម – កោះរ៉ុងសន្លឹម KH ERN 01353030 ["ទំនប់បិតត្រាំង គឺស្ថិតនៅក្នុង ហើយនៅក្បែរឃុំបិតត្រាំងនាពេលបច្ចុប្បន្ននេះ។ ទំនប់នោះមានព្រំប្រទល់សឹងតែជាប់នឹងផ្នែកម្ខាងនៃផ្លូវជាតិលេខ៤។"]។ ឯកសារ D114/80 របាយកាណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង តំបន់ចម្ការធូរេនទី១ តំបន់បិតត្រាង មូលដ្ឋានយោធាទំនុកបម្រុងក្នុងក្របខ័ណ្ឌនៃកងពលលេខ ១៦៤ KH ERN 01517446 ["ទំនប់បិតត្រាង រួមមានទំនប់ធំនៅជ្រុងភាគឦសាននៃផ្លូវជាតិលេខ៤ [...] ឈ្មោះរបស់ទំនប់បិតត្រាង [...] ភាគឦសាននៃផ្លូវជាតិលេខ៤ គឺជាគម្រោងទំនប់ដ៏ធំជាងគេបំផុត គឺទំនប់មេបិតត្រាំង"]។ ឯកសារ D114/99 របាយកាណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចំការធូរេនII ទឹកសាប បិតត្រាង KH ERN 01519503 ["ទំនប់បិតត្រាងស្ថិតនៅក្នុងនិងក្បែរឃុំបិតត្រាបច្ចុប្បន្ន។ ទំនប់នេះស្ទើរតែមានព្រំប្រទល់ម្ខាងជាប់ទៅនឹងផ្លូវជាតិលេខ៤"]។ សូមមើល ផងដែរ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.190 ["ទំនប់នោះ កាត់ទទឹងផ្លូវជាតិលេខ៤"]។

[2606] ឯកសារ D114/99 របាយកាណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចំការធូរេនII ទឹកសាប បិតត្រាង KH ERN 01519474 ["សាក្សី គុយ ណេន បានបង្ហាញថា [...] នៅក្នុងគម្រោងទំនប់នេះមាន ២ទំនប់ [...] បិតត្រាង"] KH ERN 01519480 ["ទំនប់បិតត្រាងមានទំនប់មេមួយដែលដែលស្ថិតនៅខាងប៉ែកឦសានផ្លូវជាតិលេខ៤ [...] និងមានទំនប់តូចៗផ្សេងទៀតស្ថិតនៅខាងត្បូងផ្លូវជាតិលេខ៤] KH ERN 01519503 ["ភាគពាយ័ព្យនៃផ្លូវជាតិលេខ៤ គឺជាគម្រោងទំនប់ធំជាងគេបំផុត ដែលជា ទំនប់មេបិតត្រាង។"]។ ឯកសារ D114/80 របាយកាណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង តំបន់ចម្ការធូរេនទី១ តំបន់បិតត្រាង មូលដ្ឋានយោធាទំនុកបម្រុងក្នុងក្របខ័ណ្ឌនៃកងពល ១៦៤ KH ERN 01517446 ["ទំនប់បិតត្រាងរួមមានទំនប់ធំនៅជ្រុងភាគឦសាននៃផ្លូវជាតិលេខ៤ [...] និងទំនប់តូចៗនៅភាគខាងត្បូងផ្លូវជាតិលេខ៤។"]។ ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.36 ["ទំនប់បិតត្រាំង [...] បញ្ចប់នៅប្រហែលពាក់កណ្តាលឆ្នាំ១៩៧៧។"]។ ឯកសារ D54/91 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន KH ERN 00987120 ["ទំនប់មួយទៀតធ្វើនៅប៉ែកខាងជើងឆៀងខាងកើតផ្លូវជាតិលេខ៤"]។

[2607] ឯកសារ D54/89.1 ផែនទីរដ្ឋបាលស្រុកព្រៃនប់ EN 00987086, KH 00987086។ ឯកសារ D114/99 របាយកាណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចំការធូរេនII ទឹកសាប បិតត្រាង KH ERN 01519505។ ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.22 ["ការដ្ឋាននេះលាតសន្ធឹងលើភូមិពូធឿនិងអូរប្រៃ។"]។ ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា ឆ.31 ["ស៖ តើលោកធ្លាប់ឮការសាងសង់ទំនប់ធំមួយនៅបិតត្រាំង ឬពូធឿងដែរឬទេ? ឆ.31៖ [...] ខ្ញុំបានដឹងអំពីការសាងសង់ទំនប់ពូធឿង។"]។ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.191 ["ទំនប់ហ្នឹងចាប់ពីបិតត្រាង ទៅដល់ភូមិពូតេ។"]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.188 ["ខ្ញុំចូលរួមលើកទំនប់ នៅការដ្ឋាននោះ ពីវត្តបិតត្រាង ទៅអូរប្រៃ។"]។

ពុតធឿង/ទំនប់បិតត្រាង[2608] ទំនប់អូរប្រែ[2609] ទំបន់បបុស[2610] ឬទំនប់ព្រែកចាក[2611]) និងផ្នែកម្ខាងទៀតនៅប៉ែកនិរតីពីផ្លូវជាតិលេខ ៤ ជាទូទៅ ហៅថា ទំនប់ចំណោតរាម[2612] (ប៉ុន្តែ ក៏គេហៅផង

[2608] ឯកសារ D114/99 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចំការធូរេនII ទឹកសាប បិតត្រាង KH ERN 01519476 ["សាក្សី គុយ ណែន បានបង្ហាញថា [...] នៅក្នុងគម្រោងទំនប់នេះមាន ទំនប់២ ដែលមួយមានឈ្មោះថា ទំនប់បិតត្រាង ឬទំនប់ពូធឿងស្ថិតនៅខាងជើងផ្លូវ"] KH ERN 01519480 ["ទំនប់បិតត្រាងមានទំនប់មេមួយដែលស្ថិតនៅខាងប៉ែកឦសានផ្លូវជាតិលេខ៤ (ហៅថាទំនប់ពូធឿង ឬទំនប់បិតត្រាង)"] KH ERN 01519503 ["ការដ្ឋានទំនប់នេះមានឈ្មោះថា ការដ្ឋានទំនប់ពូធាង ឬទំនប់បិតត្រាង។"]។ ឯកសារ D114/80 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង តំបន់ចម្ការធូរេនទី១ តំបន់បិតត្រាង មូលដ្ឋានយោធាទំនុកបម្រុងក្នុងក្របខ័ណ្ឌនៃកងពល ១៦៤ KH ERN 01517446 ["ទំនប់បិតត្រាងរួមមានទំនប់ធំនៅជ្រុងភាគឦសាននៃផ្លូវជាតិលេខ៤ (ទំនប់ពូធឿង (Tomnob Pu Thoean) ឬទំនប់បិតត្រាង)។"]។ ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ គុយ ណែន ឆ.36 ["ទំនប់បិតត្រាំង ឬទំនប់ពូធឿងបញ្ចប់នៅប្រហែលពាក់កណ្តាលឆ្នាំ១៩៧៧។"]។ ឯកសារ D54/91 កំណត់ហេតុស្តាប់ចម្លើយ គុយ ណែន KH ERN 00987120 ["ទំនប់មួយទៀតធ្វើនៅប៉ែកខាងជើងឆៀងខាងកើតផ្លូវជាតិលេខ៤ ហៅថាទំនប់ពូធឿង ឬទំនប់បិតត្រាំង។"]។ ឯកសារ D114/139 កំណត់ហេតុស្តាប់ចម្លើយ ងួន ឡាយ ឆ.101-102 ["មានទំនប់ ប៉ុន្តែខ្ញុំមិនដែលធ្វើការងារនៅទំនប់នោះឡើយ [...] ឆ.102៖ អាហ្នឹងទំនប់ពូធឿង។"]។ ឯកសារ D114/243 កំណត់ហេតុស្តាប់ចម្លើយ ឆក សែន ឆ.93 ["ស៖ តើលោកដែលធ្លាប់ឮអំពីការដ្ឋានទំនប់បិតត្រាំងដែរឬទេ? ឆ.93៖ដែរ។ ទំនប់ពូធឿងយើងហ្នឹង"]។ ឯកសារ D114/58 កំណត់ហេតុស្តាប់ចម្លើយ សំ សៅ ឆ.50 ["ស៖ តើលោកបានឃើញទំនប់ពូធឿងឬទេ ហើយបើលោកបានឃើញ តើទំនប់នោះបានសង់ហើយឬនៅ កាលជំនាន់នោះ? ឆ.50៖ បាទ ខ្ញុំបានឃើញពីចម្ងាយ។ ទំនប់នោះកំពុងសាងសង់នៅឡើយ។"]។

[2609] Dឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.12 ["ឥឡូវនេះមានឈ្មោះថា ទំនប់បិតត្រាំង ប៉ុន្តែពីសម័យនោះគេហៅ ទំនប់អូរប្រែក្នុងភូមិពូធឿង។"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.17 ["ហៅថា ទំនប់បបុស/អូរប្រែ/បិតត្រាំង។"]។ ឯកសារ D54/22 របាយការណ៍នៃសកម្មភាពស៊ើបអង្កេត KH ERN 01002672 ["សាក្សីបានបញ្ជាក់ថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ កន្លែងនោះមានឈ្មោះថាជាទំនប់អូរប្រែ មានទីតាំងនៅភូមិធឿង (O` Brien) សង្កាត់រាម។ [...] ប្រជាជនភាគច្រើនហៅ ទំនប់នោះថាជាបិតត្រាំង/ទំនប់បិតត្រាំង ឬទំនប់អូរប្រែ។"]។ ឯកសារ D114/240 កំណត់ហេតុស្តាប់ចម្លើយ ភិន វេញ ឆ.9 ["គេបញ្ជូនខ្ញុំទៅធ្វើទំនប់នេះ ទំនប់យើងខាងហ្នឹង ទំនប់អូរប្រែ។"]។

[2610] ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.17 ["យើងបានលើកទំនប់មួយនៅភូមិបបុស ឬហៅថាទំនប់បបុស/អូរប្រែ/បិតត្រាំង។"]។

[2611] ឯកសារ D114/39 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន KH ERN 01065091 ["សាក្សីបានពន្យល់ថា គាត់ត្រូវបានគេបង្ខំឱ្យធ្វើការនៅការដ្ឋានលើកទំនប់មួយហៅថា ព្រែកចាក។ សាក្សីបានថ្លែងថា ទីតាំងនោះគឺនៅខាងក្រោយវត្តបិតត្រាំង។"]។ ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.19 ["ទំនប់បិតត្រាំង ហៅព្រែកចាក"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.107 ["ខ្ញុំធ្វើការនៅព្រែកចាក ម្តុំរាម។"]។ ឯកសារ

ដែរថា ទំនប់ភូមិចំណោតរាម[2613] ឬទំនប់ចំណោតរាម[2614])។ ទំនប់បិតត្រាងមានប្រឡាយតូចៗជាច្រើន និងមានទ្វារទឹកយ៉ាងហោចណាស់មួយធ្វើពីបេតុង ហើយក៏មានគម្រោងទំបន់តូចៗផ្សេងទៀតក្នុងតំបន់នេះដែរ[2615]។ ទឹកត្រូវបានទប់នៅផ្នែកខាងលិចនៃទំនប់ ពេលវាហូរចុះពីទីខ្ពស់ និង

---

D114/99 របាយកាណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចំការធូរេនII ទឹកសាប បិតត្រាង KH ERN 01519503 ["សាក្សីបានកំណត់អត្តសញ្ញាណបណ្តោយទំនប់ទាំងមូលមានប្រវែងប្រមាណ ៣គម.។"]។ ឯកសារ D114/54 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខវត្តឥន្ទញាណ និងទីកន្លែងពាក់ព័ន្ធ កំពង់សោម - កោះរ៉ុងសន្លឹម KH ERN 01353011 [ផែនទី], KH ERN 01353030 ["ភ្លាមៗនោះ សាក្សីនោះបានទទួលស្គាល់ទំនប់បិតត្រាំងនេះ ថាជាការដ្ឋានព្រៃកចាក។"]។

2612 Dឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.36 ["នៅក្នុងគម្រោងសាងសង់នេះរួមមានទំនប់២ [...] មួយទៀតហៅទំនប់ចំណោតរាម នៅខាងត្បូងផ្លូវជាតិលេខ៤។"]។ ឯកសារ D114/99 របាយកាណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចំការធូរេន II ទឹកសាប បិតត្រាង KH ERN 01519503 ["ភាគនិរតីនៃផ្លូវជាតិលេខ៤ គឺជាទំនប់មេ ដែលមានឈ្មោះថា ទំនប់ភូមិចំណោតរាម ឬទំនប់ចំណោតរាម។ ក្បាលទំនប់តភ្ជាប់ទៅនឹងផ្លូវជាតិលេខ៤។ [...] សាក្សីបានរៀបរាប់ថាទំនប់មានបណ្តោយប្រមាណ ២គម.។"]។ ឯកសារ D54/91 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន KH ERN 00987120 [សាក្សីធ្លាប់ធ្វើការនៅសហការណ៍បបុសចាប់តាំងពីខែមេសា ឆ្នាំ១៩៧៥ រហូតដល់ ឆ្នាំ១៩៧៩៖ "សាក្សីបានចង្អុលបង្ហាញថាទំនប់ចំណោតរាមនេះគឺចាប់ផ្តើមពីត្រឹមផ្លូវជាតិលេខ៤ ហើយលាតសន្ធឹងប្រវែងប្រហែល២គីឡូម៉ែត្រ។ តាមបណ្តោយទំនប់នេះ គឺមានប្រឡាយលូចន្លោះពីគ្នាចម្ងាយ៥០០ម៉ែត្រៗ។ ទំនប់នេះគឺសម្រាប់ទប់ទឹក ដើម្បីស្រោចស្រពស្រែដែលស្ថិតនៅជាប់នឹងព្រលានយន្តហោះកងកេង ដែលនៅខាងកើតទំនប់។"]។

2613 ឯកសារ D114/99 របាយកាណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចំការធូរេនII ទឹកសាប បិតត្រាង KH ERN 01519503 ["ភាគនិរតីនៃផ្លូវជាតិលេខ៤ គឺជាទំនប់មេ ដែលមានឈ្មោះថា ទំនប់ភូមិចំណោតរាម ឬទំនប់ចំណោតរាម។"] KH ERN 01519505 [GPS ផែនទីកំណត់ទីតាំងភូមិសាស្ត្រ "ទំនប់រាម (ទំនប់ភូមិចំណោតរាម)"]។

2614 ឯកសារ D114/99 របាយកាណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចំការធូរេនII ទឹកសាប បិតត្រាង KH ERN 01519476-01519503 ["ទំនប់ចំណោតរាមនៅភាគខាងត្បូងនៃផ្លូវជាតិលេខ៤ [...] ភាគនិរតីនៃផ្លូវជាតិលេខ៤ គឺជាទំនប់មេ ដែលមានឈ្មោះថា ទំនប់ភូមិចំណោតរាម ឬទំនប់ចំណោតរាម។"]។

2615 សូមមើល ឧទាហរណ៍ ឯកសារ D114/99 របាយកាណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចំការធូរេនII ទឹកសាប បិតត្រាង KH ERN 01519480 ["ទំនប់បិតត្រាងលាតសន្ធឹងឆ្លងកាត់ប្រឡាយមួយហៅថាប្រឡាយអូរប្រៃ។"] KH ERN 01519502-01519503 ["ទំនប់បិតត្រាងមានប្រព័ន្ធទំនប់និងប្រឡាយជាច្រើន នៅសងខាងផ្លូវជាតិលេខ៤។ [...] ការដ្ឋានទំនប់បិតត្រាងមានប្រព័ន្ធទំនប់ពីរ និងទំនប់តូចៗបួនប្រាំ និងប្រឡាយប្រាំពីរនៅសងខាងផ្លូវជាតិលេខ៤។ [...] ពី ៤០០ ទៅ ៥០០ម៉ែត្រ មានប្រឡាយនិងទ្វារទឹកមួយភ្ជាប់ទៅនឹងទំនប់។"]។ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.190 ["ទំនប់នោះ កាត់ទទឹងផ្លូវជាតិលេខ៤ ហើយមានវាលស្រែទាំងសងខាង ហើយគេលើកប្រឡាយកាត់ទទឹងថ្នល់ ដើម្បីភ្ជាប់ស្រែម្ខាងទៅម្ខាងទៀត។"]។ សូមមើល ផងដែរ ឯកសារ D114/6 កំណត់

ត្រូវបានស្តុកទុក ដើម្បីស្រោចស្រពដំណាំនៅផ្នែកខាងកើត នៅរដូវប្រាំង[2616]។ ប្រសិនបើបញ្ចូលគ្នាផ្នែកទាំងពីរនៃទំនប់មានប្រវែងប្រហែល ៤ គីឡូម៉ែត្រ ខណ្ឌចែកស្មើៗគ្នាដោយផ្លូវជាតិលេខ ៤[2617]។ បាតទំនប់មានប្រវែងប្រហែល ២៥ ម៉ែត្រ ហើយខ្នងទំនប់មានប្រវែងប្រហែល ១០ ម៉ែត្រ[2618]។

651. វាលស្រែធំល្វឹងល្វើយ ចម្ការដំណាំហូបផ្លែ និងតំបន់សម្រាប់ដាំដំណាំផ្សេងទៀត លាតសន្ធឹងនៅសងខាងផ្លូវជាតិលេខ ៤ ហើយតំបន់ខ្លះឆ្លងកាត់ដោយទំនប់បិតត្រាង[2619]។

---

ហេតុស្តាប់ចម្លើយ យិន តេង ឆ.25, 48, 89 [“អំឡុងពេលខ្ញុំរស់នៅភូមិថ្មធំ គេឲ្យដាំដំណាំ និងជួនកាលគេឲ្យទៅជីកប្រឡាយនៅភូមិពូធឿង។ [...] ស៖ តើប្រឡាយដែលលោកស្រីនិយាយថាជីកនោះស្ថិតនៅក្នុងភូមិឃុំណា? ឆ.48៖ ប្រឡាយនោះស្ថិតនៅក្នុងភូមិបបុស។ [...] ឆ.89៖ ខ្ញុំបានធ្វើទំនប់ពូធឿង”]។ ឯកសារ D114/243 កំណត់ហេតុស្តាប់ចម្លើយ ឆក សែន ឆ.93 [“ជីកទំនប់ប្រឡាយ ចុះទៅក្រោមហ្នឹង។”]។ ឯកសារ D114/80 របាយកាណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង តំបន់ចម្ការធូរេនទី១ តំបន់បិតត្រាង មូលដ្ឋានយោធាទំនុកបម្រុងក្នុងក្របខ័ណ្ឌនៃកងពល ១៦៤ KH ERN 01517446 [“ទំនប់នោះឆ្លងកាត់អូរមួយដែលគេហៅថា ទំនប់អូរប្រែ។”]។ ឯកសារ D54/91 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន KH ERN 00987120 [“តាមបណ្តោយទំនប់មានស្ពាន ឬទ្វារទឹកមួយធំកាត់ទំនប់ហ្នឹង ហៅថាប្រឡាយអូរប្រែ។ ស្ពាន ឬទ្វារទឹកបេតុងនេះត្រូវបានសាងសង់ឡើងដោយពួកយោធាខ្មែរក្រហម។”]។ ឯកសារ D114/54 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខវត្តឥន្ទញាណ និងទីកន្លែងពាក់ព័ន្ធ កំពង់សោម - កោះរ៉ុងសន្លឹម KH ERN 01353034 [រូបភាពទ្វារទឹកបេតុង]។

2616 ឯកសារ D54/91 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន KH ERN 00987120 [“ទំនប់នេះគឺសម្រាប់ទប់ទឹក ដើម្បីស្រោចស្រពស្រែដែលស្ថិតនៅជាប់នឹងព្រលានយន្តហោះកងកេង ដែលនៅខាងកើតទំនប់។”]។ ឯកសារD114/99 របាយកាណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចំការធូរេនII ទឹកសាប បិតត្រាង KH ERN 01519503 [“គេកំណត់យកតំបន់ភាគខាងលិចនៃទំនប់ធ្វើជាអាងស្តុកទឹក រីឯតំបន់ខាងកើតគឺជាតំបន់ទទួលការស្រោចស្រព។”]។ សូមមើល ផងដែរ ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.21 [“គេថា ទប់ទឹកសម្រាប់ធ្វើស្រែប្រាំង ប៉ុន្តែគេមិនអាចធ្វើស្រែប្រាំងបានទេ ពីព្រោះទំនប់ផ្ទុកទឹកបានតិចពេក។”]។

2617 ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សម្បត្តិ ឆ.192 [“ប្រហែលជាបីបួនគីឡូម៉ែត្រ។”]។ ឯកសារ D54/91 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន KH ERN 00987120 [“សាក្សីបានចង្អុលបង្ហាញថា ទំនប់នេះមានប្រវែងប្រហែល៣គីឡូម៉ែត្រ។”]។ ឯកសារ D114/240 កំណត់ហេតុស្តាប់ចម្លើយ ភិន វេញ ឆ.16 [“ទំនប់អូរប្រែហ្នឹងមានប្រវែង២គីឡូដី”]។ សូមមើល ផងដែរ ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.22 [“ស៖ តាមដែលលោកដឹង តើការដ្ឋាននោះមានទំហំធំប៉ុន្មានដែរ? ឆ.22៖ វាមានប្រវែងប្រហែលជាង ១គីឡូម៉ែត្រ”]។ ឯកសារ D114/54 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខវត្តឥន្ទញាណ និងទីកន្លែងពាក់ព័ន្ធ កំពង់សោម - កោះរ៉ុងសន្លឹម KH ERN 01353030 [ផ្នែកខាងជើង “បណ្តោយសឹងតែ ១.៤ ទៅ ១.៧ គីឡូម៉ែត្រ”]។

2618 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.29 [“ខ្ញុំពុំដឹងថាទំនប់នោះមានប្រវែងប៉ុន្មាននោះទេ គ្រាន់តែដឹងថាបាតទំនប់នោះមានទទឹងប្រវែងប្រហែល២៥ម៉ែត្រ ខ្នងទំនប់មានប្រវែងប្រហែល១០ម៉ែត្រ។”]។

652. វត្តបិតត្រាងស្ថិតនៅកន្លែងប្រសព្វគ្នារវាងផ្នែកខាងត្បូងនៃទំនប់បិតត្រាង និងផ្លូវជាតិលេខ ៤[2620]។ វត្តត្រូវបានប្រើប្រាស់ជាការដ្ឋានស្លដែក[2621] និងរៀបចំកិច្ចប្រជុំម្តងម្កាល[2622]។

---

[2619] ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ.216-217 ["សៈ អ៊ីចឹងស្រែដែលលោកស្រីទៅស្ទូងនៅជិតព្រលានយន្តហោះកងកេង មែនទេ? ឆ.216៖ ចាស វាដីរាប់រយហិចតានៅសងខាងផ្លូវជាតិ។ សៈ ចុះបើប្រៀបនឹងព្រលានយន្តហោះវិញ? ឆ.217៖ នៅជាប់ និងនៅជុំវិញព្រលានយន្តហោះ។"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា (នីរសារក្នុងកងវរសេនាតូចលេខ ៤៣០ ត្រូវបានបញ្ជូនទៅធ្វើការនៅកងកេងក្នុងឆ្នាំ ១៩៧៦) ឆ. 17 ["កងចល័តរបស់ខ្ញុំក៏ធ្វើការនៅប៉ែកខាងត្បូងផ្លូវជាតិលេខ៤ ដែរ។ យើងធ្វើការនៅក្នុងតំបន់ជុំវិញព្រលានកងកេង។"]។ សូមមើលផងដែរ ឯកសារ D114/19.2 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឧបសម្ព័ន្ធ៖ ផែនទីប្រជុំកោះ KH ERN 01034015។ ឯកសារ D114/57 កំណត់ហេតុស្តាប់ចម្លើយ សំ សៅ ឆ.5 ["ពេលនោះ គឺនៅឆ្នាំ១៩៧៧ ឬឆ្នាំ១៩៧៨ ខ្ញុំត្រូវបានគេបញ្ជូនទៅធ្វើស្រែនៅកងកេងរយៈពេលកន្លះខែ។"]។ ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.5 ["នៅជួយធ្វើស្រែជាមួយកសិករ"]។ ឯកសារ D54/35 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.17 ["កងចល័តរបស់ខ្ញុំត្រូវបានដកចេញពីព្រែកចាកមកនៅតំបន់កងកេង [...] យើងនៅទីនោះដាំស្រូវ"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.276-277 ["សៈ ពីកន្លែងដែលលោកធ្វើការនោះ តើលោកអាចមើលឃើញព្រលានយន្តហោះកងកេង និងវាលស្រែទេ? ឆ.276៖ បាទ អាចមើលឃើញ ដោយសារកន្លែងនោះនៅជិតគ្នា។ សៈ តើលោកអាចប្រាប់យើងពីអ្វីដែលលោកឃើញនៅតំបន់កងកេងបានទេ? ឆ.277៖ ខ្ញុំឃើញប្រជាជន និងកងទ័ពធ្វើស្រែ។"]។ ឯកសារ D54/81.2 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហ៊ីង អ៊ុច (សមាជិកនៃកងវរសេនាធំ៦១ និង ៦២ កងពល ១៦៤ ដែលឈរជើងព្រលានយន្តហោះកងកេងក្នុងឆ្នាំ១៩៧៦) EN ERN 01001396 ["សៈ ខែ៧ ៧៦ ពូមកណាវិញ? ឆ៖ ខ្ញុំមកនៅព្រលានយន្តហោះកងកេង សៈ ម៉េចមកហ្នឹងវិញ? ឆ៖ មកៗជួយធ្វើស្រែ។"]។

[2620] ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.13, 18-19 ["ខ្ញុំដឹងអំពីរឿងនេះ ពីព្រោះខ្ញុំបានដើរឆ្លងកាត់វត្តនេះរាល់ពេលដែលខ្ញុំធ្វើដំណើរទៅធ្វើការនៅការដ្ឋានព្រែកចាក។ [...] ឆ.18៖ [...] ខ្ញុំដឹងពីរឿងនេះ ដោយសារខ្ញុំដើរឆ្លងកាត់វត្តនោះច្រើនដងនៅតាមផ្លូវជាតិលេខ៤ ចន្លោះពីកំពង់សោម និងរាម។ វត្តនេះ គឺមានទីតាំងនៅក្បែរផ្លូវជាតិ ដូច្នេះខ្ញុំអាចមើលឃើញច្បាស់ថា គេធ្វើអ្វីខ្លះនៅទីនោះ។ សៈ នៅវត្តបិតត្រាំង លោកនិយាយប្រាប់យើងថា ការដ្ឋានព្រែកចាកនៅជិតវត្តនេះដែរ និងថាលោកតែងតែដើរឆ្លងកាត់វត្តនេះ ពេលលោកធ្វើដំណើរទៅកាន់ការដ្ឋានធ្វើការ។ [...] តើត្រឹមត្រូវដែរឬទេ? ឆ.19៖ បាទ ត្រឹមត្រូវ។"]។ ឯកសារ D114/39 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន KH ERN 01065091 [សាក្សីរៀបរាប់ពីទីតាំងទំនប់បិតត្រាងដែលគាត់ធ្លាប់ធ្វើការនៅទីនោះ "សាក្សីបានថ្លែងថា ទីតាំងនោះគឺនៅខាងក្រោយវត្តបិតត្រាំង ព្រោះគាត់បានដើរឆ្លងកាត់វត្តនោះ ពេលគាត់ធ្វើដំណើរទៅកាន់ការដ្ឋានទំនប់នោះក្នុងសម័យខ្មែរក្រហម។"]។ ឯកសារ D114/99 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចំការធូរអេII ទឹកសាប បិតត្រាង KH ERN 01519480 ["វត្តបិតត្រាងស្ថិតតាមបណ្តោយផ្លូវជាតិលេខ៤ ប៉ែកខាងជើងផ្លូវ។"]។

[2621] ឯកសារ D54/91 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.3 ["ពួកយោធាខ្មែរក្រហមបានរើបំបែក ព្រះវិហារមួយទាំងមូលនៅក្នុងវត្តបិតត្រាំង ដើម្បីយកដែកទៅសាងសង់ស្ពាននេះ។ រឿងនេះពិត ខ្ញុំមិនបំភ្លើសទេ។"]។ ឯកសារ

653. មានព្រលានយន្តកងកេង សព្វថ្ងៃនេះគេស្គាល់ថាជាអាកាសយានដ្ឋានអន្តរជាតិកំពង់សោម នៅខាងជើងផ្លូវជាតិលេខ ៤ និងមានផ្លូវមួយទៅដល់។ បន្ថែមពីលើការធ្វើចម្ការនៅតំបន់ជុំវិញព្រលានយន្តហោះ មានការដ្ឋានធំៗបី។ ទីមួយ ចម្ការដូងចេងហេង ដែលដាក់ឈ្មោះតាមឈ្មោះរបស់ម្ចាស់មុន[2623] មានទីតាំងស្ថិតនៅចន្លោះពីព្រលានយន្តកងកេង និងឆ្នេររាម[2624] និងមានផ្ទៃក្រឡាប្រហែល

---

D54/19 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.3 ["ខ្ញុំបានឮពីចាស់ៗថា ពួកគាត់បានឃើញយោធាខ្មែរក្រហមបានវាយកម្ទេចព្រះវិហារក្នុងវត្តយកដែកទៅប្រើនៅទីនោះមែន។ [...] ក្រោយពីរបបខ្មែរក្រហមបានដួលរលំទៅ ខ្ញុំបានទៅមើលវត្តនោះ ហើយបានឃើញថា ព្រះវិហារពិតជាត្រូវបានវាយកម្ទេចមែន។"]។ ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.12 ["ខ្មែរក្រហមបាននៅភូមិពូធឿងបន្ទាប់ពីឆ្នាំ១៩៧៥។ នៅភូមិបិតត្រាំង/ពូធឿង ខ្មែរក្រហមបានបំផ្លាញវត្តអារាមដោយយកដែកទៅធ្វើជាស្ពាននិងទ្វារទំនប់ទឹកដែលឥឡូវនេះមានឈ្មោះថា ទំនប់បិតត្រាំង"]។

2622 ឯកសារ D54/123 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.3 ["មានមួយលើកទៀត ពួកយើងត្រូវបានគេកោះហៅឲ្យទៅចូលរួមប្រជុំនៅវត្តបិតត្រាំង។ ដែលក្នុងនោះ គេប្រាប់ពួកយើងថា យោធាខ្មែរក្រហមចាប់បានកប៉ាល់អាមេរិកាំងមួយឈ្មោះ ម៉ាយ៉ាហ្គេស។"]។

2623 ឯកសារ D54/122 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.6 [ចម្ការដូងត្រូវបានដាក់ឈ្មោះថា ចេងហេង តាមឈ្មោះរដ្ឋមន្ត្រីក្រសួងកសិកម្មក្នុងរបបសង្គមរាស្ត្រនិយម]។

2624 ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.21 ["សៈ តើលោកធ្លាប់ឮឬស្គាល់ចំការធូរេន/ចំការក្រូចនិងចំការដូងដែរឬទេ ដែលនៅជិតព្រលានកងកេង? ឆ.21៖ ខ្ញុំធ្លាប់ឮតែអំពីចំការដូង ដែលគេហៅថា ចំការដូងចេងហេង ពីព្រោះ ខ្ញុំបានមកធ្វើការនៅជិតនោះ។ ចំការដូងនោះឋិតនៅខាងចុងនៃវាលយន្តហោះ។"]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.57-60, 281-282 ["សៈ កងអនុសេនាតូចរបស់លោក មានមន្ទីរនៅឯណា? ឆ.57៖ នៅចម្ការដូងរាម។ សៈ ចម្ការដូងរាមហ្នឹង ជាមន្ទីររបស់វរសេនាតូច ឬកងអនុសេនាតូច? ឆ.58៖ កងវរសេនាតូច ៥៨០។ សៈ ចម្ការដូងហ្នឹងនៅកន្លែងណា? ឆ.59៖ ចម្ការដូងហ្នឹងនៅក្នុងចំណុចភូមិអុង មកទល់ព្រលានយន្តហោះកងកេង។ សៈ ចម្ការដូងហ្នឹង នៅជិតទឹក ឬជិតព្រៃ? ឆ.60៖ ជិតសមុទ្រ នៅខាងលិចជាប់ឆ្នេរសមុទ្រ មកខាងជើងនៅជិតភ្នំ មកខាងកើតនៅជាប់ព្រលានយន្តហោះ។ [...] សៈ លោកធ្លាប់ឮឈ្មោះ ចេង ហេង ទេ? ឆ.281៖ ខ្ញុំនៅលើចម្ការដូច ចេង ហេង ហ្នឹងតែម្តង។ សៈ ចេង ហេង ជាឈ្មោះចម្ការដូង ឬចម្ការទាំងអស់? ឆ.282៖ ចេងហេង ជាឈ្មោះចម្ការដូងតែប៉ុណ្ណោះ។"]។ សូមមើល ផងដែរ ឯកសារ D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉ែន ឆ.29 ["ចម្ការដូងចេងហេង នៅភូមិអុង។ នោះ! កូនខ្ញុំ គេបញ្ជូនទៅធ្វើនុ៎ង។"]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.29 ["ចម្ការដូងចេងហេង ស្ថិតនៅចន្លោះចុងព្រលានយន្តហោះកងកេង និងភ្នំ។"] ។ ឯកសារ D2/17 កំណត់ហេតុស្តាប់ចម្លើយ អ៊ិន សារឿន ឆ.9 ["ចំការដូងពេលនោះនៅមិនឆ្ងាយពីចំការធូរេនទេ។"] ។ ឯកសារ D114/156.1 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឧបសម្ព័ន្ធ៖ គំនូសបង្ហាញទីកន្លែង ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៦ KH ERN 01374692។ ឯកសារ D54/41 អ៊ូ សារ៉ាន់ (យោធាកងពលធំ ១៦៤ ត្រូវបានបញ្ជូនទៅព្រលានយន្តហោះកងកេងនៅក្នុងឆ្នាំ ១៩៧៥) ឆ.19 ["កងវរសេនាតូចរបស់ខ្ញុំត្រូវបានបញ្ជូនទៅបោះទីតាំងនៅចម្ការ

១០ គីឡូម៉ែត្រការេ[2625]។ វានៅជិតចម្ការក្រូច[2626] និងទីតាំងសម្លាប់ចម្ការទុរេន ១[2627] (ពណ៌នាខាងក្រោម)។

654. ទីពីរ នៅជិតចម្ការដូងចេងហេង មានឡូតដ្ឋមួយនៅលើផ្លូវភ្ជាប់ពីផ្លូវជាតិលេខ ៤ ទៅឆ្នេររាម (សព្វថ្ងៃនេះ គេហៅថាផ្លូវលេខ ៤៥)[2628]។ នៅឡូតដ្ឋ កម្មករជាង ១០០ នាក់ ផលិតឥដ្ឋ និងគ្រឿងសម្រាប់ប្រើសង់ទំនប់កងពល ១៦៤ ទ្វារទឹក និងគម្រោងសាងសង់ផ្សេងទៀត[2629]។

---

ដូងរបស់ ចេង ហេង និងវាលយន្តហោះកងកេង។"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ. 118 ["ស៖ លោកនិយាយថាលោកស្គាល់ចំការដូង តើចំការដូងស្ថិតនៅកន្លែងណា? ឆ.118៖ ការពិត ខ្ញុំធ្លាប់ឮថាមានចំការដូងនៅកងកេង តែខ្ញុំមិនដែលបានទៅទីនោះទេ ព្រោះខ្ញុំរវល់ជាប់ហ្វឹកហ្វឺនយោធានៅកំពង់សោម។"]។

2625 ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណារ សុខន ឆ.90 ["មានតែដើមដូង និងដើមប្រេងខ្យល់នៅទីនោះ។ វាមានប្រវែង ១០គីឡូម៉ែត្របួនជ្រុង។ យើងមិនអាចដើរជុំទេក្នុងមួយព្រឹកនោះ។"]។

2626 ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.33 ["ចម្ការក្រូច និងចម្ការធូរេន គឺនៅជិតៗគ្នា។ នៅពេលដែលលោកឃើញចម្ការធូរេន គឺលោកអាចឃើញចម្ការក្រូចផងដែរ ព្រោះវានៅជាប់គ្នា។"]។ សូមមើលផងដែរ ឯកសារ D114/58 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.44-45, 47 ["ខ្ញុំចង់ប្រាប់លោកថា ខ្ញុំទើបនឹកឃើញឈ្មោះ សាន់ ស៊ាប ហៅ សំ ដែលលោកបានបង្ហាញខ្ញុំអម្បាញ់មិញនេះ។ ឥឡូវនេះខ្ញុំចាំថាគាត់ជាអ្នកណាហើយ ខ្ញុំហៅគាត់បង។ គាត់ជាប្រធានកងវរសេនាតូច នៅចម្ការក្រូច ម្តុំកងកេង។ [...] ស៖ លោកបាននិយាយអំពីទីតាំងចម្ការក្រូច។ តើចម្ការក្រូចនេះស្ថិតនៅកន្លែងណា? ឆ.45៖ ស្ថិតនៅតំបន់រាម បើធ្វើដំណើរការតាមផ្លូវជាតិលេខ៤ពីភ្នំពេញទៅកំពង់សោម កាត់តាមព្រលានយន្តហោះកងកេង និងទៅវត្តបិតត្រាំង។ នៅវត្តបិតត្រាំងនោះយើងត្រូវចូលទៅខាងឆ្វេងដៃ។ ទីតាំងនោះនៅប្រហែលពាគីឡូម៉ែត្រពីផ្លូវជាតិលេខ៤។ [...] ស៖ តើលោកដឹងថាមានចម្ការធូរេននៅជិតចម្ការក្រូចនោះដែរឬទេ? ឆ.47៖ មានចម្ការធូរេននៅជិតចម្ការក្រូច។ គេហៅតំបន់នេះជាតំបន់ចម្ការក្រូច ឬចម្ការធូរេនរាប់ជំនាន់មកហើយ។"]។ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ (សមាជិកនៃយោធាជើងទឹកក្នុងកងពល១៦៤ ពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៧ ជានីរសារ និងជាអង្គរក្ស មាស មុត ធ្វើការនៅការដ្ឋានវាយថ្មជិតចម្ការធូរេន ចម្ការដូង និងចម្ការក្រូច ២ខែ) ឆ.13 ["ចម្ការធូរេន ចម្ការដូង និងចម្ការក្រូច គឺនៅជិតគ្នា។"]។ ឯកសារ D54/26.1 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាលស្រុកព្រៃនប់ EN- KH ERN 00955542។

2627 សូមមើល ឧទាហរណ៍ ឯកសារ D114/58 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.47 ["ស៖ តើលោកដឹងថាមានចម្ការធូរេននៅជិតចម្ការក្រូចនោះដែរឬទេ? ឆ.47៖ មានចម្ការធូរេននៅជិតចម្ការក្រូច។"]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.29 ["ចម្ការដូង ចេង ហេង ស្ថិតនៅចន្លោះចុងព្រលានយន្តហោះកងកេង និងភ្នំ។ កន្លែងនៅខាងលិចចម្ការដូង ជាប់នឹងជើងភ្នំ គឺជាចម្ការធូរេន ដែលជាកន្លែង តាមុត យកជនជាតិថៃទៅសម្លាប់ ហើយកប់សាកសពនៅក្រោមដើមធូរេនសម្រាប់ធ្វើជី។"]។ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.13 ["ចម្ការធូរេន ចម្ការដូង និងចម្ការក្រូច គឺនៅជិតគ្នា។"]។ ឯកសារ D54/26.1 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាលស្រុកព្រៃនប់ EN-KH ERN 00955542។

655. ហើយទីបី មានការដ្ឋានវាយថ្មនៅអូរម្លូ ដែលមានទីតាំងស្ថិតនៅចន្លោះព្រលានយន្តហោះកងកេង និងផែរាមដែរ ជិតចម្ការដូងចេងហេង[2630]។ ថ្មមួយចំនួនដែលយកពីការដ្ឋានវាយថ្មនេះត្រូវបានប្រើយ៉ាងហោចណាស់ដើម្បីសង់កំពង់ផែនៅស្ទឹងហាវ[2631]។

656. កម្មកររស់នៅក្នុងសហករណ៍មួយចំនួន ក្នុងតំបន់[2632] រួមទាំងសហករណ៍ពុតធឿង[2633] សហករណ៍បបុស[2634] សហករណ៍ភូមិគគីរ[2635] និងសហករណ៍ស្នាច់ដែង[2636]។ ប្រជាជនរាប់ពាន់នាក់រស់

---

[2628] ឯកសារ D114/94 កំណត់ហេតុស្តាប់ចម្លើយ សំ វុទ្ធី ឆ.74 ["សៈ តើកន្លែងធ្វើក្បឿងហ្នឹងនៅទីណាដែរ? ឆ.74៖ វានៅជិតស្នាច់ដែង នៅពាក់កណ្តាលផ្លូវពីស្នាច់ដែងទៅរាម។ គេហៅចំការដូង ចេងហេង។"]។ ឯកសារ D114/54 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខវត្តឥន្ទញាណ និងទីកន្លែងពាក់ព័ន្ធ កំពង់សោម - កោះរ៉ុងសន្លឹម KH ERN 01353017 ["រោងចក្រឡូឥដ្ឋ គឺស្ថិតនៅក្បែរវាលយន្តហោះកងកេង"] KH ERN 01353046-01353049។ ឯកសារ D54/17 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.14 ["វាជាកន្លែងការដ្ឋានពលកម្មធម្មតារបស់កងពល១៦៤ ខ្ញុំបានមកទីកន្លែងនេះម្តងនៅចុងឆ្នាំ១៩៧៥។"]។ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹក សុក ឆ.246 ["មានឡូឥដ្ឋមួយកន្លែងនៅតាមថ្នល់ជាតិ ពីព្រលានយន្តហោះទៅចម្ការដូង។"]។ ឯកសារ D114/80 របាយកាណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង តំបន់ចម្ការធូរេនទី១ តំបន់បិតត្រាង មូលដ្ឋានយោធាទំនុកបម្រុងក្នុងក្របខ័ណ្ឌនៃកងពល ១៦៤ KH ERN 01517445។ សូមមើលផងដែរ ឯកសារ D54/45 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.27 ["ភូមិថ្មធំ ដែលខ្ញុំធ្លាប់ស្នាក់នៅ នៅជិតឡូឥដ្ឋ។"]។ ឯកសារ D54/45.2 កំណត់ហេតុស្តាប់ចម្លើយ ឡុន សេង ឧបសម្ព័ន្ធ៖ ផែនទី KH ERN 00967555 ["តំបន់ដែលខ្ញុំបានរស់នៅ"]។

[2629] ឯកសារ D54/17 កំណត់ហេតុស្តាប់ចម្លើយ សយ ស៊ិន ឆ.14, 18 ["វាជាកន្លែងការដ្ឋានពលកម្មធម្មតារបស់កងពល១៦៤។ [...] ខ្ញុំមិនអាចបញ្ជាក់ពីចំនួនអ្នកធ្វើពលកម្មពិតប្រាកដបានទេ បើតាមខ្ញុំប៉ាន់ស្មានមានប្រហែលជាង ១០០ នាក់។ [...] ឆ.18៖ ឥដ្ឋនិងក្បឿងត្រូវបានផលិតដោយកងពល១៦៤ សម្រាប់ប្រើសាងសង់ទំនប់ ទ្វារទឹកនិងសំណង់ផ្សេងទៀតរបស់អង្គការ។"]។

[2630] ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.166, 230 ["នៅក្នុងកងជើងទឹកដដែល តែគេដកឲ្យមកនៅវ៉ៃថ្ម ៧ម៉ែត្រគូបក្នុងមួយថ្ងៃនៅអូរម្លូ នៅជិតចំការចេងហេង [...] តើនៅក្នុងឆ្នាំ ១៩៧៦ តើមានអ្វីកើតឡើងចំពោះលោក? ឆ.230៖ ខ្ញុំនៅអូរម្លូជិតព្រលានយន្តហោះកងកេង។"]។ ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.2 ["ខ្ញុំធ្វើស្រែនៅអូរម្លូ ដែលនៅជិតបំផុតតំបន់រាម និងព្រលានយន្តហោះកងកេង។"]។ សូមមើលផងដែរ ឯកសារ D114/77.3 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឧបសម្ព័ន្ធ៖ គំនូសបង្ហាញពីទីកន្លែង ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ KH ERN 01101698។ ឯកសារ D114/77.2 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាលខេត្តព្រះសីហនុ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ KH ERN 01101729។

[2631] ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.272-273 ["ថ្មហ្នឹង គេយកមកសាងសង់កំពង់ផែនៅស្ទឹងហាវ។ សៈ ហេតុអ្វីបានជាលោកដឹង? ឆ.273៖ ព្រោះតាញ៉ាន់គាត់និយាយពេលដែលគាត់មកការដ្ឋាន។"]។

2632 ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.14 ["ខ្ញុំក៏បានកត់សម្គាល់ផងដែរថាមានសហករណ៍ច្រើនដែរនៅម្តុំនោះ ហើយការងាររបស់ពួកគេជាចម្បងគឺធ្វើស្រែ និងចម្ការ។"]។

2633 ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន (ត្រូវបានចាត់តាំងឱ្យនៅសហករណ៍បបុសពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ហើយត្រូវបានចាត់តាំងឱ្យទៅធ្វើការនៅទំនប់ពិតត្រាំង) ឆ.2 ["នៅកន្លែងនេះមានសហករណ៍បបុស និងសហករណ៍ពូធឿង ហើយមនុស្សនៅក្នុងសហករណ៍ទាំងពីរនេះមានចំនួនរាប់ពាន់នាក់ រួមទាំងគ្រួសារយោធា យោធាផង។"]។ ឯកសារ D59/1/4.25 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡុង លី KH ERN 00930799 [ពិភាក្សាអំពីសហករណ៍ពូធឿង]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.24 ["ខ្ញុំចាំថាមាន ៤ សហករណ៍ដូចជា បបុស ពូធឿង គគីរក្រោម ស្នាច់ដែង និងសហករណ៍ផ្សេងទៀត។"]។ ឯកសារ D114/94 កំណត់ហេតុស្តាប់ចម្លើយ សំ វុទ្ធី ឆ.62 [មុននេះ សាក្សីរូបនេះបានរៀបរាប់ តើសហករណ៍ដែលគាត់ជាសមាជិកនោះ គឺសហករណ៍ពូធឿង ជាសហករណ៍តែមួយនៅក្នុងភូមិស្នាច់ដែងយ៉ាងដូចម្តេច។ "ស៖ នៅក្នុងសហករណ៍របស់លោកមានមនុស្សប៉ុន្មាននាក់? ឆ.62៖ ៣០នាក់ជាង។"]។ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ.111 ["ស៖ សហករណ៍នោះ ធំប៉ុនណាដែរ? ឆ.111៖ វាមិនធំទេ មានមនុស្សប្រហែល ៣០នាក់ មានក្មេង ២០នាក់និងមនុស្សធំជាង ១០នាក់។"]។

2634 ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុល ណែន ឆ.2 ["នៅកន្លែងនេះមាន សហករណ៍បបុស និងសហករណ៍ពូធឿង ហើយមនុស្សនៅក្នុងសហករណ៍ទាំងពីរនេះមានចំនួនរាប់ពាន់នាក់ រួមទាំងគ្រួសារយោធា យោធាផង។ ។"]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.24 ["ខ្ញុំចាំថាមាន ៤ សហករណ៍ដូចជា បបុស ពូធឿង គគីរក្រោម ស្នាច់ដែង និងសហករណ៍ផ្សេងទៀត"]។

2635 ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.10-11 ["ពេលក្រុមគ្រួសាររបស់ខ្ញុំបានមកដល់ភូមិ ស៊ីង គេបានដាក់ឪពុកម្តាយខ្ញុំទៅធ្វើការនៅសហករណ៍ភូមិគគីរ។ [...] ស៖ តើសហករណ៍ដែលឪពុកម្តាយលោកធ្វើការនោះឋិតនៅក្នុងឃុំអ្វី? ឆ.11៖ សហករណ៍នោះឋិតនៅឃុំរាម តែឥឡូវគេហៅឃុំពិតត្រាំងវិញ។ នៅទីនោះពីដើមគេហៅទំនប់អូរប្រៃ ភូមិពូធឿង ឃុំរាមទេ មិនមែនហៅថាឃុំពិតត្រាំងទេ។"]។ ឯកសារ D54/120.1 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឧបសម្ព័ន្ធ៖ គំនូសបង្ហាញទីកន្លែង EN-KH ERN 01023168។ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.158 ["ស៖ ក្នុងពេលលោកស្រីស្នាក់នៅក្នុងភូមិគគីរជាមួយបងជីដូនមួយប្រុសឈ្មោះ ហេង តើគេចាត់តាំងឱ្យលោកស្រីធ្វើការដែរឬទេ? ឆ.158៖ គេឱ្យខ្ញុំរែកដីធ្វើទំនប់ និងបែនស្រូវ។"]។ ឯកសារ D54/118 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.2-3 ["គេហៅថាភូមិគគីរ មិនទាន់ប្រែមកឈ្មោះចំណោតរាមទេ។ [...] ឆ.3៖ ក្រោយពីខ្មែរក្រហមចូលកាន់កាប់ ខ្ញុំរស់នៅភូមិគគីរ/ចំណោតរាមដដែល"]។

2636 ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.24, 148, 150 ["ខ្ញុំចាំថាមាន ៤ សហករណ៍ដូចជា បបុស ពូធឿង គគីរក្រោម ស្នាច់ដែង និងសហករណ៍ផ្សេងទៀត។ [...] ឆ.148៖ នៅស្នាច់ដែង។ [...] ស៖ ឪពុកម្តាយលោកធ្វើការនៅសហករណ៍អី? ឆ.150៖ អត់ទេ ធ្វើការធម្មតាដូចគេដូចឯង ហើយញ៉ាំនៅរោងបាយជាមួយប្រជាជនមកពីសហករណ៍។"]។ ឯកសារ D54/122 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.5 ["នៅពេលខ្មែរក្រហមចូលមកដល់ដំបូង [...] គ្រួសារខ្ញុំ និងគ្រួសារផ្សេងទៀតត្រូវបានជម្លៀសចេញពីភូមិរាម ដោយធ្វើរជើងឱ្យមកសម្រាកមួយរយៈ និងធ្វើការនៅស្នាច់ដែង ដែលយើងកំពុងធ្វើបទសម្ភាសន៍នេះ។"]។ សូមមើលផងដែរ ឯកសារ D54/123

កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.7 ["រយៈពេលប្រហែល២-៣ខែ ប្រជាជនប្រហែលពី ៥០ ទៅ ៦០ឡានពីឃុំរាមត្រូវបានគេបញ្ជូនទៅស្រុកស្រែអំបិល។ តាមខ្ញុំដឹង គេជម្លៀសប្រជាជនឱ្យចេញពីទីនេះឱ្យអស់ ដើម្បីឱ្យទាហានរស់នៅ។ គេបញ្ជូនពួកយើងទៅស្រុកស្រែអំបិល ក្នុងដើមឆ្នាំ១៩៧៦។"]។ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.40 ["បន្ទាប់គេយកប្តីបងស្រីជីដូនមួយខ្ញុំ និងខ្ញុំទៅបាត់ ហើយគេឃើញពួកខ្ញុំយំ គេដាក់ទណ្ឌកម្មពួកខ្ញុំឱ្យជាន់ដីឥដ្ឋឱ្យបានម្នាក់៨០០០ដុំក្នុង១ថ្ងៃ នៅភូមិស្នាច់ដែង។"]។ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ.185-187 ["ស៖ តើសហករណ៍នោះឈ្មោះអីដែរ? ឆ.185៖ សហករណ៍ភូមិស្នាច់ដែង។ ស៖ តើអ្នកនៅក្នុងសហករណ៍នោះធ្វើអីដែរ? ឆ.186៖ ពួកគេធ្វើស្រែ ពេលខែធ្វើស្រែ។ ស៖ ចុះបើខែអត់ធ្វើស្រែ គាត់ធ្វើអី? ឆ.187៖ ខ្លះធ្វើការងារនៅក្នុងរោងម៉ាស៊ីនកិនស្រូវ ខ្លះទៀតដឹកអង្ករយកទៅចែកតាមសហករណ៍។"]។ ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គ្រុយ សម្បត្តិ ឆ.1 ["នៅថ្ងៃទី១៨ មេសា [...] ខ្ញុំនិងគ្រួសារសាច់ញាតិរបស់ខ្ញុំបានចាកចេញពីខេត្តកំពង់សោមជាមួយនឹងរទេះមួយគ្រឿង។ ហើយយើងបានមកដល់ស្នាច់ដែង ខ្ញុំស្នាក់នៅស្នាច់ដែងជាមួយនឹងគ្រួសាររបស់ខ្ញុំ។"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.16 ["ចូលដល់ឆ្នាំ១៩៧៧ ខ្ញុំក៏ត្រូវបានគេដកចេញ ហើយបញ្ជូនឱ្យទៅនៅកងផលិត។ កងផលិតរបស់ខ្ញុំ មានឈ្មោះថា កងវរសេនាតូចលេខ២០។ ខ្ញុំត្រូវបានគេចាត់តាំងឱ្យលើកទំនប់ និងជីកប្រឡាយ អស់រយៈពេលបួនខែ នៅកន្លែងស្នាច់ដែង និងបបុស។ បន្ទាប់ពីពេលនោះមកគេបានបញ្ជូនខ្ញុំឱ្យទៅមើលក្របីនិងភ្ជួរស្រែ។ ខ្ញុំធ្វើការនៅទីនោះ រហូតដល់ខែកញ្ញា ឆ្នាំ១៩៧៨។ នៅពេលនោះ ខ្ញុំហើយនិងកងវរសេនាតូចលេខ២០របស់ខ្ញុំ ត្រូវបានគេបញ្ជូនឱ្យទៅវាយថ្មនៅការដ្ឋានវាយថ្មស្ទឹងហាវ។"]។ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.79, 101, 136, 172, 188-190 ["គេឱ្យមកធ្វើស្រែនៅស្នាច់ដែង [...] ឆ.101៖ គេឱ្យខ្ញុំមកធ្វើស្រែនៅស្នាច់ដែង។ [...] ឆ.136៖ យើងធ្វើស្រែនៅស្នាច់ដែងទាំងអស់គ្នា។ [...] ស៖ អ្នកធ្វើការនៅកងកេង និងបិតត្រាង និងអ្នកធ្វើការនៅស្នាច់ដែង តែមួយទេឬ? ឆ.172៖ បាទ ពួកគេធ្វើការនៅវាលស្រែក្នុងតំបន់ទាំងនេះជាមួយគ្នា។ [...] ឆ.188៖ យើងធ្វើស្រែទាំងអស់គ្នា ហើយយើងដាំដំឡូង។ ស៖ តើលោកមានឃើញគេសង់ទំនប់ទេ? ឆ.189៖ ឃើញមាន។ ស៖ តើលោកចាំថានៅឯណាទេ? ឆ.190៖ ទំនប់នោះ កាត់ទទឹងផ្លូវជាតិលេខ ៤ ហើយមានវាលស្រែទាំងសងខាង ហើយគេលើកប្រឡាយកាត់ទទឹងថ្នល់ ដើម្បីភ្ជាប់ស្រែម្ខាងទៅម្ខាងទៀត។ គេចាត់ឱ្យក្រុមខ្ញុំលើកទំនប់ដែរ។"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.8 ["ចាប់ពីឆ្នាំ១៩៧៦ រហូតមក គេឱ្យពួកយើងទៅស្នាក់នៅកណ្តាលវាលស្រែនៅស្នាចដែង ដោយទទួលការងារច្រូតកាត់ ដកស្ទូងនៅទីនោះ អស់រយៈពេលជិត២ឆ្នាំ។ នៅចុងឆ្នាំ១៩៧៧ គេបញ្ជូនពួកយើងទៅស្ទឹងហាវ។"]។ សូមមើលផងដែរ ឯកសារ D1.3.13.8 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព ជាមួយ ប៉ែន សារិន EN ERN 00217561 ["មានសហករណ៍ពីរនៅរាមសម្រាប់ស្ត្រី និងកូនៗរបស់យោធា និងកម្មករ។ ពួកគេធ្វើស្រែនៅស្នាច់ដែង ក្រោមការគ្រប់គ្រងរបស់តាង៉ែត ដែលជាមេបញ្ជាការកងវរសេនាធំ។"]។ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ.188-189 ["ប្រហែល ៥០ទៅ ៦០គ្រួសារ។ [...] ឆ.189៖ គ្រួសារទាហាន។"]។ ឯកសារ D114/202 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ សាវ៉ាន់ ឆ.29 ["ខ្ញុំទៅស្ទូង ហើយខាងជើងឆាកខាងកើតនៅស្នាច់ដែង។"]។ ផ្ទុយ ឯកសារ D114/202 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ សាវ៉ាន់ ឆ.36 ["ស្នាច់ដែងមានតែផ្ទះគ្រួសារទាហានតែប៉ុណ្ណឹងឯង អត់មានការដ្ឋានទេ។ គេធ្វើផ្ទះឱ្យប្រពន្ធរបស់យោធាស្នាក់នៅ តែយោធាអាចមកលេងនៅក្បែរ ដោយមានថ្ងៃគេមកលេង។ មិនមែនចង់មកលេង ចេះតែបានមកទេ។ ដល់ថ្ងៃកំណត់ ទើបអាចមកបាន។"]។

នៅក្នុងសហករណ៍ទាំងនេះ[2637] ហើយ "គេបែងចែកប្រជាជននៅក្នុងសហករណ៍ទៅតាមក្រុមតូចៗ ដែលមានគ្នាចន្លោះពី ១៥ ទៅ ២០ នាក់"[2638]។ ពេលខ្លះ កម្មាភិបាលវំសាយរស់នៅជាមួយជនស៊ីវិលក្នុងសហករណ៍[2639] ប៉ុន្តែ ក៏មានកម្មករ រួមទាំងកម្មាភិបាលវំសាយ រស់នៅកន្លែងផ្សេងទៀតមួយចំនួនផងដែរ[2640]។ លើសពីនេះទៀត អង្គភាពយោធាសកម្មផ្សេងៗក្នុងកងពល ១៦៤ ប្រចាំការនៅតាមទីតាំងជុំវិញការដ្ឋានរាម និងទីតាំងសម្លាប់ ដូចមានរៀបរាប់បន្ថែមនៅក្នុង *IV. រចនាសម្ព័ន្ធអំណាចរបស់កងពល ១៦៤ (កងពលលេខ ៣ ចាស់)* ខាងលើ។

657. ផ្នែកមួយចំនួននៃការដ្ឋានតំបន់រាមដំណើរការស្ទើរតែភ្លាមៗ ក្រោយជ័យជម្នះរបស់ ប.ក.ក នៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៧៥ ហើយការធ្វើចម្ការ និងការងារស្រោចស្រពនៅតែមានដំណើរការជាបន្ត នៅពេលវៀតណាមកាន់កាប់តំបន់នៅឆ្នាំ ១៩៧៩[2641]។ ទំនប់បិតត្រាងត្រូវបានធ្វើរួចរាល់មួយ

---

[2637] ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.2 ["នៅកន្លែងនេះមាន សហករណ៍បបុស និងសហករណ៍ពូធឿង ហើយមនុស្សនៅក្នុងសហករណ៍ទាំងពីរនេះមានចំនួនរាប់ពាន់នាក់ រួមទាំងគ្រួសារយោធា យោធាផង។"]។

[2638] ឯកសារ D54/119 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែន ឆ.6។

[2639] ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.24 ["ខ្ញុំភ្លេចប្រាប់លោកថា មានកងអនុសេនាធំមួយទៀតចំណុះឲ្យកងវរសេនាតូច១៦៧ គឺកងអនុសេនាធំ៣១ ដែលមានបញ្ជាការឈ្មោះ បងភាព (ស្រី)។ អ្វីដែលពិសេសចំពោះអង្គភាពនេះគឺថាគេបំបែកទៅជាកងតូចៗ ហើយបញ្ជូនទៅរស់នៅជាមួយប្រជាជនធម្មតាតាមឃុំ តាមភូមិ ដូចជាភូមិថ្មធំ គគីរ ពូធឿង ស្ទាច់ម៉ែង... ដើម្បីដឹកនាំប្រជាជនធ្វើការ។"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង សុំ ឆ.281 ["គេនៅកំពង់ពកពូធឿង វត្តរាម និងភូមិមួយទៀតខាងត្បូងវត្តរាម។ ប្រជាជននិងកងទ័ពរស់នៅជាមួយគ្នា។"]។

[2640] ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.23 ["គេបញ្ជូនខ្ញុំទៅរស់នៅភូមិថ្មធំ ហើយគេឲ្យខ្ញុំរើសយកខ្ទមមួយ ដែលមានទីតាំងនៅតាមជើងភ្នំរស់នៅ ដោយខ្ទមនោះមានតែគ្រែដេកមួយទេ។ គេប្រាប់យើងឲ្យដាំដំណាំ បន្លែហូប ព្រោះមិនមានអ្វីហូបទេនៅទីនោះ។"]។

[2641] សូមមើល ឧទាហរណ៍ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.78, 112, 149 ["មុនពេលដែលគេដកខ្ញុំមកដីគោក នៅថ្ងៃទី០៧ ខែ៧ ឆ្នាំ១៩៧៧។ ពេលនោះ គេដកកាំភ្លើងពីទាហានមកពីតំបន់៣៧នោះទាំងអស់។ [...] សៈ តើគេបញ្ជូនលោកពីកោះតាង មកស្ទាច់ម៉ែងគឺ ខែ៧ ឆ្នាំ ៧៧ឬ? ឆ.112៖ បាទ។ [...] សៈ តើលោកនៅស្ទាច់ម៉ែងយូរប៉ុនណា? ឆ.149៖ ខ្ញុំនៅទីនោះរហូតដល់វៀតណាមចូល។"]។ ឯកសារ D114/135 កំណត់ហេតុស្តាប់ចម្លើយ ណុប ផន ឆ.23 ["ខ្ញុំធ្វើស្រែរហូតពេលដែលសង្គ្រាមផ្ទុះឡើង ពេលដែលទាហានវៀតណាមចូលមក។"]។ ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.5, 9 ["សៈ ក្រៅពីជួយធ្វើការងារកសិករ និងជួយការងារវាលយន្តហោះកងកេង តើលោកធ្វើអ្វីរហូតដល់ដាច់ឆ្នាំ៧៥? ឆ.5៖ ពេលនោះ ខ្ញុំមិនមានការផ្លាស់ទីតាំងធ្វើការងារនៅកន្លែងណាផ្សេងទេ គឺនៅជួយធ្វើស្រែជាមួយកសិករ។ នៅព្រលានយន្តកងកេង ខ្ញុំមិនបានចាំថាឆ្នាំណាទេ ប៉ុន្តែមិនឆ្លង

ផុតឆ្នាំ៧៥ទេ គឺប្រហែលជាចុងឆ្នាំ៧៥ គឺមានការទម្លាក់គ្រាប់បែករបស់អាមេរិកាំងនៅព្រលានយន្តកងកេង នៅមូលដ្ឋានជើងទឹក រាម និងកំពង់ផែកំពង់សោម។ [...] ឆ.9៖ ខ្ញុំមិនបានចាំថ្ងៃខែពិតប្រាកដទេ ប្រហែលជាដើមឆ្នាំ៧៦ ឬចុងឆ្នាំ៧៥ គេចាប់ផ្តើមរៀបចំទ័ពជើងទឹក។ នៅពេលនោះ ក៏មានឈ្មោះខ្ញុំមួយដែរ ដែលត្រូវបានគេចាត់តាំងឲ្យទៅហ្វឹកហាត់។"]។ ឯកសារ D114/57 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.5 [សាក្សីជាអតីតទាហានក្នុងកងពលធំ ១៦៤ ដែលត្រូវបានគេបញ្ជូនឲ្យទៅធ្វើស្រែនៅក្បែរកងកេង "ពេលនោះគឺឆ្នាំ ១៩៧៧ ឬ ១៩៧៨ ខ្ញុំត្រូវបានគេបញ្ជូនទៅធ្វើស្រែនៅកងកេងរយៈពេលកន្លះខែ។"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.72, 76 ["នៅប្រហែលបីគីឡូពីកន្លែងប្រជុំ ដែលនៅព្រលានយន្តហោះកងកេង [...] ឆ.76៖ ទាល់តែពេលដែលវៀតណាមចូលមក។"]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា (យោធាក្នុងកងពលធំលេខ៣/១៦៤ ត្រូវបានបញ្ជូនទៅធ្វើការនៅព្រលានយន្តហោះកងកេងក្នុងឆ្នាំ១៩៧៧) ឆ.15 ["តាមខ្ញុំចាំគឺពីខែកក្កដា ឆ្នាំ១៩៧៧ ដល់ខែកញ្ញា ឆ្នាំ១៩៧៨។ "]។ ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី (យោធាកងវរសេនាតូច ៣៨៦ បានបញ្ជូនទៅព្រលានយន្តហោះកងកេងក្នុងឆ្នាំ ១៩៧៧) ឆ.17 ["ខ្ញុំធ្វើការនៅកងកេងរហូតដល់ពាក់កណ្តាលឆ្នាំ ១៩៧៨"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.22 ["ខ្ញុំនៅចាំច្បាស់ថាកង៨៦ទាំងអស់របស់ខ្ញុំត្រូវបានគេដកអាវុធ [...] ហេតុការណ៍នេះកើតឡើងនៅខែកក្កដា ឆ្នាំ១៩៧៧។ នៅថ្ងៃដែលដែលគេរំសាយពួកខ្ញុំ គឺគេឲ្យចបយើងម្នាក់មួយមុននឹងបញ្ជូនទៅធ្វើការនៅម្តុំព្រលានយន្តហោះកងកេង។"]។ ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង (យោធាក្នុងកងពលធំ ១៦៤ បានដាក់ឈរជើងនៅព្រលានយន្តហោះកងកេងភ្លាមៗបន្ទាប់ពីខែ មេសា ឆ្នាំ ១៩៧៥ ហើយបានត្រឡប់ទៅតំបន់វិញក្នុងឆ្នាំ ១៩៧៧) ឆ.15 ["ពេលមកពីភ្នំពេញដំបូង គេឲ្យខ្ញុំនៅព្រលានយន្តហោះកងកេង"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង សុំ (យោធាក្នុងកងពលធំ ១៦៤ ដែលធ្លាប់ធ្វើការនៅតំបន់ជុំវិញព្រលានយន្តហោះកងកេងពីចុងឆ្នាំ ១៩៧៥ រហូតដល់ ពាក់កណ្តាលឆ្នាំ ១៩៧៦) ឆ.230 ["ខ្ញុំនៅអូរម្ជិតព្រលានយន្តហោះកងកេង។ ខ្ញុំនៅទីនោះពីពាក់កណ្តាលឆ្នាំ ១៩៧៥ រហូតដល់ឆ្នាំ ១៩៧៨"]។ ឯកសារ D114/285 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន សារ៉ាត់ ឆ.8, 13 ["ស៖ ឥឡូវយើងឈានមកនិយាយអំពីពេលដែលលោកមកភ្នំពេញ។ នៅថ្ងៃរំដោះ ថ្ងៃទី ១៧ មេសា ១៩៧៥ តើពេលនោះ លោកនៅឯណាដែរ? ឆ.8៖ ថ្ងៃដែលរំដោះ ថ្ងៃ១៧ មេសា ១៩៧៥ ខ្ញុំនៅសមរភូមិខាងលិចភ្នំពេញ [...] ស៖ បើលោកចេញថ្ងៃ១៨ ហើយចំណាយពេលបីថ្ងៃធ្វើដំណើរ។ អ៊ីចឹង បានន័យថា ថ្ងៃ២២ លោកទៅដល់កំពង់សោម មែនទេ? ឆ.13៖ បើគិតអ៊ីចឹងបានឃើញ។ ខ្ញុំទៅដល់ថ្ងៃនោះ ប្រហែលថ្ងៃ២១។ ខ្ញុំទៅដល់កន្លែងហ្នឹង គឺខាងបញ្ជាការវរសេនាធំ ឲ្យខ្ញុំឈរជើងនៅចំណុចយន្តហោះកងកេង។"]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.2-4, 6, 12-13, 124["ពីឆ្នាំ ៧៥ បន្ទាប់ពីរំដោះ ខ្ញុំបានចេញពីក្រុងសីហនុ មកព្រលានយន្តហោះកងកេង។ [...] ស៖ តើគេរំដោះភ្នំពេញនៅពេលណា? ឆ.3៖ ឆ្នាំ៧៥។ ស៖ ពេលណា? ឆ.4៖ ថ្ងៃ ១៧ ខែមេសា ១៩៧៥។ [...] ស៖ ក្រោយរំដោះភ្នំពេញប៉ុន្មានថ្ងៃ ទើបលោកផ្លាស់ទៅនៅហ្នឹង? ឆ.6៖ ប្រហែល ១សប្តាហ៍ គេជម្លៀសប្រជាជនចេញទៅជនបទ។ [...] ស៖ លោកថាលោកទៅនៅជិតព្រលានយន្តហោះកងកេង តើលោកទៅនៅណាខ្លះ? ឆ.12៖ គេឲ្យខ្ញុំទៅភូមិរាម ឃុំរាម ស្រុកព្រៃនប់ ខេត្តកំពត ជិតព្រលានយន្តហោះកងកេង។ ស៖ លោកនៅទីនោះរយៈពេលប៉ុន្មាន? ឆ.13៖ ប្រហែល ២ខែ គេបំបែកខ្ញុំពីឪពុកម្តាយខ្ញុំ ទៅចូលក្នុងកងកុមារ។ [...] ស៖ លោកនៅតំបន់ព្រលានយន្តហោះកងកេងយូរប៉ុនណា? ឆ.124៖ ពីឆ្នាំ៧៥ ដល់ ៧៨"]។ ឯកសារ D54/106.2 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សាន់ កាន ហៅ ប៊ុត EN ERN 00993403-00993404 ["បន្ទាប់

ពីហ្នឹងទៅក៏ទៅដល់៧៥ ចេញពីដោះកញ្ស្បរទៅវ៉ៃ [...] មកយាមនៅកងកេងថ្ងៃ១៨-១៩ និង ២០ កងកេង រៀមនេះមកយាមយន្តហោះ។"]។ ឯកសារ D114/243 កំណត់ហេតុស្តាប់ចម្លើយ ឆក សែន ឆ.10 ["១៩៧៦ គេយកខ្ញុំទៅចម្ការដូង"]។ ឯកសារ D114/76 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.21 ["ខ្ញុំធ្វើការនេះរហូតដល់ចុងឆ្នាំ១៩៧៦ ក្រោយមក ខ្ញុំត្រូវបានគេផ្លាស់ទៅកោះតាង ជាមួយនឹងសមាជិកមួយចំនួននៅក្នុងកងវរសេនាធំលេខ៤១ របស់ខ្ញុំនេះ។ នៅលើកោះនោះ ក៏មានទាហានមកពីអង្គភាពដទៃទៀតផងដែរ។ ខ្ញុំនៅលើកោះតាង ជាងពីរខែ។ ក្រោយមកទៀត គេបញ្ជូនខ្ញុំតែឯងឲ្យមកធ្វើស្រែនៅកងកេង។ [...] ខ្ញុំធ្វើការងារនៅតំបន់រហូតដល់ឆ្នាំ១៩៧៧ នៅពេលដែលខ្ញុំត្រូវបានគេបញ្ជូនទៅកោះពូឡូវ៉ៃ។ ខ្ញុំចាំថា នៅពេលនោះគឺនៅចុងឆ្នាំ១៩៧៧។"]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ិន យ៉ើ ឆ.22 ["ធ្វើការក្នុងកងហ្នឹងលុះដល់១៩៧៩។"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.8 ["ចាប់ពីឆ្នាំ១៩៧៦រហូតមក គេឲ្យពួកយើងទៅស្នាក់នៅកណ្ដាលវាលស្រែនៅស្នាច់ដែង ដោយទទួលការងារច្រូតកាត់ ដកស្ទូងនៅទីនោះអស់រយៈពេលជិត២ឆ្នាំ។ នៅចុងឆ្នាំ១៩៧៧ គេបញ្ជូនពួកយើងទៅស្ទឹងហាវ។"]។ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ.184, 261-262, 267, 332 ["ស៖ លោកស្រីថា លោកស្រីចេញពីកងកុមារលើកទីពីរ ១៩៧៧ ហើយលោកស្រីរៀបការ ១៩៧៨ តើលោកស្រីធ្វើអ្វីនៅក្នុងឆ្នាំ១៩៧៨? ឆ.184៖ នៅកងមីង១ នៅភូមិស្នាច់ដែង ជិតព្រលានយន្តហោះកងកេង។ [...] ស៖ នៅក្នុងឆ្នាំ១៩៧៧ តើលោកស្រីនៅភូមិព្រៀងទៀតទេ? ឆ.261៖ អត់ទេ ខ្ញុំនៅស្នាច់ដែង។ ស៖ នៅសហករណ៍ស្នាច់ដែង? ឆ.262៖ ចាស។ [...] ស៖ នៅខែតុលា ឆ្នាំ១៩៧៨ តើលោកស្រីនៅក្នុងកងកុមារ ឬក៏នៅក្នុងមន្ទីរពេទ្យ? ឆ.267៖ ពេលនោះខ្ញុំនៅក្នុងសហករណ៍ស្នាច់ដែង ជិតព្រលានយន្តហោះកងកេង។ [...] ស៖ ក្នុងរយៈពេល ៣ខែ ដែលលោកស្រីរៀបការ តើលោកស្រីបន្តនៅស្នាច់ដែងទៀតមែនទេ? ឆ.332៖ ចាស រហូតដល់ពេលដែលយើងរត់ចេញពីទីនោះទៅព្រំប្រទល់ថៃនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។"]។ ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.1 ["នៅថ្ងៃទី១៨ មេសា [[...] ខ្ញុំនិងគ្រួសារសាច់ញាតិរបស់ខ្ញុំ បានចាកចេញពីខេត្តកំពង់សោមជាមួយនឹងរទេះមួយគ្រឿង។ ហើយយើងបានមកដល់ស្នាច់ដែង ខ្ញុំស្នាក់នៅស្នាច់ដែងជាមួយនឹងគ្រួសាររបស់ខ្ញុំ។ សាច់ញាតិផ្សេងទៀត និងប្រជាពលរដ្ឋមួយចំនួន បានបន្តធ្វើដំណើរទៅទិសខាងកើត។ មូលហេតុដែលខ្ញុំឈប់នៅស្នាច់ដែង ដោយសារខ្ញុំមានម្ដាយចាស់ អាយុចិតសិបឆ្នាំជាងដែលមិនអាចធ្វើដំណើរឆ្ងាយបាន។ សមាជិកគ្រួសាររបស់ខ្ញុំ និងឪពុកក្មេករបស់ខ្ញុំ ត្រូវបានគេស្គាល់ដោយសារតែជំនាញភ្ជាស់ពងទាររបស់គាត់ ហើយគាត់ត្រូវបានគេហៅថា តាចិញ្ចឹមទា។"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.16 ["ចូលដល់ឆ្នាំ១៩៧៧ ខ្ញុំក៏ត្រូវបានគេដកចេញ ហើយបញ្ជូនឲ្យទៅនៅកងផលិតរបស់ខ្ញុំ មានឈ្មោះថា កងវរសេនាតូចលេខ២០។ ខ្ញុំត្រូវបានគេចាត់តាំងឲ្យលើកទំនប់ និងជីកប្រឡាយ អស់រយៈពេលបួនខែ នៅកន្លែងស្នាច់ដែង និងបបុស។ បន្ទាប់ពីពេលនោះមក គេបានបញ្ជូនខ្ញុំឲ្យទៅមើលក្របីនិងភ្ជួរស្រែ។ ខ្ញុំធ្វើការនៅទីនោះ រហូតដល់ខែកញ្ញា ឆ្នាំ១៩៧៨។ នៅពេលនោះ ខ្ញុំហើយនិងកងវរសេនាតូចលេខ២០របស់ខ្ញុំ ត្រូវបានគេបញ្ជូនឲ្យទៅវាយថ្មនៅការដ្ឋានវាយថ្មស្ទឹងហាវ។"]។ សូមមើលផងដែរ ឯកសារ D2/7 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សារិន ឆ.3 ["ចំណែកបុគ្គលិកមួយចំនួនផ្សេងទៀត ត្រូវបានបញ្ជូនទៅការដ្ឋាននៅតំបន់ស្នាច់ដែងនិងវាលវិញ ប្រហែលជានៅក្នុងខែប្រាំ ឬប្រាំមួយ ឆ្នាំ១៩៧៥។"]។ ឯកសារ D114/94 កំណត់ហេតុស្តាប់ចម្លើយ សំ វុទ្ធី ឆ.79 ["ស៖ តើលោកធ្វើការនៅកន្លែងធ្វើក្បឿងហ្នឹងរហូតដល់ពេលណា? ឆ.79៖ រហូតដល់ពេលវៀតណាមវ៉ៃចូល។"]។

នៅ ចុងឆ្នាំ ១៩៧៧[2642]។ ទំនប់ និងប្រឡាយផ្សេងទៀត ចាប់ផ្តើមសាងសង់ ពេលវៀតណាមចូលមក[2643]។

658. មានទីតាំងសម្លាប់ធំៗចំនួនបួនក្នុងតំបន់រាម។ មន្ទីរសន្តិសុខទឹកសាបស្ថិតនៅខាងកើតការដ្ឋានរាម នៅលើផ្លូវជាតិលេខ ៤ ឆ្លងស្ពានទឹកសាប (សូមមើល *VIII.ត.៤ មន្ទីរសន្តិសុខទឹកសាប*)។ មានចម្ការទុរេនពីរប្រើជាទីតាំងសម្លាប់នៅខាងត្បូងផ្លូវជាតិលេខ ៤ (ឈ្មោះ "Chamkar Thuren" មានន័យថា "ចម្ការទុរេន" ជាភាសាខ្មែរ ពេលខ្លះ ត្រូវបានប្រើជាការសរសេរតាមសូរជាភាសាអង់គ្លេសនៅលើសំណុំរឿង[2644]) ដែលស្ថិតនៅប្រហែល ៣,៥ គីឡូម៉ែត្រពីគ្នា ម្ខាងផ្លូវភ្នំម្នាក់ នៅទិសពាយ័ព្យព្រលានយន្តហោះកងកេង[2645]។ ទីតាំងសម្លាប់ទីបួនស្ថិតនៅខាងជើងផ្លូវជាតិលេខ ៤

---

2642 ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណៃន ឆ.35-36 ["ទំនប់បិតត្រាំងចាប់ផ្តើមនៅប្រហែលខែមិថុនា ឬខែកក្កដា ឆ្នាំ១៩៧៥ គឺនៅដើមរដូវវស្សា។ សៈ តើគម្រោងទំនប់បិតត្រាំងបញ្ចប់នៅពេលណា? ឆ.36៖ ទំនប់បិតត្រាំង ឬទំនប់ពូធឿងបញ្ចប់នៅប្រហែលពាក់កណ្តាលឆ្នាំ១៩៧៧។"]។ ឯកសារ D54/35 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.17 ["យើងនៅទីនោះដាំស្រូវនិងកសាងទំនប់នៅទីនោះរហូតដល់ចុងឆ្នាំ ១៩៧៧"]។ ឯកសារ D114/96 កំណត់ហេតុស្តាប់ចម្លើយ ចេង ឡុង ឆ.73 ["សៈ នៅត្រឹមឆ្នាំ១៩៧៧ គឺនៅពេលដែលលោកចាកចេញពីភូមិបបុស តើទំនប់នោះគេធ្វើហើយឬនៅ? ឆ.73៖ ទំនប់នោះត្រូវបានសាងសង់រួចហើយ។"]។ សូមមើលផងដែរ ឯកសារ D114/58 កំណត់ហេតុស្តាប់ចម្លើយ សំ សៅ ឆ.50 ["សៈ តើលោកបានឃើញទំនប់ពូធឿងឬទេ ហើយបើលោកបានឃើញ តើទំនប់នោះបានសង់ហើយឬនៅកាលជំនាន់នោះ? ឆ.50៖ បាទ ខ្ញុំបានឃើញពីចម្ងាយ។ ទំនប់នោះកំពុងសាងសង់នៅឡើយ។"]។ ឯកសារ D54/19 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.2 ["ខ្ញុំមិនអាចនិយាយថា គេចាប់ផ្តើម និងបញ្ចប់នៅពេលណាបានទេ ដូចដែលខ្ញុំនិយាយពីម្សិលមិញ គេប្រើពេលតែមួយរដូវប្រាំង គឺសាងសង់រួចរាល់ហើយ។"]។

2643 ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សម្បត្តិ ឆ.199 ["សៈ តើលោកធ្វើទំនប់នោះដល់ពេលវៀតណាមចូលឬ? ឆ.199៖ បាទ។"]។ ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញ៉ូង ជ្រោង (សមាជិកក្រុម៣ កងអនុសេនាតូចលេខ៣ កងអនុសេនាធំ ២២ កងវរសេនាតូច ៥៥០ កងវរសេនាធំ ២២ កងពលធំលេខ ៣) ឆ.24, 25, 27 ["វរសេនាធំលេខ២២ ជាអ្នកផ្តើមធ្វើទំនប់នោះ។ [...] ឆ.25៖ នៅក្រោមកងពលលេខ ១៦៤ [...] ឆ.27៖ ទំនប់នេះចាប់ផ្តើមធ្វើនៅឆ្នាំ១៩៧៧។"]។

2644 ឯកសារ D54/118 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម KH ERN 01023151 ["ប៉ុន្តែលោកបានដឹង/ឮពីប្រជាជនថាពួកខ្មែរក្រហមបានកប់សាកសពនៅម្តុំដើមធូរេន ដើម្បីធ្វើជី គឺនៅទីកន្លែងមួយដែលមានឈ្មោះថា ចម្ការធូរេន។"]។

2645 ឯកសារ D54/91 កំណត់ហេតុស្តាប់ចម្លើយ កុយ ណៃន KH ERN 00987119 ["ចម្ការធូរេនទាំងពីរនេះមានទីតាំងនៅតាមបណ្តោយភ្នំ ដែលស្ថិតនៅផ្នែកខាងជើងឆៀងខាងលិចព្រលានយន្តហោះកងកេង។"]។ ឯកសារ D114/99 របាយកាណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចំការធូរេនII ទឹកសាប បិតត្រាង KH ERN 01519474 ["ចំការធូ

នៅទីតាំងអតីតមូលដ្ឋានយោធា លន់ នល់។ ព័ត៌មានបន្ថែមអំពីទីតាំងនៃទីតាំងសម្លាប់ទាំងនេះ ពីត្បូងទៅជើង មានដូចខាងក្រោម។

659. ទីតាំងសម្លាប់ "ចម្ការទុរេន ១" ស្ថិតនៅតាមបណ្ដោយជម្រាលជើងភ្នំ នៅប៉ែកពាយព្យនៃព្រលានយន្តហោះកងកេង និងជិតឆ្នេររាម[2646]។ ទីតាំងនេះមានផ្ទៃដីប្រមាណ ៥០០ ហិកតា[2647] ហើយពេលខ្លះ គេហៅថា "ចម្ការទុរេនចេងហេង"[2648] (នៅជាប់ចម្ការដូងចេងហេង[2649] ដោយចម្ការទាំង

---

រេនទាំងពីរស្ថិតនៅឆ្ងាយពីគ្នាតែប្រហែល (៣,៥គីឡូម៉ែត្រ) ដែលស្ថិតនៅតាមជម្រាលជើងភ្នំ ពីម្ខាងភ្នំម្ខាក់នៃជួរភ្នំប៉ែកខាងជើងវាលយន្តហោះកងកេង។"]។

2646 ឯកសារ D114/80 របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង តំបន់ចម្ការធូរេនទី១ តំបន់បិតត្រាង មូលដ្ឋានយោធាទំនុកបម្រុងក្នុងក្របខ័ណ្ឌនៃកងពល ១៦៤ KH ERN 01517438-01517439 ["ចម្ការធូរេនទី១ មានទីតាំងស្ថិតនៅក្នុងស្រុកព្រៃនប់ ក្បែរព្រលានយន្តហោះកងកេង។ [...] ចម្ការធូរេនទី១ គឺនៅជិតចម្ការធូរេនទី២ ដែលជាកន្លែងសម្លាប់មនុស្ស និងផ្នូរមួយផងដែរក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។"]។ ឯកសារ D54/91 កំណត់ហេតុស្ដាប់ចម្លើយ កុយ ណែន KH ERN 00987119 ["ចម្ការធូរេនទាំងពីរនេះមានទីតាំងនៅតាមបណ្ដោយភ្នំ ដែលស្ថិតនៅផ្នែកខាងជើងឆៀងខាងលិចព្រលានយន្តហោះកងកេង។ ចំណុចទី១ គឺនៅខាងត្បូងឆៀងខាងកើតនៃជួរភ្នំ ហើយចំណុចទី២ គឺនៅខាងជើងឆៀងខាងលិចជួរភ្នំពេញ។"]។ ឯកសារ D54/89.1 កំណត់ហេតុស្ដាប់ចម្លើយ កុយ ណែន ឧបសម្ព័ន្ធ៖ ផែនទីរដ្ឋបាលស្រុកព្រៃនប់ ចុះថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៤ KH-EN 00987086។ ឯកសារ D54/102 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.29 ["ខាងលិចចម្ការដូង ជាប់នឹងជើងភ្នំ គឺជាចម្ការធូរេន"]។ ឯកសារ D54/18 កំណត់ហេតុស្ដាប់ចម្លើយ នូ សារឿន ឆ.33 ["ស៖ តើលោកអាចប្រាប់ខ្ញុំអ្វីខ្លះអំពីចំការធូរេន ដែលនៅជិតឆ្នេរសមុទ្រនិងជិតចំការដូង? ឆ.33៖ ខ្ញុំបានដឹងថា ទីនោះជាកន្លែងដែលយោធាខ្មែរក្រហមយកមនុស្សទៅសម្លាប់ចោល។"]។ ឯកសារ D114/156 កំណត់ហេតុស្ដាប់ចម្លើយ ស៊ឹង ណុច ឆ.264 ["ស៖ នៅជិតចម្ការក្រូចមានចម្ការធូរេនទេ? ឆ.264៖ មានចម្ការធូរេន នៅខាងកើតចម្ការដូងជាប់ជើងភ្នំ ផ្លូវចូលទៅរាម។"]។ ឯកសារ D114/243 កំណត់ហេតុស្ដាប់ចម្លើយ ឆក សែន ឆ.76-77 ["ស៖ តើទីតាំងចម្ការធូរេនស្ថិតនៅទីណាដែរ កាលនោះ? ឆ.76៖ នៅជាប់ សៀរសមុទ្រ។ ស៖ តើចម្ការធូរេននោះស្ថិតនៅចម្ងាយប៉ុន្មានពីចម្ការដូង? ឆ.77៖ ប្រហែលជា១គីឡូដី។"]។

2647 ឯកសារ D54/90 កំណត់ហេតុស្ដាប់ចម្លើយ កុយ ណែន ឆ.34 ["ចម្ការនោះគឺគ្របដណ្ដប់ផ្ទៃដីប្រហែល៥០០ហិកតា។"]។

2648 ឯកសារ D114/99 របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ចំការធូរេនII ទឹកសាប បិតត្រាង KH ERN 01519474 ជើងទំព័រ ៤។ ឯកសារ D114/80 របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង តំបន់ចម្ការធូរេនទី១ តំបន់បិតត្រាង មូលដ្ឋានយោធាទំនុកបម្រុងក្នុងក្របខ័ណ្ឌនៃកងពល ១៦៤ KH ERN 01517438-01517439 ["សាក្សីជាច្រើនបានសំដៅដល់កន្លែងនេះថាជាកន្លែងរបស់អតីតម្ចាស់។ នោះគឺ "ចម្ការធូរេនរបស់ ចេង ហេង"។"]។

2649 ឯកសារ D114/2 កំណត់ហេតុស្ដាប់ចម្លើយ ឡាក់ សាផាន ឆ.1 ["នៅខាងឆ្វេងដៃផ្លូវ គឺជាចម្ការដូងដុកទ័រ សុទ្ធ ចំរើន (ខ្ញុំមិនអាចបញ្ជាក់ថាដុកទ័រនេះឈ្មោះអ៊ីចឹងពិតប្រាកដឬយ៉ាងម៉េចទេ)។ នៅជាប់នឹងចម្ការដូងនោះគឺមានព្រៃកមួយ

ពីរនេះទំនងជាកម្មសិទ្ធិរបស់មនុស្សតែម្នាក់ពីមុន)។ ចម្ការក្រូច (ពេលខ្លះ គេសរសេរតាមសូរ "Chamkar Krauch" នៅក្នុងសំណុំរឿង) ក៏នៅជិតនោះផងដែរ[2650]។ ចម្ការទុរេន ១ ស្ថិតនៅជាប់នឹងឆ្នេរ ហើយបើទៅពីឆ្នេរ "ងាយស្រួលសម្រាប់ធ្វើការដំណើរចូល"[2651] នៅម្ខាងផ្លូវភ្នំបែរមុខទៅព្រលានយន្តហោះកងកេង។ ចម្ការទុរេន ១ មិនត្រឹមតែប្រើប្រាស់ជាទីតាំងសម្លាប់មនុស្សយកពីការដ្ឋានតំបន់រាមប៉ុណ្ណោះនោះទេ វាក៏ជាទីតាំសម្លាប់ជនបរទេសដែរ រួមទាំងថៃ និងវៀតណាម

---

ហើយឆ្លងពីព្រែកនោះ គឺជាចម្ការដូង ចេង ហេង។"]។ ឯកសារ D114/80 របាយកាណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង តំបន់ចម្ការធូរេនទី១ តំបន់បិតត្រាង មូលដ្ឋានយោធាទំនុកបម្រុងក្នុងក្របខ័ណ្ឌនៃកងពល ១៦៤ KH ERN 01517453, 01517453, 01517455, 01517462-01517463។ សូមមើលផងដែរ ឯកសារ D54/113 កំណត់ហេតុស្តាប់ចម្លើយ លៀង បៀ ឆ.75 ["ខ្ញុំធ្លាប់ធ្វើដំណើរទៅរាម ហើយឃើញចម្ការដូងនៅជិតផ្លូវនោះ។"]។ ឯកសារ D54/120 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.8 ["នៅសម័យខ្មែរក្រហម នៅខាងត្បូងចម្ការធូរេនមានចម្ការដូងមួយ"]។ ឯកសារ D54/120.1 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឧបសម្ព័ន្ធ៖ គំនូសបង្ហាញទីកន្លែង EN-KH ERN 01023168។ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.253 ["ចំការធូរេន នៅជិតចំការដូង"]។ ឯកសារ D114/243 កំណត់ហេតុស្តាប់ចម្លើយ ឆក សែន ឆ.77 ["ស៖ តើចម្ការធូរេននោះស្ថិតនៅចម្ងាយប៉ុន្មានពីចម្ការដូង? ឆ.77៖ ប្រហែលជា១គីឡូដឺ។"]។ ឯកសារ D114/117.1 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ឧបសម្ព័ន្ធ៖ គំនូសបង្ហាញទីកន្លែង EN ERN 01138918។

2650 ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.13 ["ចម្ការធូរេន ចម្ការដូង និងចម្ការក្រូច គឺនៅជិតគ្នា។"]។ ឯកសារ D54/120 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.11 ["ផ្ទះយោធាខ្មែរក្រហមទៀត មុនទៅដល់ចម្ការធូរេនស្ថិតនៅតាមផ្លូវលំចុះពីផ្លូវជាតិលេខ៤ទៅ គឺស្ថិតនៅក្បែរចម្ការក្រូច ដែលទីនោះមានផ្ទះយោធាខ្មែរក្រហមពីរបីផ្ទះដែរ។"]។ ឯកសារ D54/120.1 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឧបសម្ព័ន្ធ៖ គំនូសបង្ហាញទីកន្លែង EN-KH ERN 01023168។ ឯកសារ D54/91 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន KH ERN 00987119 ["ចំណុចទី១នេះសាក្សីបាននិយាយថា ជាចំណុចចម្ការធូរេន ចម្ការម្រេច និងចម្ការក្រូច។"]។ ឯកសារ D114/58 កំណត់ហេតុស្តាប់ចម្លើយ សំ សៅ ឆ.47 ["មានចម្ការធូរេននៅជិតចម្ការក្រូច។"]។ ឯកសារ D114/139 កំណត់ហេតុស្តាប់ចម្លើយ ងួន ឡាយ ឆ.51 ["នៅមានមួយទៀត នៅជិតចម្ការដូង ចម្ការក្រូចអីហ្នឹង។"]។ ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ សួន ឈុំ ឆ.20-22 ["ចម្ការក្រូចហ្នឹងស្ថិតនៅខាងលិចឆៀងខាងត្បូងផ្លូវជាតិលេខ៤ ចុះពីសាលាឃុំបិតត្រាំងហ្នឹង។ [...] ឆ.22៖ [...] តាមជើងភ្នំសំដៅទៅសមុទ្រ"]។

2651 ឯកសារ D114/99 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចម្ការធូរេន II, ទឹកសាប, បិតត្រាំង KH ERN 01519474 ["ទីកន្លែងទីមួយដែលនៅក្នុងនេះហៅថា ចម្ការធូរេន I ត្រូវបានបង្ហាញដោយសាក្សីផ្សេងទៀតថាជាកន្លែងសម្រាប់សម្លាប់អ្នកទេសាទបរទេស។ ទីកន្លែងនេះស្ថិតនៅជាប់ឆ្នេរសមុទ្រក្បែរជើងផ្លូវភ្នំទល់មុខនឹងវាលយន្តហោះកងកេង។ ទីកន្លែងនេះគឺងាយស្រួលសម្រាប់ការធ្វើដំណើរចូល បើមកពីខាងឆ្នេរសមុទ្រ"]។ សូមមើលផងដែរ ឯកសារ D114/2 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.2 ["ចម្ការធូរេនដែលនៅខាងស្តីដៃ នៅជិតជើងភ្នំ ហើយលាតសន្ធឹងចុះរហូតដលមាត់សមុទ្រ"]។

ដែលត្រូវបានចាប់នៅសមុទ្រ ឬលើកោះផងដែរ[2652]។ នៅជិតនោះ ក៏មានមានផែមួយផងដែរនៅមាត់ពាម ដែលជនរងគ្រោះដែលយកមកពីសមុទ្រ ពេលខ្លះ ត្រូវបានបញ្ជូនទៅអង្គភាពលើដីគោក មុននឹងយកទៅសម្លាប់ចោលនៅទីនោះ[2653]។ មានផ្លូវចូលទៅចម្ការទុរេន ១ ចុះពីផ្លូវជាតិលេខ ៤[2654] និងមានប៉ុស្តិ៍ត្រួតពិនិត្យ និងផ្ទះយោធាជាច្រើន ស្ថិតនៅខាងក្រៅចម្ការ និងតាមបណ្តោយផ្លូវនេះ[2655]។

---

2652 ឯកសារ D114/99 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចម្ការធូរេន II, ទឹកសាប, បិតត្រាំង KH ERN 01519474 ["ចម្ការធូរេន I ត្រូវបានបង្ហាញដោយសាក្សីផ្សេងទៀតថាជាកន្លែងសម្រាប់សម្លាប់អ្នកទោសបរទេស"] ។ សូមមើលផងដែរ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.254 ["នៅ [...] ជាប់មាត់សមុទ្រ"]។ VIII.ខ. ឧក្រិដ្ឋកម្មមកលើជនដែលកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យចាប់បាននៅដែនទឹក និងនៅលើកោះដែលកម្ពុជាប្រជាធិបតេយ្យអះអាងថាជារបស់ខ្លួន។

2653 ឯកសារ D54/120 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.4, 7 ["ទូកនោះត្រូវបានគេនាំយកមកចតនៅមាត់ពាម ហើយអ្នកទោសទាំងនោះត្រូវបានគេយកចេញពីទូក បញ្ជូនមកដីគោក ហើយសម្រាតខោអាវចោលទាំងអស់ ទុកតែខោទ្រនាប់។ ពួកគេត្រូវបានចងដៃនឹងខ្សែអង្រឹងជាជួរៗ ហើយយកទៅចម្ការធូរេន។ [...] ឆ.7៖ មាត់ពាម/ផែ ស្ថិតនៅចន្លោះឃុំរាម និងឃុំបិតប្រាំង នៅតាមឆ្នេរប៉ែកខាងលិចព្រលានយន្តហោះកងកេង។ [...] មាត់ពាមនេះឯងដែលជាផែ ដែលគេចាប់ទូកទោសថៃមកចតនៅទីនោះ នេះបើតាមអ្នកភូមិនិយាយ"]។ ឯកសារ D114/99 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចម្ការធូរេន II, ទឹកសាប, បិតត្រាំង KH ERN 01519477។ ឯកសារ D54/120.1 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឧបសម្ព័ន្ធ៖ គំនូសទីកន្លែង KH ERN 01023168។

2654 ឯកសារ D114/80 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចម្ការធូរេន I, បិតត្រាំង, មូលដ្ឋានយោធាទំនុកបម្រុងក្នុងក្របខ័ណ្ឌនៃកងពលលេខ ១៦៤ KH ERN 01517445។

2655 ឯកសារ D114/80 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចម្ការធូរេន I, បិតត្រាំង, មូលដ្ឋានយោធាទំនុកបម្រុងក្នុងក្របខ័ណ្ឌនៃកងពលលេខ ១៦៤ KH ERN 01517445។ ឯកសារ D54/120 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.11 ["ផ្លូវចូលទៅចម្ការធូរេនត្រូវបានគ្រប់គ្រងដោយផ្ទះយោធាខ្មែរក្រហមពីរកន្លែង។ នៅសងខាងមាត់ព្រែកមានផ្ទះត្រួតពិនិត្យរបស់យោធាខ្មែរក្រហមទាំងសងខាង។ ផ្ទះយាមខ្មែរក្រហមមួយទៀត មុនទៅដល់ចម្ការធូរេន ស្ថិតនៅតាមផ្លូវលំចុះពីផ្លូវជាតិលេខ៤ទៅ គឺស្ថិតនៅក្បែរចម្ការធូរេន ដែលនៅទីនោះមានផ្ទះយោធាខ្មែរក្រហមពីរបីផ្ទះដែរ"]។ ឯកសារ D54/91 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែម KH ERN 00987119 ["ចម្ការធូរេនទី១ ដែលក្រុមស៊ើបអង្កេតរបស់ អ.វ.ត.ក បង្ហាញទៅសាក្សីមានចម្ការធូរេនភូមិស្ទង ដែលស្ថិតនៅខាងត្បូងឆៀងខាងកើតជួរភ្នំ [...] សាក្សីបាននិយាយថា ក្នុងជំនាន់ខ្មែរក្រហម នៅត្រង់ចំណុចនេះគឺជាមូលដ្ឋានរបស់យោធាខ្មែរក្រហមស្នាក់នៅ ហើយគ្មានអ្នកណាម្នាក់ត្រូវបានអនុញ្ញាតឱ្យចូលកន្លែងនោះទេ"]។ ឯកសារ D54/120.1 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឧបសម្ព័ន្ធ៖ គំនូសទីកន្លែង KH ERN 01023168។

660. ទីតាំងសម្លាប់ "ចម្ការទុរេន ២" ក៏ត្រូវបានគេស្គាល់ថាជា "ចម្ការទុរេនអូរត្រាវ" ផងដែរ[2656]។ វាស្ថិតនៅម្ខាងទៀតនៅខាងជើងជួរភ្នំ ផ្ទៀបទៅនឹងចម្ការទុរេន ១ និងនៅជិតផ្លូវជាតិលេខ ៤[2657] ហើយអាចចូលទៅបានតាមផ្លូវដី[2658]។ ចម្ការទុរេន ២ មានទំហំប្រហែល ៥០០ ហិកតា[2659]។ មានឃ្លាំងរំសេវរបស់ខ្មែរក្រហមនៅក្បែរនោះ ដែលត្រូវបានគេដុត ក្រោយរបបដួលរលំ[2660]។ ចម្ការ

---

[2656] ឯកសារ D114/99 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចម្ការធូរេន II, ទឹកសាប, បិតត្រាំង KH ERN 01519474-01519478។ ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែម ឆ.18 ["សៈ តើចម្ការធូរេននៅអូរត្រាវ គឺជាកន្លែងដែលលោកបានគូសសម្គាល់នៅលើផែនទី ដែលនៅជិតព្រលានយន្តហោះកងកេងហ្វឹង ឬយ៉ាងណា? ឆ.18៖ បាទ"]។ ឯកសារ D54/91 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែម KH ERN 00987119 ["ចម្ការធូរេនទាំងពីរនេះមានទីតាំងនៅតាមបណ្តោយភ្នំ ដែលស្ថិតនៅខាងជើងឆៀងខាងលិចព្រលានយន្តហោះកងកេង [...] សាក្សីបានពន្យល់ប្រាប់ថា ចម្ការធូរេនអូរត្រាវគឺស្ថិតនៅភ្នំ រួចហើយគាត់បាននាំក្រុមការងារស៊ើបអង្កេតយើងធ្វើដំណើរទៅកាន់ទីនោះ"]។ ឯកសារ D114/25 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដាវ ឆ.31 ["កន្លែងសម្លាប់ដែលពួកយោធាប្រាប់ខ្ញុំ គឺមានអូរត្រាវ"]។

[2657] ឯកសារ D114/99 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចម្ការធូរេន II, ទឹកសាប, បិតត្រាំង KH ERN 01519477-01519478។ ឯកសារ D114/80 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចម្ការធូរេន I, បិតត្រាំង, មូលដ្ឋានយោធាទំនុកបម្រុងក្នុងក្របខ័ណ្ឌនៃកងពលលេខ ១៦៤ KH ERN 01517448 ["ដោយផ្អែកលើការកំណត់អត្តសញ្ញាណដដែលៗដោយសាក្សីជាច្រើននេះ ពុំមានការសង្ស័យថា ទីតាំងនៃអតីតចម្ការធូរេននេះត្រូវបានគេប្រឌិតឡើងនោះទេ"]។ ឯកសារ D54/120.1 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឧបសម្ព័ន្ធ៖ គំនូសទីកន្លែង KH ERN 01023168។

[2658] ឯកសារ D114/99 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចម្ការធូរេន II, ទឹកសាប, បិតត្រាំង KH ERN 01519474-01519475។

[2659] ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែម ឆ.21-22 ["សៈ តើរណ្តៅដែលលោកឃើញនៅចម្ការធូរេនអូរត្រាវ ជារណ្តៅកប់សាកសពរួម ឬក៏រណ្តៅកប់សាក្សីម្នាក់ៗ ឬក៏រណ្តៅកប់សាកសពចម្រុះ? ឆ.21៖ ដើមធូរេនមួយៗមានរណ្តៅនៅជុំវិញ ដោយរណ្តៅមួយៗមានសាកសពម្នាក់ ឬច្រើនជាងម្នាក់។ សៈ តើលោកអាចប៉ាន់ស្មានរណ្តៅសាកសពនៅកន្លែងនោះថាមានចំនួនប៉ុន្មានទេ? ឆ.22៖ ខ្ញុំអាចមើលឃើញរណ្តៅនៅគ្រប់កន្លែង។ នៅទីនោះមានដីទំហំទទឹង១០០ម៉ែត្រ និងបណ្តោយប្រហែល២០០ម៉ែត្រ ដោយមានដើមធូរេន ដើមក្រូច ដើមចំប៉ាដក់។ កន្លែងនោះម្ខាងជាប់ភ្នំ និងម្ខាងទៀតជាប់អូរ "គូសបញ្ជាក់បន្ថែម)"]។ សូមមើលផងដែរ ឯកសារ D54/22 កំណត់ហេតុនៃកិច្ចស៊ើបសួរ KH ERN 01002674 ["រៀបរាប់អំពីអត្តសញ្ញាណទីតាំងសម្លាប់មនុស្សដែលបញ្ជាក់ដោយសាក្សីពីរនាក់"]។

[2660] ឯកសារ D54/91 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែម KH ERN 00987119 ["សាក្សីបានពន្យល់ប្រាប់ថា ចម្ការធូរេនអូរត្រាវគឺស្ថិតនៅភ្នំ រួចហើយគាត់បាននាំក្រុមការងារស៊ើបអង្កេតយើងធ្វើដំណើរទៅកាន់ទីនោះ។ នៅកន្លែងនោះសាក្សីបានបង្ហាញយើងពីទីកន្លែងឃ្លាំងដាក់គ្រាប់របស់យោធាខ្មែរក្រហម ហើយនិងទីកន្លែងដែលគាត់បានឃើញរណ្តៅសាកសព ហើយនិងឆ្អឹងខ្មោចជាច្រើននៅទីនោះ"]។ ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែម ឆ.20

ទុរេន ២ ត្រូវបានយាមកាមដោយកម្មាភិបាលប្រដាប់ដោយអាវុធ និងហ៊ុំព័ទ្ធដោយ "បន្លាឫស្សី"[2661] ។

661. ទីតាំងសម្លាប់ "សេអ៊ី" ("C.I." ជាអក្សរកាត់នៃ "Centre d'Instruction-មជ្ឈមណ្ឌលហ្វឹកហ្វឺន")[2662] ដែលគេស្គាល់ថាជា "សេស៊ី ៥" ឬ "ជម្រាលសេអ៊ី"[2663] (ហើយពេលខ្លះ សរសេរតាមសូរ "សេអ៊ុំ" នៅក្នុងសំណុំរឿង)[2664] ស្ថិតនៅខាងជើងផ្លូវជាតិលេខ ៤ និងខាងលិចទំនប់បិតត្រាង ជិតទីតាំងមូលដ្ឋានយោធា លន់ នល់ ចាស់[2665]។ មានកងទ័ពខ្មែរក្រហមឈរជើងនៅ

---

[សាក្សីរៀបរាប់អំពីរបៀបគាត់ត្រឡប់ទៅភូមិបិតត្រាំងវិញនៅឆ្នាំ១៩៧៩ នៅពេលដែលរបបខ្មែរក្រហមបានបញ្ចប់។ បន្ទាប់មកគាត់ទៅចម្ការធូរេនអូរត្រាវ ជាកន្លែងដែលគាត់រៀបរាប់អំពីអ្វីដែលគាត់បានឃើញ៖ "នៅក្បែរកន្លែងសម្លាប់នោះ មានឃ្លាំងគ្រាប់មួយដែលគេដុតចោល។ ខ្ញុំឃើញមានកេះគ្រាប់នៅសល់ ដោយកេះខ្លះគ្រាប់មិនទាន់ផ្ទុះ"]។ ឯកសារ D114/99 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចម្ការធូរេន II, ទឹកសាប, បិតត្រាំង KH ERN 01519475-01519476។

2661 ឯកសារ D114/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ចន្ធា ឆ.26-29 ["ខ្ញុំធ្លាប់ទៅឃ្វាលគោ និងកាប់ដើមទន្រ្ទានខែត្រនៅជិតនោះ ចម្ងាយប្រហែល១០០ម៉ែត្រ។ នៅទីនោះមានស្រាស់បន្លាឫស្សីជ្រោងច្រាងព័ទ្ធជុំវិញ និងមានអ្នកការពារយាមកាមផងដែរ។ ហើយខ្ញុំត្រូវបានគេដេញចេញ ដោយគេមិនអនុញ្ញាតឱ្យយើងចូលក្បែរទីនោះទេ។ ស៖ តើអ្នកយាមខ្មែរក្រហមនៅចម្ការធូរេនមានកាន់កាំភ្លើងដែរឬទេ? ឆ.27៖ ពួកគេមានកាន់កាំភ្លើងនៅនឹងដៃ។ [...] ឆ.29៖ មានទាហាន ៥ ទៅ ៦នាក់ នៅឈរឈាមគ្រប់ជ្រុងព័ទ្ធជុំវិញចម្ការធូរេននោះ"]។

2662 ឯកសារ D54/22 កំណត់ហេតុនៃកិច្ចស៊ើបសួរ KH ERN 01002681 ["គាត់ដឹងថា កន្លែងនោះមានឈ្មោះថា "សេអ៊ី៥" (ជាអក្សរបារាំង)"]។

2663 ឯកសារ D114/4 កំណត់ហេតុស្តាប់ចម្លើយ មុំ ម៉េង ឆ.25 ["ស៖ តើលោកមានធ្លាប់បានឮថា កន្លែងសេអ៊ី នោះពីដើមកជាកន្លែងដែលគេកប់សាកសពដែរឬទេ? ឆ.25៖ ទេ ខ្ញុំមិនដែលឮថាវាជាកន្លែងសម្រាប់កប់ខ្មោចពីដើមមកទេ ពីមុនមកវាជាកន្លែងមូលដ្ឋានទាហាន ហៅថា ហៅថាសេអ៊ីប្រាំ"]។ ឯកសារ D54/119 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ. 3 ["កន្លែងសេអ៊ី មានឈ្មោះហៅមួយទៀតគឺបន្ទាយ សេអ៊ី-សែង"]។ ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ ស្នួន ឈុំ ឆ.62 ["បានជាយើងដឹងថាកន្លែងសម្លាប់ គេកប់នៅកន្លែងហ្នឹង ព្រោះពីមុនកន្លែងហ្នឹងមិនមែនជាកន្លែងកប់សាកសពទេ"]។

2664 សូមមើលឧទាហរណ៍ ឯកសារ D54/22 កំណត់ហេតុនៃកិច្ចស៊ើបសួរ KH ERN 01002680-81។

2665 ឯកសារ D54/89.1 ផែនទីរដ្ឋបាល ស្រុកព្រៃនប់ ខេត្តព្រះសីហនុ KH-EN ERN 00987086។ ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.33 ["ស៖ លោកបាននិយាយអំពីទីតាំង សេអ៊ី ដែលស្ថិតនៅតាមផ្លូវចន្លោះពីបិតត្រាំងទៅកំពង់សោម។ លោកបានបង្ហាញប្រាប់យើងអំពីទីតាំងនៃអតីតជំរំហ្វឹងហ្វឺន សេអ៊ី ហើយនិយាយថា លោកស្គាល់ទីនោះដោយសារវាជាជំរំហ្វឹកហ្វឺនសម័យ លន់ នល់។ លោកពុំដឹងថាមានរឿងអ្វីកើតឡើងនៅទីតាំងនោះទេ នៅសម័យខ្មែរក្រហម។ តើត្រឹមត្រូវដែរឬទេ? ឆ.33៖ បាទ ត្រឹមត្រូវ"]។ ឯកសារ D114/4 កំណត់ហេតុស្តាប់ចម្លើយ មុំ

សេអ៊ី ភ្លាមៗបន្ទាប់ពីរបបលន់ នល់ ដួលរលំ[2666]។ ទីតាំងសម្ពាប់ស្ថិតនៅខាងលើបន្ទាយទាហាន លន់ នល់ ពីមុន[2667]។

---

ម៉េង ឆ.19 ["សៈ នៅពេលដែលលោកបង្ហាញយើងពីកន្លែងនោះ កាលពីខែសីហា ឆ្នាំ២០១៣ លោកបានបង្ហាញយើងពីទីកន្លែងរណ្ដៅដែលស្ថិតនៅខាងជើងផ្លូវជាតិលេខ៤។ តើលោកអាចរៀបរាប់បន្ថែមអំពីកន្លែងនោះបានដែរឬទេ? ឆ. 19៖ កន្លែងហ្នឹងហើយ គឺជាកន្លែងសេអ៊ី ដែលមានរណ្ដៅសាកសពប្រហែល១០០កាលពីពេលនោះ ប៉ុន្តែឥឡូវនេះកន្លែងនោះក្លាយជាចម្ការដើមអាកាស្យាអស់ហើយ"]។ ឯកសារ D114/179 កំណត់ហេតុស្ដាប់ចម្លើយ ស្ងួន ឈុំ ឆ. 60-61 ["សៈ តើលោកដឹងអ្វីខ្លះដែរ ពាក់ព័ន្ធនឹងទីតាំងឈ្មោះ សេអ៊ី? [...]ឆ.61៖ មើលទៅខាងជើងឃើញហើយប្រហែល១០០ម៉ែត្រពីផ្លូវ"]។ ឯកសារ D114/282 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.24 ["ស្គាល់ៗ ខ្ញុំស្គាល់ច្បាស់។ គេហៅចំណោទសេអ៊ី ឡើងពីភូមិគគីរ ឡើងចំណោតទៅលើ គេហៅចំណោតសេអ៊ី ហើយ"]។ ឯកសារ D59/1/4.25 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡុង លី KH ERN 00930800 ["គគីរ យើងចុះមកពីចំណោតសេអ៊ីមក ខាងនេះផ្លូវ[លេខ៤]"]។ ឯកសារ D54/119 កំណត់ហេតុស្ដាប់ចម្លើយ ព្រុំ កែម ឆ.3 ["កន្លែងសេអ៊ី មានឈ្មោះហៅមួយទៀតគឺ បន្ទាយ សេអ៊ី-សែង ហើយកន្លែងនោះជាកន្លែងហ្វឹងហ្វឺនរបស់កងទ័ព លន់ នល់ ដែលទាហានទាប់ម៉ឺននាក់ហ្វឹកហ្វឺនផ្នែកយោធា ដោយមានគ្រូអាមេរិកាំងជាអ្នកបង្ហាត់"]។ ឯកសារ D114/68 កំណត់ហេតុស្ដាប់ចម្លើយ គុយ សម្បត្តិ ឆ.8 ["ពេលខ្ញុំចូលធ្វើទាហាន លន់ នល់ គេដាក់ឱ្យខ្ញុំទៅហ្វឹកហ្វឺននៅ សេអ៊ី៥ ជិតបិតត្រាំង"]។ ឯកសារ D54/22 កំណត់ហេតុនៃកិច្ចស៊ើបសួរ KH ERN 01002680-81។ ឯកសារ D54/35 កំណត់ហេតុស្ដាប់ចម្លើយ ប្រាក់ សុខា ឆ.12 ["សេអ៊ី មានផ្ទះវែងៗរបស់ទាហាន លន់ នល់ ដែលសល់នៅក្នុងបរិវេណនោះ"]។ សូមមើលផងដែរ ឯកសារ D54/47 កំណត់ហេតុស្ដាប់ចម្លើយ អែម សុន ឆ.3 ["សៈ នៅពេលដែលលោកធ្វើដំណើរឆ្លងកាត់បន្ទាយសេអ៊ី សូមលោករៀបរាប់អំពីអ្វីដែលលោកឃើញនៅក្នុងបន្ទាយនោះ? ឆ.3៖ តាមការសង្កេតរបស់ខ្ញុំមានទាហាន លន់ នល់ ប្រហែល៥០០នាក់នៅក្នុងបន្ទាយនោះ។ ខ្ញុំមិនដឹងថាចំនួននេះស្ថិតក្នុងមួយកងវរសេនាតូច ឬក៏ទាហានចំណុះឱ្យអង្គភាពផ្សេងនោះទេ"]។ ឯកសារ D54/113 កំណត់ហេតុស្ដាប់ចម្លើយ លៀង បៀ ឆ.110 ["សៈ តើសេអ៊ី ហ្នឹងជាអ្វី? សូមលោកជួយពន្យល់? ឆ.110៖ សេអ៊ី គឺនៅលើចំណោតរាម។ កន្លែងហ្នឹងរោងចក្រ សេអ៊ី ពីមុន តែខ្ញុំមិនដឹងថារោងចក្រនេះធ្វើអ្វីទេ"]។ ឯកសារ D114/54 របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ និងទាក់ទងនឹងទីកន្លែងកំពង់សោម – -កោះរុងសន្លឹម EN ERN 01074095 [រូបភាពទីតាំងទំនប់បិតត្រាំង]។

[2666] ឯកសារ D54/35 កំណត់ហេតុស្ដាប់ចម្លើយ ប្រាក់ សុខា ឆ.10-13 ["ខ្ញុំបិតនៅកងវរសេនាតូច៤៣០ ហើយខ្ញុំជានីរសាររបស់មេបញ្ជាការកងវរសេនាតូច។ មេបញ្ជាការកងវរសេនាតូចឈ្មោះ បងបូ [] ឆ.11៖ បន្ទាប់ពីបែកភ្នំពេញ បូ នៅតែជាមេបញ្ជាការវរសេនាតូច៤៣០ ហើយវរសេនាតូចនោះបានបោះទីតាំងនៅចំណោតរាមព្រលានយន្តហោះកងកេងនៅន្លែងមួយហៅថា សេអ៊ី [...] ឆ.12៖ វរសេនាតូច៤៣០ បានរៀបចំទីបញ្ជាការដ្ឋាននៅបរិវេណសេអ៊ី [...] ឆ.13៖ កងវរសេនាតូច ៤៣០ ស្ថិតនៅក្នុងកងវរសេនាធំ១៣ ក្នុងកងពលលេខ ៣ ពេលនោះកងពលលេខ៣ មិនទាន់ប្ដូរលេខនៅឡើយទេ"]។ ឯកសារ D59/1/1.8a កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ព្រុំ សារ៉ាត់ KH ERN 00926356 ["[វរសេនាធំ] ១៥ នៅម្ដុំចំណោតហ្នឹងខ្លះ ហើយទៅដល់ចំណោតសេអ៊ី"]។ ឯកសារ D114/65

## ២. រចនាសម្ព័ន្ធអំណាច

662. **មាស មុត** មានអំណាចកំពូលលើការដ្ឋាន និងសហករណ៍នៅតំបន់រាមទាំងអស់[2668]។ សារទូរលេខមួយដែល ឌឹម អនុ របស់ **មាស មុត** បានផ្ញើទៅគាត់ បង្ហាញពីការកាន់កាប់របស់ **មាស មុត** ទៅលើតំបន់នោះ។ សារទូរលេខនោះបញ្ជាក់ថា៖

---

កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.16 ["នៅក្នុងថ្ងៃ២៣ ខែមេសា ឆ្នាំ១៩៧៥ កងរបស់ខ្ញុំ បានមកដល់កន្លែងមួយហៅថា សេអ៊ុ៥ ដែលនៅជិតចំណោតរាម។ កងរបស់ខ្ញុំស្នាក់នៅទីនោះ រហូតដល់ខែកញ្ញា ឆ្នាំ១៩៧៥ ក៏ត្រូវបានបញ្ជូនឱ្យទៅនៅមូលដ្ឋានរាម"]។ សូមមើលផងដែរ ឯកសារ D54/47 កំណត់ហេតុស្តាប់ចម្លើយ អែម សុន ឆ.4 ["នៅពេលដែលខ្ញុំធ្វើដំណើរឆ្លងកាត់បន្ទាយ សេអ៊ុ យោធាទាំងនោះបានទម្លាក់អាវុធរួចហើយទៅហើយ។ ដោយពួកគេដឹងអំពីការដួលរលំនៅភ្នំពេញ។ [...] នៅពេលនោះ ពុំមានការចាប់ចងពួកគេទេ។ តាមការដឹងរបស់ខ្ញុំ គឺយោធាតំបន់ជាអ្នកគ្រប់គ្រងទាហានដែលបានទម្លាក់អាវុធ"]។ ឯកសារ D54/119 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.3 ["ក្រោយពីគេយកពួកទាហាន លន់ នល់ ចេញពីបន្ទាយនោះអស់ កងទ័ពខ្មែរក្រហមមកកាន់កាប់បន្ទាយនោះ។ ខ្ញុំនៅចាំថា យូរៗម្តងគេហៅប្រជាជនឱ្យទៅចូលរួមមីទ្ទីងធំៗនៅក្នុងបន្ទាយសេអ៊ុ"]។ ឯកសារ D114/2 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.12 ["សេអ៊ុ គឺជាអតីបន្ទាយទាហាន លន់ នល់។ ក្រោយមកខ្ញុំឮថា នៅសម័យខ្មែរក្រហម យោធាខ្មែរក្រហមរស់នៅកន្លែងហ្នឹង"]។

2667 ឯកសារ D54/119 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.4 ["[សាក្សីត្រូវបានគេប្រាប់] ថាអ្នកទាំងនោះត្រូវបានគេយកទៅសម្លាប់នៅកន្លែងមួយនៅខាងលើបន្ទាយសេអ៊ុ"]។ ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ឈុំ ឆ.60 ["ខាងសេអ៊ុហ្នឹង តាមខ្ញុំដឹងហ្នឹង វាជាកន្លែងអាពត យកមនុស្សទៅសម្លាប់ [...] ដល់ក្រោយឆ្នាំ១៩៧៩ ហ្នឹងឃើញគេទៅគាស់ខ្មោចយកមាស។ ឃើញឃើញដាក់ក្បាលខ្មោចនៅលើដី ពេញដីទាំងអស់"]។

2668 ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.9-10 ["មាស មុត គឺជាមេបញ្ជាការកងពលលេខ៣ ហើយគាត់គឺជាអនុរបស់ សុន សេន ដែលនៅសេនាធិការរបស់កងទ័ពជាតិ។ តំបន់ទឹកដីដែលស្ថិតនៅក្រោមបញ្ជារបស់ មាស មុត សាតសន្ទឹងតាំងពីទឹកសាប កងកេង រាម កំពង់សោម ហើយនិងកោះទាំងអស់នៅក្នុងសមុទ្រ។ កន្លែងតំបន់ទាំងអស់នេះ គឺហៅថាយោធា និងទាំងប្រជាជនស៊ីវិលដែលនៅក្នុងតំបន់របស់គាត់ ឧទាហរណ៍ បើគាត់សង្កេតឃើញថា គោ ឬសត្វពាហនៈស្គម ហើយមិនត្រូវបានថែទាំជិតដល់ល្អ គាត់នឹងចេញបញ្ជាឱ្យចាប់អ្នកដែលថែទាំគោទាំងនោះ [...] ស.10៖ នៅក្រោមបញ្ជា និងការគ្រប់គ្រងរបស់គាត់ ក៏មានសហករណ៍របស់ប្រជាជនស៊ីវិលមួយចំនួនដែរ។ សហករណ៍ទាំងនោះរួមមាន សហករណ៍ថ្មធំ អូរឬស្ស ឡឥដ្ឋ ស្នាច់ដែង ពូធឿង និងបឬស"]។ ឯកសារ D54/17 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.15 ["ស៖ តើលោកដឹងដោយរបៀបណាថា ការដ្ឋាននេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពល១៦៤? ឆ.15៖ ពីព្រោះមិនមានប្រធានវរសេនាធំណាមកពិនិត្យការងារនៅទីនេះទេ ប៉ុន្តែមេបញ្ជាការកងពល១៦៤ មាស មុត ក៏បានមកពិនិត្យការងារនៅទីនោះដែរ"]។ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ.250-253 ["ស៖ ចុះកងពលធំលេខ៣ ជាអ្នកគ្រប់គ្រងការដ្ឋានការងារទាំងអស់នៅជិតសហករណ៍របស់លោកស្រីមែនទេ? ឆ.250៖ ចាស។ ទាហានទាំងអស់ជាសមាជិករបស់កងពលធំនេះ។ ស៖ តើលោកស្រី

សភាពដីគោកនៅឃុំរាម និងបបុស ពីយើងមានវិធានការចំពោះខ្មាំងដែលបង សម្រេច វាមានរត់ចូលព្រៃ ៥ នាក់ ឥឡូវយើងតាមចាប់បានទាំងអស់។ [...] ខ្ញុំ មានវិធានការទាំងនយោបាយ និងសតិអារម្មណ៍ ហើយចំពោះចាត់តាំងបង្កើន យាមល្បាត តាមដានថែម[2669]។

663. សារទូរលេខដដែលបង្ហាញថា គេរាយការណ៍ទៅ **មាស មុត** ជាប់ជានិច្ច សូម្បីតែកម្មករម្នាក់ស្លាប់ក៏ដោយ និងអំពីរឿងលម្អិតតូចៗពាក់ព័ន្ធនឹងការវិវត្តនៃការធ្វើស្រែនៅក្នុងតំបន់[2670]។ លើសពីនេះទៀត ការគ្រប់គ្រងជិតដល់ និងការដែល **មាស មុត** បានដឹងឮអំពីគ្រប់បញ្ហាលម្អិតនៅការដ្ឋានរាម ត្រូវបានបង្ហាញនៅក្នុងកំណត់ហេតុកិច្ចប្រជុំក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដែលនៅមាន។ នៅក្នុងការប្រជុំមួយរបស់មេដឹកនាំកងពល **មាស មុត** បានរាយការណ៍អំពីបរិមាណ ប្រភេទស្រូវ ក៏ដូចជាកាលបរិច្ឆេទស្ទូង ច្រូតកាត់ ប្រមូលផល និងដឹកជញ្ជូន[2671]។ កំណត់ហេតុប្រជុំរបស់កងពល

---

មានដឹងថា ឈ្មោះកងពលធំលេខ៣ ត្រូវបានប្តូរដែរឬទេ? ឆ.251៖ អត់ទេ។ ស៖ លោកស្រីមានដឹងថា កងពលធំលេខ ៣ ក្រោយមកផ្លាស់ប្តូរទៅជាកងពល ១៦៤ ទេ? ឆ.252៖ ចាស ដឹង ជាកងពលដដែល។ ស៖ តើលោកស្រីដឹងដោយរបៀបណា? ឆ.253៖ ខ្ញុំឮថា កងពលនេះ លែងហៅថា កងពលលេខ៣ ទៀតហើយ។ ហើយគេហៅថា កងពល ១៦៤ វិញ"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.19-20 ["ប្រធានកងវរសេនាតូច២០របស់ខ្ញុំឈ្មោះ បងថន ឯកងវរសេនាតូច២១ ខ្ញុំមិនស្គាល់ទេ។ កងវរសេនាតូចទាំងពីរនេះស្ថិតក្រោមការគ្រប់គ្រងរបស់កងពល១៦៤។ ស៖ ហេតុដូចម្តេចបានជាលោកដឹងរឿងនេះ? ឆ.20៖ ពីព្រោះមេបញ្ជាការបានប្រកាសក្នុងពេលប្រជុំថា កងរបស់យើងស្ថិតនៅក្រោមការត្រួតត្រារបស់កងពល"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.166 ["ស៖ កងផលិតហ្នឹងជាផ្នែកមួយនៃកង ១៦៤ ហ្នឹងឬ? ឆ.166៖ បាទ តែពួកហ្នឹងភាគច្រើនជាពួកពីកង ៣៨៦"]។

2669 ឯកសារ D4.1.699 ទូរលេខ ១១ ពី ឌឹម ជូនបងមុត ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00092628 [គូសបញ្ជាក់បន្ថែម"]។

2670 ឯកសារ D4.1.699 ទូរលេខ ១១ ពី ឌឹម ជូនបងមុត ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00092628 ["សភាពការណ៍យើង យុទ្ធជននៅកង៦២ ធ្វើស្រែ ទៅធ្វើស្រែម្ដុំចម្ការដូង ពលីម្នាក់ ដោយសារលង់ទឹក ប៉ុន្តែមូលហេតុពិនិត្យមិនទាន់ច្បាស់ [...] សភាពស្រូវនៅគ្រប់កន្លែង មានការរីកចម្រើន តែនៅកងកេងមានទឹកជ្រៅ១២ហិចតា ប៉ុន្តែបងប្អូនកំពុងប្រយុទ្ធសង្គ្រោះ ហើយចំពោះដីចម្ការកាប់ហើយតាមផែនការកំណត់ភ្ជួរហើយមួយសា ប៉ុន្តែត្រូវភ្ជួររាល់ទៀត"]។

2671 ឯកសារ D1.3.27.18 កំណត់ហេតុកិច្ចប្រជុំរបស់យោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភាររបស់កងពល និងវរសេនាធំ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00052391 ["មកដល់ថ្ងៃ ២០ ខែ ៨ បានស្ទូងហើយអស់ ទាំងស្រូវស្រាល ទាំងស្រូវធ្ងន់។ ស្រូវស្រាលដល់ថ្ងៃ ៣០ ខែ ៨ ច្រូតបាន៣០ ហិចតា ផលបាន៥០ថាំង ១ហិចតា ស្រូវកណ្តាលធ្វើបានជិត៣០០ហិចតា ប្រហែលថ្ងៃ ១០ ខែ ១០ នឹងចេញអស់។ ស្រូវធ្ងន់ ស្ទូងហើយ

១៦៤ ផ្សេងៗ ផ្ទុះបញ្ចាំងពីការពិភាក្សាអំពី "ប្រជាជនមូលដ្ឋានកងកេង មានសកម្មភាពប្លែកផ្សេងៗ" ក៏ដូចជាការចាប់ខ្លួនបុគ្គលដែលត្រូវរកឃើញថាជាអតីតយោធា លន់ នល់[2672] ហើយកំណត់ហេតុប្រជុំរបស់កងទ័ពបដិវត្តកម្ពុជាបង្ហាញថា **មាស មុត** មានវត្តមានពេល ឌឹម អនុរបស់គាត់ បានរាយការណ៍អំពីការចាប់ខ្លួននៅតំបន់កងកេង[2673]។ កំណត់ហេតុប្រជុំក៏បានបង្ហាញផងដែរថា **មាស មុត** បានរាយការណ៍ អំពី "ចោរកម្ម" នៅកងកេង[2674] និងការដាក់ពង្រាយកងកាំភ្លើងធំនៅរាម និងកងកេង[2675]។

664. ចំណេះដឹងលម្អិតនេះគឺស្របនឹងការណែនាំរបស់ សុន សេន ទៅមេដឹកនាំកងពល៖ "ត្រូវចុះឲ្យជាប់ ដឹកនាំមិនមែនចុះតែក្នុងប្រជុំទេ ត្រូវចុះឲ្យដល់ស្រែ ដល់ស្រូវ ដល់ម៉ាស៊ីនបូមទឹក។ ចុះឲ្យឃើញផង ស្តាប់សេចក្តីរាយការណ៍ផង ទើបសរុបបទពិសោធន៍បានច្បាស់"[2676]។ ហើយពិតណាស់ **មាស**

---

ទាំងកងទ័ព និងប្រជាជន ទំហំគឺ ១.៦០០ហិចតា។ កម្លាំងមនុស្សទាំងប្រជាជនទាំងកងទ័ព ១៧.០០០នាក់។ ផលស្រូវគិត២តោនស្មើ ក្នុងដី២.០០០ហិចតា ត្រូវខ្វះ៦១.០០០ថាំង"]។ សូមមើលផងដែរ ឯកសារ D1.3.27.22 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំគណៈកងពលពេញអង្គ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ KH ERN 00088929 [បង្ហាញថា មាស មុត រាយការណ៍លម្អិតអំពីទិន្នផលស្រូវ]។

2672 ឯកសារ D1.3.8.4 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំសមមិត្ត ១៦៤ KH ERN 00162489 ["ខាងគោក៖ ចូលខែ៩មក ប្រជាជនមូលដ្ឋានកងកេង មានសកម្មភាពប្លែកផ្សេងៗ៖ ឧទាហរណ៍៖ កាប់យកសាច់ក្របីមួយដុំ យកដុំថ្មដាក់ក្នុងឡាឥដ្ឋ និងសកម្មភាពលួចកើនច្រើន។ នៅក្នុងប្រជាជននេះ ភាគច្រើនល្អ តែទាហានមានចលនាមិនល្អ។ កន្លងមក រកឃើញទាហានស័ក្តិ២ ពីរនាក់ បានចាប់ហើយ"]។

2673 ឯកសារ D1.3.27.20 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃកិច្ចប្រជុំលេខា និងអនុលេខា និងវរសេនាធំឯករាជ្យ ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៧៦ KH ERN 00052404-05។

2674 ឯកសារ D1.3.27.18 កំណត់ហេតុកិច្ចប្រជុំរបស់យោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភារ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00052391 ["នៅកងកេង មានលេចសកម្មភាពលួច ច្រើនលេចចេញពីសមាសភាពទាហាន"]។

2675 ឯកសារ D1.3.8.3 កំណត់ហេតុកិច្ចប្រជុំរបស់យោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃអង្គប្រជុំការងារយោធានៅកំពង់សោម ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ១៩៧៦ KH ERN 00021496 ["I. សេចក្តីរាយការណ៍អំពីសភាពការណ៍យោធា៖ មិត្តមុត៖ ១. ការរៀបចំកម្លាំងការងារ៖ ក. កម្លាំងអាយុនៅជុំវិញកំពង់សោម លើដីគោក៖ នៅក្នុងក្រុងកំពង់សោម មានកាំភ្លើងធំ១០៥ម.ម ៤ដើម កាំភ្លើង៤០ម.ម ១ដើម កាំភ្លើង៣៧ម.ម ៦ដើម ១២.៧ម.ម ពីរដើម។ នៅរាម និងកងកេង មានកាំភ្លើងធំ ១០៥ ម.ម ៣៧ម.ម និង ១២.៨ម.ម ទាំងអស់៦ដើម"]។

2676 ឯកសារ D1.3.27.18 កំណត់ហេតុកិច្ចប្រជុំរបស់យោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភាររបស់កងពល និងវរសេនាធំ ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00052400។

**មុត** ទំនងជាធ្វើដំណើរជារឿយៗទៅតំបន់រាម[2677] ដើម្បីមើលការដ្ឋាន[2678] និងសហករណ៍[2679]។ ក្នុងអំឡុងពេលទស្សនកិច្ចខ្លះ **មាស មុត** ទំនងជាធ្វើសុន្ទរកថានៅក្នុងការប្រជុំធំៗជិតព្រលានយន្តហោះកងកេង ដែលគាត់ទំនងជាបានអាន "ចម្លើយសារភាព" របស់ "ជនក្បត់"[2680]។ អ្នកចូលរួមប្រជុំម្នាក់ ជាកម្មាភិបាលរំសាយ រៀបរាប់ថា៖ "គាត់ [មាស មុត] បញ្ជូនពួកខ្ញុំទៅកងផលិត ពេល

[2677] ឯកសារ D114/68 កំណត់ហេតុស្ដាប់ចម្លើយ គុយ សម្បត្តិ ឆ.5 ["នៅក្នុងរបបខ្មែរក្រហម ផ្ទះរបស់ខ្ញុំស្ថិតនៅជិតវាលយន្តហោះកងកេង។ [...] មាស មុតមកហូបបាយផ្ទះខ្ញុំញឹកញាប់"]។

[2678] ឯកសារ D54/17 កំណត់ហេតុស្ដាប់ចម្លើយ សយ ប៊ិន ឆ.15 ["ស៖ តើលោកដឹងដោយរបៀបណាថា ការដ្ឋាននេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពល១៦៤? ឆ.15៖ ពីព្រោះមិនមានប្រធានវរសេនាធំណាមកពិនិត្យការងារនៅទីនេះទេ ប៉ុន្តែមេបញ្ជាការកងពល១៦៤ មាស មុត ក៏បានមកពិនិត្យការងារនៅទីនោះដែរ"]។ ឯកសារ D114/53 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុក សុក ឆ.224 ["ឮតែគេថា តាមុត នឹងមកមើលការដ្ឋាន។ ជួនកាល ខ្ញុំឮគេនិយាយថា គាត់កំពុងឈរនៅលើផ្លូវជាតិ"]។

[2679] ឯកសារ D59/1/4.25 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡុង លី KH ERN 00930812 ["ស៖ [...] មាស មុត នៅក្នុងកងពលអ៊ីចឹង តែគាត់មើលការខុសត្រូវដល់សហករណ៍ដែរ? ឆ៖ ចាស គាត់ចុះមកមើលម្ដងៗខ្លះខាតអី ខ្វះខាតអីក៏យើងប្រាប់ទៅ ហើយយើងប្រធានហ្នឹង យើងមើលទៅ ខ្វះខាតអីយើងធ្វើជាក្រដាសស្នើទៅ ហើយឲ្យយកមក"]។

[2680] ឯកសារ D54/102 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.1 ["នៅពេលនោះ គេបានដកយោធាកង៣៨៦ ទាំងអស់យកទៅដាក់នៅកងផលិត។ បន្ទាប់ពីគេដកអាវុធពីពួកយើងអស់ ពួកគេមិនអនុញ្ញាតឲ្យយើងទុកកាំបិតទេ យើងគឺអនុញ្ញាតឲ្យកាន់តែចប។ បន្ទាប់មក មាស មុត បានមកធ្វើមីទ្ទីងជាមួយពួកយើងនៅភូមិគគីរ នៅជិតប្រលានយន្តហោះកងកេង ដោយមានអតីតយោធាចូលរួមប្រហែលរាប់ពាន់នាក់ ដោយមានកងវរសេនាតូច៣៨៦ និងកងផ្សេងៗទៀត។ នៅក្នុងអង្គប្រជុំ មាស មុត អានចម្លើយសារភាពរបស់ពួកក្បត់ គាត់បានរៀបរាប់ឈ្មោះកម្មាភិបាលក្បត់ចាប់ពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់មូលដ្ឋាន"]។ ឯកសារ D114/89 កំណត់ហេតុស្ដាប់ចម្លើយ សេង ស៊ីន ឆ.56, 60-61 ["ស៖ លោកនិយាយថា ពេលដែលលោកទៅដល់ដីគោក គេប្រជុំម្ដងទៀត។ តើការប្រជុំនោះ នៅទីណា ហើយពេលណា? ឆ.56៖ គេបញ្ជូនមកហ្នឹង ឈប់នៅព្រលានយន្តហោះកងកេង ហើយគេប្រជុំពេលព្រឹកហ្នឹង។ ហើយ មាស មុត ជាប្រធានអង្គប្រជុំ។ [...] ឆ.60៖ មាស មុត ប្រជុំពីបញ្ហាមេក្បត់គឺអនុមេបញ្ជាការកងពល ១៦៤ នង ឆាន ជាអ្នកក្បត់ ហើយ មាស មុត អានចម្លើយសារភាពរបស់ នង ឆាន ហ្នឹង។ [...] ឆ.61៖ គាត់អត់និយាយអ្វីទៀតទេ គាត់បញ្ជូនពួកខ្ញុំទៅកងផលិតពេលប្រជុំចប់។ កងហ្នឹងដូចអ្នកទោសអ៊ីចឹង គឺគ្មានអាវុធ"]។ ឯកសារ D114/89 កំណត់ហេតុស្ដាប់ចម្លើយ សេង ស៊ីន ឆ.56, 60, 63 ["គេបញ្ជូនមកហ្នឹង ឈប់នៅព្រលានយន្តហោះកងកេង ហើយគេប្រជុំពេលព្រឹកហ្នឹង។ ហើយ មាស មុត ជាប្រធានអង្គប្រជុំ។ [...] ឆ.60៖ មាស មុត ប្រជុំពីបញ្ហាមេក្បត់គឺអនុមេបញ្ជាការកងពល ១៦៤ នង ឆាន ជាអ្នកក្បត់ ហើយ មាស មុត អានចម្លើយសារភាពរបស់ នង ឆាន ហ្នឹង។ [...] ឆ.63៖ ចាំបានត្រង់គាត់និយាយពីចម្លើយសារភាពរបស់ពួកក្បត់ និយាយពី នង ឆាន និង មេៗរបស់ខ្ញុំទាំងពីរនាក់ហ្នឹង។ មេខ្ញុំគាត់មិនបានសារភាពទេ។ មាស មុត គ្រាន់តែនិយាយថា ពួកគាត់ក្បត់"]។

ប្រជុំចប់។ កងហ្នឹងដូចអ្នកទោសអ៊ីចឹង គឺគ្មានអាវុធ គេឲ្យធ្វើចម្ការ លើកដីបង្កបង្កើនផល ដូចប្រជាជនធម្មតាអ៊ីចឹង"[2681]។ ក្នុងពេលប្រជុំ **មាស មុត** បានហៅឈ្មោះដាក់លាក់របស់កម្មាភិបាលដែលឈរជើងនៅកងកេង និងត្រូវគេចោទប្រកាន់ថាជាជនក្បត់។ **មាស មុត** បាននិយាយថា យឺន ស្នងការកងវរសេនាធំនៅកងកេង "បានជេរចលនាបដិវត្តន៍យើង ដោយនិយាយថា ចលនាបដិវត្តន៍យើងនេះ គឺជាចលនាបដិវត្តន៍អណ្តាតភ្លើង និងបដិវត្តន៍សម្រែកឈាម"[2682]។ ស្រដៀងគ្នានេះដែរ **មាស មុត** បានប្រកាសថា អ៊ឹង វ៉េត មេបញ្ជាការកងវរសេនាតូច ៦៣១ ប្រចាំការនៅព្រលានយន្តហោះកងកេង "ក្បត់"[2683]។ ក្រោយមក អ៊ឹង វ៉េត ត្រូវគេចាប់ខ្លួន[2684] និងបញ្ជូនទៅ ស-២១[2685]។

665. **មាស មុត** ក៏ធ្លាប់បានដឹកនាំការប្រជុំ ដែលក្នុងពេលនោះ គាត់បានកំណត់ថាកម្មាភិបាលភូមិភាគបូព៌ាជាកម្មាភិបាលដែលត្រូវរំសាយ ពីព្រោះពួកគេត្រូវបានចាត់ទុកថា "ទាហានសមាសភាពមិនល្អ" ហើយបន្ទាប់មក កម្មាភិបាលទាំងនោះត្រូវបានបញ្ជូនទៅកងផលិត នៅការដ្ឋានតំបន់រាម[2686]។

---

2681 ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.61។

2682 ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.6 ["មាស មុត លើកនៅក្នុងអង្គប្រជុំ ខ្ញុំឮគាត់និយាយថា មានម្នាក់ឈ្មោះ យឺន ដែលហ៊ានប្រឆាំងជាមួយនឹងបក្សយើង។ មាស មុត និយាយថា យឺនបានជេរចលនាបដិវត្តន៍យើង ដោយនិយាយថា ចលនាបដិវត្តន៍យើងនេះ គឺជាចលនាបដិវត្តន៍អណ្តាតភ្លើង និងបដិវត្តន៍សម្រែកឈាម។ យឺន គឺជាស្នងការកងវរសេនាធំនៅកងកេង"]។

2683 ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.3 ["ស៖ តើលោកប្រាប់យើងបានទេថា [...] លោកបានគូសរង្វង់នៅលើឈ្មោះ គង់ គៀន ហៅ អ៊ឹង វ៉េត នៅក្នុងជួរបន្ទាត់កន្លែងអ្នកឆ្លើយដាក់? ឆ.3៖ តាមដែលខ្ញុំចាំ វ៉េត គឺជាប្រធានវរសេនាតូច៦៣១ តែនៅពេលនោះខ្ញុំនៅកងវរសេនាតូច៦២៣ [...] តាមុត ប្រជុំប្រាប់អំពីចម្លើយសារភាព ហើយតាមុត បានប្រកាសថា វ៉េត ក្បត់ហើយ"]។

2684 ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.3 ["ស៖ តើលោកប្រាប់យើងបានទេថា [...] លោកបានគូសរង្វង់នៅលើឈ្មោះ គង់ គៀន ហៅ អ៊ឹង វ៉េត នៅក្នុងជួរបន្ទាត់កន្លែងអ្នកឆ្លើយដាក់? ឆ.3៖ [...] វ៉េត នៅកងទ័ពជើងគោក មានទីតាំងនៅព្រលានយន្តហោះកងកេង ហើយគាត់ត្រូវបានចាប់ខ្លួន"]។

2685 ឯកសារ D114/230.1.1 បញ្ជីអ្នកទោស ស-២១ របស់ ក.ស.ច.ស EN ERN 01222427 [បង្ហាញថា លេខរៀង ២៣៦៨ ឈ្មោះជា គង់ គៀន ហៅ អ៊ឹង វ៉េត លេខាវរសេនាតូច៦៣១ ចូលស-២១ ក្នុងខែ មេសា ឆ្នាំ ១៩៧៧]។

2686 ឯកសារ D54/44 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.19, 22 ["ហេតុអ្វីបានជាលោកដឹងថា យោធាមានយោធា ១៥០០នាក់មកពីភូមិភាគបូព៌ា គេយកទៅដាក់នៅកងផលិត? ឆ.19៖ ប្រធានកងពល មាស មុត បានបើកការប្រជុំ ហើយប្រកាសថា ពួកយោធាទាំងអស់ដែលមកពីភូមិភាគបូព៌ា គឺជាយោធាដែលមានសមាសភាពមិនល្អ ដូច្នេះពួកគេត្រូវតែដកចេញឲ្យដាច់ពីកងពល [...] ស៖ កាលដែលកងពលបើកវគ្គរៀនសូត្រ ហើយប្រកាសប្រាប់ថា ពួកយោធាភូមិភាគបូព៌ា ជាសមាសភាពមិនល្អ តើលោកនៅទីនោះដែរឬទេ? ឆ.22៖ ខ្ញុំបានចូលរួមការប្រជុំដែរ បានខ្ញុំដឹង"]។

យោងតាមសាក្សីនោះ មានតែ **មាស មុត** ទេដែលទំនងជាមានសិទ្ធិអំណាចក្នុងការបញ្ជូនកម្មាភិបាលភូមិភាគបូព៌ាចំនួន ១៥០០ នាក់ ទៅកងផលិតដ៏ធំ នៅការដ្ឋានរាម[2687]។ អតីតកម្មាភិបាលម្នាក់បាននិយាយថា បញ្ជាឱ្យរំសាយកងទ័ពដែលជាប់សង្ស័យ "ច្បាស់ជាចេញមកពីតាមុត ហើយពួកគេជាមនុស្សរបស់តាមុត ដែលប្រមូលផ្តុំឱ្យពួកយើងប្រជុំ ហើយប្រាប់ពួកយើងថា នឹងត្រូវបញ្ជូនទៅតាមការដ្ឋានខុសៗគ្នា"[2688]។

666. ឈ្មោះរបស់ **មាស មុត** ត្រូវបានអ្នកគ្រប់គ្រងលើកឡើងជាញឹកញាប់នៅក្នុងការប្រជុំពិភាក្សាអំពីការងារ ដែលត្រូវអនុវត្តនៅការដ្ឋានរាម[2689]។ មេដឹកនាំបានបញ្ជាក់ថា "បញ្ជា **មាស មុត** ត្រូវតែធ្វើតាម ត្រូវតែអនុវត្តតាម ត្រូវតែគោរព បើមិនដូច្នោះទេ អាចនឹងមានបញ្ហាកើតឡើង"[2690]។ ប្រធាន

---

[2687] ឯកសារ D54/45 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.16 ["សៈ ក្រៅពីប្រធានកងពល មាស មុត តើមានអ្នកណានៅក្នុងកងពលមានសិទ្ធិ ឬក៏សម្រេចបញ្ជូនពួកយោធាចេញពីកងពលទៅកងផលិតដែរឬទេ? ឆ.16៖ អត់មានទេ"]។

[2688] ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.93។ សូមមើលផងដែរ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.95 ["មានការប្រជុំធំមួយ ដែលគ្រប់គ្នាត្រូវតែចូលរួម ហើយក្នុងការប្រជុំនោះ គេចាត់តាំងឱ្យអង្គភាពនេះ ឬក៏ការដ្ឋាននោះទៅធ្វើការនៅតាមការដ្ឋាននេះ ការដ្ឋាននោះ។ បន្ទាប់មកទៀត មានការប្រជុំតូចៗនៅតាមការដ្ឋាននោះផ្ទាល់តែម្តង ដើម្បីទទួលការណែនាំអំពីការងារ"]។

[2689] ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.153, 164-165 ["គេប្រជុំនិយាយអំពីផែនការ គេឱ្យយើងលើកប្រឡាយ ដាំដំណាំ ពង្រឹងជំហរ។ ក្នុងរយៈពេល ២ ឬ៣ អាទិត្យ គេលើកឈ្មោះតាមុត មកនិយាយម្តង [...] ឆ. 164៖ ការប្រជុំក្នុងចំណោមប្រជាជនធម្មតា គឺមិនមានលើកពីឈ្មោះតាមុត ទេ។ តែបើការបើកការប្រជុំក្នុងចំណោមកម្មាភិបាល គេលើកពីឈ្មោះតាមុត។ ខ្ញុំដឹងរឿងនេះ ព្រោះខ្ញុំធ្វើការនៅចម្ងាយប្រហែលកន្លះគីឡូម៉ែត្រពីកន្លែងប្រជុំ [...] ឆ.165៖ ការប្រជុំរវាងកម្មាភិបាលធ្វើឡើងនៅក្នុងអគារ ហើយគេនិយាយដាក់មីក្រូ ដោយខ្ញុំធ្វើការនៅក្បែរនោះ ខ្ញុំបានឮគេនិយាយឈ្មោះគាត់នៅក្នុងកិច្ចប្រជុំនោះ"]។ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.162, 164-165 ["សៈ ក្នុងពេលស្នាក់នៅភូមិគគីរ តើលោកស្រីបានចូលរួមការប្រជុំដែរឬទេ? ឆ.162៖ ចាស មានការប្រជុំ៥ថ្ងៃម្តង។ [...] សៈ តើគេមាននិយាយអំពីឈ្មោះតាមុត ដែរឬទេ នៅក្នុងការប្រជុំទាំងនោះ? ឆ.164៖ ការប្រជុំក្នុងចំណោមប្រជាជនធម្មតា គឺមិនមានលើកពីឈ្មោះតាមុត ទេ។ តែបើការបើកការប្រជុំក្នុងចំណោមកម្មាភិបាល គេលើកពីឈ្មោះតាមុត។ ខ្ញុំដឹងរឿងនេះ ព្រោះខ្ញុំធ្វើកានៅចម្ងាយប្រហែលកន្លះគីឡូម៉ែត្រពីកន្លែងប្រជុំ។ សៈ តើលោកស្រីឮគេនិយាយឈ្មោះតាមុត យ៉ាងម៉េចខ្លះ និងដោយរបៀបណា? ឆ.165៖ ការប្រជុំរវាងកម្មាភិបាលធ្វើឡើងនៅក្នុងអគារ ហើយគេនិយាយដាក់មីក្រូ ដោយខ្ញុំធ្វើការនៅក្បែរនោះ ខ្ញុំបានឮគេនិយាយឈ្មោះគាត់នៅក្នុងកិច្ចប្រជុំនោះ"]។

[2690] ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.153-154 ["សៈ លោកស្រីបាននិយាយថា បានចូលរួមប្រជុំរៀងរាល់ថ្ងៃ។ គេនិយាយអំពីឈ្មោះតាមុត ញឹកញាប់ដែរឬទេ នៅក្នុងពេលប្រជុំនោះ? ឆ.153៖ គេប្រជុំនិយាយអំពីផែនការ គេឱ្យយើងលើកប្រឡាយ ដាំដំណាំ ពង្រឹងជំហរ។ ក្នុងរយៈពេល ២ ឬ៣ អាទិត្យ គេលើកឈ្មោះតាមុត មក

សហករណ៍ម្នាក់បានប្រាប់សាក្សីម្នាក់ថា "តាមុតហ្នឹង គឺ 'អង្គការធំ' នៅកន្លែងហ្នឹង"[2691]។ **មាស មុត** ទំនងជាបានបញ្ជូននីរសារទៅប្រាប់ប្រធានសហករណ៍អំពីការប្រជុំដែលពួកគេត្រូវចូលរួមជាមួយគាត់[2692] មេភូមិបានប្រកាសក្នុងពេលប្រជុំថា ពួកគេបានជួប **មាស មុត** មួយខែម្ដង ដែលនៅពេលនោះ **មាស មុត** បានប្រាប់ពួកគេ "អំពីផែនការថ្មីរបស់អង្គការ"[2693] ហើយប្រធានសហករណ៍ទំនងក៏បានជួប គឹម ញ៉ន ជាមេដឹកនាំកងវរសេនាធំលេខ ៦៣[2694] ដែលទំនងធ្វើជាអ្នកនាំដំណឹងឱ្យ **មាស មុត**[2695]។

667. លើសពីនេះទៀត **មាស មុត** និងអ្នកផ្សេងទៀតទាំងអស់ដែលបានធ្វើដំណើរពីក្រុងកំពង់សោមទៅប៉ែកខាងកើត រួមទាំងភ្នំពេញ តាមផ្លូវត្រង់ជាងគេ គឺផ្លូវជាតិលេខ ៤ ទំនងជាបានឃើញយ៉ាងប្រាកដណាស់នូវការដ្ឋានជាច្រើននៅតំបន់រាម។

---

និយាយម្ដង។ សះ តើគេនិយាយអ្វីខ្លះពីតាមុត? ឆ.154៖ គេនិយាយថា បញ្ជាតាមុត ត្រូវតែធ្វើតាម ត្រូវតែអនុវត្តតាម ត្រូវតែគោរព បើមិនដូច្នោះទេអាចនឹងមានបញ្ហាកើតឡើង"]។

[2691] ឯកសារ D114/179 កំណត់ហេតុស្ដាប់ចម្លើយ សួន ឈុំ ឆ.14 ["ប្រធានសហករណ៍គេថា តាមុត ហ្នឹងគឺអង្គការធំ នៅកន្លែងហ្នឹង។ ហ្នឹងគ្រាន់តែឮតាមរយៈតាឡូត ហ្នឹង មិនដែលឃើញមុខផង"]។

[2692] ឯកសារ D59/1/4.25 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឡុង លី KH ERN 00930812 ["ធ្វើការតែជាមួយគ្នា កន្លែងធ្វើការគាត់នៅឆ្ងាយពីយើងអ៊ីចឹងទៅ ហើយនៅសហករណ៍នេះ ដល់ពេលគាត់មានការអី គាត់ឱ្យនីសារគាត់យកសំបុត្រមកឱ្យ ថ្ងៃនេះយើងប្រជុំ ឬថ្ងៃនេះយើងអី ទៅតាមណាត់"]។

[2693] ឯកសារ D114/6 កំណត់ហេតុស្ដាប់ចម្លើយ យិន តេង ឆ.30-34 ["សះ តើអ្នកណាជាអ្នកដឹកនាំការប្រជុំ? ឆ.30៖ ប្រធានភូមិ។ សះ តើមេភូមិដឹកនាំប្រជុំរៀងរាល់ថ្ងៃឬ? ឆ.31៖ ចាស រៀងរាល់ថ្ងៃ។ តាមខ្ញុំដឹង មេភូមិទៅប្រជុំជាមួយតាមុត នៅកន្លែងគាត់រៀងរាល់ព្រឹក មុនពេលគាត់មកប្រជុំជាមួយយើងនៅតាមភូមិនៅម៉ោង១១ព្រឹក។ សះ តើលោកស្រីដឹងថា មេភូមិទៅប្រជុំជាមួយតាមុត ដោយសារអ្វី? ឆ.32៖ ពីព្រោះគេប្រាប់នៅពេលប្រជុំរាល់ថ្ងៃថា អង្គការឱ្យធ្វើនេះធ្វើនោះ។ សះ តើមេភូមិបាននិយាយថា គាត់បានចូលរួមប្រជុំជាមួយតាមុត ដែរឬទេ? ឆ.33៖ ចាស គេបានប្រកាសប្រាប់ពួកខ្ញុំថា គាត់បានប្រជុំជាមួយតាមុត និងប្រាប់អំពីផែនការថ្មីៗរបស់អង្គការ។ សះ តើមេភូមិ គាត់ប្រាប់ថាគាត់បានប្រជុំជាមួយតាមុត ដែរឬទេ? ឆ.34៖ ខ្ញុំមិនដឹងថា គេនិយាយការពិត ឬកុហកនោះទេ ដែលថាគាត់បានប្រជុំជាមួយតាមុត ១ខែម្ដង"]។

[2694] ឯកសារ D59/1/4.25 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡុង លី KH ERN 00930812 ["អ៊ំញ៉ាន់ ហ្នឹងគាត់វរសេនាធំ គាត់ទ័ព"]។

[2695] ឯកសារ D59/1/4.25 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡុង លី KH ERN 00930812 ["សះ អ៊ីចឹងមានការអីមកតាម អ៊ំញ៉ាន់ ហ្នឹងបាន អ៊ំញ៉ាន់ ទៅអ៊ំមុត? ឆះ ទៅអ៊ំមុត ទៀតទៅ"]។

668. សាក្សីជាច្រើនបានផ្តល់សក្ខីកម្មថា សារី និងឈឿន សមាជិកកងវរសេនាធំលេខ ៦៣ ជាអ្នកគ្រប់គ្រងធំនៅការដ្ឋានរាម[2696]។ ពួកគេតែងតែចុះមើលការដ្ឋាន អមដំណើរដោយអង្គរក្សប្រដាប់

---

[2696] ឯកសារ D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉េន ឆ.53 ["ស៖ តើអ្នកណាជាអ្នកគ្រប់គ្រងនៅទំនប់បិតត្រាំងហ្នឹង? ឆ.53៖ មានតែអាសែ អាឈឿន និងអាសាញ់។ គេហៅប្រមូលប្រជាជនទៅធ្វើការនៅម៉ោងបួន ប្រាំភ្លឺ"]។ ឯកសារ D54/91 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែម ឆ.5 ["មេបញ្ជាការយោធា ដែលដឹកនាំធ្វើការងារនៅតំបន់នេះ ឈ្មោះ ឈឿន។ គាត់គឺជាមនុស្សកាចសាហាវណាស់ គាត់ជាអនុកងវរសេនាធំ១៦៤"]។ ឯកសារ D114/20 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.41 ["ស៖ យើងទទួលបានព័ត៌មានថា កម្មាភិបាលយោធាឈ្មោះ សារី និង ឈឿន មានទីតាំងនៅនឹងកងកេង ហើយជាអ្នកត្រួតពិនិត្យលើគម្រោងទាំងនោះ។ តើលោកអាចពន្យល់ប្រាប់យើងបានឬទេ? ឆ.41៖ មានម្នាក់ទៀតឈ្មោះ ឈឿន ដែរ នៅនឹងកន្លែងនោះជាមួយ សារី"]។ ឯកសារ D54/92 កំណត់ហេតុស្តាប់ចម្លើយ យ៉ែម សំអុន ឆ.28 ["ស៖ តើនរណាជាអ្នកចាត់លោកទៅជួសជុលផ្លូវរថភ្លើង? ឆ.28៖ ឈឿន ប្រធានកងវរសេនាតូច ជាអ្នកបញ្ជូនខ្ញុំទៅជួសជុលផ្លូវរថភ្លើង"]។ ឯកសារ ឯកសារ D54/122 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.6-8 ["ខ្ញុំគ្រាន់តែដឹងថា ទាហានទាំងនេះស្ថិតនៅក្រោមបញ្ជារបស់ឈ្មោះ សារី និង ឈឿន។ សារី និង ឈឿន ជាកម្មាភិបាលយោធាខ្មែរក្រហម។ ពួកគេសុទ្ធតែជាកម្មាភិបាលមេៗគ្រប់គ្រងនៅស្នាច់ដែង រាម ទឹកសាប និងបិតត្រាំង។ អាចថាមានកម្មាភិបាលជាន់ខ្ពស់ទៀតដែរ តែខ្ញុំមិនស្គាល់ទេ ខ្ញុំស្គាល់តែពីរនាក់នេះឯង [...] កាលខ្ញុំធ្វើមន្ទីរពេទ្យនៅរាម នៅមុំអតីតចម្ការដូង ចេង ហេង ពេលនោះ សារី ក៏ជាកម្មាភិបាលតាមមើលការងារខ្ញុំដែរ។ [...] ស៖ ហេតុអ្វីបានជាលោកដឹងថា សារី និង ឈឿន ជាកម្មាភិបាលយោធាជាន់ខ្ពស់នៅទីនោះ? ឆ.7៖ ពីព្រោះពួកគាត់ជាអ្នករៀបចំប្រជុំ ដឹកនាំប្រជុំ ចេញបញ្ជា [...] ស៖ លោកបាននិយាយថា សារី និង ឈឿន ជាកម្មាភិបាលយោធា។ ហេតុអ្វីបានជាលោកនិយាយដូច្នេះ? ឆ.8៖ ពីព្រោះពួកគេជាអ្នកចេញបញ្ជា និងសម្រេចរាល់ការងារទាំងអស់នៅកន្លែងហ្នឹង"]។ ឯកសារ D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉េន ឆ.11 ["ស៖ តើលោកស្រីដឹងថា អ្នកណាគេជាអ្នកគ្រប់គ្រងការដ្ឋានបិតត្រាំង? ឆ.11៖ គេសម្លាប់អស់ហើយ គឺឈ្មោះ អាសែ អាឈឿន ក្រៅពីនេះខ្ញុំភ្លេចហើយ"]។ ឯកសារ D54/123 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.2-3 ["នៅពេលនោះគេបានប្រជុំ ហើយគេប្រាប់នៅក្នុងអង្គប្រជុំថា គេលុបបាត់ចោលវណ្ណៈអ្នកមានទាំងអស់ ទុលតែវណ្ណៈកម្មករ និងកសិករ។ សារី ជាអ្នកដឹកនាំកិច្ចប្រជុំ។ [...] ឆ.3៖ ការប្រជុំដែលដឹកនាំដោយ សារី ធ្វើឡើងនៅប៉ុន្មានថ្ងៃមុនព្រឹត្តិការណ៍ ដែលគេចាប់ពូរបស់ខ្ញុំទៅ គឺគេប្រជុំនៅវាលស្រែតែម្តង។ មានមួយលើកទៀត ពួកយើងត្រូវបានគេកោះហៅឲ្យទៅចូលរួមប្រជុំនៅវត្តបិតត្រាំង។ ដែលក្នុងពេលនោះ គេប្រាប់ពួកយើងថា យោធាខ្មែរក្រហមចាប់បានកប៉ាល់អាមេរិកាំងមួយឈ្មោះ ម៉ាយ៉ាហ្គេស"]។ សូមមើលផងដែរ ឯកសារ D114/16 កំណត់ហេតុស្តាប់ចម្លើយ សុក វណ្ណា ឆ.5 ["ឈ្មោះ សារី ជាមេបញ្ជាការកងវរសេនាធំ៣១ ផ្នែកជើងគោក ហើយឈរជើងនៅកងកេង"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ KH ERN 00955495 ["ស៖ ១៦៤ ហ្នឹងបែក[១៩]៧៥ ហើយបានមានកងពលហ្នឹង? ឆ៖ បាទ។ ស៖ អ៊ីចឹងកាលពូនៅកំពង់សោមហ្នឹងពូនៅកងហា កងវង ឬកងវរសេនាធំណាទៅ? ឆ៖ កាលជំនាន់ហ្នឹង ខ្ញុំជាយុទ្ធជន។ ស៖ តែយុទ្ធជនក្នុងកងណាទៅ? នៅកងវរសេនាតូច១៦២។ ស៖ កង១៦២ ហ្នឹងមានពីណាជាប្រធាន? ឆ៖ មានតា ឈឿន"]។ ឯកសារ D59/2/3.14a កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ KH ERN

ដោយអារុធ[2697]។ សារី បានដឹកនាំការប្រជុំនៅការដ្ឋានពិភាក្សាអំពីរបៀបដែលខ្មែរក្រហម "លុបបំបាត់ចោលវណ្ណៈអ្នកមានទាំងអស់ ទុកតែវណ្ណៈកម្មករ និងកសិករ"[2698]។ មាស អ៊ឹម ប្អូនប្រុសរបស់ **មាស មុត** ក៏មានសិទ្ធិអំណាចខ្លះៗទៅលើការដ្ឋានដែរ[2699] រីឯឡូញគ្រប់គ្រងការងារស្លដែកនៅវត្តបិតត្រាង[2700]។ ជាទូទៅ សាក្សីបានដឹងថា "មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម" ទំនងជាបានមក

---

00958276 ["កាលជំនាន់ហ្នឹង ខ្ញុំជាយុទ្ធជន។ សៈ តែយុទ្ធក្នុងកងណាទៅ? ឆៈ នៅកងវរសេនាតូច១៦២។ កង១៦២ ហ្នឹងមានពីណាជាប្រធាន? ឆៈ មានតា ឈឿន"]។

2697 ឯកសារ D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉េន ឆ.54 ["សៈ តើលោកស្រីដែលឃើញឈ្មោះ សៃ, ឈឿន និង សាញ់ នៅការដ្ឋានលើកទំនប់ស្ទឹងហ្នឹងដែរទេ? ឆ.54ៈ យើងធ្វើហ្នឹង វាដើរមើលអ៊ីចឹងទៅ។ ពួកវាសម្លាប់អស់ហើយ មិនដែលឃើញទេ"]។ ឯកសារ D54/122 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.6, 8 ["កាលគេបញ្ជូនខ្ញុំទៅធ្វើទំនប់ ដើម្បីទប់ទឹកប្រែនៅតាមបណ្តោយព្រែកទឹកសាប ខ្ញុំបានឃើញ សារី ទៅត្រួតពិនិត្យមើលការសាងសង់ទំនប់នោះដែរ [] កាលខ្ញុំធ្វើមន្ទីរពេទ្យនៅរាម នៅម្តុំអតីតចម្ការដូង ចេង ហេង ពេលនោះ សារី ក៏ជាកម្មាភិបាលតាមមើលការងារខ្ញុំដែរ។ សៈ លោកបាននិយាយថា សារី និង ឈឿន ជាកម្មាភិបាលយោធា។ ហេតុអ្វីបានជាលោកនិយាយដូច្នេះ? ឆ.8ៈ ពីព្រោះពួកគេជាអ្នកចេញបញ្ជា និងសម្រេចរាល់ការងារទាំងអស់នៅកន្លែងហ្នឹង។ ពួកគេមានកូនចៅស្ពាយកាំភ្លើងដើរអមរហូត នៅពេលពួកគេទៅត្រួតពិនិត្យការងារតាមការដ្ឋាន។ ពួកគេស្លៀកពាក់ខ្មៅ ដូចមនុស្សគ្រប់គ្នាដែរ នៅពេលនោះ តែពួកគេពាក់មួយយោធាពណ៌អាចម៍សេះ"]។

2698 ឯកសារ D54/123 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.2។

2699 ឯកសារ D114/58 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.14, 16 ["ខ្ញុំមិនច្បាស់ថាអង្គភាពកម្រិតណាទេ ប៉ុន្តែខ្ញុំគិតថាទំនប់នេះស្ថិតក្រោមការគ្រប់គ្រងរបស់កងពល១៦៤។ ខ្ញុំនិយាយដូច្នេះ ដោយសារតែតំបន់ទំនប់នេះស្ថិតក្រោមការគ្រប់គ្រងរបស់កងពល១៦៤។ ខ្ញុំដឹងផងដែរថា ឈ្មោះ មាស អ៊ឹម ជាអ្នកទទួលខុសត្រូវផ្នែកភស្តុភារ។ តាមពិតខ្ញុំមិនដឹងថាពាក្យភស្តុភារនេះមានន័យថាម៉េចនោះទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថា ឈ្មោះ មាស អ៊ឹម នេះជាអ្នកមើលការខុសត្រូវទំនប់នេះ។ មាស អ៊ឹម មិនត្រឹមតែជាអ្នកទទួលខុសត្រូវទំនប់នេះទេ គាត់ជាអ្នកមើលនៅការដ្ឋាននៅកងកេង (ការដ្ឋានស្រែ និងការដ្ឋានទំនប់ពូធឿង) ផងដែរ ហើយគាត់ជាអ្នកទទួលខុសត្រូវផ្នែកភស្តុភារនៅតំបន់នេះ។ [...] ឆ.16ៈ នៅឆ្នាំ១៩៧៧ បន្ទាប់ពីខ្ញុំរៀនចប់នៅកំពង់សោម និងមុនពេលដែលគេបញ្ជូនខ្ញុំទៅកងកេង។ មាស អ៊ឹម ជាអ្នកទទួលខុសត្រូវគ្រប់ការដ្ឋានទាំងអស់ រួមទាំងការដ្ឋាននៅកងកងផង"]។ ឯកសារ D54/20 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.14 ["ខ្ញុំទៅធ្វើស្រែនៅកងចល័តស្ថិតក្រោមតាអ៊ឹម។ តាអ៊ឹម ជាកម្មាភិបាលជាន់ខ្ពស់បន្ទាប់ពី មាស មុត។ អ៊ឹម ជាអ្នកមើលការងារនៅការដ្ឋានកងកេង ហើយគាត់ជាអនុមេបញ្ជាការកងពល១៦៤ ទទួលបន្ទុកភស្តុភារ"]។

2700 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.14-15 ["សៈ នៅទីតាំងនេះ យើងបានសួរលោកថា "នរណាជាអ្នកទទួលខុសត្រូវនៅកន្លែងស្លដែកនៅក្នុងវត្តនោះ?" លោកបានឆ្លើយថា "ប្រហែលជាតាឡូញ"។ ហេតុអ្វីបានជាលោកដឹងរឿងនេះ? ឆ.14ៈ ពីព្រោះតា ឡូញ ទៅមកៗក្នុងវត្តនេះ ដើម្បីត្រួតពិនិត្យការងារនៅទីនោះ។ តាឡូញជាអ្នកទទួលខុសត្រូវភស្តុភារនៅកងពលលេខ៣។ សៈ ហេតុអ្វីបានជាលោកស្គាល់តាឡូញ? ឆ.15ៈ ព្រោះខ្ញុំទៅជួបគាត់ដោយផ្ទាល់ ជូនកាលនៅកំពង់សោម ដើម្បីសុំស៊ីម៉ង់ត៍ ឥដ្ឋ និងរបស់របរផ្សេងៗទៀតដែលត្រូវការ"]។ ឯកសារ

ត្រួតពិនិត្យការដ្ឋានសង់ទំនប់ និងបានដាក់កាលកំណត់ដែលត្រូវសម្រេចការងារ ប៉ុន្តែមិនច្បាស់ថាពួកគេជាអ្នកណានោះទេ[2701]។

669. សហករណ៍នីមួយៗមានប្រធានម្នាក់[2702] ដែលជារឿយៗ ជាប្រពន្ធរបស់កម្មាភិបាលខ្មែរក្រហម[2703] ហើយប្រធានសហករណ៍ ជារឿយៗ តែងតែថា សេចក្តីសម្រេច និងការណែនាំចេញពីអង្គការ។ "តាឡូញតែងតែលើកពាក្យអង្គការថា អង្គការចង់ឱ្យបងប្អូនលើកទំនប់ ឬធ្វើនេះ ធ្វើ

---

D54/100 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ុនហាក់ ឆ.22 ["ឡូញ ជាប្រធានកម្មករនៅកំពង់ផែកំពង់សោម និងជាអ្នកគ្រប់គ្រងកំពង់ផែកំពង់សោម"]។

2701 ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.202-204 ["ស៖ តើមានថ្នាក់ដឹកនាំជាន់ខ្ពស់ខ្មែរក្រហមចុះមកមើលទំនប់ទេ? ឆ.202៖ មាន តែខ្ញុំមិនអាចចំណាំបាន ហើយក៏មិនស្គាល់ឈ្មោះពួកគេដែរ។ ស៖ តើពួកគេចុះមកមើលទំនប់ហ្នឹងប៉ុន្មានដង? ឆ.203៖ ប្រហែលពីរទៅបីដង។ ស៖ តើគេធ្វើអ្វីខ្លះពេលគេចុះមកនោះ? ឆ.204៖ គេមកវាស់វែងហើយ ហើយគេកំណត់ចំនួនថ្ងៃឱ្យយើងធ្វើឱ្យហើយ"]។

2702 សូមមើល ឧទាហរណ៍ ឯកសារ D59/1/4.25 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡុង លី KH ERN 00930793 ["គ្រួសាររបស់ខ្ញុំឈ្មោះ មូល អឿន"], KH ERN 00930799-801 ["ជួបមុនដំបូងនៅពូធឿង។ [...] ដល់ពេលអ៊ីចឹង គេឱ្យគាត់ទៅនៅកាន់សហករណ៍ ប្រធានសហករណ៍ពូធឿង [...] ៧៧ គាត់ទៅបូព៌ាហើយ [...] មានប្រធានគេ ១-២ ដឹកនាំយើងបន្ត"]។ សូមមើលផងដែរ ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ឆ .234, 286 ["សហករណ៍ស្នាច់ដែង ហើយសមាជិកឈ្មោះ ខិន (ប្រុស)។ ខ្ញុំមិនចាំឈ្មោះ ប្រធាន និងអនុប្រធានសហករណ៍នោះទេ [...] ឆ.286៖ ពិន ជាប្រធានសហករណ៍ស្នាច់ដែង ហើយអនុឈ្មោះ ខិន"]។ ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.1 ["កាលពីពេលនោះ សហករណ៍របស់យើងស្ថិតក្រោមការគ្រប់គ្រងរបស់គណៈតំបន់។ ខ្ញុំមិនដឹងថា អ្នកណាខ្លះជាសមាជិករបស់គណៈតំបន់នោះឡើយ ប៉ុន្តែមានម្នាក់ឈ្មោះ តាឌឹម និងម្នាក់ទៀតឈ្មោះ តាយ៉ាន។ ខ្ញុំមិនស្គាល់ត្រកូលរបស់គេឡើយ។ កម្មាភិបាលទាំងបីរនាក់នេះ គឺជាអ្នកគ្រប់គ្រងសហករណ៍របស់យើង។ ខ្ញុំមិនច្បាស់ទេថា តើកម្មាភិបាលទាំងនេះ មកពីបញ្ជាការណាមួយនោះ។ អ្វីដែលខ្ញុំដឹង គឺពួកគេត្រូវបានចាត់ឱ្យគ្រប់គ្រងសហករណ៍របស់យើង"]។ ឯកសារ D1.3.13.8 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ែន សារិន EN ERN 00217561 ["មានសហរណ៍ចំនួនពីរនៅរាម សម្រាប់ប្រពន្ធ និងកូនៗរបស់យោធា និងកម្មករ។ ពួកគេធ្វើស្រែចម្ការនៅស្នាច់ដែង ក្រោមការដឹកនាំរបស់ តាង៉ែត ដែលជាមេបញ្ជាការកងវរសេនាធំ"]។

2703 ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែម ឆ.2, 10, 11, 13, 37 ["អំឡុងពេលនោះ ប្រពន្ធរបស់ខ្មែរក្រហមគឺជាប្រធាននៅតំបន់នោះ [...] ឆ.10៖ ប្រធានសហករណ៍បបុសឈ្មោះ សមមិត្ត រី [...] ឆ.11៖ ខ្ញុំមិនស្គាល់ប្តីរបស់មិត្តរី ទេ។ ខ្ញុំគ្រាន់តែដឹងថា សមមិត្ត រី ជាអ្នកមកពីតាកែវ [...] ឆ.13៖ សមមិត្ត រី ធ្វើជាប្រធានសហករណ៍បបុសចាប់ពីឆ្នាំ១៩៧៥ រហូតដល់ ១៩៧៩ [...] ឆ.37៖ កម្លាំងតាមសហករណ៍ គ្រប់គ្រងដោយប្រធានសហករណ៍ កម្លាំងខាងយោធា គឺគ្រប់គ្រងដោយថ្នាក់ដឹកនាំមកពីកងវរសេនាធំ១៦៤។

នោះជាដើម"[2704]។ មេដឹកនាំថ្នាក់ទាប ជារឿយៗ តែងតែថា បញ្ជាមកពី មាស មុត គឺបញ្ជាមកពី "ថ្នាក់លើ"[2705]។

670. កម្មាភិបាលវ៉ៃសាយស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពល ១៦៤[2706] និងបានបង្កើតជា "កងផលិត" ផ្ទាល់របស់ខ្លួនផងដែរ។ ឧទាហរណ៍ កងវរសេនាតូចលេខ ២០ និងលេខ ២១ ជាកងចល័តនៅព្រែកចាក (ជិតទំនប់បិតត្រាង) មានសមាសភាពកម្មាភិបាលវ៉ៃសាយ[2707]។ យោងតាម

---

2704 ឯកសារ D54/120 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.2, 6 ["តាមខ្ញុំចាំប្រធានសហករណ៍របស់ខ្ញុំឈ្មោះ តាឡូត មានសិទ្ធិសម្រេចលើអ្វីៗទាំងអស់។ វាអាចមានអ្នកខ្ពស់ជាងគាត់ដែរ ប៉ុន្តែខ្ញុំមិនដឹងថាអ្នកណា គឺខ្ញុំដឹងត្រឹមមកកម្រិតគាត់ប៉ុណ្ណោះ។ តាឡូត តែងតែលើកពាក្យអង្គការថា អង្គការចង់ឲ្យបងប្អូនលើកទំនប់ ឬធ្វើនេះធ្វើនោះជាដើម។ [...] ឆ.6៖ [...] ខ្ញុំធ្វើការក្រោមការគ្រប់គ្រងរបស់ប្រធានសហករណ៍អ៊ំ ឡូត។ គាត់មានអាយុប្រហែល៧០ឆ្នាំ"]។ សូមមើលផងដែរ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.113 ["ពួកគេនិយាយថា កុំសួរយើង បើយើងទទួលការងារពីអង្គការ យើងនឹងបញ្ជូនទៅអ្នកអស់គ្នាហើយ"]។ ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ សួន ឈុំ ឆ .13 ["មេសហករណ៍ខ្ញុំឈ្មោះ តាឡូតៗ តែខ្ញុំមិនដឹងនាមត្រកូលគាត់អ្វីទេ អត់ចាំ ហើយអនុប្រធានហ្នឹង តាឃាង"]។

2705 ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.98 ["នៅពេលដែលគេនិយាយថា ប្រជុំជាមួយថ្នាក់លើ គឺសំដៅទៅ តាម៉ុក និង តាមុត ហើយ។ នេះគឺជារបៀបរបបដែលគេធ្វើការ"]។

2706 ឯកសារ D54/45 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.11, 17 ["មាស មុត បានប្រកាសប្រាប់ថា មានយោធារបស់ ឌឹម មកពីភូមិភាគបូព៌ាចំនួន១៥០០នាក់ នឹងច្របាច់បញ្ចូលជាមួយកងពលយើង ដើម្បីបង្កើតជាកងទ័ពជើងទឹក។ យោធាទាំងនោះត្រូវតែឆ្លងកាត់ធ្វើការចម្រាញ់សិន មុនពេលដែលគេដាក់បញ្ចូលទៅក្នុងកងទ័ពជើងទឹកបាន។ [...] ស ៖ នៅខាងដើមលោកបាននិយាយថា ពួកយោធាភូមិភាគបូព៌ា១៥០០នាក់ ត្រូវបានបញ្ជូនទៅដាក់នៅកងផលិតធំ នៅពុទ្ធទេ [...] ឆ.17៖ [...] កងផលិតធំហ្នឹង គឺស្ថិតនៅក្រោមការក្តាប់ផ្ទាល់របស់កងពល១៦៥"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.2, 19-20 ["មេបញ្ជាការកងកាំភ្លើងធំ បានប្រជុំប្រាប់ខ្ញុំ និងយោធាដទៃទៀតថា ខ្ញុំហើយនិងយោធាទាំងនោះត្រូវបានផ្លាស់ពីកងហើយបញ្ជូនទៅនៅកងចល័តព្រែកចាក ដោយសារអង្គការចាត់យើងថាគឺជាសមាសភាពមិនល្អ ហើយត្រូវបញ្ជូនទៅលត់ដំ។ [...] ឆ.19៖ ប្រធានកងវរៈសេនាតូច២០របស់ខ្ញុំឈ្មោះ បង ថន ឯកងវរៈសេនាតូច២១ ខ្ញុំមិនស្គាល់ទេ។ កងវរៈសេនាតូចទាំងពីរនេះឋិតក្រោមការគ្រប់គ្រងរបស់កងពល ១៦៤ [...] ស៖ ហេតុដូចម្ដេចបានជាលោកដឹងរឿងនេះ? ឆ.20៖ ពីព្រោះ មេបញ្ជាការបានប្រកាសក្នុងពេលប្រជុំថា កងរបស់យើងឋិតនៅក្រោមការត្រួតត្រារបស់កងពល"]។

2707 ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.4, 16 ["មួយកងវរៈសេនាតូចមាន ៣កងអនុសេនាធំ មួយកងអនុសេនាធំមាន៣កងអនុសេនាតូច ហើយមួយកងសេនាតូចមាន៣ក្រុមដែលក្នុងមួយក្រុមៗមាន ១២នាក់។ [...] ស៖ តើមានមនុស្សប៉ុន្មាននាក់នៅក្នុងកងចល័តដែលធ្វើការនៅប៉ែកខាងជើងផ្លូវជាតិលេខ ៤ក្នុងតំបន់រាម? ឆ.16៖ មានពីរវរៈសេនាតូច គេហៅថា កងវរៈសេនាតូច ២០ និងវរៈសេនាតូច២១។ កងវរៈសេនាតូចដែលខ្ញុំនៅគឺជាកងវរៈសេនាតូចសម្រាប់អ្នកដែលមានទោសធ្ងន់ អ្នកដែលនៅក្នុងកងវរៈសេនាតូចពាក់ខោអាវ និងមួកពណ៌ ខៀវ ឯវរៈសេនា

សាក្សីម្នាក់ កងវរសេនាតូចលេខ ២០ គឺសម្រាប់ "អ្នកដែលមានទោសធ្ងន់" រីឯកងវរសេនាតូចលេខ ២១ គឺសម្រាប់ "អ្នកដែលមានទោសស្រាល"[2708]។ គឿន មេបញ្ជាការកងវរសេនាធំ និងមេកងក្នុងកងពល ១៦៤ មានទាហានវិសាយប្រមាណ ៣០០ នាក់ សុទ្ធជាបុរស ស្ថិតក្រោមបញ្ជារបស់គាត់[2709]។

671. ទោះបីជាអង្គភាពការងារខ្លះត្រូវបានបែងចែករវាងជនស៊ីវិល និងកម្មាភិបាលវិសាយក៏ដោយ ក៏ប្រធានសហករណ៍ និងមេដឹកនាំកម្មាភិបាល សម្របសម្រួលការងាររបស់ពួកគេ ហើយជារឿយៗកម្មាភិបាលវិសាយធ្វើការ ហើយពេលខ្លះ ពួកគេរស់នៅជាមួយជនស៊ីវិល[2710]។ សាក្សីម្នាក់បាន

---

តូច ២១ គឺសម្រាប់អ្នកមានទោសស្រាល អ្នកនៅក្នុងកងវរៈសេនាតូចនេះពាក់ខោអាវពណ៌ ខ្មៅ"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.16 ["ចូលដល់ឆ្នាំ ១៩៧៧ ខ្ញុំក៏ត្រូវបានគេដកចេញ ហើយបញ្ជូនឲ្យទៅនៅកងផលិត។ កងផលិតរបស់ខ្ញុំ មានឈ្មោះថា កងវរៈសេនាតូចលេខ២០។ ខ្ញុំត្រូវបានគេចាត់តាំងឲ្យលើកទំនប់ និងជីកប្រឡាយ អស់រយៈពេលបួនខែ នៅកន្លែងស្នាច់ដែង និងបបុស។ [...] ខ្ញុំធ្វើការនៅទីនោះ រហូតដល់ខែកញ្ញា ឆ្នាំ១៩៧៨។ នៅពេលនោះ ខ្ញុំ ហើយនិងកងវរៈលេខ២០ របស់ខ្ញុំ ត្រូវបានគេបញ្ជូនឲ្យទៅវាយថ្មនៅការដ្ឋានវាយថ្ម ស្ទឹងហាវ។ ខ្ញុំធ្វើការនៅទីនោះរហូតរៀតណាមចូលដល់"]។

2708 ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.16 ["កងវរៈសេនាតូចដែលខ្ញុំនៅគឺជាកងវរៈសេនាតូចសម្រាប់អ្នកដែលមានទោសធ្ងន់ អ្នកដែលនៅក្នុងកងវរៈសេនាតូចពាក់ខោអាវ និងមួកពណ៌ ខៀវ ឯវរៈសេនាតូច ២១ គឺសម្រាប់អ្នកមានទោសស្រាល អ្នកនៅក្នុងកងវរៈសេនាតូចនេះពាក់ខោអាវពណ៌ ខ្មៅ"]។

2709 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.23-25 ["ស៖ តើលោក និងអ្នកដទៃទៀតរាយការណ៍ឲ្យអ្នកណានៅទីតាំងលើកទំនប់នោះ? ឆ.23៖ នៅពេលនោះយើងត្រូវរាយការណ៍ទៅឲ្យ គឿន ដែលជាមេកងវរៈក្រោមកងពលលេខ៣។ ស៖ តើលោកអាចគូសបញ្ជាក់ឲ្យកាន់តែច្បាស់ថែមទៀតទេថា តើកងវរៈនេះមានលេខប៉ុន្មាន? ឆ.24៖ កងវរៈនេះពុំមានលេខទេ។ គឿន ជាមេកងដែលមានអ្នកធ្វើការ៣០០នាក់។ វាគឺអង្គភាពចល័តដែលសមាជិកគឺជាយោធាដែលគេវិសាយចេញពីកងពលលេខ ៣។ ឆ៖តើអ្នកធ្វើការទាំងនោះមានសមាសភាពអ្វីខ្លះទៅ? ឆ.25៖ តាមខ្ញុំដឹង អ្នកធ្វើការទាំង ៣០០ នាក់នោះគឺសុទ្ធតែប្រុសៗទាំងអស់"]។

2710 ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.15, 39 ["តាមដែលខ្ញុំដឹង សមមិត្ត រី រាយការណ៍ទៅកន្លែងទីតាំងរបស់កងវរៈសេនាធំនៅទឹកសាប [...] ឆ.39៖ មុនពេលដែលគម្រោងចាប់ផ្តើមធ្វើ គឺប្រធានសហករណ៍ ហើយនិងយោធាបើកការប្រជុំ ដើម្បីប្រកាសប្រាប់ប្រជាជនអំពីគម្រោង ហើយការងារដែលត្រូវប្រគល់ ដូចជាប្រវែងប៉ុន្មានការងារអ្វីខ្លះដែលសហករណ៍មួយៗត្រូវធ្វើ"]។ ឯកសារ D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉ែន ឆ.55-56 ["ស៖តើលោកស្រីដឹងថា ការដ្ឋានលើកទំនប់នោះគ្រប់គ្រងដោយពួកស៊ីវិល ឬដោយយោធា? ឆ.55៖ យោធាផង ស៊ីវិលផង។ វាមកធ្វើការចល័តជាមួយយើងដែរហ្នឹង កងទ័ពអាពតហ្នឹង។ ស៖ហេតុអ្វីបានលោកស្រីថាការដ្ឋាននោះគ្រប់គ្រងដោយស៊ីវិលផង និងយោធា ផង។ ឆ.56៖ វាមកមើលយើង"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.24-25 ["ខ្ញុំភ្លេចប្រាប់លោកថា មានកងអនុសេនាធំមួយទៀតចំណុះឲ្យកងវរៈសេនាតូច ១៦៧ គឺ

រៀបរាប់អំពីកម្មករស់នៅចម្រុះគ្នានៅក្នុងកងចល័តមួយ៖ "ពួកបូព៌ាមានចំនួនប្រហែល ៥០-៦០ នាក់ ប្រជាជន១៧ មេសា មាន ៣០-៤០ នាក់ និងខ្មែរកម្ពុជាក្រោមមានប្រហែល ១០-២០ នាក់ ក្រៅពីនោះសុទ្ធតែពួកកងវរសេនាតូច ៣១០ ទាំងអស់ និងអតីតៈយោធានបញ្ជូនមកពីកងដទៃទៀត"[2711]។

672. លើសពីកម្មាភិបាលរំសាយដែលត្រូវបានបញ្ជូនទៅធ្វើការជាពលករនៅការដ្ឋានរាម កម្មាភិបាលសកម្មក្នុងកងពល ១៦៤ ឈរជើងនៅតាមកន្លែងផ្សេងៗក្នុងតំបន់ដើម្បីគ្រប់គ្រង និងការពារ។ កងវរសេនាធំលេខ ២២/៦៣ បន្តឈរជើងនៅទីតាំងជិតព្រលានយន្តហោះកងកេងភ្លាមៗ បន្ទាប់ពីរដ្ឋាភិបាល លន់ នល់ បានដួលរលំ។ ដំបូង ពួកគេឈរជើងនៅប៉ែកនិរតីនៃព្រលានយន្តហោះ[2712] ប៉ុន្តែ ក្រោយមក បានផ្ទេរពីព្រលានយន្តហោះទៅទីតាំងនៅក្បែរនោះ ក្នុងភូមិថ្មធំ នៅប៉ែកនិរតី ជាទីប្រសព្វរវាងផ្លូវនាំទៅមូលដ្ឋានកងទ័ពជើងទឹករាម និងផ្លូវជាតិលេខ ៤[2713]។ (មានរូបសំណាក

---

កងអនុសេនាធំ៣១ ដែលមានមេបញ្ជាការឈ្មោះ បង ភាព (ស្រី)។ អ្វីដែលពិសេស ចំពោះអង្គភាពនេះគឺថាគេបំបែកទៅជាកងតូចៗ ហើយបញ្ជូនទៅរស់នៅជាមួយប្រជាជនធម្មតាតាមឃុំ តាមភូមិ ដូចជាភូមិថ្មធំ គគី ពូធឿង ស្មាច់ដែង ...ដើម្បីដឹកនាំប្រជាជនធ្វើការ។ [...] ឆ.25៖ ខ្ញុំគ្រាន់តែចង់និយាយថា ពួកគេទៅណែនាំ បង្ហាត់បង្ហាញប្រជាជនឱ្យធ្វើការ"]។ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.28 ["ខ្ញុំដឹងរឿងនេះនៅពេលដែលខ្ញុំត្រូវបានគេចាត់ទុកចូលទៅក្នុងកងសមាភាពមិនល្អ។ ខ្ញុំត្រូវបានគេចាត់ឱ្យទៅធ្វើការនៅស្រែក្នុងតំបន់រាមនេះដូចដែលខ្ញុំបានជម្រាបពីខាងដើម។ ខ្ញុំត្រូវបានគេដាក់ឱ្យធ្វើការជាមួយនឹងប្រជាជនមូលដ្ឋាននៅក្នុងតំបន់នោះ"]។ ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញ៉ូង ជ្រោង ឆ.24 ["វរសេនាធំលេខ២២ ជាអ្នកផ្តើមធ្វើទំនប់នោះ។ អ្នកធ្វើការនៅទីនោះរួមមានទាំងប្រជាជន កងផលិត និងកងទ័ព"]។ ប៉ុន្តែសូមមើល ឯកសារ D2/17 កំណត់ហេតុស្តាប់ចម្លើយ អ៊ិន សារឿន ឆ. 50 ["ស៖ តើកន្លែងដែលនៅក្នុងតំបន់ជុំវិញព្រលានយន្តហោះកងកេង កាលពីជំនាន់កម្ពុជាប្រជាធិបតេយ្យ តើជាកន្លែងស៊ីវិល ឬទ័ព? ឆ.50៖ នៅជំនាន់នោះ ប្រជាជនស៊ីវិលធ្វើស្រែនៅកន្លែងជុំវិញនេះ ហើយទាហាននៅជើងភ្នំ"]។

[2711] ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.11។

[2712] ឯកសារ D114/80 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចម្ការធូរេន I , បិតត្រាំង, មូលដ្ឋានយោធាទំនុកបម្រុងក្នុងក្របខណ្ឌនៃកងពលលេខ ១៦៤ KH ERN 01517458-01517459, KH ERN 01517463-01517464 ["រូបថតពណ៌នាទីតាំងបញ្ជាការដ្ឋាននៃកងវរសេនាធំលេខ ២២ កងពលធំលេខ ១៦៤ នៅឆ្នាំ ១៩៧៥"], KH ERN 01517464-01517465 ["ទិន្នន័យ GPS នៃទីតាំងកងវរសេនាធំលេខ ២២ នៅឆ្នាំ ១៩៧៥"]។ ឯកសារ D54/17 កំណត់ហេតុស្តាប់ម្លើយ សយ ប៊ិន ឆ.12 ["វរៈសេនាតូចរបស់កងវរៈសេនាធំ ២២ ឋិតនៅម្ខាងនៃព្រលានយន្តហោះកងកេង"]។

[2713] ឯកសារ D114/141 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ទឹកសាប KH ERN 01517366។ ឯកសារ D114/18 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឆ.27-28 ["ទីបញ្ជាការវរៈសេនាធំ៦៣ នោះ គឺនៅក្នុងវាលយន្ត

ហោះកងកេងតែម្តង [...] ឆ.28៖ ផ្ទះរបស់មេបញ្ជាការវរៈសេនាធំ ៦៣ ដែលស្នាក់នៅ គឺស្ថិតនៅបរិវេណវាលយន្តហោះកងកេងតែម្តង។ នៅពេលនោះ វាលយន្តហោះកងកេងមិនមានដំណើរការទេ ដូច្នេះមេបញ្ជាការស្នាក់នៅនឹងអាគារដែលនៅក្នុងបរិវេណវាលយន្តហោះតែម្តង"]។ ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.1-3 ["ខ្ញុំទៅដល់កំពង់សោមដំបូង អង្គភាពអនុសេនាធំរបស់ខ្ញុំមានការចែកកម្លាំងធ្វើការជាមួយកសិករផង និងការពារព្រលានយន្តហោះកងកេង [...] ឆ.2៖ [...] ខ្ញុំចូលទៅក្នុងកងអនុសេនាធំលេខ២២។ [...] ស៖ តើកងអនុសេនាធំលេខ២២របស់លោកមានទីបញ្ជាការនៅកន្លែងណា ហើយបញ្ជាការកងវរៈសេនាធំ២២មានទីតាំងនៅកន្លែងណា? ឆ.3៖ ទីតាំងរបស់កងវរៈសេនាធំស្ថិតនៅភូមិថ្មធំ ជាប់ព្រលានយន្តហោះ ហើយកងអនុសេនាធំរបស់ខ្ញុំស្ថិតនៅ ស្នាច់ដែង"]។ ឯកសារ D54/8 កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ឆ.22 ["វរៈសេនាធំ២២ របស់ខ្ញុំបោះទីតាំងនៅព្រលានយន្តហោះកងកេង។ ហើយកន្លែងធ្វើការរបស់យើងគឺនៅជុំវិញព្រលានយន្តហោះ កងកេងនោះ។ ក្រោយមកប្រហែលដើមឆ្នាំ១៩៧៦ ខ្ញុំបានចេញពីវរៈសេនាធំ២២"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.19 ["ពេលខ្ញុំមកដល់ទឹកសាបដំបូង ក្នុងឆ្នាំ១៩៧៧ តាជន ជាអ្នកទទួលខុសត្រូវនៅទីនោះ។ តាជន គឺជាមេបញ្ជាការវរៈសេនាធំលេខ៦៣។ ហើយ តាញ៉ាន់ គឺជាអនុរបស់គាត់។ វរៈសេនាធំ៦៣ មានទីតាំងនៅន្លែងផ្លូវបំបែកផ្លូវជាតិលេខ៤ ទៅរាមនៅជិតវាលយន្តហោះ"]។ សូមមើលផងដែរ ឯកសារ D114/243 កំណត់ហេតុស្តាប់ចម្លើយ ធក សែន ឆ.68-73 ["ស៖ តើទីបញ្ជាការកងពលលេខ៣ ស្ថិតនៅកន្លែងណាដែរ? ឆ.68៖ នៅម្តុំតារាងយន្តហោះ។ ស៖ម៉េចបានដឹង? ឆ.69៖ ឃើញនៅហ្នឹងតែម្តង ឃើញទ័ពគេនៅហ្នឹង។ ស៖ តើលោកអាចរៀបរាប់ពីទីបញ្ជាការនោះបានដែរឬទេ? ស.70៖ ទីបញ្ជាការគេមានអាវុធគ្រប់ធុន គេដាក់ប្រចាំការនៅតារាងយន្តហោះហ្នឹង។ គេមានប៉ុស្តិ៍យាម នៅប្រចាំការនៅហ្នឹង។ ស៖ តើលោកចង់សំដៅទៅលើតារាងយន្តហោះណាដែរ? ឆ.71៖ តារាងយន្តហោះកងកេង នៅស្នាច់ដែងហ្នឹង។ ស៖ តើមានអាវុធប្រភេទអ្វីខ្លះដែរ ប្រចាំការនៅទីបញ្ជាការយោធានេះ? ឆ.72៖ បើតាមខ្ញុំស្គាល់មាន បេ, បង់ត្រឡោក, អាកា, ៦០, ដេកា៧៥, សេវ៉ាន់ធីណៃ(អាកាច់ច្រក)។ ស៖ម៉េចបានដឹង? ឆ.73៖ ធ្លាប់ឃើញអ៊ីចឹង"]។ ឯកសារ D114/115 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សំអាន ឆ.15 ["មុនពេលដែលឃ្លាំងរើទៅកន្លែងថ្មី ផ្ទះរបស់មេបញ្ជាការនេះ គឺនៅកងកេងជាប់នឹងអាគារខ្ពស់ក្នុងព្រលានយន្តហោះ"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.19 ["វរៈសេនាធំ៦៣ មានទីតាំងនៅន្លែងផ្លូវបំបែកផ្លូវជាតិលេខ៤ ទៅរាម នៅជិតវាលយន្តហោះ"]។ ឯកសារ D114/19.2 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន ឧបសម្ព័ន្ធ៖ ផែនទីប្រជុំកោះ KH ERN 01034015។ ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង (សមាជិកក្នុង ពួក៣, កងអនុសេនាតូចលេខ៣, កងអនុសេនាធំ ២២, កងវរសេនាតូច ៥៥០, កងវរសេនាធំ ២២, កងពល ៣) ឆ.9, 15 ["ស៖ ក្នុងពេលនោះ ត-៤ ត្រូវបានប្តូរឈ្មោះទៅជាកងវរសេនាតូចលេខ៥៥០ ដែលស្ថិតនៅក្រោមកងវរសេនាធំលេខ២២។ ឆ.9៖ បាទ ត្រឹមត្រូវហើយ។ [...] ឆ.15៖ ពេលមកពីភ្នំពេញដំបូង គេឲ្យខ្ញុំនៅព្រលានយន្តហោះកងកេងបានប៉ុន្មានថ្ងៃ គេក៏បញ្ជូនខ្ញុំទៅកោះតាង"]។ ឯកសារ D59/1/1.10a កិច្ចសម្ភាសមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយផ្លុង ឈា (ប្រធានកងអនុសេនាតូច, កងវរសេនាតូច ៥៣០, កងវរសេនាធំ ២២) KH ERN 00926491-92 ["ស៖ ចូលភ្លាម ដកភ្លាមមកហើយ? ឆ៖ បាទ! ចូលភ្លាម ដកភ្លាម អត់មានទៅច្របូកច្របល់គ្នាទេនៅទីក្រុងភ្នំពេញទេ។[...] ដល់កំពង់សោមដំបូង ខ្ញុំទៅនៅព្រលានយន្តហោះកងកេង [...] មិនមានជាភារៈកិច្ចអីនោះទេ គ្រាន់តែការពារតាមផ្លូវអីបន្តិចបន្តួច [...]មិនដល់១អាទិត្យផង។ ស៖ កាលនៅកន្លែងកងកេងហ្នឹង អីកងពលទាំងមូលនៅហ្នឹង ឬក៏គេចែកយ៉ាងម៉េច? ឆ៖ គេចែកតាមវរៈសេនាតូច។ ឯក

នាគមួយនៅរង្វង់មូល ដែលជាសម្គាល់សម្រាប់សាក្សីជាច្រើននាក់។) លេខាកងវរសេនាធំលេខ ៦៣ ស៊ិន ជន និង គឹម ញ៉ន មានការិយាល័យនៅទីនោះ[2714] ហើយលើសពីនេះទៀត ញ៉ន មាន ទំនួលខុសត្រូវលើការដ្ឋានវាយថ្មអូរម្លូ ជាផ្នែកមួយនៃការងាររបស់គាត់ដែលពាក់ព័ន្ធភស្តុភារ[2715]។

---

សារ D114/18 កំណត់ហេតុស្តាប់ចម្លើយ ម៉ាក ឈឿន (មេបញ្ជាការកងវរសេនាតូច ៥៣០, កងវរសេនាធំ២២) ឆ. 26, 30-31 ["ទីបញ្ជាការវរៈសេនាធំលេខ៦៣ នៅក្នុងបរិវេណវាលយន្តហោះកងកេង។ [...] ឆ.30៖ ទីបញ្ជាការរបស់ សារី [មេបញ្ជាការកងវរសេនាតូច ៥៤០, កងវរសេនាធំ ៦៣] នៅកន្លែងផ្លូវបំបែកពីផ្លូវជាតិលេខ៤ ទៅកាន់វាលយន្ត ហោះកងកេង នៅកន្លែងផ្លូវបំបែកនោះ នៅខាងឆ្វេងដៃ ចុះពីផ្លូវជាតិលេខ ៤ទៅ។ [...] ឆ.31៖ កាលពីពេលនោះ ផ្លូវ បែកចេញពីផ្លូវជាតិលេខ៤ ទៅវាលយន្តហោះកងកេងមានតែមួយហ្នឹងទេ"]។

2714 ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.១៩ ["ពេលខ្ញុំមកដល់ទឹកសាបដំបូង ក្នុងឆ្នាំ១៩៧៧ តាជន ជាអ្នកទទួលខុសត្រូវនៅទីនោះ។ តាជន គឺជាមេបញ្ជាការវរៈសេនាធំលេខ៦៣។ ហើយ តាញ៉ាន់ គឺជាអនុរបស់គាត់។ [...] ក្រោយមក ជន ត្រូវបានចាប់ខ្លួន ហើយ ញ៉ាន់ ឡើងជំនួស ជន រហូត ដល់របបខ្មែរក្រហមដួលរលំ"]។ ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង រ៉េត ឆ.28, 121, 127 ["តា ញ៉ាន់ ជាមេបញ្ជាការកងវរសេនាធំ៦៣។ [...] ឆ.121៖ តាញ៉ាន់ គឺជាមេបញ្ជាការវរសេនាធំ៦៣ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពល១៦៤ ដែលមាន មាស មុត ជាមេបញ្ជាការ។ [...] ស៖ យោងទៅលើកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកនិយាយថា "តាញ៉ាន់ គឺជាមេបញ្ជាការវរសេនាធំ៦៣ ឈរជើងនៅកងកេង" តើរឿងនេះត្រឹមត្រូវដែរឬទេ? ឆ. 127៖ បាទ ត្រឹមត្រូវហើយ"]។ ឯកសារ D59/1/1.11a កិច្ចសម្ភាសន៍មណ្ឌលឯកសារកម្ពុជាជាមួយ ហៀង រ៉េត KH ERN 00926563 ["ថ្នាក់ធំៗបី ពីណាគេជាប្រធាន? ឆ៖ មានតាជន ជាប្រធាន ពីមុន តាញ៉ាន់ ដល់តាញ៉ាន់ ឡើងមក ផុតទៅ គាត់ឡើងមកភស្តុភារទៅ មានតាជន គេនៅតាមតំបន់ចែកគ្នាអីចឹងឯង"], KH ERN 00926575 [តាញ៉ាន់ គាត់ នៅកាន់វរសេនាធំ ៦៣ នៅកងកេង]។ សូមមើលផងដែរ ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សា ម៉េត ឆ.30 ["ស៖តើលោកស្គាល់មនុស្សម្នាក់ឈ្មោះ មុំ យ៉ាន ដែរឬទេ? ឆ.30៖ បាទ ខ្ញុំស្គាល់ គាត់គឺជា មេបញ្ជាការ កងវរៈសេនាធំលេខ៦៣។ មូលដ្ឋានរបស់គាត់នៅក្នុងប្រលានយន្តហោះកងកេង ជិតផ្លូវបំបែករវាងផ្លូវចូលទៅប្រលាន យន្តហោះ និងផ្លូវជាតិត្រង់ស្ពានចាស់ដែង។ គាត់គឺជាមេបញ្ជាការកងវរៈសេនាធំលេខ៦៣ មុនពេលដែល ជន ចូលមកកាន់ ជំនួស។ ខ្ញុំមិនដឹងពីអ្វីដែលបានកើតឡើងចំពោះគាត់ឡើយ"]។

2715 ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.177, 271-273 ["ស៖ អ្នកណាជាអ្នកប្រាប់លោកឱ្យវៃថ្ម ឱ្យបាន ៧ម៉ែត្រគូបក្នុងមួយថ្ងៃនោះ? ឆ.177៖ តា ញ៉ាន់។ [...] ស៖ ឥឡូវយើងត្រឡប់មកឆ្នាំ១៩៧៦វិញ។ នៅឆ្នាំ ១៩៧៦ អ្នកណាជាអ្នកគ្រប់គ្រងការដ្ឋានវៃថ្មនៅអូរម្លូ? ឆ.271៖ តា ញ៉ាន់។ គាត់កាន់ខាងភស្តុភារ។ ស៖ តើលោកដឹង ថាគេយកថ្មដែលគេវៃនោះទៅធ្វើអ្វីទេ? ឆ.272៖ ថ្មហ្នឹង គេយកមកសាងសងកំពង់ផែនៅស្ទឹងហាវ។ ស៖ ហេតុអ្វីបាន ជាលោកដឹង? ឆ.273៖ ព្រោះតាញ៉ាន់គាត់និយាយពេលដែលគាត់មកការដ្ឋាន"]។

ម៉ុម ជឹម ហៅ យ៉ាន ក៏អាចឈរជើងនៅការិយាល័យកងវរសេនាធំលេខ ៦៣ ជិតកងកេងមួយរយៈផងដែរ[2716]។

673. យ៉ាងហោចណាស់ កងវរសេនាតូចមួយនៃកងវរសេនាធំលេខ ២១/៦២ ដែលមានកម្លាំងភិបាលប្រមាណ ១៥០ នាក់ មានទីតាំងស្ថិតនៅឆ្នេររាម[2717] ដែលមុខងារមួយក្នុងចំណោមមុខងារផ្សេងៗរបស់ពួកគេ គឺទទួលអ្នកទោសដែលត្រូវបានចាប់ខ្លួនលើកោះ និងនៅសមុទ្រ និងនាំពួកគេទៅសម្លាប់នៅទីតាំងសម្លាប់ចម្ការទុរេន ១[2718]។ ពិតណាស់ សាក្សីម្នាក់បានពន្យល់ថា ចម្ការទុរេន ១

---

[2716] ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.30 ["សួរ៖ តើលោកស្គាល់មនុស្សម្នាក់ឈ្មោះ មុំ យ៉ាន ដែរឬទេ? ឆ.30៖ បាទ ខ្ញុំស្គាល់ គាត់គឺជា មេបញ្ជាការកងវរៈសេនាធំលេខ៦៣។ មូលដ្ឋានរបស់គាត់នៅក្នុងប្រលានយន្តហោះកងកេង ជិតផ្លូវបំបែករវាងផ្លូវចូលទៅប្រលានយន្តហោះ និងផ្លូវជាតិត្រង់ស្នាច់ដែង។ គាត់គឺជាមេបញ្ជាការកងវរៈសេនាធំលេខ៦៣ មុនពេលដែល ជន ចូលមកកាន់ជំនួស។ ខ្ញុំមិនដឹងពីអ្វីដែលបានកើតឡើងចំពោះគាត់ឡើយ"]។

[2717] ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.13 ["មានមួយកងវរសេនាតូចដែលមានយោធាប្រហែល១៥០ នាក់ របស់កងវរសេនាធំលេខ៦២ ដែលបោះទីតាំងនៅកន្លែងនោះ។ [...] ពួកយោធានៅក្នុងកងវរសេនាតូចមានទីតាំងនៅជិតចម្ការក្រូច និងចម្ការធូរេន"]។ ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ឆ.36 ["សួរ៖ កន្លែងចម្ការក្រូចដែលលោកបង្ហាញយើងកាលពីព្រឹកមិញ តើវាជាកន្លែងអ្វី? ឆ.36៖ វាគឺជាកន្លែងដែលកងទ័ពស្នាក់នៅ។ [...] កងដែលនៅចម្ការក្រូចនោះគឺជាកងវរសេនាធំ៦២"]។ ឯកសារ D114/292 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង EN ERN 01366048 [ផែនទីពណ៌នាតំបន់ទីតាំងកងវរសេនាធំ ៦២] ។ ឯកសារ D114/58 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.46 ["សួរ៖ តើទីតាំងនោះជាទីតាំងអ្វី[ចម្ការក្រូច]? ឆ.46៖ ទី១ វាគឺជាមូលដ្ឋានរបស់អង្គភាពកាំភ្លើងធំរបស់កងវរៈសេនាធំលេខ៦២"]។ ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ឆ. 36,43 ["សួរ៖កន្លែងចម្ការក្រូចដែលលោកបង្ហាញយើងកាលពីព្រឹកមិញ តើវាជាកន្លែងអ្វី? ឆ.36៖ វាគឺជាកន្លែងដែលកងទ័ពស្នាក់នៅ។ [...] ចំណែកខ្ញុំដែលនៅ គេបញ្ជូលទៅក្នុងកងនៅចម្ការក្រូចនេះ។ កងដែលនៅចម្ការក្រូចនោះគឺជាកងវរសេនាធំ៦២។ [...] ឆ.43៖ ពួកខាងកងវរសេនាធំលេខ៦២ ដែលពួកគេមានទីតាំងនៅរាម [...]។ ដូច្នេះពួកវរសេនាធំ៦២ ជាអ្នកយកមនុស្សមកពីរាម ទៅចម្ការធូរេន ដើម្បីសម្លាប់"]។ ឯកសារ D4.1.750 ចម្លើយពីអ្នកមិនស្គាល់អត្តសញ្ញាណពាក់ព័ន្ធនឹងឈ្លើយសឹកអាមេរិក/បាត់ខ្លួនក្នុងសង្គ្រាម KH ERN 01496677 ["យោងលើព័ត៌មានសង្ខេបផ្សេងទៀត ទីបញ្ជាការកងវរសេនាធំ ២១ នៅក្បែររាម"]។

[2718] ឯកសារ D114/297.1.20 ប៉ាក សុខ (2-TCW-1000) ប្រតិចារឹក ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 10:43:36-10:46:23 ["ពេលនុ៎ង ឃើញថា សភាពការណ៍ដែលគេយកទៅសម្លាប់នោះ ភាគច្រើននៅកងពលដែលខ្ញុំធ្លាប់រស់នៅពីមុនបាទ។ ពីមុនមកខ្ញុំនៅកងពលលេខ៦២ បាទ ពេលនុ៎ង វរសេនាធំ៦២នោះ គេចាប់បានគេបញ្ជាឱ្យយកទៅចម្ការក្រូច និងចម្ការដូង យកទៅសម្លាប់ចោលនៅទីនោះ"]។ ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ឆ.41, 43, 45 ["សួរ៖ ពេលដែលលោកនិយាយថា គេយកទៅធ្វើជីរ តើមានន័យយ៉ាងដូចម្តេច? ឆ.41៖ មានន័យថា យកទៅសម្លាប់ គឺសម្លាប់ដាក់គល់ធូរេន ដើម្បីធ្វើជីរ។ ឆ.43៖ [...] ពួកវរសេនាធំ៦២ ជាអ្នកយកមនុស្សមកពីរាម ទៅចម្ការធូរេន ដើម្បី

ស្ថិតក្រោមការគ្រប់គ្រងរបស់ អ៊ាក មៀញ លេខាកងវរសេនាធំលេខ ៦២ ដែលស្នាក់នៅទីនោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៦[2719]។ មៀញ មានផ្ទះមួយនៅចម្ការទុរេនចេងហេងដែលគាត់ស្នាក់នៅទីនោះ ពេលគាត់មិននៅលើកោះ[2720]។ ក្រោយមក មៀន ត្រូវបានដកចេញ និងជំនួយសដោយសុន[2721]។

---

សម្លាប់ [...] ឆ.45៖ខ្ញុំឮតាមរយៈកងទ័ពគ្នាឯង។ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.13 ["មានមួយកងវរសេនាតូចដែលមានយោធាប្រហែល១៥០នាក់ របស់កងវរសេនាធំលេខ៦២ ដែលបោះទីតាំងនៅកន្លែងនោះ។ តួនាទីរបស់យោធាទាំងនោះគឺសម្រាប់ចាំទទួលឃ្មួនដែលចាប់បានយកទៅសម្លាប់នៅចម្ការធូរ៉េន និងចម្ការដូង"]។ សូមមើលផងដែរ ឯកសារ D4.1.699 ទូរលេខ១១ ពី ឌឹម ជូនបងមុត ថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៧៦ KH ERN 00092628 ["សភាពការណ៍យើង យុទ្ធជននៅកង ៦២ ធ្វើស្រែ ទៅធ្វើស្រែនៅម្តុំចម្ការដូង ពលីម្នាក់ដោយលង់ទឹក ប៉ុន្តែមូលហេតុពិនិត្យមិនទាន់ច្បាស់"]។ ឯកសារ D114/99 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ចម្ការធូរេន II, ទឹកសាប, បិតត្រាំង KH ERN 01519483 ["គាត់ស្គាល់ទីកន្លែងនេះដោយចង្អុលបង្ហាញថាជាមូលដ្ឋានមួយរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យ។ [...] សាក្សីបានថ្លែងថាគាត់បានស្គាល់ទីនេះថាជា ចម្ការធូរេន ចម្ការក្រូច និងចម្ការម្រេច។ សាក្សីបានថ្លែងថាតាមការដឹងរបស់គាត់កាលពីជំនាន់កម្ពុជាប្រជាធិបតេយ្យ កងយោធាបានបោះទីតាំងនៅទីនេះ"]។ ឯកសារ D54/120.1 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឧបសម្ព័ន្ធ៖ គំនូសទីកន្លែង KH ERN 01023168។ ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.34, 39 ["ពេលខ្ញុំនៅក្នុងកងកុមារ ខ្ញុំបានឃើញយោធាខ្មែរក្រហមចាប់បានអ្នកនេសាទហើយបញ្ជូនទៅកន្លែងចំការធូរ៉េន ទៅឱ្យយោធាខ្មែរក្រហមមួយក្រុមទៀត ដើម្បីសម្លាប់ចោល។ [...] ស៖ ហេតុអ្វីបានជាលោកដឹងថាអ្នកនេសាទត្រូវបានខ្មែរក្រហមមួយក្រុមជាអ្នកបណ្តើរ ហើយមានមួយក្រុមទៀតជាអ្នកសម្លាប់? ឆ.39៖ ខ្ញុំបានឮពីប្រធានកងកុមាររបស់ខ្ញុំ និងពីអ្នកដទៃនៅក្នុងពេលមានព្រឹត្តិការណ៍នោះ"]។ ឯកសារ D54/24.1 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយប៉ាក សុខ KH ERN 00955506-07 ["ស៖មនុស្សដែលបញ្ជូនមកនឹងៗ បញ្ជូនមករៀម ឬមកដំណាក់ស្តេច? ឆ៖ មករៀម។ [...] ខ្ញុំបញ្ជូនមកត្រឹមនឹងប្រគល់ឱ្យគេត្រឹមនឹង ហើយត្រឡប់ទៅវិញ"]។

2719 ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.2, 4, 24 ["ប៉ុន្តែខ្ញុំអាចប្រាប់លោកថាចម្ការទុរ៉េននោះគឺស្ថិតក្រោមការគ្រប់គ្រងរបស់តាមៀញ ដែលជាមេបញ្ជាការកងវរៈសេនាធំលេខ៦២។ [...] ឆ៖ តើលោកដឹងថាតាមៀញ នៅតំបន់នោះពីពេលណាដល់ពេលណាដែរឬទេ? ឆ.4៖ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៦។ [...] ស៖តើលោកដឹងថានរណាជាអនុលេខាកងវរៈសេនាធំលេខ៦២ នៃកងពលលេខ១៦៤ដែរឬទេ? ឆ.24៖ខ្ញុំគ្រាន់តែដឹងថា មៀញ ជាមេបញ្ជាការហើយ ក្រោយមកត្រូវជំនួសដោយសុន"]។

2720 ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.3 ["តាមៀញ មានផ្ទះមួយនៅក្នុងចម្ការទុរ៉េននោះ។ គាត់ធ្លាប់ស្នាក់នៅទីនោះនៅពេលដែលគាត់មិនទៅតាមកោះ ដូចជានៅពេលដែលគាត់ត្រឡប់ពីកោះតាងជាដើម។ ប៉ុន្តែកូនទាហានរបស់គាត់មួយចំនួនតូចស្នាក់នៅក្នុងចម្ការទុរ៉េននោះជានិច្ចមានម្នាក់ឈ្មោះសុន ដែលជាអ្នកមើលថែផ្ទះ

## ៣. ឧក្រិដ្ឋកម្ម

### ការធ្វើឲ្យក្លាយជាទាសករ

674. កម្លាំងពលកម្ម នៅការដ្ឋានរាម មានទាំង "កងទ័ព និងប្រជាជន"[2722] នេះបើតាមពាក្យពេចន៍របស់ **មាស មុត**។ អ្នកមកពី "កងទ័ព" ភាគច្រើន ជាកម្មាភិបាលរំសាយ ដែលត្រូវគេសង្ស័យ និងលែងត្រូវបានចាត់ទុកជាកម្មាភិបាលសកម្មតទៅទៀត (ចំណុចនេះត្រូវបានរៀបរាប់លម្អិតបន្ថែមទៀត

---

របស់គាត់"]។ សូមមើលផងដែរ ឯកសារ D114/77.3 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឧបសម្ព័ន្ធ៖ គំនូសទីកន្លែង KH ERN 01101698។

[2721] ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.5 ឆ.7 ឆ.24 ["តាមៀញត្រូវបានដកចេញ និងជំនួសដោយ សុន ដែលចូលមកកាន់កងវរនៈសេនាធំលេខ៦២នៅក្នុងឆ្នាំ ១៩៧៦។ សុន នេះគឺជាមនុស្សផ្សេងម្នាក់ទៀត មិនមែនជាអ្នកដែលមើលថែផ្ទះឲ្យមេបញ្ជាការកងវរៈសេនាធំនៅក្នុងចម្ការទុរ៉េននោះឡើយ។ [...] ស៖ តាសុន មកពីណា? ឆ.7៖ គាត់ជាអ្នកខេត្តកំពត។ [...] ឆ.24៖ ខ្ញុំគ្រាន់តែដឹងថា មៀញ ជាមេបញ្ជាការ ហើយក្រោយមកត្រូវជំនួសដោយ សុន"]។

[2722] ឯកសារ D1.3.27.18 កំណត់ហេតុ នៃការប្រជុំលេខា និងភស្តុភារ របស់កងពល និងវរៈសេនាធំ KH 00052391។ សូមមើលផងដែរនូវ ឯកសារ D1.3.27.22 កំណត់ហេតុ នៃការប្រជុំគណៈកងពលពេញអង្គ KH 00088936 ["ខាងកងពល១៦៤ ស្រូវស្រាលស្ទូងបាន ២៧០ ហិកតា ទាំងកងទ័ព ទាំងប្រជាជន"]។ ឯកសារ D114/34 កំណត់ហេតុស្តាប់ចម្លើយ ណាប់ សុម៉ាលី ឆ.65 ["ស៖ តើលោកស្ថិតនៅក្នុងកងស៊ីវិល ឬយោធា? ឆ.65៖ ខ្ញុំស្ថិតនៅកងស៊ីវិល"]។ ឯកសារ D54/91 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.2 ["ស៖ លោកបាននិយាយថាស្ពានបេតុងនេះ គឺត្រូវបានសាងសង់ដោយយោធាខ្មែរក្រហម។ តើយោធាខ្មែរក្រហមដែលសាងសង់នេះ គឺមកពីអង្គភាពណា? ឆ.2៖ ពួកគេគឺជាយោធាខ្មែរក្រហមកង១៦៤"]។ ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.15 ["តាមដែលខ្ញុំចាំ គេសាងសង់ទំនប់នោះរួចក្នុងរយៈ ២-៣ខែ ពីព្រោះគេបានប្រមូលប្រជាជនជាច្រើនមកពីសហករណ៍ ពីយោធា និងពីកងចល័តនានាឲ្យមកធ្វើនៅទីនោះតាមផែនការដែលគេកំណត់"]។ ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ឆ.24 ឆ.26-27 ឆ.31-32 ["វរសេនាធំលេខ២២ ជាអ្នកផ្តើមធ្វើទំនប់នោះ។ អ្នកធ្វើការនៅទីនោះរួមមានទាំងប្រជាជនកងផលិត និងកងទ័ព។ [...] ឆ.26៖ មនុស្សមានច្រើនណាស់ ដោយប្រមូលមនុស្សទូទាំងតំបន់កងកេង ប្រហែលជា ៥០០ ទៅ៦០០នាក់។ [...] ឆ.27៖ ទំនប់នេះចាប់ផ្តើមធ្វើនៅឆ្នាំ១៩៧៧។ ទំនប់ត្រូវបានធ្វើចប់ប្រហែលជាបីបួនខែ នៅក្នុងឆ្នាំដដែល។ [...] ស៖ បន្ទាប់ពីការសង់ទំនប់ត្រូវបានបញ្ចប់ តើអ្នកដែលជាប់និន្នាការមិនល្អ និងប្រជាជន គេធ្វើយ៉ាងម៉េចចំពោះអ្នកទាំងនោះ? ឆ.31៖ អ្នកដែលនៅក្នុងកងផលិតទាំងអស់ គឺនៅធ្វើការរហូតទាល់តែពួកវៀតណាមចូលមកដល់។ ស៖ បន្ទាប់ពីគំរោងធ្វើទំនប់ត្រូវបានបញ្ចប់ តើអ្នកនៅក្នុងកងផលិត គឺធ្វើស្រែចម្ការធម្មតាមែនទេ? ឆ. 32៖ បាទ"]។

នៅក្នុងផ្នែកពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញ)[2723]។ ជារួម កម្មករវាប់ពាន់នាក់បានធ្វើការនៅការដ្ឋានតំបន់រាមក្នុងពេលមួយ[2724] រួមទាំងបុរស ស្ត្រី កុមារ និងមនុស្សចាស់[2725]។ សាក្សីម្នាក់បានអះអាង

---

[2723] ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.89-90 ["ក្រោយមក គេបានរំសាយកងទ័ព ហើយប្រែក្លាយអង្គភាពយើងទៅជាកងផលិត ដោយឱ្យធ្វើស្រែ លើកទំនប់ និងជីកប្រឡាយ។ ស៖ ហេតុអ្វីបានជាគេរំសាយអង្គភាពរបស់លោក? ឆ.90៖ គេចោទយើងជាខ្មែរខ្មាំង ដោយសារមេកងវរៈរបស់ពួកយើងត្រូវបានគេចាប់យកទៅបាញ់សម្លាប់អស់ហើយ"]។ សូមមើលផងដែរនូវ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ នៅម៉ោង 15.05.58-14.14.44 ["ស៖ អ្នកដែលមានប្រវត្តិរូបមិនល្អ ជាពិសេសអ្នកដែលមានជាប់និន្នាការរបបចាស់ អ្នកដែលមានបងប្អូនធ្វើការនៅក្នុងជួរកងទ័ព ឬក៏នៅក្នុងរដ្ឋាបាលនៃរបបចាស់ហ្នឹង គឺថាគេដកចេញ។ ដកចេញហ្នឹងលោកចង់មានន័យថាម៉េច? គេយកអ្នកទាំងអស់ហ្នឹងទៅណា? ហើយក្រោយមកមានរឿងអ្វីកើតឡើងទៀតចំពោះអ្នកទាំងអស់នេះ? ឆ៖ បាទ នៅក្នុងកងពល១៦៤ របស់យើងខ្ញុំហ្នឹង តាមការក្តាប់ មានកងចល័តមួយ កងចល័តមួយគេហៅថា "កងតាចាយ" បាទ កងតាចាយនោះ។ ពេលដែលកងទ័ពយោធាដែលមានជាប់និន្នាការនយោបាយដែលមិនល្អ ឧទាហរណ៍ថា ខ្ញុំមានឪពុកម្តាយ គេឆ្លើយថាមានឪពុកម្តាយ ឬសាច់បងប្អូន បងប្អូនហ្នឹងមានជាប់ដែលថាជា កា.ហ្សេ.បេរបស់យួន ឬមួយកា.ហ្សេ.បេ, សេ.អ៊ី.អា របស់អាមេរិកាំងបាទ គេលែងទុកចិត្តខ្ញុំហើយ គេដកខ្ញុំនេះឱ្យទៅកងចល័តហ្នឹង។ ដល់កងចល័តហ្នឹងជាកងមួយដែលសម្រាប់ធ្វើតែស្រែទេ បាទ ជាកងនេះកងចល័តធ្វើស្រែនៅម្តុំបពុស្ស នៅជិតស្នាច់ដែង បាទ ខាងជើងស្នាច់ដែងបន្តិច ខាងជើងកងកេងណោះ បាទ។ កន្លែងនោះហើយជាកន្លែងជាអ្នកជាប់និន្នាការជាប់នឹងនយោបាយអ្វីមួយ [...] នៅកងចល័តហ្នឹងសុទ្ធតែ ចំនួន មានចំនួនច្រើនដែរ ប្រហែលជាបួនទៅ ៥០០នាក់ដែរ អាហ្នឹងកងតាចាយ ហ្នឹង គឺកងផលិត"]។ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.190 ["គេចាត់ឱ្យក្រុមខ្ញុំលើកទំនប់ដែរ"]។ ឯកសារ D54/78.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ហាល (នាវាសយោធាជើងទឹក នៅវរសេនាតូច៦២២ កងពល១៦៤) KH 00926614 ["វាចេះ ៦២៤ហ្នឹងកម្លាំងចែកជា២ មួយចំណែកនៅកោះតាងដែរ មួយចំណែកមកធ្វើស្រែនៅម្តុំយើងកងកេងនេះ"]។ ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល KH 00982547 ["មុននេះ លោកសួរខ្ញុំអំពីកោះ តែឥឡូវសួរអំពីទីតាំងនៅលើដីគោកវិញ។ ខ្ញុំគ្រាន់តែដឹងថា ក្រុមខ្លះក្នុងកងវរៈសេនាធំ៦២ ត្រូវបានគេបញ្ជូនឱ្យទៅធ្វើស្រែនៅក្បែរៗនោះ"]។ ឯកសារ D54/20 កំណត់ហេតុស្តាប់ចម្លើយ សំ សោម (កងអនុសេនាធំ៤២ នៅកងវរៈសេនាតូច៦២៣ កងវរៈសេនាធំ២១) ឆ.14 ["ប៉ុន្តែក្នុងវគ្គនោះខ្ញុំបានរៀនសូត្រឆ្លងជីវទស្សន៍នៅកំពង់សោមនៅអាគារពណ៌ខៀវក្នុងរយៈពេលបីថ្ងៃទេ។ ក្រោយមកគេឱ្យទៅធ្វើពលកម្មនៅព្រលានយន្តហោះកងកេងរយៈមួយខែ។ វាជាការងារដ៏លំបាក ខ្ញុំទៅធ្វើស្រែនៅកងចល័តបិតក្រោម តាអ៊ឹម"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ (កង៨៦ តំបន់៣៧) ឆ.24 ["យ៉ាងណាមិញ ខ្ញុំក៏បានសង្កេតឃើញមានមនុស្សផ្សេង ក្រុមបុរសផ្សេងៗទៀត សែងកណ្តាប់ និងនារីៗស្ទូងស្រូវផងដែរ"]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត (កងអនុសេនាធំ១២០ នៅកងវរៈសេនាតូច២ កងវរៈសេនាធំ៥២ តំបន់២២) ឆ.10 ["នៅកងកេង គេឱ្យធ្វើស្រែដោយកាប់នឹងចប ពុំមែនប្រើគោក្របីភ្ជួររាស់នោះទេ"]។

2724 ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង សុំ ឆ.168 ឆ.278 ["សៈ តើពួកទាហានទាំងអស់ដែលគេដោះលែងមកក្នុងវរៈសេនាធំរបស់លោក គេឲ្យមកវាយថ្មទាំងអស់ឬ [នៅអូរម្លូនៅព្រលានយន្តហោះកងកេង]? ឆ.168៖ បាទ។ [...] ឆ.278៖ ច្រើននាក់ មានប្រហែលជា ៣០០០នាក់កំពុងធ្វើការនៅទីនោះ [នៅព្រលានយន្តហោះកងកេង និងនៅវាលស្រែនានា]"]។ ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.41 ["មានប្រហែលពី៨០០នាក់ទៅ១០០០នាក់ ដែលធ្វើការនៅគម្រោង [ទំនប់បិតត្រាំង] នេះ"]។ ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.14 ឆ.16 ឆ.24 ["គេបានចាត់តាំងកងកុមាររបស់ខ្ញុំឱ្យទៅកាត់ស្មៅនៅតាមវាលស្រែនៅជិតនោះ [ទំនប់បិតត្រាំង]។ [...] ឆ.16៖ តាមខ្ញុំស្មានមានមនុស្សរាប់រយនាក់ [នៅទំនប់បិតត្រាំង] ដែលមើលទៅឃើញខ្មៅពាសពេញការដ្ឋាននោះ [...] ឆ.24៖ គេមាន៣កង [កុមារ] (កង១, កង២, កង៣) ខ្ញុំឋិតនៅក្នុងកងទី១។ កងនីមួយៗមានកុមារចំនួនប្រហែលពី១០០-២០០នាក់។ តាមពិតកងនីមួយៗមានកុមារស្ទើរតែ ២០០នាក់"]។ ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.21 ["សៈ លោកនិយាយថា មានមនុស្ស៣០០នាក់ធ្វើការនៅទំនប់ទឹក [ទំនប់បិតត្រាំង] នោះ។ តើហេតុអ្វីបានជាលោកដឹងអំពីតួលេខនេះច្បាស់លាស់ម្លេះ? ឆ.21៖ ព្រោះខ្ញុំនៅទីនោះ ហើយពួកយើងធ្វើការជាមួយគ្នា។ យើងធ្វើការតាមក្រុម ហើយក្រុមនីមួយៗធ្វើការបន្តជាប់ៗគ្នា ហេតុដូច្នេះហើយបានជាខ្ញុំដឹង"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.4 [បានគណនាប្រហែលជា៦៥០នាក់នៅក្នុងកងចល័តរបស់គាត់ដែលធ្វើការនៅការដ្ឋានបិតត្រាំង]។ ឯកសារ D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉ែន ឆ.26-27 ["មានមនុស្សរាប់ពាន់នាក់ [នៅការដ្ឋានបិតត្រាំង]។ ចង្ក្រានបាយមួយៗមានមនុស្សពីរបីរយនាក់ [...] ឆ.27៖ ចង្ក្រានមួយហ្នឹងមានពីរបីរយនាក់ហើយ ចុះប៉ុន្មានចង្ក្រាន មានច្រើនចង្ក្រាន"]។ ឯកសារ D54/17 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.14 ["អ្នកធ្វើពលកម្ម[នៅការដ្ឋានមានទីតាំងនៅឡូតដ្ឋដែលនៅជិតព្រលានយន្តហោះកងកេង] ទាំងនោះមានជនស៊ីវិល និងជាយោធា [...] ខ្ញុំមិនអាចបញ្ជាក់ពីចំនួនអ្នកធ្វើពលកម្មពិតប្រាកដបានទេ បើតាមខ្ញុំប៉ាន់ស្មានមានប្រហែលជាង ១០០នាក់"]។ ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.19 ["កងផលិតធំ [ដែលបានចាត់តាំងទៅ ភូមិពុទ្ធទេ ឆ្លងថ្នល់ពីវាលយន្តហោះកងកេង] មានអតីតយោធារាប់ពាន់នាក់ ដែលចាត់ថាមានសមាសភាពមិនល្អ"]។ ឯកសារ D114/243 កំណត់ហេតុស្តាប់ចម្លើយ ធក សែន ឆ.24-25 ឆ.50-51 ឆ.96 ឆ.99 ឆ.100 ["សៈ តើមានកុមារប៉ុន្មាននាក់ក្នុងកងរបស់លោក? ឆ.24៖ មួយកងៗ ប្រហែលជា១៥០នាក់ [...] ឆ.25៖ ឲ្យរើសដូង កាប់ព្រៃ រកត្រីរកអីធម្មតា និងហាត់ហែលទឹក។ [...] សៈ តើកងកុមាររបស់លោកមានទីតាំងនៅត្រង់ណាដែរ? ឆ.50៖ នៅចម្ការទៀបមួយ នៅមាត់សមុទ្រនៅខាងចុងស្ពានបាក់នេះមួយ និងនៅចុងចម្ការដូងមួយ (នៅចុងមាត់សមុទ្រ) ទាំងអស់បីកន្លែង។ សៈ ឆ្នេរសមុទ្រណាដែរទៅ? ឆ.51៖ នៅរាមហ្នឹង ចម្ការដូងរាមហ្នឹង [ទំនប់បិតត្រាំង] សៈ តើលោកទៅធ្វើការទីនោះ [...] ក្នុងខែឆ្នាំណាដែរ? ឆ.96៖ ក្នុងឆ្នាំ១៩៧៥ ពេលខ្ញុំនៅបិតត្រាំង។ [...] សៈ តើមានមនុស្សប៉ុន្មាននាក់ ដែលធ្វើការនៅការដ្ឋានទំនប់បិតត្រាំង? ឆ.99៖ រាប់រយនាក់ [...] សៈ តើមានកុមារប៉ុន្មាននាក់ដែរ ធ្វើនៅទីនោះ? ឆ.100៖ មានប្រហែលជា៣០នាក់ មួយកងកុមារ"]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.13 ឆ.19-21 ឆ.23-24 ឆ.188 ឆ.191 ["គេបំបែកខ្ញុំ [...] ទៅចូលក្នុងកងកុមារ។ [...] សៈ នៅក្នុងកងកុមារហ្នឹង មានកុមារប៉ុន្មាននាក់ [ក្នុងកងវរៈសេនាតូច៥៨០]? ឆ.19៖ ខ្ញុំមិនដឹងថាមានក្មេងប៉ុន្មាននាក់ [...] តែខ្ញុំចាំថា គេឲ្យខ្ញុំយកភ្លួយទៅឲ្យគេ ហើយខ្ញុំចាំថា ភួយហ្នឹងមាន ៣៧១។ កងកុមារនៅកងវរៈសេនាតូច ៥៨០ ហ្នឹងមានចំនួនកុមារប៉ុណ្ណឹងនៅកងនោះទាំងមូល។ ចុះមានកុមារប៉ុន្មាននាក់នៅក្នុងកងរបស់លោកផ្ទាល់? ឆ.20៖ ខ្ញុំមិនបាន

ដឹងពីចំនួនសរុប។ ស៖ តើកងកុមាររបស់លោកហ្នឹង គេឱ្យធ្វើអ្វីខ្លះ? ឆ.21៖ កាប់ព្រៃ រើសដូងទុំ។ រួចពីហ្នឹង គេឱ្យមកច្រូតនៅក្នុងសហករណ៍ [...] ឆ.23៖ គេឱ្យទៅសហករណ៍ទាំងអស់ [នៅរាម] [...] ឆ.24៖ [...] ព្រៃបុស ពុទធឿន ស្នាច់ដែន និងសហករណ៍ផ្សេងទៀត [...] ឆ.188៖ ខ្ញុំចូលរួមលើកទំនប់ នៅការដ្ឋាននោះ ពីរវត្តបិតត្រាំង ទៅអូរប្រៃ។ [...] ស៖ តើមានប្រហែលប៉ុន្មាននាក់ ៥០ ឬ១០០? ឆ.191៖៤០០ ឬ ៥០០"]។ ឯកសារ D114/240 កំណត់ហេតុស្តាប់ចម្លើយ ភិន វេញ ឆ.11 ឆ.15-17 ឆ.24 ឆ.27 ឆ.46-47 ["ខ្ញុំនៅកុមារ ហើយដល់ពេលគេយកកុមារទៅធ្វើទំនប់ [បិតត្រាំង] ហ្នឹង។ [...] ស៖ តើគេឱ្យលោកទៅធ្វើការនៅការដ្ឋានទំនប់ចាប់ពីខែឆ្នាំណាដែរ? ឆ.15៖ ចាប់ពីឆ្នាំ១៩៧៥ ដល់១៩៧៦ ហើយ១៩៧៦ ខ្ញុំទៅចម្ការដូង [នៅផែរាម] វិញហើយ។ [...] ឆ.16៖ ទំនប់ [បិតត្រាំង] ហ្នឹងមានប្រវែង ២គីឡូដី ហើយមានប្រជាជនយើងធ្វើការច្រើនណាស់ [...] ឆ.17៖ គេឱ្យ [កុមារ] សែងដីរែកដី [...] ស៖ តើមានកុមារប៉ុន្មាននាក់ដែរ នៅក្នុងកងកុមារនោះ? ឆ.24៖ ២៥០នាក់។ [...] ឆ.27៖ ដក [កុមារ] ចេញពីហ្នឹង ទៅនៅចម្ការដូង [...] ស៖ តើមានកងកុមារចំនួនប៉ុន្មាន ដែលធ្វើការនៅចម្ការដូងនោះ? ឆ.46៖ មាន៣កង។ ស៖ តើមួយកងៗមានកុមារប៉ុន្មាននាក់ដែរ? ឆ.47៖ ក្នុងមួយកងៗមាន២៥០នាក់"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.20 ឆ.22 ឆ.24 ["គឺនៅលើកោះតាងនេះឯង ដែលគេវៃសាយអង្គភាពខ្ញុំមុននឹងបញ្ជូនពួកខ្ញុំឱ្យមកធ្វើស្រែនៅព្រលានយន្តហោះកងកេង [...] ឆ.22៖ ខ្ញុំនៅចាំច្បាស់ថាកង៨៦ទាំងអស់របស់ខ្ញុំត្រូវបានគេដកអាវុធនៅលើកោះតាង ហើយបញ្ជូនត្រឡប់មកផែរាមវិញដែលជាទីកន្លែងដែលគេវៃសាយពួកខ្ញុំ ហើយឱ្យចបពួកខ្ញុំម្នាក់មួយៗធ្វើការ។ ខ្ញុំចាំថាងហេតុការណ៍នេះកើតឡើងនៅខែកក្កដា ឆ្នាំ១៩៧៧ [...] គឺគេឱ្យចបយើងម្នាក់មួយមុននឹងបញ្ជូនទៅធ្វើការនៅម្តុំព្រលានយន្តហោះកងកេង [...] ឆ.24៖ យោធាដែលគេវៃសាយចេញពីកងរបស់ខ្ញុំមានប្រហែលជា២០០ ទៅ៣០០នាក់"]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.41 ["គេយកខ្ញុំមកដល់ព្រលានយន្តហោះកងកេង។ [...] ខ្ញុំកត់សម្គាល់ឃើញថាយោធាប្រហែល២០០ ទៅ៣០០នាក់មកធ្វើការនៅព្រលានយន្តហោះកងកេង"]។ ឯកសារ D114/135 កំណត់ហេតុស្តាប់ចម្លើយ ណុប ផន ឆ.19 ["មានទាហានប្រហែលជា៦០ ទៅ១០០នាក់ នៅក្នុងកងអនុសេនាធំរបស់ខ្ញុំ ដែលត្រូវបានគេវៃសាយ។ ទាហាននៅក្នុងអង្គភាពផ្សេងទៀត ក៏ត្រូវបានគេវៃសាយដែរ ប៉ុន្តែខ្ញុំមិនដឹងថាប៉ុន្មាននាក់ទេ [...] គេបញ្ជូនយើងឱ្យទៅចូលតាមកងចល័តនៅកងកេង ដើម្បីធ្វើស្រែ"]។ ឯកសារ D54/81.2 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ហ៊ីង អ៊ិច KH 00984339 ["ខ្ញុំមកនៅព្រលានយន្តហោះកងកេង។ [...] មកៗជួយធ្វើស្រែ [...] មកជាអង្គភាព មកទាំងអស់គ្នា"]។ ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញ៉ូង ជ្រោង (សមាជិកក្នុងពួកទី៣ នៃកងអនុសេនាតូចលេខ៣ កងអនុសេនាធំ២២ កងវរៈសេនាតូច៥៥០ កងវរៈសេនាធំ ២២ នៃកងពលទី៣) ឆ.26 ["មនុស្សមានច្រើនណាស់ ដោយប្រមូលមនុស្សទូទាំងតំបន់កងកេង ប្រហែលជា៥០០ ទៅ៦០០នាក់"]។ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ.53 ឆ.56-57 ឆ.103 ["ស៖កុមារទាំងនោះត្រូវបានគេឱ្យកាប់ទន្រ្កានខេត្តមែនទេ? ឆ.53៖ ចាស [...] ស៖ តើក្មេងនៅក្នុងកងមានប៉ុន្មាននាក់? ឆ.56៖ ២០នាក់។ ស៖ កងនោះស្ថិតនៅឯណា? ឆ.57៖ ក្នុងភូមិពូធឿង ដែលនៅចម្ងាយប្រមាណជា ៣គីឡូម៉ែត្រពីផ្លូវជាតិ [...] ឆ. 103៖ មានកងកុមារជាច្រើន។ ប៉ុន្តែមានកុមារតែ ២០នាក់ប៉ុណ្ណោះ នៅក្នុងកងរបស់ខ្ញុំ"]។ ឯកសារ D114/242 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ប៊ុននី ឆ.9 ឆ.29 ឆ.50-51 ឆ.57 ["គេយកខ្ញុំទៅប្រមូលផ្តុំក្មេងចម្ការដូងរាម [...] ស៖ តើនៅម្តុំៗនោះមានកងកុមារផ្សេងទៀតទេ? ឆ.29៖ មានច្រើនកង។ មានកង១១ កង១២ កង១៣ អីចឹង។ [...] ស៖ ក្នុងរបបនោះ តើមានគេបញ្ជូនលោកទៅធ្វើការនៅកន្លែងណាផ្សេងទៀតទេ? ឆ.50៖ គេបញ្ជូនយើងបេះដូងហើយ គេ

ឱ្យយើងធ្វើស្រែជាមួយយុវជនទៀត។ សៈ តើគេឱ្យទៅធ្វើស្រែនៅទីតាំងណាខ្លះដែរទៅ? ឆ.51៖ នៅក្បែរតារាងយន្ត ហោះកងកេង។ [...] ឆ.57៖ ក្នុង១កង មានកុមារ៥០នាក់"]។

2725 ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.188-189 ["ខ្ញុំចូលរួមលើកទំនប់ នៅការដ្ឋាននោះ ពីវត្ត បិតត្រាង ទៅអូរប្រៃ។ [...] ឆ.189៖ មានប្រុសស្រីក្មេងចាស់"]។ ឯកសារ D114/139 កំណត់ហេតុស្តាប់ចម្លើយ ងួន ឡាយ ឆ.108 ["សៈ តើលោកធ្លាប់ទៅការដ្ឋានការងារហ្នឹង ឬទំនប់ [បិតត្រាំង] ហ្នឹងទេ? ឆ.108៖ អត់មានក្មេងទេ មានប្រហែល ១ ឬ ២ភាគរយទេសម្រាប់ក្មេង"]។ ឯកសារ D114/243 កំណត់ហេតុស្តាប់ចម្លើយ ធក សែន ឆ.25 ឆ .95 ឆ.100-101 ["សៈ តើគេឱ្យពួកលោក [កងកុមារ] ធ្វើអ្វីដែរនៅក្នុងចម្ការដូង [នៅរាម] នោះ? ឆ.25៖ ឱ្យរើសដូង កាប់ព្រៃ រកត្រីរកអីធម្មតា និងហាត់ហែលទឹក។ [...] ឆ.95៖ ធ្លាប់មកជីកនៅ [បិតត្រាំង] ហ្នឹង។ [...] សៈ តើមាន កុមារប៉ុន្មាននាក់ដែរ ធ្វើនៅទីនោះ? ឆ.100៖ មានប្រហែលជា៣០នាក់ មួយកងកុមារ។ សៈ តើពួកគេមានអាយុប៉ុន្មាន ដែរ? ឆ.101៖ មានអាយុ១៣ឆ្នាំ ១៥ឆ្នាំ ត្រឹមប៉ុណ្ណឹង។ កុមារតូចៗដែរ"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ ចម្លើយ ប្រាក់ សុខា ឆ.11 ["សៈ តើលោកអាចប៉ាន់ស្មានភាគរយអតីតយោធាកងវរៈសេនាតូច ៣១០ អតីតយោធា ភូមិភាគបូព៌ា និងពួកប្រជាជន១៧មេសា និងខ្មែរកម្ពុជាក្រោមនៅក្នុងកងចល័ត [នៅព្រែកចាក] បានដែរឬទេ? ឆ.11៖ [...] [ក្រៅពីនោះ] មានកងនារីមួយកងអនុសេនាតូចផងដែរ"]។ ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ឆ.60 ឆ.106 ["ទៅចម្ការដូង ចេងហេង [នៅកំពង់សោម] គេឱ្យទៅរើសដូងនៅទីនោះ [...] សៈ អ្នកដែល ធ្វើការនៅចម្ការដូងនោះ មានទាំងប្រុសទាំងស្រីឬ? ឆ.106៖ ចាស"]។ ឯកសារ D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉ែន ឆ.15 ឆ.29 ["គេផ្លាស់ទៅនៅក្រីទឹង នៅកំពត។ ពេលខ្ញុំនៅនេះ ខ្ញុំបែកកូនចៅអស់ហើយ។ កូនៗខ្ញុំត្រូវបាន បញ្ជូនទៅធ្វើការនៅចម្ការដូង [...] ឆ.29៖ ចម្ការដូងចេងហេង នៅភូមិអុង។ នោះ! កូនខ្ញុំ គេបញ្ជូនទៅធ្វើនុ៎ង"]។ ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.14 ឆ.25 ឆ.30 ឆ.38 ["គេបានចាត់តាំងកងកុមាររបស់ខ្ញុំឱ្យ ទៅកាត់ស្មៅនៅតាមវាលស្រែនៅជិតនោះ [ទំនប់បិតត្រាំង]។ ពេលខ្លះ យើងទៅកាត់ស្មៅនៅជិតការដ្ឋានទំនប់នោះ។ [...] ឆ.25៖ គេបែងចែកទៅតាមអាយុកុមារ។ កងកុមារដែលមានអាយុតិចជាងគេ គេប្រើឱ្យធ្វើការងារស្រាលដូចជា រើសដូងទុំ ជញ្ជូនអូសតាមទឹកទៅដាក់ឃ្លាំង។ ចំពោះក្រុមកុមារដែលមានអាយុច្រើន ដូចជាខ្ញុំនៅក្នុងកងទី១ គេឱ្យប្រើ បេះដូង កាប់ឆ្ការព្រៃដូង បោចស្មៅ ឬក៏ជួយធ្វើស្រែ។ ចំពោះកុមារក្នុងកងទី២ មានអាយុប្រហែលពី១០ឆ្នាំ ឯចំណែកកង កុមារទី៣មានអាយុប្រហែលពី៧-៩ឆ្នាំ [...] ឆ.30៖ កងកុមាររបស់ខ្ញុំឋិតនៅភូមិអុង ឃុំរាម [...] ឆ.38៖ [...] ខ្ញុំ បានធ្វើការនៅក្នុងកងកុមារនៅក្នុងចំការដូង"]។ ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.25 ឆ.27 ["តាមខ្ញុំដឹង អ្នកធ្វើការ [នៅទំនប់បិតត្រាំង] ទាំង៣០០នាក់នោះគឺសុទ្ធតែប្រុសៗទាំងអស់ [...] ឆ.27៖ អ្នកទាំងនោះ មានអាយុប្រហាក់ប្រហែលខ្ញុំដែរ។ កាលនោះ ខ្ញុំមានអាយុប្រហែល២៥-២៦ឆ្នាំ ដូច្នេះអ្នកខ្លះក៏ក្មេងជាងខ្ញុំ អ្នកខ្លះក៏ មានអាយុចាស់ជាងខ្ញុំតិចតួច"]។ ឯកសារ D114/240 កំណត់ហេតុស្តាប់ចម្លើយ ភិន វេញ ឆ.9 ឆ.11 ឆ.15-16 ឆ.25 ឆ.27 ឆ.50 ["ខ្ញុំនៅកុមារ [...] គេបញ្ជូនខ្ញុំទៅធ្វើទំនប់អូរប្រៃ [...] ឆ.11៖ [...] ខ្ញុំនៅកុមារ ហើយដល់ពេលគេយក កុមារទៅធ្វើទំនប់ហ្នឹង។ [...] សៈ តើគេឱ្យលោកទៅធ្វើការនៅការដ្ឋានទំនប់ចាប់ពីខែឆ្នាំណាដែរ? ឆ.15៖ ចាប់ពីឆ្នាំ ១៩៧៥ ដល់១៩៧៦ ហើយ១៩៧៦ ខ្ញុំទៅចម្ការដូង [នៅផែរាម] វិញហើយ។ [...] ឆ.16៖ ទំនប់ [បិតត្រាំង] ហ្នឹងមាន ប្រវែង២គីឡូដី ហើយមានប្រជាជនយើងធ្វើការច្រើនណាស់ ហើយរួមទាំងកុមារផង [...] សៈ តើកុមារ [ធ្វើការនៅ ទំនប់បិតត្រាំង] ទាំងនោះមានអាយុប្រហាក់ប្រហែល និងជាមធ្យមប៉ុន្មានដែរ? ឆ.25៖ ក្មេងបំផុតអាយុ៧ឆ្នាំ ហើយធំ

បំផុតអាយុ១៤ឆ្នាំ […] ឆ.27៖ ដក [កុមារ] ចេញពីហ្នឹង ទៅនៅចម្ការដូង […] ស៖ តើការងារនៅក្នុងកងកុមារ [នៅចម្ការដូង] នោះមានអ្វីខ្លះទៅក្នុង១ថ្ងៃៗ? ឆ.50៖ ខែវស្សាហ្នឹង គេឲ្យធ្វើស្រែ។ ចុះមកធ្វើស្រែជាមួយប្រជាជនហ្នឹង។ ដល់រួចពីធ្វើស្រែ ខែប្រាំង គេឲ្យជីកប្រឡាយ។ ដល់ជីកប្រឡាយ ដល់ចម្ការដូង គេឲ្យកាយដីដាំដំណាំ ដូចជាដំឡូងផ្លា"]។ ឯកសារ D11/387 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សំ វុទ្ធី KH 00991864 ["ឆ្នាំ១៩៧៧ មេកងឈ្មោះមិត្តលន បានដកយុវជន និងយុវនារីទាំងអស់ មកធ្វើស្រែប្រាំងនិងស្រែវស្សានៅទំនប់បិតត្រាំងស្រុកព្រៃនប់ មេកងឈ្មោះមិត្តលន បានបង្ខិតបង្ខំពួកយុវជន និងយុវនារីទាំងអស់ធ្វើប្រឡាយមួយខ្សែដើម្បីយកទឹកធ្វើស្រែប្រាំងនៅខាងក្រោមទំនប់បិតត្រាំង"]។ ឯកសារ D54/121 កំណត់ហេតុស្តាប់ចម្លើយ លិន សារិន ឆ.2 ["ក្នុងរបបខ្មែរក្រហម គេឲ្យខ្ញុំធ្វើការនៅក្នុងកងកុមារ ជាមួយក្មេង១០ ឬ២០នាក់ផ្សេងទៀត ហើយគេចាត់តាំងឲ្យកាប់ដើមទន្រ្ទានខេត្តនៅតាមសងខាងផ្លូវជាតិលេខ៤ និងនៅលើខ្នងទំនប់ [បិតត្រាំង] ដើម្បីយកមកធ្វើជី"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.22 ["គេបញ្ជូនទៅធ្វើការនៅម្តុំព្រលានយន្តហោះកងកេង។ ជាចម្បងគេឲ្យពួកយើងកាប់ដី និងលើកភ្លឺស្រែដើម្បីឲ្យកងនារីស្ទូងស្រូវ"]។ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.25 ["កូនប្រុសច្បងរបស់ខ្ញុំ គេឲ្យទៅបោច/ច្រូតស្មៅនៅឆ្ងាយពីផ្ទះ [នៅភូមិថ្មធំ] ហើយកូនពីរនាក់ទៀត គេឲ្យបោច/ច្រូតស្មៅនៅជិតៗផ្ទះ"]។ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ.53-54 ឆ.57 ឆ.105 ឆ.119 ឆ.218-219 ["ស៖កុមារទាំងនោះត្រូវបានគេឲ្យកាប់ទន្រ្ទានខេត្តមែនទេ? ឆ.53៖ ចាស វាមិនមែនជាការងារធ្ងន់ឡើយ។ កុមារដែលអាចលើកទន្រ្ទានខេត្តរួច ត្រូវបានគេឲ្យលើកទន្រ្ទានខេត្ត។ ស៖ ក្មេងធំជាងគេនៅក្នុងកងអាយុប៉ុន្មាន? ឆ.54៖ ៨ ទៅ៩ឆ្នាំ […] ស៖ តើក្មេងនៅក្នុងកងមានប៉ុន្មាននាក់? ឆ.56៖ ២០នាក់។ ស៖ កងនោះស្ថិតនៅឯណា? ឆ.57៖ ក្នុងភូមិពូធឿង ដែលនៅចម្ងាយប្រមាណជា ៣គីឡូម៉ែត្រពីផ្លូវជាតិ […] ឆ.105៖ […] ពួកគេសុទ្ធតែជាកូនកងទ័ព […] ឆ.119៖ ពី៦ ទៅ៨ ឬ៩ឆ្នាំ […] ឆ.218៖ ដល់ខែធ្វើស្រែ មានទាហានច្រើននាក់ចុះមកជួយធ្វើ [ស្រែនៅជិតព្រលានយន្តហោះកងកេង] […] ឆ.219៖ ប្រពន្ធទាហានធ្វើការងារផ្សេងៗគ្នា អ្នកណាធ្វើស្រែដល់រដូវធ្វើស្រែ ត្រូវចុះមកធ្វើស្រែ"]។ ឯកសារ D2/17 កំណត់ហេតុស្តាប់ចម្លើយ អ៊ិន សារឿន ឆ.38 ["ខ្ញុំនៅក្នុងកងកុមារ ហើយគេឲ្យខ្ញុំដើររើសដូង"]។ ឯកសារ D114/242 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ប៊ុននី ឆ.9 ឆ.29 ឆ.50-51 ឆ.53 ឆ.85 ["ឆ្នាំ១៩៧៥ កាលហ្នឹងខ្ញុំអាយុប្រហែល១២ឆ្នាំ។ គេយកខ្ញុំទៅប្រមូលផ្តុំក្មេងចម្ការដូងរាម […] ស៖ តើនៅម្តុំៗនោះមានកងកុមារផ្សេងទៀតទេ? ឆ.29៖ មានច្រើនកង។ មានកង១១ កង១២ កង១៣ អីចឹង។ […] ស៖ ក្នុងរបបនោះ តើមានគេបញ្ជូនលោកទៅធ្វើការនៅកន្លែងណាផ្សេងទៀតទេ? ឆ.50៖ គេបញ្ជូនយើងបេះដូងហើយ គេឲ្យយើងធ្វើស្រែជាមួយយុវជនទៀត។ ស៖ តើគេឲ្យទៅធ្វើស្រែនៅទីតាំងណាខ្លះដែរទៅ? ឆ.51៖ នៅក្បែរតារាងយន្តហោះកងកេង។ […] ឆ.53៖ មានតែកងចាស់ៗ ធ្វើស្រែនៅជាយតារាងយន្តហោះកងកេងហ្នឹង ខាងជើងថ្នល់ […] ស៖ តើលោកអាយុប៉ុន្មានដែរ ពេលគេយកយោធានោះចេញពីតារាងយន្តហោះកងកេង? ឆ.85៖ កាលនោះខ្ញុំអាយុ១៥, ១៦ឆ្នាំហើយ ព្រោះឆ្នាំ១៩៧៧ ហើយ"]។ សូមមើលផងដែរនូវ ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ឈុំ ឆ.58 ["សាងសង់ទំនប់បិតត្រាំងហ្នឹង […] បើមានទៅគឺពួកយុវជន យុវនារីទៅខ្លះ គឺមួយចំនួនតូចទេ"]។

ថា "គ្មាននរណាម្នាក់នៅទំនេរទេ គឺមានតែទារកអាយុ ៣-៤ ខែប៉ុណ្ណោះ ដែលនៅទំនេរ។ យាយៗត្រូវគេចាត់តាំងឲ្យមើលថែទាំក្មេង ចំណែកតាៗ គេឲ្យដាំដំណាំ។ ប្រជាជនទាំងអស់ត្រូវគេបញ្ជូនឲ្យទៅធ្វើការ តាមវាលស្រែ ឬទៅសង់ទំនប់"[2726]។

675. នៅខែ កញ្ញា ឆ្នាំ ១៩៧៦ **មាស មុត** បានរាយការណ៍ថា មនុស្ស ១៧.០០០ នាក់ បានចូលរួមបង្កបង្កើនផលស្រូវតែមួយមុខនៅកំពង់សោម[2727] លើផ្ទៃដី ២.០០០ ហិចតា[2728]។ សក្ខីកម្មរបស់សាក្សីបានបញ្ជាក់អះអាងថា មនុស្សរាប់ពាន់នាក់បានចូលរួមធ្វើស្រែនៅតំបន់នោះ[2729]។ ក្រៅពីការ

---

2726 ឯកសារ D54/120 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.3។

2727 ឯកសារ D1.3.27.18 កំណត់ហេតុ នៃការប្រជុំលេខា និងភស្តុភារ របស់កងពល និងវរៈសេនាធំ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH 00052391 ["ស្រូវធ្ងន់ ស្ទូងហើយ ទាំងកងទ័ព និងប្រជាជន ទំហំគឺ ១.៦០០ ហិកតា។ កំលាំងមនុស្ស ទាំងប្រជាជន ទាំងកងទ័ព ១៧.០០០ នាក់"]។

2728 ឯកសារ D1.3.27.18 កំណត់ហេតុ នៃការប្រជុំលេខា និងភស្តុភារ របស់កងពល និងវរៈសេនាធំ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH 00052391 ["ផលស្រូវ គិត ២ តោនស្មើ ក្នុងដី ២.០០០ ហិកតា ត្រូវខ្វះ ៦១.០០០ ថាំង"]។ សូមមើលផងដែរនូវ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង សុំ ឆ.279 ["សៈ នៅកន្លែងដែលគេធ្វើស្រែហ្នឹង តើលោកប៉ាន់ស្មានទៅមានទំហំប៉ុន្មានដែរ? ឆ.279៖ រាប់ពាន់ហិកតា"]។

2729 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ នៅម៉ោង 10.49.49-10.51.34 [សាក្សីត្រូវបាន "ចាត់ឲ្យ ធ្វើស្រែ" នៅភូមិគគីរ ស្ទាច់ដែង]។ ឯកសារ D114/242 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ប៊ុនធី ឆ. 29 ឆ.50-51 ឆ.57 ["សៈ តើនៅម្ដុំៗនោះមានកងកុមារផ្សេងទៀតទេ? ឆ.29៖ មានច្រើនកង។ មានកង១១ កង១២ កង១៣ អ៊ីចឹង។ [...] ឆ.50៖ [...] គេឲ្យយើងធ្វើស្រែជាមួយយុវជនទៀត។ សៈ តើគេឲ្យទៅធ្វើស្រែនៅទីតាំងណាខ្លះដែរទៅ? ឆ.51៖ នៅក្បែរតារាងយន្តហោះកងកេង។ [...] ឆ.57៖ ក្នុង១កង មានកុមារ៥០នាក់"]។ ឯកសារ D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉េន ឆ.12 ឆ.15 ឆ.40-42 ឆ.45-46 ["ធ្វើការ [នៅការដ្ឋានការងារបិតត្រាំង] ច្រើនណាស់ មានរាប់រយ។ យើងតម្រង់ជួរវែង ចាំយកបបរហូប [...] សៈ តើនៅការដ្ឋានបិតត្រាំង គេឲ្យធ្វើអ្វីខ្លះ? ឆ.15៖ នៅធ្វើស្រែអីហ្នឹង។ [...] សៈ តើលោកស្រីធ្វើការនៅក្នុងទំនប់បិតត្រាំងនោះក្នុងឆ្នាំណាដែរ? ឆ.40៖ ឆ្នាំ ១៩៧៦ [...] ឆ.41៖ ធ្វើបាន១ឆ្នាំដែរហ្នឹង [...] ឆ.42៖ ដកស្ទូង កាប់ដី រែកដី [...] ឆ.45៖ [មនុស្សធ្វើការនៅការដ្ឋានបិតត្រាំង] មានច្រើន រាប់រយ។ សៈ តើការដ្ឋាននោះមានចង្ក្រានបាយប៉ុន្មានដែរ? ឆ.46៖ ខ្ញុំមិនបានរាប់ចង្ក្រានបាយទេ តែចង្ក្រានមួយៗធំ ហើយចង្ក្រានមួយៗមានមនុស្សពីរបីរយនាក់ ហើយគេមិនអនុញ្ញាតឲ្យយើងដើរទេ។ គេចំអិនម្ហូបហើយ គេយកឲ្យយើងហូបនៅតាមស្រែតែម្តង"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.21 ["សៈ តើអង្គភាពលោកស្រីបានទៅចូលរួមលើកទំនប់នៅបិតត្រាំងដែរឬទេ? ឆ.21៖ ខ្ញុំដឹងថាទីតាំងនេះស្ថិតនៅក្រោយទំនប់ពូធឿង។ ខ្ញុំស្គាល់ទីតាំងនេះ ដោយសារពួកយើងទៅស្ទូង និងច្រូតកាត់នៅក្បែរទំនប់នោះដែរ"]។ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ.110 ឆ.112 ["[កូនរបស់សាក្សីនៅ] សហករណ៍នោះ ឈ្មោះសហករណ៍ពូធឿង [...] ឆ.112៖ មនុស្សធំគេឲ្យទៅស្ទូងស្រូវ [នៅក្នុងសហករណ៍នោះ] ប៉ុន្តែយើងទទួលបានអង្ករជារៀង

ធ្វើស្រែ និងស្របតាមសេចក្ដីណែនាំរបស់ សុន សេន ឱ្យ "កងពល ១៦៤ ត្រូវទប់ទឹកជើងភ្នំ ទប់ព្រែកទឹកសាប ឱ្យបានដាច់ខាត និងត្រូវធ្វើអាងទឹកឱ្យបាន"[2730] មនុស្សរាប់ពាន់នាក់បានធ្វើការលើកទំនប់ និងជីកប្រឡាយ[2731]។

---

រាល់ខែ"]។ ឯកសារ D54/89 កំណត់ហេតុស្ដាប់ចម្លើយ កុយ ណែន KH 00987092 ["នៅពេលនោះ ខ្មែរក្រហមបានរៀបចំកម្លាំងបីផ្នែក [នៅភូមិបបុស] ១គឺសម្រាប់ធ្វើទំនប់ ទី២ គឺសម្រាប់ភ្ជួររាស់ស្រែ និងទី៣សម្រាប់ដកស្ទូង"] KH 00987097 ["នៅពេលនោះកងរបស់អតីតយោធាខ្មែរក្រហម គេហៅថាកងរំសាយ ពួកទាំងនេះគឺត្រូវបានបញ្ជូនឱ្យទៅធ្វើការនៅតាមវាលស្រែជាមួយប្រជាជនដែរ នៅតំបន់នេះ [ជិតទឹកសាប]"]។ ឯកសារ D54/35 កំណត់ហេតុស្ដាប់ចម្លើយ ប្រាក់ សុខា ឆ.17 ["យើង [សមាជិកកងចល័តរបស់សាក្សី] នៅទីនោះ [នៅតំបន់កងកេង] ដាំស្រូវ និងកសាងទំនប់នៅទីនោះរហូតដល់ចុងឆ្នាំ ១៩៧៧"]។ ឯកសារ D114/6 កំណត់ហេតុស្ដាប់ចម្លើយ យិន តេង ឆ.88-89 ["គេឱ្យដកស្ទូង [នៅភូមិពូធឿង] [...] ឆ.89៖ [...] ខ្ញុំជួយច្រូតនៅជិតព្រលានយន្តហោះកងកេង"]។ ឯកសារ D114/121 កំណត់ហេតុស្ដាប់ចម្លើយ សួន ផ ឆ.22 ឆ.24 ["នៅថ្ងៃដែលដែលគេរំសាយពួកខ្ញុំ គឺគេឱ្យចបយើងម្នាក់មួយមុននឹងបញ្ជូនទៅធ្វើការនៅម្ដុំព្រលានយន្តហោះកងកេង។ ជាចម្បងគេឱ្យពួកយើងកាប់ដី និងលើកភ្លឺស្រែ ដើម្បីឱ្យកងនារីស្ទូងស្រូវ [...] ឆ.24៖ យោធាដែលគេរំសាយចេញពីកងរបស់ខ្ញុំមានប្រហែលជា២០០ ទៅ៣០០នាក់ ដោយគេឱ្យចបយើងម្នាក់មួយៗសម្រាប់កាប់ដី និងលើកភ្លឺស្រែ [...] យ៉ាងណាមិញ ខ្ញុំក៏បានសង្កេតឃើញមានមនុស្សផ្សេងក្រុមបុរសផ្សេងៗទៀត សែងកណ្ដាប់ និងនារីៗស្ទូងស្រូវផងដែរ"]។ ឯកសារ D114/58 កំណត់ហេតុស្ដាប់ចម្លើយ សំ សោម ឆ.48 ["ខ្ញុំត្រូវបានគេឱ្យទៅធ្វើស្រែនៅជិតកន្លែងនេះ នៅម្ដុំកងកេង នៅក្នុងឆ្នាំ១៩៧៧"]។ ឯកសារ D114/156 កំណត់ហេតុស្ដាប់ចម្លើយ ស៊ឹង ណុច ឆ.21 ["ស៖ តើកងកុមាររបស់លោកហ្នឹង គេឱ្យធ្វើអ្វីខ្លះ? ឆ.21៖ កាប់ព្រៃ រើសដួងទុំ។ រួចពីហ្នឹង គេឱ្យមកច្រូតនៅក្នុងសហករណ៍ [នៅរាម]"]។ ឯកសារ D11/388 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ណាប់ សុម៉ាលី KH 00991884 ["ក្រោយមកប្រធានភូមិ [អណ្ដូងថ្ម នៃក្រុងព្រះសីហនុ] ឈ្មោះ យ៉ក បានប្រជុំរៀបចំឱ្យមានអ្នកដឹកនាំបុរសចាស់ នារី និងកងចល័តយុវជន យុវនារី សម្រាប់ធ្វើទំនប់ប្រឡាយ និងធ្វើស្រែ។ ពេលនោះខ្ញុំនិងគ្រួសារឱ្យចូលបុរសចាស់ធ្វើស្រែភ្ជួររាស់តាមភូមិដែលតម្រូវការរបស់អង្គការថ្នាក់លើ មេកងឈ្មោះ ម៉ាត់ [...] បញ្ជូនកម្លាំងរបស់ខ្ញុំឱ្យទៅធ្វើនៅភូមិបិតត្រាំង ទៅដល់ការដ្ឋានបិតត្រាំងចាប់ផ្ដើមដកស្ទូង"]។

2730 ឯកសារ D1.3.27.18 កំណត់ហេតុ នៃការប្រជុំលេខា និងភស្តុភារ របស់កងពល និងវរៈសេនាធំ ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ១៩៧៦ KH 00052399។ សូមមើលផងដែរនូវ ឯកសារ D1.3.27.22 កំណត់ហេតុ នៃការប្រជុំគណៈកងពលពេញអង្គ KH 00088934 ["ស្នើពិនិត្យរក ធ្វើអាងលើដីខ្ពស់ សំរាប់បង្ហូរទឹកមកដីទាប។ ខាង ១៦៤ អាចធ្វើបាន ព្រោះមានភ្នំ"]។

2731 ឯកសារ D114/239 កំណត់ហេតុស្ដាប់ចម្លើយ សៅ ម៉េន ឆ.12 ឆ.45 ["ស៖ តើលោកស្រីចាំថាមានមនុស្សប៉ុន្មាននាក់ធ្វើការនៅបិតត្រាំងដែរឬទេ? ឆ.12៖ ធ្វើការច្រើនណាស់ មានរាប់រយ។ យើងតម្រង់ជួរវែង ចាំយកបបរហូប [...] ស៖ តើមានមនុស្សប្រហែលប៉ុន្មាននាក់ដែរធ្វើការនៅទំនប់បិតត្រាំងនោះ? ឆ.45៖ មានច្រើន រាប់រយ"]។ ឯកសារ D114/243 កំណត់ហេតុស្ដាប់ចម្លើយ ធក សែន ឆ.99 ["ស៖ តើមានមនុស្សប៉ុន្មាននាក់ ដែលធ្វើការនៅការដ្ឋាន

ទំនប់បិតត្រាំង? ឆ.99៖ រាប់រយនាក់"]។ ឯកសារ D114/139 កំណត់ហេតុស្ដាប់ចម្លើយ ងួន ឡាយ ឆ.106 ["ស៖ តើលោកឃើញមនុស្សធ្វើការនៅទីនោះទេ? ឆ.106៖ ឃើញ។ មានច្រើននាក់ ប្រហែលរាប់រយ រាប់ពាន់នាក់។ [...] ឃើញកំពុងធ្វើការ"]។ ឯកសារ D54/90 កំណត់ហេតុស្ដាប់ចម្លើយ កុយ ណែន ឆ.41 ["មានប្រហែលពី៨០០នាក់ទៅ១០០០នាក់ ដែលធ្វើការនៅគម្រោងនេះ"]។ ឯកសារ D2/6 កំណត់ហេតុស្ដាប់ចម្លើយ ញូង ជ្រោង ឆ.26 ["មនុស្សមានច្រើនណាស់ ដោយប្រមូលមនុស្សទូទាំងតំបន់កងកេង ប្រហែលជា៥០០ ទៅ៦០០នាក់ [ទៅធ្វើការនៅគម្រោងសាងសង់ទំនប់]"]។ ឯកសារ D54/18 កំណត់ហេតុស្ដាប់ចម្លើយ នូ សារឿន ឆ.13 ឆ.15 ឆ.16 ["ស៖ តើខ្មែរក្រហមបានបង្ខំឱ្យប្រជាជនធ្វើការនៅទំនប់អូរប្រៃដែរឬទេ? ឆ.13៖ បាទ គេឲ្យប្រជាជន និងពួកកងចល័តធ្វើពលកម្មនៅទីនោះ ខ្ញុំមិនបានចូលរួមទេ ពីព្រោះនៅពេលនោះខ្ញុំឋិតនៅកងកុមារ [...] ឆ.15៖ [...] គេបានប្រមូលប្រជាជនជាច្រើនមកពីសហករណ៍ ពីយោធា និងពីកងចល័តនានាឲ្យមកធ្វើនៅទីនោះតាមផែនការដែលគេកំណត់ [...] ឆ.16៖ តាមខ្ញុំស្មានមានមនុស្សរាប់រយនាក់ ដែលមើលទៅឃើញខ្មៅពាសពេញការដ្ឋាននោះ"]។ ឯកសារ D114/109 កំណត់ហេតុស្ដាប់ចម្លើយ ព្រំ សម្បត្តិ ឆ.194 ["មានមនុស្សច្រើនពីកងរបស់ខ្ញុំ និងកងផ្សេងទៀត"]។ ឯកសារ D114/243 កំណត់ហេតុស្ដាប់ចម្លើយ ធក សែន ឆ.99 ["ស៖ តើមានមនុស្សប៉ុន្មាននាក់ ដែលធ្វើការនៅការដ្ឋានទំនប់បិតត្រាំង? ឆ.99៖ រាប់រយនាក់"]។ ឯកសារ D114/40 កំណត់ហេតុស្ដាប់ចម្លើយ មូល ឈិន ឆ.21 ["ស៖ លោកនិយាយថា មានមនុស្ស៣០០នាក់ធ្វើការនៅទំនប់ទឹកនោះ។ តើហេតុអ្វីបានជាលោកដឹងអំពីតួលេខនេះច្បាស់លាស់ម្ល៉េះ? ឆ.21៖ ព្រោះខ្ញុំនៅទីនោះ ហើយពួកយើងធ្វើការជាមួយគ្នា។ យើងធ្វើការតាមក្រុម ហើយក្រុមនីមួយៗធ្វើការបន្តជាប់ៗគ្នា ហេតុដូច្នេះហើយបានជាខ្ញុំដឹង។ ពួកយើងមិនត្រឹមតែធ្វើការជិតគ្នាទេ ប៉ុន្តែយើងក៏ធ្វើការទល់មុខគ្នាដែរ គឺនៅម្ខាងទំនប់ម្នាក់ដើម្បីលើកដីចាក់សងខាងទំនប់"]។ ឯកសារ D114/96 កំណត់ហេតុស្ដាប់ចម្លើយ ចេង ឡុង ឆ.72 ["មានចំនួនមនុស្សច្រើនណាស់ គឺប្រហែល២០០ ទៅ៣០០នាក់"]។ ឯកសារ D114/156 កំណត់ហេតុស្ដាប់ចម្លើយ សឹង ណុច ឆ.191 ["ស៖ តើមានប្រហែលប៉ុន្មាននាក់ ៥០ ឬ១០០? ឆ.191៖ ៤០០ ឬ ៥០០"]។ ឯកសារ D114/121 កំណត់ហេតុស្ដាប់ចម្លើយ សួន ផ (កង៨៦ តំបន់៣៧) ឆ.24 ["យោធាដែលគេរំសាយចេញពីកងរបស់ខ្ញុំមានប្រហែលជា២០០ ទៅ៣០០នាក់ ដោយគេឲ្យចបយើងម្នាក់មួយៗសម្រាប់កាប់ដី និងលើកភ្លឺស្រែ។ យ៉ាងណាមិញ ខ្ញុំក៏បានសង្កេតឃើញមានមនុស្សផ្សេង ក្រុមបុរសផ្សេងៗទៀត សែងកណ្ដាប់ និងនារីៗស្ទូងស្រូវផងដែរ"]។ សូមមើលផងដែរនូវ ឯកសារ D114/83 កំណត់ហេតុស្ដាប់ចម្លើយ សុខ នាង ឆ.20 ["ស៖ តើអង្គភាពលោកស្រីបានទៅចូលរួមលើកទំនប់នៅបិតត្រាំងដែរឬទេ? ឆ.20៖ ខ្ញុំដឹងថាទីតាំងនេះស្ថិតនៅក្រោយទំនប់ពូធឿង។ ខ្ញុំស្គាល់ទីតាំងនេះ ដោយសារពួកយើងទៅស្ទូង និងច្រូតកាត់នៅក្បែរទំនប់នោះដែរ"]។ ឯកសារ D114/65 កំណត់ហេតុស្ដាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.16 ["ចូលដល់ឆ្នាំ១៩៧៧ ខ្ញុំត្រូវបានគេដកចេញ ហើយបញ្ជូនឱ្យទៅនៅកងផលិត។ កងផលិតរបស់ខ្ញុំមានឈ្មោះថា កងវរៈសេនាតូចលេខ២០។ ខ្ញុំត្រូវបានគេចាត់តាំងឲ្យលើកទំនប់ និងជីកប្រឡាយអស់រយៈពេលបួនខែ នៅកន្លែងស្នាច់ដែង និងបបុស"]។ ឯកសារ D114/6 កំណត់ហេតុស្ដាប់ចម្លើយ យិន តេង ឆ.88 ឆ.158 ["គេឲ្យដកស្ទូង និងជីកប្រឡាយ រែកដីធ្វើទំនប់។ [...] ខ្ញុំជួយច្រូតនៅជិតព្រលានយន្តហោះកងកេង [...] ឆ.158៖ គេឲ្យខ្ញុំរែកដី ធ្វើទំនប់ និងបែនស្រូវ"]។ ឯកសារ D54/89 កំណត់ហេតុស្ដាប់ចម្លើយ កុយ ណែន KH 00987092 ["នៅពេលនោះ ខ្មែរក្រហមបានរៀបចំកម្លាំងបីផ្នែក ១គឺសម្រាប់ធ្វើទំនប់ ទី២ គឺសម្រាប់ភ្ជួរស្រែ និងទី៣សម្រាប់ដកស្ទូង"]។ ឯកសារ D54/35 កំណត់ហេតុស្ដាប់ចម្លើយ ប្រាក់ សុខា ឆ.17 ["កងចល័តរបស់ខ្ញុំត្រូវបានដកចេញពីព្រែកចាកមកនៅតំបន់កងកេង ដែលពួកគេឲ្យយើង

676. នៅវត្តបិតត្រាង កម្មាភិបាលរំសាយ[2732] ត្រូវគេឱ្យវាយកម្ទេចព្រះវិហារ ដើម្បីយកដែកទៅរំលាយ សម្រាប់ប្រើប្រាស់ក្នុងការសាងសង់ទំនប់[2733]។ កម្មករនៅវត្តត្រូវគេបង្ខំឱ្យរំលាយដែក និងអាលុយមីញ៉ូម ដើម្បីធ្វើឆ្នាំង ខ្ទះ និងសម្ភារៈផ្សេងទៀត ក្នុងអំឡុងរបបនោះ[2734]។ កម្មករនៅចម្ការដូង ចេង

---

ធ្វើការនៅភូមិប្របុស និងភូមិពូធឿង នៅខាងជើងផ្លូវជាលេខ៤ ទល់មុខភូមិបិតត្រាំង។ យើងនៅទីនោះ ដាំស្រូវ និងកសាងទំនប់នៅទីនោះរហូតដល់ចុងឆ្នាំ ១៩៧៧"]។ ឯកសារ D114/96 កំណត់ហេតុស្តាប់ចម្លើយ ចេង ឡុង ឆ.69 ["ខ្ញុំបានឃើញគេធ្វើទំនប់"]។ ឯកសារ D114/240 កំណត់ហេតុស្តាប់ចម្លើយ ភិន វេញ ឆ.16 ["មានប្រជាជនយើងធ្វើការច្រើនណាស់ ហើយរួមទាំងកុមារផង"]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ុន យ៉ើ ឆ.21 ["ភារកិច្ចរបស់ខ្ញុំ ជីកប្រឡាយ និងរែកដីតែប៉ុណ្ណោះ"]។ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.87-89 ["ស៖ ពេលនោះលោកស្រីនៅក្នុងភូមិពូធឿងនៅឡើយទេឬ? ឆ.87៖ ចាស។ ស៖ តើគេឱ្យលោកស្រីធ្វើអ្វីខ្លះ? ឆ.88៖ គេឱ្យដកស្ទូង និងជីកប្រឡាយ រែកដីធ្វើទំនប់។ ស៖ តើលោកស្រីបានចូលរួមធ្វើទំនប់អ្វីខ្លះ? ឆ.89៖ ខ្ញុំបានធ្វើទំនប់ពូធឿង ទំនប់ពុទ្ធទេ ហើយខ្ញុំជួយច្រូតនៅជិតព្រលានយន្តហោះកងកេង"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.22 ["នៅថ្ងៃដែលដែលគេរំសាយពួកខ្ញុំ គឺគេឱ្យចបយើងម្នាក់មួយមុននឹងបញ្ជូនទៅធ្វើការនៅម្តុំព្រលានយន្តហោះកងកេង។ ជាចម្បងគេឱ្យពួកយើងកាប់ដី និងលើកភ្លឺស្រែ ដើម្បីឱ្យកងនារីស្ទូងស្រូវ"]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ុន យ៉ើ ឆ.18 ["កងផលិតហ្នឹង ជីកប្រឡាយ រែកដី"]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹង ណុច ឆ.37 ឆ.99 ["ខ្ញុំដាំដំឡូង និងជីកប្រឡាយ [...] ឆ.99៖ បើយើងរួចផែនការរើសដូង គេឱ្យជីកប្រឡាយ មួយក្រុមជីកបណ្តោយ ១០ម៉ែត្រ ទទឹង ៥ម៉ែត្រ ជម្រៅ ២ម៉ែត្រ"]។

2732 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.17-18 ["យោធាទាំងអស់ដែលធ្វើការនៅកំពង់សោមគឺស្ថិតក្រោមការគ្រប់គ្រងរបស់កងពលលេខ៣។ យោធាដែលធ្វើការនៅទីនោះ ជាយោធារំសាយ ពួកគេមានអាយុចាស់ៗ។ [...] ឆ.18៖ វាចាប់ផ្តើមក្រោមជ័យជម្នះឆ្នាំ១៩៧៥ ដែលយោធាចាស់ៗត្រូវបានរំសាយមួយចំនួន"]។

2733 ឯកសារ D54/91 កំណត់ហេតុស្តាប់ចម្លើយ កុយ ណៃន ឆ.3 ឆ.5 ["ពួកយោធាខ្មែរក្រហមបានរើបំបែកព្រះវិហារមួយទាំងមូលនៅក្នុងវត្តបិតត្រាំង ដើម្បីយកដែកទៅសាងសង់ស្ពាននេះ។ រឿងនេះពិត ខ្ញុំមិនបំភ្លើសទេ [...] ឆ.5៖ មានមនុស្សជាច្រើនត្រូវបានយោធាខ្មែរក្រហមបញ្ជូនទៅរើបំបែកព្រះវិហារ។ ពួកគេនិយាយអំពីរឿងនេះ ដូច្នេះខ្ញុំមិនចាំឈ្មោះពួកគេ ថាជាអ្នកណាមួយច្បាស់ទេ"]។ ឯកសារ D114/4 កំណត់ហេតុស្តាប់ចម្លើយ មុំ ម៉េង ឆ.7 ["នៅពេលនោះ វិហារគ្មានដំបូលទេ ពីព្រោះវាបាក់បែក ឬក៏ត្រូវគេរុះរើទៅហើយ"]។ ឯកសារ D54/19 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.3 ["ខ្ញុំបានឮពីចាស់ៗថា ពួកគាត់បានឃើញយោធាខ្មែរក្រហមបានវាយកម្ទេចព្រះវិហារក្នុងវត្តយកដែកទៅប្រើនៅទីនោះមែន [...] ក្រោយពីរបបខ្មែរក្រហមបានដួលរលំទៅ ខ្ញុំបានទៅមើលវត្តនោះ ហើយបានឃើញថា ព្រះវិហារពិតជាត្រូវបានវាយកម្ទេចមែន"]។ ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.12 ["ខ្មែរក្រហមនៅភូមិពូធឿងបន្ទាប់ពីឆ្នាំ១៩៧៥។ នៅភូមិបិតត្រាំង/ពូធឿង ខ្មែរក្រហមបានបំផ្លាញវត្តអារាមដោយយកដែកទៅធ្វើស្ពាន និងទ្វារទំនប់ទឹកដែលឥឡូវនេះមានឈ្មោះថា ទំនប់ បិតត្រាំង"]។

2734 ឯកសារ D114/39 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន KH 01065091 ["សាក្សីបានពន្យល់ថាទីនោះធ្លាប់ជាកន្លែងស្លដែកធ្វើឆ្នាំងនៅសម័យខ្មែរក្រហម"]។ ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.13 ឆ.16 ឆ.18

ហេង ប្រមូលដូង[2735] ហើយមានឡឥដ្ឋ និងក្បឿង នៅជិតកន្លែងកម្មករធ្វើការ[2736] ក៏ដូចជាកន្លែងវាយថ្ម នៅអូរម្លូ[2737]។

["សៈ លោកបាននាំយើងទៅវត្តបិតត្រាំង ហើយបានប្រាប់យើងថា វត្តនេះត្រូវបានគេយកធ្វើជាកន្លែងស្លដែក និងអាឡុយមីញ៉ូមសម្រាប់ធ្វើឆ្នាំងក្នុងសម័យខ្មែរក្រហម។ ហេតុអ្វីបានជាលោកដឹងអំពីរឿងនេះ? ឆ.13៖ ខ្ញុំដឹងអំពីរឿងនេះពីព្រោះខ្ញុំបានដើរឆ្លងកាត់វត្តនេះរាល់ពេលដែលខ្ញុំធ្វើដំណើរទៅធ្វើការនៅការដ្ឋានព្រែកចាក។ [...] ឆ.16៖ គេប្រើប្រាស់កន្លែងនេះ ដើម្បីស្លដែក និងលោហៈធាតុផ្សេងៗទៀតដើម្បីធ្វើឆ្នាំង ខ្ទះ និងសម្ភារផ្សេងៗទៀត។ [...] ឆ.18៖ កន្លែងស្លដែកនៅក្នុងវត្តបិតត្រាំងចាប់ផ្តើមដំណើរការរហូតដល់ឆ្នាំ១៩៧៩"]។

2735 D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉េន ឆ.29 ["ចម្ការដូងចេងហេង នៅភូមិអុង"]។ ឯកសារ D114/242 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ប៊ុនធី ឆ.9 ឆ.17 ["ឆ្នាំ១៩៧៥ ការហ្នឹងខ្ញុំអាយុប្រហែល ១២ឆ្នាំ។ គេយកខ្ញុំទៅប្រមូលផ្តុំក្មេងចម្ការដូងរាម [...] ឆ.17៖ កាលនោះ ព្រឹកឡើងគេឲ្យយើងបេះដូង"]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.21 ឆ.99 ឆ.184 ["សៈ តើកងកុមាររបស់លោកហ្នឹង គេឲ្យធ្វើអ្វីខ្លះ? ឆ.21៖ កាប់ព្រៃ រើសដូងទុំ។ [...] ឆ.99៖ បើយើងរួចផែនការរើសដូង គេឲ្យយើងជីកប្រឡាយ [...] សៈ មានជនស៊ីវិលធ្វើការនៅក្នុងចម្ការដូងទេ? ឆ.184៖ គ្មានជនស៊ីវិលធ្វើការនៅទីនោះទេ។ ក្រៅពីខ្ញុំទៅមានកុមារតូចៗ"]។ ឯកសារ D54/41 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ សារ៉ាន់ ឆ.19 ឆ.25 ["កងវរសេនាតូចរបស់ខ្ញុំត្រូវបានបញ្ជូនទៅបោះទីតាំងនៅចម្ការដូងរបស់ ចេង ហេង និងវាលយន្តហោះកងកេង។ [...] ឆ.25៖ មិនមានកងណាផ្សេងស្ថិតនៅក្បែរនោះទេ។ យើងជាយោធាមែន ប៉ុន្តែយើងត្រូវបានគេចាត់តាំងឲ្យទៅធ្វើស្រែនៅក្បែរចម្ការដូង"]។ ឯកសារ D114/243 កំណត់ហេតុស្តាប់ចម្លើយ ធក សែន ឆ.9 ឆ.51 ["នៅចម្ការដូង មេកងឈ្មោះ តាអាន និង ផុង [...] ឆ.51៖ នៅរាមហ្នឹង ចម្ការដូងរាមហ្នឹង"]។ ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ឆ.60 ឆ.92 ["ទៅចម្ការដូងចេងហេង គេឲ្យទៅរើសដូងនៅទីនោះ។ វាជាចម្ការមួយធំ [...] ឆ.92៖ គឺមាន ៤០នាក់ដែលគេបញ្ជូនទៅ ហើយមាន ១០នាក់ជាអ្នកត្រួតពិនិត្យ ហើយមាន៣០នាក់ ជាអ្នកធ្វើការធម្មតា"]។

2736 ឯកសារ D114/94 កំណត់ហេតុស្តាប់ចម្លើយ សំ វុទ្ធី ឆ.71 ឆ.74 ["យើងត្រូវបានគេបែងចែកជាបួនប្រាំក្រុម។ ក្រុមខ្ញុំជាអ្នកយកដីទៅដាក់ក្នុងម៉ាស៊ីនពុម្ពដើម្បីផលិតចេញជារាងក្បឿង មួយក្រុមទៀតយកក្បឿងទៅហាល មួយក្រុមទៀតយកក្បឿងដែលហាលហើយ មករៀបក្នុងឡ មួយក្រុមទៀតជាអ្នកយកឧសដាក់ក្នុងឡ [...] សៈ តើកន្លែងធ្វើក្បឿងហ្នឹងនៅទីណាដែរ? ឆ.74៖ វានៅជិតស្ពានចំដែង នៅពាក់កណ្តាលផ្លូវពីស្ពានចំដែងទៅរាម។ គេហៅចម្ការដូងចេងហេង"]។ ឯកសារ D114/156.1 កំណត់ហេតុស្តាប់ចម្លើយ សំ វុទ្ធី ឧបសម្ព័ន្ធ៖ គំនូសបង្ហាញទីកន្លែង KH 01374692។

2737 ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង សុំ ឆ.166 ["នៅក្នុងកងជើងទឹកដដែល តែគេដកឲ្យមកនៅវ៉ៃថ្ម ៧ ម៉ែត្រគូបក្នុងមួយថ្ងៃនៅអូរម្លូ នៅជិត ចម្ការដូង"]។

677. ក្រៅពីការងារទាំងនេះ ជនរងគ្រោះត្រូវបានបង្ខំឲ្យបំពេញការងារមួយចំនួនទៀត ដូចជា ដាំបន្លែ សាងសង់រចនាសម្ព័ន្ធ កាប់ឆ្ការព្រៃ ធ្វើឝ្បូង និងធ្វើដី[2738]។ ពួកគេមិនត្រូវបានអនុញ្ញាតឲ្យប្រកែក នឹងបញ្ជាឲ្យធ្វើការឡើយ[2739] និងគ្មានបានប្រាក់ "១ សេនសោះ"[2740]។

678. ជាញឹកញាប់ កម្មករត្រូវគេផ្ទេរទៅផ្ទេរមកឲ្យធ្វើការ នៅតាមការដ្ឋានតំបន់រាម[2741]។ នៅពេលសួរថាតើ "អ្នកធ្វើការនៅកងកេង និងបិតត្រាង និងអ្នកធ្វើការនៅស្ទាច់ដែង តែមួយទេឬ" ព្រំ សម្បត្តិ

---

2738 ឯកសារ D114/34 កំណត់ហេតុស្តាប់ចម្លើយ ណាប់ សុម៉ាលី ឆ.70 ["សៈ តើគេឲ្យលោកធ្វើអ្វីខ្លះនៅបិតត្រាំងនោះ? ឆ.70៖ គេឲ្យខ្ញុំកាប់ឈើដើម្បីយកមកធ្វើរោងដាក់ស្រូវ"]។ ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ឈុំ ឆ.19 ["សៈ តើអង្គភាពដុតឝ្បូងរបស់លោកស្ថិតនៅទីណាដែរ? ឆ.19៖ នៅអាហ្នឹងគេហៅថាចម្ការក្រូច គេហៅថាចម្ការនៅបិតត្រាំដែរ"]។ ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.12 ["ពេលខ្ញុំនៅសហករណ៍បបុស ខ្ញុំត្រូវបានចាត់ឲ្យធ្វើផ្ទះ ធ្វើរោង ធ្វើទំនប់បិតត្រាំង ភ្លឺស្រែ នេសាទត្រីសម្រាប់ផ្គត់ផ្គង់យោធានៅទឹកសាប និងសម្រាប់សហករណ៍បបុស"]។ ឯកសារ D114/96 កំណត់ហេតុស្តាប់ចម្លើយ ចេង ឡូង ឆ.20 ["ខ្មែរក្រហមឲ្យខ្ញុំដាំបន្លែ"]។ ឯកសារ D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉េន ឆ.8 ឆ.42 [" ឆ្នាំ១៩៧៥ ធ្វើនៅហ្នឹង [នៅភូមិ] ដល់៧៦ ក៏នៅធ្វើដែរ ហើយ៧៦ ហ្នឹងធ្វើស្រែ [...] ឆ.42 ៖ ដកស្ទូង កាប់ដី រែកដី"]។ ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.16 ["ស្ថានភាពការងាររបស់យើងគឺគេឲ្យយើងកាប់ដី ដកស្ទូងស្រូវ រែកកណ្តាប់ និងភ្លឺស្រែ"]។ ឯកសារ D114/76 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.21 ["គេបញ្ជូនខ្ញុំតែឯងឲ្យមកធ្វើស្រែនៅកងកេង"]។ ឯកសារ D114/242 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ប៊ុននី ឆ.32 ["ថ្ងៃណាកាប់ព្រៃ កាប់ព្រៃ"]។ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ.39 ["៦ ទៅ ៧ឆ្នាំ ក្មេងតូចៗ ឲ្យនៅកន្លែង ក្មេងណាដែលធំឲ្យលើកបាច់ទន្ទ្រានខេត្ត [នៅសហករណ៍ក្នុងភូមិពូធឿង]"]។ ឯកសារ D59/1/4.25 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡុង លី KH 00930799 ["ការងារប្រចាំថ្ងៃយើងដឹកនាំគេធ្វើស្រែ ដឹកនាំផ្សំជីដាក់ស្រូវ"]។

2739 ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.118 ["សៈ តើលោក ឬអ្នកដទៃអាចបដិសេធមិនធ្វើការតាមការចាត់តាំងដែរឬទេ? ឆ.118៖ គឺមិនបានតែម្តង ហើយកុំតវ៉ា។ គេប្រើឲ្យធ្វើអី គិតតែធ្វើទៅ"]។

2740 ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.119។

2741 សូមមើល ឧទាហរណ៍ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.172 ["សៈ អ្នកធ្វើការនៅកងកេង និងបិតត្រាំង និងអ្នកធ្វើការនៅស្ទាច់ដែងតែមួយទេឬ? ឆ.172៖ បាទ ពួកគេធ្វើការនៅវាលស្រែក្នុងតំបន់ទាំងនេះជាមួយគ្នា"]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.66 ឆ.192 ឆ.198-199 ["មន្ទីរកងវរៈសេនាតូចនោះ ហ្នឹង នៅទីនោះរហូត។ ប៉ុន្តែគេបញ្ជូនកងអនុសេនាធំ ទៅជួយធ្វើស្រែប្រជាជន។ [...] ឆ.192៖ មកពីចម្ការដូង និងសហករណ៍ជុំវិញនោះ។ [...] ឆ.198៖ ខ្ញុំនៅនោះ ពីរបីថ្ងៃហើយទៅកន្លែងផ្សេងទៀត។ [...] ឆ.199៖ លើកទំនប់ ហើយជីកប្រឡាយ"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.4 ឆ.17 ["ចំនួនមនុស្សនៅក្នុងកង ពេលខ្លះឡើងចុះពីព្រោះពេលខ្លះ គេបញ្ជូនមនុស្សទៅឃុំនៅទឹកសាប។ ហើយជួន ពេលខ្លះ គេបញ្ជូនមនុស្សចូលមកវិញ។ [...] ឆ.17៖ កងចល័តរបស់ខ្ញុំក៏ធ្វើការនៅប៉ែកខាងត្បូងផ្លូវជាតិលេខ៤ដែរ។ យើងធ្វើការនៅក្នុង

ឆ្លើយថា "បាទ ពួកគេធ្វើការនៅវាលស្រែក្នុងតំបន់ទាំងនេះជាមួយគ្នា"[2742]។ ដូចបានរៀបរាប់រួចមកហើយ ជារឿយៗ កម្មាភិបាលវាសាយ និងជនស៊ីវិល ធ្វើការនៅក្បែរគ្នា[2743]។

---

តំបន់ជុំវិញព្រលានកងកេង ហើយនឹងតំបន់ជិតទឹកសាប យើងបានលើកទំនប់មួយនៅភូមិបបុស ឬហៅថា ទំនប់បបុស/អូរប្រៃ/បិតត្រាំង"]។ ឯកសារ D114/96 កំណត់ហេតុស្តាប់ចម្លើយ ចេង ឡូង ឆ.72 ["កម្លាំងទាំងនោះត្រូវបានគេប្រមូលមកពីភូមិផ្សេងៗយកមកធ្វើការនៅការដ្ឋានទំនប់នោះ។ ឧទាហរណ៍ មនុស្ស១០០នាក់ មកពីភូមិបបុស ឬក៏ប្រជាជនមកពីភូមិបិតត្រាំងប្រហែល២០០នាក់ជាដើម"]។ ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ ស្លូន ឈុំ ឆ.58-59 ["គេខាងសហករណ៍ពូធឿងណោះ អាហ្នឹងគេទៅធ្វើទាំងអស់គ្នា [...] ឆ.59៖ ដំបូងឡើយ គេថាកែនគ្រប់សហករណ៍ទាំងអស់ទៅធ្វើ"]។ ឯកសារ D114/34 កំណត់ហេតុស្តាប់ចម្លើយ ណាប់ សុម៉ាលី ឆ.67 ["សៈ តើលោកមានចាំថាលោកទៅបិតត្រាំងនៅឆ្នាំណាទេ? ឆ.67៖ ខ្ញុំមិនចាំទេ ខ្ញុំនៅទីនោះតែមួយរយៈខ្លីប៉ុណ្ណោះ ពេលខ្លះមួយសប្តាហ៍ ពេលខ្លះត្រឹមតែ ២-៣ថ្ងៃ។ ខ្ញុំត្រូវបានចល័តម្តងទីនេះ ម្តងទីនោះ"]។ ឯកសារ D54/121 កំណត់ហេតុស្តាប់ចម្លើយ លិន សារិន ឆ.10 ["គេបញ្ជូនខ្ញុំទៅធ្វើការទីនេះម្តង ទីនោះម្តង មិនមែននៅមួយកន្លែងនោះទេ"]។ ឯកសារ D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉េន ឆ.10 ["ដើរចល័ត ទៅពុតតេ គគីរ ពូធឿង បបុស មួយថ្ងៃពីរថ្ងៃ មុនពេលបន្តទៅកន្លែងផ្សេងៗទៀត"]។ ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.15 ឆ.17 ["គេបានប្រមូលប្រជាជនជាច្រើនមកពីសហករណ៍ ពីយោធា និងពីកងចល័តនានាឲ្យមកធ្វើនៅទីនោះតាមផែនការដែលគេកំណត់។ [...] ឆ.17៖ ពួកគាត់ [ឪពុកម្តាយខ្ញុំ] ធ្វើស្រែនៅសហករណ៍ ប៉ុន្តែគេឲ្យពួកគាត់ទៅរែកដីលើកទំនប់នោះដែរ"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.21 [អ្នកធ្វើការនៅស្នាច់ដែងបានបញ្ជាក់ថា "ពួកយើងទៅស្ទូង និងច្រូតកាត់នៅក្បែរទំនប់ [បិតត្រាំង] នោះដែរ"]។ ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ឆ.24 ឆ.26-27 ឆ.31-32 ["វរសេនាធំលេខ២២ ជាអ្នកផ្តើមធ្វើទំនប់នោះ។ អ្នកធ្វើការនៅទីនោះរួមមានទាំងប្រជាជន កងផលិត និងកងទ័ព។ [...] ឆ.26៖ មនុស្សមានច្រើនណាស់ ដោយប្រមូលមនុស្សទូទាំងតំបន់កងកេង ប្រហែលជា៥០០ ទៅ៦០០នាក់"]។ សូមមើលផងដែរនូវ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ. 88 ["គេឲ្យដកស្ទូង និងជីកប្រឡាយ រែកដីធ្វើទំនប់"]។ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក (បានធ្វើការនៅក្នុងកងកុមារនៅភូមិពូធឿងពីខែ តុលា ឆ្នាំ ១៩៧៥ ដល់ ខែ តុលា ឆ្នាំ ១៩៧៦ ហើយនិងចាប់ពី ១៩៧៧ ដល់ ១៩៧៨) ឆ.57-58 ឆ.216-217 ["[កងកុមារនៅ]ក្នុងភូមិពូធឿង ដែលនៅចម្ងាយប្រមាណជា ៣គីឡូម៉ែត្រពីផ្លូវជាតិ។ សៈ តើផ្លូវជាតិមួយណា? ឆ.58៖ ផ្លូវជាតិលេខ ៤។ [...] សៈ អ៊ីចឹងស្រែដែលលោកស្រីទៅស្ទូងនៅជិតព្រលានយន្តហោះកងកេង មែនទេ? ឆ.216៖ ចាស វាដីរាប់រយហិកតានៅសងខាងផ្លូវជាតិ។ សៈ ចុះបើប្រៀបធៀបនឹងព្រលានយន្តហោះវិញ? ឆ.217៖ នៅជាប់ និងជុំវិញព្រលានយន្តហោះ"]។

2742 ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.172។ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.23-25 [រស់នៅថ្មធំបានរយៈពេលប្រហែល៦-៧ខែ មុនគេបញ្ជូនមកភូមិពូធឿង៖ "អំឡុងពេលខ្ញុំរស់នៅភូមិថ្មធំ គេឲ្យដាំដំណាំ និងជួនកាលគេឲ្យទៅជីកប្រឡាយនៅភូមិពូធឿង"]។

2743 ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ.57-60 ["សៈ កងនោះស្ថិតនៅឯណា? ឆ.57៖ ក្នុងភូមិពូធឿង ដែលនៅចម្ងាយប្រមាណជា ៣គីឡូម៉ែត្រពីផ្លូវជាតិ។ សៈ តើផ្លូវជាតិមួយណា? ឆ.58៖ ផ្លូវជាតិលេខ ៤។ សៈ

679. ជនរងគ្រោះនៅតាមការដ្ឋានគ្មានជម្រើសអ្វី ក្រៅពីធ្វើការនោះទេ[2744] និងមិនត្រូវគេអនុញ្ញាតឱ្យដើរហើរដោយគ្មានការអនុញ្ញាតឡើយ[2745] ហើយត្រូវទៅកន្លែងណាដែលគេប្រាប់ឱ្យទៅ[2746]។ "ជំនាន់នោះ ដូចគេវាស់ម៉ែត្រឱ្យដើរតែម្តង"[2747]។ ពួកគេត្រូវនាំទៅការដ្ឋានតែម្តងនៅពេលព្រឹក និងត្រឡប់ទៅកន្លែងសម្រាកវិញ នៅពេលល្ងាច[2748]។ សាក្សីបានឆ្លើយថា "ប្រជាជនមិនត្រូវបានអនុញ្ញាតឱ្យ

---

តើនរណាជាមេបញ្ជាការកងកុមារីនោះ? ឆ.59៖ ឈ្មោះ សាត់ (ស្រី)។ ស៖ តើស្រីទាំងអស់ដែលនៅមើលថែកុមារនោះ គាត់ជាសមាជិកកងនារីមួយទៀតមែនទេ? ឆ.60៖ ទេ ពួកគេមិននៅក្នុងកងនារីណាឡើយ។ ប៉ុន្តែ មេកងឈ្មោះសាត់ ត្រូវបានផ្ទេរមកពីអង្គភាពកងទ័ពនារី"]។ ឯកសារ D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉ែន ឆ.62 ["ស៖ តើលោកស្រីដែលធ្លាប់ធ្វើការក្នុងកងចល័តជាមួយនឹងយោធាខ្មែរក្រហមដែរឬទេ? ឆ.62៖ ធ្វើជាមួយវាហ្នឹង ដកស្ទូងជាមួយវាហ្នឹង។ វាស្ទូង យើងក៏ស្ទូងដែរ។ នៅចល័តជាមួយយើង បើយើង១២នាក់ វាមានពីពីរនាក់ទៅប្រាំមួយនាក់នៅធ្វើការជាមួយយើង"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ នៅម៉ោង 14.16.09-14.19.37 ["ខ្ញុំបានរស់នៅជាមួយគ្នា បានធ្វើការជាមួយគ្នានឹងប្រជាជន១៧មេសា នៅបុស្ស ពុតទេ នៅភូមិគគីរនោះហើយ ដែលបាត់បង់អស់ហើយ ក៏យើងខ្ញុំនៅធ្វើការជាមួយអង្គភាព ដែលនៅអ្នកដឹកអ្នកធ្វើស្រែ បាទ អ្នកធ្វើស្រែនៅក្នុងកងរបស់ខ្លួន ដែលមិនល្អជាមួយគ្នានោះ ឃើញថាពេលនោះក៏គេយកចិត្តទុកដាក់ប្រឹកប្រែងកសាងខ្លួនរួចហ្នឹង ហើយក៏វិលត្រឡប់ទៅនៅក្នុងអង្គភាពចាស់វិញ។ រីឯជីវប្រវត្តិរបស់ប្រជាជន ១៧មេសា នេះឃើញថា ដូចខ្ញុំបានជម្រាបពីខាងដើមហើយព្រឹកមិញនោះ ក្រោយពីបានគេដឹកយកទៅសម្លាប់ចោលអស់"]។ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ នៅម៉ោង 14.16.09-14.19.37 ["ខ្ញុំបានរស់នៅជាមួយគ្នា បានធ្វើការជាមួយគ្នានឹងប្រជាជន១៧មេសា នៅបុស្ស ពុតទេ នៅភូមិគគីរនោះហើយ"]។

2744 ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.160 ["ស៖ តើលោកស្រីធ្វើការដោយស្ម័គ្រចិត្ត ឬក៏គេបង្ខំ? ឆ.160៖ ទោះបីខ្ញុំប្រាប់គេថា ខ្ញុំចុកពោះ ក៏គេបង្ខំឱ្យធ្វើការងារដែរ"]។ ឯកសារ D114/243 កំណត់ហេតុស្តាប់ចម្លើយ ធក សែន ឆ.13 ["ស៖ តើលោកខ្លួនឯងចង់ទៅធ្វើការនៅចម្ការដូងនោះដែរទេ? ឆ.13៖ គ្មានទេ ព្រោះបែកពីម៉ែពីឪទៅវាកម្សត់ខ្លួន"]។

2745 ឯកសារ D114/94 កំណត់ហេតុស្តាប់ចម្លើយ សំ វុទ្ធី ឆ.80-81 ["គេមិនឱ្យខ្ញុំទៅណាឡើយ [...] ឆ.81៖ គេមិនឱ្យយើងចេញពីកន្លែងរបស់យើងឡើយ"]។ ឯកសារ D114/3 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.7 ["យើងមិនដើររហេតរហូតកើតទេ"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.33 ["ស៖ តើគេអនុញ្ញាតឱ្យលោកចាកចេញពីកន្លែងស្នាក់នៅ និងកន្លែងការងារដែរឬទេ? ឆ.33៖ អត់ទេ ពេលធ្វើការគឺយើងពុំអាចចេញពីកន្លែងធ្វើការបានទេ បើមិនដូច្នេះទេ គឺគេចាប់ខ្លួនហើយ"]។

2746 ឯកសារ D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉ែន ឆ.8 ["គេបញ្ជូនទៅណាយើងទៅហ្នឹង"]។

2747 ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ សួន ឈុំ ឆ.47។

2748 ឯកសារ D114/3 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.7 ["រៀងរាល់ព្រឹក ប្រធានកងឈ្មោះ សារី នាំយើងទៅកាន់កន្លែងធ្វើការតែម្តង។ នៅពេលល្ងាច គេនាំយើងមកភូមិវិញ"]។

ដើរទៅណាមកណារហេតរហូតទេ”[2749] និង “និយាយរួម ពួកខ្ញុំដូចគេឃុំឃាំងចំហ”[2750]។ អ្នកដែលព្យាយាមរត់គេចពីការដ្ឋាន “ត្រូវគេចាប់ដាក់ខ្នោះបញ្ជូនទៅទឹកសាប”[2751]។ ជនរងគ្រោះម្នាក់បានបញ្ជាក់ថា៖ “បើខ្ញុំរត់ ហើយគេចាប់បាន គឺច្បាស់ជាស្លាប់ហើយ”[2752]។

680. នៅតាមការដ្ឋានជាច្រើន គេកំណត់ផែនការប្រចាំថ្ងៃឱ្យកម្មករធ្វើ[2753] រួមទាំងកម្មករជាកុមារ[2754]។ នៅតាមការដ្ឋានសាងសង់ទំនប់ ផែនការនេះត្រូវបានកំណត់ជារួម គឺត្រូវជីក និងរែកដីឱ្យបាន ៣

---

2749 ឯកសារ D54/90 កំណត់ហេតុស្ដាប់ចម្លើយ កុយ ណែន ឆ.19។ សូមមើលផងដែរនូវ ឯកសារ D54/123 កំណត់ហេតុស្ដាប់ចម្លើយ ឡាក់ សាផាន ឆ.2 [“គេមិនឱ្យពួកយើងដើរទៅណាមកណាទេនៅពេលយប់ លុះត្រាណាតែគេចាត់តាំងឱ្យយើងធ្វើអ្វីមួយដូចជាលើកទំនប់ និងលើកភ្លឺស្រែជាដើម”]។ ឯកសារ D114/117 កំណត់ហេតុស្ដាប់ចម្លើយ ណាវ សុខន ឆ.126 [“ស៖ ចុះលោកស្រីអាចទៅណាបានតាមចិត្តទេ? ឆ.126៖ ទេ”]។

2750 ឯកសារ D114/94 កំណត់ហេតុស្ដាប់ចម្លើយ សំ វុទ្ធី ឆ.102។ ឯកសារ D114/96 កំណត់ហេតុស្ដាប់ចម្លើយ ចេង ឡុង ឆ.21-22 [“នៅពេលនោះគឺប្រៀបដូចជារស់នៅក្នុងគុកអ៊ីចឹង [...] ឆ.22៖ ព្រោះខ្ញុំមិនត្រូវបានគេអនុញ្ញាតឱ្យទៅទីកន្លែងណាទេ”]។ សូមមើលផងដែរនូវ ឯកសារ D114/179 កំណត់ហេតុស្ដាប់ចម្លើយ សួន ឈុំ ឆ.26 [“ជំនាន់នោះដូចគេវាស់ដីឱ្យយើងដើរអ៊ីចឹង។ គ្រាន់តែដើរឆ្លងពីភូមិរបស់យើងទៅភូមិដទៃទៀត ក៏អត់បានដែរ”]។

2751 ឯកសារ D114/109 កំណត់ហេតុស្ដាប់ចម្លើយ ព្រំ សម្បត្តិ ឆ.139។ សូមមើលផងដែរនូវ ឯកសារ D114/242 កំណត់ហេតុស្ដាប់ចម្លើយ ប្រាក់ ប៊ុនធី ឆ.82-83 [“ខ្ញុំឮសួរមេៗខ្ញុំនិយាយថា សុទ្ធតែកងទ័ពខុសនយោបាយ [...] ឆ.83 ៖ អ្នកជាប់ទោសទាំងនោះ កាលជំនាន់ហ្នឹង គេយកមកមន្ទីរឃុំឃាំង នៅទឹកសាបនេះ”]។

2752 ឯកសារ D114/121 កំណត់ហេតុស្ដាប់ចម្លើយ សួន ផ ឆ.39។ សូមមើលផងដែរនូវ ឯកសារ D114/31 កំណត់ហេតុស្ដាប់ចម្លើយ មូល ឈិន ឆ.116 [“គេមកជួប និងសួរនាំខ្ញុំច្រើនដងនៅផ្ទះឪពុកម្ដាយខ្ញុំ ហើយចុងក្រោយ គេបានយកខ្ញុំទៅដាក់គុកតែម្ដង ដោយសារតែពួកគេស្គាល់ខ្ញុំ គេមិនវៃដំខ្ញុំទេ គ្រាន់តែយកទៅដាក់គុកតែប៉ុណ្ណោះ។ មិនងាយមានអ្នកណាម្នាក់អាចរត់គេចចេញពីការដ្ឋានព្រៃកចាក បានឡើយ គឺតឹងរ៉ឹងខ្លាំងណាស់។ បើសិនជាមាននរណាម្នាក់ព្យាយាមរត់គេច ហើយគេចាប់បាន គឺគេសម្លាប់ចោលភ្លាមតែម្ដង”]។

2753 ឯកសារ D114/6 កំណត់ហេតុស្ដាប់ចម្លើយ យិន តេង ឆ.35-36 [“មេភូមិខ្លួនឯងជាអ្នកប្រាប់ថា ប្រជាជនត្រូវលើកដី ១ម៉ែត្រគូបក្នុងម្នាក់ឱ្យហើយក្នុងមួយថ្ងៃ [...] ឆ.36៖ មានការងារជាច្រើនដែលគេចាត់តាំងឱ្យធ្វើ ដូចជាប្អូននាក់ត្រូវច្រូតស្រូវឱ្យហើយ១ហិកតាក្នុង១ថ្ងៃ។ ឧទាហរណ៍ ម្នាក់ៗត្រូវដាំដំឡូងជ្វាឱ្យហើយ២០រងក្នុង១ថ្ងៃ។ ប្អូននាក់ត្រូវដាំដំឡូងមី៤០រងឱ្យហើយក្នុង១ថ្ងៃ”]។ ឯកសារ D114/244 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុន យឿ ឆ.29 [“ស៖ តើគេមានឃ្លាំមើលពេលលោកធ្វើការដែរឬទេ? ឆ.29៖ មានគេខាងលើគេកំណត់ការងារ ធ្វើម្នាក់ប៉ុន្មាន អានេះយើងធ្វើឱ្យរួច១ថ្ងៃ”]។ ឯកសារ D234/2.1.64 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ នាក់ យ៉ន EN 00445712 [“[គេ]ត្រូវដាំស្រូវឱ្យបានមួយហិកតាក្នុងមួយថ្ងៃ”]។ ឯកសារ D54/20 កំណត់ហេតុស្ដាប់ចម្លើយ សំ សោម ឆ.14 [“គេចាត់តាំងឱ្យខ្ញុំកាប់ផ្ដាក់ដីស្រែដោយប្រើចបឱ្យបានពីរកុង (២០ម៉ែត្រការ៉េ) មួយថ្ងៃ”]។ ឯកសារ D114/79 កំណត់ហេតុស្ដាប់ចម្លើយ កង សុំ ឆ.175 [“ស៖ តើលោករៀបរាប់ពីការរស់នៅនៅអូរម្ចនោះបានដែរឬទេ? ឆ.175៖ ព្រលឹមឡើង

ម៉ែត្រគូប ក្នុងមួយថ្ងៃ[2755]។ សាក្សីខ្លះចាំថាគេដាក់ផែនការឱ្យលើកដីឱ្យបាន ១ ឬ ២ ម៉ែត្រគូប ក្នុងមួយថ្ងៃ ឯសាក្សីខ្លះទៀតចាំថាគេកំណត់ឱ្យលើកដីឱ្យបាន ៥ ម៉ែត្រគូប ក្នុងមួយថ្ងៃ[2756]។ ផែនការក៏

---

គេកំណត់ឱ្យម្នាក់វែថ្មឱ្យបាន ៧ម៉ែត្រគូបក្នុងមួយថ្ងៃ"]។ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន គេង ឆ.90 ["ស៖ សូមលោកស្រីរៀបរាប់អំពីការច្រូតស្រូវនៅជិតព្រលានយន្តហោះកងកេង? ឆ.90៖ គេឱ្យច្រូតស្រូវម្នាក់២ហិកតា ក្នុងរយៈពេលមួយថ្ងៃកន្លះ"]។ សូមមើលផងដែរនូវ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ. 26 ["ស៖ តើលោកស្រីអាចបដិសេធមិនធ្វើការបានដែរឬទេក្នុងគ្រានោះ? ឆ.26៖ (សាក្សីសើច) ពួកគេមានផែនការរបស់ពួកគេ។ គេឱ្យយើងបំពេញការងារតាមផែនការរបស់ពួកគេ ហើយក្រោយមក គេធ្វើការត្រួតពិនិត្យពីការងារដែលយើងបានធ្វើ គឺមេបញ្ជាការកងអនុសេនាធំរបស់ខ្ញុំតែម្តង ដែលត្រួតពិនិត្យការងាររបស់ពួកខ្ញុំ។ យើងទាំងអស់គ្នាគឺចាំ ហើយមានទម្លាប់ថា បើយើងមានសុខភាពល្អ គឺយើងត្រូវតែទៅធ្វើការ។ ប្រសិនបើអ្នកណាម្នាក់ឈឺ ក៏គេមិនបង្ខំឱ្យទៅធ្វើការដែរ តែក៏អាស្រ័យទៅលើពេលវេលាដែរ។ នៅពេលដែលយើងពុំសូវមានការងារ គឺយើងបានសម្រាកច្រើន ប៉ុន្តែបើសិនជាក្នុងរដូវច្រូតកាត់ គឺយើងត្រូវសម្រុកធ្វើការខ្លាំង"]។

2754 ឯកសារ D114/240 កំណត់ហេតុស្តាប់ចម្លើយ ភិន វេញ ឆ.19 ["ស៖ តើក្រុមកុមារ គេតម្រូវឱ្យធ្វើការបានប៉ុន្មានដែរក្នុងមួយថ្ងៃៗ? ឆ.19៖ បានច្រើន គិតទៅវាវាស់ម៉ែត្រគូបឱ្យ។ វាវាស់ឱ្យកុមារ បណ្តោយ១១០ម៉ែត្រ ទទឹង១០ម៉ែត្រ ហើយឱ្យកុមារជីកឱ្យហើយក្នុង១ថ្ងៃ"]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.98 ["គេប្រជុំគេប្រាប់ថា អង្គការដាក់ទិសដៅឱ្យរើសដូង ២០០ផ្លែ ក្នុងម្នាក់ បើរើសមិនបាន គេដាក់ឱ្យឈរហាលថ្ងៃហាលភ្លៀង ឬក៏ឱ្យធ្វើការងារធ្ងន់"]។

2755 ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.12 ["ពេលយើងលើកទំនប់នៅភូមិបបុស ម្នាក់តម្រូវឱ្យរែកដី៣ម៉ែត្រគូបឱ្យអស់ក្នុងមួយថ្ងៃ ហើយការជីកប្រឡាយក៏គេតម្រូវម្នាក់ៗឱ្យរែកអស់ ៣ម៉ែត្រគូបដែរ"]។ ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.20 ["ស៖ នៅទីតាំងទំនប់ទឹក លោកបានប្រាប់យើងថា ទឹកន្លែងនោះឯងដែលលោកពណ៌នានៅក្នុងការស្តាប់ចម្លើយរបស់លោក ដែលគេតម្រូវឱ្យលោកលើកដីបីម៉ែត្រគូបក្នុង១ថ្ងៃ [...] តើត្រឹមត្រូវដែរឬទេ ដែលថា អ្វីដែលលោកនិយាយត្រង់ចម្លើយទាំងនោះ គឺចង់សម្តៅទៅលើទីតាំងទំនប់ទឹក និងកន្លែងនានាដូចជា វាលស្រែនៅម្តុំទំនប់ទឹកនោះ។ ឆ.20៖ បាទ ត្រឹមត្រូវហើយ"]។ ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.22 ["ស៖ លោកនិយាយថា ១០នាក់ក្នុងចំណោមមនុស្សទាំង៣០០នាក់ ត្រូវបានគេចាត់តាំងឱ្យយាមទំនប់រៀងរាល់យប់។ តើគេឱ្យអ្នកទាំងនោះឈប់សម្រាកដែរឬទេ នៅថ្ងៃបន្ទាប់ ឬក៏ពួកគេត្រូវបានតម្រូវឱ្យបំពេញការងារ៣ម៉ែត្រគូបដដែលក្នុង១ថ្ងៃ? ឆ.22៖ ព្រឹកបន្ទាប់ អ្នកទាំង១០នាក់នោះ គេតម្រូវឱ្យធ្វើការជាធម្មតា ពុំឱ្យឈប់សម្រាកទេ"]។ ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.42 ["មនុស្សម្នាក់ៗត្រូវបានវាស់ដីឱ្យរែក ពី២ទៅ៣ម៉ែត្រគូបក្នុងមួយថ្ងៃ"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.112 ["យើងត្រូវច្បាស់លាស់នឹងការងារខ្លាំងណាស់ ដើម្បីអាចធ្វើការងារដែលគេដាក់ឱ្យ ឱ្យសម្រេចគឺ៣ម៉ែត្រគូបម្នាក់ក្នុង១ថ្ងៃ"]។

2756 ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.15 ["តាមដែលខ្ញុំចាំ គេសាងសង់ទំនប់នោះរួចក្នុងរយៈ ២-៣ខែ ពីព្រោះគេបានប្រមូលប្រជាជនជាច្រើនមកពីសហករណ៍ ពីយោធា និងពីកងចល័តនានាឱ្យមកធ្វើនៅទីនោះតាមផែនការដែលគេកំណត់។ គេបានបែងចែកផែនការ ដូចជាទំនប់ប្រវែង២០ម៉ែត្រទៅឱ្យក្រុមនីមួយៗឱ្យបញ្ចប់ក្នុងរយៈ

ត្រូវបានអនុវត្តផងដែរ ចំពោះការងារប្រភេទផ្សេងទៀត ដូចជា មួយក្រុមត្រូវជីកដីឱ្យបាន ១ ហិចតា ក្នុងមួយថ្ងៃ[2757] រើសដូងឱ្យបាន ១.៦០០ ផ្លែ ក្នុងមួយថ្ងៃ[2758] វាយបំបែកថ្មឱ្យបាន ៧ ម៉ែត្រគូប ក្នុងមួយថ្ងៃ[2759] ឬលើកទំនប់ឱ្យបាន ២០ ម៉ែត្រ ក្នុងរយៈពេល ១០ ថ្ងៃ[2760]។

681. ការមិនសម្រេចបានតាមផែនការត្រូវទទួលរងទណ្ឌកម្ម ហើយជារឿយៗ ទណ្ឌកម្មនេះមានទម្រង់ជាការងារបន្ថែម៖ "គេកំហិតឱ្យយើងធ្វើឱ្យហើយ បើមិនហើយ វាមិនឱ្យឈប់"[2761]។ ទម្រង់ញឹកញាប់មួយទៀតនៃទណ្ឌកម្មចំពោះការធ្វើការងារមិនហើយ គឺការបង្អត់អាហារ។ សាក្សីម្នាក់បានពន្យល់ថា ប្រសិនបើកម្មករមិនអាចបញ្ចប់ការងារដែលគេដាក់ឱ្យធ្វើ គេជេរថា៖ "ពួកឯងធ្វើការប៉ុណ្ណឹងមិនហើយ ខ្ជះខ្ជាយ មិនយកចិត្តទុកដាក់ មិនឱ្យបាយស៊ីទេ បើថ្ងៃនេះធ្វើមិនហើយទេ មិន

---

ពេល១០ថ្ងៃ។ ដូចជាគេឱ្យយើងរែកដី ៥ម៉ែត្រគីបក្នុងម្នាក់ៗក្នុងមួយថ្ងៃ"]។ ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.42 ["មនុស្សម្នាក់ៗត្រូវបានវាស់ដីឱ្យរែក ពី២ទៅ៣ម៉ែត្រគូបក្នុងមួយថ្ងៃ"]។ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.198 ["ក្នុងម្នាក់គេឱ្យជីកមួយម៉ែត្រគុណនិងមួយម៉ែត្រ ក្នុងមួយថ្ងៃ"]។ សូមមើលផងដែរនូវ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.196 ["គេកំណត់ មួយក្រុម ១០ម៉ែត្រគូប"]។

2757 ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.10 ["មនុស្ស២៥នាក់ត្រូវបានចាត់តាំងឱ្យកាប់ (ជំនួសដោយភ្ជួរ) ដីស្រែ១ហិកតាក្នុង១ថ្ងៃឱ្យហើយ"]។

2758 ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ឆ.95 ["គេឱ្យធ្វើការពីម៉ោង ៧ ដល់ ១២ ហើយក្នុងមួយព្រឹកទាំងអស់គ្នារើសឱ្យបាន ១០០០ដូង។ ហើយល្ងាច គេឱ្យរើសឱ្យបាន ៦០០ដូង ហើយធ្វើការពីម៉ោង ១ ដល់ ៦ ជិត ៧យប់"]។

2759 ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.166 ឆ.230 ["នៅក្នុងកងជើងទឹកដដែល តែគេយកឱ្យមកនៅវៃថ្ម ៧ម៉ែត្រគូបក្នុងមួយថ្ងៃនៅអូរម្លូ នៅជិត ចម្ការដូង [...] ស៖ [...] នៅក្នុងឆ្នាំ១៩៧៦ តើមានអ្វីកើតឡើងចំពោះលោក? ឆ.230៖ ខ្ញុំនៅអូរម្លូជិតព្រលានយន្តហោះកងកេង"]។

2760 ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.15 ["គេបានបែងចែកផែនការ ដូចជាទំនប់ប្រវែង២០ម៉ែត្រទៅឱ្យក្រុមនីមួយៗឱ្យបញ្ចប់ក្នុងរយៈពេល១០ថ្ងៃ"]។

2761 ឯកសារ D114/240 កំណត់ហេតុស្តាប់ចម្លើយ ភិន វេញ ឆ.21-22 ["ស៖ តើមានបញ្ហាអ្វីដែរ បើយើងធ្វើការមិនរួច? ឆ.21៖ យើងធ្វើមិនរួចអីចឹង វាដាក់កំហិតយើងទៀត។ ស៖ តើគេកំហិតអ្វីខ្លះដែរទៅ? ឆ.22៖ គេកំហិតឱ្យយើងធ្វើឱ្យហើយ បើមិនហើយ វាមិនឱ្យឈប់"]។ សូមមើលផងដែរនូវ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.98 ["គេប្រជុំគេប្រាប់ថា អង្គការដាក់ទិសដៅឱ្យរើសដូង ២០០ផ្លែ ក្នុងម្នាក់ បើរើសមិនបាន គេដាក់ឱ្យឈរហាលថ្ងៃហាលភ្លៀង ឬក៏ឱ្យធ្វើការងារធ្ងន់"]។

បាច់បាយទឹកទេ"[2762]។ ពេលខ្លះ គេដាក់ទណ្ឌកម្មឱ្យធ្វើការបន្ថែមផង កាត់បន្ថយរបបអាហារផង៖ "គេតម្រូវឱ្យយើងធ្វើឱ្យហើយ ក្នុងមួយថ្ងៃដាច់ខាត បើធ្វើមិនចប់តាមផែនការគេកំណត់ គឺមិនឱ្យឈប់សម្រាកហូបបាយទេ"[2763]។ "ប្រសិនបើនរណាម្នាក់មិនអាចធ្វើចប់តាមការកំណត់ គាត់នឹងត្រូវបន្តការងារតទៅទៀត រហូតដល់ពេលយប់។ គេមិនឱ្យបាយហូបទេ បើគាត់មិនបញ្ចប់ការងាររបស់គាត់"[2764]។

682. ជនរងគ្រោះម្នាក់បានរៀបរាប់អំពីរបៀបនៃការដាក់ឱ្យអនុវត្តផែនការ នៅចម្ការដូង ចេងហេង៖ "ពេលប្រជុំ គេប្រាប់ថា អង្គការដាក់ទិសដៅឱ្យរើសដូង ២០០ ផ្លែ ក្នុងម្នាក់ បើរើសមិនបាន គេដាក់ឱ្យឈរហាលថ្ងៃ ហាលភ្លៀង ឬក៏ឱ្យធ្វើការងារធ្ងន់"[2765]។ ការធ្វើមិនហើយតាមការកំណត់ក៏អាចមានន័យស្មើនឹងការស្លាប់ផងដែរ៖ "ចំពោះអ្នកដែលបានបញ្ចប់ការងារនេះ ទើបអាចរស់បាន ចំពោះអ្នកណាដែលខ្ជិល ឈឺ ឬប្រឆាំងនឹងការរែកដី គេនឹងយកចេញទៅ ហើយក៏បាត់ខ្លួន"[2766]។ម្តងម្កាល កម្មករ រួមទាំងកុមារ ត្រូវបានវាយឱ្យធ្វើការ[2767]។

683. អ្នកធ្វើការត្រូវបានកម្មាភិបាលឃាមកាម[2768] និងបង្ខំឱ្យធ្វើការទាំងយប់ទាំងថ្ងៃ[2769] ដោយគ្មានថ្ងៃសម្រាកទាល់តែសោះ[2770]។ ពួកគេត្រូវបានបញ្ជូនទៅការដ្ឋាន នៅម៉ោងប្រហែល ៤ ឬ ៥ ព្រឹក

---

[2762] ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.38 ["គេជេរថា "ពួកឯងធ្វើការងារប៉ុណ្ណឹងមិនហើយ ខ្លះខ្ជាយមិនយកចិត្តទុកដាក់ មិនឱ្យបាយស៊ីទេ បើថ្ងៃនេះធ្វើមិនហើយទេ មិនបាច់បាយទឹកទេ""]។

[2763] ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.112។ សូមមើលផងដែរនូវ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.156 ["ស៖ តើមានអ្វីកើតឡើងចំពោះអ្នកដែលកាប់ដីមិនបាន ១០ម៉ែត្របួនជ្រុងនោះ? ឆ.156៖ គេពិន័យ ដូចជាគេដករបបបាយ"]។

[2764] ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.12។

[2765] ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.98 ["គេប្រជុំគេប្រាប់ថា អង្គការដាក់ទិសដៅឱ្យរើសដូង ២០០ផ្លែ ក្នុងម្នាក់ បើរើសមិនបាន គេដាក់ឱ្យឈរហាលថ្ងៃហាលភ្លៀង ឬក៏ឱ្យធ្វើការងារធ្ងន់"]។

[2766] ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.15។

[2767] ឯកសារ D114/243 កំណត់ហេតុស្តាប់ចម្លើយ ធក សែន ឆ.111 ["ស៖ តើគេវៃដូចម្តេចដែរ? ឆ.111៖ គេវៃឱ្យយើងឱ្យធ្វើការងារ"]។

[2768] ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.19 ["ស៖ តាមដែលលោកនៅចាំ តើពួកណាជាអ្នកឃាមពួកប្រជាជនដែលធ្វើការនៅទីនោះ? ឆ.19៖ ពួកយោធាខ្មែរក្រហម"]។ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.168 ["ខ្ញុំឃើញមានយោធាមកតាមដានយើងធ្វើការ ពេលយើងកំពុងធ្វើការ"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.122 ["ពួកយើងស្ថិតក្រោមការឃ្លាំមើលគ្រប់ពេលវេលា ដើម្បីឱ្យដឹងថា យើង

ហើយធ្វើការរហូតដល់ម៉ោង ១១ ព្រឹក រួចបន្តធ្វើការនៅម៉ោង ១ រសៀល រហូតដល់ម៉ោង ៦ ឬ ៧ យប់[2771]។ ប៉ុន្តែ អ្នកខ្លះត្រូវងើបតាំងពីម៉ោង ៣ ព្រឹក[2772] ហើយខ្លះទៀតត្រូវធ្វើការវេនទីបីនៅពេល

---

ធ្វើសកម្មភាពប្រឆាំងនឹងរបបនោះ ឬក៏រៀបចំផែនការរត់គេច"]។ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.173 ["ស៖ ទាហានតំបន់៣៥ យាមតំបន់ទាំងបីនោះឬ? ឆ.173៖ បាទ"]។ ឯកសារ D114/135 កំណត់ហេតុស្តាប់ចម្លើយ ណុប ផន ឆ.30 ["មានគេយាម និងត្រួតពិនិត្យ ថាតើយើងបានធ្វើការងាររបស់យើងដែរឬទេ"]។ សូមមើលផងដែរនូវ ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ិន សុត ឆ.64 ["មេៗគេដើរពិនិត្យមើលយើងធ្វើការតែនៅលើភ្លឺស្រែទេ"]។ ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.4 ["ខ្ញុំកត់សម្គាល់ឃើញថា កម្មាភិបាលដែលមានកាំភ្លើង ជាអ្នកកាន់ការងារ"]។ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.92-93 ["មានអ្នកយាមពីរនាក់តាមឃ្លាំមើលខ្ញុំច្រូតស្រូវ [...] ឆ.93៖ អ្នកទាំងពីរនោះមានកាំភ្លើងអាកាមួយដើម"]។

2769 ឯកសារ D114/96 កំណត់ហេតុស្តាប់ចម្លើយ ចេង ឡូង ឆ.69 ["ខ្ញុំអាចនិយាយបានថា ប្រជាជនដែលធ្វើការនៅកន្លែងលើកទំនប់ ពិតជាធ្វើការលំបាកណាស់ ព្រោះប្រជាជនធ្វើការទាំងយប់ទាំងថ្ងៃ។ ខ្ញុំអាចមើលឃើញគេធ្វើការពីកន្លែងខ្ញុំ ហើយខ្ញុំអាចមើលឃើញច្បាស់ដោយសារមិនមានដើមឈើបាំង"]។ សូមមើលផងដែរនូវ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.161 ["ស៖ តើគេឱ្យធ្វើការចាប់ពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន នៅភូមិគគីរ? ឆ.161៖ ចាប់ពីម៉ោង៦ព្រឹក ដល់ម៉ោង៥ល្ងាច"]។

2770 ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.107 ["ស៖ ពេលលោកស្រីនៅពួធឿង តើលោកស្រីធ្វើការរាល់ថ្ងៃឬ? ឆ.107៖ ចាស ខ្ញុំធ្វើរាល់ថ្ងៃ គឺធ្វើការពីម៉ោង៦ព្រឹកដល់ម៉ោង៦ល្ងាច"]។ ឯកសារ D114/96 កំណត់ហេតុស្តាប់ចម្លើយ ចេង ឡូង ឆ.24 ["យើងមិនអាចតវ៉ាបានទេ ហើយក៏មិនអាចឈប់សម្រាកបានដែរ យើងមិនមានថ្ងៃអាទិត្យថ្ងៃអីទេ"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.35-36 ["អត់មានពេលសម្រាកទេគឺធ្វើការ១អាទិត្យ ឬ១ខែពេញៗតែម្តង [...] ឆ.36៖ យើងអត់អាចទៅលេង ឬសុំឈប់សម្រាកបានទេ"]។ ឯកសារ D114/135 កំណត់ហេតុស្តាប់ចម្លើយ ណុប ផន ឆ.38 ["ស៖ ពេលដែលលោកនៅក្នុងកងចល័ត ហើយរស់នៅរួមបែបនេះ តើគេអនុញ្ញាតឱ្យលោកសុំច្បាប់ឈប់សម្រាកបានដែរឬទេ? តើលោកធ្លាប់សម្រាក ឬក៏ទៅលេងគ្រួសាររបស់លោកដែរឬទេ? ឆ.38៖ អត់ទេ"]។

2771 ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.113 ["ជាទូទៅម៉ោងធ្វើការងារ គឺនៅពេលព្រឹក ពីម៉ោង៥ព្រឹក រហូតដល់ម៉ោង១១ថ្ងៃត្រង់សម្រាក។ នៅពេលថ្ងៃ ចាប់ពីម៉ោង១ រហូតដល់ម៉ោង៦ល្ងាច"]។ ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.19 ឆ.42 ["យើងត្រូវចាប់ផ្តើមធ្វើការពីម៉ោង៤ព្រឹក ហើយត្រឡប់មកផ្ទះវិញនៅម៉ោង៧ ឬ៨ល្ងាច [...] ឆ.42៖ គេប្រមូលកម្លាំងប្រជាជននៅម៉ោង៤ទាបភ្លឺ ហើយចែកជាក្រុមៗទើបបញ្ជូនទៅឱ្យធ្វើការតាមកន្លែងរៀងៗខ្លួន។ យើងឈប់ហូបអាហារថ្ងៃត្រង់នៅម៉ោង១១ព្រឹក។ មានអ្នកយកអាហារថ្ងៃត្រង់ទៅឱ្យអ្នកធ្វើការហូបនៅតាមការដ្ឋានធ្វើការតែម្តង។ យើងបន្តធ្វើការភ្លាមៗបន្ទាប់ពីហូបអាហារថ្ងៃត្រង់រួចហើយយើងធ្វើការរហូតដល់ម៉ោង៦ និង៧ល្ងាច"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.12 ["យើងភ្ញាក់ពីម៉ោង៤ព្រឹក ធ្វើការហាត់ប្រាណរហូតដល់ម៉ោង៧ ទើបចេញទៅធ្វើការ នៅម៉ោង១១ ចុងភៅបាននាំម្ហូបអាហារនៅ

ការដ្ឋានធ្វើការ ហើយនៅម៉ោង១រសៀល យើងចុះទៅធ្វើការវិញរហូតដល់ម៉ោង៥ល្ងាច"]។ ឯកសារ D54/120 កំណត់ហេតុស្ដាប់ចម្លើយ ព្រំ កែម ឆ.3 ["នៅក្នុងសហករណ៍ខ្ញុំ គេវាយជួងម្ដងនៅម៉ោង៩ព្រឹក ដើម្បីឱ្យក្មេងៗហូបបាយថ្ងៃត្រង់។ គេវាយជួងម្ដងទៀតនៅម៉ោង១១ ដើម្បីឱ្យចាស់ៗហូបបាយ តែក្មេងៗពុំមានរបបហូបទៀតទេ គេវាយជួងម្ដងទៀតនៅម៉ោង៤ល្ងាច ដើម្បីឱ្យក្មេងៗហូបបាយល្ងាច ចំណែកចាស់ៗហូបបាយនៅម៉ោង៥ ឬម៉ោង៦ល្ងាច"]។ ឯកសារ D114/239 កំណត់ហេតុស្ដាប់ចម្លើយ សៅ ម៉េន ឆ.43 ["ម៉ោង៦ព្រឹក ដល់ម៉ោង១១ព្រឹក ហើយហូបបាយ ចាប់ធ្វើការពីម៉ោង១២ ដល់ម៉ោង៦ល្ងាច"]។ ឯកសារ D114/240 កំណត់ហេតុស្ដាប់ចម្លើយ ភិន វេញ ឆ.51 ["ធ្វើ១ថ្ងៃ ១២ម៉ោង។ ធ្វើចាប់ពីម៉ោង៦ព្រឹក ដល់ម៉ោង១១ថ្ងៃត្រង់ ចូលហូបបាយ ហើយចាប់ពីម៉ោង១ ដល់ម៉ោង៦ល្ងាច ហើយហូបបាយ"]។ ឯកសារ D114/243 កំណត់ហេតុស្ដាប់ចម្លើយ ធក សែន ឆ.34 ឆ.103 [អំពីកុមារនៅចម្ការដូង "ពីម៉ោង៧ ហូបបាយហើយ រហូតដល់ម៉ោង១១។ ចាប់ពីម៉ោង១ ដល់ម៉ោង៥។ ការងារប្រចាំមានតែប៉ុណ្ណឹង។ ហើយយប់ឡើងយាមទៀត" [...] ឆ.103៖ នៅទំនប់នោះ "ពីម៉ោង៦ ដល់ម៉ោង១១ ហើយចុះបន្តពីម៉ោង១ ដល់ម៉ោង៥"]។ ឯកសារ D54/20 កំណត់ហេតុស្ដាប់ចម្លើយ សំ សោម ឆ.14 ["គេចាត់តាំងឱ្យខ្ញុំកាប់ផ្ទាក់ដីស្រែដោយប្រើចបឱ្យបានពីរកុង (២០ម៉ែត្រការ៉េ) មួយថ្ងៃ។ ថ្ងៃចាប់ផ្ដើមពីម៉ោង៧ ដល់ម៉ោង១១ ហើយសម្រាកមួយម៉ោង និងបន្តពីម៉ោង១ ដល់ម៉ោង៥"]។ ឯកសារ D114/89 កំណត់ហេតុស្ដាប់ចម្លើយ សេង ស៊ីន ឆ.80-81 ["យើងធ្វើពីម៉ោង៣ភ្លឺ ដល់ម៉ោង១១ ហើយថ្ងៃធ្វើម៉ោង១ ដល់ម៉ោង៦ល្ងាច។ ពេលខ្លះធ្វើលើសម៉ោង៦ល្ងាចទៀត ដល់ម៉ោង ៩យប់អីក៏មាន។ សៈ តើមានមនុស្សប៉ុន្មាននាក់ដែលធ្វើការម៉ោងដូចរៀបរាប់ខាងលើនេះ? តើមនុស្សមួយកងលោកតែម្ដងឬ? ឆ.81៖ បាទ មួយកងតែម្ដង"]។ ឯកសារ D114/156 កំណត់ហេតុស្ដាប់ចម្លើយ សឹង ណុច ឆ.68 ["ម៉ោង ៤ ចាប់ផ្ដើមឡើងទៀត"]។ ឯកសារ D114/53 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុក សុក ឆ.229 ["សៈ ធម្មតាការដ្ឋាន [កងកេង] ចាប់ផ្ដើមពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានដែរ? ឆ.229៖ ព្រឹកម៉ោង៧ ដល់ម៉ោង១១ ហើយពីម៉ោង១ ដល់ម៉ោង៥ នៅពេលរសៀល"]។ ឯកសារ D114/86 កំណត់ហេតុស្ដាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.12 ["គឺចាប់ពីម៉ោង៥ ឬ៦ព្រឹក រហូតដល់ម៉ោង១១ថ្ងៃត្រង់ និងបន្តពីម៉ោង១២កន្លះរហូតដល់ម៉ោង៥ល្ងាច"]។ ឯកសារ D114/121 កំណត់ហេតុស្ដាប់ចម្លើយ សួន ផ ឆ.23 ["ចាប់ផ្ដើមធ្វើការនៅម៉្ដុម៉ោង៧ និងបន្តធ្វើការនៅទីនោះរហូតដល់ម៉ោង៥ល្ងាច"]។ ឯកសារ D114/6 កំណត់ហេតុស្ដាប់ចម្លើយ យិន តេង ឆ.107 ["សៈ ពេលលោកស្រីនៅពួធឿង តើលោកស្រីធ្វើការរាល់ថ្ងៃឬ? ឆ.107៖ ចាស ខ្ញុំធ្វើរាល់ថ្ងៃ គឺធ្វើការពីម៉ោង៦ព្រឹកដល់ម៉ោង៦ល្ងាច"]។ ឯកសារ D114/242 កំណត់ហេតុស្ដាប់ចម្លើយ ប្រាក់ ប៊ុនធី ឆ.37 ឆ.60 ["ព្រលឹមឡើងម៉ោង៧ គឺវាឱ្យហូបបាយ ហើយពីម៉ោង៧ វាឱ្យធ្វើការដល់ម៉ោង១១។ ម៉ោង២ចុះធ្វើការទៀតចប់ម៉ោង៥ [...] ឆ.60៖ ដូចខ្ញុំរៀបរាប់ខាងលើ គឺម៉ោង៦ចេញធ្វើការ ម៉ោង១១ឡើង។ ចុះម៉ោង១ មកទល់នឹងម៉ោង៥"]។ ឯកសារ D114/109 កំណត់ហេតុស្ដាប់ចម្លើយ ព្រំ សម្បត្តិ ឆ.150 ["គេឱ្យធ្វើការចាប់ពីម៉ោង៧ ដល់ម៉ោង១១ ហើយចាប់ពីម៉ោង១ ដល់ម៉ោង៥ល្ងាច"]។ ឯកសារ D114/6 កំណត់ហេតុស្ដាប់ចម្លើយ យិន តេង ឆ.29 ["ខ្ញុំចាប់ផ្ដើមធ្វើការពីម៉ោង៧ព្រឹក ដល់ម៉ោង១២ថ្ងៃត្រង់ ហើយឈប់សម្រាកហូបបាយ។ យើងចាប់បន្តធ្វើការងារពីម៉ោង១រសៀលរហូតដល់ម៉ោង៥ល្ងាច"]។ ឯកសារ D114/135 កំណត់ហេតុស្ដាប់ចម្លើយ ណុប ផន ឆ.27 ["គ្រប់គ្នាត្រូវក្រោកនៅម៉ោង៥។ បន្ទាប់មកយើងញ៉ាំបបរជាអាហារពេលព្រឹក នៅម៉ោង៥កន្លះ ហើយត្រូវដើរប្រហែលជា១៥នាទី ទៅស្រែដែលស្ថិតនៅចម្ងាយមួយ ទៅពីរគីឡូម៉ែត្រ ដែលយើងរស់នៅ"]។

យប់ ពេលខ្លះ រហូតដល់ម៉ោង ១១ យប់ ឬលើសនេះ[2773]។ "អត់មានពេលសម្រាកទេ គឺធ្វើការមួយអាទិត្យ ឬមួយខែពេញៗតែម្តង"[2774]។

684. ទោះបីជាកម្មកររអស់កម្លាំង ឬឃ្លានយ៉ាងណាក៏ដោយ ក៏ពួកគេត្រូវបង្ខំឱ្យបន្តធ្វើការ រហូតដល់ដួលសន្លប់ ជាញឹកញាប់[2775]។ ប្រពន្ធរបស់ប្រធានសហករណ៍មួយបានបញ្ជាក់អះអាងថា៖ "យើងមិន

---

2772 ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.68 ["ធ្វើការជួនកាលធ្វើម៉ោង៣ ព្រោះការដ្ឋាននៅឆ្ងាយ"]។

2773 ឯកសារ D114/94 កំណត់ហេតុស្តាប់ចម្លើយ សំ វុទ្ធី ឆ.75-77 ["ស៖ តើលោកចាប់ផ្តើមធ្វើការនៅម៉ោងប៉ុន្មានពេលព្រឹក? ឆ.75៖ ធ្វើការពីម៉ោង៧ព្រឹក ដល់១១ថ្ងៃត្រង់ ហើយចាប់ផ្តើមម្តងទៀតនៅម៉ោង១ ដល់ម៉ោង៥ល្ងាច។ ស៖ តើគេឱ្យលោកធ្វើអ្វីនៅចន្លោះពីម៉ោង ១១ ដល់ម៉ោង១ថ្ងៃត្រង់? ឆ.76៖ គេឱ្យសម្រាក។ ស៖ ចុះបន្ទាប់ពីម៉ោង៥? ឆ.77៖ វាជាម៉ោងសម្រាកដែរ ប៉ុន្តែម្តងម្កាលពេលដែលគេដឹងខសមកច្រើន យើងត្រូវជញ្ជូនទៅដាក់ឡ"]។ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.47 ["បើធ្វើមិនហើយតាមផែនការ យើងត្រូវតែធ្វើការងារនោះឱ្យទាល់តែហើយ ជួនកាលដល់ម៉ោង៩ ឬ១០យប់ទើបចប់ផែនការ"]។ ឯកសារ D114/243 កំណត់ហេតុស្តាប់ចម្លើយ ធក សែន ឆ.34 ["ហើយយប់ឡើងយាមទៀត។ យាមក្រែងមានចោរមានអីមក។ បើយើងយាមដាច់ គេដាក់វិន័យយើង វៃយើង។ យើងដាច់មានន័យថា យើងយាមងក់អីចឹង។"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.80 ["យើងធ្វើពីម៉ោង៧ភ្លឺ ដល់ម៉ោង១១ ហើយថ្ងៃធ្វើម៉ោង១ ដល់ម៉ោង៦ល្ងាច។ ពេលខ្លះធ្វើលើសម៉ោង៦ល្ងាចទៀត ដល់ម៉ោង ៩យប់អីក៏មាន"]។ ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.16 ["យើងភ្ញាក់នៅម៉ោង៥កន្លះ ហើយឡើងគោរពទង់ជាតិនិងប្រជុំជួរ។ នៅម៉ោង៦ព្រឹក គេឱ្យយើងហូបដំឡូងម្នាក់មួយដុំ ហើយចាប់ធ្វើការពីម៉ោង៦កន្លះរហូតដល់ម៉ោង១១ ហើយសម្រាកហូបបាយថ្ងៃត្រង់។ យើងចាប់បន្តធ្វើការពីម៉ោង១ថ្ងៃត្រង់ ដល់ម៉ោង៥ល្ងាច ហើយសម្រាកហូបបាយល្ងាច។ ពីម៉ោង៦កន្លះឬម៉ោង៧ ដល់ម៉ោង៨ ឬម៉ោង៩យប់ យើងដាំបន្លែនៅជុំវិញផ្ទះ ដូចជាដាំដំឡូងមី និងដំណាំដទៃទៀត។ នៅពេលនោះ គេរឹតបន្តឹងយើង"]។ ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.21-22 ["១០នាក់ក្នុងចំណោមមនុស្សទាំង៣០០នាក់ ត្រូវបានដាក់វេនគ្នាយាមទំនប់នៅពេលយប់ ជារៀងរាល់យប់ [...] ឆ.22៖ មូលហេតុដែលគេឱ្យយើងដាក់វេនគ្នាយាមទំនប់នេះ គឺដោយសារប្រសិនជាមានទឹកច្រើននៅក្នុងអាង គឺយើងត្រូវរាយការណ៍ឱ្យគេ ដើម្បីបើទ្វារទឹកបញ្ចេញទឹក កុំឱ្យជន់បាក់ទំនប់"]។ ឯកសារ D11/388 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ណាប់ សុម៉ាលី KH 00991884 ["ពេលយប់ឡើង រែកកណ្តាប់ដាក់ជីរហូតដល់ម៉ោង១១យប់"]។

2774 ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.35 ["ស៖ តើលោកធ្វើការប៉ុន្មានថ្ងៃក្នុងមួយអាទិត្យ? ឆ.35៖ អត់មានពេលសម្រាកទេគឺធ្វើការ១អាទិត្យ ឬ១ខែពេញៗតែម្តង"]។

2775 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.31 ["ស៖ តើលោកបានឃើញមនុស្សដួលដោយសារជំងឺ និង/ឬហត់នឿយអស់កម្លាំងពេលកំពុងធ្វើការនៅទំនប់នោះដែរឬទេ? ឆ.31៖ បាទ ខ្ញុំធ្លាប់ឃើញហេតុការណ៍នោះដែរ។ ដោយសារតែហត់នឿយ អ្នកខ្លះដួល។ យើងធ្វើការទាល់តែដួល ទើបគេសែងយកទៅរោង ដើម្បីសម្រាក"]។ ឯកសារ

អាចសម្រាកនៅផ្ទះ ហើយអះអាងថាឈឺនោះទេ។ យើងនៅក្នុងអង្គភាព"[2776]។ អ្នកណាប្រកែក មិនព្រមធ្វើការ ព្យាយាមចាកចេញ តវ៉ា ឬត្រូវចាត់ទុកថាខ្ជិល ត្រូវបាត់ខ្លួន ឬត្រូវគេសម្លាប់[2777]។

---

D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.117 ["គេឲ្យប្រជាជនធ្វើការរហូតដល់ដើរលែងរួច"]។ ឯកសារ D114/135 កំណត់ហេតុស្តាប់ចម្លើយ ណុប ផន ឆ.39 ["សៈ តើលោកចង់ធ្វើការងារនេះដែរឬទេ? ឆ.39៖ ខ្ញុំមិនចង់ទេ ប៉ុន្តែខ្ញុំគ្មានជម្រើសអ្វីឡើយ"]។ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.99-100 ["ខ្ញុំឃើញមានអ្នកដួលសន្លប់ច្រើនណាស់។ [...] ឆ.100៖ ទទួលបានបាយបន្តិចបន្តួចបំផុត ហូបមិនគ្រប់គ្រាន់ទេ ហើយក៏មិនមានអាហារអ្វីដែរ ដូច្នេះហើយបានពួកគេដួលពេលកំពុងធ្វើការ"]។

2776 ឯកសារ D59/1/4.25 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡុង លី KH 00930813។ សូមមើលផងដែរនូវ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.160 ["សៈ តើលោកស្រីធ្វើការដោយស្ម័គ្រចិត្ត ឬក៏គេបង្ខំ? ឆ.160៖ ទោះបីខ្ញុំប្រាប់គេថា ខ្ញុំចុកពោះ ក៏គេបង្ខំឲ្យធ្វើការងារដែរ"]។

2777 ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.117 ["គេឲ្យប្រជាជនធ្វើការរហូតដល់ដើរលែងរួច ដេកនៅនឹងកន្ទេល។ បើអ្នកណាឈឺហើយទៅធ្វើការមិនរួច គឺត្រូវគេយកទៅសម្លាប់ចោលតែម្តង ដូចពាក្យស្លោកមួយថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត""]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.15 ["សៈ ហេតុអ្វី ហើយយ៉ាងម៉េចបានជាលោកតស៊ូ ដើម្បីរស់? ឆ.15៖ ខ្ញុំធ្វើតាមតែបញ្ជារបស់គេ ដើម្បីរស់ ហើយការងារអ្វីក៏ដោយ ដែលគេចាត់តាំងឲ្យខ្ញុំធ្វើ ខ្ញុំត្រូវតែបំពេញដើម្បីរស់"]។ ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.30 ["សៈ ក្នុងពេលធ្វើកំណត់អត្តសញ្ញាណទីតាំង លោកក៏បាននិយាយថា បើទោះជាមេឃភ្លៀងក៏ដោយ ក៏លោកនិងអ្នកដទៃទៀតនៅតែបន្តធ្វើការរហូត គឺធ្វើការក្នុងភក់ និងរែកដីសើម។ អ្នកដែលឈឺពុំហ៊ានឈប់សម្រាក ឬត្អូញត្អែរទេ គឺនៅបន្តធ្វើការរហូត ព្រោះថាបើត្អូញត្អែគឺស្លាប់។ តើនេះត្រឹមត្រូវដែរឬទេ? ឆ.30៖ បាទ ត្រឹមត្រូវហើយ"]។ ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.15 ["ចំពោះអ្នកដែលបានបញ្ចប់ការងារនេះទើបអាចរស់បាន ចំពោះអ្នកណាដែលខ្ជិល ឈឺ ឬប្រឆាំងនឹងការរែកដី គេនឹងយកចេញទៅ ហើយក៏បាត់ខ្លួន តែខ្ញុំមិនដឹងថាគេយកទៅណាទេ"]។ ឯកសារ D114/96 កំណត់ហេតុស្តាប់ចម្លើយ ចេង ឡុង ឆ.15 ["ខ្ញុំបានឃើញអ្នកដែលធ្វើខុសឧទាហរណ៍ អ្នកដែលខ្ជិលធ្វើការ និងលួចសម្រាកពីធ្វើការនឹងត្រូវចាប់ខ្លួនយកទៅសម្លាប់"]។ ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ឆ.108 ["សៈ អ្នកណាជាអ្នកបញ្ជូនទៅរៀនសូត្រ បើមិនព្រមធ្វើការ? ឆ.108៖ គឺប្រុសម្នាក់តែខ្ញុំមិនចាំឈ្មោះទេ។ តែរៀនសូត្រនោះ មិនមែនយកទៅរៀនសូត្រទេ គឺយកទៅវៃចោល។ [...] អ្នកដែលគេបញ្ជូនទៅគឺមិនដែលមកវិញទេ ហើយគេប្រាប់ថារៀនសូត្រនោះគឺគេយកទៅវៃចោលទេ"]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.110-111 ["សៈ ចុះលោក ឬក៏អ្នកផ្សេងទៀតដែលសួរថា ហេតុអ្វីបានជាត្រូវបន្តនៅកន្លែងហ្នឹងយូរទៀតទេ? ឆ.110៖ ពេលនោះ គ្មានជនណាម្នាក់ហ៊ានសួរទេ ឲ្យតែនៅរស់ទៅបានហើយ។ សៈ ហេតុអីបានអត់ហ៊ានសួរ? ឆ.111៖ ព្រោះខ្មែរក្រហមងាយយកទៅសម្លាប់"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.33 ["សៈ តើគេអនុញ្ញាតឲ្យលោកចាកចេញពីកន្លែងស្នាក់នៅ និងកន្លែងការងារដែរឬទេ? ឆ.33៖ អត់ទេ ពេលធ្វើការគឺយើងពុំអាចចេញពីកន្លែងធ្វើការបានទេ បើមិនដូច្នេះទេ គឺគេចាប់ខ្លួនហើយ"]។

"យើងមិនមានសិទ្ធិតវ៉ាទេ យើងធ្វើការយ៉ាងទម្ងន់ ហើយយើងស្គមៗ"[2778]។ មេដឹកនាំសហករណ៍ត្រូវគេតម្រូវឱ្យរាយការណ៍អំពីកម្មករដែលប្រព្រឹត្ត "កំហុស" ឬឈឺ ដើម្បី "យកទៅកសាង"[2779]។ គ្រាន់តែនៅការដ្ឋានមួយ "ក្នុងមួយខែៗ ប្រហែលបួនដប់នាក់ ប្រជាជនដែលខុស ហើយគេយកទៅហ្នឹង [...]។ កំហុសច្រើនបំផុត គឺរឿងយើងធ្វើការ ដូចជា -ធ្វើការខ្ជិល ឬលួចនេះលួចនោះ"[2780]។

685. ជនរងគ្រោះត្រូវគេបង្ខំឱ្យធ្វើការ ដោយភ័យខ្លាចថា បើមិនធ្វើការ ឬធ្វើការមិនគ្រប់គ្រាន់ គឺត្រូវទទួលរងទណ្ឌកម្ម ឬស្លាប់។ ប្រសិនបើពួកគេប្រកែកមិនព្រមធ្វើការ "គេនាំយកទៅសម្លាប់"[2781]។ សាក្សីជាច្រើននិយាយពាក្យដដែលថា៖

- "ខ្ញុំធ្វើតាមតែបញ្ជារបស់គេ ដើម្បីរស់ ហើយការងារអ្វីក៏ដោយ ដែលគេចាត់តាំងឱ្យខ្ញុំធ្វើ ខ្ញុំត្រូវតែបំពេញ ដើម្បីរស់"[2782]។
- "ខ្ញុំមិនពេញចិត្តទេ ខ្ញុំធ្វើដើម្បីរស់"[2783]។
- "ខ្ញុំមិនពេញចិត្តទេ ហើយយើងធ្វើ ព្រោះខ្លាចងាប់។ គេមិនឱ្យប្រាក់កម្រៃទេ ហើយគេក៏មិនឱ្យបាយយើងហូបគ្រប់គ្រាន់ដែរ"[2784]។
- "ខ្ញុំខំប្រឹងតស៊ូដើម្បីរស់ ខ្ញុំមិនចង់ឱ្យគេបញ្ជូនទៅទឹកសាបទេ"[2785]។

---

[2778] ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.36។

[2779] ឯកសារ D59/1/4.25 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡុង លី KH 00930813 ["យើងរាយការណ៍មក បើយើងឃើញពីណាខុសឆ្គង យើងរាយការណ៍ទៅ ហើយគេហៅប្រជុំកសាង បើយើងឈឺយើងទៅប្រាប់គេប្រធានហ្នឹង ឱ្យប្រធានហ្នឹងរាយការណ៍ទៅថា ម្នាក់នេះឈឺចេះ ឈឺចោះ ហើយជួយផ្តល់ថ្នាំមកឱ្យលេប អត់មានយើងនៅសេរី យើងដើរសេរីដូចនៅផ្ទះយើងទេ យើងនៅអង្គភាព"]។

[2780] ឯកសារ D114/242 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ប៊ុននី ឆ.100 ឆ.103។

[2781] ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.104។

[2782] ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.15 ["ស៖ ហេតុអ្វី ហើយយ៉ាងម៉េចបានជាលោកតស៊ូដើម្បីរស់? ឆ.15៖ ខ្ញុំធ្វើតាមតែបញ្ជារបស់គេ ដើម្បីរស់ ហើយការងារអ្វីក៏ដោយ ដែលគេចាត់តាំងឱ្យខ្ញុំធ្វើ ខ្ញុំត្រូវតែបំពេញដើម្បីរស់"]។

[2783] ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.103។

[2784] ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.39។

[2785] ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.13។

686. ជាញឹកញាប់ អ្នកធ្វើការនៅការដ្ឋានតំបន់រាម ត្រូវគេបញ្ជូនទៅការដ្ឋានផ្សេងទៀតផងដែរ រួមទាំងស្ទឹងហាវ[2786]។

[2786] ឯកសារ D114/121 កំណត់ហេតុស្ដាប់ចម្លើយ សួន ផ ឆ.23 ["ក្រោយមកទៀត គេបញ្ជូនខ្ញុំមកវាយថ្មនៅស្ទឹងហាវ"]។ ឯកសារ D114/65 កំណត់ហេតុស្ដាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.16 ["ខ្ញុំធ្វើការនៅទីនោះ រហូតដល់ខែកញ្ញា ឆ្នាំ ១៩៧៨។ នៅពេលនោះខ្ញុំ ហើយនិងកងវរៈលេខ២០របស់ខ្ញុំ ត្រូវបានគេបញ្ជូនទៅវាយថ្មនៅការដ្ឋានវាយថ្ម ស្ទឹងហាវ"]។ ឯកសារ D114/83 កំណត់ហេតុស្ដាប់ចម្លើយ សុខ នាង ឆ.8 ["នៅចុងឆ្នាំ១៩៧៧ គេបញ្ជូនពួកយើងទៅស្ទឹងហាវ"]។ ឯកសារ D114/79 កំណត់ហេតុស្ដាប់ចម្លើយ កង សុំ ឆ.230 ["ខ្ញុំនៅអូរម្លូជិតព្រលានយន្តហោះកងកេង។ ខ្ញុំនៅទីនោះពីពាក់កណ្ដាលឆ្នាំ ១៩៧៥ រហូតដល់ឆ្នាំ ១៩៧៨ នៅពេលដែលខ្ញុំផ្លាស់ទៅស្ទឹងហាវ"]។ ឯកសារ D54/36 កំណត់ហេតុស្ដាប់ចម្លើយ ប្រាក់ សុខា ឆ.22-23 ["ចំពោះអ្នកដែលចាត់ទុកថាមានទោសធ្ងន់ គេបញ្ជូនទៅទឹកសាប ចំពោះអ្នកដែលចាត់ទុកថាមានទោសស្រាល គេបញ្ជូនទៅស្ទឹងហាវ ដើម្បីលត់ដំ [...] ឆ.23៖ ខ្ញុំមិនដឹងពីមូលហេតុនៃការបញ្ជូនទេ គេគ្រាន់តែប្រាប់ខ្ញុំថា នេះជាគំរោងការរបស់អង្គការ ឲ្យបញ្ជូនទៅស្ទឹងហាវ"]។ ឯកសារ D54/35 កំណត់ហេតុស្ដាប់ចម្លើយ ប្រាក់ សុខា ឆ.17 ["ក្នុងឆ្នាំ១៩៧៧ តែខ្ញុំមិនចាំថ្ងៃទេ កងចល័តរបស់ខ្ញុំត្រូវបានដកចេញពីព្រែកចាកមកនៅតំបន់កងកេង [...] នៅពេលនោះ គេបានប្រាប់យើងថា ពួកយើងនឹងត្រូវគេបញ្ជូនទៅស្ទឹងហាវ"]។ ឯកសារ D54/8 កំណត់ហេតុស្ដាប់ចម្លើយ ឌុល សុង (សមាជិកកងវរៈសេនាធំ ២២ បោះទីតាំងនៅកងកេង) ឆ.22 ["វរៈសេនាធំ ២២ របស់ខ្ញុំបោះទីតាំងនៅព្រលានយន្តហោះ កងកេង។ ហើយកន្លែងធ្វើការរបស់យើងគឺនៅជុំវិញព្រលានយន្តហោះ កងកេងនោះ។ ក្រោយមកប្រហែលដើមឆ្នាំ១៩៧៦ ខ្ញុំបានចេញពីវរៈសេនាធំ ២២ ទៅនៅក្នុងវរៈសេនាធំ ១៤០ នៅរាម។ នៅក្នុងឆ្នាំ ១៩៧៦ នោះដដែល បន្ទាប់មកខ្ញុំត្រូវបានបញ្ជូនទៅស្ទឹងហាវ"]។ ឯកសារ D114/79 កំណត់ហេតុស្ដាប់ចម្លើយ កង សុំ (សមាជិកកងវរៈសេនាតូច ៣១ នៃកងវរៈសេនាធំ ៣១០) ឆ.230 ឆ. 286 ["ស៖ [...] នៅក្នុងឆ្នាំ១៩៧៦ តើមានអ្វីកើតឡើងចំពោះលោក? ឆ.230៖ ខ្ញុំនៅអូរម្លូជិតព្រលានយន្តហោះកងកេង។ ខ្ញុំនៅទីនោះពីពាក់កណ្ដាលឆ្នាំ ១៩៧៥ រហូតដល់ឆ្នាំ ១៩៧៨ នៅពេលដែលខ្ញុំផ្លាស់ទៅស្ទឹងហាវ។ ខ្ញុំនៅអូរម្លូនេះរយៈពេលបីខែ។ ស៖ ចុះបន្ទាប់ពីពាក់កណ្ដាលឆ្នាំ ១៩៧៦ តើលោកទៅណាទៀត? ឆ.286៖ គេបញ្ជូនខ្ញុំមកស្ទឹងហាវ"]។ ឯកសារ D114/244 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុន យ៉េ ឆ.42 ["ស៖ តើមានការដកសមាជិកពីកងផលិតនៅទីតាំងកងកេងដែរឬទេ? ឆ.42៖ មាន គឺដកទៅនៅស្ទឹងហាវ"]។ ឯកសារ D114/109 កំណត់ហេតុស្ដាប់ចម្លើយ ព្រំ សម្បត្តិ ឆ.211 ["ស៖ តើគេបញ្ជូនលោកទៅធ្វើការនៅស្ទឹងហាវនៅពេលណា? ឆ.211៖ ប្រហែលបីខែមុនពេលវៀតណាមចូល"]។ ឯកសារ D54/97 កំណត់ហេតុស្ដាប់ចម្លើយ ខឹម យ៉ាត (សមាជិកកងអនុសេនាធំ១២០ នៅកងវរៈសេនាតូច២ កងវរៈសេនាធំ៥២ តំបន់២២) ឆ.10 ["ក្រោយមកទៀត គេក៏បញ្ជូនខ្ញុំទៅស្ទឹងហាវ។ ពួកខ្ញុំធ្វើការនៅទីនោះបានប្រហែលកន្លះឆ្នាំ។ គេឲ្យយើងសែងថ្មចេញពីរូងភ្នំ ដែលគេគ្រោងនឹងបង្កើតធ្វើជាឃ្លាំង"]។ ឯកសារ D54/105 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.17 ["ខ្ញុំធ្វើការនៅកងកេងរហូតដល់ពាក់កណ្ដាលឆ្នាំ ១៩៧៨ ទើបគេបញ្ជូនខ្ញុំឲ្យទៅធ្វើការនៅស្ទឹងហាវ។ នៅទីនោះ គេឲ្យខ្ញុំបំបែកថ្ម ដើម្បីយកថ្មទៅធ្វើទំនប់រលក និងផែសម្រាប់ឲ្យកប៉ាល់ចម្បាំងចូលចត"]។

## ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

687. ស្ទើរតែគ្រប់គ្នា ដែលត្រូវគេបង្ខំឱ្យធ្វើការនៅការដ្ឋានតំបន់រាម ត្រូវបានបញ្ជូនទៅទីនោះ ពីព្រោះ **មាស មុត** និងកម្លាំងក្រោមការគ្រប់គ្រងរបស់គាត់ បានចាត់ទុកពួកគេជា "ខ្មាំង" របស់ ប.ក.ក ហើយត្រូវ "លត់ដំ" ខាងមនោគមន៍វិជ្ជា[2787]។ ដូច្នេះ ការជ្រើសសម្រាំងអ្នកណាត្រូវបង្ខំឱ្យរស់ និងធ្វើការក្នុងកាលៈទេសៈលំបាកលំបិន នៅតាមការដ្ឋានតំបន់រាម គឺជាអំពើធ្វើទុក្ខបុកម្នេញ។ ក្រោយពីត្រូវគេចាត់ចូលក្នុងប្រភេទមនុស្សសង្ស័យ និងត្រូវលត់ដំ ជនរងគ្រោះរស់នៅក្នុងភាពព្រួយបារម្ភ។ ជនរងគ្រោះអាចត្រូវគេដាក់ទណ្ឌកម្ម ចាប់ខ្លួន ឬសម្លាប់ ដោយសារកំហុសតូចតាច ការរកឃើញព័ត៌មានមិនអំណោយផលអំពីពួកគេ ឬដោយគ្មានហេតុផលអ្វីសោះ លើកលែងតែគំនិតខិលខូចរបស់អ្នកដែលមានការគ្រប់គ្រងពេញលេញលើពួកគេ[2788]។ ជនរងគ្រោះម្នាក់បាននិយាយថា៖ "គេទុកឱ្យខ្ញុំរស់ តែគេតាមដានខ្ញុំ។ បើសិនជាខ្ញុំធ្វើអីខុស គេនឹងចោទខ្ញុំពេញតែម្តង"[2789]។ ជនរងគ្រោះម្នាក់ទៀតបានពន្យល់ថា៖ "បើយើងមិនជឿគេតែបន្តិច ឬងាករេចេញពីគេតែបន្តិច គេនឹងដកយើងចេញភ្លាម"[2790]។

688. គេហៅខ្មាំង ដោយប្រើពាក្យផ្សេងៗ ដូចជា "ជនសង្ស័យ"[2791] "សមាសភាពអាក្រក់"[2792] អ្នកមាន "បញ្ហា ឬនិន្នាការមិនល្អ"[2793] "សមាសភាពមិនល្អ"[2794] "ជនក្បត់"[2795] អ្នក "ជាប់និន្នាការមិន

---

[2787] ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.2 ["បានប្រជុំប្រាប់ខ្ញុំ និងយោធាដ៏ទៃទៀតថា ខ្ញុំ ហើយនិងយោធាទាំងនោះត្រូវបានផ្លាស់ពីកងហើយបញ្ជូនទៅនៅកងចល័តព្រៃកចាក ដោយសារអង្គការចាត់យើងថាគឺជាពួកសមាសភាពមិនល្អ ហើយត្រូវបញ្ជូនទៅលត់ដំ"]។ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.14 ["ប្រហែលពាក់កណ្តាលឆ្នាំ ១៩៧៦ ខ្ញុំត្រូវគេចាត់ទុកថាជាសមាសភាពសង្ស័យ មិនល្អ ហើយត្រូវបានគេដកចេញពីកោះពូឡូវៃ ហើយយកមកដាក់ធ្វើការនៅវាលស្រែ"]។ ឯកសារ D54/33.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ៊ី អុន KH 00964201 ["ចូលដល់កងចល័តហើយ គេថាចូលដល់ការលុតដំ"]។

[2788] ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.19 ["នៅពេលដែលមានអ្នកណាម្នាក់ នៅក្នុងកងសមាសភាពមិនល្អទាំងនេះ ធ្វើខុស គេនឹងត្រូវបញ្ជូនទៅឃុំខ្លួននៅទឹកសាប"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.92-93 ["កាលហ្នឹង បើសិនជាមានទោស គេបញ្ជូនទៅគុក។ [...] ឆ.93៖ គុកហ្នឹងនៅស្ពានទឹកសាប"]។

[2789] ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង សុំ ឆ.328។

[2790] ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.112។

[2791] ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.17 ["ព្រៃកចាក គឺជាកន្លែងដែលគេដាក់ពួកសមាសភាពដែលសង្ស័យតាំងពីយូរណាស់មកហើយ"]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.7

["ក្រោយពីខ្ញុំបានដឹងថាខ្ញុំមានឈ្មោះនៅលើបញ្ជីនោះ ខ្ញុំភ័យបាត់ព្រលឹងរលីង ហើយពួកគេក៏បានឱ្យខ្ញុំរៀបចំឥវ៉ាន់។ តាមពិតទៅ ពួកយើងពុំមែនជាមនុស្សដែលគេឆ្លើយដាក់នោះទេ ប្រសិនបើគេឆ្លើយដាក់យើង គឺគេច្បាស់ជាបញ្ជូនយើងទៅភ្នំពេញ ឬទឹកសាបហើយ អាស្រ័យទៅតាមករណីធ្ងន់ ឬស្រាល។ ពួកខ្ញុំ គេនៅចាត់ទុកថានៅស្មោះត្រង់នឹងគេនៅឡើយ តែគេចាត់ទុកថាជាសមាសភាពគួរឱ្យសង្ស័យ"]។

2792 ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.19 ["កងផលិតធំ ដែលមានអតីតយោធារាប់ពាន់នាក់ដែលចាត់ថាមានសមាសភាពមិនល្អ"]។

2793 ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ឆ.28 ["ទាហានទាំងអស់នោះ [ដែលត្រូវបានបញ្ជូនទៅធ្វើការនៅទំនប់បិតត្រាំង] គឺគ្រប់កងទាំងអស់ ដែលមកពីកងវរៈសេនាធំ២២។ នៅពេលដែលពួកគេមានបញ្ហាអី ឬក៏មាននិន្នាការមិនល្អ គេនឹងត្រូវដកចេញពីវរៈសេនាធំ យកទៅដាក់នៅកងផលិតវិញ"]។

2794 សូមមើល ឧទាហរណ៍ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារិក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ នៅម៉ោង 10.46.19-10.49.49 ["ខ្ញុំគេដកសេចក្តីទុកចិត្តជាជនសង្ស័យ ជាជនសង្ស័យ ជាជនដែលមិនល្អនៅក្នុងកង ក៏គេដកខ្ញុំទៅនៅចម្ការក្រូចឱ្យធ្វើស្រែតែម្តង"]។ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.14 ["ប្រហែលពាក់កណ្តាលឆ្នាំ ១៩៧៦ ខ្ញុំត្រូវគេចាត់ទុកថាជាសមាសភាពសង្ស័យ មិនល្អ ហើយត្រូវបានគេដកចេញពីកោះពូឡូវ ហើយយកមកដាក់ធ្វើការនៅវាលស្រែជិតកន្លែងចម្ការធូរេន ចម្ការដូង និងចម្ការក្រូចក្នុងរយៈពេលប្រហែល២ខែ [...] នៅពេលនោះ មានយោធា១២នាក់ មកនៅជាមួយខ្ញុំដែលត្រូវចាត់ថាជាសមាសភាពសង្ស័យ"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា (យោធាកងពលលេខ៣ត្រូវបានបញ្ជូនទៅធ្វើការនៅកងកេងក្នុងឆ្នាំ ១៩៧៧) ឆ.19 ["នៅពេលនោះ នៅក្នុងកងពល១៦៤ មានបីកងដែលគេចាត់ថា ជាកងសមាសភាពមិនល្អ។ ក្នុងចំណោមទាំងបីកងនេះ ពីរកង គឺកងវរៈសេនាតូចលេខ ២០ និង ២១ ហើយមួយកងទៀត គឺជាកងអនុសេនាធំលេខ១៩។ កងទាំងបីនេះ ផ្ទុកពួកយោធាដែលចាត់ទុកថា ជាសមាសភាពមិនល្អ"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.1-2 ["ខ្ញុំត្រូវបានខ្មែរក្រហមចាត់ថាជាកងសមាសភាពមិនល្អ [...] ឆ.2៖ [...] បានប្រជុំប្រាប់ខ្ញុំ និងយោធាដ៏ទៃទៀតថា ខ្ញុំ ហើយនិងយោធាទាំងនោះត្រូវបានផ្លាស់ពីកងហើយបញ្ជូនទៅនៅកងចល័តព្រែកចាក ដោយសារអង្គការចាត់យើងថាគឺជាពួកសមាសភាពមិនល្អ ហើយត្រូវបញ្ជូនទៅលត់ដំ"]។ ឯកសារ D54/35 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.14 ["កងចល័ត [របស់សាក្សី] នោះ គឺមានអតីតយោធាកងពល ១៦៤ ណាដែលចាត់ទុកថា សមាសភាពមិនល្អ កងចល័តនោះគឺឋិតក្រោមការគ្រប់គ្រងរបស់កងពល១៦៤ដដែល ហើយគេបញ្ជូនទៅឱ្យធ្វើការនៅកន្លែងមួយហៅថា ភូមិព្រែកចាកឋិតនៅប្រហែល២គីឡូម៉ែត្រខាងកើតផែរាម"]។ សូមមើលផងដែរនូវ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.19 ["បន្ទាប់ពីត្រូវគេដកចេញពីអង្គភាព ខ្ញុំត្រូវបានគេចាត់ទុកថាជាសមាសភាពមិនល្អ"]។

2795 ឯកសារ D54/104 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.3 ["វ៉េត នៅកងទ័ពជើងគោក មានទីតាំងនៅព្រលានយន្តហោះកងកេង ហើយគាត់ត្រូវបានចាប់ខ្លួន។ ខ្ញុំមិនដឹងថា វ៉េត នៅរស់ ឬស្លាប់ទេ ប៉ុន្តែខ្ញុំជឿថាគាត់ស្លាប់ហើយ ពីព្រោះនៅពេលដែល តាមុត ប្រជុំប្រាប់អំពីចម្លើយសារភាព ហើយ តាមុត បានប្រកាសថា វ៉េត ក្បត់ហើយ"]។ ឯកសារ D54/117 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន ឆ.20 ["នៅសហករណ៍ពុតទេ គេដាក់សុទ្ធតែជាប់ពាក់ព័ន្ធ

ល្អ"[2796] និងអ្នក "ជាប់និន្នាការនយោបាយ"[2797]។ ពេលនិយាយសំដៅដល់សហករណ៍មួយ នៅជិតទំនប់បិតត្រាង សាក្សីម្នាក់បានបញ្ជាក់ថា៖ "នៅសហករណ៍ពុតទេ គេដាក់សុទ្ធតែអ្នកជាប់ពាក់ព័ន្ធ [នឹងជនក្បត់]"[2798]។ សាក្សីម្នាក់បានពន្យល់អំពីការយល់ដឹងរបស់គាត់ចំពោះការភ័យខ្លាចខ្លាំងរបស់ ប.ក.ក ដូចខាងក្រោម៖

> "ខ្មាំងផ្ទៃក្នុង" ជាមនុស្សនៅក្នុងជួរ ដែលមិនយកចិត្តទុកដាក់នឹងការងារដែលដាក់ឲ្យធ្វើ។ "ខ្មាំងសតិអារម្មណ៍ផ្ទៃក្នុង" គឺជាអ្នកដែលរួញរានឹងការងារ ហើយមិនដែលបញ្ចប់ការងារដែលប្រគល់ឲ្យ។ "ពួកសមាសភាពមិនល្អ" គឺជាពួកដែលធ្លាប់បម្រើការក្នុងរបបរដ្ឋាភិបាលមុនៗ ឬក៏មានបងប្អូនធ្លាប់ធ្វើការនៅក្នុងរបបមុនៗ"[2799]។

689. អ្នកដែលគេធ្វើទុក្ខបុកម្នេញ ដោយការបញ្ជូនទៅរស់នៅ និងធ្វើការ តាមការដ្ឋានតំបន់រាម រួមមាន៖ កម្មាភិបាលដែលត្រូវគេចាត់ទុកជា "សមាសភាពមិនល្អ" ដោយសារហេតុផលផ្សេងៗ ប្រជាជន "១៧ មេសា" និងខ្មែរក្រហម។ ប្រាក់ សុខា បានរៀបរាប់អំពីកងការងារមួយ ដែលមានមនុស្សប្រភេទទាំងនេះ៖ "ពួកបូព៌ាមានចំនួនប្រហែល ៥០-៦០ នាក់ ប្រជាជន ១៧ មេសា ៣០-៤០ នាក់ និងខ្មែរកម្ពុជាក្រោមមានប្រហែល ១០-២០ នាក់ ក្រៅពីនោះ សុទ្ធតែពួកកងវរសេនាតូច ៣១០ ទាំងអស់ និងអតីតយោធាបញ្ជូនមកពីកងផ្សេងទៀត"[2800]។

---

[ជាមួយជនក្បត់] សហករណ៍នោះនៅដែលសមុទ្រស្ពានទឹកសាបកំពង់សោម"]។ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ.147 ["នៅជិតកន្លែងរបស់ខ្ញុំ [ភូមិពូធឿង] ខ្ញុំដឹងថា មានជនក្បត់ ហើយពួកគេបាត់ខ្លួនតែម្តង"]។

2796 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ នៅម៉ោង 10.41.42-10.45.27 ["នៅក្នុងឆ្នាំ៧៦-៧៧នុ៎ង ខ្ញុំបានធ្លាប់ទៅរស់នៅក្នុងក្បែរចម្ការក្រូច ដោយមូលហេតុដែលខ្ញុំជាប់និន្នាការមិនល្អ"]។

2797 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ នៅម៉ោង 14.09.06-14.11.49 ["ខាងកងចល័តនេះ មិនមែនទោសធ្ងន់ទេ ទោសស្រាលៗ គ្រាន់តែជាប់និន្នាការនយោបាយ ហៅថាកម្ពែលចាស់ពីសម័យលន់ នល់"]។

2798 ឯកសារ D54/117 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន ឆ.20។

2799 ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.19។

2800 ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.11។

ក) កម្មាភិបាលរំសាយ

690. កម្មាភិបាល ដែលគេចាត់ទុកជា "សមាសភាពមិនល្អ" មកពីកងពល ១៦៤ ត្រូវបានរំសាយ និង ដាក់តាមកងដែលធ្វើការនៅការដ្ឋានរាម ដើម្បីលត់ដំ[2801]។ គោលនយោបាយនេះត្រូវបានបញ្ជាក់ យ៉ាងច្បាស់ដោយមេដឹកនាំយោធាកងទ័ពបដិវត្តន៍កម្ពុជា៖

---

[2801] ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ 14.07.12-14.14.44 ["ស៖ អ្នកដែលមានប្រវត្តិរូបមិនល្អ ជាពិសេសអ្នកដែលមានជាប់និន្នាការរបបចាស់ អ្នកមានបងប្អូនធ្វើការក្នុងជួរកងទ័ព ឬក៏នៅក្នុងរដ្ឋបាលនៃរបបចាស់ហ្នឹង គឺថាគេដកចេញ។ ដកចេញហ្នឹងលោកចង់មានន័យថាយ៉ាងម៉េច? គេយកអ្នកទាំងអស់ហ្នឹងទៅណា? ហើយក្រោយមកមានរឿងអ្វីកើតឡើងទៀតចំពោះអ្នកទាំងអស់នេះ? ឆ៖ បាទ នៅក្នុងកងពល១៦៤ របស់យើងខ្ញុំហ្នឹង តាមការក្តាប់ មានកងចល័តមួយ កងចល័តមួយគេហៅថា "កងតាចាយ" បាទ កងតាចាយនោះ។ ពេលដែលកងទ័ពយោធាដែលមានជាប់និន្នាការនយោបាយដែលមិនល្អ ឧទាហរណ៍ថា ខ្ញុំមានឪពុកម្តាយ គេឆ្លើយថាមានឪពុកម្តាយ ឬសាច់បងប្អូន បងប្អូនហ្នឹងមានជាប់ដែលថាជា កា.ហ្សេ.បេ របស់យួន ឬមួយ កា.ហ្សេ.បេ, សេ.អ៊ី.អា របស់អាមេរិកាំង បាទ គេលែងទុកចិត្តខ្ញុំហើយ គេដកខ្ញុំនេះឱ្យទៅកងចល័តហ្នឹង។ ដល់កងចល័តហ្នឹង ជាកងមួយដែលសម្រាប់ធ្វើតែស្រែទេ បាទ ជាកងនេះកងចល័តធ្វើស្រែនៅផ្តុំបបុស្ស នៅជិតស្ទាច់ដែង បាទ ខាងជើងស្ទាច់ដែងបន្តិច ខាងជើងកងកេងបន្តិចបាទ។ កន្លែងនោះហើយជាកន្លែង ជាអ្នកជាប់និន្នាការជាប់នឹងនយោបាយអ្វីមួយ [...] មានចំនួនច្រើនដែរ ប្រហែលជាបួនទៅ ៥០០នាក់ដែរ អាហ្នឹងកងតាចាយ ហ្នឹង គឺកងផលិត។"]។ ឯកសារ D54/35 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.14, 17 ["កងចល័តនោះ គឺឋិតនៅក្រោមការគ្រប់គ្រងរបស់កងពល១៦៤ដដែល ហើយគេបញ្ជូនទៅឱ្យធ្វើការនៅកន្លែងមួយហៅថា ភូមិព្រែកចាកឋិតនៅប្រហែលពីរគីឡូម៉ែត្រខាងកើតផែរាម [...] ឆ.17៖ ក្នុងឆ្នាំ ១៩៧៧ ខ្ញុំមិនចាំថ្ងៃទេ កងចល័តរបស់ខ្ញុំ ត្រូវបានដកចេញពីព្រែកចាកមកនៅតំបន់កងកេង ដែលគេឱ្យពួកយើងធ្វើការនៅភូមិប្របុសនិងភូមិព្នៀង នៅខាងជើងផ្លូវជាតិលេខ៤ ទល់មុខភូមិបិតត្រាំង។"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.16-17 ["កងវរៈសេនាតូច ២០ ដែលខ្ញុំនៅគឺជាកងវរៈសេនាតូចសម្រាប់អ្នកដែលមានទោសធ្ងន់ [...] ឆ.17៖ កងចល័តរបស់ខ្ញុំក៏ធ្វើការនៅប៉ែកខាងត្បូងផ្លូវជាតិលេខ៤ដែរ។ យើងនៅក្នុងតំបន់ជុំវិញព្រលានកងកេង ហើយនឹងតំបន់ទឹកសាប"]។ ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.23-24 ["ស៖ តើលោក និងអ្នកដទៃរាយការណ៍ទៅឱ្យអ្នកណានៅទីតាំងលើកទំនប់នោះ? ឆ.23៖ នៅពេលនោះ យើងត្រូវតែរាយការណ៍ទៅឱ្យ គឿន ដែលជាមេកងវរៈក្រោមកងពលលេខ៣។ ស៖ តើលោកអាចគូសបញ្ជាក់ឱ្យកាន់តែច្បាស់ថែមទៀតបានទេថា តើកងវរៈនេះមានលេខប៉ុន្មាន? ឆ.24៖ កងវរៈនេះពុំមានលេខទេ។ គឿន ជាមេកងដែលមានអ្នកធ្វើការ៣០០នាក់។ វាគឺជាអង្គភាពចល័តដែលសមាជិកគឺជាយោធាដែលគេរំសាយចេញពីកងពលលេខ៣។"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.16 ["ចូលដល់ឆ្នាំ១៩៧៧ ខ្ញុំក៏ត្រូវបានគេដកចេញ ហើយបញ្ជូនឱ្យទៅនៅកងផលិត។ កងផលិតរបស់ខ្ញុំ មានឈ្មោះថា កងវរៈសេនាតូចលេខ២០។ ខ្ញុំត្រូវបានគេចាត់តាំងឱ្យលើកទំនប់ និងជីកប្រឡាយ អស់រយៈពេលបួនខែ នៅកន្លែងស្ទាច់ដែង និង បបុស។ បន្ទាប់ពីពេលនោះមក គេបានបញ្ជូនខ្ញុំឱ្យទៅមើលក្របី និងភ្ជួរស្រែ។ ខ្ញុំធ្វើការនៅទីនោះរហូតដល់ខែកញ្ញា ឆ្នាំ១៩៧៨។ នៅពេលនោះ ខ្ញុំ

តាវៃ ដែលជាមេបញ្ជាការកងកាំភ្លើងធំ បានប្រជុំប្រាប់ខ្ញុំ និងយោធាដទៃទៀតថា ខ្ញុំ ហើយនិងយោធាទាំងនោះត្រូវបានផ្លាស់ពីកង ហើយបញ្ជូនទៅនៅកងចល័តព្រៃកចាក ដោយសារអង្គការចាត់ទុកយើងជាពួកសមាសភាពមិនល្អ ហើយត្រូវបញ្ជូនទៅលត់ដំ[2802]។

691. ជាលទ្ធផលនៃគោលនយោបាយនេះ "កងពលត្រូវបានរំសាយ គឺមានទាហានរាប់ពាន់នាក់។ ពួកគេត្រូវបានចាត់តាំងឱ្យធ្វើការក្នុងកងផលិតខុសៗគ្នា និងបញ្ជូនទៅតាមមុខព្រួញការងារខុសៗគ្នា"[2803]។

---

ហើយនិងកងវរៈលេខ២០របស់ខ្ញុំ ត្រូវបានគេបញ្ជូនឱ្យទៅវាយថ្មនៅការដ្ឋានវាយថ្ម ស្ទឹងហាវ។ ខ្ញុំធ្វើការនៅទីនោះរហូតដល់វៀតណាមចូលដល់។"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.62-63 ["សេ៖ តើមាស មុត ប្រាប់ថាហេតុអ្វីគេដកអាវុធពីពួកលោក ហើយហេតុអ្វីបានជាបញ្ជូនពួកលោកទៅកងផលិតហ្នឹង? ឆ.62៖ បើតាមការសន្និដ្ឋានរបស់ខ្ញុំ គឺដោយសារគេសន្និដ្ឋានថាមេរបស់ពួកខ្ញុំគឺពួកក្បត់។ [...] ឆ.63៖ [...] មាស មុត គ្រាន់តែនិយាយថាពួកគាត់ [មេរបស់សាក្សី] ក្បត់។"]។ ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.19 ["កងផលិតធំដែលមានអតីតយោធារាប់ពាន់នាក់ ដែលចាត់ថាមានសមាសភាពមិនល្អ។"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.19 ["នៅពេលនោះ នៅក្នុងកងពល១៦៤ មានបីកងដែលគេចាត់ថា ជាកងសមាសភាពមិនល្អ។ ក្នុងចំណោមទាំងបីកងនេះ ពីរកង គឺកងវរៈសេនាតូចលេខ ២០ និង ២១ ហើយមួយកងទៀត គឺជាកងអនុសេនាធំលេខ១៩។ ទាំងបីកងនេះ ផ្ទុកពួកយោធាដែលចាត់ទុកថា ជាសមាសភាពមិនល្អ។"]។ ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញួង ជ្រោង ឆ.28 ["ទាហានទាំងនោះ គឺគ្រប់កងទាំងអស់ ដែលមកពីកងពលវរសេនាធំ២២។ នៅពេលដែលពួកគេមានបញ្ហាអី ឬក៏មាននិន្នាការមិនល្អ គេនឹងដកចេញពីវរសេនាធំ យកទៅដាក់នៅក្នុងកងផលិតវិញ។"]។ ឯកសារ D54/113 កំណត់ហេតុស្តាប់ចម្លើយ លៀង បៀ (ទាហានកងពល១៦៤ត្រូវបានបញ្ជូនទៅធ្វើស្រែនៅកងកេង) ឆ.99 ["សេ៖ ហេតុអ្វីបានជាលោកដឹងថា គេបញ្ជូនអ្នកនោះទៅកងកេង? ឆ.99៖ ខ្ញុំឮគេនិយាយថា បើមានរឿងអីគេយកទៅធ្វើការនៅកងផលិត។"]។ សូមមើល ផងដែរ ឯកសារ D114/79.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ កង សុំ KH ERN 01104491 ["សេ៖ ដល់ពេលធ្វើស្រែ ប្រជាជននៅជិតហ្នឹងអ្នកធ្វើ ឬក៏កងទ័ពអ្នកធ្វើ? ឆ៖ កងទ័ពអ្នកធ្វើ កងពល១៦៤ ចាប់ពីចំការដូងចេងហេងមកត្បូង ទល់គ្នាគល់ស្ពានទឹកសាប។"]។

2802 ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.2។

2803 ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.92។ សូមមើល ផងដែរ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.100 ["នៅចុងឆ្នាំ១៩៧៧ ហើយកងពលចាស់ទាំងមូលត្រូវបានរំសាយទាំងស្រុង។"]។ ឯកសារ D114/65 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.16 ["ចូលដល់ឆ្នាំ១៩៧៧ ខ្ញុំក៏ត្រូវបានគេដកចេញ ហើយបញ្ជូនឱ្យទៅនៅកងផលិត។ កងផលិតរបស់ខ្ញុំ មានឈ្មោះថា កងវរៈសេនាតូចលេខ២០។ ខ្ញុំត្រូវបានគេចាត់តាំងឱ្យលើកទំនប់ និងជីកប្រឡាយ អស់រយៈពេលបួនខែ នៅកន្លែងស្នាចដែង និង បបុស។ បន្ទាប់ពីពេលនោះមក គេបានបញ្ជូនខ្ញុំឱ្យទៅមើលក្របី និងភ្ជួរស្រែ។ ខ្ញុំធ្វើការនៅទីនោះរហូតដល់ខែកញ្ញា ឆ្នាំ១៩៧៨។ នៅពេលនោះ ខ្ញុំ

ពេលនិយាយសំដៅដល់ទីតាំងមួយ នៅជិតទំនប់បិតត្រាង សាក្សីម្នាក់បានបញ្ជាក់ថា៖ "ព្រៃកចាក គឺជាកន្លែងដែលគេដាក់ពួកសមាសភាពសង្ស័យ តាំងពីយូរណាស់មកហើយ។ [...] យោធាខ្លះ ដែលមានសតិអារម្មណ៍មិននឹងនល្អ ក៏ត្រូវបញ្ជូនយកទៅដាក់នៅព្រៃកចាកដែរ"[2804]។ ក្រោយពីគេសង្ស័យ និងវាយ សមាជិកកងពល ១៦៤ កម្រត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅធ្វើជាកម្មាភិបាលសកម្មវិញណាស់[2805] គឺពួកគេអាចត្រូវបានចាប់ខ្លួន ឬសម្លាប់ និងយ៉ាងហោចណាស់ ចំពោះអ្នកខ្លះ គេបន្តស៊ើបប្រវត្តិរូប[2806]។

692. កម្មាភិបាលម្នាក់ ដែលត្រូវគេវាយ បានពន្យល់អំពីរបៀបនៃការបញ្ជូន "សមាសភាពមិនល្អ" ទៅធ្វើការនៅការដ្ឋានតំបន់រាម៖

> គេដកសេចក្តីទុកចិត្តពីខ្ញុំ គេទុកខ្ញុំជាជនសង្ស័យ ជាជនមិនល្អនៅក្នុងកង គេក៏ដកខ្ញុំទៅនៅចម្ការក្រូច ឲ្យធ្វើស្រែតែម្តង។ [...] គេដកសេចក្តីទុកចិត្តពីខ្ញុំ យកខ្ញុំទៅដាក់ឲ្យធ្វើស្រែ ដោយគេចាត់ទុកខ្ញុំជាជនសង្ស័យ ជាកាហ្សេបេ របស់យួន។
>
> [...]
>
> អ្នកដែលជាប់សមាសភាពមិនល្អ ត្រូវគេដាក់មួយក្រុម។ ឧទាហរណ៍ ខ្ញុំមានឪពុកម្តាយ ឬសាច់ញាតិជាប់ខ្សែសេរីអាមេរិក យួន ឬកាហ្សេបេ គេលែងទុកចិត្តខ្ញុំហើយ គេដកខ្ញុំ

---

ហើយនិងកងវរៈលេខ២០របស់ខ្ញុំ ត្រូវបានគេបញ្ជូនឲ្យទៅវាយថ្មនៅការដ្ឋានវាយថ្ម ស្ទឹងហាវ។ ខ្ញុំធ្វើការនៅទីនោះរហូតដល់វៀតណាមចូលដល់។"]។

2804 ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.17។

2805 ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.5 ["ស៖ តើពេលខ្លះ គេមានដោះលែងមនុស្សពីក្នុងកងនោះ ហើយបញ្ជូនមកធ្វើការក្នុងកងពល១៦៤វិញដែរឬទេ? ឆ.5៖ គ្មានទេ។ អ្នកណាក៏ដោយដែលបញ្ជូនចូលក្នុងកងនោះ គឺមិនត្រូវបានដោះលែងទេ។"]។ សូមមើល ផងដែរ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ. 233 ["ស៖ តើមានពេលណាមួយដែលគេរើសលោកឲ្យចូលមកធ្វើទាហានខ្មែរក្រហមវិញទេ? ឆ.233៖ អត់ទេ។ គេដកខ្ញុំចេញរហូតទាល់តែចប់របបខ្មែរក្រហមតែម្តង។"]។

2806 ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.29 ["ខ្ញុំគ្រាន់តែចាំថាកាលខ្ញុំធ្វើជាយោធាគេយកម្តងហើយ នៅពេលខ្ញុំធ្វើការនៅលើកោះ គេបានយកប្រវត្តិរូបខ្ញុំម្តង ពេលខ្ញុំធ្វើការនៅព្រលានយន្តហោះកងកេងគេយកម្តង និងម្តងទៀតនៅស្ទឹងហាវ។"]។

ទៅកងចល័តហ្វឹង។ កងចល័តហ្វឹងជាកងមួយដែលសម្រាប់ធ្វើតែស្រែទេ នៅផ្ទុំបបុស ខាងជើងស្ពានចំដែង និងកងកេង។ កន្លែងនោះជាកន្លែងដាក់អ្នកជាប់និន្នាការរបបចាស់[2807]។

693. ដូចបានរៀបរាប់ខាងលើ ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធអំណាច ចំពោះការដ្ឋានរាម **មាស មុត** ចូលរួមយ៉ាងសកម្មក្នុងការកំណត់មុខសញ្ញាកម្មាភិបាលដែលចាត់ទុកជា "សមាសភាពមិនល្អ" នៅទីនោះ។ សាក្សី លុន សេង បានចូលរួមក្នុងកិច្ចប្រជុំមួយ ហើយពេលនោះ មាស មុត បានប្រកាសថា "ពួកយោធាទាំងអស់ ដែលមកពីភូមិភាគបូព៌ា គឺជាយោធាដែលមានសមាសភាពមិនល្អ ដូច្នេះ ពួកគេត្រូវតែដកចេញឱ្យដាច់ពីកងពល"[2808]។ បន្ទាប់មក ទាហានទាំងនោះត្រូវគេបញ្ជូនទៅកងផលិតធំនៅការដ្ឋានតំបន់រាម[2809]។ កំណត់ហេតុកិច្ចប្រជុំរបស់កងពល ១៦៤ បង្ហាញនូវទស្សនៈថា "មានសមាសភាពមិនល្អនៅក្នុងកងទ័ព" នៅកងកេង[2810]។ **មាស មុត** បានដឹកនាំកិច្ចប្រជុំ ដែលក្នុងនោះកម្មាភិបាលត្រូវគេរំសាយ និងបញ្ជូនទៅការដ្ឋាន[2811]។ គាត់ក៏បានដឹកនាំកិច្ចប្រជុំ នៅការដ្ឋានតំបន់រាម ដែលក្នុងនោះ គាត់បានកំណត់អត្តសញ្ញាណ "ជនក្បត់" នានា ដូចជា ឆាន និង ឌឹម អាន "ចម្លើយសារភាព" របស់ពួកគេ និងរៀបរាប់ "ឈ្មោះកម្មាភិបាលក្បត់ ចាប់ពីថ្នាក់មជ្ឈិមរហូតដល់

---

2807 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ 10.48.52-10.51.34, 14.07.12-14.09.06។

2808 ឯកសារ D54/44 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.19។

2809 ឯកសារ D54/44 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.19, 22 ["សៈ ហេតុអ្វីបានជាលោកដឹងថា មានយោធា ១៥០០នាក់មកពីភូមិភាគបូព៌ា គេយកទៅដាក់នៅកងផលិតធំ? ឆ.19៖ ប្រធានកងពល មាស មុត បានបើកការប្រជុំ ហើយប្រកាសថា ពួកយោធាទាំងអស់ដែលមកពីភូមិភាគបូព៌ា គឺជាយោធាដែលមានសមាសភាពមិនល្អ ដូច្នេះពួកគេត្រូវតែដកចេញឱ្យដាច់ពីកងពល។ [...] សៈ កាលដែលកងពលបើកវគ្គប្រជុំរៀនសូត្រ ហើយប្រកាសប្រាប់ថា ពួកយោធាភូមិភាគបូព៌ា ជាសមាសភាពមិនល្អ តើលោកនៅទីនោះដែរឬទេ? ឆ.22៖ ខ្ញុំចូលរួមការប្រជុំដែរ បានខ្ញុំដឹង។"]។

2810 ឯកសារ D1.3.8.4 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុកិច្ចប្រជុំសមមិត្ត១៦៤ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00162489។

2811 ឯកសារ D54/44 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.19, 22 ["សៈ ហេតុអ្វីបានជាលោកដឹងថា មានយោធា ១៥០០នាក់មកពីភូមិភាគបូព៌ា គេយកទៅដាក់នៅកងផលិតធំ? ឆ.19៖ ប្រធានកងពល មាស មុត បានបើកការប្រជុំ ហើយប្រកាសថា ពួកយោធាទាំងអស់ដែលមកពីភូមិភាគបូព៌ា គឺជាយោធាដែលមានសមាសភាពមិនល្អ ដូច្នេះពួកគេត្រូវតែដកចេញឱ្យដាច់ពីកងពល។ [...] សៈ កាលដែលកងពលបើកវគ្គប្រជុំរៀនសូត្រ ហើយប្រកាសប្រាប់ថា ពួកយោធាភូមិភាគបូព៌ា ជាសមាសភាពមិនល្អ តើលោកនៅទីនោះដែរឬទេ? ឆ.22៖ ខ្ញុំចូលរួមការប្រជុំដែរ បានខ្ញុំដឹង។"]។

ថ្នាក់មូលដ្ឋាន"[2812]។ យ៉ាងហោចណាស់ អ្នកចូលរួមប្រជុំខ្លះ គឺជាកម្មាភិបាលរំសាយ ដែលក្រោយមក ត្រូវបាន **មាស មុត** បញ្ជូនទៅធ្វើការនៅកងផលិត[2813]។

694. អ្នកមកពីភូមិភាគបូព៌ា[2814] អ្នកមកពីតំបន់ ៣៧[2815] អ្នកមានសមាជិកគ្រួសារជាប់និន្នាការរបបលន់ នល់[2816] អ្នកដែលត្រូវវៀតណាមចាប់បាន រួចដោះលែងឲ្យត្រឡប់មកកម្ពុជាប្រជាធិបតេយ្យ

---

[2812] ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.1 ["នៅពេលនោះ គេបានដកយោធាកង៣៨៦ ទាំងអស់យកទៅដាក់នៅកងផលិត។ បន្ទាប់ពីគេដកអាវុធពីពួកយើងអស់ ពួកគេមិនអនុញ្ញាតឲ្យយើងទុកកាំបិតទេ យើងគឺអនុញ្ញាតឲ្យតែកាន់ចប។ បន្ទាប់មក មាស មុត បានមកធ្វើមីទ្ទីងជាមួយពួកយើងនៅភូមិគគីរ នៅជិតព្រលានយន្តហោះកងកេង ដោយមានអតីតយោធាចូលរួមប្រហែលរាប់ពាន់នាក់ ដោយមានកងវរសេនាតូច៣៨៦ និងកងផ្សេងៗទៀត។ នៅក្នុងការប្រជុំ មាស មុត អានចម្លើយសារភាពរបស់ពួកក្បត់។ គាត់បានរៀបរាប់ឈ្មោះកម្មាភិបាលក្បត់ចាប់ពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់មូលដ្ឋាន។"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.56, 60-61 ["ស៖ លោកនិយាយថា ពេលដែលលោកទៅដល់ដីគោក គេប្រជុំម្តងទៀត។ តើការប្រជុំនោះ នៅទីណា ហើយពេលណា? ឆ.56៖ ឈប់នៅព្រលានយន្តហោះកងកេង ហើយគេប្រជុំនៅពេលព្រឹកហ្នឹង។ ហើយ មាស មុត ជាប្រធានអង្គប្រជុំ។ [...] ឆ.60៖ ប្រជុំពីបញ្ហា មេក្បត់ គឺអនុមេបញ្ជាការកងពល ១៦៤ នង ឆាន ជាអ្នកក្បត់ ហើយ មាស មុត អានចម្លើយសារភាពរបស់ នង ឆាន ហ្នឹង។ [...] ឆ.61៖ គាត់អត់និយាយអ្វីទៀតទេ គាត់បញ្ជូនពួកខ្ញុំទៅកងផលិតពេលប្រជុំចប់។"]។

[2813] ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.61 ["ស៖ តើ មាស មុត មាននិយាយអ្វីទៀតទេ? ឆ.61៖ គាត់អត់និយាយអ្វីទៀតទេ គាត់បញ្ជូនពួកខ្ញុំទៅកងផលិតពេលប្រជុំចប់។ កងហ្នឹងដូចជាអ្នកទោសអីចឹង គឺគ្មានអាវុធទេ គេឲ្យធ្វើចំការធ្វើស្រែលើកដីបង្កបង្កើនផល ដូចប្រជាជនធម្មតាអីចឹង។"]។

[2814] ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.2, ឆ.11 ["អតីតយោធាភូមិភាគបូព៌ា ក៏ត្រូវបានបញ្ជូនទៅក្នុងកងចល័តជាមួយខ្ញុំដែរ។ ពួកយោធាភូមិភាគបូព៌ាត្រូវបានគេចាត់ថា ជាពួកក្បត់។ [...] ឆ.11៖ ពួកបូព៌ាមានប្រហែល ៥០-៦០នាក់"]។ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.33 ["បន្ទាប់ពីការចាប់ ឌឹម ទៅយោធាភូមិភាគបូព៌ាទាំងនោះត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ដែរ [...] ខ្ញុំគិតថា យោធាភូមិភាគបូព៌ាដែលត្រូវបានចាប់ខ្លួនទាំងនោះ ប្រហែលជាត្រូវបានគេសម្លាប់ចោលនៅកន្លែងសម្លាប់នោះដែរហើយ ប៉ុន្តែខ្ញុំមិនច្បាស់ទេ។"]។ ឯកសារ D54/44 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.6 ["មុនឆ្នាំ១៩៧៧ ខ្ញុំនៅកំពង់សោមនៅឡើយ ខ្ញុំដឹងថា យោធា ១៥០០នាក់មកពីភូមិភាគបូព៌ា ត្រូវបានដកកាំភ្លើង ហើយបញ្ជូនទៅដាក់នៅកងផលិតធំ នៅពុទ្ធទេ"]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.10, 41 ["កាលនោះទាំងពួកនិរតី និងពួកបូព៌ាត្រូវបានប្រមូលទាំងអស់គ្នាដោយពួកគេថា ឌឹម ដែលជាមេពួកខ្ញុំក៏ត្រូវបានគេចាប់ខ្លួនដែរ ដោយគេចោទថាក្បត់។ ក្រោយពីគេចាប់ ឌឹម គេក៏ចាប់ផ្តើមចាប់អ្នកនៅក្រោមៗតទៅទៀត។ [...] ឆ.41៖ នៅក្នុងកងអនុសេនាធំរបស់ខ្ញុំ គឺភាគច្រើនគឺជាអ្នកមកពីភូមិភាគបូព៌ា ពិសេសប្រធានកងតូច កងធំ គឺពួកគេបាត់ខ្លួន មុនពេលដែលគេយកខ្ញុំមកដល់ព្រលានយន្តហោះកងកេង ជួនកាលគេយកទាំងមេក្រុមទៀត។ មនុស្សដែលខ្ញុំស្គាល់មានឋានៈចាប់ពីមេក្រុម មេកងតូច កងធំ បាត់ខ្លួនអស់ហើយ

ពេលដែលខ្ញុំមកដល់ព្រលានយន្តហោះកងកេង។"]។ ឯកសារ D2/16 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី (កងទាហានជើងទឹកនៅអូរឈើទាល) ឆ.21 ["ស៖ លោកបានប្រាប់ពីរថ្ងៃមុនថា មិនមែនកម្លាំងបូព៌ាទាំងអស់ត្រូវបាត់ខ្លួនទាំងអស់គ្នាទេ ប៉ុន្តែមានកម្លាំងខ្លះត្រូវបានគេដកយកទៅធ្វើស្រែ តើពិតមែនដែរឬទេ? ឆ.21៖ បាទ ពិតមែនហើយ ខ្ញុំដឹងថាកម្លាំងមួយចំនួនត្រូវបានដកទៅធ្វើស្រែនៅម្តុំព្រលានយន្តហោះកងកេង។"]។

2815 ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.75, 78-79, 101, 109-110, 135, 137 ["កាលឆ្នាំ៧៧ ហ្នឹងគេថាតំបន់៣៧ក្បត់ ហើយគេថាមេៗហ្នឹងក្បត់ ហើយគាត់ក៏បោកគ្រាប់បែកសម្លាប់ខ្លួន។ [...] ស៖ តើលោកថាថាគេចោទគ្នានោះនៅឆ្នាំណាដែរ? ឆ.78៖ មុនពេលដែលគេដកខ្ញុំមកជីគោក នៅថ្ងៃទី០៧ ខែ៧ ឆ្នាំ១៩៧៧។ ពេលនោះគេដកកាំភ្លើងពីទាហានមកពីតំបន់៣៧នោះទាំងអស់។ [...] ឆ.79៖ គេឲ្យមកធ្វើការនៅស្នាច់ដែង។ [...] ឆ.101៖ គេឲ្យខ្ញុំមកធ្វើការនៅស្នាច់ដែង។ [...] ស៖ តើនោះមួយកងវរសេនាតូចចាស់របស់លោកឬ? ឆ.109៖ បាទ មួយកងវរសេនាតូចដែលមកពីតំបន់៣៧។ ស៖ តើរាប់ទាំងមេៗទៀតឬ? ឆ.110៖ បាទ។ [...] ស៖ នៅពេលដែលគេបញ្ជូនទៅស្នាច់ដែងនៅខែ កក្កដា ឆ្នាំ ៧៧តើមេបញ្ជាការកងវរសេនាតូច និងកងអនុសេនាធំត្រូវគេបញ្ជូនទៅទីនោះទាំងអស់ឬ? ឆ.135៖ បាទ។ [...] ស៖ តើពួកគេនៅតែជាមេបញ្ជាការរបស់លោកទៀត ឬជាទាហានធម្មតា? ឆ.137៖ គេដកសិទ្ធិអស់ហើយ។"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ ស្នួន ផ ឆ.21 ["ស៖ តើលោកដឹងថាហេតុអ្វីគេរំសាយអង្គភាពលោក ហើយបញ្ជូនទៅធ្វើការនៅព្រលានយន្តហោះកងកេងដែរឬទេ? ឆ.21៖ [...] ខ្ញុំឮថាគេចោទកម្មាភិបាលមកពីតំបន់៣៧ថាចូលដៃជាមួយខ្មាំង។"]។

2816 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ 14.03.18-14.07.12 ["ក្រោយពីចម្រាញ់កងទ័ពឲ្យល្អ ដោយធ្វើប្រវត្តិរូប ធ្វើជាប្រវត្តិរូប។ ប្រវត្តិរូបនោះ សង្ខេបនិងប្រវត្តិរូបលម្អិត។ ឧទាហរណ៍៖ បើខ្លួនខ្ញុំផ្ទាល់ ប្រវត្តិរូបជាប់និន្នាការនយោបាយ ឪពុកម្តាយបងប្អូនសាច់សាលោហិតធ្វើជាទាហានចាស់ បាទ ក៏មិនបាននៅក្នុងវង្វង់កងយោធាទៀតដែរ គឺគេត្រូវតែដកចេញពីកងយោធាដែរ។"], 14.07.12-14.11.54 ["ហើយខាងកងចល័តនេះ មិនមែនទោសធ្ងន់ទេ ទោសស្រាលៗ គ្រាន់តែជាប់និន្នាការនយោបាយ ហៅថា កម្ពែលចាស់ពីសម័យ លន់ នល់"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.1 ["ស៖ ហេតុអ្វីបានជាលោកត្រូវបានគេចាត់ទុកថាជាកងសមាសភាពមិនល្អ ហើយដាក់បញ្ចូលក្នុងកងចល័ត? ឆ.1៖ ពីព្រោះមា និងជីតារបស់ខ្ញុំធ្វើទាហាន លន់ នល់ [...] ខ្ញុំត្រូវបានខ្មែរក្រហមចាត់ទុកថាជាកងសមាសភាពមិនល្អពីព្រោះតែការពាក់ព័ន្ធនេះ ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំគ្មានធ្វើអ្វីខុសទេ។"]។ ឯកសារ D114/76 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.21 ["ខ្ញុំមិនច្បាស់ពីមូលហេតុដែលគេបញ្ជូនខ្ញុំមកដូច្នេះឡើយ ប៉ុន្តែខ្ញុំគិតថា គេចាត់ទុកថាខ្ញុំជាអ្នកមាននិន្នាការពាក់ព័ន្ធជាមួយសាច់ញាតិដែលធ្វើជាទាហានកាលពីរបបមុន។ នោះគឺជាពេលដែលពិបាកសម្រាប់ខ្ញុំ។"]។ ឯកសារ D114/77 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.43 ["ស៖ ចុះលោកវិញ តើគេស្រង់ប្រវត្តិរូបរបស់លោកដែរឬទេ? ឆ.43៖ បាទ ខ្ញុំក៏មានឯកសារនោះដែរ។ ឯកសារនោះត្រូវបានគេបញ្ជូនទៅថ្នាក់លើ ហើយមិនដែលបញ្ជូនត្រឡប់មកវិញឡើយ ហើយក្រោយមកទៀត ខ្ញុំបានឮពីគ្រួសាររបស់ខ្ញុំថា មានយោធាចុះទៅជួបពួកគេ ហើយពិនិត្រប្រវត្តិរូបរបស់ខ្ញុំ។ ខ្ញុំដឹងរឿងនេះ ពីប្រភពចំនួនពីរ ពីគ្រួសាររបស់ខ្ញុំផង និងពីកងវរៈសេនាតូចរបស់ខ្ញុំផង។ ខ្ញុំត្រូវបានគេប្រាប់ថា ខ្ញុំត្រូវបានគេចុះមកពិនិត្រប្រវត្តិរូបរបស់ខ្ញុំ។ កងពលធំដឹងថាខ្ញុំមានបងប្អូនជីដូនមួយ ២នាក់ធ្វើទាហាន លន់ នល់។"]។ ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.19 ["ខ្ញុំផ្ទាល់ ក៏ស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ដែរនៅពេលនោះ ពីព្រោះពូខ្ញុំម្នាក់ពាក់ស័ក្តិ៤

វិញ[2817] និងអ្នកផ្សេងទៀត[2818] ស្ថិតនៅក្នុងចំណោមប្រភេទកម្មាភិបាលសង្ស័យដែលត្រូវគេបញ្ជូនទៅធ្វើការនៅការដ្ឋានរាម។ ប្រសិនបើកម្មាភិបាលជាន់ខ្ពស់ ដែលត្រូវគេចាត់ទុកជាខ្មាំង ត្រូវបាន

---

អតីតនៅក្នុងកងទ័ពអាកាសក្នុងរបប សីហនុ និងរបប លន់ នល់ ប៉ុន្តែខ្ញុំបានលាក់ប្រវត្តិខ្ញុំជិត។"]។ សូមមើល ផងដែរ ឯកសារ D114/96 កំណត់ហេតុស្តាប់ចម្លើយ ចេង ឡុង ឆ.60-61, 75 ["គេសរសេរប្រវត្តិរូបរបស់ខ្ញុំ មនុស្សម្នាក់គេមកធ្វើប្រវត្តិរូបរបស់ខ្ញុំ។ គេសួរខ្ញុំថាខ្ញុំធ្វើអ្វី ហើយខ្ញុំធ្លាប់រស់នៅទីណា។ [...] ឆ.61៖ ឧទាហរណ៍ប្រសិនបើអតីតទាហាន លន់ នល់ ណាម្នាក់មិនលាក់ប្រវត្តិរូបគេទេ នោះ អតីតទាហាន លន់ នល់ នោះ គេនឹងនាំចេញទៅបាត់ [...] ឆ.75៖ ប្រជាជនខ្លះមានភាពស្មោះត្រង់ នៅពេលខ្មែរក្រហមមកធ្វើប្រវត្តិរូប ពួកខ្មែរក្រហមបានប្រាប់ប្រជាជនទាំងនោះឲ្យនិយាយការពិត ហើយប្រជាជនខ្លះបានប្រាប់ខ្មែរក្រហមបាននិយាយពីអ្វីដែលគេបានធ្វើនៅរបបមុន ហើយប្រជាជននោះ ត្រូវបានគេយកចេញទៅ។"]។ ឯកសារ D54/35.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប្រាក់ សុខា KH ERN 00964252-00964253 ["ស៖ ចឹងពូមានពាក់ព័ន្ធមិនទុកចិត្តយ៉ាងម៉េច ហើយដកមកខាងកងចល័តគ្រួសារពូមានរឿងអីកាលហ្នឹង? ឆ៖ មូលហេតុកាលហ្នឹងដោយសារខ្ញុំមានពាក់ព័ន្ធគេយកប៉ាខ្ញុំជាប់និន្នាការគេយកប៉ាទៅសម្លាប់ជាប់និន្នាការខ្មាំង ខ្ញុំមិនបានដឹងថាគេយកឪពុកខ្ញុំយកទៅសម្លាប់ចោលខ្ញុំអត់ដឹងផងហ្នឹង។ ស៖ ចឹងដោយសារថាអង្គការយកឪពុកទៅសម្លាប់? ឆ៖ បាទ! គេយកទៅសម្លាប់តាំងពី៧៣នោះអត់ដឹង ដល់៧៥គេដកខ្ញុំចេញអះ ដល់៧៧បានដឹង។"]។

2817 ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.2 ["នៅក្នុងកងចល័តនោះ ក៏មានអតីតយោធាវរៈសេនាតូច ៣១០ ដែលបានទៅវៃនៅកោះត្រល់ ហើយត្រូវវៀតណាមចាប់បានកាលពីនោះ បន្ទាប់ពីពួកគេត្រូវបានបញ្ជូនត្រឡប់ពីវៀតណាមមកវិញ ពួកគេត្រូវបានបញ្ជូនទៅក្នុងកងចល័តនោះ។"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង សុំ ឆ.158, 164-168 ["បន្ទាប់មក ពួកវៀតណាមដោះលែងពួកខ្ញុំនិងបញ្ជូនពួកយើងមកតាមច្រក ហាទៀង។ [...] ឆ.164៖ គេលែងទុកចិត្តយើងហើយ។ [...] ឆ.165៖ គេថាយើងមកពីស្រុកយួន គេខ្លាចយួនហ្នឹងអប់រំយើងទៅ ចូលជាភ្នាក់ងារ កា.ស្សេ.បេ ឬក៏ចូលជាភ្នាក់ងាររបស់វៀតណាមអស់ហើយ។ [...] ឆ.166៖ គេដកឲ្យខ្ញុំទៅវៃថ្ម ៧ម៉ែត្រគូបក្នុងមួយថ្ងៃនៅអូរម្លូ នៅជិតចំការដូច ចេងហេង ឆ្ងាយពីកងគេមានសមត្ថភាព។ ស៖ តើកន្លែងវាយថ្មនោះមានឈ្មោះទេ? ឆ.167៖ អូរម្លូ នៅតារាងកប៉ាល់ហោះកងកេង។ ស៖ តើពួកទាហានទាំងអស់ដែលគេដោះលែងមកក្នុងកងវរៈសេនាធំរបស់លោក គេឲ្យមកវាយថ្មទាំងអស់ឬ? ឆ.168៖ បាទ។"]។ ឯកសារ D114/79.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ កង សុំ KH ERN 01104485 ["ព្រលឹមឡើងចាញ់គេចងសេក [ដោយវៀតណាម]"], KH ERN 01104488 ["ហើយគ្រាន់តែមកដល់ភ្លាម សូម្បីតែគ្នាឯងបាត់គ្នាយូរ ហើយគួរតែនឹកគ្នាអាណិតគ្នា គេមិននិយាយរកយើងផង [...] ដកគេចទាំងអស់បំបែកគ្នា"], KH ERN 01104491 ["ស៖ អីចឹងពេលយួនចាប់បានគេលែងទុកចិត្តយើង? ឆ៖ អត់ទុកចិត្ត។ [...] ចុះលោកពូនៅនឹងកងណាវិញ? ឆ៖ នៅ១៦៤ហ្នឹងដដែល តែគេដកអត់មានធ្វើអី ឲ្យខ្ញុំទៅនៅអូរម្លូប្រាប់ប្រជាជនស្ទូង ទាញខ្សែឲ្យគេស្ទូងក្រឡាឈើត្រង់ កាំភ្លើងក៏គេមិនឲ្យកាន់"]។ ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.15, 17 ["ស៖ តើលោកបានដឹងអំពីកងវរសេនាតូច៣១០ ដែលទៅវៃនៅកោះត្រល់ ហើយត្រូវបានកងទ័ពវៀតណាមចាប់ខ្លួន ហើយក្រោយមកត្រូវបានដោះលែង និងបញ្ជូនត្រឡប់មកកងពល១៦៤ វិញដែរឬទេ? ឆ.15៖ បាទ ខ្ញុំបានឮអំពីរឿងនេះ [...] ទ័ពយួនក៏បានចាប់យោធារបស់កងវរសេនា

បញ្ជូនទៅមន្ទីរសន្តិសុខ ឬសម្លាប់ចោល ក្រោយពីដកចេញ *(សូមមើល ជាទូទៅ ផ្នែកទី VIII.ក ការបោសសម្អាតនៅក្នុងកងពល ១៦៤)* ជាទូទៅ អ្នកក្រោមបង្គាប់របស់ពួកគេក្លាយជាជនសង្ស័យ ត្រូវគេរំសាយ និងបញ្ជូនទៅការដ្ឋាន[2819]។ សាក្សីជាច្រើនបានកត់សម្គាល់ឃើញករណីនេះ។ "ពិត

តូច៣១០ទាំងអស់ ហើយបញ្ជូនទៅទុកលើកោះត្រល់។ [...] ស៖ យើងទទួលបានព័ត៌មានថា ពួកអតីតយោធាកងវរសេនាតូច៣១០ បន្ទាប់ពីយួនដោះលែងវិញ ត្រូវបានយកទៅដាក់នៅកងចល័ត ឱ្យធ្វើការនៅព្រែកចាក ក្បែរវាលយន្តហោះកងកេង ដោយសារពួកនោះគេចាត់ទុកថាជាសមាសភាពសង្ស័យ។ តើលោកធ្លាប់ដឹងអំពីរឿងនេះដែរឬទេ? ឆ. 17៖ បាទ ព្រែកចាក គឺជាកន្លែងដែលគេដាក់ពួកសមាសភាពដែលសង្ស័យតាំងពីយូរណាស់មកហើយ។ មានយោធាមកពីកងផ្សេងៗ ក៏ត្រូវគេយកមកដាក់នៅក្នុងកន្លែងព្រែកចាកនោះដែរ មិនមែនមានតែកងវរសេនាតូច៣១០ទេ។"]។ សូមមើល ផងដែរ ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.4-5 ["ស៖ តើលោកបានធ្លាប់ឮថាមានយោធាកងវរៈសេនាតូច៣១០ ដែលត្រូវបានចាប់ខ្លួនដោយវៀតណាម ហើយត្រូវបានដោះលែង ហើយត្រឡប់មកកងពល១៦៤វិញដែរឬទេ? ឆ.4៖ បាទ ខ្ញុំធ្លាប់ឮអំពីព្រឹត្តិការណ៍នេះ ពួកយោធាខ្មែរក្រហមទាំងនោះត្រូវបានចាប់ដោយវៀតណាមនៅលើកោះពូលូវៃ ប៉ុន្តែក្រោយមកត្រូវបានដោះលែងឱ្យត្រឡប់មកកម្ពុជាវិញ។ [...] ស៖ តើលោកមានដឹងថាតើមានរឿងរ៉ាវអ្វីកើតឡើង ចំពោះអតីតយោធាកងវរៈសេនាតូច៣១០ទាំងនោះទេ បន្ទាប់ពីគេយកមកដាក់បញ្ចូលទៅក្នុងកងពល១៦៤វិញ? ឆ.5៖ [...] យោធាទាំងនោះត្រូវបានដាក់ពង្រាយទៅតាមកោះផ្សេងៗ។"]។ ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ន សុត ឆ.73 ["ដល់ពេលវៀតណាមចាប់បាន ទើបបញ្ជូនទៅកោះត្រល់។ ហើយបញ្ជូនទៅកោះត្រល់ហើយ ទើបបញ្ជូនមកវិញតាមកែប ហើយបានបញ្ជូនមកកន្លែងខ្ញុំធ្វើស្រែទាំងអស់ ដោយសារគេខ្លាចថាពួកវៀតណាមបំពាក់នយោបាយអី គេមិនឱ្យធ្វើទ័ពវិញទេ។"]។ សូមមើល ផងដែរ ឯកសារ D114/187 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ឆ.55 ["កាលហ្នឹង កោះពីរហ្នឹងទាំងកោះប៉ូឡូវៃ ទាំងតូចទាំងធំហ្នឹងចាប់ទាំងអស់ ព្រោះយើងអត់មានទាហានជំនួយ យើងអត់មានម៉ារីន។ ទាំងកងទ័ពមកពី៤៥០ ត្រូវកងទ័ពយួនចាំទៅស្រុកយួន ហើយរហូតដល់ឆ្នាំ១៩៧៦ មិនដឹងខែប៉ុន្មានទេ មានការដោះដូរឈ្លើយសឹក។"]។

2818 ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.17 ["មានយោធាមកពីកងផ្សេងៗ ក៏ត្រូវគេយកមកដាក់នៅក្នុងកន្លែងព្រែកចាកនោះដែរ មិនមែនមានតែកងវរសេនាតូច៣១០ទេ។ យោធាខ្លះ ដែលមានសតិអារម្មណ៍មិននឹងនល្អ ក៏ត្រូវបញ្ជូនយកទៅដាក់នៅព្រែកចាកដែរ។"]។ ឯកសារ D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉េន ឆ.60 ["ស៖ លោកស្រីថាយោធាខ្មែរក្រហមក៏ធ្វើការក្នុងកងចល័តដែរ។ តើលោកស្រីដឹងថាពួកគេមកពីណាដែរទេ? ឆ.60៖ មិនដឹងមកពីណាទេ គេថាមកពីឈូក តាកែវ អីហ្នឹង។"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ .2 ["នៅក្នុងកងចល័តក៏មានប្រជាជន១៧មេសាដែលត្រូវបានគេជម្លៀសពីកំពង់សោមដែរ។"]។

2819 ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.89-90 ["ក្រោយមក គេបានរំសាយកងទ័ព ហើយប្រែក្លាយអង្គភាពយើងទៅជាកងផលិត ដោយឱ្យធ្វើស្រែ លើកទំនប់ និងជីកប្រឡាយ។ ស៖ ហេតុអ្វីបានជាគេរំសាយអង្គភាពរបស់លោក? ឆ.90៖ គេចោទយើងថាជាខ្មាំង ដោយសារមេកងវរៈរបស់ពួកយើងត្រូវបានគេចាប់យកទៅបាញ់សម្លាប់អស់ហើយ។"]។ ឯកសារ D54/20 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.14 ["គឺមេកងឈ្មោះ ខឿន ដែលជាមេបញ្ជាការអនុសេនាធំ៤២របស់ខ្ញុំ នៅកោះតាង។ [...] ក៏ស្លាប់ដែរពីព្រោះខ្ញុំមិនដែលបានជួបគាត់ដែរ។ ក្រោយ

ណាស់ ពេលមេរបស់យើងត្រូវគេចោទថាជាជនក្បត់ អ្នកក្រោមបង្គាប់ទាំងអស់ត្រូវគេចាត់ទុកជាជនក្បត់ ដោយស្វ័យប្រវត្តិ"[2820]។ "ក្រោយពីព្រឹត្តិការណ៍នៃការចាប់ខ្លួន [ខឹម] កងអនុសេនាធំ និងអង្គភាពជាច្រើន ត្រូវបានប្រមូលឱ្យមកធ្វើការនៅកងកេង"[2821]។ "មេៗរបស់ខ្ញុំត្រូវបានគេបញ្ជូនទៅរៀនសូត្រ ហើយបាត់ខ្លួន។ យើងដែលជាទាហានធម្មតា ត្រូវបានគេបញ្ជូនទៅដីគោក ហើយចូលតាមកងចល័ត ដើម្បីធ្វើស្រែ"[2822]។ "បើគេចាប់មេក្រុមហើយ កូនក្រុមនៅក្រោមៗ គេនឹងបញ្ជូនឱ្យទៅធ្វើស្រែ"[2823]។

695. កម្មាភិបាលរំសាយត្រូវគេដាក់នៅតាម "កងផលិត" ដែលត្រូវបានបង្ខំឱ្យធ្វើការ នៅការដ្ឋានតំបន់រាម[2824]។ "កងផលិតធំនៅពុតទេ" (ជិតទំនប់បិតត្រាង) មានកម្មាភិបាលរំសាយមកពីភូមិភាគបូព៌ា

---

មក បន្ទាប់ពីការបាត់ខ្លួនលើកទីមួយ ថ្នាក់លើបានហៅមេកងអនុសេនាធំទាំងនោះទៀត ហើយក៏បាត់ខ្លួនរហូតដូចអ្នកមុនដែរ។ [...] ទៅធ្វើពលកម្មនៅព្រលានយន្តហោះកងកេងរយៈពេល១ខែ។ វាជាការងារដ៏លំបាក"]។ ឯកសារ D54/113 កំណត់ហេតុស្តាប់ចម្លើយ លៀង បៀ ឆ.95-96 ["បើគេចាប់មេក្រុមហើយ កូនក្រុមនៅក្រោមៗគេនឹងបញ្ជូនឱ្យទៅធ្វើស្រែ។ សៈ តើគេបញ្ជូនទៅធ្វើស្រែនៅកន្លែងណាខ្លះ? ឆ.96 នៅកងកេង នៅភូមិបុស្សនៅជិតកងកេង។"]។ ឯកសារ D114/135 កំណត់ហេតុស្តាប់ចម្លើយ ណុប ផន (ទាហានដែលត្រូវគេរំសាយ ហើយបញ្ជូនទៅការដ្ឋានកងកេងនៅឆ្នាំ១៩៧៦) ឆ.5, 19 ["សៈ តើលោកដឹងថា មូលហេតុអ្វីបានជាគេរំសាយលោកដែរឬទេ? ឆ.5៖ ខ្ញុំមិនដឹងពីមូលហេតុដែលកើតឡើងនៅខាងលើៗនោះឡើយ មេៗរបស់ខ្ញុំត្រូវបានគេបញ្ជូនទៅរៀនសូត្រ ហើយបាត់ខ្លួន។ យើងដែលជាទាហានធម្មតាត្រូវគេបញ្ជូនទៅដីគោក ហើយចូលតាមកងចល័តដើម្បីធ្វើស្រែ។ [...] ឆ.19៖ មានទាហាន៦០ទៅ១០០នាក់ នៅក្នុងកងអនុសេនាធំរបស់ខ្ញុំ ដែលត្រូវបានគេរំសាយ។ ទាហាននៅក្នុងអង្គភាពផ្សេងទៀតក៏ត្រូវបានគេរំសាយដែរ ប៉ុន្តែខ្ញុំមិនដឹងថា ប៉ុន្មាននាក់ទេ។ យើងត្រូវបានគេរំសាយក្រោយពេលដែលមេៗរបស់យើងត្រូវបានគេដកចេញ ហើយគេលែងជឿទុកចិត្តយើងទៀត។ គេបញ្ជូនយើងឱ្យទៅចូលនៅកងចល័តនៅកងកេង ដើម្បីធ្វើស្រែ។"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.47, 62-63 ["គេប្រជុំដកអាវុធហើយ ពេលគេដកហើយ គេបញ្ជូនមកដីគោកភ្លាម។ [...]សៈ តើ មាស មុត ប្រាប់ថាហេតុអ្វីគេដកអាវុធពីពួកលោក ហើយហេតុអ្វីបានជាបញ្ជូនពួកលោកទៅកងផលិតហ្នឹង? ឆ.62៖ បើតាមការសន្និដ្ឋានរបស់ខ្ញុំ គឺដោយសារគេសន្និដ្ឋានថាមេរបស់ពួកខ្ញុំគឺពួកក្បត់។ សៈ តើ មាស មុត និយាយពីអ្នកក្បត់នៅក្នុងការប្រជុំហ្នឹងទេ? ឆ.63៖ [...] និយាយពី នង ឆាន និងមេៗរបស់ខ្ញុំទាំងពីរនាក់ហ្នឹង។ [...]មាស មុត គ្រាន់តែនិយាយថាពួកគាត់ [មេរបស់សាក្សី] ក្បត់។"]។

2820 ឯកសារ D114/79.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ កង សុំ KH ERN 01104496។

2821 ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.29។

2822 ឯកសារ D114/135 កំណត់ហេតុស្តាប់ចម្លើយ ណុប ផន ឆ.5។

2823 ឯកសារ D54/113 កំណត់ហេតុស្តាប់ចម្លើយ លៀង បៀ ឆ.95។

2824 ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.71-72, 78 ["គេប្រជុំហើយ គេបញ្ជូនមកកន្លែងកងផលិតហ្នឹង។ សៈ តើកងផលិតហ្នឹងនៅឯណាដែរ? ឆ.72៖ នៅប្រហែលបីគីឡូពីកន្លែងប្រជុំ ដែលនៅព្រលានយន្តហោះ

កងកេង នៅភូមិប្របុក។ [...] សៈ តើលោកអាចរៀបរាប់ពីការងាររបស់លោកនៅក្នុងកងផលិតនោះបានទេ? ឆ.78៖ កាលហ្នឹង កាប់គាស់លើកដីធ្វើស្រែផង ធ្វើចំការផងទៅតាមរដូវ។"]។ ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.17, 19 "គ្មានអ្នកណាជឿលើអ្នកណាទេ ពីព្រោះពេលខ្លះ ខ្ញុំបានឃើញអ្នកដែលធ្លាប់នៅថ្នាក់វរសេនាតូច ពីមុនមក ស្រាប់តែឃើញនៅក្នុងកងផលិតវិញ [...] ឆ.19៖ [...] នៅភូមិពុទ្ធទេ នៅខាងជើងផ្លូវជាតិលេខ៤ ឆ្លងផ្ទាល់ ពីវាលយន្តហោះកងកេង។ កន្លែងនោះ គឺជាកន្លែងកងពល១៦៤ ដាក់កងផលិតមួយកង ហៅថាកងផលិតធំ"]។ ឯក សារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន យ៉ើ ឆ.17, 27-28 ["ខ្ញុំនៅឯកងកេង ស្នាច់ដែង នៅកងផលិត។ រស់ នៅរយៈពេលខ្លី នៅកងកេងនេះ អានេះគេដកដូចថាសិទ្ធិយើងពីអ្នកតំបន់៣៧។ គេយកដាក់ដោយឡែក គេដកអាវុធ យើងចេញ។ [...] សៈ តើក្រុមលោកមានសមាជិកប៉ុន្មាននាក់ដែរ? ឆ.27៖ សមាជិកនៅក្រុមខ្ញុំ ខ្ញុំមិនអាចរៀបរាប់បាន ទាំងអស់ទេ។ វាម៉ាអង្គភាពមាន១០០នាក់អ៊ីចឹងទៅ។ មាក្រុមមាន១២នាក់។ សៈ តើមានប៉ុន្មានកងដែរ ធ្វើការនៅទី តាំងកងកេង? ឆ.28៖ មាន៣កងផលិត។"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ.170-172 ["គេនិយាយថា ជាពួកកងចល័តដូចជានៅកងចល័តនៅកងកេង និងស្នាច់ដែង។ ខ្ញុំឮថាមានកងផលិតនៅទីនោះ។ សៈ តើអ្នកណាជាអ្នកនិយាយប្រាប់រឿងនេះដល់លោក? ឆ.171៖ ពេលទៅប្រជុំយើងជិះឡានជាមួយគ្នា គេប្រាប់ថា នេះ ស្នាច់ដែង កងកេង។ សៈ តើបានន័យថា ពេលនោះគឺពេលដែលលោកបានទៅរៀននៅកំពង់សោមឬ? ឆ.172៖ បា ទ។"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.20, 24 ["នៅលើកោះតាងនោះឯង គេរំសាយអង្គ ភាពខ្ញុំមុននឹងបញ្ជូនពួកខ្ញុំឲ្យមកធ្វើស្រែនៅព្រលានយន្តហោះកងកេង។ ពេលគេរំសាយ គេចែកឲ្យចបម្នាក់១ៗដើម្បីធ្វើ ការ។ [...] ឆ.24៖ យោធាដែលគេរំសាយចេញពីកងរបស់ខ្ញុំមានប្រហែលជា២០០ ទៅ៣០០នាក់"]។ ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញ៉ូង ជ្រោង ឆ.28 ["នៅពេលដែលពួកគេមានបញ្ហាអី ឬក៏មាននិន្នាការមិនល្អ គេនឹងដក ចេញពីវរសេនាធំ យកទៅដាក់នៅក្នុងកងផលិតវិញ។"]។ សូមមើល ផងដែរ ឯកសារ D114/65 កំណត់ហេតុស្តាប់ ចម្លើយ ជេត ប៊ុណ្ណា ឆ.16 ["ចូលដល់ឆ្នាំ១៩៧៧ ខ្ញុំក៏ត្រូវបានគេដកចេញ ហើយបញ្ជូនឲ្យទៅនៅកងផលិត។ កងផលិ តរបស់ខ្ញុំ មានឈ្មោះថា កងវរៈសេនាតូចលេខ២០។ ខ្ញុំត្រូវបានគេចាត់តាំងឲ្យលើកទំនប់ និងជីកប្រឡាយ អស់រយៈ ពេលបួនខែ នៅកន្លែងស្នាច់ដែង និង បបុស។ បន្ទាប់ពីពេលនោះមក គេបានបញ្ជូនខ្ញុំឲ្យទៅមើលក្របី និងភ្ជួរស្រែ។ ខ្ញុំ ធ្វើការនៅទីនោះរហូតដល់ខែកញ្ញា ឆ្នាំ១៩៧៨។ នៅពេលនោះ ខ្ញុំ ហើយនិងកងវរៈលេខ២០របស់ខ្ញុំ ត្រូវបានគេបញ្ជូន ឲ្យទៅវាយថ្មនៅការដ្ឋានវាយថ្ម ស្ទឹងហាវ។"]។ ឯកសារ D54/113 កំណត់ហេតុស្តាប់ចម្លើយ លៀង បៀ ឆ.99 ["ឮ គេនិយាយថា បើមានរឿងអីគេយកទៅធ្វើការនៅកងផលិត។"]។ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.14 ["នៅពាក់កណ្ដាលឆ្នាំ១៩៧៦ ខ្ញុំត្រូវបានគេចាត់ទុកថាជាសមាសភាពសង្ស័យ មិនល្អ ហើយត្រូវបានគេដក ចេញពីកោះពូលៃ ហើយយកមកដាក់នៅធ្វើការជិតកន្លែងចំការធូរេន ចំការដូង និងចំការក្រូចក្នុងរយៈពេលជិត ប្រហែល២ខែ។ [...] នៅពេលនោះមានយោធា១២នាក់ មកនៅជាមួយខ្ញុំដែលគេចាត់ទុកថាជាសមាសភាពសង្ស័យ"] ។

យ៉ាងហោចណាស់ ១.៥០០ នាក់[2825]។ សាក្សីម្នាក់ទៀតបានពន្យល់ថា "បើមានរឿងអី គេយកទៅធ្វើការនៅកងផលិត"[2826]។

696. ថ្វីត្បិតតែកម្មាភិបាលខ្លះ ដែលត្រូវគេរំសាយ និងបញ្ជូនទៅធ្វើការនៅតាមការដ្ឋានតំបន់រាម ត្រូវគេយកទៅដាក់នៅតាមកងដែលមានរចនាសម្ព័ន្ធដូចកងយោធា[2827] ប៉ុន្តែ ច្បាស់ណាស់ថា ពួកគេមិនត្រូវបានចាត់ទុកស្មើនឹងកម្មាភិបាលសកម្មនោះទេ។ សាក្សីម្នាក់បាននិយាយថា៖ "គេមិនមែនថាយើងទ័ព ឬយោធាទេ គេចាត់ទុកយើងជាប្រជាជន គឺក្រោមប្រជាជនទៀត ព្រោះយើងមានជាប់និន្នាការ។ ប្រជាជនអាចសុំច្បាប់ទៅនេះទៅនោះបាន តែពួកយើង គេមិនអនុញ្ញាតទេ"[2828]។ ពេល

---

2825 ឯកសារ D54/45 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.13-16 ["ស៖ នៅខាងដើមលោកបាននិយាយថា ពួកយោធាភូមិភាគបូព៌ា១៥០០នាក់ ត្រូវបានបញ្ជូនទៅដាក់នៅកងផលិតធំ នៅពុទ្ធទេ។ តើការប្រជុំអប់រំនោះ កើតឡើងនៅពេលណា ពាក់ព័ន្ធទៅនឹងការបញ្ជូនយោធាទាំងនោះទៅពុទ្ធទេ? ឆ.13៖ ការប្រជុំដែលខ្ញុំជម្រាបនោះ គឺគេធ្វើឡើងនៅពេលការមកដល់របស់យោធាភូមិភាគបូព៌ា។ ប៉ុន្តែគេនិយាយថា យើងមិនទាន់ដឹងថា យោធាទាំងនេះល្អ ឬមិនល្អយ៉ាងណា ពីព្រោះដោយសារថ្នាក់លើបញ្ជូនពួកគេមក ដូច្នេះយើងត្រូវតែទទួលពួកគេ។ បន្ទាប់មក គេបានដកពួកយោធាភូមិភាគបូព៌ាទាំងអស់នេះបញ្ជូនទៅដាក់នៅកងផលិតធំ នៅពុទ្ធទេ។ ស៖ តើរយៈពេលប៉ុន្មានដែលលោកថា ក្រោយមកហ្នឹង បានគេបញ្ជូនពួកគេទៅកងផលិតធំ នៅពុទ្ធទេ? ឆ.14៖ ព្រឹត្តិការណ៍នេះកើតឡើងតិចជាងមួយឆ្នាំបន្ទាប់មក។ ស៖ អ្នកណាជាអ្នកសម្រេចបញ្ជូនពួកយោធាទាំងនេះទៅកងផលិតធំនោះ? ឆ.15៖ ខ្ញុំមិនច្បាស់ថាអ្នកណាពិតប្រាកដទេ ប៉ុន្តែខ្ញុំយល់ថា ជាសេចក្តីសម្រេចរបស់ប្រធានកងពល មាស មុត ស៖ ក្រៅពី ប្រធានកងពល មាស មុត តើមានអ្នកណាទៀតនៅក្នុងកងពលមានសិទ្ធិ ឬក៏សម្រេចបញ្ជូនពួកយោធាចេញពីកងពលទៅកងផលិតធំដែរឬទេ? ឆ.16៖ អត់មានទេ។"]។ សូមមើល ផងដែរ ឯកសារ D54/45.2 ផែនទីរដ្ឋបាល ទីតាំងភូមិសាស្ត្រ និងបណ្តាញផ្លូវខេត្តព្រះសីហនុ KH 00967555 [បង្ហាញថាកងផលិតធំស្ថិតនៅ បិតត្រាង]។ ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.19 ["ខ្ញុំចង់បន្ថែមអំពីទីកន្លែងមួយទៀត នៅភូមិពុទ្ធទេ នៅខាងជើងផ្លូវជាតិលេខ៤ ឆ្លងថ្នល់ពីវាលយន្តហោះកងកេង។ កន្លែងនោះ គឺជាកន្លែងកងពល១៦៤ ដាក់កងផលិតមួយកង ហៅថាកងផលិតធំ ដែលមានអតីតយោធារាប់ពាន់នាក់ ដែលចាត់ថាមានសមាសភាពមិនល្អ។"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.166 ["តែពួកហ្នឹងភាគច្រើនជាពួកពីកង ៣៨៦។"]។ ឯកសារ D54/44 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.14 ["នៅក្នុងកងផលិតធំ គឺគេរៀបចំរចនាសម្ពន្ធដូចនៅក្នុងកងយោធាដែរ"]។ ឯកសារ D54/45 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.17 ["ស៖ តើការដ្ឋានកងផលិតធំ នៅពុទ្ធទេ ស្ថិតនៅក្រោមកងពល ឬក៏វរសេនាធំ? ឆ.17៖ កងផលិតធំហ្នឹង គឺស្ថិតក្រោមការក្តាប់ផ្ទាល់របស់កងពល១៦៤។"]។

2826 ឯកសារ D54/113 កំណត់ហេតុស្តាប់ចម្លើយ លៀង ប៉ៀ ឆ.99។

2827 ឯកសារ D54/44 កំណត់ហេតុស្តាប់ចម្លើយ លុន សេង ឆ.14 ["Tនៅក្នុងកងផលិតធំ គឺគេរៀបចំរចនាសម្ពន្ធដូចនៅក្នុងកងយោធាដែរ ដោយរៀបចំចាប់ពីកងឡើងទៅ"]។

2828 ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ន សុត ឆ.68។

ខ្លះ ពួកគេត្រូវបានបណ្តើរទៅការដ្ឋានដោយកម្មាភិបាលប្រដាប់អាវុធ[2829]។ អាវុធរបស់ពួកគេត្រូវបានដកហូត[2830] ពួកគេទទួលបានរបបអាហារតិចជាងពេលនៅជាទាហាន[2831] ហើយថ្នាក់ដឹកនាំលែងទុកចិត្តពួកគេ[2832]។ កម្មាភិបាលម្នាក់បាននិយាយ ពេលគាត់ត្រូវគេរំសាយ៖ "ខ្ញុំពុំមានតួនាទីអ្វីឡើយ។ ខ្ញុំជាប្រជាជនធម្មតា"[2833]។ ពិតណាស់ ជារឿយៗ ពួកគេត្រូវបានបញ្ជូនទៅធ្វើការជាមួយជនស៊ីវិល នៅតាមការដ្ឋាន[2834]។

697. សាក្សីម្នាក់និយាយអំពីស្ថានភាពផ្ទុយគ្នាស្រឡះ នៅមុន និងក្រោយពេលគាត់ត្រូវគេរំសាយ៖

---

2829 ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.7, 11 ["នៅពេលនោះ គឺមានមនុស្ស២០ទៅ៣០នាក់លើឡានពេលដែលគេដឹងខ្ញុំទៅ [ព្រលានយន្តហោះកងកេង]។ [...] ឆ.11៖ ខ្ញុំច្បាស់ណាស់ គឺពួកគេជាយោធារបស់កងពល១៦៤។ កាលនោះ មាននាក់បើកឡានម្នាក់ និងមាននាក់ដែលមកអមជាមួយយើងពីរបីនាក់ ហើយសុទ្ធតែមានកាំភ្លើង រួមទាំងអ្នកបើកឡានផង។"]។

2830 ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.45, 47 ["កងខ្ញុំត្រូវគេដកអាវុធអស់ហើយ តែកាលហ្នឹងវាមិនមែនតែខ្ញុំមួយកងទេ ព្រោះគេបញ្ចូលគ្នា។ ពេលគេដកអាវុធអស់ហើយ គេបញ្ជូនមកដីគោកវិញ។ [...] ឆ.47៖ គេប្រជុំដកអាវុធហើយ ពេលគេដកហើយ គេបញ្ជូនមកដីគោកភ្លាម [ពីកោះតាង]"]។ ឯកសារ D114/224 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន យ៉ើ ឆ.17 ["ក្រោយពីបែកភ្នំពេញ១៩៧៥ ខ្ញុំនៅអង្គភាពកងផលិត តំបន់៣៧ ក្រុងព្រះសីហនុ។ ខ្ញុំនៅឯកងកេង ស្នាច់ដែង នៅកងផលិត។ រស់នៅរយៈពេលខ្លី នៅកងកេងនេះ អានេះគេយកដូចថាសិទ្ធិយើងពីអ្នកតំបន់៣៧។ គេយកដាក់ដោយឡែក គេយកអាវុធយើងចេញ។"]។ ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.1 ["នៅពេលនោះ គេបានដកយោធាកង៣៨៦ ទាំងអស់យកទៅដាក់នៅកងផលិត។ បន្ទាប់ពីគេដកអាវុធពីពួកយើងអស់ ពួកគេមិនអនុញ្ញាតឲ្យយើងទុកកាំបិតទេ យើងគឺអនុញ្ញាតឲ្យតែកាន់ចប។"]។

2831 ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.16 ["សម្រាប់អាហារគឺតិចជាងកាលដែលខ្ញុំនៅកន្លែងយោធាសមរភូមិមុខ។"]។

2832 ឯកសារ D114/135 កំណត់ហេតុស្តាប់ចម្លើយ ណុប ផន ឆ.19 ["យើងត្រូវបានគេរំសាយក្រោយពេលដែលមេៗរបស់យើងត្រូវបានគេដកចេញ ហើយគេលែងជឿទុកចិត្តយើងទៀត។ គេបញ្ជូនយើងឲ្យទៅចូលនៅកងចល័តនៅកងកេង ដើម្បីធ្វើស្រែ។"]។

2833 ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.90។

2834 ឯកសារ D54/33 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង ឆុន ឆ.13 ["យោធានៅទីនោះនៅពេលនោះ គេឲ្យធ្វើស្រែជាមួយប្រជាជន"]។ ឯកសារ D54/89 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.25 ["កងរំសាយ ពួកទាំងនេះ គឺត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅតាមវាលស្រែជាមួយប្រជាជនដែរ នៅតំបន់នោះ។ អតីតយោធារំសាយទាំងនោះ ពេលធ្វើការគឺមានអ្នកកាន់កាំភ្លើងចាំយាម។"]។

ពួកយើងពុំមានព្រួយបារម្ភទេ មុនការប្រកាសអំពីការចាប់ខ្លួន ឌឹម និង ឆាន ដោយសារតែពួកយើងជាយោធាដែលមានសិទ្ធិពេញលេញ។ ពួកយើងមានកាំភ្លើងប្រើ ពួកយើងអាចទៅណាមកណាបាន។ ប៉ុន្តែ ក្រោយពីការប្រកាសអំពីការចាប់ខ្លួន ឌឹម និង ឆាន និងការចាប់ខ្លួនមេវរសេនាតូច និងវរសេនាធំ ដូចជា តាហម និងតាវ៉េត មកទៀត ពួកខ្ញុំជាច្រើនកាន់តែភិតភ័យខ្លាំង ដោយសារថាយើងមិនដឹងថា គេមកចាប់យើងនៅពេលណានោះទេ។

[...]

ជីវិតខ្ញុំមានការប្រែប្រួលច្រើនទិដ្ឋភាពណាស់។ ទី ១ គេមិនឲ្យហូបគ្រប់គ្រាន់។ ទី ២ គេឲ្យធ្វើការខ្លាំង គឺចាប់ធ្វើពីម៉ោង ៥ ឬ ៦ ព្រឹក រហូតដល់ម៉ោង ១១ ថ្ងៃត្រង់ និងបន្តពីម៉ោង ១២ កន្លះ រហូតដល់ម៉ោង ៥ ល្ងាច គឺគេឲ្យទៅលើកទំនប់ ជីកប្រឡាយ រែកដី និងធ្វើស្រែ។ ការងារទាំងនេះ គឺពុំទទួលបានប្រាក់អ្វីទេ ហើយគេឲ្យធ្វើការមួយខែ ៣០ ថ្ងៃ ពុំមានថ្ងៃសម្រាកណាមួយទេ។ ទី ៣ គឺពួកគេតាមដានយើងជាប្រចាំ គឺមានអ្នកតាមដាននៅជុំវិញខ្លួនយើងទាំងអស់។ ចុងក្រោយ គឺពួកគេដកហូតសិទ្ធិទាំងអស់របស់យើង ដោយពុំអាចទៅណាមកណាដោយសេរីបានទេ។ គឺអាចតែរស់នៅតែកន្លែងដែលគេចាត់តាំង និងពេលយប់ ត្រូវនៅតាមរោងវែងៗ ដែលគេធ្វើឲ្យស្នាក់នៅ សម្រាប់មនុស្សពី ១០ ទៅ ២០ នាក់[2835]។

698. កម្មាភិបាលរំសាយ នៅតាមការដ្ឋានតំបន់រាម "ធ្វើការ ដោយមានអ្នកកាន់កាំភ្លើងចាំយាម"[2836]។ អ្នកយាមជាកម្មាភិបាលសកម្ម[2837] "ជាសមាសភាពល្អ"[2838] "មានអាហារហូបចុកគ្រប់គ្រាន់ និង

---

2835 ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.5, ឆ.12។

2836 ឯកសារ D54/89 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.25 ["អតីតយោធារំសាយទាំងនោះ ពេលធ្វើការគឺមានអ្នកកាន់កាំភ្លើងចាំយាម។"]។

2837 ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.173 ["សៈ ទាហានតំបន់៣៥យាមតំបន់ទាំងបីនោះឬ? ឆ.173៖ បាទ។"]។ ឯកសារ D114/135 កំណត់ហេតុស្តាប់ចម្លើយ ណុប ផន ឆ.30 ["បាទ មានគេយាម និងត្រួតពិនិត្យថាតើយើងបានធ្វើការងាររបស់យើងដែរឬទេ។"]។ សូមមើល ផងដែរ ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ន សុត ឆ.64 ["មេៗគេដើរពិនិត្យមើលយើងធ្វើការនៅលើភ្លឺស្រែទេ។"]។

2838 ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.32 ["គេឲ្យពួកដែលមានសមាសភាពល្អ ឲ្យមកគ្រប់គ្រងពួកយើង។ គេថាពួកខ្ញុំក្បត់"]។

មានកាំភ្លើង"[2839]។ កម្មាភិបាលសកម្មនៅតាមការដ្ឋាន "អាចទៅណាមកណាដោយសេរី" ចំណែកឯកម្មាភិបាលរំសាយ "គេដាក់ឱ្យនៅកន្លែងណា គឺនៅកន្លែងនោះរហូត"[2840]។

*ខ) ប្រជាជន ១៧ មេសា*

699. "ប្រជាជនថ្មី" ឬ "ប្រជាជន ១៧ មេសា" ដែលត្រូវគេបញ្ជូនពីកំពង់សោម និងពីតំបន់ផ្សេងទៀត គឺស្ថិតនៅក្នុងចំណោមអ្នកដែលត្រូវគេចាត់ទុកជាខ្មាំង ហើយត្រូវគេបញ្ជូនទៅធ្វើការនៅតាមការដ្ឋានតំបន់រាម[2841]។ សាក្សី ប្រាក់ សុខា បានរៀបរាប់ថាមាន "ប្រជាជន ១៧ មេសា ៣០-៤០ នាក់" នៅក្នុងកងចល័តរបស់គាត់[2842]។ សាក្សីម្នាក់ទៀតឈ្មោះ ប៉ាក សុខ ត្រូវគេចាត់តាំងឱ្យទៅធ្វើការ

---

2839 ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.182។

2840 ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.35 ["ស៖ ហេតុអ្វីបានជាលោកនិយាយថាខ្សែបណ្ដាញរបស់ មាស មុត ជាមនុស្សល្អ? ឆ.35៖ ពីព្រោះពួកគេអាចទៅណាមកណាដោយសេរី គេអាចឡើងទៅភ្នំពេញបាន ចំណែកពួកខ្ញុំ គេដាក់ឱ្យនៅកន្លែងណា គឺនៅកន្លែងនោះរហូត។"]។

2841 ឯកសារ D114/94 កំណត់ហេតុស្តាប់ចម្លើយ សំ វុទ្ធី ឆ.44-46 ["ស៖ ក្នុងចំណោមអ្នកដែលទៅហ្នឹង តើមានអ្នកដែលនៅទីនោះស្រាប់តែម្ដង ឬអ្នកដែលត្រូវបានជម្លៀសដែលចូលទៅតំបន់នោះ ឬយ៉ាងណា? ឆ.44៖ ពួកយើងសុទ្ធតែប្រជាជនថ្មី។ ស៖ តើប្រជាជនថ្មីមានន័យថាម៉េច? ឆ.45៖ ប្រជាជនថ្មី គឺគេហៅថា "អ្នក១៧" ដែលជម្លៀសមកពីភ្នំពេញ។ ស៖ អ្នក១៧ តើមានន័យថាអ្នក១៧មេសា ឬ? ឆ.46៖ បាទ។"]។ ឯកសារ D114/94 កំណត់ហេតុស្តាប់ចម្លើយ សំ វុទ្ធី ឆ.91-92 ["ស៖ តាលាន់មានប្រាប់ថាហេតុអ្វីបានជាគេបញ្ជូនលោកមកធ្វើការនៅក្នុងក្រុមនោះទេ? ឆ. 91៖ គាត់ថា គេឱ្យមកលត់ដំ កសាងខ្លួន។ ស៖ ហេតុអ្វីបានជាគេឱ្យលោកកសាងខ្លួន? ឆ.92៖ ព្រោះយើងជាប្រជាជនថ្មី។"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.2 ["បន្ទាប់ពីពួកគេត្រូវបានបញ្ជូនត្រឡប់ពីវៀតណាមមកវិញ ពួកគេត្រូវបានបញ្ជូនទៅក្នុងកងចល័តនោះ។ អតីតយោធាភូមិភាគបូព៌ា ក៏ត្រូវបានបញ្ជូនទៅក្នុងកងចល័តជាមួយខ្ញុំដែរ។ ពួកយោធាភូមិភាគបូព៌ាត្រូវបានគេចាត់ថា ជាពួកក្បត់។ នៅក្នុងកងចល័តក៏មានប្រជាជន១៧មេសាដែលត្រូវបានគេជម្លៀសពីកំពង់សោមដែរ។"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ 10.48.52-10.51.34 ["ខ្ញុំបានដឹងនូវប្រជាជន១៧មេសា នៅភូមិគគីរ ស្នាច់ដែង ពុតទេ ដែលដកពីរាម ដកពីកងកេង បាទ យកប្រមូលផ្ដុំនៅភូមិគគីរ។ នៅស្នាច់ដែងនេះ [...] ចុងឆ្នាំ៧៧នេះ ខ្ញុំដឹងព្រោះគេឱ្យធ្វើស្រែជាមួយប្រជាជន១៧មេសា។"]។

2842 ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.2, 6, 11 ["នៅក្នុងកងចល័តក៏មានប្រជាជន១៧មេសាដែលត្រូវបានគេជម្លៀសពីកំពង់សោមដែរ។ [...] ឆ.6៖ [...] តែមានប្រជាជន១៧មេសាខ្លះ ដែលជាខ្មែរកម្ពុជាក្រោមត្រូវបានគេដាក់នៅក្នុងកងចល័តនោះ [...] ឆ.11៖ ប្រជាជន១៧មេសា [...] ៣០-៤០ នាក់"]។

ជាមួយ "ប្រជាជនថ្មី" នៅតំបន់រាម[2843]។ សាក្សីម្នាក់បានសង្កេតឃើញយ៉ាងច្បាស់៖ "ខ្ញុំក៏បានកត់សម្គាល់ផងដែរថា មានការបែងចែករវាងប្រជាជនចាស់ និងប្រជាជនថ្មី ឬប្រជាជន ១៧ មេសា។ ហើយយើងមិនអាចធ្វើអ្វីបានឡើយ"[2844]។

*គ) ខ្មែរក្រោម*

700. ខ្មែរក្រោមក៏ត្រូវបានកំណត់មុខសញ្ញា ដើម្បីបញ្ជូនទៅធ្វើការនៅតាមការដ្ឋានតំបន់រាមផងដែរ[2845]។ ខ្មែរក្រហមត្រូវបានកំណត់មុខសញ្ញា ដោយសារតែ "ខ្មែរក្រហមបានចោទខ្មែរកម្ពុជាក្រោមថាមានទំនាក់ទំនងជាមួយយួន ពីព្រោះពួកគេរស់នៅវៀតណាម"[2846]។

---

2843 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ 10.48.52-10.51.34 ["ខ្ញុំបានដឹងនូវប្រជាជន១៧មេសា នៅភូមិគគីរ ស្នាច់ដែង ពុតទេ ដែលដកពីរាម ដកពីកងកេង បាទ យកប្រមូលផ្តុំនៅភូមិគគីរ។ នៅស្នាច់ដែងនេះ ឃើញថា បានដឹងព្រឹត្តិការណ៍ដែលកើតឡើងនៅឆ្នាំ៧៧ ចុងឆ្នាំ៧៧នេះ។ បាទ ប្រជាជននេះ ដោយសារដែលខ្ញុំដឹង ព្រោះខ្ញុំគេឲ្យធ្វើស្រែជាមួយប្រជាជន១៧មេសា តែខ្ញុំធ្វើចម្ការ ធ្វើស្រែជាមួយប្រជាជន១៧មេសានុ៎ង ថ្ងៃមួយ ថ្ងៃក្រោយមក ខ្ញុំចេះតែឃើញបាត់អស់ទៅៗ ខ្ញុំមានការសង្ស័យ មិនដែលឃើញប្រជាជននោះបានមកចូលរួមធ្វើការងារជាមួយគ្នាទៀត ក៏ខ្ញុំបានសួរទាហានយោធាម្នាក់ដែលឃ្លាលទានៅលើថ្នល់នោះ ជិតភូមិគគីរនោះ។ ខ្ញុំបានស្គាល់គ្នាហើយ ខ្ញុំបានសួរ "មិត្ត! ប្រជាជនដែលអ្នកធ្វើការជាមួយខ្ញុំនោះ តែឥឡូវអត់ដែលឃើញ តើលោកដឹងទេប្រជាជននោះយកទៅណា?" យោធានោះក៏និយាយប្រាប់ខ្ញុំច្បាស់លាស់ហើយថា៖ ប្រជាជន១៧មេសានោះ គេយកចំនួនពីរបីឡានទ្រុង យកទៅវៃចោលនៅលើចំណោតសេអ៊ីអស់ហើយ។ បាទ រឿងនេះជារឿងពិតប្រាកដ"។ 14.18.03-14.21.14 ["រាល់ថ្ងៃធ្វើការរស់នៅជាមួយនឹងគ្នាបាទ ជាមួយខ្ញុំ ជាមួយជនដែលសមាសភាពមិនសូវល្អហ្នឹង ឃើញថាបានធ្វើជាមួយគ្នា។ ដល់តែក្រោយមក ចេះតែបាត់ទៅៗហ្នឹង ខ្ញុំក៏បានស៊ើបសួរដែលកងនៅប្រចាំការនៅឃ្លាយទារក្បែរនុ៎ង ក៏បានសួរទៅគាត់ថាប្រជាជន១៧មេសា ប្រហែលជាពីរបីឡាននោះគេយកទៅសម្លាប់ចោលអស់ហើយ។"]។ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.28-29 ["ខ្ញុំដឹងរឿងនេះនៅពេលដែលខ្ញុំត្រូវបានគេចាត់ទុកចូលទៅក្នុងសមាសភាពមិនល្អ។ ខ្ញុំត្រូវបានគេចាត់ឲ្យទៅធ្វើការនៅស្រែក្នុងតំបន់រាមនេះដូចដែលខ្ញុំបានជម្រាបពីខាងដើម។ ខ្ញុំត្រូវបានគេដាក់ឲ្យធ្វើការជាមួយនឹងប្រជាជនមូលដ្ឋាននៅក្នុងតំបន់នោះ។ ក្រោយមក ខ្ញុំពុំបានឃើញមនុស្សមួយចំនួនដែលខ្ញុំធ្លាប់ធ្វើការពីមុនមកធ្វើការដូចសព្វដង។ ខ្ញុំក៏សួរយោធាដែលឃ្លាលទានៅទីនោះហេតុអ្វីមិនឃើញមកធ្វើការ។ យោធាទាំងនោះបានប្រាប់ខ្ញុំថា ប្រជាជន១៧ មេសា គឺត្រូវបានសម្លាប់អស់ហើយ។"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ 14.18.03-14.21.14 ["រាល់ថ្ងៃធ្វើការរស់នៅជាមួយនឹងគ្នាបាទ ជាមួយខ្ញុំ ជាមួយជនដែលសមាសភាពមិនសូវល្អហ្នឹង ឃើញថាបានធ្វើជាមួយគ្នា។ ដល់តែក្រោយមក ចេះតែបាត់ទៅៗហ្នឹង ខ្ញុំក៏បានស៊ើបសួរដែលកងនៅប្រចាំការនៅឃ្លាយទារក្បែរនុ៎ង ក៏បានសួរទៅគាត់ថាប្រជាជន១៧មេសា ប្រហែលជាពីរបីឡាននោះគេយកទៅសម្លាប់ចោលអស់ហើយ។"]។

2844 ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.1។

701. លើសពីនេះទៀត កម្មាភិបាលវំសាយ ប្រជាជន ១៧ មេសា និងខ្មែរក្រោម ត្រូវគេធ្វើទុក្ខបុកម្នេញ តាមរយៈការសម្លាប់ និងការបាត់ខ្លួនដោយបង្ខំ ដូចរៀបរាប់នៅក្នុងផ្នែកខាងក្រោម។

**មនុស្សឃាត ការសម្លាប់ផ្ដាច់ពូជ និងការបាត់ខ្លួនដោយបង្ខំ**

702. ការចាប់ខ្លួន ការបាត់ខ្លួន និងការសម្លាប់ បានកើតឡើងជាញឹកញាប់នៅតាមការដ្ឋានតំបន់រាម[2847]។ "នៅពេលថ្ងៃ គេឲ្យប្រជាជនធ្វើការ ហើយគេធ្វើការចាប់ខ្លួនមនុស្សនៅតែពេលយប់ទេ។ ១ ឬ ២

---

[2845] ឯកសារ D54/36 កំណត់ហេតុស្ដាប់ចម្លើយ ប្រាក់ សុខា ឆ.6-7 ["តែមានប្រជាជន១៧មេសាខ្លះ ដែលជាខ្មែរកម្ពុជាក្រោមត្រូវបានគេដាក់នៅក្នុងកងចល័តនោះ ហើយខ្មែរក្រោមត្រូវបានគេបញ្ជូនទៅទឹកសាប បន្ទាប់ពីគេដាក់ក្នុងកងនោះបានពី ៤-៥ខែ។ ខ្មែរក្រោម គេមិនដែលទុកយូរទេនៅក្នុងកងចល័ត។ [...] ឆ.7៖ មានតែខ្មែរក្រោមជាច្រើននៅតាមកងផ្សេងៗ តែខ្ញុំបានស្គាល់ខ្លះដែលនៅក្នុងរបស់ខ្ញុំ ខ្ញុំនៅចាំឈ្មោះ ថាច់ ប៊ិន ឡាំ ស៊ិក និង ឡាំ សាញ់ (ទាំងពីរនាក់នេះជាបងប្អូនបង្កើត)។ ខ្ញុំចាំឈ្មោះអ្នកទាំងបីនាក់នេះ ពីព្រោះគេនៅក្នុងក្រុមជាមួយខ្ញុំ គេត្រូវបានយកទៅទឹកសាប បន្ទាប់ពីគេនៅក្នុងកងជាមួយខ្ញុំបាន ៤-៥ខែ។ អ្នកណាក៏ដោយឲ្យតែគេបញ្ជូនទៅទឹកសាប គឺមិនដែលរស់ទេ។"]។

[2846] ឯកសារ D54/36 កំណត់ហេតុស្ដាប់ចម្លើយ ប្រាក់ សុខា ឆ.10 ["សៈ ហេតុអ្វីបានជាខ្មែរកម្ពុជាក្រោមត្រូវបានគេបញ្ជូនទៅកងចល័ត? ឆ.10៖ ខ្មែរក្រហមបានចោទខ្មែរកម្ពុជាក្រោមថា មានទំនាក់ទំនងជាមួយយួន ពីព្រោះពួកគេរស់នៅវៀតណាម។

[2847] សូមមើល ឧទាហរណ៍ ឯកសារ D114/239 កំណត់ហេតុស្ដាប់ចម្លើយ សៅ ម៉េន ឆ.49 ["សៈ តើលោកស្រីដឹងថាគេយកទៅណាទេ? ឆ.49៖ គេថាផ្លាស់ទៅកោះខ្យង ហើយមិនឃើញមកវិញណា។"]។ ឯកសារ D54/35.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប្រាក់ សុខា KH ERN 00964252 ["សៈ ចឹងនៅក្នុងអង្គភាពពូក្រោយមកមានបាត់ខ្លួនមានចាប់ខ្លួនខ្លះទេមានទេ? ឆ៖ មានហើយកងអ្នកមានកំហុសកងចល័តអីបាត់ខ្លួនគេយកទៅកសាងទឹកសាបទឹកអីទៅ កាលហ្នឹងដឹងថាអង្គការយកទៅកសាងមិនដឹងជាយកទៅណា។ សៈ ចឹងមានបាត់ខ្លួនដែរ? ឆ៖ បាទ។"]។ ឯកសារ D114/239 កំណត់ហេតុស្ដាប់ចម្លើយ សៅ ម៉េន ឆ.51-52 ["យកទៅកន្លែងថ្មីម្ដង១ឡាន ពេលខ្ញុំទៅដល់កំពត ខ្ញុំសួរគេ គេមិនដឹងនៅទីណា។ ចំណែកម៉ែឪខ្ញុំបាត់អស់រលីង។ សៈ លោកស្រីនិយាយថា ម្ដងគេយក១ឡានទៅ។ តើម្ដងៗនោះ គេយកមួយខែម្ដងឬក៏យ៉ាងណា? ឆ.52៖ ម្ដង១០ថ្ងៃ កន្លះខែអីចឹងទៅ។"]។ ឯកសារ D114/6 កំណត់ហេតុស្ដាប់ចម្លើយ យិន តេង ឆ.26 ["កូនប្រុសច្បងរបស់ខ្ញុំរស់នៅជាមួយខ្ញុំប្រហែលបាន២ខែ ហើយគេយកទៅដាក់នៅកងកុមារ ដោយគេប្រាប់ថា យកទៅរៀន ហើយក្រោយមកក៏បាត់ខ្លួនរហូត។"]។ ឯកសារ D54/104 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.3 ["វ៉េត នៅកងទ័ពជើងគោក មានទីតាំងនៅព្រលានយន្តហោះកងកេង ហើយគាត់ត្រូវបានចាប់ខ្លួន។"]។ ឯកសារ D54/8.1 កំណត់ហេតុកិច្ចប្រជុំកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុកិច្ចប្រជុំសមមិត្ត១៦៤ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ EN 01509242 ["មេបញ្ជាការពីររូបត្រូវបានកំណត់អត្តសញ្ញាណ និងចាប់ខ្លួន"]។ ឯកសារ D114/121 កំណត់ហេតុស្ដាប់ចម្លើយ សួន ផ ឆ.33 ["ពេលយើងធ្វើការគឺយើងពុំអាចចេញពីកន្លែងធ្វើការបានទេ បើមិនដូច្នោះទេគឺគេចាប់ខ្លួនហើយ។"]។ ឯកសារ D54/90 កំណត់ហេតុស្ដាប់ចម្លើយ កុយ ណែន ឆ.17 ["គាត់ [សមមិត្ត រី ប្រធានសហករណ៍បបុស] បាននិយាយថា [...] ប្រជាជនសហករណ៍ពូធឿង និងសហករណ៍

ផ្សេងទៀត គេយកទៅចំការធូរេនទៅអូរត្រាវ និងសេអ៊ី។"]។ ឯកសារ D1.3.8.4 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុកិច្ចប្រជុំសមមិត្ត១៦៤ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ EN 00657355 ["កាលពីពេលថ្មីៗនេះអនុប្រធានយោធាម្នាក់ត្រូវបានគេកំណត់អត្តសញ្ញាណ និងចាប់ខ្លួន"]។ ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណៃន ឆ.43 ["ខ្ញុំចង់និយាយបន្ថែមថា នៅកន្លែងការដ្ឋានលើកទំនប់ និងប្រឡាយនោះ ពួកយោធាតែងតែមកចាប់យកមនុស្ស២ឬ៣នាក់នាំយកទៅ ជួនកាល ៣ឬ៤ថ្ងៃម្តង។ គ្មានអ្នកណាម្នាក់ដឹងពីមូលហេតុនៃការចាប់ចងនោះទេ។ មនុស្សគ្រប់ៗគ្នាមានការភ័យខ្លាចយ៉ាងខ្លាំងចំពោះស្ថានភាពបែបនេះ។ ពួកយោធាមកចាប់មនុស្សទាំងកណ្តាលថ្ងៃ។"]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.112, 113, 135 ["ស៖ លោកធ្លាប់ឃើញគេយកមនុស្សទៅសម្លាប់ទេ? ឆ.112៖ ខ្ញុំធ្លាប់ឃើញគេយកទៅសម្លាប់ តែមិនដែលបានឃើញគេសម្លាប់ទេ។ ពេលនៅរោងបាយ មុនបាយល្ងាច សមាជិកក្រុមខ្ញុំ២នាក់ ត្រូវបានគេប្រាប់ថា ឲ្យទៅជាមួយឪពុកម្តាយដែលកំពុងចាំនៅលើរទេះនៅខាងក្រោយ។ ពួកគេត្រូវបានគេយកទៅទាំងគ្រួសារ។ [...] ស៖ នៅក្នុងកងវរសេនាតូចរបស់លោក តើមានមនុស្សប៉ុន្មាននាក់ដែលលោកឮ ឬឃើញគេយកទៅសម្លាប់? ឆ.113៖ ខ្ញុំមិនដឹងច្រើនទេ តែនៅកន្លែងខ្ញុំបាត់មនុស្សច្រើនណាស់។ ពួកគេថាទៅក្រោយ ហើយក៏បាត់។ [...] ស៖ ប្រហែលប៉ុន្មាន? ឆ.135៖ ប្រហែល ១៥ ឬ១៦ឆ្នាំ។ អាយុប្រហែលខ្ញុំ។"]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.14 ["ប្រសិនបើអ្នកណាម្នាក់ធ្វើអ្វីខុសគេនឹងយកអ្នកនោះទៅកន្លែងផ្សេង។"]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.10 ["មានអ្នកខ្លះក៏បាត់ខ្លួនដែរនៅពេលនោះ គឺបាត់ខ្លួនមិនដែលឃើញត្រឡប់មកវិញទេ ហើយពួកខ្ញុំក៏មិនហ៊ានសួរនាំ ឬក៏ឆ្ងល់អ្វីដែរ។"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.102-104 ["ធ្លាប់យកអ្នកធ្វើការជាមួយខ្ញុំទៅ [...] ឆ.103៖ ប្រហែលជាគេសម្គាល់ឃើញថា យើងខ្ជិល ទម្រុនការងារអីទៅ។ ស៖ តើមានមនុស្សប៉ុន្មាននាក់ដែលគេយកចេញពីកងផលិតហ្នឹងហើយ បាត់ខ្លួនតែម្តងនោះ? ឆ.104៖ ប្រហែល ៤-១០នាក់ដែរហ្នឹង។"]។ ឯកសារ D114/3 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.4-5 ["ខ្ញុំនឹកឃើញអំពីរឿងមួយអំពីអតីតទាហានជើងទឹក លន់ នល់ ម្នាក់ដែលខ្ញុំទើបនឹងឃើញ។ គាត់ពេលនោះ មានផ្ទះរស់នៅជិតខ្ញុំ។ គាត់ជាអតីតដោយបីជាន់ ឈ្មោះ សែប វិញ។ គាត់គឺជាអតីតទាហានជើងទឹករបស់ លន់ នល់ នៅរាម ដែលត្រូវគេជម្លៀសមករស់នៅជិតផ្ទះខ្ញុំនៅស្នាច់ដែង។ នៅយប់មួយពួកឈ្លបបានមកដល់ផ្ទះគាត់ ហើយហៅគាត់ និងគ្រួសារទាំងអស់ចេញពីផ្ទះ។ នៅពេលដែលគាត់ និងគ្រួសារគាត់ធ្វើដំណើរចេញទៅ ប្រពន្ធរបស់គាត់បានប្រាប់ខ្ញុំឲ្យជួយមើលផ្ទះរបស់គាត់ផង ពីព្រោះគាត់ចេញដំណើរទៅហើយ។ ពេលដែលខ្ញុំឃើញហេតុការណ៍ដូច្នេះ ខ្ញុំភ័យយ៉ាងញ័រ ដោយសារខ្លាចខ្លាំងពេក។ ប្រពន្ធរបស់ខ្ញុំ និងម្តាយក្មេកខ្ញុំ ភ័យយ៉ាងញ័រដែរ។ យើងគិតថា ពួកយើងជាមនុស្សបន្ទាប់ដែលត្រូវនាំយកទៅបន្តទៀត។ ដូចខ្ញុំជម្រាបលោកពីខាងដើមអ៊ីចឹងអ្នកណាក៏ដឹងដែរ បើកាលណាគេនាំចេញទៅ គឺចប់ហើយ។ យើងមានការភ័យខ្លាចចំពោះជីវិតរបស់ពួកយើង។ ខ្ញុំមិនអាចដឹងបានទេថាគេនាំ សែប វិញ និងគ្រួសារគាត់យកទៅណានោះ ដោយសារខ្ញុំមានការភ័យខ្លាចខ្លាំងពេក ខ្ញុំមិនអាចចាំរឿងរ៉ាវទាំងអស់ឲ្យបានច្បាស់ទេ។ ចាប់តាំងពីពេលនោះមក គាត់ និងប្រពន្ធគាត់បានបាត់ខ្លួនរហូត។ ស៖ តើខ្មែរក្រហមចាប់មនុស្សញឹកញាប់ប៉ុនណា នៅតំបន់រាម និងស្នាច់ដែង កន្លែងដែលលោករស់នៅកាលពីឆ្នាំ១៩៧៥ នៅមុនពេលគេបញ្ជូនលោកទៅស្រែអំបិល? ឆ.5៖ ការចាប់នេះគឺកើតមានរៀងរាល់យប់។ ម្តងៗមានពីរបីគ្រួសារត្រូវគេនាំចេញទៅបាត់។ ដោយសារការចាប់ចងហ្នឹងកើតមានរៀងរាល់យប់ ពួកយើងមានការភ័យខ្លាចជាប្រចាំ ហើយយើងតែងតែគិតថាមិនដឹងពេលណាដល់វេនយើងទេ។"]។ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សម្បត្តិ ឆ.

គ្រួសារបាត់ខ្លួន ជារៀងរាល់យប់"[2848]។ សាក្សីជាច្រើនបានពន្យល់ថា មនុស្សក្នុងកងរបស់ពួកគេត្រូវគេយកទៅបាត់ មិនត្រឡប់មកវិញ[2849]៖ "ប្រជាជនធម្មតាត្រូវបានគេយកម្តងមួយៗ។ មនុស្ស

---

178-179, 217-218 ["មានតែពេលលួចហើយគេចាប់យកអ្នកទាំងនោះទៅកសាង។ សៈ កសាង មានន័យថាម៉េច? ឆ.179៖ គេ កសាងយើងឱ្យល្អ។ គេឱ្យយើងធ្វើការវិញដដែល តែគេព្រមានយើងកុំឱ្យលួចម្តងទៀត។ សៈ មុនហ្នឹងលោកនិយាយអំពីអ្នកដែលគេបញ្ជូនទៅកសាង តើលោកដែលឃើញអ្នកទាំងនោះម្តងទៀតទេ? ឆ.217៖ ទេ ពួកគេបាត់ខ្លួនរហូត។ សៈ មានប្រហែលប៉ុន្មានអ្នកដែលគេបញ្ជូនទៅកសាង? ឆ.218៖ បីនាក់ នៅក្នុងកងខ្ញុំ។"]។ សូមមើល ផងដែរ ឯកសារ D114/135 កំណត់ហេតុស្តាប់ចម្លើយ ណុប ផន ឆ.41 ["ខ្ញុំខ្លាចថា គេនឹងដាក់ទោសខ្ញុំ។ គេនឹងចោទខ្ញុំថា ជាមនុស្សខ្ជិល [បើសិនជាខ្ញុំចង់ឈប់ ឬមិនព្រមរស់នៅទីនោះ] ហើយប្រហែលជាយកខ្ញុំទៅកន្លែងផ្សេង"]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹង ណុច ឆ.119-121 ["ញ៉ឹម ត្រូវបានដកចេញពីកងវរៈសេនាតូចនេះនៅឆ្នាំ៧៦ ហើយបាត់ខ្លួនរហូត។ ឆ.120៖ [...] គេចាប់កម្មាភិបាលច្រើនណាស់។ [...] ឆ.121៖ គេចាប់មេបញ្ជាការរបស់ខ្ញុំ លោក វុធ ប្រហែលម៉ោងជិត៧ ឆ្នាំ៧៦"]។ ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ឆ.193 ["អ្នករំលោភនោះ ជាអ្នកសម្លាប់បំបាត់ភស្តុតាង។"]។

2848 ឯកសារ D54/123 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.2។

2849 ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.102-104 ["ធ្លាប់យកអ្នកធ្វើការជាមួយខ្ញុំទៅ [...] ឆ.103៖ ប្រហែលជាគេសម្គាល់ឃើញថា យើងខ្ជិល ទម្រុនការងារអីទៅ។ សៈ តើមានមនុស្សប៉ុន្មាននាក់ដែលគេយកចេញពីកងផលិតហ្នឹងហើយ បាត់ខ្លួនតែម្តងនោះ? ឆ.104៖ ប្រហែល ៥-១០នាក់ដែរហ្នឹង។"]។ ឯកសារ D114/86 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.14 ["ប្រសិនបើអ្នកណាម្នាក់ធ្វើអ្វីខុស គេនឹងយកអ្នកនោះទៅកន្លែងផ្សេងដែលខ្ញុំមិនដឹង ប្រហែលជាទៅទឹកសាប។ បើទៅហើយ គឺកម្រត្រឡប់មកវិញណាស់។ ដូចខ្ញុំប្រាប់លោករួចហើយថា គេយកមនុស្សបីនាក់ពីកន្លែងខ្ញុំទៅ។"]។ ឯកសារ D54/97 កំណត់ហេតុស្តាប់ចម្លើយ ខឹម យ៉ាត ឆ.10 ["មានអ្នកខ្លះក៏បាត់ខ្លួនដែរនៅពេលនោះ គឺបាត់ខ្លួនមិនដែលឃើញត្រឡប់មកវិញទេ ហើយពួកខ្ញុំក៏មិនហ៊ានសួរនាំ ឬក៏ឆ្ងល់អ្វីដែរ។ កាលនោះ គឺមានតែកូនចៅដែលមានឋានៈតូចៗទេ ដែលនៅរស់ ចំណែកមេៗវិញគឺបាត់ខ្លួនទាំងអស់ ហើយមិនដែលឃើញត្រឡប់មកវិញទេ។"]។ ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.1, 6 ["អ្នកខ្លះ ត្រូវបានគេដាក់ទោស ដោយសារកំហុសតិចតួច។ ខ្ញុំមិនបានឃើញថា តើអ្នកទាំងនោះ ត្រូវបានគេដាក់ទោសយ៉ាងដូចម្តេចនោះទេ ប៉ុន្តែជាធម្មតា កាលពីសម័យនោះ មនុស្សត្រូវបានគេយកទៅកន្លែងមួយ ហើយមិនដែលត្រឡប់មកវិញទេ។ មនុស្សទាំងនោះ ត្រូវបានគេយកទៅទាំងពេលថ្ងៃ ទាំងពេលយប់។ [...] សៈ លោកបាននិយាយមុននេះថា អ្នកដែលប្រព្រឹត្តកំហុសតូចតាច ត្រូវបានគេយកទៅទាំងពេលថ្ងៃនិងពេលយប់ ហើយបាត់ខ្លួនជារៀងរហូត។ តើអ្នកណាជាអ្នកយកពួកគេទៅ? ឆ.6៖ អ្នកទាំងនោះរួមមានអ្នកមកពីសហករណ៍ ឈ្លបឃុំ ក្មេងៗដែលមានកាន់កាំភ្លើង និងអ្នកផ្សេងទៀតដែលខ្ញុំមិនអាចសម្គាល់ដឹងបាន។ ខ្ញុំពុំមានសេចក្តីក្លាហានដើម្បីសួរនាំថា ពួកគេមកពីកន្លែងណានោះឡើយ។ ប្រជាជនធម្មតាត្រូវបានគេយកម្តងមួយៗ។ មនុស្ស ត្រូវបានគេយកទៅដោយពុំមានការពន្យល់អ្វីឡើយ។ ហើយពួកគេ ក៏មិនត្រូវបានប្រាប់ពីទោសកំហុសរបស់ពួកគេផងដែរ។ អ្នកដែលយកមនុស្សទៅមិនដែលពន្យល់ប្រាប់ពីមូលហេតុដែលពួកគេយកមនុស្សទៅនោះឡើយ ពេលខ្លះ មនុស្សត្រូវបានគេប្រាប់ថា អង្គការត្រូវការជួបជាមួយនឹងពួកគេ។"]។ ឯកសារ

ត្រូវគេយកទៅ ដោយពុំមានការពន្យល់អ្វីឡើយ ហើយពួកគេក៏មិនត្រូវបានប្រាប់អំពីទោសកំហុសរបស់ពួកគេនោះដែរ។ ពេលខ្លះ មនុស្សត្រូវបានគេប្រាប់ថាអង្គការត្រូវការជួបជាមួយពួកគេ"[2850]។ នៅពេលផ្សេងទៀត អ្នកខ្លះត្រូវគេបញ្ជូនទៅពេទ្យ ហើយពុំឃើញត្រឡប់មកវិញទេ[2851] ឬត្រូវគេប្រាប់ឱ្យទៅរៀនសូត្រ ឬអប់រំ[2852]៖ "កូនប្រុសច្បងរបស់ខ្ញុំរស់នៅជាមួយខ្ញុំ ប្រហែលពីរខែ ហើយគេយកទៅដាក់នៅកងកុមារ ដោយគេប្រាប់ថាយកទៅរៀនសូត្រ ហើយក្រោយមក ក៏បាត់ខ្លួនរហូត"[2853]។ សាក្សីមិនមានការសង្ស័យទេចំពោះជោគវាសនារបស់អ្នកដែលបាត់ខ្លួន៖ "អ្នកណាក៏ដឹងដែរ បើកាលណាគេនាំចេញទៅ គឺចប់ហើយ"[2854]។

703. កំណត់ហេតុកិច្ចប្រជុំ នៅក្នុងសំណុំរឿង បង្ហាញឱ្យឃើញថា ឌឹម បានប្រាប់អ្នកចូលរួម រួមទាំង **មាស មុត** ថា ការចាប់ខ្លួនត្រូវបានធ្វើឡើងជាញឹកញាប់ នៅកងកេង[2855] ហើយកំណត់ហេតុផ្សេងទៀតរបស់កងពល ១៦៤ បានបញ្ជាក់ថា អតីតទាហាន លន់ នល់ ម្នាក់ ត្រូវបាន "រកឃើញ និងចាប់" នៅតំបន់នោះ[2856]។ ពិតណាស់ សាក្សីបានបញ្ជាក់ថា គ្រួសារពីរទៅបីត្រូវបានចាប់រៀងរាល់

D114/156 កំណត់ហេតុស្តាប់ចម្លើយ ស៊ឹង ណុច ឆ.104 ["ស៖ ចុះបើសមាជិកក្រុមឃើញគ្នាទៅវិញទៅមកតើមានអ្វីកើតឡើង? ឆ.104៖ មិនមានរឿងអ្វីកើតឡើងទេ បើគេយកម្នាក់ហ្នឹងទៅ។"]។

2850 ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.6។

2851 ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.14 ["អ្នកខ្លះបញ្ជូនទៅពេទ្យ ពុំឃើញត្រឡប់មកវិញទេ អ្នកធ្វើការនៅពេទ្យបាននិយាយថា អ្នកជម្ងឺទាំងនោះបានស្លាប់បាត់ទៅហើយ យើងចេះតែជឿតាមគេទៅអ្វីដែលគេប្រាប់យើង។"]។

2852 ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ឆ.109-10 ["អ្នកដែលគេបញ្ជូនទៅគឺមិនដែលមកវិញទេ ហើយគេប្រាប់ថា រៀនសូត្រនោះគឺគេយកទៅវៃចោលទេ។ ស៖ អ្នកណាជាអ្នកប្រាប់លោកស្រីពីរឿងនេះ? ឆ.110៖ គឺឃឹម ជាអ្នកប្រាប់ខ្ញុំ។"]។

2853 ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.26។

2854 ឯកសារ D114/3 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.4។

2855 ឯកសារ D4.1.85 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កិច្ចប្រជុំលេខា និងអនុកងពល និងកងវរៈសេនាធំឯករាជ្យ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៦ KH ERN 00052404 ["ជុំវិញកងកេង វាម យើងចាប់បានចោរព្រៃជាបន្តបន្ទាប់ តែជាពួកទើបចូលព្រៃថ្មី។"]។

2856 ឯកសារ D1.3.8.4 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ កំណត់ហេតុកិច្ចប្រជុំសមមិត្ត១៦៤ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ KH ERN 00162489 ["ខាងគោក ចូលខែ៩មក ប្រជាជនមូលដ្ឋានកងកេង មានសកម្មភាពប្លែកផ្សេង ពួ៖ ឧទាហរណ៍៖ កាប់យកសាច់ក្របីមួយដុំ យកដុំថ្មដាក់ក្នុងឡាឥដ្ឋ និងសកម្មភាពលួចកើតច្រើន។ នៅក្នុងប្រជា

យប់ នៅវាម និងស្នាច់ដែង[2857]៖ "ដោយសារការចាប់ចងហ្នឹងកើតមានរៀងរាល់យប់ ពួកយើងមានការភ័យខ្លាចជាប្រចាំ ហើយយើងតែងតែគិតថា មិនដឹងពេលណាដល់វេនយើងទេ"[2858]។

704. ក្រោយពីគេយកចេញហើយ "គ្មាននរណាម្នាក់ត្រឡប់មកវិញទេ។ មានតែប្រពន្ធដែលនៅមេម៉ាយ"[2859]។ សាក្សីជាច្រើនយល់ថា អ្នកដែលគេនាំយកទៅត្រូវបានសម្លាប់[2860] ហើយការសម្លាប់គឺជាទណ្ឌកម្មចំពោះការប្រព្រឹត្តិបទល្មើសផ្សេងៗ។ "នៅពេលនោះ បើមានអ្នកណាភ្ជួរស្រែ ហើយបាក់រនាស់ នង្គ័ល គេនឹងចាត់ទុកអ្នកនោះថាជាខ្មាំង ហើយគេនឹងយកទៅសម្លាប់ចោល"[2861]។ សាក្សីម្នាក់បានសង្កេតឃើញថា៖ "ចំពោះអ្នកណាដែលខ្ជិល ឈឺ ឬប្រឆាំងនឹងការរែកដី គេនឹងយកចេញទៅ ហើយក៏បាត់ខ្លួន"[2862]។ អ្នកធ្វើការអសកម្មត្រូវគេទិតៀននៅក្នុងកិច្ចប្រជុំពេលយប់

---

ជននេះ ភាគច្រើនល្អ តែទាហានមានចលនាមិនល្អ។ កន្លងមក រកឃើញទាហានសក្តិ២ពីរនាក់ [ក្នុងរបប លន់ នល់] បានចាប់ហើយ។"]។

2857 ឯកសារ D114/3 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.5 ["ការចាប់នេះគឺកើតមានរៀងរាល់យប់។ ម្តងៗមានពីរបីគ្រួសារត្រូវគេនាំចេញទៅបាត់។"]។

2858 ឯកសារ D114/3 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.5។

2859 ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.44 ["ស៖ តើលោកធ្លាប់បានឃើញអ្នកដែលត្រូវបានចាប់ខ្លួនដោយយោធាខ្មែរក្រហមនៅពេលនោះ ធ្លាប់ត្រឡប់មកវិញដែរឬទេ? ឆ.44៖ ទេ គ្មានអ្នកណាត្រឡប់មកវិញទេ មានតែប្រពន្ធដែលនៅមេម៉ាយ។"]។

2860 ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.123-124 ["ប្រជាជនមិនត្រូវបានប្រព្រឹត្តមិនល្អ ឬវាយដំនៅពេលធ្វើការនោះទេ ប៉ុន្តែនៅរាល់ល្ងាចគឺមានកិច្ចប្រជុំដើម្បីតិះទៀន ពីអ្នកអសកម្មនឹងការងារ ហើយចំពោះមនុស្ស១នាក់ គឺតិះទៀនតែបីដងប៉ុណ្ណោះ បើលើសពីនេះ គឺគេត្រូវយកទៅហើយ។ គេនិយាយថា "របបកម្ពុជាប្រជាធិបតេយ្យមិនមានគុកសម្រាប់ដាក់មនុស្សទេ គឺមានតែអន្លង់/រណ្តៅដាក់មនុស្សប៉ុណ្ណោះ។" ស៖ លោកនិយាយថាគេតិះទៀនតែបីដងប៉ុណ្ណោះ គឺគេត្រូវយកទៅហើយ តើវាមានន័យយ៉ាងដូចម្តេច? ឆ.124៖ គេយកវៃសម្លាប់ចោលដោយសារអ្នកនោះមិនកែប្រែ។"]។ ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.15 ["អ្នកដែលអាចបញ្ចប់ការងារនេះទើបអាចរស់បាន។"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.117 ["បើអ្នកណាឈឺទៅធ្វើការមិនរួច គឺគេយកទៅសម្លាប់ចោលតែម្តង។"]។

2861 ឯកសារ D54/89 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.7។

2862 ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.15 ["ចំពោះអ្នកដែលអាចបញ្ចប់ការងារនេះទើបអាចរស់បាន ចំពោះអ្នកណាដែលខ្ជិល ឈឺ ឬប្រឆាំងនឹងការរែកដី គេនឹងយកចេញទៅ ហើយក៏បាត់ខ្លួន តែខ្ញុំមិនដឹងថាគេយកទៅណាទេ។"]។

ហើយការទិតៀនដដែលៗស្មើនឹងការស្លាប់[2863] ដោយគេចាត់ទុកថាមិនស្មោះត្រង់នឹងអង្គការ[2864]។ សាក្សីម្នាក់ចាំថា អ្នកណាដែលគេយល់ឃើញថាប្រឆាំងនឹងអង្គការ ត្រូវគេចាត់ទុកជាខ្មាំង និងត្រូវសម្លាប់ចោល[2865]។ អ្នកធ្វើការក៏អាចត្រូវគេសម្លាប់ផងដែរ ដោយសារគ្រាន់តែរអ៊ូរទាំអំពីបរិមាណ ឬល័ក្ខខ័ណ្ឌការងារ[2866] ដោយសារត្រូវគេចោទថាប្រព្រឹត្ត "ខុសសីលធម៌" ដូចជា និយាយជាមួយភេទផ្ទុយគ្នា ក្នុងពេលធ្វើការ[2867] ឬដោយសារហូបអាហារ ដោយគ្មានការអនុញ្ញាត[2868]។

705. ប្រជាជន ១៧ មេសា ជាច្រើននាក់ បានបាត់ខ្លួន៖ "ពួក ១៧ មេសា មកពីទីក្រុង ឬទីផ្សារ ដែលមិនធ្លាប់ធ្វើការពីមុន ច្រើនតែបាត់ខ្លួន"[2869]។ ប្រជាជនអត់ឃ្លាន ប៉ុន្តែ បើសិនជាអ្នកណា "លួចអ្វីម្យ៉ាង ឬដណ្តើមគេហូប អ្នកនោះនឹងបាត់ខ្លួនហើយ"[2870]។ អ៊ុំង ចន្ធា ដែលរស់នៅសហករណ៍មួយ ដែល

---

2863 ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.123 ["ប្រជាជនមិនត្រូវបានប្រព្រឹត្តមិនល្អ ឬវាយដំនៅពេលធ្វើការនោះទេ ប៉ុន្តែនៅរាល់ល្ងាចគឺមានកិច្ចប្រជុំដើម្បីតិះទៀន ពីអ្នកអសកម្មនឹងការងារ ហើយចំពោះមនុស្ស១នាក់ គឺតិះទៀនតែបីដងប៉ុណ្ណោះ បើលើសពីនេះ គឺគេត្រូវយកទៅហើយ។ គេនិយាយថា "របបកម្ពុជាប្រជាធិបតេយ្យមិនមានគុកសម្រាប់ដាក់មនុស្សទេ គឺមានតែអន្លង់/រណ្តៅដាក់មនុស្សប៉ុណ្ណោះ។"]។

2864 ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.117 ["ក្មួយខ្ញុំជានីរសារកម្មាភិបាលយោធាខ្មែរក្រហមម្នាក់បានប្រាប់ខ្ញុំថា វាស្តាប់ឮមេវានិយាយថា គ្មានប្រយោជន៍នឹងទុកប្តីខ្ញុំយូរទៀតទេ ព្រោះដូចជាមិនស្មោះត្រង់នឹងអង្គការ។"]។

2865 ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ សួន ឈុំ ឆ.63 ["គេនិយាយតែមួយម៉ាត់ អង្គការឲ្យធ្វើនេះអង្គការឲ្យធ្វើនោះ គេប្រើតែអង្គការមួយម៉ាត់ហ្នឹង។ អាណាប្រឆាំង អាហ្នឹងខ្មាំង សម្លាប់។"]។

2866 ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.15 ["ស៖ ហេតុអ្វី ហើយយ៉ាងម៉េចបានជាលោកតស៊ូដើម្បីរស់? ឆ.15៖ ខ្ញុំធ្វើតាមតែបញ្ជារបស់គេ ដើម្បីរស់ ហើយការងារអ្វីក៏ដោយ ដែលគេចាត់តាំងឲ្យខ្ញុំធ្វើ ខ្ញុំត្រូវតែបំពេញដើម្បីរស់។"]។

2867 ឯកសារ D54/89 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.10 ["ពួកគេទាំងអស់ត្រូវចោទប្រកាន់ថាខុសសីលធម៌ពីព្រោះពួកគេបាននិយាយលេងជាមួយស្រីៗក្នុងអំឡុងពេលកំពុងធ្វើការ។"]។

2868 ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែន ឆ.5 ["បាទ ប្រជាជនគឺមានការភ័យខ្លាចយ៉ាងខ្លាំង ប៉ុន្តែប្រជាជនខ្លះនៅតែប្រព្រឹត្តកំហុស ហើយត្រូវបានគេចាប់ខ្លួន ដោយនាំយកទៅសម្លាប់។ ដោយសារពេលណាប្រជាជនឃ្លាន គឺពួកគេជីដំឡូងហូប ទោះបីជាដំឡូងទាំងនោះគេដាំដោយខ្លួនឯងនៅមុខផ្ទះខ្លួនក៏ដោយ បើសិនជាគេជីកដំឡូងនោះហូបដោយគ្មានការអនុញ្ញាតពីខ្មែរក្រហម ពួកគេនឹងត្រូវចាប់ខ្លួនយកទៅសម្លាប់។"]។

2869 ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.18 ["ស៖ តើមានសមាជិកឬសាច់ញាត្តិ ឬមិត្តភក្តិរបស់លោកដែលធ្វើការនៅទីនោះ បានបាត់ខ្លួនដែរឬទេ? ឆ.18៖ មិនមានសាច់ញាតិឬមិត្តភក្តិខ្ញុំបានបាត់ខ្លួនទេ ប៉ុន្តែពួកអ្នក១៧មេសា មកពីទីក្រុង ឬទីផ្សារដែលមិនធ្លាប់ធ្វើការពីមុនច្រើនតែបាត់ខ្លួន។"]។

2870 ឯកសារ D54/122 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.12។

មានអ្នក ១៧ មេសា "ធ្លាប់ឃើញមេឈ្លបភូមិខ្មែរក្រហមបោកកុមារតូច អាយុ ១ ឆ្នាំ ឬ ២ ឆ្នាំ ផ្ទប់នឹងគល់ត្នោតស្លាប់ភ្លាមៗ"[2871]។ គាត់ក៏បានឃើញអ្នក ១៧ មេសា ម្នាក់ត្រូវគេមេកងធ្វើទារុណកម្មរហូតដល់ស្លាប់ ដោយបានចោះចង្កេះឱ្យមានប្រហោងធំល្មមញាត់ក្បាលចូលបាន ហើយបង្វិលចង្កេះរហូតទាល់តែដាច់កស្លាប់ភ្លាមមួយរំពេច"[2872]។ ពេលមេកងធ្វើទារុណកម្មជនរងគ្រោះ គាត់បានសួរចម្លើយថា "មានពាក់ព័ន្ធនឹងទាហាន លន់ នល់ ទេ ហើយធ្លាប់ធ្វើជាទាហានទេ"[2873]។

706. សាក្សីម្នាក់ ដែលធ្លាប់រស់នៅភូមិគគីរ បាននិយាយថា ខ្មែរក្រហមចុះទៅតាមភូមិ ដើម្បីស្វែងរកអ្នកដែលពួកវាជឿថាជាភ្នាក់ងារស៊ើបការសម្ងាត់របស់ លន់ នល់ ឬហៅថា "ភ្នាក់ងារ ឌីបេ"[2874]។ សាក្សីបានរៀបរាប់ថា "អ្នកភូមិខ្លះត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅបាត់ឈឹង។ នៅពេលដែលគេចោទអ្នកណាម្នាក់ជាគិញ ឬភ្នាក់ងារ ឌីបេ អ្នកនោះដឹងតែបាត់ខ្លួនតែម្តង គឺមិនចាំបាច់បញ្ជូនទៅដាក់គុកទេ។ អ្នកទាំងនោះបាត់ខ្លួនតែម្តង គឺមិនឃើញត្រឡប់មកវិញទេ"[2875]។

707. សាក្សីជាច្រើនរៀបរាប់អំពីការបាត់ខ្លួនខ្មែរក្រោម (ឬអ្នកត្រូវគេចាត់ទុកជាខ្មែរក្រោម ឬជាប់សាច់ឈាមជាមួយវៀតណាម) ក្នុងពេលខុសគ្នា។ នេះជាគំរូនៃការអនុវត្តស៊ីចង្វាក់គ្នារបស់ខ្មែរក្រហមក្នុងការចុះឈ្មោះខ្មែរក្រោម ក្រោមលេសថាពួកគេត្រូវបញ្ជូនទៅវៀតណាមវិញ។ សាក្សី សួន ឈុំ ធ្លាប់នៅបិតត្រាង ហើយបានផ្តល់សក្ខីកម្មថា នៅចុងឆ្នាំ ១៩៧៥[2876] មេកង[2877] "និយាយប្រកាស

---

[2871] ឯកសារ D114/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ចន្ទា ឆ.19។

[2872] ឯកសារ D114/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ចន្ទា ឆ.19។

[2873] ឯកសារ D114/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ចន្ទា ឆ.19។

[2874] ឯកសារ D54/119 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.1 ["អ្នកភូមិខ្លះត្រូវបានគេចោទថាជាភ្នាក់ងារឌីបេ ដែលជាភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់របប លន់ នល់។"]។

[2875] ឯកសារ D54/119 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.1 ["កាលនោះ ឌីបេ ត្រូវបានបង្កើតឡើងដោយរបប លន់ នល់ ដើម្បីតាមរក និងចាប់ខ្លួនពួកខ្មែរក្រហម។ អ្នកភូមិខ្លះត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅបាត់ឈឹង។ នៅពេលដែលគេចោទថាអ្នកណាម្នាក់ជាគិញ ឬភ្នាក់ងារ ឌីបេ អ្នកនោះដឹងតែបាត់ខ្លួនតែម្តង គឺមិនបាច់បញ្ជូនទៅដាក់គុកទេ។ អ្នកទាំងនោះគឺបាត់ខ្លួនតែម្តង មិនឃើញត្រឡប់មកវិញទេ។"]។

[2876] ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ សួន ឈុំ ឆ.43 ["ប្រហែលនៅចុងឆ្នាំ១៩៧៥ តែប៉ុន្មានខែក្រោយរំដោះ។"]។

[2877] ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ សួន ឈុំ ឆ.44 ["ខ្ញុំសំដៅលើខ្មែរក្រហមដែលគ្រប់គ្រងសហករណ៍ហ្នឹងបណ្តោយ។ ក្នុងហ្នឹងវាមានមេកង អនុ ហើយនិងក្រុមសមាជិកពួកគេហ្នឹង ហើយក្រុមប្រពន្ធកងទ័ពគេហ្នឹង ចុះធ្វើ។"]។

ថាអ្នកណាខ្មែរក្រោមខ្លះ ឲ្យមកចុះឈ្មោះ ដើម្បីគេឲ្យត្រឡប់ទៅស្រុកកំណើតវិញ"[2878]។ ប្រហែលពីរខែ[2879] ក្រោយការចុះឈ្មោះ "ឃើញគេទៅពីរគ្រួសារ ស្អែកឡើង បីគ្រួសារ ខានស្អែកឡើង ពីរបីគ្រួសារទៀត ចេះតែបន្តបន្ទាប់អ៊ីចឹង"[2880]។ លើសពីនេះទៀត គ្រួសារផ្សេងទៀតដែលមិនមែនជាខ្មែរក្រោម ប៉ុន្តែ បានចុះឈ្មោះ ដោយសង្ឃឹមថាបានទៅវៀតណាម ក៏បាត់ខ្លួនផងដែរ[2881]។ "បាត់ទាំងអស់ ទាំងប្រពន្ធ កូន បាត់អស់តែម្តង"[2882]។ គ្រួសារទាំងអស់នោះត្រូវគេយកទៅពេលយប់ ហើយព្រឹកឡើង គ្រួសារ ដែលរស់នៅក្នុងផ្ទះជាមួយពួកគេ[2883] "បានខ្សឹបប្រាប់គ្នាថា អ្នកនេះ យប់មិញ គេយកទៅហើយ គ្រួសារនេះគ្រួសារនោះ"[2884]។ កម្មាភិបាល អមដោយប្រធានសហករណ៍ជាអ្នកមកយកគ្រួសារទាំងនេះទៅ[2885]។

---

[2878] ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ឈុំ ឆ.40. សូមមើល ផងដែរ ឆ.48 ["ទៅចុះឈ្មោះតាមផ្ទះ អ្នកនៅហ្នឹងតែម្តង។ គេចុះទៅដល់ផ្ទះតែម្តង។"]។

[2879] ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ឈុំ ឆ.44 ["ដល់ពេលវំលងប្រហែលពីរខែក្រោយមក ស្រាប់តែចេះតែបាត់បន្តបន្ទាប់មក។"]។

[2880] ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ឈុំ ឆ.40. សូមមើល ផងដែរ ឆ.41 ["គ្រាន់តែមួយកន្លែងជិតកន្លែងសហករណ៍ខ្ញុំហ្នឹង បើតាមខ្ញុំមើលទៅប្រហែលជាប្រាំមួយគ្រួសារ។"]។

[2881] ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ឈុំ ឆ.5, 40-41 [ធ្វើការសង្ខេបកំណត់ហេតុពីមុន៖ "ស៖ ក្នុងពេលនោះពុំមានតែគ្រួសារខ្មែរក្រោមទេ ដែលទៅ គឺមានទាំងគ្រួសារខ្មែរផង ក៏បានប្រាប់ថាស្រុកកំណើតនៅខ្មែរកម្ពុជាក្រោម ហើយក៏គេយកទៅដែរ។ ឆ៖ បាទ មានគ្រួសារខ្មែរពីរបីគ្រួសារដែរ។ [...] ឆ.40៖ [...] អ្នកស្រុកមួយចំនួនប្រហែលពីរគ្រួសារទៅជាមួយដែរ ដោយសារទៅចុះឈ្មោះនឹងគេដែរ។ ហើយអ្នកមកពីខាងក្រៅហ្នឹង ក៏មានដោយទៅខ្លះដែរ ប្រហែលបីបួនគ្រួសារហ្នឹង។ [...] ឆ.41៖ [...] ហើយពីរគ្រួសារខ្មែរទៀត គាត់ស្រុកកំណើតគាត់នៅហ្នឹង។ ប៉ុនកាលនោះ គាត់ថា បានទៅនោះ ចេះតែខំប្រឹងទៅចុះឈ្មោះគេទៅ។"]។

[2882] ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ឈុំ ឆ.41។

[2883] ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ឈុំ ឆ.49 ["ដូចផ្ទះខ្ញុំធំអ៊ីចឹងទៅ នៅប្រាំប្រាំមួយគ្រួសារអ៊ីចឹងទៅ។ អ៊ីចឹងនៅពេលគេហៅឈ្មោះនៅពេលយប់ អ្នកនៅជាមួយហ្នឹង សឹងតែរាគអាចម៍ហើយ។"]។

[2884] ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ឈុំ ឆ.42។

[2885] ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ឈុំ ឆ.52 ["ខ្ញុំចាំបានអ្នកដែលនៅជាមួយគ្នាហ្នឹង គឺកងទ័ព គឺអ្នកមកយក។ ទ័ព តាមពូបងខ្ញុំនិយាយថា មានកងទ័ពពីរនាក់មកជាមួយប្រធានសហករណ៍ហ្នឹង។ ហើយនៅគ្នាច្រើនទៀត ទ័ពនៅពីក្រោយប្រហែល១០នាក់ទៀត គេអត់បង្ហាញទេ។ របៀបគេមកហៅយកទៅហ្នឹងណា"]។

708. ស្ងួន ឈុំ បានឃើញគ្រួសារខ្លះ នៅពេលកំពុងចាកចេញ ហើយបាននិយាយថា៖ "គ្នាដែលអ្នកគេហៅទៅហ្នឹង អត់មានព្រលឹងក្នុងខ្លួនទេ ដើរសឹងមិនរួចផង"[2886]។ គាត់គ្មានការសង្ស័យទេចំពោះអ្វីដែលកើតឡើងលើគ្រួសារដែលគេនាំយកទៅ៖

> ពួកគេស្លាប់អស់មែន។ បើគាត់នៅរស់ គាត់មុខតែមកលេងហើយ ព្រោះធ្លាប់នៅជាមួយគ្នា។ បាត់ទាំងអស់រលីងប៉ុន្មានគ្រួសារ អត់មានអ្នកណាត្រឡប់មកមួយ។ ធម្មតា គាត់នៅរស់ មុខតែមកលេង មកប្រពន្ធ ឬក៏ប្ដីដែរ[2887]។

709. សាក្សី ព្រំ កែម (ប្អូនជីដូនមួយរបស់ ស្ងួន ឈុំ)[2888] បានឃើញហេតុការណ៍ស្រដៀងគ្នានេះ ក្នុងឆ្នាំ ១៩៧៦ នៅភូមិគគីរ ឃុំរាម[2889]។ គាត់ចាំបានថា ប្រធានសហករណ៍របស់គាត់ និងអនុប្រធាន (ស្រី) បានណែនាំឲ្យខ្មែរក្រោមប្រាប់អត្តសញ្ញាណ ដើម្បីអាចត្រឡប់ទៅវៀតណាមវិញ[2890]។ "អ្នកដែលមកពីកម្ពុជាក្រោមសប្បាយនឹងព័ត៌មាននេះ ដោយមានអារម្មណ៍ថា នៅពេលដែលពួកគេវិលត្រឡប់ទៅកម្ពុជាក្រោម ឬវៀតណាមវិញ ម្ហូបអាហារនឹងប្រសើរជាងនេះ។ ពួកគេក៏បានលើកដៃហើយក៏ចុះឈ្មោះ"[2891]។ ព្រំ កែម បានបញ្ជាក់ថា "អង្គភាពយោធាពិសេស" មួយ មានវត្តមាននៅក្នុងពេលប្រជុំនោះ និងទទួលខុសត្រូវក្នុងការកត់ឈ្មោះអ្នកទាំងនោះ[2892]។ អ្នកដែលបានចុះឈ្មោះហើយមាន "មនុស្សប្រុស ស្រី ក្មេង ចាស់ និងអ្នកឈឺ"[2893] ប្រហែល ១០០ នាក់ មកពីសហករណ៍

---

2886 ឯកសារ D114/179 កំណត់ហេតុស្ដាប់ចម្លើយ ស្ងួន ឈុំ ឆ.52។

2887 ឯកសារ D114/179 កំណត់ហេតុស្ដាប់ចម្លើយ ស្ងួន ឈុំ ឆ.40។

2888 ឯកសារ D114/179 កំណត់ហេតុស្ដាប់ចម្លើយ ស្ងួន ឈុំ ឆ.17 ["បងប្អូនជីដូនមួយរបស់ខ្ញុំ ស្ងួន ឈុំ ធ្វើការនិងរស់នៅក្នុងសហករណ៍របស់ខ្ញុំ។"]។

2889 ទោះបីជា ព្រំ កែម បានប្រាប់ថា ស្ងួន ឈុំ បានធ្វើការ និងរស់នៅក្នុងសហករណ៍ដូចគាត់ក៏ដោយក៏ពួកគេហាក់ដូចជាកំណត់អត្តសញ្ញាណដាច់ដោយឡែកពីគ្នាចំពោះការដកចេញនូវខ្មែរក្រោម ក្នុងពេលខុសៗគ្នា៖ ឯកសារ D54/119 កំណត់ហេតុស្ដាប់ចម្លើយ ព្រំ កែម ឆ.7 ["គឺកើតឡើងនៅឆ្នាំ១៩៧៦។"]។

2890 ឯកសារ D54/119 កំណត់ហេតុស្ដាប់ចម្លើយ ព្រំ កែម ឆ.7 ["ប្រធានសហករណ៍ឈ្មោះ អ៊ំ ឡូត និងអនុប្រធានរបស់គាត់ឈ្មោះ អ៊ំ ណែម (ស្រី) បានកោះហៅ និងអំពាវនាវឲ្យលើកដៃ និងត្រៀមខ្លួនចាំឡានមកដឹកត្រឡប់ទៅវៀតណាមវិញ។"]។

2891 ឯកសារ D54/119 កំណត់ហេតុស្ដាប់ចម្លើយ ព្រំ កែម ឆ.7។

2892 ឯកសារ D54/119 កំណត់ហេតុស្ដាប់ចម្លើយ ព្រំ កែម ឆ.7 ["អង្គភាពយោធាពិសេសមួយក៏មានវត្តមាននៅក្នុងអង្គប្រជុំនោះដែរ និងទទួលខុសត្រូវកត់ឈ្មោះអ្នកទាំងនោះ។"]។

2893 ឯកសារ D54/119 កំណត់ហេតុស្ដាប់ចម្លើយ ព្រំ កែម ឆ.11។

របស់គាត់[2894] ហើយនៅថ្ងៃដែលគេបានកំណត់ ប្រជាជនទាំងនោះក៏បានបង្ហាញខ្លួន ឡានទ្រុងចិនក៏បញ្ឈប់ចាំទទួលអ្នកទាំងនោះ បើកដោយមនុស្សស្លៀកឯកសណ្ឋានយោធា[2895]។ អ្នកខ្លះក៏បានបន្លំជាខ្មែរក្រោម ដើម្បីបានទៅវៀតណាម[2896]។ បីថ្ងៃក្រោយមក ឡានមួយក៏បានវិលត្រឡប់មកវិញ ហើយចែកខោអាវ ដែលជារបស់កម្រនៅសម័យនោះ។ "ប្រសិនបើលោកឲ្យមាស និងឲ្យខោអាវគេ គេច្បាស់ជាជ្រើសរើសយកខោអាវហើយ"[2897]។ ប្រជាជននៅក្នុងភូមិ ស្គាល់ខោអាវទាំងនោះភ្លាម ពីព្រោះម្នាក់ៗមានខោអាវតិចតួចណាស់ ហើយប្រជាជនធ្វើការជាមួយគ្នារាល់ថ្ងៃ[2898]។

> ក្រោយពីអ្នកភូមិទទួលបានខោអាវទាំងនោះ ពួកគេក៏បានដឹងភ្លាមថា ពួកគេស្គាល់ខោអាវទាំងនោះ។ ពួកគេស្គាល់ខោអាវទាំងនោះថាជារបស់អ្នកនេះ ឬរបស់អ្នកនោះ គឺអ្នកដែលគេដឹកតាមឡានទៅវៀតណាម។ ប្រជាជនមិនហ៊ាននិយាយអំពីរឿងនេះឲ្យឮដល់អ្នកក្រៅទេ គឺនិយាយតែមុខគ្នាឯងប៉ុណ្ណោះ។ ពួកយើងមិនហ៊ានឲ្យទាហាន ឬក៏ប្រធានសហករណ៍ដឹងថាពួកយើងស្គាល់ខោអាវទាំងអស់នេះទេ[2899]។

---

2894 ឯកសារ D54/119 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.9 ["ប្រជាជននៅសហករណ៍របស់ខ្ញុំមានចំនួនប្រហែលជាង១០០នាក់ ចំណែកនៅសហករណ៍ផ្សេង ខ្ញុំមិនដឹងថាមានចំនួនប៉ុន្មានទេ។"]។

2895 ឯកសារ D54/119 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.7, 14 ["នៅថ្ងៃដែលគេកំណត់ ប្រជាជនទាំងនោះក៏បានបង្ហាញខ្លួន។ ឡានទ្រុងចិនក៏បញ្ឈប់ចាំទទួលអ្នកទាំងនោះ តែខ្ញុំពុំដឹងថាអ្នកទាំងនោះត្រូវបានបញ្ជូនទៅទីណានោះទេ។ [...] ឆ.14៖ ពួកគេស្លៀកពាក់ដូចទាហានដែរគឺឯកសណ្ឋានពណ៌ខ្មៅ និងពួកពណ៌ត្រីអី (ពណ៌អាចម៍សេះ)។"]។

2896 ឯកសារ D54/119 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.10 ["អ្នកខ្លះក៏បានបន្លំ ក៏បានប្រាប់គេថា ខ្លួនបានមកពីកម្ពុជាក្រោម ដោយសង្ឃឹមថានឹងមានជីវិតប្រសើរជាងនេះ។"]។

2897 ឯកសារ D54/119 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.7 ["ប្រហែលបីថ្ងៃក្រោយមក ឡានមួយក៏វិលត្រឡប់មកវិញជាមួយនឹងគំនរខោអាវ ហើយខោអាវទាំងនោះត្រូវបានចែកចាយឲ្យប្រជាជននៅក្នុងសហករណ៍ ប្រជាជនកាលនោះត្រូវការសំលៀកបំពាក់ជាចាំបាច់។ ខ្ញុំអាចប្រាប់លោកថា បើសិនជាលោកឲ្យមាស និងឲ្យខោអាវគេ គេច្បាស់ជាជ្រើសរើសយកខោអាវហើយ។"]។

2898 ឯកសារ D54/119 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.8 ["កាលនោះយើងមានខោអាវតិចតួចណាស់ ហើយប្រជាជនធ្វើការជាមួយគ្នារាល់ថ្ងៃ ដូច្នេះពួកយើងស្គាល់ខោអាវគ្នាទៅវិញទៅមកច្បាស់។"]។

2899 ឯកសារ D54/119 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.7។

710. ព្រំ កែម បានផ្តល់សក្ខីកម្មថា គ្មានអ្នកនៅរស់រានមានជីវិតទេ៖ "ខ្មែរក្រោមទាំងអស់សុទ្ធតែបានលើកដៃ។ គ្មាននរណាម្នាក់បានវិលត្រឡប់មកវិញទេ ហើយក៏គ្មានខ្មែរក្រោមរស់រានមានជីវិតនៅទីនេះទេ"[2900]។

711. នៅខែ ឧសភា ឆ្នាំ ១៩៧៧[2901] សាក្សី គុយ សម្បត្តិ បានសង្កេតឃើញហេតុការណ៍ស្រដៀងគ្នានេះដែរ។ ជាថ្មីម្តងទៀត ខ្មែរក្រោមត្រូវគេហៅឱ្យចុះឈ្មោះ ដើម្បី "ត្រឡប់" ទៅវៀតណាមវិញ[2902] ហើយជាថ្មីម្តងទៀត ខ្មែរខ្លះបានបន្លំចុះឈ្មោះជាខ្មែរក្រោម ដោយសង្ឃឹមថាអាចត្រូវបានគេបញ្ជូនទៅវៀតណាមដែរ[2903]។ ពិតណាស់ គុយ សម្បត្តិ បានប៉ាន់ប្រមាណថា មានតែ ២០% នៃអ្នកចុះឈ្មោះប៉ុណ្ណោះ ជាខ្មែរក្រោម៖ "អ្នកផ្សេងទៀត គឺជាប្រជាជនធម្មតា ដែលសង្ឃឹមថានឹងអាចចាកចេញផុតពីកម្ពុជាប្រជាធិបតេយ្យ និងរស់នៅក្នុងស្ថានភាពប្រសើរជាងមុន"[2904]។ ក្រោយពីគេចុះឈ្មោះរួចហើយ គេប្រកាសថាអង្គការនឹងបញ្ជូនឡាននៅថ្ងៃបន្ទាប់ មកដឹកអ្នកដែលចង់ទៅប្រទេសវៀតណាម[2905]។ គុយ សម្បត្តិ បានសង្កេតឃើញឡានទ្រុងផលិតនៅប្រទេសចិន "ជាឡានយោធាមកពីខាងកំពង់សោម"[2906] មកដល់ភូមិស្នាច់ដែង តាមផ្លូវជាតិលេខ ៤ ដើម្បីមកដឹកមនុស្ស[2907]។ ច្បាស់ណាស់ថាមិនត្រឹមតែអ្នកចុះឈ្មោះប៉ុណ្ណោះទេ គឺឱ្យតែអ្នកដែលចង់ទៅ អាចឡើងឡានបាន។ យោងតាម គុយ សម្បត្តិ៖ "គេបានប្រកាសថា ឡានទាំងនេះមកដឹកមនុស្សទៅវៀតណាម ហើយ

---

2900 ឯកសារ D54/119 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.18។

2901 ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.9 ["វាស្ថិតនៅក្នុងខែមេសា ឬឧសភា ឆ្នាំ១៩៧៧"]។

2902 ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.1 ["ប្រជាជននិយាយថា ពួកគេមកពីកម្ពុជាក្រោម និងនាំគ្នាចុះឈ្មោះ"]។

2903 ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.1 ["ដោយសារតែរស់នៅពិបាកខ្លាំងពេក ប្រជាជនសង្ឃឹមថា នឹងត្រូវបានគេបញ្ជូនទៅកម្ពុជាក្រោមប្រទេសវៀតណាម"]។

2904 ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.1។

2905 ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.10 ["គេប្រកាសមុនមួយថ្ងៃ មុនពេលឡានមកដល់។ ខ្ញុំមិនអាចប្រាប់លោកបានថា តើអ្នកណាជាអ្នកប្រកាសនោះទេ ខ្ញុំគ្រាន់តែឮពីអ្នកផ្សេងទៀតថា អង្គការនឹងបញ្ជូននៅថ្ងៃបន្ទាប់ មកដឹកអ្នកដែលចង់ទៅប្រទេសវៀតណាម"]។

2906 ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.16។

2907 ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.1, 11 ["អ្វីដែលខ្ញុំបានសង្កេតផងដែរនោះ គឺនៅថ្ងៃមួយមានរថយន្តដែលផលិតនៅប្រទេសចិនចំនួនប្រាំមួយគ្រឿង បានមកដឹកប្រជាជនដែលបានចុះឈ្មោះថា ជាអ្នកកម្ពុជាក្រោម [...] ឆ.11៖ [...] កន្លែងនោះ គឺនៅមុខផ្សារស្នាច់ដែងបច្ចុប្បន្ននេះ"]។

អ្នកដែលចង់ទៅ អាចឡើងឡានបាន"[2908]។ គាត់បានប៉ាន់ប្រមាណថា មនុស្សប្រហែល ៣៦០ នាក់ បានឡើងឡាន[2909] "មានចាស់ មានក្មេង មានប្រុស មានស្រី និងកុមារ ថែមទាំងកុមារតូចៗ និង ទារកទើបនឹងកើតជាមួយនឹងម្តាយរបស់ពួកគេផង"[2910] ហើយគ្រួសារខ្លះមកពីឃុំបិតត្រាង[2911]។

712. ក្រោយមក ពេលគាត់កំពុងស្ទូងស្រូវ នៅទឹកសាប (ខាងលិចអូរទឹកសាប គឺនៅត្រើយម្ខាងនៃមន្ទីរសន្តិសុខទឹកសាប) គុយ សម្បត្តិ បានឃើញឡានបើកចុះតាមផ្លូវជាតិលេខ ៤ ឆ្លងស្ពានទឹកសាប ហើយបត់ឆ្វេងឆ្ពោះទៅមន្ទីរសន្តិសុខទឹកសាប[2912]។ ទោះបីជាគាត់មិនអាចឃើញឡាន ក្រោយពីបត់ចុះពីផ្លូវជាតិលេខ ៤ ក៏ដោយ ក៏គាត់ "អាចឮសំឡេងឡាន និងមានដីហុយទ្រលោមនៅលើផ្លូវដី"[2913]។ ឡានដដែលត្រឡប់មកសហករណ៍ស្នាច់ដែងវិញ នៅប្រហែលម៉ោង ៦ ល្ងាច[2914] ហើយកម្មាភិបាលដែលមកតាមឡានទាំងនេះ បានចែកខោអាវរបស់អ្នកដែលគេយកទៅ ដោយនិយាយថា៖

---

[2908] ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.11។

[2909] ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.15 ["ខ្ញុំប៉ាន់ស្មានថា ក្នុងមួយឡាន អាចដាក់គ្នាចំនួនប្រហែលជា ៦០ នាក់ ហើយមានទាំងអស់ប្រាំមួយឡានដាក់មនុស្សពេញ"]។

[2910] ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.1។

[2911] ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.20។

[2912] ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.1, 21, 25-26 ["ពេលដែលខ្ញុំកំពុងស្ទូងស្រូវនៅភាគខាងលិច[ទឹកសាប] [...] ខ្ញុំឃើញរថយន្តចំនួនមួយគ្រឿងពីចម្ងាយ [...] ឆ.21៖ [...]។ ខ្ញុំឃើញឡានទាំងនោះ បើកដឹកមនុស្សតាមផ្លូវជាតិលេខ ៤។ ខ្ញុំបានឃើញឡានទាំងនោះបត់ចូលទៅភ្នំ ដែលស្ថិតនៅម្ខាងទៀតនៃអូរ [...] ឆ.25៖ [...] កន្លែងនោះជាកន្លែងឃុំឃាំង [...] ឆ.26៖ វានៅខាងកើតអូរ ខាងជើងផ្លូវជាតិ"]។

[2913] ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.1។

[2914] ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.1, ឆ.28 ["ខ្ញុំដឹងថា រថយន្តដដែលនោះ បានត្រឡប់មកវិញ នៅពេលរសៀល។ រថយន្តទាំងនេះបានត្រឡប់មកសហករណ៍ស្នាច់ដែងវិញ។ សហករណ៍ស្នាច់ដែងនេះ មានទីតាំងស្ថិតនៅខាងក្រោយវត្ត [...] ឆ.28៖ ក្រោយពេលដែលខ្ញុំបញ្ចប់ការងាររបស់ខ្ញុំ ខ្ញុំបានត្រឡប់ទៅកន្លែងហូបបាយនៅសហករណ៍ស្នាច់ដែងវិញ។ ខ្ញុំមកដល់ មុនពេលដែលឡានមកដល់។ ខ្ញុំបានឃើញឡាននោះមកដល់ប្រហែលជាម៉ោងប្រាំមួយល្ងាច"]។

"ទូកដែលដឹកអ្នកកម្ពុជាក្រោមទាំងនេះ បានលិចនៅកណ្តាលសមុទ្រ ហើយអ្នកទាំងនោះបានលង់ទឹកស្លាប់អស់ហើយ"[2915]។ គុយ សម្បត្តិ មិនមែនភ្លើទេ៖

> "យើងដឹងថា នេះមិនមែនជាការពិតឡើយ ហើយអ្នកកម្ពុជាក្រោមទាំងនោះត្រូវគេសម្លាប់អស់ហើយ។ គ្រប់គ្នាដឹងអំពីរឿងនេះ ប៉ុន្តែគ្មានអ្នកណាហ៊ាននិយាយឡើយ។ ខ្ញុំក៏បានដឹងឮពីរឿងនេះដែរ។ យើងមិនហ៊ានបដិសេធមិនទទួលយកខោអាវទាំងនេះឡើយ។ ប្រជាជនចាស់ថែមទាំងគាំទ្រអ្វីដែលបានកើតឡើងនេះផងដែរ។ ប្រជាជនដែលគេយកទៅទាំងអស់សុទ្ធតែជាប្រជាជនថ្មី។ ប្រជាជនចាស់ទាំងនោះថែមទាំងនិយាយប្រាប់យើងថា យើងមិនចាំបាច់ទៅរកខ្មាំងនៅកន្លែងណាទៀតទេ។ អ្នកដែលចុះឈ្មោះទាំងនោះហើយ គឺជាខ្មាំងរបស់អង្គការ"[2916]។

713. ក្រោយឆ្នាំ ១៩៧៩ សាក្សី គុយ សម្បត្តិ បានទៅតំបន់ទឹកសាប ហើយគាត់បានឃើញក្បាលឡាន និងឃើញ "រណ្តៅ និងផ្នូរកប់សពរួមជាច្រើន" ព្រមទាំងឆ្អឹងខ្មោចប្រហែល ១.០០០ រួមទាំងក្បាលខ្មោចកុមារ និងទារកផងដែរ[2917]។ ពាក់ព័ន្ធនឹងចំណុចនេះដែរ ស្នួន ឈុំ បាននិយាយថា ក្រៅពីហេតុការណ៍ដែលគាត់បានសង្កេតឃើញ នៅឆ្នាំ ១៩៧៥ គាត់ស្គាល់គ្រួសារមួយ មានប្តី ប្រពន្ធ និងកូនៗ បានចាកចេញផងដែរ ហើយប្រពន្ធជាខ្មែរមកពីកម្ពុជាក្រោម និងធ្វើដំណើរកាត់តាមស្ទាច់ដែង[2918]។ គាត់បានបន្ថែមថា៖ "តាមពិតទៅ អ្នកដែលទៅហ្នឹង អត់មានអ្នកណា គ្រួសារណារួចខ្លួន

---

[2915] ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.28 ["រថយន្តទាំងនោះ បានយកខោអាវមកដាក់នៅជិតរោងបាយសហករណ៍ស្ទាច់ដែង គឺនៅជិតផ្ទះបាយតែម្តង។ គេប្រកាសថា ទាំងនេះគឺជាសម្លៀកបំពាក់អ្នកដែលទៅវៀតណាមមុននេះ"]។

[2916] ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.1។

[2917] ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.1 ["ក្រោយឆ្នាំ ១៩៧៩ នៅពេលដែលខ្ញុំត្រឡប់ទៅមើលកន្លែងនោះ ខ្ញុំបានឃើញរណ្តៅ និងផ្នូរកប់សពរួមជាច្រើន។ ខ្ញុំឃើញមានឆ្អឹងខ្មោចនៅទីនោះ ខ្ញុំប៉ាន់ស្មានថា នៅតំបន់នោះ មានមនុស្សរហូតដល់ ១ ពាន់នាក់ ត្រូវបានគេកប់។ ខ្ញុំគិតថា មិនច្រើនជាងចំនួននេះទេ។ ខ្ញុំក៏បានឃើញក្បាលខ្មោចកុមារ និងទារកផងដែរ"]។

[2918] ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ ស្នួន ឈុំ ឆ.54-55 ["ស៖ តើលោកបានដឹងអំពីការប្រមូលផ្តុំគ្រួសារខ្មែរក្រោមខ្នាតធំមួយនៅស្ទាច់ដែង ហើយដឹកតាមឡានចិនធំៗយកទៅបាត់ទេ? ឆ.54៖ ហ្នឹង ខ្ញុំគ្រាន់តែឮ តែអត់បានឃើញទេ [...] ឆ.55៖ [...] អ្នកដែលខ្ញុំស្គាល់ឃើញទៅមួយគ្រួសារដែរ។ ហើយវាជាអ្នកស្រុកជាមួយខ្ញុំផងណ៎ា។ ចាញ់ការបោកប្រាស់របស់វា ថាប្រពន្ធខ្ញុំនៅកម្ពុជាក្រោមដែឬ ទៅតាមប្រពន្ធ កូន បាត់រហូតដល់ឥឡូវ"]។

ទេ។ [...] គ្រួសារមួយចំនួន គឺយើងស្គាល់ច្បាស់ អ្នកស្រុកយើង។ តែទៅហើយ អត់មានឃើញអ្នកណាមកវិញ”[2919]។

714. សាក្សីជាច្រើនផ្សេងទៀតក៏បានផ្តល់ភ័ស្តុតាងផងដែរ ពាក់ព័ន្ធនឹងការបញ្ជូនអ្នកដែលគេចាប់បាន ពីការដ្ឋានតំបន់រាម ទៅទឹកសាប[2920] *(សូមមើលផងដែរ ផ្នែកទី VIII.ត.៤ មន្ទីរសន្តិសុខទឹកសាប)*។

---

2919 ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ឈុំ ឆ.55-56។

2920 ឯកសារ D114/242 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ប៊ុនធី ឆ.83-84 [“ស៖ តើអ្នកដែលជាប់ទោសនោះ ត្រូវបានគេយកចេញទៅណាទៀតទេ? ឆ.83៖ អ្នកជាប់ទោសទាំងនោះ កាលជំនាន់ហ្នឹង គេយកមកមន្ទីរឃុំឃាំងនៅទឹកសាបនេះ។ ស៖ ម៉េចបានលោកដឹង ឆ.84៖ ព្រោះអី មន្ទីរធំបំផុត គឺមន្ទីរគុកនៅទឹកសាបហ្នឹង គុកធំរបស់ពួកវា”]។ ឯកសារ D54/35.1 កិច្ចសម្ភាសន៍របស់ជម្រុមណ្ឌលឯកសារកម្ពុជាជាមួយ ប្រាក់ សុខា KH ERN 00964252 [“ស៖ ចឹងពូនៅខាងកំពង់សោម ឮថាមានគុកដែលចឹង បើគេចាប់មកដាក់គុកទៅខាងណាវិញ? ឆ៖ ហ្នឹងនៅទឹកសាបនៅក្បាលស្ពានទឹកសាប ឃើញគេបញ្ជូនមកខាងហ្នឹង គេយកមកទឹកសាបហ្នឹងហើយ។”]។ សូមមើលផងដែរ ឯកសារ D54/89 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែត ឆ.5, 28 [“អ្នកមានបណ្តាសក្តិពិតត្រូវបានគេទុកនៅវាលយន្តហោះកងកេង ហើយបន្ទាប់មកគេចាប់ចង រួកយកទៅសម្លាប់នៅទឹកសាប ពួកអតីតទាហាន លន់ នល់ ចំនួនរាប់ពាន់នាក់ត្រូវបានសម្លាប់នៅទឹកសាប់នោះ [...] ឆ.28៖ [...] បន្ទាប់ពីខ្មែរក្រហមគ្រប់គ្រងប្រទេសនៅខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រមូលអតីតទាហាន លន់ នល់ ទាំងអស់យកទៅដាក់នៅព្រលានយន្តហោះកងកេង។ ក្រោយមកពួកទាហាន លន់ នល់ ទាំងនោះ ត្រូវបាននាំយកទៅបាត់”]។ ឯកសារ D114/242 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ប៊ុនធី ឆ.83-84 [“ស៖ តើអ្នកដែលជាប់ទោសនោះ ត្រូវបានគេយកចេញទៅណាទៀតទេ? ឆ.83៖ អ្នកជាប់ទោសទាំងនោះ កាលជំនាន់ហ្នឹង គេយកមកមន្ទីរឃុំឃាំងនៅទឹកសាបនេះ។ ស៖ ម៉េចបានលោកដឹង ឆ.84៖ ព្រោះអី មន្ទីរធំបំផុត គឺមន្ទីរគុកនៅទឹកសាបហ្នឹង គុកធំរបស់ពួកវា”]។ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សម្បត្តិ ឆ.139-144, 213 [“ស៖ ចុះអ្នកព្យាយាមរត់ តើមានអ្វីកើតឡើងចំពោះអ្នកទាំងអស់នោះ? ឆ.139៖ ពេលនោះ មានអ្នករត់ហើយគេចាប់អ្នកទាំងនោះដាក់ខ្នោះជើង ឬក៏ខ្នោះដៃ ហើយបញ្ជូនទៅទឹកសាប។ ស៖ មានមនុស្សប៉ុន្មានតាមដែលលោកចាំ ដែលត្រូវបានគេបញ្ជូនទៅទឹកសាប? ឆ.140៖ មានពីរបីនាក់។ ស៖ ហេតុអ្វីបានជាលោកដឹងថា គេបញ្ជូនទៅទឹកសាប? ឆ.141៖ ព្រោះគេនិយាយប្រាប់អ៊ីចឹង ស៖ អ្នកណាជាអ្នកប្រាប់លោក ឆ.142៖ អ្នកដែលធ្វើការជាមួយគ្នា ស៖ តើលោកមានឃើញផ្ទាល់ភ្នែកថា គេដាក់ខ្នោះដៃជើងអ្នកទាំងនោះទេ? ឆ.143៖ បាន ឃើញផ្ទាល់។ ស៖ តើលោកឃើញតែពីរបីនាក់ហ្នឹង ឬអ្នកផ្សេងទៀតដែរ? ឆ.144៖ ខ្ញុំឃើញតែពីរបីនាក់ហ្នឹងទេ ពួកគេនៅក្នុងក្រុមជាមួយខ្ញុំដែរ។ [...] ស៖ លោកនិយាយថា ឃើញមនុស្សត្រូវគេដាក់ខ្នោះ ហើយបញ្ជូនទៅទឹកសាប។ តើលោកធ្លាប់ឃើញពួកគេម្តងទៀតទេ? ឆ.213៖ ទេ”]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.4, 6, 13 [“ចំនួនមនុស្សនៅក្នុងកង ពេលខ្លះឡើងចុះ ពីព្រោះពេលខ្លះ គេបញ្ជូនមនុស្សទៅឃុំនៅទឹកសាប [...] ឆ.6៖ មានប្រជាជន ១៧ មេសាខ្លះ ដែលជាខ្មែរកម្ពុជាក្រោម ត្រូវបានគេដាក់នៅក្នុងកងចល័តនោះ ហើយខ្មែរក្រោម ត្រូវបានគេបញ្ជូនទៅទឹកសាប បន្ទាប់ពីគេដាក់ក្នុងកងនោះបានពី ៤-៥ ខែ។ ខ្មែរក្រោម គេមិនដែលទុកយូរទេ នៅក្នុងកងចល័ត [...] ឆ.13៖ ខ្ញុំស្គម ហើយ

"នៅពេលនោះ អ្នកភូមិទាំងអស់ដឹងតាមគ្នាថា នៅពេលដែលមនុស្សត្រូវបានចាប់ខ្លួនពីសហករណ៍ភូមិពូធឿង គេនឹងយកទៅសម្លាប់ នៅកន្លែង សេអ៊ី។ ប៉ុន្តែ ប្រសិនបើគេចាប់មនុស្សពីសហករណ៍ភូមិបបុស គេនឹងយកទៅសម្លាប់ នៅទឹកសាប"[2921]។ សាក្សីម្នាក់បានរៀបរាប់ថា ខ្មែរក្រោមនៅក្នុងកងរបស់គាត់ត្រូវបានគេយកទៅ រួចនាំទៅទឹកសាប ៤-៥ ខែក្រោយមក[2922] ហើយ "អ្នកណាក៏ដោយឲ្យតែបញ្ជូនទៅទឹកសាប គឺមិនដែលរស់ទេ"[2923]។ សាក្សីម្នាក់ទៀតបានអះអាងថា៖ "ការសម្លាប់ គឺមានចាប់ផ្តើមខ្លាំង ពីដើមឆ្នាំ ១៩៧៦ ពេលនោះ គឺខ្មែរក្រហមបានចាប់ប្រជាជនពីតាមសហករណ៍ និងភូមិ ទៅសម្លាប់នៅទឹកសាប"[2924]។ "យកទៅដាក់ហើយ អត់ឃើញត្រឡប់មកវិញទេ សម្លាប់ចោលអស់ហើយ"[2925]។

---

រស់នៅដោយការភ័យខ្លាចដែរ ប៉ុន្តែខ្ញុំខំប្រឹងតស៊ូ ដើម្បីរស់ ខ្ញុំមិនចង់ឲ្យគេបញ្ជូនទៅទឹកសាបទេ"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ម៉ោង 10.48.52-10.51.34 ["ពាក្យដែល "ទមិឡ" គឺហៅថា "ទមិឡកុម្មុយនីស្ត" ជាទមិឡកុម្មុយនីស្តនេះជាបំភ្លើស បំភ្លៃនៃច្បាប់របស់គេ។ អ៊ីចឹងហើយ បានគេចាប់អ្នកទាំងអស់នោះយកទៅដាក់គុកនៅទឹកសាបតែម្តង"]។ សូមមើលផងដែរ ឯកសារ D54/35 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.17 ["នៅពេលនោះ គេបានប្រាប់យើងថា ពួកយើងនឹងត្រូវគេបញ្ជូនទៅស្ទឹងហាវ មិនទៅទឹកសាបទេ ដោយសារពួកយើងមានទោសស្រាល"]។

2921 ឯកសារ D54/89 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែត ឆ.9.។

2922 ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.6 -7 ["មានប្រជាជន ១៧ មេសាខ្លះ ដែលជាខ្មែរកម្ពុជាក្រោម ត្រូវបានគេដាក់នៅក្នុងកងចល័តនោះ ហើយខ្មែរក្រោម ត្រូវបានគេបញ្ជូនទៅទឹកសាប បន្ទាប់ពីគេដាក់ក្នុងកងនោះបានពី ៤-៥ ខែ។ ខ្មែរក្រោម គេមិនដែលទុកយូរទេ នៅក្នុងកងចល័ត [...] ឆ.7៖ មានខ្មែរក្រោមជាច្រើននៅតាមកងផ្សេងៗ តែខ្ញុំបានស្គាល់ខ្លះដែរ នៅក្នុងកងរបស់ខ្ញុំ។ ខ្ញុំនៅចាំឈ្មោះ ថាច់ ប៊ិន, ឡាំ ស៊ិក និង ឡាំ សាញ់ (ទាំងពីរនាក់នេះ ជាបងប្អូនបង្កើត)។ ខ្ញុំចាំឈ្មោះអ្នកទាំង ៣ នាក់នេះ ពីព្រោះគេនៅក្នុងក្រុមជាមួយខ្ញុំ គេត្រូវបានយកទៅទឹកសាប បន្ទាប់ពីគេនៅក្នុងកងជាមួយខ្ញុំបាន ៤-៥ ខែ។ អ្នកណាក៏ដោយ ឲ្យតែគេបញ្ជូនទៅទឹកសាប គឺមិនដែលរស់ទេ"]។

2923 ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.7។

2924 ឯកសារ D54/89 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែត ឆ.5។

2925 ឯកសារ D114/242 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ប៊ុនធី ឆ.86, 98 ["ខ្ញុំឃើញតែបញ្ជូនទៅបាត់ៗអ្នកទោស[...] ឆ.98៖ [...] យកទៅដាក់ហើយ អត់ឃើញត្រឡប់មកវិញទេ សម្លាប់ចោលអស់ហើយ"]។ សូមមើលផងដែរ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.4 ["ចំនួនមនុស្សនៅក្នុងកង ពេលខ្លះឡើងចុះ ពីព្រោះពេលខ្លះ គេបញ្ជូនមន្ទ្យទៅឃុំនៅនឹងទឹកសាប"]។ សូមមើលផងដែរ ឯកសារ D114/176 កំណត់ហេតុស្តាប់ចម្លើយ ចាន់ សារឿន ឆ.10, 27 ["ស៖ លោកបាននិយាយថា ឮឪពុកក្មេកលោកថា គេយកមនុស្សពីស្នាច់ដែង រាម និងចំការដូងទៅសម្លាប់នៅទីនោះដែរ។ [...] តើអ្វីដែលយើងបានសង្ខេបខាងលើ ត្រឹមត្រូវដែរឬទេ? ឆ.10៖ បាទ ត្រឹមត្រូវ [...] ស៖ តើ

715. ក្រៅពីមន្ទីរសន្តិសុខទឹកសាប ជនរងគ្រោះក៏ត្រូវបានចាប់ពីការដ្ឋានរាម រួចបញ្ជូនទៅមន្ទីរ ស-២១ *(សូមមើល ជាទូទៅ ផ្នែកទី VIII.ឃ មន្ទីរសន្តិសុខ ស-២១)*[2926] និងទីតាំងសម្លាប់មនុស្សផ្សេងទៀត នៅក្នុងតំបន់នោះ[2927]។ ទីតាំងសម្លាប់មនុស្សធំបំផុតចំនួនបី នៅការដ្ឋានតំបន់រាម គឺចម្ការទុរេនទី ១ ចម្ការទុរេនទី ២ និង សេអ៊ី។

---

លោកអាចយល់ដែរឬទេ អំពីមូលហេតុដែលពួកខ្មែរក្រហមយកមនុស្សពីស្នាច់ដែង រាម និងចំការដូង មកសម្លាប់នៅទឹកសាប? ឆ.27៖ អានេះ ខ្ញុំមិនសូវដឹងទេ វាមានអ្នកខ្ជិល មានអ្នកឧស្សាហ៍ មានអ្នកក្បត់អីចឹង បានគេយកទៅសម្លាប់ចោល"]។

[2926] ឯកសារ D114/230.1.1 បញ្ជីអ្នកទោសនៅ ស-២១ របស់ ក.ស.ច.ស EN ERN 01222358 [បង្ហាញអត្តសញ្ញាណលេខរៀងទី ៦៣៦ ថាឈ្មោះ ទូន មឿន ជាអ្នកធ្វើការនៅចម្ការដូង ចាប់ខ្លួននៅកំពង់សោម (រាម) ហើយចូលមន្ទីរ ស-២១ នៅថ្ងៃទី ៧ ខែឧសភា ឆ្នាំ១៩៧៦] EN ERN 01222359 [បង្ហាញអត្តសញ្ញាណលេខរៀងទី ៦៦៤ ថាឈ្មោះ អ៊ុន សារី ជាអ្នកធ្វើការនៅកងនេសាទ (ប្រជាជនថ្មី) ចាប់ខ្លួននៅកំពង់សោម (រាម) ហើយចូលមន្ទីរ ស-២១ នៅថ្ងៃទី ៧ ខែឧសភា ឆ្នាំ១៩៧៦], EN ERN 01222358 បង្ហាញអត្តសញ្ញាណលេខរៀងទី ៦៣៤ ថាឈ្មោះ អ៊ុំ ផាន ជាសិស្សថ្នាក់បញ្ចប់ ចាប់ខ្លួនកំពង់សោម (កងកេង) ហើយចូលមន្ទីរ ស-២១ នៅថ្ងៃទី ៤ ខែកក្កដា ឆ្នាំ១៩៧៧], EN ERN 01222358 [បង្ហាញអត្តសញ្ញាណលេខរៀងទី ៦៣៩ ថាឈ្មោះ ឈុន ហួយ ( ឈុន ហូយ) អ្នករត់ម៉ូតូឌុប (ប្រជាជនថ្មី) ចាប់ខ្លួនពីកំពង់សោម (កងកេង) ហើយចូលមន្ទីរ ស-២១ នៅថ្ងៃទី ៧ ខែឧសភា ឆ្នាំ១៩៧៦], EN ERN 01222358 [ឈុន ហួយ ( ឈុន ហូយ) អ្នករត់ម៉ូតូឌុប (ប្រជាជនថ្មី) ដែលត្រូវបានគេចាប់ខ្លួនពីកំពង់សោម (កងកេង) និងត្រូវបញ្ជូនចូលមក ស-២១ នៅថ្ងៃទី ៧ ខែឧសភា ឆ្នាំ១៩៧៦៦៤៣ ថាឈ្មោះ សំ សិត ជាយុទ្ធជនរបស់កងពលលេខ ១៦៤ មកពីភូមិភាគនិរតី (ធ្វើស្រែ) ចាប់ខ្លួនពីកំពង់សោម (កងពលធំលេខ ១៦៤) (កងកេង) ហើយចូលមន្ទីរ ស-២១ នៅថ្ងៃទី ៧ ខែឧសភា ឆ្នាំ១៩៧៦], EN ERN 01222527 បង្ហាញអត្តសញ្ញាណលេខរៀងទី ៥០២៥ ថាឈ្មោះ មូល វ៉ាន់ឌី (មូល វ៉ាន់ឌី) ធ្វើការនៅកងសម្តែងសិល្បៈ ចាប់ខ្លួនពីកំពង់សោម (កងកេង) ហើយចូលមន្ទីរ ស-២១ នៅថ្ងៃទី ៧ ខែឧសភា ឆ្នាំ១៩៧៦], EN ERN 01222567 [លេខរៀងទី ៦០៨៤ ឈ្មោះ អុំ កឺន (អ៊ុម កើន) យុទ្ធជនកងពល ១៦៤ ភូមិភាគនិរតី (យុទ្ធជនអង្គភាព ៦៣ និរតី) ចាប់ខ្លួនពីកំពង់សោម (កងពលធំ ១៦៤) (អង្គភាព ៦៣ និរតី) (កំពង់សោម កងពលនិរតី) (កងកេង) ហើយចូលមន្ទីរ ស-២១ នៅថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ១៩៧៦]។

[2927] សូមមើល ឯកសារ D114/4 កំណត់ហេតុស្តាប់ចម្លើយ មុំ ម៉េង ឆ.27-31 [សាក្សីរកឃើញកន្លែងកប់សាកសពមួយកន្លែង នៅឆ្នាំ ១៩៨៣ ស្ថិតនៅមួយគីឡូម៉ែត្រពីកន្លែងសេអ៊ី និងប្រហែលជាពីរគីឡូម៉ែត្រពីផ្លូវជាតិលេខ ៤។ ទីតាំងនោះគឺជាចំការខ្នុរ មានផ្នូរខ្មោចប្រហែល ២០។ សាក្សីនេះ មិនច្បាស់ថាតើ ផ្នូរទាំងនេះគេជីកនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏ថាតើ កន្លែងនេះគ្រាន់តែជាកន្លែងកប់ខ្មោចនោះទេ]។ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.42, 123-124, 126 ["បងប្អូនជីដូនមួយខ្ញុំឈ្មោះ ធី និងប្តីរបស់នាងឈ្មោះ ឃិន ក្រោយពីគេឃើញ ធី យំពេលយកប្តីគាត់ទៅបាត់ គេបម្រុងយកគាត់ទៅសម្លាប់នៅភូមិពុទ្ធទេ។។ ពុទ្ធទេ គឺជាកន្លែងដែលអ្នកណាៗ ក៏ដឹងថាគេយកស្ត្រីៗ ដែលជាប្រពន្ធ ដែលប្តីត្រូវបានគេយកទៅសម្លាប់ [...] ឆ.123៖ ខ្ញុំបានទៅមើលសាកសពប្តីរបស់ខ្ញុំដោយ

*ក) ទីតាំងសម្លាប់មនុស្សចម្ការទុរេនទី ១*

716. ភ័ស្តុតាងបង្ហាញឱ្យឃើញថា ទីតាំងសម្លាប់មនុស្សចម្ការទុរេនទី ១ ត្រូវគេប្រើជាកន្លែងសម្លាប់អ្នកដែលចាប់បាន នៅលើកោះ ឬនៅលើសមុទ្រ *(សូមមើល ផ្នែកទី VIII.ខ ឧក្រិដ្ឋកម្មប្រព្រឹត្តប្រឆាំងនឹងអ្នកដែលចាប់បានដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ នៅក្នុងដែនទឹក និងនៅលើកោះដែលត្រូវបានកម្ពុជាប្រជាធិបតេយ្យអះអាងថាជាកម្មសិទ្ធិរបស់ខ្លួន)* និងជាកន្លែងសម្លាប់ "ខ្មាំង" ដែលនាំយកមកពីការដ្ឋានរាមនៅជិតៗនៅជុំវិញនោះ[2928]។ ជនស៊ីវិល និងអ្នក ១៧ មេសា ត្រូវគេដឹងថាត្រូវបាននាំយកទៅសម្លាប់នៅទីនោះ[2929]។ "តាមធម្មតា គ្មាននរណាអាចរស់បានទេ នៅពេលដែលគេបញ្ជូនទៅដល់ទីនោះហើយ"[2930]។

---

ផ្ទាល់ជាមួយនឹងស្ត្រីម្នាក់ទៀត ក្រោយពីការសម្លាប់មួយថ្ងៃ។ ខ្ញុំបានដើរពីកន្លែងខ្ញុំធ្វើការទៅអូរកាច់។ កន្លែងនោះមានសាកសពប្រហែល ១០ នាក់ ខ្ញុំបានឃើញសាកសពប្តីខ្ញុំ តែមិនទាន់កប់ទេ។ ខ្ញុំស្គាល់ថាជាប្តីខ្ញុំ ព្រោះខ្ញុំបានឃើញមុខគាត់ច្បាស់។ ប្តីខ្ញុំត្រូវគេវៃត្រង់ចញ្ចឹងកសម្លាប់។ [...] ឆ.124៖ ក្រោយពីខ្ញុំបានឮពីយោធា ដែលបានវិលត្រឡប់មកជាមួយប្តីខ្ញុំ ហើយប្រាប់ថាប្តីខ្ញុំត្រូវបានគេសម្លាប់ ក្រោយពីមកពីភូមិភាគបូព៌ាវិញ។ អូរកាច់មានចម្ងាយ ៣ ទៅ ៤ គីឡូម៉ែត្រពីកន្លែងខ្ញុំរស់នៅ គឺនៅខាងជើងភូមិពូធឿន ប៉ុន្តែ ខ្ញុំត្រូវដើរកាត់ព្រៃក្រាស់ទើបទៅដល់ទីនោះ។ [...] ស៖តើលោកស្រីស្គាល់ថាជាប្តីរបស់លោកស្រីឬ? ឆ.126៖ [...] ខ្ញុំស្គាល់មុខគាត់ច្បាស់"]។

2928 ឯកសារ D2/6 កំណត់ហេតុស្តាប់ចម្លើយ ញូង ជ្រោង ឆ.40-41 ["ខ្ញុំមិនបានឃើញទេ ប៉ុន្តែ តាមខ្ញុំឮពីអ្នកផ្សេងនិយាយថា គេចាប់អ្នកដែលបានប្រព្រឹត្តខុស ហើយបញ្ជូនទៅកន្លែងនោះ ដើម្បីធ្វើជាជីសម្រាប់ដើមធូរេន។ កន្លែងនោះជាកន្លែងស្ងាត់ ដូច្នេះគ្មានប្រជាជនចូលទៅដល់ទេ ស៖ ពេលដែលលោកនិយាយថា គេយកទៅធ្វើជី តើមានន័យយ៉ាងម៉េច? ឆ.41៖ មានន័យថា យកទៅសម្លាប់ គឺសម្លាប់ដាក់គល់ធូរេន ដើម្បីធ្វើជី"]។

2929 ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.11 ["ខ្ញុំធ្លាប់ឮអំពីកន្លែងនោះ តែខ្ញុំពុំដែលទៅដល់ទេ។ ខ្ញុំមិនដឹងថា កន្លែងនោះជាកន្លែងអ្វីពិតប្រាកដទេ។ ខ្ញុំគ្រាន់តែដឹងថា ជាកន្លែងសម្ងាត់។ ខ្ញុំធ្លាប់ឮពីអ្នកឃ្វាលគោ ដែលធ្លាប់ទៅឃ្វាលគោនៅជិតវាលយន្តហោះកងកេង។ កាលពីពេលនោះ និយាយថា ចំការធុរេន គឺជាកន្លែងសម្លាប់មនុស្ស។ តាមដែលខ្ញុំដឹង ប្រជាជនស៊ីវិលដែលធ្វើខុស និងប្រជាជន ១៧ មេសា ត្រូវបាននាំយកទៅសម្លាប់នៅកន្លែងនោះ"]។

2930 ឯកសារ D54/18 កំណត់ហេតុស្តាប់ចម្លើយ នូ សារឿន ឆ.43-44 ["តាមធម្មតា គ្មាននរណាអាចរស់បានទេ នៅពេលដែលគេបញ្ជូនទៅដល់ទីនោះហើយ [...] ឆ.44៖ ខ្ញុំបានឮពីមនុស្សជាច្រើនថា អ្នកដែលគេបញ្ជូនទៅដល់ទីនោះហើយមិនដែលត្រឡប់មកវិញទេ"]។

717. ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ សាក្សីជាច្រើនបានឃើញរណ្ដៅ និងផ្នូរ[2931] ព្រមទាំងសាកសពកប់ក្រោមដើមទុរេន សម្រាប់ធ្វើជាជី[2932]។ សាក្សីម្នាក់បានរៀបរាប់ថា គាត់បានឃើញរណ្ដៅកប់សាកសពធំពីរ[2933]។ រណ្ដៅទីមួយមានជម្រៅត្រឹមភ្លៅ និងមានអង្កត់ផ្ចិតប្រហែល ៤ ម៉ែត្រ[2934]។ ឆ្អឹងខ្មោចប្អូនប្រាំនៅលើគោក ហើយរណ្ដៅមានដីលុប[2935]។ សាក្សីម្នាក់ទៀតបានសង្កេតឃើញមាន "រណ្ដៅយ៉ាងតិចចំនួន ៤ នៅជុំវិញគល់ទុរេនមួយដើម។ ចម្ការនោះធំណាស់។ [...] សាកសពមួយ

---

2931 ឯកសារ D54/18 កំណត់ហេតុស្ដាប់ចម្លើយ នូ សារឿន ឆ.39, 44 ["បន្ទាប់ពីឆ្នាំ ១៩៧៩ ខ្ញុំបានទៅទីនោះ ហើយបានឃើញ រណ្ដៅកប់សាកសព និងផ្នូរខ្មោចនៅទីនោះ [...] ឆ.44៖ ដូចដែលខ្ញុំប្រាប់ពីមុន ក្រោយពេលវៀតណាមរំដោះឆ្នាំ ១៩៧៩ ខ្ញុំបានទៅទីនោះ ហើយបានឃើញផ្នូរខ្មោច និងរណ្ដៅសាកសពមួយចំនួន"]។

2932 ឯកសារ D54/118 កំណត់ហេតុស្ដាប់ចម្លើយ ព្រំ កែម KH ERN 01023151 ["តែលោកបានដឹង/ឮពីប្រជាជនថា ពួកខ្មែរក្រហមបានកប់សាកសពនៅម្ដុំដើមធូរេន ដើម្បីធ្វើជី គឺនៅទីកន្លែងមួយដែលមានឈ្មោះថា ចម្ការធូរេន"]។ ឯកសារ D54/123 កំណត់ហេតុស្ដាប់ចម្លើយ ឡាក់ សាផាន ឆ.12 ["គេជីករណ្ដៅនៅក្រោមដើមធូរេន"]។ ឯកសារ D2/6 កំណត់ហេតុស្ដាប់ចម្លើយ ញូង ជ្រោង ឆ.41, 43 ["ស៖ ពេលដែលលោកនិយាយថា គេយកទៅធ្វើជី តើលោកមានន័យយ៉ាងម៉េច? ឆ.41៖ មានន័យថា យកទៅសម្លាប់ គឺសម្លាប់ដាក់គល់ធូរេន ដើម្បីធ្វើជី [...] ឆ.43៖ ពួកវរសេនាធំ ៦២ ជាអ្នកយកមនុស្សមកពីរាម ទៅចម្ការធូរេន ដើម្បីសម្លាប់"]។ ឯកសារ D54/26 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.16 ["ខ្ញុំដឹងតាមរយៈយោធាដែលធ្វើការនៅទីនោះ គេប្រាប់យើងថា គេបានសម្លាប់ពួកយួនជាច្រើននៅទីនោះ ហើយកប់សាកសពនៅដើមធូរេន ដើម្បីធ្វើជី"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារិក ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ម៉ោង 10.43.36-10.46.23 ["យកទៅសម្លាប់ចោលនៅទីនោះ ហើយគេយកសាកសពនោះធ្វើជាជីតែម្ដង"]។

2933 ឯកសារ D54/18 កំណត់ហេតុស្ដាប់ចម្លើយ នូ សារឿន ឆ.46 ["ខ្ញុំបានឃើញរណ្ដៅកប់ដាក់សពធំពីរ ដែលមានឆ្អឹងខ្មោច និងលលាដ៍ក្បាល។ រណ្ដៅទី ១ មានទំហំធំ និងជម្រៅជាងរណ្ដៅទី ២ ហើយរណ្ដៅទី ២ នៅម្ខាងដើមធូរេនធំមួយ។ ខ្ញុំសង្ស័យថា ឥឡូវរណ្ដៅទាំងនោះមានព្រៃដុះជុំជិត។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំបានឃើញតែរណ្ដៅសាកសពរួមតែពីរនេះទេ មិនបានឃើញផ្នូរខ្មោចទេ"]។

2934 ឯកសារ D54/18 កំណត់ហេតុស្ដាប់ចម្លើយ នូ សារឿន ឆ.47 ["រណ្ដៅទី ១ នោះមានរាងមូល ដែលអាចឃើញស្នាមលុបមិនជិតល្អ។ វាមានជម្រៅត្រឹមភ្លៅ និងមានអង្កត់ផ្ចិតប្រហែល ៤ ម៉ែត្រ"]។

2935 ឯកសារ D54/18 កំណត់ហេតុស្ដាប់ចម្លើយ នូ សារឿន ឆ.47 ["នៅពេលដែលខ្ញុំទៅដល់ទីនោះ ខ្ញុំបានឃើញមានដីលុប និងឃើញឆ្អឹងខ្មោចប្អូនប្រាំនៅលើគោក។ តាមដែលខ្ញុំដឹង គេមិនទាន់គាស់កកាយរណ្ដៅនោះនៅឡើយទេ"]។ សូមមើលផងដែរ ឯកសារ D54/123 កំណត់ហេតុស្ដាប់ចម្លើយ ឡាក់ សាផាន ឆ.12 ["គឺក្រោយពីរបបខ្មែរក្រហមដួលរលំភ្លាមៗ។ ខ្ញុំបានទៅទីនោះ ហើយបានឃើញឆ្អឹងដៃជើង និងកាលឃើញលលាដ៍ក្បាល និងសក់"]។

ក្នុងរណ្តៅមួយ”[2936]។ សាក្សីម្នាក់បានសន្និដ្ឋានថា ជនរងគ្រោះជាច្រើនត្រូវបានសម្លាប់ ដោយវាយនឹងត្បូងចប ព្រោះគាត់បានឃើញចបនៅវាយប៉ាយ នៅចម្ការទុរេនទី ១[2937]។

718. សាក្សី ប៉ាក សុខ ដែលរស់នៅជិតចម្ការទុរេនទី ១ បានផ្តល់សក្ខីកម្មថា កម្មាភិបាលកងវរសេនាធំលេខ ៦២ បានប្រាប់គាត់អំពីការសម្លាប់មនុស្សនៅទីនោះ[2938]។ “ខ្ញុំបានសួរពួកទាហាន ហើយគេប្រាប់ថាពិតជាមានការសម្លាប់មនុស្សមែន”[2939]។

*ខ) ទីតាំងសម្លាប់មនុស្សចម្ការទុរេនទី ២*

719. ប្រជាជននៅតំបន់នោះដឹងច្បាស់ថាចម្ការទុរេនទី ២ ត្រូវគេប្រើជាកន្លែងសម្លាប់មនុស្ស[2940]។ សាក្សី ឡាក់ សាផាន បានផ្តល់សក្ខីកម្មថា “ប្រជាជនមូលដ្ឋានទាំងអស់ដឹងថាមានទីតាំងសម្លាប់មនុស្សពីរ

---

[2936] ឯកសារ D54/123 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.13។

[2937] ឯកសារ D54/123 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.12 [“ប្រសិនបើខ្ញុំមិនច្រឡំទេ អ្នកទាំងនោះ ត្រូវបានគេវ៉ៃនឹងត្បូងចបហើយ ព្រោះខ្ញុំបានឃើញចបនៅវាយប៉ាយនៅទីនោះ”]។

[2938] ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារិក ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ម៉ោង 10.43.36-10.46.23 [“ព្រឹត្តិការណ៍នេះ ដែលកើតឡើង ខ្ញុំរស់នៅជិតនោះៗ ហើយជីវប្រវត្តិរបស់ខ្ញុំ នៅវរសេនាធំ ៦២ នេះជាកងវរៈចាស់របស់ខ្ញុំ។ អ៊ីចឹងហើយ កូនទាហានដែលខ្ញុំធ្លាប់ស្គាល់ ហើយធ្លាប់រស់នៅជាមួយគ្នា ស្គាល់មកឃើញថា គេនៅទីនោះ ខ្ញុំបានសាកសួរដោយស្មោះត្រង់ ហើយយោធានោះឃើញថា គឺសម្លាប់ពិតប្រាកដមែន”] ម៉ោង 10.43.36-10.46.23 [“ពេលនុំងឃើញថា សភាពការណ៍ ដែលគេយកទៅសម្លាប់នោះ ភាគច្រើននៅកងដែលខ្ញុំធ្លាប់រស់នៅពីមុន បាទ។ ពីមុន ខ្ញុំនៅកងពលវរសេនាធំ ៦២ បាទ ពេលនុំងវរសេនាធំ ៦២ នោះ គេចាប់បាន គេបញ្ជាឲ្យយកទៅចម្ការក្រូច និងចម្ការដូងយកទៅសម្លាប់ចោលនៅទីនោះ”]។

[2939] ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារិក ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ម៉ោង 10.43.36-10.46.23។ សូមមើលផងដែរ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.16 [“ខ្ញុំដឹងតាមរយៈយោធាដែលធ្វើការនៅទីនោះ គេប្រាប់យើងថា គេបានសម្លាប់ពួកយួនជាច្រើននៅទីនោះ ហើយកប់សាកសពនៅដើមធូរេន ដើម្បីធ្វើជី”]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារិក ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ម៉ោង 10.43.36-10.46.23 [“យកទៅសម្លាប់ចោលនៅទីនោះ ហើយគេយកសាកសពនោះធ្វើជាជីតែម្តង”]។

[2940] ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែត ឆ.1-2 [“បន្ទាប់ពីខ្មែរក្រហមឡើងកាន់កាប់ប្រទេសនៅឆ្នាំ ១៩៧៥ យើងដែលជាប្រជាជនមូលដ្ឋាននៅទីនោះ បានដឹងថា ខ្មែរក្រហមយកកន្លែងចម្ការធូរេននេះ សម្រាប់សម្លាប់មនុស្ស។ ប៉ុន្តែចំពោះខ្ញុំ ខ្ញុំទើបតែបានទៅឃើញចម្ការធូរេននេះដំបូង បន្ទាប់ពីវៀតណាមចូលនៅថ្ងៃមករា ឆ្នាំ១៩៧៩ ស៖ តើប្រជាជនទាំងអស់គ្នាដឹងថា ខ្មែរក្រហមយកមនុស្សទៅសម្លាប់នៅកន្លែងហ្នឹង តាមរបៀបណា? ឆ.2៖ ខ្ញុំដឹងថា ខ្មែរក្រហមយកមនុស្សទៅសម្លាប់នៅទីនោះ តាមរយៈប្រពន្ធរបស់យោធាខ្មែរក្រហម។ អំឡុងពេលនោះ ប្រពន្ធរបស់

កន្លែង" គឺចម្ការទុរេនទី ២ និងទឹកសាប[2941]។ គាត់បានឆ្លើយថា ទាហាន លន់ នល់ ត្រូវគេនាំយកយកទីតាំងសម្លាប់មនុស្សទាំងពីរកន្លែងនេះ ក្រោយពីខ្មែរក្រហមឡើងកាន់អំណាច"[2942] ហើយអ្នកទោសខ្លះដែលគេបញ្ជូនមកតាមកំពង់ផែកំពង់សោម ក៏ត្រូវបាននាំយកយកសម្លាប់ នៅចម្ការទុរេនទី ២ ដែរ[2943]។

720. ប្រធានសហករណ៍ (ស្រី) ក្បែរៗនោះ បានប្រកាសក្នុងពេលប្រជុំថា " ២ ឬ ៣ គ្រួសារនេះត្រូវបានចាប់ខ្លួន គឺត្រូវបានយកទៅសម្លាប់នៅចម្ការទុរេនហើយ" ដើម្បីបំភិតបំភ័យប្រជាជនកុំឱ្យធ្វើអ្វីឱ្យមាន "កំហុស"[2944]។ សាក្សីម្នាក់បានឮប្រធានសហករណ៍បបុស[2945] និយាយថា អ្នកដែលគេចាប់

---

យោធាខ្មែរក្រហម គឺជាប្រធានយោធាខ្មែរក្រហមនៅតំបន់នេះ។ នៅកន្លែងនេះ មានសហករណ៍បបុស និងសហករណពូធឿង ហើយមនុស្សនៅក្នុងសហកនរ៍ទាំងពីរនេះ មានចំនួនរាប់ពាន់នាក់ រួមទាំងគ្រួសារយោធាផង"]។ ឯកសារ D114/2 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.10 ["ពួកប្រជាជនមូលដ្ឋាននៅកន្លែងនេះ គេដឹងទាំងអស់គ្នាថា កន្លែងសម្លាប់មនុស្សមានពីរកន្លែង គឺមួយបនៅចម្ការធូរេនអ៊ឹងក្រពុំផ្កា និងមួយនៅចម្ការធូរេននៅទឹកសាប"]។ ឯកសារ D114/25 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដាវ ឆ.33 ["ខ្ញុំឮអំពីកន្លែងសម្លាប់នៅជិតរាម និងជិតចំណោទរាម ហើយនិងកន្លែងផ្សេងទៀតដែលគេសម្លាប់មនុស្ស កន្លែងទាំងនេះមិនសម្លាប់តែខ្មែរទេ គឺសម្លាប់បរទេសដែរ"]។

2941 ឯកសារ D114/2 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.10 ["សម្រាប់អ្នកដែលត្រូវបានខ្មែរក្រហមទៅសម្លាប់នៅពេលនោះ អ្នកណាក៏ដឹងដែរថា មុននឹងយកទៅសម្លាប់ គេបានដោះខាអាវចេញអស់ពួកប្រជាជនមូលដ្ឋាននៅកន្លែងនេះ គេដឹងទាំងអស់គ្នាថា កន្លែងសម្លាប់មនុស្សមានពីរកន្លែង គឺមួយបនៅចម្ការធូរេនអ៊ឹងក្រពុំផ្កា និងមួយនៅចម្ការធូរេននៅទឹកសាប"]។

2942 ឯកសារ D114/2 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.10 ["សូម្បីតែពួកទាហាន លន់ នល់ ដែលបានចុះចាញ់ពេលរបបខ្មែរក្រហមឡើងកាន់អំណាច ក៏ត្រូវបានខ្មែរក្រហមនាំយកទៅសម្លាប់នៅចម្ការធូរេនទាំងពីរនេះដែរ"]។

2943 ឯកសារ D114/2 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.20 ["ចុងភៅទាំងនោះបាននិយាយថា អ្នកទោសដែលចាប់បាន ហើយចូលតាមផែកំពង់សោម គឺត្រូវបានបញ្ជូនទៅចម្ការធូរេន អ៊ឹងក្រពុំផ្កា។ សម្រាប់អ្នកទោសដែលចាប់បាន ហើយចូលតាមរាម គឺត្រូវបញ្ជូនទៅសម្លាប់នៅចម្ការធូរេននៅទឹកសាប"]។

2944 ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែត ឆ.3។

2945 ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែត ឆ.10, 13 ["ប្រធានសហករណ៍បបុសឈ្មោះ សមមិត្តរី [...] ឆ.13៖ សមមិត្ត រី ធ្វើជាប្រធានសហករណ៍បបុសចាប់តាំងពីឆ្នាំ ១៩៧៥ របស់ដល់ ១៩៧៩។ គាត់កាចណាស់"]
។

ពីសហករណ៍បបុស ត្រូវបញ្ជូនទៅទឹកសាប ឯអ្នកដែលគេចាប់ពីសហករណ៍ពូធឿង ត្រូវបញ្ជូនទៅចម្ការទុរេនទី ២[2946] និង សេអ៊ី[2947]។

721. ជនរងគ្រោះមកពីសហករណ៍ក្បែរៗនោះ ត្រូវគេនាំយកទៅចម្ការទុរេនទី ២ ដោយសារបានប្រព្រឹត្ត បទល្មើសផ្សេងៗ ដូចជា លួចជីកដំឡូងហូប[2948] ជាដើម។ ក្រោយពីបានសម្លាប់នៅចម្ការទុរេនរួច កម្មាភិបាលបានយកខោអាវរបស់ជនរងគ្រោះទៅចែកឲ្យអ្នកភូមិ[2949]។ ពេលកម្មាភិបាលនាំជនរងគ្រោះទៅចម្ការទុរេនទី ២ "គេយកទៅទាំងគ្រួសារៗ រួមទាំង ឪពុកម្ដាយ និងកូនៗ"[2950]។

2946 ឯកសារ D54/90 កំណត់ហេតុស្ដាប់ចម្លើយ កុយ ណែត ឆ.17-18 ["គាត់បាននិយាយថា បើមានមនុស្សណាលួចអង្ករ ដំឡូង និងម្ហូបអាហារ គាត់នឹងរាយការណ៍ឲ្យចាប់ខ្លួនអ្នកនោះ។ គាត់និយាយថា ប្រសិនបើមនុស្សដែលចាប់ខ្លួនពីសហករណ៍បបុសនឹងត្រូវយកទៅចម្ការធូរេននៅទឹកសាប។ ហើយប្រសិនបើប្រជាជនសហករណ៍ពូធឿង និងសហករណ៍ផ្សេងទៀត គេយកទៅចម្ការធូរេននៅអូរត្រាវ និងសេអ៊ី។ ដោយអ៊ីចឹងហើយ ខ្ញុំជឿថា គ្រួសារប្អូនថ្លៃរបស់ខ្ញុំ ដែលចាប់ពីសហករណ៍បបុសហ្នឹង គឺគេយកទៅសម្លាប់ទឹកសាប។ ប្អូនបង្កើតរបស់ខ្ញុំត្រូវបានចាប់ខ្លួនពីសហករណ៍ពូធឿង ហើយយកទៅសម្លាប់នៅកន្លែងសេអ៊ី។ សៈ តើចម្ការធូរេននៅអូរត្រាវ គឺជាកន្លែងដែលលោកបានគូសសម្គាល់នៅលើផែនទី ដែលនៅជិតព្រលានយន្តហោះកងកេងហ្នឹង ឬយ៉ាងណា? ឆ.18៖ បាទ"]។

2947 ឯកសារ D54/90 កំណត់ហេតុស្ដាប់ចម្លើយ កុយ ណែត ឆ.17 ["គាត់បាននិយាយថា បើមានមនុស្សណាលួចអង្ករ ដំឡូង និងម្ហូបអាហារ គាត់នឹងរាយការណ៍ឲ្យចាប់ខ្លួនអ្នកនោះ។ គាត់និយាយថា ប្រសិនបើមនុស្សដែលចាប់ខ្លួនពីសហករណ៍បបុសនឹងត្រូវយកទៅចម្ការធូរេននៅទឹកសាប។ ហើយប្រសិនបើប្រជាជនសហករណ៍ពូធឿង និងសហករណ៍ផ្សេងទៀត គេយកទៅចម្ការធូរេននៅអូរត្រាវ និងសេអ៊ី"]។

2948 ឯកសារ D54/90 កំណត់ហេតុស្ដាប់ចម្លើយ កុយ ណែត ឆ.5 ["បាទ ប្រជាជន គឺមានការភ័យខ្លាចយ៉ាងខ្លាំង ប៉ុន្តែប្រជាជនខ្លះនៅតែប្រព្រឹត្តកំហុស យើងត្រូវបានគេចាប់ខ្លួន ដោយនាំយកទៅសម្លាប់។ ដោយសារពេលណាប្រជាជនឃ្លាន គឺពួកគេជីកដំឡូងហូប ទោះបីជាដំឡូងទាំងនោះ គេដាំដោយខ្លួនឯងនៅខាងមុខផ្ទះខ្លួនក៏ដោយ បើសិនជាគេជីកដំឡូងនោះ ហូបដោយគ្មានការអនុញ្ញាតពីខ្មែរក្រហម ពួកគេនឹងត្រូវចាប់ខ្លួន យកទៅសម្លាប់"]។

2949 ឯកសារ D54/90 កំណត់ហេតុស្ដាប់ចម្លើយ កុយ ណែត ឆ.3 ["បន្ទាប់ពីការចាប់មនុស្សយកទៅសម្លាប់ម្ដងៗ គឺនៅថ្ងៃបន្ទាប់មក ខ្មែរក្រហមបាននាំយកសម្លៀកបំពាក់របស់ជនរងគ្រោះទាំងនោះ ទៅចែកឲ្យអ្នកស្រុកភូមិវិញ"]។

2950 ឯកសារ D114/2 កំណត់ហេតុស្ដាប់ចម្លើយ ឡាក់ សាផាន ឆ.3 ["សៈ លោកនិយាយថា លោកបានឃើញឆ្អឹង ខោអាវមនុស្សប្រុសស្រីនៅចម្ការធូរេនអ៊ីង ក្រពុំផ្កា តើនៅពេលនោះ លោកសង្កេតឃើញមានឆ្អឹងកូនក្មេងដែរឬទេ? ឆ.3៖ ខ្ញុំមិនបានយកចិត្តទុកដាក់អំពីរឿងនេះទេ ពីព្រោះនៅពេលនោះ ខ្ញុំមានអារម្មណ៍រន្ធត់ ដោយសារខ្ញុំបានឃើញឆ្អឹង ឆ្អឹងលលាដ៏ក្បាល និងខោអាវជាច្រើននៅរាយប៉ាយនៅទីនោះ។ ខ្ញុំសូមបន្ថែមថា ទោះបីជាខ្ញុំមិនបានចាប់ភ្លឹកពីរឿងឆ្អឹងកូនក្មេងនៅកន្លែងនោះក្ដី ក៏ខ្ញុំសូមបញ្ជាក់ថា កាលពីជំនាន់នោះ គេចាប់មនុស្សយកទៅ គឺគេនាំយកទៅទាំងគ្រួសារ មាន

722. សាក្សី អ៊ុង ចន្ធា ដែលរស់នៅសហករណ៍មួយ ក្នុងភូមិព្រៃនប់ បានផ្តល់សក្ខីកម្មថា មានពេលមួយនោះ សមាជិកជាច្រើននៃគ្រួសាររបស់គាត់ ត្រូវគេចាប់ ដោយកម្មាភិបាលម្នាក់មកចាប់ "ចងស្លាបសេកពួកគេទាំងអស់ ហើយចាប់បញ្ជូនដាក់ឡាន យកទៅ"[2951]។ លើសពីនេះទៅទៀត គាត់បានឃើញគេចាប់មនុស្ស បីដងផ្សេងទៀត[2952]។ "អ្នកទាំងនោះត្រូវគេចងស្លាបសេកទាំងអស់ [...]។ ភាគច្រើនគេចាប់អ្នក ១៧ មេសា ដែលធ្វើស្រែ។ [...] គឺមិនដែលមាននរណារួចពីទីនោះទេ"[2953]។ គាត់បានឮពីកម្មាភិបាលនិយាយថា "គេនាំមនុស្សទាំងនោះទៅចម្ការទុរេននៅព្រៃនប់ [...]។ គ្មាននរណាម្នាក់អាចគេចផុតពីកន្លែងនោះទេ"[2954]។

723. សាក្សីបានរៀបរាប់ថា ពួកគាត់បានឃើញរណ្តៅ និងផ្នូរកប់សាកសព នៅចម្ការទុរេន ២ ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ[2955]។ សាក្សីម្នាក់ ដែលបានទៅមើលចម្ការទុរេន ២ ក្រោយឆ្នាំ ១៩៧៩ បាននិយាយថា គាត់បានដើរកាត់ "រណ្តៅសាកសព យើងឃើញឆ្អឹង និងលលាដ៍ក្បាល នៅពាសពេញលើផ្ទៃដី នៅកន្លែងនោះ ដោយមានក្លិនស្អុយ"[2956]។ សាក្សីម្នាក់ទៀត ដែលបានទៅមើលចម្ការទុរេន ២ ក្នុងខែ ឧសភា ឆ្នាំ ១៩៧៩ បានឃើញ "ឆ្អឹង លលាដ៍ក្បាល និងខោអាវនៅរាយប៉ាយពេញដី"[2957]។ មានរណ្តៅនៅជុំវិញដើមទុរេននីមួយៗ ហើយមានសាកសពមួយ

---

ឪពុកម្តាយ និងកូនៗ។ នៅពេលនោះ ខ្ញុំឃើញថា នៅពេលណាដែលខ្មែរក្រហមនាំយកមនុស្សចេញទៅ គឺគេបណ្តើរដោយឪពុកម្តាយកាន់ដៃកូនតូចៗរបស់គេទៅជាមួយ"]។

2951 ឯកសារ D114/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ចន្ធា ឆ.7។.

2952 ឯកសារ D114/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ចន្ធា ឆ.7, 17 ["នៅពេលនោះ ក៏មានអ្នកផ្សេងដទៃទៀតនៅក្នុងស្រុក និងភូមិជាមួយគ្នា ក៏ត្រូវបានគេចាប់ចង់ដូចគ្នាដែរ [...] ឆ.17៖ ខ្ញុំបានឃើញចំនួន ៣ ដង។ បើតាមខ្ញុំចាំ គឺជិតបែកសម័យខ្មែរក្រហមហើយ"]

2953 ឯកសារ D114/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ចន្ធា ឆ.9, 18-19, 24។

2954 ឯកសារ D114/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ចន្ធា ឆ.21។

2955 ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែត ឆ.20 ["នៅក្នុងឆ្នាំ ១៩៧៧ [...] ពេលដែលខ្ញុំទៅដល់ចម្ការធូរេននៅត្រាវ ដូចដែលខ្ញុំបានគូសនៅលើផែនទី [...] យើងដើរកាត់កន្លែងរណ្តៅសាកសពឮ"]។

2956 ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែត ឆ.20 ["យើងដើរកាត់កន្លែងរណ្តៅសាកសព យើងឃើញឆ្អឹង និងលលាដ៏ក្បាលនៅពាសពេញលើផ្ទៃដីនៅកន្លែងនោះ ដោយមានក្លិនស្អុយ"]។

2957 ឯកសារ D114/2 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.2-3 ["ចំណែកឯនៅខាងម្ខាងភ្នំឯណោះ គឺជាចម្ការធូរេនអ៊ុងពុំផ្ការ។ ចម្រាកធូរេននៅម្ខាងភ្នំនោះហើយ ដែលខ្ញុំបានឃើញឆ្អឹង ឆ្អឹងលលាដ៏ក្បាល និងខោអាវនៅរាយប៉ាយពេញកន្លែងនោះ [...] ឆ.3៖ ខ្ញុំបានឃើញឆ្អឹង ឆ្អឹងលលាដ៏ក្បាល និងខោអាវជាច្រើននៅរាប៉ាយនៅទីនោះ"]។

ឬច្រើន នៅក្នុងរណ្តៅនីមួយៗ[2958]។ សាកសពខ្លះមានឆ្អឹងដៃជាប់ចំណងខ្សែនីឡុង[2959]។ សាក្សី កុយ ណែន បានឃើញខោអាវខ្មៅៗ និងពណ៌ចម្រុះ[2960] ហើយគាត់គិតថា ខោអាវចម្រុះពណ៌ជារបស់ប្រជាជនមូលដ្ឋាននៅតាមសហករណ៍[2961]។ កន្លែងដែលមានរណ្តៅ និងឆ្អឹង មិនត្រូវបានប្រើប្រាស់ជាកន្លែងបញ្ចុះសពនោះទេ មុនរបបកម្ពុជាប្រជាធិបតេយ្យ ហើយក៏មិនមែនជាកន្លែងប្រយុទ្ធគ្នាជាមួយវៀតណាមដែរ ដែលនេះចង្អុលបង្ហាញថា ឆ្អឹងទាំងនេះជារបស់ជនរងគ្រោះនៃរបបខ្មែរក្រហម[2962]។

---

2958 ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែត ឆ.21-22 ["សៈ តើរណ្តៅដែលលោកឃើញនៅចម្ការធូរេនអូរត្រាវ ជារណ្តៅកប់សាកសពរួម ឬក៏រណ្តៅកប់សាកសពម្នាក់ៗ ឬក៏រណ្តៅកប់សាកសពចម្រុះ? ឆ.21៖ ដើមធូរេនមួយៗមាន រណ្តៅនៅជុំវិញ ដោយរណ្តៅមួយៗ មានសាកសពម្នាក់ ឬច្រើនជាងម្នាក់ សៈ តើលោកអាចប៉ាន់ស្មានរណ្តៅសាកសពនៅកន្លែងនោះថា មានចំនួនប៉ុន្មានទេ? ឆ.22៖ ខ្ញុំអាចមើលឃើញរណ្តៅនៅគ្រប់កន្លែង។ នៅទីនោះមានដីទំហំ ទទឹង ១០០ ម៉ែត្រ និងបណ្តោយប្រហែល ២០០ ម៉ែត្រ ដោយមានដើមធូរេន ដើមក្រូច និងដើមចំប៉ាកដក់។ កន្លែងនោះម្ខាងជាប់ភ្នំ និងម្ខាងទៀតជាប់អូរ"]។ ឯកសារ D114/2 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.6 ["ខ្ញុំទៅទីនោះម្តងៗ ប្រហែលជាងកន្លះថ្ងៃ ពីព្រោះខ្ញុំដើរពាសពេញកន្លែងហ្នឹង ដើម្បីបេះផ្លែខ្នុរ និងធូរេនមកហូប។ នៅក្រោមដើមខ្នុរ និងដើមធូរេននីមួយៗ ឃើញមាន រណ្តៅខ្មោច។ ខ្ញុំមិនមានគំរោងទៅជីកគាស់រណ្តៅខ្មោចធ្វើអ្វីទេ គឺខ្ញុំទៅបេះប្លែឈើ"]។

2959 ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែត ឆ.23 ["ខ្ញុំបានឃើញសាកសពខ្លះ មានឆ្អឹងដៃជាប់ចំណងខ្សែអង្រឹងលីលុង និងឃើញសក់ប្រុស ហើយនិងសក់ស្រីវែងៗ"]។ ឯកសារ D114/2 កំណត់ហេតុស្តាប់ចម្លើយ ឡាក់ សាផាន ឆ.8 ["ខ្ញុំបានឃើញខ្សែចំណងនៅរាយប៉ាយពេញកន្លែងនោះ ប៉ុន្តែវាមិននៅជាប់នឹងឆ្អឹងទៀតទេ ពីព្រោះឆ្អឹងទាំងនោះត្រូវបានដាច់ដោចនៅរាយប៉ាយលើដី"]។

2960 ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែត ឆ.27 ["សៈ តើសម្លៀកបំពាក់ដែលលោកឃើញហ្នឹងជាសម្លៀកបំពាក់បែបណា ជារបស់ស៊ីវិល ឬក៏ទាហាន ឬក៏ចម្រុះគ្នា? ឆ.27៖ បើតាមខ្ញុំពិនិត្យឃើញ គឺមានឃើញខោអាវខ្មៅៗ និងពណ៌ចម្រុះពណ៌។ ខ្ញុំឃើញមានសក់វែង ដែលជាសក់របស់សាកសពស្ត្រី"]។

2961 ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែត ឆ.28 ["សៈ តើតាមដែលលោកយល់ តើសម្លៀកបំពាក់ចម្រុះទាំងនោះ វាជាសម្លៀកបំពាក់អ្នកណា ដោយសារនៅជំនាន់នោះ ខ្មែរក្រហមឲ្យប្រើតែខោអាវខ្មៅៗ? ឆ.28៖ ខ្ញុំគិតថា សម្លៀក បំពាក់ស៊ីវិលចម្រុះពណ៌ទាំងនោះហ្នឹង ជារបស់ប្រជាជនមូលដ្ឋានស៊ីវិលធម្មតាតាមសហករណ៍"]
។

2962 ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែត ឆ.32-33 ["មិនមានការវ៉ៃគ្នារវាងវៀតណាម និងយោធាខ្មែរក្រហមនៅកន្លែងនោះទេ។ [...] ឆ.33៖ ខ្ញុំមិនដែលឮថា កន្លែងនោះជាកន្លែងកប់សាកសពពីមុនមកទេ"]។

### ត) ទីតាំងសម្លាប់មនុស្ស សេអ៊ី

724. សាក្សី ប៉ាក សុខ ចាំបានថា នៅឆ្នាំ ១៩៧៦ កម្មាភិបាលកងពល ១៦៤ "បានបញ្ជូនប្រជាជន ១៧ មេសា ទាំងអស់ ពីភូមិស្នាច់ដែង ភូមិគគីរ និងចំណោតរាម ហៅបិតត្រាង យកទៅសម្លាប់នៅរាម ចំណោត"[2963]។ គាត់បានពន្យល់ថា គាត់ត្រូវគេរំសាយ រួចបញ្ជូនទៅធ្វើស្រែជាមួយជនស៊ីវិល នៅតំបន់នោះ[2964]។ គាត់បានកត់សម្គាល់ឃើញថា អ្នកធ្វើការជាមួយគាត់ជាច្រើននាក់បានចាប់ផ្តើមបាត់ខ្លួន ហើយពេលគាត់សួរកម្មាភិបាលមួយចំនួនថា តើមានរឿងអ្វីកើតឡើងចំពោះអ្នកទាំងនោះ គេប្រាប់គាត់ថា "អ្នក ១៧ មេសា ទាំងនោះ ត្រូវគេដឹកតាមឡាន ២-៣ គ្រឿង យកទៅសម្លាប់នៅសេអ៊ី"[2965]។ កម្មាភិបាលបានប្រាប់គាត់ថាមនុស្សត្រូវគេដឹកបីឡាន យកទៅសម្លាប់នៅ សេអ៊ី[2966]។ ភស្តុតាងផ្សេងៗទៀតបង្ហាញយ៉ាងស៊ីចង្វាក់គ្នាថា ប្រជាជន ១៧ មេសា ត្រូវគេនាំយកទៅសម្លាប់

---

2963 ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.26។

2964 ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.28 ["ខ្ញុំដឹងរឿងនេះ នៅពេលដែលខ្ញុំត្រូវបានគេចាត់ទុកចូលទៅក្នុងកងសមាសភាគមិនល្អ។ ខ្ញុំត្រូវបានគេចាត់ឱ្យទៅធ្វើការនៅស្រែក្នុងតំបន់រាមនេះ ដូចដែលខ្ញុំបានជម្រាបពីខាងដើម។ ខ្ញុំត្រូវបានគេដាក់ឱ្យទៅធ្វើការជាមួយនឹងប្រជាជនមូលដ្ឋាននៅក្នុងតំបន់នោះ"]។

2965 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ម៉ោង 10.49.49-10.51.34។ សូមមើលផងដែរ ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.28 ["យោធាទាំងនោះបានប្រាប់ខ្ញុំថា ប្រជាជន ១៧ មេសា គឺត្រូវបានសម្លាប់អស់ហើយ"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៥ ម៉ោង 10.48.52-10.51.34 ["ប្រជាជននេះ ដោយសារដែលខ្ញុំដឹង ព្រោះខ្ញុំគេឱ្យធ្វើស្រែជាមួយប្រជាជន ១៧ មេសា តែខ្ញុំធ្វើស្រែចម្ការ ធ្វើស្រែជាមួយប្រជាជន ១៧ មេសា នុ៎ង ថ្ងៃមួយ ថ្ងៃក្រោយមក ខ្ញុំចេះតែឃើញបាត់អស់ទៅៗ ខ្ញុំមានការសង្ស័យ មិនឃើញប្រជាជននោះបានមករួមធ្វើការជាមួយគ្នាទៀត"]។

2966 ឯកសារ D54/26 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.29 ["យោងទៅតាមយោធាដែលបានប្រាប់ខ្ញុំ គឺមានមនុស្សប្រហែលបីឡានទ្រុង ដែលត្រូវបានយកទៅសម្លាប់នៅទីនោះ"]។

នៅ សេអ៊ី[2967]។ ប៉ាក សុខ ក៏បានផ្តល់សក្ខីកម្មផងដែរថា កម្មាភិបាលភូមិភាគបូព៌ាត្រូវគេសម្លាប់នៅជិតចំណោតរាម ក្រោយពីគេចាប់ ឌឹម[2968]។

725. ប្រធានសហករណ៍នារីក្បែរខាងម្នាក់បានប្រាប់សាក្សីម្នាក់ថា មនុស្សដែលគេចាប់ពីសហករណ៍ភូមិ ពូធឿង ត្រូវនាំយកទៅសម្លាប់នៅ សេអ៊ី ទាំងអស់[2969] ហើយសាក្សីជាច្រើនបានបញ្ជាក់ថា សាច់ញាតិរបស់ពួកគេត្រូវបានចាប់ខ្លួន ពីសហករណ៍ពូធឿង ឬសហករណ៍ក្បែរៗនោះ រួចនាំយកទៅសម្លាប់នៅ សេអ៊ី។ ប្អូនបង្កើតរបស់សាក្សី កុយ ណែន ត្រូវបានចាប់ខ្លួនពីសហករណ៍ពូធឿង ហើយយកទៅសម្លាប់នៅ សេអ៊ី[2970]។ ដូចគ្នានេះដែរ សាច់ញាតិរបស់សាក្សី សៅ ម៉ែន ត្រូវគេយកពីការដ្ឋានជិតទំនប់បិតត្រាង រួចនាំយកទៅ សេអ៊ី[2971]។ "អ្នកដែលគេនាំយកទៅទីនោះ [...] មិនដែលត្រឡប់មកវិញទេ"[2972]។

---

[2967] ឯកសារ D114/4 កំណត់ហេតុស្តាប់ចម្លើយ មុំ ម៉េង ឆ.15 ["មុនពេលខ្ញុំទៅកន្លែងហ្នឹង ក្នុងឆ្នាំ ១៩៨៣ ឬ ១៩៨៤ ខ្ញុំបានឮពីប្រជាជនមូលដ្ឋាននិយាយថា នៅកន្លែងផ្ទាំងថ្មធំ ផ្លូវកោងផ្លូវជាតិលេខ ៤ នេះ គឺមានអ្នកដែលគេជម្លៀសមកពីកំពង់សោម ត្រូវបានគេយកទៅសម្លាប់នៅកន្លែងនោះ ប៉ុន្តែមិនដែលមានអ្នកណាម្នាក់ហ៊ានចូលទៅមើលឲ្យឃើញច្បាស់ថា កន្លែងណាពិតប្រាកដទេ ដោយសារទីនោះ គឺគ្រប់ដណ្តប់ទៅដោយព្រៃ"]។

[2968] ឯកសារ D54/24.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប៉ាក សុខ KH ERN 00955513 ["ដល់ហើយចាប់គាត់ទៅ ខ្សែស្រឡាយ ដែលគាត់អោបទុកហ្នឹង យកមកមួយកងពលទៅ [...] យកមកសម្លាប់ កន្លែងហ្នឹងឡើងចំណោតរាម វៃចោលហើយយកអាត្រាស់មកឈូស"]។

[2969] ឯកសារ D54/89 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែត ឆ.9 ["នៅពេលនោះ អ្នកភូមិទាំងអស់ដឹងតាមគ្នាថា នៅពេលដែលមនុស្សត្រូវបានចាប់ខ្លួនពីសហករណ៍ភូមិ ពូធឿង គេនឹងយកទៅសម្លាប់នៅកន្លែង សេអ៊ី។ ប៉ុន្តែប្រសិនបើគេចាប់មនុស្សពីសហករណ៍ភូមិបបុស គេនឹងយកទៅសម្លាប់នៅទឹកសាប"]។ ឯកសារ D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉េន ឆ.20 ["ស៖ តើលោកស្រីដែលធ្លាប់គេយកមនុស្សចេញពីការដ្ឋានបិតត្រាំងដែរទេ A៖ ឃើញ គឺយកទៅទាំងថ្ងៃតែម្តង គេហៅយកទៅសេអ៊ីហ្នឹង"]។

[2970] ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែត ឆ.17 ["ប្អូនបង្កើតរបស់ខ្ញុំត្រូវបានចាប់ខ្លួនពីសហករណ៍ពូធឿង ហើយយកទៅសម្លាប់នៅកន្លែងសេអ៊ី"]។

[2971] ឯកសារ D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉េន ឆ.20 ["ស៖ តើលោកស្រីដែលធ្លាប់ឃើញគេយកមនុស្សចេញពីការដ្ឋានបិតត្រាំងដែរឬទេ? A៖ ឃើញ គឺយកទៅទាំងថ្ងៃតែម្តង គេថាយកទៅសេអ៊ីហ្នឹង។ បងប្អូនខ្ញុំច្រើនណាស់"]។

[2972] ឯកសារ D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉េន ឆ.21-22 ["ស៖ តើលោកស្រីដឹងថា ទីតាំងសេអី នៅត្រង់ណាដែរទេ? ឆ.21៖ សេអី យើងលើនេះ លើរោងចក្រនេះ។ យកទៅដឹងតែបាត់ហើយ ស៖ តើអ្នកណាគេអ្នកមកយក

726. ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំ អ្នកស្រុកជាច្រើន ដែលដឹងអំពីការសម្លាប់នៅសេអ៊ី បានទៅជីកកកាយរកមាស នៅកន្លែងនោះ[2973]។ ក្នុងពេលជីកគាស់នោះ ពួកគេរកឃើញក្បាលខ្មោច និងរណ្តៅសាកសពជាច្រើន[2974] ហើយក្បាលខ្មោចទាំងនោះត្រូវគេមើលឃើញពីផ្លូវ និង "នៅពេញដីទាំងអស់"[2975]។ សាក្សីម្នាក់ចាំបានថា គាត់បានទៅមើលកន្លែងនោះ នៅឆ្នាំ ១៩៧៩ ហើយបានឃើញរណ្តៅសាកសពចំនួនពីរ រណ្តៅទីមួយមានទំហំប្រហែល ១៥ ម៉ែត្រការ៉េ ហើយរណ្តៅទីពីរមានទំហំប្រហែល ១០ ម៉ែត្រការ៉េ[2976]។ សាក្សីម្នាក់ទៀតចាំបានថា នៅឆ្នាំ ១៩៨៣ និងឆ្នាំ ១៩៨៤ គាត់បានឃើញរណ្តៅធំពីរ ជម្រៅត្រឹមភ្លៅ មានសាកសពពី ៨ ទៅ ១០[2977]។ សាក្សី

---

អ្នកទាំងនោះទៅ ឆ.22៖ ខ្ញុំមិនស្គាល់ទេ។ អង្គាល់នោះ យកទៅច្រើនណាស់ គេមិនឱ្យយើងដឹងទេ។ គេថាយកទៅធ្វើការ តែមិនឃើញមកវិញទេ"]។

2973 ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ សួន ឈុំ ឆ.60 ["ដល់ក្រោយឆ្នាំ ៧៩ ហ្នឹង ឃើញគេទៅគាស់ខ្មោចយកមាស"]។ ឯកសារ D54/119 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.4 ["ខ្ញុំឮពីរឿងនេះ ដោយសារតែប្រជាជនដែលទៅជីករកមាស ក្នុងទីកន្លែងមួយដែលស្ថិតនៅលើបន្ទាយសេអ៊ីនេះបន្តិច គឺគេជីករកមាស និងរបស់មានតម្លៃផ្សេងៗទៀត ពីរណ្តៅខ្មោចទាំងនោះ។"]។ ឯកសារ D54/120 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.12 ["សៈ ក្នុងនាមលោកជាជំទប់ទី ១ នៅឃុំបិតត្រាំង តើលោកធ្លាប់ឮអំពីរណ្តៅសាកសព ឬក៏ការកាយរណ្តៅសាកសពនៅម្តុំអតីតចម្ការធូរេនដែរឬទេ? ឆ.12៖ ទេ ខ្ញុំមិនដែលបានឮអំពីការជីករណ្តៅសាកសពអ្វីទេ នៅចម្ការធូរេន តែខ្ញុំបានឮអំពីការជីករណ្តៅសាសព ដើម្បីរកមាសនៅបន្ទាយសេអ៊ី"]។ ឯកសារ D54/22 របាយការណ៍នៃសកម្មភាពស៊ើបអង្កេត EN ERN 00947623 ["លោក មុំ ម៉េង បានជីកគាស់កាយរណ្តៅសពហើយឃើញអ្នកភូមិដទៃទៀត ជីកគាស់កាយរណ្តៅសពរករបស់របរមានតម្លៃ និងមាស"]។

2974 ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ សួន ឈុំ ឆ.60 ["គាស់ឃើញ ដាក់ក្បាលខ្មោចនៅលើដី ពេញដីទាំងអស់។ យើងគ្រាន់តែមើលពីថ្នល់ទៅឃើញ ហើយខ្ញុំអត់បានចុះទៅដល់ទេ។ កន្លែងថ្នល់កែងហ្នឹង យើងមើលទៅឃើញហើយ។ តែអត់ដឹងគេយកពីខាងណាយកទៅសម្លាប់កន្លែងហ្នឹងទេ"]។

2975 ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ សួន ឈុំ ឆ.60-61 ["យើងគ្រាន់តែមើលពីថ្នល់ទៅឃើញហើយ ហើយខ្ញុំអត់បានចុះទៅដល់ទេ [...] ឆ.61៖ ឃើញកន្លែងកាច់ជ្រុងហ្នឹង ឃើញហើយ"]។

2976 ឯកសារ D54/91 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែត ឆ.7 ["សៈ សូមលោកពន្យល់ប្រាប់យើងដោយសង្ខេប អំពីអ្វីដែលលោកដឹងពាក់ព័ន្ធនឹងរណ្តៅសាកសពនៅកន្លែងសេអ៊ី? ឆ.7៖ នៅថ្ងៃមួយ នៅដើមឆ្នាំ១៩៧៩ ខ្ញុំបានទៅកន្លែងនោះជាមួយនឹងកងសេនាជនរបស់ខ្ញុំប្អូនប្រាំនាក់។ នៅពេលដែលយើងទៅដល់កន្លែងនោះ ខ្ញុំឃើញមានរណ្តៅចំនួនពីរ រណ្តៅមួយមានទំហំប្រហែល ១៥ ម៉ែត្របួនជ្រុង និងរណ្តៅមួយទៀតមានទំហំប្រហែល ១០ ម៉ែត្របួនជ្រុង"]។

2977 ឯកសារ D114/4 កំណត់ហេតុស្តាប់ចម្លើយ មុំ ម៉េង ឆ.18 ["សៈ នៅពេលដែលលោកទៅដល់ទីនោះ (សេអ៊ី) តើលោកបានឃើញទិដ្ឋភាពបែបនេះ ដូចដែលលោកធ្លាប់បានឮដែរឬទេ? [...] ឆ.18៖ បាទ ខ្ញុំឃើញទិដ្ឋភាពអីចឹងមែនពេលដែលខ្ញុំទៅដល់ទីនោះ។ ខ្ញុំបានឃើញអ្វីដូចដែលខ្ញុំបានឮ។ ខ្ញុំបានឃើញរណ្តៅធំៗមានសាកសពប្រហែល ៨ ទៅ

ដដែលនេះបានបញ្ជាក់ថាទីកន្លែងនោះក៏មានរណ្ដៅតូចៗប្រហែល ១០០ ផងដែរ[2978]។ រណ្ដៅតូចៗនីមួយៗ មានសាកសពចន្លោះពី ១ ទៅ ៥[2979] ហើយមានលលាដ៍ក្បាល ឆ្អឹង សម្លៀកបំពាក់ស៊ីវិល និងឯកសណ្ឋានយោធា នៅរាយប៉ាយជុំវិញរណ្ដៅ[2980]។ ពេលសាក្សីទៅមើលទីតាំងនោះ នៅដើមឆ្នាំ ១៩៧៩ មានក្លិនស្អុយភាយចេញពីសាកសពរលួយ[2981]។

---

១០។ ខ្ញុំអាចដឹងបាន ដោយសារខ្ញុំឃើញចំនួនលលាដ៍ក្បាល។ រណ្ដៅទាំងនោះភាគច្រើន គឺមានជម្រៅត្រឹមភ្លៅ"]។ សូមមើលផងដែរ ឯកសារ D54/22 របាយការណ៍នៃសកម្មភាពស៊ើបអង្កេត KH ERN 01002680-81 ["គាត់ឃើញ និងដឹងពីអ្នកជីកគាស់កាយដទៃទៀតថា មានរណ្ដៅសពរួម ដោយរណ្ដៅនីមួយៗ មានសាកសពមនុស្សប្រហែល ១០ នាក់ ហើយរណ្ដៅតូចៗ មានសាកសពមនុស្សពីរនាក់ ទៅបីនាក់"]។

2978 ឯកសារ D114/4 កំណត់ហេតុស្ដាប់ចម្លើយ មុំ ម៉េង ឆ.19, 21 ["ស៖ នៅពេលដែលលោកបង្ហាញយើងពីទីកន្លែងនោះ កាលពីខែសីហា ឆ្នាំ ២០១៣ លោកបានបង្ហាញយើងពីទីកន្លែងរណ្ដៅដែលស្ថិតនៅខាងជើងផ្លូវជាតិលេខ ៤។ តើលោកអាចរៀបរាប់បន្ថែមអំពីទីកន្លែងនោះបានដែរឬទេ? ឆ.19៖ កន្លែងហ្នឹងហើយ គឺកន្លែងសេអ៊ី ដែលមានរណ្ដៅសាកសពប្រហែល ១០០ កាលពីពេលនោះ ប៉ុន្តែឥឡូវនេះ កន្លែងនោះក្លាយជាចម្ការដើមអាកាស្យាអស់ហើយ [...] ស៖ តើលោកអាចប៉ាន់ស្មានថា នៅក្នុងរណ្ដៅសាកសពប្រហែល ១០០ ដែលលោកបានឃើញហ្នឹង មានរណ្ដៅធំៗដូចដែលលោកបានចង្អុលប្រាប់យើងមានចំនួនប៉ុន្មានរណ្ដៅ? ឆ.21៖ ខ្ញុំនៅចាំបានថា មានរណ្ដៅធំៗតែពីរប៉ុណ្ណោះ។ រណ្ដៅដទៃទៀត គឺមានទំហំតូចៗជាងនេះ"]។ សូមមើលផងដែរ ឯកសារ D54/22 របាយការណ៍នៃសកម្មភាពស៊ើបអង្កេត KH ERN 01002681 ["លោក មុំ ម៉េង មានទំនុកចិត្ត និងបានដឹងច្បាស់ពីស្ថានភាពដីនៅទីនោះ"]។

2979 ឯកសារ D114/4 កំណត់ហេតុស្ដាប់ចម្លើយ មុំ ម៉េង ឆ.16-17 ["ស៖ សូមលោករៀបរាប់ទិដ្ឋភាពនៅកន្លែងសេអ៊ី នៅពេលដែលលោកទៅដល់ដំបូងនៅក្នុងឆ្នាំ ១៩៨៣ ឬ ១៩៨៤នោះ? ឆ.16៖ នៅពេលដែលខ្ញុំទៅដល់កន្លែងនោះលើកដំបូង ខ្ញុំឃើញខោអាវ និងឆ្អឹងនៅរាយប៉ាយលើដី។ បន្ទាប់មក ខ្ញុំដើរលើឆ្អឹង និងខោអាវនោះ ដើម្បីរកមើលគ្រឿងអលង្ការ ឬមាស ហើយក្រោយមក យើងដើររកមើលឃើញរណ្ដៅដែលមិនទាន់គាស់ផ្សេងៗទៀត ពេលនោះ យើងគាស់រណ្ដៅទាំងនោះ ដើម្បីរុករកក្រែងមានគ្រឿងអលង្ការ ឬមាសនៅសេសសល់។ រណ្ដៅមួយៗ ដែលខ្ញុំគាស់មានសាកសពទី ១ ដល់ ៥ សាកសព [...] ឆ.17៖ ខ្លួនខ្ញុំផ្ទាល់ បានជីករណ្ដៅចំនួនប្រហែល ៥ រណ្ដៅប៉ុណ្ណោះ ប៉ុន្តែខ្ញុំបានកាយតាមរណ្ដៅដែលគេបានជីក ហើយជាច្រើន រណ្ដៅ"]។

2980 ឯកសារ D114/4 កំណត់ហេតុស្ដាប់ចម្លើយ មុំ ម៉េង ឆ.16, 24 ["ស៖ សូមលោករៀបរាប់ទិដ្ឋភាពនៅកន្លែងសេអ៊ី នៅពេលដែលលោកទៅដល់ដំបូងនៅក្នុងឆ្នាំ ១៩៨៣ ឬ ១៩៨៤នោះ? ឆ.16៖ នៅពេលដែលខ្ញុំទៅដល់កន្លែងនោះលើកដំបូង ខ្ញុំឃើញខោអាវ និងឆ្អឹងនៅរាយប៉ាយលើដី។ បន្ទាប់មក ខ្ញុំដើរលើឆ្អឹង និងខោអាវនោះ ដើម្បីរកមើលគ្រឿងអលង្ការ ឬមាស ហើយក្រោយមក យើងដើររកមើលឃើញរណ្ដៅដែលមិនទាន់គាស់ផ្សេងៗទៀត ពេលនោះ យើងគាស់រណ្ដៅទាំងនោះ ដើម្បីរុករកក្រែងមានគ្រឿងអលង្ការ ឬមាសនៅសេសសល់។ រណ្ដៅមួយៗ ដែលខ្ញុំគាស់មានសាកសពទី ១ ដល់ ៥ សាកសព [...] ស៖ លោកបាននិយាយថា នៅពេលនោះ លោកមានឃើញខោអាវទាហាន និង

## អំពើអមនុស្សធម៌ផ្សេងៗទៀត (ការប្រព្រឹត្តិអមនុស្សធម៌)

727. ក្រៅពីការប្រព្រឹត្តិដាក់មនុស្សដូចជាទាសករ និងការកាប់សម្លាប់ដូចដែលបានពិពណ៌នាខាងលើ ប្រជាជនដែលរស់នៅ និងធ្វើការនៅតាមការដ្ឋានក្នុងតំបន់រាម ទទួលរងនូវការប្រព្រឹត្តិដ៏អាក្រក់ក្នុងទម្រង់ផ្សេងៗទៀត ដែលជាញឹកញាប់បណ្តាលឱ្យស្លាប់បាត់បង់ជីវិត។ "ប្រជាជនស្លាប់ជារៀងរាល់ថ្ងៃនៅក្នុងសហករណ៍"[2982]។ ចំពោះអ្នកដែលអាចនៅរស់វិញ ជីវិតរបស់ពួកគេពោរពេញដោយភាពវេទនា។ "វេទនាណាស់។ មនុស្សគ្រប់រូប សុទ្ធតែបានជួបប្រទះភាពវេទនា។ យើងត្រូវគេលត់ដំ។ យើងត្រូវតស៊ូយ៉ាងខ្លាំងបំផុត ដើម្បីឱ្យនៅរស់រានមានជីវិត"[2983]។ សាក្សីមួយរូបបានពិពណ៌នាដោយសង្ខេបអំពីស្ថានភាពដែលគាត់បានជួបប្រទះ ដូចខាងក្រោម៖

> ប្រជាជនឃ្លានអាហារ នឿយហត់ ឈឺ ស្គម និងស្លេកស្លាំង ដោយសារជំងឺគ្រុនចាញ់ និងជំងឺផ្សេងៗទៀត។ គេបង្ខំឱ្យប្រជាជនធ្វើការរហូតដល់ដើរលែងរួច ហើយពួកគេដេកនៅលើកន្ទេល។ ប្រជាជនដែលមានជំងឺដែលមិនអាចទៅធ្វើការបាន ត្រូវគេយកទៅសម្លាប់ចោល។ ពាក្យស្លោករបស់ពួកគេគឺ "ទុកមិនចំណេញ ដកចេញមិនខាត"[2984]។

728. សំណុំរឿងក្តី មានពោរពេញទៅដោយភ័ស្តុតាងស្តីពីកង្វះអាហារ ដែលបណ្តាលឱ្យមនុស្សស្លាប់ដោយអត់អាហារ។ កម្រមានរបបអាហារគ្រប់គ្រាន់ណាស់[2985]។ "ប្រជាជនមានតែស្បែកដណ្តប់

---

ស៊ីវិលនៅវាយប៉ាយ និងនៅតាមរណ្តៅសាកសព។ សូមលោករៀបរាប់ប្រាប់យើងបន្ថែមបានដែរឬទេ? ឆ.24៖ ខោអាវច្រើនជាខោអាវស៊ីវិល ដែលមានពណ៌ចម្រុះ ហើយឆ្អឹងមួយចំនួន គឺមានជាប់ខោអាវ"]។

2981 ឯកសារ D54/91 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែត ឆ.7 ["ខាងលើរណ្តៅទាំងពីរនោះ មានស្មាមប្រេះដីឡើងលើដោយសារសាកសពនៅក្នុងរណ្តៅហើម។ យើងមិនអាចនៅទីនោះបានយូរទេ ដោយសារយើងទ្រាំនឹងក្លិនស្អុយនោះមិនបាន"]។

2982 ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.121។

2983 ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ន សុត ឆ.67។

2984 ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.117។ សូមមើលផងដែរ ឯកសារ D114/96 កំណត់ហេតុស្តាប់ចម្លើយ ចេង ឡុង ឆ.18 ["ការរស់នៅមានការលំបាកមែនទែន"]។

2985 ឯកសារ D59/1/4.25 កិច្ចសម្ភាសន៍របស់ជម្លួមមណ្ឌលឯកសារកម្ពុជាជាមួយ ឡុង លី KH ERN 00930800 ["ជីវភាពវាខ្វះខាត វាអត់បានបាយទេ បបរហូបទៅ"]។ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ. 25, 37 ["គ្រួសារខ្ញុំមាន ៤ នាក់ គេឱ្យអង្ករមួយកំប៉ុងក្នុ ១ ថ្ងៃ ដូច្នេះខ្ញុំហូបមិនគ្រប់គ្រាន់ទេ [...] ឆ.37៖ យើងហូបបាយមិនឆ្អែត ទឹកក៏មិនហូបគ្រប់គ្រាន់ដែរ"]។ ឯកសារ D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉េន ឆ.8, 14 ["គេឱ្យហុបបបរ [...] ស៖ តើគេឱ្យហូបគ្រប់គ្រាន់ទេ? ឆ.14៖ បើមិនគ្រប់គ្រាន់ ក៏ត្រូវតែគ្រប់ហើយ គេឱ្យតែប៉ុណ្ណឹ

ង។ គេចែកវាល់វែក"]។ ឯកសារ D114/243 កំណត់ហេតុស្តាប់ចម្លើយ ធក សែន ឆ.85 ["នៅជំនាន់នោះ ហូបមិនឆ្អែតទេ បបរវាវកក្អក"]។ ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ិន សុត ឆ.61 ["គឺពិបាកណាស់ អង្ករមួយកំប៉ុង គឺសម្រាប់មនុស្ស ៧ នាក់។ វេទនា"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.12 ["ម្ហូបអាហារ មិនគ្រប់គ្រាន់ទេ ពេលខ្លះយើងហូបបាយ ហើយពេលខ្លះទៀតយើងហូបបបរ ជាមួយសម្លព្រលឹត ឬសម្លត្រកួន"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.114 ["ស៖ តើលោកទទួលរបបអាហារគ្រប់គ្រាន់ដែរឬទេ? ឆ.114៖ ទេ មិនគ្រប់គ្រាន់ទេ។ អ្នកធ្វើការងារម្នាក់ៗទទួលបាន បាយមួយកូនចានតូច ជាមួយនឹងសម្លត្រី។ ចំពោះខ្ញុំធ្លាប់ហូបបាយពី ៣ ចាន ទៅ ៤ ចានឯណោះ ដូច្នេះបាយមួយកូនចានតូច គឺមិនគ្រប់គ្រាន់ទេ ហើយរបបអាហារទទួលបានតែ ២ ពេលប៉ុណ្ណោះក្នុង ១ ថ្ងៃ គឺថ្ងៃត្រង់ និងល្ងាច"]។ ឯកសារ D114/179 កំណត់ហេតុស្តាប់ចម្លើយ ស្លួន ឈុំ ឆ.11 ["១ ថ្ងៃ បបរតែមួយវែកប៉ុណ្ណោះ (សាក្សីធ្វើដៃប៉ុនចានចង្កឹះ)"]។ ឯកសារ D54/120 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.3 ["ចំពោះអ្នកធ្វើការនៅតាមការដ្ឋានឆ្ងាយៗ គេដឹកជញ្ជូនម្ហូបអាហារនៅទីនោះដោយពុំចាំបាច់ឱ្យត្រឡប់មកសហករណ៍វិញទេ ព្រោះខាតពេល។ គេអាចហូបបាយ ឬហូបបបរ គ្មានអ្វីផ្សេងទេ ហើយយើងមិនដែលមានហូបគ្រប់គ្រាន់នោះទេ"]។ ឯកសារ D114/156 កំណត់ហេតុស្តាប់ចម្លើយ សឹង ណុច ឆ.68-69, 71 ["អត់មានបាយថ្ងៃត្រង់ទេ [...] ឆ.69៖ មិនមានអាហារបីពេលទេ [...] ស៖ ចន្លោះពីម៉ោងពេលបាយព្រឹកទៅថ្ងៃហ្នឹង តើគេមានអីឱ្យហូបទៀតទេ? ឆ.71៖ គ្មានទេ"]។ ឯកសារ D54/20 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ. 14 ["របបអាហារមិនគ្រប់គ្រាន់ទេ ពេលព្រឹកម៉ោង ៧ ព្រឹក គេឱ្យបបរ និងពេលថ្ងៃត្រង់ និងល្ងាច គេឱ្យហូបបាយ តែការហូបចុកនោះមិនគ្រប់គ្រាន់ទេ"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.82-83 ["ចំណីរអាហារ បើនិយាយឱ្យខ្លី គឺមិនដែលស្គាល់ថ្ងៃឆ្អែត [...] ឆ.83៖ ពីរពេលក្នុងមួយថ្ងៃ"]។ ឯកសារ D54/105 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.16 ["សម្រាប់អាហារ [នៅកងកេង] គឺតិចជាងកាលខ្ញុំនៅកន្លែងយោធាសមរភូមិមុខ។ ពួកយើងទទួលបានអង្ករប្រហែល ៧ ភាគរយនៃកំប៉ុងទឹកដោះគោក្នុងមួយថ្ងៃ។ ពួកយើងដាំបាយលាយជាមួយដំឡូង ហើយហូប។ ក្នុង ១ ថ្ងៃយើងហូបពីរពេល"]។ ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ ស្លួន ផ ឆ.23 ["សម្រាប់អាហារ មួយលើកៗ គេឱ្យហូប ១ កូនចាន ដូច្នេះយើងមិនដែលហូបគ្រប់គ្រាន់នោះទេ"]។ ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.282 ["[អ្នកធ្វើស្រែ] ពួកគេមានភាពស្គមស្គាំង ព្រោះគេហូបមិនគ្រប់"]។ ឯកសារ D114/135 កំណត់ហេតុស្តាប់ចម្លើយ ណុប ផល ឆ.29 ["របបអាហារដែលគេឱ្យនោះ គឺមិនគ្រប់គ្រាន់ទេ។ ខ្ញុំឃ្លាន"]។ ឯកសារ D114/244 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន យ៉ើ ឆ.25-26 ["ជីវភាពរបស់ខ្ញុំកាលពីខ្ញុំនៅកងកេង ជីវភាពហ្នឹងវាដុនដាបណាស់ កម្លាំងពលាំងមិនសូវមាន។ ព្រោះជីវភាពហ្នឹង វាចែករបបស្តួចស្តើងពេក។ ក្នុងហូបបាយម៉ាឆ្នាំងហ្នឹង វាមានកំណត់ ១០ នាក់ ប៉ុន្មានកំប៉ុនអ៊ីចឹងទៅ"]។ ឯកសារ D114/242 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ប៊ុននី ឆ.61 ["គេមិនសូវបង្អត់ដូចចាស់ៗទេ"]។ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សម្បត្តិ ឆ.157-159 ["របបអាហារសម្រាប់ម្នាក់ៗ គឺបាយលាយដំឡូងមួយចាន ក្នុងមួយពេល ស៖ មួយចានមានទំហំប៉ុនណា? ឆ.158៖ មួយចានតូច តែហូបមិនគ្រាន់ទេ។ ស៖ មួយថ្ងៃ គេឱ្យហូបប៉ុន្មានដង? ឆ.159៖ ពីរដងក្នុងមួយថ្ងៃ"]។ ឯកសារ D114/69 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្បត្តិ ឆ.1 ["ដំបូង យើងញ៉ាំបាយជាឯកជននៅក្នុងគ្រួសារ។ បីខែក្រោយមក ខ្មែរក្រហម បានចាប់ផ្តើមប្រមូលចាន និងគ្រឿងផ្ទះបាយ។ ហើយយើងត្រូវញ៉ាំបាយជាសមូហភាព [...] នៅពេលកំពុងរស់នៅក្នុងសហករណ៍ យើងទទួលបានអាហារពីរពេលក្នុងមួយថ្ងៃ ពេលខ្លះបាយ

ឆ្អឹង។ ក្បាលរបស់ពួកគេគឺសុទ្ធតែឆ្អឹង"[2986]។ អ្នកធ្វើការត្រូវបានគេឲ្យបបរបន្តិចហូបក្នុងមួយថ្ងៃពីរដង[2987]។ "យើងត្រូវបានគេឲ្យហូបបបររាវៗពីរដងក្នុងមួយថ្ងៃ។ គេឲ្យយើងហូបបបររាវមួយកូនចានក្នុងមួយពេល។ ខ្ញុំឃ្លានយ៉ាងខ្លាំងនៅពេលនោះ។ ខ្ញុំនឿយហត់អស់កម្លាំងរហូតដល់ខ្ញុំមិនអាច

ពេលខ្លះបបរ។ សម្រាប់អាហារពេលព្រឹកវិញ យើងត្រូវដោះស្រាយដោយខ្លួនឯង។ ខ្ញុំឃើញផ្ទាល់ភ្នែកនូវមនុស្សដែលទទួលរងគ្រោះ ដោយសារការអត់ឃ្លាន កង្វះអាហាររូបត្ថម្ភ ជំងឺ ការធ្វើការងារដោយបង្ខំ និងការធ្វើបាប"]។ ឯកសារ D1.3.13.8 កិច្ចសម្ភាសនរបស់ ក.ស.ព ជាមួយ ប៉េង សារិន EN ERN 00217561 ["ពួកគេធ្វើស្រែនៅស្នាច់ដែង [...] ប្រធានកងវរសេនាធំមិនបានហូបអាហារជាមួយកម្មករទេ មានតែប្រធានសហករណ៍ប៉ុណ្ណោះហូបជាមួយ។ នៅទីនោះ គេឲ្យបបរ ២ វែក ដូចនៅស្ទឹងហាវដែរ។ ប្រធានវរសេនាធំ មើលទៅដូចជាស្រួលជាងប្រជាជនដទៃទៀត"]។ ឯកសារ D11/388 ដើមបណ្តឹងរដ្ឋប្បវេណី ណាប់ សុម៉ាលី KH ERN 00991884 ["ពេលហូប ឲ្យហូបតែបបរចែកគ្នាបានមួយចានជាមក្នុងមួយនាក់ ជាមួយសម្លប្រាច់លាយក្តាមមួយៗ"]។ ឯកសារ D11/387 ដើមបណ្តឹងរដ្ឋប្បវេណី សំ វុទ្ធី KH ERN 00991864 ["ឯការហូបចុក ពួកគេឲ្យហូបបបរខ្លះធំ សម្លព្រលិត លាយក្តាមស្រែពីប្រាំ ១ ដប់ក្តាមមួយខ្ទះឆ្នោត"]។ ផ្ទុយនឹង ឯកសារ D54/17 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ិន ឆ.14 ["តាមអ្វីដែលខ្ញុំបានដឹង ស្ថានភាពការងារ និងការហូបចុក គឺធម្មតា"]។ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ សុក អ៊ុក ឆ.112, 202 ["យើងហូបមិនអស់ទេ [...] ឆ.202៖ ហូបគ្រប់គ្រាន់រាន់ ព្រោះវានៅជិតសមុទ្រ។ ហើយមានមនុស្ស ដែលគេចាត់តាំងឲ្យទៅចាប់ត្រីសមុទ្រ"]។ ឯកសារ D54/92 កំណត់ហេតុស្តាប់ចម្លើយ យ៉ែម សំអុន ឆ.29 ["ខ្ញុំទទួលបានការហូបចុកគ្រប់គ្រាន់"]។

2986 ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.115។

2987 ឯកសារ D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉េន ឆ.8 ["គេឲ្យហូបតែបបរ"]។ ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែត ឆ.40 ["ក្នុងឆ្នាំ ១៩៧៧ លក្ខខណ្ឌការងារ និងការរស់នៅចាប់ផ្តើមលំបាកខ្លាំងណាស់។ របបអាហារគឺបបររាវៗបីវែក សម្រាប់មនុស្សម្នាក់ៗនៅក្នុងមួយពេល"]។ ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.12 ["បបរបាយ គឺមួយចានចង្កឹះមួយពេល ក្នុងមួយថ្ងៃ យើងហូបពីរពេល"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.114 ["ចំពោះខ្ញុំធ្លាប់ហូបបាយពី ៣ ចាន ទៅ ៤ ចានឯណោះ ដូច្នេះបាយមួយកូនចានតូច គឺមិនគ្រប់គ្រាន់ទេ ហើយរបបអាហារទទួលបានតែ ២ ពេលប៉ុណ្ណោះក្នុង ១ ថ្ងៃ គឺថ្ងៃត្រង់ និងល្ងាច"]។ ឯកសារ D114/94 កំណត់ហេតុស្តាប់ចម្លើយ សំ វុទ្ធី ឆ.65-66 ["ស៖ គេឲ្យរបបអាហាររបៀបម៉េច? ឆ.65៖ គេឲ្យបបរមួយចានតូចម្នាក់ ហើយសម្លមួយចានធំ សម្រាប់បួននាក់ ស៖ របបហ្នឹងសម្រាប់មួយពេលឬ? ឆ. 66៖ បាទ ហើយមួយថ្ងៃ គេឲ្យពីរពេល គឺពេលព្រឹក និងពេលល្ងាច។ គ្មានអាហារថ្ងៃត្រង់ទេ"]។ ឯកសារ D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉េន ឆ.13 ["ស៖ តើគេឲ្យលោកស្រីហូបប៉ុន្មានដងដែរ ក្នុង ១ ថ្ងៃ ឆ.13៖ ព្រឹក ល្ងាច គឺពីរពេល"]។ ឯកសារ D114/96 កំណត់ហេតុស្តាប់ចម្លើយ ចេង ឡុង ឆ.23។

កាន់ចបកាប់ដីបាន"[2988]។ ជនរងគ្រោះនៅការដ្ឋានរាម "មិនចង់ធ្វើការនៅទីនោះទេ ប៉ុន្តែពួកគេគ្មានជម្រើស។ ពួកគេស្គមស្គាំងយ៉ាងខ្លាំង ពីព្រោះពួកគេមិនមានអាហារហូបគ្រប់គ្រាន់"[2989]។

729. ទោះបីប្រជាជនមានការស្រេកឃ្លាន អ្នកដែលយកអាហារដោយគ្មានការអនុញ្ញាតនឹងត្រូវចាប់ខ្លួនឬត្រូវសម្លាប់[2990]។ ជាងនេះទៅទៀត ពេលខ្លះ ខ្មែរក្រហមដាក់ពិន័យអ្នកធ្វើការ ដោយកាត់បន្ថយរបបអាហារដ៏តិចតួចរបស់ពួកគេបន្ថែមទៀត ប្រសិនបើពួកគេមិនអាចធ្វើការងារតាមការកំណត់[2991] ឬមានជំងឺមិនអាចធ្វើការបាន[2992]។ "ខ្ញុំស្គមស្គាំងយ៉ាងខ្លាំង។ ខ្ញុំរស់នៅដោយភាពភ័យខ្លាច។ ក៏ប៉ុន្តែខ្ញុំខិតខំព្យាយាមដើម្បីរស់រានមានជីវិត ពីព្រោះខ្ញុំមិនចង់ឲ្យគេបញ្ជូនខ្ញុំទៅទីកសាប"[2993]។

---

2988 ឯកសារ D114/96 កំណត់ហេតុស្តាប់ចម្លើយ ចេង ឡុង ឆ.23។ សូមមើលផងដែរ ឯកសារ D114/239 កំណត់ហេតុស្តាប់ចម្លើយ សៅ ម៉េន ឆ.13-14 ["[អាហារ] ព្រឹក ល្ងាច គឺពីរពេល។ សៈ តើគេឲ្យហូបគ្រប់គ្រាន់ទេ? ឆ.14៖ បើមិនគ្រប់គ្រាន់ ក៏ត្រូវតែគ្រប់ហើយ គេឲ្យតែប៉ុណ្ណឹង"]។

2989 ឯកសារ D114/79 កំណត់ហេតុស្តាប់ចម្លើយ កង ស៊ុំ ឆ.282។

2990 ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែត ឆ.17 ["គាត់មិនបាននិយាយប្រាប់ទាំងអស់អំពីរឿងចម្ការធូរេនហ្នឹងទេ។ គាត់បាននិយាយថា បើមានមនុស្សណាលួចអង្ករ ដំឡូង និងម្ហូបអាហារ គាត់នឹងរាយការណ៍ឲ្យចាប់ខ្លួនអ្នកនោះ"]។ ឯកសារ D114/96 កំណត់ហេតុស្តាប់ចម្លើយ ចេង ឡុង ឆ.25-26 ["យើងមិនអាចលួចបន្លែអ្វីទេ បើគេដឹង គេនឹងយកយើងទៅសម្លាប់ចោល [...] ឆ.26៖ ឧទាហរណ៍ នៅពេលដែលខ្ញុំទៅហូបអាហារ ខ្ញុំឮគេនិយាយថា អ្នកដែលលួចបន្លែហូប ត្រូវគេចាប់យកទៅ"]។ ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ិន សុត ឆ.66 ["ពេលគ្នាហូបអត់ឆ្អែត ពេលគ្នាលួចដំឡូង គេក៏បានចាប់គ្នាចង បញ្ជូនទៅទីកសាបបាត់ទៅ"]។ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សម្បត្តិ ឆ.178-179, 217-218 ["សៈ តើមានអ្នកណាព្យាយាមរក ឬលួចអាហារហូបចុកបន្ថែមទៀតទេ? ឆ.178៖ មាន តែពេលលួចហើយ គេចាប់យកអ្នកទាំងនោះទៅកសាង។ សៈ កសាង តើមានន័យថាម៉េច? ឆ.179៖ គេកសាង យើងឲ្យល្អ។ គេឲ្យយើងធ្វើការវិញដដែល តែគេព្រមានយើងកុំឲ្យលួចម្តងទៀត។ [...] សៈ មុនហ្នឹង លោកនិយាយពី អ្នកដែលគេបញ្ជូនទៅកសាង តើលោកដែលឃើញអ្នកទាំងនោះម្តងទៀតទេ? ឆ.217៖ ទេ ពួកគេបាត់ខ្លួនរហូត។ សៈ មានប្រហែលប៉ុន្មាននាក់ដែលគេបញ្ជូនទៅកសាង ឆ.218៖ បីនាក់ នៅក្នុងកងខ្ញុំ"]។

2991 ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.12 ["ប្រសិននរណាម្នាក់មិនអាចធ្វើចប់តាមការកំណត់ គាត់នឹងត្រូវបន្តការងារតទៅទៀត រហូតដល់ពេលយប់។ គេមិនឲ្យបាយហូបទេ បើគាត់មិនបញ្ចប់ការងាររបស់គាត់"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.112 ["គេតម្រូវឲ្យយើងធ្វើការឲ្យហើយក្នុង ១ ថ្ងៃដាច់ខាត បើធ្វើមិនចប់តាមការគេកំណត់ គឺមិនឲ្យឈប់សម្រាកហូបបាយទេ"]។

2992 ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ិន សុត ឆ.67 ["បើឈឺមិនពិតប្រាកដ គឺគេអត់ឲ្យបបរហូបទេ"]។ ឯកសារ D54/120 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.3 ["ចំពោះអ្នកដែលឈឺ ហើយមិនបានទៅធ្វើការ គេមិនឲ្យហូបទេ។ នៅពេលបាយ ខ្ញុំបានឃើញអ្នកដែលឈឺតម្រង់ជួរ ដើម្បីទទួលរបបអាហារដែរ ប៉ុន្តែត្រូវគេបញ្ជូនឲ្យត្រឡប់

730. កង្វះអាហារ ត្រូវបានបន្ថែមទម្ងន់ ដោយការងារធ្ងន់ធ្ងរដែលគេតម្រូវឱ្យអ្នកធ្វើការម្នាក់ៗ ធ្វើជារៀងរាល់ថ្ងៃ[2994] ដោយការងារភាគច្រើនត្រូវបានធ្វើដោយគ្មានជំនួយពីគ្រឿងម៉ាស៊ីន ឬសត្វពាហនៈ នោះឡើយ ជាពិសេសការសាងសង់ទំនប់[2995]។ "ប្រជាជនទាំងចាស់ទាំងក្មេងសុទ្ធតែបាក់កម្លាំង និងឃ្លានអាហារជារៀងរាល់ថ្ងៃ"[2996]។ ក៏ប៉ុន្តែ ពួកគេត្រូវធ្វើការធ្ងន់ធ្ងរ រហូតទាល់តែដួល ដោយសារតែការភ័យខ្លាច[2997]។ "ខ្ញុំស្រកទម្ងន់រហូតទាល់តែខ្ញុំស្ទើរតែមិនអាចដើរបាន។ ក៏ប៉ុន្តែខ្ញុំត្រូវតែធ្វើការ។ បើមិនដូច្នោះទេ ខ្ញុំនឹងត្រូវគេសម្លាប់"[2998]។

---

មកផ្ទះវិញ។ ក្នុងករណីខ្លះ ពួកគេបានទាំងបាយក្នុងចានរួចហើយ ហើយបម្រុងឱ្យប្រជាជននោះ ប៉ុន្តែពួកគេបានដកយកចាន និងម្ហូបមកវិញ ដោយសារហេតុផលថា អ្នកនោះឈឺពុំបានទៅធ្វើការ"]។ ឯកសារ D54/90 កំណត់ហេតុស្តាប់ចម្លើយ កុយ ណែត ឆ.16 ["នៅពេលណាដែលគាត់និយាយថា អ្នកណាឈឺនឹងមិនត្រូវទទួលបានបបរហូបចុកទេ គឺគាត់ធ្វើអ៊ីចឹងមែន ហើយអ្នកឈឺនោះនឹងមិនបានទទួលអាហារហូបចុកទេ"]។

2993 ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.13។

2994 ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.23 ["នៅក្នុងពេលធ្វើការនៅកងកេង កន្លែងសម្រាកពួកខ្ញុំនៅភ្នំអំបោស នៅជិតភូមិពូធឿង ចម្ងាយប្រហែលពី ៥ ទៅ ៥ គីឡូម៉ែត្រពីព្រលានយន្តហោះកងកេង។ ពួកខ្ញុំត្រូវដើរពីកន្លែងយើងសម្រាកទៅធ្វើការនៅម្តុំព្រលានយន្តហោះជារៀងរាល់ថ្ងៃ។ យើងចាប់ផ្តើមប្រហែលនៅម៉ោង ៧ ព្រឹក ហើយចាប់ផ្តើមធ្វើការនៅម្តុំម៉ោង ៧"]។ ឯកសារ D114/135 កំណត់ហេតុស្តាប់ចម្លើយ ណុប ផល ឆ.27 ["គ្រប់គ្នាត្រូវក្រោកម៉ោងប្រាំ។ បន្ទាប់មក យើងញ៉ាំបបរជាអាហារពេលព្រឹក នៅម៉ោងប្រាំកន្លះ ហើយត្រូវដើរប្រហែលជាដប់ប្រាំនាទី ទៅស្រែ ដែលស្ថិតនៅចម្ងាយមួយ ទៅពីរគីឡូម៉ែត្រ ដែលយើងរស់នៅ"]។

2995 ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សម្បត្តិ ឆ.197។ ឯកសារ D54/97 ខឹម យ៉ាត (ជាទាហានកងពល ១៦៤ ដែលបញ្ជូនទៅធ្វើការនៅព្រលានយន្តហោះកងកេង បន្ទាប់ពីការបោសសម្អាតនោះនៅកងវរសេនាធំរបស់គាត់ នៅក្នុង ១៩៧៧) ឆ.10 ["នៅកងកេង គេធ្វើស្រែ ដោយកាប់នឹងចប ពុំមែនប្រើគោក្របីភ្ជួររាស់នោះទេ។ មនុស្ស ២៥ នាក់ ត្រូវបានចាត់តាំងឱ្យកាប់ (ជំនួសដោយភ្ជួរ) ដីស្រែ ១ ហិចតា ក្នុង ១ ថ្ងៃឱ្យហើយ"]។

2996 ឯកសារ D114/121 កំណត់ហេតុស្តាប់ចម្លើយ សួន ផ ឆ.23។

2997 ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.190 ["មានដួលសន្លប់ ពេលកំពុងធ្វើការ"]។ ឯកសារ D114/194 កំណត់ហេតុស្តាប់ចម្លើយ ស៊ន សុត ឆ.61 ["មានអ្នកខ្លះធ្វើការៗ ក៏ដួល"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ីន ឆ.95, 146 ["ស៖ តើមានអ្នកធ្វើការជាមួយលោកមានធ្លាក់ខ្លួនឈឺ ឬដួលពេលកំពុងធ្វើការទេ? ឆ.95៖ មាន [...] ឆ.146៖ ដល់ពេលហ្នឹង សុខភាព និងកម្លាំងរាពិបាក ស្គមអស់កម្លាំង ព្រោះហូបមិនគ្រប់"]។ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.40, 100 ["បន្ទាប់គេយកប្តីបងស្រីជីដូនមួយខ្ញុំ និងខ្ញុំទៅបាត់ ហើយគេឃើញពួកខ្ញុំយំ គេដាក់ទណ្ឌកម្មពួកខ្ញុំឱ្យជាន់ដីឥដ្ឋឱ្យបានម្នាក់ ៨០០០ ដុំ ក្នុង ១ ថ្ងៃ នៅភូមិស្នាច់ដែង។ ខ្ញុំពុំមានបញ្ហាអ្វីទេ តែបងស្រីជីដូនមួយខ្ញុំ គាត់ធ្លាក់ខ្លួនឈឺ ព្រោះទើបតែសម្រាលកូនហើយ ហើយគាត់បានស្លាប់ ៣ ថ្ងៃក្រោយមក ចំណែកកូនគាត់ក៏ស្លាប់ក្រោយមកដែរ [...] ឆ.100៖ ទទួលបានបាយបន្តិចបន្តួចបំផុត

731. ដោយសារស្ថានភាពរស់នៅ និងស្ថានភាពការងារមិនល្អ ជាញឹកញាប់ប្រជាជនបានធ្លាក់ខ្លួនឈឺ និងស្លាប់ដោយសារជំងឺ[2999]។ ស្ត្រីដែលទើបសម្រាលកូន ត្រូវគេបង្ខំឲ្យធ្វើការងារធ្ងន់ធ្ងរ ដែលបណ្តាលឲ្យឈឺ និងស្លាប់[3000]។ សាក្សីមួយរូបដែលធ្វើការនៅចម្ការដូង បានអះអាងថា "កុមារស្ទើរតែទាំងអស់នៅក្នុងតំបន់នោះ កើតជំងឺគ្រុនចាញ់" ដែលបណ្តាលឲ្យមានកុមារមួយចំនួនស្លាប់[3001]។ ទោះបី

---

ហូបមិនគ្រប់គ្រាន់ទេ ហើយក៏មិនមានម្ហូបអាហារអ្វីដែរ ដូច្នេះហើយបានជាពួកគេដួល ពេលកំពុងធ្វើការ"]។ ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.31 ["សៈ តើលោកបានឃើញមនុស្សដួលដោយសារជំងឺ និង/ឬហត់នឿយអស់កម្លាំង ពេលកំពុងធ្វើការនៅទំនប់នោះដែរឬទេ? ឆ.31៖ បាទ ខ្ញុំធ្លាប់ឃើញហេតុការណ៍នោះដែរ។ ដោយសារតែហត់នឿយ អ្នកខ្លះដួល។ យើងធ្វើការទាល់តែដួល ទើបគេសែងយកទៅរោង ដើម្បីសម្រាក"]។

2998 ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.130។

2999 ឯកសារ D54/36 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សុខា ឆ.14 ["សៈ កាលពីពេលនោះ តើលោកសង្កេតឃើញការលំបាក និងការសម្លាប់អ្នកដទៃទៀត នៅក្នុងកងចល័តនោះដែរ ឬយ៉ាងណា? ឆ.14៖ យើងរស់នៅក្នុងស្ថានភាពដូចគ្នាទាំងអស់ ដូចរូបខ្ញុំជាដើម ពេលណាយើងឈឺ គេបានបញ្ជូនយើងទៅពេទ្យនៅក្នុងភូមិបឫស។ អ្នកខ្លះបញ្ជូនទៅពេទ្យ ពុំឃើញត្រឡប់មកវិញទេ អ្នកធ្វើការនៅពេទ្យបាននិយាយថា អ្នកជំងឺនោះបានស្លាប់បាត់ទៅហើយ យើងចេះតែជឿតាមគេទៅ អ្វីដែលគេប្រាប់យើង"]។ ឯកសារ D114/31 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.117 ["ប្រជាជនមានសភាពស្រេកឃ្លាន អស់កម្លាំង ឈឺស្គមស្គាំង ស្បែកឡើងពណ៌លឿង ដោយសារតែជំងឺគ្រុនចាញ់ និងជំងឺផ្សេងទៀត"]។ ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.31 ["អ្នកដែលហត់នឿយអស់កម្លាំង គេឲ្យសម្រាកខ្លះ តែត្រូវត្រឡប់មកធ្វើការងារវិញដូចដើម។ ចំពោះអ្នកដែលឈឺធ្ងន់ គេបញ្ជូនទៅពេទ្យកំពង់សោម"]។ ឯកសារ D114/89 កំណត់ហេតុស្តាប់ចម្លើយ សេង ស៊ុន ឆ.95, 146 ["សៈ តើមានអ្នកធ្វើការជាមយយលោកមានធ្លាក់ខ្លួនឈឺ ឬដួលពេលកំពុងធ្វើការទេ? ឆ.95៖ មាន។ [...] ឆ.146៖ ដល់ពេលហ្នឹង សុខភាព និងកម្លាំង វាពិបាក ស្គមអស់កម្លាំង ព្រោះហូបមិនគ្រប់"]។ ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.100 ["ទទួលបានបាយបន្តិចបន្តួចបំផុត ហូមមិនគ្រប់គ្រាន់ទេ ហើយក៏មិនមានម្ហូបអាហារអ្វីដែរ ដូច្នេះហើយបានជាពួកគេដួល ពេលកំពុងធ្វើការ"]។ ឯកសារ D114/109 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ សម្បត្តិ ឆ.161-165 ["សៈ មានធ្លាក់ខ្លួនឈឺទេ? ឆ.161៖ បាទមាន សៈ អ្នកដែលឈឺមានថ្នាំពេទ្យផឹកទេ? ឆ.162៖ គេបញ្ជូនពេទ្យមកមើលតាមកង។ សៈ តើមានអ្នកណាស្លាប់ទេពេលនោះ ឆ.163៖ បាទ មានអ្នកឈឺខ្លាំងដល់ស្លាប់ សៈ តើលោកចាំថា មានប៉ុន្មាននាក់ទេ? ឆ.164៖ ខ្ញុំមិនចាំទេ គ្រាន់តែមានអ្នកស្លាប់ដោយសារជំងឺ។ សៈ មានអ្នកដែលចុះខ្សោយ ហើយស្លាប់ ឬធ្វើការខ្លាំងដល់ស្លាប់ទេ? ឆ.165៖ បាទ មានអ្នកដែលពុំមានអាហារហូបគ្រប់គ្រាន់ ចុះខ្សោយ ហើយស្លាប់"]។

3000 ឯកសារ D114/6 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.40 ["បន្ទាប់គេយកប្តីបងស្រីជីដូនមួយខ្ញុំ និងខ្ញុំទៅបាត់ ហើយគេឃើញពួកខ្ញុំយំ គេដាក់ទណ្ឌកម្មពួកខ្ញុំឲ្យជាន់ដីឥដ្ឋឲ្យបានម្នាក់ ៨០០០ ដុំ ក្នុង ១ ថ្ងៃ នៅភូមិស្នាច់ដែង។ ខ្ញុំពុំមានបញ្ហាអ្វីទេ តែបងស្រីជីដូនមួយខ្ញុំ គាត់ធ្លាក់ខ្លួនឈឺ ព្រោះទើបតែសម្រាលកូនហើយ ហើយគាត់បានស្លាប់ ៣ ថ្ងៃក្រោយមក ចំណែកកូនគាត់ក៏ស្លាប់ក្រោយមកដែរ"]។

3001 ឯកសារ D114/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹង ណុច ឆ.73។

ជាមនុស្សឈឺធ្ងន់ ជួនកាលត្រូវបានគេបញ្ជូនទៅកាន់កន្លែងព្យាបាលដ៏អត្តខាត់ក៏ដោយ[3002] ជំងឺរបស់ប្រជាជនជាច្រើនមិនត្រូវគេព្យាបាលនោះឡើយ ហើយអ្នកជំងឺទាំងនោះត្រូវបានគេបង្ខំឱ្យបន្តធ្វើការងារ[3003]។ មនុស្សជាច្រើនត្រូវបង្ខំចិត្តបន្តធ្វើការងារ ទោះបីជាខ្លួនកំពុងមានជំងឺ ដោយសារតែផលវិបាកធ្ងន់ធ្ងរ ដូចជា ការសម្លាប់ ដែលបណ្តាលមកពីការអះអាងថាមានជំងឺ[3004]។ "ពួកគេនិយាយថា អ្នកមានជំងឺ នឿយហត់ និងមិនអាចធ្វើការងារ គឺជាមនុស្សខ្ជិល ដែលធ្វើពុតថាមានជំងឺ និងបម្រើល្បិចខ្មាំង។ ប្រជាជនទាំងនោះត្រូវបានគេយកទៅសម្លាប់ នៅក្នុងព្រៃខាងក្រោយ

---

3002 ឯកសារ D54/90 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ឆ.40 ["គ្មានថ្នាំពេទ្យសម្រាប់អ្នកឈឺ គឺមានតែថ្នាំបុរាណ ហៅថា ថ្នាំអាចម៍ទន្សាយ។"]។ ឯកសារ D114/31 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.120-121 ["ស៖ តើមានរឿងអ្វីកើតឡើងដែរ ប្រសិនបើនរណាម្នាក់ឈឺថ្កាត់? ឆ.120៖ អ្នកជំងឺត្រូវបានគេបញ្ជូនទៅព្យាបាលនៅពេទ្យក្នុងសហករណ៍ ដោយផ្តល់តែថ្នាំបុរាណអាចម៍ទន្សាយប៉ុណ្ណោះ។ ស៖ តើថ្នាំនោះមានប្រសិទ្ធភាពដែរឬទេ? ឆ.121៖ មិនមានទេ។ កាន់តែលេបច្រើន គឺកាន់តែហើម ហើយស្លាប់។"]។ ឯកសារ D54/120 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ កែម ឆ.3 ["គ្មានម្ហូប គ្មានថ្នាំសង្កូវ"]។ សូមមើលផងដែរ ឯកសារ D114/239 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ម៉េន ឆ.19 ["លោកស្រីប្រាប់យើងមុននោះថា មានកូនប្រាំពីរនាក់ តែស្លាប់ពីរនាក់។ តើពីរនាក់ដែលស្លាប់នេះ គឺស្លាប់នៅពេលធ្វើការនៅកងកុមារមែនទេ? ឆ.19៖ អត់ទេ គេស្លាប់នៅឆ្នាំ ១៩៧៩។ ស្លាប់ដោយគ្មានថ្នាំសង្កូវ មើលវាមិនទាន់។"]។ ឯកសារ D114/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច ឆ.81-82 ["តើមានពេទ្យ មានថ្នាំពេទ្យគ្រប់គ្រាន់សម្រាប់អ្នកជំងឺទាំងអស់ហ្នឹងដែរទេ? ឆ.81៖ បើតាមខ្ញុំថា មិនមានគ្រប់គ្រាន់ទេ ព្រោះមានមនុស្សស្លាប់រាល់ថ្ងៃ។ ស៖ មានគ្រែសម្រាប់អ្នកជំងឺទាំងអស់ទេ? ឆ.82៖ ខ្លះ។"]។

3003 ឯកសារ D114/194 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ន សុត ឆ.65 ["មានស្លាប់ដោយសាររាគទៀត អត់មាននរណាព្យាបាលបានទេ។"]។ ឯកសារ D114/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ឆ.160 ["ស៖ តើលោកស្រីធ្វើការដោយស្ម័គ្រចិត្ត ឬក៏គេបង្ខំ? ឆ.160៖ ទោះបីខ្ញុំប្រាប់គេថា ខ្ញុំចុកពោះ ក៏គេបង្ខំឱ្យធ្វើការងារដែរ។"]។

3004 ឯកសារ D114/135 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ផន ឆ.28 ["ពេលខ្លះ ខ្ញុំឈឺដែរ ប៉ុន្តែត្រូវបន្តធ្វើការដើម្បីកុំឱ្យ គេចោទថា ខ្ញុំធ្វើពុតជាឈឺ។ មានអ្នកនៅក្រុមរបស់ខ្ញុំដែលឈឺ ហើយត្រូវបានគេពិនិត្យ ដើម្បីឱ្យដឹងថា តើពួកគេឈឺពិតប្រាកដ ឬក៏ធ្វើពត់ជាឈឺ។"]។ ឯកសារ D114/40 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ. 30 ["ស៖ [...] លោកនិយាយថា បើទោះជាមេឃភ្លៀងក៏ដោយ ក៏លោកនិងអ្នកដទៃទៀតនៅតែបន្តធ្វើការរហូត គឺធ្វើការក្នុងភក់ និងរែកដីសើម។ អ្នកដែលឈឺពុំបានឈប់សម្រាក ឬគ្រុនញាក់ទេ គឺនៅបន្តធ្វើការរហូត ព្រោះថាបើគ្រុនញាក់ គឺស្លាប់។ តើនេះ ត្រឹមត្រូវដែរឬទេ? ឆ.30៖ បាទ! ត្រឹមត្រូវហើយ។"]។

សហករណ៍"[3005]។ ក្នុងចំណោមមនុស្សតិចតួចដែលត្រូវគេបញ្ជូនទៅកាន់កន្លែងព្យាបាល អ្នកខ្លះមិនត្រឡប់មកវិញទេ[3006] ហើយនៅទីនោះ "មនុស្សជាច្រើនបានស្លាប់ជារៀងរាល់ថ្ងៃ"[3007]។

732. ជនរងគ្រោះត្រូវគេធ្វើបាបលើរូបរាងកាយ ដោយអ្នកមានអំណាចគ្រប់គ្រងលើពួកគេ។ សាក្សី ណាវ សុខន បានរៀបរាប់ថាបានឃើញស្ត្រីប្អូននាក់ត្រូវបានគេយកចូលទៅក្នុងខ្ទមមួយ ហើយបានឮពីអ្នកដទៃថា ស្ត្រីទាំងនោះត្រូវបានគេចាប់រំលោភ[3008]។ អ្នកគ្រប់គ្រងវាយដំអ្នកធ្វើការ រួមទាំងកុមារ[3009]។ "គាត់វាយក្មេងៗទាំងអស់នៅក្នុងកង។ គាត់អត់វាយខ្ញុំដោយប្រើរំពាត់ធម្មតាទេ គឺគាត់

---

3005 ឯកសារ D114/31 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល ឈិន ឆ.125។

3006 ឯកសារ D54/36 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ សុខា ឆ.14 ["អ្នកខ្លះបញ្ជូនទៅពេទ្យ ពុំឃើញត្រឡប់មកវិញទេ អ្នកធ្វើការនៅពេទ្យបាននិយាយថា អ្នកជម្ងឺទាំងនោះបានស្លាប់បាត់ទៅហើយ យើងចេះតែជឿតាមគេទៅអ្វីដែលគេប្រាប់ យើង។"]។

3007 ឯកសារ D114/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹង ណុច, ឆ.81។

3008 ឯកសារ D114/117 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាវ សុខន ឆ.117, ឆ.138, ឆ.208 ["[រំលោភស្រីៗ] នៅផ្ទះមួយខាងជើងចម្ការដូង។ [...] ឆ.138៖ វាជាផ្ទះខ្ទមនៅឆ្ងាយពីចម្ការដូងប្រហែលជាមួយគីឡូ។ [...] ឆ.208៖ ខ្លាចអ្នកមករំលោភហ្នឹងសម្លាប់ ព្រោះអីវាមានអំណាចដែរហ្នឹង។"]។ សូមមើលផងដែរ ឯកសារ D114/117.1 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាវ សុខន ឧបសម្ព័ន្ធ៖ បង្ហាញពីទីតាំងនៅក្នុងចម្ការដូងរបស់ ចេង ហេង EN 01138918។

3009 ឯកសារ D114/243 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធន សែន ឆ.34-40, ឆ.46, ឆ.111, ឆ.113, ឆ.115-116 ["យើងយាមដាច់ គេដាក់វិន័យយើង វ៉ៃយើង។ យាមដាច់ មានន័យថា យើងយាមងក់អីចឹង។ ស៖ តើលោកដែលឃើញគេវ៉ៃកុមារណាខ្លះដែរទេ? ឆ.35៖ មានវ៉ៃ ហើយវ៉ៃទាំងខ្ញុំទៀត និយាយតាមត្រង់។ ស៖ ហេតុអ្វីបានគេវ៉ៃលោក? ឆ.36៖ អាហ្នឹងដូចខ្ញុំជម្រាបអីចឹង យើងយាមដាច់។ កាលនៅក្មេងៗ យើងល្ងោភដេកដែរ។ ស៖ តើកាលនោះលោកអាយុប៉ុន្មាន? ឆ.37៖ ១៥ឆ្នាំ។ ស៖ នរណាគេជាអ្នកវ៉ៃលោក? ឆ.38៖ ឈ្មោះ ថុង អង្គុតដៃ។ ស៖ តើ ថុង វ៉ៃលោកយ៉ាងដូចម្តេចខ្លះដែរទៅ? ឆ.39៖ វ៉ៃហ្នឹង គេមិនវ៉ៃម្នាក់ទេ គឺវ៉ៃមួយកងតែម្តង។ អាហ្នឹងមិនវ៉ៃនឹងរំពាត់ធម្មតាទេ គឺវ៉ៃនឹងកន្ទុយបបែល ហើយបែកឈាមពេញ ខ្នង។ ស៖ តើគេវ៉ៃយូរប៉ុន្មានដែរ? ឆ.40៖ វ៉ៃប្រហែលកន្លះម៉ោង។ [...] ឆ.46៖ គិតទៅ វ៉ៃច្រើនលើកដែរ ឲ្យតែយាមដាច់ វ៉ៃប្រហែលប្រាំមួយលើកដែរ។ [...] ស៖ តើគេវ៉ៃដូចម្តេចដែរទៅ? ឆ.111៖ គេវ៉ៃឲ្យយើងធ្វើការងារ។ [...] ស៖ តើគេវ៉ៃប៉ុន្មានដំបងដែរទៅ? ឆ.113៖ យ៉ាងច្រើន មួយដំបង ពីរដំបង ឲ្យយើងខំធ្វើការ។ [...] ស៖ តើលោកដែលឃើញគេវ៉ៃកុមារដែរទេ នៅការដ្ឋាននោះ? ឆ.115៖ ដែរតើ តែយូរៗឃើញម្តង។ ស៖ ម៉េចបានលោកដឹង? ឆ.116៖ ទៅឃើញផ្ទាល់។"]។ ឯកសារ D114/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ឆ.160-162 ["ស៖ ពេលដែលលោកនៅកងផលិត តើមានអ្នកធ្វើការជាមួយលោកត្រូវបានគេវ៉ៃធ្វើបាបទេ? ឆ.160៖ មាន ខ្ញុំឃើញគេវ៉ៃម្នាក់តែក្រោយពីរបបខ្មែរក្រហមមក គាត់ស្លាប់បាត់ហើយ។ ស៖ ហេតុអីបានជាគេវ៉ៃអ្នកធ្វើការនោះ? ឆ.161៖ គាត់អត់កម្លាំង ហើយធ្វើការទៅមិនរួច។ ស៖ តើគេវ៉ៃគាត់យ៉ាងម៉េចដែរ? ឆ.162៖ គេ

ប្រើកន្ទុយបបែល។ វាធ្វើឱ្យខ្ញុំហូរឈាមពេញខ្នង"[3010]។ សាក្សីមួយរូបបាននិយាយថា ឈឿន ដែលជាអនុប្រធានកងពលធំលេខ១៦៤ និងជាអ្នកត្រួតពិនិត្យការដ្ឋានពលកម្មដោយបង្ខំបិតត្រាង វាយទាំងយោធា និងប្រជាជនស៊ីវិល "ដោយគ្មានលើកលែង" ដោយប្រើខ្សែតី[3011]។ ការងារដែលទាមទារកម្លាំងពលកម្មធ្ងន់ធ្ងរ ក៏ត្រូវបានគេយកមកប្រើធ្វើជាទណ្ឌកម្មផងដែរ។ ឧទាហរណ៍ សាក្សីមួយរូប ដែលពេលដំបូងគឺជាចុងភៅ ត្រូវបានគេចាត់តាំងឱ្យជីកប្រឡាយពីរម៉ែត្រគូបក្នុងមួយថ្ងៃ ដែលនេះគឺជាទណ្ឌកម្មចំពោះ "ការមិនស្មោះត្រង់ចំពោះអង្គការ" បន្ទាប់ពីគាត់បានចម្អិនបាយបន្ថែម[3012]។ "វាពិតជាការងារដ៏លំបាក។ យើងធ្វើការគ្មានពេលសម្រាក"[3013]។

---

យកជើងទាត់ធាក់គាត់។"]។ ឯកសារ D114/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ឆ.96 ["ស៖ តើគេវ៉ៃមនុស្សដែរឬទេ? ឆ.96៖ មានគេវ៉ៃមនុស្ស ៦ នាក់ នៅមុខខ្ញុំផ្ទាល់ ចំពោះអ្នកដែលធ្វើការមិនល្អ។"]។ ឯកសារ D114/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឹង ណុច ឆ.117-118 ["គាត់ធ្លាប់ចងស្លាបសេកខ្ញុំ ហើយគម្រាមកាត់កខ្ញុំ។ ពេលនោះ ខ្ញុំយំ។ [...] ឆ.118៖ មិត្តមួយនៅក្រុមរបស់ខ្ញុំ មកយកដូង ខ្ញុំថា មិត្ត! ដូងនេះរបស់ខ្ញុំទេ។ គាត់យកឈើវ៉ៃ ហើយខ្ញុំយកឈើវ៉ៃគាត់ធ្លាក់ទឹក។ ហើយគាត់ទៅប្រាប់ ញ៉ឹម ពេលនោះ ញ៉ឹម មកដល់ចាប់ខ្ញុំចងស្លាបសេក ដោយមិនសួរអីទេ។"]។

3010 ឯកសារ D114/243 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធន សែន ឆ.39 ["ស៖ តើ ថុង វ៉ៃលោកយ៉ាងដូចម្តេចខ្លះដែរទៅ? ឆ.39៖ វ៉ៃហ្នឹង គេមិនវ៉ៃម្នាក់ទេ គឺវ៉ៃមួយកងតែម្តង។ អាហ្នឹងមិនវ៉ៃនឹងរំពាត់ធម្មតាទេ គឺវ៉ៃនឹងកន្ទុយបបែល ហើយបែកឈាមពេញខ្នង។"]។

3011 ឯកសារ D54/91 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណែន ឆ.5-6 ["មេបញ្ជាការយោធា ដែលដឹកនាំធ្វើការងារនៅតំបន់នេះ ឈ្មោះ ឈឿន។ គាត់គឺជាមនុស្សកាចសាហាវណាស់ គាត់ជាអនុកងវរសេនាធំ ១៦៤។ ស៖ ហេតុអ្វីបានជាគាត់ហ្នឹង កាចសាហាវម្ល៉េះ? ឆ.6៖ គាត់ហ្នឹង កាចសាហាវមិនមានព្រំដែនទេ ប្រសិនបើគាត់ចង់ចាប់ ឬក៏វ៉ៃអ្នកណា ជាយោធា និងជាស៊ីវិលក្តី គាត់នឹងធ្វើដោយគ្មានការយោគយល់ទេ។ ឧទាហរណ៍ ខ្ញុំហើយនិងប្រជាជនមួយចំនួនទៀត ត្រូវបានចាប់ឱ្យទៅបាចទឹកចេញពីស្រែ ដើម្បីកុំឱ្យលេចសំណាប។ ដោយសារភ្លៀងខ្លាំងពេក យើងមិនអាចបាចទឹកចេញពីថ្នាលសំណាបឱ្យអស់ទាន់ពេលវេលា។ ពេល ឈឿន ឃើញដូច្នេះ គាត់បានមកវ៉ៃយើងនឹងរំពាត់ ដោយផ្ទាល់ដៃ នៅនឹងថ្នាលសំណាប។ បើសិនជាលោកចង់ឱ្យខ្ញុំរៀបរាប់អំពីអំពើឃោរឃៅរបស់ ឈឿន ទៅលើប្រជាជនពេលនោះ គឺមានរឿងច្រើនណាស់ ខ្ញុំមិនអាចរៀបរាប់អំពីអំពើរបស់គាត់ឱ្យចប់ស្រួលបួលក្នុងរយៈពេលខ្លីនោះទេ។"]។

3012 ឯកសារ D114/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ឆ.45 ["៣ ខែដំបូង គេឱ្យខ្ញុំដាំបាយនៅរោងបាយនៅភូមិ ពូធឿង ដោយសារតែខ្ញុំគិតថា ប្រជាជនហូបមិនឆ្អែត ខ្ញុំក៏ដាំបាយលើស គេចោទខ្ញុំថា ខ្ញុំមិនស្មោះត្រង់នឹងអង្គការ។ ក្រោយមក គេដាក់ទណ្ឌកម្មខ្ញុំឱ្យជីកប្រឡាយ ២ ម៉ែត្រគូបក្នុង ១ ថ្ងៃ។"]។

3013 ឯកសារ D114/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ឆ.46។

733. ប្រជាជនដែលរស់នៅក្នុងសហករណ៍ គឺរស់នៅដោយខ្លាចគេចាប់យកទៅសម្លាប់គ្រប់ពេលវេលា[3014]។ "សម្រាប់ពួកយើង ប្រសិនបើយើងមានកំហុសតូចតាច គេកៀបសង្កត់ និងធ្វើបាបយើង ហើយគេអាចនឹងអប់រំ ទិតៀន និងលត់ដំយើងនៅក្នុងសហករណ៍ ចំពោះកំហុសធ្ងន់ធ្ងរ ពួកគេបញ្ជូនយើងទៅឱ្យថ្នាក់លើអប់រំ ហើយយើងបាត់ខ្លួនជារៀងរហូត"[3015]។ សេចក្តីភ័យខ្លាចចំពោះការដាក់ទណ្ឌកម្ម ចាប់ខ្លួន ឬសម្លាប់ ត្រូវបានបង្កើន ដោយសារពួកគេដឹងថាមានការចាប់ខ្លួន និងដកមនុស្សជាច្រើននៅជុំវិញខ្លួនពួកគេ[3016]។ "យើងរស់នៅដោយសេចក្តីភ័យខ្លាច ជាពិសេសក្រុមរបស់ខ្ញុំដែលត្រូវគេប្រមូល និងបញ្ជូនទៅរស់នៅ [...] អាកាសយានដ្ឋានកងកេង។ [...] ការព្រួយបារម្ភរបស់យើង គឺថាយើងមិនដឹងថាពេលណាយើងនឹងត្រូវគេចាប់ខ្លួនផងដែរ"[3017]។ ប្រធានសហករណ៍ គំរាមអ្នកធ្វើការថានឹងត្រូវចាប់ខ្លួន និងសម្លាប់ដោយសារធ្វើខុស[3018] ហើយអ្នកធ្វើការត្រូវគេបង្ខំឱ្យទិតៀនគ្នាទៅវិញទៅមកនៅក្នុងកិច្ចប្រជុំជាប្រចាំ។ "ក្នុងចន្លោះរៀងរាល់បីថ្ងៃ យើងចូលរួមប្រជុំទិតៀនគ្នាទៅវិញទៅមក ពាក់ព័ន្ធថាតើអ្នកណាធ្វើការងារតិចជាង និងច្រើនជាង"[3019]។

---

3014 ឯកសារ D114/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង ឡុង ឆ.13 ["ខ្ញុំមិនចាំឆ្នាំទេ ពីព្រោះនៅក្នុងសម័យនោះ ខ្ញុំមិនដែលយកចិត្តទុកដាក់ពីពេលវេលា ឬកាលបរិច្ឆេទទេ។ នៅពេលនោះ ខ្ញុំគិតតែពីខំធ្វើការ ហើយខ្ញុំមិនដឹងថាថ្ងៃណា គេយកខ្ញុំទៅសម្លាប់ទេ។"]។

3015 ឯកសារ D54/120 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ កែម ឆ.3។

3016 ឯកសារ D114/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង ឡុង ឆ.65 ["ខ្ញុំមិនដែលឮថា មានតុលាការឡើយ។ ប្រជាជនទាំងនោះត្រូវបានគេយកទៅយ៉ាងសម្ងាត់ គឺនៅពេលយប់។ ពួកខ្មែរក្រហម មកនៅពេលយប់ ហើយគោះទ្វារដោយនិយាយថា 'អង្គការចាត់តាំងអ្នកឱ្យឯងទៅកន្លែងនេះ កន្លែងនោះ'។ ហើយអ្នកទាំងនោះ ក៏ត្រូវបានគេនាំចេញបាត់ទៅ។"]។ ឯកសារ D114/239 កំណត់ហេតុនៃការស្តាប់ចម្លើយ សៅ ម៉េន ឆ.20 ["ស៖ តើលោកស្រីដែលធ្លាប់ឃើញគេយកមនុស្សចេញពីការដ្ឋានបិតត្រាំងដែរទេ? ឆ.20៖ ឃើញ គឺយកទៅទាំងថ្ងៃតែម្តង គេថាយកទៅ សេ.អ៊ី ហ្នឹង។"]។ ឯកសារ D114/239 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ម៉េន ឆ.22, ឆ.26 ["ខ្ញុំមិនស្គាល់ទេ អង្គាលនោះយកទៅច្រើនណាស់ [...] ឆ.26៖ ច្រើនណាស់ ផ្លាស់ក៏ផ្លាស់ បាត់ក៏បាត់។"]។

3017 ឯកសារ D114/86 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ. 4។

3018 ឯកសារ D54/90 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កុយ ណៃន ឆ.4 ["ស៖ តើប្រធានសហករណ៍ដែលជាប្រពន្ធរបស់យោធា បាននិយាយប្រាប់ប្រជាជននៅក្នុងមូលដ្ឋាន ដោយសារមូលហេតុអ្វី? ដោយសារគេចង់និយាយបន្លាច ឬបំភ័យប្រជាជន ឬក៏គេនិយាយរអេចរអូចជាធម្មតាទេ? ឆ.4៖ ពួកគេបាននិយាយរឿងទាំងនេះ ប្រាប់ទៅកាន់ប្រជាជនដើម្បីបំភិតបំភ័យ ប្រជាជនកុំឱ្យធ្វើអ្វីឱ្យមានកំហុស។"]។

3019 ឯកសារ D54/119 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ កែម ឆ.6។

734. ជនរងគ្រោះមិនមានលទ្ធភាពសម្តែងការតវ៉ា ឬបដិសេធមិនធ្វើការនោះឡើយ ហើយពួកគេក៏មិនហ៊ានធ្វើដូច្នោះដែរ[3020]។ "បន្ទាប់ពីយើងឮ [ថាឌឹមត្រូវបានចាប់ខ្លួន] យើងមិនហ៊ានធ្វើការតវ៉ាអ្វីឡើយ។ គេបញ្ជាឱ្យយើងធ្វើអ្វី យើងធ្វើហ្នឹង។ គេឱ្យយើងនៅកន្លែងណា យើងនៅកន្លែងនោះ។ [...] ខ្ញុំខ្លាចមានគ្រោះថ្នាក់ ពីព្រោះកម្មាភិបាលជាន់ខ្ពស់ទាំងអស់ត្រូវបានចាប់ខ្លួន"[3021]។ សាក្សីមួយរូបបានរៀបរាប់អំពីការបាត់ខ្លួនរបស់បុរសម្នាក់បន្ទាប់ពីគាត់បានត្អូញត្អែរថាកង្វះអាហារធ្វើឱ្យគាត់ខ្សោយ និងមិនអាចធ្វើការឱ្យបានខ្លាំងក្លា[3022]។ "អ្វីដែលយើងជួបប្រទះដែលមានប្រភពមកពីអង្គការ ដែលជាស្ថាប័នជាន់ខ្ពស់ យើងត្រូវតែទទួល យើងត្រូវតស៊ូអត់ធ្មត់ ហើយយើងមិនអាចត្អូញ

---

3020 ឯកសារ D54/120 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ កែម ឆ.3 ["សៈ តើមានស្ថាប័នណាមួយដូចជាតុលាការដែលប្រជាជនអាចប្តឹងផ្តល់ចំពោះសកម្មភាពណាមួយរបស់អង្គការបានដែរឬទេ? ឆ.3៖ កាលនោះ គ្មានអ្វីទាំងអស់ គឺយើងគ្មានឱកាសប្តឹងផ្តល់អ្វីទាំងអស់។"]។ ឯកសារ D114/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចេង ឡុង ឆ.24 ["យើងមិនអាចតវ៉ា បានទេ"]។ ឯកសារ D114/194 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ិន សុត ឆ.67 ["សៈ តើលោកអាចមានឱកាសជំទាស់ទៅនឹងការប្រព្រឹត្តចំពោះរូបលោក និងអ្នកដទៃបានដែរឬទេ? ឆ.67៖ អ្នកណាហ៊ានជំទាស់ អ្នកណាហ៊ាននិយាយ តែនិយាយយប់ឡើងបាត់ខ្លួនហើយ។"]។ ឯកសារ D114/89 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង ស៊ីន ឆ.89-92 ["សៈ មានអ្នកបដិសេធមិនធ្វើការទេ? ឆ.89៖ អត់មានទេ។ សៈ ហេតុអ្វី? ឆ.90៖ ព្រោះដល់ពេលគេប្រកាសថា មេសុទ្ធតែក្បត់ទាំងអស់អីចឹងហើយ យើងអត់ហ៊ាន យើងខ្លាច។ សៈ តើការដ្ឋានការងារលោកនោះ នៅកន្លែងណាដែរ? ឆ.91៖ នៅភូមិប្របុក។ សៈ តើមានពិន័យសម្រាប់អ្នកធ្វើការមិនបានល្អទេ? ឆ.92៖ កាលហ្នឹង បើសិនជា មានទោស គេបញ្ជូនទៅគុក។ គុកហ្នឹង យើងគ្រាន់តែមើលទៅ ឃើញហើយគេថាកន្លែងហ្នឹងគុក"]។ ឯកសារ D114/135 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ផន ឆ.41 ["ខ្ញុំខ្លាចថា គេនឹងដាក់ទោសខ្ញុំ។ គេនឹងចោទខ្ញុំថា ជាមនុស្សខ្ជិល ហើយប្រហែលជាយកខ្ញុំនៅកន្លែងផ្សេង។"]។ ឯកសារ D54/120 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ កែម ឆ.3 ["សៈ តើមានស្ថាប័នណាមួយដូចជា តុលាការដែលប្រជាជនអាចប្តឹងផ្តល់ចំពោះសកម្មភាពណាមួយរបស់អង្គការបានដែរឬទេ? ឆ.3៖ កាលនោះ គ្មានអ្វីទាំងអស់ គឺយើងគ្មានឱកាសប្តឹងផ្តល់អ្វីទាំងអស់។"]។

3021 ឯកសារ D54/97 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម យ៉ាត ឆ.29, ឆ.31។

3022 ឯកសារ D54/122 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាក់ សាផាន ឆ.6 ["កាលគេបញ្ជូនខ្ញុំទៅធ្វើទំនប់ ដើម្បីទប់ទឹកប្រែនៅតាមបណ្តាយព្រែកទឹកសាប ខ្ញុំបានឃើញ សារី ទៅត្រួតពិនិត្យមើលការសាងសង់ទំនប់នោះដែរ។ ដោយសារអត់អាហារ និងអស់កម្លាំង ប្រជាជនម្នាក់ដែលធ្វើការនៅទំនប់នោះ ចូកបានដីតិចតួចនឹងប៉ែល នៅពេល សារី ក៏បង្ហាញប្រាប់ថា ត្រូវចូកដីឱ្យបានច្រើនក្នុងប៉ែល ដូចគាត់ធ្វើឱ្យមើល តែបុរសម្នាក់នោះបានឆ្លើយមកវិញថា ដោយសារតែមិត្តហូបបាយ ហើយខ្ញុំមានតែបបរហូប បានធ្វើមិនបានដូចមិត្ត។ យប់ឡើង បុរសម្នាក់នោះក៏ត្រូវគេយកទៅបាត់ពីកន្លែងដែលគាត់ស្នាក់នៅ ហើយបាត់ខ្លួនរហូត។"]។

ត្អូរប្រាប់អ្នកណាម្នាក់ ឬស្ថាប័នណាមួយនោះឡើយ"[3023]។ ជនរងគ្រោះមួយរូបបានរៀបរាប់អំពីអារម្មណ៍ឯកោដែលកើតមានជាមួយ និងសេចក្តីភ័យខ្លាច និងការធ្វើបាប៖

> យើងទាំងអស់គ្នាដឹងថា គ្មានអ្នកណាម្នាក់អាចជួយពួកយើងបាននោះឡើយ ហើយយើងមិនអាចត្អូញត្អែរប្រាប់អ្នកណាម្នាក់ឡើយ។ ប្រសិនបើយើងត្អូញត្អែរ ឬនិយាយអំពីការផ្លាស់ចេញរឿងរ៉ាវពិតជាកាន់តែធ្ងន់ធ្ងរ ពួកគេអាចនឹងចោទថាយើងក្បត់ផងដែរ។ និយាយឱ្យខ្លី ជីវិតរបស់យើងស្ថិតនៅក្នុងកណ្តាប់ដៃរបស់ពួកគេ។ ហេតុដូច្នេះ នៅក្នុងស្ថានភាពបែបនោះ វិធីល្អបំផុតដើម្បីឱ្យយើងនៅរស់រានមានជីវិត គឺនៅស្ងៀមស្ងាត់ និងធ្វើតាមបញ្ជា[3024]។

735. ស្ថិតនៅក្នុងស្ថានភាពដ៏អាក្រក់បែបនេះ ជនរងគ្រោះមិនត្រូវបានគេផ្តល់ឱ្យសូម្បីតែភាពកក់ក្តៅដ៏សំខាន់របស់មនុស្ស ដូចជាគ្រួសារ[3025] ឬសាសនា[3026]។ ជាក់ស្តែង អ្នកដែលសម្តែងចេញនូវអារម្មណ៍ផ្ទាល់ខ្លួន នៅពេលមនុស្សជាទីស្រឡាញ់របស់ខ្លួនត្រូវបានគេនាំយកចេញទៅបាត់ ត្រូវគេដាក់ទណ្ឌកម្ម[3027]។ សាក្សីមួយរូបបានរៀបរាប់ដោយសង្ខេបថា "នៅសម័យនោះ ប្រជាជនផ្សេង

---

3023 ឯកសារ D54/120 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ កែម ឆ.3។

3024 ឯកសារ D114/86 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជេត ប៊ុណ្ណា ឆ. 9។

3025 ឯកសារ D114/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុំ វុទ្ធី ឆ.30 ["ដឹងក្រោយពេលដែលខ្ញុំទៅនៅកងចល័តហើយ។ ហើយខ្ញុំសុំទៅមើល គេអត់ឱ្យខ្ញុំទៅ។"]។ ឯកសារ D54/120 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ កែម ឆ.3 ["ពួកយើងមិនអាចទាក់ទងក្រុមគ្រួសារទេ ពួកយើងបានជួបគ្នាតែនៅពេលធ្វើការនៅតាមការដ្ឋានប៉ុណ្ណោះ ហើយនិយាយ និងផ្លាស់ប្តូរពាក្យសម្តីគ្នាបានតិចតួចបំផុត។"]។ ឯកសារ D114/121 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន ផ ឆ.35-36 ["អត់មានពេលសម្រាកទេគឺ ធ្វើការ ១ អាទិត្យ ឬ ១ ខែពេញតែម្តង។ [...] ឆ.36៖ យើងអត់អាចទៅលេង ឬសុំឈប់សម្រាកបានទេ។"]។

3026 ឯកសារ D54/120 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ កែម ឆ.3 ["ជំនឿសាសនា ក៏ដូចជាការរៀបការតាមបែបប្រពៃណីក៏ត្រូវបានហាមឃាត់ទាំងស្រុងដែរ។"]។

3027 ឯកសារ D114/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ឆ.40-41 ["បន្ទាប់គេយកប្តីបងស្រីជីដូនមួយខ្ញុំនិងខ្ញុំទៅបាត់ ហើយគេឃើញពួកខ្ញុំយំ គេដាក់ទណ្ឌកម្មពួកខ្ញុំឱ្យជាន់ដីឥដ្ឋឱ្យបានម្នាក់ ៨០០០ ដុំក្នុង ១ ថ្ងៃ នៅភូមិស្នាច់ដែង។ ខ្ញុំពុំមានបញ្ហាអ្វីទេ តែបងស្រីជីដូនមួយខ្ញុំ បានធ្លាក់ខ្លួនឈឺ ព្រោះទើបតែសម្រាលកូនហើយ ហើយគាត់បានស្លាប់ ៣ ថ្ងៃក្រោយមក ចំណែកកូនគាត់ក៏ស្លាប់ក្រោយមកដែរ។ [...] ឆ.41៖ គ្មានអ្នកណាយកគាត់ទៅមន្ទីរពេទ្យទេ គឺគេដាក់ទណ្ឌកម្មគាត់។ អ្នកដែលយំ ក្រោយពីគេយកប្តីរបស់ពួកគេទៅបាត់ គេនឹងគម្រាមថានឹងយកស្ត្រីៗទាំងនោះទៅភូមិពុទ្ធទេ ដែលជាកន្លែងសម្លាប់មនុស្ស ហើយវាស្ថិតនៅខាងកើតភូមិពូធឿង។"]។

ទៀត និងរូបខ្ញុំមានអារម្មណ៍ថាជីវិតគឺគ្មានប្រយោជន៍ឬគោលដៅទាល់តែសោះ។ [...] ជីវិតហាក់ដូចជាគ្មានពន្លឺទាល់តែសោះ”[3028]។

## ឆ.បទឧក្រិដ្ឋប្រល័យពូជសាសន៍ប្រឆាំងជនជាតិវៀតណាម

### ១. សេចក្ដីផ្ដើម

736. បទឧក្រិដ្ឋប្រល័យពូជសាសន៍ប្រឆាំងជនជាតិវៀតណាម ដែលត្រូវបានប្រព្រឹត្តដោយ **មាស មុត** សហចារីរបស់គាត់ និងអ្នកក្រោមបង្គាប់របស់គាត់ គឺជាផ្នែកមួយនៃយុទ្ធនាការប្រល័យពូជសាសន៍ទូទាំងប្រទេស ដែលត្រូវបានរៀបចំឡើងនៅថ្នាក់ខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យ និងត្រូវបានអនុវត្តនៅទូទាំងប្រទេសកម្ពុជា។ គោលនយោបាយប្រល័យពូជសាសន៍របស់របបនោះត្រូវបានបង្ហាញតាមរយៈសេចក្ដីថ្លែងការណ៍ជាសាធារណៈរបស់មេដឹកនាំ ដោយជំរុញឲ្យបំបាត់ឲ្យសាបសូន្យទាំងស្រុងនូវប្រជាជនវៀតណាមនៅក្នុងប្រទេសកម្ពុជា ព្រមទាំងភ័ស្តុតាងស៊ីចង្វាក់នៃគោលនយោបាយទូទៅនៅក្នុងឆ្នាំចុងក្រោយៗរបស់របបនោះ ក្នុងការសម្លាប់ជនជាតិវៀតណាមទាំងអស់នៅទូទាំងប្រទេស។

737. លទ្ធផលនៃគោលនយោបាយនេះ គឺ “ការបញ្ចប់ដោយជោគជ័យនូវបទឧក្រិដ្ឋប្រល័យពូជសាសន៍”[3029] ដោយជនជាតិវៀតណាម “ស្ទើរទាំងអស់” ដែលស្ថិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានសម្លាប់នៅត្រឹមចុងបញ្ចប់នៃរបបនោះ។[3030] ប៉ុល ពត ផ្ទាល់បានអួតអំពីលទ្ធផលទាំងនេះនៅក្នុង

---

[3028] ឯកសារ D54/120 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រំ កែម ឆ.3 [“សៈ តើមានស្ថាប័នណាមួយដូចជាតុលាការដែលប្រជាជនអាចប្ដឹងផ្ដល់ចំពោះសកម្មភាពណាមួយរបស់អង្គការបានដែរឬទេ? ឆ.3៖ កាលនោះ គ្មានអ្វីទាំងអស់ គឺយើងគ្មានឱកាសប្ដឹងផ្ដល់អ្វីទាំងអស់។ ក្នុងជំនាន់នោះ ខ្ញុំនិងប្រជាជនផ្សេងៗទៀត មានអារម្មណ៍ថា ជីវិតគឺគ្មានប្រយោជន៍ និងខ្លឹមសារអ្វីទាំងអស់ ឬអាចនិយាយថា កើតមកមួយជាតិធាតុមួយចាន។ ជីវិតហាក់ដូចជាគ្មានពន្លឺរស្មីអ្វីទេ”]។

[3029] ឯកសារ D234/2.1.100 ប្រតិចារឹក Alexander Hinton ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 11.00.45-11.03.20 [“វាក៏សំដៅផងដែរ អំពីការប្រព្រឹត្តដោយជោគជ័យ នូវអំពើប្រល័យពូជសាសន៍ […] ជនជាតិវៀតណាមទាំងអស់ត្រូវបានសម្លាប់ចោលនៅក្នុងរបបនោះ”]។

[3030] ឯកសារ D234/2.1.100 ប្រតិចារឹក Alexander Hinton ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 09.21.09-09.25.43 [“ក្រោយពីការបណ្ដេញចេញហ្នឹង គឺជនជាតិវៀតណាម ២០.០០០ នាក់ នៅសល់ក្នុងប្រទេសកម្ពុជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយក្រោយមក គេគិតថា អ្នកទាំងនោះត្រូវបានគេសម្លាប់ចោលដែរ។”]។

សុន្ទរកថាមួយនៅក្នុងខែ មេសា ឆ្នាំ ១៩៧៨ ដោយគាត់និយាយថា "មិនមានជនជាតិយួននៅក្នុងទឹកដីកម្ពុជាទេ។ ពីអតីតកាល មានពួកគេប្រហែល ១.០០០.០០០ នាក់។ ឥឡូវនេះ សូម្បីតែពួកគេមួយគ្រាប់ [...] ក៏រកមិនបានដែរ"[3031]។

## ២. ជនជាតិវៀតណាម ជាក្រុមជាតិពន្ធុជាច់ដោយឡែកមួយ

738. ជនជាតិវៀតណាមគឺជាក្រុមជាតិពន្ធុដាច់ដោយឡែកមួយនៅក្នុងប្រទេសកម្ពុជា ដោយគេអាចបែងចែកភាពខុសគ្នាពីក្រុមដទៃទៀតៗ តាមរយៈលក្ខណៈពិសេសដូចជា រូបរាងកាយ ភាសា និងទំនៀមទម្លាប់។ ដូចអ្វីដែលភស្តុតាងនៅក្នុងវគ្គនេះបង្ហាញ ពួកគេគិតថា ខ្លួនគេ និងត្រូវបានសង្គមកម្ពុជាគិតថា គឺជាក្រុមជាតិពន្ធុដាច់ដោយឡែកមួយ។

### គោលនយោបាយទូទៅប្រឆាំងនឹងជនជាតិវៀតណាម

739. ចាប់តាំងពីដើមរបស់កម្ពុជាប្រជាធិបតេយ្យ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានរៀបចំផែនការលុបបំបាត់សហគមន៍ជនជាតិវៀតណាមពីប្រទេសកម្ពុជា។ ក៏ប៉ុន្តែ យុទ្ធសាស្ត្រដើម្បីលុបបំបាត់ជនជាតិវៀតណាមពីប្រទេសកម្ពុជា មានពីរទម្រង់ និងបានវិវត្តន៍ប្រែប្រួលទៅតាមពេលវេលា។ នៅឆ្នាំដំបូងៗ របបនោះពឹងផ្អែកជាចម្បងទៅលើការនិរទេសជនជាតិវៀតណាមចេញពីប្រទេស[3032] ចំណែកនៅឆ្នាំក្រោយៗមក ជនជាតិវៀតណាមដែលត្រូវបានរកឃើញទាំងអស់នឹងត្រូវសម្លាប់។ ខ្មែរក្រហមបានបណ្តេញប្រជាជនស៊ីវិលវៀតណាមប្រហែល ១៥០.០០០ នាក់ នៅអំឡុងឆ្នាំទី១ នៃរបបកម្ពុជាប្រជាធិបតេយ្យ[3033] ដោយពួកគេមួយចំនួនត្រូវបានសម្លាប់រង្គាលនៅ

---

[3031] ឯកសារ D4.1.868 ទង់បដិវត្ត ខែ មេសា ឆ្នាំ ១៩៧៨ EN 00519836 KH 00064716-00064718។ សូមមើលផងដែរ ឯកសារ D114/277.10 ប្រតិចារឹក កាំង ហ្កេកអ៊ាវ ហៅ ឌុច ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង 15.32.26-15.35.50 ["[វៀតណាម] ក្រោយ ១៧ មេសា នៅសល់តិចណាស់។ ដូច្នេះ យូរបន្តិចមកអស់"]។

[3032] ខណៈពេលដែលការនិរទេស មិនត្រូវបានចោទប្រកាន់ថា ជាអំពើប្រល័យពូជសាសន៍ វាពាក់ព័ន្ធទៅនឹងការវាយតម្លៃនៃចេតនាឧក្រិដ្ឋ (mens rea) សម្រាប់អំពើប្រល័យពូជសាសន៍ក្នុងករណីនេះ។ សូមមើលសាលដីកានៃសំណុំរឿង Krstić កថាខណ្ឌ ៣១។

[3033] ឯកសារ D114/29.1.4 សៀវភៅនិពន្ធដោយ Ben Kiernan របបប៉ុល ពត EN 00678650 KH 00637821 ["បក្សកុម្មុយនីស្តកម្ពុជាបានបណ្តេញប្រជាជនស៊ីវិលវៀតណាមចំនួន ១៥០.០០០ នាក់ ចេញពីប្រទេសកម្ពុជានៅឆ្នាំ ១៩៧៥ [ខែ កញ្ញា]"]។ ឯកសារ D234/2.1.100 ប្រតិចារឹក Alexander Hinton ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 09.21.09-09.25.43 ["ទិន្នន័យដែលចេញពីកត្តាប្រជាសាស្ត្រនោះ គឺថាក្រោយពីការបណ្តេញចេញជាដំបូង ហើយ

ពេលកំពុងធ្វើដំណើរទៅប្រទេសវៀតណាម[3034]។ គេប៉ាន់ប្រមាណថា មានជនជាតិវៀតណាម ឬ ប្រជាជនខ្មែរកាត់វៀតណាមចំនួន ២០.០០០ នាក់ បន្តស្ថិតនៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីការបណ្តេញចេញ។ ប្រជាជនទាំងនោះស្ទើរតែទាំងអស់ត្រូវបានសម្លាប់នៅត្រឹមចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[3035]។

740. អ្នកជំនាញ លោក Alexander Hinton បានកត់សម្គាល់ថា "មនុស្សគ្រប់រូបសុទ្ធតែទទួលរងទុក្ខ [ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ] ប៉ុន្តែមានក្រុមមនុស្សមួយចំនួនដែលទទួលរងទុក្ខខ្លាំងជាង ហើយក្រុមមនុស្សមួយចំនួនត្រូវបានគេកំណត់គោលដៅជាចំហដើម្បីបំផ្លាញ[3036]។ ជនជាតិវៀតណាម ជាប្រចាំត្រូវបានខ្មែរក្រហម ចាត់ទុកថាជាខ្មាំង ដែលជាគ្រោះគំរាមកំហែងសម្រាប់ប្រទេសកម្ពុជា។ គ្រាន់តែជាជនជាតិវៀតណាម គឺជាហេតុផលគ្រប់គ្រាន់សម្រាប់ឱ្យកម្មាភិបាលបក្សកុម្មុយនីស្ត កម្ពុជា សម្លាប់បុរសម្នាក់ ស្ត្រីម្នាក់ ឬកុមារម្នាក់[3037]។

---

ក្រោយពេលចាប់ផ្តើមរបបកម្ពុជាប្រជាធិបតេយ្យភ្លាម គឺថាមានជនជាតិវៀតណាមប្រហែលជា ២០.០០០ នាក់ នៅក្នុងប្រទេសកម្ពុជាប្រហែលជា ១៥០.០០០នាក់ ឬក៏ច្រើនជាងនេះ ត្រូវបានបណ្តេញចេញ"]។

[3034] ឯកសារ D114/29.1.4 សៀវភៅនិពន្ធដោយ Ben Kiernan របបប៉ុល ពត EN 00678650 KH 00637822 ["តាមការដកស្រង់សម្តីសមាជិកកងម៉ារីនកម្ពុជាប្រជាធិបតេយ្យ ៣ រូប ដែលបានរាយការណ៍ថា ជនភៀសខ្លួនវៀតណាមដែលស្វះស្វែងគេចខ្លួនចេញពីប្រទេសកម្ពុជានៅខែ មិថុនា ឆ្នាំ ១៩៧៥ ត្រូវបានគេសម្លាប់នៅកំពត]។ ឯកសារ D234/2.1.100 ប្រតិចារឹក Alexander Hinton ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 09.21.09-09.25.43 ["គឺថាមានជនជាតិវៀតណាមប្រហែលជា ២០.០០០ នាក់ នៅក្នុងប្រទេសកម្ពុជាប្រហែលជា ១៥០.០០០នាក់ ឬក៏ច្រើនជាងនេះ ត្រូវបានបណ្តេញចេញពីប្រទេសកម្ពុជា ហើយអ្នកខ្លះត្រូវបានគេប្រាប់ថា ត្រូវគេសម្លាប់ចោល។"]។

[3035] ឯកសារ D234/2.1.100 ប្រតិចារឹក Alexander Hinton ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 09.21.09-09.25.43 ["ក្រោយពីការបណ្តេញចេញហ្នឹង គឺជនជាតិវៀតណាម ២០.០០០ នាក់ នៅសល់ក្នុងប្រទេសកម្ពុជា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយក្រោយមក គេគិតថា អ្នកទាំងនោះត្រូវ បានគេសម្លាប់ចោលដែរ។"]។

[3036] ឯកសារ D234/2.1.100 ប្រតិចារឹក Alexander Hinton ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 13.50.34-13.55.37។

[3037] ឯកសារ D234/2.1.21 Elizabeth Do ការប្រព្រឹត្តចំពោះជនជាតិភាគតិចវៀតណាម ក្នុងរបបកម្ពុជាប្រជាធិបតេយ្យពី ទស្សនៈវិស័យប្រៀបធៀប EN 00548857–00548859 KH 00768962-00768964 ["ទោះបីជនជាតិភាគតិចវៀតណាមមួយចំនួន បានរស់រានមានជីវិតពីរបបខ្មែរក្រហមក៏ដោយ ក៏ការរស់រានទេះគឺ ជាការលើកលែងប៉ុណ្ណោះ មិនមានជាបទបញ្ញាទេ។ តាមពិត អ្នកផ្តល់បទសម្ភាសន៍ច្រើនលើសលុប បញ្ចេញគំនិតផ្ទាល់ខ្លួនថា ប្រសិនបើពួកខ្មែរក្រហមស្គាល់នរណាម្នាក់ថា ជាវៀតណាមនោះ អ្នកនោះត្រូវបាត់ខ្លួន ឬត្រូវបានយកទៅសម្លាប់ដោយគ្មានសាកសួរអ្វីឡើយ។ [...] អ្នកផ្តល់បទ សម្ភាសន៍ក៏បានបញ្ជាក់ផងដែរថា ប្រសិនបើពួកខ្មែរក្រហមរកឃើញថា 'ជនជាតិភាគតិចវៀតណាមដែលបន្តស្នាក់នៅក្នុងប្រទេសកម្ពុជាទទួលរងការគម្រាមកំហែងនៅចំពោះមុខដល់ជីវិតរបស់ខ្លួនជាងក្រុម

បណ្ដេញចេញ និងកម្ទេច៖ គោលនយោបាយបក្សកុម្មុយនីស្ដកម្ពុជាកម្ទេចជនជាតិវៀតណាម

741. ផែនការលុបបំបាត់ជនជាតិវៀតណាមទាំងអស់ចេញពីប្រទេសកម្ពុជា ត្រូវបានប្រកាសប្រាប់ដល់មេដឹកនាំខ្មែរក្រហមនៅក្នុងមហាមេទ្ធិញពីថ្ងៃទី ២០ ដល់ ២៥ ខែ ឧសភា ឆ្នាំ ១៩៧៥ នៅក្នុងទីក្រុងភ្នំពេញ[3038]។ ប៉ុល ពត "បាននិយាយសង្កត់ធ្ងន់អំពីសារៈសំខាន់នៃការជម្លៀសជនជាតិវៀត

---

ផ្សេងៗទៀត ពីព្រោះគោលនយោបាយ ប្រឆាំងនឹងពួកគេមិនអត់ឱនដល់អត្តិភាពរបស់ជនជាតិភាគតិចវៀតណាមសោះឡើយ'។ ដួង បំភ្លឺចំណុចនេះជាលាយលក្ខណ៍ អក្សរថា 'របបនេះ មិនបានអនុញ្ញាតិឲ្យជនជាតិភាគតិចវៀតណាម មានជម្រើសណាមួយសម្រាប់បិទបាំងអត្តសញ្ញាណជនជាតិភាគតិចរបស់ខ្លួន ដើម្បីគេចផុតពីការសម្លាប់ឡើយ។ កម្មាភិបាលខ្មែរក្រហមម្នាក់បានអះអាងថា 'ប្រសិនបើបុគ្គលម្នាក់ ជាជនជាតិវៀតណាម បុគ្គលនោះពិតជាមិនអាចរួចពីការសម្លាប់ឡើយ។ នៅពេលពួកខ្មែរក្រហមរកឃើញថា ពួកគេជាវៀតណាមហើយ ពេលនោះពួកគេនឹងត្រូវស្លាប់ហើយ'"]។

3038 ឯកសារ D98/1.2.32 ប្រតិចារឹក សៅ សារុន ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១២ ម៉ោង 11.24.29-11.25.58 ["អាហ្នឹងគឺឮគេនិយាយមែន ពីព្រោះថាដឹកវៀតណាមទៅស្រុកវិញ"]។ ការបញ្ជាក់បន្ថែម ឯកសារ D4.1.624 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ សារុន EN 00348375 KH 00345906 ["សៈ តើមាននិយាយអំពីរឿងដេញវៀតណាមចេញពីស្រុកខ្មែរឲ្យអស់? ឆ៖ មាននិយាយមែន ហើយអ្នកនិយាយគឺ ប៉ុល ពត។ ពេលក្រោយមក ខ្ញុំឮតាមកម្មាភិបាលថ្នាក់ក្រោមខ្ញុំប្រាប់ថា មានឡានដឹកវៀតណាមចេញទៅស្រុកវិញមែន ពីខេត្តកំពង់ចាម និងក្រចេះ។"]។ ឯកសារ D4.1.989 បទសម្ភាសន៍ ជាមួយ ជា ស៊ីម ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ១៩៩១ EN 00651867–00651868 KH 00713928-00713929 ["ប៉ុល ពត [...] និយាយច្រើនអំពីបញ្ហាវៀតណាម។ គាត់សង្កត់ធ្ងន់លើសារៈសំខាន់នៃបញ្ហាជម្លៀសប្រជាជនវៀតណាមទាំងអស់ចេញពីដែនដីខ្មែរ។ [...] យើងបានឮគេនិយាយគ្រប់ទីកន្លែងថា វៀតណាម គឺជាសត្រូវបន្តិចម្តងៗ។ [...] មានតែ ប៉ុល ពត និង នួន ជា ប៉ុណ្ណោះ ដែលនិយាយបែបនេះ នៅក្នុងសុន្ទរកថាទៅកាន់សាលានយោបាយ។ [...] ជម្លោះនេះ បានក្លាយជាជម្លោះបដិបក្ខនៅឆ្នាំ ១៩៧៥ [...] ពីព្រោះនៅពេលនោះ ប្រជាជនវៀតណាមត្រូវបានបណ្ដេញចេញពីទឹកដីកម្ពុជា។ ដូច្នេះ វាក្លាយជាជម្លោះបដិបក្ខ។"]។ ឯកសារ D114/29.1.4 សៀវភៅនិពន្ធដោយ Ben Kiernan របបប៉ុល ពត EN 00678522 KH 00637442 [បញ្ជីនៃចំណុចសំខាន់ចំនួន ៨ ដែលបានធ្វើឡើងនៅថ្ងៃទី ២០ ដល់ ២៥ ខែ ឧសភា ឆ្នាំ ១៩៧៥ ដោយផ្អែកលើការសម្ភាសន៍របស់អ្នកចូលរួមច្រើននាក់ ក្នុងនោះរួមមានចំនុចទី ៧៖ ការបណ្ដេញប្រជាជនជនជាតិភាគតិចវៀតណាមទាំងមូល]។ សូមមើលផងដែរ ឯកសារ D98/1.2.17 ប្រតិចារឹក កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១២ ម៉ោង 11.22.48-11.25.06 ["ប៉ុល ពត ដេញរុញទាំងកងទ័ព ទាំងអ្នកមន្ទីរ ទាំងអាណិកជន ទៅអស់។"]។

ណាមទាំងអស់ចេញផុតពីទឹកដីកម្ពុជា"[3039]។ នួន ជា បាននិយាយថា "យើងមិនអាចអនុញ្ញាតឱ្យជនជាតិភាគតិចវៀតណាម" រស់នៅក្នុងប្រទេសកម្ពុជាឡើយ[3040]។

742. យោងតាម មាស មឿន ដែលជាអនុមេបញ្ជាការកងពលធំលេខ១ របស់ភូមិភាគបស្ចិម[3041] "ចំណុចសំខាន់" អំពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា គឺថា "យួនមិនត្រូវបានអនុញ្ញាតឱ្យរស់នៅក្នុងប្រទេសកម្ពុជាឡើយ"[3042]។ ទស្សនាវដ្ដីទង់បដិវត្តន៍ ខែ មេសា ឆ្នាំ ១៩៧៦ បានបង្ហាញអំពីការរីកចម្រើននៃការលុបបំបាត់ជនជាតិវៀតណាមចេញពីប្រទេសកម្ពុជា ដោយកត់សម្គាល់ថា ខ្មែរក្រហម "បានបោសសម្អាតជនជាតិបរទេសរាប់សែននាក់ និងបានបណ្ដេញពួកគេចេញពីប្រទេសកម្ពុជា"[3043]។

743. ការសម្លាប់កើតឡើងទន្ទឹមពេលគ្នានឹងការបណ្ដេញចេញ[3044]។ ក្នុងអំឡុងពីខែ មេសា រហូតដល់ខែ ឧសភា ឆ្នាំ ១៩៧៥ មេបញ្ជាការមួយរូបបានបញ្ជូនសំណើទៅថ្នាក់លើនៅកំពង់សោម ដើម្បីសុំ

---

[3039] ឯកសារ D114/29.1.4 សៀវភៅនិពន្ធដោយ Ben Kiernan របបប៉ុល ពត EN 00678524 KH 00637445-00637448។

[3040] ឯកសារ D114/29.1.4 សៀវភៅនិពន្ធដោយ Ben Kiernan របបប៉ុល ពត EN 00678524 KH 00637447 ["លេខាធិការបក្សរូបនេះ ពិតជាបានសង្កត់ធ្ងន់លើចំណុចខ្លាំង និងពិសេសមួយ។ យោងតាម ជា ស៊ីម ថា 'ប៉ុល ពត បាននិយាយច្រើនអំពីបញ្ហា វៀតណាម។ ប៉ុល ពត សង្កត់ធ្ងន់អំពីសារសំខាន់នៃបញ្ហាជម្លៀសប្រជាជនវៀតណាមទាំងអស់ចេញពីទឹកដីកម្ពុជា'។ ហេង សំរិន បានរំលឹកឱ្យដឹងពីសម្ដីរបស់ នួន ជា ដែលថា 'យើងមិនអាចបណ្ដោយឱ្យជនជាតិភាគតិចវៀតណាម រស់នៅក្នុងប្រទេសកម្ពុជាបានទេ"'។]។

[3041] ឯកសារ D234/2.1.95 ប្រតិចារឹក មាស មឿន ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 13.53.04-13.55.03 ["ស៖ តើលោកបានក្លាយទៅជាអនុបញ្ជាការកងពលលេខ១ ហើយកងពលលេខ១នេះ គឺចំណុះឱ្យភូមិភាគបស្ចិម ដែលគ្របដណ្ដប់ឆ្នេរខេត្តកោះកុងផង តើត្រឹមត្រូវដែរទេ? ឆ៖ បាទ ត្រឹមត្រូវ។"]។

[3042] ឯកសារ D234/2.1.96 ប្រតិចារឹក មាស មឿន ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១៦, ម៉ោង 09.24.01-09.26.03។

[3043] ឯកសារ D4.1.883 ទង់បដិវត្ត ខែ មេសា ឆ្នាំ ១៩៧៦ EN 00517854 KH 00062749។

[3044] ឯកសារ D234/2.1.113 ប្រតិចារឹក ប្រាក់ ខន ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង 09.12.09-09.16.18 ["នៅសម័យ ៧៧, ៧៨ ហ្នឹងគឺខ្ញុំស្ទូមវង់ក្រចកបន្តិច ពីព្រោះជនជាតិភាគតិច គឺជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជាគឺអត់មានទេ។ គឺអ្នកមានមុនៗមក អ្នកណារត់ទៅស្រុកទាន់ក៏ទាន់ អ្នកណារត់មិនទាន់គឺសម្លាប់ចោលអស់ហើយ តាំងពីសម័យ ៧៥មក"]។

"ការណែនាំអំពីការបណ្តេញ" ជនភៀសខ្លួនជនជាតិវៀតណាមជាង១០នាក់[3045]។ ជាការឆ្លើយតប "មេបញ្ជាការជាន់ខ្ពស់នៅកំពង់សោមបានបញ្ជាមេបញ្ជាការរូបនោះឱ្យសម្លាប់ជនភៀសខ្លួនទាំងនោះ។ មេបញ្ជាការរូបនោះ និងអនុរបស់គាត់បានអនុវត្តបទបញ្ជានោះ"[3046]។ នៅឆ្នាំ ១៩៧៦ អាជ្ញាធរមូលដ្ឋាន បានចាប់ផ្តើមនាំយកជនជាតិវៀតណាមចេញទៅបាត់ ក្រោមលេសដូចជា យកទៅអប់រំ ផ្លាស់ទីលំនៅ ធ្វើការងារ ឬត្រូវចាប់ខ្លួន ហើយនៅពេលក្រោយមក ជនជាតិវៀតណាមទាំងនោះបានបាត់ខ្លួន[3047]។ មាស វឿន បានអះអាងបញ្ជាក់ថា ក្នុងចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ "[ជនជាតិវៀតណាម] ត្រូវបានគេប្រមូលផ្តុំ និងបញ្ជូនទៅថ្នាក់លើ"[3048]។ សាក្សីជាច្រើនបានផ្តល់សក្ខីកម្មថា អ្នក "ដែលត្រូវគេប្រមូល" ត្រូវគេយកទៅសម្លាប់ ដោយស្របតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា[3049]។ អ្នកទោសជនជាតិវៀតណាមស្ទើរតែទាំងអស់ ដែល

---

[3045] ឯកសារ D4.1.754 សារព័ត៌មានអាមេរិកពាក់ព័ន្ធនឹងឧបទ្ទវហេតុនាវា Mayaguez និងការស៊ើបអង្កេត នៅកោះតាង ខែ ធ្នូ ឆ្នាំ ១៩៧៥ EN 00387429 KH 00791383 ["ក្រោយពីប្រភពព័ត៌មានបានបោះទីតាំងនៅលើកោះប៉ូឡូវ៉ៃថ្មី នៅក្នុងខែ មេសា ឧសភា ឆ្នាំ ១៩៧៥ អង្គភាពរបស់គាត់បានចាប់នាវាមួយគ្រឿង ដែលបានដឹកជនភៀសខ្លួនវៀតណាមជាង ១០ នាក់ រួមទាំងស្ត្រី និងកុមារ។ [...] បន្ទាប់ពីពួកគេចាប់បាននាវានោះមក មេបញ្ជាការកងអនុសេនាធំលេខ ៤០៨ បាកទាក់ទងក្រុងកំពង់សោម ដើម្បីសុំការណែនាំស្តីពីការចាត់ចែងជនភៀសខ្លួនទាំងនោះ។"]។

[3046] ឯកសារ D4.1.754 សារព័ត៌មានអាមេរិកពាក់ព័ន្ធនឹងឧបទ្ទវហេតុនាវា Mayaguez និងការស៊ើបអង្កេត នៅកោះតាង ខែ ធ្នូ ឆ្នាំ ១៩៧៥ EN 00387429 KH 00791383 ["មេបញ្ជាការថ្នាក់លើនៅក្រុងកំពង់សោម បានបញ្ជាឱ្យមេបញ្ជាការ អនុសេនាធំនេះ សម្លាប់ជនភៀសខ្លួនទាំងនោះចោល។"]។

[3047] ឯកសារ D234/2.1.21 Elizabeth Do ការប្រព្រឹត្តចំពោះជនជាតិភាគតិចវៀតណាម ក្នុងរបបកម្ពុជាប្រជាធិបតេយ្យពី ទស្សនៈវិស័យប្រៀបធៀប EN 00548856 KH 00768962 ["អ្នកផ្តល់បទសម្ភាសន៍ខ្លះបានបញ្ជាក់ថា ចាប់ពីប្រហែលជាឆ្នាំ ១៩៧៦ ឬឆ្នាំ ១៩៧៧ ពួកខ្មែរក្រហមបានចាប់ផ្តើមប្រមូលជនជាតិវៀតណាម នៅក្នុងភូមិរបស់ពួកគេ។ អ្នកផ្តល់បទសម្ភាសន៍ទាំងនេះបាននិយាយថា នៅពេលកម្មាភិបាលខ្មែរក្រហមនាំជនជាតិវៀតណាមចេញ ពួកគេបានប្រើប្រាស់លេសផ្សេងៗដូចជា ការបញ្ជូនទៅរៀនសូត្រ ការផ្លាស់ទៅកន្លែងផ្សេង ការងារ និងការចាប់ខ្លួន។ ជាទូទៅ មនុស្សដែលត្រូវបានពួកខ្មែរក្រហមដឹកតាមរទេះសេះចេញពីភូមិ មិនធ្លាប់បានឃើញវិលត្រឡប់មកវិញឡើយ។ អ្នកផ្តល់បទ សម្ភាសន៍ដែលផ្តល់បទសម្ភាសន៍អំពីការបាត់ខ្លួនជនជាតិវៀតណាមក្នុងភូមិរបស់គេ បាននិយាយថា នៅចុងឆ្នាំ ១៩៧៧ ឬឆ្នាំ ១៩៧៨ ជនជាតិវៀតណាមភាគច្រើនបានបាត់ខ្លួន។"]។

[3048] ឯកសារ D234/2.1.96 ប្រតិចារឹក មាស វឿន ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១៦, ម៉ោង 09.13.46-09.16.14 ["តែដល់យួននៅកម្ពុជានោះ ក៏ត្រូវមានការប្រមូល"]។

[3049] សូមមើលឧទាហរណ៍ ឯកសារ D234/2.1.80 ប្រតិចារឹក ស៊ាន ស៊ង់ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥ ម៉ោង 09.59.20-10.21.13 ["អម្បាញ់មិញ លោកបានឆ្លើយរួចហើយថា ដឹងឮផ្ទាល់ពីប្រធានភូមិស្តីអំពីការសម្លាប់ជនជាតិ

ត្រូវបានគេផ្ទេរពីកំពង់សោមទៅ ស-២១ នៅថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ១៩៧៦ និងត្រូវគេសម្លាប់ក្នុងរយៈពេលពីរបីសប្តាហ៍ បន្ទាប់ពីពួកគេទៅដល់ទីនោះ ក្នុងការសម្លាប់រួមគ្នាមួយ ដែលត្រូវបានធ្វើឡើងនៅថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ១៩៧៦[3050]។

744. នៅត្រឹមឆ្នាំ ១៩៧៧ របបនោះបានប្រើប្រាស់ការកាប់សម្លាប់ធ្វើជាមធ្យោបាយបោសសម្អាតជនជាតិវៀតណាមទាំងអស់ពីកម្ពុជាប្រជាធិបតេយ្យ[3051]។ មាស វឿន បានផ្តល់សក្ខីកម្មថា "យើងត្រូវបានគេបញ្ជាថា ត្រូវកម្ទេចជនជាតិវៀតណាមទាំងអស់ ពីព្រោះពួកគេមិនអាចត្រឡប់ទៅប្រទេសរបស់ពួកគេវិញនោះឡើយ[3052]។ ប៉ាក សុក ដែលជាសមាជិកកងពលជើងទឹកលេខ១៦៤ របស់កម្ពុជាប្រជាធិបតេយ្យ[3053] និងជាអ្នកក្រោមបង្គាប់ **មាស មុត** បានផ្តល់ភ័ស្តុតាងបន្ថែម ដែល

---

វៀតណាម។ [...]ចម្លើយរបស់គាត់ថា តាមខ្ញុំដឹង ប្រធានភូមិថា ទទួលបញ្ជាពីថ្នាក់លើ ប៉ុន្តែ "ខ្ញុំមិនបានដឹងថា ជាបញ្ជាមកថ្នាក់ស្រុក ឬថ្នាក់ណានោះទេ"។ តើគាត់នៅទទួលស្គាល់ ឬបដិសេធ? [...] ឆ៖ ពិតមែន។"]។

3050 ឯកសារ D114/230.1.1 បញ្ជីអ្នកទោសមន្ទីរស២១ ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត លេខរៀង ៥៩២-៥៩៣, ៥៩៦-៥៩៧, ៦០៤, ៦២៥, ៦៥៣, ៦៦៣, ៦៧៦, ១៣៤៣២-១៣៤៣៤, ១៣៤៣៦-១៣៤៣៧, ១៣៦៤២-១៣៦៤៣។

3051 ឯកសារ D114/29.1.4 សៀវភៅនិពន្ធដោយ Ben Kiernan របបប៉ុល ពត EN 00678650 KH 00637822-00637823 ["បន្ទាប់មក នៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៧៧ មជ្ឈិមបានផ្សព្វផ្សាយឱ្យអនុវត្តមកណែនាំមួយ ដែលមានលក្ខណៈច្បាស់លាស់បំផុត។ ដោយស្ថិតនៅតែឯងក្នុងរយៈពេល ២-៣ នាទី នៅពេលដែលរងចាំជួបប្រធានស្រុកឧត្តុង្គ (តំបន់ ១៥ នៃភូមិភាគបស្ចិម) ក្នុងមន្ទីរធ្វើការរបស់គាត់នោះ ជាងជួសជុលម៉ាស៊ីនម្នាក់ឈ្មោះ រស់ សារឿន បានលួចមើលមតិណែនាំនេះដោយស្ងាត់កំបាំង។ 'មតិណែនាំ ៨៧០'នេះ (៨៧០ ជាលេខសម្ងាត់សម្រាប់មជ្ឈិម បក្សកុម្មុយនីស្តកម្ពុជា) បានបញ្ជាឱ្យអ្នកទទួលខុសត្រូវមូលដ្ឋាននានា ចាប់ខ្លួនពួកជាប់ខ្សែស្រឡាយវៀតណាមទាំងអស់ ហើយប្រគល់ទៅឱ្យផ្នែកសន្តិសុខរបស់រដ្ឋ។ សារឿន បានប្រញាប់ប្រញាល់ ត្រឡប់មកផ្ទះវិញ ដើម្បីប្រាប់ប្រពន្ធរបស់គាត់ដែលជាជនជាតិវៀតណាមឱ្យដឹងជាមុន។ ប៉ុន្តែ ដូចដែល ណាយ៉ាន់ ចាន់ដា រាយការណ៍ឱ្យដឹងពីរឿងនេះដែរថា នាងបានដឹងពីអ្វីដែលត្រូវប្រកាន់យករួចស្រេចទៅហើយ។ 'ស្ត្រីវៀតណាមម្នាក់ទើបនឹងត្រូវគេសម្លាប់ដោយពួកខ្មែរក្រហមវាយក្បាលនឹងព្រនង់ ហើយយកខ្មោចទៅកប់នៅក្រៅភូមិ។ ប្តីនាងជាជនជាតិខ្មែរ ត្រូវគេបញ្ជូនទៅកាប់ឈើនៅក្នុងព្រៃតាំងពីមុនម្ល៉េះ'។ គាត់បានរកឃើញសាកសពប្រពន្ធរបស់ខ្លួន នៅពេលក្រោយនោះបន្តិច។ ប្រពន្ធរបស់ សារឿន បានសម្រេចជោគជ័យក្នុងការលាក់អត្តសញ្ញាណរបស់នាង។"]។ សូមមើលផងដែរ ឯកសារ D4.1.564 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថេង ហ៊ុយ EN 00233300 ["បន្ទាប់មកទៀត ប្រហែលនៅចុងឆ្នាំ ១៩៧៦ និងដើមឆ្នាំ ១៩៧៧ (មុនព្រឹត្តិការណ៍ សោ ភឹម) មានការសម្លាប់គ្រួសារជនជាតិវៀតណាម។"]។

3052 ឯកសារ D234/2.1.95 ប្រតិចារឹក មាស វឿន ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 15.55.51-16.03.07។

3053 ឯកសារ D114/297.1.20 ប្រតិចារឹក ប៉ាក សុខ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 09.49.04-10.00.46។

បង្ហាញនូវបទបញ្ជាឲ្យសម្លាប់ជនជាតិវៀតណាមទាំងអស់ ដែលស្ថិតនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ គាត់បានបញ្ជាក់ថា វគ្គបណ្ដុះបណ្ដាលដែលតម្រូវឲ្យចូលរួមត្រូវបានរៀបចំនៅគ្រប់វរសេនាតូចទាំងអស់នៅក្នុងកងពលលេខ១៦៤ នៅដើមឆ្នាំ ១៩៧៧[3054] ដោយនៅក្នុងវគ្គបណ្ដុះបណ្ដាលទាំងនោះ "យើងត្រូវបានគេបញ្ជាឲ្យសម្លាប់ [ជនជាតិវៀតណាម] ទោះបីជាកូនក្មេងក៏ដោយ ពីព្រោះពួកគេគឺជាសត្រូវស្លូតបូជរបស់យើង ដូច្នេះយើងត្រូវសម្លាប់ពួកគេ"[3055]។

745. គោលនយោបាយប្រឆាំងជនជាតិវៀតណាមត្រូវបានផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ សុន្ទរកថា និងឯកសារលាយលក្ខណ៍អក្សរ។ ខ្លឹមសារនៃទស្សនាវដ្ដីទង់បក្សដិវត្តន៍ ដែលជាទស្សនាវដ្ដីគោលនយោបាយ និងឃោសនារបស់បក្ស ត្រូវបានគេយកទៅឲ្យថ្នាក់ក្រោមបំផុតរបស់បក្សសិក្សារៀនសូត្ររួមគ្នា និងដាច់ដោយឡែកពីគ្នា[3056]។ មជ្ឈិមទទួលព័ត៌មានថ្មីៗជាទៀងទាត់អំពីការអនុវត្តគោលនយោបាយនោះ[3057]។ សារទូរលេខមួយបានរៀបរាប់លម្អិតអំពីការចាប់ខ្លួន ការសួរចម្លើយ

---

[3054] ឯកសារ D114/297.1.20 ប្រតិចារឹក ប៉ាក សុខ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 13.34.17-13.37.45 ["សៈ តើយោធាទាំងអស់ ហើយនិងកងនារីកទាំងអស់នៅក្នុងវរសេនាតូច ត្រូវបានតម្រូវឲ្យគេចូលរួមវគ្គសិក្សាហ្នឹងទាំងអស់ដែរឬទេ តាមអ្វីដែលលោកចាំនោះ? ឆៈ បានជាគោលដៅរបស់បក្សកុម្មុយនីស្តកម្ពុជានោះ គឺថាប្រកាសទូទៅ ទូទាំងអស់នៅក្នុងកងពល ១៦៤ តែម្ដង។"]។ ឯកសារ D114/297.1.21 ប្រតិចារឹក ប៉ាក សុខ ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 14.15.03-14.18.59 ["សៈ សំនួរទី២របស់ខ្ញុំ ទាក់ទងនឹងពេលវេលាដែលលោករៀនអំពីថា កម្ពុជា វៀតណាម ជាសត្រូវស្លូតបូជហ្នឹងអំឡុងពេលណា? ឆៈ បាទ! ដើមឆ្នាំ ៧៧ គឺថា បានបើកវគ្គសិក្សាផ្សព្វផ្សាយពេញទំហឹងតែម្ដងនៅក្នុងអង្គភាពរបស់ខ្ញុំ"]។

[3055] ឯកសារ D114/297.1.20 ប្រតិចារឹក ប៉ាក សុខ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 13.34.17-13.40.06។

[3056] ឯកសារ D4.1.862 ទង់បដិវត្ត ខែ មេសា ឆ្នាំ ១៩៧៧ EN 00478506 KH 00062998 ["គ្រប់មូលដ្ឋាន និងគ្រប់អង្គភាពទាំងអស់ត្រូវចាត់តាំងរៀនសូត្រ ឯកសារនេះ។ [...] សមូហភាព សំខាន់ ហើយរៀនផ្ទាល់តាមក្រុម ឬបុគ្គលថែមទៀត។"]។

[3057] ឯកសារ D1.3.34.37 សារទូរលេខ លេខ ៥៩ ពី ឆុន ទៅ មន្ទីរ ៨៧០ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៧៧ EN 00185187 KH 00020874 ["នៅថ្ងៃទី ២៧ ខែ តុលា [ឆ្នាំ ១៩៧៧] អាខ្មាំងយួនមួយក្បាល វាគក់ស្ពតឡើងពួនលើផ្ទះប្រជាជន ត្រូវប្រជាជនយើងចាប់បាន រួមមាន ៣ ក្បាល។ យើងកំពុងសួរយកចម្លើយ។"]។ ឯកសារ D4.1.733 ទូរលេខ ៩៥ ពី យី ទៅ មន្ទីរ ៨៧០ ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៧ EN 00143562 KH 00021508 ["ដូចរាយការណ៍មុនៗ សភាពពីខាងក្រៅយួន ចេះតែរត់ចូលមកជាបន្តបន្ទាប់ ខាងយើងខ្ញុំក្រោយនេះ ចាប់បាន ៥ នាក់ ទៀត។ ២ នាក់ ចាប់នៅផ្លូវ ១៤ ៣នាក់ទៀត ចាប់បាននៅឃុំសំបុក ហើយកំពុងដេញតាមអា ៤ នាក់ នៅឃុំស្រែជិះ។ ឯសភាពការណ៍រុករក នៅព្រែកបោ មិនទាន់បាន ដំណឹង។"]។ ឯកសារ D4.1.303 សារទូរលេខ ៤៧ ពីសារុន ទៅ មន្ទីរ ៨៧០ ថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៧៨ EN 00324809 KH 00021054 ["យើងខ្ញុំសូមរាយការណ៍ពីស្រុក

និងការសម្លាប់ជនជាតិវៀតណាម[3058]។ ឧទាហរណ៍ នៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៧៨ **មាស មុត** បានផ្ញើសារទូរលេខមួយច្បាប់ទៅកាន់មេដឹកនាំជាន់ខ្ពស់របស់របបកម្ពុជាប្រជាធិបតេយ្យ ដោយរៀបរាប់លម្អិតអំពីការចាប់ខ្លួន និងការសម្លាប់ "យួន" ១២០នាក់ ក្នុងរយៈពេលបីថ្ងៃ នៅចុងខែ មីនា ឆ្នាំ ១៩៧៨[3059]។ ផ្ទុយទៅវិញ របាយការណ៍ដដែលបានរៀបរាប់លម្អិតអំពីការដោះលែងមនុស្សមកពីប្រទេសថៃ ដែលត្រូវបានចាប់ខ្លួន[3060]។

746. បក្សកុម្មុយនីស្តកម្ពុជា ណែនាំការអនុវត្តគោលនយោបាយនោះ។ នៅខែ ឧសភា ឆ្នាំ ១៩៧៨ រស់ ញឹម បានស្នើសុំការណែនាំពីមន្ទីរ៨៧០ អំពីរបៀបដោះស្រាយជាមួយនឹង "សមាសភាព ដូចជា [...] ជនជាតិវៀតណាម ប្តីជនជាតិខ្មែរ ដែលមានប្រពន្ធជាជនជាតិវៀតណាម ឬ ប្តីជនជាតិវៀតណាមដែលមានប្រពន្ធជាជនជាតិខ្មែរ និងប្រជាជនខ្មែរកាត់វៀតណាម"[3061]។ ខណៈកំពុងរង់ចាំ

---

ប្រជាជនយួនរត់មកចំនួន ៩ នាក់ តាមសួរចម្លើយ របស់វា គឺវាថាយួនចាត់ចែងឲ្យវាមកស៊ើបការណ៍ នៅក្នុងប្រទេសកម្ពុជា នឹងមករស់នៅ នឹងប្រជាជនកម្ពុជា ដើម្បីក្តាប់ប្រជាជន ឥឡូវ នេះបានបោសសំអាតវាហើយ។"]។ ឯកសារ D1.3.34.60 សារទូរលេខ ០០ មកពី មុត ទៅ គណៈ ម.៨៧០ ថ្ងៃទី ៣១ខែ ធ្នូ ឆ្នាំ ១៩៧៧ EN 00184995 KH 00001325 ["ប្តេជ្ញាធ្វើពលីកម្ម គ្រប់យ៉ាងទាំងអស់ ច្បាំងជាមួយយួន ការពារបក្ស កុម្មុយនីស្តកម្ពុជា ការពារប្រជាជនក្នុងមាតុភូមិកម្ពុជាដាច់ខាត។"]។

3058 ឯកសារ D1.3.34.8 សារទូរលេខ ២១ ពី ឝុន ទៅ បង ប៉ុល ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៧៦ EN 00185241 KH 00052346 [របាយការណ៍អំពីការចាប់ខ្លួនជនជាតិវៀតណាមជាច្រើនដង និងសួរចម្លើយអ្នកទោសវៀតណាមម្នាក់]។ ឯកសារ D1.3.34.38 សារទូរលេខ ៦០ ពី ឝុន ទៅ មន្ទីរ ៨៧០, ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ១៩៧៧ EN 00185189 KH 00020875 [របាយការណ៍ពីជ័យជំនះទាំងស្រុងនៅតំបន់ ២៣ និង ចាប់បានជនជាតិវៀតណាមជាបន្តបន្ទាប់]។ ឯកសារ D4.1.303 សារទូរលេខ ៤៧ ពីសារុន ទៅ មន្ទីរ ៨៧០ ថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៧៨ EN 00324809 KH 00021054 [របាយការណ៍បន្ថែមពីស្ថានភាពយួននៅក្រុងតេះ និងដាក់ដាំ និងរបាយការណ៍ពីយួនរត់គេចទៅប្រទេសវិញ]។

3059 ឯកសារ D1.3.30.25 ទូរស័ព្ទសម្ងាត់ចេញពី មុត ថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៧៨ EN 00183357 KH 00017026 ["សរុបយួនដែលចាប់បាន និងបាញ់ងាប់ ចាប់ពីថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ១៩៧៨ មកដល់ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៨ មានចំនួន ១២០ ក្បាល"]។

3060 ឯកសារ D1.3.30.25 ទូរស័ព្ទសម្ងាត់ចេញពី មុត ថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៧៨ EN 00183357 KH 00017026 ["សៀម ដែលត្រូវដោះលែង មានការយឺតយូរ មិនបានតាមការកំណត់មូលពិនិត្យ គឺមិនមានខុសទាំងស្រុងទេ [...] ទាក់ទងដល់យោបល់ក៏មិនបានតាមសំណូមពរ ដោយតេអូ មិនឮគ្នា ផ្អែកលើទូរលេខ ខាងសមមិត្ត ឡាញ"]។

3061 ឯកសារ D4.1.655 សារទូរលេខ ពី ញឹម ទៅ អង្គការ ៨៧០ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៧៨ EN 00143066 ["កិច្ចប្រជុំបានសួរថាតើការសម្រេចចិត្តយ៉ាងម៉េច ដែលត្រូវធ្វើទៅលើអ្នកដែលមានធាតុផ្សំ[មិនស្អាត] ដូចជាទាហាន

ការណែនាំរបស់អង្គការអំពីរបៀបដោះស្រាយជាមួយប្រជាជនទាំងនោះ រស់ ញឹម បានកត់សម្គាល់ថា បើមនុស្សបែបនោះណាម្នាក់ធ្វើអ្វីមួយ "ទុកឱ្យអ្នកនោះត្រូវគេបោសសម្អាតចុះ [សម្លាប់]"[3062]។

747. ភ័ស្តុតាងបង្ហាញថា មនុស្សដែលមានដើមកំណើតខ្មែរកាត់វៀតណាម ពិតជាត្រូវគេ "បោសសម្អាត"[3063]។ អ៊ុច ស៊ុនឡាយ បានផ្តល់សក្ខីកម្មថា កូនៗរបស់គាត់ត្រូវបានគេសម្លាប់ ពីព្រោះពួកគេត្រូវបានចាត់ទុកថាជាមនុស្សជំនាន់ក្រោយជនជាតិវៀតណាម ហើយគោលនយោបាយរបស់ខ្មែរក្រហមគឺ "ដកស្មៅទាំងឫស"[3064]។ គាត់ដឹងថាពាក្យនេះមានន័យថា "ពួកគេត្រូវលុបបំបាត់អ្វីៗ

---

ជនជាតិវៀតណាម - ប្តីខ្មែរ ដែលមានប្រពន្ធវៀតណាម ឬប្តីជនជាតិវៀតណាម ដែលមានប្រពន្ធខ្មែរ និងកូនកាត់ខ្មែរ-វៀតណាម ។ ការលើកបញ្ហានេះ ក្នុងកិច្ចប្រជុំនេះចង់ដាក់សំណួរទៅអង្គការ ៨៧០។ វាគឺអាស្រ័យលើអង្គការជាអ្នកសម្រេច។ សូមឱ្យយើងដឹងប្រសិនបើមានការសម្រេចចិត្តណាមួយ ចេញពីអង្គការ"]។

3062 ឯកសារ D4.1.655 សារទូរលេខ ពី ញឹម ទៅអង្គការ ៨៧០, ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៧៨ EN 00143066 ["យើងទាំងអស់គ្នារួមទាំងប្រជាជន មានការព្រួយបារម្ភ ទោះបីជាមិនទាន់មានការទំនាស់ក៏ដោយ។ បើអ្នកណាធ្វើសកម្មភាពអ្វីមួយ សូមឱ្យដឹងមុននឹងត្រូវសម្លាប់។ ចំពោះអ្នកផ្សេងទៀត ត្រូវបានស្នើសុំឱ្យទុកនៅកន្លែងមួយសិន។ ជាមួយនឹងបញ្ហានេះ ខ្ញុំគិតថាវាមិនពិបាកក្នុងការប្រមូលទេ ទោះជាយើងត្រូវបន្តគ្រប់គ្រងពួកនោះទៀត។ ប្រសិនបើពួកគេបង្កជាបាតុភាព យើងអាចគ្រប់គ្រងបានភ្លាម"]។

3063 សូមមើលឧទាហរណ៍ ឯកសារ D11/44/3 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ថាន់ ធីម ឆ.20-21 ["បាទ! មានចម្រុះ គឺមានទាំងខ្មែរក្រោម និងវៀតណាម។ ចំពោះអ្នកដែលមានសម្បុរស និង និយាយខ្មែរមិនច្បាស់ ដូចជាពួកខ្មែរក្រោម គឺពួកគេចាត់ទុកថា ជាយួនទាំងអស់ ហើយចុងក្រោយ ត្រូវគេយកទៅសម្លាប់។ ស៖ តើលោកសំដៅ 'គេ' ហ្នឹង ទៅលើអ្នកណា? ឆ.21៖ 'គេ' សំដៅ ទៅលើពួកកងឈ្លប មេភូមិ និងមេសហករណ៍។"]។ ឯកសារ D54/26 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ឆ.11-13 ["តើលោកធ្លាប់បានឮកន្លែងចម្ការធូរេន នៅរាម ដែលនៅជិតកន្លែងចម្ការដូចដែរឬទេ? ឆ.11៖ បាទ! ខ្ញុំធ្លាប់ស្គាល់ទីកន្លែងទាំងនោះ។ កន្លែងទាំងនោះ ជាកន្លែងដែលយួនជាច្រើនត្រូវបានសម្លាប់។ ស៖ តើលោកអាចប្រាប់បានទេថា តើមានយួនប៉ុន្មាននាក់ដែលត្រូវសម្លាប់នៅទីនោះ? ឆ.12៖ តាមខ្ញុំដឹង គឺមានយួនរាប់រយនាក់ ដែលត្រូវបានសម្លាប់នៅទីនោះ។ ស៖ តើយោធានៅក្នុងកងណា ដែលបោះទីតាំងនៅកន្លែងទាំងនោះ? ឆ.13៖ មានមួយកងវរសេនាតូចដែលមានយោធាប្រហែល ១៥០ នាក់ របស់កងវរសេនាធំលេខ ៦២ ដែលបោះទីតាំងនៅកន្លែងនោះ។ តួនាទីរបស់យោធាទាំងនោះ គឺសម្រាប់ចាំទទួលយួនដែលចាប់បានយកទៅសម្លាប់នៅចម្ការធូរេន និងចម្ការដូង។"]។

3064 ឯកសារ D234/2.1.98 ប្រតិចារឹក អ៊ុច ស៊ុនឡាយ ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 09.14.46-09.18.00 ["ស៖ លោក អ៊ុច ស៊ុនឡាយ លោកបានពន្យល់ថា ប្រពន្ធរបស់លោក ក្លាយជាគោលដៅនៃការសម្លាប់នេះ ដោយសារ គាត់មានសាវតាជាតិហ្នឹង ជាវៀតណាម។ ចុះលោកដឹងទេថា ហេតុអ្វីបានជាកូនៗរបស់លោកនេះ ដែលលោកមានកូនៗជាមួយប្រពន្ធជាវៀតណាម ក៏ក្លាយជាគោលដៅនៃការសម្លាប់នេះដែរ? ឆ៖ បាទ! សូមអរគុណ។ ខ្ញុំបាទហ្នឹង ច្បាស់

ទាំងអស់”[3065]។ អ្នកជំនាញ លោក Alexander Hinton បានពន្យល់ថា ការប្រើប្រាស់ពាក្យ "គ្រាប់ពូជ" ដោយប៉ុល ពត នៅក្នុងសុន្ទរកថាខែ មេសា ឆ្នាំ ១៩៧៨ របស់គាត់ ដើម្បីពិពណ៌នាការ

---

ហើយថា ប្រពន្ធ និងកូនវៀតណាម ដូច្នេះ កូនហ្នឹង គឺជាចៅកាត់វៀតណាម ពីព្រោះទ្រឹស្តីរបស់មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត នៃរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង បានផ្សព្វផ្សាយទៅដល់ថ្នាក់ក្រោមទាំងអស់ថា ជីកស្មៅត្រូវជីកទាំងឫស បានន័យថា បើយកប្រពន្ធនិងកូនដែលជាចៅកាត់វៀតណាម អាចៅទួត ចៅលួត ចៅអីក៏ដោយ ក៏ជាវៀតណាម ជាខ្មែរ ក.ហ្វេ្យ.បេ ទាំងអស់ដែរ។ នេះគឺដឹងច្បាស់ យល់ច្បាស់ ដោយមើលឃើញ និងការតាមដាន"] ។ សូមមើលផងដែរ ឯកសារ D11/94/3 កំណត់ហេតុនៃការ ស្តាប់ចម្លើយសាក្សី សោយ យ៉ែន ឆ.15 ["តើលោកស្រីដែលបានចូលរួមការប្រជុំ និង/ឬ វគ្គរៀនសូត្រអ្វីទេ ក្រោយពេលដែលពួកនិរតីមកដល់? ឆ.15៖ តាមខ្ញុំចាំ ខ្ញុំបានចូលរួមការប្រជុំដែលដឹកនាំដោយ តាឡឹក និង យាយចាន់ បីលើក នៅតាមការដ្ឋានហូបបាយរួម ក្នុងភូមិរាំងក្រោល។ ពួកគាត់បាននិយាយភាគច្រើនទាក់ទងទៅនឹងការស្អប់យួន និងការបង្កបង្កើនផលស្រូវដើម្បី ទៅប្តូរយកអាវុធជាមួយនឹងប្រទេសចិន។ ពួកគាត់និយាយថា ស្អប់យួន ហើយប្រើគ្រប់មធ្យោបាយទាំងអស់ដើម្បីជីកឫកយួនឱ្យអស់។ កាលនោះ គេតែងនិយាយពាក្យថា នៅពេលកាប់ដើម ត្រូវជីកឫសទាំងអស់។ ពួកគេក៏ចាត់ទុក ពួកយើងដែលជាខ្មែរក្រោមថា ជាយួនដែរ។ គេនិយាយជីកឫស ពួកយួនឱ្យអស់ ដូចជាការរែងអង្ករ ហើយសល់បានប៉ុណ្ណា គឺទុកប៉ុណ្ណឹង។ គេនិយាយបែបនេះ ចង់សំដៅទៅលើការបោសសម្អាត គឺទុកតែល្អៗទេ។"]។

[3065] ឯកសារ D234/2.1.98 ប្រតិចារឹក អ៊ុច ស៊ុនឡាយ ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 09.14.46-09.18.00 ["ស៖ [...] លោកទើបតែនិយាយអំពីគោលនយោបាយ ដែលលោកបាឮថា បើជីកស្មៅ ត្រូវតែជីកទាំងឫស។ តើលោកអាចពន្យល់ទ្រឹស្តីនេះ ពាក្យស្លោកនេះ [...]? ឆ៖ បាទ! សូមអរគុណ។ [...] ខ្ញុំបានរៀនយល់ដឹងផ្នែកវប្បធម៌ គឺយល់ច្បាស់ថា ជីកស្មៅជីកទាំងឫស បានន័យថា ចង់យកស្មៅមែន តែត្រូវជីកឱ្យអស់ឫស ដែលស្មៅហ្នឹងទៅខាងណាក៏ដោយ ឆ្វេង ស្តាំ មុខ ក្រោយ ឬជម្រៅប៉ុនណាក៏ដោយ។ អាហ្នឹងជាន័យអត្ថបដិរូប គឺខ្ញុំបាទយល់អីចឹង។"]។ ឯកសារ D234/2.1.98 ប្រតិចារឹក អ៊ុច ស៊ុនឡាយ ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 09.14.46-09.18.00 ["ស៖ [...] ចុះលោកដឹងទេថា ហេតុអ្វីបានជាកូនៗរបស់លោកនេះ ដែលលោកមានកូនៗជាមួយប្រពន្ធជាវៀតណាម ក៏ក្លាយជាគោលដៅនៃការសម្លាប់នេះដែរ? ឆ៖ បាទ! សូមអរគុណ។ [...] ខ្ញុំបាទហ្នឹង ច្បាស់ហើយថា ប្រពន្ធ និងកូនវៀតណាម ដូច្នេះ កូនហ្នឹង គឺជាចៅកាត់វៀតណាម ពីព្រោះទ្រឹស្តីរបស់មេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត នៃរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង បានផ្សព្វផ្សាយទៅដល់ថ្នាក់ក្រោមទាំងអស់ថា ជីកស្មៅត្រូវជីកទាំងឫស បានន័យថា បើយកប្រពន្ធនិងកូនដែលជាចៅកាត់វៀតណាម អាចៅទួត ចៅលួត ចៅអីក៏ដោយ ក៏ជាវៀតណាម ជាខ្មែរ ក.ហ្វេ្យ.បេ ទាំងអស់ដែរ។ នេះគឺដឹងច្បាស់ យល់ច្បាស់ ដោយមើលឃើញ និងការតាម ដាន"]។

បណ្តេញចេញជនជាតិវៀតណាម គឺជា "ពាក្យប្រៀបធៀបសំដៅទៅពាក្យឫស" សម្រាប់ "ការកម្ទេចនូវអ្វីដែលគេអាចហៅថាជាជាតិសាសន៍មួយ"[3066]។

748. វិធីសាស្ត្រអនុវត្តគោលនយោបាយប្រល័យពូជសាសន៍របស់បក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងជនជាតិវៀតណាម ត្រូវបានបង្ហាញច្បាស់នៅក្នុងរបាយការណ៍មួយរបស់តំបន់៣៧ ក្នុងឆ្នាំ ១៩៧៨ ផ្ញើជូនថ្នាក់ដឹកនាំនៅមជ្ឈិម។ នៅក្នុងខែ សីហា ឆ្នាំ ១៩៧៨ មន្ទីរ៤០១ បានរាយការណ៍ប្រាប់អង្គការថា ខ្លួនបានអនុវត្តតាម "ការចាត់តាំង និងគោលការណ៍ណែនាំ" របស់អង្គការ ក្នុងការចាត់វិធានការ "ត្រួតពិនិត្យ និងបោសសម្អាត" ខ្លាំង ដោយធ្វើការត្រួតពិនិត្យស្វែងរក "ជនអន្តោប្រវេសន៍វៀតណាម"[3067]។ លទ្ធផលនៃការត្រួតពិនិត្យនេះគឺ "ជនជាតិវៀតណាម១០០នាក់ ទាំងតូចទាំងធំ ទាំងចាស់ទាំងក្មេង ត្រូវបានកម្ទេច"[3068]។

749. បក្សកុម្មុយនីស្តកម្ពុជា បន្តអនុវត្តគោនយោបាយប្រឆាំងជនជាតិវៀតណាមរបស់ខ្លួនរហូតដល់ចុងបញ្ចប់នៃរបបនោះ។ របាយការណ៍មួយរបស់មន្ទីរ៨៧០ ចុះថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៧៩ បានចេញបញ្ជាថា បក្សកុម្មុយនីស្តកម្ពុជា កងទ័ពបដិវត្តន៍កម្ពុជា កម្មាភិបាលទាំងអស់ និងប្រជាជនកម្ពុ

[3066] ឯកសារ D234/2.1.100 ប្រតិចារឹក Alexander Hinton ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 11.00.45-11.03.20 ["ពាក្យ 'មួយគ្រាប់' [...] គ្រាន់តែជាន័យធៀប មួយ នៃការបំផ្លិចបំផ្លាញ ពូជសាសន៍មួយ។ ដូច្នេះ វាគឺជាប្រភពដើមនៃន័យធៀបនេះ។"]។

[3067] ឯកសារ D114/36.1.30 របាយការណ៍ពីមន្ទីរ ៤០១ ទៅ អង្គការ ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ១៩៧៨ EN 00143618 KH 00143604 ["២. សកម្មភាពខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង [...] វាធ្វើសកម្មភាពបំផុសខៃទំនាស់ វាយប្រហារ ប្រឆាំង និងបំផ្លាញយើង តាមគ្រប់រូបភាព ជាបន្តបន្ទាប់ទៀត និងកាត់តែស៊ីជម្រៅ ដែលលេចចេញពីសមាសភាពមិនល្អមួយចំនួនតូច ជាដៃជើងរបស់ខ្មាំង ឬអ្នកជាប់ចម្លើយខ្មាំង សមាសភាពដែលសំរិតសំរាំងចេញពីអង្គភាពផ្សេងៗ និងចេញពីកងទ័ពជាដើម ព្រមទាំងសមាសភាព ១៧ មេសា ជាវណ្ណការចាស់ និងអាណិកជនចិន និងយួនមួយចំនួន។ ប៉ុន្តែ លើកសកម្មភាពខាងលើនេះ វាធ្វើអ្វីយើងពុំបានជាធំដុំទេ ពីព្រោះរាល់សកម្មភាពរបស់វាគ្រប់រូបភាព ត្រូវប្រជាជន យុទ្ធជន យុទ្ធនារីយើង និងកម្មាភិបាលយើង ក្តាប់បានជាបន្តបន្ទាប់ និងមានវិធានការណ៍ដកហូត សំរិតសំរាំង និងបោសសម្អាតជាបន្តបន្ទាប់ដែរ ដោយអនុវត្តទៅតាមមាគ៌ាចាត់តាំងរបស់បក្ស។"]។

[3068] ឯកសារ D114/36.1.30 របាយការណ៍ពីមន្ទីរ ៤០១ ទៅ អង្គការ ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ១៩៧៨ EN 00143618 KH 00143604។

ជា ត្រូវបន្ត "ស្វែងរក និងឆែកឆេររកភ្នាក់ងារខ្មាំងយួន និងមិនត្រូវអនុញ្ញាតឲ្យពួកគេលាក់ខ្លួននៅកន្លែងណាមួយនោះឡើយ ដើម្បីលុបបំបាត់ពួកគេ"[3069]។

<u>មិនមែនគោលដៅយោធា៖ ការបំផ្លាញជនជាតិវៀតណាម</u>

750. គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការកាប់សម្លាប់ជនជាតិវៀតណាម មានគោលដៅប្រឆាំងជនជាតិវៀតណាមទាំងអស់ ទាំងយោធា ឬជនស៊ីវិល។ សុន្ទរកថារបស់ប៉ុល ពត នៅខែមេសា ឆ្នាំ ១៩៧៨ បានបង្ហាញយ៉ាងច្បាស់ថា គាត់ចាត់ទុកជនជាតិវៀតណាមទាំងអស់ ទាំងនៅក្នុងកម្ពុជាប្រជាធិបតេយ្យ និងប្រទេសវៀតណាម ថាជាសត្រូវស្លាប់រស់។ ដោយសំដៅទៅប្រជាជនសរុបរបស់ប្រទេសវៀតណាម និងកម្ពុជាប្រជាធិបតេយ្យ គាត់បានចោទសួរថា "យួនមានប្រជាជន ៥០.០០០.០០០ ហើយកម្ពុជាមានប្រជាជនត្រឹមតែ ៨.០០០.០០០ នាក់ [...] តើ ៨.០០០.០០០ អាចវាយពួកឈ្លានពាន៥០.០០០.០០០ នាក់បានដែរ ឬទេ?"[3070]។ ប៉ុល ពត បានរៀបរាប់អំពី "សង្គ្រាមរបស់ប្រជាជន [...] ដើម្បីយកជ័យជម្នះលើខ្មាំង" ចំណែកឯ "បក្សបានប្ដេជ្ញាវាយ និងកម្ទេចកម្លាំងរបស់ខ្មាំងជាច្រើន និងដើម្បីការពារកម្លាំងរបស់យើងឲ្យបានជាអតិបរមា"[3071]។ កម្លាំងដែលត្រូវបានកម្ទេចគឺជាប្រជាជនស៊ីវិល មិនមែនជាយោធានោះឡើយ ដែលបានបង្ហាញច្បាស់តាមរយៈការនិយាយយោងជាច្រើនដងទៅដល់ប្រជាជនវៀតណាមទាំងមូល "របួត

---

3069 ឯកសារ D1.3.19.4 បក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ ទៅ មន្ទីរ ៨៧០ ថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៧៩ EN 00183666 KH 00021108។

3070 ឯកសារ D4.1.868 ទង់បដិវត្ត ខែ មេសា ឆ្នាំ ១៩៧៨ EN 00519833 KH 00064712 ["ទោះយ៉ាងនេះក៏ដោយ ខ្ញុំនិយាយថាអាចមានទស្សនៈខ្លះថា យួនធំណាស់ យួនមានចំនួន ៥០ លាន កម្ពុជាមានតែ ៨ លាន ម៉េចទៅវាយឈ្នះពិបាកដែរ កងទ័ពវាជិត ១ លាននាក់។ ហើយខ្ញុំចង់ជម្រាបអំពីកងទ័ពយើង។ កងទ័ពស្រួច មានមិនដល់ ១ សែននាក់។ ធម្មតា គេរក្សាការសម្ងាត់កងទ័ព ប៉ុន្តែ ខ្ញុំសូមជម្រាប ពីព្រោះខ្ញុំមិនប្រាប់ក៏គេដឹងដែរ។ កងទ័ពយើងមានមិនដល់ ១ សែនទេ។ ដូច្នោះ ៨ លាន ទៅវាយ ៥០ លានមកឈ្លានពាន។ កងទ័ពមានមិនដល់ ១ សែន ទៅវាយអាជិត ១ លាន។ បើនិយាយជាលេខ ឃើញថាតិចជាងវា។ ដូច្នោះ យើងចោទបញ្ហាថា យ៉ាងម៉េចបានជាយើងវាយឈ្នះ? វាយឈ្នះ សុំជម្រាបថ មកពីយើងត្រូវការវាយឲ្យឈ្នះ។ នេះ ខទី១។"]។

3071 ឯកសារ D4.1.868 ទង់បដិវត្ត ខែ មេសា ឆ្នាំ ១៩៧៨ EN 00519833 KH 00064712-00064713 ["ជំហរនេះ ជាជំហរឈ្នះទៅហើយ មិនមែនជំហរសារភាព មិនមែនជំហរចាញ់ទេ គឺជំហរឈ្នះ។ នេះ ខទី១។ ឈរលើជំហរនេះ យើងរៀបចំមាគ៌ាប្រយុទ្ធ អនុវត្តសង្គ្រាមប្រជាជន អនុវត្តមាគ៌ាប្រយុទ្ធ ឲ្យសក្ដិសិទ្ធិ ដើម្បីឈ្នះខ្មាំង។ បក្សកំណត់ថា វាយកម្ទេចកម្លាំងរស់របស់ខ្មាំងឲ្យបានច្រើន ការពារកម្លាំងយើងអតិបរមា។ យើងតិចទៅវាយធំ ត្រូវការពារកម្លាំងឲ្យបានជាអតិបរមា ហើយកម្ទេចវាឲ្យបានច្រើន។"]។

មកដល់ថ្ងៃនេះ យើងបានអនុវត្ត១ ទល់នឹង៣០ ដែលមានន័យថា យើងបាត់បង់១ យួនបាត់បង់៣០ [...] ដូច្នេះនៅពេលយើងមាន២.០០០.០០០នាក់ យើងមានលើសពីអ្វីដែលយើងត្រូវការដើម្បីវាយប្រឆាំងពួកគេ ពីព្រោះពួកគេមានត្រឹមតែ៥០.០០០.០០០នាក់ ប៉ុណ្ណោះ"[3072]។ សុន្ទរកថានោះបានសង្កត់ធ្ងន់ថា នេះមិនមែនជាសង្គ្រាមរវាងភាគីយោធានោះឡើយ ប៉ុន្តែជាសង្គ្រាមរវាងប្រជាជន និងប្រជាជន "១ទល់នឹង៣០។ ប្រសិនបើយើងមិនអាចអនុវត្តពាក្យស្លោកនេះ យើងមិនអាចយកទឹកដីបាននោះឡើយ។ បញ្ហានេះមិនមែនអនុវត្តតែចំពោះយោធានោះឡើយ បក្សទាំងមូល កងទ័ពទាំងមូល *ប្រជាជនទាំងអស់ ជ្រួតជ្រាបនូវបន្ទាត់នយោបាយ ទស្សនៈ និងជំហរនេះ*"[3073]។ អ្នកជំនាញ Alexander Hinton បានចាត់ទុកសុន្ទរកថានេះថាជាសញ្ញាបង្ហាញនូវ "ការញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍" ហើយគាត់បានកត់សម្គាល់ថា ពាក្យ "យួន" ត្រូវ "បានគេប្រើប្រឆាំងនឹងប្រជាជនមកពីប្រទេសវៀតណាម និងប្រជាជនដែលត្រូវបានគេកំណត់អត្តសញ្ញាណថា ជាជនជាតិវៀតណាម"[3074]។

751. អ្នកស្តាប់សុន្ទរកថារបស់ ប៉ុល ពត ដែលត្រូវបានផ្សព្វផ្សាយតាមវិទ្យុកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី១១ ខែ ឧសភា ឆ្នាំ ១៩៧៨[3075] យល់ដឹងថា នោះគឺជាការអំពាវនាវឲ្យធ្វើសង្គ្រាមប្រឆាំងនឹងប្រជាជនស៊ីវិលវៀតណាម មិនមែនគ្រាន់តែជាសង្គ្រាមប្រឆាំងនឹងប្រទេសវៀតណាមនោះឡើយ។ មាស វឿន បានផ្តល់សក្ខីកម្មថា ជនជាតិវៀតណាមទាំងអស់ មិនថាមានឋានៈអ្វី ឬអាយុប៉ុន្មាន

---

[3072] ឯកសារ D4.1.868 ទង់បដិវត្ត ខែ មេសា ឆ្នាំ ១៩៧៨ EN 00519837 KH 00064717-00064718 ["នេះហៅថាដោះស្រាយទំនាស់ យកតូចទៅវាយឲ្យឈ្នះធំវិញ។ ដើម្បីតូចឈ្នះធំ លុះត្រាតែតិចនេះ ចេះប្រើកម្លាំងតិច ហើយវាយឈ្នះកម្លាំងធំ។ ដូចជាបានជម្រាបអំបាញ់មិញ គឺថា ១ ទល់ ៣០។ បើ ១ ទល់ ៣០ ហើយ វាយ ៧រយឆ្នាំ ទៀតក៏នៅតែឈ្នះ។ ប៉ុន្តែ បើថាវាយរបៀបយ៉ាងនេះទេ មិនឈ្នះទេ។ ហើយបើឃើញថា យួនមាន ៥០ លាន យើងមានតែ ៨ លាន យើងចុះចាញ់ទៅហើយ ក៏មិនឈ្នះ នេះចាញ់ស្រេចទៅហើយ។"]។

[3073] ឯកសារ D4.1.868 ទង់បដិវត្ត ខែ មេសា ឆ្នាំ ១៩៧៨ EN 00519834 KH 00064713 (សង្កត់បន្ថែម)។

[3074] ឯកសារ D234/2.1.100 ប្រតិចារឹក Alexander Hinton ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 10.55.41-10.57.13។

[3075] ឯកសារ D4.1.617 សេវាផ្សព្វផ្សាយសារព័ត៌មានបរទេស របាយការណ៍ការពារជាតិកាលពីឆ្នាំមុន ត្រូវបានពិនិត្យឡើងវិញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ១៩៧៨ EN 00294787 KH 00340549 ["ដូចដែលយើងបានលើកឡើងកាលពីមុនថា ត្រូវតែ ១ ទល់នឹង ៣០។ បើសិនជាយើងអាចប្រើមនុស្សម្នាក់ ប្រឆាំងនឹង ៣០ នាក់ យើងនឹងពិតជាទទួលបានជោគជ័យ បើទោះណាជាការវាយប្រយុទ្ធនេះ មានរយៈពេល ៧០០ ឆ្នាំ ឬក៏លើសនេះក៏ដោយ។ តែបើសិនជាយើងមិនទទួលយកមាគ៌ានេះទេ យើងនឹងមិនសម្រេចបានជោគជ័យទេ។"]។

នោះឡើយ ត្រូវបានគេចាត់ទុកថាជា "សត្រូវស្លូវពូជ"[3076]។ នួន ជា បានសង្កត់ធ្ងន់ថា ជនជាតិវៀតណាម ដែលត្រូវគេផ្តោតគោលដៅទៅលើ មិនមែនជាយោធា ដែលឆ្លងព្រំដែនមកនោះឡើយ។ នៅក្នុងខែ កក្កដា ឆ្នាំ ១៩៧៨ នួន ជា បានប្រាប់គណៈប្រតិភូមួយក្រុមដែលមកទស្សនកិច្ចថា "វៀតណាម ព្យាយាមបំផ្លាញបក្សរបស់យើងតាមមធ្យោបាយ មនោគមវិជ្ជា សេដ្ឋកិច្ច នយោបាយ និងយោធា។ ជនជាតិវៀតណាមក៏ព្យាយាមជ្រៀតចូលមកក្នុងបក្សរបស់យើងផងដែរ។ យើងមិនព្រួយបារម្ភអំពីការឈ្លានពានដោយយោធាពីខាងក្រៅនោះឡើយ។ យើងបារម្ភបំផុតអំពីខ្មាំងខាងក្នុង"[3077]។

<u>ភ័ស្តុតាងបញ្ជាក់ពីកំហឹងរបស់ ប.ក.ក ចំពោះជនជាតិវៀតណាម ជាក្រុមជនជាតិភាគតិច</u>

752. អ្នកជំនាញ Alexnader Hinton បានផ្តល់សក្ខីកម្មថា "គំនុំដែលមានពីមុន" ចំពោះជនជាតិវៀតណាម "គឺមានតាំងពីពេលចាប់ផ្តើម"[3078] របបកម្ពុជាប្រជាធិបតេយ្យ ហើយ "ឈានទៅដល់ការ

---

3076 ឯកសារ D234/2.1.96 ប្រតិចារឹក មាស វឿន ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 09.55.49-09.58.50 ["សៈ តើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លោកធ្លាប់ឮថា វៀតណាមដែលនៅក្នុង ឬក៏ក្រៅទឹកដីកម្ពុជាហ្នឹង គឺជាសត្រូវស្លូវពូជរបស់ខ្មែរទេ? ឆៈ បាទ! ឮ ប្រជាជនខ្មែរក៏ឮ ខ្ញុំក៏ឮទាំងអស់គ្នា ជាសត្រូវស្លូវពូជ។"]។ សូមមើលផងដែរ ឯកសារ D54/23 កំណត់ ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុខ ឆ.32 ["ថៃមិនមានទំនាស់ច្រើនទេ ជាមួយខ្មែរទេ នៅក្នុងប្រវត្តិសាស្ត្រ ប៉ុន្តែយួនមានទំនាស់ជាមួយខ្មែរច្រើន ទើបយួនត្រូវបានចាត់ទុកថា ជាសត្រូវស្លូវពូជ និងសត្រូវទី១។"]។

3077 ឯកសារ D4.1.195 សេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនីស្តកម្ពុជា ជូនទៅបក្សពលករកុម្មុយនីស្តដាណឺម៉ាក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៨ EN 00016999 KH 00224457 (គូសបញ្ជាក់បន្ថែម)។ សូមមើលផងដែរ ឯកសារ D1.3.27.26 ឯកសារ D4.1.91 កំណត់ហេតុនៃការប្រជុំ លេខា និងអនុលេខា កងពល និង វរសេនាធំឯករាជ្យ ថ្ងៃទី ១ ខែ មីនា ឆ្នាំ ១៩៧៧ EN 00933843 KH 00052310 ["តើយួនវាយយើងបានទេ? បើគ្មានកន្សែងវាខាងក្នុងទេ វាយយើងមិនបានទេ។ ជាយោធា វាយយើងមិនកើត ព្រោះយើងជាអ្នកធ្លាប់វាយដែរ។"]។

3078 ឯកសារ D234/2.1.100 ប្រតិចារឹក Alexander Hinton ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦, ម៉ោង 09.27.30-09.29.13 ["មិនដូចជាជនជាតិភាគតិច ជនជាតិវៀតណាម ដែលមានការបំលាស់ទី និងរស់នៅក្នុងប្រទេសកម្ពុជាតាំងពី[ដំបូង]។"]។ សូមមើលផងដែរ ឯកសារ D1.3.17.1 សៀវភៅនិពន្ធដោយ Elizabeth Becker នៅពេលដែលសង្គ្រាមរលត់ទៅ EN 00237839–00237840 KH 00232171-00232172 [រៀបរាប់ពីការចាប់ផ្តើមធ្វើកម្មវិធី "វិសុទ្ធកម្ម" នៅឆ្នាំ ១៩៧១ៈ "ជាដំបូង ពួកគេបានរករឿងអាណិកជនវៀតណាមកំពុងរស់នៅតំបន់នានា ដែលពួកគេគ្រប់គ្រងនៅភាគខាងកើតប្រទេសកម្ពុជា"]។

កំណត់គោលដៅ និងការកម្ចាត់ចោលបែបនេះ"[3079]។ ឯកសារផ្សេងៗរបស់ ប.ក.ក បានចាត់ទុកជនជាតិ វៀតណាម ជា "ខ្មាំង" [3080]។ ប្រាក់ ខន បានផ្តល់សក្ខីកម្មថា រវាងឆ្នាំ ១៩៧៧ ដល់ឆ្នាំ ១៩៧៨ នៅក្នុងវគ្គរៀនសូត្រនយោបាយ ឌុច និង សុន សេន បានប្រាប់បុគ្គលិកមន្ទីរ ស-២១ ថា វៀតណាម គឺជា"សត្រូវស្នូល"របស់ ប.ក.ក[3081]។ ទង់បដិវត្ត ខែ កក្កដា ឆ្នាំ ១៩៧៨ បានប្រកាស

---

[3079] ឯកសារ D234/2.1.100 ប្រតិចារឹក Alexander Hinton ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 14.21.34-14.25.25 ["ខ្ញុំបានលើកឡើងកាលពីមុន ពាក់ព័ន្ធនឹងជនជាតិវៀតណាម ខ្ញុំគិតថា ពាក្យហ្នឹង គឺមានការរើសអើងយ៉ាងខ្លាំង គឺមានតាំងពីពេលចាប់ផ្តើមដំបូង ដែល វាមានចរន្តមួយដែលរត់យ៉ាងដូច្នេះឯង។ ហើយជាពិសេស ដោយសារតែមានភាពតានតឹងជាមួយវៀតណាម កើនឡើង ។ ដូច្នេះ ភវនីយភាព នៃជនជាតិវៀតណាមមួយចំនួនអាចកែប្រែឡើងវិញនូវស្មារតីរបស់ពួកគេ គឺមានការធ្លាក់ចុះ។ ខ្ញុំពឹងគិតថា ទម្រង់នៃការគំនុំដែលមានពីមុនទៅលើជនជាតិវៀតណាម បានធ្វើឱ្យចរន្តខ្លាំងក្លា ឈានទៅដល់ ការកំណត់គោលដៅ និង ការកម្ទេចចោលបែបនេះឯង។"]។

[3080] ឯកសារ D1.3.27.24 កំណត់ហេតុនៃការប្រជុំ កងពល ៩២០ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៧៦ EN 00185237 KH 00052333-00052334 ["សភាពការណ៍ខ្មាំង៖ ផ្ទៃក្នុងគ្មានអ្វីប្រែប្រួលទេ ក្រោយពីអង្គការសម្រេចឱ្យសំរិតសំរាំងមក។ កម្មាភិបាលវរសេនាធំម្នាក់ឈ្មោះ អ៊ុល ធ្លាប់នៅអង្គភាពវៀតណាម មិនមានស្មារតីទទួលខុសត្រូវ និងសុខភាពក៏ខ្សោយ មិនធានាដល់ការបម្រើអង្គភាព។ ពួកចេញពីអង្គការវៀតណាមជិត ១០០ នាក់ សម្រេចប្រមូលឱ្យនៅមួយដុំត្រង់ភូមិ មឹងម៉ង់ ក្បែរទឹកឈូរអូរទេរ។ […] បញ្ហាផ្ទៃក្នុងអង្គភាព រឿងពួកធ្លាប់នៅជាមួយវៀតណាម កុំឱ្យនៅប្រមូលផ្តុំ ត្រូវបំបែកឱ្យទៅខាងជាងធ្វើផ្ទះ ពាងក្រឡ ជាដើម នៅលាយឡំជាមួយកម្លាំងយើង ដែលមានជំហាររឹងប៉ឹង។"]។

[3081] ឯកសារ D234/2.1.113 ប្រតិចារឹក ប្រាក់ ខន ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង 09.12.09-09.16.18 ["នៅសម័យ ១៩៧៧, ១៩៧៨ នេះ គឺ ដោយឡែកនិយាយអំពីរឿងពេលកំពុងធ្វើសង្គ្រាមជាមួយវៀតណាម។ អីចឹងវៀតណាមពេលហ្នឹង គេបានប្រកាស និងណែនាំពួកខ្ញុំជាបុគ្គលិកនៅស-២១ ថាវៀតណាមជាសត្រូវស្នូលរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយទិសដៅវ៉ៃយកទឹកដីកីសាំងស៊ីន ដីកម្ពុជាក្រោមមកយកមកវិញទាល់តែបាន។ ហ្នឹងជាទ្រឹស្តីរបស់ សុន សេន និង ឌុច ដែលបានបង្រៀន និងជម្រាបបុគ្គលិកស-២១ ទាំងអស់ នៅពេលមកបង្រៀននយោបាយហ្នឹង។"]។ សូមមើលផងដែរ ឯកសារ D114/297.1.20 ប្រតិចារឹក ប៉ាក សុខ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 10.56.53-10.58.13 ["ក្នុងហ្នឹង គឺជាជនជាតិ វៀតណាម ខុសប្លែកនឹងគ្នានឹងជនជាតិថៃ បាទ!។ ជនជាតិវៀតណាម គឺសត្រូវស្នូលជាមួយរបស់ បាទ! ប៉ុល ពត។ មិនអាច ទោះបីអ្នកឯងយោធា មិនយោធាក៏ដោយ ឱ្យតែមានអាវុធតបត គឺបាញ់ពន្លិចចោលតែម្តង។"]។ ឯកសារ D234/2.1.21 Elizabeth Do ការប្រព្រឹត្តចំពោះជនជាតិភាគតិចវៀតណាម ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីទស្សនៈវិស័យប្រៀបធៀប EN 00548862 KH 00768968 ["អ្នកផ្តល់បទសម្ភាសន៍ភាគច្រើនបានរំលឹកថា នៅក្នុងការប្រជុំក្នុងភូមិ និងការសន្ទនាប្រចាំថ្ងៃ មេដឹកនាំខ្មែរក្រហមបាននិយាយថា ម្តងហើយម្តងទៀតថា វៀតណាម គឺជា 'ខ្មាំងប្រវត្តិសាស្ត្រ' ហើយបាននិយាយដល់ការកេងប្រវ័ញ្ច និងការរំលោភបំពានកាលពីអតីតកាលរបស់វៀតណាមលើប្រជាជនខ្មែរ ដូចជាព្រឹត្តិការណ៍យកក្បាលខ្មែរដាំ 'តែអុង'។"]។ ឯកសារ D1.3.17.1 សៀវភៅនិពន្ធដោយ Elizabeth Becker នៅពេលដែលសង្គ្រាមរលត់ទៅ EN 00238040 KH 00232172 ។ ["ក្នុង

ថា “យួន ជាសត្រូវប្រចាំជាតិយើងតាំងពីដើមរហូតតឡូវ និងទៅខាងមុខយូរអង្វែងទៀត”[3082]។ នៅខែ កញ្ញា ឆ្នាំ ១៩៧៨ នៅក្នុងសុន្ទរកថាមួយ នួន ជា បានលើកឡើងពី “សកម្មភាពរបស់ខ្មាំងវៀតណាម” មកលើ “ប្រជាជនកម្ពុជា”[3083]។ ការឃោសនាសម្ដីបែបនេះគឺមានប្រសិទ្ធភាព។ មាស វឿន បានផ្តល់សក្ខីកម្មថា ប្រជាជនបានចាត់ទុកវៀតណាម ជាសត្រូវលេខមួយរបស់ ប.ក.ក៖[3084] “ប្រជាជនខ្មែរក៏ឮ ខ្ញុំក៏ឮទាំងអស់គ្នា ជាសត្រូវស្នូលពូជ”[3085]។

753. ការចាត់ទុកជនជាតិវៀតណាមជាសត្រូវ គឺបូករួមជាមួយនឹងការអំពាវនាវជាបន្តបន្ទាប់របស់ ប.ក.ក ជំរុញឱ្យបំផ្លាញជនជាតិវៀតណាម។ ប្រាក់ សុខ កម្មាភិបាលកងពល ១៦៤ បានផ្ដល់សក្ខីកម្មថា កងទ័ពទទួលបញ្ជាឱ្យសម្លាប់ជនជាតិវៀតណាមទាំងអស់ សូម្បីតែ កូនក្មេង “ព្រោះនេះជាសត្រូវ

---

ការឃោសនារបស់ខ្មែរក្រហម ប្រទេសវៀតណាម មិនត្រឹមតែក្លាយទៅជាប្រទេសសង្គមនិយមជិតខាងមួយប៉ុណ្ណោះទេ ប៉ុន្តែជាសត្រូវ ‘ស្នូលពូជ’ ដែលមិនអាចបោះបង់ប្រវត្តិសាស្ត្ររបស់ខ្លួនបាន ដើម្បីដណ្តើមយកប្រទេសកម្ពុជា។”]។

3082 ឯកសារ D4.1.869 ទង់បដិវត្ត ខែ កក្កដា ឆ្នាំ ១៩៧៨ EN 00428289 KH 00064486 [“ខ្មាំងយួន វាឈ្លានពាន វាតទីលេបទឹកដី បំបាត់ពូជសាសន៍កម្ពុជាយើង ពីជំនាន់មួយទៅជំនាន់មួយ។ វាជាសត្រូវប្រចាំជាតិរបស់យើង តាំងពីដើមរហូតតឡូវ និងទៅខាងមុខយូរអង្វែង។”]។

3083 ឯកសារ D64.1.46 សេវាផ្សព្វផ្សាយសារព័ត៌មានបរទេស នួន ជា រៀបចំពិធីជប់លៀង ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៧៨ EN 00170388 [“យើងរំភើបចិត្តយ៉ាងខ្លាំង ដោយសារតែការគាំទ្រយ៉ាងខ្លាំងក្លា និងសកម្មដែល CCP, NPC, រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិចិន និងប្រជាជនចិនកំពុងផ្តល់ទូវឱ្យប្រជាជនកម្ពុជារបស់យើងនូវការតស៊ូប្រឆាំងនឹងសកម្មភាពឈ្លាន ពាន និងការវាតទីយកទឹកដីរបស់សត្រូវវៀតណាម យុទ្ធសាស្ត្រសហព័ន្ធឥណ្ឌូចិន និងផែនការពង្រីកសង្គមនិយមរបស់ខ្លួន នៅអាស៊ីអាគ្នេយ៍។ យើងមានការរំជួលចិត្តយ៉ាងខ្លាំង ដោយការគាំទ្ររបស់ចិន ចំពោះកម្ពុជាក្នុងការខិតខំប្រឹងប្រែង ការការពារថែរក្សា ពង្រឹង និង អភិវឌ្ឍន៍បដិវត្តន៍របស់ខ្លួន ហើយនិងការការពារ រក្សាឯករាជ្យអធិបតេយ្យ និងបូរណភាពទឹកដី និងសិទ្ធិរបស់ប្រជាជនកម្ពុជាក្នុងការកំណត់អនាគតរបស់ខ្លួន។”]។

3084 ឯកសារ D234/2.1.96 ប្រតិចារឹក មាស វឿន ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 09.53.15-09.55.49 [“ស៖ ឥឡូវនេះ ខ្ញុំចូលនិយាយអំពីបញ្ហាវៀតណាមនៅចន្លោះឆ្នាំ ៧៧ ឆ្នាំ ៧៨។ តើលោកធ្លាប់ឮគេនិយាយថា វៀតណាមជាសត្រូវលេខ១ របស់កម្ពុជាប្រជាធិបតេយ្យទេ? ឆ៖ បាទ! ឮគេនិយាយ ឮព្រោះអី ឮហើយព្រមទាំងសភាពការណ៍តាមព្រំដែនមានការ ប៉ះពាល់ ប្រទូសប្រទាំងគ្នាខ្លះដែរ។”]។

3085 ឯកសារ D234/2.1.96 ប្រតិចារឹក មាស វឿន ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 09.53.15-09.58.50។ សូមមើលផងដែរ ឯកសារ D11/94/3 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សោយ យ៉ែន ឆ.15 [“ពួកគាត់និយាយថា ស្អប់យួន ហើយប្រើគ្រប់មធ្យោបាយទាំងអស់ដើម្បីជីកឫសយួនឱ្យអស់។”]។

ស្លូតបូត" [3086]។ នៅក្នុងអង្គប្រជុំមួយនៅខែ មេសា ឆ្នាំ ១៩៧៨ ជាថ្ងៃគម្រប់ខួបដែលខ្មែរក្រហមបាន កាន់កាប់ភ្នំពេញ[3087] អ្នកចូលរួមអង្គប្រជុំបានប្ដេជ្ញា "កម្ទេចចោលខ្មាំងគ្រប់រូបភាពទាំងអស់ ជាពិសេសពួកឈ្លានពាន ពួកខ្មាំងវាតទីនិយមវៀតណាម ដើម្បីរក្សាការពារជាតិ និងជាតិសាសន៍ កម្ពុជាជារៀងរហូត"[3088]។

754. ការលើកឡើងដដែលៗអំពីការតស៊ូរបស់"ពូជសាសន៍កម្ពុជា"[3089] និង"ប្រទេសកម្ពុជា"គឺឆ្លុះបញ្ចាំង ពីជំនឿរបស់ ប.ក.ក ដែលថា អាចមានតែពូជសាសន៍តែមួយគត់នៅកម្ពុជាប្រជាធិបតេយ្យ[3090]

---

3086 ឯកសារ D114/297.1.20 ប្រតិចារឹក ប៉ាក សុខ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 13.31.54-13.34.17 ["ជាការពិត ណាស់ ខ្ញុំជាយុទ្ធជននៅកងពល ១៦៤ ក្រោយពីបានឆ្នាំ ១៩៧៦ បាទ! គឺបើកវគ្គសាលាសិក្សា ដើម្បីប្រកាស បាទ! ប្រកាសពេញសិទ្ធិ សត្រូវស្លូតបូត គឺវា យួន"]។ ម៉ោង 13.34.17-13.37.45 ["សម្លាប់អត់មានទុក សូម្បីតែកូនង៉ែតមួយ ក៏អត់ឲ្យមានដែរ ព្រោះនេះជាសត្រូវស្លូតពូជ គឺសម្លាប់ចោលតែម្ដង ព្រោះទំនាស់បដិបក្ខ។ បាទ! នេះជាអង្គសិក្ខា សាលានៅក្នុងមន្ទីរនៃ វរសេនាតូចនីមួយៗ ទទួលផែនការច្បាស់លាស់តែម្ដង។"]។ ឯកសារ D114/297.1.21 ប្រតិ ចារឹក ប៉ាក សុខ ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 14.15.03-14.18.59 ["ស៖ [...] ហើយខ្ញុំចង់ផ្ដោតទៅលើការ រៀនសូត្ររបស់លោកនៅនឹងកោះប៉ូឡូវ៉ៃហ្នឹង រៀនដែលនិយាយអំពីថា កម្ពុជា វៀតណាម ជាសត្រូវស្លូតបូតហ្នឹង នៅ ក្នុងពាក់កណ្ដាលដំបូងដែលលោករស់នៅ ឬមួយក្នុងអំឡុងពេលណាមួយដែលអាចថា ពេលចាប់ផ្ដើមដំបូង ឬក៏ពេល ចុងក្រោយនៃការស្នាក់នៅក្នុងកោះប៉ូឡូវ៉ៃហ្នឹង? ឆ៖ ខ្ញុំនៅកោះពូធីវ៉ៃពេលធ្វើសកម្មភាពអាមេរិកហើយ ខ្ញុំទៅនៅកោះពូ ធីវ៉ៃហ្នឹងរហូតដល់នៅឆ្នាំ ៧៧។ ឆ្នាំ ៧៧ហ្នឹង ក្នុងខែ ៤ ខែ ៥ ហើយហ្នឹង បានខ្ញុំចេញពីកោះនោះមកនៅខាងនាវា កប៉ាល់។"]។

3087 ឯកសារ D234/2.1.33 សារព័ត៌មានអន្តរជាតិ SWB ខួបមិទ្ទីញ ១៧ មេសា ភ្នំពេញ ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៨ EN S 00010558។

3088 ឯកសារ D234/2.1.33 សារព័ត៌មានអន្តរជាតិ SWB ព្យុហយាត្រានៅភ្នំពេញ ដើម្បីរំលឹកខួប ១៧ មេសា ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៨ EN S 00010563 KH 00249989។

3089 ឯកសារ D4.1.868 ទង់បដិវត្ត ខែ មេសា ឆ្នាំ ១៩៧៨ EN 00519837 KH 00064718 ["ការពារទឹកដីកម្ពុជា បាន ន័យថា ការពារពូជសាសន៍កម្ពុជា។ បើប្រសិនណាជា យួនយកបានអស់ហើយ ពូជសាសន៍កម្ពុជាក្នុងរវាង៣០ឆ្នាំ"]។ EN 00519842 KH 00064725 ["យើងធ្វើឲ្យកងទ័ពយើងស្អាត បក្សស្អាត ប្រជាជនស្អាត ដើម្បីវាយខ្មាំងតទៅទៀត ការពារទឹកដីកម្ពុជា គឺការពារពូជសាសន៍កម្ពុជា។ បើមិនអីចឹង វាបាត់ពូជសាសន៍។ យើងចង់បាត់ពូជសាសន៍ទេ។ បាត់ទឹកដីហើយ បាត់ពូជសាសន៍ទៀត បើមិនការពារទេ។ យួនវាចេះតែបញ្ជូលមក ១ ឆ្នាំ មួយលាន ពីរលាន មួយ លាន ពីរលាន យើងអស់ ទឹកដី និងបាត់ពូជសាសន៍។"]។ ឯកសារ D234/2.1.21 Elizabeth Do ការប្រព្រឹត្តចំពោះ ជនជាតិភាគតិចវៀតណាម ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពីទស្សនៈវិស័យប្រៀបធៀប EN 00548862 KH 00768968 ["ក្នុងករណីមានការអះអាងពីការធ្វើទុក្ខបុកម្នេញខុសគ្នា កត្តានយោបាយ និងកត្តាជាតិសាសន៍ គឺជា ចំណុចស្នូល។ នៅពេលពួកខ្មែរក្រហមឡើងកាន់អំណាចភ្លាម របបនេះបានចេញសេចក្ដីប្រកាសជាសាធារណៈថា ទឹក

ហើយក៏ឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្រលុបបំបាត់ជនជាតិវៀតណាមទាំងអស់ នៅក្នុងប្រទេសកម្ពុជា។ នៅខែ មេសា ឆ្នាំ ១៩៧៦ *ទង់បដិវត្តន៍* បានប្រកាសថា៖

> ប្រជាជនយើង ហៅថា "ប្រជាជនកម្ពុជា"។ ក៏ប៉ុន្តែ មានជនបរទេសនៅច្រើនណាស់ រាប់សែននាក់។ ហើយ ជនបរទេសប្រភេទម្យ៉ាង មានសភាពពិសពុល គ្រោះថ្នាក់ដល់ប្រជាជនយើងខ្លាំងណាស់។ ជនទាំងនេះមានសភាពហៅថាពិសពុល ដោយវាមកត្របាក់យើង មកប្រចឹកយើង មកលេបយើង មករឹបយកគ្រប់បែបគ្រប់យ៉ាងទាំងអស់ ធ្វើឱ្យប្រជាជាតិយើង និងប្រជាជនយើង ត្រូវគ្រោះថ្នាក់អន្តរាយក្នុងពេលកន្លងមក អត់ទឹកដីជាច្រើន"[3091]។

ដីខ្មែរត្រូវមានតែជនជាតិខ្មែរមួយគត់ និងបានចាប់ផ្តើមអនុវត្តគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យ ដែលតម្រូវឱ្យមានជាតិសាសន៍តែមួយគត់។"]។

3090 ឯកសារ D114/29.1.4 សៀវភៅនិពន្ធដោយ Ben Kiernan របបប៉ុល ពត EN 00678636 KH 00637771-00637772 ["បន្ទាប់ពីការដំឡើងឋានៈ ចាន់ នៅក្នុងឆ្នាំ ១៩៧៥ អ៊ុក ប៊ុនឈឿន បានចូលមកធ្វើជាសមាជិកគណៈកម្មាធិការបក្សតំបន់ ២១ ដែរ។ ចម្លើយសាក្សីរបស់គាត់នៅឆ្នាំ ១៩៨១ មិនបាននិយាយអំពីអំពើឃោរឃៅនៅឆ្នាំ ១៩៧៥ ទេ ប៉ុន្តែបានទទួលស្គាល់ 'ស្ថានភាពខ្វះខាតក្នុងការរស់នៅ' របស់ប្រជាជននៅស្រុកក្រូចឆ្មារដែរ ដែលជា 'តំបន់មួយរងទុក្ខវេទនាជាងគេបំផុត'។ ត្រូវសាកសួរពីរឿងប្រជាជន ឈឿន បានប្រកាសថា៖ វាពុំមាននយោបាយជាក់លាក់ណាមួយស្តីពីការអត់ឱនចំពោះជនជាតិភាគតិចក្នុងប្រទេសឡើយ។ មនុស្សទាំងអស់បានត្រូវលាយបញ្ចូលគ្នា។ វាមានជាតិសាសន៍តែមួយប៉ុណ្ណោះ ចាប់តាំងពីការរំដោះប្រទេសនៅឆ្នាំ ១៩៧៥ គឺជាតិខ្មែរ។ ប៉ុល ពត ជាអ្នកជិតស្និទ្ធបំផុតនឹងពួកចារ៉ាយ និងជនជាតិភាគតិចផ្សេងៗទៀត ប៉ុន្តែគាត់បែរជាកម្មាត់ជាតិសាសន៍អ៊ីស្លាមទៅវិញ។"]។ ឯកសារ D1.3.17.1 សៀវភៅនិពន្ធដោយ Elizabeth Becker នៅពេលដែលសង្គ្រាមរលត់ទៅ EN 00237947-00237948 KH 00232321 ["ពលរដ្ឋម្នាក់ៗត្រូវតែជាជនជាតិខ្មែរពិតប្រាកដម្នាក់ ដូចដែលរដ្ឋធម្មនុញ្ញបានកំណត់យ៉ាងច្បាស់លាស់។ បេសកកម្មខ្មែរក្រហមស្ថិតនៅត្រង់ធ្វើឱ្យភាពរុងរឿង និងសេចក្តីថ្លៃថ្នូរបស់ប្រទេសកម្ពុជា រស់ឡើងវិញ ដោយផ្នែករួមទាំងរក្សាពូជសាសន៍ខ្មែរឱ្យស្ថិតស្ថេរចីរកាលតទៅ ដូចសម្តី ប៉ុល ពត បានប្រកាសពីបញ្ហានេះដោយខ្លួនឯងផ្ទាល់។"]។

3091 ឯកសារ D4.1.883 ទង់បដិវត្ត ខែ មេសា ឆ្នាំ ១៩៧៦ EN 00517853 KH 00062748។ សូមមើលផងដែរ ឯកសារ D4.1.45 យុវជន និង យុវនារី បដិវត្ត ខែ មករា-កុម្ភៈ ឆ្នាំ ១៩៧៨ EN 00278717 KH 00063495 ["ត្រូវឃើញទំនាស់បដិបក្ខស្លាប់រស់ ជាមួយខ្មាំងសត្រូវគ្រប់ប្រភេទពីខាងក្រៅ ពិសេសខ្មាំងយួនឈ្លានពានលេបទឹកដី និងបក្សពួកវាជាប់ជាប្រចាំ"]។ ឯកសារ D1.3.24.5 ទង់បដិវត្ត ខែ ឧសភា-មិថុនា ឆ្នាំ ១៩៧៨ EN 00185333 KH 00064566 ["ក្បាលដែលត្រូវវាយ គឺ សេ.អ៊ី.អា យួន និង កា.ហ្សេ.បេ។"]។

755. Alexnader Hinton បានផ្តល់សក្ខីកម្មថា ឯកសារនេះពាក់ព័ន្ធនឹង "ជនជាតិវៀតណាមដែលរស់នៅក្នុងទឹកដីកម្ពុជានៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ"[3092] ហើយគាត់បានលើកឡើងថា ប.ក.ក "និយាយពីវិសុទ្ធកម្ម"[3093] មកលើជនជាតិវៀតណាម។

756. សារបែបនេះបានលើកឡើងជាដដែលៗនៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅខែ កញ្ញា ឆ្នាំ ១៩៧៨ នួន ជា បានសរសើរ ក.ប.ក ចំពោះការបង្ក្រាបយុទ្ធសាស្ត្ររបស់វៀតណាមដែលមានបំណង"កម្ទេចចោលឲ្យអស់សូន្យនូវពូជសាសន៍អម្បូរកម្ពុជា"[3094]។ ខៀវ សំផន បានជំរុញឲ្យមានរូបភាពស្រដៀងគ្នានេះដែរ នៅពេលដែលលើកឡើងពីភាពចាំបាច់ដែលប្រជាជនកម្ពុជា ត្រូវរួមគ្នាដើម្បី "កម្ទេចអំពើឈ្លានពាន វាតទី និងអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងកម្ពុជា" ដែលធ្វើឡើងដោយវៀតណាម[3095]។ យោងតាម David Chandler ការដាក់ឲ្យខ្មែរប្រឆាំងនឹងវៀតណាម គឺជាផ្នែកមួយនៃគោលនយោបាយរបស់ ប.ក.ក នៅក្នុង"សង្គ្រាមពូជសាសន៍ប្រឆាំងវៀតណាម" [3096]។

---

3092 ឯកសារ D234/2.1.100 ប្រតិចារឹក Alexander Hinton ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 09.25.43-09.27.30។

3093 ឯកសារ D234/2.1.100 ប្រតិចារឹក Alexander Hinton ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦, ម៉ោង 09.27.30-09.29.13 ["ខ្ញុំយល់ឃើញថា គឺវាមានសារៈសំខាន់សំដៅទៅលើជនជាតិវៀតណាម និងជនជាតិចាម ក្នុងការងាកមកមើលដំណើរ ប្រវត្តិសាស្ត្រ ព្រោះខ្ញុំគិតថា ដោយសារខ្ញុំបាននិយាយអំពីសញ្ញាណនៃភាពបន្សុទ្ធិមូលវិវដ្តកម្ម ដែលមានដំណើរសាយភាយ ខុសៗគ្នា អាស្រ័យទៅលើកម្រិតនៃការគំរាមកំហែងមកលើរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងឆ្នាំ ១៩៧៦ ភាពតានតឹងនេះ ហើយនិងជម្លោះជាមួយវៀតណាមនេះ វាតឹងតែងឡើងរហូតមកដល់ឆ្នាំ ១៩៧៨ ឯណោះ។ ប៉ុន្តែ ខ្ញុំគិតថា គេច្បាស់ជានិយាយពីវិសុទ្ធកម្មហើយ។"]។

3094 ឯកសារ D4.1.193 សុន្ទរកថារបស់ នួន ជា ថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ១៩៧៨ EN 00065915 KH 00224454 ["ប្រជាជន និង កងទ័ពបដិវត្តន៍កម្ពុជា ក៏បានកម្ទេចកលល្បិច 'សហព័ន្ធឥណ្ឌូចិន' របស់វៀតណាមដែលមានគោលបំណងលេបទឹកដីកម្ពុជា និងគោលបំណងកម្ទេចចោលឲ្យអស់សូន្យពូជសាសន៍អម្បូរកម្ពុជា។ ដោយហេតុនេះ យុទ្ធសាស្ត្រ 'ការវាយលុកដូចផ្លេកបន្ទោរ ជ័យជំនះបានមកលឿនដូចផ្លេកបន្ទោរ' របស់វៀតណាមបានរងនូវបរាជ័យគួរឲ្យអាម៉ាស់មុខ។"]។

3095 ឯកសារ D64.1.39 សារព័ត៌មានអន្តរជាតិ FBIS សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលអំពាវនាវស្វែងរកជំនួយ ដើម្បីប្រយុទ្ធនឹងការឈ្លានពានរបស់សាធារណៈរដ្ឋសង្គមនិយមវៀតណាម (ឬ SRV) ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ១៩៧៩ EN 00169295 KH 00701949 [ខៀវ សំផន៖ "សមមិត្ត និងជនរួមជាតិជាទីគោរពរាប់អាន [...] កំពុងសាមគ្គីគ្នាជាធ្លុងមួយ និងកំពុងប្រឹងប្រែងឲ្យអស់សមត្ថភាព និងសក្តានុពល ដើម្បីកម្ទេចអំពើឈ្លានពាន វាតទី និងអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងកម្ពុជា ដែលវៀតណាម"]។

3096 ឯកសារ D98/1.2.40 ប្រតិចារឹក David Chandler ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ ម៉ោង 16.01.45-16.03.47 ["នៅចុងបញ្ចប់ឆ្នាំ ១៩៧៨ ហើយគោលនយោបាយហ្នឹងពាក់ព័ន្ធទៅដល់ការកម្ចាត់ជនជាតិវៀតណាម គឺនិយាយ

*ទង់បដិវត្តន៍* ខែ កក្កដា ឆ្នាំ ១៩៧៨ បានបញ្ជាក់ថា "ករណីយកិច្ចប្រចាំជាតិរបស់យើងទាំងអស់ គឺតស៊ូវាយកម្ចាត់ខ្មាំងយួនឈ្លានពាន វាតទីលេបទឹកដី បំផុតពូជសាសន៍កម្ពុជា ជាដាច់ខាត"[3097]។

757. ជនជាតិវៀតណាមត្រូវបានចាត់ទុកផងដែរថាជាជន"ក្បត់" ដោយ*ទង់បដិវត្ត* ខែ ឧសភា-មិថុនា ឆ្នាំ ១៩៧៨ បានសរសេររៀបរាប់ថា "ខ្មែរក្បត់"នៅក្នុងប្រទេសកម្ពុជាចាំបាច់ត្រូវតែវាយ ហើយ "វាយអាស្រួចជាងគេ គឺយួនឈ្លានពានលេបទឹកដី"[3098]។ តាមរយៈការបន្តចាត់ទុកជនជាតិវៀតណាមជាមនុស្សអាក្រក់បែបនេះ ប.ក.ក បានស្វះស្វែងយ៉ាងសកម្មជំរុញឱ្យមានកំហឹងប្រឆាំងជនជាតិវៀតណាម។ នៅថ្ងៃទី ៣ ខែ មករា ឆ្នាំ ១៩៧៨ មន្ទីរ ៨៧០ បានផ្សព្វផ្សាយសេចក្តីណែនាំដោយសង្កត់ធ្ងន់ថា "ត្រូវ[...]បំផុសកំហឹងជាតិ និងកំហឹងវណ្ណៈក្នុងប្រជាជនចំពោះខ្មាំងយួនឈ្លានពានឱ្យជាប់ ដើម្បីប្រែក្លាយកំហឹងនេះទៅជាកំហឹងពិតប្រាកដ ស្តែងចេញជាអំពើសកម្មភាពជាក់ស្តែងគ្រប់បែបយ៉ាង"[3099]។ សេចក្តីណែនាំទាំងនេះបានផ្សព្វផ្សាយទៅថ្នាក់ក្រោមរបស់បក្ស[3100]។ ឯកសារសេចក្តីណែនាំនេះបានធ្វើការសន្និដ្ឋានថា ប្រសិនបើអនុវត្តបាន "យួនឈ្លានពានមុខជាយកឆ្អឹងទាំងគំនរមកចោលនៅលើដីយើងហើយ"[3101]។

---

សំដៅទៅលើពូជ ពូជខ្មែរដែលពីដើម គឺមិនបានប្រើប្រាស់ជាប៉ុន្មាននោះទេ។ នេះជាពាក្យវាក្យស័ព្ទមួយ ដើម្បីជម្រុញឱ្យប្រជាជនកម្ពុជា ចូលរួមពាក់ព័ន្ធទៅនឹងពេលដែលគេធ្វើសង្គ្រាមប្រឆាំងជាមួយពូជ -- សង្គ្រាមពូជសាសន៍ជាមួយនឹងវៀតណាម [មិនមែនជនជាតិចាមទេ]។ គឺចង់សំដៅវែកមុខរកអ្នកណាមិនមែនជាខ្មែរ។" (គូសបញ្ជាក់បន្ថែម)]។

3097 ឯកសារ D4.1.869 ទង់បដិវត្ត ខែ កក្កដា ឆ្នាំ ១៩៧៨ EN 00428289 KH 00064486-00064487 ["ប្រទេសជាតិយើង ប្រជាជនយើង ពូជសាសន៍កម្ពុជាយើងថិតថេរគង់វង្សមកដល់សព្វថ្ងៃនេះ ព្រោះដូនតាយើង ម៉ែឪយើង បងប្អូនប្រជាពលរដ្ឋយើង ហើយនិងយើងទាំងអស់គ្នា បាននិងកំពុងធ្វើពលិកម្ម ពីជំនាន់មួយទៅជំនាន់មួយ លះបង់ សាច់ ឈាមឆ្អឹង រហូតដល់អាយុជីវិត វាយកំចាត់ខ្មាំងយួនឈ្លានពាន វាតទីលេបទឹកដី បំបាត់ពូជសាសន៍ បានជ័យជម្នះជាបន្តបន្ទាប់។"]។

3098 ឯកសារ D1.3.24.5 ទង់បដិវត្ត ខែ ឧសភា-មិថុនា ឆ្នាំ ១៩៧៨ EN 00185333 KH 00064567 ["សរុបសេចក្តីទៅគូទំនាស់ជាមួយយើង គឺ សេអ៊ីអា យួន និង កាសេបេ នៅក្នុងនេះ ពិសពុលស្រួចស្រាវជាងគេ គឺ យួន។ ឈរលើការវិភាគទំនាស់ស្លាប់រស់ស្រួចស្រាវនេះ តើវិធានការយើងវាយវាយ៉ាងម៉េច? ១. វាយអាស្រួចជាងគេ គឺយួនឈ្លានពានវាតទីលេបទឹកដី។ ២. ព្រមជាមួយនេះ វាយ សេអ៊ីអា និង កាសេបេ។ វាយព្រមជាមួយគ្នា ប៉ុន្តែយកចិត្តទុកដាក់វាយយួនជាងគេ ពីព្រោះវាស្រួចស្រាវ ពិសពុល ជាងគេ។"]។

3099 ឯកសារ D4.1.605 សេចក្តីណែនាំរបស់មន្ទីរ ៨៧០ ថ្ងៃទី ៣ ខែ មករា ឆ្នាំ ១៩៧៨ EN 00296007 KH 00284282។

3100 ឯកសារ D4.1.605 សេចក្តីណែនាំរបស់មន្ទីរ ៨៧០ ថ្ងៃទី ៣ ខែ មករា ឆ្នាំ ១៩៧៨ EN 00296008 KH 00284284 ["សេចក្តីណែនាំនេះ ត្រូវចែកចាយ និងសិក្សាក្នុងគណៈបក្សភាគ តំបន់ ស្រុក សហករណ៍ ក្នុងគណៈសមរភូមិ គណៈ

758. ការឃោសនាផ្ទៃក្នុងរបស់ ប.ក.ក បានសង្កត់ធ្ងន់លើការពិពណ៌នាបែបបំផុសស្មារតី និងអវិជ្ជមានយ៉ាងខ្លាំងអំពីជនជាតិវៀតណាម។ ទង់បដិវត្តន៍ ខែ មេសា ឆ្នាំ ១៩៧៧ បានលើកឡើងថា ភ្នាក់ងារសេអ៊ីអា កាហ្សេបេ និងភ្នាក់ងារ"យ" [យួន] គឺជា "ខ្មាំងបម្រើខ្មាំងយ៉ាងថោកទាប"ដែល"ត្រូវខ្មាត់ខ្មាយរប៉ាត់រប៉ាយជាមូលដ្ឋាន ប្រៀបដូចកណ្តុរត្រូវវាយបែកសំបុកធ្លាក់ទឹក ហើយកំពុងត្រូវប្រជាជនដេញសំពងឲ្យវិនាសអន្តរធាន"[3102]។ ឯកសារនេះបានណែនាំកម្មាភិបាលថា៖ "យើងត្រូវវាយវាតទៅទៀត ជាន់វាថែមទៀត [...] ហើយវាយសំរុកវាជាប់ជានិច្ចក្នុង ១ ឆ្នាំ ១៩៧៧ នេះ ឲ្យវាកាន់តែខ្ទេចខ្ទីទៅទៀត ងើបក្បាលមិនរួច"[3103]។

759. ពាក្យពេចន៍ ដូចជា លុបបំបាត់[3104] កម្ទេច[3105] ដេញឱ្យអស់[3106] បោសសម្អាត[3107] សម្លាប់[3108] និងកម្ចាត់[3109] ឧស្សាហ៍ប្រើប្រាស់នៅក្នុងឯកសារនានារបស់ ប.ក.ក ដើម្បីពិពណ៌នាអំពីអ្វីដែល

---

កងពល វរសេនាធំ វរសេនាតូច អនុសេនាធំ អនុសេនាតូច ក្រុម និង យុទ្ធជន គណៈបញ្ជាការមុខព្រួញនីមួយៗ ឲ្យជ្រួតជ្រាបសារចុះសារឡើង ដកពិសោធន៍ជាប់ និងកែលំអការអនុវត្ត"]។

3101 ឯកសារ D4.1.605 សេចក្តីណែនាំរបស់ ៨៧០ ថ្ងៃទី ៣ ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00284284។

3102 ឯកសារ D4.1.862 ទង់បដិវត្ត ខែ មេសា ឆ្នាំ ១៩៧៧ KH ERN 00062986។

3103 ឯកសារ D4.1.862 ទង់បដិវត្ត ខែ មេសា ឆ្នាំ ១៩៧៧ KH ERN 00062986។ សូមមើលផងដែរ ឯកសារ D4.1.862 ទង់បដិវត្តន៍ ខែ មេសា ឆ្នាំ ១៩៧៧ KH ERN 00062991 ["ត្រូវបំពាក់បំប៉ន និងបំពាក់មហាជនធ្វើជាកម្លាំងរកខ្មាំង ពិនិត្យខ្មាំង វិភាគខ្មាំង តាមដានខ្មាំង កៀបសង្កាត់ខ្មាំង ចាប់ខ្មាំង និងកម្ទេចខ្មាំង ធ្វើឲ្យខ្មាំងទៅជាកណ្តុរក្នុងរង្វង់ហ៊ុំព័ទ្ធ វាយកម្ទេចរបស់ប្រជាជន ដ៏កុះករ"]។

3104 សូមមើលឧទាហរណ៍ ឯកសារ D4.1.862 ទង់បដិវត្ត ខែ មេសា ឆ្នាំ ១៩៧៧ KH ERN 00062900-01 ["វានឹងខិតខំរើបម្រះ ហើយបន្តសកម្មភាពឧក្រិដ្ឋរបស់វាតទៅទៀត ទាំងផ្នែក "ស.អ.អ" ទាំងផ្នែក "ក.ស.ប" ទាំងផ្នែក "យ" និងខ្មាំងបម្រើវា។ នេះជាទស្សនៈមួយ ដែលយើងត្រូវច្បាស់លាស់ជាប់ជានិច្ច ដើម្បីមានគោលជំហរប្រុងប្រយ័ត្នបដិវត្តន៍ខ្ពស់ ទប់ទល់ និងកម្ចាត់ខ្មាំងជាមុន ដោយម្ចាស់ការជានិច្ច"]។ ឯកសារ D4.1.866 ទង់បដិវត្ត ខែ កុម្ភៈ ឆ្នាំ ១៩៧៨ KH ERN 00064441-42 ["សមមិត្តទាំងឡាយ ជាទីស្នេហា។ យើងឃើញមហាជ័យជម្នះរបស់យើង លើយួនឈ្លានពានហើយ៖ ដោយបក្សយើងទាំងមូល ឯកភាពជាធ្លុងមួយដឹកនាំវាយកម្ចាត់ខ្មាំង"]។

3105 សូមមើលឧទាហរណ៍ ឯកសារ D4.1.862 ទង់បដិវត្ត ខែ មេសា ឆ្នាំ ១៩៧៧ KH ERN 00062903 ["បញ្ហាមួយដែលត្រូវយកចិត្តទុកដាក់សំខាន់ណាស់ដែរ គឺវែកមុខពួក "ស.អ.អ" និងភ្នាក់ងាររបស់វា ពួក "ក.ស.ប" និងភ្នាក់ងាររបស់វា ពួក "យ" លេបទឹកដី និងខ្មាំងបម្រើរបស់វាឲ្យច្បាស់ និងជាបន្តបន្ទាប់ ក្នុងបក្សទាំងមូល កងទ័ពទាំងមូល និងប្រជាជនទាំងមូល វាយផ្តាច់ខ្មាំងខាងនយោបាយកុំឲ្យវាមកលបចូលបាននៅក្នុងបក្សយើង កងទ័ពយើង និងប្រជាជនយើងជារៀងរហូត។ ឯឫសចាស់របស់វាដែលនៅសេសសល់ខ្លះ ក្រោយពីយើងកម្ចាត់ឲ្យវាខ្ទេចខ្ទីនេះ ក៏ត្រូវបំផុតមហាជន ឲ្យគេបោសសម្អាតថែមទៀត ឲ្យស្អាតជាស្អាតពរ"]។

កម្មាភិបាលគួរធ្វើចំពោះជនជាតិវៀតណាម។ ឯកសារនានារបស់ ប.ក.ក ប្រើប្រាស់ពាក្យពេចន៍

---

3106 សូមមើលឧទាហរណ៍ ឯកសារ D4.1.303 ទូរលេខ៤៧ ពី សារុន គោរពជូនបង ម.៨៧០ ថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00021054 ["យើងខ្ញុំសូមរាយការណ៍ពីស្រុកប្រជាជនយួនរត់មកចំនួន៩នាក់ តាមសួរចម្លើយរបស់វាគឺវាថាយួនចាត់ចែងឲ្យវាមកស៊ើបការណ៍នៅក្នុងប្រទេសកម្ពុជា និងមករស់នៅនឹងប្រជាជនកម្ពុជា ដើម្បីក្តាប់ប្រជាជនកម្ពុជា ឥឡូវនេះបានបោសសម្អាតវាហើយ"]។ ឯកសារ D114/36.1.30 របាយការណ៍ពីមន្ទីរ ៤០១ គោរពជូនអង្គការ ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ១៩៧៨ KH ERN 00143610 ["វិធានការយើងលើសកម្មភាពខ្មាំងខាងលើនេះ៖ បន្តតាមដានស្រាវជ្រាវរកខ្មែរខ្មាំងគ្រប់ប្រភេទ ដែលបង្កប់ស៊ីរូងផ្ទៃក្នុង ហើយបោសសម្អាតវាតទៅទៀត ឲ្យស្អាតដាច់ខាតពីក្នុងមូលដ្ឋាន និងអង្គភាព មន្ទីរ ក្រសួងផ្សេងៗ"]។

3107 សូមមើលឧទាហរណ៍ ឯកសារ D4.1.374 សេវាផ្សព្វផ្សាយព័ត៌មានបរទេស កងទ័ពកម្ពុជាអនុម័តសេចក្តីសម្រេចស្តីពីជម្លោះជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00244273 ["តស៊ូដើម្បីលុបបំបាត់រាល់ទស្សនទានឯកជន និងបុគ្គលនិយមគ្រប់ប្រភេទពីខ្លួនរបស់យើងក៏ដូចជាពីជួរនៃកងទ័ពបដិវត្តន៍ទាំងមូល និងពុំពារកសាងខ្លួន និងអង្គភាពរបស់យើងឲ្យក្លាយជាងអង្គភាពរឹងមាំជានិច្ចស្របតាមជំហរសមូហភាពពលកម្មនិយម ដើម្បីប្រយុទ្ធនឹងខ្មាំងយួនដែលជាអ្នកប៉ុនប៉ងយកកម្ពុជាជាឧបសម្ព័ន្ធរបស់វា និងខ្មាំងផ្សេងៗទៀតគ្រប់ប្រភេទទាំងអស់ ដើម្បីបោសសម្អាតពួកវាទាំងស្រុងចេញពីទឹកដីនៃប្រទេសកម្ពុជា និងដើម្បីថែរក្សាកិត្តិយសរបស់ប្រជាជាតិ និងអាចប្រឹងប្រែងកសាងប្រទេសឲ្យបានល្អ និងរហ័សក្នុងល្បឿនមហាលោតផ្លោះមហាអស្ចារ្យ"]។

3108 សូមមើលឧទាហរណ៍ ឯកសារ D4.1.374 សេវាផ្សព្វផ្សាយព័ត៌មានបរទេស កងទ័ពកម្ពុជាអនុម័តសេចក្តីសម្រេចស្តីពីជម្លោះជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ថ្ងៃទី ៤ ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00244271 ["ក្រោយពីបានស្តាប់ការផ្សព្វផ្សាយសុន្ទរកថារបស់រដ្ឋាភិបាលនៃកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ និងបានរឭកឡើងវិញនៅថ្ងៃទី ១ និងទី ២ ខែ មករា ឆ្នាំ១៩៧៨ ដោយបានអំពាវនាវដល់បក្សទាំងមូល កងទ័ពទាំងមូល ក៏ដូចជាប្រជាជនទាំងអស់ឲ្យលើកកម្ពស់ប្រយុងប្រយ័ត្នបដិវត្តន៍ និងលើកទង់យុទ្ធជនឲ្យបានខ្ពស់ដើម្បីប្រយុទ្ធ និងកម្ទេចខ្មាំងយួនដែលជាអ្នកប៉ុនប៉ងយកម្ពុជាធ្វើជាឧបសម្ព័ន្ធរបស់វា យុទ្ធជន យុទ្ធនារីរបស់យើង និងកម្មាភិបាលនៃកងទ័ពបដិវត្តន៍ទាំងបីប្រភេទ មានកងទ័ពជើងគោល កងនាវាចរ និងកងទ័ពអាកាស ទាំងនៅខ្សែត្រៀមខាងមុខ និងខ្សែត្រៀមខាងក្រោយ បានប្រារព្ធធ្វើមីទ្ទីង ដូចដែលប្រជាជនកម្ពុជាបានធ្វើនៅពាសពេញប្រទេសកម្ពុជា ដើម្បីគាំទ្រសេចក្តីថ្លែងការណ៍នេះនៅក្នុងលក្ខណៈមួយម៉ឺងម៉ាត់ ប្រកបដោយការប្តេជ្ញាចិត្ត តែមិនឆេវឆាវ និងប្រកបដោយការអបអរសាទរខ្ពស់។ នៅក្នុងអង្គមីទ្ទីងនេះ ពួកគេបានសម្តែងនូវការខឹងសម្បារ និងការឈឺចាប់ចំពោះខ្មាំងយួនដែលជាអ្នកប៉ុនប៉ងយកម្ពុជាធ្វើជាឧបសម្ព័ន្ធរបស់វា"]។

3109 សូមមើលឧទាហរណ៍ ឯកសារ D4.1.893 យុវជន និងយុវនារីបដិវត្ត ខែ តុលា ឆ្នាំ ១៩៧៨ KH ERN 00376497-98 [សំខាន់ជាងនេះទៀត គឺដើម្បីត្រៀម]ស្បៀងបំប៉នកម្លាំងប្រយុទ្ធរបស់កងទ័ពបដិវត្តន៍យើងនៅសមរភូមិមុខឲ្យបានគ្រប់គ្រាន់បរិបូរជានិច្ច ត្រៀមវាយបំបាក់ និងវាយកម្ទេចផែនការវាយលុកឈ្លានពាន រដូវប្រាំងរបស់ខ្មាំងយួនវាតទីលេបទឹកដី បំបាត់ពូជសាសន៍ឲ្យបរាជ័យខ្ចាត់ខ្ចាយ កាន់តែធ្ងន់ធ្ងរថែមទៀត រហូតដល់វាត្រូវបរាជ័យរលំរលាយទាំងស្រុង"]។

បង្អាប់ និងគ្មានតម្លៃជាមនុស្សចំពោះជនជាតិវៀតណាម ដូចជា "យួនធុំក្លិនដល់ឋានលើ ហើយគេស្អប់ខ្ពើមគ្មានតម្លៃអ្វីសោះ"[3110] វៀតណាមគឺជា"ជនឧក្រិដ្ឋ"[3111] "ពិសពុល"[3112] "លោភលន់"[3113] "សាហាវ"[3114] "ជិះជាន់"[3115] "កណ្ដុរ" [3116] "ផ្ដេកបម្រើ"[3117] "មេរោគ"[3118] ហើយដោយលើកឡើង

---

3110 ឯកសារ D4.1.869 ទង់បដិវត្ត ខែកក្កដា ឆ្នាំ ១៩៧៨ EN ERN 00428289 ["ប្រទេសយើង ប្រជាជនយើងមានកិត្តិយស និងមានឈ្មោះល្បីល្បាញ ដោយសារតែយើងខំកសាងប្រទេសដោយខ្លួនឯង និងឯករាជម្ចាស់ការ។ កេរ្តិ៍ឈ្មោះអាសោចរបស់យួនទៅឋានសួគ៌ដ៏ខ្ពស់ និងត្រូវបានមើលងាយថាគ្មានអ្វីសោះ ព្រោះយួនកាន់តែធុង ហើយដើរសុំសម្រាប់សប្បុរសធម៌គ្រប់ច្រកល្ហក"]។

3111 ឯកសារ D69.1.21 សុន្ទរកថារបស់សមមិត្ត ខៀវ សំផន ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៨ KH ERN S 00704525 ["ការណ៍ដែលយើងបានការពារប្រទេសរបស់យើងប្រកបដោយជោគជ័យ ដោយបានកម្ទេចជាផេះផង់នូវរាល់សកម្មភាពបំផ្លិចបំផ្លាញរបស់ចក្រពត្តិនិយមអាមេរិក និងបក្សពួក ការណ៍ដែលយើងបានបំផ្លាញដោយជោគជ័យនូវសកម្មភាពបំផ្លិចបំផ្លាញរបស់ពួកវាតទីនិយម និងពួកប្រតិកិរិយាពីគ្រប់ទិសទី ជាពិសេសទង្វើឧក្រិដ្ឋកម្មរបស់ពួនឈ្លានពាន វាតទីនិយម និងលេបទឹកដី"]។

3112 ឯកសារ D1.3.24.5 ទង់បដិវត្ត ខែ ឧសភា-មិថុនា ឆ្នាំ ១៩៧៨ EN ERN 00064566-67 ["កម្លាំងដែលប្រឆាំងបដិវត្តន៍យើងនេះ គឺអង្គការសេ.អ៊ី.អា ដែលតំណាងឲ្យចក្រពត្តិអាមេរិក និងកម្លាំងប្រតិកិរិយាដទៃទៀត ហើយយួន និងសូវៀត ដែលវាចាត់តាំងខ្សែក្បត់នៅកម្ពុជា។ កម្លាំងនេះវាចាត់តាំងរួចមកហើយ វាកំពុងចាត់តាំង ហើយវាចាត់តាំងតទៅទៀត។ កម្លាំងប្រឆាំងទាំងនេះ ជាភ្នាក់ងារចារកម្មរបស់ សេ.អ៊ី.អា របស់យួន និងរបស់សូវៀត។ កម្លាំងទាំងនេះ ដែលយើងត្រូវវាយ។ សរុបសេចក្ដីទៅ គូទំនាស់ជាមួយយើង គឺសេ.អ៊ី.អា យួន និង កា.ហ្សេ.បេ នៅក្នុងនេះពិសពុលស្រួចស្រាវជាងគេ គឺយួន"]។

3113 ឯកសារ D234/2.1.33 SWB ជំនួបនៅទីក្រុងភ្នំពេញ សម្គាល់ថ្ងៃទី ១៧ ខែ មេសា ជាថ្ងៃបុណ្យខួប ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៨ EN ERN 00010558 ["វៀតណាមលោភលន់ មានបំណងអាក្រក់ក្នុងការលេបយកទឹកដីកម្ពុជារបស់យើង"]។

3114 ឯកសារ D1.3.17.3 របាយការណ៍ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ សៀវភៅខ្មៅ ខែ កញ្ញា ឆ្នាំ ១៩៧៨ KH ERN 00289658 ["យួនគឺជាឈ្មោះដែលប្រជាជនកម្ពុជាដាក់ឲ្យវៀតណាមតាំងពីសម័យអង្គរ ហើយវាមានន័យថា "សាហាវ"។ ពាក្យ "វៀតណាម" និង "ជនជាតិវៀតណាម" គឺជាពាក្យថ្មី និងមិនត្រូវបានប្រជាជនកម្ពុជាប្រើជាញឹកញាប់ទេ"]។ ឯកសារ D1.3.17.1 អេលីហ្សាបែត បេ៊កខ័រ នៅពេលដែលសង្គ្រាមរលត់ទៅ EN ERN 00237827 ["ពួកកុម្មុយនីស្តកម្ពុជាហៅវៀតណាមកុម្មុយនីស្តថា "យួន" ដែលនិយាយប្រដូចនឹងសត្វសាហាវ"]។

3115 ឯកសារ D1.3.29.5 សេចក្ដីថ្លែងការណ៍របស់សមមិត្ត ប៉ុល ពត ថ្ងៃទី ៥ ខែ មករា ឆ្នាំ ១៩៧៩ KH ERN 00225372 ["ប្រជាជនកម្ពុជាទាំងមូលប្ដេជ្ញាមិនព្រមធ្វើជាបាវបម្រើវៀតណាម មិនឲ្យបាត់បង់ជាតិរបស់ខ្លួនផ្ទាល់ មិនឲ្យវៀតណាមកៀបសង្កត់ កេងប្រវ័ញ្ច និងឆក់ប្លន់តាមអំពើចិត្តពួកវាទេ។ ខ្មាំងសត្រូវវៀតណាម បានបង្កើន និងកំពុងបង្កើនទំនាស់រវាងពួកគេ និងជាតិ និងប្រជាជនកម្ពុជាទាំងមូល។ ទំនាស់ទាំងនេះបានចាក់ឫសយ៉ាងជ្រៅ និងកាន់តែកើនឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ"]។

ថាជនជាតិវៀតណាមមានរូបភាពជាបញ្ញើក្អែក ចាត់ទុកជនជាតិវៀតណាម ជា"ខ្មាំងស៊ីរូងផ្ទៃក្នុង"[3119]។ ជនជាតិវៀតណាម ក៏ត្រូវបានចាត់ទុកថាខូចខាងផ្លូវភេទ ដោយត្រូវចោទថារំលោភផ្លូវភេទលើនារីកម្ពុជា[3120] ហើយលក់ខ្លួននារីវៀតណាម ដើម្បីសម្រេចបហិច្ឆតាឈ្លានពាននិយមរបស់ខ្លួន[3121]។

---

3116 ឯកសារ D4.1.862 ទង់បដិវត្ត ខែ មេសា ឆ្នាំ ១៩៧៧ KH ERN 00062986 ["ភ្នាក់ងារ "យ" [...] ត្រូវកម្ទេចជាមូលដ្ឋាន ហើយកម្លាំងដែលនៅសេសសល់ ក៏ត្រូវខ្ចាត់ខ្ចាយ រប៉ាត់រប៉ាយ ជាមូលដ្ឋានដែរ ប្រៀបបីដូចកណ្តុរត្រូវវាយបែកសំបុកធ្លាក់ទឹក ហើយកំពុងត្រូវប្រជាជនដេញសំពងឱ្យវិនាសអន្តរធាន"]។

3117 ឯកសារ D4.1.869 ទង់បដិវត្ត ខែកក្កដា ឆ្នាំ ១៩៧៨ KH ERN 00064502 ["ភ្នាក់ងារសេ.អ៊ី.អា ភ្នាក់ងារក្អែបម្រើយួននិងភ្នាក់ងារកា.ហ្សេ.បេ បានដុតភ្លើងកំហឹងជាតិ និងកំហឹងវណ្ណៈ យ៉ាងឆាបឆេះដល់សមាជិកសហករណ៍ទាំងអស់។ ភ្លើងកំហឹងជាតិ និងភ្លើងកំហឹងវណ្ណៈនេះ បានប្រែក្លាយទៅជាមហាចលនាកម្ចាត់ខ្មាំងយួនឈ្លានពានវាតតីលេបទឹកដី"]។

3118 ឯកសារ D4.1.868 ទង់បដិវត្ត ខែ មេសា ឆ្នាំ ១៩៧៨ KH ERN 00064725 ["ខ្មាំងសត្រូវជិតឆ្ងាយមកឃោសនាបន្លំបោកបញ្ឆោតយើង បំភ័យយើង ឱ្យយើងខ្លាចខ្មាំង ត្រូវកម្ចាត់វា កុំឱ្យមេរោគស៊ីរូងនៅក្នុងប្រជាជន នៅក្នុងបក្ស នៅក្នុងកងទ័ពរបស់យើង។ យើងធ្វើឱ្យកងទ័ពយើងស្អាត បក្សស្អាត ប្រជាជនស្អាត ដើម្បីវាយខ្មាំងតទៅទៀត ការពារទឹកដីកម្ពុជា គឺការពារពូជសាសន៍កម្ពុជា"]។

3119 ឯកសារ D4.1.869 ទង់បដិវត្ត ខែកក្កដា ឆ្នាំ ១៩៧៨ EN ERN 00064502 ["ភ្លើងកំហឹងជាតិ និងភ្លើងកំហឹងវណ្ណៈនេះ បានប្រែក្លាយទៅជាមហាចលនាកម្ចាត់ខ្មាំងយួនឈ្លានពានវាតតីលេបទឹកដី និងបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុងយ៉ាងទូលំទូលាយ"]។

3120 ឯកសារ D1.3.17.3 របាយការណ៍ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ សៀវភៅខ្មៅ ខែ កញ្ញា ឆ្នាំ ១៩៧៨ KH ERN 00289695 ["ប្រជាជនកម្ពុជាធ្វើម្តបជាមួយនឹងការស្អប់ខ្ពើមយ៉ាងជ្រាលជ្រៅចំពោះវៀតណាម ដូច្នោះ វាមិនចាំបាច់ធ្វើឃោសនាការដើម្បីបំផុសការស្អប់ខ្ពើមនេះទេ។ ថ្នាក់ដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជាតែងតែព្យាយាមធ្វើឱ្យស្ថានការណ៍មានសភាពរលូនល្អជាមួយវៀតណាមក៏ដូចជាជាមួយប្រជាជន"]។

3121 ឯកសារ D1.3.17.3 របាយការណ៍ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ សៀវភៅខ្មៅ ខែ កញ្ញា ឆ្នាំ ១៩៧៨ KH ERN 00289656 ["វៀតណាមជាញឹកញយបានប្រើប្រាស់វិធីសាស្ត្រថោកទាបទាំងនេះ ដែលរួមមានលក់ស្រីរបស់ពួកគេ ដើម្បីសម្រេចបាននូវមហិច្ឆតាទឹកដីរបស់ខ្លួន។ សព្វថ្ងៃនេះ ពួកគេនៅតែគ្មានការរួញរាក្នុងការបន្តវិធីសាស្ត្រដ៏គួរឱ្យស្អប់ខ្ពើមទាំងនេះក្នុងការលេបយកទឹកដីរបស់ប្រទេសដទៃ"]។

760. ប.ក.ក ក៏ដាក់គោលដៅលើជនស៊ីវិលផងដែរ នៅក្នុងការវាយប្រហារឆ្លងព្រំដែនចូលវៀតណាម[3122]។ នាពេលក្រោយមក ខៀវ សំផន បានចាត់ទុកថា ការវាយប្រហារទាំងនោះគឺជា"អំពើសាហាវយង់ឃ្នង" ដោយបញ្ជាក់ថា "ច្បាស់ណាស់ពុំអាចប្រកែកបានឡើយ៖ ខ្មែរក្រហមបានចូលទៅលុកលុយក្នុងភូមិវៀតណាមតាមព្រំប្រទល់ ហើយបានប្រព្រឹត្តអំពើសាហាវយង់ឃ្នងទៅលើប្រជាជនស៊ីវិលវៀតណាម"[3123]។

761. កងរបស់ ប.ក.ក ដែលបានចូលរួមការវាយប្រហារឆ្លងព្រំដែន មិនបានធ្វើការបែងចែកឱ្យខុសគ្នារវាងទាហានវៀតណាម និងជនស៊ីវិលធម្មតាឡើយ[3124]។ របាយការណ៍មួយចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩៧៨ ពី សុន សេន ផ្ញើជូន អៀង សារី បានលម្អិតអំពីការសម្លាប់ និងធ្វើឱ្យរបួស"ច្រើនរយក្បាល" និង"ឆេះផ្ទះរាប់រយខ្នង"នៅក្នុងការវាយប្រហារចូល"ទីប្រជុំជន" និង"ផ្សារ"ឆ្លងចូលព្រំដែនវៀតណាម[3125]។ សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយម្នាក់នៅ មន្ទីរ ស-២១ ពីខែ មករា ឆ្នាំ

---

[3122] សូមមើលឧទាហរណ៍ ឯកសារ D4.1.554 កំណត់ហេតុស្តាប់ចម្លើយ ឡាយ អ៊ាន KH ERN 00270174 ["ក្នុងពេលប្រយុទ្ធក្នុងទឹកដីវៀតណាម ក្រុមខ្ញុំ និងខ្ញុំបានបោះគ្រាប់បែក និងដុតផ្ទះ មន្ទីរពេទ្យកងទ័ព គ្រាប់រំសេវ រោងចក្រអាឈើ។ [...] ពួកខ្ញុំ និងខ្ញុំផ្ទាល់ចាប់បានប្រជាជនវៀតណាតមានបុរសខ្លះ និងភាគច្រើននារី ក្នុងម្តងបួនដប់នាក់"]។

[3123] ឯកសារ D54/74.1.15 ខៀវ សំផន ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និង គោលជំហររបស់ខ្ញុំជាបន្តបន្ទាប់ KH ERN 00103850 ["ពុំអាចប្រកែកបានឡើយ៖ ខ្មែរក្រហមបានចូលទៅលុកលុយក្នុងភូមិវៀតណាមតាមព្រំប្រទល់ ហើយបានប្រព្រឹត្តអំពើសាហាវយង់ឃ្នង ទោះបីមកពីខាងណាក៏ដោយ សុទ្ធតែគួរឱ្យស្អប់ខ្ពើម ហើយត្រូវផ្តន្ទាទោស។ ក្រោយពីបានអានរឿងរ៉ាវទាំងអស់នេះ ខ្ញុំមានការរន្ធត់ចិត្តយ៉ាងខ្លាំង"]។

[3124] ឯកសារ D69.1.6 (E3/526) ក្រសួងការបរទេសសាធារណរដ្ឋសង្គមនិយមវៀតណាម អង្គហេតុ និងឯកសារ ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00283124 ["នៅតាមកន្លែងជាច្រើន កងទ័ពកម្ពុជាបានប្រព្រឹត្តអំពោះអមនុស្សធម៌យ៉ាងខ្លាំងដោយចាប់រំលោភស្ត្រី វះយកគត៌តាមស្បូនរបស់ស្ត្រី វះពោះយុវវ័យ បារយកពោះវៀន ដុតកុមារទាំងអស់ជាដើម។ មនុស្សទាំងគ្រួសារៗជាច្រើនត្រូវបានសម្លាប់យ៉ាងព្រៃផ្សៃ។ កងទ័ពកម្ពុជាបានបង្កឱ្យមានការបាត់បង់ជីវិតមនុស្ស និងទ្រព្យសម្បត្តិយ៉ាងច្រើនអនេកសម្រាប់ប្រជាជននៅតាមមូលដ្ឋាន។ លំនៅដ្ឋានរាប់ពាន់ខ្នងៗ និងទ្រព្យសម្បត្តិច្រើនប្រភេទផ្សេងៗទៀតត្រូវបានបំផ្លិចបំផ្លាញ។ ប្រជាជនស៊ីវិលរាប់ម៉ឺននាក់ត្រូវបានចាកចេញឆ្ងាយពីព្រំដែនដើម្បីសន្តិសុខផ្ទាល់ខ្លួន។ ការពារពលកម្មដោយសន្តិភាពរបស់ប្រជាជនវៀតណាមនៅតាមបណ្តោយព្រំដែន ត្រូវបានបំផ្លាញចោលយ៉ាងធ្ងន់ធ្ងរ"], KH ERN 00283139-40។

[3125] ឯកសារ D4.1.606 ទូរលេខ ១៨ ផ្ញើពី ៤៧ (សុន សេន) ជម្រាបបង វ៉ាន់ (អៀង សារី) ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩៧៨ ["ខ្មាំងដែលបុកមកតំបន់២៤ នៅត្រពាំងព្រាម និងបារាយត្រូវយើងវាយបាក់ថយក្រោយទាំងស្រុងហើយ។ យើងបាញ់ឆេះរថក្រោះទាងអស់៥គ្រឿង។ កម្លាំងរស់ វាក៏ត្រូវស្លាប់ និងរបួសច្រើនណាស់។ យើងវាយចូលទីប្រជុំជនដុងថាប់ និងផ្សារខាងត្បូងត្រពាំងព្រាម និងតឹងចូវធ្វើឱ្យវាងាប់ និងរបួសច្រើនរយក្បាល និងឆេះផ្ទះរាប់រយខ្នង"]។

១៩៧៨ ដល់ ខែ កក្កដា ឆ្នាំ ១៩៧៨ មានលម្អិតអំពីរបៀប"យើងវាយក្នុងដីយួន" ហើយអះអាងថា កងខ្មែរក្រហម "សម្រេចគោលការណ៍ ១-៣០"[3126] ដែលនេះបង្ហាញឲ្យឃើញថា កម្លាំងរបស់ ប.ក.ក បានព្យាយាមអនុវត្តគោលនយោបាយរបស់ប៉ុល ពត ដែលថា ខ្មែរម្នាក់ត្រូវសម្លាប់វៀតណាម ៣០ នាក់។

## ការអនុវត្តគោលនយោបាយប្រល័យពូជសាសន៍មកលើជនជាតិវៀតណាម

### <u>ការនិរទេសជនជាតិវៀតណាម</u>

762. ផែនការរបស់ ប.ក.ក ដើម្បីបោសសម្អាតដែនដីកម្ពុជាប្រជាធិបតេយ្យឲ្យអស់ជនជាតិវៀតណាម បានធ្វើឲ្យជនជាតិវៀតណាមចំនួនប្រហែលជា ១៥០ ០០០ នាក់ត្រូវបាននិរទេសនៅដំណាក់កាលដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ[3127]។

763. នៅឆ្នាំ ១៩៧៦ រដ្ឋាភិបាលវៀតណាម និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានធ្វើការដោះដូរជនជាតិគ្នា គឺជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជា ត្រូវបញ្ជូនត្រឡប់ទៅវៀតណាមវិញ ហើយខ្មែរដែលរស់នៅក្នុងដែនដីវៀតណាម ត្រូវបញ្ជូនត្រឡប់មកកម្ពុជាប្រជាធិបតេយ្យវិញ[3128]។

---

3126 ឯកសារ D4.1.96 ស-២១ សៀវភៅកំណត់ហេតុសួរចម្លើយរបស់ ម៉ម ណៃ ហៅ ចាន់ KH ERN 00077894 [រៀបរាប់ពី "សកម្មភាពរវាងយើង និងយួននៅបូព៌ា" រួមទាំងវៃឈ្នះយួន "សម្រេចគោលការណ៍ ១ ( ៣០"]។

3127 ឯកសារ D4.1.624 កំណត់ហេតុស្តាប់ចម្លើយ សៅ សារុន KH ERN 00345906 ["តើមាននិយាយអំពីរឿងដេញវៀតណាមចេញពីស្រុកខ្មែរឲ្យអស់? ឆ៖ មាននិយាយមែន ហើយអ្នកនិយាយគឺ ប៉ុល ពត។ ពេលក្រោយមក ខ្ញុំឮតាមកម្មាភិបាលថ្នាក់ក្រោមខ្ញុំប្រាប់ថា មានឡានដឹកវៀតណាមចេញទៅស្រុកវិញមែន ពីខេត្តកំពង់ចាមនិងក្រចេះ"]។ ឯកសារ D114/29.1.4 ប៉ែន យៀនិន របប ប៉ុល ពត KH ERN 00637442 ["ការបរិយាយពីមុនគេបង្អស់ គឺមានកាលបរិច្ឆេទចាប់ពីពាក់កណ្តាលឆ្នាំ១៩៨០មក [...] ឈូក បានប្រាប់ ស៊ិន សុង ថា ប៉ុល ពត បានលើកឡើងនូវប្រការចំនួន ៨ចំណុច៖ [...] ៧. បណ្តេញជនជាតិភាគតិចវៀតណាមឲ្យចេញទាំងអស់"], KH ERN 00637518 ["ទាំងពីរនាក់ ប៉ុល ពត និង នួន ជា បានប្រកាសនៅក្នុងអង្គប្រជុំខែ ឧសភា ឆ្នាំ ១៩៧៥ នូវផែនការទាំងឡាយរបស់ខ្លួន ដើម្បីដកជនជាតិភាគតិចវៀតណាមទាំងអស់ចេញពីប្រទេសកម្ពុជា [...] បក្សកុម្មុយនីស្តកម្ពុជាបានបញ្ជាឲ្យពួកនេះចេញពីកម្ពុជាមុខខែកក្កដា ឆ្នាំ ១៩៧៥។ មកដល់ត្រឹមចុងខែសីហា និគមជនវៀតណាមជាងមួយសែនប្រាំម៉ឺននាក់ ដែលស្ថិតនៅក្នុងប្រទេសកម្ពុជាត្រូវបានប្រមូលផ្តុំ ហើយបញ្ជូនទៅប្រទេសវៀតណាមទាំងអស់"]។

3128 ឯកសារ D11/58/3 តាក សាន់ ប្រតិចារិកថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ម៉ោង 13:12:31-13:16:29 ["ខ្ញុំឡើងមកដោយដូរយួនហ្នឹង"]។ ឯកសារ D11/44/3.1 បេង បឿន ប្រតិចារិកថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ម៉ោង 14:40:48-14:44:00 ["គេថា អង្គការនឹងបញ្ជូនបងប្អូនវៀតណាមទៅស្រុកវិញ មិនឮថា ផ្លាស់ប្តូរទេ"]។ ឯកសារ D11/44/3.2

ពេជ្រ ជឹម អតីតលេខាស្រុកត្រាំកក់ បានផ្ដល់សក្ខីកម្មថា កម្មវិធីដោះដូរនេះគឺជាដំណោះស្រាយមួយចំពោះបញ្ហាជនជាតិវៀតណាម[3129]។

764. ខ្មែរខ្លះដែលបានរត់ទៅវៀតណាម បន្ទាប់ពីខ្មែរក្រហមបានចូលកាន់កាប់ប្រទេស បានត្រឡប់មកកម្ពុជាវិញ ដោយមិនដឹងពីស្ថានភាពយ៉ាប់យ៉ឺន នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យទេ[3130]។ តាមរយៈកម្មវិធីដោះដូរនេះ ពួកគេត្រូវបានដោះដូរតាមចំនួនស្មើគ្នាជាមួយនឹងជនជាតិវៀតណាម ដែលត្រូវបណ្ដេញចេញពីប្រទេសកម្ពុជា[3131]។

---

ថាន់ ធីម ប្រតិចារឹកថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ ម៉ោង 09:36:57-09:39:25 ["ដូរយក វៀតណាមដូរយកទៅហ្នឹង"]។ ឯកសារ D11/61/3.1 រី ពៅ ប្រតិចារឹកថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ម៉ោង 09:11:03-09:14:23 ["ខ្ញុំបានទៅរស់នៅប្រទេសវៀតណាម។ លុះដល់ខែ០២ ឆ្នាំ ១៩៧៦ ត្រូវបានដូរវៀតណាម ជាថ្នូរជាវៀតណាមមករស់នៅកម្ពុជាវិញ"]។ ឯកសារ D11/61/3 កំណត់ហេតុស្ដាប់ចម្លើយ រី ពៅ ឆ.81-82 ["ខ្ញុំមិនស្គាល់ទេ ព្រោះនៅក្នុងឃុំពេលគឺជាអ្នកដែលស្ថិតក្នុងការដោះដូរលើកទី២ [...] ការដោះដូរប្រជាជនខ្មែរក្រោមជាមួយប្រជាជនវៀតណាម គឺមានពីរលើក [...] ស៖ តើការដោះដូរលើកទី២ កើតឡើងនៅពេលណា? ឆ.82៖ នៅក្នុងឆ្នាំ១៩៧៦ ប្រហែលជាកន្លែងខែក្រោយការដោះដូរលើកទី១"]។ ឯកសារ D4.1.806 កំណត់ហេតុស្ដាប់ចម្លើយ ជាំង ស្រីមុំ ឆ.14 ["ស៖ តើនៅក្នុងភូមិរបស់អ្នកស្រីមានជនជាតិភាគតិចចាម និងវៀតណាមដែរឬទេ? ឆ.14៖ មានតិចចំនួន ដែលគេទើបជម្លៀសមកថ្មី។ នៅចុងឆ្នាំ១៩៧៦ មានការប្រកាសដោយមេឃុំ គេនឹងបញ្ជូនជនជាតិវៀតណាមត្រឡប់ទៅប្រទេសរបស់គេវិញ"]។

3129 ឯកសារ D234/2.1.72 ពេជ្រ ជឹម ប្រតិចារឹកថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៥ ម៉ោង 10:08:22-10:11:23 ["ជនជាតិវៀតណាមដោះស្រាយហើយ តែវៀតណាមទៅវិញឲ្យទៅជាមួយ"]។

3130 ឯកសារ D11/61/3.1 រី ពៅ ប្រតិចារឹកថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ម៉ោង 09:21:06-09:23:11 ["ស៖ [...] លោករត់ទៅវៀតណាម ហើយលោកស្នាក់នៅវៀងតណាមពីរបីខែ ហើយរហូតដល់ខែកុម្ភៈ ឆ្នាំ ១៩៧៦ ដែលលោកបានរៀបរាប់ពីខាងដើម ហើយបន្ទាប់មកលោកនិងគ្រួសារទាំង បានសម្រេចចិត្តថាត្រឡប់ចូលមកកម្ពុជាវិញតាមរយៈកម្មវិធីដោះដូរ [...] ឆ៖ បាទជាការពិតណាស់អារឿង -- ពេលនោះខ្ញុំអត់ដឹងពីនយោបាយរបស់ខ្មែរក្រហមដែរ ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់ ដែលបានគេចភៀសខ្លួនទៅនៅប្រទេសគេ"]។ ឯកសារ D11/91/3 យ៉ែម ខុន្នី ប្រតិចារឹកថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ម៉ោង 09:11:02-09:15:05 ["ស៖ [...] សូមលោកស្រីជួយបញ្ជាក់បន្ថែមថានៅកាលនោះ លោកស្រី និងក្រុមគ្រួសារឡើងមកដោយសារស្ម័គ្រចិត្ត ឬក៏ដោយសារមានអ្នកណាមានការរៀបចំពីអ្នកណា? ឆ៖ អត់មានអ្នកណាបង្ខំទេ ឡើងមក ឬគេនិយាយតែម្ដងថា ទៅស្រុកលើ ទៅៗ ហើយសម្បូរហូបណាស់ ហើយគេធ្វើហូបស្រាប ទៅៗមិនចេះខ្វះអីហូបទេ។ ដល់តែមក ប្រែតែមកទៅ ស្រាប់តែគញមានបបរឆ្នោត បបរដំឡូង បបរគុលចេក ស្ពរត្រកួនហ្នឹងក៏គ្មានស្អី។ ចេះតែបបួលហូបហើយ"]។

3131 ឯកសារ D11/61/3 កំណត់ហេតុស្ដាប់ចម្លើយ រី ពៅ ឆ.19 ["ស៖ ប្រហែលជាលោកដឹង ឬមិនដឹងការដោះដូរជនជាតិវៀតណាម និងប្រជាជនកម្ពុជាក្រោមនេះ តើមានជនជាតិវៀតណាមប្រហែលប៉ុន្មាននាក់ក្នុងការដោះដូរនោះ? ឆ.

765. កិច្ចខិតខំប្រឹងប្រែងនិរទេសនេះត្រូវបានអនុវត្តនៅទូទាំងប្រទេស ហើយមានប្រសិទ្ធភាព។ *ទង់បដិវត្តន៍* ខែ មេសា ឆ្នាំ ១៩៧៦ បានប្រកាសថា "បដិវត្តន៍ប្រជាធិបតេយ្យរបស់យើង បានបោសសម្អាតជនបរទេសទាំងនេះរាប់សែននាក់ ឱ្យចេញផុតពីប្រទេសយើង ពីទឹកដីយើងទាំងអស់ជាស្ថាពរ"[3132]។ ឯកសារដដែលនេះក៏បានចាត់ទុកថា ការបណ្ដេញចេញដោយបង្ខំទាំងនេះគឺ"បានដោះស្រាយបញ្ហានេះទាំងស្រុង និងជាស្ថាពរ"[3133]។

766. ប៉ុន្តែ ការបណ្ដេញចេញនៅតែបន្តធ្វើឡើង។ ប្រាក់ ឌឿន បានផ្ដល់សក្ខីកម្មថា ក្រោយពីត្រូវគេបង្ខំឱ្យផ្លាស់ទៅកោះតាម៉ូវ (Ta Mov) នៅឆ្នាំ ១៩៧៧ មក ប្រធានកងនេះបានប្រកាសថា ជនជាតិវៀតណាមត្រូវបញ្ជូនត្រឡប់ទៅវៀតណាមវិញ ហើយប្រសិនបើនរណាចង់ទៅ គេគួរតែទៅ[3134]។ ប៉ុន្តែ នេះមិនមែនជាជម្រើសពិតប្រាកដទេ ពីព្រោះថា ប្រសិនបើនៅវិញ នោះត្រូវគេសម្លាប់។ ប្រាក់ ឌឿន បានឃើញជនជាតិវៀតណាមចំនួន ២០ នាក់ទៅ ៣០ នាក់[3135] ត្រូវគេប្រមូលដាក់ចូលក្នុងទូកមួយមានឃ្លាំប់[3136]។ គាត់បានផ្ដល់សក្ខីកម្មថា នៅសល់នារីជនជាតិវៀតណាមម្នាក់នៅក្នុងសហ

---

19៖ ប្រហាក់ប្រហែលគ្នា គឺប្រហែល២០០០នាក់ទៅ ២០០០នាក់មកវិញ"]។ សូមមើលផងដែរ ឯកសារ D11/61/3.1 រី ពៅ ប្រតិចារឹកថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ម៉ោង 09:25:00-09:29:20 ["ខ្ញុំនៅចងចាំបានខ្លះដោយសារពេលនោះ ខ្ញុំដឹងចំនួនប្រជាពលរដ្ឋដែលចុះភៀសខ្លួនទៅនៅប្រទេសវៀតណាម គឺនៅក្នុងភូមិហ្នឹងមានប្រជាពលរដ្ឋចំនួន ១០០០គ្រួសារ គេដាក់ប្រមូលផ្ដុំមួយកន្លែងងាយស្រួល។ [...] ខ្ញុំដឹងថានៅក្នុងឃុំកហ្នឹង វាមានប្រហែលជា ១០០០គ្រួសារទៅ ១៥០០គ្រួសារបាទ។ អ៊ីចឹង ឡើងមកវាចន្លោះពេលហ្នឹង វាឡើងមក គេបែងចែកជាបីដង។ អ៊ីចឹងពេលឡើងមកសាមុនហ្នឹងគឺច្រើន សារក្រោយៗទៀតខ្ញុំឡើងមកហួសហើយ មិនដឹងគេទៅដឹកប៉ុន្មានទេ"]។

3132 ឯកសារ D4.1.883 ទង់បដិវត្ត ខែ មេសា ឆ្នាំ ១៩៧៦ KH ERN 00062749-50។

3133 ឯកសារ D4.1.883 ទង់បដិវត្ត ខែ មេសា ឆ្នាំ ១៩៧៦ KH ERN 00062748-49។

3134 ឯកសារ D234/2.1.81 ប្រាក់ ឌឿន ប្រតិចារឹកថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 14:01:33-14:04:20 ["ខ្ញុំបាទក៏បានឮសូរសម្ដីប្រធានកងថា កម្លាំងដែលគេត្រូវប្រមូលបងប្អូនប្រជាជនវៀតណាមហ្នឹង ដើម្បីឱ្យធ្វើដំណើរទៅប្រទេសខ្លួនវិញហើយ។ គេក៏ប្រកាសដែរ គេប្រកាសប្រាប់ថា បើអ្នកណាចង់ទៅ ឆាប់ទៅឱ្យហើយ"]។

3135 ឯកសារ D234/2.1.81 ប្រាក់ ឌឿន ប្រតិចារឹកថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 14:01:33-14:04:20 ["ខ្ញុំបាទឃើញនៅសហករណ៍ខ្ញុំបាទហ្នឹង ខ្ញុំបានឃើញមួយជាក់ស្ដែងមួយមែន តែចំនួនប្រហែល២០-៣០នាក់"]។

3136 ឯកសារ D234/2.1.81 ប្រាក់ ឌឿន ប្រតិចារឹកថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 14:01:33-14:04:20 ["ស៖ តើលោកមានធ្លាប់ឃើញទូក កាណូត ធ្វើដំណើរទៅទិសទៅវៀតណាមទេ នៅពេលដែលលោកនៅកោះតាម៉ូវ ហ្នឹង? ឆ៖ បាទ ខ្ញុំបាទជម្រាបជូន ឃើញគេប្រមូលក្នុងទូកដំបូងលមួយ ដែលខ្ញុំបានឃើញផ្ទាល់ ដែលបរ ដែលបើកទៅតាមទន្លេព្រែក"]។

ករណី ប៉ុន្តែត្រូវកម្មាភិបាលវាយ ដោយសារនាងនិយាយភាសាវៀតណាម ក្រោយមក នារីនោះក៏បានបញ្ជូនទៅវៀតណាមផងដែរ[3137]។

767. សាក្សី ជឿង យ៉ាំង ចែត ត្រូវបាននិរទេសពីកំពង់ឆ្នាំង ទៅវៀតណាម តាមព្រៃវែង ជាការដោះដូរជាមួយអង្ករ[3138]។ ពីរខែមុននោះ គ្រួសារគាត់ត្រូវគេសម្លាប់រួចហើយ[3139]។ គាត់បានធ្វើដំណើរតាមកាណូតទៅភ្នំពេញ ជាមួយកាណូត ៥០ ឬ ៦០ គ្រឿងផ្សេងទៀត ដែលដឹកជនជាតិវៀតណាម[3140]។ បន្ទាប់មក គាត់ត្រូវផ្ទេរទៅកាណូតជាមួយនឹងជនជាតិវៀតណាម ៦០ នាក់ផ្សេងទៀត ដែលធ្វើដំណើរទៅព្រៃវែង[3141]។ នៅពេលដែលពួកគេដល់អ្នកលឿង កម្មាភិបាលបានរាប់មនុស្សនៅលើសាឡាង ហើយជាការដោះដូរ ភាគីវៀតណាមបានផ្តល់ឱ្យអំបិល និងអង្ករ[3142]។

---

3137 ឯកសារ D234/2.1.81 ប្រាក់ ឌៀន ប្រតិចារឹកថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 14:04:20-14:07:53 ["ខ្ញុំក៏បានស្តាប់ [នារីម្នាក់និយាយ] [...] ភាសាវៀតណាម ហ្នឹង ញ៉េញ៉ូវៗ គេស្តាប់បាន គេហៅចុះមកដី ខ្ញុំស្មានតែគេហៅសួរចម្លើយ គេដោះស្រាយទៅ ស្រាប់ទៅដល់ ចាប់សក់ក្បាលបានវ៉ៃបណ្តោយ -- វ៉ៃបណ្តោយ រំលង២ថ្ងៃ គេចាប់បញ្ជូនទៅសេះស្លាប់ -- សេះស្លាប់ចាប់បញ្ជូនទៅខាងវៀតណាមបណ្តោយ។ កាលហ្នឹងបាត់មុខ ខ្ញុំអត់ដឹងទេ"]។

3138 ឯកសារ D234/2.1.83 ជឿង យ៉ាំង ចែត ប្រតិចារឹកថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 13:54:00-13:58:00 ["ទើបដឹងដំណឹងរបស់ខាងតាលី ហ្នឹង ក្រុមតាលីហ្នឹងគាត់ជូនទៅហ្នឹង ខាងអង្គការគេដូរអំបិល ដូរអង្ករអីជាមួយខាងវៀងតណាមហ្នឹង តែប៉ុណ្ណឹង ខ្ញុំដឹងតែប៉ុណ្ណឹង ខ្ញុំដោយសារគាត់ទៅហើយ ជួយលាក់ខ្លួនតែប៉ុណ្ណឹង"]។

3139 ឯកសារ D234/2.1.84 ជឿង យ៉ាំង ចែត ប្រតិចារឹកថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 11:30:14-13:58:08 [រៀបរាប់ពីរបៀបដែលគ្រួសារទាំងមូលរបស់គាត់ត្រូវបានសម្លាប់ ហើយគាត់បាននៅជាមួយតាលី បន្ទាប់ពីព្រឹត្តិការណ៍នោះ។ ២ខែក្រោយមក តាលី បានចេញទៅវៀតណាម ហើយបានយក ជឿង យ៉ាំង ចែត ទៅជាមួយ]។

3140 ឯកសារ D234/2.1.83 ជឿង យ៉ាំង ចែត ប្រតិចារឹកថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 15:11:44-15:19:31 ["ស៖ [...] នៅពេលដែលលោកចេញដំណើរដំបូងតាមទូករបស់តាលី នោះហើយលោកបានធ្វើដំណើរការតម្រង់មកភ្នំពេញកាលហ្នឹង តើលោកបានឃើញទូកផ្សេងៗធ្វើដំណើរមកជិតលោកទេ? បើក្នុងករណីមាន ថាតើលោកឃើញប្រហែលប៉ុន្មានដែលមកជិតៗជាមួយលោកដែរហ្នឹង? អាចចាំបានទេ? ឆ៖ ចាំបាន។ កាលហ្នឹងកាលណាអ្នកណាជិះសាឡង់ទៅដូចថាដើរទៅមុន ពួននៅព្រៃ មិនដឹងទេ គេនៅសាឡង់មុនហើយ។ ប៉ុន្តែទៅតាមផ្លូវទឹកហ្នឹង ខ្ញុំឃើញប្រហែលចូល ៦០, ៧០អី ទូកចេញដំណើរទៅភ្នំពេញ"]។

3141 ឯកសារ D234/2.1.83 ជឿង យ៉ាំង ចែត ប្រតិចារឹកថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 13:54:00-14:01:29 ["ខ្ញុំចេញតាមហ្នឹងមក ទន្លេបួនមុខហ្នឹង ខ្ញុំឡើងកប៉ាល់គេហ្នឹង កប៉ាល់គេមកយកដូរអំបិល អង្ករហ្នឹង។ គេយកឡើងកប៉ាល់ហ្នឹង គេចូលមកអ្នកលឿង [...] គេឡើងប្រហែលហាហុកសិបនាក់អី ហើយខ្ញុំឡើងទៀត"]។

3142 ឯកសារ D234/2.1.83 ជឿង យ៉ាំង ចែត ប្រតិចារឹកថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 14:09:32-14:17:01 ["នៅពេលដែលលោកទៅដល់អ្នកលឿង តើមានអ្វីកើតឡើងចំពោះប្រជាជនវៀតណាមដែលនៅលើសាឡង់? ឆ៖ ដើម្បីគេ

768. អ្នកខ្លះក្នុងចំណោមជនជាតិវៀតណាមដែលគេបានប្រមូល និងប្រាប់ថា ពួកគេត្រូវបញ្ជូនទៅវៀតណាមនោះ តាមពិត ត្រូវគេសម្លាប់ទេ[3143]។ ម្ដាយក្មេកជនជាតិវៀតណាមរបស់ អ៊ុច ស៊ុនឡាយ បានជិះឡានជាមួយនឹងជនជាតិវៀតណាមផ្សេងទៀតនៅក្រចេះ ហើយគេបានប្រាប់ថា នឹងត្រូវបញ្ជូនទៅវៀតណាម[3144]។ អ៊ុច ស៊ុនឡាយ បានផ្ដល់សក្ខីកម្មថា អ្នកបើកឡាននោះបានប្រាប់គាត់ថា មនុស្សទាំងនោះត្រូវគេសម្លាប់ហើយ[3145]។ ដំណឹងស្រដៀងគ្នានេះដែរចេញពីតំបន់ ៣៧ អំពីមនុស្សដែលត្រូវគេសម្លាប់ មិនមែនបញ្ជូនទៅវៀតណាមទេ[3146]។ អ្នកនិពន្ធ Ben Kiernan បានធ្វើការសម្ភាសន៍ជាច្រើន ក្នុងនោះ គាត់បានកត់ត្រាសេចក្ដីរាយការណ៍អំពីការសម្លាប់រង្គាលលើជនជាតិវៀតណាម ដែលស្ម័គ្រចិត្តធ្វើមាតុភូមិនិវត្តន៍នៅឆ្នាំ ១៩៧៧[3147]។

---

មកនិយាយជាមួយខាងវៀតណាមហ្នឹង គេនិយាយយ៉ាងម៉េចគេ ខ្ញុំមិនដឹងទេ ប៉ុន្តែថាឲ្យវៀតណាមហ្នឹងឡើងគោកហ្នឹង គេរាប់មនុស្ស រាប់ម្ដងនៅសាឡង់ហ្នឹងប៉ុន្មាននាក់ អ៊ីចឹងគេយកសាឡង់ហ្នឹង គេមក សាឡង់វៀតណាមហ្នឹង គេយកអំបិលយកអង្កររួច គេឲ្យ បានចេញដំណើរទៅ"]។

3143 សូមមើលឧទាហរណ៍ ឯកសារ D4.1.795 កំណត់ហេតុស្តាប់ចម្លើយ សូ ខុន KH ERN 00398490 ["នៅពាក់កណ្តាលឆ្នាំ១៩៧៧ មានការឃោសនាថា អ្នកណាជាជនជាតិយួន ឲ្យត្រឡប់ទៅស្រុកយួនវិញ ដោយធ្វើការដោះដូរជាមួយគ្រួសារខ្មែរដែលរស់នៅស្រុកយួន [...] គ្រួសារទាំងនោះក៏បានឡើងឡានទៅជាមួយគេដែរ ហើយត្រូវបានយកសម្លាប់ចោលទាំងអស់"]។

3144 ឯកសារ D234/2.1.98 អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៦ 09:27:46-09:29:12 ["នៅចុងឆ្នាំ១៩៧៨ម្ដាយក្មេករបស់ខ្ញុំ រៀងធីបេ ដែលជាជនជាតិវៀតណាម ត្រូវឈ្លបខ្មែរក្រហមឲ្យឡើងជិះឡានសំដៅទៅវត្តក្រគរ នៅក្នុងឃុំក្រគរ ស្រុកក្រចេះ នៅខេត្តក្រចេះ គឺគេថាឲ្យទៅត្រឡប់ទៅវៀតណាមវិញ។ ក៏ប៉ុន្តែខ្ញុំដឹងក្រោយមកថា កាត់ ហើយនិងជនជាតិវៀតណាមទាំងអស់នោះ គឺថាមិនត្រូវបានគេបញ្ជូនទៅប្រទេសវៀតណាមទេ គឺត្រូវបានគេយកទៅសម្លាប់នៅតាមផ្លូវទៅភ្នំ៥០០០ ស្ថិតនៅក្នុងស្រុកស្នួល ខេត្តក្រចេះ"]។

3145 ឯកសារ D234/2.1.98 អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៦ 09:22:32-09:27:01 ["ដឹងដោយវិធីណាគឺមិនដឹងទេ ប៉ុន្តែអ្វីទាំងអស់ត្រូវចប់ត្រឹមហ្នឹងហើយ ដោយសារមនុស្សបំផុតនៅស្លាប់ហ្នឹងហើយ ដែលអស់ អស់។ នេះគឺដឹងក្រោយតាមរយៈតៃកុងឡានឈ្មោះ អាង"]។

3146 ឯកសារ D114/29.1.4 ប៊ែន ឃៀនិន របប ប៉ុល ពត KH ERN 00637823 ["នៅតាមឆ្នេរសមុទ្រនៃតំបន់៣៧ គេបានបញ្ជាជាថ្មីឲ្យ "ពួកវៀតណាម" ដែលជាបេក្ខជនត្រូវបញ្ជូនឲ្យត្រឡប់ទៅប្រទេសដើមវិញ មកបង្ហាញមុខឲ្យគេស្គាល់។ អ្នកស្ម័គ្រចិត្តពីរក្រុមបានកកើតឡើងនៅឆ្នាំ១៩៧៧ រួមមានជនជាតិចិនម្នាក់ និង "ប្រជាជនខ្មែរដែលមិនចង់រស់នៅប្រទេសកម្ពុជាមួយចំនួនតូច" ផងដែរ។ មនុស្សទាំងពីរក្រុមនេះត្រូវគេសម្លាប់ចោលគ្មានសល់ម្នាក់"]។

3147 ឯកសារ D114/29.1.4 ប៊ែន ឃៀនិន របប ប៉ុល ពត KH ERN 00637823 ["នៅតាមឆ្នេរសមុទ្រនៃតំបន់៣៧ គេបានបញ្ជាជាថ្មីឲ្យ "ពួកវៀតណាម" ដែលជាបេក្ខជនត្រូវបញ្ជូនឲ្យត្រឡប់ទៅប្រទេសដើមវិញ មកបង្ហាញមុខឲ្យគេស្គា

## ការសម្លាប់ជនជាតិវៀតណាម

769. ទោះបីជាថា ការនិរទេសកំពុងបន្តអនុវត្តក៏ដោយ ក៏នៅដើមរបបកម្ពុជាប្រជាធិបតេយ្យ ប.ក.ក នៅតែសម្លាប់ជនជាតិវៀតណាមដែរ ដើម្បីធានាថា ក្រុមជនជាតិនេះត្រូវកម្ចាត់ចេញពីដែនដីកម្ពុជា ។ នៅខែ មេសា-ឧសភា ឆ្នាំ ១៩៧៥ កងពល ១៦៤ បានស្នើសុំព័ត៌មានពីថ្នាក់លើអំពីរបៀបដោះស្រាយជាមួយជនជាតិវៀតណាមដែលជាប់ឃុំខ្លួន៖

> "អង្គភាពបានចាប់នាវាមួយគ្រឿងដែលបានដឹកជនភៀសខ្លួនវៀតណាមជាង ១០ នាក់ រួមទាំងស្ត្រី និងកុមារ។ [...] មេបញ្ជាការកងអនុសេនាធំលេខ ៤០៨ បានទាក់ទងកំពង់សោម ដើម្បីសុំការណែនាំស្តីពីការចាត់ចែងជនភៀសខ្លួនទាំងនោះ។ មេបញ្ជាការថ្នាក់លើនៅកំពង់សោមបានបញ្ជាឲ្យមេបញ្ជាការកងអនុសេនាធំនេះ សម្លាប់ជនភៀសខ្លួនទាំងនោះចោល។ មេបញ្ជាការ និងអនុបញ្ជាការកងអនុសេនាធំបានអនុវត្តតាមបញ្ជានេះ"[3148]។

770. ក្រោយពីមានការបណ្តេញចេញដ៏ច្រើនបែបនេះ នៅមានជនជាតិវៀតណាមជាច្រើននាក់ដែលមិនទាន់ត្រឡប់ទៅវៀតណាម ហើយតាមគោលនយោបាយរបស់ ប.ក.ក[3149] អ្នកទាំងនេះត្រូវតែ

---

ល់។ អ្នកស្ម័គ្រចិត្តពីរក្រុមបានកកើតឡើងនៅឆ្នាំ១៩៧៧ រួមមានជនជាតិចិនម្នាក់ និង "ប្រជាជនខ្មែរដែលមិនចង់រស់នៅប្រទេសកម្ពុជាមួយចំនួនតូច" ផងដែរ។ មនុស្សទាំងពីរក្រុមនេះត្រូវគេសម្លាប់ចោលគ្មានសល់ម្នាក់"]។

3148 ឯកសារ D4.1.754 ខ្សែទំនាក់ទំនងរបស់សហរដ្ឋអាមេរិក ទាក់ទងនឹងឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស និងកាងសង្កេតទៅលើកោះតាង ខែ ធ្នូ ឆ្នាំ ១៩៧៥ KH ERN 00791383-84។

3149 ឯកសារ D234/2.1.80 ស៊ាន ស៊ីង ប្រតិចារឹកថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥ ម៉ោង 09:59:20-10:01:00 ["ស៖ [...] លោកបានឆ្លើយរួចហើយថា ដឹងឮផ្ទាល់ពីប្រធានភូមិស្តីអំពីការសម្លាប់ជនជាតិវៀតណាម។ [...] ប្រធានភូមិថាទទួលបញ្ជាពីថ្នាក់លើ ប៉ុន្តែខ្ញុំមិនបានដឹងថា ជាបញ្ជាមកពីថ្នាក់ស្រុក ឬថ្នាក់ណានោះទេ។ ឆ៖ ពិតមែន"]។ ឯកសារ D234/2.1.100 អាឡិចសាន់ឌឺ ហ៊ីនតុន ប្រតិចារឹកថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 11:07:43-11:11:29 ["ស៖ [...] តើអ្នកណាជាស្ថាប័ន ឬក៏ជានីតិបុគ្គល? ថាតើអ្នកណាជាអ្នកដឹកនាំយុទ្ធនាការ? តើយុទ្ធនាការហ្នឹង ចេញមកពីខាងណាដែរ? ឆ៖ គឺមកពីគណៈអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា ដែលជាអ្នកគ្រប់គ្រងទៅលើ ហើយនិងជាផ្សព្វផ្សាយមាគ៌ា ក៏ដូចជាការឃោសនានានា មនោគមន៍វិជ្ជា ក៏ដូចជាការចេញនូវបញ្ជាទៅគ្រប់កន្លែងទូទាំងប្រទេសកម្ពុជា ហើយនិងក្រុមខាងទាហានចល័តផងដែរ"]។

កម្ទេចចោល[3150]។ មនុស្សដែលមានជាតិពន្ធុជាវៀតណាម ត្រូវគេស្វែងរក និងសម្លាប់នៅទូទាំងប្រទេស[3151]។

---

3150 ឯកសារ D234/2.1.95 មាស វឿន ប្រតិចារឹកថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 15:58:51-16:03:07 ["សៈ តើមានជនជាតិវៀតណាមច្រើនទេ ដែលមិនព្រមទៅស្រុកវិញ ហើយត្រូវបានកម្ទេចចោល? [...] ឆៈ មាន នៅមាននៅមិនមែនទៅទាំងអស់ទេ"]។ ឯកសារ D234/2.1.97 ខូង មួយ ប្រតិចារឹកថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 14:19:47-14:25:00 ["សៈ ចុះលោកស្រីធ្លាប់ឮខ្មែរក្រហមណាម្នាក់និយាយថា ជនជាតិវៀតណាមណាដែលមិនព្រមចាកចេញពីប្រទេសកម្ពុជាទេនឹងត្រូវកម្ទេចចោលហើយ? ដែលឮអ៊ីចឹងទេ? ឆៈ ឮតើ មុនៗខ្ញុំនៅភូមិខ្ញុំហ្នឹង មានដែរ គេយកទៅមុន កម្ទេចចោលខ្លះហើយ បានខ្ញុំដឹង"]។ ឯកសារ D234/2.1.82 សៅ សាក់ ប្រតិចារឹកថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 14:43:38-14:45:40 ["ឲ្យតែជាប់កូនចៅវៀតណាម គឺត្រូវគេយកទៅសម្លាប់តែម្តង"]។ ឯកសារ D234/2.1.100 អាឡិចសាន់ឌឺ ហ៊ិនតុន ប្រតិចារឹកថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 11:07:43-11:08:20 ["សៈ [...] តាមទស្សនៈរបស់លោកផ្ទាល់ ផ្អែកតាមការសម្ភាសដែលលោកបានធ្វើ តើការឃោសនាដែលគេប្រើប្រាស់នោះ ហើយនិងការស្រាវជ្រាវដែលលោកបានធ្វើ តើជនស៊ីវិលវៀតណាមរស់នៅក្នុងប្រទេសកម្ពុជា ត្រូវបានគេកំណត់គោលដៅសម្រាប់ការសម្លាប់ដែរឬទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ? ឆៈ បាទ គឺអ៊ីចឹងមែន គឺថាគាត់មានការបង្ហាញច្បាស់លាស់ហើយរឹងមាំ"]។

3151 សូមមើលឧទាហរណ៍ ឯកសារ D4.1.523 កំណត់ហេតុស្តាប់ចម្លើយ បាន សៀក KH ERN 00 ["សៈ តើមានការបោសសម្អាតជនជាតិវៀតណាមដែរឬទេនៅពេលនោះ? អ្នកដែលជាជនជាតិវៀតណាម ត្រូវបានគេសម្លាប់ចោលទាំងអស់ [...] ប៉ុន្តែឲ្យតែជាជនជាតិយួនត្រូវបានសម្លាប់ទាំងអស់ សូម្បីតែខ្មែរភាគខាងជើង (កម្ពុជាក្រោម) ដែលធ្លាប់ត្រូវបានយួនយកទៅបង្រៀន ហើយត្រឡប់មកធ្វើជាកម្មាភិបាលខ្មែរក្រហមវិញនោះ ក៏ត្រូវបានយកទៅកម្ទេចចោលដែរ"]។ ឯកសារ D114/36.1.38 កំណត់ហេតុស្តាប់ចម្លើយ សោម រស់ KH ERN 00225367 ["គេសម្លាប់អ្នកជាប់ខ្សែវៀតណាម ខ្សែ សោ ភឹម"]។ ឯកសារ D114/36.1.40 កំណត់ហេតុស្តាប់ចម្លើយ ជុយ គឹមវ៉ា KH ERN 00225351-52 ["រៀបរាប់ពីការចាប់ខ្លួនឪពុករបស់គាត់ ហើយបាត់ខ្លួន ដោយសារជាប់ជាជនជាតិវៀតណាម"]។ ឯកសារ D4.1.803 កំណត់ហេតុស្តាប់ចម្លើយ ជិន គឹមថុង ឆ.12 ["សៈ សូមលោករៀបរាប់អំពីចំនួនអ្នកទោស និងប្រភេទអ្នកទោសដែលមាននៅក្នុងមន្ទីរសន្តិសុខអូរកន្សែង។ ឆ.12ៈ [...] មានអ្នកទោសជនជាតិភាគតិច និងជនជាតិវៀតណាមផងដែរ។ អ្នកទោសជនជាតិវៀតណាមទើបតែមាននៅចុងឆ្នាំ១៩៧៨ នៅពេលដែលមានការប៉ះទង្គិចគ្នាតាមព្រំដែនវៀតណាមខ្លាំង"]។ ឯកសារ D11/120/3 កំណត់ហេតុស្តាប់ចម្លើយ វ៉ែន វ៉ន ឆ.52 ["សៈ តើលោកដឹងដោយរបៀបណាថា ប្រព័ន្ធដើមរបស់លោក និងវៀតណាមប្រាំគ្រួសារទៀតត្រូវគេយកទៅសម្លាប់នៅទួលកកោះ? ឆ.52ៈ [...] ខ្ញុំដឹងដោយញាតិលោហិតដែលធ្វើការនៅភូមិវាល ដោយគេនិយាយថា "ប្រពន្ធរបស់អ្អែងនៅទីនោះបានតែពីរថ្ងៃទេ គេយកទៅសម្លាប់ហើយ អ្អែងកុំមាត់ណ៎ា"]។ ឯកសាសរ D114/36.1.42 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ម៉ៅ KH ERN 00225220 ["រំឭកអំពីឪពុករបស់គាត់ និងគ្រួសារមួយផ្សេងទៀតត្រូវបានចាប់ខ្លួន និងបញ្ជូនទៅបាត់ ដោយសារតែជាប់ជាជនជាតិវៀតណាម"]។ ឯកសារ D114/36.1.54 កំណត់ហេតុស្តាប់ចម្លើយ ចាន់ វឿន KH ERN 00277259 ["ខ្ញុំបានឃើញស្ត្រីកូនកាត់វៀតណាម្នាក់ ព្រមទាំងកូនស្រីអាយុប្រហែល៦ឆ្នាំ ត្រូវមេឃុំ ចាប់យកទៅបាត់ [...] ខ្ញុំឮ

*ក) ការកំណត់អត្តសញ្ញាណជនជាតិវៀតណាម*

771. រស់ សារឿន គឺជាជាងដែលអ្នកជំនាញ Ben Kiernan បានសម្ភាស។ គាត់នៅមន្ទីរស្រុកនៅឧត្តុង្គ នៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៧៧ នៅពេលដែលគាត់អាន "សេចក្ដីណែនាំពី ៨៧០" ដែលបញ្ជាឱ្យមន្ត្រីមូលដ្ឋានចាប់ខ្លួនជនជាតិវៀតណាមទាំងអស់ និងខ្មែរទាំងអស់ដែលនិយាយភាសាវៀតណាម ឬមានមិត្តភក្តិជាជនជាតិវៀតណាម ហើយប្រគល់អ្នកទាំងនោះឱ្យទៅកម្លាំងសន្តិសុខរបស់អង្គការ[3152]។ សក្ខីកម្មសាក្សី និងឯកសារនានា បានបង្ហាញថា គោលនយោបាយនេះត្រូវបានអនុវត្ត។

772. នៅខែ កក្កដា ឆ្នាំ ១៩៧៧ មាស វឿន បានចូលរួមអង្គប្រជុំរបស់ភូមិភាគបស្ចិមជាមួយនឹងមេដឹកនាំជាន់ខ្ពស់របស់ ប.ក.ក[3153]។ គាត់បានផ្ដល់សក្ខីកម្មថា គោលបំណងនៃអង្គប្រជុំនេះគឺដើម្បីណែនាំអ្នកចូលរួមអំពីការកម្ទេចខ្មាំង រួមមាន "យួន" ហើយ ប.ក.ក "រកតែខ្មាំងណាដែលបង្កប់នៅក្នុងជួរសហករណ៍ ឬក៏ក្នុងជួរកងទ័ព"[3154]។ សេចក្ដីណែនាំនេះចេញពីមេដឹកនាំជាន់ខ្ពស់ត្រូវ

---

តាមអ្នកភូមិថា គាត់ត្រូវបានយកទៅសម្លាប់នៅព្រៃចក"]។ ឯកសារD114/24 កំណត់ហេតុស្ដាប់ចម្លើយ អ៊ូ ដាវ ទ. 192-193 ["ប្រពន្ធគាត់ជាខ្មែរកម្ពុជាក្រោម [...] ទ.193៖ នៅពេលនោះគេស្រាវជ្រាវដឹងពីប្រវត្តិរូបរបស់ពួកគាត់ ក្រោយមកគេបានចាប់ខ្លួនពួកគាត់យកទៅសម្លាប់ទាំងអស់ រួមទាំងកូននៅក្នុងផ្ទៃផង"]។ ឯកសារ D4.1.801 កំណត់ហេតុស្ដាប់ចម្លើយ នោម សែ ទ.12 ["មុនពេលវៀតណាមវាយចូលខ្លាំងនៅឆ្នាំ១៩៧៨ ឃើញមានអ្នកចាប់អ្នកទោសជាជនជាតិវៀតណាម (ស៊ីវិល) មួយក្រុមមានគ្នាប្រាំមួយនាក់ ពីសមរភូមិអូរយ៉ាដាវតាមព្រំដែន"]។ ឯកសារ D54/71 កំណត់ហេតុស្ដាប់ចម្លើយ មុត ម៉ៅ ទ.39 ["ខ្ញុំបានឃើញគេយកស្រីយួនចាស់ម្នាក់ ហើយនិងក្មេងៗពីរបីនាក់យកមកសម្លាប់នៅក្នុងបរិវេណមន្ទីរក្នុង"]។

[3152] ឯកសារ D114/29.1.4 ប៊ែន ឃៀនិន របប ប៉ុល ពត KH ERN 00637822 ["បន្ទាប់មក នៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ១៩៧៧ មជ្ឈិមបានផ្សព្វផ្សាយឱ្យអនុវត្តមតិណែនាំមួយ ដែលមានលក្ខណៈច្បាស់លាស់បំផុត [...] "មតិណែនាំរបស់ ៨៧០" នេះបានបញ្ជាឱ្យអ្នកទទួលខុសត្រូវមូលដ្ឋាននានាចាប់ខ្លួនពួកជាប់ខ្សែស្រឡាយវៀតណាមទាំងអស់ ហើយប្រគល់ទៅឱ្យផ្នែកសន្តិសុខរបស់រដ្ឋ"]។ ឯកសារ D1.3.17.1 អេលីហ្សាបែត ប៊េកខ័រ នៅពេលដែលសង្គ្រាមរលត់ទៅ KH ERN 00232320 ["នៅពាក់កណ្ដាលឆ្នាំ១៩៧៧ មតិណែនាំថ្មីមួយបានបង្គាប់ឱ្យធ្វើការកម្ទេចប្រភេទសត្រូវថ្មីមួយទៀត គឺប្រជាជនកម្ពុជាដែលមានដើមកំណើតវៀតណាម"]។

[3153] ឯកសារ D234/2.1.95 មាស វឿន ប្រតិចារឹក ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 14:26:18-14:33:57 ["ខ្ញុំបានចូលរួមសន្និបាតភូមិភាគបស្ចិមនៅខេត្តកំពង់ស្ពឺ នៅចម្ការដូង ក្នុងស្រុកច្បារមន កាលពីឆ្នាំ១៩៧៧"]។

[3154] ឯកសារ D234/2.1.95 មាស វឿន ប្រតិចារឹក ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 14:33:57-14:40:00។

បានអនុវត្តនៅថ្នាក់ក្រោម។ មាស វឿន បានផ្តល់សក្ខីកម្មថា អ្នកភូមិស្គាល់នរណាជា "យួន" ហើយរាយការណ៍ទៅកងទ័ព[3155]។

773. ទាំងកម្មាភិបាលយោធា ទាំងកម្មាភិបាលស៊ីវិល មានភារកិច្ចត្រូវកំណត់អត្តសញ្ញាណជនជាតិវៀតណាមនៅក្នុងចំណោមពួកគេ[3156]។ ព្រុំ សារុន ជាប្រធានកងតូចនៅស្រុកបាណន់ក្រោយឆ្នាំ ១៩៧៥[3157] បានផ្តល់សក្ខីកម្មថា ប្រធានកងវរសេនាតូចរបស់គាត់បានប្រាប់គាត់ឲ្យរាយការណ៍អំពីជនជាតិវៀតណាមណាក៏ដោយដែលមាននៅក្នុងកងគាត់ បន្ទាប់មក ប្រធានកងវរសេនាតូចនេះនឹងបញ្ជូនរបាយការណ៍ទៅថ្នាក់លើ គឺមេស្រុក[3158]។ ព្រុំ សារុន ត្រូវគេប្រាប់ថា ថ្នាក់លើនឹង "ដោះស្រាយ" ជនជាតិវៀតណាម មានន័យថា គេនឹងសម្លាប់ជនជាតិវៀតណាម[3159]។

774. នៅខែ សីហា ឆ្នាំ ១៩៧៨ មន្ទីរ ៤០១ បានរាយការណ៍ទៅអង្គការ ថា ខ្លួនបានសម្រិតសម្រាំងរក "ជនបរទេសយួន" តាមគោលនយោបាយរបស់បក្ស[3160] ហើយបានសម្លាប់ពួកគេ[3161]។ ស្រដៀងគ្នា

---

3155 ឯកសារ D234/2.1.95 មាស វឿន ប្រតិចារឹក ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 16:03:07-16:07:30 ["ទី១និយាយមិនច្បាស់ ហើយទី២ គឺប្រជាជនគេនៅជិតខាងគេដឹងប្រវត្តិគាត់នៅហ្នឹងប៉ុន្មានឆ្នាំមកហើយអីមកហើយហ្នឹងគេ ភាគច្រើនគេៗស្គាល់ យើងៗស្គាល់ យើងៗមិនអាចស្គាល់គេបានថា ព្រោះអីគេនិយាយខ្មែរនិយាយអក្សរខ្មែរនិយាយភាសាច្បាស់លាស់មែន ក៏ប៉ុន្តែសំអាងលើប្រជាជនដែលនៅក្នុងស្រុក ក្នុងភូមិ ដែលគេនៅយូរហើយគេដឹង គេដឹងគេប្រាប់យើង]។

3156 ឯកសារ D234/2.1.97 អ៊ុច ស៊ុនឡាយ ប្រតិចារឹកថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 15:50:00-15:53:13 ["រឿងកាលដែលអង្គការចាត់មនុស្សស្រាវជ្រាវដឹងអីនោះ វាជារឿងរបស់អង្គការ យើងខ្ញុំអត់ដឹងទេ។ គ្រាន់តែថានៅភូមិឃុំហ្នឹង កូនអ្នកណាធ្វើអី កូនអ្នកណាយ៉ាងម៉េច គឺគេតែងដឹង"]។

3157 ឯកសារ D234/2.1.84 ព្រុំ សារុន ប្រតិចារឹកថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 13:31:57-13:35:10 ["ខ្ញុំនៅឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង [...] ខ្ញុំធ្វើជាមេកងតូច ពេលនោះ"]។

3158 ឯកសារ D234/2.1.84 ព្រុំ សារុន ប្រតិចារឹកថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 13:45:32-13:48:11 ["ស៖ [...] ពេលហ្នឹង គាត់សួរលោកក្នុងអង្គប្រជុំ ឬក៏ដើរទៅជួបកន្លែងណា ឬក៏សួរក្នុងស្ថានភាពណាដែរ? ឆ៖ សួរខ្ញុំតែម្នាក់ ដើរមកសួរខ្ញុំតែម្នាក់ឯង។ ខ្ញុំរាយការណ៍ប្រាប់ថាអ៊ីចឹងឯង ថាកងរបស់ខ្ញុំមិនមានយួនទេ"]។

3159 ឯកសារ D234/2.1.84 ព្រុំ សារុន ប្រតិចារឹកថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 13:48:11-13:51:10 ["ចាត់ការទៅ" ស្លាប់ មានតែ "ស្លាប់" ហ្នឹង"]។

3160 ឯកសារ D114/36.1.30 របាយការណ៍ពីមន្ទីរ ៤០១ គោរពជូនអង្គការ ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ១៩៧៨ KH ERN 00143604 ["២.សកម្មភាពខ្មាំង បង្កប់ស៊ីរូងផ្ទៃក្នុង៖ ពិនិត្យរួម សកម្មភាពខ្មាំងដែលបង្កប់ស៊ីរូងផ្ទៃក្នុង រយៈ១ខែនេះ វាធ្វើសកម្មភាពបំផុស ខែទំនាស់ វាយប្រហារ ប្រឆាំង និងបំផ្លាញយើងតាមគ្រប់រូបភាពជាបន្តបន្ទាប់ទៀត និងកាន់តែស៊ីជម្រៅ ដែលលេចចេញពីសមាសភាពមិនល្អមួយចំនួនតូច ជាដៃជើងខ្មាំង ឬអ្នកជាប់ចម្លើយខ្មាំង សមាសភាពដែល

នេះដែរ ប្រាក់ ខឿន បានផ្តល់សក្ខីកម្មថា កម្មាភិបាល ប.ក.ក នៅកោះតាម៉ូវ[3162] បានសួរគាត់ថា តើប្រពន្ធគាត់គឺជាខ្មែរ ឬវៀតណាម[3163]។ គាត់ក៏ត្រូវគេចោទសួរផងដែរថា តើមានជនជាតិវៀតណាមនៅក្នុងសហករណ៍គាត់ដែរ ឬអត់[3164]។

775. ជនដែលមានដើមកំណើតជាវៀតណាម បានព្យាយាមលាក់ជាតិពន្ធុរបស់ខ្លួន ដោយភ័យខ្លាចបាត់បង់ជីវិត។ ប្រាក់ ខឿន ដែលប្រពន្ធគាត់ជាជនជាតិវៀតណាម បានផ្តល់សក្ខីកម្មថា គាត់មិនបានប្រើប្រាស់ឈ្មោះវៀតណាមរបស់កូនស្រីម្នាក់ចាប់តាំងពីពាក់កណ្តាលឆ្នាំ ១៩៧៦[3165] ពីព្រោះគាត់ខ្លាចថា កូនស្រីគាត់នឹងត្រូវគេសម្លាប់ ប្រសិនបើគេស្គាល់ឈ្មោះវៀតណាមរបស់កូនស្រី

---

សម្រិតសម្រាំងចេញពីអង្គភាពផ្សេងៗ និងចេញពីកងទ័ពជាដើម ព្រមទាំងសមាសភាព ១៧ មេសា ជាវណ្ណការចាស់ និងអនីកជនចិន និងយួនមួយចំនួន។ ប៉ុន្តែលើសកម្មភាពខ្លាំងខាងលើនេះ វាធ្វើអ្វីយើងពុំបានជាធំដុំទេ ពីព្រោះរាល់សកម្មភាពរបស់វាគ្រប់រូបភាព ត្រូវប្រជាជន យុទ្ធជន យុទ្ធនារីយើង និងកម្មាភិបាលយើងក្តាប់បានជាបន្តបន្ទាប់ និងមានវិធានការដកហូត សម្រិតសម្រាំង និងបោសសម្អាត ជាបន្តបន្ទាប់ដែរ ដោយអនុវត្តទៅតាមមាគ៌ាចាត់តាំងរបស់បក្ស"]។

3161 ឯកសារ D114/36.1.30 របាយការណ៍ពីមន្ទីរ ៤០១ គោរពជូនអង្គការ ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ១៩៧៨ KH ERN 00143610 ["អំពីការសម្រិតសម្រាំងសមាសភាពយួន ភ្នាក់ងារ សេ.អ៊ី.អា និងសមាសភាពមិនល្អ៖ ១. កម្ទេចជនជាតិយួន ទាំងតូចទាំងធំ ទាំងចាស់ទាំងក្មេងអស់ចំនួន ១០០នាក់"]។

3162 ឯកសារ D234/2.1.81 ប្រាក់ ខឿន ប្រតិចារឹកថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 13:54:22-13:58:47 ["ស៖តើកម្មាភិបាលនៅក្នុងភូមិរបស់លោកមាននិយាយអ្វីអំពីប្រពន្ធរបស់លោក និងម្តាយក្មេងរបស់លោកដែលជាជនជាតិវៀតណាមនេះដែរទេ? ឆ៖ បាទ និយាយម្តងៗដែរ ខ្ញុំបានទៅនេសាទ ត្រឡប់មកវិញថា ប្រពន្ធមិត្តឯងខ្មែរ ឬក៏វៀតណាម?"]។

3163 ឯកសារ D234/2.1.81 ប្រាក់ ខឿន ប្រតិចារឹកថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 13:54:22-13:58:47 ["ស៖តើកម្មាភិបាលនៅក្នុងភូមិរបស់លោកមាននិយាយអ្វីអំពីប្រពន្ធរបស់លោក និងម្តាយក្មេងរបស់លោកដែលជាជនជាតិវៀតណាមនេះដែរទេ? ឆ៖ បាទ និយាយម្តងៗដែរ ខ្ញុំបានទៅនេសាទ ត្រឡប់មកវិញថា ប្រពន្ធមិត្តឯងខ្មែរ ឬក៏វៀតណាម?"]។

3164 ឯកសារ D234/2.1.81 ប្រាក់ ខឿន ប្រតិចារឹកថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 15:47:48-15:54:43 ["វាដើរស្មើសួរខ្ញុំថា ពួកឯងដែលធ្លាប់នៅស្រុកនៅភូមិដែលមកតាមសហករណ៍ តើសេសសល់ហើយនៅ? ហើយវាក៏អស់រលីងហើយនៅ?"]។

3165 ឯកសារ D234/2.1.81 ប្រាក់ ខឿន ប្រតិចារឹកថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 13:34:43-13:42:13 ["ខ្ញុំប្រើឈ្មោះផ្សេង គឺខ្ញុំមកដល់របបប្រល័យពូជសាសន៍ ខ្ញុំបាទបើហៅឈ្មោះពីដើមកំណើតបានន័យថា វាចាប់អារម្មណ៍ថា ខ្ញុំ កូនខ្ញុំជាកូនវៀតណាម"]។ 13:37:56-13:44:53["ខ្ញុំបាទក៏បានបញ្ជាក់ជូនតាមដំណើរហេតុផលដែលកើតឡើងភ័យញ័ររន្ធត់ ស្លុតខ្លាំងពេក ខ្លាចបាត់បង់ដល់កូនស្រីទៀត ម្លោះហើយខ្ញុំមានសេចក្តីចាប់អារម្មណ៍ បានខ្ញុំជម្រាបជូនដល់តុលាការ នែបញ្ហាហ្នឹងបើទុកឈ្មោះនោះដែលបានន័យថាកូនខ្ញុំត្រូវបាត់បង់ជីវិតហើយ"]។

គាត់[3166]។ ទោះបីជាគាត់បានព្យាយាមយ៉ាងណាក៏ដោយ ក៏ក្រោយមក កូនស្រីគាត់ត្រូវគេសម្លាប់ដែរ[3167]។ យុទ្ធនាការប្រឆាំងជនជាតិវៀតណាម បានធ្វើឡើងដោយច្បាស់លាស់ និងយ៉ាងព្រៃផ្សៃរហូតដល់ខ្មែរមិនហ៊ាននិយាយជាមួយជនជាតិវៀតណាម ដោយខ្លាចថា ខ្លួននឹងត្រូវគេយកទៅសម្លាប់ដែរ[3168]។

---

3166 ឯកសារ D234/2.1.81 ប្រាក់ ឡឿន ប្រតិចារឹកថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 13:34:43-13:42:13 ["ខ្ញុំប្រើឈ្មោះផ្សេង គឺខ្ញុំមកដល់របបប្រល័យពូជសាសន៍ ខ្ញុំបាទបើហៅឈ្មោះពីដើមកំណើតបានន័យថា វាចាប់អារម្មណ៍ថា ខ្ញុំ កូនខ្ញុំជាកូនវៀតណាម"]។ 13:37:56-13:44:53 ["ខ្ញុំបាទក៏បានបញ្ជាក់ជូនតាមដំណើរហេតុផលដែលកើតឡើងភ័យញ័ររន្ធត់ ស្លុតខ្លាំងពេក ខ្លាចបាត់បង់ដល់កូនស្រីទៀត ម្លោះហើយខ្ញុំមានសេចក្តីចាប់អារម្មណ៍ បានខ្ញុំជម្រាបជូនដល់តុលាការ នៃបញ្ហាហ្នឹងបើទុកឈ្មោះនៅដដែលបានន័យថាកូនខ្ញុំត្រូវបាត់បង់ជីវិតហើយ។ អ៊ីចឹងឲ្យកាឡៃឈ្មោះហ្នឹងឲ្យកូនអូនកុមារដែលនៅជំនាន់ប្រល័យពូជសាសន៍ហ្នឹងជួយហៅវាថា មីកំបាក់ មីកំពុកទៅ"]។ 13:34:43-13:42:13។ សូមមើលផងដែរ ឯកសារ D234/2.1.91 ដួង អឿន ប្រតិចារឹកថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 09:28:38-09:31:34 ["អង្កាល់ហ្នឹង ខ្លាចអាពួកហ្នឹងវាយកទៅវៃចោល ខ្ញុំដាក់ឈ្មោះវាអ៊ីចឹងទៅ។ គេប្រាប់ថាកុំដាក់ឈ្មោះវា គីម វ៉ា ដាក់ឈ្មោះវា មី កាំមាន ទៅ។ ហើយខ្ញុំក៏ដាក់តាមគេទៅ"] 09:55:09-10:02:01 ["ស៖ ចុះឈ្មោះដើមរបស់ពួកគេដែលលោកស្រីគិតថា អាចនឹងគេដឹង គេយកទៅកម្ទេចចោលហ្នឹង ឈ្មោះដើមហ្នឹងឈ្មោះអីទៅ? ឆ៖ កាលឈ្មោះដើមឈ្មោះមី គីម វ៉ា ដល់ពីនោះមក ខ្ញុំដាក់ឈ្មោះវាមី កាំមានទៅ [...] អ្នកស្រុក អ្នកភូមិប្រាប់ថា កុំដាក់ឈ្មោះវាមី គីម វ៉ា ដាក់ឈ្មោះវាមី កាំមាន។ ខ្ញុំក៏ដាក់ទៅ ខ្ញុំខ្លាចគេយកទៅដូចឪពុកអីថ្មីង ជំនាន់ហ្នឹងនោះ"]។ ផ្ទុយពី ឯកសារ D234/2.1.91 ដួង អឿន ប្រតិចារឹកថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 10:45:08-10:48:20 ["គេវាមិនចាប់មែនកាលនុ៎ងអត់មានអ្នកណាយកទៅទេ ស្មានតែកូនខ្មែរ ... អ៎! ម៉ែខ្មែរ កូនខ្មែរអត់យកទៅទេ គេយកតែឪពុកទេ។ បានជាកូនខ្ញុំនៅហ្នឹងនោះ បើគេយកទៅ ទៅទាំងអស់ហើយ"]។

3167 ឯកសារ D234/2.1.81 ប្រាក់ ឡឿន ប្រតិចារឹកថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 15:22:27-15:27:10 ["ព្រឹកឡើងបានប្រាប់ខ្ញុំថា ពូតាំងស្មារតីទៅ ព្រោះប្រពន្ធកូនអត់មានកើតមកវិញទៀតទេ។ អង្គការបានកម្ទេចហើយ ហើយក៏បានបន្ទោសពាក្យមួយមាត់ថា ចុះពួងឯងពីដើមឡើយក៏មិនយកប្រពន្ធខ្មែរ?"]។ ឯកសារ D234/2.1.82 ប្រាក់ ឡឿន ប្រតិចារឹកថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង10:49:08-10:52:28 ["គាត់ហ្នឹងមិនមែនប្រាប់ថា ខ្លួនគាត់ដែលជាអ្នកសម្លាប់ទេ ប៉ុន្តែគាត់ឲ្យយោបល់ខ្ញុំ ដែលព្រឹកឡើង ដែលគេធ្វើទារុណកម្មខ្ញុំពីល្ងាចដែលធ្វើឲ្យធ្វើស្រូវ វាយកណ្តាប់ស្រូវហ្នឹងរួចអស់ហើយ ស្រាប់តែដល់ពេលជិត គាត់ឃើញមុខខ្ញុំបាទ ក៏គ្រៀមក្រំ គាត់សួរ គាត់ថា "ពួងឯងកុំគិតអីទៀត ព្រោះគ្រួសារពួងឯង គេយកទៅសម្លាប់អស់ហើយ កុំគិត" [ ...] អាហ្នឹងគេប្រាប់ខ្ញុំអ៊ីចឹង ខ្ញុំក៏មានឲ្យយោបល់គេថា វាត្រឹមអារម្មណ៍របស់ខ្ញុំថា អស់សង្ឃឹមហើយ ដូចថ្ងៃថាលិចហើយ អត់កើតវិញទេ។ អាហ្នឹងនឹកក្នុងសន្តានចិត្តខ្ញុំបាទ ជម្រាបជូនតែប៉ុណ្ណឹង"]។

3168 ឯកសារ D11/523/3 សៀង ចាន់ធី ប្រតិចារឹកថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 15:57:26-16:01:12 ["ខ្ញុំធ្វើការគ្មានអ្នកណាស្តីរកខ្ញុំទេ។ ទៅលើកដី លើកម្នាក់ឯង កណ្តៀតម្នាក់ឯង [...] ដល់ពេលគេអត់ស្តីរកខ្ញុំ ខ្ញុំសួរ លួចសួរអ្នក

776. កម្មាភិបាលនៅតាមខេត្ត បានស្នើសុំសេចក្ដីណែនាំពីអង្គការនៅភ្នំពេញ អំពីថាតើត្រូវធ្វើយ៉ាងជាមួយនឹងជនជាតិវៀតណាម នៅពេលដែលឃាត់ខ្លួនបាន។ ទូរលេខផ្ញើពីកងពល ៨០១ នៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៧៧ បានរាយការណ៍អំពីការចាប់បានជនជាតិចារ៉ាយមួយក្រុមមកពីវៀតណាម ហើយទូរលេខនេះបានចាត់ទុកថា ក្រុមនេះគឺជា "កងទ័ពយួនចំនួន ២០៩ នាក់ ក្នុងនេះមាននារី ៩ នាក់"។ ទូរលេខនេះ ដែលបានចម្លងជូន នួន ជា និងអ្នកផ្សេងទៀត បានស្នើសុំសេចក្ដីសម្រេច "កម្រិតខ្ពស់តែម្ដង" អំពីក្រុមមនុស្សនេះ[3169]។

*ខ) ជីកឫស៖ ការដាក់គោលដៅរបស់ ប.ក.ក លើគ្រួសារខាងម្ដាយជាជនជាតិវៀតណាម*

777. ថ្នាក់ក្រោមបានស្នើសុំសេចក្ដីណែនាំពីថ្នាក់មជ្ឈិម ប.ក.ក អំពីគោលនយោបាយចំពោះគ្រួសារដែលជនជាតិវៀតណាម និងខ្មែរ បានរៀបការជាមួយគ្នា ឬមានកូនជាមួយគ្នា។ នៅខែ ឧសភា ឆ្នាំ ១៩៧៨ រស់ ញឹម បានធ្វើការស្នើមួយដោយសួរ មន្ទីរ ៨៧០ ថាតើត្រូវធ្វើយ៉ាងណាជាមួយនឹងជនជាតិវៀតណាម ដែលមានគ្រួសារជាខ្មែរ និង "កូនកាត់ខ្មែរវៀតណាម"[3170]។ តាមគោលនយោបាយរបស់ ប.ក.ក ដែលត្រូវ "ជីកឫស" ដើម្បីកម្ទេចខ្មាំងឱ្យអស់ ប.ក.ក បានដាក់គោលដៅលើកូនក្មេងដែលកើតចេញពីការរៀបការបែបនេះ ប្រសិនបើម្ដាយជាជនជាតិវៀតណាម ដោយជឿថាជាតិពន្ធុគឺយកខាងម្ដាយ[3171]។

---

កងនារីដូចគ្នា "ហេតុអ្វីបានពួកម្អែងអត់ស្ដីខ្ញុំ?" ថាអ្ហ៎ ឈ្មោះខ្ញុំនៅជាមួយអាពត ឈ្មោះខ្ញុំដាក់ឈ្មោះថា "យ៉ា" ថា "អាមីយ៉ាអើយ ម៉ែអាញឪអាញមិនឱ្យស្ដីរកម្អែងទេ ពីព្រោះអីម្អែងកូនកាត់យួន ខ្លាចគេយកម្អែងទៅវាយចោល វាយដោយអញទៀត""]។

[3169] ឯកសារ D1.3.34.20 ទូរលេខ ០៧ ពី វី ជូនបងជាទីគោរព ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៧៧ KH ERN 00001266។

[3170] ឯកសារ D4.1.655 របាយការណ៍ពី ញឹម គោរពជូន មន្ទីរ៨៧០ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ១៩៧៨ EN ERN 00143066 ["កិច្ចប្រជុំបានសួរថាតើការសម្រេចចិត្តអ្វី ដែលត្រូវធ្វើលើសមាសធាតុយោធា ប្រជាជនវៀតណាម ប្ដីខ្មែរប្រពន្ធវៀតណាម ឬប្ដីវៀតណាមប្រពន្ធខ្មែរ និងកូនកាត់ខ្មែរវៀតណាម។ ដោយបានលើកនូវបញ្ហានេះ កិច្ចប្រជុំនេះបានដាក់ជាសំណួរទៅអង្គការ ៨៧០។ វាស្រេចទៅលើអង្គការជាអ្នកសម្រេច។ សូមឱ្យយើងខ្ញុំដឹងអំពីការសម្រេចចិត្តណាមួយរបស់អង្គការ"]។

[3171] ឯកសារ D234/2.1.21 ការប្រព្រឹត្តិចំពោះជនជាតិភាគតិចវៀតណាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីទស្សនវិស័យប្រៀបធៀប ដោយ Elizabeth Do KH ERN 00768963 ["ពីដំបូង អ្នកផ្ដល់បទសម្ភាសពីភូមិពោធិ៍ចិន្ដាំបានបញ្ជាក់ពីរបៀបនៃការប្រមូលគ្រួសារវៀតណាមពីសំណាក់ពួកខ្មែរក្រហមដែលគ្រួសារទាំងនោះមានប្ដីប្រពន្ធជាខ្មែរ និងវៀតណាម។ អ្នកផ្ដល់បទសម្ភាសខ្លះបាននិយាយថា ពួកគេបានសង្កេតឃើញពួកខ្មែរក្រហមប្រមូលម្ដាយ និងកូនពីគ្រួសារ

778. ប្រពន្ធ និងកូនបីនាក់របស់ អ៊ុច ស៊ុនឡាយ ត្រូវគេសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ គាត់បានផ្ដល់សក្ខីកម្មថា កូនគាត់ត្រូវគេសម្លាប់ ពីព្រោះថា កូនគាត់ត្រូវគេចាត់ទុកថាមានដើមកំណើតជាវៀតណាម[3172]។ ដួង អឿន មានប្ដីជាជនជាតិវៀតណាម បានផ្ដល់សក្ខីកម្មថា គេមិនយកកូនស្រីគាត់ទៅទេ ដោយសារថាមានម្ដាយជាជនជាតិខ្មែរ[3173]។ បុរសខ្មែរខ្លះដែលមានប្រពន្ធជាជនជាតិវៀតណាមត្រូវគេសម្លាប់ ត្រូវបានគេលើកទឹកចិត្តឱ្យរៀបការម្ដងទៀតជាមួយនារីខ្មែរវិញ[3174]។

---

ដែលមានម្ដាយជាជនជាតិភាគតិចវៀតណាម ប៉ុន្តែបើគ្រួសារនោះមានឪពុកជាជនជាតិវៀតណាមវិញ ពួកខ្មែរក្រហមយកតែឪពុកតែប៉ុណ្ណោះ។ អ្នកផ្ដល់បទសម្ភាសបានឃើញពួកខ្មែរក្រហមប្រមូលគ្រួសារវៀតណាមចំនួន៤គ្រួសារក្នុងភូមិពោធិ៍ចិន្ដាំ និងបាននិយាយថា កម្មាភិបាលខ្មែរមិនបានធ្វើការបែងចែកដូចនេះឡើយ នៅពេលបញ្ជូនប្រជាជនផ្សេងៗទៀតចេញពីភូមិនេះ។ ទោះបីជាយ៉ាងនេះក្ដី អ្នកផ្ដល់បទសម្ភាសពីភូមិផ្សេងៗទៀតបាននិយាយថា ពួកខ្មែរក្រហមក្នុងភូមិរបស់ពួកគេប្រមូលតែឪពុក ឬម្ដាយជាជនជាតិវៀតណាម (និងមិនបានយកកូនផងទេ) ហើយអ្នកផ្ដល់បទសម្ភាសផ្សេងទៀតបាននិយាយថា កម្មាភិបាលខ្មែរក្រហមបានប្រមូលសមាជិកគ្រួសារទាំងមូល ប្រសិនបើពួកគេរកឃើញថាក្នុងគ្រួសារមួយមានសមាជិកគ្រួសារសូម្បីតែម្នាក់ក៏ដោយ។ ការប្រមូលទាំងនេះគឺជាការកត់សម្គាល់របស់អ្នកផ្ដល់បទសម្ភាសន៍ប៉ុណ្ណោះ ហើយមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈថាជាគោលនយោបាយមួយរបស់ពួកខ្មែរក្រហមឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ទម្រង់នៃការប្រមូលប្រជាជនក្នុងភូមិពោធិ៍ចិន្ដា តម្រូវឱ្យមានការសិក្សាបន្ថែមទៀត បើទោះបីជាបទពិសោធន៍ នៃការប្រមូលនេះមានភាពខុសគ្នារវាងប្រជាជនកម្ពុជានិងជនជាតិភាគតិចវៀតណាមក៏ដោយ"]។ ឯកសារ D234/2.1.91 ដួង អឿន ប្រតិចារឹកថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង10:48:20-10:50:02 ["ជនជាតិវៀតណាមហ្នឹងយកទៅទាំងអស់ហើយ វាមិនទុកទេ ជំនាន់នុំងនោះ។ ទាល់តែម៉ែខ្មែរ គេយកតែប្ដីទៅៗ"]។ ឯកសារ D234/2.1.97 ខូង មួយ ប្រតិចារឹក ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ម៉ោង 11:23:06-11:27:56 ["គាត់ថា ឆ្អែងកុំយំ ប្រយ័ត្ន កូនយាយយួនហ្នឹងស្លាប់ហើយ ឥឡូវគេមកយកកូនគាត់ធ្វើកងរយទៀត យាយសៀនៗហ្នឹងក៏គេយកទៅបាត់ គេថាគេយកទៅវ៉ៃ។ គេខ្សឹបប្រាប់ខ្ញុំ ថាឆ្អែងឈប់យំទៅប្រយ័ត្នគេយកឯងទៅវ៉ៃចោលទៀត"]។

3172 ឯកសារ D234/2.1.98 អ៊ុច ស៊ុនឡាយ ប្រតិចារឹកថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 09:14:46-09:18:00 ["សៈ [...] ចុះលោកដឹងទេថា ហេតុអ្វីបានជាកូនៗរបស់លោកនេះ ដែលលោកមានកូនៗជាមួយប្រពន្ធវៀតណាម ក៏ក្លាយជាគោលដៅនៃការសម្លាប់នេះដែរ? ឆៈ ខ្ញុំបាទហ្នឹងច្បាស់ហើយថាប្រពន្ធ និងកូនជាវៀតណាម ដូច្នេះកូនហ្នឹងគឺជាចៅកាត់វៀតណាម"]។

3173 ឯកសារ D234/2.1.91 ដួង អឿន ប្រតិចារឹកថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 10:45:08-10:48:20 ["គេវាមិនចាប់មែន កាលនុំងអត់មានអ្នកណាយកទៅទេ ស្មានតែកូនខ្មែរ...អ៎! ម៉ែខ្មែរ កូនខ្មែរអត់យកទៅទេ គេយកតែឪពុកទេ។ បានជាកូនខ្ញុំនៅហ្នឹងនោះ បើគេយកទៅ ទៅទាំងអស់ហើយ"]។

3174 ឯកសារ D234/2.1.81 ប្រាក់ ឌឿន ប្រតិចារឹកថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 15:38:39-13:41:06 ["ទាល់តែព្រឹកឡើងបានកម្មាភិបាលប្រាប់ខ្ញុំថា គេយកទៅសម្លាប់ហើយ ពូកុំសង្ស័យ គិតការងារជូនបក្ស ជូនរដ្ឋទៅ។ យើងពីត្រឹមថ្ងៃហ្នឹងទៅ ខ្វះអីស្រីគរគោក មិត្តយើងគរគោក ស្នើទៅ ដណ្ដឹងទៅ អង្គការរៀបចំឱ្យ មិនបាច់អស់លុយអស់កាក់ផង"]។

ការដាក់គោលដៅលើកូនក្មេងតូចៗ ដែលត្រូវគេជឿថាជនជាតិវៀតណាម និងការធ្វើឲ្យប្រាកដថា ខ្មែរត្រូវរៀបការជាមួយខ្មែរនោះ គឺជាការបង្ហាញពីចេតនារបស់មេដឹកនាំបក្ស ដើម្បីលុបបំបាត់មនុស្សជំនាន់ក្រោយជាជនជាតិវៀតណាម ឬកាត់វៀតណាម និងដើម្បីបំផ្លាញក្រុមជនជាតិនេះទាំងមូល។

## ការសម្លាប់នៅទូទាំងកម្ពុជាប្រជាធិបតេយ្យ

779. បន្ថែមពីលើវោហាសាស្ត្រប្រល័យពូជសាសន៍ និងសេចក្តីប្រកាសគោលនយោបាយរបស់មេដឹកនាំ ប.ក.ក នៅគ្រប់ថ្នាក់ទាំងអស់នោះ ការសម្លាប់ដែលមានគំរូស្រដៀងគ្នាជាបន្តបន្ទាប់នៅទូទាំងដែនដីកម្ពុជាប្រជាធិបតេយ្យ បានបង្ហាញឲ្យឃើញពីអត្ថិភាពនៃគោលនយោបាយរបស់ ប.ក.ក និង កម្ពុជាប្រជាធិបតេយ្យ ដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍មកលើជនជាតិវៀតណាម។

780. ការសម្លាប់ជនជាតិវៀតណាម បានកើតឡើងនៅភូមិភាគឧត្តរ[3175] ភូមិភាគពាយ័ព្យ[3176] ភូមិភាគពាយ័ព្យ[3177] ភូមិភាគបូព៌ា[3178] រួមមានជាពិសេស តំបន់ ២៣[3179] តំបន់ ២៤[3180] តំបន់ ៥០៥ (ក្រចេះ)[3181] ភូមិភាគបស្ចិម[3182] ភូមិភាគនិរតី[3183] និងនៅ មន្ទីរ ស-២១[3184]។

---

3175 ឯកសារ D234/2.1.79 (E1/357.1) សាន ស៊ីង ប្រតិចារឹកថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៥ ម៉ោង 15:05:00-15:14:50, 15:19:56-15:25:01, 15:25:01-15:34:08, 15:34:08-15:42:12, 15:53:04-15:55:09, 15:58:25-16:04:00។ ឯកសារ D234/2.1.80 ស៊ាន ស៊ីង ប្រតិចារឹកថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥ ម៉ោង 09:04:31-09:08:47, 09:17:16-09:32:19, 09:59:20-10:01:00, 11:04:10-11:13:28, 14:33:59-14:40:36។ ឯកសារ D234/2.1.85 អ៊ុំ ស៊ីន ប្រតិចារឹកថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 11:14:53-11:20:15, 11:27:16-11:32:38, 13:45:05-13:52:12, 13:59:56-14:03:41, 14:09:53-14:12:55, 14:23:55-14:27:20, 14:28:46-14:34:25, 14:34:25-14:40:49, 15:09:15-15:23:53។ ឯកសារ D234/2.1.86 អ៊ុំ ស៊ីន ប្រតិចារឹកថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 09:11:55-09:17:37, 09:24:00-09:30:01។

3176 ឯកសារ D1.3.34.20 ទូរលេខពី វី សូមរាយការណ៍ជូនបងជាទីគោរព ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៧៧ KH ERN 00001266-67។ ឯកសារ D234/2.1.104 ជិន គីមថុង ហៅ ឆាង ប្រតិចារឹកថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 11:09:33-11:11:57, 15:31:45-15:34:35, 15:34:35-15:40:42, 15:37:23-15:40:42, 15:44:09-15:47:50, 15:53:52-16:00:27, 16:02:56-16:07:22។ ឯកសារ D234/2.1.98 ផន ថុល ប្រតិចារឹកថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 11:19:57-11:24:08។ ឯកសារ D4.1.801 កំណត់ហេតុស្តាប់ចម្លើយ ឆោម សែ ឆ.12។ ឯកសារ D4.1.805 កំណត់ហេតុស្តាប់ចម្លើយ ឆោម សែ ឆ.21។ ឯកសារ D4.1.803 កំណត់ហេតុស្តាប់ចម្លើយ ជិន គីមថុង ហៅ ឆាង ឆ.11-12។ ឯកសារ D4.1.804 កំណត់ហេតុស្តាប់ចម្លើយ ជិន គីមថុង ហៅ ឆាង KH ERN 00401334

។ ឯកសារ D4.1.420 កំណត់ហេតុស្តាប់ចម្លើយ ខឹម ពៅ KH ERN 00221754-55។ ឯកសារ D10.1.35 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ផាត KH ERN 00189241។

3177 ឯកសារ D234/2.1.84 ព្រុំ សារុន ប្រតិចារឹកថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 13:35:10-13:40:00, 13:40:00-13:45:32, 13:51:10-14:01:23, 13:58:08-14:04:08, 14:04:08-14:12:37, 14:17:14-14:22:19, 15:54:11-15:56:11។ ឯកសារ D4.1.464 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម អាន់ KH ERN 00197883។ ឯកសារ D59/1/1.46 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង ឡុត បណ្ឌែត KH ERN 00927114-15។ ឯកសារ D59/1/1.52 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង ភាច រស់ KH ERN 00927186-87។ ឯកសារ D114/29.1.4 ប៉ែន ឃៀនិន របប ប៉ុល ពត KH ERN 00637821-23។

3178 ឯកសារ D114/29.1.4 ប៉ែន ឃៀនិន របប ប៉ុល ពត KH ERN 00637824-26។

3179 ឯកសារ D234/2.1.86 អ៊ុំ ស៊ន់ ប្រតិចារឹកថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 11:02:50-11:17:21, 11:17:21-11:22:39។ ឯកសារ D11/523/3 សៀង ចាន់ធី ប្រតិចារឹកថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 15:35:17-15:39:54, 15:42:26-15:49:08។ ឯកសារ D234/2.1.97 សៀង ចាន់ធី ប្រតិចារឹកថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 09:13:45-09:17:37, 09:30:10-09:35:00, 09:35:00-09:37:36, 09:43:00-09:50:32, 10:38:50-10:41:38 ។

3180 ឯកសារ D114/297.1.21 ថេង ផល ប្រតិចារឹកថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 11:04:04-11:06:30, 15:43:30-15:48:31, 15:57:47-16:05:04, 16:01:54-16:07:03។ ឯកសារ D234/2.1.91 ម្លូង អឿន ប្រតិចារឹកថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 09:21:34-09:24:55, 09:25:46-09:31:34, 09:31:34-09:39:24, 09:55:09-10:02:01, 10:38:02-10:42:00។ ឯកសារ D234/2.1.82 សៅ សាក់ ប្រតិចារឹកថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 14:30:08-14:34:36, 14:34:36-14:36:37, 14:40:39-14:45:40, 15:15:01-15:19:31, 16:00:11-16:01:40។ ឯកសារ D234/2.1.83 សៅ សាក់ ប្រតិចារឹកថ្ងៃទី៧ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 09:15:16-09:22:26, 09:26:50-09:31:02, 09:36:13-09:43:03, 09:44:16-09:51:21។ ឯកសារ D114/36.1.36 កំណត់ហេតុស្តាប់ចម្លើយ ឈួន រី KH ERN 00408518។ ឯកសារ D4.1.550 កំណត់ហេតុស្តាប់ចម្លើយ អៀង អុន KH ERN 00225355។ ឯកសារ D114/36.1.43 កំណត់ហេតុស្តាប់ចម្លើយ ស៊ុន ស៊ន់ KH ERN 00232824-25។ ឯកសារ D114/36.1.49 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង ឡេង សាម៉េត KH ERN 00033498។ ឯកសារ D98/3.1.127 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង គីម វ៉ា KH ERN 00034121-22។

3181 ឯកសារ D114/29.1.4 ប៉ែន ឃៀនិន របប ប៉ុល ពត KH ERN 00637824-26។ ឯកសារ D234/2.1.97 អ៊ុច ស៊ុនឡាយ ប្រតិចារឹកថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 15:28:37-15:37:32, 15:48:40-15:50:00, 15:53:13-16:03:00។ ឯកសារ D234/2.1.98 អ៊ុច ស៊ុនឡាយ ប្រតិចារឹកថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 09:09:24-09:14:46, 09:118:00-09:20:18។

3182 ឯកសារ D234/2.1.81 ប្រាក់ ខឿន ប្រតិចារឹកថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 11:21:43-11:27:26, 11:29:10-11:31:34, 13:50:15-13:53:48, 13:55:16-13:57:43, 14:11:05-14:12:59, 14:26:45-14:31:20, 14:36:49-14:42:33, 15:21:36-15:25:46, 15:28:02-15:34:12។ ឯកសារ D234/2.1.82 ប្រាក់ ខឿន ប្រតិចារឹកថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 10:49:08-10:52:28។ ឯកសារ D234/2.1.83 ជឿង យ៉ាំង ចែត ប្រតិចារឹកថ្ងៃទី៧ ខែ ធ្នូ ឆ្នាំ

២០១៥ ម៉ោង 10:51:51-10:54:55, 10:57:37-11:11:02, 11:12:32-11:19:46, 11:22:02-11:28:10។ ឯកសារ D64.1.34 សេវាផ្សព្វផ្សាយព័ត៌មានបរទេស ការប្រមូលរបាយការណ៍សម្រាប់ខែកញ្ញា ឆ្នាំ ១៩៧៧ EN ERN 00168725។ ឯកសារ D114/29.1.4 ប៉ែន ឃៀនិន របប ប៉ុល ពត KH ERN 00637821-23។

3183 ឯកសារ D234/2.1.65 ជាំង ស្រីមុំ ប្រតិចារឹកថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ម៉ោង 11:01:53-11:07:15, 15:33:36-15:37:25។ ឯកសារ D11/61/3.1 ពៅ រី ប្រតិចារឹកថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ម៉ោង 09:25:00-09:45:19, 11:32:56, 13:34:19-13:45:23។ ឯកសារ D11/58/3 តាក សាន់ ប្រតិចារឹកថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ម៉ោង 13:12:57-13:15:33, 13:19:21-13:22:13។ ឯកសារ D11/61/3 កំណត់ហេតុស្តាប់ចម្លើយ ពៅ រី ឆ. 81។ ឯកសារ D234/2.1.97 ខូង មួយ ប្រតិចារឹកថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 11:05:17-11:11:58, 11:14:25-11:23:06, 11:23:06-11:27:56, 13:50:08-13:56:37, 14:19:47-14:25:00។ ឯកសារ D4.1.477 កំណត់ហេតុស្តាប់ចម្លើយ ហែម សម្បត្តិ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៨ KH ERN 00206381-82។ ឯកសារ D4.1.787 កំណត់ហេតុស្តាប់ចម្លើយ ទួន លន KH ERN 00368648-49, 00368652។ សូមមើលឧទាហរណ៍ ឯកសារ D4.1.795 កំណត់ហេតុស្តាប់ចម្លើយ សូ ខុន KH ERN 00398490។ ឯកសារ D114/29.1.4 ប៉ែន ឃៀនិន របប ប៉ុល ពត KH ERN 00637821-23។

3184 ឯកសារ D98/3.1.90 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹកថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០០៩ ម៉ោង 14:32:33-14:35:04, 14:39:35-14:42:57, 16:07:07-16:09:10។ ឯកសារ D98/3.1.91 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹកថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ម៉ោង 09:10:24-09:18:05, 09:33:27-09:40:49, 11:43:39-11:47:21, 13:49:50-13:52:28។ ឯកសារ D114/277.4 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹកថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង 15:02:30-15:04:30។ ឯកសារ D114/277.5 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹកថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង 11:10:07-11:18:34។ ឯកសារ D114/277.7 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹកថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង 09:43:05-09:44:35, 11:05:26-11:07:07។ ឯកសារ D98/1.2.23 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹកថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២ ម៉ោង 09:57:07-09:59:14។ ឯកសារ D98/1.2.27 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹកថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១២ ម៉ោង 15:39:39-15:41:11។ ឯកសារ D234/2.1.112 ប្រាក់ ខន ប្រតិចារឹកថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង 15:57:03-15:59:05។ ឯកសារ D234/2.1.113 ប្រាក់ ខន ប្រតិចារឹកថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង 09:04:07-09:07:06, 09:09:11-09:11:13, 09:12:52-09:14:47។ ឯកសារ D234/2.1.111 ឡាច មាន ប្រតិចារឹកថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦ ម៉ោង 10:51:06-10:55:14, 15:37:36-15:38:29។ ឯកសារ D234/2.1.115 ហ៊ីម ហ៊ុយ ប្រតិចារឹកថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង 15:01:25-15:03:39។ ឯកសារ D234/2.1.116 ហ៊ីម ហ៊ុយ ប្រតិចារឹកថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង 09:55:12-09:58:46, 14:27:20-14:28:46, 14:30:53-14:32:38, 15:03:56-15:07:20, 15:11:10-15:15:53។ ឯកសារ D114/43 កំណត់ហេតុស្តាប់ចម្លើយ សួស ធី ឆ.23។ ឯកសារ D4.1.245 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ខន KH ERN 00146597។ ឯកសារ D114/165 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ខន ឆ.39។ ឯកសារ D4.1.346 កំណត់ហេតុស្តាប់ចម្លើយ ម៉ម ណៃ KH ERN 00162879-80, 00162889-90។ ឯកសារ D4.1.244 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ហ៊ុយ KH ERN 00146638-39។ ឯកសារ D4.1.91 កំណត់ហេតុនៃការប្រជុំលេខា អនុលេខា

## ការអនុវត្តរបស់ មាស មុត លើគោលនយោបាយប្រល័យពូជសាសន៍

### *ក) បទបញ្ជាសម្លាប់ជនជាតិវៀតណាមនៅកងពល ១៦៤*

781. ភ័ស្តុតាងបញ្ជាក់ថា **មាស មុត** បានដឹងយ៉ាងច្បាស់អំពីគោលនយោបាយរបស់ ប.ក.ក ក្នុងការបំផ្លាញជនជាតិវៀតណាម ជាក្រុមជនជាតិពន្ធុ ពិសេសមួយនៅក្នុងប្រទេសកម្ពុជា។ **មាស មុត** បានផ្សព្វផ្សាយគោលនយោបាយនេះទៅអ្នកក្រោមបង្គាប់របស់គាត់នៅកងពល ១៦៤។ ជាងនេះទៀត **មាស មុត** បានអនុវត្តគោលនបាយនេះតាមរយៈការសម្លាប់ជនជាតិវៀតណាមដែលចាប់បាននៅតំបន់គ្រប់គ្រងដោយកម្លាំងដែលស្ថិតនៅក្រោមបញ្ជាគាត់។

782. ថ្នាក់ដឹកនាំកងពល ១៦៤ បានចូលរួមការសម្លាប់ជនជាតិវៀតណាមដែលចាប់បាននៅដែនទឹកដែលកម្ពុជាអះអាងថាជារបស់ខ្លួន ដោយបានចូលរួមតាមវិធីពីរបែប។ ទីមួយ គោលនយោបាយរួមក្នុងការសម្លាប់ជនជាតិវៀតណាមទាំងអស់ត្រូវបានប្រកាសឲ្យប្រើប្រាស់នៅទូទាំងកងពល។ ទីពីរ ថ្នាក់ដឹកនាំកងពល ត្រូវបានជូនដំណឹងអំពីការចាប់បានទូកនានា ហើយបានចេញបញ្ជាជាក់លាក់ឲ្យសម្លាប់ជនជាតិវៀតណាមដែលចាប់បានម្តងៗ ហេតុនេះជាការពង្រឹង និងបញ្ជាក់ពីគោលនយោបាយរួមនេះ។

783. អ្នកក្រោមបង្គាប់ពីរនាក់របស់ **មាស មុត** នៅកលពល ១៦៤ ផ្តល់ភ័ស្តុតាងដ៏រឹងមាំបញ្ជាក់ពីការប្រកាសឲ្យប្រើប្រាស់គោលនយោបាយរួមក្នុងការសម្លាប់ជនជាតិវៀតណាម។ នៅក្នុងសំណុំរឿង ០០២/០២ ប្រាក់ សុខ ជាកងទ័ពនៅកងពល ១៦៤ បានផ្តល់សក្ខីកម្មថា សមាជិកកងពល ១៦៤

---

កងពល និងវរសេនាធំ ថ្ងៃទី ១ ខែ មីនា ឆ្នាំ ១៩៧៧ EN ERN 00933839។ ឯកសារ D1.3.34.61 ទូរលេខពី អំនួន ជម្រាបបង ជាទីគោរពស្នេហា និងរព្ទក ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ KH ERN 00020949។ ឯកសារ D4.1.96 ស-២១ សៀវភៅកំណត់ហេតុសួរចម្លើយរបស់ ម៉ម ណៃ ហៅ ចាន់ KH ERN 00077949-50។ ឯកសារ D54/80.1.38 សៀវភៅកំណត់ហេតុសួរចម្លើយ ស-២១ របស់ ប៉ុង-ទុយ KH ERN 00077518-19។ ឯកសារ D1.3.26.5 របាយការណ៍ផ្សព្វផ្សាយរបស់ ប៊ីប៊ីស៊ី ចម្លើយសារភាពរបស់ទាហានជើងទឹកសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលត្រូវបានចាប់ខ្លួន ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៧៨ KH ERN 00224832-35។ ឯកសារ D69.1.11 សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ខែ កុម្ភៈ ឆ្នាំ ១៩៧៨ KH ERN 00290870-17។ ឯកសារ D4.1.319 របាយការណ៍ផ្សព្វផ្សាយរបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ១៩៧៨ KH ERN 00225134-35។ ឯកសារ D4.1.324 របាយការណ៍ផ្សព្វផ្សាយរបស់កម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ១៩៧៨ KH ERN 00225334-35។

ទទួលបញ្ជាឲ្យសម្លាប់ជនជាតិវៀតណាមទាំងអស់ សូម្បីតែកូនង៉ែត ពីព្រោះថា ពួកគេគឺជា "សត្រូវស្នូលពូជ" របស់ខ្មែរ[3185]។ គាត់ក៏បានផ្ដល់ភស្តុតាងផងដែរបញ្ជាក់ថា ទស្សនៈដែលចាត់ទុក

---

[3185] ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 13:31:00-13:40:06 ["ស៖ [...] ប្រសិនបើលោកអាចនិយាយឲ្យបានលម្អិតបន្តិចអំពីវគ្គហ្វឹកហ្វឺននោះ។តើវគ្គហ្វឹកហ្វឺននោះគេធ្វើឡើងនៅកន្លែងណាដែរ? ឆ៖ កាលនោះ ជាវគ្គសិក្សាទៅតាមអង្គភាព ជាវរសេនាតូច។ ដោយវរសេនាតូចនោះ និងវរសេនាធំបានសិក្សាពីវគ្គមន្ទីកងពល ហើយក្រោយមកឃើញថា វគ្គសិក្សាទៅតាមសាលាតូចៗ នៅតាមជួរយោធាខាងមុខនៅលើកោះ គឺថាមានវគ្គសិក្សានៅតាមវរសេនាតូចៗនីមួយៗ ទូទាំងអស់នៅក្នុងកងពល។ ស៖ តើអ្នកណាខ្លះចូលរួមនៅក្នុងវគ្គសិក្សានោះ? តើគ្រូបង្វឹក គ្រូបង្រៀននៅកាលនោះមានអ្នកណាខ្លះ តើលោកចាំទេ? ឆ៖ បាទ អត់មាន ក្រៅពីគណៈបញ្ជាការរបស់ខ្លួន ទាំងសិទ្ធិជាវរសេនាតូច ប្រធាននៃវរសេនាតូចទេ ទទួលផែនការពីលើទៅ ពីមន្ទីរកងពលទៅ។ ស៖ តើយោធាទាំងអស់ ហើយនិងកងនារីកទាំងអស់នៅក្នុងវរសេនាតូច ត្រូវបានតម្រូវឲ្យគេចូលរួមវគ្គសិក្សាហ្នឹងទាំងអស់ដែរឬទេ តាមអ្វីដែលលោកចាំនោះ? ឆ៖បានជាគោលដៅរបស់បក្សកុម្មុយនីសកម្ពុជានោះ គឺថាប្រកាសទូទៅ ទូទាំងអស់នៅក្នុងកងពល១៦៤តែម្ដង។ ស៖ លោកសាក្សី នៅពេលដែលលោកចូលវគ្គសិក្សាបែបនេះ តើលោកទាំងអស់គ្នាហើយនិងយោធាផ្សេងៗទៀត យល់ថាវាមានសារៈសំខាន់ដូចម្ដេចទេ? តើលោកជជែកវែកញែក ឬក៏លោកអាចតទល់អ្វីអំពីមុខវិជ្ជាដែលគេបង្រៀនបានដែរឬទេ? ឆ៖ បាទ នៅក្នុងពេលនុំងឃើញថា ដោយបានសិក្សានូវសត្រូវស្នូលពូជរបស់គេបង្ហាត់បង្រៀននូវភាសានេះ ហើយក៏យោធាទាំងអស់ក៏គ្មានអ្នកណាមួយមានពាក្យអ្វីចេញដែរ ហើយអនុវត្តទៅតាមគោលការណ៍របស់កងពល និងអង្គភាពនីមួយៗទូទៅ។ ស៖ អរគុណដែលលោកបានជួយឆ្លើយបំភ្លឺ។ តើដោយពិតប្រាកដ តើគ្រូបង្ហាត់នោះ និយាយដូចម្ដេចនៅពេលដែលគាត់បង្រៀនអំពីសត្រូវស្នូលពូជវៀតណាមហ្នឹង? តើគាត់និយាយអ្វីខ្លះជាខ្លឹមសារ? ឆ៖ បាទ ជាការពិតណាស់ សត្រូវស្នូលពូជហ្នឹងគឺថា សម្លាប់អត់មានទុក សូម្បីតែកូនង៉ែតមួយក៏អត់ឲ្យមានដែរ ព្រោះនេះជាសត្រូវស្នូលពូជ គឺសម្លាប់ចោលតែម្ដង ព្រោះទំនាស់បដិបក្ខ។ បាទ នេះជាអង្គសិក្ខសាលានៅក្នុងមន្ទីរនៃវរសេនាតូចនីមួយៗទទួលផែនការច្បាស់លាស់តែម្ដង"]។ ប៉ាក សុខ ក៏បានផ្ដល់ភស្តុតាងលម្អិត ពីរបៀបធ្វើការណែនាំដែលត្រូវឆ្លងកាត់តាមឋានានុក្រម នៃកងពលធំលេខ១៦៤។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 13:43:50-13:48:28 ["ឋានៈជាវរសេនាតូច និងវរសេនាធំដែលបានទៅហ្វឹកហ្វឺនត្រឹមឋានៈត្រឹមកងពលៗទេ ហើយបានចុះផ្សព្វផ្សាយដល់យោធាទាំងអស់ ដែលនៅក្នុងកងនារីកទាំងអស់នៅតាមវរសេនាតូច"]។ 13:31:00-13:37:45 ["គ្រូបង្រៀន [បើកជាវគ្គសាលាសិក្សា ដើម្បីប្រកាស បាទប្រកាសពេញសិទ្ធិ "សត្រូវស្នូលពូជ" គឺវា យួននិងកម្ពុជា]។ អត់មានក្រៅពីគណៈបញ្ជាការរបស់ខ្លួន ទាំងសិទ្ធិជាវរសេនាតូច ប្រធាននៃវរសេនាតូចទេ ទទួលផែនការពីលើទៅ ពីមន្ទីកងពលទៅ។ [...] បាទ វាជាគោលនយោបាយរបស់បក្សកុម្មុនីស្តកម្ពុជា [ដែលយោធាទាំងអស់នៅក្នុងកងពល១៦៤ ចូលរួមក្នុងការហ្វឹកហ្វឺន ដែលថាវៀតណាមជា "សត្រូវស្នូលពូជ"]។ ពួកគេបានប្រកាសថា យោធាកងពល១៦៤ទាំងអស់ ត្រូវតែចូលរួមវគ្គហ្វឹកហ្វឺន។ 13:34:17-13:37:45 ["បាទ នៅក្នុងពេលនុំងឃើញថា ដោយបានសិក្សានូវសត្រូវស្នូលពូជរបស់គេបង្ហាត់បង្រៀននូវភាសានេះ ហើយក៏យោធាទាំងអស់ក៏គ្មានអ្នកណាមួយមានពាក្យអ្វីចេញដែរ ហើយអនុវត្តទៅតាមគោលការណ៍របស់កងពល និងអង្គភាពនីមួយៗទូទៅ"]។ ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 10:54:55-10:57:18 ["គេបញ្ជា ខាង

ជនជាតិវៀតណាម ជា "សត្រូវស្នូល" និងជា "សត្រូវលេខ ១" គឺកើតចេញដំបូងពីការរៀនសូត្រនៅថ្នាក់កងពល ហើយ **មាស មុត** ទទួលបន្ទុកខាងការអប់រំនយោបាយនៅក្នុងកងពល[3186]។ នៅក្នុងកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រាក់ សុខ ក៏បានបញ្ជាក់ថា បទបញ្ជាឱ្យសម្លាប់ជនអៀសខ្លួនវៀតណាមគឺចេញពី **មាស មុត**[3187]។

យោធាធ្វើហើយ។ អ៊ីចឹងអ្វីក៏ដោយក៏បញ្ជាតាមជាន់ថ្នាក់មក បាទ បញ្ជាតាមជាន់ថ្នាក់បានខាងយោធាធ្វើ។ អ៊ីចឹង មិនមែនថា ធ្វើទៅម្ចាស់ការនៅវរសេនាតូច ប្រធាននៃវរសេនាតូចហ្នឹង គឺថាអត់ទេ ទាល់តែបញ្ជាពីលើមកបានហ៊ានធ្វើ។ ហើយបើគេអត់បញ្ជាមក មានតែបញ្ជូន បាទ បញ្ជូនគេឱ្យទៅនៅ ទៅដីគោក"]។ 14:04:37-14:06:58 ["នៅក្នុងកំឡុងនុ៎ង គឺថាច្បាប់វិន័យរ៉ឹងតឹងណាស់ បាទ រ៉ឹងតឹងណាស់ ធ្វើអ្វីក៏ដោយដល់តែប្រជុំ។ ប្រជុំ គឺថាម៉ឹងម៉ាត់តែម្តងបាទ។ បើឱ្យសម្លាប់ សម្លាប់។ អ្នកមិនសម្លាប់ហ្នឹង សម្លាប់ខ្លួនឯងឥឡូវហើយ។ អាហ្នឹងគឺជាបញ្ជាផ្តាច់ការតែម្តង គឺថាអត់មានហៅថា ហ៎ុ! បញ្ជាហើយ ឬមួយប្រជុំប្រាប់ហើយ មិនអនុវត្តគោលនយោបាយនោះ គឺថាមិនបានទេ អាហ្នឹងជាការពិតប្រាកដ និងប្រជុំទៅតាមវរសេនាតូច វរសេនាតូច គឺផ្សព្វផ្សាយដល់យោធាទាំងអស់នៅក្នុងអង្គភាពបាទ។ នេះពិតប្រាកដ"]។ 10:54:55-11:01:31 ["វរសេនាតូចបញ្ជាពីវរសេនាធំមកហើយ បានហ៊ានបញ្ជាឱ្យយោធាកងពិសេសរបស់គាត់ធ្វើ បានហ៊ានធ្វើ"]។ សូមមើលផងដែរ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.31 ["ស៖ តាមយោបល់ និងគំនិតរបស់លោក ថាតើវាខុសគ្នា ឬត្រូវចំពោះការសម្លាប់អ្នកដែរចាប់បាន? ឆ.31៖ ខ្ញុំគិតថាវាខុសទាំងស្រុង ពីព្រោះប្រជាជនទាំងអស់នោះមិនដឹងអ្វីទាំងអស់ ពួកគេគ្រាន់តែរត់គេចពីសង្គ្រាម ដើម្បីរស់រានមានជីវិតតែប៉ុណ្ណោះ។ ប៉ុន្តែនៅពេលនោះ ខ្មែរក្រហមគិតថា ពួកយួន ជាសត្រូវស្នូល"]។

3186 ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 13:40:06-13:48:28 ["ស៖ [...] លោកបានឆ្លើយជូនសហព្រះរាជអាជ្ញាអន្តរជាតិថា លោកបានចូលរៀននៅកងពល -- អ៎! នៅវរសេនាតូច [...] ហើយលោកទទួលបញ្ជាឱ្យសម្លាប់ជនជាតិវៀតណាមពីរនាក់។ តើលោកដឹងថាគ្រូបង្រៀនលោកហ្នឹង មុនពេលបង្រៀនលោកហ្នឹងមានបានចូលរួមវគ្គបណ្តុះបណ្តាលអីទេ? [...] ឆ៖ បាទ អរគុណណាស។ ឋានៈជាវរសេនាតូច និងវរសេនាធំដែលបានទៅហ្វឹកហ្វឺនត្រឹមឋានៈត្រឹមកងពល១ទេ ហើយបានចុះផ្សព្វផ្សាយដល់យោធាទាំងអស់ដែលនៅក្នុងកងនាវិងទាំងអស់នៅតាមវរសេនាតូច"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ថ្ងៃទី ១៨ តុលា ឆ្នាំ ២០១៣ ឆ.32-34 ["ថៃមិនមានទំនាស់ច្រើនជាមួយខ្មែរទេ នៅក្នុងប្រវត្តិសាស្ត្រ ប៉ុន្តែយួនមានទំនាក់ជាមួយខ្មែរច្រើន ទើបយួនត្រូវបានចាត់ទុកថាជាសត្រូវស្នូល និងជាសត្រូវទី១។ ស៖ ហេតុអ្វីបានជាលោកដឹងអំពីរឿងអស់ទាំងនេះ? ឆ.33៖ ពីព្រោះមេបញ្ជាការកងវរសេនាតូច និងវរសេនាធំទៅរៀនសូត្រជាមួយនឹងកងពល ហើយពេលគេត្រឡប់មកវិញ គឺគេបានបង្រៀនយើងអំពីរឿងនេះនៅក្នុងវគ្គអប់រំរៀនសូត្រ។ ស៖ តើអ្នកណាជាអ្នកទទួលខុសត្រូវរួមក្នុងផ្នែកអប់រំនយោបាយនៅក្នុងកងពល១៦៥ ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩? ឆ៖ គឺ មាស មុត ដែលជាស្នងការនយោបាយរបស់កងពល"]។

3187 ឯកសារ D54/24.1 កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង ប៉ាក សុខ KH ERN 00955507-08 ["ស៖ អ៊ីចឹងបើចាប់បានពួកយួននោះ? ឆ៖ បើពួកគេចាប់បានគេយកទៅសម្លាប់ចោល។ ស៖ សម្លាប់នៅណា? ឆ៖ ជួនកាល

784. ឯក នី ជាកងទ័ពនៅកងពល ១៦៤ បានបញ្ជាក់ថា "អាហ្នឹងច្បាប់ពីខាងលើមកត្រូវតែកម្ទេសពូជសាសន៍យួនជាដាច់ខាត ទោះប្រជាជន ឬនេសាទអី ត្រូវតែចាប់ទាំងអស់"[3188]។ **មាស មុត** ក៏បានចេញបញ្ជាគួរឱ្យភ័យខ្លាចខាងក្រោមនេះទៅឱ្យ ឯក នី និងសមមិត្តគាត់នៅកងពល ១៦៤៖ "តា មុត បានបញ្ជាមកយើងកុំឱ្យខាតសាំង ដើម្បីដឹក [វៀតណាម និងថៃ] មកកំពង់សោមធ្វើអីឱ្យយកធ្វើជាជីដាក់គល់ដូងនៅលើកោះទាំងអស់ទៅ។ សាកសពម្នាក់ត្រូវកាត់ជាពីរកំណាត់ ហើយមួយកំណាត់ៗកប់នៅក្រោមដើមដូងមួយដើម"[3189]។

785. **មាស មុត** ត្រូវបានជូនដំណឹងយ៉ាងជិតដិតអំពីហេតុការណ៍នានាដែលចាប់ទូកបាន ហើយបានចេញបញ្ជាជាក់លាក់បន្ថែមទៀតឱ្យសម្លាប់អ្នកទោសជនជាតិវៀតណាម។ នៅពេលដែលកម្លាំងកងពល ១៦៤ សង្កេតឃើញទូកបរទេស ពួកគេត្រូវតម្រូវឱ្យរាយការណ៍ទៅបញ្ជាការថ្នាក់លើ ហើយសេចក្តីរាយការណ៍បែបនេះចុងក្រោយបំផុតទៅដល់ថ្នាក់កងពល[3190]។ ដោយសារថា ជោគវាសនា

---

គេសម្លាប់នៅលើកោះហ្នឹងទៅ។ សៈ គេអត់មានបញ្ជូនមកខាងទេ? ឆៈ ជួនកាលគេសម្លាប់នៅកោះ។ សៈ អាហ្នឹងច្រើនពួកកងទ័ពឬមួយយ៉ាងម៉េច? ឆៈច្រើនតែប្រជាជនដែលរត់ភៀសខ្លួនទៅប្រទេសទីបី ភាគច្រើនពួកហ្នឹងរត់គេចពីសង្គ្រាម ដល់រត់ឆ្លងមកយើងចាប់បានបាញ់សម្លាប់ចោលទៅ។ សៈ ចឹងចាប់បានបញ្ជាពីកងពលទៅឬមួយធ្វើដោយខ្លួនឯង? ឆៈបញ្ជាពីកងពលទៅ។ សៈបញ្ជាចេញពីនរណាទៅ? ឆៈ បញ្ជាចេញពីតា មុត។ សៈ បញ្ជាឱ្យសម្លាប់តែម្តង? ឆៈ បាទ"]។

3188 ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.18។

3189 ឯកសារ D54/102 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.41។ សូមមើលផងដែរ ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.63 ["ឆៈ សម្រាប់តែមុខព្រួញដែលខ្ញុំដឹង។ ដំបូងយើងបញ្ជូនមកដីគោក ក្រោយមក យើងទទួលបញ្ជាពីកងពលថា មិនបាច់បញ្ជូនមកដីគោកទេ។ ហើយយើងទទួលបញ្ជាថា យកតែមាស ហើយសនុស្សធ្វើជាជីនៅលើកោះហ្នឹងទៅ កុំចំណាយប្រេងដឹងពួកគេមកដីគោក"]។

3190 ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.25, 28 ["បើយើងឃើញទូក ឬក៏កប៉ាល់នៅលើដែនទឹករបស់យើង យើងនឹងរាយការណ៍តាមវិទ្យុទាក់ទងទៅវរសេនាតូច ហើយបញ្ជាការដ្ឋានរបស់វរសេនាតូចរាយការណ៍ទៅឱ្យវរសេនាធំ។ វរសេនាធំរាយការណ៍បន្តទៅកងពល។ រួចហើយទើបកងពលបញ្ជាតាមខ្សែរយៈត្រឡប់ចុះមកវិញថាតើយើងគួរធ្វើយ៉ាងម៉េចជាមួយទូក កប៉ាល់ ហើយនិងមនុស្សដែលចាប់បាន [...] ឆ.28៖ ត្រូវតែរាយការណ៍ឱ្យបានច្បាស់លាស់ នូវអ្វីដែលយើងចាប់បាន។ ឧទាហរណ៍ថាតើគេជាជនជាតិវៀតណាមភៀសខ្លួន ជាអ្នកនេសាទថៃ ឬជាទាហាន យើងត្រូវតែរាយការណ៍ទៅថ្នាក់លើឱ្យបានច្បាស់ជាមុន"]។ ឯកសារ D2/10 កំណត់ហេតុស្តាប់ចម្លើយ សយ ប៊ន ឆ.31 ["សៈ បើសិនជាកងនាវាត្រូវបានដាក់ពង្រាយនៅហ្នឹងព្រំដែនក្នុងសមុទ្រ រួចហើយបានឃើញនាវាបរទេសដែលរំលោភលើព្រំដែនរបស់ខ្លួន តើកងនាវាលោកធ្វើយ៉ាងដូចម្តេច? ឆ.31៖ សូម្បីតែយើងឃើញនាវាបរទេសរំលោភចូលមកដែនដីយើងក្តី ក៏យើងមិនធ្វើអ្វីតបភ្លាមដែរ ប៉ុន្តែយើងត្រូវរាយការណ៍ភ្លាមទៅអង្គការផ្នែកខាងលើ ហើយរងចាំ

របស់ជនបរទេសដែលចាប់ខ្លួនបាន ជារឿយៗគឺអាស្រ័យលើសញ្ជាតិរបស់ខ្លួននោះ ទើបកម្លាំងកងពល ១៦៤ ត្រូវតែរាយការណ៍ព័ត៌មាននេះយ៉ាងប្រយ័ត្នប្រយែង[3191]។ នៅពេលដែលរបាយការណ៍ដល់ថ្នាក់កងពល បទបញ្ជានឹងចេញជាភាសាសាមញ្ញ ដូចជា "បាញ់ពួកហ្នឹងចោលទៅ" "បញ្ជូនពួកហ្នឹងមកដីគោក"[3192]។ បទបញ្ជាទាំងនេះផ្ញើចេញជាភាសាសាមញ្ញ តាមវិទ្យុទាក់ទង ដោយមិនមានលេខដាក់កូដសម្ងាត់នោះទេ[3193]។ តាមពិត បទបញ្ជារបស់ **មាស មុត** ពាក់ព័ន្ធនឹងជនជាតិវៀតណាមដែលចាប់ខ្លួនបាននៅសមុទ្រនៅពេញមួយរយៈកាលពីចុងខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ គឺត្រូវសម្លាប់ជនជាតិវៀតណាមនៅហ្នឹងកន្លែងជាលក្ខណៈប្រព័ន្ធ[3194] បើមិនអ

---

បញ្ជាថ្នាក់លើត្រឡប់ទៅវិញ ថាតើត្រូវធ្វើយ៉ាងម៉េចជាមួយនាវានោះ។ សម្រាប់ការចាប់ចងនាវាផ្សេងៗវាជាភារៈកិច្ចរបស់កងមួយទៀតដែលគេមានជាទូកឈើសម្រាប់ដើរចាប់ចង"]។

3191 ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.25, 28 ["បើយើងឃើញទូក ឬក៏កប៉ាល់នៅលើដែនទឹករបស់យើង យើងនឹងរាយការណ៍តាមវិទ្យុទាក់ទងទៅវរសេនាតូច ហើយបញ្ជាការដ្ឋានរបស់វរសេនាតូចរាយការណ៍ទៅឲ្យវរសេនាធំ។ វរសេនាធំរាយការណ៍បន្តទៅកងពល។ រួចហើយទើបកងពលបញ្ជាតាមខ្សែរយៈត្រឡប់ចុះមកវិញ ថាតើយើងគួរធ្វើយ៉ាងម៉េចជាមួយទូក កប៉ាល់ ហើយនិងមនុស្សដែលចាប់បាន [...] ឆ.28៖[...] ត្រូវតែរាយការណ៍ឲ្យបានច្បាស់លាស់ នូវអ្វីដែលយើងចាប់បាន។ ឧទាហរណ៍ថាតើគេជាជនជាតិវៀតណាមភៀសខ្លួន ជាអ្នកនេសាទថៃ ឬជាទាហាន យើងត្រូវតែរាយការណ៍ទៅថ្នាក់លើឲ្យបានច្បាស់ជាមុ"]។

3192 ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.1-2 ["ឆ៖ ជាទូទៅនៅពេលដែលកងនាវីកនៅលើនាវាទទួលបានបញ្ជាឲ្យសម្លាប់ ឬមួយក៏បញ្ជូនពួកអ្នកដែលចាប់បាន តើបញ្ជានោះធ្វើដោយផ្ទាល់មាត់តាមវិទ្យុទាក់ទង ឬក៏តាមម៉ាស៊ីនម៉ស? ឆ.1៖ បញ្ជាគឺតាមការនិយាយផ្ទាល់មាត់តាមរយៈវិទ្យុទាក់ទង។ ឆ.2៖គេប្រើភាសាសាមញ្ញធម្មតានៅពេលបញ្ជា ឧទាហរណ៍គេនិយាយថា "បាញ់ពួកហ្នឹងចោលទៅ ឬក៏បញ្ជូនពួកហ្នឹងមកដីគោក""]។

3193 ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.1 ["៖ ជាទូទៅនៅពេលដែលកងនាវីកនៅលើនាវាទទួលបានបញ្ជាឲ្យសម្លាប់ ឬមួយក៏បញ្ជូនពួកអ្នកដែលចាប់បាន តើបញ្ជានោះធ្វើដោយផ្ទាល់មាត់តាមវិទ្យុទាក់ទង ឬក៏តាមម៉ាស៊ីនម៉ស? ឆ.1៖ បញ្ជាគឺតាមការនិយាយផ្ទាល់មាត់តាមរយៈវិទ្យុទាក់ទង"]។

3194 ឯកសារ D234/2.1.93 ព្រុំ សារ៉ាត ប្រតិចារឹក ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០១៦ ម៉ោង 09:58:11-10:00:59 ["កងពលចេញបទបញ្ជាឲ្យខ្ញុំអនុវត្ត។ ផែនការការពារដែនទឹក ដែនសមុទ្ររបស់កម្ពុជា ពេលនោះគាត់សំដៅលើនាវារបស់ជានជាតិវៀតណាមណាដែលមកដោយមានភាពជាមហិច្ឆតាជាកម្លាំងប្រដាប់អាវុធ"]។ ឯកសារ D234/2.1.93 ព្រុំ សារ៉ាត ប្រតិចារឹក ថ្ងៃទី ២៧ ខែមករា ឆ្នាំ២០១៦ ម៉ោង 13:54:26-13:58:03 ["កងទ័ពដែលឈរជើងប្រចាំការនៅលើនាវាត្រូវបំពេញភារកិច្ចរបស់ខ្លួនត្រៀមប្រយុទ្ធតែចំពោះខ្មាំងសត្រូវខាងជើងទឹក ដែលមានទ្រង់ទ្រាយចូលមករំលោភអធិបតេយ្យដែនទឹក"]។ ឯកសារD114/297.1.21 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 13:33:48-13:38:41 ["ក្រោយរំដោះនៅឆ្នាំ៧៥ហើយ កងទ័ពជាភារកិច្ចអ្នកការពារនៅទឹកដីព្រំដែនកោះ នៅសមុទ្រ [...] គ្រាន់តែការពារ តែបើមានវៀតណាមមានអីក៏ដោយចូលមកទឹកដីកម្ពុជាគឺថា មានការទប់ស្កាត់ មានការវាយ

ភ្លើងទេ ត្រូវបញ្ជូនពួកគេទៅសម្លាប់នៅលើកោះ ឬលើដីគោក[3195]។ ប្រាក់ សុខ បានបញ្ជាក់ថា វាជា "របៀបរបបការងារ" ដែល **មាស មុត** ចេញបញ្ជាឲ្យសម្លាប់[3196] ហើយនៅពេលមួយនៅឆ្នាំ

---

គ្នា។ អ៊ីចឹងការណែនាំឲ្យទៅវាយគេគឺគ្មានទេ ក្នុងពេលបច្ចុប្បន្ននុ៎ង"]។ ឯកសារ D234/2.1.96 មាស វឿន ប្រតិចារឹកថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 09:13:46-09:18:29 ["ដូច្នេះកម្ទេចយួនខាងក្រៅដែលវាល្ពានពានជាសំខាន់។ នេះដែលតាមទិសដៅខ្ញុំក្តាប់បាន ហើយនិងការណែនាំប៉ុណ្ណឹង"]។ ឯកសារ D98/3.1.178 មាស វឿន (TCW-428) ប្រតិចារឹកថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០១២ ម៉ោង 13:42:26-13:45:57 ["មានផែនការដើម្បីកម្ទេចខ្មាំងយួន និងខ្មាំងជ្រៀតចូលតាមអង្គភាព"]។

3195 ឯកសារ D234/2.1.92 ព្រុំ សារ៉ាត ប្រតិចារឹកថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 15:49:12-15:55:34 ["ចាប់បានកងទ័ពវៀតណាម ឬក៏ទូកវៀតណាមដែលចូលមកដល់ទឹកដីកម្ពុជា"]។ ឯកសារ D234/2.1.96 មាស វឿន ប្រតិចារឹកថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 09:24:01-09:26:03 ["យួនដែលខ្ញុំចាប់បានអ៊ីចឹង ខ្ញុំបញ្ជូនមកខាងៗលើ។ តែផែនការឲ្យខ្ញុំកម្ទេច ខ្ញុំអត់ទាន់បានកម្ទេចណា"]។ ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 13:41:52-13:46:16 ["បញ្ជូនទៅតាមផែអូរឈើទាល ដើម្បីឡានមកដឹក យកមកក្រុងកំពង់សោមបាទ ខ្លះទៀតក៏យកទៅខាងអូរត្រេះ យកទៅខាងចម្ការដូងបាទ ច្រើនកន្លែងដែរ ព្រោះក្នុងមួយខែៗ គឺថាចាប់ៗរហូត ឆ្នាំ៧៧ហ្នឹង ៧៨ហ្នឹងចាប់ខ្លាំងបាទ"]។ ឯកសារ D114/297.1.20 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 10:04:24-10:07:37 ["បើបញ្ជាពីកងពលឲ្យបញ្ជូនទៅដីគោក ហ្នឹងទៅដីគោក បាទ យកទៅដីគោកត្រង់គេបញ្ជូនទៅណាទៀតខ្ញុំក៏អត់បានដឹងដែរ"]។ ឯកសារ D114/297.1.21 ប៉ាក សុខ ប្រតិចារឹកថ្ងៃទី ៥ ខែមករា ឆ្នាំ ២០១៦ ម៉ោង 13:58:06-14.00.39 ["បញ្ជាពីលើមក មកវរសេនាតូច បាទ វរសេនាតូចបានបញ្ជាឲ្យយោធាធ្វើ ធ្វើសកម្មភាព។ បើចាប់បានគឺសម្លាប់ចោល អាហ្នឹងហ៊ានធ្វើហើយ។ បើថាអត់ពីខាងលើមកគឺមិនហ៊ានធ្វើទេ"]។ ឯកសារ D234/2.1.95 មាស វឿន ប្រតិចារឹកថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 14:15:00-14:19:04 ["រឿងជនភៀសខ្លួនវៀតណាម [...] ខ្លួនខ្ញុំដែលចាប់មក ចាប់បានខ្ញុំបញ្ជូនទៅតាមថ្នាក់ដឹកនាំរបស់ខ្ញុំអ៊ីចឹងទៅ ហើយថ្នាក់ដឹកនាំក៏ដោះស្រាយតាមបែបណា ក៏ស្រេចតែគាត់ទៅ]។

3196 ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.2-ឆ.3 ["គេប្រើភាសាសាមញ្ញធម្មតានៅពេលបញ្ជាឧទាហរណ៍គេនិយាយថា "បាញ់ពួកហ្នឹងចោលទៅ ឬក៏បញ្ជូនពួកហ្នឹងមកដីគោក"។ ស៖ ហេតុអ្វីបានលោកនិយាយនៅក្នុងកិច្ចសម្ភាសជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាថា ការបញ្ជាឲ្យសម្លាប់គឺជាទូទៅ គឺចេញមកពីតា មុត ? ឆ៖ តាមការយល់ដឹងរបស់ខ្ញុំ នេះគឺជារបៀបរបបការងារទូទៅរបស់កងពល"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.25 ["បើយើងឃើញទូក ឬក៏កប៉ាល់នៅលើដែនទឹករបស់យើង យើងនឹងរាយការណ៍តាមវិទ្យុទាក់ទងទៅវរសេនាតូច ហើយបញ្ជាការដ្ឋានរបស់វរសេនាតូចរាយការណ៍ទៅឲ្យវរសេនាធំ។ វរសេនាធំរាយការណ៍បន្តទៅកងពល។ រួចហើយទើបកងពលបញ្ជាតាមខ្សែរយៈត្រឡប់ចុះមកវិញ ថាតើយើងគួរធ្វើយ៉ាងម៉េចជាមួយទូកកប៉ាល់ ហើយនិងមនុស្សដែលចាប់។ ពេលនោះ កងវរសេនាតូចនឹងបញ្ជាមកយើង ថាតើយើងគួរសម្លាប់អ្នកដែលយើងចាប់នោះនៅសមុទ្រតែម្តង ឬយកឡើងមកកោះ។ ប្រសិនបើយើងចាប់បានទូកយួន ពេលខ្លះយើងទទួលបញ្ជាឲ្យបាញ់សម្លាប់ចោលនៅនឹងកន្លែង ហើយយកតែទូកមកកោះតែប៉ុណ្ណោះ"]។ សូមមើលផងដែរ ឯកសារ D54/7

១៩៧៥ មាស មុត បានរិះគន់ជាសាធារណៈចំពោះអ្នកក្រោមបង្គាប់ម្នាក់ ដោយសារបានសម្លាប់មនុស្សគ្មានការអនុញ្ញាតច្បាស់លាស់ពីមាស មុត[3197]។ នៅពេលដែលមាស មុត អវត្តមាន បទបញ្ជាឲ្យចាប់ខ្លួន ឬសម្លាប់ អាចចេញពីអនុគាត់[3198]។

---

កំណត់ហេតុស្តាប់ចម្លើយ ឌុល សុង ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៣ ឆ.15-16 ["ស៖ តើនរណាជាមេបញ្ជាការកងពលលេខ៣/១៦៤? ឆ.15៖ មេបញ្ជាការគឺ មាស មុត។ [...] ស៖តើបញ្ជាការកងពលមានសិទ្ធិអំណាចសម្រេចធ្វើអ្វីខ្លះ? ឆ.16៖តាមការយល់ដឹងរបស់ខ្ញុំ ក្នុងនាមជាមេបញ្ជាការកងពលទ័ពជើងទឹក មាស មុត គាត់ទទួលខុសត្រូវក្នុងរឿងព្រំដែនទឹក"]។ ឯកសារ D54/79 កំណត់ហេតុស្តាប់ចម្លើយ ណុប ហាល់ ឆ.3, ឆ.26 ["កងវរៈសេនាតូចរាយការណ៍ទៅកងវរៈសេនាធំអំពីទូកដែលចូលមកឈ្លានពាន ហើយជាទូទៅកងវរៈសេនាធំរាយការណ៍ទៅកងពលធំដែលមានទីតាំងនៅកំពង់សោម។ [...] ឆ.26៖ ដូចខ្ញុំបានរៀបរាប់កន្លងមក វរៈសេនាតូចដែលប្រចាំការ រាយការណ៍ទៅថានុក្រមថ្នាក់លើ នូវអ្វីដែលគេបានឃើញចូលក្នុងទឹកដីកម្ពុជា។ តា មុត គឺជាមេកងពល ហើយគាត់និង តា សេង ជាអ្នកកាន់កងពល។ តា មុត ជាថានុក្រមថ្នាក់លើ និងកាន់កងពលយូរមកហើយ"]។

3197 ឯកសារ D54/98 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង រ៉េត ឆ.120-122 ["ស៖: [...] លោកនិយាយថា 'បន្ទាប់ពីស្តាប់របាយការណ៍ហើយ បង មាស មុត បានសួរតាញ៉ាន់អំពីការសម្លាប់មនុស្ស គាត់សួរថា៖ តើនរណាគេឲ្យឯងសម្លាប់ប្រជាជនទាំងនោះ? តើនរណាគេអនុញ្ញាតឲ្យឯងស៊ើបសួរប្រជាជនតាមផ្ទះរបស់គេ? ឯងសមនឹងប្រជាជនធ្វើអីថ្លឹងដាក់ហើយ តាមពិតទៅប្រជាជនគួរតែចាក់ទឹកក្តៅលើក្បាលឯង។ ឯងគ្មានសិទ្ធិតាមដានពួកគេទេ។ មុននឹងឯងសម្លាប់មនុស្សតើឯងមានការអនុញ្ញាតពីមេរបស់ឯងដែរឬទេ?" តើលោកបានឮមាស មុត ស្តីឲ្យតាញ៉ាន់ផ្ទាល់ដែរឬទេ? ឆ.120៖ បាទ ខ្ញុំបានឮដោយផ្ទាល់ ពីព្រោះពេលនោះគឺមានសន្និបាតដែលមេៗនៅក្នុងកងពល១៦៤ បានចូលរួមប្រជុំ។ ស៖ នៅពេលដែល មាស មុត និយាយជាមួយតាញ៉ាន់ ថា"មុននឹងឯងសម្លាប់មនុស្ស ឯងត្រូវមានការអនុញ្ញាតពីមេរបស់ឯងជាមុនសិន" តើមេដែលគាត់និយាយនោះ គឺសំដៅទៅលើអ្នកណាដែរ? ឆ.121៖ តាញ៉ាន់ គឺជាមេបញ្ជាការវរសេនាធំ៦៣ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពល១៦៤ ដែលមាន មាស មុត ជាមេបញ្ជាការ។ ដូច្នេះក្នុងន័យនេះមានន័យថាគាត់ត្រូវមានការអនុញ្ញាតពីមាស មុត ជាមុនសិន។ ស៖ តើលោកដឹងថានៅក្នុងកាលៈទេសៈណាដែលប្រជាជនទាំងនោះត្រូវបានតាញ៉ាន់យកទៅសម្លាប់ដែរ? ឆ.122៖ ខ្ញុំមិនដឹងថាប្រជាជនទាំងនោះត្រូវបានតាញ៉ាន់សម្លាប់ក្នុងកាលៈទេសៈណានោះទេ។ ប៉ុន្តែខ្ញុំចាំបានថានៅក្នុងអង្គប្រជុំនោះ តាញ៉ាន់បានរាយការណ៍ប្រាប់ មាស មុត ថាគាត់បានសម្លាប់មនុស្ស"]។

3198 ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.4 ["ស៖ ក្រៅពី តាមុត តើមានអ្នកផ្សេងទៀតអាចចេញបញ្ជាឲ្យចាប់ ឬសម្លាប់ដែរឬទេ? ឆ.4៖ បើតាមុត អវត្តមានគឺមាន តាសេង ហើយបើតាសេង អវត្តមានទៀតគឺមានតាសាវឿន"]។ សូមមើលផងដែរទាក់ទងនឹងឈ្មោះអនុរបស់ មាស មុត ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក់ សុខ ឆ.1 [អនុរបស់ មាស មុត គឺ ហ៊ីង ឌឿន ហៅ ឌីម ទទួលខុសត្រូវសេដ្ឋកិច្ច ត្រូវបានជំនួសដោយ ញ៉ែត ញ៉ាន់ មេបញ្ជាការកងវរសេនាធំ៦៣ បន្ទាប់ពី ឌីម បាត់ខ្លួន សាវឿន ទទួលខុសត្រូវខាងយោធា ហើយនិង សេង។ ហើយ បូ ជាអនុមេបញ្ជាការ ទទួលខុសត្រូវកងវរសេនាធំ ១៤០"]។ ឯកសារ D54/78 កំណត់ហេតុស្តាប់ចម្លើយ ណុប ហា

*ខ) ការអះអាងរបស់ មាស មឿន ចំពោះបញ្ជាឲ្យសម្លាប់វៀតណាមទាំងអស់*

786. មាស មឿន មេបញ្ជាការរងកងពលលេខ ១ នៃភូមិភាគបស្ចិម[3199] បានផ្តល់សក្ខីកម្មដែលមានភាពស៊ីចង្វាក់យ៉ាងរឹងមាំជាមួយនឹងសក្ខីកម្មរបស់ ប៉ាក សុក និង ឯក នី ទាហានកងពល ១៦៤ ដែលថា កងពល ១៦៤ បានទទួលបញ្ជាឲ្យសម្លាប់ប្រជាជនវៀតណាមទាំងអស់។ ទោះបីជា មាស មឿន មិនស្ថិតនៅក្នុងកងពល ១៦៤ ប៉ុន្តែនៅកងពលលេខ ១ នៃភូមិភាគបស្ចិម[3200] ក៏ដោយ គាត់បានផ្តល់សក្ខីកម្មថា កងពលលេខ ១ និងកងពល ១៦៤ បានទទួលបញ្ជាដូចគ្នា[3201]។ ហេតុដូច្នេះ សក្ខីកម្មរបស់គាត់អំពីបញ្ជាដែលកងពលរបស់គាត់បានទទួល និងគោលនយោបាយនៅពីក្រោយបញ្ជានេះ មានភាពស៊ីចង្វាក់គ្នាជាមួយភ័ស្តុតាងផ្ទាល់អំពីបញ្ជា ដែលត្រូវបានទទួលក្នុងកងពល ១៦៤។

787. មាស មឿន បានផ្តល់សក្ខីកម្មយ៉ាងច្បាស់ថា មានគោលនយោបាយកម្ទេចប្រជាជនវៀតណាមនៅប្រទេសកម្ពុជា ចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដោយឆ្លើយថា៖

> មានៗឮរឿងវៀតណាមនៅក្នុងស្រុកខ្មែរហ្នឹង ពីព្រោះអីវៀតណាមដែលនៅក្នុងស្រុកខ្មែរហ្នឹងមិនមែននៅដើម្បីរកស៊ីទេ នៅដើម្បីបង្ករឿងហេតុឲ្យប្រជាជនកម្ពុជាលំបាកដែរ។ អ៊ីចឹងបានន័យថា ជាៗការងារដែលត្រូវកម្ទេចហ្នឹង ឲ្យប្រជាជនគេឲ្យទៅតាមសម្រួលហ្នឹង កាលមុនគេឲ្យទៅតាមសម្រួលដោយតាំងពីឆ្នាំ ៧០ នោះ។ រឿងៗវៀតណាម ថ្នាក់ដឹកនាំខ្មែរយើងឲ្យទៅតាំងពីឆ្នាំ ១៩៧០ រហូតមក ៧៥ ក៏ឲ្យទៅដែរ តែគេអត់ចង់ទៅ អាហ្នឹងគេមានទិសដៅ ឬផែនការ។ អ៊ីចឹងតាមអង្គភាពអ៊ីចឹង ឲ្យតែជនជាតិវៀតណាមត្រូវកម្ទេចអ៊ីចឹង។ អាហ្នឹងខ្ញុំឆ្លើយត្រង់អ៊ីចឹង។ អាហ្នឹងខ្ញុំឆ្លើយត្រង់

---

ល់ ឆ.19 [" ឌឹម គឺជាអនុ តាមុត មកពីភូមិភាគបូព៌ា"]។ ឯកសារ D59/1/1.9a កិច្ចសម្ភាសន៍រវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និង ឡាយ ប៊ុនហាក់ KH ERN 00926478 ["ប៊ុនហាក់៖ មានអនុកងពលមួយ [...] ទឹម សេង"]។

3199 ឯកសារ D234/2.1.95 មាស មឿន ប្រតិចារឹកថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 13:53:04-13:59:22 ["សៈ លោកបានក្លាយទៅជាអនុបញ្ជាកងពលលេខ១ [...] ឆៈ បាទ ត្រឹមត្រូវ"]។

3200 ឯកសារ D234/2.1.95 មាស មឿន ប្រតិចារឹកថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 13:53:04-13:59:22 ["សៈ លោកបានក្លាយទៅជាអនុបញ្ជាកងពលលេខ១ ហើយកងពលលេខ១នេះគឺចំណុះឲ្យភូមិភាគបស្ចិម ដែលគ្របដណ្តប់ឆ្នេរខេត្ត កោះកុងផង តើត្រឹមត្រូវដែរទេ? ឆៈ បាទ ត្រឹមត្រូវ"]។

3201 ឯកសារ D234/2.1.95 មាស មឿន ប្រតិចារឹក ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 14.02.05-14.04.46 ["សៈ គឺកងពល១៦៤ និងកងពលលេខ១ [...] ទទួលបញ្ជាពីថ្នាក់លើមកដូចៗគ្នាដែរទេ? ឆៈ បាទ មានដូចគ្នាដែរ"]។

អ៊ីចឹង។ បើកាលណា គេឲ្យទៅហើយ យើងមិនព្រមទៅ ហើយម្យ៉ាងបានកើតជាវៃគ្នាតាមព្រំដែន ដោយសារអី? ហ្នឹងខ្ញុំឮអ៊ីចឹង។ សូមអស់[3202]។

788. តបទៅនឹងសំណួរថា តើមានជនជាតិវៀតណាមច្រើនទេ ដែលមិនបានត្រឡប់ទៅវៀតណាម ហើយអ្នកណាខ្លះត្រូវបានកម្ទេច មាស មុត បានឆ្លើយថា៖

> មាន នៅមាននៅ មិនមែនទៅអស់ទេ។ កាលដែលគេឲ្យទៅ ទៅមិនអស់ ខ្លះក៏នៅនឹងទៅ ខ្លះក៏មានប្រពន្ធ មានកូននៅនឹងទៅ។ អាហ្នឹងក៏គេមិនថាអីដែរ ក៏ប៉ុន្តែការដែលគេឲ្យទៅស្រួល យើងមិនព្រមទៅ ប៉ុន្តែនៅភូមិភាគបស្ចិមមាននៅច្រើន ភាគច្រើនតាមមាត់ទន្លេនៅកំពង់ឆ្នាំង។ លោកឃើញស្រាប់ហើយរាល់ថ្ងៃ មានខ្មែរឯណានៅក្នុងទឹក។ អ៊ីចឹងបានន័យថាខ្មែរច្រើនតែមានការប្រទូសរ៉ាយគ្នារវាងជនជាតិវៀតណាមហ្នឹងហើយនិងខ្មែរនោះ វានៅបង្ករឿងហេតុ។ ហ្នឹងគឺក្នុងភូមិភាគបស្ចិមមាន[3203]។

789. មួយថ្ងៃបន្ទាប់ពីការផ្តល់សក្ខីកម្ម មាស មុត បានប៉ុនប៉ងដកខ្លួនពីសក្ខីកម្មរបស់គាត់ដ៏មិនគួរឲ្យជឿដោយអះអាងថា "តែដល់យួននៅក្នុងកម្ពុជានោះ ក៏ត្រូវមានការប្រមូល ប្រមូលហើយស្រាវជ្រាវថាតើយួនដែលនៅកម្ពុជាដែលយូរហើយនោះ នៅកន្លែងណាខ្លះ? ដើម្បីប្រមូលយកមកទុកមួយកន្លែងដើម្បីយើងគ្រប់គ្រង"[3204]។ ទោះជាយ៉ាងក៏ដោយ គាត់មិនអាចពន្យល់បានទេថា តើហេតុអ្វីបានជាគាត់ផ្តល់សក្ខីកម្មថាបានទទួលការណែនាំនេះមួយថ្ងៃមុន ប្រសិនបើគ្មានផែនការកម្ទេចវៀតណាមទាំងអស់នៅប្រទេសកម្ពុជានោះ។ ច្បាស់ណាស់ មាស មុត បានទទួលស្គាល់តែមួយរយៈពេលខ្លីប៉ុណ្ណោះ អំពីសារៈសំខាន់នៃសក្ខីកម្មរបស់គាត់ដែលថា គាត់ និងអតីតមិត្តរួមការងាររបស់គាត់នៅ ប.ក.ក ជាប់ពាក់ព័ន្ធក្នុងអំពើប្រល័យពូជសាសន៍ និងបានព្យាយាមផ្លាស់ប្តូរការទទួលស្គាល់នេះ ដោយពុំមានការពន្យល់ណាមួយគួរឲ្យជឿជាក់បានអំពីការកែប្រែចម្លើយរបស់គាត់ភ្លាមៗនេះទេ។

---

3202 ឯកសារ D234/2.1.95 មាស មុត ប្រតិចារឹក ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 15.55.51-15.58.51។

3203 ឯកសារ D234/2.1.95 មាស មុត ប្រតិចារឹក ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 15.58.51-16.03.07។

3204 ឯកសារ D234/2.1.96 មាស មុត ប្រតិចារឹក ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 09.13.46-09.18.29។ សូមមើលផងដែរ ឯកសារ D234/2.1.96 មាស មុត ប្រតិចារឹក ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 09.24.01-09.26.03 ["ឲ្យប្រមូលយកដើម្បីបញ្ជូនមកខាងថ្នាក់លើ។ អាហ្នឹងដែលពី៧៥ មក៧៩ហើយហ្នឹង"]។

790. ជាការគាំទ្របន្ថែមចំពោះការទទួលស្គាល់របស់ មាស មឿន អំពីគោលនយោបាយរបស់ ប.ក.ក ក្នុងការកម្ទេចប្រជាជនវៀតណាមទាំងអស់ គាត់បានទទួលស្គាល់ថាបានចូលរួមក្នុងសមាជភូមិភាគបស្ចិមមួយជាមួយមេដឹកនាំជាន់ខ្ពស់ ប.ក.ក នៅខែ កក្កដា ឆ្នាំ ១៩៧៧ នៅស្រុកច្បារមន ខេត្តកំពង់ស្ពឺ[3205]។ គោលបំណងនៃការប្រជុំនេះគឺដើម្បីពិភាក្សាអំពីការកម្ទេចខ្មាំង[3206] ដោយលើកឡើងអំពី "ឧបាយកលរបស់យួន"[3207]។ មាស មឿន បានផ្តល់សក្ខីកម្មថា "យួន" សំដៅទៅដល់ប្រជាជនវៀតណាម ដោយមិនគិតថា ពួកគេជាជនស៊ីវិល ឬទាហានឡើយ[3208]។ យោងតាមសាក្សី ប្រធានបទនៃការប្រជុំមានភាពច្បាស់លាស់ "គេរកតែខ្មាំងណាដែលបង្កប់នៅក្នុងជួរសហករណ៍ ឬក្នុងក្នុងជួរកងទ័ព"[3209]។

791. ទស្សនាវដ្តីទង់បដិវត្តន៍ចេញផ្សាយខែ សីហា ឆ្នាំ ១៩៧៧ ផ្តល់សេចក្តីលម្អិតបន្ថែមអំពីការប្រជុំភូមិភាគបស្ចិមនេះ ដែលស៊ីចង្វាក់គ្នាជាមួយនឹងសក្ខីកម្មរបស់ មាស មឿន។ យោងតាមព័ត៌មានដែលមាននៅក្នុងទង់បដិវត្តន៍ ការប្រជុំគូសបញ្ជាក់ថា "ត្រូវរៀបចំកម្លាំងទៅវៃ វៃកម្ទេចខ្មាំង"[3210] និង "បើបំផុស [ប្រជាជន] យ៉ាងនេះ ខ្មាំង [ខាងក្រៅ] ចូលមិនចុះទេ ខ្មាំងបង្កប់ផ្ទៃក្នុងធ្វើមិនបាន"[3211]។

---

[3205] ឯកសារ D234/2.1.95 មាស មឿន ប្រតិចារឹក ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 14.26.18-14.33.57 ["ខ្ញុំបានចូលរួមសន្និបាតភូមិភាគបស្ចិមនៅខេត្តកំពង់ស្ពឺ នៅចម្ការដូង ក្នុងស្រុកច្បារមន កាលពីឆ្នាំ១៩៧៧"]។

[3206] ឯកសារ D234/2.1.95 មាស មឿន ប្រតិចារឹក ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 14.26.18-14.33.57 ["នៅក្នុងមហាសន្និបាតនោះ ប្រធានបទនិយាយអំពីការរៀបចំទ័ពដើម្បីកម្ទេចខ្មាំង គឺសមាសភាពមិនល្អ ដែលបានបង្កប់ខាងក្នុង និងការគ្រប់គ្រងហសហករណ៍"]។ ឯកសារ D10.1.59 ទង់បដិវត្ត ខែ សីហា ឆ្នាំ ១៩៧៧ KH ERN 00062948 ["ការបន្តវាយបោសសំអាតខ្មាំងក្នុងជួរ ឲ្យអស់ថែមទៀត"]។

[3207] ឯកសារ D234/2.1.95 មាស មឿន ប្រតិចារឹក ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 14.33.57-14.40.00 ["ឯចំពោះខ្មាំងសត្រូវនោះ គេចង់និយាយអំពីខ្មាំងសត្រូវដែលបង្កប់នោះ គេចង់និយាយពីឧបាយកលរបស់យួន"]។

[3208] ឯកសារ D234/2.1.95 មាស មឿន ប្រតិចារឹក ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 15.55.51-15.58.51 ["ស៖ ដូច្នេះនៅសម័យនោះ បើតាមអ្វីលោកដឹងនោះ ពាក្យ "យួន" នេះ វាសំដៅទៅលើជនស៊ីវិល ឬក៏ជាទាហាន ឬក៏ឲ្យតែវៀតណាម ជនជាតិវៀតណាម គេហៅថា យួន តែម្តង? ឆ៖ តាមធម្មតា ជនជាតិខ្មែរ គេច្រើនតែហៅយួនអ៊ីចឹងតាំងគ្រប់គ្នា ខ្ញុំក៏ហៅតាមប្រជាជនខ្មែរអ៊ីចឹងដែរ ប្រជាជនកម្ពុជាអ៊ីចឹងដែរ"]។

[3209] ឯកសារ D234/2.1.95 មាស មឿន ប្រតិចារឹក ថ្ងៃទី ២ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 14.33.57-14.40.00 ["គេរកតែខ្មាំងណាដែលបង្កប់នៅក្នុងជួរសហករណ៍ ឬក៏ក្នុងជួរកងទ័ព ឬក្នុងជួរណាដែលជាឧបាយកលរបស់ខ្មាំង"]។

[3210] ឯកសារ D10.1.59 ទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៧ KH ERN 00062964 (សង្កត់ន័យបន្ថែម)។

[3211] ឯកសារ D10.1.59 ទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៧ KH ERN 00062978។

*គ) ការសម្លាប់ប្រជាជនវៀតណាមដោយបុគ្គលិកកងពល ១៦៤ - ជនរងគ្រោះដែលចាប់បាននៅសមុទ្រ*

792. ប្រជាជនវៀតណាមជាច្រើននាក់ដែលជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ ប្រព្រឹត្តដោយ **មាស មុត** និងអ្នកក្រោមបង្គាប់របស់គាត់នៅកងពល ១៦៤ គឺជាអ្នកដែលត្រូវបានចាប់នៅសមុទ្រ ហើយបន្ទាប់មក ត្រូវបានសម្លាប់នៅលើកប៉ាល់ ឬនៅលើកោះមួយដែលស្ថិតក្រោមទំនួលខុសត្រូវរបស់កងពល ១៦៤ ឬនៅកំពង់សោម ឬនៅ ស-២១។ ទោះបីជាជនរងគ្រោះនៃការសម្លាប់ក្រៅផ្លូវតុលាការប្រព្រឹត្តិដោយកងពល ១៦៤ មិនមែនសុទ្ធតែជាវៀតណាមក៏ពិតមែន ប៉ុន្តែ ពួកគេរាប់រយ ឬរាប់ពាន់នាក់ជាជនជាតិវៀតណាម។ ភ័ស្តុតាងបង្ហាញថា ការប្រព្រឹត្តិទៅលើជនជាតិវៀតណាម មានសភាពឃោរឃៅខ្លាំងជាងការប្រព្រឹត្តិទៅលើជនជាតិថៃ ដែលត្រូវបានចាប់ខ្លួនក្នុងដែនទឹកកម្ពុជា និងពេលខ្លះត្រូវបានដោះលែង ដោយដោះដូរជាមួយអាហារ ឬសម្ភារៈផ្សេងទៀត។ ការប្រព្រឹត្តិខុសគ្នាទៅលើជនជាតិថៃ និងវៀតណាម ដែលត្រូវបានចាប់ខ្លួនក្នុងកាលៈទេសៈស្រដៀងគ្នា បង្ហាញអំពីគោលនយោបាយសម្លាប់អ្នកដែលគេចាប់បាន តែដោយសារពួកគេជាវៀតណាមប៉ុណ្ណោះ។

793. សក្ខីកម្មរបស់ ប៉ាក សុខ ទាហានកងពល ១៦៤ ផ្តល់ការចង្អុលបង្ហាញអំពីវិសាភាពនៃការសម្លាប់មនុស្សដែលត្រូវបានចាប់នៅក្នុងដែនទឹក ដែលត្រូវបានអះអាងកាន់កាប់ដោយអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ។ ពេលសួរថាតើមានជនស៊ីវិល ជនភៀសខ្លួន និងអ្នកនេសាទដែលត្រូវបានចាប់នៅក្នុងដែនទឹកកម្ពុជា ប៉ុន្មាននាក់ ត្រូវបានសម្លាប់នៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ គាត់បានឆ្លើយថា "មានចំនួនរាប់ពាន់នាក់ អ្នកទាំងនោះរួមមានពួកនេសាទថៃ និងពួកនេសាទ និងជនភៀសខ្លួនវៀតណាមដែលត្រូវបានចាប់ និងសម្លាប់ចោលនៅក្នុងសមុទ្រ នៅលើកោះ និងនៅលើដីគោក"[3212]។ ស្រដៀងគ្នានេះដែរ ពេល ឯក នី ទាហានកងពល ១៦៤ ត្រូវបានស្នើឱ្យប៉ាន់ស្មានថាមានប្រជាជនប៉ុន្មាននាក់ត្រូវបានសម្លាប់ចោលនៅសមុទ្រដោយកងទ័ពជើងទឹក ក្នុងសម័យកម្ពុជា

---

[3212] ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.11។ សូមមើលផងដែរ ឯកសារ D54/24.1 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលកម្ពុជាជាមួយ ប៉ាក សុខ EN ERN 00978576, KH ERN 00955507 ["ស៖ ចឹងបើចាប់បានពួកយួននោះ? ឆ៖ បើពួកយួនចាប់បានគេយកមកសម្លាប់ចោល [...] ជួនកាលគេសម្លាប់នៅលើកោះហ្នឹងទៅ [...] ច្រើនតែប្រជាជនដែលរត់ភៀសខ្លួនទៅប្រទេសទីបី ភាគច្រើនពួកហ្នឹងរត់គេចពីសង្គ្រាមដល់រត់ឆ្លងមកយើងចាប់បានបាញ់សម្លាប់ចោលទៅ"]។

ប្រជាធិបតេយ្យ គាត់ឆ្លើយថា "បើខ្ញុំយល់ ប្រហែលខ្ទង់មួយពាន់ជាង។ [...] បើយ៉ាងតិច ក៏មិនក្រោម ១២០០ ទៅ ១៣០០ នាក់ដែរ"[3213]។

794. ចំនួនជនរងគ្រោះវៀតណាមមិនត្រូវបានដឹងឲ្យពិតប្រាដកនោះទេ ប៉ុន្តែ ភ័ស្តុតាងបង្ហាញថា ការប៉ាន់ស្មានទាំងនេះសមហេតុផល។ នៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៨ **មាស មុត** បានរាយការណ៍ទៅ ប៉ុល ពត, នួន ជា និងអ្នកផ្សេងទៀតថា "សរុបយួនដែលចាប់បាន និងបាញ់ងាប់ចាប់ពីថ្ងៃទី ២៧-៣-៧៨ មកដល់ថ្ងៃទី ៣០-៣-៧៨ មានចំនួន ១២០ ក្បាល"[3214]។ ជនរងគ្រោះទាំងនេះមកពីទូកសរុបចំនួនប្រាំ ដែលត្រូវបានចាប់ក្នុងអំឡុងពេលនោះ[3215]។ ការដែលវៀតណាម ១២០ នាក់ត្រូវបានសម្លាប់តែក្នុងរយៈពេលបួនថ្ងៃ គឺគាំទ្រដល់ការប៉ាន់ស្មានរបស់ ប៉ាក សុខ និង ឯក នី អំពីចំនួនជនរងគ្រោះសរុប។

---

3213 ឯកសារ D114/282 កំណត់ហេតុស្តាប់ចម្លើយ ឯក នី ឆ.58-61។ សូមមើលផងដែរ ឯកសារ D114/126 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ គីម ឆ.43, 46 ["សៈ ក្នុងកិច្ចសម្ភាសន៍របស់លោកជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័រទី២៧ លោកនិយាយថាមនុស្ស ៣០០ ទៅ៤០០ នាក់ត្រូវបានចាប់បាន ហើយសម្លាប់នៅកោះ។ ហេតុអ្វីបានជាលោកនិយាយបែបនេះ? ឆ.43៖ តួលេខនេះគ្រាន់តែជាការប៉ាន់ស្មានរបស់ខ្ញុំ តាមអ្វីដែលខ្ញុំសង្កេតឃើញប៉ុណ្ណោះ។ ចំនួន៣០០ ទៅ៤០០នាក់នេះ អាចជាចំនួនតិចបំផុតដែលខ្ញុំគិតថា ត្រូវបានសម្លាប់នៅលើកោះនេះ។ ពេលខ្លះមួយទូកមាន៥០នាក់ ហើយខ្លះទៀតមួយទូកមាន៧០នាក់ ពេលដែលគេចាប់បាន គឺមកបញ្ចប់នៅលើកោះទាំងអស់ ហើយទូកថៃបែបនេះច្រើនណាស់ត្រូវបានចាប់នៅពេលនេះ [...] ឆ.46៖ យ៉ាងណាមិញ ខ្ញុំមិនដឹងថាអ្នកទាំងនោះជាថៃ ឬវៀតណាមនោះទេ។ តាមពិតទៅ ខ្ញុំមិនដែលបាននៅជិតទូកទាំងនោះទេ។ តួលេខ១០០០នេះ ជាចំនួនសរុបទាំងជនជាតិទាំងពីរ ថៃ និងវៀតណាម"]។

3214 ឯកសារ D1.3.30.25 ទូរលេខសំងាត់ពី មុត ចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨ EN ERN 00183357, KH ERN 00017026។ កត់សម្គាល់៖ ឯកសារនេះបកប្រែជាភាសាអង់គ្លេសពីរច្បាប់។ ឯកសារមួយ មានលេខ EN ERN 00143507 ជាឯកសារបកប្រែទាំងមូល ចំណែកឯកសារមួយទៀត មានលេខ EN ERN 00183357 គឺជាឯកសារបកប្រែដោយផ្នែក។ ឯកសារទាំងពីរនេះខុសគ្នាត្រង់ចំនួនជនរងគ្រោះដែលបានរាយការណ៍មក (ជនរងគ្រោះមាន១០២ នាក់ នៅទំព័រ EN ERN 00143507 ជាមួយនឹង ជនរងគ្រោះ១២០នាក់ នៅទំព័រ EN ERN 00183357) ហើយភាសាដែលប្រើប្រាស់ដើម្បីពិពណ៌នាអំពីការសម្លាប់ជនជាតិវៀតណាម ("បានចាប់ខ្លួន និងដុតសម្លាប់" នៅទំព័រ EN ERN 00143507 ជាមួយនឹង "ចាប់បាន និងបាញ់សម្លាប់" នៅទំព័រ EN ERN 00183357)។ ច្បាប់ដើមជាភាសាខ្មែរ នៅទំព័រ ERN 00017026 បង្ហាញថា មានជនរងគ្រោះ១២០ នាក់ និងបញ្ជាក់យ៉ាងច្បាស់ថា ជនរងគ្រោះទាំងនោះត្រូវបានសម្លាប់ដោយប្រើកាំភ្លើង។

3215 ឯកសារ D1.3.30.25 ទូរលេខសំងាត់ពី មុត ចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨ KH ERN 00017026 ["ទូក ១០សេសដល់៣៧សេស ចំនួន៥គ្រឿង"]។

795. ការប៉ាន់ស្មានទាំងនេះត្រូវបានគាំទ្របន្ថែម ដោយការដែលថាទូករបស់ជនភៀសខ្លួនវៀតណាមឆ្ពោះទៅប្រទេសថៃ[3216] ឬកន្លែងណាផ្សេងទៀត[3217] ដឹកមនុស្សជាមធ្យម ៣០ នាក់[3218] ហើយទូកខ្លះដឹកជនភៀសខ្លួនរហូតដល់ ៥០ ទៅ ៧០ នាក់[3219]។ ការប៉ាន់ស្មានចំនួនទូករបស់វៀតណាមដែលគាត់បានឃើញគេចាប់ ឯក នី ទាហានកងពល ១៦៤ បាននិយាយថា "វៀតណាមហ្នឹង មួយខែ ៣-៤ ទូក ជួនកាល ៣-៤ ថ្ងៃ ៣-៤ ទូក វាមិនទៀត"[3220]។ ទោះយកតែចំនួនប៉ាន់ស្មានតិចពីបីទៅបួនទូកក្នុងមួយខែ និងដោយចងចាំថា ឯក នី រាយការណ៍តែអំពីហេតុការណ៍ដែលគាត់បានឃើញដោយផ្ទាល់ភ្នែកប៉ុណ្ណោះនោះ ច្បាស់ណាស់ថា ចំនួនប្រជាជនវៀតណាមដែលត្រូវបានចាប់ខ្លួន និងសម្លាប់ដោយទាហានកងពល ១៦៤ មានច្រើនសន្ធឹកសន្ធាប់។

796. ភ័ស្តុតាងបង្ហាញថា ការប្រព្រឹត្តិទៅលើជនជាតិវៀតណាមដែលត្រូវបានចាប់នៅសមុទ្រ គឺមិនរើសមុខ ដោយមិនគិតពីឋានៈរបស់ពួកគេ ហើយមនុស្សទាំងអស់ មិនថាជាយោធា ឬជនស៊ីវិល ធម្មតា ក្មេង ចាស់ ប្រុស ឬស្រី ត្រូវបានបាញ់សម្លាប់ភ្លាមៗ ឬបញ្ជូនទៅដីគោកដើម្បីសម្លាប់ចោល

---

3216 ឯកសារ D54/23 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.31, 37-38 ["ស៖ តាមយោបល់ និងគំនិតរបស់លោក ថាតើវាខុស ឬត្រូវចំពោះការសម្លាប់អ្នកដែលចាប់បាន? ឆ.31៖ ខ្ញុំគិតថា វាខុសទាំងស្រុង ពីព្រោះប្រជាជនទាំងអស់នោះមិនដឹងអ្វីទាំងអស់ ពួកគេគឺគ្រាន់តែរស់គេចពីសង្គ្រាម [...] ឆ.37៖ ពួកយួនទាំងនោះ គឺជាអ្នកភៀសខ្លួន ធ្វើដំណើរទៅកាន់ប្រទេសថៃ ហើយគេបានធ្វើដំណើរឆ្លងកាត់តាមដែនទឹករបស់យើងនៅចន្លោះកោះតាង និងកោះពូលូវៃ [...] ឆ.38៖ ពួកទាំងនោះពុំមានកាំភ្លើង និងមិនមានបំណងចង់តដៃនោះទេ"]។

3217 ឯកសារ D114/126 កំណត់ហេតុស្ដាប់ចម្លើយ អ៊ូ គីម ឆ.38-40 ["ស៖ ជាមធ្យម តើមានមនុស្សប៉ុន្មាននាក់នៅលើទូកជនភៀសខ្លួនវៀតណាមមួយៗ? ឆ.38៖ ជាមធ្យម៣០នាក់ ហើយមានស្រីមានប្រុស។ ស៖ ហេតុអ្វីបានជាលោកនិយាយថា អ្នកទាំងនោះជាជនភៀសខ្លួនវៀតណាម? ឆ.39៖ អ្នកខ្លះចេះនិយាយខ្មែរហើយប្រាប់ពួកខ្ញុំថា ពួកគេព្យាយាមធ្វើដំណើរទៅរកប្រទេសថ្មី ដូចជាហ្វីលីពីន សាំងហ្គាពួរ និងតៃវ៉ាន់ជាដើម។ ស៖ តើលោកបានឮពាក្យសម្ដីនេះដោយខ្លួនលោកផ្ទាល់មែនទេ? ឆ.40៖ អត់ទេ ខ្ញុំឮពីពួកទាហានដែលយាមល្បាតនៅតាមឆ្នេរ"]។

3218 ឯកសារ D114/126 កំណត់ហេតុស្ដាប់ចម្លើយ អ៊ូ គីម ឆ.38 ["ស៖ ជាមធ្យម តើមានមនុស្សប៉ុន្មាននាក់នៅលើទូកជនភៀសខ្លួនវៀតណាមមួយៗ? ឆ.38៖ ជាមធ្យម៣០នាក់ ហើយមានស្រីមានប្រុស"]។

3219 ឯកសារ D114/127 កំណត់ហេតុស្ដាប់ចម្លើយ អ៊ូ គីម ឆ.3 ["ខ្ញុំបានប្រាប់លោកពីចំនួនមនុស្សតិចបំផុតនៅលើទូក ប៉ុន្តែតាមពិតជួនកាលមានមនុស្ស៥០នាក់ និងជួនកាលមាន៧០នាក់ឯណោះនៅលើទូកមួយ"]។ ឯកសារ D114/126 កំណត់ហេតុស្ដាប់ចម្លើយ អ៊ូ គីម ឆ.34 ["ស៖ ជាមធ្យម តើមានអ្នកនេសាទប៉ុន្មាននាក់ [...] នៅលើទូកវៀតណាម? ឆ.34៖ [...] រីឯទូកវៀតណាមគឺជាទូកដឹកទំនិញតូចៗ តែផ្ទុកមនុស្សច្រើន ពួកគេគឺជាជនភៀសខ្លួនពីវៀតណាម"]។

3220 ឯកសារ D114/283 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.3។

នាពេលក្រោយ[3221]។ និយាយជារួម ពេលទាហានកងពល ១៦៤ ចាប់បានប្រជាជនវៀតណាមតិចជាង ២០ នាក់ ពួកគេត្រូវបានបញ្ជាឱ្យសម្លាប់អ្នកទាំងនោះនៅនឹងកន្លែង តែប្រសិនបើចាប់បានច្រើនជាង ២០ នាក់ អ្នកទាំងនោះនឹងត្រូវបញ្ជូនទៅអូរឈើទាល និងសម្លាប់នាពេលក្រោយ[3222]។ ប្រសិនបើចាប់បានទាហានវៀតណាម ទាហានទាំងនោះតែងតែត្រូវបានបញ្ជូនទៅឆ្នេរ ដើម្បីកត់ត្រាចម្លើយសារភាព មុននឹងសម្លាប់ពួកគេ[3223]។ ពេលសម្លាប់រួច របាយការណ៍ត្រូវបានបញ្ជូនត្រ

---

[3221] ឯកសារ D234/2.1.93 ព្រុំ សារ៉ាត ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 10.12.16-10.14.00 ["ឬកាណូតរបស់វៀតណាមចូលមកដល់ដែនទឹក ខាងដែនកោះគឺសម្រេចចាប់បានយ៉ាងម៉េច ហើយធ្វើការងារបញ្ជូនមកយ៉ាងម៉េចនេះជាពាក្យខ្ញុំនិយាយ"]។ ឯកសារ D114/297.1.21 ប្រាក់ សុខ ប្រតិចារឹក ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 14.29.11-14.31.58 ["ក្នុងនោះ ខ្ញុំមិនដែលទេ អត់ដែលឮទេ អត់ដែលឮថាមិនឱ្យចាប់ ដែលតែឮឱ្យចាប់តែម្តងបាទអត់។ [ជនភៀសខ្លួនជនជាតិវៀតណាម]"]។ ឯកសារ D234/2.1.92 ព្រុំ សារ៉ាត ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 15.49.12-15.52.35 ["ចាប់បានកងទ័ពវៀតណាម ឬក៏ទូកវៀតណាមដែលចូលមកដល់ទឹកដីកម្ពុជា"]។ ឯកសារ D234/2.1.92 ព្រុំ សារ៉ាត ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 10.54.04-10.57.27 ["គេជាជនជាតិវៀតណាមឆ្លងកាត់ តំបន់ដែនទឹកនៅកោះអាគ្នេយ៍ខាងកើតកោះតាង។ ហើយពួកគេបានចាប់គេ"]។ ឯកសារ D234/2.1.93 ព្រុំ សារ៉ាត ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 10.45.36-10.51.13 ["កងពលប្រាប់ចេញឱ្យថាពាក្យថាបទបញ្ជាឱ្យនាវាទាំងអស់ត្រូវមានការប្រុងប្រយ័ត្ន ហើយទទួលដឹងឮថាថ្ងៃនេះគេមានចាប់នៅកន្លែងនេះ [...] រឿងហ្នឹងវាទាក់ទងនឹងកិច្ចការរបស់ដែនកោះ"]។

[3222] ឯកសារ D114/297.1.21 ប្រាក់ សុខ ប្រតិចារឹក ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 14.00.39-14.02.38 ["បើចាប់បានពេញ គឺម្នាក់ ពីរនាក់ គឺសម្លាប់ សម្លាប់ចោលនៅលើកោះ និងនៅលើទឹកហើយ"]។ ឯកសារ D114/297.1.21 ប្រាក់ សុខ ប្រតិចារឹក ថ្ងៃទី ៥ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 14.02.38-14.04.37 ["បើគ្នាតិច អាហ្នឹងយើងសម្លាប់ចោល កាលណាបើដឹកទៅវិញ វាខាត បាទ វាខាតនៅក្នុងពេលនោះ [...] អាហ្នឹងសម្លាប់នៅលើកោះ នឹងលើទឹកហ្នឹង ហើយ មិនចាច់យកទៅឱ្យខាតអីទេ--"]។ ឯកសារ D114/297.1.20 ប្រាក់ សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 11.03.07-11.05.06 ["ហើយជនជាតិវៀតណាម ដែលជាច្រើនលើកច្រើនសា ដែលគេខ្លះក៏គេបញ្ជូនមក ពេលច្រើនគេបញ្ជូនទៅដីគោក តែបើម្នាក់ពីរនាក់ ទៅបីនាក់ គឺអត់ទេ អត់បញ្ជូនទៅលើដីគោកទេ គេសម្លាប់នៅលើកោះក៏មាន"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.25 ["ជាទូទៅ កាលណាចាប់បានតិចជាង២០នាក់ គឺបញ្ជាឱ្យសម្លាប់នៅនឹងកន្លែង បើចាប់បានច្រើនជាង២០នាក់ ត្រូវបញ្ជូនទៅអូរឈើទាល។ តាមខ្ញុំដឹង អ្នកដែលបញ្ជូនមកដីគោកទាំងនោះ ក្រោយមកត្រូវគេសម្លាប់ចោលដែរ"]។

[3223] ឯកសារ D114/297.1.20 ប្រាក់ សុខ ប្រតិចារឹក ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ ម៉ោង 13.51.59-13.53.59 ["ភាគច្រើនតែវៀតណាមរត់ទៅប្រទេសទី៣ អ៊ីចឹងទៅអ៊ីចឹងគេចាប់ដែលបានច្រើនអ៊ីចឹងកទៅសួរចម្លើយ អំពីព្រឹត្តិការណ៍ដែលនៅក្នុងប្រទេសកម្ពុជាហើយនិងប្រទេសវៀតណាមហ្នឹង តើមានចម្លើយយ៉ាងម៉េច"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.29 ["ប្រសិនបើអ្នកដែលត្រូវបានចាប់ខ្លួននោះជាទាហានវៀតណាម យើងត្រូវតែបញ្ជូនពួក

ឡប់ទៅទីបញ្ជាការកងពលតាមវិទ្យុ ដោយប្រើឃ្លាឃ្លោងច្បាស់ៗ ដូចជា "គេធ្វើហើយៗ" ឬ "គេបង្ហើយអ្នកទាំងនោះអស់ហើយ"[3224]។

797. សាក្សី និងឯកសារជាច្រើនពិភាក្សាអំពីឧទាហរណ៍ជាក់លាក់នៃការចាប់ខ្លួន និងសម្លាប់វៀតណាម ដែលត្រូវបានចាប់នៅសមុទ្រ នៅលើកោះ ឬនៅក្នុងតំបន់កំពង់សោម ជាពិសេស នៅទីតាំងសម្លាប់ចម្ការទុរេន ១ និងទឹកសាប[3225] ព្រមទាំងស្ថានការណ៍យ៉ាងហោចណាស់មួយដែលជនរងគ្រោះត្រូវ

---

នោះទីដីគោក បន្ទាប់មកគេនឹងធ្វើការចាក់ផ្សាយចម្លើយសារភាពរបស់ទាហានវៀតណាមនៅក្នុងវិទ្យុជាតិមុនពេលគេសម្លាប់"]។

3224 ឯកសារ D114/40 កំណត់ហេតុស្តាប់ចម្លើយ មូល ឈិន ឆ.81-82 ["សៈ ដូច្នេះអ្វីដែលលោកកំពុងប្រាប់យើងទាក់ទងនឹងការប្រាស្រ័យទាក់ទងគ្នា គឺដូចគ្នាទាំងស្រុងនឹងអ្វីដែលលោកបានឮនៅតាមវិទ្យុទាក់ទងដែរ មែនទេ? ឆ.81៖ ត្រឹមត្រូវហើយ ហើយតាមខ្ញុំយល់រាល់ពេលដែលគេចាប់បានទូក គឺទីបញ្ជាពាក់ព័ន្ធទាំងនោះនៅថ្នាក់កងវរៈសេនាតូចក្តី កងវរៈសេនាធំក្តី គឺគេរាយការណ៍ទៅឱ្យកងពលនៅកំពង់សោម។ សៈ តើលោកនៅចាំថា គេប្រើពាក្យពេជន៍អ្វី អំពីការទំនាក់ទំនងគ្នា ពាក់ព័ន្ធនឹងការងារនេះ? ឆ.82៖ គេប្រើពាក្យ គេធ្វើហើយៗ ឬក៏គេបង្ហើយអ្នកទាំងនោះអស់ហើយ"]។

3225 ឯកសារ D114/57 កំណត់ហេតុស្តាប់ចម្លើយ សំ សោម ឆ.11, 14, 20-21, 26-27 ["សៈ តើលោកអាចពន្យល់ប្រាប់យើងខ្ញុំអំពីអ្វីដែលលោកបានឃើញដែរឬទេ? ឆ.11៖ យប់មួយនោះ នៅពេលដែលខ្ញុំនៅលើកោះតាង ខ្ញុំបានឃើញទូកមួយត្រូវបាននាវាកងទ័ពជើងទឹករបស់កម្ពុជាប្រជាធិបតេយ្យចាប់យកមក ដែលមានជនជាតិវៀតណាមនៅលើទូកនោះ [...] សៈ តើអ្នកណាជាអ្នកចាប់ទូកនោះ? ឆ.14៖ ជានាវារបស់កងទ័ពជើងទឹក។ [...] សៈ ហេតុអ្វីបានជាលោកនិយាយថាទូកនោះមិនមែនជាទូកនេសាទ? ឆ.20៖ ដោយសារតែទូកនោះអាចដាក់មនុស្សបានច្រើន។ បើតាមការសន្មតរបស់ខ្ញុំ វាគឺជាទូកដែលគេប្រើសម្រាប់ដឹកជនចំណាកស្រុក ឬក៏ជនភៀសខ្លួនវៀតណាម។ សៈ តើអ្នកដែលត្រូវបានគេចាប់នោះមានភេទអ្វីខ្លះ? ឆ.21៖ ពួកគេមានប្រុស មានស្រី និងកូនក្មេង។ [...] សៈ តើលោកឃើញទូក ឬក៏មនុស្សទាំងនោះនៅព្រឹកថ្ងៃបន្ទាប់ដែរឬទេ? ឆ.26៖ នៅថ្ងៃបន្ទាប់នោះ ខ្ញុំមិនបានត្រឡប់មកកន្លែងនេះវិញឡើយ តែក្រោយមក ខ្ញុំបានឮពីយោធាដែលធ្វើការជាមួយគ្នាថា អ្នកទាំងនោះត្រូវបានគេសម្លាប់អស់ហើយ។ សៈ តើអ្នកដែលជាយោធាជាមួយលោកដឹងរឿងនេះដោយរបៀបណា? ឆ.27៖ ខ្ញុំមិនច្បាស់ទេ គេបានប្រាប់រឿងនេះតគ្នា។ បើតាមការសន្មតរបស់ខ្ញុំ អាចមានលទ្ធភាពចំនួនពីរកើតឡើង។ ទី១ អ្នកទាំងនោះត្រូវបានគេយកទៅសម្លាប់នៅលើកោះនោះតែម្តង ឬពួកគេត្រូវបានគេយកទៅទុកនៅលើកោះនោះ២-៣ថ្ងៃសិន រួចយកមកដីគោកវិញ"]។ ឯកសារ D54/25 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.20 ["ខ្ញុំបានឃើញព្រឹត្តិការណ៍ដំបូងគឺជាការចាប់បាន និងសម្លាប់ប្តីប្រពន្ធវៀតណាម និងកូនម្នាក់អាយុប្រហែល១ឆ្នាំ នៅកោះពូល្វៃចាស់ កាលពីចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ [...] គេកាប់សពប្តីប្រពន្ធនោះជាពីរកំណាត់ដោយចបកាប់ ហើយមួយកំណាត់ៗត្រូវបានកប់នៅក្រោមគល់ដូងមួយៗដើម្បីធ្វើជី"]។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.25, ឆ.35 ["ពួក [វៀតណាម] ដែលចាប់បាន ហើយបញ្ជូនទៅកំពង់សោម ត្រូវគេសម្លាប់ ហើយកប់ចោលនៅក្រោមដើមធូរ៉េន ដើមដូង [...] សៈ ហេតុអ្វីបានលោកដឹងថាអ្នកដែល

គេចាប់បាន ហើយបញ្ជូនទៅកំពង់សោមត្រូវគេសម្លាប់ ហើយកប់នៅក្រោមដើមធូរ៉េន និងដើមដូង? ឆ.35៖ ខ្ញុំឮតាមរយៈយោធាដែលធ្វើការនៅកំពង់សោម។ យោធាដែលធ្វើការនៅនឹងកំពង់សោមគឺជាយោធារបស់កងពល១៦៤។ អ្នកដែលគេចាប់បាន ពេលដែលនាំមកដល់ផែអូរឈើទាលនៅកំពង់សោម ត្រូវបានគេនាំចេញពីកប៉ាល់ ហើយដាក់ក្នុងឡានដឹកចេញទៅភ្នាមៗ”]។ ឯកសារ D54/26 កំណត់ហេតុស្ដាប់ចម្លើយ ប៉ាក សុខ ឆ.11-13, 16 [“ស៖ តើលោកធ្លាប់បានឮកន្លែងចម្ការធូរ៉េន នៅរាម ដែលនៅជិតកន្លែងចម្ការដូងដែរឬទេ? ឆ.11៖ បាទ ខ្ញុំធ្លាប់ស្គាល់ទីកន្លែងទាំងនោះ។ កន្លែងទាំងនោះជាកន្លែងដែលឃ្លួនជាច្រើនត្រូវបានសម្លាប់ [...] ឆ.12៖ តាមខ្ញុំដឹង គឺមានឃ្លួនរាប់រយនាក់ ដែលត្រូវបានគេសម្លាប់នៅទីនេះ។ ស៖ តើយោធានៅក្នុងកងណាដែលបោះទីតាំងនៅកន្លែងទាំងនោះ? ឆ.13៖ មានមួយកងវរសេនាតូចដែលមានយោធាប្រហែល១៥០នាក់ របស់កងវរសេនាធំលេខ៦២ ដែលបោះទីតាំងនៅកន្លែងនោះ។ តួនាទីរបស់យោធាទាំងនោះគឺសម្រាប់ទទួលឃ្លួនដែលចាប់បានយកទៅសម្លាប់នៅចម្ការធូរ៉េន និងចម្ការដូង។ ចម្ការធូរ៉េន ចម្ការដូង និងចម្ការក្រូច គឺនៅជិតគ្នា។ [...] ស៖ តើលោកដឹងគេយកឃ្លួនមកសម្លាប់នៅទីនោះ ដោយរបៀបណា? ឆ. 16៖ ខ្ញុំដឹងតាមរយៈយោធាដែលធ្វើការនៅទីនោះ គេប្រាប់យើងថា គេបានសម្លាប់ពួកឃ្លួនជាច្រើននៅទីនោះ ហើយកប់សាកសពនៅក្រោមដើមធូរ៉េន ដើម្បីធ្វើជី”]។ ឯកសារ D54/123 កំណត់ហេតុស្ដាប់ចម្លើយ ឡាក់ សាផាន ឆ.8 [“តាមការសង្កេតរបស់ខ្ញុំ អ្នកដែលចាប់បានមកពីសមុទ្រ មានខ្មែរ ថៃ និងវៀតណាម ហើយត្រូវបានគេនាំទៅទឹកសាប ហើយក៏បង្ហើយនៅទីនោះទាំងអស់ ពុំមានអ្នកណាមួយវិលត្រឡប់មកវិញទេ”]។ ឯកសារ D114/283 កំណត់ហេតុស្ដាប់ចម្លើយ ឯក នី ឆ.22, 29 [“រាប់រយ [ដើមដូង] នៅលើកោះតាងហ្គឹង ដើមដូងឈានជិតចូលដល់ ៥០០ដើម បើក្នុងមួយដើម គេដាក់មួយឬពីរនាក់ក្នុងមួយរណ្ដៅបើគេចាប់បានច្រើននាក់ តែបើមិននេះទេ គេកាត់មនុស្សជាពីរ មួយកំណាត់ៗដាក់ក្នុងមួយរណ្ដៅ [...] ឆ.29៖អំឡុងពេលនោះ ពេលដែលពួកយោធាចាប់ជនភៀសខ្លួនវៀតណាមដែលធ្វើដំណើរតាមទូក ដើម្បីទៅសុំសិទ្ធិជ្រកកោនក្នុងប្រទេសទី៣ ពួកយោធា ក៏យកជនភៀសខ្លួនវៀតណាមទាំងនោះ ទៅសម្លាប់ចោលក្នុងចំការធូរ៉េនផងដែរ។ ខ្មែរក្រហមបានហៅជនភៀសខ្លួនវៀតណាមទាំងនោះ ថាជាកូនជ្រូក។ ខ្មែរក្រហមនិយាយថែមទៀតថា ពួកគេយកជនភៀសទាំងនោះទៅធ្វើជាជីរដាក់ដើមធូរ៉េន”]។ ឯកសារ D114/262 កំណត់ហេតុស្ដាប់ចម្លើយ ជុំ ជី ឆ.46-47, 52-53 [“ស៖ [...] តើកាលនោះ មានជនភៀសខ្លួន [ជនជាតិវៀតណាម] ប៉ុន្មាននាក់ដែរ? ឆ.46៖ ចំនួនមិនច្បាស់ទេ ប្រហែលជា៧,៨នាក់។ ស្រីប្រុស ក៏អត់បានយល់ដែរ។ ស៖ តាមការចងចាំរបស់លោក តើគេសរសេរត្រឹមត្រូវដែរឬទេ នៅក្នុងរបាយការណ៍នេះថា ជនភៀសខ្លួនទាំងនោះ ត្រូវបានគេដាក់ឲ្យនៅក្បែរផែថ្ម នៅខាងកើតកោះនោះ? ឆ.47៖ ត្រឹមត្រូវ [...] ស៖ តាមលោកដឹង តើមានរឿងអ្វីកើតឡើងទៅដល់ជនភៀសខ្លួនវៀតណាមដែលគេចាប់បានពេលនោះ? ឆ.52៖ ពេលដែលយើងដឹង ខ្ញុំដឹង គេបានសម្លាប់ទៅហើយ អត់ដឹងផែនការគេយកទៅសម្លាប់ជាមុនទេ។ ស៖ តើលោកដឹងថា គេសម្លាប់អ្នកទាំងនោះដោយមធ្យោបាយអ្វី និងនៅទីណាដែរឬទេ? ឆ.53៖ ដឹងចំណុចតែ មិនបានពិតប្រាកដទេ ព្រោះកាលហ្នឹងនៅវ័យក្មេង មិនបានចាប់អារម្មណ៍ពីការកាប់សម្លាប់របស់ថ្នាក់លើ។ គេធ្វើអ្វី គេមិនដែលប្រាប់យុទ្ធជនឲ្យបានដឹងច្បាស់ទេ។ គេសម្រេចតែខាងលើៗ យើងតទៅទៀត។ ពេលគេសម្លាប់ហើយ ទើបយើងដឹង សម្លាប់ដោយបាញ់កាំភ្លើង។ សពហ្នឹងតាមមើលនៅថ្ម នៅម្ដុំជិតផែថ្ម”]។ ឯកសារ D2/6 កំណត់ហេតុស្ដាប់ចម្លើយ ញូង ជ្រោង ឆ.40-43 [“ស៖ តើលោកអាចពន្យល់ប្រាប់យើងអំពីចម្ការធូរេនបានដែរឬទេ? ឆ.40៖[...] តាមខ្ញុំឮពីអ្នកផ្សេងនិយាយថា គេចាប់អ្នកដែលបានប្រព្រឹត្តខុស ហើយបញ្ជូនទៅកន្លែងនោះដើម្បីធ្វើជាជីរសម្រាប់ដើមធូរេន។ [...] ស៖ ពេលដែលលោកនិយាយថា គេយកទៅធ្វើជីរ តើ

បានសម្លាប់ តែពីរបីម៉ែត្រពីផ្ទះរបស់ **មាស មុត** នៅកំពង់សោម[3226]។ អ្នកផ្សេងទៀតត្រូវបានដឹកបញ្ជូនទៅ ស-២១ ដែលនៅទីនោះ ពួកគេត្រូវបានសម្លាប់ផងដែរ[3227]។ យ៉ាងហោចណាស់ អ្នក

---

មានន័យយ៉ាងម៉េច? ឆ.41៖ មានន័យថា យកទៅសម្លាប់ គឺសម្លាប់ដាក់គល់ធូរេន ដើម្បីធ្វើជី។ [...] ស៖ ចំពោះអ្នកនេសាទថៃ និងវៀតណាម ដែលគេចាប់បាន តើគេយកទៅសម្លាប់នៅកន្លែងនោះដែរឬយ៉ាងម៉េច? ឆ.42៖ បាទ, គេយកទៅកន្លែងនោះដែរ។ ឆ.43៖ គឺពួកខាងកងវរសេនាធំលេខ៦២ [កងទ័ព] ដែលពួកគេមានទីតាំងនៅរាម ហើយវរសេនាធំលេខ២២ មានទីតាំងនៅទឹកសាប។ ដូច្នេះពួកវរសេនាធំ៦២ ជាអ្នកយកមនុស្សមកពីរាម ទៅចម្ការធូរេន ដើម្បីសម្លាប់"]។ ឯកសារ D2/16 កំណត់ហេតុស្តាប់ចម្លើយ ទូច សឿលី ហៅ សឿ ទូច ឆ.32-33 ["ខ្ញុំបានឮថា ពួកថៃ និងវៀតណាមដែលគេចាប់បាន និងត្រូវបានយកទៅសម្លាប់នៅកន្លែងមួយហៅថាចំការធូរេន។ ស៖ តើលោកបានឮពីមាត់មួយទៅមាត់មួយក្នុងរឿងហ្នឹង គឺក្នុងចន្លោះរយៈកាលពីឆ្នាំ១៩៧៥ ទៅ១៩៧៩ ពីអ្នកដែលនៅជាមួយគ្នាក្នុងកងពល ១៦៤ ឬយ៉ាងណា? ឆ.33៖ ពេលខ្ញុំបានឮរឿងនេះ គឺក្រោយឆ្នាំ១៩៧៩ គឺនៅពេលយើងជួបគ្នានៅព្រំដែន នៅក្នុងចន្លោះឆ្នាំ១៩៨០ ទៅ ១៩៨១"]។ ឯកសារ D1.3.30.25 ទូរលេខសំងាត់ពី មុត ចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨ EN ERN 00183357, KH ERN 00017026។ កត់សម្គាល់៖ ឯកសារនេះបកប្រែជាភាសាអង់គ្លេសពីរច្បាប់។ ឯកសារមួយមានលេខ EN ERN 00143507 ជាឯកសារបកប្រែទាំងមូល ចំណែកឯកសារមួយទៀត មានលេខ EN ERN 00183357 គឺជាឯកសារបកប្រែដោយផ្នែក។ ឯកសារទាំងពីរនេះខុសគ្នាត្រង់ចំនួនជនរងគ្រោះដែលបានរាយការណ៍មក (ជនរងគ្រោះមាន១០២នាក់ នៅទំព័រ EN ERN 00143507 ជាមួយនឹង ជនរងគ្រោះ១២០នាក់ នៅទំព័រ EN ERN 00183357) ហើយភាសាដែលត្រូវបានប្រើប្រាស់ដើម្បីពិពណ៌នាអំពីការសម្លាប់ជនជាតិវៀតណាម ("បានចាប់ខ្លួន និងដុតសម្លាប់" នៅទំព័រ EN ERN 00143507 ជាមួយនឹង "ចាប់បាន និងបាញ់សម្លាប់" នៅទំព័រ EN ERN 00183357)។ ច្បាប់ដើមជាភាសាខ្មែរ នៅទំព័រ ERN 00017026 បង្ហាញថា មានជនរងគ្រោះ១២០នាក់ និងបញ្ជាក់យ៉ាងច្បាស់ថា ជនរងគ្រោះទាំងនោះត្រូវបានសម្លាប់ដោយប្រើកាំភ្លើង។ ឯកសារ D4.1.754 សារទូរលេខសហរដ្ឋអាមេរិក ពាក់ព័ន្ធនឹងឧប្បត្តិហេតុនាវាម៉ាយ៉ាហ្គេស និងការសង្កេតអំពីកោះតាង នៅខែធ្នូ ឆ្នាំ ១៩៧៥ KH ERN 00387429 ["ក្រោយពីប្រភពព័ត៌មានបានបោះទីតាំងនៅលើកោះពូឡូវ៉ៃថ្មី នៅក្នុងខែមេសា-ឧសភាព ឆ្នាំ១៩៧ អង្គភាពរបស់គាត់បានចាប់នាវាមួយគ្រឿងដែលបានដឹកជនភៀសខ្លួនវៀតណាមជាង ១០នាក់ រួមទាំងស្ត្រី និងកុមារ។ អង្គភាពរបស់ប្រភពព័ត៌មានបានផ្តល់ចំណីអាហារ និងយកជនជាតិវៀតណាមទាំងនោះទៅទុកនៅជិតផែថ្ម ភាគខាងកើតនៃកោះពូឡូវ៉ៃថ្មីអស់រយៈពេលពីរ ឬបីថ្ងៃ។ បន្ទាប់ពីពួកគេចចាប់បាននាវានោះមក មេបញ្ជាការកងអនុសេនាធំលេខ ៤០៨ បានទាក់ទងក្រុងកំពង់សោមដើម្បីសុំការណែនាំស្តីពីការចាត់ចែងជនភៀសខ្លួនទាំងនោះ។ មេបញ្ជាការថ្នាក់លើនៅក្រុងកំពង់សោមបានបញ្ជាឲ្យមេបញ្ជាការកងអនុសេនាធំនេះសម្លាប់ជនភៀសខ្លួនទាំងនោះចោល។ មេបញ្ជាការ និងអនុមេបញ្ជាការកងអនុសេនាធំបានអនុវត្តតាមបញ្ជានេះ"]។

3226 ឯកសារ D54/71 កំណត់ហេតុស្តាប់ចម្លើយ មុត ម៉ៅ ឆ.39, 53, 56, 60-61 ["នៅយប់មួយ ខ្ញុំបានឃើញគេយកស្រីយួនចាស់ម្នាក់ ហើយនិងក្មេងៗពីរបីនាក់ យកមកសម្លាប់នៅក្នុងបរិវេណមន្ទីរក្នុង។ ពួកក្មេងអស់ទាំងនោះស្រែកយំ [...] ស៖ តើផ្ទះដែលលោកស្រីស្នាក់នៅ ស្ថិតនៅចម្ងាយណាពីផ្ទះ មាស មុត ស្នាក់នៅ? ឆ.53៖ វាស្ថិតនៅឆ្ងាយពីគ្នាប្រហែល៥០-៦០ម៉ែត្រ។ [...] ស៖ តើលោកស្រីឃើញយួនដែលគេបណ្តើរនោះចំនួនប៉ុន្មាននាក់? ឆ.56៖ ខ្ញុំឃើញ

ដែលត្រូវបានបញ្ជូនទៅ ស-២១ មួយផ្នែក ត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខ ក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **មាស មុត** ដែលនៅទីនោះ អ្នកខ្លះត្រូវបានបង្ខំឲ្យធ្វើការ[3228]។ ការសម្លាប់ទាំងនេះត្រូវបានពិភាក្សាលម្អិតជាងនេះនៅក្នុងផ្នែកផ្សេងទៀតនៃដីកាសន្និដ្ឋាននេះ[3229]។

---

យោធាបណ្តើរពួកនោះម្តងមួយៗ។ ខ្ញុំបានឃើញទាំងអស់៣នាក់ មនុស្សចាស់ស្រីម្នាក់ និងក្មេងជំទង់២នាក់ អាយុប្រហែល១០ឆ្នាំជាង។ ស្ត្រីចាស់នោះត្រូវបានសម្លាប់នៅចម្ងាយប្រហែល៣០ម៉ែត្រពីផ្ទះរបស់ខ្ញុំ ហើយនិងក្មេងៗជំទង់២នាក់ទៀត ត្រូវបានសម្លាប់នៅចម្ងាយប្រហែល១០០ម៉ែត្រពីផ្ទះរបស់ខ្ញុំ។ [...] ឆ.60៖ រឿងនេះកើតឡើងនៅចុងឆ្នាំ១៩៧៨ គឺប្រហែល២-៣ខែ មុនវៀតណាមចូល [...] សៈ តើលោកស្រីដឹងថា ពួកយួនទាំងនោះ គេយកមកពីណា? ឆ.61៖ ទេ ខ្ញុំមិនដឹងទេ ប៉ុន្តែខ្ញុំបានឮតាមពួកនីរសារនិយាយគ្នានៅទីនោះ ពួកវៀតណាមទាំងនោះ គឺគេចាប់បានជាមួយទូករបស់ពួកគេមកពីសមុទ្រ”]។

3227 សូមមើល ឧទាហរណ៍ ឯកសារ D114/43 កំណត់ហេតុស្តាប់ចម្លើយ សួស ធី ឆ.13, 23 [“សៈ តើលោកអាចប្រាប់យើងបានទេ ថាតើវាមានលក្ខណៈដូចម្តេចនៅពេលដែលលោកទទួលអ្នកទោសជនជាតិវៀតណាមពីកំពង់សោម? ឆ.13៖ អ្នកទោសជនជាតិវៀតណាមរមែងតែងតែចាប់ខ្លួននៅក្នុងទូកជាគ្រួសារ។ អ្នកទាំងនេះត្រូវបាននាំមកឲ្យខ្ញុំជាគ្រួសារ ដែលមានន័យថាក្នុងនោះរួមមានមនុស្សស្រីប្រុសក្មេងចាស់ រួមទាំងកុមារផងដែរ។ [...] ឆ.23៖ ហ៊ី ជាអ្នកនិយាយថា យើងគ្មានវិធីសួរឲ្យដឹងថា តើជនជាតិវៀតណាមទាំងនេះជាអ្នកណានៅពេលដែលពួកគេមកដល់ឡើយ។ ដូច្នេះពួកគេត្រូវកំណត់ថាជាចារកិច្ចយួន។ ប៉ុន្តែអ្នកទាំងអស់នេះរមែងតែងបានបញ្ជូនឲ្យធ្វើការសួរចម្លើយជានិច្ច ប៉ុន្តែគ្រួសារជនជាតិវៀតណាមមិនត្រូវបានគេសួរចម្លើយនោះទេ។ ខ្ញុំសន្និដ្ឋានថា គ្រួសារទាំងនេះគេមិនទុកនៅក្នុងមន្ទីរស-២១ យូរឡើយ ដោយពួកគេនឹងត្រូវយកមកសម្លាប់ចោលក្នុងពេលឆាប់ៗ”]។ ឯកសារ D1.3.32.21 កំណត់ហេតុស្តាប់ចម្លើយ គគ ស្រស់ KH ERN 00186798 [“សៈ ពេលលោកធ្វើជាអ្នកការពារ តើលោកការពារនៅទីណា ហើយបានប្រទះឃើញអ្វីខ្លះ? ឆៈ ខ្ញុំធ្វើការការពារអ្នកទោសជួនកាលនៅខាងក្រៅ ជួនកាលនៅខាងក្នុងបរិវេណស.២១ ហើយចល័តពីអគារមួយទៅអគារមួយទៀត រៀងរាល់មួយខែម្តង ដើម្បីការពារអ្នកទោស។ ខ្ញុំបានឃើញថា អ្នកទោសត្រូវបានគេឃុំចំរុះជាតិសាសន៍ ដូចជា ឥណ្ឌា ថៃ និងវៀតណាម តែត្រូវបានឃុំក្នុងកន្លែងដោយឡែកៗក្នុងបន្ទប់នីមួយៗ។ ខ្ញុំមិនដែលឃើញមានអ្នកទោសទាហានវៀតណាមឡើយ។ ខ្ញុំមិនដែលឃើញអ្នកទោសកុមារទេ តែឃើញមានអ្នកទោស្រីប្រហែល៧ ទៅ៨នាក់ ដែលត្រូវបានឃុំនៅក្នុងបន្ទប់ ដែលនៅចន្លោះអគារទទឹងថ្ងៃទាំងពីរ ក្រោយការិយាល័យរដ្ឋបាល”]។

3228 សូមមើល កថាខណ្ឌ ៤២៨, ៤៨៥។ សូមមើលបន្ថែម ឯកសារ D114/230.1.1 បញ្ជីអ្នកទោសរបស់ ក.ស.ច.ស នៅមន្ទីរស-២១ លេខរៀង ៥៩២ និង ១៤៧៨៥ [ដាំង យ៉ាំងថាន់ (ជនជាតិវៀតណាម) បញ្ជូនទៅទឹកសាបដើម្បីធ្វើចំការ - សូមមើល ឯកសារ D114/145.2.15 ប្រវត្តិរបស់ ដាំង យ៉ាំងថាន់ នៅមន្ទីរស-២១ (VN132), KH ERN 01180427 [“ទើបអង្គការបញ្ជូនទៅនៅកន្លែងទឹកសាប ធ្វើចំការ”], លេខរៀង ១៣៤៣១ [ជឹម យ៉ាំងគី (ជនជាតិវៀតណាម) - បញ្ជូនមកកន្លែងទឹកសាប “រែកដីដើម្បីដាក់គល់នៅដើមធូរេន និងសាវម៉ាវ”]។ សូមមើល ឯកសារ D114/145.2.11 ប្រវត្តិរបស់ ជឹម យ៉ាំងគី (VN122) នៅមន្ទីរស-២១ KH ERN 01180407 [“ទើបបញ្ជូនមកកន្លែងទឹកសាប ឲ្យធ្វើការដូចជារែកដីដាក់គល់ធូរេននិងសៅម៉ៅ”], លេខរៀង ១៣៤៣៣ [លេ យ៉ាំងភៀក ហៅ ជឹម យ៉ាំង

កឹង (ជនជាតិវៀតណាម) - បញ្ជូនមកកន្លែងទឹកសាប "ឱ្យធ្វើការរែកដីចាក់គល់ធូរេន និងសៅម៉ាវ"]។ សូមមើល ឯកសារ D114/145.2.11 ប្រវត្តិរបស់ ជឹម យ៉ាំងកឹង ហៅ លេ យ៉ាំងភៀក (VN 124) នៅមន្ទីរស-២១ KH ERN 01180407 ["ទើបបញ្ជូនមកកន្លែងទឹកសាប ឱ្យធ្វើការរែកដីចាក់គល់ធូរេន និងសៅម៉ាវ"], លេខរៀង ១៣៤៣៤ [ង្វៀង ខិនអ៊ី (ជនជាតិវៀតណាម) - បញ្ជូនមកកន្លែងទឹកសាប "ឱ្យធ្វើការដូចជាធ្វើស្មៅធូរេន និងសៅម៉ៅ"]។ សូមមើល ឯកសារ D114/145.2.11 ប្រវត្តិរបស់ ង្វៀង ខិនអ៊ី (VN125) នៅមន្ទីរស-២១ KH ERN 01180409, ["ទើបបញ្ជូនមកកន្លែងទឹកសាប ឱ្យធ្វើការដូចជាធ្វើស្មៅធូរេន និងសៅម៉ៅ"], លេខរៀង ១៣៤៣៦ [ង្វៀង ធីធឿង (ជនជាតិវៀតណាម) - បញ្ជូនមកកន្លែងទឹកសាប "ថែរក្សាចំការធូរេន"]។ សូមមើល ឯកសារ D114/145.2.12 ប្រវត្តិរបស់ ង្វៀង ធីធឿង (VN126) នៅមន្ទីរស-២១ KH ERN 01180412 ["ពេលចាប់ខ្លួន អង្គការបានបញ្ជូនឱ្យទៅនៅកន្លែងទឹកសាបថែរក្សាចំការធូរេន"], លេខរៀង ១៣៤៣៧ [ង្វៀង ហ៊ុវឡាង (ជនជាតិវៀតណាម) - បញ្ជូនមកកន្លែងទឹកសាបឱ្យធ្វើស្មៅ ចំការធូរេន]។ សូមមើល ឯកសារ D114/145.2.12 ប្រវត្តិរបស់ ង្វៀង ហ៊ុវឡាង(VN127) នៅមន្ទីរស-២១ KH ERN 01180414 ["ចាប់ខ្លួននៅថ្ងៃទី១០.១២.៧៥ នៅក្នុងសមុទ្រហួសកោះថាស [...] ពេលចាប់ខ្លួនហើយ អង្គការបញ្ជូនទៅកន្លែងទឹកសាបឱ្យធ្វើស្មៅ ចំការធូរេន"], លេខរៀង ១៤៧៨២ [ត្រឹង យ៉ាំងឃ្វេ - បញ្ជូនទៅនៅកន្លែងទឹកសាប "គឺធ្វើស្មៅធូរេន និង សៅម៉ៅ"]។ សូមមើល ឯកសារ D114/145.2.11 ប្រវត្តិរបស់ ត្រឹង យ៉ាំងឃ្វេ (VN121) នៅមន្ទីរស-២១ KH ERN 01180401 ["ពេលចាប់ខ្លួនហើយ អង្គការបានបញ្ជូនទៅនៅកន្លែងទឹកសាបឱ្យធ្វើការ គឺធ្វើស្មៅធូរេន និង សៅម៉ៅ"]), លេខរៀង ១៤៧៨៣ [ចឹង ថាន់ហឿង (ជនជាតិវៀតណាម) - ចាប់ខ្លួននៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៥ បញ្ជូនទៅកោះចំនួន៦ថ្ងៃ ហើយបញ្ជូនទៅទឹកសាប ដល់ថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៧៥] ។ សូមមើល ឯកសារD114/145.2.12 ប្រវត្តិរបស់ ចឹង ថាន់ហឿង (VN128) នៅមន្ទីរស-២១ KH ERN 01180417 ["ចាប់ខ្លួននៅថ្ងៃ១២.១២.៧៥ ពេលចាប់ហើយ បញ្ជូនទៅកោះ ... ចំនួន៦ថ្ងៃ ហើយបញ្ជូនទៅទឹកសាបឱ្យថែដំណាំធូរេន និងសៅម៉ៅ ដល់ថ្ងៃទី ៦.៥.៩៦"], លេខរៀង ១៤៧៨៥ [ផាម យ៉ាំងថាន់ (ជនជាតិវៀតណាម) - ចាប់ខ្លួននៅកន្លែងទឹកសាបដើម្បីថែទាំចំការធូរេន]។ សូមមើល ឯកសារ D114/145.2.14 ប្រវត្តិរបស់ ផាម យ៉ាំងថាន់ នៅមន្ទីរស-២១ KH ERN 01180425 ["បញ្ជាក់៖ ចំពោះឈ្មោះនេះ ចាប់បានតាំងពីថ្ងៃទី ១២.១១.៧៥ ហើយអង្គការបានបញ្ជូនខ្លួនទៅនៅកន្លែងទឹកសាប ឱ្យធ្វើការដូចជាថែដំណាំធូរេនជាដើម ទើបតែនៅថ្ងៃទី ៧.៥.៧៦ បញ្ជូនមកកន្លែង ស/២១ តែម្តង"]។

3229 សូមមើល VIII.ខ. ឧក្រិដ្ឋដែលប្រព្រឹត្តមកជនដែលកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យចាប់បាននៅដែនទឹក និងនៅលើកោះដែលកម្ពុជាប្រជាធិបតេយ្យអះអាងថាជារបស់ខ្លួន។ VIII.គ. មន្ទីរសន្តិសុខកងពល ១៦៤។ VIII.ឃ. មន្ទីរសន្តិសុខ ស-២១។

798. ក្នុងអំឡុងពេលដែល **មាស មុត** គ្រប់គ្រងតំបន់ ៥០៥ (ក្រចេះ) វៀតណាមយ៉ាងតិចណាស់ប្រាំមួយនាក់ ត្រូវបានចាប់ និងបញ្ជូនទៅសម្លាប់នៅ ស-២១[3230]។ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានពិភាក្សាបន្ថែមនៅក្នុងផ្នែកផ្សេងទៀតនៃដីកាសន្និដ្ឋាននេះ[3231]។

## ៤. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ

### ១. សេចក្តីផ្តើម

799. **មាស មុត** ត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ (ការរួមដំណេកដោយបង្ខំ) នៅតំបន់កំពង់សោម។ ការបង្ខំនរណាម្នាក់ឱ្យរៀបការជាមួយដៃគូដែលរបបជាអ្នកជ្រើសរើស និងបន្ទាប់មកឱ្យរួមដំណេកជាមួយគ្នា ជាផ្នែកមួយនៃគោលនយោបាយថ្នាក់ជាតិរបស់ថ្នាក់ដឹកនាំ ប.ក.ក។ **មាស មុត** បានធានាថា គោលនយោបាយនេះត្រូវបានអនុវត្តនៅក្នុងតំបន់ដែលគាត់កាន់កាប់។ ដូច្នេះ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំមានច្រើន នៅក្នុងតំបន់កំពង់សោម។ នៅទីនោះ អ្នកក្រោមបង្គាប់របស់ **មាស មុត** បានបង្ខំប្រជាជនឱ្យរៀបការ និងក្រោយមកបង្ខំពួកគេឱ្យរួមដំណេកជាមួយគ្នា។ ពួកគេគោរពតាមបញ្ជា ព្រោះខ្លាចគេយកទៅសម្លាប់ចោល ប្រសិនបើពួកគេបដិសេធ។

### ២. ការបង្កើតគោលនយោបាយជាតិស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

800. មុន ប.ក.ក គ្រួតត្រាប្រទេស អាពាហ៍ពិពាហ៍នៅក្នុងសង្គមកម្ពុជាបានចាក់ឫសក្នុងប្រពៃណីដ៏សម្បូរបែប ដែលតម្រូវឱ្យមានរៀបចំពិធីបុណ្យសាសនា[3232] ការចូលរួម និងការគ្រប់គ្រងដំណើរ

---

[3230] ឯកសារ D114/230.1.1 បញ្ជីអ្នកទោសរបស់ ក.ស.ច.ស នៅមន្ទីរស-២១ លេខរៀង ១៣៩៨១-១៣៩៨៦ [ង្វៀង ហ៊ូភៀក, ឡេ មិនតឹម, ង្វៀង ឌឹកជិន, ង្វៀង យ៉ាឡេ, ង្វៀងវ៉ាំងវ៉ាំង, ផាម វីឡាយ អ្នកទាំងអស់ត្រូវចាត់តាំងជា "ចារកម្មវៀតណាម" មកពីខេត្តក្រចេះ [ភូមិភាគឦសាន]]។

[3231] សូមមើល VIII.I. ការបោសសម្អាតកងពល ១១៧ និងតំបន់៥០៥។ VIII.ឃ. មន្ទីរសន្តិសុខស-២១។

[3232] ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សាវ៉ាន ឆ.36 ["ការរៀបការតាមប្រពៃណីគឺយើងមានភ្លេង, មានតាអាចារ្យ, មានម៉ែឪដឹងឮ, មានការកាត់សក់, មានកម្មវិធីកាត់ខាន់ស្លាជាដើម"]។ ឯកសារ D114/33 កំណត់ហេតុស្តាប់ចម្លើយ ហែម អាង ឆ.173 ["មុនសម័យខ្មែរក្រហមពេលរៀបការ មានភ្លេងប្រពៃណី មានអ្នកច្រៀង និងពិធីជប់លាង"]។ ឯកសារD114/297.1.16 Rochelle Braaf ៖អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម

ការរៀបអាពាហ៍ពិពាហ៍ដោយសមាជិកគ្រួសាររបស់គូស្វាមីភរិយា[3233] ហើយសំខាន់ជាងនេះទៀត គឺការព្រមព្រៀងគ្នារបស់កូនកំលោះ និងកូនក្រមុំ[3234]។ ការអនុវត្តទាំងនេះបានផ្លាស់ប្តូរយ៉ាងខ្លាំង

---

EN ERN 00992283 ["ជាធម្មតាវាធ្វើឡើងរយៈពេលពីរទៅបីថ្ងៃ ហើយរួមមានមិត្តភក្តិ និងគ្រួសារ ហើយមានពិធីសាសនា និងទំនៀមទម្លាប់ផ្សេងៗ"]។ ឯកសារ D4.1.1003 Bridgette Toy-Cronin ៖"ខ្ញុំចង់និយាយប្រាប់អ្នក" KH ERN 00721382 ["ទោះបីជាយ៉ាងនេះក្តី ពិធីរៀបការជាលក្ខណៈប្រពៃណីខ្មែរគឺមានរៀបចំពិធីនានាជាច្រើន និងការមានរៀបចំលាងសោយភោជន៍យ៉ាងអធិកអធមទៀតផង ដោយមានការចូលរួមពីមាតាបិតាទាំងសងខាង គ្រួសារ និងមិត្តភក្តិផងដែរ"]។

3233 ឯកសារ D114/297.1.28 ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 14.14.40-14.18.02 ["ហើយមានភ្លេងមានភ្លាត់ មានម៉ែមានឪ មានយាយតា ជីដូនជីតា បងប្អូន ហើយមានហៅជំនួន ហៅផ្កាស្លា បាចផ្កាស្លា"]។ ឯកសារ D114/297.1.29 កាស៊ូមិ ណាកាហ្កាវ៉ា ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 10.59.16-11.01.40 ["ទោះបីជានារីនៅលីវត្រូវបានពិគ្រោះយោបល់ជាមួយឪពុកម្តាយអំពីការរៀបការរបស់នាងក៏ដោយ គឺនាងត្រូវយល់ស្របដោយមិនបានពិចារណាអ្វីទេ [...] ដែលមិនល្អទេ ពីព្រោះគឺពឹងផ្អែកលើឪពុកម្តាយជាអ្នកសម្រេចឲ្យពួកគាត់"]។ ឯកសារD114/297.1.30 កាស៊ូមិ ណាកាហ្កាវ៉ា ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 09.29.53-09.33.14។ ឯកសារ D114/297.1.25 អុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៦ ម៉ោង 10.34.26-10.36.19។ ឯកសារ D114/64 កំណត់ហេតុស្តាប់ចម្លើយ អែម សារិន ឆ.209 ["ពិធីរៀបការតាមរបៀបខ្មែរក្រហម និងពិធីរៀបការតាមប្រពៃណីមានចំណុចខុសគ្នាទាំងស្រុង។ ពិធីរៀបការតាមប្រពៃណីប្រព្រឹត្តទៅយ៉ាងហោចណាស់មួយថ្ងៃ និងមួយយប់ដែរ ដោយមានភ្លេងប្រពៃណីមានមនុស្សចាស់ទុំដែលជាមេបាចូលរួម ដោយមានពិធីតាមប្រពៃណីជាច្រើនទៀត ដូចជា ពិធីចងដៃ កាត់សក់ ផ្ទឹមជាដើម ហើយនៅទីបញ្ចប់មានពិធីជប់លៀង។ ចំណែកឯពិធីរៀបការនៅក្នុងរបបខ្មែរក្រហមវិញ ប្រព្រឹត្តទៅអស់រយៈពេលជាច្រើនបំផុតគឺមួយម៉ោងកន្លះ ឬពីរម៉ោងប៉ុណ្ណោះ ដោយមិនមានភ្លេងប្រពៃណី ឬពិធីតាមប្រពៃណីណាផ្សេងទៀតនោះឡើយ"]។ ឯកសារ D114/33 កំណត់ហេតុស្តាប់ចម្លើយ ហែម អាង ឆ.174 ["ឪពុកម្តាយពេលដឹងថា កូនប្រុសខ្លួនស្រលាញ់កូនស្រីគ្រួសារណាម្នាក់ ឪពុកម្តាយកូនកំលោះនោះទៅជួប និងចែចូវ ឬភ្ជាប់ពាក្យសម្តីជាមួយឪពុកម្តាយខាងស្រី ពួកគេហូបស្លាម្លូរជុំគ្នា"]។

3234 ឯកសារ D114/297.1.26 ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 13.42.42-13.45.16 ["ចាព្រម រៀបការ"]។ ឯកសារ D114/38 កំណត់ហេតុស្តាប់ចម្លើយ ជុំ រឹម (ជា រឹម) ឆ.113 [សៈ នៅក្នុងការរៀបចំការរៀបការជាប្រពៃណី ម្តាយឪពុកជាអ្នករៀបចំការរៀបការ និងជ្រើសរើសគូស្រករឲ្យលោកស្រី ហើយលោកស្រីព្រមរៀបការ មែនទេ? ឆ.113៖ ចាស"]។ ឯកសារ D114/33 កំណត់ហេតុស្តាប់ចម្លើយ ហែម អាង ឆ.174 ["ឪពុកម្តាយខាងស្រីក៏ទៅសួរកូនក្រមុំខ្លួន ហើយបើនាងពេញចិត្តនឹងកំលោះនោះដែរ ឪពុកម្តាយទាំងសងខាងក៏កំណត់យកថ្ងៃរៀបការឲ្យពួកគេ"]។ ឯកសារ D114/297.1.30 កាស៊ូមិ ណាកាហ្កាវ៉ា ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 09.29.53 ["កូនស្រីត្រូវបានរំពឹងឲ្យឪពុកម្តាយជាអ្នកសម្រេចលើមង្គលការរបស់ខ្លួន។ អ៊ីចឹងហើយនាង [...] ត្រូវតែយល់ព្រមដោយបិទភ្នែក ហើយការរៀបចំនោះឪពុកម្តាយជាអ្នកធ្វើ ដោយសារមានការទុកចិត្តគ្នាទៅវិញទៅមករវាងឪពុកម្តាយនឹងកូនស្រី ហើយកូនស្រីគិតថា ឪពុកម្តាយនឹងជ្រើសរើសមនុស្សល្អបំផុតដែលពួកគាត់អាចធ្វើបាន។ គាត់

ពេល ប.ក.ក ឡើងកាន់អំណាច[3235]។ ពីចុងឆ្នាំ ១៩៧៥ ដល់ពេលដាច់របប ទស្សនាទាននៃគ្រួសារបដិវត្តន៍ត្រូវបានបង្កើតឡើង។ ដើម្បីបំពេញតាមគោលដៅកំណត់ដោយ ប.ក.ក ពាក់ព័ន្ធនឹងការការពារជាតិ និងផលិតកម្មកសិកម្ម មជ្ឈិមបក្សបានអនុម័តគោលនយោបាយស្តីពីការជ្រើសរើសគូស្រករ និងការរៀបអាពាហ៍ពិពាហ៍ ដើម្បីឱ្យគូស្វាមីភរិយាបង្កើតកូន និងបង្កើនចំនួនប្រជាជនឱ្យបានឆាប់រហ័ស។ អាជ្ញាធរបានជ្រើសរើសក្រុមបុរស និងស្ត្រី ដើម្បីរៀបអាពាហ៍ពិពាហ៍ទ្រង់ទ្រាយធំ ដោយមិនខ្វល់ខ្វាយពីប្រពៃណីខ្មែរ។

801. ក្រោយរៀបការរួច ប្តីប្រពន្ធត្រូវបានរំពឹងឱ្យរួមដំណេកជាមួយគ្នា ហើយអាជ្ញាធរតាមដានថាតើពួកគេអនុវត្តតាមគោលការណ៍នេះឬអត់។ អាពាហ៍ពិពាហ៍ដែលកម្ពុជាប្រជាធិបតេយ្យរៀបចំភាគច្រើន ត្រូវបានរៀបចំដោយគ្មានការព្រមព្រៀងពីប្តីប្រពន្ធណាម្នាក់ ឬពួកគេទាំងពីរទេ។ ថ្នាក់ដឹកនាំ ប.ក.ក មានចេតនាបង្ខំ គំរាមកំហែងដោយប្រើកម្លាំង ឬបង្ខិតបង្ខំជនស៊ីវិល និងសមាជិកយោធាឱ្យរៀបការ និងរួមដំណេកជាមួយគ្នា។ ហេតុការណ៍ទាំងនេះធ្វើឱ្យពួកគេមានការប៉ះទង្គិចយ៉ាងខ្លាំងនៅពេលនោះ ហើយជារឿយៗ បង្កផលវិបាកពេញមួយជីវិត រួមមានរបួសផ្លូវកាយ និងផ្លូវចិត្ត។

802. ទោះបីមានភាពខុសគ្នាតិចតួចតាមតំបន់ក៏ដោយ ការសម្រិតសម្រាំងសាវតាររបស់គូស្រករ មុននឹងផ្គូផ្គងពួកគេ ការរៀបចំ និងការជូនដំណឹងអំពីការរៀបការនាពេលខាងមុខ ពិធីរៀបការ និងការតាមដានថាតើមានការរួមដំណេកឬអត់ ត្រូវបានធ្វើឡើង ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ

---

នឹងរើសបុរសដែលល្អបំផុតតាមដែលគាត់រកបានសម្រាប់នាង។ ចំពោះនៅក្នុងរបបខ្មែរក្រហមវិញ ខ្មែរក្រហមមិនបានបង្កើតទំនុកចិត្តក្នុងចំណោមគូស្រករបុរសស្ត្រីទាំងអស់នោះទេ"]។

3235 ឯកសារ D114/297.1.28 ជា ខៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 13.56.31-14.00.31 [ការរៀបការដោយបង្ខំជាមួយទាហានពិការ នៅក្នុងឆ្នាំ ១៩៧៥ នៅក្រសួងពាណិជ្ជកម្ម]។ ម៉ោង 14.14.40-14.18.02 ["បើនិយាយពីប្រៀបធៀបរៀបការនៅជំនាន់ខ្មែរក្រហម និងសម័យមុនៗខ្មែរក្រហម មកក្រោយខ្មែរក្រហម គឺថាខុសគ្នាដាច់។ ដូចសម័យខ្មែរក្រហមរៀបការតែហៅដាក់ៗ ម្តងបួនដប់គូ ម្តងបួនប្រាំគូ ម្តង១០០គូ ក៏មានដែរ។ រួចចុះចំណែកសម័យឥឡូវនេះ [...] គេរៀបការម្តងតែមួយគូៗ ហើយមានភ្លេងមានភ្ជាត់ មានម៉ែមានឪ មានយាយតា ជីដូនជីតា បងប្អូន ហើយមានហែជំនូន បាចផ្កាស្លា [...] បើប្រៀបដូចមេឃនិងដីទៅ [...] បានថាខ្ញុំតូចចិត្តដែរហ្នឹង ដល់ឃើញសព្វថ្ងៃ [...] តូចចិត្តនឹងវាសនាខ្លួនឯង"]។ ឯកសារ D114/33 កំណត់ហេតុស្តាប់ចម្លើយ ហែម អាង ឆ.155, 173 ["គឺមានការរៀបការដែលពុំធ្វើតាមទំនៀមទម្លាប់ពីបុរាណរបស់ខ្មែរ [...] ឆ.173៖ មុនសម័យខ្មែរក្រហមពេលរៀបការ មានភ្លេងប្រពៃណី មានអ្នកច្រៀង និងពិធីជប់លាង តែក្នុងសម័យខ្មែរក្រហមគេឱ្យអង្គុយនៅតុវែងមួយទល់មុខគ្នា មានដួងមួយនៅពីមុខ ពុំមានភ្លេង ពុំមានអាហារអ្វីទេ ហើយគេឱ្យយើងឡើងប្តេជ្ញាម្តងម្នាក់ៗ"]។

ទាំងមូលដោយកម្មាភិបាល ប.ក.ក ក្នុងវិធីស្រដៀងគ្នា និងដោយមានការរៀបចំ។ ការកើតមានការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមដំណេកដោយបង្ខំជាទ្រង់ទ្រាយធំ និងវិធីស្រដៀងៗគ្នាដែលវាត្រូវបានអនុវត្តនៅទូទាំងប្រទេស បង្ហាញថា ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្ត ស្របតាមគោលនយោបាយរបស់បក្ស និងជាផ្នែកមួយនៃការវាយប្រហារជាទូទៅ និងជាប្រព័ន្ធរបស់របបកម្ពុជាប្រជាធិបតេយ្យទៅលើប្រជាជនស៊ីវិលកម្ពុជា[3236]។ ការអនុវត្តទាំងអស់នេះជាការបង្ហាញបន្ថែមឲ្យឃើញអំពីការអនុវត្តអំណាច និងភាពជាម្ចាស់របស់របបកម្ពុជាប្រជាធិបតេយ្យលើប្រជាជន[3237]។

---

[3236] ឯកសារ D114/297.1.29 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 15.00.28-15.03.03 ["សៈ [...] តើការរៀបការដោយបង្ខំ កើតឡើងនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនៅតាមបណ្ដាខេត្តផ្សេងៗទៀតនៅក្នុងអំឡុងពេលនោះឬទេ? ឆៈ ហ្នឹងគឺជាការត្រឹមត្រូវហើយ"]។ ឯកសារ D4.1.1003 Bridgette Toy-Cronin ៖"ខ្ញុំចង់និយាយប្រាប់អ្នក" KH ERN 00721382 ["ភាពស៊ីសង្វាក់នៃការពណ៌នាពីពិធីរៀបការនៅតាមទីតាំងភូមិសាស្ត្រផ្សេងៗបង្ហាញថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំជាគោលនយោបាយមួយរបស់មេដឹកនាំជាន់ខ្ពស់ [...] បញ្ជាក់យ៉ាងច្បាស់ថា គោលនយោបាយបែបនេះពិតជាមាន គ្រាន់តែការអនុវត្តមានភាពខុសប្លែកគ្នាខ្លះតែប៉ុណ្ណោះ"]។ ឯកសារ D114/297.1.16 Rochelle Braaf ៖ អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម EN ERN 00992278 ["របបនេះបានបង្ខំឲ្យប្រជាជននៅលីវ និងអ្នកពោះម៉ាយ មេម៉ាយជាច្រើនរៀបការដើម្បី "អង្គការ" [...] របបនេះបានគ្រប់គ្រងទាំងស្រុងទៅលើការជ្រើសរើសប្ដីប្រពន្ធឲ្យរៀបការជាមួយគ្នា ការរៀបចំការរៀបការ កន្លែងដែលគូស្រករត្រូវស្នាក់នៅ និងរួមសង្វាសក្រោយរៀបការ [...] ដាក់ការគ្រប់គ្រងជាទូទៅ និងជាប្រព័ន្ធមកលើប្រជាជន"]។

[3237] ឯកសារ D234/2.1.137 កំណត់ហេតុស្ដាប់ចម្លើយ ព្រាប សុខឿន ឆ.12-13 ["នៅឆ្នាំ១៩៧៧ គឺខ្មែរក្រហមបានរៀបចំរៀបការ នៅពេលនោះខ្ញុំត្រូវបានគេបង្ខំឲ្យរៀបការជាមួយនឹងបុរសជនពិការម្នាក់ ដែលខ្ញុំមិនស្រឡាញ់ [...] ឆ. 13៖ ខ្ញុំជាកម្មសិទ្ធិរបស់អង្គការ ដូច្នេះ ខ្ញុំត្រូវតាមអង្គការទោះបីជាអង្គការឲ្យខ្ញុំចូលរណ្ដៅក្លាមក៏ចូលដែរ"]។ ឯកសារ D114/32 កំណត់ហេតុស្ដាប់ចម្លើយ មាស សាវ៉ន ឆ.31-32 ["កាលពីជំនាន់នោះ គឺពួកយើងជាកម្មសិទ្ធិរបស់គេទាំងស្រុង [...] ឆ.32៖ គ្មាននរណាហ៊ានបដិសេធនឹងគេទេ [រៀបការ] ពីព្រោះពីសម័យនោះ យើងខ្លាចគេមិនឲ្យនៅ"]។ ឯកសារ D114/297.1.16 Rochelle Braaf ៖ អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម EN ERN 00992278 ["ក្នុងគោលបំណងយកតួនាទីរបស់សាសនា និងគ្រួសារក្នុងជីវិតរបស់មនុស្ស មកដាក់ក្រោមបង្គាប់ របបនេះបានគ្រប់គ្រងទាំងស្រុងទៅលើការជ្រើសរើសប្ដីប្រពន្ធឲ្យរៀបការជាមួយគ្នា ការរៀបចំការរៀបការ កន្លែងដែលគូស្រកររស់នៅ និងរួមសង្វាសក្រោយរៀបការ"]។ សូមមើលផងដែរ ឯកសារ D114/297.1.29 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 11.27.00-11.29.43 ["នីតិវិធីនៃការរៀបការ គឺថាវាមានការខុសគ្នាច្រើន ប៉ុន្តែខ្មែរក្រហមមានសិទ្ធិផ្ដាច់មុខតែម្ដងក្នុង ការអនុញ្ញាឲ្យរៀបការនេះ"] ម៉ោង 13.29.44-13.32.33

## ទស្សនាទាននៃគ្រួសារបដិវត្តន៍

803. ដូចមានពន្យល់នៅក្នុងទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្តន៍ចេញផ្សាយឆ្នាំ ១៩៧៥ ដើម្បីបម្រើបដិវត្តន៍ ម្នាក់ៗត្រូវលះបង់ "កម្មសិទ្ធិផ្ទាល់ខ្លួន ដូចជាផ្ទះសម្បែង ស្រែចម្ការ ច្បារដំណាំ គ្រួសារម៉ែឪ បងប្អូនកូនចៅ និងជាទ្រព្យសម្បត្តិផ្សេងៗទៀតទាំងអស់" រួមទាំង "មនោសញ្ចេតនា"[3238] ផងដែរ។ ដោយសារតែទំនាក់ទំនងគ្រួសារជា "កម្មសិទ្ធិឯកជន" ត្រូវលះបង់ចោលដូចនឹងទ្រព្យសម្បត្តិជាសម្ភារៈ។ មានន័យផងដែរថា ប.ក.ក មានសិទ្ធិគ្រប់គ្រងផ្ដាច់មុខលើ "ការកសាងគ្រួសារ"[3239]។

804. ដំបូង ប.ក.ក បានផ្សព្វផ្សាយទស្សនៈរបស់ខ្លួនអំពីការកសាងគ្រួសារ ក្នុងទស្សនាវដ្ដីយុវជន និងយុវនារីបដិវត្តន៍ នៅខែ កុម្ភៈ ឆ្នាំ ១៩៧៤។ ប្រាំមួយសប្ដាហ៍ក្រោយវាយបានភ្នំពេញ បក្សបាន

---

["ក្នុងសម័យខ្មែរក្រហម ដើម្បីទទួលបានការអនុញ្ញាតរៀបការ មានន័យថាឲ្យការរៀបការរបស់ខ្លួនហ្នឹងស្របច្បាប់ គឺថាខ្លួនត្រូវស្នើសុំការអនុញ្ញាតពីខ្មែរក្រហម"]។

3238 ឯកសារ D4.1.874 យុវជន និង យុវនារី បដិវត្ត នៅខែ វិច្ឆិកា ឆ្នាំ ១៩៧៥ EN ERN 00522460-61, FR ERN 00525856-58, KH ERN 00063614-17។ ឯកសារ D54/74.1.20 ហ្វីលីព ហ្សុត ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ EN ERN 00396533 [ប៉ុល ពត បានប្រាប់គណៈមជ្ឈិមថា "ម្ដាយមិនគួរជាប់ជំពាក់ជំពិនជាមួយកូនរបស់ខ្លួនច្រើនពេកទេ"។ ប្រហាក់ប្រហែលគ្នានេះដែរ ប្រសិនបើមនុស្សប្រុសមានអារម្មណ៍មនោសញ្ចេតនាលើនារីណាម្នាក់ មនុស្សប្រុសនោះគួរមានជំហរសមូហភាព និងដោះស្រាយវា [...] បើមិនធ្វើដូច្នេះទេ គឺមានជំហរឯកជនខ្លាំង"], EN ERN 00396524 [ខៀវ សំផន បាននិយាយនៅក្នុងវគ្គអប់រំនយោបាយនៅ ក-១៥ ថា៖ "ផ្លូវចិត្តខាងទ្រព្យសម្បត្តិឯកជនគឺគ្រោះថ្នាក់ជាង ព្រោះវារាប់បញ្ចូលអ្វីទាំងអស់ដែលគេយល់ថា "ជារបស់ខ្លួន" ពោលគឺអ្វីទាំងអស់ដែលគេយល់ថាពាក់ព័ន្ធនឹងខ្លួនឯង ដូចជា ឪពុកម្ដាយ ក្រុមគ្រួសារ និងប្រពន្ធ [...] ការគិតពីពាក្យថា "ខ្ញុំ" និង "របស់ខ្ញុំ" ត្រូវបានហាមឃាត់។ ប្រសិនបើគេនិយាយថា "ប្រពន្ធខ្ញុំ" នោះនោះការប្រព្រឹត្តិខុស។ គេគួរនិយាយថា "ក្រុមគ្រួសាររបស់យើង"។ ប្រជាជាតិកម្ពុជាគឺជាមហាក្រុមគ្រួសាររបស់យើង [...] នោះជាមូលហេតុដែលឲ្យនៅដាច់ពីគ្នា៖ ប្រុសដោយប្រុស ស្រីដោយស្រី កុមារដោយកុមារ។ [...] យើងគឺជាកូនរបស់អង្គការ យើងគឺជាមនុស្សរបស់អង្គការ ទាំងប្រុស ទាំងនារី"]។

3239 ឯកសារ D98/1.2.16 កាំង ហ្គេចអ៊ាវ ហៅ ឌុច ប្រតិចារឹក ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ ម៉ោង 11.12.01 [ចម្រៀងនេះនៅ ប្រហែលជាមានអ្នកថតទុកជាឯកសារបាន។ ម៉ែឪរំដោះមនុស្ស-- អ៊ំនែ បង្កើតមនុស្សបានតែម្នាក់ទេ អង្គការបដិវត្តន៍រំដោះមនុស្សបានមួយនគរ។ ដូច្នេះ ម៉ែឪអត់មានតួនាទីទេ អង្គការជាម៉ែឪ។ ហ្នឹងក្រុមគ្រួសារគេចែករបៀបហ្នឹង"]។ ឯកសារ D114/297.1.16 Rochelle Braaf ៖ អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម EN ERN 00992278។

បោះពុម្ពឯកសារនេះសាជាថ្មីដើម្បីធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ[3240]។ ចំណុចសំខាន់នៃឯកសារនេះ និងការប្រកាសអំពីជំហររបស់បក្សនាពេលក្រោយ គឺទស្សនាទាននៃទម្រង់ថ្មីមួយនៃគ្រួសារ ពោលគឺ គ្រួសារបដិវត្តន៍។ ការកសាងគ្រួសារមិនមែន "ធ្វើតាមតែចិត្តនឹកឃើញ" ឬ "ប្រយោជន៍ផ្ទាល់ខ្លួន"[3241] ទៀតទេ។ ផ្ទុយទៅវិញ ចាំបាច់ត្រូវមានភាពស្មោះត្រង់ដាច់ខាតចំពោះអង្គការហើយសេចក្តីស្រឡាញ់ចំពោះបក្សជំនួសឱ្យសេចក្តីស្រឡាញ់ចំពោះសាច់ញាតិ។ ទំនាក់ទំនងគ្រួសារផ្សេងទៀតទាំងអស់លែងមានសារៈសំខាន់[3242]។ គោលបំណងតែមួយគត់នៃ "គ្រួសារបដិវត្តន៍" គឺដើម្បីសម្រេចគោលដៅបដិវត្តន៍របស់ប្រទេសឱ្យបានកាន់តែលឿន[3243]។ គេលើកឡើង

---

[3240] ឯកសារ D114/36.1.59 ការចេញផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា លោកទស្សនៈ បដិវត្ត និងមិនបដិវត្ត ចំពោះបញ្ហាកសាងគ្រួសារ បោះពុម្ពឡើងវិញពីថ្ងៃទី២ ខែ កុម្ភៈ ឆ្នាំ ១៩៧៥ នៅថ្ងៃទី២ ខែ មិថុនា ឆ្នាំ ១៩៧៥ និងផ្សាយជាសាធារណៈឡើងវិញនៅថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៧៥ (១ ០០០ច្បាប់) ("ឯកសារគោលនយោបាយកសាងគ្រួសារ")។

[3241] ឯកសារ D114/36.1.59 ឯកសារគោលនយោបាយកសាងគ្រួសារ KH ERN 00407100។ ឯកសារ D4.1.817 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធៀន KH ERN 00368611។ ឯកសារ D234/2.1.37 កាស៊ូមិ ណាកាហ្គាវ៉ា អំពើហិង្សាលើយ៉េនឌ័រ KH ERN 00738344 ["គោលនយោបាយមួយក្នុងចំណោមគោលនយោបាយរបស់ អង្គការ គឺដើម្បីបំផ្លាញរចនាសម្ព័ន្ធប្រពៃណីគ្រួសារកម្ពុជា។ [...] វាមានទំនួរភាពជឿជាក់គ្នាទៅវិញទៅមករវាងសមាជិកគ្រួសារ ហើយសហគមន៍ ត្រូវបានបង្រួមគ្នាយ៉ាងរឹងមាំ។ របបខ្មែរក្រហមបានព្យាយាមបំផ្លាញរចនាសម្ព័ន្ធប្រពៃណីនោះដើម្បីជាការឈានទៅដល់ការសម្រេចបដិវត្តយ៉ាងឆាប់រហ័ស"]។ ឯកសារ D4.1.1003 Bridgette Toy-Cronin ៖ "ខ្ញុំចង់និយាយប្រាប់អ្នក" KH ERN 00721382 ["គោលការណ៍នេះ [...] ប្រហែលជាគោលនយោបាយនេះបង្កើតឡើងក្នុងគោលបំណងរក្សាការគ្រប់គ្រងទៅលើបុគ្គលម្នាក់ៗ ដោយធានាឱ្យមានការបន្តពូជ ទោះបីមានការប៉ុនប៉ងលុបបំបាត់មិនឱ្យមានការស្រឡាញ់គ្នានិងទំនាក់ទំនងក្នុងគ្រួសារក៏ដោយ ដែលនេះត្រូវបានចាត់ទុកថាជាការរំខានដល់គោលដៅបដិវត្តន៍"]។ ឯកសារ D1.3.17.1 អេលីហ្សាបែត ប៊េកខ័រ នៅពេលដែលសង្គ្រាមរលត់ទៅ KH ERN 00232300-01។

[3242] ឯកសារ D114/297.1.28 ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 15.13.39-15.16.20 [ខៀវ សំផន បានប្រកាស "ថាកុំអាល័យតែគិតម៉ែឪ នឹកម៉ែឪ គិតតែខំប្រឹងធ្វើការជូនបក្ស ជូនរដ្ឋទៅ រឿងម៉ែឪទុកមួយឡែក"] ម៉ោង 15.16.20-15.18.25 ["និយាយថា មិត្តនៅជាមួយអង្គការ គឺគ្រប់គ្រងអង្គការ -- ក្រោមការគ្រប់គ្រងរបស់អង្គការ មិនមែនទៅចាំម៉ែឪអាល័យតែទៅរកម៉ែរកឪទៀតទេ គឺអង្គការជាម៉ែឪហើយ"]។ ឯកសារ D4.1.806 កំណត់ហេតុស្តាប់ចម្លើយ ជាំង ស្រីមុំ ឆ.8 ["ខ្ញុំមិនហ៊ានប្រកែកតវ៉ាការរៀបការនោះទេ [...] យើងត្រូវបានគេប្រាប់គេ "យើងជាកូនរបស់អង្គការ""]។

[3243] ឯកសារ D114/36.1.59 ឯកសារគោលនយោបាយកសាងគ្រួសារ KH ERN 00407100 ["បញ្ហាគ្រួសារ ជាផ្នែកមួយបេះមិនដាច់ ពីបញ្ហាប្រទេសជាតិ [...] ដូច្នេះ ការកសាងគ្រួសារបដិវត្តយើង គឺមិនមែន គ្រាន់តែដើម្បីផលប្រយោជន៍សមគួរ បានសុខ បានសប្បាយ មានកូនមានចៅសំរាប់បន្តពូជវង្សខ្លួនប៉ុណ្ណោះទេ។ តែសំខាន់គឺដើម្បីធ្វើ

ថា បក្សមានការរីកចម្រើនបាន តែដោយ "ប្រគល់គ្រួសារជូនអង្គការ" និង "ជូនសម្ភហភាពជួយអប់រំកសាង"[3244] ប៉ុណ្ណោះ។ ហេតុដូច្នេះ ដើម្បីបម្រើគោលដៅស្តារប្រទេស គ្រួសារមិនចាំបាច់ត្រូវរស់នៅជុំគ្នាទៀតទេ និងត្រូវបានបែងចែកទៅតាមប្រភេទ និងបញ្ជូនទៅការដ្ឋានការងារផ្សេងៗគ្នា[3245]។ ក្មេងតូចៗត្រូវបានបំបែកចេញពីម្តាយ ដើម្បីឱ្យម្តាយអាចផ្តោតអារម្មណ៍លើការងារ

---

បដិវត្ត សំរេចភារកិច្ច ដ៏ឧត្តុង្គឧត្តម"]។ ឯកសារ D114/297.1.28 ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 13.48.32-13.50.10 [ឌៀវ សំផន ស្នើសមមិត្តនារីយុទ្ធជនតាមមុខក្រសួងទាំងអស់ ដែលមានអាយុពី ១៨ឆ្នាំឡើងទៅ រៀបចំឱ្យមានគ្រួសារដើម្បីបង្កើតកូន]។ ឯកសារ D11/54/3.1 កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង 15.12.03 [មណ្ឌលគីរី៖ គេគ្រាន់តែនិយាយថា បើសិនមិនបង្កើតកូនឱ្យអង្គការបានទេ គឺអ្នកឯងត្រូវខុសច្បាប់"]។ ឯកសារ D114/297.1.36 ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង 09.24.35-09.30.46 ["ខំប្តេជ្ញាចិត្ត [...] ខំបង្កកើតកូនឱ្យបានច្រើន ឱ្យបានមានកូនមានអីទៅ [...] ឱ្យបានច្រើន កុំឱ្យខ្វះខាត"]។ ឯកសារ D114/297.1.36 សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង 10.48.25-10.51.06 ["ស្រលាញ់គ្នាចាប់ពីពេលនេះតទៅ បង្កបង្កើនផល [...] ឱ្យបង្កបង្កើតជាមនុស្សឱ្យបានច្រើនដោយតម្រូវទៅតាមអង្គការត្រូវការ មនុស្សច្រើនដើម្បីការពារទឹកដី។ [...] និយាយឱ្យដូចគេថាអ៊ីចឹង"], ម៉ោង 10.53.06-10.55.16 ["ខ្ញុំមានកូន គឺមិនមែនតាមចិត្តខ្ញុំចង់ថាឱ្យមានទេ តែនេះជាទិសដៅរបស់គេ គេថាត្រូវតែមានកូន ត្រូវតែបង្កើតកូនឱ្យអង្គការ"]។ ឯកសារ D234/2.1.67 អេលីហ្សាបេត បេកឃ័រ ប្រតិចារឹក ថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ ម៉ោង 13.35.33-13.38.05 ["គ្រួសាររស់នៅរួមគ្នា [...] មិនមានការលាក់បាំងពីការបាក់ទឹកចិត្តនោះទេ ដូច្នេះហើយ គេបន្តធ្វើការជានិច្ចកាលគឺគ្មានការឈប់សម្រាកនោះឡើយ"]។ ឯកសារ D234/2.1.137 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុខឿន ឆ.31 ["គេត្រូវការឱ្យយុវជន យុវនារីរៀបការ ដើម្បីបង្កើតកូនបន្ថែមទៅលើកម្លាំងកសាងបដិវត្តន៍"]។ ឯកសារ D54/74.1.20 ហ្វីលីព ហ្សូត ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ EN ERN 00396533, FR ERN 00639883 ["គ្រួសារ [...] គោលបំណងចម្បង គឺបង្កើតកូនៗដើម្បីបម្រើឱ្យបក្ស"]។ ឯកសារ D4.1.1003 Bridgette Toy-Cronin ៖ "ខ្ញុំចង់និយាយប្រាប់អ្នក" KH ERN 00721390 ["គឺការធានាឱ្យមានការបន្តពូជនោះ ការរួមភេទដោយបង្ខំជាផ្នែកមួយដែលចាំបាច់នៃចំណងអាពាហ៍ពិពាហ៍នេះ"]។ សូមមើលផងដែរ ឯកសារ D4.1.50 យុវជន និង យុវនារីបដិវត្ត លេខពិសេស មេសា ១៩៧៦ EN ERN 00392451។

3244 ឯកសារ D114/36.1.59 ឯកសារគោលនយោបាយកសាងគ្រួសារ KH ERN 00407104។

3245 ឯកសារ D234/2.1.127 ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 09.47.07 ["ខ្ញុំសុំដែរ សុំថាជួបឪពុកម្តាយ បងប្អូនសិន ឱ្យបងប្អូនឪពុកម្តាយដឹង រួចទៅអង្គការឆ្លើយថា"មិនបាច់ទេ នៅជាមួយអង្គការ អង្គការរៀបចំដូចឪពុកម្តាយដែរ អត់ឱ្យទៅទេ"]។ ឯកសារ D234/2.1.67 អេលីហ្សាបេត បេកឃ័រ ប្រតិចារឹក ថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ ម៉ោង 13.35.33-13.38.05 ["កុមារទាំងអស់ គេបំបែកពីឪពុកម្តាយ ពីគ្រួសាររបស់គេ [...] បញ្ជូនកុមារទាំងអស់នោះ [...] កងកុមារ"]។ ឯកសារ D54/120 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.3 [អ្នកភូមិរាមធ្វើការជាសហករណ៍មួយ៖ "ពួកយើងមិនអាចទាក់ទងក្រុមគ្រួសារបានទេ ពួកយើងបានជួបគ្នាតែនៅពេលធ្វើការនៅតាមការដ្ឋានប៉ុណ្ណោះ ហើយនិយាយ និងផ្លាស់ប្តូរពាក្យសម្តីគ្នាបានតិចតួចបំផុត។ គេពុំឱ្យយើងមានមនោសញ្ចេតនាចំពោះ

ខណៈដែលកូនរបស់ពួកគេត្រូវបានបង្វឹកជា "កូនរបស់អង្គការ" ដែលជារឿយៗ ទទួលភារៈតាមដានឪពុកម្តាយរបស់ខ្លួន និងរាយការណ៍ពីការប្រព្រឹត្តិខុសរបស់ឪពុកម្តាយខ្លួនឯង[3246]។

805. ពេលពន្យល់អំពីគោលនយោបាយរបស់ ប.ក.ក ស្តីពីការរៀបអាពាហ៍ពិពាហ៍ អតីតសមាជិកសម្ព័ន្ធយុវជនកម្ពុជា[3247] បាននិយាយថា៖ "ការរៀបការអាចចែកជាពីរដំណាក់កាល គឺបានន័យថាគេផ្អាកការរៀបការ ចាប់ពីឆ្នាំ៧០ ដល់ ៧៥ នៅក្នុងតំបន់រំដោះ។ ដំណាក់កាលទីពីរ ពីឆ្នាំ៧៦ ដល់ ៧៨ ប្រជាជនត្រូវបានចាប់ឲ្យរៀបការដោយបង្ខំ"[3248]។

---

គ្នាទៅវិញទៅមកទេ សូម្បីតែឪពុកម្តាយចំពោះកូនក៏ដោយ។ ទំនាក់ទំនងពីគ្រួសារទៅគ្រួសារ ឬពីភូមិមួយទៅភូមិមួយ ឬពីឃុំមួយទៅឃុំមួយ គឺត្រូវបានកាត់ផ្តាច់ទាំងស្រុង។ [...] ចំពោះអ្នកដែលមានគ្រួសារ ប្តីគេឲ្យទៅធ្វើការនៅកន្លែងផ្សេង ហើយប្រពន្ធគេឲ្យទៅធ្វើការនៅការដ្ឋានផ្សេងមួយទៀត ហើយយូរៗម្តង ដែលមានរយៈពេលច្រើនខែ ទើបគេអនុញ្ញាតឲ្យជួបគ្នាម្តង"]។ ឯកសារ D114/123 កំណត់ហេតុស្តាប់ចម្លើយ ជួន ធី ឆ.22។ ឯកសារ D234/2.1.34 កាទ្រីណា ណាថាលី "ខ្ញុំមានអារម្មណ៍ថាព្រលឹងខ្ញុំហោះចេញពីខ្លួន" EN ERN 00992134 ["ប្តី ប្រពន្ធ ឪពុកម្តាយ និងកូន ត្រូវបំបែកឲ្យធ្វើការខុសៗគ្នា"]។ ឯកសារ D54/74.1.20 ហ្វីលីព ហ្សុត ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ EN ERN 00396534, FR ERN 00639883។

3246 ឯកសារ D114/91 កំណត់ហេតុស្តាប់ចម្លើយ សេង អុល ឆ.72 ["ដូចជាកុមារា កុមារីតូចៗ ដែលប្រមូលពីឪពុកម្តាយឲ្យនៅជុំគ្នា ហើយមានគ្រូបង្រៀនពួកគេ"]។ ឯកសារ D114/297.1.30 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹក ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 09.42.07-09.44.30 ["នៅពេលដែលម្តាយបំបៅដោះកូន គេអនុញ្ញាតឲ្យកូន ទារកនោះនៅជាមួយម្តាយនៅពេលយប់ ហើយគេអាចជួបបាននៅពេលអាហារថ្ងៃត្រង់។ ហើយខុសពីពេលហ្នឹងគឺម្តាយហ្នឹងត្រូវបានគេបង្ខំឲ្យទៅធ្វើការ [...] នៅពេលដែលម្តាយឈប់បំបៅដោះកូនហើយ គេមិនឲ្យជួបកូនទេ"]។ ឯកសារ D234/2.1.68 អេលីហ្សាបេត បេកយ័រ ប្រតិចារឹក ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ ម៉ោង 10.43.55-10.46.21 ["កូនទាំងនោះ គេមិនឲ្យនិយាយថា ឪពុកម្តាយជាឪពុកម្តាយបង្កើតនោះទេ"]។ ឯកសារ D234/2.1.132 នឹម អ៊ឹម ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 15.12.23 ["កូនៗរបស់ខ្ញុំទាំងអស់នោះក៏អត់មែនកូនខ្ញុំដែរ [...] អង្គការអ្នកកាន់កាប់"]។ ឯកសារ D234/2.1.37 កាស៊ូមិ ណាកាហ្គាវ៉ា អំពើហិង្សាលើយេនឌ័រ KH ERN 00738344 ["អង្គការ បានអប់រំទាហានកុមារដើម្បីធ្វើជាគិញស៊ើបការណ៍ពីអ្វីដែល ឪពុកម្តាយរបស់ពួកគេបាននិយាយប្រឆាំងនឹងអង្គការដើម្បីរំលាយចំណងរវាងកូន និង ឪពុកម្តាយ"]។ ឯកសារ D234/2.1.34 កាទ្រីណា ណាថាលី "មានអារម្មណ៍ថាព្រលឹងខ្ញុំហោះចេញពីខ្លួន" EN ERN 00992134។

3247 ឯកសារ D114/75 កំណត់ហេតុស្តាប់ចម្លើយ ស៊ីន ស៊ីផល ឆ.64 ["ពីព្រោះខ្ញុំបានប្រឡូកនៅក្នុងអង្គភាព សម្ព័ន្ធយុវកក ដែលជាកម្លាំងស្នូលរបស់បក្ស"]។

3248 ឯកសារ D114/75 កំណត់ហេតុស្តាប់ចម្លើយ ស៊ីន ស៊ីផល ឆ.63។ សូមមើលផងដែរ ឯកសារ D114/75 កំណត់ហេតុស្តាប់ចម្លើយ ស៊ីន ស៊ីផល ឆ.71 ["ទីមួយគឺមិនមានការរៀបការឡើយ ទោះបីជាគេចង់ក៏ដោយ។ ទីពីរ

806. ប.ក.ក បានដកហូតពីប្រជាជនកម្ពុជានូវសិទ្ធិរៀបការដោយសេរីជាមួយដៃគូតាមការជ្រើសរើសរបស់ពួកគេ[3249]។ ការស្វែងរកគូស្រករដោយការស្រឡាញ់ ផលប្រយោជន៍គ្រួសារ ឬសុភមង្គលត្រូវបានមើលឃើញថាជា "កម្មសិទ្ធិឯកជន" ដែលផ្ទុយនឹងផលប្រយោជន៍សមូហភាពរបស់ប្រទេស[3250]។ អ្នកដែលផ្តល់តម្លៃទៅលើផលប្រយោជន៍គ្រួសារ ត្រូវបានចាត់ទុកថាប្រាសចាក និងលះបង់បដិវត្តន៍[3251] និងជាគោលដៅងាយស្រួលសម្រាប់ភ្នាក់ងារខ្មាំង[3252]។ ដូចអ្នកសារព័ត៌មាន

---

បើមាន គឺមានក្នុងលក្ខណៈជាការបង្ខំដោយអង្គការ"]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡន (ណាំ ឡាន) ឆ.202 ["ខ្ញុំដឹង គេមានបំណងចង់ពង្រីកចំនួនប្រជាជន។ អ្នកដែលស្នើចង់រៀបការពីឆ្នាំ១៩៧១-៧៥ គេមិនឲ្យរៀបការឡើយ ប៉ុន្តែដល់ពេលនោះ គេបង្ខំឲ្យមនុស្សឆាប់រៀបការឲ្យអស់ ដូចជារៀបការ៤គូក្នុងមួយយប់ជាដើម"]។

3249 ឯកសារ D234/2.1.14 នៅខាងក្រោយវាលពិឃាត៖ ដោយ Gina Chon និង ថេត សម្បត្តិ KH ERN 00858253 ["មូលដ្ឋាននៃការរៀបការក៏ត្រូវផ្លាស់ប្តូរដែរក្រោមរបបខ្មែរក្រហម ដើម្បីឲ្យស្របទៅនឹងសេចក្តីត្រូវការរបស់បក្ស។ [...] ទស្សនៈរបស់កូនកម្លោះកូនក្រមុំមិនមែនជាបញ្ហាធំដុំទេ។ ការរៀបការក្លាយជាគោលនយោបាយរបស់រដ្ឋាភិបាល ហើយជារចនាសម្ព័ន្ធមួយដែលបម្រើបុព្វហេតុបដិវត្តន៍"]។

3250 ឯកសារ D114/36.1.59 ឯកសារគោលនយោបាយកសាងគ្រួសារ EN ERN 00417942, KH ERN 00407100, FR ERN 00593929 ["សព្វថ្ងៃយុវជន យុវនារី យើងជាច្រើន ដែលជ្រួតជ្រាប នូវលោកទស្សនៈ វណ្ណៈជិះជាន់នេះ គេរើសរកគ្រួសារ ឬកសាងគ្រួសារ សុទ្ធតែដើម្បីបានលាភសក្ការៈផ្ទាល់ខ្លួន [...] គេស្វែងរកផលប្រយោជន៍ ឬសុភមង្គលគ្រួសារ ដោយផ្តាច់ចេញស្រឡះ ពីផលប្រយោជន៍ ពីជោគវាសនា នៃប្រទេសជាតិ នឹងប្រជាជនទាំងមូល"], EN ERN 00417943, KH ERN 00407100-01, FR ERN 00593930 ["បើនៅក្នុងជួរដូចគ្នា គឺត្រូវរើសអ្នកដែលមានគោលជំហរបដិវត្តរឹងប៉ឹង [...] ដូច្នេះ យើងមិនមែនរើសអ្នកណាដែលមានរូបសម្បត្តិល្អ ចេះស្លៀកពាក់ តុបតែងកាយ ហ៊ឺហាទាន់សម័យចក្រពត្តិ ឬជាកូនអ្នកមានសម្បត្តិទ្រព្យ ឬជាអ្នកមានសមត្ថភាពវប្បធម៌ សង្គមចាស់ខ្ពង់ខ្ពស់ ឬជាអ្នកមានសមត្ថភាពវប្បធម៌ [...] ឬមានតួនាទីដំណែងខ្ពង់ខ្ពស់នោះទេ"]។ ឯកសារ D4.1.919 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០០៩ KH ERN 00410172 ["ក្រោយឆ្នាំ១៩៧៩ [...] ខ្ញុំ បានជួប "អ្នកដែលបានរៀបការ" ដែលបានពន្យល់ខ្ញុំថាពួកគេត្រូវបានបង្ខំរៀបការជាមួយមនុស្សម្នាក់ដែលពួកគេមិនចង់ ហើយ ការរៀបការ គឺធ្វើជារួមគ្នា [...] តាម៉ុក ប្រមូលអនាគតប្តីប្រពន្ធជាច្រើនរយគូរ ហើយ បង្ខំឲ្យរៀបការរួមគ្នា"]។ ឯកសារ D4.1.886 ទង់បដិវត្ត លេខពិសេស កញ្ញា - តុលា ១៩៧៦ KH ERN 00063104 ["កម្មសិទ្ធិឯកជនក្នុងការចាត់តាំង ចាត់តាំងតាមមនោសញ្ចេតនារបស់ខ្លួន គ្រួសាររបស់ខ្លួន បក្សពួករបស់ខ្លួន មិនឈរលើមាគ៌ានយោបាយ សតិអារម្មណ៍ ចាត់តាំងរបស់បក្ស"]។ ឯកសារ D4.1.874 យុវជន និង យុវនារី បដិវត្ត នៅខែ វិច្ឆិកា ឆ្នាំ ១៩៧៥ KH ERN 00063617។ ឯកសារ D54/74.1.20 ហ្វីលីព ហ្សត ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ EN ERN 00396533, FR ERN 00639883។

3251 ឯកសារ D4.1.886 ទង់បដិវត្ត លេខពិសេស កញ្ញា - តុលា ១៩៧៦ KH ERN 00063104 ["កម្មសិទ្ធិឯកជន មិនដែលឲ្យបច្ច័យល្អទេ [...] កម្មសិទ្ធិឯកជនវាប៉ះពាល់ដល់ផលប្រយោជន៍បដិវត្ត [...] អ្នកណាគិតគូរផលប្រយោជន៍

Elizabeth Becker បានពន្យល់ "ពួកខ្មែរក្រហមដឹងខ្លួនថាត្រូវធ្វើឲ្យបារម្ភដោយលក្ខណៈគ្រប់បែបយ៉ាងនៃសេចក្តីស្រឡាញ់ ឬការជំពាក់ចិត្តៈ រវាងប្តី និងប្រពន្ធ ឪពុក និងកូន មិត្តភក្តិ និងសហសេវិក (អ្នកមានមុខការដូចគ្នា)។ មនុស្សទាំងអស់តោងតែជម្រុះជីវិតឯកជនរបស់ខ្លួនចោល"[3253]។

## តម្រូវការកំណើនប្រជាជន

807. ប្រជាជនកម្ពុជាថយចុះយ៉ាងឆាប់រហ័ស ជាផលវិបាកផ្ទាល់នៃគោលនយោបាយរបស់ ប.ក.ក។ អត្រាស្លាប់កើនឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារតែការសម្លាប់ និងលក្ខខណ្ឌធ្វើការ និងរស់នៅអមនុស្សធម៌[3254] ខណៈដែលអត្រាកំណើតធ្លាក់ចុះដោយសារតែការធ្វើការហួសកម្លាំង កង្វះអាហារ និងបញ្ហាសុខភាពផ្សេងទៀត[3255] ការរិតត្បិតតឹងរ៉ឹងទៅលើទំនាក់ទំនងផ្លូវភេទ[3256] និងការបំបែកប្តីប្រពន្ធចេញពីគ្នា ដែលគេកម្រអនុញ្ញាតឲ្យជួបមុខគ្នា[3257]។

---

គ្រួសារច្រើន តែងតែប្រាសចាកបដិវត្ត។ លះបង់បដិវត្ត រស់នៅដោយឡែក រកសុភមង្គលក្នុងគ្រួសារវិញ មិនរកសុភមង្គលក្នុងបក្សទេ [...] ទំនាស់ជាមួយបក្ស"]។ ឯកសារ D234/2.1.20 ការផ្សព្វផ្សាយបក្សកុម្មុយនីស្តកម្ពុជា សតិអារម្មណ៍នៃវណ្ណៈអធន អោយមុតស្រួច និង ខ្លាំងក្លាបំផុត KH ERN 00452455។

3252 ឯកសារ D114/36.1.59 ឯកសារគោលនយោបាយកសាងគ្រួសារ KH ERN 00407102 ["មិត្តយុវជន - យុវនារីបដិវត្តយើងត្រូវ [...] ប្រុងប្រយ័ត្នឲ្យមែនទែន ចំពោះបញ្ហាកសាងគ្រួសារនេះ។ បើសិនជាយើង មិនគោរពអង្គការ វិន័យមិនគោរពសមូលភាព មិនប្រកាន់គោលជំហរបដិវត្តរឹងប៉ឹង ហើយសេរីខាងសីលធម៌ពាសវាលពាលកាល នោះមុខជាកសាងគ្រួសារ មិនបានត្រឹមត្រូវល្អ តាមកន្លងមាគ៌ាបដិវត្ត យើងឡើយនោះមុខជានឹងប៉ះ ទៅលើសមាសភាពមិនល្អ ឬរហូតដល់ប៉ះ ទៅលើភ្នាក់ងារបង្កប់ របស់ខ្មាំងទៀតក៏មាន"]។ ឯកសារ D4.1.893 យុវជន និង យុវនារីបដិវត្ត លេខ ១០ តុលា ១៩៧៨ KH ERN 00376494 ["បើយើងប៉ះពាល់សីលធម៌នារីបុរស ដែលជាធាតុពិតពុករលួយស្អុយគគ្រុករបស់ខ្មាំងសត្រូវ [...] គ្រោះថ្នាក់ដល់ខ្លួន គ្រោះថ្នាក់ដល់ចលនាបដិវត្ត"]។

3253 ឯកសារ D1.3.17.1 អេលីហ្សាបែត បេកខ័រ នៅពេលដែលសង្គ្រាមរលត់ទៅ KH ERN 00232298។

3254 សូមមើល VIII.ឃ. មន្ទីរសន្តិសុខស-២១។ VIII.ក.៣. ប្រភេទសមាសភាពមិនល្អ និងខ្សែសមាសភាពនៅក្នុងកងពល ១៦៤ ដែលត្រូវបានបោសសម្អាត។ VIII.គ.៣. មន្ទីរសន្តិសុខវត្តឥន្ទញាន។ VIII.គ.៤. មន្ទីរសន្តិសុខទឹកសាប។ VIII.ង.ការដ្ឋានការងារស្ទឹងហាវ – ៣. ឧក្រិដ្ឋកម្ម [មនុស្សឃាត និងការបាត់ខ្លួនដោយបង្ខំ។ អំពីអមនុស្សធម៌ផ្សេងទៀត – ក) ការធ្វើប្រព្រឹត្តិ ដោយអមនុស្សធម៌]។ VIII.ច.ការដ្ឋានការងារតំបន់រាម – ៣.ឧក្រិដ្ឋកម្ម [មនុស្សឃាត ការសម្លាប់រង្គាល និងការបាត់ខ្លួនដោយបង្ខំ។ អំពើអមនុស្សធម៌ផ្សេងទៀត (ការប្រព្រឹត្តិដោយអមនុស្សធម៌)]។

3255 ឯកសារ D11/255/3.1 ហ៊ុន សុគន្ធនី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ម៉ោង 14.39.35-14.43.25 ["មិនដែលបានញុំាអីឆ្អែតទេ [...] ពីខែ៨ ខែ៩ ខែ១០ ខែ១១ ស្រីៗនៅភូមិខ្ញុំគ្មានរដូវទេ"]។ ឯកសារ D114/297.1.36 ង៉ែត

ចាត ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង 09.24.35-09.30.46 [“ខំប្ដេជ្ញាចិត្តយកគ្នាទី ខំបង្កកើតកូនឱ្យបានច្រើន ឱ្យបានមានកូនមានអីទៅ។ ខ្ញុំមានកូនទៅ បើមនុស្សស្គមហ្វបតែបបរ បានអីមានកូន បើអត់មានកម្លាំងកំហែងអីផង”]។ ឯកសារ D11/54/3.1 កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង 14.30.00-14.35.00 [ប្រពន្ធក្មេងរបស់គាត់បានរលូតកូន ដោយសារបាក់កម្លាំង និងគូផ្សេងដទៃទៀតគឺមានបទពិសោធន៍ដូចគ្នា]។ ឯកសារ D1.3.17.1 អេលីហ្សាបែត បេកខ័រ នៅពេលដែលសង្គ្រាមរលត់ទៅ KH ERN 00232298 [“ស្ត្រីភាគច្រើនលែមានរដូវ មួយផ្នែកគឺបណ្ដាលមកពីការបរិភោគអាហារមិនគ្រប់គ្រាន់ មួយផ្នែកទៀត គឺបណ្ដាលមកពីដំណើរប៉ះទង្គិចខាងផ្លូវចិត្ត”]។ ឯកសារ D114/36.1.64 កំណត់ហេតុស្ដាប់ចម្លើយ សេង អុល ឆ.16។ ឯកសារ D114/297.1.1 កំណត់ហេតុស្ដាប់ចម្លើយ រស់ ស៊ីយ ឆ.85-86 [“មូលហេតុទី១ គឺគេចង់ឱ្យមានការកើនឡើងនៃប្រជាពលរដ្ឋ [...] សូម្បីតែស្ត្រីឆ្លងទន្លេ ក៏គេមិនឱ្យទម្លាក់ឈាមពីក្នុងខ្លួនឱ្យអស់នោះទេ ព្រោះទុកដើម្បីឱ្យស្ត្រីនោះឆាប់មានកូនទៀត។ តាមប្រពៃណីខ្មែរ ស្ត្រីឆ្លងទន្លេហើយ ឆ្អបត្រូវបារឈោរអាក្រក់ឱ្យអស់ពីខ្លួនគាត់ដើម្បីមានសុខភាពល្អ និងកុំឱ្យជាំមុខ។ មួយវិញទៀត ស្ត្រីដែលមានកូនច្រើនហើយញឹក ក៏មិនមានសុខភាពល្អដែរ។ ប៉ុន្តែសម័យនោះគេចង់ឱ្យស្ត្រីមានកូនច្រើន”]។ ចំពោះទារកដែលរលូតបន្ទាប់ពីការរៀបការបង្ខំ ដោយសារតែការងារហួសកម្លាំង និងកង្វះខាតនៃការថែទាំសុខភាព សូមមើល ឧទាហរណ៍ ឯកសារ D114/297.1.36 ប្រតិចារឹក សយ ណារឿន ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង 10.53.06-10.58.05, 11.09.48-11.12.09។

3256 ឯកសារ D114/297.1.27 សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 15.06.43 [តំបន់២៥៖ “ខ្ញុំជួបរឿងផ្ទាល់អារឿងយុវជននារី នៅទ័ពជាមួយខ្ញុំ ហើយវាស្រឡាញ់គ្នាគេហៅថាខូចគ្នាហ្នឹង។ ស្រឡាញ់រួចលួចលាក់បាញ់គ្នាចោលហើយ”]។ ឯកសារ D114/95 កំណត់ហេតុស្ដាប់ចម្លើយ យឹម ស្រឿង ឆ.258 [“កាលណាពួកគេលួចស្រឡាញ់គ្នា ដោយខុសសីលធម៌នោះ ពួកគេនឹងមានទោស”]។ ឯកសារ D114/36.1.31 កំណត់ហេតុស្ដាប់ចម្លើយ ផាត់ ដួងច័ន្ទ KH ERN 00373395 [“អ្នកខូចសីលធម៌ មានន័យថា ស្រឡាញ់គ្នា លួចស្រឡាញ់គ្នា [...] គឺត្រូវយកទៅសម្លាប់ចោល”]។ ឯកសារ D114/34 កំណត់ហេតុស្ដាប់ចម្លើយ ណាប់ សុម៉ាលី ឆ.159-161។ ឯកសារ D114/32 កំណត់ហេតុស្ដាប់ចម្លើយ មាស សារ៉ាន ឆ.119 [“គេរំឭកយើងជាប្រចាំថាបើបុរសនារីដែលលួចទាក់ទងគ្នាដោយមិនទាន់រៀបការគឺគេថាខុសសីលធម៌ ហើយនឹងមានការដាក់ទោសចំពោះអ្នកនោះ។ ដូច្នេះ ម្នាក់ៗខ្លាចពុំហ៊ានធ្វើអ្វីដែលខុសនោះទេ”]។ ឯកសារ D4.1.817 កំណត់ហេតុស្ដាប់ចម្លើយ ប៊ុន ធៀន KH ERN 00368611 [“គេនិយាយពីប្ដីមួយប្រពន្ធមួយ បើអ្នកណាប្រព្រឹត្តិខុស ត្រូវតែកម្ទេច”]។ ឯកសារ D1.3.17.1 អេលីហ្សាបែត បេកខ័រ នៅពេលដែលសង្គ្រាមរលត់ទៅ KH ERN 00232298 [“ក្នុងសហករណ៍ និងភូមិភាគជាច្រើន ទំនាក់ទំនងខាងផ្លូវភេទស្នេហាមុនពេលរៀបអាពាហ៍ពិពាហ៍អាចទទួលរងនូវការផ្ដន្ទាទោសដល់ប្រហារជីវិត [...] ពួកយុវជនត្រូវរស់នៅដោយឡែកពីពួកយុវនារី។ គេសង្ឃឹមលើពួកនេះថានឹង [...] បំភ្លេចចោលភេទមួយទៀត។ ដូចដែលបានប្រមាណទុកជាមុន អត្រាកំណើតទារកបានធ្លាក់ចុះយ៉ាងសម្បើម”]។ ឯកសារ D234/2.1.37 កាស៊ូមិ ណាកាហ្គាវ៉ា អំពើហិង្សាលើយ៉េនឌ័រ KH ERN 00738344 [“គោលនយោបាយមួយទៀត គឺការហាមឃាត់នៃ “កំហុសសីលធម៌”។ បទល្មើសនៃ “កំហុសសីលធម៌” រាប់បញ្ចូលទាំងទំនាក់ទំនងរវាងបុរស និងស្ត្រី ដោយគ្មានការរៀបអាពាហ៍ពិពាហ៍។ [...] ការមានគភ៌ ដោយពុំមានអាពាហ៍ពិពាហ៍ ត្រូវបានចាត់ទុកថាជាកំហុសសីលធម៌ [...] ទោះបីជាជនរងគ្រោះនៃការចាប់រំលោភ ក៏ត្រូវទទួលទណ្ឌកម្មសម្រាប់ការប្រព្រឹត្តនូវ “កំហុសសីលធម៌” ដែរ], KH ERN 00738346 [“ពាក្យ

808. ថ្នាក់ដឹកនាំ ប.ក.ក ព្យាយាមជំរុញយ៉ាងខ្លាំងក្លាឱ្យអត្រាកំណើតមានការកើនឡើងពីរដង ឬបីដងនៃកម្លាំងពលកម្ម[3258]។ ភាពចាំបាច់នេះមានពីរផ្នែក៖ ១) ប្រទេសត្រូវការកម្លាំងពលកម្មបន្ថែមដើម្បីអភិវឌ្ឍសេដ្ឋកិច្ចកសិកម្មដែលត្រូវការកម្លាំងពលកម្មច្រើន[3259] និង ២) មេដឹកនាំត្រូវការទាហាន

---

ស្លោកមួយរបស់អង្គការពោលថា៖ "អង្គការចាត់តាំង (ដៃគូរបស់អ្នក)។ បើសិនជាអ្នកមិនគោរពតាមអង្គការចាត់តាំងទេ ត្រូវបញ្ជូនទៅរៀនសូត្រមួយរយៈ""]។ ឯកសារ D54/74.1.20 ហ្វីលីព ហ្សូត ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ EN ERN 00396533-34, FR ERN 00639883 ["ការរៀបការ [...] ជារបស់បក្ស មិនមែនជារឿងបុគ្គលនោះទេ]។ ឯកសារ D4.1.1003 Bridgette Toy-Cronin ៖"ខ្ញុំចង់និយាយប្រាប់អ្នក" KH ERN 00721360 ["ដោយសារតែទំនាក់ទំនងផ្លូវភេទបែបនេះ ធ្វើឱ្យប៉ះពាល់ដល់គោលបំណងរបស់បដិវត្តន៍។ ប្រសិនបើអង្គការរកឃើញថា មាននរណាម្នាក់បានបំពាននូវបម្រាមនេះ អង្គការនឹងដាក់ទណ្ឌកម្ម ឬសម្លាប់ទាំងពីរនាក់បុរសនិងស្ត្រីនោះ [...] អង្គការនឹងដាក់ទណ្ឌកម្ម ឬសម្លាប់ចោលទាំងជនរងគ្រោះ និងទាំងអ្នកចាប់រំលោភនោះផងដែរ ប្រសិនបើរកឃើញថាមានការរំលោភផ្លូវភេទមែន"]។

3257 សូមមើល VIII.ជ.៣.ការអនុវត្តគោលនយោបាយថ្នាក់ជាតិអំពីការរៀបការដោយបង្ខំ - ការឱ្យនៅបែកគ្នា។

3258 ឯកសារ D4.1.888 ទង់បដិវត្ត លេខពិសេស ធ្នូ-មករា ១៩៧៦-៧៧ KH ERN 00063054 [នួន ជា៖ "សារៈសំខាន់នៃបដិវត្តសង្គមនិយម និងការកសាងសង្គមនិយម មានទិសដៅកសាងប្រទេសបានល្អ ការពារប្រទេសបានល្អ និងដោះស្រាយជីវភាពប្រជាជនបានឆាប់រហ័ស។ យើងត្រូវការប្រជាជន ពី១៥ទៅ២០លានទើបគ្រប់គ្រាន់ និងដីយើង។ ដើម្បីឱ្យប្រជាជនកើនបានឆាប់ ទាល់តែជីវភាពឡើង សុខភាពបានល្អ។ ដូច្នេះ មានតែបង្កបង្កើនផលឱ្យបានរហ័ស"]។ ឯកសារ D4.1.864 ទង់បដិវត្ត លេខពិសេស កញ្ញា ១៩៧៧ KH ERN 00063184 ["យើងខំពុះពារបែបប៉ន [...] ហើយប្រជាជនកម្ពុជា កម្របានកើនឡើងជាលំដាប់ យ៉ាងឆាប់រហ័ស ដើម្បីការពារ និងកសាងកម្ពុជាយើង"]។ ឯកសារ D69.1.42 ខៀវ សំផន ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា KH ERN 00380467 ["ហ្សូត បានមើលឃើញ ត្រូវនៅពេលដែលគាត់សរសេរថា៖ "ប៉ុលពត [...] មានទិសដៅ បង្កើនចំនួនប្រជាជនខ្មែរជាពីរ ឬបីដង។ ជាក់ស្តែងគាត់ចង់ឱ្យប្រជាជនកម្ពុជាកើនទៅដល់ "១៥ឬ២០លាននាក់ក្នុងរយៈ១០ឆ្នាំខាងមុខនេះ""]។ ឯកសារ D234/2.1.22 លិខិតរបស់ អៀង សារី លិខិតផ្ញើរជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ KH ERN 00701216 ["បីឆ្នាំបន្ទាប់ [...] គោលនយោបាយ ដែលបានបង្កើត ដើម្បីបង្កើនចំនួនប្រជាជន បានចាប់ផ្តើមដើម្បីផលិតចេញលទ្ធផលជោគជ័យទីមួយរបស់ខ្លួន"]។ ឯកសារ D1.3.17.1 អេលីហ្សាបែត បេ៊កខ័រ នៅពេលដែលសង្គ្រាមរលត់ទៅ KH ERN 00232298។ ឯកសារ D4.1.1003 Bridgette Toy-Cronin ៖"ខ្ញុំចង់និយាយប្រាប់អ្នក" KH ERN 00721390។

3259 ឯកសារ D4.1.872 ទង់បដិវត្ត លេខពិសេស តុលា-វិច្ឆិកា ១៩៧៥ KH ERN 00063246 ["ប្រែក្លាយប្រទេសយើង ពីកសិកម្មថយទៅជាកសិកម្មសម័យឱ្យឆាប់រហ័សពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ។ ពីកសិកម្មទៅឧស្សាហកម្ម ពី១៥ឆ្នាំ ទៅ ២០ឆ្នាំ [...] [ការពន្លឿនក្នុងការកសាងប្រទេសឡើងវិញ] សំណូមពរមួយទៀត គឺដើម្បីប្រជាជនយើងមានចំនួនកើនឆាប់រហ័ស" ]។ ឯកសារ D4.1.864 ទង់បដិវត្ត លេខពិសេស កញ្ញា ១៩៧៧ KH ERN 00063184។ ឯកសារ D234/2.1.40 កំណត់ហេតុនៃកិច្ចពិភាក្សាដេញដោល នួន ជា ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ KH ERN 00148677 ["ធ្វើបដិវត្ត ត្រូវការប្រជាជន ហើយ កសាងប្រទេស ត្រូវការប្រជាជនដែរ"]។

បន្ថែមជាច្រើនាក់ទៀតដើម្បីការពារប្រទេស និងជាពិសេស ដើម្បីធ្វើសង្គ្រាមជាមួយនឹងប្រទេសវៀតណាម។

809. មេដឹកនាំ ប.ក.ក បានពិភាក្សាជាសាធារណៈអំពីតម្រូវការទាំងនេះ ដោយប្រកាសថា កម្ពុជាប្រជាធិបតេយ្យត្រូវការប្រជាជន ១៥ ទៅ ២០ លាននាក់ក្នុងរយៈពេលពី ៥ ទៅ ១០ ឆ្នាំ ទើប "គ្រប់គ្រាន់នឹងដីយើង"[3260] ជាគោលបំណងហួសវិស័យ។ ប៉ុល ពត និង ខៀវ សំផន បានពន្យល់

[3260] ឯកសារ D4.1.888 ទង់បដិវត្ត លេខពិសេស ធ្នូ-មករា ១៩៧៦-៧៧ KH ERN 00063054 [ "កសាងប្រទេសបានល្អ ការពារប្រទេសបានល្អ និងដោះស្រាយជីវភាពប្រជាជនបានឆាប់រហ័ស។ យើងត្រូវការប្រជាជន ពី១៥ទៅ២០លាន ទើបគ្រប់គ្រាន់ និងដីយើង"]។ ឯកសារ D4.1.864 ទង់បដិវត្ត លេខពិសេស កញ្ញា ១៩៧៧ KH ERN 00063183-84 ["យើងត្រូវការឲ្យមានប្រជាជនកម្ពុជាចំនួនពី ១៥ លាន ទៅ ២០លាននាក់ ក្នុងកំឡុងជាង ១០ ឆ្នាំខាងមុខនេះ [...] សព្វថ្ងៃ ចំនួនប្រជាជនយើងជិត ៨ លាននាក់ នៅឆ្ងាយណាស់ ពីលទ្ធភាពរបស់ប្រទេសយើង ដែលត្រូវការមានប្រជាជនកម្ពុជា ជាង ២០លាននាក់"]។ ឯកសារ D4.1.189 លិខិតរបស់ អៀង សារី ផ្ញើជូនមហាសន្និបាត អង្គការសហប្រជាជាតិ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៧៧ KH ERN 00291028 កថាខណ្ឌ ៦០, ៦៣ ["យើងត្រូវការប្រជាជនចំនួន១៥ទៅ២០លាននាក់ ក្នុងរយៈពេល១០ឆ្នាំខាងមុខ [...] 63៖ [...] ចំនួនប្រជាជនយើង នៅខ្វះច្រើនណាស់ធៀបនឹងសមត្ថភាពរបស់ប្រទេសយើង ដែលត្រូវការប្រជាជនជាង២០លាននាក់"]។ ឯកសារ D234/2.1.40 កំណត់ហេតុនៃកិច្ចពិភាក្សាជេញដោល នួន ជា ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៧ KH ERN 00148677 ["ក្នុងផែនការ៥ឆ្នាំរបស់បក្ស គឺបង្កើនប្រជាជនឲ្យបាន១៥ លាននាក់"]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន (ណាំ ឡាន) ឆ.204 ["ផែនការរបស់ពួកគេគឺចង់ពង្រីកចំនួនប្រជាជនឲ្យដល់២០លាននាក់ត្រឹមឆ្នាំ២០០០ជាង"]។ ឯកសារ D54/74.1.6 ហ្វីប៊ីស សុន្ទរកថារបស់ ប៉ុល ពត ក្នុងមីទ្ទីងរំឭកខួបរបស់បក្សកុម្មុយនីស្តកម្ពុជា ថ្ងៃទី ២៧ ខែ កញ្ញា EN ERN 00168651។ ឯកសារ D234/2.1.33 កំណត់ហេតុរបស់ ខៀវ សំផន ចុះថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ១៩៧៨ KH ERN S 00249991 [ខៀវ សំផន រៀបចំបញ្ជីដំណោះស្រាយ ដែលត្រូវបានអនុម័តដោយបក្ស រួមមាន៖ "(៦) បង្កើនបរិមាណប្រជាជនឲ្យដល់កម្រិតអតិបរមារបស់ខ្លួន ដើម្បីសម្រេចតាមគោលដៅឲ្យមានប្រជាជនចំនួនពី ១៥ទៅ ២០.០០០.០០០ នាក់ក្នុងរយៈពេលពី ១០ ទៅ ១៥ឆ្នាំខាងមុខ" និង (៧) "បង្កើនបរិមាណប្រជាជនសម្រាប់រយៈពេលមួយឆ្នាំ បីឆ្នាំ ប្រាំឆ្នាំ ១០ឆ្នាំ និង១៥ឆ្នាំ"]។ ឯកសារ D4.1.1013 កំណត់ហេតុរបស់សមមិត្ត ប៉ុល ពត ជាមួយគណៈប្រតិភូសមាគម បែលស៊ិក-កម្ពុជា ថ្ងៃទី ៥ ខែ សីហា ឆ្នាំ ១៩៧៨ KH ERN 00106284។ ឯកសារ D4.1.871 ទង់បដិវត្ត លេខ កញ្ញា ១៩៧៨ KH ERN 00064617-18 [ប៉ុល ពត៖ "នយោបាយបង្កើនប្រជាជន របស់យើងកំពុងទទួលបានលទ្ធផលល្អ [...] ពីពាក់កណ្ដាលឆ្នាំ១៩៧៧ ដល់ពាក់កណ្ដាលឆ្នាំ១៩៧៨ ចំនួនទារក ដែលកើតថ្មី មានចំនួន ៣៩២.០០០នាក់ ក្នុងចំនួនមនុស្ស ៧.៨០០.០០០នាក់។ [...] បច្ចុប្បន្ននេះ ចំនួនមនុស្សដែលស្លាប់ទៅវិញ មានមិនដល់ ១៣ភាគពាន់ទេ ដោយបច្ចុប្បន្ននេះ ចំនួនទារក និងកុមារស្លាប់មានការថយច្រើន។ ដូច្នេះ ចំនួនប្រជាជនយើងមានការកើនល្បឿន ជាងកាលជំនាន់មុខរដ្ឋប្រហារ។ ប៉ុន្តែ ល្បឿននេះមិនទាន់គ្រប់គ្រាន់ទេ បើប្រៀបធៀប និងសំណូមពររបស់បក្ស ដែលសំដៅបង្កើនប្រជាជនបានពី ១៥ ទៅ ២០ លាន់នាក់ ក្នុងរយៈពី១០ទៅ១៥ឆ្នាំ"]។ ឯកសារ D64.1.44

នៅសម័យកម្ពុជាប្រជាធិបតេយ្យថា គោលបំណងនេះត្រូវសម្រេចឱ្យបានជាពិសេស តាមរយៈការរៀបចំអាពាហ៍ពិពាហ៍[3261] ហើយការណែនាំពាក់ព័ន្ធត្រូវបានបញ្ជូនទៅកម្មាភិបាល សម្រាប់

---

ហ្វ៊ីប៉ីស សន្និបាតវេជ្ជសាស្ត្រទូទាំងប្រទេសផ្សព្វផ្សាយនូវសេចក្ដីសម្រេចចិត្តនានា ០៩ វិច្ឆិកា ១៩៧៨ EN ERN 00170124។ នៅក្នុងចលនាឃោសនា នួន ជា បានប្រកាសក្នុងឆ្នាំ១៩៨១ ថា ចំនួនប្រជាជនកម្ពុជាប្រជាធិបតេយ្យបានកើនឡើងក្នុងឆ្នាំ១៩៧៧, ១៩៧៧ និង១៩៧៨។ សូមមើល ឯកសារ D234/2.1.38 សេចក្ដីសង្ខេបនៃពាក្យត្រូវផ្សាយ បទសម្ភាសន៍ជាមួយមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ (នួន ជា) ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៨១ KH ERN S 00644682 ["ផែនការរយៈពេលបួនឆ្នាំ ១៩៧៧-១៩៨០ មានគោលបំណងបង្កើនចំនួនប្រជាជនឱ្យឡើងដល់យ៉ាងហោចណាស់ ១៥,០០០,០០០នាក់ នៅក្នុងរយៈពេលពី ៥ ទៅ ១០ឆ្នាំ។ ជាលទ្ធផលនៃផែនការនេះចំនួនប្រជាជនរបស់យើងបានកើនឡើងដូចតទៅ: ចាប់ពីខែមិនាដល់ខែធ្នូឆ្នាំ១៩៧៦ កម្ពុជាបានបង្កើនប្រជាជនចំនួន ១៦០,០០០នាក់ ឬ ២%: នៅក្នុងឆ្នាំ១៩៧៧ កម្ពុជាបានបង្កើនចំនួនប្រជាជន ២២០,០០០នាក់ ឬ ២.៨% និងនៅក្នុងឆ្នាំ១៩៧៨ កម្ពុជាបានបង្កើនចំនួនប្រជាជន ២៦០,០០០នាក់ ឬ៣.២%"]។

[3261] ឯកសារ D114/297.1.28 ជា ខៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 13.47.14-13.51.10 ["[អំឡុងពេលប្រជុំនៅវត្តខណ្ឌាលោម] គាត់ [ខៀវ សំផន] និយាយថា "សូមស្នើសមមិត្តនារីយុវជនទាំងអស់ប្រឹងធ្វើការជូនរដ្ឋ ហើយយុវជនដែលយុវជននារីដែលមានអាយុពី ១៨ឆ្នាំឡើងទៅ ឱ្យតាមកម្មាភិបាល តាមមុខក្រសួងទាំងអស់ឱ្យរៀបចំឱ្យមានគ្រួសារទៅ" គាត់ថាអ៊ីចឹង កុំទុកឱ្យនៅច្រើនពេក [...] គាត់មិនបាននិយាយថា ស្រឡាញ់គ្នាស្រឡាញ់អីទេ គាត់គ្រាន់តែប្រាប់ថាឱ្យរៀបចំគ្រួសារទៅ តាំងពីអាយុ ១៨ឡើងទៅ យុវជនអាយុ២៥ អីទុកធ្វើអីទៀត។ ស្នើតាមក្រសួងមន្ទីរទាំងអស់ឱ្យគិតគូររៀបការយុវជននារីឱ្យអស់ទៅ [...] គាត់ថា [...] រៀបការទៅ ដើម្បីបង្កើតកូន កើតចៅឱ្យបានគ្នា [...] បានកូនចៅច្រើនទៅ ដើម្បីជាកម្លាំងការពារប្រទេសជាតិ [...] ការពី -- ក្រោយពីគាត់និយាយរួច មិនទាន់បានប៉ុន្មានផងពួកយើងខ្ញុំក៏ត្រូវរៀនការជំនាន់ខ្មែរក្រហមនោះដែរ"] ម៉ោង 15.02.15-15.06.03 ["ស៖ [...] លោក ខៀវ សំផន ហ្នឹង ការដែលគេឱ្យរៀបការហ្នឹង គោលដៅសំខាន់ហ្នឹង [...] គេចង់បង្កើតកូនមែនទេ? ឆ៖ គាត់បាននិយាយអ៊ីចឹងទៅ ហើយក៏និយាយទៅមិនថាត្រឹមតែគាត់មួយទេ ប្រជុំរៀនសូត្រកន្លែងណា ក៏លើកតែអ៊ីចឹងដែរ មិនថាតែគាត់មួយទេ គឺអ៊ីចឹងតែម្ដង។ កម្មាភិបាលណាក៏លើកតែអ៊ីចឹង ឱ្យតែពេលប្រជុំពេលរៀនសូត្រ"]។ ឯកសារ D4.1.1056 កំណត់ហេតុស្ដាប់ចម្លើយ ជួន ធី ឆ.4 [មេបញ្ជាការកងវរសេនាធំ កងពលតូចលេខ១ សំដៅទៅកិច្ចប្រជុំខែ មិថុនា ឆ្នាំ ១៩៧៨៖ ប៉ុល ពត ក៏បានបន្ថែមថា "យើងត្រូវបង្កើនចំនួនប្រជាជនក្នុងរយៈពេល១០ ទៅ ២០ឆ្នាំ ឱ្យបានពី ២០ ទៅ ៣០ លាននាក់ ដើម្បីការពារប្រទេស"។ ក្នុងន័យនេះ ប៉ុល ពត បានបញ្ជាក់ថា គាត់តម្រូវឱ្យមានអាពាហ៍ពិពាហ៍ ដើម្បីបង្កើនចំនួនប្រជាជន ដោយឱ្យថ្នាក់ក្រោមបង្គាប់ជាអ្នករៀបចំអាពាហ៍ពិពាហ៍របស់ប្រជាជន"]។ ឯកសារ D114/123 កំណត់ហេតុស្ដាប់ចម្លើយ ជួន ធី ឆ.21, 28, 32, 35 ["តាមខ្ញុំចាំ ប៉ុល ពត បាននិយាយថា យើងត្រូវការបន្ថែមកម្លាំង [...] គម្រោងក្នុងរយៈពេល ១០ ទៅ ២០ឆ្នាំទៅមុខត្រូវបង្កើនចំនួនប្រជាជនឱ្យបាន២០ ទៅ៣០លាននាក់។ ដូច្នេះ ចាប់ពីពេលនេះតទៅ គឺយើងត្រូវតែបង្កើតឱ្យមានការរៀបការរវាងយុវជននិងនារី ដើម្បីជំនឿប្រជាជន [...] ឆ.28៖ ប៉ុល ពត [...] គឺគ្រាន់តែនិយាយថាឱ្យមានការរៀបការដើម្បីបង្កើនចំនួនប្រជាជនប៉ុណ្ណោះ [...] ឆ.32៖ គេគ្រាន់តែប្រាប់ថាឱ្យយើងរៀបចំការឱ្យពួកក្មេងៗ [...] ឆ.35៖ ក្នុង

ការរៀបចំអាពាហ៍ពិពាហ៍ និងធានាថា ពួកគេរួមដំណេកជាមួយគ្នា[3262]។ យោងតាម ជួន ធី គោលនយោបាយនេះចូលជាធរមានចាប់ឆ្នាំ ១៩៧៥ ទៅ[3263]។ ដោយសារការប្រទូសរ៉ាយគ្នា

---

ពេលនោះ គោលនយោបាយជំរឿនប្រជាជននេះ គឺសាយភាពគ្រប់ទីកន្លែងទាំងអស់ គឺដោយសារគេមានសរសេរជាពាក្យស្លោក និងដាក់គ្រប់ទីកន្លែង ហើយនិងប្រកាសនៅក្នុងអង្គប្រជុំ អំពីការកសាងកម្លាំង និងបង្កើនចំនួនប្រជាជនឱ្យបាន ២០ ទៅ ៣០លាននាក់"]។ សូមមើលផងដែរ ឯកសារ D234/2.1.14 នៅខាងក្រោយវាលពិឃាត៖ ដោយ Gina Chon និង ថេត សម្បត្តិ EN ERN 00757496, FR 00849377-74, KH 00858253-54 ["ដោយសារពួកគេចង់ឱ្យមានកំណើនប្រជាជនទ្វេដង ពួកខ្មែរក្រហមក៏បង្កើនចំនួនរៀបការ [...] ទស្សនៈរបស់កូនកម្លោះកូនក្រមុំមិនមែនជាបញ្ហាធំដុំទេ។ ការរៀបការក្លាយជាគោលនយោបាយរបស់រដ្ឋាភិបាល ហើយជារចនាសម្ព័ន្ធមួយដែលបម្រើបុព្វហេតុបដិវត្តន៍"]។

3262 ឯកសារ D114/297.1.25 ស៊ូ សុធាវី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៦ ម៉ោង 15.05.01 ["ដល់គេឡើងប្រកាស គេថាប្រជាជនកម្ពុជាឥឡូវខ្សត់ខ្សោយទៅហើយ ហើយអ្នកឯងរាល់គ្នាទាំងអស់គ្នាហ្នឹង ទាំងមិត្តយុវជន យុវនារី ខំប្រឹងធ្វើការណាស់ អ៊ីចឹងអង្គការឱ្យអ្នកឯងរៀបការ ដើម្បីត្រូវការប្រជាជន ត្រូវបន្តវេនទៅថ្ងៃមុខ។ អ៊ីចឹងពួកយើងបានស្រងាកចិត្តថា ថ្ងៃនេះជាថ្ងៃគេចាប់រៀបការ"] ម៉ោង 15.11.26 ["ខ្ញុំបានប្តេជ្ញាថា "ដើរតាមអង្គការដ៏មានគុណ ដែលបានរៀបចំគ្រួសារឱ្យខ្ញុំ ខ្ញុំនឹងដឹកដៃគ្នាឱ្យមានកូន មានចៅ ដូចអង្គការចង់បាន"។ ខ្ញុំប្តេជ្ញាអ៊ីចឹង តែប៉ុណ្ណឹងឯង។ ខ្ញុំដឹងប្តេជ្ញាអីទៀត ហើយក៏គេទះដៃអបអរសាទរ"] ម៉ោង 15.17.12 ["និយាយតែរឿងបង្កើតកូនឱ្យអង្គការ។ គោរពអង្គការ ជឿជាក់លើអង្គការ អ្នកណាក្បត់ចិត្តអង្គការនឹងសម្លាប់ចោល"]។ ឯកសារ D234/2.1.96 មាស រឿន ប្រតិចារឹក ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ ម៉ោង 10.40.55-10.45.23 ["ស៖ តើការជំរុញឱ្យកងទ័ព [កងពលធំលេខ ១] រៀបការហ្នឹង វាពាក់ព័ន្ធទៅនឹងឆន្ទៈរបស់ថ្នាក់ដឹកនាំក្នុងការបង្កើនចំនួនប្រជាជននៅប្រទេសកម្ពុជា មែនទេ? ឆ៖ បាទ មែន"]។ ឯកសារ D234/2.1.137 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុខឿន ឆ.31 ["មុនពេលចាប់ផ្តើមការរៀបការនេះ គឺ ស្វ បានប្រកាស [...] "អង្គការត្រូវការកម្លាំងបន្ថែម" ដូច្នេះ គេត្រូវការឱ្យយុវជន យុវនារីរៀបការ ដើម្បីបង្កើតកូនបន្ថែមទៅលើកម្លាំងកសាងបដិវត្តន៍"]។ ឯកសារ D114/297.1.1 កំណត់ហេតុស្តាប់ចម្លើយ រស់ ស៊ុយ ឆ. 85-86 [ក្រសួងពាណិជ្ជកម្ម៖ "គេចង់ឱ្យមានការកើនឡើងនៃប្រជាពលរដ្ឋ [...] ឆ.86៖ គេមានគំនិតមួយចង់បង្កើនចំនួនប្រជាពលរដ្ឋឱ្យបានច្រើន សូម្បីតែស្ត្រីឆ្លងទន្លេ ក៏គេមិនឱ្យទម្លាក់ឈាមពីក្នុងខ្លួនឱ្យអស់នោះទេ ព្រោះទុកដើម្បីឱ្យស្ត្រីនោះឆាប់មានកូនទៀត។ [...] ស្ត្រីដែលមានកូនច្រើនហើយញឹក ក៏មិនមានសុខភាពល្អដែរ។ ប៉ុន្តែ [...] គេចង់ឱ្យស្ត្រីមានកូនច្រើន"]។ ឯកសារ D234/2.1.88 ប្រតិចារឹក ប្រាក់ យុត ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 13.41.13-13.44.17 ["ស៖ តើគូស្រករប្តីប្រពន្ធដែលគេរៀបការជាមួយគ្នាហ្នឹង តើគេតម្រូវឱ្យរួមដំណេកជាមួយគ្នាទេ? ឆ៖ បើកាលណាការហើយ បើយើងគិតទៅ វាត្រូវតែរួមដំណេក ឬក៏បើមិនរួមដំណេក ក៏យើងថា ការយ៉ាងម៉េច។ [...] ស៖ [...] នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់គឺឯកសារ E3/9507 ត្រង់ចម្លើយលេខ៨០ [យូ វ៉ាន់] បានឆ្លើយដូចតទៅ៖ "សួរ៖ អ្នកណាជាអ្នកកំណត់វិន័យហ្នឹងថា ដែលប្តីប្រពន្ធហ្នឹងត្រូវតែដេកជាមួយគ្នា? ឆ្លើយ៖ ប្រាក់ យុត ប្រាប់ខ្ញុំថា តាអាន លេខាតំបន់ប្រាប់ថា អ្នកដែលរៀបការហើយ គឺថាត្រូវតែរួមដំណេកជាមួយគ្នា។ ចាំបាច់ណាស់ត្រូវតែរួមដំណេកជាមួយគ្នា ដើម្បីឱ្យប្រទេសជាតិជឿនលឿន។" លោកស្រីនៅចាំទេថា តាអាន បានប្រកាសពីបទបញ្ញាហ្នឹង ថា

ជាមួយនឹងវៀតណាមបានឡើងកម្តៅខ្លាំង នៅឆ្នាំ ១៩៧៧-១៩៧៨ បញ្ហានេះក្លាយជារឿងបន្ទាន់ខ្លាំង ហើយចំនួនអាពាហ៍ពិពាហ៍ទូទាំងប្រទេសបានកើនឡើងទៅតាមនោះដែរ[3264]។ រស់ ស៊ុយ កម្មាភិបាលមកពីក្រសួងពាណិជ្ជកម្ម បានពន្យល់ថា អង្គភាពក្រសួងរបស់គាត់ត្រូវបានកំណត់ឲ្យរៀបចំអាពាហ៍ពិពាហ៍ឲ្យបានជាអប្បបរមាតាមផែនការកំណត់ប្រចាំខែ[3265]។ ដូច្នេះ ប្រសិនបើ

---

ប្ដីប្រពន្ធដែលរៀបការហ្នឹង គឺត្រូវតែរួមដំណេកជាមួយគ្នាដើម្បីការរីកចម្រើនរបស់ប្រទេសជាតិ? ឆ៖ កាលនោះ ខ្ញុំមិនបានចាំទាំងអស់ទេ តែមិនដឹងថាគាត់បានប្រកាស ឬមិនប្រកាស"]។

3263 ឯកសារ D114/303 កំណត់ហេតុស្តាប់ចម្លើយ ជួន ធី ឆ.22, 24, 26-27, 30, 57, 60 ["ស៖ តើលោកនៅចាំដែរទេថាលោកបានបញ្ជាក់ថាគោលបំណងនៃការរៀបការទាំងនោះគឺដើម្បីបង្កើនប្រជាជនពី១០ទៅ២០ឆ្នាំខាងមុខ គឺឲ្យបានពី១០ ទៅ២០លាននាក់? ឆ.22៖ ខ្ញុំចាំ គឺដូចខ្ញុំថា គឺមានអ៊ីចឹងមែន។ ហើយខ្ញុំក៏មានគេរៀបគ្រួសារឲ្យ ក៏ក្នុងពេលហ្នឹងដែរ [...] ស៖ ដែលយើងចង់ដឹងថាគឺថា តើគោលការណ៍នេះគឺបង្កើតនៅឆ្នាំ១៩៧៥ ពេលខ្មែរក្រហមបានអំណាចហើយភ្លាមៗ ឬក៏ក្នុង១៩៧៦ ឬ១៩៧៧? [...] ឆ.24៖ តាមដឹង គឺគេប្រកាសពេលដែលរំដោះហើយ គឺឆ្នាំ១៩៧៥ ១៩៧៦មកម្លេះ [...] ស៖ តើលោកបានដឹងពីគោលនយោបាយតាមរបៀបណាដែលថាគេចង់បង្កើនប្រជាជន? ឆ.26៖ តាមគេប្រជុំ [...] ឆ.27៖ ប្រជុំហ្នឹង គឺរបៀបទូលាយដែរ ចំហរទូលំទូលាយ គឺគ្រប់អង្គការទាំងអស់គឺត្រូវដឹងតែម្ដង [...] ឆ.30៖ ប្រជុំធ្វើមីទីងហ្នឹង គឺឈ្មោះ ប៉ុល ពត ហ្នឹងតែម្ដង [...] ស៖ លោកបានបញ្ជាក់ថាគោលការណ៍រៀបការតាំងពីដំបូងមកគឺពី៧៥ ទៅ៧៨ តើត្រឹមត្រូវទេ? ឆ.57៖ ត្រឹមត្រូវ [...] ស៖ តើពេលណាដែលលោកបានទទួលការណែនាំ ឬផែនការដំបូងឲ្យរៀបការយុវជននោះ? ឆ.60៖ បញ្ជាក់បន្ថែម គឺពី៧៥"]។

3264 ឯកសារ D114/297.1.28 ជា ខៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 13.48.32 ["ស៖ ដែល [ខៀវ សំផន] និយាយពាក្យថា យុវជន យុវនារី ដែលចាស់ៗហើយឲ្យរៀបការ។ អ៊ីចឹងគាត់មានដែលមានបានពន្យល់ប្រាប់នៅពេលដែលកំពុងតែនិយាយថា យុវជន យុវនារី រៀបការ? ឆ៖ គាត់ថា [...] រៀបការទៅ ដើម្បីបង្កើតកូន កើតចៅឲ្យបានគ្នា [...] ដើម្បីជាកម្លាំងការពារប្រទេសជាតិ"]។ ឯកសារ D234/2.1.22 លិខិតរបស់កម្ពុជាប្រជាធិបតេយ្យផ្ញើជូនអង្គការសហប្រជាជាតិ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ១៩៧៨ KH ERN 00701215-16 ["ធានាថា ប្រជាជនកម្ពុជាកើនឡើងយ៉ាងឆាប់រហ័សដើម្បីការពារ និងអភិវឌ្ឍន៍ប្រទេស និងសម្រេចបានភាពរុងរឿងមហាលោតផ្លោះមហាអស្ចារ្យ [...] ចំនួនប្រជាជន៨លាននាក់សព្វថ្ងៃនេះគឺមានកម្រិតទាបជាងសក្ដានុពលប្រទេស ដែលត្រូវការចំនួនប្រជាជនជាង២០លាននាក់ឯណោះ"]។ ឯកសារ D114/123 កំណត់ហេតុស្តាប់ចម្លើយ ជួន ធី ឆ.30 [កងពលធំ១ មេបញ្ជាការកងវរសេនាធំ៖ "ក្នុងអង្គភាពខ្ញុំរៀបការបានប៉ុន្មានគូត្រូវរាយការណ៍ទៅខាងលើ [...] ដោយសារពេលនោះសភាពការណ៍កំពុងច្របូលច្របល់ក្នុងឆ្នាំ ៧៨-៧៩ គឺគេបង្ខំឲ្យមានការរៀបការច្រើនគូ"]។ ឯកសារ D114/297.1.1 កំណត់ហេតុស្តាប់ចម្លើយ រស់ ស៊ុយ ឆ.77-78, 84, 90-91 ["ការរៀបការគឺចាប់ធ្វើតាំងពីឆ្នាំ១៩៧៦ តែវិធានការតឹងរឹង អនុវត្តចាប់ពី១៩៧៧ [...] គឺមានន័យថាមួយខែរៀបការឲ្យបានមួយរយគូ"]។

3265 ឯកសារ D114/297.1.1 កំណត់ហេតុស្តាប់ចម្លើយ រស់ ស៊ុយ ឆ.75-78, 84-85, 90 ["មានផែនការឲ្យមួយអង្គភាព (ក្រសួងឃ្លាំង) ត្រូវរៀបការមួយរយគូក្នុងមួយខែ [...] ឆ.77៖ ការរៀបការគឺចាប់ធ្វើតាំងពីឆ្នាំ១៩៧៦ តែវិធានការតឹង

ប្រជាជនដល់វ័យមួយច្បាស់លាស់ (២០ ឆ្នាំសម្រាប់ស្ត្រី និង ២៥ ឆ្នាំសម្រាប់បុរស) "ពួកគេត្រូវរៀបការ"[3266] ទោះបីជាការកម្រិតអាយុត្រូវបានបញ្ចុះនាពេលក្រោយ[3267] និងមានករណីជាច្រើនទៀតដែលនារីក្មេងៗត្រូវបានបង្ខំឲ្យរៀបការនៅគ្រប់ទីន្លែងក្នុងប្រទេស រួមទាំងនៅកំពង់សោមដែរ[3268]។

810. ស្របតាមគោលដៅបង្កើនចំនួនប្រជាជន ប្តីប្រពន្ធត្រូវបានតាមដានភ្លាមៗក្រោយពួកគេរៀបការរួចដើម្បីធានាថាពួកគេរួមដំណេកជាមួយគ្នា[3269]។

---

រឹង អនុវត្តចាប់ពី១៩៧៧ [...] ឆ.78៖ គឺមានន័យថាមួយខែរៀបការឲ្យបានមួយរយគូ។ [...] ឆ.84៖ ខ្ញុំគិតថាគឺចេញពីប្រធានក្រសួងហ្នឹងតែម្តង។ [...] ឆ.85៖ គេចង់ឲ្យមានការកើនឡើងនេះប្រជាពលរដ្ឋ [...] ឆ.90៖ ខ្ញុំគ្រាន់តែដឹងថាឈ្មោះ វីត ហៅ រឿង នេះបានបញ្ជាមកឲ្យមេរបស់ខ្ញុំ ហើយមេរបស់ខ្ញុំបញ្ជាឲ្យខ្ញុំរៀបចំឡាន [...] ការរៀបការមួយរយគូក្នុងមួយខែនេះ មិនមែនមានន័យថារៀបការមួយលើកមួយរយគូនោះទេ ក្នុងមួយខែអាចរៀបការបីដង" ]។

3266 ឯកសារ D4.1.810 កំណត់ហេតុស្តាប់ចម្លើយ សេង សឿន ឆ.65, 67 ["ខ្ញុំធ្លាប់ធ្វើជាអ្នកផ្គុំប្រុស និងស្រី ហើយប្រុសត្រូវតែមានអាយុពីរ ឬបីឆ្នាំ ចាស់ជាងស្រី។ [...] ឆ.៖ នោះគឺជាគោលនយោបាយរបស់ខ្មែរក្រហមដែរថា នៅពេលមនុស្សដល់អាយុរៀបការពួកគេត្រូវរៀបការ។ ចំពោះស្ត្រីត្រូវមានអាយុ២០ឆ្នាំឡើង និងបុរសត្រូវមានអាយុពី២៥ឆ្នាំឡើង (សង្កត់ន័យបន្ថែម)"]។ សូមមើលផងដែរ ឯកសារ D114/297.1.1 កំណត់ហេតុស្តាប់ចម្លើយ រស់ ស៊ុយ ឆ. 75។

3267 ឯកសារ D144/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.29 ["ខ្ញុំចង់ជម្រាបលោកផងដែរថា ច្បាប់ដែលមិនឲ្យមនុស្សអាយុតិចជាង២៥ឆ្នាំរៀបការ ត្រូវបានបន្ធូរបន្ថយ នៅចុងឆ្នាំ១៩៧៨"]។

3268 ឯកសារ D114/64 កំណត់ហេតុស្តាប់ចម្លើយ អែម សារិន ឆ.189-191, 199 [ការរៀបការដោយបង្ខំ មានអាយុពី១៥ទៅ១៦ឆ្នាំ នៅពេលដែលគាត់មានអាយុ២៩ ឬ៣០ឆ្នាំ"]។ ឯកសារ D114/38 កំណត់ហេតុស្តាប់ចម្លើយ ជុំ រឹម ឆ.91 [បងធី គ្រាន់តែប្រាប់ថា គេស្នើឲ្យរៀបការ ចាប់ពីអាយុ ១៥ឆ្នាំឡើងទៅ"]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.32 ["អាយុរបស់បង ពៅ និង តាសេង ខុសគ្នាឆ្ងាយណាស់។ បង ពៅ មានអាយុ១៨ ឬ១៩ឆ្នាំ ដែលប្រហាក់ប្រហែលនឹងខ្ញុំ។ ចំណែក តាសេង គាត់មានអាយុជាងសែសិបឆ្នាំទៅហើយ"]។ ឯកសារ D114/170 កំណត់ហេតុស្តាប់ចម្លើយ ព្រុំ ម៉ុន ឆ.15 ["ប្រហែលជាអាយុ១៩ឆ្នាំ"]។ ឯកសារ D114/129 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម ហុន ឆ.73 ["ពេលនោះ ខ្ញុំមានអាយុ១៦ឆ្នាំ ចូល១៧ឆ្នាំហើយ"]។ ឯកសារ D4.1.472 កំណត់ហេតុស្តាប់ចម្លើយ អះម៉ាត់ សហ្វីយ៉ាស់ ហៅ សហ្វីយ៉ាស់ KH ERN 00204407 ["ខ្ញុំបានរៀបការពេលខ្ញុំមានអាយុ ១៧ឆ្នាំ ខ្មែរក្រហមបានប្រាប់ខ្ញុំអំពីមនុស្សប្រុសដែលខ្ញុំត្រូវរៀបការជាមួយ"]។ ឯកសារ D4.1.927 កំណត់ហេតុស្តាប់ចម្លើយ ហេង ឡៃប៊ាង ឆ.30 ["ខ្ញុំមានអាយុទើបតែដប់ប្រាំបីឆ្នាំប៉ុណ្ណោះ ខ្ញុំមិនចង់រៀបការទេ"]។

3269 សូមមើល កថាខណ្ឌ ៨១៩, ជើងទំព័រ ៣៣០៩។

## ៣. ការអនុវត្តគោលនយោបាយថ្នាក់ជាតិស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

### ការរៀបចំ

811. ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រាល់ទម្រង់ប្រពៃណីបានរលាយបាត់ ហើយជាទូទៅ គ្រួសារពុំមានតួនាទីអ្វីក្នុងការរៀបអាពាហ៍ពិពាហ៍ទៀតឡើយ[3270]។ ជំនួសមកវិញ អង្គការជាអ្នកកំណត់ថា *តើ* ត្រូវរៀបការឬទេ ត្រូវរៀបការ*នៅពេលណា* និងជាមួយ*អ្នកណា*។ ទោះជាលក្ខណៈពិសេសនៃដំណើរការមានភាពខុសគ្នាក៏ដោយ ក៏មានចំណុចដូចគ្នាមួយ គឺការគ្រប់គ្រង*ទាំងស្រុង*ដោយអង្គការ[3271]។

---

[3270] ឯកសារ D114/297.1.28 ជា ឡៅ ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 13.54.56-13.56.31 ["ខ្ញុំមិនដែលបានពិភាក្សាជាមួយម៉ែឪបងប្អូនទេ [...] ទោះបីសុំគេទៅ ក៏គេមិនទៅ ក៏គេមិនឲ្យទៅដែរ គឺស្រេចតែអង្គការតែហ្នឹងហ្នឹង"]។ ឯកសារ D234/2.1.137 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុខឿន ឆ.22។ ឯកសារ D114/33 កំណត់ហេតុស្តាប់ចម្លើយ ហែម អាង ឆ.175។

[3271] ឯកសារ D234/2.1.74 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ឆ.222 ["គេត្រូវមើលថា សមាសភាពហ្នឹងស្អាតស្អំដូចគ្នាទើបអាចនៅជាមួយគ្នាបាន។ គេចង់គ្រប់គ្រងប្រជាជន ព្រោះគេខ្លាចថាប្រជាជនទាំងនោះអាចក្លាយជាខ្មាំងនៅពេលក្រោយ។ សូម្បីតែខ្ញុំផ្ទាល់ខ្ញុំក៏មិនអាចរៀបការអ្នកដែលខ្ញុំស្រឡាញ់បានផង"]។ ឯកសារ D234/2.1.37 កាស៊ូមិ ណាកាហ្គាវ៉ា អំពើហិង្សាលើយ៉េនឌ័រ KH ERN 00738344 ["គ្មានអាពាហ៍ពិពាហ៍ណាមួយត្រូវបានធ្វើឡើងដោយគ្មានសេចក្តីបង្គាប់ដោយអង្គការឡើយ។ ពាក្យស្លោកមួយរបស់អង្គការពោលថា៖ "អង្គការចាត់តាំង (ដៃគូរបស់អ្នក)។ បើសិនជាអ្នកមិនគោរពតាមអង្គការចាត់តាំងទេ ត្រូវបញ្ជូនទៅរៀនសូត្រមួយរយៈ"។ អាពាហ៍ពិពាហ៍មិនមែនជាបញ្ហាបុគ្គលទេ [...] វាត្រូវបានត្រួតពិនិត្យយ៉ាងហ្មត់ចត់ដោយអង្គការនៅថ្នាក់ភូមិ"]។ ឯកសារ D114/297.1.29 ប្រតិចារឹក កាស៊ូមិ ណាកាហ្គាវ៉ា ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 13.32.33 ["ក្នុងសម័យខ្មែរក្រហម [...] ដើម្បីទទួលបានការអនុញ្ញាតរៀបការ មានន័យថាឲ្យការរៀបការរបស់ខ្លួនហ្នឹងស្របច្បាប់"]។ ឯកសារ D234/2.1.137 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុខឿន ឆ.34 ["នៅពេលដែលប្រធានកងខាងប្រុស ចង់បាននារីណារៀបការជាមួយនឹងយុវជន គេឲ្យខាងប្រធានកងនារីអ្នករើសនារីផ្គូផ្គងឲ្យខាងប្រុស [...] យុវជន ហើយនិងយុវនារីដែលត្រូវរៀបការគឺមិនបានដឹងខ្លួនជាមុនទេ គឺរហូតដល់ថ្ងៃរៀបការតែម្តង។ ពេលខ្លះ នៅពេលដែលគេមិនអាចរកឃើញមនុស្សដែលគេដៅឈ្មោះឲ្យរៀបការ គេបានជ្រើសរើសនារីផ្សេងយកមកជំនួសទៅវិញ"]។ ឯកសារ D4.1.1003 Bridgette Toy-Cronin ៖"ខ្ញុំចង់និយាយប្រាប់អ្នក" KH ERN 00721380។ ឯកសារ D114/297.1.16 Rochelle Braaf ៖អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម EN ERN 00992278។ ឯកសារ D54/74.1.20 ហ្វីលីព ហ្សូត ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់មួយ EN ERN 00396533-34, FR ERN 00639883 ["សេរីភាពនៃការជ្រើសរើសប្តីប្រពន្ធ" ត្រូវបានហាមឃាត់យ៉ាងពិតប្រាកដ"]។

812. ពេលអាជ្ញាធរត្រូវផ្គូផ្គងគូស្រករ ពួកគេត្រូវបានណែនាំឱ្យធ្វើដូច្នេះ ដោយផ្អែកលើវណ្ណៈនយោបាយ ជាតិសាសន៍ និងសាវតារដូចគ្នា[3272]។ បន្ទាប់មក មតិយោបល់ត្រូវបានលើកឡើង និងឯកភាព ឬ ច្រានចោលដោយអាជ្ញាធរ ប.ក.ក/កងទ័ពបដិវត្តន៍កម្ពុជាមានឋានៈខ្ពស់[3273]។ កម្មាភិបាលតំបន់

---

[3272] ឯកសារ D114/36.1.59 ឯកសារគោលនយោបាយកសាងគ្រួសារ EN ERN 00417943, KH ERN 00407101, FRE ERN 00593930 [សម្រាប់សមាជិកគណៈបក្ស ឬសម្ព័ន្ធយុវជន៖ "ត្រូវពិនិត្យមើលប្រវត្តិរូប ឱ្យបាន ច្បាស់លាស់សិន។ ពោលគឺ ត្រូវស្អាតទាំងសីលធម៌រស់នៅ ស្អាតទាំងខាងនយោបាយ គ្មានជំពាក់វាក់វិន នឹងខ្សែខ្មាំង ឬ ជាមួយពួកសមាសភាពមិនល្អ [...] បើនៅក្នុងជួរដូចគ្នា គឺត្រូវរើសអ្នកដែលមាន គោលជំហរបដិវត្តរឹងប៉ឹង"]។ ឯកសារ D114/297.1.23 ប្រតិចារឹក ម៉ឹង វិត ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ ម៉ោង 09.59.18 [តំបន់១៣៖ "ដូចថា ឥឡូវនារីគាត់ជនចម្រើន ឬក៏ ស.ក ដូចសម្ព័ន្ធយុវកក [...] ខាងបុរសនេះ ខ្ញុំមានសិទ្ធិស្នើនារីហ្នឹងហើយ [...] អាហ្នឹង រឿងដែលថា ដូចថាអារឿងប្រវត្តិរូបវាត្រឹមត្រូវអីចឹងហើយ"] ម៉ោង 10.02.35 ["សម្ព័ន្ធយុវកក ជនចម្រើន សម្ព័ន្ធយុវ កក បក្ខជន។ អាហ្នឹងក្នុងអង្គប្រជុំ តែមិនមានក្រដាសស្នាមអីទេ គឺជាអង្គភាពប្រជុំ [...] ដូចថាឥឡូវ ខ្ញុំត្រូវស្រឡាញ់ ឈ្មោះ "ក" នារី១៧ ខ្ញុំយកទៅបាន បើតាមការយល់នោះ ព្រោះយកម៉េច បើគេបង្ខំឱ្យទៅយកឯណោះ ឯណាផ្សេងអី ចឹងទៅ"]។ ឯកសារ D11/255/3 មាស ឡៃហួរប្រតិចារឹក ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ ម៉ោង 09.31.25-09.37.43 ["ប្រសិនបើបុរសនោះមាន យើងមិនត្រូវបានចាប់គូគ្នាទេ ពិព្រោះប្រវត្តិខុសគ្នា [...] ប្រវត្តិផ្សេងគ្នា[...] ចាមយកចាមគ្នាឯង"]។ ឯកសារ D234/2.1.76 អ៊ុំ ជី ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៥ ម៉ោង 14.12.58 ["គេធ្វើប្រវត្តិរូបឱ្យស្របគ្នា បើមិនស្របគ្នាមិនឱ្យការ។ អីចឹងទាល់តែប្រវត្តិរូបវាធាតុកសិករ កសិករដូចគ្នា។ ពួកវណ្ណៈថ្នាក់លើ ថ្នាក់លើដូចគ្នា ក្រោមៗដូចគ្នា"] ម៉ោង 14.14.55 ["បើមកពីភ្នំពេញដូចគ្នា គេអនុញ្ញាតឱ្យយកទៅ [...] ជនជាតិចាម គឺយកជនជាតិចាម"]។ ឯកសារ D114/297.1.27 សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 09.59.48-10.03.22, 11.04.12 ["កាលឱ្យខ្ញុំផ្គងផ្គូសួរប្រវត្តិរូបខាងកងចល័ត ទាំងខាងប្រុស ខាងស្រី ហ្នឹង ខ្ញុំគ្រាន់ជាអ្នកផ្គូផ្គងទេ [...] ហើយបើជនថ្មី ជនជាតិចាស់ ថ្មី ចាស់អីហ្នឹងក៏ដោយឡែក"]។ ឯកសារ D114/297.1.28 សេង សឿន ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 11.17.37។ ឯកសារ D234/2.1.128 ណុប ងឹម ប្រតិចារឹក ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 10.46.12។ ឯកសារ D114/297.1.26 ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 09.43.44។ ឯកសារ D4.1.1003 ឯកសារ D4.1.537 កំណត់ហេតុស្តាប់ចម្លើយ ឱ ហូ KH ERN 00239911 [អ្នកថ្មីរៀបការជាមួយអ្នកថ្មី អ្នកចាស់រៀបការជាមួយអ្នក ចាស់ ចាមរៀបការជាមួយចាម ចិនរៀបការជាមួយចិន]។ ឯកសារ D4.1.926 កំណត់ហេតុស្តាប់ចម្លើយ សេង ចុន KH ERN 003390287។ ឯកសារ D4.1.810 កំណត់ហេតុស្តាប់ចម្លើយ សេង សឿន ឆ.65-66, 69។ ឯកសារ D114/36.1.63 កំណត់ហេតុស្តាប់ចម្លើយ ឃី ហ៊ុន KH ERN 00189233។ ឯកសារ D11/231/4 កំណត់ហេតុស្តាប់ ចម្លើយ ស៊ុំ ចាន់ថុល ឆ.120។ ឯកសារ D4.1.1003 Bridgette Toy-Cronin ៖ "ខ្ញុំចង់និយាយប្រាប់អ្នក" KH ERN 00721380។

[3273] ឯកសារ D234/2.1.87 យូ វ៉ាន់ ប្រតិចារឹក ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ ម៉ោង 11.29.24-11.32.17 ["គឺខាងបុរស គេស្នើទៅដល់ភូមិ ដល់ក្រុមរបស់គេ។ បានគេទាក់ទងគ្នាទៅ បានត្រូវគ្នាទៅក៏បញ្ជូនមកមន្ទីរស្រុក ទៅរៀបការទៅ"]

និងភូមិភាគត្រូវបានគេប្រាប់អំពីចំនួនគូដែលត្រូវរៀបការ ក្នុងតំបន់ពួកគេ តាមរយៈសេចក្តីរាយការណ៍ដែលបញ្ជូនទៅពួកគេទៅតាមខ្សែចង្វាក់ដើម្បីពិនិត្យ។ សេចក្តីរាយការណ៍អំពីការរៀបអាពាហ៍ពិពាហ៍ក៏ត្រូវបានធ្វើឡើងដោយភូមិភាគទៅមជ្ឈិមបក្សផងដែរ[3274]។

## ការបង្ខំឱ្យរៀបការ

813. ក្នុងករណីជាច្រើន ការរៀបអាពាហ៍ពិពាហ៍កម្មាភិបាល យោធា និងប្រជាជនស៊ីវិលធម្មតាក្នុងទ្រង់ទ្រាយធំ ត្រូវបានអង្គការរៀបចំតែឯកឯង ដោយមិនពិគ្រោះជាមុនជាមួយអ្នកពាក់ព័ន្ធ ឬពិគ្រោះដែរ តែតិចតួចបំផុត។ ជាធម្មតា នៅថ្ងៃប្រារព្ធពិធី ឬមុនហ្នឹងបន្តិច ប្រធានអង្គភាពការងារ ឬអាជ្ញាធរមូលដ្ឋានផ្សេងទៀតប្រាប់ប្រជាជនថា ពួកគេនឹងត្រូវរៀបការ និងតម្រូវឱ្យពួកគេមាន

---

។ ឯកសារ D114/146 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ឹក (អ៊ុយ ញ៉ឹក) ឆ.38-40 [“នៅពេលនោះ ខ្ញុំបានដាក់សំណើរបស់ខ្ញុំដើម្បីរៀបការដែរ [...] ឆ.39៖ សំណើរបស់ខ្ញុំនោះ ដាក់ក្នុងឆ្នាំ១៩៧៦ នៅហ្នឹងរាម ពេលដែលខ្ញុំនៅក្នុងកងពល១៦៤ [...] ឆ.40៖ មុនដំបូង យើងត្រូវធ្វើប្រវត្តិរូបសង្ខេបដាក់ទៅជាមួយនឹងការស្នើរបស់យើង។ យើងត្រូវដាក់បញ្ចូលនូវឈ្មោះកងរបស់យើង ឧទាហរណ៍ដូចជាខ្ញុំនៅក្នុងកងពល១៦៤ បើខ្ញុំចង់រៀបការជាមួយនឹងនារីណាម្នាក់នៅហ្នឹងតំបន់ ឬក៏នៅកងផ្សេង ខ្ញុំត្រូវដាក់សំណើរបស់ខ្ញុំទៅឱ្យកន្លែងគេ រួចហើយគេពិនិត្យមើលសំណើរបស់ខ្ញុំ និងប្រវត្តិរូបរបស់ខ្ញុំ។ បើគេឃើញមានការសង្ស័យត្រង់ណាមួយ នៅលើប្រវត្តិរូបរបស់ខ្ញុំ គេនឹងមិនអនុញ្ញាតទៅតាមសំណើររបស់ខ្ញុំទេ”]។ ឯកសារ D4.1.810 កំណត់ហេតុស្តាប់ចម្លើយ សេង សឿន ឆ.69 [ស្រុកស្អាង៖ “ខ្ញុំបានមើលប្រវត្តិរូប ហើយសរសេរឈ្មោះដែលអ្នកដែលត្រូវបានរៀបការ ហើយបន្ទាប់មកខ្ញុំប្រគល់ឈ្មោះនោះទៅឱ្យគណៈស្រុកដើម្បីប្រកាសថា ឱ្យអ្នកណាត្រូវរៀបការជាមួយអ្នកណា”]។ ឧទាហរណ៍ ការបដិសេធនៃការរៀបអាពាហ៍ពិពាហ៍៖ ឯកសារ D114/297.1.8 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ឆ.164 [កងពលធំលេខ ១១៧៖ “ បុរសពេលខ្លះស្នើរៀបការជាមួយនារី “ក” តែដល់ពេលរៀបការត្រូវរៀបការជាមួយនារី “ឃ” [...] ហើយគូទាំងនោះមិនអាចប្រកែកបានឡើយ”]។ ឯកសារ D234/2.1.74 កំណត់ហេតុស្តាប់ចម្លើយ មួល អេង ឆ.223-225 [យោធាបានបង្ខំឱ្យរៀបការជាមួយស្ត្រីម្នាក់ដែលគាត់មិនស្គាល់ បន្ទាប់ពីមេបញ្ជាការកងវរសេនាធំបដិសេធមិនឱ្យគាត់រៀបការជាមួយនារីដែលគាត់ស្រឡាញ់ ដោយសារតែគាត់ ជាសាច់ញាតិរបស់ទាហាន លន់ នល់]។

3274 ឯកសារ D4.1.650 របាយការណ៍ពី ម-៤០១ ជូនទៅ អង្គការ ចុះថ្ងៃទី ៤ ខែ សីហា ឆ្នាំ ១៩៧៨ EN ERN 00315383, FR ERN 00593538, KH ERN 00143617។ ឯកសារ D4.1.647 របាយការណ៍ពី ម-៤០១ ជូនទៅ អង្គការ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ១៩៧៨ EN ERN 00289924, FR ERN 00611450, KH ERN 00143579។ ឯកសារ D114/123 កំណត់ហេតុស្តាប់ចម្លើយ ជួន ធី ឆ.30 [កងពលធំ១ មេបញ្ជាការកងវរសេនាធំ៖ “ក្នុងអង្គភាពខ្ញុំរៀបការបានប៉ុន្មានគូត្រូវរាយការណ៍ទៅខាងលើ ហើយអង្គភាពគេក៏ធ្វើដូចគ្នាដែរ។ ដោយសារពេលនោះសភាពការណ៍កំពុងច្របូលច្របល់ក្នុងឆ្នាំ ៧៨-៧៩ គឺគេបង្ខំឱ្យមានការរៀបការច្រើនគូ”]។

វត្តមានក្នុងពិធី[3275]។ ជារឿយៗ រឿងនេះកើតមានឡើង ក្រោយពេលអ្នកដែលត្រូវបានជ្រើសរើសឱ្យរៀបការ ត្រូវបានប្រាប់ថាពួកគេត្រូវគោរពតាមបញ្ជារបស់អង្គការ[3276]។ អ្នកដែលត្រូវបានជ្រើសរើសឱ្យរៀបការមួយចំនួនមិនបានទទួលការជូនដំណឹងជាមុនទេ។ ពួកគេគិតថាពួកគេមកចូលរួមប្រជុំ ប៉ុន្តែ ពួកគេចេញទៅវិញជាមួយប្តី ឬប្រពន្ធរបស់ពួកគេទៅវិញ[3277]។ ភាគច្រើន ពួក

---

3275 ឯកសារ D114/297.1.29 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 14.01.59 ["គឺមានគំរូផ្សេងៗ ប៉ុន្តែពិធីដ៏ទូទៅជាងគេហ្នឹងគឺថា បុរសនិងស្ត្រីបានទទួលដំណឹងថា គេនឹងរៀបការឱ្យពួកគាត់ គឺថាដូចជាគេប្រាប់ពីព្រឹក ល្ងាចគេរៀបការ។ ឬក៏គេអាចប្រាប់មួយថ្ងៃមុនៗ ពិធីរៀបការនោះត្រូវបានរៀបចំឡើង គឺជាពិសេសនៅពេលល្ងាច នៅថ្ងៃនោះឯង គឺជាការជូនដំណឹងខ្លីណាស់ គឺថាក្នុងរយៈពេល២៤តែប៉ុណ្ណឹងទេ"]។ ឯកសារ D114/297.1.28 ប្រតិចារឹក ជា ឌៀប ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 13.53.07 ["ក្រោយពីសួរខ្ញុំ មេហ្នឹងសួរខ្ញុំរួចទៅ រយៈកាលនុ៎ង គេប្រាប់ថាបីថ្ងៃទៀត ខ្ញុំត្រូវទៅរៀបការ"]។ ឯកសារ D234/2.1.125 ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 10.09.47 [ទាហានភូមិភាគបូព៌ា៖ "ខ្ញុំទើបតែបានមុនថ្ងៃរៀបការគេប្រកាសថ្ងៃរៀបការហ្នឹងមួយថ្ងៃគត់"], ម៉ោង 14.15.36 ["តែដល់មុនការមួយថ្ងៃហ្នឹង [...] បានប្រធានកងចល័តហ្នឹង គេប្រាប់។ បានខ្ញុំតាមឈ្មោះហ្នឹង ថាខ្ញុំហ្នឹងបានរៀបការជាមួយនឹងគូ"]។ ឯកសារ D234/2.1.76 ប្រតិចារឹក ឃិន វ៉ាត ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៥ ម៉ោង 09.36.48 ["ព្រឹកនេះម៉ោងប្រាំ មិត្តឯងចាប់រៀបខ្លួនទៅ [...] ខ្ញុំអត់ទាន់ស្គាល់គាត់ទេ"]។ ឯកសារ D114/297.1.27 សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 09.56.58-09.59.48 KH ERN 01355175 [ដើមបណ្តឹងរដ្ឋប្បវេណីទទួលខុសត្រូវការរៀបចំការរៀបការក្នុងស្រុកស្អាង ខេត្តកណ្តាល ភូមិភាគនិរតី៖ "ខ្ញុំគ្រាន់តែគិតក្នុងចិត្តទេ សាមីខ្លួនដែលត្រូវរៀបការយុវជន យុវនារីទាំងអស់ហ្នឹង គ្មានដឹងខ្លួនអីទេ [...] ស្រេចលើប្រធានទេ គេជិតដល់ថ្ងៃហ្នឹងហើយ គេហៅទៅ ឈ្មោះនេះឈ្មោះនោះមកនៅជួបជុំនៅមន្ទីរស្រុក [...] រហូតដល់ -- អាហ្នឹងបើនិយាយអ៊ីចឹងថា គ្មានដឹងខ្លួនទេ ទាំងប្រុសទាំងស្រី ស្រាប់តែដល់ថ្ងៃហ្នឹងគេហៅ ក្រែងទៅរៀនសូត្រ អីក៏ប្រជុំ ក៏មិនដឹងអីទេ ស្រាប់តែទៅដល់ល្មម"]។ ឯកសារ D234/2.1.137 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុខឿន ឆ. 13, 23។ ឯកសារ D114/297.1.16 Rochelle Braaf ៖អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម EN ERN 00992279, 00992281-82។

3276 ឯកសារ D234/2.1.137 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុខឿន ឆ.13 ["ពេលដែលខ្ញុំមកដល់ភ្លាម [នី លី ប្រធានចល័ត] បានសួរខ្ញុំថា តើខ្ញុំនឹងធ្វើតាមបញ្ជារបស់អង្គការឬទេ? ខ្ញុំបានប្រាប់ទៅគាត់វិញថា ខ្ញុំជាកម្មសិទ្ធិរបស់អង្គការដូច្នេះ ខ្ញុំត្រូវតាមអង្គការទោះបីជាអង្គការឱ្យខ្ញុំចូលរូងក្តាមក៏ខ្ញុំចូលដែរ"]។ ឆ.28, ឯកសារ D4.1.740 កំណត់ហេតុស្តាប់ចម្លើយ មួរ សេដ្ឋា KH ERN 00365596 ["ក្នុងឆ្នាំ១៩៧៨ [...] មេកងឈ្មោះ រឿន បានសួរខ្ញុំថាតើខ្ញុំដើរតាមអង្គការទេ ឆ្លើយថាខ្ញុំដើរតាមអង្គការ។ ថ្ងៃបន្ទាប់ទៀត អង្គការរៀបចំការប្រជុំធំមួយដើម្បីរៀបការប្តីប្រពន្ធប្រហែលជា៣០គូ រួមទាំងខ្ញុំផង"]។

3277 ឯកសារ D234/2.1.128 ណុប ងឹម ប្រតិចារឹក ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 11.18.03 [នៅស្រុកសំឡូត៖ "គឺថ្ងៃរៀបការហ្នឹង គឺពួកខ្ញុំអត់មានដឹងទាំងអស់ ខាងយុទ្ធជនក៏អត់ដឹងដែរ ខាងបុរសក៏អត់ដឹង ខាងនារីក៏អត់ដឹងដែរ អត់សោះ"]។ ឯកសារ D11/54/3.1 ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង 15.57.50 [នៅស្រុក

គេទាំងនោះមិនដែលជួបប្ដី ឬប្រពន្ធរបស់ពួកគេ មុនពិធីរៀបអាពាហ៍ពិពាហ៍ទេ ហើយអ្នកខ្លះទៀត ក្រោយមក មិនទាំងអាចស្គាល់ប្ដី ឬប្រពន្ធរបស់ខ្លួនឯងបានផង[3278]។ ក្នុងចំណោមជនរងគ្រោះទាំង

---

បាកាន ខែសីហា ឆ្នាំ១៩៧៨៖ ខ្ញុំក៏អត់មានចាប់អារម្មណ៍ថា គូខ្ញុំមួយណា ខ្ញុំអត់ដឹងដែរ”]។ ឯកសារ D114/297.1.36 សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង 10.36.24-10.44.57 [“ខ្ញុំក៏សួរថា សួរមិត្តកងថា គេធ្វើអីច្រើនម្ល៉េះមិត្ត? ថាបន្តិចទៀតមិត្តឯងដឹងហើយ ថ្នាក់លើចុះមកធ្វើអង្គមីទ្និង [...] ឃើញមិត្តបុរសហ្នឹងអង្គុយមួយជួរ នារីអង្គុយមួយជួរ។ នាងខ្ញុំឆ្ងល់ដែរ [...] ក្រោយមកទៀត ក៏ថ្នាក់លើគាត់ [...] ឲ្យពួកខ្ញុំហ្នឹងឡើងប្ដេជ្ញាចិត្ត [...] ខ្ញុំដឹងថា គេហៅខ្ញុំមករៀបគ្រួសារ ឬម៉េច បានជាគេហៅម្ដងមួយគូ ឲ្យចាប់ដៃគ្នាប្ដេជ្ញាចិត្តនៅមុខថ្នាក់លើ។ ខ្ញុំមានអារម្មណ៍ភ័យ មានអារម្មណ៍ខ្លាច [...] នាងខ្ញុំមានអារម្មណ៍ឈឺចាប់ណាស់ ឈឺចាប់ត្រង់ថា ហេតុអីក៏ចាប់មនុស្សបញ្ចូកដូចជាសត្វគោ ចាប់យកទៅទឹម ដោយមិនបានស្គាល់មុខ”]។ ឯកសារ D114/297.1.27 សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 09.56.58 [“ស្វាមីខ្លួនដែលត្រូវរៀបការយុវជន យុវនារីទាំងអស់ហ្នឹង គ្មានដឹងខ្លួនអីទេ [...] គ្មានដឹងខ្លួនទេ ទាំងប្រុសទាំងស្រី ស្រាប់តែដល់ថ្ងៃហ្នឹងគេហៅ”]។ ឯកសារ D114/297.1.29 កាស៊ូមិ ណាកាហ្កាវ៉ា ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 13.46.30 [“និយាយឲ្យងាយយល់ទៅ គឺថាដូចអង្គប្រជុំមួយអ៊ីចឹង។ គឺថាគេប្រមូលមនុស្សមកប្រជុំមក ហើយ [...] គឺជាការរៀបការហើយ”]។ ឯកសារ D114/297.1.25 ស៊ូ សុធាវី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៦ ម៉ោង 15.05.01។ ឯកសារ D114/87 កំណត់ហេតុស្ដាប់ចម្លើយ ឈូក រីន ឆ.71 [កងពលធំលេខ២៣០៖ “ខ្ញុំត្រូវគេដាក់រៀបការឲ្យដោយមិនដឹង។ ខ្ញុំមិនស្គាល់ខាងស្រីទេ”]។ ឯកសារ D4.1.806 កំណត់ហេតុស្ដាប់ចម្លើយ ជាំង ស្រីមុំ ឆ.8 [“ខ្ញុំមានការតក់ស្លុតយ៉ាងខ្លាំងនៅពេលដែលគេមកប្រាប់ថា ខ្ញុំត្រូវរៀបចំខ្ញុំឲ្យរៀបការនៅពេលយប់នេះ។ អុល ប្រាប់ខ្ញុំថា ខ្ញុំត្រូវរៀបការជាមួយឈ្មោះ ទ្រី ទូច [...] ខ្ញុំស្អប់គាត់ខ្លាំងណាស់ [...] ខ្ញុំជឿថា ខ្ញុំមិនមានជម្រើសអ្វីផ្សេងទេ។ ក្នុងចិត្តរបស់ខ្ញុំ ខ្ញុំយំនិងកើតទុកជាខ្លាំង [...] ទ្រី ទូច [...] អត់ដឹងពីការរៀបការទេ”]។ ឯកសារ D10.1.65 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុក ភន KH ERN 00368662 [“អង្គការបានហៅខ្ញុំថាទៅប្រជុំ ពេលទៅដល់គេបានរៀបចំឲ្យខ្ញុំប្ដេជ្ញា ពេលនោះគណៈស្រុកប្រាប់ថា មិត្តឯងត្រូវគោរពតាមអង្គការចាត់តាំង”]។ ឯកសារ D234/2.1.74 កំណត់ហេតុស្ដាប់ចម្លើយ មូល អេង ឆ. 20, 208, 211។ ឯកសារ D114/32 កំណត់ហេតុស្ដាប់ចម្លើយ មាស សារ៉ាន ឆ.2, 6, 10, 13 [“ក្រោយពីបានទៅដល់រោងកុន ខ្ញុំមានការភ្ញាក់ផ្អើល [...] ខ្ញុំក៏បានសួរ [...] គេកំពុងតែរៀបចំពិធីការ។ ខ្ញុំចង់រត់ពីទីនោះដែរ ប៉ុន្តែខ្ញុំមិនអាចរត់រួចពីព្រោះទាហាន [កងពលធំលេខ៣/១៦៤]”]។ ឯកសារ D54/29 កំណត់ហេតុស្ដាប់ចម្លើយ លៀត ឡូន (ណាំ ឡូន) ឆ.3, 6។

[3278] ឯកសារ D234/2.1.75 ម៉ម សឿម ហៅ ហេង សាមួត ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥ ម៉ោង 10.00.24 [ទំនប់ត្រពាំងថ្ម នៅឆ្នាំ១៩៧៧៖ “ការៀបការរួចមិនបានទៅណាទេ នៅការដ្ឋាននោះតែម្ដង [...] ពេលវាអត់មានភ្លើងមានអីផង ចុះមកងងឹត គ្នាអាខ្លះមិនទាន់ស្គាល់គ្នាច្បាស់ផង ទៅច្រឡំគូគ្នាក៏មាន”], ម៉ោង 10.06.15 [“ដល់ពេលគេចញមកវិញ [...] គេថា [...] ច្រឡំគូគេ ចូលទៅវាក់របស់គេ [...] វាច្រើនពេក មិនដឹងគូណាមួយ”]។ ឯកសារ D234/2.1.76 ឃិន វ៉ាត ប្រតិចារឹក ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៥ ម៉ោង 09.36.48-09.39.40 [ទាហានកងពលធំ ៥០២៖ “ខ្ញុំអត់ទាន់ស្គាល់គាត់ទេ។ ទាល់តែថ្ងៃគេរៀបការ ពេលល្ងាចរៀបការហ្នឹង បានខ្ញុំស្គាល់គាត់ ស្គាល់

នោះ មាននារីវ័យក្មេងដែលស្នាក់ស្នើរ ពេលខ្លះ ត្រូវបានអង្គការផ្គូផ្គងដោយបង្ខំជាមួយអតីតព្រះសង្ឃវ័យចំណាស់[3279]។ ទាហានពិការប្រុសនៃកងទ័ពបដិវត្តន៍កម្ពុជា ត្រូវគេប្រាប់ឱ្យជ្រើសរើស ឬយកប្រពន្ធម្នាក់ដែលពួកគេមិនមែនជាអ្នកជ្រើសរើស ជា "រង្វាន់ពីអង្គការ" សម្រាប់ការលះបង់របស់ពួកគេ។ កូនក្រមុំដែលត្រូវបានជ្រើសរើស ជាទូទៅ បានជួបប្ដីជាជនពិការជាលើកដំបូងនៅក្នុងពិធី[3280]។ ជនរងគ្រោះពិបាកចិត្តជាខ្លាំង និង/ឬមានការប៉ះទង្គិចយ៉ាងខ្លាំង ដោយត្រូវរៀបការជាមួយមនុស្សដែលពួកគេមិនស្គាល់[3281]។

ឈ្មោះគាត់"]។ ឯកសារ D54/29 កំណត់ហេតុស្ដាប់ចម្លើយ លៀត ឡូន (ណាំ ឡូន) ឆ.7 [កងពលធំលេខ ១៦៤៖ "គូរស្រករថ្មីនេះ បានច្រឡំគូរគ្នា"]។ ឯកសារ D114/297.1.29 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 14.05.50-14.08.46។ ឯកសារ D234/2.1.116 ហ៊ឹម ហ៊ុយ ប្រតិចារឹក ថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៦ ម៉ោង 15.24.32-15.26.54។ ឯកសារ D114/297.1.28 ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 13.54.56-13.56.31។ ឯកសារ D228/1.1.1 កំណត់ហេតុស្ដាប់ចម្លើយ ស៊ឹម ទូន ឆ.22, 24 [កងពលធំលេខ ៣១០៖ "មានអ្នកខ្លះវង្វេងគូ"]។ ឯកសារ D114/87 កំណត់ហេតុស្ដាប់ចម្លើយ ឈុក រីន ឆ.71-72។ ឯកសារ D234/2.1.126 អ៊ុំ យឿន ប្រតិចារឹក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 15.43.58-15.46.38។ ឯកសារ D234/2.1.74 កំណត់ហេតុស្ដាប់ចម្លើយ មូល អេង ឆ.211, 218។ ឯកសារ D11/75 កំណត់ហេតុស្ដាប់ចម្លើយ ចិច សុផា ឆ.109-110។ ឯកសារ D11/231/4 កំណត់ហេតុស្ដាប់ចម្លើយ ស៊ុំ ចាន់ថុល ឆ.111។ ឯកសារ D114/297.1.1 កំណត់ហេតុស្ដាប់ចម្លើយ រស់ ស៊ុយ ឆ.75។ ឯកសារ D114/75 កំណត់ហេតុស្ដាប់ចម្លើយ ស៊ីន ស៊ីផល ឆ.32។ ឯកសារ D114/170 កំណត់ហេតុស្ដាប់ចម្លើយ ព្រំ ម៉ុន ឆ.12។ ឯកសារ D114/120 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុំ អ៊ីត ឆ.23 ["ប្រហែលក្នុងខែតុលាឆ្នាំ១៩៧៨ គេរៀបឱ្យខ្ញុំមានគ្រួសារ ក្នុងចំណោមប្រហែល10គូផ្សេងទៀត។ ប្រពន្ធខ្ញុំ និងខ្ញុំពុំដែលស្គាល់គ្នាសោះពីមុនមក"]។

3279 ឯកសារ D234/2.1.137 កំណត់ហេតុស្ដាប់ចម្លើយ ព្រាប សុខឿន ឆ.27 ["អង្គការបានជ្រើសរើសនារីក្មេងទៅឱ្យរៀបការជាមួយអតីតលោកសង្ឃចាស់ៗ ឧទាហរណ៍ មានករណីគូខ្លះ ស្ត្រីអាយុ១៨ឆ្នាំត្រូវបានផ្គូផ្គងឱ្យរៀបការជាមួយបុរសអាយុ៥០ឆ្នាំ"]។ ឯកសារ D1.3.17.1 អេលីហ្សាបែត ប៊េកខ័រ នៅពេលដែលសង្គ្រាមរលត់ទៅ EN ERN 00237959, FR ERN 00638514, KH ERN 00232336 ["ព្រះសង្ឃជាច្រើនអង្គត្រូវបានចាប់បង្ខំឱ្យរៀបការប្រពន្ធ ដែលនេះជាប្រការរារាំងមិនឱ្យព្រះសង្ឃទាំងនោះ បួសសាជាថ្មីទៀត"]។ ឯកសារ D10.1.65 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុក ភន KH ERN 00368662។

3280 ឯកសារ D114/297.1.28 ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 13.56.31 ["ក្នុងគ្រួសារទាំង ១២គូរៀបហ្នឹង គឺថាផ្នែកនារី ក៏សុទ្ធតែនារីកងស្នែង និងយោធាដែរ។ ចំណែកយុទ្ធជនសុទ្ធតែយោធាទាំងអស់។ ប៉ុន្តែពួកយុទ្ធជនទាំងអស់ហ្នឹង សុទ្ធយុទ្ធជនពិការ ព្រោះពិការវ៉ៃខ្មាំងមិនកើត គេយកមកដាក់មួយកន្លែង។ ដាក់កន្លែង ដល់ពេលរៀបការហ្នឹង គេយកសុទ្ធជនពិការហ្នឹងមករៀបការ"] ម៉ោង 14.02.33 ["អត់មានបើកឱ្យជ្រើសរើសផង"]។ ឯកសារ D114/297.1.32 សែម អំ ហៅ ព្រំ អ៊ិត ប្រតិចារឹក ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 10.07.12-

10.11.23 [ស្រុកចំការលើ៖ "គេចាប់ដឹងតែថា ជនពិការគឺសិទ្ធិរៀបការ ព្រោះគ្នាពិការហើយ"]។ ឯកសារ D234/2.1.128 ណុប ង៉ឹម ប្រតិចារឹក ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 13.42.48 ["តើយោធាពិការទាំងអស់ហ្នឹង ត្រូវបានបញ្ជូនទៅសំឡូត ពីផ្នែកផ្សេងៗនៃប្រទេសកម្ពុជាទាំងអស់ហ្នឹង ដើម្បីទៅរៀបការនៅទីនោះ ឬក៏មានមូល ហេតុផ្សេងទៀត [...] ឆ៖ គឺយើងខ្ញុំក៏ គឺយើងយកទៅរៀបការហ្នឹង"]។ ឯកសារ D114/297.1.25 ប្រតិចារឹក ស៊ូ សុធារី ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៦ ម៉ោង 15.47.37 [ស្រុកបាទី៖ "ដល់កងទ័ពមកពីមុខអ៊ីចឹងមក មកពិការដៃ ពិការជើង គេឱ្យអ្នកហ្នឹងរៀបការជាមួយអត់ហ៊ានប្រកែកទេ [...] ទុក១៨ ក៏អត់ហ៊ានប្រកែកដែរ"]។ ឯកសារ D114/297.1.36 សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង 11.01.59-11.07.26។ ឯកសារ D114/134 កំណត់ហេតុស្តាប់ចម្លើយ សួន សាំង ឆ.181, 185 ["មានទាហាន ពិការការដែរអីតើ។ ហ្នឹងគេរៀបការ អ៊ីចឹង កាលណាគេពេញចិត្ត គេការឱ្យអ្នកហ្នឹង [...] ស៖ ចុះទាហានពិការគេធ្វើអ៊ីចឹងដែរឬទេ? ឆ.185៖ ទាហាន ពិការគេឱ្យរើសដល់កន្លែង។ គេមានកន្លែងទាហានពិការគេ ហើយគេឱ្យនារីក្រមុំៗទៅដល់កន្លែង ឱ្យគេរើស"]។ ឯក សារ D234/2.1.74 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ឆ.220, 226-228 [លេខាស្រុកបារាយណ៍៖ "តា ចាយ គេប្រាប់ ឱ្យរៀបការឱ្យទាហានពិការៗ និងអ្នកមកពីស្រែអំបិល [...] ឆ.226៖ មានស្ត្រី ២នាក់ប្រកែក [...] ឆ.227៖ ខ្ញុំត្រូវតែ ពិភាក្សាជាមួយ តា ចាយ ហើយខ្ញុំប្រាប់គាត់ថា ស្ត្រី ២នាក់មិនព្រមរៀបការ ហើយតា ចាយ ប្រាប់ឱ្យខ្ញុំ អប់រំស្ត្រីទាំង ពីរនោះ ពីមូលហេតុនៃភាពពិការរបស់ទាហាននោះថា គេពិការដោយសារជាតិ [...] ឆ.228៖ គេព្រមរៀបការទាំង ក្រៀមក្រំ"]។ ឯកសារ D234/2.1.137 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុខឿន ឆ.12, 22, 24 ["នៅឆ្នាំ១៩៧៧ [...] គេបង្ខំឱ្យរៀបការជាមួយនឹងបុរសជនពិការម្នាក់ [...] ឆ.24៖ នៅពេលនោះ អ្នកដែលពិការគឺអ្នកដែលបានធ្វើការ លះបង់នៅក្នុងសមរភូមិ ដូច្នេះហើយអ្នកដែលបានលះបង់នោះត្រូវបានគេជ្រើសរើសនារីឱ្យរៀបការដូចជារង្វាន់លើក ទឹកចិត្តឱ្យយោធាពិការទាំងនោះ"]។ ឯកសារ D10.1.35 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ផាត KH ERN 00189243 [នៅស្រុកបាឡុង៖ "ខ្ញុំឃើញជួនកាលនារីក្មេងស្អាតៗទៅរៀបការជាមួយមនុស្សចាស់ ឬជនពិការ"]។ ឯកសារ D114/34 កំណត់ហេតុស្តាប់ចម្លើយ ណាប់ សុម៉ាលី ឆ.141 ["មានស្រីស្អាតម្នាក់ [...] ត្រូវបានគេឱ្យរៀបការជាមួយ នឹងឈ្លប់ម្នាក់ដែលជាជនពិការ"]។ ឯកសារ D114/64 កំណត់ហេតុស្តាប់ចម្លើយ អែម សារិន ឆ.1, 6, 9, 150, 159-163, 197 ["មេបញ្ជាការរងកងវរៈសេនាតូច កងពលលេខធំលេខ២ (ពិការ) ដោយ រ៉ែន បង្ខំឱ្យរៀបការនៅខែសីហា ឆ្នាំ១៩៧៨ ជាមួយក្មេងស្រីដែលមានអាយុ១៥-១៦ឆ្នាំ៖ "[មេបញ្ជាការកងពល រ៉ែន] ជ្រើសរើសប្រពន្ធឱ្យខ្ញុំពីរដងរួចមក ហើយ ប៉ុន្តែខ្ញុំបានបដិសេធ ចំណែកលើកនេះ គាត់មិនបានប្រាប់ខ្ញុំជាមុនទេ នៅពេលដែលខ្ញុំមកដល់ គឺគេឱ្យខ្ញុំរៀបការ តែម្តង"]។ ឯកសារ D10.1.60 កំណត់ហេតុស្តាប់ចម្លើយ Denise Affonco KH ERN 00349118។ ឯកសារ D114/297.1.8 កំណត់ហេតុស្តាប់ចម្លើយ ម៉ុង វេត ឆ.161។

3281 D234/2.1.132 មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 15.48.15 ["បានជាខ្ញុំដឹងថា គេចាប់បង្ខំ [រៀបការ] ទាំងអស់គ្នា ព្រោះគូភាគីដែលរៀបការនឹង៦០គូនោះសុទ្ធតែយំទាំងអស់ យំទាំងអស់។ មកឈរជុំគ្នាយំ ទាំងអស់ ទាល់តែពួកគេមកដល់ បាននាំគ្នាជូតទឹកភ្នែកហើយ ឈប់យំ។ ចាំគេហៅដាក់តម្រៀបជួរគ្នាទៅ [...] ទាំងខ្ញុំ ទាំងគេ យំទាំងអស់គ្នាហ្នឹងឯង មិនថាមេម៉ាយ មិនថាក្រមុំអីទេ យំតែទាំងអស់ហ្នឹង"]។ ឯកសារ D114/297.1.25 ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៦ ម៉ោង 15.12.56 ["១០៧គូហ្នឹងអត់មានអ្នកណាហ៊ានប្រកែកទេ គ្រាន់តែខ្ញុំដឹងថា រឿងចិត្តប្រកែកហ្នឹង ប្រកែកណាស់ហើយ សម្តែងដោយចេញពីទឹកភ្នែក។ នារីៗយំហើមភ្នែក"]។

814. ការប្រើប្រាស់ហិង្សាជាញឹកញាប់ដោយអង្គការ និងការស្នើសុំឱ្យមនុស្សគោរពដោយងងឹតងងុល បានបង្កើតដោយចេតនាឱ្យមានបរិយាកាសទូទៅនៃការភិតភ័យ និងការបង្ខិតបង្ខំ ដោយហេតុថា ការបដិសេធមិនគោរពបញ្ជា ឬការស្នើសុំណាមួយរបស់អង្គការ ត្រូវគេមើលឃើញថាមានគ្រោះថ្នាក់ខ្លាំង ឬអាចនាំដល់ការធ្វើអត្តឃាត។ ក្នុងបរិបទនេះ ការយល់ព្រមរៀបការជាបុគ្គល *ពិតប្រាកដ* ជាទូទៅ មិនអាចមានទេ[3282]។ តាមពិត សេចក្ដីសម្រេចរបស់អង្គការទៅលើការរៀប

ឯកសារ D234/2.1.137 កំណត់ហេតុស្ដាប់ចម្លើយ ព្រាប សុខឿន ឆ.13 ["មិត្តនារី នី លី គាត់បានសួរខ្ញុំថា ហេតុអីបានជាខ្ញុំយំ បើគេនាំមករៀបការ ហើយខ្ញុំប្រាប់ថា ពីព្រោះការរៀបការហ្នឹងមិនបានធ្វើតាមទំនៀមទម្លាប់ខ្មែរ"]។ ឯកសារ D4.1.806 កំណត់ហេតុស្ដាប់ចម្លើយ ជាំង ស្រីមុំ ឆ.8 ["ក្នុងចិត្តរបស់ខ្ញុំ ខ្ញុំយំនិងកើតទុកជាខ្លាំង"]។ ឯកសារ D4.1.524 កំណត់ហេតុស្ដាប់ចម្លើយ ទូល័ស ស្មាអេល KH ERN 00349518។

3282 ឯកសារ D114/36.1.59 ឯកសារចំពោះបញ្ហាកសាងគ្រួសារ KH ERN 00407102 ["មិត្តយុវជន -យុវនារីបដិវត្តយើង ត្រូវចាប់អារម្មណ៍ ហើយប្រុងប្រយ័ត្នឱ្យមែនទែន ចំពោះបញ្ហាកសាងគ្រួសារនេះ។ បើសិនជាយើង មិនគោរពអង្គកការ -វិន័យ មិនគោរពសមូហភាព មិនឡូរកាន់គោលជំហរបដិវត្តរឹងប៉ឹង ហើយសេរីខាងសីលធម៌ពាសវាលពាសកាល នោះមុខជាកសាងគ្រួសារ មិនបានត្រឹមត្រូវល្អ តាមគន្លងមាគ៌ាបដិវត្តយើងឡើយ នោះមុខជានឹងប៉ះទៅលើសមាសភាគមិនល្អឬរហូតដល់ប៉ះទៅលើភ្នាក់ងារបង្កប់របស់ខ្មាំងទៀតក៏មាន"]។ ឯកសារ D114/297.1.27 សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 10.14.47 ["សម័យនោះ ពិបាកណាស់ ស្រួលមិនស្រួលហ្នឹងងាប់ បាត់ខ្លួន មិនដឹងជាស្អីៗ អាហ្នឹងមិនថា ឋានៈអីទេ តែមិនស្រួលបាត់។ ហើយអ៊ីចឹង អ៎! ថាឱ្យយកក៏យកទៅអាហ្នឹង"]។ ឯកសារ D114/297.1.29 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារិក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 14.08.48 ["ជាពិសេសក្នុងឆ្នាំ ១៩៧៧-១៩៧៨ នៅពេលដែលប្រជាជននោះត្រូវបានបំភិតបំភ័យ ដោយខ្មែរក្រហមថាកាលណាការបដិសេធ អាចនឹងមានន័យថា គេនឹងត្រូវសម្លាប់អ្នកណាដែលបដិសេធមិនព្រមរៀបការ។ អ៊ីចឹងហើយមនុស្សភាគច្រើនហ្នឹងមិនហ៊ានបដិសេធទេ"], ម៉ោង 14.12.53 ["មានគំរូពីរ។ មួយគឺថា ខ្មែរក្រហម ឬក៏មេភូមិនិយាយច្បាស់ៗបែបនោះថា គេនឹងសម្លាប់អ្នកដែលគេបង្ខំ ឬសមាជិកក្រុមគ្រួសារនឹងត្រូវគេសម្លាប់ ប្រសិនបើគេបដិសេធ [...] គំរូមួយទៀត មនុស្សហ្នឹង គឺត្រូវបានទទួលការបំភិតបំភ័យរួចហើយ ពញរោះគេរស់នៅក្នុងការភ័យខ្លាចខ្លាំង ក្នុងករណីដែលគេដឹងថា បើអ្នកណាហ៊ានប្រឆាំងនឹងខ្មែរក្រហម គេនឹងត្រូវសម្លាប់"], ម៉ោង 14.20.55 ["ចំពោះតំបន់ទាំងអស់ដែលខ្ញុំបានចុះទៅដល់នោះគឺថា នារីទាំងនោះ គឺធញលាប់ស្ថិតនៅក្នុងការភ័យខ្លាច"]។ ឯកសារ D4.1.927 កំណត់ហេតុស្ដាប់ចម្លើយ ឡេង ហេងអាន ឆ.30 ["ខ្ញុំមានអាយុទើបតែដប់ប្រាំបីឆ្នាំប៉ុណ្ណោះ ខ្ញុំមិនចង់រៀបារទេ ប៉ុន្តែដោយសារតែវាជាការរៀបចំ ខ្ញុំខ្លាចបាត់បង់ជីវិត។ ប្រសិនបើខ្ញុំមិនធ្វើតាមការរៀបចំទេ ជីវិតរបស់ខ្ញុំ និងគ្រួសាររបស់ខ្ញុំនឹងមានបញ្ហាហើយ"]។ ឯកសារ D4.1.810 កំណត់ហេតុស្ដាប់ចម្លើយជាមួយ សេង សឿន ឆ.72-73 ។ ឯកសារ D4.1.807 កំណត់ហេតុស្ដាប់ចម្លើយ អៀង ឆាំ ឆ.34 [ប្រធានការដ្ឋានសាងសង់ទំនប់ ១ មករា ៖ "នៅសម័យ ពុំមាននរណាហ៊ានតវ៉ាទេ"]។ ឯកសារ D234/2.1.137 កំណត់ហេតុស្ដាប់ចម្លើយជាមួយ ព្រាប សុខឿន ឆ. 12-13, 20។ ឯកសារ D11/75 កំណត់ហេតុស្ដាប់ចម្លើយជាមួយ ចិត សុផា ឆ.115។ ឯកសារ D114/33 កំណត់ហេតុស្ដាប់ចម្លើយ ហែម អាង ឆ.162 ["គ្មាននរណាម្នាក់ហ៊ានបដិសេធទេ"]។

អាពាហ៍ពិពាហ៍ ត្រូវតែ "គោរពជាដាច់ខាត"[3283] ហើយការជំទាស់ ជាធម្មតា មិនត្រូវបានអនុញ្ញាតនោះទេ[3284]។

815. ជារឿយៗ ការគំរាមកំហែងមានលក្ខណៈជាប្រយោល។ អ្នកដែលត្រូវបានណែនាំឱ្យរៀបការដោយស្របច្បាប់ ភ័យខ្លាចថា បើពួកគេបដិសេធ ពួកគេនឹងត្រូវគេកំណត់ថាជាខ្មាំង និងអាចទទួល

---

3283 ឯកសារ D114/36.1.59 ឯកសារចំពោះបញ្ហាកសាងគ្រួសារ KH ERN 00407101-02។ ឯកសារ D114/297.1.8 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ឆ.77 ["ប្រសិនបើអង្គការកំណត់ហើយ យើងមិនអាចតវ៉ា ឬប្រឆាំងនឹងអង្គការបក្សបានទេ"]។ ឯកសារ D234/2.1.137 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុខឿនយ ឆ.20 ["នៅពេលនោះយើងមិនមានសិទ្ធិបដិសេធបញ្ជារបស់គេទេ [...] ទោះបីជាខ្ញុំមិនបានស្គាល់ប្តីរបស់ខ្ញុំពីមុនក៏ដោយ ក៏ខ្ញុំត្រូវរៀបការជាមួយប្តីរបស់ខ្ញុំដែរ"]។ ឯកសារ D10.1.65 កំណត់ហេតុស្តាប់ចម្លើយជាមួយ អ៊ុច ភន KH ERN 00368660។ សូម្បីតែសមាជិកសំខាន់របស់កម្ពុជាប្រជាធិបតេយ្យ ក៏ត្រូវគោរពសេចក្តីសម្រេចរបស់អង្គការ ក្នុងការឱ្យរៀបការផងដែរ បើទោះបីជាវាផ្ទុយពីឆន្ទៈរបស់ពួកគេក៏ដោយ ដូចជា ប្រាក់ យុត លេខាស្រុកឆ្នាំ ១៩៧៥ (បើទោះបីជាគាត់អះអាងថា វាអាចជានៅក្នុងឆ្នាំ ១៩៧៣)៖ ឯកសារ D234/2.1.94 កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប្រាក់ យុត KH ERN 00963128 ["គាត់ថា ចែងងការ គាត់ហៅខ្ញុំចែ ចែងងការទៅ ការជាមួយខ្ញុះមានខើញម្នាក់នៅកងពត។ ខ្ញុំថា ខ្ញុំមិនចង់បានទេ ដល់ហើយគាត់ការឱ្យ ៧៥ [...] នៅសម័យហ្នឹងយើងមិនអាចប្រកែបានទេ អូនឯងត្រូវជឿទៅ បើយើងប្រកេគេថាយើងប្រឆាំង"]។ ឯកសារ D114/129 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម ហុន ឆ.72, 74 ["នៅក្នុងចិត្តខ្លួនឯង មិនចង់រៀបការទេ ពេលនោះខ្ញុំបានប្រកែកដែរ តែគេថា ត្រូវគោរពតាមបញ្ជាអង្គការចាត់តាំង [...] ឆ.74៖ មិនមានអ្វីទេ តើគេនិយាយថា បើយើងប្រកែក ក៏ត្រូវតែរៀបការដែរ"]។

3284 ឯកសារ D234/2.1.108 ញ៉ែម អេន ប្រតិចារឹក ថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០១៦ ម៉ោង 14.28.33-14.33.20 [នៅក្នុងកងពលធំ ៧០៣ ស-២១ ៖ "ខ្ញុំបានជួប គឿន [...] គាត់អត់សប្បាយចិត្តទេ [...] កាលនោះ គឺអង្គការចាត់តាំងហើយឱ្យយក គឺយក។ សម័យហ្នឹង គ្មាននរណាអាចប្រកែបានទេ"]។ ឯកសារ D114/297.1.46 ប៊ិត បឿន ប្រតិចារឹក ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ម៉ោង 11.21.57-11.24.06 ["ចំពោះគ្នាជាប្រជាជន គឺគ្នាមិនសូវមានសិទ្ធិដែរ [ក្នុងការបដិសេធរៀបការ]។ ឱ្យតែអង្គការចាត់រៀប គឺត្រូវតែរៀបការ"]។ ឯកសារ D4.1.806 កំណត់ហេតុស្តាប់ចម្លើយ ជាំង ស្រីមុំ ឆ.8 ["ខ្ញុំមិនហ៊ានប្រកែកតវ៉ាការរៀបការនោះទេ ព្រោះកិច្ចកប្រជុំដែលខ្ញុំបានចូលរួម យើងត្រូវបានគេប្រាប់ថា "យើងជាកូនរបស់អង្គការ" ហើយត្រូវតែធ្វើតាមការរៀបចំរបស់អង្គការ ខ្ញុះជឿថា ខ្ញុំមិនមានជម្រើសផ្សេងទេ។ [...] ខ្ញុំត្រូវបានគេសួរថា តើខ្ញុំស្រឡាញ់បុរសនោះដោយស្ម័គ្រចិត្ត ឬដោយបង្ខំ ខ្ញុំនិយាយថា គ្មាននរណាម្នាក់មកបង្ខំខ្ញុំទេ ហើយពួកគេបានទះដៃ"]។ ឯកសារ D114/36.1.63 កំណត់ហេតុស្តាប់ចម្លើយ ឃី ហ៊ុន KH ERN 00189233។ ឯកសារ D4.1.460 កំណត់ហេតុស្តាប់ចម្លើយ ឈុត ខូង KH ERN 00195626 ។ ឯកសារ D4.1.808 កំណត់ហេតុស្តាប់ចម្លើយជាមួយ ឌុក សួរ KH ERN 00402481-82 ។ ឯកសារ D4.1.1003 Bridgette Toy-Cronin៖ "ខ្ញុំចង់និយាយអ្នក" KH ERN 00721381។ ឯកសារ D234/2.1.74 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ឆ.209-210។

ទោសធ្ងន់ ដោយសារ “មិនគោរពអង្គការ” ដូចជា បញ្ជូនទៅកសាង អប់រំ ឬសម្លាប់[3285]។ អ្នកខ្លះក៏បានឮ ឬឃើញមនុស្សដែលត្រូវគេដាក់ទោសដោយសារជំទាស់មិនព្រមរៀបការ[3286]។ អ្នកដែលអង្គការជ្រើសរើសឲ្យរៀបការ ភាគច្រើន មិនប្រថុយធ្វើការជំទាស់ទេ ហើយដូច្នេះ ពួកគេត្រូវបានបង្ខំឲ្យរៀបការ[3287]។ កុល ណែម ជនរងគ្រោះនៃការរៀបការដោយបង្ខំ នៅភូមិភាគពាយព្យ បានផ្ដល់សក្ខីកម្មថា៖ “ការក៏ការចុះ ក្រែងលោបានរស់ បានឃើញមេឃឃើញផ្កាយ”[3288]។

---

3285 ឯកសារ D114/75 កំណត់ហេតុស្ដាប់ចម្លើយ ស៊ីន ស៊ីសុផល ឆ.21, 25, 35 [“ប្រសិនបើខ្ញុំមិនព្រម ខ្ញុំប្រហែលជាត្រូវឃ្លាតឆ្ងាយពីបងប្អូន និងម្ដាយ។ ហើយការព្រាត់នេះ អាចព្រាត់ស្លាប់ ឬរស់ បើខ្ញុំមិនព្រម។ […] ឆ.25៖ ខ្ញុំមានគំនិតចង់បដិសេធ ប៉ុន្តែដូចខ្ញុំបានប្រាប់លោកអ៊ីចឹង បើខ្ញុំបដិសេធ ខ្ញុំអាចស្លាប់ ឬព្រាត់ប្រាសគ្រួសារ […] ឆ.35៖ ពាក្យចចាមអារ៉ាមថា បើមិនព្រម នឹងត្រូវស្លាប់”]។ ឯកសារ D4.1.927 កំណត់ហេតុស្ដាប់ចម្លើយ ឡេង ហេងអាន ឆ.26, 30។ ឯកសារ D114/34 កំណត់ហេតុស្ដាប់ចម្លើយជាមួយ ណាប់ សុម៉ាលី ឆ.154។ ឯកសារ D54/29 កំណត់ហេតុស្ដាប់ចម្លើយ លៀត ឡុន (ណាំ ឡុន) ឆ.6។

3286 ឯកសារ D234/2.1.137 កំណត់ហេតុស្ដាប់ចម្លើយ ព្រាប សុខឿនយ ឆ.21 [“ប្រសិនបើមានអ្នកណាបដិសេធ មិនព្រមរៀបការ តាមការស្នើសុំរបស់អង្គការ ហើយរតគេច គេនឹងតាមចាប់ខ្លួនមកសម្លាប់។ ខ្ញុំបានឃើញរឿងនេះកើតឡើងជាមួយនារីនៅក្នុងកងរបស់ខ្ញុំឈ្មោះ ព្រឿង […] ក្រោយមកសហជិពបានទៅចាប់គាត់ពីសហករណ៍មកវិញ ដោយនិយាយថា គាត់មិនព្រមស្ដាប់តាមអង្គការវិន័យ។ […] ក្រោយមកបានគេចងគាត់ ហើយដឹកតាមរទេះគោយកទៅបាត់។ គាត់បាត់ខ្លួនតាំងពីពេលនោះមក […] ដោយសារបទពិសោធន៍ដែលខ្ញុំឃើញនេះហើយ បានជាខ្ញុំមានការខ្លាចខ្លាំង”]។ ឯកសារ D10.1.28 កំណត់ហេតុស្ដាប់ចម្លើយ សោម ម៉ុន KH ERN 00163765 [“ពួកគេត្រូវបានគេបង្ខំឲ្យរៀបការ […] ជាពិសេស នារីម្នាក់ឈ្មោះ រុន បានបដិសេធ ហើយគេក៏យកនាងចេញពីអង្គការភាពទៅ”]។

3287 ឯកសារ D11/54/3.1 ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង 16.02.04-16.06.09 [“ខ្ញុំងាក់ទៅមើល ហ៊ឺ! អីក៏ចាស់មាំម្ល៉េះ ហើយយកខ្ញុំមកអាយុទើប ២០ជាង គាត់៤០ជាងហើយ […] ខ្ញុំថាប្រកែកក៏មិនដឹងប្រកែកថាម៉េច […] អត់ប៊ានប្រឆាំងទេ ខ្លាចគេបញ្ជូនទៅលើ […] ព្រោះអីប្ដីគេអូសយកទៅ ទើបប្រទាញប្រទង់គ្នាយកទៅរ៉ៃចោលមិនទាន់បាត់យំស្រួលបួលផង គេចាប់តកទៅរៀន អត់ប៊ាននិយាយ ខ្ញុំខ្លាចងាប់។ គេថាបញ្ជូនទៅលើខ្ញុំខ្លាចងាប់ចោលកូនខ្ញុំ”]។ ឯកសារ D114/297.1.36 ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង 09.10.37។ ឯកសារ D234/2.1.76 ឃិន វ៉ាតប្រតិចារិក ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០១៥ ម៉ោង 09.36.43 [ទាហានកងពល ៥០២ បានរៀបការដោយបង្ខំនៅព្រលានយន្តហោះកំពង់ឆ្នាំង]។ ឯកសារ D114/297.1.1 កំណត់ហេតុស្ដាប់ចម្លើយជាមួយ រស់ ស៊ុយ ឆ.77, 79, 83 [“អ្នកខ្លះដែលត្រូវគេចាត់តាំងឲ្យរៀបការ មិនប៊ានប្រកែកនឹងការចាត់តាំងនោះទេ ព្រោះខ្លាចគេធ្វើបាប […] ពេលគេសួរថាព្រមឬទេ ក៏ចេះតែឆ្លើយថាព្រម ព្រោះខ្លាច។ ថ្វីបើមើលទៅហាក់ដូចជាមិនមានការបង្ខំ ប៉ុន្តែតាមពិតមានការបង្ខំផ្លូវចិត្តឲ្យទទួលយកជាពិសេសគឺខ្លួនខ្ញុំផ្ទាល់តែម្ដង។ ក្នុងចំណោម ២០ គូដែលបានរៀបការជំណាលខ្ញុំ មានតែគូខ្ញុំទេ ដែលដល់សព្វថ្ងៃ”]។ ឯកសារ D114/36.1.31 កំណត់ហេតុស្ដាប់ចម្លើយ ផាត់ ដួងច័ន្ទ KH ERN 00373395។ ឯកសារ D114/34 កំណត់ហេតុស្ដាប់ចម្លើយ ណាប់ សុម៉ាលី ឆ.154។ ឯក

សារ D4.1.808 កំណត់ហេតុស្តាប់ចម្លើយ ឌុក សួរ ឆ.90-91 ["យើងមិនហ៊ានប្រកែកទេ ព្រោះអំណាចគឺនៅក្នុងដៃអង្គការ"]។ ឯកសារ D4.1.818 កំណត់ហេតុស្តាប់ចម្លើយ នុក ទូវ ឆ.103 [នៅស្រុកត្រាំកក់ ប្រធានឃុំនិយាយថា ៖ "មានអ្នកខ្លះ មានការភ័យខ្លាចចេះតែឆ្លើយថា យល់ព្រមៗ"]។ ឯកសារ D114/297.1.8 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ឆ.154, 161, 164-165, 168 [ដោយទទួលបានជោគជ័យ នៅក្នុងគោលពលធំលេខ ២ និងកងពលធំលេខ ១១៧ នៅតំបន់ ៥០៥៖ "មេៗគាត់និយាយថា "[…] នារីអាយុ ២៥ ឆ្នាំ មានសិទ្ធិយកប្តី ចំណែកយុវជនអាយុ ៣០ ឆ្នាំ មិនសិទ្ធិយកប្រពន្ធ" កំណត់ជាផ្លូវការ។ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង […] ថ្នាក់កម្មាភិបាលយុវជន គឺចាប់បង្ខំឲ្យរៀបការ ទោះមិនស្រឡាញ់គ្នាក៏ដោយ […] ឆ.161៖ នៅកន្លែងខ្លះទៀតដូចជា នារីនោះចាស់ គេរៀបចំឲ្យរៀបការជាមួយម្នាក់ទៀតមានរូបអាក្រក់ ឬពិការជាដើម។ គឺប្រធានអង្គភាពអ្នកសម្រេចបង្ខំឲ្យអ្នកទាំងពីររៀបការជាមួយគ្នា […] ឆ.164៖ ខាងនារីអត់អាចប្រកែកបានទេ។ ចំណែកខាងបុរស ពេលខ្លះស្នើរៀបការជាមួយនារី "ក" តែដល់ពេលរៀបការ ត្រូវរៀបការជាមួយនារី "ឃ" ក៏មានដែរ។ មានករណីខ្លះ ពេលគេហៅឈ្មោះឡើងមក ឈរមិនត្រូវជួរគ្នា ត្រូវចាប់ដៃគ្នាជាមួយអ្នកផ្សេងវិញក៏មាន។ ហើយគូទាំងនោះ មិនអាចប្រកែកបានឡើយ […] ឆ.165៖ ម្នាក់ៗ សុទ្ធតែខ្លាចដូចគ្នា […] ឆ.168៖ [នៅក្នុងកងពលធំលេខ ១ និង ២] បើគ្មានសំណើរសុំទេ ក៏គេចុចឈ្មោះឲ្យរៀបការដែរ"]។ ឯកសារ D4.1.522 កំណត់ហេតុស្តាប់ចម្លើយ ស៊ូ សឿន KH ERN 00348833 [ប្រពន្ធរបស់ កែ ពក៖ "ស៖ តើមាននារីនៅក្នុងក្រុមលោកស្រី ប្រកែកមិនព្រមរៀបការដែរទេ? ឆ៖ មិនមានទេ កម្រណាស់ ទោះបីជាគេមិនពេញចិត្តក៏ដោយ ហើយក្រោយមកអ្នកទាំងនោះបានលែងលះគ្នា ក្រោយពីរបបខ្មែរក្រហមត្រូវបានដួលរលំ"]។ ឯកសារ D114/87 កំណត់ហេតុស្តាប់ចម្លើយ ឈ្មុក វីន ឆ.76, 82 [កងពលធំ ២៣០ ឆ្នាំ ១៩៧៦៖ "បើគេកំណត់ឲ្យយើងរៀបការ យើងត្រូវតែរៀបការ ប្រពន្ធក៏យើងមិនអាចរើសបានទេ […] ឆ.82៖ បដិសេធឲ្យកំបុតកធ្វើអី?"]។ ឯកសារ D228/1.1.1 កំណត់ហេតុស្តាប់ចម្លើយ ទូន ស៊ីម ឆ.22។ ឯកសារ D114/36.1.66 កំណត់ហេតុស្តាប់ចម្លើយជាមួយ គង់ វាច់ ឆ.48។ ឯកសារ D234/2.1.130 កំណត់ហេតុស្តាប់ចម្លើយជាមួយ ណុប ង៉ិប ឆ.11។ ឯកសារ D4.1.926 កំណត់ហេតុស្តាប់ចម្លើយ សេង ចុន KH ERN 00390287-88។ ឯកសារ D4.1.806 កំណត់ហេតុស្តាប់ចម្លើយជាមួយ ជាំង ស្រីមុំ ឆ.8។ ឯកសារ D11/137/4 កំណត់ហេតុស្តាប់ចម្លើយ ហេង ម៉ី ឆ.186-187។ ឯកសារ D11/231/4 កំណត់ហេតុស្តាប់ចម្លើយ ស៊ុម ចាន់ថុល ឆ.111។ ឯកសារ D4.1.807 កំណត់ហេតុស្តាប់ចម្លើយជាមួយ អៀង ឆាំ ឆ.33។ ឯកសារ D11/75 កំណត់ហេតុស្តាប់ចម្លើយ ចិត សុផា ឆ.104, 115។ ឯកសារ D234/2.1.137 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុខឿនយ ឆ.20។ ឯកសារ D4.1.534 កំណត់ហេតុស្តាប់ចម្លើយជាមួយ សុខ ធុល KH ERN 00238891។ ឯកសារ D10.1.35 កំណត់ហេតុស្តាប់ចម្លើយ ម៉ោង ផាត KH ERN 00189242-43។ ឯកសារ D234/2.1.74 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ឆ.210។ ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន់ ឆ.31-32។ ឯកសារ D4.1.426 កំណត់ហេតុស្តាប់ចម្លើយ ប៉េជុយ ជីបសែ KH ERN 00224052។ ឯកសារ D114/297.1.16 Rochelle Braaf ៖ អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចនៅក្នុងរបបខ្មែរក្រហម, ERN ERN 00992279។ ឯកសារ D4.1.1003 Bridgette Toy-Cronin ៖ "ខ្ញុំចង់និយាយអ្នក" KH ERN 00721381 ["អ្នកផ្តល់បទសម្ភាសន៍បានសង្កត់ធ្ងន់ថា ខុសពីការរៀបអាពាហ៍ពិពាហ៍តាមការរៀបចំ ដែលទោះបីមាតាបិតាជាអ្នករៀបចំក៏ដោយ ក៏គូស្វាមីភរិយាពេញចិត្តនឹងចំណងមេត្រីនេះដែរ តែប្រជាជនក្នុងរបបកម្ពុជាប្រជាធិបតេយ្យគ្មាន

816. សេចក្តីសម្រេចចុងក្រោយទៅលើការរៀបអាពាហ៍ពិពាហ៍គឺអង្គការជាអ្នកសម្រេចតែឯកឯង[3289]។ ឯកសារគោលនយោបាយចម្បងស្តីពីការកសាងគ្រួសារលើកឡើងថា៖

> បើមានការអ្វី ត្រូវលើកស្នើដល់អង្គការ ដល់សមូហភាព ដោយស្មោះត្រង់ ឱ្យជួយដោះស្រាយ។ ត្រូវគោរពអង្គការ វិន័យដាច់ខាត។ ក្នុងបញ្ហាកសាងគ្រួសារនេះ បើអង្គការ សមូហភាព ពិនិត្យឃើញយ៉ាងណា សម្រេចយ៉ាងណា ត្រូវគោរពតាមដាច់ខាត

---

ជម្រើសអ្វីផ្សេងទេ ក្រៅតែពីការរៀបការជាមួយមនុស្សដែលត្រូវបានជ្រើសរើសសម្រាប់ខ្លួនបណ្តោះ។ អ្នកណាដែលប្រកែកមិនព្រមរៀបការ ត្រូវបានអង្គការចាត់ទុកថាជាខ្មាំង។”]។

3288 ឯកសារ D11/54/3.1 កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង 14.24.56-14.26.27។

3289 ឯកសារ D234/2.1.76 អ៊ុំ ជី ប្រតិចារិក ថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០១៥ ម៉ោង 15.49.07។ ឯកសារ D114/297.1.24 មឿង វ៉េត ប្រតិចារឹក ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៦ ម៉ោង 10.20.00-10.23.00 [“ស៖ […] ក្នុងឋានៈលោកជាអនុប្រធាននេះ អនុប្រធានមន្ទីរនេះ លោកមានចូលរួមក្នុងការធ្វើការសម្រេចឱ្យកម្លាំងដែលនៅក្នុងក្រោមបង្គាប់របស់លោកហ្នឹង រៀបអាពាហ៍ពិពាហ៍ទេ នៅពេលនុ៎ង? ឆ៖ ខាងខ្ញុំអត់មានសិទ្ធិសម្រេចទេ ទាល់តែខ្ញុំ ព្រោះខ្ញុំនៅជាមួយមេបញ្ជាការកងពលអីចឹង គ្រាន់តែមានសិទ្ធិថា គាត់បញ្ជាអីមក ខ្ញុំធ្វើហ្នឹងតាម។ […] ប្រសិនបើពួកនីរសារខ្ញុំអីក្តីស្រឡាញ់គ្នា ទាល់តែសួរមេដដែលហ្នឹង ខ្ញុំម៉េចមានសិទ្ធិសម្រេច ព្រោះខ្ញុំនៅក្រោមគាត់”]។ ឯកសារ D114/91 កំណត់ហេតុស្តាប់ចម្លើយ សេង អុល ឆ.158-159 [“ស៖ តើអ្នកណាអ្នកជ្រើសរើសគូស្រករឱ្យ? ឆ.158៖ មានការសម្រេចចិត្តពីថ្នាក់លើរួចជាស្រេចទៅហើយថា តើនរណារៀបការនឹងនរណា? […] ស៖ ថ្នាក់លើសំដៅថ្នាក់ណា? ឆ.159៖ ថ្នាក់ឃុំ”]។ ឯកសារ D1.3.30.28 របាយការណ៍វិភាគរបស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ថ្ងៃទី ៣០ ខែមករា ឆ្នាំ ១៩៧៩ KH ERN 00294968 [“មាត្រា ១៦៖ […] ការបំពាន់លើមាត្រានេះ […] ពាក់ព័ន្ធទៅនឹង […] ការចាំបាច់តម្រូវឱ្យស្នើសុំការអនុញ្ញាត ដើម្បីរៀបអាពាហ៍ពិពាហ៍ ការដាក់ស្រាយតាមតែទំនើងចិត្តក្នុងការអនុវត្តដូចនេះ និងការរំលោភបំពានសិទ្ធិក្នុងការជ្រើសរើស ដោយសេរីពីភាគីខាងស្រី”]។ ឯកសារ D1.3.17.1 អេលីហ្សាបែត ប៊េកខ័រ នៅពេលដែលសង្គ្រាមរលត់ទៅ EN ERN 00237962 [“នៅក្នុង [របបកម្ពុជាប្រជាធិបតេយ្យ] ប្តីប្រពន្ធអាចរៀបការជាមួយគ្នាត្រូវមានការអនុញ្ញាតពីសហករណ៍ចាស់”]។ ឯកសារ D114/297.1.28 ជា ឌៀប ប្រតិចារិក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 15.19.38-15.21.38 [សំដៅទៅលើសារមួយនិយាយដែលចេញមកពីឯកសារចំពោះបញ្ហាកសាងគ្រួសារ៖ “ខ្លឹមសារ […] ត្រូវនឹងអ្វីដែលខ្ញុំបានជួប្រទះមែន […] យើងត្រូវតែធ្វើគោរពកំនិតរបស់សមូលហភាព”]។ សូមមើលផងដែរ ឯកសារ D114/36.1.59 ឯកសារចំពោះបញ្ហាកសាងគ្រួសារ EN ERN 00417943, KH ERN 00407101, FR ERN 00593930។

កុំទោមនស្ស កុំថ្នាំងថ្នាក់។ ព្រោះមានតែអង្គការ មានសម្ផហាភាពទេ ដែលអាចពិនិត្យមើលបានម៉ត់ចត់ និងគ្រប់ជ្រុងជ្រោយបាន[3290]។

817. ប្រសិនបើនរណាម្នាក់ ឬអ្នកទាំងពីរជំទាស់នឹងសំណើសុំរៀបការ[3291] ជារឿយៗ ពួកគេត្រូវបានបង្ខំឱ្យរៀបការនាពេលក្រោយ ជាមួយអ្នកផ្សេងទៀតដែលបក្សជាអ្នកជ្រើសរើស[3292]។ អ្នកដែលស្ទាក់ស្ទើរ ឬជំទាស់មិនព្រមរៀបការតាមបញ្ជា ជាញឹកញាប់ ត្រូវគេគំរាមកំហែង[3293] ឬដាក់

---

[3290] ឯកសារ D114/297.1.28 ជា ឌៀប ប្រតិចារិក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 15.19.38-15.21.38 [សំដៅទៅលើសារមួយនិយាយដែលចេញមកពីឯកសារចំពោះបញ្ហាកសាងគ្រួសារ៖ "ខ្លឹមសារ [...] ត្រូវនឹងអ្វីដែលខ្ញុំបានជួបប្រទះមែន [...] យើងត្រូវតែធ្វើគោរពកំនិតរបស់សមូលហភាព"]។ សូមមើលផងដែរ ឯកសារ D114/36.1.59 ឯកសារចំពោះបញ្ហាកសាងគ្រួសារ EN ERN 00417943, KH ERN 00407101, FR ERN 00593930។

[3291] ឯកសារ D114/297.1.8 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ឆ.164 [កងពលធំលេខ១១៧៖ "ចំណែកខាងបុរសពេលខ្លះ ស្នើរៀបការជាមួយនារី "ក" តែដល់ពេលរៀបការមួយនារី "ឃ" ក៏មានដែរ [...] គូទាំងនោះ មិនអាចប្រកែកបានឡើយ"]។ ឯកសារ D234/2.1.74 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ឆ.223-225 [ទាហានម្នាក់ត្រូវបានគេបង្ខំឱ្យរៀបការជាមួយនឹងនារីដែលគាត់មិនបានស្គាល់ បន្ទាប់អំពីមេបញ្ជាការកងវរសេនាធំរបស់គាត់មិនឱ្យគាត់រៀបការជាមួយនឹងនារីដែលគាត់ស្រឡាញ់ ព្រោះនារីនោះ មានជាប់ពាក់ព័ន្ធនឹងទាហាន លន់ នល់]។ ឯកសារ D234/2.1.34 កាទ្រីណា ណាថាលី "ខ្ញុំមានអារម្មណ៍ថាព្រលឹងខ្ញុំហោះចេញពីខ្លួន" EN ERN 00992156។

[3292] ឯកសារ D114/297.1.25 អុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 09.06.03-09.07.44 ["អុំ ភួន [...] គាត់បានមកលេងខ្ញុំ ហើយបានគត់សម្គាល់ឃើញខ្ញុំ ហើយគាត់បានស្នើខ្ញុំ។ ប៉ុន្តែថ្ងៃរៀបការនោះ គឺបុរសផ្សេងវិញ"]។ ឯកសារ D11/54/3.1 ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង 09.25.00-09.26.53 ["កន្លងមក មានៗដូចថាកំណាន់ចិត្តអ៊ីចឹងទៅ ធ្វើការទៅ ស្គាល់គ្នាអ៊ីចឹង សុំរៀបការជាមួយ ប៉ុន្តែអង្គការគេបដិសេធមិនឱ្យយើងរៀបការជាមួយគូកំណាន់ចិត្តទេ [...] បង្ខំខាងបុរសហ្នឹងឱ្យទៅរៀបការជាមួយស្ត្រីដែលគាត់មិនពេញចិត្តអ៊ីចឹង"]។

[3293] ឯកសារ D114/297.1.29 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារិក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 14.12.53-14.14.21 ["មានគំរូពីរ។ មួយ គឺថាខ្មែរក្រហម ឬក៏មេភូមិនិយាយច្បាស់ៗបែបនោះថា គេនឹងសម្លាប់អ្នកដែលគេបង្ខំ ឬសមាជិកក្រុមគ្រួសារនឹងត្រូវគេម្លាប់ ប្រសិនបើជាពួកគេបដិសេធ"]។ ឯកសារ D114/297.1.25 ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 14.34.35-14.37.09 ["គ្មានអ្នកណាក្រៅពីប្រធានកងទេ បង្ខំរៀបការគំរាមកំហែងសម្លាប់ផង គំរាមកំហែងយកទៅរៀនសូត្រផង [...] ពេលខ្ញុំនិយាយរឿងហ្នឹងម្តងៗ ខ្ញុំឈឺចិត្តណាស់ ព្រោះពេលយើងតវ៉ា ឬបដិសេធនឹងគេ គេគំរាមកំហែងយើងថា គេនឹងយកយើងទៅសម្លាប់"]។ ឯកសារ D234/2.1.74 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ឆ.209-210 ["សៈ នៅពេលដែលគេប្រាប់លោកឱ្យលោកការ តើមានអ្នកណាប៉ានជំទាស់ទេ? ឆ.209៖ ខ្ញុំបដិសេធដែរ ព្រោះខ្ញុំអត់ស្រឡាញ់ប្រពន្ធខ្ញុំទេ។ [...] គេថា បើយើងមិនគោរពអង្គការទេ យើងគិតខ្លួនឯងទៅ។ សៈ អ៊ីចឹង តើលោកគិតថា នេះជាការប្រមាទមួយថា បើលោកមិនធ្វើតាមអង្គ

ទោសយ៉ាងច្បាស់។ ការដាក់ទោស រួមមានការអប់រំ ការធ្វើការងារធ្ងន់ និងការឃុំឃាំង[3294] ហិង្សាលើរាងកាយ[3295] ការរំលោភសេពសន្ថវៈ[3296] និងការសម្លាប់[3297]។

---

ការ នឹងអាចមានរឿង ឬផលវិបាកអ្វី នៅពេលក្រោយ ឬយ៉ាងណាដែរទេ? ឆ.210៖ បាទ វាជាការប្រមាន ព្រោះខ្ញុំអាចមានគ្រោះថ្នាក់ដល់ជីវិត បើខ្ញុំមិនគោរពតាមការសម្រេចរបស់អង្គការទេ"]។ ឯកសារ D114/75 កំណត់ហេតុស្តាប់ចម្លើយ ស៊ីន ស៊ីសុផល ឆ.10, 14 ["អនុប្រធានសហករណ៍ជាមួយឈ្លបពីរនាក់ អមជាមួយកាំភ្លើងអាកា ហើយក្នុងខ្ញុំបង្ខំខ្ញុំឱ្យរៀបការ [...] ឆ.14៖ ពេលនោះ គេភ្ជុងកាំភ្លើងខ្ញុំនៅម៉ោង ៨ យប់ ហើយបណ្តើរខ្ញុំចេញក្រៅផ្ទះទៅវាលស្រែ ហើយគេប្រាប់ថា អង្គការចង់ឱ្យខ្ញុំរៀបការ។ ហើយខ្ញុំក៏ពិចារណាភ្លាមៗដោយនៅស្ងៀម ហើយគេក៏ពន្យល់ហេតុផលថា វាជាសំណាងខ្ញុំហើយ ព្រោះគេឃើញថា ខ្ញុំជាអ្នកស្មោះត្រង់នឹងអង្គការ ទើបអង្គការចាត់ឱ្យខ្ញុំរៀបការ។ បន្ទាប់មកទៀត ខ្ញុំនៅមិនទាន់ឆ្លើយ។ ពេលនោះ គេក៏បន្តសំណួរទៀតថា តើខ្ញុំយល់ព្រម ឬមិនព្រម? ហើយខ្ញុំនៅតែមិនឆ្លើយ គេថា "បើមិត្តជឿអង្គការ មិននឹងបានជួយបងប្អូនឪពុកម្តាយបងប្អូន។ បើមិនជឿ គេក៏ហ៊ានថាម៉េចដែរ""]។ ឯកសារ D234/2.1.37 កាស៊ូមិ ណាកាហ្គាវ៉ា អំពើហិង្សាយែនឌ័រក្នុងអំឡុងពេលរបបខ្មែរក្រហម KH ERN 00738353 ["នេះគឺជារឿងរបស់អ្នកឆ្លើយជាស្ត្រីម្នាក់ដែលបានរៀបរាប់អំពីការដែលគាត់ត្រូវបានគេបង្ខំឱ្យរៀបការ កាលគាត់អាយុ ១៧ ឆ្នាំ [...] "[ប្តីបច្ចុប្បន្នរបស់ខ្ញុំ] គាត់មានទំនាក់ទំនងជាមួយប្រធានឃុំ ហើយវាពិបាកណាស់សម្រាប់ខ្ញុំក្នុងការប្រកែកមិនរៀបអាពាហ៍ពិពាហ៍។ ខ្ញុំមិនបានស្រលាញ់ប្តីខ្ញុំទេ ខ្ញុំបាននិយាយថា ខ្ញុំនឹងស្លាប់ជំនួសការរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែពួកគេមិនអនុញ្ញាតឱ្យខ្ញុំស្លាប់ទេ។ ពួកគេបាននិយាយថា ការស្លាប់មិនទាន់គ្រប់គ្រាន់ទេ ប៉ុន្តែពួកគេនឹងធ្វើឱ្យខ្ញុំខ្មាស់គេមុននឹងពួកគេសម្លាប់ខ្ញុំ។ ពួកគេបាននិយាយថា ពួកគេនឹងរំដោះសំលៀកបំពាក់ខ្ញុំនៅចំពោះមុខក្រុមមនុស្សទូទាំងភូមិ ហើយបន្ទាប់មកពួកគេនឹងសម្លាប់ខ្ញុំ។ ដូច្នេះខ្ញុំគ្មានជម្រើសទេ ក្រៅពីយល់ព្រមធ្វើជាប្រពន្ធគាត់""]។ 00738355 [ខាងក្រោមនេះជារឿងរ៉ាវរបស់មិត្តភក្តិរបស់អ្នកផ្តល់ព័ត៌មាន ឈ្មោះ ថាង (Thang)។ អ្នកផ្តល់ព័ត៌មាន និង ថាង គឺជាប្រជាជនមូលដ្ឋាននៅខេត្តតាកែវ ហើយ ជារឿយៗពួកគេបានជួបគ្នា និងជជែកគ្នាអំពីបញ្ហាជាច្រើន។ ថ្ងៃមួយ ថាង (Thang) ត្រូវបានបញ្ជាឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយបង/ប្អូនប្រុសរបស់ បង/ប្អូនស្រីថ្លៃម្នាក់។ នាងមិនបានស្រលាញ់គ្នាទេ ហើយនាងបានប្រកែកមិនធ្វើតាមបញ្ជា។ ដោយឡែកពេលនោះនាងត្រូវបានគំរាមកំហែងដោយប្រធានភូមិ បើសិនជានាងប្រកែកមិនរៀបអាពាហ៍ពិពាហ៍ នាងនឹងត្រូវធ្វើទារុណកម្ម"]។

3294 ឯកសារ D114/297.1.29 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារិក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 14.17.20-14.19.08 ["ខ្ញុំបានស្តាប់រឿងជាច្រើនអំពីការដាក់ទណ្ឌកម្ម ការដាក់ទោសចំពោះអ្នកដែលបដិសេធមិនព្រមរៀបការ [...] នាងនៅតូចពេក គឺអាយុតែ ១៥ នាងបដិសេធ។ ហើយគឺគេបានបញ្ជូននាងទៅមន្ទីរអប់រំបីខែ [...] នារីម្នាក់នៅសៀមរាបដែលប្រាប់ខ្ញុំថា គេបញ្ជូនគាត់ទៅៗមន្ទីរអប់រំកែប្រែ"]។ ឯកសារ D114/297.1.24 មឿង វ៉េត ប្រតិចារឹក ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៦ ម៉ោង 10.09.23-10.13.10។ ឯកសារ D114/34 កំណត់ហេតុស្តាប់ចម្លើយ ណាប់ សុម៉ាលី ឆ.141, 157 ["មានស្រីស្អាតម្នាក់ [...] ត្រូវបានគេឱ្យរៀបការជាមួយឈ្លបម្នាក់ដែលជាជនពិការ គាត់បដិសេធ ហើយត្រូវបានគេទះកំភ្លៀង ៤-៥ ដៃរហូតដល់ហូរឈាម ហើយគាត់ត្រូវបានគេយកទៅអប់រំ [...] ឆ.157៖ គេយកនាងទៅកន្លែងអប់រំ [...] សម្រាប់អ្នកប្រព្រឹត្តខុសផ្នែកសីលធម៌"]។ ឯកសារ D4.1.818 កំណត់ហេតុស្តាប់ចម្លើយជាមួយ នុក នួវ ឆ.106។ ឯកសារ D234/2.1.37 កាស៊ូមិ ណាកាហ្គាវ៉ា អំពើហិង្សាលើយែនឌ័រ KH ERN

00738346 [អតីតទាហានខ្មែរក្រហមម្នាក់បានពន្យល់ថា៖ "ខ្ញុំបាននិយាយទៅកាន់អង្គការពីព្រោះខ្ញុំមិនយល់លព្រម ជាមួយរឿងនេះ (អាពាហ៍ពិពាហ៍) ដូច្នេះអង្គការចាប់ខ្ញុំដាក់ពន្ធនាគារ"]។ ឯកសារ D4.1.1003 Bridgette Toy-Cronin ៖ "ខ្ញុំចង់និយាយអ្នក" KH ERN 00721381 ["គំរាមកំហែងថានឹងប្រើអំពើហិង្សា ឬប្រើអំពើហិង្សាជាក់ស្តែងតែម្តង រួមមានការវាយដំច្រំធាក់ ការងារាធ្ងន់ធ្ងរ និងអាចរហូតដល់ស្លាប់បាត់បង់ជីវិតផងក៏មាន"]។

3295 ឯកសារ D114/34 កំណត់ហេតុស្តាប់ចម្លើយជាមួយ ណាប់ សុម៉ាលី ឆ.141 ["មានស្រីស្អាតម្នាក់ ខ្ញុំគិតថាគាត់ធ្លាប់ធ្វើជាសិស្សសាលា គាត់ត្រូវបានគេឲ្យរៀបការជាមួយនឹងឈ្លបម្នាក់ ដែលជាជនពិការ គាត់បដិសេធ ហើយត្រូវបានគេទះកំភ្លៀង ៤-៥ ដៃរហូតដល់ហូរឈាម ហើយគាត់ត្រូវបានគេយកទៅអប់រំ"]។ ឯកសារ D114/297.1.16 Rochelle Braaf ៖ អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចនៅក្នុងរបបខ្មែរក្រហម EN ERN 00992281 ["ក្នុង ១០ ករណី អ្នកផ្តល់ចម្លើយត្រូវបានគេធ្វើទារុណកម្មដោយសារប្រកែកមិនព្រមរៀបការ។ ក្នុងករណីខាងក្រោមនេះ ប្តីត្រូវគេសម្លាប់មុនពេលគេស្នើឲ្យនារីនោះរៀបការ។ នៅពេលដែលគាត់ប្រកែកមិនព្រម គេដាក់គុកគាត់ និងធ្វើទារុណកម្មគាត់"]។ ឯកសារ D234/2.1.37 កាស៊ូមិ ណាកាហ្គាវ៉ា អំពើហិង្សាលើយែនឌ័រ KH ERN 00738346 ["ការបដិសេធចំពោះបញ្ជាឲ្យរៀបអាពាហ៍ពិពាហ៍ ដែលបានដាក់ចេញដោយ អង្គការ អាចមានលទ្ធផលដូចជាការទទួលទារុណកម្ម ឬស្លាប់"], 00738354 [អ្នកផ្តល់ការសម្ភាសន៍បាននិយាយថា៖ "ខ្ញុំគឺជាប្រជាជនថ្មីនៅបាត់ដំបង ហើយប្តីខ្ញុំត្រូវបានសម្លាប់បន្តិចក្រោយមកបន្ទាប់ពីខ្មែរក្រហមបានកាន់ [...] អំណាច [...] ខ្ញុំត្រូវបានរៀបអាពាហ៍ពិពាហ៍ជាមួយទាហានម្នាក់ រួមនឹងស្វាមីភរិយាជិត ៣០គូទៀត។ ខ្ញុំប្រកែកមិនព្រមធ្វើតាមបញ្ជា ហើយបន្ទាប់មកអង្គការបានចាប់ខ្ញុំទៅវាលស្រែ ហើយវ៉ៃជើងទាំងពីររបស់ខ្ញុំរហូតដល់ជើងទាំងពីរនេះបាក់។ អង្គការបានដកក្រចកខ្ញុំ ប៉ុន្តែខ្ញុំនៅតែប្រកែកមិនរៀបអាពាហ៍ពិពាហ៍"]។ ឯកសារ D4.1.1003 Bridgette Toy-Cronin ៖ "ខ្ញុំចង់និយាយអ្នក" KH ERN 00721381 ["គំរាមកំហែងថានឹងប្រើអំពើហិង្សា ឬប្រើអំពើហិង្សាជាក់ស្តែងតែម្តង រួមមានការវាយដំច្រំធាក់ ការងារាធ្ងន់ធ្ងរ និងអាចរហូតដល់ស្លាប់បាត់បង់ជីវិតផងក៏មាន [...] ផល្លា រាយការណ៍ថា គាត់ត្រូវបានដាក់ច្រវាក់ និងវាយផង]។

3296 ឯកសារ D114/297.1.29 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារិក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 14.12.53 [ស្ត្រីដែលត្រូវបានរំលោភ ដោយសារតែបដិសេធរៀបការ៖ "ស៖ តើលោកស្រីបានឮពីសាក្សីផ្សេងៗទៀតដែរឬទេ ពាក់ព័ន្ធនឹងជម្រើសក្នុងការឆ្លើយតប ទៅនឹងការគំរាមកំហែកឲ្យរៀបការ? [...] ឆ៖ ខ្ញុំបានឮរឿងបែបនេះ ហើយខ្ញុំក៏មានស្ត្រីម្នាក់ដែលត្រូវបានធ្វើ គេបង្គាប់ឲ្យទៅមើលការរំលោភស្ត្រីម្នាក់ទៀត ដែលគេបង្ខំឲ្យរៀបការ ហើយគាត់បដិសេធ"]។ ឯកសារ D234/2.1.132 មុំ វុន ប្រតិចារិក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 11.17.05-11.20.29 [នៅសៀមរៀប នៅចុងឆ្នាំ ១៩៧៥ ពីខែបន្ទាប់ប្តីទីមួយរបស់គាត់ត្រូវបានគេបញ្ជូនទៅអប់រំ (សម្លាប់)៖ "គេហៅទៅ ទៅដល់គេប្រាប់ខ្ញុំថា មិត្តឯងនៅតែពីរថ្ងៃទៀតទេ រៀបការហើយ [...] គេមានវិធានការនឹងធ្វើបាប់ខ្ញុំ មុនពេលដែលខ្ញុំរៀបការហ្នឹង។ គ្នាគេប្រាំនាក់ គេនឹងចាប់រំលោភខ្ញុំ។ ម្នាក់ម្តង"ហើយ ដល់អ្នកចុងក្រោយបានប្រាប់ខ្ញុំថា ឆាប់ចុះទៅវិញ"]។ ឯកសារ D234/2.1.37 កាស៊ូមិ ណាកាហ្គាវ៉ា អំពើហិង្សាលើយែនឌ័រ KH ERN 00738348 ["ប្តីរបស់ខ្ញុំគឺជាទាហានបារាំង។ ពួកគេបានព្យួរកប្តីរបស់ខ្ញុំ។ ប្រាំខែបន្ទាប់មកពួកគេប្រាប់ខ្ញុំថា ខ្ញុំត្រូវរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែខ្ញុំប្រកែក។ ពួកគេបានយកខ្ញុំទៅក្នុងព្រៃ ហើយបានរំលោភខ្ញុំ។ បន្ទាប់ពីពួកគេរំលោភខ្ញុំ ខ្ញុំបាននិយាយទៅកាន់ពួកគេថា "សម្លាប់ខ្ញុំមក" ... ខ្ញុំនិយាយថា "កូនទាំងប្រាំមួយនាក់របស់ខ្ញុំត្រូវបានសម្លាប់រួចហើយ ដូច្នេះសូមជីករណ្តៅ ហើយកប់ខ្ញុំជាមួយកូន

## ពិធីរៀបអាពាហ៍ពិពាហ៍

818. ប្រពៃណីដ៏ពិសិដ្ឋរបស់កម្ពុជា និងពិធីផ្សេងៗក្នុងពេលរៀបអាពាហ៍ពិពាហ៍ ដើម្បីភ្ជាប់ចំណង អបអរ និងឲ្យពរជ័យដល់ការមកដល់នៃគ្រួសារពីរ មិនមាននៅក្នុងពិធីអាពាហ៍ពិពាហ៍នៅសម័យខ្មែរក្រហមទេ[3298]។ ជាទូទៅ សមាជិកគ្រួសារមិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងពិធីទេ[3299] ហើយ

---

ដែលនៅរស់ទាំងប្អូននាក់របស់ខ្ញុំទៅ ប៉ុន្តែខ្ញុំមិនព្រមរៀបអាពាហ៍ពិពាហ៍ឡើយ ... ពេលនេះខ្ញុំដូចជាជិតឆ្កួតហើយ"]។ ឯកសារ D4.1.1003 Bridgette Toy-Cronin ៖ "ខ្ញុំចង់និយាយអ្នក" EN ERN 00449489 ["អ្នកផ្តល់បទសម្ភាសន៍មួយចំនួនបានរាយការណ៍អំពីការប្រើប្រាស់ការរំលោភដើម្បីបង្ខិតបង្ខំ ឬដាក់ទណ្ឌកម្មដល់នារីណាដែលប្រកែកមិនព្រមរៀបការ។ ចន្ទី បានពន្យល់ពីរបៀបដែលគេបានយកគាត់ទៅមន្ទីរសន្តិសុខ នៅពេលគាត់ប្រកែកមិនព្រមរៀបការជាមួយប្តីដែលអង្គការជាអ្នកជ្រើសរើសឲ្យ។ នៅក្នុង [...] ទាហានម្នាក់ [...] យកគាត់ទៅមើលនារីដែលគេរំលោភរួច៖ នារទាំងអស់អាក្រាតកាយ។ ពួកគេគ្មានសម្លៀកបំពាក់ទេ ហើយទាហានបីនាក់ក៏អាក្រាត់កាយដែរ។ នារីទាំងនោះត្រហោយ ហើយទាហាទាំងនោះយកក្រម៉ាញាត់មាត់។ ទាហានផ្តេកនាទីងនោះនៅលើគ្រែ ហើយចងដៃ និងជើងភ្ជាប់នឹងគ្រែតែម្តង [...]ពួកគេសួរខ្ញុំថា "តើនាងឯងចង់យកគំរូតាមនារីទាំងនេះឬ? [...] ខ្ញុំរន្ធត់ចិត្តយ៉ាងខ្លាំង ទើបសម្រេចចិត្តរៀបការទៅ"]។

3297 ឯកសារ D114/297.1.25 អុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 09.14.42-09.18.26 [ការរៀបការដោយបង្ខំនៅដើមឆ្នាំ ១៩៧៨ នៅស្រុកចំការលើ គាត់មិនបានបដិសេធទេ ព្រោះនរណាដែលតវ៉ា ឬបដិសេធគឺបាត់ខ្លួន។ បងប្អូនជីដូនគាត់ត្រូវបានគេសម្លាប់ ដោយសារបដិសេធមិនព្រមរៀបការជាមួយនឹងជនពិការ]។ ឯកសារ D234/2.1.132 មុំ វុន ប្រតិចារិក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 10.06.00-10.07.35 ["អ្នកដែលក្រោកចេញដោយមិនពេញចិត្តនោះ បាត់ខ្លួនទៅ"]។ ឯកសារ D114/34 កំណត់ហេតុស្តាប់ចម្លើយ ណាប់ សុម៉ាលី ឆ.155, 157 ["នាងសុខចិត្តស្លាប់ជាជាងរៀបការជាមួយជនពិកា។ [...] ឆ.157៖ គេយកនាងទៅកន្លែងអប់រំឆ្ងាយពីនេះ ចម្ងាយពីភូមិប្រហែល ៨ គីឡូ។ វាជាកន្លែងអប់រំសម្រាប់អ្នកប្រព្រឹត្តខុសសីលធម៌"]។ ឯកសារ D4.1.1003 Bridgette Toy-Cronin ៖ "ខ្ញុំចង់និយាយអ្នក" KH ERN 00721381 ["គំរាមកំហែងថានឹងប្រើអំពើហិង្សា ឬប្រើអំពើហិង្សាជាក់ស្តែងតែម្តង រួមមានការវាយដំច្រំផាក់ ការងារធ្ងន់ធ្ងរ និងអាចរហូតដល់ស្លាប់បាត់បង់ជីវិតផងក៏មាន [...] សុខាន់យ៉ា បាននិយាយថា "ខ្ញុំដឹងថា បើខ្ញុំប្រកែកមិនព្រមរៀបការ គេនឹងកាត់ក្បាលយខ្ញុំមិនខាន ព្រោះខ្ញុំបានឃើញរឿងនេះកើតឡើងច្រើនណាស់មកហើយ""], 00449489 [លីណាបាន់បានរៀបរាប់អំពីការចាប់រំលោភមកលើនាង ដោយសារនាងបានបដិសេធមិនរៀបការជាមួយប្តី ដែលអង្គការរើសឲ្យ [...] លីណា មិនបានឃើញក្មួយរបស់នាងម្តងទៀតទេ ហើយនាងសន្និតថា ទាហានបានសម្រាប់ក្មួយនឹងបន្ទាប់ពីរំលោភរួច"]។ ឯកសារ D234/2.1.37 កាស៊ូមិ ណាកាហ្គាវ៉ា អំពើហិង្សាលើយែនឌ័រ KH ERN 00738345។

3298 ឯកសារ D114/297.1.28 ជា ឡៅ ប្រតិចារិក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 14.14.05 ["វាគ្មានការសូត្រមន្តតាមប្រពៃណីអីទេ [...] គេហៅឈ្មោះយើង ហើយចាប់ដៃជាមួយខាងស្រីទៅ។ អង្គការនិយាយណែនាំតិចតួច ហើយក្រោយមកយើងគោរពទង់ជាតិបក្សមក [...] វាប្រហែលជាមិនដល់មួយម៉ោងផង"]។ ឯកសារ D234/2.1.132

កម្មាភិបាល និងល្អបជាអ្នកចូលរួមជំនួសវិញ[3300]។ ប្ដីប្រពន្ធចូលរួមក្នុងពិធីកាន់ដៃគ្នា ដែលដូចគ្នា មែនទែននឹងការប្រជុំមួយជាជាងព្រឹត្តិការណ៍ដ៏សំខាន់ក្នុងជីវិត[3301]។ ពិធីទាំងនេះត្រូវបានគេហៅថា

---

មុំ វុន ប្រតិចារិក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ 14.23.08-14.27.47។ ឯកសារ D234/2.1.71 ពេជ ជឹម ប្រតិចារឹក ថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១៥ 09.21.09។ ឯកសារ D114/297.1.29 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារិក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 13.49.40។ ឯកសារ D114/297.1.25 ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង15.17.00។ ឯកសារ D234/2.1.126 អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 15.50.40។ ឯកសារ D11/75 កំណត់ហេតុស្ដាប់ចម្លើយ ចិត សុផា ឆ.112។ ឯកសារ D4.1.927 កំណត់ហេតុស្ដាប់ចម្លើយ ឡេង ហេងអាន ឆ.26។ 10 ឯកសារ D114/64 កំណត់ហេតុស្ដាប់ចម្លើយ អ៊ឹម សារិន ឆ.209។ ឯកសារ D4.1.453 កំណត់ហេតុស្ដាប់ចម្លើយ យួក អៀម KH ERN 00195459 ។ ឯកសារ D114/297.1.16 Rochelle Braaf ៖ អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចនៅក្នុងរបបខ្មែរក្រហម ERN ERN 00992282-83។

3299 ឯកសារ D114/297.1.36 ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង 09.11.08 [នៅស្រុកបាកាន ខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ ខែសីហា ឆ្នាំ ១៩៧៨៖ "បងខ្ញុំនៅខ្មារទទឹងនុំងដែរ ប៉ុន្តែអត់ទៅផង ទៅតែខ្ញុំម្នាក់ឯង អត់បានដឹងថា ទៅរៀបគ្រួសារផង។ សមរភូមិរៀងខ្លួន អត់មានបងណាស្គាល់ ម៉េណាស្គាល់ថា កូនរៀបការអីអត់ទេ អត់ដឹងផង"]។ ឯកសារ D114/297.1.29 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារិក ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 13.48.28 ["អត់មានភ្ញៀវមកពីខាងគ្រួសារទាំងសងខាង អត់មានភ្ញៀវដែលជាមិត្តភក្តិជាអ្វីនោះទេ។ គឺមានវត្តមានតែគូស្រករ ដែលត្រូវរៀបការនេះទេ"]។ ឯកសារ D114/297.1.28 ជា ឌៀប ប្រតិចារិក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 13.54.56, 13.59.18។ ឯកសារ D234/2.1.128 ណុប ធីម ប្រតិចារិក ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 11.23.20-11.25.02។ ឯកសារ D234/2.1.132 មុំ វុន ប្រតិចារិក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 13.38.11។ ឯកសារ D11/54/3.1 ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ម៉ោង 09.37.32។ ឯកសារ D234/2.1.126 អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 15.50.40-15.52.38។ ឯកសារ D234/2.1.137 កំណត់ហេតុស្ដាប់ចម្លើយ ព្រាប សុខឿនយ ឆ.22។ ឯកសារ D10.1.28 កំណត់ហេតុស្ដាប់ចម្លើយ សោម ម៉ុន KH ERN 00163765។ ឯកសារ D114/75 កំណត់ហេតុស្ដាប់ចម្លើយ ស៊ីន ស៊ីសុផល ឆ.43។ ឯកសារ D114/297.1.16 Rochelle Braaf ៖ អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចនៅក្នុងរបបខ្មែរក្រហម EN ERN 00992282 ["នៅរាល់ករណី លើកលែងតែមួយករណី គេមិនឱ្យគ្រួសារចូលរួមទេ។ អ្នកផ្ដល់ចម្លើយទាំងនោះមិនពេញចិត្តនឹងរឿងនេះយ៉ាងខ្លាំង"]។ ឯកសារ D4.1.1003 Bridgette Toy-Cronin ៖ "ខ្ញុំចង់និយាយអ្នក" KH ERN 00721381។

3300 ឯកសារ D234/2.1.132 មុំ វុន ប្រតិចារិក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ម៉ោង 13.38.10-13.40.35 KH ERN 01382391 [នៅពិធីរៀបការរបស់គាត់នៅខេត្តសៀមរាប ចុងឆ្នាំ ១៩៧៥ ៖ "គឺគណៈអធិបតី គឺមានកម្មាភិបាល មិត្តរ៉ុម មិត្តសន និងមិត្តស៊ា ប៊ីខុសពីនោះសុទ្ធតែក្រុមកងការពាររបស់ពួកគេទាំងអស់។ ពួកមិត្តៗគេនៅអង្គុយទាំងអស់គ្នា។ ហើយខុសពីនោះសុទ្ធតែគូដែលរៀបការនោះឯង ៦០គូ មានតែប៉ុណ្ណោះទេ អត់មានម៉ែមានឪអីទៅចូលរួមទេ"]។ ឯកសារ D114/297.1.28 ជា ឌៀប ប្រតិចារិក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 13.54.56-13.56.22 KH ERN

ពិធី "ប្ដេជ្ញា" ឬ "ធ្វើការប្ដេជ្ញាចិត្ត"[3302]។ ការផ្គូផ្គងគូត្រូវបានប្រកាសតាមឈ្មោះ ឬរៀបជាជួរឈរទល់មុខគ្នា និងត្រូវបានណែនាំឲ្យកាន់ដៃអ្នកនៅមុខពួកគេ[3303]។ បន្ទាប់មក គូដែលបានផ្គូផ្គងរួច

---

01382396 [នៅភ្នំពេញ ឆ្នាំ១៩៧៥ ៖ "ឪពុកម្ដាយ និងបងប្អូនខ្ញុំ អត់បានចូលរួមនៅក្នុងពិធីនោះទេ។ មានតែអង្គការទេដែលបានចូលរួម"]។

3301 ឯកសារ D114/297.1.29 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹកថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ 13.48.28 ["ពិធីរៀបការហ្នឹងគឺខុសគ្នាពីពិធីរៀបការនៅសម័យខ្មែរក្រហម។ និយាយឲ្យងាយយល់ទៅ គឺថា ដូចអង្គប្រជុំមួយអ៊ីចឹង។"]។ ឯកសារ D234/2.1.71 ពេជ្រ ជឹម ប្រតិចារឹកថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៥ 09.18.38។ ឯកសារ D4.1.817 កំណត់ហេតុស្ដាប់ចម្លើយ ប៊ុន ធឿន KH ERN 00368611 [នៅខេត្តតាកែវ ភូមិភាគនិរតី៖ ពិធីរៀបការគឺ "គេធ្វើឡើងដូចជាពិធីប្រជុំមួយ"]។ ឯកសារ D114/129 កំណត់ហេតុស្ដាប់ចម្លើយ អ៊ឹម ហុន ឆ.៩២ ["មិនធំដុំទេ យើងអង្គុយដូចប្រជុំអ៊ីចឹង។"]។ ឯកសារ D4.1.462 កំណត់ហេតុស្ដាប់ចម្លើយ ស៊ុម អាឡាត់ KH ERN 00196810។ ឯកសារ D4.1.453 កំណត់ហេតុស្ដាប់ចម្លើយ យក់ អ៊ាម KH ERN 00195459។ ឯកសារ D4.1.454 កំណត់ ហេតុស្ដាប់ចម្លើយ កុយ ម៉ុន KH ERN 0019543-00195440។ ឯកសារ D114/123 កំណត់ហេតុស្ដាប់ចម្លើយ ជួន ធី ឆ.១២, ៣៧ [កងពល ១៖ "គឺគ្រាន់តែហៅមកចាប់ដៃ និងជប់លៀងរួចចប់សព្វគ្រប់។"]។ ឯកសារ D114/297.1.8 កំណត់ ហេតុស្ដាប់ចម្លើយ ម៉ឹង វេត ឆ.៧៥។ ឯកសារ D114/297.1.16 Rochelle Braaf, អំពើហិង្សា ផ្លូវភេទប្រឆាំង នឹងជនជាតិភាគតិចក្នុងអំឡុងរបបខ្មែរក្រហម EN ERN 00992282។

3302 ឯកសារ D114/32 កំណត់ហេតុស្ដាប់ចម្លើយ មាស សារ៉ាន់ ឆ.១០ ["នៅក្នុងសម័យនោះ គេប្រើពាក្យ "ទៅប្ដេជ្ញា" ជំនួសពាក្យថា "រៀបការ"]។ ឯកសារ D4.1.812 កំណត់ហេតុស្ដាប់ចម្លើយ ភ្នៅ យ៉ាវ ឆ.៣២។ ឯកសារ D114/36.1.63 កំណត់ហេតុស្ដាប់ចម្លើយ ឃី ហ៊ុន KH ERN 00189233។ ឯកសារ D114/33 កំណត់ហេតុស្ដាប់ចម្លើយ ហែម អាង ឆ.១៨១ ["ស៖ តើគូស្រករថ្មីនោះ ត្រូវធ្វើការប្ដេជ្ញាចិត្តចំពោះមុខអង្គការមែនដែរឬទេ? ឆ.១៨១៖ ត្រឹមត្រូវហើយ គឺអង្គការ។"]។

3303 ឯកសារ D114/297.1.25 ស៊ូ សុធាវី ប្រតិចារឹកថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ 15.09.27 ["ឈរតម្រាបជួរគ្នា ខាងស្រីមួយជួរ ខាងប្រុសមួយជួរអ៊ីចឹងមក។ ឈរកៀកៗគ្នាអ៊ីចឹងហើយ គេលេងល្បែងមួយថា ដូចល្បែងបិទពួនអ៊ីចឹង គឺគេពន្លត់ភ្លើងអគ្គិសនីនោះ គ្រឹប ឲ្យយើងទាំងអស់គ្នាហ្នឹងចាប់រាវគ្នា"]។ ឯកសារ D234/2.1.128 ណុប ធឹម ប្រតិចារឹកថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៦ 10.46.12 ["ឲ្យអង្គុយ យុទ្ធជនមួយចំហៀង ប្រុសៗមួយចំហៀង ស្រីៗមួយចំហៀងអ៊ីចឹងឲ្យឡើងចាប់ដៃគ្នា។ ហើយយើងធ្វើការប្ដេជ្ញាចិត្តទៅ"]។ ឯកសារ D114/297.1.28 ជា ឌៀប ប្រតិចារឹកថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ 13.59.01 [នៅទីក្រុងភ្នំពេញ ឆ្នាំ ១៩៧៥៖ "ក្នុងពិធីរៀបការនៅជំនាន់ខ្មែរក្រហមហ្នឹង គឺចាប់ចូលដំបូងអ៊ីចឹងទៅ គេហៅដាក់តាមគូអ៊ីចឹង ព្រោះពួកខ្ញុំ នាងខ្ញុំទាំងអស់គ្នាសុទ្ធតែអត់ស្គាល់ទេ។ ដឹងមួយណា ដឹងគូមួយណាទេ ទាល់គេហៅឈ្មោះ"]។ ឯកសារ D114/297.1.29 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹកថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ 14.05.50-14.08.46 ["នៅពេលដែលគេធ្វើដំណើរទៅដល់កន្លែងរៀបការនោះ គេឲ្យអង្គុយមួយជួរ ស្រីមួយជួរ បុរសមួយជួរ។ ជាទូទៅ គឺថា បុរសដែលនៅចំ អង្គុយចំមុខនារីនោះឯង ជាប្ដីដែលត្រូវរៀបការ។ គេរៀបចំទុកជាមុន ឬក៏គេផ្ដល់លេខសម្គាល់រួចហើយ។"]។ ឯកសារ D114/297.1.35 ប៉ែន សុចាន់ ប្រតិ

ត្រូវបានស្នើឱ្យឡើង "ប្ដេជ្ញា" ឬ "សន្យា" ថានឹង ១) បម្រើអង្គការ ឬគោរពអង្គការ និង ២) ស្រឡាញ់គ្នាជារៀងរហូត[3304]។ ជាទម្លាប់ កម្មាភិបាលបានណែនាំពួកគេថេះ "នៅជាមួយគ្នា" និង "បង្កើតកូនឱ្យអង្គការ"[3305]។

---

ចារឹកថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ 13.43.49-13.49.18, KH ERN 01365431 [នៅស្រុកបាកាន ខេត្តពោធិសាត់ ភូមិភាគពាយ័ព្យ ឆ្នាំ ១៩៧៨៖ "ខ្ញុំឃើញគេអង្គុយតម្រង់ជួរ ប្រុសមួយជួរ ស្រីមួយជួរទៅហើយ។"]។ ឯកសារ D11/75 កំណត់ហេតុស្ដាប់ចម្លើយ ចិច សុផា ឆ.៩៨-១០០។ ឯកសារ D234/2.1.137 កំណត់ហេតុស្ដាប់ចម្លើយ ព្រាប សុខឿន ឆ. ២៨។ ឯកសារ D4.1.810 កំណត់ហេតុស្ដាប់ចម្លើយ សេង សឿន ឆ.៧៩។ ឯកសារ D234/2.1.74 កំណត់ហេតុស្ដាប់ចម្លើយ មូលល អេង ឆ.២០៨។ ឯកសារ D4.1.1003 Bridgette Toy-Cronin, ខ្ញុំចង់និយាយប្រាប់អ្នក KH ERN 00721380-00721381។

3304 D114/297.1.28 ជា ខៀប ប្រតិចារឹកថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ 13.59.01 ["គេឱ្យសាមីខ្លួនហ្នឹងប្ដេជ្ញាចិត្ត ហើយកន្លែងប្ដេជ្ញាចិត្តហ្នឹង គ្មានស្អីទេ មានតែកណ្ដៀវ ហើយនិងកម្រងកួរស្រូវ កន្លែងប្ដេជ្ញាហ្នឹង [...]អង្គការគ្រាន់តែណែនាំថា ឱ្យគោរពអង្គការវិន័យ កុំឱ្យរល់រៀបគ្រួសារឱ្យហើយ កុំឱ្យធ្វើឱ្យអង្គការពិបាកចឹងទៅ ឱ្យចេញស្រឡាញ់គ្នា ហើយចេះខំប្រឹងកសាង ខំប្រឹងធ្វើការងារកសាងប្រទេសជាតិ"]។ ឯកសារ D234/2.1.128 ណុប ងឹម ប្រតិចារឹកថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៦ 10.46.12 ["គេហៅឡើង [...]ប្ដេជ្ញាចិត្តទៅ។ យើងប្ដេជ្ញាចិត្តជូនអង្គការជូនវណ្ណៈ ជូនបក្សអ៊ីចឹងទៅណា។ អ៊ីចឹងទៅ ចាប់ដៃគ្នាទៅ។"]។ ឯកសារ D234/2.1.132 មុំ វុន ប្រតិចារឹកថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ 13.38.10-13.40.35 ["កម្មាភិបាលដែលគេរៀបការឱ្យទាំង ៦០គូហ្នឹង គេមានភារកិច្ចគេឡើងប្រកាសប្រាប់ថា គូស្រករដែលរៀបការថ្មីជាប្ដីប្រពន្ធហើយនេះ [...]មើលថែរក្សាគ្នា ហើយខំបង្កបង្កើនផលឱ្យបានច្រើន ដើម្បីយើងយកសេដ្ឋកិច្ចនេះ ដើម្បីកម្ទេចខ្មាំងកុំឱ្យមានសល់ [...]គេហៅគូ គូៗដែលប្ដីប្រពន្ធ ប្ដីប្រពន្ធដែលរៀបហ្នឹង ឱ្យឡើងមានការចាប់អារម្មណ៍ឱ្យគេស្ដាប់។"]។ ឯកសារ D234/2.1.129 កំណត់ហេតុស្ដាប់ចម្លើយ ណុប ងឹម ឆ. ៦៨។ ឯកសារD114/87 កំណត់ហេតុស្ដាប់ចម្លើយ ឈូក រិន ឆ.៨៥។ ឯកសារ D4.1.817 កំណត់ហេតុស្ដាប់ចម្លើយ ប៊ុន ធឿន KH ERN 00368611។ ឯកសារ D114/36.1.64 កំណត់ហេតុស្ដាប់ចម្លើយ សេង អុល ឆ.៣៩។ ឯកសារ D4.1.806 កំណត់ហេតុស្ដាប់ចម្លើយ ជាង ស្រីមុំ ឆ.៨។ ឯកសារ D114/75 កំណត់ហេតុស្ដាប់ចម្លើយ ស៊ិន ស៊ីសុផល ឆ.៥៥។ ឯកសារ D4.1.461 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុក សាវុធ KH ERN 00196806។ ឯកសារ D4.1.423 កំណត់ហេតុស្ដាប់ចម្លើយ ឌី ពៀច KH ERN 00221552-00221553។ ឯកសារ D234/2.1.74 កំណត់ហេតុស្ដាប់ចម្លើយ ឆ.២០៨។ ឯកសារ D114/297.1.16 Rochelle Braaf, អំពើហិង្សា ផ្លូវភេទ ប្រឆាំង នឹងជនជាតិភាគតិចក្នុងអំឡុងរបបខ្មែរក្រហម EN ERN 00992282។ ឯកសារ D4.1.1003 Bridgette Toy-Cronin, ខ្ញុំចង់និយាយប្រាប់អ្នក KH ERN 00721380-00721381។

3305 សូមមើលឧទាហរណ៍ឯកសារ D234/2.1.132 មុំ វុន ប្រតិចារឹកថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ 13.38.10 ["កម្មាភិបាលដែលគេរៀបការឱ្យទាំង ៦០គូហ្នឹង គេមានភារកិច្ចឡើងប្រកាសប្រាប់ថា គូស្រករដែលរៀបថ្មីជាប្ដីប្រពន្ធហើយនេះត្រូវចេះស្រឡាញ់គ្នា មើលថែរក្សាគ្នា ហើយខំបង្កបង្កើនផលឱ្យបានច្រើន ដើម្បីយកសេដ្ឋកិច្ចនេះ ដើម្បីកម្ទេចខ្មាំងកុំឱ្យមានសល់ ហើយនិងខិតខំបង្កបង្កើនផលកូនឱ្យបានច្រើនឱ្យអង្គការ។"]។ ឯកសារ D11/54/3.1 កុល ណែម ប្រតិ

## ការរំលោភសេពសន្ថវៈនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ (ការរួមដំណេកដោយបង្ខំ)

819. អាជ្ញាធរកម្ពុជាប្រជាធិបតេយ្យទូទាំងប្រទេស បានបញ្ជូនសារយ៉ាងច្បាស់ថា គោលបំណងបឋមនៃការរៀបអាពាហ៍ពិពាហ៍គឺបង្កើតកូន[3306]។ ក្រោយពិធីចប់ ជាទូទៅ កម្មាភិបាលបានតម្រូវឲ្យប្តីប្រពន្ធថ្មីថ្មោងចំណាយពេលពីរបីយប់រួមដំណេកជាមួយគ្នា មុននឹងបញ្ជូនពួកគេត្រឡប់ទៅការដ្ឋានរៀងៗខ្លួនវិញ[3307]។ ជាញឹកញាប់ គេសង់ខ្ទមឲ្យពួកគេដេកជាមួយគ្នា[3308]។ ដើម្បីពង្រឹងការរួម

---

ចារឹកថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ 15.12.03 ["គេគ្រាន់និយាយថា បើសិនមិនបង្កើតកូនឲ្យអង្គការបានទេ គឺអ្នកឯងត្រូវខុសច្បាប់។"]។ ឯកសារ D114/297.1.36 សយ ណារឿន ប្រតិចារឹកថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ 10.48.25 ["ឲ្យស្រឡាញ់គ្នាចាប់ពីពេលនេះតទៅ [...]ឲ្យបង្កបង្កើតជាមនុស្សឲ្យបានច្រើនដោយតម្រូវទៅតាមអង្គការត្រូវការមនុស្សច្រើនដើម្បីការពារទឹកដី។ [...]ឲ្យខ្ញុំនិយាយអ៊ីចឹង និយាយឲ្យដូចគេថាអ៊ីចឹង។"]។ ឯកសារ D234/2.1.128 ណុប ងឹម ប្រតិចារឹកថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៦ 11.07.45-11.12.25 ["គាត់យកពួកខ្ញុំរៀបការ [...]គាត់ណែនាំឲ្យបានត្រូវគ្នាឲ្យខុសគ្នាអ៊ីចឹង គាត់ណែនាំអ៊ីចឹង។ [...]និយាយថ្ងៃការហ្នឹងហ្នង។"]។ D234/2.1.137 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុខឿន ឆ.៣១ ["មុនពេលចាប់ផ្តើមការរៀបការនេះ គឺ សូ បានប្រកាសនៅក្នុងអង្គប្រជុំទូទៅថា "អង្គការត្រូវការកម្លាំងបន្ថែម" ដូច្នេះ គេត្រូវការឲ្យយុវជន យុវនារីរៀបការ ដើម្បីបង្កើតកូនបន្ថែមទៅលើកម្លាំងកសាងបដិវត្តន៍។"]។ ឯកសារ D114/91 កំណត់ហេតុស្តាប់ចម្លើយ សេង អុល ឆ.៧០ ["ប៉ុន្តែគេនិយាយ នៅក្នុងពិធីរៀបការថា ក្រោយរៀបការហើយ ពួកគេត្រូវនៅជាមួយគ្នា ចេះស្រឡាញ់គ្នា ចេះសាមគ្គីគ្នារហូតដល់ចាស់។"]។ ឯកសារ D114/64 កំណត់ហេតុស្តាប់ចម្លើយ អែម សារិន ឆ.២០៥-២០៦។

3306 សូមមើល VIII.H.3. ការអនុវត្តគោលនយោបាយជាតិនៃការរៀបការដោយបង្ខំ – ពិធីរៀបការ កថាខណ្ឌ ៨១៨។ ឯកសារ D234/2.1.88 ប្រាក់ យុត ប្រតិចារឹកថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៦ 13.41.13 ["បើកាលណា ការហើយបើយើងគិតទៅ វាត្រូវតែរួមដំណេក ឬក៏បើមិនរួមដំណេក ក៏យើងថា ការយ៉ាងម៉េច។"]។

3307 ឯកសារ D234/2.1.75 យិន វ៉ាត ប្រតិចារឹកថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥ 15.29.43-15.32.29 [ព្រលានយន្តហោះកំពង់ឆ្នាំង៖ "គេហៅខ្ញុំទៅការហើយ បាន ប្រាំពីរថ្ងៃគេឲ្យខ្ញុំត្រឡប់មកវិញ មិនអាចមិនមកបានទេ ព្រោះអីការចាត់តាំងរបស់គេ។"]។ ឯកសារ D114/297.1.24 មឹង វេត ប្រតិចារឹកថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ 10.09.25 ["គេមិនឲ្យយើងនៅជាមួយគ្នាទេ។ គេត្រូវត្រឡប់ទៅកងគេវិញ។"]។ ឯកសារ D114/297.1.36 សយ ណារឿន ប្រតិចារឹកថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ 10.51.06។ ឯកសារ D234/2.1.137 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុខឿន ឆ. ៣៦។ ឯកសារ D4.1.461 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សារុធ KH ERN 00196806។ ឯកសារ D234/2.1.74 កំណត់ហេតុស្តាប់ចម្លើយ ឆ.២១២។ ឯកសារ D114/34 កំណត់ហេតុស្តាប់ចម្លើយ ណាប់ សុម៉ាលី ឆ. ១៤២។ ឯកសារD10.1.28 កំណត់ហេតុស្តាប់ចម្លើយ សោម ម៉ុន KH ERN 00163765-00163766។

3308 ឯកសារ D114/297.1.29 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹកថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ 13.52.35-13.55.11 ["ខ្មែរក្រហមគេឲ្យខ្ទមតូចៗមួយសម្រាប់គូស្រករដែលរៀបការថ្មីដើម្បីឲ្យរស់នៅជាមួយគ្នា។ ការសិក្សារបស់ខ្ញុំ គឺគេឲ្យនៅជាមួយគ្នាយូរបំផុត មួយអាទិត្យ។ ហើយក្នុងអំឡុងពេលយប់គេឲ្យរស់នៅជាមួយគ្នា ក៏ប៉ុន្តែពេលថ្ងៃ ទៅធ្វើការ

ដំណេក ជារឿយៗ គេបានឱ្យឈ្លបខ្មែរក្រហមនៅជុំវិញ ឬក្រោមខ្ទម ដើម្បីតាមដានសកម្មភាព និងការសន្ទនារបស់ពួកគេនៅពេលយប់[3309]។ ដោយខ្លាចគេដាក់ទោស និងទណ្ឌកម្មចំពោះការមិន

តាមគោលដៅរៀងៗខ្លួន។ ហើយក្រោយពីមួយសប្ដាហ៍ទៅគឺថា ប្ដីប្រពន្ធហ្នឹងគឺត្រូវបំបែកពីគ្នា។"], 14.20.55-14.23.16 ["ចំពោះមនុស្សដែលត្រូវបានគេបង្ខំឱ្យរៀងការហ្នឹង [...]គេរៀបចំផ្ទះតូចៗសម្រាប់ប្ដីប្រពន្ធមួយៗឱ្យនៅមួយយប់ ឬច្រើនយប់ ជាមួយគ្នា។ គេណែនាំឱ្យនៅជាមួយគ្នានៅក្នុងផ្ទះទាំងនោះ។ ហើយ អ៊ីចឹងហើយគឺថា អាចជាពិធីមួយដែលគេណែនាំឱ្យរួមដំណេកក្រោយពីរៀបការ។"]។ ឯកសារ D11/54/3.1 ង៉ែត ចាត ប្រតិចារឹកថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ 16.04.09-16.05.00 ["ស៖ ថាតើនៅពេលដែលអ្នកស្រីបានរៀបការរួចហ្នឹង គេមានរៀបចំកន្លែងឱ្យផ្សំដំណេកទេ? ឆ៖ ពេលរៀបហើយហ្នឹង ក៏នាំគ្នាដើរមកទាំងយប់អ៊ីចឹង។ ខ្ញុំដើរមកមួយគូ ខ្ញុំទៅកំប្រាក់កូនមកវិញ ទៅសមរភូមិកំប្រាក់កូនមកវិញ។ គេធ្វើផ្ទះគេ ខ្ទមគេតូចៗដូចថាល្មមតែឱ្យយើងដេកមួយគ្រួសារៗអ៊ីចឹងទៅ។"]។ ឯកសារ D114/297.1.33 ផេហ្គី ឡឺវ៉ាញ ប្រតិចារឹកថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦ 15.55.57-15.59.02 ["នៅក្នុងប៉ាន់របស់ខ្ញុំដែលខ្ញុំបានលើកឡើងពាក់ព័ន្ធទៅនឹងខេត្តកណ្ដាល ខ្ញុំបាននិយាយហើយថា ខ្ញុំនិយាយថា នៅក្នុងតំបន់នោះ មានខ្ទមរាត្រីទឹកឃ្មុំ នោះគឺជាតំបន់ដែលបានធ្វើខ្ទមរាត្រីទឹកឃ្មុំ នៅក្នុងពេលលំបាកលំបិននោះ។"]។

3309 ឯកសារ D11/61/3.1 វី ពៅ ប្រតិចារឹកថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ 13.52.55 [ស្រុកត្រាំកក់៖ "គេឱ្យយើងជួយតាមដានគូណារៀបការហើយត្រូវគ្នា មិន អ្នកណាខុសគ្នា អ្នកណាមិនស៊ីចុះដំណេកជាមួយគ្នា គេឱ្យយើងជួយតាមដានគេទៀត ដែលផ្ទះយើង កងយើងនៅក្បែរហ្នឹង"]។ ឯកសារ D114/297.1.25 ស៊ូ សុធារី ប្រតិចារឹកថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ 15.21.36។ ឯកសារ D234/2.1.127 ជា ឡៀប ប្រតិចារឹកថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ 10.01.56-10.07.44។ ឯកសារ D234/2.1.98 អ៊ុច ស៊ុនឡាយ ប្រតិចារឹកថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៦ 09.54.23 ["ឪពុកក្មេកហ្នឹងត្រូវគេចាប់បង្ខំឱ្យរៀបការថែមទៀត [...]គេមានពួកកងឈ្លបតាមដានទៅដល់ផ្ទះដល់សម្បែងទៀតថាតើពីរនាក់ហ្នឹងចុះសម្រុងនឹងគ្នាឬអត់? តើពីរនាក់ហ្នឹងនិយាយគ្នារឿងអីថែមទៀត ដើម្បីតាមដានសញ្ញាន់លើសញ្ញាន់រហូតដល់ចុងក្រោយ [...]យកទៅសម្លាប់។"]។ ឯកសារ D114/297.1.35 ប៉ែន សុចាន់ ប្រតិចារឹកថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ 14.38.06-14.40.23 ["គេចល័ត យប់ឡើងគេចល័តតាមដាន។ គឺជាល្បែងលេងសើចរបស់គេ។"]។ ឯកសារ D234/2.1.132 មុំ វុន ប្រតិចារឹកថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ 13.43.46-13.48.05 ["ដល់ឈ្លបគេឮសូរថាអ៊ីចឹង គេឡើងភ្លែតមក ស្រមកបីនាក់បណ្ដោយ ឡើងមកបីនាក់ហើយគេថា មិនព្រមទៀត នៅចាំបែកគ្នាដល់ណាទៀត។ រួចមក គេយកកាំភ្លើងមកភ្ជង់ ដោះអាវខាងប្រុសក៏ដោះអាវ ខាងស្រីក៏ដោះអាវឱ្យអស់ ដើម្បីរួមដំណេកជាមួយគ្នា។"]។ ឯកសារ D114/297.1.29 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹកថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ 14.25.34-14.28.11 ["ស៖ គូស្រករដែលត្រូវបានគេបង្ខំឱ្យរៀបការ តើលោកស្រីបានឮរឿងរ៉ាវពីសាក្សីថា គេនឹងតាមដានជាពិសេសដោយអាជ្ញាធរមូលដ្ឋាន ដើម្បីតាមដានមើលថា តើប្ដីប្រពន្ធហ្នឹងរួមដំណេកដែរ ឬអត់ [...]ឆ៖ ចាស ខ្ញុំមានរឿងរ៉ាវបែបនោះ។ ជាពិសេស គឺមនុស្សដែលត្រូវបានគេបង្ខំឱ្យរៀបការប្រឆាំងនឹងឆន្ទៈរបស់គេ។"]។ ឯកសារ D11/255/3 មាស ឡៃហួរ ប្រតិចារឹកថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ 09.44.45។ ឯកសារ D4.1.927 កំណត់ហេតុស្ដាប់ចម្លើយ ហេង ឡៃហ៊ាង ឆ.៣១-៣២។ ឯកសារ D234/2.1.74 កំណត់ហេតុស្ដាប់ចម្លើយ ឆ.២១២។ ឯកសារ D11/231/4 កំណត់ហេតុស្ដាប់ចម្លើយ ស៊ុំ ចាន់ថុល ឆ. ១០៦។ ឯកសារ D114/297.1.16 Rochelle Braaf, អំពើ

គោរពអង្គការ ប្តីប្រពន្ធបានបង្ខំចិត្តរួមដំណេកជាមួយអ្នកដែលពួកគេត្រូវបានផ្គូផ្គងជាមួយ[3310]។ ដោយហេតុថាបុរសជាច្រើនជាជនរងគ្រោះ និងសុខចិត្តរួមដំណេកតែដោយសារការបង្ខំប៉ុណ្ណោះ បុរសខ្លះបានចាប់បង្ខំប្រពន្ធដែលពួកគេទើបរៀបការថ្មីៗ ដោយខ្លាចមានផលវិបាកអាក្រក់ ឬព្រោះថាពួកគេមានសិទ្ធិ[3311]។ អ្នកដែលបន្តជំទាស់មិនរួមដំណេក ហើយគេបានដឹងនោះ ត្រូវគេយកទៅ

---

ហិង្សា ផ្លូវភេទ ប្រឆាំង នឹងជនជាតិភាគតិចក្នុងអំឡុងរបបខ្មែរក្រហម EN ERN 00992246 ["ស្ទើរតែគ្រប់ជនជាតិភាគតិចដែលត្រូវបានបង្ខំឱ្យរៀបការដែលបានរាយការណ៍ថា ត្រូវបានឃ្លាំមើលដោយខ្មែរក្រហមនៅពេលយប់ដើម្បីធានាថាមានការរួមដំណេក"], 00992283 ["ដោយសារតែគោលបំណងនៃការរៀបការដោយបង្ខំគឺដើម្បីបង្កើតកូនជូនអង្គការ គូស្រករថ្មីៗត្រូវបានដាក់សម្ពាធស្ទើរតែទាំងអស់ដើម្បីរួមភេទក្រោមការឃ្លាំមើលរបស់ខ្មែរក្រហម។"]។ ឯកសារ D4.1.1003 Bridgette Toy-Cronin, ខ្ញុំចង់និយាយប្រាប់អ្នក KH ERN 00721383។

3310 ឯកសារ D114/297.1.29 កាស៊ូមិ ណាកាហ្កាវ៉ា ប្រតិចារឹកថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ 14.23.16-14.25.34 ["មិនទាំងអស់ទេ ប៉ុន្តែអ្នកខ្លះ គេនិយាយច្បាស់ថា គេមិនចង់ធ្វើបែបនោះទេ ប៉ុន្តែគេត្រូវតែធ្វើ ដើម្បីឱ្យបាននៅរស់។"], 14.35.28-14.38.00 ["ស៖ […]តើពួកគេយល់ស្របទាំងស្រុង និងរួមភេទជាមួយដៃគូទេ […]?ឆ៖ ខ្ញុំមិនគិតបែបនោះទេ […]ការរៀបការដោយបង្ខំ គឺមិនមានការយល់ព្រម គឺមិនដោយឆន្ទៈរបស់ភាគីមួយៗទេ។ សេចក្តីសម្រេចក្នុងការរួមដំណេក រួមរ័កហ្នឹង គឺថាមិនចេញពីឆន្ទៈរបស់គេទេ។ ពួកគេត្រូវបានបំភិតបំភ័យ ពួកគេមានការភ័យខ្លាច ទោះបីគេរួមដំណេកក៏ដោយ គឺមិនមែនជាការព្រមព្រៀងពិតចេញពីបុរស និងស្ត្រីទេ។"]។ ឯកសារ D114/134 កំណត់ហេតុស្តាប់ចម្លើយ សួន សាំង ឆ.១៤៦-១៤៧, ១៥១ ["ស៖ តើលោកស្រីមានរួមដំណេកជាមួយគ្នាទេ? ឆ.១៤៦៖ អត់ទេ ទាល់តែបួនយប់ (យប់ទី៤) ព្រោះខ្ញុំខ្លាចពេក។ ស៖ តើលោកស្រីខ្លាចអ្វី? ឆ.១៤៧៖ មិនដឹង ខ្ញុំញាក់ ខ្ញុំខ្លាច។ […]ស៖ លោកស្រីនិយាយថា មានគមកតាមមើល មានន័យថាម៉េច? ឆ.១៥១៖ ខ្លាចយើងមិត្រូវគ្នា ខ្លាចយើងទាស់ទែងគ្នាទៅ។"]។ ឯកសារ D4.1.812 កំណត់ហេតុស្តាប់ចម្លើយ ភ្នៅ យ៉ាវ ឆ.៣២ [ស្រុកត្រាំកក់៖ "គ្មានគូណា ហ៊ានមិនចុះសម្រុងគ្នាទេ ព្រោះខ្លាចងាប់។ បើមានគូណា មិនចុះសម្រុងគ្នា ឈ្លបដឹងរាយការណ៍ទៅថ្នាក់លើ ហើយព្រឹកឡើង គេនឹងហៅទៅណែនាំ ដោយគំរាមថា នឹងយកទៅទីណាៗ ដូចយកទៅដាក់ក្រាំងតាចាន់"]។ ឯកសារ D234/2.1.37 Kasumi Nakagawa, អំពើហិង្សាយេនឌ័រ KH ERN 00738350-00738352។

3311 ឯកសារ D114/297.1.29 កាស៊ូមិ ណាកាហ្កាវ៉ា ប្រតិចារឹកថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ 14.25.34-14.28.11 ["បុរសខ្លះប្រើអំពើហិង្សា ហើយក៏អាចថា បុរសនោះក៏មានការភ័យខ្លាចថាគេ គេក៏ត្រូវតែរួមដំណេក ហើយត្រូវប្រើអំពើហិង្សាប្រឆាំងនឹងប្រពន្ធ។"]។ ឯកសារ D114/297.1.35 ប៉ែន សុចាន់ ប្រតិចារឹកថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ 14.21.19-14.23.05 ["ពេលដែលឃើញចេញមកពីធ្វើការរៀងៗខ្លួន ឃើញមុខគ្នា គឺគាត់ស្តាប់ឈ្លប គេដឹងថា ថ្ងៃរៀបការ គាត់ស្តាប់ឈ្លបឱ្យធ្វើបាបនាងខ្ញុំ ឃើញស្លៀកខោច្រើនជាន់អ៊ីចឹង គឺឈ្លបគេរាយការណ៍មកថា ឱ្យធ្វើបាបទាល់តែបាន។ ចាប់រំលោភយ៉ាងម៉េចឱ្យទាល់តែបាន។"], 15.05.00-15.07.29 ["យប់ទី៣ គេបានហែកខោហែកអាវខ្ញុំ ឈ្លបឈរមើលគឺខ្ញុំក៏មិនហ៊ានធ្វើអ្វីចំពោះគេដែរ ចាស ព្រោះដៃនាងខ្ញុំជាប់ចំណងហើយ អ៊ីចឹងគេសម្រាតយើងបានរំលោភយើងបានតាមចិត្ត។ […]ហើយពួកឈ្លបលួចមើលនោះគេថា អើ! ធ្វើអ៊ីចឹងបានល្អសម្រេចជូនអង្គការហ្នឹងឯងយកកូនជូនអង្គការ។"]។ ឯកសារ 15.42.50-15.44.46 ["គេ [ឈ្លប]គ្រាន់តែថា […]បានចាប់ដៃគ្នា គឺប្តីប្រពន្ធហើយ

អប់រំ គំរាមកំហែងសម្លាប់[3312] ឬដាក់ទោសធ្ងរធ្ងរចំពោះការមិនគោរពពួកគេ ពេលខ្លះ បានបាត់ខ្លួន ត្រូវគេធ្វើទារុណកម្ម និង/ឬសម្លាប់ចោល[3313]។

---

ត្រូវតែចាប់រំលោភឱ្យបាន"]។ ឯកសារ D234/2.1.137 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុខឿន ឆ. ៤៣-៤៤ ["នៅយប់មួយនោះ គាត់បានចាប់ហែកខោអាវរបស់ខ្ញុំហើយប្រាប់ខ្ញុំថា បើឯងមិនស្ម័គ្រចិត្តរួមរ័កទេ យើងត្រូវតែប្រើកម្លាំង។ [...] ហើយបន្ទាប់ពីការរំលោភមកគាត់បានមកសុំទោសខ្ញុំដោយប្រាប់ថា គាត់ធ្វើតាមទិសរបស់អង្គការ។ [...]ឆ. ៤៤៖[ពិពណ៌នាពីការរំលោភដោយលម្អិត]។ ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន់ ឆ.៤៩, ឆ .៥៤, ៥៦ ["ស៖ ហេតុអ្វីបានជាគេដឹងថា លោកស្រីគេចមិនរួមដំណេកជាមួយប្ដីលោកស្រី? ឆ.៤៩៖ ប្ដីរបស់ខ្ញុំប្រាប់គេ។ [...]ឆ.៥៤៖ ខ្ញុំឈប់បដិសេធ ព្រោះមានគេមកប្រាប់ថា យើងបានប្ដេជ្ញារួចហើយ យើងត្រូវតែធ្វើតាមការប្ដេជ្ញាហ្នឹង។ [...]ឆ.៥៦៖ បើខ្ញុំមិនព្រមរួមដំណេក គេក៏ចាប់បង្ខំខ្ញុំដែរ។"]។ ឯកសារ D234/2.1.37 Kasumi Nakagawa, អំពើហិង្សាយេនឌ័រ KH ERN 00738345 [ចម្លើយស្ត្រីម្នាក់បាននិយាយថា៖ "គាត់បានវាយខ្ញុំ ពីព្រោះខ្ញុំមិនស្រឡាញ់គាត់ ហើយប្រកែកមិនព្រមរួមរ័ក [...]គាត់វាយភ្លៅទាំងពីររបស់ខ្ញុំជាមួយដៃរបស់គាត់ ដូច្នេះ ខ្ញុំមិនអាចរើបម្រះបានឡើយ ហើយវាបានធ្វើឱ្យមានភាពងាយស្រួលចំពោះគាត់ក្នុងការរួមរ័កជាមួយខ្ញុំ។"], EN ERN 00421896 [អ្នកឆ្លើយតបម្នាក់ទៀតនិយាយថា៖ "ពេលខ្ញុំបដិសេធមិនរួមរ័កជាមួយគាត់ក្រោយពីការហើយ គាត់បានរាយការណ៍ទៅកម្មាភិបាល បន្ទាប់មក ពួកគេមកចាប់ខ្ញុំ ហើយបន្ទាប់មកនៅក្នុងផ្ទះគេបង្ខំឱ្យខ្ញុំស្រាតខោអាវ ដើម្បីឱ្យបុរសនោះរំលោភខ្ញុំ។ ពួកគេថា បើមិនធ្វើតាគេនឹងសម្លាប់ខ្ញុំ [...]ដូច្នេះ ខ្ញុំត្រូវយល់ព្រមព្រោះគ្មានជម្រើស។"]។ ឯកសារ D114/297.1.16 Rochelle Braaf, អំពើហិង្សា ផ្លូវភេទ ប្រឆាំង នឹងជនជាតិភាគតិចក្នុងអំឡុងរបបខ្មែរក្រហម EN ERN 00992246 ["ប្ដីមួយចំនួនត្រូវបង្ខំប្រពន្ធរបស់ខ្លួនរួមភេទ។ ការរួមភេទដោយបង្ខំនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំគឺមានការលំបាកខ្លាំងណាស់សម្រាប់ជនរងគ្រោះទាំងប្រុស ទាំងស្រី។"]។ ឯកសារ D4.1.1003 Bridgette Toy-Cronin, ចង់និយាយប្រាប់អ្នក KH ERN 00721390 ["ដោយសារគោលបំណងបឋមមួយនៃការរៀបការទាំងនេះគឺការធានាឱ្យមានការបន្តពូជនេះ ការរួមភេទដោយបង្ខំជាផ្នែកមួយដែលចាំបាច់នៃចំណងអាពាហ៍ពិពាហ៍នេះ។ [...]ក្នុងករណីខ្លះ គោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានប្រើប្រាស់ដើម្បីរំលោភលើផ្លូវភេទស្របច្បាប់។"]។

3312 ឯកសារ D114/297.1.25 ស៊ូ សុធារី ប្រតិចារឹកថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ 15.24.14-15.27.02 ["ថាបើអ្នែងមិនព្រមដេកទេ គង់តែថ្ងៃណាមួយស៊ើបការណ៍ដឹង កម្ទេចអ្នែងចោល។"]។ ឯកសារ D234/2.1.96 អ៊ិន យឿង ប្រតិចារឹកថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១៦ 15.18.25-15.21.10 ["គេបានប្រាប់ថា ត្រូវតែរួមដំណេកគ្នា បើមិនរួមដំណេកគ្នា គេយកទៅដាក់កន្លែងឃុំឱ្យដេកជាមួយគ្នា [...]បើមិនធ្វើតាមគេ ខ្ញុំខ្លាចស្លាប់។"]។ ឯកសារ D234/2.1.88 ប្រាក់ យុត ប្រតិចារឹកថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១៦ 13.47.27-13.51.44 ["ចំពោះគូស្រករមិនរួមដំណេក [...]មានតែអប់រំនៅក្នុងស្រុក ដើម្បីឱ្យគូស្រករទាំងពីរនោះចេះយល់ចិត្ត យល់គំនិតគ្នា ព្រោះយើងការរួចហើយ"]។ ឯកសារ D11/54/3.1 ព្រាប សុឃឿន ប្រតិចារឹកថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ 09.26.53-09.28.52 ["បងអឿន គេឱ្យរៀបការជាមួយបងមាន។ បងមាន ហ្នឹងគាត់ធាត់ មាឌធំ អត់សមរម្យ [...]បងអឿន គាត់ស្អាត។ ដល់ បងមាន ហ្នឹងគាត់ស្រឡាញ់បុរសហ្នឹង ព្រោះគេរៀបឱ្យ គាត់មានអារម្មណ៍ស្រឡាញ់ ក៏ប៉ុន្តែបុរសហ្នឹងមិនស្រឡាញ់គាត់ ដូចថា តែតាមខ្ញុំស្ដាប់ព័ត៌មានពី បងមាន គាត់និយាយថា គាត់ថា បើគេឱ្យទៅដេកជាមួយ គាត់ចងអង្រឹងដេក។ ហើយបងមាន គាត់ដេក

## ការបំបែកមិនឱ្យរស់នៅជាមួយគ្នា

820. ពេលរយៈពេលខ្លីដែលពួកគេត្រូវរួមដំណេកគ្នាដើម្បីបង្កើនចំនួនប្រជាជនបានកន្លងផុត ប្ដីប្រពន្ធទើបរៀបការត្រូវបានបញ្ជូនត្រឡប់ទៅធ្វើការវិញ ជារឿយៗ នៅឆ្ងាយពីប្ដី ឬប្រពន្ធរបស់ពួកគេ ដើម្បីបម្រើដល់គោលដៅបដិវត្តន៍ផ្សេងទៀតក្នុងការស្ដារប្រទេស[3314]។ ទោះជាយ៉ាងនេះក្ដី ដើម្បី

---

នៅនឹងរោងហ្នឹងទៅ គាត់ចងអង្រឹងដេកតាមសសរចម្រឹងហ្នឹងទៅ។ អ៊ីចឹងគាត់ពីរនាក់ហ្នឹង អត់បានត្រូវគ្នាទេ។ ដល់ក្រោយមក អង្គការដឹងទៅ គេហៅអប់រំ។"]។ ឯកសារ D114/297.1.35 ប៉ែន សុចាន់ ប្រតិចារឹកថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ 14.30.51-14.32.02 [បន្ទាប់ពីដើមបណ្ដឹងរដ្ឋប្បវេណីបដិសេធមិនរួមដំណេកចំពោះការរៀបការដោយបង្ខំរបស់នាងនៅស្រុកបាកាន៖ "ឃ្លាំសម័យនុ៎ង គឺដូចគាត់និយាយអ៊ីចឹង បើមិនស្រឡាញ់ គឺមិនដេក គេសម្លាប់ក្នុងពេលហ្នឹង គេធ្វើបាបគេធ្វើទារុណកម្ម។""], 14.38.06-14.40.23 ["សមមិត្តប្រធានអ៊ុំ ក៏ខ្ញុំចងចាំថា យប់ទី៣ គឺយប់ដែលខ្ញុំត្រូវស្លាប់។"]។ ឯកសារ D4.1.812 កំណត់ហេតុស្ដាប់ចម្លើយ ភ្លៅ យ៉ាវ ឆ.៣២ ["ដោយគំរាមថា នឹងយកទៅទីណាៗ ដូចយកទៅដាក់ក្រាំងតាចាន់។"]។ ឯកសារ D234/2.1.137 កំណត់ហេតុស្ដាប់ចម្លើយ ព្រាប សុខឿន ឆ. ៣៦។ ឯកសារ D114/36.1.64 កំណត់ហេតុស្ដាប់ចម្លើយ សេង អុល ឆ. ៤០។ ឯកសារ D11/75 កំណត់ហេតុស្ដាប់ចម្លើយ ចិច សុផា ឆ.១២៥។

3313 ឯកសារ D11/54/3.1 ព្រាប សុឃឿន ប្រតិចារឹកថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ 09.21.47-09.23.38 ["មិត្តព្រឿងហ្នឹងគាត់ការរួចហើយ ការប្ដីគាត់ហ្នឹងឈ្មោះ អឿន។ ប្ដីគាត់ហ្នឹងទាបល្អិត។ ដល់ពេលទៅ គាត់ថា ដូចកូនក្មេង គាត់មិនដឹងយកធ្វើប្ដីម៉េចទៅ គាត់ចេះតែបដិសេធ ដល់ក្រោយមកបានបាត់ឈ្មោះ ព្រឿង ហ្នឹង ហើយនិងប្ដីតែម្ដង។"]។ ឯកសារ D234/2.1.137 កំណត់ហេតុស្ដាប់ចម្លើយ ព្រាប សុខឿន ឆ. ២៧, ៣៤ ["នារី រិន ត្រូវបានបាត់ខ្លួនពីកងទៅ ពេលខ្ញុំសួរទៅ នី លី តើមិត្តរិន ទៅណា? ហេតុអ្វី? មិត្តលី ប្រាប់ថា គេចាប់យកទៅបាត់ហើយ ដោយសារគាត់មិនព្រមរួមភេទ"]។ ឯកសារ D4.1.808 កំណត់ហេតុស្ដាប់ចម្លើយ ឌុក សួរ ឆ.៩៣។ ឯកសារ D11/75 កំណត់ហេតុស្ដាប់ចម្លើយ ចិច សុផា ឆ.១២៥ ["គេដាក់ទោសដោយបញ្ជូនពួកគេទៅរៀនសូត្រ តែមិនឃើញអ្នកទាំងនោះត្រឡប់មកវិញ"]។

3314 ឯកសារ D114/297.1.30 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹកថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១៦ 09.35.44-09.38.58 ["គោលបំណងទូទៅរបស់ខ្មែរក្រហមនោះ តាមដែលខ្ញុំយល់ គឺសម្រេចឱ្យបាននូវបដិវត្តន៍ [...]ចូលរួមក្នុងពលកម្មដ៏ខ្លាំង [...]ដោយសារតែយុទ្ធសាស្ត្រនោះ [...]គេបំបែកប្ដីចេញពីប្រពន្ធនោះ"]។ ឯកសារ D114/297.1.29 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹកថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ 13.52.35-13.55.11 ["ហើយក្រោយពីមួយសប្ដាហ៍ទៅគឺថា ប្ដីប្រពន្ធហ្នឹងគឺត្រូវបំបែកពីគ្នា។ គឺថា ពួកគាត់ភាគច្រើនហ្នឹង គឺប្ដីរបស់គាត់គឺថាត្រូវឱ្យទៅធ្វើការនៅឆ្ងាយ រស់នៅឆ្ងាយ ទៅធ្វើពលកម្ម ធ្ងន់ធ្ងរនៅឆ្ងាយ"]។ ឯកសារ D234/2.1.75 ឃិន វ៉ាត ប្រតិចារឹកថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៥ 15.29.43-15.32.29 [ព្រលានយន្តហោះកំពង់ឆ្នាំង៖ "គេហៅខ្ញុំទៅការហើយ បាន ប្រាំពីរថ្ងៃគេឱ្យខ្ញុំត្រឡប់មកវិញ មិនអាចមិនមកបានទេ ព្រោះអីការចាត់តាំងរបស់គេ។ ម្ល៉ោះហើយ ខ្ញុំត្រូវបែកបាក់ប្ដីប្រពន្ធខ្ញុំដែលរៀបការថ្មីហ្នឹង ខ្ញុំត្រឡប់មកពោធិចិនតុងវិញ។ មិនអាចថាមិនមកបានទេ ព្រោះគេចាត់តាំងហើយ។"]។ ឯកសារ

បង្កើតកូនឲ្យអង្គការ ប្ដីប្រពន្ធត្រូវបានបញ្ជា អនុញ្ញាត ឬលើកទឹកចិត្តឲ្យជួបគ្នា ជាទូទៅ ម្ដង ឬពីរដងក្នុងមួយខែ ប៉ុន្តែត្រូវមានការអនុញ្ញាតច្បាស់លាស់ពីថ្នាក់លើរបស់ពួកគេ[3315]។

## ៤. ការអនុវត្តគោលនយោបាយនៅតំបន់កំពង់សោម

821. ការរៀបអាពាហ៍នៅកំពង់សោមនៅសម័យកម្ពុជាប្រជាធិបតេយ្យ មានលក្ខណៈខុសប្លែកពីគេមួយចំនួន ដែលពុំមាននៅផ្នែកផ្សេងទៀតនៃប្រទេស។ ប្រជាជននៅតំបន់កំពង់សោម (ទាំងប្រជាជនស៊ីវិល ទាំងយោធា) ស្ថិតក្រោមការគ្រប់គ្រងរបស់មេបញ្ជាការកងពលមជ្ឈិម។ កងពល ១៦៤ ជាកងពលមជ្ឈិមធំជាងគេក្នុងប្រទេស ដែលមានទាហានជាង ៨.៦០០ នាក់នៅឆ្នាំ ១៩៧៦ (និងបុរស

---

D114/297.1.36 សយ ណារឿន ប្រតិចារឹកថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ 10.51.06។ ឯកសារ D114/297.1.24 មឹង វ៉េត ប្រតិចារឹកថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ 10.09.25។ ឯកសារ D114/32 កំណត់ហេតុស្ដាប់ចម្លើយ មាស សារ៉ាន់ ឆ.៤៣។ ឯកសារ D4.1.461 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុក សារុធ KH ERN 00196806។ ឯកសារ D114/34 កំណត់ហេតុស្ដាប់ចម្លើយ ណាប់ សុម៉ាលី ឆ.១៤២។ ឯកសារ D10.1.28 កំណត់ហេតុស្ដាប់ចម្លើយ សោម ម៉ុន KH ERN 00163765-00163766។ ឯកសារ D54/74.1.20 Philip Short, Pol Pot: ប្រវត្តិនៃសុបិនអាក្រក់ EN ERN 00396533-34។ ឯកសារ D114/297.1.16 Rochelle Braaf, អំពើហិង្សា ផ្លូវភេទ ប្រឆាំង នឹងជនជាតិភាគតិចក្នុងអំឡុងរបបខ្មែរក្រហម EN ERN 00992283។ ឯកសារ D1.3.17.1 Elizabeth Becker, ពេលសង្គ្រាមរលត់ទៅ KH ERN 00232339-00232340។

3315 ឯកសារ D234/2.1.136 ព្រាប សុឃឿន ប្រតិចារឹកថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ 15.05.34-15.08.15 ["មួយខែមកម្ដង រួចខ្ញុំចង់ភ្លេចប្ដីបាត់ទៅហើយ បានគេឲ្យជួបម្ដងទៀត។"], 15.10.30 ["១ខែ ត្រូវជួបគ្នា ៣យប់ បើអ្នកាណាហួសកម្រិត ក៏គេដាក់ពិន័យដែរ។"]។ ឯកសារ D114/297.1.36 សយ ណារឿន ប្រតិចារឹកថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ 10.51.06 -10.53.06 ["ក្រោយមកមួយអាទិត្យគេឲ្យជួបគ្នាម្ដង"]។ ឯកសារ D114/297.1.25 ស៊ូ សុធារី ប្រតិចារឹកថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ 15.27.02-15.30.33 ["រៀងរាល់ ១០ថ្ងៃម្ដង"]។ ឯកសារ D234/2.1.87 យូ វ៉ាន់ ប្រតិចារឹកថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ 13.38.15។ ឯកសារ D234/2.1.137 កំណត់ហេតុស្ដាប់ចម្លើយ ព្រាប សុខឿន ឆ.៣៤។ ឯកសារ D4.1.522 កំណត់ហេតុស្ដាប់ចម្លើយ ស៊ូ សឿន KH ERN 00348826 [ខ្ញុំនៅបែកគ្នា គឺគាត់នៅកំពង់ចាម ខ្ញុំនៅចំការលើ។ គេយមិនឲ្យយើងរស់នៅជាមួយគ្នានោះទេ។ ប៉ុន្តែខ្ញុំអាចទៅលេងម្ដងមួយអាទិត្យ ឬពីរអាទិត្យ ក្នុងមួយខែ ជួនកាលពីរបីខែទៅម្ដង ពេលគាត់រវល់ខ្លាំង។"]។ ឯកសារ D4.1.927 កំណត់ហេតុស្ដាប់ចម្លើយ ហេង ឡៃហ៊ាង ឆ. ៣៣។ ឯកសារ D114/33 កំណត់ហេតុស្ដាប់ចម្លើយ ហែម អាង ឆ.១៦៣។ ឯកសារ D114/36.1.63 កំណត់ហេតុស្ដាប់ចម្លើយ ឃី ហ៊ុន KH ERN 00189233។ ឯកសារ D4.1.1003 Bridgette Toy-Cronin, ចង់និយាយប្រាប់អ្នក KH ERN 00721383។

នៅលើវដល់អាយុការជាច្រើននាក់)[3316]។ កងពលមានកងវរសេនាតូចនារីតែមួយប៉ុណ្ណោះ (កងវរសេនាតូច ១៦៧) មានទាហានប្រហែល ៤០០ នាក់[3317] ដែលបង្កើតឱ្យមានអតុល្យភាពជាតួលេខយ៉ាងខ្លាំងរវាងបុរស និងស្ត្រី។ ទាហានបុរសភាគច្រើនមិនមែនមកពីកំពង់សោមទេ និងគ្មានឱកាសបានជួប ស្គាល់ ឬឃើញនារីមូលដ្ឋានទេ។ នេះក៏ជាករណីសម្រាប់អ្នកដែលឈរជើងលើកោះ ឬយាមល្បាតនៅសមុទ្រដែរ។ ដោយសារនៅកងពល មាននារីមិនគ្រប់គ្រាន់ **មាស មុត** បានសម្រេចចិត្តឱ្យទាហានរបស់ខ្លួនរៀបការជាមួយនារីស៊ីវិល ដែលធ្វើការនៅសហករណ៍ និងនៅការដ្ឋានផ្សេងៗនៅកំពង់សោម[3318] ឬរស់នៅក្រៅព្រំប្រទល់កំពង់សោម ជាពិសេស នៅភូមិភាគនិរតីដែលកាន់កាប់ដោយឪពុកក្មេករបស់គាត់ តាម៉ុក។ នារីវ័យក្មេងត្រូវបានជ្រើសរើសជាពិសេស និងជាញឹកញាប់ នៅតាកែវ ឬកំពត (ជាពិសេសក្នុងចំណោមកម្មករស្រែអំបិល) ដើម្បីរៀបការជាមួយទាហានកងពល ១៦៤ និងធ្វើការនៅតាមសហករណ៍ និងចម្ការនៅកំពង់សោម ដូចដែលសាក្សីឈ្មោះ សេង អុល, ណាវ សុខន ហៅ កែន, យឹម ស្រឿង និង វុន ប៊ុណ្ណា បានឆ្លើយប្រាប់អ្នកអង្កេត[3319]។

---

3316 ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.២៩ [“មានយោធាចំនួនតិចណាស់កាលពីពេលណោះដែលមានប្រពន្ធ។”]។

3317 ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.៦, ១៣-១៤, ១៩, ២៤ [និយាយថា មាន ៤កងអនុសេនាធំ (៣១, ៣២, ៣៣ និង ៣៥) ក្នុងកងវរៈសេនាតូចនារី ១៦៧)។ ឯកសារ D54/23 កំណត់ហេតុស្តាប់ចម្លើយ ប៉ាក សុខ ឆ.២-៣។ ឯកសារ D2/9 កំណត់ហេតុស្តាប់ចម្លើយ សាយ ប៊ិន ឆ.២៦។ ឯកសារ D2/10 កំណត់ហេតុស្តាប់ចម្លើយ សាយ ប៊ិន ឆ. ៤៦។ ឯកសារ D54/17 កំណត់ហេតុស្តាប់ចម្លើយ សាយ ប៊ិន ឆ.១៣។ ឯកសារ D22.2.4 របាយការណ៍ស្ថិតិគណៈកម្មាធិការកងពល១៦៤ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៦ KH ERN 00160118 [កងវរៈសេនាតូចនារី ១៦៧៖ ៣៩១]។ ឯកសារ D22.2.5 របាយការណ៍ស្ថិតិគណៈកម្មាធិការកងពល១៦៤ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៧៦ KH ERN 00160123 [កងវរៈសេនាតូចនារី ១៦៧៖ ៣៩១]។ ឯកសារ D1.3.5.3 4 របាយការណ៍ស្ថិតិគណៈកម្មាធិការកងពល១៦៤ ដោយ មាស មុត ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៧៦ [កងវរៈសេនាតូចនារី ១៦៧៖ ៤៣៤]។ ឯកសារ D22.2.6 របាយការណ៍ស្ថិតិកងពល១៦៤ ដោយ មាស មុត ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ KH ERN 00160071 [កងវរៈសេនាតូចនារី ១៦៧៖ ៤២៩]។ សូមមើលផងដែរ កថាខណ្ឌ ២៥៨។

3318 ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន់ ឆ.២៩ [“ស៖ តើលោកស្រីដឹងថា គេផ្គូផ្គងប្តីប្រពន្ធតាមមូលហេតុអ្វីខ្លះ? ឆ.២៩៖ […]ទី២៖ គេដឹកនារីៗនៅតាមសហករណ៍តាមកប៉ាល់ទៅតាមកោះ ដើម្បីឱ្យយោធាមើល ហើយជ្រើសរើស ហើយគេក៏អាចស្គាល់គ្នាចាប់តាំងពីពេលនោះមក។”]។

3319 ឯកសារ D114/36.1.64 កំណត់ហេតុស្តាប់ចម្លើយ សេង អុល ឆ.២០-២២, ២៧ [កម្មាភិបាលស្ត្រីនៅឃុំព្រៀងញ៉ង ស្រុក ១០៥ ភូមិភាគ និរតី៖ “ក្នុងឆ្នាំ ១៩៧៧ ឬ ១៩៧៨ ធ្លាប់មានកងទ័ពមកស្នើនារីពីកងរបស់ខ្ញុំទៅរៀបការនៅកំពង់

សោម។ ពេលនោះ មានលិខិតស្នើសុំពីកងទ័ព មកជុំរបស់ខ្ញុំ ហើយគណៈឃុំក៏បានប្រាប់ខ្ញុំឱ្យជ្រើសរើសនារីយកទៅកំពង់សោម ដោយប្រាប់ថា កងទ័ពស្នើ។ ពេលនោះ ខ្ញុំ និងនារីដែលត្រូវជ្រើសរើសឱ្យទៅនោះ មិនដឹងថា គេយកទៅរៀបការជាមួយកងទ័ពពិការទេ។ [...]ខ្ញុំបានរើសនារីប្រហែលជា ៣ ទៅ ៥នាក់។ ហើយការជ្រើសរើសនេះ មិនមែនតែឃុំខ្ញុំមួយទេគឺមានឃុំផ្សេងៗក៏មានដែរ។ [...]ឆ.២១៖ ខ្ញុំមិនចាំទាំងអស់ទេ ប៉ុន្តែមានស្ត្រីម្នាក់ឈ្មោះ គេ [...]ឆ.២២៖ ប៉ុន្តែខ្ញុំមិនដឹងថា នារីទាំងនោះ ស្ម័គ្រចិត្ត ឬអត់ទេ ប៉ុន្តែនារីទាំងនោះ មិនមាននរណាម្នាក់បដិសេធទេ។ [...]ឆ.២៧៖ ខ្ញុំជ្រើសរើសនារីដែលមានចរិតចាស់ទុំ និងមានអាយុចាប់ពី ២០ឆ្នាំឡើងទៅ រួចហើយខ្ញុំបានបញ្ជូននារីទាំងនោះ ទៅមន្ទីរឃុំ។"]។ ឯកសារ D114/91 កំណត់ហេតុស្តាប់ចម្លើយ សេង អុល ឆ.១៧៣, ១៧៨, ២០៥-២០៨, ២២៣, ២២៤ ["នៅឆ្នាំ ១៩៧៦ ឬ ៧៧ ខាងលើគេឱ្យខ្ញុំជ្រើសរើសនារី ៤ ឬ ៥នាក់ទៅរៀបការជាមួយកងទ័ពនៅកំពង់សោម។ [...]តាមពិតពួកគេស្ម័គ្រចិត្តទៅ។ ខ្ញុំបាននាំពួកគេមក ហើយមានឡានដឹកគេទៅកំពង់សោម។ តាមពិតខ្ញុំមិនចាំច្បាស់ទេប្រហែលជា ១០នាក់ក៏មិនដឹង។៕ [...]ឆ.១៧៨៖ មិនបានប្រាប់ថា អ្នកណាឱ្យប្រាកដទេ ប៉ុន្តែពួកគេត្រូវរៀបការជាមួយកងទ័ព។ [...]ស៖ ចុះអាយុវិញ? ឆ.២០៥៖ អាយុមានពី ១៨, ១៩, ២០ ឡើងទៅ។ ស៖ នៅពេលលោកស្រីរើសនារីនោះ តើលោកស្រីប្រាប់ពួកគេថាម៉េច? ឆ.២០៦៖ ខ្ញុំប្រាប់ថា អង្គការរើសស្ត្រីៗទៅធ្វើការនៅកំពង់សោម។ ស៖ ពេលដែលលោកស្រីប្រាប់ពួកនារីនោះថា អង្គការជ្រើសរើសនារីៗ ទៅធ្វើការនៅកំពង់សោម តើនារីនិយាយថាម៉េចដែរ? ឆ.២០៧ ពួកគេស្ម័គ្រចិត្តទៅ ដោយមិនប្រកែកឡើយ។ ស៖ តើលោកស្រីមានបានប្រាប់ពួកនារីនោះ ថាពួកគេត្រូវរៀបការទេ? ឆ.២០៨៖ ខ្ញុំអត់បានប្រាប់ទេ [...]ស៖ ពេលលោកស្រីជ្រើសរើសនារីៗលោកស្រីដឹងថា នារីៗនោះពិតជាត្រូវរៀបការជាមួយជនពិការមែនទេ? ឆ.២២៣៖ ខ្ញុំមិនច្បាស់ទេ តែខ្ញុំគិតថា ពួកគេប្រហែលជារៀបការជាមួយជនពិការនោះខ្លះហើយ [...]ស៖ ក្នុងកិច្ចសម្ភាសន៍មុន លោកស្រីនិយាយថា ការជ្រើសរើសនេះ មិនមែនមានតែនៅក្នុងឃុំខ្ញុំទេ គឺនៅក្នុងឃុំផ្សេងទៀតដែរ តើត្រឹមត្រូវទេ? ឆ.២៤៤៖ ចាស ឃុំគូស ឃុំសំរោង ឃុំ ស្រែរនោង គឺជាឃុំដែលនៅជិតឃុំរបស់ខ្ញុំ។ ខ្ញុំសន្មត់ថា"]។ ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ហៅ កេន ឆ.៥៦-៦៥ [និយាយថា នៅក្នុងខែ កញ្ញា ឆ្នាំ ១៩៧៧ គេបញ្ជូនគាត់ពីឃុំញ៉ែងញ៉ង ស្រុកត្រាំកក់ជាមួយក្រុមនារី ៤០នាក់ដែលមានអាយុចាប់ពី ១៧ឆ្នាំ ដល់ ៣០ឆ្នាំ ទៅកំពង់សោមដើម្បីធ្វើការនៅកសិដ្ឋានចំការដូងចេងហេង], ឆ. ២៣៦, ២៤៨, ២៥០, ២៥៦, ២៥៨, ២៦២, ២៧៥, ២៩២ ["ស៖ តើលោកស្រីមានព្រមថា ទៅកំពង់សោមថាទៅរៀបការទេ? ឆ.២៣៦៖ ដំបូងគេប្រាប់ថាទៅរោង [...]ឆ.២៤៨៖ ខ្ញុំបានប្តេជ្ញារួចហើយ [...]ឆ.២៥០៖ ប្តីដែលខ្ញុំរៀបការនៅជំនាន់ប៉ុលពតនោះ ឈ្មោះ ម៉ុត [...]ស៖ ពេលដែលលោកស្រីមកដល់កំពង់សោម បានប៉ុន្មានថ្ងៃទើបគេរៀបការ? ឆ.២៥៦៖ ប្រហែលមួយខែ [...]ស៖ អ្នកណាជាអ្នកឱ្យលោកស្រីរៀបការ? ឆ.២៥៨៖ គាត់ឈ្មោះ សៀក (ស្រី) [...]ឆ.២៦២៖ គេប្រាប់ថា គេមកឱ្យលោកស្រីទៅរៀបការហើយ។ តែខ្ញុំមិនព្រម តែគាត់ប្រាប់ថា បើមិនការទេ គេនឹងដាក់គុកហើយ ដូច្នេះ ហើយទើបខ្ញុំព្រម។ [...]ឆ.២៧៥៖ មានពួកស្រីៗទាំងខ្ញុំ ៧នាក់ [...]ឆ.២៩២៖ គាត់ (តាសឿន) ថា ស្នើនារីពីចម្ការដូងមក ដើម្បីមកប្តេជ្ញានៅស្ទឹងហាវ ជាមួយអ្នកនេះ អ្នកនោះ ដែលអង្គុយទល់មុខគ្នា។"]; D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ. ២៦៤-២៦៥ ["ស៖ តើនារីដែលរៀបការជាមួយកម្មាភិបាលនោះ មកពីណាដែរ? ឆ.២៦៤៖ នារីដែលរៀបការនោះ គឺមកពីតាមអង្គភាព មកពីកងនារីស្រែអំបិល ឬក៏មកពីកន្លែងផ្សេងៗ។ ស៖ តើនារីទាំងអស់ហ្នឹង អាចជ្រើសរើសអ្នកដែលខ្លួនចង់រៀបការជាមួយបានដែរទេ? ឆ.២៦៥៖ នារីទាំងនោះ មិនអាចជ្រើសរើសបានទេ។"]។ ឯកសារ D114/304 កំណត់ហេតុស្តាប់ចម្លើយ វុន ប៊ុនណា ឆ.៦៦-៧១, ៨២, ៨៦-៨៨, ៩១-

## ការផ្សព្វផ្សាយគោលនយោបាយរបស់ ប.ក.ក ស្តីពីការរៀបអាពាហ៍ពិពាហ៍ នៅកងពល ១៦៤ និងតំបន់កំពង់សោម

822. មានភស្តុតាងបញ្ជាក់ថា គោលនយោបាយបង្កើនចំនួនប្រជាជននៅតំបន់កំពង់សោម ត្រូវបានបង្ហាញនៅក្នុងវគ្គរៀនសូត្រនយោបាយយ៉ាងហោចណាស់ម្តង ដែលដឹកនាំដោយ **មាស មុត** និង គឹម ញ៉ាន់ ហៅ ញ៉ាន់ នៅអូរឈើទាល ក្នុងឆ្នាំ ១៩៧៧ ឬ ១៩៧៨[3320]។ មេបញ្ជាការកងវរសេនាតូច ១៤៣ ឈ្មោះ លៀត ឡុន បានរាយការណ៍ក្នុងវគ្គនោះថា៖

> [តាមុត និងតាញ៉ាន់] បានដាក់ចេញនូវផែនការប្រចាំឆ្នាំអំពីចំនួនគូដែលគួររៀបការ។ ពួកគេបានពិនិត្យមើលសំណើសុំរៀបការកន្លងមកទាំងអស់ ហើយកំណត់គូដែលត្រូវរៀបការ។ ផែនការរបស់ពួកគេគឺចង់ពង្រីកចំនួនប្រជាជនឲ្យដល់ ២០ លាននាក់ [...] ផែនការរបស់ពួកគេគឺចង់រៀបការឲ្យអ្នកដែលស្នើសុំរៀបការទាំងអស់[3321]។

---

៩៨, ១០០, ១០៧-១១២, ១១៥-១១៦ [ស្រុកព្រៃនប់ (ភូមិភាគបស្ចឹម)កម្មាភិបាលស្រី ត្រូវបងប្អូនជីដូនមួយ សេ (ទឹម សេង) អនុមេបញ្ជាការកងពល ១៦៤ ដែលត្រូវបានបញ្ជូនពីកន្លែងរបស់គាត់ទៅកំពង់សោមដើម្បីការរៀបការដោយបង្ខំ ដោយសេង ជាមួយ លៀត ឡុន ហៅ ណាំ ឡុន មេបញ្ជាការកងវរៈសេនាតូច ១៤៣ នៃកងវរៈសេនាធំ ១៤។ ពិធីរៀបការធ្វើនៅខែតុលា ឬវិច្ឆិកា ឆ្នាំ ១៩៧៨ នៅមន្ទីរ ទឹម សេង និងអធិបតីដោយ សេង ដោយមានវត្តមាន តាញ៉ាន។ សាក្សីមិនចង់រៀបការទេ ប៉ុន្តែគ្មានជម្រើស ដោយបងជីដូនមួយរបស់គាត់ចង់ឲ្យគាត់រៀបការ។ ពួកគេបានរួមដំណេកនៅយប់ទី១។]។

3320 សាក្សីដែលបានចូលរួមវគ្គបណ្តុះបណ្តាល លៀត ឡុន ត្រូវទៅរៀនបច្ចេកទេសនៅចិនរយៈពេល ២០ខែ ដែលចាប់ផ្តើមពីដើមឆ្នាំ ១៩៧៦ ដល់ចុងឆ្នាំ ១៩៧៨ (ទៅជាគាត់ដូចជាមានការគណនាខុស ហើយបានត្រឡប់មកវិញនៅចុងឆ្នាំ ១៩៧៧ជំនួសវិញ ដូចដែលគាត់បានអះអាងថា បានចូលរួមវគ្គត្រីមាស ឬឆមាសជាបន្តបន្ទាប់)៖ ឯកសារ D54/28 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន ហៅ ណាំ ឡុន ឆ.១៧។ ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន ហៅ ណាំ ឡុន ឆ.៣។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន ហៅ ណាំ ឡុន ឆ.១, ១៣, ៥១, ៦២ [ចេញក្នុងឆ្នាំ ១៩៧៦ រយៈពេល ២០ខែ ហើយត្រឡប់មកវិញនៅចុងឆ្នាំ ១៩៧៨], ឆ.១២៥-១២៦ ["ស៖ ក្រោយពីលោកមកពីចិនវិញ តើលោកជួប មាស មុត ញឹកញាប់ទេ? ឆ.១២៥៖ ខ្ញុំជួបគាត់ញឹកញាប់ដែរ នៅក្នុងវគ្គរៀនសូត្រ។ ស៖ តើវគ្គរៀនស្រូ គេរៀបចំញឹកញាប់ប៉ុនណាដែរ? ឆ.១២៦៖ គេរៀបប្រចាំជាត្រីមាស និងឆមាស និងពេលខ្លះក៏គេរៀបចំភ្លាមៗដែរ មិនទៀតនោះទេ។"]។

3321 ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន ហៅ ណាំ ឡុន ឆ.២០៤។ សូមមើលផងដែរ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន ហៅ ណាំ ឡុន ឆ.២០៩ ["ខ្ញុំគិតថា មិនមែនជាផែនការរបស់ តា

ជាពិសេស **មាស មុត** បាននិយាយថា កម្មាភិបាល៖

> គួរពិនិត្យលើសំណើទាំងអស់ដែលគេស្នើសុំរៀបការ ហើយរៀបការឲ្យអ្នកទាំងនោះឲ្យអស់។ ធ្វើតាមរបៀបនេះ យើងអាចសម្រេចគោលដៅរបស់យើងចំនួនពីរ ទី១ ពង្រីកចំនួនប្រជាជនដល់ជាង ២០ លាននាក់ និងទី២ ដោះស្រាយការមិនសប្បាយចិត្តរបស់អ្នកដែលស្នើសុំរៀបការយូរមកហើយ ប៉ុន្តែមិនទាន់បានរៀបការ[3322]។

823. ទោះជាយ៉ាងណាក៏ដោយ ថ្នាក់ដឹកនាំកងពល ១៦៤ មិនមែនរៀបការឲ្យតែអ្នកដែលចង់រៀបការប៉ុណ្ណោះនោះទេ។ ឧទាហរណ៍ លៀត ឡូន ត្រូវបានឲ្យរៀបការនៅក្នុងពិធីមួយដែលដឹកនាំដោយសមាជិកគណៈកងពល គឹម ញ៉ាន់ ទោះបីជាកូនកំលោះ និងកូនក្រមុំបានបដិសេធមិនឡើងប្តេជ្ញាក៏ដោយ[3323]។

---

មុត តែឯងនោះទេ ប៉ុន្តែជាផែនការរបស់ថ្នាក់លើ ដោយសារការរៀបការបែបនេះក៏បានធ្វើឡើងនៅតាមជនបទផងដែរ។"]។

3322 ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ. ២០៦។ សូមមើលផងដែរ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ.២០៣ ["លោកនិយាយថា ដល់ពេលនោះ គេបង្ខំមនុស្សឲ្យរៀបការ តើលោកសំដៅទៅរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏ពេលណា? ឆ.២០៣៖ ចាប់ពីចុងឆ្នាំ ១៩៧៥ ពោលគឺក្នុងរបបកម្ពុជាប្រជាធិបតេយ្យតែម្តង។ មានមូលហេតុពីរយ៉ាង ទី១ គឺគេចង់ពង្រីកចំនួនប្រជាជន និងទី២ គេចង់បំពេញចិត្តអ្នកដែលស្នើរៀបការតាំងពីយូរមកហើយ។ កាលពីពេលនោះ មានយុវជនច្រើនណាស់ដែលស្នើរៀបការ តែមិនបានរៀបការ។"]។

3323 ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ.១៦១-១៦២, ១៦៩, ១៧១-១៧២, ១៧៤, ១៧៦, ១៨៥-១៨៦, ១៨៨-១៨៩, ២០៥ ["ខ្ញុំមិនដឹងថា គេរៀបចំការឲ្យខ្ញុំឡើយ ហើយខ្ញុំក៏មិនមានបំណងរៀបការដែរ។ ស៖ តើអ្នកណាជាអ្នករៀបចំការឲ្យលោក? ឆ.១៦២៖ ញ៉ាន់។ [...]ឆ.១៦៩៖ គឺនៅថ្ងៃរៀបការតែម្តង។ គេនាំខ្ញុំទៅកន្លែងរៀបការ ហើយឲ្យឡើងប្តេជ្ញា តែខ្ញុំមិនព្រម [...]ស៖ តើពេលនោះ លោកប្រកែកថា មិនព្រមរៀបការដែរឬទេ? ឆ.១៧១៖ បាទ ខ្ញុំប្រកែក ខ្ញុំនិយាយថា ខ្ញុំខឹង ព្រោះគេមិនបានប្រាប់ខ្ញុំជាមុន ហើយខ្ញុំប្រកែកមិនព្រមឡើងប្តេជ្ញាទេ។ ស៖ ចុះប្រពន្ធលោកយ៉ាងម៉េចដែរ កាលនោះ? ឆ.១៧២៖ គាត់បានប្រកែកដែរ ប៉ុន្តែតាញ៉ាន់ បានសួរថា តើតាមបក្ស ឬក៏តាមអ្នកណា? [...]ឆ.១៧៤៖ អ្នកដែលរៀបចំ គឺញ៉ាន់។ ខ្ញុំគិតថា ប្រធានកងពលក៏បានដឹងរឿងនេះដែរ។ [...]ឆ.១៧៦៖ មានតែតាញ៉ាន់ ប៉ុណ្ណោះដែលមានឋានៈធំជាងគេ។ [...]ស៖ ពេលលោក និងប្រពន្ធលោកប្រកែកមិនព្រមរៀបការ តើមានរឿងអ្វីកើតឡើង? ឆ.១៨៥៖ គេសួរខ្ញុំថា តើខ្ញុំតាមបក្ស ឬក៏តាមអ្នកណា។ ខ្ញុំឆ្លើយថា ខ្ញុំមិនដែលក្បត់បក្សឡើយ តែបក្សក្បត់ខ្ញុំ។ ស៖ ប្រពន្ធលោកបាននិយាយអ្វីខ្លះ? ឆ.១៨៦៖ គាត់មិននិយាយអ្វីទេ ហើយពួកយើងមិនបានឡើងចាប់អារម្មណ៍ឡើយ។ [...]ស៖ ពេលនោះ ទោះលោក និងប្រពន្ធលោកប្រកែកក៏ដោយ តើគេនៅតែ

824. ការណែនាំដូចគ្នាឲ្យរៀបចំអាពាហ៍ពិពាហ៍ដើម្បីបង្កើនចំនួនប្រជាជន ត្រូវបានថ្នាក់ដឹកនាំកងពល ១៦៤ លើកឡើងម្តងហើយម្តងទៀតប្រាប់ទៅដល់ទាហានរបស់ខ្លួន។ មេបញ្ជាការកងវរសេនាតូច ៦៣៣ ឈ្មោះ ម៉ា ឈឿន បានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ថា៖

> ជាទិសរបស់ថ្នាក់លើ គឺពង្រីក និងរៀបចំកម្លាំង ហើយពង្រីកម្លាំងហ្នឹង កូនដូចអីហ្នឹង [...] អាហ្នឹងព័ត៌មានពីថ្នាក់លើកំពូលរហូតដល់ខាងក្រោមហ្នឹង គឺបានត្រៀមរៀបចំ ថាប្រទេសយើងតូចតាច ប្រជាជនតិច ដីយើងវាធំដែរ ដូច្នេះយើងអាចពង្រីកកម្លាំង ឲ្យបានច្រើន ដើម្បីការពារប្រទេសយើង [...] ព័ត៌មាននេះគឺត១ពីមេថ្នាក់លើមក ឧបមាកងពល ឬក៏កងពលទទួលពី ប៉ុល ពត មកគឺបន្តគ្នា តាមអ៊ីចឹងទៅ បានធ្លាក់ទៅជាខ្សែចង្វាក់អ៊ីចឹង តាមមើល[3324]។

825. **មាស មុត** បានណែនាំអ្នកក្រោមបង្គាប់របស់ខ្លួនឲ្យរៀបចំ និងប្រារព្ធពិធីឡើងប្តេជ្ញា (រៀបអាពាហ៍ពិពាហ៍)[3325]។ មេបញ្ជាការរងកងពល ១៦៤ ឈ្មោះ ហង់ ឌឿន ហៅ ឌឹម[3326] ទឹម សេង និង គឹម ញ៉ាន់ (ដែលជាមេបញ្ជាការកងវរសេនាធំលេខ ៦៣ ដែរ) ក៏ដូចជាមេបញ្ជាការកងវរសេនាធំ ១៤០

---

ប្រកាសថាលោកបានរៀបការជាមួយគ្នាហើយមែនទេ? ឆ.១៨៨៖ បាទ។ ស៖ ពេលញ៉ាន់ ប្រកាសថា លោករៀបការជាមួយប្រពន្ធលោក គឺគាត់សំអាងលើសិទ្ធិអំណាចអ្វី សិទ្ធិអំណាចបក្ស ឬលើអង្គការ ឬព្រះអង្គម្ចាស់? ឆ.១៨៩៖ បក្ស។ [...]ស៖ ចុះអ្នកដែលមិនបានស្នើសុំរៀបការដូចលោកជាដើម ហេតុអ្វីបានជាគេរៀបការឲ្យលោក? ឆ.២០៥៖ ខ្ញុំគិតថា គេចង់ឲ្យខ្ញុំរៀបការឲ្យរួច រួចហើយ រៀបការឲ្យអ្នកដទៃទៀត។"]។ ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ.៣, ៦ ["ខ្ញុំមិនពេញចិត្តនូវហេតុការណ៍ដែលខ្ញុំមិនដឹងខ្លួន។ បន្ទាប់មក ញ៉ាន់ សួរខ្ញុំថា "មិត្តនៅខាងណា?" ខ្ញុំឆ្លើយថា "ខ្ញុំមិនដែលក្បត់បក្សទេ ប៉ុន្តែបក្សក្បត់ខ្ញុំ"។ ពេលនោះ ឪពុកម្តាយកូនក្រមុំហើយនិងកម្មាភិបាលធំៗបានប្រកាសថា យើងទាំងពីរនាក់ក្លាយជាប្តីប្រពន្ធហើយ។ [...]ឆ.៦៖ ខ្ញុំមិនមានជម្រើសទេ។ ខ្ញុំត្រូវតែទទួលយកអាពាហ៍ពិពាហ៍នោះ"]។

3324 ឯកសារ D234/2.1.141 ម៉ា ឈឿន ប្រតិចារឹកថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ 15.57.39-16.05.47។

3325 ឯកសារ D59/1/1.7a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ា ឈឿន KH ERN 00926329 ["ស៖ កាលហ្នឹង មានពីណាគេណែនាំ មានមតិណែនាំឲ្យការ? ឆ៖ តាមុត។ ស៖ កាលហ្នឹង តាមុត អត់ចូលរួមទេ? ឆ៖ កាលហ្នឹង តាមុត គាត់រវល់ទៅណា គាត់អត់បានចូលរួមនោះទេ។"]។

3326 ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន់ ឆ.២១, ២៨ [រៀបការដោយបង្ខំជាមួយទាហានកងពល ៣/១៦៤ ម្តង ៧០គូ "ក្រោយពីតាឌឹម និយាយចង់ ពីរបីគូដែលនៅខាងមុខ ហ្នឹងឈរស្រាប់ចាប់ដៃគ្នា ហើយធ្វើការប្តេជ្ញា [...]ឆ.២៨៖ តាឌឹម ដែលជាអ្នកនិយាយថា "ប្តេជ្ញា"ឲ្យគូទាំងអស់ថាតាម។"]។

ឈ្មោះ ហាន[3327] បានអនុវត្តការណែនាំទាំងនេះ ដោយរៀបចំ និងដឹកនាំពិធីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងនោះ ញ៉ាន់ មានតួនាទីយ៉ាងសកម្ម។ ម៉ា ឈឿន បានថ្លែងថា គាត់បានទទួលបញ្ជាឱ្យរៀបការ និងថា **មាស មុត** ធ្វើជាអធិបតីក្នុងពិធីរៀបអាពាហ៍ពិពាហ៍នៅថ្នាក់កងពល[3328]។

---

[3327] វុន បុណ្ណា បានអះអាងថា ការរៀបការរបស់គាត់ជាមួយ លៀត ឡូន ត្រូវបានរៀបចំដោយបងជីដូន មួយ (ទឹម) សេង និងញ៉ាន់ ពេលដែល លៀត ឡូន ដឹងថា ត្រូវរៀបចំដោយញ៉ាន់ តែម្នាក់។ ឯកសារ D114/304 កំណត់ហេតុស្តាប់ចម្លើយ វុន ប៊ុនណា ឆ.៦៨-៧០, ៨៦, ៩៦, ៩៨, ១០០, ១០៧, ១០៩, ១១២-១១៣ ["ដោយសារបងជីដូនមួយ [...]គាត់ផ្លាស់ខ្ញុំទៅ [...]ឆ.៦៩៖ ឈ្មោះសេង [...]ឆ.៧០៖ គាត់ជាកងពល [...]ឆ.៨៦៖ ការរៀបការហ្នឹងដោយ មានការចាត់តាំង ដូចបងឱ្យយកអ៊ីចឹង សម្រេចយកតាមគាត់តៅ។ បងហ្នឹង គឺបងជីដូនមួយខ្ញុំ ឈ្មោះ សេង ដែលរៀបចំការរៀបការឱ្យខ្ញុំ។ [...]ឆ.៩៦៖ អត់ទាន់ចង់រៀបការទេ ព្រោះនៅក្មេងដែរ តែបងគាត់រៀបចំហើយ ខ្ញុំអត់និយាយអីទេ។ [...] ឆ.៩៨៖ [...] ខ្ញុំដឹងតែបងជីដូនមួយដែលជាអ្នករៀបចំ។ [...]ឆ.១០០៖ [...]នៅកំពង់សោម នៅមន្ទីរគាត់ហ្នឹង។ [...] ឆ.១០៧៖ តាញ៉ាន់ គាត់បានចូលរួមដែរ តែខ្ញុំមិនដឹងពីឋានៈរបស់គាត់ទេ។ [...]ស៖ នៅក្នុងថ្ងៃរៀបការ តើអ្នកណាជាអធិបតី ដែលប្រកាសឱ្យលោកស្រីចាប់ដៃគ្នា ហើយចាប់អារម្មណ៍? ឆ.១០៩៖ វាយូរហើយ មិនដឹងថា បងជីដូនមួយខ្ញុំ ឬអ្នកផ្សេងទេ [...]ឆ.១១២៖ ខ្ញុំនិងលៀត ឡូន ទៅស្នាក់នៅផ្ទះជិតនោះ ដែលជាផ្ទះបងជីដូនមួយខ្ញុំ។ ស៖ អ្នកណាគេជាអ្នកឱ្យលោកស្រីទៅផ្ទះនោះ? ឆ.១១៣៖ បងជីដូនមួយខ្ញុំហ្នឹង ព្រោះជាផ្ទះគាត់។"]។ ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ.៣-៤, ៦ ["អ្នកនិយាយវិទ្យុទាក់ទងបានហៅមកខ្ញុំ ដោយប្រាប់ខ្ញុំថា មាស មុត ចង់ជួបខ្ញុំនៅផ្ទះ។ នៅពេលដែលខ្ញុំឡើងមកដល់ផែ មានម៉ូតូចាំទទួលខ្ញុំទៅទីនោះជាស្រេច។ នៅពេលដែលខ្ញុំទៅដល់ផ្ទះរបស់គាត់នៅជិតផ្សារកំពង់សោម ខ្ញុំបានឃើញកម្មាភិបាលធំៗប្រមូលផ្តុំគ្នានៅនឹងផ្ទះនោះ។ ពេលនោះ ខ្ញុំមិនដឹងថាគេកំពុងរៀបចំពិធីអ្វីទេ។ ភ្លាមៗនោះ តាញ៉ាន់ បានហៅកូនក្រមុំឱ្យចេញ ហើយ តាញ៉ាន់ បានប្រកាសអំពីកម្មវិធីមង្គលការ។ [...]ឆ.៤៖ ខ្ញុំបានរៀបការនៅក្នុងឆ្នាំ ១៩៧៨ [...]វៀតណាមចូលមកដល់កំពង់សោម ប្រហែល ២ខែ បន្ទាប់ពីការរៀបការរបស់ខ្ញុំ។ [...]ឆ.៦៖ ខ្ញុំគ្មានជម្រើសទេ។ ខ្ញុំត្រូវតែទទួលយកអាពាហ៍ពិពាហ៍នោះ"]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ.១៦២, ១៧១-១៧២, ១៧៤, ១៧៦ ["ស៖ តើអ្នកណាជាអ្នករៀបចំការឱ្យលោក? ឆ.១៦២៖ ញ៉ាន់។ [...]ស៖ តើពេលនោះ លោកប្រកែកថា មិនព្រមរៀបការដែរឬទេ? ឆ.១៧១៖ បាទ ខ្ញុំប្រកែក ខ្ញុំនិយាយថាខ្ញុំខឹង ព្រោះគេមិនបានប្រាប់ខ្ញុំជាមុន ហើយខ្ញុំប្រកែកមិនព្រមឡើងប្តេជ្ញាទេ។ ស៖ ចុះប្រពន្ធលោកយ៉ាងម៉េចដែរ កាលនោះ? ឆ.១៧២៖ គាត់បានប្រកែកដែរ ប៉ុន្តែតាញ៉ាន់ បានសួរថា តើតាមបក្ស ឬក៏តាមអ្នកណា [...]ឆ.១៧៤៖ អ្នករៀបចំគឺញ៉ាន់។ ខ្ញុំគិតថា ប្រធានកងពលក៏បានដឹងរឿងនេះដែរ។ [...]ឆ.១៧៦៖ មានតែតាញ៉ាន់ ប៉ុណ្ណោះដែលមានឋានៈធំជាងគេ។"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ.២២៦ [មេបញ្ជាការកងវរៈសេនាតូច ៦២៣៖ "គាត់ធ្វើពេទ្យខាងកំពង់សោម ហើយថ្នាក់លើរៀបចំការឱ្យ។ ខ្ញុំមិនដែលស្គាល់គាត់ទេ។ តាញ៉ាន់ ដែលមកជំនួស តាឆាន គឺជាអ្នករៀបចំការឱ្យ។ ប៉ុន្តែប្រពន្ធដែលរៀបការពេលនោះបានលែងលះគ្នាហើយ។"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ. ២៤៨, ២៥២-២៥៣ ["តើការរៀបការនោះ រៀបចំដោយគណៈកម្មាធិការនោះឬ? ឆ.២៤៨៖ បាទ កម្មាធិការនោះ គឺជាប្រធាន ដោយមានឈ្មោះ ហាន និងឆាវ ជាដើម។ [...]ឆ.២៥២៖ គូខ្លះ គេចាត់តាំងឱ្យរៀបការ ហើយគូខ្លះ ស្ម័គ្រចិត្តរៀបការដោយខ្លួនឯង

## ការរៀបចំ និងការជូនដំណឹង

### *ក) ការរៀបចំ*

826. អាពាហ៍ពិពាហ៍ត្រូវបានរៀបចំឡើងនៅក្នុងតំបន់កំពង់សោមយ៉ាងទៀងទាត់ ចាប់ពីឆ្នាំ ១៩៧៥[3329] រហូតដល់ចប់របប[3330] សម្រាប់ទាំងយោធា ទាំងប្រជាជនស៊ីវិល[3331]។ ការរៀបអាពាហ៍ពិពាហ៍

---

ង។ សៈ តើអ្នកណាជាអ្នកចាត់តាំងឲ្យរៀបការនោះ? ឆ.២៥៣៖ អ្នកចាត់តាំងឲ្យរៀបការ គឺមេៗ មានដូចជា មាស មុត និងហាន ជាដើម។”]។ ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.២៩ [“សៈតើអ្នកណាជាអ្នកធ្វើអធិបតីនៅក្នុងពិធីរៀបការនោះ? ឆ.២៩៖ គឺឈ្មោះ ញ៉ាន់ គាត់ធ្វើអធិតី ក្នុងពិធីរៀបការរបស់ខ្ញុំជាមួយនឹងមនុស្ស ២នាក់ទៀត ដែលមានម្នាក់ឈ្មោះអាន។”]។ ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន់ ឆ.២៦ [និយាយពីវត្តមានរបស់ ហាន នៅពិធីមង្គលការរួមរបស់នាង ក្នុងការបន្ថែមទៅលើ ឌឹម]។

3328 ទោះបីជា មាស មុត មិនបានបង្ហាញខ្លួននៅក្នុងពិធីរៀបការ ម៉ា ឈឿន ពន្យល់ថា មាស មុត បានបញ្ជាគាត់ឲ្យរៀបការ ហើយថា មាស មុត ជាអធិបតីនៃពិធីបែបនេះ នៅថ្នាក់កងពល៖ ឯកសារ D234/2.1.141 ម៉ា ឈឿន ប្រតិចារឹក ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ 15.57.39-16.00.57 [“សៈ នៅក្នុងពេលរៀបការហ្នឹង មានពីណាគេទៅធ្វើអធិបតី ឬក៏និយាយធ្វើការណែនាំអ្វីផ្សេងៗក្នុងពេលរៀបការហ្នឹងដែរឬទេ? ឆៈ បាន មានៗប្រធានគេ។ ឧបមាថាកងពល មាន ឌឹម, តាមុតអីចឹងទៅ ឬក៏វរៈសេនាធំចូលរួម។”]។ សូមមើលផងដែរ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ. ២៥២-២៥៤ [“គូខ្លះគេចាត់តាំងឲ្យរៀបការ ហើយគូខ្លះ ស្ម័គ្រចិត្តរៀបការដោយខ្លួនឯង។ សៈ តើអ្នកណាចាត់តាំងឲ្យរៀបការនោះ? ឆ.២៥៣៖ អ្នកចាត់តាំងឲ្យរៀបការ គឺមេៗ មានដូចជា មាស មុត និងហាន ជាដើម។ សៈ តើហេតុអ្វីបានជាលោកថា មាស មុត ជាអ្នកចាត់តាំងឲ្យរៀបការ? ឆ.២៥៤៖ ព្រោះគាត់ជាមេ។”]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ.១៧៤ [“អ្នករៀបចំគឺញ៉ាន់។ ខ្ញុំគិតថា ប្រធានកងពលក៏បានដឹងរឿងនេះដែរ។”]។ ឯកសារ D59/1/1.7a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ា ឈឿន KH ERN 00926329 [“មានពីណាគេណែនាំ មានមតិណែនាំឲ្យការ? តាមុត។”]។.

3329 ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ. ២៤៦, ២៥១ [“គេរៀបការមួយខែម្តង [...]ឆ.២៥១៖ ការរៀបការនោះ ខ្លះពីរបីខែ ទើបរៀបការម្តង។”]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ.២០៣, ២១១-២១២ [“លោកនិយាយថា ដល់ពេលនោះ គេបង្ខំមនុស្សឲ្យរៀបការ តើលោកសំដៅទៅរបបកម្ពុជាប្រជាធិបតេយ្យ [...]ឆ.២១១៖ ខ្ញុំមានផែនការ ហើយផែនការរបស់ខ្ញុំគឺត្រូវរៀបការឲ្យសមាជិកទាំងអស់របស់កងខ្ញុំ។ ខ្ញុំរៀបការឲ្យពួកគេបានច្រើនគូដែរ។ ខ្ញុំរៀបការឲ្យម្តងបានតែពីរគូទេ។ ខ្ញុំមិនបានរៀបចំពិធីឲ្យដល់ទៅបួនគូឡើយ ដោយសារតែខ្ញុំធ្លាប់ឮគេច្រឡំដៃគូគ្នា [...]ឆ.២១២៖ ខ្ញុំបានស្នើច្បាប់អនុញ្ញាតរៀបការឲ្យគេតាំងពីមុនពិធីទៅទៀត។”]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ. ៤៥, ៤៩ [“ខ្ញុំបានដឹងពីរឿងការរៀបការនេះច្រើនណាស់ ព្រោះគេរៀបឲ្យញឹកញាប់ដែរ។ [...]ឆ.៤៩៖ និយាយឲ្យត្រង់ទៅ នារីទាំងអស់នៅក្នុងកងអនុសេនាធំរបស់ខ្ញុំបានរៀបការចម្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។”]។

ទ្រង់ទ្រាយធំជាច្រើនត្រូវបានរៀបចំនៅកំពង់សោម ដែលនៅក្នុងពេលនោះ គូជាច្រើនរៀបការក្នុងពេលដំណាលគ្នា[3332]។ ពេលខ្លះ មានគូច្រើនណាស់ ដែលមានអ្នករៀបការជាមួយអ្នកដែលមិនមែន

---

[3330] ឯកសារ D114/94 កំណត់ហេតុស្តាប់ចម្លើយ សំ វុទ្ធី ឆ.១០៥ [“តែមិនទាន់បានរៀបការទេ ព្រោះវៀតណាមវ៉ៃចូលមក។ ពេលថ្ងៃគេឲ្យយើងមើលមុខគ្នា ហើយគេថា ពេលល្ងាច គេនឹងឲ្យយើងឡើងប្តេជ្ញា តែពេលល្ងាចនោះមានការជ្រួលច្របល់ ហើយទាហានវៀតណាមក៏វាយចូលមក។ ពេលនោះ នៅចុងឆ្នាំ ១៩៧៨។”]។ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ.១៨០-១៨១, ២៨៤ [“ស៖ តើលោកស្រីការនៅឆ្នាំណា? ឆ.១៨០៖ ១៩៧៨។ ស៖ ចាំខែណាទេ? ឆ.១៨១៖ ៣ខែមុនថ្ងៃទី ៧ ខែ មករា ឆ្នាំ ១៩៧៩។ ប្រហែលនៅក្នុងខែ តុលា។ […]ឆ.២៨៤៖ ពិធីនោះ រៀបនៅតំបន់ កងកេងដែរ។”]។

[3331] ឧទាហរណ៍ការរៀបចំអាពាហ៍ពិពាហ៍ឲ្យជនស៊ីវិល៖ ឯកសារ D114/94 កំណត់ហេតុស្តាប់ចម្លើយ សំ វុទ្ធី ឆ.១០៤-១១២ [ការពន្យល់ពីរបៀបដែល នៅចុងឆ្នាំ ១៩៧៨ បុរស ៦នាក់មកពីសហករណ៍ពុតធៀន នៅជិតបិតត្រាង ត្រូវរៀបការជាមួយនារីមកពីកងចល័តដាំបន្លែ ប៉ុន្តែដោយការមកដល់របស់វៀតណាមនៅល្ងាចនោះ ការរៀបការមិនបានកើតឡើងទេ។ គាត់ត្រូវរៀបការជាមួយកម្មាភិបាលស្រីម្នាក់ឈ្មោះ ភាព។]។ ឯកសារ D114/47 កំណត់ហេតុស្តាប់ចម្លើយ តើ រី ឆ.១០៧, ១១១។

[3332] ឯកសារ D234/2.1.141 ម៉ាក ឈឿន ប្រតិចារឹកថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ 15.55.15-15.57.39 [“មានច្រើនវាអាចទៅ ៣០គូ ឬក៏ជាង ឬក៏៤០។ […]ទាហាន និងកម្មាភិបាលយុវជន។”]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន ហៅ ណាំ ឡុន ឆ. ២១១។ ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន់ ឆ.៤ [“៧១ គូ”]។ ឯកសារ D114/47 កំណត់ហេតុស្តាប់ចម្លើយ តើ រី ឆ.៨៧[“១៧ គូ”]។ ឯកសារ D22.1.3 ទំរង់បែបបទព័ត៌មានរបស់ជនរងគ្រោះ សំ ប៊ុនឡេង KH ERN 00477159 [ដើមបណ្តឹងរដ្ឋប្បវេណី គឺជាទ័ពរសាយពីកងពលលេខ ៣/១៦៤៖ “ខ្ញុំបានហៅគូដណ្តឹងរបស់ខ្ញុំទៅរៀបការនៅកំពង់សោម នៅព្រលានយន្តហោះកងកេង ដោយមាន ៥០គូ”]។ ឯកសារ D114/146 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ើក ឆ.៤២ [“មានពេលខ្លះ ១០គូ, ពេលខ្លះ ២០គូ និងពេលខ្លះ៣០គូ នៅក្នុងការរៀបការម្តងៗ។”]។ ឯកសារ D114/66 កំណត់ហេតុស្តាប់ចម្លើយ ជេត ប៊ុណ្ណា ឆ.២៩ [“១០ គូ”]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ ក៏ម ម៉េន ឆ. ២៣២ [“៣គូ […]១០ គូ”]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ. ២៥០ [ជួនកាល ១, ២, ៣, ៥ ឬ ៧គូ]។ ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ហៅ កេន ឆ.២៧១ [“៧គូ”]។ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ.២៦៨ [“៥ គូ”]។ ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.៣០ [“មានតែ ៣គូប៉ុណ្ណោះ ដែលគេរៀបការឲ្យនៅពេលនោះ។ ទីកន្លែង គឺកន្លែងភស្តុភារ។”]។ ឯកសារ D114/139 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ងួន ហៅ អ៊ី ឆ.១៣៥ [“៥គូ”]។ ឯកសារ D54/120 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.៣ [“ការរៀបការជាក្រុម ឬការជាសហគមន៍ប៉ុណ្ណោះ ដែលជួនកាលមាន ១០គូ និងជួនកាល ១៥គូ។”]។

ជាដៃគូខ្លួនដែលបានគ្រោងទុក ពីព្រោះច្រឡំអត្តសញ្ញាណ ឬក្រោយរៀបការរួច បានកំណត់អត្តសញ្ញាណមនុស្សខុស ធ្វើជាប្តីឬប្រពន្ធរបស់ខ្លួន[3333]។

827. នៅពេលបញ្ចប់នៃរបប ទាហាននារីកងពល ១៦៧ ស្ទើរតែទាំងអស់ (ពេទ្យ ឬកម្មករមកពីកងដឹកជញ្ជូន) ត្រូវគេឲ្យរៀបការ[3334] លើកលែងតែទាហានមួយក្តាប់តូចដែលព្យាយាមរត់គេចពីជោគវាសនានេះ[3335]។ ទាហាននារីភាគច្រើនដែលរៀបការ មិនបានជ្រើសរើសប្តីរបស់ពួកគាត់ទេ ប៉ុន្តែ មិនហ៊ានជំទាស់នឹងអ្វីដែលថ្នាក់លើបានសម្រេចសម្រាប់ពួកគាត់[3336]។ ដោយសារចំនួន

---

[3333] ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡួន ហៅ ណាំ ឡួន ឆ.២១០ ["ខ្ញុំធ្លាប់ឮយោធានិយាយលេងថា មានគូខ្លះច្រឡំដៃគូគ្នា បន្ទាប់ពីរៀបការហើយ ដោយសារតែគេរៀបចំម្តងច្រើនគូ។"]។ ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡួន ហៅ ណាំ ឡួន ឆ.៧ ["ខ្ញុំបានឮថាគូស្រករថ្មីនេះ បានច្រឡំគូគ្នា។"]។

[3334] ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ. ៤៥, ៤៩-៥២ [អតីតនារីពេទ្យនៃកងវរៈសេនាតូច ១៦៧ ៖ "ខ្ញុំបានដឹងពីរឿងរៀបការនេះច្រើន ព្រោះគេរៀបឲ្យញឹកញាប់ដែរ។ […]ឆ.៤៩៖ និយាយឲ្យត្រង់ទៅ នារីទាំងអស់នៅក្នុងកងអនុសេនាធំរបស់ខ្ញុំបានរៀបការចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ។ ជាបន្តបន្ទាប់ នារីៗបានចាកចេញពីកងអនុសេនាធំរបស់ខ្ញុំអស់នៅពេលដែលពួកគេមានផ្ទៃពោះ ឬជិតសម្រាលកូន។ […]ឆ.៥០៖ ជាមធ្យមពួកគេមានអាយុក្រោម ២០ឆ្នាំ និងលើ ២០ឆ្នាំ តែក្រោម ៣០ឆ្នាំ។ ស៖ តើនារីដែលក្មេងជាងគេនៅក្នុងអង្គភាពរបស់លោកស្រីមានអាយុប៉ុន្មានឆ្នាំដែរ? ឆ.៥១៖ អាយុ ១៧ ឆ្នាំ។ ស៖ ចុះនារីៗនៅក្នុងកងអនុសេនាធំផ្សេងៗទៀត? ឆ.៥២៖ ដូចកងអនុសេនាធំខ្ញុំដែរ គឺពួកគេបានរៀបការដូចគ្នា។"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គីម ម៉េន ឆ. ២៣៣ ["ស៖ តើកូនក្រមុំយកមកពីណា? ឆ.២៣៣៖ ជាពេទ្យរបស់កងពល។ ពេលខ្លះក៏ជាយុទ្ធនារី ឬកងទ័ពនារី។"]។ ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ. ៣៣, ៣៥ ["គាត់មកពីខេត្តតាកែវ […]ឆ.៣៥៖ គាត់មកពីកងដឹកជញ្ជូននៃកងពល ១៦៤ […]គេឲ្យគាត់មកធ្វើស្រែ"]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡួន ហៅ ណាំ ឡួន ឆ. ២១៤ ["ខ្លះជ្រើសរើសមកពីខាងនារី ដូចជាកងដឹកជញ្ជូន ឬក៏អង្គភាពពេទ្យជាដើម។"]។ ឯកសារ D59/1/1.7a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ា ឈឿន KH ERN 00926325 [ពន្យល់ថា គាត់បានរៀបការនៅឆ្នាំ ១៩៧៦ នារីកងទ័ពម្នាក់មកពីកងវរៈសេនាតូចដែលប្រធានឈ្មោះ នាង។]។

[3335] ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ. ៤៥ [ពន្យល់ថា ជាទូទៅ ស្ត្រីម្នាក់មិនហ៊ានបដិសេធការរៀបការដែលរៀបចំឲ្យដោយថ្នាក់លើទេ ប៉ុន្តែគាត់គឺជាស្ត្រីម្នាក់ដែលគេហៅឲ្យទៅរៀបការ ហើយគាត់បានបដិសេធយ៉ាងខ្លាំង ហើយគ្មានរឿងអីកើតឡើងចំពោះគាត់។]។

[3336] ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.៤៥ ["ជាទូទៅ ប្រសិនបើនារី មិនហ៊ានប្រកែក ហើយមិនសូវចេះនិយាយនោះ គឺពួកគេយល់ព្រមទៅតាមការផ្សំផ្គុំនោះ […]ជាទូទៅ ថ្នាក់លើជាអ្នកសម្រេចថារៀបការជាមួយនឹងអ្នកណា គឺមិនមែនសាមីខ្លួននោះទេ ប៉ុន្តែក្នុងករណីផ្សេងទៀត ក៏បុរសនារីដែលជាសាមីខ្លួនបានស្នើទៅប្រធានរបស់ខ្លួនដែរ។ ខ្ញុំបានឮពីអ្នកដទៃថា នៅកន្លែងផ្សេងទៀត ចំពោះអ្នកដែលប្រកែកមិនព្រមរៀបការ គឺគេយកទៅសម្លាប់

ទាហាននារីដែលមាន មិនគ្រប់គ្រាន់ដើម្បីបំពេញចិត្ត "ទាហានមិនសប្បាយចិត្ត" នារីជាជនស៊ីវិល ក៏ត្រូវបានជ្រើសយក ដើម្បីធ្វើជាប្រពន្ធរបស់ទាហានដែរ[3337]។ ក្នុងចំណោមនារីទាំងនោះ នារីពីរបីនាក់បានភ្ជាប់ពាក្យរួចហើយកាលពីលើកមុនជាមួយទាហានកងពលលេខ ៣ នៅអង្គភាពដើមរបស់ពួកគេ និងត្រូវបាននាំទៅកំពង់សោមដើម្បីរៀបការ[3338]។ ទោះជាយ៉ាងនេះក្តី ដូចនៅផ្នែកផ្សេងទៀតនៃកម្ពុជាប្រជាធិបតេយ្យដែរ ប្តីប្រពន្ធភាគច្រើនមិនដែលស្គាល់គ្នាទាល់តែសោះ ឬស្ទើរតែមិនបានឃើញអនាគតដៃគូរបស់ខ្លួន មុនពិធីរៀបអាពាហ៍ពិពាហ៍ ដោយអង្គការបានសម្រេចថាអ្នកណាត្រូវរៀបការជាមួយអ្នកណា[3339]។ ប៉ុន្តែ ពួកគេគ្មានជម្រើសអ្វីក្រៅតែពីយល់ព្រមទទួលមនុស្សដែលកំណត់ដោយអង្គការប៉ុណ្ណោះ[3340]។

---

ចោលភ្លាម [...]ចំពោះអ្នកខ្លះដែលគេប្រាប់ឱ្យរៀបការ ហើយព្រមរៀបការតាមការរៀបចំគិតគូររបស់ប្រធានខ្លួន គឺដោយសារតែខ្លួនដល់អាយុគ្រប់ការ ឬក៏អ្នកខ្លះ ពុំហ៊ានប្រកែក។"]។

3337 សូមមើលកថាខណ្ឌ ៨២១។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ. ២៣៣, ២៣៧ ["អ្នកមានគូដណ្តឹងពីដើមមក ដែលនៅតាមស្រុកភូមិ ហើយគេត្រូវរៀបការឱ្យ គេអាចប្រាប់ទៅអង្គការរបស់ខ្លួន នោះអង្គភាពនឹងចាត់ចែងកម្លាំងទៅយកនារីដែលជាគូដណ្តឹងនៅស្រុកភូមិមកឱ្យរៀបការ។ គេរាយការណ៍បន្តទៅថ្នាក់លើ រួចថ្នាក់លើនឹងចាត់ចែងកម្លាំងឱ្យទៅយកនារីនោះមក។ [...]ឆ.២៣៧៖ មនុស្សភាគច្រើន ដល់អាយុត្រូវតែយក។ ពួកយើងសុទ្ធតែចាស់ ដូចខ្លះអាយុ ២៤, ២៥ ទៅ៣០ឆ្នាំហើយ។"]។

3338 សូមមើលផងដែរ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ. ២៣៣ ["ប្រសិនបើអ្នកមានគូដណ្តឹងពីដើមមក ដែលនៅតាមស្រុកភូមិ ហើយគេត្រូវរៀបការឱ្យ គេអាចប្រាប់ទៅអង្គការរបស់ខ្លួន នោះអង្គភាពនឹងចាត់ចែងកម្លាំងទៅយកនារីដែលជាគូដណ្តឹងនៅស្រុកភូមិមកឱ្យរៀបការ។ គេរាយការណ៍បន្តទៅថ្នាក់លើ រួចថ្នាក់លើនឹងចាត់ចែងកម្លាំងឱ្យទៅយកនារីនោះមក។"]។

3339 ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ហៅ កេន ឆ. ២៥៧-២៦៦ [ប្រធានកងនារីបានបញ្ជាឱ្យសាក្សីរៀបការ។ បន្ទាប់ពីសាក្សីបដិសេធ គាត់បានគំរាមកំហែង ហើយបន្ទាប់មក សាក្សីយល់ព្រមរៀបការ។ សាក្សីមិនបានស្គាល់ប្តីរបស់គាត់ជាមុនទេ និងបានទទួលប្រវត្តិរូបប្តីរបស់គាត់មុនថ្ងៃការតែប៉ុណ្ណោះ។]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន ហៅ ណាំ ឡុន ឆ. ១៦៤, ១៦៨ ["សៈ អ្នកណាជាអ្នករើសប្រពន្ធឱ្យលោក? ឆ.១៦៤៖ តាមខ្ញុំដឹង តាញ៉ាន់។ [...]សៈ តើលោកដឹងខ្លួនថា នឹងរៀបការនៅពេលណាទេ? ឆ.១៦៨៖ ខ្ញុំដឹងនៅពេលថ្ងៃរៀបការតែម្តង។"]។ ឯកសារ D114/94 កំណត់ហេតុស្តាប់ចម្លើយ សំ វុទ្ធី ឆ.១០៦-១០៧ ["សៈ [...]តើពេលនោះ ជាលើកទីមួយ ដែលលោកឃើញមុខអ្នកដែលលោកនឹងរៀបការជាមួយនោះឬ? ឆ.១០៦៖ បាទ [...]ឆ. ១០៧៖ ថ្ងៃនោះ ខ្ញុំឃើញនារីនោះតែម្តង។"]។

3340 ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ.២៦៥ ["សៈ តើនារីទាំងអស់ហ្នឹង អាចជ្រើសរើសអ្នកដែលខ្លួនចង់រៀបការជាមួយបានដែរទេ? ឆ.២៦៥៖ នារីទាំងនោះ មិនអាចជ្រើសរើសបានទេ។"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ. ៤៦ ["ការសម្រេចចិត្តគឺមិនមែនធ្វើឡើងដោយសាម៉ីខ្លួនទេ តែជាការគិតគូរ

828. ជាលំនាំដូចៗគ្នាដែលមាននៅទូទាំងប្រទេស[3341] មនុស្សជាច្រើនគូដែលត្រូវបានបង្ខំឲ្យរៀបការនៅតំបន់ក្រោមការកាន់កាប់របស់ **មាស មុត** មិនបានទទួលការជូនដំណឹង ឬបានដែរតែតិចតួច អំពីការរៀបការ រហូតដល់ថ្ងៃរៀបការ[3342]។ មាស សារ៉ាន មិនបានដឹងអំពីការរៀបការជាមុននោះទេ ពេលអ្នកស្រីត្រូវបានហៅឲ្យចូលប្រជុំនៅរោងភាពយន្តកំពង់សោម នៅចុងឆ្នាំ ១៩៧៥ ឬដើមឆ្នាំ ១៩៧៦ ជាមួយ ៧០ គូផ្សេងទៀត ហើយបន្ទាប់មក អ្នកស្រីត្រូវគេឲ្យរៀបការជាមួយបុរសម្នាក់ដែលអ្នកស្រីមិនដែលបានជួបពីមុនមកសោះ[3343]។ អ្នកផ្សេងទៀតដែលត្រូវបានហៅទៅចូលរួម

---

រៀបចំរបស់ថ្នាក់លើ។”]។ ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ. ២២ [“គូស្រករមិនបានស្គាល់គ្នាឡើយមុនពេលដែលពួកគេរៀបការ រឿងនេះកើតឡើងចំពោះខ្ញុំ និងអ្នកដទៃផងដែរ។ ក្នុងករណីរបស់ខ្ញុំ គេប្រាប់ខ្ញុំមុនមួយថ្ងៃ ហើយថ្ងៃបន្ទាប់ ខ្ញុំត្រូវរៀបការតែម្តង ដោយយើងមិនស្គាល់គ្នាឡើយ ហើយយើងក៏មិនបានណាត់ជួបគ្នា ដូចបច្ចុប្បន្ននេះដែរ គឺយើងរៀបការជាមួយគ្នាតែម្តង។”]។ ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ហៅ កេន ឆ.២៦៤ [“គេគ្រាន់តែថា អ្នែងគេចមិនរួចទេ គង់តែការទេ មិនយូរឬឆាប់។”]។

3341 សូមមើល VIII.H.3. ការអនុវត្តគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំថ្នាក់ជាតិ - អាពាហ៍ពិពាហ៍ដោយបង្ខំ។

3342 ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ.១៦៨-១៦៩ [“ស៖ តើលោកដឹងខ្លួនថានឹងរៀបការនៅពេលណាទេ? ឆ.១៦៨៖ ខ្ញុំដឹងនៅពេលថ្ងៃរៀបការតែម្តង។ [...]ឆ.១៦៩៖ គឺនៅថ្ងៃរៀបការតែម្តង។ គេនាំខ្ញុំទៅកន្លែងរៀបការ ហើយឲ្យឡើងប្តេជ្ញា តែខ្ញុំមិនព្រម។”]។ ឯកសារ D114/94 កំណត់ហេតុស្តាប់ចម្លើយ សំ វុទ្ធី ឆ.១០៥ [“ពេលថ្ងៃគេឲ្យយើងមើលមុខគ្នា ហើយគេថា ពេលល្ងាច គេនឹងឲ្យយើងឡើងប្តេជ្ញា”]។ ឯកសារ ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ. ២២ [“គូស្រករមិនបានស្គាល់គ្នាឡើយមុនពេលដែលពួកគេរៀបការ រឿងនេះកើតឡើងចំពោះខ្ញុំ និងអ្នកដទៃផងដែរ។ ក្នុងករណីរបស់ខ្ញុំ គេប្រាប់ខ្ញុំមុនមួយថ្ងៃ ហើយថ្ងៃបន្ទាប់ ខ្ញុំត្រូវរៀបការតែម្តង”]។ ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ហៅ កេន ឆ.២៦៥-២៦៦, ២៧២ [“ពេលព្រមការហើយ គេយកខ្ញុំទៅកន្លែងរៀបការនៅស្ទឹងហាវ នៅកំពង់សោម [...]ស៖ តើលោកស្រីស្គាល់ប្តីលោកស្រីមុនមកទេ? ឆ.២៦៦៖ មិនស្គាល់ទេ តែថ្ងៃការគេឲ្យប្រវត្តិរូប [...]ឆ.២៧២៖ គេទុកមួយថ្ងៃទើបរៀបការ”]។

3343 ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន់ ឆ.២-៣, ៥-៦, ១០, ១៣ [“ខ្ញុំត្រូវគេបង្ខំឲ្យរៀបការជាមួយទាហាននៅកងវរៈសេនាតូច ១៦០ ក្រោមកងពលធំលេខ ៣។ [...]ឆ.៣ [...]ខ្ញុំចាំថា នៅចុងឆ្នាំ ១៩៧៥ ឬដើម ១៩៧៦ [...]ឆ.៥៖ គេរៀបការពួកខ្ញុំនៅក្នុងរោងកុនកំពង់សោម។ គឺមានមនុស្សពេញរោងកុននោះតែម្តង។ ហើយគេក៏បានប្រកាសថា មានសរុប ៧១គូ។ [...]ឆ.៦៖ ខ្ញុំមិនដែលបានដឹងពីការរៀបចំឲ្យខ្ញុំមានគូស្រករនោះពីមុនមកសោះ។ ដល់ពេលមួយ គេហៅខ្ញុំទៅប្រជុំ ហើយគេក៏រៀបការឲ្យខ្ញុំមានគូនៅពេលនោះតែម្តង។ [...]ឆ.១០៖ ក្រោយពីទៅដល់រោងកុន ខ្ញុំមានការភ្ញាក់ផ្អើលដោយសារមានមនុស្សច្រើន ហើយខ្ញុំក៏បានសួរគេ ហើយគេប្រាប់ថា គេកំពុងតែរៀបចំពិធីការ។ ខ្ញុំចង់រត់ពីទីនោះដែរ ប៉ុន្តែមិនអាចរត់រួចពីព្រោះទាហានៅសងខាង។ [...]ឆ.១៣៖ ខ្ញុំភ្ញាក់ផ្អើលដោយសារខ្ញុំនិងបុរសនោះ មិនដែលស្គាល់គ្នាពីមុនមកសោះ។”]។

ប្រជុំ ឬវគ្គរៀនសូត្រ បន្ទាប់មក ត្រូវបានគេបង្ខំឲ្យរៀបការ[3344]។ នារីខ្លះត្រូវបានបង្ខំឲ្យរៀបការជាមួយទាហានពិការ ដែលពួកគាត់មិនដែលឃើញពីមុនមក[3345]។

829. ពេលខ្លះ គេបានផ្តល់បុព្វសិទ្ធិឲ្យទាហានបុរសក្នុងការស្នើសុំការអនុញ្ញាតពីថ្នាក់លើ ដើម្បីរៀបការជាមួយស្ត្រីជាក់លាក់ម្នាក់[3346]។ ក្នុងសង្គមមួយដែលការប៉ះពាល់រាងកាយរវាងបុរស និងស្ត្រីមិន

[3344] ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ. ១៧០ ["ញ៉ាន់ [...]បានទាក់ទងហៅខ្ញុំមកឡើងដីគោក ហើយបញ្ជូននីរសារឲ្យយកម៉ូតូមកចាំដឹកខ្ញុំ។ ខ្ញុំស្មានតែគេហៅខ្ញុំមកធ្វើការ ខ្ញុំខំយកសៀវភៅមកតាមខ្លួន តាមពិត គេហៅខ្ញុំមករៀបការសោះ។"]។ ឯកសារ D114/91 កំណត់ហេតុស្តាប់ចម្លើយ សេង អុល ឆ.២០៦, ២០៨ [អំពីការជ្រើសរើសនារីៗឲ្យរៀបការជាមួយទាហាននៅកំពង់សោម៖ "ស៖ នៅពេលដែលលោកស្រីរើសនោះ តើលោកស្រីប្រាប់ពួកគេថាម៉េច? ឆ.២០៦៖ ខ្ញុំប្រាប់ថា អង្គការរើសស្ត្រីៗទៅធ្វើការនៅកំពង់សោម។ [...]ស៖ តើលោកស្រីមានបានប្រាប់ពួកនារីនោះ ថាពួកគេត្រូវរៀបការទេ? ឆ.២០៨៖ ខ្ញុំអត់បានប្រាប់ទេ។"]។

[3345] ឯកសារ D234/2.1.141 ម៉ាក ឈឿន ប្រតិចារឹកថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ 15.55.15-15.57.39 [ពន្យល់ថា ក្នុងចំណោម ៣០ ទៅ ៤០គូដែលរៀបការពេលជាមួយគ្នា មានទាហានពិការមួយចំនួន (ពីរឬបី)។]។ អ៊ុក សុក ត្រូវបានបង្ខំឲ្យរៀបការជាមួយជនពិការ ដែលគាត់បានរៀបរាប់ថា ដំបូងជាទាហានម្នាក់ ប៉ុន្តែក្រោយមក មិនអាចអះអាងបានថា គាត់គឺអតីតទាហាន ឬក៏មិនមែនទេ៖ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ. ២៨៧-២៨៨, ២៩៣, ២៩៨-២៩៩ [កម្មករស្រីមកពីសហករណ៍ស្នាច់ជែង៖ "គាត់ជាជនពិការ ហើយបានប្រាប់ខ្ញុំថា គាត់ធ្លាប់ធ្វើជាអ្នកសម្តែងសិល្បៈពីមុន។ [...]ស៖ លោកស្រីជួយពន្យល់បន្តិច មុននេះលោកស្រីនិយាយថា ប្តីរបស់លោកស្រីជាទាហាន។ ឆ.២៨៨៖ គាត់ជាជនពិការ។ រៀបការរួច យើងនៅជាមួយគ្នាបាន ៣ថ្ងៃ។ យើងបែកគ្នា [...]ឆ.២៩៣៖ គេមកប្រាប់ខ្ញុំទៅរៀបការ ខ្ញុំមិនមានជម្រើសអ្វីឡើយ។ [...]ស៖ មុនពេលរៀបការ លោកស្រីមានស្គាល់ប្តីលោកស្រីទេ? ឆ.២៩៨៖ អត់ទេ។ ស៖ ហេតុអីបានជាលោកស្រីមិនហ៊ានប្រកែក? ឆ.២៩៩៖ ខ្ញុំខ្លាចល្មើសនឹងវិន័យ។ ខ្ញុំមិនដឹងថា គេនឹងយកខ្ញុំទៅឬក៏អត់នោះទេ ក្រោយពីខ្ញុំប្រកែក។ ប៉ុន្តែខ្ញុំមិនហ៊ានប្រកែកឡើយ។"]។

[3346] ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ. ២៣៣។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ. ២៥៣ ["បើកម្មាភិបាលណាម្នាក់ស្រឡាញ់នារីណាម្នាក់ ពេលនោះ កម្មាភិបាលនោះ ទៅប្រាប់មេរបស់គាត់ថាគាត់ចង់បាននារីនោះ ប៉ុន្តែការសម្រេចគឺស្រេចតែទៅលើបក្ស។"]។ ឯកសារ D114/146 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ិក ឆ.៤០ ["មុនដំបូង យើងត្រូវធ្វើប្រវត្តិរូបសង្ខេបដាក់ទៅជាមួយនឹងការស្នើរបស់យើង។ យើងត្រូវដាក់បញ្ចូលនូវឈ្មោះកងរបស់យើង [...]រួចហើយគេពិនិត្យមើលសំណើរបស់ខ្ញុំ និងប្រវត្តិរូបរបស់ខ្ញុំ។"]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ.២១៥ ["ដំណើរគឺបែបនេះ ដំបូងខាងប្រុសដែលជាសមាជិកអង្គការរបស់យើងជាអ្នកស្នើសុំរៀបការ បន្ទាប់មកយើងទៅសាកសួរខាងនារី និងប្រធានខាងកងនារីនោះសិន"]។

ទាន់រៀបការ ត្រូវបានហាមឃាត់ និងដាក់ទោសយ៉ាងតឹងរ៉ឹង[3347] សំណើទាំងនេះជាធម្មតាត្រូវបានធ្វើឡើងដោយផ្អែកលើប្រវត្តិរូប ឬរូបរាងខាងក្រៅតែប៉ុណ្ណោះ ព្រោះថាទាហានពុំមានឱកាសបានស្គាល់អ្នកដែលពួកគេជ្រើសរើសនោះទេ[3348]។

3347 ឯកសារ D114/297.1.27 សេង សឿន ប្រតិចារឹកថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ 15.06.43-15.08.30 [តំបន់ ២៥៖ "គឺខ្ញុំជួបផ្ទាល់អារឿងយុវជននារីនៅទ័ពជាមួយខ្ញុំ ហើយវាស្រឡាញ់គ្នា គេហៅថា ខូចគ្នាហ្នឹង។ ស្រឡាញ់រួចលួចលាក់បាញ់គ្នាចោលហើយ។"]។ ឯកសារ D54/43 កំណត់ហេតុស្តាប់ចម្លើយ សេង សុន ឆ.១៧ ["សូម្បីតែស្ត្រីដែលយើងស្រឡាញ់ ហើយចង់រៀបការជាមួយ ក៏យើងមិនហ៊ាននិយាយរកដែរ ពីព្រោះយើងមិនចង់ឲ្យគេចោទយើងថា ខុសសីលធម៌។"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ. ២៥៨ ["ហើយបើកាលណាពួកគេលួចស្រឡាញ់គ្នា ដោយខុសសីលធម៌នោះ ពួកគេនឹងមានទោស។"]។ ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន់ ឆ.១១៩ ["តែគេធ្លាប់ប្រជុំដំបូងៗដែលខ្ញុំបានចូលរួម គេរំឭកយើងជាប្រចាំថា បើបុរសនារីដែលលួចទាក់ទងគ្នាដោយមិនទាន់រៀបការ គឺគេថាខុសសីលធម៌ ហើយនឹងមានការដាក់ទោសចំពោះអ្នកនោះ។ ដូច្នេះ ម្នាក់ៗខ្លាចពុំហ៊ានធ្វើអ្វីដែលខុសនោះទេ។"]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ. ២២៩-២៣០ ["កាលពីជំនាន់ហ្នឹង បើអ្នកហ្នឹងមិនរៀបការជាមួយគ្នា តើគេអាចរួមភេទជាមួយគ្នាបានទេ? ឆ.២២៩៖ ទេ វាខុសច្បាប់។ ស៖ បើសិនជាគេរួមភេទជាមួយគ្នា មិនទាន់រៀបការ បើគេចាប់បាន គេនឹងធ្វើម៉េច? ឆ.២៣០៖ ពួកគេនឹងត្រូវបានដកចេញពីអង្គភាព តែខ្ញុំមិនដឹងថាគេយកទៅណាទៀតនោះទេ។ មានមនុស្សច្រើននាក់ រួមទាំងកម្មាភិបាលផង ត្រូវបានគេបាច់បាន ព្រោះបានរួមភេទក្រៅចំណងអាពាហ៍ពិពាហ៍។"]។ ឯកសារ D114/36.1.31 កំណត់ហេតុស្តាប់ចម្លើយ ផាត់ ដួងច័ន្ទ KH ERN 00373395 ["អ្នកខូចសីលធម៌មានន័យថា ស្រឡាញ់គ្នា លួចស្រឡាញ់គ្នា [...] ត្រូវយកទៅសម្លាប់ ចោល"]។ ឯកសារ D4.1.817 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធឿន KH ERN 00368611 ["'គេនិយាយពីប្តីមួយប្រពន្ធមួយ បើអ្នកណាប្រព្រឹត្តខុស ត្រូវតែកម្ទេច។"]។ ឯកសារ D4.1.740 កំណត់ហេតុស្តាប់ចម្លើយ មួរ សេដ្ឋា KH ERN 00365596-00365597 ។ ឯកសារ D4.1.1003 Bridgette Toy-Cronin, ចង់និយាយប្រាប់អ្នក KH ERN 00721360 ["ទំនាក់ទំនងផ្លូវភេទក្រៅចំណងអាពាហ៍ពិពាហ៍ ដោយសារតែទំនាក់ទំនងផ្លូវភេទបែបនេះ ធ្វើឲ្យប៉ះពាល់ដល់គោលបំណងរបស់បដិវត្តន៍។ ប្រសិនបើអង្គការរកឃើញថាមាននរណាម្នាក់បានបំពានទូវបម្រាមនេះ អង្គការនឹងដាក់ទណ្ឌកម្ម ឬសម្លាប់ទាំងពីរនាក់បុរស និងស្ត្រីនោះ [...]អង្គការ នឹងដាក់ទណ្ឌកម្ម ឬសម្លាប់ចោលទាំងជនរងគ្រោះ និងទាំងអ្នកចាប់រំលោភនោះផងដែរ ប្រសិនបើរកឃើញថាមានការរំលោភផ្លូវភេទមែន។"]។ ឯកសារ D234/2.1.37 Kasumi Nakagawa, អំពើហិង្សាយេនឌ័រ KH ERN 00738344។ ឯកសារ D1.3.17.1 Elizabeth Becker, ពេលសង្គ្រាមរលត់ទៅ KH ERN 00232298។

3348 ឯកសារ D234/2.1.141 ម៉ាក ឈឿន ប្រតិចារឹកថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ 15.55.15-15.57.39 ["មុនរៀបការ ការពិតមិន ពេលនោះ មិនមានថាស្រឡាញ់អី ទាក់ទងគ្នាអីជា នេះទេ ប៉ុន្តែសួរជាយោបល់ សួរជាអីទៅ ក៏គេឯកភាពទៅ យើងពីមុនមិនដែលស្រី បុរស មិនដែលទាក់ទងគ្នាមុនផង។"]។

830. ចំពោះការផ្គូផ្គងទាំងអស់ ទាំងការផ្គូផ្គងដែលដៃគូណាម្នាក់ ឬទាំងពីរនាក់បានស្វែងរក ទាំងការផ្គូផ្គងដែលមិនមែនជាការជ្រើសរើសរបស់ដៃគូណាម្នាក់ កម្មាភិបាល រួមទាំងកម្មាភិបាលថ្នាក់ខ្ពស់ត្រូវបានតម្រូវឱ្យស្នើសុំការអនុញ្ញាតពីថ្នាក់លើ[3349]។ អាជ្ញាធរពីគ្រប់កម្រិតទាំងអស់ចូលរួមក្នុងការរៀបចំអាពាហ៍ពិពាហ៍ រួមទាំងប្រធានកង និងប្រធានសហករណ៍[3350] ក៏ដូចជាមេបញ្ជាការកងវរសេនាតូច កងវរសេនាធំ និងកងពល[3351] ផងដែរ។

831. សំណើសុំរៀបការត្រូវមានភ្ជាប់ប្រវត្តិរូបរបស់បុរសមកជាមួយ ដែលនឹងត្រូវបានពិនិត្យមើលដោយថ្នាក់លើ[3352]។ មុនរៀបចំអាពាហ៍ពិពាហ៍ ថ្នាក់លើរបស់បុរស ទាក់ទងទៅប្រធានកងដែល

---

3349 ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន ហៅ ណាំ ឡុន ឆ. ២១២, ២១៥, ២១៨-២១៩ [មេបញ្ជាការកងវរៈសេនាធំ៖ "សៈ បន្ទាប់ពីរៀបការឱ្យគេហើយ តើលោករាយការណ៍ទៅថ្នាក់លើថារៀបការបានប៉ុន្មានគូៗទេ? ឆ.២១២៖ តាមពិតខ្ញុំបានស្នើសុំច្បាប់អនុញ្ញាតរៀបការឱ្យគេតាំងពីមុនពិធីទៅទៀត។ [...]ឆ.២១៥៖ដំបូងខាងប្រុសដែលជាសមាជិកអង្គការរបស់យើងជាអ្នកស្នើសុំរៀបការ បន្ទាប់មកយើងទៅសាកសួរខាងនារី និងប្រធានខាងកងនារីនោះសិន បានយើងស្នើសុំទៅថ្នាក់លើដើម្បីរៀបការឱ្យពួកគេ។ [...]ឆ.២១៨៖ បើសិនជានាងព្រម ខ្ញុំនឹងបញ្ជូនឈ្មោះទៅលើ ដើម្បីសុំការអនុញ្ញាត។ សៈ ចុះអ្នកដែលអត់ស្រឡាញ់? ឆ.២១៩៖ យើងអាចរៀបចំឱ្យអ្នកណាក៏បាន ប្រសិនបើមិនព្រម មានន័យថាគាត់មានបញ្ហាជាមួយបក្ស។"]។

3350 ឯកសារ D114/47 កំណត់ហេតុស្តាប់ចម្លើយ តើ រី ឆ.១១៦ ["សៈ តើអ្នកណាជាអ្នកសម្រេចថា លោកស្រីត្រូវចាប់គូជាមួយនឹងបុរសនោះ? ឆ.១១៦៖ មេកងរយរបស់ខ្ញុំ។"]។ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ. ២៩៤ ["សៈ តើនរណាហៅលោកស្រីទៅរៀបការ? ឆ.២៩៤៖ ប្រធានសហករណ៍របស់ខ្ញុំ។"]។

3351 ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ. ២៥ ["សៈ តើពួកគេជាអ្នកណា? តើអ្នកណាជាអ្នកលើកសំណើនេះ? ឆ.២៥៖ ជាអ្នកមកពីកងវរៈសេនាធំ។ នីរសារម្នាក់មកពីកងវរៈសេនាធំម្នាក់មកប្រាប់ថា ខ្ញុំនឹងត្រូវរៀបការ។"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ. ២៤៨ ["សៈ តើការរៀបការនោះរៀបចំដោយគណៈកម្មាធិការនោះឬ? ឆ.២៤៨៖ បាទ កម្មាធិការនោះ គឺជាប្រធាន ដោយមានឈ្មោះ ហន និង ឆាវ ជាដើម។"]។

3352 ឯកសារ D114/146 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញ៉ឹក ឆ.៣៨-៤០ ["នៅពេលនោះ ខ្ញុំបានដាក់សំណើរបស់ខ្ញុំដើម្បីរៀបការដែរ ប៉ុន្តែគេមិនអនុញ្ញាតឱ្យខ្ញុំរៀបការទេ។ [...]ឆ.៣៩៖ នៅឆ្នាំ ១៩៧៦ នៅហ្នឹងរាម ពេលដែលខ្ញុំនៅក្នុងកងពល ១៦៤។ [...]ឆ.៤០៖មុនដំបូង យើងត្រូវធ្វើប្រវត្តិរូបសង្ខេបដាក់ទៅជាមួយនឹងការស្នើរបស់យើង។ យើងត្រូវដាក់បញ្ចូលនូវឈ្មោះកងរបស់យើង ឧទាហរណ៍ដូចជាខ្ញុំនៅក្នុងកងពល ១៦៤ បើខ្ញុំចង់រៀបការជាមួយនឹងនារីណាម្នាក់នៅហ្នឹងតំបន់ ឬក៏នៅក្នុងកងផ្សេង ខ្ញុំត្រូវដាក់សំណើរបស់ខ្ញុំទៅឱ្យកន្លែងគេ រួចហើយគេពិនិត្យមើលសំណើរបស់ខ្ញុំ និងប្រវត្តិរូបរបស់ខ្ញុំ។ បើគេឃើញមានការសង្ស័យត្រង់ណាមួយ នៅលើប្រវត្តិរូបរបស់ខ្ញុំ គេនឹងមិនអនុញ្ញាតទៅតាមសំណើរបស់ខ្ញុំទេ។"]។

គ្រប់គ្រងនារីដែលគេស្នើសុំរៀបការ[3353]។ ក្នុងគ្រប់ករណីទាំងអស់ រាល់សំណើសុំរៀបការជាមួយនារីម្នាក់ ដំបូង ត្រូវមានការយល់ព្រម ហើយសេចក្តីសម្រេចចុងក្រោយអាស្រ័យលើថ្នាក់ដឹកនាំកងពល ១៦៤[3354]។ សំណើជាក់លាក់មួយចំនួនត្រូវបានជំទាស់ ហើយអង្គការទាមទារឱ្យបុគ្គលនោះរៀបការជាមួយអ្នកផ្សេងទៀត[3355]។

*ខ) ពិធីអាពាហ៍ពិពាហ៍*

832. សាក្សីមកពីតំបន់កំពង់សោមបានរៀបរាប់អំពីភាពខុសគ្នាយ៉ាងខ្លាំង រវាងការរៀបអាពាហ៍ពិពាហ៍មុន និងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងការលុបបំបាត់ចោលនូវពិធីបុណ្យសាសនា និងវប្បធម៌ផ្សេងៗ និងគ្មានការចូលរួមរបស់គ្រួសារ[3356]។ មានតែកូនកំលោះ និងកូនក្រមុំ និងអាជ្ញាធរតំណាងប៉ុណ្ណោះ ដែលមានវត្តមាននៅក្នុងពិធី[3357]។

---

[3353] ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន ហៅ ណាំ ឡុន ឆ. ២១៥ ["ដំបូងខាងប្រុសដែលជាសមាជិកអង្គការរបស់យើងជាអ្នកស្នើសុំរៀបការ បន្ទាប់មកយើងទៅសាកសួរខាងនារី និងប្រធានខាងកងនារីនោះសិន បានយើងស្នើសុំទៅថ្នាក់លើដើម្បីរៀបការឱ្យពួកគេ។"]។

[3354] ឯកសារ D234/2.1.141 ម៉ាក ឈឿន ប្រតិចារឹកថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ 15.52.50-15.55.15 ["ការពិត ខ្ញុំឃើញខាងប្រពន្ធខ្ញុំហ្នឹង វាយូរហើយ ប៉ុន្តែដល់យើងតាមសួរតាមអី តាមវរៈសេនាធំទៅ ក៏គេឯកភាព អ៊ីចឹងក៏ការទៅ។"]។ ឯកសារ D114/146 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញឹក ឆ.៤០-៤១ ["បើគេឃើញមានការសង្ស័យត្រង់ណាមួយនៅលើប្រវត្តិរូបរបស់ខ្ញុំ គេនឹងមិនអនុញ្ញាតទៅតាមសំណើរបស់ខ្ញុំទេ។ [...]ឆ.៤១៖ ឧទាហរណ៍បើមានអ្នកណាម្នាក់ស្នើសុំរៀបការជាមួយនឹងនារីម្នាក់ ឈ្មោះ ក យើងអាចធ្វើសំណើទៅបាន ប៉ុន្តែគឺស្រេចតែលើគេជាអ្នកសម្រេច។"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.២៥៣ ["ខ្ញុំសូមលើកឧទាហរណ៍មួយថា បើកម្មាភិបាលណាម្នាក់ស្រឡាញ់នារីណាម្នាក់ ពេលនោះ កម្មាភិបាលនោះ ទៅប្រាប់មេរបស់គាត់ថា គាត់ចង់បាននារីនោះ ប៉ុន្តែការសម្រេច គឺស្រេចតែទៅលើបក្ស។"]។

[3355] ឯកសារ D114/146 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ញឹក ឆ.៤១ ["ពេលខ្លះ គេមិនយល់ស្របជាមួយនឹងសំណើយើង ហើយមិនអនុញ្ញាតឱ្យយើងរៀបការតាមសំណើនោះទេ។ ប៉ុន្តែគេបានបញ្ជូននារីផ្សេងមកឱ្យរៀបការវិញ។"]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន ហៅ ណាំ ឡុន ឆ.២០២។

[3356] ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ហៅ កេន ឆ. ២៨៦-២៨៨ ["សៈ តើនោះដូចជាការរៀបការធម្មតាដែលមានវត្តមានរបស់ឪពុកម្តាយព្រះសង្ឃអាចារ្យចូលរួមដែរទេ? ឆ៖ ២៨៦៖ ទេ មិនដូចទេ។ ពេលនោះ គឺមានតែពួកយើង គ្មានចាស់ទុំឬអ្នកផ្សេងទៅចូលរួមទេ។ សៈ តើមានអ្នកណាជាអ្នកចមកឱ្យពរ ឱ្យទេវតាជួយថែរក្សាទេ? ឆ.២៨៧៖ អត់មានទេ ចុះសម័យហ្នឹង សូម្បីតែវត្តអីកម្ទេចចោលអស់ អ៊ីចឹងគ្មានការឱ្យពរទេ។ [...]ឆ. ២៨៨៖ សម័យនោះ មិនដូចការទេ។ គេគ្រាន់តែឱ្យប្តេជ្ញាចិត្តគោរពអង្គការជានិច្ច។"]។ ឯកសារ D114/95

833. អាពាហ៍ពិពាហ៍ត្រូវបានរៀបចំឡើងស្រដៀងគ្នានឹងអាពាហ៍ពិពាហ៍ ដែលរៀបចំឡើងនៅផ្នែកសេសសល់នៃប្រទេសដែរ[3358]។ ដំបូង គេឲ្យបុរស និងស្ត្រីអង្គុយក្នុងជួរដាច់ដោយឡែក និងបាន

---

កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ. ២៤៩ ["សៈ តើនៅពេលរៀបការនោះ មានព្រះសង្ឃឬទេ? ឆ.២៤៩៖ កាលនោះ គ្មានសាសនាទេ ហេតុនេះ គ្មានព្រះសង្ឃចូលរួមឡើយ។"]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ. ១៨៣-១៨៤ ["សៈ តើការរៀបការនោះ គេរៀបចំតាមប្រពៃណីព្រះពុទ្ធសាសនាដែរឬទេ? ឆ.១៨៣៖ ទេ គេរៀបការតាមរបៀបកុម្មុយនីស្ត។ [...]ឆ.១៨៤៖ [...]កម្មវិធីមានដូចតទៅ ទី១ គេណែនាំពីពិធីការនេះ ទី២ គេសួរបញ្ជាក់មតិយើង ថាតើយើងសុខចិត្តការតាមគេអត់។ ទី៣ ភ្ញៀវ ផ្តាំផ្ញើ។ ទី៤ សាម៉ីខ្លួនឡើងចាប់អារម្មណ៍។ ទី៥ ជប់លៀង ហូបចុក ជាកិច្ចបញ្ចប់។"]។ ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន់ ឆ.៣៤-៣៧, ៣៩ ["សៈ តើឪពុកម្តាយនិងគ្រួសាររបស់លោកស្រី ដឹងអំពីការរៀបការរបស់លោកស្រីដែរទេ? ឆ.៣៤៖ ទេ គាត់មិនដឹងទេ។ សៈ តើការរៀបការនោះ មានលក្ខណៈជាការរៀបការតាមបែបប្រពៃណីដែរឬទេ? ឆ.៣៥៖ ទេ គេគ្រាន់តែឲ្យយើងឡើងប្តេជ្ញាបីដង គឺហើយតែម្តង។ សៈ តើការរៀបការតាមបែបប្រពៃណីមានលក្ខណៈយ៉ាងណាដែរ? ឆ.៣៦ ការរៀបការតាមប្រពៃណី គឺយើងមានភ្លេង មានតាអាចារ្យ មានម៉ែឪដឹងឮ មានការកាត់សក់ មានកម្មវិធីកាត់ខាន់ស្លាជាដើម។ [...]ឆ.៣៧៖ ការរៀបការតាមប្រពៃណី គឺគេស្រឡាញ់គ្នា ហើយខាងប្រុសសុំឪពុកម្តាយរបស់ខ្លួនឲ្យចូលស្តីដណ្តឹងនៅផ្ទះឪពុកម្តាយខាងស្រី [...]សៈ កាលពីសម័យមុន ប្រសិនជាម៉ែឪរៀបចំឲ្យមានប្តីប្រពន្ធដោយចិត្តខ្លួនគាត់ តើពួកគេអាចបដិសេធបានដែរឬទេ? ឆ.៣៩៖ [...]កូនៗស្តាប់បង្គាប់ម៉ែឪដូច្នេះ ពួកគេរៀបការតាមការរៀបចំតាមការរៀបការរបស់ឪពុកម្តាយ គឺកម្រនឹងប្រកែកណាស់ ប៉ុន្តែក៏មានការប្រកែកខ្លះដែរ។"]។ ឯកសារ D54/120 កំណត់ហេតុស្តាប់ចម្លើយ ព្រំ កែម ឆ.៣ ["ជំនឿសាសនា ក៏ដូចជាការរៀបការតាមបែបប្រពៃណីក៏ត្រូវបានហាមឃាត់ទាំងស្រុងដែរ។ គេអនុញ្ញាត និងរៀបចំឲ្យមានតែការរៀបការជាក្រុម ឬការជាសហគមន៍ប៉ុណ្ណោះ ដែលជួនកាលមាន ១០គូ និងជួនកាល ១៥គូ។"]។

3357 ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ. ២២៩ ["ញ៉ាន់ អង្គុយនៅក្បាលតុ ហើយមានភ្ញៀវប្រហែល ប្រាំពីរ ឬប្រាំបីនាក់ ដែលជាប្រធានពេទ្យ និងពេទ្យដូចគ្នា។ ចំណែកខាងកងទ័ពមានតែ បីនាក់"]។ ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ. ៣១ ["ទាំងអស់មាន ៩នាក់ ៣គូ និងគណៈអធិបតីចំនួន ៣នាក់។"]។ សម្រាប់កម្មាភិបាលជាន់ខ្ពស់ដូចជា លៀត ឡូន និងប្រពន្ធ ដែលមានទំនាក់ទំនងជាមួយអនុបញ្ជាការកងពល ដែលមានកម្មាភិបាលជាច្រើនប្រមូលផ្តុំ ហើយសូម្បីតែឪពុកកូនក្រមុំ៖ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ. ១៧៥, ១៧៩ ["មានកម្មាភិបាលច្រើនណាស់មកពីជើងទឹក និងជើងគោក។ គេបានរៀបចំតុវែងមួយ មានម្ហូបអាហារភេសជ្ជៈ និងស្រា ហើយមានអ្នកចូលរួមទាំងចាស់ទាំងក្មេង [...]ឆ.១៧៩៖ ឪពុកខាងកូនក្រមុំបានចូលរួម។"]។ ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ហៅ កេន ឆ.២៧៥, ២៧៧-២៧៨ ["មានពួកស្រីៗទាំងខ្ញុំ ៧នាក់ [...]សៈ ក្រៅពីមនុស្ស ៧គូនោះ មានអ្នកផ្សេងទៀត? ឆ.២៧៧៖ គ្មានអ្នកណាទៀតទេ [...]ឆ.២៧៨៖ គ្មានទេ មានតែមេបញ្ជាការក្តាប់នៅទីនោះជាអ្នករៀបរាប់។"]។

3358 សូមមើល VIII.H.3. ការអនុវត្តគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំថ្នាក់ជាតិ - ពិធីរៀបការ។

ប្រកាសឈ្មោះអ្នកដែលពួកគេនឹងត្រូវរៀបការជាមួយ[3359]។ បន្ទាប់មក គូស្វាមីភរិយាត្រូវបានណែនាំឱ្យកាន់ដៃគ្នា និងឡើងធ្វើការប្ដេជ្ញា ពោលគឺការសន្យាថានឹងប្រឹងប្រែងធ្វើការដើម្បីអង្គការ និងស្រឡាញ់គ្នា[3360]។ ដើម្បីចំណេញពេលវេលា អ្នកដែលធ្វើជាអធិបតីនៃអាពាហ៍ពិពាហ៍ទ្រង់ទ្រាយធំ បានចាត់តាំងតំណាងឱ្យធ្វើការប្ដេជ្ញាតាងនាមឱ្យគូទាំងអស់[3361]។ ពិធីរៀបការលែងមានសារៈសំខាន់ ឬលែងជារឿងផ្ទាល់ខ្លួនចំពោះកូនកំលោះ និងកូនក្រមុំទៀតហើយ ព្រោះវាគ្រាន់តែដូច "ការប្រជុំ" ប៉ុណ្ណោះ[3362]។

834. ទីតាំងរៀបចំអាពាហ៍ពិពាហ៍ទាំងនេះជាទីតាំងដ៏សំខាន់ ព្រោះថាគេបានប្រើប្រាស់ទីបញ្ជាការកងពល ១៦៤ (ម១៦៤ ឬ "ផ្ទះតាញ៉ាន់") និងមន្ទីរភស្តុភាររបស់ ញ៉ាន់ ជាកន្លែងរៀប

---

[3359] ឯកសារ D114/113 កំណត់ហេតុស្ដាប់ចម្លើយ គឹម ម៉េន ឆ. ២២៩ ["ខាងស្រីបីនាក់អង្គុយទល់មុខខាងប្រុស"]។ ឯកសារ D114/95 កំណត់ហេតុស្ដាប់ចម្លើយ យឹម ស្រឿង ឆ. ២៤៧ ["ប្រុសអង្គុយមួយជួរ ហើយនារី អង្គុយមួយជួរ ជាមួយនឹងតុវែងមួយដោយអង្គុយទល់មុខគ្នា ហើយបន្ទាប់មកមានគណៈកម្មាធិការបីរូប ដោយប្រកាសថា ចាប់ពីពេលនេះទៅ យើងទទួលស្គាល់សមមិត្តទាំង ៣គូ ឬ ៥គូថាគូនឹងគ្នា ចាប់ពីពេលនេះ ម៉ោងនេះតទៅ។"]។ ឯកសារ D114/32 កំណត់ហេតុស្ដាប់ចម្លើយ មាស សារ៉ាន់ ឆ.២១ [ការពន្យល់ពីរបៀបដែលគូស្រករ ៧១គូ ដែលតំណាងដោយពីរឬបីគូ ដែលកាន់ដៃហើយប្ដេជ្ញា ហើយវាត្រឹមត្រូវប៉ុនណា បន្ទាប់ពីគូស្រករទាំងនោះចាកចេញពីរោងកុនទៅញ៉ាំអាហារក្រៅ]។

[3360] ឯកសារ D114/304 កំណត់ហេតុស្ដាប់ចម្លើយ វុន ប៊ុនណា ឆ. ១០៨ ["អត់មានធ្វើអីទេ គ្រាន់តែនិយាយពីរបីម៉ាត់ ចាប់ដៃគ្នា ហើយហូបបាយទៅអត់មានអីធំដុំផង។"]។ ឯកសារ D114/103 កំណត់ហេតុស្ដាប់ចម្លើយ លៀត ឡុន ហៅ ណាំ ឡុន ឆ. ១៨៤ ["សាម៉ីខ្លួនឡើងចាប់អារម្មណ៍"]។ ឯកសារ D114/117 កំណត់ហេតុស្ដាប់ចម្លើយ ណាវ សុខន ហៅ កេន ឆ. ២៧៧, ២៩៨ ["យើងគ្រាន់តែប្ដេជ្ញា ហើយទះដៃប៉ុណ្ណោះ។ [...]៨ឆ.២៩៨៖ គេគ្រាន់តែឱ្យប្ដេជ្ញាចិត្ត គោរពតាមអង្គការជានិច្ច។"]។

[3361] ឯកសារ D114/32 កំណត់ហេតុស្ដាប់ចម្លើយ មាស សារ៉ាន់ ឆ.២១ [រៀបការដោយបង្ខំជាមួយទាហានកងពល ៣/១៦៤ ម្ដង ៧០គូ៖ "គេជ្រើសរើសពីរ ឬបីគូឱ្យឈរនៅមុខគូផ្សេងៗទៀត [...]ជាសង្ខេប គាត់និយាយថា មិនឱ្យគូទាំងអស់ឡើងធ្វើប្ដេជ្ញាទេ ព្រោះមានពីរបីគូនៅខាងមុខនេះ នឹងធ្វើប្ដេជ្ញាជាគំរូ។ ក្រោយពីតាឌីម និយាយចប់ ពីរបីគូដែលនៅខាងមុខ នឹងឈរស្រោប់ចាប់ដៃគ្នា ហើយធ្វើការប្ដេជ្ញា"]។

[3362] ឯកសារ D114/139 កំណត់ហេតុស្ដាប់ចម្លើយ ឡាយ ងួន ហៅ អ៊ី ឆ.១៣៨ ["ស៖ តើវាជាពិធីរៀបការតាមប្រពៃណី ឬយ៉ាងដូចម្ដេចដែរ? ឆ.១៣៨៖ វាដូចជាកិច្ចប្រជុំ គេឱ្យគូស្រករអង្គុយតុមូល ទល់មុខគ្នា មានការប្រកាសថា អ្នកនេះត្រូវរៀបការជាមួយអ្នកនោះ ហើយពួកគេជូនពរយើង។"]។ ឯកសារ D114/53 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុក សុក ឆ.២៦៨ ["ពុំមានពិធីត្រឹមត្រូវឡើយ។ គេរៀបការម្ដង ៥គូ មានមេចូលរួមជាអធិបតីក្នុងពិធីនោះ។"]។

អាពាហ៍ពិពាហ៍[3363] ក៏ដូចជាកន្លែងប្រជុំធំជាងគេពីររបស់កងពល ១៦៤ (រោងភាពយន្តជិតផ្សារលើ និងកន្លែងហ្វឹកហ្វឺនរបស់កងវរសេនាធំ ១៤០ នៅអូរឈើទាល)[3364]។ នេះបង្ហាញពីការចូលរួម និងការដឹងឮរបស់ថ្នាក់ដឹកនាំកងពលអំពីព្រឹត្តិការណ៍ទាំងនេះ និងលក្ខណៈផ្លូវការ និងជាគំរូនៃអាពាហ៍ពិពាហ៍ទាំងនេះ។ ពិធីផ្សេងទៀតត្រូវបានរៀបចំនៅផ្ទះមួយនៅស្ទឹងហាវ ដែល ណាវ សុខន ហៅ កេន ត្រូវបានបង្ខំឱ្យរៀបការជាមួយកម្មាភិបាលឋានៈខ្ពស់នៃកងពល ១៦៤[3365] នៅទឹកសាប[3366] ឬនៅរោងក្បែរសហករណ៍[3367]។

---

3363 ឯកសារ D114/304 កំណត់ហេតុស្តាប់ចម្លើយ វុន ប៊ុនណា ឆ. ១០០, ១១២-១១៣ [ពិធីរៀបការធ្វើឡើងនៅមន្ទីរ ទីម សេង និងលៀត ឡុន ហើយនិងខ្លួនគាត់បានដេកនៅផ្ទះរបស់សេង មួយយប់។]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន ហៅ ណាំ ឡុន ឆ.១៧៧ ["សៈ តើលោករៀបការនៅកន្លែងណា? ឆ.១៧៧៖ នៅផ្ទះរបស់តាម៉ុក នៅកំពង់សោម។"]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ. ២៣៤ ["ការនៅកន្លែងកងពល"]។ ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ. ២៩, ៣០ ["សៈ តើអ្នកណាជាអ្នកធ្វើអធិបតីនៅក្នុងពិធីរៀបការនោះ? ឆ.២៩៖ គឺឈ្មោះ ញ៉ាន់ គាត់ធ្វើជាអធិបតី ក្នុងពិធីរៀបការរបស់ខ្ញុំជាមួយនឹងមនុស្ស២នាក់ទៀត ដែលមានឈ្មោះ អាន។ [...]ឆ.៣០៖ នៅកំពង់សោម [...]នៅជិតរូបតោបច្ចុប្បន្ននេះ មានតែបីគូប៉ុណ្ណោះ ដែលគេរៀបការឱ្យនៅពេលនោះ។ ទីកន្លែងគឺ ជាកន្លែងភស្តុភារ។"]។

3364 ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន់ ឆ.៥-៦ ["ពួកគេរៀបការពួកខ្ញុំនៅរោងកុនកំពង់សោម។ គឺមានមនុស្សពេញរោងកុននោះតែម្តង ហើយគេក៏បានប្រកាសថា មានសរុប ៧១គូ។ [...]ឆ.៦៖ ខ្ញុំមិនដែលបានដឹងពីការរៀបចំឱ្យខ្ញុំមានគូស្រករនោះពីមុនមកសោះ។ ដល់ពេលមួយ គេហៅខ្ញុំទៅប្រជុំ ហើយគេក៏រៀបការឱ្យខ្ញុំមានគូនៅពេលនោះតែម្តងទៅ។"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ.៤៥ ["ជួនកាលគេរៀបម្តងពីរគូ បីគូ ឬប្រាំគូ។ ការរៀបការគឺគេធ្វើឡើងនៅអូរឈើទាល ដោយសារមេៗរបស់កងវរៈសេនាធំ ១៤០ គឺស្នាក់នៅទីនោះ។ ទីនោះជាមូលដ្ឋានរបស់ខាងបុរស ហើយគេរៀបការនៅទីនោះ ដោយសារមានកន្លែងសមរម្យសម្រាប់រៀបការ"]។

3365 ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ហៅ កេន ឆ. ២៦៥, ២៧៣-២៧៤ ["គេយកខ្ញុំទៅកន្លែងរៀបការនៅស្ទឹងហាវ នៅកំពង់សោម ជិតហាងផលិតទឹកត្រី។ [...]ពេលរៀបការហើយ គេទុកយើងនៅទីនោះ ៧ ថ្ងៃ [...]សៈ ពេលថ្ងៃប្តូរជ្ញានោះ តើគេរៀបចំនៅទីណា? ឆ.២៧៣៖ នៅស្ទឹងហាវ វាជាទួលខ្ពស់។ សៈ តើមានរោង ឬអគារទេសម្រាប់ពិធីនោះ? ឆ.២៧៤៖ មានផ្ទះធ្វើផុតពីដីកន្លះម៉ែត្រ គេដាក់ជណ្តើរឡើង ៥កាំ។"]។

3366 ឯកសារ D114/139 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ងួន ហៅ អ៊ី ឆ.១៣៦ ["រៀបការនៅទឹកសាប"]។

3367 ឯកសារ D114/47 កំណត់ហេតុស្តាប់ចម្លើយ តើ រី ឆ.១០៩ ["គេធ្វើនៅសាលារៀនកូនក្មេង ចម្ងាយប្រហែលជាមួយគីឡូម៉ែត្រពីកន្លែងដែលយើងស្នាក់នៅ។"]។ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ.២៨៤, ២៨៦ ["ពិធីនោះ រៀបនៅតំបន់កងកេងដែរ។ ពិធីនោះ មិនធ្វើឡើងនៅក្នុងសហករណ៍ណាមួយឡើយ។ គេរៀបចំនៅកន្លែង

## គ) គ្មានការព្រមព្រៀង

835. ដូចជនរងគ្រោះរាប់ពាន់នាក់ផ្សេងទៀតទូទាំងប្រទេស[3368] បុរស និងនារីដែលត្រូវបានបង្ខំឱ្យរៀបការនៅកំពង់សោម ជាក់ស្តែង មិនបានព្រមព្រៀងចំពោះអាពាហ៍ពិពាហ៍របស់ពួកគេទេ[3369]។ ទោះក្នុងករណីដែលបុគ្គលមិនត្រូវបានគំរាមកំហែងយ៉ាងច្បាស់ក្រឡែតក្តី បរិយាកាសទូទៅនៃការភិតភ័យធ្វើឱ្យមនុស្សជាច្រើនជឿថា ពួកគេនឹងត្រូវបានដាក់ទោស វាយ ចាប់ ឬសម្លាប់ចោលចំពោះការមិនគោរពតាមបទបញ្ជាយោធា ឬបក្ស ប្រសិនបើពួកគេបដិសេធ[3370]។ ដូច្នេះ ពួកគេគ្មាន

---

ដែលគេតែងតែប្រជុំ។ [...]ឆ.២៨៦៖ អគារនៅដាច់ដោយឡែកពីគេ ស្ថិតនៅវាលទួល នៅចម្ងាយប្រហែល ១០០ម ពីសហករណ៍ស្ទាច់ដែង។ វាមិននៅជិតទីតាំងយោធាណាមួយឡើយ។"]។

3368 សូមមើល VIII.H.3. ការអនុវត្តគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំថ្នាក់ជាតិ - អាពាហ៍ពិពាហ៍ដោយបង្ខំ។

3369 ឯកសារ D114/47 កំណត់ហេតុស្តាប់ចម្លើយ តើ រី ឆ.១១២-១១៣, ១១៩-១២០ ["សៈ តើពេលនោះ លោកស្រីមានចង់រៀបការជាមួយបុរសនោះទេ? ឆ.១១២៖ អត់ទេ។ សៈ តើលោកស្រីធ្លាប់ឃើញបុរសនោះទេ? ឆ.១១៣៖ អត់ទេ។ [...]ឆ.១១៩៖ ខ្ញុំក៏ឆ្ងល់ដូច្នេះដែរ យើងមិនដែលស្គាល់គ្នាសោះ ហេតុអ្វីបានជាគេចាប់ផ្សំផ្គុំយើងបែបនេះ។ [...]ឆ.១២០៖ ខ្ញុំមានអារម្មណ៍ភ័យខ្លាច។"]។ ឯកសារ ឯកសារ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ.១៦១, ១៦៣, ១៦៨ ["ខ្ញុំក៏មិនមានបំណងរៀបការដែរ [...]សៈ តើអ្នកណាជាអ្នករើសប្រពន្ធឱ្យលោក? ឆ.១៦៣៖ តាមខ្ញុំដឹង គឺញ៉ាន់ [...]សៈ តើលោកដឹងខ្លួនថា នឹងរៀបការនៅពេលណាទៅ? ឆ.១៦៨៖ ខ្ញុំដឹងនៅពេលថ្ងៃរៀបការតែម្តង។]។

3370 ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន់ ឆ.១០, ៣១-៣២ ["ក្រោយពីទៅដល់រោងកុន ខ្ញុំមានការភ្ញាក់ផ្អើលដោយសារមានមនុស្សច្រើន ហើយខ្ញុំក៏បានសួរគេ ហើយគេប្រាប់ថា គេកំពុងតែរៀបចំពិធីការ។ ខ្ញុំចង់រត់ពីទីនោះដែរ ប៉ុន្តែមិនអាចរត់រួចពីព្រោះទាហាននៅសងខាង។ [...]ឆ.៣១៖ កាលពីជំនាន់នោះ គឺពួកយើងជាកម្មសិទ្ធិរបស់គេទាំងស្រុង មានន័យថា គេបញ្ជាឱ្យទៅណា គឺត្រូវតែទៅនោះតាមគេ។ សៈ តើមានអ្នកហ៊ានបដិសេធពុំព្រមរៀបការតាមការរៀបចំរបស់គេដែរឬទេ? ឆ.៣២៖ ទេ គ្មាននរណាហ៊ានបដិសេធនឹងគេទេ ពីព្រោះសម័យនោះ យើងខ្លាចគេមិនឱ្យនៅ។"]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ. ១៩៧, ២១៨-២១៩, ២២១ ["ខ្ញុំប្រហែលជាត្រូវគេយកទៅសម្លាប់ ដោយសារគេចោទថាក្បត់បក្ស។ [...]ឆ.២១៨៖ ខ្ញុំប្រាប់ប្រធានកងនារីថា សមាជិកកងខ្ញុំស្រឡាញ់នារីម្នាក់នេះ ហើយឱ្យគាត់ទៅសាកសួរនារីម្នាក់នោះថា គាត់ព្រមរៀបការជាមួយនឹងសមាជិកកងរបស់ខ្ញុំឬទេ។ បើសិនជានាងព្រម ខ្ញុំនឹងបញ្ជូនឈ្មោះទៅលើ [...]ឆ.២១៩៖ យើងអាចរៀបចំឱ្យអ្នកណាក៏បាន ប្រសិនបើមិនព្រម មានន័យថា គាត់មានបញ្ហាជាមួយបក្ស។ [...]ឆ.២២១៖ ប្រសិនបើឆ្លើយថា ទេ ពេលនោះ ការរៀបការមិនអាចធ្វើបានឡើយ។ ពេលខ្លះ ប្រធានកងនារីក៏ជួយនិយាយដែរ។"]។ ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ. ២៤ ["យើងខ្លាចថា យើងមានបញ្ហា"]។ ឯកសារ D114/47 កំណត់ហេតុស្តាប់ចម្លើយ តើ រី ឆ.៨៧-៨៩, ៩៥ ["ខ្ញុំបានឃើញគេបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ចំនួន ១៧ គូ នៅតំបន់

ជម្រើសអ្វីក្រៅពីយល់ព្រមនឹងអាពាហ៍ពិពាហ៍នេះទេ[3371]។ ដោយហេតុថា សេចក្តីសម្រេចរបស់អង្គការមិនចេះខុស សេចក្តីសម្រេចនោះត្រូវគោរពជាដាច់ខាត (ហើយស្រដៀងគ្នាដែរ ការលែងលះត្រូវបានហាមឃាត់)[3372]។ ដូច សំ វុទ្ធី អ្នកធ្វើការនៅកងចល័ត បានពន្យល់ "ផែនការរបស់គេគឺឱ្យយើងរៀបការនៅល្ងាចនោះ ទោះយើងព្រម ឬមិនព្រមក៏ដោយ"[3373]។

---

បឹងស្រីនោះ [...]ឆ.៨៨៖ ខ្ញុំស្គាល់មនុស្ស ៣នាក់។ [...]ឆ.៨៩៖ [...]ពួកគេមិនបានប្រកែកជាមួយនឹងការរៀបការនេះទេ។ ពួកគេប្រាប់ខ្ញុំថា បើខ្ញុំប្រកែកគេនឹងសម្លាប់ខ្ញុំចោល។ [...]ស៖ ហេតុអីបានជាគេមិនប្រកែក? ឆ.៩៥៖ ពីព្រោះពួកគេខ្លាចស្លាប់ ឬត្រូវគេវាយ។"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ. ៤៦ ["ខ្ញុំបានឮពីអ្នកដទៃថា នៅកន្លែងផ្សេងទៀត ចំពោះអ្នកដែលប្រកែកមិនព្រមរៀបការ គឺគេយកទៅសម្លាប់ចោលភ្លាម"]។ ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ. ២៤-២៦, ៣២ ["បើអ្នកបដិសេធការស្នើរបស់ពួកគេ យើងខ្លាចថាយើងមានបញ្ហា។ [...]ឆ.២៥៖ [...]នីរសារម្នាក់មកពីកងវរៈសេនាធំម្នាក់មកប្រាប់ថា ខ្ញុំនឹងត្រូវរៀបការ។ [...]ឆ.២៦៖ ខ្ញុំមិនមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងទេ ខ្ញុំមិនបានលើកស្នើអ្វីឡើយ វាក៏កើតឡើងបែបនេះ ចំពោះអ្នកដទៃផងដែរ។ ខ្ញុំរៀបការនៅឆ្នាំ ១៩៧៧ [...]ឆ.៣២៖ ខ្ញុំមិនបានតតាំងជាមួយពួកគេឡើយ ដោយសារខ្ញុំកត់សម្គាល់ឃើញថា អ្នកដែលមិនចុះសម្រុងគ្នាក្រោយពេលរៀបការរួច លែងទទួលបានការទុកចិត្តពីថ្នាក់លើរបស់ពួកគេទៀត ពួកគេនិយាយថា យើងមិនបានគោរពទៅតាមការរៀបចំរបស់អង្គការ។"]។

3371 ឯកសារ D114/304 កំណត់ហេតុស្តាប់ចម្លើយ វុន ប៊ុនណា ឆ. ៨៦, ៩៥-៩៦, ១៤៧ ["ការរៀបហ្នឹងដោយមានការចាត់តាំង [...]ស៖កាលនោះ លោកស្រីមានថា ព្រមព្រៀងនឹងរៀបការទេ? ឆ.៩៥៖ អត់មានបាននិយាយអីផង ព្រមក៏អត់ថា ទេក៏អត់ថា។ ស៖ ប៉ុន្តែពេលនោះ លោកស្រីខ្លួនឯងចង់រៀបការទេ? ឆ.៩៦៖ អត់ទាន់ចង់រៀបការទេ ព្រោះនៅក្មេងដែរ តែបងគាត់រៀបចំហើយ ខ្ញុំអត់និយាយអីទេ។ [...]ឆ.១៤៧៖ ចាស រស់នៅរហូតដល់ឆ្នាំ ៨៩ ខ្ញុំចែកផ្លូវគ្នា។"]។ ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.៣២ ["ខ្ញុំមិនបានតតាំងជាមួយពួកគេឡើយ ដោយសារខ្ញុំកត់សម្គាល់ឃើញថា អ្នកដែលមិនចុះសម្រុងគ្នាក្រោយពេលរៀបការរួច លែងទទួលបានការទុកចិត្តពីថ្នាក់លើរបស់ពួកគេទៀត ពួកគេនិយាយថា យើងមិនបានគោរពទៅតាមការរៀបចំរបស់អង្គការ។"]។ ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ.២៩៣, ២៩៩ ["គេមកប្រាប់ខ្ញុំទៅរៀបការ ខ្ញុំមិនមានជម្រើសអ្វីឡើយ។ ហើយខ្ញុំក៏មិនអាចប្រកែកបានឡើយ។ [...]ឆ.២៩៩៖ ខ្ញុំមិនហ៊ានប្រកែកឡើយ។"]។ ឯកសារ D114/83 កំណត់ហេតុស្តាប់ចម្លើយ សុខ នាង ឆ. ៤៦ ["ចំពោះអ្នកខ្លះដែលគេប្រាប់ឱ្យរៀបការ ហើយព្រមរៀបការតាមការរៀបចំគិតគូរបស់ប្រធានខ្លួន គឺដោយសារតែខ្លួនដល់អាយុគ្រប់ការ ឬក៏អ្នកខ្លះពុំហ៊ានប្រកែក"]។ ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ហៅ កេន ឆ. ២៦៤ ["ស៖ តើគេគម្រាមស្ត្រីទាំងនោះ ដូចគេគម្រាមលោកស្រីទេ? ឆ. ២៦៤៖ គេគ្រាន់តែថា អ្ហែង គេចមិនរួចទេ គង់តែការទេ មិនយូរឬឆាប់។"]។

3372 ឯកសារ D114/78 កំណត់ហេតុស្តាប់ចម្លើយ ស្វាយ សាម៉េត ឆ.២២-២៣ ["គឺយើងរៀបការជាមួយគ្នាតែម្តង។ [...]ស៖ តើលោកនៅបន្តនៅជាមួយប្រពន្ធរបស់លោកដែរឬទេ? ឆ.២៣៖ បាទ។"]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ. ១៧២ ["ស៖ ចុះប្រពន្ធលោកនិយាយថាម៉េចដែរកាលនោះ?

836. ភាពភ័យខ្លាចជាទូទៅចំពោះផលវិបាកនៃការបដិសេធ មិនមែនឥតមូលហេតុនោះទេ ដោយហេតុថាអ្នកតវ៉ាខ្លះទទួលរងនូវការគំរាមកំហែង ឬការដាក់ទណ្ឌកម្ម[3374]។ តើ វី ត្រូវបានបញ្ជូនទៅរៀន

[…]ឆ.១៧២៖ គាត់បានប្រកែកដែរ ប៉ុន្តែតាញ៉ាន់ បានសួរថា តើតាមបក្ស ឬក៏តាមអ្នកណា”]។ ចំពោះលទ្ធភាពនៃការលះលែង៖ ឯកសារ D114/83 កំណត់ហេតុស្ដាប់ចម្លើយ សុខ នាង ឆ.៤៧-៤៨ [ពន្យល់ថា គាត់មិនដែលឮថាមានស្ត្រីណាត្រូវបង្ខំឲ្យរៀបការដែលនាំឲ្យនៅបែកគ្នា ឬលែងលះក្រោយរបបនោះទេ។]។ ឯកសារ D114/234 កំណត់ហេតុស្ដាប់ចម្លើយ សាំ គំនិត ហៅ ហ៊ុត ឆ.៧៤ [“ស៖ តើការលែងលះ ឬការរស់នៅបែកគ្នា អាចប្រព្រឹត្តទៅបានទេ ក្នុងរបបខ្មែរក្រហម? ឆ.៧៤៖ អត់អាចទេ តែយកគឺយកហើយ វិន័យអង្គការ តែយកគ្នាគឺយករហូត បើទោះជាមិននៅជាមួយគ្នាអីក៏ដោយ។ តែនៅជាមួយគ្នាហើយ គឺនៅជាមួយគ្នារហូត ក៏មិនឃើញអ្នកណាបែកគ្នាដែរ។”]។

3373 ឯកសារ D114/94 កំណត់ហេតុស្ដាប់ចម្លើយ សំ វុទ្ធី ឆ.១១២ [“ស៖ ពេលដែលឃើញគ្នាហ្នឹង តើលោកមានបានយល់ព្រមរៀបការទេ? ឆ.១១២៖ យើងមិនទាន់សម្រេចចិត្តទេ តែផែនការរបស់គេគឺឲ្យយើងរៀបការនៅល្ងាចនោះ ទោះយើងព្រម ឬមិនព្រមក៏ដោយ។”]។

3374 ឯកសារ D114/117 កំណត់ហេតុស្ដាប់ចម្លើយ ណាវ សុខន ហៅ កេន ឆ. ២៦២-២៦៤ [“ស៖ តើមានអ្វីកើតឡើងពេលដែលគេមករកលោកស្រីឲ្យរៀបការ? ឆ.២៦២៖ គេប្រាប់ថា គេមកឲ្យលោកស្រីទៅរៀបការហើយ។ តែខ្ញុំមិនព្រម តែគាត់ប្រាប់ថា បើមិនការទេ គេនឹងដាក់គុកហើយ ដូច្នេះ ហើយទើបខ្ញុំព្រម។ ស៖ ចុះអ្នកផ្សេងទៀត ដែលគាត់មិនព្រមការវិញ? ឆ.២៦៣៖ បើមិនព្រមការ គឺគេសុខចិត្តស្លាប់ ហើយគេក៏នៅទីនោះទៅ។ […]ឆ.២៦៤៖ គេគ្រាន់តែថា អ្នែង គេចមិនរួចទេ គង់តែការ មិនយូរ ឬឆាប់។”]។ ឯកសារ D114/95 កំណត់ហេតុស្ដាប់ចម្លើយ យឹម ស្រឿង ឆ. ២៦៣, ២៦៦ [“ស៖ ចុះកម្មាភិបាលដែលមិនចង់រៀបការ តើមានរឿងអ្វីឡើងចំពោះពួកគេ? ឆ.២៦៣៖ ត្រូវបានគេចាប់ ដោយគេនិយាយថា មិនគោរពការចាត់តាំងរបស់បក្ស។ […]ស៖ តើលោកមានដឹងថា ប្រសិនបើមាននារី ឬក៏កម្មាភិបាលណា ដែលបានព្យាយាមប្រកែកមិនព្រមរៀបការ។ តើមានរឿងអ្វីកើតឡើងចំពោះពួកគេដែរទេ? ឆ.២៦៦៖ បាទ មាន គឺត្រូវបានគេដកចេញពីអង្គភាព ឬក៏យកទៅដាក់នៅកន្លែងណាផ្សេង។”]។ ឯកសារ D114/78 កំណត់ហេតុស្ដាប់ចម្លើយ ស្វាយ សាម៉េត ឆ.៣២ [“ខ្ញុំមិនបានតតាំងជាមួយពួកគេឡើយ ដោយសារខ្ញុំកត់សម្គាល់ឃើញថា អ្នកដែលមិនចុះសម្រុងគ្នាក្រោយពេលរៀបការរួច លែងទទួលបានការទុកចិត្តពីថ្នាក់លើរបស់ពួកគេទៀត ពួកគេនិយាយថា យើងមិនបានគោរពទៅតាមការរៀបចំរបស់អង្គការ។”]។ ឯកសារ D114/103 កំណត់ហេតុស្ដាប់ចម្លើយ លៀត ឡុន ហៅ ណាំ ឡុន ឆ. ១៧១-១៧២, ១៨៥-១៨៦ [“ខ្ញុំនិយាយថា ខ្ញុំខឹង ព្រោះគេមិនបានប្រាប់ខ្ញុំជាមុន ហើយខ្ញុំប្រកែកមិនព្រមឡើងប្ដេជ្ញាទេ។ […]ឆ.១៧២៖ គាត់បានប្រកែកដែរ ប៉ុន្តែតាញ៉ាន់ បានសួរថា តើតាមបក្ស ឬក៏តាមអ្នកណា។ […]ស៖ ពេលលោកនិងប្រពន្ធលោកប្រកែកមិនព្រមរៀបការ តើមានរឿងអ្វីកើតឡើងទេ? ឆ.១៨៥៖ គេសួរខ្ញុំថា តើខ្ញុំតាមបក្ស ឬក៏តាមអ្នកណា។ ខ្ញុំឆ្លើយថា ខ្ញុំមិនដែលក្បត់បក្សឡើយ តែបក្សក្បត់ខ្ញុំ។ ស៖ តើប្រពន្ធលោកនិយាយអ្វីខ្លះ? ឆ.១៨៦៖ គាត់មិននិយាយអ្វីទេ។ ហើយពួកយើងមិនបានឡើងចាប់អារម្មណ៍ឡើយ។”]។

សូត្រ ហើយគេបានភ្លង់គាត់[3375]។ គាត់ត្រូវបានគេនាំទៅកន្លែងស្ងាត់មួយ ហើយ "មេកងបានប្រាប់ឱ្យទាហានពីរនាក់នោះធ្វើអ្វីក៏បានមកលើខ្ញុំ ព្រោះខ្ញុំមិនធ្វើតាមបញ្ជារបស់គាត់។ ខ្ញុំត្រូវបានគេវាយរហូតដល់ពេលជិតភ្លឺ ហើយគេឱ្យខ្ញុំទៅធ្វើការ"[3376]។ មួយសប្តាហ៍ក្រោយ អាពាហ៍ពិពាហ៍ត្រូវបានរៀបចំឡើង បន្ទាប់ពីគេគំរាមគាត់ថា គាត់នឹងមិនត្រូវបានអនុញ្ញាតឱ្យទៅមើលម្តាយគាត់ទៀតទេ បើសិនគាត់នៅតែបដិសេធមិនព្រមរៀបការ[3377]។

837. ទោះបីជាទាហានបុរសនៃកងពល ១៦៤ ត្រូវបានអនុញ្ញាត (ឬបង្ខំ) ឱ្យធ្វើសំណើទៅអ្នកគ្រប់គ្រងផ្ទាល់របស់ពួកគេសុំការអនុញ្ញាតរៀបការជាមួយនារីណាម្នាក់ ជម្រើសរបស់ពួកគេ ជារឿយៗត្រូវបានកំហិតចំពោះនារីមួយក្រុមតូច។ នារីខ្លះត្រូវបាននាំទៅលើកោះ ដើម្បីបង្ហាញឱ្យទាហានឈរជើងនៅទីនោះបានឃើញ[3378]។ សាក្សី គឹម ម៉េន មេបញ្ជាការម្នាក់ក្នុងចំណោមមេបញ្ជាការ

---

[3375] ឯកសារ D114/47 កំណត់ហេតុស្តាប់ចម្លើយ តើ រី ឆ.៩៧, ១០០-១០១ ["គេប្រាប់ថា មិត្តនារី មានទ័ពស្នើមិត្តនារីឱ្យរៀបការជាមួយ ប៉ុន្តែខ្ញុំប្រកែក [...]ស៖ ពេលដែលលោកស្រីប្រកែក តើមេកងគេធ្វើម៉េចដាក់លោកស្រីពេលភ្លាមៗនោះ? ឆ.១០០៖ ខ្ញុំត្រូវបានគេប្រាប់មុនថ្ងៃលិច ហើយនៅពាក់កណ្តាលអធ្រាត្រ គេហៅខ្ញុំទៅអប់រំ។ ស៖ តើពេលនោះលោកស្រីទៅជាមួយគេឬ? ឆ.១០១៖ ចាស ខ្ញុំត្រូវបានគេភ្លង់នឹងកាំភ្លើង ខ្ញុំគ្មានជម្រើសអ្វីឡើយ។"]។

[3376] ឯកសារ D114/47 កំណត់ហេតុស្តាប់ចម្លើយ តើ រី ឆ.១០២-១០៦ ["គេយកខ្ញុំទៅកន្លែងស្ងាត់ ដែលមានមេកង និងទាហានពីរនាក់នៅទីនោះ មេកងបានប្រាប់ឱ្យទាហានពីរនាក់នោះ ធ្វើអ្វីក៏បានមកលើខ្ញុំ ព្រោះខ្ញុំមិនធ្វើតាមបញ្ជារបស់គាត់។ ខ្ញុំត្រូវបានគេវាយរហូតដល់ពេលជិតភ្លឺ ហើយគេឱ្យខ្ញុំទៅធ្វើការ។ [...]ឆ.១០៣៖ ទាហានពីរនាក់នោះជាអ្នកវាយខ្ញុំ ហើយមេកងក៏នៅទីនោះមួយភ្លែតដែរ ពេលដែលគេចាប់ផ្តើមវាយខ្ញុំ គាត់ប្រាប់ទាហានពីរនាក់នោះ ឱ្យវាយខ្ញុំឱ្យស្លាប់ដោយសារតែខ្ញុំជាមនុស្សក្បាលរឹង [...]ឆ.១០៤៖ គេនិយាយថា ខ្ញុំជាមនុស្សក្បាលរឹង បើខ្ញុំធ្វើតាមមេប្រាប់ នោះគេមិនវាយខ្ញុំទេ។ [...]ឆ.១០៥៖ គេវាយខ្ញុំនឹងដើមស្តៅតូចៗ។ ស៖ តើពេលនោះ គេវាយត្រូវកន្លែងណាខ្លះ? ឆ.១០៦៖ គេឱ្យខ្ញុំអង្គុយឱ្យគេវាយ។ គេវាយពេញខ្លួនទាំងអស់ ហើយខ្ញុំក្អកចេញឈាមកាលពីពេលនោះ។"]។

[3377] ឯកសារ D114/47 កំណត់ហេតុស្តាប់ចម្លើយ តើ រី ឆ.១០៧, ១១១។

[3378] ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ.២៣៧ ["គេនឹងយកនារីដើម្បីបង្ហាញពួកគេ ហើយសួរថាតើគេពេញចិត្តឬក៏អត់ ដូចនៅកោះខ្ញុំ គេដឹកនារីមកឱ្យយុទ្ធជនមើល"]។ មិនមែនគ្រប់នារីទាំងអស់រៀបការជាមួយទាហាននៅកោះត្រូវនាំយកទៅទីនោះទេ។ សូមមើលឧទាហរណ៍ ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សាវ៉ាន់ ឆ.១៣, ១៦-១៧, ២៩ ["ខ្ញុំភ្ញាក់ផ្អើល ដោយសារខ្ញុំនិងបុរសនោះមិនដែលស្គាល់គ្នាពីមុនមកសោះ។ [...]ឆ.១៦៖ ស្រីៗទាំងអស់រួមទាំងខ្ញុំ គឺគេឱ្យរៀបការជាមួយយោធាមកពីតាមកោះ។ [...]ឆ.១៧៖ប្តីរបស់ខ្ញុំមកពីកោះពូលូវៃ, ប្តីរបស់ អេន មកពីកោះតាង [...]ស៖ តើលោកស្រីដឹងថា តើគេផ្គូផ្គងប្តីប្រពន្ធតាមមូលហេតុអ្វីខ្លះ? ឆ.២៩៖ មានបីប្រភេទ តាមខ្ញុំដឹង [...]ទី២៖ គេដឹកនារីៗនៅតាមសហករណ៍តាមកប៉ាល់ទៅតាមកោះ ដើម្បីឱ្យយោធាមើលហើយ

កងពល ៦២៣ បាននិយាយថា គាត់បានសួរទាហានរបស់គាត់ថាតើ "ពេញចិត្តឬក៏អត់"[3379] មុននឹងពួកគេធ្វើសំណើ។ ដូចកម្មាភិបាលថ្នាក់ខ្ពស់ផ្សេងទៀតដែលទទួលខុសត្រូវផ្ទុំផ្គុង គឹម ម៉ែន អះអាងថា បុរស និងនារីទាំងនោះ*បានព្រមព្រៀង*រៀបការដោយសេរី[3380]។ ទោះជាយ៉ាងនេះក្ដី មាស សារ៉ាន ជានារីម្នាក់ដែលត្រូវបានបង្ខំឱ្យរៀបការ បានពន្យល់ថា "គ្មាននរណាហ៊ានបដិសេធនឹងគេទេ ពីព្រោះពីសម័យនោះ យើងខ្លាចគេមិនឱ្យនៅ"[3381]។ គឹម ម៉ែន ខ្លួនឯងផ្ទាល់បានទទួលស្គាល់ថា មានទម្រង់ផ្សេងៗនៃការដាក់សម្ពាធទៅលើកូនកំលោះ និងកូនក្រមុំ ឱ្យទទួលយកការ

ជ្រើសរើស ហើយគេក៏អាចស្គាល់គ្នាចាប់តាំងពីពេលនោះមក។ តែចំពោះគូខ្ញុំវិញ គឺពួកយើងមិនដែលស្គាល់គ្នាទេពីមុនមក។"]។

[3379] ឯកសារ D114/113 កំណត់ហេតុស្ដាប់ចម្លើយ គឹម ម៉ែន ឆ. ២៣៧-២៣៨ ["មនុស្សភាគច្រើនដល់អាយុត្រូវតែយក។ ពួកយើងសុទ្ធតែចាស់ ដូចខ្លះអាយុ ២៤, ២៥ ទៅ ៣០ឆ្នាំ ហើយ។ សម្រាប់ទាហាន គេនឹងយកនារីដើម្បីបង្ហាញពួកគេ ហើយសួរថា តើគេពេញចិត្ត ឬក៏អត់ ដូចនៅកោះខ្ញុំ គេដឹកនារី មកឱ្យយុទ្ធជនមើល ហើយខ្ញុំសួរយុទ្ធជនថា មិនពេញចិត្តនារីនេះទេ។ បើពេញចិត្ត យើងតក់ឈ្មោះអ្នកទាំងពី បើអត់ពេញចិត្ត ក៏អត់ទៅ [...]ពួកខ្ញុំគ្រាន់តែរៀបចំឱ្យគេបានឃើញគ្នាប៉ុណ្ណោះ។ [...]ស៖ តើកូនកំលោះ កូនក្រមុំជួបគ្នាតែម្ដងគត់ឬ? ឆ.២៣៨៖ បាទ ។"]។

[3380] ឯកសារ D114/113 កំណត់ហេតុស្ដាប់ចម្លើយ គឹម ម៉ែន ឆ. ២៣៧, ២៣៩ ["បើពេញចិត្ត យើងតក់ឈ្មោះអ្នកទាំងពី បើអត់ពេញចិត្ត ក៏អត់ទៅ [...]ស៖ តើខាងស្រី មានសិទ្ធិបដិសេធទេ? ឆ.២៣៩៖ មាន។"]។

[3381] ឯកសារ D114/32 កំណត់ហេតុស្ដាប់ចម្លើយ មាស សារ៉ាន់ ឆ.៣១-៣២ ["ស៖ តើលោកស្រីដឹងពីនារីៗដែលគេដឹកកប៉ាល់ទៅតាមកោះ ឱ្យយោធារើសពួកគេពេញចិត្តនឹងទៅដែរឬទេ? ឆ.៣១៖ កាលពីជំនាន់នោះ គឺពួកយើងជាកម្មសិទ្ធិរបស់គេទាំងស្រុង មានន័យថា គេបញ្ជាឱ្យទៅណា គឺត្រូវតែទៅនោះតាមគេ។ ស៖ តើមានអ្នកហ៊ានបដិសេធពុំព្រមរៀបការតាមការរៀបចំរបស់គេដែរឬទេ? ឆ.៣២៖ ទេ គ្មាននរណាហ៊ានបដិសេធនឹងគេទេ ពីព្រោះសម័យនោះ យើងខ្លាចគេមិនឱ្យនៅ។"]។

សម្រេចចិត្តរបស់អង្គការ[3382]។ គាត់ក៏បានថ្លែងផងដែរថា គាត់បានជួបអនាគតប្រពន្ធរបស់គាត់បានតែម្តងប៉ុណ្ណោះ និង "មិនដែលស្គាល់គាត់ទេ" មុនរៀបការដែលរៀបចំដោយតាញ៉ាន់[3383]។

838. អ្នកចូលរួមក្នុងពិធី ជាទូទៅ មានអ្នកដែលត្រូវគេបង្ខំឱ្យរៀបការ ព្រមទាំងអ្នកផ្សេងទៀតដែល "យល់ព្រមទទួលយក" ស្ថានភាពនេះ ឬរៀបការ "ដោយស្ម័គ្រចិត្ត"[3384]។ ប្រជាជនដែលហ៊ានជំទាស់មិនរៀបការ ជឿថាពួកគេអាចនឹងត្រូវគេសម្លាប់ដោយសារមិនគោរពតាមគេ។ ទោះជាយ៉ាងនេះក្តី ទាហានស្ត្រីមួយក្រុមអាចរឹងទទឹងមិនព្រមរៀបការតាមការបង្ខំ ដោយជោគជ័យ ដោយសារតែពួកគេមានសាមគ្គីភាពក្នុងក្រុម។ នារីមួយកងទាំងមូលបានបដិសេធមិនព្រមរៀបការជាមួយទាហានកងពល ១៦៤ នៅស្ទឹងហាវ ដោយសារតែឪពុកម្តាយពួកគេមិនបានចូលរួមក្នុងពិធី។ អតីតកម្មករនៅកំពត (ស្រែអំបិល) មួយក្រុមនេះ អះអាងថា ពួកគេសុខចិត្តស្លាប់ជាជាងត្រូវគេបង្ខំឱ្យរៀបការ។ ដោយសារតែទាហានបានរៀបចំគម្រោងចាប់ ឬដាក់ថ្នាំនារី (មានម្នាក់ក្នុងចំណោមពួកគេត្រូវបានរកឃើញថាស្លាប់) ពួកគេបានចាក់សោឃុំខ្លួនឯងនៅក្នុងផ្ទះមួយ។ បីថ្ងៃក្រោយមក តាម៉ុកបានបញ្ជូនពួកគេត្រឡប់ទៅភូមិភាគនិរតីវិញ[3385]។

---

[3382] ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ. ២៣៥-២៣៦ ["មិនមែនតាមបែបព្រះពុទ្ធសាសនាទេ។ ខ្ញុំសូមរៀបរាប់បន្តិច ឧទាហរណ៍ខ្ញុំខាងប្រុស ឱ្យអង្គុយ ហើយគេសួរទៅថា "សមមិត្ត ម៉េន នេះ គឺជានារី ដែលខ្ញុំនឹងរៀបការឱ្យមិត្តឯង តើមិត្តព្រមទទួលយកទេ?" រួចហើយ គេសួរខាងនារី ថា "នេះ ជាសមមិត្ត ម៉េន ហើយអង្គការរៀបចំឱ្យ តើព្រមទទួលយកទេ?" ស៖ តើមានរឿងអ្វីកើតឡើង ប្រសិនបើគេមិនព្រមទទួល? ឆ.២៣៦៖ មិនមានបញ្ហាទេ បើយើងពេញចិត្ត យើងយក បើយើងមិនពេញចិត្ត យើងថា យើងអត់ទាន់ចង់បានប្រពន្ធទេ។ បើយើងនិយាយថា យើងអត់យក ខ្លាចនារីខ្មាស។" (បញ្ជាក់បន្ថែម)]។

[3383] ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ គឹម ម៉េន ឆ. ២២៦, ២៣៨ ["គាត់ធ្វើពេទ្យខាងកំពង់សោម ហើយថ្នាក់លើរៀបចំការឱ្យ។ ខ្ញុំមិនដែលស្គាល់គាត់ទេ។ [...]ស៖ តើកូនកំលោះ កូនក្រមុំជួបគ្នាតែម្តងគត់ឬ? ឆ.២៣៨៖ បាទ ឧទាហរណ៍ដូចខ្ញុំជាដើម។"]។

[3384] ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រៀង ឆ. ២៥២ ["គូខ្លះ គេចាត់តាំងឱ្យរៀបការ ហើយគូខ្លះស្ម័គ្រចិត្តរៀបការដោយខ្លួនឯង។"]។ ឯកសារ D59/1/1.7a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ា ឈឿន KH ERN 00926330 ["ដល់អ្នកខ្លះ ត្រូវគេចាត់តាំងដែរ ចាត់តាំងដូចថាគ្នាមិនពេញចិត្តក៏មានបញ្ហាខ្លះអ៊ីចឹងដែរ កាលជំនាន់ហ្នឹង បែកបាក់គ្នាក៏មានដែរ។"]។

[3385] ឯកសារ D114/38 កំណត់ហេតុស្តាប់ចម្លើយ ជុំ រឹម (ជា រឹម) ឆ. ៨៩-៩០, ៩២, ៩៤, ៩៦ ["តើខ្មែរក្រហមមានបង្ខំលោកស្រីឱ្យរៀបការទេ? ឆ.៨៩៖ ចាស កាលនៅកំពង់សោម។ មួយកងខ្ញុំ បដិសេធមិនយកគ្រួសារទេ។ [...]ឆ.៩០៖ បងធី មកស្នើមិត្តនារីទាំងអស់នៅក្នុងកង ឱ្យរៀបការ ជាមួយយោធានៅកំពង់សោម។ ខ្ញុំថា បងប្អូនណាយកៗទៅ ខ្ញុំ

*ឃ) ការរួមដំណេកដោយបង្ខំ (ការរំលោភសេពសន្ថវៈ)*

839. គោលនយោបាយរបស់ ប.ក.ក ក្នុងការបង្ខំជនរងគ្រោះនៃការរៀបការដោយបង្ខំ ឲ្យរួមដំណេកដោយគ្មានការព្រមព្រៀងពីពួកគេ (ការរំលោភសេពសន្ថវៈ) ដើម្បីបង្កើនចំនួនប្រជាជន ត្រូវបានអនុវត្តយ៉ាងម៉ត់ចត់ដោយ **មាស មុត** និងកងកម្លាំងរបស់គាត់នៅកំពង់សោម។ កម្មាភិបាលទទួលបន្ទុកលើការរៀបអាពាហ៍ពិពាហ៍ បញ្ជាប្តីប្រពន្ធថ្មីថ្មោងឲ្យ "ស្គាល់គ្នា" "ដេកជាមួយគ្នា" ឬ "ធ្វើតាមការប្តេជ្ញាចិត្ត"[3386] ជាពាក្យសម្រាលច្បាស់ក្រឡែតប្រើសម្រាប់ការរួមដំណេក។

840. សាក្សីត្រូវបានបញ្ជាឲ្យរស់នៅជាមួយគ្នារយៈពេលពីរបីថ្ងៃនិងយប់ នៅកន្លែងដែលត្រូវបានបង្កើតឡើងជាពិសេសសម្រាប់ពួកគេ[3387]។ ប្តីប្រពន្ធត្រូវបានរំពឹងថានឹងប្រើប្រាស់ពេលវេលានេះដើម្បី

---

អត់យកទេ ពីព្រោះបែកពីម៉ែឪ។ ខ្ញុំសុខចិត្តស្លាប់។ ហើយអ្នកផ្សេងក៏បដិសេធដែរ។ [...]ស៖ តើមានរឿងអីកើតឡើងពេលពួកលោកស្រីបដិសេធមិនព្រមរៀបការ? ឆ.៩២៖ នៅពេលយប់ គេធាក់ទ្វារចង់របើកអស់ហើយ។ បន្ទាប់មកបងធី ស្នើសុំអាវុធយកមកការពារ។ បីថ្ងៃក្រោយមក កងនារីបានចេញពីកំពង់សោម។ ហើយពួកយើងបានរួចខ្លួន។ [...] ឆ.៩៤៖ កងយុវជនដាក់ផែនការចាប់កងនារី បើកងនារីដើរ បីនាក់ៗ។ ក្រោយមកពេលដើរទៅណា ពួកយើងដើរជាក្រុមៗដែលមានគ្នាច្រើន ១២នាក់។ អាហ្នឹងវាអត់ហ៊ានទេ។ តាំងពីហ្នឹងមកពិបាកការពារខ្លួនដែរ។ [...]ឆ.៩៦៖ ពេលនោះ មាននារីម្នាក់បាត់ខ្លួន ហើយយើងតាមរកហើយឃើញតែសាកសពនារីនោះ គ្របដោយស្លឹកចេក។"]។ សូមមើលផងដែរ ឯកសារ D1.3.32.5 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ជុំ រឹម (ជា រឹម) EN ERN 00183885 ["ពេល រឹម នៅកំពង់សោម កងយុវជនបានស្នើថា ពួកគេចង់រៀបការជាមួយនារីនៅក្នុងកងរបស់គាត់ដែលមានអាយុចាប់ពី ១៥ ដល់ ៣០ឆ្នាំ ប៉ុន្តែកងរបស់គាត់បានបដិសេធ។ បន្ទាប់មកបងប្រុសដែលទទួលបន្ទុកកងយោធាបានរៀបចំផែនការដើម្បីចាប់នារីដែលដើរវង្វេងផ្លូវដោយខ្លួនឯង ប៉ុន្តែស្ត្រីទាំងនោះត្រូវបានណែនាំ ឲ្យដើរជាក្រុម។ ពេលនោះ បុរសទាំងនោះ បានព្យាយាមដាក់ថ្នាំពុលក្នុងម្ហូបអាហារ ប៉ុន្តែស្ត្រីបានពង្រាយយាមកាមនៅពេលយប់។ នៅទីបំផុតស្ត្រីបានស្នើអាវុធពីអង្គការ។"]។

3386 ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សាវ៉ាន់ ឆ.២១ ["ចំពោះអ្នកដែលនៅឆ្ងាយ ពិសេសយោធាមកពីតាមកោះ គេឲ្យស្នាក់នៅក្នុងរោងកុនពីរបីថ្ងៃ ឬក៏មួយអាទិត្យដើម្បីឲ្យស្គាល់គ្នា។"(បញ្ជាក់បន្ថែម)]។ ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ហៅ កេន ឆ. ៣០៨ ["ស៖ តើគេមានឲ្យលោកស្រីគេងជាមួយប្តីឬទេ? ឆ.៣០៨៖ គេឲ្យយើងដេកជាមួយគ្នា ព្រោះយើងរៀបការរួចហើយ។"]។ ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សាវ៉ាន់ ឆ.៥៤ ["មានកគេប្រាប់ថា យើងបានប្តេជ្ញារួចហើយ យើងត្រូវតែធ្វើតាមការប្តេជ្ញាហ្នឹង។"]។

3387 ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡុន ហៅ ណាំ ឡុន ឆ. ១៨៧ ["ក្រោយមក ពួកគេបានរៀបចំផ្ទះមួយឲ្យយើងនៅ ហើយគេឲ្យយើងនៅទីនោះ ៣ថ្ងៃ។"]។ ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ហៅ កេន ឆ. ៣០៤-៣០៧ ["ជប់លៀងហើយ សឿន ឲ្យសមាជិកមកប្រាប់ថា ឲ្យស្មែកនាំប្រពន្ធៗមកនៅ

ដេកជាមួយគ្នា ទោះបីពួកគេចង់ ឬមិនចង់ក៏ដោយ[3388]។ ទោះបីជាស្ទើតែគ្មានឈ្លបឃុំណាមួយ នៅតំបន់កំពង់សោម ផ្ទុយពីតំបន់ ឬភូមិភាគឯករាជ្យផ្សេងទៀត ក៏ដោយ ក៏សាក្សីនៅតែរំឭកថា ប្ដីប្រពន្ធថ្មីថ្មោងត្រូវគេតាមដាន ដើម្បីពិនិត្យមើលថាពួកគេរួមដំណេកជាមួយគ្នា តាមផែនការរបស់អង្គការ[3389]។

---

តាមសហករណ៍។ [...]ឆ.៣០៥៖ នៅកន្លែងគេនៅស្ទឹងហាវ។ យើងនៅទីនោះ ៧ថ្ងៃមុននឹងគេបញ្ជូនយើងមកសហករណ៍។ [...]ឆ.៣០៦៖ គេមានផ្ទះឈើប្រក់ស័ង្កសីនៅទីនោះ មានបន្ទប់ ៦ ជាប់គ្នា នៅកកន្លែងរោងក្រឡឹង។ ស៖ តើមនុស្ស ទាំង៧ គូនោះ នៅទីនោះឬ? ឆ.៣០៧៖ ចាស គេឱ្យយើងស្នាក់នៅទីនោះ។"]។ ឯកសារ D114/53 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុក សុក ឆ.២៨៨, ៣០៩-៣១១ ["រៀបការរួច យើងនៅជាមួយគ្នាបាន ៣ថ្ងៃ [...]ស៖ កន្លែងសម្រាកជាផ្ទះ ឬអគារអ្វីដែរ? ឆ.៣០៩៖ ជាផ្ទះធម្មតា។ ស៖ ចុះលោកស្រីនៅផ្ទះយូរប៉ុណ្ណា? ឆ.៣១០៖ ៣យប់។ ស៖ លោកស្រីចង់នៅទីនោះទេ? ឆ.៣១១៖ អត់ទេ ក្រោយ ៣យប់នោះ យើងត្រឡប់ទៅសហករណ៍យើងវិញ។"]។ ឯកសារ D114/32 កំណត់ហេតុស្ដាប់ចម្លើយ មាស សារ៉ាន់ ឆ.៤០-៤២ [គូស្រកបានស្នាក់នៅបន្ទាប់ពីរៀបការរួចនៅក្នុងរោងកុនដែលមានបន្ទប់តូចៗ ឬផ្ទះល្វែងមួយចំនួន។]។

3388 ឯកសារ D114/103 កំណត់ហេតុស្ដាប់ចម្លើយ លៀត ឡុន ហៅ ណាំ ឡុន ឆ.១៨៧, ១៩០-១៩១ ["ក្រោយមក ពួកគេបានរៀបចំផ្ទះមួយឱ្យយើងនៅ ហើយគេឱ្យយើងនៅទីនោះ ៣ថ្ងៃ។ ខ្ញុំមិននៅទេ ខ្ញុំបានជិះម៉ូតូទៅកប៉ាល់វិញ។ ខ្ញុំមកដល់កប៉ាល់វិញ ញ៉ាន់ ឱ្យនីរសារទៅហៅខ្ញុំ។ ពេលខ្ញុំមកជួបគាត់ គាត់ដាក់កំហិតឱ្យខ្ញុំនៅផ្ទះនោះ មួយអាទិត្យ។ ខ្ញុំប្រាប់គាត់ថា ខ្ញុំនៅយ៉ាងម្ដេច បើខ្ញុំមានការងារដែលត្រូវធ្វើ។ គាត់ថា មានអ្នកជំនួសការងារនោះ។ ខ្ញុំនៅផ្ទះនោះ បានប្រហែល ១-២ថ្ងៃ ហើយខ្ញុំក៏ត្រឡប់ទៅកាន់កប៉ាល់ខ្ញុំវិញ។ [...]ស៖ តើផ្ទះដែលគេឱ្យនៅស្ថិតនៅកន្លែងណា? ឆ.១៩០៖ នៅផ្ទះល្វែងក្បែរផ្ទះតាម៉ុក។ ស៖ ពេលលោកនៅផ្ទះជាមួយប្រពន្ធរបស់លោកពីរថ្ងៃ តើមានរឿងអ្វីកើតឡើង? ឆ.១៩១៖ មិនមានរឿងអ្វីកើតឡើងទេ យើងគ្រាន់តែនិយាយគ្នាបន្តិចបន្តួចប៉ុណ្ណោះ។ ២ថ្ងៃក្រោយមក ខ្ញុំត្រឡប់ទៅកប៉ាល់ខ្ញុំ ហើយគាត់ត្រឡប់ទៅធ្វើស្រែកន្លែងគាត់វិញ។"]។ ឯកសារ D114/117 កំណត់ហេតុស្ដាប់ចម្លើយ ណាវ សុខន ហៅ កេន ឆ. ៣០៨, ៣១២ ["ស៖ តើគេមានឱ្យលោកស្រីគេងជាមួយប្ដីឬទេ? ឆ.៣០៨៖ គេឱ្យយើងដេកជាមួយគ្នា ព្រោះយើងរៀបការរួចហើយ។ [...]ស៖ តើលោកស្រីមានបានរួមដំណេកជាមួយប្ដីលោកស្រីទេ? ឆ.៣១២៖ ចាស គេងជាមួយគ្នា។"]។

3389 ឯកសារ D114/103 កំណត់ហេតុស្ដាប់ចម្លើយ លៀត ឡុន ហៅ ណាំ ឡុន ឆ.១៩២-១៩៣, ១៩៦-១៩៧ ["ស៖ តើពេលនោះ លោកបានរួមដំណេកជាមួយគាត់ទេ? ឆ. ១៩២៖ បាទ។ ស៖ ពេលនោះ ទាំងសងខាងស្ម័គ្រចិត្តទាំងសងខាងឬ? ឆ.១៩៣៖ បាទ។ ខាងខ្ញុំៗស្ម័គ្រចិត្ត តែខ្ញុំមិនដឹងថាខាងគាត់យ៉ាងម៉េចនោះទេ។ ប៉ុន្តែខ្ញុំត្រូវតែបង្ខំចិត្តធ្វើ ព្រោះខ្ញុំដឹងថា នៅពេលដែលគេឱ្យយើងនៅផ្ទះនេះ ១ អាទិត្យ មានន័យថា គេកំពុងតែតាមដានយើង។ [...]ស៖ គាត់រួមដំណេកហ្នឹង ដោយសារគាត់គិតថាមានគេតាមដានដែរ បានជាគាត់ព្រម? ឆ. ១៩៦៖ ខ្ញុំមិនដឹងថា គាត់ដឹងឬអត់នោះទេ ប៉ុន្តែខាងខ្ញុំៗដឹងថា មានគេតាមដាន។ ស៖ បើសិនជាលោកមិនព្រមរួមដំណេកជាមួយគាត់ តើពេលនោះ អាចមានរឿងអ្វីកើតឡើងចំពោះលោកទេ? ឆ.១៩៧៖ បើខ្ញុំបង់មិនទាន់នោះ ខ្ញុំប្រហែលជាត្រូវគេយកទៅសម្លាប់ ដោយសារ

841. អ្នកនៅក្រោមបង្គាប់របស់ **មាស មុត** ប្រើប្រាស់វិធានការមួយចំនួន ដើម្បីបង្ខំប្តីប្រពន្ធទើបរៀបការឱ្យដេកជាមួយគ្នា ដោយធ្វើឱ្យពួកគេជឿជាទូទៅថា ពួកគេនឹងត្រូវគេដាក់ទោស ចាប់ ឬសម្លាប់ ចំពោះ "ការជំទាស់នឹងអង្គការ" ប្រសិនបើពួកគេមិនដេកជាមួយគ្នា[3390]។ ក្នុងករណីខ្លះ អាជ្ញាធរ "អប់រំ" ឬប្រើពាក្យគំរាមកំហែងច្បាស់ៗដើម្បីបង្ខំប្តីប្រពន្ធទើបរៀបការឱ្យដេកជាមួយគ្នា ជាពិសេស ពេលទាហានបុរសរាយការណ៍ពីការបដិសេធរបស់ប្រពន្ធខ្លួនមិនព្រមដេកជាមួយ[3391]។ បន្ទាប់មក នារីភាគច្រើនបានរួមដំណេក ដោយខ្លាចគេដាក់ទោស[3392]។

---

គេចោទថា ក្បត់បក្ស។"]។ ឯកសារ D114/95 កំណត់ហេតុស្តាប់ចម្លើយ យឹម ស្រឿង ឆ.២៥៩-២៦២ ["ស៖ អម្បាញ់មិញលោកបាននិយាយថា គូខ្លះរៀបការទៅ អត់រស់នៅជាមួយគ្នាទេ តើពេលរៀបការហើយ មានគេលួចតាមដានមើល ថាពួកគេដេកនៅជាមួយគ្នាដែរ ឬក៏អត់ទេ? ឆ.២៥៩៖ ពេលរៀបហើយ គឺគេមានអ្នកតាមដានរបស់ពួកគេ ប៉ុន្តែខ្ញុំមិនបានដឹងអំពីរឿងនេះទេ។ ស៖តើលោកដឹងថា គេទៅតាមដានរកអ្វីដែរទេ? ឆ.២៦០៖ ទី១ គេចង់ដឹងថា តើអ្នកដែលរៀបការហើយ ពេញចិត្តគ្នា ឬក៏អត់។ ខ្ញុំឮគេនិយាយប្រាប់ថា ក្រោយពីការហើយ គឺមានអ្នកទៅលួចស្តាប់គូស្រករថ្មីនោះទៀតផង។ គេលួចស្តាប់ដូច្នេះ ព្រោះគេចង់ដឹងថា អ្នករៀបការនោះ រស់នៅចុះសម្រុងនឹងគ្នាឬទេ។ ហើយមួយទៀត គេខ្លាចថា អ្នកដែលមិនចុះសម្រុងជាមួយគ្នា អាចនឹងចងក សម្លាប់ខ្លួនជាដើម។ ស៖ តើគេទៅតាមដាននោះ ព្រោះគេចង់ដឹងថា អ្នកទើបរៀបការនោះ ដេកនៅជាមួយគ្នា ឬក៏អត់មែនទេ? ឆ.២៦១៖ បាទ។ [...]ឆ.២៦២ ៖ គេតាមដាន ព្រោះចង់ដឹងថា អ្នកទាំងនោះ ដេកនៅជាមួយគ្នា ឬទេ ប៉ុន្តែខ្ញុំក៏មិនយល់រឿងនេះដែរ។ អានេះ ជាគំនិតរបស់អ្នកដឹកនាំ ហើយខ្ញុំឆ្ងល់ខ្លួនឯងដែរ បើរៀបការនឹងគ្នាហើយ ហេតុអ្វីបានជាគេចាំបាច់តាមដានទៀត។"]។

3390 ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ.១៩៧-១៩៨, ២០០-២០១ ["ស៖ បើសិនជាលោកមិនព្រមរួមដំណេកជាមួយគាត់ តើពេលនោះ អាចមានរឿងអ្វីកើតឡើងចំពោះលោកទេ? ឆ.១៩៧៖ បើខ្ញុំបង់មិនទាន់នោះ ខ្ញុំប្រហែលជាត្រូវគេយកទៅសម្លាប់ ដោយសារគេចោទថា ក្បត់បក្ស។[...]ឆ.១៩៨៖ យើងត្រូវតែធ្វើតាមបញ្ជា គេឱ្យធ្វើអ្វី យើងត្រូវតែធ្វើតាមគេ។ [...]ស៖ ពេលនោះ តើលោកខ្លួនឯងមានបំណងចង់រួមដំណេកដែរឬទេ? ឆ.២០០៖ ខ្ញុំពុំមានអារម្មណ៍ចង់រួមភេទឡើយ។ ស៖ ហេតុអ្វីបានជាបក្សតម្រូវឱ្យលោករួមដំណេកក្រោយរៀបការហើយ? ឆ.២០១៖ ខ្ញុំមិនដឹងទេ វាគឺជាការរៀបចំ ខ្ញុំត្រូវធ្វើតាមបញ្ជាគេ។ បើខ្ញុំមិនធ្វើតាម ខ្ញុំប្រាកដជាមានរឿងមិនខាង។"]។

3391 ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន់ ឆ.៤៨, ៥០, ៥៣-៥៦ ["កាលពីរបីយប់ដំបូង ខ្ញុំចេះតែរត់ដែរ តែជាលទ្ធផល គេបានបញ្ជូនពួកខ្ញុំឱ្យទៅនៅផ្ទះឈើមួយជិតជើងភ្នំ ចម្ងាយប្រហែល ១គីឡូពីរោងកុន ដែលនៅទីនោះ មានមនុស្សបីបួននាក់រស់នៅទីនោះដែរ។ ស៖ ហេតុអ្វីបានជាគេដឹងថា លោកស្រីគេចមិនរួមដំណេកជាមួយប្តីលោកស្រី? ឆ.៤៩៖ ប្តីរបស់ខ្ញុំប្រាប់គេ។ [...]ឆ.៥០៖ ប្រហែលជាប្រាប់ប្រធានគាត់ហើយ បានគេគេដាក់ខ្ញុំទៅនៅកន្លែងថ្មី។ [...]ស៖ តើប្តីលោកស្រីព្យាយាមរួមដំណេកជាមួយលោកស្រីទៀតទេ? ឆ.៥៣៖ ចាស។ ស៖ តើលោកស្រីនៅតែបដិសេធដែរឬទេ? ឆ.៥៤៖ ខ្ញុំឈប់បដិសេធ ព្រោះមានគេមកប្រាប់ថា យើងបានប្តេជ្ញារួចហើយ យើងត្រូវតែធ្វើតាមការប្តេជ្ញាហ្នឹង។ ស៖ តើលោកស្រីគិតថា លោកស្រីគ្មានជម្រើសបដិសេធប្តីលោកស្រីទៀតទេ មែនទេ? ឆ.៥៥៖

842. បុរស និងនារីដែលជាជនរងគ្រោះនៃគោលនយោបាយរបស់ ប.ក.ក ស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅកំពង់សោម ជាទូទៅ ក៏ជាជនរងគ្រោះនៃការរំលោភសេពសន្ថវៈ ពីព្រោះពួកគេត្រូវបានគេបង្ខំឲ្យដេកជាមួយដោយគ្មានការព្រមព្រៀង។

*ង) របួសប៉ះទង្គិចផ្លូវកាយ និងផ្លូវចិត្តដែលជនរងគ្រោះទទួលរងនៅតំបន់កំពង់សោម*

843. ជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមដំណេកដោយបង្ខំ (ការរំលោភសេពសន្ថវៈ) នៅតំបន់កំពង់សោម ទទួលរងការប៉ះទង្គិចក្នុងទម្រង់ជាច្រើន។ ជនរងគ្រោះជាច្រើនរាយការណ៍ថាបានជួបវិបត្តិផ្លូវកាយ ពេលពួកគេបានដឹងថាពួកគេត្រូវបានបង្ខំឲ្យរៀបការជាមួយអ្នកដែលពួកគេមិនស្គាល់ ឬមិនស្រឡាញ់ និងពេលដែលពួកគេត្រូវដេកជាមួយអ្នកនោះ[3393]។ បច្ចុប្បន្ននេះ ជនរងគ្រោះខ្លះនៅតែពិបាកទទួលយកថា ពួកគេត្រូវបានបង្ខំឲ្យរៀបការនៅកំពង់សោម ហើយថែមទាំងបានព្យាយាមបិទបាំងរឿងនេះ[3394]។ ប្តីប្រពន្ធដែលត្រូវគេបង្ខំឲ្យរៀបការជាមួយគ្នាជាច្រើននាក់បានបែកបាក់គ្នា ឬលែងលះគ្នា ក្រោយឆ្នាំ ១៩៧៩[3395]។

---

ត្រឹមត្រូវហើយ។ សៈ តើប្តីលោកស្រីមានបង្ខំលោកស្រីដែរទេ? ឆ.៥៦៖ បើខ្ញុំមិនព្រមរួមដំណេក គេក៏ចាប់បង្ខំខ្ញុំដែរ។”]។

3392 ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ.២០០-២០១ [“សៈ ពេលនោះ តើលោកខ្លួនឯងមានបំណងចង់រួមដំណេកដែរឬទេ? ឆ.២០០៖ ខ្ញុំពុំមានអារម្មណ៍ចង់រួមភេទឡើយ។ សៈ ហេតុអ្វីបានជាបក្សតម្រូវឲ្យលោករួមដំណេកក្រោយរៀបការហើយ? ឆ.២០១៖ ខ្ញុំមិនដឹងទេ វាគឺជាការរៀបចំ ខ្ញុំត្រូវធ្វើតាមបញ្ជាគេ។ បើខ្ញុំមិនធ្វើតាម ខ្ញុំប្រាកដជាមានរឿងមិនខាង។”]។ ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន ហៅ កេន ឆ. ៣០៨ [“គេឲ្យយើងដេកជាមួយគ្នា ព្រោះយើងរៀបការរួចហើយ។”]។

3393 ជាឧទាហរណ៍ ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន់ ឆ.១១៣-១១៤ [“សៈ តើលោកស្រីនៅមានអារម្មណ៍ឈឺចាប់លើផ្លូវចិត្ត ឬផ្លូវអារម្មណ៍ដែរឬទេ ដែលបានឆ្លងកាត់របបខ្មែរក្រហម? ឆ.១១៣៖ ខ្ញុំនៅមានខ្លះដែរ។ […]ឆ.១១៤៖ នៅមានឈឺចាប់ដែលខ្ញុំមាននោះ គឺថា គេបញ្ជូនខ្ញុំមកឆ្ងាយ ហើយគេរៀបឲ្យខ្ញុំមានប្តីដោយម៉ែឪនិងបងប្អូនខ្ញុំមិនបានដឹង។”]។ ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ.៣, ៥ [“ខ្ញុំមិនពេញចិត្តនូវហេតុការណ៍ដែលខ្ញុំមិនបានដឹងខ្លួន។ […]ឆ.៥៖ ខ្ញុំភ្ញាក់ផ្អើលជាមួយនឹងរបៀបដែលគេរៀបចំនេះ។ ចាប់ពីពេលនេះ ខ្ញុំហាក់ដូចបាត់បង់ជំនឿពីរបៀបធ្វើការនៃរបបនោះ។”]។

3394 ណាវ សុខន ហៅ កេន ត្រូវបានកំណត់អត្តសញ្ញាណដោយ សេង អុល ជានារីម្នាក់ដែលត្រូវបានជ្រើសរើសក្នុងឃុំញ៉ែងញ៉ង ទៅរៀបការនៅកំពង់សោម៖ ឯកសារ D114/36.1.64 កំណត់ហេតុស្តាប់ចម្លើយ សេង អុល ឆ.២១ [“ខ្ញុំមិនចាំទាំងអស់ទេ ប៉ុន្តែខ្ញុំនៅចាំនារីម្នាក់ឈ្មោះ កេន នៅរស់បន្តែមិនដឹងនៅទីណា។”]។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ ណាវ សុខន បានបដិសេធយ៉ាងខ្លាំងមិនព្រមរៀបការទាល់តែសោះ ក្នុងខេត្តកំពង់សោម ដោយអះអាងថា គាត់

## ៥. សេចក្តីសន្និដ្ឋាន

844. ជនរងគ្រោះនៃគោលនយោបាយរបស់ ប.ក.ក ស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមដំណេកដោយបង្ខំ បានលះបង់តម្លៃខ្ពស់ ដើម្បីឲ្យរបបបន្តសម្រេចគោលដៅបដិវត្តរបស់ខ្លួន។ ជនរងគ្រោះជាច្រើននៅតែលះបង់តម្លៃខ្ពស់ នៅ ៤០ ឆ្នាំក្រោយទៀតដដែល។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ (ក្រោមទម្រង់ជាការរួមដំណេកដោយបង្ខំ) ប្រព្រឹត្តដោយកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ មានលក្ខណៈទូលំទូលាយ ជាប្រព័ន្ធ និងមានទម្ងន់ស្មើគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងៗទៀតដែលបានរៀបរាប់។

---

បានបដិសេធនឹងសំណើ ហើយអត់មានរឿងអីកើតឡើងចំពោះការបដិសេធរបស់គាត់នោះទេ។ ឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណារ សុខន ហៅ កេន ឆ. ២១៨-២២៨។ ទោះជាយ៉ាងណាក៏ដោយ គាត់បានសារភាពថាគាត់ត្រូវបានគេបង្ខំឲ្យរៀបការជាមួយ ស៊ុន ម៉ុត ជាមេដឹកនាំម្នាក់នៃកងពល ១៦៤ នៅស្ទឹងហាវ បន្ទាប់ពីគាត់ត្រូវបានដាក់ឲ្យឆ្លើយតទល់ជាមួយសាក្សីម្នាក់ទៀត។ សូមមើលឯកសារ D114/117 កំណត់ហេតុស្តាប់ចម្លើយ ណារ សុខន ហៅ កេន ឆ. ២៣៥-២៣៦, ២៤៨-៣៦៤។

[3395] ឯកសារ D114/53 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សុក ឆ.២៧៨ [“ខ្ញុំបានបែកជាមួយប្តីទី១របស់ខ្ញុំតាំងពីឆ្នាំ ១៩៧៩ ហើយយើងមិនដែលជួបគ្នាទៀតទេ។”]។ ឯកសារ D54/29 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ.៩ [“ខ្ញុំបានលែងលះគ្នានៅក្នុងឆ្នាំ ១៩៩១ ឬឆ្នាំ ១៩៩២។”]។ ឯកសារ D114/103 កំណត់ហេតុស្តាប់ចម្លើយ លៀត ឡូន ហៅ ណាំ ឡូន ឆ.២៤១។ ឯកសារ D114/304 កំណត់ហេតុស្តាប់ចម្លើយ វុន ប៊ុនណា ឆ. ១៤៧ [“ចាស រស់នៅរហូតដល់ឆ្នាំ ៨៩ ខ្ញុំចែកផ្លូវគ្នា។”]។ ឯកសារ D114/113 កំណត់ហេតុស្តាប់ចម្លើយ កឹម ម៉េន ឆ. ២២៦។ ឯកសារ D114/32 កំណត់ហេតុស្តាប់ចម្លើយ មាស សារ៉ាន់ ឆ.៩៦ [“មានខ្លះដែរ ប៉ុន្តែបន្ទាប់ពីសម័យខ្មែរក្រហមដួលរំលំ ទៅពួកគេបែកខ្ចាត់ខ្ចាយគ្នា។”]។

## ឈ. ការបោសសម្អាតកងពល ១១៧ និងតំបន់ ៥០៥[3396]

### ១. សេចក្តីផ្តើម

845. **មាស មុត** ត្រូវបានចាត់តាំងឱ្យទទួលបន្ទុកកងពល ១១៧ និងតំបន់ ៥០៥ នៅខេត្តក្រចេះ នៅចុង ខែ វិច្ឆិកា ឆ្នាំ ១៩៧៨ ដោយដាក់តំបន់ និងកងពលនៅក្រោមអំណាចរបស់គាត់ដែលកាន់តែរីកធំឡើង។ នៅពេលនោះ **មាស មុត** ត្រូវបានតែងតាំងរួចហើយជាអនុលេខាសេនាធិការ និងនៅតែមានតួនាទីជាលេខាកងពល ១៦៤ ដដែល។ ដំបូង គាត់បានអនុវត្តសេចក្តីសម្រេចរបស់មជ្ឈិមបក្សឱ្យចាប់ខ្លួនអតីតមេដឹកនាំកងពល និងតំបន់ ដោយរៀបចំការដឹកជញ្ជូនកម្មាភិបាលជាន់ខ្ពស់នៃកងពល ១១៧ និងតំបន់ ៥០៥ ទៅភ្នំពេញ ដែលនៅទីនោះពួកគេត្រូវបានចាប់ និងឃុំឃាំង នៅ

---

3396 ការិយាល័យសហចៅក្រមស៊ើបអង្កេតបានចោទប្រកាន់ មាស មុត ជាមួយនឹងឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តក្នុងអំឡុងពេលបោសសម្អាតកងពល ១១៧ (ឯកសារ D174 កំណត់ហេតុនៃការបង្ហាញខ្លួន ទំព័រ ៥ និង៨) ហើយទុកជាមោឃៈនៃការចោទប្រកាន់មុនៗ ដែលទាក់ទងទៅនឹងកម្មាភិបាលតំបន់ ៥០៥ (ឯកសារ D174 កំណត់ហេតុនៃការបង្ហាញខ្លួន ទំព័រ ១០)។ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ក្នុង កថាខណ្ឌ ៤៣, ៦៥-៦៦ សហព្រះរាជអាជ្ញាអន្តរជាតិ បានទទួលយល់ស្របតាម សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះរឿង បោសសម្អាតកងពល ១១៧ និង តាមរយៈឯកសារ D120 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម កថាខណ្ឌ ១២-១៤ គាត់បានអះអាងថា "ការបោសសម្អាតកម្មាភិបាលយោធាកងពល ១១៧ ហើយនិងកម្មាភិបាលស៊ីវិល តំបន់ ៥០៥ នៅក្នុងខេត្តក្រចេះ នៅចុងឆ្នាំ ១៩៧៨ [...] គឺរួមបញ្ចូលទាំងទំហំ ឧក្រិដ្ឋកម្មដែលត្រូវស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៣"។ តែយ៉ាងណាមិញ ការបោសសម្អាតកម្មាភិបាលតំបន់ ៥០៥ និងប្រជាជនស៊ីវិល ត្រូវបាន ភ្ជាប់មិនដាច់ទៅនឹងការបោសសម្អាតបុគ្គលិកយោធា កងពលធំ ១១៧ និងបង្កើតឱ្យមានកាលៈទេសៈនៃការបោសសម្អាតកងពលធំ ១១៧។ ដូចដែលបានរៀបរាប់ខាងក្រោម ទោះបីជា ខ្លួនក្លាយជាប្រជាជនស៊ីវិលទៅហើយក្តី ក៏កម្មាភិបាលជាន់ខ្ពស់ក្នុងតំបន់ ៥០៥ ត្រូវបោសសម្អាតនៅចុងឆ្នាំ ១៩៧៨ រួមទាំងលេខាតំបន់ មាស មឿន លេខាស្រុកក្រចេះ ហួន យ៉េង និងលេខាស្រុកស្នួលឈុំ ជិន ហៅ ភាន់ ជាកម្មាភិបាលកងទ័ពបដិវត្តកម្ពុជា ខ្លះទៀតមកពីកងពល ១១៧ខ្លួនឯង ហើយម្នាក់ៗពាក់ព័ន្ធនឹងការប្រយុទ្ធនៅតាមព្រំដែនជាមួយវៀតណាមជាកម្មាភិបាលយោធាកងពល ១១៧។បន្ថែមលើនេះ ការចាប់ខ្លួនមេបញ្ជាការកងពល ១១៧ និងកម្មាភិបាលតំបន់ ៥០៥ និងប្រជាជនស៊ីវិល កើតឡើងដំណាលគ្នា ជម្រុញ ដោយការយល់ឃើញថាមានអំពើក្បត់កើតឡើង បន្ទាប់ពីបរាជ័យ យោធាប្រឆាំងនឹងវៀតណាម។ អ្នកចាប់ខ្លួនត្រូវបាននាំទៅស-២១ រួមគ្នា ហើយកិច្ចប្រជុំដែលត្រូវបានកោះហៅដោយ មាស មុត ទាំងកម្មាភិបាលយោធា និងស៊ីវិល ក្នុងខណៈពេលបោសសម្អាតកំពុងដំណើរការ ។ សូមមើលការពាក់ព័ន្ធនេះ ឯកសារ D165/2/26 សេចក្តីសម្រេចដែលទាក់ទងទៅនឹង (១) បណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចលើសំណើប្រាំបួន ដែលស្នើសុំលុបចោលកិច្ចស៊ើបសួរ និង (២) សំណើសុំចំនួន ២ ដែលត្រូវបានបញ្ជូនដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០១៦ ទស្សនៈរបស់ចៅក្រម Beauvallet និង Baik នៅកថាខណ្ឌ ១៦៨-១៦៩។

ស-២១។ បន្ទាប់មក **មាស មុត** បានជំនួសកម្មាភិបាលដែលត្រូវបានបោសសម្អាតទាំងនោះ ដោយជ្រើសតាំងមេបញ្ជាការកវរសេនាធំនៃកងពល ១៦៤ របស់ខ្លួន ជាលេខាកងពល ១១៧ និងតំបន់ ៥០៥ និងដាក់កម្មាភិបាលមកពីភូមិភាគនិរតីក្នុងមុខតំណែងខ្ពស់ ក្រោមការគ្រប់គ្រងរបស់គាត់។ ដើម្បីសម្គាល់ពីការត្រួតត្រារបស់កងពល ១៦៤ **មាស មុត** ក៏បានឲ្យកងទ័ពកងពល ១៦៤ ឈរជើងនៅតំបន់ ៥០៥ ដើម្បីឃ្លាំមើលការប្រយុទ្ធគ្នានៅព្រំដែនផងដែរ។

846. ពេល **មាស មុត** បានបង្កើតអំណាចពេញលេញត្រួតត្រាលើតំបន់ និងកងពលរួច កងកម្លាំងរបស់គាត់បានបន្តធ្វើការបោសសម្អាតអ្នកមានឋានៈទាប រួមមាន ប្រធានឃុំក្នុងតំបន់ ៥០៥ ជនស៊ីវិល និងទាហានមានឋានន្តរសក្តិទាបនៃកងពល ១១៧ ពេញមួយខែ ធ្នូ ឆ្នាំ ១៩៧៨។ **មាស មុត** បានចេញបញ្ជាផ្ទាល់ឲ្យសម្លាប់យ៉ាងហោចណាស់កម្មាភិបាលតំបន់ ៥០៥ ម្នាក់ភ្លាមៗ។ ការបោសសម្អាតត្រូវបានផ្អាក តែដោយមានការឈ្លានពានរបស់វៀតណាមនៅចុងឆ្នាំ ១៩៧៨ ប៉ុណ្ណោះ ដែលធ្វើឲ្យការគ្រប់គ្រងរបស់ខ្មែរក្រហមដួលរលំ។

847. ការបោសសម្អាតនេះជាការប៉ុនប៉ងមានលក្ខណៈបំផ្លិចបំផ្លាញ និងដ៏សាហាវចុងក្រោយរបស់ថ្នាក់ដឹកនាំ ប.ក.ក ដើម្បីសម្អាតជួរអ្នកដែលពួកគេសង្ស័យថាគ្មានភាពស្មោះត្រង់ផ្នែកនយោបាយចំពោះរបបខ្មែរក្រហម។ ក្រោយពីបរាជ័យជាច្រើនលើកក្រោមដៃកងទ័ពវៀតណាមនៅចុងឆ្នាំ ១៩៧៨ ថ្នាក់ដឹកនាំ ប.ក.ក បានដឹងពីអំពើក្បត់ជាថ្មីម្តងទៀត ដោយសន្មតថាកម្មាភិបាលកងពល ១១៧ និងតំបន់ ៥០៥ ជាប់ពិរុទ្ធពីបទឃុបឃិត ឬចូលដៃជាមួយវៀតណាម ដែលតាំងខ្លួនថាជា "យួនលេបទឹកដី"[3397]។ ដូចការបោសសម្អាតនៅក្រចេះ និងភូមិភាគបូព៌ាកាលពីលើកមុនដែរ ជនរងគ្រោះភាគច្រើនដែលត្រូវគេចោទប្រកាន់ ថាបានសមគំនិតជាមួយបរទេស ដើម្បីផ្តួលរំលំរបប ជាអ្នកដែលប្រយុទ្ធដើម្បីការពារព្រំដែនកម្ពុជាប្រជាធិបតេយ្យប្រឆាំងការលុកលុយរបស់វៀតណាម។

848. មេដឹកនាំ ប.ក.ក[3398] រួមទាំងមេបញ្ជាការសេនាធិការ និងកងពលនៃកងទ័ពបដិវត្តកម្ពុជា[3399] និង **មាស មុត**[3400] មានគោលដៅតែមួយក្នុងការអនុវត្តផែនការឧក្រិដ្ឋរួមដែលមានជាយូរមកហើយ

---

3397 ឯកសារ D4.1.177 របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ធ្វើការជាមួយគណៈកម្មាធិការគ្រប់អង្គភាព ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៧៧ KH ERN 00086707 [ពិភាក្សា "កម្ទេច" និង "បោសសម្អាត" ខ្មាំងដែលជា "ស៊ីអាយអេ, កាសេបេ និងយួនលេបទឹកដី"]។

3398 សូមមើល VII. គោលការណ៍បក្សកុម្មុយនីស្តកម្ពុជាទាក់ទងនឹងសំណុំរឿងប្រឆាំងនឹងមាស មុត - ការលុបបំបាត់ទាសភាព និងការប្រឆាំងនឹងការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា។

ដើម្បីបោសសម្អាត (ចាប់ ឃុំ និងជាទូទៅ សម្លាប់ ដោយគ្មាននីតិវិធីតុលាការ) កម្មាភិបាលដែលត្រូវគេសង្ស័យថាមានភាពមិនស្មោះត្រង់ផ្នែកនយោបាយ។ នៅពេលដែលគាត់ត្រូវបានចាត់តាំងឲ្យទទួលការងារនៅក្រចេះ ភក្តីភាពរបស់ **មាស មុត** ចំពោះគោលនយោបាយឧក្រិដ្ឋរបស់ថ្នាក់ដឹកនាំ និងការរួមចំណែករបស់គាត់ក្នុងការអនុវត្តផែនការនេះ នៅកំពង់សោម ធ្វើឲ្យគាត់ទទួលបានគោរព និងទំនុកចិត្តពី ប៉ុល ពត និងមេដឹកនាំខ្ពស់បំផុតនៃ ប.ក.ក។

849. ក្នុងនាមជាមេបញ្ជាការចុងក្រោយនៃយោធាកងពល ១១៧ និងតំបន់ ៥០៥ **មាស មុត** ក៏ទទួលខុសត្រូវផងដែរលើការបញ្ជូនមនុស្សប្រាំមួយនាក់ដែលគេសន្មតថាជា "គិញ" វៀតណាម ទៅ ស-២១ នៅថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៧៨ ស្របតាមយុទ្ធនាការថ្នាក់ជាតិរបស់ខ្មែរក្រហមស្តីពីការប្រល័យពូជសាសន៍វៀតណាម[3401]។ **មាស មុត** បានអនុវត្តអំពើប្រល័យពូជសាសន៍ដោយរីករាយ និងបំពេញការងារ ដើម្បីកម្ទេចក្រុមជនជាតិវៀតណាមនៅក្រចេះ ដូចដែលគាត់បានធ្វើចំពោះជនជាតិវៀតណាមដែលត្រូវបានចាប់នៅក្នុងដែនទឹក និងនៅលើកោះកម្ពុជា[3402]។

---

3399 សូមមើល VII. គោលការណ៍បក្សកុម្មុយនីស្តកម្ពុជាទាក់ទងនឹងសំណុំរឿងប្រឆាំងនឹងមាស មុត - ការលុបបំបាត់ទាសភាព និងការប្រឆាំងនឹងការដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា។ III.3. ការរួមចំណែករបស់ មាស មុត ចំពោះឧក្រិដ្ឋកម្ម - ការចូលរួមក្នុងការធ្វើទុក្ខបុកម្នេញ និងការធ្វើសកម្មភាពរបស់ខ្មាំង - កងទ័ពបដិវត្តកម្ពុជា - ក) កងវរៈសេនាធំ និងកងពលមជ្ឈិមនៃកងទ័ពបដិវត្តកម្ពុជា។ XIII.B. របៀបនៃការទទួលខុសត្រូវ – ១. ប្រព្រឹត្តតាមសហឧក្រិដ្ឋកម្មរួម។

3400 សូមមើល III.3. ការរួមចំណែករបស់ មាស មុត ចំពោះឧក្រិដ្ឋកម្ម - ការចូលរួមក្នុងការធ្វើទុក្ខបុកម្នេញ និងការធ្វើសកម្មភាពរបស់ខ្មាំង - កងទ័ពបដិវត្តកម្ពុជា - ក) កងវរៈសេនាធំ និងកងពលមជ្ឈិមនៃកងទ័ពបដិវត្តកម្ពុជា។ III.3. ការរួមចំណែករបស់ មាស មុត ចំពោះឧក្រិដ្ឋកម្ម - ការចូលរួមក្នុងការធ្វើទុក្ខបុកម្នេញ និងការធ្វើសកម្មភាពរបស់ខ្មាំង - កងទ័ពបដិវត្តកម្ពុជា - ខ) កងពល ១៦៤។ VIII.A. ការបោសសម្អាតនៅក្នុងកងពល ១៦៤ – ១. គោលការណ៍កងទ័ពបដិវត្តកម្ពុជា/បក្សកុម្មុយនីស្តកម្ពុជា ដើម្បីបោសសម្អាតខ្មាំងផ្ទៃក្នុង និង ចេតនារបស់ មាស មុត ក្នុងកាបោសសម្អាតឋានៈនៅក្នុងកងពល ១៦៤។

3401 អាន VIII.G. អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម

3402 អាន VIII.G. អំពើប្រល័យពូជសាសន៍លើជនជាតិវៀតណាម។ III.3. ការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម--ចំពោះជនជាតិវៀតណាម។

## ២. រចនាសម្ព័ន្ធអំណាច

### តំបន់ ៥០៥ (ខេត្តក្រចេះ)

850. ខេត្តក្រចេះស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា[3403] ហើយមានព្រំដែនសំខាន់ជាយុទ្ធសាស្ត្រជាប់ប្រទេសវៀតណាមក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ពីដំបូង ខេត្តក្រចេះស្ថិតនៅភូមិភាគឦសាន ប៉ុន្តែ នៅចុងឆ្នាំ ១៩៧៦ និងដើមឆ្នាំ ១៩៧៧ ខេត្តនេះបានក្លាយជាតំបន់ស្វយ័ត ៥០៥[3404]។ តំបន់ ៥០៥ មានបីស្រុក៖ ស្រុកក្រចេះ ស្រុកស្នួល និងស្រុកសំបូរ[3405]។ ស្រុកផ្លូងស្ថិតនៅក្នុងខេត្តក្រចេះ

---

[3403] ឯកសារ D4.1.376 ផែនទី "កម្ពុជាប្រជាធិបតេយ្យ", EN 00295143, KH 00193066, FR 00295144។

[3404] ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វេត (អនុប្រធានមន្ទីរកងពល១១៧), ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 11.17.50-11.20.03, 13.32.49-13.34.27 ["[នៅឆ្នាំ១៩៧៧] ក្រចេះហ្នឹង កាត់ចេញពីភូមិភាគឦសានទៀតទេ ទៅជាតំបន់មជ្ឈិមគ្រប់គ្រង។ [...] ក្រោយពីពួកខ្ញុំទៅនេះ គឺកាត់ចូលជាតំបន់ស្វយ័ត បានន័យថាតំបន់ដែលអត់ចំណុះឲ្យភូមិភាគឦសានទៀតទេ។"]។ ឯកសារ D98/3.1.316 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង សាក្សី យុន គីម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ នៅម៉ោង 10.16.15-10.18.53 ["ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំក្តាប់បានតាមរយៈស្រុកសំបូរ គេបានប្រាប់ខ្ញុំថា តំបន់យើងនេះ គឺជាតំបន់ស្វយ័តនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ថ្នាក់មជ្ឈិម។ ហើយពីមុនតាមខ្ញុំដឹងថានៅក្នុងភូមិភាគឦសាន ពីព្រោះដល់មកក្រោយមកទៀតទេបានថា បំបែក ផ្តាច់ចេញពីភូមិភាគឦសាន ទៅជាតំបន់ស្វយ័ត។ [...] ខ្ញុំក្តាប់អត់បានដែរ បើសិនជាតាមខ្ញុំស្មានប្រហែលជាឆ្នាំ១៩៧៧ ហើយយ៉ាង ទៅជាតំបន់ស្វយ័ត ចុង៧៦ ដើម៧៧មក។ នេះការស្មានទេព្រោះខ្ញុំអត់ច្បាស់។"]។ ឯកសារ D59/2/4.16a កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី សេង សឿន EN 00753819, KH ERN 00059312 [បញ្ជាក់ថាក្រចេះស្ថិតនៅក្នុងភូមិភាគឦសានរហូតដល់ឆ្នាំ១៩៧៧។ ហើយក្រោយមកទៀតវាក៏ក្លាយជាតំបន់ស្វយ័តវិញ]។ អានបន្ថែម ឯកសារ D234/2.1.98 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ចុះថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 09.38.35-09.41.25, KH 01454729-30 ["ខ្ញុំបាទរស់នៅតំបន់៥០៥។ តំបន់៥០៥ ហ្នឹងគឺនៅខេត្តក្រចេះហ្នឹងជាតំបន់ស្វយ័ត។ តំបន់ស្វយ័ត ហ្នឹងមិនស្ថិតនៅក្រោមការដឹកនាំរបស់ភូមិភាគទេ។"]។ ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 14.01.14-14.03.54, KH 01355203 ["ស៖ ពាក់ព័ន្ធទៅនឹងស្ថានភាពរបស់ខេត្តក្រចេះ គឺតំបន់៥០៥ តោះតំបន់ក្រចេះដែលហៅថាតំបន់៥០៥ ជាផ្នែកនៃភូមិភាគនៅពេលនោះ ឬក៏ជាតំបន់ស្វយ័ត? ឆ៖ តាមខ្ញុំដឹងគេហៅថា តំបន់ស្វយ័ត អត់មាននៅក្នុភូមិភាគណាគ្រប់គ្រងទេ។"]។

[3405] ឯកសារ D98/3.1.124 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង សាក្សី យុន គីម ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ នៅម៉ោង 14.08.55-14.10.03, KH 00818700 ["ខេត្តក្រចេះ

មុនពេលខ្មែរក្រហមកាន់កាប់តំបន់នោះ ហើយសព្វថ្ងៃ ក៏ស្ថិតនៅក្នុងខេត្តក្រចេះដែរ ប៉ុន្តែពេលតំបន់ ៥០៥ ត្រូវបានបង្កើតឡើង ស្រុកឆ្លូងត្រូវបានកាត់ចូលទៅក្នុងភូមិភាគបូព៌ា[3406]។ នៅចុងឆ្នាំ ១៩៧៨ ក្រោយពីការបោសសម្អាតភូមិភាគបូព៌ា ស្រុកឆ្លូងត្រូវបានដាក់បញ្ចូលទៅក្នុងតំបន់ ៥០៥ វិញ[3407]។

---

អង្កាល់នោះគឺមានតែបីស្រុកទេ គឺស្រុកស្នួល ស្រុកក្រចេះ និងស្រុកសំបូរ"]។ ឯកសារ D98/3.1.315 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យុន គីម, EN 00345193, KH 00340152, FR 00404179 ["តំបន់នេះគេហៅតំបន់-៥០៥ ស្ថិតនៅក្នុងភូមិភាគឦសាន មានស្រុកបី៖ ស្រុកសំបូរ ស្រុកស្នួល និងស្រុកក្រចេះ។"]។

3406 ឯកសារ D98/3.1.124 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង សាក្សី យុន គីម ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ នៅម៉ោង 14.08.55-14.10.03, KH 00818700 ["ខេត្តក្រចេះអង្កាល់នោះគឺមានតែបីស្រុកទេ គឺមានស្រុកស្នួល ស្រុកក្រចេះ និងស្រុកសំបូរ ឯស្រុកឆ្លូងគេកាត់ទៅខាងភូមិភាគបូព៌ា"]។ ឯកសារ D4.1.1047 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន សារិទ្ធ ឆ.៩ KH 00486445 ["[នៅពាក់កណ្តាលឆ្នាំ១៩៧៥] ក្រុមរបស់ខ្ញុំបានធ្វើដំណើរទៅកាន់ស្រុកឆ្លូង តំបន់២១ នៃភូមិភាគបូព៌ា"]។ ឯកសារ D234/2.1.123 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ សាក្សី មាស សឿន ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ ម៉ោង09.53.36-09.56.54 KH 01329989 [ផ្តល់សក្ខីកម្មថា នៅដើមទសវត្សឆ្នាំ១៩៧០ ឪពុកគាត់ [ឈ្មោះ មាស សេងហុង ហៅ ចាន់] ធ្វើជាអភិបាលស្រុកឆ្លូង ក្នុងតំបន់២១ នៃភូមិភាគបូព៌ា], ម៉ោង 13.38.18-13.42.01 KH 01330014-15 [បញ្ជាក់ពីឈ្មោះប្រធានស្រុកទាំងអស់នៃតំបន់ ២១ ក្នុងនោះក៏មានបញ្ជាក់ពីឈ្មោះប្រធានស្រុកឆ្លូង នៅក្នុងអំឡុងឆ្នាំ១៩៧៧ផងដែរ]។ ឯកសារ D64.1.8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ៅ ភួក ធ្វើការនៅក្នុងផ្នែកឈ្លើយសឹក/យុទ្ធជនបាត់ខ្លួនក្នុងសង្គ្រាមរបស់សហរដ្ឋអាមេរិក បញ្ជាក់ថា៖ ["តំបន់២១ រួមមានស្រុក [...] ស្រុកឆ្លូងនៃខេត្តក្រចេះ"]។ សូមអាន ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ៦៨៥៤ ["ពេន ឆេ (ឆោម សាវ៉ាត) ហៅ ឆោម សាវ៉ាត់ ជាលេខាស្រុកឆ្លូង និងជាសមាជិកតំបន់២១ (លេខាស្រុកឆ្លូង និងជាសមាជិកតំបន់២១ ពីមុនជាសមាជិកស្រុកក្រូចឆ្មារ តំបន់២២) នៃភូមិភាគបូព៌ា។ ចូលថ្ងៃទី ០៨ ខែ មិថុនា ៧៧ ឬ ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ៧៧"]។

3407 ឯកសារ D4.1.810 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.៣៣ KH 00402510 [គាត់ជាប្រធានមន្ទីរតំបន់៥០៥ ទើបតែមកដល់ក្នុងខែធ្នូ ឆ្នាំ១៩៧៨ បញ្ជាក់ថា៖ "នៅខេត្តក្រចេះមានស្រុកបួន ដូចជាស្រុកក្រចេះ ស្រុកសំបូរ ស្រុកស្នួល និងស្រុកឆ្លូង [...] និងឆ.៥៨ KH 00402514A58 [...] ហាន គឺជាគណៈស្រុកឆ្លូង។"]។ ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 13.51.55-13.57.43, KH 01355200-01។ ឯកសារ D59/2/4.16a កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី សេង សឿន EN 00753840-41, KH 00039332-34។ ឯកសារ D98/3.1.262, KH 00417005 រចនាសម្ព័ន្ធតំបន់ ៥០៥ ដែលគូសដោយ សាក្សី សេង សឿន ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ២០០៩។ ឯកសារ D64.1.37 សារព័ត៌មាន FBIS ស្រង់ការផ្សាយសម្តែងរបស់បក្សកុម្មុយនិស្ត ស្តីពីរបាយការណ៍នៃការងើបបះបោរនៅក្នុងខេត្តក្រចេះ និងខេត្តព្រៃវែង ចេញផ្សាយនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៨ EN 00169080 [ដែលសំដៅទៅ "ស្រុកឆ្លូង នៃខេត្តក្រចេះ"]។ ឯក

851. អនុលោមតាមរចនាសម្ព័ន្ធឋានានុក្រម និងវិន័យចាត់តាំងដ៏រឹងមាំរបស់ ប.ក.ក[3408] តំបន់ ៥០៥ ក៏ដូចជាភូមិភាគ និងតំបន់ស្វយ័តដទៃទៀតដែរ[3409] បានរាយការណ៍ផ្ទាល់ទៅមជ្ឈិមបក្ស[3410] រួមទាំង

---

សារ D114/171 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កែវ សារួន ឆ.៥៤ KH ERN 01204180 [ជាប្រពន្ធរបស់ ហួន យ៉េង ដែលជាលេខាស្រុកក្រចេះ បន្តទៀតថា៖ "រ៉េង [...] ប្រពន្ធគណៈស្រុកឆ្លូង" សាក្សីបានប្រាប់ឱ្យដឹងថាក្នុងចំណោមប្រពន្ធរបស់កម្មាភិបាលតំបន់៥០៥ ដែលគាត់បានរៀបរាប់នោះបានបាត់ខ្លួននៅចុងឆ្នាំ១៩៧៨អស់ទៅ]។ ដូចដែលបានពន្យល់បន្ថែមនៅក្នុងឯកសារ D257/1/4 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងពាក្យសុំមោឃភាពកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សីដែលត្រូវបានចោទប្រកាន់ថាបានមកពីការធ្វើទារុណកម្ម ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១៧ កថាខណ្ឌ ១៣-១៤, KH ERN 01537474-76 និងកថាខណ្ឌ ១៨, KH ERN 01537479-80, សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បញ្ចូលនូវការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដើម្បី "បដិសេធចោល"នូវ ឆ.46-68 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កែវ សារួន (ឯកសារ D251, កថាខណ្ឌ ៥៩, KH ERN 01490705) ក្រោមហេតុផលជាកំហុសនៃអង្គហេតុ និងកំហុសផ្នែកច្បាប់។

3408 ឯកសារ D1.3.22.1 លក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា ចេញផ្សាយខែមករា ឆ្នាំ ១៩៧៦ EN 00184025, KH ERN 00053011, FR 00292917 ["បក្សមានអង្គការវិន័យតែមួយគត់"], មាត្រា ២ (២) (ខ), EN 00184031-32, KH ERN 00053016-18, FR 00292921-22 ["បក្សជនគ្រប់រូបសុទ្ធតែមានភារកិច្ច ដូចតទៅ [...] ភារកិច្ចផ្ទៃក្នុង [...] ខ. គោរពអង្គការវិន័យរបស់បក្សដោយគ្មានលក្ខណ្ឌ និងដោយភ្ញាក់រលឹកខ្ពស់។"], មាត្រា ៥(១), EN 00184033, KH ERN 00053018-19, FR 00292923 ["បក្សជនម្នាក់ៗទោះជាមាននាទីជាអ្វីក៏ដោយ ត្រូវគោរព ប្រតិបត្តិតាមវិន័យរបស់បក្សជាដាច់ខាត។ គោរពវិន័យ និងគោរពអង្គការ របស់បក្សនេះគឺគោរពមាគ៌ានយោបាយរបស់បក្ស គោរពសតិអារម្មណ៍របស់បក្ស គោលជំហរចាត់តាំង និងលក្ខន្តិកៈរបស់បក្ស។"]។

3409 ឯកសារ D98/1.2.46 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង សាក្សី នង សុផង់ ចុះថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០១២ ម៉ោង 09.42.01-09.47.02 KH ERN 00844462-63 ["ឯភូមិភាគផ្សេងៗក៏គេរៀបចំដូចគ្នាអ៊ីចឹងដ អ្នកណាក៏គ្មានសិទ្ធិឡើងគ្រង់មកទេ លើកលែងតែតំបន់ស្វយ័ត [...] គឺជាតំបន់មួយឯករាជ្យដែលមិនស្ថិតនៅក្រោមឱវាទរបស់គណៈភូមិភាគទេ។"]។ ឯកសារ D4.1.611 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី នង សុផង់, EN 00334052, KH ERN 00328034, FR 00411702 ["ដំបូងសារទូរលេខមកពីភូមិភាគនានា និងតំបន់ស្វយ័តមួយចំនួន"]។ ឯកសារ D98/3.1.114 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង សាក្សី ផាន វ៉ាន់ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១២ ម៉ោង 11.45.15-11.53.35 KH ERN 00869089-90 [បញ្ជាក់ថាតំបន់១០៥ ជាតំបន់ស្វយ័ត ហើយរាយការណ៍ជូនមន្ទីរ៨៧០]។ អានឯកសារ D98/1.2.38 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង អ្នកជំនាញ ដេវីដ ឆេនដ៍ល័រ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ ម៉ោង 13.41.17-13.43.18 KH ERN 00825999 ["វាមានលក្ខណៈជាពីរ៉ាមីត គឺថាក្រុមមួយៗយោងទៅថ្នាក់លើ ហើយក្នុងថ្នាក់លើហ្នឹងកាន់តែតូច កំពូល។ នោះហើយគឺជាៗកម្លាំងធំបំផុតរបស់អង្គការរបស់គេនោះ។ ដូចដែលខ្ញុំ គឺថាសំណើគឺមិនជាទូទៅ មិនពីក្រោមទៅលើទេ គឺភាគច្រើនពីលើមកក្រោម"]។

[3410] ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ម៉ោង 14.01.14-14.03.54, KH ERN 01355203 ["ស៖ តើលក្ខណៈសំខាន់នៃតំបន់ស្វយ័តហ្នឹងដូចម្តេច? ថាតើគណៈតំបន់ស្វយ័តហ្នឹងរាយការណ៍ទៅណាពីខេត្តក្រចេះមកនោះ? ឆ៖ [...] របាយការណ៍ចេញពីតំបន់ទៅៗមជ្ឈិមបក្ស"]។ ឯកសារ D4.1.810 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.៤៩ និង ឆ. ៥៤ KH ERN 00402513 [តំបន់៥០៥ "ផ្តល់ព័ត៌មានដល់គណៈកម្មាធិការមជ្ឈិមប្រចាំខែស្ថានភាពផ្សេងៗ" ដូចជា "ស្ថានភាពខ្មាំង ស្ថានភាពផលិតផល និងស្ថានភាពប្រជាជនទូទៅ [...] ឆ.៥៤៖ ខ្ញុំគិតថា តំបន់មានភារកិច្ចប្រជុំប្រចាំខែជាមួយនឹងការិយាល័យ៨៧០ ជាមួយនឹងទីក្រុងភ្នំពេញ ប៉ុន្តែរបាយការណ៍ត្រូវគេរក្សាទុកនៅថ្នាក់តំបន់។ ចំពោះតំបន់ស្វយ័ត ដូចជាខេត្តក្រចេះ កិច្ចប្រជុំអាចធ្វើឡើងជាមយយនឹងការិយាល័យ៨៧០"]។ ឯកសារ D98/1.2.20 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង សាក្សី កាំង ហ្កេកអ៊ាវ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ម៉ោង 10.06.39-10.08.53 KH ERN 00794530 ["ស៖ តើលោកដឹងដែរឬទេថា តើមានតំបន់ឯករាជ្យណាខ្លះដែលគេបង្កើតឡើងនៅក្នុងរបបនុ៎ង? [...] ឆ៖ ខ្ញុំមិន--ខ្ញុំចាំ [...] គឺឡើងមកលេខា និងអនុលេខាមជ្ឈិមផ្ទាល់។ ដូចជាខាងក្រចេះ ៥០៥"]។ ឯកសារ D98/3.1.316 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង សាក្សី យុន គីម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ នៅម៉ោង 10.16.15-10.18.53, KH ERN 00818234-35 ["ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំក្តាប់បានតាមរយៈស្រុកសំបូរ គេបានប្រាប់ខ្ញុំថាតំបន់យើងនេះ គឺជាតំបន់ស្វយ័តនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ថ្នាក់មជ្ឈិម។ [...] តាមខ្ញុំគិតថា តំបន់--បាទនៅក្នុងភូមិភាគ តំបន់ហ្នឹងត្រូវ រាល់ការងារត្រូវទាក់ទងជាមួយភូមិភាគផ្ទាល់។ ឯតំបន់ស្វយ័តគឺទាក់ទងជាមួយនឹងមជ្ឈិមផ្ទាល់ ជាមួយថ្នាក់លើ។ ឡើងមកភ្នំពេញតែម្តងមិនបាច់ចាំទៅភូមិភាគទេ។"]។ ឯកសារ D114/101 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន ឆ.៣០ KH ERN 01127710 និង ឆ. ៣៥-៤៣ KH ERN 01127711-12 និង ឯកសារ D114/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន ឆ.៣៩-៤០ KH ERN 01127733 និង ឆ. ៤២ KH ERN 01127734 [រៀបរាប់ពីការទាក់ទងគ្នារវាងមន្ទីរតំបន់៥០៥ ជាមួយមន្ទីរ៨៧០]។ មានសារទូរលេខនៅសេសសល់បញ្ជាក់ថាមេដឹកនាំតំបន់៥០៥រាយការណ៍ផ្ទាល់ទៅមន្ទីរ៨៧០។ អាន ឯកសារ D4.1.1036, D4.1.704 ទូរលេខពី យី (ប៊ិន ណន) ទៅមន្ទីរ៨៧០ នៅថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ១៩៧៧។ ឯកសារ D4.1.733 ទូរលេខពី យី (ប៊ិន ណន) ទៅមន្ទីរ៨៧០ នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៧, KH ERN 00021508។ ឯកសារ D4.1.655 ទូរលេខពី យី (ប៊ិន ណន) ទៅមន្ទីរ៨៧០ នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៧៧, EN 00143091។ ឯកសារ D4.1.301 ទូរលេខពី យី (ប៊ិន ណន) ទៅមន្ទីរ៨៧០ នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៧៧។ សូមអាន ឯកសារ D4.1.295 ទូរលេខពី គួន (សាន់ ប៊ុនហ៊ី) ទៅ យី (ប៊ិន ណន) តាមរយៈមន្ទីរ៨៧០ នៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧។ ឯកសារ D1.3.34.50 ទូរលេខពី គួន (សាន់ ប៊ុនហ៊ី) ទៅ យី (ប៊ិន ណន) តាមរយៈមន្ទីរ៨៧០ នៅថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៧៧។ ឯកសារ D4.1.302 ទូរលេខពី គួន (សាន់ ប៊ុនហ៊ី) ទៅ យី (ប៊ិន ណន) តាមរយៈមន្ទីរ៨៧០ នៅថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៧៧។

សុន សេន នាយសេនាធិការ[3411]។ ថ្នាក់ដឹកនាំតំបន់រាយការណ៍អំពី "សភាពការណ៍ផ្សេងៗ ជាប្រចាំខែ" រួមទាំង "សភាពការណ៍ខ្មាំង [...] និងស្ថានភាពប្រជាជនជាទូទៅ" ក៏ដូចជាប្រតិបត្តិការរបស់យោធាតំបន់[3412]។ ថ្នាក់ដឹកនាំតំបន់ក៏ជួបប្រជុំប្រចាំខែ ជាមួយមជ្ឈិមបក្ស នៅទីក្រុងភ្នំពេញផងដែរ[3413]។ តំបន់ទទួលសេចក្ដីណែនាំពីមន្ទីរ ៨៧០[3414] រួមទាំង ការកោះហៅកម្មាភិបាលឱ្យទៅចូលរួមប្រជុំនៅទីក្រុងភ្នំពេញផងដែរ[3415]។

---

3411 ឯកសារ D4.1.1036, D4.1.655, D4.1.301, D4.1.295, D1.3.34.50, D4.1.302 ជាសារទូរលេខដែលសុទ្ធតែចម្លងជូន សុន សេន ហៅ ខៀវ ទាំងអស់។ សូមអាន ឯកសារ D114/29.1.6 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សៅ សារុន, EN 00350263, KH ERN 00345912, FR 00350263 ["ម.៨៧០ មានន័យថា ជាគណៈមជ្ឈិមក្នុងនោះមានតាមខ្ញុំចាំ ប៉ុល ពត, នួន ជា, ខៀវ សំផន, សុន សេន, និងតាម៉ុក។"]។ ឯកសារ D114/285 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រុំ សារ៉ាត់ (ប៊ុន សារ៉ាត់) ឆ. ១៩៩ KH ERN 01354327 [នៅចាំថា របាយនាមវិទ្យុទាក់ទងរបស់គាត់គឺ ៨៧០]។ អានបន្ថែម ឯកសារ D234/2.1.52 របាយការណ៍អ្នកជំនាញការ Craig C. Etcheson, EN 00142835, KH ERN 00314793, FR 00314649 ["ទូរលេខ និងការទំនាក់ទំនងជាលាយលក្ខណ៍អក្សរផ្សេងទៀត មានចរន្តឥតឈប់ឈរពីថ្នាក់ក្រោម ទៅមន្ទីរ៨៧០។ បន្ទាប់មកមន្ទីរ៨៧០ ផ្សព្វផ្សាយព័ត៌មានទៅកាន់សមាជិកគណៈអចិន្ត្រៃយ៍តាមលក្ខណៈសមស្រប។"]។ សម្រង់ ឯកសារ D1.3.27.1 កំណត់ហេតុកិច្ចប្រជុំអចិន្ត្រៃយ៍ បក្សកុម្មុយនិស្តកម្ពុជា ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៧៥, EN 00183395, KH ERN 00019111, FR 00292871 ["តាំងពីទូរលេខឡើងទៅពេលទទួលបានភ្លាម មន្ទីរត្រូវប្រគល់ឱ្យផ្នែកទទួលខុសត្រូវភ្លាម ឱ្យគេពិនិត្យ ពិចារណា ហើយស្នើអចិន្ត្រៃយ៍"]។

3412 ឯកសារ D4.1.810 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សេង សឿន ឆ.៥៤ KH ERN 00402513។ ឯកសារ D4.1.1036 (និងឯកសារ D4.1.704) ទូរលេខពី យី (ប៊ិន ណន) ទៅមន្ទីរ៨៧០ នៅថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ១៩៧៧។ ឯកសារ D4.1.733 ទូរលេខពី យី (ប៊ិន ណន) ទៅមន្ទីរ៨៧០ នៅថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៧៧, EN 00143562, KH ERN 00021508, FR 00623149 [រាយការណ៍ពីការចាប់ខ្លួនកងទ័ពវៀតណាម៥នាក់ ដោយបញ្ជាក់ថានឹងមាន "វិធានការ" និងមានការតាមដាន តាមសហករណ៍ និងតាមព្រៃតទៅទៀត។]។ ឯកសារ D4.1.655 ទូរលេខពី យី (ប៊ិន ណន) ទៅមន្ទីរ៨៧០ នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ១៩៧៧, EN 00143091 [រាយការណ៍អំពីការតាមរកចាមចំនួន៣នាក់]។ ឯកសារ D1.3.34.50 ទូរលេខពី គួន (សាន់ ប៊ុនហ៊ី) ទៅ យី (ប៊ិន ណន) តាមរយៈមន្ទីរ៨៧០ នៅថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៧៧ [រាយការណ៍អំពីការកម្ទេចខ្មាំង និងបាញ់ឱ្យរបួសក្នុងអំឡុងពេលប្រយុទ្ធគ្នានៅតាមព្រំដែនជាមួយវៀតណាម។ ហើយបានស្នើសុំអាវុធ និងគ្រាប់រំសេវទៀតផង]។ ឯកសារ D4.1.302 ទូរលេខពី គួន (សាន់ ប៊ុនហ៊ី) ទៅ យី (ប៊ិន ណន) តាមរយៈមន្ទីរ៨៧០ នៅថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៧៧ [រាយការណ៍ពីការប៉ះទង្គិចគ្នាជាមួយវៀតណាម ស្នើសុំអាវុធ និងគ្រាប់រំសេវ]។ ឯកសារ D4.1.295 ទូរលេខពី គួន (សាន់ ប៊ុនហ៊ី) ទៅ យី (ប៊ិន ណន) តាមរយៈមន្ទីរ៨៧០ នៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧, EN 00324808, KH ERN 00020884, FR 00623016។

3413 ឯកសារ D4.1.810 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សេង សឿន ឆ.៥៤ KH ERN 00402513 [បញ្ជាក់ថាគណៈកម្មាធិការតំបន់មានកិច្ចប្រជុំប្រចាំខែជាមួយការិយាល័យ៨៧០ ក្នុងទីក្រុងភ្នំពេញ]។

852. នៅក្នុងតំបន់ ៥០៥ គណៈតំបន់ ក្នុងឋានៈជាអង្គការប្រតិបត្តិការខ្ពស់ជាងគេបង្អស់[3416] ទទួលបន្ទុកក្នុងការក្តាប់ប្រជាជនទាំងមូល ព្រមទាំងអង្គការស្រុក និងឃុំដែលចំណុះឲ្យតំបន់[3417]។ តំបន់អនុវត្តវិន័យ[3418] និងទទួលខុសត្រូវលើយោធាតំបន់[3419]។ នៅក្នុងតំបន់ស្វយ័ត ដូចជា តំបន់ ៥០៥ លេខា

---

[3414] ឯកសារ D4.1.810 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.៥៥-៥៦ KH ERN 00402513-14 [អតីតប្រធានមន្ទីរតំបន់៥០៥រូបនេះរៀបរាប់ថាបានទទួលសំបុត្រពីមន្ទីរ៨៧០]។ ឯកសារ D234/2.1.52 របាយការណ៍អ្នកជំនាញការ Craig C. Etcheson, EN 00142835, KH ERN 00314793, FR 00314649 [“មជ្ឈឹមបានបញ្ជូនសេចក្តីណែនាំផ្សេងៗទៅកម្មាភិបាលនៅតាមភូមិភាគ តំបន់ ស្រុក និងថ្នាក់សហករណ៍ ព្រមទាំងទៅគ្រប់ថ្នាក់នៃកងទ័ពបដិវត្តកម្ពុជា”] ដោយដកស្រង់ចេញពី ឯកសារ D1.3.34.78 សារទូរលេខរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ, សេចក្តីណែនាំរបស់ ៨៧០ ថ្ងៃទី ៣ ខែ មករា ឆ្នាំ ១៩៧៨ ។ ឯកសារ D1.3.19.4 សេចក្តីណែនាំរបស់បក្សកុម្មុយនិស្តកម្ពុជា, ប្រកាសភាពប្រយុទ្ធជាប្រចាំ និងដាច់ខាតប្រឆាំងនឹងខ្មាំងយួន ឈ្លានពានវាតទីលេបទឹកដី ចុះថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៧៩។

[3415] ឯកសារ D98/1.2.45 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង សាក្សី នង សុផង់ ចុះថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១២ ម៉ោង 10.01.05-10.04.57 KH ERN 00844184 [“រឿងមកជួប មកគណៈមជ្ឈឹមនេះ ក៏ពេលខ្លះ ក៏គេធ្វើតាមសារទូរលេខសម្ងាត់។ ឧបមាថា សំណើសុំជួប បងណាៗ នៅកន្លែងណាៗ គឺឲ្យមានសារទូរលេខខ្លះ គេឲ្យដំណឹងមុន [...] ពីព្រោះត្រូវពិភាក្សាគ្នាល្អិតល្អន់ [...] គឺគេសុំជួប គេធ្វើសារខ្លីៗសុំជួបមុន [...] ខ្ញុំជួបប្រទះច្រើនដែរ នូវការអញ្ជើញកម្មាភិបាលភូមិភាគមកប្រជុំ។ គេធ្វើជាសារខ្លីៗទេ [...] គេមានធ្វើសារអញ្ជើញគ្រប់តំបន់ គ្រប់ភូមិភាគ”]។ ឯកសារ D4.1.611 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នង សុផង់, EN 00334052, KH ERN 00328033, FR 00411702 [“សារអញ្ជើញមកប្រជុំដែរ ប៉ុន្តែក្នុងនាមគណៈ៨៧០។”]។

[3416] ឯកសារ D1.3.22.1 លក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា ចេញផ្សាយ ខែ មករា ឆ្នាំ ១៩៧៦, មាត្រា៧(៣), EN 00184038, KH ERN 00053025, FR 00292927 [“ក្នុងរយៈពេលពីសន្និបាតតំបន់ ឬក្រុងមួយ ទៅមួយទៀត មានអង្គការប្រតិបត្តិការ ខ្ពស់ជាងគេបំផុត សម្រាប់តំបន់ ឬក្រុងនិមួយៗនោះគឺ គណៈកម្មាធិការតំបន់ ឬក្រុង។”]។

[3417] ឯកសារ D1.3.22.1 លក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា ចេញផ្សាយ ខែ មករា ឆ្នាំ ១៩៧៦, មាត្រា១៦(២)-(៣), EN 00184042-43, KH ERN 00053030-31, FR 00292930 [“ភារកិច្ចរបស់គណៈកម្មាធិការតំបន់-ក្រុង គឺ៖ [...] ២- ក្តាប់មហាជន ក្នុងសហជីព សហករណ៍ និកងទ័ពបដិវត្តន៍ឲ្យណែនជានិច្ច ខាងនយោបាយ សតិអារម្មណ៍ ចាត់តាំង ដោយអប់រំបំពាក់បំប៉នគេ ខាងនយោបាយ សតិអារម្មណ៍ ចាត់តាំង [...] ៣- ក្តាប់អង្គការស្រុក អង្គការសាខា កម្មាភិបាល បក្ខជន និងអង្គការស្នូលទាំងអស់នៅក្នុងតំបន់ ខាងប្រវត្តិរូប ខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង”]។

[3418] ឯកសារ D1.3.22.1 លក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា ចេញផ្សាយ ខែ មករា ឆ្នាំ ១៩៧៦, មាត្រា១៦(៤), EN 00184042-43, KH ERN 00053031, FR 00292930 [“ភារកិច្ចរបស់គណៈកម្មាធិការតំបន់គឺ៖ [...] អនុវត្តវិន័យក្នុងក្របខណ្ឌតំបន់-ក្រុង”]។

[3419] ឯកសារ D114/29.1.6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សារុន, EN 00350263, KH ERN 00345912, FR 00361763 [“យោធាតំបន់មានសិទ្ធិរាយការណ៍មកតែគណៈតំបន់ ចំណែកឯកងពលមជ្ឈិមត្រូវរាយការណ៍ទៅ

តំបន់ដើរតួនាទីសំខាន់ក្នុងការសម្របសម្រួលជាមួយថ្នាក់ដឹកនាំមជ្ឈិម និងកំណត់អត្តសញ្ញាណជនដែលត្រូវចាប់បញ្ជូនទៅមន្ទីរ ស-២១[3420]។

853. គណៈស្រុករាយការណ៍ផ្ទាល់ទៅគណៈតំបន់ និងទទួលបញ្ជាពីគណៈតំបន់មកវិញ[3421]។ ដូចគ្នាដែរ មេឃុំជាច្រើនរាយការណ៍ និងទទួលបញ្ជាពីគណៈស្រុក[3422]។ លេខាស្រុកក៏ក្តាប់អ្នកក្រោមបង្គាប់

---

មជ្ឈិមផ្ទាល់។ [...] កងពលគឺតំណាងឱ្យយោធា និងជាយោធាមជ្ឈិម"]។ ឯកសារ D1.3.22.1 លក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា ចេញផ្សាយ ខែ មករា ឆ្នាំ ១៩៧៦, មាត្រា១៦(២)-(៣), KH ERN 00053030-31។ អាន ឯកសារ D98/3.1.315 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យុន គីម, EN 00345193-94, KH ERN 00340152, FR 00404179-80 ["[អនុលេខតំបន់] គួន ជាអនុប្រធានទទួលខុសត្រូវខាងយោធា [...] [អនុលេខតំបន់] ខុន ទទួលខាងយោធា"]។ ឯកសារ D114/64 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.២៦៤, ឆ.២៦៨, ឆ.២៧៣, និងឆ.២៧៩, KH ERN 01089483-01089484 ["ខុន ជាអនុប្រធានតំបន់ [...]ឆ.២៦៨៖ ខុន ទទួលបន្ទុកយោធា [...] ឆ.២៧៣៖ កាន់ខាងយោធានៅសមរភូមិ [...]ឆ.២៧៩៖ ពេលមានប្រជុំកងទ័ព គឺ ខុន ជាអ្នកទៅប្រជុំ"]។ ឯកសារ D114/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.៧, KH ERN 01127727 ["ខ្ញុំបានឃើញនៅក្នុងបញ្ជីឈ្មោះដែលលោកបង្ហាញខ្ញុំម្សិលមិញ មានឈ្មោះ ខុន ដែលជាយោធាតំបន់ក្រចេះ"]។ ឯកសារ D114/101 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.១៣, KH ERN 01127707 [បញ្ជាក់ថា លេខាតំបន់ក្រចេះឈ្មោះ មាស មឿន "ជាអ្នកកាន់សមរភូមិមុខ"]។

3420 មើល ឧ. ឯកសារ D4.1.578 ទូរលេខ ៥៤ ពី សារុន គោរពជូនបង ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៧៨, KH ERN 00017027, EN 00296220, FR 00531910 [ទូរលេខពីលេខាតំបន់ ១០៥ ពិភាក្សាពីការចាប់ខ្លួន មិត្ត សុទ ដែលជាប់ចម្លើយពួកក្បត់ អា ជួន"]។ ឯកសារ D4.1.404 កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច, EN 00242932, KH ERN 00242921, FR 00242942 ["ចម្លើយសារភាព ត្រូវបានផ្ញើរទៅប្រធានអង្គភាព ដោយមានគោលបំណង២៖ ទី១ ប្រាប់ដំណឹងដល់គាត់អំពីសកម្មភាពរបស់ខ្មាំងនៅក្នុងអង្គភាពនោះ និងទី២ អនុញ្ញាតឱ្យគាត់គិតពីការចាប់ខ្លួនមនុស្សដែលគេឆ្លើយដាក់"]។ ឯកសារ D4.1.1118 កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ ឈ្មោះ កាំង ហ្គេកអ៊ាវ, KH ERN 00195593-94។ ឯកសារ D114/277.5 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនិតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៦, ម៉ោង 14.34.50-15.00.04 KH ERN 01311943 ["ប៉ុន្តែភូមិភាគក៏ដោយច្រើនតែខាងលើប្រគល់រុញទៅហើយ ខ្មាំងឆ្លើយដាក់ប៉ុន្មានដែលខាងលើគិតថា អាណាមានលទ្ធភាពធំជាងគេ ចាប់ហើយ។"]។ ឯកសារ D10.1.1 ចម្លើយសារភាពពី ស-២១ អ្នកទោស យង់ ពៅ, EN 00182829, KH ERN 00004599, FR 00766979 [ចំណាររលើចម្លើយសារភាពរបស់ប្រធានមន្ទីរសន្តិសុខតំបន់១០៦៖ "មួយច្បាប់ជូន ស/ម ពក"]។

3421 ឯកសារ D1.3.22.1 លក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា ចេញផ្សាយ ខែ មករា ឆ្នាំ ១៩៧៦, មាត្រា៦(៥), EN 00184037, KH 00053024, FR 00292926 ["តាមកាលកំណត់និមួយៗថ្នាក់ក្រោម ត្រូវរាយការណ៍ជូនថ្នាក់លើ អពីសភាពការណ៍ និងអំពីកិច្ចការដែលខ្លួនបានធ្វើ។ តាមកាលកំណត់និមួយៗដែរ ថ្នាក់លើត្រូវរាយការណ៍ជូនថ្នាក់ក្រោម

ផ្សេងទៀត ដូចជាសន្តិសុខស្រុក និងប្រធានឃោធា[3423] ដែលជារឿយៗ ទទួលខុសត្រូវអនុវត្តបញ្ជា ពាក់ព័ន្ធនឹងការចាប់ខ្លួន និងសម្លាប់[3424] ក៏ដូចជាមើលការខុសត្រូវលើមន្ទីរសន្តិសុខ[3425]។ នៅពេល

---

អំពីសភាពការណ៍រួម អំពីសេចក្តីណែនាំ ជាទិសការងារផ្សេងៗ។"], មាត្រា១៣(៤), EN 00184041-42, KH ERN 00053028-29, FR 00292929 ["ភារកិច្ចរបស់គណៈកម្មាធិការស្រុកគឺ៖ [...] ៤- [...] មានរបបរាយការណ៍អំពីស្ថានការណ៍ និងការងាររបស់ស្រុកជូនថ្នាក់លើ។"]។ ឯកសារ D4.1.788 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ រឿន, EN 00381135, KH ERN 00379478, FR 00426230 [លេខាស្រុកសំបូរបានចូលរួមប្រជុំ "នៅតំបន់" ក្នុងទីរួមខេត្តក្រចេះ ហើយបានរាយការណ៍បញ្ហាផ្សេងៗ]។ ឯកសារ D4.1.811 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យុន គីម, EN 00412195, KH ERN 00402526, FR 00434571 ["ថ្នាក់ស្រុកចូលរួមប្រជុំប្រចាំសប្តាហ៍ជាមួយថ្នាក់ខេត្ត។ [...] ប៉ុន្តែប្រសិនបើមានបញ្ហាបន្ទាន់គេប្រើប្រាស់នីរសារឲ្យរត់សំបុត្រ"]។

3422 ឯកសារ D98/3.1.316 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង សាក្សី យុន គីម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ នៅម៉ោង 14.05.10-14.07.33, KH ERN 00818270 ["ជាគោលការណ៍ គឺក្នុងនាមជាគណៈឃុំ ត្រូវតែស្តាប់បទបញ្ជាពីលើ"]។ ឯកសារ D4.1.811 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យុន គីម, EN 00412191, KH ERN 00402522, FR 00434567 ["ឃុំបញ្ជូនរបាយការណ៍ទៅស្រុក ហើយស្រុកទៅខេត្តតែប៉ុណ្ណោះ"]។ ឯកសារ D4.1.458 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តន់ សារឿន (ប្រធានគុក គោកក្តួច) EN 00225532, KH ERN 00196824, FR 00272776 ["ធម្មតាប្រធានសហករណ៍តែងតែទៅប្រជុំនៅមន្ទីរស្រុកដើម្បីទទួលគោលនយោបាយ"។ នៅពេលប្រជុំនោះហើយជាពេលដែលគេសម្រេច "ចោទប្រកាន់" នោះ, KH ERN 00196828 ["ខ្ញុំធ្លាប់ចូលរួមប្រជុំនៅមន្ទីរស្រុកតែប៉ុណ្ណោះរៀងរាល់ខែ។ [...] ក្នុងពេលប្រជុំ រឿន [លេខាស្រុកសំបូរ] គឺជាប្រធានអង្គប្រជុំ។ នៅក្នុងអង្គប្រជុំនោះ មានប្រធានសហករណ៍"]។ ឯកសារ D4.1.788 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ រឿន, EN 00381135, KH ERN 00379478, FR 00426230 [បញ្ជាក់ថាកិច្ចប្រជុំរវាងគណៈស្រុកនឹងគណៈឃុំធ្វើឡើងពីរដងក្នុងមួយខែ]។

3423 ឯកសារ D4.1.458 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តន់ សារឿន (ប្រធានគុក គោកក្តួច) EN 00225536, KH ERN 00196828, FR 00272781 ["ខ្ញុំធ្លាប់ចូលរួមប្រជុំនៅមន្ទីរស្រុកតែប៉ុណ្ណោះរៀងរាល់ខែ។ [...] ក្នុងពេលប្រជុំ រឿន [លេខាស្រុកសំបូរ] គឺជាប្រធានអង្គប្រជុំ។ នៅក្នុងអង្គប្រជុំនោះ មានប្រធានសហករណ៍ ប្រធានមន្ទីរក្រសួង យោធា និងសន្តិសុខ"]។

3424 ឯកសារ D4.1.458 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តន់ សារឿន EN 00225532, KH ERN 00196824, FR 00272776 ["ជាធម្មតាប្រធានសហករណ៍ និងឈ្លបនៅសហករណ៍ជាអ្នកចាប់អ្នកទោសទាំងនោះ ហើយបញ្ជូនមកឲ្យមន្ទីរគោកក្តួច។ [មន្ទីរសន្តិសុខស្រុកសំបូរ] ការចាប់ចងនេះ ដោយធ្វើឡើងដោយ ប្រធានសហករណ៍ ដោយយោងទៅតាមគោលនយោបាយពីថ្នាក់ស្រុក និងថ្នាក់លើបន្តៗទៀត។"]។

3425 ឯកសារ D4.1.458 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តន់ សារឿន EN 00225532, KH ERN 00196824, FR 00272777 ["អ្នកទោសខ្លះត្រូវខាងស្រុក ឬខេត្តមកចេញ[ពីមន្ទីរសន្តិសុខ]យកទៅ"], EN 00225534-35, KH ERN 00196826-27, FR 00272779 [ពន្យល់ថា លេខាស្រុកសំបូរ សំ រឿន "គ្រប់គ្រងពីលើ" មន្ទីរសន្តិសុខគោកក្តួច "មក

ប្រធានសហករណ៍ចាប់មនុស្សនៅទីណា ពួកគេត្រូវជួបកម្មាភិបាលស្រុកជាមុនសិន ដើម្បីទទួលសេចក្ដីណែនាំ[3426]។ កម្មាភិបាលស្រុកជាអ្នកក្រោមបង្គាប់របស់លេខាតំបន់ និងជាថ្នាក់លើរបស់ប្រធានសហករណ៍។

854. ទីតាំងរបស់ខេត្តក្រចេះនៅជិតវៀតណាម ជម្លោះប្រដាប់អាវុធកាន់តែឡើងកំដៅខ្លាំង រវាងកម្ពុជាប្រជាធិបតេយ្យ និងប្រទេសជិតខាង[3427] ការភ័យខ្លាចកាន់តែរីកធំឡើងរបស់ថ្នាក់ដឹកនាំ ប.ក.ក ថា "ខ្មាំងផ្ទៃក្នុង" កំពុងឃុបឃិតជាមួយវៀតណាមដើម្បីផ្ដួលរំលំរបបនោះ[3428] បានជំរុញឲ្យមជ្ឈិមធ្វើការបោសសម្អាតថ្នាក់ដឹកនាំតំបន់ ៥០៥ ជាច្រើនដង។ បន្ទាប់ពីលេខាតំបន់ដំបូង តាយ៉ែម ហៅស៊ុន ត្រូវគេបញ្ជូនទៅព្យុងយ៉ាង ក្នុងឆ្នាំ ១៩៧៦[3429] ប៊ិន ណាន ហៅយី បានឡើងជំនួសគាត់ជា

---

ពិនិត្យការងារ [...] ជារៀងរាល់ថ្ងៃ" ហើយបានផ្ដល់ការណែនាំថា "ឃ្លាំមើលសកម្មភាពរបស់ខ្មាំង ក្នុងចំណោមកម្មាភិបាល និងអ្នកទោស ក្រែងមានមនុស្សបន្លំខ្លួនចូលមកក្នុងជួរ"], EN 00225536, KH ERN 00196828, FR 00272781 [មន្ទីរសន្តិសុខគោកក្ដួចត្រូវរាយការណ៍ទៅគណៈកម្មាធិការស្រុក]។ ឯកសារ D4.1.451 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ួង ឃឿ, EN 00272638, KH ERN 00194494-95, FR 00272640។

3426 ឯកសារ D4.1.458 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី តន់ សារឿន EN 00225532, KH ERN 00196824, FR 00272776 ["ធម្មតាប្រធានសហករណ៍តែងតែទៅប្រជុំនៅមន្ទីរស្រុកដើម្បីទទួលគោលនយោបាយ"]។

3427 អានផ្នែក VI. ជម្លោះប្រដាប់អាវុធជាអន្តរជាតិ

3428 អានផ្នែក VII. គោលនយោបាយរបស់បក្សកុម្មុយនីសកម្ពុជា ពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំង មាស មុត – ការលុបបំបាត់ខ្មាំង និងអ្នកប្រឆាំងនឹងមេដឹកនាំបក្សកុម្មុយនីសកម្ពុជា

3429 ឯកសារ D234/2.1.98 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលទីពីរ ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ចុះថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 09.41.25-09.44.05, KH ERN 01454730 ["លោកគ្រូឈ្មោះ ស៊ឹម សុន ហើយដូរឈ្មោះជាសមមិត្ត យ៉ែម។ ក្រោយមកគេបញ្ជូនសមមិត្ត យ៉ែម ហ្នឹងទៅធ្វើទូតនៅកូរ៉េ។"]។ ឯកសារ D4.1.811 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យុន គីម, EN 00412200, KH ERN 00402530, FR 00434575 ["តា យ៉ែម ដែលមានឈ្មោះថា ស៊ុន គឺជាប្រធានតំបន់[៥០៥]ពីឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៧"]។ ឯកសារ D98/3.1.315 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យុន គីម, EN 00345193-94, FR 00404179, KH ERN 00340152 ["តាយ៉ែម ជាប្រធាន [តំបន់៥០៥] [...] ក្នុងឆ្នាំ ១៩៧៦ តាយ៉ែម បានផ្លាស់ទៅធ្វើទូតនៅកូរ៉េខាងជើង"]។ ឯកសារ D4.1.927 កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី [ហេង] ឡៃហ៊ាង ធ.៤ KH ERN 00405486 ["លោក យ៉ែម ជាប្រធានតំបន់៥០៥ ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៦ [...] តំបន់៥០៥ មានគណៈតំបន់ ហើយមនុស្សខាងក្រោមនេះជាផ្នែកនៃគណៈកម្មាធិការនោះ៖ មានឈ្មោះ យ៉ែម ជាប្រធាន"]។ ឯកសារ D114/36.1.31 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ផាត់ ដួងច័ន្ទ, EN 00375683, KH ERN 00373395, FR 00426185 ["ប្រហែលជាចុងឆ្នាំ១៩៧៦ ឬដើម៧៧ ចែត ត្រូវបានចាប់ខ្លួនដោយគណៈខេត្តដែលមានឈ្មោះ យ៉ែ

លេខតំបន់ ៥០៥[3430]។ យី មើលការខុសត្រូវលើការបោសសម្អាត នៅឆ្នាំ ១៩៧៧ រួមទាំងការបញ្ជូន បាន សារឿន ហៅកង អនុលេខាតំបន់ ៥០៥ កម្មាភិបាលជាន់ខ្ពស់តំបន់ ៥០៥ ទៅមន្ទីរ ស-២១[3431]។ មិនដល់មួយឆ្នាំក្រោយមក យី ត្រូវគេចាប់ រួមជាមួយ គួន អនុលេខា និងជាប្រធានយោធាតំបន់[3432] ក្នុងក្របខ័ណ្ឌនៃការបោសសម្អាតទ្រង់ទ្រាយធំ នៅចុងខែ មីនា និងដើមខែ មេសា

---

ម"]។ ឯកសារ D4.1.917 សារទូរលេខរបស់យ៉ែម (ពីព្យុងយ៉ាង) ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៧៧ KH ERN 00033317, EN 00434860, FR 00611893។

3430 ឯកសារ D98/3.1.315 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យុន គីម, EN 00345194, KH ERN 00340152, FR 00404179 ["យី ឡើងជំនួស យ៉ែម"]។ ឯកសារ D98/3.1.316 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង សាក្សី យុន គីម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ នៅម៉ោង 09.07.20 (sic!) [10.07.20]-10.09.19 KH ERN 00818232 ["ខ្ញុំសូមជម្រាបថា លោក យ៉ែម នេះគាត់ជាលេខាបក្សខេត្ត មិនមែនលេខាបក្សស្រុកទេ គឺគាត់ជាលេខាបក្សខេត្ត។ ដល់ក្រោយមក គឺផ្លាស់គាត់បាត់ទៅ ហើយឡើង លោក យី ហ្នឹង គាត់បន្តការងារហ្នឹង។"]។ ឯកសារ D4.1.811 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យុន គីម, EN 00412200, KH ERN 00402530, FR 00434575 ["ហើយក្រោយមក តា យី ជាប្រធានតំបន់"]។ ឯកសារ D234/2.1.98 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ចុះថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 09.38.35-09.41.25 KH ERN 01454729 ["ប្រធានតំបន់៥០៥ ហ្នឹង ធ្លាប់រៀនសូត្រនៅ លីសេ កុសុមៈហ្នឹងជាមួយគ្នា ឈ្មោះ បូណាន"], និងម៉ោង 09.41.25-09.44.05 KH ERN 01454730 ["ឈ្មោះដើមថា បូណាន គាត់ដូរឈ្មោះបដិវត្ត ហៅថាសមមិត្ត យី [កាន់] តំបន់៥០៥។"]។

3431 ឯកសារ D4.1.811 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យុន គីម, EN 00412200-01, KH ERN 00402531, FR 00434575 ["[ក្នុងសម័យ តា យ៉ែម], កង ទទួលខុសត្រូវខាងសន្តិសុខ [...] គាត់ជាប្រធានសន្តិសុខ៥០៥ ពីឆ្នាំ ១៩៧០ ទៅប្រហែលជាឆ្នាំ១៩៧៧ ហើយនៅក្នុងឆ្នាំនោះ គាត់បានបាត់ខ្លួនក្នុងអំឡុងកម្ពេច។"]។ ឯកសារ D98/3.1.316 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង សាក្សី យុន គីម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ នៅម៉ោង 14.36.30-14.38.41, KH ERN 00818278 ["កងទទួលសន្តិសុខមួយខេត្ត [...] ដូចជាចាប់ខ្លួនតាំងពីមុនសភាពការណ៍ចាប់ គួន ហ្នឹងទៀត។ បាត់ខ្លួនដូចបន្តបន្ទាប់"]។ ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសនៅ ស-២១ របស់ ក.ស.ច.ស, លេខរៀង ១១០ [អនុលេខាតំបន់ ឈ្មោះ បាន សារឿន, ថ្ងៃចូល ២២ ខែ មេសា ឆ្នាំ ១៩៧៧], លេខរៀង ១១៥៥២ [ប្រធានមន្ទីរតំបន់ ឈ្មោះ សៀង ផា ហៅ ផល, ចូលថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៧៧], លេខរៀង ១៦៨៣ [ហ៊ិន សំភួន សមាជិកស្រុកសំបូរ ថ្ងៃចូល ២១ ខែ សីហា ឆ្នាំ ១៩៧៧]។

3432 ឯកសារ D98/3.1.315 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យុន គីម, EN 00345193-94, KH ERN 00340152, FR 00404179 ["គួនជាអនុប្រធានទទួលខុសត្រូវខាងយោធា [...] យី និងគួនគេចាប់ឆ្នាំ១៩៧៨ ដោយចោទថាក្បត់"]។ ឯកសារ D98/3.1.316 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង សាក្សី យុន គីម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ នៅម៉ោង 10.14.09-10.16.15 KH ERN

ឆ្នាំ ១៩៧៨[3433]។ សមាជិកគណៈស្រុកជាច្រើន ប្រធានការដ្ឋាន និងប្រធានមន្ទីរពេទ្យ ត្រូវគេនាំយកទៅមន្ទីរ ស-២១[3434]។ កម្មាភិបាលថ្នាក់ទាប ៥១ នាក់ នៃតំបន់ ៥០៥ បានចូលមន្ទីរ ស-២១

---

00818234 ["ឯ មឿន នេះគឺជាអ្នកមកទទួលខេត្តក្រចេះនៅពេលដែលចាប់យី [...] រួច"], ម៉ោង 14.29.22-14.31.56 KH ERN 00818276-77 ["សភាពការណ៍នៅក្នុងខេត្តក្រចេះហ្នឹង គឺមានការច្របូកច្របល់នៅដើមឆ្នាំ៧៨ ហ្នឹង។ លោក យី ហ្នឹងគាត់ជាលេខាបក្សខេត្ត អ៎!បក្សតំបន់ ហើយនៅឆ្នាំ៧៨ ហ្នឹង គឺខាងយោធាចូលទៅហ្នឹង គឺចាប់ទាំងអស់ ហើយ លោក យី ហ្នឹងមិនដឹងគេចាប់បាននៅឯណា ឮ គ្រាន់ឮថាបើកកាណូតមកភ្នំពេញ ហើយគេចាប់តាមផ្លូវទៅ។"], ម៉ោង 14.33.57-14.36.30, KH ERN 00818278 ["នៅពេលបោសម្អាតហ្នឹង [ដើមឆ្នាំ ១៩៧៨] គួន ហ្នឹងគេចាប់ បាត់រហូតមិនដែលបានជួប"]។ ឯកសារ D234/2.1.98 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ចុះថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 09.38.35-09.41.25 KH ERN 01454729 ["ប្រធានតំបន់ ៥០៥ [...] ឈ្មោះ បូណាន។ តែចុងក្រោយបំផុតគាត់ ក៏ត្រូវគណៈបូព៌ាយកទៅសម្លាប់ផងដែរ។"]។ ឯកសារ D4.1.927 កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី [ហេង] ឡៃហ៊ាង ឆ.៤ KH ERN 00405486 ["គួន ទទួលបន្ទុកខាងយោធា"]។ ឯកសារ D59/2/4.16a កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី សេង សឿន, EN 00753833-34, KH ERN 00059326 ["[...] ពីណាគេអ្នកធ្វើលេខាចក្រចេះហ្នឹងពូ? ឆ៖ យី គួនហ្នឹងហើយមុនគេ។ ស៖ តាយី លេខា តាគួន អនុ? ឆ៖ បាទ!"]។ ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសនៅ ស-២១ របស់ ក.ស.ច.ស, លេខរៀង ១៥០, និងលេខរៀង ៨១០៩ [លេខាតំបន់ ប៊ិន ណាន និងអនុលេខា ឈ្មោះ សាន់ ប៊ុនហ៊ី ហៅគួន ទាំងពីរនាក់នេះចូលមន្ទីរ ស-២១ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៧៨]។ ឯកសារ D10.1.53 ចម្លើយសារភាព របស់ ប៊ិន ណាន ហៅ យី, លេខាតំបន់៥០៥, ខែមីនា-ឧសភា ឆ្នាំ ១៩៧៨។

3433 ឯកសារ D98/3.1.316 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង សាក្សី យុន គីម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ នៅម៉ោង 09.39.36-09.41.58 KH ERN 00818224 ["ដល់ឆ្នាំ៧៨ហ្នឹង វាមានសភាពចាប់ច្រើនណាស់ ៧៨ហ្នឹងគឺបើខាងស្រុកសំបូរខ្ញុំ មេឃុំចង់ចាប់ទាំងអស់។ បាទ នៅសល់ពីរបីទេ។ ហើយគណៈស្រុកអីគេចាប់អស់រលីង ហើយខេត្តហ្នឹងក៏ចាប់អស់ដែរ"], ម៉ោង 14.29.22-14.33.57 KH ERN 00818276-77 ["សភាពការណ៍នៅក្នុងខេត្តក្រចេះហ្នឹង គឺមានការច្របូកច្របល់នៅដើមឆ្នាំ៧៨ ហ្នឹង។ លោក យី ហ្នឹងគាត់ជាលេខាបក្សខេត្ត អ៎!បក្សតំបន់ ហើយនៅឆ្នាំ៧៨ ហ្នឹង គឺខាងយោធាចូលទៅហ្នឹង គឺចាប់ទាំងអស់។ [...] ខាងយោធាទៅហ្នឹង [...] ចាប់ពួកគណៈស្រុក គណៈខេត្តពីមុន [...] នៅកន្លែងខ្ញុំអីចាប់តាំងពីអនុប្រធានខ្ញុំ ចាប់តាំងពីមន្ទីរពេទ្យខ្ញុំ [...] ក្នុងសភាពការណ៍ហ្នឹង គឺចាប់ភាគច្រើនចាប់ថ្នាក់ដឹកនាំ។ ថ្នាក់ដឹកនាំស្រុក គឺចាប់គ្មានសល់ទេ។ ថ្នាក់ដឹកនាំខេត្តក៏ចាប់អត់មានសល់ដែរ។ ហើយក្រៅពីហ្នឹងក្នុងឃុំក៏មានចាប់ខ្លះ"]។ អានបន្ថែម ឯកសារ D234/2.1.98 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ចុះថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១៦ ម៉ោង 09.41.25-09.44.05, KH ERN 01454730។

3434 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសនៅ ស-២១ របស់ ក.ស.ច.ស, លេខរៀង ១៥០ [លេខាតំបន់ ប៊ិន ណាន, ចូលថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៧៨], លេខរៀង ៤៦៣ [ប្រធានការដ្ឋានតំបន់ ឈុន ឡាយ, ចូលថ្ងៃទី ១ ខែ មី

ត្រឹមតែរយៈពេលពីរថ្ងៃ គឺពីថ្ងៃទី ៣០ ខែ មីនា ដល់ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ១៩៧៨[3435]។ ក្រោយពីធ្វើការបោសសម្អាតរួចហើយ មជ្ឈិមបក្សបានអបអរសាទរខ្លួនឯង ចំពោះការសម្លាប់រង្គាលក្នុងទស្សនាវដ្តី "ទង់បដិវត្តន៍"[3436]។

855. ការបោសសម្អាត ឆ្នាំ ១៩៧៨ ចង្អុលបង្ហាញយ៉ាងសំខាន់អំពីការពង្រឹងការគ្រប់គ្រងលើតំបន់ ៥០៥ របស់កងទ័ពបដិវត្តន៍កម្ពុជា[3437] ក្រោមបញ្ជារបស់ មាស មឿន[3438] ជាលេខាតំបន់ថ្មី និងអនុរបស់

---

នា/មេសា ឆ្នាំ ១៩៧៨], លេខរៀង ៤៣៨២ [ប្រធានពេទ្យតំបន់ ឈ្មោះ លាង ស៊ីមហាន (លាង ស៊ឹម) ហៅ រស់ ឬ ហាន រស់, ចូលថ្ងៃទី ៤ ខែ មីនា ឆ្នាំ ១៩៧៨ ឬ ៣/៥ ខែ មេសា ឆ្នាំ ១៩៧៨], លេខរៀង ៨១០៩ [អនុលេខាតំបន់ ឈ្មោះ សាន់ ប៊ុនហ៊ី ហៅ គួន, ចូលថ្ងៃទី ២១ ខែ មីនា ឆ្នាំ ១៩៧៨], លេខរៀង ១០៩៥ [ឈ្មោះ ឈឺ ហ៊ (ឈី ហ៊) ហៅ ផាន, សមាជិកស្រុកក្រចេះ តំបន់៥០៥], លេខរៀង ១៤៨០ [អ៊ាវ សារាយ (ខៀវ សារាយ) ហៅ ភឿន, សមាជិកស្រុកសំបូរ], លេខរៀង ៦៨៩៨ [ផង់ នី (ផន នី), សមាជិកស្រុកសំបូរ], លេខរៀង ៨៤៥២ [ស៊ាង ខាន់ (សាង ខាន់) ហៅខន, សមាជិកស្រុកស្នួល], លេខរៀង ១៣០៥៩ [អ៊ុច នាង, សមាជិកគណៈកម្មាធិការស្រុកស្នួល]។ ឯកសារ D98/3.1.316 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង សាក្សី យុន គីម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ នៅម៉ោង 14.29.22-14.31.56 KH ERN 00818276-77 ["នៅសំបូរអ៊ីចឹង ឈ្មោះ ភឿន ឈ្មោះ នី អីហ្នឹងគេចាប់នៅនឹងកន្លែងស្រុកហ្នឹងតែម្តង។"], ម៉ោង 14.33.57-14.36.30 KH ERN 00818278 ["ហើយ ឈ្មោះ ភឿន នោះវាជាយោធាស្រុកទេ ហ្នឹងក៏គេចាប់ដែរ។"], ម៉ោង 15.11.22-15.14.02 KH ERN 00818282 ["ក្រោយមក [ឈ្មោះ នី] គឺគាត់ដូចជាប្រធានស្រុកផង ទទួលសេដ្ឋកិច្ចផងក្រោយពី ផាន ត្រូវផ្លាស់ទៅក្រចេះ [...] តា នី ហ្នឹងអ្នី ហើយនិង ភឿនហ្នឹងទទួលខាងយោធា។ យោធាផង ក៏ដូចជាសន្តិសុខផងពេលហ្នឹងវា ព្រោះកម្លាំងនៅខ្វះ។ អ៊ីចឹងអ្នកពីរនាក់នេះ គេចាប់ក្នុងសភាពការណ៍ដើមឆ្នាំ៧៨ហ្នឹង ក្រោយពីគេចាប់ឈ្មោះយី និងឈ្មោះគួន ទៅឈ្មោះ យី ហើយនិងឈ្មោះនែ! ភឿនហ្នឹងត្រូវចាប់ខ្លួនទៀត។"]។

3435 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសនៅ ស-២១ របស់ ក.ស.ច.ស, លេខរៀង៥៨៥៩, លេខរៀង៨៨០៧-៨៨៧០, លេខរៀង៨៨៧៣-៨៨៧៤, លេខរៀង៨៨៧៦-៨៨៨៣, លេខរៀង៨៨៨៥-៨៨៩៤, លេខរៀង៨៩៥៤-៨៩៥៨, លេខរៀង៨៩៦០, លេខរៀង៨៩៦៣-៨៩៧០, លេខរៀង៨៩៧២-៨៩៨១, លេខរៀង១១៨៨០, លេខរៀង១៣៣៤៤។

3436 ឯកសារ D1.3.24.5 ទង់បដិវត្តន៍, លេខខែឧសភា-មិថុនា ឆ្នាំ ១៩៧៨, EN 00185341, KH ERN 00064577 ["យើងកំទេចបាននូវក្បាលម៉ាស៊ីនដឹកនាំក្បត់ទូទាំងប្រទេស ព្រមទាំងបក្សពួកវា ជាក់ស្តែងគឺយើងបានកំទេចកម្លាំងក្បត់នៅ [...] ក្រចេះ"]។

3437 ឯកសារ D98/3.1.316 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង សាក្សី យុន គីម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ នៅម៉ោង 09.39.36-09.41.58 KH ERN 00818224 ["ឆ្នាំ៧៨ ហ្នឹង វាមានសភាពចាប់ច្រើនណាស់ [...] ខ្ញុំអត់ដឹងថា ខាងនាអ្នកចាប់អ្នកអី ប៉ុន្តែគ្រាន់តែ បន្ទាប់មកឃើញយោធាទៅទទួលខុសត្រូវនៅកន្លែងខ្ញុំបាទ។ [...] ក្រោយពីសភាពការណ៍ដែល ខ្ញុំដូចបានជម្រាប់ហ្នឹង ចាប់គណៈស្រុកជាបន្ត

គាត់ឈ្មោះ ខុន[3439]។ កម្មាភិបាលមកពីកងពលមជ្ឈិម រួមទាំង កងពល ១១៧ ត្រូវបានបញ្ជូនទៅបំពេញតំណែងទំនេរ នៅក្នុងគណៈតំបន់ ៥០៥។ មាស មឿន លេខាតំបន់ ហួន យ៉េង លេខាស្រុក

---

បន្ទាប់មក ខាងយោធាដំបូងមានតែម្នាក់ទេ បាទទៅកាន់កាប់កន្លែងនោះ"], ម៉ោង 14.31.56-14.36.30 KH ERN 00818277-78 ["ស្ថានភាពច្របូកច្របល់នៅដើមឆ្នាំ៧៨ នេះគឺ ខាងយោធាទៅហ្នឹងគឺកាន់កាប់អំណាចម្ដង ចាប់ពួកអ្នកគណៈស្រុក គណៈខេត្តពីមុន [...]។ កាលពីពេលនោះគឺមាន យោធា គឺថាពាក់អាវពណ៌បៃតង។ បៃតងហ្នឹងគេថាមកពីភូមិភាគណាទេ ខ្ញុំដូចជាភ្លេចភ្លាំងដែរ។ ពួកហ្នឹងនិយាយជាមួយប្រជាពលរដ្ឋថា "ញោម"ៗ។"]។ ឯកសារ D114/64 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អែម សារិន, ឆ.២៧៤, ឆ.២៧៦-២៧៧, និងឆ.២៨៣, KH ERN 01089484-85 ["សរ៖ តើវាជារឿងធម្មតាទូទៅ ឬករណីពិសេស ដែលក្នុងតំបន់ស្វយ័តមន្ត្រីខាងស៊ីវិលអាចកាន់ការងារកងទ័ព(ស៊ីក)? [...]ឆ.២៧៤៖ [...] គ្រាន់តែដឹងអំពីរចនាសម្ព័ន្ធនៅទីនោះ [ក្រចេះ] គឺអ៊ីចឹង។ [...]ឆ.២៧៦៖ ខ្ញុំមិនដឹងកងពលទេ ខ្ញុំតែកងទ័ពតំបន់ ឬកងទ័ពខេត្តក្រចេះ។ សរ៖ តើវាជាអង្គភាពអ្វីដែរ? ឆ.២៧៧៖ វាជាអង្គភាពកងទ័ពមានវរសេនាធំ វរសេនាតូច។ [...] ឆ.២៨៣៖ គឺ មឿន ចេញពីកងទ័ពទៅខេត្តក្រចេះដែរ។"]។ ឯកសារ D98/3.1.315 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យុន គីម, EN 00345194, KH ERN 00340152, FR 00404179-80 ["ខុន ទទួលខាងយោធា និងយ៉េង តែខ្ញុំមិនច្បាស់អំពីតួនាទីរបស់គាត់ទេ។ ពួកទាំងនោះសុទ្ធសឹងជាសមាសភាពមកខាងយោធា"]។

3438 ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលទីពីរ សាក្សីម៉ឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 15.33.55-15.36.26, KH ERN 01329933 ["លេខាតំបន់៥០៥ [...] គឺមានពូ មឿន, មានពូ ខុន អ៊ីចឹង តាមលេខរៀង លំដាប់ថ្នាក់"]។ ឯកសារ D98/3.1.316 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលដំបូង សាក្សី យុន គីម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ នៅម៉ោង 10.14.09-10.16.15 KH ERN 00818234 ["ឯ មឿន នេះ គឺជាអ្នកមកទទួលខេត្តក្រចេះនៅពេលដែលចាប់ យី ចាប់ គួន អីហ្នឹងរួចទៅមានឈ្មោះ មឿន មក។"]។ ឯកសារ D98/3.1.315 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យុន គីម, EN 00345194, KH 00340152, FR 00404179 ["ក្នុងឆ្នាំ ១៩៧៨ បន្ទាប់ពីកម្មាភិបាលចាស់ៗត្រូវចាប់អស់ មានឈ្មោះ មឿន ជាប្រធាន"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈាង ជូ, ឆ. ៥០, KH ERN 01071602-03 ["មាស មឿន លេខាតំបន់៥០៥"]។ ឯកសារ D114/101 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អែម សារិន, ឆ.២, KH ERN 01127705 ["មាស មឿន គឺជាលេខាតំបន់ក្រចេះ។ តំណែងនេះ បើបច្ចុប្បន្នគឺស្មើនឹង អភិបាលខេត្ត។"]។ ឯកសារ D114/64 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អែម សារិន, ឆ.២៥៩, និងឆ.២៦៤, KH ERN 01089482-83 ["ឈ្មោះមឿន [លេខាខេត្ត] [...]ឆ.២៦៤៖ មឿន ជាប្រធាន [តំបន់៥០៥]"]។

3439 ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលទីពីរ សាក្សីម៉ឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 15.33.55-15.36.26, KH ERN 01329933 ["លេខាតំបន់៥០៥ [...] គឺមានពូ មឿន, មានពូ ខុន អ៊ីចឹង តាមលេខរៀង លំដាប់ថ្នាក់"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈាង ជូ, ឆ. ៥០, KH ERN 01071602-03 ["ឈឹម ខុន គាត់គឺជាអនុលេខាតំបន់៥០៥"]

ក្រចេះ[3440] ឈុំ ចិន ហៅភ័ន លេខាស្រុកស្នួល[3441] និង សំ វឿន លេខាស្រុកសំបូរ[3442] សុទ្ធតែជាកម្មាភិបាលយោធានៃកងទ័ពបដិវត្តន៍កម្ពុជា ដែលត្រូវបានចាត់តាំងឲ្យទៅកាន់មុខតំណែងទាំងនេះ ដែលកាលពីមុនជាមុខតំណែងស៊ីវិល[3443]។

---

។ ឯកសារ D114/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.៧, KH ERN 01127727 ["ខ្ញុំបានឃើញនៅក្នុងបញ្ជីឈ្មោះដែលលោកបង្ហាញខ្ញុំម្សិលមិញ មានឈ្មោះ ខុន ដែលជាយោធាតំបន់ក្រចេះ"]។ ឯកសារ D114/64 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.២៦៤, ឆ.២៦៨ និងឆ.២៧៩, KH ERN 01089483-84 ["ខុន ជាអនុប្រធានតំបន់ [...] ឆ.២៦៨៖ ខុន តួនាទីទទួលបន្ទុកយោធា។ [...] ឆ.២៧៩៖ ពេលមានប្រជុំកងទ័ព គឺខុន ជាអ្នកទៅចូលរួមប្រជុំ"]។ ឯកសារ D98/3.1.315 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យុន គីម, EN 00345194, KH ERN 00340152, FR 00404179-80 ["ខុន ទទួលខាងយោធា និងយ៉េង តែខ្ញុំមិនច្បាស់អំពីតួនាទីរបស់គាត់ទេ។ ពួកទាំងនោះសុទ្ធសឹងជាសមាសភាពមកខាងយោធា"]។

3440 ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ. ៥២, KH ERN 01071603 ["ហួន យ៉េង លេខាស្រុកក្រចេះ"]។ ឯកសារ D114/101 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.២០, KH ERN 01127708 ["ខ្ញុំស្គាល់លេខ១០ [ឯកសារ D1.3.28.141] ឈ្មោះ ហួន យ៉េង [...] យ៉េង គឺជាលេខាស្រុកក្រចេះ"]។ ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី សេង សឿន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 14.06.19-14.09.39 KH ERN 01355204 ["យ៉េង ជាលេខាស្រុកក្រចេះ"]។ ឯកសារ D114/171 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ សារួន ឆ.៣៩ KH ERN 01204179 [សាក្សីរូបនេះជាអតីតប្រពន្ធរបស់លេខាស្រុកក្រចេះ ហួន យ៉េង៖ "ខ្ញុំទៅហ្នឹង គាត់ធ្វើការនៅកន្លែងតំបន់ក្រចេះ ស្រុកក្រចេះ។ ការងារគាត់ជាគណៈស្រុកក្រចេះ។"]។

3441 ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ. ៥២, KH ERN 01071603 ["ឈុំ ចិន ហៅភ័ន លេខាស្រុកស្នួល"]។ ឯកសារ D114/101 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.២០, KH ERN 01127708 ["ខ្ញុំស្គាល់លេខ១១ [...] [ឯកសារ D1.3.28.141] ឈ្មោះ ឈុំ ចិន នេះខ្ញុំស្គាល់តែឈ្មោះហៅក្រៅគាត់ថាឈ្មោះ ភ័ន តែប៉ុណ្ណោះ [...] ភ័ន ហៅ ឈុំ ចិន គឺជាលេខាស្រុកស្នួល។"]។ ឯកសារ D54/60 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វ៉េត ឆ.៦ KH ERN 00975689 ["ខ្ញុំត្រូវបានគេបញ្ជូនទៅក្រចេះ ទៅនៅជាមួយពូរបស់ខ្ញុំ។ ពូរបស់ខ្ញុំឈ្មោះ ឈុំ ចិន ហៅភណ្ឌ ជាលេខាស្រុកស្នួល ខេត្តក្រចេះ"]។

3442 ឯកសារ D98/3.1.316 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង សាក្សី យុន គីម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ នៅម៉ោង 15.21.28-15.23.51 KH ERN 00818285 ["[នៅពេលគេចាប់ នី និង ភឿន], វឿន ហ្នឹងជាប្រធាន ហើយ ឈូក ជាអនុប្រធានស្រុក [សំបូរ]"]។ ឯកសារ D4.1.810 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.៥៨ KH ERN 00402514 ["ប្រធានស្រុកសំបូរ [...] ពុំមានការផ្លាស់ប្តូរនៅពេលដែលខ្ញុំទៅដល់តំបន់៥០៥។ វឿន គឺជាគណៈស្រុកសំបូរ"]។ ឯកសារ D4.1.451 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ួង ឃឿ, EN 00272636, KH ERN 00194492, FR 00705434 ["គណៈស្រុកសំបូរមានឈ្មោះ វឿន ជាប្រធាន [...] ឈ្មោះ ឈូក មិនដឹងកាន់ផ្នែកអី"]។ ឯកសារ D4.1.458 កំណត់ហេតុនៃការស្តាប់ចម្លើយ

សាក្សី តន់ សារឿន EN 00225531, KH ERN 00196823, FR 00272775-76 ["រឿន ជាគណៈស្រុកមកពីនិរតី ឈ្មោះ ជាអនុ"]។ ឯកសារ D4.1.788 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ រឿន, EN 00381133, KH ERN 00379476-77, FR 00426228 [លេខាស្រុកសំបូររូបនេះបានរៀបរាប់ពីការផ្លាស់គាត់ពីកំពង់ស្ពឺ នៃភូមិភាគបស្ចិម (អតីតភូមិភាគនិរតី) ទៅក្រចេះនៅដើមឆ្នាំ១៩៧៨។ គាត់អះអាងថាគេចាត់តាំងគាត់ជាអនុលេខាស្រុកសំបូរ។ ប៉ុន្តែសាក្សីដទៃទៀត (ដូចជាប្រធានមន្ទីរតំបន់៥០៥ និងគណៈឃុំសំបូរ) បញ្ជាក់ថាសាក្សីខាងលើជាលេខាស្រុក]។

3443 D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វ៉េត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.44.15-09.46.50 KH ERN 01329783 ["ហើយគណៈស្រុក និងគណៈតំបន់សុទ្ធចេញពីកងពល[១១៧]ហ្នឹងទាំងអស់"]។ មាស មឿន៖ ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វ៉េត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.20.00-09.21.57 KH ERN 01329774 ["គាត់[មាស មឿន]អ្នកស្រុកកំពត។ ហើយពីដើមចេញពីមុនគាត់ទៅក្រចេះនេះ គឺគាត់ជាប្រធានវរៈសេនាធំនៅខាងអង្គរបុរី។ ដល់អ៊ីចឹងកាលពីជំនាន់នៅកំខ្ញុំអាចស្គាល់ដែរ"]។ ឯកសារ D114/64 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.២៨៣, KH ERN 01089485 ["គឺមឿន ចេញពីកងទ័ពទៅខេត្តក្រចេះដែរ។"]។ ឯកសារ D114/101 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.៤-៥, KH ERN 01127706 និងឆ.១២-១៣, KH ERN 01127707 ["ខ្ញុំស្គាល់ [មាស មឿន] តាំងពីឆ្នាំ១៩៧៣។ គាត់នៅក្នុងវរសេនាតូចលេខ៣៨០ ក្នុងវរសេនាធំលេខ១១ កងពលលេខ២។ [...] គាត់មកពីស្រុកស្រែក្នុង នៅខេត្តកំពត។ ស៖ តើហេតុអ្វីបានជាលោកស្គាល់គាត់? ឆ.៥៖ ពីដំបូង គឺខ្ញុំមកពីតំបន់១៣ នៅវរៈសេនាតូចលេខ៤០៦។ ក្រោយមកវរសេនាតូចលេខ៤០៦ ត្រូវបានដាក់បញ្ចូលនៅក្រោមវរសេនាធំលេខ១១ [...] ឆ.១២ ៖ [...] ខ្ញុំស្គាល់ មាស មឿន ពេលខ្ញុំចូលនៅថ្នាក់វរសេនាធំ [...] ឆ.១៣៖ មាស មឿន ជាអ្នកកាន់សមរភូមិមុខ ឯខ្ញុំកាន់នៅសមរភូមិក្រោយ [...] យើងនិយាយគ្នាតាមតេអូរាល់ថ្ងៃ។ យើងជួបមុខគ្នាផ្ទាល់ប្រហែល១០ ទៅ១៥ថ្ងៃម្តង។"]។ ឯកសារ D114/216 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ឆ.៣៧ KH ERN 01301459 [បញ្ជាក់ប្រាប់ថាប្អូនជីដូនមួយរបស់គាត់ជាយោធានៅក្រចេះ]។ ហួន យ៉េង៖ ឯកសារ D98/3.1.316 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង សាក្សី យុន គីម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ នៅម៉ោង 15.27.24-15.29.07 KH ERN 00818286 ["ក្រោយពីចាប់គណៈតំបន់ គណៈស្រុកអីអស់ហ្នឹង នៅក្រចេះ [...] មកទទួលខាងយោធា ហើយម្នាក់ទៀតឈ្មោះ យ៉េង"]។ ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ សាក្សីម៉ឹង វ៉េត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 15.36.26-15.38.37, KH ERN 01329933 ["លេខាស្រុកក្រចេះ គឺខ្ញុំដឹងកាលពីមុនហ្នឹងគឺ បង យ៉េង [...]។ គាត់នៅលេខាស្រុកក្រចេះ ក៏គាត់ចេញពីជួរទ័ពខាង ទៅពីលង្វែកទៅ"]។ ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វ៉េត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.23.36-09.27.08 KH ERN 01329776 ["យ៉េង គឺទៅពី[កងពល]១១៧ដូចគ្នា ចេញពីលង្វែកដូចគ្នា"]។ ឯកសារ D59/1/3.51b ប្រវត្តិអ្នកទោសជាប់ឃុំឃាំង ស-២១ ឈ្មោះ ហួន យ៉េង ថ្ងៃឃាត់ខ្លួន ថ្ងៃទី១២ ខែ១២ ឆ្នាំ១៩៧៨, EN 01531794, KH ERN 00929689 ["ក្រសួង និងនាទីចាប់ពីថ្ងៃចូលបដិវត្ត រហូតបច្ចុប្បន្ន៖ - ប្រធានកងធំ កងពលទី១ ភូមិភាគបស្ចិម - លេខាស្រុកក្រចេះ តំបន់ ៥០៥"]។ ឯក

**កងពល ១១៧**

សារ D114/171 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ សារួន ឆ.៣២-៣៣ KH ERN 01204178 និង ឆ.៣៧ KH ERN 01204179 [អតីតប្រពន្ធលេខាស្រុក ឈ្មោះ ហួន យ៉េង បញ្ជាក់ប្រាប់ថា គាត់បានជួប យ៉េង នៅក្នុងឆ្នាំ ១៩៧៧ ពេលនោះ យ៉េង ជាយោធានៅកោះកុង មុនពេលគាត់ទៅក្រចេះជាមួយនៅឆ្នាំ១៩៧៨]។ ឯកសារ D59/2/4.16a កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី សេង សឿន, EN 00753840, KH ERN 00039332 ["ពួកហ្នឹងយកចេញពីទ័ពទេត្រឹមថានៈវរៈសេនាតូចអីយកចេញមកធ្វើគណៈស្រុក ហ្នឹងទាំង [...] យ៉េង [...]។ យកពីទ័ពកងពលលេខមួយរបស់ តាសឿង"]។ ឃុំ ចិន ហៅភ័ន៖ ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ សាក្សី ម៉ឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 15.33.55-15.36.00, KH ERN 01329933 ["[ពូរបស់ខ្ញុំឈ្មោះ ឃុំ ចិន ហៅ ភ័ន] គាត់ត្រឹមលេខាស្រុកស្នួល [...] ហ្នឹងគាត់ចេញពី ១១៧ ដដែលទេ គ្រាន់តែចេញពីទ័ពមក ទៅនៅគ្រប់គ្រងក្នុងស្រុក"]។ ឯកសារ D54/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៥ KH ERN 00975779 ["ពូរបស់ខ្ញុំឈ្មោះ ឃុំ ចិន ហៅ ភណ្ឌ ដែលជាមេបញ្ជាការវរៈសេនាធំ នៃកងពល១១៧ ហើយក្រោយមកក្លាយជាលេខាស្រុកស្នួល ខេត្តក្រចេះ [...] ពូរបស់ខ្ញុំ និងរុំ ជាមិត្តភក្តិនឹងគ្នា។"]។ ឯកសារ D59/2/4.16a កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី សេង សឿន, EN 00753840, KH ERN 00059332 ["ពួកហ្នឹងយកចេញពីទ័ពទេត្រឹមថានៈវរៈសេនាតូចអីយកចេញមកធ្វើគណៈស្រុកហ្នឹងទាំង [...] អាភាន់, អាចិន ស្រុកស្នួល [...] យកពីទ័ពកងពលលេខមួយរបស់ តាសឿង"]។ ឯកសារ D251.1.2 ប្រវត្តិរូបរបស់ ឃុំ ចិន ហៅ ភ័ន នៅស-២១ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៨, EN 01531790, KH ERN 01531791 ["ក្រសួង និងនាទីចាប់ពីថ្ងៃចូលរដិវត្តរហូតដល់បច្ចុប្បន្ន៖ -មុន ប្រធានកងធំកងពលទី១ ភូមិភាគបស្ចឹម, -លេខាស្រុកស្នួល តំបន់ ៥០៥"]។ សំ វឿន និងឈូក ជាអនុប្រធាន៖ ឯកសារ D4.1.458 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តន់ សារឿន EN 00225534, KH ERN 00196826, FR 00272779 ["ទ័ពខាងនិរតីដែលដឹកនាំដោយឈ្មោះ វឿន ឈូក និងវ៉ាន់ បានមកដល់ទីនេះ ហើយធ្វើការបោសសំអាតដោយចាប់ នី និង អឿន។ [...] ដើម្បីចាប់ខ្លួន នី និងអឿន វឿន បានហៅពួកគេមកប្រជុំហើយចាប់តែម្តង។"]។ ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី សេង សឿន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 14.03.54-14.06.19 KH ERN 01355203-04 បញ្ជាក់បន្ថែមនៅលើ ឯកសារ D59/2/4.16a កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី សេង សឿន, EN 00753840, KH ERN 00059332 ["ពួកហ្នឹងយកចេញពីទ័ពទេ ត្រឹមថានៈវរៈសេនាតូចអីយកចេញមកធ្វើគណៈស្រុកហ្នឹងទាំងបងវឿន, ឈូក [...] យកទីទ័ពកងពលលេខមួយរបស់ តាសឿង"]។ ឯកសារ D4.1.788 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ វឿន, EN 00381133-34, KH ERN 00379476-77, FR 00426228-29 [រៀបរាប់ពីការចេញដំណើរជាមួយ ពេទ្យ សឿង "ប្រធានកងពលតូចលេខ១" ពីភូមិភាគបស្ចឹម ទៅខេត្តក្រចេះ នៅទីនោះគេចាត់តាំងគាត់ជាគណៈស្រុកសំបូរ]។

856. នៅឆ្នាំ ១៩៧៧ តបនឹងសំណើសុំបង្កើនវត្តមានយោធានៅព្រំដែនវៀតណាម កងពល ១១៧ ត្រូវបានបង្កើតឡើង នៅលង្វែក ខេត្តកំពង់ឆ្នាំង ជាសាខាកងពលលេខ ១ របស់ភូមិភាគបស្ចិម[3444]។

---

3444 ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វេត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 11.17.50-11.20.03 KH ERN 01329808 ["កងទ័ពចេញទៅការពារព្រំដែនទាំងអស់ ពី៧៧ ចេញគ្រប់កង ចេញគ្រប់ភូមិភាគ។ [] ខាងកងពលទី១ បំបែកមក១១៧ មកក្រចេះនេះ ក៏មកទប់ព្រំដែនព្រោះនិយាយរួមបុក៧៧ យួនបុកៗទាំងអស់ហ្នឹង [...] ដល់ក្រចេះមានតែទ័ពតំបន់"]។ ឯកសារ D54/62 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៣ KH ERN 00975779 ["កងពល១១៧ គឺបំបែកចេញពីកងពលលេខ១ របស់ភូមិភាគបស្ចិមក្រោមបញ្ជាការរបស់ សឿង ដែលមានទីតាំងនៅលង្វែក ខេត្តកំពង់ឆ្នាំងកាលពីពេលនោះ។"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈាង ជូ, ឆ.១-៤ និង ឆ.៦ KH ERN 01071594 ["គេបញ្ជូនខ្ញុំទៅក្រចេះ នៅឆ្នាំ១៩៧៧ ជាមួយនឹងកងពល១១៧។ [...] ឆ.២៖ កងពល១១៧ ត្រូវបានរៀបចំឡើងនៅចុងឆ្នាំ១៩៧៧ នៅលង្វែក គឺនៅប្រហែលជាខែវិច្ឆិកា ឬខែធ្នូ ឆ្នាំ១៩៧៧។ [...]ឆ.៣៖ កងពលនេះត្រូវបានរៀបចំឡើង ដើម្បីប្រយុទ្ធជាមួយយួន។ [...]ឆ.៤៖ កាលនៅលង្វែក កងពល១១៧ ស្ថិតនៅក្រោមបញ្ជារបស់ភូមិភាគបស្ចិម។ ឆ.៦៖ នៅពេលកងពល១១៧ រៀបចំឡើង កាលនៅលង្វែក គឺស្ថិតនៅក្រោម តាសឿង និងចាន់ស៊ី"។ ឆ.៣០ KH ERN 01071599 និងឆ.៣៧ KH ERN 01071600 សាក្សីប្រាប់ថាគាត់ធ្លាប់ធ្វើការជាមួយមេបញ្ជាការកងពល១១៧ ឃុន វុំ និងជាមួយមេបញ្ជាការកងពល១ វ័ន្ត លាង]។ ឯកសារ D114/192 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ចិន ផាត, ឆ.១៦ KH ERN 01221844 ["ស៖ លោកថា គេបញ្ជូនលោកទៅក្រចេះ តើហេតុអ្វីបានជាគេបញ្ជូនលោកទៅក្រចេះ ហើយបញ្ជូនទៅក្នុងឆ្នាំណាដែរ? ឆ.១៦៖ កាលឆ្នាំ១៩៧៧ ប្រហែលចុង៧៧។ កាលនោះ ដែលវៀតណាមបុកចូលមកហ្នឹង។ កាលនោះគេបញ្ជូនទៅខែ១១ ឬខែ១២ ដែលគេបញ្ជូនទៅ។"] បញ្ជាក់បន្ថែម ឯកសារ D114/157.1.3 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី ចិន ផាត, KH ERN 01197638-41 ["កើត៧៧បានខ្ញុំឡើងមកក្រចេះ។ [...] កាលនោះកងទ័ពវៀតណាម យើងវ៉ៃតាមព្រំដែន ដល់ចឹងគេត្រូវប្រមូលគ្រប់អង្គភាពទាំងអស់ដើម្បីបញ្ជូនមកវ៉ៃយួននៅព្រំដែន។, KH ERN 01197641 [...] [គេរៀបកងពល] បាទ!ពីលង្វែកទៅ [...] កងពលលេខ១១៧, KH ERN 01197638 ឆ្នាំ៧៧ដែរ [...] អាចខែ៤ [ខែមេសា]"]។ ឯកសារ D114/190 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហោ អោ ឆ.១៨, ឆ.២០-២៣ និងឆ.២៧ KH ERN 01221820-21 ["ស៖ តើលោកនៅចាំបានទេថា ប្រធានកងពលឈ្មោះអីដែរ? ឆ.១៨៖ ស្គាល់តែមួយទេ ស្គាល់តែមេមួយ តាសឿង ប៉ុន្តែស្លាប់បាត់ទៅហើយ ថ្នាក់កងពល [...] ឆ.២០៖ បញ្ជូនទៅក្រចេះអ៊ីចឹងទៅ។ [...] ឆ.២១៖ នៅលង្វែកដល់១៩៧៧ ទៅក្រចេះចុង១៩៧៨ទៀត។ [...] ឆ.២២៖ នៅទីនោះបានប្រហែលបីបួនខែ មុនរត់នៅឆ្នាំ១៩៧៩។ [...] ស៖ តើកងវរសេនាធំ១៦របស់លោកទាំងអស់ដែលបញ្ជូនទៅពីភ្នំពេញ គ្រូគេបញ្ជូនបន្តទៅខេត្តក្រចេះដើម្បីវាយជាមួយនឹងវៀតណាមមែនទេ? ឆ.២៣៖ បាទ មែន។ [...] ឆ.២៧៖ កងពលថ្មី ទៅ១១៧មែន។"]។ បញ្ជាក់នៅក្នុង ឯកសារ D114/157.1.4 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី ហោ ឱ, EN 01507103-06, KH ERN 01197696-98 [អតីតយោធាកងពលលេខ១ ភូមិភាគបស្ចិម រៀបរាប់ពីកិច្ចការកាងនៅលង្វែកពីឆ្នាំ១៩៧៥ មុនពេលគេយកទៅចូលកងពល១១៧ ហើយបញ្ជូនទៅវ៉ៃនៅព្រំដែនវៀតណាមក្នុងឆ្នាំ

ក្រោយពេលបង្កើតបានបន្តិច កងពលថ្មីនេះត្រូវបានផ្ទេរទៅខេត្តក្រចេះ (តំបន់ ៥០៥) ហើយត្រូវបានដាក់ឱ្យស្ថិតនៅក្រោមបញ្ជារបស់មជ្ឈិម និងចាប់ផ្តើមរាយការណ៍ទៅសេនាធិការ[3445]។ បញ្ជា

---

១៩៧៧។ អានជាពិសេសនៅ, EN 01507107, KH ERN 01197699 ["កងពេលថ្មី [នៅក្រចេះ]។ [...] [កងពល] ១១៧។ ស៖ អ៊ីចឹងគេបំបែកចេញពីកងពលតាសឿង ហើយ? ឆ៖ បំបែកអស់ហើយ។"] និង EN 01507109, KH ERN 01197700 ["ស៖ ហើយបង្កើតកងពលនៅលង្វែកហ្នឹងហើយ បានបញ្ជូនមកក្រចេះ ស្អួ? ឆ៖ បាទ។"]។ ឯកសារ D114/84 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក សុផល ឆ.២៦, KH ERN 01110619 [អនុមេបញ្ជាការកងវរៈសេនាធំលេខ១ ទទួលបញ្ជាឱ្យនាំកម្លាំង និងរៀបចំកងពលថ្មីមួយសម្រាប់មជ្ឈិម គឺ កងពល១១៧ ដើម្បីវ៉ៃកងទ័ពវៀតណាម]។

3445 ឯកសារ D54/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឺង វ៉េត ឆ.៤ KH ERN 00975779 ["កងពល១១៧ គឺយកចេញពីភូមិភាគបស្ចិម ដើម្បីឱ្យស្ថិតនៅក្រោមបញ្ជារបស់មជ្ឈិម។"]។ ឯកសារ D54/63 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឺង វ៉េត ឆ.១៥-១៦, KH ERN 00975796 ["កងពល១១៧នេះ ស្ថិតនៅក្រោមបញ្ជាសេនាធិការផ្ទាល់ មិនឆ្លងកាត់តាមភូមិភាគទេ។ [...] ឆ.១៦៖ [របាយការណ៍]ដាក់ជូនទៅអគ្គសេនាធិការ"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.៤-៥ KH ERN 01071594 និងឆ.៤០ KH ERN 01071601 ["កាលនៅលង្វែក កងពល១១៧ ដែលស្ថិតនៅក្រោមបញ្ជាការរបស់បស្ចិម។ នៅពេលដែលគេញូនកងពលនេះទៅក្រចេះ គឺកងពលនេះស្ថិតនៅក្រោមបញ្ជាការរបស់មជ្ឈិម។ ស៖ តាមើងយល់ កងពល១១៧ ដែលស្ថិតនៅក្រោមបញ្ជាការរបស់មជ្ឈិមហ្នឹង បានន័យថាកងពលហ្នឹងស្ថិតនៅក្រោមសេនាធិការឬ? ឆ.៥៖ បាទ ត្រឹមត្រូវហើយ។ [...] ឆ.៤០៖ ថ្នាក់លើកងពលហ្នឹងទៀតគឺថ្នាក់មជ្ឈិម ពីព្រោះកងពលនេះ គឺស្ថិតនៅក្រោមបញ្ជារបស់មជ្ឈិមផ្ទាល់"]។ ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ម៉ឺង វ៉េត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 11.20.03-11.22.19 KH ERN 01329809 [ផ្តល់សក្ខីកម្មថា អគ្គសេនាធិការមានបញ្ជាឱ្យ "ទប់នៅគ្រប់សមរភូមិ" គ្រប់កងពលទាំងអស់នៅតាមបណ្តាយព្រំដែន មានទាំងកងពល១១៧ផងដែរ។], ម៉ោង 13.34.27-13.36.31 KH ERN 01329813 [ផ្តល់សក្ខីកម្មថា "កងពល[១១៧]នេះរាយការណ៍បញ្ជូនសារទូរលេខអឺបញ្ជូនមកអគ្គសេនាធិការបណ្តោយ" ដោយឡែក "អាវុធយុទ្ធភ័ណ្ឌអីស្អីផ្សេងៗ គេមកយកទទួលពីរដ្ឋបណ្តោយ ពីអគ្គសេនាធិការទៅបណ្តោយ"], និងម៉ោង 13.40.21-13.42.35 KH ERN 01329815 [ផ្តល់សក្ខីកម្មថា របាយការណ៍ប្រចាំថ្ងៃត្រូវផ្ញើទៅអគ្គសេនាធិការ ហើយថាសេចក្តីណែនាំផ្ទាល់នោះគឺមកពីមន្ទីរ ៨៧០ "នៅពេលជាក់លាក់ណាមួយ" ឧទាហរណ៍ "ដាក់ថាសភាពការណ៍យួនបុកហើយ" ខាងក្រោមត្រៀមទ័ពតែប៉ុណ្ណឹងទេ"]។ ឯកសារ D114/297.1.24 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ម៉ឺង វ៉េត ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.41.57-09.49.05 KH ERN 01330085-86 ["អ៊ឹៗទាំងបីហ្នឹង--ខាងខ្ញុំរាយការណ៍ទៅ គឺរាយការទៅអគ្គសេនាធិការ អាហ្នឹងជាប្រចាំថ្ងៃ។ តែខាងគាត់ហ្នឹង គាត់ខាងណាទទួលក៏បានដែរ។ [...] អ៊ីចឹង គឺគាត់ជួយក៏ជួយ បើគាត់មិនជួយអាហ្នឹងឡើងដល់គាត់ សារដល់គាត់ហើយ ព្រោះក្នុងមួយថ្ងៃរាយការណ៍ព្រឹកល្ងាចជាប្រចាំ [...] ទូរលេខវាទាក់ទងទៅអគ្គសេនាធិការ មួយគ្រឿង សម្រាប់ទាក់ទងទៅលើ"]។ ឯកសារ D114/84 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក សុផល ឆ.២៦,

ចេញពីមន្ទីរ ៨៧០ ត្រូវបញ្ជូនទៅកងពល តាមរយៈសេនាធិការ[3446]។ កងពល ១១៧ មានទីបញ្ជាការនៅស្រុកស្នួល[3447] ជិតព្រំដែនវៀតណាម និងមានមន្ទីរមួយទៀត នៅជិតក្រុងក្រចេះ[3448]។

857. ពេលកងពល ១១៧ ត្រូវបានផ្ទេរទៅក្រចេះ ឃុន រំ (ឃុន រុំ ឬ ឃុន សារុំ) ត្រូវបានចាត់តាំងជាមេបញ្ជាការ ដោយមាន រ័ត្ន លាង ជាមេបញ្ជាការរង[3449]។ ស្វាយ ណូញ ជាប្រធានមន្ទីរកងពល

---

KH ERN 01110619 ["កងពល១១៧ [...] ជាកងពលរបស់មជ្ឈិម"]។ អាន ឯកសារ D114/29.1.6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សារុន, EN 00350263, KH ERN 00345912, FR 00361763 ["ចំណែកឯកកងពលមជ្ឈិមត្រូវរាយការណ៍ទៅមជ្ឈិមផ្ទាល់។"]។ ឯកសារ D114/157.1.3 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី ចិន ផាត, EN 01507012, KH ERN 01197633 ["មួយចំនួនធំគេបញ្ជូនមក ហៅកងទ័ពមជ្ឈិមមកក្រចេះនេះ"]។

3446 ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វេត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 13.46.24-13.48.51 KH ERN 01329817 ["ធម្មតាបទបញ្ជាត្រូវចេញពី ម-៨៧០ មុន បានជូនមកអគ្គសេនាធិការហើយ"]។

3447 ឯកសារ D114/170 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ ម៉ុន ឆ.៣០ KH ERN 01204168 [សាក្សីរូបនេះជាប្រពន្ធរបស់អតីតលេខាកងពល១១៧៖ គាត់[ឃុន រុំ] មិននៅក្រចេះទេ គាត់នៅស្នួល"]។ ឯកសារ D114/190 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ អោ ឆ.៣០ KH ERN 01221822 ["តើគេបញ្ជូនរូបលោកទៅឈរជើងនៅត្រង់ចំណុចណាដែរ ក្នុងខេត្តក្រចេះ? ឆ.៣០៖ នៅស្នួល"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.២៣-២៤ KH ERN 01071597 ["បញ្ជាការកងពលលេខ១១៧ ស្ថិតនៅភូមិកាត់ដៃ មានចម្ងាយប្រហែល៥-៦ គីឡូម៉ែត្រពីស្នួល។ [...] ឆ.២៤៖បញ្ជាការកងវរៈសេនាតូច [១២១] របស់ខ្ញុំស្ថិតនៅភូមិផ្អក ជិតភូមិកាត់ដៃ។ ចំណែកបញ្ជាការកងវរៈសេនាធំលេខ១១៥ គឺនៅជិតៗនោះដែរ។"]។ ឯកសារ D114/204 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ស៊ីយ៉ាត, ឆ.៤៤ KH ERN 01238668-69 ["យើងគឺនៅក្នុងកងពល១១៧ [...] ទៅឈរជើងនៅស្រុកស្នួល"]។ ឯកសារ D114/191 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សួ, ឆ.១២-១៣ KH ERN 01221832-33 ["ឈរជើងនៅស្រុកស្នួល [...] ឆ.១៣៖ នៅក្រចេះ កងពល១១៧"]។ ឯកសារ D114/157.1.3 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី ចិន ផាត, EN 01507030, KH ERN 01197645 [បញ្ជាក់ថាមន្ទីរកងពល១១៧តាំងនៅស្នួល ខាងត្បូងភូមិកាត់ដៃ]។

3448 ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វេត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 13.31.37-13.34.27 KH ERN 01329813 ["នៅក្នុងស្រុកស្នួលមួយកន្លែង មន្ទីរខ្ញុំនៅក្នុងស្រុកក្រចេះមួយកន្លែងទៅ បាទ នៅក្រគរ ហៅស្ពានក្រគរ"]។

3449 ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ សាក្សីម៉ឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 15.36.26-15.38.37, KH ERN 01329933 ["មេបញ្ជាការកងពលឈ្មោះ រុំម, ឈ្មោះ លាង, ឈ្មោះ នឹម ហ្នឹងជាមេបញ្ជាការកងពល១១៧ [...] រុំម ជាស្នងការ, លាង

១១៧[3450] ចំណែកឯសាក្សី ម៉ឹង វេត ជាអនុប្រធានមន្ទីរនៅក្រុងក្រចេះ[3451]។ កងពល ១១៧ មាន ៣ កងវរសេនាធំ គឺកងវរសេនាធំលេខ ១៥, ១៦ និង ១៧[3452] ហើយក្នុងមួយកងវរសេនាធំមាន ៣

---

ជាមេបញ្ជាការ ដូចថាវរបបប្រធានពីរ។ អ្ហ៎! តានឹម សមាជិកអ៊ីចឹងមក បីៗ មានបី។ តែលេខពីរ គឺបងលាង [...] លេខមួយគឺពូរ៉ុម"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.៦ KH ERN 01071594-95 និងឆ.៥០ KH ERN 01071602-03 ["មេបញ្ជាការកងពល១១៧ ឈ្មោះ រុំ និងអនុរបស់គាត់ឈ្មោះ លាង។ [...] ឆ.៥០៖[...] វ័ត្ត លាង ជាអនុលេខាកងពល១១៧។ [...] ឃុន រុំ ជាលេខាកងពល១១៧។"]។ ឯកសារ D114/101 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.១, KH ERN 01127705 ["ឃុន រុំ [...] ជាមេបញ្ជាការកងពល លេខ១១៧"]។ ឯកសារ D114/157.1.4 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី ហោ ឱ, EN 01507107, KH ERN 01197699 ["ពីណាគេប្រធានកងពល១១៧? ឆ៖ តារុំ ហើយតា ភ្លេចឈ្មោះមេមួយទៀត។"]។ ឯកសារ D114/191 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សួ, ឆ.១៤ KH ERN 01221833, និងឆ.២៩ KH ERN 01221834 ["ស៖ ពេលលោកទៅដល់ក្រចេះ តើលោកនៅចាំថា មេបញ្ជាការកងពល១១៧ ឈ្មោះអ្វីដែរឬទេ? ឆ.១៤៖ ឈ្មោះ សារុំ, តាលៀង [...] ស៖ ពេលលោកទៅដល់ភ្លាមៗ តើលោកនៅចាំថាមេបញ្ជាការកងពល១១៧ ឈ្មោះអ្វីដែរឬទេ? ឆ.២៩៖ ឈ្មោះ រុំ"]។ ឯកសារ D114/204 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ស៊ីយ៉ាត, ឆ.៤៧-៤៨ KH ERN 01238669 ["ស៖ ពេលលោកទៅដល់ដំបូង មេបញ្ជាការកងពល១១៧ ឈ្មោះអី? ឆ.៤៧៖ ឈ្មោះ រុំ។ ស៖ ចុះមេបញ្ជាការរង? ឆ.៤៨៖ ឈ្មោះ លាង"]។ ឯកសារ D114/192 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចិន ផាត ឆ.២២ និងឆ.២៥, KH ERN 01221845 ["ស៖ ពេលនោះ តើមេបញ្ជាការកងពល១១៧ ឈ្មោះអ្វីដែរ? ឆ.២២៖ ឈ្មោះ រុំ [...] ឆ.២៥៖ មានតែលោក លៀង និងរុំ ហ្នឹងឯងនៅការពារ"]។ ឯកសារ D4.1.313 ទូរលេខកងទ័ពកម្ពុជាប្រជាធិបតេយ្យ ពី ឃុន រ៉ុម កងពល១១៧ រាយការណ៍ជូនសេនាធិការ ចុះថ្ងៃទី២ ខែមីនា ឆ្នាំ១៩៧៨។

3450 D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.៥០ KH ERN 01071602-03 ["ឈ្មោះ ស្វាយ ណូញ ជាប្រធានមន្ទីរកងពល១១៧"]។ ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោសនៅ ស-២១ របស់ ក.ស.ច.ស, លេខរៀង ៨៤៧១ ["ស្វាយ ញ៉ូន, ប្រធានមន្ទីរកងពល១១៧"]។

3451 ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ សាក្សីម៉ឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 15.29.14-15.33.55 KH ERN 01329931-32 [បញ្ជាក់ថាគាត់មាននាទីជាអនុប្រធានមន្ទីរកងពល ១១៧ ដែលមានទីតាំងនៅក្បែរស្ពានក្រគរ ក្រៅក្រុងក្រចេះ]។ សូមអាន ឯកសារ D114/297.1.8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.១៥៥, KH ERN 01136727 ["ខ្ញុំនៅក្នុងសេនាធិការរបស់កងពលលេខ១១៧ ពេលខ្ញុំនៅក្នុងខេត្តក្រចេះ តំបន់៥០៥"]។ ឯកសារ D54/60.2 កំណត់នៃកិច្ចសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី ម៉ឹង វេត, EN 00992991, KH ERN 00975731, FR 00996571 ["[មន្ទីរកងពល១១៧] នៅក្រគរយើង ខាងជើងក្រចេះហ្នឹង (អានឯកសារជាភាសាខ្មែរ)"]។

3452 ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.៩ KH ERN 01071595 ["មានបីកងវរៈសេនាធំ។ គឺកងវរៈសេនាធំលេខ១៥, ១៦, និង១៧។"]។ ឯកសារ D114/191 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី

កងវរសេនាតូច ពីលេខ ១២០ ដល់ ១២៨[3453]។ កងវរសេនាធំលេខ ១៥ មានឈ្មោះ ផន[3454] ជាមេបញ្ជាការ កងវរសេនាធំលេខ ១៦ មានឈ្មោះ នឹម[3455] ជាមេបញ្ជាការ និងកងវរសេនាធំលេខ ១៧ មានឈ្មោះ ឈុត[3456] ជាមេបញ្ជាការ។ តាំងពីពេលបង្កើតមក និងជាពិសេស ពេលមនុស្ស

---

សៅ សូ, ឆ.២៦ KH ERN 01221834 ["សះ តើលោកនៅចាំថាមានកងវរៈសេនាធំអ្វីខ្លះដែរ ក្រោមកងពល១១៧? ឆ.២៦៖ [...] វរៈសេនាធំមានបីទេ វរៈសេនាធំ១៥, ១៦, ១៧"]។ ឯកសារ D114/192 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចិន ផាត ឆ.២១, KH ERN 01221845 ["វរៈសេនាធំ [ចំណុះឱ្យកងពល១១៧] មាន ១៥, ១៦, និង១៧"]។ ឯកសារ D54/60.2 កំណត់នៃកិច្ចសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី ម៉ឹង វ៉េត, EN 00992990, KH ERN 00975729, FR 00996570 ["សះ ដល់ពេលក្នុងកងពលហ្នឹង មានបីវរៈសេនាធំ? ឆះ មានបី មានវ១៥ មាន១៦ មាន១៧"]។

3453 ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.១០, KH ERN 01071595 និងឆ.១៩ KH ERN 01071596 ["នៅក្នុងកងវរៈសេនាធំលេខ១៥ មានបីកងវរៈសេនាតូច គឺកងវរៈសេនាតូចលេខ១២០, ១២១, ១២២។ ឆ.១៩៖ [កងវរៈសេនាធំលេខ១៦] មានបីកងវរៈសេនាតូច គឺកងវរៈសេនាតូចលេខ១២៣, ១២៤, ១២៥។ ចំណែកកងវរៈសេនាធំលេខ១៧ មានបីកងវរៈសេនាតូច គឺកងវរៈសេនាតូចលេខ ១២៦, ១២៧, ១២៨"]។

3454 ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ. ឆ.១១, KH ERN 01071595 ["សះ តើមេបញ្ជាការកងវរៈសេនាធំលេខ១៥ ឈ្មោះអ្វី? ឆ.១១៖ ឈ្មោះ ផន និងអនុឈ្មោះ វ៉េង"]។ ឯកសារ D114/192 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចិន ផាត ឆ.១៨-១៩, KH ERN 01221844 ["ខ្ញុំវរៈសេនាធំ១៥។ ១១៧ កងពលគេ។ សះ តើមេកងវរៈសេនាធំរបស់លោក ឈ្មោះអ្វីដែរ? ឆ.១៩៖ ឈ្មោះ ផន។ អនុឈ្មោះ វ៉េង"]។ ឯកសារ D54/60.2 កំណត់នៃកិច្ចសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី ម៉ឹង វ៉េត, EN 00992990, KH ERN 00975729, FR 00996570 ["សះ ១៥ ពីណាគេប្រធាន? ឆះ កាលហ្នឹង បង ផន។"]។

3455 ឯកសារ D114/52 52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.១៧ KH ERN 01071596 ["សះ តើមេបញ្ជាការកងវរៈសេនាធំលេខ១៦ ឈ្មោះអ្វី? ឆ.១៧៖ មេបញ្ជាការឈ្មោះ នឹម"]។ ឯកសារ D114/191 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សូ, ឆ.១៦ KH ERN 01221833 ["វរៈសេនាធំចាំបានតែ នឹម។ នឹម ជាមេវរៈសេនាធំ១៦"]។ ឯកសារ D114/192 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចិន ផាត ឆ.២១, KH ERN 01221845 ["ហើយ[វរៈសេនាធំ] ១៦ ឈ្មោះ នឹម"]។ ឯកសារ D114/210 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង្ស ខន ឆ.៣១-៣២, KH ERN 01247453 ["គេឱ្យចូលទៅនៅវ.១៦ ដដែល និងនៅកងពល១១៧។ [...] ឆ.៣២៖ មេវ.១៦ថ្មី ឈ្មោះ នឹម ហើយមេកងពលឈ្មោះ រ៉ុម"]។

3456 ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.២១, KH ERN 01071596 ["សះ តើមេបញ្ជាការកងវរៈសេនាធំលេខ១៧ ឈ្មោះអ្វី? ឆ.២១៖ ឈ្មោះ ឈុត"]។ ឯកសារ D114/191 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សូ, ឆ.១៦ KH ERN 01221833 ["ឈុត ជាមេវរៈសេនាធំ១៧។"]។ ឯកសារ D114/192 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចិន ផាត ឆ.២១, KH ERN 01221845 ["ហើយ[វរៈសេនាធំ]១៧ឈ្មោះ ឈុត"]។ ឯកសារ D114/204 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ស៊ីយ៉ាត, ឆ.៤៥-៤៦ KH ERN

ស្លាប់ និងរបួសកើនឡើង កងពល ១១៧ គឺជាកន្លែងចម្រុះសម្រាប់ទាហានមកពីកងពលមជ្ឈិម និងកងពលភូមិភាគជាច្រើន[3457]។

01238669 ["សៈ ពេលលោកទៅ គឺលោកនៅក្នុងកងពល១១៧ ហើយក្នុងវរសេនាធំ១៧ តើមេបញ្ជាការឈ្មោះអី? ឆ. ៤៥៖ ឈ្មោះ ឈុត ស្លាប់ហើយ។ សៈ តើមេបញ្ជាការរងឈ្មោះអី? ឆ.៤៦៖ ផេង ជារងតែស្លាប់អស់ហើយ។"]។

3457 ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ សាក្សីម៉ឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 11.26.24-11.29.25 KH ERN 01329898 ["ដូចថា ឥឡូវខាងខ្ញុំទៅពីណា ទៅពីតាកែវ ពីកំពតអ៊ីចឹងទៅៗក្រចេះ"] និងម៉ោង 13.36.10-13.38.39, KH ERN 01329902-03 ["កម្មាភិបាលថ្នាក់នៅនិរតីផ្លាស់មក ថានៅមកក្រចេះអ៊ីចឹង មក ឧទាហរណ៍៥០៥ [...] ឧទាហរណ៍ ពីតាកែវ ខ្ញុំទៅនៅក្រចេះអ៊ីចឹង"]។ ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វេត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.41.29-09.44.15 KH ERN 01329782 ["[...] នៅកម្លាំងពីគាត់យកមកជួយមួយវរសេនាធំទៀត"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.៦ KH ERN 01071594 ["កងពល១១៧ ត្រូវបានបង្កើតឡើងដោយយកកងយោធាចេញពីកងពលលេខ១ របស់ភូមិភាគបស្ចិម និងកងដទៃទៀត។"]។ ឯកសារ D114/204 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ស៊ីយ៉ាត, ឆ.៣៨-៣៩ KH ERN 01238668 [យោធាពីកោះកុងរូបនេះត្រូវគេបញ្ជូនទៅក្រចេះនៅពាក់កណ្តាលឆ្នាំ១៩៧៨ ដើម្បីទៅប្រយុទ្ធជាមួយកងទ័ពវៀតណាម]។ ឯកសារ D114/192 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចិន ផាត ឆ.៨-១២, KH ERN 01221843-44 [រៀបរាប់ពេលដែលគាត់នៅយោធាតំបន់៣១ (ភូមិភាគបស្ចិម) មុនពេលដែលគេបញ្ជូនចូលកងពល១១៧ នៅក្រចេះ]។ ឯកសារ D114/191 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សូ, ឆ.៤៣-៤៤ KH ERN 01221836 ["សៈ តើលោកដឹងថា យោធាទាំង៣០០០នាក់ដែលត្រូវបានគេបញ្ជូនទៅតំបន់ក្រចេះនោះ មកពីតំបន់ ឬភូមិភាគនាខ្លះដែរ? ឆ.៤៣៖ ភូមិភាគពាយ័ព្យ បស្ចិម។ [...] ពីសៀមរាបទៅដែរ ភូមិភាគ៣០៩ [...] សៈ តើមានកម្លាំងដែលត្រូវបានបញ្ជូនមកពីកំពង់សោម និងភូមិភាគនិរតីដែរឬទេ? ឆ.៤៤៖ មានតើ"]។ ឯកសារ D114/157.1.2 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយសាក្សី សោ សូ, KH ERN 01197588-89 [គេបញ្ជូនយោធាពីភូមិភាពពាយ័ព្យទៅចូលកងពល១១៧ ក្នុងឆ្នាំ១៩៧៧ ឬឆ្នាំ១៩៧៨ ដោយសារមានសភាពការណ៍ច្របូកច្របល់នៅតាមព្រំដែន], KH ERN 01197595-96 ["សៈ ដែលពាក់កណ្តាល១១៧ ពាក់កណ្តាលមកកងពល តាវិន នឹងសុទ្ធតែមកបូព៌ាសុទ្ធ ក៏កាត់ពីណាមកផ្សេងទៀតទេ? ឆៈ មិនមានសុទ្ធតែបូព៌ាទេ ចូលពួកក្រចេះនោះឯង ក្រចេះចូលគ្រប់ ប់សុទ្ធពួកគេចូលខាង ៨០១, ៩២០"]។ ឯកសារ D114/157.1.3 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី ចិន ផាត, EN 01507025, KH ERN 01197641-42 ["ខ្ញុំគិតទៅ គេយកមកពីកំពង់ឆ្នាំងខ្លះ កាលនឹងមកពីតាកែវខ្លះ បាត់ដំបងខ្លះ ពោធិ៍សាត់ខ្លះ មកច្រើន។ [...] មកពីតាកែវ មកពីកំពង់សោមមក ព្រោះទៅស្គាល់គ្នាដល់ក្រចេះ បានស្គាល់គ្នា។"]។ ឯកសារ D114/210 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង្ស ខន ឆ.៣០-៣២, KH ERN 01247453 [អតីតយោធាពីកងពល១រូបនេះបញ្ជាក់ថាគេបំពាក់អាវុធឱ្យគាត់ និងបញ្ជូនទៅចូលក្នុងកងពល១១៧ នៅខែធ្នូ ឆ្នាំ១៩៧៨]។

858. ដោយសហការជាមួយអង្គភាពយោធានៃតំបន់ ៥០៥[3458] កងពល ១១៧ ការពារព្រំដែនវៀតណាម នៅខេត្តក្រចេះ[3459]។ ក្នុងអំឡុងឆ្នាំ ១៩៧៧ និងឆ្នាំ ១៩៧៨ មានការប្រយុទ្ធគ្នាជាញឹកញាប់ នៅក្នុងតំបន់ ដោយកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យ និងវៀតណាម បានចូលលុកលុយក្នុងទឹកដីគ្នាទៅវិញទៅមកជាប្រចាំ[3460]។ កម្លាំងរបស់របស់កម្ពុជាប្រជាធិបតេយ្យតែងតែចាប់[3461] និងសម្លាប់[3462]

---

[3458] D4.1.313 ទូរលេខកងទ័ពកម្ពុជាប្រជាធិបតេយ្យ ពី យុន រ៉ុម កងពល១១៧ រាយការណ៍ជូនសេនាធិការ ចុះថ្ងៃទី២ ខែមីនា ឆ្នាំ១៩៧៨, EN 00795287, KH ERN 00001071, FR 00597360 [“នៅថ្ងៃ២៧-២-៧៨ អង្គភាពខ្ញុំបានសហការណ៍ជាមួយកងតំបន់ បានលើកផែនការវ៉ៃទីតាំងរបស់ខ្មាំងយួន”]។ ឯកសារ D114/101 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.១៣, KH ERN 01127707 [បញ្ជាក់ថាលេខាតំបន់ឈ្មោះ មាស មឿន “កាន់នៅសមរភូមិមុខ”]។ អាន បន្ថែម ឯកសារ D4.1.301 ទូរលេខពី យី (ប៊ន ណន) ផ្ញើទៅកាន់មន្ទីរ ៨៧០ ថ្ងៃទ១៦ ខែធ្នូ ឆ្នាំ ១៩៧៧ [រាយការណ៍ពីការប្រយុទ្ធគ្នារវាយរវាងកម្លាំងយោធាតំបន់៥០៥ និងកងទ័ពវៀតណាម]។ ឯកសារ D4.1.295 ទូរលេខពី គួន (សាន់ ប៊ុនហ៊ី) ទៅ យី (ប៊ន ណន) តាមរយៈមន្ទីរ៨៧០ នៅថ្ងៃទី ៥ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧, KH ERN 00020884 [រាយការណ៍ពី “សភាពការណ៍តាមបណ្តោយព្រំដែនយួន” ដោយបានរៀបរាប់ពីការផ្ទុះអាវុធដាក់គ្នារវាងកម្លាំងយោធាតំបន់៥០៥ និងកងទ័ពវៀតណាម]។

[3459] ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.២៦-២៧ KH ERN 01071597-98 [“កងវរៈសេនាតូចរបស់ខ្ញុំដាក់ពង្រាយការពារនៅតាមព្រំដែន នៅកន្លែងមួយត្រពាំងស្បែក វាលកូនឈ្លូស។ យើងបោះទីតាំងនៅកន្លែងនោះ ដើម្បីការពារព្រំដែនប្រហែល៣-៤ខែ។ [...] ឆ.២៧៖ នៅខាងជើងកងពល១១៧ គឺកងតំបន់៥០៥ ដែលវាយតាមបណ្តោយព្រំដែនឆ្ពោះទៅខាងមណ្ឌលគិរី។ ហួសពីកងតំបន់៥០៥ គឺកងពល៩២០។ មកខាងត្បូងកងពល១១៧ ក៏ជាកងតំបន់៥០៥ដែរ។ កងពល១១៧គឺនៅកណ្តាល។ មកខាងត្បូងទៀតគឺប្រហែលជាយោធារបស់តំបន់២១ ខេលនៅក្នុងតំបន់មេមត់ និងស្នួង។”]។ សូមអាន ជើងទំព័រលេខ ៣៤៦៧-៣៤៦៨។

[3460] ឯកសារ D4.1.313 ទូរលេខកងទ័ពកម្ពុជាប្រជាធិបតេយ្យ ពី យុន រ៉ុម កងពល១១៧ រាយការណ៍ជូនសេនាធិការ ចុះថ្ងៃទី២ ខែមីនា ឆ្នាំ១៩៧៨, EN 00795287, KH ERN 00001071, FR 00597360 [“នៅថ្ងៃ២៧-២-៧៨ អង្គភាពខ្ញុំបានសហការណ៍ជាមួយកងតំបន់ បានលើកផែនការវ៉ៃទីតាំងរបស់ខ្មាំងយួន នៅលើថ្នល់ជាតិលេខ ១៣ ចំងាយពីដីយើងចំនួន ១ គ.ម [...] សព្វថ្ងៃក្រោយពេលដែលអង្គភាព កំពុងតែបន្តវាយ សំរុកកំទេចខ្មាំង ដែលនៅជិត១ព្រំដែនឲ្យបានជាបន្តបន្ទាប់។”]។ ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វ៉េត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 11.07.06-11.09.10 KH ERN 01329805 [“ពេលទៅដល់ហ្នឹង គឺសភាពការណ៍នៅ៧៧ ហ្នឹង គឺយួនបុកគ្រប់១តំបន់។ ដល់អ៊ីចឹងនៅក្រចេះហ្នឹងគឺវាយកបានត្រឹមចម្ការស្នួល ចម្ការកៅស៊ូស្នួលហើយ។ [...]គាត់បំបែកចេញឲ្យខាងលើ ឲ្យទៅជួយវ៉ៃ១១៧ហ្នឹង តែទៅជួយទប់នៅក្រចេះហ្នឹង គឺចម្ការកៅស៊ូស្នួល យួនយកបាត់ហើយ។ [...] ខ្ញុំទៅដល់ហ្នឹងគឺទៅដល់ចម្ការកៅស៊ូហើយ បានវ៉ៃទៅវិញមួយសារ។ [...] បីបួនថ្ងៃយក ទម្រាំតែបានរោងចក្រអារឈើឃ្សឹមវិញ។ ហើយអ៊ីចឹងបានជាយើងរុញទៅដល់នោះ យើងវ៉ៃទៅចូលស្រុកវាម្តងហើយ។ បានជាដល់ចុង៧៨នេះបុកមកមួយសារទៀត។”], ម៉ោង 11.27.20-11.28.50 KH ERN 01329811 [“ខ្ញុំទៅដល់ហ្នឹង គឺយួនមកដល់ហ្នឹងបាត់ហើយ។ ដល់អ៊ីចឹងទៅការវ៉ៃគ្នា

រុញចុះរុញឡើង ក៏វានៅតែត្រង់នុំង វាអត់ៗ កិលទៅមុខក៏មិនទៅ មកក្រោយក៏មិនមក កិលបានទៅមុខបន្តិចមកក្រោយបន្តិច។ [...] ប្រហែលជាដល់ដើម៧៨វិញ អាហ្នឹងវ៉ៃចូលបានមួយចំនួនវិញ ព្រោះខឹងថាគេវ៉ៃមកយើងណា។ តែដល់ក្នុងចុង ប្រហែលជាចុង៧៨ហើយ ប្រហែលជាទៅដល់នៅប៉ុន្មានថ្ងៃផង គេបុកមកវិញយកអាហ្នឹងមកដល់វិញដដែល។”], និងម៉ោង 15.16.21-15.18.49 KH ERN 01329842 [“ចុង៧៨នេះ បានវាបុកមកវិញមួយសារទៀត បានវាយកស្នួលបានទាំងមូលនេះ”]។ ឯកសារ D54/60.2 កំណត់នៃកិច្ចសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយសាក្សី ម៉ឹង វ៉េត, EN 00992986, KH ERN 00975723, FR 00996564 [យោធាកងពល១១៧រូបនេះរៀបរាប់ពីជម្លោះនៅតាមព្រំដែន “បុកមកខ្លាំងឆ្នាំ៧៧ ដែលខ្ញុំនៅក្រចេះហ្នឹង វាថាខាហ្នឹងក៏បុក ខាងក្រចេះក៏បុក ខ្ញុំមកដល់ស្នួល យួនបុកមកដល់ចម្ការកៅស៊ូស្នួលបាត់ហើយហ្នឹង។”], EN 00992998, KH ERN 00975742, FR 00996564 [“យួនបុកគ្រប់ទិស ស្នួលហ្នឹងមិនទាន់យកបានទេ ស្នួលហ្នឹងទើបតែនៅរោងចក្រអារឈើនៅឡើយ”]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.២៦ KH ERN 01071597, ឆ.២៩ KH ERN 01071598, និងឆ.៥៨ KH ERN 01071605 [យោធានៃកងពល១១៧រូបនេះបានពណ៌នាអំពីជម្លោះតាមព្រំដែនថា៖ “នៅអំឡុងពេលនោះ យោធារបស់យើង និងទាហានវៀតណាម វ៉ៃគ្នារុញគ្នាទៅវិញទៅមក។ ពេលខ្លះ វៀតណាមរុញយើងចូលមកដីយើង ពេលខ្លះយើងរុញវៀតណាមចូលទៅក្នុងដីវៀតណាម។ ពេលនោះ ខ្ញុំធ្លាប់វ៉ៃរុញពួកវៀតណាមពីបង្គោលលេខ៥៤ ចូលជ្រៅដល់១០គីឡូម៉ែត រហូតដល់ ឡុកនីង/វ៉ាល់លី ខេត្តស៊ុងប៊ែ។ ឆ.២៩៖[...] [ប្រហែលខែវិច្ឆិកា ឆ្នាំ១៩៧៨] ទ័ពវៀតណាមក៏វ៉ៃខ្សែត្រៀមយើងទៀត។ ដូច្នេះយើងនាំគ្នាដកថយមកទៀត មករហូតដល់ព្រែកឆ្លូង។ ពេលនៅព្រែកឆ្លូង ទ័ពវៀតណាមបានវ៉ៃយើងខ្លាំងមែនទែន រហូតដល់មានយន្តហោះមកទម្លាក់គ្រាប់បែកលើយើងគ្រប់ទិសទី។ ឆ.៥៨៖ [...] ខ្ញុំដឹងថានៅពេលនោះ [ខែតុលា ឆ្នាំ១៩៧៨] យន្តហោះកម្ពុជាប្រជាធិបតេយ្យបានទម្លាក់គ្រាប់បែកលើកងទ័ពវៀតណាមនៅឆ្លូង និងនៅកន្ទួត”]។ សូមអាន ឯកសារ D1.3.33.1 សារទូរលេខរបស់ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ ផ្ញើជូនទៅប្រធានក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៨, EN 00081489, KH ERN 00224424, FR 00224427 [“នៅថ្ងៃទី ២៥, ២៦, ២៧, ២៨, ២៩ និង៣០ ខែធ្នូ ឆ្នាំ១៩៧៨ នៅខេត្តក្រចេះ កងពលធំ ន៣ និង៥ បានវាយប្រហារ និងចូលយ៉ាងជ្រៅមកក្នុងដែនដីកម្ពុជាតាមផ្លូវជាតិលេខ៧ (អតីតផ្លូវជាតិលេខ១៣) នៅឆ្ងាយបន្តិចពីប្រជុំជនសំខាន់នៃស្រុកស្នួល។ ឥឡូវនេះវៀតណាមកំពុងព្យាយាមបន្តចូលមកកាន់តែជ្រៅក្នុងទឹកដីកម្ពុជាថែមទៀត។”]។ ឯកសារ D64.1.37 សារព័ត៌មាន FBIS, AFPរាយការណ៍ពីការឈ្លានពានរបស់កងទ័ពវៀតណាម នៅម្តុំក្រចេះ ចេញផ្សាយថ្ងៃទី៧ ខែធ្នូ ឆ្នាំ១៩៧៨, EN 00169056 [“កងទ័ពឈ្លានពានវៀតណាមកំពុងតែរំកិលខ្លួនចូលមកទឹកដីក្រុងក្រចេះស្ថិតនៅលើច្រាំងទន្លេមេគង្គ ក្នុងគោលបំណងយ៉ាងច្បាស់ក្រឡែតដើម្បីកាត់ផ្តាច់តំបន់ព្លិសានទាំងមូលពីរដ្ឋបាលភ្នំពេញ។ [...] មុខព្រួញវៀតណាមមួយបានចូលមកដល់ចម្ងាយត្រឹមតែ៨០គីឡូម៉ែត្រ (ប្រមាណ៥២,៥ម៉ៃល៍)ភាគខាងជើងក្រចេះ។ ជាមួយគ្នានោះដែរមុខព្រួញទីពីរបានវាយលុកតាមផ្លូវជាតិលេខ១៣ពីភាគខាងកើត”], កងទ័ពនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម បោះទីតាំងនៅចម្ងាយ៣០ម៉ៃល៍ខាងត្បូងទីក្រុងភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៨ [“កងទ័ពវៀតណាម [...] កំពុងវាយប្រយុទ្ធ [...] សំដៅទៅក្រចេះ”], កម្លាំងនៅសមរភូមិមុខបន្តរុញច្រានកម្លាំងឈ្លានពានវៀតណាម, ថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៧៨, EN 00169141 [“[កងព័ទវៀតណាម] បន្តបាញ់រះ និងផ្តោងចូលដីកម្ពុជា [...] មូលហេតុនេះហើយទើបវីរទ័ពឈ្លប និងវីរយុទ្ធជននៃកងទ័ពបដិវត្តនៅសមរភូមិមុខ [...] ក្រចេះ, ផ្លូវលេខ៧ [...] រួម

ចិត្តរួមកាយតែមួយវាយបកទៅលើទ័ពបច្ចាមិត្រវៀតណាមវិញ"]។ អាន ឯកសារ D54/50 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ឆ.១៧, KH ERN 00970611 ["យោងតាមអ្វីដែលពួយោធាប្រាប់ខ្ញុំ នៅពេលនោះកងទ័ពរបស់យួន និងយោធារបស់កងពលលេខ១ គឺបានវៃរុញគ្នាទៅវិញទៅមកក្នុងទឹកដីប្រទេសកម្ពុជា និងប្រទេសវៀតណាម។ [...] ប៉ុន្តែខ្ញុំមិនដឹងពីឈ្មោះទឹកន្លែងដែលគេវៃចូលទៅដល់នោះទេ"]។

3461 ឯកសារ D4.1.313 ទូរលេខកងទ័ពកម្ពុជាប្រជាធិបតេយ្យ ពី ឃុន វ៉ុម កងពល១១៧ រាយការណ៍ជូនសេនាធិការ ចុះថ្ងៃទី២ ខែមីនា ឆ្នាំ១៩៧៨, EN 00795287, KH ERN 00001071, FR 00597360 ["សូមបញ្ជាក់ថា យើងចាប់បាន [ខ្មាំងយួន]១ក្បាល"]។ ឯកសារ D4.1.733 ទូរលេខពី យី (ប៊ិន ណន) ផ្ញើទៅមន្ទីរ៨៧០ ថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៧, EN 00143562, KH ERN 00021508, FR 00623149 [រាយការណ៍ពីការចាប់ខ្លួនកងទ័ពវៀតណាម៥នាក់ ដោយបញ្ជាក់ថានឹងមាន "វិធានការ" និងមានការតាមដាន តាមសហករណ៍ និងតាមព្រៃតទៅទៀត។]។ ឯកសារ D64.1.37 សារព័ត៌មាន FBIS, VOCP: ពួកបះបោរក្រោកឡើងប្រឆាំងនឹងកងទ័ពរដ្ឋាភិបាល, ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៧៨, ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៨, EN 00169108 ["ថ្ងៃទី២៥ ខែធ្នូ នៅស្វាយជាតិ ខេត្តក្រចេះ យុទ្ធជនរបស់យើងបានពើបប្រយុទ្ធជាមួយក្រុមកុម្មង់ដូ និងក្រុមឈ្លបយការណ៍របស់ខ្មាំង។ ខ្មាំងជាង២០០នាក់ត្រូវសម្លាប់ និងចាប់ខ្លួន"]។ អាន ឯកសារ D4.1.408 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈូក រិន, EN 00268873, KH ERN 00194469, FR 00268887 ["ទាហានវៀតណាមទាំងអស់ដែលចាប់បានតាមព្រំដែនជិតខេត្តស្វាយរៀង និងព្រៃវែងត្រូវបានបញ្ជូនទៅភ្នំពេញ។ [...] វិទ្យុកម្ពុជាប្រជាធិបតេយ្យបានចាក់ផ្សាយព័ត៌មានចម្លើយសារភាពរបស់ឈ្លើយសង្គ្រាមវៀតណាមដែលត្រូវចាប់ខ្លួននៅភូមិភាគបូព៌ា និងបញ្ជូនមកភ្នំពេញនៅចន្លោះឆ្នាំ១៩៧៧-៧៨។ ខ្ញុំគិតថាពួកនេះត្រូវបានគេបញ្ជូនទៅឲ្យ ឌុច នៅស-២១"]។

3462 ឯកសារ D4.1.313 ទូរលេខកងទ័ពកម្ពុជាប្រជាធិបតេយ្យ ពី ឃុន វ៉ុម កងពល១១៧ រាយការណ៍ជូនសេនាធិការ ចុះថ្ងៃទី២ ខែមីនា ឆ្នាំ១៩៧៨, EN 00795287, KH ERN 00001071, FR 00597360 ["មួយថ្ងៃមួយយប់ យើងម្ចាស់ការបានលើទីតាំង និងកំទេចខ្មាំងបានទាំងស្រុង។ ២- សរុបជាលទ្ធផល មានដូចខាងក្រោមនេះ យើងកំទេចខ្មាំងយួនបាន៩៨ក្បាល ដាប់នៅកន្លែង នៅសល់តែ៦ក្បាលទេ ដែលរត់រួចទៅឡុកនិញ ក្រៅពីនេះយើងកំទេចបានទាំងអស់។ [...] យើងកំទេចកម្លាំងរស់របស់ខ្មាំងបាន៩៩ភាគរយ"]។ ឯកសារ D1.3.34.50 ទូរលេខពី កួន (សាន់ ប៊ុនហ៊ី) ផ្ញើទៅ យី (ប៊ិន ណន) តាមរយៈមន្ទីរ៨៧០, ថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៧, KH ERN 00020915, EN 00183630, FR 00291041 ["ខាងខ្មាំងត្រូវកំទេច និងរបួសប្រហែល២៥០ក្បាល។"]។ ឯកសារ D1.3.25.40 សារព័ត៌មាន SWB, ប្រទេសកម្ពុជារាយការណ៍អំពីការបន្តទម្លាក់គ្រាប់បែករបស់វៀតណាម, ថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៧៨, EN S 00010448, KH ERN 00701663, FR S 00726759 ["ចាប់តាំងពីថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៨ មក នៅពេលកងទ័ព និងប្រជាជនដ៏មានវីរភាពរបស់យើងវាយបណ្តេញពួកឈ្លានពានវៀតណាមឲ្យត្រឡប់ទៅទឹកដីរបស់ពួកវាវិញ ពួកវៀតណាលេបយកទឹកដី និងវាតទីនិយម បានបន្តយ៉ាងមិនស្រាកស្រាននូវសកម្មផាពបង្ករឿង និងទន្ទ្រានទឹកដីកម្ពុជា [...] ខ្មាំងវៀតណាមបន្តបាញ់ផ្លោងពីទឹកដីរបស់ពួកវា ចូលមកលើទឹកដីរបស់យើង ហើយបញ្ជូនពួកចារកម្ម និងកុំម្មង់ដូរឲ្យមកស៊ើបការណ៍ និងធ្វើវិទ្ធង្សនា ព្រមទាំងសកម្មភាពបំផ្លិចបំផ្លាញប្រជាជន និងទ្រព្យសម្បត្តិរបស់យើង។ ខ្មាំងវៀតណាមបានបាញ់ផ្លោង និងបាញ់ប្រហារមកលើទឹកដីយើង។ ខ្មាំងវៀតណាមក៏បានបង្កើនការទម្លាក់គ្រាប់មែកមកលើទឹកដីយើងនៅម្តុំបរិវេណផ្លូវជាតិលេខ៧ ប្រហែល១០គីឡូម៉ែតពីព្រំដែន"]។

ប្រជាជនវៀតណាម។ ជារឿយៗ ប្រជាជនវៀតណាមដែលចាប់បាន ត្រូវបាន ប.ក.ក ប្រកាសថា បានធ្វើសកម្មភាពស៊ើបការណ៍[3463] និងត្រូវគេបញ្ជូនពីខេត្តក្រចេះ ទៅទីក្រុងភ្នំពេញ រួចត្រូវបានសួរចម្លើយ នៅមន្ទីរ ស-២១[3464] ហើយចម្លើយសារភាពត្រូវបានចាក់ផ្សាយតាមវិទ្យុ[3465]។

## ៣. ការចោសសម្អាត ការជំនួស និងការត្រួតពិនិត្យ

859. នៅខែ តុលា ឆ្នាំ ១៩៧៨ មាស មុត បានកាន់ឡើងជាអនុរបស់ សុន សេន នៅសេនាធិការ[3466]។ គាត់បញ្ជាកម្លាំងកងពល ១១៧ ទទួលរបាយការណ៍ និងចេញបញ្ជាដល់កងទ័ពដែលចូលរួមប្រយុទ្ធ

---

3463 អានឧទាហរណ៍ ឯកសារ D64.1.37 សារព័ត៌មាន FBIS, កម្លាំងនៅសមរភូមិមុខបន្តរុញច្រានកម្លាំងឈ្លានពានវៀតណាម, ថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៧៨, EN 00169141 ["[កងព័ទវៀតណាម] បន្តបាញ់រះ និងផ្លោងចូលដីកម្ពុជា និងបញ្ជូនកងកុម្មង់ដូរចូលឈ្លបយកការណ៍ និងធ្វើសកម្មភាពចារកិច្ចក្នុងទឹកដីរបស់យើងយ៉ាងគឃ្លើន"]។

3464 អាន ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ៨៨៩៨ [Ngien Van-An Corporal-Star 1 "វៀតណាម", ចាប់ខ្លួនពីក្រចេះ ស្រុកស្នួល តំបន់៥០៥, ចូល ស-២១ ថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៨]។ វៀតណាមមួយក្រុមត្រូវបានគេចាប់បញ្ជូនចូល ស-២១ ថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៧៨ ដោយផ្នែកចារកម្មពីស្រុកស្នួល ខេត្តក្រចេះ តំបន់៥០៥។ បន្ទាប់មកមានកងទ័ពវៀតណាមពីរនាក់ក៏ត្រូវបានចាប់បញ្ជូនមកនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៧៨។ អាន ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ១២៥៩៥-១២៥៩៩ (ថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៧៨), លេខរៀង១២៦៤៥-១២៦៤៦ (ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៧៨)។

3465 ឯកសារ D64.1.43 សារព័ត៌មាន FBIS, ឈ្លើយសឹកវៀតនាមសារភាពថាខ្លួនទទួលបានការណែនាំឱ្យចូលមកប្រទេសកម្ពុជា ថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៨ ["ស្ថានីយ៍វិទ្យុរាយការណ៍នៅថ្ងៃទី៤ ខែឧសភា ពីចម្លើយសារភាពរបស់ពលបាលត្រីកងទ័ពសាធារណរដ្ឋសង្គមនិយមវៀតណាមម្នាក់ឈ្មោះ ង្វៀន វ៉ាន់ អាន ដែលត្រូវគេចាប់ខ្លួនបាននៅថ្ងៃទី២១ ខែមេសា នៅស្រុកស្នួល តំបន់ក្រចេះ ភូមិភាគឦសាន"]។ អាន ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ៨៨៩៨ [ង្វៀន វ៉ាន់ អាន ពលបាលត្រី ផ្កាយ១ "វៀតណាម", ចាប់ខ្លួនពីស្រុកស្នួល ក្រចេះ តំបន់៥០៥, ចូលស-២១ ថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៨]។

3466 អាន III.2 តួនាទីរបស់មាស មុត- អនុលេខាសេនាធិការ។ សូមអាន ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី សេង សឿន ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១៦ នៅម៉ោង 13.54.58-13.57.43, និងម៉ោង 13.01.14-14.03.54 KH ERN 01355200-03 Seng Soeun, T. 29 Aug 2016, ["ពីមុនគាត់ [ស៊ូ ម៉េត] កាន់[កងពល]ទី១ ហើយបង មុត កងពលលេខ៣។ [...] ពូសុន សេន នោះក្រសួងការពារជាតិហ្នឹងក៏លែងទៅណាទៅណីដែរ។ ស្រាប់តែពីរនាក់ហ្នឹង គាត់ទៅកាន់តំណែងក្រសួងការពារជាតិហ្នឹងទៅ។ ស្រាប់ដល់ បង មុត ទៅចាត់តាំងខ្ញុំហ្នឹង។"]។ ឯកសារ D114/169 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន, ឆ.២៥ KH ERN 01203859 ["កាលនុ៎ងគាត់[មាស មុត] កាន់កងជើងទឹក កងទ័ពជើងទឹកផង មកកាន់គេហៅអនុក្រសួងការពារជាតិជំនួស សុន សេន [...] មុត ពនុ ហើយចុះមករៀបចំតំបន់ក្រចេះ"]។

តាមព្រំដែនវៀតណាម[3467]។ ក្នុងអំឡុងពេលនោះ ជម្លោះព្រំដែន រវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម បានចាប់ផ្តើមឡើងកម្តៅខ្លាំង ហើយកម្លាំងវៀតណាមបានចូលលុកលុយយ៉ាងជ្រៅក្នុង

---

ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វ៉េត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 13.48.51-13.50.21 KH ERN 01329818 [“ខ្ញុំនៅ[កងពល]១១៧ ដល់អ៊ំ[មាស មុត] គាត់នៅអគ្គសេនាធិការ [...] កម្ពុជាប្រជាធិបតេយ្យមានអ៊ំ សុន សេន អគ្គសេនាធិការ។ អ្ហ៎!មាន មាស មុត អគ្គសេនាធិការរង។ អ្ហ៎! មក ស៊្វ ម៉េត ជើងអាកាស អគ្គសេនាធិការរងទៀត។”]។ អានបន្ថែម ឯកសារ D54/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វ៉េត ឆ.២២-២៣ KH ERN 00975783 [“តាមដែលខ្ញុំដឹង មាស មុត ជាអគ្គសេនាធិការរងរបស់កងទ័ព មានន័យថា អនុរបស់ សុន សេន។ [...] ឆ.២៣៖ សុន សេន ជាមេបញ្ជាការអគ្គសេនាធិការទទួលខុសត្រូវរួម និងកងថ្មើរជើង។ មាស មុត ជាអនុរបស់ សុន សេន ទទួលខុសត្រូវខាងជើងទឹក។ [...] រាល់ទំនាក់ទំនងតាមវិទ្យុទាក់ទង និងសារទូរលេខគឺត្រូវតែឆ្លងកាត់អគ្គសេនាធិការ។”]។ ឯកសារ D59/1/1.8a កំណត់នៃកិច្ចសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី ព្រុំ សារ៉ាត់, EN 00974225-27, KH ERN 00926401-03, FR 01413165-67 [ប្រហែលខែកញ្ញា ឆ្នាំ១៩៧៨ មាស មុត បានទៅភ្នំពេញ។ មាស មុត ជាមេបញ្ជាការរងនៃសេនាធិការ។ តួនាទីនេះត្រូវគេតំឡើងនៅចុងឆ្នាំ ១៩៧៨]។

3467 ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វ៉េត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 13.46.24-13.48.51 KH ERN 01329817-18 [“ច្រកផ្លូវមុខដូចទៅក្រចេះអ៊ីចឹង សារត្រូវបញ្ជូនឲ្យគាត់ [អ៊ំមុត] [...] ខ្ញុំត្រូវទំនាក់ទំនងមកគាត់។ ដល់អ៊ីចឹងទៅ រឿងគាត់ គាត់ទំនាក់ទំនងគ្នាបានហើយ។ [...] ដូចគ្រាប់ត្រូវគ្រាប់ប៉ុន្មានកប៉ាល់ ត្រូវអាវុធប៉ុន្មានដើម។”]។ ឯកសារ D54/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វ៉េត ឆ.២២ KH ERN 00975783 និងឆ.២៥ KH ERN 00975784 [“នៅពេលយួនវ៉ៃបុកមកលើយើងនៅតាមព្រំដែន មាស មុត ត្រូវតែទៅត្រួតពិនិត្យស្ថានការណ៍នៅសមរភូមិ [...] ឆ.២៥៖ តាមខ្ញុំដឹង ក្នុងនាមគាត់ជាអគ្គសេនាធិការរង ដូច្នេះគាត់ត្រូវតែទៅពិនិត្យស្ថានការណ៍នៅកន្លែងមានជម្លោះនៅតាមព្រំដែន។”]។ ឯកសារ D54/63 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វ៉េត ឆ.១១-១៧, KH ERN 00975795-96 និងឆ.១៩ KH ERN 00975796-97 [“មាស មុត នៅសេនាធិការ ដូច្នេះគាត់មានសិទ្ធិអំណាចបញ្ជាទៅកងទ័ពទាំងបីប្រភេទ។ [...] ឆ.១២៖ [...] [ខែតុលា ឆ្នាំ១៩៧៨] យើងក៏បានស្នើសុំទៅ មាស មុត តែម្តង ហើយគាត់បានប្រាប់ រុំ ឲ្យចាំបន្តិច ហើយនៅពេលរសៀល គាត់បានបញ្ជូនយន្តហោះមកជួយយើងង [...] ឆ.១៣៖ ក្នុងនាមជានីរសារ ខ្ញុំធ្វើការនៅក្នុងមន្ទីរជាមួយនឹងអ្នកសារទូរលេខ ហើយនិងមេបញ្ជាការ ដូច្នេះខ្ញុំអាចដឹងអំពីអ្វីៗដែលកើតមាននៅក្នុងមន្ទីរហ្នឹង។ ស៖ នៅពេលដែលលោកនិយាយថា មាស មុត បញ្ជាឲ្យរុំ រង់ចាំ តើគាត់ប្រាប់តាមសារទូរលេខ ឬតាមវិទ្យុទាក់ទង? ឆ.១៤៖ គាត់បានឆ្លើយតបមកវិញ តាមសារទូរលេខ។ ស៖ ពេលផ្ញើរបាយការណ៍ពីកងពល១១៧ ទៅឲ្យ មាស មុត តើគេធ្វើជាប្រចាំថ្ងៃ ឬក៏ធ្វើឡើងរាល់ពេលដែលមានព្រឹត្តិការណ៍កើតឡើង? ឆ.១៥៖ មុនពេលមានការវ៉ៃគ្នា របាយការណ៍នេះគឺផ្ញើទៅជាប្រចាំថ្ងៃ រាល់ៗថ្ងៃ ប៉ុន្តែក្រោយពីមានព្រឹត្តិការណ៍វ៉ៃគ្នា របាយការណ៍ត្រូវបានផ្ញើរាល់ពេលដែលមានហេតុការណ៍កើតឡើង។ [...] ឆ.១៦៖ គឺដាក់ថា ជូនទៅអគ្គសេនាធិការ គឺមិនមែនដាក់ទៅបុគ្គលណាជាក់លាក់ទេ ប៉ុន្តែយើងដឹងថាអ្នកទទួលសារទូរលេខ គឺជាអ្នកដែលធ្វើការឲ្យអ្នកណាម្នាក់ហើយ។

ទឹកដីកម្ពុជា[3468]។ កម្លាំងកម្ពុជាប្រជាធិបតេយ្យមិនអាចទប់ទល់នឹងការវាយប្រហាររបស់វៀតណាម ដែលមានប្រៀបខាងយោធាបានឡើយ[3469] ហើយចាប់ផ្តើមដកថយ[3470]។ ក្នុងពេលដដែលនោះ

---

ឧទាហរណ៍ ធី និង គង់ ជាអ្នកកាន់សារទូរលេខឱ្យ មាស មុត។ សៈ ហេតុអ្វីបានជាលោកដឹង មាស មុត ជាអ្នកផ្ញើសារទូរលេខឱ្យ រុំ ឱ្យរង់ចាំការបញ្ជូនយន្តហោះនៅពេលនោះ? ឆ.១៧៖ [...] ខ្ញុំឃើញសារទូរលេខ។ [...] ឆ.១៩៖ [...] មាស មុត ចាប់ផ្តើមពាក់ព័ន្ធទទួលខុសត្រូវបញ្ជានៅតាមព្រំដែនខាងកើតក្នុងឆ្នាំ១៩៧៨ ពេលដែលយួនវ៉ៃបុកខ្លាំង។"]។ ឯកសារ D114/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត់ (ប៊ុន សារ៉ាត់) ឆ.២២៩, KH ERN 01354332 ["ពេល មាស មុត គាត់ធ្វើដំណើរទៅក្រចេះ គោលបំណងសំខាន់ គឺសង្គ្រាមតាមព្រំដែនរវាងវៀតណាម កម្ពុជាចាប់ផ្តើមមានការប្រយុទ្ធក្នុងសភាពតានតឹង"]។

3468 ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វ៉េត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.10.54-09.13.47 KH ERN 01329770-71 ["ពេលយួនបុកមកដល់ហ្នឹងគឺច្របូកច្របល់ពេលហ្នឹង [...] កម្លាំងខ្ញុំដែលជុំវិញកងពលមួយចំនួនដឹកសម្ភារៈទៅស្ទឹងត្រែងត្រូវយួនបុកហើយ [...]។ ហើយកម្លាំងខ្ញុំដែលធំៗត្រូវវ៉ៃយួនកើត ត្រូវមកទប់នៅខាងព្រែកទេរវិញ។ ដល់អ៊ីចឹងទៅ ត្រូវទទួលគ្រោះថ្នាក់ហ្នឹងវាត្រូវធ្លាក់ទឹកទន្លេខ្លះរត់ប្រសេចប្រសាច"], និងម៉ោង 15.16.21-15.18.49 KH ERN 01329842 ["ចុង៧៨នេះ បានវាបុកមកវិញមួយសារទៀត [...] គឺយកស្រុកស្នួលបានទាំងមូលត្រឹមថ្ងៃទី១១ ខែ១០ ឆ្នាំ៧៩ ដែលយកយន្តហោះវាបួនគ្រឿង និងទ័ពវៀតណាមមកបុកហ្នឹង។"]។ ឯកសារ D54/63 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វ៉េត ឆ.២, KH ERN 00975792-93 ["ការប្រយុទ្ធគ្នាខ្លាំងនៅថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៧៨ [...] វៀតណាមក៏បញ្ជូនយន្តហោះមកទម្លាក់គ្រាប់បែកលើឃ្លាំងគ្រាប់ និងស្បៀងអាហារនៅខាងកើតព្រែកឆ្លូងដែរ។ ក្រោយមក ខាងកងទ័ពយើងបានហៅយន្តហោះ២គ្រឿងមកជួយទម្លាក់គ្រាប់លើរថក្រោះវៀតណាម និងក្រោយមកទៀតមានយន្តហោះ២គ្រឿងទៀតមកទម្លាក់លើកងទ័ពវៀតណាមម្តងទៀត។ យន្តហោះស្លាបកាត់២គ្រឿងរបស់យើងបានបើករត់ទៅចុះនៅឡាវ ហើយយន្តហោះ១គ្រឿងទៀតបានត្រឡប់ទៅភ្នំពេញវិញទេ។ ក្រោយមកយន្តហោះរបស់យើងមួយគ្រឿងត្រូវបានកងទ័ពវៀតណាមបាញ់ទម្លាក់"]។ ឯកសារ D4.1.458 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តន់ សារឿន EN 00225534, KH ERN 00196826, FR 00272778 ["នៅចុងឆ្នាំ១៩៧៨ [...] វៀតណាមវាយបុកចូលខ្លាំង"]។ ឯកសារ D114/149 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច ឈុំ, ឆ.៣០ KH ERN 01184226 ["នៅចុងឆ្នាំ[១៩]៧៨ យួនវ៉ៃបុក"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.២៨ KH ERN 01071598 ["កងពល១១៧ ចាប់ដកចេញពីព្រំដែនវៀតណាមនៅប្រហែលខែ តុលា ឆ្នាំ ១៩៧៨ ដោយសារកងទ័ពវៀតណាម វ៉ៃសង្កត់យើងខ្លាំង"]។ ឯកសារ D114/171 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ សារួន ឆ.៦៤ KH ERN 01204181-82 [សាក្សីរូបនេះជាអតីតប្រពន្ធរបស់លេខាស្រុកក្រចេះឈ្មោះ ហួន យ៉េង "ស៖ ពេលនោះ [ក្នុងខែវិច្ឆិកា ឬដើមខែធ្នូ ឆ្នាំ១៩៧៨] មានការប្រយុទ្ធគ្នាតានតឹងទេ នៅតំបន់នោះ? ឆ.៦៥៖ មានភាពតឹងតែងនៅស្រុកស្នួល ប្រយុទ្ធគ្នាជាមួយយួន"]។

3469 ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វ៉េត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.41.29-09.44.15 KH ERN 01329781 ["គឺដឹង

វន វេត បានឆ្លើយដាក់មេដឹកនាំជាន់ខ្ពស់កងពល ១១៧ និងតំបន់ ៥០៥ ដោយសារការធ្វើទារុណកម្មនៅមន្ទីរ ស-២១[3471]។ ជាលទ្ធផល មជ្ឈិមនៅតែសង្ស័យពីអំពើក្បត់របស់ថ្នាក់ដឹកនាំតំបន់[3472]។

---

ហើយថាកម្លាំងគេធំជាង កាំភ្លើងគេទំនើបជាង កម្លាំងគេច្រើនជាង"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.២៥ KH ERN 01071597 ["ដោយសារទ័ពវៀតណាមខ្លាំងជាងយើង យើងត្រូវដកថយ"]។

3470 ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ សាក្សីម៉ឺង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 13.38.39-13.41.28 KH ERN 01329904 ["ដល់ចុងកន្ទុយ [ចុងឆ្នាំ១៩៧៨] ពេលដែលយួនបុកមកខ្លាំងនេះ ដែលទប់លែងជាប់"], និងម៉ោង 15.38.37-15.41.39, KH ERN 01329934 ['យួន យកស្នួលបានទាំងមូលហើយ"]។ ឯកសារ D54/63 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីម៉ឺង វេត ឆ.២, KH ERN 00975792-93 ["យន្តហោះស្ពាបកាត់២គ្រឿងរបស់យើងបានបើករត់ទៅចុះនៅឡាវហើយយន្តហោះ១គ្រឿងទៀតបានត្រឡប់ទៅភ្នំពេញវិញទេ។ ក្រោយមកយន្តហោះរបស់យើងមួយគ្រឿងត្រូវបានកងទ័ពវៀតណាមបាញ់ទម្លាក់"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.២៨-៣០ KH ERN 01071598-99 ["កងពល១១៧ ចាប់ដកចេញពីព្រំដែនខ្មែរវៀតណាមនៅប្រហែលខែតុលា ឆ្នាំ១៩៧៨ ដោយសារតែកងទ័ពវៀតណាមវ៉ៃសង្កត់យើងខ្លាំង។ ឆ.២៩៖ យើងដកថយពីបន្ទាត់ព្រដែនកមនៅត្រឹមស្នួល។ យើងនៅស្នួលប្រហែលជា១ខែ រៀបចំខ្សែត្រៀម ប្រហែល១ខែក្រោយមក ទ័ពវៀតណាមវ៉ៃបាក់ខ្សែត្រៀមយើងទៀត។ ដូច្នេះយើងនាំគ្នាថយមកទៀតមកឈប់នៅត្រឹមព្រែកឆ្លូង។ ពេលនៅព្រែកឆ្លូង ទ័ពវៀតណាមបានវ៉ៃយើងខ្លាំងមែនទែនរហូតដល់មានយន្តហោះមកទម្លាក់គ្រាប់បែកលើយើងគ្រប់ទិសទី។ [...] ឆ.៣០៖ បន្ទាប់ពីយើងដកពីឆ្លូង យើទៅរៀបចំគ្នាឡើងវិញ ហើយខ្សែការពារនៅស្វាយជ្រះ ទឹកពុល ឆ្ពោះទៅភ្នំប្រាំពាន់។ អំឡុងពេលនោះ ការបោសសម្អាតបានចាប់ផ្តើម"]។ សូមអាន ឯកសារ D114/167 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុំ យ៉ា, ឆ.៤៦ KH ERN 01202863 [សាក្សីជាប្អូនស្រីរបស់អតីតលេខាស្រុកស្នួល ឈ្មោះ ឈុំ ចិន ហៅ ភ័ន ពន្យល់ថា នៅឆ្នាំ១៩៨២ ឬឆ្នាំ១៩៨៣ ប្រពន្ធរបស់ ឈុំ ចិន បានប្រាប់គាត់ថាគេចាប់ប្តីគាត់ដោយសារ "គេចោទថាយើងធ្វើការមិនកើតទើបយួនចូលស្រុកបាន"]។

3471 វន វេត ត្រូវចាប់ខ្លួន ហើយបញ្ជូនទៅកាន់មន្ទីរ ស-២១ នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ១៩៧៨ (អាន ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ១៤៥១៤) "ចម្លើយសារភាព"មួយចំនួនរបស់គាត់បានឆ្លើយដាក់ទៅលេខា និងអនុលេខាកងពល១១៧ ឈ្មោះ ឃុន រ៉ុ និងវ៉ាត្ន លាង, លេខា និងអនុលេខាតំបន់៥០៥ ឈ្មោះ មាស មឿន និងឈឹម ខុន។ អាន ឯកសារ D4.1.28 ចម្លើយសារភាពរបស់ វន វេត នៅមន្ទីរ ស-២១, EN 00767787, 00767791-92, 00767805, KH ERN 00009984, 00009986-87, 00009997 (ខែវិច្ឆិកា ឆ្នាំ១៩៧៨), EN 00767820, KH 00010018-19 (24 November 1978), EN 00767831, KH ERN 00010035-36 (ថ្ងៃទី១ ខែធ្នូ ឆ្នា១៩៧៨), EN 00767887, KH 00010161-62 (ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៨)។ អានបន្ថែម ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី

មុឹង វេត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 13.50.21-13.52.28 KH ERN 01329818-19 ["មុនដែលយួនចូល មុនចាប់ទាំង១១នាក់នេះ អ៊ំវន វេត បានទៅ [...] គាត់ត្រឡប់មកភ្នំពេញបាន១ថ្ងៃ ឬ២ថ្ងៃ ថាចាប់គាត់ហើយ បានចាប់អ្នក១១នាក់នេះ។ [...] គាត់ទៅត្រួតពិនិត្យនៅក្រចេះហ្នឹង ទៅ៣ថ្ងៃ។ [...] វាចន្លោះពីខែ១២ ខែ១១នេះ វានៅចន្លោះត្រង់ហ្នឹង។ ខ្ញុំវាមិនបានចាំថ្ងៃទេ [...] ហើយគាត់មកភ្នំពេញវិញ ឮដំណឹងថាចាប់គាត់ទៅ។ ហើយក្រោយមក បានប្រហែលជាប៉ុន្មានថ្ងៃទៀត ហ្នឹងថ្នាក់ដឹកនាំ"]។

3472 ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សីមុឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 13.38.39-13.41.28 KH ERN 01329904 ["ទប់[យួន] លែងជាប់ ចាប់ផ្តើមលែងទុកចិត្តខាងខ្ញុំបណ្តោយ [...] ដោយខ្សែកថ្នាក់លើៗនោះ ត្រូវចោទប្រកាន់ថ្នាក់លើនោះវិញ"]។ ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី មុឹង វេត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.10.54-09.13.47 KH ERN 01329770-71 ["អ្នកទៅជួរថ្មីនេះ ដូចជាមានគណៈតំបន់ថ្មី កងពលថ្មីដែលទៅនេះ គាត់បាននិយាយថាមេឯងក្បត់អស់ហើយ។ ហ្នឹងដែលបានពួកខ្ញុំនោឡោ ពេលយួនបុកមកដល់ហ្នឹងគឺច្របូកច្របល់ពេលហ្នឹង លែងទុកចិត្តគ្នាទាំងអស់។"], និងម៉ោង 09.39.51-09.41.29 KH ERN 01329781 ["គាត់ [មាស មុត] គ្រាន់តែថា "ពួកហ្លែងគ្រប់គ្នាអត់វៃយួនសោះ ឲ្យយួនបុកយកបានទាំងមូល។"]។ ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី សេង សឿន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 13.48.25-13.51.55 KH ERN 01355199-200 [បញ្ជាក់ថាកម្មាភិបាលមុនៗនៅក្រចេះត្រូវបានគេចាប់ខ្លួនដោយសារ "គេថាសុទ្ធតែខ្សែក្បត់"] ដោយបញ្ជាក់នៅក្នុង ឯកសារ D114/169 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.២៧, KH ERN 01203859 ["សម័យនុំងកំពុងតែចាប់ពួកអ្នកនៅខ្សែយួន"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.៣៤ និងឆ.៣៩ KH ERN 01071599-600 ["យើងដឹងថា រ៉ុ និង លាង ត្រូវបានចាប់យកទៅសម្លាប់ ដោយពួកយើងកងពល១១៧ ត្រូវបានចោទប្រកាន់ថា ជាយោធាទន់ខ្សោយ មិនអាចវៃទ័ពវៀតណាមបាន។ [...] គេចោទកងពល១១៧ ថាចូលដៃចូលជើងជាមួយយួន ហើយវៃមិនឈ្នះយួន និងចេះតែដកថយ ពេលយួនវៃចូល។"]។ ឯកសារ D54/63 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុឹង វេត ឆ.២, KH ERN 00975792-93 ["មាស មុត បានខឹង ដោយកាត់និយាយថា ពួកយើងមិនដាច់ខាតវៃនឹងយួនទេ។ ដោយសារតែព្រឹត្តិការណ៍ទាំងនេះ បានជា តា មុត គាត់ឈប់ជឿលើថ្នាក់ដឹកនាំកងពល ហើយដកអ្នក១១នាក់នោះចេញ"]។ ឯកសារ D114/216 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ឆ.៤៣ KH ERN 01301460 [បញ្ជាក់ថាមានគេមកប្រាប់គាត់ថា មាស មឿន ត្រូវគេចាប់ខ្លួនហើយ "មកពី មាស មឿន ធ្វើមេធំ ហើយទប់យួនមិនបាន វៃយួនមិនបាន"]។ ឯកសារ D114/210 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង្ស ខន ឆ.៣៧, KH ERN 01247453 [បញ្ជាក់ថានៅពេលដែលគេបញ្ជូនគាត់ទៅក្រចេះនៅចុងឆ្នាំ១៩៧៨ "យូរៗគេលែងទុកចិត្តគ្នាឯង។ នៅពេលនោះសង្គ្រាមផ្ទៃក្នុងកំពុងបែកបាក់"]។ ឯកសារ D114/167 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុំ យ៉ា, ឆ.៤៦ KH ERN 01202863 [សាក្សីជាប្អូនស្រីរបស់អតីតលេខាស្រុកស្នួល ឈ្មោះ ឈុំ ចិន ហៅ ភ័ន ពន្យល់ថា នៅឆ្នាំ១៩៨២ ឬឆ្នាំ១៩៨៣ ប្រពន្ធរបស់ ឈុំ ចិន បានប្រាប់គាត់ថាគេចាប់ប្តីគាត់ដោយសារ "គេចោទថាយើងធ្វើការមិនកើតទើបយួនចូលស្រុកបាន។"]។ ឯកសារ D114/203 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុិញ នឿម ឆ.១២ KH ERN 01238656 និងឆ.៤២ KH ERN

860. ជាការឆ្លើយតប ក្នុងអំឡុងចុងខែវិច្ឆិកា ឆ្នាំ ១៩៧៨ **មាស មុត** បានទៅក្រចេះ[3473] តាងនាមមជ្ឈិមបក្ស[3474] ដើម្បីសម្របសម្រួលការបញ្ជូនកម្មាភិបាលជាន់ខ្ពស់បំផុតរបស់កងពល ១១៧ និងតំបន់

---

01238660 ["[មេបញ្ជាការកងពល១១៧] ឈ្មោះ រុំ តែគាត់ស្លាប់ហើយ។ គេចាប់គាត់ដោយគេចោទថាគាត់ក្បត់ [...] ឆ.៤២៖ ដល់ពេលយើងចាញ់វៀតណាម រុំ និងលៀង ស្លាប់អស់ទៅ គឺគេចាប់យកទៅ"]។

3473 មាស មុត ខ្លួនឯងទទួលស្គាល់ថាគាត់ទៅក្រចេះ។ ប៉ុន្តែវាមិនស៊ីសង្វាក់គ្នាជាមួយភ័ស្តុតាងដទៃទៀតនៅក្នុងសំណុំរឿងឡើយ។ គាត់បានបញ្ជាក់ថាដំណើរទៅនោះគឺនៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៨។ ឯកសារ D54/16/1R ឯកសារសម្លេងនៃកិច្ចសម្ភាសន៍រវាង David Kattenburg ជាមួយ មាស មុត កាលពីខែមេសា ឆ្នាំ២០០៩ នៅចន្លោះម៉ោង 34:37-35:28 ["ខ្ញុំមិននៅកំពង់សោមទេ។ ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៨ ខ្ញុំបានចេញពីកំពង់សោមហើយ។ ស៖ តើគាត់ទៅឯណា? ឆ៖ គេចាត់តាំងខ្ញុំឱ្យទៅធ្វើការនៅខេត្តក្រចេះ ក្បែរព្រំដែនឡាវ។ ស៖ តើគាត់ចេញពីកងពល ១៦៤ ចាប់ពីខែកុម្ភៈ ឆ្នាំ១៩៧៨ នោះមែនទេ? ឆ៖ អត់ទេ តួនាទីខ្ញុំនៅដដែលទេ ប៉ុន្តែគេចាត់តាំងខ្ញុំឱ្យធ្វើបេសកកម្មមួយទៀតនៅក្រចេះ"]។ អាន ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ សាក្សីម៉ឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 15.38.37-15.41.39, KH ERN 01329934 ["ការផ្លាស់ប្តូរមុខតំណែង វាត្រូវអ្នកថ្មីទៅជួរ អ្នកចាស់ត្រូវជកជិះយន្តហោះមកភ្នំពេញ មកក៏ត្រូវបាត់ខ្លួនរហូត។ យួនបុកខ្លាំងនេះហើយ សភាពការណ៍តឹងតែងមែនទែន ដែលយួនយកស្នួលបានទាំងមូល។ អ៊ំ មុត គាត់ទៅ"]។ ឯកសារ D54/60.2 កំណត់នៃកិច្ចសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី ម៉ឹង វេត, EN 00992990, KH ERN 00975728, FR 00996569 ["ឆ្នាំ៧៨នេះ បានគាត់ [មាស មុត] ទៅក្រចេះបានតែន្តិចហ្នឹង ទៅក្រោយចាប់ អ៊ំ វន វេត ហើយទេ"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.៤២ KH ERN 01071601 ["ស៖ តើមាស មុត ទៅដល់តំបន់ក្រចេះនៅពេលណា? ឆ.៤២៖ តាមព្រឹត្តិការណ៍ដែល តាញ៉ាន់ ទៅកាន់បញ្ជាការកងពល១១៧ គឺប្រហែល១ខែមុនពេលវៀតណាមចូល គឺនៅប្រហែលជាចុងខែវិច្ឆិកា ឬដើមខែធ្នូ ឆ្នាំ១៩៧៨។ ដូច្នេះខ្ញុំគិតថា មាស មុត ទៅដល់ទីនោះនៅអំឡុងពេលនោះឯង"]។ ឯកសារ D54/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាក សុក ឆ.៨-៩ KH ERN 00955482-83 ["មាស មុត ត្រូវបានគេបញ្ជូនទៅក្រចេះ ពីព្រោះពេលនោះមានការចាប់កម្មាភិបាលគឺមានសន្ទុះខ្លាំង។ [...] ឆ.៩៖ គាត់ទៅទីនោះនៅចុងឆ្នាំ១៩៧៨ ក្នុងរយៈពេលខ្លី គឺប្រហែលជាពីរអាទិត្យ ឬកន្លះខែតែប៉ុណ្ណោះ"]។

3474 ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ សាក្សីម៉ឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 15.43.54-15.46.25 KH ERN 01329936-37។ និង ឯកសារ D114/297.1.24 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វេត ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.52.25-09.55.21 KH ERN 013300888 [ផ្តល់សក្ខីកម្មថាគាត់បានឃើញសំបុត្រពី ម-៨៧០ ដែលនិរសាររបស់ មាស មុត ឈ្មោះ ធី និង គង់ យកមកឱ្យមេបញ្ជាការកងពល១១៧ឈ្មោះ រុំ។ ខ្លឹមសារសំបុត្រនោះគឺហៅកម្មាភិបាលចំនួន១១រូបពីកងពល១១៧ និងពីតំបន់៥០៥ ទៅភ្នំពេញដោយបញ្ជាក់ថាពួកគេត្រូវធ្វើដំណើរទៅតាមយន្តហោះ]។ បញ្ជាក់បន្ថែមលើ ឯកសារ D54/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.២៤ KH ERN 00975783-84 និង ឆ.២៩ KH ERN 00975785

៥០៥ ទៅទីក្រុងភ្នំពេញ[3475] ហើយពួកគេត្រូវបានឃុំ នៅមន្ទីរ ស-២១។ កម្មាភិបាលទាំងនេះត្រូវគេដឹកតាមយន្តហោះ[3476] ដោយគេយកលេសដូចៗគ្នាថាទៅចូលរួមប្រជុំការងារ ឬរៀនសូត្រ[3477]។

---

។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជូ, ឆ.៣០-៣២ KH ERN 01071599 និងឆ.៤០ KH ERN 01071601["អំឡុងពេលនោះ ការបោសសម្អាតបានចាប់ផ្តើម។ គេដកមិត្តរួមអាវុធរបស់ខ្ញុំដូចជា រ៉ុ និងលាង។ [...] គេហៅពួកគាត់ទៅប្រជុំនៅក្រចេះ ហើយបន្ទាប់មកបាត់ខ្លួនរហូត។ [...] ឆ.៣១៖ 'គេ' គឺថ្នាក់មជ្ឈិម។ [...] ឆ.៣២៖ នៅពេលនោះ មុនពេល រ៉ុ និង លាង ទៅប្រជុំនៅក្រចេះ គេប្រជុំជាមួយយើង ដោយប្រាប់ថាពួកគេត្រូវបានហៅទៅប្រជុំនៅក្រចេះដោយមជ្ឈិម។ ពេលនឡគេមិនហៅមជ្ឈិមទេ គេហៅថា "៨៧"។ [...] ឆ.៤០៖ ថ្នាក់លើកងពលហ្នឹងទៀត គឺថ្នាក់មជ្ឈិម ពីព្រោះកងពលនេះគឺស្ថិតនៅក្រោមបញ្ជារបស់មជ្ឈិមផ្ទាល់។ ខ្ញុំមិនដឹងថាអ្នកណាពិតប្រាកដនៅថ្នាក់មជ្ឈិមទេ ប៉ុន្តែនៅពេលនោះ មាស មុត បានមករៀបចំកងពល១១៧"]។ ឯកសារ D114/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ សារ៉ាត់ (ប៊ុន សារ៉ាត់) ឆ.២៣០, KH ERN 01354332 ["ស៖ តើអ្នកណាជាអ្នកបញ្ជូន មាស មុត ទៅ[ក្រចេះ]? ឆ.២៣០៖ តាមខ្ញុំដឹង អគ្គបញ្ជាការ"]។ ឯកសារ D114/101 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.២៤-៤០, KH ERN 01127709-11 [បញ្ជាក់ថា គាត់សម្របសម្រួលជាមួយមន្ទីរ ៨៧ ក្នុងការរៀបចំឱ្យ យ៉េង និងភ័ន ជិះយន្តហោះទៅភ្នំពេញ]។

3475 ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ សាក្សីម៉ឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 15.43.54-15.46.25 KH ERN 01329936-37 និងឯកសារ D114/297.1.24 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វេត ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.52.25-09.55.21 KH ERN 013300888 [ផ្តល់សក្ខីកម្មថាគាត់បានឃើញសំបុត្រពី ម-៨៧០ ដែលនិរសាររបស់ មាស មុត ឈ្មោះ ធី និង គង់ យកមកឱ្យមេបញ្ជាការកងពល១១៧ឈ្មោះ រ៉ុ។ ខ្លឹមសារសំបុត្រនោះគឺហៅកម្មាភិបាលចំនួន១១រូបពីកងពល១១៧ និងពីតំបន់៥០៥ ទៅភ្នំពេញដោយបញ្ជាក់ថាពួកគេត្រូវធ្វើដំណើរទៅតាមយន្តហោះ]។ បញ្ជាក់បន្ថែមលើ ឯកសារ D54/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.២៤ KH ERN 00975783-84 និង ឆ.២៩ KH ERN 00975785 ។ ឯកសារ D114/169 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន, ឆ.៣០ KH ERN 01203860 ["មុត ជាអ្នកបញ្ជូនអ្នកដែលចាប់ខ្លួននោះតាមយន្តហោះមកភ្នំពេញ។ [...] ត្រង់ហ្នឹង គឺ បងមុត ជាអ្នកបញ្ជូនឡើងយន្តហោះ បន្ថែមចំណុចហ្នឹង ឱ្យយល់។ អ្នកមុនហ្នឹង មុត ជាអ្នកចាត់ចែង"]។ ឯកសារ D114/170 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រុំ ម៉ុន ឆ.៣៦ និងឆ.៣៨ KH ERN 01204169 [សាក្សីរូបនេះជាប្រពន្ធរបស់អតីតលេខាកងពល ១១៧ ឈ្មោះ ឃុន រ៉ុ៖ "លឹម ថាប្តីរបស់ខ្ញុំគេចាប់យកទៅ។ តាមុត ជាអ្នកបញ្ជាឱ្យចាប់។ [...] ឆ.៣៨៖ [...]មានប្តីខ្ញុំ, តាមឿន និងតាលាង"]។ ឯកសារ D114/136.2 ចម្លើយសារភាព របស់ វ័ន្ត លាង ថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៧៨, EN 01189375, KH ERN 01165523 ["រហូតដល់ថ្ងៃទី២៩.១១.១៩៧៨ បងមុត ប្រាប់ថា "[...] ពេលសមមិត្ត [សំដៅលើខ្ញុំ] ទៅដល់ពោធិ៍ចិនតុង ជួបសមមិត្ត ម៉ែត នឹងដឹងហើយ។" មកជាមួយខ្ញុំមាន មិត្ត ណួញ ប្រធានមន្ទីរកងពល និង មិត្ត ផន លេខាវរសេនាធំ១៥ មកជាមួយគ្នា។ ដល់ថ្ងៃទី១ ខែ១២ ឆ្នាំ១៩៧៨ អង្គការ ចាប់ខ្លួនខ្ញុំមកទីនេះ"]។ ទាក់ទងទៅនឹងចម្លើយដែលទទួលបានដោយសារទារុណកម្មនៃការចាប់ជនរងគ្រោះ ជាពិសេសការឆ្លើយដាក់ក្រោយពីរង

ទារុណកម្មនោះ គប្បីរក្សាទុក អនុលោមតាមមាត្រា១៥ នៃ អនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម ដោយហេតុផលមួយចំនួនដូចខាងក្រោម។ មាត្រា១៥ នៃ អនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម ចែងថា៖ "រដ្ឋភាគីនិមួយៗត្រូវធានាថារាល់ចម្លើយដែលទទួលបានពីការធ្វើទារុណកម្មនោះនឹងមិនត្រូវប្រើប្រាស់ជាភស្តុតាងសម្រាប់សវនាការទេ លើកលែងតែសវនាការនោះធ្វើឡើងសម្រាប់ជំនុំជម្រះបុគ្គលដែលបង្កឱ្យមានទារុណកម្ម ហើយនាំឱ្យទទួលបានចម្លើយនោះតែប៉ុណ្ណោះ។" ចម្លើយរបស់ វត្ន លាង "មិនបានដោយសារទារុណកម្ម"ទេ។ រាល់ព័ត៌មានអាចបញ្ជាក់បាន យ៉ាងច្បាស់ និងអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យគ្រប់ជាន់ថ្នាក់ក៏ដឹងរឿងនេះដែរ ហើយគាត់ក៏មិននិយាយអំពីរឿងនេះឡើយ ដោយសារគាត់រងទារុណកម្ម ឬដើម្បីបំពេញចិត្តអ្នកសួរចម្លើយនៅមន្ទីរស-២១។ (អានសំណុំរឿង០០២ ឯកសារ -F26/12 អង្គជំនុំជម្រះតុលាការកំពូល សេចក្តីសម្រេចលើសេចក្តីជំទាស់ទៅនឹងបញ្ជីឯកសារសំអានហេតុពេញលេញ កថាខណ្ឌ ៦៨ KH ERN 01186003-04 ["ថាតើព័ត៌មាន [...] បានមកពីការធ្វើទារុណកម្មដែរ ឬយ៉ាងណានោះ គឺជាបញ្ហានៃភស្តុតាង"]។ សំណុំរឿង០០២ ឯកសារ-E350/8 សេចក្តីសម្រេចលើភស្តុតាងដែលបានមកដោយការធ្វើទារុណកម្មរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៤៩ KH ERN 01200928 ["អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ព័ត៌មានសត្យានុម័តមួយចំនួនដែលមាននៅក្នុងចម្លើយសារភាព ដែលមាននៅក្នុងចម្លើយសារភាព មិនមែនជាផ្នែកនៃចម្លើយដែលបានមកដោយការធ្វើទារុណកម្មនោះទេ ដូច្នេះវាស្ថិតនៅក្រៅវង្វង់នៃវិធានបដិសេធន៍ក្នុងមាត្រា១៥" (ដោយមានការបញ្ជាក់បន្ថែម)]។ សំណុំរឿង០០២ ឯកសារ 002-E3/1555 ដីកាសម្រេចលើការប្រើប្រាស់ភស្តុតាងដែលបានមក ឬដែលអាចបានមកដោយការធ្វើទារុណកម្ម កថាខណ្ឌ១៩ KH ERN 00355911-12 ["ឯកសារដែលបានលើកឡើងនៅក្នុងរឿងនេះ មានផ្ទុកនូវព័ត៌មានមួយចំនួនដែលមិនមែនទទួលបានដោយអំពើធ្វើទារុណកម្ម។ [...] ប្រភេទដូចគ្នានឹងឯកសារខាងលើនេះដែរ ចំពោះព័ត៌មានសត្យានុម័តនានា ដែលមានក្នុងចម្លើយសារភាព និងទទួលបានដោយមិនមានការពាក់ព័ន្ធជាមួយនឹងការសួរចម្លើយ ជាពិសេសដូចជាកាលបរិច្ឆេទនៃការចាប់ខ្លួន [...] រួមទាំងព័ត៌មានផ្សេងៗទៀតដែលទាក់ទងនឹងប្រវត្តិរូប ដូចជាឈ្មោះ អាយុ មុខងារ ឬអង្គភាពការងាររបស់ជនដែលទទួលរងនូវអំពើទារុណកម្ម។"]។ លើសពីនេះចម្លើយនេះពាក់ព័ន្ធផ្ទាល់ជាមួយនឹង មាស មុត ដែលរងការចោទប្រកាន់ថាមានតួនាទីក្នុងការឃុំខ្លួន ការធ្វើទារុណកម្ម និងការបញ្ជូនកម្មាភិបាលកងទ័ពបដិវត្តកម្ពុជាឱ្យទៅស្លាប់នៅមន្ទីរសន្តិសុខ ស-២១ ក្នុងចំណោមកម្មាភិបាលទាំងនោះក៏មាន វត្ន លាង ម្នាក់ផងដែរ បើផ្អែកតាមចំណារនៅលើចម្លើយសារភាពថាគាត់បានទទួលរងនូវការធ្វើទារុណកម្មលើរូបរាងកាយ។ (អាន ឯកសារ D114/136.2, EN 01189352, KH ERN 01165508 [ចំណារ៖ "មិត្ត វុន គាត់ធ្វើទារុណកម្មជាប់កន្លះខែ ហើយ។ វាទទួលហើយ សរសេរបានឯកសារនេះ"])។ ការសម្រេចប្រើប្រាស់ឯកសារដែលមិនអាចទទួលយកបាននេះគឺផ្ទុយនឹងគោលបំណងនៃអនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម និងការពារអ្នកប្រព្រឹត្តឧក្រិដ្ឋកម្មដោយរាំងរាការប្រើប្រាស់ឯកសារភស្តុតាងពាក់ព័ន្ធប្រឆាំងនឹងពួកគេ។

3476 ឯកសារ D114/101 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.២៩-៤០, KH ERN 01127709-11 [បញ្ជាក់ថា គាត់សម្របសម្រួលជាមួយមន្ទីរ ៨៧ ក្នុងការរៀបចំឱ្យ យ៉េង និងភ័ន ជិះយន្តហោះទៅភ្នំពេញ។ ហើយក៏បានបញ្ជាក់ថា រុំ និង មាស មឿន ក៏ជិះយន្តហោះមកភ្នំពេញដែរ។]។ ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ សាក្សីម៉ឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 15.48.22-15.59.27 KH ERN 01329937-40 និងឯកសារ D114/297.1.23 កំណត់ហេតុជា

---

លាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វេត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.23.36-09.27.08 KH ERN 01329776 [បញ្ជាក់ប្រាប់ថាមនុស្សទាំង១១នាក់នោះជិះយន្តហោះមកភ្នំពេញ]។ ឯកសារ D114/170 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ ម៉ុន ឆ.៤០ KH ERN 01204169 [សាក្សីរូបនេះជាប្រពន្ធរបស់អតីតលេខាកងពល១១៧ ឈ្មោះ ឃុន រ៉ុំ៖ "អត់ដឹងទេ ដឹងតែថាគេចាប់ [ឃុន រ៉ុំ, មាស មឿន, និងរ័ត្ន លាង] ដាក់លើយន្តហោះយកទៅ"]។ ឯកសារ D114/167 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុំ យ៉ា, ឆ.៤៧-៤៨, KH ERN 01202863 [សាក្សីជាប្អូនស្រីរបស់អតីតលេខាស្រុកស្នួល ឈ្មោះ ឈុំ ចិន ហៅ ភ័ន បញ្ជាក់ថាប្រពន្ធរបស់ ឈុំ ចិន ប្រាប់គាត់ថាអ្នកដែលគេហៅទៅភ្នំពេញនោះគឺត្រូវដឹកតាមយន្តហោះ]។ ឯកសារ D114/136.2 ចម្លើយសារភាព របស់ រ័ត្ន លាង ថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៧៨, EN 01189368, KH ERN 01165518 ["ថ្ងៃ២៩/១១ អង្គការ អងញ្ជើញខ្ញុំមកមកជួប។ ថ្ងៃ៣០/១១ ខ្ញុំជិះយន្តហោះពីក្រចេះមកចុះពោធិ៍ចិនតុង សំរាកមួយយប់ល្ងាចថ្ងៃ១/១២ ខ្ញុំអង្គការ ចាប់ខ្លួនរហូតដល់ថ្ងៃនេះ]។

3477 ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ សាក្សីម៉ឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 15.43.54-15.46.25 KH ERN 01329936 ["កាលនុំងហើយដែលឃើញ ម-៨៧០ សូមអញ្ជើញមកធ្វើការនៅភ្នំពេញ"]។ ឯកសារ D114/170 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ ម៉ុន ឆ.៣៥ KH ERN 01204168 [សាក្សីរូបនេះជាប្រពន្ធរបស់អតីតលេខាកងពល១១៧ ឈ្មោះ ឃុន រ៉ុំ៖ "[នីរសាររបស់គាត់[ឃុន រ៉ុំ] ឈ្មោះ សួង មកប្រាប់ខ្ញុំភ្លាម។ គាត់ប្រាប់ខ្ញុំថា គេយកគាត់ទៅរៀន [...] ហើយប្រហែលជាពីរបីថ្ងៃក្រោយមក បានគាត់មកប្រាប់ខ្ញុំថា គេចាប់ប្តីខ្ញុំយកទៅហើយ។ គេមិនមែនយកគាត់ទៅរៀនទេ"]។ ឯកសារ D114/171កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ សារួន ឆ.៤៤ KH ERN 01204179 [សាក្សីរូបនេះជាអតីតប្រពន្ធរបស់លេខាស្រុកក្រចេះឈ្មោះ ហួន យ៉េង "ស៖ លោកស្រីអាចប្រាប់បានទេ ម៉េចបានគេចាប់គាត់ ហើយគេចាប់គាត់នៅពេលណា? ឆ.៤៤៖ ខ្ញុំអត់ដឹង។ ខ្ញុំដឹងថាគេចាប់គាត់ពេលទៅសន្និបាត។"]។ ឯកសារ D114/64 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ែម សារិន, ឆ.២៨៥, KH ERN 01089485 ["គ្រាន់តែថាទៅៗធ្វើការ ហើយគាត់[មឿន]ក៏ទៅបាត់ទៅ"]។ ឯកសារ D114/190 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ អោ ឆ.៣២-៣៣ KH ERN 01221822 ["[លៀង និងរ៉ុំ] ទៅរៀន។ មិនដឹងទៅរៀនឯណា។ ព្រោះគេដកកងពលឲ្យទៅរៀនសូត្រទៅប្រជុំណា។ ហើយដល់នេះ យួនចូល រត់បែកបាក់គ្នាអស់ហើយ។ [...] ឆ.៣៣៖ ហៅទៅរៀន អត់បានឃើញទេ"]។ ឯកសារ D114/191 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សូ, ឆ.៣៣ KH ERN 01221835 ["[ខ្ញុំ]ដឹងថាគេយកគាត់ [រ៉ុំ និងលាង] ទៅរៀន ហើយក្រោយមក ដឹងថាគេចាប់។ ប៉ុណ្ណឹង។ មានអ្នកណាបញ្ជា មានតែប៉ុល ពត។ អ្នកដឹកនាំ ហៅទៅរៀន"]។ អាន ឯកសារ D114/167 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុំ យ៉ា, ឆ.៤៦ KH ERN 01202863 [សាក្សីជាប្អូនស្រីរបស់អតីតលេខាស្រុកស្នួល ឈ្មោះ ឈុំ ចិន ហៅ ភ័ន និយាយថា៖ "គេថាយកមករៀនសូត្រ តែបងខ្ញុំហាកបីដូចជាដឹងថា អង្គការចាប់គាត់។"]។ ឯកសារ D114/64 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ែម សារិន, ឆ.២៩៦-២៩៧, KH ERN 01089486 ["គេចាប់ខ្លួនខ្ញុំនៅដើមខែ១២ ឆ្នាំ១៩៧៨។ ខ្ញុំអត់ដឹងថា គេចាប់ខ្លួនខ្ញុំទេ។ គេគ្រាន់តែប្រាប់ខ្ញុំឲ្យជួយរៀបចំកន្លែងពាណិជ្ជរបស់ខេត្តក្រចេះ នៅភ្នំពេញ។ ស៖ នៅពេលដែលគេប្រាប់លោកឲ្យទៅភ្នំពេញ លោកអត់សង្ស័យទេ? ឆ.២៩៧៖ ខ្ញុំអត់សង្ស័យទេ"]។

ដោយអង្គុយកៅអីទំនេរ ក្នុងយន្តហោះសម្រាប់ដឹកទាហានរបួសទៅព្យាបាលនៅទីក្រុងភ្នំពេញ[3478]។ សេង សឿន ជាអ្នកឡើងជំនួសប្រធានមន្ទីរតំបន់ ៥០៥ បានឃើញ **មាស មុត** ដោយផ្ទាល់ភ្នែក ពេលកម្មាភិបាលពីរនាក់ ដែលជាមុខសញ្ញានៃការបោសសម្អាត ឡើងជិះយន្តហោះទៅភ្នំពេញ[3479]។

---

3478 ឯកសារ D114/101 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.១៨, ឆ.២៤, ឆ.២៩, ឆ.៣៣ ឆ.៤០, និង ឆ. ៤២ KH ERN 01127708-12 [ក្នុងនាមជាលេខាមន្ទីរតំបន់ អែម សារិន ទទួលខុសត្រូវក្នុងការរៀបចំដឹកជញ្ជូន តាមការណែនាំពីមជ្ឈិម។ គាត់បានពន្យល់ថា យុន វ៉ុំ, មាស មឿន, ហួន យ៉េង, និងឈុំ ចិន ហៅ ភ័ន ធ្វើដំណើរទៅភ្នំពេញតាមយន្តហោះ ដាកូតា ពីរផ្សេងគ្នា "យន្តហោះនេះ ជាយន្តហោះដែលគេដឹកទាហានរបួសទៅភ្នំពេញ" ដើម្បីកុំឱ្យខាតសាំង]។ ឯកសារ D114/64 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.៣០២, KH ERN 01089487 [រៀបរាប់ថា គេហៅគាត់ទៅភ្នំពេញ តាមរយៈសារទូរលេខមួយមកពីមជ្ឈិម ដោយឱ្យគាត់ធ្វើដំណើរតាមយន្តហោះជាមួយអ្នករបួស។"]។ ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ សាក្សីម៉ឺង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 15.48.22-15.52.40, KH ERN 01329938 ["របួស គឺដឹកតាមរយៈយន្តហោះ"]។ អានបន្ថែម ឯកសារ D114/137 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ គីម ឆ.១៣៧, KH ERN 01171467។ ឯកសារ D98/3.1.17 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា ថា, EN 00327177, KH ERN 00251662, FR 00296099 [បញ្ជាក់ថា យោធាត្រូវរបួសនៅក្រចេះត្រូវដឹកយកមកព្យាបាលនៅពេទ្យក្បែរវត្តភ្នំ នៅភ្នំពេញ]។ កាលបរិច្ឆេទរបស់កម្មាភិបាលចូល ស-២១ បង្ហាញពីការចាប់ធ្វើឡើងជាបន្តបន្ទាប់គ្នា។ អាន លេខជើងទំព័រ ៣៤៨១-៣៤៨៨។

3479 ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី សេង សឿន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 14.03.54-14.09.39 KH ERN 01355203-204 [សាក្សី សេង សឿន បានឃើញលេខាស្រុកក្រចេះ ឈ្មោះ ហួន យ៉េង និងលេខាស្រុកស្នួល ឈ្មោះ ឈុំ ចិន ហៅ ភ័ន "ដាក់យន្តហោះទៅភ្នំពេញ។" សាក្សី សេង សឿន និងភ័ន ធ្លាប់ស្គាល់គ្នាតាំងតែពីក្មេងៗមកម្លេះ "អត់ហ៊ាននិយាយរកគ្នាទេ ព្រោះ មាស មុត ហ្នឹងនៅក្តែក្បែរខ្លួនដែរ"]។ ឯកសារ D114/169 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន, ឆ.៣០ KH ERN 01203860, ឆ.៤០-៤២ KH ERN 01203861, ឆ.៤៧ និងឆ.៤៩ KH ERN 01203862 ["មុត ជាអ្នកបញ្ជូនអ្នកដែលចាប់ខ្លួននោះតាមយន្តហោះមកភ្នំពេញ។ [...] ត្រង់ហ្នឹង គឺ បងមុត ជាអ្នកបញ្ជូនឡើងយន្តហោះ បន្ថែមចំណុចហ្នឹង ឱ្យយល់។ អ្នកមុនហ្នឹង មុត ជាអ្នកចាត់ចែង [...] ឆ.៤០៖ អាចិន ខ្ញុំស្គាល់ច្បាស់។ អាយ៉េង ខ្ញុំស្គាល់ពេលហៅឡើងយន្តហោះ។ [...] [ចិន]មុនឡើងយន្តហោះបានជួបគ្នា។ រៀបនឹងនិយាយគ្នា វាក៏ចង់និយាយជាមយខ្ញុំដែរ តែ មុត មើលមុខថ្លៃ យើងក៏អត់ហ៊ាននិយាយគ្នាទៅ។ [...] ឆ.៤៧៖ ពេលនោះ មុត ហៅទៅជួបគាត់ ត្រូវប្រមូលទ័ព ចំជើងយន្តហោះហ្នឹងមក ពីរនាក់ហ្នឹង[ចិន និងយ៉េង]គេចាប់យកមកហើយ។ [...] ឆ.៤៩៖ មកប្រចាំការរៀបចំ ហើយបានគេហៅអ្នកណាៗត្រូវនាំខ្លួនឱ្យឡើងយន្តហោះ"]។ ឯកសារ D4.1.810 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.៣៥-៣៦ KH ERN 00402510-11 ["[យ៉េង] គេដឹកគាត់តាមយន្តហោះប្រហែលជាទៅកាន់ទីក្រុងភ្នំពេញ ដើម្បីសម្លាប់។ ខ្ញុំដឹងព័ត៌មាននេះដោយសារ មាស មុត និយាយថាមនុស្សទាំងនោះ

គាត់បានពន្យល់ថា មាស មុត "មកប្រចាំការរៀបចំ ហើយបានហៅអ្នកណាៗត្រូវនាំខ្លួនឱ្យឡើងយន្តហោះ"[3480]។

861. ជាពិសេស **មាស មុត** ទទួលខុសត្រូវលើការបញ្ជូនទៅទីក្រុងភ្នំពេញនូវកម្មាភិបាលជាន់ខ្ពស់ដូចខាងក្រោម ដែលត្រូវបានឃុំ និងសម្លាប់ជាបន្តបន្ទាប់ នៅមន្ទីរ ស-២១៖

(ក) មាស សឿន លេខាតំបន់ ៥០៥[3481] និង ឈឹម ខុន អនុលេខា[3482]

---

ត្រូវគេយកទៅកម្ទេច [...] ឆ.៣៦៖ [ចិន] ក៏ត្រូវបានគេបញ្ជូនទៅភ្នំពេញដើម្បីសម្លាប់ដែរ។ ខ្ញុំបានឃើញ ភាន់ និង យ៉េង នៅពេលពួកគេឡើងយន្តហោះ"]។

3480 D114/169 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន, ឆ.៤៩ KH ERN 01203862។

3481 D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ១៣៣៩៦ ["មាស មឿន លេខាតំបន់ ៥០៥, ចូលស-២១ ថ្ងៃទី ៨ ខែធ្នូ ឆ្នាំ១៩៧៨"] និង លេខរៀង ១៤៣៧៣ [ប្រមូលឯកសារ "ចម្លើយសារភាព" របស់ មាស កេត ហៅ មឿន "ក្រុមប៉ុល ពត នៅខេត្តក្រចេះ" ចូលស-២១ ថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៨។ នេះជាការចុះបញ្ជីស្ទួន] ។ ឯកសារ D1.3.28.137 បញ្ជីឈ្មោះអ្នកទោសនៅស-២១ "ផ្នែក គុកពិសេស" ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៨, EN 00758336-37, KH ERN 00086822-23, FR 00761763-64 [មាស មឿន លេខរៀង ១៥]។ ឯកសារ D1.3.28.138 បញ្ជីឈ្មោះអ្នកទោសនៅស-២១ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៨, EN 00789491-92, KH ERN 00088520-21, FR 00810226-27 [មាស មឿន លេខរៀង១៧]។ ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វ៉េត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.18.38-09.20.00 KH ERN 01329773 [សាក្សីបញ្ជាក់ថាគាត់បានឃើញឈ្មោះលេខាតំបន់ ៥០៥ មាស មឿន នៅក្នុងបញ្ជីឈ្មោះ ដែលមន្ទីរ៨៧០ ហៅឱ្យមកភ្នំពេញ]។ ឯកសារ D114/216 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ឆ.៣៨-៣៩ KH ERN 01301459 ["ដល់ឆ្នាំ១៩៨០ ខ្ញុំឮគេថា ឈ្មោះមឿន គេចាប់ពីក្រចេះបញ្ជូនមកភ្នំពេញ។ [...] គឺពេលដែលយួនចូលមកដល់ក្រចេះហ្នឹង។ មិនដឹងថាចុង៧៨ ឬក៏៧៩ហើយទេ។ ហ្នឹងមានគេនិយាយប្រាប់ខ្ញុំ។ [...] ឆ.៣៩៖ អ្នកដែលប្រាប់ខ្ញុំហ្នឹង គឺលោក ទឹម សេង មេកងពលខ្ញុំហ្នឹង តែម្តង។"]។ ឯកសារ D114/101 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.១៥-១៨ KH ERN 01127707-08, ឆ.២៨-២៩ 01127709-10 និងឆ.៣២ KH ERN 01127710 [មាស មឿន បានប្រាប់សាក្សីរូបនេះថា គាត់ត្រូវគេហៅទៅភ្នំពេញ]។ ឯកសារ D114/170 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ ម៉ុន ឆ.៣៨ និងឆ.៤២ KH ERN 01204169 [សាក្សីរូបនេះជាប្រពន្ធរបស់អតីតលេខាកងពល១១៧ ឈ្មោះ ឃុន រ៉ុះ "[គេចាប់]មានប្តីខ្ញុំ, តាមឿន, និង តាលាង [...] ឆ.៤២៖ តាមឿន ជាសាច់ញាតិ តាមុត [ក៏ត្រូវចាប់ខ្លួន] ដែរ"]។ ឯកសារ D59/2/4.16a កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី សេង សឿន, EN 00753848, KH ERN 00059342 ["ពេលគេមកចាប់មឿន និងខុន"]។

(ខ) ឈុំ ចិន (ឬ ចិន) ហៅភ័ន លេខាស្រុកស្អួល និង ហួន យ៉េង លេខាស្រុកក្រចេះ[3483]

---

[3482] D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ១០៣៩ ["ឈឹម ខុន អនុលេខាតំបន់ ៥០៥, ចូល ស-២១ ថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨"]។ ឯកសារ D1.3.28.137 បញ្ជីឈ្មោះអ្នកទោសនៅស-២១ "ផ្នែក គុក ពិសេស" ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៨, EN 00758336-37, KH ERN 00086822-23, FR 00761763-64 [ឈឹម ខុន លេខរៀង៤]។ ឯកសារ D1.3.28.138 បញ្ជីឈ្មោះអ្នកទោសនៅស-២១ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៨, EN 00789491-92, KH ERN 00088520-21, FR 00810226-27 [ឈឹម ខុន លេខរៀង៤]។ ឯកសារ D59/2/4.16a កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី សេង សឿន, EN 00753848, KH ERN 00059342 ["ពេលគេមកចាប់មឿន និងខុន"]។ ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វេត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.16.50-09.18.38 KH ERN 01329772 [សាក្សីបញ្ជាក់ថាគាត់បានឃើញឈ្មោះអនុលេខាតំបន់៥០៥ ឈឹម ខុន នៅក្នុងបញ្ជីឈ្មោះ ដែលមន្ទីរ៨៧០ ហៅឱ្យមកភ្នំពេញ]។

[3483] D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ១២៩០៣-១២៩០៤ ["ឈ្មោះ ហួន យ៉េង លេខាស្រុកក្រចេះ ភូមិភាគឦសាន [តំបន់៥០៥]" និង "ឈុំ ចិន ហៅ ភ័ន លេខាស្រុកស្អួល ភូមិភាគឦសាន [តំបន់៥០៥]"]។ ទាំងពីរនាក់នេះ ចូល ស-២១ ថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៨ និងត្រូវគេសម្លាប់នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ១៩៧៨]។ ឯកសារ D1.3.28.146 បញ្ជីឈ្មោះអ្នកទោស ស-២១ ដែលបានសួរចម្លើយ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៨, EN 00789507, KH ERN 00086832 [លេខរៀង ១០ និង១១]។ ឯកសារ D251.1.2 ប្រវត្តិរូបរបស់ ឈុំ ចិន ហៅ ភ័ន នៅស-២១ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៨, KH ERN 01531791។ ឯកសារ D59/1/3.51b ប្រវត្តិអ្នកទោសជាប់ឃុំឃាំង ស-២១ ឈ្មោះ ហួន យ៉េង ថ្ងៃឃាត់ខ្លួន ថ្ងៃទី១២ ខែ១២ ឆ្នាំ១៩៧៨, KH ERN 00929689។ ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលពីរ សាក្សី សេង សឿន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 14.03.54-14.09.39 KH ERN 01355203-204 [សាក្សី សេង សឿន បានឃើញលេខាស្រុកក្រចេះ ឈ្មោះ ហួន យ៉េង និងលេខាស្រុកស្អួល ឈ្មោះ ឈុំ ចិន ហៅ ភ័ន "ដាក់យន្តហោះទៅភ្នំពេញ។" សាក្សី សេង សឿន និងភ័ន ធ្លាប់ស្គាល់គ្នាតាំងតែពីក្មេងៗមកម្លេះ "អត់ហ៊ាននិយាយរកគ្នាទេ ព្រោះ មាស មុត ហ្នឹងនៅខ្នែក្បែរខ្លួនដែរ។ សាក្សី សេង សឿន ឃើញមានឈ្មោះ យ៉េង និងឈ្មោះ ភ័ន នៅក្នុងបញ្ជីអ្នកទោស ស-២១ គឺឯកសារ D1.3.28.146 (CF2: E3/1651) នៅ EN 00789507, FR 00841431, KH ERN 00086832), លេខរៀងទី១០ និងលេខរៀងទី១១]។ ឯកសារ D4.1.810 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សេង សឿន ឆ.៣៥-៣៦ KH ERN 00402510-11 [បានឃើញ យ៉េង និងភាន់ "ដាក់ក្នុងយន្តហោះ" ទៅទីក្រុងភ្នំពេញ ដើម្បីសម្លាប់ ហើយមាស មុត ប្រាប់ថា "មនុស្សទាំងនោះត្រូវគេបោសសម្អាតហើយ"]។ ឯកសារ D114/101 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អែម សារិន, ឆ.២០-២៨ KH ERN 01127708-09 [រៀបចំយន្តហោះឱ្យដឹក យ៉េង និងភ័ន ទៅភ្នំពេញ]។ ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលទីពីរ សាក្សីម៉ឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 15.55.04-15.59.27, KH ERN 01329939-40 និងឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំ

(គ) ឃុន រ៉ំ លេខាកងពល ១១៧[3484] វ៉ន្ន លាង អនុលេខា[3485] និង ស្វាយ ណូញ ប្រធានមន្ទីរកងពល[3486]

---

ជម្រះក្ដីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វ៉េត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.18.38-09.23.36 KH ERN 01329773-75 [សាក្សីផ្ដល់សក្ខីកម្មថាគាត់បានជូនកម្មាភិបាល រួមមាន លេខាស្រុកក្រចេះ ហួន យ៉េង, លេខាស្រុកស្នួល ឈុំ ចិន ហៅ ភ័ន ទៅព្រលានយន្ដហោះ]។ ឯកសារ D54/62 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឹង វ៉េត ឆ.២៤ KH ERN 00975783-84 និង ឆ.៣២-៣៣ KH ERN 00975786 [កម្មាភិបាលមួយក្រុមដែលគេបញ្ជាឲ្យមកភ្នំពេញក្នុងនោះមាន ពូរបស់គាត់ឈ្មោះ ភណ្ឌ និងឈ្មោះយ៉េង]។ ឯកសារ D114/171 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កែវ សារួន ឆ.៤៣-៤៤ KH ERN 01204179 [សាក្សីរូបនេះជាអតីតប្រពន្ធរបស់លេខាស្រុកក្រចេះបញ្ជាក់ថានីរសាររបស់ប្ដីគាត់បានមកប្រាប់គាត់ថាគេចាប់ប្ដីគាត់ហើយ។]។ ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលពីរ សាក្សី សេង សឿន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 14.03.54-14.09.39 KH ERN 01355203-204 ["ឯពីរនាក់ដែលបង មុត ឲ្យឡើងយន្ដហោះទៅក៏មិនដឹងគេយកទៅណា ប៉ុន្តែដឹងតែទៅភ្នំពេញហើយ ប្រហែលបាត់ខ្លួន"]។ ឯកសារ D114/167 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈុំ យ៉ា, ឆ.៤៦ KH ERN 01202863 [សាក្សីជាប្អូនស្រីរបស់អតីតលេខាស្រុកស្នួល ឈ្មោះ ឈុំ ចិន ហៅ ភ័ន ពន្យល់ថា នៅឆ្នាំ១៩៨២ ឬឆ្នាំ១៩៨៣ ប្រពន្ធរបស់ ឈុំ ចិន បានប្រាប់គាត់ថាគេចាប់ប្ដីគាត់ដោយសារ "គេចោទថាយើងធ្វើការមិនកើតទើបឃ្មួនចូលស្រុកបាន"]។

[3484] D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ៤០៣២ ["ឃុន រ៉ំ លេខាកងពល១១៧, ចូល ស-២១ ថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៨"]។ ឯកសារ D1.3.28.137 បញ្ជីឈ្មោះអ្នកទោសនៅស-២១ "ផ្នែក គុកពិសេស" ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៨, EN 00758336-37, KH ERN 00086822-23, FR 00761763-64 [ឃុន រ៉ំ លេខរៀង១៨]។ ឯកសារ D1.3.28.138 បញ្ជីឈ្មោះអ្នកទោសនៅស-២១ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៨, EN 00789491-92, KH ERN 00085520-21, FR 00810226-27 [ឃុន រ៉ំ លេខរៀង២០]។ ឯកសារ D251.1.3 ប្រវត្តិរូបរបស់ ឃុន សារ៉ុម ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៨។ ឯកសារ D114/136.1 ចម្លើយសារភាពរបស់ ឃុន សារ៉ុម ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៨។ សូមអាន ឯកសារ D114/52 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈាង ជួ, ឆ.២-៦ KH ERN 01071594-95 និង ឆ.២៨-៣៤ KH ERN 01071598-600 [រៀបរាប់ពីការបោសសម្អាតកងពល១១៧ ដោយមានបញ្ជាការកងពល រ៉ំ និងលាង ក្រោយពីកម្លាំងរបស់កងពលនេះបង្ខំចិត្តដកថយដោយការវាយសន្ទាប់ពីកងទ័ពវៀតណាមនៅក្នុងខែតុលា ឆ្នាំ១៩៧៨នោះ]។ ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលទីពីរ សាក្សីម៉ឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 15.52.40-15.55.04, KH ERN 01329939 និងឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វ៉េត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.21.57-09.27.08 KH ERN 01329774-76 [សាក្សីបញ្ជាក់ថា ឃុន រ៉ំ ជិះយន្ដហោះពីក្រចេះមកភ្នំពេញ]។ ឯកសារ D54/62 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឹង វ៉េត ឆ.២៤ KH ERN 00975783-84 និង ឆ.២៩ KH ERN 00975785 [សំបុត្រផ្ញើមកពី ម-៨៧០ បញ្ជាឲ្យ រ៉ំ ទៅភ្នំពេញប្រគល់ឲ្យដោយនីរសាររបស់ មាស មុត]។ ឯកសារ D114/170

កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ ម៉ុន ឆ.១៩-២១, KH ERN 01204167 និងឆ.៣២-៤០ KH ERN 01204169 [សាក្សីរូបនេះជាប្រពន្ធរបស់អតីតលេខាកងពល១១៧ ឈ្មោះ ឃុន រុំ ប្រាប់ថា មាស មុត បញ្ជាឱ្យចាប់ខ្លួនប្តីរបស់គាត់ ហើយគាត់បញ្ជាក់ថា៖ "[គេចាប់]មានប្តីខ្ញុំ, តាមឿន, និងតាលាង"]។ ឯកសារ D114/191 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សូ, ឆ.៣២ KH ERN 01221834 ["កាលនោះ គេចាប់យក តារុំ និតាលៀង ទៅបាត់ទៅ"]។ ឯកសារ D114/192 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចិន ផាត ឆ.២៧-២៩, KH ERN 01221845 [បញ្ជាក់ថានៅចុងឆ្នាំ១៩៧៨ លៀង និងរុំ ត្រូវបានអង្គការកោះហៅឱ្យទៅភ្នំពេញ។]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជូ, ឆ.៣៤ KH ERN 01071599-600 ["ពេលថ្នាក់ដឹកនាំថ្មីមកដល់ គេបានប្រកាសអំពីការមកដល់របស់ពួកគេ ហើយនិយាយថា រុំ និងលាង ត្រូវបានផ្លាស់ទៅកន្លែងផ្សេង។ យ៉ាងណាមិញ យើងនៅក្នុងកងពល១១៧ គឺមិនជឿទេ យើងដឹងថា រុំ និង លាង ត្រូវបានយកទៅសម្លាប់"]។ ឯកសារ D114/203 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ុញ នឿម ឆ.១២ KH ERN 01238656 និងឆ.៤២ KH ERN 01238660 ["[មេបញ្ជាការកងពល១១៧] ឈ្មោះ រុំ តែគាត់ស្លាប់ហើយ។ គេចាប់គាត់ដោយគេចោទថាគាត់ក្បត់ […] ឆ.៤២៖ ដល់ពេលយើងចាញ់វៀតណាម រុំ និងលៀង ស្លាប់អស់ទៅ គឺគេចាប់យកទៅ"]។

3485 D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ៧៨៦២ ["រ័ត្ន លាង អនុលេខាកងពល ១១៧ ចូល ស-២១ ថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៧៨"]។ ឯកសារ D1.3.28.137 បញ្ជីឈ្មោះអ្នកទោសនៅស-២១ "ផ្នែក គុកពិសេស" ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៨, EN 00758336-37, KH ERN 00086822-23, FR 00761763-64 [រ័ត្ន លាង លេខរៀង៨]។ ឯកសារ D1.3.28.138 បញ្ជីឈ្មោះអ្នកទោសនៅស-២១ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៨, EN 00789491-92, KH ERN 00085520-21, FR 00810226-27 [រ័ត្ន លាង លេខរៀង៩]។ ឯកសារ D251.1.1 ប្រវត្តិរូបរបស់ រ័ត្ន លាង នៅស-២១ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៧៨។ ឯកសារ D114/136.2 ចម្លើយសារភាពរបស់ រ័ត្ន លាង ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៨។ ឯកសារ D114/164 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ែន ធារី ឆ.១១-១៣, KH ERN 01202830 [សាក្សីជាក្មួយស្រីរបស់រ័ត្ន លាង (ម្តាយរបស់គាត់គឺជាបងស្រីរបស់ រ័ត្ន លាង) រៀបរាប់ថា ជីដូនរបស់គាត់បានប្រាប់ថា មុត សម្លាប់ពូ លាង]។ ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ សាក្សីម៉ឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 15.52.40-15.55.04, KH ERN 01329939 ["ពូលាង [មក]មុនប្រហែលមួយថ្ងៃ ពីថ្ងៃមុននោះ មុន ពូរុំ"], 15.57.31-15.59.27, KH ERN 01329940 ["បងលាង គាត់ទៅមុន"]។

3486 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ៨៤៧១ ["ស្វាយ ញ៉ន ប្រធានមន្ទីរកងពល១១៧ ចូល ស-២១ ថ្ងៃទី១ ខែធ្នូ ឆ្នាំ១៩៧៨"]។ ឯកសារ D1.3.28.137 បញ្ជីឈ្មោះអ្នកទោសនៅស-២១ "ផ្នែក គុកពិសេស" ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៨, EN 00758336-37, KH ERN 00086822-23, FR 00761763-64 [ស្វាយ ណុញ លេខរៀង៦]។ ឯកសារ D1.3.28.138 S-21 បញ្ជីឈ្មោះអ្នកទោសនៅស-២១ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៨, EN 00789491-92, KH ERN 00085520-21, FR 00810226-27 [ស្វាយ ណុញ លេខរៀង៧]។ ឯកសារ D114/145.1.12 ចម្លើយសារភាព របស់ ស្វាយ ណុញ។ អាន ឯកសារ D114/136.2 ចម្លើយសារភាព របស់ រ័ត្ន លាង ថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៧៨, EN 01189375, KH ERN 01165523 ["រហូតដល់ថ្ងៃទី២៩.១១.១៩៧៨ បងមុត

(ឃ) មេបញ្ជាការកងវរសេនាធំទាំងបី នៃកងពល ១១៧៖ កិល សុផន ហៅផន លេខាកងវរសេនាធំលេខ ១៥[3487] ចាប ហឿន លេខាកងវរសេនាធំលេខ ៨១ និង ប៊ី រី (ឬ រី) លេខាកងវរសេនាធំលេខ ៨២[3488]។

---

ប្រាប់ថា "[...] ពេលសមមិត្ត [សំដៅលើខ្ញុំ] ទៅដល់ពោធិ៍ចិនតុង ជួបសមមិត្ត ម៉េត នឹងដឹងហើយ។" មកជាមួយខ្ញុំមាន មិត្ត ណួញ ប្រធានមន្ទីរកងពល។

3487 D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ៣៩៧៩ ["កិល សុផន ហៅ ផន លេខាកងវរៈសេនាធំ១៥ នៃកងពល១១៧ (លេខាកងវរៈសេនាធំ១៥ កងពលមជ្ឈិម ១១៧) ភូមិភាគឧត្តរ ចូល ស-២១ ថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ១៩៧៨ ត្រូវសម្លាប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៨"]។ ឯកសារ D1.3.28.141 បញ្ជីឈ្មោះអ្នកទោស ស-២១ ដែលបានសួរចម្លើយ, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៨, EN 00789707-08, KH ERN 00086766, FR 00834853-54 [លេខរៀង ៥]។ ឯកសារ D1.3.28.146 បញ្ជីឈ្មោះអ្នកទោស ស-២១ ដែលបានសួរចម្លើយ, ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ ១៩៧៨, EN 00789505, KH ERN 00086831, FR 00841429 [លេខរៀង៥]។ ឯកសារ D1.3.28.144 បញ្ជីឈ្មោះអ្នកទោស ស-២១, EN 01305703, KH ERN 00040057 [ផ្នែកភូមិភាគឧត្តរ លេខរៀង៥]។ ឯកសារ D54/60.2 កំណត់នៃកិច្ចសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី ម៉ឹង វ៉េត, EN 00992993-95, KH ERN 00975733-38, FR 00996575-77 [បញ្ជាក់ថាកម្មាភិបាលដែលគេចាប់នោះ ត្រូវបញ្ជូនតាមយន្តហោះទៅភ្នំពេញ។ ក្នុងនោះក៏មានមេបញ្ជាការវរៈសេនាធំ ឈ្មោះ ផន ម្នាក់ដែរ។]។ អាន ឯកសារ D114/136.2 ចម្លើយសារភាពរបស់ រ័ត្ន លាង ថ្ងៃទី៣ ខែធ្នូ ឆ្នាំ១៩៧៨, EN 01189375, KH ERN 01165523 ["រហូតដល់ថ្ងៃទី២៩.១១.១៩៧៨ បងមុត ប្រាប់ថា "[...] ពេលសមមិត្ត [សំដៅលើខ្ញុំ] ទៅដល់ពោធិ៍ចិនតុង ជួបសមមិត្ត ម៉េត នឹងដឹងហើយ។" មកជាមួយខ្ញុំមាន មិត្ត ណួញ ប្រធានមន្ទីរកងពល និងមិត្ត ផន លេខាវរសេនាធំ១៥"]។

3488 D114/230.1.1 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ៨៩៣ ["ចាប ហឿន លេខាកងវរៈសេនាធំ៨១ កងពល១១៧ ភូមិភាគកណ្ដាល, ភូមិភាគឧត្តរ ឬភូមិភាគកណ្ដាល ចូល ស-២១ ថ្ងៃទី ៩ ខែធ្នូ ឆ្នាំ១៩៧៨ ត្រូវសម្លាប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៨"]។ ឯកសារ D1.3.28.141 បញ្ជីឈ្មោះអ្នកទោស ស-២១ ដែលបានសួរចម្លើយ ថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៨, EN 00789707-08, KH ERN 00086766, FR 00834853-54 [ចាប ហឿន ភូមិភាគឧត្តរ លេខរៀង២, ប៊ី រី ភូមិភាគឧត្តរ លេខរៀង៣]។ ឯកសារ D1.3.28.146 បញ្ជីឈ្មោះអ្នកទោស ស-២១ ដែលបានសួរចម្លើយ, ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៨, EN 00789505, KH ERN 00086831, FR 00841429 [លេខរៀង២]។ ឯកសារ D1.3.28.144 S-21 Prisoner List, EN 01305703 [North Zone Section, no. 2]។ អានបន្ថែម ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលទីពីរ សាក្សីម៉ឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 15.38.37-15.41.39, KH ERN 01329934 និងឯកសារ D54/60.2 កំណត់នៃកិច្ចសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី ម៉ឹង វ៉េត, EN 00992994-95, KH ERN 00975736-37, FR 00996575-77 [បញ្ជាក់ថាកម្មាភិបាលបួននាក់ដែលគេចាប់បញ្ជូនតាមយន្តហោះទៅភ្នំពេញនោះ សុទ្ធតែថ្នាក់កងវរៈសេនាធំ ប៉ុន្តែគាត់នៅចាំឈ្មោះតែមេបញ្ជាការវរៈសេនាធំ១៥ តែម្នាក់ប៉ុណ្ណោះ គឺឈ្មោះ ផន]។ ព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ថា កងវរៈសេនាធំ៨១ និងកងវរៈសេនាធំ៨២ មិន

862. ដោយហេតុថា ទាំងកម្លាំងកងពល ១១៧ និងតំបន់ ៥០៥ កំពុងការពារព្រំដែនវៀតណាម[3489] និង ដោយសារតែប្រវត្តិយោធារបស់កម្មាភិបាលជាន់ខ្ពស់តំបន់ ៥០៥[3490] គ្មានការភ្ញាក់ផ្អើលទេថា ការ បោសសម្អាតកម្លាំងទាំងពីរនេះបានកើតឡើងក្នុងពេលជាមួយគ្នា និងមានលំនាំដូចគ្នា។ ឧទាហរណ៍ គួរឱ្យចាប់អារម្មណ៍បំផុត គឺថាកម្មាភិបាលជាន់ខ្ពស់បំផុត៖ មាស សឿន លេខាតំបន់ ៥០៥ និង ឃុន រំ លេខាកងពល ១១៧ បានឡើងជិះយន្តហោះរួមគ្នា ទៅទីក្រុងភ្នំពេញ ហើយចូល ស-២១ ជាមួយគ្នា នៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៧៨[3491]។ ការបោសសម្អាតកម្មាភិបាលពីររូបនេះគួរឱ្យចាប់ អារម្មណ៍ណាស់ ពីព្រោះថា មាស សឿន ជាប្អូនជីដូនមួយរបស់ **មាស មុត** ហើយ ឃុន រំ ជាក្មួយ របស់ **មាស មុត**[3492]។ ការស្មោះត្រង់របស់ **មាស មុត** ចំពោះបក្ស និងការប្តេជ្ញាចិត្តអនុវត្តតាម

---

មាននៅក្នុងកងពល១១៧ទេ ហើយនេះអាចជាកំហុសរបស់មន្ទីរស-២១ ក្នុងការកត់ត្រាលេខកងវរៈសេនាធំ ឬក៏លេខ កងពលខុស។

[3489] អាន កថាខណ្ឌ ៨៥៨។

[3490] អាន កថាខណ្ឌ ៨៥៥។

[3491] លេខាតំបន់៥០៥ ឈ្មោះ មាស មឿន និងមេបញ្ជាការកងពល១១៧ ឈ្មោះ ឃុន រំ បានធ្វើដំណើររួមគ្នានៅក្នុងយន្ត ហោះតែមួយមកកាន់ក្រុងភ្នំពេញ (អាន ឯកសារ D114/101 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ .២៩ KH ERN 01127710 ["តាមអ្វីដែលខ្ញុំដឹង រុំ និងមាស មឿន ជិ:យន្តហោះជាមួយគ្នា ចំណែកយ៉េង និងភ័ន ជិ: យន្តហោះមួយទៀតទៅជាមួយគ្នា។ នៅលើយន្តហោះទាំងពីរជើងនោះ មានអីវ៉ាន់ផ្សេងទៀត និងទាហាន និងទាហាន របួស ផងដែរ ប៉ុន្តែខ្ញុំចាំថា កម្មាភិបាលដែលធ្វើដំណើរលើយន្តហោះនោះ គឺមានតែពីរនាក់ទេ"]) តាមរយ:ឯកសារ D114/230.1.1 (បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស) លេខរៀង ៤០៣២- ឈ្មោះ ឃុន រុំ និងលេខរៀង ១៣៣៩៦- ឈ្មោះ មាស មឿន ចូលមន្ទីរ ស-២១ នៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ១៩៧៨។

[3492] ឯកសារ D114/216 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ីម ឆ.៣៥-៣៦ KH ERN 01301458-59 [ប្អូន ប្រុសរបស់ មាស មុត៖ "ខ្ញុំមានជីដូនមួយម្នាក់ឈ្មោះ មឿន ធ្វើទ័ពធ្វើទាហានទៅនៅក្រចេះហ្នឹងដែរ [...] ឆ.៣៦៖ ត្រូវជាកូនរបស់ឪពុកមារបស់ខ្ញុំ ដែលត្រូវជាប្អូនបង្កើតរបស់ឪពុកខ្ញុំ ឈ្មោះ មាស អៀម។]។ ឯកសារ D114/170 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ ម៉ុន ឆ.៤២ KH ERN 01204169 [សាក្សីរូបនេះជាប្រពន្ធរបស់អតីត លេខាកងពល១១៧ ឈ្មោះ ឃុន រុំ៖ "ស៖ តើអ្នកដែលគេចាប់ទៅនោះ មានអ្នកណាជាសាច់ញាតិ តាមុត ទេ? ឆ.៤២ ៖ ចាស តាមឿន ជាសាច់ញាតិ តាមុត ដែរ។ មឿន ជាឪពុកមារបស់ប្តីខ្ញុំ"]។ ឯកសារ D114/52 កំណត់ហេតុនៃការ ស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.៥០ KH ERN 01071602-603 ["ខ្ញុំចង់បញ្ជាក់ប្រាប់លោកថា [...] មាស មឿន និង [...] ឃុន រុំ គឺជាក្មួយរបស់ មាស មុត"]។ ឯកសារ D114/157.1.3 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី ចិន ផាត, EN 01507028, KH ERN 01197644 ["រុំ គាត់មកពីខាង តាកែវ ព្រោះគាត់នឹងត្រូវជាកូនក្មួយខាង តាមុត នេះ។"]។ ឯកសារ D54/60.2 កំណត់នៃកិច្ចសម្ភាសរបស់មជ្ឈមណ្ឌល ឯកសារកម្ពុជា ជាមួយសាក្សី ម៉ឹង វ៉េត, EN 00993000, KH ERN 00975746, FR 00996586 ["ស៖ ក្រែង រុំ

គោលនយោបាយកម្ទេចខ្មាំងផ្ទៃក្នុង ធ្វើឱ្យគាត់មានឆន្ទៈក្នុងការបោសសម្អាត និងបញ្ជូនសាច់ញាតិរបស់គាត់ ទៅមន្ទីរ ស-២១។

863. ការចូលរួមពាក់ព័ន្ធរបស់ **មាស មុត** នៅក្រចេះ មិនកម្រិតត្រឹមការមើលការខុសត្រូវលើការបោសសម្អាតកម្មាភិបាលឈានមុខនោះទេ។ "គេឱ្យ **មាស មុត** មករៀបចំទាំងយោធា និងស៊ីវិលនៅតំបន់ក្រចេះ"[3493] នេះជាការនិយាយសម្រាលឱ្យ **មាស មុត** និងជាការកាន់កាប់កងពល ១១៧ និងតំបន់ ៥០៥ ដោយកងពល ១៦៤[3494]។ **មាស មុត** ដឹងថា កម្មាភិបាលចាស់ៗមិនត្រឡប់មកពីទីក្រុងភ្នំពេញវិញទេ។ ដូច្នេះ ពេលអនុវត្តការបោសសម្អាត គាត់បានកោះហៅកម្មាភិបាលនៅសេស

---

ហ្នឹងត្រូវជាក្មួយគាត់បង្កើត? ឆ៖ បើគាត់ថាក្មួយគាត់ក្បត់គាត់ដែរ។"]។ អានបន្ថែម ឯកសារ D54/63 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.២, KH ERN 00975792-93 ["សូម្បីតែអ្នកទាំង១១នាក់នោះ ដែលបញ្ជូនទៅភ្នំពេញ គឺសុទ្ធតែជាសាច់ញាតិបងប្អូនរបស់គាត់ ប៉ុន្តែគាត់មិនជឿលើពួកទាំងអស់នោះទេ។"]។

3493 ឯកសារ D114/169 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន, ឆ.២៣ KH ERN 01203858-59។ អានបន្ថែម ឯកសារ D114/169 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន, ឆ.២៥ KH ERN 01203859 ["បងមុត ជាអនុប្រធាន [ក្រសួងការពារជាតិ] ហើយចុះមករៀបចំតំបន់ក្រចេះ"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.៤០-៤១ KH ERN 01071601 និងឆ.៥៤ KH ERN 01071604 ["មាស មុត បានមករៀបចំកងពល១១៧ ហើយចាត់តាំង តាញ៉ាន់ ជាបញ្ជាការកងពល១១៧នេះ។ ដូច្នេះខ្ញុំគិតថា មាស មុត គឺតំណាងមកពីមជ្ឈិម។ ស៖ តើម៉េចបានជាលោកដឹងថា មាស មុត ចាត់តាំងឱ្យ តាញ៉ាន់ ធ្វើជាបញ្ជាការកងពល ១១៧? ឆ.៤១៖ ខ្ញុំដឹងតាមរយៈអ្នកដែលមកកាន់កាប់ថ្មីហ្នឹង គឺតាញ៉ាន់។ តាញ៉ាន់និយាយថា "បង មាស មុត ចុះមកក្រចេះ ដើម្បីរៀបចំកងពល១១៧ឡើងវិញ។ [...] ឆ.៥៤៖ នៅពេលនោះ តាញ៉ាន់ ប្រជុំផ្សព្វផ្សាយប្រាប់កម្មាភិបាលថ្នាក់ក្រោមថា តាមុត មកពីភ្នំពេញ មករៀបចំកងពលថ្មី និងរៀបចំថ្នាក់ដឹកនាំថ្មី។ [...] ដូច្នេះខ្ញុំកំណត់ថា តាមុត ទៅរៀបចំកងពលថ្មីនេះ គឺ តាមុត តំណាងឱ្យគណៈមជ្ឈិមហើយ។"]។ ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ សាក្សីម៉ឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 15.38.37-15.41.39, KH ERN 01329934 ["ការផ្លាស់ប្តូរមុខតំណែង វាត្រូវអ្នកថ្មីទៅដូរ អ្នកចាស់ត្រូវដកជិះយន្តហោះមកភ្នំពេញ មកក៏ត្រូវបាត់ខ្លួនរហូត។ [...] អ៊ំ មុត គាត់ទៅ"]។

3494 អានបន្ថែម ឯកសារ D114/51 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ ឆ.១, KH ERN 01071583-84 ["លោកបានប្រាប់យើងថាខាងមជ្ឈិមបានចាត់ចែងសម្រួលបញ្ជូន មាស មុត ឱ្យមកក្តាប់នៅតំបន់នោះ។ លោកបានដឹងរឿងនេះនៅក្នុងកិច្ចប្រជុំនៃថ្នាក់ដឹកនាំវរៈសេនាធំ ពេលដែលគេប្រកាសថា បង មុត មកទីនេះដើម្បីក្តាប់នៅទីនេះ។ ស៖ ពេលនេះ នៅក្រោមការស្បថរួចហើយ តើលោកចាត់ថា សេចក្តីសង្ខេបដែលយើរៀបរាប់នេះគឺពិតជាត្រឹមត្រូវតាមការសន្ទនារបស់យើងកាលពីម្សិលមិញដែរឬទេ? ឆ៖ បាទ ត្រឹមត្រូវហើយ"]។

សល់នៃកងពល ១១៧ និងតំបន់ ៥០៥ ហើយប្រកាសថា មេដឹកនាំចាស់ៗក្បត់ហើយ[3495] គឺ "មិនដាច់ខាតក្នុងការវ៉ៃជាមួយកងទ័ពយួន"[3496] និងបញ្ជាក់អះអាងអំពីការផ្លាស់ប្ដូរកម្មាភិបាលទាំងនេះ[3497]។

---

[3495] ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វ៉េត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.35.25-09.41.29 KH ERN 01329779-81 [សាក្សីរៀបរាប់ពីការជួបប្រជុំមួយដែលមានគ្នាប្រហែលជា៧០នាក់ មានទាំងយោធាពីកងពល និង "ក្រុមនីរសា ពួកតែកុងឡាន ពួកហ្គារ៉ាសឡាន ពួកអីៗសម្រាប់នេះហ្នឹង ពេទអីហ្នឹងមួយចំនួនហ្នឹង" មាស មុត បានប្រកាសថា "មេអ្នែងក្បត់អស់ហើយ" ហើយ "ឥឡូវត្រូវដូរមក ឥឡូវ ញ៉ាន់ ឡើងជាមេបញ្ជាការប្រធានកងពល"។ "មាស មុត និយាយថា ពួកអ្នែងអត់វ៉ៃយួនសោះ ឱ្យយួនបុកយកបានទាំងមូល។"]។ ឯកសារ D54/63 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឹង វ៉េត ឆ.២, KH ERN 00975792-93 ["មុនពេល មាស មុត ដើរមកចូលរួមប្រជុំ គាត់បាននិយាយថានៅខាងក្រៅជាមួយនីរសារ និងយោធាផ្សេងៗទៀតថា "មេៗរបស់ឯងក្បត់អស់ហើយ។""]។ ឯកសារ D54/60.2 កំណត់នៃកិច្ចសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី ម៉ឹង វ៉េត, EN 00992993-94, 00993000-01, KH ERN 00975735, 00975745-46, FR 00996575, 00996585 [សាក្សីរូបនេះរៀបរាប់ពីការជួបប្រជុំ ពេលនោះ មាស មុត ប្រកាសថា "មេក្បត់ហើយ" ហើយចាត់តាំងកម្មាភិបាលឱ្យទៅ "វ៉ៃយួន"]។

[3496] ឯកសារ D54/63 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឹង វ៉េត ឆ.២, KH ERN 00975792-93 ["មាស មុត បានខឹង ដោយកាត់និយាយថា ពួកយើងមិនដាច់ខាតវ៉ៃនឹងយួនទេ។ ដោយសារតែព្រឹត្តិការណ៍ទាំងនេះ បានជា តា មុត គាត់ឈប់ជឿលើថ្នាក់ដឹកនាំកងពល ហើយដកអ្នក១១នាក់នោះចេញ"]។

[3497] ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វ៉េត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.37.06-09.39.51 KH ERN 01329772 ["[មាស មុត] ហៅប្រជុំជួរនៅក្នុងមន្ទីរ និយាយរួមនៅក្នុងមន្ទីរទាំងអស់ គាត់ហៅប្រជុំហ្នឹងដើម្បីប្រកាសថា ឥឡូវគាត់ត្រូវដូរមេកងពល។ [...] ឥឡូវ ញ៉ាន់ ឡើងមេបញ្ជាការប្រធានកងពល"]។ ឯកសារ D54/63 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឹង វ៉េត ឆ.១, KH ERN 00975792 ["ខ្ញុំបានចូលរួមប្រជុំជាមួយ មាស មុត ម្ដង នៅពេលដែលគាត់មកបើកការប្រជុំ និងប្រកាសការផ្លាស់ប្ដូរថ្នាក់ដឹកនាំកងពល"]។ អានបន្ថែម ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វ៉េត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.08.57-09.10.54 KH ERN 01329770 [សាក្សីបញ្ជាក់ថាអ្នកដែលត្រូវបញ្ជូនមកភ្នំពេញអត់បានត្រឡប់ទៅវិញទេ។ "ត្រូវប្ដូរកងពលថ្មី វរសេនាធំថ្មីមួយចំនួន គណៈតំបន់ថែមពីរពីលើមកទៀត"]។ ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលទីពីរ សាក្សី ម៉ឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 15.38.37-15.41.39, KH ERN 01329934 ["ការផ្លាស់ប្ដូរមុខតំណែង វាត្រូវអ្នកថ្មីទៅដូរ អ្នកចាស់ត្រូវដកជិះយន្តហោះមកភ្នំពេញ មកក៏ត្រូវបាត់ខ្លួនរហូត។ [...] អ៊ំ មុត គាត់ទៅ"]។ ឯកសារ D114/102 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អែម សារិន, ឆ.២២, KH ERN 01127729-30 ["ញ៉ា

864. **មាស មុត** កាន់មុខតំណែងពីរសំខាន់បំផុត ជាមួយនឹងមេបញ្ជាការកងវរសេនាធំរបស់គាត់មកពីកងពល ១៦៤៖ ភាព មេបញ្ជាការកងវរសេនាធំលេខ ៦១ (ឈ្មោះពេញ គង់ ភាព ឬ សុខ ភាព)[3498] បានជំនួស មាស សឿន ជាលេខាតំបន់ ៥០៥[3499]។ គឹម ញ៉ាន អតីតមេបញ្ជាការកងវរសេនាធំលេខ ៦៣ និងជាសមាជិកគណៈកងពល ១៦៤[3500] ត្រូវបានចាត់តាំងឲ្យកាន់តំណែងជាលេខាថ្មីនៃកងពល ១១៧[3501]។ **មាស មុត** ក៏បានដាក់ពង្រាយទាហានជាច្រើននៃកងពល ១៦៤ ឲ្យក្ដាប់កម្លាំង

---

ន់, ទី, និងប៉ក់ ជាកម្មាភិបាលថ្នាក់ខ្ពស់ គេមកជំនួសអ្នកនៅតំបន់ក្រចេះ [...] ខ្ញុំបានឃើញពួកគេនៅក្រចេះមុនពេលខ្ញុំមកភ្នំពេញ។ អានលេខចុងទំព័រ ៣៤៩៩ និង៣៥០១។

3498 អានផ្នែក IV. កងពល១៦៤ (ពីមុនកងពល៣) រចនាសម្ព័ន្ធបញ្ជាការ-- សមាសធាតុ និងតួនាទីនៃកងវរសេនាធំ ១៦១,១៦២,១៦៣ និងកងវរសេនាធំជើងទឹក (កងវរសេនាធំ១៤០) - ក) កងវរសេនាធំ១៦១ (ពីមុនកងវរសេនាធំ២០)។

3499 ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលពីរ សាក្សី សេង សឿន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 13.48.25-13.51.55, KH ERN 01355199-200 និងម៉ោង 13.51.55-13.54.58 KH ERN 01355200 ["ភាព មកធ្វើជាលេខាតំបន់។ ភាព ហ្នឹងគេនៅកងពលជើងទឹកជាមួយបង មុត។ [...] ទៅៗដល់ហ្នឹងទៅជួបអីហ្នឹង ហៅប្រជុំ [...]ប្រជុំហ្នឹង បង មាស មុត ហ្នឹងប្រកាសឲ្យមិត្ត ភាព លេខាតំបន់"]។ ឯកសារ D4.1.810 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សេង សឿន ឆ.៣២ KH ERN 00402510 ["សុខ ភាព គឺជាប្រធានគណៈកម្មាធិការតំបន់៥០៥ ចំណែកខ្ញុំគឺជាប្រធានមន្ទីរតំបន់"]។ ឯកសារ D59/2/4.16a កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី សេង សឿន, EN 00753837, KH ERN 00059329 ["សុខ ភាព សៅ ផុន មកលេខា អនុលេខាទង់មានអនុណាទៀតទេ"]។ ឯកសារ D54/62 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឹង វ៉េត ឆ.២៤ KH ERN 00975783-84 ["ខ្ញុំបានដឹងតាមរយៈកងវរៈសេនាធំរមួយកងរបស់កងទ័ពជើងទឹកក្រោមបញ្ជារបស់ ភាព ទៅជួយកងពលលេខ១១៧របស់ខ្ញុំ។ នៅពេលនោះក៏មានការបោសសម្អាតដែលត្រូវបានធ្វើឡើងផងដែរ។ ពេលដែល ភាព គាត់មកជាមេយយកងវរៈសេនាធំរបស់គាត់ គាត់បានឡើងធ្វើជាលេខាតំបន់៥០៥ ពីព្រោះពេលហ្នឹងគេចាប់ មឿន ហើយ។"] ឆ.២៦-២៧ KH ERN 00975784 ["កងវរៈសេនាធំរបស់ភាព គឺជាកងកម្លាំងពិសេសរបស់ មាស មុត" ដែលមកដល់ក្រចេះ "ប្រហែលចុងខែវិច្ឆិកា ឆ្នាំ ១៩៧៨។"]។

3500 អានផ្នែក IV. កងពល១៦៤ (ពីមុនកងពល៣) រចនាសម្ព័ន្ធបញ្ជាការ-- សមាសធាតុ និងតួនាទីនៃកងវរសេនាធំ ១៦១,១៦២,១៦៣ និងកងវរសេនាធំជើងទឹក (កងវរសេនាធំ១៤០) - គ) កងវរសេនាធំ១៦១ (ពីមុនកងវរសេនាធំ២២)។

3501 ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វ៉េត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.35.25-09.41.29 KH ERN 01329779-81 [សាក្សីរៀបរាប់ពីកិច្ចប្រជុំនៅក្រចេះនៅពេល មាស មុត ប្រកាស ថាមេដឹកនាំមុនៗ "ជាជនក្បត់" ហើយ "មេបញ្ជាការកងពលត្រូវផ្លាស់ប្ដូរ"។ មាស មុត ប្រកាសនៅក្នុងអង្គប្រជុំថា ញ៉ាន់ ត្រូវឡើងជាមេបញ្ជាការកងពល]។ ឯក

ផ្សេងទៀត នៅក្រចេះ[3502]។ ពិតណាស់ ការគ្រប់គ្រងរបស់កងពល ១៦៤ កាន់តែមានឥទ្ធិពលខ្លាំងឡើង ពេលពួកគេបានចាប់ផ្តើមបាញ់សម្លាប់កម្លាំងកម្ពុជាប្រជាធិបតេយ្យ ដែលដកថយពីការវាយប្រយុទ្ធជាមួយវៀតណាម[3503] ស្របតាមគោលនយោបាយរបស់មជ្ឈិម[3504]។

---

សារ D54/63 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វ៉េត ឆ.១-៣, KH ERN 00975792-93 [បញ្ជាក់ថានៅក្នុងកិច្ចប្រជុំនោះ មាស មុត "ប្រកាសការផ្លាស់ប្តូរថ្នាក់ដឹកនាំកងពល" ដោយនិយាយថា "ញ៉ាន់ នឹងមកទទួលដឹកនាំជំនួស រុំ នៅក្នុងកងពល១១៧"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.៤០-៤១ KH ERN 01071601 ["មាស មុត បានមករៀបចំកងពល១១៧ ហើយចាត់តាំង តាញ៉ាន់ ជាបញ្ជាការកងពល១១៧នេះ។ [...] ឆ.៤១៖ ខ្ញុំដឹងតាមរយៈអ្នកដែលមកកាន់កាប់ថ្មីហ្នឹង គឺតាញ៉ាន់។ តាញ៉ាន់និយាយថា "បង មាស មុត ចុះមកក្រចេះ ដើម្បីរៀបចំកងពល១១៧ឡើងវិញ។ [...]ឆ.៤១៖ ខ្ញុំដឹងតាមរយៈអ្នកដែលមកកាន់កាប់ថ្មីហ្នឹង គឺតាញ៉ាន់។ តាញ៉ាន់និយាយថា "បង មាស មុត ចុះមកក្រចេះ ដើម្បីរៀបចំកងពល១១៧ឡើងវិញ""]។ ឯកសារ D54/110 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេនង ឆ.៥-៦, KH ERN 00997254-55 ["ញ៉ាន់ គឺជាមនុស្សម្នាក់ដែលបានទៅក្រចេះជាមួយ មាស មុត។ [...] ឆ.៦៖ មាស មុត ត្រូវតែនាំទៅជាមួយគាត់ដូចជា ញ៉ាន់ មេបញ្ជាការកងពិសេស និងមេបញ្ជាការផ្សេងៗទៀតដែលគាត់ជឿទុកចិត្ត។ ខ្ញុំបានដឹងរឿងទាំងអស់នេះទៅក្រចេះ ពីព្រោះនៅពេលប្រជុំ មេបញ្ជាការរបស់ខ្ញុំបានធ្វើការប្រកាសប្រាប់ពួកយើងអំពីឈ្មោះថ្នាក់ដឹកនាំណាទៅកន្លែងណាខ្លះ។"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.៣៥ KH ERN 01071600 ["ឈ្មោះ តាញ៉ាន់ មកកាន់កងពល១១៧។"]។ ឯកសារ D114/157.1.3 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី ចិន ផាត, EN 01507038-39, KH ERN 01197651 ["កាលនោះឃើញគេបញ្ជូន អ៊ំ ញ៉ាន់នេះ [ទៅជំនួស រុំ និង លាង] [...]គាត់ជំនួសខាងកងពល"]។ ឯកសារ D114/203 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ិញ នឿម ឆ.៤៤ KH ERN 01238660 ["ស៖ តើលោកដែលធ្លាប់ស្គាល់ឈ្មោះ ញ៉ាន់ ក្រោយការចាប់ខ្លួនរបស់ រុំ ទេ? ឆ.៤៤៖ ញ៉ាន់ ស្គាល់។ គាត់ក៏ជាប្រធានកងពល[១១៧]ដែរ"]។ ឯកសារ D114/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.២៥, KH ERN 01127730 [បញ្ជាក់ថាស្គាល់រូបថត ញ៉ាន់ ឯកសារ D114/18.1 ជា ញ៉ាន់ ធ្វើការនៅក្រចេះឆ្នាំ១៩៧៨នោះប្រាកដមែន]។ អាន ឯកសារ D114/191 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សួ, ឆ.៤៦ KH ERN 01221836 [ប្រាប់ថាគាត់ឃើញគាត់[ញ៉ាន] នៅក្រចេះក្នុងខែធ្នូ ឆ្នាំ១៩៧៨]។ ឯកសារ D114/18 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ាក ឈឿន (ម៉ា ឈឿន) ឆ.១៦-១៧, KH ERN 01024006 [អតីតកម្មាភិបាលនៅក្រោមបញ្ជារបស់ ញ៉ាន់ នៅកំពង់សោម បញ្ជាក់ថា គាត់បានឈប់រាយការណ៍ទៅឲ្យញ៉ាន់ទៀតហើយ គឺនៅ "ជិតចុងបញ្ចប់របបខ្មែរក្រហម" "ដោយសារពេលនោះ តាញ៉ាន់ ត្រូវបានបញ្ជូនចេញទៅបាត់។ [...] ឲ្យទៅវ៉ៃជាមួយវៀតណាមនៅតាមព្រំដែន"]។

3502 ឯកសារ D54/110 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេនង ឆ.៦-៧, KH ERN 00997255 ["មាស មុត ត្រូវតែនាំទៅជាមួយគាត់ដូចជា ញ៉ាន់ មេបញ្ជាការកងពិសេស និងមេបញ្ជាការផ្សេងៗទៀតដែលគាត់ជឿទុកចិត្ត។ ខ្ញុំបានដឹងរឿងទាំងអស់នេះទៅក្រចេះ ពីព្រោះនៅពេលប្រជុំ មេបញ្ជាការរបស់ខ្ញុំបានធ្វើការប្រកាសប្រាប់ពួកយើងអំពីឈ្មោះថ្នាក់ដឹកនាំណាទៅកន្លែងណាខ្លះ។ ស៖ តើលោកដឹងថា មានយោធាចំនួនប៉ុន្មាននាក់ទៅក្រចេះជាមួយ មាស

មុត? ឆ.៧៖ យោធាបាភគច្រើននៃកងជើងគោករបស់កម្លាំងកងទ័ពជើងទឹកត្រូវបានបញ្ជូនទៅក្រចេះទៅវៀជាមួយ តាមុត លើកលែងតែអ្នកកាន់នាវា"]។ ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទីពីរ សាក្សីម៉ឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 15.38.37-15.41.39, KH ERN 01329934 ["កងទ័ពគាត់ [មាស មុត] ទៅពីកំពង់សោមទៅ គាត់យកមួយវរសេនាធំ ទម្លាក់នៅ ភាព [...] កងគាត់វាត្រូវអង្គភាពហ្នឹងនៅឃុំគោលាប់ នៅអី ម៉ុំភ្នំសំបុក"]។ ឯកសារ D54/63 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វ៉េត ឆ.២១, និងឆ.១៣-១៤ KH ERN 00975797 ["ស៖ តើកាលពីពេលនោះពួកមជ្ឈិមបានយកយោធាប៉ុន្មានកង ដាក់ពង្រាយនៅក្រចេះ? ឆ.២១៖ ដំបូងគឺមានកងពល១១៧ ហើយក្រោយមកកងវរៈសេនាធំមួយទៀតមកពីកងពល១៦៤ ត្រូវបានដាក់ពង្រាយនៅទីនោះ។ ស៖ បើសិនជា មាស មុត ទៅក្រចេះ តើគាត់ស្នាក់នៅកន្លែងណា? ឆ.២៣៖ ខ្ញុំមិនដឹងទេ ប៉ុន្តែជាធម្មតា គាត់ស្នាក់នៅភូមិគោលាប់ ដែលជាកន្លែងយោធាកងវរៈសេនាធំរបស់កងពល១៦៤ បោះទីតាំងនៅ។ [...] ឆ.២៤៖ កងវរៈសេនាធំ កងពល១៦៤នៅទីនោះ វាយលុកដល់កងទ័ពយួនវៀបុកខ្លាំង នៅក្នុងខែធ្នូ ឆ្នាំ១៩៧៨។"]។ ឯកសារ D54/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វ៉េត ឆ.២៧ (ស៊ីក) KH ERN 00975784 ["កងវរៈសេនាធំរបស់ ភាព គឺជាកម្លាំងពិសេសរបស់ មាស មុត"]។ ឯកសារ D114/191 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សូ, ឆ.៤៤ KH ERN 01221836 ["[ខ្ញុំ]ដឹងថាកងពលមកពីកំពង់សោមនៅជាមួយ តាមុត [...] ពួកគេមកជួយកងពល១១៧ ដែលវាយអត់ឈ្នះ។"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.៥៦ KH ERN 01071604 ["ខ្ញុំឮថាមានយោធាទៅ [ក្រចេះ] ជាមួយ តាញ៉ាន់"]។ ឯកសារ D54/98 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាង រ៉េត, ឆ.៣៦, KH ERN 00990389 ["កងពល១៦៤ ត្រូវបញ្ជូនកម្លាំងមួយចំនួនទៅជួយកម្លាំងដែលឈរជើងនៅតាមព្រំដែន។ ពេលនោះ មាស មុត បានដឹកនាំកម្លាំងយោធាជាងពាក់កណ្តាលពីកងវរៈសេនាធំ៦១, ៦២, និង៦៣ ទៅវៀវៀតណាមនៅឯព្រំដែន [...] គាត់ទៅនោះគែប្រហែលជានៅខែតុលា ឆ្នាំ១៩៧៨"]។ ឯកសារ D114/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត់ (ប៊ុន សារ៉ាត់) ឆ.២២៦, KH ERN 01354332 [បញ្ជាក់ថា មាស មុត បាននាំយកកងទ័ពកងពល១៦៤ទៅក្រចេះជាមួយគាត់]។ ឯកសារ D54/50 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ឆ.៤, KH ERN 00970608 [មេបញ្ជាការកងពលលេខ១ ប្រាប់ថាកម្លាំងកងពលលេខ១៦៤ "បញ្ជាផ្ទាល់ដោយ តាមុត" ឈរជើងតាមបណ្តោយព្រំដែនវៀតណាម "នៅខ្សែត្រៀមខាងក្រោយ" ហើយក៏បានរៀបរាប់ពីព្រឹត្តិការណ៍កើតឡើងចំពោះកងពលលេខ១ និងកងពលលេខ១៦៤ "នៅក្នុងខែវិច្ឆិកា ឬខែធ្នូ ឆ្នាំ១៩៧៨"]។ អានបន្ថែម ឯកសារ D54/63 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វ៉េត ឆ.៣២, KH ERN 00975799 [នៅចាំបានថា ទូច ជានីរសាររបស់ ញ៉ាន់, ឈ្មោះ វៃ ជាអ្នកបកសារទូរលេខ និងឈ្មោះ ខាជាអ្នកវាយសារទូរលេខ សុទ្ធតែមកពីកងពល១៦៤ ដែលគេបញ្ជូនទៅក្រចេះ]។ គេកេណ្ឌយោធាពីកន្លែងនានាយកមកកងពលរបស់ ញ៉ាន់។ ឯកសារ D114/149 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច ឈុំ, ឆ.១-៧១ KH ERN 01184224-31 [រៀបរាប់ពី ស៊ូ ម៉េត បានបញ្ជូនគាត់ទៅក្រចេះ ទៅវៀវៀតណាម។ ម៉េត បានប្រាប់គាត់ថា៖ (ឆ.១៣) "ទៅសហការណ៍ជាមួយកង១៦៤ ក្រោមការគ្រប់គ្រងរបស់ ញ៉ាន់។"។ នៅទីនោះសាក្សីរូបនេះរាយការណ៍ឲ្យ ញ៉ាន់។ ថ្វីបើគាត់មិនបានចងចាំច្បាស់អំពីកាលបរិច្ឆេទនៃការផ្លាស់ទៅក្តី គាត់ប្រហែលថាវានៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨។ អាន ឯកសារ D59/2/2.18a កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយសាក្សី ទូច ឈុំ, EN 01333949, KH RN 00736737, FR 01432261 ["ឲ្យខ្ញុំទៅព្រំដែន៧៨ ខែ១១។"]។

865. កម្មាភិបាលប្រហែល ៥ នាក់ នៃភូមិភាគនិរតី ក៏បានជិះយន្តហោះទៅបំពេញមុខតំណែងជាន់ខ្ពស់ បន្សល់ទុកដោយកម្មាភិបាលដែលត្រូវគេបោសសម្អាត[3505] ក្នុងនោះ ផុន ហៅទី ត្រូវបានតែងតាំង

---

[3503] ឯកសារ D54/50 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស វឿន ឆ.៤-១៧, KH ERN 00970608-11 [មេបញ្ជាការកងពលលេខ១ បានឮពីកងយោធារបស់ខ្លួនដែលបានដកថយពីខ្សែប្រយុទ្ធនៅព្រំដែនវៀតណាមថាពួកគេ "កងកម្លាំងរបស់កងពលលេខ១៦៤ ក្រោមបញ្ជា មាស មុត បានដេញតាមវាយប្រហារលើពួកគេបន្ថែមទៀត"។ គាត់បន្ថែមទៀតថា "កងពលលេខ១មិនអាចទប់ទល់ជាមួយទ័ពយួនបាន កងពលលេខ១៦៤បានរើកងពលលេខ១ ដោយចោទយើងថាមិនស្នេហាជាតិ មិនដាច់ខាត និមិនមានការប្តេជ្ញាខ្ពស់។"។ "នៅពេលដែលយួនវ៉ៃខ្លាំងមកលើខ្សែត្រៀមរបស់កងពលលេខ១ យោធារបស់កងពលលេខ១ដកថយ គេក៏បានបាញ់ និងផ្តោងគ្រាប់ដាក់កងយោធាដែលកំពុងដកថយនោះ។" "មជ្ឈិមគេមានសិទ្ធិ និងបាញ់សម្លាប់ យោធាកងពលណាដែលដកថយពីសមរភូមិមុខ។" "តាមដែលខ្ញុំដឹងមានយោធារបួសប្រហែល៣-៤នាក់ និងស្លាប់៤-៥នាក់ ប៉ុន្តែមួយចំនួនទៀតបានលង់ទឹកស្លាប់នៅពេលពួកគេបានហែលទឹកឆ្លងទន្លេ ពេលដែលពួកយោធាកងពល១៦៤ដេញបាញ់ពីក្រោយ"]។

[3504] ឯកសារ D4.1.849 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃុន គីម ឆ.៥ KH ERN 00407756 [រៀបរាប់ពីជំនួបជាមួយនួនជា ក្នុងឆ្នាំ១៩៧៧ ពេលនោះគាត់បានប្រកាសអំពីការឈ្លានពានរបស់វៀតណាមមកលើទឹកដីកម្ពុជា ដោយសារតែ "ខ្មាំងស៊ីរូងផ្ទៃក្នុងក្នុងជួរកងទ័ព និងរដ្ឋបាលខ្មែរក្រហមដែលបានសហការណ៍បើកដៃឲ្យវៀតណាម", ដោយបន្ថែមទៀតថា កងទ័ពត្រូវតែខិតខំការពារ "ទឹកដី"កុំឲ្យបាត់បង់ បើបាត់មួយចំអាន មានន័យថាក្បត់ជាតិហើយ"]។ ឯកសារ D4.1.791 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ ជាតិ, EN 00398840, KH ERN 00389517, FR 00422233 ["ពេលនោះគេមានដាក់បញ្ញត្តិយ៉ាងតឹងរ៉ឹងថា បើវាយចាញ់អត់បាន ឬបើចាញ់ត្រូវមានមូលហេតុច្បាស់លាស់ និយាយរួមមិនឲ្យដករត់ទេ បើរត់ត្រូវមានមូលហេតុ"]។ ឯកសារ D32/4 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ីន សុផល ឆ.៥៧, KH ERN 00787934 ["នៅពេលណាដែលយោធា និងកម្មាភិបាលភូមិភាគបូព៌ាដកថយពីសមរភូមិ យោធាភូមិភាគកណ្តាលនៅចាំទីនោះ ចាប់ពួកនោះ និងសម្លាប់នៅទីនោះតែម្តង។"]។

[3505] ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី សេង សឿន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 09.28.39-09.32.00 KH ERN 01355168-69 ["[ខ្ញុំ]នៅធ្វើការងាររដ្ឋបាល ធ្វើជាមន្ទីរស្រុកស្អាង [ភូមិភាគនិរតី]។ រួចពីតមក បានផ្លាស់ខ្ញុំឲ្យទៅក្រចេះ មិនបានពេញមួយខែទេ ដែល "យួន"វ៉ៃចូលស្រុកខ្មែរនេះ"], និងនៅម៉ោង 10.07.35-10.10.02 KH ERN 01355177-78 ["សៅ ផុន គណៈស្រុក [ស្អាង]"], ម៉ោង 10.12.47-10.35.46 KH ERN 01355178-78 ["ផុន ទាំងខ្ញុំ ហើយនិងពីរនាក់ទៀត នៅស្រុកស្អាងជាមួយខ្ញុំហ្នឹង ផ្លាស់ទៅក្រចេះ។"], និងម៉ោង 13.48.25-13.51.55 KH ERN 01355199 ["បួននាក់ទាំងខ្ញុំគឺបងផុន [...] តំបន់ក្រចេះ"], នៅមុនម៉ោង 13.54.58 បន្តិច KH ERN 01355201 ["គេឲ្យទៅ [ក្រចេះ] ជិះយន្តហោះទៅ"]។ ឯកសារ D114/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.២២, KH ERN 01127729-30 ["ញ៉ាន់, ទី, និង ប៉ក់ ជាកម្មាភិបាលថ្នាក់ខ្ពស់ គេមកជិនួសអ្នកនៅតំបន់ក្រចេះ [...] ពួកគេមកក្នុងក្រុមដែលមានមនុស្សប្រាំនាក់ ហើយខ្ញុំបានឃើញពួកគេនៅក្រចេះ មុនពេលដែលខ្ញុំមកភ្នំពេញ។"]។ ឯកសារ D4.1.810 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.២៧ KH ERN 00402509 ["នៅពេលដែលខ្ញុំជិះយន្តហោះពី

ជាអនុលេខាថ្មី នៃតំបន់ ៥០៥[3506] ហើយ ឡេង ប៉ក់ ជំនួស យ៉េង ជាលេខាស្រុកក្រចេះ[3507]។ សាន ក្លាយជាប្រធានយោធាស្រុកក្រចេះ[3508] ហើយ ខុន ទទួលខុសត្រូវខាងកសិកម្ម[3509]។ សាក្សី សេង សឿន ត្រូវគេចាត់តាំងឱ្យធ្វើជាប្រធានមន្ទីរតំបន់[3510]។ អ្នកទទួលបានការតែងតាំងថ្មីទាំងនេះបាន រាយការណ៍ទៅ **មាស មុត** ពេលមកដល់[3511] ហើយគាត់ចាត់តាំងពួកគេឱ្យកាន់មុខតំណែងថ្មី[3512]។

---

ភ្នំពេញ មកដល់ក្រចេះ [...] មានមនុស្សប្រាំនាក់នៅលើយន្តហោះ មានឈ្មោះ៖ សៅ ផុន, ឡេង ប៉ក់, ខ្លួនខ្ញុំ សាន និង ខុន។"]។ ឯកសារ D54/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៣៥ KH ERN 00975787 ["មនុស្ស ទាំង៥នាក់ [សៅ ផុន, ឡេង ប៉ក់, សេង សឿន, សាន, និងខុន] មកពីភ្នំពេញតាមយន្តហោះក្នុងពេលជាមួយគ្នានឹង ការបញ្ជូនមនុស្ស១១នាក់ត្រឡប់ទៅភ្នំពេញវិញ។ មនុស្សទាំង៥នាក់នេះគឺមកជំនួសមនុស្សទាំង១១នាក់នោះ។"]។ ឯក សារ D114/101កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.៤៨ KH ERN 01127712-13 ["ផុន គេ ច្រើនហៅគាត់ថា ទី។ ខ្ញុំស្គាល់គាត់។ ខ្ញុំក៏ស្គាល់ ប៉ក់, សឿន, និង កប ដែរ។ ខ្ញុំមិនស្គាល់ សាន និង ខុន ទេ។ [...] ពួក គេមកជាមួយគ្នា មកជួបខ្ញុំនៅមន្ទីរស្រុកក្រចេះ និងសាកសួរអំពីស្ថានការណ៍ ព្រោះពេលនោះពួកវៀតណាមវាយបុក យើងខ្លាំង។"]។

3506 ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ម៉ឹង វេត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.08.57-09.10.54 KH ERN 01329770 ["ពូផុន ហៅទី នោះយកមកធ្វើជាអនុលេខាតំបន់៥០៥"]។ ឯកសារ D4.1.810 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.២៩ KH ERN 00402510 ["សៅ ផុន ជាអនុប្រធានគណៈតំបន់"]។ អានបន្ថែម ឯកសារ D114/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.២២, KH ERN 01127729-30 ["បញ្ជាក់ថា ញ៉ាន់, ទី, និង ប៉ក់ ជាកម្មាភិបាលថ្នាក់ខ្ពស់ ថ្នាក់លើបញ្ជូនមកឱ្យធ្វើការជំនួសអ្នកដែលគេដកយកទៅអស់]។

3507 ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទី ពីរ សាក្សីម៉ឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 15.43.54-15.46.25, KH ERN 01329936 ["ពូប៉ក់ ហ្នឹងគណៈតំបន់ស្រុកក្រចេះនោះជំនួស ពូយ៉េង"]។ ឯកសារ D4.1.810 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.៥៨ KH ERN 00402514 ["ឡេង ប៉ក់ ជំនួស យ៉េង"]។ អានបន្ថែម ឯកសារ D114/102 កំណត់ហេតុនៃ ការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.២២, KH ERN 01127729-30 ["បញ្ជាក់ថា ញ៉ាន់, ទី, និង ប៉ក់ ជាកម្មាភិបា លថ្នាក់ខ្ពស់ ថ្នាក់លើបញ្ជូនមកឱ្យធ្វើការជំនួសអ្នកដែលគេដកយកទៅអស់]។

3508 ឯកសារ D4.1.810 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.២៩ KH ERN 00402510 ["សាន ជា ប្រធានយោធាស្រុកក្រចេះ"]។

3509 ឯកសារ D4.1.810 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.២៩ KH ERN 00402510 ["ខុន ទទួល ផ្នែកកសិកម្មតំបន់"]។

3510 ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី សេង សឿន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 13.48.25-13.51.55 KH ERN 01355199 ["ខ្ញុំធ្វើ

866. ចាប់ពីត្រង់នេះទៅ **មាស មុត** មានវត្តមាននៅក្រចេះ ដោយបានកសាងទំនាក់ទំនងជិតស្និទ្ធជាមួយមេដឹកនាំតំបន់[3513]។ ក្នុងពេលជាមួយគ្នានោះ គាត់បន្តបំពេញភារកិច្ចនៅសេនាធិការនៅភ្នំពេញ[3514]

---

ប្រធានមន្ទីរស្រុក--ប្រធានមន្ទីរតំបន់"]។ ឯកសារ D4.1.810 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.២៩ KH ERN 00402510 ["ខ្ញុំទទួលបានការតែងតាំងជាប្រធានមន្ទីរតំបន់៥០៥"]។

3511 ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី សេង សឿន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 13.51.55-13.57.43 KH ERN 01355200 [ផ្តល់សក្ខីកម្មថា ពេលទៅដល់ភ្លាម កម្មាភិបាលទើបតែងតាំងថ្មីចំនួនប្រាំរូបនោះត្រូវបានហៅទៅជួបប្រជុំជាមួយ មាស មុត]។ ឯកសារ D114/169 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន, ឆ.១៩ KH ERN 01203858។ ["សះ តើលោកជួប បងមុតហ្នឹង គាត់មកទទួលនៅយន្តហោះ ឬក៏លោកចុះពីយន្តហោះទៅជួបនៅឯផ្ទះ? ឆ.១៩៖ មកដល់មន្ទីរតំបន់ក្រចេះហើយហ្នឹង យប់បានមកទទួល ប៉ុន្តែនៅសមរភូមិ។"]។

3512 ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី សេង សឿន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 13.48.25-13.57.43 KH ERN 01355199-201 [បញ្ជាក់ថា មាស មុត "គាត់អ្នកទៅរៀបចំ ខេត្តក្រចេះ"។ នៅពេលសាក្សីបានទៅដល់ខេត្តក្រចេះជាមួយកម្មាភិបាលថ្មីៗដើម្បីជំនួសកម្មាភិបាលចាស់ៗនោះ ពួកគេបានប្រគល់ប្រវត្តិរូបទៅឲ្យ មាស មុត "ប្រធានអង្គប្រជុំប្រកាសចាត់តាំង [...] ជំនួសមុខ ប៉ុល ពត"។ មាស មុត សម្រេចចិត្តដោយផ្ទាល់ដោយចាត់តាំង សេង សឿន ទទួលខុសត្រូវមន្ទីរតំបន់៥០៥]។ ឯកសារ D4.1.810 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.២៧ KH ERN 00402509 ["លិខិតនោះបញ្ជាក់ថា មាស មុត គឺជាអ្នកទទួលខុសត្រូវចាត់ចែងការងារឲ្យមនុស្សខាងលើ"], ឆ.៣១ KH ERN 00402510 [បញ្ជាក់ថា គេបញ្ជូនគាត់មកខេត្តក្រចេះមុន ដើម្បីរៀបចំតែងតាំងការងារថ្មីឲ្យពួកយើង"]។ D114/169 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន, ឆ.២០ KH ERN 01203858 ["កាលជួប [មាស មុត] ដំបូងប្រគល់លិខិតដែលឲ្យមកហ្នឹង ជួបនៅកន្លែងមន្ទីរតំបន់របស់ក្រចេះហ្នឹង។ ទាំងអស់គ្នាមកហ្នឹង រួចបានកាត់ប្រកាសចាត់តាំង។"]។ ឯកសារ D59/2/4.16a កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយសាក្សី សេង សឿន, EN 00753838, KH 00059330 ["[មាស មុត] មករៀបចំខ្ញុំហ្នឹង ពេលដែលខ្ញុំមកនៅថ្ងៃ ៥ ខែ១២ ឆ្នាំ៧៨"]។

3513 ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី សេង សឿន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 13.54.58-13.57.43 KH ERN 01355201 និងម៉ោង 13.59.44-14.01.14 KH ERN 01355202 [ផ្តល់សក្ខីកម្មថា [មាស] មុត ធ្វើការនៅមន្ទីរ៥០៥ជាមួយគាត់]។ ឯកសារ D114/169 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន, ឆ.២៤ KH ERN 01203859 ["នៅជាមួយគ្នា ដេកជាមួយគ្នា បងផុន, បងភាព, និង បងមុត នុំង នៅកន្លែងហ្នឹង។ មានអង្គរក្សរៀងខ្លួន ប៉ុន្តែនៅជុំទាំងអស់គ្នាហ្នឹង។"]។ ឯកសារ D54/63 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.២៣, KH ERN 00975797 ["ស៖ បើសិនជា មាស មុត ទៅក្រចេះ តើគាត់ស្នាក់នៅកន្លែងណា? ឆ.២៣៖ ខ្ញុំមិនដឹងទេ ប៉ុន្តែជាធម្មតា គាត់ស្នាក់នៅភូមិគោលាប់ ដែលជាកន្លែងយោធាកងវរសេនាធំ របស់កងពល១៦៤ បោះទីតាំងនៅ។"]។

និងបញ្ជាកងពល ១៦៤ នៅកំពង់សោម[3515]។ ក្រៅពីបុគ្គលិកកងពល ១៦៤ របស់គាត់ផ្ទាល់ គាត់នៅតែបញ្ជា និងគ្រប់គ្រងទាំងកម្មាភិបាលតំបន់ ៥០៥ និងមេបញ្ជាការកងពល ១១៧[3516] ដូចមាន

---

3514 ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដីនៅដំណាក់កាលពីរ សាក្សី សេង សឿន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 13.54.58-13.57.43 KH ERN 01355201 និងម៉ោង 13.59.44-14.01.14 KH ERN 01355202 [ផ្ដល់សក្ខីកម្មថា [មាស] មុត នៅមន្ទីរតំបន់៥០៥រាយការណ៍ពីសភាពការណ៍ទៅកាន់ ស៊ូ ម៉េត]។ ឯកសារ D54/63 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ម៉ឹង វ៉េត ឆ.១០-១១, KH ERN 00975794-95 ["ថ្ងៃបន្ទាប់មក ខ្ញុំបានឃើញ ញ៉ាន់ ទទួលបានសារទូរលេខ ថា មាសមុត ត្រឡប់ទៅដល់ភ្នំពេញវិញហើយ។ [...] ឆ.១១៖ មាស មុត នៅសេនាធិការ"]។

3515 ឯកសារ D54/16/1R ឯកសារសម្លេងនៃកិច្ចសម្ភាសន៍រវាង David Kattenburg ជាមួយ មាស មុត កាលពីខែមេសា ឆ្នាំ២០០៩ នៅចន្លោះម៉ោង 34:37-35:28 ["គេចាត់តាំងខ្ញុំឱ្យទៅធ្វើការនៅខេត្តក្រចេះ ក្បែរព្រំដែនឡាវ។ ស៖ តើគាត់ចេញពីកងពល ១៦៤ ចាប់ពីខែកុម្ភៈ ឆ្នាំ១៩៧៨នោះមែនទេ? ឆ៖ អត់ទេ តួនាទីខ្ញុំនៅដដែលទេ ប៉ុន្តែគេចាត់តាំងខ្ញុំឱ្យធ្វើបេសកកម្មមួយទៀតនៅក្រចេះ"]។ ឯកសារ D54/87 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ព្រំ សារ៉ាត, ឆ.១៧១-១៧២ KH ERN 00985341 ["ស៖ លោកបានបញ្ជាក់នៅខាងដើមថា មាស មុតបានទៅស្រុកមេមត់នៅចុងឆ្នាំ ១៩៧៨ តាមការណែនាំរបស់លោក សុន សេន។ តើ មាស មុតនៅតែមានអំណាចដឹកនាំគ្រប់គ្រងអ្វីៗនៅខេត្តកំពង់សោមដដែលទេ នៅពេលដែលគាត់ទៅស្រុកមេមត់នោះ? ឆ.១៧១៖ ការងាររបស់គាត់នៅពេលនោះ គឺគាត់នៅមានឥទ្ធិពល និងសិទ្ធិគ្រប់គ្រងដាច់ខែង គឺមិនទាន់ដាច់ចេញពីកំពង់សោមទេ។ ស៖ តើលោកដឹងដោយរបៀបណា? ឆ.១៧២៖ ដឹងតាមប្រព័ន្ធទាក់ទង តាមតេអ៊ូ"]។ ឯកសារ D54/99.1 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី ឡាយ ប៊ុនហាក់, EN 01115988, KH ERN 00990786-87 ["ស៖ តាមុត គាត់អើគ្រប់គ្រងនៅខាងកំពង់សោម នៅកំពង់សោមហ្នឹងរហូតដល់បែក៧៩ឬក៏? ឆ៖ បាទ! រហូតមក ចុង៧៨គាត់គេដកមកគាត់ ក្រោយមកគាត់ឡើងនាយអគ្គសេនាធិការរង [...] ដល់ពេល៧៩គាត់ត្រឡប់ទៅរកអង្គភាពយើងវិញ។ ស៖ បាទ! ប៉ុនពេលដែលគាត់ឡើងមកអគ្គសេនាធិការរងមកនៅភ្នំពេញ ប៉ុន្តែគាត់នៅតែបញ្ជា នៅតាក្ដោបក្ដាប់មក? ឆ៖ មានអើមានអនុកងពលមួយនៅទទួលជំនួស ជ្រនា[ប៉ែកខាង]ណោះដែរ។ ស៖ ពីណាគេ? ឆ៖ ឯកឧត្តម ទឹម សេង។ ស៖ គាត់[ទឹម សេង]ទទួលការពីណា? ឆ៖ ការងារពី តាមុត ផ្នែកយោធាណា។ ស៖ បាទ! ប៉ុន្តែផ្សេងៗនៃការងារអីនៅតាទាក់ទងមក តាមុត ដដែល? ឆ៖ បាទ! អ្នកទទួលបញ្ជាពីលើមករបាយការណ៍"]។ ឯកសារ D54/23 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ាក សុក ឆ.១ KH ERN 00955480-81 ["មាស មុត ជាប្រធានកងពល១៦៤ ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។"]។ ឯកសារ D114/181 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី សែម កុល ឆ.១១, KH ERN 01211916 ["ស៖តើលោកស្ថិតនៅក្នុងអង្គភាពក្រោមបេបញ្ជាការ មាស មុត បានយូរប៉ុនណាដែរ? ឆ.១១៖ បានយូររហូតដល់៧៩។ ព្រោះគាត់ក្ដោបក្ដាប់កងទ័ពជើងទឹកនៅសមុទ្រ រហូតដល់ឆ្នាំ៧៩ទៀត។"]។ ឯកសារ D59/1/1.11a កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី ហៀង វ៉េត, EN 00974098, KH ERN 00926542-43 ["ស៖ ហើយមានពីណា[ជាអ្នកគ្រប់គ្រងវរៈសេនាធំ១៤០]? ឆ៖ បើនិយាយទៅ ទឹម សេង [...] មុនដំបូងគាត់គ្រប់គញ្ញរងជើងទឹក ដល់មកដល់ក្រោយមកគាត់មកគ្រប់គ្រងកងពល១៦៤ ហើយមាស មុត ឡើងមក

បញ្ជាក់ភស្តុតាងដោយបញ្ជាដែលគាត់បានចេញ[3517]។ សេង សឿន បានពន្យល់ថា "យោធាតំបន់ និងកងពល អាហ្នឹងលើដៃបងមុត"[3518]។

ធ្វើជាមេបញ្ជាការនៅភ្នំពេញ"], EN 00974119, KH ERN 00926561 ["ស៖ ចឹងតា មុត គាត់ផ្លាស់មកភ្នំពេញនៅឆ្នាំណា? ឆ៖ នៅឆ្នាំ៧៧តាមមើល។ ឆ៖ បានយូរដែរ។ ស៖ បានប៉ុន្មានបានបែក? ឆ៖ បានមួយឆ្នាំជាងដែលហ្នឹង គាត់មកនៅភ្នំពេញហ្នឹងបានគាត់រត់ចេញពីភ្នំពេញឆ្នាំ៧៩ហ្នឹង បានកាត់ដាក់បទបញ្ជាឱ្យដកពីកំពង់សោម។ ស៖ ចឹងគាត់នៅភ្នំពេញគាត់នៅតែបញ្ជា? ឆ៖គាត់នៅឥទ្ធិពល។ ស៖ ចឹងគាត់នៅទទួលខាងកងពល១៦៤ដដែលឬយ៉ាងម៉េច? ឆ៖ បាទ! តែគាត់ទទួលខាងជើងទឹក"]។

3516 ឯកសារ D54/60.2 កំណត់នៃកិច្ចសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី ម៉ឹង វ៉េត, EN 00993000, KH ERN 00975745, FR 00996585 ["ស៖ មានតែ មាស មុត តែមួយទេ [ជាមេនៅទីនោះ]? ឆ៖ បាទ។"]។ ឯកសារ D54/110 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លុន សេនង ឆ.១-២, KH ERN 00997254 ["សៅ ផុន គឺជាអតីតមេបញ្ជាការកងពិសេសរបស់ មាស មុត។ គាត់មានឈ្មោះហៅក្រៅថា ផុនមាន់ចែ។ [...] ឆ.២៖ បន្ទាប់ពីឆ្នាំ ១៩៧៩ ខុន មកជាមួយយោធាមួយចំនួនពីខេត្តក្រចេះ។"]។

3517 កម្មាភិបាលតំបន់ ៥០៥៖ ឯកសារ D54/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វ៉េត ឆ.២៦ KH ERN 00975784 ["កងវរៈសេនាធំរបស់ ភាព គឺជាកម្លាំងពិសេសរបស់ មាស មុត"]។ ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី សេង សឿន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 10.58.13-11.00.53 KH ERN 01355186 និងម៉ោង 14.01.14-14.03.54 KH ERN 01355203 ["មាស មុត បញ្ជាខ្ញុំឱ្យដើរប្រមូលទ័ព [...] បង មុត ឱ្យខ្ញុំឱ្យប្រមូលទ័ពដែលបាក់ចេញពីព្រំដែនយួនមកហ្នឹង"] ចម្លើយនេះមានបញ្ជាក់នៅក្នុង ឯកសារ D114/297.1.28 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី សេង សឿន ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 09.04.02-09.06.49, KH ERN 01364502 ["ខ្ញុំមកដល់ក្រចេះ [...] គាត់[មាស មុត] ប្រើ[ខ្ញុំ]ឱ្យប្រមូលទ័ពដែលកំពុងបាក់ពីយួនទៅព្រំដែនស្នួលនោះ។"]។ យោធាកងពល១១៧ ក្នុងនោះមាន ញ៉ាន់ ផងដែរ៖ D54/63 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វ៉េត ឆ.១០-១១, KH ERN 00975794-95 ["ថ្ងៃបន្ទាប់មក ខ្ញុំបានឃើញ ញ៉ាន់ ទទួលបានសារទូរលេខ ថា មាសមុត ត្រឡប់ទៅដល់ភ្នំពេញវិញហើយ។ [...] ឆ.១១៖ មាស មុត នៅសេនាធិការ ដូច្នេះគាត់មានសិទ្ធិអំណាចបញ្ជាទៅកងទ័ពទាំងបីប្រភេទ។"]។ ឯកសារ D54/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វ៉េត ឆ.៣០ KH ERN 00975785-86 ["មាស មុត ប្រាប់ពួកគេថា [...] 'ពួកអាធំៗទៅវ៉ៃយួន ចំណែកពួកអាតូចៗក្មេងៗដឹកសម្ភារៈទៅស្ទឹងត្រែង'"]។ អានបន្ថែម ឯកសារ D54/60.2 កំណត់នៃកិច្ចសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី ម៉ឹង វ៉េត, EN 00993000, KH ERN 00251440(ស៊ីក!)[00975745], FR 00996585 ["គាត់ប្រាបថា អែងអាធំៗទៅវ៉ៃយួន នេះមេកងពលឯងនេះ មានញ៉ាន់"]។

3518 ឯកសារ D114/169 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន, ឆ.២៣ KH ERN 01203858-59។

## ៤. ការបន្តបោសសម្អាត

867. ពេញមួយខែ ធ្នូ ឆ្នាំ ១៩៧៨ **មាស មុត** និងអ្នកក្រោមបង្គាប់របស់គាត់ បន្តបោសសម្អាត ដោយចាប់កម្មាភិបាលថ្នាក់ទាប និងជនស៊ីវិល ហើយអ្នកខ្លះត្រូវគេហៅទៅ រួច "បាត់ខ្លួនរហូត" [3519]។ **មាស មុត** បានបញ្ជាដោយផ្ទាល់ឲ្យសម្លាប់កម្មាភិបាលយោធាតំបន់[3520] ឈ្មោះ ម៉ៅ អឿង[3521]

[3519] ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជូ, ឆ.៣៤ KH ERN 01071599-600 ["បន្ទាប់មកទៀត មេបញ្ជាការកងវរៈសេនាធំ និងមេបញ្ជាការកងវរៈសេនាតូចខ្លះ ត្រូវបានហៅទៅទៀត ហើយបាត់ខ្លួនរហូត។ ពេលនោះបញ្ជាការវរៈសេនាតូច វរៈសេនាធំខ្លះ បានរត់ចោលកង ព្រោះខ្លាចគេចាប់យកទៅសម្លាប់ចោលដែរ។"]។ ឯកសារ D114/75 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ីន សុផល ឆ.១៥៣-១៦៥, KH ERN 01101165-66 [សាក្សីរូបនេះបានឃើញការដក និងការចាប់មេបញ្ជាការកងវរៈសេនាតូចនៅក្រចេះ ក្នុងខែធ្នូ ឆ្នាំ១៩៧៨ ដោយ "ទាហានភូមិភាគនិរតី"។ ទាហានថ្នាក់តូចៗ "ត្រូវគេចោទថាក្បត់ ដោយសារមេបញ្ជាការត្រូវបានគេចាប់អស់ហើយ"។ សាក្សីក៏បានលើកឡើងពីឈ្មោះ ពីន, សុភី និងឈ្មោះឌីវ៉ាន់ ដែលគាត់ឃើញគេ "ចាប់បោះឡើងឡាន ដូចជ្រូក"។"]។ ឯកសារ D98/3.1.316 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលដំបូង សាក្សី យុន គីម ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១២ នៅម៉ោង 15.52.58-16.01.18 KH ERN 00818294-95 [ភាគីបានបង្ហាញ ឯកសារ D1.3.28.146 (CF2: E3/1651) ដែលជាបញ្ជីអ្នកទោស ស-២១។ ក្នុងបញ្ជីនោះមានឈ្មោះអ្នកមកពីតំបន់៥០៥ចំនួន២២នាក់ អ្នកទាំងនោះបានមកដល់ស-២១ នៅថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៧៨។ គាត់បានបញ្ជាក់ថាស្គាល់ឈ្មោះ "សម្បត្តិ មកពីឃុំសំបូរ"។ សៈ តើលោកធ្លាប់ចាំថាបានឮដែរឬទេ នៅចុងឆ្នាំ១៩៧៨ ដែលប្រធានឃុំ ឬប្រធានសហករណ៍នេះត្រូវបានគេចាប់ខ្លួន? តើលោកចាំថាធ្លាប់ឮបញ្ហានេះដែរឬទេ? ឆៈ ខ្ញុំធ្លាប់ឮដែរ នៅពេលដែលគេចាប់គណៈតំបន់ ឃើញថាគេចាប់ហូរហែរតគ្នា។ នៅខាងឃុំថ្មគ្រែហ្នឹងក៏ចាប់ ឃុំសំបុកហ្នឹងក៏ចាប់ ហើយនៅឃុំផ្សេងៗទៀត ឃើញតែចាប់បន្តបន្ទាប់ដែរ។"]។ ឯកសារ D114/193 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សារុន ឆ.៦៤, KH ERN 01221859 [ឮតែគេថា ថាគាត់ "[ញ៉ាន់] ជាកងពលជើងទឹកមកក្រចេះហ្នឹង មកចាប់មកចងហ្នឹង"] ដែលមានបញ្ជាក់នៅ ឯកសារ D4.1.444 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សារុន, EN 00278696-97, FR 00486012, KH ERN 00251440 ["ឈ្មោះ ញ៉ាន់ អតីតកងពលធំផ្នែកជើងទឹកនៅកំពង់សោម បានធ្វើដំណើរមកដល់ក្រចេះ ហើយគាត់ឮតៗពីគេមកថា ពួកគាត់ប្រហែលជាអង្គការឲ្យមកចាប់ខាងស៊ីវិល និងយោធា"]។

[3520] ឯកសារ D59/2/4.16a កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយសាក្សី សេង សឿន, EN 00753848-49, KH ERN 00059342 ["ពេលគេមកចាប់មឿន និងខុនទៅនៅអាអឿង។ វាដូចថាអនុយោធាហ្នឹង វាទទួលប្រធានយោធាតំបន់ហ្នឹងបន្ទាប់ពីអាពីរនាក់[មឿន និងខុន]ហ្នឹងមកយោធាលើវា។"]។ ឯកសារ D54/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វ៉េត ឆ.១២ KH ERN 00975780-81 ["មេបញ្ជាការវរៈសេនាធំម្នាក់ ឈ្មោះ អឿង និងមេបញ្ជាការយោធាស្រុកស្នួល ឈ្មោះ ក្រេន បានចូលរួម [ពិធីឧទ្ទេសនាម ម៉ឹង វ៉េត ឲ្យចូលជាសមាជិកបក្សថ្មី]"]។

ដោយបានប្រាប់ សេង សឿន ថា "អញដោះស្រាយរួចហើយ"[3522]។ សាក្សី អែម សារិន លេខាមន្ទីរតំបន់ ៥០៥[3523] ត្រូវបានបញ្ជូនទៅភ្នំពេញជាមួយ ផេង[3524] មេបញ្ជាការរងកងវរសេនាធំ នៃកងពល ១១៧ តាមបញ្ជារបស់ ទី ជាអនុលេខាថ្មី នៃតំបន់ ៥០៥[3525]។ អែម សារិន ត្រូវកងពល ៥០២ ឃុំអស់បីថ្ងៃ នៅជិតផ្សារពោធិចិនតុង[3526]។

868. កម្មាភិបាល ២២ (ម្ភៃពីរ) នាក់ នៃតំបន់ ៥៥ រួមមានប្រធានសហករណ៍ មេឃុំ និងជនស៊ីវិល នៃតំបន់ ៥០៥ (ប្រហែលជាអ្នកភូមិដែលរត់គេចពីការរុលចូលរបស់កងទ័ពវៀតណាម[3527]) ត្រូវគេ

---

3521 ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី សេង សឿន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 14.16.13-14.18.51 KH ERN 01355206 [ផ្តល់សក្ខីកម្មថា "មាស មុត បញ្ជាឲ្យនិរសារគាត់បាញ់សម្លាប់ ម៉ៅ អឿង" ដែលជាមិត្តរួមថ្នាក់ និងមកពីភូមិជាមួយសាក្សីផងនោះ។ មាស មុត បានប្រាប់ទៅសាក្សីដោយផ្ទាល់ថា៖ "អើ អញដោះស្រាយរួចហើយ"]។ ឯកសារ D114/169 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន, ឆ.២៧-៣០ [៣៥?] KH ERN 01203859-60 [បញ្ជាក់ថា ពីរឬបីថ្ងៃក្រោយពីមកដល់ក្រចេះ មាស មុត "បញ្ជាឲ្យគេសម្លាប់ អឿង ភ្លាម"។ មុត បានហៅសាក្សីរូបនេះទៅមន្ទីររបស់គាត់ហើយប្រាប់ថា៖ ""អាអឿង អញឲ្យគេដោះស្រាយហើយ"" សាក្សីពន្យល់ថា "បងមុត មិនមែនអ្នកនេះទេ អង្គរក្សគេអ្នកបាញ់"]។

3522 ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី សេង សឿន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 14.16.13-14.18.51 KH ERN 01355206។

3523 ឯកសារ D114/64 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.២៦៦, និងឆ.២៦៧, KH ERN 01089483 [បញ្ជាក់ថាគាត់មានតួនាទីជាប្រធានមន្ទីរខេត្ត]។

3524 ឯកសារ D114/204 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួស ស៊ីយ៉ាត, ឆ.៤៥-៤៦ KH ERN 01238669 ["ស៖ ពេលលោកទៅ គឺលោកនៅក្នុងកងពល១១៧ ហើយក្នុងវរសេនាធំ១៧ តើមេបញ្ជាការឈ្មោះអី? ឆ.៤៥៖ ឈ្មោះ ឈុត ស្លាប់ហើយ។ ស៖ តើមេបញ្ជាការរងឈ្មោះអី? ឆ.៤៦៖ ផេង ជារងតែស្លាប់អស់ហើយ។"].

3525 ឯកសារ D114/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.៧ KH ERN 01127727 និង ឆ.៣០, KH ERN 01127731 ["ប្រាប់ថា បានទទួលបានលិខិតបញ្ជាឲ្យទៅធ្វើការនៅភ្នំពេញ គឺចុះហត្ថលេខាដោយឈ្មោះ ទី ជំនួសមុខឲ្យមជ្ឈិម។ សាក្សីរូបនេះធ្វើដំណើរដោយយន្តហោះជាមួយ ផេង "យោធា"]។

3526 ឯកសារ D114/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.៣២-ឆ.៣៨ KH ERN 01127732-33 [រៀបរាប់ពីការឃុំខ្លួនគាត់នៅផ្សារពោធិ៍ចិនតុង ដោយកងពល៥០២ "ដើម្បីរង់ចាំការសម្រេចថា ត្រូវធ្វើយ៉ាងម៉េចជាមួយយើង"។ គាត់បានពន្យល់ថា "តែងតែមានអ្នកយាមនៅពីមុខ និងក្រោយផ្ទះឈើដែលគេឃុំខ្លួនយើង។"]។

3527 ឯកសារ D4.1.458 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គន់ សាអឿន EN 00225534, KH ERN 00196826, FR 00272779 ["ហើយក៏មានអ្នកទោសចាប់បានពីសហករណ៍មួយៗដែរ។ នៅក្នុងករណីខ្លះប្រជាជនភៀសខ្លួនពីភូមិមួយទៅភូមិមួយ ដោយនិយាយថា វៀតណាម បានវាយចូលមកដល់ភូមិរបស់គាត់។ ប្រជាជនទាំងនោះត្រូវបានចាប់មក

បញ្ជូនទៅភ្នំពេញ និងចូល ស-២១ ជាមួយគ្នា នៅថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៧៨។ ពួកគេត្រូវបាន សម្លាប់ បួនថ្ងៃក្រោយមក គឺនៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៨[3528]។ កម្មាភិបាលផ្សេងទៀតនៃកង ពល ១១៧ និងជនស៊ីវិលនៃតំបន់ ៥០៥ ត្រូវគេបញ្ជូនទៅមន្ទីរសន្តិសុខមូលដ្ឋាន ក្នុងខេត្តក្រចេះ[3529]

---

សួរចម្លើយ ថាតើការអះអាងរបស់គាត់ពិត ឬមិនពិត ដោយគេសង្ស័យថា គាត់អាចនឹងនិយាយបំផុសបំផុល។ ប្រជាជនទាំងនេះ គឺភៀសខ្លួនមកពីភូមិរបស់គាត់ដែលនៅក្នុងតំបន់-៥៥០។"]។

3528 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ១២៩០៥ [ពិន យឹម ប្រធានឃុំថ្មី ស្រុកក្រចេះ តំបន់៥០៥], លេខរៀង ១២៩០៦ [ប៉ៀន លន់ ប្រជាជនសហករណ៍ទំនប់ ឃុំអញ្ចាញ តំបន់៥០៥], លេខរៀង ១២៩០៧ [សេក ណាន ប្រធានក្រុមឃ្វាលគោ សហករណ៍សំបុក ស្រុកក្រចេះ តំបន់ ៥០៥], លេខរៀង ១២៩០៨ [ម៉ឹង សឹង ហៅ សេន ប្រជាជនចិញ្ចឹមជ្រូក [ចិញ្ចឹមសត្វ] នៅសហករណ៍ស្រែរនាម តំបន់៥០៥], លេខរៀង ១២៩០៩ [ហង់ ហុន ប្រជាជននៅសហករណ៍ក្រសាំង ស្រុកក្រចេះ តំបន់៥០៥], លេខរៀង១២៩១០ [យឹម យ៉ន សមាជិកកងតូច ចម្ការកៅស៊ូស្នួល តំបន់៥០៥], លេខរៀង ១២៩១១ [យ៉ាវ ផូ អនុកងតូចនៅសហករណ៍ទ្រាប តំបន់ ៥០៥], លេខរៀង១២៩១២ [សួន យុត ហៅ យា យុទ្ធជន កងវរៈសេនាតូច៥០ កងតំបន់៥០៥ តំបន់៥០៥], លេខរៀង១២៩១៣ [ឈ ខឹម ប្រជាជនឃុំក្រវាញ ស្នួល តំបន់៥០៥], លេខរៀង១២៩១៤ [និល សំ ប្រធានសហករណ៍ឃុំសំបុក ស្រុកក្រចេះ តំបន់៥០៥], លេខរៀង១២៩១៥ [មៀន ផន ប្រជាជនសហករណ៍ព្រែកក្តី ឃុំស្នួល តំបន់៥០៥], លេខរៀង១២៩១៦ [នុន យុត អនុលេខាឃុំថ្មី ស្រុកក្រចេះ តំបន់៥០៥], លេខរៀង១២៩១៧ [ម៉ុប ប៊ិន ហៅ សុខា ប្រធានសេដ្ឋកិច្ចពេទ្យស្រុកស្នួល តំបន់៥០៥], លេខរៀង១២៩១៨ [អ៊ុន គឹមហាវ ហៅ ហាវ សមាជិកគណៈកម្មាធិការឃុំ១០០ ស្រុកក្រចេះ តំបន់៥០៥], លេខរៀង១២៩១៩ [ឃួន គិមសុត ប្រជាជនសហករណ៍ព្រែកក្តី ឃុំស្នួល តំបន់ ៥០៥], លេខរៀង១២៩២១ [កែ ថុន យុទ្ធជនចល័តស្រុកឆ្លូង តំបន់៥០៥], លេខរៀង១២៩២២ [មី គឿន ហៅ ស៊ីថា យុទ្ធជនកងចល័តស្រុក តំបន់៥០៥], លេខរៀង១២៩២៣ [កួប ហ៊ីម ប្រជាជនសហករណ៍ស្នួល ស្រុកស្នួល តំបន់ ៥០៥], លេខរៀង១២៩២៤ [យុន តេង ប្រធានកងភ្ជួរឃុំសំបុក ស្រុកក្រចេះ តំបន់៥០៥], លេខរៀង ១២៩២៥ [ទុយ ស៊ាន ប្រធានកងតូច សហករណ៍ព្រែកស្មាច់ ស្រុកឆ្លូង តំបន់៥០៥], លេខរៀង១២៩២៦ [នាង យឿន ប្រធានកងតូច ឃុំសំបុក ស្រុកក្រចេះ តំបន់៥០៥]។ អានបន្ថែម ឯកសារ D1.3.28.146 បញ្ជីឈ្មោះអ្នកទោស ស-២១ ដែលបានសួរចម្លើយ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៨, EN 00789508-00789510, KH ERN 00086833-34, FR 00841432-34។

3529 ឯកសារ D4.1.810 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន ឆ.៣៦ KH ERN 00402511 ["មានតែគណៈស្រុកប៉ុណ្ណោះដែលត្រូវបានគេបញ្ជូន [តាមយន្តហោះ] ទៅកម្ពេច ចំណែកឯមនុស្សនៅកម្រិតទាបជាងនេះត្រូវបានគេបញ្ជូនទៅកម្ពេចនៅមណ្ឌលសន្តិសុខក្នុងខេត្តក្រចេះ។"]។ ឯកសារ D4.1.458 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តន់ សារឿន EN 00225534, KH ERN 00196826, FR 00272779 ["ហើយក៏មានអ្នកទោសចាប់បានពីសហករណ៍មួយៗដែរ។ នៅក្នុងករណីខ្លះប្រជាជនភៀសខ្លួនពីភូមិមួយទៅភូមិមួយ ដោយនិយាយថា វៀតណាម បានវាយចូលមកដល់ភូមិរបស់គាត់។ ប្រជាជនទាំងនោះត្រូវបានចាប់មកសួរចម្លើយ ថាតើការអះអាងរបស់គាត់ពិត ឬមិនពិត ដោយគេសង្ស័យថា គាត់អាចនឹងនិយាយបំផុសបំផុល។ ប្រជាជនទាំងនេះ គឺភៀសខ្លួនមកពីភូមិរបស់គាត់ដែលនៅក្នុងតំបន់-៥៥០។"]។

ដូចជា មន្ទីរសន្តិសុខគោកក្តួចនៅស្រុកសំបូរ ជាដើម[3530] ហើយមនុស្សជាច្រើនទៀតបានរត់គេច ដោយខ្លាចការចាប់ខ្លួន[3531]។

869. លើសពីនេះទៅទៀត "គិញ" វៀតណាម ៦ នាក់ ត្រូវបានបញ្ជូនពីខេត្តក្រចេះ នៅថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៧៨[3532] ដោយគាប់ជួនគ្នាជាមួយនឹងការចូលលុកលុយទ្រង់ទ្រាយធំរបស់កងទ័ពវៀតណាម ក្នុងខេត្តក្រចេះ[3533]។

---

3530 ឯកសារ D4.1.458 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តន់ សារឿន EN 00225534, KH ERN 00196826, FR 00272778-79 ["នៅចុងឆ្នាំ១៩៧៨ ពេលវៀតណាមវាយបុកចូលខ្លះ ប្រភេទអ្នកទោសច្រើន[នៅក្នុងមន្ទីរសន្តិសុខគោកក្តួច]ជាអតីតកងទ័ព ដែលមេធំៗបានរត់ចូលទៅវៀតណាម [...]។ ហើយក៏មានអ្នកទោសចាប់បានពីសហាករណ៍មួយៗដែរ។ នៅក្នុងករណីខ្លះប្រជាជនភៀសខ្លួនពីភូមិមួយទៅភូមិមួយ ដោយនិយាយថា វៀតណាម បានវាយចូលមកដល់ភូមិរបស់គាត់។ ប្រជាជនទាំងនោះត្រូវបានចាប់មកសួរចម្លើយ ថាតើការអះអាងរបស់គាត់ពិត ឬមិនពិត ដោយគេសង្ស័យថា គាត់អាចនឹងនិយាយបំផុសបំផុល។ ប្រជាជនទាំងនេះ គឺភៀសខ្លួនមកពីភូមិរបស់គាត់ដែលនៅក្នុងតំបន់-៥៥០។"], KH ERN 00196827 ["មានការចាប់អ្នកទោសជារៀងរាល់ថ្ងៃក្នុងមួយថ្ងៃពីរ ទៅបីដោយចោទថា បានចូលដៃចូលជើងជាមួយវៀតណាម។ អ្នកទោសទាំងនោះ មកពីគ្រប់ទីកន្លែងទូទាំងតំបន់"]។

3531 ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.៣៤ KH ERN 01071599-600 ["ពេលនោះបញ្ហាការវរៈសេនាតូច វរៈសេនាធំខ្លះ បានរត់ចោលកង ព្រោះខ្លាចគេចាប់យកទៅសម្លាប់ចោលដែរ។"]។ ឯកសារ D4.1.458 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តន់ សារឿន EN 00225534, KH ERN 00196826, FR 00272778-79 ["នៅចុងឆ្នាំ១៩៧៨ ពេលវៀតណាមវាយបុកចូលខ្លះ ប្រភេទអ្នកទោសច្រើនជាអតីតកងទ័ព ដែលមេធំៗបានរត់ចូលទៅវៀតណាម"]។

3532 ឯកសារ D114/230.1.1 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ១៣៩៨១-១៣៩៨៦ [ង្វៀន ហូ ហ្វុក, ឡេ មិញតឹម, ង្វៀន ឌឹកជិន, ង្វៀន យ៉ាឡេ, ង្វៀង វ៉ាំងវ៉ាំង, ផាម វីឡេ ទាំងអស់នេះត្រូវគេចាត់ទុកជា "គិញវៀតណាម" ពីក្រចេះ [ភូមិភាគឦសាន]]។

3533 ឯកសារ D1.3.33.1 សារទូរលេខរបស់ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ ផ្ញើជូនទៅប្រធានក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៨, EN 00081489, KH ERN 00224424, FR 00224427 ["នៅថ្ងៃទី ២៥, ២៦, ២៧, ២៨, ២៩ និង៣០ ខែធ្នូ ឆ្នាំ១៩៧៨ នៅខេត្តក្រចេះ កងពលធំ ន៣ និង៥ បានវាយប្រហារ និងចូលយ៉ាងជ្រៅមកក្នុងដែនដីកម្ពុជាតាមផ្លូវជាតិលេខ៧ (អតីតផ្លូវជាតិលេខ១៣) នៅឆ្ងាយបន្តិចពីប្រជុំជនសំខាន់នៃស្រុកស្នួល។ ឥឡូវនេះវៀតណាមកំពុងព្យាយាមបន្តចូលមកកាន់តែជ្រៅក្នុងទឹកដីកម្ពុជាថែមទៀត។"]។ ឯកសារ D64.1.39 សារព័ត៌មាន FBIS, ទោះបីជាទទួលរងបរាជ័យ សាធារណរដ្ឋសង្គមនិយមវៀតណាមបន្តឈ្លានពានភូមិភាគនិរតី, ថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៩, EN 00169318 ["នៅសមរភូមិស្នួល-ក្រចេះ៖ ពីថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ១៩៧៨ ដល់ថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៩ យើងបានកម្ទេចកងទ័ពខ្មាំងយួនឈ្លានពានជាង១០០០ក្បាល និងធ្វើឱ្យវារបួសជាច្រើនទៀត"]។

## ៥. ឧក្រិដ្ឋកម្ម

### ការដាក់ក្នុងមន្ទីរឃុំឃាំង

870. ដូចបានរៀបរាប់ខាងលើ នៅចុងខែ វិច្ឆិកា និងពេញមួយខែ ធ្នូ ឆ្នាំ ១៩៧៨ កម្មាភិបាលជាច្រើននៃកងពល ១១៧ និងតំបន់ ៥០៥ ព្រមទាំងជនស៊ីវិលនៃតំបន់ ៥០៥ ក៏ដូចជា "គិញ" វៀតណាម ត្រូវចាប់ខ្លួន និងដាក់គុកនៅ ស-២១ នៅជិតផ្សារពោធិចិនតុងនៅភ្នំពេញ ឬនៅតាមមន្ទីរសន្តិសុខស្ថិតនៅខេត្តក្រចេះ រួមទាំងមន្ទីរសន្តិសុខគោកក្ដួច។

871. ការចាប់ និងឃុំកម្មាភិបាលកងពល ១១៧ និងតំបន់ ៥០៥ ជនស៊ីវិល និង "គិញ" វៀតណាម បានធ្វើឡើង ដោយគ្មានដំណើរការក្ដីតាមផ្លូវច្បាប់ និងតាមទំនើងចិត្ត។ អាជ្ញាធរកម្ពុជាប្រជាធិបតេយ្យមិនបានបង្កើតតុលាការ ក្រមព្រហ្មទណ្ឌ ឬការកាត់សេចក្ដីតាមផ្លូវច្បាប់[3534]។ ជាលទ្ធផល គ្មានការអនុញ្ញាតតាមផ្លូវតុលាការ ឬការពិនិត្យមើលឡើងវិញនូវការចាប់ និងឃុំខ្លួនឡើយ។ អ្នកទោសមិនទទួលបានការជូនដំណឹងអំពីបទចោទប្រកាន់នឹងខ្លួន។ ផ្ទុយទៅវិញ កម្មាភិបាលខ្មែរក្រហមជាច្រើន

---

[3534] ឯកសារ D4.1.191, D114/37.1.7 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន(UNHCHR) ជាមួយ កាំង ហ្គេកអ៊ាវ ហៅ ឌុច, ថ្ងៃទី៤-៦ ខែឧសភា ឆ្នាំ១៩៩៩, EN 00185022-23 ["ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺគ្មានតុលាការ គ្មានគុក គ្មានក្រសួងយុត្តិធម៌ទេ។ មានសភាជាតិប៉ុន្តែមិនសូវដែលបានជួបប្រជុំឡើយ។ ប្រធានតុលាការកំពូលឈ្មោះ កង ចាប ត្រូវគេចាប់ខ្លួនហើយបញ្ជូនទៅកាន់មន្ទីរសន្តិសុខ ស-២១។ នរណាក៏ដោយឱ្យតែចូលទៅជាប់នៅមន្ទីរសន្តិសុខស-២១ នោះគឺត្រូវតែស្លាប់ទាំងអស់ដោយមិនមានបញ្ហាឡើយទោះបីជាមាន ឬគ្មានចម្លើយសារភាពក្តី។ ដូច្នេះគោលបំណងនៃចម្លើយសារភាពគឺមិនមែនប្រើប្រាស់សម្រាប់ផ្លូវច្បាប់ដូចនៅកន្លែងផ្សេងៗទេ។ [...] អ្នកដែលគេចាប់ខ្លួនគឺប្រាកដជាស្លាប់"]។ ឯកសារ D4.1.1109 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្គេកអ៊ាវ, EN 00177588, KH ERN 00177581, FR 00177596 ["ស៖ តើលោកនៅតែបញ្ជាក់អះអាងថាគ្មានពេលណាមួយដែលនៅ ស-២១ មានការដាក់ឱ្យដំណើរការនូវការធានាផ្នែកនីតិវិធីដែលមានទិសដៅវាយតំលៃចាំបាច់ក្នុងការចាប់ខ្លួន និងជុំខ្លួន និងផ្ដល់ឱ្យចនជាប់ខុះនូវការកាត់សេចកតីមួយមិនពេលសម្លាប់ឡើយឬ? ឆ៖ ខ្ញុំទទួលស្គាល់ចំណុចនេះ។ រាល់សេចក្តីសម្រេចសំខាន់ៗ ត្រូវបានធវ្ើលោយបក្ស ដែលដឹកនាំប្រទេសផ្តាច់មុខ និងតាមរបៀបផ្តាច់ការ [...] គោលការណ៍នេះគឺមានវិសមិតភាពជាមយយនឹងអត្ថិភាពនៃតុលាការ និងការធានាផ្នែកនីតិវិធី។"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈាង ជួ, ឆ.៥៩ KH ERN 01071605 ["ខ្ញុំមិនដែលឮថាមានប្រព័ន្ធតុលាការទេ នៅពេលនោះ។"]។ ឯកសារ D114/37.1.73 កំណត់ហេតុជាលាយលក្ខអក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដី "ឌុច" ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩ នៅម៉ោង 10.21.01-10.24.33 KH ERN 00361493 ["គឺមិនមានច្បាប់ មិនមានចៅក្រម មិនមានមេធាវី មិនមាតុលាការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ យើងឃើញមានថា តុលាការចែងនៅក្នុងរដ្ឋធម្មនុញ្ញ ប៉ុន្តែចៅក្រមក៏ត្រូវបានគេសម្លាប់ផងដែរ។"]។

ត្រូវគេឃុំ ក្រោមលេសបញ្ជូនទៅរៀនសូត្រ ឬធ្វើការ។ គ្មានអ្នកទោសណាម្នាក់មានសិទ្ធិជំទាស់តវ៉ានឹងការចាប់ដាក់គុក តាមរយៈយន្តការតាមផ្លូវតុលាការ ឬទទួលបានការជំនុំជម្រះក្តីឡើយ។

872. ក្នុងករណីភាគច្រើន "ការសង្ស័យ" របស់របបនោះ លើអ្នកដែលចាប់ខ្លួន កើតចេញតែពីចម្លើយសារភាពដែលទទួលបានតាមរយៈការធ្វើទារុណកម្មទៅលើអ្នកដែលចូល ស-២១ និងមន្ទីរសន្តិសុខផ្សេងទៀតរបស់កម្ពុជាប្រជាធិបតេយ្យ[3535]។ ការដែលកម្មាភិបាលកងពល ១១៧ និងតំបន់ ៥០៥ ត្រូវបានអ្នកទោស ដូចជា វន វ៉េត[3536] ឬកម្មាភិបាលដទៃផ្សេងទៀត ឆ្លើយដាក់ ក្នុងការសួរចម្លើយនៅ ស-២១ គឺមិនអាចជឿជាក់បានទាល់តែសោះ និងខកខានមិនបានផ្តល់យុត្តិកម្មសម្រាប់ការចាប់ឃុំ ឬសម្លាប់ឡើយ។ ដូចមេដឹកនាំ ប.ក.ក បានដឹងស្រាប់ហើយ[3537] ចម្លើយសារភាព ដែលទទួល

---

[3535] D54/6.1.14 កំណត់ហេតុជាលាយលក្ខអក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច" ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ នៅម៉ោង 10.18.09-10.29.11 KH ERN 00341902 ["ពាក់ព័ន្ធទៅនឹងការចាប់ខ្លួនដោយផ្អែកទៅលើចម្លើយសារភាពរបស់អ្នកដទៃ"], និងនៅម៉ោង 10.40.00-11.10.36, KH ERN 00341907។ ឯកសារ D4.1.191, D114/37.1.7 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន(UNHCR) ជាមួយ កាំង ហ្កេកអ៊ាវ ហៅ ឌុច, ថ្ងៃទី៤-៦ ខែឧសភា ឆ្នាំ១៩៩៩, EN 00185023 ["ការយកចម្លើយសារភាពនោះគឺមានបំណងឲ្យថ្នាក់លើអាចវិភាគលើចម្លើយទាំងនោះ ហើយអាចរែកមុខជនក្បត់ក៏ដូចជារកខ្សែក្បត់ឃើញ"]។ ឯកសារ D4.1.406 សេចក្តីអធិប្បាយ និងចម្លើយជាលាយលក្ខអក្សររបស់ ឌុច, EN 00434343, KH ERN 00408229, FR 00408245 ["ការងារស្នូលនៃមន្ទីរសន្តិបាលជំនាក់នោះ គឺបញ្ជូនចម្លើយសារភាពទៅថ្នាក់លើ នេះឯង។ គឺចម្លើយសារភាពហ្នឹងហើយដែលខាងលើត្រូវការ ដើម្បីបង្កើនការសង្ស័យ បន្តការចាប់ចងកាប់សម្លាប់មនុស្ស ដែលជាសាច់ឯងឈាមឯងយ៉ាងងងិតងងល់តទៅទៀត។"]។ ឯកសារ D234/2.1.110 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ឡាច មាន ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ នៅម៉ោង 15.52.12-15.54.54, KH ERN 01247413 ["គេឲ្យយើងសួរចម្លើយដើម្បីរកខ្សែបណ្តាញ រកខ្សែដែលទាក់ទងខ្សែរយៈក្បត់"]។ ឯកសារ D234/2.1.112 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ប្រាក់ ខន ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦ នៅម៉ោង 11.21.41-11.25.00 KH ERN 01249378 ["តាមការឆ្លើយដាក់ពីអ្នកទោសមុនៗមក ឆ្លើយដាក់ទៅបានចាប់អ្នកក្រោយទៀត។ អ៊ីចឹងការឆ្លើយដាក់ពី ស-២១ទៅ អាហ្នឹងវា គេត្រូវស្រាវជ្រាវតាមខ្សែបណ្តាញដែលឆ្លើយដាក់ហ្នឹង។"], និងនៅម៉ោង 15.46.26-15.48.17, KH ERN 01249414-15។

[3536] អាន កថាខណ្ឌ ៨៥៩។

[3537] អាន ឧទាហរណ៍ ឯកសារ D4.1.191, D114/37.1.7 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន(UNHCR) ជាមួយ កាំង ហ្កេកអ៊ាវ ហៅ ឌុច, ថ្ងៃទី៤-៦ ខែឧសភា ឆ្នាំ១៩៩៩ ទំព័រ៣៩ និងទំព័រ៤៥, EN 00185034, FR 00160921 ["យើងដឹងថាចម្លើយសារភាពបែបនោះ មានច្រើនណាស់ គឺអាចបំផ្លាញបក្សកុម្មុយនិស្តកម្ពុជាទាំងមូល។ [...] គ្មាននរណាជឿចម្លើយនោះទេ"]។

បានក្នុងកាលៈទេសៈបែបនេះ មិនអាចជឿទុកចិត្តបានទេ។ ក្នុងករណីណាក៏ដោយ ច្បាស់ណាស់ថា ការសម្រេចចាប់កម្មាភិបាលថ្នាក់ខ្ពស់ ត្រូវបានធ្វើរួចមកហើយ ពេល **មាស មុត** ទៅក្រចេះ។

873. ដូចបានពិភាក្សាលម្អិត នៅក្នុងផ្នែកទី *VIII.ឃ មន្ទីរសន្តិសុខ ស-២១*[3538] ពេលនៅ ស-២១ អ្នកទោសទាំងអស់ត្រូវគេដកហូតសេរីភាព តាមវិធីអមនុស្សធម៌បំផុត។ អ្នកទោសត្រូវគេនាំទៅកន្លែងមិនអាចគេចរួច ដោយគេដាក់ខ្នោះដៃ និងបិទមុខ ហើយត្រូវជាប់ខ្នោះរហូត លើកលែងតែពេលគេយកទៅសួរចម្លើយ ឬសម្លាប់។ ដូចគ្នានេះដែរ អ្នកទោសនៅមន្ទីរសន្តិសុខគោកក្តួចត្រូវគេដាក់ខ្នោះដៃ និងខ្នោះជើងជាប់ជាមួយអ្នកទោសផ្សេងទៀត ពេលមកដល់ ហើយអ្នកទោសធ្ងន់ត្រូវគេដាក់ខ្នោះដៃ ខ្នោះជើងជាប់រហូត ក្នុងពេលឃុំខ្លួន[3539]។ អែម សារិន ក៏បានរៀបរាប់អំពីការឃុំខ្លួនគាត់ដោយកងពល ៥០២ នៅផ្សារពោធិចិនតុង ដោយមានអ្នកយាមចាំមើល[3540]។

## មនុស្សឃាត ការសម្លាប់រង្គាលផ្តាច់ពូជ និងការបាត់ខ្លួនដោយបង្ខំ

874. ក្រៅពីការសម្លាប់ ម៉ៅ អឿង ដោយខុសច្បាប់ នៅខេត្តក្រចេះ តាមបញ្ជាផ្ទាល់របស់ **មាស មុត**[3541] យ៉ាងហោចណាស់ កម្មាភិបាលកងពល ១១៧ និងជនស៊ីវិលតំបន់ ៥០៥ ចំនួន ៣២ នាក់ ព្រមទាំង "គិញ" វៀតណាម ៦ នាក់ ត្រូវគេសម្លាប់ដោយខុសច្បាប់ នៅ ស-២១។ កាលៈទេសៈនៃការស្លាប់ នៅ ស-២១ ត្រូវបានពិភាក្សាបន្ថែមទៀត នៅផ្នែកទី *VIII.ឃ មន្ទីរសន្តិសុខ ស-២១*។

---

3538 អានផ្នែក VIII.D. មន្ទីរសន្តិសុខ ស-២១ – ៥. ឧក្រិដ្ឋកម្ម – ការឃុំឃាំង – ក) ការដកហូតសេរីភាពរបស់អ្នកដែលត្រូវគេបញ្ជូនទៅមន្ទីរ ស-២១។

3539 ឯកសារ D4.1.458 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តន់ សារឿន EN 00225532-33, KH ERN 00196824, FR 00272776-77 ["អ្នកទោសមកថ្មី ត្រូវបានគេដាក់ខ្នោះដៃ-ជើង ទាំងថ្ងៃទាំងយប់ [...] អ្នកទោសធ្ងន់ត្រូវគេឃុំឃាំងនៅក្នុងអគារដាច់ដោយឡែកមួយ ដោយមានដាក់ខ្នោះដៃខ្នោះជើង"], EN 00225536, KH ERN 00196828, FR 00272780 ["អ្នកទោសខ្លះ ត្រូវបានគេដាក់ខ្នោះឃុំខ្លួនបន្ត ហើយអ្នកទោសខ្លះទៀតត្រូវបានគេមិនដាក់ខ្នោះទេ ហើយប្រើឲ្យធ្វើការងារនៅក្នុងមន្ទីរតែម្តង។"]។

3540 ឯកសារ D114/102 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អែម សារិន, ឆ.៣២-ឆ.៣៨ KH ERN 01127732-33 [រៀបរាប់ពីការឃុំខ្លួនគាត់នៅផ្សារពោធិ៍ចិនតុង ដោយកងពល៥០២ "ដើម្បីរង់ចាំការសម្រេចថា ត្រូវធ្វើយ៉ាងម៉េចជាមួយយើង"។ គាត់បានពន្យល់ថា "តែងតែមានអ្នកយាមនៅពីមុខ និងក្រោយផ្ទះឈើដែលគេឃុំខ្លួនយើង។"]។

3541 អានកថាខណ្ឌ ៨៦៧។

875. នៅក្នុងរបបមួយ ដែលជារឿយៗ ត្រូវបានហៅថាជា "របបលាក់ការណ៍"[3542] មានព័ត៌មានតិចតួច ឬគ្មានតែម្តង អំពីអ្នកដែលត្រូវគេចាប់ខ្លួន។ ចំពោះអ្នកនៅរស់ អ្នកទាំងនេះ "បាត់ខ្លួន" តែម្តង[3543]។ ពុំមានតុលាការ ឬប្រព័ន្ធផ្សេងទៀត សម្រាប់ប្តឹងអំពីការបាត់ខ្លួនឡើយ[3544]។

---

[3542] ឯកសារ D234/2.1.140 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី ធុច ស៊ីថន ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៦ ម៉ោង 14.30.20-14.33.11, KH ERN 01392437 ["ធម្មតា ពិបាក ដែរនៅជំនាន់ហ្នឹងគឺថា ការសម្ងាត់គឺម្នាក់ៗអត់មានការហ៊ាននិយាយលេងអី ឬក៏ចេញអីទេ"]។ ឯកសារ D54/87 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រំ សារ៉ាត ឆ.១៦០ KH ERN 00985339 ["ទេ ខ្ញុំមិនដឹងទេ។ សម័យនោះ ថ្នាក់លើ គេនិយាយថារបបលាក់ការណ៍សម្ងាត់។ បើសិនគេចាប់បាន ឬគេបញ្ជូនអ្នកណាទៅអប់រំរៀនសូត្រ គឺគេចាប់ ដោយសម្ងាត់ យើងមិនអាចដឹងបានទេ។ ខ្ញុំដឹងតែរឿងមួយទេ គឺ សានដែលជាអ្នកធ្វើការជាមួយខ្ញុំ គឺបាត់ខ្លួននៅឆ្នាំ ១៩៧៧។"]។ ឯកសារ D4.1.195 សេចក្តីថ្លែងការណ៍របស់បក្សកុម្មុយនិស្តកម្ពុជាជូនចំពោះបក្សកុម្មុយនិស្តដាណឺម៉ាក , ខែកក្កដា ឆ្នាំ១៩៧៨, KH ERN ERN 00224469 ["ស៖ ហេតុអ្វីបានជាការងារមិនស្របច្បាប់នៅតែជាការងារមូល ដ្ឋាន? ឆ៖ នៅក្នុងអំឡុងពេលនេះ ក្រោយពីការរំដោះ ការងារសម្ងាត់ ជាការងារមូលដ្ឋាន។ យើងលែងប្រើពាក្យ "ស្របច្បាប់" និង"មិនស្របច្បាប់"តទៅទៀតហើយ យើងប្រើពាក្យថា "សម្ងាត់" និង "ចំហ" វិញ។ ការងារសម្ងាត់គឺ ជាការងារមូលដ្ឋានសម្រាប់អ្វីៗទាំងអស់ដែលយើងធ្វើ។ ឧទាហរណ៍ ការបោះឆ្នោតជ្រើសរើសកម្មាភិបាល សម្រាប់ ការងារដឹកនាំ គឺធ្វើឡើងដោយសម្ងាត់។ ទីកន្លែងដែល ថ្នាក់ដឹកនាំរបស់យើងរស់នៅ គឺត្រូវរក្សាជាសម្ងាត់។ យើងរក្សា ការសម្ងាត់ចំពោះពេលវេលា និងទីកន្លែងប្រជុំ។ ម្យ៉ាង នេះជាបញ្ហាគោលការណ៍ទូទៅ និងម្យ៉ាងទៀតនេះជា មធ្យោបាយមួយក្នុងការការពារខ្លួនយើងពីគ្រោះថ្នាក់នៃការជ្រៀតចូលរបស់សត្រូវ។ ឲ្យតែមានការតស៊ូវណ្ណៈ ឬចក្រពត្តិនិយម ការងារសម្ងាត់នឹងនៅតែជាការងារមូលដ្ឋាន។ គឺមានតែតាមរយៈការងារសម្ងាត់ប៉ុណ្ណោះទើបយើង អាចម្ចាស់ការលើស្ថានភាពបាន ហើយទទួលជោគជ័យលើសត្រូវ ដ្បិតសត្រូវមិនអាចដឹងបានថានរណាជានរណាឡើ យ។

ការងារនេះក៏អាចអនុវត្តចំពោះកិច្ចការបរទេសបានដែរ។ ឧទាហរណ៍ សូវៀតបានស្នើសុំមកភ្នំពេញនៅពេលរំដោះហើយ គេបាន រៀបចំបញ្ជូនមនុស្ស២០០នាក់មកកាន់ស្ថានទូត។ យើងខ្ញុំបានឆ្លើយថា យើងខ្ញុំមិនអាចទទួលពួកគេបានទេហើយពួកគេ ខឹងសម្បារយ៉ាងខ្លាំង។ យើងពឹងផ្អែកអ្វីៗទាំងអស់ទលើការងារសម្ងាត់។ ធ្វើដូចនេះគឺដើម្បីផលប្រយោជន៍របស់វណ្ណៈ អធន។"]។"].

[3543] អានឧទាហរណ៍ ឯកសារ D114/171 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ សារួន ឆ.៥៣ និងឆ.៥៥-៥៦ KH ERN 01204180-81 [សាក្សីរូបនេះជាអតីតប្រពន្ធលេខាស្រុកក្រចេះឈ្មោះ ហួន យ៉េង៖ ស៖ ពេលដែលគេចាប់ប្តី បាត់ទៅ តើលោកស្រីបានពិភាក្សាគ្នាជាមួយនឹងប្រពន្ធកម្មាភិបាលដែលបាត់ខ្លួនដែរឬទេ? ឆ.៥៣៖ បានជួបសួរ និយាយគ្នាដែរ ប៉ុន្តែមិនបានដឹងព័ត៌មានអីទេ។ [...] ស៖ តើប្រពន្ធអស់ហ្នឹង ពេលពិភាក្សា គេប្រាប់ថាម៉េចទេ? ឆ.៥៥ អត់មានដំណឹងអីទាំងអស់។ ស៖ លោកស្រីគិតថា ប្តីនៅរស់ទេ ឬក៏យ៉ាងម៉េច? ឆ.៥៦៖ អត់ទេ ខ្ញុំគិតថា បើគាត់នៅ រស់ គាត់មករកខ្ញុំហើយ។"]។ ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.៣០-៣៤ KH ERN 01071599-600 ["អំឡុងពេលនោះ ការបោសសម្អាតបានចាប់ផ្តើម។ គេដកមិត្តរួមអាវុធរបស់ខ្ញុំ ដូចជា រ៉ុំ និង

## ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

876. ម៉ឹង វេត បានរៀបរាប់អំពីកិច្ចប្រជុំមួយ ដែល មាស មុត បានហៅកម្មាភិបាលកងពល ១១៧ និង តំបន់ ៥០៥ ថាជា "ជនក្បត់" នឹងរបបកម្ពុជាប្រជាធិបតេយ្យ ពីព្រោះពួកគេត្រូវបានដកទំនុកចិត្ត ក្រោយពីបានដកថយពីព្រំដែន ពេលវៀតណាមវាយចូល[3545]។ សេង សឿន បានផ្តល់សក្ខីកម្ម ស្រដៀងគ្នាថា គាត់ត្រូវគេប្រាប់ថា កម្មាភិបាលមុនៗ នៅក្រចេះ ត្រូវបានចាប់ខ្លួន ដោយសារតែ "ជាប់ខ្សែក្បត់"[3546]។ ឈាង ជួ អតីតទាហានកងពល ១១៧ បាននិយាយអំពីការ "ចូលដៃចូលជើង

---

លាង។ [...] គេហៅពួកគាត់ទៅប្រជុំនៅក្រចេះ ហើយបន្ទាប់មកបាត់ខ្លួនរហូត។ [...] ឆ.៣៤៖ បន្ទាប់មកទផត បញ្ជាការកងវរៈសេនាធំ និងមេបញ្ជាការកងវរៈសេនាតូចខ្លះត្រូវបានគេហៅទៅទៀត បាត់ខ្លួនរហូត។ ពេលនោះ បញ្ជាការវរៈសេនាតូច វរៈសេនាធំខ្លះបានរត់ចោលកង ព្រោះខ្លាចគេចាប់យកទៅសម្លាប់ដែរ។"]។

3544 ឯកសារ D114/116 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្វាយ សំអាន, ឆ.៤៤-៤៥, KH ERN 01138914 ["មានមនុស្សជាច្រើនមកពីតាមកងវរសេនាតូចផ្សេងៗ ដែលក្នុងនោះរួមទាំងបងជីដូនមួយខ្ញុំផងបានបាត់ខ្លួន ហើយ ភ័យខ្លាចបាត់បង់អាយុជីវិត។ សៈ តើមានប្រព័ន្ធតុលាការ ដែលអាចឱ្យប្រជាជនដាក់ពាក្យបណ្តឹងអំពីការណីបាត់ខ្លួន បែបនេះដែរឬទេ? ឆ.៤៥៖ ពុំមានទេ។"]។ អានកថាខណ្ឌ ៨៧១។

3545 ឯកសារ D114/297.1.22 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលទី ពីរ សាក្សីម៉ឹង វេត, ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦, ម៉ោង 13.38.39-13.41.28 KH ERN 01329904 ["ទប់ [យួន]លែងជាប់ ចាប់ផ្តើមលែងទុកចិត្តខាងខ្ញុំបណ្តោយ [...] ដោយឡែកថ្នាក់លើៗនោះ ត្រូវចោទប្រកាន់ថ្នាក់លើនោះ វិញ"]។ ឯកសារ D114/297.1.23 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់ កាលពីរ សាក្សី ម៉ឹង វេត ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦ នៅម៉ោង 09.10.54-09.13.47 KH ERN 01329770-71 ["គណៈតំបន់ថ្មី កងពលថ្មីដែលទៅនេះ គាត់បាននិយាយថា មេឯងក្បត់អស់ហើយ។ ពេលយួនបុកមកដល់ហ្នឹងគឺ ច្របូកច្របល់ពេលហ្នឹង លែងទុកចិត្តគ្នាទាំងអស់។"], និងម៉ោង 09.39.51-09.41.29 KH ERN 01329781 ["គាត់ [មាស មុត] ថា ពួកអ្នែងគ្រប់គ្នាអត់វៃយួនសោះ ឱ្យយួនបុកយកបានទាំងមូល។"]។ ឯកសារ D54/63 កំណត់ហេតុ នៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.២, KH ERN 00975792-93 ["មាស មុត បានខឹង ដោយកាត់និយាយថា ពួក យើងមិនដាច់ខាតវៃនឹងយួនទេ។ ដោយសារតែព្រឹត្តិការណ៍ទាំងនេះ បានជា តា មុត គាត់ឈប់ជឿលើថ្នាក់ដឹកនាំកង ពល ហើយដកអ្នក១១នាក់នោះចេញ។"]។

3546 ឯកសារ D114/297.1.27 កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តីនៅដំណាក់កាលពីរ សាក្សី សេង សឿន ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ នៅម៉ោង 13.48.25-13.51.55 KH ERN 01355199-200។ ដោយបញ្ជាក់បន្ថែម ឯកសារ D114/169 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេង សឿន, ឆ.២៧ KH ERN 01203859 ["សម័យនុំងកំពុងតែចាប់ពួកអ្នកនៅខ្សែយួន"]។

ជាមួយយួន"[3547]។ សាក្សីផ្សេងទៀត រួមទាំងសាច់ញាតិរបស់កម្មាភិបាលដែលត្រូវគេបោសសម្អាត យល់ឃើញថា ការចោទពីអំពើក្បត់ទៅលើកម្មាភិបាលដែលត្រូវគេបោសសម្អាត ដោយសារតែពួកគេបរាជ័យក្នុងការទប់ទល់នឹងការលុកលុយចូលរបស់វៀតណាម[3548]។ កម្មាភិបាលកងពល ១១៧ និងតំបន់ ៥០៥ ត្រូវគេកំណត់មុខសញ្ញា ពីព្រោះពួកគេត្រូវបានមេដឹកនាំ ប.ក.ក រួមទាំង **មាស មុត** ចាត់ទុកជា "ជនក្បត់" ឬ "ខ្មាំងផ្ទៃក្នុង" ដែលបង្កការគំរាមកំហែងដល់ថ្នាក់ដឹកនាំ ប.ក.ក ក៏ដូចជាចូលដៃជាមួយវៀតណាមជារដ្ឋសត្រូវ ព្រមទាំងប្រឆាំងនឹងវិន័យរបស់ ប.ក.ក។

877. "គិញ" វៀតណាម ដែលចាប់បាន នៅក្រចេះ និងបញ្ជូនទៅ ស-២១ ត្រូវបាន **មាស មុត** និងអ្នកនៅក្រោមបង្គាប់ កំណត់មុខសញ្ញា ដោយផ្អែកលើការចាត់ថ្នាក់ដោយ ប.ក.ក ថាជាខ្មាំងរបស់របបកម្ពុជាប្រជាធិបតេយ្យ។ គេបានប្រកាសក្នុងកិច្ចប្រជុំមេបញ្ជាការកងពលមជ្ឈិម និងកងវរសេនាធំឯករាជ្យ ឆ្នាំ ១៩៧៦ ដូចខាងក្រោម៖

> ក្នុងឋានៈជាកងទ័ព ត្រូវស្គាល់កម្មវត្ថុដែលត្រូវវាយ គឺចក្រពត្តិអាមេរិក ពួកសេរីវៀតណាម និងដៃជើងក្បត់របស់វា[3549]។

---

[3547] ឯកសារ D114/52 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាង ជួ, ឆ.៣៤ និងឆ.៣៩ KH ERN 01071599-600 ["យើងដឹងថា រ៉ុំ និង លាង ត្រូវបានគេយកទៅសម្លាប់ ដោយពួកយើងកងពល១១៧ ត្រូវបានចោទប្រកាន់ថា ជាយោធាទន់ខ្សោយ មិនអាចវ៉ៃទ័ពវៀតណាមបាន។ [...] ឆ.៣៩៖ [...] គេចោទកងពល១១៧ ថាចូលដៃចូលជើងជាមួយយួន ហើយវ៉ៃមិនឈ្នះយួន ចេះតែដកថយ ពេលយួនវ៉ៃចូល។"]។

[3548] ឯកសារ D114/216 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មាស អ៊ឹម ឆ.៤៣ KH ERN 01301460 [បញ្ជាក់ថាមានគេមកប្រាប់គាត់ថា មាស មឿន ត្រូវគេចាប់ខ្លួនហើយ "មកពីទប់យួនមិនបាន វ៉ៃយួនមិនបាន"]។ ឯកសារ D114/210 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង្ស ខន ឆ.៣៧, KH ERN 01247453 [បញ្ជាក់ថានៅពេលដែលគេបញ្ជូនគាត់ទៅក្រចេះនៅចុងឆ្នាំ១៩៧៨ "យួនៗគេលែងទុកចិត្តគ្នាឯង។ នៅពេលនោះសង្គ្រាមផ្ទៃក្នុងកំពុងបែកបាក់។"]។ ឯកសារ D114/167 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈុំ យ៉ា, ឆ.៤៦ KH ERN 01202863 [សាក្សីជាប្អូនស្រីរបស់អតីតលេខាស្រុកស្នួល ឈ្មោះ ឈុំ ចិន ហៅ ភ័ន ពន្យល់ថា នៅឆ្នាំ១៩៨២ ឬឆ្នាំ១៩៨៣ ប្រពន្ធរបស់ឈុំ ចិន បានប្រាប់គាត់ថាគេចាប់ប្ដីគាត់ដោយសារ "គេចោទថាយើងធ្វើការមិនកើតទើបយួនចូលស្រុកបាន។"]។ ឯកសារ D114/203 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ុញ នឿម ឆ.១២ KH ERN 01238656 ["[មេបញ្ជាការកងពល១១៧] ឈ្មោះ រ៉ុំ តែគាត់ស្លាប់ហើយ។ គេចាប់គាត់ដោយគេចោទថាគាត់ក្បត់ [...] ឆ.៤២, KH ERN 01238660, ដល់ពេលយើងចាញ់វៀតណាម រ៉ុំ និងលៀង ស្លាប់អស់ទៅ គឺគេចាប់យកទៅ។"]។

[3549] ឯកសារ D1.3.27.20 កំណត់ហេតុនៃកិច្ចប្រជុំកងទ័ពកម្ពុជាប្រជាធិបតេយ្យ, ថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧៦, EN 00940354, KH ERN 00052413។

## IX. អង្គច្បាប់

## ក. ឧក្រិដ្ឋកម្ម

878. **មាស មុត** ត្រូវបានចោទប្រកាន់អំពីឧក្រិដ្ឋកម្ម ដូចមានរៀបរាប់នៅក្នុងមាត្រា ៤ មាត្រា ៥ និង មាត្រា ៦ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលផ្តល់យុត្តាធិការឱ្យ អ.វ.ត.ក កាត់សេចក្តីលើអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩។ ការប្រព្រឹត្តិឧក្រិដ្ឋកម្មណាមួយក្នុងចំណោមឧក្រិដ្ឋកម្មទាំងនេះអាចកើតឡើងតាមរយៈអំពើសកម្ម ឬអកម្ម[3550] និងមិនកម្រិតត្រឹមការប្រព្រឹត្តិដោយផ្ទាល់ដៃនោះទេ[3551]។

### ១. អំពើប្រល័យពូជសាសន៍

879. មាត្រា ៤ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ផ្តល់យុត្តាធិការឱ្យតុលាការកាត់សេចក្តីលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដូចបានកំណត់នៅក្នុងអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឆ្នាំ ១៩៤៨។ ធាតុផ្សំសត្យានុម័តិនៃអំពើប្រល័យពូជសាសន៍ គឺការប្រព្រឹត្តិ[3552] យ៉ាងហោចណាស់ នូវអំពើប្រល័យពូជសាសន៍ប្រភេទណាមួយដូចបានរៀបរាប់ (បង្ហាញលម្អិតខាងក្រោម)[3553]។ ធាតុផ្សំអត្តនោម័តិរួមមានចេតនាដែលតម្រូវឱ្យមានក្នុងការប្រព្រឹត្តិអំពើណាមួយ

---

[3550] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ ៤៨០, KH ERN 00573605។ Tadić, សាលដីកា កថាខណ្ឌ ១៨៨។ Nahimana, សាលដីកា កថាខណ្ឌ៤៧៨។

[3551] សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ១៤៣១, KH ERN 00605725-26។ Gacumbitsi, សាលដីកា កថាខណ្ឌ៦០។ Seromba, សាលដីកា កថាខណ្ឌ១៦១។ អានលក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ, មាត្រា២៥(៣)(ក)បញ្ជាក់ថាជនដែលអាចប្រព្រឹត្តឧក្រិដ្ឋកម្ម "តាមរយៈបុគ្គលម្នាក់ទៀត"។ ទស្សនៈនៃមធ្យោបាយនៃជនល្មើស ត្រូវបានគេរៀបចំឡើងដោយប្រព័ន្ធច្បាប់ពិភពលោក។ អានឧទាហរណ៍ គំរូក្រមព្រហ្មទណ្ឌ(ស.រ.អា ឆ្នាំ ១៩៦២) ផ្នែក២.០៦(១)-(២)។ Archbol៖ បទឧក្រិដ្ឋ, ភស្តុតាង និងការអនុវត្ត (UK, 2007), §18-7។

[3552] ដូចដែលបានកំណត់ ក្រោមច្បាប់ អ.វ.ត.ក មាត្រា៤ចែងថា៖ "ការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ការសមគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងការចូលរួមប្រព្រឹត្តអំពើប្រល័យពូជសាសន៍" ជាបទល្មើសត្រូវផ្តន្ទាទោសបាននៅអ.វ.ត.ក។

[3553] អាន ផ្នែក IX.A.1. អំពើប្រល័យពូជសាសន៍ – ពិរុទ្ធភាព ផ្នែកខាងក្រោម។

និងចេតនាជាក់លាក់ក្នុងការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍៖ "ចេតនាបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ"[3554]។

## ក្រុមដែលត្រូវការពារ

880. ស្របតាមអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងអំពីក្រុមដែលត្រូវការពារចំនួនបួនប្រភេទ៖ ជាតិ ជាតិពន្ធុ[3555] ពូជសាសន៍ និងសាសនា។ ក្រុមដែលត្រូវការពារត្រូវកំណត់ជាវិជ្ជមាន ដោយផ្អែកលើអត្តសញ្ញាណរួម និងមិនអវិជ្ជមាន ដោយផ្អែកលើកង្វះខាតអត្តសញ្ញាណដោយឡែកណាមួយ[3556]។ ពេលក្រុមលើសពីមួយត្រូវបានកំណត់គោលដៅ ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ត្រូវពិចារណា ដោយធៀបនឹងក្រុមនីមួយៗ ដាច់ដោយឡែកពីគ្នា[3557]។

881. ការប៉ុនប៉ងបែងចែកប្រភេទក្រុមនីមួយៗ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យវិទ្យាសាស្ត្រ អាចមិនស្របគ្នានឹងកម្មវត្ថុ និងគោលបំណង នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍[3558]។ ក្នុងសេចក្តីសម្រេចលេខ ៩៦(១) មហាសន្និបាតអង្គការសហប្រជាជាតិបានកំណត់និយមន័យអំពើប្រល័យពូជសាសន៍ថាជា "ការបដិសេធសិទ្ធិរស់រានមានជីវិតរបស់ក្រុមនុស្សទាំងមូល"[3559]។ សេចក្តីសម្រេចនេះត្រូវបានអនុវត្តដោយលេខាធិការដ្ឋានអង្គការសហប្រជាជាតិ (ឆ្នាំ ១៩៤៨)[3560] និងតុលាការយុត្តិធម៌

---

[3554] Krstić, សាលដីកា កថាខណ្ឌ២០។ Croatia តទល់នឹង Serbia, កថាខណ្ឌ១៣២។ Al Bashirសេចក្តីសម្រេចចេញដីកាចាប់ខ្លួនលើកទីមួយ, កថាខណ្ឌ១៣៩។ របាយការណ៍គណៈកម្មាធិការ Darfur, កថាខណ្ឌ៤៩១។

[3555] ទោះបី សន្ធិសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងច្បាប់អ.វ.ត.ក ប្រើប្រាស់ពាក្យ "ជាតិពន្ធុ" នៅក្នុងយុត្តិសាស្ត្រគឺមានន័យថា ក្រុម"ពូជសាសន៍" ក្នុងគោលបំណងប្រើប្រាស់ខេមរយានកម្មទំនើបតែប៉ុណ្ណោះ។

[3556] Stakić, សាលដីកា កថាខណ្ឌ 16-28។ Karadžić, សាលក្រម កថាខណ្ឌ 541។ Brđanin, សាលក្រម កថាខណ្ឌ 685។ សេចក្តីសម្រេចចេញដីកាចាប់ខ្លួនAl Bashirលើកទីមួយកថាខណ្ឌ 135។ Bosnia តទល់នឹង Serbia, កថាខណ្ឌ 193-196។

[3557] Stakić, សាលដីកា កថាខណ្ឌ២៨។ Karadžić, សាលក្រម កថាខណ្ឌ៥៤១។ Brđanin, សាលក្រមកថាខណ្ឌ៦៨៦។

[3558] Krstić, សាលក្រម កថាខណ្ឌ៥៥៦។ Brđanin, សាលក្រម កថាខណ្ឌ៦៨២។

[3559] សេចក្តីសម្រេច UNGA ៩៦(I), ថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៤៦, អ.ស.ប ឯកសារលេខ A/RES/៩៦(I), ទំព័រ១៨៨-១៨៩ (ដោយបញ្ជាក់បន្ថែម)។

[3560] ទំនាក់ទំនងរវាងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ទៅនឹងការតាក់តែងគោលការណ៍Nurnberg និងការរៀបចំសេចក្តីព្រាងក្រមព្រហ្មទណ្ឌនៃបទល្មើសប្រឆាំងសន្តិភាព និងសន្តិសុខលើអ្នកដទៃ, ថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៤៨, E/AC.

អន្តរជាតិ (ឆ្នាំ ១៩៥១)[3561] ហើយក្រោយមក ត្រូវបានបញ្ជាក់អះអាងឡើងវិញដោយតុលាការយុត្តិធម៌អន្តរជាតិ[3562] តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី[3563] និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា[3564]។ អង្គជំនុំជម្រះសាលាដំបូង នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី នៅក្នុងរឿងក្តី *Krstić* បានកត់សម្គាល់ថា៖

> ការងារត្រៀមរបស់អនុសញ្ញាបង្ហាញថា ការកំណត់បញ្ជីបែបនេះត្រូវបានធ្វើឡើងឲ្យបានច្រើន ដើម្បីរៀបរាប់អំពីបាតុភូតតែមួយ ដែលត្រូវគ្នាយ៉ាងខ្លាំងជាមួយនឹងអ្វីដែលត្រូវបានទទួលស្គាល់ នៅមុនសង្គ្រាមលើកលើកទី ២ ថាជា "ជនជាតិភាគតិចជាតិ" ជាជាងការសំដៅដល់គំរូដើមនៃក្រុមមនុស្សដាច់ដោយឡែកជាច្រើន[3565]។

882. ដូច្នេះ តុលាការ និងគណៈកម្មាធិការនានា ដែលអនុវត្តអនុសញ្ញា បានចៀសវាងបំផុតក្នុងការផ្តល់និយមន័យជាក់ស្តែង ឬកំណត់ព្រំដែនច្បាស់លាស់ នៃក្រុមដែលត្រូវការពារ និងបានគូសបញ្ជាក់អំពីការចូលចិត្តបកស្រាយប្រភេទទាំងនេះ តាមបែបបត់បែន។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី[3566] និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា[3567] និងគណៈកម្មាធិការដាហ្វួរ[3568] បានបញ្ជាក់អះអាងរួមគ្នាថា អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍

---

២៥/៣/Rev.១, ទំព័រ៦ ["[អំពើប្រល័យពូជសាសន៍] មានគោលបំណងសម្លាប់ក្រុមមនុស្សជាប្រព័ន្ធ [...] ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍នេះគឺជាក្រុមមនុស្ស"]។

3561 មតិយោបល់របស់តុលាការយុត្តិធម៌អន្តរជាតិស្តីពីអំពើប្រល័យពូជសាសន៍, ទំព័រ២៣ ["ដើមកំណើតនៃអនុសញ្ញានេះបង្ហាញថាវាជាគោលបំណងនៃអង្គការសហប្រជាជាតិដើម្បីថ្កោលទោសនិងដាក់ទណ្ឌកម្មទៅលើអំពើប្រល័យពូជសាសន៍ជាបទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិដែល"ពាក់ព័ន្ធនឹងការបដិសេធរាល់សិទ្ធិនៃការរស់រានរបស់មនុស្សជាតិទូទៅ" (ដោយបញ្ជាក់បន្ថែម)]។

3562 Croatia តទល់នឹង Serbia កថាខណ្ឌ ៨៧, ៥០៤។ Bosnia តទល់នឹង Serbia កថាខណ្ឌ ១៦១, ១៩៤, ៤២២។ Croatia តទល់នឹង Serbia, កថាខណ្ឌ៨៧, ៥០៤។ Bosnia តទល់នឹង Serbia, កថាខណ្ឌ១៦១, ១៩៤, ៤២២។

3563 អានឧទាហរណ៍ Krstić, សាលដីកា កថាខណ្ឌ៣៦ ["ក្រុមជនល្មើសកំណត់អត្តសញ្ញាណក្រុមមនុស្សដើម្បីសម្លាប់ឲ្យផុតពូជ"]។

3564 អានឧទាហរណ៍ Akayesu, សាលក្រម កថាខណ្ឌ៥២២។ Kayishema & Ruzindana, សាលក្រម កថាខណ្ឌ៩៩។

3565 Krstić, សាលក្រម កថាខណ្ឌ៥៥៦។

3566 Jelisić, សាលក្រម កថាខណ្ឌ៦៩។

3567 Akayesu, សាលក្រម កថាខណ្ឌ៥១១, ៥១៦, ៧០២។ Musema, សាលក្រម កថាខណ្ឌ ១៦២។

3568 របាយការណ៍គណៈកម្មាធិការ Darfur, កថាខណ្ឌ៤៩៨, ៥០១។

និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ មានសមត្ថកិច្ចផ្តន្ទាទោសអំពើប្រល័យពូជសាសន៍ ដែលមានចេតនាបំផ្លិចបំផ្លាញក្រុមមនុស្សស្លេរភាព និងអចិន្ត្រៃយ៍ ដែលមានសមាជិក ដោយមិនគិតពីបំណងប្រាថ្នាផ្ទាល់ខ្លួនរបស់ពួកគេ ទោះបីជាពួកគេមិនចូលក្នុងក្រុមទាំងបួន ដូចបានចែងនៅក្នុងអនុសញ្ញាក៏ដោយ។

883. ការកំណត់ពីលក្ខខណ្ឌដែលបង្កើតបានជាក្រុមដែលត្រូវការពារមួយ ក្នុងករណីណាក៏ដោយ ត្រូវធ្វើឡើង ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យសត្យានុម័ត និងអត្តនោម័តិ[3569]។ លក្ខណៈវិនិច្ឆ័យសត្យានុម័តរួមបញ្ចូលបរិបទពាក់ព័ន្ធខាងនយោបាយ សង្គម ប្រវត្តិសាស្ត្រ និងវប្បធម៌[3570]។ លក្ខណៈវិនិច្ឆ័យអត្តនោម័តិរួមបញ្ចូលការដៀលត្មះ ឬការកំណត់គោលដៅលើក្រុមមួយ ដោយចារី ផ្អែកលើចរិតលក្ខណៈរបស់ក្រុម[3571] រួមទាំង តាមរយៈការប្រើប្រាស់វិសេសស័ព្ទប្រមាថមើលងាយ[3572]។ ក្នុងករណីខ្លះ ជនរងគ្រោះអាចចាត់ទុកខ្លួនឯងជាសមាជិកក្រុម[3573]។ នៅក្នុងរឿងក្តី *Bagilishema* តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា បានចង្អុលបង្ហាញថា៖

> ក្រុមមួយអាចមិនបានកំណត់ព្រំដែនឱ្យបានច្បាស់ ហើយអាចមានការលំបាកក្នុងការផ្តល់ចម្លើយស្តាពរថា តើជនរងគ្រោះជាសមាជិកក្រុមដែលត្រូវការពារដែរឬទេ។ លើសពីនេះទៀត ចារីនៃអំពើប្រល័យពូជសាសន៍អាចកំណត់ចរិតលក្ខណៈក្រុមគោលដៅ តាមវិធីមិនសមស្របទាំងស្រុងទៅនឹងទស្សនៈរបស់ក្រុមដែលបានចែករំលែក ជា

---

3569 Gacumbitsi, សាលក្រម កថាខណ្ឌ ២៥៤។ Semanza, សាលក្រម កថាខណ្ឌ ៣១៧។ Blagojević&Jokić, សាលក្រម កថាខណ្ឌ ៦៦៧។ របាយការណ៍ ISIS-Yazidi Report, កថាខណ្ឌ ១០៥។ របាយការណ៍គណៈកម្មាធិការ Darfur, កថាខណ្ឌ ៤៩៩-៥០១។

3570 Kamuhanda, សាលក្រម កថាខណ្ឌ៦៣០។ Semanza, សាលក្រម កថាខណ្ឌ៣១៧។ Rutaganda, សាលក្រម កថាខណ្ឌ៣៧៣។ Musema, សាលក្រម កថាខណ្ឌ១៦៣។ Krstić, សាលក្រម កថាខណ្ឌ៥៥៧។

3571 Stakić, សាលដីកា កថាខណ្ឌ២៥។ Musema, សាលក្រម កថាខណ្ឌ១៦១។ Rutaganda, សាលក្រម កថាខណ្ឌ៥៦។ Brđanin, សាលក្រម កថាខណ្ឌ៦៨៣។ Krstić, សាលក្រម កថាខណ្ឌ៥៥៧។ Jelisić, សាលក្រម កថាខណ្ឌ៧០។ Kayishema& Ruzindana, សាលក្រម កថាខណ្ឌ៩៨។ របាយការណ៍ ISIS-Yazidi, កថាខណ្ឌ១០៥។ របាយការណ៍គណៈកម្មាធិការ Darfur កថាខណ្ឌ៤៩៩។

3572 របាយការណ៍ ISIS-Yazid, កថាខណ្ឌ១០៥។ របាយការណ៍គណៈកម្មាធិការ Darfur, កថាខណ្ឌ៥១១។

3573 Brđanin, សាលក្រម កថាខណ្ឌ៦៨៣។ Musema, សាលក្រម កថាខណ្ឌ១៦១។ Rutaganda, សាលក្រម កថាខណ្ឌ៥៦។ Kayishema& Ruzindana, សាលក្រម កថាខណ្ឌ៩៨។ Krstić, សាលក្រម កថាខណ្ឌ៥៥៩។

ទូទៅ ឬដោយផ្អែកផ្សេងទៀតនៃសង្គម។ ក្នុងករណីបែបនេះ អង្គជំនុំជម្រះយល់ឃើញថា ផ្អែកតាមភ័ស្តុតាង ប្រសិនបើជនរងគ្រោះត្រូវបានចារីយល់ថាជាសមាជិកក្រុមដែលត្រូវការពារ ជនរងគ្រោះអាចត្រូវបានអង្គជំនុំជម្រះចាត់ទុកជាសមាជិកក្រុមដែលត្រូវការពារ សម្រាប់គោលបំណងនៃអំពើប្រល័យពូជសាសន៍[3574]។

884. តុលាការអន្តរជាតិនានាបានប្រកាន់យកវិធីសាស្ត្របត់បែន យ៉ាងស៊ីចង្វាក់គ្នា ដើម្បីដាក់បញ្ចូលជនគោលដៅ ឲ្យត្រូវនឹងប្រភេទក្រុមទាំងបួននៃអនុសញ្ញា។ នៅក្នុងរឿងក្តី *Akayesu* អង្គជំនុំជម្រះសាលាដំបូង នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា បានកំណត់និយមន័យក្រុម ***ជាតិ*** ថាជា "បណ្តុំមនុស្ស ដែលគេយល់ថាមានចំណងផ្លូវច្បាប់ដូចគ្នា ផ្អែកលើសញ្ជាតិរួម គួបផ្សំនឹងបដិការនៃសិទ្ធិ និងករណីយកិច្ច"[3575]។ ទោះជាយ៉ាងនេះក្តី សហព្រះរាជអាជ្ញាយល់ឃើញថា និយមន័យនេះចង្អៀតពេក និងមិនពេញលេញទាល់តែសោះ។ ពេលគាំទ្រនិយមន័យយុត្តិសាស្ត្រនេះ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា បានពឹងផ្អែកយ៉ាងច្បាស់លើការកត់សម្គាល់ក្រៅសាច់រឿងរបស់តុលាការយុត្តិធម៌អន្តរជាតិ ក្នុងសាលដីកាលើរឿងក្តី *Nottebohm* ប៉ុន្តែ ក្នុងបរិបទនេះ តុលាការយុត្តិធម៌អន្តរជាតិបានចាប់អារម្មណ៍លើការកំណត់អត្ថន័យនៃ "សញ្ជាតិ" ក្នុងបរិបទនៃសិទ្ធិរបស់រដ្ឋមួយក្នុងការអនុវត្តការការពារខាងការទូត។ គ្មានការព្រួយបារម្ភលើអត្ថន័យនៃ "ក្រុមជាតិ" ក្នុងអត្ថន័យនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ នោះឡើយ។ "ជាតិ" មិនត្រូវបានបង្កើតឡើង ដោយផ្អែកសុទ្ធសាធលើភាពជាពលរដ្ឋរួមឡើយ។ សញ្ជាតិមិនមែនមានន័យស្មើនឹង "ក្រុមជាតិ" ឡើយ។ ក្រុមជាតិខ្លះអាចមានសញ្ជាតិរបស់រដ្ឋមួយទៀត ឬគ្មានសញ្ជាតិ[3576]។ ដូច Oppenheim បានដាស់តឿន "សញ្ជាតិ" ក្នុងន័យនៃភាពជាពលរដ្ឋរបស់រដ្ឋមួយ មិនត្រូវច្រឡំគ្នាជាមួយសមាជិកភាពនៅក្នុងជាតិជាក់លាក់ណាមួយ ក្នុងន័យនៃ "ពូជសាសន៍" ឡើយ[3577]។

---

[3574] Bagilishema, សាលក្រម កថាខណ្ឌ៦៥។

[3575] Akayesu, សាលក្រម កថាខណ្ឌ៥១២។

[3576] Schabas, អំពើប្រល័យពូជសាសន៍(ឆ្នាំ២០០០), ទំព័រ១១៥។ Shaw, ""អំពើប្រល័យពូជសាសន៍ និងច្បាប់អន្តរជាតិ", in Yoram Dinstein, ed, ច្បាប់អន្តរជាតិនៅក្នុងកាលៈទេសៈតានតឹង (សំណេរសរសេរឡើងដើម្បីក្តីគោរពដល់ Shabtai Rosenne), ទំព័រ៧៩៧-៨២០ និងទំព័រ៨០៧។

[3577] ច្បាប់អន្តរជាតិរបស់ Oppenheim ភាគ ១ ទំព័រ៨៥៧ (Robert Jennings & Arthur Watts eds., កំណែលើកទី៩ឆ្នាំ ១៩៩២)។

885. ជាការពិត ពេលអនុវត្តទស្សនាទាន "ក្រុមជាតិ" នៅក្នុងរឿងក្តី *Krstić* និងរឿងក្តីក្រោយៗកទៀត តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មានភាពស្ទាក់ស្ទើរក្នុងការវិភាគភាពជាពលរដ្ឋនៃក្រុម ឬបែងចែកឲ្យបានច្បាស់ រវាងសញ្ជាតិនៃក្រុមគោលដៅមួយ និងក្រុមដទៃទៀត។ ទោះបីជាខ្វះភាពជាពលរដ្ឋតែមួយក៏ដោយ ក៏តុលាការនេះយល់ឃើញថា មូស្លីមបូស្នី គឺជា "ក្រុមជាតិ" មួយ ដោយផ្អែកលើការទទួលស្គាល់ជា "ជាតិ" មួយ ដោយរដ្ឋធម្មនុញ្ញយូហ្គោស្លាវី ឆ្នាំ ១៩៦៣ និងការចាត់ទុកមូស្លីមបូស្នី ជាក្រុមជាតិជាក់លាក់មួយ ដោយអាជ្ញាធរនយោបាយ និងយោធាបូស្នី-ស៊ែប[3578]។ ការរកឃើញថា មូស្លីមបូស្នី ជា "ក្រុមដែលត្រូវការពារ" ត្រូវបានអនុវត្តតាមដោយគ្មានការវិភាគឲ្យបានស៊ីជម្រៅ ក្នុងរឿងក្តី *Blagojević*[3579] *Brdenan*[3580] *Popović*[3581] *Karadžić*[3582] និង *Tolimir*[3583]។ ការពិត ក្នុងរឿងក្តីភាគច្រើនជាបន្តបន្ទាប់ ពុំមានការសំដៅដល់ការចាត់ថ្នាក់ជា "ក្រុមជាតិ" ដែលបានធ្វើឡើង ក្នុងរឿងក្តី *Krstić* នោះឡើយ ហើយភាគច្រើនចំណាយពេលវេលាច្រើន ក្នុងការពិភាក្សាអំពីមូស្លីមបូស្នី ក្រូអាស៊ីបូស្នី និងស៊ែបបូស្នី ជាជាតិពន្ធុដាច់ដោយឡែក[3584]។ តុលាការយុត្តិធម៌អន្តរជាតិក៏បានទទួលយកមូស្លីមបូស្នីជា "ក្រុមគោលដៅ" ដោយមិនបានបញ្ជាក់ថាស្ថិតនៅក្នុងប្រភេទណាមួយនៃប្រភេទទាំងបួនឡើយ[3585]។

---

3578 Krstić, សាលក្រម កថាខណ្ឌ៥៥៩-៥៦០។ គេរកឃើញថាក្រុមមូស្លីមបូស្នៀត្រូវបានការពារ ហើយពុំមាននរណាយាយីដល់ក្រុមនេះឡើយដោយសារមានការអំពាវនាវមួយ។ See Krstić, សាលដីកា កថាខណ្ឌ៦, ១៥។

3579 Blagojević&Jokić, សាលក្រម កថាខណ្ឌ៦៦៧។ អង្គជំនុំជម្រះពុំបានបញ្ជាក់ថាក្រុមមូស្លីមបូស្នៀនោះបង្កើតបានជាក្រុមប្រជាជាតិមួយឡើយ។ ប៉ុន្តែគេគ្រាន់តែដឹងថា "ក្រុមនេះទទួលបានការការពារ", ស្រង់ចេញពីសាលក្រមគាំទ្រ Krstić។

3580 Brđanin, សាលក្រម កថាខណ្ឌ៧៣៤-៧៣៦។ អង្គជំនុំជម្រះរកឃើញថាមានក្រុមចំនួនពីរទទួលបាននូវការការពារ គឺក្រុមមូស្លីមបូស្នៀ និងក្រុមក្រូអាតបូស្នៀ ប៉ុន្តែអង្គជំនុំជម្រះមិនបានផ្តល់នូវសេចក្តីសន្និដ្ឋាន ឬការវិភាគណាមួយអំពីមូលហេតុដែលក្រុមក្រូអាតបូស្នៀមួយក្នុងចំណោមក្រុមទាំងបួនទទួលបាននោះទេ។ លេខជើងទំព័រ១៧៨៤អង្គជំនុំជម្រះបញ្ជាក់ថាក្រូអាតបូស្នៀ "ពុំមានមាតុប្រទេសទេ។ ពួកគេពុំទស្សនវិស្ស័យដើម្បីទទួលបានកិច្ចគាំពារពីសហគមន៍ដទៃទៀតក្រៅពីបូស្នៀហឺហ្សូវីណា និងក្រុមជាតិពន្ធុជាមូស្លីមបូស្នៀឡើយ"។

3581 Popović, សាលក្រម កថាខណ្ឌ ៨៤០។

3582 Karadžić, សាលក្រម កថាខណ្ឌ ២៥៧៤។

3583 Tolimir, សាលក្រម កថាខណ្ឌ៧៥០, អនុម័តលើបណ្តឹងឧទ្ធរណ៍ Tolimir, សាលដីកា កថាខណ្ឌ១៨៥។

3584 អានឧទាហរណ៍ Blagojević& Jokić, សាលក្រម កថាខណ្ឌ៩៤, ១៥៥, ៦៧៤។ Popović, សាលក្រម កថាខណ្ឌ ៩៩១, ៩៩៥, ១១៩៣, ១១៩៤, ១៣៣១, ១៣៩៨, ១៤២៦។ Tadić, សាលក្រម កថាខណ្ឌ៥៦-៥៧, ៨៣។ Brđanin, សាលក្រម កថាខណ្ឌ៥៨, ៨០, លេខជើងទំព័រ៩៣។ Tolimir, សាលក្រម កថាខណ្ឌ១៥៩, ៨១៣, ១១៩០។

886. ក្រុមជាតិ***ពន្ធុ***ត្រូវបានកំណត់ចរិតលក្ខណៈជា "ក្រុមមួយដែលសមាជិកចែករំលែកភាសា ឬវប្បធម៌រួមគ្នា"[3586]។ ទោះជាយ៉ាងនេះក្តី ក្នុងរឿងក្តី *Akayesu* អង្គជំនុំជម្រះសាលាដំបូងដដែល ដែលបានកំណត់និយមន័យនេះ បានរកឃើញថា ទុតស៊ី ជា "ក្រុមជាតិពន្ធុ" មួយដាច់ដោយឡែក ទោះបីជាទុតស៊ី និង ហ៊ូទូ មិនអាចត្រូវបានបែងចែកឲ្យដាច់ពីគ្នា ដោយផ្អែកលើភាសា ឬវប្បធម៌ ក៏ដោយ។ អង្គជំនុំជម្រះបានផ្អែកសេចក្តីសម្រេចរបស់ខ្លួន លើអត្តសញ្ញាណប័ណ្ណដែលសំដៅដល់ក្រុមជាតិពន្ធុរវ៉ាន់ដា ការលើកឡើងផ្សេងៗអំពីក្រុមជាតិពន្ធុទាំងនេះនៅក្នុងលិខិតុបករណ៍ជាតិ និងអន្តរជាតិ និងចម្លើយរបស់សាក្សីនៅក្នុងសវនាការដែល "បានឆ្លើយដោយឯកឯង ដោយគ្មានស្ទាក់ស្ទើរ" ពាក់ព័ន្ធនឹងអត្តសញ្ញាណជាតិពន្ធុរបស់ពួកគេ (ការយល់ឃើញដោយខ្លួនឯង)[3587]។ នៅក្នុងរឿងក្តី *Al Bashir* តុលាការឧក្រិដ្ឋកម្មអន្តរជាតិបានរកឃើញថា Fur, Masalit និង Zaghawa គឺជាក្រុមជាតិពន្ធុដាច់ដោយឡែកពីគ្នា សម្រាប់គោលបំណងនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ដោយ

---

Karadžić, សាលក្រម កថាខណ្ឌ៣២, លេខជើងទំព័រ៦០ [អង្គជំនុំជម្រះបានទទួលស្គាល់ថាពាក្យថា "ជនជាតិភាគតិច" មិនអាចពណ៌នាឲ្យបានទូលំទូលាយនូវលក្ខណៈពិសេសនៃជនជាតិម៉ូស្លីមបូស្នៀ, ក្រូអាតបូស្នៀ ឬស៊ែបបូស្នៀ ដោយហេតុថាកត្តាដទៃទៀតដូចជាសាសនានិងសញ្ជាតិទាក់ទងទៅនឹងនិយមន័យរបស់ក្រុមជនទាំងនោះ ប៉ុន្តែអង្គជំនុំជម្រះបានបញ្ជាក់ថាខ្លួននឹងប្រើប្រាស់ពាក្យ"ជនជាតិភាគតិច"នេះនៅទូទាំងសាលដីកា "ដោយសារវាខ្លី"], ៦០៣, ២៥៩៨។

3585 Bosnia តទល់នឹង Serbia, កថាខណ្ឌ កថាខណ្ឌ១៩៦។

3586 Akayesu, សាលក្រម កថាខណ្ឌ៥១៣។ Kayishema & Ruzindana, សាលក្រម កថាខណ្ឌ៩៨. ដើម្បីពិពណ៌នាអំពី "វប្បធម៌"ដែលជាពាក្យអរូបីគណៈកម្មាធិការសេដ្ឋកិច្ចសង្គមនិងសិទ្ធិទទួលបានវប្បធម៌របស់អង្គការសហប្រជាជាតិបានកំណត់ថា៖"គណៈកម្មាធិបានចាត់ទុកវប្បធម៌ [...] នោះរួមបញ្ចូលទាំងរបៀបរស់នៅ, ភាសា, អក្សរសិល្ប៍បែបនិទាន និងអក្សរសិល្ប៍បែបសំណេរ, ចម្រៀងនិងតន្ត្រី,ភាសាកាយវិការ,សាសនាឬជំនឿពិធី, កីឡានិងល្បែង, វិធីសាស្ត្រនៃការផលិតឬបច្ចេកវិទ្យា, បរិយាកាសធម្មជាតិនិងបង្កើតឡើងដោយមនុស្ស,អាហារ, សំលៀកបំពាក់និងទីជម្រកនិងសិល្បៈ, ទំនៀមទម្លាប់និងប្រពៃណីដែលបុគ្គលម្នាក់ៗ ក្រុមមនុស្សមនុស្ស និងសហគមន៍បង្ហាញពីអ្វីដែលជាមនុស្សជាតិ ហើយពួកគេកំណត់អត្ថន័យដែលបង្ហាញថាអ្វីដែលរៀបរាប់ខាងលើនេះប្រាកដជាមាន"។ "អានមតិយោបល់ទូទៅរបស់គណៈកម្មាធិការសេដ្ឋកិច្ចសង្គមនិងសិទ្ធិទទួលបានវប្បធម៌របស់អង្គការសហប្រជាជាតិ (UNESC) លេខ. ២១ ...មនុស្សគ្រប់រូបមានសិទ្ធិក្នុងការចូលរួមក្នុងជីវភាពវប្បធម៌, E/C.១២/GC/២១, កថាខណ្ឌ ១២-១៣។សេចក្តីប្រកាសជាសកលស្តីពីនានាភាពចំរុះនៃវប្បធម៌នៅថ្ងៃទី២ខែវិច្ឆិកាឆ្នាំ២០០១(បុព្វកថា) ពន្យល់ថាវប្បធម៌ជា "បណ្តុំនៃស្មារតី, សម្ភារៈ, បញ្ញាញាណ និងសញ្ចេតនាបង្ហាញនៅក្នុងសង្គម ឬក៏ក្នុងក្រុមរបស់ពួកគេដោយរួមបញ្ចូលទាំងសិល្បៈ និងអក្សរសិល្ប៍, បែបផែននៃជីវិត, របៀបរបបនៃការរស់នៅជាមួយគ្នា, ការឲ្យតម្លៃគ្នា, ប្រពៃណី និងជំនឿ"។

3587 Akayesu, សាលក្រម កថាខណ្ឌ 170-171, 702.Akayesu, សាលក្រម កថាខណ្ឌ១៧០-១៧១, ៧០២។

ហេតុថា ក្រុមនីមួយមានភាសា ទំនៀមទម្លាប់កុលសម្ព័ន្ធ និងចំណងប្រពៃណីភ្ជាប់ទៅនឹងដីរបស់ពួកគេរៀងៗខ្លួន[3588]។

887. ក្រុម***ពូជសាសន៍*** ត្រូវបានកំណត់និយមន័យ "ផ្អែកលើលក្ខណៈរូបកាយតពូជ ដែលជាញឹកញាប់ត្រូវបានកំណត់អត្តសញ្ញាណ រួមជាមួយតំបន់ភូមិសាស្ត្រ ដោយមិនគិតពីកត្តាភាសា វប្បធម៌ ជាតិ ឬសាសនា"[3589]។ ប៉ុន្តែ "ពូជសាសន៍" បង្ហាញថាមានភាពពិបាកក្នុងការកំណត់ចរិតលក្ខណៈ។ តុលាការយោធាអន្តរជាតិហៅប្រជាជនជ្វីហ្វថាជា "ក្រុមពូជសាសន៍" ជាជាង "ក្រុមសាសនា" ដោយគ្មានការវិភាគប្រកបដោយន័យខ្លឹមសារ[3590]។ ពេលសង្កត់ធ្ងន់ពីបញ្ហាប្រឈមខាងនិយមន័យ និងអន្តរទំនាក់ទំនងរវាងក្រុមដែលត្រូវការពារ អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ បានកំណត់និយមន័យនៃពាក្យ ការរើសអើង "ពូជសាសន៍" (ពាក់ព័ន្ធដោយផ្អែកនឹងការចាត់ថ្នាក់ក្រុមផ្សេងទៀត) ថាជា "ការប្រកាន់បែងចែក ការផាត់ចេញ ការរឹតត្បិត ឬការនិយម ផ្អែកលើពូជសាសន៍ ពណ៌សម្បុរ បុព្វញាតិ ឬដើមកំណើតជាតិ ឬជាតិពន្ធុ"[3591]។

888. ក្រុម***សាសនា*** គឺជា "ក្រុមមួយដែលសមាជិកចែករំលែកសាសនា និកាយ ឬវិធីសក្ការៈដូចគ្នា"[3592]។ របាយការណ៍របស់គណៈកម្មាធិការស៊ីរីថ្មីៗនេះ បានចាត់ថ្នាក់ Yazidis ជាក្រុមសាសនាមួយ ផ្អែកលើលក្ខណៈវិនិច្ឆ័យសត្យានុម័ត និងអត្តនោម័តិ[3593]។

## ធាតុផ្សំសត្យានុម័ត

889. មាត្រា ៤ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលឆ្លុះបញ្ចាំងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ រៀបរាប់នូវអំពើប្រល័យពូជសាសន៍ដូចតទៅ៖ (១) ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម (២) ការធ្វើឲ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬសតិបញ្ញាសមាជិកនៃក្រុម (៣) ការធ្វើដោយចេតនាឲ្យក្រុមនេះទទួលរងនូវស្ថានភាពរស់នៅមួយ ដែលបានរៀបចំឡើង សម្រាប់បំផ្លិចបំផ្លាញ

---

3588 សេចក្តីសម្រេចចេញដីកាចាប់ខ្លួនAl Bashir លើកទីមួយ, កថាខណ្ឌ១៣៧។

3589 Akayesu, សាលក្រម កថាខណ្ឌ៥១៤។ Kayishema& Ruzindana, សាលក្រម កថាខណ្ឌ ៩៨។

3590 សាលដីកា IMT, ទំព័រ៣០៥។

3591 ICEAFRD, មាត្រា១(១)។

3592 Akayesu, សាលក្រម កថាខណ្ឌ ៥១៥។ Kayishema & Ruzindana, សាលក្រម កថាខណ្ឌ ៩៨។

3593 របាយការណ៍ ISIS-Yazidi, កថាខណ្ឌ១០៣-១០៥។

វាយការទាំងស្រុង ឬមួយផ្នែក (៤) ការដាក់នូវវិធានការនានា ដែលមានបំណងរារាំងមិនឱ្យមានការផ្ដល់កំណើតដល់ទារក និង (៥) ការបញ្ជូនកុមារដោយបង្ខំ ពីក្រុមមួយ ទៅឱ្យក្រុមមួយផ្សេងទៀត។ ដោយសារមានតែចំណុចទី ១ ពាក់ព័ន្ធនឹងសំណុំរឿង **មាស មុត** សហព្រះរាជអាជ្ញាកម្រិតការវិភាគរបស់ខ្លួនទៅតាមនោះដែរ។

## ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម

890. ធាតុផ្សំសត្យានុម័តនៃការសម្លាប់ ក្នុងនាមជាអំពើប្រល័យពូជសាសន៍ ដូចគ្នានឹងធាតុផ្សំសត្យានុម័តនៃអំពើមនុស្សឃាត ក្នុងនាមជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3594]។ ការវាយតម្លៃជាតួលេខលើចំនួនមនុស្សដែលត្រូវបានសម្លាប់ មិនទាមទារឱ្យបង្ហាញធាតុផ្សំសត្យានុម័តិឡើយ[3595]។ ជនរងគ្រោះត្រូវតែស្ថិតនៅក្នុងក្រុមដែលត្រូវការពារ[3596] ឬចារីនៃឧក្រិដ្ឋកម្មជឿជាក់ថាជនរងគ្រោះស្ថិតនៅក្នុងក្រុមដែលត្រូវការពារ[3597]។ ការសម្លាប់នៅក្នុងបរិបទនៃអំពើប្រល័យពូជសាសន៍មិនចាំបាច់ត្រូវគិតទុកជាមុនឡើយ[3598]។

---

3594 Karadžić, សាលក្រម កថាខណ្ឌ ៥៤២។

3595 សាលដីកា Karadžić អនុលោមតាមវិធាន៩៨ស្ទួន កថាខណ្ឌ២៣, យោងទៅ Karadžić, សាលក្រម កថាខណ្ឌ ៥៤២។ ទោះជាយ៉ាងណាក៏ដោយកម្រិតនៃភាពយង់ឃ្នងគឺពាក់ព័ន្ធទៅនឹងការវាយតម្លៃនៃ ចេតនានៃឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍។

3596 Nahimana, សាលដីកា កថាខណ្ឌ ៤៩៦។ Muhimana, សាលក្រម កថាខណ្ឌ ៥០០។ Brđanin, សាលក្រម កថាខណ្ឌ ៦៨៩-៦៩០, ៦៩២។ អាន ធាតុផ្សំនៃបទឧក្រិដ្ឋរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ, មាត្រា៦(ក)-(ង), ធាតុផ្សំ២, ដែលប្រើប្រាស់ដើម្បីសម្រេចក្នុងការចេញដីកាចាប់ខ្លួន Al Bashir ជាលើកទី២, កថាខណ្ឌ១០-១២។

3597 Bagilishema, សាលក្រម កថាខណ្ឌ៦៥។ Gacumbitsi, សាលក្រម កថាខណ្ឌ២៥៥។ Muhimana, សាលក្រម កថាខណ្ឌ៥០០។ Ndindabahizi, សាលក្រម កថាខណ្ឌ៤៦៨-៤៦៩។ Kajelijeli, សាលក្រម កថាខណ្ឌ៨១៣។ Seromba, សាលក្រម កថាខណ្ឌ៣១៨។ Rutaganda, សាលក្រម កថាខណ្ឌ៥៦។

3598 Kayishema & Ruzindana, សាលដីកា កថាខណ្ឌ១៥១។ Stakić, សាលក្រម កថាខណ្ឌ៥១៥។ Muvunyi I, សាលក្រម កថាខណ្ឌ៤៨៦។ Kajelijeli, សាលក្រម កថាខណ្ឌ៨១៣។ Krstić, សាលក្រម កថាខណ្ឌ៥៧២, ៧១១ (អាន Krstić, សាលដីកា កថាខណ្ឌ២៥៦-២៥៩)។ Seromba, សាលក្រម កថាខណ្ឌ៣១៧។ Semanza, សាលក្រម កថាខណ្ឌ៣១៩។

## ធាតុផ្សំអត្តនោម័តិ

### *ក) ចេតនាបំផ្លិចបំផ្លាញក្រុម "បែបនេះ"*

891. ចេតនា "បំផ្លិចបំផ្លាញ ]ក្រុមដែលត្រូវការពារ [ទាំងស្រុង ឬមួយផ្នែក[3599] បែងចែកអំពើប្រល័យពូជសាសន៍ ខុសពីឧក្រិដ្ឋកម្មផ្សេងទៀត[3600]។ ដូចបានលើកឡើងពីខាងលើ[3601] អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ត្រូវបានអនុម័ត ដោយមានកម្មវត្ថុ និងគោលបំណងលើកស្ទួយការរស់រានមានជីវិតរបស់ក្រុមមនុស្ស និងផ្តន្ទាទោសជនដែលព្យាយាមលុបបំបាត់ពួកគេ។ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មិនកើតឡើងឡើយ ពីព្រោះការធ្វើបាប ឬការសម្លាប់សមាជិកនៃក្រុមមួយ មិនត្រូវបានផ្តន្ទាទោស។ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានដាក់ទោសព្រហ្មទណ្ឌ និងផ្តន្ទាទោសរួចហើយ ក្នុងនាមជាអំពើមនុស្សឃាត ការសម្លាប់ផ្តាច់ពូជ និង/ឬ ការធ្វើទុក្ខបុកម្នេញ។ ផ្ទុយទៅវិញ អនុសញ្ញាទទួលស្គាល់ព្យសនកម្មដោយឡែកដែលទទួលរង ពេលក្រុមទាំងមូលត្រូវបានកំណត់គោលដៅ៖

> *ជនរងគ្រោះចុងក្រោយនៃអំពើប្រល័យពូជសាសន៍ គឺជាក្រុម* ទោះបីជាការបំផ្លិចបំផ្លាញទាមទារជាចាំបាច់ ឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងនឹងសមាជិកក្រុមក៏ដោយ និយាយឲ្យចំ គឺប្រឆាំងនឹងបុគ្គលដែលជាសមាជិកក្រុមនោះ[3602]។

892. ស្របតាមហេតុផលជាដើមកំណើតនៃអំពើប្រល័យពូជសាសន៍ លក្ខខណ្ឌតម្រូវឱ្យចារីមានចេតនាបំផ្លិចបំផ្លាញក្រុមមួយ "បែបនេះ" មានន័យថា បំផ្លិចបំផ្លាញក្រុមនេះ ក្នុងនាមជា *"អង្គភាពផ្សេង*

---

[3599] និយមន័យនៃអំពើប្រល័យពូជសាសន៍ក្នុងមាត្រា II នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍, និងនៅក្នុងលក្ខន្តិកៈរបស់ ICTY, ICTR, និង ICC (លក្ខន្តិកៈរបស់ ICTY, មាត្រា៤។ លក្ខន្តិកៈរបស់ ICTR, មាត្រា២។ លក្ខន្តិកៈរបស់ ICC, មាត្រា៦) មានឃ្លា "ដូចជា" ភ្ជាប់ជាមួយនូវពាក្យ "ជាតិ, ជាតិពន្ធុ, ពូជសាសន៍ ឬក្រុមសាសនា"។ នេះក៏បានឆ្លុះបញ្ចាំងនៅក្នុងច្បាប់អ.វ.ត.ក ជាភាសាបារាំងផងដែរ ["On entend par crime de génocide, qui est imprescriptible l'un quelconque des actes ci-après, commis dans l'intention de détruire, en tout ou en partie, un groupe national, ethnique, racial ou religieux, comme tel" (ដោយបញ្ជាក់បន្ថែម)]។

[3600] Jelisić, សាលក្រម កថាខណ្ឌ៦៦។ Kayishema& Ruzindana, សាលក្រម កថាខណ្ឌ៩១។ Croatia តទល់នឹង Serbia, កថាខណ្ឌ១៣២, ១៣៩។

[3601] អាន IX.ក.១. អំពើប្រល័យពូជសាសន៍ - ក្រុមដែលទទួលបានការការពារ។

[3602] Brđanin, សាលក្រម កថាខណ្ឌ៦៩៨។ សាលដីការសម្រេចឱ្យ Sikirica រួចពីការចោទប្រកាន់, កថាខណ្ឌ៨៩។ Stakić, សាលក្រម កថាខណ្ឌ៥២១។

*ដាច់ដោយឡែក"*[3603] ហើយបើទោះជាសមាជិកក្រុម ឬបច្ឆាញាតិនៅរស់ ក៏ពួកគេមិនអាចត្រូវបានកំណត់អត្តសញ្ញាណ និងមិនអាចកំណត់អត្តសញ្ញាណខ្លួនឯងថាជាសមាជិកក្រុមបាន។ មានការកំណត់ថាពាក្យ "បែបនេះ" មានន័យថាជាលក្ខខណ្ឌតម្រូវឲ្យអំពើឃាតមានភាពសមមូលនឹងអំពើប្រល័យពូជសាសន៍ ប្រសិនបើអំពើនោះត្រូវបានប្រព្រឹត្តទៅលើជនរងគ្រោះ "ជាពិសេសព្រោះតែ" សមាជិកភាពនៅក្នុងក្រុមដែលត្រូវការពារ[3604] ដោយមាន "*ឥទ្ធិពលសំខាន់* ក្នុងការបែងចែកច្បាស់ រវាងការសម្លាប់រង្គាល និងឧក្រិដ្ឋកម្មដែលចារីកំណត់គោលដៅលើក្រុមជាក់លាក់មួយដោយសារតែសញ្ជាតិ ពូជសាសន៍ ជាតិពន្ធុ ឬសាសនា"[3605]។ ប៉ុន្តែ ការបកស្រាយនេះអាចធ្វើឲ្យពាក្យ "បែបនេះ" ក្លាយជាមិនសំខាន់ ដោយសារតែចេតនាបំផ្លិចបំផ្លាញក្រុម ទាំងមូល ឬមួយផ្នែកគ្របដណ្តប់រួចទៅហើយនូវសញ្ញាណនៃសមាជិកភាពរបស់ជនរងគ្រោះ ក្នុងក្រុមគោលដៅ។ ទន្ទឹមនឹងនេះ វាមិនយល់ពីខ្លឹមសារសំខាន់នៃអំពើប្រល័យពូជសាសន៍។ តុលាការយុត្តិធម៌អន្តរជាតិបានពន្យល់ថា ធាតុផ្សំអត្តនោម័តិនៃអំពើប្រល័យពូជសាសន៍ទៅហួសការកំណត់គោលដៅលើជនមួយចំនួន ដោយសារតែសមាជិកភាពក្នុងក្រុមដោយឡែកណាមួយ[3606]។ ចេតនារើសអើងបែបនេះគ្រប់គ្រាន់សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការធ្វើទុក្ខបុកម្នេញ ប៉ុន្តែ មិនគ្រប់គ្រាន់សម្រាប់អំពើប្រល័យពូជសាសន៍ ដែលជនចារីត្រូវព្យាយាមបំផ្លិចបំផ្លាញសហគមន៍ដាច់ដោយឡែកបែបនេះ[3607]។

893. លក្ខខណ្ឌតម្រូវនៃចេតនាប្រល័យពូជសាសន៍ ក្នុងការបំផ្លិចបំផ្លាញក្រុម ទាំងមូល ឬមួយផ្នែក ក្នុងឋានៈជាអង្គភាពផ្សេងដាច់ដោយឡែក មានភាពខុសគ្នាពីលក្ខខណ្ឌតម្រូវសម្រាប់សកម្មភាពឃាតឃាត់ ឬធាតុផ្សំសត្យានុម័តិនៃអំពើប្រល័យពូជសាសន៍[3608]។ ចៅក្រម Shahabuddeen បាន

---

[3603] Bagilishema, សាលក្រម កថាខណ្ឌ៦៤។ Jelisić, សាលក្រម កថាខណ្ឌ៧៩។ ILC ១៩៩៦សេចក្តីព្រាង ក្រម (ដោយមានការពន្យល់បន្ថែម), ទំព័រ៤៥។ អានបន្ថែម Blagojević& Jokić, សាលក្រម កថាខណ្ឌ៦៦៥។ Brđanin, សាលក្រម កថាខណ្ឌ៦៩៨។

[3604] អានឧទាហរណ៍Niyitegeka, សាលដីកា កថាខណ្ឌ៥០។ Akayesu, សាលក្រម កថាខណ្ឌ៥២១។

[3605] Niyitegeka, សាលដីកា កថាខណ្ឌ៥៣។

[3606] Bosnia តទល់នឹង Serbia, កថាខណ្ឌ១៨៧។ អាន Jelisić, សាលក្រម កថាខណ្ឌ៧៩។ Akayesu, សាលក្រម កថាខណ្ឌ៥២២។

[3607] Jelisić, សាលក្រម កថាខណ្ឌ៧៩។

[3608] សាលដីកា Karadžić អនុលោមតាមវិធាន៩៨ស្ទួន កថាខណ្ឌ២២។ Stakić, សាលដីកា កថាខណ្ឌ៣៣-៣៥។ Croatia តទល់នឹង Serbia, កថាខណ្ឌ១៣០។

កត់សម្គាល់នៅក្នុងរឿងក្តី *Krstić* ថា យើងមិនត្រូវ "មើលរំលងភាពខុសគ្នា រវាងប្រភេទនៃអំពើដូចបានរៀបរាប់ និងចេតនាដែលអំពើទាំងនោះត្រូវបានប្រព្រឹត្តនោះឡើយ"[3609]។ ដូច្នេះ ទោះបីជា "ចេតនារបស់ចារីក្នុងការបំផ្លិចបំផ្លាញ" ក្រុមដែលត្រូវការពារ នឹងត្រូវស្តែងឡើងជារឿយៗ តាមរយៈការចូលរួមរបស់ចារីក្នុងការប្រព្រឹត្តិអំពើដូចបានរៀបរាប់ ដែលបង្កើតជាធាតុផ្សំសត្យានុម័ត ហើយការចូលរួមក្នុងអំពើណាមួយត្រូវបានតម្រូវ ដើម្បីបំពេញធាតុផ្សំសត្យានុម័តិនៃអំពើប្រល័យពូជសាសន៍ ក៏ដោយ ក៏គ្មានបទប្បញ្ញត្តិណាមួយក្នុងអនុសញ្ញាទាមទារឲ្យចារីរៀបចំផែនការបំផ្លិចបំផ្លាញក្រុម ទាំងមូល ឬមួយផ្នែក តែតាមរយៈអំពើមួយ ឬច្រើនឡើយ។

894. យុត្តិសាស្ត្រអន្តរជាតិមួយចំនួនបានរកឃើញថា "ការបំផ្លិចបំផ្លាញ" ដោយចេតនា ចំពោះក្រុមមួយត្រូវតែមានលក្ខណៈ "រូបវន្ត ឬជីវសាស្ត្រ"[3610]។ ប៉ុន្តែ អត្ថិភាពរបស់ក្រុមមួយគឺជាបញ្ហាដាច់ដោយឡែកមួយខុសពីការរស់រានមានជីវិតរបស់សមាជិកក្រុម។ ក្រុមមួយ គឺជាអង្គភាពមួយ ដែលមានអត្ថិភាព ទាំងខាងរូបវន្ត និងសង្គម។ ពិតណាស់ ក្រុមនេះមានប្រជាជន និងប្រវត្តិសាស្ត្រ ប្រពៃណី ទំនាក់ទំនងរវាងសមាជិកខ្លួន ទំនាក់ទំនងជាមួយក្រុមដទៃទៀត និងទំនាក់ទំនងជាមួយទឹកដីដែលចងភ្ជាប់សមាជិកក្រុមនីមួយៗ[3611]។ ដូច្នេះ ការបំផ្លិចបំផ្លាញក្រុម ដែលអាចកំណត់អត្តសញ្ញាបានជាអង្គភាពផ្សេងដាច់ដោយឡែក អាចមានទម្រង់ផ្សេងទៀត ដែលអាចមិនតម្រូវឲ្យមានការបំផ្លិចបំផ្លាញរូបវន្តលើសមាជិកក្រុម (ការស្លាប់) ឬបំផ្លិចបំផ្លាញលទ្ធភាពបុគ្គលក្នុងការបន្តពូជ។ ក្រុមមួយអាចត្រូវបានដកហូតអត្ថិភាព តាមរយៈការបំផ្លិចបំផ្លាញលក្ខណៈពិសេសជាក់លាក់ ឬបំបែកសមាជិក ដែលនាំឲ្យមានការរំលាយឯកភាព និង/ឬ អត្តសញ្ញាណរួម ក្នុងលក្ខណៈជាមូលដ្ឋាន និងមិនអាចកែខៃបាន។ ចៅក្រម Shahabuddeen បានបញ្ជាក់នៅក្នុងរឿងក្តី *Krstić* ថា៖

> ការសង្កត់ធ្ងន់ នៅក្នុងឯកសារស្តីពីតម្រូវការសម្រាប់ការបំផ្លិចបំផ្លាញរូបវន្ត ឬជីវសាស្ត្រនាំឲ្យក្រុមមួយអាចត្រូវបំផ្លិចបំផ្លាញ តាមវិធីមិនមែនរូបវន្ត ឬមិនមែនជីវសាស្ត្រ។ វាមិនច្បាស់ទេថា ហេតុអ្វីបានជាចេតនាបំផ្លិចបំផ្លាញក្រុមមួយ តាមវិធី

3609 Krstić, សាលដីកា ទស្សនៈដាច់ដោយឡែករបស់ចៅក្រម Shahabuddeen, កថាខណ្ឌ៤៨។

3610 អានឧទាហរណ៍ Krstić, សាលដីកា កថាខណ្ឌ២៥។ Karadžić, សាលក្រម កថាខណ្ឌ៥៥៣។ Croatia តទល់នឹង Serbia, កថាខណ្ឌ១៣៦។

3611 Blagojević &Jokić, សាលក្រម កថាខណ្ឌ៦៦៦។

មិនមែនរូបវ័ន្ត ឬមិនមែនជីវសាស្ត្រ ត្រូវស្ថិតនៅក្រៅវិសាលភាពធម្មតានៃអនុសញ្ញា [...][3612]។

នេះជាក្រុមដែលត្រូវការពារ។ ក្រុមមួយត្រូវបានបង្កើតឡើងដោយចរិតលក្ខណៈអរូបី ដែលចងបណ្តុំមនុស្សភ្ជាប់គ្នាជាអង្គភាពសង្គមមួយ។ ប្រសិនបើចរិតលក្ខណៈទាំងនេះត្រូវបានបំផ្លិចបំផ្លាញ ស្របតាមចេតនា ដែលអំពើត្រូវបានប្រព្រឹត្ត [...] វាមិនគួរឱ្យជឿជាក់ទេក្នុងការនិយាយថា ការបំផ្លិចបំផ្លាញ ទោះបីជាលុបបំបាត់ក្រុមនេះណាក៏ដោយ មិនមែនជាអំពើប្រល័យពូជសាសន៍ទេ ពីព្រោះការលុបបំបាត់នោះមិនមែនជារូបវ័ន្ត ឬជីវសាស្ត្រ[3613]។

895. ពិតណាស់ អនុសញ្ញានេះផ្ទុះបញ្ចាំងទស្សនៈនេះ ដោយសារតែអំពើប្រល័យពូជសាសន៍ ដូចបានរៀបរាប់ក្នុងអនុសញ្ញា មិនតម្រូវជាចាំបាច់ឱ្យមានការបំផ្លិចបំផ្លាញជារូបវ័ន្ត ឬជីវសាស្ត្រ នោះទេ។ ឧទាហរណ៍ "ការបញ្ជូនកុមារដោយបង្ខំ ពីក្រុមមួយ ទៅក្រុមមួយផ្សេងទៀត" ត្រូវបានចាត់ទុកថាជាអំពើប្រល័យពូជសាសន៍[3614]។ ទោះបីជាត្រូវបានបញ្ជូន ដោយគ្មានព្យសនកម្មលើរាយកាយ និងសូម្បីតែទោះបីជាកុមារត្រូវបានផ្តល់នូវស្តង់ដារខ្ពស់នៃជីវិតសម្ភារៈនៅក្នុងក្រុមថ្មីក៏ដោយ[3615] ក៏ការបញ្ជូនកុមារ ជាវិធីមានប្រសិទ្ធភាពក្នុងការបំផ្លិចបំផ្លាញចរិតលក្ខណៈរបស់ក្រុម ដែល "ចងបណ្តុំ

---

[3612] Krstić, សាលដីកា ទស្សនៈដាច់ដោយឡែករបស់ចៅក្រម Shahabuddeen, កថាខណ្ឌ៤៩។

[3613] Krstić, សាលដីកា ទស្សនៈដាច់ដោយឡែករបស់ចៅក្រម Shahabuddeen, កថាខណ្ឌ៥០។ អានសាលដីការបស់ Düsseldorf ឆ្នាំ១៩៩៩ កថាខណ្ឌ៣៨។ ["[D]er Tatbestand [des Gesetzes] [setzt] nicht zwingend voraus, daß der Täter die körperliche Vernichtung, die physische Zerstörung der Gruppe anstrebt. Es reicht aus, daß er handelt um die Gruppe in ihrer sozialen Existenz ('als solche'), als soziale Einheit in ihrer Besonderheit und Eigenart und in ihrem Zusammengehörigkeitsgefühl zu zerstören." ការបកប្រែមិនផ្លូវការ៖ "វាមិនចាំបាច់ទាល់តែជនល្មើសបំផ្លិចបំផ្លាញរូបរាងកាយនៃក្រុមនោះទេគ្រាន់តែអំពើបំផ្លិចបំផ្លាញអត្ថិភាពសង្គមរបស់ក្រុមនោះវាគ្រប់គ្រាន់ណាស់ទៅហើយ ("ក្នុងន័យជាបែបនេះ") ក្នុងសមត្ថភាពរបស់ខ្លួនដែលជាអង្គភាពសង្គមដែលមានលក្ខណៈពិសេសនិងអារម្មណ៍នៃកម្មសិទ្ធិរួមគ្នា"]។ សាលដីកា Jorgić, កថាខណ្ឌ២០, ២២, ២៨, ៣៣។ ការដាក់ទណ្ឌកម្មទៅលើ ណាស៊ីស និងអ្នករួមដៃ ក្រោមច្បាប់ ឆ្នាំ១៩៥០, មាត្រា១(ខ)(៦) [សម្រេចថា "ការបំផ្លិចបំផ្លាញ ឬការប្រមាថសាសនា ឬកេតនភ័ណ្ឌឬតម្លៃនៃវប្បធម៌របស់ជនជាតិជ្វីស" ជាអំពើប្រល័យពូជសាសន៍ ប្រសិនបើប្រព្រឹត្តដោយចេតនានោះ]។

[3614] អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍, មាត្រា II(ង)។

[3615] កំណត់ត្រាជាផ្លូវការសង្ខេបចំនួន៣នៃមហាសន្និបាតរបស់គណៈកម្មាធិការទី៦ (១៩៤៨) (សម័យប្រជុំលើកទី៨៣), ទំព័រ ១៩៥ (វេណេហ្សុយអេឡា)។

មនុស្សភ្ជាប់គ្នាជាអង្គភាពសង្គមមួយ[3616]។ ប្រសិនបើរដ្ឋាភិបាលត្រូវបញ្ជូនកុមារទាំងអស់ចេញពីគ្រួសារ ដែលជាសមាជិកក្រុមជនជាតិភាគតិចដាច់ពីគេមួយ ទៅស្ថាប័នរដ្ឋ ឬគ្រួសារនៅក្រៅក្រុមមួយ ឬពីរជំនាន់ក្រោយ ក្រុម "បែបនោះ" នឹងរលាយបាត់។ អ្នកធ្វើសេចក្តីព្រាងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ទទួលស្គាល់ថា ការបំពាក់បំប៉នកុមារដោយបង្ខំ ឲ្យចូលទៅក្នុងទំនៀមទម្លាប់ ភាសា សាសនា និងគុណតម្លៃនៃក្រុមបរទេសមួយ "ស្មើនឹងការបំផ្លិចបំផ្លាញក្រុម] កុមារ [ដែលអនាគតរបស់ក្រុមអាស្រ័យលើជំនាន់របស់កុមារទាំងនោះ"[3617]។ ច្បាស់ណាស់ នេះគឺជាអ្វីដែលរបាយការណ៍ថ្មីរបស់គណៈកម្មាធិការស៊ើបអង្កេតលើការព្រមានរបស់ស៊ីរី អំពីការបន្តប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទៅលើជនជាតិ Yazidis ដោយពួក ISIS បានរកឃើញថាកំពុងកើតឡើងទៅលើកុមារ Yazidis៖ តាមរយៈការដកកុមារចេញពីគ្រួសាររបស់ពួកគេ "ពួក ISIS មានចេតនាព្យាយាមបំផ្លិចបំផ្លាញការយល់ឃើញរបស់កុមារ Yazidis ផ្ទាល់ថាខ្លួនជាជនជាតិ Yazidis ដោយកម្ទេចចោលនូវការជាប់ជំពាក់ជំពិននឹងសាសនា Yazidis។ ខណៈដែលកុមារី Yazidis ត្រូវហាមឃាត់ការប្រណិប័តន៍សាសនារបស់ខ្លួន កុមារា Yazidis ត្រូវបានបំពាក់បំប៉នទាំងស្រុងទៅក្នុងមនោគមវិជ្ជា ISIS"[3618]។ ដូច្នេះ ថ្វីត្បិតតែការបញ្ជូនកុមារមិនបានបំផ្លាញក្រុម "តាមវិធីរូបវន្ត ឬជីវសាស្ត្រ" ដោយសារតែកុមារនៅមានជីវិត ប៉ុន្តែ វាពិតជាបំផ្លិចបំផ្លាញក្រុម "បែបនេះ" ដោយហេតុថាកុមារដែលត្រូវគេបញ្ជូននឹងលែងកំណត់អត្តសញ្ញាណខ្លួនឯងជាមួយក្រុម។

896. ដូចគ្នានេះដែរ អំពើ ដូចជា ការនិរទេស/ការបញ្ជូនក្រុមដាច់ដោយឡែកណាមួយដោយបង្ខំ ដែលមិនស្ថិតនៅក្នុងបញ្ជីនៃអំពើ ដែលបង្កើតបានជាធាតុផ្សំសត្យានុម័តិនៃអំពើប្រល័យពូជសាសន៍ អាចនាំមកនូវការបំផ្លិចបំផ្លាញក្រុម "បែបនេះ" ហើយអាចបង្កើតជាភ័ស្តុតាងនៃធាតុផ្សំអត្តនោម័តិ ដែលបង្ហាញអំពីចេតនារបស់ចារីក្នុងការបំផ្លិចបំផ្លាញក្រុម។ នៅក្នុងរឿងក្តី *Blagojević* អង្គជំនុំជម្រះសាលាដំបូងបានពន្យល់ថា៖

---

[3616] Krstić, សាលដីកា ទស្សនៈដាច់ដោយឡែករបស់ចៅក្រម កថាខណ្ឌ៥០។ អានសាលដីការបស់ Düsseldorf ឆ្នាំ ១៩៩៩ កថាខណ្ឌ៣៨។

[3617] កំណត់ត្រាជាផ្លូវការសង្ខេបចំនួន៣នៃមហាសន្និបាតរបស់គណៈកម្មាធិការទី៦ (១៩៤៨) (សម័យប្រជុំលើកទី៨៣), ទំព័រ ១៩៥ (វេណេហ្ស៊ុយអេឡា)។សូមអានឯកសារកំណត់ត្រានៃសម័យប្រជុំលើកទី៨២, ទំព័រ១៨៦ (ប្រទេសក្រិច និងប្រទេសបារាំង) [ចាត់ទុកការបញ្ជូនកុមារដោយបង្ខិតបង្ខំជាអំពើប្រល័យពូជសាសន៍ផ្នែកវប្បធម៌]។

[3618] របាយការណ៍ ISIS-Yazidi Report, កថាខណ្ឌ១៤៨។

ការបំផ្លិចបំផ្លាញក្រុម តាមវិធីរូបវន្ត ឬជីវសាស្ត្រ ជាលទ្ធផលនៃការបញ្ជូនប្រជាជនដោយបង្ខំ ពេលការបញ្ជូននេះត្រូវបានធ្វើឡើង តាមវិធីដែលធ្វើឱ្យក្រុមនេះលែងអាចបង្កើតឡើងវិញដោយខ្លួនឯងបាន ជាពិសេស ពេលវាពាក់ព័ន្ធនឹងការបំបែកសមាជិកក្រុម។ ក្នុងករណីបែបនេះ [...] ការបញ្ជូនមនុស្សដោយបង្ខំអាចនាំឱ្យមានការបំផ្លិចបំផ្លាញជាក់ស្តែងទៅលើក្រុម ពីព្រោះក្រុមនោះលែងមានអត្ថិភាពជាក្រុមមួយ ឬយ៉ាងហោចណាស់ ជាក្រុមរបស់ខ្លួន[3619]។

នៅទីនេះ អង្គជំនុំជម្រះសាលាដំបូង ក្នុងរឿងក្តី *Blagojević* បានទទួលយកយុត្តាធិការពីមុនរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលថា ការបំផ្លិចបំផ្លាញ "រូបវន្ត ឬជីវសាស្ត្រ" ត្រូវតម្រូវឱ្យមាន ប៉ុន្តែ បកស្រាយការបំផ្លិចបំផ្លាញរូបវន្តដើម្បីដាក់បញ្ចូលស្ថានភាពដែលសមាជិកក្រុមនៅរស់ ប៉ុន្តែ ត្រូវបានបំបែកឱ្យបែកខ្ញែកគ្នា ថាជាការបំផ្លិចបំផ្លាញលទ្ធភាពក្នុងការបន្តអត្ថិភាពជាក្រុម។

897. ក្នុងន័យនេះ អង្គជំនុំជម្រះតុលាការកំពូល ក្នុងរឿងក្តី *Krstić* បានគាំទ្រថាការបញ្ជូនស្ត្រី កុមារ និងមនុស្សចាស់ ពីតំបន់ Srebrenica ទៅកាន់ទឹកដីក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលបូស្នី "អាចជាមធ្យោបាយបន្ថែមទៀត ដើម្បីធានាឱ្យមានការបំផ្លិចបំផ្លាញរូបវន្តទៅលើសហគមន៍មូស្លីមបូស្នីនៅ Srebrenica" ដោយសារតែវាកម្ទេច "លទ្ធភាពនៅសេសសល់ថា សហគមន៍មូស្លីមនៅតំបន់នោះអាចបង្កើតឡើងវិញដោយខ្លួនឯង"[3620]។ ជាការពិត មុនឆ្នាំ ១៩៧៥ រដ្ឋមួយចំនួនបានដាក់បញ្ចូលការបញ្ជូនមនុស្សពេញវ័យដោយបង្ខំ បន្ថែមលើកុមារ ជាអំពើប្រល័យពូជសាសន៍[3621]។

---

3619 Blagojević &Jokić, សាលក្រម កថាខណ្ឌ៦៦៦។ Krstić, សាលដីកា ទស្សនៈដាច់ដោយឡែករបស់ចៅក្រម Shahabuddeen, កថាខណ្ឌ៤៥-៥៨។ Tolimir, សាលដីកា កថាខណ្ឌ២៥៤។ សាលក្រម Düsseldorf ឆ្នាំ១៩៩៩, កថាខណ្ឌ៣៨។

3620 Krstić, សាលដីកា កថាខណ្ឌ៣១។

3621 អាន ក្រមព្រហ្មទណ្ឌ បូលីវី៖ ប្រកាសឱ្យប្រើច្បាប់ លេខ១០៤២៦ ថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៧២, មាត្រា១៣៨។ អែលសាវ៉ាឌ័រ៖ ក្រមព្រហ្មទណ្ឌ សាធារណរដ្ឋអែលសាវ៉ាឌ័រ (ក្រឹត្យ លេខ១០៣០) --ថ្ងៃទី១៥ខែធ្នូឆ្នាំ១៩៧៤, មាត្រា៣៦១។ អេត្យូពី៖ ក្រមព្រហ្មទណ្ឌ អេត្យូពី១៩៥៧, មាត្រា២៨១។ ក្វាតេម៉ាឡា៖ ក្រមព្រហ្មទណ្ឌ ក្វាតេម៉ាឡាក្រឹត្យ លេខ១៧-៧៣ (ឆ្នាំ១៩៧៣), ផ្នែក IV, មាត្រា៣៧៦។ នីការ៉ាក្វា៖ ក្រមព្រហ្មទណ្ឌ សាធារណរដ្ឋនីការ៉ាក្វា (ឆ្នាំ១៩៧៤), មាត្រា៥៤៩។

898. ដូចគ្នានេះដែរ ការផ្លាស់ប្តូរ ឬការលះបង់សាសនាដោយបង្ខំ បង្ហាញអំពីចេតនាបំផ្លិចបំផ្លាញក្រុមសាសនា "បែបនេះ"។ ប្រសិនបើគ្មាននរណាម្នាក់គោរពប្រណិប័តន៍សាសនាទេ ក្រុមនេះលែងមានអត្ថិភាពជាក្រុមសាសនាទៀតហើយ។ គណៈកម្មាធិការស៊ីរីបានរកឃើញថា "បុរស និងក្មេងប្រុស Yazidis ត្រូវបានគេបង្ខំឱ្យផ្លាស់ប្តូរសាសនា បើមិនអ៊ីចឹងទេ នឹងត្រូវស្លាប់ ហើយក្នុងករណីណាមួយក៏ដោយ វានាំទៅដល់ការបំផ្លិចបំផ្លាញពួកគេ ក្នុងនាមជា Yazidis"[3622]។ ពិតណាស់ ការផ្លាស់ប្តូរ តាមរយៈការបញ្ចុះបញ្ចូលបែបទស្សនវិជ្ជា សីលធម៌ ឬសេដ្ឋកិច្ច ឬសូម្បីតែតាមរយៈរូបភាពនៃការរើសអើង ក្រៅពីអំពើប្រល័យពូជសាសន៍ដូចបានរៀបរាប់ គឺមិនស្មើនឹងអំពើប្រល័យពូជសាសន៍ផ្ទាល់ទេ។ អំពើប្រល័យពូជសាសន៍អាចកើតឡើង តែនៅពេលការបំផ្លិចបំផ្លាញក្រុមត្រូវបានធ្វើឡើង យ៉ាងហោចណាស់មួយផ្នែក តាមរយៈអំពើប្រល័យពូជសាសន៍មួយក្នុងចំណោមអំពើទាំងប្រាំ គឺធាតុផ្សំសត្យានុម័តចាំបាច់។ ទោះយ៉ាងណាក៏ដោយ ពេលការផ្លាស់ប្តូរត្រូវបានអនុវត្តឧទាហរណ៍ ដោយការសម្លាប់អ្នកប្រកែកមិនព្រមផ្លាស់ប្តូរ ទោះបីជាមានចំនួនតិចតួចក៏ដោយ ក្នុងចេតនាបំផ្លិចបំផ្លាញក្រុមសាសនា នេះគឺជាអំពើប្រល័យពូជសាសន៍យ៉ាងច្បាស់ក្រឡែត។

899. លើសពីនេះទៅទៀត ទង្វើ ដែលមិនត្រូវបានរៀបរាប់ អាចត្រូវបានចាត់ទុកជាភ័ស្តុតាងបញ្ជាក់អំពីចេតនាបំផ្លិចបំផ្លាញក្រុម[3623]។ ចៅក្រម Shahabuddeen បានកត់សម្គាល់ថា "ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិវប្បធម៌អាចត្រូវបានប្រើជាភ័ស្តុតាងបញ្ជាក់ពីចេតនាមួយ ដែលត្រូវទាញការសន្និដ្ឋានចេញកាលៈទេសៈផ្សេងទៀត ក្នុងការបំផ្លិចបំផ្លាញក្រុមបែបនេះ"[3624]។ តុលាការយុត្តិធម៌អន្តរជាតិបានគាំទ្រដល់ការប្រកាសរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងរឿងក្តី *Krstić* ថា "ទីណាមានការបំផ្លិចបំផ្លាញជារូបវ័ន្ត ឬជីវសាស្ត្រ ជារឿយៗ ទីនោះ មានការវាយប្រហារក្នុងពេលដំណាលគ្នាទៅលើទ្រព្យសម្បត្តិវប្បធម៌ និងសាសនា និងនិមិត្តរូបនៃក្រុមគោលដៅផងដែរ ហើយការវាយប្រហារទាំងនេះអាចត្រូវបានចាត់ទុកតាមផ្លូវច្បាប់ជាភ័ស្តុតាងនៃចេតនាបំផ្លិចបំផ្លាញក្រុមខាងរូបវ័ន្ត"[3625]។

---

3622 របាយការណ៍ ISIS-Yazidi កថាខណ្ឌ១៥៩។

3623 Tolimir, សាលដីកា កថាខណ្ឌ២៥៤។ Karadžić, សាលក្រម កថាខណ្ឌ៥៥៣។ Krstić, សាលដីកា កថាខណ្ឌ៣៣, ១៣៣។ Krstić, សាលក្រម កថាខណ្ឌ៥៨០។ Blagojević &Jokić, សាលដីកា កថាខណ្ឌ១២៣។

3624 Krstić, សាលដីកា ទស្សនៈដាច់ដោយឡែករបស់ចៅក្រម Shahabuddeen, កថាខណ្ឌ៥៣។

3625 Bosnia តទល់នឹង Serbia, កថាខណ្ឌ៣៤៤, សម្រង់ Krstić, សាលក្រម កថាខណ្ឌ៥៨០។

900. សរុបមក អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ត្រូវតែបកស្រាយ ក្នុងន័យថា ដោយសារតែបានប្រព្រឹត្តអំពើដូចបានរៀបរាប់ (ធាតុផ្សំសត្យានុម័ត) ចេតនាបំផ្លិចបំផ្លាញក្រុម "បែបនេះ" អាចត្រូវបានបង្ហាញឡើង តាមរយៈភ័ស្តុតាងអំពីចេតនាបង្កឱ្យមានការបំផ្លិចបំផ្លាញក្រុម ដោយអំពើ ដែលមិនមានចែងនៅក្នុងអនុសញ្ញាស្តីពីប្រល័យពូជសាសន៍ ឬច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ ដូច្នេះ តុលាការគួរក្រឡេកមើលទស្សនាទានពេញលេញនៃអំពើប្រឆាំងនឹងក្រុមដែលត្រូវការពារ ក្នុងការពិចារណាលើអំពើល្មើសរបស់ជនជាប់ចោទ។ ក្នុងន័យនេះ ការបញ្ជូនស្ត្រី និងកុមារ នៅតំបន់ Srebrenica មិនអាចត្រូវគេមើលរំលងឡើយ ពីព្រោះវាជាផ្នែកមួយនៃផែនការមួយ ក្នុងការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ ពាក់ព័ន្ធនឹងការសម្លាប់ ការផ្លាស់ប្តូរដោយបង្ខំ និងការបំផ្លិចបំផ្លាញផ្ទះសម្បែង"[3626]។

*ខ) ទាំងស្រុង ឬមួយផ្នែក*

901. ជនដែលប្រព្រឹត្តអំពើឃាតកម្ម នឹងជាប់ពិរុទ្ធពីបទប្រល័យពូជសាសន៍ ប្រសិនបើជននោះមានចេតនាបំផ្លិចបំផ្លាញក្រុមគោលដៅ ទាំងមូល ឬមួយផ្នែក។ ពុំមានតួលេខជនរងគ្រោះចាំបាច់ដើម្បីបង្ហាញអំពើប្រល័យពូជសាសន៍នោះទេ[3627]។

902. ចំពោះចេតនាបំផ្លិចបំផ្លាញក្រុមមួយផ្នែក គេត្រូវបង្ហាញថាជនជាប់ចោទមានចេតនាបំផ្លិចបំផ្លាញផ្នែកសំខាន់នៃក្រុមដែលត្រូវការពារ[3628]។ តួលេខតែមួយមុខ "មិនមែនជាចំណុចបញ្ចប់នៃការស៊ើបអង្កេតក្នុងគ្រប់រឿងក្តីទាំងអស់នោះទេ"[3629]។ ការកំណត់ថាតើផ្នែកគោលដៅសំខាន់ឬអត់ អាស្រ័យលើកត្តាមួយចំនួនខាងបរិមាណ និងគុណភាព។ ទំហំគួរតែត្រូវវាយតម្លៃ មិនត្រឹមតែក្នុងន័យដាច់

---

[3626] Krstić, សាលដីកា ទស្សនៈដាច់ដោយឡែករបស់ចៅក្រម Shahabuddeen, កថាខណ្ឌ៣៥។ អានបន្ថែម របាយការណ៍ចុងក្រោយរបស់គណៈកម្មាធិការជំនាញ ដែលបង្កើតឡើង អនុលោមតាមសេចក្តីសម្រេចចិត្តលេខ ៧៨០ (ឆ្នាំ ១៩៩២) របស់ក្រុមប្រឹក្សាសន្តិសុខ, ឯកសារ អ.ស.ប S/១៩៩៤/៦៧៤, ថ្ងៃទី២៧ខែឧសភា ឆ្នាំ១៩៩៤, កថាខណ្ឌ ៩៤។

[3627] Seromba, សាលក្រម កថាខណ្ឌ៣១៩។ Semanza, សាលក្រម កថាខណ្ឌ៣១៦។ Bagosora, សាលក្រម កថាខណ្ឌ ២១១៥។

[3628] Karadžić, សាលក្រម កថាខណ្ឌ៥៥៥។ Krstić, សាលដីកា កថាខណ្ឌ៨។ Bagosora, សាលក្រម កថាខណ្ឌ ២១១៥។ Gacumbitsi, សាលដីកា កថាខណ្ឌ៤៤។ Bosnia តទល់នឹង Serbia, កថាខណ្ឌ១៩៨, ២០០-២០១។ Croatia តទល់នឹង Serbia, កថាខណ្ឌ១៤២។

[3629] Krstić, សាលដីកា កថាខណ្ឌ១២។ សាលដីកា Karadžić អនុលោមតាមវិធាន៩៨ស្ទួន កថាខណ្ឌ៦៦។

ខាតប៉ុណ្ណោះទេ ប៉ុន្តែក៏ទាក់ទងផងដែរនឹងចំនួនប្រជាជនសរុបរបស់ក្រុម៖ ប្រសិនបើផ្នែកមួយមានទំហំធំគ្រប់គ្រាន់ ជានិមិត្តរូប ឬមានភាពលេចធ្លោ នៅក្នុងក្រុម ឬសំខាន់ចំពោះការរស់រានមានជីវិតរបស់ក្រុម វាអាចត្រូវបានចាត់ទុកជាផ្នែកសំខាន់[3630]។ លក្ខណៈវិនិច្ឆ័យទាំងនេះមិនមានភាពពេញលេញទេ[3631]។ ផ្នែកនោះត្រូវសំខាន់គ្រប់គ្រាន់ រហូតថ្នាក់ការបំផ្លិចបំផ្លាញនឹងមានផលប៉ះពាល់ ឬគំរាមកំហែងដល់ការរស់រានមានជីវិតរបស់ក្រុមទាំងមូល[3632]។ លក្ខខណ្ឌតម្រូវនេះអាចកើតមានប្រសិនបើថ្នាក់ដឹកនាំក្រុមមួយត្រូវបានកំណត់គោលដៅសម្រាប់ការបំផ្លិចបំផ្លាញ[3633]។

903. ចេតនាបំផ្លិចបំផ្លាញក្រុមមួយផ្នែកអាចលាតសន្ធឹងដល់តំបន់ភូមិសាស្ត្រមានកម្រិត ដូចជា សាសនារបស់ប្រទេសមួយ ឬក្រុងមួយ[3634]។ ដែននៃសកម្មភាព ការគ្រប់គ្រង និងកម្រិតនៃការចូលទៅដល់របស់ចារី គឺជាកត្តានីមួយៗដែលជាប់ពាក់ព័ន្ធនឹងការវាយតម្លៃចេតនាបំផ្លិចបំផ្លាញផ្នែកសំខាន់មួយរបស់ក្រុមដែលត្រូវការពារ[3635]។ ភាពអាចអនុវត្តបាន និងទម្ងន់មិនដាច់ខាតនៃកត្តាទាំងនេះ នឹងប្រែប្រួល អាស្រ័យតាមកាលៈទេសៈនៃករណីជាក់លាក់ណាមួយ[3636]។

*គ) ការបង្ហាញឱ្យឃើញចេតនា*

904. នៅក្នុងរឿងក្តី *Krstić* អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានកត់សម្គាល់ថា ជាធម្មតា ចេតនាប្រល័យពូជសាសន៍មិនមានភស្តុតាង

---

[3630] Krstić, សាលដីកា កថាខណ្ឌ៨, ១២, ២៨-២៩។ Karadžić, សាលក្រម កថាខណ្ឌ៥៥៥។ Bosnia តទល់នឹង Serbia, កថាខណ្ឌ២០០។ Croatia តទល់នឹង Serbia, កថាខណ្ឌ១៤២។

[3631] Krstić, សាលដីកា កថាខណ្ឌ១៤។ Bosnia តទល់នឹង Serbia, កថាខណ្ឌ២០១។

[3632] Karadžić, សាលក្រម កថាខណ្ឌ កថាខណ្ឌ៥៥៥។ Krstić, សាលដីកា កថាខណ្ឌ៨, ១២។ Tolimir, សាលក្រម ខណ្ឌ៧៤៩។ Jelisić, សាលក្រម កថាខណ្ឌ៨២។ Bosnia តទល់នឹង Serbia, កថាខណ្ឌ១៩៣, ១៩៨។ សាលដីកា Karadžić អនុលោមតាមវិធាន៩៨ស្ទួន កថាខណ្ឌ៦៦។

[3633] Jelisić, សាលក្រម កថាខណ្ឌ៨២។ សាលដីកាលើកលែងការចោទប្រកាន់ Sikirica, កថាខណ្ឌ៧៧។ សេចក្តីសម្រេចលើកលែងការចោទប្រកាន់ Milošević, កថាខណ្ឌ១៣២។

[3634] Jelisić, សាលក្រម កថាខណ្ឌ៨០, ៨៣។ Krstić, សាលក្រម កថាខណ្ឌ៥៨៩-៥៩០។ Bosnia តទល់នឹង Serbia, កថាខណ្ឌ១៩៩។

[3635] Krstić, សាលដីកា កថាខណ្ឌ១៣។ Karadžić, សាលក្រម កថាខណ្ឌ៥៥៥។ Tolimir, សាលក្រម កថាខណ្ឌ៧៤៩។ Bosnia តទល់នឹង Serbia, កថាខណ្ឌ១៩៩។ Croatia តទល់នឹង Serbia, កថាខណ្ឌ១៤២។

[3636] Karadžić, សាលក្រម កថាខណ្ឌ៥៥៥។ Krstić, សាលដីកា កថាខណ្ឌ១៤។

ផ្ទាល់នោះទេ ប៉ុន្តែ ជារឿយៗ អាចទាញសេចក្តីសន្និដ្ឋានចេញពីអង្គហេតុ និងកាលៈទេសៈនៃសំណុំរឿង[3637]។ អង្គហេតុបែបនេះមិនចាំបាច់បង្កើតបានជាធាតុផ្សំសត្យានុម័តនៃឧក្រិដ្ឋកម្មនោះទេ[3638]។

905. កត្តាពាក់ព័ន្ធនឹងការវិភាគនេះ អាចរួមបញ្ចូលបរិបទទូទៅ, ការប្រព្រឹត្តិអំពើពិរុទ្ធផ្សេងទៀតសំដៅជាប្រព័ន្ធប្រឆាំងនឹងក្រុមដដែល (មិនថាប្រព្រឹត្តដោយជនល្មើសដដែល ឬអ្នកផ្សេង), ទំហំនៃអំពើឃោរឃៅដែលបានប្រព្រឹត្ត, អាវុធប្រើប្រាស់ និងវិសាលភាពនៃការបង្ករបួសស្នាមខាងរាងកាយ, ការកំណត់គោលដៅជាប្រព័ន្ធលើជនរងគ្រោះ ដោយមូលហេតុសមាជិកភាពនៃក្រុមដោយឡែកណាមួយ, ភាពដដែលៗនៃអំពើបំផ្លិចបំផ្លាញ និងរើសអើង, ការប្រើភាសាប្រមាថដល់សមាជិកនៃក្រុមគោលដៅ, ការធ្វើផែនការតាមវិធីសាស្ត្រនៃការសម្លាប់ជាប្រព័ន្ធ[3639], សុន្ទរកថា ឬគម្រោងរៀបចំគ្រឹះ និងផ្តល់យុត្តិកម្មដល់អំពើដែលមានបំណងបំផ្លាញមូលដ្ឋានគ្រឹះរបស់ក្រុមគោលដៅ[3640], និងលទ្ធិនយោបាយដែលនាំទៅដល់អំពើដែលបានរៀបរាប់[3641]។ នៅក្នុងការវាយតម្លៃភស្តុតាងអំពីចេតនាអំពើប្រល័យពូជសាសន៍ តុលាការគួរពិចារណាថា តើភស្តុតាងទាំងអស់រួមគ្នាបង្ហាញអំពីសភាពផ្លូវចិត្តប្រល័យពូជសាសន៍ដែរឬទេ ជំនួសឲ្យការពិចារណាដាច់ដោយឡែកពីគ្នាថា តើជនជាប់ចោទមានចេតនាបំផ្លិចបំផ្លាញក្រុមដែលត្រូវការពារ តាមរយៈអំពើប្រល័យពូជសាសន៍ពាក់ព័ន្ធដែរឬទេ[3642]។

---

3637 សាលដីកាKaradžić អនុលោមតាមវិធាន៩៨ស្ទួន កថាខណ្ឌ៨០, សម្រង់ Gacumbitsi, សាលដីកា កថាខណ្ឌ៤០។ Rutaganda, សាលដីកា កថាខណ្ឌ៥២៥។ Kayishema & Ruzindana, សាលដីកា កថាខណ្ឌ១៥៩។

3638 Tolimir, សាលដីកា កថាខណ្ឌ២៥៤។ Krstić, សាលដីកា កថាខណ្ឌ៣៣។ អាន Croatia តទល់នឹង Serbia, កថាខណ្ឌ១៦២-១៦៣, ៤៣៨។ Bosnia តទល់នឹង Serbia, កថាខណ្ឌ១៩០។

3639 Karadžić, សាលក្រម កថាខណ្ឌ៥៥០។ សាលដីកា Karadžić អនុលោមតាមវិធាន៩៨ស្ទួន កថាខណ្ឌ៨០។ Tolimir, សាលដីកា កថាខណ្ឌ២៤៦។ Popović, សាលដីកា កថាខណ្ឌ៤៦៨។ Hategekimana, សាលដីកា កថាខណ្ឌ១៣៣។ Jelisić, សាលដីកា កថាខណ្ឌ៤៧។ Seromba, សាលដីកា កថាខណ្ឌ១៧៦។ Gacumbitsi, សាលដីកា កថាខណ្ឌ៤០-៤១។ របាយការណ៍ ISIS-Yazidi កថាខណ្ឌ១៥២។

3640 Gacumbitsi, សាលដីកា កថាខណ្ឌ៤៣។ Kamuhanda, សាលដីកា កថាខណ្ឌ៨១-៨២។ Karadžić, សាលក្រម កថាខណ្ឌ៥៥០។ Tolimir, សាលក្រម កថាខណ្ឌ៧៤៥។

3641 Seromba, សាលដីកា កថាខណ្ឌ១៧៦។

3642 Karadžić, សាលក្រម កថាខណ្ឌ៥៥០។ Stakić, សាលដីកា កថាខណ្ឌ៥៥។ សាលដីកា Karadžić អនុលោមតាមធាន៩៨ស្ទួន កថាខណ្ឌ៥៦។ Tolimir, សាលដីកា កថាខណ្ឌ២៤៦-២៤៧។ Mpambara, សាលក្រម កថាខណ្ឌ

906. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មិនទាមទារឲ្យមានអត្ថិភាពគោលនៃនយោបាយ ឬផែនការណាមួយឡើយ[3643] ទោះបីជាអត្ថិភាពណាមួយអាចជួយសម្រួលដល់ការបង្ហាញចេតនា និងឧក្រិដ្ឋកម្មផ្ទាល់ក៏ដោយ[3644]។ ដោយសារតែវាអាចត្រូវបានបង្ហាញថាមានចេតនាបំផ្លិចបំផ្លាញក្រុមនេះ ទាំងមូលឬមួយផ្នែក មូលហេតុដែលនាំឲ្យមានការសម្រេចប្រព្រឹត្តឧក្រិដ្ឋកម្ម (ដូចជា ផលចំណេញខាងនយោបាយ យោធា ឬសេដ្ឋកិច្ច ការភ័យខ្លាច ការស្អប់ ឬការសងសឹក) គឺមិនពាក់ព័ន្ធ[3645]។ ការលើកលែងចំពោះបុគ្គលមួយចំនួន ឬអនុប្រជាជននៅក្នុងក្រុមដែលត្រូវការពារ មិនរារាំងជាចាំបាច់ដល់អត្ថិភាពនៃចេតនាប្រល័យពូជសាសន៍ទេ ដរាបណាក្រុមដែលត្រូវការពារនៅតែត្រូវបានកំណត់គោលដៅសម្រាប់ការបំផ្លិចបំផ្លាញដល់ផ្នែកសំខាន់[3646]។

907. ការបំផ្លិចបំផ្លាញក្រុមដោយជាក់ស្តែង ឬសូម្បីតែការបំផ្លិចបំផ្លាញមនុស្សក្នុងចំនួនច្រើន មិនមែនជាបុរេលក្ខខណ្ឌ ក្នុងការរកឃើញចេតនាប្រល័យពូជសាសន៍ឡើយ។ ការសម្លាប់តែមួយដង បើសិនជាប្រព្រឹត្ត ក្នុងចេតនាតម្រូវឲ្យមាន ដើម្បីបំផ្លិចបំផ្លាញក្រុមទាំងមូល ឬមួយផ្នែក អាចស្មើនឹងអំពើប្រល័យពូជសាសន៍[3647]។ ដូចគ្នាដែរ ការបរាជ័យរបស់ចារីក្នុងការអនុវត្តចេតនាឲ្យអស់លទ្ធភាពដោយបន្សល់ទុកនូវអំពើបំផ្លិចបំផ្លាញមិនពេញលេញ មិនរារាំងដល់ការរកឃើញចេតនាប្រល័យ

---

១២១។ អានបន្ថែម Croatia តទល់នឹង Serbia, កថាខណ្ឌ៤១៩។ អាន IX.ក.១. អំពើប្រល័យពូជសាសន៍-ចេតនានៃឧក្រិដ្ឋកម្ម- ក.) ចេតនាក្នុងការផ្តាច់ផ្តិលក្រុមមួយ "បែបនោះ" ដែលបានរៀបរាប់នៅផ្នែកខាងលើ។

3643 Popović, សាលដីកា កថាខណ្ឌ៤៣០។ Jelisić, សាលដីកា កថាខណ្ឌ៤៨។ Kayishema & Ruzindana, សាលដីកា កថាខណ្ឌ១៣៨។ Simba, សាលដីកា កថាខណ្ឌ២៦០។

3644 Jelisić, សាលដីកា កថាខណ្ឌ៤៨។ Semanza, សាលដីកា កថាខណ្ឌ២៦០។ Rutaganda, សាលដីកា កថាខណ្ឌ៥២៥។ Bosnia តទល់នឹង Serbia, កថាខណ្ឌ៣៧៣។

3645 Karadžić, សាលក្រម កថាខណ្ឌ៥៥៤។ Simba, សាលដីកា កថាខណ្ឌ៨៨, ២៦៩។ Kayishema & Ruzindana, សាលដីកា កថាខណ្ឌ១៦១។ Stakić, សាលដីកា កថាខណ្ឌ៤៥។ Jelisić, សាលដីកា កថាខណ្ឌ៤៩។

3646 Kayishema& Ruzindana, សាលដីកា កថាខណ្ឌ១៤៩។ Akayesu, សាលក្រម កថាខណ្ឌ១៩២-១៩៣។ Muhimana, សាលដីកា កថាខណ្ឌ៣២។ Rutaganda, សាលដីកា កថាខណ្ឌ៥៣៧។ Ntabakuze, សាលដីកា កថាខណ្ឌ២៤១។

3647 Ndindabahizi, សាលដីកា កថាខណ្ឌ១៣៥។ Mpambara, សាលក្រម កថាខណ្ឌ៨។

ពូជសាសន៍ឡើយ[3648]។ ពុំមានលក្ខខណ្ឌតម្រូវឲ្យចារីជ្រើសរើសវិធីសាស្ត្រដ៏មានប្រសិទ្ធភាពបំផុត ដើម្បីសម្រេចបំណងបំផ្លិចបំផ្លាញក្រុមគោលដៅ ឬផ្នែកណាមួយឡើយ[3649]។

*ឃ) ទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបាន*

908. មាត្រា ៤ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ចែងថា ការប៉ុនប៉ង និងការសមគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ក៏ដូចជាការចូលរួមប្រព្រឹត្តអំពើប្រល័យពូជសាសន៍ អាចត្រូវបានផ្ដន្ទាទោសនៅអ.វ.ត.ក។ ដោយសារតែការប៉ុនប៉ង ឬការសមគំនិត មិនត្រូវបានចោទប្រកាន់ នៅក្នុងដីកាដំណោះស្រាយ សហព្រះរាជអាជ្ញាកម្រិតការវិភាគរបស់ខ្លួនត្រឹមអត្ថន័យនៃ "ការចូលរួមប្រព្រឹត្តអំពើប្រល័យពូជសាសន៍"។

909. បើអានរួមគ្នាជាមួយមាត្រា ២៩ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ឃ្លា "ការចូលរួមប្រព្រឹត្តអំពើប្រល័យពូជសាសន៍" បង្ហាញថា ទម្រង់ទូទៅនៃការចូលរួមក្នុងឧក្រិដ្ឋកម្ម ដែលមានចែងក្នុងមាត្រា ២៩ ថ្មី (ការប្រព្រឹត្ត ការរៀបចំផែនការ ការញុះញង់ ការបញ្ជា ការជួយនិងជំរុញ និងការទទួលខុសត្រូវរបស់ថ្នាក់លើ) ត្រូវយកមកអនុវត្តស្មើគ្នានឹងមាត្រា ៤។

910. ពាក្យ "ការចូលរួម" មិនមែនជាពាក្យសិល្បៈទេ។ អត្ថន័យធម្មតារបស់វាគឺ "អំពើចូលពាក់ព័ន្ធក្នុងការប្រព្រឹត្តអ្វីមួយ ដូចជា [...] ឧក្រិដ្ឋកម្ម"[3650]។ "ការចូលរួម" ត្រូវបានប្រើ ដើម្បីសំដៅជារួមដល់ទម្រង់នៃការទទួលខុសត្រូវចំពោះការប្រព្រឹត្ត ការរៀបចំផែនការ ការញុះញង់ ការបញ្ជា ការជួយនិងជំរុញ រួមទាំងទាក់ទងនឹងអំពើប្រល័យពូជសាសន៍[3651]។ លើសពីនេះទៅទៀត មាត្រា ២៩ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ធ្វើឲ្យទម្រង់នៃការចូលរួមក្នុងឧក្រិដ្ឋកម្មអាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍៖ "ជនសង្ស័យណាមួយ ដែលមានផែនការ ញុះញង់ បញ្ជា ប្រព្រឹត្ត ឬជួយនិងជំរុញក្នុងការរៀបចំផែនការ ឬការប្រព្រឹត្តឧក្រិដ្ឋកម្ម ក្នុងមាត្រា [...] មាត្រា ៤ [...] នៃ

---

[3648] Krstić, សាលដីកា កថាខណ្ឌ៣២។

[3649] Krstić, សាលដីកា កថាខណ្ឌ៣២។

[3650] វចនានុក្រម Black's Law បោះពុម្ពផ្សាយលើកទី៩ (ឆ្នាំ២០០៩).

[3651] អានឧទាហរណ៍ Kayishema & Ruzindana, សាលដីកា កថាខណ្ឌ១៨៥។ Musema, សាលក្រម កថាខណ្ឌ១១៤។ Kamuhanda, សាលក្រម កថាខណ្ឌ៥៨៨។ Čelebići, សាលដីកា កថាខណ្ឌ៣៥១។

ច្បាប់នេះ ត្រូវទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនេះ[3652]។ ក្រោមបទប្បញ្ញត្តិដដែលនេះ ជនជាប់ចោទណាម្នាក់អាចទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ក្នុងឋានៈជាថ្នាក់លើ[3653]។

911. លក្ខន្តិកៈរបស់តុលាការ*ចំពោះកិច្ច*មានចែង បន្ថែមពីលើបញ្ជីនៃអំពើដែលអាចផ្តន្ទាទោស នៅក្នុងបទប្បញ្ញត្តិស្តីពីអំពើប្រល័យពូជសាសន៍ (ករណីរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មាត្រា ៤(៣)) នូវទម្រង់បែបបទនៃការចូលរួមក្នុងឧក្រិដ្ឋកម្មស្រដៀងគ្នានឹងទម្រង់ដែលមានចែងនៅក្នុងមាត្រា ២៩ ថ្មី (លក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មាត្រា ៧(១) និងមាត្រា ៧(៣)) ដែលលក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីចែងច្បាស់ អាចយកមកអនុវត្តបានចំពោះអំពើប្រល័យពូជសាសន៍។ ក្នុងការដោះស្រាយ "ការត្រួតគ្នានេះ" អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានលើកឡើងថា "ទម្រង់នៃការចូលរួម" គួរតែត្រូវ "ដាក់បញ្ចូល" នៅក្នុងបទប្បញ្ញត្តិស្តីពីអំពើប្រល័យពូជសាសន៍របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី "ពីព្រោះលក្ខន្តិកៈត្រូវតែបកស្រាយ ដោយក្តីគោរពបំផុតចំពោះភាសាដែលត្រូវបានប្រើដោយអ្នកតាក់តែងច្បាប់"[3654]។

912. អាស្រ័យហេតុនេះ មាស មុត អាចទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ក្រោមទម្រង់នៃការចូលរួមក្នុងឧក្រិដ្ឋកម្មទាំងអស់ ដូចមានចែងនៅក្នុងមាត្រា ២៩ ថ្មី[3655]។ សហព្រះរាជអាជ្ញាកត់សម្គាល់ថា សហឧក្រិដ្ឋកម្មរួម មានន័យស្មើនឹង "ការប្រព្រឹត្ត" នៅក្នុងដែនកំណត់នៃមាត្រា ២៩ ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[3656] ហើយការទទួលខុសត្រូវចំពោះការចូលរួមក្នុងសហឧក្រិដ្ឋកម្ម

---

3652 ច្បាប់ អ.វ.ត.ក, មាត្រា២៩ថ្មី។

3653 ច្បាប់ អ.វ.ត.ក, មាត្រា២៩ថ្មី ["អំពើទាំងឡាយណា[យោងទៅមាត្រា៤ នៃច្បាប់នេះ]បានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់នោះ មិនអាចជួយឲ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះបានទេ"]។

3654 Krstić, សាលដីកា កថាខណ្ឌ១៣៨-១៣៩។

3655 កិច្ចពិភាក្សាទូទៅនៃរបៀបទទួលខុសត្រូវមាននៅខាងក្រោម។ អាន IX.ខ. របៀបនៃការទទួលខុសត្រូវ –១. ផ្នែកទំនួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្ម។

3656 សំណុំរឿង០០២ ឯកសារ D97/15/9 សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ លើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៤៩។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥១១។ សំណុំរឿង០០២ ឯកសារ E100/6 សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ២២។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង០០២/០១, កថាខណ្ឌ៦៩០។

រួម គឺជាទម្រង់មួយនៃការទទួលខុសត្រូវស្មើនឹងអំពើប្រល័យពូជសាសន៍[3657]។ ជាការពិត ជនជាប់ចោទមួយចំនួននៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា ត្រូវបានផ្តន្ទាទោសពីបទប្រល័យពូជសាសន៍យោងតាមទម្រង់មូលដ្ឋាន គឺសហឧក្រិដ្ឋកម្មរួម ទម្រង់ទី ១[3658]។

## ២. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

913. មាត្រា ៥ នៃច្បាប់ អ.វ.ត.ក ផ្តល់យុត្តាធិការឲ្យ អ.វ.ត.ក លើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងរយៈកាលនៃយុត្តាធិការ ពេលវេលានៃ អ.វ.ត.ក[3659]។ បទល្មើសជាក់លាក់រួមបញ្ចូល ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ជាទាសករ ការដាក់ពន្ធនាគារ ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា និងអំពើអមនុស្សធម៌ដទៃទៀត។ ធាតុផ្សំនៃបទល្មើសនីមួយៗនៃបទល្មើសទាំងនេះត្រូវបានពិភាក្សាដូចខាងក្រោម។

### លក្ខខណ្ឌតម្រូវទូទៅ

914. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ត្រូវបានបែងចែកដោយលក្ខខណ្ឌតម្រូវដែលថា ឧក្រិដ្ឋកម្មទាំងនេះត្រូវប្រព្រឹត្ត "ជាផ្នែកមួយនៃការវាយប្រហារជាទូទៅ ឬជាលក្ខណៈប្រព័ន្ធ សំដៅលើប្រជាជនស៊ីវិលដោយមូលហេតុជាតិ នយោបាយ ពូជសាសន៍ ឬសាសនា"[3660]។ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពុំ

---

3657 Tadić, សាលដីកា កថាខណ្ឌ១៨៨។ សេចក្តីសម្រេចសហឧក្រិដ្ឋកម្មរួមអំពើប្រល័យពូជសាសន៍របស់ Rwamakuba, កថាខណ្ឌ៣១។

3658 អានឧទាហរណ៍ Karadžić, សាលក្រម កថាខណ្ឌ៥៨៣១។ Karemera& Ngirumpatse, សាលក្រម កថាខណ្ឌ ១៦១៦-១៦១៧, ១៦២៣, ១៦២៨, ១៦៣៤, ១៦៣៩, ១៦៤៤, ១៦៤៨, ១៦៥៣, ១៦៥៧-១៦៥៨។

3659 សំណុំរឿង០០១ ឯកសារ F28 សាលដីការបស់ ឌុច, កថាខណ្ឌ១០១-១០៤។ សំណុំរឿង០០២ ឯកសារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ១៣៣។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង០០២/០១, កថាខណ្ឌ១៧៦។ សំណុំរឿង០០១ ឯកសារ E188 សាលក្រមរបស់ ឌុច, កថាខណ្ឌ២៨៣-២៨៦។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ១២៩៩, ១៣០៦, ១៣១៣។

3660 ច្បាប់ អ.វ.ត.ក, មាត្រា៥។ សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ១០៦។

តម្រូវឲ្យមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធ ឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្ម ប្រឆាំងសន្តិភាពឡើយ[3661]។ ធាតុផ្សំនីមួយៗនៃលក្ខខណ្ឌតម្រូវ*ទូទៅ* ត្រូវបានបង្ហាញតាមលំដាប់លំដោយដូចខាងក្រោម។

## ការវាយប្រហារ

915. "ការវាយប្រហារ" គឺជាទង្វើពាក់ព័ន្ធការប្រព្រឹត្តិអំពើហិង្សា ឬការធ្វើបាបប្រជាជនស៊ីវិល ដោយរួមបញ្ចូលអំពើដែលឆ្លុះបញ្ចាំងតាមរយៈបទល្មើសជាមូលដ្ឋានក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក[3662]។ អំពើដែលជាការវាយប្រហារ ពុំចាំបាច់ជាអំពើដែលអាចផ្តន្ទាទោសបាន ក្នុងប្រភេទជាឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិ និងមិនកំហិតត្រឹមការប្រើប្រាស់កម្លាំងប្រដាប់អាវុធឡើយ[3663]។ លើសពីនេះ "ការវាយប្រហារ" លើប្រជាជនស៊ីវិល គឺជាទស្សនាទានដាច់ដោយឡែកមួយពីជម្លោះប្រដាប់អាវុធ។ ប្រសិនបើមានជម្លោះប្រដាប់អាវុធ ការវាយប្រហារអាចកើតមានមុន ឬបន្តតាមរយៈការជម្លោះនោះ ដោយមិនចាំបាច់ជាផ្នែកមួយនៃជម្លោះប្រដាប់អាវុធឡើយ[3664]។

---

[3661] សំណុំរឿង០០២ ឯកសារ F36 សំណុំរឿង០០២/០១សាលក្រមបណ្តឹងឧទ្ធរណ៍, កថាខណ្ឌ៧១១-៧២១។ ឯកសារ D87/2/1.7/1/1/7 សេចក្តីសម្រេច នៃអង្គបុរេជំនុំជម្រះស្តីពីសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទាងជាមួយនឹងជម្លោះប្រដាប់អាវុធ។ សំណុំរឿង០០២ ឯកសារ E95/8 សេចក្តីសម្រេច នៃអង្គជំនុំជម្រះសាលាដំបូងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ឯកសារ D87/2/1.7/1 សេចក្តីសម្រេច នៃ ក.ស.ច.ស ស្តីពីដីកាសម្រេចលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ។

[3662] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ២៩៨។ សំណុំរឿង០០២ ឯកសារ E313 សវនាកាសំណុំរឿង០០២/០១, កថាខណ្ឌ១៧៨។ Kordić&Čerkez, សាលដីកា កថាខណ្ឌ៦៦៦។ Kunarac, សាលដីកា កថាខណ្ឌ ៨៦។ Nahimana, សាលដីកា កថាខណ្ឌ៩១៦-៩១៨។ Taylor, សាលក្រម កថាខណ្ឌ៥០៦។

[3663] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ២៩៨។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង០០២/០១, កថាខណ្ឌ១៧៨។ Nahimana, សាលដីកា កថាខណ្ឌ៩១៦, ៩១៨។ Kordić&Čerkez, សាលដីកា កថាខណ្ឌ៦៦៦។ Taylor, សាលក្រម កថាខណ្ឌ៥០៦។

[3664] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ២៩៩។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង០០២/០១, កថាខណ្ឌ១៧៨។ Kunarac, សាលដីកា កថាខណ្ឌ៨៦។ Tadić, សាលដីកា កថាខណ្ឌ២៥១។ Sesay, សាលក្រម កថាខណ្ឌ៧៧។

## លក្ខណៈរាលដាល ឬលក្ខណៈជាប្រព័ន្ធ

916. ការវាយប្រហារត្រូវតែមានលក្ខណៈរាលដាល *ឬ* ជាលក្ខណៈប្រព័ន្ធ។ មិនថាលក្ខណៈមួយណាក្នុងលក្ខណៈទាំងពីរនេះទេ គឺវាគ្រប់គ្រាន់ហើយ[3665]។ ពាក្យ "លក្ខណៈរាលដាល" សំដៅទៅរក "លក្ខណៈជាទ្រង់ទ្រាយធំនៃការវាយប្រហារ និងចំនួនជនរងគ្រោះ"[3666] និងត្រូវបានបញ្ជាក់ដោយ "អានុភាពត្រួតនៃសើរីនៃអំពើអមនុស្សធម៌ ឬអានុភាពទោលនៃអំពើអមនុស្សធម៌ដែលមានទំហំធំធេង"[3667]។ ពាក្យ "ជាលក្ខណៈប្រព័ន្ធ" ពុំតម្រូវឲ្យការវាយប្រហារមានទ្រង់ទ្រាយធំឡើយ ប៉ុន្តែទាក់ទង "លក្ខខណៈដែលត្រូវបានរៀបចំឲ្យកើតមានអំពើហិង្សា និងលទ្ធភាពដែលថា ការកើតឡើងនេះមិនមែនជាការចៃដន្យនោះទេ"[3668]។ ភាពជាប្រព័ន្ធអាចត្រូវបានបង្ហាញដោយភ័ស្តុតាងនៃ "ការកើតឡើងដដែលៗ ដោយអចៃដន្យនៃអំពើឧក្រិដ្ឋស្រដៀងៗគ្នា"[3669]។

## សំដៅលើប្រជាជនស៊ីវិល

917. ការវាយប្រហារត្រូវតែ "សំដៅលើប្រជាជនស៊ីវិល"។ ចំណុចនេះតម្រូវឲ្យប្រជាជនស៊ីវិលជាគោលដៅចម្បងនៃការវាយប្រហារ ជាជាងគ្រាន់តែជាជនរងគ្រោះដោយចៃដន្យ[3670]។

---

3665 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣០០។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង០០២/០១, កថាខណ្ឌ១៧៩។ Kunarac, សាលដីកា កថាខណ្ឌ៩៣។

3666 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣០០។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង០០២/០១, កថាខណ្ឌ១៧៩។ Kordić&Čerkez, សាលដីកា កថាខណ្ឌ៩៤។ Nahimana, សាលដីកា កថាខណ្ឌ៩២០។ Taylor, សាលក្រម កថាខណ្ឌ៥១១។

3667 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣០០។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង០០២/០១, កថាខណ្ឌ១៧៩។ Blagojević& Jokić, សាលក្រម កថាខណ្ឌ៥៤៥។

3668 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣០០។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង០០២/០១, កថាខណ្ឌ១៧៩។ Kordić&Čerkez, សាលដីកា កថាខណ្ឌ៩៤។ Nahimana, សាលដីកា កថាខណ្ឌ៩២០។ Sesay, សាលក្រម កថាខណ្ឌ៧៨។

3669 សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង០០២/០១, កថាខណ្ឌ១៧៩។ Kordić&Čerkez, សាលដីកា កថាខណ្ឌ៩៤។

3670 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣០៥, ៣០៨។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង០០២/០១, កថាខណ្ឌ១៨២។ Kunarac, សាលដីកា កថាខណ្ឌ៩១។ Taylor, សាលក្រម កថាខណ្ឌ៥០៧។

918. សញ្ញាណនៃ "ជនស៊ីវិល" សម្រាប់គោលបំណងនៃធាតុផ្សំនេះ សំដៅទៅរកបុគ្គលទាំងអស់ដែលពុំមែនជាសមាជិកនៃកម្លាំងប្រដាប់អាវុធសត្រូវ ដែលបានចូលរួមយ៉ាងសកម្មក្នុងអរិភាព និង ហេតុដូច្នេះរួមបញ្ចូលបុគ្គលនានា ដូចជាសមាជិកកងកម្លាំងប្រដាប់អាវុធ ដែលបានទម្លាក់អាវុធ និងមនុស្សទាំងឡាយដែលត្រូវបានដាក់ជា *យុទ្ធជនបាត់បង់សមត្ថភាពប្រយុទ្ធ* ដោយជំងឺ របួស ការឃុំឃាំង ឬមូលហេតុដទៃទៀត[3671]។ ដូចដែលបានកត់សម្គាល់ដោយអង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង *Blaskic* "ស្ថានភាពជាក់ស្តែងរបស់ជនរងគ្រោះ នៅពេលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត ជាជាងឋានៈរបស់គាត់ត្រូវតែយកមកពិចារណា ក្នុងការសម្រេចអំពីឋានៈរបស់គាត់ជាជនស៊ីវិល"[3672]។ នៅពេលដែលច្បាប់សង្គ្រាមទទួលស្គាល់ភាពស្របច្បាប់នៃការដាក់សត្រូវរបស់នរណាម្នាក់ជាគោលដៅក្នុងជម្លោះណាមួយ វាមានភាពសមហេតុផលដែលថា ការសម្លាប់ដោយស្របច្បាប់ទៅលើយុទ្ធជនសត្រូវដែលពុំត្រូវបានចាត់ទុកជា *យុទ្ធជនបាត់បង់សមត្ថភាពប្រយុទ្ធ* ត្រូវបានផាត់ចេញពីវិសាលភាពនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ក្នុងកាលៈទេសៈទាំងអស់ដទៃទៀត អ្នកដែលទទួលបានការការពារ គួរត្រូវបានចាត់ទុកជា "ជនស៊ីវិល" សម្រាប់គោលបំណងនៃមាត្រា ៥។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាមិនឯកភាពជាមួយយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង និង អ.ជ.ត.ក ដែលបានសម្រេចថា "ជនស៊ីវិល" គួរត្រូវបានកំណត់និយមន័យដើម្បីមិនរាប់បញ្ចូលទាហាន *យុទ្ធជនបាត់បង់សមត្ថភាពប្រយុទ្ធ* ឡើយ[3673]។ ពាក្យ "អ្នកណាក៏ដោយ" ធានាថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពុំត្រូវបានរឹតត្បិត ក្នុងការអនុវត្តតែទៅលើក្រុមជនស៊ីវិលជាក់លាក់ណាមួយឡើយ ដែលត្រូវបានបែងចែកដោយសញ្ជាតិ ជាតិពន្ធុ ឬកត្តាដទៃទៀត[3674]។

---

3671 Akayesu, សាលក្រម កថាខណ្ឌ៥៨២។ Bisengimana, សាលក្រម កថាខណ្ឌ៤៨។ Tadić, សាលក្រម កថាខណ្ឌ ៦៣៩។ Limaj, សាលក្រម កថាខណ្ឌ១៨៦។ Blaškić, សាលក្រម កថាខណ្ឌ២១៤។ Kordić&Čerkez, សាលដីកា កថាខណ្ឌ៤២១។

3672 Blaškić, សាលក្រម កថាខណ្ឌ២១៤។

3673 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង០០២/០១, កថាខណ្ឌ៧៣៨។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣០៤។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង០០២/០១, កថាខណ្ឌ១៨៥-១៨៦។

3674 សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង០០២/០១, កថាខណ្ឌ១៨៧។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣១២។ Vasiljević, សាលក្រម កថាខណ្ឌ៣៣។ Semanza, សាលក្រម កថាខណ្ឌ ៣៣០។

919. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចរួមបញ្ចូលការវាយប្រហាររបស់រដ្ឋមួយទៅលើប្រជាជនរបស់ខ្លួន[3675]។ ចំណុចនេះរួមបញ្ចូលកម្លាំងប្រដាប់អាវុធរបស់រដ្ឋ ឬអង្គការ ដែលជាជនស៊ីវិលសម្រាប់គោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3676]។ ជំហរនេះស្របជាមួយការវិវត្តន៍ មុនសង្គ្រាមលោកលើកទីពីរនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3677] យុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរទាំងអស់[3678] លិខិតុបករណ៍អន្តរជាតិមុនឆ្នាំ ១៩៧៥ ដែលពាក់ព័ន្ធជាមួយឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3679] និងនិយាមសិទ្ធិមនុស្សអន្តរជាតិមុនឆ្នាំ ១៩៧៥ ដែលការពារសិទ្ធិជាសារវន្ត ដូចគ្នាជា

---

[3675] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣១២។ សំណុំរឿង០០២ ឯកសារ E313 សាលក្រម សំណុំរឿង០០២/០១, កថាខណ្ឌ១៨៧។ Mrkšić, សាលក្រម កថាខណ្ឌ៤៤១។ Kunarac, សាលក្រម កថាខណ្ឌ ៤២៣។

[3676] ឯកសារ D191/18 សេចក្តីសម្រេចចិត្ត ICIJ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់របប ឬរដ្ឋនោះ ។ សហព្រះរាជអាជ្ញាបានប្រកាន់យកនូវជំហរដែលគាត់បានកំណត់នៅក្នុងការដាក់ឯកសារថ្មីៗអំពីបញ្ហានេះ៖ ឯកសារ D191/1 សារណាទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់របប ឬរដ្ឋនោះ ។

[3677] តាំងពីការចាប់ផ្តើមរបស់ខ្លួន CAH មានគោលបំណងការពារសិទ្ធិមនុស្សមិនថាជាតិសាសន៍អ្វី ទោះនៅទីកន្លែងណាក៏ដោយ នោះរាប់បញ្ចូលទាំងកងទ័ពផងដែរ ប្រឆាំងនឹងការរីករាលដាល នៃអំពើឃោរឃៅរបស់ប្រព័ន្ធរដ្ឋាភិបាល ឬអង្គការចាត់តាំងនានា។ នៅឆ្នាំ១៩១៩របាយការណ៍របស់គណៈកម្មាធិការស្តីពីទំនួលខុសត្រូវរបស់អាឡឺម៉ង់ និងសម្ព័ន្ធមិត្តនឹងឧក្រិដ្ឋកម្មដែលខ្លួនបានប្រព្រឹត្តក្នុងអំឡុងសង្គ្រាមលោកលើកទី១។ គណៈកម្មាធិការបានរៀបចំប្រភេទនៃឧក្រិដ្ឋកម្មអន្តរជាតិដែល "ប្រឆាំងច្បាប់មនុស្សជាតិ" (អានឧទាហរណ៍១៩១៩របាយការណ៍គណៈកម្មាធិការ, ទំព័រ១១៣, ១១៥) ដែលអាចប្រើប្រាស់ប្រឆាំងនឹងការវាយប្រហាររបស់ទួគីទៅនឹងជាតិសាសន៍របស់ខ្លួន ជាពិសេសការវាយប្រហារទៅលើជនជាតិអាមេនីនៅលើទឹកដីរបស់ខ្លួន។ ក្នុងការរៀបចំសេចក្តីសន្និដ្ឋានទាំងនោះ គណៈកម្មាធិការពឹងផ្អែកទៅលើភស្តុតាងដែលទួរគីបានកំណត់គោលដៅទៅលើជនជាតិអាមេនី ក្នុងជួរកងទ័ព Ottoman ដោយដកអាវុធកងទ័ពសាសន៍អាមេនីទាំងនោះ បញ្ជូនពួកគេទៅធ្វើការធ្ងន់ធ្ងរនៅក្នុងកងពលតូចដែលគេរៀបចំ ហើយក្រោយមកពួកគេគឺជាកម្មវត្ថុក្នុងការប្រហារជីវិត។អាន១៩១៩របាយការណ៍គណៈកម្មាធិការ, ទំព័រ១១២-១១៣និងឧបសម្ព័ន្ធ I, ទំព័រ៣០, យោងទៅលើរបាយការណ៍របស់គណៈកម្មាធិការអង់គ្លេស ក្រោមលោក Viscount Bryce ស្តីពីការប្រព្រឹត្តទៅលើជនជាតិអាមេនីក្នុងអាណាចក្រ Ottoman, ជាពិសេស "សេចក្តីសង្ខេបប្រវត្តិសាស្ត្រ អាមេនី មកដល់បច្ចុប្បន្ន ដោយរួមបញ្ចូលទាំងឆ្នាំ១៩១៥ - ផ្នែក VI: ការនិរទេស នៃឆ្នាំ១៩១៥៖ នីតិវិធី", កថាខណ្ឌ៣, ៤, ៧។

[3678] ឯកសារ D191/18 សេចក្តីសម្រេចចិត្ត ICIJ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់របប ឬរដ្ឋនោះ, កថាខណ្ឌ៣៥-៤៣, KH ERN 01426588-89។ ឯកសារ D191/1 សារណាទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់របប ឬរដ្ឋនោះ, កថាខណ្ឌ៨, KH ERN 01242000-01។

[3679] ឯកសារ D191/18 សេចក្តីសម្រេចចិត្ត ICIJ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់របប ឬរដ្ឋនោះ, កថាខណ្ឌ៤៤-៤៥, KH ERN 01426593-94។ ឯកសារ D191/1 សារណាទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់របប ឬរដ្ឋនោះ, កថាខណ្ឌ៩, KH ERN 01242001។

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3680] ដែលអនុវត្តទៅលើមនុស្សទាំងអស់របស់រដ្ឋ ដោយមិនគិតអំពីមុខរបររបស់ពួកគាត់[3681]។ លទ្ធផលនៃការអនុវត្តបែបនេះគឺភាពសមហេតុផលដែលខ្វះលក្ខណៈប្រាកដប្រជា។ ក្នុងករណីដែលជនរងគ្រោះជាកម្លាំងប្រដាប់អាវុធរបស់ចារី លក្ខណសម្បត្តិជាយុទ្ធជនរបស់ពួកគាត់គឺពុំពាក់ព័ន្ធទាល់តែសោះ។ និយមន័យនៃច្បាប់មនុស្សធម៌អន្តរជាតិអំពី "យុទ្ធជន" និង "ជនស៊ីវិល" ត្រូវបានសរសេរ ដើម្បីកំណត់អំពីជម្លោះប្រដាប់អាវុធ ទោះជាជម្លោះប្រដាប់អាវុធអន្តរជាតិ ឬមិនមែនអន្តរជាតិក៏ដោយ រវាងកម្លាំងប្រឆាំងគ្នា ដើម្បីបង្កើតសិទ្ធិនិងភារកិច្ចរបស់ពួកគាត់ចំពោះគ្នាទៅវិញទៅមក ដើម្បីកំណត់ថាតើបុគ្គលណាខ្លះអាចត្រូវបានដាក់ជាគោលដៅដោយស្របច្បាប់ និងដែលត្រូវតែទទួលបានការការពារ។ ក្នុងករណីដែលចារី និងជនរងគ្រោះមិនបានចូលរួមក្នុងជម្លោះប្រដាប់អាវុធជាមួយគ្នា ទោះជាវាកើតឡើង ឬមិនកើតឡើងក្នុងបរិបទនៃ

---

[3680] សិទ្ធិរស់រាន៖ ICCPR, មាត្រា៦(១)។ ECHR, មាត្រា២។ UDHR, មាត្រា៣។ សិទ្ធិជៀសផុតពីការធ្វើទារុណកម្ម៖ ICCPR, មាត្រា៧។ UDHR, មាត្រា៥(២)។ ECHR, មាត្រា៣។ សិទ្ធិជៀសផុតពីអំពើឃោរឃៅ, អំពើអមនុស្សធម៌ ឬអំពើប្រមាថ៖ UDHR, មាត្រា៥។ ECHR, មាត្រា៣។ ICCPR, មាត្រា១០។ សេរីភាពក្នុងការរៀបការជាមួយមនុស្សដែលខ្លួនជ្រើសរើស៖ UDHR, មាត្រា១៦។ ICCPR, មាត្រា២៣(៣)។ សេរីភាពជៀសផុតពីការធ្វើពលកម្មដោយបង្ខំ៖ ICCPR, មាត្រា៨(៣)។ ECHR, មាត្រា៤។ សេរីភាពជៀសផុតពីអំពើទាសភាព៖ ICCPR, មាត្រា៨(១)។ UDHR, មាត្រា៤។ ECHR, មាត្រា៤។ សេរីភាពជៀសផុតពីការចាប់ឃុំខ្លួនដោយបំពាន៖ UDHR, មាត្រា៩, ១០។ ICCPR, មាត្រា៩, ១៤។ UDHR, មាត្រា៣។ ECHR, មាត្រា៥, ៧។ សេរីភាពក្នុងការគិត បញ្ចេញសម្បជញ្ញៈ និងជំនឿសាសនា៖ ICCPR, មាត្រា១៨, ២៧។ UDHR, មាត្រា១៨។ ECHR, មាត្រា៩។ សេរីភាពជៀសផុតពីការរើសអើង៖ ICCPR, មាត្រា២៦។ UDHR, មាត្រា២, ៧។ ECHR, មាត្រា១៤។ ICEAFRD។

[3681] អនុលោមតាមបុព្វកថារបស់ UDHR (អំណះអំណាងទី១) ចែងថា៖["ទទួលស្គាល់នូវសេចក្តីថ្លៃថ្នូរសិទ្ធិស្មើភាពគ្នានិងសិទ្ធិមិនអាចកាត់ផ្តាច់បាន នៃមូលដ្ឋានគ្រឹះរបស់មនុស្សស្តីពីសេរីភាពយុត្តិធម៌និងសន្តិភាពនៅក្នុងពិភពលោក" (ដោយបញ្ជាក់បន្ថែម)], មាត្រា២ ["បុគ្គលគ្រប់រូបមានសិទ្ធិនិងសេរីភាពទាំងអស់ដែលមានចែងនៅក្នុងសេចក្តីប្រកាសនេះដោយមិនរើសអើងពូជសាសន៍ពណ៌សម្បុរ ភេទ ភាសាសាសនា នយោបាយឬទស្សនៈ សញ្ជាតិ ឬប្រភពដើមនៃសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពផ្សេងទៀតឡើយ។" (ដោយបញ្ជាក់បន្ថែម)]។ អនុលោមតាមបុព្វកថា ICCPR (អំណះអំណាងទី១), មាត្រា២។ បុព្វកថារបស់ ICEAFRD (អំណះអំណាងទី៣) ចែងថា៖ ["មនុស្សទាំងអស់មានសិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់ហើយមានសិទ្ធិទទួលបានការការពារស្មើគ្នាដោយច្បាប់ប្រឆាំងនឹងការរើសអើង"]។ ECHR, មាត្រា១, ១៤។ អាន សាលក្រម Engel, កថាខណ្ឌ៥៤ ["អនុសញ្ញានេះអនុវត្តជាគោលការណ៍មិនសម្រាប់តែជនស៊ីវិលប៉ុណ្ណោះទេ វាក៏ត្រូវគេអនុវត្តសម្រាប់ សមាជិកនៃកងកម្លាំងប្រដាប់អាវុធផងដែរ"]។ សាលក្រម Grigoriades, កថាខណ្ឌ៤៥ ["មាត្រា១០មិនគ្រាន់តែអនុវត្តនៅតែក្នុងបន្ទាយកងទ័ពប៉ុណ្ណោះទេ។ វាក៏ត្រូវគេអនុវត្តលើកងកម្លាំងប្រដាប់អាវុធទាំងឡាយ និងបុគ្គលដទៃទៀតនៅក្នុងយុត្តាធិការរបស់រដ្ឋដែលទទួលបានកិច្ចសន្យានោះផងដែរ"]។

ជម្លោះប្រដាប់អាវុធក៏ដោយ ដោយជាយន្តការផ្លាស់ប្តូរន័យរបស់ពាក្យ "យុទ្ធជន" និង "ជនស៊ីវិល" ដូចនឹងន័យដែលត្រូវបានកំណត់និយមន័យក្នុងច្បាប់មនុស្សធម៌អន្តរជាតិ ទៅក្នុងច្បាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺមិនសមស្របសោះឡើយ។ លើសពីនេះ វិធីសាស្ត្រនេះនឹងបង្កើតលទ្ធផលមិនសមទំនងនៃការអនុញ្ញាតឱ្យរដ្ឋាភិបាល ឬអង្គការមួយប្រព្រឹត្តអំពើឃោរឃៅជាទ្រង់ទ្រាយធំដោយនិទណ្ឌភាព តាមរយៈការកេណ្ឌអ្នកទាំងឡាយដែលស្ថិតក្នុងចំណោមមនុស្ស ដែលខ្លួនកំពុងដាក់ជាគោលដៅទៅក្នុងកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន។ វាក៏នឹងមានន័យថា នគរបាលស៊ីវិលប្រដាប់អាវុធនឹងទទួលបានការការពារ ចំណែកទាហានដែលគ្មានអាវុធនឹងមិនទទួលបានការការពារ។

920. គេមិនចាំបាច់ដើម្បីបង្ហាញថា ប្រជាជនទាំងអស់នៃតំបន់ភូមិសាស្ត្រពាក់ព័ន្ធ ស្ថិតក្រោមការវាយប្រហារឡើយ។ "ប្រជាជនស៊ីវិល" ក៏អាចរួមបញ្ចូលទាំងជនមិនមែនស៊ីវិលផងដែរ ដោយមិនបាត់បង់លក្ខណៈជាជនស៊ីវិលរបស់ខ្លួន ល្គឹកណាប្រជាជនជាជនស៊ីវិលមានចំនួនធំធេងជាង[3682]។

921. ក្នុងករណីដែលមានការបង្ហាញថា ការវាយប្រហារមានលក្ខណៈរាលដាល ឬជាលក្ខណៈប្រព័ន្ធទៅលើប្រជាជនស៊ីវិលបានកើតឡើង វាគ្មានភាពចាំបាច់ដើម្បីបង្ហាញថា ជនរងគ្រោះម្នាក់ៗនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជា "ជនស៊ីវិល" ឡើយ[3683]។ ទាហាន *ដែលបាត់បង់សមត្ថភាពប្រយុទ្ធ* ក៏អាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ[3684]។

---

[3682] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៧៣៨, ៧៤០។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ១៨៣។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣០៥-៣០៦។ Milošević (Dragomir), សាលដីកា កថាខណ្ឌ៥០-៥១, ៥៨។ Blaškić, សាលដីកា កថាខណ្ឌ១១៣។ Mrkšić &Šljivančanin, សាលដីកា កថាខណ្ឌ៣១។ Taylor, សាលក្រម កថាខណ្ឌ ៥០៧។

[3683] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៧៤០។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣១១។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង០០២/០១, កថាខណ្ឌ១៨៧, ១៩៤។ Popović, សាលដីកា កថាខណ្ឌ៥៦៩។ Martić, សាលដីកា កថាខណ្ឌ៣០៧-៣១៤។ Mrkšić &Šljivančanin, សាលដីកា កថាខណ្ឌ២៨-២៩, ៣២-៣៣។ Tolimir, សាលដីកា កថាខណ្ឌ១៤១-១៤៣។ Taylor, សាលក្រម កថាខណ្ឌ៥០៧។

[3684] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣១១។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង០០២/០១, កថាខណ្ឌ១៨៧, ១៩៤។ Mrkšić& Šljivančanin, សាលដីកា កថាខណ្ឌ២៨-២៩។ Martić, សាលដីកា កថាខណ្ឌ៣១១, ៣១៣-៣១៤។

## ការរឹតត្បិតត្បិតនៃយុត្តាធិការ

922. មាត្រា ៥ នៃច្បាប់ អ.វ.ត.ក តម្រូវថា ការវាយប្រហារទៅលើប្រជាជនស៊ីវិលត្រូវផ្អែកលើមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា[3685]។ ការតម្រូវនេះគឺជាការតម្រូវផ្នែកយុត្តាធិការដែលបង្រួមវិសាលភាពនៃយុត្តាធិការរបស់ អ.វ.ត.ក លើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅពេលប្រៀបធៀបជាមួយច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលមានជាធរមាននៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[3686]។ នៅពេលការវាយប្រហារទូលំទូលាយត្រូវតែប្រព្រឹត្ត ដោយមូលហេតុមួយក្នុងចំណោមមូលហេតុទាំងនេះ ពុំមានលក្ខខណ្ឌតម្រូវដែលថា វាត្រូវតែប្រព្រឹត្តដោយមូលហេតុរើសអើងឡើយ[3687]។ តាមពិត លើកលែងតែក្នុងករណីនៃការធ្វើទុក្ខបុកម្នេញ ចេតនារើសអើងពុំត្រូវបានតម្រូវដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិជាធាតុផ្សំគតិយុត្តិ សម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ[3688]។

---

3685 ច្បាប់ អ.វ.ត.ក, មាត្រា៥។

3686 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៧៤៤-៧៤៥។ សំណុំរឿង ០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ ៣១៣-៣១៤។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង០០២/០១, កថាខណ្ឌ១៨៨។ ថ្វីត្បិតតែការប្រើប្រាស់ពាក្យពេចន៍មានភាពខុសគ្នាក្តី, មាត្រា៣នៃលក្ខន្តិកៈ ICTRផ្តល់ជូននូវតម្រូវការស្រដៀងគ្នាដែលត្រូវបានកាត់ក្តីប្រកបដោយតម្រូវការផ្នែកយុត្តាធិការ និងមិនមែនជាតម្រូវការមួយដែលតម្រូវដោយ CIL: Akayesu, សាលដីកា កថាខណ្ឌ៤៦៤-៤៦៥។ ទោះបីជា ICTR សំអាងលើមូលដ្ឋាន “រើសអើង”, តុលាការកំពូលបានចាត់ទុកថាខ្លួនមិនត្រូវបានចងភ្ជាប់នូវតម្រូវការយុត្តាធិការដែលកំណត់ដោយ ICTR ទៅនឹងតម្រូវការយុត្តាធិការរបស់ខ្លួនឡើយ។ អានសំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៧៤៨។

3687 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៧៤៥, ៧៤៨។

3688 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៧៤៦។ សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ២៣៨។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣១៣-៣១៤។ ឯកសារ E313 សាលក្រមសំណុំរឿង០០២/០១, កថាខណ្ឌ១៨៨។ Tadić, សាលដីកា កថាខណ្ឌ៣០៥។ Akayesu, សាលដីកា កថាខណ្ឌ៤៦១, ៤៦៤-៤៦៦។ លក្ខន្តិកៈ ICC, មាត្រា៧(១), ជាពិសេសមាត្រា៧(១)(ជ) ពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញ។

## ទំនាក់ទំនងរវាងអំពើរបស់ចារី និងការវាយប្រហារ

923. អំពើរបស់ចារីត្រូវតែជាផ្នែកមួយនៃការវាយប្រហារ។ ទំនាក់ទំនងដែលត្រូវបានតម្រូវរវាងអំពើរបស់ចារី និងការវាយប្រហារ មានធាតុផ្សំពីរ។ ការប្រព្រឹត្តិអំពើដែលតាមលក្ខណៈ ឬផលវិបាករបស់វា គឺជាផ្នែកមួយនៃការវាយប្រហារ[3689] ផ្គួបជាមួយការដឹងឮរបស់ចារីដែលថាមានការវាយប្រហារទៅលើប្រជាជនស៊ីវិល និងដែលថាអំពើរបស់គាត់ជាផ្នែកមួយនៃការវាយប្រហារនោះ[3690]។

924. ទាក់ទងធាតុផ្សំទីមួយ អំពើពុំចាំបាច់ត្រូវបានប្រព្រឹត្តក្នុងការវាយប្រហារ ដើម្បីត្រូវបានភ្ជាប់ឲ្យបានគ្រប់គ្រាន់ទៅនឹងការវាយប្រហារឡើយ។ អំពើដែលត្រូវបានប្រព្រឹត្ត មុនឬក្រោយការវាយប្រហារ ឬនៅឆ្ងាយពីការវាយប្រហារ នៅតែអាចត្រូវបានចាត់ទុកជាផ្នែកមួយនៃការវាយប្រហារ ប្រសិនបើវាមានទំនាក់ទំនងគ្រប់គ្រាន់។ ប៉ុន្តែ ឧក្រិដ្ឋកម្មនេះមិនមែនជាអំពើដាច់ដោយឡែកនោះទេ។ ឧក្រិដ្ឋកម្មមួយនឹងត្រូវបានចាត់ទុកជាអំពើដាច់ដោយឡែក នៅពេលវាត្រូវបានដកចេញឆ្ងាយពីការវាយប្រហារនោះ ដែលគេមិនអាចនិយាយដោយសមហេតុផលថាជាផ្នែកមួយនៃការវាយប្រហារឡើយ បន្ទាប់ពីបានពិចារណាអំពីបរិបទ និងកាលៈទេសៈដែលអំពើនោះត្រូវបានប្រព្រឹត្ត[3691]។ អំពើរបស់ជនជាប់ចោទ - សូម្បីតែនៅពេលពួកគាត់ពុំមែនជាចារីផ្ទាល់ក៏ដោយ - ត្រូវតែជាផ្នែកមួយនៃការវាយប្រហារ[3692]។

---

3689 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៧៥២-៧៥៣។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣១៨។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ១៩០។ Kunarac, សាលដីកា កថាខណ្ឌ៨៥, ៩៩។ Martić, សាលដីកា កថាខណ្ឌ៣១៦។

3690 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៧៥២។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣១៩។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ១៩១។ Kunarac, សាលដីកា កថាខណ្ឌ៨៥, ៩៩។ Taylor, សាលក្រម កថាខណ្ឌ៥១៣, ៥១៥។

3691 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣១៨។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ១៩០។ Kunarac, សាលដីកា កថាខណ្ឌ១០០។ Mrkšić& Šljivančanin, សាលដីកា កថាខណ្ឌ៤១។ Semanza, សាលក្រម កថាខណ្ឌ៣២៦។

3692 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៧៥៤។

925. សម្រាប់ធាតុផ្សំទីពីរ ការដឹងឮសេចក្ដីលម្អិតនៃការវាយប្រហារ ពុំត្រូវបានតម្រូវឡើយ[3693]។ មានភាពគ្រប់គ្រាន់ដែលថា ចារីដឹងអំពីបរិបទទូទៅដែលអំពើរបស់គាត់កើតឡើង[3694]។ ចេតនារបស់ចារីគឺមិនមានភាពពាក់ព័ន្ធ[3695] ហើយវាមិនចាំបាច់ដើម្បីឱ្យចារីមានគោលបំណង ឬគោលដៅ ពីក្រោយការវាយប្រហារនោះឡើយ[3696]។ វាក៏មិនពាក់ព័ន្ធផងដែរ ថាតើចារីមានចេតនាឱ្យអំពើរបស់គាត់សំដៅទៅលើប្រជាជនដែលត្រូវបានដាក់ជាគោលដៅ ឬត្រឹមតែទៅលើជនរងគ្រោះរបស់គាត់[3697]។

## **បទល្មើសជាក់លាក់**

## <u>ការធ្វើមនុស្សឃាត</u>

926. ការធ្វើមនុស្សឃាត ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិមកទល់ឆ្នាំ ១៩៧៥[3698]។ លើសពីនេះ មានភាពប្រមើលឃើញ និងភាពអាចដឹងបានចំពោះ **មាស មុត** ដែលថាគាត់អាចត្រូវបានផ្តន្ទាទោស ពីបទមនុស្សឃាតក្នុងប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3699]។

---

[3693] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣១៩។ សំណុំរឿង០០២ ឯកសារ E313 សាលក្រម សំណុំរឿង ០០២/០១, កថាខណ្ឌ១៩១។ Kunarac, សាលដីកា កថាខណ្ឌ១០២។ Taylor, សាលក្រម កថាខណ្ឌ ៥១៣។

[3694] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣១៩។ Limaj, សាលក្រម កថាខណ្ឌ១៩០។ Taylor, សាលក្រម កថាខណ្ឌ៥១៣។

[3695] Kordić &Čerkez, សាលដីកា កថាខណ្ឌ៩៩។ Tadić, សាលដីកា កថាខណ្ឌ២៤៨, ២៥២។

[3696] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣១៩។ សំណុំរឿង០០២ ឯកសារ E313 សាលក្រម សំណុំរឿង ០០២/០១, កថាខណ្ឌ១៩១។ Kunarac, សាលដីកា កថាខណ្ឌ១០៣។ Sesay, សាលក្រម កថាខណ្ឌ៩០។

[3697] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣១៩។ Kunarac, សាលដីកា កថាខណ្ឌ១០៣។

[3698] អានសំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤១១, និងសម្រង់ភ្ជាប់។ សំណុំរឿង ០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៣១។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣១៤, លេខជើងទំព័រ៥១៨៦។ អំពើមនុស្សឃាតជាបទល្មើសឧក្រិដ្ឋនៅក្រោមច្បាប់កម្ពុជា នៅឆ្នាំ១៩៧៥,ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦, មាត្រា៥០១, ៥០៣-៥០៨។

[3699] អានសំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤១១។ សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៧៦៥។

927. *ធាតុផ្សំសត្យានុម័ត* នៃអំពើមនុស្សឃាតដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវការភ័ស្តុតាងនៃធាតុផ្សំពីរ៖ (១) ការស្លាប់របស់ជនរងគ្រោះ និង (២) ការស្លាប់បង្កឡើងដោយអំពើសកម្ម ឬអំពើអកម្មរបស់ចារី[3700]។ សាកសពរបស់ជនរងគ្រោះពុំត្រូវបានតម្រូវជាភ័ស្តុតាងដើម្បីបង្ហាញអំពីការស្លាប់ឡើយ[3701]។ ទាក់ទងលក្ខខណ្ឌតម្រូវហេតុនិងផល ការបញ្ជាក់ថាការស្លាប់របស់ជនរងគ្រោះ "ត្រូវបានបង្ក" ដោយអំពើសកម្ម ឬអំពើអកម្មរបស់ចារី ពុំមានន័យថា វាចាំបាច់ត្រូវតែជាមូលហេតុ តែមួយគត់នៃការស្លាប់ឡើយ។ មានភាពគ្រប់គ្រាន់ដែលថា ទង្វើរបស់ចារី បានរួមចំណែកយ៉ាងច្រើនដល់ការស្លាប់របស់ជននោះ[3702]។ ទាំងអង្គហេតុនៃការស្លាប់របស់ជនរងគ្រោះ និង ធាតុផ្សំហេតុនិងផល អាចត្រូវបានសន្និដ្ឋានពីកាលៈទេសៈនានានៃករណីនោះ ល្គឹកណាមានការបង្ហាញថាការសន្និដ្ឋានដ៏សមហេតុផលតែមួយគត់គឺថា ជនរងគ្រោះស្លាប់ដោយសារអំពើសកម្ម ឬអំពើអកម្មរបស់ចារី[3703]។ ការផ្តន្ទាទោសពីបទមនុស្សឃាតពុំត្រូវបានហាមឃាត់ ដោយសារការគ្មានលទ្ធភាពដើម្បីបង្ហាញឲ្យបានត្រឹមត្រូវអំពីចំនួនមនុស្សស្លាប់សរុប ឬដើម្បីកំណត់អត្តសញ្ញាណ តាម

---

[3700] សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤១២។ សំណុំរឿង០០១ ឯកសារ-E188 សាលក្រម ឌុច, កថាខណ្ឌ៣៣១។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣៧៤។ Milošević (Dragomir), សាលដីកា កថាខណ្ឌ១០៨។ Taylor, សាលក្រម កថាខណ្ឌ៤១២។ ធាតុផ្សំនៃអំពើឧក្រិដ្ឋរបស់ ICC, មាត្រា៧(១)(ក), ធាតុផ្សំ១។ Bemba, សាលក្រម កថាខណ្ឌ៨៧។

[3701] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៤២០។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤១៣។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៣២។ Lukić& Lukić, សាលដីកា កថាខណ្ឌ១៤៩, ២០៨, ២៤៩, ៣១៦។ Bemba, សាលក្រម កថាខណ្ឌ៨៨។

[3702] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៣១។ Milutinović, សាលក្រម (ភាគ ១), កថាខណ្ឌ១៣៧។ Čelebići, សាលក្រម កថាខណ្ឌ៤២៤, លេខជើងទំព័រ៤៣៥។ Taylor, សាលក្រម កថាខណ្ឌ៤១៣។

[3703] សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤១៣។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៣២។ សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៤២០។ Šainović, សាលដីកា កថាខណ្ឌ៥៤៥។ Đorđević, សាលដីកា កថាខណ្ឌ៧៦៣។ Bemba, សាលក្រម កថាខណ្ឌ៨៨។កាលៈទេសៈដែលមរណភាពអាចត្រូវបានគេយកមកពិចារណា មានដូចខាងក្រោម៖ (i) ឧប្បត្តិហេតុនៃការធ្វើបាបដោយផ្ទាល់ទៅលើជនរងគ្រោះ។ (ii) បែបផែននៃការធ្វើបាបនិងការបាត់ខ្លួនរបស់បុគ្គលផ្សេងទៀត។ (iii) បរិយាកាសទូទៅគឺគ្មានច្បាប់នៅទីកន្លែងដែលអំពើរងការចោទប្រកាន់បានប្រព្រឹត្តនៅទីនោះ។ (iv) មនុស្សម្នាក់បានបាត់ខ្លួនក្នុងរយៈពេលយូរ។ និង (v) ជាការពិតជនរងគ្រោះមិនអាចទាក់ទងទៅមនុស្សដទៃទៀតដែលគេមានបំណងទាក់ទងដូចជាសមាជិកគ្រួសារជាដើម។ អានសំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៣២។ Krnojelac, សាលក្រម កថាខណ្ឌ៣២៧។ Brima, សាលក្រម កថាខណ្ឌ៦៨៩។

ករណីនីមួយៗ របស់ចារីផ្ទាល់ និងជនរងគ្រោះរបស់ពួកគាត់[3704]។ ការធ្វើអត្តឃាតរបស់ជនណាម្នាក់ជាការធ្វើមនុស្សឃាតទៅលើជននោះ ក្នុងករណីដែលអំពើសកម្ម ឬអំពើអកម្មរបស់ចារី "បានជំរុញចិត្តជនរងគ្រោះឱ្យប្រព្រឹត្តអំពើ ដែលញ៉ាំងទៅរកការស្លាប់របស់ជនរងគ្រោះ"[3705]។

928. ការសម្លាប់ដោយគ្មានដំណើរការច្បាប់ ឬមិនស្របជាមួយការធានាអំពីដំណើរការត្រឹមត្រូវ ជាអំពើមនុស្សឃាត ពុំមែនជាទោសប្រហារជីវិតឡើយ[3706]។ សិទ្ធិក្នុងការមិនត្រូវបានដកហូតតាមអំពើចិត្តនូវជីវិតរបស់នរណាម្នាក់ ពុំអាចត្រូវបានប្រមាថក្នុងកាលៈទេសៈណាក៏ដោយ ដោយរួមបញ្ចូលទាំងគ្រោះអាសន្នរបស់ជាតិផង[3707] ហើយជីវិតមិនអាចត្រូវបានបំផ្លាញ រហូតដល់កម្រិតអំពើប្រល័យពូជសាសន៍ឡើយ[3708]។

---

3704 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៤២០សម្រង់ Stakić, សាលក្រម កថាខណ្ឌ២០១។ អានសំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៤២១។

3705 Krnojelac, សាលក្រម កថាខណ្ឌ៣២៩។

3706 ICCPR, មាត្រា៦(២) ["ចំពោះប្រទេសដែលមិនទាន់បានលុបចោលនូវទោសប្រហារជីវិតការផ្តន្ទាទោសប្រហារជីវិតអាចត្រូវបានដាក់សម្រាប់តែឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតអនុលោមតាមច្បាប់ជាធរមាននៅពេលដែលប្រព្រឹត្តបទល្មើសហើយមិនផ្ទុយពីបទប្បញ្ញត្តិនៃអនុសញ្ញាបច្ចុប្បន្ន និង[អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍]។ ការផ្តន្ទាទោសនេះអាចអនុវត្តបានលុះត្រាតែមានការវិនិច្ឆ័យចុងក្រោយដោយតុលាការមានសមត្ថកិច្ច។ (ដោយបញ្ជាក់បន្ថែម)]។គណៈកម្មាធិការសិទ្ធិមនុស្សបានបញ្ជាក់ថាការប្រហារជីវិតធ្វើឡើងដោយរំលោភលើកិច្ចធានានៃការជំនុំជម្រះដោយយុត្តិធម៌ដែលមាននៅក្នុងនឹងរំលោភលើ ICCPR, មាត្រា៦(២)។ អាន Mbenge តទល់នឹង Zaire, កថាខណ្ឌ១៧ ["ការខកខានមិនបានគោរពរបស់រដ្ឋភាគីទៅនឹងតម្រូវការដែលពាក់ព័ន្ធនៃមាត្រា១៤(៣) នាំទៅដល់ការសន្និដ្ឋានថាការកាត់ទោសប្រហារជីវិតដែលត្រូវបានប្រកាសប្រឆាំងនឹង [Mbenge] ផ្ទុយទៅនឹងបញ្ញត្តិនៃកតិកាសញ្ញាហើយ។ ដូច្នេះគេចាត់ទុកថាវាជាការរំលោភលើមាត្រា៦ (២)"]។ ECHR, មាត្រា២(១) ["សិទ្ធិរស់រានមានជីវិតរបស់មនុស្សគ្រប់រូបត្រូវបានការពារដោយច្បាប់។ ពុំមាននរណាម្នាក់ត្រូវគេដកហូតសិទ្ធិរស់រានរបស់ខ្លួនដោយចេតនាក្នុងការអនុវត្តច្បាប់ប្រហារជីវិតតាមប្រព័ន្ធតុលាការបន្ទាប់ពីគេកាត់ទោសគាត់ក្នុងសំណុំរឿងឧក្រិដ្ឋកម្មដែលការពិន័យនេះត្រូវបានផ្តល់ដោយច្បាប់ក៏ដោយ" (ដោយបញ្ជាក់បន្ថែម)]។ ACHR, មាត្រា៤(២)។ GCs ភាពទូទៅនៃមាត្រា៣ ["អំពើទាំងឡាយខាងក្រោមនេះនឹងត្រូវហាមឃាត់ទោះនៅក្នុងកាលៈទេសៈ និងទីកន្លែងណាក៏ដោយ [...] ការធានាបាននូវការវិនិច្ឆ័យប្រកបដោយគតិយុត្តិជារឿងសំខាន់ដែលទទួលស្គាល់ដោយសង្គមអរិយធម៍នោះខិតខំប្រឹងប្រែងធ្វើយ៉ាងណាថាការអនុវត្តទោសប្រហារជីវិតត្រូវធ្វើក្រោយពីការជំនុំជម្រះនិងប្រកាសរបស់តុលាការ។" (ដោយបញ្ជាក់បន្ថែម)]។

3707 ICCPR, មាត្រា៦(១) ["មនុស្សគ្រប់រូបមានសិទ្ធិរស់រានមានជីវិត។ សិទ្ធិនេះត្រូវបានការពារដោយច្បាប់។ បុគ្គលគ្រប់រូបមិនអាចត្រូវបានគេដកហូតតាមអំពើចិត្តឡើយ"], ៤(២) [" ពុំមានដិប្បញ្ញត្តិពី [មាត្រា ៦] ... អាចត្រូវបានបង្កើត

929. ចំពោះ *ធាតុផ្សំអត្តនោម័តិ* ពុំមានលក្ខខណ្ឌតម្រូវដែលថា ការសម្លាប់ត្រូវតែជាការសម្លាប់ដោយគិតទុកជាមុនឡើយ[3709]។ ធាតុផ្សំអត្តនោម័តិរួមបញ្ចូលចេតនាផ្ទាល់ក្នុងការសម្លាប់ព្រមទាំងការសម្លាប់ *ដោយការប្រមើលឃើញជាមុន (dolus eventualis)*[3710]។

## ការសម្លាប់រង្គាល

930. ការសម្លាប់រង្គាលត្រូវបានទទួលស្គាល់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមកទល់ឆ្នាំ១៩៧៥[3711]។ វាមានភាពអាចប្រមើលឃើញ និងអាចដឹងបានចំពោះ **មាស មុត** ដែលថា គាត់អាចត្រូវបានផ្តន្ទាទោសពីបទសម្លាប់រង្គាលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3712]។

---

ឡើងក្រោមប្បញ្ញត្តិនេះ [អនុញ្ញាតឱ្យដិប្បញ្ញត្តិមានកំណត់ចំពោះកាតព្វកិច្ច ECHR មួយចំនួននៅ"ពេលមានអាសន្នជាសាធារណៈដែលគំរាមកំហែងដល់អាយុជីវិតនិងអត្ថិភាពរបស់ជាតិដែលប្រកាសឡើងជាផ្លូវការនោះ"]"]។។ ECHR, មាត្រា២(១), ១៥(២) ["ពុំមានដិប្បញ្ញត្តិមាត្រា២ ទេ, លើកលែងតែការស្លាប់ដែលកើតឡើងដោយសារអំពើស្របច្បាប់នៃសង្គ្រាម"]។ ACHR, មាត្រា៤ និងមាត្រា២៧(២) ["បញ្ញត្តិដែលលើកឡើងខាងលើដែលលើកឡើងពី [កាតព្វិច្ចនៃដិប្បញ្ញត្តិក្នុងកាលៈទេសៈសង្គ្រាម មហន្តរាយដល់សាធារណៈ ឬឧប្បត្តិហេតុណាមួយដែលគម្រាមកំហែងឯករាជ្យភាពឬសន្តិសុខរបស់រដ្ឋភាគី] មិនអនុញ្ញាតឱ្យព្យួរ [...] មាត្រា៤ (សិទ្ធិរស់រានមានជីវិត)"]។ សហព្រះរាជអាជ្ញាកត់សម្គាល់ថាស្ថានភាពបន្ទាន់សាធារណៈ គ្រប់កាលៈទេសៈទាំងអស់ត្រូវតែប្រកាសជាផ្លូវការដោយរដ្ឋាភិបាលនៃរដ្ឋភាគី។ អាន ICCPR, មាត្រា៤(១)។ CCPR យោបល់ទូទៅ លេខ២៩ក្នុងមាត្រា៤, កថាខណ្ឌ២ ["មុននឹងរដ្ឋភាគីមួយសំអាងលើមាត្រា៤ខ្លួនត្រូវបំពេញលក្ខខណ្ឌចាំបាច់ចំនួនពីរ៖ ស្ថានភាពត្រូវតែជាបញ្ហាបន្ទាន់សាធារណៈដែលគំរាមកំហែងដល់អាយុជីវិតរបស់ជាតិហើយរដ្ឋភាគីត្រូវតែប្រកាសជាផ្លូវការនូវភាពអាសន្ននោះ។ តម្រូវការមួយទៀតនោះគឺត្រូវតែថែរក្សាគោលការណ៍នីត្យានុកូលភាពនិងវិធានច្បាប់នៅពេលដែលចាំបាច់ប្រើប្រាស់បំផុត"]។

[3708] ICCPRមាត្រា៦(២)-៦(៣)។ការហាមឃាត់អំពើប្រល័យពូជសាសន៍ គឺជាបទដ្ឋាននៃ jus cogens ដែលមិនអនុញ្ញាតិឱ្យមានដិប្បញ្ញត្តិនោះឡើយ។អានឧទាហរណ៍ DRC តទល់នឹង Rwanda, កថាខណ្ឌ៦៤ [ពិភាក្សាគ្នាអំពីបទដ្ឋានដែលមានចរិតលក្ខណៈនៃបទដ្ឋានរបស់ច្បាប់អន្តរជាតិទូទៅ (jus cogens), "ដែលពិតជាទាក់ទងនឹងសំណុំរឿងនេះដែលពាក់ព័ន្ធនឹងការហាមឃាត់នៃអំពើប្រល័យពូជសាសន៍"]។

[3709] ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤១២។ Đorđević, សាលដីកា កថាខណ្ឌ៥៥១-៥៥២។ Akayesu, សាលក្រម កថាខណ្ឌ៥៨៨។ Brima, សាលក្រម កថាខណ្ឌ៦៩០។

[3710] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៤០៩-៤១០។ អានបន្ថែម សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤១២។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៣៣។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣៧៩។ Kvočka, សាលដីកា កថាខណ្ឌ២៥៩, ២៦១។ Milošević (Dragomir), សាលដីកា កថាខណ្ឌ១០៨។ Semanza, សាលដីកា កថាខណ្ឌ៣២០។ Brima, សាលក្រម កថាខណ្ឌ៦៨៨, ៦៩០។

931. ឧក្រិដ្ឋកម្មសម្លាប់រង្គាល គឺជាការសម្លាប់ទ្រង់ទ្រាយធំ[3713]។ *ធាតុផ្សំអត្តនោម័តិ* នៃការសម្លាប់រង្គាលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានអំពើសកម្ម ឬអំពើអកម្ម ឬអំពើទាំងពីរផ្សំបញ្ចូលគ្នា ដែលរួមចំណែកដល់ការស្លាប់មនុស្សជាទ្រង់ទ្រាយធំ[3714]។ តួនាទីរបស់ចារីអាចជាតួនាទីពីចម្ងាយ ឬប្រយោល[3715] និងអាចរួមបញ្ចូលទាំងការបង្កើតលក្ខខណ្ឌរស់នៅដែលសំដៅទៅរកការបំផ្លាញប្រជាជនមួយផ្នែក ដូចជាការដកហូតចំណីអាហារ ឬថ្នាំសង្កូវ[3716]។ គ្មានលក្ខខណ្ឌតម្រូវដែលថា ជនរងគ្រោះ "ត្រូវតែបានទទួលរងលក្ខខណ្ឌនានា *ដែលនាំទៅរកសេចក្តីស្លាប់ ដោយជៀសមិនរួច*"[3717] នោះទេ។

932. ការផ្តន្ទាទោសពីបទសម្លាប់រង្គាលគ្រាន់តែតម្រូវឱ្យបំពេញលក្ខខណ្ឌឱ្យហួសពីវិមតិសង្ស័យ អំពីការកើតឡើងនៃការសម្លាប់ជាទ្រង់ទ្រាយធំ[3718]។ វាគ្មានលក្ខខណ្ឌតម្រូវដែលថា ការសម្លាប់

---

[3711] សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤១៥ និងសម្រង់។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៣៤។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ១៣១៤, លេខជើងទំព័រ៥១៨៧។

[3712] អានសំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤១៥។

[3713] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥២៥។ Seromba, សាលដីកា កថាខណ្ឌ១៨៩។ Ntakirutimana, សាលដីកា កថាខណ្ឌ៥១៦។

[3714] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៣៤។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤១៦។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣៨២។ Seromba, សាលដីកា កថាខណ្ឌ១៨៩។ ធាតុផ្សំនៃបទល្មើសឧក្រិដ្ឋកម្ម របស់ ICC, មាត្រា៧(១)(ខ), ធាតុផ្សំ១-២។

[3715] សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤១៦។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៣៥។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣៨២។ Seromba, សាលដីកា កថាខណ្ឌ១៨៩។ Ndindabahizi, សាលដីកា លេខជើងទំព័រ២៦៨។ Brđanin, សាលក្រម កថាខណ្ឌ៣៨៩។

[3716] សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤១៦។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៣៥។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣៨២។ Brđanin, សាលក្រម កថាខណ្ឌ៣៨៩។ Krstić, សាលក្រម កថាខណ្ឌ៤៩៨, ៥០៣។ លក្ខន្តិកៈ ICC, មាត្រា៧(២)(ខ)។ ធាតុផ្សំនៃបទល្មើសឧក្រិដ្ឋកម្ម របស់ ICC, មាត្រា៧(១)(ខ), ធាតុផ្សំ១។

[3717] សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤២១-៤២៤។

[3718] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៤២១។ Ntakirutimana, សាលដីកា កថាខណ្ឌ៥២១។ Gacumbitsi, សាលដីកា កថាខណ្ឌ៨៩។ Sesay, សាលក្រម កថាខណ្ឌ១៣២។

នីមួយៗ ត្រូវតែបង្ហាញឲ្យហួសពីវិមតិសង្ស័យនោះទេ ដរាបណាមានភស្តុតាងដែលបង្ហាញឲ្យហួសពីវិមតិសង្ស័យថា ការសម្លាប់ជាទ្រង់ទ្រាយធំបានកើតឡើង[3719]។ ការកំណត់អត្តសញ្ញាណ ការពិពណ៌នា ឬការរៀបចំជាក់លាក់តាមឈ្មោះរបស់ជនរងគ្រោះ ពុំមែនជាធាតុផ្សំមួយនៃបទល្មើសសម្លាប់រង្គាលឡើយ[3720]។ ដូចដែលអង្គជំនុំជម្រះតុលាការឧទ្ធរណ៍ក្នុងសំណុំរឿង *Ntakirutimana* បានបង្ហាញ "ការតម្រូវឲ្យកំណត់អត្តសញ្ញាណជនរងគ្រោះទាំងនោះឲ្យបានទូលំទូលាយជាងនេះនឹង [...] បង្កើនបន្ទុកបង្ហាញភស្តុតាង ក្នុងកម្រិតមួយដែលវាបន្ទុចបង្អាក់ការផ្តន្ទាទោសមួយចំនួនធំពីបទសម្លាប់រង្គាល"។ ការកំណត់អំពីចំនួនមនុស្សស្លាប់ជាក់លាក់ក៏មិនតម្រូវដែរ[3721]។

933. គ្មានចំនួនជនរងគ្រោះអប្បបរមា ដែលត្រូវបានតម្រូវដើម្បីបំពេញលក្ខខណ្ឌតម្រូវដែលថាវិសាលភាពនៃការស្លាប់ត្រូវតែមានទ្រង់ទ្រាយ "ធំ" ឡើយ[3722]។ ទោះបីជាទូទៅការសម្លាប់រង្គាលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានរកឃើញថា វាទាក់ទងការសម្លាប់មនុស្សរាប់ពាន់នាក់ក៏ដោយ[3723]

---

[3719] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៤២១។ អានបន្ថែម សាលក្រមយុត្តិធម៌, ទំព័រ១០៤៦, ១០៥៣-១០៥៤, ១០៧៩ [[ជនជាប់ចោទរកឃើញថាមានទោសអនុលោមតាមCAH ដោយរួមបញ្ចូលទាំងការសម្លាប់រង្គាលទោះបីជាពុំមានការរកឃើញឲ្យហួសពីវិមតិសង្ស័យណាមួយនៃការសម្លាប់ដោយខុសច្បាប់ចំពោះបុគ្គលម្នាក់ៗ]។ Gacumbitsi, សាលដីកា កថាខណ្ឌ៨៩ [រកឃើញថាមិនចាំបាច់បង្ហាញពីការស្លាប់របស់បុគ្គលដែលមានឈ្មោះនៅក្នុងដីកាបញ្ជូនរឿងដើម្បីធានាការផ្តន្ទាទោសចំពោះការសម្លាប់រង្គាលនោះ ដែលជាវិមតិសង្ស័យដែលថា"ជនភៀសខ្លួនជាច្រើនត្រូវបានសម្លាប់"]។ Kajelijeli, សាលក្រម កថាខណ្ឌ៨៨៦។

[3720] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៤២១។ Ntakirutimana, សាលដីកា កថាខណ្ឌ៥១៨, ៥២១បានលើកឡើងដោយមានការអនុម័តនៅក្នុង Stakić, សាលដីកា លេខជើងទំព័រ ៥៥២។ Sesay, សាលក្រម កថាខណ្ឌ១៣២។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ ១៣៨២។

[3721] Rukundo, សាលដីកា កថាខណ្ឌ១៨៧, ១៨៩។ Stakić, សាលក្រម កថាខណ្ឌ៦៥៤-៦៥៥។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣៨២។

[3722] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៥១។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤១៦។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៣៦។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣៨៣។ Lukić& Lukić, សាលដីកា កថាខណ្ឌ៥៣៧។ Ndindabahizi, សាលដីកា កថាខណ្ឌ១៣៥។

[3723] Lukić& Lukić, សាលដីកា កថាខណ្ឌ៥៣៧។ Krstić, សាលក្រម កថាខណ្ឌ៧៩, ៨៤, ៤២៦, ៥០៥។ Ntakirutimana, សាលដីកា កថាខណ្ឌ៥២១។

ការសម្លាប់មនុស្សចំនួនតិចតួចក៏ត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ[3724]។ ជនរងគ្រោះមួយចំនួនធំអាចជាស្ថានទម្ងន់ទាក់ទងការផ្តន្ទាទោស ប្រសិនបើវិសាលភាពនៃការសម្លាប់លើសពីលក្ខខណ្ឌតម្រូវសម្រាប់ការសម្លាប់រង្គាល[3725]។ អត្ថិភាពនៃ "សហាមនុស្សឃាតទ្រង់ទ្រាយធំ" ពុំមែនជាធាតុផ្សំមួយនៃការសម្លាប់រង្គាលឡើយ[3726]។

934. លក្ខខណ្ឌតម្រូវនៃវិសាលភាពត្រូវតែវាយតម្លៃទៅតាមករណីនីមួយៗ ដោយពិចារណាអំពីកាលៈទេសៈដែលការសម្លាប់បានកើតឡើង[3727]។ កត្តាពាក់ព័ន្ធរួមបញ្ចូល *ក្នុងចំណោមកត្តាផ្សេងៗ* ពេលវេលា និងទីកន្លែងសម្លាប់[3728] ការជ្រើសរើសជនរងគ្រោះ និងលក្ខណៈដែលពួកគាត់ត្រូវបានដាក់ជាគោលដៅ[3729] និងថាតើការសម្លាប់ត្រូវបានធ្វើឡើងសំដៅទៅរកក្រុមរួម ជាជាងជនរងគ្រោះ ក្នុងឋានៈរបស់ពួកគាត់ម្នាក់ៗ[3730]។ ប៉ុន្តែគ្មានលក្ខខណ្ឌតម្រូវដែលថាក្រុម ឬ(ផ្នែកមួយនៃ)

---

3724 ឧទាហរណ៍, Lukić& Lukić, សាលដីកា កថាខណ្ឌ៥៤០-៥៤៤, ការសម្លាប់ "មនុស្ស៥៩នាក់" និង "យ៉ាងហោចណាស់មនុស្ស៦០នាក់"គ្រប់គ្រាន់សមល្មមសម្រាប់ចាត់ទុកថាវាជាការសម្លាប់រង្គាល។នៅក្នុងសំណុំរឿង Brđanin, ការសម្លាប់មនុស្សរវាង៦៨ ទៅ៣០០នាក់ "តាមកាលៈទេសៈដែលកើតឡើង [ចាត់ទុកថា] ការសម្លាប់នោះក្នុងបំណងសម្លាប់រង្គាល" (Brđanin, សាលដីកា កថាខណ្ឌ៤៧២)។ ស្រដៀងគ្នានោះដែរ, ICTR បានរកឃើញថាការសម្លាប់មនុស្សប្រហែល៣០-៤០ នាក់គ្រប់គ្រាន់ល្មមអាចកំណត់បានថាជាអំពើសម្លាប់មនុស្សរង្គាល (Setako, សាលក្រម កថាខណ្ឌ៤៨១ (ការរកឃើញនេះត្រូវបានលើកឡើងនៅលើបណ្តឹងឧទ្ធរណ៍, Setako, សាលដីកា កថាខណ្ឌ៣០១))។

3725 Ndindabahizi, សាលដីកា កថាខណ្ឌ១៣៥។

3726 ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥២៧-៥២៨។

3727 សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤១៦។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៣៦។ Lukić& Lukić, សាលដីកា កថាខណ្ឌ៥៣៨។ Sesay, សាលក្រម កថាខណ្ឌ១៣២។

3728 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៥១។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤១៦។ Lukić& Lukić, សាលដីកា កថាខណ្ឌ៥៣៨។

3729 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៥១។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤១៦។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៣៧។ Lukić& Lukić, សាលដីកា កថាខណ្ឌ៥៣៨។ Nahimana, សាលក្រម កថាខណ្ឌ១០៦១។

3730 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៥១។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤១៦។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៣៧។ Lukić& Lukić, សាលដីកា កថាខណ្ឌ៥៣៨។ Stakić, សាលក្រម កថាខណ្ឌ៦៣៩, ៦៥៣។

មនុស្សដែលត្រូវបានសម្លាប់ ត្រូវមានលក្ខណៈដូចគ្នាឡើយ[3731] ឬដែលថាចារីមានចេតនាបំផ្លាញក្រុមមួយ ឬមួយផ្នែកនៃក្រុមមួយ ដែលជនរងគ្រោះស្ថិតនៅ[3732]។ ការរៀបចំឧក្រិដ្ឋកម្មនេះក៏អាចត្រូវបានពិចារណានៅពេលកំណត់អំពី *ធាតុផ្សំអត្តនោម័តិ* នៃការសម្លាប់រង្គាល[3733]។

935. ធាតុផ្សំទំហំនៃបទល្មើសសម្លាប់រង្គាលអាចត្រូវបានបង្ហាញដោយផ្អែកលើមូលដ្ឋានរួម ល្គឹកណាការសម្លាប់ទាំងនោះកើតចេញពីទង្វើតែមួយរបស់ជនជាប់ចោទ[3734] ដូចជាការសម្លាប់ដែលកើតឡើងក្នុងប្រព័ន្ធមន្ទីរសន្តិសុខដែលគ្រប់គ្រងដោយរដ្ឋ។ ក្នុងករណីដែលការសម្លាប់ជាទ្រង់ទ្រាយធំជាលទ្ធផលនៃគោលនយោបាយមួយ ដែលត្រូវបានតាក់តែង និងសម្របសម្រួលពីរដ្ឋាភិបាលកណ្ដាលពីសំណាក់បុគ្គលដដែល ដែលបានមានចេតនាឲ្យមានការសម្លាប់ជាទ្រង់ទ្រាយធំ វានឹងមានភាពមិនសមទំនងក្នុងការសម្រេចថា បុគ្គលទាំងនោះមិនមែនជាអ្នកទទួលខុសត្រូវចំពោះការសម្លាប់រង្គាល ដោយសារការសម្លាប់បានកើតឡើងនៅតាមទីតាំងជាច្រើន។

936. យោងតាម អ.ជ.ត.ក *ធាតុផ្សំសត្យានុម័ត* ផ្សំឡើងដោយចេតនាសម្លាប់មនុស្សជាទ្រង់ទ្រាយធំ ឬបង្កើតស្ថានភាពរស់នៅក្នុងបំណងនាំទៅដល់ការស្លាប់មនុស្សក្នុងចំនួនច្រើន[3735]។ ការដឹងឮអំពីការ

---

[3731] អានសំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥១៩-៥២០, សម្រង់ ILC ១៩៩៦សេចក្ដីព្រាងក្រម (ដោយមានការពន្យល់បន្ថែម), ទំព័រ៤៨។

[3732] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៣៧។ Musema, សាលដីកា កថាខណ្ឌ៣៦៦។ Stakić, សាលក្រម កថាខណ្ឌ៦៣៩។

[3733] Lukić & Lukić, សាលដីកា កថាខណ្ឌ៥៣៨, សម្រង់ Krstić, សាលក្រម កថាខណ្ឌ៥០១។

[3734] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៥២ ["មូលដ្ឋាននៃទំនួលខុសត្រូវរបស់ជនជាប់ចោទត្រូវតែរកឲ្យឃើញដើម្បីឲ្យឃើញថា"អំពើមាននៅក្នុងបទល្មើសគឺតែមួយ"]។

[3735] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥២១-៥២២, ៥២៥, ផ្អែកតាម Krstić, សាលក្រម កថាខណ្ឌ៥០៣។ Ntakirutimana, សាលដីកា កថាខណ្ឌ៥២២។ Gacumbitsi, សាលដីកា កថាខណ្ឌ៨៦។

ស្លាប់មួយចំនួន ពុំត្រូវបានតម្រូវឡើយ[3736]។ ចេតនាសម្លាប់ជនរងគ្រោះក្នុងចំនួនណាមួយ[3737] ឬការដឹងឮអំពី "សហាមនុស្សឃាតទ្រង់ទ្រាយធំ"[3738] ជាធាតុផ្សំនៃការសម្លាប់រង្គាល។

## ការដាក់ជាទាសករ

937. មិនអាចប្រកែកបានឡើយដែលថា ការដាក់ជាទាសករត្រូវបានទទួលស្គាល់ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅឆ្នាំ ១៩៧៥[3739]។ លើសពីនេះ មានភាពអាចប្រមើលឃើញ និងអាចដឹងបានចំពោះ **មាស មុត** ដែលថា គាត់អាចត្រូវបានផ្តន្ទាទោសពីបទដាក់ជាទាសករជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3740]។

938. ការដាក់ជាទាសករត្រូវបានកំណត់និយមន័យថា ជាការប្រើប្រាស់សិទ្ធិជាម្ចាស់លើបុគ្គលណាម្នាក់[3741]។ សញ្ញាណនៃការដាក់ជាទាសកររួមបញ្ចូល៖ "ការគ្រប់គ្រងការដើរហើររបស់មនុស្ស ការត្រួតត្រាបរិស្ថានរូបរាងកាយ ការត្រួតត្រាផ្លូវចិត្ត វិធានការនានាដែលត្រូវបានអនុវត្តដើម្បីទប់ស្កាត់ ឬទប់ស្កាត់ការរត់គេចខ្លួន ការបង្ខំ ការគំរាមកំហែងអំពីការប្រើប្រាស់កម្លាំង ឬការចាប់បង្ខំ ថិរវេលា ការអះអាងអំពីភាពផ្តាច់មុខ ការដាក់ឱ្យស្ថិតក្រោមការធ្វើបាប ការបំពាន ការត្រួត

---

3736 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥២០។

3737 Stakić, សាលដីកា កថាខណ្ឌ២៦០-២៦១។

3738 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥២៧-៥២៨។ សំណុំរឿង ០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤១៩។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៣៧។ Stakić, សាលដីកា កថាខណ្ឌ២៥៩។

3739 សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ១៣១-១៣២, ១៣៩, ១៤៤, ១៥២, ១៦១-១៦២ និងសម្រង់។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៤២។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣១៤, លេខជើងទំព័រ៥១៨៨។

3740 សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ១៦១-១៦២។

3741 សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ១៥២-១៥៣។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៤២។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣៩២។ Kunarac, សាលដីកា កថាខណ្ឌ១១៦-១១៧។ Sesay, សាលក្រម កថាខណ្ឌ១៩៧-១៩៨។ លក្ខន្តិកៈ ICC, មាត្រា៧(២)(គ)។ ធាតុផ្សំនៃបទល្មើសឧក្រិដ្ឋកម្ម របស់ ICC, មាត្រា៧(១)(គ), ធាតុផ្សំ១។

គ្រាជីវិតផ្លូវភេទ និងការងារពលកម្មដោយបង្ខំ"[3742]។ ធាតុផ្សំនៃការដាក់ជាទាសករអាចត្រូវបានបំពេញដោយមិនចាំបាច់មានភ័ស្តុតាងអំពីការធ្វើបាបបន្ថែមឡើយ[3743]។

939. ក្នុងការពិនិត្យសញ្ញាណទាំងនេះ គេត្រូវតែកំណត់អត្តសញ្ញាណនៃលក្ខណវិនិច្ឆ័យនៃ "ភាពជាម្ចាស់"[3744] នោះគឺ អង្គហេតុដែលបង្ហាញថា ជនរងគ្រោះត្រូវបានធ្លាក់ខ្លួនជាកម្មវត្ថុនៃ "ការកាន់កាប់ជាកម្មសិទ្ធិ" ហើយគាត់អាចត្រូវបានប្រើប្រាស់ (ជាឧទាហរណ៍ សម្រាប់គោលបំណងផ្លូវភេទ ឬគោលបំណងផ្សេងៗ) ត្រូវបានកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច និង/ឬ បោះបង់ចោលនៅទីបំផុត[3745]។ អ្វីដែលមានក្នុងអំណាចជាម្ចាស់ គឺការខិតខំបង្កើនផលប្រយោជន៍ខ្លះតាមរយៈការអនុវត្តអំណាចទាំងនោះ ទោះជាវាមិនមែនជាធាតុផ្សំបន្ថែមនៃឧក្រិដ្ឋកម្មនេះក៏ដោយ[3746]។ ថិរវេលានៃការដាក់ជាទាសករ ពុំមែនជាធាតុផ្សំនៃឧក្រិដ្ឋកម្មនេះឡើយ ប៉ុន្តែថិរវេលាអាចមានភាពពាក់ព័ន្ធក្នុងការកំណត់អំពីប្រភេទនៃទំនាក់ទំនង[3747]។

940. ការងារពលកម្មដោយបង្ខំ ឬដោយមិនស្ម័គ្រចិត្តក៏អាចជាការដាក់ជាទាសករផងដែរ[3748]។ គេត្រូវតែបង្ហាញថា បុគ្គលពាក់ព័ន្ធគ្មានជម្រើសពិតប្រាកដអំពីថាតើពួកគាត់នឹងធ្វើការងារនោះ ឬយ៉ាងណា ដែលជាការសម្រេចជាក់ស្តែងដែលត្រូវធ្វើ ដោយពិចារណាអំពីលក្ខណវិនិច្ឆ័យនៃការដាក់ជា

---

3742 សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ១៥៤។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៤២។ Kunarac, សាលដីកា កថាខណ្ឌ១១៩។ Sesay, សាលក្រម កថាខណ្ឌ១៩៩។

3743 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៤៤។ Kunarac, សាលដីកា កថាខណ្ឌ១២៣។ Sesay, សាលក្រម កថាខណ្ឌ២០៣។

3744 សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ១៥៥-១៥៦។ទោះបីជាសញ្ញាណនៃទាសកម្មស្ថិតនៅក្នុងភាពជាកម្មសិទ្ធិយ៉ាងណាក៏ដោយ ក៏វាមិនទាក់ទងគ្នានឹង"ទាសភាព"ឡើយ៖សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ១៥៥។ Kunarac, សាលដីកា កថាខណ្ឌ១១៧។

3745 សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ១៥៦។

3746 ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ១៥៧-១៥៨។

3747 Kunarac, សាលដីកា កថាខណ្ឌ១២១, ៣៥៦។ Taylor, សាលក្រម កថាខណ្ឌ៤៤៧។

3748 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៤២, ៣៤៤។ Kunarac, សាលដីកា កថាខណ្ឌ១១៩។ Krnojelac, សាលក្រម កថាខណ្ឌ៣៥៩។ Simić, សាលក្រម កថាខណ្ឌ៨៥។ Sesay, សាលក្រម កថាខណ្ឌ១៩៩, ២០២។

ទោសករ ដែលត្រូវបានកំណត់អត្តសញ្ញាណ[3749]។ អវត្តមាននៃបៀវត្សរ៍ ពុំមែនជាធាតុផ្សំនៃការដាក់ជាទាសករឡើយ ប៉ុន្តែអាចជាកត្តាភ័ស្តុតាងពាក់ព័ន្ធក្នុងការសម្រេចថាតើការធ្វើការងារពលកម្ម ត្រូវបានបង្ខំដែរ ឬយ៉ាងណា[3750]។

941. កង្វះការឯកភាពក៏ពុំមែនជាធាតុផ្សំនៃបទល្មើសនៃការដាក់ជាទាសករដែរ ដោយហេតុថា ការដាក់ជាទាសករត្រូវបានសម្គាល់ ដោយការអនុវត្តអំណាចរបស់ចារី ប៉ុន្តែវាអាចពាក់ព័ន្ធជាភ័ស្តុតាង ទៅនឹងការបង្ហាញអំពីការអនុវត្តអំណាចជាម្ចាស់[3751]។ អវត្តមាននៃការឯកភាពអាចត្រូវបានសន្មតក្នុងករណីដែលការសម្តែងការឯកភាព ពុំអាចឱ្យធ្វើទៅបាន[3752] ដូចជានៅពេលដែលជនរងគ្រោះរស់នៅក្នុង "បរិយាកាសនៃការភ័យខ្លាច"[3753]។ ក្នុងកាលៈទេសៈទាំងនេះ កង្វះការបដិសេធ ឬអវត្តមាននៃកង្វះការឯកភាពជាក់ស្តែង និងជាប់ជាប្រចាំ នឹងមិនត្រូវបានបកស្រាយថាជាសញ្ញានៃការព្រមព្រៀងឡើយ[3754]។ មានការសម្រេចថាលក្ខខណ្ឌមនុស្សកកកុញ អនាម័យមិនល្អ កង្វះដំណេក កង្វះចំណីអាហារ ការចាក់សោទ្វារ ការវាយដំជាញឹកញាប់ ការបំពានផ្លូវចិត្ត និងស្ថានភាពរស់នៅបែបព្រៃផ្សៃ បានធ្វើឱ្យអ្នកជាប់ឃុំមិនអាចព្រមព្រៀងធ្វើការងារ និងថាការធ្វើការងារពលកម្មរបស់ពួកគាត់គឺជាការធ្វើដោយបង្ខំ[3755]។

---

[3749] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៤៤។ Krnojelac, សាលដីកា កថាខណ្ឌ១៩៤-១៩៥។ Sesay, សាលក្រម កថាខណ្ឌ២០២។ Taylor, សាលក្រម កថាខណ្ឌ៤៤៨។

[3750] Sesay, សាលដីកា កថាខណ្ឌ១០៨២។ Kunarac, សាលដីកា កថាខណ្ឌ១១៩។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣៩៥។

[3751] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៤៣។ Kunarac, សាលដីកា កថាខណ្ឌ១២០។ Sesay, សាលដីកា កថាខណ្ឌ៧៣៥។ Taylor, សាលក្រម កថាខណ្ឌ៤៤៧។

[3752] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៤៣។ Kunarac, សាលដីកា កថាខណ្ឌ១២០។

[3753] Krnojelac, សាលដីកា កថាខណ្ឌ១៩៥។

[3754] Kunarac, សាលដីកា កថាខណ្ឌ១២០។ Krnojelac, សាលដីកា កថាខណ្ឌ១៩៤-១៩៥។

[3755] Krnojelac, សាលដីកា កថាខណ្ឌ១៩៣-១៩៥។

942. ចំពោះ *ធាតុផ្សំសត្យានុម័ត* គេត្រូវតែបង្ហាញថាចារីបានអនុវត្តដោយចេតនានូវអំណាចណាមួយក្នុងចំណោមអំណាចទាំងឡាយដែលភ្ជាប់ទៅនឹងសិទ្ធិជាម្ចាស់[3756]។

## ការចាប់ដាក់ពន្ធនាគារ

943. ការចាប់ដាក់ពន្ធនាគារត្រូវបានទទួលស្គាល់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ ១៩៧៥[3757]។ លើសពីនេះ វាអាចឲ្យ **មាស មុត** ប្រមើលឃើញ និងអាចដឹងបានថាគាត់អាចត្រូវបានផ្ដន្ទាទោសពីបទចាប់ដាក់ពន្ធនាគារជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3758]។

944. *ធាតុផ្សំអត្ថនោម័តិ* នៃការចាប់ដាក់ពន្ធនាគារ[3759] តម្រូវថា បុគ្គលណាម្នាក់ត្រូវបានដកហូតសេរីភាពរបស់គាត់តាមទំនើងចិត្ត *ពោលគឺ* ដោយគ្មានមូលដ្ឋានគតិយុត្តិសមស្រប និងដោយគ្មានដំណើរការត្រឹមត្រូវតាមច្បាប់[3760]។ ប្រសិនបើច្បាប់ជាតិត្រូវបានយកមកសំអាង បញ្ញត្តិពាក់ព័ន្ធមិនត្រូវ

---

[3756] សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ១៥២-១៥៣។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៤៥។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣៩៥។ Kunarac, សាលដីកា កថាខណ្ឌ១១៦, ១២២។ Taylor, សាលក្រម កថាខណ្ឌ៤៤៦។

[3757] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៤៧។ សំណុំរឿង០០២ ឯកសារ D427/1/30 សេចក្ដីសម្រេចលើដីកាដំណោះស្រាយ អៀង សារី, កថាខណ្ឌ៣១៧-៣២៧, ៣៣២និងសម្រង់ភ្ជាប់។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣១៤, លេខជើងទំព័រ៥១៩០។ Krnojelac, សាលក្រម កថាខណ្ឌ១០៩ និងសម្រង់ភ្ជាប់ជាមួយ។

[3758] សំណុំរឿង០០២ ឯកសារ D427/1/30 សេចក្ដីសម្រេចលើដីកាដំណោះស្រាយ អៀង សារី, កថាខណ្ឌ៣២៨-៣៣២។

[3759] ឈ្មោះបន្ថែមទៀតសម្រាប់ឧក្រិដ្ឋកម្មដែលនឹងត្រូវ "ដាក់ពន្ធនាគារដោយគ្មានដំណើរការត្រឹមត្រូវ" ឬ ICTY អង្គជំនុំជម្រះ Karadžić បានបញ្ជាក់ថា, "ការដាក់ពន្ធនាគារទាំងបំពាន"៖ Karadžić, សាលក្រម កថាខណ្ឌ៥១៩។

[3760] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៤៧-៣៤៨។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៤០៣។ Kordić&Čerkez, សាលដីកា កថាខណ្ឌ១១៦។ Krnojelac, សាលក្រម កថាខណ្ឌ១១៣-១១៥។

រំលោភច្បាប់អន្តរជាតិឡើយ[3761]។ ស្ថានភាពបន្ទាន់មិនអាចធ្វើយុត្តិកម្មដល់ការដាក់ពន្ធនាគារតាមទំនើងចិត្តឡើយ[3762]។

945. ក្នុងការសម្រេចថាតើមូលដ្ឋាន និងនីតិវិធីសម្រាប់ការដកហូតជាបឋមនូវសេរីភាព មានភាពស្របច្បាប់ដែរឬយ៉ាងណា តុលាការអាចពិចារណាអំពីកត្តានានា ដោយរួមបញ្ចូលថាតើ៖ (i) ការចាប់ខ្លួន បានផ្អែកលើដីកាដែលមានសុពលភាពដែរ ឬយ៉ាងណា[3763] (ii) អ្នកជាប់ឃុំឃាំងបានដឹងនៅពេលចាប់ខ្លួនអំពីហេតុផលនៃការចាប់ខ្លួនដែរ ឬយ៉ាងណា[3764] (iii) អ្នកជាប់ឃុំឃាំងបានដឹងទាន់ពេលវេលាអំពីបទចោទ មកលើខ្លួន និង/ឬ ត្រូវបានចោទជាផ្លូវការដែរ ឬយ៉ាងណា[3765] (iv) អ្នកជាប់ឃុំឃាំងត្រូវបានជូនដំណឹងអំពីសិទ្ធិតាមនីតិវិធីរបស់គាត់ដែរ ឬយ៉ាងណា[3766] ដោយរួមបញ្ចូលការ

[3761] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៤៨។ Krnojelac, សាលក្រម កថាខណ្ឌ១១៤។ Ntagerura, សាលក្រម កថាខណ្ឌ៧០២។

[3762] CCPR មតិទូទៅលេខ២៩ចំពោះមាត្រា៤, កថាខណ្ឌ១១ ["គ្រប់កាលៈទេសៈទាំងអស់រដ្ឋភាគីទាំងឡាយមិនអាចសំអាងលើមាត្រាទ៤នៃកតិកាសញ្ញានេះដើម្បីធ្វើជាយុត្តិកម្មសម្រាប់សកម្មភាពរំលោភច្បាប់មនុស្សធម៌ឬបទបញ្ញានានានៃច្បាប់អន្តរជាតិដូចជាការចាប់ចំណាប់ខ្មាំងដែលនេះជាទណ្ឌកម្មរួមលើសេរីភាពតាមអំពើចិត្ត ឬផ្ទុយពីគោលការណ៍គ្រឹះក្នុងការកាត់ទោសដោយយុត្តធម៌ នោះរួមបញ្ចូលទាំងការសន្មតភាពគ្មានទោសពៃរ៍"], ១២ ["ប្រសិនបើវិធានការដែលធ្វើឡើងក្រោមរដ្ឋអំណាចជាមូលដ្ឋានសម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌដោយបុគ្គលទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដោយជនដែលជាប់ពាក់ព័ន្ធក្នុងសកម្មភាពនោះ, មាត្រា៤នៃកតិកាសញ្ញានេះមិនអាចយកមកធ្វើជាយុត្តិកម្មថាក្នុងសភាពការបន្ទាន់មួយរដ្ឋភាគីត្រូវទទួលបានការលើកលែងពីការចោទសួរពីទំនួលខុសត្រូវរបស់ខ្លួនទាក់ទងនឹងទង្វើនោះឡើយ"]។ សាលក្រម Aksoy តទល់នឹង Turkey, កថាខណ្ឌ៦៥-៨៧ [ទោះបីរកឃើញថាសកម្មភាពភេរវកម្មរបស់ក្រុម PKK នៅភាគអាគ្នេយ៍ប្រទេសទួកគី បានបង្ហាញយ៉ាងច្បាស់ក្រឡែតពីការព្រួយបារម្ភក្នុងតំបន់នោះថា ជា "មហន្តរាយសាធារណៈដែលគំរាមកំហែងដល់ជីវិតរបស់ជាតិ" ក៏ដោយក៏ទួកគីមិនមានយុត្តិកម្មក្នុងការឃុំខ្លួនជនសង្ស័យភេរវករនោះក្នុងរយៈពេល១៤ថ្ងៃដោយគ្មានអន្តរាគមន៍ពីតុលាការនោះទេ។ECtHR បានបញ្ជាក់ថាការឃុំខ្លួនដោយគ្មានដំណើរការសមស្រប"មិនមែនជាកាតព្វកិច្ចតម្រូវតាមស្ថានភាព" ត្រូវធ្វើយុត្តិកម្មនោះទេ"]។សូមមើលផងដែរ Nuray Şen តទល់នឹង Turkey [ឈានដល់ការសន្និដ្ឋានដូចគ្នាថាការឃុំឃាំងមានរយៈពេល១១ថ្ងៃជា'ការឃុំឃាំងដោយបំពាន]។

[3763] Ntagerura, សាលក្រម កថាខណ្ឌ៧០២។

[3764] Ntagerura, សាលក្រម កថាខណ្ឌ៧០២។ ICCPR, មាត្រា៩(២)។ ECHR, មាត្រា៥(២)។

[3765] Krnojelac, សាលក្រម កថាខណ្ឌ១២១។ Ntagerura, សាលក្រម កថាខណ្ឌ៧០២។ ICCPR, មាត្រា៩(២)។ ECHR, មាត្រា៥(២), ៦(៣)(ក)។

[3766] Krnojelac, សាលក្រម កថាខណ្ឌ១២១។ Ntagerura, សាលក្រម កថាខណ្ឌ៧០២។

ទទួលបានមេធាវី[3767] និង (v) អ្នកជាប់ឃុំឃាំងត្រូវបាននាំខ្លួនទាន់ពេលវេលាមកចំពោះមុខបុគ្គល ដែលត្រូវបានអនុញ្ញាតដោយច្បាប់ ដើម្បីអនុវត្តអំណាចតុលាការ (និងជននោះជាបុគ្គលឯករាជ្យ និងមិនលម្អៀង)[3768]។ អ្នកជាប់ឃុំមានសិទ្ធិទទួលបានកិច្ចដំណើរការនីតិវិធី ដែលភាពស្របច្បាប់ នៃការឃុំឃាំងរូបគាត់ ត្រូវបានសម្រេចយ៉ាងឆាប់រហ័សដោយតុលាការ និងត្រូវបានដោះលែង ប្រសិនបើការឃុំឃាំងត្រូវបានរកឃើញថាមិនស្របច្បាប់[3769]។ គាត់ក៏ទទួលបានការជំនុំជម្រះដោយយុត្តិធម៌និងជាសាធារណៈនៅក្នុងរយៈពេលសមស្រប ឬទទួលបានការដោះលែង[3770] និងទទួលបានការសន្មតជាមុនថា គ្មានទោសរហូតទាល់តែមានការបង្ហាញអំពីពិរុទ្ធភាព[3771]។ ហេតុដូច្នេះ "ការសង្ស័យ" តែមួយមុខដែលថាជនណាម្នាក់អាចបានជាប់ពាក់ព័ន្ធក្នុងអំពើក្បត់ មិនគ្រប់គ្រាន់ជាមូលដ្ឋានគតិយុត្តិ ដើម្បីធ្វើយុត្តិកម្មការឃុំឃាំងបុគ្គលនានា ដោយគ្មានដំណើរការត្រឹមត្រូវ-ដោយគ្មានការចោទប្រកាន់ ដោយគ្មានការពិនិត្យភ័ស្តុតាង គ្មានមេធាវី និងគ្មានសិទ្ធិទទួលបានការជំនុំជម្រះ ឡើយ។

946. ចំពោះ *ធាតុផ្សំអត្តនោម័តិ* គេត្រូវតែបង្ហាញថាចារីបានមានចេតនាដកហូតតាមទំនើងចិត្តនូវសេរីភាពរបស់បុគ្គលនោះ ឬថាគាត់បានអនុវត្តដោយដឹងយ៉ាងសមស្របថា ទង្វើរបស់គាត់អាចបង្កទៅជាការដកហូតតាមទំនើងចិត្តនូវសេរីភាពរូបរាងកាយ[3772]។

## ទារុណកម្ម

947. បទឧក្រិដ្ឋនៃការធ្វើទារុណកម្ម ត្រូវបានទទួលស្គាល់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅឆ្នាំ ១៩៧៥[3773] និងក៏ជាឧក្រិដ្ឋកម្មក្រោមច្បាប់កម្ពុជានៅពេលនោះផងដែរ[3774]។ វាអាចឲ្យ **មាស មុត**

---

[3767] ECHR, មាត្រា៦(៣)(គ)។

[3768] ICCPR, មាត្រា៩(៣)។ ECHR, មាត្រា៥(៣)-(៤)។ Kulomin តទល់នឹង Hungary, កថាខណ្ឌ១១.៣។

[3769] ICCPR, មាត្រា៩(៤)។ ECHR, មាត្រា៥(៤)។

[3770] ECHR, មាត្រា៥(៣), ៦(១)។ ICCPR, មាត្រា៩(៣)។

[3771] ICCPR, មាត្រា១៤(២)។ ECHR, មាត្រា៦(២)។

[3772] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៥០។ Simić, សាលក្រម កថាខណ្ឌ៦៤។ Krnojelac, សាលក្រម កថាខណ្ឌ១១៥។

[3773] សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ១៨៨, ១៩៦, ២០៥-២០៦។ សំណុំរឿង០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ៣៤២-៣៥១ និងសម្រង់។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣១៤, លេខជើងទំព័រ៥១៩១។

ប្រមើលឃើញ និងអាចដឹងបានថា គាត់អាចត្រូវបានផ្ដន្ទាទោសពីបទធ្វើទារុណកម្មជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3775]។

948. ទាំង អ.ប.ជ និង អ.ជ.ត.ក បានសម្រេចថា និយមន័យ និងធាតុផ្សំនៃទារុណកម្មដែលមានក្នុងសេចក្ដីប្រកាសឆ្នាំ ១៩៧៥ ស្ដីពីទារុណកម្មបានឆ្លុះបញ្ចាំងអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥[3776]។ លើសពីនេះ គិតត្រឹមឆ្នាំ ១៩៧៥ ការហាមឃាត់ទារុណកម្មគឺជានិយាម*អាជ្ញាព្រឹត្តិ*[3777]ដែលការឃ្លាតចាកពីនេះពុំត្រូវបានអនុញ្ញាតទោះស្ថិតក្រោមកាលៈទេសៈណាក៏ដោយ ដោយរួមបញ្ចូលគ្រោះអាសន្នសាធារណៈ ឬក្នុងផលប្រយោជន៍សន្តិសុខជាតិ[3778]។

---

3774 ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦, មាត្រា៥០០។

3775 សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ២១១-២១២។ សំណុំរឿង០០២ ឯកសារ D427/1/30 សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ៣៥២-៣៥៦។

3776 សំណុំរឿង០០២ ឯកសារ D427/1/30 សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ៣៥៥។ សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ១៩៦, ២០៥។

3777 សាលក្រម Belgium តទល់នឹង Senegal, កថាខណ្ឌ៩៩, ដកស្រង់ទាំងស្រុងអំពីសិទ្ធិមនុស្ស និងឧបករណ៍ IHL បញ្ចប់មុន ឆ្នាំ១៩៧៥. អាន UDHR (១៩៤៨), មាត្រា៥។ GC I (១៩៤៩), មាត្រា៣, ១២, ៥០។ GC II (១៩៤៩), មាត្រា៣, ១២, ៥១។ GC III (១៩៤៩), មាត្រា៣, ១៧, ៨៧, ១៣០។ GC IV (១៩៤៩), មាត្រា៣, ៣២, ១៤៧។ ICCPR (១៩៦៦), មាត្រា៧។ សេចក្ដីថ្លែងការណ៍ស្ដីពីការធ្វើទារុណ្ណកម្ម ឆ្នាំ១៩៧៥. សូមអាន ECHR (១៩៥០), មាត្រា៣។ ACHR (១៩៦៩), មាត្រា៥(២)។ Furundžija, សាលក្រម កថាខណ្ឌ១៤៣-១៤៦។

3778 មាត្រា៣នៃសេចក្ដីថ្លែងការណ៍ស្ដីពីការធ្វើទារុណកម្មឆ្នាំ១៩៧៥ បញ្ជាក់យ៉ាងច្បាស់នូវការដកហូតសិទ្ធិពីការហាមឃាត់ការធ្វើទារុណកម្មថា៖“គ្មានរដ្ឋណាមួយអាចអនុញ្ញាតឬអធ្យាស្រ័យចំពោះអំពើឃោរឃៅ អមនុស្សធម៌ ឬការប្រព្រឹត្តថោកទាប ឬទណ្ឌកម្មនានាឡើយ។ កាលៈទេសៈពិសេសដូចជាស្ថានភាពកលយុគ ឬការគំរាមកំហែងនៃសង្គ្រាមអស្ថិរភាពនយោបាយផ្ទៃក្នុងឬបញ្ហាសាធារណៈផ្សេងទៀតមិនអាចធ្វើយុត្តិកម្មសំអាងនៃការធ្វើទារុណកម្មឬទណ្ឌកម្មឃោរឃៅអមនុស្សធម៌ឬអំពើថោកទាប ឬទណ្ឌកម្មនានាឡើយ។” ឧបករណ៍ដទៃទៀតរបស់អន្តរជាតិដែលមានបញ្ចូលការប្រហារជីវិតឥតជំនុំជម្រះ ដូចជាសន្ធិសញ្ញាស្ដីពីការធ្វើទារុណកម្ម ឆ្នាំ១៩៨៤, មាត្រា២(២)។ ICCPR, មាត្រា៧, ៤(២)។ ECHR, មាត្រា៣, ១៥(២)។ ACHR, មាត្រា៥, ២៧(២)។សូមអានផងដែរនូសាលដីកា Ireland តទល់នឹង United Kingdom, កថាខណ្ឌ១៦៣ [“អនុសញ្ញានេះហាមឃាត់ដាច់ខាតមិនឱ្យមានការធ្វើទារុណកម្មនិងអំពើអមនុស្សធម៌ ឬការប្រព្រឹត្តដោយអំពើបន្ទាបបន្ថោក ឬទារុណកម្ម ដោយមិនគិតពីទង្វើរបស់ជនរងគ្រោះនោះឡើយ។ ខុសពីគន្លឹះសំខាន់ៗនានា [...], មាត្រា៣ [...]មិនបានចែងអំពីការលើកលែងហើយក្រោមមាត្រា១៥កថាខណ្ឌ២ [...]មិនមានចែងពីដិប្បញ្ញត្តិសូម្បីតែក្នុងករណីមានគ្រោះអាសន្នជាសាធារណៈដែលគម្រាមកំហែងដល់អាយុជីវិតរបស់ជាតិក៏ដោយ។” (ដោយបញ្ជាក់បន្ថែម)]។ សាលក្រម Ilașcu et al. តទល់នឹង Moldova និង Russia, កថាខណ្ឌ

949. *ធាតុផ្សំសត្យានុម័ត* នៃទារុណកម្មតម្រូវឱ្យមានអំពើសកម្ម ឬអំពើអកម្មដែលបង្កការឈឺចាប់ ឬទុក្ខវេទនាធ្ងន់ធ្ងរ ទោះជាលើរូបរាងកាយក្តី ឬផ្លូវចិត្តក្តី[3779]។ ក្នុងការសម្រេចថាតើអំពើសកម្ម ឬអំពើអកម្មមួយ ជាការឈឺចាប់ ឬទុក្ខវេទនាធ្ងន់ធ្ងរ គេចាំបាច់ត្រូវពិចារណាអំពីកត្តាអត្តនោម័តិ និងសត្យានុម័តទាំងអស់[3780]។ កត្តាសត្យានុម័តរួមបញ្ចូលភាពធ្ងន់ធ្ងរនៃព្យសនកម្មដែលត្រូវបានបង្ក។ លក្ខខណ្ឌអត្តនោម័តិអាចរួមបញ្ចូលអាយុ ភេទ ស្ថានភាពសុខភាពរបស់ជនរងគ្រោះ ឬផលប៉ះពាល់ផ្លូវកាយ ឬផ្លូវចិត្តនៃការប្រព្រឹត្តិទៅលើជនរងគ្រោះ[3781]។ បន្ថែមពីលើនេះ លក្ខណៈ និងបរិបទនៃការបង្កការឈឺចាប់ ការគិតទុកជាមុន និងការដាក់ឱ្យស្ថិតនៅក្រោមការធ្វើបាប ស្ថានភាពផ្លូវកាយនៃជនរងគ្រោះ លក្ខណៈ និងវិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ និងតួនាទីតូចទាបនៃជនរងគ្រោះជាកត្តាពាក់ព័ន្ធទាំងអស់[3782]។ នៅពេលដែលបុគ្គលម្នាក់បានរងការធ្វើបាបអស់ពេលជាយូរ ឬគាត់បានស្ថិតក្រោមទម្រង់ច្រំដែល ឬទម្រង់ផ្សេងៗនៃការធ្វើបាប ភាពធ្ងន់ធ្ងរនៃអំពើទាំងនោះគួរត្រូវបានវាយតម្លៃជារួម[3783]។

---

៩២៩ [“តុលាការបានរម្លឹកឡើងវិញថាមាត្រា៣នៃអនុសញ្ញាចែងពីតម្លៃមូលដ្ឋានគ្រឹះនៃសង្គមប្រជាធិបតេយ្យ។ សូម្បីតែនៅក្នុងកាលៈទេសៈដ៏លំបាកបំផុតដូចជាការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្មនិងឧក្រិដ្ឋកម្មដែលមានអង្គការចាត់តាំង ក៏អនុសញ្ញានេះហាមឃាត់ដាច់ខាតនូវការធ្វើទារុណកម្មនិងអំពើអមនុស្សធម៌ ការប្រព្រឹត្តដោយបន្ថោកបន្ទាប ឬការដាក់ទណ្ឌកម្ម។ ខុសពីគន្លឹះសំខាន់ៗនានានៅក្នុងអនុសញ្ញា និងពិធីសារ លេខ១និងលេខ៤, មាត្រា៣មិនបានចែងបញ្ញត្តិណាមួយដែលលើកលែង និងដិប្បញ្ញត្តិក្នុងការអនុញ្ញាតក្រោមមាត្រា១៥§២នៃអនុសញ្ញា សូម្បីតែក្នុងករណីមានគ្រោះអាសន្នជាសាធារណៈដែលគម្រាមកំហែងកល់អាយុជីវិតរបស់ជាតិក៏ដោយ”]។

[3779] សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឧុច, កថាខណ្ឌ១៩១-១៩២, ១៩៥-១៩៦, ២០១, ២០៥។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៥៣-៣៥៤។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៤០៩។ សេចក្តីថ្លែងការណ៍ស្តីពីទារុណកម្ម ឆ្នាំ១៩៧៥, មាត្រា១។ Kunarac, សាលដីកា កថាខណ្ឌ១៤២-១៤៤, ១៤៩។ Čelebići, សាលក្រម កថាខណ្ឌ៤៦៨។ Ntagerura, សាលក្រម កថាខណ្ឌ៧០៣។ ធាតុផ្សំនៃបទល្មើសឧក្រិដ្ឋកម្ម របស់ ICC, មាត្រា៧(១)(ច), ធាតុផ្សំ១។ សូមអានសន្ធិសញ្ញាស្តីពីការធ្វើទារុណកម្ម ឆ្នាំ១៩៨៤, មាត្រា១។

[3780] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៥៥។ Kvočka, សាលក្រម កថាខណ្ឌ១៤៣។

[3781] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៥៥។ Kvočka, សាលក្រម កថាខណ្ឌ១៤៣។

[3782] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៥៥។ Krnojelac, សាលក្រម កថាខណ្ឌ១៨២។

[3783] Krnojelac, សាលក្រម កថាខណ្ឌ១៨២។

950. គ្មានការកំណត់ប្រភេទនៃអំពើដែលអាចជាទារុណកម្មឱ្យបានសព្វគ្រប់នោះឡើយ[3784]។ ផលវិបាកនៃអំពើសកម្ម ឬអំពើអកម្ម មិនចាំបាច់មានភាពជាក់ស្តែងទៅលើជនរងគ្រោះឡើយ[3785]។ គ្មានលក្ខខណ្ឌអប្បបរមានៃការឈឺចាប់ដែលបង្កឡើងឡើយ[3786] ហើយក៏គ្មានលក្ខខណ្ឌតម្រូវដែលថាព្យសនកម្មត្រូវតែជាព្យសនកម្មអចិន្ត្រៃយ៍នោះដែរ[3787]។

951. អំពើដែលធ្ងន់ធ្ងរគ្រប់គ្រាន់ដើម្បីជាទារុណកម្ម អាចកើតចេញពីស្ថានភាពនានាដែលបានដាក់ទៅលើអ្នកទោស និងបានរួមបានបញ្ចូល ការវាយដំ អំពើហិង្សាផ្លូវភេទ ការបង្អត់ដំណេក អាហារ អនាម័យ និងជំនួយវេជ្ជសាស្ត្រ អស់ពេលជាយូរ ការដាក់ក្នុងភាពស្រពេចស្រពិលជាប់ជាប្រចាំ ការសម្លាប់ដែលត្រូវបានធ្វើត្រាប់តាម និងការគំរាមប្រើទារុណកម្ម ការរំលោភផ្លូវភេទ ឬព្យាបាទ ឬសម្លាប់សាច់ញាតិ[3788]។ ការរស់នៅក្នុងសភាពថប់អារម្មណ៍ និងភាពស្រពេចស្រពិលជាប់ជាប្រចាំ ដែលជាលទ្ធផលនៃការបំពានរូបរាងកាយ និងការបង្ខាំង ជាទុក្ខវេទនាផ្លូវចិត្តដែលស្មើនឹងការធ្វើទារុណកម្ម[3789]។ ស្រដៀងនេះ ការគំរាមកំហែងដែលអាចជឿជាក់បានអំពីការប្រើប្រាស់ទារុណកម្មលើរូបរាងកាយ ការបង្កគ្រោះថ្នាក់ ឬការសម្លាប់ជនរងគ្រោះគឺជាទារុណកម្មផ្លូវចិត្ត[3790]។ លើសពីនេះ បុគ្គលម្នាក់អាចទទួលរងព្យសនកម្មផ្លូវចិត្តធ្ងន់ធ្ងរតាមរយៈការបានឃើញអំពើនានាប្រឆាំងនឹង

---

3784 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៥៥។ Kunarac, សាលដីកា កថាខណ្ឌ១៤៩។

3785 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៥៥។ Kunarac, សាលដីកា កថាខណ្ឌ១៥០។

3786 Kunarac, សាលដីកា កថាខណ្ឌ១៤៩។ Kvočka, សាលក្រម កថាខណ្ឌ១៤៣។ Brđanin, សាលក្រម កថាខណ្ឌ ៤៨៣។

3787 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៥៥។ Kvočka, សាលក្រម កថាខណ្ឌ១៤៨។ Brđanin, សាលក្រម កថាខណ្ឌ៤៨៤។

3788 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៥៥, Čelebići, សាលក្រម កថាខណ្ឌ៤៦៧។ Kvočka, សាលក្រម កថាខណ្ឌ១៥១។ Krnojelac, សាលក្រម កថាខណ្ឌ២៥៥. សូមអានរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីអំពើធ្វើទារុណកម្ម ថ្ងៃទី១៩ ខែកុម្ភៈ ១៩៨៦, UN Doc E/CN.៤/១៩៨៦/១៥, កថាខណ្ឌ១១៩។ សាលដីកា Akkoç តទល់នឹង Turkey, កថាខណ្ឌ១១៦-១១៧។ Maritza Urrutia តទល់នឹង Guatemala, កថាខណ្ឌ៥៨.៦, ៨៥, ៩៤។ សាលដីកា Ilaşcu et al. តទល់នឹង Moldova និង Russia, កថាខណ្ឌ៤៣៥, ៤៤០។

3789 សាលដីកា Hajrulahu កថាខណ្ឌ១០១-១០២។

3790 អានឧទាហរណ៍ Estrella តទល់នឹង Uruguay, កថាខណ្ឌ១.៦, ៨.៣, ១០។ Maritza Urrutia តទល់នឹង Guatemala, កថាខណ្ឌ៥៨.៦, ៨៥, ៩៤។

បុគ្គលដទៃ[3791]។ អំពើមួយចំនួនត្រូវបានចាត់ទុកជាការឈឺចាប់ និងទុក្ខវេទនាធ្ងន់ធ្ងរ ដែលរួមបញ្ចូលការរំលោភផ្លូវភេទ[3792] អំពើហិង្សាផ្លូវភេទ[3793] និងការកាត់ផ្នែកនានានៃរាងកាយ[3794]។

952. ទោះបីក្រោមយុត្តិសាស្ត្រនៃតុលាការ ICTY/ICTR ចារីមិនចាំបាច់បានប្រព្រឹត្តក្នុងតួនាទី ជាផ្លូវការក៏ដោយ[3795] ក៏ អ.ជ.ត.ក បានសម្រេចអំពីនិយមន័យនៃទារុណកម្មដែលត្រូវបានប្រទះឃើញក្នុង សេចក្តីប្រកាសឆ្នាំ ១៩៧៥ ស្តីពីទារុណកម្ម ដោយរួមបញ្ចូលលក្ខខណ្ឌតម្រូវជាមន្ត្រីសាធារណៈ ថា ជាការប្រកាសអំពីច្បាប់ទម្លាប់អន្តរជាតិក្នុងឆ្នាំ ១៩៧៥[3796]។ អនុលោមតាមនិយមន័យនោះ អំពើសកម្ម ឬអំពើអកម្មត្រូវបានតែអនុវត្ត "តាមរយៈការញុះញង់របស់មន្ត្រីសាធារណៈ"[3797]។

---

[3791] Kayishema & Ruzindana, សាលក្រម កថាខណ្ឌ១៥៣។

[3792] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៥៥។ Kunarac, សាលដីកា កថាខណ្ឌ១៥០-១៥១។

[3793] Kunarac, សាលដីកា កថាខណ្ឌ១៥០។

[3794] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៥៥។ Kvočka, សាលក្រម កថាខណ្ឌ១៤៤។

[3795] Kunarac, សាលដីកា កថាខណ្ឌ១៤៨។ Kvočka, សាលដីកា កថាខណ្ឌ២៨៤។ Semanza, សាលដីកា កថាខណ្ឌ ២៤៨, ២៨៦។

[3796] សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ១៩១-១៩២, ១៩៥-១៩៧, ២០៥។ សេចក្តីថ្លែងការណ៍ស្តីពីការធ្វើទារុណ្ណកម្ម ឆ្នាំ១៩៧៥, មាត្រា១។

[3797] បញ្ហានេះមិនពាក់ព័ន្ធទៅនឹងការវិនិច្ឆ័យលើសំណុំរឿងនាពេលបច្ចុប្បន្ននេះទេព្រោះអំពើទារុណកម្មទាំងអស់ដែលរងការចោទប្រកាន់គឺប្រព្រឹត្តដោយមន្ត្រីឬយោធានៃរបបនោះ។ ទោះបីជាយ៉ាងណានេះក៏ដោយចុះ តាមច្បាប់សហព្រះរាជអាជ្ញាបានដាក់ស្នើទៅខណៈដែលសេចក្តីយោងទៅអ្នកធ្វើទារុណកម្មដែលជាមន្ត្រីរដ្ឋាភិបាលមួយឆ្លុះបញ្ចាំង CIL ដែលជាកាតព្វកិច្ចរបស់រដ្ឋភាគីត្រូវយកចិត្តទុកដាក់ICTY និង ICTR បានបដិសេធយ៉ាងត្រឹមត្រូវនូវតម្រូវការរបស់មន្ត្រីសាធារណៈពាក់ព័ន្ធនឹងវិសាលភាពនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។សេចក្តីថ្លែងការណ៍ស្តីពីការធ្វើទារុណ្ណកម្ម ឆ្នាំ១៩៧៥, និងសន្ធិសញ្ញាស្តីពីការធ្វើទារុណកម្ម ឆ្នាំ១៩៨៤ត្រូវបញ្ជូនទៅកាន់រដ្ឋភាគី និងស្វែងរកការកំណត់ការប្រតិបត្តិរបស់ខ្លួន។ នៅក្នុងបរិបទនេះយើងយល់បានថាពួកគេដោះស្រាយជាមួយនឹងសកម្មភាពរបស់បុគ្គលនានាដែលធ្វើសកម្មភាពក្នុងនាមខ្លួនជាមន្ត្រីសាធារណៈ ផ្ទុយទៅវិញក្នុងនាមCAH វាមិនសមហេតុសមផលសោះដោយបែងចែកមន្ត្រីសាធារណៈទៅនឹងបុគ្គលផ្សេងៗនោះដែលបានប្រព្រឹត្ត និងមិនបានប្រព្រឹត្តអំពើដូចៗគ្នា និងមានចេតនាផ្សេងៗគ្នា ហើយជនរងគ្រោះទទួលផលវិបាកដូចគ្នា ដែលការរងទុក្ខវេទនាមិនស្រាកស្រាន្តដោយដឹងថាបុគ្គលនោះមិនមែនជាមន្ត្រីសាធារណៈទេនោះ។

953. ចំពោះ *ធាតុផ្សំអត្តនោម័តិ* ការឈឺចាប់ និងទុក្ខវេទនាដែលជាទារុណកម្ម ត្រូវតែបង្កឡើងដោយចេតនា[3798]។ អំពើសកម្ម ឬអំពើអកម្មក៏ត្រូវតែបានប្រព្រឹត្តដើម្បីសម្រេចបានលទ្ធផល ឬគោលបំណងណាមួយ។ គោលបំណងទាំងនោះរួមបញ្ចូលការទទួលបានព័ត៌មាន ឬចម្លើយសារភាព ការផ្តន្ទាទោស ការបង្ខិតបង្ខំ ឬការបំភិតបំភ័យ ឬការរើសអើង ដោយមូលហេតុណាមួយប្រឆាំងជនរងគ្រោះ ឬតតិយបុគ្គល[3799]។ គោលបំណងទាំងនេះពុំមែនជាបញ្ជីពេញលេញក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ និងជំនួសមកវិញគ្រាន់តែជាតំណាងប៉ុណ្ណោះ[3800]។ គ្មានលក្ខខណ្ឌតម្រូវដែលថា អំពើនេះត្រូវបានប្រព្រឹត្តផ្តាច់មុខ សម្រាប់គោលបំណងដែលត្រូវបានហាមឃាត់ណាមួយឡើយ និងដែលថាគោលបំណងនោះត្រូវតែជា "ផ្នែកមួយនៃចេតនាដែលស្ថិតពីក្រោយទង្វើនោះ ហើយវាមិនចាំបាច់ជាគោលបំណងសំខាន់ ឬគោលបំណងតែមួយគត់ឡើយ"[3801]។

---

[3798] សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ១៩១-១៩២, ១៩៥-១៩៦, ២០១, ២០៥។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៥៨។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៤១៣។ សេចក្តីថ្លែងការណ៍ស្តីពីការធ្វើទារុណ្ឌកម្ម ឆ្នាំ១៩៧៥, មាត្រា១។ Krnojelac, សាលក្រម កថាខណ្ឌ១៧៩។ Furundžija, សាលក្រម កថាខណ្ឌ១៦២។

[3799] សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ១៩២, ២០៥។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៥៦។ សំណុំរឿង០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ៣៥៥។ សេចក្តីថ្លែងការណ៍ស្តីពីការធ្វើទារុណ្ឌកម្ម ឆ្នាំ១៩៧៥, មាត្រា១។ សន្និសញ្ញាស្តីពីការធ្វើទារុណកម្ម ឆ្នាំ១៩៨៤, មាត្រា១។ Kunarac, សាលដីកា កថាខណ្ឌ១៤២, ១៤៤។ Ntagerura, សាលក្រម កថាខណ្ឌ៧០៣។ទោះបីជា SCC បានចាត់ទុកថានិយមន័យនៃការធ្វើទារុណកម្មដូចដែលមាននៅក្នុងរបាយការណ៍ស្តីពីការធ្វើទារុណកម្មឆ្នាំ១៩៧៥គឺជាការឆ្លុះបញ្ចាំងពី CIL នៅឆ្នាំ១៩៧៥ដែរ។ ហើយបានគូសបញ្ជាក់ពីការគោលបំណងចង្អៀតដែលមិនរាប់បញ្ចូលនូវការយោងយ៉ាងជាក់ស្តែងចំពោះហេតុផលរើសអើងដែលមាននៅក្នុងសន្និសញ្ញាស្តីពីការធ្វើទារុណកម្ម ឆ្នាំ១៩៨៤ (សំណុំរឿង០០១ ឯកសារ -F28 សាលដីកា ឌុច, កថាខណ្ឌ១៩២), សហព្រះរាជអាជ្ញាកត់សម្គាល់ថាសេចក្តីចែងដែលមាននៅក្នុងសេចក្តីថ្លែងការណ៍ស្តីពីការធ្វើទារុណ្ឌកម្ម ឆ្នាំ១៩៧៥ គ្រាន់តែជាតំណាងជាជាងអនុវត្តឱ្យអស់ពីលទ្ធភាព (Čelebići, សាលក្រម កថាខណ្ឌ៤៧០-៤៧២) ហើយដូច្នេះមិនបានច្រានចោលសកម្មភាពឬការលុបចោលអំពើដែលធ្វើឡើងផ្អែកលើមូលដ្ឋានរើសអើងឡើយ។

[3800] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៥៦។ Čelebići, សាលក្រម កថាខណ្ឌ៤៧០-៤៧២។

[3801] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៥៦។ Kunarac, សាលក្រម កថាខណ្ឌ៤៨៦។

<u>ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា</u>

954. ការធ្វើទុក្ខបុកម្នេញជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានមានអត្ថិភាពក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅឆ្នាំ ១៩៧៥[3802]។ វាអាច **មាស មុត** អាចប្រមើលឃើញ និងអាចដឹងបានថា គាត់អាចត្រូវបានផ្តន្ទាទោសពីបទធ្វើទុក្ខបុកម្នេញជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3803]។

955. *ធាតុផ្សំសត្យានុម័ត* នៃការធ្វើទុក្ខបុកម្នេញគឺជាអំពើសកម្ម ឬអំពើអកម្ម ដែលរើសអើងជាក់ស្តែង និងដែលបដិសេធ ឬរំលោភសិទ្ធិជាសារវន្តដែលមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬច្បាប់សន្ធិសញ្ញា[3804]។

*ក) អំពើសកម្ម ឬអំពើអកម្មដែលបដិសេធ ឬរំលោភសិទ្ធិជាសារវន្ត*

956. "អំពើធ្វើទុក្ខបុកម្នេញ" អាចរួមបញ្ចូលបទល្មើសជាមូលដ្ឋានដទៃទៀតសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ព្រមទាំងអំពើអកម្ម ឬអំពើសកម្មដទៃ ដែលមានទម្ងន់ និងភាពធ្ងន់ធ្ងរដូចគ្នា ទោះជាអំពើនោះជាអំពើដាច់ដោយឡែក ឬផ្គួបជាមួយអំពើដទៃទៀតក្តី[3805]។ អំពើសកម្ម ឬអំពើអកម្មដទៃ

---

[3802] សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ២១៦-២២៥ និងសម្រង់។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤២៦។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ ៣៧៤។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣១៤, លេខជើងទំព័រ៥១៩៣.

[3803] សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ២៦១, ២៧៩-២៨០។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤២៦។ ការធ្វើទុក្ខបុកម្នេញដល់សាសនាជាអំពើឧក្រិដ្ឋក្រោមច្បាប់កម្ពុជាឆ្នាំ១៩៧៥។ អានក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦, មាត្រា២០៩-២១០។

[3804] សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ២៥៧, ២៦១-២៦២, ២៧១។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៧៦។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤២៧។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៤១៥។ Stakić, សាលដីកា កថាខណ្ឌ៣២៧។ Nahimana, សាលដីកា កថាខណ្ឌ៩៨៥។

[3805] សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ២៤៤-២៤៥, ២៥៣-២៥៤, ២៥៧-២៥៩, ២៦១។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤៣២-៤៣៣។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៧៨។ Kordić&Čerkez, សាលដីកា កថាខណ្ឌ១០២, ៦៧១។ Blaškić, សាលដីកា កថាខណ្ឌ១៣៥, ១៣៨។ Popović, សាលដីកា កថាខណ្ឌ៧៦៦។ Nahimana, សាលដីកា កថាខណ្ឌ៩៨៧ [បញ្ជាក់ថាផលប៉ះពាល់កើនឡើងទ្វេដងចំពោះការធ្វើទុក្ខបុកម្នេញដែលត្រូវទៅដល់កម្រិតស្មើគ្នាទៅនឹងកម្រិត CAH ផ្សេងៗទៀត]។

ទាំងនេះអាចជា[3806] ឧក្រិដ្ឋកម្មអន្តរជាតិដោយស្វ័យប្រវត្តិ ប៉ុន្តែ ពុំចាំបាច់ត្រូវតែជាឧក្រិដ្ឋកម្មអន្តរជាតិនោះឡើយ[3807]។ ថាតើអំពើទាំងនោះពិតជាការធ្វើទុក្ខបុកម្នេញដែរ ឬយ៉ាងណា គឺជាការស៊ើបអង្កេតជាក់លាក់លើអង្គហេតុ[3808]។

957. បរិបទដែលអំពើសកម្ម ឬអំពើអកម្មកើតឡើង មានសារៈសំខាន់សម្រាប់គោលបំណងនៃការវាយតម្លៃអំពីស្ថានទម្ងន់ ឬភាពធ្ងន់ធ្ងររបស់វា[3809]។ កត្តាដទៃដែលគួរត្រូវបានពិចារណាក្នុងការវាយតម្លៃនោះរួមបញ្ចូល (i) ថាតើវាត្រូវបានប្រព្រឹត្តក្នុងបរិបទនៃ ឬជាផ្នែកមួយនៃបណ្តាញហេតុការណ៍ក្នុងយុទ្ធនាការរើសអើងដ៏ទូលំទូលាយ ដែលគោលដៅចុងក្រោយ និងលទ្ធផលចុងក្រោយនៃយុទ្ធនាការនោះគឺមានភាពធ្ងន់ធ្ងរក្រៃលែង ដោយបានបណ្តាលឱ្យមានការរំលោភយ៉ាងកម្រោលលើសិទ្ធិជាសារវន្ត[3810] និង (ii) ផលប៉ះពាល់នៃការរើសអើង ដែលខ្លួនព្យាយាមលើកទឹកចិត្តក្នុងចំណោមប្រជាជនទូទៅប្រឆាំងក្រុមដែលត្រូវបានដាក់ជាគោលដៅ[3811]។

958. បន្ទាប់ពីការពិនិត្យដ៏ល្អិតល្អន់អំពីយុត្តិសាស្ត្រពីតុលាការ IMT និងសាលាក្តីនានាដែលអនុវត្តតាមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ អ.ជ.ត.ក បានសម្រេចថា នៅមាន "អំពើដទៃទៀតដែលគ្មានក្នុងលិខិតុបករណ៍ទាំងនេះ ដូចជា ការរំលោភសិទ្ធិបុគ្គល ដោយរួមបញ្ចូលសិទ្ធិមានទ្រព្យសម្បត្តិ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ការការពារដោយស្មើភាពចំពោះមុខច្បាប់ សិទ្ធិទទួលបានសញ្ជាតិ ការងារ ការអប់រំ អាពាហ៍ពិពាហ៍ ភាពឯកជន និងសេរីភាពដើរហើរ"[3812]។

---

[3806] សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឧទ, កថាខណ្ឌ២៥៨, ២៦០។ Krnojelac, សាលដីកា កថាខណ្ឌ២១៩។ Brđanin, សាលដីកា កថាខណ្ឌ២៩៦។

[3807] សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឧទ, កថាខណ្ឌ២៤៤-២៤៥, ២៦១។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤៣៣។ Nahimana, សាលដីកា កថាខណ្ឌ៩៨៥។ Brđanin, សាលដីកា កថាខណ្ឌ២៩៦។

[3808] Brđanin, សាលដីកា កថាខណ្ឌ២៩៥។

[3809] សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤៣៣។ Nahimana, សាលដីកា កថាខណ្ឌ៩៨៧។

[3810] សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឧទ, កថាខណ្ឌ២៥៩។

[3811] សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឧទ, កថាខណ្ឌ២៥៩។

[3812] សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឧទ, កថាខណ្ឌ២៥៤, បន្ទាប់ពីបានពិនិត្យយុត្តិសាស្ត្រឡើងវិញ នៅកថាខណ្ឌ២៤២-២៥៣។

ដូចគ្នានេះផងដែរ អំពើខាងក្រោមដែលពុំត្រូវបានបង្ហាញជាក់លាក់ក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក ត្រូវបានចាត់ទុកជាការធ្វើទុក្ខបុកម្នេញនៅតុលាការ ICTY និង ICTR[3813] ដែលមានដូចជា ការបំផ្លិចបំផ្លាញអគារសាសនា[3814] អំពើយាយី ការធ្វើឲ្យអាម៉ាស ការបន្ទាបបន្ថោក និងការបំពានផ្លូវចិត្ត ដោយរួមបញ្ចូលការបង្ខំឲ្យជនរងគ្រោះមើលឃើញ ឬស្តាប់ឮទារុណកម្ម ការស្ងួចម្ល៉េយ និងភាពសាហាវយង់ឃ្នងដោយឥតត្រៀមទុកក្នុងជំរំពន្ធនាគារ[3815] ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជន និងសាធារណៈ ដោយរួមបញ្ចូលវិហារសាសនា និងទីសក្ការៈបូជា[3816] ការងារពលកម្មដោយបង្ខំ[3817] ការនិរទេសដោយបង្ខំ[3818] ស្ថានភាពរស់នៅបែបអមនុស្សធម៌[3819] ការបាត់ខ្លួនដោយបង្ខំ[3820] ការដកហូតសិទ្ធិទទួលបានការងារ សេរីភាពដើរហើរ ដំណើរការយុត្តិធម៌ដ៏ត្រឹមត្រូវ និងការថែទាំវេជ្ជសាស្ត្រដ៏ត្រឹមត្រូវ[3821] សម្ពីបង្កការស្អប់ខ្ពើម និងការអំពាវនាវឲ្យមានអំពើហិង្សា[3822]។

## ខ) ការរើសអើងជាក់ស្តែង

959. អំពើសកម្ម ឬអំពើអកម្មត្រូវតែ "រើសអើងជាក់ស្តែង"[3823] ដែលនោះគឺវាត្រូវតែមានផលវិបាកនៃការរើសអើងជាក់ស្តែង[3824]។ អ.ជ.ត.ក បានសម្រេចថា "ការរើសអើងជាក់ស្តែង" កើតឡើងនៅ

---

3813 មួយចំនួនត្រូវបានគេដកស្រង់ដោយមានការអនុញ្ញាតពីអង្គជំនុំជម្រះអ.វ.ត.ក។ អានសំណុំរឿង០០១ ឯកសារ E188 សាលក្រម ឧុច, កថាខណ្ឌ៣៧៨។

3814 Kordić &Čerkez, សាលក្រម កថាខណ្ឌ២០៦។

3815 Kvočka, សាលដីកា កថាខណ្ឌ៣២៣-៣២៥។ Kvočka, សាលក្រម កថាខណ្ឌ១៩០-១៩២។ Stakić, សាលក្រម កថាខណ្ឌ៧៥៨-៧៦០, ៨០៧-៨០៨។

3816 Karadžić, សាលក្រម កថាខណ្ឌ៥៣០-៥៣៤។ Blaškić, សាលដីកា កថាខណ្ឌ១៤៦, ១៤៩។

3817 Krnojelac, សាលដីកា កថាខណ្ឌ១៩៨-២០៣។

3818 Krnojelac, សាលដីកា កថាខណ្ឌ២២២។ Blaškić, សាលដីកា កថាខណ្ឌ១៥៣។

3819 Karadžić, សាលក្រម កថាខណ្ឌ៥១៤។ Krajišnik, សាលក្រម កថាខណ្ឌ៧៥៥--៧៥៦។ Nikolić (Dragan) SJ, កថាខណ្ឌ៦៩។

3820 Gotovina, សាលក្រម កថាខណ្ឌ១៨៣៩។

3821 Brđanin, សាលដីកា កថាខណ្ឌ២៩៤-២៩៧។ Stanišić & Župljanin, សាលក្រម ភាគ ១ កថាខណ្ឌ៩១-៩២។

3822 Nahimana, សាលដីកា កថាខណ្ឌ៩៨៦-៩៨៨។

3823 សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ២៦៧។ សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៦៦៧។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៩២៧។

ពេលជនរងគ្រោះត្រូវបានដាក់ជាគោលដៅ ដោយសារជនរងគ្រោះជាសមាជិកក្រុមមួយពិតប្រាកដ ឬតាមការយល់ឃើញ *ដែលត្រូវបានផ្តល់និយមន័យដោយចារី* ដោយសារហេតុផលមួយចំនួន ដែលមានជាអាទិ៍ ហេតុផលនយោបាយ ពូជសាសន៍ ឬសាសនា[3825] ហើយជនរងគ្រោះស្ថិតក្នុងក្រុមនយោបាយ ពូជសាសន៍ ឬសាសនា ដែលគេអាចសម្គាល់បានយ៉ាងជាក់ស្តែងគ្រប់គ្រាន់[3826]។ ក្រុមនេះអាចត្រូវបានកំណត់និយមន័យយ៉ាងទូលាយដោយចារី។ នេះអាចក្នុងន័យអវិជ្ជមាន និងអាចរួមបញ្ចូល គូកន និងអ្នកគាំទ្រ ព្រមទាំងជនសង្ស័យ[3827]។ ការធ្វើទុក្ខបុកម្នេញអាចដាក់គោលដៅទៅលើក្រុមរួម ដោយមិនចាំបាច់មានអត្តសញ្ញាណ ឬរបៀបវារៈរួមឡើយ[3828]។

960. ទាក់ទងការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ គ្មានលក្ខខណ្ឌតម្រូវដែលថាក្រុមដែលត្រូវបានដាក់ជាគោលដៅ ពិតជាប្រកាន់យកទស្សនៈនយោបាយជាក់លាក់ណាមួយឡើយ[3829]។ ការធ្វើទុក្ខបុកម្នេញ ដោយហេតុផលនយោបាយអាចកើតឡើង នៅពេលការរើសរើស មានសុពលភាពតាមចេតនានយោបាយ ឬរបៀបវារៈ *ប្រឆាំង* ក្រុមមួយ ដោយផ្អែកលើការវាយតម្លៃដោយអត្តនោម័តិ អំពីការគំរាមកំហែងផ្នែកនយោបាយរបស់ក្រុមនោះ ឬគ្រោះថ្នាក់របស់ក្រុមនោះចំពោះចារី[3830]។

---

3824 សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ២៦៧។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៧៧។

3825 សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ២៧២-២៧៣។ សំណុំរឿង០០២ ឯកសារ F36 សំណុំរឿង ០០២/០១, កថាខណ្ឌ៦៦៧, ៦៦៩, ៦៩០។ សូមអានសំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤២៨។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៧៧។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៤១៥។ Karadžić, សាលក្រម កថាខណ្ឌ៤៩៨។ Kvočka, សាលដីកា កថាខណ្ឌ៣៦៣, ៣៦៦, ៤៥៥។ Blagojević & Jokić, សាលក្រម កថាខណ្ឌ៥៨៣។

3826 សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ២៧៤-២៧៦។ សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៦៦៧។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤២៨។

3827 សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ២៧២-២៧៣។ Kvočka, សាលដីកា កថាខណ្ឌ៣៦៣, ៣៦៦, ៤៥៥។ Simić, សាលក្រម កថាខណ្ឌ៤៩។ Stakić, សាលក្រម កថាខណ្ឌ៧៣៤។

3828 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៦៧៨។

3829 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៦៦៩។

3830 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៦៦៩។ សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ២៧២។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤៣០, លេខជើងទំព័រ១២៩០ និងសម្រង់។

ក្រុមដែលត្រូវបានធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ អាចរួមបញ្ចូលមនុស្សជាច្រើនប្រភេទដូចជា៖ មន្ត្រី និងសកម្មជននយោបាយ បុគ្គលដែលមានទស្សនៈ ឬជំនឿណាមួយ មនុស្សដែលមានជាតិពន្ធុ ឬសញ្ជាតិណាមួយ ឬតំណាងមជ្ឈដ្ឋានសង្គមណាមួយ (ឧទាហរណ៍ "បញ្ញវន្ត" បុព្វជិក ឬគហបតិ)[3831]។

*គ) ធាតុផ្សំអត្តនោម័តិ*

961. ចំពោះ *ធាតុផ្សំអត្តនោម័តិ* ការធ្វើទុក្ខបុកម្នេញតម្រូវឲ្យមានការប្រព្រឹត្តិដោយចេតនានូវអំពើសកម្ម ឬអំពើអកម្មដោយមានចេតនាជាក់លាក់ក្នុងការរើសអើងដោយ ហេតុផលនយោបាយ ពូជសាសន៍ ឬសាសនា[3832]។ ចេតនារើសអើងតម្រូវថា ចារីបានប្រព្រឹត្តដោយចេតនាជាក់លាក់ដើម្បីព្យាបាទជនរងគ្រោះ ដោយសារគាត់ស្ថិតក្នុងសហគមន៍ ឬក្រុមណាមួយ[3833]។ មិនចាំបាច់មានលក្ខខណ្ឌតម្រូវដែលថា ចារីមានចេតនារើសអើងនោះទេ ពោលគឺ ចេតនាដកបុគ្គលដែលត្រូវបានដាក់ជាគោលដៅចេញពីសង្គម ឬភាពជាមនុស្ស ហួសពីចេតនារើសអើងទៅទៀត[3834]។

962. ចេតនាត្រូវបានសន្និដ្ឋាន "តាមរយៈការចូលរួមដោយចេតនារបស់ចារីក្នុងប្រព័ន្ធ ឬគម្រោង ដែលបានរើសអើងដោយហេតុផលនយោបាយ ពូជសាសន៍ ឬសាសនា"[3835]។ ប៉ុន្តែអត្ថិភាពនៃគោលនយោបាយរើសអើងពុំមែនជាលក្ខខណ្ឌតម្រូវ សម្រាប់បង្ហាញអំពីការធ្វើទុក្ខបុកម្នេញឡើយ[3836]។ ភ័ស្តុតាងនៃទំនាក់ទំនងខ្លះរវាងចារី និងក្រុមគោលដៅ ពុំហាមឃាត់មិនឲ្យអ្នកវិនិច្ឆ័យអង្គហេតុមិន

---

[3831] សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ២៧២។ សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៦៦៩។

[3832] សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ២៣៦-២៤០។ សំណុំរឿង០០២ ឯកសារ E313 សាលក្រម សំណុំរឿង ០០២/០១, កថាខណ្ឌ៤២៧។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៧៩។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៤២៣។សូមអានឧទាហរណ៍ Stakić, សាលដីកា កថាខណ្ឌ៣២៧-៣២៨។ Nahimana, សាលដីកា កថាខណ្ឌ៩៨៥។

[3833] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៧៩។ Kordić&Čerkez, សាលដីកា កថាខណ្ឌ១១១។ Blaškić, សាលដីកា កថាខណ្ឌ១៦៥។ Karadžić, សាលក្រម កថាខណ្ឌ៥០០។

[3834] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៧៩។ Kordić&Čerkez, សាលដីកា កថាខណ្ឌ១១១។ Blaškić, សាលដីកា កថាខណ្ឌ១៦៥។

[3835] Simić, សាលក្រម កថាខណ្ឌ៥១។

[3836] Karadžić, សាលក្រម កថាខណ្ឌ៥០០។ Popović, សាលក្រម កថាខណ្ឌ៩៦៧។

ឲ្យយល់ឃើញដោយសមហេតុផល អំពីចេតនាចាំបាច់ដើម្បីប្រព្រឹត្តការធ្វើទុក្ខបុកម្នេញជាចាំបាច់ឡើយ[3837]។

<u>អំពើអមនុស្សធម៌ដទៃទៀត</u>

963. "អំពើអមនុស្សធម៌ដទៃទៀត" ត្រូវបានបង្កើតឡើងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមច្បាប់ទម្លាប់អន្តរជាតិមុនឆ្នាំ ១៩៧៥[3838]។ លើសពីនេះ វាអាចឲ្យ **មាស មុត** ប្រមើលឃើញ និងដឹងបានថាអំពើដែលនាំទៅដល់លក្ខណៈជា "អំពើអមនុស្សធម៌ដទៃទៀត" អាចត្រូវបានចោទប្រកាន់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3839]។ "អំពើអមនុស្សធម៌ដទៃទៀត" គឺជាឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ[3840]។ គ្មានលក្ខខណ្ឌតម្រូវដែលថា ប្រភេទតូចៗនីមួយៗ ត្រូវចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែកមួយ ពីឆ្នាំ ១៩៧៥-១៩៧៩ ឡើយ។ ការតម្រូវដូច្នេះនឹងធ្វើឲ្យប្រភេទ "អំពើអមនុស្សធម៌ដទៃទៀត" គ្មានអត្ថន័យ[3841]។ ប៉ុន្តែ "អំពើអមនុស្សធម៌ដទៃទៀត" គឺជាប្រភេទ

---

3837 Kvočka, សាលដីកា កថាខណ្ឌ២៣២-២៣៣។

3838 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៧៦។ សំណុំរឿង០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ ៣៧១, ៣៧៩-៣៨៥, ៣៩៥-៣៩៦, ៣៩៨ និងសម្រង់។ សំណុំរឿង០០២ ឯកសារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ១៥៦-១៥៧, ១៦៥។ សំណុំរឿង០០២ ឯកសារ- E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤៣៥។ សំណុំរឿង០០១ ឯកសារ- E188 សាលក្រម ឌុច, កថាខណ្ឌ៣៦៧។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣១៤, លេខជើងទំព័រ៥១៩៤. សូមអាន Stakić, សាលដីកា កថាខណ្ឌ៣១៥-៣១៦, លេខជើងទំព័រ៦៤៩។ Brima, សាលដីកា កថាខណ្ឌ១៨៣, លេខជើងទំព័រ២៧៥។

3839 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៧៧-៥៨៦។ សំណុំរឿង ០០២ ឯកសារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ១៦៥។ សំណុំរឿង០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ៣៩៦, ៣៩៨។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤៣៥។ Stakić, សាលដីកា កថាខណ្ឌ៣១៥។

3840 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៧៦។

3841 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៨៥។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤៣៦។ សំណុំរឿង០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ៣៧១, ៣៧៨។ សំណុំរឿង០០២

បន្ទាប់បន្សំ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលចាត់ទុកជាបទល្មើសនូវទង្វើដែលបំពេញលក្ខខណ្ឌនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែពុំស្ថិតក្នុងឧក្រិដ្ឋកម្មជាមូលដ្ឋានដែលត្រូវបានបញ្ជាក់មួយក្នុងចំណោមឧក្រិដ្ឋកម្មនានា[3842]។ អំពើសកម្ម ឬអំពើអកម្មត្រូវតែស្រដៀងគ្រប់គ្រាន់ទាំងលក្ខណៈ និងភាពធ្ងន់ធ្ងរ ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែងដទៃទៀត[3843]។

964. អ.ជ.ត.ក ទើបបានសម្រេចថា ដើម្បីចាត់ទុកអំពើមួយជាអំពើអមនុស្សធម៌ដទៃទៀត ធាតុផ្សំខាងក្រោមត្រូវតែបំពេញ៖ (i) មានអំពើសកម្មឬអំពើអកម្ម ដែលមានភាពធ្ងន់ធ្ងរស្រដៀងនឹងអំពើដទៃទៀតដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មជាប្រឆាំងមនុស្សជាតិ (ii) អំពើសកម្ម ឬអំពើអកម្មបានបង្កទុក្ខវេទនា ឬរបួសនកម្មផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ឬជាការវាយប្រហារដ៏ធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និង (iii) អំពើសកម្ម ឬអំពើអកម្មត្រូវបានប្រព្រឹត្តដោយចេតនា[3844]។

965. ហេតុដូច្នេះ ថាតើទង្វើមួយបំពេញលក្ខខណ្ឌនៃការកំណត់ជា "អំពើអមនុស្សធម៌ដទៃទៀត" ដែរឬយ៉ាងណា គឺជាបញ្ហាដែលពាក់ព័ន្ធទាំងអង្គច្បាប់ និងអង្គហេតុ[3845]។ ភាពធ្ងន់ធ្ងរនៃអំពើមួយ ត្រូវ

---

ឯកសារ -D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ១៥៦។ Stakić, សាលដីកា កថាខណ្ឌ៣១៥-៣១៦។

[3842] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៧៦, ៥៧៨។ សំណុំរឿង ០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤៣៧។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៦៧។ Stakić, សាលដីកា កថាខណ្ឌ៣១៥-៣១៦។ Kordić&Čerkez, សាលដីកា កថាខណ្ឌ ១១៧។ Brima, សាលដីកា កថាខណ្ឌ១៨៣, ១៩៨។

[3843] សំណុំរឿង០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ៣៩៥-៣៩៦។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៦៧។ សំណុំរឿង ០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤៣៨, ៤៤០។ សំណុំរឿង០០៤/២ ឯកសារ D257/1/8 សេចក្តីពិចារណាលើ អាពាហ៍ពិពាហ៍ដោយបង្ខំ៖ ចៅក្រមអន្តរជាតិ, កថាខណ្ឌ១៥។ Krajišnik, សាលដីកា កថាខណ្ឌ៣៣១។ Brima, សាលដីកា កថាខណ្ឌ១៩៨។ Lukić& Lukić, សាលក្រម កថាខណ្ឌ៩៦០។ ធាតុផ្សំនៃបទល្មើសឧក្រិដ្ឋកម្ម របស់ ICC, មាត្រា៧(១)(ឋ), ធាតុផ្សំ២។

[3844] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៨០។

[3845] អានឧទាហរណ៍សំណុំរឿង០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ៣៩៧។ សំណុំរឿង០០២ ឯកសារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ១៦៦. សូមអានសំណុំរឿង០០៤/២ ឯកសារ D257/1/8 សេចក្តីពិចារណាលើ អាពាហ៍ពិពាហ៍ដោយបង្ខំ៖ ចៅក្រមអន្តរជាតិ, កថាខណ្ឌ១៨។

វាយតម្លៃទៅតាមករណីនីមួយៗ ដោយពិចារណាអំពីកាលៈទេសៈនីមួយៗនៃករណីនោះ[3846] ហើយអង្គហេតុទាំងនោះត្រូវតែវាយតម្លៃអំពីស្ថានទម្ងន់របស់វាទាំងមូល[3847]។ កាលៈទេសៈនីមួយៗអាចរួមបញ្ចូលលក្ខណៈនៃអំពើសកម្ម ឬអំពើអកម្ម បរិបទដែលអំពើនោះបានកើតឡើង កាលៈទេសៈផ្ទាល់ខ្លួនរបស់ជនរងគ្រោះដោយរួមបញ្ចូល អាយុ ភេទ និងសុខភាព និងផលប៉ះពាល់ផ្លូវកាយ និងផ្លូវចិត្តនៃអំពើនោះមកលើជនរងគ្រោះ[3848]។ ពុំមានលក្ខខណ្ឌតម្រូវដែលថា ជនរងគ្រោះត្រូវតែទទួលរងផលប៉ះពាល់រយៈពេលយូរឡើយ ទោះបីចំណុចនេះអាចពាក់ព័ន្ធភាពធ្ងន់ធ្ងរនៃអំពើទាំងនោះក៏ដោយ[3849]។ លក្ខខណ្ឌតម្រូវស្តីពីភាពធ្ងន់ធ្ងរអាចត្រូវបានបំពេញតាមរយៈការបង្ហាញថាសិទ្ធិស្រដៀងៗនេះ និងការហាមឃាត់នានាមានក្នុងលិខិតុបករណ៍សិទ្ធិមនុស្សអន្តរជាតិដែលមានជាធរមាន នៅពេលវេលាពាក់ព័ន្ធ[3850]។ ការប្រសូត្រនិយាមសិទ្ធិមនុស្សថ្មី ដែលជាក់លាក់ជាងមុនក្រោយឆ្នាំ ១៩៧៥ ដោយរួមបញ្ចូលនិយាមនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ អាចជួយផ្តល់ការបញ្ជាក់អះអាងបន្ថែមអំពីភាពមិនស្របច្បាប់នៃទង្វើមុនដែលត្រូវបានចោទថាជា "អំពើអមនុស្សធម៌ដទៃទៀត" និងត្រូវបានប្រើប្រាស់ជាឧបករណ៍ដើម្បីវាយតម្លៃថាតើទង្វើនោះ ឈានដល់កម្រិតនៃភាពធ្ងន់ធ្ងរតាមលក្ខខណ្ឌតម្រូវដែរ ឬយ៉ាងណា[3851]។

---

3846 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៦៩។ សំណុំរឿង០០២ ឯកសារ E313 សាលក្រម សំណុំរឿង ០០២/០១, កថាខណ្ឌ៤៣៨។ សំណុំរឿង០០៤/២ ឯកសារ D257/1/8 សេចក្តីពិចារណាលើអាពាហ៍ពិពាហ៍ដោយបង្ខំ៖ ចៅក្រមអន្តរជាតិ, កថាខណ្ឌ១៦។ Kordić&Čerkez, សាលដីកា កថាខណ្ឌ១១៧។ Lukić& Lukić, សាលក្រម កថាខណ្ឌ៩៦១។

3847 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៩០។

3848 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៦៩។ សំណុំរឿង០០២ ឯកសារ E313 សាលក្រម សំណុំរឿង ០០២/០១, កថាខណ្ឌ៤៣៨។ Vasiljević, សាលដីកា កថាខណ្ឌ១៦៥។ សំណុំរឿង០០៤/២ ឯកសារ D257/1/8 សេចក្តីពិចារណាលើ អាពាហ៍ពិពាហ៍ដោយបង្ខំ៖ ចៅក្រមអន្តរជាតិ, កថាខណ្ឌ១៦ សម្រង់ សំណុំរឿង ០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៦៩។

3849 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៦៩។ សំណុំរឿង០០២ ឯកសារ E313 សាលក្រម សំណុំរឿង ០០២/០១, កថាខណ្ឌ៤៣៩។ Vasiljević, សាលដីកា កថាខណ្ឌ១៦៥។ Lukić& Lukić, សាលក្រម កថាខណ្ឌ៩៦១, លេខជើងទំព័រ២៨៨៧។

3850 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៨៤-៥៨៥។

3851 សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៨៥។

966. ហេតុដូច្នេះ អំពើជាមូលដ្ឋានមិនត្រូវការ "និយមន័យ *គតិយុត្តិ* និងធាតុផ្សំជាក់លាក់" ឡើយ[3852]។ អ.ជ.ត.ក ទើបបានពន្យល់ថា "បញ្ហានាំមុខ [...] គឺថាតើទង្វើនោះ ដោយពិចារណាអំពីកាលៈទេសៈជាក់លាក់ទាំងអស់នៃសំណុំរឿងក្នុងដៃ ពិតជាបានបំពេញនិយមន័យនៃអំពើអមនុស្សធម៌ដទៃទៀតដែរ ឬយ៉ាងណា"[3853]។ ហេតុដូច្នេះ ពុំមានភាពចាំបាច់ដើម្បីវាយតម្លៃអង្គហេតុជាមួយធាតុផ្សំ នៃឧក្រិដ្ឋកម្មដែលជាមូលដ្ឋាននៃអំពើអមនុស្សធម៌ដទៃទៀតឡើយ ប៉ុន្តែចាំបាច់ត្រូវវាយតម្លៃ ថាតើអង្គហេតុទាំងអស់ នៅពេលពិចារណារួមគ្នាអំពី "លក្ខណៈ និងភាពធ្ងន់ធ្ងររបស់វាស្រដៀងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានកំណត់ដែរ ឬយ៉ាងណា"[3854]។

967. បន្ថែមពីលើអំពើដែលត្រូវបានពិនិត្យលម្អិតបន្ថែមខាងក្រោមនេះ "អំពើអមនុស្សធម៌ដទៃទៀត" ត្រូវបានប្រទះឃើញថារួមបញ្ចូលៈ ការប្រព្រឹត្តិបែបយង់ឃ្នង ការព្យាបាទ ឬបែបបន្ទាបបន្ថោក[3855] ពេស្យាចារដោយបង្ខំ[3856] ព្យសនកម្មផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ[3857] ការកាត់អវៈយវៈ ការវាយដំ និងព្យសនកម្មផ្លូវកាយធ្ងន់ធ្ងរក្នុងប្រភេទផ្សេងៗ[3858] លក្ខខណ្ឌឃុំឃាំងដ៏យ៉ាប់យ៉ឺន[3859] អំពើហិង្សាផ្លូវភេទ[3860] ការប្រើប្រាស់អ្នកជាប់ឃុំឃាំងជាខែលមនុស្ស[3861] ការមើលឃើញអំពីឧក្រិដ្ឋ ទៅលើ

---

[3852] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៨៩ (បញ្ជាក់បន្ថែមនៅក្នុងច្បាប់ដើម)។

[3853] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៨៩។

[3854] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៩០។

[3855] Kupreškić, សាលក្រម កថាខណ្ឌ៥៦៦។ Kvočka, សាលក្រម កថាខណ្ឌ២០៨។

[3856] Kupreškić, សាលក្រម កថាខណ្ឌ៥៦៦។ Kvočka, សាលក្រម កថាខណ្ឌ២០៨។

[3857] Blaškić, សាលក្រម កថាខណ្ឌ២៣៩។ Kayishema & Ruzindana, សាលក្រម កថាខណ្ឌ១៥១។

[3858] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៧០។ Muvunyi I, សាលក្រម កថាខណ្ឌ៥២៨។ Kvočka, សាលក្រម កថាខណ្ឌ២០៨។ Tadić, សាលក្រម កថាខណ្ឌ៧៣០។

[3859] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៨១សម្រង់ Krnojelac, សាលក្រម កថាខណ្ឌ១៣៣។

[3860] Muvunyi I, សាលក្រម កថាខណ្ឌ៥២៨។ Brima, សាលដីកា កថាខណ្ឌ១៨៤, ១៨៦។

[3861] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៨១សម្រង់ Naletilić& Martinović, សាលក្រម កថាខណ្ឌ២៤៥។ Blaškić, សាលក្រម។ Kordić&Čerkez, សាលក្រម កថាខណ្ឌ៧៧៣។

គ្រួសារឬមិត្តភ័ក្ត្រ[3862] ការកាត់ស្បែកចុងលិង្គ ឬការគ្រៀវដោយបង្ខំ[3863] ការសម្លាប់នៅចំពោះមុខកុមារ[3864] ការបង្ករបួសទៅលើបាតុករ[3865] និងភាពអាក្រាតដោយបង្ខំ[3866]។

968. នៅក្នុងការបង្ហាញខ្លួនលើកដំបូង **មាស មុត** ត្រូវបានចោទពីបទអំពើអមនុស្សធម៌ដទៃទៀត ដោយផ្អែកលើការបាត់ខ្លួនដោយបង្ខំ អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទ ដែលបានកើតឡើង ដោយហេតុថា រដ្ឋអំណាចបានតម្រូវឱ្យមានការផ្សំដំណេក ក្នុងអាពាហ៍ពិពាហ៍ទាំងនោះ ការប្រព្រឹត្តិបែបអមនុស្សធម៌ ការវាយប្រហារសេចក្តីថ្លៃថ្នូរមនុស្សជាតិ ដោយសារលក្ខខណ្ឌនៃការឃុំឃាំង និងការងារពលកម្មដោយបង្ខំ[3867]។ របៀបដែលទង្វើពាក់ព័ន្ធនីមួយៗក្នុងចំណោមអំពើទាំងនេះ បំពេញធាតុផ្សំគតិយុត្តិនៃ "អំពើអមនុស្សធម៌ដទៃទៀត" ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយរបៀបណានោះ ត្រូវបានពិភាក្សាខាងក្រោម។

*ក) ការប្រព្រឹត្តិបែបអមនុស្សធម៌*

969. ការប្រព្រឹត្តិបែបអមនុស្សធម៌[3868] ត្រូវបានហាមឃាត់យ៉ាងដាក់លាក់ ដោយលិខិតុបករណ៍សិទ្ធិមនុស្សជាច្រើន ដោយរួមបញ្ចូល UDHR, ICCPR និង ECHR[3869]។ លិខិតុបករណ៍នីមួយៗ

---

[3862] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៨១សម្រង់ Kupreškić, សាលក្រម កថាខណ្ឌ៨១៩។ Kayishema & Ruzindana, សាលក្រម កថាខណ្ឌ១៥៣។ Brima, សាលដីកា កថាខណ្ឌ១៨៩។

[3863] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៨១សម្រង់ Kenyatta ការបញ្ជាក់ពីសេចក្តីសម្រេចចោទប្រកាន់, កថាខណ្ឌ២៧០-២៧៣។

[3864] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៨១សម្រង់ Kenyatta ការបញ្ជាក់ពីសេចក្តីសម្រេចចោទប្រកាន់, កថាខណ្ឌ២៧៦-២៧៧។

[3865] សំណុំរឿង០០២ ឯកសារ F36 សាលក្រមសាលាឧទ្ធរណ៍សំណុំរឿង ០០២/០១, កថាខណ្ឌ៥៨១សម្រង់ Kenyatta ការបញ្ជាក់ពីសេចក្តីសម្រេចចោទប្រកាន់, កថាខណ្ឌ២៨០។

[3866] Akayesu, សាលក្រម កថាខណ្ឌ៦៩៧។ Brđanin, សាលក្រម កថាខណ្ឌ១០១៣។

[3867] ឯកសារ D174 កំណត់ហេតុនៃការបង្ហាញខ្លួនជាលើកដំបូង។

[3868] អំពើប្រព្រឹត្ត"ដោយពុំមានត្រាប្រណី"ត្រូវគេកំណត់ថាជាអំពើ"អមនុស្សធម៌" នៅក្នុង GC I, មាត្រា៥០, GC II, មាត្រា៥១, GC III, មាត្រា១៣០, GC IV, មាត្រា១៤៧, និងក្រោយៗមកទៀតមាននៅឧបករណ៍នានាខាងក្រោម។

[3869] UDHR មាត្រា៥។ ICCPR មាត្រា៧។ ACHR មាត្រា៥(២)។ ធម្មនុញ្ញអាហ្វ្រិកស្តីពីមនុស្ស និងពលរដ្ឋ 'សិទ្ធិ, មាត្រា៥។ ECHR មាត្រា៣។

ចាត់ទុកការប្រព្រឹត្តិបែបអមនុស្សធម៌ ការប្រព្រឹត្តិបែបបន្ទាបបន្ថោក និងទារុណកម្ម ជាអំពើដែលត្រូវបានហាមឃាត់ផ្សេងពីគ្នា[3870] ដែលអាចបែងចែកតាមរយៈកម្រិត កាលៈទេសៈ និងគោលបំណង នៃការប្រព្រឹត្តិ ឬការផ្តន្ទាទោសនោះ[3871]។

970. តុលាការ ICTY បានទទួលស្គាល់ថា ការប្រព្រឹត្តិបែបអមនុស្សធម៌ ជាអំពើអមនុស្សធម៌ដទៃទៀត មានធាតុផ្សំដូចគ្នាជាមួយការប្រព្រឹត្តិបែបព្រៃផ្សៃជាឧក្រិដ្ឋកម្មសង្គ្រាម និងការប្រព្រឹត្តិបែបអមនុស្សធម៌ជាការបំពានធ្ងន់ធ្ងរនៃ GC ក្នុងករណីដែលទង្វើដោយចេតនារបស់ចារី បានបង្កព្យសនកម្ម ឬទុក្ខវេទនាផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ឬការវាយប្រហារធ្ងន់ធ្ងរមកលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ[3872]។ អំពើនានាដែលត្រូវបានរកឃើញថាជាការប្រព្រឹត្តិបែបព្រៃផ្សៃ ការប្រព្រឹត្តិបែបអមនុស្សធម៌ ឬអំពើជាមូលដ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ជាការធ្វើទុក្ខបុកម្នេញ បានរួមបញ្ចូលការវាយដំ[3873] ការបង្កការទង្គិចក្បាល[3874] ការប្រើប្រាស់សរិយាបថលំបាក

---

[3870] UDHR មាត្រា៥ ["បុគ្គលគ្រប់រូបមិនត្រូវទទួលរងនូវការធ្វើទារុណកម្មឬទណ្ឌកម្មឃោរឃៅ, ទណ្ឌកម្មប្រកបដោយអមនុស្សធម៌ឬទណ្ឌកម្មប្រកបដោយក្តីថោកទាបឡើយ"]។ ICCPR មាត្រា៧ ["បុគ្គលគ្រប់រូបមិនត្រូវទទួលរងនូវការធ្វើទារុណកម្មឬទណ្ឌកម្មឃោរឃៅ, ទណ្ឌកម្មប្រកបដោយអមនុស្សធម៌ឬទណ្ឌកម្មប្រកបដោយក្តីថោកទាបឡើយ"]។ ACHR មាត្រា៥(២) [""បុគ្គលគ្រប់រូបមិនត្រូវទទួលរងនូវការធ្វើទារុណកម្មឬទណ្ឌកម្មឃោរឃៅ, ទណ្ឌកម្មប្រកបដោយអមនុស្សធម៌ឬទណ្ឌកម្មប្រកបដោយក្តីថោកទាប ឬការប្រព្រឹត្តដោយបន្ថោកបន្ទាបឡើយ"]។ ធម្មនុញ្ញអាហ្វ្រិកស្តីពីមនុស្ស និងពលរដ្ឋ 'សិទ្ធិ, មាត្រា៥ ["រាល់ទម្រង់នៃការកេងប្រវ័ញ្ច និងការបន្ថោកបន្ទាបមនុស្ស ជាពិសេសអំពើទាសភាព ការជួញដូរទាសករ ការធ្វើទារុណកម្ម ការដាក់ទណ្ឌកម្មដោយអមនុស្សធម៌ ឬការដាក់ទណ្ឌកម្មយ៉ាងថោកទាប និងការធ្វើបាបនានាត្រូវបានហាមឃាត់"]។ ECHR មាត្រា៣ ["បុគ្គលគ្រប់រូបមិនត្រូវទទួលរងការធ្វើទារុណកម្មឬការដាក់ទណ្ឌកម្មដោយអមនុស្សធម៌ឬការដាក់ទណ្ឌកម្មយ៉ាងថោកទាបឡើយ]។

[3871] សាលដីកា Ireland តទល់នឹង United Kingdom, Judgment, កថាខណ្ឌ១៦២, ១៦៧-១៦៨។

[3872] អានឧទាហរណ៍ Orić, សាលក្រម កថាខណ្ឌ៣៥០។ Simić, សាលក្រម កថាខណ្ឌ៧៥។ Krnojelac, សាលក្រម កថាខណ្ឌ១៣០។ សូមអាន IX.ក.៣. ការរំលោភយ៉ាងធ្ងន់ធ្ងរទៅនឹងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ - ទោសជាក់លាក់ - ២. ការធ្វើទារុណកម្ម ឬការធ្វើបាបយ៉ាងអមនុស្សធម៌ ផ្នែកខាងក្រោមត្រូវបានលើកយកមកពិភាក្សាយ៉ាងល្អិតល្អន់ពាក់ព័ន្ធនឹងសម្ភារៈ និងធាតុផ្សំនៃការរំលោភយ៉ាងធ្ងន់ធ្ងរចំពោះការធ្វើបាបដោយអមនុស្សធម៌ និងការធ្វើទារុណកម្ម។

[3873] អានឧទាហរណ៍ Simić, សាលក្រម កថាខណ្ឌ៧៧០-៧៧១ [ឃើញអំពើឃោរឃៅ និងការធ្វើបាបយ៉ាងអមនុស្សធម៌ក្នុងអំពើធ្វើទុកបុកម្នេញ ដែលអ្នកជាប់ឃុំដែលមិនមែនជាជនជាតិស៊ែបរងនូវការវាយដំយ៉ាងធ្ងន់ធ្ងរដោយវត្ថុផ្សេងៗមានជាអាទិ៍ កាំភ្លើង ដំបងដែក ដំបងវាយកូនបាល់ ច្រវ៉ាក់ដែក ដំបងនគរបាល និងជើងតុជាដើម]។ Delić, សាលក្រម កថាខណ្ឌ៣១៥-៣១៩ [ឃើញការធ្វើបាបយ៉ាងឃោរឃៅជាឧក្រិដ្ឋកម្មសង្គ្រាម ស្ត្រីត្រូវគេវាយដោយដៃ កណ្តាប់

និងតឹងតែង[3875] និងការបង្ខាំងក្រោមលក្ខខណ្ឌអមនុស្សធម៌[3876]។ ជាបញ្ហាគោលការណ៍ ទង្វើស្រដៀងនេះដែលជាការប្រព្រឹត្តិបែបអមនុស្សធម៌ នឹងបំពេញលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរសម្រាប់ការចាត់ទុកជា "អំពើអមនុស្សធម៌ដទៃទៀត"។

*ខ) ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិដោយសារលក្ខខណ្ឌនៃការឃុំឃាំង*

971. ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ អាចបណ្តាលមកពីការដកហូតអាហារ ទឹក ទីជម្រក ជំនួយវេជ្ជសាស្ត្រគ្រប់គ្រាន់ និងលក្ខខណ្ឌអនាម័យអប្បបរមា។ អង្គជំនុំជម្រះសាលាដំបូង

---

ដៃ ដំបងដែក ស្ប៉យកាំភ្លើង និងទាត់ធាក់ជាដើម]។ Orić, សាលក្រម កថាខណ្ឌ៤១៤-៤៧៤ [ឃើញការធ្វើបាបយ៉ាងឃោឃៅជាឧក្រិដ្ឋកម្មសង្គ្រាម ចំពោះអ្នកជាប់ឃុំត្រូវគេទាតធាក់ ជាន់ពីលើ ដាល់ដោយកណ្តាប់ដៃ វាយនឹងមែកឈើ ដំបងឈើ បង្គោលឈើ ស្បែកជើង ស្ប៉យកាំភ្លើង ដំបងដែក រំពាត់ដែក ដំបងវាយកូនបាល់ និងចាក់ដោយកាំបិត]។

3874 Orić, សាលក្រម កថាខណ្ឌ៤៤៣, ៤៦៩ [ឃើញការធ្វើបាបយ៉ាងឃោឃៅជាឧក្រិដ្ឋកម្មសង្គ្រាម ចំពោះអ្នកជាប់ឃុំត្រូវគេបោកក្បាលទៅនឹងរ៉ាឌ្យាទ័របណ្តាលឲ្យគាត់បាត់ស្មារតី]។

3875 អានឧទាហរណ៍ Delić, សាលក្រម កថាខណ្ឌ២៥៥-២៥៨, ២៧០, ២៧៣ [ឃើញការធ្វើបាបយ៉ាងឃោឃៅជាឧក្រិដ្ឋកម្មសង្គ្រាម ចំពោះអ្នកជាប់ឃុំត្រូវគេញួរជើងឡើងលើ ដងខ្លួននៅលើដី និងដៃចងស្ពាបសេក ហើយទុកចោលនៅទីនោះមួយយប់ជាមួយចំណងរឹតយ៉ាងតឹង។ អ្នកជាប់ឃុំម្នាក់បានពណ៌នាថាមើលទៅដូចសឹងតែដាច់ជើងតែម្តង]។ Boškoski & Tarčulovski, សាលក្រម កថាខណ្ឌ៣៨៣, ៣៨៥ [ឃើញការធ្វើបាបយ៉ាងឃោឃៅជាឧក្រិដ្ឋកម្មសង្គ្រាម ចំពោះបុរសជនជាតិភាគតិចអាល់បានីត្រូវគេឲ្យដេកលើដីចងមុខ និងភ្នែកយ៉ាងជិត ហើយគេវាយហើយវាយទៀតឥតឈប់ឈរ]។

3876 អានឧទាហរណ៍ Simić, សាលក្រម កថាខណ្ឌ៧៧៣ [ឃើញការធ្វើបាបយ៉ាងឃោឃៅជាការធ្វើទុក្ខបុកម្នេញចំពោះអ្នកជាប់ឃុំដែលមិនមែនជាជនជាតិស៊ែបដោយពួកគេរងនូវការបំពាន និងចំអកឡកឡឺយ ការដាក់ឃុំក្នុងស្ថានភាពចង្អៀតកកកុញ ម្ហូបអាហារនិងទឹកបរិភោគមិនគ្រប់គ្រាន់ គ្មានអនាម័យ មិនទទួលបានសេវាសុខភាពសមរម្យ និងរងនូវការវាយដំនិងទារុណកម្ម]។ Krnojelac, សាលក្រម កថាខណ្ឌ១៣៣, ១៣៥-១៧៣, ៥៣៤ [ឃើញការធ្វើបាបយ៉ាងឃោឃៅជាឧក្រិដ្ឋកម្មសង្គ្រាម គឺជាការធ្វើទុក្ខបុកម្នេញចំពោះអ្នកមិនមែនជាជនជាតិស៊ែបដោយពួកគេរងនូវជីវភាពរស់នៅយ៉ាងលំបាកនិងឃោឃៅ រួមមាន ការរស់នៅកន្លែងតូចចង្អៀតនិងគ្មានអនាម័យ ពុំមានម្ហូបអាហារគ្រប់គ្រាន់ បដិសេធន៍នូវកិច្ចគាំពារជាមូលដ្ឋានខណៈសីតុណ្ហភាពចុះរហូតដល់កកក្តី]។ Čelebići, សាលក្រម កថាខណ្ឌ១១១២-១១១៩ [ឃើញការធ្វើបាបយ៉ាងឃោរឃៅជាឧក្រិដ្ឋកម្មសង្គ្រាម គឺជាការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើ GCs នៅពេលដែលអ្នកជាប់ឃុំពុំទទួលបានម្ហូបអារហារនិងទឹកបរិភោគគ្រប់គ្រាន់ ពុំទទួលបានការថែទាំសុខភាព និងគ្មានបង្គន់អនាម័យត្រឹមត្រូវ។ ពួកគេត្រូវទទួលរងដេកហាលក្តៅនិងរងា រីឯដំណេកទៀតសោតគឺពុំមានការរៀបចំឲ្យបានគ្រប់គ្រាន់ទេគឺពួកគេត្រូវដេកនៅកន្លែងចង្អៀតមនុស្សកកកុញ ហើយទទួលរងហិង្សាតាមទំនើងចិត្តក្នុងបរិយាកាសគួរឲ្យភ័យខ្លាច។]។

បានសម្រេចថា ការដកហូតបែបនេះ អាចមានទម្ងន់ស្រដៀងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវបានកំណត់អាស្រ័យតាមអង្គហេតុ និងហេតុដូច្នេះស្ថិតក្នុងចង្កោមទទួលខុសត្រូវនៃ "អំពើអមនុស្សធម៌ដទៃទៀត"[3877]។ យោងតាម អ.វ.ត.ក និងយុត្តិសាស្ត្រអន្តរជាតិ ការដកហូតស្រដៀងនេះក្នុងបរិបទនៃការឃុំឃាំង អាចជាអំពើអមនុស្សធម៌ដទៃទៀតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3878]។ ការដកហូតទាំងអស់នោះត្រូវបានរកឃើញថាមានកម្រិតធ្ងន់ធ្ងរដូចឧក្រិដ្ឋកម្មដទៃទៀត ដែលមានរៀបរាប់ក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក និងជាការធ្វើទុក្ខបុកម្នេញជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3879] ព្រមទាំងជាបទល្មើសនៃការប្រព្រឹត្តិបែបព្រៃផ្សៃ ជាការរំលោភច្បាប់ឬទំនៀមទម្លាប់ ក្រោមលក្ខន្តិកៈតុលាការ ICTY[3880]។ ក្នុងបរិបទនៃអំពើប្រល័យពូជសាសន៍ ការដកហូតដដែលនេះ ត្រូវបានពិចារណាថា បង្ហាញអំពីស្ថានភាពរស់នៅ ដែលនឹងនាំមកនូវការបំផ្លាញរូបរាងកាយរបស់ក្រុមមួយ[3881]។

972. ហេតុដូច្នេះ ការដកហូតបែបនេះអាចមានទម្ងន់ស្រដៀងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានរៀបរាប់ និងហេតុដូច្នេះអាចស្ថិតក្រោមចង្កោមទទួលខុសត្រូវនៃ "អំពើអមនុស្សធម៌ដទៃទៀត"។

---

3877 សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៤៥៦-៤៥៨។

3878 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៧០។ Krnojelac, សាលក្រម កថាខណ្ឌ១៣៣។ Kvočka, សាលក្រម កថាខណ្ឌ២០៩។

3879 Blaškić, សាលដីកា កថាខណ្ឌ១៥៥។ Karadžić, សាលក្រម កថាខណ្ឌ៥១៤។ Krajišnik, សាលក្រម កថាខណ្ឌ៧៤៥-៧៤៧, ៧៥៥-៧៥៦។ Stanišić&Župljanin, សាលក្រម កថាខណ្ឌ២០៣, ២២៦-២២៧, ៦៧៨-៦៧៩, ៦៨១, ៦៨៣, ៧០១។ Kvočka, សាលក្រម កថាខណ្ឌ២០៩។

3880 Prlić, សាលក្រម ភាគ ៣, កថាខណ្ឌ១១៥៩, ១១៦១, ១១៦៤, ១១៦៧-១១៦៨, ១១៧០-១១៧២, ១១៧៦-១១៧៨, ១១៨១-១១៨២, ១១៨៤, ១១៩២-១១៩៤, ១១៩៧-១១៩៩, ១២០១-១២០២, ១២០៤-១២០៥។ Limaj, សាលក្រម កថាខណ្ឌ២៨៨-២៨៩, ៣៣៣, ៦៥២។ Čelebići, សាលក្រម កថាខណ្ឌ១១១៩។ អានបន្ថែម Prlić, សាលក្រម ភាគ ៣, កថាខណ្ឌ១១០២-១១១១, ១១១៤-១១១៦, ១១១៨-១១២០, ១១២៤-១១២៦, ១១២៩-១១៣០, ១១៣២-១១៣៣, ១១៣៥-១១៣៧, ១១៤០-១១៤២, ១១៤៥-១១៤៧, ១១៤៩-១១៥០, ១១៥២-១១៥៣ [ឃើញថាមានការធ្វើបាបដែលបង្កឲ្យមានការប្រព្រឹត្តល្មើយ៉ាងអមនុស្សធម៌ ដែលជាការរំលោភយ៉ាងធ្ងន់ធ្ងរទៅនឹងអនុសញ្ញាក្រុងហ្សឺណែវ]។

3881 សាលដីកា Karadžić អនុលោមតាមវិធាន៩៨ស្ទួន កថាខណ្ឌ៤៨-៤៩។ Brđanin, សាលក្រម កថាខណ្ឌ៦៩១។ Kayishema & Ruzindana, សាលក្រម កថាខណ្ឌ១១៥-១១៦។

*គ) អាពាហ៍ពិពាហ៍ដោយបង្ខំ*

973. ក.ស.ច.ស និង SCSL បានទទួលស្គាល់ថា អាពាហ៍ពិពាហ៍ដោយបង្ខំអាចមានទម្ងន់ស្រដៀងទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលមានចែង និងហេតុដូច្នេះស្ថិតក្នុងចង្កោមទទួលខុសត្រូវនៃ "អំពើអមនុស្សធម៌ដទៃទៀត"[3882]។ សិទ្ធិរួចផុតពីអាពាហ៍ពិពាហ៍ដោយបង្ខំ ជាសិទ្ធិសារវន្តដែលត្រូវបានទទួលស្គាល់ក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលអនុម័តដោយមហាសន្និបាត អ.ស.ប នៅថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨[3883]។ លិខិតុបករណ៍ជាច្រើនទៀត ដែលមានជាធរមាននៅឆ្នាំ ១៩៧៥ ក៏ទទួលស្គាល់សារៈសំខាន់នៃការព្រមព្រៀង មុនពេលចូលទៅដល់អាពាហ៍ពិពាហ៍[3884]។

974. អាពាហ៍ពិពាហ៍ដោយបង្ខំកើតឡើង នៅពេលចារីបង្ខំបុគ្គលណាម្នាក់ដោយកម្លាំង ការគំរាមកំហែងអំពីកម្លាំង ឬការបង្ខិតបង្ខំដើម្បីដើរតួនាទីជាដៃគូប្តីប្រពន្ធ[3885]។ "អាពាហ៍ពិពាហ៍" មានន័យថា ទំនាក់ទំនងផ្តាច់មុខរវាង "ប្តី" និង "ប្រពន្ធ"[3886]។ អាស្រ័យតាមកាលៈទេសៈ "អាពាហ៍ពិពាហ៍" អាចពាក់ព័ន្ធភារកិច្ចជាច្រើន ដូចជា ការរួមភេទ ការងារផ្ទះសម្បែង ការមានគភ៌ និងការថែទាំកូនៗដែលបានពី "អាពាហ៍ពិពាហ៍"[3887] និងអាចពាក់ព័ន្ធការប្រព្រឹត្តិឧក្រិដ្ឋកម្មអន្តរជាតិមួយ ឬច្រើនដូចជាការដាក់ជាទាសករ ការរំលោភផ្លូវភេទ ការបំពានផ្លូវភេទ ឬទាសករផ្លូវភេទ ក្នុង

---

3882 Brima, សាលដីកា កថាខណ្ឌ១៩៨-២០១។ Sesay, សាលក្រម កថាខណ្ឌ២៣០៦-២៣០៧។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣១៤, ១៤៤២-១៤៤៣, លេខជើងទំព័រ៥១៩៥។

3883 UDHR មាត្រា១៦(២) ["ការរៀបការត្រូវរៀបចំឡើងដោយមានការយល់ព្រមដោយស្ម័គ្រចិត្តរវាងអនាគតគូស្វាមីភរិយានោះ"]។

3884 អានឧទាហរណ៍អនុសញ្ញាស្តីពីការរៀបការដោយស្ម័គ្រចិត្ត (បុព្វកថានៃអនុសញ្ញានេះរម្លឹកឡើងវិញនូវមាត្រា១៦នៃ UDHR)។ មាត្រា១ចែងថា៖ "[ការរៀបការមួយដែលចាត់ទុកថាស្របច្បាប់នោះដរាបណាការរៀបចំនោះទទួលបានការយល់ព្រមពេញលេញដោយស្ម័គ្រចិត្តពីភាគីទាំងពីរ"។ ICCPR, មាត្រា២៣(៣) ["ការរៀបការត្រូវរៀបចំឡើងដោយមានការយល់ព្រមដោយស្ម័គ្រចិត្ត និងពេញលេញរវាងអនាគតគូស្វាមីភរិយានោះ"]។ ECHR, មាត្រា៨ [បរិយាយ "សិទ្ធិទទួលបានការគោរពជីវិតឯកជន និងជីវិតគ្រួសារ", ដោយលើកឡើងថា "[បុគ្គលគ្រប់រូបមានសិទ្ធិទទួលបានការគោរពនូវជីវិតឯកជន និងជីវិតគ្រួសាររៀងៗខ្លួន", និង "[នោះមានន័យថាអាជ្ញាធរសាធារណៈពុំមានសិទ្ធិមកលូកដៃក្នុងជីវិតឯកជន និងជីវិតគ្រួសារ លើកលែងតែអំពើមានចែងក្នុងច្បាប់តែប៉ុណ្ណោះ"], ១២ [ពាក់ព័ន្ធនឹង "សិទ្ធិក្នុងការរៀបការ", ចែងថា "បុរស និងស្ត្រីគ្រប់វ័យរៀបការ មានសិទ្ធិរៀបការ និងបង្កើតគ្រួសារ"]។

3885 Brima, សាលដីកា កថាខណ្ឌ១៩៦។ Sesay, សាលដីកា កថាខណ្ឌ៧៣៥-៧៣៦។

3886 Brima, សាលដីកា កថាខណ្ឌ១៩៥។

3887 Brima, សាលដីកា កថាខណ្ឌ១៩០។

ចំណោមឧក្រិដ្ឋកម្មអន្តរជាតិនានា[3888]។ ប៉ុន្តែ អាពាហ៍ពិពាហ៍ដោយបង្ខំពុំមែនជាឧក្រិដ្ឋកម្មផ្លូវភេទដ៏ច្រើនលើសលប់ជាងគេនោះទេ ហើយអាពាហ៍ពិពាហ៍ដោយបង្ខំអាចកើតឡើង ដោយមិនចាំបាច់គិតថាតើ "ប្ដី" និង "ប្រពន្ធ" មានទំនាក់ទំនងផ្លូវភេទដែរ ឬយ៉ាងណានោះឡើយ[3889]។

975. កម្លាំងដែលត្រូវបានប្រើប្រាស់ដើម្បីបង្ខំឱ្យបុគ្គលណាម្នាក់រៀបការ មិនកំហិតត្រឹមការបង្ខំផ្លូវកាយឡើយ ប៉ុន្តែរួមបញ្ចូលការគំរាមកំហែងអំពីកម្លាំង ឬការបង្ខិតបង្ខំ ដូចជាការគំរាមកំហែងដែលបង្កឡើងដោយការភ័យខ្លាចអំពើហិង្សា ការបង្ខិតបង្ខំ ការឃុំឃាំង ការបង្ក្រាបផ្លូវចិត្ត ឬការបំពានអំណាច ឬតាមរយៈការកេងចំណេញពីបរិយាកាសចាប់បង្ខំ[3890]។ ក្នុងករណីដែលមានការបង្ហាញថាបរិយាកាសមានលក្ខណៈចាប់បង្ខំដែលធ្វើឱ្យការជ្រើសរើសដោយសេរី មិនអាចធ្វើទៅបាន ភាគីទាំងនោះមិនអាចបានព្រមព្រៀងទៅនឹងអាពាហ៍ពិពាហ៍ណាមួយឡើយ។ កាលៈទេសៈនានាទូទៅក្នុងករណីភាគច្រើនដែលត្រូវបានចោទប្រកាន់ជាឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ "នឹងស្ទើរតែមានលក្ខណៈចាប់បង្ខំជាសកល" ដែលធ្វើឱ្យការព្រមព្រៀងពិតប្រាកដមិនអាចធ្វើទៅបាន[3891]។ ស្រដៀងនេះ បរិយាកាសភ័យខ្លាច[3892] ឬស្ថានភាពនៃការបង្ខាំង ឬការឃុំឃាំង [3893] ត្រូវបានទទួលស្គាល់ថាជាការធ្វើមោឃភាពការព្រមព្រៀងពិតប្រាកដ។ ក្នុងបរិយាកាសចាប់បង្ខំ ផលប្រយោជន៍នានា ដែលជនរងគ្រោះនៃអាពាហ៍ពិពាហ៍ដោយបង្ខំ អាចទទួលពីចារី ពុំបង្ហាញអំពីការព្រមព្រៀងទៅនឹងទំនាក់ទំនងប្តីប្រពន្ធដោយបង្ខំ ឬធ្វើមោឃភាព លក្ខណៈឧក្រិដ្ឋនៃទង្វើរបស់ចារីឡើយ[3894]។

---

3888 Brima, សាលដីកា កថាខណ្ឌ២០១។

3889 Brima, សាលដីកា កថាខណ្ឌ១៩៥។

3890 Sesay, សាលដីកា កថាខណ្ឌ៧៣៦។ Stakić, សាលដីកា កថាខណ្ឌ២៨១។

3891 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៦៣។ Gacumbitsi, សាលដីកា កថាខណ្ឌ១៥១។ Taylor, សាលក្រម កថាខណ្ឌ៤១៦។ ទោះបីជារបកគំហើញនេះពាក់ព័ន្ធទៅនឹងការរំលោភសេពសន្ថវៈក្តី វាក៏អាចប្រើប្រាស់បានក្នុងបរិបទនៃការរៀបការដោយបង្ខំដែរ។

3892 Krnojelac, សាលដីកា កថាខណ្ឌ១៩៤។

3893 Sesay, សាលដីកា កថាខណ្ឌ៧៣៦។ សូមអាន Kvočka, សាលដីកា កថាខណ្ឌ៣៩៦។ Kunarac, សាលដីកា កថាខណ្ឌ១៣២-១៣៣។ Muhimana, សាលក្រម កថាខណ្ឌ៥៤៥។ Krnojelac, សាលដីកា កថាខណ្ឌ១៩៤-១៩៥, ២២៦-២៣៣។

3894 Brima, សាលដីកា កថាខណ្ឌ១៩០។

*ឃ) ការរំលោភផ្លូវភេទ*

976. ទោះបីការរំលោភផ្លូវភេទត្រូវបានចែងថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ក៏ដោយ ក៏ អ.ប.ជ និង អ.ជ.ត.ក បានសម្រេចថា អំពើរំលោភសេពសន្ថវៈ ពុំមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែក ក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ឡើយ[3895]។ ប៉ុន្តែ អ.ប.ជ បានបញ្ជាក់អះអាងថា អង្គហេតុដែលចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់អំពើរំលោភសេពសន្ថវៈ អាចត្រូវបានចាត់ទុកបន្ថែមថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ "អំពើអមនុស្សធម៌ដទៃទៀត"[3896]។ លើសពីនេះ តុលាការ ICTY, ICTR, SCSL និង ICC បានទទួលស្គាល់អំពើរំលោភសេពសន្ថវៈ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែក[3897]។ អំពើរំលោភសេពសន្ថវៈក៏អាចជាទារុណកម្មផងដែរ ប្រសិនបើធាតុផ្សំនៃទារុណកម្មត្រូវបានរកឃើញ[3898]។ ហេតុដូច្នេះ លក្ខខណ្ឌតម្រូវស្តីពីភាពធ្ងន់ធ្ងរសម្រាប់ការកំណត់ប្រភេទបទល្មើសលើអង្គហេតុដែលជាអំពើរំលោភសេពសន្ថវៈជា "អំពើអមនុស្សធម៌ដទៃទៀត" ត្រូវបានបំពេញយ៉ាងពិតជាក់ស្តែង។

977. ចំពោះអ្វីទៅដែលហៅថា "អំពើរំលោភសេពសន្ថវៈ" មានការមិនស៊ីចង្វាក់ខ្លះក្នុងនិយមន័យរបស់វាក្នុងចំណោមអង្គជំនុំជម្រះ អ.វ.ត.ក និងសាលាក្តីអន្តរជាតិ។ ក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ក.ស.ច.ស បានប្រើប្រាស់យ៉ាងទូលាយនូវនិយមន័យ ដែលប្រើប្រាស់ដោយអង្គជំនុំជម្រះ

---

[3895] សំណុំរឿង០០១ ឯកសារ F28 សាលដីកា ឌុច, កថាខណ្ឌ១៨៣, ២១៣។ សំណុំរឿង០០២ ឯកសារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ១៥៤។ សំណុំរឿង០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ៣៦៤-៣៦៥, ៣៧១។

[3896] សំណុំរឿង០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ៣៧២។ សំណុំរឿង០០២ ឯកសារ D427/2/15 សេចក្តីសម្រេចនៃដីកាដំណោះស្រាយនួន ជា និង អៀង ធីរិទ្ធ, កថាខណ្ឌ១៥៤។

[3897] ICTY: ICTY លក្ខន្តិកៈ, មាត្រា៥(ឆ)។ Kunarac, សាលដីកា កថាខណ្ឌ១៧៩។ ICTR: ICTR លក្ខន្តិកៈ, មាត្រា៣(ឆ)។ Akayesu, សាលក្រម កថាខណ្ឌ៥៩៦។ SCSL: SCSL លក្ខន្តិកៈ, មាត្រា២(ឆ)។ Sesay, សាលក្រម កថាខណ្ឌ១៤៤។ ICC: លក្ខន្តិកៈ ICC, មាត្រា៧(១)(ឆ)។

[3898] សំណុំរឿង០០១ ឯកសារ F28 សាលក្រមសាលាឧទ្ធរណ៍ ឌុច, កថាខណ្ឌ២០៧-២០៨, ២១១។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៥៥, ៣៦៦។ Akayesu, សាលក្រម កថាខណ្ឌ៦៨៧។

សាលាដំបូងនៃតុលាការ ICTR ក្នុងសំណុំរឿង *Akayesu*[3899] ដោយបានសម្រេចថា "តាមរយៈការផ្សំដំណោកនៃអាពាហ៍ពិពាហ៍ដោយបង្ខំ[3900] ចារីបានប្រព្រឹត្តការបំពានផ្លូវកាយដែលមានលក្ខណៈផ្លូវភេទទៅលើជនរងគ្រោះក្នុងកាលៈទេសៈចាប់បង្ខំ ដែលមិនមានការព្រមព្រៀងពីជនរងគ្រោះ"[3901]។ ទាំងបុរស និងស្ត្រីអាចស្ថិតក្រោមការបំពានផ្លូវកាយ[3902] ហើយ **មាស មុត** ត្រូវបានចោទប្រកាន់ពីអំពើហិង្សាផ្លូវភេទ ដែលជាអំពើរំលោភសេពសន្ថវៈ តាមរយៈការផ្សំដំណោកដោយបង្ខំនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ប្រឆាំងទាំងបុរស និងស្ត្រី។

978. និយមន័យចង្អៀតជាងនេះដទៃទៀតនៃអំពីរំលោភសេពសន្ថវៈ ត្រូវបានស្នើឡើង ។ ក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តតាម ICTY ក្នុងការកំណត់និយមន័យធាតុផ្សំជាក់ស្តែងឲ្យកាន់តែចង្អៀតជាងមុនជាការស៊កបញ្ចូល ទោះជាបន្តិចបន្តួចចូលក្នុង (ក) យោនី ឬរន្ធគូថរបស់ជនរងគ្រោះ ដោយលិង្គចារី ឬវត្ថុផ្សេងៗដែលប្រើដោយចារី ឬ (ខ) មាត់របស់ជនរងគ្រោះដោយលិង្គចារី ប្រសិនបើការស៊កបញ្ចូលប្រដាប់ភេទកើតឡើងដោយគ្មានការព្រមព្រៀងពីជនរងគ្រោះ[3903]។ និយមន័យ ICC ចែកចេញជាពីរ ដែលតម្រូវថា "ចារីបានបំពានរាងកាយបុគ្គលណាម្នាក់ តាមរយៈទង្វើដែលបានញ៉ាំងទៅដល់ការស៊កបញ្ចូល ទោះជាបន្តិចបន្តួចនៃផ្នែកណាមួយនៃរាងកាយជនរងគ្រោះ ឬរបស់ចារីជាមួយប្រដាប់ភេទ ឬការបើករន្ធគូថ ឬប្រដាប់ភេទរបស់ជនរងគ្រោះ ជាមួយវត្ថុនានា ឬផ្នែកនានានៃរាងកាយ"[3904]។

979. សហព្រះរាជអាជ្ញាលើកឡើងថា និយមន័យដែលប្រើនៅតុលាការ ICTY, ICC និងប្រើដោយអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ មានភាពចង្អៀតមិនសមស្រប ដោយសារនិយមន័យទាំងនោះត្រូវបានសរសេរដើម្បីឲ្យត្រូវទៅនឹងអង្គហេតុដែលចារីបានកំពុងស៊កបញ្ចូល ឬ (នៅ ICC មួយប៉ុណ្ណោះ) កំពុងត្រូវបានស៊កបញ្ចូល ដោយផ្នែកមួយនៃរាងកាយរបស់ជនរងគ្រោះ ដោយ

---

3899 Akayesu, សាលក្រម កថាខណ្ឌ៥៩៨ [ពន្យល់ថា រំលោភសេពសន្ថវៈ "គឺជាការឈ្លានពានលើកេរភេទ ដែលប្រព្រឹត្តឡើងដោយការបង្ខិតបង្ខំ"]។

3900 យោងទៅលើតថភាពនៃរបកគំហើញក្នុងសំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ៨៥៨។

3901 សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៤៣១។ សូមអានកថាខណ្ឌ១៤២៧។

3902 ផ្ទុះបញ្ហាំងពីធាតុផ្សំនៃបទល្មើសឧក្រិដ្ឋកម្ម របស់ ICC, លេខជើងទំព័រ១៥. អានលេខជើងទំព័រ៣៩០៤ខាងក្រោម។

3903 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៦២។ Kunarac, សាលដីកា កថាខណ្ឌ១២៧។

3904 ធាតុផ្សំនៃបទល្មើសឧក្រិដ្ឋកម្ម របស់ ICC, មាត្រា៧(១)(ឆ)-១, ធាតុផ្សំ១ លេខជើងទំព័រ១៥, វាត្រូវគេចាត់ថ្នាក់ជា "ការយល់ឃើញជាចេតនា'ក្នុងការឈ្លានពាន"មានន័យទូលំទូលាយគ្រប់គ្រាន់ពាក់ព័ន្ធនឹងភេទ"។

គ្មាន ការព្រមព្រៀងពីជនរងគ្រោះ។ និយមន័យដែលស៊ីជម្រៅ ទូលំទូលាយ និងដែលមានសមភាពយែនឌ័រ នឹងតម្រូវឱ្យមានការស៊កបញ្ចូលទោះជាបន្តិចបន្តួចទៅក្នុងយោនី រន្ធគូថរបស់ជនណាម្នាក់ដោយវត្ថុ ឬផ្នែកនៃរាងកាយរបស់ជនម្នាក់ទៀត ឬការប៉ះប្រដាប់ភេទរបស់ជនណាម្នាក់ដោយផ្នែកណាមួយនៃមាត់របស់ជនម្នាក់ទៀត ដោយគ្មានការព្រមព្រៀងពីសំណាក់អ្នកចូលរួមម្នាក់ ឬទាំងពីរក្នុងសកម្មភាពផ្លូវភេទ។ ក្នុងករណីណាក៏ដោយ ដោយមិនគិតថាតើវាឆ្លើយតបទៅនឹងនិយមន័យគតិយុត្តិមុនៗនៃបទល្មើសរំលោភសេពសន្ថវៈ ដោយបង្ខំឱ្យបុគ្គលណាម្នាក់ ឬប្ដីប្រពន្ធមានទំនាក់ទំនងផ្លូវភេទដោយគ្មានការព្រមព្រៀងរបស់ពួកគាត់ គឺពិតជាបទល្មើសដែលមានភាពធ្ងន់ធ្ងរដូចគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដទៃទៀត[3905]។ ទង្វើនេះឆ្លើយតបជាក់ស្ដែងទៅនឹងនិយមន័យនៃ "អំពើអមនុស្សធម៌ដទៃទៀត" ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយបានបង្កទុក្ខវេទនាផ្លូវចិត្ត ឬផ្លូវកាយធ្ងន់ធ្ងរ ទៅលើជនរងគ្រោះ និងជាការវាយប្រហារធ្ងន់ធ្ងរមួយទៅលើសេចក្ដីថ្លៃថ្នូររបស់ជនរងគ្រោះ។

980. ការព្រមព្រៀងសម្រាប់គោលបំណងនេះ ត្រូវតែផ្ដល់ដោយស្ម័គ្រចិត្ត ដែលជាលទ្ធផលនៃឆន្ទៈសេរីរបស់ជនរងគ្រោះដែលត្រូវបានវាយតម្លៃក្នុងបរិបទនៃកាលៈទេសៈជុំវិញ[3906]។ ការបង្ខំ ឬការគំរាមអំពីការបង្ខំ អាចផ្ដល់ភ័ស្តុតាងអំពីការមិនឯកភាព ប៉ុន្តែការបង្ខំពុំមែនជាធាតុផ្សំនៃអំពើរំលោភសេពសន្ថវៈឡើយ ហើយមានកត្តានានាក្រៅពីការបង្ខំដែលធ្វើឱ្យការដាក់លិង្គបញ្ចូល កើតឡើងដោយមិនដោយការព្រមព្រៀង ឬការស្ម័គ្រចិត្តពីសំណាក់ជនរងគ្រោះ[3907]។ ភ័ស្តុតាងអំពីការមិនព្រមព្រៀង (ឬការមិនព្រមព្រៀងជាបន្តបន្ទាប់) របស់ជនរងគ្រោះក៏ពុំត្រូវបានតម្រូវផងដែរ[3908]។ ជនណាម្នាក់អាចមិនមានលទ្ធភាពផ្ដល់ការព្រមព្រៀងពិតប្រាកដ ប្រសិនបើជននោះអសមត្ថភាពពី

---

3905 ការទាមទារឱ្យអ្នកដទៃរួមភេទជាមួយគ្នា ឃើញថាជាបទល្មើសប្រទុស្តកេរហើយមានទោសមានចែងនៅក្នុងផ្នែកអំពីនៃការធ្វើទុក្ខបុកម្នេញរបស់ CAH។ អាន Brđanin, សាលក្រម កថាខណ្ឌ១០១២-១០១៣។

3906 Kunarac, សាលដីកា កថាខណ្ឌ១២៧-១២៨។ Taylor, សាលក្រម កថាខណ្ឌ៤១៦។

3907 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៦៣។ Kunarac, សាលដីកា កថាខណ្ឌ១២៩-១៣០។ Taylor, សាលក្រម កថាខណ្ឌ៤១៦។ Brima, សាលក្រម កថាខណ្ឌ៦៩៤។

3908 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៦៣។ Kunarac, សាលដីកា កថាខណ្ឌ១២៨។ Gacumbitsi, សាលដីកា កថាខណ្ឌ១៥៥។ Taylor, សាលក្រម កថាខណ្ឌ៤១៦។

ធម្មជាតិ ឬអសមត្ថភាពដោយសារកត្តាទាក់ទងនឹងអាយុ[3909]។ កាលៈទេសៈទាំងឡាយទូទៅក្នុងសំណុំរឿងភាគច្រើនដែលត្រូវបានចោទប្រកាន់ជាឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ "នឹងមានលក្ខណៈចាប់បង្ខំស្មើរតែជាសកល" ដែលធ្វើឲ្យការព្រមព្រៀងពិតប្រាកដមិនអាចធ្វើទៅបាន[3910]។ ភ័ស្តុតាងពិស្តារអាចត្រូវបានប្រើប្រាស់ដើម្បីបង្ហាញអំពីអំពើរំលោភសេពសន្ថវៈ[3911]។

*ង) ការបាត់ខ្លួនដោយបង្ខំ*

981. ក.ស.ច.ស អង្គជំនុំជម្រះសាលាដំបូងរបស់ អ.វ.ត.ក តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន សុទ្ធតែបានទទួលស្គាល់ថា ការបាត់ខ្លួនដោយបង្ខំ អាចជាផ្នែកមួយនៃស្ថានទម្ងន់ចាំបាច់បង្កើតបានជា "អំពើអមនុស្សធម៌ដទៃទៀត" ដោយបំពេញលក្ខខណ្ឌផ្សេងទៀតទាំងអស់។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិក៏ទទួលស្គាល់ផងដែរថា ការបាត់ខ្លួនដោយបង្ខំ គឺជាឧក្រិដ្ឋកម្មដាច់ដោយឡែកមួយ ដែលមានចែងនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

982. ការបាត់ខ្លួនដោយបង្ខំត្រូវបានរកឃើញថាបានកើតឡើង នៅពេល (i) បុគ្គលម្នាក់ត្រូវបានដកហូតសេរីភាពរបស់គាត់ ដូចជា តាមរយៈការចាប់ខ្លួន ការឃុំឃាំង ឬការចាប់ពង្រត់ និង (ii) ការដកហូតសេរីភាពត្រូវបានអម ឬកើតមានតាមក្រោយដោយការបដិសេធមិនបញ្ចេញព័ត៌មានទាក់ទងនឹងជោគវាសនា ឬកន្លែងលាក់ខ្លួនរបស់បុគ្គលពាក់ព័ន្ធ ឬមិនទទួលស្គាល់ការដកហូតសេរីភាពនោះ និងហេតុនេះ បដិសេធជម្រើសនីមួយៗលើដំណោះស្រាយផ្នែកច្បាប់ ដែលអាចអនុវត្តបាន និងការធានាផ្នែកនីតិវិធី និង (iii) ធាតុផ្សំទីមួយ និងទីពីរ ត្រូវបានធ្វើឡើងដោយភ្នាក់ងាររដ្ឋ ឬដោយមានការអនុញ្ញាត ការគាំទ្រ ឬការយល់ព្រមពីសំណាក់រដ្ឋ ឬអង្គការនយោបាយមួយ។

---

[3909] Sesay, សាលក្រម កថាខណ្ឌ១៤៨។ Taylor, សាលក្រម កថាខណ្ឌ៤១៦. សូមអានធាតុផ្សំនៃបទល្មើសឧក្រិដ្ឋកម្មរបស់ ICC, មាត្រា៧(១)(ឆ)-១, ធាតុផ្សំ២, លេខជើងទំព័រ១៦។

[3910] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៦៣។ Gacumbitsi, សាលដីកា កថាខណ្ឌ១៥១។ Taylor, សាលក្រម កថាខណ្ឌ៤១៦។

[3911] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៦៤។ Muhimana, សាលដីកា កថាខណ្ឌ៤៨-៤៩។ Sesay, សាលក្រម កថាខណ្ឌ១៤៩។

## ច) ពលកម្មដោយបង្ខំ

983. ច្បាប់អន្តរជាតិ និងលិខិតុបករណ៍សិទ្ធិមនុស្ស ហាមឃាត់យ៉ាងទូលំទូលាយលើពលកម្មដោយបង្ខំ ឬដោយអចេតនា[3912]។ លើសពីនេះទៀត ទាំងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងតុលាការពិសេសសម្រាប់សៀរ៉ាឡេអូន សុទ្ធតែបានទទួលស្គាល់ថា ពលកម្មដោយបង្ខំអាចបំពេញយ៉ាងច្បាស់លាស់នូវលក្ខខណ្ឌស្ថានទម្ងន់ដែលជា "អំពើអមនុស្សធម៌ដទៃទៀត"[3913]។ ដូចដែលបានពិភាក្សានៅខាងលើ ពលកម្មដោយបង្ខំអាចជាការធ្វើឱ្យទៅជាទាសករ នៅពេលវាអមដោយសញ្ញាបង្ហាញពីភាពជាម្ចាស់[3914]។ អំពើនៃពលកម្មដោយបង្ខំដែលត្រូវបានប្រព្រឹត្តឡើងដោយចេតនារើសអើង និងដែលមានអានុភាពត្រូវ ដែលកើនឡើងដល់កម្រិតស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលបានរៀបរាប់ក្នុងមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ត្រូវបានរកឃើញថាជាការធ្វើទុក្ខបុកម្នេញក្នុងន័យជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[3915]។

984. ចំណុចថាតើពលកម្មត្រូវបានបង្ខំ ឬក៏អត់ គឺជាការកំណត់អង្គហេតុ ដែលត្រូវតែយកមកពិចារណាតាមរយៈកាលៈទេសៈពាក់ព័ន្ធទាំងអស់ ដោយផ្អែកតាមករណីនីមួយៗ[3916]។ ជារួម វាត្រូវតែមានការបង្ហាញថា ជនរងគ្រោះគ្មានជម្រើសពិតប្រាកដទាក់ទងនឹងថាតើពួកគេនឹងធ្វើការ ឬមួយក៏អត់[3917]។ កង្វះការយល់ព្រមទៅនឹងការងារ អាចនឹងត្រូវបានសន្និដ្ឋាននៅត្រង់ចំណុចណាដែលការ

---

3912 ICCPR មាត្រា៨(៣)(ក) ["បុគ្គលគ្រប់រូបមិនត្រូវរងនូវការធ្វើពលកម្មដោយបង្ខំ ឬជាប់កាតព្វកិច្ចពលកម្មឡើយ"]។ ECHR មាត្រា៤(២) ["បុគ្គលគ្រប់រូបមិនត្រូវរងនូវការធ្វើពលកម្មដោយបង្ខំ ឬជាប់កាតព្វកិច្ចពលកម្មឡើយ"]។ ACHR មាត្រា៦(២) ["បុគ្គលគ្រប់រូបមិនត្រូវរងនូវការធ្វើពលកម្មដោយបង្ខំ ឬជាប់កាតព្វកិច្ចពលកម្មឡើយ"]។

3913 Krnojelac, សាលក្រម កថាខណ្ឌ៣៥៩។ Sesay, សាលក្រម កថាខណ្ឌ២០២។

3914 អាន IX.ក.២. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ -បទល្មើសជាក់ស្តែង-៣. ផ្នែកទាសភាព។

3915 អានឧទាហរណ៍សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៧៨។ Krnojelac, សាលដីកា កថាខណ្ឌ១៩៩-២០៣។ Blaškić, សាលដីកា កថាខណ្ឌ១៥៤-១៥៥។ Krajišnik, សាលក្រម កថាខណ្ឌ៧៦០-៧៦១, ៨១៦-៨១៨។

3916 នេះជាវិធីសាស្ត្រដែលបានប្រើប្រាស់ក្នុងការវិភាគថាតើការធ្វើពលកម្មដោយបង្ខំនាំឱ្យក្លាយជាទាសកម្ម ប៉ុន្តែក៏លើកឡើងផងដែរនូវលក្ខណវិនិច្ឆ័យដែលពាក់ព័ន្ធនៅក្រៅបរិបទនៃអំពើទាសកម្ម។ អានឧទាហរណ៍ Krnojelac, សាលក្រម កថាខណ្ឌ៣៥៩, ៣៧២។ Sesay, សាលក្រម កថាខណ្ឌ២០២។

3917 Krnojelac, សាលក្រម កថាខណ្ឌ៣៥៩, ៣៧២។ Sesay, សាលក្រម កថាខណ្ឌ២០២។ Taylor, សាលក្រម កថាខណ្ឌ៤៤៨។

បញ្ចេញមតិពីការយល់ព្រមនេះមិនអាចធ្វើទៅបាន[3918] ដូចជាត្រង់ចំណុចដែលជនរងគ្រោះរស់នៅក្នុង "បរិយាកាសភ័យខ្លាច" ជាដើម[3919]។ ក្នុងកាលៈទេសៈទាំងនេះ កង្វះការតស៊ូរើបម្រះ ឬ អវត្តមាននៃកង្វះការយល់ព្រមច្បាស់ៗ និងស៊ីចង្វាក់ នឹងមិនត្រូវបានបកស្រាយថាជាសញ្ញានៃការយល់ព្រមនោះទេ[3920]។ ឧទាហរណ៍ គេមិនអាចរំពឹងថា អ្នកជាប់ឃុំឃាំងសម្តែងការជំទាស់ ឬថាបុគ្គលម្នាក់សម្តែងការជំទាស់ នៅចំពោះមុខបុគ្គលម្នាក់ដែលមានសិទ្ធិអំណាចគំរាមកំហែងថានឹងដាក់ទណ្ឌកម្មលើគាត់ បើបុគ្គលនោះបដិសេធមិនព្រមធ្វើការនោះទេ[3921]។

985. ខណៈដែលកាលៈទេសៈបង្ខិតបង្ខំ អាចនាំឱ្យការព្រមព្រៀងធ្វើការពិតប្រាកដមិនអាចធ្វើទៅបាន ជំនឿអត្តនោម័តិរបស់ពលករដែលថា ពួកគេត្រូវបានបង្ខំឱ្យធ្វើការ ក៏ត្រូវបានគាំទ្រផងដែរដោយភស្តុតាងសត្យានុម័តិដើម្បីបង្ហាញពីកង្វះការយល់ព្រម[3922]។ កត្តាផ្សេងទៀតដែលត្រូវបានយកពិចារណាក្នុងការកំណត់នេះ រួមមាន កង្វះការផ្តល់សំណង ទីតាំងងាយរងគ្រោះរបស់ពលករ ផលវិបាកដែលរងការចោទប្រកាន់ថានឹងកើតមានចំពោះអ្នកដែលមិនអាច ឬមិនមានឆន្ទៈធ្វើការ ការត្អូញត្អែរអំពីផលវិបាករយៈពេលវែងនៃពលកម្មនោះ ការពិតដែលថា ពលករត្រូវបានគេឃុំឃាំង ហើយលក្ខខណ្ឌអមនុស្សធម៌មានពិតប្រាកដមែននៅក្នុងមន្ទីរឃុំឃាំង[3923]។ មានការសម្រេចថា លក្ខខណ្ឌដែលមានមនុស្សកកកុញធ្ងន់ធ្ងរ អនាម័យដ៏គួរឱ្យសង្វេគ កង្វះដំណេក អាហារមិនគ្រប់គ្រាន់ ការចាក់សោរទ្វារ ការវាយដំជាញឹកញាប់ ការរំលោភបំពានផ្លូវចិត្ត និងស្ថានភាពរស់នៅដ៏ឃោរឃៅ ដែលធ្វើឱ្យអ្នកជាប់ឃុំមិនអាចបដិសេធមិនធ្វើការ ហើយថា ពលកម្មរបស់ពួកគេត្រូវបានបង្ខំ[3924]។ អង្គជំនុំជម្រះចំនួនពីរក៏បានចាត់ទុករឿងក្តី *Pohl* ពីសង្គ្រាមលោកលើកទីពីរថាមានការជាប់ពាក់

---

[3918] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៣៨៣។ Kunarac, សាលដីកា កថាខណ្ឌ១២០។

[3919] Krnojelac, សាលដីកា កថាខណ្ឌ១៩៤។

[3920] Kunarac, សាលដីកា កថាខណ្ឌ១២០។ Krnojelac, សាលដីកា កថាខណ្ឌ១៩៤-១៩៥។

[3921] Krnojelac, សាលដីកា កថាខណ្ឌ១៩៤។

[3922] Krnojelac, សាលដីកា កថាខណ្ឌ១៩៤-១៩៥។ Krnojelac, សាលក្រម កថាខណ្ឌ៣៥៩, ៣៧២។ Krajišnik, សាលក្រម កថាខណ្ឌ៧៥៨, ៨១៥។ Sesay, សាលក្រម កថាខណ្ឌ២០២។

[3923] Krnojelac, សាលក្រម កថាខណ្ឌ៣៧៣។ Sesay, សាលដីកា កថាខណ្ឌ១០៨២។

[3924] Krnojelac, សាលដីកា កថាខណ្ឌ១៩៣-១៩៥។

ព័ន្ធផងដែរ ដែលបានសម្រេចថា ទោះបីជាជនរងគ្រោះត្រូវបានប្រព្រឹត្តដាក់យ៉ាងល្អក្តី ក៏ពលកម្ម ដែលគ្មានសំណង និងខានមិនបាននេះ នៅតែជាពលកម្មទាសភាពដដែល[3925]។

986. វាជាការសំខាន់ណាស់ដែលត្រូវកត់សម្គាល់ថា ជាការពិត មានកាលៈទេសៈមួយចំនួនដែលបុគ្គលម្នាក់ៗនៅក្នុងមន្ទីរឃុំឃាំងអាចត្រូវបានបង្ខំឱ្យធ្វើការស្របច្បាប់ដោយគ្មានសំណង។ ការងារបែបនោះត្រូវតែធ្វើឡើងក្នុងអំឡុងពេលធម្មតានៃការឃុំឃាំង*ស្របច្បាប់* មិនមែនក្រៅប្រព័ន្ធតុលាការនោះទេ និងមិនអាចបង្កឱ្យមានការរងទុក្ខ ឬការរងរបួសផ្នែកផ្លូវចិត្ត ឬផ្លូវកាយ មិនមែនជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស និងមិនភ្ជាប់នឹងប្រតិបត្តិការសង្គ្រាម ឬមានចរិតលក្ខណៈ ឬគោលបំណងយោធាឡើយ[3926]។

---

[3925] Kunarac, សាលដីកា កថាខណ្ឌ១២៣។ Sesay, សាលក្រម កថាខណ្ឌ២០៣។ ស្រង់ពីសង្គ្រាមលោកលើកទី២ទាំងពីរគឺសំណុំរឿង US តទល់នឹង Oswald Pohl និងសាលដីកាដទៃទៀត ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ១៩៤៧, បោះពុម្ពឡើងវិញការជុំនុំជម្រះក្តីជនល្មើសនៃឧក្រិដ្ឋកម្មសង្គ្រាម នៅចំពោះមុខតុលាការយោធា Nuremberg ក្រោមក្រុមប្រឹក្សាត្រួតពិនិត្យ លេខ១០ ភាគ ៥ (ឆ្នាំ១៩៩៧), ទំព័រ៩៧០។

[3926] ECHR មាត្រា៤(៣) ["គោលបំណងនៃមាត្រានេះ"ពលកម្មដោយបង្ខំ ឬជាប់កាតព្វកិច្ចពលកម្ម"នឹងមិនត្រូវរាប់បញ្ចូលទេ៖ (ក) ការងារណាដែលតម្រូវឱ្យធ្វើជាធម្មតានៅក្នុងអំឡុងពេលជាប់ឃុំ អនុលោមតាមបញ្ញត្តិមាត្រា៥ នៃអនុសញ្ញានេះ"]។ ICCPR មាត្រា៨(៣)(ខ) ["កថាខណ្ឌ៣(ក) មិនត្រូវបដិសេធទេ នៅប្រទេសមួយចំនួន អ្នកជាប់ឃុំត្រូវធ្វើការជាទម្ងន់ នោះជាទណ្ឌកម្មសម្រាប់បទល្មើសដែលខ្លួនបានប្រព្រឹត្ត ការអនុវត្តទោសបែបនេះត្រូវធ្វើឡើងត្រូវអនុលោមតាមការផ្តន្ទាទោសដោយតុលាការតែប៉ុណ្ណោះ"], មាត្រា៨(៣)(គ) ["គោលបំណងនៃកថាខណ្ឌនេះ "ពលកម្មដោយបង្ខំ ឬជាប់កាតព្វកិច្ចពលកម្ម" នឹងមិនត្រូវរាប់បញ្ចូលទេ៖ (i) រាល់ការងារ ឬសេវាកម្ម មិនមានយោងក្នុងកថាខណ្ឌតូច (ខ) ទេ។ ជាធម្មតាគេទាមទារឱ្យមនុស្សដែលនៅជាប់ឃុំនូវផលវិបាកនៃដីកាស្របច្បាប់ពីតុលាការ"]។ ACHR មាត្រា៦(២) ["បទបញ្ញត្តិនេះនឹងមិនត្រូវបកស្រាយថា នៅក្នុងប្រទេសទាំងនោះដែលមានទណ្ឌកម្មបែបនេះសម្រាប់ឧក្រិដ្ឋរបស់អ្នកជាប់ឃុំថាជាការដកហូតនូវសេរីភាពបុគ្គលចំពោះការងារដោយបង្ខំនោះទេ ការដាក់ទណ្ឌកម្មបែបនេះចេញដោយតុលាការត្រូវបានហាមឃាត់។ ការងារដោយបង្ខំនេះមិនត្រូវផ្ទុយនឹងសេក្តីថ្លៃថ្នូរ ឬរូបរាងកាយ ឬបញ្ញាញាណរបស់អ្នកទោសទេ"], មាត្រា៦(៣) ["គោលបំណងនៃមាត្រានេះ, ចំណុចខាងក្រោមនេះមិនអាចចាត់ជាពលកម្មដោយបង្ខំ ឬជាប់កាតព្វកិច្ចពលកម្មទេ៖ ១. កិច្ចការ ឬសេវាជាធម្មតាដែលអ្នកជាប់ទោសម្នាក់ត្រូវធ្វើដើម្បីអនុវត្តទោសរបស់ខ្លួន ឬសេចក្តីសម្រេចជាផ្លូវការដែលចេញដោយអាជ្ញាធរតុលាការ"]។ Krnojelac, សាលដីកា កថាខណ្ឌ២០០ [កិច្ចការដែលទាមទារឱ្យបុគ្គលម្នាក់ធ្វើជាប្រចាំ ដោយស្របច្បាប់នៅក្នុងឃុំខ្លួន ដោយមិនគិតពីពលកម្មដោយបង្ខំ ឬជាប់កាតព្វកិច្ចពលកម្មលើយ]។ Blaškić, សាលដីកា កថាខណ្ឌ៥៩៦-៩៧ [ការបង្ខំអ្នកជាប់ឃុំឱ្យជីកលេនដ្ឋានគឺជា "ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្សយ៉ាងធ្ងន់ធ្ងរ" វាបណ្តាលឱ្យមានវិបត្តិផ្លូវចិត្តធ្ងន់ធ្ងរ ឬរបួសផ្នែករាងកាយដោយសារតែការងារមិនពាក់ព័ន្ធនឹងប្រតិបត្តិការសង្គ្រាម ឬមានលក្ខណៈ ឬគោលបំណងជាកងទ័ព]។

## ៣. ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ

987. មាត្រា ៦ នៃច្បាប់ អ.វ.ត.ក ផ្តល់ដល់ អ.វ.ត.ក នូវយុត្តាធិការលើការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ។ ការបំពារបំពានធ្ងន់ធ្ងរ គឺជាឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិក្នុងអំឡុងពេលនៃយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ដែលអាចប្រមើលមើលដឹង និងអាចដឹងថាមានច្បាប់ ពីសំណាក់ជនជាប់ចោទ[3927]។ បទល្មើសជាក់លាក់ដែលមានចែងក្នុងមាត្រា ៦ រួមមាន ការសម្លាប់ដោយចេតនា ការធ្វើទារុណកម្ម ឬការប្រព្រឹត្តិមកលើដោយអមនុស្សធម៌ ការបង្កការឈឺចាប់ធ្ងន់ធ្ងរដោយចេតនា ឬរបួសធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬប្រជាជនស៊ីវិលនូវសិទ្ធិក្នុងការទទួលការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ និងដោយប្រក្រតី និងការនិរទេស ឬផ្ទេរ ឬឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។ ធាតុផ្សំនៃបទល្មើសទាំងនេះ ត្រូវបានពិភាក្សាដូចខាងក្រោម។

988. ចំពោះការប្រព្រឹត្តិបទល្មើសដែលបង្កើតជាការបំពារបំពានធ្ងន់ធ្ងរទាំងនេះ លក្ខខណ្ឌតម្រូវទូទៅមួយចំនួនត្រូវតែបានបំពេញ៖ ១) បទល្មើសជាក់លាក់ត្រូវតែបានប្រព្រឹត្តឡើងក្នុងបរិបទនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ២) ចារីត្រូវតែដឹងពីកាលៈទេសៈអង្គហេតុដែលបង្ហាញពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធ ៣) អំពើត្រូវតែបានប្រព្រឹត្តឡើងប្រឆាំងនឹងបុគ្គល ឬទ្រព្យសម្បត្តិដែលត្រូវបានការពារ ក្រោមអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ មួយ ឬច្រើន និង ៤) ចារីត្រូវតែដឹងពីកាលៈទេសៈអង្គហេតុ ដែលបង្ហាញពីឋានៈទទួលបានការការពារនេះ[3928]។

---

Krnojelac, សាលក្រម កថាខណ្ឌ៣៦០ [ពាក់ព័ន្ធនឹងលក្ខណ្ឌទាំងនេះ និងវិធានការណ៍ការពារត្រូវតែអង្កេតឲ្យបានដិតដល់]។

[3927] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤០២-៤០៨។ សំណុំរឿង០០២ ឯកសារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ១២៤។

[3928] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤០៩-៤១០។ Naletilić& Martinović, សាលដីកា កថាខណ្ឌ១១០, ១១៦-១២១។

## លក្ខខណ្ឌតម្រូវទូទៅ

### ជម្លោះប្រដាប់អាវុធអន្តរជាតិ

989. លក្ខខណ្ឌតម្រូវនៃជម្លោះប្រដាប់អាវុធអន្តរជាតិ មានធាតុផ្សំចំនួនពីរ៖ ១) ត្រូវតែមានជម្លោះប្រដាប់អាវុធ និង ២) ត្រូវតែមានទំនាក់ទំនងគ្នារវាងជម្លោះ និងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់។

990. ជម្លោះប្រដាប់អាវុធអន្តរជាតិត្រូវតែមានអត្ថិភាពជាក់ស្តែង[3929]។ ជម្លោះប្រដាប់អាវុធមានអត្ថិភាព "នៅពេលណាដែលមានការពើបប្រយុទ្ធដោយប្រើកងកម្លាំងប្រដាប់អាវុធ រវាងរដ្ឋ និងរដ្ឋ ឬអំពើហិង្សាប្រដាប់អាវុធអូសបន្លាយ រវាងអាជ្ញាធររដ្ឋាភិបាល និងក្រុមប្រដាប់អាវុធដែលបានរៀបចំ ឬរវាងក្រុមបែបៗនោះ នៅក្នុងរដ្ឋមួយ" [3930]។ ជម្លោះប្រដាប់អាវុធមានលក្ខណៈជាអន្តរជាតិ នៅពេលណាដែលជម្លោះនោះជាប់ពាក់ព័ន្ធនឹងរដ្ឋពីរ ឬច្រើន[3931]។ ការអនុវត្តដោយភូមិសាស្ត្រ និងដោយពេលនៃអនុសញ្ញាទីក្រុងហ្សឺណែវ ពង្រីកហួសពីរង្វង់អរិភាពពិតប្រាកដ និងការឈប់ប្រយុទ្ធគ្នា[3932]៖ នៅពេលណាមានការកំណត់បានថា ជម្លោះប្រដាប់អាវុធអន្តរជាតិបានកើតមាននៅកន្លែង និងនៅពេលវេលាដែលពាក់ព័ន្ធទៅនឹងការចោទប្រកាន់នោះ ច្បាប់មនុស្សធម៌អន្តរជាតិនឹងអនុវត្តលើដែនដីទាំងមូលរបស់រដ្ឋដែលពាក់ព័ន្ធ មិនថាការវាយប្រយុទ្ធពិតប្រាកដកើតឡើងនៅទីនោះ ឬក៏អត់នោះទេ ហើយនឹងបន្តអនុវត្តបន្ថែមក្រោយពីការឈប់មានអរិភាពទៀត រហូតដល់ពេលបញ្ចប់ដោយសន្តិភាពជាទូទៅត្រូវបានសម្រេច[3933]។

---

[3929] មាត្រា២ របស់ GC។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤១១-៤១៣។ សេចក្តីសម្រេចយុត្តាធិការ Tadić, កថាខណ្ឌ៧៩។ Naletilić& Martinović, សាលដីកា កថាខណ្ឌ១១៧។

[3930] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤១២។ សេចក្តីសម្រេចយុត្តាធិការ Tadić, កថាខណ្ឌ៧០។ Prlić, សាលក្រម (ភាគ ១), កថាខណ្ឌ៨៤។

[3931] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤១៤។ Kordić&Čerkez, សាលដីកា កថាខណ្ឌ៣៧៣។ Bemba សេចក្តីសម្រេចចិត្តរបស់ អ.ប.ជ អំពីបទចោទទាំងអស់, កថាខណ្ឌ២២០។

[3932] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤១៥។ Prlić, សាលក្រម (ភាគ ១), កថាខណ្ឌ៨៥។

[3933] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤១៥។ សេចក្តីសម្រេចយុត្តាធិការ Tadić, កថាខណ្ឌ៧០។ Kordić&Čerkez, សាលដីកា កថាខណ្ឌ៣២១។

991. ត្រូវតែមានទំនាក់ទំនងគ្នារវាងជម្លោះប្រដាប់អាវុធអន្តរជាតិ និងឧក្រិដ្ឋកម្មដែលត្រូវបានចោទ[3934]។ លក្ខខណ្ឌតម្រូវឱ្យមានទំនាក់ទំនងនេះត្រូវបានបំពេញ នៅពេលណាដែលមានការបង្ហាញថា ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ "មានទំនាក់ទំនងយ៉ាងជិតស្និទ្ធ" ទៅនឹងជម្លោះប្រដាប់អាវុធទាំងមូល[3935]។ តាមន័យនេះ "ជម្លោះប្រដាប់អាវុធមិនចាំបាច់ទាល់តែជាមូលហេតុនៃការប្រព្រឹត្តិឧក្រិដ្ឋកម្មនេះនោះទេ ប៉ុន្តែអត្ថិភាពនៃជម្លោះប្រដាប់អាវុធត្រូវតែ យ៉ាងហោចណាស់ មានតួនាទីជាផ្នែកសំខាន់មួយនៅក្នុងលទ្ធភាពប្រព្រឹត្តឧក្រិដ្ឋកម្មរបស់ចារី នៅក្នុងការសម្រេចប្រព្រឹត្តឧក្រិដ្ឋកម្មរបស់គាត់ នៅក្នុងបែបបទដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត ឬគោលបំណងនៃការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះ"[3936]។ *វា*មិនចាំបាច់ត្រូវតែមានការបង្ហាញថា មានសកម្មភាពប្រយុទ្ធពិតប្រាកដនៅក្នុងតំបន់ដែលអំពើដែលរងការចោទប្រកាន់នោះកើតឡើងនោះទេ ឬថា សកម្មភាពប្រយុទ្ធទាំងនោះគឺជាផ្នែកនៃគោលនយោបាយ ឬការអនុវត្តដែលអនុញ្ញាតឱ្យកើតមាន ដោយភាគីណាមួយទៅនឹងជម្លោះប្រដាប់អាវុធនោះ។

<u>បុគ្គលដែលទទួលបានការការពារ</u>

992. មាត្រា ៦ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ផ្តល់ឱ្យ អ.វ.ត.ក នូវយុត្តាធិការលើ "អំពើប្រឆាំងនឹងបុគ្គល [...] ដែលទទួលបានការការពារក្រោមបទប្បញ្ញត្តិ" នៃអនុសញ្ញាទីក្រុងហ្សឺណែវ[3937]។ ឯកសារយោងនេះគ្របដណ្តប់ "បុគ្គលដែលទទួលបានការការពារ" ដូចដែលបានកំណត់និយមន័យដោយអនុលោមតាមមាត្រា ៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV (ទាក់ទងនឹងជនស៊ីវិល) និងមាត្រា ៤ក នៃអនុសញ្ញាទីក្រុងហ្សឺណែវ III (ទាក់ទងនឹងឈ្លើយសឹក)។

993. អនុសញ្ញាទីក្រុងហ្សឺណែវ III ពង្រីកការការពារទៅដល់ *ក្នុងចំណោមអ្នកដទៃទៀត* "សមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់ភាគីមួយ ទល់នឹងជម្លោះ ក៏ដូចជាសមាជិកនៃកងជីវពល ឬកងស្ម័គ្រចិត្តដែលបង្កើតបានជាផ្នែកមួយនៃកងកម្លាំងប្រដាប់អាវុធ" ដែលបាន "ធ្លាក់ចូលក្នុងអំណាចរបស់

---

3934 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤១៦។ Halilović, សាលក្រម កថាខណ្ឌ២៨។ Brđanin, សាលក្រម កថាខណ្ឌ១២៨។

3935 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤១៦។ Halilović, សាលក្រម កថាខណ្ឌ២៨។ សេចក្តីសម្រេចយុត្តាធិការTadić, កថាខណ្ឌ៧០។ Vasiljević, សាលក្រម កថាខណ្ឌ២៤។

3936 Kunarac, សាលដីកា កថាខណ្ឌ៥៨។

3937 ច្បាប់ អ.វ.ត.ក, មាត្រា៦។ សូមអានសំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤១៧។

សត្រូវ"[3938]។ គ្មានលក្ខខណ្ឌតម្រូវថា បុគ្គលបែបនេះត្រូវបានចាប់ខ្លួន នៅអំឡុងពេលវាយប្រយុទ្ធនោះទេ[3939]។

994. ចំពោះជនស៊ីវិលវិញ អនុសញ្ញាទីក្រុងហ្សឺណែវ IV ពង្រីកឋានៈ "បុគ្គលដែលទទួលបានការការពារ" ទៅដល់ជនស៊ីវិលដែល "ស្ថិតក្រោមការគ្រប់គ្រងរបស់ភាគីក្នុងជម្លោះ ឬភាគីកាន់អំណាចដែលពួកគេមិនមែនជាជនរួមជាតិជាមួយគ្នា"[3940]។ ប្រការនេះការពារ ក្នុងចំណោមជនដទៃទៀត ជនស៊ីវិលដែលយល់ថា ខ្លួនឯងស្ថិតនៅលើទឹកដីដែលគ្រប់គ្រងដោយរដ្ឋជាសត្រូវ ឬនៅក្នុងតំបន់ប្រយុទ្ធ ឬជាអ្នកដែលគ្មានរដ្ឋ[3941]។ ទោះជាយ៉ាងណា បុគ្គលម្នាក់អាចនឹងត្រូវដាក់ក្នុងឋានៈទទួលបានការការពារនេះ បើទោះជាការពិត គាត់មានសញ្ជាតិដូចគ្នានឹងភាគីក្នុងជម្លោះក្តី[3942]។ ឋានៈទទួលបានការការពាររបស់បុគ្គលម្នាក់ មិនអាស្រ័យលើចំណងផ្លូវការ និងទំនាក់ទំនងផ្លូវច្បាប់សុទ្ធសាធនោះទេ ប៉ុន្តែអាស្រ័យទៅលើអង្គសេចក្តីនៃទំនាក់ទំនងដែលមានរវាងបុគ្គលនោះ និងរដ្ឋ[3943]។ ការពិចារណាជាសំខាន់ នៅពេលវិភាគទំនាក់ទំនងសំខាន់ៗទាំងនេះ គឺ ភក្តីភាព ឬកង្វះភក្តីភាព ដែលបុគ្គលម្នាក់មានចំពោះភាគីក្នុងជម្លោះ[3944] ដែលប្រហែលជាពឹងផ្អែកលើអត្តសញ្ញាណជាតិពន្ធខ្លាំងជាងសញ្ជាតិ[3945]។ ដូច្នេះ ជនស៊ីវិលអាចនឹងត្រូវបានចាត់ទុកថាជាបុគ្គលដែលទទួលបានការការពារ ស្របតាមគោលបំណងនៃអនុសញ្ញាទីក្រុងហ្សឺណែវ IV ដែលក្នុងអនុសញ្ញានោះ

---

3938 GC III, មាត្រា៤.ក។

3939 សេចក្តីពន្យល់បន្ថែមរបស់ ICRC ទៅលើ GC III, ទំព័រ៥០។

3940 GC IV, មាត្រា៤(១)។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤១៨។

3941 Tadić, សាលដីកា កថាខណ្ឌ១៦៤។ Naletilić& Martinović, សាលក្រម កថាខណ្ឌ២០៨។ សេចក្តីពន្យល់បន្ថែមរបស់ ICRC ទៅលើGC IV, ទំព័រ៤៦-៤៧។

3942 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤១៩។ Tadić, សាលដីកា កថាខណ្ឌ១៦៦។ Aleksovski, សាលដីកា កថាខណ្ឌ១៥១។ Čelebići, សាលដីកា កថាខណ្ឌ៥៨។

3943 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤១៩។ Tadić, សាលដីកា កថាខណ្ឌ១៦៦, ១៦៨។ Čelebići, សាលដីកា កថាខណ្ឌ៨៤។

3944 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤១៩។ Tadić, សាលដីកា កថាខណ្ឌ១៦៦។ Kordić&Čerkez, សាលដីកា កថាខណ្ឌ៣២៨-៣៣១។ Aleksovski, សាលដីកា កថាខណ្ឌ១៥១-១៥២។

3945 Prlić, សាលក្រម (ភាគ ១), កថាខណ្ឌ១០០។

ពួកគេត្រូវបានមើលឃើញដោយរដ្ឋដែលគ្រប់គ្រងពួកគេ "ថាជាកម្មសិទ្ធិរបស់ភាគីប្រឆាំងនៅក្នុងជម្លោះប្រដាប់អាវុធ និងជាជនដែលបង្កការគំរាមកំហែងដល់រដ្ឋ [នោះ][3946]។

## ការដឹងពីកាលៈទេសៈអង្គហេតុ

995. ចារី ក្រៅពីមាន*ចេតនាប្រព្រឹត្តបទល្មើស*ចាំបាច់សម្រាប់ឧក្រិដ្ឋកម្មជាក់លាក់ទាំងនោះ ត្រូវតែដឹងពីកាលៈទេសៈអង្គហេតុដែលបង្ហាញពី៖ ១) អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ និង ២) ឋានៈទទួលបានការការពាររបស់ជនរងគ្រោះ[3947]។ ការដឹងថា រដ្ឋបរទេសបានចូលរួមនៅក្នុងជម្លោះប្រដាប់អាវុធនេះ នឹងបំពេញលក្ខណៈឲ្យធាតុផ្សំទីមួយ[3948]។ ការដឹងថា ជនរងគ្រោះជាកម្មសិទ្ធិរបស់ភាគីជម្លោះដែលជាសត្រូវ នឹងបំពេញលក្ខណៈឲ្យធាតុផ្សំទីពីរ[3949] (ទោះបីជា ដូចដែលបានកត់សម្គាល់ខាងលើ នេះមិនមែនជាសេណារីយ៉ូតែមួយគត់ ដែលជ្រកក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្តី)។

## បទល្មើសជាក់លាក់

## ការសម្លាប់ដោយចេតនា

996. ធាតុផ្សំនៃបទល្មើសសម្លាប់ដោយចេតនា[3950] ក្រោមមាត្រា ៦ នៃច្បាប់ អ.វ.ត.ក (ការរំលោភបំពានធ្ងន់ធ្ងរ) គឺដូចគ្នានឹងធាតុផ្សំនៃការធ្វើមនុស្សឃាតក្រោមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ដែរ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ)[3951]។

---

3946 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤១៩។ Čelebići, សាលដីកា កថាខណ្ឌ៨៤។

3947 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤២០-៤២២។ Naletilić& Martinović, សាលដីកា កថាខណ្ឌ១១០-១២១។ Kordić&Čerkez, សាលដីកា កថាខណ្ឌ៣១១. សូមអានធាតុផ្សំនៃបទល្មើសឧក្រិដ្ឋកម្ម របស់ ICC, មាត្រា៨(២)(ក)(i)-(viii)។

3948 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤២២។ Kordić&Čerkez, សាលដីកា កថាខណ្ឌ៣១១។

3949 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤២២។

3950 GC III, មាត្រា១៣០។ GC IV, មាត្រា១៤៧។

3951 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៣១។ Brđanin, សាលក្រម កថាខណ្ឌ៣៨០។

<u>ការធ្វើទារុណកម្ម ឬការប្រព្រឹត្តដោយអមនុស្សធម៌</u>

997. ការបំពារបំពានធ្ងន់ធ្ងរនៃ "ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌"[3952] រួមផ្សំពីបទល្មើសរងពីរផ្សេងគ្នា៖ (ក) ការធ្វើទារុណកម្ម និង (ខ) ការប្រព្រឹត្តិដោយអមនុស្សធម៌។ ធាតុផ្សំនៃបទល្មើសការធ្វើទារុណកម្ម ក្រោមមាត្រា ៦ នៃច្បាប់ អ.វ.ត.ក (ការរំលោភបំពានធ្ងន់ធ្ងរ) គឺដូចគ្នានឹងធាតុផ្សំនៃការធ្វើទារុណកម្មក្រោមមាត្រា ៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែរ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ)[3953]។ ការប្រព្រឹត្តិដោយអមនុស្សធម៌ ត្រូវបានកំណត់និយមន័យថាជាអំពើសកម្ម ឬអកម្ម ដែលបណ្តាលឲ្យមានផលប៉ះពាល់ ឬរបួសខាងផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ឬជាការវាយប្រហារធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូររបស់មនុស្ស[3954]។ ប្រភេទបទល្មើសនេះគឺជាបញ្ញត្តិកំពូលមួយ ដែលក្រោមបញ្ញត្តិកំពូលនេះ ការបំពារបំពានទាំងឡាយដែលមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ ដែលមិនត្រូវបានបញ្ជាក់ច្បាស់នៅក្នុងមាត្រា ៦ អាចនឹងត្រូវបានចាត់ទុកថាជាការបំពារបំពានធ្ងន់ធ្ងរ[3955]។ ថាតើអំពើជាក់លាក់ណាមួយបង្កើតបានជាការប្រព្រឹត្តិដោយអមនុស្សធម៌ឬក៏អត់ គឺជាបញ្ហាអង្គហេតុដែលត្រូវវិនិច្ឆ័យតាមរយៈកាលៈទេសៈទាំងអស់[3956]។

998. អំពើដែលបង្កើតជាការធ្វើទារុណកម្ម ឬការបង្កការឈឺចាប់ដោយចេតនា ឬរបួសធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព នឹងបង្កើតជាប្រព្រឹត្តិដោយអមនុស្សធម៌ក្នុងពេលតែមួយ។ បទល្មើសនេះពង្រីកក្តោបផងដែរលើអំពើដទៃទៀត ដែលបំពានលើគោលការណ៍នៃការប្រព្រឹត្តិដោយអមនុស្សធម៌ ជាពិសេសទាក់ទងនឹងសេចក្តីថ្លៃថ្នូររបស់មនុស្ស[3957]។ អំពើដែលមិនបំពេញដល់កម្រិតនៃការធ្វើ

---

[3952] GC III, មាត្រា១៣០។ GC IV, មាត្រា១៤៧។

[3953] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៣៩។ Brđanin, សាលក្រម កថាខណ្ឌ៤៨២។ Krnojelac, សាលក្រម កថាខណ្ឌ១៧៨។

[3954] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៤០-៤៤១។ Čelebići, សាលដីកា កថាខណ្ឌ៤២៦។ Prlić, សាលក្រម (ភាគ ១), កថាខណ្ឌ១១៣. សូមអាន ICRC កំណត់ពន្យល់ GC IV, ទំព័រ៥៩៨។ ធាតុផ្សំនៃបទល្មើសឧក្រិដ្ឋកម្ម របស់ ICC, មាត្រា៨(២)(ក)(ii)-២, ធាតុផ្សំ១។

[3955] Čelebići, សាលក្រម កថាខណ្ឌ៥៤៣។

[3956] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៤២។ Čelebići, សាលក្រម កថាខណ្ឌ៥៤៤។ Blaškić, សាលក្រម កថាខណ្ឌ១៥៥។

[3957] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៤២។ Čelebići, សាលក្រម កថាខណ្ឌ៥៤៤។ កំណត់ពន្យល់ GC IV, ទំព័រ៥៩៨។

ទារុណកម្ម ដោយសារតែការខកខានមិនបានបង្ហាញថា អំពើទាំងនោះត្រូវបានអនុវត្តឡើងក្នុងគោលបំណងដែលបានហាមឃាត់ ក៏អាចបង្កើតជាការប្រព្រឹត្តិដោយអមនុស្សធម៌ផងដែរ[3958]។ ការប្រព្រឹត្តិដោយអមនុស្សធម៌លើអ្នកជាប់ឃុំ ត្រូវបានចាត់ទុកថាស្ថិតក្នុងវិសាលភាពនៃប្រភេទនៃការរំលោភធ្ងន់ធ្ងរនេះ[3959]។ អំពើដូចជា ការកាត់អវៈយវៈ និងប្រភេទដទៃទៀតនៃការធ្វើឲ្យមានរបួសលើរាងកាយធ្ងន់ធ្ងរ ការវាយដំ និងអំពើហិង្សាដទៃទៀត[3960] ការរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទ[3961] និងការបង្ករបួសផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ[3962] ត្រូវបានចាត់ទុកថាជាការប្រព្រឹត្តិ ដោយអមនុស្សធម៌។

999. ចំពោះ*ចេតនាប្រព្រឹត្តបទល្មើស* ចារីត្រូវតែមានបំណងធ្វើអំពើសកម្ម ឬអកម្ម ដោយប្រព្រឹត្តដោយចេតនា ឬ*ដោយភាពធ្វេសប្រហែសធ្ងន់ធ្ងរ* ទាក់ទងទៅនឹងការបង្កឲ្យមានការរងរបួសផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ឬការវាយប្រហារធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សដែលបណ្តាលមកពីអំពើសកម្ម ឬអកម្មរបស់គេ[3963]។

<u>ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព</u>

1000. ឧក្រិដ្ឋកម្មនេះត្រូវបានកំណត់និយមន័យថា ជាអំពើសកម្ម ឬអកម្មដោយចេតនា ដែលបង្កឲ្យមានរបួសផ្លូវចិត្ត ឬផ្លូវកាយធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព រួមទាំងសុខភាពផ្លូវចិត្តផង[3964]។ បទល្មើសនេះរួមបញ្ចូលទាំងអំពើដែលមិនបំពេញគ្រប់តម្រូវការនៃការធ្វើទារុណកម្ម ឧទាហរណ៍ ដោយតម្រូវឲ្យមានគោលបំណងជាក់លាក់ ទោះបីជាអំពើនៃការធ្វើ

---

3958 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៤៣។ Čelebići, សាលក្រម កថាខណ្ឌ៥៤២។

3959 Kordić &Čerkez, សាលក្រម កថាខណ្ឌ២៥៦។ Prlić, សាលក្រម (ភាគ ១), កថាខណ្ឌ១១៥, ១១៧-១១៨។ អានបន្ថែម GC III, មាត្រា១៣, ២៥-២៦, ២៩, ៣០, ៣៧។ GC IV, មាត្រា២៧, ៨២-៨៨។

3960 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៤២។ Tadić, សាលក្រម កថាខណ្ឌ៧៣០។ Prlić, សាលក្រម (ភាគ ១), កថាខណ្ឌ១១៤-១១៥។

3961 Prlić, សាលក្រម (ភាគ ១), កថាខណ្ឌ១១៦។

3962 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៤២។ Blaškić, សាលក្រម កថាខណ្ឌ២៣៩។

3963 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៤៤, Prlić, សាលក្រម (ភាគ ១), កថាខណ្ឌ១២០។ Aleksovski, សាលក្រម កថាខណ្ឌ៥៦។ Blaškić, សាលក្រម កថាខណ្ឌ១៥២។

3964 GC III, មាត្រា១៣០។ GC IV, មាត្រា១៤៧។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៥០។ Čelebići, សាលដីកា កថាខណ្ឌ៤២៤។ ធាតុផ្សំនៃបទល្មើសឧក្រិដ្ឋកម្ម របស់ ICC, មាត្រា៨(២)(ក)(iii), ធាតុផ្សំ១។

ទារុណកម្មទាំងអស់ អាចនឹងស្ថិតក្នុងវិសាលភាពនៃបទល្មើសនេះក្តី[3965]។ ទោះបីជាជនរងគ្រោះត្រូវតែទទួលរងគ្រោះ "ធ្ងន់ធ្ងរ" ក្តី ក៏មិនចាំបាច់ត្រូវមានការបញ្ជាក់ថា របួសផ្លូវកាយ ឬផ្លូវចិត្តនោះជារបួសអចិន្ត្រៃយ៍ ឬជារបួសដែលអាចព្យាបាលជានោះដែរ[3966] ប៉ុន្តែរបួសនោះត្រូវតែរបួសដែលលើសពីភាពមិនសប្បាយចិត្ត ភាពអាម៉ាស់ ឬភាពអាប់អោនបណ្តោះអាសន្ន[3967] និងលើសពីការប៉ះពាល់ទាក់ទងតែនឹងសេចក្តីថ្លៃថ្នូររបស់មនុស្សរបស់ជនរងគ្រោះ[3968]។ ដូចគ្នានឹងការប្រព្រឹត្តិដោយអមនុស្សធម៌ដែរ *ចេតនាប្រព្រឹត្តបទល្មើស* គឺជាការបូកបញ្ចូលគ្នារវាងចេតនា និង*ភាពធ្វេសប្រហែសធ្ងន់ធ្ងរ* ទាក់ទងនឹងការឈឺចាប់ ឬការរងរបួសដែលបង្កឡើង[3969]។

<u>ការដកហូតដោយចេតនានូវសិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ និងទៀងទាត់</u>

1001. អំពើដកហូតដោយចេតនាពីឈ្លើយសឹក ឬប្រជាជនស៊ីវិលនូវសិទ្ធិក្នុងការទទួលការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ និងដោយទៀងទាត់ ដោយមិនព្រមផ្តល់ឲ្យមានការធានារ៉ាប់រងផ្នែកតុលាការ ដូចដែលបានកំណត់នៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវ III និងទីក្រុងហ្សឺណែវ IV គឺជាការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទាំងនោះ[3970]។ ការធានារ៉ាប់រងផ្នែកតុលាការទាំងនេះរួមមាន៖ (១) សិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការវិនិច្ឆ័យដោយតុលាការឯករាជ្យ និងមិនលម្អៀង[3971] (២) សិទ្ធិទទួលបានការជូនដំណឹងភ្លាមៗពីបទល្មើសដែលជនជាប់ចោទត្រូវបានចោទប្រកាន់[3972] (៣) ការការពារប្រឆាំងនឹងឯកត្តកម្មនៃទោស[3973] (៤) សិទ្ធិទទួលបានការការពារ

---

[3965] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៥៣។ Čelebići, សាលក្រម កថាខណ្ឌ៥០៨, ៥១១។ Blaškić, សាលក្រម កថាខណ្ឌ១៥៦។

[3966] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៥៤។ Naletilić& Martinović, សាលក្រម កថាខណ្ឌ ៣៤០-៣៤២។

[3967] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៥៤។ Krstić, សាលក្រម កថាខណ្ឌ៥១៣។

[3968] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៥៣។ Čelebići, សាលដីកា កថាខណ្ឌ៤២៤។ Kordić&Čerkez, សាលក្រម កថាខណ្ឌ២៤៤-២៤៥។

[3969] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៥៥។

[3970] GC III, មាត្រា១៣០។ GC IV, មាត្រា១៤៧។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៥៨-៤៥៩។ ICC ធាតុផ្សំ, មាត្រា៨(២)(ក)(vi), ធាតុផ្សំ១។

[3971] GC III, art. 84។ GC III, មាត្រា៨៤។

[3972] GC III, មាត្រា១០៤។ GC IV, មាត្រា៧១។

[3973] GC III, មាត្រា៨៧។ GC IV, មាត្រា៣៣។

ក្រោមគោលការណ៍នៃនីត្យានុកូលភាព[3974] (៥) សេរីភាពរួចផុតពីការគាបសង្កត់ផ្លូវចិត្ត ឬរាងកាយដើម្បីបង្ខំឱ្យសារភាពចំពោះបទល្មើសដែលបានចោទ[3975] (៦) សិទ្ធិ និងមធ្យោបាយទទួលបានការការពារ[3976] (៧) សិទ្ធិមិនត្រូវទទួលការផ្តន្ទាទោសលើសពីមួយដងចំពោះអំពើតែមួយ ឬចំពោះបទចោទប្រកាន់តែមួយ[3977] (៨) សិទ្ធិទទួលបានការជូនដំណឹងអំពីសិទ្ធិប្តឹងតវ៉ា[3978] និង (៩) សិទ្ធិមិនត្រូវបានកាត់ទោស ឬប្រហារជីវិត ដោយគ្មានការវិនិច្ឆ័យពីមុនតាមអំណាចដីការបស់តុលាការដែលបានបង្កើតឡើងជាប្រក្រតី[3979]។

## ការឃុំឃាំងប្រជាជនស៊ីវិលដោយខុសច្បាប់

1002. ធាតុផ្សំនៃការឃុំឃាំងដោយខុសច្បាប់ ក្នុងន័យជាការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ គឺស្រដៀងទៅនឹងធាតុផ្សំនៃការដាក់ក្នុងមន្ទីរឃុំឃាំង ក្នុងន័យជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ[3980]។ ការឃុំឃាំងប្រជាជនស៊ីវិលនៅក្នុងជម្លោះប្រដាប់អាវុធ អាចជារឿងស្របច្បាប់នៅក្នុងកាលៈទេសៈមានកំណត់មួយចំនួន ប៉ុន្តែ "មានតែនៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ [នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV]" និង "នៅចំណុចដែលបទប្បញ្ញត្តិនៃមាត្រា ៤៣ [នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV] ត្រូវបានអនុវត្តប៉ុណ្ណោះ"[3981]។

1003. ដូច្នេះ ការឃុំឃាំងប្រជាជនស៊ីវិល មានលក្ខណៈស្របច្បាប់ តែនៅពេលណាដែលមាន*មូលហេតុសមហេតុផល*នឹងជឿថា សន្តិសុខនៃអំណាចឃុំឃាំង "ធ្វើឱ្យការឃុំឃាំងនោះ*ចាំបាច់យ៉ាងពិត*

---

3974 GC III, មាត្រា៩៩។ GC IV, មាត្រា៦៧។

3975 GC III, មាត្រា៩៩។ GC IV, មាត្រា៣១។

3976 GC III, មាត្រា៩៦, ៩៩, ១០៥។ GC IV, មាត្រា៧២។

3977 GC III, មាត្រា៨៦។ GC IV, មាត្រា១១៧។

3978 GC III, មាត្រា១០៦។ GC IV, មាត្រា៧៣។

3979 GC III, មាត្រា៣, ៨៤។ GC IV, មាត្រា៦៤-៧១, ៧៤-៧៥។

3980 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៦៤។ Simić, សាលក្រម កថាខណ្ឌ៦៣។ Kordić&Čerkez, សាលក្រម កថាខណ្ឌ៣០១។ ទោះបីថាអង្គជំនុំជម្រះ Krnojelac ពន្យល់យ៉ាងច្បាស់ថា ការដាក់ឃុំឃាំង CAH មិនត្រូវបានកំហិតដោយបទបញ្ញត្តិនៃអនុសញ្ញាទីក្រុងហ្សឺណែវទេ។ អាន Krnojelac, សាលក្រម កថាខណ្ឌ១១១។

3981 Čelebići, សាលដីកា កថាខណ្ឌ៣២២។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៦៥។

*ប្រាកដ*"[3982]។ ការសម្រេចចិត្តបែបនោះត្រូវតែធ្វើឡើង តែបន្ទាប់ពីការពិចារណាដោយប្រុងប្រយ័ត្ន លើករណីជាបុគ្គលនីមួយៗប៉ុណ្ណោះ និងមិនដែលទាល់តែសោះលើករណីជាសមូហភាព[3983]។ អង្គហេតុដែលគ្រាន់តែថា បុគ្គលម្នាក់មានសញ្ជាតិដូចគ្នា ឬដើរស្របនឹងសត្រូវ មិនអាចត្រូវបានចាត់ទុកថាជាការគំរាមកំហែងដល់សន្តិសុខរបស់ប្រទេសដែលគាត់រស់នៅនោះទេ[3984] ហើយអង្គហេតុដែលថា បុគ្គលម្នាក់ស្ថិតក្នុងវ័យយោធាតែឯង ក៏មិនអាចបង្ហាញពីភាពត្រឹមត្រូវនៃការឃុំឃាំងខ្លួនគេដែរ[3985]។ ការឃុំឃាំងស្របច្បាប់ដំបូងបានក្លាយជាខុសច្បាប់ ប្រសិនបើភាគីឃុំឃាំងនោះខកខានមិនបានគោរពសិទ្ធិនីតិវិធីជាមូលដ្ឋានរបស់អ្នកជាប់ឃុំ និងមិនបានបង្កើតតុលាការ ឬក្រុមប្រឹក្សារដ្ឋបាលត្រឹមត្រូវ ដើម្បីធ្វើការពិនិត្យលើការឃុំឃាំង ដូចមានចែងក្នុងមាត្រា ៤៣ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV[3986]។

## ខ. ទម្រង់នៃការទទួលខុសត្រូវ

1004. មាត្រា ២៩ ថ្មី នៃច្បាប់ អ.វ.ត.ក ចែងអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាបុគ្គលរបស់ជនជាប់ចោទដែល៖ ១) គ្រោងទុក ញុះញង់ បញ្ជា ជួយនិងជំរុញ ឬប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក និង ២) ជាថ្នាក់លើដែលខកខានមិនបានទប់ស្កាត់ ឬដាក់ទណ្ឌកម្មលើការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងឡាយដែលបានចែងនៅក្នុងច្បាប់ អ.វ.ត.ក ដោយអ្នកក្រោមបង្គាប់របស់ខ្លួ

---

3982 GC IV, មាត្រា៤២ (ដោយបញ្ជាក់បន្ថែម)។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៦៥។ Čelebići, សាលដីកា កថាខណ្ឌ៣២០-៣២១។ Kordić&Čerkez, សាលដីកា កថាខណ្ឌ៧០, ៧២-៧៣។ Kordić&Čerkez, សាលក្រម កថាខណ្ឌ២៨៤. ដូចបណ្តឹងឧទ្ធរណ៍ ICTY អង្គជំនុំជម្រះបានពន្យល់ថា GC IV, មាត្រា៥ គាំទ្រនូវគោលការណ៍ដែលគោលការណ៍នោះនៅខាងក្រោយមាត្រា៤២, ថាការដាក់កំហិតស្តីពីសិទ្ធិនៃទទួលបាននូវការការពារជនស៊ីវិល ដូចជាការដកហូតសេរីភាពដោយ ការបង្ខាំង អាចអនុញ្ញាតទៅបានដរាបណាមានមូលដ្ឋានសមហេតុផលមួយដែលអាចទុកចិត្តបានពីសន្តិសុខនៃរដ្ឋភាគីនេះស្ថិតនៅក្នុងស្ថានភាពប្រថុយប្រថាន។ អាន Čelebići, សាលដីកា កថាខណ្ឌ៣២១។ Kordić&Čerkez, សាលដីកា កថាខណ្ឌ៧២។

3983 Kordić&Čerkez, សាលក្រម កថាខណ្ឌ២៨៥។ Prlić, សាលក្រម (ភាគ ១), កថាខណ្ឌ១៣៥។

3984 Kordić &Čerkez, សាលក្រម កថាខណ្ឌ២៨៥។ Čelebići, សាលដីកា កថាខណ្ឌ៣២៧។ ICRC កំណត់ពន្យល់ GC IV, ទំព័រ២៥៨។

3985 Kordić &Čerkez, សាលក្រម កថាខណ្ឌ២៨៥។ Prlić, សាលក្រម (ភាគ ១), កថាខណ្ឌ១៣៤។

3986 GC IV, មាត្រា៤៣។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៦៥។ Kordić&Čerkez, សាលដីកា កថាខណ្ឌ៧០, ៧៣។ Čelebići, សាលដីកា កថាខណ្ឌ៣២០។

ន។ ទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌទាំងនេះ ត្រូវបានរៀបរាប់កាន់តែលម្អិតនៅខាងក្រោម។

## ១. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌជាលក្ខណៈបុគ្គល

### ការប្រព្រឹត្ត

<u>សហឧក្រិដ្ឋកម្មរួម</u>

1005. សហឧក្រិដ្ឋកម្មរួម គឺជាទម្រង់នៃការទទួលខុសត្រូវ ដែលដាក់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌលើបុគ្គលនានាចំពោះសកម្មភាពដែលបានប្រព្រឹត្តដោយមនុស្សមួយក្រុម ដើម្បីលើកកម្ពស់គម្រោងឧក្រិដ្ឋកម្មរួម។ ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម មានន័យស្មើនឹងការប្រព្រឹត្ត នៅក្នុងវិសាលភាពនៃមាត្រា ២៩ថ្មី នៃច្បាប់ អ.វ.ត.ក[3987]។ យុត្តាធិការអន្តរជាតិបានកំណត់ទម្រង់ខុសៗគ្នា ប៉ុន្តែមានចំណងទាក់ទងគ្នានៃសហឧក្រិដ្ឋកម្មរួមចំនួន ៣៖ ទម្រង់***មូលដ្ឋាន*** (“JCE I”) ដែលក្នុងទម្រង់នេះ អ្នកចូលរួមទាំងអស់ធ្វើសកម្មភាព ដោយអនុលោមតាមគោលបំណងឧក្រិដ្ឋកម្មរួម និងចែករំលែកចេតនាចាំបាច់សម្រាប់ឧក្រិដ្ឋកម្មមួយដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក នៅពេលធ្វើដូច្នេះ[3988] ទម្រង់***ជាប្រព័ន្ធ*** (“JCE II”) ដែលជាទម្រង់ក្លាយនៃទម្រង់មូលដ្ឋាន ដែលអាចកំណត់លក្ខណៈបាន ដោយអត្ថិភាពនៃប្រព័ន្ធធ្វើបាបដែលបានរៀបចំ ដូចជា ការឃុំឃាំង ឬជំរំប្រមូលផ្តុំ[3989]

---

[3987] សំណុំរឿង០០២ ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៤៩។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥១១។ សំណុំរឿង០០២ ឯកសារ E100/6 សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ២២។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩០។

[3988] សំណុំរឿង០០១ ឯកសារ D99/3/42 សំណុំរឿង០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ “ឌុច”, កថាខណ្ឌ១៣២។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥០៧។ សំណុំរឿង០០២ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៣៧។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩០។ Tadić, សាលដីកា កថាខណ្ឌ១៩៦-២០១។ Vasiljević, សាលដីកា កថាខណ្ឌ៩៧។ Gacumbitsi, សាលដីកា កថាខណ្ឌ១៥៨។

[3989] សំណុំរឿង០០១ ឯកសារ D99/3/42 សំណុំរឿង០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ “ឌុច”, កថាខណ្ឌ១៣២។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥០៧។ សំណុំរឿង ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់

និងទម្រង់***ទូលាយ*** ("JCE III") ដែលត្រូវបានចាត់ទុកថាមិនអាចអនុវត្តបានចំពោះកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក។

1006. អ.ជ.ត.ក, អ.ប.ជ និង អ.ជ.ដ សុទ្ធតែសម្រេចថា នៅត្រឹមឆ្នាំ ១៩៧៥ JCE I និង JCE II ត្រូវបានទទួលស្គាល់ថាជាទម្រង់នៃការទទួលខុសត្រូវក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ[3990] និងថាការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ អនុលោមតាមទម្រង់ទាំងនេះ គឺជាការទទួលខុសត្រូវដែលអាចប្រមើលឃើញ និងអាចដឹងថាមានច្បាប់ចែងផង[3991]។ អង្គជំនុំជម្រះដូចគ្នានេះបានបញ្ជាក់ផងដែរថា JCE III មិនមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នោះទេ នៅត្រឹមឆ្នាំ ១៩៧៥[3992]។

*ក) អំពើពិរុទ្ធ*

1007. JCE I សក្តិសមយ៉ាងខ្លាំងទៅនឹងអង្គហេតុនៃសំណុំរឿង ០០៣។ *អំពើពិរុទ្ធ*នេះមានធាតុផ្សំចំនួន ៣។ ទីមួយ វាតម្រូវឲ្យមាន "មនុស្សច្រើននាក់"[3993]។ ក្រុមមនុស្សមិនចាំបាច់ត្រូវស្ថិតក្នុង

---

សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៣៧។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩០។ Tadić, សាលដីកា កថាខណ្ឌ២០២-២០៣។ Vasiljević, សាលដីកា កថាខណ្ឌ៩៨។

[3990] សំណុំរឿង០០២ ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៥៧-៧២។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥១១-៥១២។ សំណុំរឿង០០២ ឯកសារ E100/6 សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ២២។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩១។ សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ៧៧៩-៧៨៩, ៨០៧-៨១០។

[3991] សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ១០៩៣។ សំណុំរឿង០០២ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៧២។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥១២។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩១។

[3992] សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ៧៩១-៨០៧។ សំណុំរឿង០០២ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៧៧, ៨៣, ៨៧-៨៨។ សំណុំរឿង០០២ឯកសារ E100/6 សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៣៨។

[3993] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥០៨។ សំណុំរឿង០០២ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ

វចនាសម្ព័ន្ធយោធា នយោបាយ ឬរដ្ឋបាលនោះទេ[3994]។ ខណៈពេលដែលការកំណត់អត្តសញ្ញាណមនុស្សច្រើននាក់ដែលចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម គឺជាការចាំបាច់ អ្នកចូលរួមអាចនឹងត្រូវបានកំណត់អត្តសញ្ញាណតាមប្រភេទ និងមិនចាំបាច់ត្រូវវាយឈ្មោះម្នាក់ៗនោះទេ[3995]។

1008. ទីពីរ វាតម្រូវឲ្យមានគោលបំណងរួម[3996] ដែលមានន័យស្មើ[3997] ឬជាប់ពាក់ព័ន្ធនឹង[3998] ការប្រព្រឹត្តិឧក្រិដ្ឋកម្មមួយដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក[3999]។ អ.ជ.ត.ក ថ្មីៗនេះបានសម្រេចថា

> វាមិនចាំបាច់ទាល់តែអ្នកដែលយល់ស្របលើគោលបំណងរួមនោះ ពិតជា*ចង់* ឲ្យឧក្រិដ្ឋកម្មនោះប្រព្រឹត្តឡើងមែននោះទេ ដរាបណាពួកគេទទួលស្គាល់ថា ឧក្រិដ្ឋ

---

៣៨។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩២។ Tadić, សាលដីកា កថាខណ្ឌ២២៧។ Brđanin, សាលដីកា កថាខណ្ឌ៤៣០។ Munyakazi, សាលដីកា កថាខណ្ឌ១៦០។ Brima, សាលដីកា កថាខណ្ឌ៧៥។

3994 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥០៨។ Tadić, សាលដីកា កថាខណ្ឌ២២៧។ Vasiljević, សាលដីកា កថាខណ្ឌ១០០។

3995 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥០៨។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩២។ Brđanin, សាលដីកា កថាខណ្ឌ៤៣០។ Nizeyimana, សាលដីកា កថាខណ្ឌ៣១៨។

3996 គឺថា គោលបំណងនេះត្រូវតែចែករំលែក។ វាពុំទាន់គ្រប់គ្រាន់នៅឡើយទេដែលថាសមាជិកដែលរងនូវការចោទប្រកាន់នៃបទល្មើសច្រើនដោយឡែកៗពីគ្នាមានគោលបំណងដូចៗគ្នា។ អាន Brđanin, សាលដីកា កថាខណ្ឌ៤៣០។ Sesay, សាលដីកា កថាខណ្ឌ១០៣៤, ១១៤០។

3997 សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ៨០៧ ["គោលបំណងរួម "គឺជា"ការប្រព្រឹត្តបទឧក្រិដ្ឋ ប្រសិនបើការប្រព្រឹត្តបទឧក្រិដ្ឋនោះគឺជា ឬស្ថិតក្នុងចំណោមគោលដៅចម្បងនៃគោលបំណងរួម"]។

3998 សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ៨០៨ ["គោលបំណងរួមមានការ"ពាក់ព័ន្ធ" ទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋ ប្រសិនបើបទឧក្រិដ្ឋនោះ គឺជាមធ្យោបាយដើម្បីសម្រេចគោលដៅចុងក្រោយមួយ (ដែលគោលដៅនេះអាចពុំមែនជាល្មើស)"] សូមរង់ Brima, សាលដីកា កថាខណ្ឌ៨០។

3999 សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ៧៨៩, ៨១៤។ សំណុំរឿង០០២ឯកសារ - D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៣៨។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥០៨។ សំណុំរឿង០០២ ឯកសារ E100/6 សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ១៧។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩២។ Tadić, សាលដីកា កថាខណ្ឌ២២៧។ Vasiljević, សាលដីកា កថាខណ្ឌ១០០។ Munyakazi, សាលដីកា កថាខណ្ឌ១៦០។ Brima, សាលដីកា កថាខណ្ឌ៧៥។

កម្មនោះនឹងត្រូវតែប្រព្រឹត្តដើម្បីសម្រេចឲ្យបាននូវគោលដៅលាក់កំបាំង។ នេះអាចរួមបញ្ចូលឧក្រិដ្ឋកម្មនានា ដែលគេអាចដឹងមុនបានថាជាមធ្យោបាយដើម្បីសម្រេចបាននូវគោលបំណងរួមដែលផ្ដល់នោះ *បើទោះបីជាការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះមិនជាក់លាក់ក្ដី*។ [...] ដូច្នេះ ប្រសិនបើការសម្រេចគោលដៅរួមនោះអាចនាំមកនូវការប្រព្រឹត្តិឧក្រិដ្ឋកម្ម ប៉ុន្តែការជួយជ្រោមជ្រែងឲ្យសម្រេចគោលបំណងនោះត្រូវបានយល់ស្រប ដោយមិនគិតពីការប្រព្រឹត្តិ នោះឧក្រិដ្ឋកម្មទាំងនេះត្រូវបានក្ដោបដោយគោលបំណងរួម ព្រោះ បើទោះបីជាឧក្រិដ្ឋកម្មទាំងនេះមិនត្រូវបានប៉ងដោយផ្ទាល់ក៏ដោយ ក៏ឧក្រិដ្ឋកម្មទាំងនេះត្រូវបានពិចារណាល្អិតល្អន់ដោយសារគោលបំណងនោះដែរ។ ថាតើឧក្រិដ្ឋកម្មមួយត្រូវបានរៀបចំដោយការពិចារណាល្អិតល្អន់អំពីគោលបំណងរួម ឬអត់ គឺជាបញ្ហាចម្បងនៃអង្គហេតុ ហើយថា អវត្តមាននៃការព្រមព្រៀងច្បាស់លាស់ ត្រូវតែវាយតម្លៃដោយពិចារណាទៅលើគ្រប់កាលៈទេសៈពាក់ព័ន្ធទាំងអស់ រួមទាំងគោលដៅរួមនៃគោលបំណងរួម និងភាពទំនងជាថា គោលដៅនោះ អាចនឹងសម្រេចបាន តែនៅពេលណាដែលមានការប្រព្រឹត្តឧក្រិដ្ឋកម្មនោះប៉ុណ្ណោះ។ អ្វីដែលគួរឲ្យកត់សម្គាល់ទៀតនោះគឺ គោលបំណងរួមអាចក្ដោបលើឧក្រិដ្ឋកម្មនានា ដែលការប្រព្រឹត្តិមិនត្រូវគេចង់បាន ហើយក៏មិនមានលក្ខណៈប្រាកដប្រជាផងដែរ [...][4000]។

អ្វីដែលគប្បីត្រូវសង្កត់ធ្ងន់នោះគឺ នៅក្នុងសេណារីយ៉ូទាំងអស់ដែលបានរៀបរាប់ខាងលើ មានការរួមគំនិតគ្នាមួយ ដោយផ្ទាល់ ឬដោយប្រយោល ទាក់ទងនឹងបញ្ហានេះរបស់អ្នកដែលយល់ស្របលើគោលបំណងរួម។ *ដូច្នេះ សមាជិកនៃសហឧក្រិដ្ឋកម្មរួមត្រូវតែទទួលយកការប្រព្រឹត្តិឧក្រិដ្ឋកម្មមិនថាជាគោលដៅ ជាផលវិបាកដែលជៀសមិនរួចនៃគោលបំណងចម្បង ឬជាចុងបញ្ចប់ដែលត្រូវបានប្រព្រឹត្តដោយភាពព្រងើយកន្តើយក្ដី*[4001]។

4000 សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ៨០៨ (ដោយបញ្ជាក់បន្ថែម)។

4001 សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ៨០៩ (ដោយបញ្ជាក់បន្ថែម)។

1009. ដូច្នេះ វាមិនចាំបាច់ទាល់តែគោលដៅចុងក្រោយនៃផែនការរួមគឺជាឧក្រិដ្ឋកម្មនោះទេ ដរាបណាអ្នកចូលរួមរំពឹងទុកថា ផែនការនោះនឹងត្រូវបានអនុវត្ត តាមរយៈមធ្យោបាយព្រហ្មទណ្ឌទៅបានហើយ។ ទាំងគោលដៅ និងមធ្យោបាយដែលគេបានពិចារណាល្អិតល្អន់ដើម្បីសម្រេចបាននូវគោលដៅនោះ បង្កើតបានជាគ្រោងការ ឬផែនការរួម[4002]។ ដូច្នេះ គោលបំណងរួម នឹងក្លាយជាឧក្រិដ្ឋកម្មដែលក្នុងនេះ ឧក្រិដ្ឋកម្មត្រូវបានភ្ជាប់យ៉ាងពិតប្រាកដទៅនឹងគោលនយោបាយ នូវការអនុវត្តដែលមានន័យស្មើនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម[4003]។ មិនមានដែនកំណត់លើវិសាលភាពនៃសហឧក្រិដ្ឋកម្មរួមនោះទេ មិនថាដោយភូមិសាស្ត្រ ឬអ្វីផ្សេងទៀតក៏ដោយ។ ការទទួលខុសត្រូវរបស់ជនជាប់ចោទ "អាចតូច ឬធំប៉ុនផែនការដែលគេបានចូលរួមដោយចេតនា"[4004]។ ជាចុងក្រោយ គោលបំណងមិនចាំបាច់ទាល់តែត្រូវបានរៀបចំ ឬបង្កើតទុកមុននោះទេ។ វាអាចកើតមានដោយមិនបានគិតទុកជាមុន និងអាចទាញចេញបានពីអង្គហេតុ[4005]។

1010. ទីបី ជនជាប់ចោទត្រូវតែចូលរួមក្នុងគោលបំណងរួម[4006]។ ជនជាប់ចោទមិនចាំបាច់ទាល់តែចូលរួមក្នុងការបង្កើតផែនការរួម[4007] ឬក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះទេ។ វាត្រូវការត្រឹមតែការជួយ ឬការរួមចំណែក (ដោយផ្ទាល់ ឬដោយប្រយោល) ក្នុងការអនុវត្តផែនការ ឬគោលបំណងរួមនោះ

---

4002 សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ៧៨៩។ សំណុំរឿង០០២ឯកសារ E100/6 សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ១៧។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩៦។ Sesay, សាលដីកា កថាខណ្ឌ៣០០. សូមអានសេចក្តីសម្រេចចិត្តនៃបណ្តឹងឧទ្ធរណ៍របស់ Taylor ស្តីពីសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ១៥, លេខជើងទំព័រ៦៣។ Brima, សាលដីកា កថាខណ្ឌ ៧៦, ៨០។

4003 សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ១០៧៥។

4004 សេចក្តីសម្រេចលើសហឧក្រិដ្ឋកម្មរួមនៃអំពើប្រល័យពូជសាសន៍របស់សំណុំរឿង Rwamakuba, កថាខណ្ឌ២៥. សូមអាន Brđanin, សាលដីកា កថាខណ្ឌ៤២៥។ Sesay, សាលដីកា កថាខណ្ឌ១០៦, ៣១៦។

4005 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥០៨។ Tadić, សាលដីកា កថាខណ្ឌ២២៧។ Brđanin, សាលដីកា កថាខណ្ឌ៤១៧-៤១៩។ Šainović, សាលដីកា កថាខណ្ឌ៦០៩។

4006 សំណុំរឿង០០២ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៣៨។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ ៥០៨។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩២-៦៩៣។ Tadić, សាលដីកា កថាខណ្ឌ២២៧។ Stakić, សាលដីកា កថាខណ្ឌ៦៤។ Munyakazi, សាលដីកា កថាខណ្ឌ១៦០។

4007 Simba, សាលដីកា កថាខណ្ឌ២៥០។

ប៉ុណ្ណោះ[4008]។ *វា*មិនដូចជាការជួយនិងជំរុញ នៅត្រង់ថា ការជួយនិងជំរុញតម្រូវឱ្យជនជាប់ចោទបានរួមចំណែកយ៉ាងធំធេងនៅក្នុងឧក្រិដ្ឋកម្មជាក់លាក់ដែលបានចោទនោះទេ ចំណែកឯសហឧក្រិដ្ឋកម្មរួមតម្រូវឱ្យមានត្រឹមតែការបង្ហាញថា ជនជាប់ចោទបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជួយជ្រោមជ្រែងសហឧក្រិដ្ឋកម្មរួម ដើម្បីឱ្យគេទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងអស់នៅក្នុងផែនការ[4009]។ ទាំងមុខតំណែងមានសិទ្ធិអំណាចរបស់ជនជាប់ចោទ[4010] ទាំងវត្តមានរបស់គេនៅចំពេលដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត[4011] មិនតម្រូវឱ្យមាននោះទេ។ លើសពីនេះទៀត អង្គហេតុដែលថា ការចូលរួមរបស់ជនជាប់ចោទដែលមានន័យមិនលើសពី "ភារកិច្ចជាប្រចាំ" របស់គេ នឹងមិនធ្វើឱ្យគាត់រួចទោសនោះទេ[4012]។ គ្រប់យ៉ាងដែលត្រូវការគឺ គេបានចូលរួមតាមវិធីមួយចំនួនក្នុងការជួយជ្រោមជ្រែងគោលបំណងរួមនេះ[4013] ដែលត្រឡប់មកវិញមានឥទ្ធិពលដោយផ្ទាល់ ឬដោយប្រយោលលើការប្រព្រឹត្តិឧក្រិដ្ឋកម្ម[4014]។ ការចូលរួមចំណែកនោះអាចធ្វើឡើងតាមរបៀបអកម្មទាំងមូល ឬដោយផ្នែក[4015]។ ដូចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការពិសេសសម្រាប់សៀរ៉ាឡេអូនបានពន្យល់ "របៀបដែលសមាជិកនៃសហឧក្រិដ្ឋកម្មរួមធ្វើអន្តរកម្ម និងសហការគ្នា

---

[4008] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥០៨។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩៣។ Tadić, សាលដីកា កថាខណ្ឌ២២៧, ២២៩។ Šainović, សាលដីកា កថាខណ្ឌ៩៨៥។ Sesay, សាលដីកា កថាខណ្ឌ៦១១។

[4009] Tadić, សាលដីកា កថាខណ្ឌ២២៩ (iii)។

[4010] Šainović, សាលដីកា កថាខណ្ឌ១៨២៣។ Kvočka, សាលដីកា កថាខណ្ឌ១៩២។

[4011] Kvočka, សាលដីកា កថាខណ្ឌ១១២-១១៣, ២៧៦។ Krnojelac, សាលដីកា កថាខណ្ឌ៨១។ Simba, សាលដីកា កថាខណ្ឌ២៩៦។ ត្បិតអីវាអាចជាសូចនាករមួយនៃការចូលរួមរបស់ប្រតិបត្តិករ។

[4012] Popović, សាលដីកា កថាខណ្ឌ១៦១៥។

[4013] សំណុំរឿង០០២ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៣៨។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥០៨។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩៣។ Tadić, សាលដីកា កថាខណ្ឌ២២៩ (iii)។ Brđanin, សាលដីកា កថាខណ្ឌ៤២៧។ Popović, សាលដីកា កថាខណ្ឌ១៣៧៨។ Krajišnik, សាលដីកា កថាខណ្ឌ២១៨។ Simba, សាលដីកា កថាខណ្ឌ២៥០។ Sesay, សាលដីកា កថាខណ្ឌ៦១១, ១០៣៤។

[4014] សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ៩៨៣-៩៨៤។

[4015] Kvočka, សាលដីកា កថាខណ្ឌ១៨៧, ៤២១។ សូមអានសំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩៣។

អាចមានច្រើនទម្រង់ ដូចដែលបានបង្កើតឡើង ដោយអ្នកចូលរួមដើម្បីជួយជ្រោមជ្រែងឲ្យសម្រេចបាននូវគោលបំណងឧក្រិដ្ឋកម្មរួមរបស់ខ្លួន"[4016]។

1011. ការរួមចំណែករបស់ជនជាប់ចោទត្រូវតែសំខាន់[4017] ប៉ុន្តែមិនទាមទារទាល់តែចាំបាច់ ឬខានមិនបាននោះទេ[4018]។ ហេតុនេះ មិនចាំបាច់ទាល់តែជាធាតុផ្សំដ៏សំខាន់សម្រាប់ការប្រព្រឹត្តិឧក្រិដ្ឋណាមួយឡើយ[4019]។ សារៈសំខាន់នៃការចូលរួមចំណែកក្នុងសហឧក្រិដ្ឋកម្មរួម គឺត្រូវតែកំណត់ដោយផ្អែកតាមករណីនីមួយៗ ដោយពិចារណាទៅលើកត្តាផ្សេងៗជាច្រើនរួមមាន៖ ទំហំ ភាពធ្ងន់ធ្ងរ និងវិសាលភាពនៃផែនការឧក្រិដ្ឋកម្ម និងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត មុខតំណែងជាក់ស្តែង និងស្របច្បាប់របស់ជនជាប់ចោទ កម្រិត និងប្រសិទ្ធភាពនៃការចូលរួមរបស់គេ មតិយោបល់ជាសាធារណៈពាក់ព័ន្ធទាំងអស់ដែលគេបានបញ្ចេញ និងកិច្ចខិតខំប្រឹងប្រែងទាំងអស់ដើម្បីទប់ស្កាត់កុំឲ្យមានឧក្រិដ្ឋកម្ម[4020]។ នៅក្នុងការវាយតម្លៃបែបនេះ អង្គជំនុំជម្រះគប្បីពិចារណាលើសកម្មភាពទាំងមូលរបស់ជនជាប់ចោទ ការចូលរួមចំណែកពិសេសមិនគួរត្រូវបានវាយតម្លៃដាច់តែឯងនោះ

---

4016 Sesay, សាលដីកា កថាខណ្ឌ១០៣៥, ១០៦៣។

4017 សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ៩៨០។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩២។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ ៥០៨។ សំណុំរឿង០០២ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៣៨។ Brđanin, សាលដីកា កថាខណ្ឌ៤២៧, ៤៣០, ៤៣២។ Simba, សាលដីកា កថាខណ្ឌ៣០៣។ Sesay, សាលដីកា កថាខណ្ឌ៦១១។

4018 សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ៩៨០ ["វាគ្រប់គ្រាន់ណាស់សម្រាប់ចោទប្រកាន់ជនជាប់ចោទថាមានកំហុសបានប្រព្រឹត្តដើម្បីបំពេញបំណងរួមដែលខ្លួនបានចូលរួមផ្ទាល់ដោយខ្លួនមិនមែនជាអ្នកគ្រាន់តែឃើញព្រឹត្តិការណ៍នោះទេ"], កថាខណ្ឌ៩៨០។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ ៥០៨។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩២។ Brđanin, សាលដីកា កថាខណ្ឌ៤៣០។ Popović, សាលដីកា កថាខណ្ឌ១៣៧៨។ Simba, សាលដីកា កថាខណ្ឌ៣០៣។

4019 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥០៨។ សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ៩៨០។ Kvočka, សាលដីកា កថាខណ្ឌ៩៨។ Sesay, សាលដីកា កថាខណ្ឌ៤០១។

4020 សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩៣។ សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ៩៨០។ Kvočka, សាលក្រម កថាខណ្ឌ២៩២, ៣១១។ Kvočka, សាលដីកា កថាខណ្ឌ១០១, ១៩២។ Krstić, សាលក្រម កថាខណ្ឌ៦៤២។

ទេ[4021]។ ការចូលរួមចំណែកនេះត្រូវតែធ្វើឡើងដើម្បីឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ប៉ុន្តែត្រឹមតែការជួយជ្រោមជ្រែង និងគាំទ្រការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ *ដោយប្រយោល* ប៉ុណ្ណោះ។ ដូចនេះ សូម្បីតែសកម្មភាពដែលបង្ហាញយ៉ាងច្បាស់ថាមិនពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មក្តី ក៏អាចត្រូវបានយកមកពិចារណាផងដែរ នៅពេលកំណត់ថាតើជនជាប់ចោទបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មមែន ឬអត់នោះ[4022]។

1012. អ.ជ.ត.ក បានលើកឡើង[4023] ពីប្រភេទនៃការប្រព្រឹត្តិដែលបង្កើតជាការរួមចំណែកយ៉ាងសំខាន់ក្នុងសហឧក្រិដ្ឋកម្មរួមដូចខាងក្រោម៖

> (ក) ការបង្កើត ផ្តួចផ្តើម លើកកម្ពស់ ចូលរួមក្នុង និង/ឬលើកទឹកចិត្តឱ្យមានការបង្កើត និងការអនុវត្ត [...] គោលនយោបាយរដ្ឋាភិបាល ដែលមានបំណងលើកតម្កើងគោលដៅនៃសហឧក្រិដ្ឋកម្មរួម
>
> (ខ) ការចូលរួមក្នុងការបង្កើត គាំទ្រ ឬថែរក្សា [...] ស្ថាប័នរដ្ឋាភិបាលនៅថ្នាក់ [ជាតិ] ថ្នាក់តំបន់ ថ្នាក់ក្រុង និងថ្នាក់មូលដ្ឋាន [...] ដែលតាមរយៈស្ថាប័នទាំងនេះ [គេ] អាចអនុវត្តគោលដៅនៃសហឧក្រិដ្ឋកម្មរួមបាន
>
> (គ) ការគាំទ្រ លើកទឹកចិត្ត សម្របសម្រួល ឬចូលរួមក្នុងការចែកចាយព័ត៌មានដើម្បី [...] ទទួលបានការគាំទ្រ និងការចូលរួមក្នុងការសម្រេចឱ្យបាននូវគោលដៅនៃសហឧក្រិដ្ឋកម្មរួម
>
> (ឃ) ដឹកនាំ ញុះញង់ លើកទឹកចិត្ត និងផ្តល់សិទ្ធិ [...] ដល់កងកម្លាំងឱ្យអនុវត្តសកម្មភាពនានា ដើម្បីជួយជ្រោមជ្រែងគោលដៅនៃសហឧក្រិដ្ឋកម្មរួម
>
> [...]

---

[4021] សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ៩៨០សម្រង់ Kvočka, សាលដីកា កថាខណ្ឌ៩៥។ Šainović, សាលដីកា កថាខណ្ឌ៩២០, ៩៧០-៩៧២។ Krajišnik, សាលដីកា កថាខណ្ឌ២១៧។

[4022] សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ៩៨៤។

[4023] សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ៩៨២សម្រង់ Krajišnik, សាលដីកា កថាខណ្ឌ២១៦-២១៧។

(ង) ចូលរួមក្នុង គាំទ្រ ឬសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងដែលត្រូវបានណែនាំដល់តំណាងសហគមន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសាធារណជន ដោយបដិសេធ ឬផ្តល់ព័ត៌មានខុសឆ្គងអំពីឧក្រិដ្ឋកម្ម។

1013. អ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម អាចទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយចារីផ្ទាល់ ដែលមិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ព្រោះគេបានកំណត់ច្បាស់ថា ឧក្រិដ្ឋកម្មអាចត្រូវបានចោទទៅលើអ្នកចូលរួមសហឧក្រិដ្ឋកម្មរួមយ៉ាងហោចណាស់ម្នាក់ និងថា អ្នកចូលរួមម្នាក់នោះ នៅពេលប្រើប្រាស់ចារីផ្ទាល់ម្នាក់ បានប្រព្រឹត្តដើម្បីជួយជ្រោមជ្រែងគោលបំណងរួមនេះ[4024]។ ការបង្កើតចំណងរវាងឧក្រិដ្ឋកម្មដែលកំពុងចោទ និងសមាជិកនៃសហឧក្រិដ្ឋកម្មរួម គឺត្រូវតែវាយតម្លៃ ដោយផ្អែកតាមករណីនីមួយៗ[4025]។ ចំណងនេះអាចនឹងត្រូវបានបង្កើតឡើងនៅលើមូលដ្ឋានដែលបង្ហាញថា សមាជិកនៃសហកម្មឧក្រិដ្ឋកម្មរួម (i) បានសហការយ៉ាងជិតស្និទ្ធជាមួយចារីជាក់ស្តែង ឬចារីអន្តរការី ដើម្បីសម្រេចគោលបំណងរួម[4026] (ii) ស្នើដោយផ្ទាល់ ឬដោយប្រយោលដល់ជនដែលមិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម[4027] ឬ (iii) បានញុះញង់ បញ្ជា លើកទឹកចិត្ត ឬបើមិនដូច្នេះទេជួយជាប្រយោជន៍ដល់ជនមិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួមផ្ទាល់ ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម[4028]។ វាអាចជាការជាប់ពាក់ព័ន្ធផងដែរថា តើឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តដោយកងកម្លាំងក្រោមការគ្រប់គ្រងរបស់សមាជិកនៃសហឧក្រិដ្ឋ

---

4024 សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ១០៥០។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ២២៥។ Brđanin, សាលដីកា កថាខណ្ឌ៤១០-៤១៤, ៤១៨, ៤៣០។ Krajišnik, សាលដីកា កថាខណ្ឌ២២៥។ Đorđević, សាលដីកា កថាខណ្ឌ១៦៥។ Sesay, សាលដីកា កថាខណ្ឌ ៣៩៨-៤០០។

4025 Brđanin, សាលដីកា កថាខណ្ឌ៤១៣។ Martić, សាលដីកា កថាខណ្ឌ១៦៩។ Sesay, សាលដីកា កថាខណ្ឌ៤១៤។

4026 Brđanin, សាលដីកា កថាខណ្ឌ៤១០។ Sesay, សាលដីកា កថាខណ្ឌ៤១៤។

4027 Krajišnik, សាលដីកា កថាខណ្ឌ២២៦។ Popović, សាលដីកា កថាខណ្ឌ១៤១៤។ Sesay, សាលដីកា កថាខណ្ឌ ៤១៤។

4028 Krajišnik, សាលដីកា កថាខណ្ឌ២២៦។ Popović, សាលដីកា កថាខណ្ឌ១៤១៤។ Sesay, សាលដីកា កថាខណ្ឌ ៤១៤។

កម្មរួម[4029] ឬដោយការសហការគ្នាជាមួយកងកម្លាំងក្រោមការគ្រប់គ្រងរបស់សមាជិកនៃសហឧក្រិដ្ឋកម្មរួម[4030]។

1014. ទោះជាយ៉ាងណា វាមិនចាំបាច់ទាល់តែសមាជិកនៃសហឧក្រិដ្ឋកម្មរួម បានអនុវត្តការត្រួតត្រាដោយពិតប្រាកដ[4031] ឬតាមពិតមាន "ការត្រួតត្រា និងឥទ្ធិពល" ណាមួយ[4032] លើចារីនោះទេ។ ហើយក៏មិនចាំបាច់ទាល់តែចារីឧក្រិដ្ឋកម្ម និងជនជាប់ចោទ មានការយល់ដឹង ឬមានកិច្ចព្រមព្រៀងរវាងគ្នា ទាក់ទងនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មដែរ[4033]។ បញ្ហាពាក់ព័ន្ធនៅក្នុងបរិបទនៃការទទួលខុសត្រូវក្នុងទម្រង់ JCE I គឺថា តើសមាជិកនៃសហឧក្រិដ្ឋកម្មរួមបានប្រើប្រាស់ជនដែលមិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួមឱ្យប្រព្រឹត្តអំពើពិរុទ្ធនៃឧក្រិដ្ឋកម្ម ដែលបង្កើតជាផ្នែកមួយនៃគោលបំណងរួមដែរ ឬទេ។ អ.ជ.ត.ក បានកំណត់លក្ខណៈនៃចំណុចនេះថាជាទម្រង់មួយនៃការផ្ទេរអំណាចទៅដល់ចារីផ្ទាល់ ឱ្យធ្វើការសម្រេចទាក់ទងទៅនឹងការអនុវត្តចុងក្រោយ នៃអំពើពិរុទ្ធនេះ ដោយកត់សម្គាល់ថា ចំណុចនេះមានភាពស្រដៀងគ្នានឹងគោលគំនិតនៃ*ភាពធ្វេសប្រហែសធ្ងន់ធ្ងរ*ដែរ[4034]។ គេមិនអាចកំណត់បានទេថា តើជនដែលមិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួមបានរួមចំណែកក្នុងចេតនាប្រព្រឹត្តបទល្មើស របស់សមាជិកនៃសហឧក្រិដ្ឋកម្មរួមដែរ ឬអត់ ឬថាតើគាត់បានដឹងអំពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមដែរ ឬអត់នោះទេ[4035]។ ឧទាហរណ៍ វាមិនចាំបាច់ទាល់តែចារីផ្ទាល់នៃឧក្រិដ្ឋកម្មមានចេតនាប្រល័យពូជសាសន៍ ទើបអាចឱ្យសមាជិកនៃសហឧក្រិដ្ឋ

---

4029 Martić, សាលដីកា កថាខណ្ឌ១៦៩, ១៩៥។ Stakić, សាលដីកា កថាខណ្ឌ៧៩-៨៥។ Sesay, សាលដីកា កថាខណ្ឌ ៥១៥។

4030 Martić, សាលដីកា កថាខណ្ឌ១៩៥, ២០៥។ Sesay, សាលដីកា កថាខណ្ឌ៥១៥។

4031 Šainović, សាលដីកា កថាខណ្ឌ១៣៦៨។ Kvočka, សាលដីកា កថាខណ្ឌ១៩៥។

4032 Sesay, សាលដីកា កថាខណ្ឌ៥១៥, ៩០៧។

4033 Brđanin, សាលដីកា កថាខណ្ឌ៤១៥, ៤១៨។

4034 សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ៨០៩។

4035 សាលដីកា Karadžić អនុលោមតាមវិធាន៩៨ស្ទួន កថាខណ្ឌ៧៩។ Krajišnik, សាលដីកា កថាខណ្ឌ២២៦។ សូមអាន Brđanin, សាលដីកា កថាខណ្ឌ៤១០។ អានបន្ថែម Sangkul Kim, ការចងក្រងបណ្ដុំទ្រឹស្ដីនៃចេតនារបស់អំពើប្រល័យពូជសាសន៍, ទំព័រ២២១ ["តួអង្គដែលមានឋានៈតូចទាបមិនមានតួនាទីដែលបង្កជាវិនាសកម្មក្រុមណាមួយឡើយ ដូច្នេះគេមិនអាចបង្កើតចេតនាច្បាស់លាស់មួយឡើយ។ [...] អ្វីដែលជាចម្ងល់ថាតើជនដែលដែលជាកម្មាភិបាលជាន់ទាបនៃចេតនាដំណើរការសហឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លែងមានការពាក់ព័ន្ធនឹងការរួមចំណែកនៃគោលការណ៍ចំបងនៃអំពើប្រល័យពូជសាសន៍ដែរឬយ៉ាងណា"]។

កម្មរួមដែលជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម និងមានចេតនាបែបនោះយ៉ាងច្បាស់ក្រឡែតទទួលខុសត្រូវលើអំពើប្រល័យពូជសាសន៍នោះទេ[4036]។

1015. ទំនាស់រវាងមេដឹកនាំនៅក្នុងអង្គការធំមួយ មិនមានឥទ្ធិពលលើបញ្ហានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ក្រោមសហឧក្រិដ្ឋកម្មរួមនោះទេ ដរាបណាធាតុផ្សំទាំងអស់សម្រាប់ទម្រង់នៃការទទួលខុសត្រូវនេះត្រូវបានបង្កើតឡើង[4037]។ វាមានជាប់មកជាមួយតែម្តងនៅក្នុងសញ្ញាណពិតប្រាកដនៃសហកម្មឧក្រិដ្ឋកម្មរួមដែលថា សមាជិករបស់ខ្លួនបានចូលរួមតាមរូបភាពផ្សេងៗ នៅក្នុងការអនុវត្តគោលបំណងរួមនេះ។ ការពិតដែលថា សមាជិកមួយចំនួនមានកម្រិតស្វ័យភាពចំពោះការអនុវត្តទិដ្ឋភាពនានានៃគោលបំណងរួមនេះ មិនបានច្រានចោលការទទួលខុសត្រូវរបស់សមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមឡើយ[4038]។

*ខ) ចេតនាប្រព្រឹត្តបទល្មើស*

1016. ដើម្បីរ៉ាប់រងការទទួលខុសត្រូវ ដោយអនុលោមតាម JCE I ជនជាប់ចោទត្រូវតែចែករំលែកជាមួយអ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមផ្សេងៗទៀត ទាំងចេតនាប្រព្រឹត្តបទល្មើសដែលពាក់ព័ន្ធនៅក្នុងគោលបំណងរួម[4039] នៅពេលមានការប្រព្រឹត្តិបទល្មើសទាំងនោះ[4040] និងទាំងចេតនាចូលរួមក្នុងផែនការរួមដែលគ្រោងឲ្យមានការប្រព្រឹត្តិបទល្មើសទាំងនោះ[4041]។ ចំពោះឧក្រិដ្ឋកម្មដោយ

---

[4036] សាលដីកា Karadžić អនុលោមតាមវិធាន៩៨ស្ទួន កថាខណ្ឌ៧៩។

[4037] សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ១០៥២។

[4038] សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ១០៥២។

[4039] ចេតនានៃសហឧក្រិដ្ឋកម្មរួម(JCE)១, ជាទម្រង់នៃការប្រព្រឹត្ត (i) ប្រកបដោយចេតនាឧក្រិដ្ឋផ្ទាល់ (dolus directus កម្រិតទី១), និង (ii) ការដឹងថាឧក្រិដ្ឋកម្មនោះនឹងកើតមានឡើងក្នុងដំណើរធម្មតា ឬនិយាយម្យ៉ាងទៀតថា គឺជាការយល់ដឹងនៃខ្លឹមសារដែលអាចកើតឡើង (dolus directus កម្រិតទី២)។ អាន Lukić& Lukić, សាលក្រម កថាខណ្ឌ ៩០០។ Limaj, សាលក្រម កថាខណ្ឌ៥០៩។ Kvočka, សាលក្រម កថាខណ្ឌ២៥១. សូមអានលក្ខន្តិកៈ ICC, មាត្រា ៣០(២)(ខ)។ និយមន័យនៃចេតនានេះស៊ីសង្វាក់គ្នានឹងចេតនានៃឧក្រិដ្ឋកម្មតម្រូវការនៃទំនួលខុសត្រូវផ្ទាល់ដូចជាការធ្វើផែនការ ការដឹកនាំគិត និងការបញ្ជា។

[4040] សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ១០៨២។

[4041] សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១, កថាខណ្ឌ១០៥៣។ សំណុំរឿង០០២ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៣៧, ៣៩។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥០៩។ សំណុំរឿង

ចេតនាជាក់លាក់ដូចជា ការធ្វើទុក្ខបុកម្នេញ ឬអំពើប្រល័យពូជសាសន៍ ជនជាប់ចោទក៏ត្រូវតែចែករំលែកចេតនាជាក់លាក់ដែលពាក់ព័ន្ធនេះផងដែរ[4042]។ ចេតនាឧក្រិដ្ឋដែលបានចែករំលែកនេះ មិនតម្រូវទាល់តែមានការពេញចិត្ត ឬភាពត្រេកត្រអាល ឬការផ្តួចផ្តើមផ្ទាល់ខ្លួនរបស់ជនជាប់ចោទនៅក្នុងការរួមចំណែកដល់សហឧក្រិដ្ឋកម្មរួមនោះទេ[4043]។ លើសពីនេះទៀត ជនជាប់ចោទមិនតម្រូវថា ត្រូវតែដឹងអំពីឧប្បត្តិហេតុឧក្រិដ្ឋជាក់លាក់ដែលកំពុងចោទនេះទេ[4044]។ ចេតនាអាចនឹងត្រូវទាញចេញពីការដឹងរបស់មនុស្សម្នាក់ រួមផ្សំនឹងការបន្តចូលរួមនៅក្នុងឧក្រិដ្ឋកម្មទាំងនេះ[4045]។ សារៈសំខាន់ និងវិសាលភាពនៃការចូលរួមជាក់ស្តែងរបស់បុគ្គលម្នាក់ នៅក្នុងសហឧក្រិដ្ឋកម្មរួម ក៏អាចពាក់ព័ន្ធក្នុងការកំណត់ថាតើបុគ្គលនោះមានចេតនាប្រព្រឹត្តបទល្មើស ដែលបានតម្រូវនោះដែរ ឬអត់ផងដែរ[4046]។

## ផែនការ

1017. អំពើពិរុទ្ធនៃ "ការគ្រោងផែនការ" តម្រូវឲ្យបុគ្គលម្នាក់ ឬច្រើនចូលរួមនៅក្នុងកាតាក់តែងអំពើសកម្ម ឬអកម្ម និងដោយហេតុនេះមានឥទ្ធិពលយ៉ាងខ្លាំងលើការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលតាមពិត

០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩០, ៦៩៥។ Tadić, សាលដីកា កថាខណ្ឌ១៩៦, ២២០, ២២៨។ Brđanin, សាលដីកា កថាខណ្ឌ៣៦៥។ Šainović, សាលដីកា កថាខណ្ឌ១៤៧០។ Popović, សាលដីកា កថាខណ្ឌ១៣៦៩។ Munyakazi, សាលដីកា កថាខណ្ឌ១៦០។ Sesay, សាលដីកា កថាខណ្ឌ៤៧៤-៤៧៥។

4042 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, លេខជើងទំព័រ៨៩៧។ សំណុំរឿង០០២ឯកសារ E100/6 សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ១៦។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩៥។ Kvočka, សាលដីកា កថាខណ្ឌ១១០។ Krnojelac, សាលដីកា កថាខណ្ឌ ១១១។

4043 Popović, សាលដីកា លេខជើងទំព័រ២៩៧១។ Krnojelac, សាលដីកា កថាខណ្ឌ១០០។

4044 Šainović, សាលដីកា កថាខណ្ឌ១៤៩១។ Kvočka, សាលដីកា កថាខណ្ឌ២៧៦។ Sesay, សាលដីកា កថាខណ្ឌ ៩០៦។

4045 Popović, សាលដីកា កថាខណ្ឌ១៣៦៩។ Đorđević, សាលដីកា កថាខណ្ឌ៥១២។ Krajišnik, សាលដីកា កថាខណ្ឌ ២០២, ៦៩៧។

4046 សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩៥។ Kvočka, សាលដីកា កថាខណ្ឌ ៩៧, ១៨៩។

ត្រូវបានគេប្រព្រឹត្ត[4047]។ ហេតុដូច្នេះ ជនជាប់ចោទមិនចាំបាច់រចនាការប្រព្រឹត្តិតែម្នាក់ឯងនោះទេ[4048]។ ហើយគាត់ក៏ពុំចាំបាច់ជាអ្នកតាក់តែង ឬគ្រោងផែនការដើមនោះដែរ[4049] ការគាំទ្រផែនការដែលស្នើឡើងដោយអ្នកផ្សេងគឺគ្រប់គ្រាន់ហើយ[4050]។ ភ័ស្តុតាងប្រយោលអាចនឹងផ្តល់នូវភ័ស្តុតាងដែលបង្ហាញពីអត្ថិភាពនៃផែនការនេះ[4051]។ ការផ្តន្ទាទោសលើការគ្រោងផែនការមិនតម្រូវឱ្យមានការរកឃើញតំណែងដែលមានសិទ្ធិអំណាចនោះទេ[4052]។

1018. ផែនការនេះត្រូវតែដើរមុន និងរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម[4053]។ ចំណុចដែលថាតើអំពើពិសេសៗ មានន័យស្មើនឹងការចូលរួមចំណែកជាសារវន្ត ឬអត់ គឺត្រូវតែវាយតម្លៃដោយផ្អែកតាមករណីនីមួយៗ តាមរយៈភ័ស្តុតាងនេះទាំងមូល[4054]។

1019. ចំពោះខ្លឹមសារនៃផែនការ វាមិនចាំបាច់ត្រូវគិតដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មជាក់លាក់ណាមួយឡើយ។ ការគ្រោងផែនការអាចជាផ្នែកមួយនៃគោលដៅដែលត្រូវតែសម្រេចឱ្យបាន ដោយការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ ដូចនេះ លក្ខណៈស្របច្បាប់នៃប្រតិបត្តិការមួយ មិនបានទាត់ចោលការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ ចំពោះការគ្រោងផែនការឧក្រិដ្ឋកម្ម ដែលត្រូវប្រព្រឹត្តនៅអំឡុងពេលប្រតិបត្តិការ ប្រសិនបើគោលដៅនោះត្រូវតែសម្រេចឱ្យបាន ដោយការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះទេ[4055]។ នៅពេលដែលជនជាប់ចោទគ្រោងផែនការប្រព្រឹត្ត ដែលមានគោលបំណង

---

[4047] សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩៨។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥១៨។ Taylor, សាលដីកា កថាខណ្ឌ៣៦៨, ៤៩៤។ Kordić&Čerkez, សាលដីកា កថាខណ្ឌ២៦។ Milošević (Dragomir), សាលដីកា កថាខណ្ឌ២៦៨។ Nahimana, សាលដីកា កថាខណ្ឌ៤៧៩។

[4048] Taylor, សាលដីកា កថាខណ្ឌ៤៩៤។ Boškoski & Tarčulovski, សាលដីកា កថាខណ្ឌ១៥៤។

[4049] Boškoski&Tarčulovski, សាលដីកា លេខជើងទំព័រ៤១៨។ Taylor, សាលដីកា កថាខណ្ឌ៤៩៤។

[4050] Bagilishema, សាលក្រម កថាខណ្ឌ៣០។ Semanza, សាលក្រម កថាខណ្ឌ៣៨០។

[4051] Nahimana, សាលដីកា កថាខណ្ឌ៩៥៨-៩៥៩។ Brima, សាលដីកា កថាខណ្ឌ៣០១។ Blaškić, សាលក្រម កថាខណ្ឌ២៧៩។

[4052] Kanyarukiga, សាលដីកា កថាខណ្ឌ២៥៨។

[4053] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥១៨។ សំណុំរឿង០០២ ឯកសារ E313 សាលក្រម សំណុំរឿង ០០២/០១, កថាខណ្ឌ៦៩៨។ Kordić&Čerkez, សាលដីកា កថាខណ្ឌ២៦។ Nahimana, សាលដីកា កថាខណ្ឌ៤៧៩, ៤៩២, លេខជើងទំព័រ២១១៦។ Sesay, សាលដីកា កថាខណ្ឌ៦៨៧, ១១៧០។

[4054] Sesay, សាលដីកា កថាខណ្ឌ៧៦៩។ Taylor, សាលដីកា កថាខណ្ឌ៤៩៤។

[4055] Boškoski&Tarčulovski, សាលដីកា កថាខណ្ឌ១៧២។ Taylor, សាលដីកា កថាខណ្ឌ៤៩៣-៤៩៤។

យ៉ាងច្បាស់ចង់វាយប្រហារប្រជាជនស៊ីវិលដោយមិនរើសមុខ នោះមានន័យថា រូបគេគ្រោងផែនការអនុវត្តដែលបង្កើតជាឧក្រិដ្ឋកម្មហើយ[4056]។

1020. ចំពោះ*ចេតនាប្រព្រឹត្តបទល្មើស* ជនជាប់ចោទត្រូវតែមានចេតនា ឬដឹងពីភវនីភាពជាសារវន្តនៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម នៅពេលប្រតិបត្តិផែនការនោះ[4057]។ *ចេតនាប្រព្រឹត្តបទល្មើស*របស់ជនជាប់ចោទអាចទាញចេញបានពីកាលៈទេសៈមួយចំនួន[4058]។ ពេលដែលគេកំណត់ថា អាទិចារី បានដឹងអំពីកាលៈទេសៈជាក់ស្តែង ដែលបង្ហាញពីឋានៈរបស់ជនរងគ្រោះ (ឧទាហរណ៍ ប្រជាជនស៊ីវិល ទាហាន*បាត់បង់សមត្ថភាពប្រយុទ្ធ* ជាដើម) ការរកឃើញបែបនោះគឺមិនចាំបាច់សម្រាប់ការផ្តន្ទាទោសពីបទគ្រោងផែនការឡើយ[4059]។

## ការញុះញង់

1021. ដើម្បីទទួលខុសត្រូវលើការញុះញង់ ជនជាប់ចោទត្រូវតែ ដោយវិធីសកម្ម ឬអកម្ម ញុះញង់បុគ្គលម្នាក់ទៀតឱ្យធ្វើសកម្មភាព តាមរបៀបជាក់លាក់ដែលមានឥទ្ធិពលខ្លាំងលើការប្រព្រឹត្តិឧក្រិដ្ឋកម្ម[4060]។ ទម្រង់នៃការទទួលខុសត្រូវនេះក៏ត្រូវបានចាត់ទុកផងដែរថាជា "ការជំរុញ ឬការលើកទឹកចិត្ត"[4061]។ *វា*មិនតម្រូវទាល់តែថា ការញុះញង់នោះត្រូវបានធ្វើឡើង "ដោយផ្ទាល់ និងជាសាធារណៈ" នោះទេ[4062]។ ទាំងអំពើសកម្ម និងអកម្ម អាចបង្កើតជាការញុះញង់[4063] ដែលអាចទទួលបាន

---

[4056] Taylor, សាលដីកា កថាខណ្ឌ៤៩៣។ Boškoski & Tarčulovski, សាលដីកា កថាខណ្ឌ១៧១។

[4057] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥១៩។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៦៩៨។ Kordić&Čerkez, សាលដីកា កថាខណ្ឌ២៩, ៣១, ១១២។ Boškoski & Tarčulovski, សាលដីកា កថាខណ្ឌ៦៨, ១៧៥។ Milošević (Dragomir), សាលដីកា កថាខណ្ឌ២៦៨។ Nahimana, សាលដីកា កថាខណ្ឌ៤៧៩។ Taylor, សាលដីកា កថាខណ្ឌ៤៩៤។

[4058] Galić, សាលក្រម កថាខណ្ឌ១៧២។ Čelebići, សាលក្រម កថាខណ្ឌ៣២៨។

[4059] Boškoski &Tarčulovski, សាលដីកា កថាខណ្ឌ៦៧។

[4060] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥២២។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៧០០។ Kordić&Čerkez, សាលដីកា កថាខណ្ឌ២៧, ៣២។ Taylor, សាលដីកា កថាខណ្ឌ៣៦៨, ៥៨៩។ Nzabonimana, សាលដីកា កថាខណ្ឌ១៤៦។

[4061] Seromba, សាលក្រម កថាខណ្ឌ៣០៤។ Mpambara, សាលក្រម កថាខណ្ឌ១៨។

[4062] Akayesu, សាលដីកា កថាខណ្ឌ៤៧៨-៤៨៣។

តាមរយៈការញុះញង់ដោយប្រយោល ជាលាយលក្ខណ៍អក្សរ ឬជាពាក្យសម្ដីផ្សេងៗទៀត ដោយជនជាប់ចោទ[4064]។ *វា*មិនមានភាពចាំបាច់ត្រូវបង្ហាញពីភាសា ឬសកម្មភាពញុះញង់ជាក់លាក់ដែលជនជាប់ចោទបានប្រើនោះទេ[4065]។

1022. ដើម្បីឱ្យជនជាប់ចោទម្នាក់ទទួលខុសត្រូវលើឧក្រិដ្ឋកម្មដោយឈរលើមូលដ្ឋាន នៃការញុះញង់នោះ ឧក្រិដ្ឋកម្មត្រូវតែបង្ហាញថាពិតជាត្រូវបានប្រព្រឹត្តមែន[4066] បើទោះបីជាការកំណត់អត្តសញ្ញាណច្បាស់លាស់របស់អាទិចារី នៃឧក្រិដ្ឋកម្មជាក់លាក់មិនតម្រូវឱ្យមានក្ដី[4067]។ លើសពីនេះទៀត អំពើនៃការញុះញង់ត្រូវតែកើតមានមុន និងរួមចំណែកជាសារវន្តដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនេះ[4068]។ ទោះជាយ៉ាងណា វាមិនចាំបាច់មានការបង្ហាញថា ឧក្រិដ្ឋកម្មនោះនឹងមិនបានកើតឡើង ដោយគ្មានការចូលរួមពីសំណាក់ជនជាប់ចោទនោះទេ[4069]។ តាមពិត ជនជាប់តម្រូវឱ្យមានត្រឹមតែញុះញង់បុគ្គលម្នាក់ផ្សេងទៀតឱ្យធ្វើសកម្មភាពតាមរបៀបជាក់លាក់មួយប៉ុណ្ណោះ និងមិនចាំបាច់ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ឬបទល្មើសសំខាន់ៗដោយខ្លួនឯងនោះទេ[4070]។

1023. *ចេតនាប្រព្រឹត្តបទល្មើស*សម្រាប់ការទទួលខុសត្រូវ ដោយឈរលើមូលដ្ឋាននៃការញុះញង់នេះ គឺជាចេតនាញុះញង់ឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬការដឹងអំពីភវនីយភាពជាសារវន្តនៃឧក្រិដ្ឋកម្មនោះ

---

4063 Nahimana, សាលដីកា កថាខណ្ឌ៥៩៥។ Taylor, សាលដីកា កថាខណ្ឌ៥៨៩ដែលគាំទ្រ Taylor, សាលក្រម កថាខណ្ឌ៤៧២។ Brđanin, សាលក្រម កថាខណ្ឌ២៦៩។

4064 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥២២។ សំណុំរឿង០០២ ឯកសារ E313 សាលក្រម សំណុំរឿង ០០២/០១, កថាខណ្ឌ៧០០។ Taylor, សាលដីកា កថាខណ្ឌ៥៨៩ រក្សា Taylor, សាលក្រម កថាខណ្ឌ៤៧២។ Brđanin, សាលក្រម កថាខណ្ឌ២៦៩។

4065 Semanza, សាលដីកា កថាខណ្ឌ២៩៦។

4066 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥២២។ Mpambara, សាលក្រម កថាខណ្ឌ១៨។ Galić, សាលក្រម កថាខណ្ឌ១៦៨។

4067 Karera, សាលដីកា កថាខណ្ឌ៣១៨។ Boškoski & Tarčulovski, សាលដីកា កថាខណ្ឌ៧៥។

4068 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥២២។ សំណុំរឿង០០២ ឯកសារ E313 សាលក្រម សំណុំរឿង ០០២/០១, កថាខណ្ឌ៧០០។ Kordić&Čerkez, សាលដីកា កថាខណ្ឌ២៧។ Karera, សាលដីកា កថាខណ្ឌ៣១៧។ Taylor, សាលដីកា កថាខណ្ឌ៥៨៩។

4069 Kordić &Čerkez, សាលដីកា កថាខណ្ឌ២៧។ Nyiramasuhuko, សាលដីកា កថាខណ្ឌ៣៣២៧។ Nahimana, សាលដីកា កថាខណ្ឌ៤៨០, ៥០២, ៦៦០។

4070 Boškoski&Tarčulovski, សាលដីកា កថាខណ្ឌ១៧២។ Taylor, សាលដីកា កថាខណ្ឌ៤៩៣។

នឹងត្រូវបានប្រព្រឹត្តឡើងជាលទ្ធផលនៃការញុះញង់នេះ[4071]។ នៅពេលដែលគេកំណត់ថា អាទិចារីបានដឹងអំពីកាលៈទេសៈជាក់ស្តែង ដែលបង្ហាញពីឋានៈរបស់ជនរងគ្រោះ (ឧទាហរណ៍ ប្រជាជនស៊ីវិល ទាហាន*បាត់បង់សមត្ថភាពប្រយុទ្ធ* ជាដើម) ការរកឃើញបែបនោះគឺមិនចាំបាច់សម្រាប់ការផ្តន្ទាទោសពីបទគ្រោងផែនការឡើយ[4072]។

## ការបញ្ជា

1024. អំពើនៃការបញ្ជាកើតមាន នៅពេលដែលបុគ្គលម្នាក់ស្ថិតក្នុងមុខតំណែងមានសិទ្ធិអំណាច បង្គាប់ដល់បុគ្គលម្នាក់ទៀតឱ្យធ្វើអំពើសកម្ម ឬចូលរួមក្នុងអំពើអកម្ម ដែលមានឥទ្ធិពលជាសារវន្តលើការប្រព្រឹត្តិឧក្រិដ្ឋកម្ម[4073]។ វាមិនមានការតម្រូវទាល់តែថា បុគ្គលដែលចេញបញ្ជា និងចារីផ្ទាល់ត្រូវតែមានទំនាក់ទំនងផ្លូវការជាថ្នាក់លើ-ថ្នាក់ក្រោមនោះទេ[4074] ឬថា ជនជាប់ចោទប្រើប្រាស់ការត្រួតត្រាដ៏មានឥទ្ធិពលលើរូបគេនោះឡើយ[4075] ប៉ុន្តែ ត្រូវតែមានភស្តុតាងដែលបង្ហាញពីមុខតំណែងដ៏មានសិទ្ធិអំណាចនៅខាងជនជាប់ចោទនៅលើអង្គច្បាប់ ឬលើអង្គហេតុដែលនឹងបង្ខំឱ្យបុគ្គលម្នាក់

---

[4071] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥២៤។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៧០០។ Kordić&Čerkez, សាលដីកា កថាខណ្ឌ២៩, ៣២។ Boškoski & Tarčulovski, សាលដីកា កថាខណ្ឌ៦៨, ១៧៤។ Nahimana, សាលដីកា កថាខណ្ឌ៤៨០។ Taylor, សាលដីកា កថាខណ្ឌ៥៨៩។

[4072] Boškoski &Tarčulovski, សាលដីកា កថាខណ្ឌ៦៧។

[4073] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥២៧-៥២៨។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៧០២។ Kordić&Čerkez, សាលដីកា កថាខណ្ឌ២៨, ៣២។ Milošević (Dragomir), សាលដីកា កថាខណ្ឌ២៦៧។ Nahimana, សាលដីកា កថាខណ្ឌ៤៨១។ Renzaho, សាលដីកា កថាខណ្ឌ៣១៥។ Taylor, សាលដីកា កថាខណ្ឌ៥៨៩។

[4074] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥២៧។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៧០២និងសម្រង់។ Kordić&Čerkez, សាលដីកា កថាខណ្ឌ២៨។ Galić, សាលដីកា កថាខណ្ឌ១៧៦។ Renzaho, សាលដីកា កថាខណ្ឌ៣១៥។ Sesay, សាលដីកា កថាខណ្ឌ១៦៤។

[4075] Seromba, សាលដីកា កថាខណ្ឌ២០២។ Kamuhanda, សាលដីកា កថាខណ្ឌ៧៥។

ផ្សេងទៀតប្រព្រឹត្តឧក្រិដ្ឋកម្ម[4076]។ សិទ្ធិអំណាចនោះអាចជាសិទ្ធិអំណាចមិនផ្លូវការ ឬមានលក្ខណៈបណ្ដោះអាសន្នសុទ្ធសាធ[4077]។

1025. បញ្ជាមិនចាំបាច់ត្រូវបានផ្ដល់ឲ្យជាលាយលក្ខណ៍អក្សរ ឬក្រោមទម្រង់ជាក់លាក់ណាមួយនោះទេ[4078]។ បញ្ជានោះអាចជាបញ្ជាដោយផ្ទាល់ ឬប្រយោល និងអាចត្រូវបានបង្ហាញដោយប្រយោល[4079]។ អត្ថិភាពនៃបញ្ជា អាចនឹងត្រូវទាញចេញពីកត្តាផ្សេងៗជាច្រើន រួមមាន ចំនួន និងប្រភេទនៃបុគ្គលិកពាក់ព័ន្ធ ការត្រួតត្រា និងការបញ្ជាដ៏មានឥទ្ធិពលលើបុគ្គលិកទាំងនេះ ភ័ស្តុភារដែលពាក់ព័ន្ធ ការកើតមានដ៏រីករាលដាលនៃអំពើខុសច្បាប់ស្រដៀងៗគ្នា ចង្វាក់កលយុទ្ធនៃប្រតិបត្តិការ វិធីធ្វើនៃអំពើស្រដៀងៗគ្នា ទីកន្លែងរបស់ថ្នាក់លើនៅពេលនោះ ការដឹងរបស់គាត់អំពីអំពើឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្ត នៅក្រោមការបញ្ជារបស់គាត់[4080]។

1026. ជនជាប់ចោទមិនចាំបាច់ទាល់តែផ្ដល់បញ្ជាដោយផ្ទាល់ទៅដល់ចារីជាក់ស្ដែងនោះទេ។ ការទទួលខុសត្រូវលើការបញ្ជាអាចរ៉ាប់រងបាន នៅពេលណាដែលជនជាប់ចោទចេញ បញ្ជូនចុះបន្ត ឬបើមិនដូច្នេះទេផ្ញើបញ្ជា រួមទាំងតាមរយៈអន្តរការី[4081]។ បញ្ជានោះត្រូវតែកើតមានមុន និងរួមចំណែកជា

---

[4076] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥២៧។ Boškoski & Tarčulovski, សាលដីកា កថាខណ្ឌ១៦៤។ Setako, សាលដីកា កថាខណ្ឌ២៤០។ ថាតើការដែលមានអាជ្ញាធរបែបនេះជាចំណោទសួរដែរឬទេ៖ Semanza, សាលដីកា កថាខណ្ឌ៣៦៣. សូមអាន Gacumbitsi, សាលដីកា កថាខណ្ឌ១៨២ [ការបញ្ជា "ទាមទារគ្រាន់តែឲ្យអាជ្ញាធរបញ្ជា, លក្ខណៈវិនិច្ឆ័យសត្យានុម័តដែលពឹងផ្អែកទៅលើកាលៈទេសៈ និងការយល់ឃើញរបស់អ្នកស្ដាប់"]។

[4077] Semanza, សាលដីកា កថាខណ្ឌ៣៦៣។ Setako, សាលដីកា កថាខណ្ឌ២៤០។

[4078] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥២៧។ សំណុំរឿង០០២ ឯកសារ E313 សាលក្រម សំណុំរឿង ០០២/០១, កថាខណ្ឌ៧០២។ Boškoski & Tarčulovski, សាលដីកា កថាខណ្ឌ១៦០។ Kamuhanda, សាលដីកា កថាខណ្ឌ៧៦។

[4079] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥២៧។ សំណុំរឿង០០២ ឯកសារ E313 សាលក្រម សំណុំរឿង ០០២/០១, កថាខណ្ឌ៧០២។ Galić, សាលដីកា កថាខណ្ឌ១៧៨។ Kamuhanda, សាលដីកា កថាខណ្ឌ ៧៦។ Ndindiliyimana, សាលដីកា កថាខណ្ឌ២៩១។ Sesay, សាលដីកា កថាខណ្ឌ១៦៤។

[4080] Galić, សាលក្រម កថាខណ្ឌ១៧១, ៧៤១។ Milošević (Dragomir), សាលដីកា កថាខណ្ឌ២៧២-២៧៣។

[4081] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥២៧។ សំណុំរឿង០០២ ឯកសារ E313 សាលក្រម សំណុំរឿង ០០២/០១, កថាខណ្ឌ៧០២។ សាលក្រម Milutinović (ភាគ ១), កថាខណ្ឌ៨៧។ Blaškić, សាលក្រម កថាខណ្ឌ២៨២។ Taylor, សាលដីកា កថាខណ្ឌ៥៨៩, រក្សា Taylor, សាលក្រម កថាខណ្ឌ៤៧៦។

សារវន្តដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដែលក្រោយមកត្រូវបានប្រព្រឹត្ត[4082]។ ប៉ុន្តែ វាមិនចាំបាច់ទាល់តែមានការបង្ហាញថា ឧក្រិដ្ឋកម្ម ឬបទល្មើសពាក់ព័ន្ធនោះនឹងប្រហែលជាមិនត្រូវបានប្រព្រឹត្តទេ បើមិនមែនតាមការបញ្ជារបស់ជនជាប់ចោទនោះ[4083]។

1027. ចំពោះខ្លឹមសារនៃការបញ្ជានេះ វាត្រូវការតែការបញ្ជាឲ្យធ្វើអំពើសកម្ម ឬអកម្មប៉ុណ្ណោះ។ មិនចាំបាច់ទាល់តែមានការបង្ហាញថា ការបញ្ជានោះគឺជាការបញ្ជាខុសច្បាប់ដែលបង្ហាញយ៉ាងច្បាស់ដោយខ្លួនឯង[4084] ឬជាការបញ្ជាជាក់ស្តែងទាក់ទងទៅនឹងផលវិបាកដែលការបញ្ជានោះនឹងមានឡើយ[4085]។ លក្ខណៈស្របច្បាប់នៃប្រតិបត្តិការមួយ មិនបានទាត់ចោលការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ ចំពោះការបញ្ជាឲ្យមានឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅអំឡុងពេលប្រតិបត្តិការ ប្រសិនបើគោលដៅនោះត្រូវតែសម្រេចឲ្យបាន ដោយការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះទេ[4086]។

1028. ចំពោះ*ចេតនាប្រព្រឹត្តបទល្មើស* ជនជាប់ចោទត្រូវតែមានចេតនា ឬដឹងអំពីភាវនីយភាពជាសារវន្តដែលថា ការប្រតិបត្តិ ឬការអនុវត្តតាមបញ្ជានោះនឹងនាំឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម[4087]។

---

[4082] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥២៧។ សំណុំរឿង០០២ ឯកសារ E313 សាលក្រម សំណុំរឿង ០០២/០១, កថាខណ្ឌ៧០២។ Boškoski & Tarčulovski, សាលដីកា កថាខណ្ឌ១៦០។ Hategekimana, សាលដីកា កថាខណ្ឌ៦៧។ Taylor, សាលដីកា កថាខណ្ឌ៣៦៨, ៥៨៩។

[4083] Taylor, សាលដីកា កថាខណ្ឌ៥៨៩, រក្សា Taylor, សាលក្រម កថាខណ្ឌ៤៧៧។ សាលក្រម Milutinović (ភាគ ១), កថាខណ្ឌ៨៨។

[4084] Kordić &Čerkez, សាលដីកា កថាខណ្ឌ២៨, ៣២។ Blaškić, សាលដីកា កថាខណ្ឌ៤២។ Milošević (Dragomir), សាលដីកា កថាខណ្ឌ២៦៧។ Nahimana, សាលដីកា កថាខណ្ឌ៤៨១។ Nyiramasuhuko, សាលដីកា កថាខណ្ឌ ១៨៩៥។ លេខជើងទំព័រ៤៤៤៨។ Taylor, សាលដីកា កថាខណ្ឌ៥៨៩។

[4085] Milošević (Dragomir), សាលដីកា កថាខណ្ឌ២៦៧។

[4086] Boškoski&Tarčulovski, សាលដីកា កថាខណ្ឌ១៧២។ Taylor, សាលដីកា កថាខណ្ឌ៤៩៣។

[4087] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥២៨។ សំណុំរឿង០០២ ឯកសារ E313 សាលក្រម សំណុំរឿង ០០២/០១, កថាខណ្ឌ៧០២។ Kordić&Čerkez, សាលដីកា កថាខណ្ឌ២៩-៣០។ Martić, សាលដីកា កថាខណ្ឌ២២១-២២២។ Boškoski & Tarčulovski, សាលដីកា កថាខណ្ឌ៦៨។ Renzaho, សាលដីកា កថាខណ្ឌ ៣១៥។ Taylor, សាលដីកា កថាខណ្ឌ៥៨៩។

## ការជួយនិងជំរុញ

1029. ការជួយនិងជំរុញ[4088] រួមមាន ជំនួយជាក់ស្តែង ការលើកទឹកចិត្ត ឬការគាំទ្រផ្នែកស្មារតីដែលមានឥទ្ធិពលខ្លាំងលើការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនោះ[4089]។ "សេចក្តីបង្គាប់ជាក់លាក់" មិនមែនជាធាតុផ្សំមួយនៃការទទួលខុសត្រូវលើការជួយនិងជំរុញឡើយ នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ[4090]។

1030. ការផ្តន្ទាទោសលើការជួយនិងជំរុញមិនទាមទារឲ្យមានភស្តុតាងដែលបង្ហាញថា ចារីនៃឧក្រិដ្ឋកម្មនេះធ្លាប់ត្រូវបានជំនុំជម្រះ ឬសូម្បីតែកំណត់អត្តសញ្ញាណបានក្តី[4091]។ គ្មានផែនការ ឬកិច្ចព្រមព្រៀងណារវាងអ្នកជួយនិងជំរុញ និងអាទិចារី ត្រូវតម្រូវឲ្យមាន សម្រាប់ការទទួលខុសត្រូវដោយឈរលើមូលដ្ឋាននៃការជួយ និងការបង្កលក្ខណៈងាយស្រួលនេះទេ[4092] តាមពិត វាជាការមិនចាំបាច់នោះទេដែលអាទិចារីត្រូវដឹងពីការចូលរួមចំណែករបស់អ្នកជួយនិងជំរុញ[4093]។

---

[4088] ការជ្រោមជ្រែង និងការសមគំនិតមិនមែនជាសទិសន័យនឹងគ្នាទេ។ ការជ្រោមជ្រែងគឺពាក់ព័ន្ធនឹងការផ្តល់ជំនួយ, រីឯការសមគំនិតទាក់ទិននឹងការជួយសម្របសម្រួល លើកទឹកចិត្ត ផ្តល់ប្រឹក្សា ឬផ្តល់ការគាំទ្រជាមតិយោបល់ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មនោះ (សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៣៣។ សាលក្រម Milutinović (ភាគ ១), លេខជើងទំព័រ១០៧។ Akayesu, សាលក្រម កថាខណ្ឌ៤៨៤។ Gacumbitsi, សាលក្រម កថាខណ្ឌ២៨៦)។

[4089] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៣៣។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៧០៤។ Blaškić, សាលដីកា កថាខណ្ឌ៤៦។ Šainović, សាលដីកា កថាខណ្ឌ១៦៤៩។ Popović, សាលដីកា កថាខណ្ឌ១៧៣២, ១៧៨៣។ Taylor, សាលដីកា កថាខណ្ឌ៣៦៨។

[4090] សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៧០៧-៧១០។ Taylor, សាលដីកា កថាខណ្ឌ៤៨១។ Šainović, សាលដីកា កថាខណ្ឌ១៦៤៩, ១៦៦៣។ Popović, សាលដីកា កថាខណ្ឌ១៧៥៨។ Stanišić& Simatović, សាលដីកា កថាខណ្ឌ១០៦, ១០៨។

[4091] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៣៤។ Krstić, សាលដីកា កថាខណ្ឌ១៤៣។ Brđanin, សាលដីកា កថាខណ្ឌ៣៥៥។

[4092] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៣៤។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៧០៤។ Tadić, សាលដីកា កថាខណ្ឌ២២៩(ii)។ Brđanin, សាលដីកា កថាខណ្ឌ២៦៣។ Seromba, សាលដីកា កថាខណ្ឌ៥៧។

[4093] Tadić, សាលដីកា កថាខណ្ឌ២២៩(ii)។ Kalimanzira, សាលដីកា កថាខណ្ឌ៨៧។ Brđanin, សាលដីកា កថាខណ្ឌ២៦៣។

1031. ទោះបីជាការជួយនិងជំរុញត្រូវតែមានឥទ្ធិពលខ្លាំងលើការប្រព្រឹត្តិឧក្រិដ្ឋកម្មក្តី[4094] ក៏វាមិនចាំបាច់ត្រូវតែមានទំនាក់ទំនងហេតុ និងផល ឬមិនចាំបាច់ទាល់តែទង្វើបែបនោះ គឺជាលក្ខខណ្ឌដែលកើតមានមុនការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះដែរ[4095]។ *ចំណុច*ថាតើការចូលរួមចំណែកជាក់លាក់មានលក្ខណសម្បត្តិគ្រប់គ្រាន់ថាជាការចូលរួមចំណែក "សារវន្ត" ឬក៏អត់ គឺជាបញ្ហាមួយដែលផ្អែកលើអង្គហេតុ[4096]។ ទង្វើដែលបង្កើតបានជាការជួយនិងជំរុញ អាចកើតឡើងមុន ក្នុងអំឡុងពេល ឬបន្ទាប់ពី[4097] ការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះ និងនៅកន្លែងខុសគ្នាពីឧក្រិដ្ឋកម្ម[4098]។

1032. បុគ្គលម្នាក់អាចនឹងត្រូវបានរកឃើញថា ជាអ្នកទទួលខុសត្រូវចំពោះការជួយនិងជំរុញដល់ឧក្រិដ្ឋកម្ម នៅពេលណាដែលមានការបង្ហាញថា ទង្វើរបស់គាត់មានន័យស្មើនឹងការយល់ព្រម និងការលើកទឹកចិត្តឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មយ៉ាងស្ងៀមស្ងាត់ និងថា ទង្វើបែបនោះបានរួមចំណែកជាសារវន្តក្នុងឧក្រិដ្ឋកម្មនោះ[4099]។ ខណៈពេលដែលនៅក្នុងករណីបែបនោះ សិទ្ធិអំណាចរបស់ជនជាប់

---

[4094] អានឧទាហរណ៍ Tadić, សាលដីកា កថាខណ្ឌ២២៩(iii)។ Gotovina & Markač, សាលដីកា កថាខណ្ឌ១២៧។ Ntawukulilyayo, សាលដីកា កថាខណ្ឌ២១៤។ Taylor, សាលដីកា កថាខណ្ឌ៤៨១។

[4095] Popović, សាលដីកា កថាខណ្ឌ១៧៤០, ១៧៨៣។ Ndahimana, សាលដីកា កថាខណ្ឌ១៤៩។ Taylor, សាលដីកា កថាខណ្ឌ៥២២។

[4096] Lukić& Lukić, សាលដីកា កថាខណ្ឌ៤៣៨។ Kalimanzira, សាលដីកា កថាខណ្ឌ៨៦។ Taylor, សាលដីកា កថាខណ្ឌ៤៧៥។

[4097] ដោយមានលក្ខណ្ឌតម្រូវថាការផ្តល់ជំនួយ, ការផ្តល់កម្លាំងចិត្ត ឬការផ្តល់ជាស្មារតីត្រូវតែមានផលប៉ះពាល់សំខាន់ទៅលើអំពើនៃឧក្រិដ្ឋកម្មនោះ, ភាពពាក់ព័ន្ធចាំបាច់នានានឹងមិនអាចកើតមានបានទេខណៈដែលការផ្តល់ជំនួយធ្វើឡើងនៅក្រោយពេលដែលអំពើល្មើសបានប្រព្រឹត្តចប់សព្វគ្រប់ហើយនោះ។ ផ្ទុយទៅវិញប្រសិនបើមានការបំពេញតម្រូវការចាំបាច់នានាដូចជាកិច្ចព្រមព្រៀងធ្វើឡើងមុន ឬក្នុងអំឡុងពេលប្រព្រឹត្តឧក្រិដ្ឋកម្ម ហើយការផ្តល់ជំនួយកើតឡើងមែនក្រោយពេលនោះ វាគ្រប់គ្រាន់ល្មមក្នុងការពាក់ព័ន្ធគ្នាហើយ។ អានសំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៧១២-៧១៣។ Blagojević& Jokić, សាលក្រម កថាខណ្ឌ៧៣១។ Furundžija, សាលក្រម កថាខណ្ឌ២៣០។ Aleksovski, សាលក្រម កថាខណ្ឌ៦២។ Brđanin, សាលដីកា កថាខណ្ឌ២៧៧។

[4098] Mrkšić &Šljivančanin, សាលដីកា កថាខណ្ឌ៨១។ Ntagerura, សាលដីកា កថាខណ្ឌ៣៧២។ Fofana & Kondewa, សាលដីកា កថាខណ្ឌ៧២។

[4099] Šainović, សាលដីកា កថាខណ្ឌ១៦៨៧។ Brđanin, សាលដីកា កថាខណ្ឌ២៧៣, ២៧៧ [សំដៅទៅលើ "អ្នកទស្សនាស្ងៀមស្ងាត់"]។ Ndahimana, សាលដីកា កថាខណ្ឌ១៤៧។ Kayishema & Ruzindana, សាលដីកា កថាខណ្ឌ២០១-២០២ [សំដៅទៅលើ"អ្នកទស្សនាដែលយល់ស្រប"]។ Sesay, សាលដីកា កថាខណ្ឌ៥៤១។

ចោទគឺជាកត្តាមួយ[4100] មិនចាំបាច់ត្រូវមានការបង្ហាញថា ជនជាប់ចោទមានសិទ្ធិអំណាចលើចារី ផ្ទាល់នោះទេ[4101]។

1033. ជនជាប់ចោទក៏អាចជួយនិងជំរុញដោយអំពើអកម្មផងដែរ ដែលក្នុងករណីនេះ ការតម្រូវនៅក្នុង អំពើពិរុទ្ធ និងចេតនាប្រព្រឹត្តបទល្មើស គឺមានលក្ខណៈដូចគ្នានឹងការជួយនិងជំរុញដោយអំពើសកម្ម ផងដែរ[4102]។ *វា*ត្រូវតែមានការបង្ហាញថា ជនជាប់ចោទមាន "លទ្ធភាពធ្វើសកម្មភាព ឬក្នុងន័យ ម្យ៉ាងទៀតថា មានមធ្យោបាយដែលអាចរកបានចំពោះជនជាប់ចោទ ដើម្បីបំពេញកាតព្វកិច្ច នេះ"[4103]។ ទិដ្ឋភាពនៃការជួយនិងជំរុញដោយអំពើអកម្មនេះ ត្រូវបានបកស្រាយដោយមានន័យថា ប្រសិនបើជនជាប់ចោទបានធ្វើសកម្មភាព នោះភាវនិយភាពនៃការប្រព្រឹត្តិឧក្រិដ្ឋកម្មនឹងមិនទំនង កើតឡើងជាសារវន្តនោះទេ[4104]។

1034. ចំពោះ*ចេតនាប្រព្រឹត្តបទល្មើស* ជនជាប់ចោទត្រូវតែដឹង នៅពេលដែលគាត់ផ្តល់ការជួយ[4105] ថា ឧក្រិដ្ឋកម្មអាចនឹងត្រូវបានប្រព្រឹត្ត ហើយថា ទង្វើរបស់គាត់បានជួយ ឬសម្របសម្រួលដល់ការ ប្រព្រឹត្តិឧក្រិដ្ឋកម្មនោះ[4106]។ *វា*ជាការមិនចាំបាច់នោះទេសម្រាប់អ្នកជួយនិងជំរុញ ដែលត្រូវដឹងថា ឧក្រិដ្ឋកម្មច្បាស់លាស់ត្រូវបានប្រព្រឹត្តដោយអាទិចារី។ វាជាការគ្រប់គ្រាន់ដែលគាត់ដឹងថា ឧក្រិដ្ឋ កម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មជាច្រើននឹងប្រហែលជាត្រូវបានប្រព្រឹត្ត ហើយឧក្រិដ្ឋកម្មមួយក្នុង

---

[4100] Ibid សូមអានឧទាហរណ៍ Muvunyi I, សាលដីកា កថាខណ្ឌ៨០។

[4101] Blagojević &Jokić, សាលដីកា កថាខណ្ឌ១៩៥។ Nahimana, សាលដីកា កថាខណ្ឌ៦៧២។ Sesay, សាលដីកា កថាខណ្ឌ៥៤១។

[4102] Popović, សាលដីកា កថាខណ្ឌ១៨១២។ Mrkšić& Šljivančanin, សាលដីកា កថាខណ្ឌ៤៩, ១៤៦។ Nahimana, សាលដីកា កថាខណ្ឌ៤៨២។

[4103] Šainović, សាលដីកា កថាខណ្ឌ១៦៧៧។ Nyiramasuhuko, សាលដីកា កថាខណ្ឌ២២០៥។

[4104] Popović, សាលដីកា កថាខណ្ឌ១៧៤១។ Šainović, សាលដីកា កថាខណ្ឌ១៦៧៩, ១៦៨២, លេខជើងទំព័រ៥៥១០។ Mrkšić& Šljivančanin, សាលដីកា កថាខណ្ឌ៩៧, ១០០។

[4105] Krstić, សាលដីកា កថាខណ្ឌ១៤០។ Seromba, សាលដីកា កថាខណ្ឌ៥៧-៥៨។

[4106] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៣៥។ សំណុំរឿង០០២ ឯកសារ E313 សាលក្រម សំណុំរឿង ០០២/០១, កថាខណ្ឌ៧០៤។ Blaškić, សាលដីកា កថាខណ្ឌ៤៥-៤៦, ៤៩-៥០។ Popović, សាលដីកា កថាខណ្ឌ១៧៣២។ Nahimana, សាលដីកា កថាខណ្ឌ៤៨២។

ចំណោមឧក្រិដ្ឋកម្មទាំងនោះ តាមពិតត្រូវបានប្រព្រឹត្តមែន[4107]។ ជនជាប់ចោទក៏ត្រូវតែដឹងផងដែរ អំពីធាតុផ្សំសំខាន់ៗនៃឧក្រិដ្ឋកម្ម រួមទាំងស្ថានភាពខាងសតិបញ្ញារបស់ចារី ប៉ុន្តែមិនចាំបាច់ត្រូវចែករំលែកចេតនារបស់ចារីក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មនោះទេ[4108]។ ឧក្រិដ្ឋកម្មដោយចេតនាជាក់លាក់ ដូចជា ការធ្វើទុក្ខបុកម្នេញ ឬអំពើប្រល័យពូជសាសន៍ តម្រូវឱ្យអ្នកជួយនិងជំរុញត្រូវតែដឹង ប៉ុន្តែមិនចាំបាច់ត្រូវចែករំលែកចេតនាជាក់លាក់របស់អាទិចារីនោះទេ[4109]។ ការដឹងនេះអាចត្រូវបានសន្និដ្ឋានចេញពីកាលៈទេសៈ[4110]។

## ២) ការទទួលខុសត្រូវរបស់ថ្នាក់លើ

1035. ការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលអាចអនុវត្តបានទាំងចំពោះថ្នាក់លើផ្នែកយោធា និងស៊ីវិល ត្រូវបានទទួលស្គាល់ នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅឆ្នាំ ១៩៧៥[4111]។ នៅពេលនោះ

---

4107 Blaškić, សាលដីកា កថាខណ្ឌ៥០។ Šainović, សាលដីកា កថាខណ្ឌ១៧៧២។ Nahimana, សាលដីកា កថាខណ្ឌ ៤៨២។ Sesay, សាលដីកា កថាខណ្ឌ៥៤៦។

4108 សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៧០៤។ Šainović, សាលដីកា កថាខណ្ឌ១៧៧២។ Ndahimana, សាលដីកា កថាខណ្ឌ១៥៧។ Brima, សាលដីកា កថាខណ្ឌ២៤៤. ដូចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃ ICTY ពន្យល់នៅក្នុងសំណុំរឿង Šainović ថា៖ "កម្រិតនៃចំណេះវិជ្ជាជាប់ទាក់ទងគ្នានឹងភាពពិស្តារនៃបទឧក្រិដ្ឋ ដែលបណ្តាលឱ្យក្លាយទៅជាចេតនានៃឧក្រិដ្ឋកម្មហើយការជ្រោមជ្រែង និងការសមគំនិតវាអាស្រ័យទៅលើកាលៈទេសៈនៃសំណុំរឿង, ដោយរាប់បញ្ចូលទាំងទំហំនៃបទឧក្រិដ្ឋ និងប្រភេទនៃជំនួយដែលបានផ្តល់ឱ្យ"៖ Šainović, សាលដីកា កថាខណ្ឌ១៧៧៣។

4109 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៣៥។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៧០៤។ Popović, សាលដីកា កថាខណ្ឌ១៨៣០។ Krnojelac, សាលដីកា កថាខណ្ឌ ៥២។ Blagojević& Jokić, សាលដីកា កថាខណ្ឌ១២៧។ Ndahimana, សាលដីកា កថាខណ្ឌ១៥៧។ Fofana & Kondewa, សាលដីកា កថាខណ្ឌ៣៦៧។ Vasiljević, សាលដីកា កថាខណ្ឌ១៤២។ Krstić, សាលដីកា កថាខណ្ឌ ១៤០។ Ntakirutimana, សាលដីកា កថាខណ្ឌ៥០០-៥០១។

4110 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៣៥។ Milutinović, សាលក្រម (ភាគ ១), កថាខណ្ឌ ៩៤។

4111 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៧៦-៤៧៨។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៧១៤, ៧១៨-៧១៩។ សំណុំរឿង០០២ ឯកសារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ១៩០-២៣២។ សំណុំរឿង០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ៤១៣-៤៦០។ឯកសារ D145/3 សេចក្តីសម្រេចស្តីពីការអនុវត្តទំនួលខុសត្រូវនៃបទបញ្ជាក្រៅពីជម្លោះប្រដាប់

ទ្រឹស្តីនេះមិនត្រឹមតែអាចអនុវត្តបានចំពោះជម្លោះប្រដាប់អាវុធអន្តរជាតិ និងមិនមែនអន្តរជាតិប៉ុណ្ណោះទេ[4112] ប៉ុន្តែថែមទាំង អាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផងដែរ[4113]។ តាមមាត្រា ២៩ ថ្មី នៃច្បាប់ អ.វ.ត.ក និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ការទទួលខុសត្រូវរបស់ថ្នាក់លើ គឺផ្អែកលើអត្ថិភាពនៃធាតុផ្សំទាំងបីខាងក្រោម៖

(១) ទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោម រវាងជនជាប់ចោទ និងបុគ្គលដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម។ ថ្នាក់លើត្រូវតែមានអំណាចគ្រប់គ្រងដ៏មានឥទ្ធិពលលើថ្នាក់ក្រោម[4114]

(២) ដែលថ្នាក់លើបានដឹង ឬមានមូលហេតុដឹងថា ថ្នាក់ក្រោមបានប្រព្រឹត្ត ឬហៀបនឹងប្រព្រឹត្តឧក្រិដ្ឋកម្ម និង

(៣) ដែលថ្នាក់លើខកខានមិនបានចាត់វិធានការចាំបាច់ និងសមហេតុផលដើម្បីទប់ស្កាត់កុំឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬដើម្បីដាក់ទោសចារី[4115]។

---

អាវុធអន្តរជាតិ ចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៦, កថាខណ្ឌ៣០-៣១។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣០៧, ១៣១៨-១៣១៩, ១៥៥៨។

4112 ឯកសារ D145/3 របស់ ICIJ ស្តីពីសេចក្តីសម្រេចចំពោះទំនួលខុសត្រូវនៃបទបញ្ជា, កថាខណ្ឌ៣៣។ Hadžihasanović សេចក្តីសម្រេចចំពោះទំនួលខុសត្រូវនៃបទបញ្ជា, កថាខណ្ឌ១០-៣១។ សហព្រះរាជអាជ្ញាអនុម័តលើជំហរដែលបានកំណត់ជាស្រេចក្នុងការដាក់បញ្ចូលឯកសារលើបញ្ហានេះ, ឯកសារ D145/1 ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសារណារបស់ មាស មុត ប្រឆាំងនឹងការប្រើប្រាស់ទំនួលខុសត្រូវបទបញ្ជា ទៅនឹងបទល្មើសដែលមិនពាក់ព័ន្ធជាមួយជម្លោះប្រដាប់អាវុធអន្តរជាតិនោះ, ថ្ងៃទី៣ខែសីហា ឆ្នាំ២០១៥។

4113 ឯកសារ D145/3 របស់ ICIJ ស្តីពីសេចក្តីសម្រេចចំពោះទំនួលខុសត្រូវនៃបទបញ្ជា, កថាខណ្ឌ៣២-៣៣។ សំណុំរឿង ០០២ ឯកសារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ២៣១-២៣២។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៨៩៨, ៩១៧, ៩៣៩។

4114 ច្បាប់ អ.វ.ត.ក, មាត្រា២៩ថ្មី មានបញ្ជាក់ពីតម្រូវការចាំបាច់ដែលថ្នាក់លើមាន៖ "បញ្ជា និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាព ឬមានអំណាច និងការត្រួតពិនិត្យតៅលើអ្នកនៅក្រោមបង្គាប់" នេះស្របគ្នាជាមួយសំណុំរឿងច្បាប់កាត់ក្តីពិសេសដែលបានអនុវត្តក្នុងការរកភាពទុកចិត្តបាននៃឧក្រិដ្ឋកម្មនៅមូលដ្ឋានទំនាក់ទំនងរវាងថ្នាក់លំ និងថ្នាក់ក្រោម។ វាបង្ហាញថាថ្នាក់លើគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពទៅលើជនដែលល់។ ការបកស្រាយបែបនេះក៏ត្រូវបានយកមកប្រើប្រាស់ដោយអង្គជំនុំជម្រះ អ.វ.ត.កផងដែរ។ អានសំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ ៥៤០។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៧១៥។

**ទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោម**

1036. ដោយមិនគិតថាតើជនជាប់ចោទជាថ្នាក់លើជាស៊ីវិល ឬយោធានោះទេ[4116] ទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោម រវាងជនជាប់ចោទ និងចារីឧក្រិដ្ឋកម្ម អាចមានទាំងជាផ្លូវការ និងក្រៅផ្លូវការ ពោលគឺ *ដោយស្របច្បាប់ ឬជាក់ស្តែង*[4117]។ *វា*ត្រូវតែមានការបង្ហាញថា ថ្នាក់លើមាន "ការត្រួតត្រាដ៏មានឥទ្ធិពល" លើថ្នាក់ក្រោមរបស់គាត់[4118] ឬក្នុងន័យម្យ៉ាងទៀត មាន "លទ្ធភាពជាក់ស្តែង" ក្នុងការទប់ស្កាត់ការប្រព្រឹត្តឧក្រិដ្ឋកម្ម[4119]។ ទំនាក់ទំនងថ្នាក់លើ-ថ្នាក់ក្រោម អាចជាទំនាក់ទំនងដោយផ្ទាល់ ឬប្រយោល និងមិនចាំបាច់ផ្តាច់មុខនោះទេ។

---

4115 ច្បាប់ អ.វ.ត.ក, មាត្រា២៩ថ្មី។ សំណុំរឿង០០២ ឯកសារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ១៩១។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៣៨។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៧១៥-៧១៦និង ឧទាហរណ៍ Gotovina & Markač, សាលដីកា កថាខណ្ឌ១២៨។ Gacumbitsi, សាលដីកា កថាខណ្ឌ១៤៣។ Sesay, សាលដីកា កថាខណ្ឌ៨៤២, ៨៧៣។

4116 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៧៧។ សំណុំរឿង០០២ ឯកសារ E313 សាលក្រម សំណុំរឿង ០០២/០១, កថាខណ្ឌ៧២០។ សំណុំរឿង០០២ ឯកសារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និងអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ២៣០, ២៣២។ សំណុំរឿង០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ៤១៨, ៤៥៩-៤៦០។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣១៩, ១៥៥៨។ Čelebići, សាលដីកា កថាខណ្ឌ១៩៥។ Kajelijeli, សាលដីកា កថាខណ្ឌ៨៥។ Brima, សាលដីកា កថាខណ្ឌ២៥៧។

4117 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៤៧៧, ៥៤០។ Čelebići, សាលដីកា កថាខណ្ឌ១៩៣-១៩៧, ៣០៣។ Halilović, សាលដីកា កថាខណ្ឌ៥៩, ២១០។ Nyiramasuhuko, សាលដីកា កថាខណ្ឌ៩៨៥។ Brima, សាលដីកា កថាខណ្ឌ២៥៧, ២៨៩។

4118 ច្បាប់ អ.វ.ត.ក, មាត្រា២៩ថ្មី។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៤០។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៧២០។ Čelebići, សាលដីកា កថាខណ្ឌ១៩៦-១៩៧, ៣០៣។ Blaškić, សាលដីកា កថាខណ្ឌ៦៩។ Gacumbitsi, សាលដីកា កថាខណ្ឌ១៤៣-១៤៤។ Fofana & Kondewa, សាលដីកា កថាខណ្ឌ១៧៥។

4119 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៤០។ សំណុំរឿង០០២ ឯកសារ E313 សាលក្រម សំណុំរឿង ០០២/០១, កថាខណ្ឌ៧១៥។ Popović, សាលដីកា កថាខណ្ឌ១៨៥៧។ Nahimana, សាលដីកា កថាខណ្ឌ ៦២៥។ Brima, សាលដីកា កថាខណ្ឌ២៥៧។

1037. លក្ខខណ្ឌវិនិច្ឆ័យនៃការត្រួតត្រាដ៏មានឥទ្ធិពលនេះ មានលក្ខណៈដូចគ្នាទាំងសម្រាប់ថ្នាក់លើជាយោធា និងស៊ីវិល[4120]។ នៅពេលដែលការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានអនុវត្តចំពោះជនស៊ីវិល នោះមិនចាំបាច់មានលក្ខខណ្ឌតម្រូវថា ការត្រួតត្រាដែលធ្វើឡើងដោយគាត់ មានចរិតលក្ខណៈដូចគ្នានឹងការត្រួតត្រាដែលធ្វើឡើងដោយមេបញ្ជាការយោធានោះទេ វាត្រឹមតែតម្រូវឱ្យមានកម្រិតដូចគ្នាប៉ុណ្ណោះ[4121]។

1038. សូចនាករនៃការត្រួតត្រាដ៏មានឥទ្ធិពល គឺជាបញ្ហាមួយដែលចោទលើអង្គហេតុ ជាជាងអង្គច្បាប់ និងគប្បីត្រូវបានវាយតម្លៃដោយផ្អែកមួយករណីនីមួយៗ[4122]។ កត្តាដែលនឹងបង្ហាញថា ជនជាប់ចោទបានត្រួតត្រាពិតប្រាកដលើថ្នាក់ក្រោមរបស់គាត់ រួមមាន៖ ចរិតលក្ខណៈនៃមុខតំណែងរបស់ជនជាប់ចោទ រួមទាំងមុខតំណែងរបស់គាត់ នៅក្នុងរចនាសម្ព័ន្ធយោធា ឬនយោបាយផង[4123] នីតិវិធីសម្រាប់ការតែងតាំង និងភារកិច្ចពិតប្រាកដដែលបានអនុវត្ត[4124] សមត្ថភាពរបស់ជនជាប់ចោទក្នុងការចេញបញ្ជា និងថាតើបញ្ជាបែបនោះពិតជាបានអនុវត្តមែន ឬក៏អត់[4125] សិទ្ធិអំណាចដើម្បី

---

[4120] សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៧២០។ Aleksovski, សាលដីកា កថាខណ្ឌ៧៦។ Bagilishema, សាលដីកា កថាខណ្ឌ៥០។ Brima, សាលដីកា កថាខណ្ឌ២៥៧។

[4121] Čelebići, សាលដីកា កថាខណ្ឌ១៩៧-១៩៨។ Bagilishema, សាលដីកា កថាខណ្ឌ៥០, ៥២, ៥៥។ Kajelijeli, សាលដីកា កថាខណ្ឌ៨៧។ Nahimana, សាលដីកា កថាខណ្ឌ៦០៥, ៧៨៥។

[4122] សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៧២០។ សំណុំរឿង០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ៤៥៩។ Strugar, សាលដីកា កថាខណ្ឌ២៥៤។ Bizimungu (Augustin), សាលដីកា កថាខណ្ឌ១១៥។

[4123] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៤១។ Halilović, សាលដីកា កថាខណ្ឌ៦៦។ ទោះបីជានីតិន័យថាចាំបាច់ឬមិនចាំបាច់សម្រាប់បញ្ជាក់ពីប្រសិទ្ធភាពនៃការគ្រប់គ្រងក៏ដោយ ក៏វាបង្កើតឱ្យមានមូលដ្ឋានសមហេតុសមផលសម្រាប់សន្និដ្ឋានថាជនជាប់ចោទមានប្រសិទ្ធភាពនៃការគ្រប់គ្រងលើអ្នកក្រោមបង្គាប់របស់គាត់រួចជាស្រេចហើយ។ អាននូវឧទាហរណ៍Čelebići, សាលដីកា កថាខណ្ឌ១៩៧។ Hadžihasanović& Kubura, សាលដីកា កថាខណ្ឌ២០-២១។ Nahimana, សាលដីកា កថាខណ្ឌ៦២៥។ Ntabakuze, សាលដីកា កថាខណ្ឌ១៦៩។

[4124] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៤១។ Halilović, សាលដីកា កថាខណ្ឌ៦៦។

[4125] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៤១។ Strugar, សាលដីកា កថាខណ្ឌ២៥៣-២៥៤, ២៥៦។ Nyiramasuhuko, សាលដីកា កថាខណ្ឌ១០០០, ២១០៩។ ទោះបីជាពុំមានភស្តុតាងណាមួយសំអាងពីការបញ្ជាក្តី នោះពុំមានន័យថាវាមិនមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងនោះទេ ជាការពិតអ្នកក្រោមបង្គាប់អាចប្រព្រឹត្តអំពើឧក្រិដ្ឋដោយខ្លួនឯងដោយគ្មានបទបញ្ជានោះ មិនអាចបញ្ជាក់ថាថ្នាក់លើខ្វះសមត្ថភាពក្នុងការបង្ការ ឬដាក់ទណ្ឌកម្មចំពោះអ្នកប្រព្រឹត្តល្មើសនោះឡើយ។ អាន Bagosora & Nsengiyumva, សាលដីកា កថាខណ្ឌ៤៧២។

កំណត់វិធានការវិន័យ[4126] និងសិទ្ធិអំណាចដើម្បីដោះលែង ឬផ្ទេរអ្នកទោស[4127]។ គោលគំនិតនៃលទ្ធភាពសំខាន់ក៏ចាំបាច់ត្រូវពិចារណាផងដែរលើកត្តាទាំងអស់ ដែលអាចបង្អាក់ដល់លទ្ធភាពរបស់ថ្នាក់លើក្នុងការទប់ស្កាត់ និងការផ្តន្ទាទោស[4128]។

## ការដឹង ឬមានមូលហេតុត្រូវដឹង

1039. ចំពោះលក្ខខណ្ឌតម្រូវឲ្យមានការដឹងនោះ ពាក្យ "ដឹង" សំដៅលើការដឹងពិតប្រាកដថា ឧក្រិដ្ឋកម្មដែលពាក់ព័ន្ធត្រូវបានប្រព្រឹត្ត ឬហៀបនឹងត្រូវប្រព្រឹត្ត ដែលអាចនឹងត្រូវបានបង្ហាញតាមរយៈភ័ស្តុតាងផ្ទាល់ ឬប្រយោល[4129]។ ថ្នាក់លើមិនចាំបាច់ត្រូវដឹងអត្តសញ្ញាណច្បាស់លាស់របស់ថ្នាក់ក្រោមដែលប្រព្រឹត្តឧក្រិដ្ឋកម្មនោះទេ។

1040. លក្ខណវិនិច្ឆ័យនៃ "មូលហេតុត្រូវដឹង" តម្រូវឲ្យថ្នាក់លើមានព័ត៌មានទូទៅដែលអាចរកបានសម្រាប់គាត់ ដែលនឹងប្រាប់គាត់អំពីអំពើខុសច្បាប់ដែលអាចមាន ដោយថ្នាក់ក្រោមរបស់គាត់[4130]។ បទដ្ឋាននេះនឹងត្រូវបំពេញតាមបាន ប្រសិនបើព័ត៌មាននេះប្រកាសអាសន្នគ្រប់គ្រាន់នឹងបង្ហាញអំពីភាពត្រឹមត្រូវក្នុងការធ្វើការស៊ើបអង្កេតបន្ថែមទៀត[4131]។ *វា*មិនមានតម្រូវថាត្រូវតែមាន "ភាវនីយភាព" ឬ "ហានិភ័យច្បាស់លាស់ និងខ្លាំងក្លា" នៃឧក្រិដ្ឋកម្មបន្តបន្ទាប់នោះទេ[4132]។ បទដ្ឋាន "មូលហេតុត្រូវដឹង" នេះ មិនបានដាក់កាតព្វកិច្ចត្រូវទទួលបានព័ត៌មាននោះទេ។ បទដ្ឋាននេះមិនដូចគ្នានឹងបទដ្ឋាន "គួរណាស់តែបានដឹង" ពោលគឺបទដ្ឋាននៃការធ្វេសប្រហែសនោះទេ។ ថ្នាក់លើមិនអាចទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ចំពោះការខកខានមិនបានស្វែងរកការដឹងឮពាក់ព័ន្ធបាន

---

[4126] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៤១។ Strugar, សាលដីកា កថាខណ្ឌ២៦០-២៦២។

[4127] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៤១។ Čelebići, សាលដីកា កថាខណ្ឌ២០៦។

[4128] Popović, សាលដីកា កថាខណ្ឌ១៨៥៧។

[4129] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៤៣។ Bagilishema, សាលដីកា កថាខណ្ឌ៣៧។ Kordić&Čerkez, សាលក្រម កថាខណ្ឌ៤២៧។ Taylor, សាលក្រម កថាខណ្ឌ៤៩៧។

[4130] សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៤៤។ Blaškić, សាលដីកា កថាខណ្ឌ៦២។ Popović, សាលដីកា កថាខណ្ឌ១៩១០, ១៩១២។ Nahimana, សាលដីកា កថាខណ្ឌ៧៩១។ Sesay, សាលដីកា កថាខណ្ឌ៨៥២-៨៥៣។

[4131] សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៧១៥។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៤៤។ Popović, សាលដីកា កថាខណ្ឌ១៩១០។ Strugar, សាលដីកា កថាខណ្ឌ២៩៨។

[4132] Strugar, សាលដីកា កថាខណ្ឌ៣០៤។

ឡើយ[4133]។ ទោះជាយ៉ាងណា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនឹងត្រូវបានដាក់លើជនជាប់ចោទ ដែល *មានចេតនា* រារាំងមិនឱ្យមានការស្វែងរកព័ត៌មានពាក់ព័ន្ធ[4134]។

1041. ព័ត៌មានដែលទទួលបានមិនចាំបាច់ទាល់តែផ្តល់ព័ត៌មានជាក់លាក់ អំពីអំពើខុសច្បាប់ដែលបានប្រព្រឹត្ត ឬហៀបនឹងប្រព្រឹត្តនោះឡើយ[4135]។ ចំពោះគោលបំណងនៃការបង្ហាញថា ព័ត៌មាននេះគឺជាកម្មសិទ្ធិរបស់ថ្នាក់លើ វាមិនចាំបាច់ទាល់តែមានការបង្ហាញថា គាត់ពិតជាបានដឹងព័ត៌មាននោះដោយខ្លួនឯងនោះទេ គឺត្រឹមតែថា ព័ត៌មាននោះត្រូវបានផ្តល់ទៅឱ្យគាត់ ឬអាចរកបានសម្រាប់គាត់ទៅបានហើយ[4136]។ មុខតំណែងដែលអាចចេញបញ្ជារបស់ជនជាប់ចោទ អាចជាកត្តាមួយបង្ហាញពីការដឹងរបស់គាត់អំពីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តដោយថ្នាក់ក្រោមរបស់គាត់[4137]។ ថ្នាក់លើមិនចាំបាច់ទាល់តែចែករំលែកចេតនាជាមួយថ្នាក់ក្រោមរបស់គាត់នោះទេ[4138]។

## ការខកខានក្នុងការទប់ស្កាត់ ឬដាក់ទណ្ឌកម្ម

1042. ថ្នាក់លើរួចផុតពីករណីយកិច្ច ប្រសិនបើគាត់បានចាត់វិធានការ "ចាំបាច់ និងសមហេតុផល" ដើម្បីទប់ស្កាត់ ឬដាក់ទណ្ឌកម្មលើការប្រព្រឹត្តិឧក្រិដ្ឋកម្ម ដោយអ្នកក្រោមបង្គាប់ ក្នុងបរិបទនៃស្ថានភាពពិសេសណាមួយ។ ដូច្នេះ ការទទួលខុសត្រូវកើតមាន នៅពេលគាត់ខកខានមិនបានធ្វើបែបនេះ[4139]។

---

4133 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៤៤។ Čelebići, សាលដីកា កថាខណ្ឌ២២៦។ Blaškić, សាលដីកា កថាខណ្ឌ៦២-៦៤។ Bagilishema, សាលដីកា កថាខណ្ឌ៣៤-៣៥។ Taylor, សាលក្រម កថាខណ្ឌ ៤៩៨-៤៩៩។

4134 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៤៤។ Čelebići, សាលដីកា កថាខណ្ឌ២២៦។ Blaškić, សាលដីកា កថាខណ្ឌ៤០៦។ Taylor, សាលក្រម កថាខណ្ឌ៤៩៩។ (ដោយបញ្ជាក់បន្ថែម)

4135 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៤៤។ Čelebići, សាលដីកា កថាខណ្ឌ២៣៨។ Bagilishema, សាលដីកា កថាខណ្ឌ៤២។ Nahimana, សាលដីកា កថាខណ្ឌ៧៩១។

4136 Čelebići, សាលដីកា កថាខណ្ឌ២៣៩។

4137 Blaškić, សាលដីកា កថាខណ្ឌ៥៦-៥៧។

4138 Nahimana, សាលដីកា កថាខណ្ឌ៨៦៥។ Bagosora & Nsengiyumva, សាលដីកា កថាខណ្ឌ៣៨៤, ៣៩៩។

4139 ច្បាប់ អ.វ.ត.ក, មាត្រា២៩ ថ្មី។ សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៤៥-៥៤៧។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៧១៦។ Boškoski & Tarčulovski, សាលដីកា កថាខណ្ឌ២៣០។ Popović, សាលដីកា កថាខណ្ឌ១៩៤៣។ Nahimana, សាលដីកា កថាខណ្ឌ៤៨៤។ Sesay, សាលដីកា កថាខណ្ឌ៥០២, ៨៤២។

ច្បាប់ជាតិមិនតម្រូវឲ្យមានអត្ថិភាពនៃកាតព្វកិច្ចតាមផ្លូវច្បាប់ដាច់ដោយឡែក ក្នុងការចាត់វិធានការឡើយ[4140]។ ភារកិច្ចទប់ស្កាត់ និងដាក់ទណ្ឌកម្ម គឺខុសគ្នា និងនាំឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌដាច់ដោយឡែកពីគ្នា។ ភារកិច្ចទប់ស្កាត់ឧក្រិដ្ឋកម្មកើតឡើង មុនពេលប្រព្រឹត្ត គឺពេលថ្នាក់លើបានដឹងភ្លាម ឬមានហេតុផលត្រូវដឹងថា ឧក្រិដ្ឋកម្មហៀបនឹងប្រព្រឹត្ត។ មិនចាំបាច់បង្ហាញទំនាក់ទំនងហេតុនិងផល រវាងការខកខានរបស់ថ្នាក់លើក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មរបស់អ្នកក្រោមបង្គាប់ និងការកើតឡើងនូវឧក្រិដ្ឋកម្មទេ[4141]។ ការខកខានក្នុងការទប់ស្កាត់ ឬដាក់ទណ្ឌកម្មឧក្រិដ្ឋកម្ម អាចត្រូវបានទាញការសន្និដ្ឋានចេញពីកត្តានានា ដូចជា លក្ខណៈបន្តជាហូរហែ ឬរីករាលដាល នៃអំពើហិង្សាដែលប្រព្រឹត្តដោយអ្នកក្រោមបង្គាប់[4142]។

1043. ការកំណត់ថា តើអ្វីជាវិធានការចាំបាច់ និងសមហេតុផល ត្រូវធ្វើឡើងករណីតាមករណី[4143]។ ការកំណត់ថា តើអ្វីអាចធ្វើបានជាក់ស្តែង ពាក់ព័ន្ធនឹងការបំពេញកាតព្វកិច្ច ត្រូវតែវាយតម្លៃដោយផ្អែកលើកម្រិតនៃការគ្រប់គ្រងពិតប្រាកដរបស់ថ្នាក់លើ[4144]។ អត្ថិភាពនៃស្ថានភាពវឹកវរមិនអាចជួយឲ្យថ្នាក់លើរួចផុតពីកាតព្វកិច្ចនោះទេ[4145]។

---

4140 សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៧២០។

4141 Blaškić, សាលដីកា កថាខណ្ឌ៧៧។ Hadžihasanović& Kubura, សាលដីកា កថាខណ្ឌ៣៨-៤០។

4142 Bizimungu (Augustin), សាលដីកា កថាខណ្ឌ១០៤។ Bagosora & Nsengiyumva, សាលដីកា កថាខណ្ឌ៦៨៥។

4143 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ៥៤៥។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមសំណុំរឿង ០០២/០១, កថាខណ្ឌ៧១៦។ Blaškić, សាលដីកា កថាខណ្ឌ៧២, ៤១៧។ Halilović, សាលដីកា កថាខណ្ឌ៦៣។ Orić, សាលដីកា កថាខណ្ឌ១៧៧។ Hadžihasanović& Kubura, សាលដីកា កថាខណ្ឌ៣៣។ Kayishema & Ruzindana, សាលដីកា កថាខណ្ឌ៣០២។ Bagosora & Nsengiyumva, សាលដីកា កថាខណ្ឌ៦៧២, ៦៨៣។

4144 Boškoski&Tarčulovski, សាលដីកា កថាខណ្ឌ២៣១។ Popović, សាលដីកា កថាខណ្ឌ១៩២៨។ Bagosora & Nsengiyumva, សាលដីកា កថាខណ្ឌ៦៧២។

4145 Bagosora & Nsengiyumva, សាលដីកា កថាខណ្ឌ៦៧២។

1044. ភារកិច្ចរបស់ថ្នាក់លើក្នុងការដាក់ទណ្ឌកម្មចារីនៃឧក្រិដ្ឋកម្ម រួមមាន យ៉ាងហោចណាស់ កាតព្វកិច្ចស៊ើបអង្កេតលើឧក្រិដ្ឋកម្មដែលអាចមាន ដើម្បីបង្ហាញអង្គហេតុ និងដាក់ទណ្ឌកម្មចារីដោយផ្ទាល់ ឬរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច តាមការសមស្រប[4146]។

## គ. បទដ្ឋានភស្តុតាងដែលតម្រូវឲ្យមានចំពោះឧប្បត្តិហេតុ

1045. វិធាន ៦៧(៣)(គ) នៃវិធានផ្ទៃក្នុង ចែងថា សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាលើកលែងចោទប្រកាន់ ក្នុងករណី "ពុំមានភស្តុតាងគ្រប់គ្រាន់ ដើម្បីផ្តន្ទាទោសជនត្រូវចោទ"[4147]។ ស្រដៀងគ្នាដែរ មាត្រា ២៤៧(៣) នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ចែងថា ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់ នៅក្នុងករណី "គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ"[4148]។ គ្មានឯកសារណាមួយកំណត់ថា តើ "ភស្តុតាងគ្រប់គ្រាន់" មានន័យថាម៉េចទេ ក្នុងការអនុវត្តនោះទេ[4149]។

1046. សហចៅក្រមស៊ើបអង្កេតបានអនុវត្តបទដ្ឋាននៃ "ភស្តុតាងគ្រប់គ្រាន់" នៅក្នុងសំណុំរឿង ០០១[4150] និងសំណុំរឿង ០០២[4151] ដើម្បីបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ។ សហចៅក្រមស៊ើបអង្កេតបានអះអាងថា បទដ្ឋានភស្តុតាងជាធរមាន ដែលគ្របដណ្តប់ដោយពាក្យ "ភស្តុតាងគ្រប់គ្រាន់" គឺភវនីយភាពនៃពិរុទ្ធភាព ជាជាងលទ្ធភាពសុទ្ធសាធនៃពិរុទ្ធភាព[4152]។ សហចៅក្រមស៊ើបអង្កេតបានពន្យល់ថា "ភស្តុតាងនៅក្នុងសំណុំរឿងត្រូវមានលក្ខណៈខ្លាំងក្លា និងស៊ីចង្វាក់គ្រប់គ្រាន់ ដើម្បី

---

4146 Halilović , សាលដីកា កថាខណ្ឌ១៨២។ Boškoski & Tarčulovski, សាលដីកា កថាខណ្ឌ២៣០, ២៣៤-២៣៥។ Hadžihasanović& Kubura, សាលដីកា កថាខណ្ឌ១៥៤។ Popović, សាលដីកា កថាខណ្ឌ១៩៣២។ Bagosora & Nsengiyumva, សាលដីកា កថាខណ្ឌ៥១០។

4147 អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (កំណែលើកទី៩), ដែលបានពិនិត្យឡើងវិញនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥, វិធាន៦៧(៣)(គ)។

4148 ក្រមនីតិព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៨មាត្រា២៤៧(៣)។

4149 សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣២១។

4150 សំណុំរឿង០០១ ឯកសារ D99 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣០។

4151 សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣២១។

4152 សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣២៣។

ឲ្យមានតម្លៃជាភស្តុតាងបន្ទាល់”[4153]។ ការកំណត់ជាចុងក្រោយអំពីពិរុទ្ធភាពឲ្យហួសពីវិមតិសង្ស័យ ត្រូវវាយតម្លៃដោយអង្គជំនុំជម្រះសាលាដំបូង[4154]។

1047. ដើម្បីគាំទ្រដល់ការកំណត់ពី “ភស្តុតាងគ្រប់គ្រាន់” សហចៅក្រមស៊ើបអង្កេតបានយោងដល់ច្បាប់បារាំង និងយុត្តិសាស្ត្រនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ[4155]។ ចំពោះច្បាប់បារាំង មាត្រា ១១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង ចែងអំពីបទដ្ឋានដូចគ្នានៃ “ភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់” (“ភស្តុតាងគ្រប់គ្រាន់)”[4156] ប៉ុន្តែ មិនបានផ្តល់និយមន័យនោះទេ។ នៅក្នុងប្រព័ន្ធបារាំង ចៅក្រមស៊ើបអង្កេតទទួលបានឆន្ទានុសិទ្ធិដោយឥស្សរចិត្តក្នុងការកំណត់ ក្នុងការអនុវត្ត[4157]។

1048. យុត្តិសាស្ត្រព្រហ្មទណ្ឌអន្តរជាតិផ្តល់សេចក្តីណែនាំបន្ថែម ដើម្បីវាយតម្លៃបទដ្ឋានចាំបាច់នៃភស្តុតាងសម្រាប់ការបញ្ជូនទៅជំនុំជម្រះ។ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៦១(៥) ដែលគ្រប់គ្រងការបញ្ជាក់អំពីបទចោទ ចែងថា “រដ្ឋអាជ្ញាត្រូវគាំទ្របទចោទនីមួយៗ ដោយភស្តុតាងគ្រប់គ្រាន់ដើម្បីបង្កើតឲ្យមានមូលដ្ឋានច្បាស់លាស់ ក្នុងការជឿជាក់ថា ជននោះបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានចោទប្រកាន់”[4158]។ នៅក្នុងសេចក្តីសម្រេចថ្មីៗនេះ ក្នុងរឿងក្តី *Al Mahdi* អង្គបុរេជំនុំជម្រះទី ១ បានអះអាងថា គោលបំណងនៃការបញ្ជាក់អំពីការចោទប្រកាន់ គឺដើម្បីធានាថា “មានតែជនដែលមានបទចោទអាចជឿជាក់បានគ្រប់គ្រាន់ហួសពីទ្រឹស្តីសុទ្ធសាធ ឬមានការសង្ស័យប៉ុណ្ណោះ

---

4153 សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣២៣។

4154 វិធាន៨៧(១)។

4155 សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣២១។

4156 ក្រមនីតិព្រហ្មទណ្ឌរបស់សាធារណរដ្ឋបារាំង ឆ្នាំ២០១៧, មាត្រា១៧៧[“Si le juge d'instruction estime que les faits ne constituent ni crime, ni délit, ni contravention, ou si l'auteur est resté inconnu, ou s'il n'existe pas de charges suffisantes contre la personne mise en examen, il déclare, par une ordonnance, qu'il n'y a lieu à suivre”]។

4157 សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ, កថាខណ្ឌ១៣២២។

4158 លក្ខន្តិកៈ ICC មាត្រា៦១(៥) [“នៅអំឡុងពេលសវនាការ ព្រះរាជអាជ្ញាត្រូវផ្តល់ភស្តុតាងចំពោះបទចោទឲ្យបានគ្រប់គ្រាន់ដើម្បីជាមូលដ្ឋានគ្រឹះដើម្បីឲ្យទុកចិត្តបានថាជនដែលបានប្រព្រឹត្តល្មើសនឹងត្រូវផ្តន្ទាទោស។ ព្រះរាជអាជ្ញាអាចពឹងផ្អែកលើឯកសារ ឬភស្តុតាងសង្ខេប ហើយមិនតម្រូវឲ្យគាស់ហៅសាក្សីឲ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះឡើយ”]។

ទើបត្រូវបានបញ្ជូនទៅជំនុំជម្រះ"[4159]។ អង្គបុរេជំនុំជម្រះទី ១ បានបន្ថែមទៀតថា បទដ្ឋានភស្តុតាងជាធរមានត្រូវបានបង្ហាញ នៅពេលរដ្ឋអាជ្ញាផ្តល់ "ភស្តុតាងជាក់ស្តែង និងរូបី ដែលបង្ហាញអំពីការវែកញែកច្បាស់លាស់ដែលជាមូលដ្ឋាន [...] នៃការចោទប្រកាន់ជាក់លាក់[4160]។

1049. វិធានស្តីពីនីតិវិធី និងភស្តុតាង នៃយន្តការដោះស្រាយបញ្ហាសេសសល់របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា និងអតីតយូហ្គោស្លាវី ចែងថា រដ្ឋអាជ្ញាត្រូវចោទប្រកាន់ប្រសិនបើ "មានភស្តុតាងគ្រប់គ្រាន់សម្រាប់ផ្តល់ជាមូលដ្ឋានសមហេតុផលក្នុងការជឿជាក់ថាឧក្រិដ្ឋកម្មមួយ [...] ត្រូវបានប្រព្រឹត្ត"[4161]។ មុននេះ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា បានថ្លែងថា "មូលដ្ឋានសមហេតុផលអាចត្រូវបានបកស្រាយថាជាអង្គហេតុ និងកាលៈទេសៈដែលអាចនាំឱ្យមនុស្សប្រុងប្រយ័ត្នមានហេតុផល ឬសាមញ្ញ ជឿជាក់ថា ជនសង្ស័យបានប្រព្រឹត្ត

---

[4159] Al Mahdi សេចក្តីបញ្ជាក់សម្រេច, កថាខណ្ឌ១៥, សម្រង់៖ Lubanga សេចក្តីបញ្ជាក់សម្រេច, កថាខណ្ឌ៣៧។ Abu Garda សេចក្តីបញ្ជាក់សម្រេច, កថាខណ្ឌ៣៩។ Banda & Jerbo សេចក្តីបញ្ជាក់សម្រេច, កថាខណ្ឌ៣១។ Mbarushimana សេចក្តីបញ្ជាក់សម្រេច, កថាខណ្ឌ៤១។

[4160] Al Mahdi សេចក្តីបញ្ជាក់សម្រេច, កថាខណ្ឌ១៨, សម្រង់៖ Lubanga សេចក្តីបញ្ជាក់សម្រេច, កថាខណ្ឌ៣៩។ Katanga & Ngudjolo សេចក្តីបញ្ជាក់សម្រេច, កថាខណ្ឌ៦៥។ សេចក្តីសម្រេចលើបទចោទនៃអង្គបុរេជំនុំជម្រះ Bemba, កថាខណ្ឌ២៩។ Abu Garda សេចក្តីបញ្ជាក់សម្រេច, កថាខណ្ឌ៣៧។ Mbarushimana សេចក្តីបញ្ជាក់សម្រេច, កថាខណ្ឌ៤០។ Muthaura et al. សេចក្តីបញ្ជាក់សម្រេចកថាខណ្ឌ៥២។ Ntaganda សេចក្តីបញ្ជាក់សម្រេចកថាខណ្ឌ៩។ Gbagbo សេចក្តីបញ្ជាក់សម្រេចកថាខណ្ឌ១៩។ Bemba et al. សេចក្តីបញ្ជាក់សម្រេចកថាខណ្ឌ២៥។ Blé Goudé សេចក្តីបញ្ជាក់សម្រេចកថាខណ្ឌ១២។ Ongwen សេចក្តីបញ្ជាក់សម្រេច, កថាខណ្ឌ១៧។

[4161] វិធាន MICT ផ្នែកនីតិវិធី និងភស្តុតាង, វិធាន៤៨(ខ) ["កាលណាការស៊ើបអង្កេតបិទបញ្ចប់ដោយក្តីសោមនស្ស និងប្រមូលបានភស្តុតាងគ្រប់គ្រាន់សម្រាប់ជាមូលដ្ឋានថាឧក្រិដ្ឋកម្មនោះប្រាកដជាបានប្រព្រឹត្ត អនុលោមតាមមាត្រា១កថាខណ្ឌ៤នៃលក្ខន្តិកៈហើយនោះ ព្រះរាជអាជ្ញាត្រូវរៀបចំ និងបញ្ជូនការចោទប្រកាន់ដោយភ្ជាប់ជាមួយនូវឯកសារគាំទ្រដទៃទៀតដើម្បីស្នើសុំការអនុម័តពីអង្គចៅក្រមតាមរយៈក្រឡាបញ្ជី។"]។ ICTY វិធានស្តីពីនីតិវិធី និងភស្តុតាងវិធាន៤៧(ខ) ["កាលណាការស៊ើបអង្កេតបិទបញ្ចប់ដោយក្តីសោមនស្ស និងប្រមូលបានភស្តុតាងគ្រប់គ្រាន់សមល្មមជាមូលដ្ឋានក្នុងការចោទប្រកាន់ជនសង្ស័យថាបានប្រព្រឹត្តល្មើសស្ថិតនៅក្នុងយុត្តាធិការនៃអង្គជំនុំជម្រះហើយ ព្រះរាជអាជ្ញាត្រូវរៀបចំ និងបញ្ជូនការចោទប្រកាន់ដើម្បីស្នើសុំការអនុម័តពីអង្គចៅក្រមតាមរយៈក្រឡាបញ្ជីដោយភ្ជាប់ជាមួយនូវឯកសារគាំទ្រដទៃទៀត។"]។ ICTR វិធានស្តីពីនីតិវិធី និងភស្តុតាងវិធាន៤៧(ខ) ["កាលណាការស៊ើបអង្កេតបិទបញ្ចប់ដោយក្តីសោមនស្ស និងប្រមូលបានភស្តុតាងគ្រប់គ្រាន់សមល្មមជាមូលដ្ឋានក្នុងការចោទប្រកាន់ជនសង្ស័យថាបានប្រព្រឹតល្មើសស្ថិតនៅក្នុងយុត្តាធិការនៃអង្គជំនុំជម្រះហើយ ព្រះរាជអាជ្ញាត្រូវរៀបចំ និងបញ្ជូនការចោទប្រកាន់ដើម្បីស្នើសុំការអនុម័តពីអង្គចៅក្រមតាមរយៈក្រឡាបញ្ជីដោយភ្ជាប់ជាមួយនូវឯកសារគាំទ្រដទៃទៀត"]។

ឧក្រិដ្ឋកម្ម។ ដើម្បីឲ្យមានមូលដ្ឋានសមហេតុផល ត្រូវមានអង្គហេតុដែលបង្ហាញនូវការសង្ស័យយ៉ាងច្បាស់ថា ជនសង្ស័យមានពិរុទ្ធភាពពីបទប្រព្រឹត្តបទល្មើស”[4162]។

1050. លើសពីនេះទៅទៀត លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា តម្រូវឲ្យចៅក្រមអង្គជំនុំជម្រះសាលាដំបូងត្រូវ “បំពេញឲ្យបានថា សំណុំរឿងត្រូវបានបង្កើតឡើង តាមការពិនិត្យបឋម” ដើម្បីបញ្ជាក់អំពីបទចោទ[4163]។ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានកំណត់ “សំណុំរឿងតាមការពិនិត្យបឋម” ជា “សំណុំរឿងអាចជឿជាក់បាន (ប្រសិនបើមិនជំទាស់ដោយមេធាវីការពារក្តី) ដែលជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់ផ្តន្ទាទោសជនជាប់ចោទ ផ្អែកតាមបទចោទ”[4164]។

## ឃ. យុត្តាធិការបុគ្គល

1051. ទាំងកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក ចែងថា ការបង្កើតតុលាការនេះមានគោលបំណង “វិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត” ចំពោះឧក្រិដ្ឋកម្ម នៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ដែលបានប្រព្រឹត្ត ក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩[4165]។

---

4162 សេចក្តីសម្រេចបឋមលើសារណាក្នុងសំណុំរឿង Ntakirutimana, កថាខណ្ឌ៦។

4163 លក្ខន្តិកៈរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាសម្រាប់អតីតយូហ្គោស្លាវីដែលធ្វើបច្ចុប្បន្នភាពនៅក្នុងខែកញ្ញា ឆ្នាំ២០០៩ មាត្រា១៩(១) [“ការពិនិត្យឡើងវិញនៃបទចោទ - កាលណាបទចោទបានបញ្ជូនទៅដល់ដៃចៅក្រមអង្គជំនុំជម្រះរូបណាហើយ ចៅក្រមរូបនោះត្រូវនិត្យមើលសំណុំរឿង។កាលណាសំណុំរឿងរៀបចំដោយព្រះរាជអាជ្ញាមានមូលដ្ឋានគ្រប់គ្រាន់សមស្របហើយ ចៅក្រមត្រូវអនុម័តលើបទចោទនោះ។ ក្នុងករណីមិនពេញចិត្តនឹងបទចោទនោះចៅក្រមត្រូវទម្លាក់បទចោទនោះ”]។ ICTR លក្ខន្តិកៈ, មាត្រា១៨(១) [“ចៅក្រមនៃអង្គជំនុំជម្រះក្រោយពីទទួលបានបទចោទនោះហើយត្រូវតែពិនិត្យ។ ក្នុងករណីសំណុំរឿងរៀបចំដោយព្រះរាជអាជ្ញាមានមូលដ្ឋានគ្រប់គ្រាន់សមស្របហើយ ចៅក្រមត្រូវអនុម័តលើបទចោទនោះ។”]។

4164 ការពិនិត្យបទចោទក្នុងសំណុំរឿង Rajić, ទំព័រ៦។ Milošević et al. សេចក្តីសម្រេចលើការស៊ើបអង្កេត និងពាក្យស្នើសុំ, កថាខណ្ឌ៤។

4165 កិច្ចព្រមព្រៀងរបស់ អ.វ.ត.ក, មាត្រា១, ២។ ច្បាប់ អ.វ.ត.ក, មាត្រា១, ២ថ្មី។

1052. ពាក្យ "មេដឹកនាំជាន់ខ្ពស់" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" មិនត្រូវបានកំណត់និយមន័យច្បាស់លាស់នោះទេ ទាំងនៅក្នុងច្បាប់ អ.វ.ត.ក ទាំងនៅក្នុងកិច្ចព្រមព្រៀង។ ផ្អែកលើការវិភាគសព្វជ្រុងជ្រោយនៃការងារត្រៀម និងប្រវត្តិនៃការចរចាកិច្ចព្រមព្រៀង អ.វ.ត.ក[4166] អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសំណុំរឿង ឌុច បានរកឃើញថា អ.វ.ត.ក មានយុត្តាធិការបុគ្គលលើតែកម្មាភិបាលខ្មែរក្រហម[4167] ហើយពាក្យ "មេដឹកនាំជាន់ខ្ពស់" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" សំដៅដល់កម្មាភិបាលខ្មែរក្រហមពីរប្រភេទខុសគ្នា៖

> ប្រភេទទីមួយ គឺជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ពីព្រោះមេដឹកនាំជាន់ខ្ពស់ម្នាក់មិនមែនជាជនសង្ស័យ ដោយផ្អែកតែទៅលើតួនាទីជាអ្នកដឹកនាំរបស់ខ្លួនប៉ុណ្ណោះទេ។ ប្រភេទមួយផ្សេងទៀត គឺអ្នកដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ប៉ុន្តែ ជាអ្នកដែលស្ថិតនៅក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតផងដែរ[4168]។

អាស្រ័យហេតុនេះ ប្រសិនបើជនត្រូវចោទណាមួយជាកម្មាភិបាលខ្មែរក្រហម ជននោះមិនចាំបាច់ជាមេដឹកនាំជាន់ខ្ពស់ ដើម្បីស្ថិតនៅក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះទេ។

1053. សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយល់ស្របថា ការរកឃើញថា ជនត្រូវចោទជា "មេដឹកនាំជាន់ខ្ពស់" និង/ឬ កម្មាភិបាលខ្មែរក្រហម "ដែលទទួលខុសត្រូវខ្ពស់បំផុត" "ត្រូវធ្វើឡើង នៅពេលបិទកិច្ចស៊ើបសួរ ដោយផ្អែកលើភស្តុតាងសរុបនៅក្នុងសំណុំរឿង"[4169]។

## ១. អ្នកទទួលខុសត្រូវខ្ពស់បំផុត

1054. ក្នុងការសម្រេចថា តើជនណាម្នាក់ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មអន្តរជាតិដែរ ឬទេ អ.វ.ត.ក និងតុលាការព្រហ្មទណ្ឌអន្តរជាតិ បានប្រកាន់យកលក្ខណវិនិច្ឆ័យពីរ៖ (១) ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់ប្រឆាំងនឹងជននោះ និង (២) កម្រិតនៃការទទួលខុសត្រូវរបស់ជន ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ។

---

[4166] សំណុំរឿង០០១ ឯកសារ F28 សាលក្រមសាលាឧទ្ធរណ៍ ឌុច, កថាខណ្ឌ៤៦-៥៧។

[4167] សំណុំរឿង០០១ ឯកសារ F28 សាលក្រមសាលាឧទ្ធរណ៍ ឌុច, កថាខណ្ឌ៥២, ៦១។

[4168] សំណុំរឿង០០១ ឯកសារ F28 សាលក្រមសាលាឧទ្ធរណ៍ ឌុច, កថាខណ្ឌ៥៧ (សម្រង់ពីផ្ទៃក្នុងត្រូវបានដកចេញ)។

[4169] ឯកសារ D181 ICIJ សេចក្តីសម្រេចលើយុត្តាធិការបុគ្គល, កថាខណ្ឌ២៧។

1055. តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ត្រូវបានប្រគល់អាណត្តិឱ្យ (ជាផ្នែកមួយនៃយុទ្ធសាស្ត្របញ្ចប់របស់ខ្លួន) ផ្តោតលើ "មេដឹកនាំជាន់ខ្ពស់បំផុត ដែលត្រូវបានសង្ស័យថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម"[4170] នៅពេលសំដៅដល់ចារីសេសសល់ ដែលត្រូវកាត់ទោសនៅថ្នាក់ជាតិ[4171]។ ក្នុងការវាយតម្លៃលើអ្នកទទួលខុសត្រូវខ្ពស់បំផុត ក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានពិចារណាអំពី "ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលចោទប្រកាន់" និង "កម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ"[4172]។ គោលការណ៍ពីរនេះត្រូវបានឆ្លុះបញ្ចាំង ក្នុងសេចក្តីសម្រេចរបស់តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន[4173] សេចក្តីថ្លែងការណ៍របស់ការិយាល័យរដ្ឋអាជ្ញានៃតុលាការព្រហ្មទណ្ឌអន្តរជាតិ[4174] ហើយត្រូវបានអនុម័តដោយអង្គជំនុំជម្រះសាលាដំបូង[4175] អង្គជំនុំជម្រះតុលាការកំពូល[4176] និងសហចៅក្រមស៊ើបអង្កេត[4177] នៃ អ.វ.ត.ក។ ការអនុវត្តគោលការណ៍ទាំងពីរនេះមិនតម្រូវឱ្យមានការប្រៀបធៀប និងការចាត់ថ្នាក់ការទទួលខុសត្រូវរបស់ចារីដែលអាចមានទាំងអស់ទេ[4178] ប៉ុន្តែ

---

4170 សេចក្តីសម្រេចលេខ ១៥៣៤ (ឆ្នាំ២០០៤)របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ, ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៤, អ.ស.ប ឯកសារលេខ S/Res/១៥៣៤, កថាខណ្ឌ៥-៦។ សេចក្តីសម្រេចលេខ ១៥០៣របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៣, អ.ស.ប ឯកសារលេខ S/Res/១៥០៣, រៀបរាប់នៅក្នុងបុព្វកថា៧។

4171 វិធានស្តីពីនីតិវិធី និងភស្តុតាងរបស់ICTYវិធាន១១ស្ទួន និងវិធាន១១ស្ទួន(គ) យោងសេចក្តីសម្រេចលេខ១៥៣៤ របស់ក្រុមប្រឹក្សាសន្តិសុខ លើកឡើងថាICTYនឹងពិចារណាលើ "ទម្ងន់នៃការចោទប្រកាន់" និង "កម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ" ហើយសម្រេចថាតើត្រូវបញ្ជូនសំណុំរឿងនោះឬយ៉ាងនា។ សូមអាន Milošević (Dragomir) ដោយយោងលើសេចក្តីសម្រេចក្នុងសំណុំរឿង, កថាខណ្ឌ១-៣។

4172 យោងតាមសេចក្តីសម្រេចLukić& Lukić,កថាខណ្ឌ២៦-២៨។

4173 សេចក្តីសម្រេចយុត្តាធិការបុគ្គលFofana,កថាខណ្ឌ២២។

4174 ICC OTP, របាយការណ៍ស្តីពីគោលនយោបាយមួយចំនួនចេញផ្សាយនៅចំពោះមុខការិយាល័យព្រះរាជអាជ្ញា, តុលាការឧក្រិដ្ឋកម្មអន្តរជាតិ, ចុះខែកញ្ញា ឆ្នាំ២០០៣, ទំព័រ៧។

4175 សំណុំរឿង០០១ ឯកសារ E188 សាលក្រម ឌុច, កថាខណ្ឌ២២-២៤។

4176 សំណុំរឿង០០១ ឯកសារ F28 សាលក្រមសាលាឧទ្ធរណ៍ ឌុច, កថាខណ្ឌ៧១។

4177 ឯកសារ D48 សេចក្តីសម្រេចយុត្តាធិការបុគ្គល I, កថាខណ្ឌ១៥។ ឯកសារ D49 សេចក្តីសម្រេចយុត្តាធិការបុគ្គល II, កថាខណ្ឌ១៥។

4178 សំណុំរឿង០០១ ឯកសារ F28 សាលក្រមសាលាឧទ្ធរណ៍ ឌុច, កថាខណ្ឌ៦២។

ផ្ទុយទៅវិញ គួរពាក់ព័ន្ធនឹងសំណុំរឿងផ្សេងទៀត ដែលតុលាការបានជំនុំជម្រះ ក៏ដូចជាកាលៈទេសៈពិសេស និងបរិបទ នៃការប្រព្រឹត្តឧក្រិដ្ឋកម្ម[4179]។

1056. សេចក្តីសម្រេចបញ្ជូនរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានបញ្ជាក់ថា កត្តាពាក់ព័ន្ធដើម្បីកំណត់ភាពធ្ងន់ធ្ងរនៃបទល្មើស ដែលបានប្រព្រឹត្ត រួមមាន៖ ដែនកំណត់ខាងភូមិសាស្ត្រ និងពេលវេលា នៃឧក្រិដ្ឋកម្ម[4180] របៀបនៃការប្រព្រឹត្តិឧក្រិដ្ឋកម្ម[4181] ចំនួននៃឧប្បត្តិហេតុ[4182] និងចំនួនជនរងគ្រោះ[4183]។ ការវាយតម្លៃលើកត្តាទាំងនេះមិនគួរជាលំហាត់គណិតវិទ្យារឹងត្អឹងទេ ប៉ុន្តែទាមទារឲ្យមានការវិភាគត្រួតខុសៗគ្នា[4184]។

1057. កត្តាពាក់ព័ន្ធដើម្បីកំណត់អំពីកម្រិតនៃការទទួលខុសត្រូវរបស់បុគ្គល ដែលត្រូវចោទប្រកាន់ថាបានប្រព្រឹត្តិឧក្រិដ្ឋកម្ម រួមមាន៖ កម្រិតនៃការចូលរួមក្នុងបទឧក្រិដ្ឋដែលនចោទប្រកាន់[4185] ឋានានុក្រម ឬមុខតំណែងរបស់ជនជាប់ចោទ[4186] រួមបញ្ចូលទាំងចំនួនអ្នកក្រោមបង្គាប់ និងថ្នាក់លើ[4187] សិទ្ធិ

---

4179 ដោយយោងលើសេចក្តីសម្រេចក្នុងសំណុំរឿងAdemi,កថាខណ្ឌ២៨។

4180 យោងលើសេចក្តីសម្រេចក្នុងសំណុំរឿង Janković,កថាខណ្ឌ១៩។ ដោយយោងលើសេចក្តីសម្រេចក្នុងសំណុំរឿង Ademi,កថាខណ្ឌ២៨។ ដោយយោងលើសេចក្តីសម្រេចក្នុងសំណុំរឿងKovačević,កថាខណ្ឌ២០។ ដោយយោងលើសេចក្តីសម្រេចក្នុងសំណុំរឿងLukić& Lukić,កថាខណ្ឌ២៧។ ដោយយោងលើសេចក្តីសម្រេចឧទ្ធរណ៍ក្នុងសំណុំរឿង Todović,កថាខណ្ឌ១៣, ១៦។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នាំICTYបញ្ជាក់ថា, ផ្ទុយទៅវិញនោះគឺជាការទម្ងន់ដ៏ធ្ងន់ ដែលមិនគួរទំលាក់កំហុសទៅលើអ្នកមូលដ្ឋាន ព្រោះថាអ្នកដឹកនាំមូលដ្ឋានទាំងនោះតាមពិតទៅមានឥទ្ធិពលយ៉ាងសំខាន់ក្នុងការចុចឈ្មោះឲ្យគេចាប់មនុស្ស នេះក៏ដោយសារអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតជាអ្នកចង្អុលបង្ហាញឲ្យគេធ្វើតែប៉ុណ្ណោះ។ អានសេចក្តីសម្រេចឧទ្ធរណ៍ក្នុងសំណុំរឿងLukić,កថាខណ្ឌ២២។

4181 យោងលើសេចក្តីសម្រេចក្នុងសំណុំរឿងLukić& Lukić,កថាខណ្ឌ២៧។

4182 យោងលើសេចក្តីសម្រេចក្នុងសំណុំរឿងLukić& Lukić,កថាខណ្ឌ២៧។

4183 យោងលើសេចក្តីសម្រេចក្នុងសំណុំរឿងJanković,កថាខណ្ឌ១៩។ ដោយយោងលើសេចក្តីសម្រេចក្នុងសំណុំរឿង Kovačevićកថាខណ្ឌ១២, ២០។ ដោយយោងលើសេចក្តីសម្រេចក្នុងសំណុំរឿងLukić& Lukić,កថាខណ្ឌ២៧ និង ២៩។ ដោយយោងលើសេចក្តីសម្រេចក្នុងសំណុំរឿងRašević& Todović,កថាខណ្ឌ២៣។ ដោយយោងលើសេចក្តីសម្រេចឧទ្ធរណ៍ក្នុងសំណុំរឿងTodović,កថាខណ្ឌ២៥។

4184 អានសេចក្តីសម្រេចឧទ្ធរណ៍ក្នុងសំណុំរឿង Ntaganda មាត្រា៥៨, កថាខណ្ឌ៧៦។

4185 យោងលើសេចក្តីសម្រេចក្នុងសំណុំរឿងAdemi, កថាខណ្ឌ២៩។ ដោយយោងលើសេចក្តីសម្រេចក្នុងសំណុំរឿង Lukić& Lukić, កថាខណ្ឌ២៨។ សេចក្តីសម្រេចឧទ្ធរណ៍ក្នុងសំណុំរឿង Lukić,កថាខណ្ឌ២១។

4186 យោងលើសេចក្តីសម្រេចក្នុងសំណុំរឿងAdemi,កថាខណ្ឌ២៩។ យោងលើសេចក្តីសម្រេចក្នុងសំណុំរឿងKovačević, កថាខណ្ឌ២០។ យោងលើសេចក្តីសម្រេចក្នុងសំណុំរឿង Milošević (Dragomir), កថាខណ្ឌ២៣។ ដោយយោងលើ

អំណាចពិតប្រាកដ[4188] និងលទ្ធភាពក្នុងការចេញបញ្ជា[4189] វិសាលភាពពេលវេលានៃការគ្រប់គ្រង[4190] សិទ្ធិអំណាចក្នុងការចរចា ចុះហត្ថលេខា ឬអនុវត្តកិច្ចព្រមព្រៀង[4191] ការដឹងឮជាក់ស្តែងអំពីឧក្រិដ្ឋកម្ម និងថាតើអ្នកដែលមានឋានៈខ្ពស់ជាងត្រូវបានផ្តន្ទាទោសរួចហើយដែរ ឬទេ[4192]។

## ២. មេដឹកនាំជាន់ខ្ពស់

1058. ទាក់ទងនឹងពាក្យ "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ" ប្រវត្តិច្បាប់របស់ អ.វ.ត.ក[4193] និងយុត្តិសាស្ត្រអន្តរជាតិ[4194] កំណត់ថាពាក្យនេះមិនកម្រិតត្រឹមសមាជិកគណៈអចិន្ត្រៃយ៍ ប.ក.ក ឬ "អ្នកតាក់តែងគោលនយោបាយទូទៅ" នោះទេ។ ប៉ុន្តែ សហព្រះរាជអាជ្ញាយល់ឃើញថា ន័យត្រង់នៃពាក្យនេះបង្ហាញថា វារួមបញ្ចូលក្រុមមនុស្សមានកម្រិតនៅថ្នាក់កំពូលនៃឋានានុក្រមនយោបាយ និងយោធា របស់ ប.ក.ក និងរបបកម្ពុជាប្រជាធិបតេយ្យ។

---

សេចក្តីសម្រេចក្នុងសំណុំរឿងLukić& Lukić, កថាខណ្ឌ២៨។ សេចក្តីសម្រេចឧទ្ធរណ៍ក្នុងសំណុំរឿង Lukić,កថាខណ្ឌ២១។

4187 យោងលើសេចក្តីសម្រេចក្នុងសំណុំរឿងMilošević (Dragomir),កថាខណ្ឌ២៣។ សេចក្តីសម្រេចឧទ្ធរណ៍ក្នុងសំណុំរឿង Lukić,កថាខណ្ឌ២១។

4188 ដោយយោងលើសេចក្តីសម្រេចក្នុងសំណុំរឿងLukić& Lukić, កថាខណ្ឌ២៨។ ដោយយោងលើសេចក្តីសម្រេចក្នុងសំណុំរឿងAdemi, កថាខណ្ឌ២៩។

4189 ដោយយោងលើសេចក្តីសម្រេចក្នុងសំណុំរឿងAdemi, កថាខណ្ឌ២៩។

4190 យោងលើសេចក្តីសម្រេចក្នុងសំណុំរឿងMilošević (Dragomir), កថាខណ្ឌ២៣។

4191 យោងលើសេចក្តីសម្រេចក្នុងសំណុំរឿងMilošević (Dragomir), កថាខណ្ឌ២៣។

4192 ដោយយោងលើសេចក្តីសម្រេចក្នុងសំណុំរឿងKovačević, កថាខណ្ឌ២០។

4193 សំណុំរឿង០០១ ឯកសារ F28 សាលក្រមសាលាឧទ្ធរណ៍ ឌុច, កថាខណ្ឌ៧៦-៧៧។ដោយដកស្រង់សម័យប្រជុំលើកទី១ នីតិកាលទី៣ នៃសភាជាតិកម្ពុជា ថ្ងៃទី៤-៥ខែតុលា ឆ្នាំ២០០៤ទំព័រ២៣។ សំណុំរឿង០០២ឯកសារE188សាលក្រម ឌុច, កថាខណ្ឌ១៩។សម្រង់របាយការណ៍របស់ក្រុមអ្នកជំនាញកថាខណ្ឌ១០៩។

4194 យោងលើសេចក្តីសម្រេចក្នុងសំណុំរឿង Milošević (Dragomir) កថាខណ្ឌ២២។ ដោយយោងលើសេចក្តីសម្រេចក្នុងសំណុំរឿងLukić & Lukićកថាខណ្ឌ២៨។

## X. ឧក្រិដ្ឋកម្មជាតិ និងឧក្រិដ្ឋកម្មដែលមិនត្រូវបានចោទប្រកាន់

### ឧក្រិដ្ឋកម្មនៅក្រោមក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ១៩៥៦

1059. សហព្រះរាជអាជ្ញាជានិច្ចកាលបានរក្សាគោលជំហររបស់ខ្លួន[4195] ដែលគាំទ្រដោយអង្គបុរេជំនុំជម្រះ[4196] ថា យោងតាមមាត្រា ៣ ថ្មី នៃច្បាប់ អ.វ.ត.ក, អ.វ.ត.ក អាចអនុវត្តយុត្តាធិការលើឧក្រិដ្ឋកម្មមនុស្សឃាតដោយគិតទុកជាមុន[4197] ទារុណកម្ម[4198] និងការវាយប្រហារលើសាសនា[4199] (ហៅជារួមថា"ឧក្រិដ្ឋកម្មជាតិ") ដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ និងមិនត្រូវបានហាមឃាត់មិនឲ្យធ្វើបែបនេះ ដោយអាជ្ញាយុកាល ១០ ឆ្នាំ ដូចមានចែងក្នុងមាត្រា ១០៩ នៃក្រមនេះ[4200]។

---

4195 សហព្រះរាជអាជ្ញាធ្លាប់បានអធិប្បាយពីមុនមកអំពីជំហររបស់ខ្លួនទាក់ទងនឹងលក្ខន្តិកៈនៃការកំហិតឧក្រិដ្ឋកម្មក្នុងយុត្តាធិការរបស់អ.វ.ត.ក អនុលោមតាមមាត្រា៣ ថ្មី នៅចំពោះមុខអង្គជំនុំជម្រះ និងអង្គបុរេជំនុំជម្រះ។សហព្រះរាជអាជ្ញាសំអាងលើCIJsចំពោះសំណុំរឿង០០២ ឯកសារ E51/5/3/1ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញាដើម្បីការពារវិធាន៨៩,ការជំទាស់ដំបូង, ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១។ សំណុំរឿង០០២ ឯកសារ E51/7/1 សំណើសុំរបស់សហព្រះរាជអាជ្ញាស្តីពីលក្ខន្តិកៈនៃការកំណត់ឧក្រិដ្ឋកម្មជាតិ ចុះថ្ងៃទី២៧ខែឧសភា ឆ្នាំ២០១១ ("លក្ខន្តិកៈ OCP ស្តីពីការកំណត់សំណើសុំ")។ សំណុំរឿង០០២ ឯកសារ D427/1/17 ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសារទុក្ខរបស់ នួន ជា, អៀង សារី និងអៀង ធីរិទ្ធប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០។

4196 សំណុំរឿង០០២ ឯកសារ D427/1/30សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ២៧១-២៩២, ២៩៧។

4197 ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦, មាត្រា៥០១, ៥០៣-៥០៨។

4198 ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦, មាត្រា៥០០។

4199 ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦, មាត្រា២០៩, ២១០។

4200 ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦, មាត្រា១០៩ផ្តល់នូវផ្នែកពាក់ព័ន្ធគឺថា "ជនល្មើសណានឹងមិនត្រូវផ្តន្ទាទោសដោយផ្អែកទៅលើអំពើរបស់ខ្លួនបានប្រព្រឹត្តកាលពីជាងដប់ឆ្នាំមុន" (ឯកសារបកប្រែមិនផ្លូវការត្រូវអង្គជំនុំជម្រះយកមកប្រើប្រាស់និងអនុម័តដោយ អ.ប.ជ។អានសំណុំរឿង០០១ ឯកសារ E187 សេចក្តីសម្រេចស្តីពីការការពារការជំទាស់លើកដំបូងពាក់ព័ន្ធនឹងលក្ខន្តិកៈកំណត់ឧក្រិដ្ឋកម្មជាតិ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ("សេចក្តីសម្រេចលក្ខន្តិកៈរបស់អង្គជំនុំជម្រះ"), លេខជើងទំព័រ១៣)។សូមអានក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦, មាត្រា១១១ (លើកឡើងថាអាជ្ញាយុកាលបានខើចបន្តិចម្តងៗបើធៀបទៅនឹងពេលវេលាដែលអំពើដែលរងការចោទប្រកាន់បានប្រព្រឹត្តនោះ) និងមាត្រា១១២-១១៤

1060. ដូចអង្គបុរេជំនុំជម្រះបានបញ្ជាក់[4201] អាជ្ញាយុកាលត្រូវបានព្យួរ រហូតដល់យ៉ាងហោចណាស់ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ដោយសារតែលក្ខខណ្ឌនៅក្នុងប្រទេសកម្ពុជា។ លក្ខខណ្ឌទាំងនេះ ដែលអង្គបុរេជំនុំជម្រះបានទម្លាក់កំហុសទៅលើខ្មែរក្រហម រួមមាន កង្វះដំណើរការប្រព័ន្ធយុត្តិធម៌ ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋប្រជាមានិតកម្ពុជា ចន្លោះពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ ១៩៨២។ បន្ទាប់មក "រហូតដល់ព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតឡើងដោយការប្រកាសឲ្យប្រើរដ្ឋធម្មនុញ្ញ នៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ការពិចារណាមួយចំនួនលើកត្តាប្រវត្តិសាស្ត្រ និងបរិបទ បានរារាំងយ៉ាងខ្លាំងដល់សមត្ថភាពក្នុងការចោទប្រកាន់ និងស៊ើបអង្កេតក្នុងស្រុក"[4202]។ ដូច្នេះ ការពន្យារអាជ្ញាយុកាលដោយរដ្ឋសភាកម្ពុជា នៅក្នុងឆ្នាំ ២០០១ ដល់ ២០ ឆ្នាំ[4203] រួចនៅ ឆ្នាំ ២០០៤ ដល់ឆ្នាំ ៣០ ឆ្នាំ[4204] មិនបានបំពានគោលការណ៍នីត្យានុកូលភាពនោះទេ[4205]។ លើសពីនេះទៅទៀត សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានសមភាពចំពោះមុខច្បាប់ មិនត្រូវបានរំលោភបំពានដោយការចោទប្រកាន់លើឧក្រិដ្ឋកម្មជាតិ នៅ អ.វ.ត.ក[4206] នោះទេ ហើយការកំណត់របស់ក្រុមប្រឹក្សាធម្មនុញ្ញថា មាត្រា ៣ ថ្មី នៃច្បាប់ អ.វ.ត.ក មិនរំលោភលើសិទ្ធិ

---

(ដោយលើកឡើងថាការស៊ើបអង្កេត ឬការកាត់ទោសប៉ះពាល់ដល់ពេលវេលាបានកំណត់ដោយសារមូលហេតុខាងដើម (ក្នុងសំណុំរឿងឧក្រិដ្ឋ), សម្រាប់ពេលថ្មីមានរយៈពេល១០ឆ្នាំ)។

4201 សំណុំរឿង០០២ ឯកសារ D427/1/30សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ២៨៥-២៨៦, សម្រង់, សំណុំរឿង០០១ ឯកសារ E187សេចក្តីសម្រេចលក្ខន្តិកៈកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ១៤, ១៦-១៧, ២៧, ២៩ (បញ្ជាក់ថាលក្ខន្តិកៈនៃការកំណត់នឹងមិនដំណើរការកាលណាស្ថាប័នយុត្តិធម៌មិនអាចដំណើរការបាន), ១៩, ២០, ២៥ (ឃើញថាចៅក្រមចំនួនបីរូបរបស់កម្ពុជាសម្រាប់អង្គជំនុំជម្រះសាលាដំបូងនៅខ្វះខាតសមត្ថភាពគ្រប់គ្រាន់នៅក្នុងតុលាការកម្ពុជាទេ ទាល់តែដល់ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ទើបពួកគាត់ទទួលបានសមត្ថភាពពេញលេញ)។

4202 សំណុំរឿង០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ២៨៦, ការដកស្រង់សំណុំរឿង០០១ ឯកសារ E187 សេចក្តីសម្រេចលក្ខន្តិកៈកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង, កថាខណ្ឌ២០។

4203 ច្បាប់ អ.វ.ត.ក, មាត្រា៣។

4204 ច្បាប់ អ.វ.ត.ក, មាត្រា៣ថ្មី។

4205 សំណុំរឿង០០២ ឯកសារ D427/1/30សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ២៨៧។

4206 សំណុំរឿង០០២ ឯកសារ D427/1/30សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ២៨៨-២៩២។

ក្នុងរដ្ឋធម្មនុញ្ញ គឺបិទផ្លូវតវ៉ា ចងកាតព្វកិច្ច និងមិនអាចត្រូវបានតុលាការនេះពិនិត្យឡើងវិញទេ[4207] ។ ជាលទ្ធផល ពុំមានបញ្ហាអាជ្ញាយុកាល ពាក់ព័ន្ធនឹងភាពអាចអនុវត្តបាននៃឧក្រិដ្ឋកម្មជាតិនៅក្នុង សំណុំរឿង ០០៣ នោះទេ។ ប៉ុន្តែ គួរកត់សម្គាល់ថា ពេលបញ្ហាដដែលនេះស្ថិតនៅចំពោះមុខអង្គ ជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ ចៅក្រមខកខានមិនបានសម្រេចនូវការបោះឆ្នោត ចាំបាច់ ដើម្បីចេញសេចក្ដីសម្រេចទេ ទោះបីជាសំឡេងភាគច្រើនគាំទ្រទស្សនៈថា ឧក្រិដ្ឋកម្មជាតិ ដែលបានចោទប្រកាន់នៅក្នុងសំណុំរឿងនោះ មិនត្រូវបានរាំងដោយអាជ្ញាយុកាល ១០ ឆ្នាំ ក៏ ដោយ[4208]។

1061. សហព្រះរាជាអាជ្ញាពិតជាមិនបានស្វែងរកការជំនុំជម្រះ **មាស មុត** ចំពោះឧក្រិដ្ឋកម្មជាតិនោះទេ ទោះបីជាភស្តុតាងពីកិច្ចស៊ើបសួរបំពេញធាតុផ្សំសម្រាប់ការចោទប្រកាន់ពីបទឧក្រិដ្ឋក៏ដោយ។ នេះ ក៏ព្រោះតែសហព្រះរាជអាជ្ញាជឿជាក់ថា អំពើឧក្រិដ្ឋរបស់ **មាស មុត** ត្រូវបានពិពណ៌នាល្អជាង ពេលកំណត់ប្រភេទតាមផ្លូវច្បាប់ជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍អន្តរជាតិ និងឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិ (ជាពិសេស មនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុ នយោបាយ)។ លើសពីនេះទៅទៀត តាមរយៈការកំណត់អំពើនេះជាឧក្រិដ្ឋកម្មអន្តរជាតិ ជាជាង ឧក្រិដ្ឋកម្មជាតិ ការជំទាស់តវ៉ាមិនចាំបាច់អាចត្រូវបានចៀសវាង ដើម្បីធានាបាននូវកិច្ចដំណើរការ នីតិវិធីឆាប់រហ័ស។

## ឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវ ដែលមិនត្រូវបានចោទប្រកាន់ពីមុន

1062. សហព្រះរាជអាជ្ញាសូមបញ្ជាក់ថា គ្មានវិធាន អ.វ.ត.ក ណាមួយ ហាមឃាត់ដីកាដំណោះស្រាយ មិនឱ្យបញ្ជូនទៅជំនុំជម្រះនូវឧក្រិដ្ឋកម្ម ឬទម្រង់នៃការទទួលខុសត្រូវ ដែលសហចៅក្រមស៊ើប អង្កេតមិនបានចោទប្រកាន់ នៅពេលបង្ហាញខ្លួនដំបូង ឬនៅពេលក្រោយឡើយ ប្រសិនបើឧក្រិដ្ឋកម្ម

---

[4207] សំណុំរឿង០០២ ឯកសារ D427/1/30សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, កថាខណ្ឌ២៧៩-២៨០។

[4208] សំណុំរឿង០០១ ឯកសារ E187សេចក្ដីសម្រេចលក្ខន្តិកៈកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង, ក្នុងនោះមតិភាគ ច្រើនមានចៅក្រមចំនួនបីរូបមាន ចៅក្រម និល ណុន, ចៅក្រម ធូរ មុនី និងចៅក្រម យ៉ា សាខន យល់ឃើញថាលក្ខន្តិ កៈនៃការកំណត់ត្រូវរហូតដល់ឆ្នាំ១៩៩៣, រីឯចៅក្រមSilvia Cartwrightនិងចៅក្រម Jean-Marc Lavergneសន្និដ្ឋាន ថារយៈពេលនៃការកំណត់នោះបានផុតកំណត់តាំងពីឆ្នាំ១៩៨៩មកម្ល៉េះ ហើយចំពោះការពន្យាដល់ឆ្នាំ២០០១នោះគឺមិន អាចទៅរួចឡើយ។

ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីអង្គហេតុ ដែលសហចៅក្រមស៊ើបអង្កេតបានទទួលបណ្តឹង[4209]។ អនុលោមតាមច្បាប់ អ.វ.ត.ក និងច្បាប់កម្ពុជា ចៅក្រមស៊ើបអង្កេតទទួលបានបណ្តឹងជារឿងក្តីទាំងមូល រួមនឹងការចោទប្រកាន់អំពីអង្គហេតុទាំងអស់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ព្រះរាជអាជ្ញា[4210]។ សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចស៊ើបសួរលើអង្គហេតុទាំងនេះ និងពិចារណាថាតើភ័ស្តុតាងបង្ហាញឲ្យឃើញថា ជនដែលមានឈ្មោះនៅក្នុងដីកា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្ម ក្រោមទម្រង់ជាធរមាននៃការទទួលខុសត្រូវ ដែរឬទេ ហើយចេញដីកាសម្រេច ដោយមានសំអាងហេតុ[4211]។

1063. មេធាវីការពារក្តី **មាស មុត** ត្រូវបានជូនដំណឹងអំពីអង្គហេតុ ដែលអាចឈានដល់ការបញ្ជូនទៅជំនុំជម្រះ តាមរយៈការចូលមើលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា។ យោងតាមប្រព័ន្ធច្បាប់ស៊ីវិលឡូ ដែលមានចៅក្រមស៊ើបអង្កេត ដូចជានៅ អ.វ.ត.ក មេធាវីការពារក្តីដឹងថា សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចស៊ើបសួរលើគ្រប់អង្គហេតុទាំងអស់ នៅក្នុងដីកានោះ និងពិចារណាអំពីភ័ស្តុតាងដែលកើតចេញពីការស៊ើបសួរនោះ។ ដូច្នេះ មេធាវីការពារក្តីមិនគួរភ្ញាក់ផ្អើល ឬប្រកាន់នោះទេ ពេលសហចៅក្រមស៊ើបអង្កេតធ្វើបែបនេះ។ ពេល **មាស មុត** បង្ហាញខ្លួនដំបូង សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់យ៉ាងច្បាស់ថា ឧក្រិដ្ឋកម្មបន្ថែម ផ្អែកតាមដីកាសន្និដ្ឋានបន្ថែមនាពេលខាងមុខរបស់សហព្រះរាជអាជ្ញា អាចត្រូវបានចោទប្រកាន់ មុនពេលបិទកិច្ចស៊ើបសួរ ប្រសិនបើមានភ័ស្តុតាងច្បាស់លាស់ និងស៊ីចង្វាក់គ្នាថា **មាស មុត** ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះ[4212]។ វិធាន ៦៧(១) ចែងយ៉ាងច្បាស់ថា សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរ ដោយចេញដីកាដំណោះស្រាយ។

---

[4209] បញ្ហាដដែលថ្មីៗនេះក្លាយជាកម្មវត្ថុក្នុងការទាមទារចំពោះមុខអង្គបុរេជំនុំជម្រះ។ អានសំណុំរឿង០០៤/១ ឯកសារ D308/3/1/1បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិចំពោះដីកាដំណោះស្រាយ (សំអាងហេតុ) ថ្ងៃទី៩ខែសីហាឆ្នាំ២០១៧។

[4210] សំណុំរឿង០០២ ឯកសារ D198/1 ដីកាសម្រេចលើ សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យធ្វើការបំភ្លឺ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩, កថាខណ្ឌ៦។

[4211] សំណុំរឿង០០២ ឯកសារ D198/1 ដីកាសម្រេចលើ សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យធ្វើការបំភ្លឺ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩, កថាខណ្ឌ១០។

[4212] ឯកសារD174 កំណត់ហេតុនៃការចូលខ្លួនជាលើកដំបូង, ទំព័រ១១។

ដូច្នេះ យោងតាមវិធានផ្ទៃក្នុង នៅដំណាក់កាលចេញដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតត្រូវបានអនុញ្ញាតឲ្យពិចារណា និងបន្ថែមបទចោទ ផ្អែកលើអង្គហេតុដែលត្រូវបានប្តឹងត្រឹមត្រូវ។

1064. វិធានផ្ទៃក្នុងមិនផ្តល់ឱកាសឲ្យសហព្រះរាជអាជ្ញាបញ្ចេញមតិយោបល់លើឧក្រិដ្ឋកម្ម ដែលសហចៅក្រមស៊ើបអង្កេតបញ្ចូលទៅក្នុងការជូនដំណឹងអំពីបទចោទ អនុលោមតាមវិធាន ៥៧ ហើយសហព្រះរាជអាជ្ញាមិនត្រូវបានស្នើឲ្យដាក់សេចក្តីសន្និដ្ឋានអំពីបញ្ហានោះ ឬចូលរួមក្នុងសវនាការស្តីពីបទចោទឡើយ។ លើសពីនេះទៅទៀត កំណត់ហេតុស្តីពីការបង្ហាញខ្លួនបន្ថែមទៀត មិនមែនជា "ដីកាសម្រេច" សម្រាប់គោលបំណងនៃវិធាន ៧៤ ដែលអាចប្តឹងឧទ្ធរណ៍បានឡើយ។ ដូច្នេះ ដីកាសន្និដ្ឋានស្ថាពរ គឺជាឱកាសតែមួយគត់របស់សហព្រះរាជអាជ្ញាក្នុងការបញ្ចេញមតិយោបល់ថា តើភ័ស្តុតាងចេញពីកិច្ចស៊ើបសួរ បង្ហាញអំពីការទទួលខុសត្រូវរបស់ **មាស មុត** ចំពោះឧក្រិដ្ឋកម្ម ដូចបានចោទប្រកាន់ ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែរឬទេ[4213]។ ប្រសិនបើទឡ្ហីករណ៍ ក្នុងដីកាសន្និដ្ឋានស្ថាពរនេះ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវដែលមិនត្រូវបានចោទប្រកាន់ពីមុន ត្រូវគេមិនអើពើជាស្វ័យប្រវត្តិ និង

---

[4213] អានឧទាហរណ៍សំណុំរឿង០០៤/២ ឯកសារ D121/4/1/4ការពិចារណារបស់អង្គបុរេជំនុំជម្រះលើ [កោសលុប] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធសំណើលើសំណើសុំពិនិត្យមើលឯកសារសំណុំរឿង និងចូលរួមក្នុងកិច្ចស៊ើបអង្កេត ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤, ទស្សនៈយល់ឃើញរបស់ចៅក្រមChang-Ho Chungនិងចៅក្រម Rowan Downing, កថាខណ្ឌ៩, KH ERN 00969126 ["គោលការណ៍យុត្តិធម៌ធម្មជាតិ និងភាពយុត្តិធម៌ផ្នែកនីតិវិធីតម្រូវឲ្យភាគីណាមួយ ឬបុគ្គលពាក់ព័ន្ធផ្សេងទៀតដែលមានសិទ្ធិ ឬផលប្រយោជន៍របស់បុគ្គល ឬភាគីទាំងនោះ អាចរងការប៉ះពាល់ មានសិទ្ធិធ្វើការឆ្លើយតប មុនពេលធ្វើការសម្រេចបែបនេះ"], សម្រង់ដោយមានការយល់ព្រម, inter alia, សំណុំរឿង០០២ ឯកសារ E163/5/1/13សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿង០០២/០១ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣, កថាខណ្ឌ៤២, KH ERN 00885818-19 ["ភាពចាំបាច់ក្នុងការគោរពសិទ្ធិទទួលបានការជំនុំជម្រះ នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ [...] ត្រូវធ្វើឡើងដោយភាពត្រឹមត្រូវ និងផលប្រយោជន៍យុត្តិធម៌ដ៏មានអត្ថន័យ និងស្របទៅតាមបទដ្ឋានគតិយុត្តអន្តរជាតិ"], សាលដីកាតុលាការយុត្តិធម៌អន្តរជាតិ, Australia តទល់នឹង France, (សំណុំរឿងការសាកល្បងអាវុធនុយក្លេអ៊ែ - មតិជំទាស់របស់ចៅក្រម Sir Garfield Barwick), ចុះថ្ងៃទី២០ខែធ្នូ ឆ្នាំ១៩៧៤, ទំព័រ៣៩១ ["ក្នុងករណីណាក៏ដោយអ្នកដាក់ពាក្យត្រូវទទួលបានសិទ្ធិស្នើសុំគ្រប់បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងការសម្រេចចិត្តរបស់តុលាការ"]។ ECtHR, Niderost-Huber តទល់នឹង Switzerland, ពាក្យសុំលេខ១៨៩៩០/៩១, សាលដីកា ចុះថ្ងៃទី១៨ខែកុម្ភៈ ឆ្នា១៩៩៧, កថាខណ្ឌ២៩ [បញ្ជាក់ថា "ការជឿទុកចិត្តរបស់គូវិវាទទៅនឹងកិច្ចការយុត្តិធម៌ [...] ផ្អែកទៅលើចំណេះដឹងដែលពួកគេមានឱកាសក្នុងការសំដែងទស្សនៈខ្លួនលើគ្រប់ឯកសារនៅក្នុងសំណុំរឿង។"]។

ទុកចោលមិនដោះស្រាយ ក្នុងដីកាដំណោះស្រាយ វានឹងបណ្ដាលឱ្យអង្គហេតុត្រូវបានជម្រុះចោល ដោយមិនផ្ដល់ឱកាសឱ្យសហព្រះរាជអាជ្ញាបញ្ចេញយោបល់ឱ្យសហចៅក្រមស៊ើបអង្កេតស្ដាប់ និង បណ្ដាលឱ្យរារាំងដល់ការពិនិត្យមើលឡើងវិញដោយអង្គបុរេជំនុំជម្រះ នៅក្នុងដំណាក់កាលបណ្ដឹង ឧទ្ធរណ៍។ ពិតណាស់ នេះមិនមែនជាគោលបំណងរបស់វិធានផ្ទៃក្នុងនោះទេ។

## XI. យុត្តាធិការលើរឿងក្តី

### ក. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

<u>ការវាយប្រហារលើជនស៊ីវិល</u>

1065. បទល្មើស ដូចបានរៀបរាប់លម្អិតនៅក្នុងដីកាសន្និដ្ឋាននេះ គឺជាផ្នែកមួយនៃការវាយប្រហារ ដែល នាំឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មជាច្រើន នៅក្នុងប្រព័ន្ធបង្ក្រាបដែលមានការរៀបចំ។ អំពើទាំងនេះ រួមមាន (១) ការបណ្ដេញប្រជាជនដោយបង្ខំឱ្យចេញពីតំបន់ទីក្រុង និងការជម្លៀសដោយបង្ខំទៅ កាន់តំបន់ជនបទ (២) ការធ្វើឱ្យប្រជាជនក្លាយជាទាសករ នៅតាមសហករណ៍ និងការដ្ឋាន ដែល ប.ក.ក បានបង្កើតឡើង (៣) ពលកម្មដោយបង្ខំក្នុងទ្រង់ទ្រាយធំ (៤) ការតម្រូវឱ្យរៀបការដោយ បង្ខំ និងការរំលោភសេពសន្ថវៈ (៥) ការបដិសេធសិទ្ធិ-សេរីភាពជាមូលដ្ឋានរបស់មនុស្ស និងការ រឹបអូសទ្រព្យសម្បត្តិ និង (៦) ការអនុវត្តទម្រង់ផ្សេងៗនៃការបង្ក្រាប តាមរយៈការចាប់ខ្លួន ការឃុំ និងការសម្លាប់តាមទំនើងចិត្ត។ ការវាយប្រហារនេះត្រូវបានធ្វើឡើងជាចម្បងប្រឆាំងនឹងជនស៊ីវិល របស់កម្ពុជាប្រជាធិបតេយ្យ ដោយមូលហេតុនយោបាយ សាសនា ជាតិពន្ធុ និងពូជសាសន៍[4214]។

1066. មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ រួមទាំង **មាស មុត** និងមេបញ្ជាការកងពលផ្សេងទៀតនៃកងទ័ព បដិវត្តន៍កម្ពុជា ក៏បានធ្វើការវាយប្រហារដោយខុសច្បាប់ប្រឆាំងនឹងសមាជិកកងទ័ពរបស់ខ្លួន[4215]។ ទាហានរាប់ពាន់នាក់នៃកងទ័ពបដិវត្តន៍កម្ពុជា ត្រូវបានបង្ខំឱ្យដាក់អាវុធ រួចបញ្ជូនទៅសហករណ៍ និងការដ្ឋាន ហើយនៅទីនោះ ពួកគេត្រូវបានធ្វើឱ្យក្លាយជាទាសករ ទទួលរងនូវការប្រព្រឹត្តិ និង

---

[4214] អានផ្នែក VII. គោលនយោបាយរបស់បក្សកុម្មុយនីសកម្ពុជា ពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំង មាស មុត ។

[4215] អានផ្នែក VII. គោលនយោបាយរបស់បក្សកុម្មុយនីសកម្ពុជា ពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំង មាស មុត – ការលុប បំបាត់ខ្មាំង និងអ្នកប្រឆាំងនឹងមេដឹកនាំបក្សកុម្មុយនីសកម្ពុជា។

លក្ខខណ្ឌអមនុស្សធម៌ និងជាចុងក្រោយ ទាហានជាច្រើនត្រូវបានសម្លាប់[4216]។ អំពើទាំងនេះបាន កើតឡើង ក្នុងពេលជម្លោះប្រដាប់អាវុធអន្តរជាតិជាមួយវៀតណាម ប៉ុន្តែទាហានវំសាយនៃកងទ័ព បដិវត្តន៍កម្ពុជាមិនបានចងសម្ព័ន្ធភាពជាមួយវៀតណាម ឬផ្តល់ការគាំទ្រខាងយោធាដល់វៀតណាម នោះឡើយ។ ដូច្នេះ ការវាយប្រហាររបស់កម្ពុជាប្រជាធិបតេយ្យទៅលើកងទ័ពខ្លួនឯង គឺស្មើនឹង ការវាយប្រហារប្រឆាំងនឹងជនស៊ីវិល ហើយការវាយប្រហារនេះបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិ ស្របតាមច្បាប់ដែលមានអត្ថិភាព ចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[4217]។

## លក្ខណៈរាលដាល ឬជាប្រព័ន្ធ

1067. ការវាយប្រហារលើជនស៊ីវិលមានលក្ខណៈរាលដាល និងជាប្រព័ន្ធ។ ការវាយប្រហារមានលក្ខណៈ រាលដាល ដោយសារតែចរិតទ្រង់ទ្រាយធំ រយៈពេលអូសបន្លាយ តំបន់ភូមិសាស្ត្រដែលការវាយ ប្រហារនោះបានកើតឡើង និងចំនួនជនរងគ្រោះច្រើនជាគោលដៅនៃការវាយប្រហារ។ ការវាយ ប្រហារកំណត់គោលដៅលើប្រជាជនស៊ីវិលភាគច្រើនលើសលុបនៅក្នុងប្រទេស នៅទូទាំងទឹកដីនៃ កម្ពុជាប្រជាធិបតេយ្យ ហើយមានរយៈពេល ៣ ឆ្នាំ ៨ ខែ[4218]។ ប្រជាជនស៊ីវិលទាំងមូលត្រូវបាន ជម្លៀសដោយបង្ខំ ពីទីក្រុងទៅជនបទ ហើយប្រជាជនរាប់លាននាក់ត្រូវបានធ្វើឲ្យក្លាយជាទាសករ

---

4216 អានឧទាហរណ៍VII. គោលនយោបាយរបស់បក្សកុម្មុយនីសកម្ពុជា ពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំង មាស មុត– កសិកម្ម, សេដ្ឋកិច្ច, និងគោលនយោបាយសង្គមកិច្ច– ១. ការបង្កើតសហករណ៍ និងការដ្ឋាន។ ផ្នែកVIII.ង. ការដ្ឋាន ស្ទឹងហាវ[អានជាពិសេសរចនាសម្ព័ន្ធបញ្ជាការ។ ការធ្វើទាសកម្ម។ ការធ្វើទុក្ខបុកម្នេញលើហេតុផលនយោបាយ។ ការកាប់សម្លាប់ និងធ្វើឲ្យបាត់ខ្លួន និងអំពើអមនុស្សធម៌ដទៃទៀត]។ ផ្នែកVIII.ច. ការដ្ឋានតំបន់រាម [អានជាពិសេស ការធ្វើទាសកម្ម។ ការធ្វើទុក្ខបុកម្នេញលើហេតុផលនយោបាយ។ ការកាប់សម្លាប់, ការកាប់សម្លាប់រង្គាល និងធ្វើឲ្យ បាត់ខ្លួន និងអំពើអមនុស្សធម៌ដទៃទៀត ក) ការប្រព្រឹត្តទៅដោយអមនុស្សធម៌]។

4217 អានឯកសារD191/18 ការជូនដំណឹងស្តីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់របប ឬរដ្ឋនោះ, ថ្ងៃទី៧ខែកុម្ភៈ ២០១៧, កថាខណ្ឌ៦៩។

4218 អានផ្នែក VII. គោលនយោបាយរបស់បក្សកុម្មុយនីសកម្ពុជា ពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំង មាស មុត។

នៅតាមសហករណ៍ និងការដ្ឋាន[4219]។ ប.ក.ក ក៏បានបង្កើតមន្ទីរសន្តិសុខប្រមាណ ១៩៦[4220] ដែលនៅទីនោះ ជនស៊ីវិលរាប់ពាន់នាក់ត្រូវបានឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់[4221]។

1068. ការវាយប្រហារទៅលើជនស៊ីវិលក៏មានលក្ខណៈជាប្រព័ន្ធផងដែរ។ គណៈអចិន្ត្រៃយ៍ ប.ក.ក បានបង្កើតគោលនយោបាយនៅថ្នាក់កណ្តាលដែលនាំឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម ចេញសេចក្តីណែនាំសម្រាប់ការអនុវត្តគោលនយោបាយទាំងនេះ និងទទួលបានរបាយការណ៍ជាទៀងទាត់ពីគ្រប់ជាន់ថ្នាក់របស់ ប.ក.ក អំពីការអនុវត្តគោលនយោបាយនៅតាមមូលដ្ឋាន[4222]។ លំនាំស្រដៀងគ្នានៃការប្រព្រឹត្តិអមនុស្សធម៌ អំពើហិង្សា និងទង្វើឧក្រិដ្ឋផ្សេងទៀត ដែលលេចឡើង នៅទូទាំងប្រទេសដោយសារតែគោលនយោបាយ ដែលបានអនុវត្ត ក៏បង្ហាញផងដែរអំពីការវាយប្រហារដោយមានការរៀបចំ និងជាប្រព័ន្ធ[4223]។

## មូលហេតុរើសអើង

1069. ការវាយប្រហារលើជនស៊ីវិលផ្អែកលើមូលហេតុនយោបាយ សាសនា ជាតិពន្ធុ និងរើសអើងពូជសាសន៍។ ប.ក.ក ដាក់ឲ្យអនុវត្តនូវបដិវត្តន៍នយោបាយមួយ ដែលមិនអនុញ្ញាតឲ្យមានការ

---

[4219] អានផ្នែកVII. គោលនយោបាយរបស់បក្សកុម្មុយនីសកម្ពុជា ពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំង មាស មុត – កសិកម្ម, សេដ្ឋកិច្ច, និងគោលនយោបាយសង្គមកិច្ច– ១. ការបង្កើតសហករណ៍ និងការដ្ឋាន។ ផ្នែកVIII.ង. ការដ្ឋានស្ទឹងហាវ– ៣. ឧក្រិដ្ឋកម្ម– ទាសកម្ម។ ផ្នែក VIII.ច. ការដ្ឋានតំបន់រាម–៣. ឧក្រិដ្ឋកម្ម–ទាសកម្ម។

[4220] ឯកសារ D4.1.629 បញ្ជីឈ្មោះអ្នកទោសក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ថ្ងៃទី១៨ខែកុម្ភៈឆ្នាំ២០០៨។

[4221] អានផ្នែកVII. គោលនយោបាយរបស់បក្សកុម្មុយនីសកម្ពុជា ពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំង មាស មុត – ការលុបបំបាត់ខ្មាំង និងអ្នកប្រឆាំងនឹងមេដឹកនាំបក្សកុម្មុយនីសកម្ពុជា. សូមអានផ្នែកVIII.គ. មន្ទីរសន្តិសុខកងពល១៦៤។ផ្នែក VIII.ឃ. មន្ទីរសន្តិសុខ ស-២១។

[4222] អានផ្នែកVII. គោលនយោបាយរបស់បក្សកុម្មុយនីសកម្ពុជា ពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំង មាស មុត – កសិកម្ម, សេដ្ឋកិច្ច, និងគោលនយោបាយសង្គមកិច្ច– ១. ការបង្កើតសហករណ៍ និងការដ្ឋាន,ជាពិសេសកថាខណ្ឌ៣២១។ ផ្នែក V.២. ការទាក់ទងគ្នានៅក្នុងកងពល១៦៤។

[4223] អានផ្នែកVII. គោលនយោបាយរបស់បក្សកុម្មុយនីសកម្ពុជា ពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំង មាស មុត – កសិកម្ម, សេដ្ឋកិច្ច, និងគោលនយោបាយសង្គមកិច្ច– ១. ការបង្កើតសហករណ៍ និងការដ្ឋាន។ ផ្នែកVIII.គ. មន្ទីរសន្តិសុខកងពល១៦៤។ ផ្នែកVIII.ឃ. មន្ទីរសន្តិសុខ ស-២១។ ផ្នែក VIII.ង. ការដ្ឋានស្ទឹងហាវ។ និងផ្នែកVIII.ច. ការដ្ឋានតំបន់រាម។

ជំទាស់។ ជនស៊ីវិលទាំងអស់ត្រូវបានចាត់ទុកជាខ្មាំងពិតប្រាកដ ឬសក្តានុពល ហើយត្រូវបាននាំយកទៅអប់រំ ធ្វើឱ្យក្លាយជាទាសករ ឃុំឃាំង និងសម្លាប់[4224]។ "ខ្មាំង" របស់របបនោះរួមមាន អ្នកជាប់និន្នាការជាមួយអតីតរបប លន់ នល់ កម្មាភិបាលក្នុងជួរ ប.ក.ក ស្ថិតក្រោមការសង្ស័យ អ្នកមានចំណងទាក់ទងជាមួយបរទេស ដែលត្រូវបានកំណត់ថាជា "គិញ" ស៊ើបការណ៍ឱ្យរដ្ឋាភិបាលបរទេស និង "ប្រជាជនថ្មី" ឬ "ប្រជាជន ១៧ មេសា" ដែលត្រូវបាន ប.ក.ក យល់ឃើញថាប្រឆាំងនឹងបដិវត្តន៍[4225]។ ក៏រួមបញ្ចូលផងដែរនូវជនស៊ីវិល ដែលសង្ស័យថាមិនស្មោះត្រង់នឹងរបប ឬបដិវត្តន៍ ដោយសារតែអាកប្បកិរិយាស្លូតត្រង់ ដូចជា ការសម្តែងការមិនពេញចិត្តចំពោះលក្ខខណ្ឌរស់នៅ ឬការធ្វើឱ្យបាក់សម្ភារៈ ឬសូម្បីតែស្តាបព្រាមួយ[4226]។ ប.ក.ក បានប្រើកម្មវិធីដូចជា ការបំពាក់បំប៉នឧនយោបាយ វគ្គរៀនសូត្រ ការលត់ដំ និងការតាមដានជាប្រចាំ ដើម្បីស្វែងរកអ្នកដែលអាចខ្វះការស្មោះត្រង់។

1070. ការវាយប្រហារលើជនស៊ីវិលក៏ផ្អែកលើមូលហេតុសាសនាផងដែរ ដោយសារតែវានាំឱ្យមានការលុបចោល ឬបំបាត់សាសនា និងការគោរពប្រណិប័តន៍សាសនា ក៏ដូចជាការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាសនា។ ជាចុងក្រោយ ជនជាតិភាគតិច ដូចជា វៀតណាម ត្រូវគេធ្វើទុក្ខបុកម្នេញ និងកម្ទេច ដោយផ្អែកលើអត្តសញ្ញាណពូជសាសន៍ ឬជាតិពន្ធុ[4227]។

## ការដឹងឮរបស់ មាស មុត អំពីការវាយប្រហារ

1071. **មាស មុត** និងចារីដទៃទៀត បានដឹងឮអំពីការវាយប្រហារប្រឆាំងនឹងជនស៊ីវិល និងដឹងថា អំពើរបស់ខ្លួនបង្កើតបានជាផ្នែកមួយនៃការវាយប្រហារ។ ការវាយប្រហារមានភាពជាក់ស្តែងសម្រាប់អ្នកឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យ ដែលសាបព្រោះសភាពភ័យរន្ធត់ទៅលើប្រជាជន។ លើស

[4224] អានផ្នែកVII. គោលនយោបាយរបស់បក្សកុម្មុយនីសកម្ពុជា ពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំង មាស មុត – ការកម្ទេចខ្មាំង និងអ្នកប្រឆាំងនឹងមេដឹកនាំបក្សកុម្មុយនីសកម្ពុជា។

[4225] អានផ្នែក VII. គោលនយោបាយរបស់បក្សកុម្មុយនីសកម្ពុជា ពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំង មាស មុត – ការកម្ទេចខ្មាំង និងអ្នកប្រឆាំងនឹងមេដឹកនាំបក្សកុម្មុយនីសកម្ពុជា។

[4226] អានផ្នែកVII. គោលនយោបាយរបស់បក្សកុម្មុយនីសកម្ពុជា ពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំង មាស មុត – កសិកម្ម, សេដ្ឋកិច្ច, និងគោលនយោបាយសង្គមកិច្ច–១. ការបង្កើតសហករណ៍ និងការដ្ឋាន

[4227] អានផ្នែកVII. គោលនយោបាយរបស់បក្សកុម្មុយនីសកម្ពុជា ពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំង មាស មុត – ការកម្ទេចខ្មាំង និងអ្នកប្រឆាំងនឹងមេដឹកនាំបក្សកុម្មុយនីសកម្ពុជា។ផ្នែកVIII.ឆ. អំពើប្រល័យពូជសាសន៍ជនជាតិវៀតណាម។

ពីនេះទៅទៀត ការដឹងឮរបស់ **មាស មុត** អំពីការវាយប្រហារ ត្រូវបានស្តែងឡើង តាមរយៈការរួមចំណែកយ៉ាងទូលំទូលាយ និងការចូលរួមក្នុងការវាយប្រហារ ដូចបានពិភាក្សានៅផ្នែកផ្សេងទៀតនៅក្នុងដីកាសន្និដ្ឋាននេះ[4228]។

## ខ. ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ

<u>ជម្លោះប្រដាប់អាវុធអន្តរជាតិ</u>

1072. ភស្តុតាង នៅក្នុងសំណុំរឿង បង្ហាញថា ជម្លោះប្រដាប់អាវុធអន្តរជាតិ រវាងកម្ពុជាប្រជាធិបតេយ្យ និង ស.ស.វ កើតមានឡើង ចាប់ពីខែ ឧសភា ឆ្នាំ ១៩៧៥ រហូតដល់ពេលបញ្ចប់រយៈកាលស្ថិតក្រោមកិច្ចស៊ើបសួរ គឺថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩[4229]។ ជម្លោះប្រដាប់បានចាប់ផ្តើមជាមួយនឹងការចូលលុកលុយគ្នាទៅវិញទៅមករបស់កងទ័ពនៃប្រទេសទាំងពីរ នៅក្នុងខែ ឧសភា ឬខែ មិថុនា ឆ្នាំ ១៩៧៥[4230]។ ទោះបីជាមានការអះអាងថា មានការប៉ុនប៉ងស្វែងរកដំណោះស្រាយនយោបាយក៏ដោយ ក៏ភាពធ្ងន់ធ្ងរនៃជម្លោះ បានកើនឡើង នៅឆ្នាំ ១៩៧៧ ដោយមានការវាយប្រយុទ្ធឆ្លងព្រំដែនទាំងសងខាង និងការលុកលុយទ្រង់ទ្រាយធំចូលទឹកដីកម្ពុជាដោយកងទ័ពរបស់ ស.ស.វ នៅចុងឆ្នាំ ១៩៧៧[4231]។ កម្ពុជាប្រជាធិបតេយ្យបានកាត់ផ្តាច់ទំនាក់ទំនងការទូតជាផ្លូវការជាមួយ ស.ស.វ នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ ហើយការវាយគ្នានៅតែបន្ត នៅតាមព្រំដែន រវាងប្រទេសទាំងពីរ ពេញមួយឆ្នាំ ១៩៧៨[4232]។ ការលុកលុយពេញទំហឹងរបស់ ស.ស.វ ចូលក្នុងទឹកដីកម្ពុជានៅចុងខែ ធ្នូ ឆ្នាំ ១៩៧៨ គឺជាដំណាក់កាលចុងក្រោយនៃជម្លោះប្រដាប់អាវុធ ដែលបញ្ចប់ដោយការវាយយកបានទីក្រុងភ្នំពេញ ដោយកងកម្លាំងវៀតណាម នៅថ្ងៃទី ០៧ ខែ មករា ឆ្នាំ ១៩៧៩[4233]។

---

4228 អានផ្នែកIII. តួនាទីរបស់ មាស មុត និងផ្នែកទទួលខុសត្រូវនិងផ្នែកXIII.ខ.១. ការប្រព្រឹត្តឧក្រិដ្ឋកម្មរួម។

4229 អានផ្នែក VI. ជម្លោះប្រដាប់អាវុធជាអន្តរជាតិ ផ្នែកនៃសារណានេះ។

4230 អាន កថាខណ្ឌ ៣០៨-៣១០។

4231 អាន កថាខណ្ឌ ៣១១-៣១២។

4232 អាន ជើងទំព័រលេខ ១០៤៤ និងកថាខណ្ឌ ៣១៣-៣១៤។

4233 អាន កថាខណ្ឌ ៣១៤។

1073. តម្រុយបង្ហាញថា ជម្លោះប្រដាប់អាវុធនៅតែបន្តកើតមាន រួមមាន ការដាក់ពង្រាយកងពលមជ្ឈិមរបស់ ប.ក.ក និងកងពលភូមិភាគរបស់កងទ័ពបដិវត្តន៍កម្ពុជា ក៏ដូចជាឈ្លប ប្រឆាំងនឹង ស.ស.វ, ការពើបប្រយុទ្ធគ្នារបស់កងទ័ព ស.ស.វ, ការចេញសេចក្តីណែនាំរបស់គណៈអចិន្ត្រៃយ៍ ប.ក.ក អំពីបញ្ហាយោធា និងសេចក្តីសម្រេចទប់ទល់នឹងការចូលទន្ទ្រានរបស់វៀតណាម, ការប៉ះទង្គិចគ្នាមិនឈប់ឈរវាងកម្លាំង ស.ស.វ និងកម្ពុជាប្រជាធិបតេយ្យ និងការចូលលុកលុយទៅក្នុងទឹកដីគ្នាទៅវិញទៅមក, និងការរាយការណ៍ជាទៀងទាត់របស់មេដឹកនាំកងទ័ពបដិវត្តន៍កម្ពុជា និងមេដឹកនាំភូមិភាគ ជូនមជ្ឈិមបក្ស អំពីឧប្បត្តិហេតុយោធា ក្នុងអំឡុងរយៈកាលនោះ[4234]។

1074. ឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយកងកម្លាំង និងកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ មានទំនាក់ទំនងជិតស្និទ្ធនឹងជម្លោះប្រដាប់អាវុធអន្តរជាតិនេះ[4235]។ ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តលើទាហាននៃកងទ័ពរបស់ ស.ស.វ ជាប្រទេសដែលមានជម្លោះប្រដាប់អាវុធជាមួយកម្ពុជាប្រជាធិបតេយ្យ និងលើជនស៊ីវិល ដែលបានរកឃើញនៅតំបន់ប្រយុទ្ធ ឬនៅក្នុងទឹកដីកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវគេចាត់ទុកថាជាការគំរាមកំហែងដល់កម្ពុជាប្រជាធិបតេយ្យ ពីព្រោះពួកគេជាប្រជាជន (ឬត្រូវចាត់ទុកជាប្រជាជន) របស់ភាគីជម្លោះម្ខាងទៀត។ ឧក្រិដ្ឋកម្មទាំងនោះត្រូវបានធ្វើឡើង ដើម្បីបម្រើឱ្យគោលបំណងខាងយោធារបស់ ប.ក.ក ប្រឆាំងនឹង ស.ស.វ ហើយត្រូវបានប្រព្រឹត្ត ក្នុងអំឡុងពេលវាយប្រហារដោយមានរៀបចំរបស់កងទ័ពបដិវត្តន៍កម្ពុជា ចូលក្នុងទឹកដីវៀតណាម។ ជាចុងក្រោយ ចារីបានអនុវត្តគោលនយោបាយរបស់ ប.ក.ក ដើម្បីសម្លាប់ផ្តាច់ពូជប្រជាជនវៀតណាមនៅកម្ពុជា ដែលមានដើមកំណើតក្នុងបំណងប្រាថ្នារបស់ ប.ក.ក ក្នុងការទប់ទល់នឹងការវាតទីរបស់វៀតណាម។

---

[4234] អានផ្នែកIV. កងពល១៦៤ (ពីមុនកងពល៣)រចនាសម្ព័ន្ធបញ្ជាការ - កងពល១៦៤ (ខែកក្កដាឆ្នាំ១៩៧៥-ខែមករា ឆ្នាំ១៩៧៩)។ ផ្នែក IV. កងពល១៦៤ (ពីមុនកងពល៣) រចនាសម្ព័ន្ធបញ្ជាការ - សមាសភាពកងវរសេនាធំ១៦១, ១៦២, ១៦៣និងកងទ័ពជើងទឹក (កងវរសេនាធំ១៤០)។ផ្នែកV.២. ការទាក់ទងគ្នាខាងក្នុងកងពល១៦៤។ ផ្នែកVIII.ខ. ឧក្រិដ្ឋកម្មប្រព្រឹត្តឡើងប្រឆាំងនឹងអ្នកដែលកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យចាប់បាន នៅដែនទឹក និងដែនកោះ ដែលអះអាងថាជាបូរណភាពរបស់កម្ពុជាប្រជាធិបតេយ្យ។ កថាខណ្ឌ២០៩ខាងលើ [រៀបរាប់ពីថានានុក្រមក្នុងការរាយការណ៍ក្នុងអង្គភាពកងទ័ព និងដោយបញ្ជាក់ថាក្នុងការរាយការណ៍ និងការផ្តល់ព័ត៌មានពីសមរភូមិ ជាភារកិច្ចចាំបាច់ "ដាច់ខាត"]។

[4235] សម្រាប់ព័ត៌មានពិស្តារពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត, អានផ្នែកVIII.ខ. ឧក្រិដ្ឋកម្មប្រព្រឹត្តឡើងប្រឆាំងនឹងអ្នកដែលកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យចាប់បាន នៅដែនទឹក និងដែនកោះ ដែលអះអាងថាជាបូរណភាពរបស់កម្ពុជាប្រជាធិបតេយ្យ។ ផ្នែកVIII.ឃ. មន្ទីរសន្តិសុខ ស-២១។

ជនដែលត្រូវការពារ

1075. ទាហាន និងជនស៊ីវិលវៀតណាម ដែលជាជនរងគ្រោះនៃឧក្រិដ្ឋកម្ម ដូចបានរៀបរាប់នៅផ្នែកផ្សេងទៀត ក្នុងដីកាសន្និដ្ឋាននេះ[4236] ជាជនត្រូវការពារ យោងតាមអនុសញ្ញាទីក្រុងហ្សឺណែវ ទី ៣ និងទី ៤។ ជនស៊ីវិលវៀតណាមស្ថិតនៅក្នុងកណ្ដាប់ដៃរបស់ភាគីជម្លោះម្ខាង ដែលពួកគេមិនមែនជាប្រជាជន (កម្ពុជាប្រជាធិបតេយ្យ) ហេតុដូច្នេះ ពួកគេមានឋានៈជាជនដែលត្រូវការពារ យោងតាមអនុសញ្ញាទីក្រុងហ្សឺណែវ ទី ៤។ ទាហាវ ស.ស.វ ដែលកងកម្លាំងកម្ពុជាប្រជាធិបតេយ្យចាប់បាន គឺជាឈ្លើយសឹក ដែលធ្លាក់ចូលទៅក្នុងអំណាចរបស់សត្រូវ និងមានឋានៈជាជនត្រូវការពារ យោងតាមអនុសញ្ញាទីក្រុងហ្សឺណែវ ទី ៣[4237]។

ការយល់ដឹងអំពីជម្លោះប្រដាប់អាវុធ

1076. ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរប្រឆាំងនឹងវៀតណាមត្រូវបានប្រព្រឹត្តដោយ៖ (១) ទាហាននៃកងទ័ពបដិវត្តន៍កម្ពុជា ដែលបានចូលរួមក្នុងការប្រឈមមុខដាក់គ្នាដោយអាវុធជាមួយវៀតណាម និងការលុកលុយចូលទឹកដីវៀតណាម និង (២) កម្មាភិបាលគុក អ្នកសួរចម្លើយ និងអ្នកយាម នៅមន្ទីរសន្តិសុខ រួមទាំង ស-២១ ដែលនៅទីនោះ ឈ្លើយសឹក និងជនស៊ីវិលវៀតណាម ត្រូវបានដាក់ឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់។ ភស្តុតាងក្នុងសំណុំរឿងបង្ហាញថា ចារីទាំងពីរក្រុមនេះយល់ដឹងអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ និងស.ស.វ។ ទាហាននៃកងទ័ពបដិវត្តន៍កម្ពុជា ដែលបានធ្វើការលុកលុយចូលវៀតណាម និងប្រយុទ្ធនៅតាមព្រំដែន ឬនៅសមុទ្រ យល់ដឹងយ៉ាងច្បាស់អំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធ ហើយទាហានវៀតណាមដែលចាប់បាន និងបញ្ជូនទៅឃុំឃាំងនៅទីក្រុងភ្នំពេញ គឺជាទាហាននៃកងទ័ព ស.ស.វ ជារដ្ឋមានសង្គ្រាមជាមួយ

4236 សម្រាប់ព័ត៌មានពិស្តារពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត, អានផ្នែកVIII.ខ. ឧក្រិដ្ឋកម្មប្រព្រឹត្តឡើងប្រឆាំងនឹងអ្នកដែលកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យចាប់បាន នៅដែនទឹក និងដែនកោះ ដែលអះអាងថាជាបូរណភាពរបស់កម្ពុជាប្រជាធិបតេយ្យ។ ផ្នែកVIII.ឃ. មន្ទីរសន្តិសុខ ស-២១។ ផ្នែក VIII.ឆ. អំពើប្រល័យពូជសាសន៍ជនជាតិវៀតណាម។

4237 អានផ្នែកIX.ក.៣.ការរំលោភយ៉ាងធ្ងន់ធ្ងរទៅនឹងអនុសញ្ញាក្រុងហ្សឺណែវ–តម្រូវការទូទៅ–អ្នកដែលត្រូវការពារ

កម្ពុជាប្រជាធិបតេយ្យ។ ពួកគេក៏ដឹងដែរថា ជនស៊ីវិលដែលពួកគេចាប់បាន សម្លាប់ ឬបញ្ជូនទៅ ស-២១ គឺជាប្រជាជនរបស់រដ្ឋបរទេស ដែលជាគូបដិបក្ខ នៅក្នុងជម្លោះ[4238]។

1077. កម្មាភិបាល ប.ក.ក នៅ ស-២១ ក៏យល់ផងដែរថា ពួកគេកំពុងឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់ ជនរងគ្រោះវៀតណាម នៅក្នុងបរិបទនៃជម្លោះប្រដាប់អាវុធ ដែលកំពុងបន្តជាមួយវៀតណាម។ ឧទាហរណ៍ ជនស៊ីវិលវៀតណាមដែលចាប់ខ្លួននៅសមុទ្រ រួចបញ្ជូនទៅ ស-២១ ត្រូវគេចុះឈ្មោះ ជាគិញ ជាទូទៅ នៅក្នុងបញ្ជី ស-២១។ ជនស៊ីវិល និងទាហានវៀតណាម ដែលជាប់ឃុំ នៅស-២១ ត្រូវគេធ្វើទារុណកម្ម ដើម្បីធ្វើចម្លើយសារភាពពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ និងគោលបំណង វាតទីនិយមរបស់វៀតណាម ដែលត្រូវគេចាក់ផ្សាយតាមវិទ្យុកម្ពុជាប្រជាធិបតេយ្យ។ អ្នកទោស វៀតណាម ដែលគេបានចាប់ និងបញ្ជូនទៅ ស-២១ ត្រូវបានធ្វើកំណត់ហេតុ ដោយរៀបរាប់អំពី ឋានៈ អង្គភាពយោធានៅ ស.ស.វ និងទីកន្លែងចាប់ខ្លួន[4239]។

## XII. យុត្តាធិការបុគ្គល

1078. ភ័ស្តុតាង ដែលរកបាននៅក្នុងកិច្ចស៊ើបសួរលើសំណុំរឿង ០០៣ បង្ហាញថា **មាស មុត** ស្ថិតនៅ ក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។ **មាស មុត** ជា "មេដឹកនាំជាន់ខ្ពស់" នៃរបបកម្ពុជាប្រជា ធិបតេយ្យ ដោយមិនអាចប្រកែកបាន ដោយគាត់កាន់តំណែងមានអំណាច ទាំងនៅក្នុងឋានានុក្រម យោធា និងនយោបាយ ដែលអនុញ្ញាតឱ្យគាត់ដើរតួនាទីយ៉ាងសំខាន់ ក្នុងការបង្កើត និងអនុវត្ត គោលនយោបាយជាតិ ដើម្បីត្រួតពិនិត្យផ្នែកសំខាន់នៃកម្លាំងយោធារបស់កម្ពុជាប្រជាធិបតេយ្យ នៅពេលពួកគេប្រព្រឹត្តឧក្រិដ្ឋកម្មផ្សេងៗ និងដើម្បីគ្រប់គ្រងលើជីវិតជនស៊ីវិលរាប់ម៉ឺននាក់ នៅតាម តំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់គាត់។

1079. ភ័ស្តុតាងបង្ហាញថា ខណៈដែលសមាជិកដទៃទៀត នៃយោធាកម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក ស្ថិតក្រោមការសង្ស័យ និងត្រូវគេបោសសម្អាត **មាស មុត** ត្រូវបានប្រគល់អំណាច និងការទទួល ខុសត្រូវកាន់តែកើនឡើងមិនធ្លាប់មាន។ **មាស មុត** ត្រូវគេចាត់ទុកជាអ្នកស្មោះត្រង់នឹង ប៉ុល ពត

[4238] អានផ្នែក VI. ជម្លោះប្រដាប់អាវុធជាអន្តរជាតិ។ ផ្នែកVIII.ខ. ឧក្រិដ្ឋកម្មប្រព្រឹត្តឡើងប្រឆាំងនឹងអ្នកដែលកងទ័ពជើង ទឹកកម្ពុជាប្រជាធិបតេយ្យចាប់បាន នៅដែនទឹក និងដែនកោះ ដែលអះអាងថាជាបូរណភាពរបស់កម្ពុជាប្រជាធិបតេ យ្យ។ ផ្នែកVIII.ឃ. មន្ទីរសន្តិសុខ ស-២១

[4239] អានផ្នែកVIII.ឃ. មន្ទីរសន្តិសុខ ស-២១

ហើយត្រូវគេទុកចិត្តឱ្យអនុវត្តគោលនយោបាយឧក្រិដ្ឋរបស់ ប.ក.ក ជាមួយកងកម្លាំងដ៏ខ្លាំងក្លា ក្រោមបញ្ជារបស់គាត់។ **មាស មុត** បានប្រើមុខតំណែងយោធា និងសិទ្ធិអំណាចខាងស៊ីវិល ដើម្បីជំរុញផែនការឧក្រិដ្ឋ ហើយគាត់បានដើរតួយ៉ាងសំខាន់ និងខុសពីគេ នៅក្នុងឧក្រិដ្ឋកម្មដ៏សាហាវព្រៃផ្សៃបំផុតដែលពិភពលោកបានជួបប្រទះ ជាឧក្រិដ្ឋកម្មដែលនាំទៅដល់ការធ្វើឱ្យទៅជាទាសករ ការធ្វើទារុណកម្ម និងការសម្លាប់ប្រជាជនកម្ពុជាអស់រាប់ម៉ឺននាក់។

## ១. មេដឹកនាំជាន់ខ្ពស់[4240]

1080. **មាស មុត** បានកាន់តំណែងជាន់ខ្ពស់ជាច្រើន នៅកម្ពុជាប្រជាធិបតេយ្យ ទាំងនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ដែលធ្វើឱ្យគាត់ស្ថិតនៅក្នុងចំណោមមេដឹកនាំជាន់ខ្ពស់ និងមានអំណាចបំផុតនៃរបបនេះ។ ការឡើងឋានៈយ៉ាងឆាប់រហ័សរបស់ **មាស មុត** គាប់ជួននឹងការកើនឡើងដំណាលគ្នានូវចំនួន និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនកម្ពុជា។ ប៉ុល ពត, សុន សេន, តាម៉ុក និងមេដឹកនាំជាន់ខ្ពស់ដទៃទៀតនៃរបបនេះ បានចាត់ទុក **មាស មុត** ជាមនុស្សស្មោះត្រង់ និងមានប្រសិទ្ធភាព ហើយបានផ្តល់សិទ្ធិ និងអំណាចកាន់តែច្រើនឡើងដល់គាត់ ដើម្បីឱ្យគាត់អនុវត្តគោលនយោបាយឧក្រិដ្ឋ ដែលថ្នាក់ដឹកនាំចាត់មើលឃើញថាមានភាពចាំបាច់ដល់ការរក្សាអំណាច នៅក្នុងរបបផ្តាច់ការទន់ខ្សោយ និងសាហាវព្រៃផ្សៃបំផុតដែលមិនធ្លាប់មាន។

1081. ការតែងតាំង **មាស មុត** ទៅក្នុងគណៈមជ្ឈិម ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ជាភស្តុតាងនៃការយកចិត្តទុកដាក់ខ្ពស់របស់គណៈអចិន្ត្រៃយ៍ទៅលើការងារគាត់ ក្នុងការអនុវត្តគោលនយោបាយបក្ស នៅកងពល ១៦៤ និងនៅតំបន់ស្វយ័តកំពង់សោម។ គណៈមជ្ឈិម គឺជាអង្គការធ្វើសេចក្តីសម្រេចខ្ពស់បំផុត នៅក្នុង ប.ក.ក ហើយទទួលខុសត្រូវចំពោះការអនុវត្តគោលនយោបាយបក្ស និងការណែនាំដល់ភូមិភាគ តំបន់ស្វយ័ត និងកងទ័ព ឱ្យអនុវត្តគោលនយោបាយទាំងនេះ។ ក្នុងឋានៈជាសមាជិកគណៈមជ្ឈិម **មាស មុត** ស្ថិតនៅក្នុងចំណោមសមាជិកមានឥទ្ធិពលបំផុតរបស់ ប.ក.ក។ អំណាចគ្មានដែនកំណត់ តាមផ្លូវច្បាប់ និងសីលធម៌របស់គណៈមជ្ឈិម ត្រូវបានបង្ហាញនៅក្នុងសេចក្តីសម្រេច នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៦ ស្តីពីការផ្ទេរអំណាចឱ្យសម្លាប់ក្រៅប្រព័ន្ធ

---

[4240] អាន ផ្នែកIII.២. តួនាទីរបស់ មាស មុត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ អានផ្នែកVII.គោលនយោបាយរបស់បក្សកុម្មុយនីសកម្ពុជា ពាក់ព័ន្ធនឹងសំណុំរឿងប្រឆាំង មាស មុត – ការលុបបំបាត់ខ្មាំង និងអ្នកប្រឆាំងនឹងមេដឹកនាំបក្សកុម្មុយនីសកម្ពុជា

តុលាការដល់សេនាធិការ ភូមិភាគ និងគណៈកម្មាធិការផ្សេងទៀត នៅក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ។

1082. ក្រៅពីតំណែងនៅក្នុងបក្ស **មាស មុត** បានដើរតួយ៉ាងសំខាន់ ក្នុងឋានៈជាសមាជិកសេនាធិការនៃកងទ័ពបដិវត្តន៍កម្ពុជា តាំងពីពេលបង្កើតនៅឆ្នាំ ១៩៧៥ រហូតដល់ពេលរបបនេះដួលរលំ។ សេនាធិការនៃកងទ័ពបដិវត្តន៍កម្ពុជា ជាស្ថាប័នយោធាខ្ពស់បំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានសិទ្ធិអំណាចចេញបញ្ជាទៅកាន់អង្គភាពទាំងអស់នៃកងទ័ពបដិវត្តន៍កម្ពុជា។ នៅចុងរបបនេះ **មាស មុត** និង ស៊្វ មេត ត្រូវបានតែងតាំងជាអនុប្រធានគណៈសេនាធិការ។ លើសពីនេះទៅទៀត ក្នុងឋានៈជាលេខាតំបន់ ១៦៤ តាំងពីពេលបង្កើតនៅឆ្នាំ ១៩៧៥ **មាស មុត** បញ្ជាកងពលមួយ ក្នុងចំណោមកងពលធំបំផុតទាំងប្រាំបួន នៃកងទ័ពបដិវត្តន៍កម្ពុជា។ ជាមួយនឹងទាហានរហូតដល់ ១ ម៉ឺននាក់ កងពល ១៦៤ មានបុគ្គលិក ៤០% ច្រើនជាងកងពលធំបំផុតបន្ទាប់។ ដូច្នេះ **មាស មុត** បានគ្រប់គ្រងផ្នែកដ៏សំខាន់នៃបរិធានសន្តិសុខទាំងមូលរបស់កម្ពុជាប្រជាធិបតេយ្យ។

1083. ចំពោះវិសាលភាពនៃតំបន់ភូមិសាស្ត្រដែលស្ថិតនៅក្នុងដែនអំណាចរបស់គាត់ ក្នុងឋានៈជាលេខាកងពល ១៦៤ មេដឹកនាំកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ និងលេខាតំបន់ស្វយ័តកំពង់សោម **មាស មុត** គឺជាអាជ្ញាធរដឹកនាំនៅក្នុងតំបន់ ដែលរួមបញ្ចូលដែនទឹក និងកោះកម្ពុជា នៅតាមបណ្តោយឆ្នេរប្រមាណជា ៤០០ គីឡូម៉ែត្រ និងតំបន់ស្វយ័តកំពង់សោម។ ក្រោយមក ក្នុងអំឡុងពេលបោសសម្អាតផ្ទៃក្នុងរបស់កម្ពុជាប្រជាធិបតេយ្យ **មាស មុត** ត្រូវបានចាត់តាំងឲ្យដឹកនាំតំបន់ស្វយ័ត ៥០៥ (ក្រចេះ) ហើយសិទ្ធិអំណាចរបស់គាត់បានលាតសន្ធឹងដល់តំបន់ដ៏ធំនេះ។ តំណែងនយោបាយ និងយោធា របស់ **មាស មុត** បានផ្តល់សិទ្ធិអំណាចឲ្យគាត់គ្រប់គ្រងលើកម្មាភិបាល និងជនស៊ីវិលទាំងអស់ ដែលរស់នៅក្នុងតំបន់ស្វយ័តទាំងពីរនេះ និងលើកោះ។

1084. សិទ្ធិអំណាចយោធា និងនយោបាយរួមផ្សំគ្នាចេញមកពីតំណែងទាំងនេះ បានផ្តល់ឲ្យ **មាស មុត** នូវអំណាច និងឥទ្ធិពល នៅកម្ពុជាប្រជាធិបតេយ្យ ក្នុងកម្រិតស្មើនឹងមេដឹកនាំកំពូលតែប៉ុន្មាននាក់ប៉ុណ្ណោះនៃរបបនោះ។ លើសពីនេះទៅទៀត ឥទ្ធិពលរបស់ **មាស មុត** បានលាតសន្ធឹងទៅទូទាំងប្រទេសតាមរយៈតួនាទីរបស់គាត់នៅក្នុងគណៈមជ្ឈិម និងតំណែងរបស់គាត់ជាអនុលេខាសេនាធិការ។

## ២. អ្នកទទួលខុសត្រូវខ្ពស់បំផុត[4241]

1085. ក្រៅពីតួនាទីជាអ្នកដឹកនាំជាន់ខ្ពស់ នៅកម្ពុជាប្រជាធិបតេយ្យ **មាស មុត** ក៏ជាកម្មាភិបាលមួយរូប ដែល "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត នៅរបបកម្ពុជាប្រជាធិបតេយ្យ។ **មាស មុត** បានដើរតួយ៉ាងសំខាន់ នៅក្នុងឧក្រិដ្ឋកម្មធ្ងន់ធ្ងរហួសហេតុដែលប្រព្រឹត្តដោយកងកម្លាំងក្រោមឱវាទរបស់គាត់ និងនៅក្នុងការបោសសម្អាតផ្ទៃលើលា និងសម្លាប់ទាហានផ្ទាល់នៃកងទ័ពបដិវត្តន៍កម្ពុជា។ **មាស មុត** បានជួយសម្រួល និងលើកទឹកចិត្ត ដល់ចារីផ្ទាល់នៃឧក្រិដ្ឋកម្ម និងបានចេញបញ្ជាផ្ទាល់ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការប្រល័យពូជសាសន៍ ការធ្វើទារុណកម្ម ការឃុំឃាំងតាមអំពើចិត្ត ការធ្វើឲ្យក្លាយជាទាសករ និងអំពើអមនុស្សធម៌ (រួមបញ្ចូលទាំងការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈ)។

1086. ឧក្រិដ្ឋកម្មទាំងអស់ ដូចបានពិភាក្សាក្នុងដីកាសន្និដ្ឋាននេះ ហើយដែលសហព្រះរាជអាជ្ញាអន្តរជាតិស្វែងរកការបញ្ជូន **មាស មុត** ទៅជំនុំជម្រះ គឺមានសភាពធ្ងន់ធ្ងរបំផុត និងបានបង្កការឈឺចាប់យ៉ាងសម្បើមដល់ជនរងគ្រោះ។ ជាការពិត ឧក្រិដ្ឋកម្មទាំងនេះនៅតែមានផលប៉ះពាល់ រហូតដល់សព្វថ្ងៃនេះ។ គ្រួសារនានាកាន់ទុក្ខចំពោះការបាត់បង់មនុស្សជាទីស្រលាញ់។ សហគមន៍ខ្វះការអភិវឌ្ឍ ដោយសារតែបាត់បង់សមាជិកដែលមានផលិតភាពច្រើនបំផុតរបស់ខ្លួន (ដូចជាវេជ្ជបណ្ឌិត គ្រូបង្រៀន (ហើយអ្នករស់រានមានជីវិតរស់នៅជាមួយការចងចាំគួរឲ្យរន្ធត់ ឈឺចាប់ និងជាញឹកញាប់ គួរឲ្យអាម៉ាស់ ដែលតែងតែបន្តប៉ះពាល់ដល់សុខភាព និងទំនាក់ទំនងរបស់ពួកគេ។ ឧក្រិដ្ឋកម្មភាគច្រើន ដែលបានពិពណ៌នានៅក្នុងដីកាសន្និដ្ឋាននេះ ស្ថិតនៅក្នុងប្រភេទ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ជាពាក្យដែលទទួលស្គាល់ថា មនុស្សជាតិទាំងអស់មានការចាប់អារម្មណ៍ក្នុងការធានាថា មិនមាននិទណ្ឌភាពសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរទាំងនោះទេ។ ឧក្រិដ្ឋកម្មទាំងអស់ ដែលបានពិភាក្សានៅក្នុងដីកាសន្និដ្ឋាននេះ ជាប់ទាក់ទងដោយផ្ទាល់ទៅនឹង **មាស មុត**៖ ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តដោយអ្នកក្រោមបង្គាប់របស់ **មាស មុត** តាមបញ្ជារបស់គាត់ ឬស្របតាមគោលនយោបាយដែលគាត់បានជួយតាក់តែង និងឃោសនា ហើយត្រូវបានប្រព្រឹត្តនៅតាមទីតាំងសម្លាប់មនុស្ស មន្ទីរសន្តិសុខ និងការដ្ឋាន ដែលត្រូវបាន **មាស មុត** បង្កើតឡើងស្ទើរតែទាំងអស់។

---

[4241] អាន ផ្នែកIII.៣.ការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម អានផ្នែកIII.២.តួនាទីរបស់ មាស មុត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ–ប្រសិទ្ធភាពនៃការគ្រប់គ្រង

1087. លើសពីនេះទៅទៀត ក្នុងការពិចារណាថា តើ **មាស មុត** ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬទេ វាជាការសំខាន់ក្នុងការពិចារណាអំពីតួនាទីមានឆន្ទៈ និងសំខាន់របស់គាត់ នៅក្នុងយុទ្ធនាការមួយ ដែលបង្កើតបានជាអំពើប្រល័យពូជសាសន៍។ កម្ពុជាស្ថិតក្នុងចំណោមរដ្ឋភាគីដំបូងនៃរដ្ឋភាគីទាំង ១៤៧ នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ឆ្នាំ ១៩៤៨ ដោយបានចូលជាសមាជិកនៃអនុសញ្ញា នៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៥០។ ក្នុងឋានៈជាសមាជិកនៃសន្ធិសញ្ញា កម្ពុជាមានកាតព្វកិច្ចផ្លូវច្បាប់ ក្នុងការធ្វើអ្វីៗគ្រប់បែបយ៉ាងឲ្យអស់ពីលទ្ធភាព ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍ និងផ្តន្ទាទោសចារី។ ក្នុងនាមជាប្រទេសមួយដែលប្រជាជនរបស់ខ្លួនបានរងគ្រោះ ដោយសារយុទ្ធនាការប្រល័យពូជសាសន៍ កាតព្វកិច្ចខាងសីលធម៌របស់កម្ពុជាកាន់តែធំធេងទៅទៀត។

1088. ប្រាកដណាស់ អ្នកដែលបានចរចាកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ បានទទួលស្គាល់កាតព្វកិច្ចនេះ។ វាសមហេតុផលដែលសន្មតថា តាមរយៈការពង្រីកយុត្តាធិការបុគ្គលរបស់តុលាការទៅដល់ជនទាំងឡាយដែល "ទទួលខុសត្រូវបំផុត" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ មេដឹកនាំដែលបានចូលរួមយ៉ាងសកម្ម និងរួមចំណែកយ៉ាងសំខាន់ ចំពោះអំពើប្រល័យពូជសាសន៍ ដែលប្រព្រឹត្តដោយរបបកម្ពុជាប្រជាធិបតេយ្យ នឹងត្រូវនាំយកមកកាត់ទោស តាមគោលបំណងដែលភាគីចង់បាន។

1089. ឧក្រិដ្ឋកម្មរបស់ **មាស មុត** ដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋាននេះ ត្រូវបានប្រព្រឹត្តឡើងប្រឆាំងនឹងមនុស្សរាប់ម៉ឺននាក់ នៅតំបន់ស្វយ័តកំពង់សោម ដែនទឹក ឆ្នេរសមុទ្រ និងកោះកម្ពុជា និងនៅតំបន់ ៥០៥។ ជនរងគ្រោះត្រូវបានគេធ្វើឲ្យក្លាយជាទាសករ នៅតាមការដ្ឋាន ក្នុងលក្ខខណ្ឌអមនុស្សធម៌ បង្ខំឲ្យរៀបការ និងត្រូវបានចាប់ឃុំខ្លួន តាមទំនើងចិត្ត ឬក្នុងករណីរាប់ពាន់ ត្រូវបានសម្លាប់ដោយរបបនេះ។ ជាងនេះទៅទៀត ដោយសារលទ្ធផលនៃការអនុវត្តរបស់សេនាធិការនូវការបោសសម្អាតផ្ទៃក្នុងទៅលើកងវរសេនាធំ និងកងពលមជ្ឈិម នៃកងទ័ពបដិវត្តន៍កម្ពុជា យ៉ាងហោចណាស់ អ្នកទោស ៤.៩០០ នាក់ មកពីកងទ័ពបដិវត្តន៍កម្ពុជា ត្រូវបានបញ្ជូនទៅ ស-២១ ជាស្ថាប័នគ្រប់គ្រង និងគាំទ្រដោយសេនាធិការ។

1090. ក្នុងឋានៈជាអនុលេខាគណៈសេនាធិការ **មាស មុត** បានដើរតួយ៉ាងសំខាន់ក្នុងការសម្លាប់ទាំងនេះ ដោយសារគាត់បានឯកភាពចំពោះការបោសសម្អាតទាហាននៃកងទ័ពបដិវត្តន៍កម្ពុជា តាមផែនការ

នៅក្នុងកិច្ចប្រជុំសេនាធិការ និងបានធ្វើការ ដើម្បីអនុវត្តការបោសសម្អាត នៅក្នុងតំបន់ក្រោមការទទួលខុសត្រូវរបស់គាត់ ដោយបានបញ្ជាផ្ទាល់ឲ្យបញ្ជូនអ្នកក្រោមបង្គាប់ជាច្រើន ទៅ ស-២១។ លើសពីនេះទៅទៀត មនុស្សរាប់ពាន់នាក់ទៀតត្រូវបានសម្លាប់ នៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស ដោយបុគ្គលិកកងពល ១៦៤ និងកងកម្លាំងដទៃទៀត ក្រោមបញ្ជារបស់ **មាស មុត** ដែលប្រតិបត្តិការ នៅតំបន់ស្វយ័តកំពង់សោម ដែនទឹក កោះ ឆ្នេររបស់កម្ពុជាប្រជាធិបតេយ្យ និងតំបន់ស្វយ័ត ៥០៥ នៅពេលតំបន់ទាំងនេះស្ថិតក្រោមការគ្រប់គ្រងរបស់ **មាស មុត**។

1091. យ៉ាងហោចណាស់ ទាហាន និងជនស៊ីវិល មួយម៉ឺននាក់ ត្រូវបានបង្ខំឲ្យធ្វើការ ក្រោមលក្ខខណ្ឌ ដែលបង្កើតបានឧក្រិដ្ឋកម្មនៃការធ្វើឲ្យក្លាយជាទាសករ នៅតំបន់កំពង់សោម។ មនុស្សរាប់រយនាក់ត្រូវបានដាក់គុកក្នុងលក្ខខណ្ឌអមនុស្សធម៌ ធ្វើទារុណកម្ម និងសម្លាប់ ដោយគ្មានដំណើរការក្តីតាមផ្លូវច្បាប់។ ជនជាតិវៀតណាម និងថៃ ជាងមួយពាន់នាក់ និងពួកបស្ចិមប្រទេស ១០ នាក់ ត្រូវបានសម្លាប់ នៅតំបន់កំពង់សោម នៅលើសមុទ្រ ឬកោះ ឬបញ្ជូនទៅសម្លាប់នៅ ស-២១។ វៀតណាម ១៩៤ នាក់ ដែល **មាស មុត** បញ្ជូនទៅ ស-២១ គឺស្មើនឹងមួយភាគបីនៃចំនួនវៀតណាមសរុបដែលត្រូវបានបញ្ជូនទៅទួលស្លែង ពីទូទាំងប្រទេសកម្ពុជា។ ជាសរុប **មាស មុត** បានបញ្ជាឲ្យបញ្ជូនមនុស្សប្រហែល ៧០៦ នាក់ ដែលគេចាត់ទុកជា "ខ្មាំង" ទៅ ស-២១។ ប្តីប្រពន្ធរាប់រយគូត្រូវគេបង្ខំឲ្យរៀបការ នៅកំពង់សោម ស្របតាមគោលនយោបាយដែលបញ្ជា និងជួយសម្រួលដោយ **មាស មុត**។ គាត់បានបញ្ជាដោយផ្ទាល់ឲ្យគូជាក់លាក់មួយចំនួនរៀបការ ហើយពិធីរៀបការជាច្រើនត្រូវបានរៀបចំឡើង ក្រោមអធិបតីភាពមេបញ្ជាការរងរបស់គាត់។

1092. ឧក្រិដ្ឋកម្មរបស់ **មាស មុត** មិនមែនដាច់ពីគ្នា ឬនៅដុំៗនោះឡើយ។ វាកើតឡើងជាបន្តបន្ទាប់ក្រោមយុត្តាធិការពេលវេលាទាំងមូលរបស់តុលាការ ដែលជាផ្នែកមួយនៃការធ្វើទុក្ខបុកម្នេញប្រជាជនជាប្រព័ន្ធ។ នៅតំបន់កំពង់សោម **មាស មុត** បានបញ្ជូនជនសង្ស័យទៅធ្វើទុក្ខបុកម្នេញ និងសម្លាប់នៅ វត្តឥន្ទញ្ញាណ ទឹកសាប និង ស-២១ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ ដូចគ្នានេះដែរ **មាស មុត** បានបង្កើតការដ្ឋានថ្នាក់តំបន់នៅរាម និងស្ទឹងហាវ ហើយនៅទីនោះ គាត់បានធ្វើឲ្យទាហានរំសាយនៃកងទ័ពបដិវត្តន៍កម្ពុជា និងជនស៊ីវិល ក្លាយជាទាសករ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ ការសម្លាប់វៀតណាមដោយកងពល ១៦៤ បានចាប់ផ្តើមនៅឆ្នាំ ១៩៧៥ និងបានបន្តរហូតដល់ចុងឆ្នាំ ១៩៧៨ យ៉ាងហោចណាស់។ ការប្រព្រឹត្តិលើវៀតណាម ដែលកងពល ១៦៤

ចាប់បាន មានភាពស៊ីចង្វាក់ ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ គឺវៀតណាមទាំងអស់ត្រូវគេសម្លាប់ ឬបញ្ជូនទៅសម្លាប់ ក្រោយពីចាប់បាន។

1093. ការទទួលខុសត្រូវរបស់ **មាស មុត** ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ក្នុងដីកាសន្និដ្ឋាននេះ គឺខ្ពស់ណាស់។ គាត់បានដើរតួនាទីដ៏មានឥទ្ធិពល ក្នុងគោលនយោបាយឧក្រិដ្ឋ ដោយសារតែសិទ្ធិអំណាចយ៉ាងទូលំទូលាយរបស់គាត់។ ការរួមចំណែករបស់គាត់មានភាពសកម្ម និងផ្ទាល់ រួមទាំងការបញ្ជាផ្ទាល់ឱ្យប្រព្រឹត្តឧក្រិដ្ឋកម្ម។ ក្នុងឋានៈជាអាជ្ញាធរខ្ពស់បំផុត នៅតំបន់កំពង់សោម និងនៅក្នុងកងពល ១៦៤ គាត់បានបញ្ជា រៀបចំផែនការ និងញុះញង់ឱ្យមានឧក្រិដ្ឋកម្មទាំងនេះ។ នៅក្នុងតួនាទីរបស់គាត់នៅសេនាធិការ គាត់បានលើកទឹកចិត្តមេបញ្ជាការកងពល និងកងវរសេនាតូចដទៃទៀតឱ្យបោសសម្អាតខ្មាំងក្នុងជួរ។ គាត់បានធ្វើការបោសសម្អាតដោយខ្លួនឯងផ្ទាល់ ដោយការចាប់ និងបញ្ជូនកម្មាភិបាលទៅសម្លាប់ ក្នុងក្របខ័ណ្ឌនៃការបោសសម្អាតកងពល ១១៧ តំបន់ ៥០៥។ គាត់បានរៀបចំប្រព័ន្ធមួយ ដើម្បីកំណត់អត្តសញ្ញាណ ស្វែងរក ចាប់ខ្លួន កសាង ឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់អ្នកដែលគេហៅថាខ្មាំងរបស់ ប.ក.ក។

1094. **មាស មុត** បានបំពាក់បំប៉នដោយផ្ទាល់ដល់អ្នកក្រោមបង្គាប់ អំពីគោលនយោបាយខ្មាំង ដើម្បីធ្វើទុក្ខបុកម្នេញ និងសម្លាប់អ្នកគេដែលសង្ស័យថាខ្មាំងរបស់ ប.ក.ក ដោយគ្មានការកាត់សេចក្តី។ ស្របតាមបញ្ជារបស់គាត់ និងគោលនយោបាយដែលគាត់បានបង្កើតឡើង អ្នកទោសត្រូវគេឃុំក្នុងស្ថានភាពអមនុស្សធម៌ នៅតាមការដ្ឋាន និងមន្ទីរសន្តិសុខ។ គាត់បានបញ្ជា និងបំពាក់បំប៉នអ្នកក្រោមបង្គាប់ឱ្យបង្ខំប្តីប្រពន្ធឱ្យរៀបការ និងរួមដំណេកផ្ទុយពីឆន្ទៈរបស់ខ្លួន។ ជារួម **មាស មុត** បានប្រើអ្នកក្រោមបង្គាប់ឱ្យអនុវត្តគោលនយោបាយឧក្រិដ្ឋ ដើម្បីធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្មាំង និងធ្វើឱ្យប្រជាជនក្លាយជាទាសករ សំដៅសម្រេចទិសដៅនយោបាយរបស់ ប.ក.ក ដោយដឹង និងចង់ឱ្យឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្ត។

1095. **មាស មុត** មានអំណាចក្នុងការចេញបញ្ជា តែងតាំង បញ្ចុះឋានៈបុគ្គលិក និងដាក់ទណ្ឌកម្មអ្នកក្រោមបង្គាប់។ ការគ្រប់គ្រងរបស់គាត់ គឺទូលំទូលាយ។ គាត់មានឈ្មោះល្បី ក្នុងចំណោមកូនទាហានរបស់គាត់ថាជាមនុស្ស "តឹងរ៉ឹងខ្លាំង" "ហ្មត់ចត់" "កាច" និង "អាក្រក់"។ គាត់បានគ្រប់គ្រងគ្រប់ផ្នែកទាំងអស់នៃកងពល ១៦៤ និងតំបន់កំពង់សោម ដោយបានចេញបញ្ជាទាក់ទិននឹងប្រតិបត្តិការយោធា ការល្បាត ការចាប់ទូក ការរំសាយ និងការបញ្ជូនកងទ័ព ផលិតកម្មកសិកម្ម ការរៀបការ ការកំណត់អត្តសញ្ញាណបុគ្គលិកយោធា និងប្រជាជនសាមញ្ញ ដែលសង្ស័យ

ថាមិនស្មោះត្រង់នឹងរបប ការចាប់ និងសម្លាប់។ ជាផ្នែកមួយនៃតួនាទីរបស់គាត់នៅសេនាធិការ **មាស មុត** ក៏បានចេញបញ្ជាស្រដៀងគ្នាទៅកងពល ១១៧។ គាត់ដក និងដាក់ជំនួសកម្មាភិបាលនៃកងពល ១៦៤ កងពល ១១៧ និងតំបន់ ៥០៥។

1096. ក្នុងការវាយតម្លៃថា តើ **មាស មុត** ស្ថិតនៅក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែរឬទេ យើងគួរប្រៀបធៀបតួនាទីរបស់គាត់ជាមួយនឹងតួនាទីរបស់ កាំង ហ្កេកអ៊ាវ ហៅឌុច ដែលត្រូវបានកំណត់ថាស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងសំណុំរឿង ០០១[4242]។ **មាស មុត** មានតំណែងខ្ពស់ជាង ឌុច ឆ្ងាយណាស់។ ពេលសហចៅក្រមស៊ើបអង្កេតសួរអំពីចម្លើយសារភាពមួយ នៅស-២១ ដោយមានចំណារ ផ្ញើជូន "សមមិត្ត **មុត**" និងសួរថាតើគាត់ជាអ្នកសរសេរចំណារនោះមែនដែរឬទេ ឌុច បានឆ្លើយថា "ខ្ញុំមិនអាចនិយាយទៅកាន់ **មាស មុត** ថា "សមមិត្ត" ទេ ដោយគិតពីឋានៈ និងអាយុរបស់គាត់ ដែលធំ និងច្រើនជាងខ្ញុំ"[4243]។ នៅក្នុងឯកសារកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ ១៩៧៧ មន្ទីរ ស-២១ របស់ ឌុច បានចុះបញ្ជីថាមានបុគ្គលិក ២.៣១៧ នាក់ ឯកងពល ១៦៤ របស់ **មាស មុត** មានបុគ្គលិក ៨.៥៦៨ គឺលើសជិតបួនដង[4244]។

1097. ច្បាស់ណាស់ **មាស មុត** មានឋានៈខុសគ្នាស្រឡះ និងខ្ពស់ជាង ឌុច នៅ ប.ក.ក ពីព្រោះគាត់មានសមាជិកភាពនៅក្នុងគណៈមជ្ឈិម គណៈសេនាធិការ គណៈកងពល ១៦៤ និងគណៈតំបន់កំពង់សោម ដោយមិននិយាយដល់ទំនាក់ទំនងផ្ទាល់ខ្លួនរបស់គាត់ជាមួយ តាម៉ុក។ **មាស មុត** មានការទទួលខុសត្រូវកម្រិតគោលនយោបាយ ច្រើនជាង ឌុច ដែលមានតួនាទីតែមួយគត់ក្នុងប្រតិបត្តិការមន្ទីរសន្តិសុខ ស-២១។ លើសពីនេះទៅទៀត ដូចបានលើកឡើងក្នុងដីកាសន្និដ្ឋាននេះ **មាស មុត** ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងទៀត តាមរយៈការរៀបការដោយបង្ខំ ដែលមិនមែនជាឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹង ឌុច។

---

4242 អានសំណុំរឿង០០១ ឯកសារ F28 សាលក្រមសាលាឧទ្ធរណ៍ ឌុច។

4243 ឯកសារ D4.1.766 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច, EN 00398210, KH ERN 00398202 ["ឯកសារទី១ (ERN 00174375) ត្រូវបានធ្វើចំណារដោយសុន សេន SON Sen ផ្ញើរទៅប៉ុល ពត POL Pot។ ខ្ញុំមិនមែនជាអ្នកសរសេរវាទេ (ខ្ញុំ មិនអាចនិយាយទៅកាន់ មាស មុត MEAS Mut ថា សមមិត្តទេ ដោយគិតពីឋានៈ និងអាយុរបស់គាត់ដែលធំ និងច្រើនជាងខ្ញុំ)"]។

4244 ឯកសារ D1.3.30.9 របាយការណ៍កម្ពុជាប្រជាធិបតេយ្យ ពីអគ្គសេនាធិការកងទ័ពបដិវត្តកម្ពុជា, ថ្ងៃទី៧ខែមេសា ឆ្នាំ ១៩៧៧, EN 00183956, KH ERN 00052319។

1098. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាអន្តរជាតិសូមបញ្ជាក់ថា ភស្តុតាងសរុបបានមកពីកិច្ចស៊ើបសួរបង្ហាញថា **មាស មុត** ស្ថិតក្នុងចំណោមមេដឹកនាំជាន់ខ្ពស់របស់ ប.ក.ក និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយគាត់ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។

1099. សហព្រះរាជអាជ្ញាអន្តរជាតិក៏ទទួលស្គាល់ និងកោតសរសើរចំពោះក្តីព្រួយបារម្ភរបស់សហព្រះរាជអាជ្ញាជាតិថា មុននឹងចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវគិតគូរដល់គោលបំណង អ.វ.ត.ក ដូចបានបង្ហាញ នៅក្នុងបុព្វកថា នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។ បុព្វកថា នៃកិច្ចព្រមព្រៀង បញ្ជាក់ថា មហាសន្និបាតអង្គការសហប្រជាជាតិបានទទួលស្គាល់ការព្រួយបារម្ភពេញច្បាប់របស់រដ្ឋាភិបាល និងប្រជាជនកម្ពុជា ក្នុង "ការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខ"[4245]។ ដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិបានពិចារណាដោយប្រុងប្រយ័ត្នទូវផលប៉ះពាល់នៃការបញ្ជូន **មាស មុត** ទៅជំនុំជម្រះ លើយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខ នៅកម្ពុជា។

1100. ដើម្បីវាយតម្លៃថា តើការបង្រួបបង្រួមជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខ អាចត្រូវបានប៉ះពាល់ដោយការបញ្ជូន **មាស មុត** ទៅជំនុំជម្រះ ដែរឬទេ សហព្រះរាជអាជ្ញាអន្តរជាតិបានពិនិត្យមើលថា តើការជំនុំជម្រះមុនៗ នៅ អ.វ.តក បានជះឥទ្ធិពលលើការព្រួយបារម្ភ និងគោលបំណងទាំងនេះដោយរបៀបណា។ លើសពីនេះទៅទៀត ដោយសារអត្តសញ្ញាណជនសង្ស័យ ដែលជាកម្មវត្ថុនៃការស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ត្រូវបានផ្សព្វផ្សាយជាសាធារណៈមួយរយៈមកហើយ សហព្រះរាជអាជ្ញាអន្តរជាតិបានពិនិត្យមើលថា ប្រសិនបើមានការយល់ដឹងជាសាធារណៈថា អ.វ.ត.ក កំពុងធ្វើការស៊ើបអង្កេតបទឧក្រិដ្ឋរបស់ជនទាំងនេះ រួមទាំង **មាស មុត** តើមានផលប៉ះពាល់អ្វីខ្លះ ទៅលើរបៀបដែលប្រជាជនកម្ពុជាមើលឃើញអំពីស្ថានភាពយុត្តិធម៌នៅក្នុងប្រទេស ហើយតើមានផលប៉ះពាល់អ្វីខ្លះ ទៅលើការបង្រួបបង្រួមជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខ។

---

[4245] អានកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ ជាមួយរាជរដ្ឋាភិបាលកម្ពុជាពាក់ព័ន្ធនឹងការកាត់ទោសក្រោមច្បាប់កម្ពុជាចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, កថាខណ្ឌ២។

1101. ចេញពីភស្តុតាងទាំងអស់ដែលសហព្រះរាជអាជ្ញាអន្តរជាតិអាចពិនិត្យមើលបាន ច្បាស់ណាស់ថា ការផ្តន្ទាទោស និងការកាត់ទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត ក្នុងសំណុំរឿង ០០១ និងសំណុំរឿង ០០២/០១ ពុំមានផលប៉ះពាល់អវិជ្ជមានទៅលើការបង្រួបបង្រួមជាតិ ស្ថិរភាព សន្តិភាព ឬ សន្តិសុខឡើយ ហើយប្រហែលជាមានផលវិជ្ជមានច្រើន។ លើសពីនេះទៅទៀត ពុំមានប្រតិកម្មអវិជ្ជមានជាសាធារណៈចំពោះការបង្ហាញថា **មាស មុត** និងជនសង្ស័យដទៃទៀត កំពុងស្ថិតនៅក្រោមកិច្ចស៊ើបសួរ ក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ហើយក៏ពុំមានប្រតិកម្មអវិជ្ជមានជាសាធារណៈ នៅពេលមានការប្រកាសជាសាធារណៈថា គាត់ត្រូវបានចោទប្រកាន់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឬនៅពេលមានការប្រកាសជាសាធារណៈថា កិច្ចស៊ើបសួរតាមផ្លូវតុលាការប្រឆាំងគាត់បានបិទបញ្ចប់។ សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា គ្មានហេតុផលត្រូវជឿថា ការបញ្ជូន **មាស មុត** ទៅជំនុំជម្រះ នឹងធ្វើឱ្យប៉ះពាល់ដល់ការបង្រួបបង្រួមជាតិ ស្ថិរភាពសន្តិភាព ឬសន្តិសុខ នៅកម្ពុជាឡើយ។ ផ្ទុយទៅវិញ កិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យមេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដ៏សម្បើម ទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន នឹងបង្កើនទំនុកចិត្តពីសាធារណជនថា អ្នកមានឥទ្ធិពលមិនអាចគេចផុតជារៀងរហូតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះឡើយ ហើយយុត្តិធម៌អាចសម្រេចបាន ដែលរឹតតែធ្វើឱ្យមានស្ថិរភាព និងសន្តិភាពយូរអង្វែងនៅកម្ពុជា។

1102. ជនជាប់ចោទ ក្នុងសំណុំរឿង ០០២ គឺជាសមាជិកជាន់ខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យដែលនៅរស់រានមានជីវិត។ នួន ជា គឺជាមនុស្សទី ២ នៅក្នុងឋានានុក្រម ប.ក.ក និងដៃស្តាំរបស់ ប៉ុល ពត ចំណែកឯ ខៀវ សំផន គឺជាអតីតប្រមុខរដ្ឋ និងជាតំណាងសាធារណៈរបស់រដ្ឋកម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក ក្រោមឈ្មោះហៅផ្សេងៗ អស់រយៈពេលជាច្រើនឆ្នាំ។ ការជំនុំជម្រះក្តីសំណុំរឿង ០០២/០១ បានចាប់ផ្តើមក្នុងឆ្នាំ ២០០១។ នៅឆ្នាំ ២០១៤ សាលក្រមត្រូវបានចេញដោយកាត់ទោស នួន ជា និង ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងផ្តន្ទាទោសជនជាប់ចោទម្នាក់ៗឱ្យជាប់ពន្ធនាគារអស់មួយជីវិត។ ការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងទោសជាប់ពន្ធនាគារអស់មួយជីវិត ត្រូវបានតម្កល់ នៅក្នុងសាលដីការបស់អង្គជំនុំជម្រះតុលាការកំពូល នៃ អ.វ.ត.ក ដែលត្រូវបានប្រកាសក្នុងខែ វិច្ឆិកា ឆ្នាំ ២០១៦[4246]។

---

[4246] សំណុំរឿង០០២ ឯកសារ F36 សាលដីកាសំណុំរឿង ០០២/០១។

1103. គ្មានការរាយការណ៍អំពីប្រតិកម្មអវិជ្ជមាននឹងការផ្តន្ទាទោស ឬការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងនេះទេ។ គ្មានវិធានការសន្តិសុខវិសាមញ្ញត្រូវបានរៀបចំឡើង សម្រាប់ការជំនុំជម្រះនោះទេ ហើយការពិត គ្មានបាតុកម្ម ឬការតវ៉ារបស់អតីតកម្មាភិបាលខ្មែរក្រហម ដែលប្រតិកម្មអវិជ្ជមាននឹងការផ្តន្ទាទោសឡើយ។ គ្មានការចង្អុលបង្ហាញថា ការជំនុំជម្រះក្តី ការផ្តន្ទាទោស និងការកាត់ទោស នួន ជា និង ខៀវ សំផន ឲ្យជាប់ពន្ធនាគារអស់មួយជីវិត បានគំរាមកំហែងដល់សន្តិភាព សន្តិសុខ ស្ថិរភាព ឬការបង្រួបបង្រួមជាតិ នៅកម្ពុជាឡើយ។

1104. ខណៈដែលជនជាប់ចោទ ក្នុងសំណុំរឿង ០០២ ស្ថិតនៅពីលើ **មាស មុត** ក្នុងឋានានុក្រមកម្ពុជាប្រជាធិបតេយ្យ ជនជាប់ចោទ ក្នុងសំណុំរឿង ០០១ ឌុច មានឋានៈទាបជាងក្នុងឋានានុក្រម។ ឌុច មិនមែនជាសមាជិកគណៈមជ្ឈិម និងមិនត្រូវបានចាត់តាំងខាងនយោបាយណាផ្សេងទៀតឡើយ។ គាត់មិនបានគ្រប់គ្រងសូម្បីតែមួយតំបន់ កុំនិយាយដល់គ្រប់គ្រងពីរតំបន់ ដូច **មាស មុត** ហើយ ឌុច ក៏មិនបានគ្រប់គ្រងសូម្បីតែតំបន់រដ្ឋបាលតូចមួយ។ ឌុច បញ្ជាមនុស្សតិចជាង **មាស មុត** ឆ្ងាយណាស់។ ប៉ុន្តែ គ្មានប្រតិកម្មអវិជ្ជមាន ឬឧប្បត្តិហេតុសន្តិសុខណាមួយពីការចាប់ខ្លួន ការជំនុំជម្រះ និងការផ្តន្ទាទោសមេដឹកនាំខ្ពស់បំផុត របស់ ប.ក.ក នោះឡើយ ក៏គ្មានប្រតិកម្មអវិជ្ជមាននឹងការចោទប្រកាន់ និងការផ្តន្ទាទោស ឌុច ជាកម្មាភិបាលថ្នាក់មធ្យម ដែលមានសិទ្ធិអំណាចទាបជាង **មាស មុត** ឆ្ងាយណាស់។

1105. ខ្មែរក្រហមលែងជាការគំរាមកំហែងដល់សន្តិភាព និងសន្តិសុខរបស់កម្ពុជា តាំងពីយូរមកហើយ។ ចលនានេះបានដួលរលំ អស់រយៈពេលជិតពីរទសវត្សរ៍មកហើយ ពេលពួកកាកសំណល់នៃ ប.ក.ក ត្រូវបានញាំញីដោយជម្លោះផ្ទៃក្នុង និងការបំបែកគ្នា នៅចុងទសវត្សរ៍ឆ្នាំ ១៩៩០។ សព្វថ្ងៃនេះ របប ប៉ុល ពត ត្រូវគេប្រមាថ ស្ទើរតែជាសកល នៅកម្ពុជា ហើយគ្មានការគាំទ្រជាសាធារណៈធំដុំ ឬការរំពឹងទុកថាចលនានេះលេចឡើងសាជាថ្មីទេ។

1106. ជំនួសឲ្យការនាំទៅរកភាពរំជើបរំជួល ឬការតវ៉ា ប្រជាពលរដ្ឋខ្មែរបានបង្ហាញការយកចិត្តទុកដាក់ និងការគាំទ្រចំពោះការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងនេះ។ ដើមបណ្តឹងរដ្ឋប្បវេណីរាប់ពាន់នាក់បានចូលរួម ឬដាក់ពាក្យស្នើសុំចូលរួម ក្នុងរឿងក្តីទាំងនេះ ហើយប្រជាជនជាង ២ សែននាក់បានចូលរួមក្នុងការជំនុំជម្រះក្តី រហូតមកទល់ពេលនេះ។ ដោយសារការកាត់ទោសកម្មាភិបាល **មាស មុត** (នួន ជា និង ខៀវ សំផន) និងក្រោម មាស មុត ក្នុងឋានានុក្រមនយោបាយ និងយោធារបស់កម្ពុជាប្រជាធិបតេយ្យ (ឌុច) ពុំមានផលប៉ះពាល់អវិជ្ជមានលើសន្តិភាព សន្តិសុខ ឬការបង្រួប

បង្រួមជាតិ គ្មានមូលហេតុអ្វីត្រូវជឿថា ការកាត់ទោស **មាស មុត** នៅរយៈពេល ៣៩ ឆ្នាំ ក្រោយការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ និង ២៦ ឆ្នាំ ក្រោយការចុះហត្ថលេខាកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នឹងគំរាមកំហែងដល់សន្តិភាព សន្តិសុខ ឬការបង្រួបបង្រួមជាតិឡើយ។

1107. ជាងនេះទៅទៀត ការផ្សព្វផ្សាយឲ្យដឹងសាធារណៈថា **មាស មុត** ជាជនសង្ស័យ ក្នុងកិច្ចស៊ើបសួរសំណុំរឿង ០០៣ ត្រូវបានធ្វើឡើង តាំងពីឆ្នាំ ២០១១ មកម្ល៉េះ[4247]។ ប្រាំមួយឆ្នាំមកហើយ គ្មានភាពចលាចល ឬប្រតិកម្មអវិជ្ជមានជាសាធារណៈនឹងដំណឹងនេះ ដែលអាចគំរាមកំហែងដល់សន្តិភាព សន្តិសុខ ឬការបង្រួបបង្រួមជាតិរបស់កម្ពុជាឡើយ។ ការមានឋានន្តរស័ក្តិយោធារបស់ **មាស មុត** មិនចង្អុលបង្ហាញថា រាល់ការប៉ុនប៉ងឲ្យគាត់ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម នឹងគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈឡើយ។ ចាប់តាំងពីការចុះហត្ថលេខាកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជាមក មន្ត្រីយោធាជាន់ខ្ពស់ជាច្រើនរូប រួមទាំងឧត្តមសេនីយ៍ ត្រូវបានកាត់ទោស ដោយគ្មានផលវិបាកណាមួយទៅលើសណ្តាប់ធ្នាប់សាធារណៈ រួមទាំងអតីតឧត្តមសេនីយ៍ខ្មែរក្រហមផងដែរ[4248]។ បើតាមសហព្រះរាជអាជ្ញាអន្តរជាតិដឹង អ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត អាចសម្ភាសអតីតកម្មាភិបាលខ្មែរក្រហមអំពី **មាស មុត** និងជនសង្ស័យ ក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ ដោយគ្មានឧប្បត្តិហេតុធ្ងន់ធ្ងរ។

1108. សហព្រះរាជអាជ្ញាអន្តរជាតិបច្ចុប្បន្ននេះ អតីតសហព្រះរាជអាជ្ញា និងសហព្រះរាជអាជ្ញារងអន្តរជាតិដែលបានធ្វើជាសហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានយល់ឃើញយ៉ាងស៊ីចង្វាក់គ្នាថា នឹងមិន

---

4247 ព្រឹត្តិបត្រព័ត៌មាន The CambodiaDaily, សកម្មជនបង្ហាញឈ្មោះជនសង្ស័យ៣នាក់នៅក្នុងសំណុំរឿង០០៤ ចេញផ្សាយថ្ងៃទី៦ខែឧសភា ឆ្នាំ២០០១។

4248 ព្រឹត្តិបត្រព័ត៌មាន Chicago Tribune, អតីតឧត្តមសេនីយ៍ខ្មែរក្រហមត្រូវផ្តន្ទាទោសពីបទចាប់ពង្រត់, សម្លាប់ទេសចរសាក់កាដូរចំនួន៣នាក់ ចេញផ្សាយថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០២។ ព្រឹត្តិបត្រព័ត៌មាន Phnom Penh Post, សម្លាប់មនុស្សពីរនាក់ ឧត្តមសេនីយ៍ម្នាក់ត្រូវផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ចេញផ្សាយថ្ងៃទី២៥ខែកក្កដាឆ្នាំ២០១៥, នៅឯhttp://www.phnompenhpost.com/post-weekend/double-murder-earns-general-life-sentence។ ព្រឹត្តបត្រព័ត៍មាន The Cambodia Daily, សាលក្រមបានចេញហើយនៅក្នុងសំណុំរឿងសម្លាប់មនុស្សរបស់ឧត្តមសេនីយ៍ម្នាក់ ចេញផ្សាយថ្ងៃទី១៥ខែមិថុនាឆ្នាំ២០១៥នៅឯhttps://www.cambodiadaily.com/archives/first-verdicts-delivered-in-generals-murder-case-85609/។ សូមអាន ព្រឹត្តិបត្រព័ត៌មានPhnom Penh Post, ការផ្តន្ទាទោស ហេង ពៅ គឺនៅដដែល, ចេញផ្សាយថ្ងៃទី២៨ខែកញ្ញា ឆ្នាំ២០១៧ នៅឯ http://www.phnompenhpost.com/national/heng-pov-convictions-upheld-again។

មានសំណុំរឿងបន្ថែមទៀតទេ នៅ អ.វ.ត.ក បន្ទាប់ពីសំណុំរឿង ០០៣ និងសំណុំរឿង ០០៤។ ដោយសារតែដំណាក់កាលវិវត្តនៃ អ.វ.ត.ក គ្មានហេតុផលអ្វីដែលគ្រប់គ្នាត្រូវខ្លាចថា ប្រសិនបើ **មាស មុត** ត្រូវបញ្ជូនទៅជំនុំជម្រះ ជនសង្ស័យបន្ថែមទៀតនឹងត្រូវចោទប្រកាន់នោះឡើយ។ ដូច្នេះ គ្មានមូលដ្ឋានសមហេតុផល ដែលអតីតកម្មាភិបាលខ្មែរក្រហមគំរាមកំហែងដល់សន្តិសុខប្រទេសនោះទេ ពីព្រោះពួកគេខ្លាចការចាប់ខ្លួន ប្រសិនបើ **មាស មុត** ត្រូវបញ្ជូនទៅជំនុំជម្រះ។

## XIII. ទំនួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល

### ក. ទិដ្ឋភាពទូទៅ

1109. **មាស មុត** ទទួលខុសត្រូវជាបុគ្គលចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ យោងតាមមាត្រា ៤, ៥ និង ៦ នៃច្បាប់ អ.វ.ត.ក ដូចដែលត្រូវបានបង្ហាញដោយភស្តុតាង នៅក្នុងការស៊ើបអង្កេតលើសំណុំរឿង ០០៣ ដែលត្រូវបានពិភាក្សានៅក្នុងដីកាសន្និដ្ឋាននេះ។

1110. **មាស មុត** ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនេះ យោងតាមមាត្រា ២៩ ថ្មី នៃច្បាប់ អ.វ.ត.ក ជាពិសេស (i) ចំពោះការប្រព្រឹត្តិ រៀបចំផែនការ ញុះញង់ បញ្ជា និង/ឬ ជួយនិងជំរុញក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ និង (ii) មិនអាចបង្ការការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬដាក់ទណ្ឌកម្មចារី ក្នុងឋានៈជាថ្នាក់លើដែលបានដឹង ឬមានហេតុផលដឹងថា អ្នកនៅក្រោមបង្គាប់ហៀបនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តនូវសកម្មភាពបែបនេះ។ **មាស មុត** បានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះមិនមែនក្នុងឋានៈជាចារីរូបវន្តទេ ប៉ុន្តែក្នុងឋានៈជាអ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម។

## ក. ទម្រង់នៃការទទួលខុសត្រូវ

### ១. ការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្មរួម[4249]

1111. **មាស មុត** បានប្រព្រឹត្តឧក្រិដ្ឋកម្មនីមួយៗនៃឧក្រិដ្ឋកម្មនានា ដែលត្រូវបានចោទប្រកាន់ តាមរយៈការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម (JCE)។ JCE តម្រូវឱ្យមានទម្រង់មូលដ្ឋាន ("JCE I") នៃទំនួលខុសត្រូវលើផែនការរួម។

1112. សមាជិក JCE មានផែនការឧក្រិដ្ឋរួមដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលត្រូវបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះ ជាមធ្យោបាយដើម្បីឱ្យ ប.ក.ក បន្តកាន់អំណាច និងអនុវត្តគោលនយោបាយកសិកម្ម សេដ្ឋកិច្ច និងសង្គមកិច្ចទាំងស្រុងរបស់ថ្នាក់ដឹកនាំ ប.ក.ក។

1113. ខណៈដែលផែនការរួមលាតសន្ធឹងចំពោះតំបន់ទាំងអស់នៃប្រទេសកម្ពុជា JCE ដែលត្រូវបានរៀបរាប់ក្នុងដីកាសន្និដ្ឋាននេះ ពាក់ព័ន្ធនឹងការអនុវត្តផែនការរួមក្នុងតំបន់គ្រប់គ្រងដោយកងកម្លាំងរបស់ **មាស មុត** ដែលរួមមានតំបន់ស្វយ័តកំពង់សោម កោះដែលត្រូវបានកាន់កាប់ ឬគ្រប់គ្រងដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ និងនៅចុងឆ្នាំ ១៩៧៨ តំបន់ស្វយ័ត ៥០៥ និងការបោសសម្អាត "ខ្មាំង" នៅក្នុងជួរកងពលមជ្ឈិម និងកងវរសេនាធំឯករាជ្យនៃកងទ័ពបដិវត្តន៍កម្ពុជា។

1114. ផែនការនេះព្យាយាមកែប្រែសង្គមទាំងស្រុង ដើម្បីសម្រេចឱ្យបានតាមមធ្យោបាយឧក្រិដ្ឋ នូវសង្គមមួយគ្មានសាសនា និងវណ្ណៈ ជាមួយនឹងអត្តសញ្ញាណជាតិ និងពូជសាសន៍តែមួយ។ ដើម្បីលុបបំបាត់ការប្រឆាំង និងអ្នកដែលត្រូវបានសន្មតថាជាខ្មាំង និងដើម្បីឱ្យ ប.ក.ក បន្តកាន់អំណាច ផែនការតម្រូវឱ្យមានការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្នុងទម្រង់ជា**ការសម្លាប់ផ្តាច់ពូជ ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ការដាក់ក្នុងមន្ទីរឃុំឃាំង ការដាក់ឱ្យធ្វើជាទាសករ ការធ្វើទុក្ខបុកម្នេញ** និង**អំពើអមនុស្សធម៌ផ្សេងទៀត** និងការបំពារបំពានយ៉ាង

---

[4249] អាន ផ្នែក III.២. តួនាទីរបស់ មាស មុត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ផ្នែក IV. កងពល១៦៤ (ពីមុនកងពល ៣) វចនាសម្ព័ន្ធបញ្ជាការ។ III.៣. ការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម – ការរួមចំណែកក្នុងការធ្វើទុក្ខបុកម្នេញ និងការសម្លាប់ខ្មាំង។ III.៣. ការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម – ការចូលរួមក្នុងការធ្វើទាសកម្មនៅឯការដ្ឋាន។ ផ្នែកIII.៣. ការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម– ការចូលរួមបង្ខំមនុស្សឱ្យរៀបការ និងអំពើសេពសន្ថវៈ។ ផ្នែក VII. គោលនយោបាយរបស់បក្សកុម្មុយនិស្តកម្ពុជាទាក់ទិននឹងសំណុំរឿងប្រឆាំង មាស មុត– កសិកម្ម, សេដ្ឋកិច្ច, និងគោលនយោបាយសង្គមកិច្ច - ការរៀបការដោយបង្ខំ និងការរំលោភសេពសន្ថវៈ។

ធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ក្នុងនោះមាន ការឃុំខ្លួនដោយខុសច្បាប់ ការធ្វើទារុណកម្ម ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព និង ការធ្វើមនុស្សឃាតដោយចេតនា ប្រឆាំងនឹងប្រភេទផ្សេងៗទៀតនៃអ្នកដែលគេសន្មតថាជាខ្មាំង។

1115. ខ្មាំងទាំងនេះរួមបញ្ចូលទាំងបុគ្គលិកកងទ័ពបដិវត្តន៍កម្ពុជា និងកម្មាភិបាលដែលគេសន្មតថាមិន ស្មោះត្រង់ គ្រួសាររបស់ពួកគេ និងអ្នកផ្សេងទៀតដែលត្រូវបានសន្មតថាជាប់ពាក់ព័ន្ធជាមួយពួកគេ អតីតទាហាន និងអ្នករដ្ឋការនៃរបប លន់ នល់ និងអ្នកផ្សេងទៀត ដែលត្រូវបានសន្មតថាជាប់ពាក់ ព័ន្ធជាមួយពួកគេ ក្រុមមនុស្សដែលត្រូវបានបញ្ជូនចេញដោយបង្ខំពីទីក្រុង ហៅជារួមថា "ប្រជាជន ថ្មី" ឬ "ប្រជាជន ១៧ មេសា" អ្នកដែលត្រូវបានចាត់ទុក ឬកំណត់ដោយអាជ្ញាធរថាជាគិញរបស់ សេអ៊ីអា ឬ កាហ្សេបេ ជនជាតិវៀតណាម និងអ្នកមានសញ្ជាតិវៀតណាម ឬអ្នកផ្សេងទៀតដែល ត្រូវបានសន្មតថាជាប់ពាក់ព័ន្ធជាមួយពួកគេ អ្នកមកពីវណ្ណៈ "គហបតី" "សក្តិភូមិ" ឬ "មូលធន" និងពលរដ្ឋសាមញ្ញទាំងឡាយណា ដែលត្រូវបានសន្មតថាមិនស្មោះត្រង់នឹងរបប ឬបដិវត្តន៍ ទោះ មានហេតុផលអ្វីក៏ដោយ។ ផែនការក៏តម្រូវឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (តាម រយៈការសម្លាប់) ក្នុងគោលបំណងដើម្បីកម្ទេចប្រជាជនវៀតណាមនៅក្នុងប្រទេសកម្ពុជា ជាក្រុម ពូជសាសន៍ ជាតិសាសន៍ និងជាតិពន្ធុដាច់ដោយឡែកមួយ។

1116. ដើម្បីសម្រួលដល់គោលនយោបាយកសិកម្ម សង្គមកិច្ច និងយោធារបស់ ប.ក.ក តាមរយៈការ បង្កើនចំនួនប្រជាជនឱ្យបានឆាប់រហ័ស JCE តម្រូវឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្ស ជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ផ្សេងទៀត តាមរយៈការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និង ការបង្ខំប្តីប្រពន្ធដែលត្រូវបានរៀបការដោយបង្ខំ ឱ្យរួមដំណេកជាមួយគ្នា ដោយគ្មានការព្រម ព្រៀងពីពួកគេណាម្នាក់ ឬពីពួកគេទាំងពីរ (ការរំលោភសេពសន្ថវៈ)។ ការសម្រួលផ្សេងទៀតដល់ គោលនយោបាយទាំងនេះ តម្រូវឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជា ការដាក់ឱ្យធ្វើជាទាសករ ការធ្វើមនុស្សឃាត ការសម្លាប់ផ្តាច់ពូជ ការធ្វើទារុណកម្ម និងអំពើ អមនុស្សធម៌ផ្សេងទៀត (ការបាត់ខ្លួនដោយបង្ខំ និងការធ្វើបាបអមនុស្សធម៌) ប្រឆាំងនឹងកម្មករ នៅសហករណ៍ និងការដ្ឋាន។

1117. **មាស មុត** និងសមាជិកផ្សេងទៀតនៃ JCE មានចេតនាចង់ឱ្យឧក្រិដ្ឋកម្មទាំងនេះនីមួយៗ និងឧក្រិដ្ឋ កម្មទាំងអស់ដែលត្រូវបានរៀបរាប់ក្នុងដីកាសន្និដ្ឋានស្ថាពរនេះ ត្រូវបានប្រព្រឹត្ត ស្របតាមសហ ឧក្រិដ្ឋកម្មរួមនេះ។

1118. **មាស មុត** ក្លាយជាសមាជិក JCE នេះ យ៉ាងហោចណាស់ ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ពេលដែលគាត់បានដឹកនាំកងពលលេខ ៣ នៃកងទ័ពបដិវត្តន៍កម្ពុជាចូលក្នុងទីក្រុងភ្នំពេញ។ **មាស មុត** នៅតែជាសមាជិក JCE រហូតដល់ត្រឹមយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ពោលគឺ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩។

1119. **មាស មុត** ធ្វើសកម្មភាពដោយពិគ្រោះយោបល់ជាមួយសមាជិក JCE ផ្សេងទៀត រួមទាំង ប៉ុល ពត, នួន ជា, ខៀវ សំផន, សុន សេន, សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ សមាជិកគណៈកម្មាធិការកណ្តាល សេនាធិការកងទ័ពបដិវត្តន៍កម្ពុជា លេខា និងអនុលេខាកងពលមជ្ឈិម និងកងវរសេនាធំឯករាជ្យ អ្នកនៅក្រោមបង្គាប់របស់ **មាស មុត** ក្នុងជួរថ្នាក់ដឹកនាំកងពល ១៦៤ និងនៅតំបន់ស្វយ័តកំពង់សោម រួមទាំង ធុច រិន ហៅ គ្រិន (អនុលេខាតំបន់កំពង់សោម និងប្រធានកំពង់ផែកំពង់សោម) និង ឡូញ (សមាជិកគណៈតំបន់កំពង់សោម)។

1120. នៅក្នុងកងពល ១៦៤ សមាជិក JCE រួមមាន ហ៊ីង ខឿន ហៅ ឌីម (អនុលេខាកងពល ១៦៤) ទឹម សេង (អនុលេខាកងពល ១៦៤ និងលេខាស្តីទីនៅចុងឆ្នាំ ១៩៧៨ លេខាកងវរសេនាធំ ១៤០ អនុលេខាកងវរសេនាធំ ១៤០) ជ័យ ហាន ហៅ ឆាន (អនុលេខា កងពល ១៦៤ និងសមាជិកគណៈកងពល ១៦៤) ម៉ុម ជឹម ហៅ យ៉ាន (សមាជិកគណៈកងពល ១៦៤ មេបញ្ជាការកងវរសេនាធំ ១៦៣) ម៉ែន ង៉ែត (អនុកងពល ១៦៤ សមាជិកគណៈកងពល ១៦៤ មេបញ្ជាការកងវរសេនាធំ ១៦១) ឡុង សារឿន ហៅ រឿន/រិន (អនុកងពល ១៦៤ មេបញ្ជាការកងវរសេនាធំ ១៤០ ប្រធានកំពង់ផែនកំពង់សោម) គឹម ញ៉ាន់ ហៅ ញ៉ាន់ (សមាជិកគណៈកងពល ១៦៤ មេបញ្ជាការកងវរសេនាធំ ១៦៣) ម៉ៅ សុន ហៅ សុន (មេបញ្ជាការកងវរសេនាធំ ១៦១) សុខ ភាព (មេបញ្ជាការកងវរសេនាធំ ១៦១ អនុប្រធានកំពង់ផែកំពង់សោម) អ៊ាក មៀញ (មេបញ្ជាការកងវរសេនាធំ ១៦២) សុន និង យាង (មេបញ្ជាការកងវរសេនាធំ ១៦២) សាន ស៊ាប ហៅ សំ (អនុលេខាកងវរសេនាធំ ១៦២) ស៊ិន ជន (មេបញ្ជាការកងវរសេនាធំ ១៦៣) ស្រស់ (មេបញ្ជាការរងកងវរសេនាធំ ១៦៣) ហាន (មេបញ្ជាការកងវរសេនាធំ ១៤០) និងមឿន, ឆាវ, ឈិន, សម្បត្តិ ហៅ បូ និងអ៊ួច (អនុ និងសមាជិកគណៈកងវរសេនាធំ ១៤០)។

1121. សមាជិក JCE ផ្សេងទៀតក្នុងកងពល ១៦៤ រួមមាន ស មឿន ហៅ មឿន (មេបញ្ជាការកងវរសេនាតូច ១៦៥ (៤៥០) និងប្រធានមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ) ឈុន លន់ ហៅ សំអាត ហៅ ស៊ុន (មេបញ្ជាការរងកងវរសេនាតូច ១៦៥ (៤៥)) ធាន និង ឯម ស៊ុំ (សមាជិកគណៈកងវរសេនា

តូច ១៦៥ (៤៥)) នន (ប្រធានសន្តិសុខកងវរសេនាតូច ១៦៥ (៤៥) ឈរជើងនៅទីបញ្ជាការកងពល និងប្រធានមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ) បុគ្គលិកកងពល ១៦៤ ទទួលបន្ទុកសហករណ៍ ការដ្ឋាន និងទីតាំងសម្លាប់ស្ថិតនៅតំបន់រាម និងស្ទឹងហាវ បុគ្គលិកកងពល ១៦៤ ទទួលបន្ទុកលើប្រតិបត្តិការមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ និងទឹកសាប និងមេបញ្ជាការ និងមេបញ្ជាការរងទាំងអស់នៃកងវរសេនាធំ និងកងវរសេនាតូចនៃកងពល ១៦៤ រួមមាន កងវរសេនាតូច ៦១១, ៦១២, ៦១៣, ៦២១, ៦២២, ៦២៣, ៦២៤, ៦៣១, ៦៣២, ១៤១, ១៤២, ១៤៣, ១៤៤ និងកងវរសេនាតូចឯករាជ្យ ១៦៥, ១៦៦, ១៦៧, ១៦៦៨, ១៦៩ និង ១៧០។

1122. កម្មាភិបាលមូលដ្ឋាន រួមទាំងប្រធានភូមិ និងសហករណ៍ អ្នកគ្រប់គ្រងការដ្ឋាន ទាហាន ឈ្លប និងកម្មាភិបាលក្រោមបញ្ជារបស់សមាជិក JCE ជាសមាជិក JCE ឬត្រូវបានសមាជិក JCE ប្រើប្រាស់ដើម្បីអនុវត្តផែនការឧក្រិដ្ឋ។

1123. **មាស មុត** បានចូលរួមចំណែកយ៉ាងសំខាន់ក្នុង JCE តាមរយៈអំពើដូចខាងក្រោម ដោយ៖

**ការចូលរួមចំណែកក្នុងការធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្មាំង**[4250]

(ក) **ញុះញង់ រៀបចំផែនការ បញ្ជា និងជួយនិងជំរុញ**ឲ្យមានការចាប់ខ្លួន ដាក់ក្នុងមន្ទីរឃុំឃាំង ធ្វើបាបដោយអមនុស្សធម៌ ធ្វើទារុណកម្ម បាត់ខ្លួន និងសម្លាប់មនុស្សដែលត្រូវបានចាត់ទុកជាខ្មាំងរបស់ ប.ក.ក ជាពិសេសនៅក្នុងកងពលមជ្ឈិម និងកងវរសេនាធំឯករាជ្យទាំងអស់នៃកងទ័ពបដិវត្តន៍កម្ពុជា កងពល ១៦៤ កងពល ១១៧ តំបន់ ៥០៥ ព្រមទាំងជនជាតិវៀតណាម ថៃ ពួកបស្ចិមប្រទេស និងអ្នកដែលត្រូវបានឃុំនៅមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ ទឹកសាប និង ស-២១ នៅភ្នំពេញ

(ខ) ប្រជុំជាមួយមេបញ្ជាការកងពលមជ្ឈិម និងកងវរសេនាធំឯករាជ្យនៃកងទ័ពបដិវត្តន៍កម្ពុជាផ្សេងទៀតជារៀងរាល់ខែ ដើម្បីទទួលការណែនាំពី សុន សេន អំពីគោលនយោបាយរបស់ ប.ក.ក ដើម្បីអប់រំ ធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្មាំងនៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា

---

4250 អាន ផ្នែកIII.ពា.ការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម – ការរួមចំណែកក្នុងការធ្វើទុក្ខបុកម្នេញ និងការសម្លាប់ខ្មាំង។

(គ) **រួមចំណែក**ក្នុងការពិភាក្សាជាមួយមេបញ្ជាការកងពលមជ្ឈិម និងកងវរសេនាធំឯករាជ្យនៃកងទ័ពបដិវត្តន៍កម្ពុជាផ្សេងទៀត ដែលនៅពេលពិភាក្សានោះ លក្ខណៈវិនិច្ឆ័យនៃខ្មាំង ប.ក.ក ត្រូវបានលើកឡើង និងបកស្រាយ

(ឃ) **សម្របសម្រួល**ជាមួយមេបញ្ជាការកងពលមជ្ឈិម និងកងវរសេនាធំឯករាជ្យនៃកងទ័ពបដិវត្តន៍កម្ពុជាផ្សេងទៀត ដើម្បីអនុវត្តផែនការធ្វើទុកបុកម្នេញ និងសម្លាប់ខ្មាំងនៅក្នុងអង្គភាពរៀងៗខ្លួនរបស់ពួកគេ

(ង) **ជំរុញ**មេបញ្ជាការកងពលមជ្ឈិម និងកងវរសេនាធំឯករាជ្យនៃកងទ័ពបដិវត្តន៍កម្ពុជាផ្សេងទៀត ឲ្យធ្វើទុកបុកម្នេញ និងសម្លាប់ខ្មាំងនៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា

(ច) **បញ្ជា**ឲ្យចាប់ និងបញ្ជូនខ្មាំងដែលអ្នកក្រោមបង្គាប់របស់គាត់ចាប់បាននៅក្នុងតំបន់ដែលគាត់កាន់កាប់ទៅមន្ទីរសន្តិសុខ ស-២១ ដើម្បីឃុំឃាំង សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់ និង

(ឆ) **រាយការណ៍**ជាប្រចាំទៅ សុន សេន និងសមាជិកគណៈអចិន្ត្រៃយ៍ផ្សេងទៀតអំពីស្ថានភាពនៃការអនុវត្តគោលនយោបាយ ប.ក.ក ស្តីពីខ្មាំង នៅកងពល ១៦៤ និងតំបន់កំពង់សោម តាមលិខិតទំនាក់ទំនងជាលាយលក្ខណ៍អក្សរ និងការចូលរួមប្រជុំ។

<u>នៅតំបន់ ១៦៤</u>[4251]

(ក) **សហការ**ជិតស្និទ្ធជាមួយ សុន សេន និងអ្នកក្រោមបង្គាប់របស់ **មាស មុត** ដើម្បីកំណត់អត្តសញ្ញាណ ស្វែងរក ចាប់ខ្លួន ធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្មាំងក្នុងកងពល ១៦៤ ឬខ្មាំងដែលមាននៅតំបន់ស្វយ័តកំពង់សោម និងតំបន់ផ្សេងទៀតក្រោមការគ្រប់គ្រងរបស់ **មាស មុត**

(ខ) **អនុវត្ត**ប្រព័ន្ធមួយដើម្បីកំណត់អត្តសញ្ញាណខ្មាំងនៅក្នុងកងពល ១៦៤ ដើម្បីចាប់ ឃុំឃាំង ដាក់ឲ្យធ្វើជាទាសករ និងសម្លាប់

(គ) **បញ្ជា**ឲ្យមានការកត់ត្រាប្រវត្តិរូបរបស់បុគ្គលិកកងពល ១៦៤ ដើម្បីវាយតម្លៃរកមុខសញ្ញាខ្មាំង

---

[4251] អាន ផ្នែកIII.ព.ការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម – ការរួមចំណែកក្នុងការធ្វើទុក្ខបុកម្នេញ និងការសម្លាប់ខ្មាំង– កងទ័ពបដិវត្តកម្ពុជា– ខ) កងពល១៦៤។

(ឃ) **បង្កើត**គណៈកម្មាធិការត្រួតពិនិត្យមួយនៅក្នុងកងពល ១៦៤ ដើម្បីពិនិត្យប្រវត្តិរូបរបស់បុគ្គលិក និងស៊ើបអង្កេតលើសុពលភាពនៃប្រវត្តិរូបទាំងនោះ

(ង) **តាមដាន**ជាបន្តនូវសកម្មភាពរបស់សមាជិកកងពល ១៦៤ ទាំងអស់ ដើម្បីស្វែងរកអាកប្បកិរិយាខ្មាំង

(ច) **ពិនិត្យមើល**ចម្លើយសារភាព ស-២១ ជាមួយ សុន សេន ដើម្បីកំណត់ថាតើបុគ្គលដែលត្រូវបានលើកឡើងក្នុងចម្លើយសារភាពទាំងនោះ ជាជនក្បត់ និងដើម្បីចាត់វិធានការ ដោយធ្វើទុក្ខបុកម្នេញ ឬសម្លាប់បុគ្គលដែលត្រូវបានកំណត់អត្តសញ្ញាណទាំងនោះ

(ឆ) **ដឹកនាំ**វគ្គហ្វឹកហ្វឺន ដែលនៅក្នុងនោះ កម្មាភិបាល ប.ក.ក ត្រូវបានណែនាំអំពីគោលនយោបាយ ប.ក.ក ស្តីពីខ្មាំង ពាក់ព័ន្ធនឹងការបោសសម្អាតខ្មាំងផ្ទៃក្នុងកងទ័ពបដិវត្តន៍កម្ពុជា ភាពចាំបាច់ដែលត្រូវស្វែងរកខ្មាំងនៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា និងរាយការណ៍ពីសកម្មភាពសង្ស័យ និងការក្រើនរំឭកដល់កម្មាភិបាល ប.ក.ក ថាប្រសិនបើពួកគេមិនអាចធ្វើបាន ពួកគេនឹងត្រូវចាប់ និងសម្លាប់

(ជ) **ដឹកនាំ**ការប្រជុំដែលនៅពេលនោះ ចម្លើយសារភាពរបស់អ្នកនៅក្រោមបង្គាប់យកពី ស-២១ ដែលបានកំណត់អត្តសញ្ញាណបុគ្គលផ្សេងទៀតក្នុងកងពល ១៦៤ ដែលត្រូវបានចាត់ទុកជាខ្មាំង ត្រូវបានអានឱ្យបុគ្គលិកកងពល ១៦៤ ស្តាប់ ដើម្បីជំរុញឱ្យធ្វើការស្រាវជ្រាវរកខ្មាំងក្នុងកងពលបន្ថែមទៀត និងប្រើជាការក្រើនរំឭកដល់អ្នកក្រោមបង្គាប់អំពីផលវិបាកនៃការមានអាកប្បកិរិយាខ្មាំង

(ឈ) **បញ្ជា**ឱ្យដកហូតអាវុធ ឃុំឃាំង និងដាក់ឱ្យក្លាយជាទាសករមនុស្សរាប់ពាន់នាក់ពីកងពល ១៦៤ និងសម្លាប់ទាហានទាំងនោះរាប់រយនាក់

(ញ) **បញ្ជា**ឱ្យបញ្ជូនអ្នកក្រោមបង្គាប់ថ្នាក់ទាបក្នុងកងទ័ពបដិវត្តន៍កម្ពុជា ដែលត្រូវបានចាត់ទុកថាជាខ្មាំង ទៅមន្ទីរសន្តិសុខ និងការដ្ឋាននៅតំបន់កំពង់សោមដែលដំណើរការដោយអ្នកក្រោមបង្គាប់ផ្សេងទៀត ក្រោមការគ្រប់គ្រងរបស់ខ្លួន

(ដ) **បញ្ជា**ឱ្យចាប់ខ្លួនបុគ្គលិកកងពល ១៦៤ រួមទាំងអ្នកដែលពីមុនមកពីភូមិភាគបូព៌ា និងក្រោយមកត្រូវបានជឿថាជាខ្មាំង និង

(ឋ) **បញ្ជា**ឲ្យចាប់ និងបញ្ជូនបុគ្គលិកកងពល ១៦៤ ចំនួន ៦៧ នាក់ រួមមាន អនុរបស់ **មាស មុត** ឈ្មោះ ហ៊ីង ឌឿន ហៅ ឌឹម និងសមាជិកគណៈកងពល ១៦៤ ឈ្មោះ ជ័យ ហាន ហៅ ឆាន ដែលត្រូវបានចាត់ទុកជាខ្មាំង ទៅ ស-២១ ដើម្បីឃុំឃាំងក្នុងលក្ខខណ្ឌអមនុស្សធម៌ ធ្វើទារុណកម្ម និងសម្លាប់។

<u>នៅក្នុងកងពល ១១៧ និងតំបន់ ៥០៥</u>[4252]

(ក) **ដឹកនាំ និងបញ្ជា**ឲ្យបោសសម្អាតមេបញ្ជាការ និងកម្មាភិបាលកងពល ១១៧ និងតំបន់ ៥០៥ ដែលត្រូវបានចាត់ទុកថាជាខ្មាំង នៅចុងឆ្នាំ ១៩៧៨ និងបញ្ជូនពួកគេទៅ ស-២១ ដើម្បីឃុំឃាំងក្នុងលក្ខខណ្ឌអមនុស្សធម៌ ធ្វើទារុណកម្ម និងសម្លាប់

(ខ) **គ្រប់គ្រង**លើការបញ្ជូនមេបញ្ជាការ និងមេដឹកនាំកងពល ១១៧ និងតំបន់ ៥០៥ មួយចំនួនទៅ ស-២១ ដោយគាត់មានវត្តមានផ្ទាល់នៅអាកាសយានដ្ឋានក្រចេះ នៅពេលហេតុការណ៍នោះកើតឡើង

(គ) **បញ្ជា**ឲ្យសម្លាប់ ម៉ៅ អឿន សមាជិកគណៈតំបន់ ៥០៥ ទទួលបន្ទុកកិច្ចការយោធា

(ឃ) **ជំនួស**កម្មាភិបាលកងពល ១១៧ និងតំបន់ ៥០៥ ដែលត្រូវបានបោសសម្អាត ដោយអ្នកដែលខ្លួនបានជ្រើសរើស

(ង) **ដឹកនាំ**ការប្រជុំមួយនៅក្រចេះ ដែលនៅពេលនោះ គាត់បានធ្វើការណែនាំដល់អ្នកក្រោមបង្គាប់នៃកម្មាភិបាលថ្នាក់ខ្ពស់មកពីកងពល ១១៧ និងតំបន់ ៥០៥ ថា ថ្នាក់លើរបស់ពួកគេត្រូវបានបញ្ជូនទៅ ស-២១ ពីព្រោះពួកគេជាជនក្បត់ ដោយសារពួកគេមិនដាច់ខាត នៅពេលប្រយុទ្ធជាមួយវៀតណាម

(ច) **បញ្ជា**ឲ្យសម្លាប់កងកម្លាំងនៃកងទ័ពបដិវត្តន៍កម្ពុជាដែលដកថយ ពេលវៀតណាមរុលចូលមកក្នុងតំបន់ ៥០៥ និង

[4252] អាន ផ្នែកIII.៣. ការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម – ការរួមចំណែកក្នុងការធ្វើទុក្ខបុកម្នេញ និងការសម្លាប់ខ្មាំង – កងទ័ពបដិវត្តកម្ពុជា –គ)កងពល១១៧ និងតំបន់៥០៥។

(ឆ) **បន្ត**បោសសម្អាតកម្មាភិបាលថ្នាក់ទាបនៃកងពល ១១៧ និងតំបន់ ៥០៥ និងជនស៊ីវិលក្នុងតំបន់ ៥០៥។

<u>ជនជាតិវៀតណាម</u>[4253]

(ក) **បញ្ជា និងជំរុញ**ឲ្យមានការសម្លាប់ជាប្រព័ន្ធទៅលើជនជាតិវៀតណាម ដែលបានចាប់ខ្លួន

(ខ) **បញ្ចូលមនោគមវិជ្ជា**ទាហានថ្នាក់ទាបអំពីគោលនយោបាយ ប.ក.ក ពាក់ព័ន្ធនឹងខ្មាំងខាងក្រៅ រួមទាំងវៀតណាម ដោយប្រើភាសាដុតបញ្ឆេះដើម្បីញុះញង់ឲ្យស្អប់ខ្ពើមជនជាតិវៀតណាម

(គ) **អនុវត្ត**វគ្គហ្វឹកហ្វឺនដែលនៅពេលនោះ កម្មាភិបាលកងពល ១៦៤ ត្រូវបានណែនាំឲ្យសម្លាប់វៀតណាម រៀងរាល់ពេលដែលពួកគេត្រូវបានចាប់ និងណែនាំអ្នកចូលរួមប្រជុំឲ្យផ្សព្វផ្សាយការណែនាំទៅដល់អ្នកក្រោមបង្គាប់របស់ពួកគេបន្តទៀត

(ឃ) **បញ្ជា**អ្នកក្រោមបង្គាប់របស់ខ្លួនឲ្យចាប់ បញ្ជូន ឬសម្លាប់នៅនឹងកន្លែងជនជាតិវៀតណាម ដែលត្រូវបានកំណត់ទីតាំង នៅក្នុងតំបន់ដែលខ្លួនកាន់កាប់ នៅសមុទ្រ ឬនៅលើកោះ

(ង) **តាមដាន**យ៉ាងម៉ត់ចត់លើការចាប់ជនជាតិវៀតណាមនៅសមុទ្រ ដោយអ្នកនៅក្រោមបង្គាប់របស់ខ្លួន ដោយណែនាំពួកគេឲ្យរាយការណ៍រៀងរាល់ពេលមានការចាប់ជនជាតិវៀតណាម

(ច) **គាំទ្រ**ការសម្រេចចិត្តក្នុងពេលប្រជុំមេបញ្ជាការកងពលមជ្ឈិម និងកងវរសេនាធំឯករាជ្យរបស់សេនាធិកា នៅខែ តុលា ឆ្នាំ ១៩៧៦ ដើម្បីសម្លាប់ជនជាតិវៀតណាម និងក្រុមផ្សេងទៀត

(ឆ) **រាយការណ៍**ទៅគណៈអចិន្ត្រៃយ៍តាមរយៈមន្ទីរ ៨៧០ ពីគោលបំណងរបស់ខ្លួនក្នុងការសម្លាប់ជនជាតិវៀតណាមទាំងអស់ នៅក្នុងតំបន់ដែលខ្លួនគ្រប់គ្រង

(ជ) **បញ្ជា**ឲ្យសម្លាប់ជនភៀសខ្លួនវៀតណាម ដែលត្រូវបានចាប់ចំនួន ១០ នាក់ នៅខែ មេសា ឬខែ ឧសភា ឆ្នាំ ១៩៧៥

(ឈ) **បញ្ជា**ឲ្យសម្លាប់ទាហានវៀតណាម ព្រមទាំងជនភៀសខ្លួន អ្នកនេសាទ និងខ្មែរក្រោម

---

4253 អាន ផ្នែកIII.៣.ការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម –ការរួមចំណែកក្នុងការធ្វើទុក្ខបុកម្នេញ និងការសម្លាប់ខ្មាំង–ជនជាតិវៀតណាម។

(ញ) **បញ្ជា**អ្នកនៅក្រោមបង្គាប់របស់ខ្លួនឲ្យបញ្ជូនជនជាតិវៀតណាម ដែលត្រូវបានចាប់ទៅឲ្យគាត់នៅកំពង់សោម ដើម្បីសម្លាប់នៅចម្ការទុរេន នៅដើមរបបកម្ពុជាប្រជាធិបតេយ្យ

(ដ) **បញ្ជា**អ្នកនៅក្រោមបង្គាប់របស់គាត់ឲ្យសម្លាប់ជនជាតិវៀតណាម នៅលើកោះដែលពួកគេត្រូវបានចាប់ នៅចុងរបបកម្ពុជាប្រជាធិបតេយ្យ

(ឋ) **រាយការណ៍**ទៅគណៈអចិន្ត្រៃយ៍អំពីភាពជោគជ័យរបស់គាត់ ក្នុងការធ្វើទុក្ខបុកម្នេញ និងសម្លាប់ជនជាតិវៀតណាម និង

(ឌ) **បញ្ជា**ឲ្យចាប់ និងបញ្ជូនជនជាតិវៀតណាម ១៩៤ នាក់ដែលត្រូវបានចាត់ទុកថាជាខ្មាំង ទៅ ស-២១ ដើម្បីឃុំឃាំងក្នុងលក្ខខណ្ឌអមនុស្សធម៌ ធ្វើទារុណកម្ម និងសម្លាប់។

<u>ជនជាតិថៃ និងពួកបស្ចិមប្រទេស</u>[4254]

(ក) **បញ្ជា**ឲ្យសម្លាប់ពលរដ្ឋថៃរាប់រយនាក់ នៅក្នុងតំបន់ដែលខ្លួនទទួលខុសត្រូវ

(ខ) **បញ្ជា**ឲ្យចាប់ទូកបរទេស ពេលចូលក្នុងដែនទឹក ជាបន្តទៀត

(គ) **រាយការណ៍**ទៅ សុន សេន អំពីការចាប់ និងសួរចម្លើយជនជាតិថៃ

(ឃ) **បញ្ជា**ឲ្យសម្លាប់ជនជាតិនៅថៃចម្ការទុរេន ១

(ង) **បញ្ជា**ឲ្យចាប់ និងបញ្ជូនជនជាតិថៃ ៥៨ នាក់ រួមទាំង ជនជាតិថៃ ៨ នាក់ពីមន្ទីរសន្តិសុខទឹកសាប ដែលត្រូវបានចាត់ទុកជាខ្មាំង ទៅ ស-២១ ដើម្បីឃុំឃាំងក្នុងលក្ខខណ្ឌអមនុស្សធម៌ ធ្វើទារុណកម្ម និងសម្លាប់

(ច) **បញ្ជា**ឲ្យឃុំ និងសម្លាប់ទាហានអាមេរិកពីរនាក់ នៅលើដីគោកនៅកំពង់សោម នៅមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ និង

---

[4254] អាន ផ្នែកIII.៣.ការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម –ការរួមចំណែកក្នុងការធ្វើទុក្ខបុកម្នេញ និងការសម្លាប់ខ្មាំង–ជនជាតិថៃ និងពួកបស្ចិមប្រទេស។

(ឆ) **បញ្ជា**ឲ្យចាប់ និងបញ្ជូនពួកបរទេសប្រាំបីនាក់ដែលត្រូវបានចាប់ ទៅ ស-២១ ដើម្បីឃុំ ធ្វើទារុណកម្ម សួរចម្លើយ និងសម្លាប់។

<u>ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខវត្តឥន្ទញាណ</u>[4255]

(ក) **បង្កើត និងគ្រប់គ្រង** តាមរយៈការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់អ្នកនៅក្រោមបង្គាប់របស់គាត់ នូវមន្ទីរសន្តិសុខវត្តឥន្ទញាណ ដែលទាហានកងពល ១៦៤ និងប្រជាជនស៊ីវិល រួមទាំងស្ត្រី និងកុមារ ត្រូវបានឃុំឃាំងក្នុងលក្ខខណ្ឌដ៏អមនុស្សធម៌៖ ពួកគេត្រូវបានបង្អត់អាហារ ធ្វើទារុណកម្ម ជាប់ខ្នោះទាំងថ្ងៃទាំងយប់ និងបង្ខំឲ្យធ្វើចម្ការ។ ពួកគេជាច្រើននាក់ត្រូវបានសម្លាប់ចោល ពីព្រោះតែគេសង្ស័យថាពួកគេក្បត់

(ខ) **ញុះញង់ រៀបចំផែនការ បញ្ជា និងជួយនិងជំរុញ**ឲ្យមានការចាប់ ការឃុំឃាំង ការធ្វើបាបអមនុស្សធម៌ ការធ្វើទារុណកម្ម ការបាត់ខ្លួន និងការសម្លាប់បុគ្គលទាំងនេះនៅវត្តឥន្ទញាណ តាមរយៈការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់គាត់ទៅលើអ្នកក្រោមបង្គាប់ ដែលដំណើរការមន្ទីរសន្តិសុខនេះ និងចេតនារបស់គាត់ចង់បោសសម្អាតខ្មាំងទាំងក្នុងទាំងក្រៅកងទ័ពបដិវត្តន៍កម្ពុជា ក៏ដូចជាការដឹងឮរបស់គាត់អំពីលក្ខខណ្ឌអមនុស្សធម៌ ដែលមាននៅមន្ទីរសន្តិសុខនោះ

(គ) **សួរចម្លើយ** និងកត់ត្រាចម្លើយរបស់អ្នកទោស ហើយបន្ទាប់មក បញ្ជូនពួកគេចេញទៅ និង

(ឃ) **បញ្ជា**ឲ្យឃុំ និងសម្លាប់ទាហានអាមេរិកពីរនាក់ដែលត្រូវបានចាប់នៅលើកោះតាង និងបញ្ជូនទៅវត្តឥន្ទញាណនៅឆ្នាំ ១៩៧៥។

<u>ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខទឹកសាប</u>[4256]

(ក) **បង្កើត និងគ្រប់គ្រង** តាមរយៈការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់អ្នកនៅក្រោមបង្គាប់របស់គាត់ នូវមន្ទីរសន្តិសុខទឹកសាប ដែលទាហានកងពល ១៦៤ ខ្មែរក្រោម និងប្រជា

[4255] អាន ផ្នែកIII.៣.ការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម –ការរួមចំណែកក្នុងការធ្វើទុក្ខបុកម្នេញ និងការសម្លាប់ខ្មាំង–មន្ទីរសន្តិសុខកងពល១៦៤–ក) មន្ទីរសន្តិសុខវត្តឥន្ទ្រញាណ។

[4256] អាន ផ្នែកIII.៣.ការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម –រួមចំណែកក្នុងការធ្វើទុក្ខបុកម្នេញ និងការសម្លាប់ខ្មាំង–មន្ទីរសន្តិសុខកងពល១៦៤–ខ) មន្ទីរសន្តិសុខទឹកសាប។

ជន ស៊ីវិលដទៃទៀត ត្រូវបានឃុំឃាំង ពីព្រោះពួកគេបានប្រព្រឹត្ត "កំហុស" និងត្រូវបានដាក់ខ្នោះ សួរចម្លើយ ធ្វើទារុណកម្ម និងហូបអាហារមិនសមស្រប និងត្រូវបានបង្ខំឲ្យធ្វើការ។ អ្នកទោសជាច្រើនត្រូវបានសម្លាប់នៅចម្ការទុរេន និងសាវម៉ាវនៅក្នុងតំបន់នោះ

(ខ) **ញុះញង់ រៀបចំផែនការ បញ្ជា និងជួយនិងជំរុញ**ឲ្យមានការចាប់ ការឃុំឃាំង ការធ្វើបាបអមនុស្សធម៌ ការធ្វើទារុណកម្ម ការបាត់ខ្លួន និងការសម្លាប់បុគ្គលទាំងនេះនៅមន្ទីរសន្តិសុខទឹកសាប តាមរយៈការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់គាត់ទៅលើអ្នកក្រោមបង្គាប់ដែលដំណើរការមន្ទីរសន្តិសុខនេះ និងចេតនារបស់គាត់ចង់បោសសម្អាតខ្មាំងទាំងក្នុងទាំងក្រៅកងទ័ពបដិវត្តន៍កម្ពុជា ក៏ដូចជាការដឹងឮរបស់គាត់អំពីលក្ខខណ្ឌអមនុស្សធម៌ដែលមាននៅមន្ទីរសន្តិសុខនោះ

(គ) **រក្សា**ទំនាក់ទំនងជាមួយអ្នកក្រោមបង្គាប់របស់ខ្លួន នៅមន្ទីរសន្តិសុខ តាមរយៈការប្រជុំ និងការរាយការណ៍ និងទស្សនកិច្ចនៅមន្ទីរសន្តិសុខ និង

(ឃ) **បញ្ជា**ឲ្យឃុំខ្លួន និងបញ្ជូនអ្នកទោស ២២ នាក់ពីទឹកសាបទៅ ស-២១ ដើម្បីឃុំឃាំងក្នុងលក្ខខណ្ឌអមនុស្សធម៌ ធ្វើទារុណកម្ម និងសម្លាប់។

<u>ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខ ស-២១</u>[4257]

(ក) **ញុះញង់ រៀបចំផែនការ បញ្ជា និងជួយនិងជំរុញ**ឲ្យមានការចាប់ ការបញ្ជូន ការឃុំឃាំងក្នុងលក្ខខណ្ឌអមនុស្សធម៌ ការធ្វើទារុណកម្ម និងការសម្លាប់មនុស្ស ៧០៧ នាក់ ដែលត្រូវបានចាត់ទុកថាជាខ្មាំង នៅ ស-២១ តាមរយៈការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់ខ្លួនទៅលើអ្នកក្រោមបង្គាប់ ទំនាក់ទំនងការងាររបស់គាត់ជាមួយកម្មាភិបាលពី ស-២១ ចេតនារបស់គាត់ចង់បោសសម្អាតខ្មាំងទាំងក្នុងទាំងក្រៅកងទ័ពបដិវត្តន៍កម្ពុជា ក៏ដូចជាការដឹងឮរបស់គាត់អំពីគោលបំណងឧក្រិដ្ឋនរបស់ ស-២១

(ខ) **សហការ**ជាមួយ សុន សេន និង នួន ជា ក្នុងការធ្វើសេចក្តីសម្រេចថា តើអ្នកណាត្រូវបញ្ជូន ស-២១ ដើម្បីឃុំឃាំង ធ្វើទារុណកម្ម សួរចម្លើយ និងសម្លាប់

---

[4257] អាន ផ្នែកIII.ព.ការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម –រួមចំណែកក្នុងការធ្វើទុក្ខបុកម្នេញ និងការសម្លាប់ខ្មាំង–មន្ទីរសន្តិសុខ ស-២១។

(គ) **ចូលរួម**ប្រជុំ ដែលនៅពេលនោះ គាត់បានទទួលព័ត៌មានពីតំណាង ស-២១ អំពីការប្រព្រឹត្តិទៅនៃ ស-២១ និង

(ឃ) **ប្រើប្រាស់**ចម្លើយសារភាពដែលគាត់ទទួលបានពី ស-២១ ដើម្បីជំរុញ និងលើកទឹកចិត្តឲ្យធ្វើការស្រាវជ្រាវរកខ្មាំងនៅក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជា និងក្រើនរំឭកកងទ័ពរបស់គាត់អំពីផលវិបាកនៃការចូលរួមក្នុងសកម្មភាពខ្មាំង។

<u>នៅគ្រប់ទីកន្លែងទាំងអស់</u>[4258]

(ក) **ខកខានក្នុងការទប់ស្កាត់**អ្នកនៅក្រោមបង្គាប់របស់គាត់នៅក្នុងកងពល ១៦៤ និង ១១៧ ដែលបានប្រព្រឹត្តដោយផ្ទាល់នូវការចាប់ចង ការដាក់ឃុំឃាំង ការធ្វើបាបអមនុស្សធម៌ ការបាត់ខ្លួន និងការសម្លាប់មនុស្សដែលត្រូវបានចាត់ទុកជាខ្មាំងរបស់ ប.ក.ក កុំឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ ទោះគាត់បានដឹងថាឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្ត និងទោះបីជាការគ្រប់គ្រង់របស់ខ្លួនទៅលើអ្នកនៅក្រោមបង្គាប់មានប្រសិទ្ធភាពក៏ដោយ និង

(ខ) **ខកខានក្នុងការដាក់ទណ្ឌកម្ម**អ្នកនៅក្រោមបង្គាប់របស់ខ្លួននៅក្នុងពល ១៦៤ និង ១១៧ ដែលបានប្រព្រឹត្តដោយផ្ទាល់នូវការចាប់ចង ការដាក់ឃុំឃាំង ការធ្វើបាបអមនុស្សធម៌ ការបាត់ខ្លួន និងការសម្លាប់មនុស្សដែលត្រូវបានចាត់ទុកជាខ្មាំងរបស់ ប.ក.ក ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម
ទាំងនេះ ទោះបានដឹងថាឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្ត និងទោះបីជាការគ្រប់គ្រង់របស់ខ្លួនទៅលើអ្នកនៅក្រោមបង្គាប់ មានប្រសិទ្ធភាពក៏ដោយ។

**ការរួមចំណែកក្នុងការដាក់ឲ្យធ្វើជាទាសករនៅការដ្ឋាន**[4259]

(ក) **ចូលរួម**ក្នុងការប្រជុំសេនាធិការជាមួយមេបញ្ជាការកងពលមជ្ឈិម និងកងវរសេនាធំឯករាជ្យនៃកងទ័ពបដិវត្តន៍កម្ពុជា ដែលនៅពេលនោះ សុន សេន បានពិភាក្សាអំពីគោលនយោបាយ

---

4258 អាន ផ្នែកIII.៣.ការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម –រួមចំណែកក្នុងការធ្វើទុក្ខបុកម្នេញ និងការសម្លាប់ខ្មាំង។

4259 អាន ផ្នែកIII.៣.ការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម –រួមចំណែកក្នុងការធ្វើទាសកម្មនៅឯការដ្ឋាន

និងគោលដៅរបស់ ប.ក.ក ស្តីពីការផលិត និងជាពិសេស គោលដៅក្នុងការបង្កបង្កើនផលដំណាំ និងហេដ្ឋារចនាសម្ព័ន្ធឲ្យបានកាន់តែឆាប់រហ័ស

(ខ) **គាំទ្រ** "ផែនការថ្មីរបស់អង្គការ" ជាសាធារណៈ ពាក់ព័ន្ធនឹងការផលិត នៅទូទាំងតំបន់កំពង់សោម

(គ) **អនុវត្ត**គោលនយោបាយស្តីពីការផលិត និងហេដ្ឋារចនាសម្ព័ន្ធ និងគោលដៅផ្សេងៗនៅតំបន់កំពង់សោមដែលមិនអាចសម្រេចបាន ដោយដឹងថា ការងារនេះអាចសម្រេចបាន តែតាមរយៈការដាក់ឲ្យធ្វើជាទាសករ និងការធ្វើបាបអមនុស្សធម៌ទៅលើប្រជាជនក្រោមការគ្រប់គ្រងរបស់ខ្លួនប៉ុណ្ណោះ

(ឃ) **រាយការណ៍**ទៅមជ្ឈិមអំពីលក្ខខណ្ឌការងារពិបាកនៅតាមការដ្ឋាននានា រួមទាំងអាហារមិនគ្រប់គ្រាន់ ដែលធ្វើឲ្យកម្មករឈឺ និងស្លាប់ក្នុងទ្រង់ទ្រាយធំ នៅតាមការដ្ឋាន និង

(ង) **រាយការណ៍**ទៅមជ្ឈិមអំពីការវិវត្តន៍នៃកងពល តាមរយៈការប្រជុំ សារទូរលេខ និងសេចក្តីរាយការណ៍ប្រចាំខែ។

<u>ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនៅការដ្ឋានតំបន់រាម</u>[4260]

(ក) **បង្កើត និងគ្រប់គ្រង** តាមរយៈការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់អ្នកនៅក្រោមបង្គាប់របស់គាត់នៅកងវរសេនាធំ ១៦៣ នូវការដ្ឋានតំបន់រាម ដែលទាហានរំសាយនៃកងពល ១៦៤ និងប្រជាជនស៊ីវិល ត្រូវសាងសង់ទំនប់ ធ្វើការនៅការដ្ឋានវាយថ្ម ធ្វើចម្ការ និងធ្វើការងារផ្សេងៗទៀតនៅវាលស្រែ ដែលនៅទីនោះ ពួកគេពុំបានទទួលអាហារគ្រប់គ្រាន់ ស្លាប់ដោយការអត់ឃ្លាន ឬត្រូវបានសម្លាប់នៅទីតាំងសម្លាប់ក្នុងមូលដ្ឋាន ដែលនៅទីនោះជនជាតិថៃ និងវៀតណាមក៏ត្រូវបានសម្លាប់ផងដែរ

(ខ) **ញុះញង់ ធ្វើផែនការ បញ្ជា និងជួយនិងជំរុញ**ឲ្យមានការចាប់ខ្លួន ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើឲ្យទៅជាទាសករ ការប្រព្រឹត្តិអមនុស្សធម៌ ការធ្វើទារុណកម្ម ការបាត់ខ្លួន និងការ

---

[4260] អាន ផ្នែកការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម – រួមចំណែកក្នុងការធ្វើទាសកម្មនៅឯការដ្ឋាន –ការដ្ឋានរាម។

សម្លាប់បុគ្គលនានា នៅការដ្ឋានក្នុងតំបន់រាម ដោយសារតែការគ្រប់គ្រងដ៏មានប្រសិទ្ធភាពរបស់គាត់លើអ្នកនៅក្រោមបង្គាប់របស់គាត់ ដែលបានប្រតិបត្តិការនៅតាមការដ្ឋានទាំងនេះ ចេតនារបស់គាត់ក្នុងការបោសសម្អាតខ្មាំងទាំងនៅក្នុង និងនៅក្រៅកងទ័ពបដិវត្តន៍កម្ពុជា និងក្នុងការសម្រេចបានទិសដៅផលិតកម្មដែលមិនអាចសម្រេចទៅបាន ព្រមទាំងការដឹងឮរបស់គាត់ពីលក្ខខណ្ឌអមនុស្សធម៌ ដែលកើតមាននៅការដ្ឋានទាំងនេះ

(គ) **បញ្ជា**ឲ្យចាប់ខ្លួនបុគ្គលជាក់លាក់ ដែលត្រូវបានលាបពណ៌ថាជាខ្មាំងនៅការដ្ឋាន និង

(ឃ) **ខកខាន**មិនបានកាត់បន្ថយលក្ខខណ្ឌអនុមនុស្សធម៌នៅការដ្ឋាន បន្ទាប់ពីទទួលបានរបាយការណ៍ពីអ្នកនៅក្រោមបង្គាប់របស់គាត់អំពីការស្លាប់ ដែលកើតមានឡើង ដោយសារលក្ខខណ្ឌទាំងនោះ។

## ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលកើតមាននៅការដ្ឋានស្ទឹងហាវ[4261]

(ក) **បង្កើត និងគ្រប់គ្រង**តាមរយៈការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើអ្នកនៅក្រោមបង្គាប់របស់គាត់ ការដ្ឋាននានានៅស្ទឹងហាវ ជាទីដែលទាហានរំសាយត្រូវបានតម្រូវឲ្យធ្វើការងារយ៉ាងលំបាកនៅការដ្ឋានវាយបំបែកថ្ម កំពង់ផែ និងផ្លូវ ព្រមទាំងដាំដំណាំចម្រុះផ្សេងៗ ដែលក្នុងអំឡុងពេលនោះ ពលករភាគច្រើនត្រូវបានចាប់ខ្លួន ធ្វើទារុណកម្ម បាត់ខ្លួន និងត្រូវបានសម្លាប់ជាញឹកញាប់ ដោយសារឋានៈជាខ្មាំងរបស់ពួកគេ និង

(ខ) **ញុះញង់ ធ្វើផែនការ បញ្ជា និងជួយនិងជំរុញ**ឲ្យមានការចាប់ខ្លួន ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើឲ្យទៅជាទាសករ ការប្រព្រឹត្តិអមនុស្សធម៌ ការធ្វើទារុណកម្ម ការបាត់ខ្លួន និងការសម្លាប់បុគ្គលនានានៅការដ្ឋានក្នុងតំបន់រាម ដោយសារតែការគ្រប់គ្រងដ៏មានប្រសិទ្ធភាពរបស់គាត់លើអ្នកនៅក្រោមបង្គាប់របស់គាត់ ដែលបានប្រតិបត្តិការនៅតាមការដ្ឋានទាំងនេះ ចេតនារបស់គាត់ក្នុងការបោសសម្អាតខ្មាំងទាំងនៅក្នុង និងនៅក្រៅកងទ័ពបដិវត្តន៍កម្ពុជា

---

[4261] អាន ផ្នែកIII.ពា.ការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម – រួមចំណែកក្នុងការធ្វើទាសកម្មនៅឯការដ្ឋាន–ការដ្ឋានស្ទឹងហាវ។

និងក្នុងការសម្រេចបានទិសដៅផលិតកម្មដែលមិនអាចសម្រេចទៅបាន ព្រមទាំងការដឹងឮរបស់គាត់ពីលក្ខខណ្ឌអមនុស្សធម៌ ដែលកើតមាននៅការដ្ឋានទាំងនេះ។

<u>នៅគ្រប់ទីកន្លែងទាំងអស់</u>[4262]

(ក) **ខកខានមិនបាន**ទប់ស្កាត់អ្នកនៅក្រោមបង្គាប់របស់គាត់នៅក្នុងកងពលធំលេខ ១៦៤ ដែលកំពុងប្រព្រឹត្តដោយផ្ទាល់នូវអំពើនៃការធ្វើឲ្យទៅជាទាសករ ការធ្វើទារុណកម្ម ការបាត់ខ្លួន ការធ្វើទុក្ខបុកម្នេញ ការប្រព្រឹត្តិអមនុស្សធម៌ និងការសម្លាប់បុគ្គលទាំងឡាយដែលត្រូវបានចាត់ទុកថាជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលកំពុងប្រព្រឹត្ត និងរៀបនឹងប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ បើទោះជាបានដឹងថា ឧក្រិដ្ឋកម្មទាំងនេះបានកំពុងត្រូវបានប្រព្រឹត្ត និងបើទោះជាមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពរបស់គាត់លើអ្នកនៅក្រោមបង្គាប់ទាំងនេះក៏ដោយ

(ខ) **ខកខានមិនបាន**ដាក់ទណ្ឌកម្មដល់អ្នកនៅក្រោមបង្គាប់របស់គាត់ ក្នុងកងពលធំលេខ ១៦៤ ដែលបានប្រព្រឹត្តដោយផ្ទាល់នូវអំពើនៃការធ្វើឲ្យទៅជាទាសករ ការធ្វើទារុណកម្ម ការបាត់ខ្លួន ការធ្វើទុក្ខបុកម្នេញ ការប្រព្រឹត្តអមនុស្សធម៌ និងការសម្លាប់បុគ្គលទាំងឡាយដែលត្រូវបានចាត់ទុកថាជាខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ បើទោះជាបានដឹងថា ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្ត និងបើទោះជាមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពរបស់គាត់លើអ្នកនៅក្រោមបង្គាប់ទាំងនេះក៏ដោយ។

**ការចូលរួមចំណែកចំពោះការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ**[4263]

(ក) **បង្កើត បញ្ជា សម្របសម្រួល និងគ្រប់គ្រង**ប្រព័ន្ធរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមដំណេកដោយបង្ខំ (រំលោភសេពសន្ថវៈ) នៅតំបន់កំពង់សោម ដើម្បីបង្កើនចំនួនប្រជាជនស្របតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា តាមរយៈការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើអ្នកនៅក្រោមបង្គាប់របស់គាត់ក្នុងកងពលធំលេខ ១៦៤

---

4262 អាន ផ្នែកIII.៣.ការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម –រួមចំណែកក្នុងការធ្វើទាសកម្មនៅឯការដ្ឋាន។

4263 អាន ផ្នែកIII.៣.ការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម –រួមចំណែកក្នុងការបង្ខំមនុស្សឲ្យរៀបការ និងអំពើរំលោភសេពសន្ថវៈ។

(ខ) **ញុះញង់ ធ្វើផែនការ បញ្ជា និងជួយនិងជំរុញ**ឱ្យមានការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងក្របខ័ណ្ឌអាពាហ៍ពិពាហ៍ទាំងនោះ រវាងបុគ្គលដែលរស់នៅក្នុងតំបន់ស្វយ័តកំពង់សោម ដោយសារការគ្រប់គ្រងដ៏មានប្រសិទ្ធភាពរបស់គាត់លើអ្នកនៅក្រោមបង្គាប់របស់គាត់ ដែលបានរៀបចំអាពាហ៍ពិពាហ៍ដោយបង្ខំទាំងនេះ ចេតនារបស់គាត់ក្នុងការអនុវត្តតាមគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការបង្កើនចំនួនប្រជាជនរបស់របបកម្ពុជាប្រជាធិបតេយ្យឱ្យបានឆាប់រហ័ស ព្រមទាំងការដឹងឮរបស់គាត់អំពីបរិយាកាសបង្ខិតបង្ខំ ដែលកើតចេញពីការភ័យខ្លាចចំពោះការដាក់ទណ្ឌកម្មធ្ងន់ធ្ងរ ប្រសិនបើអ្នកណាម្នាក់មិនបានអនុវត្តតាមបទបញ្ជារបស់បក្សកុម្មុយនីស្តកម្ពុជានោះ

(គ) **ណែនាំ**អ្នកនៅក្រោមបង្គាប់របស់គាត់អំពីគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំរបស់បក្សកុម្មុយនីស្តកម្ពុជា

(ឃ) **បញ្ជា**ឱ្យអ្នកនៅក្រោមបង្គាប់របស់គាត់ រៀបចំការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំសម្រាប់ទាហានក្នុងកងពលធំលេខ ១៦៤

(ង) **បញ្ជា**ការពិនិត្យមើលឡើងវិញ និងការអនុញ្ញាតឱ្យមានការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងកងពលធំលេខ ១៦៤

(ច) **អនុញ្ញាត**ឱ្យមានការរៀបចំការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅលំនៅដ្ឋានរបស់គាត់

(ឆ) **ដាក់ទណ្ឌកម្ម**បុគ្គលទាំងឡាយណាដែលបានបដិសេធមិនរៀបអាពាហ៍ពិពាហ៍ នៅពេលដែលត្រូវបានស្នើ

(ជ) **ខកខានមិនបានទប់ស្កាត់**អ្នកនៅក្រោមបង្គាប់របស់គាត់ក្នុងកងពលធំលេខ ១៦៤ ដែលកំពុងប្រព្រឹត្តដោយផ្ទាល់នូវការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភពសេពសន្ថវៈក្នុងក្របខ័ណ្ឌអាពាហ៍ពិពាហ៍ទាំងនោះ រវាងបុគ្គលដែលរស់នៅក្នុងតំបន់ស្វយ័តកំពង់សោម ដែលកំពុងប្រព្រឹត្ត និងរៀបនឹងប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ បើទោះជាបានដឹងថា ឧក្រិដ្ឋកម្មទាំងនេះ បានកំពុងត្រូវបានប្រព្រឹត្ត និងបើទោះជាមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពរបស់គាត់លើអ្នកនៅក្រោមបង្គាប់ទាំងនេះក៏ដោយ

(ឈ) **ខកខានមិនបានទប់ស្កាត់**អ្នកនៅក្រោមបង្គាប់របស់គាត់ក្នុងកងពលធំលេខ ១៦៤ ដែលបានប្រព្រឹត្តការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភពសេពសន្ថវៈក្នុងក្របខ័ណ្ឌអាពាហ៍ពិពាហ៍ទាំងនោះរវាងបុគ្គល ដែលរស់នៅក្នុងតំបន់ស្វយ័តកំពង់សោម បើទោះជាបានដឹងថា ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្ត និងបើទោះជាមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពរបស់គាត់លើអ្នកនៅក្រោមបង្គាប់របស់គាត់ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះក៏ដោយ។

1124. អំពើ និងការប្រព្រឹត្តិរបស់ **មាស មុត** ដែលបានរៀបរាប់ខាងលើ ក៏បង្ហាញឲ្យឃើញផងដែរថាគាត់បានចែករំលែក និងមានចេតនារៀបចំផែនការឧក្រិដ្ឋកម្មរួមបន្ថែមទៀត និងមានចេតនាបង្កឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនីមួយៗនៃឧក្រិដ្ឋកម្មនានាដែលស្ថិតក្នុងផែនការឧក្រិដ្ឋកម្មរួមនេះ។

1125. អង្គហេតុខាងក្រោមបង្កើតបានជាភ័ស្តុតាងបន្ថែមទៀតដែលបង្ហាញពីចេតនារបស់ **មាស មុត** ក្នុងការចូលរួមចំណែកដ៏សំខាន់ចំពោះផែនការឧក្រិដ្ឋកម្មរួមនេះ ចេតនារបស់គាត់បង្កឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មនីមួយៗនៃឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់ និងការដឹងឮរបស់គាត់អំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ៖

(១) ការទទួលយក និងការចូលរួមរបស់គាត់ក្នុងការចាត់តាំងមុខតំណែងជាន់ខ្ពស់ និងតួនាទីនានាដែលផ្តល់លទ្ធភាពឲ្យគាត់ចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម

(២) សកម្មភាពរបស់គាត់ក្នុងការជំរុញឲ្យមានឧក្រិដ្ឋកម្ម រួមជាមួយនឹងសហចារីរបស់គាត់ និងការជំរុញឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនោះ តាមរយៈការចូលរួមចំណែកដែលបានពិពណ៌នាខាងលើ

(៣) សុន្ទរកថា និងសេចក្តីថ្លែងការណ៍របស់គាត់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ រួមទាំងសុន្ទរកថា និងសេចក្តីថ្លែងការណ៍ដែលគាត់បានថ្លែងថា កងទ័ពបដិវត្តន៍កម្ពុជាត្រូវបានយាយីដោយ "ខ្មាំង" បង្កប់ ដែលវត្តមានរបស់ពួកគេបានបង្កឲ្យមានការរីករាលដាលនៃការចាប់ខ្លួន និងការសម្លាប់ដែលចាំបាច់ និងការបដិសេធផ្តល់សិទ្ធិជាមូលដ្ឋានដល់ប្រជាជនផ្សេងទៀតទាំងអស់

(៤) ការចូលរួមចំណែករបស់គាត់ក្នុងការផ្សព្វផ្សាយ និងការគាំទ្រការបោះពុម្ពផ្សាយរបស់បក្សកុម្មុនីស្តកម្ពុជា (រួមទាំងសេចក្តីថ្លែងការណ៍នានានៅក្នុងទស្សនាវដ្តី *ទង់បដិវត្តន៍*)

(៥) សេចក្តីថ្លែងការណ៍របស់គាត់ក្នុងអំឡុងពេលបញ្ចុះបញ្ចូលនយោបាយ និងការលត់ដំកម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា

(៦) សុន្ទរកថា និងសេចក្តីថ្លែងការណ៍របស់គាត់ ដែលលើកទឹកចិត្តឲ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្ម និងការពារគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលគាត់បានលើកឡើងម្តងហើយម្តងទៀតអំពីការគាំទ្រ និងការអំពាវនាវឲ្យកម្មាភិបាលពង្រឹង និងអនុវត្តគោលនយោបាយទាំងនោះ

(៧) ការទទួលយករបស់គាត់នូវការឃោសនារបស់បក្សកុម្មុយនីស្តកម្ពុជា ដែលគាត់បានយល់ព្រម និងបានគាំទ្រ

(៨) ការខកខានរបស់គាត់ក្នុងការមិនបានទប់ស្កាត់ ឬដាក់ទណ្ឌកម្មដល់អ្នកនៅក្រោមបង្គាប់របស់គាត់ពីការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងនេះ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និង

(៩) សកម្មភាព សំណេរ និងសេចក្តីថ្លែងការណ៍របស់គាត់ រួមទាំងសកម្មភាព សំណេរ និងសេចក្តីថ្លែងការណ៍ទាំងឡាយណា ដែលគាត់បានព្យាយាមទប់ស្កាត់មិនឲ្យមានការរកឃើញឧក្រិដ្ឋកម្ម និងការប៉ុនប៉ងរបស់គាត់ក្នុងការការពារទង្វើទាំងនោះ។

## ២. ធ្វើផែនការ ញុះញង់ បញ្ជា និងជួយនិងជំរុញ[4264]

1126. បន្ថែមលើការទទួលខុសត្រូវរបស់គាត់លើការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ *តាមរយៈ* សហឧក្រិដ្ឋកម្មរួម **មាស មុត** ក៏ទទួលខុសត្រូវផងដែរលើការធ្វើផែនការ ការញុះញង់ ការបញ្ជា និងការជួយនិងការជំរុញឲ្យមានឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់។

1127. **មាស មុត បានធ្វើផែនការ**ឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងដីកាសន្និដ្ឋាននេះ។ ដោយសារតួនាទីរបស់គាត់ក្នុងគណៈមជ្ឈិម សេនាធិការ និងនៅកងពលធំ និងនៅថ្នាក់តំបន់ **មាស មុត** មានអំណាចរៀបចំ និង/ឬចូលរួមក្នុងការរៀបចំរបៀបអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្ត

[4264] អាន ផ្នែកIII.២. តួនាទីរបស់ មាស មុត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនិងផ្នែកIII.៣.ការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម។

កម្ពុជា។ ការចូលរួមរបស់គាត់ក្នុងការរៀបចំ និងការបង្កើតការអនុវត្តថ្នាក់តំបន់នូវគោលនយោបាយថ្នាក់ជាតិរបស់បក្សកុម្មុយនីស្តកម្ពុជា បានចូលរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មដោយអង្គភាពមជ្ឈិមរបស់កងទ័ពបដិវត្តន៍កម្ពុជា រួមទាំងកងពលធំលេខ ១៦៤ និងលេខ ១១៧ ផងដែរ។ **មាស មុត** ដែលមានចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម ឬដោយសារតែតួនាទី និងមុខតំណែងរបស់គាត់នោះ បានដឹងឮពីភវនីយភាពយ៉ាងច្បាស់ថា ឧក្រិដ្ឋនឹងត្រូវបានប្រព្រឹត្តក្នុងការអនុវត្តតាមអំពើដែលគាត់បានចូលរួមក្នុងការធ្វើផែនការ។

1128. **មាស មុត បានជំរុញ**ឲ្យមានឧក្រិដ្ឋកម្ម ដូចដែលបានបង្ហាញ។ តាមរយៈមុខតំណែងរបស់គាត់ គាត់បានលើកទឹកចិត្ត ជំរុញ គាំទ្រ ប្រកួកប្រកាស និងញុះញង់ចារីដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។ ការញុះញង់ឲ្យមានឧក្រិដ្ឋកម្មបានចូលរួមចំណែកយ៉ាងខ្លាំង ចំពោះការប្រព្រឹត្តិរបស់ពួកគេ។ សេចក្តីថ្លែងការណ៍ជាញឹកញាប់របស់ **មាស មុត** ស្តីពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាទៅកាន់កម្មាភិបាលថ្នាក់ក្រោម បង្ហាញថា គាត់មានចេតនាញុះញង់ចារីផ្ទាល់ឲ្យប្រព្រឹត្តកម្មឧក្រិដ្ឋ ឬយ៉ាងហោចណាស់ គាត់បានដឹងពីភវនីយភាពយ៉ាងច្បាស់ថា ឧក្រិដ្ឋកម្មនឹងត្រូវបានប្រព្រឹត្តក្នុងការអនុវត្តតាមអំពើដែលគាត់បានញុះញង់។

1129. **មាស មុត បានបញ្ជា**ឲ្យបង្កឧក្រិដ្ឋកម្ម ដូចដែលមានបង្ហាញលម្អិតក្នុងដីកាសន្និដ្ឋាននេះ។ ស្របតាមមុខតំណែងដែលមានអំណាចរបស់គាត់ **មាស មុត** បានបង្កើត និងចេញបទបញ្ជា និងការណែនាំទៅកាន់កម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម។ **មាស មុត** មានចេតនាឲ្យអ្នកទាំងឡាយដែលស្ថិតក្រោមអំណាច *ស្របច្បាប់* និង/ឬ *ជាក់ស្តែង* របស់គាត់ប្រព្រឹត្តឧក្រិដ្ឋកម្ម ឬយ៉ាងហោចណាស់ គាត់បានដឹងពីភវនីយភាពយ៉ាងច្បាស់ថា ឧក្រិដ្ឋកម្មនឹងត្រូវបានប្រព្រឹត្តក្នុងការអនុវត្តតាមបទបញ្ជាទាំងនេះ។ ដោយសាររចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា និងកងទ័ពបដិវត្តន៍កម្ពុជា **មាស មុត** បានដឹងថា គាត់មានអំណាចក្នុងការជំរុញកម្មាភិបាលថ្នាក់ក្រោមឲ្យធ្វើសកម្មភាព។

1130. **មាស មុត បានជួយនិងជំរុញ**ឲ្យមានឧក្រិដ្ឋកម្ម។ គាត់បានធ្វើដូច្នេះតាមរយៈការជំរុញ ការផ្តល់ការលើកទឹកចិត្ត និងជំនួយសម្រាប់ការអនុវត្តដល់កងទ័ពរបស់កងទ័ពបដិវត្តន៍កម្ពុជា និងកម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។ ការជំរុញ ការផ្តល់ការលើកទឹកចិត្ត និងជំនួយសម្រាប់ការអនុវត្តនេះ មានឥទ្ធិពលយ៉ាងខ្លាំងដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ ដោយសារមុខតំណែងដែលមានអំណាចរបស់គាត់ និងរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា និងកងទ័ព

បដិវត្តន៍កម្ពុជា **មាស មុត** បានដឹងថា អំពើនៃការជំរុញ និងការផ្តល់ការលើកទឹកចិត្ត និងជំនួយសម្រាប់ការប្រព្រឹត្តិរបស់គាត់ កំពុងជួយដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម និងមានចេតនាផ្តល់ជំនួយនោះ។ **មាស មុត** បានដឹងពីសមាសធាតុសំខាន់ៗនៃឧក្រិដ្ឋកម្ម ដែលគាត់កំពុងជួយនិងជំរុញ ដោយសារគាត់បន្តទទួលបានព័ត៌មានអំពីសកម្មភាពរបស់ចារីផ្ទាល់។

## ៣. ការទទួលខុសត្រូវរបស់ថ្នាក់លើ

1131. ជាងនេះទៀត និងជាជម្រើស **មាស មុត** មានការទទួលខុសត្រូវលើឧក្រិដ្ឋកម្មបុគ្គលក្នុងនាមជាថ្នាក់លើម្នាក់ ស្របតាមមាត្រា ២៩*ថ្មី* នៃច្បាប់ស្តីពី អ.វ.ត.ក ដោយសារតែ (i) មុខតំណែងរបស់គាត់ក្នុងនាមជាថ្នាក់លើរបស់ចារីដែលប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលមានចែងលម្អិតក្នុងដីកាសន្និដ្ឋាននេះ (ii) ការដឹងឮពិតប្រាកដរបស់គាត់ ឬការមានព័ត៌មានដោយឈរលើមូលដ្ឋានដែលគាត់មានហេតុផលត្រូវដឹងថា អ្នកនៅក្រោមបង្គាប់របស់គាត់ បានប្រព្រឹត្ត ឬរៀបនឹងប្រព្រឹត្តឧក្រិដ្ឋកម្ម និង (iii) ការខកខានរបស់គាត់ក្នុងការទប់ស្កាត់ការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬដាក់ទណ្ឌកម្មដល់ចារី។

1132. ទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់បានកើតមានរវាង **មាស មុត** និងសមាជិកទាំងអស់របស់កងទ័ពបដិវត្តន៍កម្ពុជា និងកម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានចូលរួមពាក់ព័ន្ធដោយផ្ទាល់នៅក្នុងឧក្រិដ្ឋកម្ម ដែលបានពិពណ៌នាក្នុងដីកាសន្និដ្ឋាននេះនៅទីតាំងទាំងអស់លើកលែងតែមន្ទីរសន្តិសុខ ស-២១។ បើទោះជាទំនាក់ទំនងមួយចំនួននៃទំនាក់ទំនងទាំងនេះ អាចជាទំនាក់ទំនងមិនផ្ទាល់ ឬជាទំនាក់ទំនង*ជាក់ស្តែង* ក៏ដោយ ក៏ **មាស មុត** គឺជាថ្នាក់លើរបស់បុគ្គលទាំងនេះ ដោយសារការគ្រប់គ្រងដ៏មានប្រសិទ្ធភាពរបស់គាត់លើពួកគេ ក្នុងនាមជាថ្នាក់ដឹកនាំយោធា និងតំបន់ជាន់ខ្ពស់មួយរូប។ **មាស មុត** មានលទ្ធភាពសំខាន់ដើម្បីទប់ស្កាត់អ្នកនៅក្រោមបង្គាប់មិនឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ដើម្បីដកពួកគេចេញពីមុខតំណែងរបស់ខ្លួន និង/ឬដាក់ទណ្ឌកម្មពួកគេ ដូចដែលបានបង្ហាញ*ក្នុងចំណោមនោះ* តាមរយៈការចូលរួមពាក់ព័ន្ធរបស់គាត់ក្នុងការបោសសម្អាតកម្មាភិបាលរបស់កងពលធំលេខ ១៦៤ និងលេខ ១១៧ និងការតែងតាំងមន្ត្រី និងកម្មាភិបាល[4265]។

1133. **មាស មុត** បានដឹងឮពិតប្រាកដពីឧក្រិដ្ឋកម្ម ដែលកំពុងត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់របស់គាត់ ដែលបង្ហាញឲ្យឃើញតាមរយៈតួនាទីរបស់គាត់ក្នុងការរៀបចំឲ្យកងទ័ពបដិវត្តន៍កម្ពុជា

---

[4265] អាន ផ្នែកIII.២.តួនាទីរបស់ មាស មុត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ–ប្រសិទ្ធភាពនៃការគ្រប់គ្រង។

និងតំបន់កំពង់សោម អនុវត្តគោលនយោបាយរបស់បក្សកម្មុយនីស្តកម្ពុជា ដែលបង្កឱ្យមានឧក្រិដ្ឋកម្ម និងតាមរយៈរបាយការណ៍ជាញឹកញាប់ដែលគាត់បានទទួល ទាក់ទងនឹងលទ្ធផលរបស់ព្រឹត្តិការណ៍នានាក្នុងតំបន់ ដែលស្ថិតក្រោមអំណាចរបស់គាត់។ **មាស មុត** បានខកខានក្នុងការចាត់វិធានការណាមួយដើម្បីទប់ស្កាត់ ឬដាក់ទណ្ឌកម្មដល់ឧក្រិដ្ឋកម្មទាំងនេះ បើទោះជាគាត់មានសមត្ថភាពធ្វើដូច្នេះក៏ដោយ[4266]។

## XIV. បទចោទប្រកាន់

1134. ផ្អែកលើអង្គហេតុ និងច្បាប់ជាធរមានក្នុងដីកាសន្និដ្ឋាននេះ សហព្រះរាជអាជ្ញាអន្តរជាតិសូមគោរពស្នើឱ្យសហចៅក្រមស៊ើបអង្កេតមេត្តាចេញដីកាចោទប្រកាន់ និងបញ្ជូន **មាស មុត** ទៅជំនុំជម្រះទោសដោយផ្អែកតាមបទចោទប្រកាន់ដូចខាងក្រោម ៖

(១) **<u>បទចោទប្រកាន់ទី ១ - ការធ្វើមនុស្សឃាត ៖</u>** នៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃទី ៦ខែមករាឆ្នាំ ១៩៧៩**មាសមុត**ដែលធ្វើសកម្មភាពដោយខ្លួនឯងនិងរួមគ្នានឹងអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក និងប្រើប្រាស់កងកម្លាំងក្រោមការគ្រប់គ្រងរបស់គាត់ និងការគ្រប់គ្រងពួកគេ បានធ្វើផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬ*តាមរយៈ*សហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា ៥ មាត្រា ២៩ *ថ្មី* និងមាត្រា ៣៩ *ថ្មី* នៃច្បាប់ អ.វ.ត.ក។ **មាស មុត** បានធ្វើសកម្មភាពដោយមានចេតនាសម្លាប់ ឬបានដឹងពីលទ្ធភាពយ៉ាងច្រើនដែលអាចបង្កជាការស្លាប់យ៉ាងច្រើន ដោយសារសកម្មភាពរបស់គាត់។ ក្រៅពីនេះ **មាស មុត** មានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើចារីនៃឧក្រិដ្ឋកម្មនេះ នៅគ្រប់ទីកន្លែងទាំងអស់ លើកលែងតែមន្ទីរ ស-២១។ **មាស មុត** បានដឹង ឬមានហេតុផលក្នុងការដឹងថា អ្នកនៅក្រោមបង្គាប់របស់គាត់ រៀបនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាត ហើយគាត់មិនបានចាត់វិធានការចាំបាច់ និងសមហេតុផលដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មនេះ ឬដាក់ទណ្ឌកម្មចារីឡើយ។ ដូច្នេះ គាត់ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ។ **មាស មុត** ទទួលខុសត្រូវលើការធ្វើមនុស្សឃាតនៅតាមទីតាំងដូចខាងក្រោម ៖

[4266] អាន ផ្នែកIII.៣.ការរួមចំណែករបស់ មាស មុត ទៅនឹងឧក្រិដ្ឋកម្ម។

(ក) មន្ទីរសន្តិសុខ ស-២១ (*តាមរយៈ*សហឧក្រិដ្ឋកម្មរួមទាំងស្រុងសម្រាប់ជនរងគ្រោះដែលជាកងទ័ពបដិវត្តន៍កម្ពុជា ដែលមិនត្រូវបានបញ្ជូនមកដោយ **មាស មុត** ឬអ្នកនៅក្រោមបង្គាប់របស់គាត់)

(ខ) មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ

(គ) មន្ទីរសន្តិសុខទឹកសាប

(ឃ) ក្នុងដែនទឹក និងដែនកោះដែលកម្ពុជាប្រជាធិបតេយ្យអះអាងជាកម្មសិទ្ធិរបស់ខ្លួន

(ង) ការដ្ឋានស្ទឹងហាវ

(ច) ការដ្ឋានតំបន់រាម និងទីកន្លែងសម្លាប់មនុស្ស ដូចជា ចម្ការទុរេនទី ១ និងទី ២ និង សេអ៊ី និង

(ឆ) តំបន់ផ្សេងទៀតដែលពាក់ព័ន្ធនឹងការបោសសម្អាតកងពលធំលេខ ១៦៤ និងលេខ ១១៧ និងតំបន់ ៥០៥។

(២) **<u>បទចោទប្រកាន់ទី ២ - ការសម្លាប់រង្គាល</u> ៖** នៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ **មាស មុត** ដែលធ្វើសកម្មភាពដោយខ្លួនឯង និងរួមគ្នានឹងអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក និងប្រើប្រាស់កងកម្លាំងក្រោមការគ្រប់គ្រងរបស់គាត់ និងការគ្រប់គ្រងពួកគេ បានធ្វើផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬ*តាមរយៈ*សហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា ៥ មាត្រា ២៩ *ថ្មី* និងមាត្រា ៣៩ *ថ្មី* នៃច្បាប់ អ.វ.ត.ក តាមរយៈការសម្លាប់ក្រៅប្រព័ន្ធតុលាការ។ ការសម្លាប់ទាំងនេះកើតឡើងនៅតាមទីកន្លែងយ៉ាងច្រើនដែលជាផ្នែកមួយនៃប្រព័ន្ធ ដែលមានការរៀបចំ ដូចជា ការដ្ឋាន មន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្ស។ **មាស មុត** មានចេតនាសម្លាប់មនុស្សយ៉ាងច្រើនដែលគេចាត់ទុកថាជា "ខ្មាំង" របស់របបនេះ ដូចជា អ្នកដែលពាក់ព័ន្ធនឹងអតីតរបបខ្មែរសាធារណរដ្ឋ ជនជាតិវៀតណាម ឬអ្នកដែលគេយល់ថាជាជនជាតិវៀតណាម ជនបរទេសផ្សេងទៀត នៅកម្ពុជា និងអ្នកដែលរបបនេះសង្ស័យថា អាចមិនស្មោះត្រង់នឹងមាគ៌ានយោបាយបក្ស (ជាពិសេសកម្មាភិបាលក្នុងជួរកងទ័ពបដិវត្តន៍កម្ពុជា និងជនស៊ីវិល)

។ ក្រៅពីនេះ **មាស មុត** មានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើចារីនៃឧក្រិដ្ឋកម្មនេះ នៅគ្រប់ទីកន្លែងទាំងអស់ លើកលែងតែមន្ទីរ ស-២១។ **មាស មុត** បានដឹង ឬមានហេតុផលក្នុងការដឹងថា អ្នកនៅក្រោមបង្គាប់របស់គាត់ រៀបនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល ហើយគាត់មិនបានចាត់វិធានការចាំបាច់ និងសមហេតុផលដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មនេះ ឬដាក់ទណ្ឌកម្មចារីឡើយ។ ដូច្នេះ គាត់ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ។ ការសម្លាប់ទាំងនេះដែលពាក់ព័ន្ធនឹង **មាស មុត** និងអ្នកនៅក្រោមបង្គាប់របស់គាត់ កើតឡើងនៅតាមការដ្ឋាន មន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្ស ដែលសុទ្ធតែជាផ្នែកនៃប្រព័ន្ធដែលមានការរៀបចំ ពាក់ព័ន្ធគ្នា និងតែមួយ ដូចខាងក្រោម ៖

(ក) មន្ទីរសន្តិសុខ ស-២១ (*តាមរយៈ*សហឧក្រិដ្ឋកម្មរួមទាំងស្រុងសម្រាប់ជនរងគ្រោះដែលជាកងទ័ពបដិវត្តន៍កម្ពុជា ដែលមិនត្រូវបានបញ្ជូនមកដោយ **មាស មុត** ឬអ្នកនៅក្រោមបង្គាប់របស់គាត់)

(ខ) មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ

(គ) មន្ទីរសន្តិសុខទឹកសាប

(ឃ) ក្នុងដែនទឹក និងដែនកោះដែលកម្ពុជាប្រជាធិបតេយ្យអះអាងជាកម្មសិទ្ធិរបស់ខ្លួន

(ង) ការដ្ឋានតំបន់រាម និងទីកន្លែងសម្លាប់មនុស្ស ដូចជា ចម្ការទុរេនទី ១ និងទី ២ និងសេអ៊ី និង

(ច) តំបន់ផ្សេងទៀតដែលពាក់ព័ន្ធនឹងការបោសសម្អាតកងពលធំលេខ ១៦៤ និងលេខ ១១៧ និងតំបន់ ៥០៥។

(៣) <u>**បទចោទប្រកាន់ទី ៣ - អំពើប្រល័យពូជសាសន៍ ៖**</u> យ៉ាងហោចណាស់ចាប់ពីដើមឆ្នាំ ១៩៧៧ រហូតដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ **មាស មុត** ដែលធ្វើសកម្មភាពដោយខ្លួនឯង និងរួមគ្នានឹងអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក និងប្រើប្រាស់កងកម្លាំងក្រោមការគ្រប់គ្រងរបស់គាត់ និងការគ្រប់គ្រងពួកគេ បានធ្វើផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬ*តាមរយៈ*សហឧក្រិដ្ឋកម្មរួម ប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា ៤ មាត្រា ២៩ *ថ្មី* និងមាត្រា ៣៩ *ថ្មី* នៃច្បាប់ អ.វ.ត.ក តាមរយៈការ

សម្លាប់ជនជាតិវៀតណាមក្នុងចេតនាបំផ្លាញទាំងស្រុង ឬដោយផ្អែកលើជនជាតិវៀតណាមក្នុងនាមជាក្រុមសញ្ជាតិ ជាតិពន្ធុ ឬក្រុមពូជសាសន៍នៅកម្ពុជា។ អ្នកដែលពិតជា ឬគេយល់ថាជាក្រុមសញ្ជាតិ ជាតិពន្ធុ និង/ឬក្រុមពូជសាសន៍វៀតណាម ដែលប្រទះនឹងកងកម្លាំងក្រោមបញ្ជារបស់ **មាស មុត** នៅដែនទឹក និងដែនកោះដែលកម្ពុជាប្រជាធិបតេយ្យអះអាងជាកម្មសិទ្ធិរបស់ខ្លួន ដូចជា កោះត្រល់ និងកោះពូលូវ៉ៃ និង/ឬដែនដីគោករបស់កម្ពុជា ត្រូវបានចាប់ខ្លួន និងសម្លាប់ ឬបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ដោយមានចេតនា ឬបានដឹងពីលទ្ធភាពថា ពួកគេនឹងត្រូវបានសម្លាប់ជាបន្តបន្ទាប់។ ក្រៅពីមន្ទីរ ស-២១ **មាស មុត** មានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើចារីនៃឧក្រិដ្ឋកម្មនេះ។ **មាស មុត** បានដឹង ឬមានហេតុផលក្នុងការដឹងថា អ្នកនៅក្រោមបង្គាប់របស់គាត់ រៀបនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ហើយគាត់មិនបានចាត់វិធានការចាំបាច់ និងសមហេតុផលដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មនេះ ឬដាក់ទណ្ឌកម្មចារីឡើយ។ ដូច្នេះ គាត់ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ។

(៤) <u>**បទចោទប្រកាន់ទី ៤ - ការដាក់ក្នុងមន្ទីរឃុំឃាំង ៖**</u> នៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ **មាស មុត** ដែលធ្វើសកម្មភាពដោយខ្លួនឯង និងរួមគ្នានឹងអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក និងប្រើប្រាស់កងកម្លាំងក្រោមការគ្រប់គ្រងរបស់គាត់ និងការគ្រប់គ្រងពួកគេ បានធ្វើផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬ*តាមរយៈ*សហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការដាក់ក្នុងមន្ទីរឃុំឃាំងដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា ៥ មាត្រា ២៩ *ថ្មី* និងមាត្រា ៣៩ *ថ្មី* នៃច្បាប់ អ.វ.ត.ក តាមរយៈការឃុំខ្លួនជនរងគ្រោះដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋាននេះ តាមទំនើងចិត្ត *ពោលគឺ*គ្មានមូលដ្ឋានសមហេតុផល និងគ្មានដំណើរការផ្លូវច្បាប់សមស្របឡើយ។ ក្រៅពីនេះ **មាស មុត** មានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើចារីនៃឧក្រិដ្ឋកម្មនេះនៅគ្រប់ទីកន្លែងទាំងអស់ លើកលែងតែមន្ទីរ ស-២១។ **មាស មុត** បានដឹង ឬមានហេតុផលក្នុងការដឹងថា អ្នកនៅក្រោមបង្គាប់របស់គាត់ រៀបនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការដាក់ក្នុងមន្ទីរឃុំឃាំង ហើយគាត់មិនបានចាត់វិធានការចាំបាច់ និងសមហេតុផលដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មនេះ ឬដាក់ទណ្ឌកម្មចារីឡើយ។ ដូច្នេះ គាត់ត្រូវ

ទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ។ **មាស មុត** ទទួលខុសត្រូវលើការដាក់ក្នុងមន្ទីរឃុំឃាំង នៅតាមទីកន្លែងដូចខាងក្រោម ៖

(ក) មន្ទីរសន្តិសុខ ស-២១ (*តាមរយៈ*សហឧក្រិដ្ឋកម្មរួមទាំងស្រុងសម្រាប់ជនរងគ្រោះ ដែលជាកងទ័ពបដិវត្តន៍កម្ពុជា ដែលមិនត្រូវបានបញ្ជូនមកដោយ **មាស មុត** ឬអ្នក នៅក្រោមបង្គាប់របស់គាត់)

(ខ) មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ

(គ) មន្ទីរសន្តិសុខទឹកសាប

(ឃ) ការដ្ឋានស្ទឹងហាវ

(ង) ដែនកោះដែលកម្ពុជាប្រជាធិបតេយ្យអះអាងជាកម្មសិទ្ធិរបស់ខ្លួន និង

(ច) ខេត្តក្រចេះ។

(៥) <u>**បទចោទប្រកាន់ទី ៥ - ការធ្វើទារុណកម្ម ៖**</u> នៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និង ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ **មាស មុត** ដែលធ្វើសកម្មភាពដោយខ្លួនឯង និងរួមគ្នានឹងអាជ្ញាធរ កម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក និងប្រើប្រាស់កងកម្លាំងក្រោមការគ្រប់គ្រងរបស់គាត់ និងការគ្រប់គ្រងពួកគេ បានធ្វើផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬ*តាមរយៈ* សហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្ម ដែលជាឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិ ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា ៥ មាត្រា ២៩ *ថ្មី* និងមាត្រា ៣៩ *ថ្មី* នៃច្បាប់ អ.វ.ត.ក តាមរយៈការបង្កព្យសនកម្មរាងកាយ និងផ្លូវចិត្ត និងការរងគ្រោះធ្ងន់ធ្ងរ ដោយចេតនាលើជនរងគ្រោះ ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋាននេះ។ ក្រៅពីនេះ **មាស មុត** មានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើចារីនៃឧក្រិដ្ឋកម្មនេះ នៅគ្រប់ទីកន្លែងទាំងអស់ លើកលែងតែមន្ទីរ ស-២១។ **មាស មុត** បានដឹង ឬមានហេតុផលក្នុងការដឹងថា អ្នកនៅ ក្រោមបង្គាប់របស់គាត់ រៀបនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្ម ហើយគាត់មិនបានចាត់វិធានការចាំបាច់ និងសមហេតុផលដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មនេះ ឬ ដាក់ទណ្ឌកម្មចារីឡើយ។ ដូច្នេះ គាត់ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ។ **មាស មុត** ទទួលខុសត្រូវលើការធ្វើទារុណកម្មនៅតាមទីកន្លែងដូចខាងក្រោម ៖

(ក) មន្ទីរសន្តិសុខ ស-២១ (*តាមរយៈ*សហឧក្រិដ្ឋកម្មរួមទាំងស្រុងសម្រាប់ជនរងគ្រោះ ដែលជាកងទ័ពបដិវត្តន៍កម្ពុជា ដែលមិនត្រូវបានបញ្ជូនមកដោយ **មាស មុត** ឬអ្នក នៅក្រោមបង្គាប់របស់គាត់)

(ខ) មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ

(គ) មន្ទីរសន្តិសុខទឹកសាប និង

(ឃ) ការដ្ឋានស្ទឹងហាវ។

(៦) **<u>បទចោទប្រកាន់ទី ៦ - ការធ្វើឱ្យទៅជាទាសករ ៖</u>** នៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ **មាស មុត** ដែលធ្វើសកម្មភាពដោយខ្លួនឯង និងរួម គ្នានឹងអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក និងប្រើប្រាស់កងកម្លាំងក្រោមការគ្រប់ គ្រងរបស់គាត់ និងការគ្រប់គ្រងពួកគេ បានធ្វើផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ និង/ ឬ*តាមរយៈ*សហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការធ្វើឱ្យទៅជាទាសករដែលជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា ៥ មាត្រា ២៩ *ថ្មី* និង មាត្រា ៣៩ *ថ្មី* នៃច្បាប់ អ.វ.ត.ក តាមរយៈការអនុវត្តសិទ្ធិអំណាចជាម្ចាស់ដោយចេតនាលើ ជនរងគ្រោះ ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋាននេះ។ ក្រៅពីនេះ **មាស មុត** មានការគ្រប់ គ្រងដ៏មានប្រសិទ្ធភាពលើចារីនៃឧក្រិដ្ឋកម្មនេះ។ **មាស មុត** បានដឹង ឬមានហេតុផលក្នុង ការដឹងថា អ្នកនៅក្រោមបង្គាប់របស់គាត់ រៀបនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការ ធ្វើឱ្យទៅជាទាសករ ហើយគាត់មិនបានចាត់វិធានការចាំបាច់ និងសមហេតុផលដើម្បី ទប់ស្កាត់ឧក្រិដ្ឋកម្មនេះ ឬដាក់ទណ្ឌកម្មចារីឡើយ។ ដូច្នេះ គាត់ត្រូវទទួលខុសត្រូវក្នុងនាម ជាថ្នាក់លើ។ **មាស មុត** ទទួលខុសត្រូវលើការធ្វើឱ្យទៅជាទាសករនៅតាមទីកន្លែងដូចខាង ក្រោម ៖

(ក) ការដ្ឋានស្ទឹងហាវ និង

(ខ) ការដ្ឋានតំបន់រាម។

(៧) **<u>បទចោទប្រកាន់ទី ៧ - ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ៖</u>** នៅចន្លោះថ្ងៃ ទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ **មាស មុត** ដែលធ្វើ

សកម្មភាពដោយខ្លួនឯង និងរួមគ្នានឹងអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក និងប្រើប្រាស់កងកម្លាំងក្រោមការគ្រប់គ្រងរបស់គាត់ និងការគ្រប់គ្រងពួកគេ បានធ្វើផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬ*តាមរយៈ*សហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា ៥ មាត្រា ២៩ *ថ្មី* និងមាត្រា ៣៩ *ថ្មី* នៃច្បាប់ អ.វ.ត.ក តាមរយៈការបដិសេធដាច់ខាត ឬការរំលោភបំពានលើសិទ្ធិជាសារវន្តរបស់អ្នកដែលគេចាត់ទុកជា "ខ្មាំង" នយោបាយ។ ក្រៅពីនេះ **មាស មុត** មានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើចារីនៃឧក្រិដ្ឋកម្មនេះនៅគ្រប់ទីកន្លែងទាំងអស់ លើកលែងតែមន្ទីរ ស-២១។ **មាស មុត** បានដឹង ឬមានហេតុផលក្នុងការដឹងថា អ្នកនៅក្រោមបង្គាប់របស់គាត់ រៀបនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយ ហើយគាត់មិនបានចាត់វិធានការចាំបាច់ និងសមហេតុផលដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មនេះ ឬដាក់ទណ្ឌកម្មចារីឡើយ។ ដូច្នេះ គាត់ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ។ **មាស មុត** ទទួលខុសត្រូវលើការធ្វើទុកបុកម្នេញ ដោយសារហេតុផលនយោបាយលើអ្នកដែលគេចាត់ទុកជាខ្មាំងនយោបាយ នៅតាមទីកន្លែងដូចខាងក្រោម ៖

(ក) មន្ទីរសន្តិសុខ ស-២១ (តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត (ការប្រព្រឹត្តិអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ) (*តាមរយៈ*សហឧក្រិដ្ឋកម្មរួមទាំងស្រុងសម្រាប់ជនរងគ្រោះ ដែលជាកងទ័ពបដិវត្តន៍កម្ពុជា ដែលមិនត្រូវបានបញ្ជូនមកដោយ **មាស មុត** ឬអ្នកនៅក្រោមបង្គាប់របស់គាត់)

(ខ) មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ (តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត (ការប្រព្រឹត្តិអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)

(គ) មន្ទីរសន្តិសុខទឹកសាប (តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត (ការប្រព្រឹត្តិអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)

(ឃ) ការដ្ឋានស្ទឹងហាវ (តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត (ការប្រព្រឹត្តិអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)

(ង) ក្នុងដែនទឹក និងដែនកោះដែលកម្ពុជាប្រជាធិបតេយ្យអះអាងជាកម្មសិទ្ធិរបស់ខ្លួន (តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត (ការប្រព្រឹត្តិអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)

(ច) ការដ្ឋានតំបន់រាម និងទីកន្លែងសម្លាប់មនុស្ស ដូចជា ចម្ការទុរេនទី ១ និងទី ២ និងសេអ៊ី (តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត (ការប្រព្រឹត្តិអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ) និង

(ឆ) តំបន់ផ្សេងទៀតដែលពាក់ព័ន្ធនឹងការបោសសម្អាតកងពលធំលេខ ១៦៤ និងលេខ ១១៧ និងតំបន់ ៥០៥ (តាមរយៈបទល្មើសនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត (ការប្រព្រឹត្តិអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)។

(៨) **<u>បទចោទប្រកាន់ទី ៨ - អំពើអមនុស្សធម៌ផ្សេងទៀត (ការប្រព្រឹត្តអមនុស្សធម៌) ៖</u>** នៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ **មាស មុត** ដែលធ្វើសកម្មភាពដោយខ្លួនឯង និងរួមគ្នានឹងអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក និងប្រើប្រាស់កងកម្លាំងក្រោមការគ្រប់គ្រងរបស់គាត់ និងការគ្រប់គ្រងពួកគេ បានធ្វើផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬ*តាមរយៈ*សហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀតនៃប្រព្រឹត្តកម្មអមនុស្សធម៌ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា ៥ មាត្រា ២៩ *ថ្មី* និងមាត្រា ៣៩ *ថ្មី* នៃច្បាប់ អ.វ.ត.ក តាមរយៈការប្រព្រឹត្តអំពើអមនុស្សធម៌តាមទំនើងចិត្តលើអ្នកទោស និងកម្មករនៅតាមទីតាំងខាងក្រោម ដែលបានបង្កជាព្យសនកម្មផ្លូវចិត្ត ឬរាងកាយ ឬការរងរបួសធ្ងន់ធ្ងរ ឬវាយប្រហារយ៉ាងធ្ងន់ធ្ងរលើសេចក្តីថ្លៃថ្នូរជាមនុស្សរបស់ពួកគេ។ ក្រៅពីនេះ **មាស មុត**

មានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើចារីនៃឧក្រិដ្ឋកម្មនេះ នៅគ្រប់ទីកន្លែងទាំងអស់ លើកលែងតែមន្ទីរ ស-២១។ **មាស មុត** បានដឹង ឬមានហេតុផលក្នុងការដឹងថា អ្នកនៅក្រោមបង្គាប់របស់គាត់ រៀបនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀត តាមរយៈការប្រព្រឹត្តិអមនុស្សធម៌ ហើយគាត់មិនបានចាត់វិធានការចាំបាច់ និងសមហេតុផលដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មនេះ ឬដាក់ទណ្ឌកម្មចារីឡើយ។ ដូច្នេះ គាត់ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ។ **មាស មុត** ទទួលខុសត្រូវលើអំពើអមនុស្សធម៌ផ្សេងទៀតនៃប្រព្រឹត្តកម្មអមនុស្សធម៌នៅតាមទីកន្លែងដូចខាងក្រោម ៖

(ក) មន្ទីរសន្តិសុខ ស-២១ (*តាមរយៈ*សហឧក្រិដ្ឋកម្មរួមទាំងស្រុងសម្រាប់ជនរងគ្រោះដែលជាកងទ័ពបដិវត្តន៍កម្ពុជា ដែលមិនត្រូវបានបញ្ជូនមកដោយ **មាស មុត** ឬអ្នកនៅក្រោមបង្គាប់របស់គាត់)

(ខ) មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ

(គ) មន្ទីរសន្តិសុខទឹកសាប

(ឃ) ការដ្ឋានស្ទឹងហាវ

(ង) ក្នុងដែនទឹក និងដែនកោះដែលកម្ពុជាប្រជាធិបតេយ្យអះអាងជាកម្មសិទ្ធិរបស់ខ្លួន

(ច) ការដ្ឋានតំបន់រាម និង

(ឆ) តំបន់ផ្សេងទៀតដែលពាក់ព័ន្ធនឹងការបោសសម្អាតកងពលធំលេខ ១៦៤ និងលេខ ១១៧ និងតំបន់ ៥០៥។

(៩) **<u>បទចោទប្រកាន់ទី ៩ - អំពើអមនុស្សធម៌ផ្សេងទៀត (ការបាត់ខ្លួនដោយបង្ខំ) ៖</u>** នៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ **មាស មុត** ដែលធ្វើសកម្មភាពដោយខ្លួនឯង និងរួមគ្នានឹងអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក និងប្រើប្រាស់កងកម្លាំងក្រោមការគ្រប់គ្រងរបស់គាត់ និងការគ្រប់គ្រងពួកគេ បានធ្វើផែនការញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬ*តាមរយៈ*សហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀតនៃការបាត់ខ្លួនដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្ស

ជាតិ ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា ៥ មាត្រា ២៩ *ថ្មី* និងមាត្រា ៣៩ *ថ្មី* នៃច្បាប់ អ.វ.ត.ក តាមរយៈការលាក់បាំងជោគវាសនារបស់អ្នក ដែលបានបាត់ខ្លួននៅតាមទីកន្លែងខាងក្រោម។ ក្រៅពីនេះ **មាស មុត** មានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើចារីនៃឧក្រិដ្ឋកម្មនេះនៅគ្រប់ទីកន្លែងទាំងអស់ លើកលែងតែមន្ទីរ ស-២១។ **មាស មុត** បានដឹង ឬមានហេតុផលក្នុងការដឹងថា អ្នកនៅក្រោមបង្គាប់របស់គាត់ រៀបនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀតនៃការបាត់ខ្លួនដោយបង្ខំ ហើយគាត់មិនបានចាត់វិធានការចាំបាច់ និងសមហេតុផលដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មនេះ ឬដាក់ទណ្ឌកម្មចារីឡើយ។ ដូច្នេះ គាត់ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ។ **មាស មុត** ទទួលខុសត្រូវលើអំពើអមនុស្សធម៌ផ្សេងទៀតនៃការបាត់ខ្លួនដោយបង្ខំនៅតាមទីកន្លែងដូចខាងក្រោម ៖

(ក) មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ

(ខ) មន្ទីរសន្តិសុខទឹកសាប

(គ) មន្ទីរសន្តិសុខ ស-២១ (*តាមរយៈ*សហឧក្រិដ្ឋកម្មរួមទាំងស្រុងសម្រាប់ជនរងគ្រោះដែលជាកងទ័ពបដិវត្តន៍កម្ពុជា ដែលមិនត្រូវបានបញ្ជូនមកដោយ **មាស មុត** ឬអ្នកនៅក្រោមបង្គាប់របស់គាត់)

(ឃ) ក្នុងដែនទឹក និងដែនកោះដែលកម្ពុជាប្រជាធិបតេយ្យអះអាងជាកម្មសិទ្ធិរបស់ខ្លួន

(ង) ការដ្ឋានតំបន់រាម និងទីកន្លែងសម្លាប់មនុស្ស ដូចជា ចម្ការទុរេនទី ១ និងទី ២ និងសេអ៊ី និង

(ច) តំបន់ផ្សេងទៀតដែលពាក់ព័ន្ធនឹងការបោសសម្អាតកងពលធំលេខ ១៦៤ និងលេខ ១១៧ និងតំបន់ ៥០៥។

(១០) <u>**បទចោទប្រកាន់ទី ១០ - អំពើអមនុស្សធម៌ផ្សេងទៀត (អាពាហ៍ពិពាហ៍ដោយបង្ខំ)**</u> ៖ នៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ **មាស មុត** ដែលធ្វើសកម្មភាពដោយខ្លួនឯង និងរួមគ្នានឹងអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក និងប្រើប្រាស់កងកម្លាំងក្រោមការគ្រប់គ្រងរបស់គាត់ និងការគ្រប់គ្រងពួកគេ បានធ្វើផែនការញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬ*តាមរយៈ*សហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មនៃ

អំពើអមនុស្សធម៌ផ្សេងទៀតនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា ៥ មាត្រា ២៩ *ថ្មី* និងមាត្រា ៣៩ *ថ្មី* នៃច្បាប់ អ.វ.ត.ក តាមរយៈការបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ដោយមានការបង្ខិតបង្ខំ ការគំរាមប្រើកម្លាំង ឬការគាបសង្កត់ក្នុងតំបន់ស្វយ័តក្រុងកំពង់សោម និងដែនកោះដែលគ្រប់គ្រងដោយកងកម្លាំងស្ថិតក្រោមបញ្ជារបស់ **មាស មុត**។ ក្រៅពីនេះ **មាស មុត** មានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើចារីនៃឧក្រិដ្ឋកម្មនេះ។ **មាស មុត** បានដឹង ឬមានហេតុផលក្នុងការដឹងថា អ្នកនៅក្រោមបង្គាប់របស់គាត់ រៀបនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តអំពើអមនុស្សធម៌ផ្សេងទៀតនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយគាត់មិនបានចាត់វិធានការចាំបាច់ និងសមហេតុផលដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មនេះ ឬដាក់ទណ្ឌកម្មចារីឡើយ។ ដូច្នេះ គាត់ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ។

(១១) <u>**បទចោទប្រកាន់ទី ១១ - អំពើអមនុស្សធម៌ផ្សេងទៀត (ការរំលោភសេពសន្ថវៈ) ៖**</u> នៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ **មាស មុត** ដែលធ្វើសកម្មភាពដោយខ្លួនឯង និងរួមគ្នានឹងអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក និងប្រើប្រាស់កងកម្លាំងក្រោមការគ្រប់គ្រងរបស់គាត់ និងការគ្រប់គ្រងពួកគេ បានធ្វើផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬ*តាមរយៈ*សហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀតនៃការរំលោភសេពសន្ថវៈ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា ៥ មាត្រា ២៩ *ថ្មី* និងមាត្រា ៣៩ *ថ្មី* នៃច្បាប់ អ.វ.ត.ក តាមរយៈការគាបសង្កត់ឱ្យដៃគូម្នាក់ ឬទាំងពីរនាក់ដែលត្រូវបានបង្ខំឱ្យរួមដំណេកក្នុងតំបន់ស្វយ័តក្រុងកំពង់សោម និងដែនកោះដែលគ្រប់គ្រងដោយកងកម្លាំងស្ថិតក្រោមបញ្ជារបស់ **មាស មុត**។ ក្រៅពីនេះ **មាស មុត** មានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើចារីនៃឧក្រិដ្ឋកម្មនេះ។ **មាស មុត** បានដឹង ឬមានហេតុផលក្នុងការដឹងថា អ្នកនៅក្រោមបង្គាប់របស់គាត់ រៀបនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងទៀតនៃការរំលោភសេពសន្ថវៈ ហើយគាត់មិនបានចាត់វិធានការចាំបាច់ និងសមហេតុផលដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មនេះ ឬដាក់ទណ្ឌកម្មចារីឡើយ។ ដូច្នេះ គាត់ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ។

(១២) **<u>បទចោទប្រកាន់ទី ១២ - ការរំលោភបំពានធ្ងន់ធ្ងរ (ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់) ៖</u>** នៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ **មាស មុត** ដែលធ្វើសកម្មភាពដោយខ្លួនឯង និងរួមគ្នានឹងអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក និងប្រើប្រាស់កងកម្លាំងក្រោមការគ្រប់គ្រងរបស់គាត់ និងការគ្រប់គ្រងពួកគេ បានធ្វើផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬ*តាមរយៈ*សហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ដែលជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា ៦ មាត្រា ២៩ *ថ្មី* និងមាត្រា ៣៩ *ថ្មី* នៃច្បាប់ អ.វ.ត.ក តាមរយៈការឃុំខ្លួនជនស៊ីវិល ដែលពាក់ព័ន្ធ ឬគេយល់ថាពាក់ព័ន្ធនឹងវៀតណាម ដោយគ្មានមូលដ្ឋានសមហេតុផល ដើម្បីបញ្ជាក់ថាសំដៅធានាការពារសន្តិសុខកម្ពុជាប្រជាធិបតេយ្យ។ ក្រៅពីនេះ **មាស មុត** គឺជាមេបញ្ជាការ និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើចារីនៃឧក្រិដ្ឋកម្មនេះ នៅគ្រប់ទីកន្លែងទាំងអស់ លើកលែងតែមន្ទីរ ស-២១។ **មាស មុត** បានដឹង ឬមានហេតុផលក្នុងការដឹងថា អ្នកនៅក្រោមបង្គាប់របស់គាត់ រៀបនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ហើយគាត់មិនបានចាត់វិធានការចាំបាច់ និងសមហេតុផលដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មនេះ ឬដាក់ទណ្ឌកម្មចារីឡើយ។ ដូច្នេះ គាត់ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ។ **មាស មុត** ទទួលខុសត្រូវលើការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ នៅតាមទីកន្លែងដូចខាងក្រោម ៖

(ក) មន្ទីរសន្តិសុខ ស-២១

(ខ) ក្នុងដែនទឹក និងដែនកោះដែលកម្ពុជាប្រជាធិបតេយ្យអះអាងជាកម្មសិទ្ធិរបស់ខ្លួន និង

(គ) មន្ទីរសន្តិសុខទឹកសាប។

(១៣) **<u>បទចោទប្រកាន់ទី ១៣ - ការរំលោភបំពានធ្ងន់ធ្ងរ (ការសម្លាប់ដោយចេតនា) ៖</u>** នៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ **មាស មុត** ដែលធ្វើសកម្មភាពដោយខ្លួនឯង និងរួមគ្នានឹងអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក និងប្រើប្រាស់កងកម្លាំងក្រោមការគ្រប់គ្រងរបស់គាត់ និងការគ្រប់គ្រងពួកគេ បានធ្វើផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬ*តាមរយៈ*សហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មនៃ

ការសម្លាប់ដោយចេតនា ដែលជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា ៦ មាត្រា ២៩ *ថ្មី* និងមាត្រា ៣៩ *ថ្មី* នៃច្បាប់ អ.វ.ត.ក តាមរយៈអំពើសកម្ម ឬអកម្មដែលធ្វើឲ្យមានការសម្លាប់ពលរដ្ឋ និង/ឬកងទ័ពវៀតណាម ឬអ្នកដែលគេយល់ថាពាក់ព័ន្ធនឹងវៀតណាម។ ក្រៅពីនេះ **មាស មុត** គឺជាមេបញ្ជាការ និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើចារីនៃឧក្រិដ្ឋកម្មនេះ នៅគ្រប់ទីកន្លែងទាំងអស់ លើកលែងតែមន្ទីរ ស-២១។ **មាស មុត** បានដឹង ឬមានហេតុផលក្នុងការដឹងថាអ្នកនៅក្រោមបង្គាប់របស់គាត់ រៀបនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការសម្លាប់ដោយចេតនា ហើយគាត់មិនបានចាត់វិធានការចាំបាច់ និងសមហេតុផលដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មនេះ ឬដាក់ទណ្ឌកម្មចារីឡើយ។ ដូច្នេះ គាត់ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ។

**មាស មុត** ទទួលខុសត្រូវលើការសម្លាប់ដោយចេតនានៅតាមទីកន្លែងដូចខាងក្រោម ៖

(ក) មន្ទីរសន្តិសុខ ស-២១

(ខ) មន្ទីរសន្តិសុខទឹកសាប

(គ) ក្នុងដែនទឹក និងដែនកោះដែលកម្ពុជាប្រជាធិបតេយ្យអះអាងជាកម្មសិទ្ធិរបស់ខ្លួន និង

(ឃ) ទីកន្លែងសម្លាប់មនុស្សចម្ការទុរេន ១។

(១៩) <u>**បទចោទប្រកាន់ទី ១៩ - ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ (ការបង្កព្យសនកម្ម ឬការរងរបួសយ៉ាងធ្ងន់ធ្ងរលើរាងកាយ ឬសុខភាពដោយចេតនា)**</u>៖ នៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ **មាស មុត** ដែលធ្វើសកម្មភាពដោយខ្លួនឯង និងរួមគ្នានឹងអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក និងប្រើប្រាស់កងកម្លាំងក្រោមការគ្រប់គ្រងរបស់គាត់ និងការគ្រប់គ្រងពួកគេ បានធ្វើផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬ*តាមរយៈ*សហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការបង្កព្យសនកម្ម ឬការរងរបួសយ៉ាងធ្ងន់ធ្ងរលើរាងកាយ ឬសុខភាពដោយចេតនា ដែលជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា ៦ មាត្រា ២៩ *ថ្មី* និងមាត្រា ៣៩ *ថ្មី* នៃច្បាប់ អ.វ.ត.ក តាមរយៈការបង្កព្យសនកម្ម ឬការរងរបួសធ្ងន់ធ្ងរលើ

រាងកាយ ឬសុខភាពរបស់ពលរដ្ឋ និងទាហានវៀតណាម ឬអ្នកដែលគេយល់ថា ពាក់ព័ន្ធនឹងវៀតណាម។ ក្រៅពីនេះ **មាស មុត** គឺជាមេបញ្ជាការ និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើចារីនៃឧក្រិដ្ឋកម្មនេះ នៅគ្រប់ទីកន្លែងទាំងអស់ លើកលែងតែមន្ទីរ ស-២១។ **មាស មុត** បានដឹង ឬមានហេតុផលក្នុងការដឹងថា អ្នកនៅក្រោមបង្គាប់របស់គាត់នឹងប្រព្រឹត្ត ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការបង្កព្យសនកម្ម ឬការរងរបួសធ្ងន់ធ្ងរលើរាងកាយ ឬសុខភាពដោយចេតនា ហើយគាត់មិនបានចាត់វិធានការចាំបាច់ និងសមហេតុផលដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មនេះ ឬដាក់ទណ្ឌកម្មចារីឡើយ។ ដូច្នេះ គាត់ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ។ **មាស មុត** ទទួលខុសត្រូវលើការបង្កព្យសនកម្ម ឬការរងរបួសធ្ងន់ធ្ងរលើរាងកាយ ឬសុខភាពដោយចេតនាលើអ្នកដែលត្រូវបានឃុំខ្លួននៅតាមទីកន្លែងដូចខាងក្រោម ៖

(ក) មន្ទីរសន្តិសុខ ស-២១

(ខ) មន្ទីរសន្តិសុខទឹកសាប និង

(គ) ក្នុងដែនទឹក និងដែនកោះដែលកម្ពុជាប្រជាធិបតេយ្យអះអាងជាកម្មសិទ្ធិរបស់ខ្លួន។

(១៥) **<u>បទចោទប្រកាន់ទី ១៥ - ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ (ការធ្វើទារុណកម្ម) ៖</u>** នៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ **មាស មុត** ដែលធ្វើសកម្មភាពដោយខ្លួនឯង និងរួមគ្នានឹងអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក និងប្រើប្រាស់កងកម្លាំងក្រោមការគ្រប់គ្រងរបស់គាត់ និងការគ្រប់គ្រងពួកគេ បានធ្វើផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬ*តាមរយៈ*សហឧក្រិដ្ឋកម្មរួម បានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្ម ដែលជាការបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ដែលអាចផ្តន្ទាទោសបានក្រោមមាត្រា ៦ មាត្រា ២៩ *ថ្មី* និងមាត្រា ៣៩ *ថ្មី* នៃច្បាប់ អ.វ.ត.ក តាមរយៈការបង្កការឈឺចាប់ ឬព្យសនកម្មយ៉ាងធ្ងន់ធ្ងរលើទាហាន ឬពលរដ្ឋវៀតណាម ឬអ្នកដែលគេយល់ថាពាក់ព័ន្ធនឹងវៀតណាម។ ក្រៅពីនេះ **មាស មុត** ជាមេបញ្ជាការ និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពលើចារីនៃឧក្រិដ្ឋកម្មនេះនៅគ្រប់ទីកន្លែងទាំងអស់ លើកលែងតែមន្ទីរ ស-២១។ **មាស មុត** បានដឹង ឬមានហេតុផលក្នុងការដឹងថា អ្នកនៅក្រោមបង្គាប់របស់គាត់ រៀបនឹងប្រព្រឹត្ត ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្ម ហើយគាត់មិនបានចាត់វិធានការចាំបាច់ និងសមហេតុផលដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មនេះ ឬដាក់ទណ្ឌកម្មចារីឡើ

យ។ ដូច្នេះ គាត់ត្រូវទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ។ **មាស មុត** ទទួលខុសត្រូវលើការធ្វើទារុណកម្មអ្នកដែលត្រូវបានឃុំខ្លួននៅតាមទីកន្លែងដូចខាងក្រោម៖

(ក) មន្ទីរសន្តិសុខ ស-២១ និង

(ខ) ក្នុងដែនទឹក និងដែនកោះដែលកម្ពុជាប្រជាធិបតេយ្យអះអាងជាកម្មសិទ្ធិរបស់ខ្លួន។

សូមលោកចៅក្រមមេត្តាទទួលយកដីកាសន្និដ្ឋាននេះដោយក្តីគោរព។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៧ | **លោក** Nicholas KOUMJIAN<br>**សហព្រះរាជអាជ្ញាអន្តរជាតិ** | ទីក្រុងភ្នំពេញ | |